# ព្រះគម្ពីរសិក្សា

## ព្រះគម្ពីរ សញ្ញាចាស់

រៀបរៀងដោយ

ផ្សព្វផ្សាយព្រះបន្ទូលព្រះតាំងពីឆ្នាំ១៩៣៨
Sharing God's Word Since 1938

សម្ព័ន្ធព្រះគម្ពីរកម្ពុជា
SAMPONPRASKUMPI KAMPUCHEA
THE BIBLE LEAGUE CAMBODIA

ប្រអប់សំបុត្រលេខ : ២០៤០ ភ្នំពេញ កម្ពុជា
P.O.Box : 2040 Phnom Penh
Kingdom of Cambodia

បោះពុម្ពលើកទី១

៥០០០ច្បាប់

# ព្រះគម្ពីរបរិសុទ្ធ  សម្រាប់សិក្សា

©អត្ថបទព្រះគម្ពីរៈ រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល អនុញ្ញាតសិទ្ធិប្រើប្រាស់ដោយសមាគមព្រះគម្ពីរកម្ពុជា
© សេចក្ដីពន្យល់ និងខយោងៈ រក្សាសិទ្ធិដោយសម្ព័ន្ធព្រះគម្ពីរកម្ពុជា
បោះពុម្ពផ្សាយដោយសម្ព័ន្ធព្រះគម្ពីរកម្ពុជា

Scripture Text © United Bible Societies, used by permission from The Bible Society in Cambodia
Study Notes © The Bible League
Published by The Bible League Cambodia

ទស្សនៈរបស់សម្ព័ន្ធព្រះគម្ពីរ

ព្រះអម្ចាស់ទ្រង់បានត្រាស់ហៅយើងទាំងអស់គ្នា ដើម្បីជួយផ្គត់ផ្គង់ព្រះគម្ពីរ និងបណ្ដុះបណ្ដាលមនុស្សទូទាំងពិភពលោក ដែលព្រះវិញ្ញាណបរិសុទ្ធបានដៅចំណាំ ប្រយោជណ៍ឱ្យពួកគេបានស្គាល់ទ្រង់ និងចូលមកប្រកបគ្នាក្នុងព្រះវិហាររបស់ទ្រង់ ។

កិច្ចការងារបម្រើ

**១. ការជួយផ្គត់ផ្គង់** : ព្រះគម្ពីរ និងសម្ភារៈផ្សាយដំណឹងល្អ បង្កើតសិស្ស បង្កើតព្រះវិហារដល់គ្រប់ស្ថាប័នបម្រើការងារព្រះ និងមនុស្សទាំងឡាយណាដែលត្រូវការក្នុងតម្លៃសមរម្យ ឬតាមសេចក្ដីត្រូវការបែបជាក់ស្ដែងណាមួយ ។ល។

**២. ការជួយលើកទឹកចិត្ត** : បុគ្គល គ្រួសារ និងក្រុមសិក្សាព្រះគម្ពីរ ។

**៣. ការសហការ** : ជាមួយព្រះវិហារគ្រីស្ទបរិស័ទ និកាយ អង្គការផ្សេងៗ ដើម្បីចូលរួមបណ្ដុះបណ្ដាលក្នុងការបង្កើតពួកជំនុំ និងផ្គត់ផ្គង់ ។

ព្រះគម្ពីរ និងសម្ភារៈផ្សេងៗដែលពាក់ព័ន្ធ ក្នុងតម្លៃសមរម្យ ឬអាចជាមធ្យោបាយផ្សេងៗ ។

**៤. ការទទួលខុសត្រូវ** : អ្នករួមចំណែកសម្រាប់ការងារនេះ ត្រូវមានភាពទទួលខុសត្រូវលើវិធានការ និងរបាយការណ៍ក្នុងការផ្ដល់លទ្ធផលដែលយើងទទួលបានគឺ ដោយសារព្រះគុណរបស់ព្រះអម្ចាស់ ។

# អារម្ភកថា

ជាបឋមយើងខ្ញុំជាគណៈកម្មការអភិវឌ្ឍន៍ព្រះគម្ពីរនៃសម្ព័ន្ធព្រះគម្ពីរកម្ពុជា សូមថ្លែងអំណរអរព្រះគុណចំពោះព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានបើកសំដែងអង្គទ្រង់ដល់ប្រជាជនខ្មែរ និងផ្តល់សិទ្ធិគ្រប់គ្រាន់ក្នុងការជួបជុំថ្វាយបង្គំទ្រង់ ហើយក៏សូមអរគុណយ៉ាងខ្លាំងដល់សមាគមព្រះគម្ពីរកម្ពុជាដែលជាគូកនបម្រើព្រះអម្ចាស់យ៉ាងជិតស្និទ្ធនៃយើងខ្ញុំ ក្នុងការអនុញ្ញាតសិទ្ធិបញ្ញា មកសម្ព័ន្ធព្រះគម្ពីរកម្ពុជាប្រើប្រាស់អត្ថបទព្រះគម្ពីរបរិសុទ្ធជាភាសាខ្មែរ បកប្រែចាស់ (ឆ្នាំ១៩៥៤ ដោយ លោកអ័រធើរ ហាម៉ុង "Old Version by Arthur L Hammond") ដើម្បីរៀបចំជាព្រះគម្ពីរមួយ ដែលមានឈ្មោះថា "**ព្រះគម្ពីរបរិសុទ្ធ សម្រាប់សិក្សា (Khmer Bible Study)**"។

ព្រះគម្ពីរ នៅក្នុងដៃរបស់លោកអ្នក គឺជាទ្រព្យសម្បត្តិដ៏សម្បូរបែបខាងឯព្រលឹងវិញ្ញាណ ជាទ្រព្យដ៏មានតម្លៃយ៉ាងពិតប្រាកដ ដែលនាំមកនូវសន្តិភាព អំណរ សុភមង្គល អំណាចព្រះចេស្តារបស់ព្រះ និងគោលដៅថ្មីក្នុងជីវិតរបស់លោកអ្នកនាពេលបច្ចុប្បន្ន និងទៅអនាគត ។ ទ្រព្យសម្បត្តិខាងឯវិញ្ញាណនេះគឺជាមូលដ្ឋានគ្រឹះមួយដែលព្រះអម្ចាស់បានប្រទានមកឱ្យលោកអ្នកមានជីវិតថ្មី ដែលមិនចេះរុះរោយ ដូចព្រះគម្ពីរបានចែងថា: *[១២]អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឱ្យបានត្រឡប់ជាកូនព្រះ [១៣]គឺជាកូនដែលមិនមែនកើតមកពីឈាម ឬតាមប្រាថ្នាខាងរូបសាច់ ឬតាមចំណង់នៃមនុស្សឡើយ គឺកើតមកអំពីព្រះវិញ (យ៉ូហាន ១:១២-១៣)*។ នៅក្នុងព្រះគម្ពីរសិក្សានេះ លោកអ្នកនឹងឃើញទ្រព្យសម្បត្តិខាងឯវិញ្ញាណដែលមានន័យយ៉ាងច្បាស់លាស់ ហើយនាំឱ្យលោកអ្នកទទួលជឿថា ព្រះយេស៊ូវគ្រីស្ទគឺ ជាព្រះរាជបុត្រានៃព្រះ ដោយសេចក្តីជំនឿនេះហើយដែលដឹកនាំលោកអ្នកឱ្យមានជីវិតនៅក្នុងទ្រង់ (យ៉ូហាន ២០:៣១)។

យើងខ្ញុំទាំងអស់គ្នាសុទ្ធតែទទួលស្គាល់ថា ឫទ្ធិអំណាចនៃព្រះគម្ពីរគឺជាព្រះបន្ទូលព្រះដ៏ពិតប្រាកដដែលទ្រង់មានបន្ទូលមកកាន់មនុស្សលោក ហេតុដូច្នេះបានជាយើងខ្ញុំប្រឹងប្រែងដោយស្មោះអស់អំពីចិត្តក្នុងការអភិវឌ្ឍន៍ព្រះគម្ពីរខ្មែរនេះឱ្យមានលក្ខណៈកាន់តែងាយស្រួលក្នុងការសិក្សា ហើយមានប្រសិទ្ធិភាពថែមទៀតនៅក្នុងជីវិតជាគ្រីស្ទបរិស័ទនាពេលបច្ចុប្បន្ន ក៏ដូចទៅអនាគត ។ ប៉ុន្តែសួរថា ហេតុអ្វីចាំបាច់ត្រូវការអភិវឌ្ឍន៍ឱ្យមានព្រះគម្ពីរសិក្សានេះនៅពេលដែលអត្ថបទព្រះគម្ពីរមានន័យយ៉ាងច្បាស់លាស់រួចស្រេចទៅហើយនោះ! ពិតហើយ ពុំមានសៀវភៅណាផ្សេងទៀតអាចយកមកជំនួសអត្ថបទគម្ពីរនេះបានឡើយ ។ ជាងនេះទៅទៀត មានតែព្រះវិញ្ញាណមួយអង្គប៉ុណ្ណោះដែលគ្រប់លក្ខណ៍ ហើយមានអំណាចគ្រប់គ្រាន់ក្នុងការបើកចំហរចិត្តមនុស្សឱ្យយល់ពីព្រះបន្ទូលរបស់ទ្រង់បាន ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ព្រះវិញ្ញាណបរិសុទ្ធទ្រង់ប្រើមនុស្សឱ្យបកស្រាយពន្យល់ព្រះបន្ទូលព្រះ ទៅកាន់មនុស្សដទៃទៀតៗផងដែរ ។ គឺព្រះវិញ្ញាណនេះហើយ ដែលបានដឹកនាំសាវ័កភីលីពឱ្យមកជួបនឹងរទេះរបស់មនុស្សកំរៀវសាសន៍អេធីយ៉ូពីម្នាក់កំពុងតែជិះ ហើយសាវ័ករូបនេះបានសួរទៅគាត់ថា តើលោកមើលយល់ឬទេ? គាត់ក៏ឆ្លើយឡើងថា បើគ្មានអ្នកណាដឹកនាំខ្ញុំ នោះធ្វើដូចម្តេចឱ្យខ្ញុំយល់បាន?" (កិច្ចការ ៨: ៣០-៣១)។ បន្ទាប់មក លោកភីលីពក៏ពន្យល់គាត់អំពីទំនាក់ទំនងគ្នារវាងអត្ថបទគម្ពីរសញ្ញាចាស់ និងសេចក្តីដែលចែងអំពីព្រះយេស៊ូវ ។ ទំនាក់ទំនងនេះគឺមានប្រយោជន៍ខ្លាំងណាស់សម្រាប់ជួយពន្យល់អំពីអត្ថន័យនៃទ្រព្យសម្បត្តិខាងឯព្រលឹងវិញ្ញាណនៅក្នុងព្រះគម្ពីរនេះទាំងមូល ។ **តែសូមចាំថា** ជំនួយទាំងនេះគឺគ្រាន់តែជាសេចក្តីបង្រៀនរបស់គ្រូបង្រៀនព្រះគម្ពីរ ដើម្បីជួយលោកអ្នកឱ្យយល់នូវខ្លឹមសារអត្ថបទព្រះគម្ពីរឱ្យកាន់តែច្បាស់ថែមទៀតប៉ុណ្ណោះ មិនត្រូវបានចាត់ទុកដូចអត្ថបទព្រះគម្ពីរ នោះឡើយ ។

### លក្ខណៈពិសេស និងរបៀបប្រើព្រះគម្ពីរសិក្សា

ព្រះគម្ពីរនេះមានអត្ថបទដើមជាព្រះគម្ពីរខ្មែរបកប្រែចាស់ទាំងស្រុង មានទម្រង់ជាលក្ខណៈអន្តរជាតិ មានសេចក្តីផ្តើម ចំណងជើង គម្រោងសង្ខេប ពន្យល់ពាក្យសំខាន់ៗ ខយោង ផែនទី និងតារាងផ្សេងៗ ។

១. អត្ថបទព្រះគម្ពីរមានពីរចន្លោះសងខាង ហើយខយោងនៅចំកណ្តាល *(**ឧ:** មថ ១:១ "នេះបញ្ជីពង្សាវតារពីព្រះយេស៊ូវគ្រីស្ទ ជាវង្សហ្លួងដាវីឌ^ក...")* អក្សរ "^ក" នៅខាងលើគឺសម្រាប់មើលទៅចំណុចខយោងនៅចន្លោះកណ្តាល (**ឧ:** ១:១ ក ២សយ ៧:១២-១៦ អស ៩:៦,៧ ១១:១ យរ ២៣:៥,៦ មថ ៩:២៧ លក ១:៣២,៦៩ *វវ* ២២:១៦) មានន័យថាអត្ថបទនៃព្រះគម្ពីរទាំងអស់នេះគឺនិយាយអំពីហ្លួងដាវីឌ។

២. នៅផ្នែកខាងក្រោមនេះគឺជាសេចក្តីពន្យល់ពាក្យ ឬខណាដែលពិបាកៗ និងខសំខាន់ៗ (**ឧ:** ១:១ បុត្រានៃហ្លួងដាវីឌ) ជាអក្សរទ្រេតសំគាល់ថា ជាពាក្យដកស្រង់ចេញពីព្រះគម្ពីរ ហើយខាងចុងជាសេចក្តីពន្យល់នៃពាក្យនោះ ។

៣. កាលណាឃើញពាក្យថា "មើលការពន្យល់" នោះសូមអានខគម្ពីរនោះជាមុនសិន ទើបងាយយល់នូវសេចក្តីពន្យល់នោះ ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្រទាំងកម្លាំងកាយ និងកម្លាំងចិត្តពីសំណាក់លោកគ្រូ អ្នកគ្រូគង្វាល អ្នកដឹកនាំ និងគ្រីស្ទបរិស័ទជាច្រើនទាំងនៅភ្នំពេញ និងនៅតាមបណ្តាខេត្តនានាដែលបានគាំទ្រដល់យើងខ្ញុំក្នុងការធ្វើកិច្ចការនេះ ។

ជាទីបញ្ចប់ សូមលោកអ្នកមេត្តាជួយពិនិត្យផ្តល់មតិ និងសំណូមពរផ្សេងៗ រួចផ្ញើមកយើងខ្ញុំវិញ នោះយើងខ្ញុំរីករាយនឹងទទួលមតិល្អៗ មកអភិវឌ្ឍបន្ថែមទៀត ។ សូមព្រះយេស៊ូវគ្រីស្ទប្រទានពរលោក អ្នកគ្រប់ពេលវេលា!

# បញ្ជីកណ្ឌព្រះគម្ពីរសញ្ញាចាស់


| ឈ្មោះកណ្ឌគម្ពីរ | អក្សរកាត់ | ជំពូក | ទំព័រ |
|---|---|---|---|
| លោកុប្បត្តិ | (លប) | ៥០ | ១ |
| និក្ខមនំ | (នក) | ៤០ | ១១៣ |
| លេវីវិន័យ | (លវ) | ២៧ | ១៨៩ |
| ជនគណនា | (ជន) | ៣៦ | ២៣៨ |
| ចោទិយកថា | (ចទ) | ៣៤ | ៣១២ |
| យ៉ូស្វេ | (យស) | ២៤ | ៣៧៤ |
| ពួកចៅហ្វាយ | (ពច) | ២១ | ៤២០ |
| នាងរស់ | (នរ) | ៤ | ៤៧១ |
| សាំយូអែល ទី១ | (១សយ) | ៣១ | ៤៨២ |
| សាំយូអែល ទី២ | (២សយ) | ២៤ | ៥៥៣ |
| ពង្សាវតារក្សត្រ ទី១ | (១ពវ) | ២២ | ៦០៧ |
| ពង្សាវតារក្សត្រ ទី២ | (២ពវ) | ២៥ | ៦៧៦ |
| របាក្សត្រ ទី១ | (១រប) | ២៩ | ៧៤១ |
| របាក្សត្រ ទី២ | (២រប) | ៣៦ | ៧៩៤ |
| អែសរ៉ា | (អរ) | ១០ | ៨៥៣ |
| នេហេមា | (នហ) | ១៣ | ៨៨១ |
| នាងអេសធើរ | (នអ) | ១០ | ៩១៥ |
| យ៉ូប | (យប) | ៤២ | ៩៣១ |
| ទំនុកដំកើង | (ទដ) | ១៥០ | ៩៩២ |
| សុភាសិត | (សភ) | ៣១ | ១២៤៩ |
| សាស្តា | (សស) | ១២ | ១៣១៨ |
| បទចំរៀងសាឡូម៉ូន | (បស) | ៨ | ១៣៣៥ |
| អេសាយ | (អស) | ៦៦ | ១៣៥០ |
| យេរេមា | (យរ) | ៥២ | ១៤៧៩ |
| បរិទេវ | (បទ) | ៥ | ១៦១៨ |
| អេសេគាល | (អគ) | ៤៨ | ១៦៣៣ |
| ដានីយ៉ែល | (ដយ) | ១២ | ១៧៣៩ |
| ហូសេ | (ហស) | ១៤ | ១៧៦៧ |
| យ៉ូអែល | (យអ) | ៣ | ១៧៩០ |
| អេម៉ុស | (អម) | ៩ | ១៨០០ |
| អូបាឌា | (អប) | ១ | ១៨១៩ |
| យ៉ូណាស | (យណ) | ៤ | ១៨២៤ |
| មីកា | (មីក) | ៧ | ១៨៣២ |
| ណាហ៊ុម | (ណហ) | ៣ | ១៨៤៦ |
| ហាបាគុក | (ហប) | ៣ | ១៨៥៣ |
| សេផានា | (សផ) | ៣ | ១៨៦១ |
| ហាកាយ | (ហក) | ២ | ១៨៦៩ |
| សាការី | (សក) | ១៤ | ១៨៧៥ |
| ម៉ាឡាគី | (មឡ) | ៤ | ១៩០០ |


# បញ្ជីកណ្ឌព្រះគម្ពីរសញ្ញាថ្មី


| ឈ្មោះកណ្ឌគម្ពីរ | អក្សរកាត់ | ជំពូក | ទំព័រ |
|---|---|---|---|
| ម៉ាថាយ | (មថ) | ២៨ | ១៩១៤ |
| ម៉ាកុស | (មក) | ១៦ | ១៩៧៦ |
| លូកា | (លក) | ២៤ | ២០២៦ |
| យ៉ូហាន | (យហ) | ២១ | ២១០៨ |
| កិច្ចការ | (កច) | ២៨ | ២១៨៧ |
| រ៉ូម | (រម) | ១៦ | ២២៧៥ |
| កូរិនថូស ទី១ | (១កថ) | ១៦ | ២៣១៩ |
| កូរិនថូស ទី២ | (២កថ) | ១៣ | ២៣៥៦ |
| កាឡាទី | (កទ) | ៦ | ២៣៨១ |
| អេភេសូរ | (អភ) | ៦ | ២៣៩៥ |
| ភីលីព | (ភល) | ៤ | ២៤១៣ |
| កូល៉ុស | (កល) | ៤ | ២៤២៧ |
| ថែស្សាឡូនីច ទី១ | (១ថន) | ៥ | ២៤៣៨ |
| ថែស្សាឡូនីច ទី២ | (២ថន) | ៣ | ២៤៤៩ |
| ធីម៉ូថេ ទី១ | (១ធថ) | ៦ | ២៤៥៦ |
| ធីម៉ូថេ ទី២ | (២ធថ) | ៤ | ២៤៦៧ |
| ទីតុស | (ទត) | ៣ | ២៤៧៥ |
| ភីលេម៉ូន | (ភម) | ១ | ២៤៨២ |
| ហេព្រើរ | (ហព) | ១៣ | ២៤៨៥ |
| យ៉ាកុប | (យក) | ៥ | ២៥១៤ |
| ពេត្រុស ទី១ | (១ពត) | ៥ | ២៥២៤ |
| ពេត្រុស ទី២ | (២ពត) | ៣ | ២៥៣៨ |
| យ៉ូហាន ទី១ | (១យហ) | ៥ | ២៥៤៩ |
| យ៉ូហាន ទី២ | (២យហ) | ១ | ២៥៦១ |
| យ៉ូហាន ទី៣ | (៣យហ) | ១ | ២៥៦៣ |
| យូដាស | (យដ) | ១ | ២៥៦៥ |
| វិវរណៈ | (វវ) | ២២ | ២៥៧០ |

# សង្ខេបព្រះគម្ពីរ

## ព្រះគម្ពីរសញ្ញាចាស់

ព្រះគម្ពីរសញ្ញាចាស់បានសរសេរឡើងមុនការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ហើយប្រាប់យើងនូវរបៀបដែលព្រះបានត្រាស់ហៅជនជាតិអ៊ីស្រាអែល និងរបៀបដែលព្រះបានកែឆ្នៃអ៊ីស្រាអែលក្នុងឋានៈពួកគេជារាស្ត្រដ៏ពិសេសរបស់ទ្រង់ ហើយតាមរយៈរាស្ត្រនេះដែលទ្រង់បានប្រទានព្រះរាជបុត្រាទ្រង់តែមួយគត់ឱ្យមកប្រសូត ។ ព្រះគម្ពីរសញ្ញាចាស់ គឺពោរពេញទៅដោយរឿងរ៉ាវនៃអំពើបាបរបស់អ៊ីស្រាអែល ការជំនុំជម្រះ ការអត់ទោស ការនិរទេស និងលាយឡំទៅដោយប្រវត្តិសាស្ត្រ ចម្រៀង កំណាព្យក្នុងពេលអ៊ីស្រាអែលថ្វាយបង្គំព្រះ ។ លើសពីនេះទៅទៀតនោះបានប្រាប់នូវរបៀបទទួលព្រះបន្ទូលពីព្រះតាមរយៈពួកហោរា និងក្រឹត្យវិន័យផ្សេងៗ សម្រាប់គ្រប់គ្រងនិងព្រមានរាស្ត្រអ៊ីស្រាអែល និងជំនុំជំរះនៅពេលគេបានធ្វើបាប ដែលភ្ជាប់មកជាមួយនឹងព្រះបន្ទូលសន្យាអំពីការ ប្រោសលោះ ការយាងមករបស់ព្រះគ្រីស្ទផង ។

### ព្រះគម្ពីរសញ្ញាចាស់ចែកចេញជា៤:

#### ១. ប្រវត្តិសាស្ត្រ

ព្រះគម្ពីរគឺពោរពេញទៅដោយរឿងរ៉ាវនៃការបង្កើតពិភពលោក ការធ្លាក់ចុះក្នុងអំពើបាបរបស់មនុស្ស ទឹកជំនន់ ដើមកំណើតដំបូងនៃអ៊ីស្រាអែល ។ លោកអ្នកនឹងឃើញចាប់ពីលោកុប្បត្តិរហូតដល់នាងអេសធើរ លើកលែងតែលេវីវិន័យ ជនគណនា និងចោទិយកថា។

#### ២. ក្រឹត្យវិន័យ

ព្រះគម្ពីរលេវីវិន័យ ជនគណនា និងចោទិយកថា គឺជាព្រះគម្ពីរដំបូង ដែលនិយាយអំពីក្រឹត្យវិន័យ ច្បាប់ស៊ីវិល សម្រាប់គ្រប់គ្រងប្រជារាស្ត្រអ៊ីស្រាអែល និងក្រឹត្យវិន័យខាងសាសនាក្នុងការដឹកនាំការថ្វាយបង្គំ និងក្បួនច្បាប់សម្រាប់ទំនាក់ទំនងផ្សេងៗ មានប្រវត្តិសាស្ត្រ និងក្រឹត្យវិន័យនៅលាយឡំគ្នា ។

#### ៣. កំណាព្យ

មាន៥កណ្ឌក្នុងព្រះគម្ពីរសញ្ញាចាស់ដូចជា: យ៉ូប ទំនុកដំកើង សុភាសិត សាស្តា និងបទចំរៀងសាឡូម៉ូន ។ កំណាព្យដែលងាយស្រួលអានជាងគេបំផុតនោះ គឺជាទំនុកដំកើង ដូចជានៅក្នុងទំនុកដំកើងជំពូក២៣ជាដើម សូម្បីតែក្មេងតូចៗ ក៏ចេះកំណាព្យនេះដែរ ហើយពោរពេញទៅដោយសេចក្តីសន្យានៃការថែរក្សាដ៏ផ្អែមល្ហែមរបស់ព្រះ ដល់អស់អ្នកណាដែលស្រឡាញ់ទ្រង់ ។

#### ៤. ទំនាយ

វគ្គចុងក្រោយនៃព្រះគម្ពីរគឺពិបាកអានបន្តិច ដែលសរសេរឡើងដោយពួកហោរានៃសាសន៍អ៊ីស្រាអែល ព្រះគម្ពីរទាំងនេះដោះស្រាយ ជាមួយនឹងការព្រមាននៃអំពើបាប ការជិតមកដល់នៃការជំនុំជម្រះរបស់ព្រះ ការសន្យានៃសេចក្តីសង្គ្រោះ និងទំនាយនៃការយាងមករបស់ព្រះគ្រីស្ទ ដែលចាប់ផ្តើមពីគម្ពីរអេសាយទៅដល់ចុងបញ្ចប់គម្ពីរសញ្ញាចាស់ម៉ាឡាគី ។

## ព្រះគម្ពីរសញ្ញាថ្មី

ព្រះគម្ពីរសញ្ញាថ្មីបានពិពណ៌នាអំពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ជាព្រះអង្គសង្គ្រោះពិភពលោក លោកអ្នក នឹងឃើញមានព្រះគម្ពីរ៤ប្រភេទនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

#### អំពីព្រះយេស៊ូវគ្រីស្ទ

ព្រះគម្ពីរ៤កណ្ឌដំបូងត្រូវបានគេហៅថា "ព្រះគម្ពីរដំណឹងល្អ" រួមមានម៉ាថាយ ម៉ាកុស លូកា យ៉ូហាន ព្រះគម្ពីរទាំងនេះបានប្រាប់អំពីកំណើត ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ព្រះអង្គបានបើកសំដែងឱ្យមនុស្សទាំងបួននាក់នេះ បានកត់ចុះនូវរឿងរ៉ាវជាច្រើនសម្រាប់អ្នកស្តាប់ អ្នកអានខុសៗគ្នា ហើយគោលបំណងក៏ខុសគ្នាដែរ ព្រមទាំងរបៀបសរសេរក៏ខុសគ្នាទៀត គម្ពីរនិមួយៗបានបញ្ចូលនូវសាច់រឿងសំខាន់ៗនៃដំណើរជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ ។

#### អំពីពួកជំនុំ

នៅក្នុងព្រះគម្ពីរកិច្ចការបានប្រាប់យើងអំពីរបៀប និងការរីកចម្រើននៃពួកជំនុំនៅក្នុងគម្ពីរសញ្ញាថ្មី និងជាព្រះគម្ពីរដំបូងដែលងាយស្រួលអាន ។

#### អំពីសេចក្តីបង្រៀន

ពួកសាវ័កដើមដំបូងបានសរសេរសំបុត្រជាច្រើនផ្ញើទៅកាន់ពួកជំនុំ ហើយនៅក្នុងគម្ពីរសញ្ញាថ្មីត្រូវបានគេហៅថា (សំបុត្រ) សម្រាប់ជាសេចក្តីបង្រៀនគោលលទ្ធិនៃការរស់នៅជាជីវិតគ្រីស្ទបរិស័ទ ចាប់ផ្តើមពីគម្ពីររ៉ូមដល់យូដាស ។

**អំពីទំនាយ**

ព្រះគម្ពីរវិវរណៈជាគម្ពីរចុងក្រោយ ដែលសំដែងពីទីសំគាល់ចុងក្រោយបំផុតនៃគម្ពីរដំណឹងល្អរបស់គ្រីស្ទបរិស័ទ ហើយនៅពីរជំពូកចុងក្រោយបាននិយាយអំពីរូបភាពយ៉ាងល្អស្អាតនៅឯស្ថានសួគ៌ និងផែនដីថ្មី ដែលព្រះនឹងតាំងឡើងនៅពេលព្រះយេស៊ូវគ្រីស្ទនឹងយាងមកម្តងទៀត ។

ព្រះគម្ពីររបស់គ្រីស្ទបរិស័ទដំណឹងល្អទាំងអស់មាន៦៦កណ្ឌ សញ្ញាចាស់៣៩ និងសញ្ញាថ្មី២៧ បើលើសពីនេះ នោះពុំមែនជាគម្ពីររបស់គ្រីស្ទបរិស័ទ ដំណឹងល្អនោះឡើយ ។

# ព្រះគម្ពីរលោកុប្បត្តិ

**ចំណងជើង**

តាមព្រះគម្ពីរភាសាហេព្រើរ ឃ្លាដំបូងក្នុង ១:១ ចាប់ផ្តើមពីពាក្យ "ប៊ីរេស៊ីត"(bereshith) ដែលមានន័យថា "កាលដើមដំបូង" គេបានយកមកដាក់ធ្វើជាចំណងជើងព្រះគម្ពីរលោកុប្បត្តិ (បើតាមទំនៀមទម្លាប់ពីបុរាណកាលមក សៀវភៅជាច្រើនគេបានដាក់ឈ្មោះតាមពាក្យទី១ឬទី២) ។ នៅក្នុងភាសាអង់គ្លេសវិញ ពាក្យថា "ចែនណឺស៊ិស" (Genesis) គឺជាពាក្យដែលក្លាយមកពីភាសាក្រិក "ចែនណឺស៊ិស" (Geneseos) ដែលមានន័យថា "លោកុប្បត្តិ"ដែលបានលេចឡើង ក្នុងការបកប្រែព្រះគម្ពីរមកជាភាសាក្រិក នៅសម័យមុនគ្រីស្ទសករាជ"សែបទូជិន" (Septution) នៅ ២:៤ ៥:១ ។ ដោយយោងទៅតាមបរិបទគម្ពីរនេះ ពាក្យនេះមានន័យថា "កំណើត" ឬ"ដំណវង្ស" ឬក៏ "ប្រវត្តិសាស្ត្រដើម" ។ ទាំងភាសាហេព្រើរក្តី ទាំងភាសាក្រិកក្តី ចំណងជើងនៃព្រះគម្ពីរលោកុប្បត្តិ គឺសុទ្ធតែពណ៌នាអំពីផ្ទៃរឿងទាំងមូល នៃព្រះគម្ពីរនេះតែម្តង ហើយផ្ទៃរឿងដែលបានពិពណ៌នានោះ ពីព្រោះជាព្រះគម្ពីរដែលនិយាយពីការចាប់ផ្តើម ។

**ប្រវត្តិដើម**

ចាប់តាំងពីជំពូកទី១ដល់ជំពូកទី៣៨ គឺបានពិពណ៌នាអំពីកិច្ចការងារជាច្រើន ដែលយើងទាំងអស់គ្នាបានដឹងតាមឯកសារផ្សេងៗ ដែលទាក់ទងទៅនឹងអ្នករស់នៅតំបន់មេសូប៉ូតាមា និងវប្បធម៌របស់ពួកគេ ។ ការបង្កើត តំណវង្ស មហន្តរាយនៃទឹកជន់ ប្រវត្តិសាស្ត្រផែនដី ការប៊ុនប្រសប់ អន្តោរប្រវេសណ៍ ការលក់ដូរដីធ្លី ដោយស្របច្បាប់ ការចិញ្ចឹមសត្វចៀម និងគោ ទាំងអស់នោះគឺជាបញ្ហាមួយ ដែលមានសារៈសំខាន់បំផុត សម្រាប់ពួកកូនចៅមេសូប៉ូតាមានាពេលនោះ ។ ជាមួយគ្នានោះផងដែរ ពួកគេម្នាក់ៗអាចរកប្រយោជន៍ផ្ទាល់ខ្លួនសម្រាប់ពួកគេ សម្រាប់ក្រុមគ្រួសាររបស់ពូជអំបូររបស់គេ បានតាមរយៈការអានព្រះគម្ពីរ៣៨ ជំពូកដំបូងនៃព្រះគម្ពីរលោកុប្បត្តិ ។ មិនតែប៉ុណ្ណោះសោត អ្នកនិពន្ធបានលើកឡើងអំពីសួនច្បារអេដែន ដែលជាផ្ទះរបស់មនុស្សដំបូង ដែលស្ថិតនៅក្នុង ឬនៅក្បែរតំបន់មេសូប៉ូតាមា ដែលនៅកន្លែងនោះគេបានសង់ប៉មបាបិលឡើង លោកអ័ប្រាហាំក៏បានកើតនៅទីនោះ អ៊ីសាកក៏បានយកប្រពន្ធនៅកន្លែងនោះផងដែរ មិនតែប៉ុណ្ណោះសោត លោកយ៉ាកុបក៏បានរស់នៅទីនោះ អស់រយៈពេល២០ឆ្នាំផងដែរ ។ ទោះបីជាពួកគ្រូ និងពួកព្យុកោរបស់គេ បានតាំងលំនៅ នៅក្នុងស្រុកកាណានក៏ដោយ ក៏ដែនដីកំណើតរបស់គេគឺ មេសូប៉ូតាមា ។

អ្នកនិពន្ធបានបង្ហាញយ៉ាងច្បាស់ថា ស្ថានភាពអក្សរសាស្ត្របុរាណមានការទាក់ទងទៅនឹងលោកុប្បត្តិជំពូក១-៣៨ ក៏មានប្រភពមកពីអ្នកនៅតំបន់មេសូប៉ូតាមាដែរ ។ "អេនូម៉ាអេលិស"(Enuma elish) គឺជាសៀវភៅមួយ ដែលនិយាយពីប្រវត្តិរបស់ព្រះ"ម៉ាឌាក់" “Marduk” ដែលអ្នកស្រុកបាប៊ីឡូនបាននាំគ្នាលើកឡើងធ្វើជាព្រះដ៏អស្ចារ្យរបស់ពួកគេ ហើយការនេះគឺមានភាពប្រហាក់ប្រហែលគ្នាខ្លះៗ ទៅនឹងទិដ្ឋភាពជាក់ស្តែងមួយ ដែលមាននៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក១ ដែលនិយាយអំពីការបង្កើតពង្សាវតាររបស់ពួកគេ ។ បញ្ជីឈ្មោះស្តេចដ៏សំខាន់ខ្លះ ត្រូវបាននិយាយនៅក្នុងជំពូកទី៥ ។ អត្ថបទកំណាព្យសិលាចារឹកទី១១ឈ្មោះ "គីលកាម៉េស អេពិក" (Gilgamesh epic) គឺវារិតតែដូចគ្នានឹងការរៀបរាប់ស្តីអំពីទឹកជន់នៅក្នុងលោកុប្បត្តិ ជំពូក ៦-៨ ។ មានព្រឹត្តិការណ៍២ឬ៣ ដែលជាព្រឹត្តិការណដ៏សំខាន់នៅក្នុងជំពូក ១-៨ គឺជារឿងដែលដូចគ្នាទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងអត្ថបទសិលាចារឹក "អត្រាហាស៊ិស អេពិក" *(Atrahasis epic)* នោះដែរ ។ សិលាចារឹកសម័យក្រោយៗមកទៀត ក៏ដូចគ្នានឹងគំរូនៃការបង្កើតដំបូង ការបះបោរ ទឹក ជន់ ដែលដូចគ្នាទៅអ្វីដែលព្រះគម្ពីរបានបង្រៀន ។ សិលាចារឹកដីឥដ្ឋ១ គេបានរកឃើញនៅឆ្នាំ ១៩៧៤ កាលពីសម័យបុរេប្រវត្តិ (ប្រហែលជានៅឆ្នាំ ២៥០០-២៣០០ មុនគ.ស) ដែលស្ថិតនៅ "អេប្លា" (Ebla)"ថែលម៉ាឌិក" (Tell Mardikh សម័យទំនើប) នៅប៉ែកខាងជើងប្រទេសស៊ីរី មានការស្របគ្នាខ្លះទៅនឹងផ្ទៃរឿងព្រះគម្ពីរលោកុប្បត្តិ ។

នៅមានឯកសារ២ខ្សែផ្សេងទៀត បានភ្ជាប់មកជាមួយឯកសារ ដែលនិយាយពីលទ្ធិប្រជាធិបតេយ្យរបស់អ្នកនៅតំបន់មេសូប៉ូតាមា នៅក្នុង៣៨ជំពូកដំបូង នៃព្រះគម្ពីរលោកុប្បត្តិ ។ តាមរយៈសំបុត្ររបស់ម៉ារា (Maria) ដែលបានសរសេរនៅសម័យពួកព្យុ កោដំបូងមក (រាប់បញ្ចូលជាពិសេសដូចជាលោកអ័ប្រាហាំ យ៉ាកុប និងយ៉ូបជាដើម) អ្នកទាំងអស់នោះគឺសុទ្ធតែបានរស់នៅក្នុងសម័យ នោះ ។ ជាមួយគ្នានោះផងដែរ តាមរយៈសំបុត្រនេះក៏បានបញ្ជាក់ប្រាប់យើងឱ្យបានច្បាស់ថែមទៀត អំពីសេរីភាពក្នុង ការធ្វើដំណើរប្រកបដោយជោគជ័យមួយ តាមបណ្តាស្រុកផ្សេងៗទៀតនៃទឹកដីស្រុកអាម៉ូរី(Amorite) ដែលជាកន្លែងមេគ្រួរបស់ពួកគេរស់នៅ ។ មានសិលាចារឹកឈ្មោះថា "នូស៊ី" (Nuzi) ទោះបីជាមានការយឺតយ៉ាវជាង២ឬ៣សតវត្សរ៍ កាលពីសម័យពួកព្យុកោជំនាន់មុន បានរស់

នៅក៏ដោយ ក៏មានលក្ខណៈដូចគ្នាដែរ គឺពួកគេបានរស់នៅជាច្រើនសតវត្សរ៍ ។ សិទ្ធិក្នុងការទទួលមរតករបស់សមាជិកក្នុងផ្ទះ ឬពួកអ្នកបម្រើ (សូមមើល ១៥:១-៤) កាតព្វកិច្ចរបស់ស្ត្រីអារគឺត្រូវតែបង្កើតកូនឱ្យប្តីតាមរយៈស្ត្រីអ្នកបម្រើ (សូមមើល ១៦:២-៤) អំណាចច្បាប់តាមមាត់ តាមប្រពៃណី ដើម្បីទាស់ប្រឆាំង និងបណ្តេញអ្នកបម្រើ និងកូននាងចេញ (២១:១០-១១) របស់អ្នកនៅមជ្ឈឹមបូព៌ា នាសម័យបុរាណ ដូចជាការរៀបចំបុណ្យសព (២៧:១-៤,២២-២៣,៣៣) សិទ្ធិស្របច្បាប់ទាំងនោះ គឺសុទ្ធតែមាននិយាយនៅក្នុងច្បាប់ និងកិច្ចសន្យាជាផ្លូវការ ព្រមទាំងមាននៅក្នុងឯកសាររបស់ពួកមេសូប៉ូតាមា ។

អត្ថបទនៃព្រះគម្ពីរលោកុប្បត្តិពីជំពូក ១-៣៨ និយាយទាក់ទងទៅនឹងលក្ខណៈ និងប្រវត្តិនៃតំបន់មេសូប៉ូតាមា ដូនេះចាប់តាំងពីជំពូក៣៩-៥០ និយាយឆ្លុះបញ្ចាំងពីឥទ្ធិពលនៃពួកសាសន៍អេស៊ីព្ទវិញ ។ ឧទាហរណ៍អំពីឥទ្ធិពលនៃសាសន៍អេស៊ីព្ទ គឺមានដូចជាការប្រមូលផលចំការទំពាំងបាយជូរ(៤០:៩-១១) ទេសភាពមាត់ទន្លេ (ជំពូក ៤១) ស្រុកអេស៊ីព្ទ ដែលដូចជាកន្ត្រកនំប៉័ង របស់ពួកកាណាន (ជំពូក៤២) ស្រុកកាណានដែលជាប្រភពនៃផលិតផលជាច្រើនដែលពួកអេស៊ីព្ទត្រូវការ (ជំពូក ៤៣) សាសនា និងវប្បធម៌របស់អេស៊ីព្ទ (ជំពូក៤៣,៤៦) ការរៀបចំប្រព័ន្ធរដ្ឋបាលរបស់អេស៊ីព្ទ (៤៧) ការរេបៀបចំពិធីបុណ្យសព (៥០) និងពាក្យឈ្មោះជាភាសាអេស៊ីព្ទ ចំនួនពីរបីត្រូវបានគេប្រើនៅក្នុងជំពូកទាំងអស់នេះ ។ ស្នាដៃអក្សរសាស្ត្រអេស៊ីព្ទមួយដែលមានចំណងជើងថា "រឿងនិទានរបស់បងប្អូនប្រុសពីរនាក់" (Tell of Two Brother) មានចំណុចស្របគ្នាមួយចំនួននឹងរឿងរបស់លោកយ៉ូសែប និងប្រពន្ធរបស់លោកប៉ូទីផា (ជំពូក៣៩) ។ អត្ថបទស្វ័យជីវប្រវត្តិរបស់ពួកអេស៊ីព្ទ (ដូចជា"រឿងស៊ីនូហេ និងការរាយការណ៍នៃវេណាមូម" *Story of Sinuhe and the Report of Wenamun* ) និងរឿងព្រេងប្រវត្តិសាស្ត្រផ្សេងៗទៀត មានលក្ខណៈស្របគ្នានឹងព្រះគម្ពីរលោកុប្បត្តិ ។

**អ្នកនិពន្ធ និងកាលបរិច្ឆេទនៃការនិពន្ធ**

តាមប្រវត្តិសាស្ត្រ ពួកសាសនាយូដាក៏ដូចជាគ្រីស្ទបរិស័ទ បានជឿថា លោកម៉ូសេគឺជាអ្នកនិពន្ធព្រះគម្ពីរទាំង៥កណ្ឌដំបូង នៃព្រះគម្ពីរសញ្ញាចាស់ ។ សៀវភៅទាំងអស់នោះ គេបានឱ្យឈ្មោះថា "បញ្ចកណ្ឌ" (គឺមានន័យថា "សៀវភៅមួយដែលមាន៥ខ្សែ")។ ផ្អែកទៅលើទំលៀមទម្លាប់របស់ពួកយូដា គេហៅកណ្ឌទាំងប្រាំដំបូងនេះថា ព្រះគម្ពីរក្រឹត្យវិន័យទាំងប្រាំកណ្ឌរបស់លោកម៉ូសេ ។ គម្ពីរកិច្ចការ ១៥:១ បានលើកឡើងពីការកាត់ស្បែកថាជា "ទំលាប់របស់លោកម៉ូសេ"(មាននៅក្នុងជំពូក១៧) ហើយតាមបទគម្ពីរនេះ គេអាចសន្និដ្ឋានបានថា តាមព្រះគម្ពីរបរិសុទ្ធ លោកម៉ូសេជាអ្នកនិពន្ធនៃព្រះគម្ពីរលោកុប្បត្តិ ។

គេអាចដឹងបានអំពីសម័យកាលប្រវត្តិសាស្ត្រដែលលោកម៉ូសេបានរស់ តាមរយៈព្រះគម្ពីរ ពង្សាវតារក្សត្រខ្សែទីមួយ ។ យើងអាចដឹងបានថា "នៅឆ្នាំទី៤នៃការដឹកនាំរបស់ស្តេចសាឡូម៉ូនលើស្រុកអ៊ីស្រាអែល" គឺមិនខុសអ្វីពីរយៈពេល "៤៨០ឆ្នាំបន្ទាប់ពីពួកកូនចៅអ៊ីស្រាអែល បានចាកចេញពីស្រុកអេស៊ីព្ទ"(១ពវ៦:១)នោះឡើយ ។ ស្តេចសាឡូម៉ូនប្រហែលជាគ្រប់គ្រងអ៊ីស្រាអែល នៅក្នុងរវាងឆ្នាំ៩៦៦ មុន គ.ស. ដូចនេះពួកអ៊ីស្រាអែលប្រហែលជានិរទេសចាកចេញពីស្រុកអេស៊ីព្ទនៅឆ្នាំ១៤៤៦ មុន គ.ស.(កាលបរិច្ឆេទទាំងពីរនេះគឺយក តាមចន្លោះពេល ៤៨០ ឆ្នាំ ដែលមាននិយាយនៅក្នុង ១ពវ ៦:១, មើលសេចក្តីផ្តើមព្រះគម្ពីរពួកចៅហ្វាយ ត្រង់ចំណុចប្រវត្តិដើម)។ រយៈ ពេល៤០ឆ្នាំ ដែលពួកអ៊ីស្រាអែលត្រូវវិលវល់ក្នុងទីរហោស្ថាន ប្រហែលជាចាប់ពីឆ្នាំ១៤៤៦ដល់១៤០៦ មុនគ.ស ហើយទំនងជារយៈពេលដែលលោកម៉ូសេសរសេរនូវកណ្ឌព្រះគម្ពីរ ដែលសព្វថ្ងៃនេះយើងស្គាល់ថាជាព្រះគម្ពីរបញ្ចកណ្ឌ ។

នៅក្នុងអំឡុងពេល៣សតវត្សចុងក្រោយនេះ អ្នកកាត់ស្រាយជាច្រើនបានអះអាងថា ពួកគេបានរកឃើញប្រភពឯកសារបួនយ៉ាងដែលជាមូលដ្ឋានគ្រឹះនៃព្រះគម្ពីរបញ្ចកណ្ឌ ។ គេសង្ស័យថា ឯកសារទាំងនោះ គេបាននិពន្ធនៅសតវត្សរ៍ទីដប់ ដល់សតវត្សរ៍ទីប្រាំ មុន គ.ស. ហើយគេហៅឈ្មោះតាមអក្សរកាត់ភាសាអង់គ្លេស ដូចជា ជេ (J) ដែលមកពីពាក្យយ៉ាវេហ៍ (Jahweh /Yahweh គឺជាព្រះនាមព្រះនៅ ក្នុងសម័យសញ្ញាចាស់) អ៊ី “E” ដែលមកពីពាក្យ "អេឡូហ៊ីម" (Elohim ជាព្រះនាមដែលប្រើដំបូងបំផុតក្នុងព្រះគម្ពីរភាសាហេព្រើ) ឌី ”D” ដែលមកពីពាក្យ "នៃចោទិយកថា" (Deuteronomic) ហើយ ភី “P” ដែលមកពីពាក្យ "នៃពួកសង្ឃ" (Priestly) ។ ឯកសារនិមួយៗ គឺ សុទ្ធតែមានអំណះអំណាងថា មានចរិតលក្ខណៈ និងវិជ្ជាសិក្សាអំពីព្រះផ្ទាល់ខ្លួន ដែលច្រើនតែផ្ទុយនឹងឯកសារផ្សេងៗទៀត ។ ឯកសារទាំងនោះបានពិពណ៌នាថា ព្រះគម្ពីរបញ្ចកណ្ឌជាស្នាដៃនិពន្ធមួយដែលចម្រុះទៅដោយ រឿង កំណាព្យ និងក្រឹត្យវិន័យ ។ ទោះជាយ៉ាងណាក៏ដោយ ទស្សនៈនេះមិនមានភស្តុតាងគ្រប់គ្រាន់ ដើម្បីធ្វើជាអំណះអំណាងឡើយ ហើយការស្រាវជ្រាវខាងបុរាណវត្ថុវិទ្យា និងអក្សរសាស្ត្រ បានបង្ហាញថា ទស្សនៈនេះមិនអាចបដិសេធការដែលលោកម៉ូសេជាអ្នកនិពន្ធបានឡើយ ។

**ខ្លឹមសារនៃវិជ្ជាសិក្សាអំពីព្រះ និងព្រះបន្ទូលព្រះ**

ព្រះគម្ពីរលោកុប្បត្តិ គឺបានពណ៌នាអំពីការចាប់ផ្តើមនៃ ផ្ទៃមេឃ និងផែនដី ពន្លឺ និងងងឹត សមុទ្រ និងផ្ទៃមេឃ ផែនដី និងរុក្ខជាតិ

ព្រះអាទិត្យ និងព្រះច័ន្ទ ហើយនិងហ្វូងតារា សត្វសមុទ្រ សត្វហើរលើអាកាស និងសត្វលើគោក មនុស្សជាតិ(ព្រះបានបង្កើតមនុស្សមកឱ្យត្រូវនឹងរូងអង្គទ្រង់ គឺជាស្នាព្រះហស្ថដ៏ល្អបំផុតរបស់ទ្រង់) អាពាហ៍ពិពាហ៍ និងគ្រួសារ សង្គម និងអារ្យធម៌ អំពើបាប និងការប្រោសលោះ ។ កិច្ចការទាំងអស់នេះ គឺនៅតែបន្តជារៀងរហូតទៅ ។ ពាក្យគន្លឹះរបស់ព្រះគម្ពីរលោកុប្បត្តិគឺ "ការរៀបរាប់ពីហេតុការណ៍" ដែលបានបែងចែកជា១០ផ្នែកសំខាន់ៗ (មើលលក្ខណៈអក្សរសាស្ត្រ និងគម្រោងសង្ខេបអក្សរសាស្ត្រ) ហើយក៏បានរាប់បញ្ចូលខ្លឹមសារនៃការចាប់កំណើត ពង្សាវតារ និងប្រវត្តិសាស្ត្រ ។

ព្រះគម្ពីរលោកុប្បត្តិគឺជាមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងអំពីកណ្ឌនៃព្រះគម្ពីរដទៃទៀត ។ នៅក្នុងខ្លឹមសាររបស់ព្រះគម្ពីរលោកុប្បត្តិ គឺមានលក្ខណៈល្អប្រណីត ហើយក៏ស្មុគស្មាញណាស់ដែរ ។ មួយវិញទៀតគឺវាមានមាតិកា ដែលមានលក្ខណៈច្បាស់លាស់បំផុត ។ ព្រះគម្ពីរលោកុប្បត្តិ គឺជាគម្ពីរមួយដែលអស្ចារ្យបំផុត ដែលនិយាយអំពីទំនាក់ទំនងរវាងព្រះជាមួយនឹងស្នាព្រះហស្ថទ្រង់ រវាងព្រះជាមួយនឹង មនុស្ស ហើយមនុស្សជាមួយនឹងមនុស្សដូចគ្នា ។ ព្រះគម្ពីរនេះបង្ហាញយ៉ាងច្បាស់លាស់ថា ព្រះពិតមានតែមួយ (Monotheism) ដែលសក្តិសមនឹងការសរសើរពីព្រះនាមទ្រង់ ហើយបានបដិសេធនូវជំនឿដែលថា មានព្រះច្រើន (Polytheism) គ្មានព្រះទាល់តែសោះ (Atheism) និងអ្វីៗសុទ្ធតែជាព្រះ (Pantheism) ។ ព្រះគម្ពីរនេះបានបង្រៀនយ៉ាងច្បាស់ថា ព្រះពិតតែមួយនោះទ្រង់មានអំណាចគ្រប់គ្រងលើគ្រប់អ្វីៗទាំងអស់ដែលមាន (គឺរបស់ទាំងអស់ដែលទ្រង់បង្កើត) ហើយជាញឹកញាប់ទ្រង់ប្រើសេរីភាពដ៏គ្មានកំណត់របស់ទ្រង់ ដើម្បី បំផ្លាញ ប្រពៃណី ទំនាមទម្លាប់ និងផែនការណ៍របស់មនុស្ស ។ ព្រះគម្ពីរនេះបាននាំឱ្យយើងស្គាល់នូវរបៀបដែលព្រះទ្រង់ផ្តួចផ្តើម និងតាំងសេចក្តីសញ្ញាជាមួយនឹងរាស្ត្ររើសតាំងរបស់ទ្រង់ ដោយសន្យាប្រទាននូវសេចក្តីស្រឡាញ់ និងសេចក្តីស្មោះត្រង់របស់ទ្រង់ដល់ពួកគេ ហើយដោយត្រាស់ហៅពួកគេ ឱ្យសន្យាថ្វាយទ្រង់នូវសេចក្តីទាំងនេះវិញ ។ ព្រះគម្ពីរនេះនិយាយអំពីការថ្វាយយញ្ញបូជា ដើម្បីលោះជីវិត ដោយថ្វាយជីវិតសត្វជាជំនួស(ជំពូក ២២) ហើយបង្ហើបប្រាប់យើងដោយប្រយោល ឱ្យបានដឹងអំពីផែនការរបស់ព្រះសម្រាប់ការប្រោសលោះពីអំណាចនៃសេចក្តីអាក្រក់ (ផ្ទៀបនឹង ៣:១៥ ជាមួយនឹង រម ១៦:១៧-២០) ហើយបានបង្ហាញអំពីសេចក្តីជំនឿជាគំរូរបស់មនុស្ស ជាន់ដើម (១៥:៦ និងការពន្យល់) ។ តួអង្គសំខាន់ៗនៅក្នុងព្រះគម្ពីរលោកុប្បត្តិ គេបានលើកយកមកនិយាយនៅក្នុងព្រះគម្ពីរហេព្រើរអស់ជាងពាក់កណ្តាលនៃជំពូក ១១ ផងដែរ ។

## លក្ខណៈអក្សរសាស្ត្រ

ខ្លឹមសារនៅក្នុងព្រះគម្ពីរទាំងមូល ជានិច្ចកាលគឺបានរៀបចំសរសេរឡើងតាមបែបអក្សរសាស្ត្រ ហើយសាមញ្ញ ។ នៅក្នុងព្រះគម្ពីរលោកកុប្បត្តិទាំងមូល គឺត្រូវបុនចែកជា១០ផ្នែកសំខាន់ៗ ហើយនៅក្នុងផ្នែកនិមួយៗត្រូវបានចាប់ផ្តើមដោយពាក្យថា "ពង្សាវតារ" (សូមមើលនៅក្នុង ២:៤ ៥:១ ៦:៩ ១០:១ ១១:១០ ១១:២៧ ២៥:១២ ២៥:១៩ ៣៦:១ ៣៦:៩ និង ៣៧:២) ។ សម្រាប់៥ផ្នែកដំបូងគឺអាចស្ថិតនៅក្នុងក្រុមតែមួយ ហើយវាជាសេចក្តីផ្តើមសម្រាប់គម្ពីរទាំងមូលផងដែរ (១:១២:៣) គេហៅថា "ដើមកំណើតនៃប្រវត្តិសាស្ត្រ" (១:១១ ១:២៦) ។ សេចក្តីផ្តើមនេះ គឺជាផ្ទៃរឿងសំខាន់ៗ ចាប់តាំងពីលោកអ័ដាមរហូតដល់លោកអ័ប្រាហាំ ហើយបានប្រាប់យើង អំពីមធ្យោបាយរបស់ព្រះជាមួយនឹងមនុស្សទាំងអស់នៅលើផែនដីយើងនេះ ។ ហើយនៅ៥ផ្នែកចុងក្រោយបន្តទៀត គឺវារិតតែច្រើនជាងមុន ប៉ុន្តែបានបង្រួមឱ្យស្មើគ្នា)អំពីពង្សាវតារ ហើយនិងទំនាក់ទំនងការសន្យារបស់ព្រះជាមួយពួកព្ទយកោនៃរាស្ត្រជ្រើសតាំងរបស់ទ្រង់ គឺពួកកូនចៅអ៊ីស្រាអែល(លោកអ័ប្រាហាំ អ៊ីសាក យ៉ាកុប ហើយនិងលោកយ៉ូសែប ព្រមទាំងក្រុមគ្រួសាររបស់គេ) ។ នៅក្នុងផ្នែកនិមួយៗ គឺហៅថា "ប្រវត្តិនៃមេគ្រួ" (១១:២៧ ៥០:២៦) ។ គេបែងចែកអត្ថបទនេះជាបីផ្នែកគឺ ពីអ័ប្រាហាំដល់អ៊ីសាក (១១:២៧-២៥:១១) ពីអ៊ីសាកដល់យ៉ាកុប(២៥:១៩ ៣៥:២៩ ៣៧:១) និងពីយ៉ាកុបដល់យ៉ូសែប(៣៧:២ ៥០:២៦) ។ ពូជពង្សរបស់អ៊ីសម៉ាអែល(២៥:១២-១៨) ហើយនិងអេសាវ (ជំពូក៣៦) ។

ជាញឹកញាប់ប្រវត្តិសាស្ត្រទាំងអស់នេះ គឺនិយាយអំពីការដណ្តើមសិទ្ធជាកូនច្បងរបស់កូនប្អូន ។ សេតដណ្តើមសិទ្ធិពីកាអ៊ីន សឹមដណ្តើមយ៉ាផែត(សូមមើល ១០:២១) អ៊ីសាកដណ្តើមពីអ៊ីស្មាអែល យ៉ាកុបដណ្តើមពីអេសាវ យូដាហើយនិងយ៉ូសែបបានដណ្តើមពីបងរបស់ពួកគេ មិនតែប៉ុណ្ណោះសោតអេប្រាអ៊ីមបានដណ្តើមពីម៉ាន៉ាសេ ។ ដូចគ្នានិងលក្ខណៈពិសេសនៃការបង្កើតរបស់ព្រះ គឺព្រះអង្គបានរើសតាំងមនុស្សហើយនិងក្រុមគ្រួសាររបស់ពួកគេ នោះគឺបានបង្ហាញយើងយ៉ាងច្បាស់អំពីលក្ខណៈរបស់អក្សរសាស្ត្រ ហើយនិងវិជ្ជាសិក្សាអំពីព្រះដ៏សាមញ្ញមួយនៃព្រះគម្ពីរលោកុប្បត្តិទាំងមូល បានធ្វើឱ្យយើងម្នាក់ៗចាប់អារម្មណ៍ ហើយទទួលយកសេចក្តីពិតដែលថារាស្ត្ររបស់ព្រះមិនមែនកើតឡើងដោយសារតែធម្មជាតិនោះឡើយ ប៉ុន្តែពួកគេគឺជាលទ្ធផលនៃការបង្កើតដ៏អស្ចារ្យនិងល្អប្រណិតមួយ

របស់ព្រះអង្គ ហើយនិងការធ្លាក់ចុះក្នុងប្រវត្តិសាស្ត្រមនុស្ស ។ ព្រះអង្គទ្រង់បានរៀបចំឱ្យពួកគេបានគេចផុតពីការធ្លាក់ចុះដោយបានបង្កើតគេជាថ្មីឡើងសក្តិសមនិងព្រះអង្គ ។ ព្រះអង្គត្រាស់ហៅពួកគេឱ្យក្លាយជារាស្ត្ររបស់ព្រះអង្គហើយចែកចាយព្រះពររបស់ទ្រង់ទៅបណ្តាមនុស្សផ្សេងៗទៀតនៅលើសកលលោកទាំងមូល ។

ចំនួនលេខ និងអត្តសញ្ញាណផ្សេងៗគឺមានសារៈសំខាន់ណាស់នៅក្នុងព្រះគម្ពីរលោកុប្បត្តិ ។ លេខ១០គឺជាលេខដែលគេបែងចែកព្រះគម្ពីរលោកុប្បត្តិជាផ្នែកសំខាន់ៗហើយវាក៏ជាចំនួននៃពូជពង្សវតារ នៅក្នុងជំពូកទី៥ និងទី១១ផងដែរ (សូមមើល ៥:៥)។ លេខ៧ក៏ជួបប្រទះញឹកញាប់ណាស់ដែរ ។ ក្នុងអត្ថបទក្នុងព្រះគម្ពីរភាសាហេព្រើរ ជំពូក១:១ គឺមានពាក្យថា ពិតប្រាកដ ចំនួន៧ ហើយនៅក្នុង១:២មាន ១៤ដង(៧គុណនឹង២) ។ រយៈពេលនៃការបង្កើតមាន៧ថ្ងៃមានពង្សាវតា៧នៅក្នុងជំពូកទី៤(សូមមើលក្នុង៤:១៧-១៨ហើយ៤:១៥,២៤, ៥:៣១)។មានហេតុការណ៍៧ផ្សេៗទៀតក្នុងប្រវត្តិនៃទឹកជំនន់ ។ កូនចៅទាំង៧០របស់លោកណូអេ(ជំពូក១០)ការសន្យាទាំង៧ដែលព្រះបានសន្យាជាមួយលោកអ័ប្រាហាំ(១២:២៣) ។ ៧ឆ្នាំនៃការសំបូរហូរហៀរនិង៧ឆ្នាំនៃការអត់ឃ្លាននៅក្នុងស្រុកអេស៊ីព្ទ(ជំពូក៤១) ។ ពួក កូនចៅទាំង៧០របស់យ៉ាកុប(ជំពូក៤៦) ហើយនៅមានចំនួនលេខដែលសំខាន់ៗផ្សេងៗទៀតដូចជាលេខ១២ ហើយនិងលេខ៤០ គឺមាននិយាយជាញឹកញាប់ និងប្រហាក់ប្រហែលគ្នានេះដែរ ។

ព្រះគម្ពីរលោកុប្បត្តិ គឺជាមូលដ្ឋានគ្រឹះនៃអក្សរសាស្ត្រដែលមានលក្ខណៈសម្រាយ បង្ហាញពីរបៀបប្រើប្រាស់ដោយមានលក្ខណៈជាកំណាព្យខ្លីៗ(កណ្ឌវែងជាងគេគឺការត្រាស់ហៅនិងប្រទានពរដល់យ៉ាកុបនៅក្នុងជំពូកទី៤៩:២-២៧)។ ភាគច្រើននៃពាក្យសម្រាយនោះគឺធ្វើឱ្យយើងមានអារម្មណ៍អណ្តែតអណ្តូង ហើយពេញនិយមបំផុតក្នុងការនិយាយ ហើយលក្ខណៈពិសេសនៃពាក្យនោះគឺអារម្មណ៍កថា មានលក្ខណៈល្អប្រណិត ។ លក្ខណៈនៃការបង្កើតនៅថ្ងៃទី៣គឺមានការប្រហាក់ប្រហែលគ្នា និងស្មើភាពគ្នា(មើលនៅក្នុងជំពូក១:១១)។ លំនាចនិងជន់នៃអំពើបាប បានចាប់ផ្តើមឡើងនៅក្នុងជំពូកទី៣ (សត្វពស់និងស្ត្រី និងមនុស្សបានប្រព្រឹត្តអំពើបាបតគ្នា ព្រះបានសួរសំណួរដល់ពួកគេជាមុនហើយព្រះបានដាក់ទោសពួកគេ) នៅចុងបញ្ចប់ជំពូក៥ បានប្រាប់ពីអំណាចនៃពួកគេត្រូវបានបាត់ហើយគេនឹងស្លាប់ "ប៉ុន្តែព្រះបាននឹកចាំពីលោកណូអេ"(៨:១) ។ បន្ទាប់ពីមានទឹកជំនន់មក ពួកគេបានសាងសង់ប៉មបាបិល ១១:១-៩(នៅក្នុងខ.១-២,៨-៩ បញ្ជាក់នៅក្នុងខ.៣-៤,៦-៧ ខ.៥ សកម្មភាពគឺមានការផ្លាស់ប្តូរ)។ ការដាក់ទណ្ឌកម្មដ៏គួរឱ្យស្អប់ខ្ពើម ៥០:១៩ (សូមមើល ៥០:១៣)។ ការទាស់ប្រឆាំងរបស់ពួកពង្សាវតាតូចៗអំពីសិទ្ធិអំណាចបងច្បង និងពង្សាវតារគ្នាច្រើនអំពីកូនពៅ បញ្ហាទាំងនោះ ហើយនិងអក្សរសាស្ត្រផ្សេងៗទៀតបានធ្វើឱ្យយើងចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗថែមទៀតព្រមទាំងអ្នកអានផងដែរ ។ ទាំងផ្ទៃរឿង ទាំងប្រធានបទផ្សេងៗនៅក្នុង៣ជំពូកដំបូងនៃព្រះគម្ពីរលោកុប្បត្តិដែលផ្តោតនៅក្នុងគម្ពីរវិវរណៈ៣ជំពូកចុងក្រោយវាមិនបានកើតឡើង តំណាលគ្នានោះឡើយ ។ យើងគ្រាន់តែមានការភ្ញាក់ផ្អើលចំពោះអ្នកត្រួតពិនិត្យ ដែលមានឥទ្ធិពលនៃព្រះផ្ទាល់ដែលបានធានា ចំពោះយើងថា "គ្រប់ទាំងអស់នៃបទគម្ពីរ គឺព្រះជាអ្នកបណ្តាលឱ្យតែង"(២ធថ ៣:១៦) ។ ហើយអស់អ្នកដែលសរសេរ "ទំនាយមកពីព្រះ ដែលបានទាយដោយវិញ្ញាណបរិសុទ្ធរបស់ទ្រង់ "( ២ពត ១:២១)។

**គម្រោងសង្ខេប**

**គម្រោងតាមលក្ខណៈអក្សរសាស្ត្រ**

**I. សេចក្តីផ្តើម (១:១-២:៣)**

**II. តួសេចក្តី (២:៤-៥០:២៦)**

១. ដើមកំណើតផ្ទៃមេឃ និងផែនដី (២:៤-៤:២៦)

២. ពូជពង្សលោកអ័ដាម (៥:១-៦:៨)

៣. ពូជពង្សលោកណូអេ (៦:៩-៩:២៩)

៤. ពូជពង្សសឹម ហាំ និងយ៉ាផែត (១០:១-១១:៩)

៥. តំណវង្សរបស់សឹម (១១:១០-២៦)

៦. តំណវង្សរបស់ថេរ៉ា (១១:២៧-២៥:១១)

៧. តំណវង្សរបស់អ៊ីស្មាអែលជាកូនអ័ប្រាហាំ (២៥:១២-១៨)

៨. តំណវង្សរបស់អ៊ីសាក់កូនប្រុសអ័ប្រាហាំ (២៥:១៩-៣៥:២៩)

៩. តំណវង្សរបស់អេសាវ (៣៦:១–៣៧:១)
១០. តំណវង្សរបស់យ៉ាកុប (៣៧:២–៥០:២៦

**គម្រោងនៃខ្លឹមសារសាច់រឿង**

**I. ការបង្កើត (១:១–២:៣)**

**II. បុរេប្រវត្តិ (២:៤–១១:២៦)**

១. លោកអ័ដាម និងអេវ៉ាក្នុងសួនច្បារអេដែន (២:៤–២៥)
២. ការធ្លាក់ចុះរបស់មនុស្ស និងការវិនាសកម្ម (ជំពូក ៣)
៣. ការរីកចំរើននៃអំពើបាប (៤:១–១៦)
៤. តំណវង្សរបស់កាអ៊ីន (៤:១៧–២៦)
៥. តំណវង្សរបស់សេត (ជំពូក ៥)
៦. ការឆ្លើយតបរបស់ព្រះចំពោះទង្វើរអាក្រក់របស់មនុស្ស (៦:១–៨)
៧. ទឹកជន់ធំ (៦:៩–៩:២៩)
ក. ការរៀបចំសម្រាប់ទឹកទំនន់ (៦:៩–៧–១០)
ខ. ការជំនុំជម្រះនិងការប្រោសលោះ (៧:១១–៨:១៩)
១. ទឹកចាប់ឡើង (៧:១១–២៤)
២. ទឹកចាប់ផ្តើមស្រក (៨:១–១៩)
គ. លទ្ធផលនៃទឹកជន់ (៨:២០–៩:២៩)
១. ការតាំងសេចក្តីសន្យាថ្មី (៨:២០–២២)
២. ការប្រទានពរ និងការតាំងសញ្ញាថ្មី (៩:១–៧)
៣. ទំនាកទំនងថ្មី (៩:៨–១៧)
៤. សេចក្តីល្បួង (៩:១៨–២៣)
៥. ចុងបញ្ចប់នៃព្រះបន្ទូល (៩:២៤–២៩)
៨. ការបែងចែកពូជសាសន៍ (១០:១–១១:២៦)
ក. ការកើនឡើងរបស់ជាតិសាសន៍ (ជំពូក១០)
ខ. ការបំភាន់ភាសា (១១:១–៩)
គ. ដំណវង្សរបស់កូនសិមលើកដំបូង (១១:១០–១១:២៦)

**III. តំណាក់កាលបន្ទាប់ទៀតនៃប្រវត្តិសាស្ត្រ (១១:២៧–៥០:២៦)**

១. ជីវិតរបស់លោកអ័ប្រាហាំ (១១:២៧–២៥:១១)
ក. ប្រវត្តិដើមរបស់លោកអ័ប្រាហាំ (១១:២៧–៣២)
ខ. ការត្រាស់ហៅនិងការទទួលខុសត្រូវរបស់លោកអ័ប្រាហាំ (ជំពូក ១២–១៤)
គ. សេចក្តីជំនឿរបស់លោកអ័ប្រាហាំ និងសេចក្តីសញ្ញារបស់ព្រះ (ជំពូក ១៥–២២)
ឃ. ការងារនាពេលចុងក្រោយរបស់លោកអ័ប្រាហាំ (២៣:១–២៥:១១)
២. ពូជពង្សរបស់អ៊ីម៉ាសអែល (២៥:១២–១៨ )
៣. ជីវិតរបស់លោកយ៉ាកុប (២៥:១៩–៣៥:២៩)
ក. យ៉ាកុបស្នាក់អាស្រ័យនៅផ្ទះ (២៥:១៩–២៧:៤៦)
ខ. យ៉ាកុបបានចាកចេញពីផ្ទះ (ជំពូក ២៨–៣០)
គ. យ៉ាកុបត្រឡប់មកផ្ទះវិញ (ជំពូក ៣១–៣៥)

៤. ពូជពង្សរបស់អេសាវ (៣៦:១–៣៧:១)

៥. ជីវិតរបស់លោកយ៉ូសែប (៣៧:២–៥០:២៦)

ក. ការងាររបស់លោកយ៉ូសែប (៣៧:២–៤១:៥៧)

ខ. ការចំណូលស្រុករបស់យ៉ាកុប (ជំពូក ៤២–៤៧)

គ. ជីវិតចុងក្រោយរបស់យ៉ាកុប (៤៨:១–៥០:១៤)

ឃ. ជីវិតចុងក្រោយរបស់យ៉ូសែប (៥០:១៥–២)

## ការតាំងសញ្ញាសំខាន់ៗនៅក្នុងសញ្ញាចាស់

| ការតាំងសញ្ញាជាមួយ | ខគម្ពីរយោង | ប្រភេទនៃការតាំងសញ្ញា | មនុស្សដែលចូលរួម | ការពិពណ៌នាពីសេចក្តីសញ្ញា |
|---|---|---|---|---|
| លោកណូអេ និងកូនចៅគាត់ | លប៩:៨-១៧ | ច្បាប់សម្រាប់ហ្លួង | ជាមនុស្ស"សុចរិត" (៦:៩) លោកណូអេ និងកូនចៅរបស់គាត់ព្រមទាំងសត្វទាំងឡាយដែលនៅជាមួយគាត់ ។ | ព្រះយេហូវ៉ាទ្រង់បានសន្យាដោយគ្មានលក្ខខណ្ឌថា គ្រប់សាច់ទាំងអស់នឹងមិនត្រូវវិនាសដោយសារទឹកជន់ទៀត ដោយព្រះទ្រង់បានដាក់ធ្នូរបស់ព្រះទុកជាទីសំគាល់ ។ |
| កូនចៅលោកអ័ប្រាហាំ (ក) | លប១៥:៩-២១ | ច្បាប់សម្រាប់ហ្លួង | ជាមួយមនុស្សសុចរិតឪពុករបស់គាត់ត្រូវបាន"ទ្រង់រាប់សេចក្តីជំនឿនោះទុកជាសេចក្តីសុចរិតដល់គាត់ "(៦) ទាំងលោកអ័ប្រាហាំនឹងកូនចៅរបស់លោក (១៦) | ព្រះយេហូវ៉ាទ្រង់សន្យាដ៏គ្មានលក្ខខណ្ឌថា ទ្រង់នឹងសម្រេចឱ្យទឹកដីដល់គេ ដោយទ្រង់នឹងនឹកចាំពីសេចក្តីសម្បថរបស់ទ្រង់ ខ. ១៧ |
| កូនចៅលោកអ័ប្រាហាំ (ខ) | លប ១៧ | ទាសករ | លោកអ័ប្រាហាំគឺជាឰយុកោ នឹងជាអ្នកដឹកនាំដ៏ចំណាននៅក្នុងផ្ទះរបស់គាត់ | ព្រះយេហូវ៉ាទ្រង់បានធ្វើការសន្យាដោយមានលក្ខខ័ណ្ឌ ថាព្រះអង្គនឹងធ្វើព្រះរបស់លោកអ័ប្រាហាំ និងកូនចៅរបស់លោក(ប្រៀបធៀបជាមួយនឹង ពាក្យថា"ឯអញ" (១៤)នឹងពាក្យថា "ឯឯង"(១៩) លក្ខខ័ណ្ឌនេះគឺពួកអ៊ីស្រាអែលត្រូវតែទទួលការកាត់ស្បែកទុកជាទីសំគាល់ នៃការគោរពចំពោះ ព្រះយេហូវ៉ា ។ |
| កូនចៅស៊ីណៃ | នក១៩-២០ | ទាសករ | ពួកអ៊ីស្រាអែល ជាកូនចៅលោកអ័ប្រាហាំ គឺជាមួយអ៊ីសាក់ ហើយនិងយ៉ាកុប ព្រមទាំងរាស្ត្ររបស់ព្រះ ដែលបានទទួលការប្រោសលោះ ពីភាពជាទាសករ ឆ្ពោះទៅកាន់ទឹកដីថ្មី គឺជាទឹកដីសន្យា | ព្រះយេហូវ៉ាទ្រង់សន្យាដោយមានលក្ខខណ្ឌថា នឹងធ្វើជាព្រះរបស់អ៊ីស្រាអែល (ជាអ្នកការពារ និងជាអ្នកធានាចំពោះព្រះពររបស់គេ)។លក្ខខណ្ឌនោះគឺរាស្ត្រអ៊ីស្រាអែល ត្រូវតែរស់នៅក្រោមការដឹកនាំ របស់ព្រះនឹងស្តាប់បង្គាប់ព្រះព្រមទាំងធ្វើជាអ្នកបម្រើព្រះ ។ |
| ភីនេហាស | ជន២៥:១០-១៣ | ច្បាប់សម្រាប់ហ្លួង | ជាមួយសម្តេចសង្ឃ ភីនេហាស | ព្រះយេហូវ៉ាទ្រង់បានធ្វើការតាំងសញ្ញាដោយគ្មានលក្ខខណ្ឌថា ទ្រង់នឹងនឹកចាំពីក្រុមគ្រួសារលោកភីនីហាសថា"ជាសង្ឃក្រោយគេបង្អស់" (ទ្រង់នឹងប្រទានពរដល់គេដោយគ្មានកំណត់ ។ |
| កូនចៅដាវីឌ | ២សយ៧:៥-១៦ | ច្បាប់សម្រាប់ហ្លួង | តាំងសញ្ញាជាមួយស្តេចដាវីឌជាស្តេចដែលមានភាពស្មោះត្រង់បន្ទាប់ពីព្រះអង្គបានទទួលស្គាល់ព្រះយេហូវ៉ាថាទ្រង់ជា ក្សត្រលើអ៊ីស្រាអែល(១២) | ព្រះយេហូវ៉ាបានតាំងសញ្ញាដោយគ្មានលក្ខខណ្ឌថា នឹងតាំងដាវីឌឱ្យធ្វើជាស្តេច ហើយរាជ្យរបស់ដាវីឌ នឹងមិនដែលបាត់ឡើយ (១ពវ ៤:២-២១,៥:៣-៤) ។ |
| អ្នកផ្សេងៗទៀត | យរ៣១:៣១-៣៤ | ច្បាប់សម្រាប់ហ្លួង | ព្រះយេហូវ៉ាទ្រង់នឹងដកសេចក្តីសន្យាចេញពីពួកអ៊ីស្រាអែល ហើយនឹងបណ្តេញគេចេញពីទឹកដីសន្យា បើគេមិនស្តាប់តាមទ្រង់ (មើល លវ ២៦:២៧-៣៩ ចទ ២៨:៣៦-៣៧, ៤-៦៨) ។ | ព្រះយេហូវ៉ាទ្រង់បានតាំងសញ្ញាដោយគ្មានលក្ខខណ្ឌ ជាមួយអ៊ីស្រាអែលថា ព្រះអង្គទ្រង់នឹងអត់ទោស ឱ្យពួកគេហើយនឹងបង្កើតគេជាថ្មី តាមរយៈក្រិត្យវិន័យរបស់ទ្រង់ ដោយបានដាក់ក្រិត្យវិន័យបេស់ទ្រង់ "នៅក្នុងចិត្តរបស់គេ" គឺជាសេចក្តី សញ្ញាពីការបន្សុសចិត្តគេ ។ |

## សេចក្តីសញ្ញារបស់ហ្លួងសំខាន់ៗ/ពិពណ៌នាពីពួកស្បែរមជ្ឈឹមបូព៌ាសម្បុរាណ

| ច្បាប់សម្រាប់ហ្លួង | ភាពស្មើគ្នា | ទាសករ |
|---|---|---|
| ការថ្វាយសួយសារអាករដល់ស្តេច(ដីធ្លីឬវត្ថុ ដែលមានតម្លៃផ្សេងៗទៀត)គឺបង្ហាញពីភាពស្មោះត្រង់ចំពោះស្តេច។ ជានិច្ច កាលសួយសារអាករទាំងនោះគេត្រូវថ្វាយដល់ស្តេចអស់មួយជីវិត ហើយថ្វាយដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ប៉ុន្តែការកម្មីររបស់ពួកអ្នកបម្រើ គឺអាចបន្តបានលុះត្រាតែឪពុករបស់គេមានភក្តីភាពប៉ុណ្ណោះ (ប្រៀបធៀប ១សយ ៨:១៤ ២២:៧ ២៧:៦ នអ ៨:១ | នៅពេលធ្វើការតាំងសញ្ញាភាគគីទាំង២ត្រូវមានភាពស្មើគ្នា ត្រូវបង្ខិចិត្តដោយរាប់អានគ្នាទៅវិញទៅមក ដោយនិយាយជាមួយគ្នា ដោយនូវពាក្យ "បងប្អូន" (ប្រៀបធៀប លប ២១:២៧ ២៦:៣១ ៣១:៤៤-៥៤ ១ពវ ៥:១២ ១៥:១៩ ២០:៣២-៣៤ អម១:៩)។ | ជានិច្ចកាល ពេលធ្វើការតាំងសញ្ញា គឺតែងតែធ្វើឡើងដោយ ហ្លួងស្តេច ហើយនឹងអ្នកណាម្នាក់ទៀតដែលមានទំនាក់ទំនង ជាមួយស្តេច ។ ហ្លួងជាអ្នកធ្វើការប្រកាសអំពីសិទ្ធិជានៃការតាំងសញ្ញា នឹងអំពីអធិបតេយ្យភាពរបស់ព្រះ ហើយព្រះមហាក្សត្រនោះបានធ្វើការសំណូមពរដល់ភាគគីម្យាងទៀតឱ្យ "ស្រឡាញ់ដល់បាវ" របស់ខ្លួន ព្រមទាំងការពារគេដែរ ដោយស្ថិតនៅក្នុងលក្ខខណ្ឌមួយ គឺដរាបណា បាវ នោះមាន ភាពស្មោះត្រង់ជាមួយខ្លួន ។ ភាគីទាំង២ត្រូវតែស្មោះត្រង់ចំពោះ សេចក្តីសម្បថ ដែលបានធ្វើឡើង ហើយជួនកាលនិយាយដោយនូវ "ព្រះនាមរបស់ព្រះ""អ្នកបំរើ" "ឪពុក"" កូន(ប្រៀបធៀប យស ៩:៦, ៨ អគ ១៧:១៣-១៨ ហស១២:១) ។ |

# ពូជអំបូរនៃសាសន៍អ៊ីស្រាអែល




* ឈ្មោះរបស់លោកយ៉ាកុប បានទទួលការប្តូរទៅជាអ៊ីស្រាអែលវិញ នៅពេលដែលគាត់បានបោកចំបាប់ជាមួយព្រះនៅឯពេនីអែល ។ ដោយសារគាត់ជាព្ធយុកោនៃអំបូរទាំង១២ នោះអំបូរទាំងនោះរួមគ្នាមកជាសាសន៍មួយ ដែលមានឈ្មោះថា អ៊ីស្រាអែល ដូចជាគាត់ដែរ ដែលជាញឹកញាប់គេនៅតែហៅក្នុងបទកំណាព្យផ្សេងៗថា "យ៉ាកុប"ដដែល ។

**ពួកលេវីមិនបានទទួលចំណែកទឹកដី ក្នុងចំណោមពូជអំបូរផ្សេងទៀត នៅពេលដែលពួកគេចូលកាន់កាប់ទឹកដីកាណានឡើយ(សូមផ្ទៀបនឹង លប ៤៩:៧)។ ដោយសារលោកម៉ូសេបានញែកពួកលេវីចេញពីអំបូរផ្សេងទៀត សម្រាប់ការងារជាសង្ឃថ្នាក់ជាតិ ថ្វាយដល់ព្រះអម្ចាស់ (ជន ៣:១–៤,៤៩)។ ក្រោយមកលោកយ៉ូស្វេបានប្រគល់ទីក្រុងចំនួន៤៨ ដល់អំបូរមួយនេះ ដែលមានទីតាំងនៅតាម តំបន់ផ្សេងៗរបស់សាសន៍អ៊ីស្រាអែល(យស ២១:១–៤៥)។

***លោកយ៉ូសែបបានក្លាយជាឪពុករបស់អំបូរ២ នៅក្នុងប្រទេសអ៊ីស្រាអែល នៅពេលលោកយ៉ាកុបទទួលចិញ្ចឹមកូនប្រុសទាំង២របស់គាត់ គឺអេប្រាអិម និងម៉ាន៉ាសេ ។

## កាលដើមដំបូង

**១** [១]កាលដើមដំបូងឡើយ[ក] ព្រះបានបង្កើត[ខ]ផ្ទៃមេឃ[គ] និង
ផែនដី[ឃ] ។
[២]ឯផែនដីបានខូច[ង] ហើយនៅទទេ[ច]មានសុទ្ធតែងងឹតនៅ
គ្របលើជំរៅទឹក[ឆ] ហើយព្រះវិញ្ញាណនៃព្រះ[ជ]ក៏រេរា[ឈ]នៅ
ពីលើទឹក [៣]នោះព្រះទ្រង់មានបន្ទូលថា[ញ] ចូរឱ្យមានពន្លឺ

**១:១** ក ទដ ១០២:២៥ សក ៨:២៣ អស ៤០:២១ ៤១:៤,២៦ យហ ១:១–២ ខ ខ.២១,២៧ លប ២:៣ គ ខ.៦ នហ ៩:៦ យប ៩:៨ ៣៧:១៨ ទដ ៩៦:៥ ១០៤:២ ១១៥:១៥ ១២១:២ ១៣៦:៥ អស ៤០:២២ ៤២:៥ ៥១:១៣ យរ ១០:១២ ៥១:១៥ ឃ លប ១៤:១៩ ២ពវ ១៩:១៥ នហ ៩:៦ យប ៣៨:៤ ទដ ៩០:២ ១៣៦:៦ ១៤៦:៦ អស ៣៧:១៦ ៤០:២៨ ៤២:៥ ៤៤:២៤ ២៥:១២,១៨ យរ ២៧:៥ ៣២:១៧ កច ១៤:១៥ ១៧:២៤ អភ ៣:៩ កល ១:១៦ ហព ៣:៤ ១១:៣ វវ ៤:១១ ១០:៦ **១:២** ង អស ២៣:១ ២៤:១០ ២៧:១០ ៣២:១៤ ៣៤:១១ ច អស ៤៥:១៨ យរ ៤:២៣ ឆ លប ៨:២ យប ៧:១២ ២៦:៨ ៣៨:៩ ទដ ៣៦:៦ ៤២:៧ ១០៤:៦ ១០៧:២៤ ទដ ៣០:៤ ជ លប ២:៧ យប ៣៣:៤ ទដ ១០៤:៣០ អស ៣២:១៥ ឈ ចទ ៣២:១១ អស ៣១:៥ **១:២** ង អស ២៣:១ ២៤:១០ ២៧:១០ ៣២:១៤ ៣៤:១១ ច អស ៤៥:១៨ យរ ៤:២៣ ឆ លប ៨:២ យប ៧:១២ ២៦:៨ ៣៨:៩ ទដ ៣៦:៦ ៤២:៧ ១០៤:៦ ១០៧:២៤ ទដ ៣០:៤ ជ លប ២:៧ យប ៣៣:៤ ទដ ១០៤:៣០ អស ៣២:១៥ ឈ ចទ ៣២:១១ អស ៣១:៥ **១:៣** ញ ខ.៦ ទដ ៣៣:៦,៩ ១៤៨:៥ ហព ១១:៣ ដ ២កថ ៤:៦ ១យហ ១:៥–៧

**១:១–២:៣** ប្រជាជនដែលរស់នៅតំបន់មជ្ឈឹមបូព៌ា កាលពីសម័យបុរាណ គេតែងតែពិពណ៌នា ដែលទាក់ទងទៅនឹងរបៀបដែលពិភពលោកនេះបានកើតឡើងយ៉ាងដូចម្ដេច ។ សាច់រឿងទូទៅនៅក្នុងនិទានកថាទាំងអស់នោះ គឺបានពណ៌នាថា មានព្រះ១អង្គក្នុងចំណោមព្រះជាច្រើនបានទទួលជ័យជម្នះ លើអំណាចនិងភាពកាចសាហាវរបស់សត្វ និងមនុស្សដែលគ្មានសណ្ដាប់ធ្នាប់ដូចដែលបានឃើញស្រាប់ដែលមានលើ លោកិយយើងនេះ ប៉ុន្ដែបែរជាមានព្រះដទៃទៀតបាននិយាយថា ខ្លួនគេគឺជាព្រះ "ស្ដេច" ដែលបានគ្រប់គ្រងលើរបស់ដែលត្រូវបានបង្កើតឡើង ។ អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិ គាត់បានបដិសេធន៍ចំពោះទស្សនៈរបស់ទេវកថាទាំងនោះ ដោយគាត់បានបង្រៀននូវមូលដ្ឋានគ្រឹះនៃគោលលទ្ធិថ្មីមួយ ស្ដីពីការបង្កើតថា ព្រះជាម្ចាស់នៃសេចក្ដីពិតតែមួយទ្រង់មិនបាន ធ្វើការប្រកួតប្រជែងយកអំណាចធ្វើឱ្យមានភាពច្របូកច្របល់នោះឡើយ ប៉ុន្ដែព្រះអង្គគ្រាន់តែចង់បង្ហាញឱ្យយើងបានដឹងថា តាមរយៈការបង្កើតលោកិយក្រោមព្រះរាជបង្គាប់របស់ព្រះអង្គជាដំណាក់កាល ដែលមានតាំងពីដំបូងមក គឺពោរពេញដោយសណ្ដាប់ធ្នាប់ ហើយព្រះរាជបន្ទូល របស់ព្រះអង្គកំពុងបន្ដលើកតម្កើង និងគ្រប់គ្រងលើអាណាចក្រដែលមនុស្សទាំងអស់ បានមើលឃើញនេះ ។ អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិគាត់បានបង្រៀនយើង អំពីគោលលទ្ធិនៃការបង្កើតនេះរៀបរាប់ ដោយគាត់បានលើកយករឿងរ៉ាវសកម្មភាពនៃការបង្កើតរបស់ព្រះអម្ចាស់មករ៉ាយរ៉ាប់ពន្យល់យើងឱ្យយល់ ។ អ្នកនិពន្ធបានរៀបរាប់ពីសកម្មភាពនៃការបង្កើតទាំងនោះ ចេញពីទស្សនៈវិស័យរបស់មនុស្សម្នាក់ដែលជាសាក្សី នៃការបង្កើតរបស់ព្រះអង្គ ។ សម្រាប់ទស្សនៈវិស័យដែលស្ដីពីការពិពណ៌នាដែលមានភាពប្រហាក់ប្រហែលគ្នានឹងនិទានកថានៅទីនេះ សូមមើល យប ១:៦–១២ ២:១–៦ ។

**១:១** នៅខនេះគឺជាកថាដ៏សង្ខេបមួយ ដែលជាសេចក្ដីផ្ដើមនៃការបង្កើតទាំង៦ថ្ងៃ (សូមមើលការពន្យល់ ២:១) ។ សេចក្ដីពិតដែលបានពណ៌នានៅក្នុងខនេះ ត្រូវបានបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់នៅក្នុងកណ្ឌកំណាព្យ (ទដ ១០២:២៥) និងនៅក្នុងកណ្ឌនៃពួកហោរា (អស ៤០:២១) ។ *កាលដើមដំបូងឡើយព្រះ* នៅក្នុងឃ្លានេះចង់បញ្ជាក់ប្រាប់ថា ជានិច្ចកាលព្រះគម្ពីរតែងតែនិយាយដោយធ្វើការសន្មត ប៉ុន្ដែមិនដែលមានជម្លោះអ្វីកើតឡើងនោះឡើយ ពីព្រោះភាពស្ថិតស្ថេររបស់ព្រះអង្គ ។ ទោះបីជាអ្វីៗទាំងអស់ទើបនឹងចាប់ផ្ដើមក៏ដោយ ក៏ព្រះអម្ចាស់ទ្រង់ជាព្រះតាំងពីអស់កល្បរហូតដល់អស់កល្បជានិច្ច (សូមមើល ទដ ៩០:២)។ *កាលដើមដំបូងឡើយ* នៅក្នុងឃ្លានេះគឺដូចគ្នានឹងឃ្លាដែលស្ដីពីការងារ ឬព្រះរាជកិច្ចរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដែលព្រះអង្គទ្រង់បានបង្កើតលោកិយឡើងដែលមាននិយាយនៅក្នុង យហ ១:១–១០ ។ *ព្រះបានបង្កើត* ពាក្យថា "ព្រះ" នៅក្នុងភាសាហេព្រើរគឺ "អេឡូហ៊ីម" (Elohim) ពាក្យនេះជានាមពហុវចនៈ ប៉ុន្ដែបើកិរិយាស័ព្ទវិញ ពាក្យថា "ព្រះ" នេះគឺជាឯកវចនៈដែលមនុស្សជាច្រើនបានប្រើជាសាមញ្ញទៅហើយនៅក្នុងសញ្ញាចាស់ នៅពេលដែលគេចង់និយាយទៅលើព្រះពិតតែមួយ ។ នៅក្នុងឃ្លានេះត្រូវបានគេប្រើជាពហុវចនៈសម្រាប់ពណ៌នាពីអំណាចដ៏ខ្លាំងពូកែ វិសាលភាព និងសក្ដានុភាពរបស់ព្រះម្ចាស់ ។ កិរិយារស័ព្ទព្រះគម្ពីរភាសាហេព្រើរនៃពាក្យ "បង្កើត" ដែលនិយាយនៅក្នុងគម្ពីរសញ្ញាចាស់ គឺគេប្រើដើម្បីពណ៌នាពីព្រះអម្ចាស់ប៉ុណ្ណោះ មិនដែលមានគេនិយាយពីមនុស្សនោះឡើយ ។ *ផ្ទៃមេឃ និងផែនដី* នៅក្នុងឃ្លានេះគឺចង់និយាយពីអ្វីៗទាំងអស់ ដែលព្រះអម្ចាស់ទ្រង់ជាអ្នក បង្កើតឡើង (សូមមើល អស ៤៤:២៤) ។ នៅក្នុងព្រះគម្ពីរមួយចំនួនទៀតដូចជា សស ១១:៥ យរ ១០:១៦ យហ ១:៣ កល ១:១៦ ហព ១:២ ក៏បាននិយាយថា ព្រះអម្ចាស់ទ្រង់ជាអ្នកបង្កើតគ្រប់ទាំងអស់ដែរ ។

**១:២** *ផែនដី* នៅក្នុងឃ្លានេះ គឺចង់និយាយសំដៅលើកិច្ចការងារបង្កើតតែម្ដង ។ *ផែនដីបានខូចហើយនៅទទេ* ឃ្លានេះនឹងឃើញមាននិយាយម្ដងទៀតតែនៅក្នុង យរ ៤:២៣ ប៉ុណ្ណោះ (សូមមើលការពន្យល់ក្នុង ខ.១១) ។ ការ "ញែកចេញ" និងការ "ប្រមូលផ្ដុំ" របស់ព្រះអម្ចាស់នៅក្នុងថ្ងៃទី១–៣ ដើម្បីធ្វើឱ្យមានទម្រង់ឡើង ហើយការ "បង្កើត" និងការ "សំរេច" របស់ព្រះអង្គដែលមានតាំងពីថ្ងៃទី៤–៦គឺដើម្បីផ្លាស់ពីភាពទទេ ។ *ងងឹត... ទឹក* នៅក្នុងឃ្លានេះចង់មានន័យថា ដើម្បីឱ្យពិភពលោកដែលព្រះអម្ចាស់ទ្រង់បង្កើតមកគ្រប់លក្ខណៈ គឺត្រូវការរងចាំឱ្យមានពន្លឺមកពីព្រះអម្ចាស់ផ្ដល់ឱ្យ ។ *ហើយ* ឬ "ប៉ុន្ដែ" ការភ័យខ្លាចគឺជាទិដ្ឋភាពដើមដំបូងនៃការបង្កើត ដែលយើងមើលឃើញនេះ គឺទទួលរងដោយព្រះវិញ្ញាណដ៏មានអំណាចរបស់ព្រះអម្ចាស់ដែលរេរាលើគ្រប់ទាំងអស់នៃការបង្កើតរបស់ព្រះអម្ចាស់ ។ *ព្រះវិញ្ញាណនៃព្រះ* ព្រះវិញ្ញាណនៃព្រះអម្ចាស់ គឺមានសកម្មភាពរស់រវើកក្នុងការបង្កើត ហើយអំណាចនៃការច្នៃប្រឌិតរបស់ទ្រង់កំពុងបន្ដរហូតដល់សព្វថ្ងៃនេះ (សូមមើល យប ៣៣:៤ ទដ ១០៤:៣០) ។ *រេរាពីលើ* ត្រង់ចំណុចនេះចង់មានន័យថា ព្រះវិញ្ញាណនៃព្រះទ្រង់រេរាពីលើទឹក ដូចជាឥន្ទ្រីដែលរេរាពីលើកូនវា ពេលដែលកូនរៀនហើរកាលពីនៅតូចដូច្នេះដែរ (សូមមើល ចទ ៣២:១១ ធៀបនឹង អស ៣១:៥) ។

**១:៣** *ព្រះទ្រង់មានបន្ទូលថា* នៅទីនេះចង់មានន័យថា ព្រះអម្ចាស់ទ្រង់បានប្រើព្រះបន្ទូលរបស់ព្រះអង្គក្នុងការបង្កើត តាំងពីដើមដំបូងមកម្ល៉េះ (សូមមើលក្នុង ទដ ៣៣:៦ ១៤៨:៥ ហព ១១:៣) ។ *ចូរឱ្យមានពន្លឺ* ការបង្កើតដំបូងរបស់ព្រះអម្ចាស់គឺឱ្យមានពន្លឺនៅកណ្ដាលងងឹត ។ ហេតុដែលព្រះអង្គបានបង្កើតឱ្យមានពន្លឺមុនងងឹត ពីព្រោះពន្លឺមានសារៈសំខាន់ណាស់ដើម្បីឱ្យការបង្កើតរបស់ព្រះអង្គមានសកម្មភាពរស់រវើក និងដើម្បីទ្រទ្រង់ជីវិត

ឡើង ដូច្នេះពន្លឺក៏មានឡើង[ដ] ៤ព្រះទ្រង់ឃើញពន្លឺនោះក៏
យល់ថាល្អហើយ[ឋ] រួចទ្រង់ញែកពន្លឺពីងងឹតចេញ[ឌ] ៥ទ្រង់
ហៅ[ឍ]ពន្លឺថាជាថ្ងៃ ហើយហៅងងឹតថាជាយប់[ណ] នោះក៏
មានល្ងាច មានព្រឹកឡើង[ត] ជាថ្ងៃទី១ ។
៦បន្ទាប់មកព្រះទ្រង់មានបន្ទូលថា[ថ] ចូរឱ្យមានប្រឡោះ[ទ]
នៅកណ្ដាលទឹក ដើម្បីញែកទឹកចេញពីគ្នា[ធ] ៧ទ្រង់ក៏ធ្វើ
ប្រឡោះនោះ ទាំងញែកទឹកដែលនៅក្រោមប្រឡោះចេញ
ពីទឹកដែលនៅលើប្រឡោះ[ន] ក៏មានដូច្នោះ[ប] ៨រួចព្រះទ្រង់
ហៅ[ផ]ប្រឡោះនោះថាជាមេឃ[ព] នោះក៏មានល្ងាចមានព្រឹក
ឡើង[ភ]ជាថ្ងៃទី២ ។
៩បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរឱ្យទឹកនៅក្រោម
មេឃប្រមូលគ្នានៅកន្លែងតែ១[ម] ហើយឱ្យមានទីគោក[យ]ដុះ
លេចឡើង នោះក៏មានដូច្នោះ[រ] ១០ទ្រង់ហៅ[ល]ទីគោកនោះ
ថាជាដី ហើយទីទឹក[វ]ដែលប្រមូលគ្នានោះថាជាសមុទ្រ[ស]
នោះទ្រង់ក៏ឃើញថាល្អ[ហ] ១១រួចព្រះទ្រង់មានបន្ទូលថា ចូរ
ឱ្យដីដុះតិណជាតិឡើង[ឡ] គឺជាពួកស្មៅដែលមានគ្រាប់ និង
រុក្ខជាតិមានផ្លែតាមពូជ ដែលមានគ្រាប់ក្នុងផ្លែនោះនៅ
ផែនដី[អ] នោះក៏មានដូច្នោះ[ក] ១២ដីក៏ដុះតិណជាតិទាំងឡាយ
ឡើង គឺពួកស្មៅដែលមានគ្រាប់តាមពូជ[ខ] និងរុក្ខជាតិមាន
ផ្លែតាមពូជដែរ ហើយមានគ្រាប់នៅក្នុងផ្លែនោះឯង រួច
ទ្រង់ឃើញថាល្អ[គ] ១៣នោះក៏មានល្ងាចមានព្រឹកឡើង[ឃ] ជា

**១:៤** ឋ ខ.១០,១២,១៨,២១,២៥,៣១ ទដ ១០៤:៣១ ១១៩:៦៨ យរ ៣១:៣៥ ឌ ខ.១៤ នក ១០:២១–២៣ យប ២៦:១០ ៣៨:១៩ ទដ ១៨:២៨ ១០៤:២០ ១០៥:២៨ អស ៤២:១៦ ៤៥:៧ **១:៥** ឍ ខ.៨,១០ លប ២:១៩,២៣ ណ ទដ ៧៤:១៦ ត ខ.៨,១៣,១៩,២៣,៣១ **១:៦** ថ ខ.៣ ទ ខ.១ អស ៤៤:២៤

២ពត ៣:៥ ធ ខ.៩ ទដ ២៤:២ ១៣៦:៦ **១:៧** ន លប ៧:១១ យប ២៦:១០ ៣៨:៨–១១,១៦ ទដ ៦៨:៣៣ ១៤៨:៤ សភ ៨:២៨ ប ខ.៩,១១,១៥,២៤ **១:៨** ផ ខ.៥ ព យប ៩:៨ ៣៧:១៨ ទដ ១៩:១ ១០៤:២ អស ៤០:២២ ៤៤:២៤ ៤៥:១២ យរ ១០:១២ សក ១២:១ ភ ខ.៥ **១:៩** ម យប ៣៨:៨–១១ ទដ ៣៣:៧ ១០៤:៦–៩ សភ ៨:២៩ យរ ៥:២២ ២ពត ៣:៥ យ ទដ ៩៥:៥ យហ ១:៩ ហក ២:៦ រ ខ.៧ **១:១០** ល ខ.៥ វ ទដ ៣៣:៧ ស យប ៣៨:៨ ទដ ៩០:២ ៩៥:៥ ហ ខ.៤ **១:១១** ឡ ទដ ៦៥:៩–១៣ ១០៤:១៤ អ ខ.១២,២១,២៤,២៥ លប ២:៥ ៦:២០ ៧:១៤ លវ១:១៤,១៩,២២ ចទ ១៤:១៣, ១៨ ក ខ.៧ **១:១២** ខ ខ.១១ គ ខ.៤ **១:១៣** ឃ ខ.៥

ទាំងឡាយ ។ ក្នុងព្រះគម្ពីរសញ្ញាចាស់"ពន្លឺ"គឺជានិមិត្តរូបនៃជីវិតនិងព្រះពររបស់ព្រះអម្ចាស់(សូមមើល ២សយ ២២:២៩ យប ៣:២០ ៣០:២៦ ៣៣:៣០ ទដ ៤៩:១៩ ៥៦:១៣ ៩៧:១១ ១១២:៤ អស ៥៣:១១ ៥៨:៨,១០ ៥៩:៩ ៦០:១,៣)។ លោកសាវ័កប៉ុលបានប្រើពាក្យនេះ ដើម្បីពន្យល់អំពីការបង្កើតពន្លឺឡើងវិញរបស់ព្រះអង្គនៅក្នុងអំពើបាប ដែលអំពើបាបនោះគឺជាសេចក្ដីងងឹតនៅក្នុងចិត្ត(សូមមើល ២កថ ៤:៦)។

**១:៤** នៅក្នុងខនេះចង់និយាយថា គ្រប់ទាំងអស់ដែលព្រះបង្កើតមកគឺសុទ្ធតែល្អ(សូមមើល ខ.១០,១២,១៨,២១,២៥)។ ព្រះអម្ចាស់ទ្រង់បានមានបន្ទូលថា"ល្អណាស់"(ខ.៣១)។ ព្រះអម្ចាស់ទ្រង់បានធ្វើឱ្យរបស់ទាំងអស់ដែលទ្រង់បង្កើតមក ពេញដោយសណ្ដាប់ធ្នាប់ ពេញដោយពន្លឺ ហើយក៏គ្មានអ្វីមួយដែលព្រះអម្ចាស់បង្កើតមកដើម្បីឱ្យទាស់ប្រឆាំងជាមួយព្រះអម្ចាស់ និងរាស្ត្ររបស់ព្រះអង្គដែរ ។ សូម្បីតែងងឹតនិងទីជម្រៅដែលឃើញមាននៅក្នុងលោកិយនេះ គឺសម្រាប់ជាព្រះពរ និងទ្រទ្រង់ជីវិតទាំងឡាយដែលមាន(មើលការពន្យល់ ទដ ១០៤:១៩–២៦ ១២៧:២) ។

**១:៥** *ហៅ* សូមមើលការពន្យល់ក្នុង ខ.៨ និង ខ.១០ ។ នៅមជ្ឈឹមបូព៌ាកាលពីសម័យបុរាណ កាលណាស្ដេចដាក់ឈ្មោះឱ្យមនុស្សម្នាក់ឬវត្ថុអ្វីមួយត្រូវបានគេប្រកាសជាសាធារណៈដើម្បីឱ្យបណ្ដាជនផ្សេងៗទៀតបានដឹងឮ(សូមមើល ១៧:៥,១៥ ៤១:៤៥ ២ពវ ២៣:៣៤ ២៤:១៧ ដយ ១:៧) ។ នៅក្នុងការបង្កើតរបស់ព្រះអង្គ ទ្រង់បានដាក់ឈ្មោះឱ្យរបស់ដែលទ្រង់បានបង្កើតដោយផ្ទាល់ដែលមានដូចជា ថ្ងៃ យប់ មេឃ ដី និងសមុទ្រ ។ ព្រះអង្គទ្រង់បានអនុញ្ញាតិឱ្យមនុស្សដំបូងដែលព្រះអង្គបង្កើតមក បានដាក់ឈ្មោះលើការបង្កើតទាំងឡាយដែលមានជីវិត ហើយឱ្យគ្រប់គ្រងលើ (សូមមើលការពន្យល់ក្នុងខ.២៦ ២:១៩) ។ *ថ្ងៃទី១* មានអ្នកខ្លះបាននិយាយថា ព្រះអម្ចាស់ទ្រង់បានធ្វើការបង្កើតរយៈពេល២៤ម៉ោងក្នុង១ថ្ងៃហើយអ្នកខ្លះទៀតនិយាយថាគ្មានពេលកំណត់ឡើយ ។

**១:៦** *ប្រឡោះ* ប្រឡោះដែលបាននិយាយនៅកន្លែងនេះ គឺសំដៅលើ"ផ្ទៃមេឃ"(សូមមើល ខ.៨) ដែលយើងមើលឃើញពីផែនដីនេះទៅ ។ "រឹងដូចកញ្ចក់"(សូមមើល យប ៣៧:១៨)ហើយ"ដូចជាបាររាំ" (សូមមើល អស ៤០:២២) គឺជារូបភាពមួយក្នុងចំណោមរូបភាពជាច្រើនទៀតដែលអ្នកនិពន្ធបានលើកមកដើម្បីធ្វើការពណ៌នាអំពីប្រឡោះនេះប៉ុណ្ណោះ ។

**១:៧** *ក៏មានដូច្នេះ* នៅកន្លែងនេះគឺចង់និយាយតែលទ្ធផលដែលវិជ្ជមានប៉ុណ្ណោះទោះបីវាជាការ ថ្លែងដោយពិត (សូមមើល ខ.៩,១១,១៥,២៤,៣០) ឬការប្រៀបធៀប ចំពោះពាក្យដែលព្រះអង្គទ្រង់បានមានបន្ទូលថា "ចូរឱ្យមាន" (សូមមើលការពន្យល់ ទដ ៣៣:៦,៩) ។

**១:៩** *កន្លែងតែ១* ពាក្យថាកន្លែងតែ១ដែលនិយាយនេះគឺសំដៅទៅលើសមុទ្រ(ខ.១០)ដែលនៅជុំវិញទីដីគោកទាំងអស់ ហើយដីនោះបានដុះចេញពីទឹកទន្លេ និងទឹកសមុទ្រ (សូមមើលក្នុង ២ពត ៣:៥) ហើយបាន "តាំងឱ្យមាំមួននៅលើទឹកទាំងពួង"(សូមមើល ទដ ២៤:២) ហើយទឹកមិនអាច"ហូរលើព្រំខណ្ឌដែលបានកំណត់" បានឡើយ (សូមមើលការពន្យល់ ទដ ១០៤:៧–៩ យរ ៥:២២)។

| *ថ្ងៃបង្កើត* | *ថ្ងៃដែលរួចរាល់* |
|---|---|
| ១. "ពន្លឺ"( ខ៣) | ៤. "តួពន្លឺ "(ខ១៤) |
| ២."ទឹកនៅក្រោមប្រឡោះ.....ទឹកនៅពីលើពីលើប្រឡោះ" (ខ៧) | ៥."ជីវិតទាំងឡាយដែលកំរើក និងកើតមាន រវិនរវល់នៅក្នុងទឹកតាមពូជ ហើយគ្រប់ទាំងសត្វស្លាបដែរ"(ខ២១)។ |
| ៣.ក "ទីគោក" (ខ៩) | ៦.ក១"សត្វស្រុក សត្វលូនវារ នឹងសត្វ ព្រៃនៅផែនដីតាពូជ"(ខ២៤)។ ៦.ក២ " មនុស្ស " (ខ ២៦) |
| ៣.ខ " តិណជាតិ "(ខ១១) | ៦.ខ អស់ទាំងរុក្ខជាតិខ្ចីៗទុកជាអាហារ" ខ៣០) |

**១:១១** *ព្រះទ្រង់មានបន្ទូល* នៅក្នុងថ្ងៃទី៣នៃការបង្កើតរបស់ព្រះអង្គ ឃ្លានេះបានប្រើពាក្យ២ដង (មើល ខ.៩,១១) ហើយ៣ដងនៅក្នុងថ្ងៃទី៦នៃការបង្កើតរបស់ព្រះអង្គ (មើល ខ.២,៤,២៦,២៩) ។ បើប្រៀបធៀបទៅនឹងការទាំង២ គឺការរៀបចំឡើងវិញ និងការដែលនៅទំនេមិនអាចកំណត់"ព្រំខណ្ឌ"បានឡើយ(មើលការពន្យល់ ទដ ១០៤:៧–៩ យរ ៥:២២) ។

ថ្ងៃទី៣ ។
១៤ បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរឱ្យមានតួពន្លឺ[ង]
នៅនាផ្ទៃមេឃ ដើម្បីនឹងញែកថ្ងៃចេញពីយប់[ច] សំរាប់ទុក
ជាទីសំគាល់[ឆ]នៃរដូវ[ជ] ថ្ងៃ និងឆ្នាំ[ឈ] ១៥ ហើយសំរាប់ជាពន្លឺ
នៅផ្ទៃមេឃ ដើម្បីបំភ្លឺមកផែនដី នោះក៏មានដូច្នោះ[ញ]
១៦ ទ្រង់ធ្វើពន្លឺធំជា២តួ ១ដែលធំជាង[ដ] នោះសំរាប់បំភ្លឺ[ឋ]ក្នុង
ពេលថ្ងៃ ហើយ១ដែលតូចជាងសំរាប់បំភ្លឺ[ឌ]ក្នុងពេលយប់[ឍ]
ក៏ធ្វើឱ្យមានផ្កាយទាំងប៉ុន្មានដែរ[ណ] ១៧ ទ្រង់ដាក់តួពន្លឺទាំង
នោះនៅផ្ទៃមេឃ សំរាប់នឹងបំភ្លឺមកលើផែនដី ១៨ ឱ្យមាន
អំណាចនៅពេលថ្ងៃនិងពេលយប់[ត] ហើយឱ្យញែកពន្លឺ
ចេញពីងងឹត រួចទ្រង់ឃើញថាជាល្អ[ថ] ១៩ នោះក៏មានល្ងាច
មានព្រឹកឡើង[ទ]ជាថ្ងៃ ទី៤ ។
២០ បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរឱ្យមានមច្ឆាជាតិ
រវើកនៅក្នុងទឹកជាបរិបូរ[ធ] និងបក្សីជាតិហើរលើដីនៅនា
អាកាស[ន] ២១ ទ្រង់ក៏បង្កើត[ប]អស់ទាំងសត្វសំបើមៗ[ផ] និង
ជីវិតទាំងឡាយដែលកំរើក ដែលកើតមានរវិនរវ័ណ្ឌនៅ
ក្នុងទឹកតាមពូជ[ព] ហើយអស់ទាំងសត្វស្លាបតាមពូជដែរ[ភ] រួច

**១:១៤** ង ទដ ៧៤:១៦ ១៣៦:៧ ច ខ.៤ ឆ យរ ១០:២ ជ ទដ ១០៤:១៩ ឈ លប ៨:២២ យរ ៣១:៣៥–៣៦ ៣៣:២០,២៥ **១:១៥** ញ ខ.៧ **១:១៦** ដ ចទ ១៧:៣ យប ៣១:២៦ យរ ៤៣:១៣ អគ ៨:១៦ ឋ ទដ ១៣៦:៨ ឌ ១៣៦:៩ ឍ យប ៣៨:៣៣ ទដ ៧៤:១៦ ១០៤:១៩ យរ ៣១:៣៥ យក ១:១៧ ណ ចទ ៤:១៩ យប ៩:៩ ៣៨:៧ ៣១–៣២ ទដ ៨:៣ ៣៣:៦ សស ១២:២ អស ៤០:២៦ យរ ៨:២ អម ៥:៨

ទ្រង់ឃើញថាល្អ[ម] ២២ ទ្រង់ក៏ប្រទានពរដល់សត្វទាំងឡាយ
នោះ ហើយមានបន្ទូលថា ចូរបង្កើតកូនឱ្យចំរើនជាច្រើន
ឡើង ឱ្យមានពេញពាសនៅក្នុងទឹកសមុទ្រ ហើយឱ្យសត្វ
ស្លាបចំរើនឡើងនៅផែនដីដែរ[យ] ២៣ នោះក៏មានល្ងាចមាន
ព្រឹកឡើង[រ] ជាថ្ងៃទី៥ ។
២៤ បន្ទាប់មក ព្រះទ្រង់មានបន្ទូលថា ចូរឱ្យមានចតុប្បាទ[ល]
ជាតិកើតមកនៅដីគោកតាមពូជ[វ] គឺជាសត្វស្រុកសត្វលូនវារ
និងសត្វព្រៃនៅផែនដីតាមពូជ នោះក៏មានដូច្នោះ[ស] ២៥ ទ្រង់
ក៏ធ្វើសត្វព្រៃ[ហ]នៅផែនដីតាមពូជ សត្វស្រុកតាមពូជ ហើយ
គ្រប់ទាំងសត្វដែលលូនវារនៅដីគោកតាមពូជដែរ[ឡ] រួច
ទ្រង់ឃើញថាល្អ[អ] ២៦ ទ្រង់ក៏មានបន្ទូលថា ចូរយើង[ក]ធ្វើ

**១:១៨** ត យរ ៣៣:២០,២៥ ថ ខ.៤ **១:១៩** ទ ខ.៥ **១:២០** ធ ទដ ១៤៦:៦ ន លប ២:១៩ **១:២១** ប ខ.១៨ យប ៣:៨ ៧:១២ ទដ ៧៤:១៣ ១៤៨:៧ អស ២៧:១ អគ ៣២:២ ព ទដ ១០៤:២៥–២៦ ភ ខ.១១ ម ខ.៤ **១:២២** យ ខ.២៨ លប ៨:១៧ ៩:១៧,១៩ ៤៧:២៧ លវ ២៦:៩ អគ ៣៦:១១ **១:២៣** រ ខ.៥ **១:២៤** ល លប ២:១៩ វ ខ.១១ ស ខ.៧ **១:២៥** ហ លប ៧:២១–២២ យរ ២៧:៥ ឡ ខ.១១ អ ខ.៤ **១:២៦** ក លប ៣:៥, ២២ ១១:១៧ ទដ ១០០:៣ អស ៦:៨

**១:១៤** *ទុកជាទីសំគាល់* នៅក្នុងកន្លែងនេះគឺចង់មានន័យចំៗតែម្តង មិនមែនសំដៅលើមាត្រដ្ឋានផ្សេងៗនោះឡើយ ។

**១:១៦** *ពន្លឺធំជា២* ពាក្យថា"ព្រះអាទិត្យ" និង"ព្រះចន្ទ" មើលទៅហាក់ដូចជាបានដាច់ចេញពីគ្នាដោយសារមានការរៀបចំទុកជាមុន ។ ព្រោះថា ទាំង២នេះគឺត្រូវបានអ្នកមិនជឿព្រះគិតថា វាជារូបកាយមួយនៃស្ថានសួគ៌ ។ តាមពិតពួកវាគ្រាន់តែជាតួពន្លឺមួយ ដែលមនុស្សកោតសរសើរប៉ុណ្ណោះ មិនមែនសម្រាប់ឱ្យមនុស្សកោតខ្លាចនោះឡើយ ពីព្រោះព្រះគឺជាម្ចាស់ នៃសេចក្តីពិតជាអ្នកបង្កើតឡើង (សូមមើល អយ ៤០:២៦) ។ តាំងពីមានពន្លឺធំទាំង២គឺមាន១ធំជាងហើយមួយទៀតតូចជាង ផ្កាយមើលទៅដូចជាមិនត្រូវបានគេយកចិត្តទុកដាក់ឡើយ ។ ប៉ុន្តែបើសិនជាយើងមើល ទដ ១៣៦:៩ បានចែងមកដូច្នេះថា ហ្វូងផ្កាយបានជួយដល់ព្រះចន្ទ "សម្រាប់បំភ្លឺ នៅពេលយប់"។ ព្រះអាទិករ គឺជាមហាក្សត្រដែលបានបង្គាប់ឱ្យសត្វលោកទាំងអស់ ដែលទ្រង់បង្កើតមកយ៉ាងមានសណ្តាប់ធ្នាប់ (មើល ខ.២៦,២៨) ។

**១:១៧–១៨** មុខងារសំខាន់ៗទាំង៣នេះគឺជារូបកាយរបស់ស្ថានសួគ៌ ។

**១:២១** *រវិនរវណ្ឌ័នៅក្នុងទឹក* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះត្រូវបានប្រើនៅក្នុងរឿងព្រេងរបស់ពួកកាណាន ដែលបានដាក់ឈ្មោះឱ្យសមុទ្រដ៏គួរឱ្យខ្លាចមួយ ។ ជាញឹកញាប់គាត់បានប្រើពាក្យប្រៀបធៀបកំណាព្យក្នុងសញ្ញាចាស់ គឺសំដៅទៅលើព្រះដែលមានអំណាចទាស់ប្រឆាំង ។ ព្រះយេហូវ៉ាទ្រង់គឺជាតម្រុយរបស់ប្រជាជាតិបាប៊ីឡូន យរ ៥១:៣៤ អេស៊ីព្ទ អស ៥១:៩ អរ ២៩:៣ ៣២:២) ឬក៏ជារឿងនិទាន យប ៧:១២ ទដ ៧៤:១៣ អស ២៧:១ ថ្វីដ្បិតតែមានអ្នកខ្លះនិយាយថា វាសំដៅទៅលើអេស៊ីព្ទក៏ដោយ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងគម្ពីរលោកុប្បត្តិរវិនរវណ្ឌ័នៅក្នុងទឹកគឺជារូបដែលមិនមែនជាសត្រូវដែលគួរឱ្យខ្លាចឡើយ ប៉ុន្តែគឺជាផ្នែកមួយនៃការបង្កើតរបស់ព្រះ ដើម្បីឱ្យយើងបានសរសើរប៉ុណ្ណោះ (មើលការពន្យល់ ទដ ១០៤:៦) ។

**១:២២** *ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង* នៅត្រង់ចំណុចនេះព្រះអម្ចាស់ទ្រង់បានប្រសិទ្ធិពរជ័យដល់បណ្តាសត្វទាំងឡាយដែលរស់នៅក្នុងទឹក និងហើរលើអាកាស ។ ដោយសារមានការប្រសិទ្ធិពរមកពីព្រះអម្ចាស់ បានធ្វើឱ្យសត្វទាំងអស់នោះមានការរីកចម្រើន និងកើតកូនចម្រើនឡើងពាសពេញផែនដី (សូមមើលខ.២៨) ។ តាមរយៈការគ្រប់គ្រងរបស់ព្រះលើបណ្តាជីវិតទាំងឡាយ ដែលមាននៅក្នុងលោកិយនេះ បានធ្វើឱ្យពួកគេមានតម្លៃ និងរស់នៅប្រកបដោយព្រះពរមកពីព្រះអម្ចាស់ ។

**១:២៦** *យើង . . . យើង . . . យើង* នៅកន្លែងនេះព្រះអម្ចាស់ទ្រង់បានមានបន្ទូលមកកាន់ព្រះអង្គផ្ទាល់ប្រៀបដូចជាព្រះអង្គបានមានបន្ទូលទៅកាន់ពលបរិវាររបស់ព្រះអង្គនៅក្នុងដំណាក់របស់ទ្រង់ដែរ (សូមមើលការពន្យល់ ៣:២២ ១១:៧ អស ៦:៨ និង ១ពវ ២២:១៩–២៣ យប ១៥:៨ យរ ២៣:១៨) ។ *ជារូប . . . ឱ្យមានភាពដូច* នៅក្នុងចំណុចនេះចង់និយាយថា គ្មានការវែកញែកណាដែលបញ្ជាក់ថា មនុស្សត្រូវតែបង្កើតដើម្បីឱ្យមាន "ជារូប" និង"មានរូបដូច" ព្រះអង្គនោះឡើយ ទោះទាំងសញ្ញាចាស់ (សូមមើលការពន្យល់ ៥:១៩:៦) និងសញ្ញាថ្មី (មើល ១កថ ១១:៧ កល ៣:១០ យក ៣:៩) ។ នៅពេលដែលមនុស្សបានបង្កើតមកឱ្យមានភាពដូចជា អង្គទ្រង់ ពួកគេទាំអស់មានកិត្តិយសដ៏ធំ សក្តិសមទទួលការកោតសរសើរយ៉ាងក្រៃលែង មិនមែនសម្រាប់ឱ្យគេកំចាយឈាម (មើល ៩:៦) ហើយក៏មិនមែនសម្រាប់ឱ្យគេដាក់បណ្តាសានោះដែរ (សូមមើលការពន្យល់ យក ៣:៩) ។ ពាក្យថា "ឱ្យដូចជារូប" គឺដូចទាំងអត្តចរិតដែល "ស្មោះត្រង់ និងសុចរិត" (មើល អភ ៤:២៤) និង "សេចក្តីចេះដឹង" (សូមមើល កល ៣:១០) ។ អ្នកជឿគ្រប់រូបត្រូវតែ "ផ្លាស់ប្រែដើម្បីឱ្យដូចជា" ព្រះអង្គ (មើល រម ៨:២៩) ដើម្បីថ្ងៃណាមួយនឹងបាន ដូចជាទ្រង់តែម្តង (សូមមើល ១យហ

មនុស្ស[ខ]ឱ្យដូចជារូបយើង[គ] ឱ្យមានភាពដូចយើង[ឃ] ហើយឱ្យ
មានអំណាច[ង] លើត្រីសមុទ្រ សត្វហើរលើអាកាស[ច] និងសត្វ
ជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារ
ដែលវារនៅលើផែនដីផង ។
២៧ ទ្រង់ក៏បង្កើត[ឆ]មនុស្ស[ជ]ឱ្យដូចរូបអង្គទ្រង់[ឈ] គឺបានបង្កើត
គេឱ្យចំនឹងរូបអង្គទ្រង់នោះឯង[ញ] ក៏បង្កើតគេ[ដ]ឡើងជាប្រុស
ជាស្រី[ឋ]
២៨ ទ្រង់ប្រទានពរដល់គេ ហើយមានបន្ទូល[ឌ]ថា
ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង[ឍ] ឱ្យមានពេញពាស
លើផែនដីចុះ[ណ] ត្រូវបង្ក្រាបផែនដី[ត] ហើយមានអំណាចលើ
ត្រីសមុទ្រ សត្វហើរលើអាកាស និងជីវិតផងទាំងឡាយ
ដែលកំរើកនៅផែនដីផង[ថ]
២៩ ទ្រង់មានបន្ទូលថា មើល
អញឱ្យគ្រប់ទាំងតិណជាតិមានគ្រាប់ពូជដែលដុះនៅផែនដី
និងគ្រប់ទាំងតិណជាតិទាំងឡាយដែលកើតផ្លែ មានគ្រាប់
ពូជទុកជាអាហារដល់ឯង[ទ]
៣០ ហើយអញក៏ឱ្យគ្រប់ទាំង
តិណជាតិខ្ចីៗ ទុកជាអាហារ[ធ]ដល់អស់ទាំងសត្វនៅលើដី
សត្វហើរលើអាកាស និងសត្វលូនវារនៅដី ដែលមានជីវិត
ទាំងប៉ុន្មានដែរ[ន] នោះក៏មានដូច្នោះ
៣១ រួចព្រះទ្រង់ទត
គ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ[ប] ក៏ឃើញថាទាំងអស់
ជាការល្អប្រពៃ[ផ] នោះក៏មានល្ងាចមានព្រឹកឡើង[ព] ជា
ថ្ងៃទី៦ ។

**២**
១ ដូច្នេះផ្ទៃមេឃនិងផែនដីក៏បានរួចជាស្រេច ព្រមទាំង
របស់សព្វសារពើផង[ភ]
២ លុះដល់ថ្ងៃទី៧[ម] ការដែលព្រះ
ទ្រង់ធ្វើ នោះបានហើយជាស្រេច ទ្រង់ក៏ឈប់ផ្អាកសំរាក
នៅថ្ងៃទី៧នោះ ពីគ្រប់ទាំងការដែលទ្រង់ធ្វើ[យ]
៣ ព្រះទ្រង់

**១:២៦** ខ អស ៤៥:១៨ គ ខ.២៧ លប ៥:៣ ៩:៦ ទដ ៨:៥ ៨២:៦ ៨៩:៦ ១កថ ១១:៧ ២កថ ៤:៤ កល ១:១៥ ៣:១០ យក ៣:៩ ឃ កថ ១៧:២៨–២៩ ង លប ៩:២ ទដ ៨:៦–៨ច ទដ ៨:៨ **១:២៧** ឆ ខ.១ ជ លប ២:៧ ទដ ១០៣:១៤ ១១៩:៧៣ ឈ ខ.២៦ ញ លប ៥:១ ដ ចទ ៤:៣២ ឋ លប ៥:២ មថ ១៩:៤ មក ១០:៦ កទ ៣:២៨ **១:២៨** ឌ លប ៣៣:៥ យក ២៤:៣ ទដ ១១៣:៩ ១២៧:៣,៥ ឍ លប ១៧:៦ ណ ខ.២២ លប ៦:១ កថ ១៧:២៦ ត ខ.២៦ ទដ ១១៥:១៦ ថ ទដ ៨:៦–៨ **១:២៩** ទ លប ៩:៣ចទ ១២:១៥ ទដ ១០៤:១៤ ១ធថ ៤:៣ **១:៣០** ធ យប ៣៨:៤១ ទដ ៧៨:២៥ ១០៤:១៤,២៧ ១១១:៥ ១៣៦:២៥ ១៤៥:១៥ ១៤៧:៩ ន លប ២:៧ **១:៣១** ទដ ១០៤:២៤ ១៣៦:៥ សភ ៣:១៩ យរ ១០:១២ ផ ខ.៤ ១ធថ ៤:៤ ព ខ.៥ **២:១** ភ ចទ ៤:១៩ ១៧:៣ ២ពវ ១៧:១៦ ២១:៣ ទស ១០៤:២ អស ៤៤:២៤ ៤៥:១២ ៤៨:១៣ ៥១:១៣ **២:២** ម ចទ ៥:១៤ យ ខ.២–៣ នក ២០:១១ ៣១:១៧ ៣៤:២១ យហ ៥:១៧ ហព ៤:៤ **២:៣** រ នក ១៦:២៣ ២០:១០ ២៣:១២៣១:១៥ ៣៥:២ លវ ២៣:៣ នហ ៩:១៤ អស ៥៨:១៣ យរ

៣:២) ។ *ហើយឱ្យមានអំណាច* នៅក្នុងឃ្លានេះមានន័យថា ប្រហែលជាព្រះអង្គទ្រង់ចង់ឱ្យយើងយល់ក្នុងអារម្មណ៍នូវពាក្យដែលបាននិយាយថា “ដូច្នេះគេអាចមានអំណាច” ក្នុងអំឡុងពេលដែលព្រះអង្គកំណត់លោកិយយ៉ាងជាក់ច្បាស់ ព្រះអង្គទ្រង់បានដាក់ឱ្យមនុស្សមានអំណាចរស់រវើក ដែលតំណាងឱ្យភ្នាក់ងារ នៃទំនាក់ទំនងរបស់ព្រះអម្ចាស់ជាមួយនឹងបណ្តារបស់ផ្សេងៗទៀត ដែលព្រះអង្គបានបង្កើតមកក្នុងនាមជា (ទី១) តំណាងឱ្យការបង្កើតរបស់ព្រះអង្គ ហើយគ្រប់គ្រងលើអ្វីដែលព្រះយេហូវ៉ាបានបង្កើតមក ។ (ទី២) គឺបំពេញនូវ សក្តានុភូតឱ្យមានសមិទ្ធិកម្ម ហើយសរសើរពីសិរីល្អនៃព្រះអាទិករ (នៅក្នុងតំបន់មជ្ឈឹមបូព៌ានាសម័យបុរាណ ព្រះមហាក្សត្រទ្រង់បានបង្ហាញច្បាស់ អំពីទឹកដីដែលច្បាំងដណ្តើមបាន ដោយបានដាក់រូបភាពរបស់ព្រះមហាក្សត្រផ្ទាល់ ដើម្បីបង្ហាញពីព្រំប្រទល់ទឹកដីនិងអំណាចរបស់ខ្លួន) ។ នៅក្នុង ទដ ៨:៥–៨ បានថែងអំពីការគ្រប់គ្រងរបស់មនុស្សលើស្នាព្រះហសរបស់ព្រះអង្គហើយនៅក្នុង ហព ២:៥–៩ បាននិយាយអំពីមនុស្សតំណាងឱ្យអំណាចរបស់ព្រះក្នុងការបង្កើត ។ *គ្រប់គ្រង* នៅក្នុងឃ្លានេះមានន័យថា មនុស្សគឺស្ថិតនៅក្នុងលំដាប់ខ្ពស់ជាងគេនៅក្នុងចំណោមស្នាព្រះហស្តរបស់ព្រះអង្គ ហើយព្រះបានបំពាក់មកុដនៃ“សិរីល្អនិងកិត្តិយស” ហើយបានឱ្យពួកគេគ្រប់គ្រងលើ ស្នាព្រះហស្តទាំងអស់របស់ព្រះអង្គ (មើលការពន្យល់ ទដ ៨:៥៨) ។ ពួកគេត្រូវបានបង្កើតមកក្នុងរូបភាពនៃព្រះអាទិករសម្រាប់ជាសិរីល្អរបស់ទ្រង់ ។

**១:២៧** នៅក្នុងខនេះគឺជាខមួយដែលមានសារៈសំខាន់បំផុត ដែលកើតឡើងដំបូងគេនៅក្នុងជីវិតករិនិពន្ធក្នុងព្រះគម្ពីរសញ្ញាចាស់ (អ្នកនិពន្ធទាំងអស់មានប្រមាណជា៤០នាក់) ។ *បង្កើត* ពាក្យនេះមានប្រើក្នុងខ.នេះចំនួន៣ដង ដើម្បីពិពណ៌នាអំពីការងាររបស់ព្រះអាទិករដែលមាននៅក្នុងថ្ងៃទាំង៦នៃការបង្កើតរបស់ព្រះអង្គ (សូមមើលការពន្យល់ក្នុងខ.១) ។ *ជាប្រុសជាស្រី* នៅក្នុងន័យនេះចង់បង្ហាញថា ពួកគេម្នាក់ៗគឺបានកើតមកក្នុងរូបភាពនៃព្រះក្រោយមកទៀតពួកគេក៏បាននាំព្រះពររបស់ព្រះដល់អ្នកឯទៀតៗផងដែរ ។

**១:២៨** *ទ្រង់ប្រទានពរដល់គេ . . . ពេញពាស . . . បង្ក្រាប . . . អំណាច* ព្រះទ្រង់បានបង្កើតរបស់ទាំងអស់មកដោយស្នាព្រះហស្តរបស់ទ្រង់ផ្ទាល់ ហើយព្រះអម្ចាស់ទ្រង់បានប្រទានពរដល់ពួកគេ ឱ្យពួកគេបង្កើតកូនឱ្យបានចម្រុងចម្រើនពេញពាសលើផែនដីតាមពូជរបស់គេ ហើយប្រើអំណាចគ្រប់គ្រង លើសត្វផ្សេងៗទៀត ដែលព្រះអង្គបានបង្កើតមក (សូមមើលការពន្យល់ ខ.២៦ ២:១៥ ទដ ៨:៦–៨) ។ វប្បធម៌របស់មនុស្សជាតិ មិនមែនដើម្បីទាស់ប្រឆាំងជាមួយព្រះអម្ចាស់នោះឡើយ (ដោយសារការធ្លាក់ចុះជានិច្ចកាល មនុស្សគេតែងតែមានអំនួតហើយទាស់ប្រឆាំងជាមួយព្រះ) ។ លក្ខណៈនៃអ្នកដែលបានកើតមកក្នុងរូបភាពនៃព្រះ គឺត្រូវធ្វើជាអ្នកបម្រើរបស់ព្រះអម្ចាស់ ក្រោមការគ្រប់គ្រងមកពីព្រះ ។

**១:២៩–៣០** នៅក្នុងខនេះចង់និយាយថា ទាំងមនុស្សទាំងសត្វហាក់បីដូចជាជាអ្នកដែលបរិភោគបន្លែតាំងពីដើមមកម៉្លេះ (មើល ៩:៣ និងការពន្យល់) ។

**១:៣១** *ល្អប្រពៃ* មើលការពន្យល់អំពីឃ្លានេះក្នុង ខ.៤ ។ *ថ្ងៃទី៦* នៅក្នុងឃ្លានេះប្រហែលជាចង់និយាយអំពីថ្ងៃចុងក្រោយ និងថ្ងៃដែលមានសារៈសំខាន់ក្នុងការបង្កើតរបស់ទ្រង់ ។

**២:១** នៅក្នុងខនេះគឺជាការសង្ខេបលទ្ធផលរួម នៃការបង្កើតទាំង៦ថ្ងៃរបស់ព្រះអម្ចាស់ (សូមមើលការពន្យល់ ១:១) ។

**២:២** *នោះបានហើយជាស្រេច ទ្រង់ក៏ឈប់ផ្អាក* ព្រះទ្រង់បានសម្រាកនៅថ្ងៃទី៧មិនមែនដោយសារតែព្រះអង្គទ្រង់អស់កម្លាំងនោះឡើយ ប៉ុន្តែគឺដោយសារតែគ្មានអ្វីដែលនៅទទេឬខ្វះទៀតនោះឡើយ ។ សកម្មភាពនៃការបង្កើតរបស់ព្រះអង្គបានចប់សព្វគ្រប់ ហើយលទ្ធផលនៃការបង្កើតគឺ “ល្អប្រពៃ” (សូមមើល ១:៣១) ។

**២:៣** *ព្រះទ្រង់ក៏ប្រទានពរដល់ថ្ងៃទី៧នោះ . . . ឈប់សំរាក* ទោះបីជាពាក្យថា “សាបាត់” (Sabath) ពាក្យនេះមានន័យថា “សម្រាក” មិនត្រូវបាន

ក៏ប្រទានពរដល់ថ្ងៃទី៧នោះ ព្រមទាំងញែកទុកជាថ្ងៃ
បរិសុទ្ធ[ល] ពីព្រោះនៅថ្ងៃនោះ ទ្រង់បានឈប់សំរាក[ល]ពីគ្រប់
ទាំងការដែលទ្រង់បានបង្កើត[វ]បានធ្វើ ។

## លោកអ័ដាម និងនាងអេវ៉ា

៤នេះហើយជាដើមកំណើត[ស]នៃផ្ទៃមេឃនិងផែនដីក្នុង
កាលដែលបានកើតមក[ហ] គឺនៅវេលាដែលព្រះយេហូវ៉ា
ដ៏ជាព្រះទ្រង់បានធ្វើផែនដី និងផ្ទៃមេឃនោះឯង ៥រីឯនៅ
ផែនដីនោះមិនទាន់មានអ្វីដុះនៅឡើងទេ ក៏មិនទាន់មាន
តិណជាតិណានៅវាលដែរ[ឡ] ពីព្រោះព្រះយេហូវ៉ាដ៏ជា
ព្រះ ទ្រង់មិនបានបង្អុរភ្លៀងមកលើផែនដីសោះ[អ] ហើយក៏
គ្មានមនុស្សណានឹងភ្ជួររាស់ដីផង ៦គ្រាន់តែមានចំហាយ
ឡើងពីដីមកស្រោចស្រប់គ្រប់លើផែនដីប៉ុណ្ណោះ ៧ព្រះ
យេហូវ៉ាដ៏ជាព្រះទ្រង់យកធូលី[ក]ដី[ខ]មកសូន[គ]ធ្វើជាមនុស្ស[ឃ]
ទ្រង់ផ្លុំខ្យល់ដង្ហើម[ង]ជីវិត[ច] បញ្ចូលទៅក្នុងរន្ធច្រមុះ នោះ
ក៏ត្រឡប់ជាមានព្រលឹងរស់ឡើង[ឆ]។
៨រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ធ្វើសួនច្បារ១នៅស្រុក
អេដែន[ជ]ទិសខាងកើត ក៏ដាក់មនុស្សដែលទ្រង់បានសូនធ្វើ

**២:៣** ១៧:២២ ល ទដ ៩៥:១១ ហព ៤:១–១១ វ លប ១:១ **២:៤** ស លប ៥:១ ៦:៩ ១០:១ ១១:១០,២៧ ២៥:១២,១៩ ៣៦:១,៩ ៣៧:២ហ លប ១:១ យប ៣៨:៨–១១ **២:៥** ឡ លប ១:១១ អ យប ៣៨:២៨ ទដ ៦៥:៩–១០ យរ ១០:១៣

**២:៧** ក លប ៣:១៩ ១៨:២៧ យប ៤:១៩ ១០:៩ ១៧:១៦ ៣៤:១៥ ទដ ៩០:៣ សស ៣:២០ ១២:៧ ខ លប ៣:២៣ ៤:២ ទដ ១០៣:១៤ យរ ១៨:៦ ១កថ ១៥:៤៧ គ អស ២៩:១៦ ៤៣:១,២១ ៤៤:២ ឃ លប ១:២៧ ង លប ១:២ យប ២៧:៣ អស ២:២២ ច លប ១:៣០ អស ៤២:៥ កច ១៧:២៥ ឆ យប ១២:១០ ៣២:៨ ៣៣:៤ ៣៤:១៤ ទដ ១០៤:២៩ អស៥៧:១៦ អគ ៣៧:៥ ១កថ ១៥:៤៥ **២:៨** ជ ខ.១០,១៥ លប ៣:២៣,២ ៤៤:១៦ ១៣:១០ អស ៥១:៣ អគ ២៨:១៣ ៣១:៩,១៦ ៣៦:៣៥

ប្រើក្នុងខនេះ ក៏ដោយក្នុងកិរិយាស័ព្ទនៃព្រះគម្ពីរភាសាហេព្រើរ គេប្រើពាក្យថា រ៉ែស (Rested) (សូមមើល ខ.២ នៅក្នុងភាសាខ្មែរពាក្យនេះមានន័យថា សម្រាកឬឈប់សម្រាក) ដែលជាទម្រង់នាមដើមនៃពាក្យ សាបាត់ នៅក្នុងចំណុចចាប់ផ្តើមនៃកថាខណ្ឌធំៗនិមួយៗ (មើលក្នុងសេចក្តីផ្តើម (Sabath) ដែរ ។ នៅក្នុងព្រះគម្ពីរ នក ២០:១១ បានដកស្រង់ចេញពីផ្នែកទី១ នៃពាក់កណ្តាលខ.៣កន្លែងនេះ ដោយជំនួសពាក្យថា "Sabath" នេះដោយប្រើពាក្យថ្ងៃទី៧វិញ ដោយព្រោះពាក្យនេះមានតម្លៃសមមូលគ្នា ។ កំណត់ត្រាច្បាប់ថ្ងៃឈប់សម្រាកដំបូងដែលជាបញ្ញត្តិរបស់ព្រះអម្ចាស់ នោះគឺនៅពេល ដែលពួកអ៊ីស្រាអែលគេចាកចេញពីស្រុកអេស៊ីព្ទឆ្ពោះទៅភ្នំស៊ីណាយ (សូមមើល នក ជំពូក ១៦) ប៉ុន្តែនៅក្នុង នហ ៩:១៣–១៤ បាននិយាយថា ថ្ងៃឈប់សម្រាកមិនមែនជាច្បាប់នៃសេចក្តីសញ្ញានោះឡើយ រហូតដល់គ្រាដែលព្រះអម្ចាស់ទ្រង់បានប្រទានក្រឹត្យវិន័យនៅភ្នំស៊ីណាយមក ទើបថ្ងៃឈប់សម្រាកបានក្លាយជាច្បាប់មួយ ។

**២:៤–៤:២៦** នៅក្នុងខទាំងនេះគឺជាការពណ៌នាពីព្រឹត្តិការណ៍តាំងពីពេលចាប់ផ្តើមមានប្រវត្តិសាស្ត្ររបស់មនុស្សជាតិដំបូង និងកិច្ចការបង្កើតដែលមាននៅក្នុង ១:១–២:៣ (សូមមើលការពន្យល់នៅទីនោះ)។

**២:៤** *ដើមកំណើត* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យថា"ដើមកំណើត"មានប្រើចំនួន១០ដងនៅក្នុងព្រះគម្ពីរលោកុប្បត្តិទាំងមូល ។ គេអាចឃើញឃ្លានេះព្រះគម្ពីរលោកុប្បត្តិ ត្រង់ចំណុចលក្ខណៈអក្សរសាស្ត្រ) ។ *ផ្ទៃមេឃនិងផែនដី* មើលការពន្យល់ ១:១ ។ នៅឃ្លាដែលនិយាយថា "នេះហើយជាដើមកំណើតផ្ទៃមេឃនិងផែនដី" វាគឺជាសេចក្តីផ្តើមដែលជាការណែនាំថាតើនៅក្នុងការបង្កើតរបស់ព្រះអម្ចាស់ ទ្រង់បានបង្កើតអ្វីឡើង ហើយមានអ្វីកើតឡើង ។ ដោយសារអំពើបាបនិងការបះបោររបស់អ័ដាម និងនាងអេវ៉ា បានធ្វើឱ្យមានបណ្តាសារ៣ បានកើតឡើងគឺ (១).បណ្តាសានោះបានធ្លាក់មកលើសាតាំង (២).ដីត្រូវបណ្តាសាដោយព្រោះអំពើបាបរបស់អ័ដាម (សូមមើលក្នុង ៣:១៧) (៣).បណ្តាសាបានធ្លាក់ទៅលើកាអ៊ីន (មើលក្នុង ៤:១១) ។ *ព្រះយេហូវ៉ាដ៏ជាព្រះ* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យ "ព្រះយេហូវ៉ា"គឺ "យ៉ាវេ" គឺជារបស់ព្រះអម្ចាស់ និងនាមដែលគេប្រើក្នុងការតាំងសញ្ញា (សូមមើលការពន្យល់ នក ៣:១៥) ដើម្បីបញ្ជាក់ពីតួនាទីរបស់ព្រះអង្គថា ព្រះអម្ចាស់ទ្រង់គឺជាអ្នកប្រោសលោះពួកអ៊ីស្រាអែល និងជាព្រះនៃសេចក្តីសញ្ញា (មើលការពន្យល់ នក ៦:៦) រីឯពាក្យថា "ព្រះ" ដែលព្រះគម្ពីរភាសាហេព្រើរគេពាក្យ"អេឡូហ៊ីម" គឺជានាមទូទៅរបស់ព្រះអម្ចាស់ ។ ព្រះនាមទាំង២នេះ គឺទាំង"យ៉ាវេ" និងអេឡូហ៊ីម គឺមានប្រើនៅក្នុងសញ្ញាចាស់ចំនួន១ពាន់ដង ហើយជានិច្ចកាលគេប្រើព្រះមានទាំង២នេះជាមួយគ្នាតែម្តង ជាក់ស្តែងដូចនៅកន្លែងនេះជាដើម គេបានប្រើពាក្យ "ព្រះយេហូវ៉ា ដ៏ជាព្រះ" គឺដើម្បីបង្ហាញឱ្យឃើញច្បាស់ថា ទោះបីជាព្រះអង្គមាននាមច្រើន តែនាមនោះគឺជាព្រះពិតតែមួយប៉ុណ្ណោះ ។

**២:៧** *សូន* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ កិរិយាស័ព្ទនេះ គឺប្រើសំដៅលើកិច្ចការរបស់ជាងស្មូន (សូមមើលការពន្យល់ អស ៤៥:៩ យរ ១៨:៦) ដែលពួកជាងទាំងនោះរចនាភាជណ៌ពីដីឥដ្ឋ (មើលការពន្យល់ យប ៣៣:៦)។ អ្នកនិពន្ធបានប្រើពាក្យថា "ធ្វើ"(ខ.២៦) "បង្កើត" (ខ.២៧) និង "សូន" ដើម្បីពណ៌នាពីការបង្កើតរបស់ព្រះអង្គទាំងមនុស្ស និងសត្វ (សូមមើល ខ.១៩ ១:២១,២៥)។ *ខ្យល់ដង្ហើមជីវិត* នៅក្នុងឃ្លានេះចង់ និយាយថា ព្រះអង្គបានបង្កើតមនុស្ស និងសត្វមកដោយបានដាក់ខ្យល់ដង្ហើមនៃជីវិតដល់ពួកគេ (សូមមើល ១:៣០ យប ៣៣:៤) ។ *នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង* នៅក្នុងព្រះគម្ពីរភាសាហេព្រើរឃ្លានេះគេប្រើពាក្យថា"ចាប់ផ្តើមមានជីវិត" ហើយនៅក្នុង ១:២០,២៤ បានប្រើពាក្យថា"មច្ឆាជាតិ រវើក" ។ ដូច្នេះព្រះបន្ទូលនៅក្នុង ២:៧ ចង់មានន័យថា មនុស្សនិងសត្វគឺកើតឡើង ក្នុងសភាពដូចគ្នា ។ តែអ្វីដែលខុសគ្នានេះ គឺមនុស្សត្រូវបានបង្កើតមកក្នុង "រូបអង្គនៃព្រះ" (សូមមើល ១:២៧) ហើយមានទំនាក់ទំនងជាមួយព្រះក្នុងនាមជាអ្នកបម្រើរបស់ទ្រង់ និងមានទំនាក់ទំនងលើស្នាព្រះហស្តរបស់ទ្រង់ និងការគ្រប់គ្រងមកពីព្រះអម្ចាស់ (សូមមើលការពន្យល់ ទដ ៨:៥–៨)។

**២:៨** *ទិសខាងកើត* នៅក្នុងឃ្លានេះចង់និយាយថា នៅក្នុងគំនិតរបស់អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិ គាត់បានគិតថា សួនច្បារនោះគឺមានទីតាំងដំបូងជិតទន្លេងប្រសប់គ្នានៃទន្លេហ៊ីដេកែល និងទន្លេអ៊ើប្រាត (សូមមើលខ.១៤) ហើយ សព្វថ្ងៃនេះ ទន្លេនេះស្ថិតនៅភាគខាងត្បូងនៃប្រទេសអ៊ីរ៉ាក់ ។ *អេដែន* ឈ្មោះរបស់សួនច្បារនេះ គឺមានន័យដូចគ្នានឹងពាក្យថា "ស្ថានសួគ៌" ដែល ភាសាហេព្រើរមានន័យថា "បរមសុខ" ឬ"សេចក្តីអំណរ" ឯនៅក្នុងភាសា របស់ពួកមេសូប៉ូតាមាវិញ ពាក្យនេះមានន័យថា "ខ្ពង់រាប" ។ ប្រហែលជា អ្នកនិពន្ធប្រើពាក្យថា អេដែននេះ គឺក្នុងគោលបំណងនិយាយ

ឱ្យនៅទីនោះ ៩ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ក៏ធ្វើឱ្យដីដុះគ្រប់
អស់ទាំងដើមឈើ[ឈ]ដែលគួរពិចពិលរមិលមើល ហើយ
សំរាប់ជាអាហារផង ក៏ដាំដើមជីវិត[ញ] និងដើមសំរាប់ដឹង
ខុសត្រូវ[ដ] នៅកណ្ដាលសួនច្បារនោះដែរ ១០មានទន្លេ១[ឋ]
ហូរចេញពីស្រុកអេដែន[ឌ]មកស្រោចសួនច្បារនោះ រួចហូរ
បែកពីនោះទៅជា៤មុខ ១១ទី១ឈ្មោះពិសុន គឺជាទន្លេដែល
ហូរព័ទ្ធស្រុកហាវីឡា[ឍ]ដែលមានមាស ១២មាសដែលមកពី
ស្រុកនាះជាមាសយ៉ាងល្អ[ណ] ក៏មានទាំងប្ដេល្លាម និងត្បូង
អូនីក្សផង ១៣ទី២ឈ្មោះគីហុន គឺជាទន្លេដែលហូរព័ទ្ធស្រុក
គូស ១៤ទី៣ឈ្មោះហីដេកែល[ត] គឺជាទន្លេដែលហូរចាក់ទៅ
ខាងកើតស្រុកអាសស៊ើរ ហើយទន្លេទី៤ឈ្មោះអ៊ើប្រាត[ថ]
១៥ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកអ័ដាមទៅដាក់នៅក្នុងសួន
ច្បារអេដែន[ទ] ឱ្យគាត់ធ្វើការ ហើយថែរក្សា ១៦ព្រះយេហូវ៉ា
ដ៏ជាព្រះទ្រង់បង្គាប់ទៅអ័ដាមថា ឯងនឹងស៊ីផ្លែឈើទាំងអស់
ក្នុងសួនច្បារនេះបានតាមចិត្ត[ធ] ១៧តែឯត្រង់ដើមដឹងខុស
ត្រូវ[ន]នោះ មិនត្រូវឱ្យឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណា
ដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន[ប] ។
១៨ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលថា ដែលមនុស្ស
នេះនៅតែម្នាក់ឯង នោះមិនស្រួលទេ អញនឹងធ្វើឱ្យមាន
ម្នាក់ជាជំនួយសំរាប់ជួយវា[ផ] ១៩ព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់
បានយកដីមកសូនធ្វើគ្រប់ទាំងសត្វជើង៤[ព] និងសត្វហើរ
ទាំងប៉ុន្មាន[ភ] រួចក៏នាំមកឯអ័ដាម ដើម្បីឱ្យដឹងជាគាត់នឹង
ហៅ[ម]យ៉ាងដូម្ដេច ឯឈ្មោះណាដែលអ័ដាមបានដាក់ឱ្យដល់
ជីវិតផងទាំងឡាយ[យ] នោះបានសំរេចជាឈ្មោះរបស់សត្វ
នោះឯង ២០អ័ដាមដាក់ឈ្មោះឱ្យដល់គ្រប់ទាំងសត្វស្រុក
សត្វព្រៃ និងសត្វហើរលើអាកាសទាំងប៉ុន្មានជាស្រេច តែ
មិនឃើញមានជំនួយណាសំរាប់ឱ្យជួយគាត់សោះ[រ] ២១នោះ
ព្រះយេហូវាដ៏ជាព្រះទ្រង់ធ្វើឱ្យអ័ដាមដេកលក់ស៊ប់ទៅ[ល] រួច

យអ ២:៣
**២:៩** ឈ អគ ៣១:៨ ញ លប ៣:២២,២៤ សភ ៣:១៨ ១១:៣០ វវ ២:៧ ដ អគ ៤៧:១២
**២:១០** ឋ ជន ២៤:៦ ទដ ៤៦:៤ អគ ៤៧:៥ ឌ ខ.៨
**២:១១** ឍ លប ១០:៧ ២៥:១៨
**២:១២** ណ ជន ១១:៧
**២:១៤** ត លប ៤១:១ ដយ ១០:៤ ថ លប ១៥:១៨ ៣១:២១
**២:១៥** ទ ខ.៨
**២:១៦** ធ លប ៣:១–២
**២:១៧** ន លប ៣:១១,១៧ ប លប ៣:១,៣ ៥:៥ ៩:២៩ ចទ ៣០:១៥,១៩ យរ ៤២:១៦ អគ ៣:១៨ រម ៥:១២ ៦:២៣**២:១៨** ផ សភ ៣១:១១ ១កថ ១១:៩ ១ធថ ២:១៣ **២:១៩** ព ទដ ៨:៧ ភ លប ១:២០ ម លប ១:៥ យ លប ១:២៤ **២:២០** រ លប ៣:២០ ៤:១ **២:២១** ល លប ១៥:១២ ១សយ ២៦:១២ ១សយ ២៦:១២ យប ៣៣:១៥

សំដៅលើភាសាទាំង២នោះតែម្ដង ។

**២:៩** *ដើមជីវិត* នៅក្នុងឃ្លានេះចង់និយាយថា ដើមឈើនោះមានសារៈសំខាន់ណាស់ ពីព្រោះវាបានផ្ដល់ជីវិតឱ្យមនុស្ស ។ អ្នកណាដែលបរិភោគផលពីដើមឈើនោះ នឹងគ្មានសេចក្ដីស្លាប់ឡើយ (សូមមើលការពន្យល់ ៣:២២ វវ ២:៧ ២២:២,១៤) ។ *ដើមសំរាប់ដឹងខុសត្រូវ* នៅក្នុងឃ្លានេះចង់និយាយថា នៅពេលដែលមនុស្សបរិភោគផលនៃដើមឈើសម្រាប់ដឹងខុសត្រូវគឺធ្វើឱ្យយើងមានចំណេះដឹងស្គាល់ការល្អ និងការអាក្រក់ ថែមទាំងនាំឱ្យយើងមានសេចក្ដីស្លាប់ថែមទៀត (សូមមើលការពន្យល់ក្នុង ខ.១៧ ៣:៣)។ "ដឹងខុសត្រូវ" នៅក្នុងឃ្លានេះគឺចង់និយាយសំដៅទៅលើចំណេះដឹង ផ្នែកសីលធម៌ ឬកិរិយាប្រព្រឹត្តិត្រឹមត្រូវ (សូមមើលការពន្យល់ ចទ ១:៣៩ អស ៧:១៥–១៦) ។ ដោយព្រោះព្រះអម្ចាស់ទ្រង់បានបង្កើតអ័ដាម និងអេវ៉ាមកដោយស្នាព្រះហស្តរបស់ទ្រង់ផ្ទាល់ នោះព្រះអង្គបានឱ្យពួកគេទាំងជីវិត និងចំណេះដឹងខុសត្រូវ ។ នៅពេលដែលព្រះអម្ចាស់ទ្រង់បាននាំអ័ដាម និងអេវ៉ាមកឯដើមឈើនៃជីវិត នោះគឺចង់មានន័យថា ព្រះអម្ចាស់ទ្រង់សព្វព្រះទ័យឱ្យពួកគេមានជីវិត ។ កាលពីសម័យបុរាណ ពួកសាសន៍ដទៃគេមានជំនឿថាព្រះ (រូបព្រះ) បានមានបំណងចង់ឱ្យមនុស្សស្លាប់ ។ លោកអ័ដាម និងអេវ៉ា បរិភោគផលផ្លែពីដើមឈើដឹងខុសត្រូវ នៅពេលដែលគេបានគិតថា អ្នកទាំងនោះជាអ្នកនាំឱ្យមនុស្សនិងស្នាព្រះហស្តផ្សេងៗទៀត ស្គាល់ខុសស្គាល់ត្រូវ ក្នុងគោលបំណងមិនពឹងពាក់ស្នាក់អាស្រ័យលើព្រះអម្ចាស់ ។

**២:១១** *ពិសុន* ទីកន្លែងពិតប្រាកដរបស់ទន្លេនេះគេមិនបានដឹងឡើយ ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះគឺជាសាធារណនាម ដែលមានន័យថា "អណ្ដូង" ។ *ស្រុកហាវីឡា* ទីកន្លែងពិតរបស់ស្រុកនេះ គេក៏មិនដឹងដែរ ។ គេនឹងឃើញឈ្មោះស្រុកនេះម្ដងទៀតក្នុង ១០:២៩ ។ ប្រហែលជាស្រុកហាវីឡានេះហើយ ដែលជាស្រុកដ៏ល្បីឈ្មោះមួយក្នុងប្រទេសអេស៊ីព្ទ ដែលមាននិយាយនៅក្នុង ១០:៧ ។

**២:១៣** *គីហុន* ទីកន្លែងពិតនៅឯណា នោះគ្មាននរណាបានដឹងឡើយ ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះគឺជាសាធារណនាម ដែលមានន័យថា "ហូហៀរ" (Spurter) ។ ពិសុន និងគីហុន ប្រហែលជាស ្ទឹងមួយ ដែលស្ថិតនៅត្រង់ស្រុកមេសូប៉ូតាមាខាងក្រោម ជាប់ដៃសមុទ្រចក្រភពពើស៊ី ។ ឈ្មោះរបស់ទន្លេទាំង២នេះ គឺមានក្នុងពេលដែលព្រះគម្ពីរលោកុប្បត្តិចាប់ផ្ដើមសរសេរ ។

**២:១៤** *អាសស៊ើរ* អាសស៊ើរ គឺជាទីក្រុងបុរាណមួយរបស់ប្រទេសអាសស៊ើរ ។ *អ៊ើប្រាត* គេតែងតែហៅទន្លេអ៊ើប្រាត (សូមមើលការពន្យល់ ១ពវ ៤:២១,២៤) ពីព្រោះវាមានទំហុំធំ និងមានសារៈសំខាន់ ។

**២:១៥** *ធ្វើការ ហើយថែរក្សា* សូមមើលការពន្យល់ឃ្លានេះនៅក្នុង ១:២៨ ។ នៅក្នុងឃ្លានេះគឺចង់មានន័យថា មនុស្សមានតួនាទីជាអ្នកថែរក្សា និងគ្រប់គ្រងលោកិយដែលព្រះអង្គបង្កើតមក ក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ។

**២:១៦** *ផ្លែឈើទាំងអស់* នៅក្នុងឃ្លានេះចង់មានន័យថា គឺផ្លែនៃដើមឈើជីវិត (សូមមើលការពន្យល់ ខ.៩)។

**២:១៧** *នឹងត្រូវស្លាប់ជាមិនខាន* នៅក្នុងឃ្លានេះចង់និយាយថា ទោះបីសាតាំងវាបានប្រាប់ថា ការបរិភោគផ្លែឈើនេះវាមិនស្លាប់ក៏ដោយ (មើលការពន្យល់ ៣:៤) ចំពោះការមិនស្ដាប់បង្គាប់ព្រះ គឺនាំឱ្យមានសេចក្ដីស្លាប់ ។

**២:១៨–២៥** នៅក្នុងខទាំងនេះចង់និយាយថា ការបង្កើតស្ត្រីដំបូងបង្អស់ចេញពីបុរសមក ។

**២:១៨** *មិនស្រួល . . . នៅតែម្នាក់ឯង* នៅក្នុងឃ្លានេះចង់និយាយថាបើគ្មានស្ត្រីសម្រាប់ធ្វើជាមិត្តសំឡាញ់ ហើយជាដៃគូក្នុងការបន្តពូជទេ បុរសមិនអាចគ្រប់លក្ខណៈជាមនុស្សជាតិឡើយ ។

**២:១៩** *ដើម្បីឱ្យដឹងថាជាយ៉ាងដូចម្ដេច* នៅក្នុងឃ្លានេះចង់និយាយថា ការងារដំបូងរបស់លោកអ័ដាម គឺគ្រប់គ្រងលើបណ្ដាសត្វទាំងឡាយដែលនៅជុំវិញខ្លួនគាត់ (សូមមើលការពន្យល់ ១:៥) ។

ទ្រង់យកឆ្អឹងជំនីគាត់១ ហើយភ្ជិតសាច់ទៅវិញ ២២ រីឯឆ្អឹង[វ]
ដែលព្រះយេហូវ៉ាដ៏ជាព្រះបានយកពីអ័ដាមមក នោះទ្រង់
ជប់ឱ្យកើតឡើងជាមនុស្សស្រី ក៏នាំទៅឯអ័ដាម ២៣ អ័ដាមក៏
ថា នេះហើយជាឆ្អឹងពីឆ្អឹងអញជាសាច់ពីសាច់អញ[ស] នឹង
ត្រូវហៅ[ហ]ថា"ស្ត្រី" ពីព្រោះបានយកចេញពីបុរសមក[ឡ]
២៥ ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពី
ឪពុកម្តាយខ្លួន ទៅនៅជាប់[អ]នឹងប្រពន្ធវិញ ហើយអ្នកទាំង២
នោះ នឹងត្រឡប់ជាសាច់តែ១សុទ្ធ[ក] ២៥ រីឯអ័ដាមនិងប្រពន្ធ
គាត់ក៏នៅជាអាក្រាតទទេ[ខ] ឥតមានសេចក្តីអៀនខ្មាស
ឡើយ ។

## ការធ្លាក់ចុះនៃមនុស្សជាតិ

៣ ១ ឯពស់[ក]ជាសត្វចេះឧបាយកលលើសជាងអស់ទាំងសត្វ
ព្រៃ ដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានបង្កើត វានិយាយ
ទៅកាន់ស្ត្រីថា តើព្រះមានបន្ទូលហាមមិនឱ្យអ្នកបរិភោគ
ផ្លែឈើណានៅក្នុងសួនច្បារ មែនឬ[ខ] ២ ស្ត្រីឆ្លើយតបថា
យើងបរិភោគអស់ទាំងផ្លែឈើនៅក្នុងសួនច្បារបាន[គ] ៣ តែ
ត្រង់ដើមឈើ១ដែលនៅកណ្តាលសួនច្បារនោះ ព្រះទ្រង់
មានបន្ទូលថា កុំឱ្យបរិភោគផ្លែនោះឡើយ ថែមទាំងកុំឱ្យប៉ះ
ពាល់ផង ក្រែងលោស្លាប់[ឃ] ៤ រួចពស់ក៏និយាយទៅស្ត្រី[ង]ថា
អ្នកមិនស្លាប់ជាពិតមែនទេ ៥ ដ្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃ
ណា ដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង
ហើយអ្នកនឹងបានដូចជាព្រះដែរ[ច] ព្រមទាំងដឹងការខុសត្រូវ
ផង ៦ កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបានក៏ជា
ទីគាប់ដល់ភ្នែក ហើយជាដើមដែលល្អមគួរនឹងចង់បាន[ឆ]
ដើម្បីឱ្យបានប្រាជ្ញា នោះនាងក៏យកផ្លែមកបរិភោគព្រម

**២:២២** វ ១កថ ១១:៨ ៩:១២ ១ធថ ២:១៣ **២:២៣** ស លប ២៩:១៤ អភ ៥:២៨–៣០ ហ លប ១:៥ ឡ ១កថ ១១:៨ **២:២៤** អ មទ្ឋ ២:១៥ ក មថ ១៩:៥ មក ១០:៧–៨ ១កថ ៦:១៦ អភ ៥:៣១ **២:២៥** ខ លប ៣:៧ ១០–១១ អស ៤៧:៣ បទ ១:៨ **៣:១** ក យប ១:៧ ២:២ ២កថ ១១:៣ វវ ១២:៩ ២០:២ ខ លប ២:១៧

**៣:២** គ លប ២:១៦ **៣:៣** ឃ លប ២:១៧ **៣:៤** ង យហ ៨:៤៤ ២កថ ១១:៣ **៣:៥** ច លប ១:២៦ ១៤:១៨,១៩ ទជ ៧:៨ អស ១៤:១៤ អគ ២៨:២ **៣:៦** ឆ យក ១:១៤–១៥ ១យហ ២:១៦ ជ ជន ៣០:៧–៨ យរ ៤៤:១៥,១៩,២៤ ឈ ២កថ ១១:៣ ១ធថ ២:១៤

**២:២៤** *លាចេញពីឪពុកម្តាយខ្លួន* នៅក្នុងឃ្លានេះចង់និយាយថា ជាជាងបន្តរស់នៅក្រោមការថែរក្សាពីឪពុកម្តាយ បុរស និងប្រពន្ធរបស់គាត់គួរតែចាកចេញពីឪពុកម្តាយ ហើយបង្កើតជាគ្រួសារថ្មីមួយឡើង ។ *ត្រឡប់ជាសាច់តែ១សុទ្ធ* នៅក្នុងឃ្លានេះចង់មានន័យថា ព្រះអម្ចាស់ទ្រង់មានបំណងឱ្យប្តីនិងប្រពន្ធស្មោះត្រង់នឹងគ្នា ដោយមានប្តីមួយប្រពន្ធមួយ ។ ពួកគេមិនអាចរស់នៅឆ្ងាយពីគ្នា ដូចជាឪពុកម្តាយ និងកូនរបស់ពួកគេឡើយ ។ ឪពុកម្តាយនិងកូនៗរបស់ពួកគេគឺជា"សាច់ឈាមតែ១"ដូច្នេះប្តីនឹងប្រពន្ធត្រូវតែរស់នៅជាមួយគ្នាក្នុងនាមជា "សាច់តែ១" ដរាបណាពួកគេនៅមានជីវិតរស់នៅ (សូមធៀបជាមួយ ១កថ ៦:១៦) ។

**២:២៥** *នៅជាអាក្រាតទទេ ឥតមានសេចក្តីអៀនខ្មាសឡើយ* នៅក្នុងឃ្លានេះចង់និយាយថា ភាពមិនអៀនខ្មាសចំពោះការអាក្រាតដែលជាអត្តសញ្ញាណនៃភាពស្អាតស្អំរបស់មនុស្ស នឹងត្រូវបាត់បង់ដោយសារអំពើបាប (សូមមើលការពន្យល់ក្នុង ៣:៧) ។

**៣:១–២៤** នៅក្នុងខទាំងអស់នេះគឺចង់និយាយអំពីការមិនស្តាប់បង្គាប់របស់លោកអ័ដាម នាងអេវ៉ា និងការឆ្លើយតបរបស់ព្រះអម្ចាស់ដល់មនុស្សទាំងអស់ ដោយព្រោះទង្វើរបស់អ្នកទាំង២ (ធៀបជាមួយ រម ៥:១២–២១) ។

**៣:១** *ពស់* នៅក្នុងឃ្លានេះចង់និយាយថា សត្វពស់គឺមេបោកបញ្ឆោតដ៏ពូកែមួយ ដែលនៅជាប់នឹងព្រះអម្ចាស់ ។ វាគឺជាស្នាព្រះហស្តដ៏ល្អមួយក្នុងចំណោមស្នាព្រះហស្តផ្សេងៗទៀត ដែលព្រះអម្ចាស់ទ្រង់បានបង្កើតមក ។ មិនតែប៉ុណ្ណោះសោត វាជាសត្វមួយដែលពូកែកុហក និងធ្វើការបះបោរដោយប្រើភាពវៃឆ្លាត ដើម្បីផលប្រយោជន៍ខ្លួនឯង ។ ដោយសារការទាំងអស់នេះហើយ ទើបពេលក្រោយមកទៀតនៅពេលដែលគេនិយាយអំពី "អារក្សឬសាតាំង" គឺចង់និយាយសំដៅលើសត្វពស់ចាស់សម័យបុរាណ (សូមមើលការពន្យល់ វវ ១២:៩ ២០:២) ។ *ឧបាយកល* នៅក្នុងភាសាហេព្រើរ ពាក្យថា"ឧបាយកល" និងពាក្យថា"អាក្រាត"គឺមានន័យស្ទើរតែដូចគ្នាទាំងស្រុង ។ នៅពេលដែលអ័ដាមនិងនាងអេវ៉ាអាក្រាត ពួកគេគ្មានអារម្មណ៍អៀនខ្មាស់ឡើយ (សូមមើលការពន្យល់ ២:២៥) ។ ដោយសារឧបាយកលរបស់សត្វពស់ បានធ្វើឱ្យពួកគេប្រព្រឹត្តអំពើបាប ហើយដោយសារអំពើបាប បានធ្វើឱ្យគេមានសេចក្តីអៀនខ្មាសនៅពេលដែលពួកគេដឹងថាខ្លួនអាក្រាត (សូមមើលការពន្យល់ ៦.៧) ។ *តើព្រះមានបន្ទូល . . . ?* ដោយសារសំណួរបែបនេះ និងការឆ្លើយតបទៅវិញបានធ្វើឱ្យប្រវត្តិសាស្ត្ររបស់មនុស្សមានការប្រែប្រួល ។ ដោយសារតែនាងអេវ៉ាមានការសង្ស័យលើព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះសាតាំងបានមានឱកាសនាំការអាក្រក់ដល់លោកិយទាំងមូល ។ ការបោកបញ្ឆោតរបស់សត្វពស់នៅទីនេះធ្វើឱ្យមនុស្សបានក្លាយជាខ្មាំងជាមួយព្រះអម្ចាស់ ហើយកន្លែងខ្លះទៀតសាតាំងបានធ្វើឱ្យព្រះបោះបង់មនុស្សលោកចោល (មើលការពន្យល់ យប ១–២ សក ៣:១) ។

**៣:៣** *ថែមទាំងកុំឱ្យប៉ះពាល់ផង* នៅក្នុងឃ្លានេះ ស្ត្រីបានបន្ថែមលើព្រះបន្ទូលរបស់ព្រះ បំផ្លើសលើសេចក្តីពិតដែលព្រះអង្គទ្រង់បានបង្គាប់មក ជាហេតុធ្វើឱ្យអារក្សមានឱកាសប្រើល្បិចកិច្ចកលដើម្បីបំពុលផែនដី ។

**៣:៤** *អ្នកមិនស្លាប់ជាពិតមែនទេ* នៅក្នុងឃ្លានេះចង់និយាយថា សាតាំងវាបានបដិសេធលើព្រះបន្ទូលដ៏ល្អឥតខ្ចោះរបស់ព្រះអម្ចាស់ (សូមមើលក្នុង ២:១៧) ។

**៣:៥** *ព្រះជ្រាប* នៅក្នុងឃ្លានេះចង់និយាយថា អារក្សសាតាំងវាបានចោទប្រកាន់ថា ព្រះអម្ចាស់ទ្រង់គ្មានបំណងល្អជាមួយមនុស្ស ។ ក្នុង យប ១:៩,១១ ២:៤ សាតាំងវាបានចោទប្រកាន់ចំពោះសេចក្តីសុចរិតរបស់យ៉ូប ។ *នោះភ្នែកអ្នកនិងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជាព្រះដែរ* សំដីរបស់សាតាំងគឺត្រូវតែពាក់កណ្តាលប៉ុណ្ណោះ ។ នៅពេលដែលគេបរិភោគភ្នែកគេបានភ្លឺឡើងមែន (សូមមើលការពន្យល់ ៦.៧) ប៉ុន្តែលទ្ធផលពិតប្រាកដនៃការបរិភោគផ្លែឈើនេះ វាខុសពីអ្វីដែលសាតាំងបានសន្យាទាំងស្រុង ។ *ដឹងខុសត្រូវ* សូមមើលការពន្យល់ ២:៩ ។

**៣:៦** *ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក. . .ដើម្បីឱ្យបានប្រាជ្ញា* ទាំងអស់នេះ គឺជាមូលហេតុដែលជម្រុញឱ្យមនុស្សធ្លាក់ក្នុងសេចក្តីល្បួង (សូមធៀបជាមួយ លក ៤:៣,៥,៩ ១យហ ២:១៦) ។

ទាំងចែកឱ្យដល់ប្ដីដែរ[ជ] គាត់ក៏បរិភោគតាម[ឈ] ៧នោះស្រាប់
តែភ្នែករបស់អ្នកទាំង២បានភ្លឺឡើង ហើយគេដឹងថាខ្លួននៅ
ជាអាក្រាត[ញ] ក៏យកស្លឹកល្វាមកក្លាស់ធ្វើជាប្រដាប់ប៉ឹង[ដ] ៨រួច
មកបានឮសំឡេងព្រះយេហូវ៉ាដ៏ជាព្រះ ដែលទ្រង់យាង[ឋ]
ក្នុងសួនច្បារនៅពេលថ្ងៃល្ងើយ នោះអ័ដាមនិងប្រពន្ធគាត់
ក៏ពួន[ឌ]នឹងព្រះយេហូវ៉ាដ៏ជាព្រះនៅកណ្ដាលដើមឈើក្នុង
សួនច្បារ ។
៩ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ហៅរកអ័ដាមដោយបន្ទូលថា
ឯងនៅឯណា[ឍ] ១០គាត់ទូលឆ្លើយថា ទូលបង្គំបានឮសំឡេង
ទ្រង់នៅក្នុងសួនច្បារ ក៏រត់ទៅពួនដោយនឹកភ័យខ្លាច[ណ]
ពីព្រោះនៅខ្លួនទទេ[ត] ១១នោះព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មាន
បន្ទូលសួរថា តើអ្នកណាប្រាប់ឱ្យឯងដឹងថា ឯងនៅខ្លួនទទេ[ថ]
ដូច្នេះ តើឯងបានស៊ីផ្លែឈើដែលអញហាមមិនឱ្យស៊ីឬអី[ទ]
១២អ័ដាមទូលទ្រង់ថា ស្ត្រីដែលទ្រង់បានប្រទានឱ្យនៅជាមួយ
នឹងទូលបង្គំ[ធ] វាឱ្យផ្លែឈើនោះមកទូលបង្គំ ទូលបង្គំក៏
ទទួលទានទៅ ១៣រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូល
សួរទៅស្ត្រីថា ឯងបានធ្វើអ្វីដូច្នេះ នាងទូលឆ្លើយថា
ពស់វាមកល្បួងបញ្ឆោត[ន]ខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់បាន ទទួល
ទាន ១៤រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលទៅពស់ថា
ដោយព្រោះឯងបានធ្វើដូច្នេះនោះនៅក្នុងអស់ទាំងពួក
សត្វស្រុក សត្វព្រៃឯងជាសត្វត្រូវបណ្ដាលសា[ប] ហើយ គឺឯង
ត្រូវលូនតែនឹងពោះ ហើយត្រូវស៊ីធូលីដី[ផ]អស់១ជីវិត ១៥អញ
នឹងធ្វើឱ្យឯង ហើយនិងស្ត្រី គឺទាំងពូជឯង[ព]និងពូជនាង[ភ]
មានសេចក្ដីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង[ម] ហើយឯង
នឹងចឹកកែងជើងគេ ១៦ទ្រង់ក៏មានបន្ទូលទៅស្ត្រីវិញថា អញ
នឹងចំរើនឱ្យឯងមានសេចក្ដីព្រួយលំបាកជាច្រើនឡើង ក្នុង
វេលាដែលមានផ្ទៃពោះ ឯងនឹងបង្កើតកូនដោយឈឺចាប់[យ]
ចិត្តឯងនឹងប្រាថ្នាខាងឯប្ដី ហើយប្ដីនឹងត្រួតត្រាលើឯង[រ]
១៧រួចទ្រង់ក៏មានបន្ទូលទៅអ័ដាមថា ដោយព្រោះឯងបាន
ស្ដាប់តាមប្រពន្ធឯង ហើយស៊ីផ្លែឈើនោះ ដែលអញបាន
ហាមមិនឱ្យស៊ីឡើយ[ល] នោះដីវ[វ]ត្រូវបណ្ដាសា[ស]ដោយព្រោះ

**៣:៧** ញ លប ២:២៥ ដ ឌ.២១ **៣:៨** ឋ លវ២៦:១២ ចទ២៣:១៤ ឌ យប ១៣:១៦ ២៣:៧ ៣១:៣៣ ៣៤ ៣១:៣៣ ៣៤:២២, ២៣ ទដ ៥:៥ ១៣៩:៧-១២អស ២៩:១៥ យរ១៦:១៧ ២៣:២៤ ៤៩:១០ វវ ៦:១៥-១៦ **៣:៩** ឍ លប ៤:៩ ១៦:៨ ១៨:៩ ១ពវ ១៩:៩,១៣ **៣:១០** ណ នក ១៩:១៦ ២០:១៨ចទ ៥:៥ ១សយ ១២:១៨ ត លប ២:២៥ **៣:១១** ថ លប ២:២៥ ទ លប ២:១៧ **៣:១២** ធ លប ២:២២ **៣:១៣** ន រម ៧:១១ ២កថ ១១:៣ ២កថ ១១:៣ ១ធថ ២កថ ២:១៤ **៣:១៤** ប ចទ ២៨:១៥-២០ ផ ទដ ៧២:៩ អស ៤៩:២៣ ៦៥:២៥ មីក ៧:១៧ **៣:១៥** ព យហ ៨:៤៤ កថ ១៣:១០ ១យហ ៣:៨ ភ លប ១៦:១១ ពច ១៣:៥ អស ៧:១៤ ៨:៣ ៩:៦ មថ ១:២៣ លក ១:៣១ កទ ៤:៤ វវ ១២:១៧ ម រម ១៦:២០ មព ២:១៤ **៣:១៦** យ ទដ ៤៨:៥-៦អស ១៣:៨ ២១:៣ ២៦:១៧ យរ៤:៣១៦:២៤ មីក ៤:៩រ ១ធថ ២:១៥ ១កថ ១១:៣ អភ ៥:២២ **៣:១៧** ល លប ២:១៧ វ លប ៦:១៣ ៨:២១ អស ៥៤:៩ ស លប ៥:២៩ ជន ៣៥:៣៣

**៣:៧** *គេដឹងថាខ្លួននៅជាអាក្រាត* នៅពេលនេះគេមិនមែនមិនដឹងអីដូចជាកូនក្មេងទៀតឡើយ ដោយឥឡូវនេះពួកគេមានសតិសម្បជញ្ញៈ និងការយល់ដឹងថ្មី ពីភាពអាក្រាតរបស់ខ្លួនគេ និងចំពោះអ្នកដទៃ ដែលជាហេតុធ្វើឱ្យពួកគេមានអារម្មណ៍អៀនខ្មាស ។ *ក៏យកស្លឹកល្វា . . . ធ្វើជាប្រដាប់ប៉ឹង* នៅកន្លែងនេះគឺចង់បង្ហាញថា ការព្យាយាមយកស្លឹកមកធ្វើជាប្រដាប់ប៉ឹងនោះជាភាពកម្សោយរបស់ពួកគេ ហើយវាគ្មានប្រយោជន៍អ្វីទាល់តែសោះមានតែព្រះអម្ចាស់ប៉ុណ្ណោះ ដែលអាចបិទបាំងសេចក្ដីខ្មាសអៀនរបស់ពួកគេបាន (សូមមើលការពន្យល់ ៦.២១) ។

**៣:៨** *សួនច្បារ* នៅកន្លែងនេះចង់និយាយថា សួនច្បារដែលធ្លាប់តែជាកន្លែងមួយដែលមានពេញដោយអំណរនិងជាទីទំនាក់ទំនងជាមួយព្រះ តែពេលនេះក្លាយជាកន្លែងមួយគួឱ្យភ័យខ្លាច នឹងសម្រាប់ពួនគេចពីព្រះអម្ចាស់វិញ ។

**៣:៩** *ឯងនៅឯណា* នេះគឺជាសំណួរមួយបែបបំភ្លៃវោហាស៍ ដែលព្រះអម្ចាស់បានសួរពីលើវេហាស៍មក (សូមមើលការពន្យល់ ៦.២១) ។

**៣:១២** *ស្ត្រីដែលទ្រង់បានប្រទានឱ្យនៅជាមួយនឹងទូលបង្គំ វាឱ្យផ្លែឈើនោះមកទូលបង្គំ* នៅកន្លែងនេះចង់និយាយថា បុរសនោះមិនទទួលកំហុសឡើយ ថែមទាំងបានស្ដីបន្ទោសដល់ព្រះនិងស្ត្រី ព្រមទាំងអ្នកគ្រប់គ្នា ប៉ុន្តែគឺខ្លួនគាត់ផ្ទាល់ជាអ្នកប្រព្រឹត្តអំពើបាប ។

**៣:១៣** *ពស់វាមកល្បួងបញ្ឆោតខ្ញុំម្ចាស់* នៅកន្លែងនេះចង់និយាយថាស្ត្រីមិនបានទទួលកំហុសឡើយ គឺបានស្ដីបន្ទោសដល់សត្វពស់ទៅវិញ ។

**៣:១៤** *បណ្ដាសា* នៅកន្លែងនេះចង់និយាយថា ដោយព្រោះតែអំពើបាបដែលអ័ដាមបានប្រព្រឹត្ត នោះទាំងសត្វពស់ ទាំងស្ត្រី និងបុរសគឺសុទ្ធតែត្រូវទទួលការជំនុំជម្រះមកពីព្រះទាំងអស់ ប៉ុន្តែមានតែសត្វពស់ និងដីទេដែលត្រូវទទួលបណ្ដាសាក្រោយគេ (សូមមើលក្នុង ៦.១៧) ។ *ធូលីដី* ធូលីដីដែលជានិមិត្តរូបនៃសេចក្ដីស្លាប់ (សូមមើល ៦.១៩) ពេលនេះបានក្លាយជាអាហាររបស់សត្វ ។

**៣:១៥** *ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ* នៅក្នុងឃ្លានេះចង់និយាយថា គឺនិមិត្តរូបនៃជម្លោះ តស៊ូយ៉ាងមុតមាំរវាងព្រះអម្ចាស់និងអារក្សសាតាំង ហើយជម្លោះនេះបានបង្កប់ នៅក្នុងចិត្តមនុស្សគ្រប់ៗរូប ។ ជ័យជម្នះរបស់ព្រះគ្រីស្ទយេស៊ូវលើអារក្សសាតាំង និងជ័យជម្នះរបស់អ្នកជឿគ្រប់រូប គឺបានបង្ហាញពីសេចក្ដីសម្រេច ដែលព្រះអង្គទ្រង់សន្យាថាកូនចៅរបស់ស្ត្រី និងកិនក្បាលសត្វពស់ (មើលការពន្យល់ក្នុង រម ១៦:២០) ។

**៣:១៦** *សេចក្ដីព្រួយលំបាកក្នុងវេលាមានផ្ទៃពោះ* នៅក្នុងកន្លែងនេះគឺចង់មានន័យថា នេះគឺជាការជំនុំជម្រះតែមួយគត់ដែលព្រះអម្ចាស់ទ្រង់បានទម្លាក់លើស្ត្រីហើយឱ្យធ្វើ "អ្នកជំនួយដ៏ល្អ" របស់ប្ដីនាង ។ ចំណែកឯបុរសវិញក៏ទទួលនូវការឈឺចាប់ដែលប្រហាក់ប្រហែលគ្នានេះដែរ គឺត្រូវរកស៊ីពីដីដោយការ "នឿយហត់" (មើលក្នុង៦.១៧) ។ ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា "ឈឺចាប់" "សេចក្ដីឈឺចាប់" និង "នឿយហត់" ដែលយើងបានឃើញនៅទីនេះ គឺចង់និយាយពីបន្ទុកការងារដ៏ធន់ធ្ងរមួយ (សូម មើលក្នុង សភ ៥:១០ ដែលនិយាយពីការ "នឿយហត់" និង ១៤:២៣ និយាយ ពីការ "ការដែលខំធ្វើ") ។ *ឯងនឹងបង្កើតកូន* នៅក្នុងឃ្លានេះចង់និយាយថា ការបង្កើតកូនគឺជាព្រះពរ និងព្រះគុណរបស់ព្រះអម្ចាស់តាំងពីដើមមក ដែលទោះបីជាគេត្រូវជាប់ជំនុំជម្រះក៏ដោយ (សូមមើលក្នុង ១:៨) ។ *ចិត្តឯង . . . ត្រួតត្រាលើឯង* នៅក្នុងឃ្លានេះចង់និយាយថា ចំណង់ផ្លូវភេទរបស់នាងនិងប្រាថ្នាលើប្ដី ហើយប្ដីនាងនិងត្រួតត្រាលើនាង ។

**៣:១៧-១៩** *ឯងនឹងបានស៊ី* នៅក្នុងឃ្លានេះចង់និយាយថា ទោះបីជាគាត់ត្រូវធ្វើការងាររកស៊ីដោយលំបាក និងមានរយៈពេលយូរក៏ដោយ (ការជំនុំ

ឯង ឯងត្រូវរកស៊ីពីដីដោយនឿយ[ហ]ហត់អស់១ជីវិត[ឡ] ១៨ដីនឹង
ដុះជាបន្លាហើយនិងអញ្ចាញឱ្យឯង[អ] ឯងត្រូវស៊ីអស់ទាំង
តិណជាតិដែលដុះនៅស្រែចំការ[ក] ១៩ឯងនឹងបានអាហារ
ស៊ី[ខ]ដោយការបែកញើស[គ] ដរាបដល់ឯងត្រឡប់ទៅជាដី
វិញ ពីព្រោះអញបានយកឯងពីដីមកដ្បិតឯងជាធូលីដី ក៏ត្រូវ
ត្រឡប់ទៅជាធូលីដីវិញ[ឃ] ២០អ័ដាមបានឱ្យឈ្មោះប្រពន្ធ
គាត់ថា "អេវ៉ា"[ង] ពីព្រោះនាងជាម្តាយនៃមនុស្សទាំងអស់
២១នោះព្រះយេហូវ៉ាដ៏ជា ព្រះទ្រង់ក៏ធ្វើអាវពីស្បែក ឱ្យ
អ័ដាម និងប្រពន្ធគាត់ពាក់បិទបាំងកាយ[ច] ។
២២រួចព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានបន្ទូលថា មើល
មនុស្សបានត្រឡប់ដូចជាយើង១ដែរ[ឆ] ទាំងដឹងខុសត្រូវផង
ឥឡូវខ្លាចក្រែងវាលូកដៃទៅបេះផ្លែជីវិតស៊ីទៀត[ជ] ហើយ
រស់ជារៀងរាបដរាបទៅ ២៣ដូច្នេះព្រះយេហូវ៉ាដ៏ជាព្រះ
ទ្រង់ក៏បណ្តេញគាត់ពីសួនច្បារអេដែន[ឈ] ចេញឱ្យទៅភ្ជួរ
រាស់ដី[ញ] ដែលទ្រង់បានយកមកបង្កើតគាត់នោះវិញ ២៤ទ្រង់
បណ្តេញមនុស្សចេញ ហើយដាក់រូបចេរូប៊ីន[ដ]នៅខាងកើត
សួនច្បារអេដែន[ឋ]និងដាវ[ឌ] ដែលជាអណ្តាតភ្លើង រេបែរ
ទៅគ្រប់ទិស ដើម្បីនឹងរក្សាផ្លូវទៅឯដើមជីវិត[ឍ]។

ទដ ១០៦:៣៩ អស ២៤:៥ យរ ៣:១ រម ៨:២០–២២ ហ លប ២៩:៣២ ៣១:៤២ នក ៣:៧ ទដ ៦៦:១១ ១២៧:២ សស ១:១៣ ឡ លប ៤៧:៩ យប ៥:៧ ៧:១ ១៤:១ សស ២:២៣ យរ ២០:១៨ **៣:១៨** អ យប ៣១:៤០ អស ៥:៦ ហព ៦:៨ ក ទដ ១០៣:១៤ **៣:១៩** ខ ទដ ១០៤:២៣ គ លប ១៤:១៨ ចទ ៨:៣,៩ ២៣:៤ នរ ១:៦ ២:៤១ ២ថន ៣:១០ ឃ លប ២:៧ យប ៧:២១ ទដ ១៤៦:៤ ១កថ ១៥:៤៧ ហព៩:២៧

## លោកកាអ៊ីន និងលោកអេបិល

**៤** ១អ័ដាមក៏ស្គាល់អេវ៉ា[ក]ជាប្រពន្ធ[ខ]ហើយនាងមានទំងន់
បង្កើតបានកាអ៊ីន[គ] រួចនាងនិយាយថា អញបានកូនប្រុស១
ដោយព្រះយេហូវ៉ាទ្រង់ប្រោសប្រទាន ២នាងក៏បង្កើតបាន
អេបិលជាប្អូនទៀត[ឃ] ឯអេបិលជាអ្នកគង្វាលហ្វូងសត្វ តែ
កាអ៊ីនជាអ្នកធ្វើស្រែចំការវិញ[ង] ៣កន្លងក្រោយមកកាអ៊ីន
បានយកផលដែលកើតពីដី មកថ្វាយជាដង្វាយ[ច]ដល់ព្រះ
យេហូវ៉ា[ឆ] ៤ហើយអេបិលក៏ធ្វើដូចគ្នា គឺគាត់យកកូនជា
ដំបូង១ពីហ្វូង[ជ]សត្វមកថ្វាយ ព្រមទាំងខ្លាញ់វាផង[ឈ] រួច
ព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យចំពោះអេបិល និង

**៣:២០** ង លប ២:២០ ២កថ ១១:៣ ១ធថ ២:១៣ **៣:២១** ច ខ.៧ **៣:២២** ឆ លប ១:២៦ ជ លប ២:៩ វវ ២:៧ **៣:២៣** ឈ លប ២:៨ ញ លប ២:៧ **៣:២៤** ដ នក ២៥:១៨–២២ ១សយ ៤:៤ ២សយ ៦:២ ២២:១១ ១ពវ ៦:២៧ ៨:៦ ២ពវ ១៩:១៥ ២របៈ ៥:៨ ទដ ១៨:១០ ៨០:១ ៩៩:១ អស ៣៧:១៦ អគ ១០:១ ២៨:១៦ ឋ លប ២:៨ ឌ យប ៤០:១៩ ទដ ១០៤:៤ អស ២៧:១ ឍ លប ៩**៤:១** ក លប :២០ ខ ខ.១៧,២៥ គ ហព ១១:៤ ១យហ ៣:១៣ យដ ១:១១ **៤:២** ឃ មថ ២៣:៣៥ លក ១១:៥១ ហព ១១:៤ ១២:២៤ ង លប ២:៧ **៤:៣** ច លវ ២:១–២ អស ៤៣:២៣ យរ ៤១:៥ ឆ ជន ១៨:១២ **៤:៤** ជ នក ១៣:២, ១២ ចទ ១៥:១៩ ឈ លវ ៣:១៦ ញ ហព ១១: ៤

ជម្រះ) ក៏ព្រះអម្ចាស់ទ្រង់ប្រទានពរឱ្យគាត់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីរកអាហារក្នុងការទ្រទ្រង់ជីវិតរបស់គាត់បានដែរ ។

**៣:១៨** នៅក្នុងខនេះចង់និយាយថា បញ្ហាធំរបស់មនុស្ស គឺនៅពេលដែលគេធ្វើកសិកម្មដី និងគ្រាប់ពូជដែលគេចង់បាន វានឹងបង្កើតជាតិណជាតិដែលជា "អញ្ចាញ និងបន្លា"វិញ ។

**៣:១៩** *ដរាបដល់ឯងត្រឡប់ទៅជាដីវិញ . . . ក៏ត្រឡប់ទៅជាដីវិញ* នៅក្នុងឃ្លានេះចង់និយាយថា ការងាររបស់លោកអ័ដាម មិនអាចរារាំងមិនឱ្យគាត់ស្លាប់បានឡើយ ។ រូបកាយដើមរបស់គាត់ (សូមមើល ២:៧) និងប្រភពនៃអាហាររបស់គាត់ (សូមមើល ២:៧) ជានិមិត្តរូបមួយដែលបង្ហាញថា គាត់និងត្រូវស្លាប់ជាពិតប្រាកដ ។

**៣:២០** *ឱ្យឈ្មោះប្រពន្ធគាត់* អត្ថន័យនៅកន្លែងនេះគឺចង់និយាយថា មិនមែនដាក់បែបជាមានអំណាចលើនាងឡើយ (មើលការពន្យល់ ១:៥ ២:១៩) ប៉ុន្តែគឺដើម្បីបង្ហាញថា នាងជាមនុស្សសំខាន់សម្រាប់គាត់ និងពូជពង្សនៃមនុស្សក្រោយៗទៀត ។

**៣:២១** *ពាក់បិទបាំងកាយ* គឺចង់មានន័យថា ព្រះដ៏ជាព្រះទ្រង់បានប្រទានឱ្យអ័ដាមនិងប្រពន្ធគាត់នូវសំលៀកបំពាក់ដ៏សមរម្យ (សូមមើល ខ.៧) ដើម្បីធ្វើជាប្រដាប់ប៉ិងរបស់ពួកគេ ។

**៣:២៤** *ចេរូប៊ីន* ចេរូប៊ីនមានសណ្ឋានប្រហាក់ប្រហែលគ្នានឹងរូបចំលាក់ដែលមានស្លាបឈរយាមនៅច្រកទ្វាររាជវាំង និងក្នុងព្រះវិហារនៃពួកកូនចៅមេសូប៉ូតាមាជិនាន់មុនដែរ (សូមមើលក្នុង នក ២៥:១៨) ។ *ដើម្បីនឹងរក្សា* នៅកន្លែងនេះចង់និយាយថា ដាវនៃការជំនុំជម្រះរបស់ព្រះអម្ចាស់បានដាក់ឱ្យឈរនៅរវាងមនុស្សដែលបានប្រព្រឹត្តបាប ហើយនិងសួនច្បាររបស់ព្រះអម្ចាស់ ។ មូលហេតុដែលព្រះអម្ចាស់ទ្រង់ធ្វើបែបនេះ គឺមាននិយាយនៅក្នុង ខ.២២ ។ មានតែការប្រោសលោះរបស់ព្រះអម្ចាស់តាមរយៈព្រះគ្រីស្ទយេស៊ូវប៉ុណ្ណោះ ដែលមនុស្សអាចមានផ្លូវចូលក្នុងសួននៃដើមជីវិតបានម្តងទៀ (សូមមើលការពន្យល់ វវ ២:៧ ២២:២,១៤,១៩) ។

**៤:១–២៦** នៅក្នុងខទាំងនេះគឺនិយាយអំពីរបៀបដែលអំពើបាបរបស់មនុស្សបានរីកចម្រើនឡើងតាមរយៈការសម្លាប់ប្អូនប្រុសនៅក្នុងតំណវង្សទី២ រហូតដល់គ្រាដែលមនុស្សមានអំនួតអួតអាងមិនពឹងអាស្រ័យលើព្រះអម្ចាស់ ដែលការទាំងអស់នេះបានកើតឡើងក្នុងដំណវង្សទី៧ ។

**៤:១** *ដោយព្រះយេហូវ៉ា ទ្រង់ប្រោសប្រទាន* នៅក្នុងខនេះនាងអេវ៉ាបានទទួលស្គាល់ថា ព្រះអម្ចាស់ទ្រង់ជាប្រភពនៃជីវិតទាំងឡាយ (សូមមើល កច ១៧:២៥) ។

**៤:២** *អេបិល* ឈ្មោះនេះមានន័យថា "ដង្ហើម" ឬ "បណ្តោះអាសន្ន" ឬ"ឥតប្រយោជន៍"(ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះ មានន័យដូចគ្នានឹង សស ១:២ ១២:៨) ឈ្មោះនេះបានក្លាយជាតំរុយនៃអាយុជីវិតដ៏ខ្លីរបស់អេបិល ។

**៤:៣–៤** *កាអ៊ីនបានយកផលដែលកើតពីដី . . . អេបិលក៏ធ្វើដូចគ្នា គឺគាត់យកកូនជាដំបូង១ពីហ្វូងសត្វមកថ្វាយព្រមទាំងខ្លាញ់ផង* ភាពខុសគ្នានៃដង្វាយរបស់ពួកគេមិនមែនដោយព្រោះម្នាក់ថ្វាយសត្វ ហើយម្នាក់ទៀតថ្វាយរុក្ខជាតិនោះឡើយ ប៉ុន្តែអ្វីដែលខុសគ្នានោះគឺការធ្វេសប្រហែស នៃការថ្វាយដោយមិនស្ម័គ្រពីចិត្ត និងដង្វាយដែលស្ម័គ្រពីចិត្តវិញ(សូមធៀបជាមួយ លវ ៣:១៦) ។ ហេតុផល និងទឹកចិត្ត គឺមានសារៈសំខាន់ណាស់ ហើយដែលព្រះអម្ចាស់ទ្រង់សព្វព្រះទ័យលើអេបិល និងដង្វាយរបស់គាត់ នោះគឺដោយសារតែគាត់មានសេចក្តីជំនឿជឿលើព្រះអម្ចាស់ (សូមមើលការពន្យល់ក្នុង

ដង្វាយរបស់គាត់[ញ] 5 តែមិនសព្វព្រះហឫទ័យចំពោះដង្វាយ
របស់កាអ៊ីនទេ នោះកាអ៊ីនក៏ក្តៅក្រហាយ ហើយឡើងទឹក
មុខក្រញូវ 6 ព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរកាអ៊ីនថា
ឯងខឹងធ្វើអី ហេតុអ្វីបានជាឯងធ្វើទឹកមុខក្រញូវដូច្នេះ[ដ] 7 បើ
ឯងធ្វើល្អ តើមិនបានទឹកមុខរីករាយវិញទេឬអី បើឯងធ្វើ
មិនល្អ នោះមានដង្វាយលោះបាបដេកនៅមាត់ទ្វារ[ឋ] ស្រាប់
ហើយ ចិត្តវានឹងបណ្តោយតាមឯង ហើយឯងមានអំណាច
លើវាដែរ[ឌ]។

8 កាអ៊ីន ក៏ដំណាលប្រាប់ដល់អេបិលជាប្អូន រួចមានកាល
១ថ្ងៃកំពុងដែលគេនៅឯវាល នោះស្រាប់តែកាអ៊ីនក្រោក
ឡើងសំឡាប់អេបិលជាប្អូនទៅ[ឍ] 9 ព្រះយេហូវ៉ាក៏មានបន្ទូល
សួរកាអ៊ីនថា អេបិលប្អូនឯងនៅឯណា[ណ] គាត់ទូលឆ្លើយថា
ទូលបង្គំមិនដឹងទេ[ត] តើទូលបង្គំជាអ្នកថែរក្សាប្អូនឬអី 10 នោះ
ទ្រង់មានបន្ទូលសួរថា ឯងបានធ្វើអ្វីដូច្នេះ ពីព្រោះឮសូរ
សំរែកនៃឈាមរបស់ប្អូនឯងពីដីឡើងទៅដល់អញ[ថ] 11 ឥឡូវ
នេះ ឯងត្រូវដីដាក់បណ្តាសា[ទ] ដោយបានទទួលឈាមនៃប្អូន
ពីដៃឯង 12 កាលណាឯងធ្វើស្រែចំការ នោះដីនឹងមិន
បង្កើតផលឱ្យឯងដ៏ពេញកំឡាំងទៀតទេ[ធ] ឯងត្រូវសាត់
ព្រាត់[ន] ហើយអណ្តែតទៅមកលើផែនដីវិញ[ប] 13 នោះកាអ៊ីន
ទូលទៅព្រះយេហូវ៉ាថា ទោសរបស់ទូលបង្គំធ្ងន់ពេក
ណាស់ នឹងទ្រាំទ្រមិនបានទេ 14 មើល នៅថ្ងៃនេះទ្រង់បាន
បណ្តេញទូលបង្គំចេញពីស្រុកហើយ ដូច្នេះទូលបង្គំនឹង

**៤:៦** ដ យហ ៤:៤ **៤:៧** ឋ លប ៤៤:១៦ ជន ៣២:២៣ អស ៥៩:១២ ឌ យប ១១:១៥ ២២:២៧ ទដ ២៧:៣ ៤៦:២ រម ៦:១៦ **៤:៨** ឍ មថ ២៣:៣៥ លក ១១:៥១ ១យហ ៣:១២ ពច ១:១១ **៤:៩** ណ លប ៣:៩ ត យហ ៨:៤៤ **៤:១០** ថ លប ៩:៥ ៣៧:២០,២៦ នក ១:១២ ជន ៣៥:៣៣ ចទ ២១:៧,៩ ២សយ ៤:១១ យប ១៦:១៨ ២៤:២ ៣១:៣៨ ទដ ៩:១២ ១០៦:៣៨ ហព ១២:២៤ ១២:២៤ វវ ៦:៩ ១០ **៤:១១** ទ ចទ១១:២៨ ២ពវ ២:២៤ **៤:១២** ធ ចទ ២៨: ១៥–២៤ ន ទដ ៣៧:២៥ ៥៩:១៥១០៩:១០ ប ខ.១៤

ហព ១១:៤) ។ *កូនជាដំបូង* ជានិមិត្តរូបមួយដែលបង្ហាញថា អេបិលគាត់ទទួលស្គាល់ថា គ្រប់ទាំងភោគផលនៃហ្វូងសត្វទាំងអស់គឺសុទ្ធតែមកអំពីព្រះ ហើយគ្រប់នៃហ្វូងសត្វទាំងនោះក៏សម្រាប់ព្រះអម្ចាស់ផងដែរ ។

**៤:៥** *ក្តៅក្រហាយ* នៅត្រង់កន្លែងនេះ ព្រះអម្ចាស់ទ្រង់មិនសព្វព្រះហឫទ័យចំពោះកាអ៊ីន និងដង្វាយរបស់គាត់ឡើយ ដូច្នេះហើយទើបកាអ៊ីនគាត់ (ហេតុផល និងអាកប្បកិរិយារបស់គាត់អាក្រក់តាំងពីដើម) ក៏បានបង្ហាញពីប្រតិកម្មរបស់គាត់ ។

**៤:៧** *បាបដេកនៅមាត់ទ្វារស្រាប់ហើយ* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យ "ដេក"គឺមានន័យដូចគ្នានឹងពាក្យដែលពួកកូនចៅបាប៊ីឡូនប្រើ និងនិយាយសំដៅលើវិញ្ញាណអាក្រក់ ដែលវាបានដេកនៅត្រង់ទ្វារផ្ទះ ដើម្បីបន្លាចដល់មនុស្សដែលនៅក្នុងផ្ទះនោះ ។ បាបដែលនិយាយនៅកន្លែងនេះ គឺប្រៀបដូចជាវិញ្ញាណអាក្រក់ ឬខ្មោចដែលកំពុងតែរងចាំសង្គ្រប់លើលោកកាអ៊ីន ។ ប្រហែលជាកាអ៊ីនបានរៀបចំគម្រោងការណ៍រួចជាស្រេចដើម្បីធ្វើឃាតដល់ប្អូនរបស់គាត់ ។ *ចិត្តវានឹងបណ្តោយតាមឯង* ក្នុងព្រះគម្ពីរភាសាហេព្រើរឃ្លា ត្រង់នេះគឺមានន័យដូចគ្នានឹងឃ្លាដែលថា "ចិត្តឯងនឹងប្រាថ្នាលើប្តី" (សូមមើលការពន្យល់ ៣:១៦ និង សស ៧:១០) ។

**៤:៨** *នោះស្រាប់តែកាអ៊ីនក្រោកឡើងសំឡាប់អេបិលជាប្អូនទៅ* អំពើឃាតកម្មលើកដំបូង គឺជារឿងដ៏ចម្លែកពិសេសមួយពីព្រោះ គឺជារឿងឃាតកម្មដែលមានការរៀបចំទុកជាមុន (សូមមើលការពន្យល់ត្រង់ឃ្លាដែលនិយាយថា "សូមឱ្យយើងចេញទៅក្រៅ") ដើម្បីទាស់ប្រឆាំងនឹងប្អូនរបស់ខ្លួន (សូមមើល ខ.៩–១១ ១យហ ៣:១២) ហើយប្រឆាំងនិងមនុស្សល្អ (មថ ២៣:៣៥ ហព ១១:៤)។

**៤:៩** *អេបិលប្អូនឯងនៅឯណា* នេះជាសំណួរបែបបំភ្លៃវោហារសាស្ត្រដែលព្រះអម្ចាស់ទ្រង់បានសួរពីលើមក (សូមមើលការពន្យល់ ៣:៩) ។ *ទូលបង្គំមិនដឹងទេ* នៅក្នុងកន្លែងនេះចង់បង្ហាញថា ចម្លើយរបស់កាអ៊ីន គឺជាចម្លើយកុហកទាំងស្រុង ។ *តើទូលបង្គំជាអ្នកថែរក្សាប្អូនឬអី* នៅក្នុងន័យនេះចង់បង្ហាញពីការប្រព្រឹត្តដោយគ្មានមេត្តា ដែលគាត់មិនបានយកចិត្តទុកដាក់នឹងប្អូនខ្លួនឯងហើយការទាំងអស់នេះ គឺកើតឡើងដោយបណ្តាសារបស់មនុស្ស។

**៤:១០** *សំរែកនៃឈាមប្អូនឯង* ដោយសារតែ"សេចក្តីសុចរិតរបស់អេបិល" (មើល មថ ២៣:៣៥) បានធ្វើឱ្យពួក "ហោរា" (មើល លក ១១:៥០–៥១) នៅតែដំណាលពីគាត់ជានិច្ចទោះបីជាគាត់បានស្លាប់ហើយក៏ដោយ (សូមមើលការពន្យល់ ហព ១១:៤) ពីព្រោះឈាមរបស់គាត់នៅតែស្រែកចំពោះព្រះអម្ចាស់ដើម្បីទាស់ប្រឆាំងនឹងមនុស្សទាំងឡាយណា ដែលបង្កើតជម្លោះចំពោះអ្នកដទៃ ។ ប៉ុន្តែទោះជាបែបនេះមែនក៏ដោយ ក៏ព្រះលោហិតនៃព្រះយេស៊ូវបាន "សំម្តែងពីសេចក្តីប្រសើរ ជាជាងឈាមរបស់អេបិលទៅទៀតផង"(សូមមើល ហព ១២:២៤) ។

**៤:១១** *បណ្តាសា* ដោយសារតែអំពើបាបរបស់មនុស្ស បានធ្វើឱ្យដីត្រូវបណ្តាសា (សូមមើលការពន្យល់ ៣:៧) ហើយឥឡូវនេះដីបានដាក់បណ្តាសាដល់កាអ៊ីនវិញ ។ កាលពីគ្រាមុន គាត់បានធ្វើការងារនៅលើដី ហើយដីក៏បង្កើតផលឱ្យគាត់ដែរ(សូមមើល ខ.២–៣) តែឥឡូវនេះដីបានស្រូបយកឈាមរបស់ប្អូនគាត់ ជាមូលហេតុដែលធ្វើឱ្យដីមិនបង្កើតផលឱ្យគាត់ទៀតឡើយ (សូមមើលការពន្យល់ក្នុង ខ.១២) ។

**៤:១២** *អណ្តែត* នៅក្នុងន័យនេះចង់បង្ហាញថា គាត់ត្រូវរស់នៅឃ្លាតពីអ្នកដទៃ ហើយសូម្បីតែដីក៏មិនអំណោយផលដល់គាត់ដែរ ទីបំផុតគាត់នឹងក្លាយជាមនុស្សរស់នៅបែបអណ្តែតត្រសែតនៅលើផែនដី (សូមមើលការពន្យល់ក្នុង ខ.១៦) ។

**៤:១៣** *ទោសរបស់ទូលបង្គំធ្ងន់ពេកណាស់* នៅក្នុងន័យនេះចង់និយាយថា កាអ៊ីនគាត់មិនព្រមទទួលយកលទ្ធផលពីការកាត់ទោសចំពោះបទឧក្រិដ្ឋ និងបណ្តាសាដែលគាត់ត្រូវទទួលនោះឡើយ ប៉ុន្តែផ្ទុយមកវិញ បានធ្វើឱ្យគាត់មានអារម្មណ៍សោកស្តាយចំពោះខ្លួនឯងវិញ ។ អំពើបាបរបស់គាត់ មានជាអាទិ៍: ប្រមាថចំពោះព្រះ (ខ.៣) ក្តៅក្រហាយ(ខ.៥) ច្រណែន បោកប្រាស់ និងកាប់សម្លាប់ (ខ.៨) កុហក (ខ.៩) ព្រមទាំងអាត្មានិយម (ខ.១៣) ។ លទ្ធផលចុងក្រោយនៃអំពើបាប បានធ្វើឱ្យគាត់ឃ្លាតឆ្ងាយពីព្រះអម្ចាស់ (សូមមើលការពន្យល់ ខ.១៤,១៦) ។

**៤:១៤–១៥** *អស់អ្នកណា . . . អ្នកណា . . . កុំឱ្យអ្នកណា* ពាក្យទាំងអស់នេះមើលទៅហាក់បីដូចជាពាក្យប្រៀបធៀប ពីវត្តមានសមាជិកទាំងឡាយដែល

ត្រូវឃ្លាតពីទ្រង់ទៅ[ផ] ហើយត្រូវសាត់ព្រាត់អណ្តែតទៅមក
លើផែនដី[ព] រួចអស់អ្នកណាដែលឃើញទូលបង្គំ គេនឹង
សំឡាប់ទូលបង្គំបង់[ភ] ១៥តែព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅ
គាត់ថា ដូច្នេះបើអ្នកណាដែលសំឡាប់ឯង[ម] នោះនឹងត្រូវ
ទោស[យ] ១ជា៧ស្ងួន[រ] រួចព្រះយេហូវ៉ាទ្រង់ក៏ដៅចំណាំកាអ៊ីន
ដើម្បីកុំឱ្យអ្នកណា ដែលឃើញគាត់បានសំឡាប់បង់ឡើយ ។
១៦នោះកាអ៊ីនក៏ចេញពីចំពោះព្រះយេហូវ៉ា[ល] ទៅនៅឯ
ស្រុកណូឌ ខាងកើតអេដែនទៅ[វ] ១៧ហើយកាអ៊ីនបានស្គាល់
ប្រពន្ធគាត់[ស] នោះនាងមានផ្ទៃពោះបង្កើតបានអេណុក
គាត់ក៏សង់ទីក្រុង១[ហ] ហើយដាក់ឈ្មោះទីក្រុងនោះតាម
ឈ្មោះអេណុកកូនខ្លួន[ឡ] ១៨អេណុកបង្កើតបានអ៊ីរ៉ាឌៗបង្កើត
មហ៊ូយ៉ែលៗបង្កើតមធូសែល ហើយមធូសែលបង្កើត
ឡាមេក ១៩ឯឡាមេកគាត់យកប្រពន្ធ[អ]២[ក] មួយឈ្មោះអ័ដា

**៤:១៤** ផ ២ពវ ១៧:១៨ ទដ ៥១:១១ ១៣៩:៧–១២ យរ ៧:១៥ ៥២:៣ ព ខ.១២ ចទ ២៨:៦៤–៦៧ ភ លប ៩:៦ នក ១២
**៤:១៥** ម អគ ៩:៤,៦ យ នក ២១:២០ រ ខ.២៤ លវ ២៦:២១ ទដ ៧៩:១២
**៤:១៦** ល ពច ១:១១ វ លប ២:៨
**៤:១៧** ស ខ.១ ហ ទដ ៥៥:៩ ឡ ទដ ៤៩:១១
**៤:១៩** អ លប ៦:២

មួយទៀតឈ្មោះស៊ីឡា ២០នាងអ័ដាបង្កើតបានយ៉ាបាល
ដែលជាឪពុកនៃអស់ពួកអ្នកនៅក្នុងត្រសាលហើយមានហ្វូង
សត្វ ២១ប្អូនគាត់ឈ្មោះយូបាល ជាឪពុកនៃពួកអ្នកលេង
ស៊ុង[ខ]និងខ្លុយ[គ] ២២ឯនាងស៊ីឡាក៏បង្កើតបានទូបាល–កាអ៊ីន
ជាមេបង្រៀន[ឃ]ពួកជាងលង្ហិននិងជាងដែក ប្អូនស្រីទូបាល–
កាអ៊ីន គឺនាងនាអាម៉ា ។
២៣ឯឡាមេក គាត់និយាយទៅប្រពន្ធគាត់ទាំង២ថា ម្នាល
អ័ដានិងស៊ីឡាអើយ ចូរស្តាប់ពាក្យអញចុះ ឱប្រពន្ធឡាមេក
រាល់គ្នាអើយ ចូរផ្ទៀងត្រចៀកស្តាប់ពាក្យអញចុះ ដ្បិតអញ

ក លប ២៩:២៨ ចទ ២១:១៥ នរ ៤:១១ ១សយ ១:២ **៤:២១** ខ លប ៣១:២៧ នក១៥:២០ ១សយ ១៦:១៦ ១រប ២៥:៣ ទដ ៣៣:២ ៤៣:៤ សយ ១៦:១១ ដយ ៣:៥ គ យប ២១:១២ ៣០:៣១ ទដ ១៥០:៤ **៤:២២** ឃ នក ៣៥:៣៥ ១សយ ១៣:១៩ ២ពវ ២៤:១៤ **៤:២៣** ង លប ៩:៥–៦ នក ២០:១៣ ២១:១២ ២៣:៧ លវ១៩:១៨ ២៤:១៧ ចទ

មិនមែនជាសមាជិករបស់កាអ៊ីននាពេលឥឡូវ ប៉ុន្តែតាមពិតប្រហែលជាចង់និយាយសំដៅលើមនុស្សជំនាន់ក្រោយវិញ ។ ការដែលកាអ៊ីនបាននិយាយសំដៅលើខ្លួនគាត់ផ្ទាល់នោះ គឺគាត់បានរាប់បញ្ចូលទាំងជំនួរវង្សរបស់គាត់ថែមទៀត ដែលពួកគេទាំងអស់ក៏សុទ្ធតែជាប់ជំនុំជម្រះ ជាមួយគាត់ដែរ (ដូចជាគ្រួសាររបស់អ័ដាមដែរ) ។ មានការគួរឱ្យកត់ សំគាល់មួយគឺកាអ៊ីនបានសាងទីក្រុង១ឡើង (សូមមើល ខ.១៧) ហើយឡាមេកជាកូនចៅរបស់គាត់ បានអួតអាងពីការសងសឹកចំពោះខ្លួនគាត់ដែរ (សូមមើលការពន្យល់ ខ.២៣–២៤) ។

**៤:១៥** *ដៅចំណាំ* ការដៅចំណាំនេះ គឺព្រះយេហូវ៉ាទ្រង់បានដាក់ដើម្បីធ្វើជាសញ្ញាសម្គាល់និងព្រមានមិនឱ្យមានគេសងសឹកនឹងគាត់ ។ តាំងពីគ្រាដំបូងនោះមក ព្រះអម្ចាស់ទ្រង់តែងតែរក្សារជីវិតអ្នកដែលប្រព្រឹត្តអំពើឃាតកម្ម (ប៉ុន្តែសូមមើល ៦:៧ ៩:៦) ។ សម្រាប់រឿងប្រហាក់ប្រហែលគ្នានេះ សូមមើល អគ ៩:៤ ។

**៤:១៦** *ណូឌ* ទីកន្លែងពិតប្រាកដរបស់ស្រុកនេះមិនដឹងច្បាស់ឡើយ ។

**៤:១៧–១៨** *កាអ៊ីន . . . អេណុក . . . អ៊ីរ៉ាឌ . . . មហ៊ូយ៉ែល . . . មធូសែល . . . ឡាមេក* នៅក្នុងកន្លែងនេះចង់និយាយថា ពួកគេទាំងអស់នេះគឺសុទ្ធតែកើតពីអ័ដាមមក ហើយពួកគេក៏បានកើនឡើងរហូតដល់៧នាក់ដែលចំនួន៧នេះជានិមិត្តរូបនៃចំនួនពេញលក្ខណៈ (សូមមើលការពន្យល់ ខ.១៥) ។ ឈ្មោះរបស់គេម្នាក់ៗក្នុងចំណោមអ្នកទាំង៦ដែលនិយាយនៅកន្លែងនេះ គឺមានការប្រហាក់ប្រហែល ឬដូចគ្នាដែលជាអត្តសញ្ញាណសំគាល់ពីជំនួរវង្សរបស់សេត ដែលមាននិយាយនៅក្នុងជំពូក៥ ហើយដែលមានឈ្មោះដូចតទៅ :កៃណាន (៥:១២) អេណុក (៥:២១) យ៉ារេឌ (៥:១៨) ម៉ាលេ–លាល (៥:១៥) មធូសាឡា (៥:២៥) ឡាមេក (៥:២៨) ។ ការប្រហាក់ប្រហែលគ្នារវាងឈ្មោះ ២តំណនេះគឺមានសារៈសំខាន់ណាស់ ព្រមទាំងបានបង្ហាញពីការជ្រើសរើសរបស់ព្រះចំពោះជំនួរវង្សរបស់ពួកគេ (សូមមើលការពន្យល់ក្នុង ៥:៥ ព្រមទាំងសេចក្តីផ្តើមព្រះគម្ពីរ១របាក្យត្រត្រង់ចំណុចជំនួរវង្ស) ។

**៤:១៧** *ទីក្រុង* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះអាចនិយាយសំដៅលើកន្លែងស្នាក់អាស្រ័យជាអចិន្ត្រៃយ៍ ទោះជាមានលក្ខណៈតូចក៏ដោយ ។ នៅពេលនេះកាអ៊ីនគាត់ព្យាយាមរំដោះខ្លួនគាត់ចេញពីការសាត់ព្រាត់និងអណ្តែតលើផែនដីនេះ ដោយទង្វើដែលចេញពីដៃគាត់ផ្ទាល់ នៅលើទឹកដីនៃការសាត់ព្រាត់របស់គាត់ដោយការកសាងទីក្រុង១ឡើង ។

**៤:១៩** *យកប្រពន្ធ២* នេះគឺជាការចាប់ផ្តើមក្នុងប្រវត្តិសាស្ត្រ ដែលមនុស្សអាចមានប្រពន្ធច្រើន ។ ឡាមេកជាពូជពង្សរបស់កាអ៊ីន ហើយជាមនុស្សស្ថិតក្នុងជំនួរវង្សទី៧រាប់ពីអ័ដាមមក គាត់បានរកឃើញព្រះពររបស់ព្រះអម្ចាស់ដែលទ្រង់បានប្រទានពរតាំងពីដំបូងមក (សូមមើល ១:២៨) តាមរយៈបំណងចិត្តខ្លួនឯង ដោយការយកប្រពន្ធ២ ។ ទោះបីជាយ៉ាងណាក៏ដោយក៏ឯកពន្ធភាព គឺជាគោលបំណងដើមរបស់ព្រះអម្ចាស់ចំពោះមនុស្សដែលព្រះអង្គបង្កើតមក (សូមមើលការពន្យល់ ២:២៣–២៤) ។

**៤:២០–២២** *យ៉ូបាល . . . យូបាល . . . ទូបាល–កាអ៊ីន* កូនប្រុសទាំង៣របស់ឡាមេក គឺមានឈ្មោះប្រហាក់ប្រហែលគ្នា ហើយឈ្មោះរបស់ពួកគេនិមួយៗ គឺដាក់តាមឈ្មោះ ក្នុងព្រះគម្ពីរភាសាហេព្រើរ ដែលមានន័យថា "នាំមក យកមក និងដឹកនាំ" ហើយតាមរយៈឈ្មោះរបស់គេនេះ ក៏ចង់និយាយសំដៅលើអាកប្បកិរិយារបស់ពួកគេម្នាក់ដែរ ។ ឈ្មោះរបស់ទូបាស–កាអ៊ីនជាឈ្មោះពិសេសមួយ ហើយ "កាអ៊ីន"មានន័យថា"ជាងលោហៈ"។

**៤:២២** *ដែក* ដែកគឺជាវត្ថុមួយដែលគេប្រើសម្រាប់ធ្វើកសិកម្ម សំណង់ និងក្នុងសង្គ្រាមផងដែរ (សូមមើល ១សយ ១៣:១៩–២១) ។

**៤:២៣** *សំឡាប់មនុស្សម្នាក់ពីព្រោះវាបានធ្វើឱ្យអញមានរបួស* នៅក្នុងឃ្លានេះចង់និយាយថា អំពើហិង្សា និងការបំផ្លិចបំផ្លាញដ៏សាហាវព្រៃផ្សៃដែលមនុស្សមាន គឺកើតចេញពីដៃនៃមនុស្សម្នាក់ដែលបានអះអាងថា ខ្លួនគេឈប់ពឹងពាក់ស្នាក់អាស្រ័យលើព្រះយេហូវ៉ាទៀតហើយ ដោយគេបានសងសឹកដោយដៃគេផ្ទាល់ (សូមមើលការពន្យល់ ចទ ៣២:៣៥) ។ លោកឡាមេកគាត់បាននិយាយដោយអំនួតអួតអាងថា នឹងធ្វើជាអ្នកកំណត់វាសនាខ្លួនឯងដោយគាត់បានគិតរបៀបនេះជាមួយកូនប្រុសរបស់គាត់ផ្ទាល់ តាមរយៈទង្វើផ្សេងៗដែលគេបានប្រព្រឹត្តកន្លងមក ហើយគាត់ក៏គិតទៀតថាទង្វើទាំងនោះនឹងជួយឱ្យគាត់បានរួចចេញពីបណ្តាសា ដែលមានតាមរយៈតំណវង្សកាអ៊ីន

បានសំឡាប់[ង]មនុស្សម្នាក់ ពីព្រោះវាបានធ្វើឱ្យអញមាន
របួស គឺជាមនុស្សកំឡោះម្នាក់ ដោយហេតុវាបានវាយអញ
ឱ្យជាំ ២៤បើសិនជាត្រូវសងសឹក[ច]ជួសកាអ៊ីន១ជា៧ដង[ឆ]
នោះក៏ត្រូវសងសឹកជួសឡាមេក១ជា៧៧ដងវិញ[ជ] ។
២៥រួចមកអ័ដាបានស្គាល់ប្រពន្ធម្តងទៀត[ឈ] ហើយនាង
បង្កើតបានកូនប្រុស១ ឱ្យឈ្មោះថា សេត[ញ] ព្រោះនាងថា
ព្រះទ្រង់បានប្រទានពូជ១ទៀតមកអញជំនួសអេបិល ដែល
កាអ៊ីនបានសំឡាប់ទៅនោះ[ដ] ២៦ឯសេតគាត់ក៏បង្កើតបានកូន
ប្រុស១ដែរ ដាក់ឈ្មោះថា អេណុស[ឋ] ហើយនៅជាន់នោះ
គេចាប់តាំងអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា[ឌ] ។

## ចាប់ពីលោកអ័ដាម ដល់លោកណូអេ

**៥** ១នេះជាបញ្ជីពង្សាវតារ[ក]នៃពូជអ័ដាម[ខ] នៅថ្ងៃដែល
ព្រះបានបង្កើតមនុស្សមក នោះទ្រង់ធ្វើឱ្យមានភាពមើល
ទៅដូចជាអង្គទ្រង់[គ] ២ទ្រង់ក៏បង្កើតគេជាប្រុស[ឃ]ជាស្រី[ង] រួច
ប្រទានពរឱ្យ ព្រមទាំងឱ្យឈ្មោះថា អ័ដាម ក្នុងថ្ងៃដែលបាន
បង្កើតមកនោះ ៣ឯអ័ដាមគាត់រស់នៅបាន១៣០ឆ្នាំ នោះ
ទើបបង្កើតបានកូនប្រុស១តាមរូបភាពគាត់[ច] ហើយមើល
ទៅដូចជាគាត់ក៏ឱ្យឈ្មោះថាសេត[ឆ] ៤រួចក្រោយគ្រាដែលប
ង្កើតសេតមក នោះគាត់រស់នៅបាន៨០០ឆ្នាំទៀតទាំង
បង្កើតបានកូនជាប្រុសជាស្រីតទៅ ៥អាយុអ័ដាមទាំងអស់
បាន៩៣០ឆ្នាំ រួចគាត់ក៏ស្លាប់ទៅ[ជ] ។
៦សេតអាយុ១០៥ឆ្នាំ នោះគាត់បង្កើតបានអេណុស[ឈ]
៧រួចក្រោយគ្រាដែលបង្កើតអេណុសមក នោះគាត់រស់នៅ
បាន៨០៧ឆ្នាំទៀតទាំងបង្កើតបានកូនជាប្រុសជាស្រីតទៅ
៨អាយុសេតទាំងអស់បាន៩១២ឆ្នាំ រួចគាត់ក៏ស្លាប់ទៅ ។
៩អេណុសអាយុបាន៩០ឆ្នាំ នោះគាត់បង្កើតបានកៃណាន
១០រួចក្រោយគ្រាដែលបង្កើតកៃណានមក នោះគាត់រស់នៅ
បាន៨១៥ឆ្នាំទៀត ទាំងបង្កើតបានកូនជាប្រុសជាស្រីតទៅ
១១អាយុអេណុសទាំងអស់បាន៩០៥ឆ្នាំរួចគាត់ក៏ស្លាប់ទៅ ។
១២កៃណានអាយុបាន៧០ឆ្នាំ នោះគាត់បង្កើតបាន
ម៉ាលេ–លាល[ដ] ១៣រួចក្រោយគ្រាដែលបង្កើតម៉ាលេលាល
មក នោះគាត់រស់នៅបាន៨៤០ឆ្នាំទៀត ទាំងបង្កើតបានកូន
ជាប្រុសជាស្រីតទៅ ១៤អាយុកៃណានទាំងអស់៩១០ រួចគាត់
ស្លាប់ទៅ ។
១៥ម៉ាលេលាលអាយុបាន៦៥ឆ្នាំ នោះគាត់បង្កើតបាន
យ៉ារេឌ[ឋ] ១៦រួចក្រោយគ្រាដែលបង្កើតយ៉ារេឌមក នោះ
គាត់រស់នៅបាន៨៣០ឆ្នាំទៀត ទាំងបង្កើតបានកូនជាប្រុស

២៧:២៤ ៣២:៣៥ **៤:២៤** ច ចទ ៣២:៣៥ ២ពវ ៩:៧ ទដ ១៨:៤៧ ៩៤:១ អស ៣៥:៤ យរ ១៨:២២ **៤:២៥** ឈ ខ.១ ញ លប ៥:៣ ១រប ១:១ ដ ខ.៨ **៤:២៦** ឋលប ៥:៦ ១រប ១:១ លក ៣:៣៨ ឌ លប ១២:៨ ១៣:៤ ២១:៣៣ ២២:៩ ២៦:២៥ ៣៣:២០ ៣៥:១ នក ១៧:១៥ ១ពវ ១៨:២៤ ទដ ១១៦:១៧ យអ ២:៣២ សផ ៣:៩ កច ២:២១ **៥:១** ក លប ២:៤ ខ ១រប ១:១ គ លប ១:២៧ កល ៣:១០ **៥:២** ឃ លប ១:២៨ ង លប ១:២៧ មថ ១៩:៤ មក ១០:៦
ក.ទ ៣:២៨ **៥:៣** ច លប ១:២៦ ១កច ១៥:៤៩ ឆ លប ៤:២៥ លក ៣:៣៨ **៥:៥** ជ លប ២:១៧ ហព ៩:២៧ **៥:៦** ឈ លប ៤:២៦ លក ៣:៣៨ **៥:៩** ញ ១រប ១:២ លក ៣:៣៧ **៥:១២** ដ ១រប ១:២ លក ៣:៧ **៥:១៥** ឋ ១រប ១:២ លក ៣:៣៧ ពច ១:១៤

អំនួតដ៏ជ្រុសបែបនេះ បានបង្ហាញពីកំរិតនៃអំពើបាប ដែលបានចាប់ផ្តើមកើតឡើងតាំងពីដង្វាយគ្មានន័យរបស់កាអ៊ីន និងអំពើឃាតកម្មលើប្អូនប្រុសរបស់គាត់ ។

**៤:២៤** *១ជា៧៧ដង* ចំនួនសេចក្តីអំនួតរបស់ឡាមេក ដែលនិយាយអំពីការសងសឹកនេះ បានក្លាយទៅជាចំនួននៃការអត់ទោស ដែលព្រះយេស៊ូវទ្រង់បានឆ្លើយតបចំពោះសំណួរដែលពេត្រុសបានចោទសួរ (សូមមើលក្នុង មថ ១៨:២១–២២) ។

**៤:២៥** *ស្គាល់ប្រពន្ធម្តងទៀត...បង្កើតបានកូនប្រុស១* ដោយសារតែអេបិលបានស្លាប់ទៅហើយ ហើយកាអ៊ីនក៏បានរសាត់អណ្តែតលើផែនដីទៀត ដូច្នេះនេះជាមូលហេតុមួយដែលអ័ដាម និងនាងអេវ៉ាបានព្រមព្រៀងគ្នាបង្កើតកូនប្រុសទី៣ដើម្បីបន្តវង្សត្រកូលបន្តទៀត ។

**៤:២៦** *អេណុស* ឈ្មោះនេះក៏ដូចគ្នានឹង "អ័ដាម" ដែរ (សូមមើល ២:៧) ដែលមានន័យថា"បុរស"ឬ"មនុស្សដំបូង" ។ *គេចាប់តាំងអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា* ផ្ទុយពីសេចក្តីអំនួតអួតអាងក្នុងជំនួរវង្សរបស់កាអ៊ីនក្នុងកាលដែលឡាមេកគាត់បានអួតអាងថា គាត់អាចពឹងពាក់លើខ្លួនឯងបានដោយមិនចាំបាច់ពឹងលើព្រះយេហូវ៉ាឡើយ បែរជាជំនួរវង្សរបស់សេតក្លាយជាអ្នកដែលពឹងពាក់ស្នាក់អាស្រ័យលើព្រះយេហូវ៉ា ដោយការចាប់តាំងអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ាទៅវិញ ។

**៥:១** *បញ្ជីពង្សាវតារ* សូមមើលការពន្យល់ ២:៤ ។ *ឱ្យមានភាពដូចជាអង្គទ្រង់* សូមមើលការពន្យល់ ១:២៦ ។

**៥:២** *ជាប្រុសជាស្រី* សូមមើលការពន្យល់ ១:២៧ ។ *រួចប្រទានពរឱ្យ* សូមមើលការពន្យល់ ១:២៨ ។ *ឱ្យឈ្មោះ* សូមមើល ១:៥ ។

**៥:៣** *តាមរូបភាពគាត់...ដូចគាត់* សូមមើល ១:២៦ ។ នៅកន្លែងនេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់បានបង្កើតលោកអ័ដាមមកក្នុងរូបភាពនៃទ្រង់ដោយគ្មានអំពើបាបសោះ តែឥឡូវនេះលោកអ័ដាមគាត់បង្កើតបានកូនប្រុស១តាម រូបភាពនៃគាត់ក្នុងនិស្ស័យជាអ្នកមានបាបវិញ ។

**៥:៥** *៩៣០ឆ្នាំ* សូមមើលខ.២៧ ៦:៣ ។ ទោះបីជាមានការពណ៌នាពីដើមជំពូកដំបូងក្នុងព្រះគម្ពីរលោកុប្បត្តិថា មនុស្សជាតិមានអាយុកាលយូរអង្វែងក៏ដោយ ក៏ការនោះវាមិនមែនជាការពិតដែរ ។ អ្នកខ្លះជឿថាចំនួននៃអាយុកាលដ៏ច្រើនរបស់ពួកគេមួយចំនួន គឺសុទ្ធតែមានសារៈសំខាន់និងអត្ថន័យរបស់ពួកគេ ជាក់ស្តែងដូចជា អេណុក គាត់មានអាយុកាលរហូតដល់ ៣៦៥ឆ្នាំ (ខ.២៣) (ចំនួន៣៦៥គឺជាចំនួនថ្ងៃដែលឈានចូលឆ្នាំថ្មីដូច្នេះបង្ហាញថា គាត់មានអាយុពេញលេញ) ហើយឡាមេកគាត់មានអាយុកាល ៧៧៧ឆ្នាំ (ខ.៣១) (ចំនួន៧៧៧ គឺជាចំនួននៃការចាប់ផ្តើមរីកចម្រើនឡើងហើយក៏ជាចំនួនដ៏ច្រើននៃផលគុណ៧ ដែលជាចំនួនមួយដ៏គ្រប់លក្ខណឬភាពបរិបូរ សូមធ្វើការប្រៀបធៀបចំនួន "៧៧៧"របស់ឡាមេកម្នាក់ទៀតដែលមាននិយាយនៅ ៤:២៤) ។ នៅក្នុងជំពូកទី៥ បាននិយាយពីឈ្មោះមនុស្សពិតប្រាកដចំនួន១០នាក់ (ដូចជាជំនួរវង្ស ដែលបាននិយាយនៅក្នុង ១១:១១–២៦) គឺពួកគេទាំងនោះមានអាយុកាលដ៏ច្រើនដូចគ្នា ។ *រួចគាត់ក៏ស្លាប់ទៅ* នៅក្នុងឃ្លានេះគឺចង់និយាយអំពីការជំនុំជម្រះរបស់ព្រះយេហូវ៉ា

ជាស្រីតទៅ ១៧អាយុម៉ាលេលាលទាំងអស់បាន៨៩៥ឆ្នាំ
រួចគាត់ ក៏ ស្លាប់ទៅ ។
១៨យ៉ារេឌអាយុបាន១៦២ឆ្នាំ នោះគាត់បង្កើតបាន
ហេណុក[ឱ] ១៩រួចក្រោយគ្រាដែលបង្កើតហេណុកមក នោះ
ទាំងបង្កើតបានកូនជាប្រុសជាស្រីតទៅ ២០អាយុយ៉ារេឌ
ទាំងអស់បាន៩៦២ឆ្នាំ រួចគាត់ក៏ស្លាប់ទៅ ។
២១ហេណុកអាយុបាន៦៥ឆ្នាំ នោះគាត់បង្កើតបានមធូ
សាឡា[ឈ] ២២រួចក្រោយគ្រាដែលបង្កើតមធូសាឡាមកនោះ
គាត់ក៏ដើរជាមួយនឹងព្រះ[ណ]អស់៣០០ឆ្នាំ ទាំងបង្កើតបានកូន
ជាប្រុសជាស្រីតទៅ ២៣អាយុហេណុកទាំងអស់បាន៣៦៥ឆ្នាំ
២៤ហេណុកគាត់ជាអ្នកដើរជាមួយនឹងព្រះ[ត] នោះគាត់មិន
នៅទៀតទេ ពីព្រោះព្រះទ្រង់បានទទួលយកគាត់ទៅ[ថ]។
២៥មធូសាឡា គាត់អាយុបាន១៨៧ឆ្នាំ នោះគាត់បង្កើត
បានឡាមេក[ទ] ២៦រួចក្រោយគ្រាដែលបង្កើតឡាមេកមក
នោះ គាត់រស់នៅបាន៧៨២ឆ្នាំទៀត ទាំងបង្កើតបានកូនជា
ប្រុសជាស្រីតទៅ ២៧អាយុរបស់មធូសាឡាទាំងអស់ បាន
៩៦៩ឆ្នាំ រួចគាត់ក៏ស្លាប់ទៅ ។
២៨ឡាមេក អាយុ១៨២ឆ្នាំ នោះគាត់បង្កើតបានកូន
ប្រុស១ ២៩ដែលគាត់ឱ្យឈ្មោះថាណូអេ[ធ] ដោយនិយាយថា
កូននេះនឹងកំសាន្តចិត្តយើងក្នុងការដែលយើងធ្វើ ហើយនិង
សេចក្តីនឿយហត់របស់ដៃយើង ដោយព្រោះដីដែលព្រះ
យេហូវ៉ាបានដាក់បណ្តាសា[ន] ៣០រួចក្រោយគ្រាដែលបង្កើត
ណូអេមក នោះគាត់រស់នៅបាន៥៩៥ឆ្នាំទៀត ទាំងបង្កើត
បានកូនជាប្រុសជាស្រីតទៅ ៣១អាយុឡាមេកទាំងអស់បាន
៧៧៧ឆ្នាំ រួចគាត់ក៏ស្លាប់ទៅ ។
៣២ឯណូអេ គាត់អាយុបាន៥០០ឆ្នាំ[ប] នោះបង្កើតបាន
សឹម[ផ] ១ ហាំ១ និងយ៉ាផែត១[ព]។

**ទឹកជន់**

**៦** ១កាលពួកមនុស្សចាប់តាំងមានគ្នាច្រើននៅលើផែនដី[ក]
ឡើង ហើយបង្កើតបានកូនស្រីៗ ២នោះពួកកូនប្រុសរបស់

**៥:១៨** ឱ ១រប ១:៣ លក ៣:៣៧ ពច ១:១៤
**៥:២១** ឈ ១រប ១:៣ លក ៣:៣៧
**៥:២២** ណ ខ.២៤ លប ៦:៩ ១៧:១ ២៤:៤០ ៤៨:១៥ ២ពវ ២០:៣ ទដ ១១៦:៩ មីក ៦:៨ មឡ ២:៦
**៥:២៤** ត ខ.២២ ថ ២ពវ ២:១,១១ ទដ ៤៩:១៥ ៧៣:២៤ ៨៩:៤៨ ហព ១១:៥
**៥:២៥** ទ ១រប ១:៣ លក ៣:៣៦
**៥:២៩** ធ ១រប ១:៣ លក ៣:៣៦ ន លប ៣:១៧ រម ៨:២០
**៥:៣២** ប លប ៧:៦,១១ ៨:១៣ ផ លក ៣:៣៦ ព លប ៦:១០ ៩:១៨ ១០:១ ១រប ១:៤ អស ៦៥:២០ **៦:១** ក លប ១:២៨

ចាប់តាំងពីគ្រាដែលអ័ដាមបានធ្វើបាបមក ។

**៥:២២** *ដើរជាមួយនឹងព្រះ* ទោះបីជានៅក្នុងជំពូកផ្សេងៗទៀតក៏គេប្រើឃ្លានេះជំនួសដោយពាក្យថា"រស់នៅជាមួយព្រះ"ក៏ដោយ ក៏ឃ្លាដែលថា"ដើរជាមួយព្រះ និងរស់នៅជាមួយព្រះ" វាមិនដូចគ្នានោះទេ ។

**៥:២៤** *នោះគាត់មិននៅទៀតទេ ពីព្រោះព្រះទ្រង់បានទទួលយកគាត់ទៅ* នៅក្នុងជំពូកផ្សេងៗទៀត ឃ្លានេះគេប្រើជំនួសមកវិញដោយពាក្យថា"ហើយគាត់ក៏ស្លាប់ទៅ" ។ វាមិនខុសគ្នាជាមួយនឹងលោកអេលីយ៉ាដែលព្រះបាន"លើកឡើង"(២ពវ ២:១០) ទៅស្ថានសួគ៌ ហើយលោកហេណុកក្នុងកាលដែលព្រះយេហូវ៉ាទ្រង់ទទួលយកទៅនៅជាមួយព្រះអង្គ (សូមធៀបជា មួយ ទដ ៤៩:១៥ ៧៣:២៤) ដោយគ្មានឃើញសេចក្តីស្លាប់ឡើយ (សូមមើល ហព ១១:៥) ។ ឡាមេកជាជំនួរវង្សកាអ៊ីន ហើយជាមនុស្សស្ថិតនៅក្នុងតំណវង្សទី៧រាប់ពីអ័ដាមមក គាត់គឺជាតួអង្គមួយដែលដំណាងឱ្យការអាក្រក់ តែ"ហេណុកជាជំនួរវង្សសេត ស្ថិតក្នុងតំណវង្សទី៧រាប់ពីលោកអ័ដាម"មកដែរ (សូមមើល ពច ជំពូក១៤) គាត់គឺជាម្នាក់ដែលតំណាងឱ្យ "អ្នកដែលធ្វើឱ្យព្រះទ្រង់សព្វព្រះទ័យ" (សូមមើល ហព ១១:៥) ។

**៥:២៧** *៩៦៩ឆ្នាំ* នៅក្នុងគ្រាទឹកជន់គឺមានតែលោកណូអេ និងក្រុមគ្រួសារគាត់ប៉ុណ្ណោះ ដែលរស់រានមានជីវិត ។ បើសិនជាអាយុនេះជាអាយុពិតរបស់មធូសាឡាមែន នោះមធូសាឡាគាត់ពិតជាបានស្លាប់ក្នុងគ្រាមានទឹកជន់ដ៏ធំនៅលើផែនដីនោះជាប្រាកដ (សូមមើល ខ.២៥,២៨ និង ៧:៦ ឃើញថា មធូសាឡាគាត់ពិតជាមានអាយុ ៩៦៥ មែន) ។

**៦:១–៨** នៅក្នុងខទាំងនេះ គឺពិពណ៌នាអំពីប្រវត្តិសាស្ត្រដំបូងរបស់មនុស្សក្នុងកាលដែលពួកគេអនុញ្ញាតឱ្យអំពើពុករលួយជ្រាបចូលក្នុងជីវិតរបស់ពួកគេ ដែលព្រះយេហូវ៉ាទ្រង់បានបំបែរព្រះទ័យរបស់ទ្រង់ហើយនាំនូវឫសគល់នៃការជំនុំជម្រះមកលើស្នាព្រះហស្តរបស់ទ្រង់ ។

**៦:១** *ចាប់តាំងមានគ្នាច្រើន* សូមមើលក្នុង ១:២២ ។

**៦:២** *ពួកកូនប្រុសរបស់ព្រះគេឃើញកូនស្រីរបស់មនុស្ស . . . ក៏យកធ្វើជាប្រពន្ធ* សូមមើល ខ.៤ ។ ពាក្យថា"ពួកកូនព្រះ"នៅកន្លែងនេះ គឺសំដៅទៅលើទាំងពួកទេវតា និងមនុស្សដំបូងដែលព្រះយេហូវ៉ាទ្រង់បានបង្កើតមក ។ នៅក្នុងព្រះគម្ពីរផ្សេងៗទៀត ដូចជា យប ១:៦ ២:១ ជាដើម ពាក្យដែលនិយាយថា "កូនរបស់ព្រះ"គឺសំដៅលើពួកទេវតា ហើយកន្លែងផ្សេងៗទៀតក៏បាននិយាយថាជាពួកទេវតាដែរ ដូចជានៅក្នុង ទដ ២៩:១ (កន្លែងដែលនិយាយថា"កូនព្រះដ៏មានឥទ្ធិឫទ្ធិ") ។ មិនតែប៉ុណ្ណោះសោត មានការកាត់ស្រាយផ្សេងៗទៀត ដូចជានៅក្នុងព្រះគម្ពីរពួកចៅហ្វាយ ជំពូក ៦–៧ (និងអក្សរសាស្ត្ររបស់ពួកយូដា) ក៏បាននិយាយថា ឃ្លាដែលថា"ពួកកូនព្រះ"គឺជាពួកទេវតាដែរ ។ មួយវិញទៀតទោះបីជាមានអំណះអំណាងនៅក្នុងរឿងនិទានកាលពីសម័យបុរាណថា មានពួកទេវតានឹងមនុស្សបានរៀបការ ហើយរស់នៅជាមួយគ្នាក៏ដោយ ក៏ការនោះមិនអាចរាប់ថាវាជាការពិតបានដែរ ព្រោះវាខុសពីលក្ខណៈធម្មជាតិដែលព្រះអង្គបង្កើតមក (សូមមើល ជំពូក ១ និង មក ១២:២៥) ។ នៅកន្លែងផ្សេងៗទៀតបាននិយាថា"កូនប្រុសរបស់ព្រះ" គឺសំដៅលើមនុស្ស(ចទ ១៤:១ ៣២:៥ ទដ ៧៣:១៥ អស ៤៣:៦ ហស ១:១០ ១១:១ លក ៣:៣៨ ១យហ ៣:១–២,១០)។ "កូនប្រុសរបស់ព្រះ" ដែលមាននិយាយនៅ ខ.២,៤ គឺអាចសំដៅលើពួកអ្នកដែលស្រឡាញ់ព្រះ ហើយ"កូនស្រីរបស់មនុស្ស" គឺសំដៅលើស្ត្រីដែលមានបាប(ដូច្នេះទើបគេមិនត្រូវបានហៅថា "កូនស្រីរបស់ព្រះ")ហើយប្រហែលពួកគេ គឺជាមនុស្សដែលកើតចេញពីជំនួរវង្សកាអ៊ីន បើសិនជាការពិតមែន នោះបង្ហាញថា អ្វីដែលនិយាយក្នុង ខ.១–២ គឺពណ៌នា អំពីការរៀបការរវាងពួកសេត("កូនប្រុសរបស់ព្រះ") ដែលនិយាយនៅក្នុងជំពូក៥ ជាមួយពួកកូនចៅកាអ៊ីន("កូនរបស់មនុស្ស")នៅក្នុងជំពូក៤ ហើយបង្ហាញថា មនុស្សមានការបែងចែងជា២ក្រុម ។ រឿងដែលគួរឱ្យយក ជាការបានមួយទៀតដែលនិយាយអំពី "កូនប្រុសរបស់ព្រះ" ថាជាពូជពង្សរបស់ស្តេច(នៅ

ព្រះ[ខ] គេឃើញកូនស្រីរបស់មនុស្ស[គ] ថាជាស្រស់ល្អ[ឃ] ក៏យក
ធ្វើជាប្រពន្ធ[ង] តាមតែចិត្តគេទៅ ៣ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា វិញ្ញាណអញ[ច] នឹងមិនតវ៉ានឹងមនុស្សជាដរាបទៅ[ឆ]
ពីព្រោះគេជាសាច់ឈាមប៉ុណ្ណោះ អាយុគេនឹងបានត្រឹមតែ
១២០ឆ្នាំវិញ ៤នៅជំនាន់នោះ មានមនុស្សរូបធំសំបើមនៅ[ជ]
ផែនដី ក្រោយនោះមក កាលពួកកូនប្រុសរបស់ព្រះបាន
ចូលទៅឯកូនស្រីរបស់មនុស្ស[ឈ] ហើយនាងទាំងនោះបាន
បង្កើតកូនឱ្យគេ នោះបានជាមនុស្សខ្លាំងពូកែដែលរស់នៅ
កាលពីដើម ជាមនុស្សមានល្បីឈ្មោះ[ញ]។
៥ព្រះយេហូវ៉ាទ្រង់ឃើញថា ការអាក្រក់របស់មនុស្សបាន
ចំរើនជាច្រើនឡើងនៅផែនដី[ឋ] ហើយអស់ទាំងគំនិត ក្នុង
ចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ចដូច្នោះ[ឌ] ៦នោះព្រះយេហូវ៉ា
ទ្រង់ស្តាយ[ឍ] ដោយបានបង្កើតមនុស្សមកនៅលើផែនដី
ហើយទ្រង់មានព្រះហឫទ័យព្រួយ ៧រួចព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា អញនឹងលុបមនុស្សដែលអញបានបង្កើតមក
ឱ្យសូន្យបាត់ពីផែនដីចេញ[ណ] ចាប់តាំងពីមនុស្សរហូតដល់
សត្វជើង៤ សត្វលូនវារ និងសត្វហើរលើអាកាសផង ដ្បិត
អញស្តាយដែលអញបានបង្កើតគេមក[ត] ៨ប៉ុន្តែណូអេ[ថ] បាន
ប្រកបដោយព្រះគុណនៅចំពោះព្រះយេហូវ៉ាវិញ[ទ] ។
៩នេះជាពង្សាវតារ[ធ] របស់ណូអេ គាត់ជាអ្នកសុចរិត

**៦:២** ខ យប ១:៦ ២:១ គ ខ.៤ ឃ ចទ ២១:១១ ង លប ៤:១៩ **៦:៣** ច យប ៣៤:១៤ កទ ៥:៦–១៧ឆ អស ៥៧:១៦១ពត ៣:២០ ជ យប ១០:៩ ទដ ៧៨:៣៩ ១០៣:១៤ អស ៤០:៦ **៦:៤** ឈ ជន ១៣: ៣៣ ញ ខ.២ ដ កទ ១១:៤ **៦:៥** ឋ កទ ៣៨:៧ យប ៣៤:២៦ យរ១:១៦ ៤៤:៥ អគ ៣:១៩ ឌ លប ៨:២១ ទដ ១៤:១–៣ **៦:៦** ឍ នក ៣២:១៤ ១សយ ១៥:១១, ៣៥ ២សយ ២៤:១៦ ១របា ២១:១៥ សយ ៦៣:១០ យរ ១៨:៧–១០ អភ ៤:៣០ **៦:៧** ណ អគ ៣៣:២៨ សផ ១:២, ១៨ ត ខ.១៧ លប ៧:៤,២១ ចទ ២៨:៦៣ ២៩:២០ **៦:៨** ថ អគ ១៤:១៤ ទ លប ១៩:១៩ ៣៩:៤ នក ៣៣:១២, ១៣,១៧ ៣៤:៩ ជន ១១:១៥ រម២:២ លក ១:៣០ កច ៧:៤៦ **៦:៩** ធ លប ២:៤

មជ្ឈឹមបុព៌ាសម័យបុរាណ ពួកស្តេចតែងតែមានទំនាក់ទំនងជិតស្និទ្ធិទៅនិងរូបព្រះ) ដែលតែងតែអួតពីអំណាច និងអំពើពុករលួយ ដែលមាននៅក្នុងជីវិតឡាមេកដែលជាកូនកាអ៊ីន ។

**៦:៣** ក្នុងព្រះគម្ពីរភាសាហេព្រើរ ខនេះមានប្រយោគសំខាន់ៗ២ដែលមានលក្ខណៈមិនច្បាស់លាស់គឺៈ ឃ្លាទី១បកប្រែថា "តវ៉ា" ហើយឃ្លាទី២គឺ "ពីព្រោះគេជាសាច់ឈាមប៉ុណ្ណោះ" ។ នៅក្នុងខនេះហាក់បីដូចជាចង់និយាយថា មនុស្សអាចរស់នៅក្នុងសម័យព្រះគុណ ដែលនៅចន្លោះពេលការជំនុំជម្រះរបស់ព្រះនឹងចុងបំផុតគឺ មានត្រឹមតែ១២០ឆ្នាំប៉ុណ្ណោះ (សូមផ្ទៀបនិង ១ពត ៣:២០) ។

**៦:៤** *មនុស្សរូបធំសំបើម* មនុស្សធំសម្បើមដែលនិយាយនៅកន្លែងនេះគឺសំដៅលើមនុស្សដែលមានមាឌធំ ហើយមានកំឡាំងខ្លាំងក្លា (សូមមើលក្នុង ជន ១៣:៣១–៣៣)។ ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "អ្នកដែលធ្លាក់ចុះ" (ជាអ្នកដែលប្រព្រឹត្តបាប)។ មនុស្សតែងតែគិតអំពីពួកគេថា ជា"មនុស្សខ្លាំងពូកែដែលរស់នៅកាលពីដើម ជាមនុស្សមានល្បីឈ្មោះ" ប៉ុន្តែនៅក្នុងព្រះនេត្ររបស់ព្រះយេហូវ៉ាវិញពួកគេជាអ្នកមានបាប "ធ្លាក់ចុះ"យ៉ាងក្រាសក្រៃ ។

**៦:៥** នៅក្នុងខនេះគឺពណ៌នាយ៉ាងលម្អិត ពីការអាក្រក់ក្រៃលែងរបស់មនុស្សក្នុងចំណោមអំពើអាក្រក់ផ្សេងៗទៀតដែលមាននៅក្នុងព្រះគម្ពីរ ។ ដោយសារនិស្ស័យពីធម្មជាតិរបស់មនុស្សមិនអាចប្តូរផ្លាស់បាន នោះគ្រប់ទាំងជីវិតមិនអាចទទួលយកការប្រសើរក្រោយពេលទឹកជន់នោះបានឡើយ (សូមមើល ៨:១២) ។

**៦:៦** *នោះព្រះយេហូវ៉ាទ្រង់ស្តាយ . . . ហើយទ្រង់មានព្រះហឫទ័យព្រួយ* នៅក្នុងឃ្លានេះចង់និយាយថា នៅពេលដែលមនុស្សប្រព្រឹត្តអំពើបាប នោះព្រះអម្ចាស់ទ្រង់មានព្រះហឫទ័យព្រួយនិងក្តួលអាណិត (មើល អភ ៤:៣០)។

**៦:៧** *អញនឹងលុបមនុស្ស . . . ឱ្យសូន្យបាត់ពីផែនដីចេញ* នៅក្នុងឃ្លានេះចង់និយាយថា នៅចុងបញ្ចប់សម័យកាលនៃព្រះគុណនឹងមកដល់ (សូមមើល ខ.៣) ។ *សត្វជើង៤ សត្វលូនវា និងសត្វហើរលើអាកាស* ព្រះអម្ចាស់ទ្រង់នឹងបំផ្លាញទាំងអស់ សូម្បីតែសត្វដែលមានលក្ខណៈល្អប្រពៃដូចជាពពួកសត្វល្មូនលូនវារជាដើម ក៏ត្រូវទទួលការជំនុំជម្រះដោយសារតែអំពើបាបដ៏អាក្រក់របស់មនុស្សដែរ ។

**៦:៨–៩** *បានប្រកបដោយព្រះគុណ . . . ជាអ្នកសុចរិត . . . គ្រប់លក្ខណ៍ . . . ក៏ដើរជាមួយនឹងព្រះ* សូមមើលការពន្យល់ ៥:២២ ។ ភក្តីភាព និងការស្រឡាញ់ដល់ព្រះយេហូវ៉ារបស់លោកណូអេ គឺមានអំណាចអស្ចារ្យណាស់ និងមានលក្ខណៈផ្ទុយពីមនុស្សអាក្រក់ជាច្រើនទៀតដែលបានរស់នៅក្នុងជំនាន់ជាមួយលោក (សូមមើល ខ.៥,១២) ។ ការពិពណ៌នាអំពីលោកណូអេនៅកន្លែងនេះ មិនមែនមានន័យថា ណូអេគាត់មិនដែលប្រព្រឹត្តិបាបនោះឡើយ ។

**៦:៩–៩:២៩** នៅក្នុងរឿងព្រេងជាច្រើនចំណោមរឿងព្រេងទាំងឡាយរបស់មនុស្ស ដែលនៅមជ្ឈិមបូព៌ា មានព្រះមួយក្នុងចំណោមព្រះធំៗជាច្រើនបានបំផ្លាញផែនដីដោយសារទឹកជន់ ពីព្រោះមនុស្សទាំងនោះ បានធ្វើបាបទាស់នឹងព្រះ (សូមមើលសេចក្តីផ្តើមរបស់ប្រវត្តិ) ។ អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិ ក៏បានបង្ហាញអំពីទឹកជន់ដ៏ធំ នៅលើផែនដីទាំងមូលបានបំផ្លាញមនុស្សទាំងអស់លើកលែងតែគ្រួសារមួយប៉ុណ្ណោះ ។ ក្នុងការបង្កើតរបស់ទ្រង់ ព្រះអាទិករគឺជាព្រះតែមួយអង្គប៉ុណ្ណោះ ទ្រង់មានព្រះទ័យព្រួយដោយសារតែអំពើដ៏អាក្រក់ផ្សេងៗបានហ៊ុំព័ទ្ធ ហើយរាលដាលដល់ស្នាព្រះហស្តរបស់ទ្រង់ដែលទ្រង់បានបង្កើតគេមក តាមរូបអង្គនៃព្រះ ព្រមទាំងអ្នកដែលទ្រង់យកព្រះទ័យទុកដាក់ ។ នៅចំពោះព្រះ ពួកគេបានប្រព្រឹត្តការអាក្រក់យ៉ាងខ្លាំងមកលើស្នាព្រះហស្តដ៏ល្អឥតខ្ចោះរបស់ទ្រង់ ដែលមានតែព្រះអង្គមួយប៉ុណ្ណោះជាអ្នកជំនុំជម្រះ ដែលអាចត្រួតពិនិត្យមើលលើការអាក្រក់និងនាំមនុស្សដែលទ្រង់បង្កើតធ្វើជារាស្ត្ររបស់ទ្រង់ ។ ព្រះតែងមានបន្ទូលមកដល់កូនចៅអ៊ីស្រាអែលជានិច្ច ។ អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិបានប្រឆាំងចំពោះពួកអ្នកមិនជឿព្រះ អំពីរូបព្រះនិងមនុស្សដែលបានពិពណ៌នានៅក្នុងរឿងរបស់ពួកគេ ដែលនិយាយពីអំណាច និងការបង្ក្រាបដោយទឹកជន់ ។ គាត់បានបដិសេធចំពោះរឿង ដែលគេនិយាយអំពីទឹកជន់នេះ ដោយសំអាងលើទេវសាស្ត្រផ្សេងៗគ្នា ។ នៅក្នុងពេលទឹកជន់គឺរបស់ទាំងអស់ត្រូវបានបំផ្លាញដោយសារទឹកជន់ និងធម្មជាតិផ្សេងៗទៀតមនុស្សបានរាប់បញ្ចូលជាមួយនឹងសេចក្តីសុចរិតរបស់ព្រះអាទិករ ។

**៦:៩** *ពង្សាវតារ* (មើល ២:៤) ។ *សុចរិត* (មើល ទដ ១:៥) ។ បន្ទាប់ពី

ហើយគ្រប់លក្ខណ៍[ន]នៅក្នុងដំណវង្សខ្លួន[ប] គាត់ក៏ដើរជាមួយ
នឹងព្រះ[ផ] ១០ហើយបង្កើតបានកូនប្រុស៣ គឺសិម១[ព] ហាំ១
និងយ៉ាផែត១[ភ] ១១ឯផែនដី នោះបានខូចអាក្រក់[ម] នៅចំពោះ
ព្រះ ក៏មានពេញជាសេចក្ដីកាចសហ័សផង[យ] ១២ហើយព្រះ
ទ្រង់ទតមើលផែនដី ឃើញថាខូចអាក្រក់[រ]ដូច្នេះ ដ្បិតគ្រប់
ទាំងសាច់ បានបង្ខូចផ្លូវខ្លួននៅផែនដីទៅហើយ[ល] ។
១៣ព្រះទ្រង់មានបន្ទូលទៅណូអេថា អស់ទាំងសាច់ត្រូវ
ផុតពីមុខអញហើយ ដ្បិតផែនដីបានពេញជាសេចក្ដីកាច
សហ័សដោយសារគេ មើល អញនឹងបំផ្លាញគេ[វ]ទៅជាមួយ
នឹងផែនដីផង[ស] ១៤ចូរឯងយកឈើម៉ៃសាក់[ហ]ធ្វើជាទូកធំ
សំរាប់ឯង ត្រូវឱ្យធ្វើបន្ទប់នៅក្នុងទូកនោះ ហើយពរជ័រ
ទាំងខាង[ឡ]ក្នុងខាងក្រៅ ១៥ត្រូវឱ្យឯងធ្វើយ៉ាងដូច្នេះ គឺ
បណ្ដោយ៣00 ហត្ថ ទទឹង៥0ហត្ថ ហើយកំពស់៣0ហត្ថ
១៦ត្រូវធ្វើបង្អួចក្នុងទូកចុះពីលើ១ហត្ថ ហើយត្រូវឱ្យមានទ្វារ
នៅពីខាងចំហៀង ត្រូវធ្វើឱ្យមានថ្នាក់ក្រោម ថ្នាក់ទី២
និងថ្នាក់ទី៣ ១៧នោះអញ មើល គឺអញនេះហើយ និងធ្វើ
ឱ្យមានជំនន់[អ]លើផែនដី ដើម្បីនឹងបំផ្លាញគ្រប់ទាំងសាច់
ដែលមានដង្ហើមជីវិតពីក្រោមមេឃចេញ គ្រប់ទាំងអស់នៅ
ផែនដីនឹងត្រូវស្លាប់បង់[ក] ១៨តែអញនឹងតាំងសេចក្ដីសញ្ញា

ន លប ១៧:១ ចទ ១៨:១៣ ២សយ ២២:២៤ យប ១:១ ៤:៦ ៩:២១១២:៤ ៣១:៦ ទដ ១៥:២ ១៨:២៣ ១៩:១៣ ៣៧:៣៧ ទដ ២:៧
ប លប ៧:១ ទដ ៣៧:៣៩ យរ ១៥:១ អគ ១៤:១៤,២០ ដយ ១០:១១ លក ១:៦ ហព ១១:៧ ២ពត ២:៥ ផ លប៥:២២
**៦:១០** ព លក ៣:៣៦ ភ លប ៥:៣២
**៦:១១** ម ចទ ៣១:២៩ ពច ២:១៩ យ ទដ ៧:៩ ៧៣:៦ អគ ៧:២៣ ៨:១៧ ២៨:១៦ មឡ ២:១៦
**៦:១២** រ នក ៣២:៧ ចទ ៤:១៦ ៩:១២, ២៤ ល ទដ ១ ៤:១–៣

អញ ចំពោះឯង[ខ] ហើយឯងនឹងចូលទៅក្នុងទូកធំនោះ[គ] ព្រម
ទាំងប្រពន្ធកូន និងកូនប្រសាឯង ជាមួយនឹងឯងដែរ ១៩ឯ
ត្រូវអស់ទាំងសាច់ដែលមានជីវិតទាំងឡាយ នោះចូរឱ្យឯង
នាំយក១គូៗ ទាំងឈ្មោលទាំងញីគ្រប់តែពូជចូលទៅក្នុងទូក
ឱ្យបានរួចជីវិតជាមួយនឹងឯងផង[ឃ] ២០គឺសត្វហើរតាមពូជ
សត្វជើង៤តាមពូជ[ង] ទាំងសត្វលូនវារ នៅដីគ្រប់មុខតាម
ពូជផង គ្រប់ទាំងពូជសត្វនឹងមកឯឯង១គូៗ[ច] ឱ្យបាន
រួចជីវិត[ឆ] ២១ត្រូវឱ្យឯងយកអាហារគ្រប់មុខ ដែលធ្លាប់
បរិភោគ ប្រមូលមកទុកជាស្បៀងសំរាប់ឯងនឹងសត្វទាំង
នោះ ២២ណូអេក៏ធ្វើដូច្នោះ តាមគ្រប់ទាំងសេចក្ដីដែលព្រះ
បានបង្គាប់ គាត់ធ្វើការនោះសំរេចទាំងអស់[ជ] ។

**៧** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅណូអេថា "ត្រូវឱ្យឯង
និងពួកគ្រួឯង[ក]ចូលទាំងអស់ទៅក្នុងទូក ពីព្រោះក្នុងពួក

**៦:១៣** វ ចទ ២៨:៦៣ ២ពវ ៨:១៩ អគ ៩:១៤ យរ ៤៤:១១ ស ឧ.១៧ លប ៧:៤,២១–២៣ យប ៣៤:១៥ អស ៥:៦ ២៤:១–៣ យរ ៤៤: ២៧ អភ ៧:២–៣ **៦:១៤** ហ ហព ១១:៧ ១ពត ៣:២០ ឡ នក ២:៣ **៦:១៧** អ ទដ ២៩:១០ ក ឧ.៧,១៣ ២ពត ២:៥ ៣:២០ គ លប ៧:១,៧,១៣ **៦:១៩** ឃ លប៧:១៥ **៦:២០** ង លប ១:១១ ច លប ៧:១៥ ឆ លប ៧:៣ **៦:២២** ជ លប ៧:៥,៩,១៦ នក ៧:៦ ៣៩:៤៣ ៤០:១៦, ១៩,២១,២៣,២៥, ២៧,២៩,៣២ **៧:១** ក លប ៦:១៨ មថ២៤:៣៨ លក ១៧:២៦–២៧ ហព ១១:៧ ១ពត ៣:២០ ២ពត ២:៥

ពីទ្រង់អត់ធ្មត់ដ៏យូរលង់មក ព្រះទ្រង់បានជំនុំជម្រះគ្រប់ទាំងជីវិត ដែលទ្រង់បានបង្កើតមកតាមរូបអង្គទ្រង់ និងមនុស្សដែលទ្រង់ឱ្យគេគ្រប់គ្រងលើរបស់ដែលទ្រង់បានបង្កើតមក ។ ការជំនុំជម្រះរបស់ព្រះចំពោះមនុស្ស គឺព្រះទ្រង់បានដាក់ទឹកជន់ ដែលតំណាងឱ្យការជ្រមុជខាងសេចក្ដីស្លាប់ ហើយរស់ឡើងវិញខាងឯសេចក្ដីសុចរិត គឺការស្លាប់ខាងឯជីវិតចាស់ ហើយរស់ខាងឯព្រះវិញ (សូមមើល ៩:៨–១៧ និងការពន្យល់) ។

**៦:១៤** *ទូកធំ* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះប្រើក្នុងន័យផ្សេងទៀត គឺសំដៅទៅលើកន្ត្រកដែលបណ្ដែតលោកម៉ូសេ កាលពីគាត់នៅតូចប៉ុណ្ណោះ (នក ២:៣៥) ។ *ពរជ័រ* ម្ដាយរបស់លោកម៉ូសេបានធ្វើកន្ត្រក ដែលមិនអាចឱ្យទឹកជ្រាបចូលបាន (នក ២:៣) ។

**៦:១៦** *បង្អួច* ប្រហែលជាលយចេញ ដើម្បីការពារទឹកភ្លៀងកុំឱ្យសាចចូលក្នុង ។ ចុះពីលើ១ហត្ថទូកធំរបស់ណូអេ ប្រហែលជាមានបង្អួចតូចៗជាច្រើន (មើល ៨:៦) ព័ទ្ធជុំវិញទ្វារចូល ហើយមានកំពស់១ហត្ថ ដើម្បីឱ្យមានពន្លឺ និងខ្យល់ចូលគ្រប់គ្រាន់ ។

**៦:១៧** *ជំនន់លើផែនដី ដើម្បីនឹងបំផ្លាញគ្រប់ទាំងសាច់ . . . ពីក្រោមមេឃចេញ* អ្នកខ្លះជឿថាទឹកជន់នោះ គឺមានពាសពេញផែនដីទាំងអស់មិនមែនមានតែ១ផ្នែកប៉ុណ្ណោះឡើយ ពីព្រោះគេឃើញជាក់ស្ដែងនៅក្នុងបរិបទនេះ និងនៅកន្លែងផ្សេងៗទៀត (ខ.៧,១២,១៣ ៧:៤,១៩,២១,២៣ ៨:២១ ៩:១១ ,១៥ ២ពត ៣:៦) ។ អ្នកខ្លះទៀតជជែកថា គ្មានរឿងព្រេងអ្វីដែលបានកើតឡើងនៅក្នុងជំពូកទាំងអស់នេះទេ ។ ជំពូក ៦–៩ គឺជាការទប់ស្កាត់ចំពោះទឹកជន់ ដែលមានតាំងពីដំបូងមកតាមតំបន់ប៉ុណ្ណោះ ហើយអ្វីៗទាំងអស់បានបំផ្លាញក្នុងរយៈពេលដ៏ខ្លីមួយ ប៉ុន្តែស្ថានការណ៍មិនពិតនេះវាមានដែនកំណត់ហើយរឿងនេះក៏បាននិយាយតាំងពីសម័យលោកម៉ូសេមកដែរ ។ "ផែនដី" ប្រហែលជាមានអត្ថន័យជាង "ដី" (មើល ២:៥) ។ "ជីវិតក្រោមមេឃ" ប្រហែលជាសត្វទាំងអស់នៅក្នុងអំឡុងពេលដែលលោកណូអេបានរៀបចំឱ្យចូលទៅក្នុងទូកនោះ ។

**៦:១៨** *សេចក្ដីសញ្ញា* សូមមើល ៩:៩ ។ លោកណូអេមិនបានទទួលការតាំងសញ្ញាពិសេសជាមួយនឹងព្រះរហូតដល់ក្រោយពេលទឹកជន់បានស្រកចុះ វិញ (មើល ៩:៨–១៧) ។ ចូលទៅក្នុងទូកធំ ពេលដែលលោកណូអេបានរួចពីទឹកជន់ គឺបង្ហាញអំពីការប្រោសលោះរបស់ព្រះ ចំពោះកូនរបស់ទ្រង់ (សូមមើល ហព ១១:៧ ២ពត ២:៥) គឺជាគំរូពីបុណ្យជ្រមុជទឹក (១ពត ៣:២០–២១) ។ *ប្រពន្ធកូន និងកូនប្រសាឯងជាមួយនឹងឯងដែរ* ព្រះទ្រង់សព្វព្រះហឫទ័យផ្ដល់នូវសេចក្ដីស្រឡាញ់ដល់លោកណូអេ និងគ្រួសារដ៏សុចរិតរបស់លោក ដែលជាគំរូពីការប្រស្រ័យទាក់ទងរបស់ព្រះនិងរាស្ត្ររបស់ទ្រង់ដូចជាទំនាក់ទំនងរវាងឪពុកម្ដាយ និងកូនចៅរបស់គេដែរ (មើល ១៧:៧–២៧ ១៨:១៩ ចទ ៣០:១៩ ទដ ៧៨:១–៧ ១០២:២៨ ១០៣:១៧–១៨ ១១២:១–១កថ ២:៣៨–៣៩ ១៦:៣១ ១កថ ៧:១៤) ។

**៦:២០** *តាមពូជ* មើល ១:១ ។

**៦:២២** *ធ្វើដូច្នោះតាមគ្រប់ទាំងសេចក្ដីដែលព្រះបង្គាប់មក* ការស្ដាប់បង្គាប់របស់លោកណូអេ (មើល ៧:៥ ៩:១៦) ។

**៧:១** *ចូលទាំងអស់ទៅក្នុងទូក* គឺជាព្រះបន្ទូលចុងក្រោយរបស់ព្រះចំពោះលោកណូអេ មុនពេលទឹកជន់មកដល់ ។ ព្រះបន្ទូលរបស់ព្រះដំបូងបន្ទាប់ពី

មនុស្សជាន់នេះ អញឃើញមានតែឯងទេ ដែលសុចរិត[ខ]
នៅចំពោះអញ ២ខាងឯសត្វជើង៤ដែលស្អាត[គ] នោះឯង
ត្រូវយក៧គូ ហើយសត្វជើង៤ដែលមិនស្អាត នោះឱ្យយក
តែ១គូវិញ គឺទាំងឈ្មោលទាំងញីផង ៣ឯសត្វហើរលើ
អាកាស នោះត្រូវយក៧គូដែរព្រមទាំងឈ្មោលទាំងញី
ដើម្បីទុកពូជវាឱ្យរស់[ឃ]នៅគ្រប់លើផែនដី ៤ដ្បិតនៅ៧ថ្ងៃ
ទៀត អញនឹងបង្អុរភ្លៀង[ង]មកលើផែនដី[ច]៤០ថ្ងៃ[ឆ]៤០យប់[ជ]
ហើយអញនឹងលុបគ្រប់ទាំងជីវិតដែលអញបានបង្កើតមក
ឱ្យសូន្យបាត់ពីផែនដីចេញ[ឈ]" ៥នោះណូអេក៏ធ្វើសំរេចតាម
គ្រប់ទាំងសេចក្ដីដែលព្រះយេហូវ៉ាបានបង្គាប់មក[ញ]។
៦ណូអេអាយុបាន៦០០ឆ្នាំ[ដ] ក្នុងកាលដែលទឹកជន់ឡើង
លិចផែនដី ៧ហើយណូអេ ព្រមទាំងប្រពន្ធកូននិងកូនប្រសា
ស្រីគាត់ ក៏នាំគ្នាចូលទៅក្នុងទូក[ឋ]ដោយព្រោះទឹកជន់ ៨ឯសត្វ
ជើង ៤ ទាំងស្អាតទាំងមិនស្អាត[ឌ] និងសត្វស្លាប ហើយសត្វ
លូនវារនៅដីគ្រប់មុខ ៩ក៏ចូល១គូៗទាំងឈ្មោលទាំងញីទៅ
ឯណូអេក្នុងទូក ដូចជាព្រះទ្រង់បានបង្គាប់មកណូអេ[ឍ] ១០រួច
ដល់ផុតពី៧ថ្ងៃនោះមក[ណ] ជំនន់ក៏ឡើងលើផែនដី ១១គឺនៅ
ឆ្នាំ៦០០ក្នុងអាយុ[ត]ណូអេក្នុងថ្ងៃ១៧ខែទី២[ថ] ថ្ងៃនោះឯង
គ្រប់អស់ទាំងរន្ធទឹកនៅទីជំរៅធំ[ទ]ក៏ធ្លាយ ហើយទ្វារទំនប់
នៅលើមេឃ[ធ] ក៏ត្រូវបើកចេញ ១២មានភ្លៀងធ្លាក់មកលើ
ផែនដី ៤០ថ្ងៃ៤០យប់[ន] ១៣គឺនៅថ្ងៃនោះឯងដែលណូអេ សិម
ហាំ និងយ៉ាផែត ជាកូនគាត់[ប] ហើយប្រពន្ធណូអេ និងកូន
ប្រសាស្រីទាំង៣បានចូលទៅក្នុងទូកទាំងអស់គ្នា[ផ] ១៤ទាំង
ខ្លួនគេហើយគ្រប់ទាំងសត្វព្រៃតាមពូជ គ្រប់ទាំងសត្វស្រុក
តាមពូជ និងអស់ទាំងសត្វដែលលូនវារនៅលើដីតាមពូជ
ហើយគ្រប់ទាំងសត្វហើរតាមពូជដែរ[ព] គឺសត្វស្លាបគ្រប់មុខ
ទាំងអស់ ១៥ក៏នាំគ្នាចូលទាំងគូៗទៅឯណូអេក្នុងទូក[ភ] ពីគ្រប់
ទាំងពូជសត្វ ដែលមានដង្ហើមជីវិត ១៦ឯអស់ទាំងសត្វដែល
ចូលទៅ នោះក៏ចូលទាំងឈ្មោលទាំងញីពីគ្រប់ទាំងពូជសត្វ
ដូចជាព្រះបានបង្គាប់ដល់ណូអេ[ម] រួចព្រះយេហូវ៉ាទ្រង់បិទ
ទ្វារទូកជិត ។
១៧លុះទឹកជន់លិចផែនដីបាន៤០ថ្ងៃ[យ]ហើយបានកាន់តែ
ធំឡើង នោះទូកធំក៏អណ្ដែតផុតពីដីឡើង ១៨ជំនន់នោះបាន
មានកំឡាំងក្រៃលែង ក៏កាន់តែចំរើនឡើងជាលើសលប់
នៅលើផែនដី ហើយទូកនោះបានអណ្ដែតនៅលើទឹក
១៩ជំនន់នោះជាធំយ៉ាងអស្ចារ្យនៅលើផែនដី ទាល់តែអស់
ទាំងភ្នំខ្ពស់ៗនៅក្រោមមេឃ បានលិចបាត់អស់រលីងទៅ[រ]
២០រួចទឹកក៏ឡើង១៥ហត្ថទៀតលិចភ្នំទាំងអស់[ល] ២១គ្រប់ទាំង
សាច់ដែលកំរើកនៅផែនដី ទោះទាំងសត្វហើរសត្វស្រុក
សត្វព្រៃ ហើយគ្រប់ទាំងសត្វដែលលូនវារនៅដី និងមនុស្ស
ក៏ស្លាប់ទាំងអស់ដែរ[វ] ២២គឺគ្រប់ទាំងអស់ដែលមានខ្យល់
ដង្ហើមជីវិត[ស]នៅក្នុងរន្ធច្រមុះនៅលើគោកក៏ស្លាប់ទាំងអស់
២៣គ្រប់ទាំងជីវិតទាំងឡាយនៅលើផែនដី ក៏ត្រូវផ្លាញលាញ

ខ លប អក ១៤:១៤ **៧:២** គ ខ.៨ លប ៨:២០ លវ ១០:១០ ១១:១–៤៧ ចទ ១៤:៣–២០ អគ ៤៤:២៣ ហក ២:២១ កច ១០:១៤–១៥ **៧:៣** ឃ លប ៦:២០ **៧:៤** ង លប ៨:២ ច ១ ពវ ១៣:៣៤ យរ ២៨:១៦ ឆ ជន ១៣:២៥ ចទ ៩:៩ ១សយ ១៧: ១៦ ១ពវ ១៩:៨ ជ ខ.១២,១៧ នក ២៤:១៨ ៣២:១ ៣៤:២៨ ចទ ៩:៩, ១១,១៨,២៥ ១០:១០ យប ៣៧:៦, ១៣ មថ ៤:២ ឈ លប ៦:៧,១៣ **៧:៥** ញ លប ៦:២២ **៧:៦** ដ លប ៥:៣២ **៧:៧** ឋ លប ៦:១៨ **៧:៨** ឌ ខ.២ **៧:៩** ឍ លប ៦:២២ **៧:១០** ណ ខ.៤ **៧:១១** ត លប ៥:៣២ ថ លប ៨:៤,១៤ ទ លប ១:៧ យប ២៨:១១ ទដ ៣៦:៦ ៤២:៧ ទដ ៨:២៤ អស ៥១:១០ អគ ២៦:១៩ ធ លប ៨:២ ២ពវ ៧:២ ទដ ៧៨:២៣ អស ២៤:១៨ មឡ ៣:១០ **៧:១២** ន ខ.៤ ១សយ១២:១៧ យប ២៨:២៦ **៧:១៣** ប លប ៨:១៦ ១ពត ៣:២០ ២ពត ២:៥ ផ លប ៦:១៨ **៧:១៤** ព ប ១:១១ **៧:១៥** ភ ខ.៨–៩ លប ៦:១៩ **៧:១៦** ម លប ៦:២២ **៧:១៧** យ ខ.៤ **៧:១៩** រ ទដ ១០៤:៦ **៧:២០** ល លប ៨:៤–៥ ២ពត ៣:៦ **៧:២១** វ លប ៦:៧, ១៣ ២ពត ៣:៦ **៧:២២** ស លប ១:៣០

មានទឹកជន់មក គឺប្រហាក់ប្រហែលគ្នា "ចូរឯងចេញពីទូកចុះ" (៨:១៦) ។ *សុចរិត* (សូមមើល ៦:៨៩) ក្រោយមកគាត់ក្លាយជា "អ្នកប្រកាសពីសេចក្ដីសុចរិត" (២ពត ២:៥) ជាអ្នកដែលត្រូវបានតំណាលពីការជំនុំជម្រះ និងទីបន្ទាល់ពីសេចក្ដីជំនឿដ៏ខ្លាំងរបស់គាត់ (ហព ១១:៧) ។

**៧:២** *សត្វជើង៤ដែលស្អាតនោះឯងត្រូវយក៧គូ ហើយសត្វជើង៤ដែលមិនស្អាតនោះឱ្យយកតែ១គូវិញ* សត្វជើង៤ដែល "មិនស្អាត" អាចកើតច្រើនវិញនៅពេលដែលពួកគេបន្តពូជក្រោយទឹកជន់ ប៉ុន្តែសត្វដែល "ស្អាត" គឺត្រូវការជាចាំបាច់ សម្រាប់ធ្វើជាដង្វាយដុតនៅពេលដែលលោកណូអេធ្វើយញ្ញបូជា (៨:២០) និងសម្រាប់ធ្វើជាអាហារ (៩:៣) ។

**៧:៤** *៤០ថ្ងៃ៤០យប់* រយៈពេលដ៏យូរបែបនេះជាញឹកញាប់ គឺនិយាយអំពីលក្ខណៈពិសេសនៃការប្រោសលោះ នៅក្នុងប្រវត្តិសាស្ត្រ (ខ.១២ ចទ ៩:១១ មថ ៤:១–១១) ។

**៧:៧** *ក៏នាំគ្នាចូលទៅក្នុងទូកដោយព្រោះទឹកជន់* លោកណូអេ និងក្រុមគ្រួសារគាត់ត្រូវបានសង្គ្រោះប៉ុន្តែមនុស្សផ្សេងៗទៀត មិនត្រូវបានទទួលសង្គ្រោះឡើយ (មថ ២៤:៣៧–៣៩) ។

**៧:១៣** ណូអេ សិម ហាំ និងយ៉ាផែត ជាកូនគាត់ ហើយប្រពន្ធណូអេ និងកូនប្រសាស្រីទាំង៣ បានចូលទៅក្នុងទូកទាំងអស់គ្នាមានតែមនុស្ស ៨នាក់ (១ពត ៣: ២០ ២ពត ២:៥) ដែលនៅសល់ពីទឹកជន់ដ៏ធំ ។

**៧:១៤** *គ្រប់ទាំងសត្វព្រៃ . . . គ្រប់ទាំងសត្វស្រុក . . . សត្វលូនវារនៅលើដី . . . សត្វហើរលើអាកាស* មានប្រភេទសត្វជើង៤ ក្នុងចំណោមទាំង៥ បាននិយាយក្នុង ១:២១–២៥ ។ ប្រភេទសត្វទី៥ ជាសត្វសមុទ្រ ដូច្នេះវាអាចរស់បានដោយមិនចាំបាច់ចូលក្នុងទូកឡើយ ។

**៧:១៦** *ព្រះយេហូវ៉ាបានបង្គាប់ណូអេ . . . ទ្រង់បិទទ្វារទូកជិត* "ព្រះបានបង្គាប់ គឺព្រះបានផ្ដល់ការប្រោសលោះវិញ "ព្រះយេហូវ៉ា" (មើល ២:៤ នក ៦:៦) ព្រះទ្រង់បានបិទទ្វារទូកពីក្រោយលោកណូអេ និងក្រុមគ្រួសាររបស់គាត់ ។ ព្រះនាម "ព្រះអម្ចាស់" មិនបានផ្ដោតសំខាន់នៅក្នុងជំពូក៧ឡើយតែអ្វីដែលសំខាន់នោះ គឺនិយាយអំពីកំហឹងរបស់ព្រះថា ទ្រង់មិនបានអត់ឱនដល់មនុស្សមានបាបឡើយ ។

**៧:២០** *ឡើង១៥ហត្ថទៀតលិចភ្នំទាំងអស់* ទូកមានកំពស់៣០ហត្ថ ដូច្នេះ ទឹកមានគ្រប់គ្រាន់ដើម្បីឱ្យទូកអាចរសាត់បាន ។

**៧:២២** *ខ្យល់ដង្ហើមជីវិត* អំណោយទានរបស់ព្រះនាពេលបង្កើតពិភពលោក ១:៣០ ២:៧ ត្រូវបានដកចេញដោយព្រោះអំពើបាប ។

ទាំងអស់ទៅ តាំងពីមនុស្សរហូតដល់សត្វជើង៤ សត្វលូនវារនិងសត្វហើរលើអាកាស នោះត្រូវវិនាសចេញពីផែនដីទាំងអស់[ហ] នៅសល់តែណូអេ និងពួកអ្នកដែលនៅក្នុងទូកជាមួយនឹងគាត់ប៉ុណ្ណោះ[ឡ] ២៤ទឹកធំនោះក៏ទ្រើងនៅលើផែនដីអស់១៥០ថ្ងៃ[អ] ។

**៨** ១ព្រះទ្រង់ក៏នឹកចាំ[ក] ពីណូអេ និងអស់ទាំងសត្វព្រៃសត្វស្រុកទាំងប៉ុន្មាន ដែលនៅក្នុងទូកជាមួយនឹងគាត់ រួចទ្រង់ធ្វើឱ្យខ្យល់បក់មកលើផែនដី[ខ] ហើយទឹកក៏ស្រកទៅ ២ឯរន្ធទឹកនៅទីជំរៅនិងទ្វារទំនប់ នៅលើមេឃ[គ] បានបិទវិញ ហើយភ្លៀង[ឃ] ដែលធ្លាក់ពីលើមេឃមកក៏រាំងទៅ ៣ទឹកបានថយចេញពីផែនដីជាដរាប លុះដល់ផុតពី១៥០ថ្ងៃទៅ[ង] ទើបបានស្រកបន្តិច ៤ដល់ថ្ងៃ១៧ ខែទី៧[ច] នោះទូកធំបានកឿងនៅលើភ្នំ[ឆ] អារ៉ារ៉ាត[ជ] ៥ទឹកក៏ចេះតែស្រកទៅដរាបដល់ខែទី១០ លុះដល់ថ្ងៃចូលខែទី១០ នោះទើបឃើញមានកំពូលភ្នំលេចឡើង ។

៦កាលបានកន្លងទៅ៤០ថ្ងៃទៀត[ឈ] នោះណូអេ គាត់បើកបង្អួចដែលបានធ្វើក្នុងទូក ៧ក៏លែងក្អែក១ទៅ[ញ] តែវាហើរទៅមកទាល់តែទឹកបានរីងស្ងួតពីផែនដីអស់[ដ] ៨គាត់ក៏លែងព្រាប១ដែរ[ឋ] ដើម្បីឱ្យដឹងជាទឹកបានស្រកពីដីទៅហើយឬនៅ ៩តែព្រាបនោះរកកន្លែងណានឹងទំគ្មាន បានជាវិលមកឯគាត់ក្នុងទូកវិញ ពីព្រោះទឹកនៅពេញលើផែនដីនៅឡើយ នោះគាត់ក៏លូកដៃទៅចាប់យកមកក្នុងទូកវិញ ១០គាត់ ផ្អាកចាំអស់៧ថ្ងៃ រួចលែងព្រាបចេញពីទូកទៅម្តងទៀត ១១លុះដល់ពេលល្ងាច ព្រាបនោះត្រឡប់ចូលមកឯគាត់វិញ ឃើញមានពាំយកស្លឹកអូលីវដែលវាបានចឹកមកជាមួយផង ដូច្នេះណូអេបានដឹងថា ទឹកបានស្រកពីផែនដីបន្តិចហើយ[ឌ] ១២រួចគាត់រង់ចាំ៧ថ្ងៃទៀត ក៏លែងព្រាបឱ្យទៅ តែវាមិនបានវិលមកឯគាត់វិញទេ ។

១៣នៅឆ្នាំ៦០១[ឍ] ក្នុងថ្ងៃចូលខែទី១ នោះទឹកបានរីងស្ងួតពីផែនដីអស់ទៅ ណូអេក៏បើកដំបូលទូកមើលឃើញថា ទឹកបានស្ងួតពីដីហើយ ១៤ដល់ថ្ងៃ២៧ខែទី២[ណ] នោះដីបានស្ងួតផង ១៥ព្រះទ្រង់មានបន្ទូលទៅណូអេថា ១៦ចូរឯងចេញពីទូកចុះ ព្រមទាំងប្រពន្ធកូននិងកូនប្រសាស្រីឯងដែរ[ត] ១៧ចូរនាំអស់ទាំងសត្វគ្រប់ពូជ ដែលនៅជាមួយនឹងឯងចេញមកផង ទោះទាំងសត្វស្លាបសត្វជើង៤ និងគ្រប់ទាំងសត្វដែលលូនវារនៅដីក្តី ដើម្បីឱ្យបានមកបង្កើតកូនចំរើនជាបរិបូរនៅពេញពាសលើផែនដី[ថ] ។

**៧:២៣** ហ យប ១៤:១៩ ២១:១៨ ២២:១១,១៦ ទដ ៩០:៥ អស ២៨:២ មថ ២៤:៣៩ លក ១៧:២៧ ១ពត ៣:២០ ២ពត ២:៥ ឡ ហព ១១:៧ **៧:២៤** អ លប ៨:៣ យប ១២:១៥ **៨:១** ក លប ៩:១៥ ១៩:២៩ ២១:១ ៣០:២២ នក ២:២៤ ជន ១០:៩ នរ ៤:១៣ ណហ ២:៧ មថ ៣:១៦ ១០:១៦ យហ ១:៣២ ១សយ ១:១១,១៩ ២ពវ ២០:៣ ១រប ១៦:១៥ នហ ១:៨ ៥:១៩ ១៣:១៤, ២២ ៣១ យប ១៤:១៣ ទដ ១០៥:៤២ ១០៦:៤ លក ១:៥៤, ៧២ ខ នក ១៤:២១ យស ២:១០ ៣:១៦ យប ១២:១៥ ទដ ៦៦:៦ អស ១១:១៥ ៤៤:២៧ ណហ ១:៤

**៨:២** គ លប ៧:១១ ឃ លប ៧:៤ **៨:៣** ង លប ៧:២៤ **៨:៤** ច លប ៧:១១ ឆ លប ៧:២០ ជ ២ពវ ១៩:៣៧ យរ ៥១:២៧ **៨:៦** ឈ លប ៧:១២ **៨:៧** ញ លវ ១១:១៥ ចទ ១៤:១៤ ១ពវ ១៧:៤,៦ យប ៣៨:៤១ ទដ ១៤៧:៩ សភ ៣០:១៧ អស ៣៤:១១ លក ១២:២៤ ដ ឧ.១១ **៨:៨** ឋ យប ៣០:៣១ ណហ ២:៧ មថ ៣:១៦ ១០:១៦ យហ ១:៣២ ទដ ៥៥:៦ ៧៤:១៩ ២:១២,១៤ អស ៣៨:១៤ ៥៩:១១ ៦០:៨ យរ ៤៨:២៨ អគ ៧:១៦ ហស ៧:១១ ១១:១១ **៨:១៦** ត លប ៧:១៣ **៨:១៧** ថ លប១:២២

**៨:១** ជាយូរលង់ណាស់មកហើយ ការរៀបរាប់ដែលនិយាយអំពីទឹកជន់ គឺជាការជំនុំជម្រះរបស់ព្រះ តែឥឡូវនេះ គឺនិយាយអំពីការប្រោសលោះវិញ ។ ព្រះទ្រង់នឹកចាំពីលោកណូអេ ទោះបីជាគាត់មិនបាននិយាយនៅក្នុង ៧:១៦ ឬបានឮគេនិយាយពីគាត់អស់រយៈពេល១៥០ថ្ងៃក៏ដោយ (៧:២៤) ក៏ព្រះទ្រង់មិនបានភ្លេចពីគាត់ និងក្រុមគ្រួសាររបស់គាត់ឡើយ ។ ការ "នឹកចាំ" ជាញឹកញាប់ក្នុងព្រះគម្ពីរ មិនគ្រាន់តែនិយាយពីការត្រាស់ហៅមកវិញ និងការយកចិត្តទុកដាក់ចំពោះមនុស្សនោះទេ គឺថែមទាំងពិពណ៌នាអំពីការព្រួយបារម្ភដោយក្តីស្រឡាញ់ចំពោះពួកគេទៀតផង ។ នៅពេលដែលព្រះទ្រង់នឹកចាំអំពីកូនតូចណាមួយរបស់ទ្រង់ គឺទ្រង់តែងតែ "ចម្រើនព្រះគុណ" នហ ៥:១៩ ១៣:៣១) ។ *ខ្យល់* ក្នុងព្រះគម្ពីរភាសាហេព្រើរ បកប្រែថា "ព្រះវិញ្ញាណ" និង ១:២ បានបកប្រែថា "ខ្យល់" និងសេចក្តីពន្យល់ដូចគ្នានឹងព្រឹត្តិការណ៍ក្នុងជំពូកទី៨–៩ រួមនឹងជំពូកទី១ ។ សូមប្រៀបធៀប ៨:២ ១:៧ ៨:៥ ១:៩ ៨:៧ ១:២៥ ៩:១ ១:២៨ ក ៩:២ ១:២៨ ខ ព្រមទាំង ៩:៣ ១:៣០ ។ នៅក្នុងជំពូកទី១ គឺពិពណ៌នាអំពីការបង្កើតពិភពលោកជាលើកដំបូង ហើយក្នុងជំពូកទី ៨–៩ គឺពិពណ៌នាអំពីការបង្កើតពិភពលោក ឡើងវិញក្រោយគ្រាទឹកជន់ ។

**៨:៤** *ភ្នំ* ពាក្យនេះគឺជាពហុវចនៈ ហើយសំដៅលើជួរភ្នំ ។ *អារ៉ារ៉ាត* ឈ្មោះនេះ គឺមានទំនាក់ទំនងទៅនឹងជនជាតិ "អាស៊ីរីអ៊ូរ៉ាធូ" (AssyrianUrartúe) ហើយបានត្រឡប់ជាអាណាចក្រភ្នំដ៏ធំមួយ (មើលក្នុង យរ ៥១:២៧ អស ៣:៣៨) និងអាណាខែត្រជាច្រើននៅក្នុងតំបន់ភាគខាងជើង នៃប្រទេស "ម៉េសូប៉ូតាមា" (Mesopotamia) ហើយនិងតំបន់ទាន់សម័យភាគខាងកើតនៃប្រទេសទួរគី ។

**៨:៦** *បង្អួច* សូមមើល ៦:១៦ ។

**៨:១១** *ព្រាបនោះត្រឡប់... ឃើញមានពាំយកស្លឹកអូលីវដែលវាបានចឹកមកជាមួយផង* ដើមអូលីវមិនបានដាំនៅលើកន្លែងដែលមានកំពស់ខ្ពស់នោះទេ ហើយស្លឹកខៀវខ្ចី គឺជាសញ្ញាមួយប្រាប់ដល់ណូអេថា ទឹកបានស្រកចុះពីផែនដីវិញហើយ ។ សម័យបច្ចុប្បន្ននេះ សត្វព្រាបជានិមិត្តរូបតំណាងឱ្យសន្តិភាព គឺមានពាំមែកអូលីវនៅចំពុះរបស់វា ។ និមិត្តរូបបែបនេះ គឺបានបង្ហាញពីប្រវត្តិសាស្ត្រក្នុងព្រះគម្ពីរ ។

**៨:១៣** *នៅឆ្នាំ៦០១ក្នុងថ្ងៃចូលខែទី១* គឺជារបៀបកំណត់ថ្ងៃខែរបស់មនុស្សក្រោយគ្រាទឹកជន់ ។

**៨:១៤** *ថ្ងៃ២៧ខែទី២* ច្រើនជាងមួយឆ្នាំនៅក្រោយពេលទឹកជន់ (មើល ៧:១១) ។

**៨:១៦** *ចេញពីទូក* មើលក្នុង ៧:១ ។

**៨:១៧** *បង្កើតកូនចំរើនជាបរិបូរនៅពេញពាសលើផែនដី* មើលការពន្យល់ ១:២១ ។ សត្វជើង៤ និងសត្វស្លាបអាចរស់នៅតាមទម្លាប់មុនឡើងវិញ ។

១៨នោះណូអេក៏ចេញមក ព្រមទាំងប្រពន្ធកូន និងកូន
ប្រសាស្រីគាត់[ទ] ១៩ហើយគ្រប់ទាំងសត្វជើង៤ សត្វលូនវារ
និងសត្វស្លាបទាំងប៉ុន្មានផង គឺគ្រប់ទាំងសត្វដែលកំរើកនៅ
ផែនដី នោះក៏ចេញពីទូកមកតាមពូជ ។
២០ណូអេបានស្អាងអាសនា១ថ្វាយព្រះយេហូវ៉ា[ធ] ក៏យក
សត្វជើង៤ពីសត្វដ៏ស្អាតគ្រប់មុខ[ន] ហើយពីសត្វស្លាបស្អាត
គ្រប់មុខ មកថ្វាយជាដង្វាយដុត[ប]លើអាសនានោះ ២១ព្រះយេ
ហូវ៉ាទ្រង់ធុំក្លិនឈ្ងុយ[ផ] រួចទ្រង់សំរេចក្នុងព្រះហឫទ័យថា
អញនឹងមិនដាក់បណ្តាសាដី[ព] ដោយព្រោះមនុស្សទៀតទេ
ពីព្រោះគំនិតក្នុងចិត្តមនុស្ស នោះអាក្រក់តាំងតែពីក្មេងមក[ភ]
អញក៏មិនធ្វើទោស[ម]ដល់ជីវិតទាំងឡាយ[យ] ដូចជាអញទើប
នឹងធ្វើនោះទៀតដែរ ២២កាលនៅមានផែនដីនៅឡើយ
នោះមិនដែលខាននឹងមានរដូវសាបព្រោះ រដូវច្រូតកាត់[រ]
ត្រជាក់ហើយក្តៅ ប្រាំង[ល]វស្សា ថ្ងៃហើយយប់ទៀតឡើយ[វ] ។

## សេចក្តីសញ្ញារបស់ព្រះជាមួយនឹងលោកណូអេ

**៩** ១ព្រះទ្រង់ក៏ប្រទានពរដល់ណូអេ និងកូនគាត់ ព្រមទាំង
មានបន្ទូលថា "ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង ឱ្យបាន
នៅពេញពាសលើផែនដីចុះ[ក] ២ឯគ្រប់ទាំងសត្វនៅផែនដី
សត្វហើរលើអាកាស សត្វលូនវារនៅដី និងត្រីក្នុងសមុទ្រ
ទាំងប៉ុន្មាន និងកោតខ្លាច ហើយស្ញប់ស្ញែងដល់ឯងរាល់គ្នា
អញប្រគល់វាមកក្នុងអំណាចឯងហើយ[ខ] ៣បណ្តាសត្វទាំង
ប៉ុន្មានដែលកំរើកហើយនៅរស់ នោះនឹងបានជាអាហារ
ដល់ឯង[គ] ដូចជាតិណជាតិទាំងអស់ដែលអញបានឱ្យដល់ឯង
នោះដែរ[ឃ] ៤តែសាច់ណាដែលនៅមានជីវិត គឺជាឈាម
នោះកុំឱ្យបរិភោគឡើយ[ង] ៥រីឯជីវិតមនុស្សវិញ បើអ្នកណា
យកជីវិតគេ នោះអញនិងទារ[ច]ឈាមដែលជាជីវិតរបស់អ្នក
នោះជាមិនខាន អញនឹងទារឈាមអ្នកនោះ ដោយសារ
អស់ទាំងសត្វ[ឆ]ហើយដោយសារដៃរបស់មនុស្ស គឺដោយ
សារដៃរបស់បងប្អូននៃអ្នកដែលស្លាប់នោះផង[ជ] ។

**៨:១៨** ទ ១ពត ៣:២០ ២ពត ២:៥ **៨:២០** ធ លប ១២:៧–៨ ១៣:១៨ ២២:៩ ២៦:២៥ ៣៣:២០ ៣៥:៧ នក ១៧:១៥ ២៤:៤ ន លប ៧:៨ ប លប ២២:២,១៣ នក ១០:២៥ ២០:២៤ ៤០:២៩ លវ ១:៣ ៤:២៩ ៦:៨–១៣ ជន ៦:១១ ពច ៦:២៦ ១១:៣១ ១សយ ២០:២៩ យប ១:៥ ៤២:៨ **៨:២១** ផ នក ២៩:១៨,២៥ លវ ១:៩,១៣ ២:៩ ៤:៣១ ជន ១៥:៣,៧ ២កថ ២:១៥ ព លប ៣:១៧ ភ លប ៥ទដ ៥១:៥ យរ ១៧:៩ មថ ១៥:១៩ រម ១:២១ ម យរ ៤៤:១១ យ លប ៩:១១,១៥ អស ៥៤:៩
**៨:២២** រ យស ៣:១៥ ទដ ៦៧:៦ យរ ៥:២៤ ល ទដ ៧៤:១៧ សក ១៤:៨ វ លប ១:១៤ **៩:១** ក លប ១:២២ **៩:២** ខ លប ១:២៦ **៩:៣** គ លប ១:២៩ ឃ កច ១០:១៥ កល ២:១៦ **៩:៤** ង លវ ៣:១៧ ៧:២៦ ១៧:១០–១៤ ១៩:២៦ ចទ ១២:១៦, ២៣–២៥ ១៥:២៣ ១សយ ១៤:៣៣ អគ ៣៣:២៥ កច ១៥:២០,២៩ **៩:៥** ច លប ៤២:២២ ៥០:១៥ ១ពវ ២:៣២ ២របា ២៤:២២ ទដ ៩:១២ ឆ នក ២១:២៨–៣២ ជ លប ៤:១០

**៨:២០** *ព្រះយេហូវ៉ា* ពេលដែលយើងថ្វាយបង្គំព្រះនាមព្រះយេហូវ៉ា គឺមានសារៈសំខាន់ណាស់ (មើល ២:៤) ជាព្រះដែលលោកណូអេបាននាំយកយញ្ញបូជារបស់គាត់មកថ្វាយដល់ព្រះអង្គ (មើល ៤:៤) ។
**៨:២១** *ក្លិនឈ្ងុយ* គឺជាការប្រៀបប្រដូចមួយដែលនិយាយថា ព្រះទ្រង់សព្វព្រះហឫទ័យចំពោះដង្វាយរបស់ណូអេ (អភ ៥:២ភ លព ៤:១៨) ។ ដីត្រូវបណ្តាសា ទោះក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យ"បណ្តាសា"ក្នុងខនេះ មានន័យផ្សេងពីពាក្យ "បណ្តាសា" ក្នុង (៣:១៧) ក៏ដោយ ក៏ព្រះយេហូវ៉ាទ្រង់សន្យាថា នឹងមិនដាក់បណ្តាសាលើបណ្តាសាមួយទៀត ដែលព្រះអង្គបានដាក់លើកាអ៊ីននោះឡើយ (៤:១២) ។ ពីព្រោះគំនិតក្នុងចិត្តមនុស្សនោះអាក្រក់ សម្រាប់ប្រយោគផ្សេងទៀត ដែលស្ទើរតែដូចគ្នានោះ សូមមើល ៦:៥ ។ ដោយសារតែការអាក្រក់ដ៏ហួសល្បត់របស់មនុស្ស ព្រះទ្រង់បានបំផ្លាញពួកគេចោល (៦:៧) ដោយសារទឹកជន់ដ៏ធំមួយ (៦:១៧) ។ ទោះបីជាលោកណូអេនិងក្រុមគ្រួសារគាត់ត្រូវបានសង្គ្រោះក៏ដោយ ក៏គាត់មានកូនចៅរបស់គាត់ ដែលមកពីអ័ដាមហើយនៅក្នុងចិត្តរបស់ពួកគេ គឺមានអំពើបាបដែលបន្សល់ទុកតាមរយៈពូជពង្សគេដែរ ។ ព្រះគុណរបស់ព្រះគឺជាសេចក្តីសន្យាដែលព្រះបានសន្យាថា និងមិនបំផ្លាញផែនដីនេះដោយទឹកជន់ទៀតឡើយ (៩:១១ និង ខ.១៥) ។ ប្រវត្តិសាស្ត្រមនុស្សជាតិត្រូវបាន . . .។ *តាំងតែពីក្មេងមក* ឃ្លានេះជិនួសឱ្យ"គ្រប់ពេល"នៅ (៦:៥) និងតាមរយៈសេចក្តីពិតដែលថា មនុស្សមានបាបតាំងពីកំណើត (ទដ ៥១:៥៥ ៨:៣) ។
**៨:២២** ទាំងពេលវេលា និងរដូវកាលគឺព្រះទ្រង់បានបង្កើតតាំងពីដើមដំបូងមកម្ល៉េះ (១:១៤) ដែលមាននៅជាដរាបលើផែនដីនេះ ។
**៩:១–៧** នៅក្នុងគ្រាសញ្ញាថ្មីនេះ ព្រះទ្រង់បានប្រទានពរឡើងវិញ នូវអ្វីដែលទ្រង់បានប្រទានពរពីមុនមក (១:២៨) ព្រមទាំងផ្គត់ផ្គង់អាហារដល់មនុស្ស (ខ.៣ ១:២៩–៣០) ។ ប៉ុន្តែ ដោយសារតែអំពើបាបបានបង្កើតឱ្យមានជម្លោះ និងអំពើហឹង្សានៅលោកិយ និងដោយសារតែឥឡូវនេះ ព្រះទ្រង់បានកំណត់ថា សាច់គឺជាផ្នែកមួយសម្រាប់ឱ្យមនុស្សធ្វើជាអាហារ (ខ.៣) ពីនេះទៅមុខព្រះអាទិករ ទ្រង់នឹងប្រទានឱ្យមានបន្ថែមទៀត (ខ.៤–៦) ។ អ្វីដែលទ្រង់ប្រទានពរគឺការគ្រប់គ្រង (ខ.៧) ។
**៩:២** *អញប្រគល់វាមកក្នុងអំណាចឯងហើយ* ព្រះទ្រង់បានបញ្ជាក់ឡើងវិញថាមនុស្សជាតិគឺជាអ្នកគ្រប់គ្រងលើអ្វីៗ ដែលព្រះបានបង្កើតមក ដោយរាប់បញ្ចូលទាំងសត្វជើង៤ (១:២៦) ។
**៩:៣** *បណ្តាសត្វទាំងប៉ុន្មាន ដែលកំរើកហើយនៅរស់នឹងបានជាអាហារ* ឥឡូវនេះសាច់សត្វគឺត្រូវបានផ្គត់ផ្គង់ ដល់មនុស្សសម្រាប់ធ្វើជាអាហារ ។
**៩:៤** *តែសាច់ណាដែលនៅមានជីវិតគឺជាឈាមនោះកុំឱ្យបរិភោគឡើយ* លវ ១៧:១៤ ។ ផ្តោតលើការបង្គាប់យ៉ាងកំហិត២ដងអំពីទំនាក់ទំនងរវាងឈាមហើយនិងជីវិតដែលបាននិយាយដូច្នេះថា "ដ្បិតជីវិតនៃរូបសាច់នោះនៅក្នុងឈាម" ជីវិតគឺជាអំណោយទានដ៏មានតម្លៃនឹងជាសេចក្តីអាថ៌កំបាំងមកអំពីព្រះ មនុស្សមិនអាចស្វែងរកនិងអភិរក្សព្រមទាំងបង្កើតឱ្យរីកចម្រើនបានក្នុងកំឡុងពេលដែលពួកគេបរិភោគ"ជីវិត"ដែលមាននៅក្នុង"ឈាម" (លវ ១៧:១១) ដូចជាមនុស្សដែលមិនជឿព្រះជាច្រើនគេគិតថា ពួកគេអាចញ៉ាំបាននោះឡើយ ។
**៩:៥** *រីឯជីវិតមនុស្សវិញ . . . អញនឹងទារឈាមអ្នកនោះដោយសារអស់ទាំងសត្វ* ព្រះយេហូវ៉ាទ្រង់ផ្ទាល់គឺជាអ្នកបង្កើតជីវិតមនុស្សឡើង (៤:៩–១២) គឺជាអ្នកដែលមានតម្លៃបំផុតសម្រាប់ព្រះអង្គ ពីព្រោះទ្រង់បានបង្កើតគេឡើងតាមរូបអង្គនៃទ្រង់ (ខ.៦) ហើយម្យ៉ាងទៀតពួកគេគឺជាអ្នកតំណាងឱ្យផែនដីដែលជាអ្នកសម្របសម្រួលនៅក្នុងនគរព្រះ ។ តាំងពីពួកពូជយុកោ (នគរព្រះ) គឺ

៦អ្នកណាដែលកំចាយឈាមរបស់មនុស្ស នោះឈាមអ្នក
នោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ[ឈ] ដ្បិតព្រះ
ទ្រង់បានបង្កើតមនុស្សឱ្យដូចជារូបអង្គទ្រង់[ញ] ៧ឯងរាល់គ្នា
ចូរបង្កើតកូនឱ្យចំរើនជាច្រើនឡើង ហើយឱ្យបានសាយ
ក្រាយនៅផែនដីជាបរិបូរចុះ[ដ] ។
៨រួចព្រះទ្រង់មានបន្ទូលទៅណូអេ និងពួកកូនគាត់ថា
៩ឯអញ មើល អញតាំងសញ្ញានឹងឯងរាល់គ្នា[ឋ] ហើយនិងពូជ
ឯងរាល់គ្នាតរៀងទៅ ១០និងគ្រប់ទាំងជីវិតទាំងឡាយ ដែល
នៅជាមួយនឹងឯងរាល់គ្នា ទាំងសត្វស្លាប សត្វស្រុក និងសត្វ
ព្រៃនៅផែនដីផង គឺនឹងគ្រប់ទាំងសត្វនៅផែនដី ដែល
បានចេញពីទូកធំមក ១១អញនឹងតាំងសញ្ញា[ឌ]នឹងឯងរាល់
គ្នា[ឍ]ថា គ្រប់សាច់ទាំងអស់នឹងមិនត្រូវវិនាសដោយទឹកជន់
ទៀតឡើយ នឹងលែងមានទឹកជន់បំផ្លាញផែនដីទៀត[ណ]
១២ព្រះទ្រង់ក៏មានបន្ទូលថា នេះជាទីសំគាល់នៃសេចក្ដី
សញ្ញា[ត]ដែលអញតាំងនឹងឯងរាល់គ្នា ហើយនិងគ្រប់ជីវិត
ទាំងឡាយដែលនៅជាមួយនឹងឯង នៅអស់ទាំងតំណអស់
កល្បជានិច្ច[ថ] ១៣គឺអញដាក់ធ្នូ[ទ]របស់អញនៅនាពពកនោះ
ហើយជាទីសំគាល់នៃសេចក្ដីសញ្ញា ដែលអញតាំងនឹង
ផែនដី ១៤កាលណាអញប្រមូលពពកមកលើផែនដី នោះ
នឹងឃើញឥន្ទធនូ[ធ]ស្ថិតនៅលើពពកនោះ ១៥ហើយអញនឹង
នឹកចាំពីសេចក្ដីសញ្ញា[ន] ដែលអញបានតាំងនឹងឯងរាល់គ្នា
ហើយនិងអស់ទាំងសត្វគ្រប់ពូជដែរ នោះនឹងគ្មានទឹកជន់
ឡើងលិចផែនដី ដើម្បីបំផ្លាញគ្រប់ទាំងសាច់ទៀតឡើយ[ប]
១៦ឥន្ទធនូ[ផ]នោះនឹងនៅលើពពក ហើយអញនឹងមើលឃើញ
ដើម្បីឱ្យនឹកចាំពីសេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ច[ព] ដែល
ព្រះបានតាំងនឹងអស់ទាំងជីវិតគ្រប់ពូជនៅផែនដី ។
១៧ព្រះទ្រង់ក៏មានបន្ទូលទៅណូអេថា នេះហើយជាទី
សំគាល់នៃសេចក្ដីសញ្ញា[ភ] ដែលអញបានតាំងនឹងគ្រប់ទាំង

**៩:៦** ឈ លប ៤:១៤ ពច ៩:២៤ មថ ២៦:៥២ ញ លប ១:២៦ **៩:៧** ដ លប ១:២២ **៩:៩** ឋ ខ.១១ លប ៦:១៨ **៩:១១** ឌ ខ.១៦ អស ២៤:៥ ៣៣:៨ ហស ៦:៧ ឍ ខ.៩ ណ លប ៨:២១ **៩:១២** ត ខ.១៧ លប ១៧:១១ ថ លប ១៧:១២ នក ១២:១៤ លវ ៣:១៧ ៦:១៨ ១៧:៧ ជន ១០:៨ **៩:១៣** ទ ខ.១៤ អក ១:២៨ វវ ៤:៣ ១០:១ **៩:១៤** ធ ខ.១៣ **៩:១៥** ន លប ៨:១ នក ២:២៤ ៦:៥ ៣៤:១០ លវ ២៦:៤២,៤៥ ចទ ៧:៩ ទដ ៨៩:៣៤ ១០៣:១៨ ១០៥:៨ ១០៦:៤៥ អក១៦:៦០ ផ លប ៨:២១ **៩:១៦** ប ខ.១៣ ព ខ.១១ លប ១៧:៧,១៣,១៩ ២សយ ៧:១៣ ២៣:៥ ទដ ១០៥:៩–១០ អស ៩:៧ ៥៤:១០ ៥៥:៣ ៥៩:២១ ៦១:៨ យរ ៣១:៣១–៣៤:៤០ ៣៣:២១ អគ ១៦:៦០ ៣៧:២៦ ហព ១៣:២០ **៩:១៧** ភ ខ.១២

មានទីតាំងនៅលើភ្នំស៊ីណាយ សត្វស្រុកណាដែលបានសម្លាប់មនុស្សក៏ត្រូវចោលសម្លាប់នឹងដុំថ្មដែរ (នក ២១:២៨–៣០) ។

**៩:៦** *អ្នកណាដែលកំចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ* នៅគ្រាពួកព្យុកោក្រោយទៀតឃាតកម្មដែលមានការគ្រោងទុក និងត្រូវទទួលទោសប្រហារជីវិត (នក ២១:១២,១៤ ជន ៣៥:១៦៣២ រម ១៣:៣៤ ១ពត ២:១ ៣:១៤) ។ *ដ្បិតព្រះទ្រង់បានបង្កើតមនុស្សឱ្យដូចជារូបអង្គទ្រង់* សូមមើល ១:២៦ និងការពន្យល់ ។ ការសម្លាប់មនុស្សដំបូងអ្នកប្រព្រឹត្តបទឧក្រិដ្ឋបានប្រមាថមើលងាយនៅចំពោះព្រះ (សភ ១៤:៣១ ១៧:៥ យក ៣:៩ និងការពន្យល់) ។

**៩:៨–១៧** មូលដ្ឋានគ្រឹះសំខាន់ៗជាច្រើននៃការតាំងសញ្ញាលើកដំបូងរបស់ព្រះជាមួយជីវិតទាំងឡាយដែលព្រះបានបង្កើតមក ។ ការតាំងសញ្ញានេះគឺទាក់ទងទៅនឹងសណ្ដាប់ធ្នាប់នៃការបង្កើតនឹងទីសំគាល់ដែលបានបង្កប់នៅក្នុងការបង្កើតទាំងឡាយ ដែលមានសណ្ដាប់ធ្នាប់ទាំងអស់នោះ ។ នៅក្នុងកំឡុងពេលដែលព្រះទ្រង់ជិនុំជម្រះពិភពលោកដោយទឹកជន់ មើលទៅហាក់បីដូចជាព្រះបានបង្កើតពិភពលោកឡើងវិញ ឱ្យបានគ្រប់លក្ខណ៍ ។ អំពើបាបរបស់មនុស្សត្រូវការតាំងសញ្ញា និងការធានារាប់រងមកពីព្រះ គឺជាការធានាថា នឹងមិនបំផ្លាញជីវិតទាំងឡាយដោយទឹកជន់ទៀតទេ ។

**៩:៩** *ឯអញ មើលអញនឹងតាំងសញ្ញា* ព្រះយេហូវ៉ាទ្រង់គឺជាអធិបតីភាពនៃសេចក្ដីសន្យា ដែលទ្រង់តាំងសញ្ញាជាមួយលោកណូអេ កូនចៅលោកណូអេ និង ជីវិតទាំងឡាយផ្សេងៗទៀត គឺជាពូជនៃព្រះគុណ ដែលបានដោយសារសេចក្ដីសុចរិតរបស់លោកណូអេជាបិតានៃមនុស្សជាតិថ្មី (សូមមើល ៦:១៨) ថាទ្រង់នឹងមិនបំផ្លាញផែនដី ព្រមទាំងមនុស្សទាំងនោះទៀតឡើយរហូតដល់ចុងបញ្ចប់នៃផែនដី (៨:២២) ។ មានសេចក្ដីសន្យាមួយ ប្រហាក់ប្រហែលគ្នានេះដែរ គឺជាការតាំងសញ្ញារបស់ព្រះជាមួយលោកអាប់រ៉ាម (១៥:១៨,២០) ជាមួយលោកភីនេហាស (ជន ២៥:១០,១៣) និងជាមួយដាវីឌ (២សយ ជំពូក ៧) ។

**៩:១១** *គ្រប់សាច់ទាំងអស់នឹងមិនត្រូវវិនាសដោយទឹកជន់ទៀត* សេចក្ដីសង្ខេបនៃការតាំងសញ្ញារបស់ព្រះជាមួយលោកណូអេ គឺជាសេចក្ដីសន្យាដ៏អស់កល្បដូចដែលមានពាក្យថា "មិនដែល"(មើល ខ.១១,១៦) "នៅអស់ទាំងតំណអស់កល្បជានិច្ច" (មើល ខ.១២) ហើយនិង "ដ៏នៅអស់កល្បជានិច្ច" (មើល ខ.១៦) ។

**៩:១២** *ទីសំគាល់* ត្រានៃការតាំងសញ្ញា គឺយើងអាចមើលយ៉ាងច្បាស់ ដើម្បីរំឭកពីការតាំងសញ្ញាដ៏នៅអស់កល្បជានិច្ច ។ ការកាត់ស្បែកអាចជាទីសំគាល់ពីការតាំងសញ្ញាមួយ ដែលព្រះបានធ្វើជាមួយលោកអ័ប្រាហាំ (១៧:១១) ហើយថ្ងៃឈប់សម្រាកក៏អាចជាទីសំគាល់មួយដែលព្រះបានតាំងជាមួយពួកកូនចៅអ៊ីស្រាអែលនៅភ្នំស៊ីណាយ (នក ៣១:១៦–១៧) ។

**៩:១៣** *ឥន្ទធនូ* (ធ្នូ) ភ្លៀងហើយនិងឥន្ទធនូមានតាំងពីយូយារណាស់មកហើយ គឺមុនពេលមានទឹកជន់ទៅទៀត ប៉ុន្តែបន្ទាប់ពីទឹកជន់មក ឥន្ទធនូមានអត្ថន័យថ្មី គឺក្លាយជាទីសំគាល់មួយក្នុងការតាំងសញ្ញាជាមួយលោកណូអេ ។ ព្រះគម្ពីរភាសាហេព្រើរប្រើពាក្យដែលជាភាសាអង់គ្លេសគឺ "បូ" (bow) គឺមានន័យថា "ធ្នូ" ដូចក្នុង ២៧:៣ ៤៨:២២ ។ ឥន្ទធនូប្រហែលជាតំណាងឱ្យធ្នូគឺជាព្រួញនៃរន្ទះរបស់ទ្រង់ ដែលព្រះបានបាញ់តម្រង់មកផែនដី ទដ ១៨:១៤ ៧៧:១៧ ១៤៤:៦ ហប ៣:៩,១១ សម្រាប់សំដៅលើព្រះកាន់ធ្នូ (សូមមើល ទដ ៧:១២ ២១:១២ បទ ២:៤ សក ៩:១៣ និងតំណាងឱ្យព្រួញរបស់ព្រះ (សូមមើល ចទ ៣២:២៣,៤២ យប ៦:៤ ៣៤:៦ ទដ ៣៨:២៦ ៤:៧ បទ ៣:១២,១៣ អរ ៥:៦) ។ ប៉ុន្តែបន្ទាប់ពីទឹកជន់ ធ្នូរបស់ព្រះគឺតម្រង់មកព្រះអង្គទ្រង់ផ្ទាល់ អាវុធនោះនឹងត្រឡប់មកអ្នកដែលបាញ់ធ្នូនោះ (ទដ ៣៧:១៥ ៦៤:៣៤,៧៨ យរ ២១:៤) ។ ដោយសារមូលហេតុទាំងអស់នេះហើយ បានជាព្រះទ្រង់បានដាក់ឥន្ទធនូមក ដើម្បីធ្វើជាទីសំគាល់អំពីសេចក្ដីសន្យាដ៏នៅអស់កល្បរបស់ទ្រង់ (១៥:១៧ ៩:១៦)។

សាច់នៅលើផែនដី ។

**កូនរបស់លោកណូអេ**

១៨ រីឯកូនណូអេដែលចេញពីទូកធំមក នោះគឺសិម ហាំ
និងយ៉ាផែត[ម] ឯហាំនោះជាឪពុកកាណាន[យ] ១៩ អ្នកទាំង៣
នោះជាកូនរបស់ណូអេ[រ] គឺកូនចៅអ្នកទាំងនោះហើយ ដែល
បានចេញទៅនៅពេញពាសលើផែនដី[ល]។

២០ ឯណូអេ គាត់ចាប់តាំងភ្ជួរ រាស់ដីធ្វើចំការ ហើយដាំ
ទំពាំងបាយជូរ ២១ គាត់បានផឹកស្រាទំពាំងបាយជូរនោះ[វ]
ហើយក៏ស្រវឹងទៅ រួចដេកអាក្រាតនៅក្នុងត្រសាលគាត់
២២ ឯហាំជាឪពុកកាណាន បានឃើញឪពុកអាក្រាតដូច្នេះ[ស]
ក៏ទៅបកកេរប្រាប់ដល់បងប្អូនទាំង២ ដែលនៅខាងក្រៅ
២៣ នោះសិមនិងយ៉ាផែតនាំគ្នាយកអាវវែងមកត្រដាងពី
ស្មាទាំង២នាក់ ដើរថយក្រោយទៅបាំងកេរខ្មាសឪពុក
ទាំងមើលចំទៅខាងមុខ មិនឱ្យឃើញកេរខ្មាសរបស់គាត់
ឡើយ ២៤ លុះកាលណូអេស្វាងពីស្រាឡើង ក៏បានដឹងការ
ដែលកូនពៅបានធ្វើ ២៥ នោះគាត់និយាយថា កាណាន[ហ]ត្រូវ
បណ្តាសា[ឡ]ហើយ វានឹងត្រូវធ្វើជាអ្នកបំរើដល់ពួកបាវ
របស់បងប្អូនវា[អ] ២៦ ហើយគាត់និយាយទៀតថា សូមឱ្យព្រះ
យេហូវ៉ាជាព្រះនៃសិម[ក]បានប្រកបដោយព្រះពរ ហើយត្រូវ
ឱ្យកាណានធ្វើជាបាវបំរើ[ខ]ដល់សិមវិញ ២៧ សូមព្រះទ្រង់
វាតទីឱ្យយ៉ាផែត[គ] សូមឱ្យវាបានអាស្រ័យនៅក្នុងទីលំនៅ
របស់សិម[ឃ] ហើយឱ្យកាណានបានធ្វើជាបាវបំរើរបស់វា
ដែរ ២៨ លុះក្រោយទឹកជន់លិចមក នោះណូអេ គាត់ក៏រស់
នៅបាន៣៥០ឆ្នាំទៅទៀត ២៩ អាយុរបស់ណូអេ ទាំងអស់រួម
បាន៩៥០ឆ្នាំ រួចគាត់ក៏ស្លាប់ទៅ[ង]។

**តារាងនៃជាតិសាសន៍**

**១០** ១ ក្រោយពីគ្រាទឹកជន់លិចមក នោះពួកកូនណូអេបាន
បង្កើតកូនតទៅ ឯបញ្ជីដំណវង្ស[ក]ពីសិម ហាំ និងយ៉ាផែត[ខ]
ជាកូនគាត់នោះ[គ]គឺដូច្នេះ ។

**៩:១៨** ម លប ៥:៣២ ក ៣:៣៦ យ ខ.២៥–២៧ លប ១០:៦,១៥ **៩:១៩** រ លប ៥:៣២ ល លប ១:២២ ១០:៣២ ១១:៤,៨,៩ **៩:២១** វ លប ១៩:៣៥ **៩:២២** ស ហ៣ ២:១៥ **៩:២៥** ហ ខ.១៨ នក ២០:៥ ទដ ៧៩:៨ អស ១៤:២១ យរ ៣១:២៩ ៣២:១៨ ឡ លប ២៧:១២ អ លប ២៥:២៣ ២៧:២៩,៣៧, ៤០,៣៧:១០ **៩:២៦** ក លប ១៤:២០ នក ១៨:១០ ទដ ៧:១៧ ខ ១ពវ ៩:២១**៩:២៧** គ លប ១០:២–៥ ឃ អភ ២:១៣–១៤ ៣:៦ **៩:២៩** ង លប២:១៧ **១០:១** ក លប ២:៤ ខ លប ៥:៣២ គ ខ.៣២ ១រប ១:៤

**៩:១៩** *ដែលបានចេញទៅនៅពេញពាសលើផែនដី* គឺជាការប៉ាន់ស្មានអំពីពូជសាសន៍នៅក្នុងជំពូក១០ (សូមមើលការពន្យល់ ១១:៨) ។

**៩:២០** *ចាប់តាំងភ្ជួរដីធ្វើចំការ* ដូចជាឡាមេកដែលជាឪពុករបស់គាត់ដែរ (មើល ៥:២៩) ។

**៩:២១** *គាត់បានផឹកស្រាទំពាំងបាយជូរនោះហើយក៏ស្រវឹងទៅ* គាត់គឺជាមនុស្សដំបូងដែលបានផលិតស្រាហើយផឹករហូតស្រវឹង (សភ ២០:១ និងការពន្យល់) ។ *ដេកអាក្រាតនៅក្នុងត្រសាល* ការផឹកស្រាដ៏ហួសប្រមាណរហូតលែងមានការអៀនខ្មាស់ (១៩:៣០–៣៥) ។

**៩:២២** *ឪពុកកាណាន* យើងលើកយកមកនិយាយនៅទីនេះពីព្រោះសកម្មភាពរបស់ហាំបានប្រព្រឹត្តខ្លួនគាត់ ដូចជាឪពុករបស់កូនចៅសាសន៍កាណាន (សូមមើល ១៥:១៦) ។ *ប្រាប់ដល់បងប្អូនទាំង២* គាត់ផ្សព្វផ្សាយប្រសើរជាងដែលគាត់គ្របបាំងឱ្យឪពុកគាត់ ។

**៩:២៣** *ទាំងមើលចំទៅខាងមុខ មិនឱ្យឃើញកេរខ្មាស់របស់គាត់ឡើយ* ពួកគេចង់គេចវេះឱ្យឆ្ងាយពីឪពុករបស់គេ ។

**៩:២៤** *ស្វាងពីស្រា* គឺគាត់ឈប់ស្រវឹងដែលបណ្តាលមកពីស្រា ។

**៩:២៥** *កាណានត្រូវបណ្តាសា* អ្នកខ្លះគិតថាកូនប្រុសរបស់ហាំ (ខ.១៨,២២) ត្រូវតែទទួលទណ្ឌកម្មពីព្រោះអំពើបាបឪពុករបស់គាត់ (សូមមើល នក ២០:៥) ប៉ុន្តែនៅក្នុងនិក្ខមនំជំពូក២០គឺបាននិយាយថា ព្រះនឹងដាក់ទណ្ឌកម្មចំពោះអ្នកណាដែល"ស្អប់អញ" ។ ពួកកូនចៅអ៊ីស្រាអែល គឺជាពង្សាវតារនៃបណ្តាសា និងព្រះពររបស់ណូអេ ។ មានហេតុផលដែលរឹតតែច្បាស់ជាងនេះទៅទៀតនោះ គឺកាណានត្រូវបានគេឱ្យគាត់រស់នៅទីនេះតែម្នាក់ឯង ក្នុងចំណោមពួកកូនចៅរបស់ហាំដែលជាអ្នកទទួលរងបណ្តាសារបស់លោកណូអេ ។ ពួកអ៊ីស្រាអែលអាចក្លាយជាអ្នកប្រព្រឹត្តអំពើបាបយ៉ាងខ្លាំងដូចពួកកូនចៅកាណានដែរ (សូមមើល លវ ១៨:២៦,៣០) ហើយព្រះទ្រង់នឹងជំនុំជម្រះពួកគេដោយសេចក្តីឃោរឃៅរបស់ទ្រង់ ។ នៅក្នុងការជំនុំជម្រះ បណ្តាសារបស់លោកណូអេមួយចំណែកត្រូវបានធ្លាក់មកលើកូនចៅរបស់ហាំ ។ ប៉ុន្តែកូនចៅរបស់ហាំទាំងប៉ុន្មានដែលមានចែងឈ្មោះក្នុង ១០:៦,១៣ (រួមបញ្ចូលនឹងសត្រូវរបស់ពួកកូនចៅអ៊ីស្រាអែល អេស៊ីព្ទ ភីលីស្ទីន អាសេរី បាប៊ីឡូន) ពួកគេទាំងនោះក៏ធ្លាប់ទទួលការជំនុំជម្រះមកពីព្រះដែរពីព្រោះពួកគេបានបដិសេធចំពោះអ៊ីស្រាអែល និងព្រះនៃសាសន៍អ៊ីស្រាអែល ។ វានឹងត្រូវធ្វើជាអ្នកបម្រើ បានតម្រូវឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក (យស ៩:២៧) ហើយត្រូវតែធ្វើការងារយ៉ាងច្រើន (យស ១៦:១០ ពច ១:២៨ ៣០,៣៣,៣៥ ១ពវ ៩:២០–២១) ពួកស្បែកខ្មៅទាំងឡាយដែលក្លាយជាទាសករ មិនមែនដោយសារតែបណ្តាសារបស់លោកណូអេនោះឡើយ ។

**៩:២៦** *សូមឱ្យព្រះយេហូវ៉ាជាព្រះនៃសិមបានប្រកបដោយព្រះពរ* ព្រះយេហូវ៉ា (ជាព្រះនៃសិម) គឺត្រូវបានប្រទានពរ (សរសើរ) ពីព្រោះទ្រង់ គឺជាប្រភពនៃព្រះពររបស់សិម ។ ព្រះអង្គក៏ជា "ព្រះនៃសិម" ហើយនិងកូនចៅរបស់គាត់និង (ពួកកូនចៅអ៊ីស្រាអែល) ។

**៩:២៧** *អាស្រ័យនៅក្នុងទីលំនៅរបស់សិម* សិមបានចែកចាយព្រះពររបស់គាត់ដល់អ្នកផ្សេងៗទៀត ។

**៩:២៩** *រួចគាត់ក៏ស្លាប់ទៅ* សូមមើលការពន្យល់ ៥:៥ ។ គាត់គឺជាមនុស្សទី១០នឹងជាសមាជិកចុងក្រោយនៅក្នុងអំបូររបស់សេត (៥:៣,៣២) ដែលលោកណូអេ បាននិយាយនៅពេលដែលគេទទួលមរណៈភាពដូចជាពួកព្ទឃុកោផ្សេងៗទៀតរបស់ពួកគេ ។

**១០:១** *បញ្ជីដំណវង្ស* សូមមើល ២:៤ ។ ការនិយាយអះអាងអំពីពង្សាវតារនៅទីនេះប្រហែលជាមិនបាននិយាយឱ្យលំអិតគ្រប់ពូជពង្សនោះឡើយ ប៉ុន្តែបានរាប់បញ្ចូលជាមួយនឹងលក្ខណៈភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ភាសាវិទ្យានៅក្នុងសង្គមទៀតផង (មើល ខ.៥,២៨ ១១:១០ និងការពន្យល់) នៅក្នុងសេចក្តីផ្តើមនៃព្រះគម្ពីរ១ពង្សាវតារក្សត្រ ដែលនិយាយអំពីពង្សាវតារ ។

## កូនរបស់យ៉ាផែត

*១០:២-៥ – ១រប ១:៥-៧*

២ឯកូនរបស់យ៉ាផែត គឺកូមើរ[ឃ] ម៉ាកុក[ង] ម៉ាដាយ
យ៉ាវ៉ាន[ច] ទូបាល[ឆ] មែសេក[ជ] និងទីរ៉ាស ៣កូនរបស់កូមើរ
គឺអ័សក្នាស[ឈ] រីផាត និងតូកាម៉ា[ញ] ៤កូនរបស់យ៉ាវ៉ាន គឺ
អេលីសា[ដ] តើស៊ីស[ឋ] ពួកគីទីម[ឌ] និងពួកដូដានីម ៥គឺពួកអ្នក
ទាំងនោះហើយដែលបានបែកទៅ នៅក្នុងអស់ទាំងកោះ
របស់នគរទាំងប៉ុន្មាន តាមស្រុក តាមភាសា តាមគ្រួ ហើយ
តាមនគររបស់គេ[ឍ]។

## កូនរបស់ហាំ

*១០:៦-២០ – ១រប ១:៨-១៦*

៦ឯកូនរបស់ហាំ គឺគូស[ណ] មីសរ៉ែម ពូត[ត] និងកាណាន[ថ]
៧កូនរបស់គូស គឺសេបា[ទ] ហាវីឡា[ធ] សាប់តា រ៉ាម៉ា[ន] និង
សាប់តិកា កូនរបស់រ៉ាម៉ា គឺសេបា[ប] និងដេដាន់[ផ]។
៨គូសក៏បង្កើតនីមរ៉ុឌ[ព] អ្នកនោះចាប់តាំងមានអំណាចនៅ
ផែនដី ៩គាត់ជាព្រានព្រៃ[ភ]ខ្លាំងពូកែ[ម]នៅចំពោះព្រះយេហូវ៉ា
បានជាមានពាក្យប្រៀបថា "ដូចជានីមរ៉ុឌ ជាព្រានព្រៃខ្លាំង
ពូកែនៅចំពោះព្រះយេហូវ៉ា" ១០ដើមនគររបស់គាត់ នោះ
គឺបាបិល[យ] អេរេក[រ] អាកាឌ និងកាលនេ[ល] ជាទីក្រុងដែល
នៅស្រុកស៊ីណើរ[វ] ១១គឺពីស្រុកនោះហើយដែលគាត់ចេញ
ទៅដល់ស្រុកអាសស៊ើរ[ស] ក៏សងទីក្រុងនីនីវេ[ហ] រេហូបូត
កាឡាស ១២និងរេសែន ដែលនៅកណ្តាលនីនីវេនិង
កាឡាស ឯទីក្រុងនោះធំណាស់ ។
១៣មីសរ៉ែម គាត់បង្កើតពួកលូឌីម ពួកអ័ណាមីម ពួកលេ

**១០:២** ឃ អក ៣៨:៦ ង អក ៣៨:២ ៣៩:៦ វវ ២០:៨ ច អក ២៧:១៩ ឆ អស ៦៦:១៩ អក ២៧:១៣ ៣២:២៦ ជ អក ៣៩:១ **១០:៣** ឈ យរ ៥១:២៧ ញ អក ២៧:១៤ ៣៨:៦ **១០:៤** ដ អក ២៧:៧ ឋ ទដ ៤៨:៧៧ ២:១០ អស ២:១៦ ២៣:១,៦,១០,១៤ ៦០:៩ ៦៦:១៩ យរ ១០:៩ អក ២៧:១២, ២៥ ៣៨:១៣ យហ ១:៣ ឌ ជន ២៤:២៤ អស ២៣:១២ យរ ២:១០ អក ២៧:៦ ដយ ១១:៣០

**១០:៥** ឍ លប៩:២៧ **១០:៦** ណ ២ពវ ១៩:៩ ២រប ១២:៣ ១៦:៨ អស ១១:១១ ១៨:១ ២០:៣ ៤៣:៣ យរ ៤៦:៩ អក ៣០:៤,៩ ៣៨:៥ ណាហ ៣:៩ សផ ២:១២ ៣:១០ ត អក ២៧:១០ ៣៨:៥ ថ លប ៩:១៨ **១០:៧** ទ អស ៤៣:៣ ធ លប ២:១១ ន អក ២៧:២២ ប លប ២៥:៣ ១ពវ ១០:១ ២រប ៩:១ យប ១:១៥ ៦:១៩ ១៦:១១ ទដ ៧២:១០,១៥ អស ៦០:៦ យរ ៦:២០ អក ២៧:២២ ៣៨:១៣ យអ ៣:៨ ផ រម ១:៣២ អស ២១:១៣ យរ ២៥:២៣-២៤ ៤៩:៨ អក ២៧:១៥,២០ ៣៨:១៣ **១០:៨** ព មីក ៥:៦ **១០:៩** ភ លប ២៥:២៧ ២៧:៣ ម ២រប ១៤:៩ ១៦:៨ អស ១៨:២ **១០:១០** យ លប ១១:៩ ២រប ៣៦:១៧ អស ១៣:១ ៤៧:១ យរ ២១:២ ២៥:១២ ៥០:១ រ អរ ៤:៩ ល អស ១០:៩ អម ៦:២ វ លប ១១:២ ១៤:១ សក ៥:១១ **១០:១១** ស ទដ ៨៣:៨ មីក ៥:៦ ហ ២ពវ ១៩:៣៦ អស ៣៧:៣៧ យហ១:២ ៣:២,៣ ៤:១១ ណាហ ១:១ សផ ២:១៣

**១០:២** *កូន* សូមមើលអត្ថបទគម្ពីរ ។ *យ៉ាផែត* គឺជាមនុស្សចុងក្រោយ នៅក្នុងការពិពណ៌នានៃព្រះគម្ពីរ ហើយប្រហែលជាកូនច្បងរបស់លោកណូអេ (មើល ៩.២១) ពូជពង្សរបស់ គាត់គឺបាននិយាយតាំងពីដំបូងមក ។ ពូជពង្សរបស់សិមគឺជាពូជពង្សជ្រើសរើស ដែលយកមកនិយាយចុងក្រោយគេ នៅក្នុងជិពូក (សូមមើល ២:១-៣១ ១១:១០,២៦) ។ មាន១៤ អំបូរមកពីគ្រួសារយ៉ាផែត ៣០អំបូរមកពីគ្រួសារហាំ ២៦អំបូរមកពីគ្រួសារសិម និងមានជាង៧០អំបូរផ្សេងៗទៀត ពហុគុណ១០គុណ៧លេខទាំងពីរគឺជាចំនួនដែលគ្រប់លក្ខណ៍ (សូមមើល ៥:៥) ប្រហែលជា៧០អំបូរនោះមកពីគ្រួសារលោកយ៉ាកុប ដែលត្រឡប់មកអេស៊ីព្ទ (សូមមើល ៤៦:២៧ នក ១:៥ ចទ ៣២:៨) ។

**១០:៣** *អ័សក្នាស* គឺជា"ស៊ីតឌៀន"បន្ទាប់ទៀត ។ ឈ្មោះមនុស្សទាំង៣នៅក្នុងខនេះ គឺសំដៅទៅលើឈ្មោះមនុស្សដែលរស់នៅក្នុងតំបន់អ៊ើប្រាតខាងលើ ។

**១០:៤** *អេលីសា* គឺដូចគ្នានឹង"ឡាស់សៀ"ជាឈ្មោះដើមរបស់(Cyprus) ។ ឬមួយសំដៅលើ (Sicil) ដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសអ៊ីតាលី ។ *តើស៊ីស* ប្រហែលស្ថិតនៅភាគខាងត្បូងនៃប្រទេសអេស្ប៉ាញ ។ *គីទីម* គឺជាមនុស្សមួយក្រុមដែលរស់នៅក្នុងតំបន់ សាយប្រុស ។ *ដូដានីម* ឈ្មោះនេះប្រហែលជាផ្តោតទៅលើ (Rhodes) ជាកោះមួយរបស់ប្រទេសក្រិក ។

**១០:៥** សូមមើលក្នុង ខ.២០,៣១ ។ *តាមស្រុក . . . តាមភាសា . . . តាមគ្រួ* ភូមិសាស្ត្រ ជាតិសាសន៍នយោបាយ ភាសាគឺស្ថិតនៅលើតំបន់ដែលគេរស់នៅរៀងៗខ្លួន ។ មានពូជអំបូរ២ ឬ៣បានរស់នៅ ក្នុងតំបន់ផ្សេងៗគ្នា ។

**១០:៦** *ហាំ* កូនចៅរបស់ហាំទាំងប៉ុន្មានដែលមានឈ្មោះក្នុងទីនេះជាអ្នករស់នៅក្នុងតំបន់ភាគខាងត្បូងឈាងខាងលិច នៃទ្វីបអាស៊ីនិងខាងជើងឈាងខាងកើតនៃទ្វីបអាហ្វ្រិច ។ គូសគឺជាអ្នករស់នៅតំបន់ទន្លេនីលខាងលើភាគខាងត្បូងនៃប្រទេសអេស៊ីព្ទ ។ *មីសរ៉ែម* មានន័យថា "អេស៊ីព្ទទាំង២" (គឺសំដៅភាគខាងលើខាងត្បូង នឹងភាគខាងក្រោមភាគខាងជើង) ក្នុងប្រទេសអេស៊ីព្ទ ។ *ពូត* គឺជាលីបយ៉ាហុន (សូមមើលការពន្យល់ ខ.១៣) ឬក៏ជាដី ដែលជាកន្លែងពួកអេស៊ីព្ទស័មមុនរស់នៅដែលមានឈ្មោះថា"ផុន" (Punt) គឺជាទីក្រុងទាន់សម័យមួយ ។ កាណានឈ្មោះនេះគឺមានន័យថា "ទឹកដីពណ៌ស្វាយ"សម្រាប់ភាសាក្រិកគឺមានន័យថាទឹកន្លែងទូទៅ ។ កាណានគឺជាទីកន្លែងមួយ ក្នុងការផលិតលក្ខពណ៌ស្វាយសម្រាប់ជ្រលក់សំលៀកបំពាក់ ។ ហើយទទួលបានពានរង្វាន់ពីព្រះមហាក្សត្រ ។ ទឹកដីនេះត្រូវបានគេហៅថាបាលេស្ទីនក្រោយមកទៀតគឺពួកភីលីស្ទីន (មើល ខ.១៤) ។

**១០:៧** *កូនរបស់គូស* អំបូរទាំង៧នៅទីនេះគឺសំដៅលើពួកអ្នកដែលរស់នៅក្នុងរ៉ាប៊ីត ។ សេបានឹងដេដានឈ្មោះរបស់ពួកគេដូចគ្នានឹងអ្នកដទៃទៀតប្រហែលជាឃើញមាននៅក្នុងឈ្មោះចៅរបស់លោកអ័ប្រាហាំទាំងពី(មើលក្នុង ២៥:៣) ។ ឈ្មោះពួកទាំងពីនេះនឹងរ៉ាម៉ាគឺមាននិយាយក្នុងអេសេគាល ២៧:២០-២២ ។

**១០:៨** *គូស* ប្រហែលជាមិនមែនជាគូសនៅក្នុងខ.៦ នោះទេ ។ ពួកគេរស់នៅក្នុងតំបន់មេសូប៉ូតា ហើយឈ្មោះនេះប្រហែលជាទាក់ទងគ្នាទៅនិងឈ្មោះ "កាសស៊ីត" (kassites) ។ *នីមរ៉ុឌ* ឈ្មោះដូចគ្នានឹងឈ្មោះរបស់អ្នកដឹកនាំជនជាតិហេព្រើរម្នាក់ជាអ្នកគ្រប់គ្រងលើអាកាឌដំបូងគេ (សូមមើល ខ.១០) ។

**១០:១០** *អេរេក* ក្នុងព្រះគម្ពីរភាសាហេព្រើរ "យ៉ូរ៉ុក"(Uruk) គឺជាទីក្រុងមួយដ៏មានសារៈសំខាន់ សម្រាប់ពួកមេសូប៉ូតាមាសម័យបុរាណ ។

**១០:១២** *ទីក្រុងនោះធំណាស់* អាចជាទីក្រុង "កាឡាស់" (Calah) ។ ប៉ុន្តែវាដូចគ្នាច្រើនជាមួយនិងនីនីវេជាង(យណ ១:២ ៣:២ ៤:១១)។ *ទីក្រុងទាំងពីរ* គឺស្ថិតនៅដាច់ពីគ្នា ឬស្ថិតនៅជិវិញតំបន់ "យ៉ូបាន" (Urban)ទាំងមូលតែម្តង ។

**១០:១៣** *លូឌីម* ប្រហែលជាប្រទេសដ៏ធំមួយ (Lydains) ស្ថិតក្នុងប្រទេសអាស៊ីមីន័រ (សូមមើលការពន្យល់ ខ.២២) ។ *អ័ណាមីម* ស្ថិតនៅភាគខាង

ហាប៊ីម ពួកណាបធូហ៊ីម ¹⁴ពួកប៉ាទ្រូស៊ីម ពួកកាសលូហ៊ីម
(ដែលពួកភីលីស្ទីន[ឡ]កើតពីពួកនោះមក) ហើយពួកកាប់-
ថោរីម[អ] ។
១៥ ឯកាណាន[ក]គាត់បង្កើតស៊ីដូន[ខ]ជាកូនច្បង[គ] និងហេតដែរ[ឃ]
១៦ ព្រមទាំងពួកយេប៊ូស[ង] ពួកអាម៉ូរី[ច] ពួកគេកាស៊ី[ឆ]
១៧ ពួកហេវី[ជ] ពួកអើគី ពួកស៊ីនី ១៨ ពួកអើវ៉ាឌីត[ឈ] ពួក
សេម៉ារីត និងពួកហាម៉ាធីត[ញ] រួចក្រោយមក អស់ទាំងគ្រួ
ពួកកាណាន[ដ]ក៏បែកគ្នាសុសសាយ ១៩ ឯព្រំស្រុកនៃពួក
កាណាន[ឋ] គឺចាប់តាំងពីស៊ីដូន[ឌ] ទៅខាងកេរ៉ា[ឍ] ហើយតាម
កាសា[ណ]ទៅខាងសូដុំម កូម៉ូរ៉ា អាត់ម៉ា និងសេបោម[ត] រហូត
ដល់ឡាសារ ២០ នោះហើយជាពូជហាំតាមគ្រួតាមភាសា
នៅអស់ទាំងស្រុកនិងនគររបស់គេ ។

## កូនរបស់សិម

*១០:២១–៣១– លប ១១:១០–២៧ ១រប ១:១៧–២៧*

២១ ឯសិម ដែលជាឪពុកនៃពួកកូនចៅហេប៊ើរ[ថ] ហើយ
ជាបងយ៉ាផែត នោះក៏មានកូនដែរ ២២ ឯកូនរបស់សិម
គឺអេឡាំ[ទ] អាសស៊ើរ[ធ] អើប៉ាក់សាឌ[ន] លូឌ និងអើរ៉ាម[ប]
២៣ កូនរបស់អើរ៉ាម គឺអ៊ុស[ផ] ហ៊ុល កេធើរ និងម៉ាស ២៤ អើ

**១០:១៤** ឡ លប ២១:៣២, ៣៤ ២៦:១៨ យស ១៣:២ ពច ៣:៣ អស ១៤:៣១ យរ ៤៧:១, ៤ អម ៩:៧ អ ចទ ២:២៣ ១រប ១:១២ **១០:១៥** ក លប ៩:១៨ ខ ខ.១៩ យស ១១:៨ ពច ១០:៦ អស ២៣:២,៤ យរ ២៥:២២ ២៧:៣ ៤៧:៤ អគ ២៨:២១ ៣២:៣០ យអ ៣:៤ សក ៩:២ គ នក ៤:២២ ជន ១:២០ ៣:២ ១៨:១៥ ២៦:៥ ៣៣:៤ ឃ លប ១៥:២០ ២២:៣,២០ ២៥:១០ ២៦:៣៤ ៣:៤៦ ៤៩:៣២ ជន ១៣:២៩ យស ១:៤ ១សយ ២៦:៦ អគ ១៦:៣ **១០:១៦** ង ពច ១៩:១០ ១រប ១១:៤ច នក ៣:៨ ជន ១៣:២៩ ២១:១៣ ៣២:៣៩ ចទ ១:៤ យស ២:១០ ២រប ៨:៧ ឆ លប ១៥:១៨–២១ ចទ ៧:១ **១០:១៧** ជ លប ៣៤:២ ៣៦:២ នក ៣:៨ ចទ ៧:១ ពច ៣:៣ **១០:១៨** ឈ អគ ២៧:៨ ញ ១រប ១៨:៣ ដ លប ១២:៦ ១៣:៧ ៥០:១១ នក ១៣:១១ ជន ១៣:២៩ ១៤:២៥ ២១:៣ ៣៣:៤០ ចទ ១:៧ ពច ១:១ **១០:១៩** ឋ លប ១១:៣១ ១២:១ ១៣:១២ ១៧:៨ ២៤:៣ ២៦:៣៤ ២៧:៤៦ ២៨:១,៦,៨ ៣១:១៨ ៣៥:៦ ៣៧:១ លវ ២៥:៣៨ ឌ ខ.១៥ លប ៤៩:១៣ យស ១៩:២៨ ពច ១:៣១ ១៨:២៨ ២សយ ២៤:៦ ឍ ២រប ១៤:១៣ ណ ចទ ២:២៣ យស ១០:៤១ ១១:២២ ១៥:៤៧ ពច ១:១៨ ៦:៤ ១៦:១,២១ ១សយ ៦:១៧ យរ ២៥:២០ ៤៧:១ អម ១:៦ សផ ២:៤ ត លប ១៤:២ ចទ ២៩:២៣ **១០:២១** ថ ខ.២៤ ជន ២៤:២៤ **១០:២២** ទ លប ១៤:១ អស ១១:១១ ២១:២ យរ ២៥:២៥ ៤៩:៣៤ អគ ៣២:២៤ ដយ ៨:២ ធ ជន ២៤:២២,២៤ អគ ២៧:២៣ ន លក ៣:៣៦ ប ពច ៣:១០ ១ពវ ១១:២៥ ១៩:១៥ ២០:៣៤ ២២:៣១ ២ពវ ៥:១ ៨:៧ **១០:២៣** ផ លប ២២:២១ យប ១:១ យរ ២៥:២០ បទ ៤:២១

ជើងនៃទ្វីបអាហ្វ្រិចភាគខាងលិចនៃប្រទេសអេស៊ីព្ទ ក្បែរទីក្រុង"ស៊ីរ៉ែន" (Cyrene) ។ លេហាប៊ីមប្រហែលជាពួកពូជអំបូររស់ក្នុងតំបន់ទីរហោស្ថាន "លីបយ៉ាន" (Libyan) (សូមមើលការពន្យល់ ខ.៦) ។ *ណាបធូហ៊ីម* គឺជាពួកមនុស្សរស់នៅក្នុងប្រទេសអេស៊ីព្ទភាគខាងក្រោម ។

**១០:១៤** *ពួកប៉ាទ្រូស៊ីម* គឺជាអ្នកស្រុករស់នៅក្នុងប្រទេសអេស៊ីព្ទភាគខាងលើ (សូមមើលការពន្យល់ ខ.៦)។ *កាលលូហ៊ីម* គឺជាកោះមួយដែលមានឈ្មោះថាកោះក្រេត កោះនេះជាកន្លែងមួយដែលពួកភីលីស្ទីនបានរស់នៅជាក្រុមផ្សេងៗគ្នា (មើល យរ ៤៧:៤ អម ៩:៧) ។ ពួកភីលីស្ទីនគេរឹងប៉ឹងមាំមួនឡើងនៅក្នុងតំបន់ឥណ្ឌូអឺរ៉ុបរស់នៅជិតសមុទ្រ ហើយបានឈ្លានពានចូលប្រទេសអេស៊ីព្ទកាលពីដើមសតវត្សរ៍ទី១២មុន គ.ស ។ បន្ទាប់ពីបានបណ្ដេញចេញមកពួកគេជាច្រើនបានផ្លាស់ទីលំនៅ មករស់នៅក្នុងតំបន់និរតីនៃប្រទេសកាណានក្រោយនោះមក ពួកគេបានពង្រីកកូនចៅរបស់ពួកគេឱ្យរស់នៅ ស្ទើរតែពាសពេញផ្ទៃប្រទេសតែម្ដង ។ ប្រវត្តិកាលរបស់ពួកភីលីស្ទីន (សូមមើល ២១:៣២,៣៤ ២៦:១៨,១៤,១៥–១៨) គឺពួកគេបានតាំងលំនៅដ្ឋានមុនរួចជាស្រេចនៅក្នុងប្រទេសកាណាន ហើយបានទទួលនូវសន្តិភាពនិងរស់នៅជាក្រុមតូចៗ ។

**១០:១៥** *ស៊ីដូន* គឺជាទីក្រុងជំនួញដ៏សំខាន់មួយដែលស្ថិតនៅទិសពាយព្យនៃឆ្នេរសមុទ្រក្នុងប្រទេសកាណាន ។*ហេត* គឺក្រុមមនុស្សដែលរស់នៅក្នុងតំបន់ឥណ្ឌូអឺរ៉ុបដែលបានផ្លាស់ទីលំនៅពីទិសអាគ្នេយ៍ទ្វីបអឺរ៉ុបនាសហស្សវត្សទី៣ មុន គ.ស ហើយចូលមកក្នុងតំបន់អាណាតូបុរាណ គឺជាតំបន់ទំនើបភាគខាងលិចនៃប្រទេសទួរគី ។ ពួកគេបានគ្រប់គ្រងភាគខាងជើងនៃតំបន់កណ្ដាលក្នុងតំនប់អាណាតូលៀរ នៅក្នុងពាក់កណ្ដាលសហស្សវត្សទី២ មុន គ.ស ហើយពួកគេបានហៅខ្លួនឯងថា ពួកហេតគឺពួកគេបានយកលំនាំតាមឈ្មោះរបស់ជនជាតិដើម ។ ពួកគេបានទទួលសិទ្ធិអំណាចគ្រប់គ្រាន់នៅពេលមានជម្លោះរវាងបាប៊ីឡូននឹងអេស៊ីព្ទ ។ ទំនាក់ទំនងរវាងពួកហេត ឬជាមួយអ្នកផ្សេងទៀតនៅក្នុងប្រទេសកាណាន គឺមាននៅក្នុងព្រះគម្ពីរដទៃទៀតដែលការនេះមិនច្បាស់លាស់ទេ (សូមមើល អស ១៦:៣ និងការពន្យល់)។

**១០:១៦** *យេប៊ូស* រស់នៅក្នុងទីក្រុងយេរូសាឡិមក្នុងកំឡុងពេលដែលមានជម្លោះរវាងអ៊ីស្រាអែលនឹងពួកកាណាន ។ តាមប្រវត្តិសាស្ត្រទីក្រុងយេរូសាឡិមត្រូវបានគេស្គាល់ថាជាទីក្រុងយេប៊ូស(មើលក្នុង ចទ ១៩:១០–១១,១រប ១១:៤) ។ *អាម៉ូរី* ឈ្មោះនេះមកពីភាសា "អាកាឌៀន" (Akkadian) ដែលមានន័យថា "ពួកបច្ចិមប្រទេស"(ទស្សនៈវិស័យរបស់ពួកបាប៊ីឡូន) ។ ជនជាតិអាម៉ូរីរស់នៅលើភ្នំក្នុងប្រទេសកាណាននាពេលមួយដែលប្រជាជនអ៊ីស្រាអែលមានជម្លោះ ។

**១០:១៧–១៨** មនុស្សក្នុងជំពូកទាំង២ប្រភេទនេះហើយ និងគេកាស៊ី(ខ.១៦) គឺជាក្រុមមនុស្សដែលរស់នៅក្នុងតំបន់ដ៏តូចក្នុងចំណោមតំបន់ផ្សេងៗទៀតរបស់ប្រទេសកាណាន ។

**១០:១៩** *សូដុំម កូម៉ូរ៉ា អាត់ម៉ា និងសេបោម* សូមមើល ១៤:២៨ និងការពន្យល់ ១៣:១០ ។ ទីកន្លែងទាំងនេះប្រហែលជាស្ថិតនៅខាងកើត ឬទិសអាគ្នេយ៍នៃសមុទ្រស្លាប់ ។

**១០:២១** *នោះក៏មានកូនដែរ* ឪពុកនៃសិមគឺត្រូវហៅថាពួកសិម (Shemit) ដែលក្រោយមកទៀតគឺសឹម (Semite) ។ *ហេប៊ើរ* គេគិតថាគាត់គឺជាបងប្អូនសាច់ឆ្ងាយជាមួយសិម(មើល ខ.២៤,២៥ ១១:១៤,១៧) ។ សារៈសំខាន់របស់ហេប៊ើរ គឺគាត់ជាឪពុកនៃពួកហេព្រើរ "ហេប៊ើរ" គឺជាភាសាដើមរបស់ "ហេព្រើរ" ។

**១០:២២** *អេឡាំ* សាសន៍នេះរស់នៅក្នុងតំបន់ខាងកើតនៃពួកមេសូប៉ូតាមា ។ *អាសស៊ើរ* គឺជាឈ្មោះដើមរបស់ពួកអាស៊ើរី (សូមមើល ២:១៤) ដែលស្ថិតនៅតំបន់ខាងជើងនៃពួកមេសូប៉ូតាមា ។ អើប៉ាក់សាឌ សូមមើល ១១:១០–១៣ ។ គឺប្រហែលជាការក្លាយមកពីការបញ្ចូលគ្នានៃភាសាហេព្រើរ "ឆាលដៀរ" (Chaldea)ដែលស្ថិតនៅភាគខាងត្បូងនៃពួកមេសូប៉ូ តាមា ។ *លូឌ* ប្រហែលជាតំបន់ដ៏ធំមួយដែលស្ថិតនៅក្នុងអាស៊ីមីន័រ (សូម មើល ខ.១៣) ។ *អើរ៉ាម* ស្ថិតនៅភាគខាងជើងនៃស្រុកកាណានដែលជា ប្រទេសស៊ើរីសព្វថ្ងៃនេះ ។

**១០:២៤** *សេឡា* សូមមើល ១១:១២–១៥ ។

ប៉ាក់សាឌគាត់បង្កើតសេឡា ហើយសេឡាបង្កើតហេប៊ើរ[ត]
២៥ហេប៊ើរនោះបង្កើតបានកូនប្រុស២ មួយឈ្មោះផាលេក
ដ្បិតនៅជាន់អ្នកនោះផែនដីបានបែកគ្នា ហើយប្អូនគាត់
ឈ្មោះយ៉ុកថាន ២៦ឯយ៉ុកថាន គាត់បង្កើតអាល់ម៉ូដាឌ
សេលែប ហាសាម៉ាវែត យេរ៉ា ២៧ហាដូរ៉ាម អ៊ូសាល[ភ]
ឌិកឡា ២៨អូបាល អ័ប៊ីម៉ែល សេបា[ម] ២៩អូភារ[យ] ហាវីឡា
និងយ៉ូបាប់ នោះសុទ្ធតែជាកូនរបស់យ៉ុកថាន ៣០ឯទីលំនៅ
របស់គេ គឺចាប់តាំងពីមេសាទៅខាងសេផាជាភ្នំដែលនៅ
ខាងកើត ៣១នោះហើយជាពួកកូនរបស់សិមតាមគ្រួ តាម
ភាសា តាមអស់ទាំងស្រុក និងនគររបស់គេ ៣២នោះសុទ្ធតែ
ជាគ្រួទាំងប៉ុន្មានរបស់ពួកកូនចៅណូអេ[រ] តាមពូជដំណនៅ
នគរគេ គឺជាពួកអ្នកទាំងនោះហើយ ដែលបានបែក
ខ្ញែកគ្នា ចេញទៅជាសាសន៍ផ្សេងៗ នៅផែនដី[ល] ក្រោយទឹក
ជន់លិច ។

## ប៉មបាបិល

**១១** ១រីឯនៅផែនដីទាំងមូល នោះមានភាសាមានសំដី[ក]
តែ១ទេ ២ហើយកំពុងដែលគេដើរដំណើរនៅស្រុកខាង
កើត នោះក៏ប្រទះឃើញវាល១នៅស្រុកស៊ីណើរ[ខ] ហើយគេ
នាំគ្នាតាំងទីលំនៅនៅទីនោះ ។
៣គេនិយាយគ្នាទៅវិញទៅមកថា ចូរយើងធ្វើឥដ្ឋ[គ]ដុត
ឱ្យឆ្អិនទៅ នោះគេមានឥដ្ឋទុកជាថ្ម[ឃ] និងជ័រដី[ង]ទុកជា
បាយអ ៤រួចនិយាយគ្នាថា ចូរយើងសង់ទីក្រុង១សំរាប់
យើង និងប៉ម១ ដែលខ្ពស់ដល់ផ្ទៃមេឃ[ច] ដើម្បីឱ្យយើងបាន
កេរ្តិ៍ឈ្មោះ[ឆ] ក្រែងយើងរាល់គ្នាត្រូវខ្ចាត់ខ្ចាយ[ជ]ទៅគ្រប់
លើផែនដីទៅ[ឈ] ៥នោះព្រះយេហូវ៉ាទ្រង់យាងចុះមក[ញ]
ដើម្បីទតមើលទីក្រុង ហើយនិងប៉មដែលពួកមនុស្សជាតិ

**១០:២៤** ត ខ.២១ លក ៣:៣៥ **១០:២៧** ភ អគ ២៧:១៩ **១០:២៨** ម ១ពវ ១០:១ យប ៦:១៩ ទដ ៧២:១០, ១៥ អស ៦០:៦ អគ ២៧:២២ **១០:២៩** យ ១ពវ ៩:២៨ ១០:១១ ១រប ២៩:៤ យប ២២:២៤ ២៨:១៦ ទដ ៤៥:៩ អស ១៣:១២ **១០:៣២** រ ខ.១ ល លប ៩:១៩ **១១:១** ក ខ.៦ **១១:២** ខ លប ១០:១០ **១១:៣** គ នក ១:១៤ ៥:៧ យរ ៤៣:៩ ឃ អស ៩:១០ អម ៥:១១ ង លប ១៤:១០ **១១:៤** ច ចទ ១:២៨ ៦:១០ ៩:១ យប ២០:៦ យរ ៥១:៥៣ ៦:៤ ឆ ចទ ៣០:៣ ១ពវ ២២:១៧ នអ ៣:៨ ទដ ៤៤:១១ យរ ៣១:១០ ៤០:១៥ អគ ៦:៨ យអ ៣:២ ឈ លប ៩:១៩ ចទ :២៧ **១១:៥** ញ ខ.៧ លប ១៨:២១ នក ៣:៨ ១៩:១១,១៨,២០ ទដ ១៨:៩ ១៤៤:៥

**១០:២៥** *ផាលេក* សូមមើលការពន្យល់ ១១:១៦,១៩ ។ ផែដីបានបែកគ្នា ប្រហែលជាលទ្ធផលនៃការបែកខ្ញែកគ្នារបស់មនុស្ស ដែលបានពិពណ៌នា ១១:១–៩ ។

**១០:២៦** *យ៉ុកថាន* ជាពួកអ្នកស្លាប់ដ៏ច្រើននាសម័យមុនដែលស្ថិតក្នុងប្រទេសអារ៉ាបេន (Arabain) ភាគខាងត្បូង ។

**១០:២៨** *សេបា* ស្ថិតនៅទិសនិរតីនៃប្រទេស "អារ៉ាបា" (Araba) ដូចគ្នានិងតំបន់ "យីមិន"(Yemen) ក្រោយមកទៀតព្រះមហាក្សត្រីនៃស្រុកសេបា បានបង្កើតអនុស្សាវរីយ៍ ដោយការយាងសួរសុខទុក្ខស្តេចសាឡូម៉ូននៅសតវត្សរ៍ទី១០ មុន គ.ស (សូមមើល ១ពវ ១០:១–៣) ។

**១០:២៩** *អូភារ* គឺជាប្រភពមាសដ៏មហាសាល របស់ស្តេចសាឡូម៉ូន (មើល ១ពវ ៩:២៨ ១០:១១) ។ ទីកន្លែងនេះហាក់បីដូចជាស្ថិតនៅភាគត្បូងនៃស្រុកកាណានប្រហែលមួយផ្នែកនៃប្រទេសនេះស្ថិតនៅក្នុងទ្វីបអាហ្វ្រិច ឬស្ថិតនៅខាងត្បូងនៃប្រទេសអារ៉ាបៀ (សូមមើល ១ពវ ៩:២៨) ។

**១១:១–៩** នៅក្នុងផ្នែកនេះបានផ្តល់ឱ្យយើង នូវហេតុផលសំខាន់ៗរបស់មនុស្សមួយចំនួនដែលបាននិយាយក្នុងជំពូកទី១០ ។ ផ្ទៃរឿងនេះបានបង្ហាញនូវគំរូដ៏ល្អអំពីការត្រឡប់ឬការសាងសង់នូវនាឡិកាខ្សាច់មួយ (សូមមើលសេចក្តីផ្តើម) ។ អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិបានលើកយករឿងទឹកជន់និងប៉មបាបិល ដើម្បីពិពណ៌នាអំពីរបៀបដែលមនុស្សប្រព្រឹត្តជាមួយព្រះ នឹងការឆ្លើយតបរបស់ព្រះ ចំពោះមនុស្សតាមរយៈសកម្មភាពនៃការជំនុំជម្រះរបស់ទ្រង់ក្នុងគោលបំណងបំបាក់អំនួតរបស់មនុស្ស ដែលគេមានបំណងចង់ត្រួតត្រាពិភពលោកនិងការបង្កើតរបស់ទ្រង់ មិនមែនតំណាងនូវសេចក្តីស្មោះត្រង់របស់ព្រះឡើយ ប៉ុន្តែពួកគេមានការប្រឆាំងបះបោរចំពោះព្រះវិញ ។ អត្តចរិតអំនួតរបស់មនុស្សបានធ្វើឱ្យគេស្ថិតនៅក្រៅការសង្គ្រោះរបស់ព្រះ ជាហេតុធ្វើឱ្យអ្នកនិពន្ធបានលើកយកអំពីការត្រាស់ហៅរបស់ព្រះចំពោះលោកអាប់រ៉ាម ដែលគាត់ស្ថិតនៅក្រោយជំនាន់ប៉មបាបិល ដើម្បីបង្ហាញអំពីកិច្ចការសង្គ្រោះ ដែលបានបង្ហាញក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល ។

**១១:១** *ផែនដីទាំងមូល* អ្នកដែលរស់នៅពីទឹកជន់នឹងព្យុះកោរបស់ពួកគេ (ខ.៤ ៨–៩) ។

**១១:៣** *នោះគេមានឥដ្ឋទុកជាថ្ម និងជ័រដីទុកជាបាយអ* ថ្មនិងបាយអគឺជាវត្ថុធាតុដើមដែលអ្នកស្រុកកាណានបានយកវាមកប្រើប្រាស់ ដើម្បីសាងសង់សំណង់ ។ នៅក្នុងតំបន់មេសូប៉ូតាមា គឺជាថ្មកម្រមានណាស់តែទោះបីជាយ៉ាងណាក៏ដោយ ក៏គេអាចមានឥដ្ឋនិងបាយអសម្រាប់ប្រើប្រាស់ដែរ គឺបានរៀបរាប់តាមរយៈការធ្វើកំណាយ ។

**១១:៤** *យើង . . . សំរាប់យើង . . . យើង . . . យើង* គំរោងការណ៍របស់មនុស្សទាំងនេះ គឺអត្តទត្តបុគ្គលនឹងមានអំនួត ។ *ប៉ម* គឺតាមបែបផែនរបស់ពួកមេសូប៉ូតាមា ដែលគេស្គាល់ថាជាជណ្តើរដ៏ខ្ពស់មួយ (ziggurat) ដែលផ្ទៃក្រោមមានរាង៤ជ្រុង ហើយមានរាងទេមានជណ្តើរនៅខាងដែលអាចឱ្យយើងឡើងទៅលើបានគឺកន្លែងទីសការៈនៅកំពូល ។ *ខ្ពស់ដល់ផ្ទៃមេឃ* ប្រហែលដូចគ្នានិងជណ្តើរដែលបាននិយាយក្នុង ២៨:១២ ពួកមេសូប៉ូតាមាផ្សេងទៀត ។ ជណ្តើរត្រូវគេបានឱ្យឈ្មោះផ្ទុយពីនេះគឺមានន័យថាជណ្តើរដែលអាចបម្រើពីផែនដីរហូតដល់ផ្ទៃមេឃ ។ "ផ្ទះដែលបានភ្ជាប់រវាងស្ថានសួគ៌នឹងផែនដី"នៅឡាសា (Larsa) "ផ្ទះនៃអ្នកនាំផ្លូវទាំង៧" នៅក្នុងបូស៊ីផា (Borsippa) ផ្ទះនៃគ្រឹះពីស្ថានសួគ៌មកផែនដី"នៅបាប៊ីឡូន" ផ្ទះនៃភ្នំនៅលើពិភពលោក"នៅអាសសើរ ។ ឈ្មោះនៅក្នុងសញ្ញាចាស "ឈ្មោះ"គឺសំដៅទៅលើកិត្តិនាមឬកេរ្តិ៍ឈ្មោះ ។ មនុស្សមានមាឌធំ គឺជាអ្នកមានកេរ្តិ៍ឈ្មោះល្បី ៦:៤ ។ នៅឯបាបិល (មើល ខ.៩) មនុស្សដែលបះបោរតស៊ូព្យាយាមជាក្រុមមួយ នឹងគ្មានជំនឿលើព្រះដោយខិតខំកសាងប៉មនេះដោយកម្លាំងគេផ្ទាល់តាមរយៈការធ្វើជាសហគ្រាសធំមួយ ធ្វើឱ្យកន្លែងនោះក្លាយជាកន្លែងដែលមានឈ្មោះល្បី ដោយសារគេប្រឆាំងនឹងការបង្កើតរបស់ទ្រង់(មើល ១០:៨–១២ ២សយ ១៨:១៨)។ *ខ្ចាត់ខ្ចាយ* មើល ខ.៨ ។

កំពុងធ្វើ ៦រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល គេ
ជាពួកតែ១ ក៏និយាយភាសាតែ១[ដ]គេចាប់ផ្តើមធ្វើអំពើ
យ៉ាងដូច្នេះហ្ន៎ ឥឡូវនេះ គ្មានអ្វីនឹងឃាត់មិនឱ្យគេធ្វើកើត
តាមបំណងចិត្តនោះទេ ៧ចូរយើង[ឋ]ចុះ[ឌ]ទៅបំភាន់ភាសាគេ
ដើម្បីកុំឱ្យគេស្តាប់គ្នាបានទៀត[ឍ] ៨ដូច្នេះព្រះយេហូវ៉ាទ្រង់
កំចាត់កំចាយគេ ពីទីនោះទៅគ្រប់លើផែនដីវិញ[ណ]ហើយ
គេក៏លែងសង់ទីក្រុងនោះទៅ ៩ដោយហេតុនោះ បានជា
គេហៅឈ្មោះក្រុងនោះថាបាបិល[ត] ពីព្រោះនៅទីនោះ
ព្រះយេហូវ៉ាទ្រង់ បានបំភាន់ភាសា[ថ]លោកិយទាំងអស់[ទ]
ហើយកំចាត់កំចាយ[ធ]គេពីទីនោះទៅគ្រប់លើផែនដី ។

## ចាប់ពីសិមដល់អាប់រ៉ាម

*១១:១០-២៧ – លប ១០:២១-៣១ ១រប ១:១៧-២៧*

១០នេះជាបញ្ជីដំណវង្ស[ន]របស់សិម គឺក្រោយទឹកជន់២ឆ្នាំ
កាលសិមអាយុបាន១០០ឆ្នាំហើយ នោះគាត់បង្កើតបាន
អើប៉ាក់សាឌ[ប] ១១ក្រោយដែលបង្កើតអើប៉ាក់សាឌមកនោះ
គាត់រស់នៅ៥០០ឆ្នាំទៀត ទាំងបង្កើតបានកូនប្រុសកូនស្រី ។
១២អើប៉ាក់សាឌអាយុបាន៣៥ឆ្នាំ នោះគាត់បង្កើតបាន
សេឡា[ផ] ១៣ក្រោយដែលបង្កើតសេឡាមក នោះគាត់រស់នៅ
៤០៣ឆ្នាំទៀត ទាំងបង្កើតបានកូនប្រុសកូនស្រី ។
១៤សេឡាអាយុបាន៣០ឆ្នាំ នោះគាត់បង្កើតបានហេ
បើរ[ព] ១៥ក្រោយដែលបង្កើតហេបើរមក នោះគាត់រស់នៅ
៤០៣ឆ្នាំទៀត ទាំងបង្កើតបានកូនប្រុសកូនស្រី ។
១៦ហេបើរអាយុបាន៣៤ឆ្នាំ នោះគាត់បង្កើតបានផា
លេក[ភ] ១៧ក្រោយដែលបង្កើតបានផាលេកមក នោះគាត់
រស់នៅ៤៣០ឆ្នាំទៀត ទាំងបង្កើតបានកូនប្រុសកូនស្រី ។
១៨ផាលេកអាយុបាន៣០ឆ្នាំ នោះគាត់បង្កើតបានរេហ៊ូវ[ម]
១៩ក្រោយដែលបង្កើតរេហ៊ូវមក នោះគាត់រស់នៅ២០៩ឆ្នាំ
ទៀត ទាំងបង្កើតបានកូនប្រុសកូនស្រី ។
២០រេហ៊ូវអាយុបាន៣២ឆ្នាំ នោះគាត់បង្កើតបានសេរូក[យ]
២១ក្រោយដែលបង្កើតសេរូកមក នោះគាត់រស់នៅ២០៧
ឆ្នាំទៀត ទាំងបង្កើតបានកូនប្រុសកូនស្រី ។
២២សេរូកអាយុបាន៣០ឆ្នាំ នោះគាត់បង្កើតបានណាឃរ[រ]
២៣ក្រោយដែលបង្កើតណាឃរមក នោះគាត់រស់នៅ២០០
ឆ្នាំទៀត ទាំងបង្កើតបានកូនប្រុសកូនស្រី ។
២៤ណាឃរអាយុបាន២៩ឆ្នាំ នោះគាត់បង្កើតបានថេរ៉ា[ល]
២៥ក្រោយដែលបង្កើតថេរ៉ាមក នោះគាត់រស់នៅ១១៩ឆ្នាំ
ទៀត ទាំងបង្កើតបានកូនប្រុសកូនស្រី ។
២៦ថេរ៉ាអាយុបាន៧០ឆ្នាំ រួចគាត់បង្កើតបានអាប់រ៉ាម[វ]
ណាឃរ[ស] និងហារ៉ាន[ហ] ២៧នេះជាដំណវង្ស[ឡ]របស់ថេរ៉ា។

**១១:៦** ដ ខ.១ **១១:៧** ឋ លប ១:២៦ ឌ ខ.៥ ឍ លប ៤២:២៣ ចទ ២៨:៤៩ អស ២៨:១១ ៣៣:១៩ យរ ៥:១៥ ១កថ ១៤:២,១១ **១១:៨** ណ លប ៩:១៩ ចទ ៣២:៨ លក ១:៥១ **១១:៩** ត លប ១០:១០ ថ ទដ ៥៥:៩ ទ កច ២:៥-១១ធ អស ២:១០, ២១ ១៣:១៤ ២៤:១ **១១:១០** ន លប ២:៤ ប លក ៣:៣៦ **១១:១០** ន លប ២:៤ ប លក ៣:៣៦ **១១:១២** ផ លក ៣:៣៥ **១១:១៤** ព លក ៣:៣៥ **១១:១៦** ភ លប ៣:៣៥ **១១:១៨** ម លក ៣:៣៥ **១១:២០** យ លក ៣:៣៥ **១១:២២** រ លក ៣:៣៤ **១១:២៤** ល លក ៣:៣៤ **១១:២៦** វ លក ៣:៣៤ ស យស ២៤:២ ហ ២ពវ ១៩:១២ អស ៣៧:១២ អគ ២៧:២៣ **១១:២៧** ឡ លប ២:៤ អ ខ.២៩

**១១:៦** *មើល . . . ឥឡូវនេះ* បើសិនជាមនុស្សគ្រប់ពូជសាសន៍ទាំងអស់នៅតែខំប្រឹងពុះពារលើវាសនារបស់គេដោយសារដៃផ្ទាល់ខ្លួន ដើម្បីបំពានប្រវត្តិសាស្ត្រ ពួកគេនិងមិនអាចបញ្ឈប់នូវការបះបោរប្រឆាំងជាមួយព្រះឡើយ ។ នគរដែលមិនកោតខ្លាចព្រះត្រូវតែបំផ្លាញហើយដាក់មកវិញនូវនគរព្រះ ។

**១១:៧** *ចូរយើង* សូមមើលការពន្យល់ ១:១,២៦ ព្រះយេហូវ៉ា "ចូរយើង" ទ្រង់បានយាងមកពីស្ថានសួគ៌ ដើម្បីជំទាស់ជាមួយនឹងសេចក្តីអំនួតរបស់មនុស្សដោយបន្ទូលថា "ចូរយើង" (ខ.៤) ឱ្យចេញពីផែនដី ។ ដើម្បីកុំឱ្យគេស្តាប់គ្នាបានទៀត វាមិនមែនជាពាក្យបែបមិនគួរសមនោះឡើយ ខ.៨ ។

**១១:៨** *កំចាត់កំចាយ* សូមមើល ខ.៤ ៩:១,១៩ ។ ព្រះយេហូវ៉ាទ្រង់កំចាត់គេឱ្យបែកខ្ញែកដោយព្រោះតែការបះបោរ និងសេចក្តីអំនួតរបស់គេ ។ ទោះបីជាមនុស្សមានអំណាចខ្លាំងក្លាយ៉ាងណាក៏ដោយ ក៏មិនអាចបំពានលើព្រះអម្ចាស់ ហើយពួកគេក៏មិនអាចរស់នៅបានយូរនោះឡើយ ។

**១១:៩** *បាបិល* សូមមើល ១០:១០ ។ ពាក្យនេះមកពីភាសាអាកាឌែន ដែលមានន័យថា "ផ្លូវចូលទៅឯព្រះ" ជណ្តើររបស់យ៉ាកុបអាចហៅថា "ជណ្តើរនៃនគរស្ថានសួគ៌" (សូមមើល ២៨:១៧) ។ *បំភាន់* នៅក្នុងភាសាហេព្រើរទីនេះគេប្រើពាក្យ "បាបិល" ស្តាប់ទៅគឺប្រហាក់ប្រហែលនឹង "បាបិល" ដែលជាភាសាដើមនៃភាសាហេព្រើរថា បាប៊ីឡូន និងភាសាដើមនៃភាសាអង់គ្លេសគឺ "បាបិល" ។

**១១:១០-២៦** បញ្ជីតំណវង្សទាំង១០នេះ គឺដូចគ្នានឹងតំណវង្សសេតដែរ (សូមមើល ៥:៣,៣១ និង ៥:៥) មិនដូចជាពួកកូនចៅរបស់សេតឡើយ តែទោះបីជាយ៉ាងណាក៏ដោយ ក៏តំណវង្សរបស់សិមមិនបានផ្តល់ឱ្យយើង នូវចំនួនអាយុពិតប្រាកដនៅពេលដែលពួកគេស្លាប់នោះឡើយ ហើយនៅចុងបញ្ចប់អត្ថបទក៏មិនបាននិយាយថា "ហើយគាត់ក៏ស្លាប់ទៅ" ។ សិមបានគ្រប់គ្រងលើស្រុកក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ មិនមែនដូចជាអ័ប្រាហាំនោះឡើយ ។

**១១:១០** បញ្ជីតំណវង្ស សូមមើល ២:៤ ។

**១១:២៦** *ថេរ៉ា . . . គាត់បង្កើតបានអាប់រ៉ាម ណាឃរ និងហារ៉ាន* នៅក្នុងហេតុការណ៍នេះដូចជាសេត ហាំ ហើយនិងយ៉ាផែត ឈ្មោះរបស់អ្នកទាំងបីនេះប្រហែលជាមិនស្ថិតនៅក្នុងតំណវង្សរហូតអស់មួយជីវិតគេនោះទេ (សូមមើល ៩:២៤ ១០:២១ និងការពន្យល់) ។ *ហារ៉ាន* គាត់ស្លាប់នៅពេលដែលឪពុកនៅរស់នៅឡើយ (មើល ខ.២៨) ។

**១១:២៧-២៥:១១** ការត្រាស់ហៅរបស់ព្រះចំពោះលោកអាប់រ៉ាម ចេញពីមនុស្សនៅឯប៉មបាបិល គឺជារឿងមួយដែលនិយាយពីផ្លូវរបស់ព្រះជាមួយមនុស្ស ត្រូវបានផ្លាស់ប្តូរដោយចាប់ផ្តើមពីប្រវត្តិសាស្ត្រផែនដី និងប្រវត្តិនៃទំនាក់ទំនងរបស់ព្រះជាមួយនឹងមនុស្ស ពិសេសនឹងបណ្តាជនទាំងឡាយ ។ នៅទីនេះគឺចាប់ផ្តើមពីការងារសង្គ្រោះចំពោះមនុស្សមានបាប មិនមែនតែការជំនុំជម្រះដោយសារ (ទឹកជន់) ឬប្រឆាំងប៉ម (បាបិល) នោះឡើយ ប៉ុន្តែគឺបង្ហាញពីការអត់ទោសតាមរយៈការថ្វាយដង្វាយឱ្យធួននិងបាប ហើយនិង

បង្កើតអាប់រ៉ាម ណាឃរ[អ] និងហារ៉ាន ហើយហារ៉ាន
បង្កើតឡុត[ក] ២៨រួចហារ៉ាន គាត់ស្លាប់ចំពោះមុខថេរ៉ា
ជាឪពុកនៅក្រុងអើរក្នុងស្រុកខាល់ដេ[ខ] ជាស្រុកកំណើត
របស់គាត់ទៅ ២៩អាប់រ៉ាម និងណាឃរ[គ]ក៏យកប្រពន្ធ ឯ
ប្រពន្ធរបស់អាប់រ៉ាម នោះឈ្មោះសារ៉ាយ[ឃ] ហើយប្រពន្ធ
របស់ណាឃរឈ្មោះមីលកា[ង] ជាកូនហារ៉ាន ដែលជាឪពុក
មីលកា និងយីសកា ៣០ឯសារ៉ាយ នាងជាស្ត្រីអារគ្មានកូន
សោះ[ច]។

៣១ថេរ៉ាគាត់យកអាប់រ៉ាម កូនគាត់ឡុត[ឆ]ជាកូនហារ៉ាន
ត្រូវជាចៅគាត់ ហើយសារ៉ាយជាកូនប្រសា[ជ] គឺប្រពន្ធ
អាប់រ៉ាមកូនគាត់នាំគ្នាចេញពីអើរស្រុកខាល់ដេ[ឈ] ដើម្បីនិង
ទៅឯស្រុកកាណាន[ញ] លុះបានទៅដល់ខារ៉ាន[ដ]ហើយ នោះ
ក៏តាំងទីលំនៅនៅទីនោះ ៣២អាយុថេរ៉ា[ឋ]បាន២០៥ឆ្នាំរួច
ក៏ស្លាប់នៅត្រង់ខារ៉ានទៅ ។

## ការត្រាស់ហៅលោកអាប់រ៉ាម

**១២** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងអាប់រ៉ាមថា ចូរ
ឯង ចេញពីស្រុក ពីញាតិសន្តាន និងពីផ្ទះ[ក]ឪពុកឯងទៅនៅ
ឯស្រុក[ខ]ដែលអញនឹងបង្ហាញឯងចុះ[គ] ២អញនឹងបង្កើតនគរ១
យ៉ាងធំ[ឃ]ពីឯង អញនឹងឱ្យពរដល់ឯង[ង] ទាំងលើកឈ្មោះ
ឯងជាធំផង ឯងនឹងបានធ្វើជាទីបញ្ចេញពរដល់មនុស្ស
ទាំងឡាយ[ច] ៣អញនឹងឱ្យពរដល់អស់អ្នកណាដែលឱ្យពរដល់
ឯង ហើយនិងដាក់បណ្តាសា ដល់អស់អ្នកណាដែលផ្តាសា

លប ៣១:៥៣ ក ខ.៣១ លប ១២:៤ ១៣:១,៥,៨,១២ ១៤:១២ ១៩:១ លក ១៧:២៨ ២ពត ២:៧ **១១:២៨** ខ ខ.៣១ លប ១៥:៧ នហ ៩:៧ យប ១:១៧ ១៦:១១ អគ ២៣:២៣ កច ៧:៤ **១១:២៩** គ ខ.២៧, ៣១ លប ២២:២០, ២៣ ២៤:១០,១៥, ២៤ ២៩:៥ ឃ លប ១២:៥,១១ ១៦:១ ១៧:១៥ ង លប ២២:២០ **១១:៣០** ច លប ១៦:១ ១៨:១១ ២៥:២១ ២៩:៣១ ៣០:១,២២ ពច ១៣:២ ១សយ ១:៥ ទដ ១១៣:៩ លក ១:៧,៣៦ **១១:៣១** ឆ ខ.២៧ ជ លប ៣៨:១១ លវ១៨:១៥ ២០:១២ នរ ១:៦,២២ ២:២០ ៤:១៥ ១សយ ៤:១៩ ១របា ២:៤ អគ ២២:១១ មីក ៧:៦ ឈ ខ.២៨ ញ លប ១០:១៩ ដ ខ.២៩ លប ១២:៤ ២៧:៤៣ ២៨:៥,១០ ២៩:៤ ២ពវ ១៩:១២ អគ ២៧:២៣ **១១:៣២** ឋ យស ២៤:២ **១២:១** ក លប ២០: ១៣ ២៤:៤,២៧,៤០ ខ លប ១០:១៩ គ លប ១៥:៧ ២៦:២ យស ២៤:៣ កច ៧:៣ ហេព១១:៨ **១២:២** ឃ លប ១៣: ១៦ ១៥:៥ ១៧:២,៤ ១៨:១៨ ២២:១៧ ២៦:៤ ២៨:៣,១៤ ៣២:១២ ៣៥: ១១ ៤១:៤៩ ៤៦:៣ ៤៧:២៧ ៤៨:៤, ១៦,១៩ នក ១:៧ ៥:៥ ៣២:១៣ ចទ ១:១០ ១០:២២ ១៣: ១៧ ២៦:៥ យស ១១:៤ ២៤:៣ ២សយ ១៧:១១ ១ពវ ៣:៨ ៤:២០ ១របា ២៧:២៣ ២របា ១:៩ នហ ៩: ២៣ ទដ ១០៧:៣៨ អស ៦:១៣ ១០:២២ ៤៨:១៩ ៥១:២ ៥៤: ៣ ៦០:២២ យរ៣៣: ២២ មីក ៤:៧ង លប ២៤:១,៣៥ ២៥: ១១ ២៦:៣ ២៨:៤ នក ២០: ២៤ជន២២:១២ ២៣:៨,២០ ២៤:៩ ទដ ៦៧:៦ ១១៥:១២ អស ៤៤:៣ ៦១:៩ ៦៥:២៣ មឡ ៣:១២ ច លប ២២:១៨ អស ១៩:២៤ យរ ៤:២ ហក ២:១៩ សក ៨:១៣

ការខិតខំប្រឹងតាមរយៈការបន្សុសចិត្តមនុស្ស ។ នៅក្នុងជីពូកទាំងមូលបានលាតត្រដាងអំពីប្រវត្តិសាស្ត្រនេះប្រៀបដូចជាការខិតខំរកអំបោះមាស ។ លទ្ធផលចុងក្រោយគឺបានធ្វើឱ្យយើងដឹងថា គឺមានតែព្រះយេស៊ូវគ្រីស្ទតែមួយប៉ុណ្ណោះ (មើល លក ៣:៣៣ មថ ១:១១៧ កទ ៣:១៦) គឺជាព្រះរាជសារដ៏សំខាន់នៅក្នុងសញ្ញាថ្មី ។ តំណវង្សរបស់ព្រះនិងលោកអាប់រ៉ាមបានរកឃើញទំនាក់ទំនងនៅទីនេះ គឺជាប្រថ្នូលមួយថា ព្រះទ្រង់មានមធ្យោបាយជាច្រើនដើម្បីទាក់ទងជាមួយអ៊ីស្រាអែល ហើយការសាកល្បងព្រមទាំងទទួលជ័យជម្នះនៃសេចក្តីជំនឿរបស់លោកអាប់រ៉ាម បានធ្វើឱ្យគាត់ក្លាយជាអ្នកដែលមានសេចក្តីជំនឿដ៏ល្អសម្រាប់កូនចៅរបស់លោក ។

**១១:២៧** *តំណវង្ស* សូមមើល ២:៤ ។

**១១:២៨** *ក្រុងអើរក្នុងស្រុកខាល់ដេ* ស្ថិតនៅភាគខាងជើងនៃតំបន់មេសូប៉ូតាមាប៉ុន្តែ ភាគច្រើនគេថាស្ថិតនៅតំបន់អើប្រ៉ាតភាគខាងត្បូងនៃប្រទេសអ៊ីរ៉ាក់ជាប់និងតំបន់ (LeonardWoolley) ចន្លោះឆ្នាំ ១៩២២ នឹង ១៩៣៤ ។ សំណល់បាក់បែកនឹងវត្ថុបុរាណបង្ហាញអំពីអរិយ្យធម៌ នឹងវប្បធម៌របស់ក្រុងអើរ ដែលមានតាំងពីមុនសម័យលោកអាប់រ៉ាមមកម្លេះ ព្រះមហាក្សត្រប្រហែលរស់នៅក្នុងជំនាន់លោកអាប់រ៉ាម គាត់គឺជាមហាក្សត្រដែលល្បីល្បាញដោយសារតែក្បួនច្បាប់របស់គាត់ល្អដាច់គេ ។ ស្រុកខាល់ដេ (សូមមើល អរ ៥:១២ យប ១:៧) ។

**១១:៣០** *ឯសារ៉ាយនាងជាស្ត្រីអារ* ជាប្រពន្ធដែលមិនអាចបង្កើតកូនឱ្យលោកអាប់រ៉ាម (មើល ១៥:២១ ១៧:១) ។ កត្តាពិតមួយបានបង្ហាញថារាស្ត្ររបស់ព្រះមិនអាចមានកូនតាមធម្មជាតិសម្រាប់មនុស្សដែលស្ថិតក្រោយរឿងប៉មបាបិលនោះឡើយ ។ ព្រះអម្ចាស់បាននាំមនុស្សជាថ្មីតាមរយៈលោកអាប់រ៉ាម (មើល ១៧:៥) ដូចគ្នានឹងលោកអ័ដាមនឹងលោកណូអេដែលជាឪពុករបស់មនុស្សដែលធ្លាក់ចុះដែរ ។

**១១:៣១** *លុះបានដល់ខារ៉ានហើយ* ក្នុងព្រះគម្ពីរភាសាហេព្រើរ ឈ្មោះរបស់ទីក្រុងគឺសរសេរខុសពីអ្វីដែល បងប្រុសរបស់លោកអាប់រ៉ាមសរសេរ (មើល ខ.២៦)។ ព្រះខែត្រូវបានគេនាំគ្នាថ្វាយបង្គំទាំងនៅទីក្រុងអើរទាំងទីក្រុងខារ៉ាន ហើយនៅគ្រានេះថេរ៉ាគាត់ជាអ្នកគោរពថ្វាយបង្គំរូបព្រះ (មើល យស ២៤:២) គាត់ប្រហែលជាចាកចេញពីផ្ទះ ហើយទៅរស់កន្លែងផ្សេងទៀត ។ ខារ៉ាន់បានក្លាយជាទីក្រុងទេសចរណ៍ដ៏ល្បីល្បាញនាសតវត្សរ៍ទី១៩ មុន គ.ស ។ នៅសតវត្សរ៍ទី១៨ មុន គ.ស ទីក្រុងនេះត្រូវបានគ្រប់គ្រងដោយពួកអាម៉ូរី (មើល ១០:១៦) ។

**១២:១** *មានបន្ទូល* ព្រះយេហូវ៉ាទ្រង់បានមានបន្ទូលមកកាន់លោកអាប់រ៉ាម "ក្នុងខណៈពេលដែលគាត់រស់នៅក្នុងស្រុក មេសូប៉ូតាមា (Mesopotamia) គឺជាកន្លែងមួយដែលគាត់រស់នៅ មុនពេលមករស់នៅស្រុកហារ៉ាន" (កច ៧:២) ។ *ចេញពីស្រុក . . . អញនឹងបង្ហាញឯងចុះ* លោកអាប់រ៉ាម ត្រូវតែចាកចេញពីលំនៅដ្ឋានលោកិយដែលបានកើតឡើងដោយសារប្រជាជាតិបាបិល ហើយចាប់ផ្តើមដើរជាមួយព្រះ គឺជាកន្លែងដ៏ប្រសើ១ ដែលព្រះយេហូវ៉ា ទ្រង់បានបង្កើតឡើង (មើល ២៤:៧ ហព ១១:១០ ១១:១–៩) ។

**១២:២–៣** សេចក្តីសន្យារបស់ព្រះចំពោះលោកអាប់រ៉ាម គឺមាន៧ចំណុចសំខាន់ៗ: (១) "អញនឹងបង្កើតនគរមួយយ៉ាងធំពីឯង" (២) "អញនឹងឱ្យពរដល់ឯង" (៣) "ទាំងលើកឈ្មោះឯងជាធំផង" (៤) "ឯងនិងបានធ្វើជាទីបញ្ចេញពរដល់មនុស្សទាំងឡាយ" (៥) "អញនឹងឱ្យពរដល់អ្នកណាដែលឱ្យពរដល់ឯង" (៦) "ហើយនិងដាក់បណ្តាសាដល់អ្នកដែលផ្តាសាឯង" (៧) "គ្រប់ទាំងគ្រួរនៅផែនដីនឹងបានពរដោយសារឯង" ។ ការប្រទានពររបស់ព្រះយេហូវ៉ាជាលើកដំបូងដល់មនុស្សទាំងអស់ (មើល ១:២៨) អាចជាព្រះពរពិសេសសម្រាប់តែអាប់រ៉ាម និងកូនចៅរបស់គាត់តែប៉ុណ្ណោះ ។ សេចក្តីសន្យាដែលមានកម្រិត និងមានលក្ខណៈផ្សេងៗគ្នា ដែលព្រះយេហូវ៉ា

៤អាប់រ៉ាមក៏ចេញទៅ ដូចជាព្រះយេហូវ៉ាបានបង្គាប់ ឡុត[ឈ]
ក៏ទៅជាមួយដែរ កាលអាប់រ៉ាមចេញពីខារ៉ានទៅ[ញ] នោះ
គាត់អាយុបាន៧៥ឆ្នាំហើយ[ដ] ៥ក៏យកសារ៉ាយ[ឋ]ជាប្រពន្ធ
និងឡុតជាក្មួយ ព្រមទាំងរបស់ទ្រព្យទាំងប៉ុន្មាន ដែលបាន
ប្រមូលទុក[ឌ]និងមនុស្សទាំងអស់[ឍ] ដែលបានកាលនៅខារ៉ាន
ផង នាំគ្នាចេញពីទីនោះ ដើម្បីទៅឯស្រុកកាណាន[ណ] ក៏ចូល
ទៅក្នុងស្រុកនោះ ។
៦អាប់រ៉ាម គាត់ដើរកាត់ស្រុក[ត]ទៅត្រឹមដើមម៉ៃសាក់
របស់ម៉ូរេ[ថ]នៅកន្លែង១ឈ្មោះស៊ីគែម[ទ] ដែលនៅវេលា
នោះសាសន៍កាណាន[ធ]នៅស្រុកនោះដែរ ៧ព្រះយេហូវ៉ា
ទ្រង់លេចមកឱ្យអាប់រ៉ាមឃើញ[ន] ហើយមានបន្ទូលថា
អញនឹងឱ្យស្រុកនេះដល់ពូជឯង[បផ] រួចនៅទីនោះគាត់ក៏
ស្អាងអាសនា១ថ្វាយព្រះយេហូវ៉ា[ព] ដែលទ្រង់លេចមកឱ្យ
ឃើញនោះ ៨គាត់ចេញពីទីនោះទៅឯភ្នំនៅខាងកើត
បេត-អែល[ភ] ក៏ដំឡើងត្រសាល[ម] នៅឯណោះ មានបេត-
អែលនៅជាខាងលិច និងអៃយ[យ]នៅខាងកើត ហើយស្អាង
អាសនា១ ថ្វាយព្រះយេហូវ៉ានៅទីនោះដែរ រួចអំពាវនាវ
ដល់ព្រះនាមព្រះយេហូវ៉ា[រ] ៩អាប់រ៉ាមក៏ចេះតែដើរដំណើរ
ទៅ ឯត្បូងទៀត[ល] ។

**លោកអាប់រ៉ាមនៅស្រុកអេស៊ីព្ទ**

*១២:១០-២០ - លប ២០:១-១៨ ២៦:១-១១*

១០នៅស្រុក[វ]នោះកើតមានអំណត់អត់ ហើយអាប់រ៉ាមចុះ

**១២:៣** ឆ លប ២៧:២៩ នក ២៣:២២ ជន ២៤:៩ ចទ ៣០:៧ ជ លប ១៥:៥ ១៨:១៨ ២២:១៨ ២៦:៤ ២៨:៤,១៤ ចទ ៩:៥ ទដ ៧២:១៧ អស ១៩:២៥ កច ៣:២៥ កទ ៣:៨ **១២:៤** ឈ លប ១១:២៧ ញ លប ១១:៣១ ដ លប ១៦:៣,១៦ ១៧:១, ១៧, ២៤ ២១:៥ **១២:៥** ឋ លប ១១:២៩ ឌ ខ.១៦ លប ១៣:២,៦ ៣១:១៨ ៤៦:៦ ឍ លប ១៤:១៤ ១៥១៧:២៣ សស ២:៧ ណ លប ១១:៣១ ១៦:៣ ហព ១១:៨ **១២:៦** ត ហព ១១:៩ ថ លប ៣៥:៤ ចទ ១១:៣០ យស ២៤:២៦ ពច ៧:១ ៩:៦ ទ លប ៣៣:១៨ ៣៧:១២ យស ១៧:៧ ២០:៧ ២៤:១ ពច ៨:៣១ ២១:១៩ ១ពវ ១២:១ ទដ ៦០:៦ ១០៨:៧ ធ លប ១០:១៨ **១២:៧** ន លប ១៧:១ ១៨:១ ២៦:២ ៣៥:១ នក ៦:៣ កច ៧:២ ប នក ៣:៨ ជន ១០:២៩ ចទ ៣០:៥ ហព ១១:៨ ផ លប ១៣:១៥,១៧ ១៥:១៨ ១៧:៨ ២៣:១៨ ២៤:៧ ២៦:៣-៤ ២៨:៣-៤ ២៨:១៣ ៣៥:១២ ៤៨:៤ ៥០:២៤ នក ៦:៤,៨ ១៣:៥,១១ ៣២:១៣ ៣៣:១ ជន ១១:១២ ចទ ១:៨ ២:៣១ ៩:៥ ១១:៩ ៣៤:៤ ២ពវ ២៥:២១ ១របា ១៦:១៦ ២របា ២០:៧ ទដ ១០៥:៩-១១ យរ ២៥:៥ អគ ៤៧:១៤ កច ៧:៥ រម ៤:១៣ កទ ៣:១៦ ព លប ៨:២០ ១៣:៤ **១២:៨** ភ លប ១៣:៣ ២៨:១១,១៩ ៣៥:១, ៨,១៥ យស ៧:២ ៨:៩ ១សយ ៧:៦១ ១ពវ ១២:២៩ ហស ១២:៤ អម ៣:១៤ ៤:៤ ម ២៦:២៥ ៣៣:១៩ ហព ១១:៩ យ យស ៧:២ ១២:៩ អរ ២:២៨ នហ ៧:៣២ យរ ៤៩:៣ រ លប ៤:២៦ ៨:២០ **១២:៩** ល លប ១៣: ១,៣ ២០:១ ២៤:៦២ ជន ១៣:១៧ ៣៣:៤០ ចទ ៣៤:៣ យស ១០: ៤០ **១២:១០** វ លប ៤១:២៧,៥៧ ៤២:៥ ៤៣:១ ៤៧:៤, ១៣ រម ១:១ ២សយ ២១:១ ២ពវ ៨:១ ទដ ១០៥:១៩ ស លប ៤១:៣០, ៥៤, ៥៦ ៤៧:២០ ទដ ១០៥:១៦

ទ្រង់បានសន្យានឹងលោកអាប់រ៉ាម (ខ.៧ ១៥:៥-២១ ១៧:៤-៨ ១៨:១៨-១៩ ២២:១៧-១៨) ទៅអ៊ីសាក់ (២៦:២-៤) ទៅយ៉ាកុប (២៨:១៣-១៥ ៣៥:១១-១២ ៤៦:៣) ហើយជាមួយលោកម៉ូសេ (នក ៣:៦-៨ ៦:២-៨) ។ សេចក្ដីសន្យាទី៣គឺបានដកស្រង់ចេញពី កច ៣:២៥ ដែលនិយាយសំដៅចំពោះអ្នកស្ដាប់លោកពេត្រុសទាំងប៉ុន្មាន ដែលជាជនជាតិយូដា (មើល កច ៣:១២) និយាយអំពីកូនចៅរបស់លោកអាប់រ៉ាមនៅ កទ ៣:៨ សំដៅលើសាសន៍ដទៃ ដែលជាអ្នកស្ដាប់លោកប៉ុលទាំងប៉ុន្មាន ដែលពួកគេជាវិញ្ញាណនៃកូនចៅលោកអាប់រ៉ាម ។

**១២:៤** *អាប់រ៉ាមក៏ចេញទៅដូចជាព្រះយេហូវ៉ាបានបង្គាប់* សូមមើល ហព ១១:៨ ។ នៅក្នុង១ជីវិតលោកអាប់រ៉ាម បានបង្ហាញនូវការស្ដាប់បង្គាប់ព្រះយ៉ាងទៀងទាត់ (មើល ១៧:២៣ ២១:១៤ ២២:៣) ។ *ឡុតក៏ទៅ ជាមួយដែរ* សូមមើល ១៣:១ និងខ.៥ ។ ឡុតត្រូវបានជ្រើសរើសឱ្យដើរជាមួយនឹងពូរបស់គាត់គឺលោកអាប់រ៉ាម ដើម្បីស្វែងរកជីវិតដែលប្រសើរសម្រាប់ថ្ងៃអនាគត ។ *៧៥ឆ្នាំហើយ* ទោះបីជាពេលដែលព្រះយេហូវ៉ាទ្រង់ត្រាស់ហៅលោកអាប់រ៉ាមពេលដែលគាត់មានអាយុច្រើនក៏ដោយ ក៏លោកអាចរស់នៅរហូតដល់សតវត្សរ៍បន្ទាប់ទៀតដែរ (មើល ២៥:៧ និង ៥:៥) ។

**១២:៥** *មនុស្សទាំងអស់ដែលបាន* ចំពោះអ្នកមាននាសម័យនោះគឺគេតែងតែមានអ្នកបម្រើការងាររបស់ពួកគេ ។ អ្នកខ្លះក្លាយជាខ្ញុំកញ្ជះ ហើយអ្នកខ្លះទៀតក្លាយជាអ្នកបម្រើតាមជម្រើស អ្នកទាំងអស់នោះត្រូវយកចិត្តទុកដាក់និងពិចារណា ដើម្បីឱ្យក្លាយជាសមាជិក "ក្នុងផ្ទះ" ក្នុងផ្នែកដែលគេបម្រើ (សូមមើល ១៤ :១៤ ១៥:៣ ១៧:១២-១៣ ២៤:២) ។

**១២:៦** *ដើមម៉ៃសាក់* ប្រហែលជាដូចគ្នានឹងដើមឈើដែលនិយាយក្នុង (៣៥:៤ និង ពច ៩:៦,៣៧) ។ *ម៉ៃសាក់* មានន័យថា "គ្រូ" ពួកកាណាននាំគ្នាស្វែងរកព្រះរបស់គេតាមរយៈដើមឈើនេះ ។ *ស៊ីគែម* គឺជាទីក្រុងដ៏មានសារៈសំខាន់របស់ស្រុកកាណាន ដែលបានកសាងឡើងដោយសារពួកមនុស្សជំនាន់មុន ។

**១២:៧** *ព្រះយេហូវ៉ាទ្រង់លេចមក* ការលេចមករបស់ព្រះយេហូវ៉ា នៅកន្លែងខ្លះជាលក្ខណៈព្យុះកោ និងលក្ខណៈផ្សេងៗទៀត ប៉ុន្តែមិនមែនគ្រប់យ៉ាងសុទ្ធតែជាសិរីល្អនោះទេ (នក ៣៣:១៨-២០ យហ ១:១៨) ។ *អាសនា* គឺជាអាសនាដំបូងក្នុងចំណោមអាសនា២ឬ៣ទៀត ដែលលោកអាប់រ៉ាមស្អាងឡើង (មើល ខ.៨ ១៣:១៨ ២២:៩) ។ គាត់ទទួលស្គាល់ថា ទឹកដីកាណាន គឺជាកម្មសិទ្ធិរបស់ព្រះនៅក្នុងលក្ខណៈពិសេសជាច្រើន (នក ២០:២៤ យស ២២:១៩) ។

**១២:៨** *បេតអែល* ស្ថិតនៅភាគខាងជើងនៃទីក្រុងយេរូសាឡិម វាគឺជាទីក្រុងសំខាន់មួយដែលនិយាយពីប្រវត្តិសាសនា និងរាស្ត្ររបស់ព្រះ (២៨:១០,២២ ៣៥:១-៨០ ១ពវ ១២:២៦-២៩) ។

**១២:៩** *ឯត្បូង* ជាកន្លែងដីស្ងួតហើយទុកចោលដែលលាតសន្ធឹងពីទិសខាងត្បូងមកដល់បេសសេបា ។ ព្រះគម្ពីរសាហេព្រើរប្រើពាក្យដែលប្រែថា "ខាងត្បូង" ១៣:១៤ ។

**១២:១០** *ចុះទៅសំណាក់នៅឯស្រុអេស៊ីព្ទវិញ . . . ដ្បិតអំណត់* ការផ្គត់ផ្គង់ស្បៀងនៅស្រុកអេស៊ីព្ទ គឺតែងតែគ្រប់គ្រាន់ជានិច្ច ពីព្រោះទឹកទន្លេនីល បានផ្គត់ផ្គង់គ្រប់គ្រាន់ និងផ្ដល់ទំនុកចិត្តយ៉ាងខ្លាំង ។ បទពិសោធន៍បន្ទាប់បន្សំរបស់លោកអាប់រ៉ាម បានក្លាយជាស្រមោលនៃបទពិសោធន៍របស់ពួកកូនចៅអ៊ីស្រាអែល នៅក្នុងស្រុកអេស៊ីព្ទដូចគ្នានឹងអ្វីដែលអ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិ បានបញ្ជាក់យ៉ាងច្បាស់បន្តទៀតនៅក្នុងព្រះគម្ពីរនិក្ខមនំ ។ ការប្រៀបធៀបនេះ បានធ្វើឱ្យយើងចាប់អារម្មណ៍ ដូច្នេះអំណត់ដែលកើតមាននៅក្នុងស្រុក (៤៧:៤) បានធ្វើឱ្យពួកគេមានការទុក្ខព្រួយ ដែលសេចក្ដីទុក្ខព្រួយនោះបណ្ដាលមកពីពួកអេស៊ីព្ទ (ខ.១២,១៥ នក ១:១១,១៤) ជាហេតុធ្វើ

ទៅសំណាក់នៅឯស្រុកអេស៊ីព្ទវិញ ដ្បិតអំណត់នៅស្រុក
កាណានបានខ្លាំងណាស់[ស] ១១កាលគាត់ជិតចូលទៅក្នុងស្រុក
អេស៊ីព្ទហើយ នោះគាត់និយាយទៅសារ៉ាយ[ហ]ជាប្រពន្ធថា
មើល អញដឹងថាឯងជាស្ត្រីមានរូបស្រស់ល្អ[ឡ] ១២កាលណា
ពួកសាសន៍អេស៊ីព្ទឃើញឯង នោះក្រែងគេនឹងនិយាយពី
ឯងថាជាប្រពន្ធអញ រួចគេនឹងសំឡាប់អញទៅ ហើយទុក
ឯងឱ្យរស់នៅវិញ ១៣ដូច្នេះចូរឯងប្រាប់គេថា ឯងជាប្អូន
អញទេ[អ] ដើម្បីឱ្យគេបានប្រព្រឹត្តល្អនឹងអញដោយព្រោះឯង
ហើយឱ្យអញមានជីវិតរស់នៅដោយសារឯងផង ។
១៤កាលអាប់រ៉ាមបានចូលទៅក្នុងស្រុកអេស៊ីព្ទហើយ
នោះពួកសាសន៍អេស៊ីព្ទឃើញថា ប្រពន្ធគាត់មានរូបស្រស់
ល្អមែន[ក] ១៥ចំណែកពួកនាម៉ឺនរបស់ផារ៉ោនក៏ឃើញនាង
ដែរ ហើយគេសរសើរពីនាងនៅចំពោះទ្រង់ រួចនាំទៅ
នៅឯព្រះរាជដំណាក់ទៅ ១៦ទ្រង់ក៏ប្រព្រឹត្តល្អនឹងអាប់រ៉ាម
ដោយព្រោះនាង ហើយគាត់បានហ្វូងចៀម ហ្វូងគោ និង
លាឈ្មោល លាញី ហើយនិងអូដ្ឋ ព្រមទាំងបាវប្រុសបាវ
ស្រី[ខ]ផង ១៧តែព្រះយេហូវ៉ាទ្រង់ធ្វើឱ្យផារ៉ោន និងអស់ពួក
ព្រះរាជដំណាក់[គ]កើតមានសេចក្ដីវេទនាជាខ្លាំង ដោយ
ព្រោះសារ៉ាយជាប្រពន្ធរបស់អាប់រ៉ាម ១៨រួចផារ៉ោនទ្រង់
ហៅអាប់រ៉ាមមកសួរថា តើឯងបានធ្វើអ្វីដល់អញដូច្នេះ[ឃ]
ហេតុអ្វីបានជាឯងមិនបានប្រាប់អញដោយត្រង់ថានាងជា
ប្រពន្ធឯង[ង] ១៩ម្ដេចក៏ឯងថាជាប្អូនវិញ[ច] ដើម្បីបើកឱកាសឱ្យ
អញបានយកនាងមកធ្វើជាប្រពន្ធដូច្នេះ នេះនែប្រពន្ធឯង
ហើយ ចូរយកនាងទៅវិញឥឡូវ ហើយចេញទៅចុះ ២០ផា
រ៉ោនក៏បង្គាប់ដល់ពួកទ្រង់ពីដំណើរគាត់ ហើយគេបញ្ជូន
គាត់ ព្រមទាំងប្រពន្ធ និងរបស់ទ្រព្យគាត់ទាំងអស់ឱ្យចេញ
ទៅ ។

## លោកអ័ប្រាហាំ និងលោកឡុតបែកគ្នា

**១៣** ១នោះអាប់រ៉ាមក៏ចេញពីស្រុកអេស៊ីព្ទ[ក] ឡើងទៅឯ
ស្រុកត្បូង[ខ] ព្រមទាំងប្រពន្ធនិងទ្រព្យសម្បត្តិទាំងអស់ហើយ
ឡុត[គ]ដែរ ២អាប់រ៉ាមគាត់មាន[ឃ]ហ្វូងសត្វ[ង] ហើយប្រាក់មាស
ជាច្រើនណាស់ ៣គាត់ដើរដំណើរពីស្រុកត្បូង[ច] រហូតទៅ
ដល់បេត–អែល[ឆ]ត្រង់កន្លែងដែលគាត់បានតំឡើងត្រសាល
កាលពីដើម គឺនៅកណ្ដាលបេត–អែលនិងអៃយ[ជ] ៤ជា
កន្លែងដែលគាត់បានស្អាងអាសនាកាលជាន់មុន[ឈ] រួចនៅទី
នោះអាប់រ៉ាមក៏អំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា[ញ] ។

**១២:១១** ហ លប ១១:២៩ ឡ ខ.១៤ លប ២៤:១៦ ២៦:៧ ២៩:១៧ ៣៩:៦ **១២:១៣** អ លប ២០:២ ២៦:៧ **១២:១៤** ក ខ.១១ **១២:១៦** ខ ខ.៥ លប ២៤:៣៥ ២៦:១៤ ៣០:៤៣ ៣២:៥ ៣៤:២៣ ៤៧:១៧ យប ១:៣ ៣១:២៥ **១២:១៧** គ ២ពវ ១៥:៥ យប ៣០:១១ អស ៥៣:៤,១០ ឃ ១របា ១៦:២១ ទដ ១០៥:១៤ ង អស ៤៣:២៧ ៥១:២ អគ ១៦:៣ **១២:១៩** ច លប ២០:៥ ២០:៩ **១៣:១** ក លប ៤៥:២៥ ខ លប ១២:៩ គ លប ១១:២៧
**១៣:២** ឃ លប ១២:៥ ២៦:១៣ សភ ១០:២២ ង លប ៣២:១៥ យប ១:៣ ៤២:១២ **១៣:៣** ច លប ១២:៩ ឆ លប ១២:៨ជ យស ៧:២ **១៣:៤** ឈ លប

ឱ្យព្រះយេហូវ៉ា ទ្រង់ខ្វាល់ចំពោះពួកអេស៊ីព្ទ (ខ.១៧ នក ៨:១១) ហើយលទ្ធផលចុងក្រោយ ពួកអេស៊ីព្ទបានបញ្ជូនមនុស្សទាំងអស់នោះឱ្យចេញទៅវិញ (ខ.១៩–២០ នក ១២:៣១–៣២) ពួកអេស៊ីព្ទបានអនុញ្ញាតឱ្យពួកអ៊ីស្រាអែល យកអ្វីដែលគេមានទៅជាមួយ (ខ.២០ នក ១២:៣២) ប្រជាជនអ៊ីស្រាអែលទទួលបានទ្រព្យសម្បត្តិជាច្រើន ពីប្រទេសអេស៊ីព្ទ (ខ.១៦ នក ១២:៣៦) ដូច្នេះពួកគេក៏នាំគ្នាវិលត្រឡប់ទៅស្រុកកាណានវិញ ឆ្លងកាត់ទីរហោស្ថាន (១៣:១–៣ និក្ខមនំ ជនគណនា ចោទិយកថា យ៉ូស្វេ) ពួកគេក៏ទៅដល់ស្រុកកាណានវិញ ជាទីកន្លែងដែលគេថ្វាយបង្គំព្រះយេហូវ៉ា (១៣:៤ យស ៥:១០ ៨:៣០–៣៥ ២៤:១២៧) ។ លោកអាប់រ៉ាមគឺជា "ឪពុក" នៃសាសន៍អ៊ីស្រាអែលយ៉ាងពិតប្រាកដ ។

**១២:១១** *កាលគាត់ជិតចូលទៅក្នុងស្រុកអេស៊ីព្ទហើយ* ការចាកចេញពីទឹកដីសន្យាដើម្បីស្វែងរកស្បៀងអាហារ នាពេលមានអំណត់នៅក្នុងស្រុក (នរ ១:១) ដោយគ្មានការដឹកនាំ ឬការយល់ព្រមមកពីព្រះឡើយ (មើល ៤៦:៣៤ ២ពវ ៨:១) អាប់រ៉ាមបានបង្ហាញថាគាត់ត្រូវតែទុកចិត្តចំពោះព្រះយេហូវ៉ា ដែលទ្រង់បានត្រាស់ហៅគាត់ ហើយបានសន្យាជាមួយនឹងគាត់ថា ព្រះយេហូវ៉ា ទ្រង់អាចនឹងផ្ដត់ផ្គង់ការពារគាត់ និងសារ៉ាយ (ខ.៣) ទោះបីជាគាត់ស្ថិតនៅក្រៅពីទឹកដីសន្យាក៏ដោយ (សូមមើល ជិពូក ២០) ។ ការខិតខំប្រឹងប្រែងរបស់លោកអាប់រ៉ាម គឺដើម្បីឱ្យបានទទួលនូវជ័យជម្នះនឹងសុវត្ថិភាពលើការខិតខំរបស់នាងសារ៉ាយ ដែលបានព្យាយាមយកឈ្នះលើភាពជាស្ត្រីអា (ជិពូក១៦) ។ មានរូបស្រស់ល្អ សូមមើលខ.១៤ ។ នៅពេលនោះនាងមានអាយុ ៦៥ឆ្នាំ (ខ.៤ ១៧:១៧) មានម្នាក់ឈ្មោះថា (pocryphon) បាននិយាយសរសើរចំពោះ រូបឆោមរបស់នាងសារ៉ាយ ។

**១២:១៣** *ចូរឯងប្រាប់គេថាឯងជាប្អូនអញទេ* បើសិនជាព្រះចៅផារ៉ោនបានយកនាងសារ៉ាយមកធ្វើជាស្រីស្នំម្នាក់ទៀតខណៈពេលដែលគាត់បានដឹងថាសារ៉ាយគឺជាប្រពន្ធរបស់លោកអាប់រ៉ាម នោះប្រហែលជាគាត់សម្លាប់លោកអាប់រ៉ាមមុន ។

**១២:១៥** *ផារ៉ោន* សូមមើលក្នុង នក ១:១១ ។

**១២:១៦** នៅសម័យបុរាណហ្វូងសត្វគឺមានសារៈសំខាន់ណាស់ដើម្បីបង្ហាញថាអ្នកណាមានទ្រព្យសម្បត្តិប៉ុន្មាន (សូមមើល ១៣:២) បាវប្រុសបាវស្រី មើល ខ.៥ ។ *អូដ្ឋ* ទោះបីជាសត្វអូដ្ឋ គេមិនប្រើវាពាសពេញពិភពលោកដូចជាសម័យក្រោយទៀតក៏ដោយ (សូមមើល ពច ៦:៥) ក៏អ្នកស្រាវជ្រាវវត្ថុបុរាណបាននិយាយថា វាគឺជាសត្វដែលពួកព្ទយុកោបានផ្សាំងវានាពេលមុនដែរ ។

**១២:១៩** *ម្ដេចក៏ឯងថាជាប្អូនវិញ* ប្រជាជនអេស៊ីព្ទគេគិតថាការនិយាយសេចក្ដីពិត គឺពិតជាមានសារសំខាន់ណាស់ តែលោកអាប់រ៉ាមគាត់បែជានិយាយកុហកវិញ ។

**១២:២០** *ផារ៉ោនក៏បង្គាប់* មើល នក ១២:៣១ ។

**១៣:១–៣** *ស្រុកត្បូង* មើល ១២:៩។

**១៣:២** *មានហ្វូងសត្វហើយប្រាក់មាស ជាច្រើនណាស់* នៅពេលលោកអាប់រ៉ាមចាកចេញពីស្រុកអេស៊ីព្ទ គាត់មានទ្រព្យជាច្រើនគឺច្រើនជាងមុនគាត់ចូលមកគឺដូចគ្នានឹងពួកកូនចៅអ៊ីស្រាអែលដែលចេញពីស្រុកអេស៊ីព្ទនៅពេលក្រោយៗទៀតដែរ (មើល នក ៣:២២ ១២:៣៦) ។

**១៣:៤** *អាប់រ៉ាមក៏អំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា* ពីមុនគាត់ក៏បានអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ានៅកន្លែងនេះដែរ (១២:៨)។

៥ឯឡុត[ដ]ដែលទៅជាមួយនឹងអាប់រ៉ាម គាត់ក៏មានហ្វូង
ចៀម ហ្វូងគោ និងត្រសាលជាច្រើនដែរ ៦តែស្រុកនោះ
មិនល្មមនឹងចិញ្ចឹមគេឱ្យនៅជាមួយគ្នាបានទេ ពីព្រោះគេ
មានទ្រព្យសម្បត្តិសន្ធឹកណាស់ ដល់ម៉្លេះបានជាគេនៅជា
មួយគ្នាពុំបាន[ឋ] ៧មួយទៀត ពួកគង្វាលរបស់អាប់រ៉ាម និង
ពួកគង្វាលរបស់ឡុតក៏ចេះតែប្រឈ្លោះគ្នា[ឌ] នៅវេលានោះ
ពួកសាសន៍កាណាន[ឍ] និងសាសន៍ពេរិស៊ីត[ណ]បាននៅស្រុក
នោះ[ត] ៨នោះអាប់រ៉ាមនិយាយទៅឡុតថា[ថ] សូមកុំឱ្យឯង
ហើយនិងអញ[ទ] ឬពួកគង្វាលរបស់ឯង និងពួកគង្វាលរបស់
អញមានរឿងទាស់ទែងគ្នាឡើយ ដ្បិតយើងជាបងប្អូននិង
គ្នា[ធ] ៩ស្រុកទាំងមូលនេះ តើមិនមែននៅមុខឯងទេឬអី
ដូច្នេះសូមឱ្យឯងញែកបែកចេញពីអញទៅ បើឯងរើសយក
ខាងឆ្វេង[ន] នោះអញនឹងទៅខាងស្តាំ ឬបើឯងរើសយកខាង
ស្តាំនោះអញនឹងទៅខាងឆ្វេងវិញ ១០ឡុតក៏ងើបភ្នែកមើល
ទៅឃើញវាល[ប]ទន្លេយ័រដាន់[ផ]ទាំងអស់ ថាជាស្រុកមាន
ទឹកស្រួលល្អនៅគ្រប់ទីកន្លែង មុនដែលព្រះយេហូវ៉ា[ព]បាន
បំផ្លាញសូដុំម[ភ] និងកូម៉ូរ៉ា[ម] គឺដូចជាសួនច្បារផងព្រះយេ
ហូវ៉ា ហើយដូចស្រុកអេស៊ីព្ទ[យ] ដែលនៅខាងសូអារផង[រ]
១១ដូច្នេះ ឡុតក៏រើសយកវាលទន្លេយ័រដាន់ទាំងអស់ ជា
របស់ផងខ្លួន រួចចេញដំណើរដើរទៅខាងកើត គេបាន
ឃ្លាតចេញពីគ្នាដូច្នោះឯង ១២ឯអាប់រ៉ាមគាត់តាំងទីលំនៅ
នៅក្នុងស្រុកកាណានវិញ[ល] តែឡុត[វ]គាត់ស្នាក់នៅអស់
ទាំងទីក្រុងនៅស្រុកវាលនោះ[ស]ហើយក៏ផ្លាស់ត្រសាលគាត់
ទៅត្រឹមសូដុំម[ហ] ១៣រីឯពួកក្រុងសូដុំម[ឡ] គេជាមនុស្ស
អាក្រក់ ធ្វើបាបនឹងព្រះយេហូវ៉ាយ៉ាងសន្ធឹក[អ] ។
១៤គ្រាក្រោយដែលឡុតបានឃ្លាតចេញទៅ នោះព្រះ
យេហូវ៉ាមានបន្ទូលនឹងអាប់រ៉ាមថា ចូរឯងងើបភ្នែកឡើង
ឥឡូវ ហើយមើលពីកន្លែងឯងនោះ ទៅខាងជើង ខាងត្បូង
ខាងកើត ហើយខាងលិចចុះ[ក] ១៥ដ្បិតស្រុកទាំងប៉ុន្មាន
ដែលឯងមើលឃើញ នោះអញនឹងឱ្យដល់ឯង និងពូជឯងជា
ដរាបតទៅ[ខ] ១៦អញនឹងធ្វើឱ្យពូជឯងបានចំរើនឡើងដូច

១២:៧ ញ លប ៤:២៦ **១៣:៥** ដ លប ១១:២៧ **១៣:៦** ឋ លប ១២:៥ ៣៣:៩ ៣៦:៧ **១៣:៧** ឌ លប ២៦:២០,២១ ឍ ជន ២០:៣ ណ លប ១០:១៨ ត លប ១៥:២០ ៣៤:៣០ ១៥:២០ ៣៤:៣០ នក ៣:៨ ពច ១:៤ ត លប ១២:៦ ៣៤:៣០ **១៣:៨** ថ លប ១១:២៧ ទ ទដ ១៥:១៨ ២០:៣ ធ លប ១៩:៩ នក ២:១៤ ជន ១៦:១៣ ទដ ១៣៣:១ **១៣:៩** ន លប ២០:១៥ ៣៤:១០ ៤៧:៦ យរ ៤០:៤ **១៣:១០** ប ១ពវ ៧:៤៦ ២រប ៤:១៧ ផ ជន ១៣:២៩ ៣៣:៤៨ ព លប ២:៨–១០ អស ៥១:៣ អគ ៣១:៨–៩ ភ ចទ ២៩:២៣ យប ៣៩:៦ ទដ ១០៧:៣៤ យរ ៤:២៦ ម លប ១៤:៨ ១៩:១៧–២៩ យ លប ៤៦:៧ រ លប ១៤:២ ១៩:២២,៣០ ចទ ៣៤:៣ អស ១៥:៥ យរ ៤៨:៣៤ **១៣:១២** ល លប ១០:១៩ វ លប ១:២៧ ស ខ.១០ លប ១៩:១៧ ២៥,២៩ ហ លប ១៤:១២ **១៣:១៣** ឡ លប ១៩:៤ អស ១:១០ ៣:៩ អ លប ១៨:២០ ១៩:៥ ២០:៦ ៣៩:៩ ជន ៣២:២៣ ១សយ ១២:២៣ ២សយ ១២:១៣ ទដ ៥១:៤ អគ ១៦:៤៩–៥០ ២ពត ២:៨ **១៣:១៤** ក លប ២៨:១៤ ៣២:១២ ៤៨:១៦ ចទ ៣:២៧ ១៣:១៧ អស ៥៤:៣ **១៣:១៥** ខ លប ១២:៧ លប ៣:១៦

**១៣:៥–១៨** ការបែកចេញរបស់ឡុតពីលោកអាប់រ៉ាម ហើយនិងជម្រើសរបស់គាត់ពីអ្វីដែលកើតមានឡើងដល់រូបគាត់ ធ្វើឱ្យគាត់អាចទទួលជោគជ័យលើការសម្រេចចិត្តក្នុងការទទួលយកទឹកដី ដែលមិនមែនជាចំណែកមរតកដែលជាព្រះពរនៃសេចក្តីសន្យាដែលព្រះសន្យាជាមួយលោកអាប់រ៉ាម ប្រសើរជាងគាត់ជាប់ទាក់ទងជាមួយពួកក្រុងសូដុំម និងកូម៉ូរ៉ា (១៤:១២–១៦ ១៩:១,៣៨) ជាកន្លែងដែលអាប់រ៉ាមទទួលនូវការធានាថាកូនចៅរបស់លោកនឹងទទួលបានមរកតនៅក្នុងស្រុកនេះទាំងមូល ហើយនិងមានគ្នាចម្រើនឡើង (ខ.១៥–១៧) ។

**១៣:៦** *តែស្រុកនោះមិនល្មម និងចិញ្ចិមគេឱ្យនៅជាមួយគ្នាបានទេ* ការដាក់ហ្វូងសត្វជាមួយគ្នាគឺជាផ្នែកមួយនៃទ្រព្យសម្បត្តិ ដ៏មហាសាលរបស់ពួកគេ ដូច្នេះហើយតំបន់ជុំវិញក្រុងបេត–អែល និងក្រុងអៃយមិនអាចមានទឹកហើយស្មៅគ្រប់គ្រាន់សម្រាប់ហ្វូងសត្វព្រមទាំងកន្លែងដ៏ធំបែបនេះបានឡើយ (មើល ខ.១០ ២៦:១៧–២២ ៣២ ៣៦:៧)។

**១៣:៧** *ពេរិស៊ីត* អត្តសញ្ញាណរបស់ពួកគេគឺមិនច្បាស់នោះឡើយ ប៉ុន្តែប្រហែលជាពួកគេរស់នៅក្នុងតំបន់ជនបទមួយដែលមានការផ្ទុយគ្នានិងអ្នកដែលរស់នៅក្នុងទីក្រុងនេះ ។

**១៣:៨** *បងប្អូន* គឺជាសាច់ញាតិតែងតែនិយាយជារឿយៗ (ក្នុងព្រះគម្ពីរ) ។

**១៣:៩** *ខាងឆ្វេង . . . ខាងស្តាំ* កន្លែងនេះគឺចង់និយាយថា *ខាងជើង . . . ខាងត្បូង* ។ ជានិច្ចកាលលោកអាប់រ៉ាមគាត់ចិត្តល្អណាស់ គឺគាត់បានផ្តល់ឱកាសឱ្យក្មួយប្រុសរបស់គាត់ ជ្រើសរើសយកទឹកដីដែលគាត់ចង់បាន ។ លោកអាប់រ៉ាម ខ្លួនគាត់ផ្ទាល់មិនចង់បានទ្រព្យសម្បត្តិឡើយ លើកលែងតែព្រះប្រទានពរឱ្យ (១៤:២២–២៤)។

**១៣:១០** *វាល* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះនពិពណ៌នាថា តំបន់នេះមានរាងមូលទ្រវែងដូចជាពងក្រពើ ។ តំបន់"វាល"ហើយនិង"ទីក្រុង" (ខ.១២) នេះគឺនៅតែមានការជជែកវែកញែកនៅឡើយ ។ ហេតុផលមួយគួឱ្យជឿបាននិយាយថា ទីកន្លែងទាំង២នេះគឺស្ថិតនៅទិសពាយព្យនៃសមុទ្រស្លាប់ ។ ដូចស្រុកអេស៊ីព្ទ ពីព្រោះតំបន់នេះសំបូរទឹកហើយអាចទុកចិត្តបាន (១២:១០) អេស៊ីព្ទអាចប្រៀបទៅនិងសួនច្បាអេដែន (២:១០) ។ ព្រះយេហូវ៉ាបានបំផ្លាញក្រុងសូដុំមនិងកូម៉ូរ៉ាជាពិសេស មើល ១៨:១៦ ១៩:២៩ ។ ក្រុងសូដុំម និងកូម៉ូរ៉ា បានក្លាយជាសុភាសិតមួយដែលគ្មានតម្លៃពោរពេញដោយអំពើអាក្រក់ហើយព្រះយេហូវ៉ា ទ្រង់បានជំនុំជម្រះទីក្រុងនេះដោយព្រោះតែអំពើបាប ។

**១៣:១២** *ឡុត . . . ហើយក៏ផ្លាស់ត្រសាលគាត់ទៅត្រឹមសូដុំម* នៅពេលដែលដឹងថាមនុស្សទាំងអស់នៅក្រុងសូដុំមប្រព្រឹត្តអំពើបាប ខ.១៣ ឡុតបែរជាចង់ផ្លាស់លំនៅរបស់គាត់មករស់នៅជិតក្រុងសូដុំមដែលផ្ទុយពីលោកអាប់រ៉ាមវិញ (ខ.១៨) ។

**១៣:១៤** *ចូរឯងងើបភ្នែកឡើងឥឡូវហើយមើលពីកន្លែងឯងនោះ* សូមមើល ចទ ៣៤:១៤ ឡុតហើយនិងអាប់រ៉ាមគឺមានភាពផ្ទុយគ្នា ។ មុនដំបូងមើលទៅដូចជាអត្មានិយម ហើយលោភលន់ (ខ.១០) តែក្រោយមកមើលទៅ គឺជាការបង្គាប់របស់ព្រះនឹងការប្រទានពរ ។

**១៣:១៦** *ដូចជាធូលីដី* ការប្រៀបធៀបវាជាការធម្មតាសម្រាប់អ្នករស់នៅមជ្ឈឹមបូពាំសម័យបុរាណនេះ គឺសម្រាប់ការកើនឡើងយ៉ាងច្រើននៃកូន

ជាធូលីដី បានជាបើអ្នកណាអាចនឹងរាប់ធូលីដីបាន នោះ
នឹងរាប់ពូជឯងបានដែរ[គ] ១៧ចូរឯងក្រោក ហើយដើរចុះ
ឡើងក្នុងស្រុកនេះ តាមបណ្តោយនិងទទឹងចុះ[ឃ] ដ្បិតអញ
នឹងឱ្យដល់ឯងហើយ”[ង] ១៨អាប់រ៉ាមក៏រើត្រសាលទៅនៅ
ក្បែរដើមម៉ៃសាក់របស់ម៉ាមរេ[ច] ដែលនៅត្រង់ហេប្រុន
វិញ[ឆ] ហើយគាត់ស្អាងអាសនា១ថ្វាយព្រះយេហូវ៉ានៅទី
នោះ[ជ]។

## លោកអាប់រ៉ាមសង្គ្រោះលោកឡុត

**១៤** ១នៅជំនាន់អាំរ៉ាផែលជាស្តេចស្រុកស៊ីណើរ[ក]អើយ៉ុក
ជាស្តេចស្រុកអេឡាសា កេដូឡោមើរ[ខ] ជាស្តេចស្រុក
អេឡាំ[គ] និងធីដាលជាស្តេចកូយីម ២នោះគេលើកគ្នាទៅ
ច្បាំងនឹងបេរ៉ាជាស្តេចក្រុងសូដុំម ប៊ីរសាជាស្តេចក្រុង
កូម៉ូរ៉ា ស៊ីណាប ជាស្តេចក្រុងអាត់ម៉ា សេមេប៊ើរជាស្តេច
ក្រុងសេបោម[ឃ] ហើយនិងស្តេចក្រុងបេឡា គឺជាសូអារ[ង]
៣ស្តេចទាំងនោះក៏មូលគ្នានៅវាលច្រកស៊ីឌីម[ច] គឺជាសមុទ្រ
អំបិល[ឆ] ៤គេបានចុះចូលកេដូឡោមើរ[ជ]អស់១២ឆ្នាំ តែដល់
ឆ្នាំទី១៣ ក៏នាំគ្នាបះបោរវិញ ៥លុះដល់ឆ្នាំទី១៤កេដូឡោ
មើរ[ឈ] ហើយអស់ទាំងស្តេចដែលនៅជាមួយក៏មកវាយពួក
រេផែម[ញ] នៅត្រង់អាសថារ៉ូត-កើណែម និងពួកស៊ូស៊ីមនៅ
ត្រង់ស្រុកហាំ ពួកអេមីម[ដ] នៅត្រង់វាលការយ៉ាថែម
៦ហើយពួកហូរី[ឋ] នៅក្នុងភ្នំសៀរ[ឌ] ជាស្រុករបស់ខ្លួនគេ
រហូតទៅដល់អែល-ប៉ារ៉ាន[ឍ] ដែលនៅខាងទីរហោស្ថាន
៧រួចគេវិលមកឯអេន-មីសផាត គឺជាកាដេស[ណ] ក៏វាយ
ស្រុកអាម៉ាលេកទាំងអស់[ត] និងពួកអាម៉ូរី[ថ]ដែលនៅហា
សាសូន-តាម៉ារដែរ[ទ]។
៨ស្តេចក្រុងសូដុំម ស្តេចក្រុងកូម៉ូរ៉ា[ធ] ស្តេចក្រុងអាត់ម៉ា
ស្តេចក្រុងសេបោម[ន]និងស្តេចក្រុងបេឡា គឺជាសូអារ[ប] ក៏នាំ
គ្នាចេញទៅដំរៀបទ័ពច្បាំងនឹងពួកទាំងនោះ នៅត្រង់វាល
ច្រកស៊ីឌីម[ផ] ៩គឺច្បាំងនឹងកេដូឡោមើរ[ព]ជាស្តេចអេឡាំ[ភ] ធី
ដាលជាស្តេចកូយីម អាំរ៉ាផែលជាស្តេចស៊ីណើរ និងអើ
យ៉ុកជាស្តេចអេឡាសារ មានស្តេច៤អង្គច្បាំងនឹងស្តេច
៥អង្គ ១០ឯវាលច្រកស៊ីឌីម[ម]នោះមានសុទ្ធតែអណ្តូងជ័រ[យ]

**១៣:១៦** គ លប ១២:២ ១៦:១០ ១៧:២០ ២១:១៣,១៨ ២៥:១៦ ជន ២៣:១០ **១៣:១៧** ឃ ខ.១៥ ជន ១៣:១៧-២៥ ង លប ១២:៧ ១៥:៧ **១៣:១៨** ច លប ១៤: ១៣,២៤ ១៨:១២ ៣:១៧,១៩ ២៥:៩ ៤៩:៣០ ៥០:១៣ ឆ លប ២៣:២៣ ៥:២៧ ៣៧:១៤ ជន ១៣:២២ យស ១០:៣,៣៦ ពច ១:១០ ១សយ ៣០:៣១ ២សយ ២:១,៣,១១ ១របា ១១:១ ជ លប ៨:២១ **១៤:១** ក លប ១០:១០ ខ ខ.៤,៩, ១៧ គ លប ១០:២២ **១៤:២** ឃ លប ១០:១៩ ង លប ១៣:១០ **១៤:៣** ច ខ.៨,១០ **១៤:៣** ច ខ.៨,១០ ឆ ជន ៣:១៧ យស ៣:១៦ ១២:៣ ១៥:២,៥ ១៨:១៩ **១៤:៤** ជ ខ.១ **១៤:៥** ឈ ខ.១ ញ លប ១៥:២០ ចទ ២:១១,២០ ៣:១១,១៣ យស ១២:៤ ១៣:១២ ១៧:១៥ ១របា ២០:៤ ដ ចទ ២:១០ **១៤:៦** ឋ លប ៣៦:២០ ចទ ២:១២, ២២ ឌ លប ៣២:៣ ៣៣:១៤,១៦ ២៦:៨ ចទ ១:២ ២:១,៥, ២២ យស ១១:១៧ ២៤:៤ ១របា ៤:៤២ អស ៣៤:៥ អគ ២៥:៨ ៣៥:២ អម ១:៦ ឍ លប ២១:២១ ជន ១០:១២ ១២:១៦ ១៣:៣,២៦ ហព ៣:៣ **១៤:៧** ណ លប ១៦:១៤ ២០:១ ជន ១៣:២៤ ២០:១ ៣២:៨ ចទ ១:២ យស ១០:៤១ ពច ១១:១៦ ទដ ២៩:៨ ត នក ១៧:៨ ជន ១៣:២៩ ១៤:២៥ ២៤:២០ ចទ ២៥:១៧ ពច ៣:១៣ ៦:៣ ១០:១២ ១២:១៥ ១សយ ១៤:៤៨:២ ២សយ ១:១ ១របា ៤:៤៣ ទដ ៨៣:៧ ថ ជន ១៣:២៩ ចទ ១:៤ យស ២:១០ ១៣:៤ ទ ២របា ២០:២ អគ ៤៨:២៨ **១៤:៨** ធ លប ១៣:១០ ន ចទ ២៩:២៣ ហស ១១:៨ ប លប ១៣:១០ ផ ខ.៣ **១៤:៩** ព ខ.១ ភ លប ១០:២២ **១៤:១០** ម ខ.៣ យ លប ១១:៣ រ ខ.១៧,២១

ចៅលោកអាប់រ៉ាម (មើល ២៨:១៤ ២របា ១:៩ ជន ២៣:១០) ។ ការប្រៀបនៅកន្លែងនេះគឺ“នឹងចម្រើនពូជឯងឱ្យមានគ្នាសន្ធឹកដូចផ្កាយលើមេឃ ហើយដូចខ្សាច់នៅមាត់សមុទ្រ (២២:១៧) ។

**១៣:១៧** *ដើរ . . . តាមបណ្តោយនិងទទឹង* ទាំង២នេះគឺបានពិនិត្យយ៉ាងល្អិតល្អន់ ឬអាចនិយាយថាជាការប្រកាសអំពីសិទ្ធិអំណាចក្នុងការចូលមករស់នៅលើទឹកដីនេះដែលគេបានទន្ទឹងរងចាំជាយូរមកហើយ (សូមប្រៀបធៀបនិង ចទ ៣២:៤៨-៤៩)។

**១៣:១៨** *ដើមម៉ៃសាក់* មើល ១២:៦ ។ *ម៉ាមរេ* ទីកន្លែងនេះបានកើតឡើងបន្ទាប់ពីមានការតាំងសញ្ញារបស់លោកអាប់រ៉ាម ក្នុងចំណោមការតាំងសញ្ញាផ្សេងៗទៀត (១៤:១៣) *ហេប្រុន* (២៣:២) *អាសនា* សូមមើល ១២:៧ ។

**១៤:១-២៤** សេចក្តីជំនឿរបស់លោកអាប់រ៉ាមបានឈ្នះលើការឈ្លានពានពីសំណាក់មហាក្សត្រប្រទេសដទៃ ដែលចង់បានទឹកដីសន្យាមកគ្រប់គ្រងហើយ មិនតែប៉ុណ្ណោះគាត់មានសមត្ថភាពជួយសង្គ្រោះឡុត ដែលជាក្មួយរបស់គាត់មកវិញដោយសុវត្ថិភាព ។ គាត់ក៏បានដឹងជាមុនដែរថាគាត់នឹងទទួលជ័យជម្នះ លើមហាក្សត្រដែលគាត់បានច្បាំងជាមួយ មើល ១២:២ “ទាំងលើកឈ្មោះឯងជាធំផង”ហើយបានផ្តល់ឱកាសឱ្យគាត់បានធ្វើបន្ទាល់ពីព្រះរបស់គាត់ឡើងដែរ ។

**១៤:១** អាំរ៉ាផែលជាស្តេចស្រុកស៊ើណើរមិនមែនជាស្តេចដែលល្បីល្បាញនៅបាប៊ីឡូនដែលមានឈ្មោះថា“ហាំមូ៉រ៉ាពី” (Hummurapi) ដូចដែលគេគិតនោះឡើយ ។*អេឡាំ* សូមមើលការពន្យល់ ១០:២២ ។ *កូយីម* ក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យថា “សាសន៍ដ៏ទៃ” ហើយប្រហែលជានាមធម្មតាប៉ុណ្ណោះ(អស ៩:១)។

**១៤:៣** *សមុទ្រអំបិល* គឺជាសមុទ្រស្លាប់ដែលមានចំណុះទឹកប្រមាណ៥ដងដែលកើតឡើងពីការប្រមូលផ្តុំគ្នារវាងក្លររ៉ៃ ហើយនិងសារធាតុប្រូមច្រើនជាងទឹកសមុទ្រផ្សេងៗទៀតលើសាកលលោក ដែលអាចយកវាមកធ្វើជារូបកាយដ៏ធំមួយអំពីទឹក ។

**១៤:៥** *រេផែម* គឺជារូមមនុស្សដ៏ធំមួយ (មើល ចទ ៣:១១) ។

**១៤:៦** *ហូរី* កាលពីមុនគិតថាមានបន្ទប់ក្រោមដីមួយសម្រាប់អ្នកស្នាក់អាស្រ័យ ភាសាហេព្រើរ “ហូ” មានន័យថា “គុហា” ឥឡូវនេះពួកគេបានគិតថាជាពួកកូនចៅ “ហេរ៉ូនហូរិន” (haeron Hurrians) មិនមែនជាពួកកូនចៅសិមដែលបានបែកខ្ញែកពាសពេញផែនដីនាមជ្ឈឹមបូព៌ាពីសម័យបុរាណនោះ ។

**១៤:៧** *អេនមីសផាត* មានឈ្មោះមួយទៀតគឺកាដេសដែលមានន័យថា“យុត្តិធម៌” ។ គេតែងហៅថាមេរីបាកាដេស ”ជម្លោះ/វិវាទនៅកាដេស” នៅក្នុង (ចទ ៣២:៥១ មើល ជន ២៧:១៤) ។ *កាដេស* ស្ថិតនៅទិសនិរតីខាងត្បូង (១២:៩) ក្រោយមកទៀតគេហៅថាកាដេសបានា (មើល ជន ៣២:៨)។ *អាម៉ាលេក* គឺជាពូជអំបូរដែលរស់នៅទិសខាងត្បូងហើយនិងក្នុងតំបន់ឧបទ្វីបស៊ីណៃយ ។ *អាម៉ូរី* សូមមើល ១០:១៦ ។

ហើយស្តេចក្រុងសូដុំម និងស្តេចក្រុងកូម៉ូរ៉ា[រ] គេរត់ទៅក៏
ដួលនៅទីនោះ ឯអស់អ្នកដែលនៅសល់ គេរត់ទៅឯភ្នំ[ល]
១១រួចស្តេចទាំងនោះក៏យកទ្រព្យសម្បត្តិ[វ]នៃក្រុងសូដុំម និង
ក្រុងកូម៉ូរ៉ាទាំងអស់ ព្រមទាំងស្បៀងអាហារទាំងប៉ុន្មាន
ចេញបាត់ទៅ ១២ក៏ចាប់ឡុត[ស]ជាក្មួយអាប់រ៉ាម ដែលនៅ
ក្រុងសូដុំម និងទ្រព្យសម្បត្តិរបស់គាត់ នាំទៅជាមួយដែរ ។
១៣មានមនុស្សម្នាក់ដែលបានរត់រួចពីចំបាំង គាត់ទៅ
ជំរាបដល់អាប់រ៉ាមជាសាសន៍ហេព្រើរ[ហ] ដែលនៅត្រង់
ដើមម៉ៃសាក់របស់ម៉ាមរេ[ឡ] ជាសាសន៍អាម៉ូរី ដែលជាបង
អែសកុល[អ] ហើយនិងអាន់នើរដែលបានចងមិត្តមេត្រីនឹង
អាប់រ៉ាម ១៤កាលអាប់រ៉ាមបានឮថា គេចាប់ក្មួយខ្លួន[ក]ទៅ
ជាឈ្លើយដូច្នោះ នោះគាត់នាំពួកបំរើទាំងប៉ុន្មានដែលកើត
ក្នុងផ្ទះគាត់ សុទ្ធ[ខ]តែជាមនុស្សថ្នឹកសង្គ្រាម មានចំនួន៣១៨
នាក់[គ] លើកគ្នាចេញទៅដេញតាមគេរហូតដល់ដាន់[ឃ]
១៥គាត់ចែកបាវ[ង]ឱ្យទៅទាស់នឹងគេទាំងយប់ ក៏វាយគេ
ហើយដេញតាមរហូតដល់ហូបា ដែលនៅខាងជាឆ្វេងនៃ
ក្រុងដាម៉ាស[ច] ១៦រួចនាំអស់ទាំងទ្រព្យសម្បត្តិវិលមកវិញ[ឆ]
ព្រមទាំងឡុតជាក្មួយនឹងទ្រព្យសម្បត្តិរបស់គាត់ដែរ[ជ] ទាំង
ពួកស្ត្រីនឹងមនុស្សទាំងអស់ផង ។
១៧កាលគាត់បានត្រឡប់មកពីវាយកេដូឡោមើរ[ឈ] នឹង
ពួកស្តេចដែលនៅជាមួយនឹងទ្រង់វិញហើយ នោះស្តេច
ក្រុងសូដុំម[ញ]ក៏ចេញមកទទួលគាត់ នៅត្រង់វាលច្រកភ្នំសា
វេគឺជាច្រកភ្នំនៃស្តេច[ដ] ១៨ហើយម៉ិលគីស្សាដែក[ឋ]ជាស្តេច
ក្រុងសាឡិម[ឌ] ក៏នាំយកនំបុ័ង[ឍ] និងស្រាទំពាំងបាយជូរមក[ណ]
ពីព្រោះទ្រង់ជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុត[ត] ១៩ទ្រង់ប្រទាន
ពរដល់គាត់[ថ]ថា សូមឱ្យអាប់រ៉ាមបានពរពីព្រះដ៏ខ្ពស់បំផុត[ទ]
ជាម្ចាស់នៃស្ថានសួគ៌និងផែនដី[ធ] ២០ហើយសូមព្រះដ៏ខ្ពស់

ល លប ១៩:១៧, ៣០ យស ២:១៦ ទដ ១១:១ **១៤:១១** វ ខ.១៦,២១ **១៤:១២** ស លប ១១:២៧ **១៤:១៣** ហ លប ៣៧:២៨ ៣៩:១៤,១៧ ៤០:១៥ ៤១:១២ ៤៣:៣២ នក ៣:១៨ ១សយ ៤:៦ ១៤:១១ ឡ ខ.២៤ លប ១៣:១៨ អ ជន ១៣:២៣ ៣២:៩ ចទ ១:២៤ **១៤:១៤** ក ខ.១២ ខ ចទ ៤:៩ ទដ ២២:៦ គ លប ១២:៥ ឃ ចទ ៣៤:១ ពច ១៨:២៩ ១ពវ ១៥:២០

**១៤:១៥** ង ពច ៧:១៦ ច លប ១៥:២ ២សយ ៨:៥ ១ពវ ២០:៣៤ ២ពវ ១៦:៩ សយ ៧:៨ ៨:៤ ១០:៩ ១៧:១ យរ ៤៩:២៣,២៧ អគ ២៧:១៨ អម ១:៣–៥ **១៤:១៦** ឆ ១សយ ៣០:៨,១៨ ជ ខ.១១ **១៤:១៧** ឈ ខ.១ ញ ខ.១០ ដ ២សយ ១៨:១៨ **១៤:១៨** ឋ ទដ ១១០:៤ ហព ៥:៦ ៧:១៧,២១ ឌ ទដ ៧៦:២ ហព ៧:២ ឍ លប ៣:១៩ ណ ពច ៩:១៣ ១៩:១៩ នអ ១:១០ ទដ ១០៤:១៥ សភ ៣១:៦ សស ១០:១៩ ១:២ ត ខ.២២ ទដ ៧:៨,១៧ ដយ ៧:២៧ **១៤:១៩** ថ ៧:៦ ទ ខ.១៨ ធ ខ.២២ លប ១:១ ២៤:៣

**១៤:១០** *អណ្តូងជ័រ* គំនរជ័រនេះគឺអាចឃើញអណ្តែតនៅតំបន់ភាគខាងត្បូងបំផុតនៃសមុទ្រស្លាប់ ។

**១៤:១២** *ឡុត . . . ដែលនៅក្រុងសូដុំម* គាត់បានផ្លាស់មករស់នៅក្នុងទីក្រុងក្នុងចំណោមមនុស្សអាក្រក់ (២ពត ២:៨) ។ ទោះបីជាឡុត"សុចរិត"ឥឡូវនេះគាត់ស្ថិតក្នុងការគ្រោះថ្នាក់ដោយការប្រព្រឹត្តតាម "ដោយព្រោះកិរិយាខូចអាក្រក់របស់មនុស្សទទឹងច្បាប់ទាំងនោះ"(ពត ២:៧) ។

**១៤:១៣** *សាសន៍ហេព្រើរ* លោកអាប់រ៉ាមជាឪពុកនៃសាសន៍ហេព្រើរ វាគឺជាលើកដំបូងដែលព្រះគម្ពីរ បាននិយាយថាសាសន៍ហេព្រើរ (សូមមើលពាក្យ "ហេព្រើរ" ក្នុង ១០:២១) ។ ជានិច្ចកាលក្រុមមនុស្សក្នុងព្រះគម្ពីរសម្រាប់អ្នកដែលមិនមែនជាជនជាតិអ៊ីស្រាអែល គឺគេប្រើវាជាលក្ខណៈធម្មតាដើម្បីបង្ហូចកិត្តិយស (៣៩:១៧) ។ នៅក្រៅព្រះគម្ពីរមនុស្សទាំងនេះត្រូវបានគេស្គាល់ថា "ហាប្រ៊ូ" (Habiru) ឬ "អាពីរូ" (Apiru) ពាក្យនេះប្រហែលទាក់ទងនឹងពាក្យ "ហេព្រើរ" វាសំដៅលើមិនមែនជាកម្មសិទ្ធមិនមែនឯករាជ្យជាសង្គមជនអន្តោប្រវេសប្រសើរជាង ។ មានការរៀបរាប់ដែលផ្ទុយពីនេះទៀតគឺមាននៅក្នុងអាមាណាសិលាចារិកដីឥដ្ឋ ដែលឃើញមាននៅប្រទេសអេស៊ីព្ទ ។ *ម៉ាមរេ* គឺជាទីក្រុងមួយដែលកើតឡើងបន្ទាប់ពីមានគាត់ (១៣:១៨ និងការពន្យល់) ។

**១៤:១៤** *ដែលកើតក្នុងផ្ទះគាត់ សុទ្ធតែជាមនុស្សថ្នឹកសង្គ្រាមមានចំនួន៣១៨នាក់* គឺបានចង្អុលបង្ហាញឱ្យឃើញកាន់តែច្បាស់ថែមទៀត អំពីទ្រព្យសម្បត្តិជាច្រើនរបស់អាប់រាម ។ នៅក្នុងភាសាហេព្រើរពាក្យថា"ថ្នឹកសង្គ្រាម"គឺមានតែកន្លែងនេះទេដែលបាននិយាយក្នុងព្រះគម្ពីរ ។ មានពាក្យផ្សេងទៀតដែលបានប្រើក្នុងកន្លែងផ្សេងៗ នៅក្នុងពួកកូនចៅជំនាន់ក្រោយគឺ "ថ្នឹកចំបាំង" ។ *ដាន់* គឺជាទីក្រុងដ៏ល្បីល្បាញមួយនៅភាគខាងជើងដែលពីមុនទីក្រុងនេះមិនមែនឈ្មោះថា"ដាន់"ឡើយ គឺរហូតដល់គ្រាពួកចៅហ្វាយ (ពច ១៨:៧) ។ កាលពីមុនវាមានឈ្មោះថា"ឡាអ៊ីស"ឬ"ឡាស៊ីម" (សូមមើល ពច ១៨:៧) ការរើសយកកន្លែងនៅកន្លែងនេះ គឺវាមានការដូចគ្នាច្រើនទៅនឹងពេលក្រោយទៀត ។

**១៤:១៧** *ច្រកភ្នំនៃស្តេច* ស្ថិតនៅក្បែរក្រុងយេរូសាឡឹម ។ (សូមមើល ២សយ ១៨:១៨) ។

**១៤:១៨** *ហើយម៉ិលគីស្សាដែកជាស្តេចក្រុងសាឡិម . . . ជាសង្ឃ* មើល ហព ៧:១ ។ នៅសម័យបុរាណសម្រាប់ព្រះមហាក្សត្រនិងសង្ឃ ដែលមិនមែនជាជនជាតិអ៊ីស្រាអែលត្រូវបានគេដាក់ឈ្មោះ"ម៉ិលគីស្សាដែក"ដែរដែលមានន័យថា "ព្រះមហាក្សត្រនៃខ្ញុំជាអ្នកកាន់សាសនា" ឬក៏ "ស្តេចនៃសេចក្តីសុចរិត" មើល ហព ៧:២ ។ "សាឡិម" គឺជាឈ្មោះកាត់ដែលមកពីពាក្យថា "យេរ៉ូសាឡិម"(ទដ ៧៦:២) វាមានទំនាក់ទំនងពាក្យជាភាសាហេព្រើរដែលមានន័យថា "សន្តិភាព" (ហព ៧:២ យស ១០:២១ និងការពន្យល់)។ នំបុ័ងនិងស្រាទំពាំងបាយជូរ គឺជាអាហារសម្រាប់អ្នកបួស(មើល ពច ១៩:១៩) វាមិនដូចគ្នាទៅនឹងអាហារពេលធ្វើពិធីលៀងព្រះអម្ចាស់នៅក្នុងសញ្ញាថ្មីនោះឡើយ ។ ចំណាប់អារម្មណ៍របស់លោកម៉ិលគីស្សាដែកចំពោះជ័យជម្នះកងកម្លាំងលោកអាប់រ៉ាម គឺដូចជានយោបាយដែរ ហើយជ័យជម្នះរបស់លោកអាប់រ៉ាមបានធ្វើឱ្យលោក មានការរីករាយជាមួយនឹងការបូករួមការប្រសិទ្ធិពរជ័យបានធ្វើឱ្យលោកអាប់រ៉ាម ក្លាយជាមនុស្សម្នាក់ដែលមានការកោតខ្លាចចំពោះលោកម៉ិលគីស្សាដែក ។

**១៤:១៩** *ព្រះដ៏ខ្ពស់បំផុតជាម្ចាស់នៃស្ថានសួគ៌និងផែនដី* នៅក្នុងសម័យបុរាណពាក្យថា"ដ៏ខ្ពស់បំផុត""ព្រះយេហូវ៉ានៃស្ថានសួគ៌"ព្រះអទិករនៃផែនដី"ជារឿយៗគឺសំដៅលើព្រះរបស់ជនជាតិកាណាន ។ ប៉ុន្តែលោកម៉ិលគីស្សាដែកប្រទានពរដល់លោកអាប់រ៉ាមដោយនូវព្រះនាម"ព្រះដ៏ខ្ពស់បំផុត" នឹង "ព្រះយេហូវ៉ា" (ខ.២២) គឺជាបន្ទាល់អំពីព្រះពិតតែមួយ ។

**១៤:២០** *គាត់ក៏ថ្វាយ១ភាគក្នុង១០ពីគ្រប់របស់ទាំងអស់ដល់ទ្រង់* ១ភាគក្នុង១០គឺជាចំណែករបស់ស្តេច (មើល ១សយ ៨:១៥,១៧) ។ តាមរយៈដង្វាយ១

បំផុត[ន]បានប្រកបដោយព្រះពរ ជាព្រះដែលបានប្រគល់
ខ្មាំងសត្រូវ មកក្នុងកណ្ដាប់ដៃឯង រួចគាត់ក៏ថ្វាយ១ភាគក្នុង
១០ ពីគ្រប់របស់ទាំងអស់ដល់ទ្រង់[ប] ។
២១ឯស្តេចក្រុងសូដុំម[ផ]ក៏មានបន្ទូលនឹងអាប់រ៉ាមថា ចូរឱ្យ
តែមនុស្សមកខ្ញុំបានហើយ ឯរបស់ទ្រព្យទាំងប៉ុន្មាន[ព] ចូរ
យកទុកជារបស់ផងអ្នកចុះ ២២តែអាប់រ៉ាមគាត់ទូលទៅស្តេច
សូដុំម[ភ]ថា ទូលបង្គំបានលើកដៃ[ម]ស្បថចំពោះព្រះយេហូវ៉ា
ជាព្រះដ៏ខ្ពស់បំផុត[យ] ជាម្ចាស់នៃស្ថានសួគ៌និងផែនដី[រ]ថា
២៣ទូលបង្គំនឹងមិនយកអ្វីសោះ សូម្បីតែចេស១សរសៃ ឬ
ខ្សែស្បែកជើង១ ឬអ្វីៗរបស់ទ្រង់[ល]ឡើយខ្លាចក្រែងទ្រង់
មានបន្ទូលថា អញបានធ្វើឱ្យអាប់រ៉ាមទៅជាអ្នកមាន
២៤សូមយកតែរបស់ណាដែលពួកបាវបំរើ បានទទួលទាន
ទៅហើយប៉ុណ្ណោះ ឯចំណែកពួកមនុស្សដែលបានចេញទៅ
ជាមួយនឹងទូលបង្គំនេះ គឺអាន់នើរ អែសកុល និងម៉ាមរេ[វ]
នោះឱ្យគេយកចំណែករបស់គេចុះ ។

## ការតាំងសញ្ញារបស់ព្រះដល់លោកអាប់រ៉ាម

**១៥** ១ក្រោយការទាំងនោះមក ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលនឹងអាប់រ៉ាម[ក]ដោយការជាក់ស្តែង[ខ]ថា អាប់រ៉ាម
អើយ កុំឱ្យខ្លាចអ្វីឡើយ[គ] អញជាខែល[ឃ] ហើយជារង្វាន់ដ៏
ធំក្រៃលែងរបស់ឯង[ង]" ២នោះអាប់រ៉ាមគាត់ទូលសួរថា
ឱព្រះយេហូវ៉ាជាព្រះអម្ចាស់អើយ[ច] តើទ្រង់នឹងប្រទានអ្វី
មកទូលបង្គំ ដែលទូលបង្គំចេះតែនៅដោយឥតមានកូន
ដូច្នោះ[ឆ] ហើយអ្នកដែលត្រូវធ្វើជាម្ចាស់លើផ្ទះទូលបង្គំ
នោះមានតែអេលាសើរជាអ្នកស្រុកដាម៉ាសនេះប៉ុណ្ណោះ[ជ]
៣អាប់រ៉ាមក៏ទូលទៀតថា មើល ទ្រង់មិនបានប្រទានឱ្យទូល
បង្គំមានកូនសោះ ហើយមើល បាវម្នាក់[ឈ]ដែលកើតនៅផ្ទះ
ទូលបង្គំ[ញ]វានឹងគ្រងមរដករបស់ទូលបង្គំហើយ ៤នោះព្រះ
យេហូវ៉ាទ្រង់មានបន្ទូលនឹងគាត់ថា អ្នកនោះមិនត្រូវស៊ី
មរដករបស់ឯងទេ គឺជាម្នាក់ដែលកើតពីឯងមកវិញទេតើ
ដែលត្រូវស៊ីមរដករបស់ឯងនោះ[ដ] ៥រួចទ្រង់នាំគាត់ទៅក្រៅ
ប្រាប់ថា ចូរមើលទៅលើមេឃឥឡូវ ហើយរាប់ផ្កាយចុះ

យស ២:១១ ទដ ១៤៨:៥ មថ ១១:២៥ **១៤:២០** ន លប ៩:២៦ ២៤:២៧ ប លប ២៨:២២ ចទ ១៤:២២ ២៦:១២ លក ១៨:១២ ហព ៧:៤ **១៤:២១** ផ ខ.១០ ព ខ.១១ **១៤:២២** ភ ខ.១០ ម នក ៦:៨ ជន ១៤:៣០ ចទ ៣២:៤០ នហ ៩:១៥ អក ២០:៥ ដយ ១២:៧ វវ ១០:៥–៦ យ ខ.១៨ រ ខ.១៩ **១៤:២៣** ល ១សយ ១៥:៣,១៩ ២ពវ ៥: ១៦ នអ ៨:១១ ៩:១០ ១៥ **១៤:២៤** វ លប ១៣: ១៨ **១៥:១** ក ១ស ១៥:១០ ២សយ ៧:៤ ១ពវ ៦:១១ ២:២២ យរ ១:១៣ អគ ៣:១៦ ដយ ១០:១ ខ លប ៤៦:២ ជន ១២:៦ ២៤:៤ រម ១:២០យប ៣៣:១៥ គ លប ២១:១៧ ២៦:២៤ ៤៦:៣ នក ១៤:១៣ ២០:២០ ២ពវ ៦:១៦ ២របា ២០:២៥,១៧ ទដ ២៧:១ អស ៧:៤ ៤១:១០,១៣–១៤ ៤៣:១,៥ យរ ១:៨ ហក ២:៥ ឃ ចទ ៣៣:២៩ ២សយ ២២:៣,៣១ ទដ ៣:៣ ៥:១២ ១៨:២ ២៨:៧ ៣៣:២០ ៨៤:១១ ១១៩:១១៤ សភ ២:៧ ៣០:៥ ង ទដ ១៨:២៩ ៣៧:២៥ ៥៨:១១ អស ៣:១០ **១៥:២** ច ខ.៨ ស ៤៩:២២ រយ ៤៤:២៦ អគ ៥:១១ ១៦:៤៨ ឆ កច ៧:៥ ជ លប ១៤:១៥ **១៥:៣** ឈ លប ២៤:២,៣៤ ញ លប ១២:៥ **១៥:៤** ដ កទ ៤:២៨ **១៥:៥** ឋ យប ១១:៨ ៣៥:៥ ទដ ៨:៣ ១៤៧:៤ យរ ៣៣:២២ ឌ កទ ១២:២ យរ

ភាគក្នុង១០លោកអាប់រ៉ាមត្រូវតែបង្ហាញពីទំនួលខុសត្រូវ ចំពោះសកម្មភាពរបស់ស្តេចម៉ិលគីស្សាដែក ដោយគាត់ត្រូវតែបង្ហាញការដឹងគុណចំពោះពូជពង្សរបស់ទ្រង់នៅសាឡិមវិញ ។ ដូចគ្នាផងដែរការទទួលយកព្រះពររបស់ស្តេចម៉ិលគីស្សាដែក គឺដូចជាការប្រទានពរមកអំពីព្រះយេហូវ៉ា ជាដង្វាយ១ភាគក្នុង១០ ដែលលោកអាប់រ៉ាមបានថ្វាយចំពោះសង្ឃម៉ិលគីស្សាដែក គឺបានបង្ហាញយើងថាលោកមិនបានជំពាក់លោកម៉ិលគីស្សាដែកនោះឡើយប៉ុន្តែ ដែលគាត់ថ្វាយ គឺថ្វាយចំពោះព្រះយេហូវ៉ា (សូមមើល ខ.២៣ និងការពន្យល់) ។ លោកម៉ិលគីស្សាដែក គឺត្រូវបាននិយាយបន្ទាប់ទៀត ដែលប្រៀបបានទៅនឹង"គំរូ"ឬ"ព្រះយេស៊ូវ" ដែលជាសម្តេចសង្ឃដ៏ខ្ពស់បំផុតនៃយើងរាល់គ្នា (ហព ៤:១៤) ហេតុដូច្នេះហើយអ្នកតំណាងឱ្យសម្តេចសង្ឃមិនមែនជាលោកអាប់រ៉ាមឡើយ គឺជាលោកម៉ិលគីស្សាដែកវិញ (ហព ៧:១១ ទដ ១១០:៤) ។

**១៤:២២** *ទូលបង្គំបានលើកដៃ* គឺជារបៀបស្បថនៅសម័យកាលបុរាណ (ចទ ៣២:៤០ វវ ១០:៥–៦) ។

**១៤:២៣** *ទូលបង្គំនឹងមិនយកអ្វីសោះ* សូមប្រៀបធៀប ២ពវ ៥:១៦ ។ លោកអាប់រ៉ាមបានបដិសេធន៍ និងមិនអនុញ្ញាតឱ្យខ្លួនរបស់គាត់យកអាសាពីអ្នកណាម្នាក់នោះឡើយ លើកលែងតែព្រះយេហូវ៉ាប៉ុណ្ណោះ ។ បើសិនជាគាត់ព្រមទទួលនោះប្រហែលជាពេលក្រោយ ស្តេចនៃសាសន៍កាណាននេះនឹងប្រកាសពីសិទ្ធិរបស់គេគ្រប់គ្រងលើលោកអាប់រ៉ាម ។

**១៥:១–២១** នៅទីនេះអ្វីដែលសំខាន់នោះ គឺនិយាយអំពីការតាំងសញ្ញារវាងព្រះនឹងលោកអាប់រ៉ាម ។ ជាការឆ្លើយតបចំពោះសេចក្តីជំនឿដែលស្មោក់ស្មើររបស់លោកអាប់រ៉ាម ព្រះយេហូវ៉ាបានបន្ថែមព្រះគុណរបស់ទ្រង់តាមរយៈសេចក្តីសន្យាដែលព្រះយេហូវ៉ាទ្រង់បានស្បថ ។

**១៥:១** *អញជាខែល* ទោះបីជា "ខែល" ឬ "អធិបតេយ្យ" មានន័យដូចគ្នាក៏ដោយ (សូមមើលការពន្យល់) គឺសំដៅទៅលើព្រះយេហូវ៉ាជាស្តេចនៃលោកអាប់រ៉ាម ។ កន្លែងផ្សេងទៀត"ខែល"តំណាងឱ្យស្តេច (ចទ ៣៣:២៩ ២សយ ២២:៣ ទដ ៧:១០ ៨៤:៩) ។ *ហើយជារង្វាន់ដ៏ធំក្រៃលែងរបស់ឯង* ទោះបីជាលោកអាប់រ៉ាមជាអ្នកមានហើយក៏ដោយ (១៣:២ ១៤:២៣) ព្រះយេហូវ៉ា ព្រះអង្គទ្រង់ផ្ទាល់ គឺជាទ្រព្យសម្បត្តិដ៏ធំក្រៃលែងរបស់លោកអាប់រ៉ាមប្រៀបធៀប (ចទ ១០:៩) ។

**១៥:២** *អេលាសើរ* ជាអ្នកស្រុកដាម៉ាសអ្នកបម្រើនេះ ប្រហែលជាលោកអាប់រ៉ាមទទួលគាត់នៅពេលដែលលោកធ្វើដំណើរ ពីហារ៉ាន់ឆ្ពោះទៅកាន់ទិសខាងត្បូង (មើល ១២:៥) ។ ប្រហែលគាត់ជា "បាវដែលចាស់ជាងគេ"គ្មានឈ្មោះនោះហើយ (២៤:២) ។

**១៥:៣–៤** តាមរយៈឯកសារនាសម័យបុរាណ ដែលបានបើកដីដែងនៅ "នូស៊ី" (Nuzi) ដែលស្ថិតនៅក្បែរ "គីគូក" (Kirkük) ដែលជាដៃទន្លេ "ទីរិស" (Tigris) គឺជាកន្លែងដែលអ្នកគ្មានកូនអាចទទួលយកអ្នកបម្រើប្រុសម្នាក់មកចញ្ចឹមដោយផ្គត់ផ្គង់អាហារសម្រាប់គាត់ ។ លោកអាប់រ៉ាមអាចគិតថា និងរើសយកអេលាសើរ ឬមួយគាត់បានធ្វើវារួចមកហើយ ។

**១៥:៥** *ហើយរាប់ផ្កាយចុះបើឯងនឹងអាចរាប់ទាំងអស់បាន* សូមមើលក្នុង ២២:១៧ ។ ផ្កាយច្រើនជាង៨000 គឺបានឃើញផ្ទាល់នឹងភ្នែកនាពេលយប់នៅមជ្ឈឹមបូព៌ា ។ *ពូជឯងនឹងបានដូច្នេះដែរ* សេចក្តីសន្យាដំបូង គឺព្រះយេហូវ៉ាទ្រង់បានសន្យានៅពេលដែលលោកអាប់រ៉ាម ស្ថិតនៅក្នុងប្រទេសអេស៊ីព្ទ (នក ជំពូក១ ចទ ១:១០ ហព ១១:១២) ។ ចំនួនដ៏ច្រើនបែបនេះ

បើឯងអាចនិងរាប់ទាំងអស់បាន រួចទ្រង់មានបន្ទូលប្រាប់ថា
ពូជឯងនិងបានដូច្នោះដែរ 6 គាត់ក៏ជឿដល់ព្រះយេហូវ៉ា
ហើយទ្រង់រាប់សេចក្ដីជំនឿនោះ ទុកជាសេចក្ដីសុចរិតដល់
គាត់ 7 នោះទ្រង់មានបន្ទូលទៅគាត់ថា អញជាព្រះយេហូវ៉ា
ដែលនាំឯងចេញពីស្រុកអើរបស់សាសន៍ខាល់ដេមក ដើម្បី
និងឱ្យស្រុកនេះដល់ឯងទុកជាកេរ្ដិ៍ករ 8 រួចគាត់ទូលសួរថា
ឱព្រះយេហូវ៉ាជាព្រះអម្ចាស់អើយ[ទ] តើទូលបង្គំនឹងដឹង[ធ]
ដោយសារអ្វីថា ទូលបង្គំនឹងបានស្រុកជាកេរ្ដិ៍អាករពិត[ន]
9 នោះទ្រង់មានបន្ទូលសួរថា ចូរយកគោញី១[ប] អាយុ៣ខួប[ផ]
ពពែញី១អាយុ៣ខួប ចៀមឈ្មោល១អាយុ៣ខួបហើយ
លលក១នឹងព្រាបជំទើរ១មកឱ្យអញ 10 គាត់ក៏យកសត្វទាំង
នោះមកពុះជា២ភាគ រួចដាក់ចំហៀងប្រទល់គ្នា[ភ] តែសត្វ
ស្លាបគាត់មិនពុះទេ[ម] 11 ឯពួកសត្វហើរក៏ចុះមកលើខ្មោច
នៃសត្វទាំងនោះ[យ] តែអាប់រ៉ាម ដេញវាទៅ ។
12 លុះដល់វេលាថ្ងៃកំពុងតែលិច អាប់រ៉ាមក៏ដេកលក់
យន់ទៅ[រ] នោះឃើញមានងងឹតយ៉ាងខ្លាំងគួរស្ញែងខ្លាចចុះ
មកគ្របលើគាត់ 13 រួចទ្រង់មានបន្ទូលប្រាប់អាប់រ៉ាមថា
ចូរដឹងជាប្រាកដថា ពូជឯងនឹងត្រូវទៅជាអ្នកដទៃនៅ
ស្រុក១ដែលមិនមែនជាស្រុករបស់ផងខ្លួន ហើយត្រូវបំរើ[ល]
ពួកស្រុកនោះ ដែលគេនឹងសង្កត់សង្កិនឯងអស់រវាង៤០០
ឆ្នាំ[វ] 14 តែអញនឹងជំនុំជំរះសាសន៍ដែលឯងត្រូវបំរើនោះ
រួចពីនោះមក ពូជឯងនឹងចេញមក[ស]ទាំងមានទ្រព្យសម្បត្តិ
ជាច្រើនវិញ[ហ] 15 ឯឯងនឹងទៅឯពួកឰយុកោឯង[ឡ]ដោយសុខ
សាន្ត ហើយគេនឹងកប់ឯង ក្រោយដែលឯងមានអាយុវែង
ល្អហើយ[អ] 16 ដល់តំណទី៤[ក] នោះគេនឹងវិលមកឯណេះវិញ[ខ]
ដ្បិតសេចក្ដីទុច្ចរិតរបស់ពួកសាសន៍អាម៉ូរី[គ] មិនទាន់ពោរ
ពេញនៅឡើយ 17 រួចកាលថ្ងៃលិចទៅ បានងងឹតហើយ
នោះឃើញមានគុកភ្លើងហុយផ្សែង នឹងចន្លុះដែលឆេះ
ទៅ[ឃ]មកនៅកណ្ដាលដុំសាច់ទាំងនោះ[ង] ។

៣០:១៩ រម ៤:១៨ ហព ១១:១២ **១៥:៦** ល ទដ ១០៦:៣១ រម ៤:៣,២០–២៤ កទ ៣:៦ យក ២:២៣ **១៥:៧** ណ កទ ១២:១ នក ២០:២ កច ៧:៣ ហព ១១:៨ ត កទ ១១:២៨ កច ៧:៤ ថ កទ ១៣:១៧ ១៧:៨ ២៨:៤ ៣៥:១២ ៤៨:៤ នក ៦:៨ ចទ ៩:៥ **១៥:៨** ទ ឧ.២ ធ លក ១:១៨ ន ចទ ១២:២០ ១៩:៨ **១៥:៩** ប ជន ១៩:២ ចទ ២១:៣ ហស ៤:១៦ អម ៤:១ ផ ១សយ ១:២៤ ព លវ ១:១៤ ៥:៧,១១ ១២:៨ **១៥:១០** ភ ឧ.១៧ យរ ៣៤:១៨ ម លវ ១:១៧ ៥:៨ **១៥:១១** យ ចទ២៨:២៦ យរ ៧:៣៣ **១៥:១២** រ កទ ២:២១ **១៥:១៣** ល នក ១:១១ ៣:៧ ៥:៦,១០–១៤,១៨ ៦:៥ ចទ ៥:១៥ យប ៣:១៨ វ ឧ.១៦ នក ១២:៤០ ជន ២០:១៥ កច ៧:៦,១៧ កទ ៣:១៧ **១៥:១៤** ស លប ៥០:២៤ នក ៣:៨ ៦:៦–៨ ១២:២៥ ជន ១០:២៩ យស ១:២ កច ៧:៧ ហ នក ១២:២–៣៨ **១៥:១៥** ឡ លប ៤៧:៣០ ៤៩:២៩ ចទ ៣១:១៦ ២សយ ៧:១២ ១ពវ ១:២១ ទដ ៤៩:១៩ អ លប ២៥:៨ ៣៥:២៩ នក ២៣:២៦ ចទ ៣៤:៧ យស ១៤:១១ ពច ៨:៣២ ១រប ២៩:២៨ យប ៥:២៦ ២១:២៣ ៤២:១៧ ទដ ៩១:១៦ សភ ៣:១៦ ៩:១១ អស ៦៥:២០ **១៥:១៦** ក ឧ.១៣ នក ១២:៤០ ខ លប ២៨:១៥ ៤៦:៤ ៤៨:២១ ៥០:២៤ នក ៣:៨,១៧ គ លវ ១៨:២៨ យក ១៣:៤ ពច ១០:១១ ១ពវ ២១:២៦ ២ពវ ១៦:៣ ២១:១១ អគ ១៦:៣ **១៥:១៧** ឃ ពច ៧:១៦,២០ ១៥:៤,៥ ង ឧ.១០

---

គឺជារបស់ផងព្រះគ្រីស្ទដែលជាកូនចៅលោកអាប់រ៉ាម (កទ ៣:២៩) ។

**១៥:៦** អាប់រ៉ាមគឺជា"ឪពុកនៃអ្នកជឿគ្រប់គ្នា" (រម ៤:១១) ។ ហើយនៅក្នុងខនេះគឺខដំបូងដែលនិយាយសំដៅលើសេចក្ដីជំនឿ ចំពោះសេចក្ដីសន្យារបស់ព្រះ ។ វាក៏បានបង្រៀនយើងទៀតថា ព្រះយេហូវ៉ាជាព្រះពេញដោយព្រះគុណដែលបានឆ្លើយតបចំពោះសេចក្ដីជំនឿ តាមរយៈការរាប់ជាសុចរិតដល់អស់អ្នកណាដែលជឿ (ហព ១១:៧) ។

**១៥:៧** *អញជាព្រះយេហូវ៉ាដែលនាំឯងចេញ* ការតាំងសញ្ញារបស់ព្រះនាសម័យបុរាណគឺចាប់ផ្ដើមដោយ (១) ស្ដេចត្រូវតែណែនាំព្រះនាមទ្រង់ផ្ទាល់ (២) បុព្វកថាដ៏ខ្លី (មើល នក ២០:២) ។

**១៥:៨** *តើទូលបង្គំនឹងដឹងដោយសារអ្វី* សូមប្រៀបធៀប លក ១:១៨ ។ លោកអាប់រ៉ាមជឿចំពោះសេចក្ដីសន្យា ដែលព្រះយេហូវ៉ាសន្យាថានឹងប្រទានកូនឱ្យ ប៉ុន្តែគាត់ចង់បានការធានាចំពោះសេចក្ដីសន្យានោះ ។

**១៥:៩–២១** នេះគឺជាការពិពណ៌នាអំពីការចងមេត្រីរវាងព្រះយេហូវ៉ានឹងលោកអាប់រ៉ាមនៅក្នុងតំបន់មជ្ឈឹមបូព៌ាសម័យបុរាណ ដែលសន្ធិសញ្ញានេះស្ថិតនៅពេញពាសផែដី ។

**១៥:១០** *សត្វ . . . តែសត្វស្លាបមិនពុះជា២ភាគទេ* ប្រហែលជាសត្វនោះតូចពេក (មើល លវ ១:១៧) ។

**១៥:១៣** *ស្រុក១ដែលមិនមែនជាស្រុករបស់ផងខ្លួន* គឺជាស្រុកអេស៊ីព្ទ (មើល ៤៦:៣៤) ។ អស់ជាង៤០០ឆ្នាំ ប្រហាក់ប្រហែល៤០០ឆ្នាំ ។ ដោយយោងតាម នក ១២:៤០ ពួកអ៊ីស្រាអែលបានរស់នៅស្រុកអេស៊ីព្ទ ៤៣០ឆ្នាំ ។

**១៥:១៥** បានសម្រេចក្នុង ២៥:៨ ។

**១៥:១៦** *ដល់តំណទី៤* គឺកើតឡើងបន្ទាប់ពី៤០០ឆ្នាំទៅ (មើល ខ.១៣) ។ ១តំណគឺជាអាយុរបស់មនុស្ស ពេលដែលគាត់បង្កើតបានកូនប្រុសដំបូង កើតឡើងនៅក្នុងអំបូរលោកអាប់រ៉ាមរយៈពេល១០០ឆ្នាំ ។ ដ្បិតសេចក្ដីទុច្ចរិតរបស់សាសន៍អាម៉ូរីមិនទាន់ពោរពេញនៅឡើយ គឺគ្រាន់តែបង្ហាញថាអំពើបាបដ៏ក្រៃលែងដែលពួកកាណានបានប្រព្រឹត្ត ឥឡូវនេះយើងអាចដឹង គឺតាមរយៈវត្ថុបុរាណនិងលក្ខណៈអក្សរសាស្ត្រនិងការរកឃើញនៅឯ"រ៉ាសាមម៉ា" (RasShamra) (យូហ្គារីតសម័យបុរាណ) ដែលស្ថិតនៅភាគខាងជើងនៃឆ្នេរស៊ីរ៉ានដែលបានកសាងឡើងក្នុងឆ្នាំ១៩២៩ ។ ការថ្វាយបង្គំរបស់ពួកគេគឺពហុទេវដោយបូករួមនឹងរូបព្រះ ពេស្យាចា ការទស្សទាយ (ចទ ១៨:៩១២) ហើយគេក៏យកកូនក្មេងមកធ្វើជាយញ្ញបូជា ។ ព្រះយេហូវ៉ាទ្រង់មានព្រះទ័យអត់ធ្មត់ចំពោះការជំនុំជម្រះទោះបីជាមួយពួកកាណាន ដែលប្រព្រឹត្តការអាក្រក់ក៏ដោយ ។

**១៥:១៧** *គុកភ្លើងហុយផ្សែងនឹងចន្លុះ* គឺជានិមិត្តសញ្ញាអំពីវត្តមានរបស់ព្រះ (នក ៣:២១ ៤:២៤ ១៩:១៨ ១ពវ ១៨:៣៨ កច ២:៣–៤) ។ ឆេះមកនៅកណ្ដាលដុំសាច់ទាំងនោះការសម្លាប់សត្វ (ខ.១០) ។ នៅក្នុងសម័យបុរាណជួនកាលនៅពេលមានពិធីជប់លៀង គឺគេធ្វើឡើងជាឱឡារិក គេនាំគ្នាដើរកណ្ដៀតក្អមនៅមាត់ច្រកដោយមានកាន់បន្ទះសាច់សត្វ ដែលគេបានសម្លាប់នោះ (យរ ៣៤:១៨–១៩) ។ អត្ថន័យនៃពិធីនេះ គឺដើម្បីបង្ហាញសេក្ដីសម្បថរបស់ខ្លួនឯងផ្ទាល់ "វាប្រហែលជាកើតឡើងដល់រូបខ្ញុំបើខ្ញុំមិនបានរក្សាសេចក្ដីសម្បថនឹងពាក្យសន្យា" ។ តាមរយៈសេចក្ដីជំនឿរបស់លោកអាប់រ៉ាម ដែលបានរាប់ជាសុចរិតឥឡូវនេះព្រះគុណនៃព្រះយេហូវ៉ា បាន

១៨នៅថ្ងៃនោះឯង ព្រះយេហូវ៉ាទ្រង់តាំងសញ្ញានឹង
អាប់រ៉ាមថា[ច] អញឱ្យស្រុកនេះដល់ពូជឯង[ឆ]ចាប់តាំងពីទន្លេ
ស្រុកអេស៊ីព្ទ[ជ]រហូតដល់ទន្លេធំ គឺជាទន្លេអឺប្រាត[ឈ] ១៩ព្រម
ទាំងពួកកែន[ញ] ពួកគេនិស៊ីត ពួកកាត់ម៉ូនី ២០ពួកហេត[ដ] ពួក
ពេរិស៊ីត[ឋ] ពួករេផែម[ឌ] ២១ពួកអាម៉ូរី ពួកកាណាន ពួកគើកា
ស៊ី ហើយនិងពួកយេប៊ូសផង[ឍ] ។

## នាងហាការ និងលោកអ៊ីសម៉ាអែល

**១៦** ១រីឯសារ៉ាយ[ក]ប្រពន្ធអាប់រ៉ាម នាងមិនបង្កើតកូនឱ្យ
គាត់សោះ[ខ] តែនាងមានបាវស្រីសាសន៍អេស៊ីព្ទម្នាក់[គ]ឈ្មោះ
ហាការ[ឃ] ២ដូច្នេះសារ៉ាយក៏និយាយទៅអាប់រ៉ាមថា មើល
ព្រះយេហូវ៉ាទ្រង់បង្ខាំងមិនឱ្យខ្ញុំមានកូនទេ[ង] ហេតុនោះ
សូមអ្នកអញ្ជើញចូលទៅឯបាវស្រីរបស់ខ្ញុំចុះប្រហែលជា
ខ្ញុំនឹងបានកូនដោយសារវា[ច] អាប់រ៉ាមក៏ស្តាប់តាម ៣រួច
សារ៉ាយប្រពន្ធអាប់រ៉ាមក៏ឱ្យហាការជាសាសន៍អេស៊ីព្ទ
បាវខ្លួន ទៅធ្វើជាប្រពន្ធរបស់ប្តីទៅ ក្នុងពេលក្រោយដែល
អាប់រ៉ាម បាននៅស្រុកកាណាន[ឆ]១០ឆ្នាំហើយ[ជ] ៤គាត់ក៏ចូល
ទៅឯហាការ[ឈ] ហើយនាងមានទំងន់ លុះដឹងខ្លួនថាមាន
ទំងន់ដូច្នោះ នោះក៏តាំងមើលងាយដល់ចៅហ្វាយខ្លួនវិញ[ញ]
៥សារ៉ាយនាងនិយាយទៅអាប់រ៉ាមថា សូមឱ្យសេចក្តី
កំហុសរបស់ខ្ញុំធ្លាក់ទៅលើអ្នកចុះ ដ្បិតខ្ញុំបានឱ្យបាវស្រីរបស់
ខ្ញុំទៅអ្នកឱប ឥឡូវនេះដែលវាដឹងថា មានទំងន់ហើយ នោះ
បែរជាមើលងាយដល់ខ្ញុំវិញ ដូច្នេះសូមឱ្យព្រះយេហូវ៉ា
ជំនុំជំរះរឿងរបស់យើងចុះ[ដ] ៦នោះអាប់រ៉ាមគាត់ឆ្លើយនឹង
សារ៉ាយថា មើល បាវស្រីឯងវានៅក្នុងអំណាចរបស់
ឯងស្រាប់ហើយ[ឋ] ចូរប្រព្រឹត្តនឹងវា តាមតែឯងគិតឃើញថា
យ៉ាងណាស្រួលចុះ" នោះសារ៉ាយ ក៏ប្រព្រឹត្តនិងនាងដោយ
តឹងរ៉ឹងណាស់[ឌ] បានជានាងរត់ចេញពីគាត់ទៅ ។
៧ទេវតានៃព្រះយេហូវ៉ា[ឍ] ទ្រង់ឃើញនាងនៅទីរហោ

**១៥:១៨** ច លប ១៧:២,៤,៧ នក ៦:៤ ៣៤:១០,២៧ ១រប ១៦:១៦ ទដ ១០៥:៩ ឆ លប ១២:៧ ជ ជន ៣៤:៥ យក ១៥:៤,៤៧ ១ពវ ៨:៦៥ ២ពវ ២៤:៧ ២រប ៧:៨ អស ២៧:១២ យរ ៣៧:៥ ៤៦:២ បទ ៤:១៧ អគ ៣០:២២ ៤៧:១៩ ឈ លប ២:១៤ **១៥:១៩** ញ ជន ២៤:២១ ពច ១:១៦ ៤:១១,១៧ ៥:២៤ ១សយ ១៥:៦ ២៧:១០ ៣០:២៩ ១រប ២:៥៥ **១៥:២០** ដ លប ១០:១៥ ចទ ៧:១ ឋ លប ១៣:៧ ឌ លប ១៤:៥ **១៥:២១** ឍ លប ១០:១៦ យស ៣:១០ ២៤:១១ នហ ៩:៨ **១៦:១** ក លប ១១:២៩ ខ លប ១១:៣០ លក ១:៧,៣៦ កទ ៤:២៤–២៥ គ កទ ២១:៩ ២៤:៦១ ២៩:២៤,២៩ ៣១:៣៣ ៤៦:១៨ ឃ ខ.៣–៤,៨,១៥ លប ២១:១៤ ២៥:១២ **១៦:២** ង លប ២៩:៣១ ៣០:២ ច លប ១៩:៣២ ៣០:៣–៤,៩–១០ **១៦:៣** ឆ លប ១២:៥ ជ លប ១២:៤ **១៦:៤** ឈ ខ.១ ញ លប ៣០:១ ១សយ ១:៦ **១៦:៥** ដ លប ៣១:៥៣ នក ៥:២១ ពច ១១:២៧ ១សយ ១១:២៧ ១សយ ២៤:១២,១៥ ២៦:១០,២៣ ទដ ៥០:៦ ៧៥:៧ **១៦:៦** ឋ យស ៩:២៥ ឌ លប ៣១:៥០ **១៦:៧** ឍ ខ.១១ លប ២១:១៧

---

បំពេញនូវសេចក្តីដម្រូវការរបស់គាត់ គឺការធានារ៉ាបរងលើទឹកដី ។ ព្រះយេហូវ៉ា ទ្រង់បានយល់ព្រមនឹងសេចក្តីសន្យាដែលទ្រង់បានតាំងជាមួយលោកអាប់រ៉ាមដូចគ្នានឹងសេចក្តីសន្យាដែលទ្រង់បានធ្វើជាមួយលោកណូអេដែរ (៩:៩ និងការពន្យល់) ។

**១៥:១៨** *តាំងសញ្ញា* "កាត់សេចក្តីសញ្ញា"គឺសំដៅលើសត្វដែលបានសម្លាប់ដូចគ្នានឹងកិរិយាស័ព្ទរបស់ហេព្រើរដែលបកប្រែថា "តាំង" ហើយ "កាត់" នៅក្នុង (យរ ៣៤:១៨) ។ អញនិងឱ្យស្រុកនេះបានសម្រេចតាមសេចក្តីសន្យារបស់ព្រះ ដំបូងគឺតាមរយៈលោកយ៉ូស្វេ (មើល យស ១:២៩ ២១:៤៣ ១ពវ ៤:២០–២១) ។ ទន្លេស្រុកអេស៊ីព្ទប្រហែលជាទន្លេដែលល្បីឈ្មោះមួយដែលមានឈ្មោះថា "វេដឌែល–អារីស" Wadiel-Arish ដែលស្ថិតនៅភាគខាងជើងពីតំបន់ស៊ីណៃយ ។ អឺប្រាតគឺជាទន្លេដែលមានចំងាយវែងជាងគេក្នុងទ្វីបអាស៊ីខាងត្បូង (ប្រហែល ១៧០០ម៉ាយ) ។ វាបានធ្វើឱ្យយើងកត់សំគាល់ចំពោះព្រំដែនពួកអ៊ីស្រាអែល និងប្រវត្តិសាស្ត្រសេដ្ឋកិច្ចរបស់អ៊ីស្រាអែល អាស៊ី និងបាប៊ីឡូន រហូតដល់តំបន់ខាងកើត (ប្រៀបធៀប អស ៨:៥–៨)។

**១៥:១៩–២១** ឈ្មោះសហគមន៍នេះគឺប្រហាក់ប្រហែលនឹង សហគមន៍កាណានដែលមាននិយាយក្នុង (១០:១៥–១៨ មើលការពន្យល់) ។ នៅទីនេះមានមនុស្សចំនួន១០នាក់ហើយលេ ខ.១០ គឺជាលេខដែលមានសារៈសំខាន់ ។ សំរាប់ឈ្មោះផ្សេងៗទៀតដែលបានតាំងលំនៅក្នុងទឹកដីកាណាន សូមមើល នក ៣:៨,១៧ ១៣:៥ ២៣:២៣ ៣៣:២ ៣៤:១១ ជន ១៣:២៩ ចទ ៧:១ ២០:១៧ យស ៣:១០ ៩:១ ១១:៣ ១២:៨ ២៤:១១ ពច ៣:៥ ១រប ១:១៤ ២រប ៨:៧ អរ ៩:១ នហ ៩:៨ ។

**១៦:១–១៥** ការខ្វះនូវសេចក្តីជំនឿនិងធ្វើឱ្យយើងព្យាយាមប្រព្រឹត្តដោយមិនអៀនខ្មាស់តាមមធ្យោបាយផ្ទាល់របស់មនុស្ស នូវអ្វីដែលព្រះយេហូវ៉ាទ្រង់មិនសព្វព្រះហឫទ័យនិងហាមឃាត់ ។ សារ៉ាយគឺជាអ្នកចាប់ផ្តើមផ្តល់គំនិត (ខ.២) ហើយលោកអាប់រ៉ាមជាអ្នកអនុវត្តន៍ "អ៊ីស្មាអែល" (សូមមើល ខ.១៥ និងការពន្យល់) នូវការមិនចេះរងចាំរបស់ពួកគេជាមួយព្រះចំពោះភាព ជាស្ត្រីអាររបស់នាងសារ៉ាយ ។

**១៦:១** *មិនបង្កើតកូនឱ្យគាត់សោះ* សូមមើល ១១:៣០ ជាជនជាតិអេស៊ីព្ទ ។ ប្រហែលជាលោកអាប់រ៉ាមនឹងសារ៉ាយបានទទួលយកនាងហាកាយមកធ្វើជាអ្នកបម្រើក្នុងអំឡុងពេល ដែលពួកគេរស់នៅក្នុងស្រុកអេស៊ីព្ទមកម្ល៉េះ (មើល ១២:១០–២០) ។

**១៦:២** *ព្រះយេហូវ៉ាទ្រង់បង្ខាំងមិនឱ្យខ្ញុំមានកូនទេ* ពេលខ្លះព្រះយេហូវ៉ាទ្រង់សម្តែងឱ្យគេបានដឹងតាំងពីក្នុង ១៥:៤ មកម្ល៉េះ (មើល ១៦:៣) ដោយសារការមិនចេះអត់ធ្មត់ធ្វើឱ្យសារ៉ាយនិយាយបញ្ឆិតថា ព្រះយេហូវ៉ាទ្រង់មិនបានរក្សាសេចក្តីសន្យារបស់ទ្រង់ឡើយ ។ *សូមអញ្ជើញចូលទៅឯបាវស្រីរបស់ខ្ញុំចុះ* តាមទំនៀមទម្លាប់ពីបុរាណការរៀបការ គឺមានការផ្គុំយគ្នាដូចជា ឧ. បញ្ជាក់អំពីពួកអាសេីរជំនាន់មុនគឺគេប្រព្រឹត្តតាមច្បាប់របស់"ហាម់មូរាបពី" (Hammurapi) នឹងសិលាចារឹករបស់ពួក "នូស៊ី" (Nuzi) (មើល ១៥:៣៤) ដែលបានធានាអំពីនឹងមានម្នាក់ជាអ្នកស៊ីមរតក ។

**១៦:៣** *១០ឆ្នាំ* ឥឡូវនេះអាប់រ៉ាមមានអាយុ៨៥ឆ្នាំ (មើល ១២:៤ ១៦:១៦)។

**១៦:៤** *មើលងាយដល់ចៅហ្វាយខ្លួនវិញ* គឺដូចគ្នានឹងទង្វើររបស់នាងពេនីណា បានធ្វើមកនាងហាណាដែរ (១សយ ១:៦) ។

**១៦:៥** *ដូច្នេះសូមឱ្យព្រះយេហូវ៉ាទ្រង់ជំនុំជំរះរឿងរបស់យើងចុះ* គឺជាការរៀបរាប់អំពីការមិនយល់ព្រម ឬសង្ស័យចំពោះព្រះ (សូមមើល ៣១:៥៣ ៣១:៤៩ និងការពន្យល់) ។

**១៦:៧** *ទេវតានៃព្រះយេហូវ៉ា* នៅក្នុងអំឡុងពេលដែលទេវតានៃព្រះយេហូវ៉ាបាននាំព្រះបន្ទូលពីព្រះយេហូវ៉ាមកកាន់មនុស្សជាលើកដំបូង (ខ.១០) នាង

ស្ថានជិតក្បាលទឹក១[ណ] គឺជាក្បាលទឹកដែលនៅតាមផ្លូវទៅ
ឯស្រុកស៊ើរ[ត] ៨ទ្រង់មានបន្ទូលសួរថា នែហាការ[ថ]បាវ
សារ៉ាយអើយ តើឯងមកពីណា ហើយគិតទៅឯណាហ្នឹង[ទ]
នាងទូលឆ្លើយនឹងទេវតាថា ខ្ញុំម្ចាស់រត់ចេញពីសារ៉ាយ
ជាចៅហ្វាយរបស់ខ្ញុំម្ចាស់មក ។
៩នោះទេវតានៃព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅនាងថា
ចូរវិលទៅឯចៅហ្វាយឯងវិញទៅ ហើយចុះចូលនឹង
អំណាចរបស់គាត់វិញ ១០ទេវតានៃព្រះយេហូវ៉ាក៏មាន
បន្ទូលទៅនាងថា អញនឹងចំរើនពូជឯង ឱ្យមានសន្ធឹកឥត
គណនា[ធ] ១១ទេវតានៃព្រះយេហូវ៉ា[ន]មានបន្ទូលនឹងនាង
ទៀតថា មើលឯងមានទំងន់ ឯងនឹងបង្កើតបានកូន ប្រុស១[ប]
ដែលត្រូវឱ្យឈ្មោះថា[ផ] អ៊ីសម៉ាអែល[ព]ពីព្រោះ ព្រះយេហូវ៉ា
ទ្រង់ជ្រាបពីសេចក្តីទុក្ខលំបាករបស់ឯង[ភ] ១២វានឹងបានដូច
ជាលាព្រៃ[ម]នៅកណ្តាលមនុស្ស ដៃវានឹងបានទាស់នឹង
មនុស្សទាំងអស់ ហើយដៃមនុស្សទាំងអស់នឹងបានទាស់នឹង
វាដែរ វានឹងតាំងទីលំនៅនៅមុខពួកបងប្អូនវាទាំងអស់
គ្នា[យ] ១៣នោះនាងក៏ហៅព្រះនាមព្រះយេហូវ៉ាដែលកំពុង
មានបន្ទូលនឹងនាងថា "ព្រះដ៏ទតឃើញ"[រ]ដ្បិតនាងគិតថានៅ
ទីនេះអញបានឃើញព្រះដែលទ្រង់ទតឃើញអញទេតើ[ល]
១៤ហេតុនោះបានជាគេហៅក្បាលទឹកនោះ[វ]ថា ក្បាលទឹក
ឡាហាយ-រយ[ស] នោះនៅកណ្តាលកាដែស[ហ]និងបារេឌ ។
១៥ហាការ[ឡ]ក៏បង្កើតកូនប្រុស១[អ]ឱ្យអាប់រ៉ាម ហើយអាប់
រ៉ាមឱ្យកូនដែលហាការបង្កើតនោះឈ្មោះអ៊ីសម៉ាអែល[ក]
១៦គ្រាដែលហាការបានបង្កើតអ៊ីសម៉ាអែល នោះអាប់រ៉ាម
គាត់អាយុបាន៨៦ឆ្នាំហើយ[ខ] ។

## ការតាំងសញ្ញានៃការកាត់ស្បែក

**១៧** ១លុះដល់អាប់រ៉ាមអាយុបាន៩៩ឆ្នាំ[ក] នោះព្រះយេហូ
វ៉ាទ្រង់លេចមកឯគាត់[ខ]ប្រាប់ថា "អញជាព្រះដ៏មានគ្រប់
ព្រះចេស្តា[គ] ចូរឯងដើរនៅមុខអញ ហើយឱ្យបានគ្រប់

២២:១១,១៥ ២៤:៧,៤០ ៣១:១១ ៤៨:១៦ នក ៣:២ ១៤:១៩ ២៣:២០,២៣ ៣២:៣៤ ៣៣:២ ជន ២២:២២ ពច ២:១ ៦:១១ ១៣:៣ ២សយ ២៤:១៦ ១ពវ ១៩:៥ ២ពវ ១:៣ ១៩:៣៥ ទដ ៣៤:៧ សក ១:១១ ណ ខ.១៤ លប ២១:១៩ ត លប ២០:១ ២៥:១៨ នក ១៥:២២ ១សយ ១៥:៧ ២៧:៨ **១៦:៨** ថ ខ.១ ទ លប ៣:៩ **១៦:១០** ធ លប ១៣:១៦ **១៦:១១** ន ខ.៧ កច ៥:១៩ ប លប ៣:១៥ ផ លប ១២:២-៣ ១៨:១៩ នហ ៩:៧ អស ៤៤:១ អម ៣:២ មថ ១:២១ លក ១:១៣,៣១ ព លប ១៧:១៩ ២១:៣ ៣៧:២៥,២៨ ៣៩:១ ពច ៨:២៤ ភ លប ២៩:៣២ ៣១:៤២ នក ២:២៤ ៣:៧,៩ ៤:៣១ ជន ២០:១៦ ចទ ២៦:៧ ១សយ ៩:១៦ **១៦:១២** ម លប ៦:៥ ១១:១២ ២៤:៥ ៣៩:៥ ទដ ១០៤:១១ យរ ២:២៤ ហស ៨:៩ យ លប ២៥:១៨ **១៦:១៣** រ ទដ ១៣៩:១-១២ ល លប ៣២:៣០ ៣៣:១០ នក ២៤:១០ ៣៣:២០,២៣ ជន ១២:៨ ពច ៦:២២ ១៣:២២ អស ៦:៥ **១៦:១៤** វ ខ.៧ ស លប ២៤:៦២ ២៥:១១ ហ លប ១៤:៧ **១៦:១៥** ឡ ខ.១ អ លប ២១:៩ កទ ៤:២២ ក កទ ១៧:១៨ ២៥:១២ ២៨:៩ **១៦:១៦** ខ លប ១២:៤ **១៧:១** ក លប ១២:៤ ខ លប ១២:៧ គ លប ២៨:៣ ៣៥:១១ ៤៣:១៤ ៤៨:៣ ៤៩:២៥ នក ៦:៣ នរ ១:២០ យប ៥:១៧ ៦:៤,១៤ ២២:២១ ៣៣:១៩ ៣៦:១៦ អស ១៣:៦ យអ ១:១៥ មីក ៦:៩

ហាការក៏បាននិយាយពីព្រះនាមព្រះយេហូវ៉ាថា ព្រះយេហូវ៉ាជាអ្នកដែលមានបន្ទូលមកកាន់នាង (ព្រះទតឃើញខ្ញុំ) (ខ.១៣) ទេវតានៃព្រះយេហូវ៉ាបានលេចមកយ៉ាងល្អក្រៃលែង ដែលមកពីព្រះយេហូវ៉ាពេលនោះហៅថា "អ្នកនាំសារ" ពីព្រោះក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យ "ទេវតា" មានន័យថា "អ្នកនាំសារ" ហើយនាងក៏បានមានទំនាក់ទំនងជាមួយទេវតានោះ ។ សម្រាប់ការវែកញែកនឹងការណែនាំដែលមានការប្រហាក់ប្រហែលគ្នានេះទៀតយើងអាចរកឃើញនៅ ១៩:១,២១ ៣១:១១,១៣ នក ៣:២៤ ពច ២:១-៥ ៦:១១-១២,១៤ ១៣:៣,៦,៨-១១,១៥-១៧,២០-២៣ អស ៣:១៦ ១២:៨ ។ តាមទម្លៀមទម្លាប់របស់គ្រីស្ទបរិស័ទបាននិយាយថា "ទេវតា" គឺជាអ្នកនាំការបើកដំដែង ពីព្រះគ្រីស្ទដែលជាអ្នកនាំព្រះរាជសារព្រះយេហូវ៉ាមក ។ វាអាចក្លាយជាការពិតបានតែទោះបីជាយ៉ាងណាក៏ដោយអ្នកនាំព្រះរាជសាររបស់ព្រះយេហូវ៉ាគឺជាអ្នកតំណាងឱ្យទ្រង់ផ្ទាល់ទេវតាអាចនិយាយក្នុងនាមនាំអស់ទាំងពាក្យអ្នកដែលបញ្ជូនខ្លួនមក (សូមមើល ១៩:២១ ប្រៀបធៀបនិង ១៨:២,២២ ១៩:២) ។ ទោះបីជាយ៉ាងណាក៏ដោយ "ទេវតា" នេះគឺជាមនុស្សទី២ក្នុងចំណោមព្រះត្រៃឯកដែលការនិយាយ ដូច្នេះមិនពិតនោះឡើយ (ធៀបនឹង លក ២:៩ និងការពន្យល់) ។ *ស៊ើរ* ស្ថិតនៅភាគខាងកើតនៃស្រុកអេស៊ីព្ទក្រោម (២៥:១៨ ១សយ ១៥:៧) ។

**១៦:៨** *ខ្ញុំម្ចាស់រត់ចេញពីសារ៉ាយជាចៅហ្វាយរបស់ខ្ញុំម្ចាស់មក* នាងហាការបានឆ្លើយនូវសំណួរដំបូងរបស់ទេវតាដោយមិនទាន់ដឹងប្រាកដថា នាងទៅកន្លែងណាឡើយ ។

**១៦:១០** សេចក្តីសន្យានេះបាននិយាយម្តងទៀតក្នុង ១៧:២០ ហើយបានសម្រេចក្នុង ២៥:១៣-១៦ ។

**១៦:១១** *អ៊ីសម៉ាអែល* មើលការពន្យល់នៃអត្ថបទ ១៧:២០ ។

**១៦:១២** *លាព្រៃ* ប្រហែលជាសត្វលាព្រៃគឺជាសត្វត្រាច់ចរនៅលើកន្លែងហួតហែងនៅមជ្ឈិមបូព៌ា ។ អ៊ីសម៉ាអែលអាចត្រាច់ចរលើវាលរហោស្ថានដូចជាលាព្រៃ (យប ២៤:៥ ហស ៨:៩) ។ *ទាស់* ទម្នាស់រវាងនាងសារ៉ាយនិងហាការ (មើល ខ.៤៦) គឺបានបន្តពីជំនាន់មួយទៅជំនាន់មួយ (២៥:១៨) ។

**១៦:១៣** *អញបានឃើញព្រះដែលទតឃើញអញទេតើ* ប្រៀបធៀប នក ៣៣:២៣ ។ ការឃើញព្រះភ័ក្រទ្រង់ នឹងធ្វើឱ្យស្លាប់ (៣២:២០ នក ៣៣:២០) ។

**១៦:១៤** *ក្បាលទឹកឡាហាយ-រយ* មានការបកប្រែផ្សេងទៀតដែលសក្តិសមនឹងអត្ថបទនេះគឺ "អ្នកដែលទតឃើញអញគឺជាអ្នកដែលមានព្រះជន្មរស់នៅ" ដូចជាហាការបាននិយាយ ។ *កាដែស* សូមមើលក្នុង ១៤:៧ ។

**១៧:១-២៧** ការតាំងសញ្ញារជាថ្មីម្តងទៀតរវាងព្រះនឹងលោកអាប់រ៉ាម ។ បន្ទាប់ពីលោកអាប់រ៉ាម និងនាងសារ៉ាយបានព្យាយាមដើម្បីឱ្យបានកូនតាមរយៈផ្ទៃរបស់អ្នកបម្រើនាងសារ៉ាយមកព្រះយេហូវ៉ាបានលេចមកឯលោកអាប់រ៉ាមដើម្បីប្រកាសពីសេចក្តីសន្យារបស់ទ្រង់ជាថ្មីម្តងទៀត ។ ប៉ុន្តែព្រះយេហូវ៉ាទ្រង់បានបញ្ជាក់បន្ថែមទៀតថា បើសិនជាលោកអាប់រ៉ាមគាត់ទទួលកម្រៃតាមរយៈការតាំងសញ្ញារបស់ព្រះ គាត់ត្រូវតែទៅរស់នៅកន្លែងផ្សេង "សម្រាប់ឱ្យមនុស្សចុះចូលតាមសេចក្តីជំនឿ" (រ៉ូម១:៥ និងជំពូក ២២) ។ នៅចុងបញ្ចប់ព្រះយេហូវ៉ាបានហៅលោកអាប់រ៉ាមឱ្យមកធ្វើសេចក្តីសញ្ញាលើការតាំងសញ្ញានឹងការស្តាប់បង្គាប់ទ្រង់ ។

**១៧:១** *៩៩ឆ្នាំ* រយៈពេល១៣ឆ្នាំបន្ទាប់ពីកំណើតអ៊ីសម៉ាអែល ព្រះយេហូវ៉ា

លក្ខណ៍ចុះ[ឃ] 2នោះអញនឹងតាំងសញ្ញានឹងឯង[ង] ហើយនិង
ចំរើនឯងឱ្យមានគ្នាជាសន្ធឹកឡើង[ច] 3អាប់រ៉ាមក៏ក្រាប
ផ្កាប់មុខ[ច] រួចព្រះទ្រង់មានបន្ទូលនឹងគាត់ថា 4ឯអញ មើល
អញបានតាំងសេចក្តីសញ្ញានឹងឯងហើយ[ជ] ឯងនឹងធ្វើជា
ឪពុកនៃសាសន៍ជាច្រើន[ឈ] 5ឈ្មោះឯងមិនត្រូវហៅថា
អាប់រ៉ាមទៀតទេ គឺត្រូវហៅថា អ័ប្រាហាំវិញ[ដ] ដ្បិតអញ
បានតាំងឯង ឱ្យធ្វើជាឪពុកនៃសាសន៍ជាច្រើន[ថ] 6អញនឹង
ធ្វើឱ្យឯងបង្កើតកូនសុសសាយសន្ធឹក[ឌ] ឱ្យមាននគរផ្សេងៗ
កើតចេញអំពីឯងមក ព្រមទាំងស្តេចជាច្រើនដែរ[ឍ] 7អញ
នឹងតាំងសញ្ញា[ណ,ត]នឹងឯង ហើយនិងពូជឯងតាមដំណគេ
តទៅ ទុកជាសេចក្តីសញ្ញាដ៏នៅអស់កល្បជានិច្ច[ថ,ទ] ដើម្បីឱ្យ
អញបានធ្វើជាព្រះនៃឯង[ធ] និងពូជឯងតទៅ[ន] 8ឯស្រុក
កាណានទាំងអស់[ប]ដែលឯងសំណាក់នៅជាមួយអ្នកដទៃ[ផ]
នោះអញនឹងឱ្យដល់ឯងនិងពូជឯងតរៀងទៅ[ព] ទុកជាកេរ្តិ៍
អាករអស់កល្បជានិច្ច ហើយអញនឹងធ្វើជាព្រះដល់គេ[ភ]។
9រួចទ្រង់មានបន្ទូលនឹងអ័ប្រាហាំទៀតថា ឯឯង ត្រូវឱ្យ
ឯងកាន់តាមសេចក្តីសញ្ញារបស់អញ[ម] ទាំងឯងនិងពូជឯងត
រៀងទៅតាមដំណគេ[យ] 10នេះជាសេចក្តីសញ្ញារបស់អញ
ដែលឯងនិងពូជឯងត្រូវកាន់ចំពោះអញតរៀងទៅ គឺថា

ឃ លប ៥:២២ ២០:៥ ចទ ១៨:១៣ ១ពវ ៣:៦ ៩:៤ យប ១:១ ទដ ១៥:២ ១៨:២៣ ៧៨:៣២ ១០១:២ **១៧:២** ង លប ១៥:១៨ ២២:១៦–១៨ ច លប ១២:២ **១៧:៣** ឆ ខ.១៧ លប ១៨:២ ១៩:១ ៣៣:៣ នក ១៨:៧ ជន ១៤:៥ យស ៥:១៤ ៧:៦ ពច ១៣:២០ អគ ១:២៨ ៣:២៣ **១៧:៤** ជ លប ១៥:១៨ ញ ខ.១៦ លប ១២:២ ២៥:២៣ **១៧:៥** ដ ខ.១៥ លប ៣២:២៨ ៣៥:១០ ៣៧:៣,១៣ ៤៣:៦ ៤៦:២ ១ពវ ១៨:៣១ ២ពវ ១៧:៣៤ ១រប ១:៣៤ នហ ៩:៧ អស ៤៨:១ យហ ១:៤២ ឋ រម ៤:១៧ **១៧:៦** ឌ លប ១:២៨ ២២:១៧ ២៦:២២ ២៨:៣ ៣៥:១១ ៤១:៥២ ៤៧:២៧ ៤៨:៤ ៤៩:២២ លវ ២៦:៩ ចទ ៧:១៣ ឍ ខ.១៦,១៩ លប ១៨:១០ ២១:១ ៣៦:៣១ អស ៥១:២ មថ ១:៦ **១៧:៧** ណ លប ១៥:១៨ លវ ២៦:៩, ១៥ ត លប ៦:១៨ ថ ហព ១៣:២០ ទ លប ៩:១៦ ធ នក ៦:៧ ២០:២ ២៩:៤៥,៤៦ លវ ១១:៤៤–៤៥ ១៨:២ ២២:៣៣ ២៥:៣៨ ២៦:១២,៤៥ ជន ១៥:៤១ ចទ ៤:២០ ៧:៦,២១ ២៩:១៣ ២សយ ៧:២៤ យរ ១៤:៩ វវ ២១:៧ ន រម ៩:៨ កទ ៣:១៦ **១៧:៨** ប លប ១០:៩ ផ លប ២៣:៤ ២៨:៤ ៣៥:២៧ ៣៧:១ នក ៦:៤ ១រប ២៩:១៥ ព ទដ ១២:៧ ១៥:៧ ភ ខ.៧ យរ ៣១:១១ **១៧:៩** ម លប ២២:១៨ នក ១៩:៥ ចទ ៥:២ យ លប ១៨:១៩ **១៧:១០** រ ខ.២៣ លប ២១:៤ លវ ១២:៣ យស ៥:២,៥,៧ យហ

ទ្រង់បានលេចមក(មើលការពន្យល់ ១២:៧)។ *អញ* មើល ១៥:៧ ។ តាមព្រះគម្ពីរភាសាហេព្រើរ ពាក្យព្រះដ៏មានគ្រប់ព្រះចេស្តា(អែលសាដាយ) មានន័យថា"ព្រះនៃភ្នំមួយ"ដែលសារៈសំខាន់នៃឈ្មោះទាំង២នេះ គឺនិយាយពីអំណាចព្រះចេស្តាដែលមិនចេះបរាជ័យរបស់ព្រះ ឬក៏ចង់សំដៅទៅលើភ្នំដែលជានិមិត្តរូបនៃតំណាក់របស់ព្រះ (ទដ ២១:១) ។ គឺជាព្រះនាមពិសេសមួយ ដែលព្រះយេហូវ៉ាទ្រង់បានបើកសំដែងអង្គទ្រង់ឱ្យពួកព្ធយុកោជីនាន់មុនបានស្គាល់ (នក ៦:៣) ។ *សាដាយ* ពាក្យនេះមាន៣១ដង នៅក្នុងព្រះគម្ពីរយ៉ូបនិងមាន១៧ដងទៀត នៅក្នុងព្រះគម្ពីរទាំងមូល ។ ចូរឯងដើរនៅមុខអញ ហើយឱ្យបានគ្រប់លក្ខណ៍ចុះប្រហែលមានន័យដូចគ្នានឹងពាក្យថា "ចូរឯងដើរជាមួយអញ ហើយឱ្យបានគ្រប់លក្ខណ៍ចុះ" (មើលការពន្យល់ ៥:២២ ៦:៨–៩) ។

**១៧:២** *តាំងសញ្ញា* មើល ១៥:៤៥ ។ សេចក្តីសញ្ញានោះគឺជារបស់ព្រះ ព្រះយេហូវ៉ាទ្រង់បានមានបន្ទូលថា"តាំងសញ្ញា"មាន៩ដងចាប់ពី ខ.២–២១ ហើយព្រះយេហូវ៉ាទ្រង់ជាអ្នកចាប់ផ្តើម(១៥:១៨)ធានាអះអាង(ខ.២) តាំងឡើង(៧) ។ ចម្រើនពូជឯងឱ្យមានគ្នាជាសន្ធឹកឡើងនៅក្នុង ១:២៨ ចំពោះ (អ័ដាម) និង ៩:៧ (ណូអេ) បានបង្ហាញអំពីផែនការណ៍ និងបំណងព្រះហឫទ័យរបស់ព្រះចំពោះមនុស្ស ដែលព្រះបានបង្កើតត្រូវបានបំផ្លាញដោយសារ អំពើបាបរបស់មនុស្សតែបានសម្រេចមកវិញតាមរយៈលោកអាប់រ៉ាមនិងកូនចៅរបស់គាត់ នក ១:៧ និងការពន្យល់ ។ សូមមើល ១៣:៦ និងការពន្យល់ ។ ដំបូងព្រះយេហូវ៉ា ទ្រង់បានធ្វើការតាំងសញ្ញាដែលទាក់ទងនឹងទឹកដីសន្យា (ជំពូក១៥) ហើយនៅទីនេះគឺនិយាយពីការរីកចម្រើននៃកូនចៅរបស់ពួកគេ ។

**១៧:៥** *អាប់រ៉ាម . . . អ័ប្រាហាំ* សូមមើលក្នុងសេចក្តីពន្យល់ ។ ឈ្មោះដំបូងមានន័យថា "ឪពុកដែលគួរនឹងលើកតម្កើង" ប្រហែលជាសំដៅលើព្រះយេហូវ៉ា ឧទាហរណ៍ "ព្រះយេហូវ៉ា" (ជាព្រះវរបិតាដែលគួរទទួលការលើកតម្កើង) ហើយឈ្មោះបន្ទាប់មានន័យថា "ឪពុកនៃសាសន៍ជាច្រើន" សំដៅលើលោកអ័ប្រាហាំ ។ ត្រូវហៅតាមរយៈការដាក់ឈ្មោះថ្មីឱ្យអាប់រ៉ាម (មើល ៩:៧) ព្រះយេហូវ៉ាដៅចំណាំគាត់ធ្វើជាអ្នកបម្រើពិសេស(មើលការពន្យល់ ១:៥ ២:១៩) ។

**១៧:៦** *ឱ្យមាននគរ . . . ព្រមទាំងស្តេចជាច្រើន* ព្រះយេហូវ៉ាទ្រង់ក៏បានសន្យាជាមួយនឹងសារ៉ានូវសេចក្តីសន្យាបែបនេះដែរ (ខ.១៦) ហើយសេចក្តីសន្យានេះកើតឡើងម្តងទៀត នៅពេលដែលព្រះអង្គសន្យាជាមួយលោកយ៉ាកុប ៣៥:១១ (មើល ៤៨:១៩) ។ គឺសំដៅលើការរីកសាយនៃកូនចៅរបស់លោកអ័ប្រាហាំ ដូចជាកូនចៅរបស់លោកណូអេដែរ(មើលជំពូក១០) ដែលនៅថ្ងៃណាមួយគេនឹងក្លាយជានគរដ៏ធំមួយ ដែលមានគ្នាច្រើនពេញពាសផែនដី ។ ចំនួនដ៏ច្រើនបែបនេះ បានសម្រេចដូចជានៅក្នុង រម ៤:១៦–១៨ ១៥:៨–១២ កទ ៣:២៩ វវ ៧:៩ ២១:២៤ ។

**១៧:៧** *អស់កល្បជានិច្ច* ព្រះយេហូវ៉ាទ្រង់បានសម្រេចព្រះទ័យចំពោះសេចក្តីសញ្ញារបស់ទ្រង់ថា ជាសេចក្តីសញ្ញាដ៏ស្ថិតស្ថេរអស់កល្បជានិច្ច(មើលខ.១៣ និង ខ.១៩) ប៉ុន្តែ កូនចៅលោកអ័ប្រាហាំអាចនឹងកាត់ចេញពីសាសន៍(ខ.១៤ ប្រៀបធៀប អស ២៤:៥ យរ ៣១:៣២) ។ *ធ្វើជាព្រះនៃឯង* វាជាចំណុចស្នូល ដើម្បីរក្សាសេចក្តីសញ្ញារបស់ព្រះដែលបាននិយាយម្តងហើយម្តងទៀតនៅក្នុងសញ្ញាចាស់ ឧទាហរណ៍ (ខ.៨ យរ ២៤:៧ ៣១:៣៣ អគ ៣៤:៣០,៣១ ហស ២:២៣ សក ៨:៨) ។ នេះជាសេចក្តីសន្យារបស់ព្រះ គឺព្រះអង្គធ្វើជាអ្នកធានាអះអាងចំពោះអនាគតរបស់ពួកគេ (១៥:១) ។

**១៧:៨** *ស្រុក* មើល ១២:៧ ១៥:១៨ កច ៧:៥ ។ ទុកជាកេរ្តិ៍អាករអស់កល្បជានិច្ច ទោះជាព្រះអង្គឱ្យគេទុកជាកេរ្តិ៍អាករអស់កល្បជានិច្ចពិតមែន ប៉ុន្តែថ្ងៃណាមួយនឹងបាត់បង់ ដោយសារការមិនស្តាប់បង្គាប់ព្រះ (ចទ ២៨:៦២–៦៣ ៣០:១–១០) ។

**១៧:១០** *កាត់ស្បែក* ការកាត់ស្បែកគឺការបង្គាប់របស់ព្រះ"ទីសំគាល់ពីសេចក្តីសន្យា" ដែលជាទីសំគាល់ពីការប្តេជ្ញាចិត្តរបស់លោកអ័ប្រាហាំ ក្នុងពេលតាំងសញ្ញាជាមួយព្រះថា មានតែព្រះយេហូវ៉ាមួយប៉ុណ្ណោះ ដែលជាព្រះរបស់លោក ដែលលោកត្រូវតែទុកចិត្តនិងគោរពបម្រើ ។ ការតាំងសញ្ញានេះ ក៏ជានិមិត្តសញ្ញាមួយដែលបង្ហាញអំពីបណ្តាសាមួយដែរ "បើសិន

គ្រប់ទាំងពួកប្រុសៗក្នុងពួកឯង ត្រូវតែកាត់ស្បែក[រ]
១១ឯងរាល់គ្នាត្រូវកាត់ស្បែកស្រោមចុងស្វាស[ល] ទុកជាទីសម្គាល់
[វ]ពីសេចក្ដីសញ្ញាដែលយើងបានតាំងជាមួយនឹងគ្នា
១២គ្រប់ទាំងកូនប្រុសៗនៅអស់ទាំងដំណាងតទៅ[ស] ទោះបើកើត
នៅផ្ទះ ឬបានយកប្រាក់ទិញពីសាសន៍ណាដទៃ ដែលមិន
មែនជាពូជឯងក្ដី ដល់កើតមកបាន៨ថ្ងៃ នោះត្រូវតែកាត់
ស្បែក[ហ]ឱ្យ
១៣ទោះបើកូនដែលកើតនៅផ្ទះឯង ឬកូនដែល
បានទិញនឹងប្រាក់មកក្ដី នោះក៏ត្រូវតែកាត់ស្បែកទាំងអស់
ដែរ[ឡ] ទើបសេចក្ដីសញ្ញារបស់អញនឹងនៅជាប់ក្នុងសាច់
ឯងរាល់គ្នា ទុកជាសេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ច[អ]
១៤មនុស្សប្រុសណាដែលមិនកាត់ស្បែក[ក] គឺមិនបានកាត់
ស្រោមចុងស្វាស អ្នកនោះនឹងត្រូវកាត់កាល់ចេញពីសាសន៍
របស់ខ្លួន[ខ] ព្រោះបានលះចោលសេចក្ដីសញ្ញារបស់អញ
ហើយ[គ] ។

១៥រួចព្រះទ្រង់ក៏មានបន្ទូលនឹងអ័ប្រាហាំទៀតថា ឯសា
រ៉ាយ[ឃ]ជាប្រពន្ធឯង នោះឯងមិនត្រូវហៅថាសារ៉ាយទៀត
ទេ គឺត្រូវហៅថាសារ៉ាវិញ[ង]
១៦អញនឹងឱ្យពរដល់នាង
ហើយនិងឱ្យឯងមានកូនពីនាងដែរ[ច] អញនឹងឱ្យពរដល់
នាងជាពិត នាងនឹងធ្វើជាម្ដាយនៃនគរផ្សេងៗ ហើយនឹង
មានស្ដេច[ឆ] នៃសាសន៍ជាច្រើនចេញពីនាងមក
១៧នោះ
អ័ប្រាហាំក៏ក្រាបផ្កាប់មុខ[ជ] នឹកអស់សំណើច[ឈ]ក្នុងចិត្តថា
តើនឹងមានកូនកើតដល់មនុស្សអាយុ១០០ឆ្នាំបានដែរឬ[ញ]
ហើយសារ៉ាដែលអាយុ៩០ឆ្នាំទៅហើយ តើនឹងបង្កើតកូន
បានឬទេ[ដ]
១៨រួចអ័ប្រាហាំទូលថា ឱបើសិនជាអ៊ីសម៉ាអែល
[ឋ]នឹងរស់នៅចំពោះទ្រង់ទៅអេះ[ឌ]
១៩នោះព្រះទ្រង់មាន
បន្ទូលថា សារ៉ាប្រពន្ធឯងនឹងបង្កើតកូនឱ្យឯងមែន[ឍ] ហើយ
ឯងត្រូវឱ្យឈ្មោះថាអ៊ីសាក[ណ] អញនឹងតាំងសញ្ញានឹងវា[ត]
ទុកជាសេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ច[ថ] សំរាប់ពូជវាត
រៀងទៅ
២០ឯអ៊ីសម៉ាអែល អញបានយល់ព្រមហើយ
មើលអញបានឱ្យពរដល់វា ហើយនិងធ្វើឱ្យវាកើតបានកូន
ចំរើនឡើងសន្ធឹកណាស់ដែរ[ទ] វានឹងបង្កើតចៅហ្វាយ១២
នាក់[ធ] ហើយអញនឹងធ្វើឱ្យវាបាន ត្រឡប់ជានគរ១យ៉ាងធំ[ន]
២១តែឯសេចក្ដីសញ្ញារបស់អញ[ប] នោះនឹងបានតាំងនឹង
អ៊ីសាកវិញ ដែលសារ៉ានឹងបង្កើតឱ្យដល់ឯង[ផ]នៅកំណត់ឆ្នាំ
ក្រោយនេះ[ព]
២២លុះព្រះទ្រង់មានបន្ទូលនឹងអ័ប្រាហាំស្រេច
ហើយ នោះទ្រង់ឃ្លាតចេញពីគាត់ហោះឡើងទៅ[ភ] ។

២៣ឯអ័ប្រាហាំយកអ៊ីសម៉ាអែលកូនខ្លួន ព្រមទាំងមនុស្ស

៧:២២ កច ៧:៨ រម ៤:១១ **១៧:១១** ល នក ១២:៤៨ ចទ ១០:១៦ វ លប ៩:១២ រម ៤:១១ **១៧:១២** ស លប ៩:១២ ហ លប ២១:៤ លវ ១២:៣ យស ៥:២ លក ១:៥៩ **១៧:១៣** ឡ នក ១២:៤៤,៤៨ អ លប ៩:១៦ **១៧:១៤** ក ខ.២៣ ខ នក ៤:២៤–២៦ ១២:១៥,១៩ ៣០:៣៣ លវ ៧:២០, ២៥ ១៧:៤ ១៨:២៩ ១៩:៨ ២០:១៧ ជន ៩:១៣ ១៥:៣០ ១៩:១៣ ចទ ១៧:១២ យស ៥:២–៨ យប ៣៨:១៥ ទដ ៣៧:២៨ គ អគ ៤៤:៧ **១៧:១៥** ឃ លប ១១:២៩ ង ខ.៥

**១៧:១៦** ច ខ.៦ អស ២៩:២២ ឆ ខ.៤ លប ២៤:៦០ កទ ៤:៣១ **១៧:១៧** ជ ខ.៣ ឈ លប ១៨:១២ ២១:៦ ញ លប ១២:៤ ដ លប ១៨:១១, ១៣ ២១:៧ ២៤:១,៣៦ យរ ២០:១៥ លក ១:១៨ រម ៤:១៩ កទ ៣:២៣ ហព ១១:១១ **១៧:១៨** ឋ លប ១៦:១៥ ឌ លប ២១:១១ **១៧:១៩** ឍ ខ.៦,២១ លប ១៨:១៤ ២១:២ ១សយ ១:២០ណ លប ១៦:១១ មថ ១:២១ លក ១:១៣, ៣១ ត លប ២៦:៣ ៥០:២៤ នក ១៣:១១ ចទ ១:៨ ថ លប ៩:១៦ កទ ៣:១៦ **១៧:២០** ទ លប ១៣:១៦ ធ លប ២៥:១២–១៦ ន លប ២៥:១៨ ៤៨:១៩ **១៧:២១** ប នក ៣៤:១០ ផ ខ.១៩ ព លប ១៨:១០,១៤ **១៧:២២** ភ លប ១៨:៣៣ ៣៥:១៣ ជន ១២:៩

ជាទូលបង្គំមិនស្មោះត្រង់ នឹងមិនស្ដាប់បង្គាប់ព្រះយេហូវ៉ាទេនោះសូមឱ្យព្រះយេហូវ៉ាទ្រង់កាត់ទូលបង្គំនឹងកូនចៅទូលបង្គំ ចេញពីសាសន៍របស់ខ្លួន (មើលខ.១៤) ឧ.ដូចជាទូលបង្គំបានកាត់ស្បែកស្រោមចុងស្វាសរបស់ទូលបង្គំដែរ"ស្រដៀងគ្នានឹងសេចក្ដីដែលព្រះយេហូវ៉ាបានស្បថនឹងអង្គទ្រង់ដែរ (មើលការពន្យល់ ១៥:១៧) ។ ដូច្នេះលោកអ័ប្រាហាំបានប្រគល់ខ្លួនឱ្យស្ថិតនៅក្រោមការគ្រប់គ្រង់មកពីព្រះយេហូវ៉ា ដូចជាស្ដេចរបស់គាត់ដែលថ្វាយខ្លួនគាត់កូនចៅគាត់នឹងគ្រប់ទាំងអស់ និងទ្រព្យសម្បត្តិដែលគាត់មានដើម្បីបម្រើដល់ព្រះយេហូវ៉ា ។ ការកាត់ស្បែកដែលជាសញ្ញាថ្វាយខ្លួននៅចំពោះព្រះ (សូមមើល ចទ ១០:១៦ ៣០:៦ យរ ៤:៤ ៩:២៥–២៦ អស ៤៤:៧ និងការពន្យល់ ៤៤:៩ ប្រៀបធៀប រម ២:២៩ ។ សាសន៍ដទៃទៀតក៏ទទួលការកាត់ស្បែកដែរ (យរ ៩:២៥–២៦ អរ ៣២:១៨–១៩) ប៉ុន្តែមិនមែនដោយសារតែការតាំងសញ្ញាដូចជាពួកអ៊ីស្រាអែលធ្វើនោះឡើយ ។

**១៧:១១** *ជាទីសំគាល់ពីសេចក្ដីសញ្ញា* សូមមើល ៩:១២ ។

**១៧:១២** *កើតមកបាន៨ថ្ងៃ* (មើល ២១:៤ និង កច ៧:៨ អ៊ីសាក) (លក ១:៥៩ យ៉ូហានបាទ្ទីស) (២:២១ ព្រះយេស៊ូវ) (ភល ៣:៥ លោកប៉ុល) ។ នៅពេលលោកអ័ប្រាហាំគាត់ទទួលការកាត់ស្បែកដំបូង គាត់មានអាយុ៩៩ឆ្នាំ (ខ.២៤) ។ ពួកអារាប់ដែលរាប់ខ្លួនឯងថាជាកូនចៅរបស់អ៊ីសម៉ាអែលក៏បានទទួលការកាត់ស្បែកដែរ ។

**១៧:១៤** *កាត់កាលចេញពីសាសន៍របស់ខ្លួន* ព្រះយេហូវ៉ាទ្រង់នឹងដកចេញពីការតាំងសញ្ញាពីរាស្ត្រទ្រង់(ខ.១០) ។

**១៧:១៥** *សារ៉ាយ . . . សារ៉ា* តាមការអះអាងមួយនិយាយថាឈ្មោះទាំង២នោះមានន័យថា "ក្សត្រី" ។ ការដាក់ឈ្មោះឱ្យជាថ្មីនោះ គឺចង់បញ្ជាក់ថានាងនិងក្លាយជាម្ដាយនៃនគរផ្សេងៗ ហើយនិងមានស្ដេចជាច្រើនចេញពីនាងមក (ខ.១៦) ហើយអ្នកទាំងនោះគឺជាអ្នកបម្រើដល់ព្រះយេហូវ៉ា (មើលការពន្យល់ ខ.៥) ។

**១៧:១៦** *កូន* បានសម្រេចនៅក្នុងគ្រាអ៊ីសាក (២១:២–៣) ។

**១៧:១៧** *អស់សំណើច* បង្ហាញពីភាពមិនជឿរយៈពេលខ្លី (១៨:១២ ប្រៀបធៀប រម ៤:១៩,២១) ។ សម្លេងនេះគឺបានធ្លាក់លើអ៊ីសាកដែលមានន័យថា "អស់សំណើច"(មើល ខ.១៩ និង ២១:៣ ១៨:១២–១៥ ២១:៦) ។

**១៧:២០** *កើតបានកូន* មើល ១៣:៦ ។ វានិងបង្កើតចៅហ្វាយ១២នាក់សម្រេច ២៥:១៦ ។

**១៧:២១** លោកប៉ុលបានយកឧទាហរណ៍ពីការជ្រើសរើសរបស់ទ្រង់ ចំពោះអ៊ីសាកមកបញ្ជាក់ (មិនមែនជាអ៊ីសម៉ាអែល) គឺជាម្នាក់ដែលព្រះយេហូវ៉ាបានផ្ដល់សិទ្ធិអំណាចដើម្បីបានសង្គ្រោះតាមរយៈព្រះគុណតែមួយប៉ុណ្ណោះ (មើល រម ៩:៦–១៣) ។ *ឆ្នាំក្រោយនេះ* មើល ២១:២ ។

**១៧:២២** *ទ្រង់ឃ្លាតចេញពីគាត់ហោះឡើងទៅ* បន្ទាប់ពីបញ្ចប់ការសន្ទនា ។

ប្រុស១ ដែលបានកើតនៅផ្ទះខ្លួន[ម] និងមនុស្សដែលបាន
ទិញដោយប្រាក់ផង គឺគ្រប់ទាំងប្រុស១នៅក្នុងពួកផ្ទះគាត់
ទាំងប៉ុន្មាន មកកាត់ស្បែកស្រោមចុងស្វាសទាំងអស់គ្នា
នៅថ្ងៃនោះឯង ដូចជាព្រះបានបង្គាប់មក[យ] ២៤ឯអ័ប្រាហាំ
កាលគាត់ទទួលកាត់ស្បែក[រ] នោះមានអាយុ៩៩ឆ្នាំហើយ[ល]
២៥ចំណែកអ៊ីសម៉ាអែល[វ]កូនគាត់ក៏មានអាយុ១៣ឆ្នាំដែរ
២៦ទាំងអ័ប្រាហាំនិងអ៊ីសម៉ាអែលជាកូន ក៏បានទទួលកាត់
ស្បែកនៅថ្ងៃដដែលនោះ ២៧ហើយមនុស្សប្រុស១ទាំងអស់
នៅផ្ទះគាត់[ស] គឺទាំងពួកអ្នកដែលកើតនៅផ្ទះគាត់ នឹងពួក
អ្នកដែលបានយកប្រាក់ទិញពីពួកសាសន៍ដទៃទាំងប៉ុន្មានផង
គេបានកាត់ស្បែកជាមួយនឹងគាត់ទាំងអស់គ្នា ។

## ទេវតាមកសួរសុខទុក្ខ

**១៨** ១រួចព្រះយេហូវ៉ាទ្រង់លេចមកឯគាត់[ក] នៅត្រង់ដើម
ម៉ែសាក់របស់ម៉ាមរេ[ខ] ក្នុងកាលដែលគាត់កំពុងអង្គុយនៅ
មាត់ទ្វារត្រសាល[គ]នៅវេលាថ្ងៃពេញកំដៅ ២គាត់ងើបភ្នែក
ឡើង[ឃ] ក៏មើលឃើញមនុស្ស៣នាក់[ង]ឈរនៅចំពោះមុខ
កាលគាត់ឃើញដូច្នោះ នោះគាត់រត់ពីមាត់ទ្វារត្រសាល
ទៅទទួល ដោយក្រាបរាបនឹងដី[ច] ៣ក៏ទូលថា ព្រះអម្ចាស់
អើយ បើសិនជាទូលបង្គំបានប្រកបដោយព្រះគុណនៅ
ចំពោះទ្រង់[ឆ] នោះសូមកុំអាលយាងហួសពីទូលបង្គំជាបាវ
បំរើទ្រង់[ជ]ទៅឡើយ ៤សូមរង់ចាំឱ្យគេយកទឹកមកបន្តិច
នឹងលាងព្រះបាទទ្រង់[ឈ] ហើយសូមទ្រង់ឈប់សំរាកក្រោម
ដើមឈើនេះសិន ៥ទូលបង្គំនឹងយកនំបុ័ងបន្តិចបន្តួច

**១៧:២៣** ម លប ១២:៥ យ ខ.១០,១៤ **១៧:២៤** រ រម ៤:១១ ល លប ១២:៤ **១៧:២៥** វ លប ១៦:១៦ **១៧:២៧** ស លប ១៤:១៤ **១៨:១** ក លប ១៩:២ ១២:៧ កច ៧:២ ខ លប ១៣:១៨ គ លប ១៩:១ ២៣:១០,១៨ ៣៤:២០,២៤ រម ៤:១ ទដ ៦៩:១២ ហព ១១:៩ **១៨:២** ឃ លប ២៤:៦៣ ង ខ.១៦, ២២ លប ១៩:១,១០ ៣២:២៤ យស ៥:១៣ ពច ១៣:៦–១១ ហស ១២:៣–៤ ហព ១៣:២ ច លប ១៧:៣ ៤៣:២៨ **១៨:៣** ឆ លប ១៩:១៩ ៣៩:៤ រម ២:២,១០,១៣ ១សយ ១:១៨ នអ ២:១៥ ជ លប ៣២:៤,១៨,

មកថ្វាយ[ញ] ឱ្យទ្រង់មានកំឡាំងឡើង រួចសឹមយាងទៅចុះ
ដ្បិត ទ្រង់បានយាងមកដល់ទូលបង្គំជាអ្នកបំរើទ្រង់ហើយ
នោះទ្រង់មានបន្ទូលថា ចូរធ្វើដូចជាឯងបាននិយាយចុះ
៦អ័ប្រាហាំក៏ប្រញាប់ប្រញាល់ចូលទៅក្នុងត្រសាល ប្រាប់
សារ៉ាថា ចូរយកម្សៅយ៉ាងម៉ដ្ត៣រង្វាល់មកលាយធ្វើនំុឱ្យ
ឆាប់១[ដ] ៧រួចគាត់រត់ទៅឯហ្វូងសត្វ ចាប់យកកូនគោ១
ដែលមានសាច់ទន់ល្វន់ល្អ[ឋ] ប្រគល់ឱ្យដល់បាវបំរើម្នាក់
ហើយបាវនោះក៏បានចាត់ចែងយ៉ាងប្រញាប់ប្រញាល់
៨នោះគាត់យកខ្លាញ់[ឌ]ទឹកដោះ[ឍ] ហើយនិងទឹកដោះរាវ និង
កូនគោដែលបានរៀបចំទៅថ្វាយដល់ទ្រង់[ណ] រួចឈរនៅ
ក្រោមដើមឈើជិតទ្រង់ ហើយទ្រង់ក៏សោយទៅ ។

៩ទ្រង់មានបន្ទូលសួរគាត់ថា សារ៉ា[ត]ប្រពន្ធឯងនៅឯណា
គាត់ទូលឆ្លើយថា នៅក្នុងត្រសាលឯណោះ ១០ទ្រង់មាន
បន្ទូលថា ដល់កំណត់ អញនឹងមកឯឯងវិញជាមិនខាន[ថ]
នោះសារ៉ាប្រពន្ធឯងនឹងមានកូនប្រុស១[ទ] ចំណែកសារ៉ា
ដែលនៅមាត់ទ្វារត្រសាលខាងក្រោយគាត់ នាងក៏បានឮ
ដែរ ១១រីឯអ័ប្រាហាំនិងសារ៉ា គាត់ជាមនុស្សចាស់មាន
អាយុច្រើនណាស់[ធ] សារ៉ាអស់មានរដូវកាលតាមទំលាប់

២០ ៣៣:៥ **១៨:៤** ឈ លប ២៤:៣២ ៤៣:២៤ ពច ១៩:២១ ២សយ ១១:៨ លក ៧:៤៤ **១៨:៥** ញ ពច ១៣:១៥ ១៩:៥ **១៨:៦** ដ លប ១៩:៣ ២សយ ១៣:៨ **១៨:៧** ឋ ១សយ ២៨:២៤ លក ១៥:២៣ **១៨:៨** ឌ អស ៧:១៥,២២ ឍ ពច ៤:១៩ ៥:២៥ ណ ពច ៦:១៩ **១៨:៩** ត លប ៣:៩ ថ លប ២៤:៦៧ ហព ១១:៩ **១៨:១០** ទ លប ១៧:២១ ២១:២ ២ពវ ៤:១៦ ធ លប ១៧:៦ រម ៩:៩

**១៧:២៣** *នៅថ្ងៃនោះឯង* លោកអ័ប្រាហាំបានបង្ហាញពីការស្តាប់បង្គាប់ព្រះយ៉ាងទៀងពេលវេលា (១២:៤) ។

**១៨:១–៣៣** ព្រះយេហូវ៉ាទ្រង់បានលេចមកឯលោកអ័ប្រាហាំ ដោយមានទាំងអ្នកតំណាង២នាក់មកជាមួយផងដែលគិតថា "ទេវតា" នៅក្នុង (១៩:១) ដែលជាអ្នកមានតួនាទីនៅស្ថានលើ (មើល ១ពវ ២២:១៩–២២ ហើយនិង ២២:១៩ យរ ២៣:១៨–២២ និងការពន្យល់ ២៣:១៨) ។ ព្រះយេហូវ៉ាទ្រង់បានលេចមកដើម្បីប្រកាសប្រាប់ដល់លោកអ័ប្រាហាំ (មើល ខ.១៧) ។

**១៨:១** *លេចមក* សូមមើលការពន្យល់ ១២:៧ ។ *ដើមម៉ែសាក់* មើល ១២:៦ *ម៉ាមរេ* មើល ១៣:១៨ ។ *ថ្ងៃពេញកំដៅ* មុនពេលរសៀលមកដល់ ។

**១៨:២** *មនុស្ស៣នាក់* ២នាក់ក្នុងអ្នកទាំង៣ជាទេវតា (១៩:១ ១៦:៧) ។ អ្នកទី៣គឺជាព្រះយេហូវ៉ា (ខ.១,១៣,១៧,២០,២៦,៣៣ ជាពិសេស ខ.២២) ។ រឿងរ៉ាវដែលកើតឡើងក្នុងខ.២៧ពួកអ្នកនៅមជ្ឈឹមបូព៌ាបាននិយាយថា មានរបៀប៣ឬ៤ខុស១គ្នាពីការទទួលព្រះយេហូវ៉ា ដែលមានជាអាទិ: (១) លោកអ័ប្រាហាំបានចេញមកទទួលភ្ញៀវយ៉ាងប្រញាប់ប្រញាល់ (ខ.២៦៧)។ (២) គាត់បានឱនចុះផ្ទាល់ដី (ខ.២) ។ (៣) គាត់បាននិយាយទៅកាន់ភ្ញៀវដោយពាក្យយ៉ាងគួរសម "ព្រះអម្ចាស់អើយ" ហើយបានហៅខ្លួនគាត់ថា "ទូលបង្គំជាអ្នកបម្រើទ្រង់ហើយ" (ខ.៣ និង ខ.៥) ពាក្យនេះ គឺជាពាក្យធម្មតា សម្រាប់និយាយទៅកាន់អ្នកដែលមានឋានៈប្រសើរជាង ឧ. (១៩:២, ១៨–១៩) ។ (៤) ទង្វើរបស់គាត់ហាក់ដូចជាចង់និយាយថាបើសិនជាពួកគេអនុញ្ញាតឱ្យគាត់បម្រើនោះ គាត់នឹងបានទទួលការប្រោសប្រណី (ខ.៣–៥) (៥) គាត់បានសុំទឹកឱ្យគេយកមកលាងព្រះបាទទ្រង់ (ខ.៤) ដែលការប្រព្រឹត្តបែបនេះជាការឱនលំទោនចំពោះអ្នកដំណើរ ដែលធ្វើដំណើរនារដូវក្តៅនិងមានធូលីច្រើន (១៩:២ ២៤:៣២ ៤៣:២៤) ។ (៦) គាត់បានរៀបចំអាហារសម្រាប់ពួកគេយ៉ាងបរិបូរណ៍ ខ.៥៨ ប្រហាក់ប្រហែលគ្នានិងដង្វាយយ៉ាងច្រើន ដែលគេបានថ្វាយព្រះយេហូវ៉ា (ពច ៦:១–១៩ ១៣:១៥–១៦) ។ (៧) គាត់បានឈរនៅជិត (ខ.៨) ដែលបង្ហាញឫកពានៃអ្នកបម្រើ (ខ.២២) ក្នុងគោលបំណងឱ្យពួកគេមានសេចក្តីសុខ ។ ហព ១៣:២ ប្រហែលជាបានដកស្រង់ចេញពី ខ.២–៨ និង ១៩:១–៣ ។

**១៨:៦** *នំ* សម្រាប់ពហុវចនៈ ពាក្យនេះគឺសំដៅលើនំបុ័ងស្តើង១ ។

**១៨:១០** មើល ១៧:២១ ។ លោកសាវ័កប៉ុលគាត់បានដកស្រង់សេចក្តីសន្យាពីកំណើតអ៊ីសាក (ខ.១៤)នៅ រម ៩:៩ និងទំនាក់ទំនងព្រលឹងវិញ្ញាណកូនចៅលោកអ័ប្រាហាំ (រ៉ូម ៩:៧–៨)។

ស្ត្រីទៀតហើយ[ន] ១២នាងនឹកអស់សំណើច[ប]ក្នុងខ្លួនថា អញ
ចាស់ប៉ុណ្ណេះទៅហើយ តើនឹងនៅមានដំរេកទៀតដែរឬអី
ណាមួយលោកម្ចាស់ប្តីអញ[ផ]ក៏ចាស់ណាស់ដែរ ១៣តែព្រះ
យេហូវ៉ាទ្រង់មានបន្ទូលនឹងអ័ប្រាហាំថា ហេតុអ្វីបានជា
សារ៉ាសើចដូច្នេះថា ដែលចាស់ប៉ុណ្ណេះហើយ តើនឹងមាន
កូនដែរឬ[ព] ១៤តើមានការអ្វីដែលព្រះយេហូវ៉ាធ្វើមិនកើត
ដែរឬអី[ភ] ដល់វេលាកំណត់[ម] នោះអញនឹងមកឯឯង លុះ
គ្រប់ខែហើយ សារ៉ានឹងបង្កើតបានកូនប្រុស១[យ] ១៥ឯសារ៉ា
នាងប្រកែកថា ខ្ញុំម្ចាស់មិនបានសើចទេ ពីព្រោះនាងខ្លាច
តែទ្រង់មានបន្ទូលថា ទេ គឺឯងបានសើចមែន ។

## លោកអ័ប្រាហាំអង្វរឱ្យក្រុងសូដុំម

១៦លុះមនុស្សទាំង៣[រ]បានក្រោកពីទីនោះហើយ ក៏ងាក
បែរមើលទៅខាងក្រុងសូដុំម ឯអ័ប្រាហាំគាត់ដើរជាមួយ
ដែរ ដើម្បីជូនទៅ ១៧នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
តើត្រូវលាក់នឹងអ័ប្រាហាំ[ល]ពីការដែលអញរៀបនឹងធ្វើឬទេ
១៨ដ្បិតអ័ប្រាហាំនឹងត្រឡប់ជានគរ១យ៉ាងធំ[ស] ហើយពូកែ
ជាពិតប្រាកដ គ្រប់ទាំងសាសន៍នៅផែនដីនឹងបានពរ
ដោយសារគាត់ ១៩ដ្បិតអញស្គាល់គាត់ថា[ហ] គាត់នឹងបង្គាប់
ដល់កូនចៅ[ឡ] និងពួកផ្ទះគាត់តរៀងទៅ ឱ្យគេកាន់ខ្ជាប់តាម
ផ្លូវនៃព្រះយេហូវ៉ា[អ] ដើម្បីឱ្យបានប្រព្រឹត្តសេចក្តីសុចរិត
និងសេចក្តីទៀងត្រង់[ក] ប្រយោជន៍ឱ្យព្រះយេហូវ៉ាបាន
សំរេចដល់គាត់ តាមសេចក្តីដែលទ្រង់មានបន្ទូលពីដំណើរ
គាត់[ខ] ២០រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ពីព្រោះសំរែក
នៃក្រុងសូដុំម[គ]និងក្រុងកូម៉ូរ៉ាបានឮជាខ្លាំង[ឃ] ហើយអំពើ
បាបរបស់គេក៏ធ្ងន់ណាស់ផង[ង] ២១នោះបានជាអញចុះទៅ
មើលឥឡូវ[ច] ដើម្បីឱ្យដឹង បើគេបានប្រព្រឹត្តដូចជាសំរែក
ដែលអញបានឮនោះឬទេ បើមិនមែនទេ នោះអញនឹង
បានដឹង ២២រួច[ឆ]ក៏បែរចេញពីនោះដំរង់ទៅខាងឯក្រុង
សូដុំមទៅ[ជ] តែអ័ប្រាហាំគាត់ឈរនៅចំពោះព្រះយេហូវ៉ា
នៅឡើយ[ឈ] ។

២៣អ័ប្រាហាំក៏ចូលទៅជិតទូលសួរថា តើទ្រង់នឹងបំផ្លា
ញមនុស្សសុចរិតជាមួយនឹងមនុស្សអាក្រក់ផងដែរឬអី[ញ]
២៤បើសិនជាមានមនុស្សសុចរិត៥០នាក់នៅក្នុងក្រុងនោះ
តើទ្រង់នឹងបំផ្លាញអស់រលីងទៅ ឥតមានប្រណីដល់ទីក្រុង
ដោយព្រោះមនុស្សសុចរិត៥០នាក់ ដែលនៅទីនោះទេឬ

**១៨:១១** ន លប ១៧:១៧ លក ១:១៨ ប លប ១១:៣០ រម ៤:១៩ ហព ១១:១១–១២ **១៨:១២** ផ លប ១៧:១៧ ព ១ពត ៣:៦ **១៨:១៣** ភ លប ១៧:១៧ **១៨:១៤** ម យប ៤២:២ អស ៤០:២៩ ៥០:២ ៥១:៩ យរ ៣២:១៧,២៧ មថ ១៩:២៦ រម ៤:២១ យ ខ.១០ រ លប ១៧:១៩ រម ៩:៩ កទ?៤:២៣ **១៨:១៦** ល ខ.២ **១៨:១៧** វ អម ៣:៧ ស លប ១៩:២៤យប ១៩:២៤ យប ១:១៦ ទដ ១០៧:៣៤ **១៨:១៨** ហ លប ១២:២ កទ ៣:៨ **១៨:១៩** ឡ លប ១៧:៩ អ ចទ ៤:៩–១០ ៦:៧ យស ២៤:១៥ អភ ៦:៤ ក លប ២២:១២, ១៨ ២៦:៥ ២សយ ៨:១៥ ទដ ១៧:២ ៩៩:៤ យរ ២៣:៥ ខ លប ១៦:១១ អស ១៤:១ **១៨:២០** គ អស ១:១០ យរ ២៣:១៤ អគ ១៦:៤៦ឃ លប ១៩:១៣ ង លប ១៣:១៣ **១៨:២១** ច លប ១១:៥ **១៨:២២** ឆ ខ.២ ជ លប ១៩:១ ឈ ខ.១ លប ១៩:២៧ **១៨:២៣** ញ នក ២៣:៧ លវ ៤:៣,២២, ២៧ ជន ១៦:២២ ចទ ២៧:២៥ ២សយ ២៤:១៧ ទដ ១១:៤–៧ ៩៤:២១ អគ ១៨:៤ ២ពត ២:៩

**១៨:១២** *អស់សំណើច* ការមិនជឿនេះក៏ដូចគ្នានឹងអ័ប្រាហាំដែរ (មើល ១៧:១៧) ។

**១៨:១៤** *តើមានការអ្វីដែលព្រះយេហូវ៉ាធ្វើមិនកើតដែរឬអី* ចម្លើយគឺគ្មានទេសម្រាប់នាងសារ៉ានិងពូជពង្សរបស់នាងម៉ារា និងអេលីសាបិត (មើល លក ១:៣៤–៣៧)។ គ្មានអ្វីដែលព្រះមិនអាចធ្វើកើតនោះឡើយទោះបីជាការបង្កើតក៏ដោយ (យរ ៣២:១៧) ឬការប្រោសលោះ (មថ ១៩:២៥–២៦) គឺមិនពិបាកឡើយសម្រាប់ទ្រង់ ។

**១៨:១៦** *សូដុំម* មើល ១០:១៩ ១៣:១០ ។

**១៨:១៧** អ័ប្រាហាំគាត់គឺជាភឿនដ៏ល្អរបស់ព្រះ (ខ.១៩ ២រប ២០:៧ យក ២:២៣ អស ៤១:៨ ប៉ុន្តែសូមមើលការពន្យល់) ។ ដោយព្រោះឥឡូវនេះលោកអ័ប្រាហាំគឺជាមិត្តសម្លាញ់ នឹងសេចក្តីសញ្ញារបស់ព្រះ (យប ២៩:៤) ធ្វើឱ្យព្រះបានតាំងសញ្ញាថា និងតាំងគាត់ជាទីប្រឹក្សាជាន់ខ្ពស់របស់ព្រះ (១:២៦) នៅឯត្រសាលរបស់លោក ។ នៅទីនោះព្រះយេហូវ៉ាបានប្រាប់ពីគោលបំណងរបស់ទ្រង់ចំពោះលោកអ័ប្រាហាំ (ខ.១០) និងសម្រាប់អ្នកប្រព្រឹត្តបាបផងដែរ (ខ.២០–២១) គឺពីការប្រោសលោះនិងជំនុំជម្រះ ។ ព្រះយេហូវ៉ាទ្រង់ក៏បានផ្តល់ឱ្យលោកអ័ប្រាហាំមានឱកាសនិយាយសុំទោសជំនួសមនុស្សសុចរិតនៅក្រុងសូដុំមនិងកូម៉ូរ៉ា នៅចំពោះអ្នកកាត់ក្តីរបស់ទ្រង់ទៀតផង ។ ក្រោយមកទៀតលោកអ័ប្រាហាំត្រូវបានព្រះអង្គត្រាស់ហៅឱ្យធ្វើអ្នកកង្វាល (២០:៧) ។ ទាំងនេះគឺគ្រាន់តែឧទាហរណ៍ខ្លះៗពីឯកសិទ្ធិដ៏ប្រពៃមួយ នៃសេចក្តីសញ្ញារបស់ទ្រង់ចំពោះរាស្ត្រទ្រង់គ្រប់តំណថា ព្រះយេហូវ៉ាទ្រង់បានបើកសម្តែងឱ្យគេបានស្គាល់ពីបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់ពួកគេនិងអនុញ្ញាតស្តាប់សម្រែករបស់គេ (ការអង្វរជំនួសអ្នកណាម្នាក់) នៅទីកាត់ក្តីរបស់ទ្រង់ នៅក្នុងនគរស្ថានសួគ៌ ។

**១៨:១៨** *ត្រឡប់ជានគរមួយយ៉ាងធំពូកែ* ជាពិតប្រាកដគ្រប់ទាំងសាសន៍នៅផែនដីនិងបានពរដោយសារគាត់ មើល ១២:២–៣ ។

**១៨:១៩** *សេចក្តីសុចរិត និងសេចក្តីទៀងត្រង់* មើល ទដ ១១៩:១២១ ។

**១៨:២០** *សំរែក* សម្រែកនៃមនុស្សសុចរិតប្រៀបធៀបនឹងឈាមរបស់អេបិល (៤:១០) គឺជាមូលហេតុមួយក្នុងការបំផ្លាញទីក្រុង (១៩:១៣) ។ *ក្រុងកូម៉ូរ៉ា* សូមមើល ១០:១៩ ១៣:១០ ។

**១៨:២១** *អញចុះទៅមើល* លទ្ធផលនៃការចុះមកមើលគឺទទួលការជំនុំជម្រះដូចក្នុង (១១:៥៩) ប៉ុន្តែជាមួយគ្នានោះដែរការយាងចុះមកក៏នាំការប្រោសលោះមកជាមួយដែរ (នក ៣:៨) ។ *ដើម្បីឱ្យដឹង* មិនមែនបដិសេធន៍ចំពោះចំណេះដឹងរបស់ព្រះដែលគ្មានព្រំដែននោះឡើយ ប៉ុន្តែគឺគ្រាន់តែជាការប្រៀបធៀបមួយថា "ព្រះទ្រង់ជាចៅក្រម" (ខ.២៥) ដែលមិនបានធ្វើការផ្អែកលើការរអ៊ូរទាំពីមនុស្សនោះឡើយ ។

**១៨:២២** *អ័ប្រាហាំគាត់ឈរនៅចំពោះព្រះយេហូវ៉ានៅឡើយ* ទាំងអត្ថបទនេះ គឺសុទ្ធតែបាននិយាយពីការបម្រើគ្នាទៅវិញទៅមករវាងព្រះយេហូវ៉ានឹងអ្នកបម្រើទ្រង់ ។

**១៨:២៣** ជាលើកទី២ដែលលោកអ័ប្រាហាំ គាត់បានចូលធ្វើអន្តរាគមន៍សម្រាប់សាច់ញាតិគាត់នៅក្រុងសូដុំម (មើល ១៤:១៤–១៦) ។

អ៊ី[ដ] ២៥មិនគួរគប្បីឱ្យទ្រង់ប្រព្រឹត្តដូច្នោះ[ឋ] នឹងសំឡាប់មនុស្ស
សុចរិតជាមួយនឹងមនុស្សអាក្រក់នោះទេ យ៉ាងនោះឈ្មោះ
ថា ធ្វើឱ្យមនុស្សសុចរិត[ឌ]បានដូចជាមនុស្សអាក្រក់ដែរ[ឍ]
សូមកុំឱ្យទ្រង់ធ្វើដូច្នោះឡើយ ឯព្រះដ៏ជាចៅក្រមនៃផែនដី
ទាំងមូល តើទ្រង់មិនត្រូវប្រព្រឹត្ត[ណ]ដោយយុត្តិធម៌ទេឬអ៊ី[ត]
២៦នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា បើអញឃើញមាន
មនុស្សសុចរិត៥០នាក់ នៅក្នុងទីក្រុងសូដុំម នោះអញនឹង
ប្រណីដល់ទីនោះ ដោយយល់ដល់គេវិញ[ថ] ២៧រួចអ័ប្រាហាំ
គាត់ទូលថា មើល ឥឡូវទូលបង្គំបានផ្ដើមទូលនឹងព្រះ
អម្ចាស់ ដែលទូលបង្គំជាធូលីដីហើយជាផេះទទេ[ទ] ២៨ក្នុង
មនុស្សសុចរិតទាំង៥០នាក់នោះ ប្រហែលជានឹងមានខ្វះ
៥នាក់ ដូច្នេះ តើទ្រង់នឹងបំផ្លាញទីក្រុងទាំងមូលដោយ
ព្រោះខ្វះ៥នាក់ឬអ៊ី នោះទ្រង់មានបន្ទូលថា បើអញឃើញ
មាន៤៥នាក់ នោះអញមិនបំផ្លាញទេ ២៩គាត់ក៏ទូលទ្រង់
ទៀតថា ប្រហែលជារកបានតែ៤០នាក់ទេ នោះទ្រង់មាន
បន្ទូលថា អញមិនធ្វើអ្វីទេ ដោយយល់ដល់៤០នាក់នោះ
៣០រួចគាត់ទូលថា សូមកុំឱ្យព្រះអម្ចាស់ខ្ញាល់[ធ] នោះទូលបង្គំ
នឹងទូលទៀតថា នៅទីនោះប្រហែលជានឹងឃើញមានតែ
៣០នាក់ទេ នោះទ្រង់មានបន្ទូលថា បើអញឃើញមាន
៣០នាក់ នោះអញក៏មិនធ្វើអ្វីដែរ ៣១រួចគាត់ទូលថា មើល
ឥឡូវទូលបង្គំបានផ្ដើមទូល នឹងព្រះអម្ចាស់ប្រហែល ជារក
បានតែ២០នាក់ប៉ុណ្ណោះនៅទីនោះ ទ្រង់ក៏មានបន្ទូលថា
អញមិនបំផ្លាញទេ ដោយយល់ដល់២០នាក់នោះ ៣២នោះ
គាត់ទូលថា សូមកុំឱ្យព្រះអម្ចាស់ខ្ញាល់ឡើយ ទូលបង្គំនឹង
ទូលតែម្ដងនេះទៀតថា[ន] នៅទីនោះប្រហែលជារកបាន
តែ១០នាក់ទេ រួចទ្រង់មានបន្ទូលថា អញមិនបំផ្លាញឡើយ
ដោយ យល់ដល់១០នោះ[ប] ។
៣៣កាលព្រះយេហូវ៉ាបានលែងមានបន្ទូល[ផ]នឹងអ័ប្រាហាំ
ហើយ នោះទ្រង់យាងចេញបាត់ទៅ[ព] ហើយអ័ប្រាហាំក៏
វិលទៅឯទីលំនៅរបស់គាត់វិញ[ភ] ។

## ការបំផ្លាញទីក្រុងសូដុំម និងកូម៉ូរ៉ា

១៩ ១ដល់ពេលព្រលប់ នោះទេវតាទាំង២[ក]ក៏ទៅដល់
ក្រុងសូដុំម[ខ] ឯឡុត[គ]គាត់អង្គុយនៅមាត់ទ្វារក្រុង[ឃ] គាត់ក៏
ឃើញ ហើយក្រោកទៅទទួល រួចក្រាបផ្កាប់មុខ[ង]នឹងដី
ជិរាបថា ២លោកម្ចាស់ខ្ញុំអើយ ឥឡូវ សូមអញ្ជើញចូលទៅ
ក្នុងផ្ទះខ្ញុំជាអ្នកបំរើលោក ដើម្បីនឹងលាងជើង[ច] ហើយ
សំណាក់នៅ១យប់នេះសិន រួចសឹមភ្ញាក់ឡើងពីព្រលឹម
អញ្ជើញទៅទៀតចុះ តែទេវតានោះឆ្លើយថា ទេយប់នេះ
យើងនឹងដេកនៅតាមផ្លូវវិញ[ឆ] ៣ប៉ុន្តែដោយគាត់បង្ខំ[ជ]ណាស់
បានជាទេវតាក៏ចូលទៅក្នុងផ្ទះគាត់[ឈ] ហើយគាត់ក៏រៀបចំ
ជប់លៀង គាត់ដុតនំបុ័ងឥតដំបែ[ញ] ហើយទេវតាក៏បរិភោគ[ដ]
៤កាលមិនទាន់ដេកនៅឡើយ នោះពួកមនុស្សទាំងឡាយ
ទាំងក្មេងទាំង ចាស់នៅក្នុងក្រុងសូដុំម[ឋ] គេមកឡោមព័ទ្ធផ្ទះ

**១៨:២៤** ដ ខ.២៦ យរ ៥:១ **១៨:២៥** ឋ លប ៤៤:៧,១៧ ចទ ៣២:៤ យប ៨:៣-៧ ៣៤:១០ ឌ អស ៥:២០ អម ៥:១៥ មឡ ២:១៧ ៣:១៨ ឍ ចទ ១:១៦-១៧ ណ ពច ១១:២៧ យប ៩:១៥ ទដ ៧:១១ ៩៤:២ ហព ១២:២៣ ត លប ២០:៤ ចទ ៣២:៤ ២របា ១៩:៧ អរ:១៥ នហ ៩:៣៣ យប ៨:៣,២០ ៣៤:១០ ៣៦:២៣ ទដ ៥៨:១១ ៧៥:៧ ៩៤:២ ១១៩: ១៣៧ អស ៣:១០-១១ អក ១៨:២៥ ដយ ៤:៣៧ ៩:១៤ មឡ ២:១៧ រម ៣:៦ **១៨:២៦** ថ ខ.២៤ **១៨:២៧** ទ លប ២:៧ យប ២:៨ **១៨:៣០** ធ ខ.៣២ លប ៤៤:១៨ នក ៣២:២២ **១៨:៣២** ន ខ.៣០

ពច ៦:៣៩ ប យរ ៥:១ **១៨:៣៣** ផ នក ៣១:១៨ ព លប ១៧:២២ ភ លប ៣១:៥៥ **១៩:១** ក លប ១៨:២ ហព ១៣:២ ខ ១៨:២២ គ លប ១១:២៧ ឃ លប ១៨:១ ង លប ១៧:៣ ៤៨:១២ នរ ២:១០ ១សយ ២៥:២៣ ២សយ ១៤:៣៣ ២ពរ ២:១៥ **១៩:២** ច លប ១៨:៤ លក ៧:៤៤ ឆ ពច ១៩:១៥,២០ **១៩:៣** ជ លប ៣៣:១១ ឈ យប ៣១:៣២ ញ នក ១២:៣៩ ដ លប ១៨:៦ **១៩:៤** ឋ លប ១៣:១៣

**១៨:២៥** ព្រះដ៏ជាចៅក្រមនៃផែនដីទាំងមូល លោកអ័ប្រាហាំបានទូលអង្វរដល់ព្រះយេហូវ៉ាដោយបានពឹងផ្អែកលើសេចក្ដីសុចរិត នឹងសេចក្ដីយុត្តិធម៌របស់ព្រះ ហើយគាត់បានទុកចិត្តនិងព្រះថា ទ្រង់នឹងធ្វើអ្វីៗទាំងអស់យ៉ាងត្រឹមត្រូវ (ចទ ៣២:៤) ។

**១៨:២៧** *ព្រះអម្ចាស់* រាល់ពេលដែលលោកអ័ប្រាហាំអធិស្ឋាន លោកតែងតែប្រើពាក្យថាព្រះអម្ចាស់ (Lord) មិនដូចជាពេលតាំងសញ្ញាដែលគាត់ហៅព្រះនាមរបស់ព្រះថា "ព្រះយេហូវ៉ា" នោះឡើយ ។ គាត់បានអំពាវនាវដល់ព្រះថា "ទ្រង់ជាចៅក្រមនៃផែនដីទាំងមូល" ។ *ធូលីដី* ហើយជាផេះទទេ លោកអ័ប្រាហាំគាត់បានពិពណ៌នាខ្លួនគាត់ថា ជាមនុស្សដែលគ្មានតម្លៃនិងគ្មានសារៈសំខាន់ គឺផ្ទុយពីអ្វីដែលព្រះយេហូវ៉ាបានលើកដម្កើងគាត់ (យប ៣០:១៩ ៤២:៦) ។

**១៨:៣២** *ទូលបង្គំនឹងទូលតែម្ដងទៀត* សំណួររបស់លោកអ័ប្រាហាំតាំងពី ខ.២៣-៣២ វាមិនមែនជាការតវ៉ានោះឡើយ ប៉ុន្តែគឺជាការអង្វរដោយការអាណិតអាសូរចំពោះសាច់ញ្ញាតិរបស់គាត់ប៉ុណ្ណោះ ដោយគាត់ចង់ឱ្យគេបានស្គាល់ផ្លូវរបស់ព្រះ ។ ១០នាក់ប្រហែលជាគាត់ឈប់សុំព្រះអង្គបន្តទៀត ហើយ ពីព្រោះគាត់បានអធិស្ឋានឱ្យលោកឡុតប្រពន្ធរបស់គាត់កូនប្រុស២នាក់ (១៩:១២) និងប្រហែលជាមានកូនស្រី២នាក់បានរៀបការ ហើយរួមនិងប្ដីរបស់ពួកគេ (១៩:១៤ និងការពន្យល់) ព្រមទាំងកូនស្រី២ទៀតដែលមិនទាន់រៀបការ (១៩:៨) ។

**១៨:៣៣** *ទីលំនៅ* នៅម៉ាមរេ (ខ.១) ហើយព្រឹកបន្ទាប់ទៀតលោកអ័ប្រាហាំត្រឡប់មកកន្លែងដែលគាត់បានឈរនៅចំពោះព្រះយេហូវ៉ាវិញ (១៩:២៧)

**១៩:១-៣** មើល ១៨:២ ។

**១៩:១** *ទេវតាទាំង២* មើល ១៦:៧ ១៨:២ ។ *ឯឡុតគាត់អង្គុយនៅមាត់ទ្វារក្រុង* ប្រហែលជាលោកឡុតបានក្លាយជាអ្នកគ្រប់គ្រងកំពូលនៅទីក្រុងសូដុំម នៅឯទ្វារក្រុងគឺជាអ្នកត្រួតត្រា និងជាចៅក្រមដ៏ល្អដែលជាកន្លែងវិនិច្ឆ័យពិភាក្សា (នរ ៤:១-១២) ។

**១៩:២** *តាមផ្លូវ* ស្ថិតនៅជិតទ្វារក្រុង (មើល ២របា ៣២:៦) ជាកន្លែងដែលមនុស្សប្រមូលគ្នាលាក់ពួនពីអ្នកណាម្នាក់ ។ ទីក្រុងដែលមានសារៈសំខាន់ដូចជាក្រុងយេរូសាឡិមជាដើមផ្លូវនេះអាចមាន២ ឬក៏ច្រើនជាងនេះសម្រាប់ឱ្យមនុស្សស្នាក់នៅបាន (មើល នហ ៨:១៦) ។

**១៩:៣** *នំបុ័ងឥតដំបែ* គឺជាប្រភេទនំដែលអាចដុតបានក្នុងរយៈពេលដ៏ខ្លី (មើល ១៨:៦ នក ១២:៨,៣៩) ។

គឺជាមនុស្សទាំងអស់ពីគ្រប់ក្នុងទីក្រុង ៥ គេស្រែកហៅឡុត
សួរថា មនុស្សដែលចូលមកក្នុងផ្ទះឯងអម្បាញ់មិញនេះ
តើនៅឯណា ចូរឯងនាំវាចេញមកឯយើង ឱ្យយើងបាន
ស្គាល់ផង[ឌ] ៦ នោះឡុតចេញមកឯគេ[ឍ]ដល់មាត់ទ្វារ រួចបិទ
ទ្វារទៅវិញ ៧ គាត់អង្វរថា បងប្អូនខ្ញុំអើយ សូមកុំធ្វើអាក្រក់
ដូច្នេះឡើយ ៨ មើល ខ្ញុំមានកូនស្រី២នាក់ វាមិនទាន់ដែល
ស្គាល់ប្រុសណាទេ ចាំខ្ញុំនាំវាចេញមកប្រគល់ឱ្យអ្នករាល់
គ្នាប្រព្រឹត្តនឹងវាតាមតែចិត្តចុះ សូមកុំឱ្យតែធ្វើអ្វីដល់មនុស្ស
ទាំង២នោះឡើយ ពីព្រោះលោកបានចូលមកសំណាក់នៅ
ផ្ទះខ្ញុំហើយ[ណ] ៩ តែគេកំហែងទៅថា ចូរចៀសចេញ ហើយ
មានខ្លះ គេនិយាយថា អា១នេះបានចូលមកស្នាក់នៅទីនេះ[ត]
ឥឡូវ ចង់តាំងខ្លួនធ្វើជាចៅក្រមវិញ[ថ] អើ បើដូច្នេះយើងនឹង
ធ្វើឯងឥឡូវ ឱ្យអាក្រក់ជាង២នាក់ នោះទៅទៀតផង
រួចគេក៏ប្រជៀតលើឡុតជាខ្លាំង ព្រមទាំងរំលោភចូលទៅ
ជិតចង់ទំលាយទ្វារ ១០ តែទេវតា[ទ]លូកដៃទៅចាប់ឡុតទាញ
ចូលមកក្នុងផ្ទះវិញរួចបិទទ្វារជិត ១១ ក៏ធ្វើឱ្យមនុស្សទាំង
អស់ដែលនៅត្រង់មាត់ទ្វារ នោះខ្វាក់ភ្នែកទៅ[ធ]ទាំងតូច
ទាំងធំបានជាគេអស់ចិត្តនឹងរកទ្វារទៀត ។
១២ រួចទេវតាសួរឡុតថា តើឯងមានអ្នកណាទៀតនៅទី
នេះឬទេ ទោះបើកូនប្រសា ឬកូនប្រុសកូនស្រីឯងក្តី ចូរនាំ
ពួកឯងទាំងអស់[ន]ចេញពីទីក្រុងនេះទៅ ១៣ ដ្បិតយើង[ប] នឹង
បំផ្លាញទីនេះ ពីព្រោះសំរែករបស់គេបានឮកាន់ខ្លាំងឡើង[ផ]
នៅចំពោះព្រះយេហូវ៉ាហើយ នេះគឺព្រះយេហូវ៉ាទ្រង់បាន
ចាត់ឱ្យយើងមកបំផ្លាញចេញ[ព] ១៤ នោះឡុតក៏ចេញទៅប្រាប់
ដល់កូនប្រសា ដែលបានយកកូនស្រីគាត់ថា ចូរក្រោកឡើង
ចេញពីទីនេះទៅ ពីព្រោះព្រះយេហូវ៉ារៀបនឹងបំផ្លាញ
ទីក្រុងចោល[ភ] តែពួកកូនប្រសាគាត់ស្មានថា គាត់និយាយ
លេងទេ[ម] ។
១៥ លុះពេលភ្លឺឡើង នោះទេវតាបង្ខំឡុតថា ចូរក្រោក
ឡើង យកប្រពន្ធហើយនិងកូនស្រីឯងទាំង២នាក់ ដែលនៅ
ឯណេះទៅ ក្រែងឯងត្រូវវិនាស[យ]ក្នុងអំពើទុច្ចរិតរបស់
ទីក្រុងនេះដែរ[រ] ១៦ តែគាត់នៅបង្អែបង្អង់ នោះទេវតាក៏ចាប់
ដៃគាត់និងដៃប្រពន្ធ ហើយនិងកូនស្រីគាត់ទាំង២[ល]នាំចេញ
ទៅលែងឯក្រៅទីក្រុង ដ្បិតព្រះយេហូវ៉ាទ្រង់មេត្តាប្រណី
ដល់គាត់[វ] ១៧ កាលបាននាំចេញផុតទៅក្រៅហើយ នោះ
ទេវតាប្រាប់ថា ចូររត់ទៅឱ្យបានរួចជីវិតចុះ[ស] កុំឱ្យមើល
មកក្រោយឡើយ[ហ] ក៏កុំឱ្យឈប់នៅស្រុកវាលឯណានីមួយ
ផង[ឡ] ចូររត់ទៅឯភ្នំវិញ[អ] ក្រែងឯងត្រូវវិនាសដែរ ១៨ តែ
ឡុតប្រកែកថា ទេ លោកម្ចាស់អើយ ១៩ មើល ឥឡូវនេះ
លោកបានផ្តល់ព្រះគុណ[ក]មកខ្ញុំជាអ្នកបំរើលោក ហើយ
បានចំរើនសេចក្តីមេត្តាករុណា[ខ]របស់លោកឱ្យខ្ញុំឃើញ
ដោយការពារជីវិតខ្ញុំ តែខ្ញុំរត់ទៅឯភ្នំមិនបានទេ[គ] ក្រែង
សេចក្តីអាក្រក់តាមខ្ញុំទាន់ ហើយខ្ញុំត្រូវស្លាប់វិញ ២០ មើលនំ
មានទីក្រុង១នុ៎ះស្ថិតនៅ ជិតបង្កើយហើយក៏តូចផងឬមិន
តូចទេ នោះល្មមនឹងរត់ទៅឱ្យរួចបាន សូមឱ្យខ្ញុំរត់ទៅឯ
ណោះវិញ នោះខ្ញុំនឹងបានរួចជីវិតហើយ ២១ ទេវតាក៏ឆ្លើយ
ថា មើល អញបានព្រមតាមឯងក្នុងការនេះដែរ[ឃ] ឯទីក្រុង

**១៩:៥** ឌ លប ១៣:១៣ លវ ១៨:២២ ចទ?២៣:១៨ ពច ១៩:២២ រម ១:២៤–២៧ **១៩:៦** ឍ ពច ១៩:២៣ **១៩:៨** ណ ពច ១៩:២៤ ២ពត ២:៧–៨ **១៩:៩** ត លប ២៣:៤ ថ លប ១៣:៨ កច ៧:២៧ **១៩:១០** ទ លប ១៨:២ **១៩:១១** ធ ចទ ២៨:២៨–២៩ ២ពវ ៦:១៨ កច ១៣:១១ **១៩:១២** ន លប ៦:១៨ **១៩:១៣** ប នក ១២:២៩ ២សយ ២៤:១៦ ២ពវ ១៩:៣៥ ១រប ២១:១២ ២រប ៣២:២១ ផ លប ១៨:២០ ព ១រប ២១:១៥ ទដ ៧៨:៤៩ យរ២១:១២ ២៥:១៨ ៤៤:២២ ៥១:៤៥ **១៩:១៤** ភ ជន ១៦:២១ វវ ១៨:៤

ម នក ៩:២១ ១ពវ ១៣:១៨ យរ ៥:១២ ៤៣:២ លក ១៧:២៨ **១៩:១៥** យ ជន ១៦:២៦ យប ២១:១៨ ទដ ៥៨:៩ ៧៣:១៩ ៩០:៥ រ វវ ១៨:៤ **១៩:១៦** ល ២ពត ២:៧ វ នក ៣៤:៦ ទដ ៣៣:១៨–១៩ **១៩:១៧** ស ១ពវ ១៩:៣ យរ ៤៨:៦ ហ ខ.២៦ ឡ លប ១៣:១២ អ ខ.១៩ លប ១៤:១០ មថ ២៤:១៦ **១៩:១៩** ក លប ៦:៨ ១៨:៣ ខ លប ២៤:១២ ៣៩:២១ ៤០:១៤ ៤៧:២៩ នរ ១:៨ ២:២០ ៣:១០ គ ខ.១៧,៣០ **១៩:២១** ឃ ១សយ ២៥:៣៥ ២សយ ១៤:៨

**១៩:៤–៩** សូមមើល ពច ១៩:២២–២៥ ។

**១៩:៥** *ឱ្យយើងបានស្គាល់ផង* (ស្គាល់គឺរួមរក្ស) ។ ការរួមរក្សដែលមានគ្នាច្រើនបែបនេះវាជាសាមញ្ញសម្រាប់អ្នកនៅក្នុងក្រុងសូដុំម (មើល ពច ជិពូក ៧) ។ នៅក្នុងភាសាអង់គ្លេស "ប្រជាជនសូដុំម" គឺគេបានបកប្រែឡើងវិញនៅឯទីក្រុងបុរាណ ។

**១៩:៨** *លោកបានចូលមកសំណាក់នៅផ្ទះខ្ញុំហើយ* នៅសម័យបុរាណ ការទទួលភ្ញៀវតម្រូវឱ្យម្ចាស់ផ្ទះជាអ្នកការពារដល់ភ្ញៀវរបស់ពួកគេ វាគឺជាកាតួរសមបំផុត ។

**១៩:៩** *អា១នេះបានចូលមកស្នាក់នៅទីនេះ ឥឡូវចង់តាំងខ្លួនធ្វើជាចៅក្រមវិញ* នៅក្នុងសតវត្សរ៍ក្រោយមកទៀត លោកម៉ូសេក៏ត្រូវគេរាប់ថាជាអ្នកក្រៅហើយបានចោទប្រកាន់ថា គាត់បានតាំងខ្លួនជាចៅក្រមដែរ (នក ២:១៤ កច ៧:២៧) ។

**១៩:១៣** *យើងនឹងបំផ្លាញទីនេះ* អំពើដ៏អាក្រក់របស់ក្រុងសូដុំមនិងត្រូវទទួលការបំផ្លាញ (អស ៣:៩ យរ ២៣:១៤ បទ ៤:៦ សផ ២:៨–៩ ២ពត ២:៦ ពច ជិពូក ៧) ។

**១៩:១៤** *ពួកកូនប្រសាគាត់ស្មានថាគាត់និយាយលេង* លោកឡុតគាត់ដូចជាអស់ឥទ្ធិពលក្នុងការបញ្ចុះបញ្ចូលពួកគេទាំងអស់គ្នា ក្នុងចំណោមគ្រួសាររបស់គាត់ ។

**១៩:១៦** *នៅបង្អែបង្អង់* ការស្ទាក់ស្ទើនេះប្រហែលដោយសារគាត់ពិបាកក្នុងការចាកចេញពីទ្រព្យសម្បត្តិរបស់គាត់ ។ *ក៏ចាប់ដៃគាត់និងដៃប្រពន្ធគាត់ហើយនិងកូនស្រីគាត់ទាំង២* មនុស្សសុចរិតទាំង១០នាក់ដែលលោកអ័ប្រាហាំគាត់សុំដើម្បីសង្គ្រោះទីក្រុងសូដុំម (១៨:៣២) ឥឡូវនេះបានកាត់បន្ថយមកត្រឹម៤នាក់ប៉ុណ្ណោះ ។ ព្រះយេហូវ៉ាទ្រង់មេត្តាប្រណីដល់គាត់ ការសង្គ្រោះគឺជាការងាររបស់ព្រះអាទិករ ដែលទ្រង់ពេញដោយការប្រោសប្រណីមិនមែនដោយសារតែអំពើសុចរិតរបស់មនុស្សនោះឡើយ (ប្រៀបធៀប ទត ៣:៥) ។

១ដែលឯងនិយាយនោះ អញមិនបំផ្លាញទេ ២២ចូរប្រញាប់
ឡើង ហើយរត់ទៅឯណោះឱ្យរួចចុះ ដ្បិតអញធ្វើអ្វីមិន
កើតទាល់តែឯងបានទៅដល់សិន ដូច្នេះទីក្រុងនោះបាន
ហៅឈ្មោះថាសូអារ[ង]។
២៣លុះកាលឡុតចូលទៅក្នុងសូអារ[ច] នោះថ្ងៃបានរះ
ហើយ ២៤ព្រះយេហូវ៉ាទ្រង់បង្អុរភ្លៀងជាស្ពាន់ធ័រនិងភ្លើង[ឆ]
ពីលើមេឃ[ជ] មកលើក្រុងសូដុំមនិងក្រុងកូម៉ូរ៉ា[ឈ] ២៥ទ្រង់ក៏
បំផ្លាញក្រុងទាំងនោះ[ញ] និងស្រុកវាលទាំងមូល[ដ] ហើយអស់
ទាំងមនុស្សនៅទីក្រុងនោះ និងគ្រប់ទាំងអស់ដែលដុះនៅដី
ផង[ឋ] ។
២៦ឯប្រពន្ធឡុតក៏ងាកបែរមើលទៅក្រោយវិញ[ឌ] នោះ
ស្រាប់តែទៅជាបង្គោលអំបិលទៅ[ឍ]។
២៧ឯអ័ប្រាហាំគាត់ក្រោកពីព្រលឹមឡើង នៅឯកន្លែង
ដែលបានឈរនៅចំពោះព្រះយេហូវ៉ា[ណ] ២៨គាត់មើលទៅ
ឯក្រុងសូដុំម ក្រុងកូម៉ូរ៉ា និងស្រុកវាលទាំងអស់ឃើញមាន
សុទ្ធតែផ្សែងហុយឡើងពីដីមក ដូចជាផ្សែងនៃគុកភ្លើង[ត]។
២៩ក្នុងខណៈដែលព្រះទ្រង់បំផ្លាញទីក្រុងនៅស្រុកវាល[ថ]
ទាំងប៉ុន្មាន នោះទ្រង់នឹកចាំ[ទ]ពីអ័ប្រាហាំ ក៏ឱ្យឡុតចេញ
រួចពីការហិនវិនាសនោះ[ធ] ក្នុងកាលដែលទ្រង់បានរំលាយ
ទីក្រុងទាំងនោះដែលឡុតបាននៅ[ន]។

## លោកឡុត និងកូនស្រីទាំង២

៣០ឯឡុត ព្រមទាំងកូនស្រីទាំង២ ក៏ចេញពីសូអារ[ប] ឡើង
ទៅនៅឯភ្នំវិញ[ផ] ដ្បិតគាត់ខ្លាចមិនហ៊ាននៅក្នុងក្រុងសូអារ
ទេ គាត់ក៏នៅក្នុងរអាងភ្នំជាមួយនឹងកូនស្រីរបស់គាត់ទាំង
២ទៅ ៣១ចំណែកនាងបងនិយាយទៅកាន់ប្អូនថា ឪពុក
យើង គាត់ចាស់ហើយ គ្មានប្រុសណានៅគ្រប់ក្នុងស្រុកនេះ
នឹងចូលមកឯយើងតាមបវេណីផែនដីទេ ៣២បើដូច្នេះ ចូរ
យើងបំផឹកស្រាឪពុកយើង ហើយទៅដេកជាមួយនឹងគាត់
ទៅ ដើម្បីឱ្យបានតពូជ[ព]ឱ្យឪពុកយើងវិញ[ភ] ៣៣នោះគេក៏
បំផឹកស្រាឪពុកគេនៅយប់នោះឯង រួចនាងបងទៅដេក
ជាមួយនឹងឪពុកខ្លួនទៅ តែគាត់ឥតមានដឹងជាកាលនាង
ដេក ឬកាលនាងក្រោកឡើយ[ម] ៣៤លុះថ្ងៃស្អែកទៀត
នាងបងនិយាយទៅប្អូនថា មើល យប់មិញអញបានដេកជា
មួយ នឹងលោកឪពុក យប់នេះចូរ យើងបំផឹកស្រាគាត់ទៀត
រួចឱ្យឯងចូលទៅដេកជាមួយនឹងគាត់ម្តង ដើម្បីឱ្យយើង
បានតពូជរបស់ឪពុកយើង[យ] ៣៥គេក៏បំផឹកស្រា[រ]ឪពុកគេនៅ
យប់នោះទៀត នោះនាងប្អូនក៏ក្រោកទៅដេកជាមួយនឹង
ឪពុកទៅ តែគាត់ឥតដឹងជាកាលនាងដេក ឬកាលនាង
ក្រោកឡើយ[ល] ៣៦ដូច្នេះ កូនស្រីរបស់ឡុតទាំង២ក៏មានទំងន់
នឹងឪពុកខ្លួន[វ] ៣៧នាងបងបង្កើតបានកូនប្រុស១ នាងឱ្យ
ឈ្មោះថាម៉ូអាប់[ស] គឺអ្នកនោះហើយដែលជាឪពុកនៃសាសន៍
ម៉ូអាប់[ហ] ដរាបដល់សព្វថ្ងៃនេះ ៣៨ហើយនាងប្អូនក៏បង្កើត
បានកូនប្រុស១ដែរ នាងឱ្យឈ្មោះថាបេន-អាំមី[ឡ] គឺអ្នក
នោះហើយដែលជាឪពុកនៃកូនចៅអាំម៉ូន ដរាបដល់សព្វ
ថ្ងៃនេះ ។

យប ៤២:៩ **១៩:២២** ង លប ១៣:១០ **១៩:២៣** ច លប ១៣:១០ **១៩:២៤** ឆ យប ១៨:១៥ ទដ ១១:៦ អស ៣០:៣៣ ៣៤:៩ អគ ៣៨:២២ ជ លប ១៨:១៧ លវ ១០:២ មថ ១០:១៥ លក ១៧:២៩ ឈ ចទ ២៩:២៣ អស ១:៩ ១៣:១៩ យរ ៤៩:១៨ ៥០:៤០ អម ៤:១១ **១៩:២៥** ញ ខ.២៤ អគ ២៦:១៦ សផ ៣:៨ ហក ២:២២ ដ លប ១៣:១២ ឋ ទដ ១០៧:៣៤ អស ១:១០ យរ ២០:១៦ ២៣:១៤ បទ ៤:៦ អគ ១៦:៤៨ **១៩:២៦** ឌ ខ.១៧ ឍ លក ១៧:៣២ **១៩:២៧** ណ លប ១៨:២២ **១៩:២៨** ត លប ១៥:១៧ នក ១៩:១៨ វវ ៩:២ ១៨:៩ **១៩:២៩** ថ លប ១៣:១២ ទ លប ៨:១ ធ ២ពត ២:៧ ន លប ១៤:១២ អគ ១៤:១៦

**១៩:៣០** ប ខ.២២ លប ១៣:១០ ផ ខ.១៩ លប ១៤:១០ **១៩:៣២** ព លប ១៦:២ ភ ខ.៣៤,៣៦ លប ៣៨:១៨ **១៩:៣៣** ម ខ.៣៥ **១៩:៣៤** យ ខ.៣២ **១៩:៣៥** រ លប ៩:២១ ល ខ.៣៣ **១៩:៣៦** វ ខ.៣២ **១៩:៣៧** ស លប ៣៦:៣៥ នក ១៥:១៥ ជន ២៥:១ អស ១៥:១ ២៥:១០ យរ ២៥:២១ ៤៨:១ អគ ២៥:៨ សផ ២:៩ ហ ជន ២២:៤ ២៤:១៧ ចទ ២:៩៣ច ៣:២៨ នរ ១:៤,២២ ១សយ ១៤:៤៧ ២២:៣-៤ ២សយ ៨:២ ២ពវ ១:១ ៣:៤ អរ ៩:១ ទដ ១០៨:៩ យរ ៤៨:១ **១៩:៣៨** ឡ ជន ២១:២៤ ចទ ២:១៩ ២៣:៣ យស ១២:២ ពច ១:១៣ ១០:៦,៧ ១សយ ១១:១-១១ ១៤:៤៧ ១របា ១៩:១ ២របា ២០:២៣ ២៦:៨ ២៧:៥ នហ ២:១៩ ៤:៣ យរ ២៥:២១ ៤០:១៤ ៤៩:១ អគ ២១:២៨ ២៥:២ អម ១:១៣

**១៩:២៤** *ភ្លៀងជាស្ពាន់ធ័រនិងភ្លើង* ប្រហែលជាមកពីការកំអួតនៃរញ្ជួយផែនដីព្រួសឡើងលើដូចដែលយើងឃើញមាននៅសម័យបច្ចុប្បន្ននេះ (ប្រៀបធៀប អស ៣៤:៩ និងការពន្យល់) ។

**១៩:២៦** *ឯប្រពន្ធរបស់ឡុតក៏ងាកបែរមើលទៅក្រោយវិញ នោះស្រាប់តែទៅជាបង្គោលអំបិលទៅ* ប្រពន្ធឡុតនាងមានការស្ទាក់ស្ទើរ ដោយមិនបានស្តាប់បង្គាប់ (សូមមើល ខ.១៧) ហើយទង្វើរបស់នាងបានក្លាយជារឿងមួយដែលគេនិយាយតំណាលឡើងនៅពេលក្រោយៗទៀត (សូមមើល លក ១៧:៣២) ។ ទោះបីសព្វថ្ងៃនេះ ក៏មានរូបអំបិលនេះតាំងនៅក្បែរតំបន់ខាងត្បូងនៃសមុទ្រស្លាប់ដែរ ដោយទុកជាការរំលឹកពីការឆ្វេសប្រហែសរបស់នាងដែរ ។

**១៩:២៩** *ទ្រង់ក៏នឹកចាំពីអ័ប្រាហាំ* សូមមើល ៨:១ ។ *ក៏ឱ្យឡុតចេញផុតពីការហិនវិនាសនោះ* ការដោះលែងជីវិតឡុតគឺជាការព្រួយបារម្ភយ៉ាងក្រៃលែងបំផុតដែលលោកអ័ប្រាហាំបានអធិស្ឋានទូលសូម (១៨:២៣-៣២) ដល់ព្រះយេហូវ៉ាហើយឥឡូវនេះ ព្រះយេហូវ៉ាទ្រង់បានឆ្លើយតបមកដល់គាត់ហើយ ។

**១៩:៣៣** *គេបំផឹកស្រាឪពុកគេនៅយប់នោះឯង រួចនាងបងទៅដេកជាមួយឪពុកខ្លួនទៅ* ទោះបីជាតួនាទីរបស់ឡុតគឺជាបញ្ហាមួយដែលទទួលរងនូវអំពើបែបនេះក៏ដោយ ក៏គាត់មានការខ្វល់ខ្វាយចំពោះការទទួលខុសត្រូវនូវអ្វីដែលកើតឡើងមកលើនាង នឹងចម្រូតរបស់ព្រះដល់ក្រុងសូដុំមដែរ (មើល ១៣:១០-១២ និងការពន្យល់) ។

**១៩:៣៦-៣៨** កូនដែលកើតពីកូនស្រីរបស់ឡុតត្រូវបានក្លាយជាពួកព្ធយុកោរបស់ពួកម៉ូអាប់និងពួកអាំម៉ូន (ចទ ២:៩,១៩) ។ ពូជសាសន៍ទាំង២នេះគឺជាខ្មាំងសត្រូវដ៏ខ្លាំង ជាមួយពូជលោកលោកអ័ប្រាហាំ (១សយ ១៤:៤៧ ២ពវ ២០:១) ។

## លោកអ័ប្រាហាំ និងលោកអ័ប៊ីម៉្មាឡិច

*២០:១-១៨ – លប ១២:១០-២០ ២៦:១-១១*

**២០** ១ ឯអ័ប្រាហាំ គាត់ចេញពីទីនោះ[ក] ធ្វើដំណើរទៅ
ឯស្រុកត្បូង[ខ] គាត់តាំងទីលំនៅត្រង់កេរ៉ា[គ,ឃ] នាកណ្ដាល
កាដេស[ង] និងស៊ើរ[ច] ២ អ័ប្រាហាំក៏និយាយពីសារ៉ាប្រពន្ធ
គាត់ថាជាប្អូនវិញ[ឆ] រួចអ័ប៊ីម៉្មាឡិច[ជ]ជាស្ដេច កេរ៉ាទ្រង់ចាត់
គេឱ្យទៅនាំយកសារ៉ាមក[ឈ] ៣ តែព្រះទ្រង់មកពន្យល់សប្តិ[ញ]
ប្រាប់អ័ប៊ីម៉្មាឡិច[ដ]នៅពេលយប់ថា មើល ឯងទុកដូចជា
មនុស្សស្លាប់[ឋ] ដោយព្រោះស្ត្រីដែលឯងបានយកនេះ ពី
ព្រោះនាងជាប្រពន្ធគេទេ[ឌ] ៤ តែអ័ប៊ីម៉្មាឡិចមិនបានចូលទៅ
ជិតសារ៉ាសោះ ក៏ទូលសួរថា ឱព្រះអម្ចាស់អើយ តើទ្រង់
នឹងបំផ្លាញទាំងនគរសុចរិតដែរឬអី[ឍ] ៥ តើគាត់មិនបាន
ប្រាប់ទូលបង្គំថា នាងជាប្អូនទេឬអី[ណ] ហើយនាងក៏និយាយ
ដែរថា គាត់ជាបងខ្ញុំ ដូច្នេះទូលបង្គំបានធ្វើការនេះដោយ
ទៀងត្រង់ទេ[ត] ហើយដោយដៃស្អាតផង[ថ] ៦ ក្នុងសប្តិនោះ
ព្រះទ្រង់មានបន្ទូលទៅថា អញដឹងហើយ ថាឯងបានធ្វើ
ការនេះដោយទៀងត្រង់ ហើយអញក៏បានឃាត់[ទ]មិនឱ្យឯង
ធ្វើបាបនឹងអញដែរ[ធ] ហេតុនោះបានជាអញមិនបើកឱ្យឯង
ពាល់នាងឡើយ ៧ ដូច្នេះចូរប្រគល់ប្រពន្ធគេទៅវិញឥឡូវ
ទៅ នោះគាត់នឹងអធិស្ឋានឱ្យឯង[ន] ហើយឯងនឹងបានរស់
នៅតទៅដ្បិតគាត់ជាហោរា[ប] បើឯងមិនប្រគល់ទៅវិញទេ
នោះត្រូវដឹងថា ឯងនឹងស្លាប់ជាប្រាកដទាំងឯងនិងពួកឯង
ទាំងអស់ផង[ផ] ។
៨ អ័ប៊ីម៉្មាឡិចក៏ក្រោកពីព្រលឹម ទៅហៅពួកបំរើទ្រង់ទាំង
អស់មក ប្រាប់សេចក្តីទាំងនោះដល់ត្រចៀកគេ គេក៏មាន
សេចក្តីភ័យស្លុតទាំងអស់គ្នា ៩ រួចអ័ប៊ីម៉្មាឡិចហៅអ័ប្រាហាំ
មកបន្ទោសថា អ្នកបានធ្វើអ្វីដល់យើងដូច្នេះ តើខ្ញុំធ្វើបាប
នឹងអ្នកដូចម្តេច បានជាអ្នកនាំឱ្យខ្ញុំ ហើយនឹងនគរខ្ញុំមាន
បាបជាធ្ងន់ដល់ម៉្លេះ អ្នកបានប្រព្រឹត្តនឹងខ្ញុំចំពោះសេចក្តី
ដែលមិនត្រូវប្រព្រឹត្តឡើយ[ព] ១០ អ័ប៊ីម៉្មាឡិចក៏សួរអ័ប្រាហាំ
ថា តើអ្នកឃើញដូចម្តេចបានជាធ្វើដូច្នេះ ១១ អ័ប្រាហាំទូល
ថា ពីព្រោះទូលបង្គំនឹកថា ប្រាកដជាគ្មានសេចក្តីកោតខ្លាច
ដល់ព្រះ[ភ]នៅទីនេះទេ ហើយថា គេនឹងសំឡាប់ទូលបង្គំ
ចោលដោយព្រោះប្រពន្ធរបស់ទូលបង្គំនេះ[ម] ១២ មួយទៀត
នាងជាប្អូនទូលបង្គំមែន[យ] គឺជាកូនរបស់ឪពុកទូលបង្គំ ប៉ុន្តែ
មិនមែនជាពោះមួយនឹងគ្នាទេ ហើយទូលបង្គំបានយកធ្វើជា
ប្រពន្ធទៅ ១៣ កាលព្រះទ្រង់បានធ្វើឱ្យទូលបង្គំដើរ[រ]ចាក
ចោលផ្ទះឪពុកមក[ល] នោះទូលបង្គំបាននិយាយនឹងនាងថា
ត្រូវឱ្យឯងអាណិតដល់អញយ៉ាងនេះ គឺនៅកន្លែងណាដែល
យើងទៅនោះត្រូវនិយាយពីអញថាជាបងឯង ១៤ នោះ
អ័ប៊ីម៉្មាឡិច[វ]ក៏យកហ្វូងចៀមហ្វូងគោ និងបាវប្រុសបាវស្រី
ប្រទានដល់អ័ប្រាហាំ[ស] ព្រមទាំងប្រគល់សារ៉ាជាប្រពន្ធទៅ

**២០:១** ក លប ១៨:១ ខ លប ២៦:១,៦,១៧ គ លប ១២:៩ ឃ ប ១៤:៧ ង លប ១៦:៧ ច លប ២៦:៣ **២០:២** ឆ ខ.១២ លប ១២:១៣ ជ ខ.១៤ លប ២១:២២ ២៦:១ ឈ លប ១២:១៥ **២០:៣** ញ លប ២៨:១២ ៣១:១០,២៤ ៣៧:៥,៩ ៤០:៥ ៤១:១ ជន ១២:៦ ចទ ១៣:១ យប ៣៣:១៥ ដយ ២:១ ៤:៥ ដ ជណ ២២:៩ ឋ នក ១០:៧ ១២:៣៣ ទដ ១០៥:៣៨ ឌ ខ.៧ លប ២៦:១១ ១រប ១៦:២១ ទដ ១០៥:១៤ **២០:៤** ឍ លប ១៨:២៥ **២០:៥** ណ លប ១២:១៩ ត លប ១៧:១ ថ ទដ ៧:៨ ២៥:២១ ២៦:៦ ៤១:២១ **២០:៦** ទ ១សយ ២៥:២៦,៣៤ ធ ទដ ១៣:១៣ ទដ ៤១:៤ ៥១:៤ **២០:៧** ន ខ.១៧ នក ៨:៨ ជន ១១:២ ១២:១៣ ១សយ ៧:៥ ១ពវ ១៣:៦ យប ៤២:៨ យរ ១៨:២០ ៣៧:៣ ៤២:២ ប ចទ ១៨:១៨ ៣៤:១០ ២ពវ ៣:១១ ៥:៣ ១រប ១៦:២២ ទដ ១០៥:១៥ ផ ខ.៣ ទដ ៩:៥ **២០:៩** ព លប ១២:១៨ ៣៤:៧ **២០:១១** ភ លប ៤២:១៨ នហ ៥:១៥ យប ៣១:២៣ ទដ ៣៦:១ សភ ១៦:៦ ម លប ១២:១២ ៣១:៣១ **២០:១២** យ លប ១២:១៣ **២០:១៣** រ ចទ ២៦:៥ ១រប ១៦:២០ អស ៣០:២៨ ៦៣:១៧ ល លប ១២:១ **២០:១៤** វ ខ.២ ស លប ១២:១៦

**២០:១-១៨** សូមមើល ១២:១០-២០ និងការពន្យល់ ។

**២០:១** *ស្រុកត្បូង* សូមមើល ១២:៩ ។ *នាកណ្ដាលកាដេសនិងស៊ើរ* មើល ១៤:៧ ១៦:៧ ។ *កេរ៉ា* មានទីតាំងនៅជាប់ប្រទេសភីលីស្ទីន ប្រហែលជាពាក់កណ្ដាលពីកាសាដែលស្ថិតនៅជិតសមុទ្រមេឌីទែរ៉ាណេ និងបៀរសេបាខាងជើងស្រុកត្បូង ។

**២០:២** *អ័ប៊ីម៉្មាឡិច* ប្រហែលជាឪពុក ឬជាជីតារបស់ស្ដេចមួយអង្គក្រោយទៀតដែលមានឈ្មោះដូចគ្នានេះដែរ សូមមើល ២៦:១ ។

**២០:៣** *ពន្យល់សប្តិ* គ្រាមួយព្រះយេហូវ៉ាទ្រង់បានជួយធ្វើអន្តរាគមន៍ ដើម្បីបម្រុងឱ្យនាងបានធ្វើជាម្ដាយនៃសេចក្ដីសន្យាថា និងមានកូនចៅជាច្រើន ។ ជារឿយៗរាល់ការយល់សប្តិ ព្រះយេហូវ៉ាទ្រង់តែងតែបង្ហាញតាមរយៈការបើកសម្ដែងនៅក្នុងសញ្ញាចាស់ (មើល ២៨:១២ ៣២:១០-១១ ៣៧:៥-៩ ៤០:៥ ៤១:១ ជន ១២:៦ ពច ៧:១៣ ១ ប ៣:៥ ដយ ២:៣ ៤:៥ ៧:១)។

**២០:៧** *ហោរា* សូមមើល ទ១៨:១៧ សក ១:១ ។ លោកអ័ប្រាហាំគាត់គឺជាមនុស្សដំបូង ដែលព្រះយេហូវ៉ាបានតាំងឱ្យធ្វើជាហោរា (មើល ទដ ១០៥:១៥) ។

**២០:៩** *នាំឱ្យខ្ញុំ ហើយនិងនគរខ្ញុំមានបាបជាធ្ងន់ដល់ម៉្លេះ*ឬ "ធ្វើឱ្យខ្ញុំហើយនិងនគរខ្ញុំប្រព្រឹត្តបាបធន់ម៉្លេះ" ។ ពាក្យថា "អំពើបាបដ៏ធ្ងន់" គឺជាការផិតក្បត់គ្នា (មើល ខ.២-៣,ខ.៦ ហើយ "អំពើបាបដ៏ធន់" គឺសំដៅលើការស្បថ នៅក្នុងអេស៊ីព្ទនិងពួកកាណានដែរ) ។ នៅកន្លែងផ្សេងទៀតដែលកើតឡើងក្នុងគ្រាសញ្ញាចាស់ គឺសំដៅលើការថ្វាយបង្គំរូបព្រះ (នក ៣២:២១ ៣០-៣១ ២ពវ ១៧:២១) គឺជាការផិតក្បត់ខាងឯវិញ្ញាណ (ហស ១:២) ។ ការផិតក្បត់នឹងការថ្វាយបង្គំរូបព្រះនោះ គឺជាការក្បត់ចំពោះការតាំងសញ្ញាជាមួយនិងព្រះហើយ ។

**២០:១១** *សេចក្តីកោតខ្លាចដល់ព្រះ* គឺជាការតាំងសញ្ញាគឺដូចគ្នានឹងពាក្យថា "សាសនាដ៏ពិត" ។ "កោតខ្លាច" នៅទីនេះគឺមានន័យថា ទុកចិត្តចំពោះព្រះ ហើយប្ដេជ្ញាថា និងស្មោះត្រង់ហើយធ្វើតាមព្រះបន្ទូលទ្រង់ (ទដ ៣៤:៨-១៤ និងការពន្យល់) ។

**២០:១២** *នាងជាប្អូនទូលបង្គំមែន គឺជាកូនរបស់ឪពុកទូលបង្គំប៉ុន្តែមិនមែនជាពោះមួយនឹងគ្នាទេ* ការមិនទុកចិត្តពាក់កណ្ដាលរបស់លោកអ័ប្រាហាំ គឺជាអំពើបាបតែមួយផ្នែកប៉ុណ្ណោះ មិនមែនជាអំពើបាបពេញទីនោះឡើយ ។

**២០:១៤-១៦** ទង្វើល្អរបស់លោកអ័ប៊ីម៉្មាឡិច គឺខ្លាំងជាងអ្វីដែលលោកអ័ប្រាហាំបានគិតទៅទៀត ។

វិញផង ១៥រួចអ័ប៊ីម៉ាឡិចមានបន្ទូលថា មើល ស្រុកខ្ញុំនៅ
មុខអ្នកស្រាប់ ចូរអ្នកនៅកន្លែងណាដែលអ្នកឃើញថា
ស្រួលចុះ[ហ] ១៦ហើយទ្រង់ក៏មានបន្ទូលទៅសារ៉ាថា មើល
អញឱ្យប្រាក់១ពាន់ដល់បងនាង សំរាប់នឹងបាំងភ្នែកនៃអស់
អ្នកដែលនៅជាមួយនឹងនាង គឺយ៉ាងនោះដែលបានបន្ទោស
ដល់សារ៉ា ១៧នោះអ័ប្រាហាំគាត់អធិស្ឋានដល់ព្រះ[ឡ] ហើយ
ព្រះ ទ្រង់ក៏ប្រោសអ័ប៊ីម៉ាឡិចឱ្យបានជារួចភរិយានិងពួក
អ្នកម្នាងរបស់ទ្រង់បានកើតកូនទៀត ១៨ពីព្រោះព្រះ
យេហូវ៉ា ទ្រង់បានបង្ខាំងពោះនៃពួកដំណាក់អ័ប៊ីម៉ាឡិច
ដោយព្រោះសារ៉ាជាប្រពន្ធអ័ប្រាហាំ[អ] ។

**កំណើតរបស់លោកអ៊ីសាក់**

**២១** ១ព្រះយេហូវ៉ាទ្រង់ក៏ប្រោសដល់សារ៉ា[ក] ដូចជា
ទ្រង់បានមានបន្ទូល គឺទ្រង់ធ្វើសំរេចឱ្យសារ៉ា តាមដែល
ទ្រង់សន្យា[ខ] ២សារ៉ាក៏មានទំងន់បង្កើតបានកូនប្រុស១[គ]ឱ្យ
អ័ប្រាហាំ ក្នុងកាលដែលគាត់ចាស់ហើយ[ឃ] ត្រូវតាមពេល
កំណត់ដែលទ្រង់បានប្រាប់គាត់[ង] ៣អ័ប្រាហាំគាត់ដាក់ឈ្មោះ
ឱ្យកូនដែលសារ៉ាបានបង្កើតនោះថា អ៊ីសាក[ច] ៤លុះកើតមក
បាន៨ថ្ងៃ នោះអ័ប្រាហាំក៏កាត់ស្បែកឱ្យ[ឆ] ដូចជាព្រះទ្រង់
បង្គាប់មក ៥អ័ប្រាហាំអាយុបាន១០០ឆ្នាំហើយ[ជ] ក្នុងកាល
ដែលអ៊ីសាកកូនគាត់កើតមក ។

៦សារ៉ានិយាយថា ព្រះទ្រង់បានធ្វើឱ្យអញសើច[ឈ]ហើយ
អស់អ្នកណាដែលឮ ក៏នឹងសើចជាមួយនឹងអញដែរ” ៧នាង
ពោលទៀតថា តើអ្នកណានឹងហ៊ានប្រាប់អ័ប្រាហាំថា
សារ៉ានឹងបំបៅកូន ប៉ុន្តែអញបានបង្កើតកូនឱ្យគាត់ក្នុង
កាលដែលគាត់ចាស់ហើយវិញ[ញ]។

**ការបញ្ជូននាងហាការ និងលោកអ៊ីសម៉ាអែលចេញ**

៨ឯអ៊ីសាកក៏ធំឡើង ហើយគេផ្តាច់ដោះចេញ[ដ] រួចនៅថ្ងៃ
ដែលផ្តាច់ដោះ នោះអ័ប្រាហាំក៏រៀបជប់លៀងយ៉ាងធំ ។
៩សារ៉ាឃើញកូនដែលហាការជាសាសន៍អេស៊ីព្ទបាន
បង្កើតឱ្យអ័ប្រាបហាំ[ឋ]វាសើចឡកឱ្យ[ឌ] ១០នោះនាងនិយាយ
នឹងអ័ប្រាហាំថា ចូរបណ្តេញបាវស្រីនេះ[ឍ]និងកូនវាចេញ
ទៅ ដ្បិតកូនរបស់បាវស្រីនេះមិនត្រូវស៊ីមរដកជាមួយនឹង
អ៊ីសាកកូនខ្ញុំទេ[ណ] ១១តែសេចក្តីនោះនាំឱ្យអ័ប្រាហាំពិបាក
ចិត្តណាស់ ដោយព្រោះកូនគាត់[ត] ១២រួចព្រះទ្រង់មានបន្ទូល
ទៅអ័ប្រាហាំថា កុំឱ្យឯងពិបាកចិត្តដោយព្រោះកូនក្មេង
ហើយនិងបាវស្រីរបស់ឯងឡើយ ត្រូវស្តាប់តាមគ្រប់ទាំង
សេចក្តីដែលសារ៉ាបានប្រាប់ឯងវិញ ដ្បិតពូជឯងនឹងបាន
រាប់ដោយសារតែអ៊ីសាកទេ[ថ] ១៣ឯកូនរបស់បាវស្រីនោះ
គង់តែអញនឹងធ្វើឱ្យវាបានត្រឡប់ជានគរ១ដែរ[ទ] ព្រោះវា
ជាពូជឯង ១៤នោះអ័ប្រាហាំក៏ក្រោកឡើងពីព្រលឹមយក

**២០:១៥** ហ លប ១៣:៩ ៤៥:១៨ **២០:១៧** ឡ ខ.៧ យប ៤២:៩ **២០:១៨** អ លប ១២:១៧ **២១:១** ក ១សយ ២:២១ ខ លប ៨:១ ១៧:១៦,២១ ១៨:១៤ កទ ៤:២៣ ហព ១១:១១ **២១:២** គ លប ១៧:១៩ ៣០:៦ ឃ កទ ៤:២២ ហព ១១:១១ ង កទ ១៨:១០ **២១:៣** ច កទ ១៦:១១ ១៧:១៩ យស ២៤:៣ **២១:៤** ឆ លប ៧:៨ ១៧:១០,១២ កច **២១:៥** ជ លប ១២:៤ ហព ៦:១៥ **២១:៦** ឈ លប ១៧:១៧ យប ៨:២១ ទដ ១២៦:២ អស ១២:៦ ៣៥:២ ៤៤:២៣ ៥២:៩ ៥៤:១

**២១:៧** ញ លប ៧:១៧ **២១:៨** ដ ១សយ ១:២៣ **២១:៩** ឋ លប ១៦:១៥ ឌ លប ៣៩:១៤ កទ ៤:២៩ **២១:១០** ឍ លប ៣៩:១៧ ណ លប ២៥:៦ កទ ៤:៣០ **២១:១១** ត លប ១៧:១៨ **២១:១២** ថ មថ ១:២ រម ៩:៧ ហព ១១:១៨ **២១:១៣** ទ ខ.១៨ លប ១៣:១៦ **២១:១៤** ធ លប ១៦:១ ន ខ.៣១,៣២ លប ២២:១៩ ២៦:៣៣ ២៨:១០ ៤៦:១,៥ យស ១៥:២៨ ១៩:២ ពច ២០:១ ១សយ

**២០:១៦** *ប្រាក់១ពាន់* ទោះពាក្យនេះមិនមែនជាព្រះគម្ពីរភាសាហេព្រើរក៏ដោយ ពាក្យនេះវាពិតជាត្រឹមត្រូវ ហើយក្នុងសម័យបុរាណជាទូទៅគេប្រើរង្វាស់នេះ នៅគ្រាដែលគេបោះពុម្ពកាក់ ពាក្យដើមរបស់វាជារង្វាស់ទម្ងន់មិនមែនជាកាក់នោះឡើយរហូតដល់សតវត្សរ៍ទី៧ មុន គ.ស ។

**២១:១** មើល ១៧:១៦ ។ *សំរេចឱ្យសារ៉ាតាមដែលទ្រង់សន្យា* មើល កទ ៤:២២–២៣ ២៨ ។ សេចក្តីសន្យាថានឹងប្រទានឱ្យមានកូន គឺតាមរយៈអ្នកណាដែលព្រះយេហូវ៉ាទ្រង់នៅតែបន្តការតាំងសញ្ញាជាមួយ ១៧:២១ ថានិងបាននៅពេលក្រោយ ។

**២១:៣** *អ៊ីសាក* មើល ១៧:១៧ ។

**២១:៤** មើល ១៧:១០ ខ.១២ ។

**២១:៥** នៅពេលដែលព្រះយេហូវ៉ា ទ្រង់បានសម្រេចសេចក្តីសន្យារបស់ទ្រង់ចំពោះលោកអ័ប្រាហាំ (១៧:១៦) តាមរយៈការអស្ចារ្យលោកអ័ប្រាហាំគាត់ក្លាយជាឪពុកនៅគ្រាដែលគាត់មានអាយុ១០០ឆ្នាំ (មើល ១៧:១៧) ។

**២១:៦** *សើច . . . សើច* មើល ១៧:១៧ ។

**២១:៨** *ផ្តាច់ដោះ* តាមវប្បធម៌របស់ពួកអ្នកដែលរស់នៅតំបន់មជ្ឈឹមបូព៌ា កូនរបស់ពួកគេត្រូវផ្តាច់ដោះនៅពេលអាយុ២ឬ៣ឆ្នាំ ។

**២១:៩** *កូនដែលហាការជាសាសន៍អេស៊ីព្ទបានបង្កើត* អ៊ីសម៉ាអែសពេលនោះមិនទាន់ជិទង់នៅឡើយ(១៦:១៥–១៧) ។ *សើចឡកឱ្យ* ឬ“មើលងាយ” ទង្វើទាំង២នេះដោយសារតែនាងគិតថា អ៊ីសម៉ាអែលគឺជាអ្នកស៊ីមរតករបស់អ៊ីសាក (ខ.១០) ។

**២១:១០** *ចូរបណ្តេញបាវស្រីនេះនិងកូនវាចេញទៅ* មើល កទ ៤:២១–៣១ ការបណ្តេញពួកគេចេញ អាចនឹងមិនចែកទ្រព្យសម្បត្តិឱ្យ ។

**២១:១១** *សេចក្តីនោះនាំឱ្យអ័ប្រាហាំពិបាកចិត្តណាស់* ទាំងការស្រឡាញ់និងការបណ្តេញចេញ គឺជាការមួយធ្វើឱ្យលោកអ័ប្រាហាំគាត់មានការពិបាកចិត្តយ៉ាងខ្លាំង ។ គាត់បានដឹងថា តាមរយៈប្រពៃណីរបស់គាត់ថ្ងៃនេះវានឹងជះឥទ្ធិពល ហើយគេនឹងចារក្នុងសិលាចារឹកមួយឈ្មោះថា“នូស៊ី” (Nuzi) ។

**២១:១២** *ត្រូវស្តាប់តាមគ្រប់ទាំងសេចក្តីដែលសារ៉ាបានប្រាប់ឯងវិញ* ព្រះយេហូវ៉ាទ្រង់ជាអ្នកគ្រប់គ្រងនិងដោះស្រាយលើបញ្ហាទាំងនេះដូចអ្វីដែលទ្រង់បានធ្វើកាលពីដើម (១៥:៤) ចំពោះអ្វីដែលទ្រង់សន្យាថា និងឱ្យអ៊ីសាកនិងអ៊ីសម៉ាអែលមានកូនចៅដ៏ច្រើន ។ *ពូជឯងនឹងបានរាប់ដោយសារតែអ៊ីសាកវិញទេ* មើល ១៧:១៩ ២២:១៨ រម ៩:៦៨ ហព ១១:១៧–១៩ សម្រាប់ព័ត៌មានបន្ថែមទៀតពីការនេះ ។

**២១:១៤** *ព្រលឹម* ទោះបីជាពេលនេះលោកអ័ប្រាហាំគាត់បានបែកចេញពីអ៊ីសម៉ាអែលជាលើកដំបូងក៏ដោយ ក៏គាត់ត្រូវតែបង្ហាញពីការទទួលខុសត្រូវរបស់គាត់ចំពោះព្រះយេហូវ៉ានូវអ្វីដែលទ្រង់បានបង្គាប់មក (មើល ១២:៤) ។ *បៀរសេបា* មើល ខ.៣១ ។

នំប៉័ងនឹងថង់ស្បែកមានទឹកពេញ ប្រគល់ឱ្យហាការ[ធ] ទាំង
ដាក់លើស្មាបញ្ជូនឱ្យនាងទៅព្រមទាំងកូននាងដែរ នាងក៏
ចេញទៅ ដើរចុះឡើងក្នុងទីរហោស្ថានក្បែរបៀរសេបា[ន]
១៥ឯទឹកក្នុងថង់ស្បែកក៏អស់ទៅ រួចនាងចោលកូននៅ
ក្រោមដើមឈើតូច១ ១៦ហើយថយទៅអង្គុយប្រឈមមុខ
នឹងវា ចំងាយពី១ជួរធ្នូរ ដោយគិតថា កុំឱ្យអញឃើញកូន
នេះស្លាប់ឡើយ ដូច្នេះនាងក៏អង្គុយប្រឈមមុខនិងកូន ស្រែក
យំឡើង[ប] ១៧ព្រះទ្រង់ឮសំឡេងកូនជិទង់នោះ[ផ] ហើយទេវតា
នៃព្រះ[ព]ក៏ហៅហាការពីលើមេឃ[ភ]សួរថា វាថ្វី ហាការ
អើយ កុំឱ្យខ្លាចឡើយ[ម] ដ្បិតព្រះទ្រង់បានឮសំឡេងរបស់កូន
ជិទង់ពីកន្លែងវាហើយ ១៨ចូរក្រោកឡើងទៅលើកកូនមក
ដ្បិតអញនឹងធ្វើឱ្យវាត្រឡប់ជាសាសន៍១យ៉ាងធំ[យ] ១៩រួចព្រះ
ទ្រង់បំភ្លឺភ្នែក[រ]ហាការឱ្យឃើញអណ្ដូងទឹក១[ល] នាងក៏ទៅ
ដងដាក់ពេញថង់ស្បែកយកមកឱ្យកូនផឹក ២០ព្រះទ្រង់ក៏គង់
ជាមួយនឹងកូនជិទង់នោះ[វ] វាកាន់តែធំឡើង ហើយនៅតែ
ក្នុងទីរហោស្ថាន ក៏បានត្រឡប់ជាអ្នកប្រមាញ់ធ្នូ ២១វា
អាស្រ័យនៅក្នុងទីរហោស្ថានប៉ារ៉ាន[ស] ហើយម្ដាយក៏នាំយក
ស្ត្រីម្នាក់ពីស្រុកអេស៊ីព្ទមកឱ្យធ្វើជាប្រពន្ធ[ហ] ។

## ពាក្យសម្បថនៅបៀរ–សេបា

២២នៅវេលានោះ អ័ប៊ីម៉្មាឡិច[ឡ] និងភីកុល ជាមេទ័ពទ្រង់[អ]
ក៏មកនិយាយនឹងអ័ប្រាហាំថា ព្រះទ្រង់គង់ជាមួយនឹងអ្នកក្នុង
គ្រប់ការដែលអ្នកធ្វើ[ក] ២៣ដូច្នេះសូមឱ្យអ្នកស្បថ[ខ] នឹងព្រះឱ្យ
ខ្ញុំនៅទីនេះឥឡូវ ថាអ្នកនឹងមិនប្រព្រឹត្តចំពោះខ្ញុំ ឬកូនចៅ
ខ្ញុំតរៀងទៅ[គ]ដោយសេចក្ដីភូតភរឡើយ សូមប្រព្រឹត្តនឹងខ្ញុំ
ហើយស្រុកដែលអ្នកបានសំណាក់នៅនេះដោយសេចក្ដី

៣:២០ ១រប ៤:២៨ នហ ១១:២៧ **២១:១៦** ប យរ ៦:២៦ អម ៨:១០ សក ១២:១០ **២១:១៧** ផ នក ៣:៧ ជន ២០:១៦ ចទ ២៦:៧ ទដ ៦:៨ ព លប ១៦:៧ ភ លប ២២:១១,១៥ ម លប ១៥:១ **២១:១៨** យ ខ.១៣ លប ១៧:២០ **២១:១៩** រ ជន ២២:៣១ ល លប ៧ **២១:២០** វ លប ២៦:៣,២៤ ២៨:១៥ ៣៩:២,២១,២៣ លក ១:៦៦ **២១:២១** ស លប ១៤:៦ ហ លប ២៤:៤,៣៨ ២៨:២ ៣៤:៤,៨ ពច ១៤:២ **២១:២២** ឡ លប ២០:២ អ ខ.៣២ លប ២៦:២៦ ក ខ.២៣ លប ២៦:២៨ ២៨:១៥ ៣១:៣,៥, ៤២ ៣៩:២,៣ ១សយ ៣:១៩ ១៦:១៨ ២រប ១:១ ទដ ៤៦:៧ អស ៧:១៤ ៨:៨,១០

សប្បុរស ដូចជាខ្ញុំបានប្រព្រឹត្តនឹងអ្នកដែរ"[ឃ] ២៤អ័ប្រាហាំ
ទូលឆ្លើយថា ទូលបង្គំសុខចិត្តស្បថ ២៥តែអ័ប្រាហាំគាត់
បន្ទោសដល់អ័ប៊ីម៉្មាឡិចពីដំណើរអណ្ដូងទឹក ដែលពួកបាវ
ទ្រង់បានដណ្ដើមយក[ង] ២៦អ័ប៊ី–ម៉្មាឡិចក៏ឆ្លើយថា ខ្ញុំមិនដឹង
ជាអ្នកណាបានធ្វើការនោះទេ អ្នកក៏មិនបានប្រាប់ខ្ញុំ ហើយ
ខ្ញុំឥតបានឮអ្វីឡើយ ដរាបមកដល់ថ្ងៃនេះ ២៧អ័ប្រាហាំគាត់
យកចៀមនិងគោមកថ្វាយអ័ប៊ីម៉្មាឡិច រួចក៏តាំងសញ្ញានឹង
គ្នាទៅវិញទៅមក[ច] ២៨អ័ប្រាហាំគាត់ដាក់កូនចៀម៧ដោយ
ខ្លួន ២៩នោះអ័ប៊ីម៉្មាឡិចសួរថា កូនចៀម៧ដែលអ្នកដាក់
ដោយខ្លួននេះតើមានន័យដូចម្ដេច ៣០គាត់ទូលឆ្លើយថា
ទ្រង់ត្រូវទទួលកូនចៀម៧នេះពីដៃទូលបង្គំ ទុកជាទីបន្ទាល់[ឆ]
ដល់ទូលបង្គំថា ទូលបង្គំបានជីកអណ្ដូងនេះ[ជ] ៣១ដោយហេតុ
នោះបានជាគាត់ហៅទីនោះថា "បៀរ–សេបា"[ឈ] ពីព្រោះ
បានស្បថគ្នា [ញ]នៅទីនោះឯង ៣២គឺយ៉ាងនោះហើយដែល
បានតាំងសញ្ញានឹងគ្នា[ដ] នៅត្រង់បៀរ–សេបា[ឋ] រួចហើយ
អ័ប៊ីម៉្មាឡិច នឹងភីកុល ជាមេទ័ពទ្រង់[ឌ]ក៏ក្រោកឡើង វិល
ត្រឡប់ទៅឯស្រុកភីលីស្ទីនវិញទៅ[ឍ] ។
៣៣ឯអ័ប្រាហាំគាត់ដាំដើមឈើ១[ណ]នៅត្រង់បៀរ–សេបា
ហើយនៅទីនោះ គាត់អំពាវនាវដល់ព្រះនាម ព្រះយេហូវ៉ា[ត]

៤១:១០ ៤៣:៥ **២១:២៣** ខ ខ.៣១ លប ២៥:៣៣ ២៦:៣១ ៣១:៥៣ យស ២:១២ ១ពវ ២:៨ គ ១សយ ២៤:២១ ឃ ខ.២២ យស ២:១២ **២១:២៥** ង លប ២៦:១៥,១៨,២០–២២ **២១:២៧** ច ខ.៣១,៣២ លប ២៦:២៨,៣១ ៣១:៤៤,៥៣ **២១:៣០** ឆ លប ៣១:៤៤,៤៧, ៤៨,៥០ ៥២ យស ២២:២៧, ២៨,៣៤ ២៤:២៧ អស ១៩:២០ មឡ ២:១៤ ជ ខ.២៥ លប ២៦:២៥,៣២ **២១:៣១** ឈ ខ.១៤ ញ ខ.២៣,២៧ **២១:៣២** ដ ខ.២៧ ឋ ខ.១៤ ឌ ខ.២២ ឍ លប ១០:១៤ **២១:៣៣** ណ ១សយ ២២:៦ ៣១:១៣ ត លប ៤:២៦ ថ នក ១៥:១៨ ចទ ៣២:៤០ ៣៣:២៧ យប ៣៦:២៦ ទដ ១០:១៦ ៤៥:៦៩០:២

**២១:១៥** *ដើមឈើតូច១* មើល ខ.៣៣ ។

**២១:១៧** *ព្រះទ្រង់ឮសំឡេង . . . ដ្បិតព្រះទ្រង់ឮសំឡេង* ឈ្មោះ "អ៊ីសម៉ាអែល" (មើល ១៦:១១ ១៧:២០) ។

**២១:២១** *ទីរហោស្ថានប៉ារ៉ាន* ស្ថិតនៅភាគខាងជើងនៃភ្នំស៊ីណាយ ។ ហើយម្ដាយក៏នាំយកស្ត្រីម្នាក់ពីស្រុកអេស៊ីព្ទមកឱ្យធ្វើជាប្រពន្ធ ជានិច្ចកាលឪពុកម្ដាយ គឺជាអ្នករៀបការឱ្យកូនរបស់ពួកគេ (ជំពូក ២៤) ។

**២១:២២** *អ័ប៊ីម៉ាឡិច* មើល ២០:២ ។ *ភីកុល* ក្នុងខណៈពេលដែលគាត់លេចមុខជាថ្មីម្ដងទៀត គឺប្រហែលជាជាង៦០ឆ្នាំក្រោយមកគេយកឈ្មោះទាំង២ដាក់ឱ្យក្រុមគ្រួសាររបស់គេ ឬក៏ជាឈ្មោះក្នុងជួរមន្ត្រី (សូមមើល ២៥:២៦) ដូចគ្នានឹង ២៦:២៦ ។

**២១:២៣** *ស្បថនឹងព្រះឱ្យខ្ញុំ . . . សូមប្រព្រឹត្តនឹងខ្ញុំ . . . ដោយសប្បុរស* ពាក្យនេះគេប្រើវាជាការធម្មតានៅពេលធ្វើការតាំងសញ្ញា ឬក៏ធ្វើសន្ធិសញ្ញាមួយ(មើល ខ.២៧,៣២) ។ "ចិត្តល្អ" ពាក្យដែលប្រើនៅទីនេះ គឺសំដៅលើមិត្តភាព (ប្រៀបធៀប ខ.២៧ ២០:១៤ ទដ ៦:៤ និងការពន្យល់) ។ ជានិច្ចកាល ការតាំងសញ្ញា គឺជាប់ទាក់ទងនឹងសេចក្ដីសម្បថ ។

**២១:២៧** *ចៀម និងគោ* ប្រហែលសម្រាប់ប្រើក្នុងពេលតាំងសញ្ញា (មើល ១៥:១០) ។

**២១:៣០** *ទុកជាទីបន្ទាល់* "ទីបន្ទាល់" ដើម្បីតាំងសញ្ញាឬព្រឹត្តិការណ៍ដែលសំខាន់ផ្សេងៗទៀត (គឺមិនមែនគិតតែប្រយោជន៍ផ្ទាល់ខ្លួននោះមនុស្សទី៣) ជាសាក្សីក្នុងការធ្វើបន្ទាល់ (មើល ៣១:៤៤,៤៨,៥២ ចទ ៤:២៦ ៣០:១៩ ៣១:១៩,២៦ ៣២:១ យស ២២:២៧–២៨ ២៤:២៧ ១សយ ៦:១៨ និងការពន្យល់) ហើយនិងជំនួសមកវិញនៅ ទដ ៥០:១ អស ១:២ មីក ៦:១–២ ។

**២១:៣១** *បៀរសេបាពីព្រោះបានស្បថគ្នា នៅកន្លែងនោះឯង* សម្រាប់ឈ្មោះប្រហែលគ្នានេះទៀត មើល ២៦:៣៣ ។ បៀរសេបាគឺជាទីក្រុងមួយដែលមានសារៈសំខាន់នៅភាគខាងជើងស្រុកត្បូង ហើយវានៅខាងត្បូងបំផុតនៃព្រំប្រទល់ប្រទេសអ៊ីស្រាអែល ដែលក្រោយមកដំបន់នេះក្លាយជាកន្លែងមួយដែលមានលទ្ធិប្រជាធិបតេយ្យពេញលេញ (មើល ២សយ ១៧:១១) ។ តាំងពីបុរាណកាលមកអណ្ដូងនោះគេនៅតែហៅថា "អណ្ដូងលោកអ័ប្រាហាំ" (មើល ខ.២៥) ប៉ុន្តែគេមិនបានដឹងច្បាស់នោះទេ ។

**២១:៣២** *ភីលីស្ទីន* សូមមើល ១០:១៤ ។

ជាព្រះដ៏មានព្រះជន្មអស់កល្បជានិច្ច[ប] ៣៤រួចគាត់សិចតនៅ
ស្រុកភីលីស្ទីន[ទ]នោះជាយូរថ្ងៃ ។

## កាលល្បួងលោកអ័ប្រាហាំ

**២២** ១ក្រោយការទាំងនោះមក ព្រះទ្រង់ល្បួង[ក]អ័ប្រាហាំ
ដោយមានបន្ទូលហៅគាត់ថា អ័ប្រាហាំអើយ គាត់ក៏ទូល
ឆ្លើយថាព្រះកុរណាវិសេសព្រះអម្ចាស់[ខ] ២រួចទ្រង់មាន
បន្ទូលថា ចូរយកអ៊ីសាកកូនឯង[គ] ដែលជាកូនសំឡាញ់តែ១
នោះទៅឥឡូវ នាំគ្នាទៅឯស្រុកម៉ូរីយ៉ា[ឃ] រួចថ្វាយវាជា
ដង្វាយដុត[ង] នៅលើភ្នំ១ក្នុងស្រុកដែលអញនឹងបង្ហាញប្រាប់
ឯងនោះ[ច]។
៣អ័ប្រាហាំក៏ក្រោកឡើងពីព្រលឹម[ឆ] ចាត់ចែងចងកែប
លាខ្លួន ហើយពុះឧសសំរាប់ដង្វាយដុត រួចនាំយកបាវ២
នាក់និងអ៊ីសាកជាកូនទៅជាមួយ ក៏ដើរដំរង់ទៅឯកន្លែង
ដែលព្រះមានបន្ទូលប្រាប់នោះ ៤លុះដើរបាន៣ថ្ងៃហើយ
នោះគាត់ក៏ងើបភ្នែកឡើង មើលទៅ ឃើញកន្លែងនោះពី
ចំងាយ ៥រួចប្រាប់ទៅបាវថា ចូរឯងនៅទីនេះសិនមើល
លាផង អញនិងទៅឯណោះថ្វាយបង្គំជាមួយនឹងកូនអញ
រួច សឹមមកឯឯងវិញ[ជ] ៦នោះគាត់ចាប់យកឧសដែលសំរាប់

៩៣:២ ១០២:២៤ ១០៣:១៩ ១៤៦:១០ អស ៤០:២៨ យរ ១០:១០ ហព ១:១២ ៣:៦ ហព ១៣:៨ **២១:៣៤** ទ លប ១០:១៤ **២២:១** ក នក ១៥:២៥ ១៦:៤ ២០:២០ ចទ ៨:២,១៦ ១៣:៣ ពច ២:២២ ៣:១ ២រប ៣២:៣១ ទដ ៦៦:១០ ហព ១:១៧ យក ១:១២–១៣ ខ ខ.១១ លប ៣១:១១ ៤៦:២ ១សយ ៣:៤,៦,៨ អស ៦:៨ **២២:២** គ ខ.១២, ១៦ យហ ៣:១៦ ហព ១១:១៧ ១យស ៤:៩ ឃ ២រប ៣:១ង

ដង្វាយដុត ដាក់ឱ្យអ៊ីសាកជាកូនលី[ឈ] ហើយគាត់យកភ្លើង
និងកាំបិតកាន់នៅដៃ[ញ]បណ្តើរគ្នាទៅ ៧អ៊ីសាកនិយាយនឹង
ឪពុកថា លោកឪពុកអើយ គាត់ក៏ឆ្លើយថា អីកូន រួចវា
និយាយថា នេះមានភ្លើងនិងឧសហើយ តែកូនចៀម[ដ]
សំរាប់ដង្វាយដុតតើនៅឯណា ៨អ័ប្រាហាំឆ្លើយថា កូន
អើយ កូនចៀម[ឋ]ដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹង
ផ្គត់ផ្គង់ឱ្យ[ឌ] ដូច្នេះក៏នាំគ្នាទៅទៀត ។
៩លុះដល់កន្លែងដែលព្រះបានមានបន្ទូលប្រាប់គាត់
ហើយ[ឍ] នោះអ័ប្រាហាំក៏ស្អាងអាសនា១[ណ]នៅទីនោះ រួចដំ
រៀបឧស[ត] ហើយចងអ៊ីសាកជាកូនដាក់លើឧសនៅលើ
អាសនា[ថ] ១០គាត់លូកដៃទៅចាប់យកកាំបិត[ទ]មកប្រុងនឹង
សំឡាប់កូន[ធ] ១១តែទេវតានៃព្រះយេហូវ៉ា[ន]មានបន្ទូលពីលើ
មេឃ[ប]ហៅគាត់ថា អ័ប្រាហាំៗអើយ[ផ] នោះគាត់ទូលឆ្លើយ

លប ៨:២០ ច ខ.៩ **២២:៣** ឆ យស ៨:១០ **២២:៥** ជ នក ២៤:១៤ **២២:៦** ឈ យហ ១៩:១៧ ញ ខ.១០ ពច ១៩:២៩ **២២:៧** ដ នក ២៩:៣៨–៤២ លវ ១:១០ វវ ១៣:៨ **២២:៨** ឋ ខ.១៣ យហ ១:២៩ ឌ ខ.១៤ **២២:៩** ឍ ខ.២ ណ លប ៤:២៦ ៨:២០ ត លវ ១:៧ ១ពវ ១៨:៣៣ ថ ហព ១១:១៧–១៩ យក ២:២១ **២២:១០** ទ ខ.៦ ធ ខ.៣ **២២:១១** ន លប ១៦:៧ ប លប ២១:១៧ ផ លប ៤៦:២ ព ខ.១

**២១:៣៣** *ដាំដើមឈើ* គឺជាដើមឈើតូចៗដែលដុះក្នុងតំបន់ហួតហែងនៅក្នុងសម័យនោះ ។ ស្លឹករបស់វាផ្តល់ជាម្លប់យ៉ាងក្រៃលែងហើយប្រហែលជាវាមិនមែនជាដើមឈើ ដែលហាការបានដាក់អ៊ីសម៉ាអែលនោះឡើយ (ខ.១៥) ។ ព្រះដ៏មានព្រះជន្មអស់កល្បជានិច្ច ក្នុងព្រះគម្ពីរភាសាហេព្រើរ "អេឡូហ៊ីម" គឺមាននិយាយតែម្តងគត់នៅក្នុងអត្ថបទនេះ ។ វាគឺជាពាក្យ១ក្នុងចំណោមព្រះនាមផ្សេងៗទៀតរបស់ព្រះយេហូវ៉ា ដែលប្រើពាក្យ "អែល" (ព្រះ) មើលក្នុង ១៤:១៩ និងការពន្យល់ (១៧:១ ៣៣:២០ ៣៥:៧) ។

**២២:១–១៩** ផែនការរបស់ព្រះយេហូវ៉ាភាគច្រើនគឺទាក់ទងជាមួយលោកអ័ប្រាហាំដែលបានប្តេជ្ញាចិត្តចំពោះខ្លួនគាត់នៅពេលតាំងសញ្ញាថា និងស្តាប់បង្គាប់ព្រះហើយត្រូវតែថ្វាយកូនរបស់គាត់ ទៅចំពោះព្រះតាមរយៈការកាត់ស្បែក ។ ព្រះយេហូវ៉ាបានដាក់អ្នកបម្រើរបស់ទ្រង់មានសេចក្តីជំនឿយ៉ាងខ្លាំងនឹងភក្តីចំពោះទ្រង់យ៉ាងខ្លាំងដែរ ។ តាមការរៀបរាប់ពីអ័ប្រាហាំ អ៊ីសាក ហើយនិងកូនចៅរបស់ពួកគេ ឱ្យធ្វើជាស្តេចនៅក្នុងសេចក្តីសញ្ញារបស់ព្រះ ដែលព្រះអង្គបង្គាប់ ។ ការល្បួងនេះក៏ជាប្រផ្នូលមួយ ដែលនិយាយពីការថ្វាយយញ្ញបូជាដ៏ល្អឥតខ្ចោះរបស់កូនចៅជំនាន់ក្រោយទៀតរបស់លោកអ័ប្រាហាំ (មើល ខ.១៦) ដើម្បីបង្ហាញពីការថ្វាយដង្វាយយ៉ាងគ្រប់គ្រាន់របស់លោកអ័ប្រាហាំ ហើយនិងព្រលឹងវិញ្ញាណកូនចៅជំនាន់ក្រោយៗទៀតរបស់លោកចំពោះព្រះព្រមទាំងឱ្យសេចក្តីសន្យារបស់ទ្រង់បានសម្រេច ។

**២២:៣** *ពីព្រលឹម* លោកអ័ប្រាហាំបបានបង្ហាញពីការស្តាប់បង្គាប់ព្រះដូចជាការកាត់ស្បែកជាដើម (១២:៤) ។

**២២:៤** *៣ថ្ងៃហើយ* រយះពេល៣ថ្ងៃ គឺដូចជានឹងដំណើរដែលគាត់បានធ្វើដំណើរពីបៀរសេបាវិញ (ខ.១៩) ដើម្បី "ទៅឯស្រុកម៉ូរីយ៉ា" យេរូសាឡិម (មើល ខ.២ និងការពន្យល់) ដែលមានចម្ងាយប្រហែលជា ៦ គីឡូម៉ែត ។ មួយវិញទៀតការ "ធ្វើដំណើរ៣ថ្ងៃ"ប្រហែលជាការធ្វើដំណើរក្នុងរយះពេលដ៏ខ្លីមួយមិនមែន៣ថ្ងៃនោះ ធ្វើដំណើរជាប់នោះឡើយ (មើល ៣០:៣៦ នក ៣:១៨ ៥:៣ ៨:២៧ ១៥:២២ ជន ១០:៣៣ ៣៣:៨ យស ៩:១៦ យណ ១:១៧ ៣:៣) ។

**២២:៥** *កូន* សូមមើល ខ.១២ និងការពន្យល់ ខ.១ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យថា "កូន" គឺមានន័យទូលំទូលាយណាស់ អាចរាប់ចាប់តាំងពីទារក(នក ២:៦) រហូតដល់វ័យកំឡោះ(១រប ១២:២៨) ។ *រួចសឹមមកឯឯងវិញ* លោកអ័ប្រាហាំ គឺជាមនុស្សនៃសេចក្តីជំនឿហើយជា "ឪពុកនៃពួកអ្នកជឿ"(រម ៤:១១)"លោកបានរៀបរាប់ថាព្រះនឹងប្រោសកូននោះឱ្យរស់ពីស្លាប់"(ហព ១១:១៩) បើសិនជាការនោះជាការសំខាន់ដើម្បីបំពេញសេចក្តីសន្យារបស់គាត់ ។

**២២:៨** *កូនចៀមដែលសំរាប់ជាដង្វាយដុត នោះព្រះទ្រង់នឹងផ្គត់ផ្គង់ឱ្យ* ការឆ្លើយតបចំពោះការទុកចិត្តរបស់លោកអ័ប្រាហាំ នូវអ្វីដែលហៀបនឹងធ្វើនោះគឺជាកូនចៀមឈ្មោល១ (ខ.១៣) ប៉ុន្តែការងារចុងក្រោយមួយ គឺសម្រេចនៅលើកូនចៀមនៃព្រះ (យហ ១:២៩ ៣៦) ។

**២២:៩** *ហើយចងអ៊ីសាកជាកូនដាក់លើឧសនៅលើអាសនា* នៅទីនេះអ៊ីសាកគឺជាស្រមោលព្រះគ្រីស្ទ(ដូចជាព្រះគ្រីស្ទ) សូមមើល ខ.១៦ ។

**២២:១១** *ទេវតានៃព្រះយេហូវ៉ា* មើល ១៦:៧ ។ "ទេវតានៃព្រះយេហូវ៉ា" គឺជាអ្នកដែលបានឃើញសុវត្ថិភាពរបស់អ៊ីសម៉ាអែល ជាកូនប្រុសលោកអ័ប្រាហាំ ហើយជាអ្នកដែលបានមានបន្ទូលពីថ្ងៃអនាគតរបស់ អ៊ីសម៉ាអែល

ថាព្រះករុណាវិសេសព្រះអម្ចាស់[ត] ១២រួចទ្រង់មានបន្ទូលថា
កុំឱ្យលូកដៃទៅលើកូនក្មេងនោះឡើយ កុំឱ្យធ្វើអ្វីដល់វា ឱ្យ
សោះ ដ្បិតឥឡូវនេះអញដឹងថា ឯងកោតខ្លាចដល់ព្រះ
ហើយ[ភ] ដោយព្រោះមិនបានសំចៃទុកនូវកូនឯងតែ១នេះ
នឹងអញសោះ[ម] ១៣នោះអ័ប្រាហាំគាត់ងើបភ្នែកឡើងឃើញ
ចៀមឈ្មោល១ជាប់ស្នែង[យ] នៅព្រៃខាងក្រោយខ្លួនរួច ក៏
ទៅយកចៀមឈ្មោលនោះ មកថ្វាយជាដង្វាយដុតជំនួស
កូនខ្លួនវិញ[រ] ១៤អ័ប្រាហាំហៅ[ល]កន្លែងនោះថា យេហូវ៉ា–
យីរេ[វ] ដូចជាគេក៏និយាយដរាបដល់សព្វថ្ងៃនេះដែរថា នៅ
ភ្នំនៃព្រះយេហូវ៉ា គឺទ្រង់នឹងផ្គត់ផ្គង់ឱ្យ[ស] ។
១៥ទេវតានៃព្រះយេហូវ៉ា[ហ] ទ្រង់ក៏ហៅពីលើមេឃ[ឡ] មក
អ័ប្រាហាំម្តងទៀត ១៦ទ្រង់មានបន្ទូលថា អញបានស្បថ
ដោយនាមរបស់អញ[អ] ព្រោះឯងបានធ្វើដូច្នេះ គឺដែលមិន
បានសំចៃទុកនូវកូនឯងតែ១នេះ[ក] ១៧នោះអញនឹងឱ្យពរ
ដល់ឯង[ខ] ហើយនិងចំរើនពូជឯង[គ]ឱ្យមានគ្នាសន្ធឹកដូចផ្កាយ
នៅលើមេឃ[ឃ] ហើយដូចខ្សាច់នៅមាត់សមុទ្រ[ង] ពូជឯងនឹង
បានគ្រប់គ្រងលើទ្វារក្រុងនៃពួកខ្មាំងសត្រូវ[ច] ១៨គ្រប់ទាំង
សាសន៍នៅផែនដីនឹងបានពរ[ឆ]ដោយសារពូជឯង ពីព្រោះ
ឯងបានស្តាប់តាមពាក្យអញ[ជ] ១៩នោះអ័ប្រាហាំក៏វិលទៅ
ឯបាវវិញ ហើយគេក្រោកឡើងដើរជាមួយគ្នាទៅឯបៀរ–
សេបាទៅ[ឈ] ក៏អាស្រ័យនៅ ត្រង់បៀរ–សេបានោះ ។

**កូនរបស់លោកណាឃរ**

២០ក្រោយការទាំងនោះមក មានគេមកប្រាប់អ័ប្រាហាំ
ថា មើល នាងមីលកាក៏បានបង្កើតកូនឱ្យណាឃរ[ញ]ប្អូន
លោកដែរ ២១គឺអ៊ូស[ដ]ជាកូនច្បងគាត់ ហើយប៊ូស[ឋ]ជាប្អូននិង
កេមូអែលដែលជាឪពុកអើរ៉ាម ២២ហើយកេសែឌហាសូរ
ពីលដាស យីតឡាប និងបេធូអែល[ឌ] ២៣ឯបេធូអែលបាន
បង្កើតរេបិកា[ឍ] គឺកូនទាំង៨នាក់នោះ ដែលមីលកាបាន
បង្កើតឱ្យណាឃរជាប្អូនអ័ប្រាហាំ[ណ] ២៤ចំណែកប្រពន្ធចុង
របស់គាត់[ត] ដែលឈ្មោះរេយូម៉ា នាងបង្កើតបានតេបា
កាហាំ ថាហាស និងម្អាកា ។

**២២:១២** ភ លប ១៨:១៩ ៤២:១៨ នក ១៨:២១ ១សយ ១៥:២២ យប ១:១ ៣៧:២៤ សភ ៨:១៣ យក ២:២១–២២ ម ឧ.២ យហ ៣:១៦ ១យហ ៤:៩ **២២:១៣** យ ឧ.៨ រ លប ៨:២០ រម ៨:៣២ **២២:១៤** ល នក ១៧:១៥ ពច ៦:២៤ វ អស ៣០:២៩ ស ឧ.៨ **២២:១៥** ហ លប ១៦:៧ ឡ លប ២១:១៧ **២២:១៦** អ នក ១៣:១១ ៣២:១២ ៣៣:១ អស ៤៥:២៣ ៦២:៨ យរ ២២:៥ ៤៤:២៦ ៤៩:១៣ ៥១:១៤ អម ៦:៨ លក ១:៧៣ ហព ៦:១៣ ក ឧ.២ **២២:១៧** ខ លប ១២:២ គ ហព ៦:១៤ ឃ លប ១៥:៥ នក ៣២:១៣ ចទ ៧:៧ ២៨:៦២ ង លប ១២:២ ២៦:២៤ ហស ១:១០ រម ៩:២៧ ហព ១១:១២ ច លប ២៤:៦០ នរ ៩:២ **២២:១៨** ឆ លប ១២:២,៣ កច ៣:២៥ កទ ៣:៨ ជ ឧ.១០ លប ១៧:២,៩ ទដ ១០៥:៩ **២២:១៩** ឈ លប ២១:១៤ ២៦:២៣ ២៨:១០ **២២:២០** ញ លប ១១:២៩ **២២:២១** ដ លប ១០:២៣ ឋ យប ៣២:២ យរ ២៥:២៣ **២២:២២** ឌ លប ២៤:១៥,៤៧ ២៥:២០ **២២:២៣** ឍ លប ២៤:១៥ ណ លប ១១:២៩ **២២:២៤** ត លប ២៥:៦ ៣៥:២២ ៣៦:១២ ពច ៨:៣១ ២សយ ៣:៧ ១ពវ ២:២២ ១១:៣ ១រប

(១៦:៧,១២ ២១:១៧–១៨) ។ ឥឡូវនេះទេវតានោះបានជួយសង្គ្រោះជីវិតអ៊ីសាកដែលជាកូនរបស់លោកអ័ប្រាហាំហើយ ក៏បានមានបន្ទូលអំពីថ្ងៃអនាគតរបស់អ៊ីសាកដែរ (ខ.១៧–១៨) ។ *អ័ប្រាហាំៗអើយ* ការនិយាយស្ទួនៗគ្នាពីឈ្មោះអ្នកណាម្នាក់គឺជាការចង្អុលបង្ហាញពីកិច្ចការ បន្ទាន់ណាមួយ (មើល ៤៦:២ នក ៣:៤ ១សយ ៣:១០ កច ៩:៤) ។ *ព្រះករុណាវិសេស* សូមមើល ខ.១ ។

**២២:១២** *កោតខ្លាចដល់ព្រះ* សូមមើល ២០:១១ ។ *ដោយព្រោះមិនសំចៃទុកនូវ កូនឯងតែ១នេះនឹងអញសោះ* (សូមមើល ខ.១៦) ។ សេចក្តីជំនឿរបស់លោកអ័ប្រាហាំបានគ្រប់លក្ខណ៍ ដោយសារការដែលគាត់ប្រព្រឹត្ត (យក ២:២១–២២) ។

**២២:១៣** *ជំនួស* ការដោះដូរយញ្ញបូជាពីជីវិតមួយសម្រាប់ជីវិតមួយទៀតគឺបានកើតឡើងដំបូងបំផុតនៅទីនេះ ។ ដូចជាចៀមឈ្មោលដែលបានស្លាប់ជំនួសអ៊ីសាកនោះព្រះយេស៊ូវទ្រង់ក៏បានលះព្រះជន្មរបស់ទ្រង់ជាថ្លៃប្រោសលោះ "សម្រាប់" (ជំនួស)មនុស្សជាច្រើន (មក ១០:៤៥) ។

**២២:១៤** *ទ្រង់នឹងផ្គត់ផ្គង់ឱ្យ* លោកអ័ប្រាហាំបាននឹកចាំពីការអស្ចារ្យមួយដែលព្រះយេហូវ៉ាបានផ្តល់ឱ្យគាត់មានសេចក្តីសង្ឃឹម(ខ.៨)។ ក្នុងព្រះគម្ពីរភាសាហេព្រើរ "នឹងផ្គត់ផ្គង់" វាគឺគ្រាន់តែនិយាយបែបន័យត្រង់ប៉ុណ្ណោះ ។ "នឹងឃើញវា" ឬ "ការទតឃើញ" របស់ព្រះយេហូវ៉ាធ្វើឱ្យព្រះអង្គទ្រង់រក្សាទុកជីវិតអ៊ីសាកដូចគ្នានឹងអ្វីដែលទ្រង់បានទតឃើញ ហើយរក្សាជីវិតអ៊ីសម៉ាអែលដែរ តាំងពីនៅក្នុងផ្ទៃហាការ (១៦:១៣–១៤ និងការពន្យល់ ហើយប្រៀបធៀបជាមួយ ២១:១៥–២១) ។ *ភ្នំនៃព្រះយេហូវ៉ា* នៅក្នុងអំឡុងពេលដែលប្រទេសអ៊ីស្រាអែលមានលទ្ធិប្រជាធិបតេយ្យប្រហែលជាសំដៅលើព្រះវិហារដែលនៅភ្នំនាក្រុងយេរូសាឡិម (ទដ ២៤:៣ អស ២:៣ ៣០:២៩ សក ៨:៣) ។

**២២:១៦** *អញបានស្បថដោយនាមរបស់អញ* ពីព្រោះគ្មាននាមណាដែលធំជាងនេះទៀតឱ្យទ្រង់ស្បថនោះឡើយ (ហព ៣:១៦) ។ *ឯង . . . មិនបានសំចៃទុកនូវកូនឯងតែ១នេះ* ការលះបង់របស់លោកអ័ប្រាហាំ គឺមានការដូចគ្នានឹងសេចក្តីស្រឡាញ់របស់ព្រះចំពោះយើងទាំងអស់គ្នា តាមរយៈព្រះយេស៊ូវគ្រីស្ទ ដូចបាននិយាយក្នុង យហ ៣:១៦ រម ៨:៣២ ។

**២២:១៧** *ហើយនិងចំរើនពូជឯងឱ្យមានគ្នាសន្ធឹកដូចជា ផ្កាយនៅលើមេឃ* មើល ១៣:១៦ ១៥:៥ ។ *ហើយដូចជាខ្សាច់នៅមាត់សមុទ្រ* ការនេះបានសម្រេចនៅក្នុងរាជ្យស្តេចសាឡូម៉ូន (សូមមើល ១ពវ ៤:២០) ។ *ទ្វារក្រុង* តាមផ្នែកអក្សរសាស្ត្រគេនិយាយថា "ទ្វារ" គឺនិយាយសំដៅលើទ្វារដ៏ធំរបស់ទីក្រុងមួយគឺដូចគ្នានឹងពាក្យថា ទ្វារក្រុងនេះដែរ (២៤:៦០) ។

**២២:១៨** *គ្រប់ទាំងសាសន៍នៅផែនដី នឹងបានពរដោយសារពូជឯង* មើល ១២:២៣ ។ *ពីព្រោះឯងបានស្តាប់តាមពាក្យអញ* សូមមើល ១៧:៩ ។

**២២:២៣–២៤** ណាឃរជាប្អូនលោកអ័ប្រាហាំ គាត់បានបង្កើតកូន៨នាក់ជាមួយនឹងប្រពន្ធរបស់គាត់ ហើយ៤នាក់ទៀតតាមរយៈប្រពន្ធចុងរបស់គាត់ (២៥:៦) ។ ពួកគេបានក្លាយជាពួកឰយុកោនៃពូជអំបូរទាំង១២ នៃពួកអើរ៉ាម(ខ.២១)ដូចគ្នានឹងអ៊ីសម៉ាអែលជាកូនលោកអ័ប្រាហាំក្លាយជាឰយុកោនៃពូជអំបូរទាំង១២ (២៥:១៦) ហើយក៏ដូចគ្នានឹងយ៉ាកុបជាចៅលោកអ័ប្រាហាំក៏បានក្លាយជាឰយុកោទាំង១២នៃពួកអ៊ីស្រាអែលដែរ (៤៩:២៨) ។

## ការស្លាប់របស់នាងសារ៉ា

**២៣** ១នាងសារ៉ាអាយុបាន១២៧ឆ្នាំ នោះជាចំនួននៃឆ្នាំ
អាយុរបស់នាង ២រួចនាងស្លាប់នៅក្រុងគារយ៉ាត់អើបាទៅ[ក]
គឺជាហេប្រុន[ខ]នៅក្នុងស្រុកកាណាន អ័ប្រាហាំក៏មកដើម្បី
កាន់ទុក្ខ ហើយយំសោកនឹងសពសារ៉ា[គ] ៣រួចគាត់ក្រោក
ចេញពីមុខសព ទៅនិយាយនឹងពួកកូនចៅហេត[ឃ]ថា ៤ខ្ញុំជា
អ្នកដទៃ ដែលគ្រាន់តែសំណាក់នៅ[ង]ជាមួយនឹងអ្នករាល់គ្នា
ប៉ុណ្ណោះ ដូច្នេះសូមឱ្យខ្ញុំមានកន្លែងកប់ខ្មោចនៅជាមួយនឹង
អ្នករាល់គ្នាផង ដើម្បីឱ្យខ្ញុំបានយកសពនេះពីមុខខ្ញុំចេញទៅ
កប់[ច] ៥នោះពួកកូនចៅហេត គេឆ្លើយទៅអ័ប្រាហាំថា
៦លោកម្ចាស់អើយ សូមស្ដាប់យើងខ្ញុំ លោកជាអ្នកធំ[ឆ]
របស់ព្រះដែលនៅជាមួយនឹងយើងខ្ញុំរាល់គ្នា ដូច្នេះសូមឱ្យ
លោកកប់សពរបស់ប្រពន្ធលោកនៅក្នុងផ្នូរដែលល្អជាង
គេរបស់យើងខ្ញុំចុះ ក្នុងពួកយើងខ្ញុំនោះគ្មានអ្នកណាមួយនឹង
ប្រកែកថា មិនឱ្យលោកកប់ខ្មោចនៅក្នុងផ្នូររបស់យើងខ្ញុំ
នោះទេ ៧នោះអ័ប្រាហាំក្រោកឡើង ឱនគោរពចំពោះ
អស់ពួកកូនចៅហេត ដែលនៅស្រុកនោះ ៨ហើយនិយាយ
ថា បើអ្នករាល់គ្នាសុខចិត្តឱ្យខ្ញុំយកសពនេះពីមុខខ្ញុំទៅកប់
នោះសូមស្ដាប់ខ្ញុំសិន សូមជួយអង្វរអេប្រុនជាកូនសូហារ[ជ]
ជិន្នួសខ្ញុំផង ៩ឱ្យគាត់ចំណាយរអាងម៉ាក់ពេឡា[ឈ] ដែលនៅ
ចុងចំការរបស់គាត់មកខ្ញុំ គឺសូមឱ្យគាត់លក់ពេញថ្លៃមកខ្ញុំ
ទុកជាកេរ្ដិ៍អាករសំរាប់ជាទីកប់ខ្មោច នៅកណ្ដាលពួកអ្នក
រាល់គ្នាចុះ ១០រីឯអេប្រុនជាសាសន៍ហេត[ញ] គាត់ក៏អង្គុយ
ជាមួយនឹងពួកបងប្អូននោះដែរ ហើយគាត់ឆ្លើយទៅ
អ័ប្រាហាំនៅមុខពួកបងប្អូនខ្លួន គឺនៅចំពោះអស់ពួកអ្នក
ដែលចូលតាមទ្វារក្រុង[ដ]នោះថា ១១ទេលោកម្ចាស់អើយ
សូមស្ដាប់ខ្ញុំវិញ ចំការនោះខ្ញុំជូន[ឋ]លោកហើយ ព្រមទាំង
រអាងដែលនៅឯណោះដែរ ខ្ញុំជូនលោកទាំងអស់នៅមុខ
ពួកបងប្អូនសាសន៍ខ្ញុំនេះហើយ សូមលោកកប់សពរបស់
ប្រពន្ធលោកចុះ ១២អ័ប្រាហាំគាត់ក៏ឱនខ្លួនគោរពចំពោះ
ពួកអ្នកស្រុកនោះ ១៣ហើយនិយាយទៅអេប្រុននៅចំពោះ
មុខពួកអ្នកស្រុកថា បើអ្នកសុខចិត្តនោះសូមស្ដាប់ខ្ញុំវិញ
ខ្ញុំនឹងចេញថ្លៃចំការឱ្យ សូមយកពីខ្ញុំចុះ រួចខ្ញុំនឹងកប់សពនៅ
ទីនោះ ១៤អេប្រុនក៏ឆ្លើយទៅអ័ប្រាហាំថា ១៥លោកម្ចាស់
អើយ សូមលោកស្ដាប់ខ្ញុំ បើចំពោះលោកហើយនិងខ្ញុំ

១:៣២ ៦:៨ **២៣:២** ក យស ១៤:១៥ ១៥:១៣ ២០:៧ ២១:១១ ខ ឧ.១៩ លប ១៣:១៨ គ លប ២៤:៦៧ **២៣:៣** ឃ លប ១០:១៥ **២៣:៤** ង លប ១៧:៨ ១៩:៩ នក ២:២២ លវ ២៥:២៣ ទដ ៣៩:១២ ១០៥:១២ ១១៩:១៩ ហព ១១:៩,១៣ ច លប ៤៩:៣០ កច ៧:១៦ **២៣:៦** ឆ លប ១៤:១៤–១៦ ២៤:៣៥ **២៣:៨** ជ លប ២៥:៩ **២៣:៩** ឈ ឧ.១៧,១៩ លប ២៥:៩ ៤៧:៣០ ៤៩:៣០ ៥០:១៣ **២៣:១០** ញ ឧ.១៨ ដ លប ១៨:១ ចទ ២២:១៥ ២៥:៧ យស ២០:៤ នរ ៤:១១ ២សយ ១៥:២ ២ពវ ១៥:៣៥ ទដ ១២៧:៥ ទដ ៣១:២៣ យរ ២៦:១០ ៣៦:១០ **២៣:១១** ឋ ២សយ ២៤:២៣

**២៣:១–២០** ប្រាប់ដល់យើងពីការដែលលោកអ័ប្រាហាំបានទិញដី ដើម្បីបញ្ចុះសពសារ៉ាហើយនិងខ្លួនគាត់នៅក្នុងស្រុកកាណាន ហើយតាមរយៈសេចក្ដីសន្យាមកពីព្រះ ធ្វើឱ្យគាត់រាប់ទឹកដីកាណានជាទឹកដីរបស់គាត់ ។

**២៣:២** *គារយ៉ាត់អើបា* មានន័យថា"ទីក្រុងអើបា"អើបាគឺជាទីកន្លែងដែលមនុស្សល្បីល្បាញជាច្រើនមករស់នៅក្នុងតំបន់ហេប្រុន សូមមើល យស ១៤:១៥ ហើយពាក្យនេះក៏មានន័យថា "ទីក្រុងទាំង៤" គឺសំដៅលើកន្លែងរបស់អ័ណាក់ (មើល យស ១៥:១៣–១៤ ២១:១១) ហើយក៏ជាកន្លែងដែលកូនទាំង៣របស់គាត់រស់នៅដែរ (ពច ១:១០ ២០) ។ *មក* គឺមកតាំងពីបៀរ– សេបា ឆ្ពោះមកហេប្រុន ឬក៏ទៅកន្លែងដែលបញ្ចុះសពសារ៉ា ។

**២៣:៣** *កូនចៅហេត* សូមមើល ១០:១៥ ។ សព្វថ្ងៃនេះពួកគេនៅតែបន្តគ្រប់គ្រងតំបន់ហេប្រុនដដែល ។

**២៣:៤** *ខ្ញុំជាអ្នកដទៃ ដែលគ្រាន់តែសំណាក់នៅជាមួយនឹងអ្នករាល់គ្នាប៉ុណ្ណោះ* ជាញឹកញាប់ឃ្លានេះ គឺពួកព្ធយុកោនឹងដូនតារបស់គេប្រើសំដៅលើពួកគេផ្ទាល់ប៉ុណ្ណោះ មិនមែនអ្នកផ្សេងឡើយ (១របា ២៩:១៥ ទដ ៣៩:១២ ហព ១១:១៣) ។ នៅលើផែនដីនេះលោកអ័ប្រាហាំ"រស់នៅក្នុងត្រសាល" (ហព ១១:៩) ជាកន្លែងដែលគាត់យកវាធ្វើជាកន្លែងរស់នៅជាបណ្ដោះអាសន្ន ។ ប៉ុន្តែគាត់បានទន្ទឹងរងចាំកន្លែងជាអចិន្ត្រៃយ៍មួយ ដែលព្រះយេហូវ៉ាទ្រង់សន្យាជាមួយគាត់ នោះគឺជាទីកន្លែងមួយដែលអ្នកនិពន្ធព្រះគម្ពីរហេព្រើរហៅថា "ជាក្រុង១ដែលមានឫសជញ្ជាំង ដែលព្រះទ្រង់ជាអ្នកគូរ ហើយជាអ្នកសាងសង់" (ហព ១១:១០) ។

**២៣:៦** *លោកជាអ្នកធំរបស់ព្រះ* ប្រហែលជាពាក្យបញ្ជោរ ។

**២៣:៩** *រអាងម៉ាក់ពេឡា* ផ្នូររបស់ពួកព្ធយុកោរ ហើយនិងប្រពន្ធរបស់គេដែលមានឈ្មោះដូចជា: លោកអ័ប្រាហាំហើយនិងសារ៉ា អ៊ីសាកហើយនិងរេបេកា ព្រមទាំងលេអា (មើលខ.១៩ ២៥:៨–៩ ៤៩:៣០–៣១ ៥០:១២–១៣) ។ ដោយយោងតាមទំនៀមទម្លាប់មួយគេបាននិយាយថា ទីតាំងនោះស្ថិតនៅខាងក្រោយវិហារអ៊ីស្លាមមួយនៅហេប្រុន ។ ចុងចំការ ប្រហែលជាលោកអ័ប្រាហាំគាត់ចង់ទិញដីតែផ្នែកណាមួយប៉ុណ្ណោះ នោះគាត់សុខចិត្តឱ្យទៅអ័ប្រាហាំទាំងអស់ពីព្រោះគាត់បានគិតថា ការទិញដីទាំងអស់អាចធ្វើឱ្យលោកអ័ប្រាហាំមានការទទួលខុសត្រូវចំពោះការបង់ពន្ធដី នឹងការតព្វកិច្ចនៅក្នុងសង្គមតាមច្បាប់របស់ជនជាតិហេតបានកំណត់ដូច្នេះថា បើសិនជាម្ចាស់ដីលក់តែផ្នែកណាមួយនៃទ្រព្យ ដែលគាត់មានទៅឱ្យអ្នកណាមួយនោះម្ចាស់ដីត្រូវតែបន្តបង់ពន្ធសម្រាប់ដីនោះ ប៉ុន្តែបើសិនជាអ្នកលក់ដីនោះលក់ទាំងអស់វិញម្ចាស់ដីថ្មីត្រូវតែបង់ពន្ធវិញ ។

**២៣:១០** *នៅចំពោះមុខអស់អ្នកដែលចូលតាមទ្វារក្រុងនោះ* ជាធម្មតាទ្វារនោះគឺជាទ្វារដ៏សំខាន់មួយនៅក្នុងទីក្រុង ហើយក៏ជាកន្លែងមួយសម្រាប់ដោះស្រាយបញ្ហាផ្សេងៗ ដែលស្របច្បាប់នឹងស្បថផងដែរ (ខ.១៨ ១៩:១) ។

**២៣:១១** *លោកម្ចាស់អើយ* ប្រហែលជាគេបញ្ជោរលោកអ័ប្រាហាំ (មើល ខ.១៥) ។

**២៣:១៥** *៤០០រៀលមិនជាការអ្វីទេ* សូមមើលក្នុង ២០:១៦ ។ ទោះបីជាយ៉ាងណាក៏ដោយអេប្រុនបានធ្វើពុតជាចិត្តល្អពីព្រោះតម្លៃដី៤០០រៀល គឺជាចំនួនដ៏ច្រើនបំផុតសម្រាប់ដីនោះ (មើល យរ ៣២:៩) ។ ហេប្រុនគាត់បាននិយាយពីចំណុចល្អៗរបស់លោកអ័ប្រាហាំនៅក្នុងអំឡុងពេលដែលលោកអ័ប្រាហាំគាត់មានសេចក្ដីទុក្ខសោក ដោយព្រាត់ប្រាស់ ។ គាត់ដឹងថាលោកអ័ប្រាហាំពិតជាធ្វើការសម្រេចចិត្តយ៉ាងឆាប់ ដើម្បីបានកន្លែងសម្រាប់បញ្ចុះ

នោះដីដែលថ្លៃ៤00រៀល[ឌ]មិនជាការអ្វីទេ ដូច្នេះសូម
អញ្ជើញលោកកប់សពចុះ ១៦អ័ប្រាហាំក៏ស្ដាប់តាមអេប្រុន
ហើយគាត់ថ្លឹងប្រាក់ ប្រគល់ឱ្យដល់អេប្រុន នៅចំពោះមុខ
នៃពួកកូនចៅហេត តាមដែលគាត់និយាយ គឺជាប្រាក់៤00
រៀល[ឍ]ដែលពួកជំនួញធ្លាប់ចាយ[ណ]។
១៧ដូច្នេះចំការរបស់អេប្រុន ដែលនៅម៉ាក់ពេឡា[ត]ខាង
មុខម៉ាមរេ[ថ] និងរអាងដែលនៅទីនោះ ហើយនិងដំណាំ
ដែលនៅក្នុងចំការនោះ ព្រមទាំងរបងដែលព័ទ្ធជុំវិញផង
១៨បានប្រគល់ផ្ដាច់ទាំងអស់ទុកជាកេរ្ដិ៍[ទ]របស់អ័ប្រាហាំ នៅ
មុខពួកកូនចៅហេត[ធ] គឺនៅចំពោះមុខនៃអស់អ្នកដែលចូល
តាមទ្វារក្រុង[ន]គេ ១៩រួចអ័ប្រាហាំក៏កប់សពសារ៉ាប្រពន្ធគាត់
នៅក្នុងរអាងនៃចំការម៉ាក់ពេឡា[ប] ខាងមុខម៉ាមរេទៅ ឯ
ម៉ាមរេនោះ គឺជាហេប្រុន[ផ]ក្នុងស្រុកកាណាន[ព] ២០ចំការនិង
រអាងដែលនៅទីនោះ ពួកកូនចៅហេតបានប្រគល់ផ្ដាច់[ភ]
ទៅអ័ប្រាហាំ ទុកសំរាប់ជាកន្លែងកប់ខ្មោចតទៅ[ម]។

## លោកអ៊ីសាក់ និងនាងរេបិកា

**២៤** ១ឯអ័ប្រាហាំគាត់ចាស់ណាស់ហើយ មានអាយុវែង[ក]
ហើយព្រះយេហូវ៉ាទ្រង់បានប្រទានពរ[ខ]ដល់គាត់ក្នុងគ្រប់
ការទាំងអស់[គ] ២នោះអ័ប្រាហាំនិយាយទៅបាវជាអ្នកចាស់
ជាងគេ[ឃ]ក្នុងផ្ទះ ដែលត្រួតត្រាលើរបស់ទ្រព្យទាំងអស់[ង]ថា
ចូរឯងដាក់ដៃនៅក្រោមភ្លៅអញ[ច] ៣អញនឹងឱ្យឯងស្បថ
នឹងព្រះយេហូវ៉ាជាព្រះនៃស្ថានសួគ៌[ឆ] ហើយជាព្រះនៃផែន
ដី[ជ]ថា ឯងនឹងមិនយកប្រពន្ធឱ្យកូនអញ[ឈ]ពីពួកកូនស្រីសាសន៍
កាណាន[ញ] ដែលអញនៅកណ្ដាលគេនេះឡើយ[ដ] ៤គឺត្រូវឱ្យ
ឯងទៅឯស្រុកអញ នឹងយកប្រពន្ធឱ្យអ៊ីសាកជាកូនអញ[ឋ] ពី
ញាតិសន្ដាន[ឌ]អញវិញ ៥បាវនោះក៏ឆ្លើយទៅគាត់ថា
ប្រហែលជាស្ត្រីនោះមិនព្រមតាមខ្ញុំមកស្រុកនេះទេ[ឍ]
បើដូច្នេះ តើត្រូវឱ្យខ្ញុំនាំកូនលោកត្រឡប់ទៅនៅស្រុកដែល
លោកបានចោលនោះឬអី[ណ] ៦អ័ប្រាហាំប្រាប់ថាចូរឯង
ប្រយ័ត្នកុំឱ្យនាំកូនអញត្រឡប់ទៅឯណោះវិញឡើយ[ត] ៧ព្រះ
យេហូវ៉ាជាព្រះនៃស្ថានសួគ៌[ថ] ដែលបានយកអញចេញពី
ផ្ទះឪពុកអញ ហើយពីស្រុកកំណើតរបស់អញមក[ទ] ដែល
ទ្រង់បានមានបន្ទូលនឹងអញ ទាំងស្បថថា អញនឹងឱ្យស្រុក
នេះ[ធ]ដល់ពូជឯង[ន] ព្រះអង្គនោះទ្រង់នឹងចាត់ទេវតាទ្រង់
ទៅមុនឯង[ប] ដូច្នេះឯងនឹងបានយកប្រពន្ធពីនោះមកឱ្យកូន
អញហើយ ៨បើស្ត្រីនោះមិនព្រមមកតាមឯងទេ នោះឯង
នឹងបានរួចពីសម្បថដែលឯងសូមនឹងអញនេះ[ផ] ប៉ុន្តែកុំឱ្យ
ឯងនាំកូនអញទៅឯណោះឡើយ[ព] ៩នោះបាវបានដាក់ដៃ
ក្រោមភ្លៅ[ភ]អ័ប្រាហាំចៅហ្វាយខ្លួន[ម]ហើយក៏ស្បថនឹងគាត់
ពីដំណើរនោះ ។
១០បាវនោះក៏យកអូដ្ឋ១០ពីហ្វូងអូដ្ឋរបស់ចៅហ្វាយខ្លួន[យ]
ចេញទៅ ពីព្រោះទ្រព្យសម្បត្តិទាំងប៉ុន្មាន[រ]របស់ចៅហ្វាយ
គាត់ ក៏នៅក្រោមអំណាចគាត់ទាំងអស់ គាត់ក្រោកឡើង

**២៣:១៥** ឌ អក ៤៥:១២ **២៣:១៦** ឍ ២សយ ២៤:២៤ យរ ៣២:៩ សក ១១:១២ ២សយ ១៤:២៦ **២៣:១៧** ណ ខ.៩ ត លប ១៣:១៨ **២៣:១៨** ថ លប ១២:៧ ទ ខ.១០ ធ លប ១៨:១ **២៣:១៩** ន ខ.៩ ប លប ១៣:១៨ យស ១៤:១៣ ១រប ២៩:២៧ ផ លប ៤៩:១៣ **២៣:២០** ព យរ៣២:១០ ភ លប ១០:១៥ ៣៥:២៩ ៤៧:៣០ ៤៩:៣០ ៥0:៥,១៣ **២៤:១** ក លប ១៧:១៧ យស ២៣:១ ខ លប ១២:២ កទ ៣:៩ គ ខ.៣៥ **២៤:២** ឃ លប ១៥:៣ ង លប ៣៩:៤–៦ ច ខ.៩ លប ៤៧:២៩ **២៤:៣** ឆ លប ៤៧:៣១ ៥0:២៥ ជ ខ.៧ ឈ លប ១៤:១៩ ជន ២0:១៤ ចទ ៧:៣ ២កថ ៦:១៤–១៧ ញ លប ១0:១៥–១៩ ដ ខ.៣៧ **២៤:៤** ឋ ខ.២៩ លប ២១:២១ ឌ លប ១២:១ ពច ១៤:៣ **២៤:៥** ឍ ខ.៣៩ ណ ហព ១១:១៥ **២៤:៦** ត ខ.៨ **២៤:៧** ថ ខ.៣ ទ លប ១២:១ ធ រម ៤:១៣ លប ៣:១៦ ន លប ១២:៧ ប លប ១៦:៧ **២៤:៨** ផ ខ.៤១ យស ២:១២, ១៧, ២0 ៩:២0 ព ខ.៦ **២៤:៩** ភ ខ.២ ម លប ៣២:៤ ៣៣:៨ **២៤:១០** យ ខ.១៩ ១ពវ ១០:២ ១រប ១២:៤0 អស ៣0:៦ រខ.២២,៣0,៤៧, ៥៣ លប ៤៣:១១ ៤៥:២៣

សពសារ៉ា ដូច្នេះគាត់ក៏ទទូចឱ្យលោកអ័ប្រាហាំទិញដីនោះទាំងអស់ដោយគាត់គិតថាលោកអ័ប្រាហាំជាអ្នកទទួលខុសត្រូវក្នុងការបង់ពន្ធដីនោះ ។

**២៣:១៦** *ជាប្រាក់៤00រៀលដែលពួកអ្នកជំនួញធ្លាប់ចាយ* វាបានផ្លាស់ប្ដូរតាមស័មយកាលមួយទៅស័មយកាលមួយដូច្នេះហើយតម្លៃនេះ វាជាតម្លៃមិនពិតមួយហើយច្រើនជាងនៅក្នុងស័មយក្រោយទៀត (២សយ ១៤:២៦) ។

**២៣:១៧** នឹងរអាងដែលនៅទីនោះ ហើយនិងដំណាំដែលនៅក្នុងចំការនោះ ដើម្បីឱ្យគាត់រួចខ្លួនពីកាតព្វកិច្ចនៃការបង់ពន្ធទៅលើចំការ ដែលស្ថិតក្នុងរអាងម៉ាក់ពេឡានោះលោកអេប្រុនគាត់សម្រេចចិត្តលក់ចំការនោះទាំងអស់ (មើល ខ.៩) ។

**២៣:១៩** *កប់សពប្រពន្ធគាត់ . . . ក្នុងស្រុកកាណាន* តាមវប្បធម៌របស់គេ គឺគេមានវត្ថុបំណងយ៉ាងខ្លាំងក្នុងការបញ្ចុះសពជាមួយឪពុកពួកគេ (មើល ២៥:៨) នៅក្នុងទឹកដីកំណើតរបស់គេ ។ លោកអ័ប្រាហាំគាត់មិនបានងាកចេញពីសេចក្តីសន្យារបស់ព្រះនោះឡើយ នៅក្នុងពេលដែលគាត់ទិញកន្លែងបញ្ចុះសពក្នុងទឹកដីកាណាន ។ កាណានគឺជាស្រុកថ្មីរបស់គាត់ ។

**២៤:១–៦៧** លោកអ័ប្រាហាំកបានរកប្រពន្ធឱ្យអ៊ីសាកដោយការទុកចិត្តលើព្រះយេហូវ៉ាចំពោះសេចក្តីសន្យា ដែលទ្រង់បានតាំងសញ្ញាជាមួយគាត់ថានឹងប្រទានប្រពន្ធដ៏ល្អឱ្យកូនចៅរបស់គាត់ គឺជាអ្នកដែលប្រទានទឹកដីនេះជាមរតក (ខ.៦–៧) ។

**២៤:២** *បាវជាអ្នកចាស់ជាងគេក្នុងផ្ទះ* ប្រហែលជាអេលាសើរជាអ្នកស្រុកដាម៉ាស(១៥:២) ។ *ចូរឯងដាក់ដៃនៅក្រោមភ្លៅអញ* នៅក្បែរអង្គជាតិរបស់គាត់ ពីព្រោះប្រហែលពាក្យសម្បថនេះទាក់ទងទៅនឹងបំណងចិត្តចុងក្រោយរបស់លោកអ័ប្រាហាំ ។ អ៊ីសាកត្រូវតែទទួលយកជម្រើសរបស់លោកអ័ប្រាហាំ និងជម្រើសរបស់ព្រះ (មើល ៤៧:២៩ និងការពន្យល់) ។

**២៤:៣** *ព្រះយេហូវ៉ាជាព្រះនៃស្ថានសួគ៌ ហើយជាព្រះនៃផែនដី* សូមមើល ខ.៧ នឹង ១:១ ។ លោកអ័ប្រាហាំបាននិយាយពីនាមនេះនៅពេលគាត់ស្បថជាមួយព្រះ (សូមមើល ១៤:២២) ។

**២៤:៤** *ស្រុកអញ* គឺនៅមេសូប៉ូតាមា(មើល ខ.១0) ។ *នឹងយកប្រពន្ធឱ្យអ៊ីសាកកូនអញ* សូមមើល ២១:២១ ។

**២៤:៧** *អញនឹងឱ្យស្រុកនេះដល់ពូជឯង* រំឭកសេចក្តីសន្យាពីក្នុង ១២:៧ ។ *ទេវតាទ្រង់* មើល ១៦:៧ ។

**២៤:១០** *អូដ្ឋ* មើលក្នុង ១២:១៦ ។ អើរ៉ាម ឈ្មោះនេះមានន័យថា "អើរ៉ាមដែលនៅកណ្ដាលទន្លេទាំង២"គឺទន្លេអើប្រាត" និងទន្លេហីដេកែល ។ អើរាម

ទៅឯស្រុកអើរ៉ាម[ល]ដែលនៅកណ្ដាលទន្លេទាំង២គឺដល់ទី
ក្រុងរបស់ណាឃរ[វ] ១១គាត់ឱ្យសត្វអូដ្ឋលុតជង្គង់នៅខាង
ក្រៅទីក្រុងជិតអណ្ដូងទឹក[ស] នៅពេលល្ងាច គឺជាពេលដែល
ពួកស្រីៗធ្លាប់ចេញមកដងទឹក[ហ] ១២រួចក៏ទូលថា ឱព្រះ
យេហូវ៉ា ជាព្រះនៃអ័ប្រាហាំចៅហ្វាយទូលបង្គំអើយ[ឡ] នៅ
ថ្ងៃនេះសូមប្រោសមេត្តា[អ]ដល់ទូលបង្គំ សូមសំដែងសេចក្ដី
សប្បុរស[ក]ដល់អ័ប្រាហាំ ជាចៅហ្វាយទូលបង្គំផង ១៣មើល
ទូលបង្គំឈរនៅជិតអណ្ដូងទឹកនេះ ដូច្នេះកាលណាពួកកូន
ស្រីរបស់មនុស្សក្នុងក្រុងនេះចេញមកដងទឹក[ខ] ១៤នោះនាង
ក្រមុំណាដែលទូលបង្គំនិយាយថា សូមនាងដាក់ក្អមចុះមក
ឱ្យខ្ញុំផឹកផង ហើយនាងនោះនឹងឆ្លើយមកថា អញ្ជើញពិសា
ចុះ[គ] ខ្ញុំនឹងដងទឹកឱ្យអូដ្ឋផឹកដែរ[ឃ] សូមឱ្យត្រូវត្រង់រូបស្ត្រី
នោះឯង ដែលទ្រង់ដំរូវឱ្យអ៊ីសាក[ង]ជាអ្នកបំរើទ្រង់ យ៉ាង
នោះទូលបង្គំនឹងដឹង[ច]ថា ទ្រង់បានសំដែងសេចក្ដីសប្បុរស
ចំពោះចៅហ្វាយទូលបង្គំមែន ។
១៥កាលគាត់កំពុងតែអធិស្ឋានមិនទាន់ផុតនៅឡើយ[ឆ]
នោះស្រាប់តែរេបិកា[ជ]កណ្ដៀតក្អមចេញមក នាងនោះជា
កូនបេធូអែល[ឈ] ដែលជាកូនមីលកា[ញ] ប្រពន្ធណាឃរ[ដ]
ជាប្អូនអ័ប្រាហាំ ១៦នាងមានរូបស្រស់បស់ល្អណាស់[ឋ] ក៏នៅ
ក្រមុំសុទ្ធ[ឌ] គ្មានប្រុសណាបានស្គាល់នាងឡើយ នាងចុះទៅ
ក្នុងអណ្ដូងដងទឹកពេញក្អម រួចឡើងមកវិញ ១៧បាវនោះ
ក៏រត់ទៅស្ទាក់ផ្លូវនាង ហើយនិយាយថា នាង សូមឱ្យខ្ញុំសុំ
ទឹកពីក្អមនាងផឹកបន្តិចសិន[ឍ] ១៨រួចនាងឆ្លើយថា ចាស
អញ្ជើញពិសាចុះ[ណ]លោកម្ចាស់ ហើយនាងក៏ដាក់ក្អមចុះមក
ជាប្រញាប់ឱ្យគាត់ផឹក ១៩កាលនាងបានឱ្យគាត់ផឹករួចហើយ
នោះនាងនិយាយថា ខ្ញុំនឹងដងឱ្យអូដ្ឋ[ត]របស់លោកផឹកទាល់
តែឆ្អែតដែរ[ថ] ២០នោះនាងក៏ចាក់ទឹកពីក្នុងក្អមចុះទៅក្នុង
ស្នូកជា១រំពេច រួចរត់ទៅដងថែមទៀតយកមកឱ្យអូដ្ឋគាត់
ផឹកទាំងអស់[ទ] ២១បាវនោះសំឡឹងមើលនាងទាំងមានសេចក្ដី
អស្ចារ្យ តែគាត់នៅស្ងៀម ដោយចង់ដឹង បើព្រះយេហូវ៉ា
នឹងធ្វើឱ្យដំណើរគាត់ដើរមកនោះបានសំរេចការឬទេ[ធ]
២២កាលអូដ្ឋបានផឹកឆ្អែតអស់ហើយ នោះគាត់ក៏យកក្រវិល[ន]
មាសទំងន់១ជី នឹងកងដៃ២ដុំ[ប] ទំងន់២០ជីឱ្យដល់នាង
២៣ហើយសួរថា នាងជាកូនអ្នកណាសូមប្រាប់ខ្ញុំផង[ផ] ហើយ
នៅផ្ទះឪពុកនាង តើមានកន្លែងណាល្មមឱ្យខ្ញុំស្នាក់នៅបាន
ឬទេ[ព] ២៤នាងឆ្លើយថា ខ្ញុំជាកូនបេធូអែល គឺជាចៅណាឃរ
និងមីលកា[ភ] ២៥រួចនាងឆ្លើយទៅគាត់ទៀតថា នៅផ្ទះខ្ញុំមាន
ចំបើងនឹងស្មៅជាបរិបូរ[ម] ហើយកន្លែងសំរាប់ស្នាក់នៅក៏
មានដែរ ២៦បាវនោះក៏ឱនខ្លួនថ្វាយបង្គំដល់ព្រះយេហូវ៉ា[យ]
២៧ដោយទូលថា សូមឱ្យព្រះយេហូវ៉ា[រ]ជាព្រះនៃអ័ប្រាហាំ[ល]
ចៅហ្វាយទូលបង្គំ ដែលទ្រង់មិនបានខាននឹងផ្ដល់សេចក្ដី
សប្បុរស និងសេចក្ដីស្មោះត្រង់[វ]ដល់ចៅហ្វាយទូលបង្គំ
បានប្រកបដោយព្រះពរ ឯទូលបង្គំសោត ក៏ព្រះយេហូវ៉ា
ទ្រង់បាននាំផ្លូវ[ស]មកដល់ផ្ទះពួកបងប្អូនរបស់ចៅហ្វាយទូល
បង្គំហើយ[ហ] ២៨នាងក៏រត់ទៅប្រាប់ដំណើរនេះដល់ពួកផ្ទះ
ម្ដាយខ្លួន[ឡ]។
២៩រេបិកាមានបងប្រុស១ឈ្មោះឡាបាន[អ] ហើយឡាបាន
ក៏រត់ទៅឯបាវនោះនៅឯក្រៅត្រង់អណ្ដូង ៣០កាលគាត់
ឃើញក្រវិលនឹងកងដែលប្អូនពាក់នៅដៃ[ក] ហើយបានឮ

ល ជន ២៣:៧ ចទ ២៣:៤ ពច ៣:៨ វ លប ១១:២៩ **២៤:១១** ស នក ២:១៥ ហ ខ.១៣ លប ២៩:២,៩–១០ នក ២:១៦ ១សយ ៩:១១ យហ ៤:៧ **២៤:១២** ឡ ខ.២៧, ៤២,៤៨ លប ២៦:២៤ ២៨:១៣ ៣១:៤២,៥៣ ៣២:៩ ៤៣:២៣ ៤៦:៣ នក ៣:៦,១៥,១៦ ៤:៥ ១ពវ ១៨:៣៦ ទដ ៧៥:៩ ៩៤:៧ អ ខ.២១, ៤០,៥១,៥៦ លប ២៧:២០ នហ ១:១១ ក លប ១៩:១៩ យស ២:១២ យប ១០:១២ **២៤:១៣** ខ ខ.១១, ៤៣ លប ២៩:៨ **២៤:១៤** គ ខ.១៨, ៤៦ ឃ ខ.១៩ ង ខ.៤៤ ច យស ២:១២ ពច៦:១៧, ៣៧ ១សយ ១៤:១០ ១ពវ ១៣:៣ ទដ ៨៦:១៧ អស ៣៨:៧ យរ ៤៤:២៩ **២៤:១៥** ឆ ខ.៤៥ ជ លប ២២:២៣ ឈ លប ២២:២២ ញ លប ១១:២៩ ដ លប ១១:២៩ ឌ ចទ? ២២:១៥–២១ **២៤:១៦** ឋ លប ១២:១១ **២៤:១៧** ឍ ខ.៤៥ ១ពវ ១៧:១០ យហ ៤:៧ **២៤:១៨** ណ ខ.១៤ **២៤:១៩** ត ខ.១០ ថ ខ.១៤ **២៤:២០** ទ ខ.៤៦ **២៤:២១** ធ ខ.១២ **២៤:២២** ន ខ.៤៧ លប ៤១:៤២ អស ៣:២១ អគ ១៦:១១–១២ ប ខ.១០ **២៤:២៣** ផ ខ.៤៧ ព ពច ១៩:១៥ ២០:៤ **២៤:២៤** ភ ខ.២៩, ៤៧ លប ១១:២៩ **២៤:២៥** ម ខ.៣២ពច ១៩:១៩ **២៤:២៦** យ ខ.៤៨, ៥២ នក ៤:៣១ ១២:២៧ ១របា ២៩:២០ ២រប ២០:១៨ **២៤:២៧** រ លប ១៤:២០ ន ១៨:១០ នរ ៤:១៤ ១សយ ២៥:៣២ ២សយ ១៨:២៨ ១ពវ ១:៤៨ ៨:៥៦ ទដ ២៨:៦ ៤១:១៣ ៦៨:១៩ ១០៦:៤៨ លក ១:៦៨ ល ខ.១២ វ ខ.៤៩ លប ៣២:១០ ៤៧:២៩ យស ២:១៤ទដ ៩៨:៣ ស ខ.២១ ហ ខ.១២,៤៨ លប ១២:១ **២៤:២៨** ឡ លប ២៩:១២ **២៤:២៩** អ ខ.៤ លប ២៥:២០ ២៧:៤៣ ២៨:២, ៥ ២៩:៥,១២, ១៣ **២៤:៣០** ក ខ.១០ អគ ២៣:៤២

(មើល ១០:២២) គឺស្ថិតនៅខាងជើងតំបន់មួយដែលគេហៅជាភាសាក្រិកថា "មេសូប៉ូតាមា" ដែលមានន័យថា "រវាងទន្លេ" ។ *ទីក្រុងរបស់ណាឃរ* ដូចគ្នានឹងឈ្មោះរបស់ប្អូនប្រុសអ័ប្រាហាំដែរ (មើល ខ.១៥ ១១:២៦) ។ ទីក្រុងនេះគេកត់សំគាល់នៅក្នុងសិលាចារឹកដីឥដ្ឋ ដែលជីករកដោយប្រទេសបារាំងនាឆ្នាំ១៩៣៣ នៅក្នុងទីក្រុងម៉ារី និងអេីប្រាត ដែលជាទីក្រុងបុរាណ ណាឃរស្ថិតនៅក្នុងស្រុកហារ៉ាន់ (មើល ១១:៣១) ហើយគ្រប់គ្រងដោយពួកអាម៉ូរីនាដើម ស.ត ទី១៨ មុន គ.ស ។

**២៤:១១** *នៅពេលល្ងាច គឺជាពេលដែលពួកស្រីៗធ្លាប់ចេញមកដងទឹក* បន្ទាប់ពីថ្ងៃត្រង់កំដៅថយចុះ ។

**២៤:១៤** *យ៉ាងនោះទូលបង្គំនឹងដឹងថា* ដូចជាចៅហ្វាយរបស់គាត់អ័ប្រាហាំដែរអ្នកបម្រើ គាត់ត្រូវការទីសំគាល់ដើម្បីបញ្ជាក់ពីការងារដែលគាត់នឹងធ្វើ (មើល ១៥:៨) ។ *សេចក្ដីសប្បុរស* មើល ខ.២៧ ។ ប្រហែលជាសំដៅលើការតាំងសញ្ញារបស់ព្រះជាមួយលោកអ័ប្រាហាំ ដែលសន្យាថានឹងឱ្យកូនចៅរបស់គេចម្រើនឡើងតាមរយៈអ៊ីសាក (១៧:១៩ ២១:១២) ។

**២៤:១៥** *កាលគាត់កំពុងអធិស្ឋានមិនទាន់ចប់នៅឡើយ* ព្រះទ្រង់បានឆ្លើយតបមកគាត់រួចទៅហើយ ។ *រេបិកា . . . ជាកូនបេធូអែលដែលជាកូន . . . ប្រពន្ធណាឃរជាប្អូនអ័ប្រាហាំ* អ៊ីសាកគាត់នឹងរៀបការជាមួយក្មួយដែលជាចៅស្រីរបស់ឪពុកគាត់ (ខ.៤៨) ។

**២៤:២២** *១ជី* ស្មើនឹងកន្លះរៀល (នក ៣៨:២៦) និងសូមមើលការពន្យល់ ២០:១៦ ។

សេចក្ដីទាំងប៉ុន្មានដែលរេបិកាជាប្អូនបានប្រាប់ពីអ្នកនោះ
ថា គាត់បាននិយាយនឹងខ្ញុំយ៉ាងនេះមួយៗ នោះក៏ចេញទៅ
ឯគាត់ ឃើញកំពុងឈរនៅក្បែរអូដ្ឋជិតអណ្ដូងនៅឡើយ
៣១ នោះឡាបាន់និយាយថា សូមអញ្ជើញចូលមកឱអ្នកដែល
ប្រកបដោយព្រះពរនៃព្រះយេហូវ៉ាអើយ[ខ] ហេតុអ្វីបានជា
អ្នកឈរនៅខាងក្រៅវិញ ខ្ញុំបានរៀបចំទីផ្ទះនឹងកន្លែង
សំរាប់ឱ្យអូដ្ឋជាស្រេចហើយ ។
៣២ បាវនោះក៏ចូលទៅក្នុងផ្ទះ ហើយដោះអីវ៉ាន់ពីអូដ្ឋ
ចេញ រួចមានគេយកចំបើងនិងស្មៅមកឱ្យអូដ្ឋស៊ី[គ] ហើយ
និងទឹកមកសំរាប់លាងជើងគាត់[ឃ] ព្រមទាំងមនុស្សឯទៀត
ដែលមកជាមួយនឹងគាត់ដែរ ៣៣ រួចលើកភោជនាហារ
មកជូនគាត់បរិភោគ តែគាត់ប្រកែកថា ខ្ញុំមិនទទួលទានទេ
លុះត្រាតែខ្ញុំបានជំរាបពីរឿងខ្ញុំហើយសិន នោះឡាបាន់ក៏
និយាយថា សូមមានប្រសាសន៍មកចុះ ៣៤ រួចគាត់និយាយថា
ខ្ញុំជាបាវរបស់អ័ប្រាហាំ[ង] ៣៥ ព្រះយេហូវ៉ាទ្រង់បានប្រទាន
ពរ[ច]ឱ្យចៅហ្វាយខ្ញុំយ៉ាងសន្ធឹក[ឆ]ហើយលោកបានត្រឡប់ជា
ធំ[ជ] គឺទ្រង់បានប្រទានឱ្យលោកមានចៀម គោ មាស ប្រាក់
បាវប្រុស បាវស្រី អូដ្ឋ ហើយ និងលា[ឈ] ៣៦ ឯលោក
យាយសារ៉ាជាប្រពន្ធរបស់ចៅហ្វាយខ្ញុំ នោះបានបង្កើតកូន
ប្រុស១ឱ្យចៅហ្វាយខ្ញុំ ក្នុងកាលដែលលោកចាស់ហើយ[ញ]
លោកក៏បានចែករបស់ទ្រព្យទាំងអស់ដល់កូននោះ[ដ] ៣៧ ចៅ
ហ្វាយខ្ញុំក៏បានឱ្យខ្ញុំស្បថ[ឋ] ដោយមានប្រសាសន៍ថា កុំឱ្យ
ឯងយកប្រពន្ធឱ្យកូនអញ ពីពួកកូនស្រីសាសន៍កាណាន
ដែលអញនៅស្រុកគេនេះឡើយ[ឌ] ៣៨ តែត្រូវឱ្យឯងទៅឯផ្ទះ
ឪពុកអញ ហើយនិងញាតិសន្ដានអញវិញ ដើម្បីនឹងយក
ប្រពន្ធមកឱ្យកូនអញ[ឍ] ៣៩ ខ្ញុំបានជំរាបចៅហ្វាយខ្ញុំថា ប្រ
ហែលជាស្ត្រីនោះមិនព្រមមកតាមខ្ញុំទេ[ណ] ៤០ នោះលោក
មានប្រសាសន៍ថា ព្រះយេហូវ៉ាដែលអញដើរ[ត]នៅចំពោះ
ទ្រង់ៗនឹងចាត់ទេវតាទ្រង់ទៅជាមួយនឹងឯង[ថ] ដើម្បីធ្វើឱ្យ
ដំណើរឯងបានកើតការ[ទ] ហើយឯងនឹងយកប្រពន្ធឱ្យកូន
អញពីញាតិសន្ដានអញ គឺពីពួកវង្សឪពុកអញមកជាពិត
៤១ ឯងនឹងបានរួចពីសម្បថនេះ[ធ] គឺបើកាលណាឯងបានទៅ
ដល់ញាតិសន្ដានអញហើយ រួចគេមិនព្រមឱ្យនាងនោះមក
ទេ នោះឯងនិងបានរួចពីសម្បថ ដែលអញឱ្យឯងស្បថនេះ

៤២ ដូច្នេះ នៅថ្ងៃនេះខ្ញុំក៏បានមកដល់អណ្ដូងទឹក ហើយខ្ញុំទូល
ថា ឱព្រះយេហូវ៉ាជាព្រះនៃអ័ប្រាហាំ ជាចៅហ្វាយទូលបង្គំ
អើយ បើទ្រង់នឹងធ្វើឱ្យដំណើរទូលបង្គំបានកើតការ[ន]ក្នុង
គ្រាឥឡូវនេះ ៤៣ មើល ទូលបង្គំនឹងឈរនៅត្រង់អណ្ដូងទឹក
នេះ[ប] ដូច្នេះបើនាងក្រមុំណា[ផ]ដែលចេញមកដងទឹក ហើយ
ទូលបង្គំនិយាយថា សូមឱ្យខ្ញុំសុំទឹកពីក្អមនាងផឹកបន្តិច[ព]
៤៤ ហើយនាងនោះនឹងឆ្លើយមកទូលបង្គំថា ចាសអញ្ជើញ
ពិសាចុះ ខ្ញុំនឹងដងទឹកឱ្យអូដ្ឋអ្នកផឹកដែរ នោះសូមឱ្យត្រូវត្រង់
រូបស្ត្រីនោះឯង ដែលព្រះយេហូវ៉ាទ្រង់ដំរូវដល់កូនរបស់
ចៅហ្វាយទូលបង្គំ[ភ] ៤៥ កាលខ្ញុំអធិស្ឋាននៅក្នុងចិត្តមិនទាន់
ផុតនៅឡើយ[ម] នោះមើល ស្រាប់តែនាងរេបិកាកណ្ដៀត
ក្អមចេញមក[យ] នាងបានចុះទៅក្នុងអណ្ដូងដងទឹកមក ហើយ
ខ្ញុំបាននិយាយទៅនាងថា សូមឱ្យខ្ញុំផឹកផង[រ] ៤៦ នោះនាងក៏
ដាក់ក្អមចុះពីលើស្មាជា១រំពេច ដោយពាក្យថា អញ្ជើញ
ពិសាចុះ ខ្ញុំនឹងឱ្យអូដ្ឋផឹកដែរ[ល] ដូច្នេះ ខ្ញុំក៏បានទទួលទានរួច
នាងឱ្យអូដ្ឋផឹកផង[វ] ៤៧ ហើយខ្ញុំសួរថា នាងជាកូនអ្នកណា[ស]
នាងឆ្លើយថា ខ្ញុំជាកូនបេធូអែ[ហ]ជាចៅណាឃរ និងមីលកា[ឡ]
នោះខ្ញុំក៏បំពាក់ក្រវិលនៅច្រមុះ[អ] ហើយនិងកងនៅដៃនាង[ក]
៤៨ ខ្ញុំបានឱនក្រាបថ្វាយបង្គំទាំងសរសើរដំកើងដល់ព្រះ
យេហូវ៉ា[ខ] ជាព្រះនៃអ័ប្រាហាំ[គ]ចៅហ្វាយខ្ញុំ ដែលទ្រង់បាន
នាំដំរង់ខ្ញុំតាមផ្លូវរៀងមក ដើម្បីឱ្យបានកូនស្រីរបស់បងប្អូន
ចៅហ្វាយខ្ញុំ យកទៅជូនដល់កូនលោក[ឃ] ៤៩ ឥឡូវនេះបើ
អ្នករាល់គ្នាគិតប្រព្រឹត្តនឹងចៅហ្វាយខ្ញុំ ដោយសប្បុរស
ស្មោះត្រង់[ង] នោះសូមតបមកខ្ញុំចុះ ពុំនោះទេ សូមប្រាប់ខ្ញុំឱ្យ
ដឹងផង ដើម្បីឱ្យខ្ញុំងាកបែរទៅខាងស្តាំ ឬខាងឆ្វេងទៀត។
៥០ នោះឡាបាន់នឹងបេធូអែល[ច]ក៏ឆ្លើយថា ការនេះ
សំរេចតែពីព្រះយេហូវ៉ាទេ[ឆ] ទោះបីយើងឆ្លើយនឹងអ្នកជា
អាក្រក់ឬល្អក៏ពុំបានដែរ[ជ] ៥១ មើល រេបិកានៅមុខអ្នក
ស្រាប់ហើយ ចូរយកវាទៅ ឱ្យវាធ្វើជាប្រពន្ធរបស់កូនចៅ
ហ្វាយអ្នកចុះ ដូចជាព្រះយេហូវ៉ាទ្រង់បានមានបន្ទូលមក[ឈ]
៥២ កាលបាវរបស់អ័ប្រាហាំបានឮដូច្នោះ នោះគាត់ក៏ឱន
ក្រាបដល់ដីថ្វាយបង្គំដល់ព្រះយេហូវ៉ា[ញ] ៥៣ រួចបញ្ចេញ

**២៤:៣១** ខ លប ២៩ ទដ ១១៥:១៥
**៤:៣២** គ ខ.២៥ ឃ លប ១៨:៤
**២៤:៣៤** ង លប ១៥:៣
**២៤:៣៥** ច លប ១២:២ ឆ ខ.១ ជ លប ២៣:៦ ឈ លប ១២:១៦
**២៤:៣៦** ញ លប ១៧:១៧ ដ លប ២៥:៥ ២៦:១៤
**២៤:៣៧** ឋ លប ៥០:៥,២៥ ឌ ខ.៣
**២៤:៣៨** ឍ លប ២១:២១
**២៤:៤០** ណ លប ៥:២២ ត លប ១៦:៧ ថ ខ.១២ ទ លប ១២:១
**២៤:៤១** ធ ខ.៨
**២៤:៤២** ន ខ.១២
**២៤:៤៣** ប ខ.១៣ ផ សភ ៣០:១៩ អស ៧:១៤ ព ខ.១៤
**២៤:៤៤** ភ ខ.១៤
**២៤:៤៥** ម ១សយ ១:១៣ យ ខ.១៥ រ ខ.១៧ យហ ៤:៧
**២៤:៤៦** ល ខ.១៨–១៩ វ ខ.២០
**២៤:៤៧** ស ខ.២៣ ហ លប ២២:២២ ឡ ខ.២៤ អ ខ.២២ ក ខ.១០ អស ៣:១៩ អគ ១៦:១១–១២
**២៤:៤៨** ខ ខ.២៦ គ ខ.១២ ឃ ខ.២៧
**២៤:៤៩** ង ខ.២៧
**២៤:៥០** ច លប ២២:២២ ឆ ទដ ១១៨:២៣ ជ លប ៣១:៧,២៤,២៩,៤២ ៤៨:១៦
**២៤:៥១** ឈ ខ.១២ **២៤:៥២** ញ ខ.២៦

**២៤:៣២–៣៣** សូមមើល ១៨:២ ។
**២៤:៣៤–៤៩** អ្នកបម្រើនោះគាត់បានពន្យល់ពីការងាររបស់គាត់ដល់ក្រុមគ្រួសាររបស់នាងរេបិកា ។ សម្ដីរបស់គាត់គឺជាការសង្ខេបសាច់រឿងពីដើមជំពូកឡើងវិញដែលជាគំរូរដ៏ល្អមួយរបស់ពួកព្ទយុកោជិនាន់ដើម ដែលអ្នកនិយាយរឿងនោះគាត់មានការចងចាំខ្ពស់ ហើយបកស្រាយសាច់រឿងយ៉ាងលំអិតដល់អ្នកស្ដាប់ ។
**២៤:៤០** *ព្រះយេហូវ៉ាដែលអញដើរនៅចំពោះទ្រង់* (សូមមើល ៥:២២ ៦:៨–៩ ១៧:១) ។

គ្រឿងមាសគ្រឿងប្រាក់ និងសំលៀកបំពាក់[ដ]ឱ្យដល់រេបិកា
ព្រមទាំងជូនរបស់ទ្រព្យដ៏មានដំឡៃ[ឋ] ទៅបងនាងនឹងម្ដាយ
នាងដែរ ៥៤រួចគាត់ក៏បរិភោគទៅ ព្រមទាំងពួកអ្នកដែល
មកជាមួយផង ហើយផ្អាកនៅក្នុងយប់នោះឯង លុះដល់
ពេលព្រឹក កាលគេបានក្រោកឡើងហើយ នោះគាត់
ជំរាបលាគេថា ខ្ញុំសូមវិលទៅ[ឌ]ឯចៅហ្វាយខ្ញុំវិញហើយ
៥៥តែបងនឹងម្ដាយនាងនិយាយថា សូមឱ្យនាងនៅជាមួយ
នឹងយើងសិន បើតិចណាស់ត្រឹមតែ១០ថ្ងៃ[ឍ] រួចសឹមយក
ទៅចុះ ៥៦គាត់ឆ្លើយថា កុំឃាត់ខ្ញុំឡើយ ព្រោះព្រះ
យេហូវ៉ាបានធ្វើឱ្យដំណើរខ្ញុំកើតការហើយ[ណ] ដូច្នេះខ្ញុំសូម
លាត្រឡប់[ត]ទៅឯចៅហ្វាយខ្ញុំវិញ ៥៧នោះគេឆ្លើយថា
ចាំយើងហៅនាងមកសួរសិន[ថ] ៥៨រួចគេក៏ហៅរេបិកាមក
សួរថា ឯងព្រមទៅជាមួយនឹងអ្នកនេះឬទេ នាងទទួលថា
ព្រម[ទ] ៥៩នោះគេក៏ឱ្យរេបិកាជាប្អូន ព្រមទាំងមេនំនាង[ធ] និង
បាវអ័ប្រាហាំ ហើយនិងពួកគាត់ទាំងប៉ុន្មានចេញទៅ[ន] ៦០គេ
ក៏ឱ្យពរ[ប]ដល់រេបិកាដោយពាក្យថា ប្អូនយើងអើយ សូមឱ្យ
ឯងបង្កើតបានទាំងពាន់ទាំងម៉ឺន[ផ] ហើយឱ្យពូជឯងគ្រប់
គ្រងលើទ្វារក្រុងនៃពួកអស់អ្នកដែលស្អប់ដល់គេចុះ"[ព]
៦១រេបិកាក៏ក្រោកឡើង ព្រមទាំងពួកស្រីបំរើនាង[ភ] ឡើងជិះ
អូដ្ឋទៅតាមបាវនោះ ហើយគាត់ក៏នាំយកនាងធ្វើដំណើរ
ចេញទៅ ។
៦២ឯអ៊ីសាក គាត់ដើរមកតាមផ្លូវដែលមកពីអណ្ដូង
ឡាហាយ-រយ[ម] ដ្បិតគាត់នៅស្រុកត្បូង[យ] ៦៣ហើយគាត់ក៏
ចេញទៅរំពឹងគិត[រ]នៅត្រង់ទីវាល ក្នុងកាលដែលពេលជិត
ព្រលប់ គាត់ក្រឡេកភ្នែកមើលទៅ[ល] ស្រាប់តែឃើញមាន
សត្វអូដ្ឋដើរចូលមក ៦៤ឯរេបិកាក៏ងើបភ្នែកឡើងដែរ កាល
បានឃើញអ៊ីសាក នោះក៏លោតចុះពីលើអូដ្ឋមក[វ] ៦៥ហើយ
សួរទៅបាវនោះថា អ្នកណានុ៎ះ ដែលដើរកាត់ វាលដំរង់
មកឯយើងនោះ បាវនោះឆ្លើយថា នោះហើយជាចៅ
ហ្វាយរបស់ខ្ញុំ រួចនាងយកស្បៃ[ស]មកបាំងមុខ ៦៦បាវនោះ
ក៏រៀបរាប់ប្រាប់អ៊ីសាក ពីគ្រប់ទាំងការដែលគាត់បានធ្វើ
៦៧រួចអ៊ីសាកនាំរេបិកាចូលទៅក្នុងត្រសាល[ហ] របស់សារ៉ា
ជាម្ដាយខ្លួន[ឡ] ហើយក៏យកនាងធ្វើជាប្រពន្ធ[អ]ព្រមទាំង
ប្រតិព័ទ្ធស្រឡាញ់ដល់នាង[ក] នោះអ៊ីសាក គាត់បានក្សាន្តចាក
ទុក្ខពីម្ដាយស្លាប់[ខ] ។

## មរណៈភាពរបស់លោកអ័ប្រាហាំ

*២៥:១-៤ – ១រប ១:៣២-៣៣*

**២៥** ១អ័ប្រាហាំគាត់ក៏យកប្រពន្ធ១ទៀត ឈ្មោះកិទូរ៉ា
២នាងនោះបង្កើតកូនឱ្យគាត់ គឺសីមរ៉ាន[ក] យ៉ុកសាន មីដាន
ម៉ាឌាន[ខ] អ៊ីសបាក់ និងស៊ូអា[គ] ៣ឯយ៉ុកសានគាត់បង្កើតបាន
សេបា[ឃ]និងដេដាន់[ង] ឯកូនចៅដេដាន់ គឺពួកអាសសើរ ពួក
លេទូស និងពួកលេវមី ៤ឯពួកកូនរបស់ម៉ាឌាន គឺអេផា[ច]
អេភើរ ហេណុក អ័ប៊ីដា និងអែលដ្អា នោះសុទ្ធតែជាកូន
ចៅរបស់កិទូរ៉ា ។
៥អ័ប្រាហាំ គាត់ប្រគល់របស់ទ្រព្យទាំងអស់ ឱ្យដល់
អ៊ីសាក[ឆ] ៦តែបានចែកអំណោយខ្លះដល់ពួកកូនចៅរបស់
ប្រពន្ធចុងគាត់ដែរ[ជ] រួចក៏ឱ្យគេចាកចេញពីអ៊ីសាកកូនគាត់[ឈ]

**២៤:៥៣** ដ លប ៤៥:២២ នក ៣:២២ ១២:៣៥ ២ពវ ៥:៥ ឋ ខ.១០,២២ **២៤:៥៤** ឌ ខ.៥៦,៥៩ លប ៣០:២៥ **២៤:៥៥** ឍ ពច ១៩:៤ **២៤:៥៦** ណ ខ.១២ ត ខ.៥៤ **២៤:៥៧** ថ ពច ១៩:៣ **២៤:៥៨** ទ នរ ១:១៦ **២៤:៥៩** ធ លប ៣៥:៨ ន ខ.៥៤ **២៤:៦០** ប លប ២៧:៤,១៩ ២៨:១ ៣១:៥៥ ៤៨:៩,១៥, ២០ យស ២២:៦ ផ លប ១៧:១៦ ព លប ២២:១៧ ទដ ១២៧:៥ សភ ២៧:១១ **២៤:៦១** ភ លប ១៦:១ ៣០:៣ ៤៦:២៥ **២៤:៦២** ម លប ១៦:១៤ យ ១២:៩ **២៤:៦៣** រ យស ១:៨ ទដ ១:២ ៧៧:១២ ១១៩:១៥,២៧,៤៨, ៩៧,១៤៨ ១៤៣:៥ ១៤៥:៥ ល លប ១៨:២

**២៤:៦៤** វ លប ៣១:១៧,៣៤ ១សយ ៣០:១៧ **២៤:៦៥** ស លប ៣៨:១៤ ១:៧ ៤:១,៣ ៦:៧ អស ៤៧:២ **២៤:៦៧** ហ លប ៣១:៣៣ ឡ លប ១៨:៩ អ លប ២៥:២០ ៤៩:៣១ ក លប ២៩:១៨,២០ ៤៣:៣ ពច ១៦:៤ ខ លប ២៣:១-២ **២៥:២** ក យរ ២៥:២៥ ខ លប ៣៦:៣៥ ៣៧:២៨, ៣៦ នក ២:១៥ ជន ២២:៤ ២៥:៦,១៨ ៣១:២ យស ១៣:២១ ពច ៦:១,៣ ៧:១ ៨:១,២២,២៤ ៩:១៧ ១ពវ ១១:១៨ ទដ ៨៣:៩ អស ៩:៤ ១០:២៦ ៦០:៦ ហប ៣:៧ គ យប ២:១១ ៨:១ **២៥:៣** ឃ លប ១០:៧ ង លប ១០:៧ **២៥:៤** ច អស ៦០:៦ **២៥:៥** ឆ លប ២៤:៣៦ **២៥:៦** ជ លប ២២:២៤ ឈ លប ២១:១០, ១៤ ញ លប ២៩:១ ពច ៦:៣,៣៣ ១ពវ ៤:៣០ យប ១:៣ អគ ២៥:៤

**២៤:៥៣** អំណោយជាច្រើន ដែលផ្ដល់ឱ្យរេបិកាហើយនិងក្រុមគ្រួសារ គឺជាសក្ខីភាពមួយដែលបញ្ជាក់ពីទ្រព្យសម្បត្តិពួកអ្នកផ្ទះដែលបានសុំនាងរៀបការជាមួយ ដែលស្ថិតនៅឆ្ងាយពីនាងហើយពីស្រុកកំណើត ។

**២៤:៦០** មើល ២២:១៧ និងការពន្យល់ ។

**២៤:៦២** *អណ្ដូងឡាហាយ-រយ* មើល ១៦:១៤ ។ *ស្រុកត្បូង* មើល ១២:៩ ។

**២៤:៦៥** *នាងយកស្បៃមកបាំងមុខ* គឺជាសញ្ញាមួយបញ្ជាក់ថានាងមិនទាន់រៀបការទេ (ប្រៀបធៀប ៣៨:១៤,១៩) ។

**២៤:៦៧** *ត្រសាល* ជាញឹកញាប់គេប្រើវាធ្វើជាបន្ទប់សម្រាប់រៀបការ (មើល ទដ ១៩:៤-៥) ។

**២៥:១-៦** ការរៀបចំចែកទ្រព្យក្រោយរបស់លោកអ័ប្រាហាំ ។

**២៥:១** *យក* ឬ "បានយក" អំឡុងពេលនោះលោកអ័ប្រាហាំគាត់មានអាយុ ១៤០ឆ្នាំហើយ ។ *ប្រពន្ធ* កន្លែងផ្សេងទៀតនិយាយថា "ប្រពន្ធចុង" លោកអ័ប្រាហាំ (១រប ១:៣២) ។

**២៥:២** *នាងនោះបង្កើតកូនឱ្យគាត់* កូនចៅជាច្រើនរបស់នាងកិទូរ៉ាបញ្ជាក់ថាលោកអ័ប្រាហាំគាត់ក្លាយជា "ឪពុកនៃសាសន៍ជាច្រើន" (១៧:៤-៦ និងការពន្យល់ ១៧:៦) ។

**២៥:៥** *គាត់ប្រគល់របស់ទ្រព្យទាំងអស់ឱ្យដល់អ៊ីសាក* ដោយសារអ៊ីសាកគឺជាកូនតែ "មួយគត់" របស់គាត់នឹងសារ៉ា (២២:២ និងការពន្យល់) ដូច្នេះហើយ អ៊ីសាកជាអ្នកទទួលយកកេរ្តិ៍មរតកដ៏ស្របច្បាប់ពីអ័ប្រាហាំ (ប្រៀបធៀប ២១:១០) ។

**២៥:៦** *ប្រពន្ធចុង* សម្រាប់អ្នករស់នៅក្នុងតំបន់មជ្ឈឹមបូព៌ា សម័យបុរាណ ការយកប្រពន្ធចុងមួយទៀត នោះគឺជាវប្បធម៌ដ៏សាមញ្ញមួយរបស់ពួកគេ ។ សូម្បីតែអ្នកដែលស្រឡាញ់ព្រះកាលពីសម័យបុរាណក៏យកប្រពន្ធច្រើនដែរ ទោះបីវាមិនមែនជាការតម្រូវទុកជាមុនរបស់ព្រះក៏ដោយ (មើល ៤:១៩) ។

ទៅឯស្រុកខាងកើតវិញ ក្នុងកាលដែលគាត់នៅរស់នៅ
ឡើយ[ញ] ៧រីឯចំនួនឆ្នាំអាយុរបស់អ័ប្រាហាំ ដែលគាត់រស់
នៅរួមទាំងអស់បាន១៧៥ឆ្នាំ[ដ] ៨កាលគាត់បានអាយុវែង
ល្អ[ឋ]ព្រមទាំងស្កប់ស្កល់នឹងអាយុរបស់ខ្លួនហើយ នោះក៏ផុត
ដង្ហើមស្លាប់ទៅ បានប្រមូលទៅមូលនឹងញាតិគាត់វិញ[ឌ]
៩រួចអ៊ីសាក និងអ៊ីសម៉ាអែលជាកូនក៏បញ្ចុះសពគាត់[ឍ] នៅ
ក្នុងរអាងម៉ាក់ពេឡា[ណ] នាចំការអេប្រុន[ត]កូនសូហារ ជា
សាសន៍ហេត[ថ]ដែលនៅខាងមុខម៉ាមរេ[ទ] ១០ជាចំការដែល
អ័ប្រាហាំ បានទិញពីពួកកូនចៅហេតមក[ធ] គឺនៅទីនោះ
ហើយដែល បានបញ្ចុះសពអ័ប្រាហាំនិងសារ៉ាជាប្រពន្ធ ។
១១ក្រោយដែល អ័ប្រាហាំស្លាប់ទៅ នោះព្រះទ្រង់ប្រទាន
ពរឱ្យអ៊ីសាក[ន]ជាកូនគាត់ អ៊ីសាកក៏នៅត្រង់អណ្តូង ឡាហា
យ-រយ[ប] ។

## កូនរបស់លោកអ៊ីសម៉ាអែល

*២៥:១២–១៦ – ១របា ១:២៩–៣១*

១២នេះជាដំណវង្ស[ផ]ពីអ៊ីសម៉ាអែល ជាកូនអ័ប្រាហាំ ដែល
ហាការ[ព]សាសន៍អេស៊ីព្ទ ជាបាវស្រីរបស់សារ៉ាបានបង្កើត
ឱ្យគាត់[ភ] ។
១៣ហើយនេះជាបញ្ជីឈ្មោះនៃពួកកូនចៅអ៊ីសម៉ាអែល
តាមឈ្មោះ តាមដំណគេ កូនច្បងរបស់អ៊ីសម៉ាអែល គឺ
នេបាយ៉ូត[ម] រួចកេដារ[យ] អ័ឌបែ្អល មីបសាម ១៤មីសម៉ា
ឌូម៉ា[រ] ម៉ាសា ១៥ហាដាឌ់ ថេម៉ា[ល] យេធើរ[វ] ណាភីស ហើយ
កេតម៉ា ១៦នោះឯងជាពួកកូនរបស់អ៊ីសម៉ាអែល ហើយនិង
ឈ្មោះគេតាមភូមិតាមទីដំឡើងត្រសាលរបស់គេ គឺជាចៅ
ហ្វាយ១២នាក់[ស] តាមសាសន៍គេ[ហ] ១៧ឯចំនួនឆ្នាំអាយុរបស់
អ៊ីសម៉ាអែលទាំងអស់បាន១៣៧ឆ្នាំ រួចគាត់ផុតដង្ហើម
ស្លាប់ទៅបានប្រមូលទៅមូលនឹងញាតិរបស់គាត់វិញ[ឡ] ១៨ឯ
ពូជគាត់[អ]ទាំងនោះគេអាស្រ័យនៅ ចាប់តាំងពីហាវីឡា
រហូតដល់ស៊ើរ[ក] ជាស្រុកដែលនៅខាងមុខស្រុកអេស៊ីព្ទ
តាមផ្លូវទៅឯស្រុកអាសស៊ើរ គាត់ក៏ស្លាប់នៅចំពោះមុខ
នៃពួកបងប្អូនគាត់ទាំងអស់គ្នា[ខ] ។

## លោកយ៉ាកុប និងលោកអេសាវ

១៩ហើយនេះជាដំណវង្ស[គ]ពីអ៊ីសាកជាកូនអ័ប្រាហាំ គឺ
អ័ប្រាហាំបានបង្កើតអ៊ីសាក ២០ឯអ៊ីសាក កាលយករេបិកា[ឃ]
ជាកូនបេធូអែល[ង]សាសន៍អើរ៉ាម ជាអ្នកនៅស្រុកប៉ាដាន់–
អើរ៉ាម[ច] ដែលនាងជាប្អូនឡាបាន់[ឆ]មកធ្វើជាប្រពន្ធ នោះ
គាត់មានអាយុ៤០ឆ្នាំ[ជ]ហើយ[ឈ] ២១អ៊ីសាកគាត់សូមអង្វរដល់
ព្រះយេហូវ៉ាពីដំណើរប្រពន្ធគាត់ ពីព្រោះនាងជាស្ត្រីអារ[ញ]

**២៥:៧** ដ ខ.២៦ លប ១២:៤ ៣៥:២៨ ៤៧:៩,២៨ ៥០:២២,២៦ យប ៤២:១៦ **២៥:៨** ឋ លប ១៥:១៥ ឌ ខ.១៧ លប ៣៥:២៩ ៤៩:២៩,៣៣ ជន ២០:២៤ ៣១:២ ចទ ៣១:១៤ ៣២:៥០ ៣៤:៥ **២៥:៩** ឍ លប ៣៥:២៩ ៤៧:៣០ ៤៩:៣១ ណ លប ២៣:៩ ត លប ៤៩:២៩ ៥០:១៣ ថ លប ២៣:៨ ទ លប ១៣:១៨ **២៥:១០** ធ លប ១០:១៥ **២៥:១១** ន លប ១២:២ ប លប ១៦:១៤ **២៥:១២** ផ លប ២:៤ ព លប ១៦:១ ភ លប ១៧:២០ ២១:១៨ **២៥:១៣** ម លប ២៨:៩ ៣៦:៣ យ ទដ ១២០:៥ ១:៥ អស ២១:១៦ ៤២:១១ ៦០:៧ យរ ២:១០ ៤៩:២៨ អគ ២៧:២១ **២៥:១៤** រ យស ១៥:៥២ អស ២១:១១ អប ១:១ **២៥:១៥** ល យប ៦:១៩ អស ២១:១៤ យរ ២៥:២៣ វ ១របា ៥:១៩ **២៥:១៦** ស ១៧:២០ ហ លប ១៣:១៦ ទដ ៨៣:៦ **២៥:១៧** ឡ ខ.៨ **២៥:១៨** អ លប ១៧:២០ ២១:១៨ ក លប ១៦:៧ ខ លប ១៦:១២ **២៥:១៩** គ លប ២:៤ **២៥:២០** ឃ លប ២៤:២៩ ង លប ២៤:៦៧ ច លប ២២:២២ ឆ លប ២៨:១,៥,៦ ៣០:២០ ៣១:១៨ ៣៣:១៨ ៣៥:៩,២៦ ៤៦:១៥ ៤៨:៧ ជ ខ.២៦ លប ២៦:៣៤ ៣៥:២៨ ឈ លប ៣១:២០,២៤ ចទ ២៦:៥**២៥:២១** ញ លប ១១:៣០

**២៥:៧** *១៧៥ឆ្នាំ* លោកអ័ប្រាហាំបានរស់នៅក្នុងទឹកដីសន្យារយៈពេល ១០០ ឆ្នាំ (មើល ១២:៤) ។

**២៥:៨** *ផុតដង្ហើមទៅ* ដូចនឹងអ្វីដែលព្រះយេហូវ៉ាទ្រង់បានសន្យាជាមួយគាត់ (មើល ១៥:១៥) ។ *ស្កប់ស្កល់នឹងអាយុរបស់ខ្លួន* ពាក្យនេះសូម្បីតែលោកយ៉ូបដែលជាឰយុកោយើងក៏បានប្រើដែរ (យប ៤២:១៧) ។ *បានប្រមូលទៅមូលនឹងញាតិគាត់វិញ* គឺបានជួបជុំជាមួយពួកឰយុកោរបស់គាត់ហើយនិងសាច់ញាតិរបស់គាត់នៅពេលដែលគាត់ស្លាប់នោះ (មើល ២ពរ ២២:២០ ២របា ៣៤:២៨) ។

**២៥:៩** *អ៊ីសាក និងអ៊ីសម៉ាអែល* ដោយសារអ៊ីសាកគឺជាកូនតាមសេចក្តីសន្យាហើយជាអ្នកទទួលមរតក (មើល ខ.៥) ។

**២៥:១១** *អណ្តូងឡាហាយ–រយ* សូមមើល ១៦:១៤ ។

**២៥:១២–១៨** គឺជាការរៀបរាប់សង្ខេបពីកូនចៅអ៊ីសម៉ាអែលបានសម្រេចដូចអ្វីដែលព្រះយេហូវ៉ាទ្រង់សន្យាជាមួយនាងហាការ (១៦:១០) ហើយនិងលោកអ័ប្រាហាំ (១៧:២០) ថានឹងឱ្យពូជពង្សគេចម្រើនឡើង ប៉ុន្តែការតម្រូវទុកជាមុនរបស់ព្រះយេហូវ៉ា គឺបានសម្រេចតាមពូជអ័ប្រាហាំនឹងនាងសារ៉ាវិញ (១៦:១២) ។

**២៥:១២** *ដំណវង្ស* សូមមើល ២:៤ ។

**២៥:១៣** បញ្ជីឈ្មោះនៃពួកកូនចៅអ៊ីសម៉ាអែលឈ្មោះជាច្រើនត្រូវបានដាក់តាមបែបអារ៉ាប់ ពីព្រោះដើម្បីបង្ហាញពីការគោរពលើឰយុកោរបស់គេគឺជាអ៊ីសម៉ាអែល ។

**២៥:១៦** *ចៅហ្វាយ១២នាក់* ចៅហ្វាយទាំង១២នាក់ដែលកើតចេញពីលោកអ៊ីសម៉ាអែលដែលជាកូនរបស់លោកអ័ប្រាហាំ ដូចជាការតម្រូវទុកក្នុង (១៧:២០) គឺដូចគ្នានឹងសេចក្តីពិតមួយដែលបានកើតឡើងចំពោះណាយរប្អូនលោកអ័ប្រាហាំដែរ (មើល ២២:២៣–២៤) ។

**២៥:១៨** *អាស្រ័យនៅ* សូមមើល ១៦:១២ នឹង ២៥:៦ ។

**២៥:១៩–៣៥:២៩** ឥឡូវនេះអ្នកនិពន្ធគាត់បានលើកយករឿងរបស់លោកយ៉ាកុបមកនិយាយវិញម្តង ហើយគាត់ក៏បានបន្តរឿងនេះរហូតដល់ការស្លាប់របស់អ៊ីសាក ។ អ៊ីសាកគាត់គឺជាម្នាក់ដែលបានកើតឡើងចន្លោះពីអ័ប្រាហាំនិងយ៉ាកុប ហើយរឿងរ៉ាវរបស់ពួកគេគឺស្មុកស្មាញណាស់ ២៥:១៩ ដំណវង្ស (មើល ២:៤) ។

**២៥:២០** *ប៉ាដាន់–អើរ៉ាម* ពាក្យនេះមានន័យថា "ខ្ពង់រាបអើរ៉ាម" ហើយនៅមានឈ្មោះស្រុកអើរ៉ាមមួយផ្សេងទៀតមើល (២៤:១០) ។

**២៥:២១** *ពីព្រោះនាងជាស្ត្រីអារ* នាងជាស្ត្រីអារដូចជានាងសារ៉ាដែរ (មើល ១១:៣០ និងការពន្យល់) ។ នាងរេបិកាជាស្ត្រីអាររយៈពេល២០ឆ្នាំ (សូមមើល ខ.២០,២៦) ។ កូនចៅរបស់អ៊ីសាកដូចគ្នានឹងកូនចៅលោកអ័ប្រាហាំដែរ ពួកគេគឺជាអំណោយទានដ៏វិសេសដែលកើតមកតាមសេចក្តី

ហើយព្រះយេហូវ៉ាទ្រង់ទទួលព្រមតាម[ដ] រួចនាងក៏មាន
ទំងន់ ២២ឯកូនក្នុងផ្ទៃនាងវាប្រធាក់គ្នា នាងក៏និយាយថា
បើដូច្នេះ តើនឹងកើតមានជាដូចម្ដេចទៅ រួចនាងទៅ
ទូលសួរដល់ព្រះយេហូវ៉ា[ឋ] ២៣ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ប្រាប់នាងថា មាននគរ២[ឌ]នៅក្នុងផ្ទៃឯង គឺនឹងមានសាសន៍
២ ចេញពីពោះឯងមក សាសន៍១នឹងបានខ្លាំងជាងសាសន៍១
គឺកូនច្បងនឹងត្រូវបំរើប្អូន[ឍ] ។
២៤លុះនាងគ្រប់ខែហើយ[ណ]នោះមើល មានកូនភ្លោះតាំង
នៅក្នុងផ្ទៃនាង[ត] ២៥កូនដែលកើតមកមុន នោះមានសម្បុរ
ក្រហមទង់ដែង[ថ]នៅពេញខ្លួន វិស័យដូចជាអាវរោម[ទ] គេ
បានឱ្យឈ្មោះថាអេសាវ[ធ] ២៦បន្ទាប់នោះ កូនប្អូនក៏ចេញមក[ន]
ទាំងមានដៃកាន់កែងជើងអេសាវ[ប] នោះគេឱ្យឈ្មោះថា
យ៉ាកុប[ផ] ឯអ៊ីសាកគាត់មានអាយុ៦០ឆ្នាំហើយ[ព] ក្នុងកាល
ដែលនាងបង្កើតកូនមក ២៧កូនទាំង២នោះក៏ធំឡើងអេសាវ
បានទៅជាអ្នកចំណានខាងឯវិជ្ជាព្រានប្រមាញ់[ភ] ជាមនុស្ស
នៅតែទីវាល[ម] ឯយ៉ាកុបជាមនុស្សរមទម នៅតែក្នុង
ត្រសាលវិញ ២៨អ៊ីសាកក៏ស្រឡាញ់ពេញចិត្តចំពោះអេសាវ
ដោយព្រោះធ្លាប់បានបរិភោគសាច់ក្តាន់របស់គាត់[យ] ឯ
រេបិកានាងស្រឡាញ់ យ៉ាកុបវិញ[រ] ។
២៩សម័យ១យ៉ាកុបកំពុងតែស្ងួសំឡ[ល] នោះអេសាវមកពី

**២៥:២១** ដ លប ៣០:១៧,២២ ១សយ ១:១៧,២៣ ១រប ៥:២០ ២រប ៣៣:១៤ អរ ៨:២៣ ទដ ១២៧:៣ **២៥:២២** ឋ នក ១៨:១៥ ២៨:៣០ ៣៣:៧ លវ ២៤:១២ ជន ៩:៦–៨ ២៧:៥,២១ ចទ ១៧:៩ ៣ច ១៨:៥ ១សយ ៩:៩ ១០:២២ ១៤:៣៦ ២២:១០ ១ពវ ២២:៨ ២ពវ ៣:១១ ២២:១៣ អស ៣០:២ យរ ២១:២ ៣៧:៧,១៧ អគ ១៤:៧ ២០:១,៣ **២៥:២៣** ឌ លប ១៧:៤ ឍ លប ៩:២៥ ៤៨:១៤ រម ៩:១១–១២ **២៥:២៤** ណ លក ១:៥៧ ត លប ៣៨:២៧ **២៥:២៥** ថ ១សយ

វាល[វ]ទាំងហេវ ៣០ក៏និយាយថា សូមចែកសំឡក្រហមនោះ
ឱ្យបងបរិភោគផង[ស] ដ្បិតបងហេវណាស់ ហេតុនោះបាន
ជាគេហៅឈ្មោះគាត់ថាអេដំមវិញ[ហ] ៣១តែយ៉ាកុបនិយាយ
ថា សូមឱ្យបងផ្ទេរអំណាចមរដករបស់បងច្បងមកឱ្យខ្ញុំ
សិន[ឡ] ៣២នោះអេសាវឆ្លើយថា បងស្លាប់ឥឡូវហើយ ដូច្នេះ
តើអំណាចនោះមានប្រយោជន៍អ្វីដល់បងទៀត ៣៣យ៉ាកុប
ក៏និយាយថា ចូរស្បថ[អ]ឱ្យខ្ញុំឥឡូវចុះ រួចគាត់ក៏ស្បថឱ្យ ហើយ
លក់អំណាចនោះ[ក] ឱ្យដល់យ៉ាកុបទៅ ៣៤យ៉ាកុបក៏ឱ្យនំបុ័ង
និងសំឡសណ្តែកបាយដល់អេសាវ[ខ] គាត់ក៏បរិភោគ រួច
ក្រោកដើរចេញបាត់ទៅ អេសាវបានមើលងាយអំណាច
មរដកនៃបងច្បងរបស់ខ្លួន ដោយអាការយ៉ាងដូច្នោះ ។

### លោកអ៊ីសាក និងស្ដេចអ័ប៊ីម៉្មាឡិច

*២៦:១–១១ – លប ១២:១០–២០ ២០:១–១៨*

**២៦** ១សម័យនោះ មានកើតអំណត់នៅក្នុងស្រុកផ្សេង[ក]ពី

១៦:១២ ទ លប ២៧:១១ ធ លប ២៧:១,១៥ **២៥:២៦** ន លប ៣៨:២៩ ប ហស ១២:៣ ផ លប ២៧:៣៦ ៣២:២៧ ចទ ២៣:៧ យស ២៤:៤ អប ១:១០, ១២ព ឧ.៧,២០ **២៥:២៧** ភ លប ១០:៩ ម ឧ.២៩ លប ២៧:៣,៥ **២៥:២៨** យ លប ២៧:៣,៤,៩,១៤,១៩រ លប ២៧:៦ ៣៧:៣**២៥:២៩** ល ២ពវ ៤:៣៨–៤០ វ ឧ.២៧ **២៥:៣០** ស ឧ.៣៤ ហ លប ៣២:៣ ៣៦:១,៨,៨–៩ ជន ២០:១៤ ចទ ២៣:៧ ទដ ១៣៧:៧ យរ ២៥:២១ ៤០:១១៤៩:៧ **២៥:៣១** ឡ ចទ ២១:១៦–១៧ ១រប ៥:១–២ **២៥:៣៣** អ លប ២១:២៣ ៤៧:៣១ ក លប ២៧:៣៦ ហព ១២:១៦ **២៥:៣៤** ខ ឧ.៣០

សន្យាដែលទ្រង់បានតាំងសញ្ញា ។

**២៥:២២** *ប្រធាក់គ្នា* តាំងពីក្នុងផ្ទៃម្តាយមកយ៉ាកុបនិងអេសាវប្រវាយប្រតប់គ្នាជានិច្ច (មើលខ.២៦) ។ *ទៅ* ប្រហែលជានាងទៅកន្លែងណាមួយដែលនៅជិតដើម្បីថ្វាយបង្គំព្រះយេហូវ៉ា ។

**២៥:២៣** *កូនច្បងនឹងត្រូវបំរើប្អូន* តាមច្បាប់សិទ្ធិរបស់កូនច្បងនាសម័យបុរាណ (ប្រៀបធៀបជាមួយ ចទ ២១:១៥,១៧) បាននិយាយដូច្នេះថា : ក្នុងករណីដែលមានកូនភ្លោះ២ នោះកូនប្អូនត្រូវតែបម្រើកូនច្បង ។ ព្រះអង្គទ្រង់បានជ្រើសរើសយកកូនប្អូនគឺដើម្បីបញ្ជាក់ថា រាស្ត្ររបស់ព្រះគឺព្រះជាអ្នកបង្កើតគេឡើង មិនមែនជាធម្មជាតិឬដោយសារការវិវឌ្ឍន៍ នៃពិភពលោកនោះឡើយ ប៉ុន្តែគឺដោយសារតែព្រះដែលទ្រង់ជាអ្នកផ្តល់ឱ្យគេនូវភាពយុត្តិធម៌ (មើល ១១:៣០) ។ ផ្នែកខ្លះនៃខគម្ពីរនេះគឺនិយាយនៅ រម ៩:១០–១២ ដែលនិយាយពីសេចក្តីសុចរិតរបស់ព្រះអង្គ "ទ្រង់ធ្វើការដែលគាប់ព្រះហឫទ័យទ្រង់"(ទដ ១១៥:៣) មិនមែនព្រះអង្គទ្រង់ជាព្រះទុច្ចរិតនោះឡើយ (រម ៩:១៤) ប៉ុន្តែគឺដោយសារបំណងព្រះហឫទ័យរបស់ទ្រង់វិញទេ ។

**២៥:២៤–២៦** សម្រាប់កូនភ្លោះផ្សេងៗទៀត សូមមើល ៣៨:២៧–៣០ ។

**២៥:២៥** *ក្រហម* អំបោះក្រហមនេះ ចងឱ្យអេដំមដែលជាឈ្មោះមួយទៀតរបស់អេសាវ (ខ.៣០) ។

**២៥:២៦** *ទាំងមានដៃកាន់កែងជើងអេសាវ* ជម្លោះរវាងកូនចៅអ៊ីស្រាអែល (កូនចៅរបស់យ៉ាកុប) ហើយនិងពួកអេដំម (កូនចៅរបស់អេសាវ) គឺជាជម្លោះមួយដ៏ធ្ងន់ធ្ងរជាងអ្វីដែលយើងគិតទុកទៅទៀត (មើលក្នុង ជន ២០:១៤–២១ អប ៩–១០) ។ យ៉ាកុបឈ្មោះនេះបានក្លាយជារឿងមួយដែលគួរឱ្យស្រងាកចិត្តបំផុត (មើល យរ ៩:៤) ។

**២៥:៣១** *សូមឱ្យបងផ្ទេរអំណាចមរដករបស់បងច្បងមកឱ្យខ្ញុំសិន* នៅសម័យបុរាណសិទ្ធរបស់កូនច្បង គឺរួមបញ្ចូលនឹងសិទ្ធិទទួលកេរ្តិ៍មរតករបស់កូនដំបូងថែមទៀត (ហព ១២:៦) ។ លោកយ៉ាកុបគាត់បានរៀបចំគម្រោងការណ៍ ដោយប្រើប្រាស់គ្រប់មធ្យោបាយដើម្បីឱ្យគ្រប់គ្រងលើគេ ។ ប៉ុន្តែការនេះគឺព្រះយេហូវ៉ាទ្រង់ជាអ្នករៀបចំ ហើយជាអ្នកថែរក្សាគេ មិនមែនដោយសារតែប្រាជ្ញារបស់យ៉ាកុបនោះឡើយ ដូច្នេះហើយទើបធ្វើឱ្យគាត់រស់នៅក្រោមព្រះគុណព្រះជានិច្ច ។

**២៥:៣៣** *ចូរស្បថឱ្យខ្ញុំឥឡូវ* ពាក្យសម្បថផ្ទាល់មាត់គឺទាមទារឱ្យធ្វើការសម្រេចចិត្តនិងការបង្ខំផងដែរ ។

**២៥:៣៤** *សណ្តែកបាយ* គឺជាប្រភេទសណ្តែកដែលគេដាំរៀងរាល់ឆ្នាំ ។ ផ្លែវាមានពណ៌ក្រហមលាយត្នោត នៅពេលស្ងោរវា ។ ទោះបីជាដីមិនល្អក៏វាផ្តល់ផលឱ្យ ហើយលូតលាស់បានល្អដែរ មិនតែប៉ុណ្ណោះវាជាធនធានមួយដ៏មានសារៈសំខាន់ក្នុងការទ្រទ្រង់ជីវិតពួកអ្នកមជ្ឈឹមបូព៌ានាសម័យបុរាណ (មើល ២សយ ១៧:២៨ ២៣:១១ អស ៤:៩) ។ *គាត់ក៏ស្បថឱ្យ* ការធ្វើដូច្នេះគឺបង្ហាញថាខ្លួនគាត់គឺ "មិនបានស្រឡាញ់ព្រះ" (ហព ១២:១៦) នៅពេលដែលព្រះអង្គបានមានបន្ទូលអំពីសិទ្ធិជាកូនច្បងតាមរយៈសេចក្តីសន្យាថាអ៊ីសាកជាអ្នកទទួលមរតកពីលោកអ័ប្រាហាំ ។

អំណត់ជាន់មុន ដែលកើតមាននៅជំនាន់អ័ប្រាហាំ ហើយ
អ៊ីសាក គាត់ទៅឯអ័ប៊ីម៉ាឡិច ជាស្តេចសាសន៍ភីលីស្ទីន[ខ] នៅ
កេរ៉ា[គ] 2 នោះព្រះយេហូវ៉ាលេចមក[ឃ]ឯគាត់មានបន្ទូលថា
កុំឱ្យចុះទៅឯស្រុកអេស៊ីព្ទឡើយ[ង] ចូរឯងនៅក្នុងស្រុកដែល
អញនឹងប្រាប់ឯងវិញ[ច] 3 ចូរសំណាក់នៅក្នុងស្រុកនេះចុះ[ឆ]
នោះអញនឹងនៅជាមួយនឹងឯង[ជ] ព្រមទាំងឱ្យពរផង[ឈ]អញ
នឹងឱ្យស្រុកទាំងនេះដល់ឯងនិងពូជឯង[ញ] ហើយអញនឹង
សំរេចតាមសេចក្តីសម្បថ ដែលអញបានស្បថនឹងអ័ប្រាហាំ
ឪពុកឯង[ដ] 4 អញនឹងចំរើនពូជឯង[ឋ]ឱ្យបានដូចជា ផ្កាយនៅ
លើមេឃ[ឌ] ហើយនិងឱ្យស្រុកទាំងនេះ[ឍ]ទៅពូជឯង រួចគ្រប់
ទាំងសាសន៍នៅផែនដីនឹងបានពរ[ណ] ដោយសារពូជឯង
5 ពីព្រោះអ័ប្រាហាំបានស្តាប់តាមពាក្យអញ[ត] ព្រមទាំងរក្សា
បញ្ញើ និងបញ្ញត្តិ ហើយច្បាប់[ថ] និងក្រិត្យវិន័យ[ទ] របស់អញ ។
6 នោះអ៊ីសាកក៏នៅក្នុងស្រុកកេរ៉ា[ធ] 7 ហើយមនុស្សនៅ
ស្រុកនោះគេសួរពីដំណើរប្រពន្ធគាត់ នោះគាត់ប្រាប់ថា
"គឺជាប្អូនខ្ញុំទេ[ន]" ដ្បិតគាត់ខ្លាចមិនហ៊ានប្រាប់ថាជាប្រពន្ធ
ឡើយ ក្រែងមនុស្សស្រុកនេះសំឡាប់គាត់ដោយព្រោះ
រេបិកា ព្រោះនាងមានរូបស្រស់ល្អណាស់ 8 កាលគាត់បាន
នៅស្រុកនេះជាយូរទៅ អ័ប៊ីម៉ាឡិច[ប] ស្តេចសាសន៍ភីលីស្ទីន
ក៏ទតតាមបង្អួចមក ឃើញអ៊ីសាកកំពុងប្រឡែង និងរេបិកា
ជាប្រពន្ធ 9 អ័ប៊ីម៉ាឡិចទ្រង់ហៅអ៊ីសាកមកសួរថា នេះប្រាកដ ជាប្រពន្ធអ្នកពិត ហេតុដូចម្តេចបានជាអ្នកនិយាយថា នាង
ជាប្អូនវិញដូច្នេះ[ផ] រួចអ៊ីសាកទូលឆ្លើយថា ពីព្រោះទូលបង្គំ
នឹកខ្លាចក្រែងទូលបង្គំត្រូវស្លាប់ដោយព្រោះនាង 10 អ័ប៊ីម៉ា
ឡិចមានបន្ទូលតបថា អ្នកបានធ្វើអ្វីដល់យើង[ព] ដូច្នេះ ក្រែង
មានពួករាស្ត្រណាមួយបានរួមដំណេកជាមួយនឹងប្រពន្ធអ្នក
យ៉ាងនោះនឹងនាំឱ្យយើងទាំងអស់គ្នាមានទោសដែរ 11 រួច
អ័ប៊ីម៉ាឡិចទ្រង់ហាមដល់រាស្ត្រទាំងអស់ថា អ្នកណាដែល
ពាល់[ភ]មនុស្សនេះឬប្រពន្ធគាត់ នោះនឹងត្រូវសំឡាប់ជាពិត[ម]
12 អ៊ីសាកគាត់ក៏សាបព្រោះនៅស្រុកនោះ ហើយនៅឆ្នាំ
នោះឯងគាត់បានផល១ជា១រយភាគឡើង[យ] ដោយព្រះ
យេហូវ៉ាទ្រង់ប្រទានពរឱ្យ[រ] 13 គាត់ក៏ត្រឡប់បានជាអ្នកមាន
ហើយចេះតែចំរើនជាច្រើនឡើងទាល់តែមានយ៉ាងស្តុក
ស្តម្ភ[ល] 14 គាត់មានហ្វូងចៀម ហ្វូងគោ ហើយនិងបាវបំរើ
ជាច្រើន[វ] ឯពួកភីលីស្ទីនគេក៏កើតមានសេចក្តីច្រណែននឹង

**២៦:១** ក លប ១២:១០ ចទ ៣២:២៤ ខ លប ១០:១៤ ពច ១០:៦ គ លប ២០:១ **២៦:២** ឃ លប ១២:៧ ង លប ៤៦:៣ ច លប ១២:១ **២៦:៣** ឆ លប ២០:១ ជ លប ២១:២០ ២៧:៤៥ ៣១:៣,៥ ៣២:៩ ៣៥:៣ ៤៨:២១ នក ៣:១២ ៣៣:១៤–១៦ ជន ២៣:២១ ចទ ៣១:២៣ យស ១:៥ អស ៤៣:២ យរ ១:៨ ហក ១:១៣ ឈ ខ.១២ លប ១២:២ ញ លប ១២:៧ កច ៧:៥ ដ លប ១៧:១៩ **២៦:៤** ឋ ខ.២៤ លប ៤៨:៤ ឌ លប ១២:២ ជន ១០:៣៦ ឍ លប ១២:៧ ណ លប ១២:៣ កច ៣:២៥ កទ ៣:៨ **២៦:៥** ត លប ១៨:១៩ ថ ទដ ១១៩:៨០,១១២ អគ ១៨:២១ ទ លវ ១៨:៤,៥,២៦ ១៩:១៩,៣៧ ២០:៨,២២ ២៥:១៨ ២៦:៣ ជន ១៥:៤០ ចទ ៤:៤០ ៦:២ ១១:១ ១ពវ ២:៣ **២៦:៦** ធ លប ២០:១ **២៦:៧** ន លប ១២:១៣ **២៦:៨** ប លប ១០:១៤ ផ លប ១២:១៩ **២៦:១០** ព លប ១២:១៨ **២៦:១១** ភ ១សយ ២៤:៦ ២៦:៩ ទដ ១០៥:១៥ ម លប ២០:៣ **២៦:១២** យ មថ ១៣:៨ រ ខ.៣ **២៦:១៣** ល លប ១៣:២ ចទ ៨:១៨ **២៦:១៤** វ លប ១២:១៦ ២៤:៣៦ ៣២:២៣

**២៦:១–៣៣** ព្រឹត្តិការណ៍ដែលមាននៅក្នុងខខ្លះ ខ. (ខ.១–១១) គឺបានកើតឡើង តាំងពីមុនកំណើតរបស់អេសាវហើយនិងយ៉ាកុបទៅទៀត ។ ខ.១–១១ គឺគ្រាន់តែនិយាយពីសារៈសំខាន់របស់សិទ្ធិជាកូនច្បង ហើយនិងការប្រទានពររបស់ព្រះចំពោះយ៉ាកុបដែលបានបដិសេធន៍ ពីអ្វីដែលឪពុកគាត់ជាអ្នករៀបចំឱ្យ (២៥:២២,៣១,៣៣ ២៧:៥២៩) ដែលទាក់ទងទៅនឹងសេចក្តីសញ្ញាពីការទទួលមរតកដែលលោកអ័ប្រាហាំតាំងគឺ អ៊ីសាកជាអ្នកមានសិទ្ធិទទួលយក ។

**២៦:១** *ដែលមាននៅជំនាន់លោកអ័ប្រាហាំ* មើល ១២:១០ ។ *អ័ប៊ីម៉ាឡិច* ប្រហែលជាកូនឬជាចៅរបស់ស្តេចអ័ប៊ីម៉ាឡិចជំនាន់មុន (មើល ២០:២) ។ *ភីលីស្ទីន* សូមមើល ១០:១៤ ។ *កេរ៉ា* មើល ២០:១ ។

**២៦:២** *លេចមក* មើល ១២:៧ ។

**២៦:៣** *អញនឹងនៅជាមួយឯង* សេចក្តីសន្យារបស់ព្រះដែលថាព្រះទ្រង់នឹងផ្គត់ផ្គង់ហើយនិងការពាររាស្ត្រទ្រង់ គឺព្រះអង្គតែងតែរំលឹកគេម្តងហើយម្តងទៀត (មើល ខ.២៤ ២៨:១៥ ៣១:៣ យស ១:៥ អស ៤១:១០ យរ ១:៨,១៩, មថ ២៨:២០ កច ១៨:១០ លក ១៧:៧) ។ *ដែលអញបានស្បថនឹងអ័ប្រាហាំឪពុកឯង* មើល ២២:១៦–១៨ ។

**២៦:៤** *អញនឹងចំរើនពូជឯងឱ្យដូចជាផ្កាយលើមេឃ* មើល ១៣:១៦ ១៥:៥ និងការពន្យល់ ។ *គ្រប់ទាំងសាសន៍នៅផែនដីនឹងបានពរដោយសារពូជឯង* មើល ១២:២–៣ ។

**២៦:៥** *ពីព្រោះលោកអ័ប្រាហាំបានស្តាប់តាមពាក្យអញ* មើល ១៧:៩ ។ *បញ្ញើ . . . បញ្ញត្ត . . . ច្បាប់ . . . ក្រិត្យវិន័យ* គឺជាពាក្យមួយដែលព្រះយេហូវ៉ាទ្រង់បានធ្វើការពិពណ៌នានូវបទបញ្ជា ដែលមានលក្ខណៈផ្សេងៗគ្នាដែលរាស្ត្រទ្រង់គ្រប់គ្នាត្រូវតែរក្សាទុកនិងកាន់តាម (មើល លវ ២៦:១៤–១៥,៤៦ ចទ ១១:១) ។ ចំពោះការតាំងសញ្ញាវិញអ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិគាត់បានប្រើពាក្យដែលមានលក្ខណៈម៉ត់ចត់និងតឹងតែងបន្តិចដែលប្រជាជនអ៊ីស្រាអែលបានប្រើក្នុងការតាំងសញ្ញា បន្ទាប់ពីការតាំងសញ្ញានៅភ្នំស៊ីណាយ ប៉ុន្តែអ្វីដែលសំខាន់សម្រាប់ពួកអ៊ីស្រាអែលនោះគឺលោកអ័ប្រាហាំដែលជាឪពុករបស់គេ គាត់ជាអ្នកស្តាប់តាមព្រះបន្ទូលនិងព្រះហឫទ័យរបស់ព្រះនៅក្នុងអំឡុងពេលដែលគាត់រស់នៅ ដូច្នេះពួកគេត្រូវតែយកគំរូតាមលោកអ័ប្រាហាំជាឪពុករបស់គេ បើសិនជាពួកគេព្រមទទួលយកសេចក្តីសន្យានៃការតាំងសញ្ញានេះ ។

**២៦:៧** *ពីព្រោះនាងមានរូបស្រស់ល្អណាស់* មើល ១២:១១,១៤ ។

**២៦:៨** *ប្រឡែង* ក្នុងព្រះគម្ពីរភាសាហេព្រើរ ជាទម្រង់កិរិយាស័ព្ទមានន័យថា "សើច"នៅក្នុង (១៧:១៧ ១៨:១២,១៥ ២១:៦ ឬ "សើចឡក" សូមមើលនៅក្នុង ២១:៩) គឺជាពាក្យមួយដែលគេបានជ្រើសរើសមក ដើម្បីដាក់ឈ្មោះឱ្យលោកអ៊ីសាក ។

**២៦:១២** *ផល១ជា១០០* ចង់បញ្ជាក់ថាទឹកដីសន្យា គឺជាទឹកដីមួយដែលមានអំណោយផលល្អ ក្នុងការសាបព្រោះ ។

គាត់[ស] [១៥]ហើយអណ្តូងទាំងប៉ុន្មាន[ហ] ដែលពួកបាវរបស់ឪពុក
គាត់ បានជីកពីកាលដែលនៅរស់នៅឡើយ នោះពួក
ភីលីស្ទីន គេលុប[ឡ]ដីពេញទាំងអស់ទៅ [១៦]រួចអ័ប៊ីម៉្មាឡិច
មានបន្ទូលនឹងអ៊ីសាកថា ត្រូវឱ្យអ្នកថយចេញពីយើងទៅ[អ]
ពីព្រោះអ្នកពូកែជាងយើងហើយ[ក] ។
[១៧]អ៊ីសាកចេញពីទីនោះ ទៅដំឡើងត្រសាលត្រង់វាល
ច្រកកេរ៉ា[ខ] ហើយក៏អាស្រ័យនៅឯនោះវិញ [១៨]រួចគាត់ស្តារ
អណ្តូងទឹកទាំងប៉ុន្មាននោះ[គ] ដែលគេបានជីកនៅជាន់
អ័ប្រាហាំជាឪពុកគាត់ឡើងវិញ ពីព្រោះពួកភីលីស្ទីនបាន
លុបទាំងអស់ក្រោយដែលអ័ប្រាហាំស្លាប់ទៅ រួចគាត់ដាក់
ឈ្មោះ អណ្តូងទាំងនោះតាមឈ្មោះដែលឪពុកបានដាក់មក
ដែរ [១៩]ពួកបាវរបស់អ៊ីសាកក៏ជីកអណ្តូង១នៅក្នុងវាលច្រក
នោះបានទឹកដ៏ហូរហៀរ [២០]ឯពួកគង្វាលនៅស្រុកកេរ៉ាក៏
ប្រឈ្លោះគ្នា[ឃ]នឹងពួកគង្វាលរបស់អ៊ីសាកថា ទឹកនេះជា
របស់ផងយើង[ង] រួចគាត់ហៅអណ្តូងនោះថា អេសែកពី
ព្រោះគេបានឈ្លោះនឹងគាត់ [២១]នោះក៏ជីកអណ្តូង១ទៀត
ហើយគេឈ្លោះគ្នា[ច]ពីអណ្តូងនោះដែរ រួចគាត់ហៅអណ្តូង
នោះថា ស៊ីតនា [២២]គាត់ចេញពីទីនោះទៅជីកអណ្តូង១ទៀត
តែឥតមានគេឈ្លោះគ្នាពីអណ្តូងនោះទេ បានជាគាត់ដាក់
ឈ្មោះថា រេហូបូត[ឆ] ដោយនិយាយថា ឥឡូវនេះព្រះ
យេហូវ៉ាទ្រង់បានប្រទានឱ្យយើង[ជ]បានទូលាយហើយ[ឈ]
យើងនឹងបានចំរើនឡើងក្នុងស្រុកនេះ [២៣]រួចគាត់ចេញពី
ទីនោះឡើងទៅឯបៀរ–សេបា[ញ] [២៤]ហើយនៅយប់នោះឯង
ព្រះយេហូវ៉ាទ្រង់លេចមកឯគាត់មានបន្ទូលថា អញជាព្រះ
នៃអ័ប្រាហាំឪពុកឯង[ដ] ដូច្នេះកុំឱ្យខ្លាចអ្វីឡើយ[ឋ] ពីព្រោះអញ
នៅជាមួយ[ឌ] ហើយនិងឱ្យពរទាំងចំរើនពូជឯងឱ្យច្រើន
ឡើង[ឍ] ដោយព្រោះអ័ប្រាហាំជាអ្នកបំរើអញ[ណ] [២៥]រួចគាត់
ស្អាងអាសនា១[ត]នៅស្រុកនោះ ក៏អំពាវនាវដល់ព្រះនាម
ព្រះយេហូវ៉ា[ថ] គាត់ដំឡើងត្រសាលនៅទីនោះ ហើយពួកបាវ
គាត់ក៏ជីកអណ្តូង១នៅកន្លែងនោះដែរ[ទ] ។
[២៦]ឯអ័ប៊ីម៉្មាឡិច អ័ហ៊ូសាតជាសំឡាញ់ទ្រង់ និងភីកុលជា
មេទ័ពទ្រង់ ក៏ចេញពីកេរ៉ាទៅឯគាត់[ធ] [២៧]នោះអ៊ីសាកសួរ
ថា ហេតុអ្វីបានជាមកឯទូលបង្គំ ដ្បិតទ្រង់ស្អប់ទូលបង្គំហើយ
បានទាំងបណ្តេញទូលបង្គំចេញផង[ន] [២៨]គេឆ្លើយតបថា
យើងបានឃើញជាក់ច្បាស់ថា ព្រះយេហូវ៉ា ទ្រង់គង់ជាមួយ
នឹងអ្នក[ប] បានជាយើងបាននិយាយគ្នាថា គួរឱ្យយើងតាំង
សម្បថ[ផ] ចំពោះគ្នាទៅវិញមកឥឡូវ យើងសូមតាំងសញ្ញា
និងអ្នកថា [២៩]អ្នកនិងមិនធ្វើអាក្រក់ដល់យើងឡើយ[ព] ដូចជា
យើងក៏មិនបានពាល់ដល់អ្នកដែរ គឺយើងបានប្រព្រឹត្តចំពោះ
តែសេចក្តីណាដែលល្អដល់អ្នកប៉ុណ្ណោះ យើងបានឱ្យអ្នក
ចេញ មកដោយសេចក្តីសុខសាន្ត ឥឡូវនេះអ្នកជាមនុស្ស
មានព្រះពរនៅចំពោះព្រះយេហូវ៉ា[ភ] [៣០]នោះគាត់រៀបជប់
លៀង[ម]ដល់គេ ហើយក៏បរិភោគទាំងអស់គ្នាទៅ [៣១]លុះ
ព្រលឹមស្រាងកាលណា នោះក៏ក្រោកឡើងស្បថនឹងគ្នាទៅ
វិញទៅមក[យ] រួចអ៊ីសាកបញ្ជូនអ័ប៊ីម៉្មាឡិចទៅ ហើយទ្រង់ក៏
ចេញពីគាត់ទៅដោយមេត្រីចិត្ត [៣២]នៅថ្ងៃនោះឯង ពួកបាវ
របស់អ៊ីសាកមកជំរាបគាត់ពីដំណើរអណ្តូង[រ] ដែលទើបនឹង
ជីកថា យើងជីកបានទឹកហើយ [៣៣]គាត់ដាក់ឈ្មោះអណ្តូង
នោះថា សេបា ហេតុនោះបានជា ឈ្មោះទីក្រុងនោះហៅ
ថា បៀរ–សេបា[ល] ដរាបដល់សព្វថ្ងៃនេះ ។
[៣៤]ឯអេសាវ កាលគាត់យកនាងយូឌីតជាកូនបេរីសាសន៍
ហេត ហើយនាងបាសម៉ាតជាកូនអេឡូនសាសន៍ហេត[វ] ធ្វើ

ស លប ៣៧:១១
**២៦:១៥** ហ លប ២១:៣០ ឡ លប ២១:២៥
**២៦:១៦** អ ខ.២៧ ពច ១១:៧ ក នក ១:៩ ទដ ១០៥:២៤–២៥
**២៦:១៧** ខ លប ២០:១
**២៦:១៨** គ លប ២១:៣០
**២៦:២០** ឃ លប ១៣:៧ ង លប ២១:២៥
**២៦:២១** ច លប ១៣:៧
**២៦:២២** ឆ លប ៣៦:៣៧ ជ ទដ ១៨:១៩ អស ៣៣:២០ ៥៤:២ អម ៩:១១ ឈ លប ១៧:៦
**២៦:២៣** ញ លប ២២:១៩
**២៦:២៤** ដ លប ២៤:១២ ឋ លប ១៥:១ យស ៨:១ ឌ លប ២១:២០ ឍ ខ.៤ ណ ខ.៤ លប ១៧:៧ ២២:១៧ ២៨:១៤ ៣០:២៧ ៣៩:៥ ចទ ១៣:១៧
**២៦:២៥** ត លប ៨:២០ ថ លប ៤:២៦ កច ២:២១ ទ លប ២១:៣០
**២៦:២៦** ធ លប ២១:២២ **២៦:២៧** ន ខ.១៦ **២៦:២៨** ប លប ២១:២២ ផ លប ២១:២៧ យស ៩:៦ **២៦:២៩** ព លប ៣១:២៩,៥២ ភ លប ២៤:៣១ **២៦:៣០** ម លប ៣១:៥៤ នក ១៨:១២ ២៤:១១ ១សយ ២០:២៧ **២៦:៣១** យ លប ២១:២៣,២៧ **២៦:៣២** រ លប ២១:៣០ **២៦:៣៣** ល លប ២១:១៤ **២៦:៣៤** វ លប ១០:១៥ ២៨:៩ ៣៦:២ យស ៣:១០ ១សយ

**២៦:១៦** *អ្នកពូកែជាងយើងហើយ* គឺបង្ហាញថា សេចក្តីសន្យាដែលព្រះយេហូវ៉ាបានធ្វើការតាំងសញ្ញាពីមុននោះ ឥឡូវនេះបានសម្រេចហើយ ។ មនុស្សផ្សេងៗទៀតដែលនៅក្នុងលោកិយ គេនិងធ្វើការបៀតបៀនឈ្លានពានដល់រាស្ត្ររបស់ព្រះនៅក្នុងទឹកដីសន្យានេះ ដូចដែលគេបានធ្វើចំពោះពួកព្ធយុកោគេពីមុនមកដែរ ។ បើមនុស្សក្នុងលោកិយ គេនៅតែរស់នៅដោយប្រព្រឹត្តិការអាក្រក់ នោះរាស្ត្ររបស់ទ្រង់គ្រប់គ្នា គឺស្ថិតនៅក្នុងការបៀតបៀននឹងឈ្លានពានរបស់គេជានិច្ច ។ ១០០ឆ្នាំក្រោយមកទៀតការបៀតបៀនគាបសង្កត់មួយបានកើតឡើង នៅចំពោះពួកអ៊ីស្រាអែលតាមរយៈព្រះចៅផារ៉ោន ដែលជាអ្នកគ្រប់គ្រងក្នុងស្រុកអេស៊ីព្ទទាំងមូល (សូមមើល នក ១:៩) ។

**២៦:២០** *ទឹកនេះជារបស់ផងយើង* ភាពរាំងស្ងួតនៅសម័យនោះធ្វើឱ្យមានជម្លោះដណ្តើមសិទ្ធិកាន់កាប់ទឹកដីនិងវាលស្មៅ (១៦:៦ ២១:២៥ ៣៦:៧) ។

**២៦:២៥** *ស្អាងអាសនា* មើល ១២:៧ ។ អំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា (សូមមើល ៤:២៦ និងការពន្យល់ ។

**២៦:២៦** *ភីកុល* មើល ២១:២២ ។

**២៦:៣០** *រៀបចំជប់លៀង* នៅក្នុងការតាំងសញ្ញាជានិច្ចកាលគឺតែតែងមានការបរិភោគអាហារ ដើម្បីបង្ហាញពីទំនាក់ទំនងដ៏ជិតស្និទ្ធ (៣១:៥៤ នក ២៤:១១ និងការពន្យល់) ។

**១៦:៣៣** *ហេតុនោះបានជាឈ្មោះទីក្រុងនោះហៅថាបៀរ–សេបា* សូមមើល ២១:៣១ ។

**២៦:៣៤** *នោះគាត់មានអាយុ៤០ឆ្នាំហើយ* ដូចជាអ៊ីសាកឪពុកគាត់ដែរ (២៥:២០) ។ រយៈពេល៤០ឆ្នាំគឺជាពេលវេលាមួយដែលកូនចៅគេជិនាន់

ជាប្រពន្ធ នោះគាត់មានអាយុ៤០ឆ្នាំហើយ[ស] ៣៥នាងទាំង២
នោះក៏នាំឱ្យអ៊ីសាកហើយនិងរេបិកាពិបាកចិត្តណាស់[ហ]។

## លោកយ៉ាកុបបានទទួលពរពីលោកអ៊ីសាក

**២៧** ១កាលអ៊ីសាកគាត់ចាស់ ហើយភ្នែកក៏ងងឹតដល់ទៅ
មើលមិនឃើញទៀត[ក] នោះគាត់ហៅអេសាវកូនច្បង[ខ]មក
ដោយពាក្យថា កូនអើយ អេសាវឆ្លើយថា បាទ ២នោះ
គាត់ប្រាប់ថា មើល ឥឡូវនេះអញចាស់ហើយ មិនដឹងជា
ថ្ងៃណាដែលអញនឹងត្រូវស្លាប់ទេ[គ] ៣ដូច្នេះចូរឯងយក
គ្រឿងប្រដាប់មកឥឡូវ គឺបំពង់ព្រួញនិងធ្នូ ហើយចេញទៅ
ឯវាល[ឃ] ដើម្បីនឹងបាញ់សត្វយកមក ៤រួចរៀបជាម្ហូបយ៉ាង
ឆ្ងាញ់តាមដែលអញចូលចិត្ត[ង]មកឱ្យអញស៊ីម្ដង ដើម្បីឱ្យ
អញឱ្យពរដល់ឯង[ច] ក្នុងពេលមុនដែលអញស្លាប់[ឆ] ៥ដូច្នេះ
អេសាវក៏ចេញទៅឯវាល[ជ] ដើម្បីនឹងបាញ់សត្វយកមកជូន
ឪពុក ឯរេបិកា កាលអ៊ីសាកកំពុងតែនិយាយនឹងអេសាវ ជា
កូននោះនាងក៏ឮដែរ ។

៦រួចរេបិកាប្រាប់យ៉ាកុប[ឈ]ជាកូនថា មើល អញឮឪពុក
ឯងនិយាយនឹងអេសាវបងឯងថា ៧ចូរទៅបាញ់សត្វយកមក
រៀបម្ហូបយ៉ាងឆ្ងាញ់ឱ្យអញស៊ីម្ដង ដើម្បីឱ្យអញបានឱ្យពរ
ដល់ឯងនៅចំពោះព្រះយេហូវ៉ា មុនពេលដែលអញស្លាប់[ញ]
៨ដូច្នេះកូនអើយ ចូរឯងស្ដាប់តាមបង្គាប់អញចុះ[ដ] ៩ចូរទៅ
ឯហ្វូងសត្វយកកូនពពែ២យ៉ាងល្អមកឥឡូវ[ឋ] អញនឹងរៀបជា
ម្ហូបឱ្យយ៉ាងឆ្ងាញ់ជូនឪពុកឯង តាមដែលគាត់ចូលចិត្ត[ឌ]
១០រួចសឹមឯងយកទៅជូនឪពុកពិសាទៅ ដើម្បីឱ្យគាត់បានឱ្យ
ពរដល់ឯងវិញ មុនពេលដែលគាត់ស្លាប់[ឍ] ១១តែយ៉ាកុប
ឆ្លើយទៅម្ដាយថា មើល អេសាវបងខ្ញុំមានរោមដុះស្កូញ
ស្កាញ[ណ] តែខ្ញុំគ្មានទេ ១២ក្រែងលោឪពុកស្ទាបខ្ញុំរួចនឹង
មើលទៅ[ត] ដូចជាអ្នកឆបោកដល់គាត់ ដូច្នេះមិន មែននាំ
ឱ្យខ្ញុំបានពរទេ គឺនឹងនាំឱ្យខ្ញុំត្រូវបណ្ដាសា[ថ]វិញ ១៣នោះ
ម្ដាយប្រាប់ថា កូនអើយ សូមឱ្យសេចក្ដីបណ្ដាសានោះធ្លាក់
មកលើអញវិញចុះ[ទ] ឱ្យឯងគ្រាន់តែស្ដាប់តាមអញ[ធ] ហើយ
ទៅយកពពែមកឱ្យប៉ុណ្ណោះ ១៤គាត់ក៏ទៅយកមក រួចម្ដាយ
តាំងរៀបចាត់ចែងម្ហូបយ៉ាងឆ្ងាញ់ តាមដែលអ៊ីសាកធ្លាប់
ចូលចិត្ត[ន] ១៥រេបិកានាងយកសំលៀកបំពាក់ យ៉ាងល្អ[ប]របស់
អេសាវជាកូនច្បង[ផ] ដែលនៅនឹងនាងក្នុងផ្ទះមកបំពាក់ឱ្យ
យ៉ាកុបជាកូនពៅវិញ ១៦នាងដាក់ស្បែកពពែភ្ជាប់នៅដៃ
ហើយនិងកញ្ចឹងកផង[ព] ១៧រួចប្រគល់ម្ហូបដ៏ឆ្ងាញ់នោះនិង
នំបុ័ងដែលបានធ្វើដល់យ៉ាកុបជាកូន ឱ្យទ្រនាំយកទៅ ។

២៦:៦ ១ពវ ១០:២៩ ស លប ២៥:២០ **២៦:៣៥** ហ លប ២៧:៤៦ ២៨:៨ យស ៧:១៦ **២៧:១** ក លប ៤៨:១០ ចទ ៣៤:៧ ១សយ ៣:២ ខ លប ២៥:២៥ **២៧:២** គ លប ៤៧:២៩ ១ពវ ២:១ **២៧:៣** ឃ ពច ២៥:២៧ **២៧:៤** ង លប ២៥:២៨ ច ខ.១០, ២៥,៣១ លប ២៤:៦០ ៤៩:២៨ ចទ ៣៣:១ ហព ១១:២០ ឆ ខ.៧ **២៧:៥** ជ លប ២៥:២៧ **២៧:៦** ឈ លប ២៥:២៨ **២៧:៧** ញ ខ.៤ **២៧:៨** ដ ខ.១៣,៤៣ **២៧:៩** ឋ ១សយ ១៦:២០ ឌ លប ២៥:២៨ **២៧:១០** ឍ ខ.៤ **២៧:១១** ណ លប ២៥:២៥ **២៧:១២** ត ខ.២២ ថ លប ៩:២៥ **២៧:១៣** ទ មថ ២៧:២៥ ធ ខ.៨ **២៧:១៤** ន លប ២៥:២៨ **២៧:១៥** ប ខ.២៧ ៤:១១ ផ លប ២៥:២៥ **២៧:១៦** ព ខ.២២–២៣

ក្រោយវង្វេងក្នុងទីរហោស្ថានដោយសារសេចក្ដីខ្ញាល់របស់ព្រះ (សូមមើល ជន ៣២:១៣) ។ *យូឌីត . . . បាសម៉ាត* បន្ថែមពីលើប្រពន្ធទាំង២នេះលោកអេសាវគាត់ក៏បានរៀបការជាមួយនាង ម៉ាហាឡាត់ "ប្អូននេបាយ៉ូតជាកូនអ៊ីសម៉ាអែល" (២៨:៩) ។ ពង្សាវតាររបស់អេសាវ ដែលនិយាយក្នុងជំពូក ៣៦ គឺបាននិយាយថា ពួកគេក៏មានប្រពន្ធ៣ដែរ ប៉ុន្តែ បាននិយាយថាពួកគេគឺជា "អ័ដាជាកូនអេឡូនសាសន៍ហេត" ហើយ "អ័ហូលីបាម៉ាជាកូនរបស់" *អ័នា . . . សាសន៍ហេវី* "ព្រមទាំង" បាសម៉ាតជាកូនអ៊ីសម៉ាអែលហើយជាប្អូននេបាយ៉ូត (៣៦:២–៣) ។ ពួកគេក៏ទទួលឈើចាប់ឬមានបញ្ហាខ្លះៗនៅពេលចែកកេមរតដែរ ហើយអ្នកទាំងនោះប្រហែលជាអ្នកដែលបានរៀបរាប់ឈ្មោះទាំងប៉ុន្មាននៅទីនេះហើយ ។ លោកអេសាវគាត់ប្រហែលជាមានប្រពន្ធលើសពី៣នាក់ទៅទៀត ។

**២៦:៣៥** *នាងទាំង២នោះក៏នាំឱ្យអ៊ីសាកហើយនិងរេបិកា* ពួកគេមិនបានអនុញ្ញាតឱ្យយ៉ាកុបគាត់ធ្វើកំហុសដដែលៗ ដោយរៀបការជាមួយស្ត្រីសាសន៍ហេតនិងកាណាននោះឡើយ (មើល ២៧:៤៦–២៨:២) ។

**២៧:១–៤០** និយាយអំពីគម្រោងការណ៍របស់នាងរេបិកា និងយ៉ាកុបក្នុងការបោកបញ្ឆោតបំណាងចិត្តចុងក្រោយរបស់លោកអ៊ីសាក និងការនិយាយពីមូលហេតុនៃគម្រោងការណ៍របស់គេ ។

**២៧:១** *ហើយភ្នែកក៏ងងឹតដល់មើលមិនឃើញទៀតឡើយ* នៅសម័យបុរាណអ្នកងងឹបឬជិតងងឹតភ្នែកគឺពួកគេរស់នៅជាធម្មតាក្នុងចំណោមមនុស្សចាស់ៗដទៃទៀតដែរ (មើល ៤៨:១០ ១សយ ៤:១៥) ។ អេសាវឆ្លើយថាបាទ មើល ២២:១ ។

**២៧:៤** *ម្ហូបយ៉ាងឆ្ងាញ់តាមដែលអញចូលចិត្ត* នាងរេបិកានិងយ៉ាកុបពួកគេបានឆ្លៀតឱកាសដណ្ដើមយកសេចក្ដីស្រឡាញ់របស់អ៊ីសាក ដែលគាត់បានបម្រុងទុកឱ្យអ្នកដែលធ្វើម្ហូបយ៉ាងឆ្ងាញ់ពិតប្រាកដ ឱ្យគាត់ពិសារមុនពេលដែលគាត់ស្លាប់ (មើល ខ.៩,១៤) ។ *ដើម្បីឱ្យអញនឹងឱ្យពរដល់ឯងក្នុងពេលមុនដែលអញស្លាប់* ការនិយាយផ្ទាល់មាត់បែបនេះគឺគាត់ចង់ប្រគល់មរតកឱ្យមុនពេលដែលគាត់បានស្លាប់ (៤៩:២៨,៣៣) គឺត្រូវបានហាមឃាត់សម្រាប់ច្បាប់ពួកអ្នកដែលនៅមជ្ឈិមបូព៌ានាសម័យបុរាណ ។ *ឱ្យពរ* មើល ខ.៣៦ ។

**២៧:៥** *នោះនាងក៏ឮដែរ* គឺនាងបានលួចស្ដាប់ ។

**២៧:៦** *រេបិកា* ពេញផ្ទៃរឿងទាំងអស់នៃរឿងរបស់លោកយ៉ាកុបអ្នកនិពន្ធគាត់បានផ្ដោតសំខាន់លើពាក្យ "អំណាចមរតករបស់បងច្បង" (បេកូរ៉ា) ហើយនិង"ឱ្យពរ"(បេរ៉ាកា) ឋានៈទាំង២នេះគឺជាអ្វីដែលលោកយ៉ាកុបគាត់ស្វែងរកដូច្នេះហើយទើបបណ្ដាលឱ្យនាងរេបិកា បានធ្វើការដែលល្អសម្រាប់អនាគតកូនដែលនាងស្រឡាញ់ ។ ប្រាប់យ៉ាកុបជាកូនញាតិវង្សជាទីស្រឡាញ់ដែលបានផ្ដោតក្នុង ២៥:២៨ ប្រហែលជាពេលនេះបង្ហាញឱ្យឃើញ ផលផ្លែដ៏អាក្រក់របស់គាត់ហើយ ។

**២៧:៨** *ដូច្នេះកូនអើយចូរឯងស្ដាប់តាមបង្គាប់អញចុះ* នាងរេបិកាបង្ហាញពីគម្រោងការណ៍ក្បត់ដូចគ្នានឹងយ៉ាកុបដែលឈ្មោះរបស់វាជាអ្នកបោកប្រាសគេ(ខ.៣៦ ២៥:២៦)។

១៨ គាត់ក៏ចូលទៅឯឪពុកជំរាបថា លោកឪពុកអើយ
ឪពុកឆ្លើយថា អីកូន ឯងជាអ្នកណាហ្នឹង[ភ] ១៩ យ៉ាកុបឆ្លើយថា
ខ្ញុំនេះជាអេសាវកូនច្បង[ម]របស់លោកឪពុក ឥឡូវ ខ្ញុំបានធ្វើ
ដូចជាលោកឪពុកបង្គាប់ហើយ អញ្ជើញក្រោកអង្គុយឡើង
ពិសាសាច់ដែលខ្ញុំបាញ់មកចុះ[យ] ដើម្បីឱ្យលោកឪពុកបានឱ្យ
ពរដល់ខ្ញុំ[រ] ២០ អ៊ីសាកសួរថា កូនអើយម្តេចឡើយបានឯង
រកបានឆាប់ដល់ម៉្លេះ នោះគាត់ឆ្លើយថា ពីព្រោះព្រះ
យេហូវ៉ាជាព្រះនៃលោកឪពុកទ្រង់បានជួយខ្ញុំ[ល] ២១ អ៊ីសាក
និយាយទៅយ៉ាកុបថា កូនអើយ ចូរឯងមកជិតដើម្បីអញនិង
ស្ទាបឯង[វ]មើលឱ្យដឹង បើឯងជាអេសាវកូនអញពិតមែន
២២ យ៉ាកុបក៏ចូលទៅជិតអ៊ីសាក[ស]ឪពុកខ្លួន ហើយគាត់ស្ទាប[ហ]
មើលរួចនិយាយថា សំឡេងជាសំឡេងយ៉ាកុប តែដៃជាដៃ
អេសាវពិត ២៣ គាត់មិនបានជាសំគាល់ទេ ដ្បិតដៃនោះមាន
រោមដូចជាដៃអេសាវជាបងដែរ[ឡ] ដូច្នេះគាត់ក៏ឱ្យពរ
២៤ តែគាត់បញ្ជាក់ថា ឯងជាអេសាវកូនអញពិតមែនឬអី រួច
យ៉ាកុបឆ្លើយថា ខ្ញុំពិតមែនហើយ ២៥ នោះគាត់និយាយថា
ចូរដាក់ម្ហូបជិតអញមក ឱ្យអញស៊ីសាច់ដែលឯងបានបាញ់
ដើម្បីឱ្យអញបានឱ្យពរដល់ឯង[អ] យ៉ាកុបក៏យកទៅដាក់នៅ
ជិតឪពុក ហើយគាត់ក៏ពិសាទៅ រួចយកស្រាទំពាំងបាយជូរ
មកជូនដែរគាត់ក៏ពិសាទៀត ២៦ អ៊ីសាកឪពុកគាត់ប្រាប់ថា
ឥឡូវនេះចូរឯងមកថើបអញ កូនអើយ ២៧ យ៉ាកុបក៏ចូល
ទៅថើប[ក,ខ] ហើយគាត់ក៏ធុំក្លិនសំលៀកបំពាក់នោះ[គ] រួច
គាត់ឱ្យពរថា មើល ក្លិនកូនអញដូចជាក្លិននៃវាលដែល
ព្រះយេហូវ៉ាបានប្រទានពរឱ្យ[ឃ] ២៨ សូមឱ្យព្រះទ្រង់ប្រទាន
សន្សើមពីលើមេឃ[ង] ហើយផលពីផែនដី[ច] ជាស្រូវ[ឆ]និង
ស្រាទំពាំងបាយជូរជាបរិបូរដល់ឯង[ជ] ២៩ ឱ្យមាននគរនានា
បំរើដល់ឯង[ឈ] ហើយសាសន៍ផ្សេងៗក្រាបចុះចំពោះឯង
ឱ្យឯងបានជាចៅហ្វាយលើបងប្អូនឯង ហើយឱ្យកូនពោះ
មួយនឹងឯងបានក្រាបគោរពដល់ឯងដែរ[ញ] សូមឱ្យត្រូវ
បណ្តាសាដល់អ្នកណាដែលផ្តាសាឯង ហើយឱ្យបានពរ
ដល់អ្នកណាដែលឱ្យពរឯង[ដ] ។

៣០ កាលអ៊ីសាកបានឱ្យពរដល់យ៉ាកុបរួចជាស្រេច
ហើយយ៉ាកុបចេញពីអ៊ីសាកជាឪពុក ទៅសឹងតែមិនទាន់
នោះអេសាវជាបងក៏វិលមកពីបាញ់សត្វវិញ ៣១ គាត់បាន
រៀបម្ហូបយ៉ាងឆ្ងាញ់យកមកជូនឪពុកដែរ គាត់ជំរាបថា
អញ្ជើញលោកឪពុកក្រោកឡើង ពិសាសាច់ដែលកូនបាន
បាញ់មក ដើម្បីនឹងបានឱ្យពរដល់ខ្ញុំ[ឋ] ៣២ នោះអ៊ីសាកឪពុក
គាត់សួរថា ចុះឯងជាអ្នកណា[ឌ] គាត់ឆ្លើយថាខ្ញុំនេះជា
អេសាវកូនច្បងរបស់លោកឪពុក[ឍ] ៣៣ អ៊ីសាកក៏ញ័រខ្លួន
ជាខ្លាំងណាស់ទាំងសួរថា ដូច្នេះតើអ្នកណាដែលទើបនឹង
យកសាច់មកឱ្យអញ ហើយអញបានស៊ីគ្រប់មុខអម្បាញ់
មិញ[ណ] មុនដែលឯងមកនេះ អញក៏ឱ្យពរដល់វាទៅ ហើយ
វានឹងបានពរមែន[ត] ៣៤ កាលអេសាវ បានឮពាក្យឪពុកដូ
ច្នោះ នោះគាត់ក៏ស្រែកឡើងជាខ្លាំង ដោយឈឺចិត្តយ៉ាងក្រៃ
លែង[ថ] រួចនិយាយទៅឪពុកថា ឱលោកឪពុកអើយ សូម
ចែកពរ[ទ]មកខ្ញុំផង ៣៥ តែគាត់ឆ្លើយថា ប្អូនឯងបានមកដោយ
ឧបាយកល[ធ] ភ្លែងដណ្តើមយកពរឯងហើយ[ន] ៣៦ រួចអេ
សាវនិយាយថា គេបានដាក់ឈ្មោះវាថា "យ៉ាកុប"[ប]
ត្រូវណាស់ ព្រោះវាបាន ដណ្តើមខ្ញុំ២ដងនេះ[ផ]ហើយ គឺ
បានយកអំណាចមរដកបងច្បងរបស់ខ្ញុំម្តង[ព] ហើយមើល

**២៧:១៨** ភ ខ.៣២
**២៧:១៩** ម ខ.៣២
យ លប ២៥:២៨
រ ខ.៤
**២៧:២០** ល លប
២៤:១២
**២៧:២១** វ ខ.១២
**២៧:២២** ស លប
៤៥:៤ ហ ខ.១២
**២៧:២៣** ឡ ខ.១៦
**២៧:២៥** អ ខ.៤
**២៧:២៧** ក លប
៣១:២៨,៥៥ ៣៣:៤
៤៨:១០ នក ៤:២៧
១៨:៧ នរ ១:៩
១សយ ២០:៤១
២សយ ១៤:៣៣
១៩:៣៩ ខ ហព
១១:២០ គ ខ.១៥
ឃ ទដ ៦៥:៩–១៣
**២៧:២៨** ង ចទ
៣៣:១៣ ២សយ
១:២១ យប ១៨:១៦
២៩:១៩ សភ ៣:២០
អស ២៦:១៩ ហស
១៤:៥ ហក ១:១០
សក ៨:១២ ច
ខ.៣៩ លប ៤៩:២៥
លវ ២៦:២០ ចទ
៣៣:១៣ ឆ ទដ
៦៥:៩ ៧២:១៦
ជ ខ.៣៧ ជន
១៨:១២ ចទ ៧:១៣
៣៣:២៨ ២ពវ
១៨:៣២ ទដ ៤:៧
អស ៣៦:១៧ យរ
៣១:១២ ៤០:១០ **២៧:២៩** ឈ ២សយ ៨:១៤ ទដ ៦៨:៣១ ៧២:១១ អស
១៩:២១,២៣ ២៧:១៣ ៤៥:១៤, ២៣ ៤៩:៧,២៣ ៦០:១២,១៤ ៦៦:១២,១៤
៦៦:២៣ យរ ១២:១៧ ដយ ២:៤៤ សក ១៤:១៧–១៨ ញ លប ៩:២៥
២៥:២៣ ៣៧:៧ ដ ខ.៣៣ លប ១២:៣ **២៧:៣១** ឋ ខ.៤ **២៧:៣២** ឌ ខ.១៨
ឍ ខ.១៩ **២៧:៣៣** ណ ខ.៣៥ ត ខ.២៩ **២៧:៣៤** ថ ហព ១២:១៧ ទ នក
១២:៣២ **២៧:៣៥** ធ យរ ៩:៤ ១២:៦ ន ខ.១៩,៤៥ **២៧:៣៦** ប លប ២៥:២៦
លប ២៩:២៥ ៣១:២០,២៦ ៣៤:១៣ ១សយ ២៨:១២ ព លប ២៥:៣៣

**២៧:២០** *ព្រះយេហូវ៉ាជាព្រះនៃលោកឪពុក* ពាក្យនេះត្រូវបានយ៉ាកុបនិយាយឡើងវិញក្នុងកន្លែងផ្សេងៗទៀតដូចជា (៣១:៥,៤២ ៣២:៩) ។ មិនមែនទាល់តែគាត់បានចាកចេញពីហារ៉ានដោយសុវត្ថិភាព ទើបគាត់និយាយថាព្រះយេហូវ៉ាជាព្រះពិតរបស់គាត់នោះឡើយប្រៀបធៀប (២៨:២០–២១ ៣៣:១៨–២០ និងការពន្យល់) ។

**២៧:២៤** *ឯងជាអេសាវកូនអញពិតឬអី* នៅចុងបំផុតការក្លែងបន្លំបានធ្វើឱ្យអ៊ីសាកគាត់មានការសង្ស័យ ។

**២៧:២៧** *ឱ្យឯងបានជាចៅហ្វាយលើបងប្អូនឯង* អ៊ីសាកគាត់គ្មានបំណងចិត្តឱ្យពរដល់យ៉ាកុបនោះឡើយហើយការនេះគឺដើម្បីឱ្យបានសម្រេចតាមសេចក្តីសន្យាដែលព្រះយេហូវ៉ាទ្រង់បានសន្យាជាមួយរេបិកាក្នុង (២៥:២៣ សូមមើលការពន្យល់) ។ *ត្រូវបណ្តាសា . . . ផ្តាសាឯង . . . ឱ្យបានពរ . . . ដែលឱ្យពរឯង* សូមធ្វើការប្រៀបធៀបនិង ១២:៣ ។

**២៧:៣៣** *ហើយវាក៏បានពរទៅ* នៅសម័យបុរាណគេជឿថាការឱ្យពរហើយនិងការដាក់បណ្តាសា គឺមានប្រសិទ្ធិភាពខ្ពស់ណាស់ ។ អ៊ីសាកគាត់បានទទួលព្រះពរនិងអំណាចកាន់កាប់មរតករបស់កូនច្បងមកពីព្រះយេហូវ៉ា តែគាត់បានផ្ទេរមរតកនេះឱ្យទៅយ៉ាកុប ដោយការបង្ខិតបង្ខំ (មើល ខ.៤) ។

**២៧:៣៤** *ស្រែកឡើងយ៉ាងខ្លាំង* ទឹកភ្នែករបស់អេសាវ"គង់តែរកផ្លូវប្រែចិត្តមិនឃើញទេ"(ហព ១២:១៧) ។

**២៧:៣៦** *គេបានដាក់ឈ្មោះវាថា "យ៉ាកុប"នោះត្រូវណាស់* សូមមើល ២៥:២៦ ។ *បានយកអំណាចមរតកបងច្បងរបស់ខ្ញុំម្តង ហើយមើលឥឡូវនេះវាបានដណ្តើមយកពររបស់ខ្ញុំទៀត* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា "អំណាចមរតកបងច្បង"(គឺបេកូរ៉ា) និង "ពរ"(គឺបេរ៉ាកា) មើល ខ.៦។

ឥឡូវនេះវាមកដណ្ដើមយកពររបស់ខ្ញុំទៀត[ភ] រួចគាត់សួរ
ថា តើលោកឪពុកគ្មានបំរុងពរណាទុកសំរាប់ឱ្យខ្ញុំផងទេ
ឬអី ។
៣៧អ៊ីសាកឆ្លើយទៅអេសាវថា មើល អញបានតាំងឱ្យវា
ធ្វើជាចៅហ្វាយលើឯង ហើយបានឱ្យបងប្អូនវាទាំងអស់ធ្វើ
ជាបាវបំរើដល់វា ទាំងឱ្យវាលៀងជីវិតដោយស្រូវហើយ
និងស្រាទំពាំងបាយជូរ[ម] ដូច្នេះកូនអើយ តើឱ្យអញធ្វើអ្វីឱ្យ
ឯងទៀត ៣៨អេសាវគាត់សួរដល់ឪពុកថា លោកឪពុក
អើយ តើមានពរតែ១នេះទេឬអី? ឱលោកឪពុកអើយសូម
ឱ្យពរដល់ខ្ញុំផង រួចអេសាវក៏ឡើងសំឡេងយំ[យ] ៣៩អ៊ីសាក
ឪពុកគាត់ក៏ប្រាប់ថា[រ] មើល ទីលំនៅឯងនឹងនៅឆ្ងាយពីផល
បរិបូរនៃដី ហើយពីទឹកសន្សើម[ល]អំពីមេឃ[វ] ៤០ឯងនឹងរស់
នៅដោយសារដាវឯងវិញ ហើយនិងបំរើ[ស]ដល់ប្អូន[ហ] តែ
កាលណាឯងផ្តាច់ចំណង នោះនឹងបានដោះនឹមរបស់វាពី
កឯងចេញ[ឡ] ។

### លោកយ៉ាកុបរត់គេចទៅរកលោកឡាបាន់

៤១អេសាវក៏ស្អប់[អ]យ៉ាកុប[ក] ដោយព្រោះពរដែលឪពុក
បានឱ្យ ហើយគាត់សំរេចក្នុងចិត្តថា ថ្ងៃកាន់ទុក្ខ[ខ]ឪពុកអញ
ជិតដល់ហើយ នោះអញនឹងសំឡាប់[គ]យ៉ាកុបជាប្អូនចោល[ឃ]
៤២មានគេនាំយកពាក្យនោះ[ង] ទៅជំរាបដល់រេបិកា រេបិកា
ក៏ចាត់គេឱ្យទៅហៅយ៉ាកុប ជាកូនពៅមកប្រាប់ថា មើល
អេសាវបងឯងបានកំសាន្តចិត្តពីដំណើរឯងហើយ ដោយ
សង្ឃឹមថា នឹងសំឡាប់ឯងចោល[ច] ៤៣ដូច្នេះកូនអើយ ត្រូវ
ស្តាប់តាមអញ[ឆ]ឥឡូវ ចូរឯងរៀបចំរត់ទៅឯឡាបាន់[ជ] ជា
បងអញនៅខារ៉ានទៅ[ឈ] ៤៤ហើយនៅជាមួយនឹងគាត់ឱ្យ
យូរបន្តិច[ញ] ដរាបដល់បងឯងបាត់ក្តៅក្រហាយ ៤៥កាលណា
បងឯងលែងខឹងនឹងឯង ហើយភ្លេចពីការដែលឯងបានធ្វើ
ដល់វា[ដ] នោះអញនឹងចាត់ឱ្យទៅនាំឯងពីនោះមកវិញ[ឋ]
ក្រែង អញបាត់ឯងទាំង២ចេញនៅថ្ងៃតែ១ ។
៤៦នោះរេបិកានិយាយទៅអ៊ីសាកថា ខ្ញុំមិនចង់រស់នៅ
ទៀតទេ ដោយព្រោះកូនស្រីនៃសាសន៍ហេតទាំងនេះ[ឌ] បើ
កាលណាយ៉ាកុបយកប្រពន្ធ ក្នុងពួកកូនស្រីសាសន៍ហេត
ដូចជាពួកកូនស្រីស្រុកនេះដែរ[ឍ] នោះតើឱ្យខ្ញុំនៅរស់ធ្វើអ្វី
ទៀត[ណ] ។
**២៨** ១អ៊ីសាកក៏ហៅយ៉ាកុបមកឱ្យពរ[ក] រួចផ្តាំថា កុំឱ្យឯង
យកប្រពន្ធពីពួកកូនស្រីកាណានឡើយ[ខ] ២ចូររៀបចំខ្លួន
ឡើងទៅឯផ្ទះបេធូអែល[គ] ជាជីតាខាងម្តាយឯងនៅប៉ាដាន់
-អើរ៉ាម[ឃ] ហើយយកប្រពន្ធពីនោះក្នុងពួកកូនស្រីឡាបាន់
ឪពុកធំខាងម្តាយឯងវិញ ៣សូមព្រះដ៏មានគ្រប់ព្រះចេស្តា[ង]
ប្រទានពរ[ច]ដល់ឯង ទាំងធ្វើឱ្យឯងបង្កើតកូនចំរើនជាច្រើន
ឡើង[ឆ] ឱ្យឯងបានជាសាសន៍១មានគ្នាដ៏ច្រើន[ជ] ៤ព្រមទាំង
ប្រទានពររបស់អ័ប្រាហាំ[ឈ]ដល់ឯងនិងពូជឯងផង ដើម្បីឱ្យ
ឯងបានស្រុក[ញ]ដែលឯងស្នាក់នៅ[ដ]ទុកជាកេរ្តិ៍អាករ គឺស្រុក

ភ ហព ១២:១៦-១៧ **២៧:៣៧** ម ខ.២៨ ចទ ១៦:១៣ អរ ៦:៩ អស ១៦:១០ យរ ៤០:១២ **២៧:៣៨** យ លប ២៩:១១ ជន ១៤:១ ពច ២:៤ ២១:២ នរ ១:៩ ១សយ ១១:៤ ៣០:៤ ហព ១២:១៧ **២៧:៣៩** រ ហព ១១:២០ ល ខ.២៨ វ លប ៣៦:៦ **២៧:៤០** ស ២សយ ៨:១៤ ហ លប ៩:២៥ ឡ ២ពវ ៨:២០-២២ **២៧:៤១** អ លប ៣៧:៤ ៤៩:២៣ ៥០:១៥ ១សយ ១៧:២៨ ក លប ៣១:១៧ ៣២:១១ ហស ១០:១៤ ខ លប ៥០:៤,១០ ជន ២០:២៩ គ ខ.៤២ ឃ អប ១:១០ **២៧:៤២** ង លប ៣២:៣,១១ ៣៣:៤ ច ខ.៤១ **២៧:៤៣** ឆ ខ.៨ ជ លប ២៤:២៩

ឈ លប ១១:៣១ **២៧:៤៤** ញ លប ៣១:៣៨,៤១ **២៧:៤៥** ដ ខ.៣៥ ឋ លប ២៦:៣ **២៧:៤៦** ឌ លប ១០:១៥ ឍ លប ១០:១៥-១៩ ណ លប ២៦:៣៥ យប ៧:៧ **២៨:១** ក លប ២៤:៦០ ខ លប ២៤:៣ **២៨:២** គ លប ២៥:២០ ឃ លប ២៥:២០ ង លប ២១:២១ ២៤:២៩ **២៨:៣** ច លប១៧:១ ឆ លប ៤៨:១៦ ជន ៦:២៤ នរ ២:៤ ទដ ១២៩:៨ ១៣៤:៣ យរ ៣១:២៣ ជ លប ១៧:៦ ឈ លប ១២:២ **២៨:៤** ញ លប ១២:២,៣ យ លប ១៥:៧ ដ លប ១៧:៨

ទោះបីជាអេសាវព្យាយាមបែងចែក"ពរ"និងអំណាចមរតកបងច្បងក៏ដោយ ក៏ជំហានដំបូងវាមិនអាចកើតឡើងបានឡើយ ក្នុងអំឡុងពេលដែលពួកគេទាំង២នាក់សុទ្ធតែចង់បានអំណាចមរតកបងច្បងរៀងៗខ្លួនដូច្នេះ (ហព ១២:១៧) ។

**២៧:៣៩** *នៅឆ្ងាយពីផលបរិបូរនៃដីហើយពីទឹកសន្សើមអំពីមេឃ* ប្រៀបធៀបខ.២៨ ។ ពរទី២ដែលអ៊ីសាកឱ្យទៅអេសាវគឺជាការបំប្លែងពរដំបូងដែលគាត់បានឱ្យទៅយ៉ាកុប ។

**២៧:៤០** សូមមើល ២៥:២៣ ហើយនិង ២៥:២២,២៦ ។

**២៧:៤១-៤៥** ជម្លោះដ៏សាហាវរបស់អេសាវចំពោះយ៉ាកុប និងផលវិបាករបស់វា ។ "គំគួននឹងច្រណែន" នៃតំណវង្សអេសាវហើយនិងការផ្សះផ្សាឡើងវិញរបស់តំណវង្សប្អូនគាត់ (៣៣:១១៧) បាននិយាយបំប្លែងពីរឿងរបស់លោកយ៉ាកុបដែលបានរត់គេចពីកាណាន ឆ្ពោះទៅកាន់ប៉ាដាន់-អើរ៉ាម ជាកន្លែងដែលគាត់យកប្រពន្ធនៅទីនោះហើយបានក្លាយជាឪពុកនៃសាសន៍ជាច្រើនមិនតែប៉ុណ្ណោះ វាក៏ជាកន្លែងមួយដែលផ្តល់ឱ្យគាត់នូវទ្រព្យជាច្រើនមុនពេលគាត់ត្រឡប់មកទឹកដីសន្យាវិញ ។ ចំណងនៃព្រឹត្តការណ៍នេះវាដូចគ្នានឹងបទពិសោធន៍លោកយ៉ូសែប ដែលគាត់បាននិយាយទៅកាន់បងៗរបស់គាត់ក្នុង ៥០:២០ ។

**២៧:៤៣** *ត្រូវស្តាប់តាមអញឥឡូវ* ពីមុនមកនាងបានផ្តល់ដំបូន្មានអាក្រក់ម្តងរួចទៅហើយ (សូមមើល ខ.៨,១៣) ប៉ុន្តែពេលនេះនាងបានផ្តល់ជាដំបូន្មានដ៏ល្អវិញ ។

**២៧:៤៤** *ឱ្យយូរបន្តិច* គាត់បានទៅរស់នៅទីនោះអស់រយៈពេល ២០ឆ្នាំ (៣១:៣៨,៤១) ។

**២៧:៤៥** ឯងទាំង២ គឺទាំងអេសាវ ហើយនិងយ៉ាកុប ។ អេសាវអាចនិងស្លាប់ ដោយសារការប្រព្រឹត្តរបស់គាត់ (មើល ៩:១២ នក ២១:១២ លវ ២៤:១៧ ជន ៣៥:១៩,២១,២៧,៣៣ ២សយ ១៤:៦-៧) ។

**២៧:៤៦** មើល ២៦:៣៥ ។

**២៨:២** *ប៉ាដាន់អើរ៉ាម* មើល ២៥:២០ ។ *ហើយយកប្រពន្ធនៅទីនោះ* មើល ២៤:៣-៤ ។

**២៨:៣** *ព្រះដ៏មានគ្រប់ព្រះចេស្តា* មើល ១៧:១ ។

**២៨:៤** *ព្រះពររបស់លោកអ័ប្រាហាំ* លោកសាវ័កប៉ុលគាត់បានដកស្រង់ឃ្លាទាំងនេះយកទៅបង្រៀនទូន្មានដល់ពួកអ្នកជឿគ្រប់គ្នា (សូមមើលក្នុង កទ ៣:១៤) ។

នេះឯងដែលព្រះបានប្រទានដល់អ័ប្រាហាំ ៥នោះអ៊ីសាកឱ្យ
យ៉ាកុបទៅ[ឋ] គាត់ក៏ទៅឯស្រុកប៉ាដាន់–អើរ៉ាម[ឌ] ដល់
ឡាបាន់ជាកូនបេធូអែលសាសន៍អើរ៉ាម[ឍ] ជាបងរេបិកា[ណ]
ដែលជាម្តាយយ៉ាកុបហើយនិងអេសាវ ។
៦រីឯអេសាវគាត់ឃើញថា អ៊ីសាកបានឱ្យពរដល់យ៉ាកុប
ព្រមទាំងឱ្យគាត់ទៅឯស្រុកប៉ាដាន់–អើរ៉ាម ដើម្បីនឹងយក
ប្រពន្ធពីនោះមក ហើយថា ក្នុងខណដែលឱ្យពរនោះ គាត់
ក៏ផ្តាំថា កុំឱ្យឯងយកប្រពន្ធក្នុងពួកកូនស្រីស្រុកកាណាន
ឡើយ[ត] ៧ហើយឃើញថា យ៉ាកុបបានស្តាប់តាមឪពុកម្តាយ
ហើយ ទាំងចេញទៅឯស្រុកប៉ាដាន់–អើរ៉ាមផង ៨ដូច្នេះ
អេសាវយល់ថា កូនស្រីស្រុកកាណាន[ថ]មិនជាទីពេញចិត្ត
ដល់អ៊ីសាកជាឪពុកខ្លួនទេ[ទ] ៩នោះគាត់ទៅឯអ៊ីសម៉ាអែល[ធ]
យកនាងម៉ាហាឡាត់ ប្អូននេបាយ៉ូត[ន] ជាកូនអ៊ីសម៉ាអែល
ចៅអ័ប្រាហាំមកធ្វើជាប្រពន្ធថែមទៀត[ប] ។

## ការយល់សប្តិរបស់លោកយ៉ាកុបនៅបេតអែល

១០ឯយ៉ាកុប គាត់ចេញពីបៀរ–សេបា[ផ] ទៅឯខារ៉ាន[ព]
១១បានដល់កន្លែង១[ភ] ក៏សំណាក់នៅទីនោះ១យប់ ពីព្រោះ
ថ្ងៃលិចហើយ គាត់យកថ្មនៅទីនោះមកកើយក្បាល[ម]ដេក
លក់ទៅ ១២គាត់យល់សប្តិ[យ] ឃើញថា មានជណ្តើរ១បញ្ឈរ
នៅលើដីមានចុងទល់នឹងផ្ទៃមេឃ ក៏ឃើញមានពួកទេវតា
របស់ព្រះឡើងចុះតាមជណ្តើរនោះ[រ] ១៣ព្រះយេហូវ៉ា[ល]ក៏
សណ្ឋិតនៅពីលើជណ្តើរ ទ្រង់មានបន្ទូលថា អញជា
ព្រះយេហូវ៉ាជាព្រះនៃអ័ប្រាហាំជីតាឯង ហើយជាព្រះនៃ
អ៊ីសាក[វ] ឯដី[ស]ដែលឯងដេកនៅនេះ[ហ] អញនឹងឱ្យដល់ឯង
ហើយនិងពូជឯងតទៅ ១៤ពូជឯងនឹងមានគ្នាច្រើនដូចធូលីដី
ហើយឯង[ឡ]នឹង បានវាតទីទៅខាងលិច ខាងកើត ខាងជើង
ហើយខាងត្បូង[អ] គ្រប់ទាំងគ្រួសារនៅផែនដីនឹងបានពរ
ដោយសារឯងនឹងពូជឯង[ក] ១៥មើល អញនៅជាមួយនឹង
ឯង[ខ] អញនឹងថែរក្សាឯង[គ,ឃ]នៅកន្លែងណាដែលឯងទៅ[ង]
ហើយ និងនាំឯងមកក្នុងស្រុកនេះវិញ[ច] ពីព្រោះអញមិន
ចោលឯងឡើយ[ឆ] ទាល់តែអញបានធ្វើសំរេចសេចក្តីដែល
អញបានប្រាប់ឯងហើយ[ជឈ] ។
១៦នោះយ៉ាកុបគាត់ភ្ញាក់ពីដេកឡើង[ញ] ក៏នឹកក្នុងចិត្តថា
ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់គង់នៅទីនេះហើយ តែអញ
មិនបានដឹងទេ ១៧គាត់ក៏នឹកភ័យ ហើយនិយាយថា ទីកន្លែង
នេះ[ដ]គួរឱ្យស្ញែងខ្លាចណាស់ ទីនេះមិនមែនជាអ្វីទេ គឺជា
ដំណាក់នៃព្រះ[ឋ]ហើយជាទ្វារស្ថានសួគ៌ពិត ១៨លុះព្រឹក
ឡើងយ៉ាកុបក្រោកពីព្រលឹម ក៏យកថ្មដែលគាត់បានកើយ
កើយនោះ[ឌ]បញ្ឈរឡើងធ្វើជាបង្គោល[ឍ] រួចចាក់ប្រេងពី
លើ[ណ] ១៩គាត់ដាក់ឈ្មោះទីនោះថា បេត–អែល[ត] តែពីដើម

**២៨:៥** ឋ លប ១១:៣១ ឌ ហស ១២:១២ ឍ លប ២៥:២០ ណ លប ២៤:២៩ **២៨:៦** ត ខ.១ **២៨:៨** ថ លប ១០:១៥–១៩ ទ លប ២៦:៣៥ **២៨:៩** ធ លប ១៦:១៥ ន លប ២៥:១៣ ប លប២៦:២៤ **២៨:១០** ផ លប ២១:១៤ ព លប ១១:២១ **២៨:១១** ភ លប ១២:៨ ម ខ.១៨ **២៨:១២** យ លប ២០:៣ ៣៧:១៩ រ យហ ១:៥១ **២៨:១៣** ល លប ១២:៧ ៣៥:៧,៩ ៤៨:៣ វ លប ២៤:១២ ៤៨:១៦ ៤៩:២៥ ៥០:១៧ ស លប ១២:៧ ហ លប ៤៦:៤ ៤៨:២១ **២៨:១៤** ឡ លប ២៦:៤ អ លប ១២:២ ១៣:១៤ ២៦:២៤ ក លប ១២:៣ កច ៣:២៥ កទ ៣:៨ **២៨:១៥** ខ លប ២១:២០ គ ទដ ១២១:៥,៧–៨ ឃ ខ.២០ ង ខ.២២ លប ៣៥:៣ ច ខ.២១ លប ១៥:១៦ ៣០:២៤ ៣១:៣០ ឆ ចទ ៣១:៦,៨ យស ១:៥ នហ ៤:១៤ ទដ ៩:១០ ជ លវ ២៦:៤២ ឈ ទដ ១០៥:១០ **២៨:១៦** ញ ១ពវ៣:១៥ យរ ៣១:២៦ **២៨:១៧** ដ នក ៣:៥ ១៩:២១ យស ៥:១៥ ទដ ៦៨:២៤,៣៥ ឋ លប ៣២:២ ១របា ២២:១ ២រប ៣:១ **២៨:១៨** ឌ ឍ ខ.២២ លប ៣១:១៣,៤៥,៥១ ៣៥:១៤ នក ២៤:៤ យស ២៤:២៦,២៧ អស ១៩:១៩ ណ លវ ៨:១១ យស ៤:៩ **២៨:១៩** ត លប ១២:៨

**២៨:៩** *មកធ្វើជាប្រពន្ធថែមទៀត* មើលក្នុង ២៦:៣៤ និងការពន្យល់ ។

**២៨:១០–២២** ការលេចមករបស់ព្រះយេហូវ៉ា គឺដើម្បីធ្វើការធានាអះអាងចំពោះយ៉ាកុបប្រហែលមុនពេលដែលគាត់ជិតចាកចេញពីទឹកដីដែលព្រះយេហូវ៉ាទ្រង់បានសន្យា ។ ព្រឹត្តិការណ៍ និងការលេចមករបស់ព្រះអង្គ គឺបានកើតឡើងនៅឯស្ទឹងយ៉ាបុក (៣២:២២–៣២) ។

**២៨:១១** *ថ្ម . . . កើយក្បាល* នៅសម័យបុរាណពិបាករកខ្នើយសម្រាប់កើយណាស់ (ឧ.នៅស្រុកអេស៊ីព្ទជាដើម) ជួនកាលគេយកលោហៈធាតុមកធ្វើជាខ្នើយសំរាប់កើយ ។ មនុស្សនាសម័យនោះ ពួកគេធ្លាប់ដេកនៅផ្ទាល់នឹងដីតែម្តងថែមទៀតផង ។

**២៨:១២** *ជណ្តើរ* មិនមែនជាជណ្តើរដែលមានជាកាំៗនោះឡើយវាដូចគ្នានឹងប៉មដែលនិយាយក្នុង ១១:៤ ដែរ ។ ពួកទេវតារបស់ព្រះឡើងចុះតាមជណ្តើរនោះគឺជាសញ្ញាមួយដែលនឹងបង្ហាញថា ព្រះយេហូវ៉ាទ្រង់ចង់ធ្វើជាព្រះរបស់យ៉ាកុប ។ ព្រះយេស៊ូវទ្រង់បានមានបន្ទូលទៅកាន់សិស្សរបស់ទ្រង់ថា "អ្នករាល់គ្នានឹងឃើញមេឃបើកចំហ និងពួកទេវតានៃព្រះហោះឡើងហោះចុះលើកូនមនុស្ស" (មើល យហ ១:៥១) ។ ព្រះយេស៊ូវទ្រង់គឺជាស្ពានដែលនាំយើងឆ្លងពីផែនដីឆ្ពោះទៅកាន់ឋានសួគ៌ (សូមមើល យហ ១៤:៦) គឺជាអ្នកសង្រួប សង្រួមរវាងព្រះ ហើយនិងមនុស្ស (សូមមើល ១ធថ ២:៥) ។

**២៨:១៣** *ព្រះយេហូវ៉ាក៏សណ្ឋិតនៅពីលើជណ្តើរ* នៅចុងបំផុតនៃជណ្តើររបស់ពួកអ្នករស់នៅតំបន់មេសូប៉ូតាមា គឺមានដូចជាកន្លែងទីសការៈមួយដែលគេប្រើសម្រាប់អធិស្ឋានដល់ព្រះគេ ។

**២៨:១៤** *ដូចជាធូលីដី* សូមមើល ១៣:១៦ ។ *គ្រប់ទាំងគ្រួសារនៅផែនដីនឹងបានពរដោយសារឯងនិងពូជឯង* គឺនិយាយឡើងវិញ ១២:៣ ។

**២៨:១៥** *អញនៅជាមួយនឹងឯង* មើល ២៦:៣ ។ *អញមិនចោលឯងឡើយ* មិនដូចជាព្រះរបស់ពួកលោកិយនោះឡើយ ពួកព្រះទាំងនោះស្ថិតនៅតែមួយកន្លែងហើយការពារនឹងគ្រប់គ្រងបានតែលើទឹកដីរបស់គេមួយផ្នែកប៉ុណ្ណោះ គឺព្រះយេហូវ៉ាជាព្រះនៃសេចក្តីពិតតែមួយព្រះអង្គ តាមការពារយ៉ាកុបជានិច្ចតាំងពីគាត់ចេញដំណើររហូតដល់ពេលត្រឡប់មកវិញ ។

**២៨:១៧** *ដំណាក់នៃព្រះហើយជាទ្វារស្ថាសួគ៌ពិត* ជណ្តើរដែលយ៉ាកុបបានឃើញនៅទីនេះវាមានទំនាក់ទំនងគ្នាទៅនឹងប៉មដែលពួកកូនចៅមេសូប៉ូតាមាបានសង់ឡើង (១១:៤,៩) ។

**២៨:១៨** *បង្គោល* ដើម្បីរំឭកពីការថ្វាយបង្គំ ឬបង្ហាញទំនាក់ទំនងរវាងព្រះ ហើយនិងមនុស្សដែលគេតែងតែធ្វើនៅសម័យបុរាណ ។ ចាក់ប្រេងពីលើគេធ្វើឡើងដើម្បីប្រសិទ្ធវា (នក ៣០:២៥–២៩) ។

មកទីក្រុងនោះហៅលូសទេ[ថ] ។
២០ យ៉ាកុបក៏បន់[ទ]ថា "បើព្រះទ្រង់គង់ជាមួយនឹងទូលបង្គំ
ហើយរក្សាទូលបង្គំ[ធ]តាមផ្លូវដែលដើរទៅនេះ ព្រមទាំង
ប្រទានអាហារឱ្យទូលបង្គំបានទទួលទាន និងសំលៀក
បំពាក់ផង[ន] ២១ ហើយបើឱ្យទូលបង្គំបានត្រឡប់ទៅដល់ផ្ទះ
ឪពុកទូលបង្គំវិញ[ប]ដោយសុខសាន្ត[ផ] នោះទូលបង្គំនឹងយក
ព្រះយេហូវ៉ាទុកជាព្រះនៃទូលបង្គំពិត[ព] ២២ ឯថ្មដែលទូលបង្គំ
បានបញ្ឈរទុកជាបង្គោលនេះ[ភ] នោះនឹងបានជាដំណាក់នៃ
ព្រះ[ម] ហើយទូលបង្គំនឹងថ្វាយទ្រង់១ភាគក្នុង១០ ពីគ្រប់ទាំង
របស់ដែលទ្រង់ប្រទានមកទូលបង្គំដែរ[យ]" ។

## លោកយ៉ាកុបមកដល់ប៉ាដាន់–អើរ៉ាម

**២៩** ១ យ៉ាកុបក៏ដើរដំណើរ ទៅដល់ស្រុករបស់ពួកមនុស្ស
ពីទិសខាងកើត[ក] ២ គាត់ក្រឡេកមើលទៅឃើញអណ្តូង១នៅ
ទីវាល ក៏ឃើញមានចៀម៣ហ្វូងដេកនៅត្រង់នោះ ដ្បិតគេ
ធ្លាប់តែឱ្យហ្វូងសត្វផឹកទឹកនៅទីអណ្តូងនោះ[ខ] តែថ្ម[គ]ដែល
គ្របមាត់អណ្តូងធំណាស់ ៣ គេប្រមូលហ្វូងចៀមទាំងអស់មក
ទីនោះ នាំគ្នាប្រមៀលថ្មពីមាត់អណ្តូងចេញ[ឃ] ដងទឹកឱ្យ
ចៀមផឹក[ង] រួចយកថ្មគ្របមាត់អណ្តូងវិញ ។
៤ ឯយ៉ាកុបគាត់សួរគេថា បងប្អូនអើយ អ្នករាល់គ្នានៅ
ស្រុកណា[ច] គេឆ្លើយថា យើងនៅខារ៉ាន[ឆ] ៥ រួចគាត់សួរថា
អ្នករាល់គ្នាស្គាល់ឡាបាន់ ជាកូនណាឃរឬទេ[ជ] គេឆ្លើយថា
ស្គាល់ដែរ ៦ គាត់សួរថា គាត់សុខសប្បាយជាទេឬ គេក៏
ឆ្លើយថា ជាទេ នុ៎ះន៏ រ៉ាដែល[ឈ]ជាកូនគាត់កំពុងតែនាំចៀម
មក[ញ] ៧ យ៉ាកុបនិយាយថា ថ្ងៃនៅខ្ពស់នៅឡើយមិនមែនជា
វេលាឱ្យហ្វូងសត្វប្រជុំគ្នាទេ ចូរឱ្យវាផឹក ហើយនាំទៅឱ្យស៊ី
ទៀតទៅ ៨ តែគេឆ្លើយថា មិនកើតទេ ទាល់តែហ្វូងចៀម
ទាំងអស់បានមូលមកព្រម ហើយបានប្រមៀលថ្ម[ដ]ពីមាត់
អណ្តូងចេញ នោះទើបយើងដងទឹក[ឋ]ឱ្យចៀមផឹកបាន ។
៩ កាលគាត់កំពុងនិយាយនឹងគេនៅឡើយ នោះរ៉ាដែល
នាងនាំហ្វូងចៀមរបស់ឪពុកមកដល់[ឌ] ដ្បិតគឺនាងហើយ
ដែលជាអ្នកឃ្វាល ១០ កាលយ៉ាកុបក្រឡេកឃើញរ៉ាដែល[ឍ]
ជាកូនឡាបាន់ឪពុកធំគាត់ នោះគាត់ចូលទៅប្រមៀលថ្ម[ណ]
ពីមាត់អណ្តូងចេញ ហើយដងទឹក[ត]ឱ្យចៀមរបស់ឡាបាន់
ឪពុកធំផឹក[ថ] ១១ យ៉ាកុបក៏ថើបរ៉ាដែល[ទ] រួចឡើងសំឡេងយំ[ធ]
១២ នោះយ៉ាកុបប្រាប់រ៉ាដែលថា ខ្លួនជាបងប្អូន[ន] និងឪពុក
នាង គឺជាកូនរេបិកា[ប] រួចនាងក៏រត់ទៅប្រាប់ដល់ឪពុក[ផ]
១៣ កាលឡាបាន់[ព]បានឮនិយាយពីយ៉ាកុប ជាកូនរបស់ប្អូន
ខ្លួន នោះគាត់ក៏រត់ទៅទទួលហើយឱប[ភ]ថើប រួចនាំចូល
ទៅក្នុងផ្ទះ យ៉ាកុបក៏សាសព្ទសេចក្តីទាំងនោះប្រាប់ដល់
ឡាបាន់ ១៤ ឡាបាន់និយាយថា ឯងជាសាច់ឈាមរបស់អញ
ពិតមែន[ម] រួចយ៉ាកុបក៏នៅជាមួយនឹងគាត់១ខែ ។

ថ លប ៣៥:៦ ៤៨:៣ យស ១៦:២ ១៨:១៣ ពច ១:២៣,២៦ **២៨:២០** ទ លប ៣១:១៣ លវ ៧:១៦ ២២:១៨ ២៣:៣៨ ២៧:២,៩ ជន ៦:២ ១៥:៣ ចទ ១២:៦ ពច ១១:៣០ ១សយ ១:២១ ២សយ ១៥:៨ ធ ខ.១៥ ន ១ធថ ៦:៨ **២៨:២១** ប ខ.១៥ ផ ពច ១១:៣១ ព នក ១៥:២ ចទ ២៦:១៧ យស ២៤:១៨ ទដ ៤៨:១៤ ១១៨:២៨ **២៨:២២** ភ ខ.១៨ ១សយ ៧:១២ ម ខ.១៧ យ លប ១៤:២០ ជន ១៨:២១ លក ១៨:២១ **២៩:១** ក លប ២៥:៦ **២៩:២** ខ លប ២៤:១១ គ ខ.៣ ,៨,១០ **២៩:៣** ឃ ខ.២ ង ខ.៨ **២៩:៤** ច លប ៤២:៧ ពច ១៩:១៧

ឆ ពច ១១:៣១ **២៩:៥** ជ លប ១១:២៩ **២៩:៦** ឈ លប ៣០:២២–២៤ ៣៥:១៦ ៤៦:១៩,២២ ញ នក ២:១៦ **២៩:៨** ដ ខ.២ ឋ លប ២៤:១៣ **២៩:៩** ឌ នក ២:១៦ **២៩:១០** ឍ ខ.១៦ ណ ខ.២ ត លប ២៤:១១ ថ ខ.៣ នក ២:១៧ **២៩:១១** ទ ខ.១៣ ធ លប ៣៣:៤ ៤២:២៤ ៤៣:៣០ ៤៥:២,១៤–១៥ ៤៦:២៩ ៥០:១,១៧ នរ ១:៩ **២៩:១២** ន ខ.១៥ ប លប ២៤:២៩ ផ លប ២៤:២៨ **២៩:១៣** ព លប ២៤:២៩ ភ លប ៣៣:៤ ៤៥:១៤–១៥,១៤ ៤៨:១០ នក ៤:២៧ ១៨:៧ លក ១៥:២០ **២៩:១៤** ម លប ២:២៣ ៣៧:២៧ ពច ៩:២ ២សយ ៥:១ ១៩:១២–១៣ ២០:១ នហ ៥:៥ អស ៥៨:៧

**២៨:២១** *ទៅដល់ផ្ទះឪពុកទូលបង្គំវិញដោយសុខសាន្ត* ផ្នែកខ្លះបានសម្រេចនៅក្នុង ៣៣:១៨ ។ *នោះទូលបង្គំនឹងយកព្រះយេហូវ៉ាទុកជាព្រះនៃទូលបង្គំពិត* ពីដំបូងលោកយ៉ាកុបគាត់ត្រូវការពេលវេលា ដើម្បីពិចារណាដោយមានល័ក្ខខ័ណ្ឌ "បើសិនជា . . ." (ខ.២០) ហើយនិយាយដោយនូវព្រះនាមព្រះនៃលោកអ័ប្រាហាំ ហើយនិងអ៊ីសាក (មើល ខ.១៣ ២៧:២០) ថាជាព្រះរបស់គាត់ ។ លោកយ៉ាកុបគាត់ទទួលស្គាល់ព្រះក្នុងករណីដែលគាត់ត្រឡប់ពីហារ៉ាន់ហើយទៅដល់ផ្ទះឪពុកគាត់ដោយសេចក្តីសុខសាន្តប៉ុណ្ណោះ (មើល ៣៣:២០) ។

**២៨:២២** *ឯថ្ម . . . ជាតំណាក់នៃព្រះ* ការធ្វើដូច្នេះដើម្បីទុកជាទីរំឭកពីទំនាក់ទំនង លោកយ៉ាកុបគាត់បានជួបជាមួយព្រះនៅបេតអែល (មើល ខ.១៩) ។ *ទូលបង្គំនឹងថ្វាយ១ភាគក្នុង១០ពីគ្រប់ទាំងរបស់ដែលទ្រង់ប្រទានមកទូលបង្គំ* គឺជាការសំដែងពីការដឹងគុណចំពោះព្រះយេហូវ៉ាជាព្រះនៃគាត់ (១៤:២០) ។

**២៩:៥** *ឡាបាន់ជាកូនណាឃរ* មើល ២៤:១៥,២៩ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរគេនិយាយថា"ចៅ"។ ពាក្យ"កូន" គឺនិយាយសំដៅលើកូនចៅប្រុសៗ របស់គេទាំងអស់ទោះបីជាចៅក្តីជាកូនបង្កើតក្តី សូមមើល ១៤:២០ ។

**២៩:៩** *អ្នកឃ្វាល* គឺជាកិច្ចការងារទទួលខុសត្រូវថែរក្សាចៀម និងពពែរបស់មនុស្សសម័យមជ្ឈឹមបូព៌ា ។

**២៩:១០** *ប្រមៀលថ្មពីមាត់អណ្តូងចេញ* ថ្មនៅមាត់អណ្តូងនោះធំណាស់ (ខ.២) ដូច្នេះវាគឺជាកម្លាំងដ៏ខ្លាំងពូកែមួយ ដែលលោកយ៉ាកុបមានខុសប្លែកពីមនុស្សដទៃទៀត ។

**២៩:១១** *ឡើងសំលេងយំ* ដោយព្រោះតែពួកគេសប្បាយនិងរំភើបនៅពេលដែលពួកគេជួបគ្នា ។

**២៩:១៣** *ឱបថើប* គឺជាសញ្ញាណមួយដើម្បីបង្ហាញពីសេចក្តីស្រឡាញ់ដល់សាច់ញាតិរបស់ខ្លួនទោះជាប្រុសៗក៏ដោយ (មើល ៣៣:៤ នក ៤:២៧ រម ១៦:១៦ ១កថ ១៦:២០) ។

**២៩:១៤** *សាច់ឈាម* ទាំងក្នុងព្រះគម្ពីរភាសាហេព្រើរ និងព្រះគម្ពីរភាសាអង់គ្លេសគឺពាក្យនេះ មានន័យដូចគ្នាទេ ដោយគេចង់និយាយថា "ឆ្អឹងនិងសាច់" តែអ្វីដែលសំខាន់នោះ គឺចង់និយាយទៅលើពាក្យដែលថា "សាច់ឈាម"(ឧទាហរណ៍ មើល ក្នុង ២:២៣)។

## លោកយ៉ាកុបរៀបការជាមួយនាងលេអា និងនាងរ៉ាជែល

១៥ឡាបាន់និយាយទៅយ៉ាកុបថា តើត្រូវឱ្យឯងបំរើអញ
ទទេ ដោយព្រោះតែឯងជាបងប្អូន[យ] នឹងអញឬអី ចូរប្រាប់
អញចុះ តើឯងចង់បានឈ្នួលជាអ្វី [រ] ១៦រីឯឡាបាន់ គាត់
មានកូនស្រី២ កូនច្បងឈ្មោះ លេអា[ល] ហើយកូនពៅឈ្មោះ
រ៉ាជែល[វ] ១៧នាងលេអាមាន ភ្នែកទន់ឯរ៉ាជែល[ស]មានរូប
ឆោមលោមពណ៌ស្រស់បស់ល្អណាស់[ហ] ១៨ឯយ៉ាកុបគាត់
ចាប់ចិត្តស្រឡាញ់រ៉ាជែល[ឡ] ហើយក៏និយាយថា ខ្ញុំសូម
នៅបំរើឪពុកធំ៧ឆ្នាំ ដើម្បីឱ្យបានរ៉ាជែលជាកូនពៅរបស់
លោក[អ] ។

១៩ឡាបាន់តបថា អើ ដែលអញឱ្យវាដល់ឯង នោះល្អជា
ជាងឱ្យដល់គេ ដូច្នេះចូរនៅជាមួយនឹងអញចុះ ២០យ៉ាកុបក៏
ខំបំរើអស់៧ឆ្នាំ ដើម្បីឱ្យបានរ៉ាជែល[ក]តែនោះមើលទៅ
ដូចជាប្អូនដប់ថ្ងៃទេ ដោយព្រោះគាត់ស្រឡាញ់ដល់នាង
ណាស់[ខ] ។

២១រួចយ៉ាកុបនិយាយទៅឡាបាន់ថា សូមឱ្យប្រពន្ធខ្ញុំមក
ខ្ញុំពីព្រោះដល់កំណាត់ហើយ ដើម្បីឱ្យខ្ញុំបានចូលទៅឯ នាង[គ]
២២ឡាបាន់ក៏អញ្ជើញមនុស្សនៅទីនោះទាំងអស់មក ហើយ
រៀបជប់លៀងដល់គេ[ឃ] ២៣ដល់ពេលយប់ ឡាបាន់ ប្តូរយក
លេអា[ង]ជាកូនច្បងទៅឱ្យគាត់ នោះគាត់ក៏ចូលទៅឯនាង
២៤ឡាបាន់ឱ្យស៊ីលផា[ច] ជាបាវស្រីរបស់ខ្លួនបំរើដល់លេអា[ឆ]
២៥លុះព្រឹកឡើង នោះស្រាប់តែឃើញថាជានាងលេអាទេ
រួចយ៉ាកុបនិយាយទៅឡាបាន់ថា តើលោកឪពុកបានធ្វើអ្វី
ដល់ខ្ញុំដូច្នេះ[ជ] ក្រែងខ្ញុំបានបំរើលោកឪពុកនេះ ដើម្បីឱ្យ
បានតែរ៉ាជែលមែនឬមិនមែន ហេតុអ្វីបានជាបញ្ឆោតខ្ញុំ
ដូច្នេះ[ឈ] ២៦ឡាបាន់ឆ្លើយថា នៅស្រុកយើងនេះ គេមិន
ដែលឱ្យប្អូនមុនបងដូច្នោះទេ[ញ] ២៧ចូរឯងនៅគ្រប់១អាទិត្យ
នឹងនាងនេះសិន[ដ] រួចសឹមយើងឱ្យនាងនោះ ទៅឯង
ដែរទុកជាឈ្នួលការដែលឯងនឹងបំរើអញ៧ឆ្នាំទៀត[ឋ]
២៨យ៉ាកុបក៏ធ្វើដូច្នោះ គាត់នៅគ្រប់១អាទិត្យជាមួយនឹង
លេអារួចឡាបាន់ឱ្យរ៉ាជែលទៅធ្វើជាប្រពន្ធរបស់យ៉ាកុប
ទៀត[ឌ] ២៩ហើយឱ្យប៊ីលហា[ឍ]ជាបាវស្រីខ្លួនទៅបំរើរ៉ាជែល
ដែរ[ណ] ៣០យ៉ាកុបក៏ចូលទៅឯរ៉ាជែល ហើយស្រឡាញ់នាង
ជាងលេអា[ត] រួចគាត់នៅបំរើឡាបាន់៧ឆ្នាំទៀត[ថ] ។

## កូនរបស់លោកយ៉ាកុប

៣១ព្រះយេហូវ៉ាទ្រង់ឃើញថា យ៉ាកុបស្អប់លេអា[ទ]នោះ
ទ្រង់ប្រោសឱ្យនាងបង្កើតកូនបាន[ធ] តែរ៉ាជែលនាងមាន
ពោះអារវិញ ៣២លេអាក៏មានទំងន់បង្កើតបានកូនប្រុស១[ន]
ឱ្យឈ្មោះថារូបេន[ប] ដោយនឹកថា ព្រះយេហូវ៉ាទ្រង់បានទត
មើលសេចក្តីទុក្ខលំបាករបស់អញនេះហើយ[ផ] ឥឡូវនេះប្តី
អញនឹងស្រឡាញ់ដល់អញ ៣៣នាងមានទំងន់បង្កើតបានកូន

**២៩:១៥** យ ខ.១២ រ លប ៣០:២៨,៣២ ៣១:៧,៤១ **២៩:១៦** ល ខ.១៧,២៣,២៨,៣០ លប ៣០:៩ ៣៥:២៣ ៤៧:៣០ ៤៩:៣១ នរ ៤:១១ វ ខ.៩–១០ **២៩:១៧** ស ខ.១៦ ហ លប ១២:១១ **២៩:១៨** ឡ លប ២៤:៦៧ អ ខ.២០,២៧,៣០ លប ៣០:២៦ ហស ១២:១២ **២៩:២០** ក ខ.១៨ លប ៣១:១៥ ខ ៨:៧ ហស ១២:១២ **២៩:២១** គ ពច ១៥:១ **២៩:២២** ឃ ពច ១៤:១០ អស ២៥:៦ យហ ២:១–២ **២៩:២៣** ង ខ.១៦ **២៩:២៤** ច លប ៣០:៩ ឆ លប ១៦:១ **២៩:២៥** ជ លប ១២:១៨ ឈ លប ២៧:៣៦ **២៩:២៦** ញ ពច ១៥:២ ១សយ ១៤:៤៩ ១៨:១៧,២០ ២សយ ៦:២៣ **២៩:២៧** ដ ពច ១៤:១២ ឋ ខ.១៨ លប ៣១:៤១ **២៩:២៨** ឌ ខ.១៦ លប ៤:១៩ **២៩:២៩** ឍ លប ៣០:៣ ៣៥:២២ ៤៩:៤ ចទ ២២:៣០ ១របា ៥:១ ណ លប ១៦:១ **២៩:៣០** ត ខ.១៦ ថ ខ.២០ **២៩:៣១** ទ ខ.៣៣ ចទ ២១:១៥–១៧ ធ លប ១១:៣០ ១៦:២ នរ ៤:១៣ ១សយ ១:១៩ ទដ ១២៧:៣ **២៩:៣២** ន លប ៣០:២៣ នរ ៤:១៣ ១សយ ១:២០ ប លប ៣៧:២១ ៤៦:៨ ៤៨:៥,១៤ ៤៩:៣ នក ៦:១៤ ជន ១:៥,២០ ២៦:៥ ចទ ៣៣:៦ យស ៤:១២ ១រប ៥:១,៣ ផ លប ១៦:១១

**២៩:១៥** សំណួររបស់ឡាបាន់ និងផ្ទៃរឿងក្នុង ៣០:៤៣ គឺបញ្ជាក់ពីទម្រង់កូនចៅ និងពូជពង្សរបស់លោកយ៉ាកុបថា ពេលនេះពួកគេបានទទួលព្រះពរដែលលោកអ៊ីសាកបានឱ្យហើយ ។ សូមមើលពីព្រះពរដែលព្រះយេហូវ៉ាទ្រង់បានប្រទានឱ្យលោកយ៉ាកុបក្នុង ២៨:១៤ ។

**២៩:១៦** *លេអា . . . រ៉ាជែល* ឈ្មោះរបស់ពួកគេគឺមានន័យថា "មេគោ" ហើយនិង "ចៀមញី" ដែលឈ្មោះទាំងនេះសក្តិសមទៅនឹងក្រុមគ្រួសារអ្នកចិញ្ចឹមសត្វ ។

**២៩:២១** *ប្រពន្ធខ្ញុំ* បើសិនជាលោកយ៉ាកុបបាននិយាយថា "សូមឱ្យរ៉ាជែល" មកខ្ញុំនោះប្រហែលជាលោកឡាបាន់មិនអាចរកហេតុផលដោះសារ ដើម្បីលើកនាង"លេអា"ឱ្យគាត់នោះឡើយ ។

**២៩:២២** *រៀបជប់លៀង* ជាទូទៅក្នុងពិធីមង្គលការ គឺប្រព្រឹត្តទៅរយៈពេល៧ថ្ងៃ (មើល ខ.២៧–២៨ ពច ១៤:១០,១២) ។

**២៩:២៣** *ដល់ពេលយប់ . . . នោះគាត់ក៏ចូលទៅឯនាង* ងងឹតឬក៏ដោយសារតែនាងបាំងស្បៃនៅមុខ (២៤:៦៥) ដើម្បីកុំឱ្យលោកយ៉ាកុបបានស្គាល់ថាជានាងលេអាឡើយ ។

**២៩:២៤** មើល ខ.២៩ ។ ពួកបាប៊ីឡូនគេមានកិច្ចសន្យាធ្វើបែបនេះនៅពេលដែលពួកគេរៀបការ ។

**២៩:២៥** *លោកបញ្ឆោតខ្ញុំ* ឈ្មោះរបស់លោកយ៉ាកុបមានន័យថា "បញ្ឆោត" (២៥:២៦ ២៧:៣៦) ហើយគាត់ក៏ជាអ្នកបញ្ឆោតខ្លួនឯងដែរ (២៧:៣៦) ។ គាត់គឺជាមនុស្សម្នាក់បានធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីឱ្យបានផលពីកូនច្បង ប៉ុន្តែឥឡូវនេះបែរជាមិនបានទៅវិញ ដោយជិទាស់នឹងបំណងចិត្តរបស់គាត់ថែមទៀតគាត់ត្រូវតែទទួលយកកូនច្បងមុន (ខ.១៦,២៦) ។

**២៩:២៨** *រួចឡាបាន់ឱ្យរ៉ាជែលទៅធ្វើជាប្រពន្ធរបស់យ៉ាកុបទៀត* ពីមុនលោកយ៉ាកុបគាត់បានបម្រើ៧ឆ្នាំម្តងហើយ (ខ.៣០) ។

**២៩:៣១–៣៥** ទោះបីជាលោកយ៉ាកុបមិនស្រឡាញ់នាងលេអាយ៉ាងណាក៏ដោយ ពេលនេះនាងបានបង្កើតកូន៤នាក់ឱ្យយ៉ាកុបគឺលេវីជាពូជសង្ឃក្នុងអំបូរអើរ៉ុន យូដាជាវង្សាដាវីឌ និងព្រះយេស៊ូវ ។

**២៩:៣២** *ឱ្យឈ្មោះថា រូបេនដោយនឹកថាព្រះយេហូវ៉ាទ្រង់ទតមើលសេចក្តីទុក្ខលំបាករបស់អញនេះ* ហើយអ៊ីសម៉ាអែលបានទទួលឈ្មោះប្រហាក់ប្រហែលគ្នាក្នុងស្ថានការណ៍បែបនេះដែរ (១៦:១១) ។

ប្រុស១ទៀត ហើយនឹកថា ព្រះយេហូវ៉ាទ្រង់បានឮថាគាត់
ស្អប់អញ[ព] បានជាទ្រង់ប្រទានកូននេះមកអញទៀត" នាងឱ្យ
ឈ្មោះថា ស៊ីម្មាន[ភ] ៣៤រួចនាងមានទំងន់បង្កើតបានកូន
ប្រុស១ទៀត នោះនាងគិតថា ឥឡូវប្ដីអញមុខជាចូលចិត្ត
នឹងអញម្ដងណេះហើយ[ម] ដ្បិតអញបានបង្កើតកូនប្រុស៣
ឱ្យគាត់" ដូច្នេះនាងក៏ឱ្យឈ្មោះថា លេវី[យ] ៣៥នាងមានទំងន់
បង្កើតបានកូនប្រុស១ទៀតហើយនាងគិតថា ម្ដងណេះ
អញនឹងសរសើរដល់ព្រះយេហូវ៉ា ដោយហេតុនោះបាន
ជានាងឱ្យឈ្មោះថា យូដា[រ] នោះនាងក៏ផ្អាកមានកូនទៅ[ល]។

**៣០** ១កាលរ៉ាជែលឃើញថា ខ្លួនមិនបានបង្កើតកូនឱ្យយ៉ា
កុបសោះ[ក] នោះនាងមានចិត្តច្រណែននឹងបង[ខ] ហើយក៏
និយាយទៅយ៉ាកុបថា ចូរឱ្យខ្ញុំមានកូនផង បើមិនដូច្នោះខ្ញុំ
ស្លាប់ហើយ ២នោះយ៉ាកុបក៏នឹកក្ដៅចិត្តនឹងរ៉ាជែល ហើយ
តបថា តើអញជាព្រះឬអី[គ] ដែលបានបង្ខាំងមិនឱ្យឯងមាន
កូនដូច្នេះ[ឃ] ៣នោះនាងនិយាយថា មើលនុ៎ះន៍ ប៊ីលហា[ង] ជា
បាវស្រីខ្ញុំ[ច] សូមឱ្យអ្នកចូលទៅឯវាចុះ ដើម្បីឱ្យវាបានបង្កើត
កូនដាក់នៅភ្លៅខ្ញុំ នោះខ្ញុំនឹងបានកូនដោយសារវា[ឆ] ៤នាង
ក៏ឱ្យប៊ីលហាជាបាវស្រីទៅធ្វើជាប្រពន្ធយ៉ាកុប[ជ] ហើយគាត់
ចូលទៅឯនាង[ឈ] ៥ដូច្នេះប៊ីលហាមានទំងន់បង្កើតបានកូន
ប្រុស១ឱ្យយ៉ាកុប ៦នោះរ៉ាជែលគិតថា ព្រះទ្រង់បានជំនុំ
ជំរះអញ[ញ] ហើយបានឮសំឡេងអញ ព្រមទាំង ឱ្យអញមាន
កូនប្រុស១[ដ] នាងក៏ឱ្យឈ្មោះថា ដាន់[ឋ] ៧រួចប៊ីលហា[ឌ]ជា
បាវរ៉ាជែលមានទំងន់បង្កើតបានកូនប្រុស១ទៀតឱ្យយ៉ាកុប
៨ហើយរ៉ាជែលនឹកថា អញបានប្រណាំងនឹងបងអញជាខ្លាំង
ហើយ ក៏បានឈ្នះផង[ឍ] នាងឱ្យឈ្មោះថា ណែបថាលី ។
៩កាលលេអា[ណ]ឃើញថាខ្លួនមិនមានកូនទៀត[ត] នោះនាង
យកស៊ីលផា[ថ] ជាបាវស្រីរបស់នាង ឱ្យទៅធ្វើជាប្រពន្ធ
យ៉ាកុបដែរ[ទ] ១០ស៊ីលផា[ធ]បាវស្រីលេអាក៏បង្កើតបានកូន
ប្រុស១ ឱ្យយ៉ាកុប ១១នោះលេអានឹកថា មានសំណាំងហើយ
នាងក៏ឱ្យឈ្មោះថា កាឌ់[ប] ១២រួចស៊ីលផាបាវស្រីលេអាក៏
បង្កើតកូន ១ទៀតឱ្យយ៉ាកុប ១៣នោះលេអានឹកថា ខ្ញុំសប្បាយ
ណាស់ ហើយដ្បិតគ្រប់ទាំងស្ត្រីនឹងថា[ផ]ខ្ញុំមានពរ[ព] នាងក៏ឱ្យ
ឈ្មោះថា អេស៊ើរ[ភ] ។
១៤ឯរូបេនក៏ចេញទៅឯវាលនៅវេលាច្រូតស្រូវភោជ្ជ
សាលី[ម] ឃើញផ្លែស្នេហ៍[យ] រួចយកមកជូនដល់លេអាជា
ម្ដាយ នោះរ៉ាជែលនិយាយទៅលេអាថា សូមឱ្យផ្លែស្នេហ៍
របស់កូនបងខ្លះមកខ្ញុំផង ១៥តែលេអាឆ្លើយថា ដែលឯង
ដណ្ដើមយកប្ដីអញ នោះតើជាការស្រាលឬ[រ] បានជាឥឡូវ
ចង់យកផ្លែស្នេហ៍របស់កូនអញទៅទៀត រ៉ាជែលនិយាយ
ថា បើឱ្យផ្លែស្នេហ៍របស់កូនបងមកខ្ញុំ នោះឱ្យប្ដីយើងដេក
ជាមួយនឹងបងនៅយប់នេះចុះ[ល] ១៦ដល់ល្ងាចកាលយ៉ាកុប
វិលមកពីចំការវិញ នោះលេអាក៏ចេញទៅទទួលដោយ
ពាក្យថា អ្នកត្រូវអញ្ជើញចូលទៅឯខ្ញុំ ដ្បិតខ្ញុំបានជួលអ្នក
ដោយផ្លែស្នេហ៍របស់កូនខ្ញុំហើយ[វ] ដូច្នេះគាត់ក៏ដេកជាមួយ
នឹងនាងក្នុងយប់នោះទៅ ១៧ព្រះទ្រង់ក៏ស្ដាប់តាមលេអា[ស]

**២៩:៣៣** ព ខ.៣១ ភ លប ៣៤:២៥ ៤៦:១០ ៤៨:៥ ៤៩:៥ នក ៦:១៥ ជន ១:៦, ២២ ៣៤:២០ ១របា ៤:២៤ អគ ៤៨:២៤ **២៩:៣៤** ម លប ៣០:២០ ១សយ ១:២–៤ យ លប ៣៤:២៥ ៤៦:១០ ៤៨:៥ ៤៩:៥ នក ៦:១៥ ជន ១:៦,២២ ៣៤:២០ ១របា ៤:២៤ អគ ៤៨:២៤ **២៩:៣៥** រ លប ៣៥:២៣ ៣៧:២៦ ៣៨:១ ៤៣:៨ ៤៤:១៤ ,១៨ ៤៦:១២ ៤៩:៨ ១របា ២:៣ ៤:១ អស ៤៨:១ មថ ១:២–៣ ល លប ៣០:៩ **៣០:១** ក លប ១១:៣០ អស ៥៩:២១ ៥៤:១ ខ លប ១៦:៤ លប ១៨:១៨ **៣០:២** គ លប ១១:៣០ អស ៥៩:២១ ៥៤:១ ឃ លប ១៦:៤ លវ ១៨:១៨ **៣០:៣** ង ខ.៧ លប ២៩:២៩ ច លប ២៤:១៦ ឆ លប ១៦:២ **៣០:៤** ជ ខ.៩,១៨ ឈ លប ១៦:៣–៤ **៣០:៦** ញ ទដ ៣៥:២៤ ៤៣:១ ដ ខ.២៣ លប ២១:២ នរ ៤:១៣ ១សយ ១:២០ ឋ លប ៤៦:២៣ ៤៩:១៦–១៧ ជន ២៦:៤២–៤៣ យស ១៩:៤០–៤៨ ពច ១:៣៤ ១៣:២ ១៨:២ យរ ៤:១៥ ៨:១៦ អគ ៤៨:១ **៣០:៧** ឌ ខ.៣ **៣០:៨** ឍ លប ៣២:២៨ ហស ១២:–៤ ណ លប ៣៥:២៥ ៤៦:២៤ ៤៩:២១ ជន ១:៤២ ២៦:៤៨ ចទ ៣៣:២៣ ពច ៤:៦ ៥:១៨ ១របា ៧:១៣ **៣០:៩** ត លប ២៩:១៦ ថ ២៩:៣៥ ទ ២៩:២៤ ធ ខ.៤ **៣០:១០** ន លប ៤៦:១៨ **៣០:១១** ប លប ៣៥:២៦ ៤៦:១៦ ៤៩:១៩ នក ១:៤ ជន ១:២៤ ២៦:១៨ យស ៤:១២ ១របា ៥:១១ ១២:៨ យរ ៤៩:១ **៣០:១៣** ផ ទដ ១២៧:៣ ព នរ ៤:១៤ ទដ ១២៧:៤–៥ លក ១:៤៨ ភ លប ៣៥:២៦ ៤៦:១៧ ៤៩:២០ ជន ១:៤០ ២៦:៤៧ ចទ ៣៣:២៤ យស ១៩:២៤–៣១ ១របា ៧:៣០–៣១ **៣០:១៤** ម នក ៣៤:២២ ពច ១៥:១ នរ ២:២៣ ១សយ ៦:១៣ ១២:១៧ យ ខ.១៥,១៦ ៧:១៣ **៣០:១៥** រ ជន ១៦:៩,១៣ អស ៧:១៣ អគ ៣៤:១៨ ល លប ៣៨:១៦ អគ ១៦:៣៣ ហស ៩:១ **៣០:១៦** វ ខ.១៤ **៣០:១៧** ស លប ២៥:២១

**៣០:១** *នាងមានចិត្តច្រណែននឹងបង* ដូចគ្នានឹងលោកយ៉ាកុបគាត់បានច្រណែនជាមួយបងប្រុសរបស់ខ្លួនដែរ ។ *ចូរឱ្យខ្ញុំមានកូនផងបើមិនដូច្នោះទេខ្ញុំស្លាប់ហើយ* គឺជាពាក្យសំដីប្រកបដោយសេចក្ដីទុក្ខលំបាក (មើល ៣៥:១៦–១៩) ។

**៣០:២** *តើអញជាព្រះឬអី . . .* ជានិច្ចកាលលោកយ៉ាកុបគាត់តែងតែខិតខំធ្វើការងារដោយខ្លួនឯង ដើម្បីឱ្យបានព្រះពរ តែពេលនេះគាត់ទទួលស្គាល់ថាព្រះគឺជាអ្នកប្រទានពរទៅវិញ (៣១:៧,១៣ ព្រះបានប្រទានឱ្យគាត់មានហ្វូងសត្វជាច្រើន) ។ ក្រោយមកទៀតលោកយ៉ូសែប ក៏បាននិយាយពាក្យបែបនេះដែរ (៥០:១៩) ។

**៣០:៣** *សូមឱ្យអ្នកចូលទៅឯវាចុះ* មើលក្នុង ខ.៩ ១៦:២ និងការពន្យល់ ។ *ដើម្បីឱ្យវាបង្កើតកូនដាក់លើភ្លៅខ្ញុំ* ប្រហែលចង់និយាយថាទុកជារបស់ខ្លួន (៤៨:១០–១៦) ឬមួយ "ជារបស់ខ្ញុំ" (មើល ៥០:២៣ និងការពន្យល់) ។

**៣០:៤** *ធ្វើជាប្រពន្ធ* គឺជាប្រពន្ធចុង (៣៥:២២) ។

**៣០:៥–១២** កូនទី៥ ទី៦ ទី៧ នឹងទី៨ របស់លោកយ៉ាកុបគឺសុទ្ធតែកើតពីប្រពន្ធចុងទាំង២របស់គាត់ ។

**៣០:១៤** *សូមឱ្យផ្លែស្នេហ៍របស់កូនបងខ្លះមកខ្ញុំផង* ផ្លែស្នេហ៍នោះគឺមានសាច់ឫសជាចំពាមប្រហាក់ប្រហែលនឹងរូបកាយរបស់មនុស្ស ហើយគេមានជំនឿថាបើកាលណាបរិភោគនឹងឱ្យគេមានកូនបាន (មើល បស ៧:១៣) នាងរ៉ាជែលក៏ដូចជាយ៉ាកុបដែរ (ខ.៣៧–៤៣) ពួកគេសុទ្ធតែព្យាយាមចង់បានអ្វីដែលនាងរ៉ាជែលចង់បានតាមរយៈ អំណាចមកពីក្រៅ ។

**៣០:១៦** *ជួល* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះគឺជាងារដែលបានដាក់ឱ្យឈ្មោះ អ៊ីសាខា (ខ.១៨) ។

ហើយនាងមានទំងន់បង្កើតបានកូនប្រុសទី៥ឱ្យយ៉ាកុប
១៨នោះលេអាគិតថា ព្រះទ្រង់បានប្រទានរង្វាន់មកអញពី
ព្រោះអញបានឱ្យបាវស្រីទៅប្ដីហើយ[ហ] រួចនាងឱ្យឈ្មោះ
ថា អ៊ីសាខារ[ឡ] ១៩នាងក៏មានទំងន់ទៀត បង្កើតបានកូនប្រុស
ទី៦ឱ្យយ៉ាកុប ២០នោះនាងគិតថា ព្រះទ្រង់បានប្រទាន
អំណោយទានយ៉ាងល្អមកអញ ម្ដងណេះប្ដីអញនឹងនៅជា
មួយនឹងអញ[អ] ដោយព្រោះអញបានបង្កើតកូន៦ឱ្យគាត់
ហើយ រួចនាងឱ្យឈ្មោះថា សាប់យូល៉ូន[ក] ២១ក្រោយនោះ
មក នាងបង្កើតបានកូនស្រី១ ក៏ឱ្យឈ្មោះថា ឌីណា[ខ]។
២២ព្រះទ្រង់នឹកចាំពីរ៉ាជែល[គ] ក៏ស្ដាប់តាមនាង[ឃ] ហើយ
ប្រោសឱ្យនាងបង្កើតកូនបាន[ង] ២៣នោះនាងមានទំងន់បង្កើត
បានកូនប្រុស១[ច] រួចនាងគិតថា ព្រះទ្រង់បានដកសេចក្ដី
ដំនៀលពីអញចេញ[ឆ] ២៤ហើយនាងឱ្យឈ្មោះថា យ៉ូសែប[ជ]
ដោយថា សូមព្រះយេហូវ៉ាបន្ថែមឱ្យខ្ញុំម្ចាស់មានកូន១
ទៀត[ឈ]។

## ហ្វូងសត្វរបស់លោកយ៉ាកុបកើនឡើង

២៥កាលរ៉ាជែលសំរាលបានយ៉ូសែបហើយ នោះយ៉ាកុប
និយាយទៅឡាបាន់ថា ខ្ញុំសូមលា[ញ]លោកឪពុកត្រឡប់ទៅ
ឯទីកន្លែងខ្ញុំ ឯស្រុកខ្ញុំវិញហើយ[ដ] ២៦សូមឱ្យប្រពន្ធកូនរបស់
ខ្ញុំ ដែលខ្ញុំបានបំរើលោកឪពុកឱ្យបាននេះ[ឋ] បានទៅជាមួយ
នឹងខ្ញុំផង ដ្បិតលោកឪពុកជ្រាបការដែលខ្ញុំបានធ្វើជូនរួច
ហើយ ២៧នោះឡាបាន់ឆ្លើយថា បើសិនជាឯងចូលចិត្តនឹង
អញ[ឌ]នោះកុំអាលទៅសិន ពីព្រោះអញយល់ឃើញថា[ឍ] ព្រះ
យេហូវ៉ាបានប្រទានពរមកអញដោយព្រោះឯង[ណ] ២៨គាត់
ក៏និយាយថា ចូរគិតថ្លៃឈ្នួលឯងចុះ[ត] នោះអញនឹងបើកឱ្យ
២៩រួចយ៉ាកុបនិយាយថា លោកឪពុកជ្រាបហើយថា ខ្ញុំ
បាននៅបំរើលោកឪពុក[ថ] ហើយថា ហ្វូងសត្វលោកឪពុក
បានកើតសាយក្រោយជាយ៉ាងណា ក្នុងគ្រាដែលខ្ញុំបាន
ឃ្វាល[ទ] ៣០ដ្បិតមុនដែលខ្ញុំមក នោះលោកឪពុកមានតិច
ណាស់ ឥឡូវនេះវិញបានចំរើនកើនឡើងយ៉ាងសន្ធឹក ហើយ
ព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់លោកឪពុក ដោយ
សារខ្ញុំ[ធ] ឥឡូវនេះ តើចាំដល់កាលណាទៀតទើបឱ្យខ្ញុំផ្គត់
ផ្គង់ដល់គ្រួរបស់ខ្ញុំផង[ន] ៣១នោះឡាបាន់សួរថា តើចង់ឱ្យ
អញឱ្យអ្វីដល់ឯង យ៉ាកុបឆ្លើយថា មិនត្រូវឱ្យអ្វីមកខ្ញុំសោះ
បើលោកឪពុកនិងធ្វើដូច្នេះ នោះខ្ញុំនិងនៅឃ្វាល ហើយថែ
រក្សាហ្វូងសត្វរបស់លោកឪពុកទៀត ៣២គឺខ្ញុំនឹងទៅក្នុងគ្រប់
ទាំងហ្វូងចៀមរបស់លោកឪពុកនៅថ្ងៃនេះ ដើម្បីនឹងញែក
យកអស់ទាំងសត្វពព្លាក់នឹងពពាល ហើយនិងសត្វខ្មៅទាំង
អស់ ក្នុងកូនចៀមទាំងប៉ុន្មាន ព្រមទាំងសត្វដែលពពាលព
ព្លាក់ ក្នុងហ្វូងពពែផង[ប] ឱ្យបានជាឈ្នួលដល់ខ្ញុំ[ផ] ៣៣ដូច្នេះ
ទៅមុខទៀត កាលណាលោកឪពុកចូលមកសាកសួរពី
ឈ្នួលខ្ញុំ នោះសេចក្ដីសុចរិតរបស់ខ្ញុំ នឹងសំដែងឱ្យឃើញ

**៣០:១៨** ហ ខ.៤ ឡ លប ៤៦:១៣ ៤៩:១៤ ជន ១:៨, ២៨,២៩ ២៦:២៥ ចទ ២៧:១២ ៣៣:១៨ យស ១៧:១០ ១៩:១៧ ២១:៦,២៨ ពច ៥:១៥ ១០:១ ១របា ៧:១ **៣០:២០** អ លប ២៩:៣៤ ១ពត ៣:៧ ក លប ៣៥:២៣ ៤៦:១៤ ៤៩:១៣ ជន ១:៣០ ២៦:២៧ ៣៤:២៥ ចទ ៣៣:១៨ ពច ៥:១៨ **៣០:២១** ខ លប ៣៤:១ ៤៦:១៥ **៣០:២២** គ លប ៨:១ ឃ លប ២៥:២១ ង លប ១១:៣០ **៣០:២៣** ច ខ.៦ លប ២៩:៣២ ឆ អស ៤:១ ២៥:៨ ៤៥:១៧ ៥៤:៤ លក ១:២៥ **៣០:២៤** ជ លប ២៩:៦ ៣២:២២ ៣៣:២,៧ ៣៥:២៤ ៣៧:២ ៣៩:១ ៤៩:២២–២៦ ចទ ៣៣:១៣ ឈ លប ៣៥:១៧ ១សយ ៤:២០ **៣០:២៥** ញ លប ២៤:៥៤ ដ លប ២៨:១៥ **៣០:២៦** ឋ លប ២៩:១៨ **៣០:២៧** ឌ លប ៣៣:១០ ៥០:៤ នអ ២:១៥ ឍ លប ៤៤:៥,១៥ លវ ១៩:២៦ ជន ២២:៧ ២៣:២៣ ២៤:១ យក ១៣:២២ ២ពរ ១៧:១៧ យរ ២៧:៩ ណ ខ.៣០ លប ២៦:២៤ ៣១:៣៨ ចទ ២៨:១១ ២សយ ៦:១១ **៣០:២៨** ត លប ២៩:១៥ **៣០:២៩** ថ លប ៣១:៦ ទ លប ៣១:៣៨–៤០ **៣០:៣០** ធ ខ.២៧ ន ១ធច ៥:៨ **៣០:៣២** ប ខ.៣៣,៣៥ ៣៩:៤០ លប ៣១:៨,១២ ផ លប ២៩:១៥

**៣០:១៧–២០** កូនទី៩ នឹងទី១០ របស់លោកយ៉ាកុបគឺកើតចេញពីនាងលេអា នាងជាម្នាក់ដែលមានកូន៦ ក្នុងចំណោមកូនទាំង១២នាក់ដែលលោកយ៉ាកុបមាន (សូមមើល ២៩:៣១–៣៥) ។

**៣០:២០** *ប្រទានអំណោយទានយ៉ាងល្អ* ពាក្យនេះក្នុងព្រះគម្ពីរភាសាហេព្រើរ គឺគេប្រើជាងារសម្រាប់ដាក់ឱ្យសាប់យូល៉ូន ។

**៣០:២១** *ឌីណា* មើលក្នុងជំពូក ៣៤ ។

**៣០:២២** *ព្រះទ្រង់នឹកចាំពីរ៉ាជែល* មើលក្នុង ៨:១ ។

**៣០:២៣** *សេចក្ដីដំនៀល* ភាពអារធ្វើឱ្យនាងមានសេចក្ដីខ្មាសហើយបង្ហាញថាព្រះទ្រង់មិនប្រណីដល់នាងឡើយ (មើលក្នុង ១៦:២ ៣០:២) ។

**៣០:២៤** *សូមព្រះយេហូវ៉ាបន្ថែមឱ្យខ្ញុំម្ចាស់មានកូន១ទៀត* ព្រះយេហូវ៉ាទ្រង់និងសម្រេចឱ្យនាងនៅមុនពេលដែលស្លាប់ (មើល ៣៥:១៦–១៩) ។

**៣០:២៦** *បានទៅជាមួយនឹងខ្ញុំផង* លោកយ៉ាកុបគាត់បានចប់កិច្ចការដែលគាត់បានសន្យានឹងប្ដេជ្ញាចិត្តហើយ ។ ជាមួយទ្រព្យដែលគាត់មានដោយមិនលើសមិនខ្វះជាមួយឡាបាន់ធ្វើឱ្យគាត់សុំការអនុញ្ញាតចាកចេញពីទីនេះ ដោយសុំឱ្យក្រុមគ្រួសារទៅជាមួយគាត់ ។ ក្រោយមកទៀតនៅពេលដែលគាត់ចាកចេញគាត់បានយកទាំងទ្រព្យសម្បត្តិជាច្រើនរបស់ឡាបាន់មកជាមួយដែរ (មើល ៣០:៤៣–៣១:១) ។

**៣០:២៧** *យល់ឃើញថា* ការព្យាយាមស្វែងយល់ពីចំណេះតាមរយៈកម្លាំងរបស់ខ្លួន (៤៥:៥) មានន័យថាជាប្រថ្នុលមួយ (អគ ២១:២១) ឬជាអំណាចធម្មជាតិ (កច ១៦:១៦) ។ ការនេះត្រូវបានហាមឃាត់សម្រាប់អ៊ីស្រាអែល (លវ ១៩:២៦ ចទ ១៨:១០,១៤) ពីព្រោះវាបានគិតចំពោះពួកអ្នកមិនជឿលើព្រះគេនិយាយថាពិភពលោកគ្រប់គ្រងដោយវិញ្ញាណអាក្រក់ ដូច្នេះហើយគេមិនគិតថាព្រះជាអ្នកគ្រប់គ្រងឡើយ ។ ព្រះយេហូវ៉ាទ្រង់បានប្រទានពរមកអញដោយព្រោះអញដូចអ្វីដែលព្រះយេហូវ៉ាទ្រង់បានសន្យាជាមួយយ៉ាកុបនៅបេតអែល (២៨:១៤) ហើយដោយពឹងផ្អែកលើសេចក្ដីសន្យាដែលព្រះបានសន្យាជាមួយលោកអ័ប្រាហាំ (១២:២ និង ២២:១៨ ៣៩:៥, ២៣ ៤១:៤១–៥៧) ។

**៣០:៣២** ចៀមភាគច្រើនគឺតែងតែមានពណ៌សហើយពពែមានពណ៌ខ្មៅ ដូច្នេះលោកយ៉ាកុបបានជ្រើសរើសយកប្រាក់ខែរបស់គាត់ ដោយយកចៀមពណ៌ខ្មៅហើយពពែណាមានពណ៌សវិញដែលជាប្រាក់ខែដ៏ច្រើនបំផុត ។

ច្បាស់ដូច្នេះ គឺបើមានសត្វណានៅជាមួយនឹងខ្ញុំ ដែលមិន
ពពាលពព្លាក់ក្នុងហ្វូងពពែ ហើយដែលមិនខ្មៅក្នុងហ្វូង
ចៀម[ព] នោះនឹងរាប់ទុកជារបស់លួច[ភ] [៣៤]ឡាបាន់ក៏និយាយ
ថា អើ ចូរតាមពាក្យឯងចុះ [៣៥]ហើយនៅថ្ងៃនោះឯង
ឡាបាន់ក៏បានញែកពពែឈ្មោលឆ្នូតៗ ហើយពពាលនិង
អស់ទាំងពពែញីដែលពព្លាក់ហើយពពាល គ្រប់ទាំងសត្វ
ដែលមានសម្បុរសដុំៗ និងអស់ទាំងសត្វខ្មៅក្នុងហ្វូងចៀម
ទាំងអស់[ម] ប្រគល់ទៅក្នុងកណ្ដាប់ដៃរបស់កូនខ្លួនទាំង
ប៉ុន្មាន[យ] [៣៦]រួចគាត់ចេញពីយ៉ាកុបទៅចំងាយដើរ ផ្លូវអស់
៣ថ្ងៃ[រ] ឯយ៉ាកុបក៏ឃ្វាលហ្វូងសត្វរបស់ឡាបាន់ដែលនៅ
សល់នោះ ។

[៣៧]នោះយ៉ាកុបគាត់យកមែករលួស ចំបក់[ល] និងក្រចៅ[វ]
ស្រស់ មកក្រើបកសំបកជាកង់ៗ ឱ្យឃើញសាច់ស[ស] [៣៨]ហើយ
ដាក់មែកដែលគាត់បានបកនោះ[ហ] នៅក្នុងប្រឡាយនឹងស្នូក[ឡ]
ជាកន្លែងដែលសត្វមកផឹកទឹក ហើយវាក៏ជាន់គ្នា[អ] ក្នុងកាល
ដែលសត្វវាមកផឹកនោះ [៣៩]គឺជាន់គ្នានៅត្រង់មុខមែកឈើ
ទាំងនោះ[ក] នោះក៏បង្កើតកូនមកមានឆ្នូត មានពព្លាក់ មាន
ពពាល[ខ] [៤០]រួចយ៉ាកុបញែកចៀមចេញពីគ្នា ក៏ដំរង់ឈ្មោល
ទៅឯពួកចៀមឆ្នូត នឹងចៀមខ្មៅទាំងអស់[គ] ក្នុងហ្វូងសត្វ
របស់ឡាបាន់វិញ តែបានបង្ខាំងហ្វូងសត្វរបស់ឡាបាន់
ឡើយ [៤១]កាលបើសត្វណាដែលខ្លាំងចង់ជាន់គ្នា[ឃ] នោះ
យ៉ាកុបតែងតែទៅដាក់មែកឈើនោះនៅក្នុងប្រឡាយ ចំពី
មុខវា ដើម្បីឱ្យបានជាន់គ្នានៅត្រង់មុខមែកឈើនោះចុះ[ង]
[៤២]តែចំណែកឯសត្វណាដែលខ្សោយវិញ នោះគាត់មិន
ដាក់មែកឈើនោះទេ ហេតុនោះបានជាសត្វណាដែល
ខ្សោយៗជារបស់ផងឡាបាន់ ហើយសត្វណាដែលខ្លាំងៗជា
របស់ផងយ៉ាកុបទាំងអស់[ច] [៤៣]ដូច្នេះគាត់ក៏បានចំរើនឡើង
យ៉ាងសន្ធឹក គាត់មានហ្វូងសត្វជាច្រើន និងបាវប្រុសបាវស្រី
ព្រមទាំងអូដ្ឋហើយនិងលាដែរ[ឆ] ។

**លោកយ៉ាកុបគេចពីលោកឡាបាន់**

**៣១** [១]រួចមកគាត់បានឮពាក្យរបស់ពួកកូន[ក] ឡាបាន់
និយាយគ្នាថាយ៉ាកុបបានចូលលួចរបស់ទ្រព្យឪពុកយើងទាំ
ង អស់ហើយ គឺពីរបស់ឪពុកយើងទេតើដែលវាបានទៅជា
មានដូច្នេះ[ខ] [២]ហើយយ៉ាកុបមើលមុខឡាបាន់ឃើញថា មិន
សូវស្រួលចំពោះខ្លួនដូចពីដើមទេ[គ] [៣]ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលនឹងយ៉ាកុបថា ចូរឯងវិលត្រឡប់ទៅ[ឃ] ក្នុងស្រុកឪពុក

**៣០:៣៣** ព ខ.៣២ ភ លប ៣១:៣៩
**៣០:៣៥** ម ខ.៣២ យ លប ៣១:១
**៣០:៣៦** រ លប ៣១:២២ នក ៣:១៨ ៥:៣ ៨:២៧
**៣០:៣៧** ល យរ ១:១១ វ អគ ៣១:៨ ស ខ.៣៨,៤១
**៣០:៣៨** ហ ខ.៣៧ ឡ នក ២:១៦ អ ខ.៤១ យរ ២:២៤
**៣០:៣៩** ក ខ.៤១ ខ ខ.៣២
**៣០:៤០** គ ខ.៣២
**៣០:៤១** ឃ ខ.៣៨ ង ខ.៣៧
**៣០:៤២** ច លប ៣១:១,៩,១៦,៤៣
**៣០:៤៣** ឆ លប ១២:១៦
**៣១:១** ក លប ៣០:៣៥ ខ លប ៣០:៤២

**៣១:២** គ ខ.៥ **៣១:៣** ឃ ខ.១៣ លប ៣២:៩ ចទ ៣០:៣ អស ១០:២១ ៣៥:១០ យរ ៣០:៣ ៤២:១២ ង លប ២១:២២ ២៦:៣

**៣០:៣៥** *ញែក* លោកឡាបាន់បានញែកចេញដោយសម្ងាត់ហើយមិនបាន ប្រាប់យ៉ាកុបឡើយ ។

**៣០:៣៦** ហ្វូងសត្វរបស់ឡាបាន់ដែលនៅសល់ឥឡូវនេះ គាត់បានដូរហើយ នៅសល់តែចៀមពណ៌ស និងពពែទាំងអស់ពណ៌ខ្មៅ ។

**៣០:៣៧** *រលួស . . . ឃើញសាច់ស* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះ ប្រើសម្រាប់និយាយអំពីឡាបាន់ ។ ដូចជាយ៉ាកុបគាត់បានទទួលការល្អពី អេសាវដែរ ដែលមានឈ្មោះផ្សេងជាអេដំមដែលមានន័យថា "ក្រហម" (មើល ២៥:២៥) តាមរយៈអត្ថន័យពីអំបោះក្រហមនេះ (២៥:៣០) ដូច្នេះ ឥឡូវនេះគាត់ព្យាយាមយកអ្វីៗដែលល្អពីឡាបាន់ទៀតឈ្មោះគាត់មានន័យថា "ពណ៌ស" គឺដោយសារមែកឈើពណ៌ស ។ ពេលនេះយ៉ាកុបគាត់បានយក ល្បិចដែលឡាបាន់ប្រើជាមួយគាត់យកមកប្រើជាមួយឡាបាន់វិញ ។

**៣០:៣៩** គឺជាគម្រោងការណ៍មួយដែលបានរៀបចំជាមុន ប៉ុន្តែហេតុការណ៍ ទាំងអស់នោះ គឺជាព្រះយេហូវ៉ាទ្រង់ជាអ្នករៀបចំ (មើល ៣១:៩) មិនមែន ដោយសារតែភាពវៃឆ្លាតរបស់យ៉ាកុបនោះឡើយ ។

**៣០:៤៣** *គាត់ក៏ចំរើនឡើងយ៉ាងសន្ធឹក* រយៈពេល៦ឆ្នាំបន្ទាប់ពីគាត់បានបម្រើ ឡាបាន់១៤ឆ្នាំ ។ នៅក្នុងអំឡុងពេលដែលគាត់រស់នៅហារ៉ាន់ហើយដោយ សារយ៉ាកុបគាត់ព្យាយាមប្រឹងប្រែងធ្វើឱ្យគ្រួសារទាំង២នេះមានទ្រព្យសម្បត្តិ មហាសាល ។ ទ្រព្យសម្បត្តិរបស់គាត់បានមកដោយសារតែមនុស្សក្នុងតំបន់ ពាយព្យនៃតំបន់មេសូប៉ូតាមា ជាអ្នកឱ្យគាត់ដូចគ្នានឹងទ្រព្យរបស់លោក អ័ប្រាហាំ (១២:១៦) ទ្រព្យអ៊ីសាក (នក ១២:៣៦) ដែលបានមកពីស្រុក អេស៊ីព្ទមក (អយ ៦០:៥–១៦៧) ។

**៣១:១–៥៥** នៅពេលដែលលោកយ៉ាកុបគាត់ចាកចេញពីឡាបាន់ គាត់មាន ទ្រព្យសម្បត្តិប្រហាក់ប្រហែលគ្នា និងទ្រព្យសម្បត្តិរបស់ពួកអ៊ីស្រាអែលនៅ ពេលដែលគេចាកចេញពីអេស៊ីព្ទដែរ ការនេះដោយសារ (១) ការប្រទាន ពររបស់ព្រះយេហូវ៉ាចំពោះយ៉ាកុបបានដាស់ស្មារតីរបស់ឡាបាន់ នឹងកូនៗ របស់គាត់ដូចគ្នានិងព្រះយេហូវ៉ា ទ្រង់បានដាស់ស្មារតីពួកអេស៊ីព្ទព្រះចៅ ផារ៉ោនតាមរយៈព្រះពរដែលព្រះប្រទានឱ្យពួកអ៊ីស្រាអែលដែរ ។ (២) លោកយ៉ាកុបបានយកទ្រព្យសម្បត្តិជាច្រើន ដែលគាត់រកបានពីឡាបាន់ ដូចគ្នានឹងពួកអ៊ីស្រាអែលយកពីស្រុកអេស៊ីព្ទមកដែរ ។ (៣) នៅពេលដែល គាត់ធ្វើដំណើរមកលោកបានឆ្លងកាត់សមុទ្រអើប្រាតដូចគ្នានឹងពួកអ៊ីស្រា អែលឆ្លងកាត់សមុទ្រក្រហមដែរ ។ (៤) លោកឡាបាន់ គាត់បានដេញតាម លោកយ៉ាកុប ដូចគ្នានឹងពួកអ៊ីស្រាអែល ត្រូវបានពួកអេស៊ីព្ទដេញតាមដែរ ។ (៥) ព្រះយេហូវ៉ាទ្រង់ការពារយ៉ាកុប ដូចគ្នានិងព្រះការពារពួកអ៊ីស្រាអែល ផងដែរ ។

**៣១:១** *យ៉ាកុបបានចូលលួចរបស់ទ្រព្យឪពុកយើងទាំងអស់ហើយ* ក្នុងអំឡុង ពេលដែលកូនរបស់ឡាបាន់ជាអ្នកមើលហ្វូងសត្វដែលមានស្នាមអុជៗនោះ លោកយ៉ាកុប អាចមានហ្វូងសត្វដ៏ច្រើនបែបនោះដែរ ។

**៣១:៣** *ចូរឯងវិលត្រឡប់ទៅក្នុងស្រុកឪពុកឯង* សញ្ញាសំគាល់ទាំងអស់ លោកយ៉ាកុបបានទទួលពីប្រពន្ធរបស់គាត់ (មើល ខ.១៤,១៦) ពីឡាបាន់ (ខ.២) ហើយនិងកូនរបស់ឡាបាន់ (ខ.១) ហើយឥឡូវនេះព្រះយេហូវ៉ាទ្រង់ ជាអ្នកបង្ហាញផ្លូវឱ្យគាត់ទៀតថា ដល់ពេលដែលគាត់ចូលក្នុងទឹកដីកាណាន វិញហើយ ។ *អញនឹងនៅជាមួយនឹងឯង* មើល ២៦:៣ ។

ឯង ឯញាតិសន្តានឯងវិញទៅ នោះអញនឹងនៅជាមួយនឹង
ឯង[ង] ៤យ៉ាកុបគាត់ចាត់គេឱ្យទៅហៅរ៉ាជែលនិងលេអា
មកឯហ្វូងសត្វត្រង់ទីវាល ៥ប្រាប់ថា អញឃើញឫកពា
របស់ឪពុកឯង[ច] ហាក់ដូចជាមិនសូវស្រួលនឹងអញដូចពី
ដើមសោះ[ឆ] តែព្រះនៃឪពុកអញទ្រង់បានគង់នៅជាមួយនឹង
អញ[ជ] ៦ឯងក៏ដឹងថា អញបានបំរើឪពុកឯងអស់ពីកំឡាំង
ដែរ[ឈ] តែឪពុកឯងបានបញ្ឆោតអញ[ញ] ហើយបានបំផ្លាស់
ឈ្នួលរបស់អញ[ដ]១០ដងហើយ[ឋ] ៧តែព្រះទ្រង់មិនព្រមបើក
ឱកាសឱ្យគាត់ប្រទូស្តចំពោះអញទេ[ឌ] ៨កាលណាគាត់ថា
សត្វពពាលនឹងជាបានជាឈ្នួលឯង នោះពួកសត្វមេៗទាំង
អស់កើតកូនមកសុទ្ធតែពពាល បើកាលណាគាត់ថា សត្វ
ឆ្នូតនឹងបានជាឈ្នួលឯង[ឍ] នោះពួកមេៗទាំងអស់ក៏កើតកូន
មកសុទ្ធតែឆ្នូតដែរ ៩ដូច្នេះព្រះទ្រង់បានដកហ្វូងសត្វរបស់
ឪពុកឯង[ណ]ប្រទានមកឱ្យអញវិញហើយ[ត] ១០នៅរដូវដែល
សត្វធ្លាប់ជាន់គ្នា នោះអញនឹងងើបភ្នែកឡើងក្នុងសប្តិ[ថ]ថា
សត្វឈ្មោលដែលជាន់ញីវាមានឆ្នូត មានពពាល ហើយនិង
ប្រផេះ ១១នោះទេវតានៃព្រះយេហូវ៉ា[ទ]មានបន្ទូលមក
អញក្នុងសប្តិនោះ[ធ]ថា យ៉ាកុបអើយ អញទូលឆ្លើយថា
ព្រះករុណាវិសេសព្រះអម្ចាស់[ន] ១២នោះទ្រង់មានបន្ទូលថា
ចូរឯងងើបភ្នែកឡើង មើលទៅសត្វឈ្មោលទាំងប៉ុន្មាន
ដែលជាន់ញីនោះមានឆ្នូតមានពពាល ហើយប្រផេះ[ប]
ដ្បិតអញបានឃើញអស់ទាំងការ ដែលឡាបាន់បានធ្វើដល់
ឯង[ផ] ១៣អញជាព្រះនៃបេត-អែល[ព] ជាកន្លែងដែលឯង
បានចាក់ប្រេងលើបង្គោលនោះ[ភ,ម] ហើយដែលឯងបានបន់
ដល់អញឥឡូវនេះឱ្យរៀបចំ ហើយចេញពីស្រុកនេះ វិល
នៅឯស្រុកកំណើតឯងវិញទៅ[យ] ១៤ឯរ៉ាជែលនឹងលេអាក៏
ឆ្លើយទៅប្តីថា ចុះយើងនៅមានចំណែក ឬមរដក[រ]នៅក្នុង
ផ្ទះឪពុកយើងឯណា ១៥តើគាត់មិនរាប់យើងទុកដូចជាអ្នក
ដទៃទេឬអី[ល] ដ្បិតគាត់បានលក់យើងហើយស៊ីបង្ហិនប្រាក់
បណ្ណាការរបស់យើងអស់រលីងផង[វ] ១៦គ្រប់ទាំងរបស់
ទ្រព្យណាដែលព្រះបានដកពីឪពុកយើងមក នោះជារបស់
ផងយើងនិងកូនចៅយើងហើយ[ស] ដូច្នេះការអ្វីដែលព្រះ
បានបង្គាប់មកអ្នកសូមអ្នកធ្វើឥឡូវចុះ ។
១៧យ៉ាកុបក៏ក្រោកឡើង បញ្ជិះប្រពន្ធកូន[ហ]លើសត្វអូដ្ឋ[ឡ]
១៨នាំហ្វូងសត្វរបស់គាត់ទាំងអស់ និងទ្រព្យដែលបាន
ប្រមូលទាំងប៉ុន្មាន[អ] គឺជាហ្វូងសត្វដែលបានពីកាលនៅ
ប៉ាដាន់-អើរ៉ាម[ក] ដើម្បីទៅឯអ៊ីសាក[ខ] ឪពុកខ្លួននៅស្រុកកា
ណានវិញ[គ] ១៩រីឯឡាបាន់គាត់មានកិច្ចចេញទៅកាត់រោម
ចៀម[ឃ] ពេលនោះនាងរ៉ាជែលបានលួចយករូបព្រះទាំង
ប៉ុន្មានរបស់ឪពុក[ង] ២០ឯយ៉ាកុបគាត់ចេញទៅ[ច]ដោយលួច
លាក់ មិនបានប្រាប់[ឆ]ឱ្យឡាបាន់ជាសាសន៍អើរ៉ាម[ជ]ដឹងផង
ទេ ២១គាត់បាននាំយករបស់គាត់ទាំងអស់រត់ចេញទៅ[ឈ]
ក៏ឆ្លងកាត់ទន្លេ[ញ] ដំរង់ឆ្ពោះមុខទៅឯភ្នំកាឡាតទៅ[ដ] ។

**៣១:៥** ច ខ.២៩,៤២ ៥៣ លប ៤៣:២៣ ដយ ២:២៣ ឆ ខ.២ ជ លប ២១:២២ ២៦:៣ **៣១:៦** ឈ លប ៣០:២៩ ញ លវ ៦:២ អម ៨:៥ ដ លប ២៩:១៥ ឋ ខ.៤១ ជន ១៤:២២ យប ១៩:៣ **៣១:៧** ឌ ខ.៥២ លប ២៤:៥០ **៣១:៨** ឍ លប ៣០:៣២ **៣១:៩** ណ យប ៣៩:២ អគ ៣១:៦ ត លប ៣០:៤២ **៣១:១០** ថ លប ២០:៣ **៣១:១១** ទ លប ១៦:៧ ធ លប ២០:៣ ន លប ២២:១ នក ៣:៤ **៣១:១២** ប លប ៣០:៣២ ផ នក ៣:៧ **៣១:១៣** ព លប ២៨:១០-២២ ភ លប ២៨:១៨ ម លប ២៨:២០ យ ខ.៣ **៣១:១៤** រ ២សយ ២០:១ ១ពវ ១២:១៦

**៣១:១៥** ល ចទ ១៥:៣ ២៣:២០ នរ ២:១០ ២សយ ១៥:១៩ ១ពវ ៨:៤១ អប ១:១១ វ លប ២៩:២០ **៣១:១៦** ស លប ៣០:៤២ **៣១:១៧** ហ លប ២៧:៤១ ឡ លប ២៤:៦៣-៦៤ **៣១:១៨** អ លប ១២:៥ ក លប ២៥:២០ ខ លប ៣៥:២៧ គ លប ១០:១៩ **៣១:១៩** ឃ លប៣៨:១២, ១៣ ១ស ២៥:២, ៤,៧ ២សយ ១៣:២៣ ង ខ.៣០,៣២,៣៤-៣៥ លប៣៥:២ យស ២៤:១៤ ពច ១៧:៥ ១៨:១៤,១៧,២៤,៣០ ១សយ ៧:៣ ១៩:១៣ ២ពវ ២៣:២៤ ហស ៣:៤ **៣១:២០** ច ខ.២៧ ឆ លប ២៧:៣៦ ជ លប ២៥:២០ **៣១:២១** ឈ ខ.២២ នក ២:១៥ ១៤:៥ ១ពវ ១៨:៤៦ ១៩:៣ យរ ២៦:២១ ញ លប ២:១៤ ដ ខ.២៣,២៥ លប ៣៧:២៥ ជន ២៦:៣០ ៣២:១ ចទ ៣:១០ យស ១២:២

**៣១:៤** *រ៉ាជែលនិងលេអា* នៅចុងក្រោយ (ខ.១៤) រ៉ាជែលក្មេងជាង នាងមានឋានៈខ្ពស់ជាងលេអា ប៉ុន្តែបន្តិចក្រោយមកនាងបានបពោតប្តីនាង (មើលក្នុង ខ.៣១,៣៥) ។

**៣១:៧** សូមមើលក្នុង ខ.៤១ ។ "១០" ប្រហែលជាសញ្ញាសំគាល់ពីចំនួនគ្រប់លក្ខណ៍ ។ តាមពិតលោកយ៉ាកុបគាត់បានចោទប្រកាន់ឡាបាន់ ជជែកគ្នាពីបញ្ហាវិលត្រឡប់របស់គាត់ ។

**៣១:៩** មើល ៣០:៣៩ ។

**៣១:១១** *ទេវតានៃព្រះយេហូវ៉ា* មើល ១៦:៧ ។ ព្រះករុណាវិសេសព្រះអម្ចាស់ មើល ២២:១ ។

**៣១:១៣** *បេត-អែលជាកន្លែងដែលឯងចាក់ប្រេងលើបង្គោលនោះ* សូមមើល ២៨:១៨ ។

**៣១:១៥** *ស៊ីបង្ហិនប្រាក់បណ្ណាការរបស់យើងអស់រលីង* នៅពេលដែលលោកយ៉ាកុបចូលមកក្នុងប៉ាដាន់អើរ៉ាមគាត់គ្មានអ្វីឡើយហើយគាត់បានសុំប្រាក់ខែដែលធ្វើជំនួសដោយទ្រព្យសម្បត្តិសម្រាប់ប្រពន្ធគាត់ (ប្រៀបធៀប ២៤:១០) ។ ដូច្នេះអ្វីដែលគាត់បានស៊ីបង្ហិននោះគឺជាផលផ្លែការងាររបស់លោកយ៉ាកុបសម្រាប់ឪពុកគាត់វិញ (៣០:២៧,៣០) ។

**៣១:១៨** *ប៉ាដាន់-អើរ៉ាម* សូមមើល ២៥:២០ ។

**៣១:១៩** *រូបព្រះ* គឺជារូបព្រះតូច១ដែលដាក់នៅលើតុហើយមូលហេតុដែលរ៉ាជែលលួចប្រហែលជានាងគិតថាអាចការពារ ហើយនឹងអាចប្រទានពរដល់ពួកគេ ។ ម្យ៉ាងវិញទៀតប្រហែលជានាងចង់យកវាមកសម្រាប់ថ្វាយបង្គំនៅពេលដែលគេធ្វើដំណើរយ៉ាងឆ្ងាយបែបនេះ ហើយនាងគឺមនុស្សដំបូងដែលមានគំនិតបែបនេះក្នុងសតវត្សរ៍ទី១ ។ មួយវិញទៀតនាងមិនទាន់មានសេរីភាពពីព្រះរបស់នាងនៅឡើយនោះទេ (សូមមើល ៣៥:២ យប ២៤:២) ។

**៣១:២១** *រត់ចេញ* ដូចជាពេលដែលគាត់បានរត់ចេញពីលោកអេសាវដែរ (២៧:៤២៤៣) ។ អំពើទុច្ចរិតរបស់យ៉ាកុបបានធ្វើឱ្យគាត់មានជម្លោះជាមួយមនុស្សដែលត្រូវតែរត់គេចចេញ ។ *កាឡាត* គឺជាកន្លែងដ៏មានជីវជាតិមួយស្ថិតនៅទិសបូព៌ានៃបឹងកាលីឡេ ជន ៣២:១ ។

## លោកឡាបាន់ដេញតាមយ៉ាកុប

២២លុះកន្លងបាន៣ថ្ងៃក្រោយមក[ឋ] នោះមានគេទៅជំរាប
ដល់ឡាបាន់ថា យ៉ាកុបបានរត់បាត់ទៅហើយ[ឌ] ២៣ឡាបាន់ក៏
យកបងប្អូនគាត់[ឍ]ទៅជាមួយ[ណ] ដេញតាមចំនួនដើរផ្លូវអស់
៧ថ្ងៃ បានទាន់នៅនាភ្នំកាឡាត[ត] ២៤នៅវេលាយប់ ព្រះទ្រង់
មកពន្យល់សប្តិប្រាប់ឡាបាន់ ជាសាសន៍អើរ៉ាម[ថ]ថា[ទ] ចូរ
ប្រយ័ត្ន កុំឱ្យឯងនិយាយពាក្យណា ទោះល្អឬអាក្រក់នឹង
យ៉ាកុបឡើយ[ធ] ២៥នោះឡាបាន់ក៏ទៅដល់គាត់ឯយ៉ាកុប
បានដំឡើងត្រសាលនៅលើភ្នំកាឡាត[ន] ហើយឡាបាន់
និងបងប្អូនគាត់ ក៏ដំឡើងត្រសាលគេនៅលើភ្នំនោះដែរ
២៦ឡាបាន់និយាយទៅយ៉ាកុបថា ដូចម្តេចបានជាឯងធ្វើ
ដូច្នេះ[ប] គឺដែលឯងចេញមកដោយលួចលាក់មិនឱ្យអញ
ដឹងសោះ[ផ]ព្រមទាំងនាំពង្រត់កូនស្រីអញមក ដូចជាឈ្លើយ
ដែលចាប់បានដោយដាវផង[ព] ២៧ហេតុអ្វីបានជាឯងលួច
រត់ចេញមកពីអញ ដោយស្ងាត់កំបាំងដូច្នេះ ឥតប្រាប់ឱ្យ
អញដឹងផង[ភ] ដើម្បីឱ្យអញបានជូនមកដោយសេចក្តីអំណរ
គឺដោយច្រៀងចំរៀង និងបន្ទរក្រាប់[ម] ព្រមទាំងចាប់ស៊ុង
ដែរ[យ] ២៨ឯងមិនបានឱ្យអញថើបលាកូនចៅរបស់អញ
សោះ[រ] ដូច្នេះឯងបានប្រព្រឹត្តបែបចំកួតហើយ ២៩អញមាន
អំណាចនឹងធ្វើបាបឯងបាន[ល] តែព្រះនៃឪពុកឯង[វ] ទ្រង់មាន
បន្ទូលនឹងអញពីយប់មិញថា ចូរប្រយ័តកុំឱ្យនិយាយពាក្យ
ណា ទោះល្អឬអាក្រក់នឹងយ៉ាកុបឡើយ[ស] ៣០ឥឡូវនេះ ឯង
បានចេញមកពីព្រោះតែឯងរឭកដល់ផ្ទះឪពុកឯងខ្លាំង[ហ]
ពេក តែហេតុអ្វីបានជាឯងលួច[ឡ]យកព្រះរបស់អញមក
ផង[អ] ៣១នោះយ៉ាកុបឆ្លើយទៅឡាបាន់ថា ពីព្រោះខ្ញុំខ្លាច
ទាំងគិតក្រែងលោលោកឪពុកដកយកកូនស្រីពីខ្ញុំទៅវិញ
ដោយអំណាច[ក] ៣២បើលោកឪពុករកឃើញមានព្រះទាំង
នោះនៅ លើរូបអ្នកណា អ្នកនោះមិនត្រូវនៅរស់ទៀតទេ[ខ]
សូមឆែកឆេរនៅចំពោះមុខបងប្អូនយើងនេះចុះ មើលបើ
មានរបស់ណាជារបស់ផងលោកឪពុក នៅនឹងខ្ញុំនោះសូម
យកវិញចុះ ឯយ៉ាកុបគាត់មិនដឹងជារ៉ាជែលបានលួចយក
រូបព្រះទាំងនោះទេ[គ] ៣៣នោះឡាបាន់ក៏ចូលទៅក្នុងត្រសាល
យ៉ាកុប ត្រសាលលេអា[ឃ] និងត្រសាលរបស់បាវស្រីទាំង២[ង]
រកមិនឃើញសោះ[ច] រួចគាត់ចេញពីត្រសាលលេអា ចូល
ទៅក្នុងត្រសាលរ៉ាជែល ៣៤ឯរ៉ាជែលនាងបានយករូបព្រះ
ទាំងនោះ[ឆ] ទៅដាក់ក្នុងប្រដាប់អូដ្ឋទាំងប៉ុន្នាន[ជ] ហើយអង្គុយ
ពីលើ ឡាបាន់ឆែករក[ឈ]ពេញក្នុងត្រសាលមិនឃើញសោះ
៣៥រួចនាងនិយាយទៅឪពុកថា សូមកុំឱ្យលោកឪពុកខឹងនឹង
ខ្ញុំដែលខ្ញុំក្រោកនៅមុខលោកឪពុកពុំបាននោះឡើយ[ញ] ពី
ព្រោះខ្ញុំកើតមានកិច្ចដូចជាស្រីៗធ្លាប់មាន[ដ] គាត់ក៏ពិនិត្យរក
តែមិនឃើញរូបព្រះទាំងនោះសោះ[ឋ] ។
៣៦ឯយ៉ាកុបគាត់ខឹង ហើយក៏ឈ្លោះនឹងឡាបាន់ដោយ
ពាក្យថា តើខ្ញុំមានទោសអ្វី ឬបានធ្វើបាបណា[ឌ] បានជា
លោកឪពុកដេញតាមខ្ញុំដោយចិត្តក្តៅយ៉ាងដូច្នេះ[ឍ] ៣៧លោក
ឪពុកបានឆែកឆេររបស់ខ្ញុំ សព្វគ្រប់ទាំងអស់ហើយ តើ
បានឃើញរបស់ណាជារបស់ពីផ្ទះលោកឪពុកខ្លះ[ណ] ចូរ
ដាក់បង្ហាញនៅមុខបងប្អូនខ្ញុំ ហើយនិងបងប្អូន[ត]របស់
លោកឪពុកមកមើល ដើម្បីឱ្យគេជំនុំជំរះពីរឿងយើងទាំង
នេះ[ថ] ៣៨នេះពេញ២០ឆ្នាំគត់ហើយ[ទ] ដែលខ្ញុំនៅជាមួយនឹង
លោកឪពុក ចៀមនិងពពែរបស់លោកឪពុកមិនដែល មាន
រលូត១សោះ[ធ] ហើយខ្ញុំក៏ឥតដែលបានទទួលទានចៀម
ឈ្មោលពីហ្វូងរបស់លោកឪពុកដែរ ៣៩សត្វណាដែលត្រូវ
សត្វព្រៃខាំ នោះខ្ញុំមិនដែលយកមកជូនទេ ខ្ញុំបានទទួលសង
គឺលោកឪពុកបាន ចាប់ឱ្យខ្ញុំសង ទោះបើលួចបាន[ន]នៅ
ពេលថ្ងៃឬពេលយប់ក្តី[ប] ៤០ខ្ញុំក៏ត្រូវតែដូច្នោះ គឺនៅពេលថ្ងៃ

យរ ២២:៦
**៣១:២២** ឋ លប ៣០:៣៦ ឌ ខ.២១
**៣១:២៣** ឍ ខ.៣៧ ណ នក ១៤:៩ ត ខ.២១
**៣១:២៤** ថ លប ២៥:២០ ទ លប ២០:៣ ធ លប ២៤:៥០
**៣១:២៥** ន ខ.២១
**៣១:២៦** ប លប ១២:១៨ ផ លប ២៧:៣៦ ព លប ៣៤:២៩ ១សយ ៣០:២–៣
**៣១:២៧** ភ ខ.២០ ម នក ១៥:២០ ពច ១១:៣៤ ១សយ ១០:៥ ២សយ ៦:៥ ទដ ៦៨:២៥ អស ២៤:៨ យរ ៣១:៤ យ លប ៤:២១
**៣១:២៨** រ ខ.៥៥ លប ២៧:២៧ នរ ១:១៤ កច ២០:៣៧
**៣១:២៩** ល ខ.៧ លប ២៦:២៩ វ ខ.៥ ស លប ២៤:៥០
**៣១:៣០** ហ លប ២៨:១៥ យប ២៩:២ ឡ លប ៤៤:៨ អ ខ.១៩
**៣១:៣១** ក លប ២០:១១
**៣១:៣២** ខ លប ៤៤:៩ គ ខ.១៩
**៣១:៣៣** ឃ លប ២៤:៦៧ ង លប ១៦:១ ង ខ.៣៧ **៣១:៣៤** ឆ ខ.១៩ ជ លប ២៤:៦៣–៦៤ ឈ ខ.៣៧ លប ៤៤:១២ **៣១:៣៥** ញ នក ២១០:១២ លវ ១៩:៣។៣២៣ ចទ ២១:១៨ ២៧:១៦ យរ ៣៥:១៨ ដ លវ ១៥:១៩–២៣ ឋ ខ.១៩ **៣១:៣៦** ឌ ១សយ ១៩:៥ ២០:៣២ ឍ ១សយ ២៣:២៣ ២៤:១១ **៣១:៣៧** ណ ខ.៣៣ ត ខ.២៣ ថ ចទ ១:១៦ ១៦:១៨ **៣១:៣៨** ទ លប ២៧:៤៤ ធ លប ៣០:២៧ **៣១:៣៩** ន លប ៣០:៣៣ ប នក ២២:១៣

**៣១:២៤** *កុំឱ្យឯងនិយាយពាក្យណាទោះល្អឬអាក្រក់* កុំឱ្យឈ្លោះប្រកែកជាមួយគាត់ ខ.២៩ (ធៀបនឹង ២៤:៥០) ។

**៣១:២៦** *លួចលាក់* នោះគឺជាអត្តចរិតរបស់លោកយ៉ាកុបដែលសក្តិសមសម្រាប់ឈ្មោះរបស់គាត់ (២៥:២៦ ២៧:៣៦) ដែលបាននិយាយម្តងហើយម្តងទៀត ។

**៣១:២៧** *ស៊ុង* ជាប្រដាប់ភ្លេងធុនតូចហើយមានខ្សែជានិច្ចកាលខ្សែ (៦–១២) ច្រើនជាងឧបករណ៍ផ្សេងៗទៀត ។

**៣១:៣២** *បើលោកឪពុករកឃើញមានព្រះទាំងនោះនៅលើរូបអ្នកណាអ្នកនោះមិនត្រូវនៅរស់ទៀតទេ* ទោះបីជាគាត់បង្ហាញពីភាពស្មោះត្រង់ក៏ដោយ លោកយ៉ាកុប ស្ទើរតែបោះបង់សេចក្តីស្រឡាញ់ចំពោះនាងរ៉ាជែល ។ ឥឡូវនេះសូម្បីតែប្រពន្ធគាត់ ក៏មិនស្មោះត្រង់នឹងគាត់ដែរ ។

**៣១:៣៤** *ដាក់ក្នុងប្រដាប់អូដ្ឋទាំងប៉ុន្នានហើយអង្គុយពីលើ* រូបព្រះទាំងអស់នោះតូចៗហើយគ្មានអំណាចអ្វីនោះទេ ។

**៣១:៣៥** *ពីព្រោះខ្ញុំកើតមានកិច្ចដូចជាស្រីៗធ្លាប់មាន* នៅពេលក្រោយៗមកទៀតនៅពេលស្ត្រីមានរដូវ នោះត្រូវបានរាប់ថាជាមិនស្អាតហើយ (សូមមើល លវ ១៥:២០) ។

**៣១:៣៩** *ខ្ញុំបានទទួលសង* តាមច្បាប់ពីសម័យបុរាណ បើសិនជាសត្វណាស៊ីហើយមានភស្តុតាង នោះមិនត្រូវសងនោះឡើយ (នក ២២:១៣) ។

ខ្ញុំ តែងត្រូវចំហាយក្តៅ ហើយពេលយប់ត្រូវរងា ភ្នែកខ្ញុំអត់
ងងុយដ្រប់[ផ] ៤១ខ្ញុំបាននៅផ្ទះលោកឪពុកអស់២០ឆ្នាំនេះ
ហើយ[ព] គឺខ្ញុំបានបំរើលោកឪពុក១៤ឆ្នាំ[ភ] ឱ្យបានកូនស្រី
របស់លោកឪពុកទាំង២រូប ហើយ៦ឆ្នាំទៀតឱ្យបានចៀម
របស់លោកឪពុក[ម] តែលោកឪពុកបានបំផ្លាស់ឈ្នួលខ្ញុំ[យ]១០
ដងហើយ[រ] ៤២បើព្រះនៃឪពុកខ្ញុំ[ល] គឺព្រះនៃអ័ប្រាហាំ[វ] ដែល
អ៊ីសាកបានកោតខ្លាច[ស] ទ្រង់មិនបានគង់នៅខាងខ្ញុំទេ[ហ] នោះ
ប្រាកដជាលោកឪពុកបានឱ្យខ្ញុំ ត្រឡប់មកដោយដៃទទេ
ហើយ[ឡ] ព្រះទ្រង់បានឃើញសេចក្តីទុក្ខលំបាករបស់ខ្ញុំនឹង
ការនឿយហត់ដែលដៃខ្ញុំធ្វើដូច្នេះ ហើយបានជាទ្រង់
បន្ទោសដល់លោកឪពុកពីយប់មិញនេះ[អ] ។
៤៣នោះឡាបាន់ឆ្លើយទៅយ៉ាកុបថា ស្ត្រីទាំងនេះជាកូន
អញ ហើយក្មេងទាំងនេះក៏ជាចៅអញ ហ្វូងសត្វទាំងនេះជា
ហ្វូងសត្វរបស់អញ[ក] ហើយរបស់ទាំងប៉ុន្មានដែលឯងឃើញ
ក៏ជារបស់ផងអញទាំងអស់ដែរ តែនៅថ្ងៃនេះតើអញ
នឹងធ្វើអ្វីដល់កូនអញ ហើយនិងកូនដែលវាបានបង្កើត
ទាំងប៉ុន្មាននេះបាន ៤៤ដូច្នេះ ចូរយើងចុះសញ្ញានឹងគ្នាទៅ
វិញទៅមក[ខ] ដើម្បីនឹងទុកជាទីបន្ទាល់ដល់ឯង ហើយនឹង
អញ[គ] ៤៥នោះយ៉ាកុបគាត់យកថ្ម១មកបញ្ឈរធ្វើជាបង្គោល[ឃ]
៤៦ហើយប្រាប់ដល់បងប្អូនថា ចូរយកថ្មមក នោះគេក៏ទៅ
យកថ្មមកដាក់ជាគំនរ[ង] រួចនាំគ្នាបរិភោគនៅលើគំនរនោះ
៤៧ឡាបាន់គាត់ហៅគំនរថ្មនោះថា យេការ–ហាឌូថា តែ
យ៉ាកុបគាត់ហៅថា កាលេឌវិញ[ច] ៤៨រួចឡាបាន់និយាយថា
គំនរថ្មនេះ[ឆ] ជាទីបន្ទាល់ដល់ឯង ហើយនិងអញនៅថ្ងៃ
នេះ[ជ] ហេតុនោះបានជាគេដាក់ឈ្មោះថា កាលេឌ ហើយ
មីសប៉ា[ឈ] ៤៩ពីព្រោះគាត់និយាយថា សូមឱ្យព្រះយេហូវ៉ា

**៣១:៤០** ផ ទដ ១៣២:៤ ២កថ ១១:២៧
**៣១:៤១** ព លប ២៧:៤៤ ភ លប ២៩:៣០ ម លប ៣០:៣២ យ លប ២៩:១៥ រ ខ.៧
**៣១:៤២** ល ខ.៥ នក ៣:១៥ វ លប ២៤:១២ ស ខ.៥៣ លប ៤៦:១ ហ លប ២១:២២ ទដ ៤:១២ ឡ លប ៣:១៧ អ លប ២៤:៥០
**៣១:៤៣** ក លប ៣០:៣២,៤២
**៣១:៤៤** ខ លប ២ ១:២៧ គ លប ២១:៣០
**៣១:៤៥** ឃ លប ២៨:១៨
**៣១:៤៦** ង ខ.៤៨ ,៥១,៥២
**៣១:៤៧** ច លប ២១:៣០
**៣១:៤៨** ឆ ខ.៤៦ ជ លប ២១:៣០ យរ ២៩:២៣ ៤២:៥ ឈ យរ ១១:២ ពច ១០:១៧ ១១:២៩
**៣១:៥០** ញ លប ១៦:៦ ដ ចទ ៣១:១៩ យស

ទតមើលឯង ហើយនិងអញ ក្នុងកាលដែលយើងនៅឃ្លាត
ពីគ្នា ៥០បើឯងធ្វើបាបកូនអញ[ញ] ឬយកប្រពន្ធទៀតលើសពី
កូនអញ ក្នុងកាលដែលគ្មានមនុស្សណានៅជាមួយ នោះ
មើលព្រះទ្រង់ជាសាក្សី[ដ]ដល់ឯងហើយនិងអញស្រាប់ហើយ[ឋ]
៥១រួចឡាបាន់និយាយទៅយ៉ាកុបទៀតថា មើល គំនរថ្មនេះ[ឌ]
និងបង្គោល[ឍ]នេះហើយ ដែលអញបានដាក់នៅកណ្តាលឯង
ហើយនិងអញ ៥២គំនរនេះនិងបង្គោលនេះនឹងបានជាទី
បន្ទាល់ថា[ណ] អញមិនរំលងគំនរនេះទៅឯឯង[ត] ហើយឯង
ក៏មិនរំលងគំនរឬបង្គោលនេះមកឯអញ ប្រយោជន៍នឹងធ្វើ
អាក្រក់អ្វីឡើយ[ថ] ៥៣សូមឱ្យព្រះនៃអ័ប្រាហាំនៃ[ទ]ណាឃរ[ធ]
គឺជាព្រះនៃឰយុកោរបស់លោក ទ្រង់ជំនុំជំរះយើងចុះ[ន]
នៅទីនោះយ៉ាកុបក៏ស្បថនឹងព្រះ[ប] ដែលជាទីកោតខ្លាចនៃ
អ៊ីសាកឪពុកខ្លួនដែរ[ផ] ។
៥៤យ៉ាកុបក៏រៀបចំបូជាយញ្ញថ្វាយ[ព]នៅលើភ្នំនោះ ហើយ
ហៅពួកបងប្អូនមកជួបជុំបរិភោគ គេក៏នាំគ្នាបរិភោគទៅ[ភ]
រួចដេកនៅលើភ្នំក្នុងយប់នោះ ៥៥ដល់ព្រលឹមស្រាងនោះ
ឡាបាន់ក្រោកឡើងថើបកូនចៅគាត់ទាំងប៉ុន្មាន[ម] ព្រមទាំង
ឱ្យពរ[យ] រួចលាត្រឡប់វិលទៅឯទីកន្លែងខ្លួនវិញ[រ] ។

## លោកយ៉ាកុបត្រៀមខ្លួនជួបនឹងលោកអេសាវ

**៣២** ១ឯយ៉ាកុបគាត់ក៏ធ្វើដំណើរតទៅ ហើយមានពួក

២៤:២៧ ពច ១១:១០ ១សយ ១២:៥ ២០:១,២៣,
៤២ យប ១៦:១៩ យរ ២៩:២៣ ៤២:៥ មីក ១:២ ឋ លប ២១:៣០ ចទ ៤:២៦
យរ ៧:១១ **៣១:៥១** ឌ ខ.៤៦ ឍ លប ២៨:១៨ **៣១:៥២** ណ លប ២១:៣០ ត
ខ.៤៦ ថ ខ.៧ **៣១:៥៣** ទ លប ២៤:១២ ធ លប ១១:២៧ ន លប ១៦:៥ ប
លប ២១:២៣ ,២៧ ផ ខ.៤២ **៣១:៥៤** ព លប ៤៦:១ នក ២៤:៥ លប ៣:១
ភ លប ២៦:៣០ **៣១:៥៥** ម ខ.២៨ នរ ១:៩ យ លប ២៤:៦០ ន ៣៩:៤៣ រ
លប ១៨:៣៣

**៣១:៤២** *កោតខ្លាច* ក្នុងខនេះគឺជំនួសដោយព្រះយេហូវ៉ា ម្យ៉ាងទៀតក្នុងព្រះគម្ពីរភាសាហេព្រើរឃ្លានេះ គឺមានន័យថា "ញាតិសណ្តាន" ដែលសំដៅលើទំនាក់ទំនងរបស់ព្រះយេហូវ៉ា ជាមួយពួកឰយុកោជិនាន់មុន ។

**៣១:៤៤** មើល ខ.៤៨,៥២ និង ២១:៣០ និងការពន្យល់ ។

**៣១:៤៦** *បរិភោគ* សូមមើល ២៦:៣០ ។

**៣១:៤៨** សម្រាប់ការដាក់ឈ្មោះឱ្យអាសនា នៅពេលដែលគេបានសាងសង់នោះ សូមមើល យស ២២:១០–១២,៣៤ ។

**៣១:៤៩** *សូមឱ្យ . . . នៅឃ្លាតពីគ្នា* ហេតុដែលគេប្រសិទ្ធនាមឱ្យថា មីសប៉ា គឺដោយសារមានការប្តឹងតវ៉ាចំពោះគ្នាទៅវិញទៅមក ឬដោយសារតែពួកគេត្រូវបណ្តាសានៅទីនោះ ។

**៣១:៥១** *គំនរថ្មនេះ និងបង្គោលនេះហើយ . . . នៅកណ្តាលឯងហើយនិងអញ* គឺដើម្បីបញ្ជាក់ពីព្រំប្រទល់ រវាងទឹកដីរបស់ឡាបាន់ ហើយនិងយ៉ាកុប កាលេឌ គឺជាឈ្មោះគំនរថ្មរបស់លោកយ៉ាកុប(ខ.៤៧ និងការពន្យល់)។

**៣១:៥៣** *ព្រះនៃឰយុកោរបស់លោក* នៅក្នុងន័យនេះអាចមានន័យថា "រូបព្រះនៃឪពុករបស់គេ" គឺថេរ៉ាដែលចង់និយាយពីប្រវត្តិរបស់លោកឡាបាន់ជាអ្នកគោរពលើព្រះជាច្រើន (មើលក្នុង យស ២៤:២) ។ *ដែលជាទីកោតខ្លាចនៃអ៊ីសាកឪពុកខ្លួនដែរ* សូមមើល ខ.៤២ ។ លោកយ៉ាកុបគាត់បានជួប "ព្រះនៃអ៊ីសាក" នៅបេតអែលកាលពី២០ឆ្នាំមុន (មើល ២៨:១៣) ។

**៣១:៥៤** *បូជាយញ្ញ . . . បរិភោគទៅ* សេចក្តីពិតទាំង២ គឺតែងតែធ្វើនៅពេលដែលយើងធ្វើការតាំងសញ្ញាជាមួយព្រះ (មើល ខ.៤៤) ហើយរបៀបដែលគេធ្វើនោះគឺបានប្រាប់យើងនៅក្នុង (នក ២៤:៥–៨,១១) ។ *ពួកបងប្អូន* ពួកអ្នកទាំងនោះគឺសុទ្ធតែបានធ្វើការតាំងសញ្ញា ។ នៅពេលដែលពួកគេនាំគ្នាបរិភោគអាហារជុំគ្នា គឺបញ្ជាក់ប្រាប់យើងថា ពួកគេសុខចិត្តតាមព្រះអង្គជារៀងរហូត(មើល ២៦:៣០)។

**៣១:៥៥** *ឱ្យពរ* យើងអាចនិយាយម្យ៉ាងទៀតថា "លាហើយ" (សូមមើលក្នុង ៤៧:១០ ៣១:២៨)។

ទេវតារបស់ព្រះ[ក]មកជួបនឹងគាត់ ២កាលឃើញហើយនោះ
គាត់និយាយថា នេះជាពួកពលរបស់ព្រះ[ខ] គាត់ក៏ហៅ
កន្លែងនោះថា ម៉ាហាណែម[គ] ។
៣យ៉ាកុបចាត់អ្នកបំរើទៅមុន[ឃ] ឱ្យទៅឯអេសាវជាបង[ង]
នៅវាលអេដំម[ច]ក្នុងស្រុកសៀរ[ឆ] ៤ដោយបង្គាប់ថា ចូរឯង
រាល់គ្នាជំរាបដល់អេសាវ ជាលោកម្ចាស់អញ[ជ] យ៉ាងនេះ
ថា យ៉ាកុបជាអ្នកបំរើរបស់លោក[ឈ]ផ្តាំមកដូច្នេះថា ខ្ញុំបាន
នៅជាមួយនឹងឡាបាន់[ញ]ដរាបដល់ឥឡូវនេះ ៥ខ្ញុំមានគោ
មានលា មានហ្វូងចៀម ហើយមានបាវប្រុសស្រី[ដ] ខ្ញុំបាន
ចាត់គេមកជំរាបលោកម្ចាស់[ឋ] ដើម្បីឱ្យខ្ញុំបានប្រកបដោយ
គុណលោក[ឌ] ៦ពួកអ្នកបំរើក៏ត្រឡប់មកឯយ៉ាកុបវិញ ជំរាប
ថា យើងខ្ញុំបានទៅដល់អេសាវជាបងលោកហើយ លោក
ក៏អញ្ជើញមកដែរ ព្រមទាំងនាំមនុស្ស៤០០នាក់មកជាមួយ
ផង[ឍ] ៧នោះយ៉ាកុប គាត់ភ័យខ្លាចជាខ្លាំង[ណ] ហើយមាន
សេចក្តីថប់ព្រួយក្នុងទ្រូង[ត] ក៏ចែកពួកគាត់ ព្រមទាំងហ្វូង
ចៀម ហ្វូងគោ និងអូដ្ឋជា២ពួក[ថ] ៨ដោយគិតថា បើអេសាវ
មកវាយពួក១ នោះពួក១ទៀតនឹងរត់រួចបាន ៩យ៉ាកុបក៏ទូល
ថា ឱព្រះនៃអ័ប្រាហាំជីតាទូលបង្គំ[ទ] ជាព្រះនៃអ៊ីសាក ឪពុក
របស់ទូលបង្គំ[ធ] ឱព្រះយេហូវ៉ាអើយ ទ្រង់បានមានបន្ទូល
នឹងទូលបង្គំថា ចូរវិលទៅឯញាតិសន្តានឯងនៅស្រុកឯង
វិញទៅ នោះអញនឹងប្រោសសេចក្តីល្អដល់ឯង[ន] ១០ទូលបង្គំ
មិនគួរឱ្យបានអស់ទាំងសេចក្តីសប្បុរស និងអស់ទាំងសេចក្តី
ស្មោះត្រង់[ប]ដែលទ្រង់បានផ្តល់មកទូលបង្គំ ជាអ្នកបំរើទ្រង់
ទេ ដ្បិតទូលបង្គំបានឆ្លងទន្លេយ័រដាន់នេះ មានតែដំបង១
ប៉ុណ្ណោះ[ផ] តែឥឡូវនេះ ទូលបង្គំបានកើតជា២ពួកហើយ[ព]
១១សូមទ្រង់ប្រោសឱ្យទូលបង្គំរួចពីកណ្តាប់ដៃនៃអេសាវជា
បង ដ្បិតទូលបង្គំខ្លាច[ភ]ក្រែងគាត់មកវាយពួកទូល បង្គំនេះ[ម]
ទាំងម្តាយកូនផង[យ] ១២ទ្រង់បានមានបន្ទូលថា អញនឹង
ប្រោសសេចក្តីល្អដល់ឯងជាពិតប្រាកដ ហើយនិងធ្វើឱ្យពូជ
ឯងបានគ្នាច្រើនដូចជាខ្សាច់[រ] នៅសមុទ្រដែលប្រមាណមិន
បាន[ល]។
១៣យប់នោះគាត់សំណាក់នៅទីនោះ រួចក៏យករបស់

**៣២:១** ក លប ១៦:១១ ២ពវ ៦:១៦-១៧ ១រប ២១:១៥ ទដ ៣៤:៧ ៣៥:៥ ៩១:១១ ដយ ៦:២២ **៣២:២** ខ លប ២៨:១៧ គ យស ១៣:២៦,៣០ ២១:៣៨ ២សយ ២:៨,២៩ ១៧:២៤ ១៩:៣២ ១ពវ ២:៨ ៤:១៤ ១រប ៦:៨០ **៣២:៣** ឃ ជន ២១:២១ ពច ១១:១៧ ង លប ២៧:៤១-៤២ ច លប ២៥:៣០ ៣៦:១៦ ឆ លប ១៤:៦ ជន ២៤:១៨ **៣២:៤** ជ លប ២៤:៩ ឈ លប ១៨:៣ ញ លប ៣១:៤១ **៣២:៥** ដ លប ១២:១៦ ឋ លប ២៤:៩ ឌ លប ៣៣:៨,១០,១៥ ៣៤:១១ ៤៧:២៥, ២៩ ៥០:៤ នរ ២:១៣ **៣២:៦** ឍ លប ៣៣:១ **៣២:៧** ណ ខ.១១ ត លប ៣៥:៣ ទដ ៤:១ ៧៧:២ ១០៧:៦ ថ ខ.១០ លប ៣៣:១ **៣២:៩** ទ លប ២៤:១២ ធ លប ២៨:១៣ ន លប :៣ ៣១:១៣ **៣២:១០** ប លប ២៤:២៧ ផ លប ៣៨:១៨ ៤៧:៣១ ជន ១៧:២ ព ខ.៧ **៣២:១១** ភ ខ.៧ ម លប ៤៣:១៨ ទដ ៥៩:២ យ លប ២៧:៤១ **៣២:១២** រ លប ២២:១៧ ១ពវ ៤:២០,២៩ ល លប ១២:២ ១៣:១៤ ហស ១:១០ រម ៩:២៧

**៣២:១-៣២** ហេតុដែលធ្វើឱ្យលោកយ៉ាកុបមានអំណរគឺ ដោយសារគាត់បានជួបនឹងម្នាក់ដែលជាគូជម្លោះជាមួយគាត់ នោះគឺជាលោកអេសាវជាបងគាត់ដែលគាត់បានធ្វើដំណើរទៅក្នុងទឹកដីសន្យាដោយសុវត្ថិភាព ។

**៣២:១** *ពួកទេវតារបស់ព្រះមកជួបគាត់* លោកយ៉ាកុបគាត់ទើបតែបានចាកចេញពីលោកឡាបាន់ ជាទីកន្លែងមួយដែលគាត់មានជម្លោះនិងគ្នា ហើយឥឡូវនេះគាត់បានធ្វើដំណើរទៅជាមួយលោកអេសាវ ដែលកាលពីមុនពួកគេទាំង២នាក់ធ្លាប់មានជម្លោះជាមួយគ្នាដែរ ។ ពួកទេវតានៃព្រះបានមកជួបគាត់ គឺជាទេវតាដែលគាត់បានជួបនៅបេតអែលម្តងរួចទៅហើយក្នុងអំឡុងពេលដែលគាត់បានរត់គេចពីលោកអេសាវ ទៅឯលោកឡាបាន់ (សូមមើល ២៨:១២) ។ ពួកទេវតាទាំងនោះ បាននៅជាមួយលោកយ៉ាកុបដូចអ្វីដែលពួកគេបានសន្យាជាមួយលោកយ៉ាកុប (សូមមើល ២៨:១៥ ៣១:៣ ២៦:៣) ។

**៣២:២** *ម៉ាហាណែម* មានទីតាំងស្ថិតនៅក្នុងតំបន់ភ្នំកាឡាត (៣១:២១) ភាគខាងកើតនៃទន្លេយ័រដាន់ ហើយភាគខាងជើងនៃស្ទឹងយ៉ាបុក (ខ.២២) ។ ទីតាំងទាំង២នេះ គឺជាកន្លែងដែលគេទើបតែមានជម្លោះជាមួយគ្នា ហើយពេលនេះបានក្លាយជាកន្លែងមួយដែលមានសន្តិភាពពិតប្រាកដ ។ ប៉ុន្តែលោកយ៉ាកុបគាត់បានហៅកន្លែងសំខាន់ទាំង២នោះថា "ជំរុំទាំង២" បន្ទាប់ពីគាត់បានឃើញទេវតានៃព្រះបានមក តាំងជាបន្ទាយដ៏រឹងមាំសម្រាប់គាត់ ហើយជាអ្នកធានាអះអាងចំពោះគាត់ ។ ទេវតាទាំងនោះគឺជាទាហាននៃព្រះដែលបានមកហែរហម នឹងជាអ្នកជូនដំណើរគាត់ឱ្យចូលក្នុងទឹកដីកាណានដែលជាទឹកដីសន្យាដោយសុវត្ថិភាព (៣៣:១២,១៥) ។ ក្នុងអំឡុងពេលដែលគាត់ជួបអេសាវទាំងការភ័យខ្លាច គាត់បានបែងចែកផ្ទះរបស់គាត់ជា២ផ្នែក (មើល ខ.៧,១០) គាត់នៅតែព្យាយាមការពារខ្លួនគាត់ ដោយការប្រើឧបាយកលរបស់គាត់ ។

**៣២:៣** *វាលអេដំមក្នុងស្រុកសៀរ* តំបន់នោះស្ថិតនៅភាគខាងត្បូងហើយវានៅឆ្ងាយជាងអ្វីដែលលោកយ៉ាកុបបានគិតទៅទៀត ប៉ុន្តែគាត់គិតថាមិនយូរមិនឆាប់ លោកអេសាវនឹងមករកគាត់ដើម្បីសងសឹក ដូច្នេះហើយគាត់ក៏សម្រេចចិត្តធ្វើដំណើរត្រឡប់ក្រោយវិញ ។

**៣២:៤** *ជាអ្នកបំរើរបស់លោក* ឃ្លានេះបង្ហាញថា គាត់មានការឱនលំទោននិងបន្ទាបខ្លួនចំពោះបងគាត់ ។

**៣២:៦** *៤០០នាក់* ចំនួនមនុស្សដ៏ច្រើនទាំងនោះ ពួកគេសុទ្ធតែថ្មីកនឹងចំបាំង (១សយ ២២:២ ២៥:១៣ ៣០:៣០) ។ នៅក្នុងពេលដែល លោកយ៉ាកុបគាត់រស់នៅមានពេញដោយសន្តិភាព នៃចិត្តជាអ្នកគង្វាល លោកអេសាវគាត់ពេញទៅដោយ "សេចក្តីទុក្ខសោក" ដូចអ្វីដែលលោកអ៊ីសាកបាននិយាយជាមុន (សូមមើល ២៧:៤០) ។

**៣២:៩** *យ៉ាកុបក៏ទូលថា* នេះគឺជាសេចក្តីអធិស្ឋានលើកដំបូងរបស់លោកយ៉ាកុបបន្ទាប់ពីគាត់បានចាកចេញពីបេត-អែល ។

**៣២:១១** *ទាំងម្តាយទាំងកូន* លោកយ៉ាកុបគាត់បានដឹងថា បើសិនជាអេសាវនៅតែបន្តចង់សងសឹកនឹងគាត់ នោះទាំងប្រពន្ធនិងកូនៗរបស់គាត់ គឺមានចំណែករងទុក្ខជាមួយគាត់ដែរ ។

**៣២:១២** *ហើយនឹងធ្វើឱ្យពូជឯងមានគ្នាច្រើនដូចជាខ្សាច់ នៅសមុទ្រដែលប្រមាណមិនបាន* នេះជាការរំឭកសេចក្តីសន្យារបស់ព្រះ ដែលព្រះយេហូវ៉ាទ្រង់បានសន្យានៅក្នុង ២៨:១៤ (សូមមើល ២២:១៧) ។

**៣២:១៣** *ជំនូន* នេះប្រហែលជាការលេងពាក្យប៉ុណ្ណោះ ។ ពាក្យនេះជា

ទ្រព្យគាត់ខ្លះ ទុកជាជំនូនសំរាប់ជូនដល់អេសាវជាបង ១៤គឺ
ពពែញី២០០ពពែឈ្មោល២០ ចៀមញី២០០ចៀមឈ្មោល
២០[ស] ១៥អូដ្ឋញីដែលបំបៅកូន៣០ព្រមទាំងកូនផង គោញី
៤០ គោឈ្មោល១០ លាញី២០និងកូនលា១០[ហ] ១៦គាត់
ប្រគល់សត្វទាំងនោះ ទៅក្នុងដៃនៃពួកបំរើគាត់ដោយហ្វូង
ៗ ហើយប្រាប់ពួកបាវនោះថា ចូរឆ្លងទៅមុនអញដើរឱ្យ
ដាច់ពីគ្នាដោយពួកៗ[ឡ] ១៧គាត់ក៏បង្គាប់ដល់អ្នកដែលដើរ
មុនគេថា កាលណាអេសាវបងអញមកជួបនឹងឯង ហើយ
សួរថា ឯងជាពួករបស់អ្នកណា ហើយទៅឯណា តើហ្វូង
សត្វនៅមុខឯងទាំងនេះ ជារបស់ផងអ្នកណា ១៨នោះត្រូវ
ជំរាបថា នេះជារបស់ផងយ៉ាកុបជាអ្នកបំរើលោក[អ] គឺជា
ជំនូន[ក] ផ្ញើមកជូនដល់អេសាវជាលោកម្ចាស់ខ្ញុំ ហើយមើល
លោកក៏អញ្ជើញមកតាមក្រោយយើងខ្ញុំដែរ ១៩គាត់បង្គាប់
អ្នកទី២ដូច្នោះដែរ ព្រមទាំងអ្នកទី៣ និងពួកអ្នកដែលដើរ
តាមហ្វូងសត្វទាំងអស់ផងថា កាលណាឃើញអេសាវ នោះ
ចូរជំរាបតាមពាក្យនេះដូចគ្នា ២០គឺត្រូវជំរាបលោកថា
មើលយ៉ាកុបជាអ្នកបំរើលោក[ខ]ក៏មកតាមក្រោយ យើងខ្ញុំ
ដែរនេះ ដ្បិតគាត់គិតថា អញនឹងរំងាប់ចិត្តបង ដោយជំនូន[គ]
ដែលទៅមុនអញ[ឃ] រួចអញនឹងឃើញមុខបង នោះប្រហែល
ជានឹងទទួលអញដោយស្រួលហើយ[ង] ២១ដូច្នេះជំនូននោះ[ច]
ក៏ឆ្លងទៅមុនគាត់ តែឯខ្លួនគាត់បានដេកនៅក្នុងទីសំណាក់
នោះ១យប់សិន ។

**លោកយ៉ាកុបចំបាប់នឹងព្រះ**

២២រួចគាត់ក្រោកឡើងទាំងយប់នាំយកប្រពន្ធទាំង ២ និង
បាវស្រីទាំង២ ព្រមទាំងកូនគាត់ទាំង១១នាក់[ឆ] ឆ្លងស្ទឹង
យ៉ាបុកត្រង់ផ្លូវឆ្លងទៅ[ជ] ២៣គាត់នាំអ្នកទាំងនោះទៅឱ្យឆ្លង
ស្ទឹង ហើយក៏ឱ្យគេយកអីវ៉ាន់គាត់ឆ្លងទៅដែរ[ឈ]។
២៤ដូច្នេះយ៉ាកុបនៅតែម្នាក់ឯង[ញ] ហើយមានម្នាក់[ដ]មក
ចំបាប់នឹងគាត់រហូតដល់ភ្លឺ ២៥កាលអ្នកនោះឃើញថាមិន
ឈ្នះគាត់ទេ នោះក៏ពាល់ត្រង់សន្លាក់ត្រគាកគាត់[ឋ] ហើយ
សន្លាក់ត្រគាកក៏ថ្លូស់ក្នុងខណដែលកំពុងតែចំបាប់គ្នានោះ
២៦អ្នកនោះនិយាយថា ចូរលែងឱ្យអញទៅ ដ្បិតភ្លឺហើយតែ
គាត់ឆ្លើយថា ខ្ញុំមិនឱ្យលោកទៅទេ ទាល់តែបានឱ្យពរដល់
ខ្ញុំសិន[ឌ] ២៧អ្នកនោះសួរថា ឯងឈ្មោះអី គាត់ឆ្លើយថា ខ្ញុំ
ឈ្មោះយ៉ាកុប[ឍ] ២៨រួចអ្នកនោះប្រាប់ថា ឈ្មោះឯង[ណ] មិន
ត្រូវហៅថា យ៉ាកុបទៀតទេ គឺត្រូវហៅថា អ៊ីស្រាអែល[ត]វិញ
ពីព្រោះឯង មានអំណាចចំពោះព្រះហើយនិងមនុស្សក៏បាន
ឈ្នះផង[ថ] ២៩យ៉ាកុបក៏សួរអ្នកនោះដែរថា សូមលោក
ប្រាប់ឈ្មោះលោកឱ្យខ្ញុំដឹងផង[ទ] តែអ្នកនោះតបមកវិញថា

**៣២:១៣** វ ខ.១៣–១៥,១៨, ២០,២១ លប ៣៣:១០ ៤៣:១១,១៥,២៥,២៦ ១សយ ១៦:២០ សភ ១៨:១៦ ២១:១៤ **៣២:១៤** ស ជន ៧:៨៨ **៣២:១៥** ហ លប ១៣:២ ៤២:២៦ ៤៥:២៣ **៣២:១៦** ឡ លប ៣៣:៨ **៣២:១៨** អ លប ១៨:៣ ក ខ.១៣ **៣២:២០** ខ កប ១៨:៣ គ ខ.១៣ ១សយ ៩:៧ ២ពវ ៨:៨ យរ ៤០:៥ ឃ ១សយ ២៥:១៩ ង លប ៣៣:១០ នក ៨:៣៨ លវ ១:៤ មឡ ១:៨ **៣២:២១** ច ខ.១៣ **៣២:២២** ឆ លប ៣០:២៤ ជ ជន ២១:២៤ ចទ ២:៣៧ ៣:១៦ យស ១២:២ **៣២:២៣** ឈ លប ២៦:១៤ **៣២:២៤** ញ ដយ ១០:៨ ដ លប ១៨:២ **៣២:២៥** ឋ ខ.៣២**៣២:២៦** ឌ ហស ១២:៤ **៣២:២៧** ឍ លប ២៥:២៦ **៣២:២៨** ណ អស ១:២៦ ៥៦:៥ ៦០:១៤ ៦២:២,៤,១២ ៦៥:១៥ ត លប ១៧:៥ ថ លប ៣០:៨ **៣២:២៩** ទ នក ៣:១៣ ៦:៣ ពច ១៣:១៧

ការបំបែកចេញពី "ជំរុំទាំង២" ដែលក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យថា ម៉ាហាណៃម(ខ.២,៧–៨,១០)។ លោកយ៉ាកុបបានជ្រើសរើស "ជំនូន" (មីនហាស់) ដ៏ល្អៗសម្រាប់បងប្រុសរបស់គាត់ ។

**៣២:២២** *យ៉ាបុក* សព្វថ្ងៃនេះមានឈ្មោះថា "វ៉ាឌី សឺការ" (Wadi Zerqa) ឆ្ពោះទៅទិសខាងលិចចាក់ចូលក្នុងទន្លេយ័រដាន់ ដែលមានចម្ងាយប្រមាណជា ៣០ គ.ឡ ភាគខាងជើងនៃសមុទ្រស្លាប់ ។

**៣២:២៤** *នៅតែម្នាក់ឯង* ដូចគ្នានឹងអ្វីដែលគាត់ធ្លាប់ធ្វើនៅបេតអែលដែរ (២៨:១០–២២) ។ *ម្នាក់* អ្នកនោះគឺជាព្រះយេហូវ៉ាផ្ទាល់ (លោកយ៉ាកុបគាត់បានឃើញព្រះយេហូវ៉ាផ្ទាល់ភ្នែករបស់គាត់ ខ.៣០) ដែលបានលេចមកក្នុងរូបភាពជាទេវតា(មើល ហស ១២:៣–៤ និងការពន្យល់ លក ១៦:៧)។ *ចំបាប់* ការដែលព្រះយេហូវ៉ាទ្រង់បានចំបាប់(យេអាប៊ីក) ជាមួយលោកយ៉ាកុបនៅឯស្ទឹងយ៉ាបុក គឺដោយសារតែអ្នកនិពន្ធ គាត់ចង់បង្ហាញពីការតស៊ូរបស់លោកប៉ុណ្ណោះ ។ ពេញមួយជីវិតរបស់លោក គឺពោរពេញដោយការតស៊ូជារហូត ។ លើកដំបូងគាត់បានប្រឈរមុខជាមួយលោកអេសាវ ហើយក្រោយមកទៀតជាមួយលោកឡាបាន់ ហើយឥឡូវនេះដែរ គាត់ហៀបនិងចូលក្នុងទឹកដីកាណាន គាត់ត្រូវតែប្រឈរមុខចំបាប់ជាមួយព្រះយេហូវ៉ាផ្ទាល់ មិនមែនជាមួយលោកអេសាវឬជាមួយនឹងអ្នកផ្សេងដែលក្រៅពីព្រះយេហូវ៉ានោះឡើយ ។

**៣២:២៥** *កាលណាអ្នកនោះឃើញថាមិនឈ្នះគាត់ទេ នោះក៏ពាល់ត្រង់សន្លាក់ត្រគាកគាត់* ព្រះយេហូវ៉ាទ្រង់បានលេចមកក្នុងរូបភាពមួយ ដើម្បីឱ្យលោកយ៉ាកុបអាចចំបាប់ជាមួយគាត់ដោយជោគជ័យ ហើយព្រះយេហូវ៉ាទ្រង់ក៏បង្ហាញដល់យ៉ាកុបថា ព្រះអង្គក៏អាចធ្វើឱ្យលោកយ៉ាកុបក្លាយជាមនុស្សអសមត្ថភាពបានដែរ ។

**៣២:២៦** *ខ្ញុំមិនឱ្យលោកទៅទេ* នោះគ្រាន់តែជាសេចក្តីកំពុតមួយរបស់លោកយ៉ាកុប ដែលគាត់ចង់ឱ្យព្រះប្រទានពរដល់គាត់ឆាប់ៗប៉ុណ្ណោះ (សូមមើល ខ.២៩) ។ *ទាល់តែបានឱ្យពរដល់ខ្ញុំសិន* នៅទីបញ្ចប់លោកយ៉ាកុប គាត់ព្រមទទួលស្គាល់ថាមានតែព្រះយេហូវ៉ាទេដែលជាប្រភពនៃព្រះពរទាំងឡាយ ។

**៣២:២៨** *ឈ្មោះឯងមិនត្រូវហៅថា យ៉ាកុបទៀតទេ* ឥឡូវនេះ បន្ទាប់ពីលោកយ៉ាកុបគាត់ព្រមទទួលស្គាល់ថា ព្រះយេហូវ៉ាគឺជាប្រភពនៃព្រះពរទាំងឡាយ នឹងជាអ្នកនាំគាត់ឱ្យចូលក្នុងទឹកដីសន្យាមក នោះព្រះយេហូវ៉ាទ្រង់ក៏ព្រមទទួលស្គាល់ថា យ៉ាកុបជាអ្នកបម្រើរបស់ទ្រង់ដោយព្រះអង្គបានប្តូរឈ្មោះឱ្យគាត់ (មើល ១៧:៥ និងការពន្យល់) ។ *អ៊ីស្រាអែល* ដោយសារលោកយ៉ាកុបគឺអ៊ីស្រាអែល នោះបានធ្វើឱ្យប្រជាជនអ៊ីស្រាអែលទាំងអស់ក្លាយជាៈ ប្រជាជនដែលបានតស៊ូជាមួយព្រះ(ដើម្បីរំលឹកដល់ឈ្មោះលោកអ៊ីស្រាអែល) នឹងជាមួយមនុស្សផ្សេងៗទៀត (រំលឹកដល់ឈ្មោះយ៉ាកុប) ព្រមទាំងអ្នកជំនាន់ក្រោយ ។ ក្រោយមកទៀតព្រះយេហូវ៉ាទ្រង់បានបញ្ជាក់ពីឈ្មោះថ្មីរបស់លោកម្តងទៀតនៅ ៣៥:១០ ។

**៣២:២៩** *ហេតុអ្វីបានជាសួររកឈ្មោះអញ* វាមានលក្ខណៈដូចគ្នានិងសំណួម

ហេតុអ្វីបានជាសួររកឈ្មោះអញ[ធ] រួចក៏ឱ្យពរ[ន]ដល់គាត់
នៅទីនោះ ៣០យ៉ាកុបគាត់ហៅកន្លែងនោះថា ពេនីអែល[ប]
ដ្បិតគាត់នឹកថា អញបានឃើញព្រះនៅប្រទល់មុខ ហើយ
ជីវិតអញបានគង់វង្សនៅ ៣១កាលគាត់ឆ្លងត្រង់ពេនីអែល[ផ]
រួចហើយ នោះថ្ងៃបានរះឡើង គាត់ក៏ដើរខ្ញើចៗ ៣២ហេតុ
នោះបានជាពួកកូនចៅអ៊ីស្រាអែល គេមិនដែលស៊ីសាច់
ត្រគាក[ព] ដែលនៅត្រង់សន្លាក់ត្រគាកដរាបដល់សព្វថ្ងៃនេះ
ពីព្រោះទ្រង់បាន ពាល់ត្រង់សន្លាក់ត្រគាករបស់យ៉ាកុប ។

## លោកយ៉ាកុបជួបនឹងលោកអេសាវ

**៣៣** ១យ៉ាកុបគាត់ងើបភ្នែកឡើង មើលទៅឃើញអេ
សាវកំពុងមក មានទាំងមនុស្ស៤០០នាក់មកជាមួយផង[ក] រួច
គាត់ចែកកូនឱ្យដល់លេអា រ៉ាជែល ហើយនិងបាវស្រី
ទាំង២នាក់[ខ] ២គាត់ឱ្យបាវស្រីទាំង២និងកូនគេ[គ]ដើរទៅមុន
បន្ទាប់មកលេអានិងកូននាង រួចរ៉ាជែលនិងយ៉ូសែប[ឃ] ជា
ខាងក្រោយបង្អស់ ៣ខ្លួនគាត់ក៏ដើរទៅខាងមុខ ហើយឱន
ក្រោម[ង]ចុះដល់ដី៧ដង[ច] ទាល់តែជិតដល់បង ៤អេសាវ[ឆ]ក៏
រត់មកទទួល ហើយឱបថើប[ជ]រួចយំជាមួយគ្នាទាំង២នាក់[ឈ]
៥នោះអេសាវងើបភ្នែកឡើង ឃើញពួកស្រីៗនឹងកូនក្មេង
ទាំងនោះក៏សួរថា អ្នកទាំងនេះដែលនៅនិងឯង តើជាអ្នក
ណាយ៉ាកុបឆ្លើយថា នោះគឺជាកូនដែលព្រះទ្រង់បានប្រទាន
មកខ្ញុំជាអ្នកបំរើរបស់បង[ញ] ។
៦បាវស្រីទាំងពីនិងកូនគេ[ដ] ក៏ចូលមកឱនក្រាបចុះទាំង
អស់គ្នា[ឋ] ៧បន្ទាប់មកលេអានិងកូននាង[ឌ]ក៏ចូលមកឱនក្រាប
ចុះ[ឍ] ក្រោយនោះយ៉ូសែបនិងរ៉ាជែល[ណ]ក៏ចូលមកឱនក្រាប
ចុះដែរ ៨គាត់សួរយ៉ាកុបថា ឯងឱ្យពួកទាំងនោះដែល
អញឃើញអម្បាញ់មិញមកធ្វើអ្វី[ត] យ៉ាកុបជំរាបថា នោះ
ប្រយោជន៍ ឱ្យខ្ញុំបានប្រកបដោយគុណរបស់បង[ថ] ៩តែ
អេសាវឆ្លើយថា ប្អូនអើយ អញមានបរិបូរហើយ[ទ]ចូរឯង
ទុករបស់ផងឯងចុះ ១០តែយ៉ាកុបប្រកែកថា ទេ បើខ្ញុំ ប្រកប
ដោយគុណរបស់បង[ធ] នោះសូមទទួលជំនូនពីដៃខ្ញុំទៅ[ន] ដ្បិត
ខ្ញុំបានឃើញមុខបង ទុកដូចជាឃើញព្រះភក្ត្រនៃព្រះដែរ[ប]
ហើយបងបានទទួលខ្ញុំដោយស្រួល[ផ] ១១សូមជំនូនរបស់ខ្ញុំ[ព]
ដែលគេបាននាំមកជូនចុះ ដ្បិតព្រះទ្រង់បាន ប្រទានពរមក
ខ្ញុំ[ភ] ខ្ញុំក៏មានគ្រប់គ្រាន់ហើយ[ម] រួចអេសាវទទួលយកដោយ
គាត់បង្ខំ[យ] ១២អេសាវនិយាយថា ល្មមធ្វើដំណើរទៅហើយ
ចូរយើងទៅ អញនឹងដើរនាំមុខឯងទៅ ១៣តែយ៉ាកុបឆ្លើយ

ធ ពច ១៣:១៨ ន លប ២៥:១១ ៣៥:៩ ៤៨:៣ **៣២:៣០** ប លប ១៦:១៣ ១កថ ១៣:១៣ **៣២:៣១** ផ ពច ៨:៩ **៣២:៣២** ព ខ.២៥ **៣៣:១** ក លប ៣២:៦ ខ លប ៣២:៧ **៣៣:២** គ ខ.៦ ឃ លប ៣០:២៤ **៣៣:៣** ង ខ.៦,៧ លប ១៧:៣ ៣៧:៧–១០ ៤២:៦ ៤៣:២៦ ៤៤:១៤ ៤៨:១២ ១សយ ២០:៤១ ច ២ពវ ៥:១០,១៤ **៣៣:៤** ឆ លប ២៧:៤១–៤២ ជ លប ២៩:១១ លក ១៥:២០ ឈ លប ២៧:២៧ **៣៣:៥** ញ លប ១៨:៣ លក ៤៨:៩ ទដ ១២៧:៣ អស ៨:១៨ **៣៣:៦** ដ ខ.២ ឋខ.៣ **៣៣:៧** ឌ ខ.២ ឍ ខ.៣ ណ លប ៣០:២៤ **៣៣:៨** ត លប ៣២:១៤–១៦ ថ លប ២៤:៩ ៣២:៥ **៣៣:៩** ទ ខ.១១ លប ១៣:៦ **៣៣:១០** ធ លប ៣០:២៧ ៣២:៥ ន លប ៣២:១៣ ប លប ១៦:១៣ ផ លប ៣២:២០ **៣៣:១១** ព ១សយ ២៥:២៧ ៣០:២៦ ភ លប ៣០:៤៣ម ខ.៩ យ លប ១៩:៣

ពររបស់ព្រះយេហូវ៉ាដែរ គឺមិនត្រូវគិតថាវាជាការសំខាន់ឬក៏ចាំបាច់នោះឡើយ (សូមមើល ពច ១៣:១៧–១៨) ។

**៣២:៣០** *អញបានឃើញព្រះនៅប្រទល់មុខ* មើល ១៦:១៣ ពច ៦:២២–២៣ ១៣:២២ ។ ពីមុនយើងអាចមើលឃើញតែពីខាងក្រោយប៉ុណ្ណោះ (នក ៣៣:២៣) ឬឃើញត្រឹមតែព្រះបាទទ្រង់ប៉ុណ្ណោះ (មើល កន ២៤:១០) ឬឃើញតែរូបរាងប៉ុណ្ណោះ (មើល ជន ១២:៨) ។ *ជីវិតអញបានគង់វង់នៅ* ជីវិតរបស់លោកយ៉ាកុបបានគង់វង់នៅ ដោយសារតែព្រះប៉ុណ្ណោះ ហើយគាត់បានអធិស្ឋានសម្រាប់ជីវិតរបស់គាត់ឱ្យបានគង់វង់នៅ ពេលដែលគាត់ប្រឈរមុខជាមួយលោកអេសាវ (ខ.១១) ។

**៣២:៣២** *មិនដែលស៊ីសាច់ត្រគាក* ប្រហែលស្ថិតនៅជាប់នឹងសាច់ដុំ ។ ការនិយាយបែបនេះនៅក្នុងបទគម្ពីរផ្សេងៗទៀត នោះប្រហែលជាសំណេររបស់ពួកសាសនាយូដា ក្រោយៗមកទៀតប៉ុណ្ណោះ ។ លោកយ៉ាកុបបានរក្សាទុករូបកាយរបស់គាត់ ហើយអ៊ីស្រាអែលក៏បានកាន់តាមដោយមិនស៊ីសាច់ត្រគាកនេះរហូតមក ។

**៣៣:២** *រ៉ាជែលនិងយ៉ូសែបជាក្រោយបង្អស់* លោកយ៉ាកុបគាត់ចង់ដាក់ប្រពន្ធនិងកូនរបស់គាត់ឱ្យនៅឆ្ងាយពីគ្រោះថ្នាក់ដែលនឹងមកដល់ ។

**៣៣:៣** *ហើយឱនក្រាបចុះដល់ដី៧ដង* គឺជាសញ្ញានៃការបន្ទាបខ្លួនចុះចូលនិងការស្តាប់បង្គាប់ ។ គេរកឃើញឯកសាស្ត្រពិការ ឱនក្រាបចុះដល់ដីនេះដែលមានឈ្មោះថា "ធេលលេស–អាមាណា" (Tellel-Amarna) នៅក្នុងប្រទេសអេស៊ីព្ទក្នុងអំឡុងពេលសតវត្សរ៍ទី១៤ មុន គ.ស ។

**៣៣:៤** គ្រប់ទាំងសេចក្តីភ័យខ្លាចរបស់លោកយ៉ាកុប ត្រូវបានបង្ហាញឱ្យគាត់បានឃើញនាពេលនេះ ។ គឺជាពេលដែលព្រះយេហូវ៉ាទ្រង់ប្រទានពរដល់លោកអេសាវ នូវទ្រព្យសម្បត្តិជាច្រើន(ខ.៩) ដូច្នេះហើយទើបគាត់មិនប្រឆាំងនិងសងសឹកជាមួយយ៉ាកុបទេ ។

**៣៣:៩** *អញមានបរិបូរហើយ* លោកអេសាវ មានទ្រព្យសម្បត្តិដ៏បរិបូរ គឺដោយការខិតខំរបស់គាត់ផ្ទាល់ ក្នុងអំឡុងពេលដែលគាត់បានតាំងលំនៅក្នុង "ស្រុកសៀរ" (មើល ៣២:៣ ប្រៀបធៀបនិង ៣៣:១៦) ដែលស្ថិតនៅក្នុងភាគខាងត្បូងពីទឹកដីសន្យា ហើយលោកយ៉ាកុបបានតាំងព្រំប្រទល់របស់គាត់ក្នុង ប៉ាដាន់–អើរ៉ាម ភាគខាងជើងទឹកដីសន្យា ។ *ប្អូនអើយ* ការឆ្លើយតបរបស់លោកអេសាវខុសគ្នា នឹងការប្រយ័ត្ននិងការភ័យខ្លាចរបស់លោកយ៉ាកុបដែលគាត់និយាយថា "គុណរបស់បង"(ខ.៨) ។

**៣៣:១១** *ជំនូន* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា"ជំនូន" គឺមានន័យដូចគ្នានឹងពាក្យថា "ឱ្យពរ"ដែលនិយាយក្នុង ២៧:៣៥ ។ អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិបានបង្ហាញថា ពេលលោកយ៉ាកុប គាត់ព្រមទទួលស្គាល់ថាគ្រប់ទាំងព្រះពរ គឺសុទ្ធតែមកពីព្រះយេហូវ៉ា ។ នៅក្នុងការព្យាយាមចុងក្រោយរបស់គាត់គឺ គាត់បានផ្សះផ្សាឡើងវិញជាមួយអេសាវ ដោយគាត់មានគំនិតចង់ឱ្យពរទៅបងគាត់វិញដែលគាត់បានលួចពីបងគាត់ ។

**៣៣:១២** *អញនឹងដើរនាំមុខឯង* ជាលទ្ធផលដែលកើតចេញពីកន្លែង "ជំរុំទាំង២" (៣២:២) ។ លោកអេសាវគាត់ធ្វើដំណើរមក ដោយមានទាំងទ័ព៤០០នាក់មកជាមួយ ដើម្បីនឹងនាំយ៉ាកុបចូលទៅផ្ទះវិញឱ្យបានប្រកបដោយ

ថា បង់ជ្រាបហើយថា កូនក្មេងវានៅទន់ ហើយហ្វូងចៀម
ហ្វូងគោដែលនៅជាមួយនឹងខ្ញុំក៏បំបៅកូន[ល] បើបង្ខំវាឱ្យ
ដើរតែ១ថ្ងៃទៅ នោះនឹងស្លាប់ទាំងអស់ជាមិនខាន ១៤ដូច្នេះ
សូមឱ្យបងអញ្ជើញទៅមុនខ្ញុំ ជាមួយប្អូនចុះ ឯខ្ញុំៗនឹងដើរ
ទៅមួយៗតាមកំឡាំងហ្វូងសត្វ[វ] ដែលដើរមុខខ្ញុំ ហើយតាម
កំឡាំងកូនក្មេងដែរ ទាល់តែខ្ញុំទៅដល់បងនៅស្រុកសៀរ[ស]
១៥នោះអេសាវនិយាយថា បើដូច្នោះ ឱ្យអញទុកពួកអញនៅ
ជាមួយនឹងឯងដែរឬ តែគាត់ប្រកែកថា មិនថ្វីទេ សូម
ឱ្យខ្ញុំបានប្រកបដោយគុណបងចុះ[ហ] ១៦ដូច្នេះនៅថ្ងៃនោះ
ឯងអេសាវក៏ត្រឡប់វិលតាមផ្លូវទៅឯស្រុកសៀរវិញទៅ[ឡ]
១៧ហើយយ៉ាកុប គាត់ក៏ដើរដំណើរទៅដល់ស៊ុកូត[អ] រួចគាត់
ធ្វើផ្ទះសំរាប់ខ្លួន និងក្រោលសំរាប់ហ្វូងសត្វ ហេតុនោះបាន
ជាគាត់ហៅកន្លែងនោះថា ស៊ុកូត ។

១៨កាលយ៉ាកុបបានចេញពីស្រុកប៉ាដាន់–អើរ៉ាម[ក]មក
នោះគាត់ទៅដល់ស៊ីគែម[ខ] នៅស្រុកកាណាន ដោយសុខ
សាន្ត ហើយក៏ដំឡើងត្រសាលនៅមុខទីក្រុងនោះ ១៩ឯ
ដី[គ]ដែលគាត់ដំឡើងត្រសាល[ឃ] នោះគាត់ទិញពីពួកកូនចៅ
ហាម៉ោរ[ង]ជាឪពុកស៊ីគែម[ច] ថ្លៃជាប្រាក់១០០ដួង ២០រួចគាត់
ស្អាងអាសនា១នៅទីនោះ[ឆ] ក៏ដាក់ឈ្មោះថា អែល–អែល៉ូ
ហេ–អ៊ីស្រាអែល ។

## នាងឌីណា និងព្រះអម្ចាស់ស៊ីគែម

**៣៤** ១ឯឌីណា[ក] ជាកូនស្រីដែលលេអាបានបង្កើតឱ្យយ៉ា
កុប នាងចេញទៅមើលពួកកូនស្រីស្រុកនោះ ២ខណ
នោះស៊ីគែម[ខ] ជាបុត្រហាម៉ោរសាសន៍[គ]ហេវី[ឃ] ជាស្តេច
ស្រុកនោះ ទ្រង់ឃើញនាង ក៏នាំយកទៅដេកបង្ខូច[ង] ៣ទ្រង់
សព្វព្រះទ័យនឹងឌីណា[ច]ជាកូនយ៉ាកុបណាស់[ឆ] ព្រមទាំង
ប្រតិព័ទ្ធនឹងនាងផង[ជ] ហើយនិយាយលួងលោម[ឈ]ដល់នាង
៤ស៊ីគែមទូលហាម៉ោរជាបិតាថា សូមយកនាងនេះមកឱ្យ
ធ្វើជាប្រពន្ធទូលបង្គំចុះ[ញ] ៥រីឯយ៉ាកុបគាត់ក៏ឮថា គេបាន
បង្ខូចឌីណាជាកូនហើយ[ដ] តែកូនប្រុសៗរបស់គាត់កំពុងតែ
ឃ្វាលហ្វូងសត្វនៅឯវាលទាំងអស់គ្នា ដូច្នេះយ៉ាកុបក៏នៅ
ស្ងៀមទាល់តែគេបានមកវិញ ។

៦ចំណែកហាម៉ោរជាបិតាស៊ីគែមក៏មកមានបន្ទូលនឹង
យ៉ាកុប[ឋ] ៧ឯពួកកូនរបស់យ៉ាកុប កាលបានឮដំណឹងនោះ
គេក៏វិលមកទីវាលវិញ គេមានសេចក្តីឈឺចិត្ត[ឌ] ហើយខឹងជា
ខ្លាំង[ឍ] ដោយព្រោះទ្រង់បានប្រព្រឹត្តការអាស្រូវភាសនៅ
ក្នុងពួកអ៊ីស្រាអែល[ណ] គឺបានរួមដំណេកនឹងកូនក្រមុំរបស់
យ៉ាកុបជាការដែលមិនគួរគប្បីធ្វើឡើយ[ត] ៨ហាម៉ោរ ក៏មាន

**៣៣:១៣** វ ខ.៨ ល អស ៤០:១១ យរ ៣១:៨ **៣៣:១៤** វ នក ១២:៣៨ ស លប ១៤:៦ **៣៣:១៥** ហ លប ៣២:៥ **៣៣:១៦** ឡ លប ១៤:៦ **៣៣:១៧** អ យស ១៣:២៧ ពច ៨:៥,៦,៨,១៤, ១៤–១៦,១៥, ១៦ ១ពវ ៧:៤៦ ២របា ៤:១៧ ទដ ៦០:៦ ១០៨:៧ **៣៣:១៨** ក លប ២៥:២០ ខ លប ១២:៦ **៣៣:១៩** គ លប ៣៤:១០,១៦,២១ ៤៧:២៧ ឃ លប ១២:៨ ង លប ៣៤:២ ពច ៩:២៨ កច ៧:១៦ ច លប ៣៤:២ យស ២៤:៣២ **៣៣:២០** ឆ លប ៤:២៦ ៨:២០ **៣៤:១** ក លប ៣០:២១ **៣៤:២** ខ លប ៣៣:១៩ គ លប ៣៣:១៩ ឃ លប ១០:១៧ ង ចទ ២១:១៤ ២សយ ១៣:១៤ **៣៤:៣** ច ខ.២៦ ឆ ខ.១៩ ជ លប ២៤:៦៧ ឈ លប ៥០:២១ អស ១៤:១ ៤០:២ **៣៤:៤** ញ លប ២១:២១ **៣៤:៥** ដ ខ.២,១៣, ២៧ លប ៣៥:២២ ៤៩:៤ ចទ ២៧:២០ ៣៣:៦ ១របា ៥:១ **៣៤:៦** ឋ ពច ១៤:២–៥ **៣៤:៧** ឌ ១កថ ៥:២ ឍ លប ៣៩:១៩ ៤៩:៦–៧ នអ ៧:៧ សភ ៦:៣៤ ណ ចទ ២២:២១ ពច ១៩:២៣ ២០:៦ ២សយ ១៣:១២ យរ ២៩:២៣ ត លប ២០:៩

សុវត្ថិភាព (ខ.១៥) ។ លោកយ៉ាកុបបានទុកចិត្តចំពោះព្រះជាជាងទុក្ខចិត្តអេសាវនិងអ្នកបម្រើរបស់គាត់ ។

**៣៣:១៤** *ទាល់តែខ្ញុំទៅដល់បងនៅស្រុកសៀរ* យ៉ាកុបគាត់នៅតែបន្តការបោកប្រាស់ចំពោះអេសាវដដែល ដោយគាត់មិនព្រមទៅជាមួយបងប្រុសរបស់គាត់គ្រប់ទាំងផ្លូវនោះឡើយ ។

**៣៣:១៨** *ប៉ាដាន់–អើរ៉ាម* មើលក្នុង ២៥:២០ ។ *សុខសាន្ត* គឺជាចម្លើយដែលព្រះទ្រង់បានឆ្លើយដល់យ៉ាកុបចំពោះសេចក្តីអធិស្ឋាន ដែលគាត់បានអធិស្ឋានទៅព្រះកាលពី២០ឆ្នាំមុន (មើល ២៨:២១) ។ *ស៊ីគែម* មើល ១២:៦ ។ លោកយ៉ាកុបគាត់បានដើរតាមលោកអ័ប្រាហាំ (មើល ១២:៦) លោកយ៉ាកុបគាត់បានប្រព្រឹត្តយ៉ាងល្អ (សូមមើល យហ ៤:៥–៦) ។

**៣៣:១៩** *ប្រាក់១០០ដួង* ក្នុងភាសាហេព្រើរពាក្យនេះមានតែ៣ដងប៉ុណ្ណោះដែលគេនិយាយក្នុងពួកព្ធយុកោមុនៗ (សូមមើល យស ២៤:៣២ យប ៤២:១១) ។

**៣៣:២០** *ស្អាងអាសនា* មើល ១២:៧ ។ *ក៏ដាក់ឈ្មោះថា អែលអែល៉ូហេ–អ៊ីស្រាអែល* ។ លោកយ៉ាកុបធ្វើដូច្នេះដើម្បីអរព្រះគុណព្រះដែលទ្រង់ជាឪពុកហើយជាព្រះរបស់គាត់ (២៨:២១) ។ គាត់បានស្អាងអាសនានេះនៅស៊ីគែមដោយគាត់មិនបានត្រឡប់ទៅបេត–អែលវិញឡើយ (៣៥:១) ។

**៣៤:១–៣១** ឥឡូវនេះលោកយ៉ាកុបបានចូលក្នុងទឹកដីកាណាន ហើយត្រូវប្រឈរមុខនឹងគ្រោះថ្នាក់យ៉ាងខ្លាំង ដោយសារពួកគេបានភ្ជាប់ទំនាក់ទំនងជាមួយពួកកាណាន (ខ.៩,១៦) ហើយក្រោយមកទៀត គាត់បានប្រឈរមុខជាមួយនឹងបញ្ហាមួយទៀត គឺក្រោយពីជម្លោះកូនៗរបស់គាត់(មើល ខ.៣០) ។ ទាំងនោះគឺជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរមួយរបស់អ៊ីស្រាអែល ដែលបង្កើតឡើងដោយសារតែមនុស្សនៅជុំវិញខ្លួនគាត់ ។ ការផ្សព្វភ្ជាប់ទំនាក់ទំនងទាំងជម្លោះផ្សេងៗទៀតមកពីអ្នកដទៃ បញ្ហាទាំងនោះនឹងកើតមានឡើងដល់រាស្ត្ររបស់ព្រះគ្រប់មួយតំណជីវិតរបស់ពួកគេ ។ ព្រះនាមរបស់ព្រះត្រូវគេមិននិយាយទៀតឡើយនៅចុងបញ្ចប់ ជំពូក៣៣ ហើយចាប់ផ្តើមនិយាយឡើងវិញនៅក្នុង ជំពូក ៣៥ ប៉ុន្តែពេលនេះ មិនត្រូវលើកមកនោះឡើយ ដោយព្រោះតែការអាក្រក់របស់មនុស្ស (មើល ៧:១៦) ។

**៣៤:២** *ស៊ីគែម* សូមមើល ៣៣:១៩ ។ ប្រហែលជាឈ្មោះដែលគេបានដាក់ឱ្យបន្ទាប់ពីគេបានសង់ទីក្រុងឡើង ។

**៣៤:៤** *សូមយកនាងនេះមកឱ្យធ្វើជាប្រពន្ធទូលបង្គំចុះ* សូមមើលការពន្យល់ក្នុង ២១:២១ ។

**៣៤:៧** *អ៊ីស្រាអែល* គឺសំដៅលើពូជអំបូររបស់ប្រជាជនអ៊ីស្រាអែលទាំងអស់ ។ *ជាការដែលមិនគួរគប្បីធ្វើឡើយ* សូមប្រៀបធៀបជាមួយនឹងការអង្វររបស់នាងតាម៉ារ ចំពោះអាំណូន ដែលនាងស្ថិតក្នុងស្ថានភាពដូចគ្នានេះដែរ (២សយ ១៣:១២) ។

បន្ទូលនឹងគេថា ស៊ីគែមកូនខ្ញុំបាន ពេញចិត្តនឹងកូនស្រី
របស់អ្នកណាស់ ដូច្នេះ សូមអ្នកឱ្យនាង ទៅធ្វើជាប្រពន្ធវា
ទៅ[ថ] ៩ចូរអ្នករាល់គ្នាភ្ជាប់ញាតិពន្ធនឹងពួកយើងដោយឱ្យ
កូនក្រមុំរបស់អ្នករាល់គ្នាដល់ពួកយើង ហើយយកកូនក្រមុំ
របស់ពួកយើងទៅវិញចុះ[ទ] ១០នោះអ្នករាល់គ្នានឹងបាន
អាស្រ័យនៅជាមួយនឹងយើង[ធ] ហើយស្រុកយើងនេះនឹង
បាននៅចំហចំពោះអ្នករាល់គ្នា[ន] ចូរអ្នករាល់គ្នាអាស្រ័យ
នៅ ហើយធ្វើជំនួញចុះ[ប] ព្រមទាំងទិញដីទុកជាកេរ្តិ៍អាករ
សំរាប់អ្នករាល់គ្នាតទៅ[ផ] ១១ឯស៊ីគែមទ្រង់មានបន្ទូលនឹង
ឪពុកហើយនិងពួកបងប្អូននាងថា សូមអាណិតឱ្យខ្ញុំប្រកប
ដោយគុណរបស់អ្នករាល់គ្នាផង[ព] អ្វីៗដែលអ្នករាល់គ្នា
បង្គាប់មកនោះ ខ្ញុំនឹងជូនទាំងអស់ ១២ទោះបើដំឡើង
បណ្ណាការ[ភ] និងជំនូនដ៏សន្ធឹកយ៉ាងណាក៏ដោយ គង់តែខ្ញុំនឹង
ជូនតាមដែលអ្នករាល់គ្នាបង្គាប់មកមិនខាន សូមតែអាណិត
ឱ្យនាងមកធ្វើជាប្រពន្ធ របស់ខ្ញុំចុះ។
១៣នោះពួកកូនយ៉ាកុបក៏ទូលឆ្លើយដល់ស៊ីគែម នឹងហា
ម៉ោរជាបិតាទ្រង់ដោយឧបាយកលវិញ[ម] ពីព្រោះស៊ីគែម
បានបង្ខូចឌីណាជាប្អូនស្រីរបស់គេ[យ] ១៤គឺគេទូលថា យើង
ខ្ញុំនឹងឱ្យប្អូនស្រីរបស់យើងខ្ញុំ ដល់មនុស្សដែលមិនកាត់ស្បែក
ដូច្នេះមិនបានទេ[រ] ធ្វើដូច្នោះ នឹងនាំឱ្យមានសេចក្តីអាម៉ាស់
ខ្មាសដល់យើងខ្ញុំណាស់ ១៥បើចង់ឱ្យយើងខ្ញុំព្រម តាមទ្រង់
នោះមានតែ[ល]ពួកទ្រង់ត្រឡប់ដូចជាយើងខ្ញុំដែរ ដោយកាត់
ស្បែកដល់ពួកប្រុសៗទាំងអស់គ្នា[វ] ១៦នោះទើបយើងខ្ញុំនឹងឱ្យ
កូនស្រីរបស់យើងខ្ញុំដល់ពួកទ្រង់ ហើយនឹងយកកូនស្រីរបស់
ពួកទ្រង់មកវិញដែរ[ស] ដូច្នេះ យើងខ្ញុំនឹងអាស្រ័យនៅជាមួយ
នឹងទ្រង់ ហើយនឹងត្រឡប់ទៅជាសាសន៍តែ១[ហ] ១៧ប៉ុន្តែបើ
ពួកទ្រង់មិនព្រមកាត់ស្បែកធ្វើតាមយើងខ្ញុំទេ នោះយើងនឹង
យកកូនស្រីរបស់យើងមកវិញ ហើយនឹងចេញបាត់ទៅ ។

១៨ពាក្យទាំងនោះក៏នាំឱ្យពេញព្រះទ័យហាម៉ោរនឹង
ស៊ីគែមជាបុត្រទ្រង់ដែរ ១៩បុត្រកំឡោះនោះមិនបានបង្អង់
នឹងធ្វើការនោះទេ ពីព្រោះទ្រង់មានព្រះទ័យអំណរនឹង
កូនស្រីរបស់យ៉ាកុបណាស់[ឡ] ទ្រង់ជាមនុស្សដែលគេរាប់
អាន លើសជាងទាំងអស់[អ]នៅក្នុងពួកដំណាក់បិតាទ្រង់
២០នោះហាម៉ោរនឹងស៊ីគែមជាបុត្រក៏ទៅឯទ្វារក្រុង[ក]មាន
បន្ទូលនឹងពួកមនុស្សនៅទីក្រុងទ្រង់ថា ២១មនុស្សទាំងនោះ
គេមានសេចក្តីមេត្រីនឹងយើងទេ ដូច្នេះចូរឱ្យគេអាស្រ័យ
នៅក្នុងស្រុកនឹងធ្វើជំនួញជួញប្រែចុះ[ខ] ដ្បិតមើល ស្រុកនេះ
ធំល្មមឱ្យគេនៅបាន ចូរយើងយកកូនស្រីរបស់គេមកធ្វើ
ជាប្រពន្ធ ហើយឱ្យកូនស្រីរបស់ពួកយើងទៅគេដែរ[គ] ២២តែ
ដែលគេនឹងព្រមនៅជាមួយនឹងយើង ហើយត្រឡប់ជា
សាសន៍តែ១ នោះលុះត្រាតែកាលណាពួកប្រុសៗទាំងអស់
ខាងយើងបានកាត់ស្បែក[ឃ]ដូចជាគេដែរ ២៣ដូច្នេះ តើហ្វូង
គោ ទ្រព្យសម្បត្តិ និងសត្វរបស់គេទាំងអស់មិនត្រឡប់មក
ជារបស់ផងយើងទេឬអី[ង] ចូរយើងគ្រាន់តែព្រមតាមគេ
ប៉ុណ្ណោះ នោះគេនឹងនៅជាមួយយើងហើយ[ច] ២៤ឯពួកអ្នក
ដែលចេញចូលតាមទ្វារក្រុងនោះ[ឆ] គេក៏ស្តាប់តាមហាម៉ោរ
នឹងស៊ីគែមជាបុត្រទ្រង់ រួចពួកប្រុសៗគេកាត់ស្បែកទាំង
អស់គ្នា គឺអស់អ្នកដែលចេញចូលតាមទ្វារក្រុងទ្រង់ ។
២៥ដល់៣ថ្ងៃក្រោយមក កាលគេឈឺ[ជ] នោះកូនយ៉ាកុប២
នាក់ គឺស៊ីម្មាន[ឈ] និងលេវី[ញ]ជាបងឌីណាក៏កាន់យកដាវ
រៀងខ្លួន[ដ] ចូលទៅឯទីក្រុងនោះ[ឋ] ដោយឥតកោតញញើត
ហើយកាប់សំឡាប់មនុស្សប្រុសៗទាំងអស់ទៅ[ឌ] ២៦គេ
សំឡាប់ហាម៉ោរ និងស៊ីគែមជាបុត្រទ្រង់ដោយដាវ[ឍ] រួចក៏

**៣៤:៨** ថ លប ២១:២១ ចទ ២១:១១
**៣៤:៩** ទ ខ.១៦,២១ ចទ ៧:៣ យស ២៣:១២
**៣៤:១០** ធ ខ.២៣ លប ៤៦:៣៤ ៤៧:៦,២៧ ន លប ១៣:៩ ប លប ៤២:៣៤ ផ លប ៣៣:១៩
**៣៤:១១** ព លប ៣២:៥
**៣៤:១២** ភ នក ២២:១៦ ចទ ២២:២៩ ១សយ ១៨:២៥
**៣៤:១៣** ម លប ២៧:៣៦ យ ខ.៥
**៣៤:១៤** រ លប ១៧:១៤ ពច ១៤:៣ ១សយ ៣១:៤ អស ៥២:១
**៣៤:១៥** ល ១សយ ១១:២ វ ខ.២២ នក ១២:៤៨
**៣៤:១៦** ស ខ.៩ ហ លប ៣៣:១៩
**៣៤:១៩** ឡ ខ.៣ អ លប ៤៩:៣ ១របា ១១:២១
**៣៤:២០** ក លប ១៨:១
**៣៤:២១** ខ លប ៣៣:១៩ គ ខ.៩
**៣៤:២២** ឃ ខ.១៥ **៣៤:២៣** ង ខ.២៨ លប ១២:១៦ ច ខ.១០ **៣៤:២៤** ឆ លប ១៨:១ **៣៤:២៥** ជ យស ៥:៨ ឈ លប ២៩:៣៣ ញ លប ២៩:៣៤ ដ លប ៤៩:៥ មឡ ២:១៦ ឋ ពច ១៨:៧,១០,២៧ អគ ៣៨:១១ ឌ លប ៤៩:៧ **៣៤:២៦** ឍ ខ.៧ លប ៤៨:២២

**៣៤:៩** *ចូរអ្នករាល់ភ្ជាប់ញាតិពន្ធនិងពួកយើង* ពួកកាណានចង់បានព្រះរបស់លោកយ៉ាកុប ដែលគាត់ទទួលបានព្រះពរដ៏ល្អនេះមកពីព្រះ (ទាំងកូនចៅទាំងទ្រព្យសម្បត្តិរបស់ពួកគេ (ខ.២១–២៣) ។

**៣៤:១២** *ដំឡើងបណ្ណាការ* គឺជាទំនៀមទម្លាប់ដែលស្តីពីអាពាហ៍ពិពាហ៍ សូមមើល ២៤:៥៣ និងការពន្យល់ ។

**៣៤:១៣** *នោះពួកកូនយ៉ាកុបក៏ទូលឆ្លើយដល់ស៊ីគែម នឹងហាម៉ោរជាបិតាទ្រង់ដោយឧបាយកល្បវិញ* ឪពុកនិងកូនមិនខុសគ្នាឡើយ ពួកគេពោរពេញដោយការកុហក (សូមមើល ២៧:២៤ និងការពន្យល់ ២៥:២៦) ។

**៣៤:១៥** ការធ្វើពិធីកាត់ស្បែកដោយរបៀបនេះ វាគឺជាសញ្ញានៃអំពើបាបមួយ (មើល ២៧:២៤ និងការពន្យល់ ២៥:២៦) ។

**៣៤:២០** *ទ្វារក្រុង* សូមមើលការពន្យល់ ១៩:១ ២៣:១០ ។

**៣៤:២៣** ដោយសារការលោភលន់របស់ស៊ីគែម នោះគាត់ត្រូវស្លាប់ ។

**៣៤:២៤** ហេតុដែលពួកកាណានគេព្រមធ្វើតាមបំណងចិត្ត និងចុះខសន្យាជាមួយពួកគេអ៊ីស្រាអែល គឺដោយសារតែពួកគេចង់បានទ្រព្យរបស់ពួកអ៊ីស្រាអែលប៉ុណ្ណោះ ។

**៣៤:២៥** *ស៊ីម្មាន និងលេវី* ដោយសារពួកគេបានបំផ្លាញ និងទទួលជ័យជម្នះលើស៊ីគែម នោះពួកកូចៅរបស់ពួកគេនិងត្រូវខ្ចាត់ខ្ចាយទៅ (មើលការពន្យល់ ៤៩:៧) ។ *ជាបងឌីណា* អ្នកទាំង៣នោះជាកូនរបស់លេអា (២៩:៣៣–៣៤ ៣០:២១) ។ *កាប់សំឡាប់មនុស្សប្រុសៗទាំងអស់* បទអាជ្ញារបស់ ស៊ីគែម គឺមានសភាពខ្លាំងក្លា នឹងពោរពេញទៅដោយការសងសឹក (ខ.២៧–២៩) ។ កូនរបស់លោកយ៉ាកុប ពួកគេបាននាំការជំនុំជម្រះរបស់ព្រះមកលើពួកកាណាន (មើល ១៥:១៦ ហើយនិងការពន្យល់) ។

នាំឌីណា[ណ]ពីសំណាក់ស៊ីគែមចេញមក ២៧ឯពួកកូនយ៉ាកុប
ទាំងប៉ុន្មាន ក៏មកដល់ខ្មោចស្លាប់ទាំងនោះ ហើយប្លន់
ទីក្រុង[ត] ដោយព្រោះតែបានបង្ខូចប្អូនស្រីគេ[ថ] ២៨គេយកទាំង
ហ្វូងចៀម ហ្វូងគោ និងលា[ទ] ព្រមទាំងរបស់ទ្រព្យនៅក្នុង
ក្រុង ហើយនៅស្រែចំការរបស់អ្នកទាំងនោះផង[ធ] ២៩គេ
ចាប់យកទ្រព្យសម្បត្តិទាំងអស់ និងប្រពន្ធកូនរបស់ពួកនោះ[ន]
ទៅជាឈ្លើយ ហើយប្លន់យកទាំងអស់[ប] គឺគ្រប់របស់ដែល
នៅក្នុងផ្ទះគេផង[ផ] ៣០នោះយ៉ាកុបគាត់និយាយនឹងស៊ីម្មាន
ហើយនិងលេវីថា ឯងរាល់គ្នាបានធ្វើឱ្យអញថប់ព្រួយ
ណាស់[ព] ដោយសំអុយឈ្មោះអញ[ភ]នៅកណ្តាលពួកសាសន៍
កាណាន និងសាសន៍ពេរិស៊ីត ជាពួកអ្នកនៅស្រុកនេះ[ម]
ដែលអញក៏មានគ្នាតិចផង[យ] ក្រែងចួនជាគេប្រមូលគ្នាមក
វាយគ្នា នោះទាំងអញនិងពួកគ្រួអញនឹងត្រូវវិនាសទាំង
អស់ទៅ ៣១តែគេឆ្លើយថា តើគួរគប្បីដែរឬឱ្យវាមក
ប្រព្រឹត្តនឹងប្អូនយើងដូចជាស្រីសំផឹងដូច្នេះ[រ] ។

## លោកយ៉ាកុបត្រឡប់ទៅបេត-អែលវិញ

**៣៥** ១រួចមកព្រះទ្រង់មានបន្ទូលនឹងយ៉ាកុបថា ចូររៀប
ចំឡើងទៅឯបេត-អែល[ក] ហើយអាស្រ័យនៅទីនោះចុះត្រូវ
ស្អាងអាសនា១[ខ]ថ្វាយព្រះ[គ]ដែលបានលេចមកឯឯង[ឃ]
ក្នុងកាលដែលឯងរត់ចេញពីអេសាវបងឯង[ង] ២នោះ
យ៉ាកុប គាត់ប្រាប់ដល់ពួកគ្រួគាត់ និងអស់អ្នក ដែលនៅជា
មួយ[ច]ថា ចូរចោលព្រះដទៃទាំងប៉ុន្មាន[ឆ] ដែលនៅក្នុងពួក
ឯងរាល់គ្នាចេញ រួចសំអាតខ្លួន ហើយផ្លាស់សំលៀក
បំពាក់ឯងចុះ[ជ] ៣ចូរយើងរៀបចំឡើងទៅឯបេត-អែល
នៅទីនោះអញនឹងស្អាងអាសនា១ថ្វាយព្រះ[ឈ] ដែលទ្រង់បាន
ឆ្លើយមកអញ ក្នុងកាលដែលអញមានសេចក្តីវេទនា[ញ]
ហើយបានគង់ជាមួយនឹងអញ តាមផ្លូវដែលអញដើរដំណើរ
មក[ដ] ៤នោះគេក៏ប្រគល់ព្រះ ដទៃទាំងប៉ុន្មាន ដែលនៅដៃ
គេ ព្រមទាំងការវទាំងអស់ ដែលនៅត្រចៀកគេដល់យ៉ាកុប[ឋ]
រួចគាត់កប់ចោលនៅក្រោមដើមម៉ៃសាក់[ឌ] ដែលនៅជិត
ស៊ីគែម[ឍ] ៥គេក៏ធ្វើដំណើរទៅឯគ្រប់ទាំងទីក្រុង នៅជុំវិញ
ទាំងឡាយ ក៏កើតមានសេចក្តីស្ញែងខ្លាចជាខ្លាំង[ណ] គេមិន
បានដេញតាមពួកកូនយ៉ាកុបទេ[ត]។
៦យ៉ាកុបនឹងពួកអ្នកទាំងប៉ុន្មាន ដែលនៅជាមួយនឹងគាត់
ក៏ទៅដល់លូស[ថ] ដែលនៅក្នុងស្រុកកាណាន[ទ] គឺជាបេត-
អែល ៧នៅទីនោះគាត់ស្អាងអាសនា១[ធ] រួចដាក់ឈ្មោះទី
នោះថា អែល-បេត-អែល[ន] ដ្បិតគឺនៅទីនោះហើយ ដែល
ព្រះទ្រង់បានលេចមក[ប]ឯគាត់ក្នុងកាលដែលគាត់រត់ពីបង
ទៅ[ផ] ៨គ្រានោះដេបូរ៉ាជាមេនំរេបិកា[ព]ក៏ស្លាប់ ហើយគេកប់
នាងនៅ ក្រោមដើមម៉ៃសាក់[ភ]ខាងក្រោមបេត-អែល[ម]
ដែលគេ ហៅថា ដើមម៉ៃសាក់ទឹកភ្នែក ។
៩កាលយ៉ាកុបបានត្រឡប់មកពីប៉ាដាន់-អើរ៉ាម[យ]ហើយ
នោះព្រះទ្រង់លេចមកឯគាត់ម្តងទៀត ព្រមទាំងប្រទានពរ
ដល់គាត់[រ] ១០ទ្រង់មានបន្ទូលថា ឯងមានឈ្មោះថាយ៉ាកុប

ណ ខ.៣ **៣៤:២៧** ត ២ពវ ២១:១៤ ថ ខ.៥ **៣៤:២៨** ទ លប ៤៣:១៨ ធ ខ.២៣ **៣៤:២៩** ន លប ៣១:២៦ ប ជន ១៤:៣ ៣១:៩,៥៣ ចទ ២:៣៥ យស ៧:២១ ផ ២ពវ ៨:១២ អស ១៣:១៦ បទ ៥:១១ អម ១:១៣ សក ១៤:២ **៣៤:៣០** ព លប ៤៣:៦ នក ៥:២៣ ជន ១១:១១ ភ នក ៥:២១ ៦:៩ ១សយ ១៣:៤ ២៧:១២ ២សយ ១០:៦ ១របា ១៩:៦ ម លប ១៣:៧ យ លប ៣៥:២៦ ៤៦:២៧ នក ១:៥ ចទ ១០:២២ ២៦:៥ ១របា ១៦:១៩ ទដ ១០៥:១២ **៣៤:៣១** រ ខ.២ **៣៥:១** ក លប ១២:៨ ខ លប ៤:២៦ ៨:២០ គ ខ.៣ ឃ លប ១២:៧ ង ខ.៧ លប ២៧:៤៣ **៣៥:២** ច លប ១៨:១៩ យស ២៤:១៥ ឆ លប ៣១:១៩ យស ២៤:១៤ ជ នក ១៩:១០,១៤ **៣៥:៣** ឈ ខ.១ ញ លប ៣២:៧ ពច ២:១៥ ដ លប ២៦:៣ **៣៥:៤** ឋ លប ២៤:២២ នក ៣២:៣ ៣៥:២២ ពច ៨:២៤ សភ ២៥:១២ ឌ ខ.៨ ឍ លប ១២:៦ **៣៥:៥** ណ នក ១៥:១៦ ២៣:២៧ ចទ ២:២៥ យស ២:៩ ១សយ ៧:១០ ១៣:៧ ១៤:១៥ ២របា១៤:១៤១៧:១០ ២០:២៩ ទដ ៩:២០ អស ១៩:១៧ សក ១៤:១៣ ត ទដ ១០៥:១៤ **៣៥:៦** ថ លប ២៨:១៩ ទ លប ១០:១៩ **៣៥:៧** ធ លប ៨:២០ ន លប ២៨:១៩ ប លប ២៩:១៣ ផ ខ.១ **៣៥:៨** ព លប ២៤:៥៩ ភ ខ.៤ ម លប ១២:៨ ១សយ ១០:៣ **៣៥:៩** យ លប ២៥:២០ រ លប ២៨:១៣ ៣២:២៩

**៣៤:៣០** *សាសន៍ពេរិស៊ីត* មើលក្នុងការពន្យល់ ១៣:៧ ។

**៣៥:១–១៥** គឺព្រោះតែលោកអាប់រ៉ាម គាត់បានធ្វើដំណើរមកដល់ស៊ីគែម នៅចុងបញ្ចប់នៃដំណើររបស់គាត់ចូលក្នុងទឹកដីកាណាន ហើយនៅកន្លែងនេះហើយដែលព្រះយេហូវ៉ាទ្រង់សន្យាថា និងឱ្យទឹកដីកាណានដល់កូនចៅរបស់គាត់ (១២:៦–៧) ចំណែកលោកយ៉ាកុបវិញគាត់បានធ្វើដំណើរត្រឡប់ថយក្រោយវិញ ដោយគាត់ចាប់ផ្តើមធ្វើដំណើរចេញពីស៊ីគែមឆ្ពោះទៅកាន់បេតអែល ហើយនៅកន្លែងបេតអែលនោះឯងលោកយ៉ាកុបគាត់បានបោកចំបាប់ជាមួយព្រះ (២៨:១០–២២) ។

**៣៥:១** *ព្រះដែលបានលេចមកឯឯង ក្នុងកាលដែលឯងរត់ចេញពីអេសាវបងឯង* មើល ខ.៧ ២៨:១៣ ។

**៣៥:២** *ព្រះដទៃទាំងប៉ុន្មានដែលនៅក្នុងពួកឯងរាល់គ្នា* សូមមើលការពន្យល់ ៣១:១៩ និង យស ២៤:២៣ ។

**៣៥:៣** *ព្រះ . . . ហើយបានគង់ជាមួយអញ* សូមមើលការពន្យល់ ២៦:៣ ។

**៣៥:៤** *ការវ* វាមានលក្ខណៈដូចជាគ្រឿងគាថា កន្សែងយន្ត ឬជាស្នេហ៍ ហើយពួកអ្នកមិនជឿព្រះគេគិតថា វាជាសឹកមួយក្នុងសង្គ្រាម (ប្រៀបធៀបជាមួយ ហស ២:១៣) ។ *ដើមម៉ៃសាក់ដែលនៅជិតស៊ីគែម* គេស្គាល់ថាវាជាដើមឈើមួយប្រហែលជា "ដើមឈើដ៏ធំ" មួយដែលបាននិយាយក្នុង ១២:៦ (មើល យស ២៤:២៦) ។

**៣៥:៥** *សេចក្តីស្ញែងខ្លាច* ព្រះយេហូវ៉ាទ្រង់ការពារដល់អ្នកបម្រើទ្រង់ ។

**៣៥:៧** *ស្អាងអាសនា១* មើលការពន្យល់ក្នុង ១២:៧ ។

**៣៥:៨** *ដេបូរ៉ាជាមេនំរេបិកាក៏ស្លាប់* ដេបូរ៉ាបានស្លាប់ បន្ទាប់ពីនាងបានបម្រើរេបិកា ប្រកបដោយភាពស្មោះត្រង់ជាយូរមកហើយ (២៤:៥៩) ។ *ដើមម៉ៃសាក់* ជាថ្មីម្តងទៀត វាប្រហែលជាដើមឈើដ៏ធំមួយដែលគេនិយាយ ១សយ ១០:៣ ។ *ខាងក្រោម* ប្រហែលជានៅក្រោម ឬមួយស្ថិតនៅខាងត្បូងដើមម៉ៃសាក់ ។

**៣៥:៩** *យ៉ាកុបបានត្រឡប់មកពីប៉ាដាន់-អើរ៉ាម* (សូមមើលការពន្យល់ ២៥:២០) ។

**៣៥:១០** *យ៉ាកុប . . . អ៊ីស្រាអែលវិញ* ពីមុនគាត់មានឈ្មោះថាយ៉ាកុបតែឥឡូវនេះព្រះយេហូវ៉ាទ្រង់ហៅគាត់ថា អ៊ីស្រាអែលវិញពីព្រោះព្រះអង្គចង់បញ្ជាក់ពីការងាររបស់គាត់ជាថ្មីម្តងទៀតឱ្យគាត់បានដឹង (មើល ៣២:២៨)

តែមិនត្រូវហៅថាយ៉ាកុបទៀតទេគឺត្រូវហៅថា អ៊ីស្រាអែល
[ល]វិញដូច្នេះ ទ្រង់បានដាក់ឈ្មោះថា អ៊ីស្រាអែលឱ្យគាត់
១១រួចទ្រង់មានបន្ទូលនឹងគាត់ថា អញជាព្រះដ៏មានគ្រប់
ទាំងព្រះចេស្តា[វ] ចូរឯងបង្កើតកូនចំរើនជាច្រើនឡើង[ស]
និងមានសាសន៍១[ហ] គឺសាសន៍ជាច្រើនរួមគ្នាតែ១កើតពីឯង
មក ក៏នឹងមានស្តេចជាច្រើនចេញពីឯងដែរ[ឡ] ១២ឯស្រុក
ដែលអញបានឱ្យដល់អ័ប្រាហាំនិងអ៊ីសាកនោះ អញនឹងឱ្យ
ដល់ឯង គឺអញនឹងឱ្យស្រុកនោះ ដល់ពូជឯងតរៀងទៅ[អក]
១៣ព្រះទ្រង់ក៏ហោះឡើងចេញពីគាត់[ខ] នៅត្រង់កន្លែងដែល
ទ្រង់បានមានបន្ទូលនឹងគាត់ទៅ ១៤រួចយ៉ាកុបយកថ្ម១
បញ្ឈរឡើង[គ] ជាបង្គោលត្រង់កន្លែងដែលទ្រង់មានបន្ទូល
នឹងគាត់នោះ ហើយច្រួចដង្វាយច្រួច[ឃ]ពីលើ ព្រមទាំងចាក់
ប្រេងផង[ង] ១៥គាត់ហៅកន្លែងដែលព្រះបានមានបន្ទូលនឹង
គាត់ នោះថា បេត-អែល[ច] ។

## ការស្លាប់របស់នាងរ៉ាជែល និងលោកអ៊ីសាក

*៣៥:២៣-២៦ - ១របា ២:១-២*

១៦រួចមកគេចេញពីបេត-អែលដើរដំណើរទៅ នៅតែ
បន្តិចទៀត និងបានដល់អេប្រាតា[ឆ] នោះរ៉ាជែល[ជ]ក៏ឈឺ
ពោះនឹងសំរាលកូន នាងសំរាលមកដោយពិបាក ១៧កាល
នាងកំពុងតែសំរាលកូនដោយពិបាកដូច្នេះ នោះឆ្មប[ឈ]
ប្រាប់ថា កុំខ្លាចអី ដ្បិតនាងបានកូនប្រុស១ទៀត[ញ] ១៨តែ
កាលព្រលឹងកំពុងតែចេញពីនាងទៅ ដ្បិតនាងត្រូវស្លាប់
នោះនាងឱ្យកូនឈ្មោះថាបេន-អូនី[ដ] តែឪពុកហៅថា បេន-
យ៉ាមីនវិញ[ឋ] ១៩រ៉ាជែលក៏ស្លាប់ទៅ ហើយគេកប់នាងតាម
ផ្លូវទៅឯអេប្រាតា[ឌ] គឺជាបេថ្លេហិម[ឍ] ២០យ៉ាកុបគាត់បញ្ឈរ
បង្គោលថ្ម ១នៅលើផ្នូរសពនាង [ណ]គឺជាបង្គោលផ្នូរសព
របស់រ៉ាជែល ដរាបដល់សព្វថ្ងៃនេះ[ត] ។

២១រួចអ៊ីស្រាអែល គាត់ដើរដំណើរទៅដំឡើងត្រសាល
នៅខាងនាយប៉មអេឌើរ[ថ] ២២កំពុងដែលគាត់នៅក្នុងស្រុក
នោះរូបេន ក៏បានទៅរួមដំណេកនឹងប៊ីលហា[ទ]ជាប្រពន្ធ

**៣៥:១០** ល លប ១៧:៥
**៣៥:១១** វ លប ១៧:១ ស លប ១២:២ ហ លប ១២:២ ឡ លប ១៧:៦
**៣៥:១២** អ លប ២៨:១៣ ក លប ១២:៧ ១៥:៧
**៣៥:១៣** ខ លប ១៧:២២
**៣៥:១៤** គ លប ២៨:២២ ឃ នក ២៩:៤០ លវ ២៣:១៣ ជន ៦:១៥,១៧ ១៥:៥ ២៨:៧,១៤ ២សយ ២៣:១៦ ២របា ២៩:៣៥ ង លប ២៨:១៨
**៣៥:១៥** ច លប ១២:៨

**៣៥:១៦** ឆ ខ.១៩ លប ៤៨:៧ នរ ១:២ ៤:១១ ១សយ ១៧:១២ មីក ៥:២ ជ លប ២៩:៦ **៣៥:១៧** ឈ លប ៣៨:២៨ នក ១:១៥ ញ លប ៣០:២៤ **៣៥:១៨** ដ ១សយ ៤:២១ ១៤:៣ ឋ ខ.២៤ លប ៤២:៤ ៤៣:១៦,២៩ ៤៥:១២,១៤ ៤៩:២៧ ជន ១:៣៦ ចទ ៣៣:១២ **៣៥:១៩** ឌ ខ.១៦ ឍ លប ៤៨:៧ យស ១៩:១៥ ពច ១២:៨ ១៧:៧ ១៩:១,១៨ នរ ១:១, ១៩ ១សយ ១៧:១២ មីក ៥:២ **៣៥:២០** ណ ១សយ ១០:២ ត យក ៤:៩ ៧:២៦ ៨:២៨ ១០:២៧ ១សយ ៦:១៨ **៣៥:២១** ថ យក ១៥:២១ **៣៥:២២** ទ លប ២២:២៤

ហើយសម្រាប់គំរូឌ.ដែលមានការដូចគ្នានេះ (សូមប្រៀបធៀប ២១:៣១ ជាមួយ ២៦:៣៣ ២៨:១៩ ជាមួយ ៣៥:១៩) ។

**៣៥:១១-១២** ព្រឹត្តិការណ៍ទាំងនេះបានកើតចំពោះលោកអ៊ីសាក-យ៉ាកុបម្តងហើយម្តងទៀត(មើលក្នុងសេចក្តីផ្តើម) ។ ឥឡូវនេះគឺជាពេលវេលាចុងក្រោយរបស់លោកយ៉ាកុបចំពោះដំណើរមកបេត-អែលវិញ ជាកន្លែងដែលព្រះយេហូវ៉ាទ្រង់បានមានបន្ទូលជាមួយនឹងយ៉ាកុបផ្ទាល់ ពីទំនាក់ទំនងរបស់ព្រះនិងគាត់ ដោយព្រះអង្គបានបញ្ជាក់ថា ពូជរបស់យ៉ាកុបគឺជាពូជជ្រើសរើស ដែលព្រះយេហូវ៉ា បានធ្វើការសន្យាជាមួយលោកអ័ប្រាហាំ នាពេលតាំងសញ្ញា (១៧:១-៨ ២៨:៣) ។ ព្រះបន្ទូលរបស់ទ្រង់ គឺមានលក្ខណៈដូចគ្នានឹងព្រះបន្ទូលដើមដែលព្រះអង្គបានមានបន្ទូលជាមួយមនុស្សដែលព្រះអង្គបានបង្កើតដំបូង (១:២៨) ហើយព្រះអង្គក៏បានមានបន្ទូលជាថ្មីម្តងទៀតក្រោយទឹកជន់ (៩:១,៧) ។ តាមរយៈលោកយ៉ាកុប នឹងកូនចៅរបស់គាត់នោះព្រះពររបស់ព្រះចំពោះមនុស្សទាំងឡាយត្រូវបានសម្រេច (មើលក្នុង ៤៧:២៧ នក ១:៧) ។

**៣៥:១១** នៅទីនេះ ព្រះយេហូវ៉ាទ្រង់បានសម្តែងអង្គទ្រង់ថាជា "ព្រះដ៏មានគ្រប់ព្រះចេស្តា"(អែល-សាដាយ) ។ នៅឯបេត-អែល ព្រះអង្គទ្រង់បានមានបន្ទូលថា"អញជាព្រះយេហូវ៉ាជាព្រះនៃអ័ប្រាហាំជីតាឯង ហើយជាព្រះនៃអ៊ីសាក" តែទោះជាយ៉ាងនេះក៏ដោយ ព្រះនាមទាំងនោះ គឺសំដៅលើព្រះអង្គទ្រង់ផ្ទាល់ ដែលមានព្រះនាមពិតថា"អែល-សាដាយ"(មើល ១៧:១ និងការពន្យល់ ២៨:៣) ជាពិសេស ៤៨:៣ នក ៦:៣ ។

**៣៥:១៣** មើលការពន្យល់ ១៧:២២ ។

**៣៥:១៤** មើល ២៨:១៨ និងការពន្យល់ ។ *ច្រួចដង្វាយច្រួចពីលើ* គឺជាវត្ថុរាវដែលមានលក្ខណៈបរិសុទ្ធសម្រាប់ថ្វាយព្រះ ។

**៣៥:១៥** សូមមើល ២៨:១៩ និងការពន្យល់ ខ.១០ ។

**៣៥:១៦-២៩** សេចក្តីសន្និដ្ឋានរួម ពីជីវិតយ៉ាកុប ។

**៣៥:១៦** *អេប្រាតា* ពីមុនវាមានឈ្មោះថា បេថ្លេហិម (មើល ខ.១៩) ស្ថិតក្នុងស្រុកយូដា (មើល នរ ១:២ មីក ៥:២) ។

**៣៥:១៧** *កូនប្រុស១ទៀត* ដូចគ្នានឹងនាងរ៉ាជែលដែរ ដោយសារសម្រែករបស់នាង នោះព្រះទ្រង់បានប្រទានឱ្យនាងមានកូន១ទៀត គឺកំណើតយ៉ូសែប (មើល ៣០:២៤) ។

**៣៥:១៨** *បេនយ៉ាមីន* ឈ្មោះនេះអាចមានន័យថា "កូននៃទិសខាងត្បូង" ពីព្រោះកូនរបស់គាត់ផ្សេងៗទៀតកើតមក ក្នុងកាលដែលគេនៅក្នុងភាគខាងជើង ។

**៣៥:១៩** *រ៉ាជែលក៏ស្លាប់ទៅ* នាងបានស្លាប់នៅពេលឆ្លងទន្លេ (មើលការពន្យល់ ៣០:១) ។

**៣៥:២០** *ផ្នូរសពរបស់រ៉ាជែល* សូមមើល ១សយ ១០:២ ។ វាស្ថិតនៅក្បែរភូមិបេថ្លេហិម ។

**៣៥:២១** *ប៉មអេឌើរ* មានន័យថា "បណ្តុំគ្នានៃប៉ម" ដែលគេកសាងឡើងដើម្បីយាម កុំឱ្យចោរចូលលួចសត្វចៀម ឬសត្វផ្សេងៗទៀត (មើល ២របា ២៦:១០) ។ នៅក្នុងឃ្លាភាសាហេព្រើរមួយទៀត គេបានប្រៀបធៀបប៉មនេះទៅនឹងការបណ្តុំគ្នារបស់ជនជាតិយូដា (សូមមើល មីក ៤:៦-៧) ។

**៣៥:២២** ទង្វើរបស់រូបេន គឺពោរពេញដោយសេចក្តីអំនួត ជាពិសេសគឺគាត់បានទាមទារសិទ្ធិជាកូនច្បង (មើលក្នុង ២សយ ៣:៧ ១២:៨ ១៦:២១ ១ពរ ២:២២ និងការពន្យល់) ។ ដោយសារទង្វើបែបនេះគាត់នឹងត្រូវបាត់បង់សិទ្ធិជាកូនច្បង(សូមមើល ៤៩:៣-៤ ១របា ៥:១ និងមើលការពន្យល់ ៣៧:២១) ។

ចុងរបស់ឪពុកខ្លួន[ធ] ហើយអ៊ីស្រាអែលក៏ឮនិយាយ ។
វីឯកូនប្រុសរបស់យ៉ាកុប មាន១២នាក់ ២៣ឯកូនរបស់
នាងលេអា[ន] គឺរូបេន ជាកូនច្បង[ប]យ៉ាកុប ១ ស៊ីម្មាន១
លេវី១ យូដា១[ផ] អ៊ីសាខារ និងសាប់យូ៉លូ៉ន១[ព] ២៤កូន
របស់នាងរ៉ាជែល គឺយ៉ូសែប១[ភ] និងបេនយ៉ាមិន១[ម] ២៥កូន
របស់នាងប៊ីលហា[យ] ជាបាវស្រីរ៉ាជែល នោះគឺដាន់១នឹង
ណែបថាលី១[រ] ២៦កូនរបស់នាងស៊ីលផា[ល] ជាបាវ ស្រីលេអា
នោះគឺកាឌ់១[វ] និងអេស៊ើរ១[ស] នោះជាកូនប្រុសរបស់
យ៉ាកុបទាំងប៉ុន្មាន[ហ] ដែលបានកើតឡើងឱ្យដល់គាត់នៅ
ប៉ាដាន់-អើរ៉ាម[ឡ]។
២៧យ៉ាកុបក៏ទៅដល់អ៊ីសាក[អ] ជាឪពុកនៅម៉ាមរេ[ក]ជា
ទីក្រុងរបស់អើបា[ខ] គឺជាហេប្រុន[គ] ជាកន្លែងដែលអ័ប្រាហាំ
នឹងអ៊ីសាកបានសំណាក់នៅ[ឃ] ២៨ឯអ៊ីសាកគាត់បានអាយុ
១៨០ឆ្នាំហើយ[ង] ២៩នោះក្នុងកាលដែលចាស់ជរា[ច] ហើយ
ស្កប់ចិត្តនឹងអាយុខ្លួនផង[ឆ] អ៊ីសាកក៏ផុតដង្ហើមស្លាប់ទៅ
ហើយបានប្រមូលទៅមូលនឹងញាតិរបស់គាត់ រួចអេសាវ
និងយ៉ាកុបជាកូនក៏បញ្ចុះសពទៅ[ជ]។

## ដំណវង្សពីអេសាវ

*៣៦:១០-១៤ - ១រប ១:៣៥-៣៧*

*៣៦:២០-២៨ - ១រប ១:៣៨-៤២*

**៣៦** ១នេះជាបញ្ជីដំណវង្ស[ក]ពីអេសាវ គឺជាអេដំម[ខ]
២អេសាវ គាត់យកប្រពន្ធក្នុងពួកកូនស្រីស្រុកកាណាន[គ] គឺ
អ័ដា ជាកូនអេឡូន សាសន៍ហេត[ឃ] ហើយអ័ហូលីបាម៉ា[ង] ជា
កូនអ័ន៉ា[ច]ដែលជាកូនស៊ីបៀនសាសន៍ហេវី[ឆ] ៣និងបាសម៉ាត[ជ]
ជាកូនអ៊ីសម៉ាអែល ហើយជាប្អូននេបាយ៉ូត[ឈ] ៤ឯអ័ដា
នាងបង្កើតអេលីផាសឱ្យអេសាវ ហើយបាសម៉ាតនាង
បង្កើតរេហួល[ញ] ៥នាងអ័ហូលីបាម៉ាក៏បង្កើតយេអ៊ូសយ៉ា
ឡាមនិងកូរេ[ដ] នោះជាកូនរបស់អេសាវ ដែលបានកើត
ឡើងដល់គាត់នៅស្រុកកាណាន ៦រួចអេសាវ គាត់នាំប្រពន្ធ
និងកូនប្រុសកូនស្រីរបស់គាត់ ព្រមទាំងពួកអ្នកនៅផ្ទះគាត់
ទាំងអស់ និងហ្វូងសត្វ ហើយនិងរបស់ទ្រព្យទាំងប៉ុន្មាន
ដែលគាត់បានកាលនៅស្រុកកាណាន[ឋ] ចេញទៅនៅស្រុក
មួយឃ្លាតពីយ៉ាកុបជាប្អូន[ឌ] ៧ពីព្រោះទ្រព្យសម្បត្តិរបស់គេ
មានយ៉ាងសន្ធឹក និងនៅជាមួយគ្នាពុំបានស្រុកដែលគេ
សំណាក់នៅនោះ មិនល្មមនឹងចិញ្ចឹមដល់គេបានទេ ដោយ
ព្រោះហ្វូងសត្វទាំងនោះ[ឍ] ៨ដូច្នេះ អេសាវ[ណ]គាត់តាំងទី
លំនៅ នៅត្រង់ភ្នំសៀរ[ត] ឯអេសាវ នោះគឺជាអេដំម[ថ] ។
៩នេះជាដំណវង្ស[ទ] តពីអេសាវជាឰយុកោពួកសាសន៍
អេដំម[ធ] នៅក្នុងស្រុកភ្នំសៀរ ១០នេះជាឈ្មោះនៃពួកកូនចៅ
អេសាវ គឺអេលីផាសជាកូនអ័ដាប្រពន្ធអេសាវ និង រេហួល
ជាកូនបាសម៉ាតប្រពន្ធអេសាវ[ន] ១១ហើយកូនចៅរបស់

ធ លប ២៩:២៩ ៣៤:៥ លវ ១៨:៨ **៣៥:២៣** ន លប ២៩:១៦ ប លប ៤៣:៣៣ ៤៦:៨ ផ លប ២៩:៣៥ ព លប ៣០:២០ **៣៥:២៤** ភ លប ៣០:២៤ ម ខ.១៨ **៣៥:២៥** យ លប ៣៧:២ រ លប ៣០:៨ **៣៥:២៦** ល លប ៣៧:២ វ លប ៣០:១១ ស លប ៣០:១៣ ហ លប ៣៤:៣០ ៤៦:៨ នក ១:១-៤ ឡ លប ២៥:២០ **៣៥:២៧** អ លប ៣១:១៨ ក លប ១៣:១៨ ខ លប ២៣:២ យស ១៥:៥៤ ពច ១:១០ នហ ១១:២៥គ លប ១៣:១៨ ឃ លប ១៧:៨ **៣៥:២៨** ង លប ២៥:៧,២០ **៣៥:២៩** ច លប ១៥:១៥ ឆ លប ២៥:៨ ជ លប ២៣:២០ ២៥:៩ **៣៦:១** ក លប ២:៤ លប ២៥:៣០ ខ :៣០ **៣៦:២** គ លប ២៨:៨-៩ ឃ លប ២៦:៣៤ ង ខ.១៤ ,១៨ ច ខ.២៥ ១រប ១:៤០ ឆ ខ.២៤ លប ១០:១៧ ១រប ១:៤០ **៣៦:៣** ជ ខ.៤,១០, ១៣,១៧ ឈ លប ២៥:១៣ **៣៦:៤** ញ ខ.៣ ១រប ១:៣៥ **៣៦:៥** ដ ខ.១៤,១៨ ១រប ១:៣៥ **៣៦:៦** ឋ លប ១២:៥ ឌ លប ២៧:៣៩ **៣៦:៧** ឍ លប ១៣:៦ **៣៦:៨** ណ ចទ ២:៤ ត លប ១៤:៦ ថ លប ២៥:៣០ **៣៦:៩** ទ លប ២:៤ ធ ខ.១,៤៣ **៣៦:១០** ន ខ.៣ **៣៦:១១** ប ខ.១៥-១៦ ១រប ១:៤៥ យប ២:១១ ៤:១

**៣៥:២៦** *កូនប្រុសរបស់យ៉ាកុប . . . ដែលកើតឡើងដល់គាត់នៅប៉ាដាន់-អើរ៉ាម* នេះគឺជាសេចក្ដីសង្ខេបមួយ ក្នុងអំឡុងពេលដែលបេនយ៉ាមីនគាត់កើតមកក្នុងទឹកដីកាណាន (មើល ខ.១៦-១៨) ។

**៣៥:២៧** *ម៉ាមរេជាទីក្រុងរបស់អើបា គឺជាហេប្រុន* សូមមើល ១៣:១៨ ២៣:២ ។

**៣៥:២៩** សូមមើលការពន្យល់ ២៥:៨ ។ *បញ្ចុះសពទៅ* គេយកគាត់មកបញ្ចុះនៅក្នុងផ្នូរនៃក្រុមគ្រួសាររបស់គាត់ នៅឯរអាង ម៉ាក់ពេឡា (សូមមើល ៤៩:៣០-៣១) ។

**៣៦:១-៤៣** នេះគឺជាសេចក្ដីសង្ខេបអំពីតំណវង្សរបស់អេសាវដែលបានត្រឡប់ជា "នគរដ៏ធំ" ដូចដែលព្រះយេហូវ៉ាទ្រង់បានសន្យាជាមួយលោកអ័ប្រាហាំនិងនាងសារ៉ាយ (១៧:៥-៦,១៦) ពីមុនពួកគេជាកូនចៅរបស់យ៉ាកុប (មើល ៣៧:១-៥០:២៦ ៣៧:២) ។ សូមប្រៀបធៀបជាមួយកូនចៅអ៊ីសម៉ាអែល ២៥:១២-១៨ ។

**៣៦:១** *បញ្ជីដំណវង្ស* សូមមើលការពន្យល់ ២:៤ ។ ទោះបីជាពាក្យនេះត្រូវបានលើកមកនិយាយម្ដងទៀតក្នុងខ.៩ គឺដោយពាក្យទាំងនោះមិនខុសគ្នាឡើយ គឺមាននិយាយជារហូតចាប់ពី ខ.៩-៤៣ ហើយបានពង្រីកន័យក្នុង ខ.១-៨ ។ *អេសាវ* (គឺជាអេដំម) មើល ២៥:៣០ និងការពន្យល់ ។ ជនជាតិអេដំមរស់នៅភាគខាងត្បូង ឈាងខាងកើតពីសមុទ្រស្លាប់ ។

**៣៦:២-៣** សូមមើល ២៣៦:៣៤ ។

**៣៦:៧** សូមមើល ១៣:៦ ២៦:២០ និងការពន្យល់ទីនេះ ។

**៣៦:៨** *សៀរ* គឺជាឈ្មោះមួយទៀតរបស់អេដំម ។ នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរដែលមានន័យថា "សក់" គឺពាក្យនេះក៏មានន័យថា "អេសាវ" ដែរ (មើលការពន្យល់ ២៥:២៥) ។ កូនចៅឬកុលសម្ព័ន្ធរបស់ អេសាវត្រូវខ្ចាត់ខ្ចាយទៅឆ្ងាយ ដែលពួកអ្នកទាំងនោះគឺជាដើមកំណើតសាសន៍ហូរី (ខ.២០) ដែលបានតាំងលំនៅ នៅឯភ្នំសៀរ (១៤:៦) ។ កូនចៅរបស់សៀរត្រូវបាននិយាយក្នុង ខ.២០-២៨ ។

**៣៦:១០-១៤** ពួកគេទាំងនោះគឺជាកូនចៅអេសាវដដែល (សូមមើល ១រប ១:៣៥-៣៧) ដែលគេលើកមកនិយាយម្ដងទៀតក្នុង ខ.១៥-១៩ ពួកគេគឺសុទ្ធតែជាមេគ្រួរក្នុងពូជអំបូររបស់ពួកគេ ។

**៣៦:១១** *អេលីផាស ថេម៉ាន* មិត្តរបស់លោកយ៉ូបម្នាក់ឈ្មោះថាអេលីផាសជាសាសន៍ថេម៉ាន (យប ២:១១) ហើយលោកយ៉ូបផ្ទាល់គាត់បានមកពីស្រុកអ៊ូស (យប ១:១) ។ ដូច្នេះប្រហែលជាលោកយ៉ូបគាត់រស់នៅក្នុងស្រុកអេដំម

អេលីផាស[ប] គឺថេម៉ាន[ផ] អូម៉ារ សេផូរ កាថាម និង
កេណាស[ព] ១២ឯធីមណាជាប្រពន្ធចុង[ភ]របស់អេលីផាសកូន
អេសាវ នាងបង្កើតអាម៉ាលេក[ម]ឱ្យអេលីផាស នោះសុទ្ធ
តែជាកូនចៅរបស់អ័ដា ប្រពន្ធអេសាវទាំងអស់[យ] ១៣ហើយ
នេះជាកូនចៅរេហួល គឺណាហាត់ សេរ៉ាស សាំម៉ា នឹង
មីសសា នោះសុទ្ធតែជាកូនចៅរបស់បាសម៉ាត ប្រពន្ធ
អេសាវដែរ[រ] ១៤ហើយអ័ហូលីបាម៉ា[ល] ជាកូនអ័ន៉ាដែល
ជាកូន ស៊ីបៀនប្រពន្ធអេសាវ នាងបង្កើតយេអ៊ូស យ៉ាឡាម
និង កូរេឱ្យអេសាវ[វ] ។
១៥នេះជាមេ[ស]ក្នុងពួកកូនចៅអេសាវទាំងប៉ុន្មាន គឺក្នុងកូន
ចៅអេលីផាសជាកូនច្បងរបស់អេសាវ មានថេម៉ាន១[ហ]
អូម៉ារ១ សេផូរ១ កេណាស១[ឡ] ១៦កូរេ១ កាថាម១ នឹងអា
ម៉ាលេក១ នោះជាពួកមេដែលកើតពីអេលីផាស[អ] នៅស្រុក
អេដំម[ក] សុទ្ធតែជាកូនចៅរបស់អ័ដាទាំងអស់[ខ] ។
១៧នេះជាមេក្នុងពួកកូនចៅរេហួល[គ] កូនអេសាវ គឺ
ណាហាត់១ សេរ៉ាស១ សាំម៉ា១ ហើយនិងមីសសា១ នោះ
ជាពួកមេដែលកើតពីរេហួលនៅស្រុកអេដំម សុទ្ធតែជា
កូនចៅរបស់បាសម៉ាតប្រពន្ធអេសាវទាំងអស់[ឃ] ។
១៨នេះជាមេក្នុងពួកកូនចៅអ័ហូលីបាម៉ា[ង] ប្រពន្ធរបស់
អេសាវ គឺយេអ៊ូស១ យ៉ាឡាម១ ហើយនឹងកូរេ១[ច] នោះជា
ពួកមេដែលកើតពីអ័ហូលីបាម៉ា កូនអ័ន៉ា ប្រពន្ធអេសាវ
១៩នោះសុទ្ធជាកូនចៅអេសាវ[ឆ] ហើយជាមេគេទាំងអស់[ជ]
ឯអេសាវ គឺជាអេដំម[ឈ] ។
២០ឯកូនចៅសៀរ សាសន៍ហូរី[ញ]ដែលនៅក្នុងស្រុកនោះ
គឺឡូថាន សូបាល ស៊ីបៀន អ័ន៉ា[ដ] ២១ឌីសុន អេស៊ើរ នឹងឌី
សាន នោះជាពួកមេដែលកើតពីសាសន៍ហូរី ជាកូនចៅ
សៀរនៅក្នុងស្រុកអេដំមទាំងអស់[ឋ] ២២កូនចៅឡូថាន គឺ
ហូរី ហេម៉ាម ហើយប្អូនស្រីឡូថាន គឺធីមណា ២៣នេះជា
កូនចៅរបស់សូបាល គឺអាលវ៉ាន ម៉ាន៉ាហាត់ អេបាល
សេផូរ ហើយអូណាម ២៤នេះជាកូនចៅស៊ីបៀន[ឌ] គឺអៃយ៉ា
ហើយអ័ន៉ា គឺអ័ន៉ានេះដែលប្រទះឃើញក្បាលទឹកក្តៅ[ឍ]
នៅទីរហោស្ថានក្នុងកាលដែលកំពុងតែឃ្វាលលា[ណ]របស់
ស៊ីបៀន ជាឪពុកខ្លួន ២៥នេះជាកូនចៅអ័ន៉ា[ត] គឺឌីសុន និង
អ័ហូលីបាម៉ា[ថ] កូនស្រីអ័ន៉ា ២៦នេះជាកូនចៅឌីសុន គឺ
ហែមដាន់ អែសបាន់ យីតរ៉ាន និងកេរ៉ាន ២៧នេះជាកូន
ចៅអេស៊ើរ គឺប៊ីលហាន សាវ៉ាន និងយ៉ាកាន ២៨នេះជាកូន
ចៅឌីសាន គឺអ៊ូស និងអើរ៉ាន ២៩នេះជាពួកមេដែលកើតពី
ពួកហូរីមក គឺឡូថាន១ សូបាល១ ស៊ីបៀន១ អ័ន៉ា១[ទ] ៣០ឌីស
សុន១ អេស៊ើរ១ ហើយឌីសាសាន១ នោះសុទ្ធតែ ជាមេ[ធ]
ដែលកើតពីពួកហូរី នៅក្នុងស្រុកសៀរ តាមមេគេទាំង
ប៉ុន្មាន ។

### អ្នកដឹកនាំស្រុកអេដំម

*៣៦:៣១ –៤៣ – ១រប ១:៤៣–៥៤*

៣១នេះជាពួកស្តេច ដែលសោយរាជ្យនៅស្រុកអេដំម
ក្នុងគ្រាមុនដែលមានស្តេចណាមួយសោយរាជ្យលើពួកកូន
ចៅអ៊ីស្រាអែល[ន]នៅឡើយ ៣២គឺបេឡាជាកូនបេអ៊ោរ បាន
សោយរាជ្យនៅស្រុកអេដំម ហើយទីក្រុងរបស់ទ្រង់ គឺឌីន
ហាបា ៣៣បេឡាក៏សុគតទៅ រួចយ៉ូបាប់ជាកូន សេរ៉ាស
ពីបុសរ៉ា[ប] បានសោយរាជ្យជំនួសទ្រង់ ៣៤យ៉ូបាប់ក៏សុគត
ទៅ រួចហ៊ូសាមកពីស្រុកពួកថេម៉ាន[ផ] បានសោយរាជ្យ
ជំនួសទ្រង់ ៣៥ហ៊ូសាមក៏សុគតទៅ រួចហាដាឌ់ជាកូនបេដាឌ់
ដែលបានវាយពួកម៉ាឌាន[ព] នៅវាលស្រុកម៉ូអាប់[ភ] បាន
សោយរាជ្យជំនួសទ្រង់ឡើង ហើយទីក្រុងទ្រង់ គឺអាវីត
៣៦ហាដាឌ់ក៏សុគតទៅ រួចសាំឡាពីម៉ាសរេកា បានសោយ
រាជ្យជំនួសទ្រង់ ៣៧សាំឡាក៏សុគតទៅ រួចសូលពីរេហូបូត[ម]
ដែលនៅមាត់ទន្លេ បានសោយរាជ្យជំនួសទ្រង់ ៣៨សូលក៏
សុគតទៅ រួចបាល–ហាណាន់ជាកូនអ័កបោរបានសោយ
រាជ្យជំនួសទ្រង់ ៣៩បាស–ហាណាន់ជាកូនអ័កបោរ ក៏
សុគតទៅ រួចហាដារបានសោយរាជ្យជំនួសទ្រង់ ទីក្រុង
ទ្រង់ហៅថាប៉ាវ ហើយភរិយាទ្រង់នាមជាមហេថាបែល
ជាកូនម៉ាតរេឌ ដែលជាកូនមេសាហាប់ ។
៤០នេះជាឈ្មោះនៃពួកមេ[យ]ដែលកើតពីអេសាវមកតាម
គ្រួតាមស្រុក តាមឈ្មោះគេ គឺធីមណា១ អាលវ៉ា១
យេថេត១ ៤១អ័ហូលីបាម៉ា១ អេឡា១ ពីណូន១
៤២កេណាស១ ថេម៉ាន១ មីបសារ១ ៤៣ម៉ាកឌាល១ នឹងអ៊ី

ផ យរ ៤៩:៧,២០ អគ ២៥:១៣ អម ១:១២ អប ១:៩ ហព ៣:៣ ព ខ.១៥ **៣៦:១២** ភ លប ២២:២៤ ម នក ១៧:៨,១៦ ជន ២៤:២០ ចទ ២៥:១៧,១៩ ១សយ ១៥:២ ២៧:៨ យ ខ.១៦ **៣៦:១៣** រ ខ.៣ **៣៦:១៤** ល ខ.២ វ ខ.៥ **៣៦:១៥** ស ខ.១៩,៤០ នក ១៥:១៥ ហ យប ២:១១ យរ ៤៩:៧ អគ ២៥:១៣ អម ១:១២ ហព ៣:៣ ឡ ខ.១១ **៣៦:១៦** អ ខ.១១ ក លប ៣២:៣ នក ១៥:១៥ ជន ២០:១៤ ៣៣:៣៧ ខ ខ.១២ **៣៦:១៧** គ ១រប ១:៣៧ ឃ ខ.៣ **៣៦:១៨** ង ខ.២ ច ខ.៥ **៣៦:១៩** ឆ ១រប ១:៣៥ ជ ខ.១៥ ឈ លប ៣០ **៣៦:២០** ញ លប ១៤:៦ ដ ខ.២៩ **៣៦:២១** ឋ ខ.៣០ **៣៦:២៤** ឌ ខ.២ ឍ យស ១៥:១៩ ណ យប ១:១៤ **៣៦:២៥** ត ខ.២ ថ ខ.២ **៣៦:២៩** ទ ខ.២០ **៣៦:៣០** ធ ខ.២១ **៣៦:៣១** ន លប ១៧:៦ **៣៦:៣៣** ប អស ៣៤:៦ ៦៣:១ យរ ៤៩:១៣,២២ **៣៦:៣៤** ផ យរ ៤៩:៧ អគ ២៥:១៣ អប ១:៩ **៣៦:៣៥** ព លប ២៥:២ ភ លប ១៩:៣៧ ជន ២១:១១ ២២:១ ចទ ១:៥ ពច ៣:៣០ នរ ១:១,៦ **៣៦:៣៧** ម លប ២៦:២២ **៣៦:៤០** យ ខ.១៥

---

(សូមមើល ខ.២៨,៣៤) ។

**៣៦:១២** *អាម៉ាលេក* សូមមើល ១៤:៧ ។

**៣៦:២០–២៨** សូមមើល ខ.៨ ។ ពួកគេទាំងនោះគឺជាកូនចៅរបស់សៀរ (១រប ១:៣៨–៤២) គឺបានលើកមកពី ខ.២៩–៣០ ដែលអ្នកទាំងនោះគឺជាមេគ្រួររបស់គេ ។

**៣៦:៣០** *មេ* គឺជាមេនៃពូជអំបូររបស់គេ (ប្រៀបធៀប យស ១១:២៣) ។

**៣៦:៣១** *មុនដែលមានស្តេចណាមួយសោយរាជ្យលើពួកកូនចៅអ៊ីស្រាអែល* មើលទៅហាក់បីដូចជានិយាយថា ពួកកូនចៅអ៊ីស្រាអែលគេរស់នៅប្រកបដោយសេរីភាព និងរស់ដោយរាជាធិបតេយ្យ (សូមមើល ១៤:១៤) ។

**៣៦:៤៣** *នេះជាព្ធយុកោនៃពួកសាសន៍អេដំម* នេះគឺជាការសង្ខេបមួយក្នុង

រ៉ាម១ នោះជាពួកមេរបស់សាសន៍អេដំម តាមទីលំនៅគេ
នៅក្នុងស្រុកជាកេរ្តិ៍អាកររបស់គេ អ៊ីអេសាវនេះជាព្ធយុ
កោនៃពួកសាសន៍អេដំម[វ] ។

## សុបិន្តរបស់លោកយ៉ូសែប

**៣៧** ១ឯយ៉ាកុបគាត់អាស្រ័យនៅក្នុងស្រុកកាណានជាស្រុក
ដែលឪពុកបានស្នាក់នៅ[ក] ទុកដូចជាសាសន៍ដទៃ[ខ] ២នេះ
ជាពង្សាវតារ[គ]នៃពួកកូនចៅរបស់យ៉ាកុប រីឯយ៉ូសែប[ឃ]
កាលមានអាយុ១៧ឆ្នាំ[ង] នោះគាត់តែងតែឃ្វាលហ្វូងសត្វ[ច]
ជាមួយនឹងពួកបងប្អូន ក្មេងជំទង់នោះក៏នៅជាមួយនឹងពួក
កូនប៊ីលហា[ឆ] និងកូនស៊ីលផា[ជ] ជាប្រពន្ធរបស់ឪពុកខ្លួន
ហើយគាត់នាំរឿងពីការអាក្រក់របស់គេ[ឈ]មកប្រាប់ដល់
ឪពុក ៣ឯអ៊ីស្រាអែល[ញ]គាត់ស្រឡាញ់យ៉ូសែបលើសជាងកូន
ទាំងអស់[ដ] ពីព្រោះជាកូនដែលកើតមកក្នុងកាលដែលគាត់
ចាស់ហើយ[ឋ] គាត់ធ្វើអាវ១ដ៏មានពណ៌ច្រើន[ឌ]ឱ្យពាក់[ឍ] ៤បង
ទាំងប៉ុន្មានក៏ឃើញថា ឪពុកស្រឡាញ់យ៉ូសែបលើសជាង
កូនទាំងអស់ បានជាគេព្រួតគ្នាស្អប់ដល់គាត់[ណ] ហើយ
និយាយអ្វីនឹងគាត់ដោយស្រួលពុំបានទេ ។
៥មានថ្ងៃ១ យ៉ូសែបបានយល់សប្តិ[ត] ក៏និយាយសប្តិនោះ
ប្រាប់ដល់ពួកបងៗទាំងប៉ុន្មាន[ថ] តែនោះគេរឹតតែស្អប់គាត់
ជាខ្លាំងទៅទៀត[ទ] ៦គាត់ប្រាប់ថា សូមស្តាប់សប្តិខ្ញុំនេះសិន
៧ដ្បិត យើងរាល់គ្នាកំពុងតែចង[ធ]កណ្តាប់នៅស្រែនោះ
កណ្តាប់របស់ខ្ញុំក៏ឈរឡើង ហើយមើល កណ្តាប់របស់
អ្នករាល់គ្នាបានមកព័ទ្ធជុំវិញ ហើយក្រាបគោរពចំពោះ
កណ្តាប់របស់ខ្ញុំ[ន] ៨ពួកបងៗឆ្លើយឡើងថា បើដូច្នេះឯង
នឹងគ្រប់គ្រងលើយើងឬ ឯងនឹងធ្វើជាចៅហ្វាយ លើយើង
មែនឬ[ប] ហើយគេក៏ស្អប់គាត់រឹតតែខ្លាំងឡើង[ផ] ដោយ
ព្រោះសប្តិនឹងពាក្យ សំដីរបស់គាត់ ។
៩គាត់យល់សប្តិឃើញទៀត[ព] ហើយក៏ប្រាប់ដល់ពួកបង
គាត់ថា ខ្ញុំបានយល់សប្តិឃើញដូច្នេះទៀត គឺថ្ងៃ ខែ និង
ផ្កាយទាំង១១[ភ] បានក្រាបគោរពដល់ខ្ញុំ[ម] ១០គាត់ក៏និយាយ
ប្រាប់ដល់ទាំងឪពុកហើយនិងពួកបងៗដែរ[យ] តែឪពុក
បន្ទោស[រ]ថា ឯងបានយល់សប្តិឃើញអ្វីដូច្នេះ តើត្រូវឱ្យអញ
និងម្តាយឯង ហើយបងប្អូនទាំងអស់ក្រាបនៅ ដីគោរពដល់

**៣៧:១** ក លប ១៧:៨ ខ លប ១០:១៩ **៣៧:២** គ លប ២:៤ ឃ លប ៣០:២៤ ង លប ៤១:៤៦ ២សយ ៥:៤ ច លប ៤៦:៣២ ១សយ ១៦:១១ ១៧:១៥ ទដ ៧៨:៧១ អម ៧:១៥ ឆ លប ៣៥:២៥ ជ លប ៣៥:២៦ ឈ ១សយ ២:២៤ **៣៧:៣** ញ លប ១៧:៥ ដ លប ២៥:២៨ ឋ លប ៤៣:២៧ ៤៤:២០ ឌ ខ.២៣,៣១,៣២ ២សយ ១៣:១៨–១៩ ឍ លប ៤៣:៣៤ ៤៥:២២ ១សយ ១:៤–៥ នក ២:៩ **៣៧:៤** ណ ខ.២៤ លប ២៧:៤១ កច ៧:៩ **៣៧:៥** ត លប ២០:៣ ២៨:១២ ថ ខ.១០ ទ ខ.៨ **៣៧:៧** ធ នរ២:៧,១៥ ន ខ.៩,១០ លប ២៧:២៩ ៤២:៦,៩ ៤៣:២៦,២៨ ៤៤:១៤ ៥០:១៨ ២សយ ១:២ ៩:៦ **៣៧:៨** ប លប ៤១:៤៤ ៤២:១០ ៤៤:១៦,១៨ ៤៨:២២ ៤៩:២៦ ចទ ៣៣:១៦ ផ ខ.៥ **៣៧:៩** ព ខ.៧ លប ២៨:១២ ភ វវ ១២:១ ម ចទ ៤:១៩ ១៧:៣ **៣៧:១០** យ ខ.៥ រ នរ ២:១៦ ទដ ៩:៥ ៦៨:៣០ ១០៦:៩ ១១៩:២១ អស ១៧:១៣ ៥៤:៩ សក ៣:២ ល ខ.៧ លប ៩:២៥ ៣៣:៣ **៣៧:១១** វ លប ២៦:១៤ កច ៧:៩ ស

ជំពូកទាំងអស់ (ដូចជា ខ.១ គឺជាចំណងជើងក្នុងជំពូកទាំងមូល) ។

**៣៧:១–៥០:២៦** នៅក្នុងជំពូកទាំងនេះ គឺនិយាយអំពីយ៉ាកុបនិងយ៉ូសែប (មើលក្នុងសេចក្តីផ្តើម) ។ ម្យ៉ាងវិញទៀត នៅក្នុងជំពូកទាំងនោះបានផ្តោតសំខាន់លើកូនៗរបស់លោកយ៉ាកុប នឹងរបៀបដែលពួកគេតំណាងឱ្យទាំងការល្អនិងជម្ងឺ នៅក្នុងត្រកូលលោកអ័ប្រាហាំ អ៊ីសាក ហើយនិងយ៉ាកុប ដែលអ្នកទាំងនោះ គឺជាមនុស្សដែលព្រះបានរើសឡើង ដើម្បីបង្ហាញពីសេចក្តីសង្គ្រោះរបស់ទ្រង់ ។

**៣៧:១** *ស្រុកកាណាន* លោកយ៉ាកុបបានយកទឹកដីសន្យានេះតាំងជាលំនៅរបស់គាត់ ហើយក្រោយមកទៀត ក៏បានបញ្ចុះសពគាត់នៅក្នុងទឹកដីកាណាននេះទៀត (៤៩:២៩–៣០ ៥០:១៣) ។ មិនតែប៉ុណ្ណោះសោត លោកយ៉ូសែបក៏បានបញ្ចុះសពនៅទីនេះដែរ ពីព្រោះវាជាទឹកដីដែលព្រះបានសន្យាឱ្យគេ (៥០:២៤–២៥) ។

**៣៧:២** *ពង្សាវតារ* សូមមើល ២:៤ ។ ព្រះបន្ទូលទីនេះ គឺនិយាយពីសេចក្តីផ្តើមនឹងចុងបញ្ចប់ផ្នែកសំខាន់ៗទាំង១០នៃព្រះគម្ពីរលោកុប្បត្តិ ។ *យ៉ូសែប* អ្នកនិពន្ធបានលើកពីលោកយ៉ូសែបមកនិយាយ ពីព្រោះលោកយ៉ូសែបគាត់គឺជាមនុស្សចុងក្រោយក្នុងចំណោមពួកព្ធយុកោសំខាន់ៗ ។ នៅក្នុងចំណោមតំណវង្ស គាត់គឺជាមនុស្សម្នាក់ដែលប្រកបដោយភាពទទួលខុសត្រូវ ហើយតំណាងឱ្យពួកកូនចៅអ៊ីស្រាអែលទាំងអស់ ដែលបានតស៊ូជាមួយព្រះ នឹងបណ្តាជន (៣២:២៨) ហើយមិនតែប៉ុណ្ណោះ គាត់គឺជាប្រភពនៃព្រះពរទាំងឡាយដល់មនុស្សទាំងអស់(១២:២–៣) ។ មួយវិញទៀតតាមរយៈជីវិតរបស់យ៉ូសែប នោះក្រុមគ្រួសារទាំងឡាយដែលព្រះយេហូវ៉ាទ្រង់បានតាំងសញ្ញាជាមួយដែលរស់នៅក្នុងទឹកដីកាណាន បានក្លាយជាអ្នកមានទ្រព្យសម្បត្តិជាច្រើននៅក្នុងស្រុកអេស៊ីព្ទ រហូតដល់គ្រាដែលគេចាកចេញ ។ ផ្ទៃរឿងដែលនិយាយពីទំនាក់ទំនងដ៏ល្អរបស់ព្រះ ជាមួយរាស្ត្រទ្រង់ វាគឺជាស្រមោលមួយដែលបង្ហាញពីទំនាក់ទំនងរបស់ទ្រង់ជាមួយពួកកូនចៅអ៊ីស្រាអែលក្រោយៗទៀតដែលមាននៅក្នុងព្រះគម្ពីរ ។

**៣៧:៣** *ធ្វើអាវ១ដ៏មានពណ៌ច្រើន* បង្ហាញពីសេចក្តីស្រឡាញ់របស់លោកយ៉ាកុប "ដ្បិតពួកបុត្រីស្តេច ដែលនៅក្រមុំធ្លាប់តែងអង្គយ៉ាងនោះ" ២សយ ១៣:១៨។

**៣៧:៥** *យល់សប្តិ* សូមមើល ២០:៣ ។

**៣៧:៧** *ក្រាបគោរព* សុបិន្តរបស់លោកយ៉ូសែប នឹងក្លាយជាការពិត (៤២:៦ ៤៣:២៦ ៤៤:១៤) ។

**៣៧:៨** *ឯងនឹងធ្វើជាចៅហ្វាយលើយើងមែនឬ* ក្រោយមកលោកយ៉ូសែបត្រូវបាន "ពង្រាត់ចេញពីបងប្អូនខ្លួន" (ចទ ៣៣:១៦) បន្ទាប់មកទៀតគាត់ទទួល "អំណាចនៃបងច្បង"(១របា ៥:២) ហើយនៅចុងក្រោយ លោកយ៉ូសែបបានទទួលចំណែកមរតក២ដងលើបងប្អូនរបស់គាត់ (២៥:៥) ក្នុងអំឡុងពេលដែលឪពុករបស់គាត់ ចិញ្ចឹមកូនប្រុសរបស់គាត់២នាក់ទៀត (៤៨:៥) ។

**៣៧:១០** *ម្តាយឯង* ប្រហែលជាលោកយ៉ាកុបនិយាយពីនាងលេអា ពីព្រោះនាងរ៉ាជែលបានស្លាប់ហើយ (សូមមើល ៣៥:១៩) ។ *ក្រាបនៅដីគោរពដល់ឯងឬ* របៀបនៃការនិយាយ ដូចគ្នានឹងការឱ្យពររបស់លោកអ៊ីសាកចំពោះយ៉ាកុបដែរ (២៧:២៩) ។

ឯងឬ[ល] ១១ហើយពួកបងៗក៏ច្រណែននឹងគាត់[វ] តែឪពុក
បានកំណត់រឿងនោះទុក[ស] ។

## លោកយ៉ូសែបត្រូវបងៗលក់

១២ពួកបងគាត់នាំគ្នាទៅឃ្វាលហ្វូងសត្វរបស់ឪពុកនៅ
ឯស៊ីគែម[ហ] ១៣ហើយអ៊ីស្រាអែល[ឡ]និយាយទៅយ៉ូសែបថា
ពួកបងឯងបានទៅឃ្វាលសត្វឯស៊ីគែមហើយ[អ] ចូរឯងមក
ណេះអញនឹងប្រើទៅឯគេ នោះគាត់ឆ្លើយទៅឪពុកថា
"បាទ" ១៤រួចឪពុកប្រាប់ថា ចូរឯងទៅមើលឥឡូវ តើបងៗ
របស់ឯង[ក] និងហ្វូងសត្វសុខសប្បាយទេឬ រួចសឹមមក
ប្រាប់ដល់អញវិញ ដូច្នេះឪពុកក៏ចាត់ឱ្យគាត់ចេញពីវាល
ច្រកហេប្រុនទៅ[ខ] ហើយគាត់ទៅដល់ស៊ីគែម ១៥នោះមាន
មនុស្សម្នាក់ឃើញ គាត់ដើរវើមវាមនៅវាល ក៏សួរថា
ឯងរកអី ១៦គាត់ឆ្លើយថា ខ្ញុំរកបងប្អូនខ្ញុំសូមប្រាប់ឱ្យខ្ញុំ
ដឹងកន្លែង ដែលគេឃ្វាលសត្វផង ១៧អ្នកនោះប្រាប់ថា
គេបានចេញពីនេះទៅហើយអញឮគេថា ចូរយើងទៅឯ
ដូថាន់វិញ នោះយ៉ូសែបក៏ទៅតាម ឃើញនៅឯដូថាន់[គ] ។
១៨លុះគេឃើញគាត់ពីចំងាយ នោះគេមត់សំរេចគ្នាថា
នឹងសំឡាប់គាត់ចោល ក្នុងកាលមុនដែលគាត់ទៅដល់[ឃ]
១៩គេនិយាយគ្នាទៅវិញទៅមកថា នុ៎ះន៎ អាមេសប្តិបាន
មកដល់ហើយ[ង] ២០ចូរយើងសំឡាប់វាឥឡូវ ទំលាក់ចុះក្នុង
អណ្តូងណាមួយទៅ[ច] រួចសឹមនិយាយថា មានសត្វសាហាវ[ឆ]
ណាបានហែកវាស៊ីទៅហើយ[ជ] យើងនឹងមើល តើនឹងមានអ្វី
កើតពីសប្តិនោះមក[ឈ] ២១ឯរូបេន[ញ]ក៏ឮ ហើយគាត់ខំជួយ
ឱ្យបានរួចពីកណ្តាប់ដៃគេ គាត់និយាយថា កុំឱ្យយើងយក
ជីវិតវាឡើយ[ដ] ២២រួចរូបេននិយាយទៅគេថា កុំឱ្យកំចាយ
ឈាមអីឱ្យគ្រាន់តែទំលាក់វាទៅក្នុងអណ្តូង[ឋ] នៅទីរហោ
ស្ថាននេះចុះ កុំឱ្យដាក់ដៃធ្វើវាឡើយ ដោយគំនិតគាត់ប៉ង
នឹងជួយឱ្យយ៉ូសែបរួចពីកណ្តាប់ដៃរបស់គេ ដើម្បីនឹង
បញ្ជូនឱ្យត្រឡប់ទៅឯឪពុកវិញ[ឌ] ២៣កាលយ៉ូសែបបានមក
ដល់ពួកបងហើយ នោះគេក៏បកអាវគាត់ចេញ គឺជាអាវ
មានពណ៌ច្រើន[ឍ] ដែលគាត់ពាក់មកនោះឯង ២៤គេក៏យក
គាត់ទៅទំលាក់នៅក្នុងអណ្តូងទៅ[ណ] ឯអណ្តូងនោះគ្មានទឹក
ទេ ២៥រួចគេនាំគ្នាអង្គុយបរិភោគបាយ គេក៏ងើបភ្នែកឡើង
ឃើញពួកអ៊ីសម៉ាអែល[ត] ដែលកំពុងតែមកពីស្រុកកាឡាត[ថ]
មានគ្រឿងម្ហូប ជ័រពិដោរ[ទ] និងជ័រល្វីងទេស[ធ] ផ្ទុកលើសត្វ
អូដ្ឋរៀងខ្លួន ដើម្បីនាំទៅឯស្រុកអេស៊ីព្ទ[ន] ២៦នោះយូដា[ប]

លក ២:១៩,៥១ **៣៧:១២** ហ លប ១២:៦ **៣៧:១៣** ឡ លប ១៧:៥ អ លប ៣៣:១៩ **៣៧:១៤** ក ១សយ ១៧:១៨ ខ លប ១៣:១៨ **៣៧:១៧** គ ២ពវ ៦:១៣ **៣៧:១៨** ឃ ១សយ ១៩:១ ២របា២៤:២១ ទដ ៣១:១៣,២០ ៣៧:១២មថ ១២:១៤ មក ១៤:១ កច២៣:១២ **៣៧:១៩** ង លប ២៨:១២ **៣៧:២០** ច ខ.២២ យរ ៣៨:៦,៩ ឆ ខ.៣៣ លវ ២៦:៦ ២២ ចទ ៣២:២៤ ២ពវ ១៧:២៥ អក ៣៤:២៥ ជ ខ.៣១–៣៣ លប ៤:១០ ឈ លប ៥០:២០ **៣៧:២១** ញ លប ២៩:៣២ ដ លប ៤២:២២ **៣៧:២២** ឋ ខ.២០ ឌ ខ.២៩–៣០ **៣៧:២៣** ឍ ខ.៣ **៣៧:២៤** ណ ខ.៤ លប ៤៩:២៣ យរ ៣៨:៦ ៤១:៧ អក ២២:២៧ **៣៧:២៥** ត លប ១៦:១១ ថ លប ៣១:២១ ៤:១ ទ យរ ៨:២២ ២២:៦ ៤៦:១១ ធ លប ៤៣:១១ នក ៣០:២៣ ទដ ៤៥:៨ សភ ៧:១៧ ១:១៣ ម ថ ២:១១ ន ខ.២៨ លប ៣៩:១ ទដ ១០៥:១៧ **៣៧:២៦** ប លប

**៣៧:១១** *បានកំណត់រឿងនោះទុក* វាគឺជាតម្រុយមួយបញ្ជាក់ថា នៅពេលមួយលោកយ៉ាកុប គាត់នឹងរាប់រឿងនេះជារឿងពិត ។ ប្រៀបធៀបរឿងនេះជាមួយនឹងរឿងដែលកើតឡើងចំពោះនាងមារា ដែលនាងបានឆ្លើយតបក្នុងអំឡុងពេលកុមារភាពរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល លក ២:១៩,៥១) ។

**៣៧:១២** *ស៊ីគែម* សូមមើល ១២:៦ ៣៣:១៨ និងការពន្យល់ ។

**៣៧:១៧** *ដូថាន់* មានចម្ងាយប្រមាណជា៣ម៉ៃយ ភាគខាងជើងនៃតំបន់ស៊ីគែម ហើយសព្វថ្ងៃនេះ ដូថាន់គឺបានក្លាយជាទីក្រុងបុរាណទៅហើយ ។

**៣៧:១៩** *អាមេសុបិន្ត* ក្នុងភាសាហេព្រើរពាក្យនេះមានន័យថា "មេសុបិន្ត" ឬ "ជំនាញនៃសុបិន្ត" ហើយនៅទីនេះ បងៗរបស់គាត់ប្រើពាក្យនេះគឺដើម្បីបញ្ឈឺចិត្តយ៉ូសែបប៉ុណ្ណោះ ។

**៣៧:២១** *ឯរូបេនក៏ឮ ហើយគាត់ខំជួយឱ្យបានរួចពីកណ្តាប់ដៃគេ* គឺជាកូនច្បងរបស់លោកយ៉ាកុប ពីមុនគាត់មិនបានទទួលខុសត្រូវចំពោះយ៉ូសែបទេ នៅថ្ងៃនេះ គាត់អាចនឹងចងចាំពីប្អូនរបស់គាត់ទុកក្នុងចិត្ត (៤២:២២) ។ ដំបូងឡើយការប៉ុនប៉ងរបស់រូបេនមើលទៅហាក់បីដូចជាទទួលជ័យជម្នះ (៣០:១៤,១៧) ។ ប៉ុន្តែបន្ទាប់ពីគាត់បានប្រព្រឹត្តសាហាយស្មន់ជាមួយនាងប៊ីលហាមក (៣៥:២២ និងការពន្យល់) គ្រប់ការទាំងអស់ដែលគាត់ធ្វើគឺគ្មានតម្លៃទៀតឡើយ (៤២:៣៧–៣៨) គាត់ត្រូវបាត់បង់អំណាចជាបងច្បង (៤៩:៣–៤) ។ អំណាចនៃការដឹកនាំត្រូវបានមកយូដាវិញ (មើល ខ.២៦–២៧ ៤៣:៣–៥,៨–១០ ៤៤:១៤–៣៤ ៤៦:២៨ ៤៩:៨–១២) ។

**៣៧:២៣–២៤** សម្រាប់ភាពប្រហាក់ប្រហែលគ្នា (សូមមើលការពន្យល់ ខ.២១) ។ នៅក្នុងស្រុកអេស៊ីព្ទ លោកយ៉ូសែប (ទោះបីជាគាត់មិនបានធ្វើអ្វីខុសក៏ដោយ) គាត់អាចត្រូវគេដកចេញពីតំណែង ហើយបញ្ជូនគាត់ទៅក្នុងគុកដោយសារល្បិចកល (ជំពូក៣៩) អាវរបស់គាត់ត្រូវបានរហែកហើយយកបំណែកនោះទៅបង្ហាញបូទីផា ប៉ុន្តែនៅចុងបំផុតគាត់ត្រូវបានរួចខ្លួនវិញ (មើល ៤១:១៤) ។

**៣៧:២៥** *ពួកអ៊ីសម៉ាអែល* ពួកនេះគេអាចហៅម្យ៉ាងទៀតថាពួកសាសន៍ម៉ាឌាន (ខ.២៨ ពច ៨:២២,២៤,២៦) និងសាសន៍ម៉ាឌាន (ខ.៣០) ។ ក្រុមផ្សេងៗទៀតបានមានទំនាក់ទំនងជាមួយគ្នា ចាប់តាំងពីគ្រាដែលពួកម៉ាឌានគឺជាអ៊ីសម៉ាអែល ជាកូនលោកអ័ប្រាហាំមកម្ល៉េះ ។ *កាឡាត* សូមសូមមើល ៣១:២១ ។ *ជ័រពិដោរ* គឺជាប្រេងឬជាការជាឱសថសម្រាប់ព្យាបាលជម្ងឺបានយ៉ាងសក្តិសិទ្ធិ (យរ ៥១:៨) ផលិតចេញពីផ្លែឈើ ឬចម្រាញ់ចេញពីដើមឈើតូចៗជាច្រើនមុខ ។ ជ័រពិដោររបស់ស្រុកកាឡាតគឺជាជ័រមួយដែលមានតម្លៃបំផុត (យរ ៨:២២ ៤៦:១១) ។ *ជ័រល្វីងទេស* ប្រហែលវាជាជ័រដែលមានក្លិនក្រអូប (ទដ ៤៥:៨ សភ ៧:១៧ បស ៣:៦ ៥:១៣) ។ ជ័រនេះផលិតឡើងដោយសារផ្កាកុលាប ។ ជ័រនេះគេក៏ប្រើជាឱសថសម្រាប់ព្យាបាលជម្ងឺដែរ (មើល នអ ២:១២) ពេលខ្លះគេយកវាមកលាយចូលគ្នាជាមួយស្រាហើយពិសារ ដើម្បីបំបាត់ការឈឺចាប់ (មក ១៥:២៣) ។ ជ័រនេះជាដង្វាយដ៏សក្តិសមសម្រាប់ស្តេច ហើយវាក៏ជាជ័រមួយដែលគេបានយកមកថ្វាយព្រះយេស៊ូវបន្ទាប់ពីទ្រង់ប្រសូតមក (មថ ២:១១) មិនតែប៉ុណ្ណោះជ័រនេះគេបានយកវាមកដាក់ជាមួយព្រះសពព្រះយេស៊ូវ បន្ទាប់ពីទ្រង់បានសុគត (យហ ១៩:៣៩–៤០) ។

និយាយទៅបងប្អូនថា បើយើងសំឡាប់ប្អូនទៅ ហើយលាក់
ឈាមវាតើមានកំរៃអ្វី[ផ] ២៧ដូច្នេះ ចូរយើងលក់វាទៅឱ្យពួក
អ៊ីសម៉ាអែលវិញ កុំឱ្យយើងពាល់វាឡើយ ដ្បិតវាជាបងប្អូន[ព]
ជាសាច់ឈាមនឹងយើងដែរ[ភ] នោះបងប្អូនក៏យល់ព្រមតាម
២៨ពេលនោះពួកសាសន៍ម៉ាឌាន[ម]ជាអ្នកជំនួញនោះក៏មកដល់
រួចពួកបងរបស់យ៉ូសែបនាំគ្នា ស្រង់គាត់ឡើងពីអណ្តូងមក[យ]
ហើយលក់[រ]ឱ្យទៅពួកអ៊ីសម៉ា អែលដំឡៃជាប្រាក់២០ដួង[ល]
ពួកនោះ[វ]ក៏នាំយកគាត់ទៅឯ ស្រុកអេស៊ីព្ទទៅ[ស] ។
២៩រួចមក រូបេនគាត់ត្រឡប់ទៅឯអណ្តូងវិញ តែមើល
គ្មានយ៉ូសែបនៅក្នុងអណ្តូងទៀតទេ នោះគាត់ហែក
សំលៀកបំពាក់របស់ខ្លួន[ហ] ៣០ក៏វិលទៅឯបងប្អូនប្រាប់ថា
ក្មេងនោះបាត់ទៅហើយ ចុះឯខ្ញុំតើនឹងទៅឯណា[ឡ] ៣១នោះ
គេក៏សំឡាប់ពពែ១ រួចយកអាវយ៉ូសែប[អ]ទៅប្រឡាក់នឹង
ឈាម[ក] ៣២បញ្ជូនអាវច្រើនពណ៌នោះ[ខ]ទៅជំរាបដល់ឪពុក
ថា យើងខ្ញុំបានឃើញអាវនេះ សូមពិនិត្យមើល តើជាអាវ
របស់កូនលោកឪពុកឬមិនមែន ៣៣គាត់ក៏ចំណាំស្គាល់អាវ
នោះ ហើយនិយាយថា គឺជាអាវរបស់កូនអញ ពិត
មុខជាសត្វសាហាវ[គ]បានហែកវាស៊ីហើយ យ៉ូសែបបានត្រូវ
ហែកខ្ទេចខ្ទីជាប្រាកដ[ឃ] ៣៤នោះយ៉ាកុបក៏ហែកសំលៀក
បំពាក់ខ្លួន[ង] រួចស្លៀកសំពត់ធ្មៃ[ច] ហើយកាន់ទុក្ខកូនជាយូរ
ថ្ងៃ[ឆ] ៣៥ពួកកូនប្រុសកូនស្រីទាំងអស់ក៏ខំជួយរំដោះ ទុក្ខគាត់[ជ]
តែគាត់មិនព្រមទេ[ឈ] ដោយថា អញនឹងចុះទៅឯ កូនអញ
នៅស្ថានឃុំព្រលឹងមនុស្សស្លាប់[ញ]ទាំងកាន់ទុក្ខផង[ដ] ហើយ
គាត់ក៏យំសោកនឹងកូន ៣៦ឯពួកម៉ាឌាន[ឋ] គេនាំយ៉ូសែប[ឌ]ទៅ
ដល់ស្រុកអេស៊ីព្ទ លក់ឱ្យប៉ូទីផារជាមេទ័ព របស់ផារ៉ោន
គឺជាមេក្រុមរក្សាអង្គ[ឍ]។

## លោកយ៉ូដា និងនាងតាម៉ារ

**៣៨** ១នៅគ្រានោះយូដា[ក]គាត់ឃ្លាតចេញពីពួកបងប្អូន
ចូល ទៅនៅជាមួយនឹងមនុស្សម្នាក់ ដែលនៅអាឌូឡាម[ខ]
ឈ្មោះហ៊ីរ៉ា[គ] ២នៅទីនោះយូដាឃើញស្រីក្រមុំម្នាក់របស់
សាសន៍កាណាន ឈ្មោះស៊ូអា[ឃ] គាត់ក៏យកនាងនោះ ហើយ
ចូលទៅឯនាង ៣នាងក៏មានទំងន់បង្កើតបានកូនប្រុស១ គាត់
ឱ្យឈ្មោះថា អ៊ើរ[ង] ៤នាងមានទំងន់ទៀត បង្កើតបានកូន

២៩:៣៥ ផ លប ៤:១០ **៣៧:២៧** ព លប ៤២:២១ ភ លប ២៩:១៤ **៣៧:២៨** ម លប ២៥:២ យ យរ ៣៩:១៣ រ នក ២១:១៦ ល លវ ២៧:៥ មថ ២៦:១៥ វ លប ១៦:១១ ស ខ.៣៦ លប ៣៩:១ ៤៥:៤-៥ ទដ ១០៥:១៧ យរ ១២:៦ កច ៧:៩ **៣៧:២៩** ហ ខ.៣៤ លប ៤៤:១៣ ជន ១៤:៦ យស ៧:៦ ២សយ ១:១១ ២ពវ ២:១២ ៥:៧ ១១:១៤ ២២:១១ យប ១:២០ ២:១២ អស ៣៦:២២ ៣៧:១ យរ ៣៦:២៤ ៤១:៥ យអ ២:១៣ **៣៧:៣០** ឡ ខ.២២ **៣៧:៣១** អ ខ.៣ ក វវ ១៩:១៣ **៣៧:៣២** ខ ខ.៣ **៣៧:៣៣** គ ខ.២០ ឃ លប ៤២:១៣,៣៨ ៤៤:២០,២៨ **៣៧:៣៤** ង ខ.២៩ ច ២សយ ៣:៣១ ១ពវ ២០:៣១ ២១:២៧ ២ពវ ៦:៣០ ១៩:១,២ យប ១៦:១៥ ទដ ៦៩:១១ អស ៣:២៤ ១៥:៣ ២២:១២ ៣២:១១ ៣៧:១ យរ ៤៨:៣៧ ៤៩:៣ យអ ១:១៣ ឆ លប ៥០:៣,១០,១១ ជន ២០:២៩ ចទ៣៤:៨ **៣៧:៣៥** ជ យប ២:១១ ១៥:១១ ១៦:៥ ៤២:១១ ឈ ២សយ ១២:១៧ ទដ ៧៧:២ យរ ៣១:១៥ ញ លប ៤២:៣៨ ៤៤:២២ ២៩:៣១ ដ ២សយ ១២:២៣ **៣៧:៣៦** ឋ លប ២៥:២ ឌ ខ.២៨ ឍ លប ៣៩:១ ៤០:៣ ១០,១២ ១សយ ២២:១៤ **៣៨:១** ក លប ២៩:៣៥ ខ យស ១២:១៥ ១៥:៣៥ ១សយ ២២:១ ២សយ ២៣:១៣ ២របា ១១:៧ គ ខ.១២,២០ **៣៨:២** ឃ ខ.១២ ១របា ២:៣ **៣៨:៣** ង ខ.៦ លប ៤៦:១២ ជន ២៦:១៩

**៣៧:២៨** *២០ដួង* នៅសម័យក្រោយមក ចំនួន២០ដួងនេះ គឺជាតម្លៃនៃអាយុយ៉ូសែប ដែលគាត់បានសម្រេចចិត្តតាមព្រះយេហូវ៉ា (លវ ២៧:៥) ។
**៣៧:៣១-៣៣** ជាថ្មីម្តងទៀត ពួកអ្នកសម្លាប់សត្វពពែគឺគេធ្វើឡើងដើម្បីបោកបញ្ឆោតប៉ុណ្ណោះ (២៧:៥-១៣) ។
**៣៧:៣៤** *ហែកសំលៀកបំពាក់ខ្លួន ស្លៀកសំពត់ធ្មៃ* សម្រាប់ការហែកសំលៀកបំពាក់អ្នកណាម្នាក់ (ខ.២៩) ហើយនិងការស្លៀកសំពត់ធ្មៃដ៏គួរឱ្យខ្ពើមជំនួសសំពត់ដែលល្អស្អាត គឺតំណាងឱ្យការកាន់ទុក្ខ ។
**៣៧:៣៥** *កូនស្រីៗ* នៅក្នុងបរិបទនេះប្រហែលជារាប់បញ្ចូលទាំងកូនប្រសារ (ឧ. កូនប្រសារយ៉ាកុបដែលបានិយាយក្នុង ៣៨:២) ។ *ទុក្ខ* ដោយយោងទៅតាមពាក្យក្នុងភាសាហេព្រើខ្លះៗគេនិយាយថា"សេអូល" (មើលការពន្យល់) ក៏អាចសំដៅលើកន្លែងដែលនាំឱ្យមានសេចក្តីស្លាប់ (ចទ ៣២:២២) ។
**៣៧:៣៦** *លក់* គឺលក់ឱ្យធ្វើជាទាសករ (ទដ ១០៥:១៧) ប្រជាជនអារ៉ាប់ដែលរស់នៅក្នុងទីរហោស្ថាន ពួកគេបានក្លាយជាទាសកររយៈពេលជាយូរ (ប្រៀបធៀបជា អម ១:៦,៩) ។ *ក្រុមរក្សាអង្គ* នៅក្នុងភាសាហេព្រើរពាក្យនេះក៏អាចមានន័យថា"ពេជ្រឃាត" (ជាមេក្រុមមើលការទទួលខុសត្រូវលើអ្នកទោសក្នុងវាំង) មើល ៤០:៤ ហើយក៏មានន័យថា "អ្នកសម្លាប់" (ជាមេក្រុមលើចុងភៅក្នុងរាជ្យវាំង) ប្រៀបធៀប ១សយ ៩:២៣-២៤ ។
**៣៨:១-៣០** ព្រឹត្តិការណ៍ដែលគួរឱ្យក្រៀមក្រំនៅក្នុងជំពូកនេះ គឺបានបង្ហាញយើងឱ្យឃើញច្បាស់ពីគ្រោះថ្នាក់មួយរបស់ប្រជាជនអ៊ីស្រាអែលថា បើសិនជាពួកគេបន្តការរស់នៅជាមួយពួកកាណាន នោះព្រះយេហូវ៉ាទ្រង់នឹងបោះបង់គេចោល (១៥:១៦ និងការពន្យល់) ។ នៅក្នុងប្រទេសអេស៊ីព្ទពួកអ៊ីស្រាអែលត្រូវបានញែកចេញពីពួកអេស៊ីព្ទ ពីព្រោះគេបានស្អប់ខ្ពើមពួកកូនចៅអ៊ីស្រាអែល (៤៣:៣២) ។ ក្នុងអំឡុងពេលដែលពួកគេរស់នៅទីនោះរាស្ត្ររបស់ព្រះបានទទួលការរីកចម្រើន ហើយបានក្លាយខ្លួនជាប្រជាជាតិមួយដែលមិនបានបាត់បង់នូវអត្តសញ្ញាណរបស់ពួកគេឡើយ ។ ទង្វើទាំងឡាយរបស់យូដា គឺមានការផ្ទុយគ្នាជាមួយនិងទង្វើរបស់យ៉ូសែប (មើលជំពូក៣៩) ។ យូដាបាននៅជាមួយបងៗរបស់ខ្លួនក្នុងអំឡុងពេលដែលគេបានលក់យ៉ូសែបឱ្យធ្វើទាសករដល់ឈ្មួញ ហើយពេលដែលគេមកស្រុកអេស៊ីព្ទដើម្បីទិញស្បៀង នោះយូដាក៏មកជាមួយដែរ ។ មើលទៅអ្នកនិពន្ធហាក់បីដូចជានិយាយថា រឿងរ៉ាវដែលកើតឡើងក្នុងជំពូកនេះ គឺបានកើតឡើងរយៈពេល២១ឆ្នាំ ក្រោយពីគេលក់យ៉ូសែបមក ។ ម្យ៉ាងទៀតយើងអាចនិយាយថាលោកយូដាគាត់បានចំណាយពេលពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីមើលការងារគាត់នៅទីនេះ ។
**៣៨:១** *ឃ្លាតចេញពីពួកបងប្អូន* លោកយ៉ូសែបបានឃ្លាតឆ្ងាយពីបងប្អូនរបស់គាត់ដោយសារតែមានការព្យាបាទពីពួកបងៗរបស់គាត់ ប៉ុន្តែសម្រាប់លោកយូដាវិញ គាត់បានស្ម័គចិត្តចាកចេញពីបងប្អូន ដើម្បីស្វែងរកជោគវាសនារបស់គាត់នៅក្នុងចំណោមពួកកាណាន ។ *អាឌូឡាម* ទីក្រុងនេះស្ថិតនៅទិសនិរតី ពីទីក្រុងយេរូសាឡិម (សូមមើលក្នុង ២របា ១១:៥,៧) ។

ប្រុស១ នាងឱ្យឈ្មោះថា អូណាន់[ច] ៥រួចនាងបង្កើតបានកូន
ប្រុស១ទៀត ក៏ឱ្យឈ្មោះថា សេឡា[ឆ] កាលនាងសំរាលកូន
នោះយូដានៅត្រង់កេស៊ីប ៦យូដាក៏យកប្រពន្ធឱ្យអ៊ើរជាកូន
ច្បង នាងនោះឈ្មោះតាម៉ារ[ជ] ៧តែអ៊ើគ្រូនច្បងយូដា ជា
មនុស្សកាចអាក្រក់ នៅចំពោះព្រះនេត្រព្រះយេហូវ៉ា[ឈ]
ហើយព្រះយេហូវ៉ាទ្រង់ប្រហារគាត់ទៅ[ញ] ៨នោះយូដាគាត់
និយាយនឹងអូណាន់ថា ចូរឱ្យចូលទៅឯប្រពន្ធរបស់បងឯង
ដើម្បីនឹងសំរេចកិច្ចតាមរបៀបច្បាប់របស់ប្អូនថ្លៃដល់នាង
ហើយយកនាងបង្កើតពូជឱ្យបងឯងចុះ[ដ] ៩តែអូណាន់គាត់
ដឹងថា ពូជនោះមិនបានជារបស់ផងខ្លួនទេ បានជាកាល
ណាគាត់ចូលទៅឯប្រពន្ធរបស់បង នោះគាត់សំរក់ចោល
ទៅដីវិញ ដើម្បីមិនឱ្យកើតពូជដល់បងឡើយ ១០អំពើដែល
គាត់ធ្វើនោះ ឈ្មោះថាអាក្រក់នៅព្រះនេត្រព្រះយេហូវ៉ា
ណាស់ ហើយទ្រង់ក៏ប្រហារគាត់ទៅដែរ[ឋ] ១១នោះយូដា
និយាយទៅតាម៉ារ[ឌ]ជាកូនប្រសា[ឍ]ថា ចូរឯងនៅជាមេម៉ាយ
ក្នុងផ្ទះឪពុកឯងសិន[ណ] ទំរាំដល់សេឡា[ត] កូនអញបានធំ
ឡើង[ថ] ដ្បិតគាត់គិតថា ក្រែងវាស្លាប់ដូចជាបងវាដែរនោះ
តាម៉ារក៏ទៅនៅឯផ្ទះឪពុកខ្លួនវិញ ។
១២លុះយូរក្រោយមក នោះកូនរបស់ស៊ូអា[ទ]ដែលជា
ប្រពន្ធយូដាក៏ស្លាប់ទៅ រួចកាលយូដាបានរសាយទុក្ខទៅ
ហើយ នោះគាត់ឡើងទៅឯពួកកាត់រោមចៀម[ធ]នៅធីម-

**៣៨:៤** ច ខ.៨,៩ លប ៤៦:១២ ជន ២៦:១៩ **៣៨:៥** ឆ ជន ២៦:២០ **៣៨:៦** ជ ខ.១១,១៣ **៣៨:៧** ឈ លប ៦:៥ ញ ខ.១០ លប ៤៦:១២ លវ ១០:១–២ ១របា ២:៣ **៣៨:៨** ដ ចទ ២៥:៥–៦ នរ ៤:៥ មថ ២២:២៤–២៨ **៣៨:១០** ឋ ខ.៧ ចទ ២៥:៧–១០ **៣៨:១១** ឌ ខ.៦ ឍ លប ១១:៣១ ណ នរ ១:៨ ត ខ.១៤, ២៦ ថ នរ ១:១៣ **៣៨:១២** ទ ខ.២ ធ លប ៣១:១៩

ន ខ.១៤ យស ១៥:១០,៥៧ ១៩:៤៣ ពច ១៤:១,២ ២របា ២៨:១៨ ប ខ.១ **៣៨:១៣** ផ ខ.៦ ព លប ៣១:១៩

ណា[ន] ព្រមទាំងហ៊ីរ៉ា ជាសំឡាញ់ដែលនៅអាឌូឡាម[ប]ដែរ
១៣មានគេទៅប្រាប់ដល់តាម៉ារ[ផ]ថា មើល ឪពុកក្មេកនាង
រៀបឡើងទៅឯធីមណា ដើម្បីកាត់រោមចៀមរបស់គាត់
ហើយ[ព] ១៤ដូច្នេះនាងដោះសំលៀកបំពាក់កាន់ទុក្ខចេញ[ភ]
រួចក៏យកស្បៃមកគ្រលុំខ្លួន[ម] បាំងមុខទៅអង្គុយ[យ]នៅត្រង់ផ្លូវ
ចូលទៅភូមិអេណែមតាមផ្លូវទៅឯធីមណា[រ] ដ្បិតនាងឃើញ
ថាសេឡា[ល]បានធំហើយ តែមិនទាន់ឱ្យនាងទៅធ្វើជាប្រពន្ធ
នៅឡើយ ១៥កាលយូដាឃើញនាង នោះគាត់ស្មានថាជា
ស្រីសំផឹង[វ] ដ្បិតនាងបានបាំងមុខ ១៦នោះគាត់ក៏បែរ
ទៅឯនាងតាមផ្លូវនិយាយថា ចូរយើងទៅ សូមឱ្យខ្ញុំចូលទៅ
ឯនាងឥឡូវ[ស] ពីព្រោះគាត់មិនដឹង[ហ]ថា នាងជាកូនប្រសាទេ[ឡ]
តែនាងសួរថា តើអ្នកនឹងឱ្យអ្វីដល់ខ្ញុំខ្លះ ដែលអ្នកចូលមកឯ
ខ្ញុំនេះ[អ] ១៧គាត់ឆ្លើយថា "ខ្ញុំនឹងផ្ញើកូនពពែ១[ក] ពីហ្វូងមកឱ្យ
តែនាងសួរថា អ្នកមានអ្វីនឹងបញ្ចាំចិត្តខ្ញុំឬទេ[ខ] ទំរាំតែបាន
ផ្ញើពពែនោះមកដល់ ១៨គាត់តបថា តើចង់ឱ្យខ្ញុំឱ្យអ្វីបញ្ចាំ
ចិត្តនាង រួចនាងឆ្លើយថា សូមឱ្យត្រា[គ] និងខ្សែហើយដំបង[ឃ]

**៣៨:១៤** ភ ខ.១៩ ម លប ២៤:៦៥ យ យរ ៣:២ រ ខ.១២ ល ខ.១១ **៣៨:១៥** វ ពច ១១:១ ១៦:១ **៣៨:១៦** ស លប ១៨:១៥ ២០:១២ នរ ១:៦ ហ លប ៣៩:៧, ១២ ២សយ ១៣:១១ ឡ លប ៤២:២៣ អ លប ៣០:១៥ **៣៨:១៧** ក ពច ១៥:១ ខ ខ.២០ **៣៨:១៨** គ ខ.២៥ ២ពវ ២១:៨ នអ ៣:១២ ៨:៨ ៨:៦ អស ៤៩:១៦ យរ ២២:២៤ ហាក ២:២៣ ២កថ ១:២២ អភ ១:១៣ ឃ លប ៣២:១០ នក ៤:២

**៣៨:៣–៤** *អ៊ើរ . . . អូណាន់* តាមឯកសារដែលគេបានរកឃើញសព្វថ្ងៃនេះបាននិយាយថា ឈ្មោះពួកគេទាំងនោះ គឺមានលេចឡើងក្នុងកុលសម្ព័ន្ធមេសូប៉ូតាមា ។

**៣៨:៥** *កេស៊ីប* ប្រហែលជាអាក់ស៊ីប (យស ១៥:៤៤) ។ ទីក្រុងនេះមានចម្ងាយប្រមាណជា៣ម៉ៃយ ភាគខាងលិចពីក្រុងអាឌូឡាម ។ ជនជាតិ "កូសេបា" គឺជាកូនចៅរបស់ស៊ីឡាសជាកូនយូដា (មើល ១របា ៤:២១–២២) ។ នៅក្នុងភាសាហេព្រើរ ឈ្មោះនេះមានន័យថា "កំភូត" (មើល មក ១:១២) ផ្ទៃរឿងកំភូតនេះ បានកើតឡើងចំពោះលោកយ៉ាកុប ហើយនឹងកូនៗរបស់គាត់ជារៀងរហូត ។

**៣៨:៦** *យូដាក៏យកប្រពន្ធឱ្យអ៊ើរ* មើល ២១:២១ ។

**៣៨:៨** គឺជាការពិពណ៌នាដ៏សង្ខេបមួយដែលនិយាយពីវប្បធម៌នៃការ "រៀបការជាមួយបងប្អូនថ្លៃ" បន្ទាប់ពីបងប្អូនបានស្លាប់ទៅ ។ តាមភាសាឡាតាំងពាក្យថា លេវីរ គឺមានន័យថា "បងថ្លៃ" ។ សកម្មភាពនេះបានបញ្ជាក់ប្រាប់យើងច្បាស់ថែមទៀតនៅក្នុង (ចទ ២៥:៥–៦ សូមមើលការពន្យល់) ។ ការធ្វើដូច្នេះវាជារឿងធម្មតា ហើយស្របសម្រាប់ប្រជាជនអ៊ីស្រាអែលសម័យនោះ (សូមប្រៀបធៀបជាមួយ មថ ២២:២៤ និងការពន្យល់) ។ វប្បធម៌ទាំងនេះ ក៏បានបង្ហាញយើងបន្ថែមទៀត (សូមមើល នរ ៤:៥ និងការពន្យល់) ទោះបីជាគេបានពន្យាពេលដើម្បីរស់នៅជាមួយគ្នាក៏ដោយ "លោះសាច់ញាតិ" (មើលក្នុង នរ ៣:១២ ២:២០) ពេលនោះបូអូសមិនបានចូលទៅជិតសាច់ញាតិឡើយ គឺរាប់ជាបងថ្លៃវិញ ។

**៣៨:៩** *គាត់ដឹងថា ពូជនោះមិនបានជារបស់ផងខ្លួនទេ* ប្រហាក់ប្រហែលគ្នានិងសាច់ញាតិនាងរស់ដែរ គឺគាត់ពេញដោយការកោតខ្លាច ដោយគាត់បានដឹងថា បើសិនជាគាត់រៀបការជាមួយនាងរស នោះគាត់នឹងមានគ្រោះថ្នាក់ដល់កូនចៅរបស់គាត់ (នរ ៤:៥–៦ មើលក្នុង នរ ៤:៦ ម្តងទៀត) ។ *សំរក់ចោលទៅដីវិញ* ការអត់ទ្រាំបែបនេះពេលខ្លះគេហៅថា សម្រើបដោយខ្លួនឯង (បន្ទាប់ពីសម្រើបហើយ) ។

**៣៨:១០** *អំពើដែលគាត់ធ្វើនោះ* គាត់បានបដិសេធមិនព្រមមានទំនាក់ទំនងជាមួយនឹងសាច់ញាតិគាត់ ។

**៣៨:១១** *ដ្បិតគាត់គិតថា ក្រែងវាស្លាប់ដូចជាបងវាដែរ* ពេលនេះយូដាមិនបានឱ្យសេឡា ទៅនាងតាម៉ារឡើយ (មើល ខ.១៤) ។

**៣៨:១២** *ធីមណា* សម្រាប់ទីកន្លែងណាមួយដែលពិតនោះយើងមិនបានដឹងឡើយគ្រាន់តែដឹងថា វាស្ថិតនៅភ្នំណាមួយក្នុងស្រុកយូដា (សូមមើល យស ១៥:៤៨,៥៧) ។

**៣៨:១៤** *អង្គុយនៅត្រង់ផ្លូវ* នាងធ្វើបែបនេះដើម្បីឱ្យគេគិតថាជាស្រីសំផឹង (មើលក្នុង ខ.១៥) គឺធ្វើតាមទម្លាប់ ដោយយកឋានៈរបស់ខ្លួនទៅអង្គុយនៅតាមដងផ្លូវ (មើល យរ៣:២) ។ *អេណែម* មានន័យថា "និទាឃរដូវ២" ប្រហែលដូចគ្នានឹងអេណាម ដែលស្ថិតនៅខាងលិចភ្នំដែលយូដាបានដើរកាត់ (មើលក្នុង យស ១៥:៣៣–៣៤) ។

ដែលអ្នកកាន់នៅដៃនោះមក គាត់ក៏ឱ្យដល់នាង រួចចូល
ទៅឯនាង ហើយនាងក៏មានទំងន់ដោយសារគាត់[ង] ១៩នោះ
នាងក្រោកឡើងចេញទៅដោះស្បៃពីខ្លួនចេញ រួចពាក់អាវ
កាន់ទុក្ខរបស់ខ្លួន[ច]វិញ ២០យូដាគាត់ផ្ញើកូនពពែទៅជា១នឹង
សំឡាញ់គាត់ ដែលនៅអាឌូឡាម[ឆ]ឱ្យលោះរបស់បញ្ចាំពី
ស្ត្រីនោះមកវិញ[ជ] តែគាត់រកនាងមិនឃើញសោះ ២១រួច
គាត់សួរពួកអ្នកនៅកន្លែងនោះថា ស្រីសំផឹង[ឈ] ដែលអង្គុយ
នៅមាត់ផ្លូវជិតអេណែមនោះតើនៅឯណា គេឆ្លើយថា
គ្មានស្រីសំផឹងណានៅទីនេះទេ ២២រួចគាត់វិលទៅឯយូដា
ប្រាប់ថា ខ្ញុំរកមិនឃើញទេ ហើយ ពួកអ្នកដែល
នៅកន្លែងនោះក៏ប្រាប់ថា គ្មានស្រីសំផឹងណានៅទីនោះ
ដែរ ២៣យូដានិយាយថា ចូរឱ្យវាយកទៅចុះ[ញ] ក្រែងយើង
ត្រូវមានសេចក្ដីខ្មាស[ដ] មើល ខ្ញុំបានផ្ញើកូនពពែទៅដែរ តែ
អ្នករកវាមិនឃើញសោះ ។
២៤ដល់ប្រហែលជា៣ខែក្រោយមក នោះមានគេទៅ
ជិរាបដល់យូដាថា តាម៉ារជាកូនប្រសាអ្នកបានធ្វើសំផឹង
មើលវាមានទំងន់ដោយការធ្វើសំផឹងហើយ[ឋ] នោះយូដា
ប្រាប់ថា ចូរនាំវាចេញមកដុតចោលទៅ ២៥តែកាលគេ
នាំនាងចេញមក នោះនាងក៏ផ្ញើទៅឪពុកក្មេកជិរាបថា ខ្ញុំ
មានទំងន់នឹងម្ចាស់របស់ទាំងនេះ នាងក៏ថា សូមមើលត្រា
និងខ្សែ ហើយដំបងនេះចុះ តើជារបស់ផងអ្នកណា[ឌ]
២៦យូដាក៏ទទួលស្គាល់ រួចគាត់និយាយថា វាសុចរិតជាង
អញ[ឍ] ដ្បិតអញមិនបានឱ្យដល់សេឡាជាកូនអញទេ[ណ] នោះ
គាត់ក៏លែងស្គាល់នាងទៀត ។
២៧កាលគ្រប់ខែដែលនាងត្រូវ សំរាលមក នោះមើល
មានកូនភ្លោះនៅក្នុងផ្ទៃនាង[ត] ២៨ហើយកាលនាងឈឺនិង
សំរាល នោះកូន១បញ្ចេញដៃមក ឆ្មប[ថ]ក៏យកអំបោះក្រហម
ចងដៃវា[ទ] ដោយពាក្យថា មួយនេះបានកើតមុន ២៩តែកាល
កូននោះទាញដៃទៅវិញ នោះមើលបងវាក៏សំរាលចេញ
មក[ធ] ហើយឆ្មបនិយាយថា ធ្វើដូចម្ដេចឱ្យឯងប្រជែងចេញ
មកដូច្នេះ នោះគេដាក់ឈ្មោះថា ពេរេស[ន] ៣០បន្ទាប់នោះ
ប្អូនវាដែលមានអំបោះក្រហមនៅដៃ[ប]ក៏សំរាលមក ហើយ
គេដាក់ឈ្មោះថាសេរ៉ាស[ផ] ។

## លោកយ៉ូសែប និងប្រពន្ធរបស់លោកប៉ូទីផារ

**៣៩** ១រីឯយ៉ូសែប[ក] គេក៏នាំគាត់ទៅឯស្រុកអេស៊ីព្ទ ហើយ
មានមេទ័ពសាសន៍អេស៊ីព្ទម្នាក់ឈ្មោះ ប៉ូទីផារ ជាមេក្រុម
រក្សាអង្គ[ខ]របស់ផារ៉ោន លោកទិញគាត់ពីដៃនៃពួកអ៊ីសម៉ា

ង លប ១៩:៣២ **៣៨:១៩** ច ខ.១៤ **៣៨:២០** ឆ ខ.១ ជ ខ.១៧ **៣៨:២១** ឈ លប ១៩:៥ លវ ១៩:២៩ ចទ ២២:២១ ២៣:១៧ ២ពវ ២៣:៧ ហស ៤:១៤ **៣៨:២៣** ញ ខ.១៨ ដ នក ៣២:២៥ យប ១២:៤ យរ ២០:៧ បទ ៣:១៤ **៣៨:២៤** ឋ លវ ២០:១០,១៤ ២១:៩ ចទ ២២:២១,២២ យស ៧:២៥ ពច ១៥:៦ ១សយ ៣១:១២ យប ២១:១១,២៨ អគ ១៦:៣៨ **៣៨:២៥** ឌ ខ.១៨ **៣៨:២៦** ឍ ១សយ ២៤:១៧ ណ ខ.១១ **៣៨:២៧** ត លប ២៥:២៤ **៣៨:២៨** ថ លប ៣៥:១៧ ទ ខ.៣០ **៣៨:២៩** ធ លប២៥:២៦ ន លប ៤៦:១២ ជន ២៦:២០,២១ នរ ៤:១២,១៨ ២សយ ៥:២០ ៦:៨ ១រប ២:៤ ៩:៤ អស ២៨:២១ មថ ១:៣ **៣៨:៣០** ប ខ.២៨ ផ លប ៤៦:១២ ១រប ២:៤ នហ ១១:២៤ **៣៩:១** ក លប ៣០:២៤ ខ លប ៣៧:៣៦

**៣៨:១៨** *ត្រា និងខ្សែ* ប្រហែលជាបំពង់ត្រាតូចមួយ ដែលគេធ្លាប់ប្រើជាសញ្ញាដើម្បីគ្រប់គ្រងលើអ្នកណាម្នាក់ ។ ម្ចាស់របស់ត្រានេះ បានពាក់វានៅលើក ។

**៣៨:២១** *ស្រីសំផឹង* នៅក្នុងភាសាហេព្រើរកន្លែងនេះ មានការខុសគ្នានឹងពាក្យថា"ស្រីសំផឹង"ក្នុងខ.១៥ ។ មិត្តភ័ក្រលោកយូដាប្រហែលជាគាត់បានទទួលការអនុញ្ញាតដើម្បីប្រើវាយ្យស័ព្ទបែបនេះច្រើនថែមទៀត ក្នុងអំឡុងពេលដែលស្ត្រីសំផឹងមានសិទ្ធិយ៉ាងទូលំទូលាយ ក្នុងស្រុកកាណាន (មើលក្នុង ២០:៩) ។

**៣៨:២៤** *ចូរនាំវាចេញមកដុតចោលទៅ* សម័យក្រោយមកការដុត គឺជាទារុណកម្មស្របច្បាប់មួយដែលគេប្រើសម្រាប់ដាក់លើស្ត្រីសំផឹង (មើល លវ ២១:៩) ។

**៣៨:២៧–៣០** សម្រាប់ក្មេងភ្លោះផ្សេងៗទៀត សូមមើល ២៥:២៤–២៦ ។

**៣៨:២៩** *ពេរេស* ក្រោយមក គាត់បានក្លាយជាមេដឹកនាំនៅក្នុងពូជអំបូរយូដាហើយគាត់ក៏ជាព្ធយុកោដាវីឌ (នរ ៤:១៨,២២) ព្រមទាំងជាព្ធយុកោរបស់ព្រះយេស៊ូវដែរ (មថ ១:១–៦) ។

**៣៩:១–២៣** បន្តរឿងលោកយ៉ូសែប (មើល ៣៧:៣៦) គឺជាតំណាក់កាលដំបូងនៃការធ្វើដំណើររបស់អ៊ីស្រាអែល ចាប់តាំងពីទឹកដីកាណាន រហូតដល់ស្រុកអេស៊ីព្ទ ។

**៣៩:១** *នាំគាត់ទៅស្រុកអេស៊ីព្ទ* បទពិសោធន៍ទាំងឡាយដែលយ៉ូសែបបានជួបនៅស្រុកអេស៊ីព្ទ វាដូចគ្នានឹងអ្វីដែលគាត់ជួបនាពេលវៃយកម្លោះរបស់គាត់ ក្នុងស្រុកកាណានដែរ (មើល ៣៧:២៣–២៤) គឺមានការប្រហាក់ប្រហែលគ្នាទៅនឹងបទពិសោធន៍ ដែលប្រជាជាតិអ៊ីស្រាអែលមាននៅក្នុងអេស៊ីព្ទដែរ ។ ដំបូងដោយសារព្រះពររបស់ព្រះនោះ លោកយ៉ូសែប់បានទទួលមុខតំណែងនិងមានកិត្តិយស (នៅក្នុងផ្ទះប៉ូទីផារ) ហើយក្រោយមកគាត់ត្រូវគេបញ្ជូនទៅក្នុងគុក ដោយភាពអយុត្តិធម៌ ដែលបណ្ដាលមកពីរូបសម្រស់របស់គាត់ ហើយគាត់មិនព្រមប្រព្រឹត្តតាមនូវទង្វើអសីលធម៌របស់ប្រពន្ធលោកប៉ូទីផារ តែនៅចុងបញ្ចប់គាត់ត្រូវលើកឡើងនៅក្នុងចំណោមប្រជាជនអេស៊ីព្ទបញ្ហាទាំងអស់នេះកើតឡើងបានដោយសារតែព្រះយេហូវ៉ាទ្រង់បានគង់នៅជាមួយគាត់ ឃុំគ្រង់ការរស់នៅរបស់គាត់នៅក្នុងព្រះហស្តរបស់ព្រះអង្គ ។ ដូចគ្នានេះដែរ ដំបូងប្រជាជនអ៊ីស្រាអែលទាំងអស់គេទទួលកិត្តិយសដ៏ប្រពៃនៅក្នុងអេស៊ីព្ទ (ដោយសារលោកយ៉ូសែប) តែក្រោយមកបានក្លាយជាទាសកររបស់គេទៅវិញ ហេតុការណ៍នេះបានកើតឡើងដោយសារតែអេស៊ីព្ទ គេមើលឃើញពីតម្រុយនៃព្រះពរដ៏លើសលប់របស់ព្រះចំពោះជនជាតិអ៊ីស្រាអែល ហើយនៅចុងបញ្ចប់ព្រះអង្គក៏បានលើកពួកអ៊ីស្រាអែលនៅនឹងភ្នែកពួកអេស៊ីព្ទដែរ (តាមរយៈការងាររបស់លោកម៉ូសេ) ពួកគេបានស្ញែងខ្លាច ហើយទទួលស្គាល់ថា ព្រះយេហូវ៉ាទ្រង់គឺជាអ្នកការពារប្រជាជនអ៊ីស្រាអែល ។ អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិគាត់បានដឹងពីព្រឹត្តិការណ៍ទាំងឡាយដែលកើតនៅក្នុងព្រះគម្ពីរនិក្ខមនំ ហើយបានបង្ហាញពីប្រវត្តិសាស្ត្ររបស់ព្រះ ជាមួយពួកព្ធយុកោជំនាន់មុន (១៥:១៣–១៦ ៤៨:២១–២២ ៥០:២៤–២៥) ។ *ពួកអ៊ីសម៉ាអែល* សូមមើល ៣៧:២៥ ។

អែលដែលនាំចុះមកស្រុកនោះ[គ] ២ព្រះយេហូវ៉ាទ្រង់ក៏គង់នៅ
ជាមួយនឹងយ៉ូសែប[ឃ] ហើយគាត់ចេះតែចំរើនឡើង គាត់នៅ
ក្នុងផ្ទះរបស់ចៅហ្វាយខ្លួន ជាសាសន៍អេស៊ីព្ទនោះ ៣ចៅ
ហ្វាយក៏ឃើញថា ព្រះយេហូវ៉ាទ្រង់គង់នៅជាមួយនឹង គាត់[ង]
ហើយថា ព្រះយេហូវ៉ាទ្រង់ធ្វើ ឱ្យគ្រប់ការទាំងអស់
បានកើតឡើងដោយសារដៃគាត់[ច] ៤យ៉ូសែបបានជាទីពេញ
ចិត្តដល់លោកណាស់[ឆ] ហើយក៏ខំប្រឹងបំរើលោក លោក
តាំងគាត់ឱ្យត្រួតត្រាលើផ្ទះលោក[ជ]ក៏ប្រគល់របស់ទាំងអស់
ទៅក្នុងកណ្តាប់ដៃគាត់[ឈ] ៥ហើយចាប់តាំងពីលោកតាំង
គាត់ឡើងឱ្យត្រួតត្រាលើផ្ទះ និងទ្រព្យសម្បត្តិទាំងអស់មក
នោះព្រះយេហូវ៉ាទ្រង់ប្រទានពរដល់ផ្ទះ[ញ]នៃសាសន៍អេស៊ីព្ទ
នោះ ដោយព្រោះយ៉ូសែប[ដ] ហើយព្រះយេហូវ៉ាក៏ផ្តល់
ព្រះពរមកលើគ្រប់ទាំងរបស់លោក ដែលនៅក្នុងផ្ទះ
និងនៅស្រែចំការដែរ[ឋ] ៦លោកទុករបស់លោកទាំងអស់
នៅក្នុងកណ្តាប់[ឌ]ដៃយ៉ូសែប ហើយមិនបានដឹងជាមានរបស់
ណាមួយទេ លើកតែភោជនាហារដែលលោកពិសារ
ប៉ុណ្ណោះ រីឯយ៉ូសែបគាត់មានរូបឆោមដ៏ពិសី ហើយស្រៀវ
ស្រស់ល្អ[ឍ] ។

៧កាលក្រោយការទាំងនោះមក នោះប្រពន្ធរបស់
ចៅហ្វាយគាត់ ចេះតែដេញភ្នែកជាប់តាម មើលយ៉ូសែប
ហើយនិយាយថា ចូរមកដេកនឹងអញ[ណ] ៨តែគាត់មិនព្រម
សោះ[ត] ក៏និយាយទៅប្រពន្ធចៅហ្វាយខ្លួនថា មើល
ចៅហ្វាយខ្ញុំ លោកឥតដឹងជាមានអ្វីៗ នៅនឹងខ្ញុំ ក្នុងផ្ទះផង
លោកបានប្រគល់គ្រប់របស់ទាំងអស់ មកក្នុងកណ្តាប់ដៃខ្ញុំ[ថ]
៩គ្មានអ្នកណាធំជាងខ្ញុំក្នុងផ្ទះនេះទេ[ទ] ហើយលោកក៏មិន
បានហួងទុករបស់ណាមួយនឹងខ្ញុំដែរ លើកតែលោកស្រី

គ លប ៣៧:២៥
**៣៩:២** ឃ លប ២១:២០,២២ យស ១:៥ ពច ១:១៩ ១សយ ១៨:១៤ កច ៧:៩
**៣៩:៣** ង លប ២១:២២ ច ខ.២៣ យ ១៨:១៤ ២ពវ ១៨:៧ ២របា ២០:២០ ទដ ១:៣ ១២៨:២ អស ៣៣:៦
**៣៩:៤** ឆ លប ៦:៨ ១៨:៣ ជ លប ៤៧:៦ ១ពវ ១១:២៨ សភ ២២:២៩ ឈ ខ.៨, ២២ លប ៤០:៤ ៤២:៣៧
**៣៩:៥** ញ ២សយ ៦:១១ ដ លប ២៦:២៤ ឋ ចទ ២៨:៣ ទដ ១២៨:៤
**៣៩:៦** ឌ លប ២៤:២ ឍ លប ១២:១១ នក ២:២ ១សយ ៩:២ ១៦:១២ ១៧:៤២ នក ២:៧ ដយ ១:៤
**៣៩:៧** ណ លប ៣៨:១៦ សភ ៧:១៥–១៨
**៣៩:៨** ត សភ ៦:២៣–២៤ ថ ខ.៤
**៣៩:៩** ទ លប

ប៉ុណ្ណោះ ពីព្រោះលោកស្រីជាប្រពន្ធរបស់លោក ដូច្នេះធ្វើ
ដូចម្តេចឱ្យខ្ញុំប្រព្រឹត្តការដែលអាក្រក់យ៉ាងធំនេះទៅបាន
ធ្វើយ៉ាងនោះនឹងមានបាបនៅចំពោះព្រះផង[ធ] ១០ឯនាង
ចេះតែនិយាយនឹងយ៉ូសែបជារាល់ថ្ងៃ តែគាត់មិនព្រម
ស្តាប់តាម[ន]និងទៅដេកជាមួយនឹងនាង ឬនឹងទៅជិតនាង
សោះ ១១មានកាល១ថ្ងៃនោះ គាត់ចូលទៅធ្វើការ[ប] ក្នុងផ្ទះ
ហើយគ្មានអ្នកណាមួយ[ផ]នៅក្នុងផ្ទះសោះ ១២នោះនាងក៏
ចាប់អាវគាត់[ព]ទាំងនិយាយថា មកដេកនឹងអញសិន[ភ] តែ
គាត់រលាស់អាវចោលនៅដៃនាងរត់ចេញទៅក្រៅទៅ[ម]
១៣កាលនាងឃើញថា គាត់ចោលអាវនៅដៃ ហើយ
រត់ចេញទៅដូច្នោះ ១៤នោះនាងក៏ហៅពួកអ្នកផ្ទះ[យ] មក
ប្រាប់ថា ឃើញឬទេ លោកបាននាំអាសាសន៍ហេព្រើរ
នេះ[រ]មកឱ្យមើលងាយយើង[ល] វាបានចូលមកចង់ដេកនឹង
អញ តែអញបានស្រែកជាខ្លាំង[វ] ១៥កាលវាឮអញឡើង
សំឡេងស្រែក នោះវាទុកអាវចោលនៅខាងអញនេះរត់
ចេញទៅក្រៅបាត់[ស] ១៦នាងក៏ដាក់អាវយ៉ូសែបទុកនៅក្បែរ
ខ្លួនចាំទំរាំតែចៅហ្វាយគាត់វិលមកផ្ទះវិញ ១៧រួចនាង
ជំរាបលោក តាមពាក្យដដែលនោះ[ហ]ថា អាបាវ[ឡ]សាសន៍
ហេព្រើរ[អ] ដែលលោកបាននាំមកឯយើងរាល់គ្នា វាចូល
មកចង់មើលងាយខ្ញុំ ១៨តែកាលខ្ញុំស្រែកឡើង នោះវារត់
ទៅក្រៅទុកអាវចោល នៅក្បែរខ្ញុំនេះ ១៩កាលចៅហ្វាយ

៤១:៣៣,៤០ ធ លប ១៣:១៣ ជន ២២:៣៤ **៣៩:១០** ន នក ៣:៤ **៣៩:១១** ប នក ១៨:២០ ចទ ១:១៨ ផ ខ.១៤ **៣៩:១២** ព ២សយ ១៣:១១ សភ ៧:១៣ ភ លប ៣៨:១៦ ម ខ.១៥ សភ ៥:៨ ២ធថ ២:២២ **៣៩:១៤** យ ខ.១១ រ លប ១៤:១៣ ល លប ២១:៩ វ ចទ ២២:២៤,២៧ **៣៩:១៥** ស ខ.១២ **៣៩:១៧** ហ នក ២០:១៦ ២៣:១,៧ ចទ ៥:២០ ទដ ១០១:៥ ឡ លប ២១:១០ អ លប ១៤:១៣

**៣៩:២–៦** មើល ខ.២០–២៣ ។ ទោះបីជាស្ថានភាពនេះ លោកយ៉ូសែបគាត់ផ្លាស់ប្តូរយ៉ាងលឿនក៏ដោយ ក៏ព្រះវត្តមាននិងទំនាក់ទំនងរបស់ព្រះនៅជាមួយគាត់ជានិច្ច ។

**៣៩:២** *ព្រះយេហូវ៉ាទ្រង់ក៏គង់នៅជាមួយនឹងយ៉ូសែប* សូមមើលការពន្យល់ ២៦:៣ ។ ខនេះត្រូវបានលើកមកនិយាយម្តងហើយម្តងទៀតនៅកន្លែងនេះ (ខ.៣,២១,២៣) លោកស្ទេផានក៏និយាយពីការងារទាំងនេះ (កច ៧:៩) ។

**៣៩:៥** *នោះព្រះយេហូវ៉ាទ្រង់ប្រទានពរដល់ផ្ទះនៃសាសន៍អេស៊ីព្ទនោះដោយព្រោះយ៉ូសែប* ដូចគ្នានិងព្រះពររបស់ព្រះចំពោះឡាបាន់ ដោយសារតែយ៉ាកុបដែរ (៣០:២៧) ។ កូនចៅរបស់លោកអ័ប្រាហាំ នៅតែបន្តទទួលព្រះពរ នឹងជាទីបញ្ចេញពរដល់ប្រជាជាតិទាំងឡាយ (មើល ១២:២–៣) ។

**៣៩:៦** *លោកទុករបស់លោកមានទាំងអស់នៅកណ្តាប់ដៃយ៉ូសែប* ដូចជាឡាបាន់ គាត់បានប្រគល់ហ្វូងសត្វដែលគាត់មាន ឱ្យទៅយ៉ាកុបជាអ្នកមើលការទទួលខុសត្រូវ (៣០:៣១–៣៤) ។ លោកយ៉ូសែបមានការទទួលខុសត្រូវខ្ពស់លើទ្រព្យសម្បត្តិ និងកិច្ចការងារក្នុងផ្ទះលោកប៉ូទីផារ ហើយក្រោយមកគាត់ជាអ្នកទទួលខុសត្រូវនៅក្នុងគុកទៀតផង (ខ.២២–២៣) មិនយូរប៉ុន្មានគាត់ក្លាយជាអ្នកគ្រប់គ្រងលើស្រុកអេស៊ីព្ទទាំងមូល (៤១:៤១) ។ ជានិច្ចកាលពួកអ៊ីស្រាអែលបានការសង្គ្រោះដោយសារ "ពាក្យសំដី" ដែលចេញពីមាត់និងពីដៃគាត់ ប៉ុន្តែតាមពិតគឺដោយសារតែព្រះពរនឹងការគ្រប់គ្រងមកពីព្រះមិនមែនមកពីប្រាជ្ញាដែលលោកយ៉ូសែបគាត់មាននោះទេ ហើយក៏មិនដូចជាយ៉ាកុបឪពុកគាត់បានធ្វើនោះឡើយ ។

**៣៩:៧** *ដេញភ្នែកជាប់តាម* នាងមើលទៅលោកយ៉ូសែបដោយក្តីប្រាថ្នាចង់បានមកគេងជាមួយ ។

**៣៩:៩** *ធ្វើយ៉ាងនោះនឹងមានបាបធំនៅចំពោះព្រះផង* គ្រប់ទាំងអំពើបាបគឺតែងតែទាស់ប្រឆាំងជាមួយព្រះ គឺមានតាំងពីដើមមក (ទដ ៥១:៤) ។

**៣៩:១០** *ឯនាងចេះតែនិយាយនឹងយ៉ូសែបជារាល់ថ្ងៃ តែគាត់មិនព្រមស្តាប់តាម* សាំសុនគាត់បានចាញ់បោកគេ ដោយសារការបង្ខំ២ឬ៣ដងរបស់ដេបូរ៉ាប៉ុណ្ណោះ (ពច ១៤:១៧ ១៦:១៦–១៧) ។

**៣៩:១៤** *អាសាសន៍ហេព្រើរ* មើលក្នុង ខ.១៧ និង ១៤:១៣ ។

គាត់បានឮពាក្យដែលប្រពន្ធប្រាប់ថា បាវលោកបាន
ប្រព្រឹត្តនឹងនាងដូច្នោះ នោះលោកមានចិត្តឆួលក្តៅឡើង[ក]
២០ហើយក៏យកគាត់ទៅដាក់គុក[ខ] នៅកន្លែងដែលសំរាប់
ឃុំពួកអ្នកទោសរបស់ស្តេច គាត់ក៏ជាប់នៅក្នុងគុកនោះ ។
២១តែព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងយ៉ូសែប[គ] ហើយ
ក៏ផ្តល់សេចក្តីសប្បុរស[ឃ]ដល់គាត់ ព្រមទាំងធ្វើឱ្យមេភូឃុំ
អាណិតមេត្តាដល់គាត់ផង[ង] ២២មេភូឃុំនោះក៏ប្រគល់ពួក
អ្នកទោសដែលនៅក្នុងគុក ទៅក្នុងអំណាចរបស់យ៉ូសែប
ទាំងអស់ ការអ្វីៗដែលគេធ្វើនៅក្នុងគុក នោះគឺជាគាត់
ដែលបង្កើតការនោះ[ច] ២៣មេភូឃុំលែងត្រួតត្រាមើលអ្វី
ទាំងអស់ដែលនៅក្រោមអំណាចគាត់[ឆ]ពីព្រោះព្រះយេហូវ៉ា
ទ្រង់គង់ជាមួយនឹងគាត់ ហើយការអ្វីដែលគាត់ធ្វើ នោះទ្រង់
ធ្វើឱ្យចំរើនឡើងគ្រប់ជំពូក[ជ] ។

## អ្នកពិសេសថ្វាយពែង និងពួកអ្នកដុតនំ

**៤០** ១ក្រោយនោះមក អ្នកពិសេសថ្វាយពែង[ក]របស់ស្តេច
ស្រុកអេស៊ីព្ទ នឹងអ្នកដុត[ខ]នំថ្វាយទ្រង់ គេធ្វើបង្អាក់ព្រះទ័យ
នៃស្តេចជាម្ចាស់គេ ២ផារ៉ោនក៏ខ្ញាល់[គ]នឹងអ្នកបំរើទ្រង់ទាំង
២នោះ[ឃ] គឺនឹងនាយពិសេសថ្វាយពែងហើយនឹងមេពួកអ្នក
ដុតនំ ៣ទ្រង់ឃុំគេទុកក្នុងគុករបស់មេក្រុមរក្សាអង្គ[ង] ជា
កន្លែងដែលយ៉ូសែបជាប់នៅនោះដែរ ៤ឯមេក្រុមរក្សា
ស្តេច[ច] លោកប្រគល់គេទៅឱ្យយ៉ូសែប[ឆ]ត្រួតត្រាមើល គាត់
ក៏បំរើគេ ហើយគេនៅជាប់ឃុំ[ជ]ជាយូរថ្ងៃ ៥មានកាល១យប់
នោះ នាយពិសេសថ្វាយពែង នឹងមេដុតនំថ្វាយស្តេចស្រុក
អេស៊ីព្ទ ដែលនៅជាប់គុក គេបានយល់សប្តិទាំង២នាក់

**៣៩:១៩** ក លប ៣៤:៧ នក ១:១២ **៣៩:២០** ខ លប ៤០:៣ ៤១:១០ ទដ ១០៥:១៨ **៣៩:២១** គ លប ២១:២០ ឃ លប ១៩:១៩ ង នក ៣:២១ ១១:៣ ១២:៣៦ នក ២:៩ ទដ ១០៦:៤៦ សភ ១៦:៧ ដយ ១:៩ **៣៩:២២** ច ខ.៤ **៣៩:២៣** ឆ លប ២១:២០ ជន ១៤:៤៣ ជ ខ.៣ **៤០:១** ក ខ.៩,១៣, ២១ នហ ១:១១ ខ ខ.១៦,២០ **៤០:២** គ ទដ ១៦:១៤, ១៥ ១៩:១២ ឃ លប ៤១:១០ នក ២:២១ **៤០:៣** ង លប ៣៧:៣៦ ៣៩:២០ **៤០:៤** ច លប ៣៧:៣៦ ឆ លប ៣៩:៤ ជ ខ.៧ លប **៤០:៥** ឈ លប ២០:៣ ញ លប ៤១:១១

ដែលសប្តិ[ឈ]នោះមានសំរាយផ្សេងពីគ្នារៀងខ្លួន[ញ] ៦ដល់
ព្រឹកឡើង យ៉ូសែបចូលទៅឯគេឃើញគេមានទឹកមុខព្រួយ
៧ក៏សួរដល់មេរបស់ផារ៉ោនទាំង២នោះ ដែលជាប់ឃុំជា
មួយគ្នានៅក្នុងគុក[ដ]របស់ចៅហ្វាយគាត់ថា ថ្ងៃនេះហេតុអ្វី
បានជាលោកមានទឹកមុខព្រួយដូច្នេះ[ឋ] ៨គេឆ្លើយថា
យើងបានយល់សប្តិ តែគ្មានអ្នកណាអាចនឹងកាត់ស្រាយឱ្យ
បានសោះ[ឌ] នោះយ៉ូសែបគាត់និយាយទៅគេថា សេចក្តី
សំរាយ ស្រេចនៅព្រះទេតើ[ឍ] សូមលោកប្រាប់សប្តិនោះ
មកខ្ញុំមើល ។
៩នោះនាយពិសេសថ្វាយពែង[ណ]ក៏រ៉ាយរ៉ាប់សប្តិប្រាប់យ៉ូ
សែបថា ឯក្នុងសប្តិខ្ញុំ ឃើញមានដើមទំពាំងបាយជូរនៅ
ត្រង់មុខខ្ញុំ ១០ដើមនោះមានខ្នែង៣ មើលទៅដូចជាពន្លក
ហើយផ្កាក៏រីក[ត] រួចកើតមានចង្កោមផ្លែទុំ ១១ពែងរបស់
ផារ៉ោនក៏នៅក្នុងដៃខ្ញុំ នោះខ្ញុំបេះផ្លែទំពាំងបាយជូរមកគាប
ដាក់ពែងរបស់ផារ៉ោន យកទៅថ្វាយដល់ព្រះហស្តទ្រង់"
១២ឯយ៉ូសែបក៏ស្រាយដូច្នេះថា សប្តិនោះមានន័យយ៉ាងនេះ[ថ]
ចំណែកខ្នែង៣ នោះគឺជា៣ថ្ងៃ[ទ] ១៣នៅ៣ថ្ងៃទៀត[ធ] ផារ៉ោន
នឹងលើកមុខលោក[ន] ទាំងតាំងឱ្យធ្វើក្នុងដំណែងដើមរបស់
លោកវិញ ហើយលោកនឹងបានថ្វាយពែងផារ៉ោនដល់
ព្រះហស្តទ្រង់ទៀត ដូចលោកធ្លាប់ធ្វើពីកាលនៅបំរើថ្វាយ

**៤០:៧** ដ ខ.៤ ឋ នហ ២:២ **៤០:៨** ឌ លប ៤១:៨,១៥ ឍ លប ៤១:១៦,២៥, ២៨,៣២ ចទ ២៩:២៩ ដយ ២:២២,២៦,៤៧ **៤០:៩** ណ ខ.១ **៤០:១០** ត អស ២៧:៦ ៣៥:១–២ ហស ១៤:៧ **៤០:១២** ថ ខ.១៦ លប ៤១:១២,១៥, ២៥ ដយ ២:៣៦ ៤:១៩ ទខ.១៨ **៤០:១៣** ធ ខ.១៩, ២០ យស ១:១១ ៣:២ អរ ៨:៣២ នហ ២:១១ ន ខ.១៩ ប ខ.១

**៣៩:២០–២៣** សូមមើល ខ.២–៦ ។

**៣៩:២០** *នៅកន្លែងដែលឃុំពួកអ្នកទោសរបស់ស្តេច* ទោះបីជាចៅហ្វាយខឹងយ៉ាងណាក៏ដោយ (មើល ខ.១៩) ក៏លោកប៉ូទីផារយកលោកយ៉ូសែបទៅដាក់គុករបស់មេក្រុមអង្គរក្ស (មើល ៤០:៣) មិនមែនជាកន្លែងអាក្រក់នោះឡើយ ។

**៤០:១–៤១:៤៧** ព្រះយេហូវ៉ាទ្រង់បានផ្តល់ ដល់យ៉ូសែបនូវការកាត់ស្រាយសុបិន្ត២យ៉ាង គឺព្រះយេហូវ៉ាទ្រង់បានរៀបផ្លូវឱ្យយ៉ូសែប ដើម្បីឱ្យគាត់អាចកាត់ស្រាយសុបិន្តទាំង២របស់ព្រះចៅផារ៉ោន (ជំពូក ៤១) ហើយពេលក្រោយមកត្រូវបានសម្រេច (ជំពូក ៤២–៤៦) ដែលមានទំនាក់ទំនងចំពោះការយល់សប្តិទាំង២របស់លោកយ៉ូសែបដែរ (៣៧:៥–១១) ។

**៤០:២** *ផារ៉ោន* សូមមើលក្នុង នក ១:១១ ។ *អ្នកថ្វាយពែង* ប្រហែលជាអ្នកដែលបានទទួលតែងតាំជាតំណាង ដើម្បីឱ្យណែនាំដល់ លោកយ៉ូសែបចំពោះផារ៉ោន (៤១:៩–១៤) ។

**៤០:៥** *ដែលសប្តិនោះមានសំរាយផ្សេងពីគ្នារៀងខ្លួន* ស្ទើតែគ្រប់គ្នានៃមនុស្សដែលរស់នៅមជ្ឈឹមបូព៌ាសម័យបុរាណ គេមានជំនឿថាពេលខ្លះសប្តិអាចបញ្ជាក់ពីវាសនានៅថ្ងៃអនាគត បើសិនជាអ្នកសំរាយត្រឹមត្រូវនោះនឹងនាំពន្លឺដល់ប្រទេស (២០:៣) ។ តាមរយៈការសំរាយសប្តិនេះបង្ហាញថាព្រះទ្រង់បានលើកលោកយ៉ូសែបឡើងនៅក្នុងស្រុកអេស៊ីព្ទ ។

**៤០:៨** *សេចក្តីសំរាយស្រេចនៅព្រះទេតើ* មានតែព្រះទេដែលដឹងពីថ្ងៃ អនាគត ដែលជាអ្នកសំរាយសប្តិដ៏ល្អ (មើល ៤១:១៦,២៥,២៨ ដយ ២:២៨) ។ *សូមលោកប្រាប់សប្តិនោះមកខ្ញុំមើល* លោកយ៉ូសែបគាត់បានចាត់ទុកខ្លួនគាត់ថា ជាភ្នាក់ងាររបស់ព្រះ ហើយតាមរយៈព្រះ នោះគាត់ទទួលបានការបើកសម្តែង ដើម្បីសំរាយសប្តិរបស់គេ បង្ហាញថាអ៊ីស្រាអែលជាហោរារបស់ព្រះ ដែលព្រះនាំការបើកសម្តែងតាមរយៈពួកគេ (១៨:១៧ ៤១:១៦, ២៨,៣២) ។

**៤០:១៣** *លើកមុខលោក ទាំងតាំងឱ្យធ្វើក្នុងតំណែងដើមរបស់លោកវិញ* សូមមើល ទដ ៣៣:៣ ២៧:៦ ។ អត្ថន័យនៃពាក្យនេះ"លើកមុខអ្នកណាម្នាក់ឡើង" សូមមើល ២ពវ ២៥:២៧ ហើយ យរ ៥២:៣១ នៅក្នុងភាសាហេព្រើរសម្រាប់ពាក្យ"ជួលបន្ត"ដែលមាននៅក្នុងបរិបទនេះ គឺមានន័យដូចគ្នានិងពាក្យ "លើកឡើង" ។

ពែងទ្រង់ពីដើម[ប] ១៤កាលណាលោកបានសុខសាន្តហើយ
នោះសូមនឹកចាំពីខ្ញុំផង[ផ] ហើយសូមផ្សាយសេចក្តីសប្បុរស
មកខ្ញុំ[ព] ក៏សូមដំណាលពីខ្ញុំទូលផារ៉ោន[ភ] ដើម្បីឱ្យខ្ញុំបានរួចពី
គុកនេះផង ១៥ពីព្រោះគេបានលួចខ្ញុំ ពីស្រុកពួកហេព្រើរ
មក[ម] ហើយនៅទីនេះ ខ្ញុំក៏មិនបានធ្វើអ្វី ដែលគួរឱ្យគេដាក់ខ្ញុំ
ក្នុងគុកជ្រៅនេះដែរ[យ] ។
១៦កាលមេពួកដុតនំ[រ]បានឃើញថា សេចក្តីសិរាយនោះ
ស្រួលល្អ[ល] នោះគាត់និយាយប្រាប់យ៉ូសែបថា ខ្ញុំក៏បាន
យល់សប្តិដែរ មើល ខ្ញុំមានទូលនំបុ័ងស៣កញ្ច្រែង[វ] ១៧ក្នុង
កញ្ច្រែងលើបង្អស់មាននំគ្រប់មុខសិរាប់ថ្វាយផារ៉ោន តែ
សត្វហើរមកចឹកស៊ីនំក្នុងកញ្ច្រែង ដែលនៅលើក្បាលខ្ញុំ
ទាំងអស់ទៅ ១៨យ៉ូសែបស្រាយថា សប្តិនេះមានន័យដូច្នេះ
ឯកញ្ច្រែង៣ នោះគឺជា៣ថ្ងៃ[ស] ១៩នៅ៣ថ្ងៃទៀត[ហ]ផារ៉ោន
នឹងចងកលោក[ឡ]ព្យួរនៅជាប់លើឈើ[អ] នោះសត្វហើរនឹង
ចឹកស៊ីសាច់លោកទៅ[ក] ។
២០ក្រោយ៣ថ្ងៃមក[ខ] ជាថ្ងៃបុណ្យចំរើនព្រះជន្មផារ៉ោន[គ]
នោះទ្រង់រៀបជប់លៀងដល់ពួកនាម៉ឺនទាំងប៉ុន្មាន[ឃ] ហើយ
ទ្រង់ហៅនាយពិសេសថ្វាយពែង នឹងមេពួកដុតនំ[ង]មកនៅ
កណ្តាលពួកនាម៉ឺនទាំងនោះ ២១ទ្រង់ក៏តាំងនាយពិសេស
ថ្វាយពែង[ច]ក្នុងដំណែងដើមឡើងវិញ[ឆ] ហើយគាត់ក៏ថ្វាយ
ពែងដល់ព្រះហស្តផារ៉ោនតទៅ[ជ] ២២តែឯមេពួកដុតនំ ទ្រង់
បានចងព្យួរវិញ[ឈ] ដូចជាយ៉ូសែបបានកាត់សេចក្តីឱ្យ[ញ]
២៣ចំណែកនាយពិសេសថ្វាយពែង គាត់ភ្លេចឈឹងមិនបាន
នឹកចាំពីយ៉ូសែបសោះ[ដ] ។

## សុបិនរបស់ស្តេចផារ៉ោន

**៤១** ១ដល់ផុត២ឆ្នាំមក នោះផារ៉ោនទ្រង់សុបិននិមិត្ត
ឃើញថា[ក] ទ្រង់ឈរនៅមាត់ទន្លេ[ខ] ២ហើយមើល មានគោ
ញី៧មានសាច់ច្រើនធាត់ល្អ[គ] ឡើងពីទន្លេមកស៊ីនៅទីវាល[ឃ]
៣រួចមក មានគោញី៧ទៀតឡើងពីទន្លេមកវាស្គមពេក
ហើយអាក្រក់មើល ក៏ឈរនៅក្បែរមាត់ទន្លេជិតគោឯទៀត
៤គោសិគម ហើយអាក្រក់មើលនោះ បានស៊ីលេបគោ
ទាំង៧ដែលធាត់ល្អនោះអស់ទៅ នោះផារ៉ោន ទ្រង់តើន
ឡើង[ង] ៥រួចទ្រង់ផ្ទំលក់ទៅវិញ ក៏សុបិននិមិត្តទៀតថាមាន
គួរស្រូវ៧[ច] មានគ្រាប់ធំថ្លោសល្អបែកឡើងនៅដើមតែ១
៦រួចមកមានគួរស្រូវ៧តូចៗ ហើយស្កកដោយខ្យល់ពីទិស
ខាងកើត បែកមកជាខាងក្រោយ[ឆ] ៧ឯគួរស្រូវតូចៗក៏លេប
គួរស្រូវធំថ្លោសល្អទាំង៧នោះទៅ រួចផារ៉ោនទ្រង់តើន
ឡើង[ជ] ហើយមើលនោះជាសុបិនទេ ៨លុះព្រឹកឡើងទ្រង់
មានព្រះទ័យវិតក្កណាស់[ឈ] ទើបចាត់គេឱ្យទៅហៅពួក
ហោរ[ញ] និងពួកអ្នកប្រាជ្ញនៅស្រុកអេស៊ីព្ទមក រួចទ្រង់
សំដែងប្រាប់សុបិននោះដល់គេ តែគ្មានអ្នកណាមួយអាច
នឹងកាត់ស្រាយថ្វាយទ្រង់បានឡើយ[ដ] ។
៩នោះនាយពិសេសថ្វាយពែងក៏ទូលទៅផារ៉ោនថា ថ្ងៃ
នេះទូលបង្គំនឹកឃើញពីសេចក្តីកំហុសរបស់ទូលបង្គំហើយ[ឋ]
១០ទ្រង់ព្រះករុណាបានខ្ញាល់នឹងពួកអ្នកបំរើទ្រង់[ឌ] ហើយក៏
ឃុំទូលបង្គំ នឹងមេពួកអ្នកដុតនំទុកក្នុងគុករបស់មេក្រុមរក្សា
ទ្រង់[ឍ] ១១យើងខ្ញុំទាំង២នាក់បានយល់សប្តិ ក្នុងយប់តែ១
ហើយដែលយើងខ្ញុំបានយល់សប្តិនោះ ក៏មានសេចក្តី
សិរាយផ្សេងពីគ្នា[ណ] ១២នៅទីនោះមានមនុស្សកំឡោះ
សាសន៍ហេព្រើរម្នាក់[ត] ជាបាវរបស់មេក្រុមរក្សាទ្រង់[ថ] បាន

**៤០:១៤** ផ ១សយ ២៥:៣១ លក ២៣:៤២ ព លប ១៩:១៩ ១សយ ២០:១៤,៤២ ២សយ ៩:១ ១ពវ ២:៧ ភ ខ.២៣ លប ៤១:៩ សស ៩:១៥ **៤០:១៥** ម លប ១៤:១៣ យ លប ៣៩:២០ យប ១៣:២៧ **៤០:១៦** រ ខ.១ ល ខ.២ វ អម ៨:១–២ **៤០:១៨** ស ខ.១២ **៤០:១៩** ហ ខ.១៣ ឡ ខ.១៣ អ ខ.២២ ចទ ២១:២២–២៣ នអ ២:២៣ ៧:១០ ក ចទ ២៨:២៦ ១សយ ១៧:៤៤ ២សយ ២១:១០ ១ពវ ១៤:១១ ១៦:៤ ២១:២៤ អគ ៣៩:៤ **៤០:២០** ខ ខ.១៣ គ មថ ១៤:៦–១០ ឃ នក ២:១៨ មក ៦:២១ ង ខ.១ **៤០:២១** ច ខ.១ ឆ ២ពវ ២៥:២៧ យរ ៥២:៣១ ជ ខ.១៣ **៤០:២២** ឈ ខ.១៩ ញ លប ៤១:១៣ ទដ ១០៥:១៩ **៤០:២៣** ដ ខ.១៤ សស ១:១១

**៤១:១** ក លប ២០:៣ ខ ខ.១៧ លប ២:១៤ នក ១:២២ ២:៥ ៧:១៥ **៤១:២** គ ខ.២៦ យរ៥:២៨ ឃ ខ.១៨ នក ២:៣ យប ៤០:២១ អស ១៩:៦ **៤១:៤** ង ខ.៧ **៤១:៥** ច យស ១៣:៣ ២ពវ ៤:៤២ ១រប ១៣:៥ អស២៣:៣ យរ ២:១៨ **៤១:៦** ឆ នក ១០:១៣ ១៤:២១ យប ៦:២៦ ១១:២ ១៥:២ ទដ ១១:៦ ៤៨:៧ អស ១១:១៥ ២៧:៨ យរ ៤:១១ ១៨:១៧ អគ ១៩:២១ ២៧:២៦ ហស ១២:១ ១៣:១៥ យហ ៤:៨**៤១:៧** ជ ខ.៤ **៤១:៨** ឈ យប ៧:១៤ ដយ ២:១,៣ ៤:៥,១៩ ញ នក ៧:១១,២២ ដយ ១:២០ ២:២,២៧ ៤:៧ ៥:៧ ដ ខ.២៤ លប ៤០:៨ ដយ ៤:១៨ **៤១:៩** ឋ លប ៤០:១៤ **៤១:១០** ឌ លប ៤០:២ ឍ លប ៣៧:៣៦ ៣៩:២០ **៤១:១១** ណ លប ៤០:៥ **៤១:១២** ត លប ១៤:១៣ ៣៩:១៧ ថ លប ៣៧:៣៦ ៤០:៤

**៤០:១៤** *កាលណាលោកបានសុខសាន្តហើយ នោះសូមនឹកចាំពីខ្ញុំផង* គួរឱ្យសោកស្តាយសម្រាប់យ៉ូសែបណាស់ អ្នកថ្វាយពែងនោះបាន"ភ្លេច"គាត់ (ខ.២៣) រហូតដល់២ឆ្នាំក្រោយមក (មើល ៤១:១,៩–១៣) ។

**៤០:១៥** *គុកជ្រៅ* ប្រហែលជាបានបំភ្លើស ដើម្បីឱ្យយ៉ូសែបគាត់អស់សង្ឃឹមប៉ុណ្ណោះ (មើល ៣៩:២០) ។ ពេលនោះ នៅក្នុងភាសាហេព្រើរគឺសំដៅលើអណ្តូង មើល ៣៧:២៤ ។ អ្នកនិពន្ធព្រះគម្ពីរលោកុប្បត្តិបានឱ្យលោកយ៉ូសែបគាត់ទទួលយកបទពិសោធន៍មុនបងៗរបស់គាត់ ។

**៤០:១៩** *នៅ៣ថ្ងៃទៀតផារ៉ោននឹងចងកលោកព្យួរជាប់លើឈើ* ទណ្ឌកម្មឃោរឃៅបែបនេះ គឺពឹងផ្អែកលើពាក្យដែលបានប្រើក្នុង ខ.១៣ និងការពន្យល់ ។

**៤១:២** *ហើយមើលមានគោញី៧* ជាញឹកញាប់ សត្វគោបានឆ្លងពីទន្លេនីលមកដើម្បីស្វែងរកចំណី ។

**៤១:៦** *ហើយស្កកដោយដោយខ្យល់ពីទិសខាងកើត* នៅប្រទេសប៉ាលេស្ទីនខ្យល់តែងតែបក់មកពីទីរហោស្ថាន (មើល ហស ១៣:១៥) ។ នៅចុងរដូវនៃនិទាឃរដូវឈានចូលរដូវស្លឹកឈើជ្រុះ ស្ទោបន្លែស្លឹកឈើ ជាញឹកញាប់គឺត្រូវក្រៀមស្វិតជាយូរថ្ងៃ (មើល អស ៤០:៧ អគ ១៧:១០ និងការពន្យល់) ។

**៤១:៨** *ទ្រង់មានព្រះទ័យវិតក្កណាស់* សូមមើល ៤០:៦–៧ ។ *ពួកហោរ* ប្រហែលជាសង្ឃ ដែលមានចំណេះដឹងជ្រៅជ្រះ អាចដឹងពីសេចក្តីអាថ៌កំបាំងផ្សេងៗ ។ *តែគ្មានអ្នកណាមួយអាចនឹងកាត់ស្រាយថ្វាយទ្រង់បានឡើយ* សូមមើល ដយ ២:១០–១១ ។

នៅជាមួយនឹងយើងខ្ញុំ ហើយយើងខ្ញុំក៏រ៉ាយរ៉ាប់សប្តិប្រាប់
ដល់គាត់ រួចគាត់បានកាត់ស្រាយឱ្យយើងខ្ញុំតាមសប្តិរៀង
រាល់ខ្លួន[ទ] ១៣ នោះក៏កើតដល់យើងខ្ញុំដូចជាគាត់បានកាត់
ស្រាយមែន ឯទូលបង្គំ គាត់កាត់ថា នឹងបានតាំងឡើងក្នុង
ដំណែងដើមរបស់ទូលបង្គំ ហើយអ្នក១នោះគាត់កាត់ថា
នឹងត្រូវចងព្យួរវិញ[ធ] ។
១៤ នោះផារ៉ោន ទ្រង់ចាត់គេ ឱ្យទៅហៅយ៉ូសែបមក
គេក៏ទៅនាំគាត់ចេញពីគុកជ្រៅនោះមកជាប្រញាប់[ន] គាត់
កោរពុកមាត់[ប]ហើយផ្លាស់សំលៀកបំពាក់[ផ] រួចចូលទៅ
គាល់ផារ៉ោន ១៥ ផារ៉ោនទ្រង់មានបន្ទូលទៅយ៉ូសែបថា
យើងបានយល់សប្តិ តែគ្មានអ្នកណាចេះកាត់សោះ[ព] ឥឡូវ
បានឮនិយាយពីឯងថា ឯងចេះកាត់សប្តិបាន[ភ] ១៦ យ៉ូសែប
ទូលឆ្លើយទៅផារ៉ោនថា ការនោះមិនស្រេចលើទូលបង្គំ
ទេ គឺព្រះនឹងឆ្លើយមកទ្រង់ព្រះករុណាជាសេចក្តីសុខវិញ[ម]
១៧ ផារ៉ោនមានបន្ទូលទៅយ៉ូសែបថា ក្នុងសប្តិរបស់យើង
នោះឃើញថា យើងឈរនៅមាត់ទន្លេ[យ] ១៨ ស្រាប់តែមាន
គោញី៧ មានសាច់ធាត់ល្អឡើងពីទន្លេមកស៊ីនៅទីវាល[រ]
១៩ រួចឃើញមានគោញី៧ទៀត ឡើងមកតាមក្រោយ វាស្គម
ហើយអាក្រក់មើលណាស់ គឺស្គមដល់ម្ល៉េះបានជាយើងមិន
ដែលឃើញសត្វអាក្រក់យ៉ាងនោះ នៅគ្រប់ក្នុងស្រុក
អេស៊ីព្ទផង ២០ គោសំគមហើយអាក្រក់មើលនោះ ក៏ស៊ី
លេបគោញីមុន ដែលធាត់ៗទាំង៧អស់ទៅ ២១ តែកាល
បានស៊ីទៅហើយ នោះក៏មិនដឹងជាបានស៊ីអ្វីផង ដ្បិតនៅតែ
អាក្រក់មើលដូចកាលពីមុនដែរ នោះយើងក៏ភ្ញាក់ឡើង
២២ រួចយល់សប្តិទៀតថា មានគួរស្រូវ៧ មានគ្រាប់ធំ
ថ្លោសល្អបែកឡើងនៅដើមតែ១ ២៣ រួចមានគួរ៧ទៀតមាន
គ្រាប់តូចៗ ស្វិតហើយស្កកដោយខ្យល់ពីទិសខាងកើតបែក
ឡើងជាខាងក្រោយ ២៤ ហើយគួរស្រូវគ្រាប់តូចៗក៏លេបគួរ
ដែលមានគ្រាប់ធំថ្លោសទាំង៧នោះទៅ យើងបានរ៉ាយ
រ៉ាប់សប្តិនេះប្រាប់ដល់ពួកហោរដែរ តែគ្មានអ្នកណាមួយ
អាចនឹងកាត់ស្រាយឱ្យយើងបានសោះ[ល] ។

២៥ យ៉ូសែបគាត់ទូលទៅផារ៉ោនថា ឯសុបិនរបស់ទ្រង់
ព្រះករុណា នោះតែ១ទេ[វ] ព្រះបានសំដែងឱ្យព្រះករុណា
ជ្រាបពីការដែលរៀបនឹងធ្វើ[ស] ២៦ ឯគោញីល្អទាំង៧[ហ]នោះ
គឺជា៧ឆ្នាំ ហើយគួរស្រូវល្អទាំង៧ នោះគឺជាឆ្នាំ៧នោះដែរ
គឺជាសុបិនតែ១ទេ ២៧ គោញីសំគមហើយអាក្រក់មើលទាំង
៧ដែលឡើងតាមក្រោយមក នោះគឺជា៧ឆ្នាំ ឯគួរស្រូវទទេ
ដែលស្កកដោយខ្យល់ពីទិសខាងកើតនោះនិងត្រូវជា៧ឆ្នាំ
អំណត់[ឡ] ២៨ គឺសេចក្តីនេះឯងដែលទូលបង្គំបានទូលដល់
ទ្រង់ព្រះករុណាថា សេចក្តីដែលព្រះរៀបនឹងធ្វើ នោះទ្រង់
បានសំដែងឱ្យទ្រង់ព្រះករុណាជ្រាបហើយ[អ] ២៩ គឺថានឹងត្រូវ
មាន៧ឆ្នាំ ដែលសម្បូរ[ក]នៅពេញក្នុងស្រុកអេស៊ីព្ទ ៣០ រួច
ក្រោយនោះទៅនឹងមានអំណត់៧ឆ្នាំវិញ[ខ] នោះគេនឹងភ្លេច
ពីផលបរិបូរក្នុងស្រុកអេស៊ីព្ទអស់ ដ្បិតអំណត់នោះនឹង
បង្ហិនស្រុកនេះទៅ[គ] ៣១ គេនឹងលែងស្គាល់សេចក្តីបរិបូរ នៅ
ក្នុងស្រុកទៀត ដោយព្រោះអំណត់ដែលត្រូវមកតាមក្រោយ
ដ្បិតអំណត់នោះនឹងបានខ្លាំងណាស់ ៣២ ហើយដែលព្រះ
ករុណា បានទ្រង់សុបិនឃើញ២ដង នោះគឺដោយព្រោះ
ព្រះបានសំរេចការនោះ[ឃ] ហើយក៏ប្រញាប់នឹងធ្វើដែរ[ង] ។
៣៣ ដូច្នេះ គួរតែព្រះករុណាពិនិត្យរកមនុស្សមានដំរិះ
មានប្រាជ្ញា[ច] ដើម្បីនឹងតាំងឱ្យត្រួតត្រាលើស្រុកអេស៊ីព្ទទៅ[ឆ]
៣៤ គួរឱ្យទ្រង់ព្រះករុណាបានធ្វើដូច្នោះ ហើយតាំងឱ្យមាន
ពួកដំរួត[ជ]នៅក្នុងស្រុក សំរាប់ឱ្យហូតយក១ភាគក្នុង៥[ឈ] ពី
អស់ទាំងផលក្នុងស្រុកអេស៊ីព្ទ នៅរវាង៧ឆ្នាំដែលសម្បូរ
ផង[ញ] ៣៥ ឱ្យគេប្រមូលស្បៀងអាហារទាំងអស់ក្នុងឆ្នាំល្អ
ដែលត្រូវមកទាំងនេះ ហើយទុកស្រូវនៅក្រោមអំណាច
ទ្រង់ព្រះករុណាសំរាប់ជាអាហារ នៅក្នុងទីក្រុងទាំងប៉ុន្មាន
ហើយឱ្យអ្នកទាំងនោះគ្រប់គ្រងរក្សាទុក[ដ] ៣៦ ឯស្បៀងអា
ហារនោះ នឹងបានបំរុងទុកសំរាប់ស្រុកអំណត់ទាំង៧ឆ្នាំ
ដែលត្រូវមកក្នុងស្រុកអេស៊ីព្ទ[ឋ] ដើម្បីកុំឱ្យស្រុកនេះត្រូវ
វិនាសទៅដោយសារអំណត់នោះឡើយ ។

ទ លប ៤០:១២
**៤១:១៣** ធ លប ៤០:២២
**៤១:១៤** ន ទដ ១០៥:២០ ប អស ១៨:២,៧ ផ លប ៣៥:២ ៤៥:២២ នរ ៣:៣ ២សយ ១២:២០
**៤១:១៥** ព លប ៤០:៨ ភ លប ៤០:១២ ដយ ៤:១៨ ៥:១៦
**៤១:១៦** ម លប ៤០:៨
**៤១:១៧** យ ខ.១
**៤១:១៨** រ ខ.៨
**៤១:២៤** ល ខ.៨
**៤១:២៥** វ លប ៤០:១២ ស លប ៤០:៨ អស ៤៦:១១ ដយ ២:៤៥
**៤១:២៦** ហ ខ.២
**៤១:២៧** ឡ លប ១២:១០
**៤១:២៨** អ លប ៤០:៨
**៤១:២៩** ក ខ.៤៧
**៤១:៣០** ខ ខ.៥៤ លប ៤៥:៦,១១ ៤៧:១៣ ទដ ១០៥:១៦ គ ខ.៥៦ លប ១២:១០
**៤១:៣២** ឃ ដយ ២:៥ ង លប ៤០:៨
**៤១:៣៣** ច ខ.៣៩ ឆ លប ៣៩:៩
**៤១:៣៤** ជ នអ ២:៣ ឈ លប ៤៧:២៤,២៦ ១សយ ៨:១៥
ឋ ៤៨ លប ៤៧:១៤ **៤១:៣៥** ដ ខ.៤៨ **៤១:៣៦** ឋ ខ.៥៦លប ៤២:៦ អស ១៩:១១

**៤១:១៣** *នោះក៏កើតដល់យើងខ្ញុំដូចជាគាត់បានកាត់ស្រាយមែន* ពីព្រោះពាក្យដែលចេញពីយ៉ូសែប គឺបានមកពីព្រះយេហូវ៉ា (មើល ទដ ១០៥:១៩) ។
**៤១:១៤** *នោះផារ៉ោន ទ្រង់ចាត់គេឱ្យទៅហៅយ៉ូសែបមក* ចាប់ពីពេលនោះមក លោកយ៉ូសែបត្រូវបានដោះលែងឱ្យមានសេរីភាពជាអចិន្ត្រៃយ៍ (ទដ ១០៥:២០) ។ *កោរពុកមាត់* ប្រជាជនអេស៊ីព្ទ គេកម្រនឹងកោរពុកមាត់ណាស់ ក្នុងខណៈពេលដែលពួកប៉ាលេស្ទីនគេទុកពុកចង្ការ (២សយ ១០:៤ យរ ៤១:៥ និងការបន្យល់) ។
**៤១:១៦** *ការនោះមិនស្រេចលើទូលបង្គំទេ គឺព្រះនឹងឆ្លើយមកទ្រង់ព្រះករុណាជាសេចក្តីសុខវិញ* (សូមមើល ៤០:៨ និងការពន្យល់ ដយ ២:២៧–២៨, ៣០ ហើយប្រៀបធៀបជាមួយ ២កថ ៣:៥) ។
**៤១:២៧** *នោះនិងត្រូវជា៧ឆ្នាំអំណត់* មើលក្នុង កច ៧:១១ ។ អំណត់អត់ជាច្រើនឆ្នាំកើតឡើងនៅស្រុកអេស៊ីព្ទកម្រនឹងមានណាស់ ពីព្រោះជានិច្ចកាលប្រទេសនេះសម្បូរណាស់ ដោយសារបានទទួលទឹកពីទន្លេនីល ទោះបីមិនគ្រប់កន្លែងទាំងអស់ក៏ដោយ (មើល ២ពវ ៨:១) ។
**៤១:៣២** ភាពស្ទួនៗគ្នានៃការបើកសម្តែងរបស់ព្រះជានិច្ចកាលគឺចង់បង្ហាញពីកិច្ចការសំខាន់ណាមួយ (៣៧:៥–៧ អម ៧:១–៦,៧–៩ ៨:១–៣) ។

៣៧សេចក្ដីនោះក៏គាប់ព្រះទ័យដល់ផារ៉ោន[ឱ] និងពួក
មហាតលិកទ្រង់ទាំងអស់គ្នា ៣៨នោះផារ៉ោនទ្រង់មានបន្ទូល
ទៅពួកមហាតលិកទ្រង់ថា តើយើងនឹងរកមនុស្សឯណា
ហើយដូចមនុស្សនេះ ដែលមានព្រះវិញ្ញាណរបស់ព្រះ
សណ្ឋិតនឹងគាត់បាន[ឍ] ៣៩រួចផារ៉ោទ្រង់មានបន្ទូលទៅ
យ៉ូសែបថា ដែលព្រះបានសំដែងឱ្យឯងដឹងសេចក្ដីទាំង
នេះ[ណ] នោះគ្មានអ្នកណាមានដំរិះមានប្រាជ្ញាដូចឯងនោះ
ទេ[ត] ៤០គឺឯងនេះហើយ ដែលត្រូវកាន់កាប់ត្រួតត្រាលើ
ជនជាតិរបស់យើង[ថ] ហើយរាស្ត្រយើងទាំងអស់នឹងចុះចូល
តាមបង្គាប់ឯង[ទ] យើងនឹងធំជាងឯង តែនៅបល្ល័ង្ករាជ្យ
ប៉ុណ្ណោះ[ធ] ។

## លោកយ៉ូសែបត្រួតលើប្រទេសអេស៊ីព្ទ

៤១រួចផារ៉ោនទ្រង់មានបន្ទូលទៅយ៉ូសែបថា នែ យើង
តាំងឯងឱ្យត្រួតត្រាលើស្រុកអេស៊ីព្ទទាំងមូលហើយ[ន] ៤២ផា
រ៉ោនទ្រង់ដោះព្រះទំរង់ពីព្រះហស្ត[ប] ទៅបំពាក់នៅដៃ
យ៉ូសែបវិញ ក៏យកសំលៀកបំពាក់សំពត់ទេស[ផ]យ៉ាងម៉ដ្ត[ព]
មកបំពាក់គាត់ ព្រមទាំងបំពាក់ខ្សែមាសនៅកឱ្យគាត់ផង[ភ]
៤៣ទ្រង់ឱ្យគាត់ជិះរាជរថបន្ទាប់របស់ទ្រង់[ម] ហើយមានគេ
ស្រែកនៅខាងមុខ[យ]ថា ចូរក្រាបចុះទាំងអស់គ្នាទៅ[រ]
ដូច្នេះទ្រង់បានតាំងគាត់ឱ្យត្រួតត្រាលើស្រុកអេស៊ីព្ទទាំង
មូល[ល] ៤៤ផារ៉ោនទ្រង់ក៏មានបន្ទូលទៅយ៉ូសែបថា យើងនេះ
ជាផារ៉ោន បើឯងមិនបង្គាប់ នោះគ្មានអ្នកណានិងលើកដៃ
លើកជើងនៅគ្រប់ក្នុងស្រុកអេស៊ីព្ទទេ[វ] ៤៥ផារ៉ោនក៏ហៅ
ឈ្មោះយ៉ូសែប[ស]ថា សាប់នាត់–ផានា ក៏ឱ្យនាងអាសនាត់ជា
កូនប៉ូទី–ផេរ៉ា ជាសង្ឃ[ហ]នៅក្រុងអូន[ឡ]ធ្វើជាប្រពន្ធ[អ]រួច
យ៉ូសែបចេញដើរទៅពេញក្នុងស្រុកអេស៊ីព្ទ ។

៤៦កាលយ៉ូសែបឈរនៅ[ក]ចំពោះផារ៉ោន ជាស្ដេចស្រុក
អេស៊ីព្ទ នោះគាត់មានអាយុ៣០ឆ្នាំហើយ[ខ] គាត់ក៏ចេញពី
ចំពោះផារ៉ោនដើរទៅពេញក្នុងស្រុកអេស៊ីព្ទទាំងអស់
៤៧នៅក្នុងឆ្នាំសម្បូរទាំង៧នោះ[គ] ដីបានបង្កើតផលជា
បរិបូរ ៤៨គាត់ក៏ប្រមូលស្បៀងអាហារនៅស្រុកអេស៊ីព្ទ
ទាំងអស់ក្នុងរវាង៧ឆ្នាំនោះហើយបានរក្សាទុកស្បៀងទាំង
នោះនៅក្នុងទីក្រុងទាំងប៉ុន្មាន គឺថាស្បៀងពីស្រែចំការ
ដែលនៅជុំវិញទីក្រុងណា[ឃ] នោះគាត់បានប្រមូលទុកក្នុងទី
ក្រុងនោះឯង ៤៩យ៉ូសែបបានប្រមូលស្រូវយ៉ាងសន្ធឹកណាស់
ដូច ជាខ្សាច់នៅនាសមុទ្រ[ង]ទាល់តែគាត់លែងរាប់ ពីព្រោះ
រាប់មិនបាន ៥០គ្រាមុនដែលកើតមានឆ្នាំអំណត់នោះ
យ៉ូសែប មានកូនប្រុស២ ដែលនាងអាសនាតជាកូនប៉ូទី–
ផេរ៉ាជាសង្ឃនៅក្រុងអូនបានបង្កើតឱ្យ[ច] ៥១យ៉ូសែបឱ្យកូន

**៤១:៣៧** ឱ លប ៤៥:១៦ នអ ២:៤ អស ១៩:១១ **៤១:៣៨** ឍ ជន ២៧:១៨ ចទ ៣៤:៩ ដយ ២:១១ ៤:៨,៨–៩,១៨ ៥:១១,១៤ **៤១:៣៩** ណ ដយ ២:១១ ៥:១១ ត ខ.៣៣ **៤១:៤០** ថ ១ពវ ៤:៦ ២ពវ ១៥:៥ អស ២២:១៥ ៣៦:៣ ទ លប ៣៩:៩ ទដ ១០៥:២១–២២ កច ៧:១០ ធ នអ ១០:៣ **៤១:៤១** ន ខ.៤៣, ៥៥ លប ៤២:៦ ៤៥:៨,១៣,២៦ នអ ៨:២ យរ ៤០:៧ ដយ ៦:៣ **៤១:៤២** ប លប ២៤:២២ នអ ៣:១០ ៨:២,៨ ផ ១សយ ១៧:៣៨ ១៨:៤ ១ពវ ១៩:១៩ នអ ៦:៨,១១ ដយ ៥:២៩ សក ៣:៤ ព នក ២៥:៤ នអ ៨:១៥ ដយ ៥:២៩ ភ ទដ ៧៣:៦ ៤:៩ អស ៣:១៨ អគ ១៦:១១ ដយ ៥:៧,១៦,២៩ **៤១:៤៣** ម លប ៤៦:២៩ ៥០:៩ អស ២:៧ ២២:១៨ យ នអ ១០:៣ រ នអ ៦:៩ ល ខ.៤១ **៤១:៤៤** វ លប ៣៧:៨ នអ ១០:២ ទដ ១០៥:២២ **៤១:៤៥** ស នអ ២:៧ ហ នក ២:១៦ ឡ អគ ៣០:១៧ អ ខ.៥០ **៤១:៤៦** ក លប ៣៧:២ ខ ១សយ ៨:១១ ១៦:២១ សភ ២២:២៩ ដយ ១:១ **៤១:៤៧** គ ខ.២៩ **៤១:៤៨** ឃ ខ.៣៤ **៤១:៤៩** ង លប ១២:២ **៤១:៥០** ច ខ.៤៥

**៤១:៣៨** *វិញ្ញាណរបស់ព្រះ* តាមច្បាប់របស់ពួកអ្នកមិនជឿ ព្រះគេគិតថា "ព្រះវិញ្ញាណ" មិនសំខាន់ឡើយ ព្រោះវាជារបស់ក្រៅខ្លួន ។

**៤១:៤០** *គឺឯងនេះហើយ ដែលត្រូវកាន់កាប់ត្រួតត្រាលើជនជាតិរបស់យើង* ស្ដេចផារ៉ោន ទ្រង់បានទទួលយកដំបូន្មានរបស់លោកយ៉ូសែប (ខ.៣៣) ដែលលោកយ៉ូសែបបានផ្ដល់ឱ្យ ហើយចុងបញ្ចប់ទ្រង់សម្រេចព្រះទ័យថា គឺមានតែយ៉ូសែបទេ ដែលអាច"ត្រួតត្រាលើស្រុកអេស៊ីព្ទ"(កច ៧:១០ ទដ ១០៥:២១) ។ *ហើយរាស្ត្រយើងទាំងអស់នឹងចុះចូលតាមបង្គាប់ឯង* តាមលក្ខណៈអក្សរសាស្ត្រជាច្រើន បាននិយាយថា"ដោយសារពាក្យបង្គាប់របស់ឯង នោះរាស្ត្រអញនិងថើប(ឯង)" គឺថើបដៃ ឬជើងដើម្បីបង្ហាញពីការចុះចូលនឹងស្ដាប់បង្គាប់(មើលក្នុង ទដ ២:១២ នឹងអត្ថបទពន្យល់) ។

**៤១:៤២** មាននិមិត្តរូប៣យ៉ាងនៅក្នុងការផ្លាស់ប្ដូរ ឬការចែករំលែកសិទ្ធិរបស់ព្រះមហាក្សត្រ ហើយក៏ដូចគ្នានឹង នអ ៣:១០ (សញ្ញាសំគាល់ដោយព្រះទំរង់ "ចិញ្ចៀន") នអ ៦:១១ (សញ្ញាសំគាល់ដោយព្រះពស្ត្ររាជ) ដយ ៥:៧,១៦,២៩ (សញ្ញាសំគាល់ដោយខ្សែមាស) ។

**៤១:៤៣** *ត្រួតត្រា* តួរនាទីដ៏សំខាន់នឹងធំដូច្នេះប្រហែលជាសំដៅលើព្រះមហាក្សត្រទ្រង់ផ្ទាល់ ។

**៤១:៤៥** *ហៅឈ្មោះយ៉ូសែបថា សាប់នាត់–ផានា* ផារ៉ោន ព្រះអង្គទ្រង់បានតែងតាំងយ៉ូសែបឱ្យមានតួរនាទីស្របច្បាប់ដើម្បីត្រួតត្រានៅក្នុងតំណាក់ (មើលការពន្យល់ ១:៥) ។ ស្ដេចផារ៉ោន បានរៀបចំគម្រោងការជាមុនរួចជាស្រេច ក្នុងការផ្ដល់ទេយ្យទាន ដល់អ្នកបម្រើរបស់ព្រះប្រយោជន៍ឱ្យរាជ្យរបស់ទ្រង់ (ស្ដេចផារ៉ោន) ផ្ទាល់ ហើយនៅពេលក្រោយមកទៀតស្ដេចផារ៉ោនបានប៉ុនប៉ង រំលោភយកព្រះពររបស់អ៊ីស្រាអែលដែលរីកចម្រើននៅក្នុងស្រុកអេស៊ីព្ទ (នក ១) ។ តាមពិតគាត់មិនបានទទួលស្គាល់ថា យ៉ូសែប ជាមនុស្សដែលមានអំណាចខ្ពស់ ហើយប្រទេសរបស់គាត់ក៏មិនអាចទទួលការប្រោសលោះតាមរយៈលោកយ៉ូសែបបានឡើយ ។ (ឈ្មោះដែលគាត់បានដាក់ឱ្យនោះមិនពិតទេ) ។ *អាសនាត់* នេះជាឈ្មោះរបស់ជនជាតិអេស៊ីព្ទហើយប្រហែលជាមានន័យថា"កម្មសិទ្ធរបស់ព្រះ"ដូចគ្នានឹងប៉ូទីផេរ៉ាដែរ ។ ឈ្មោះនេះមិនមែនដូចគ្នានឹងឈ្មោះប៉ូទីផារក្នុង (សូមមើល ៣៧:៣៦ ៣៩:១) ដែលឈ្មោះរបស់គាត់ក៏ជាឈ្មោះរបស់អេស៊ីព្ទដែរ តែមានន័យថា ជាកម្មសិទ្ធិរបស់ "ព្រះអាទិត្យ" ។ *ក្រុងអូន* មានចម្ងាយប្រហែលជា៣ម៉ៃយភាគខាងជើងឈាងខាងកើតទីក្រុងខារ៉ូទំនើប ហើយវាត្រូវគេហៅថា "អេលីប៉ូលីស" (ទីក្រុងព្រះអាទិត្យ) ជាក្រុងដ៏សំខាន់របស់ក្រេក និងជាទីក្រុងដែលគេនាំគ្នាមកថ្វាយបង្គំដល់"រេ"ដែលមានប្រាសាទជាច្រើននៅទីនោះផងដែរ ។

**៤១:៤៦** *៣០ឆ្នាំ* គឺរយៈពេលតែ១៣ឆ្នាំប៉ុណ្ណោះ (៣៧:២) យ៉ូសែបគាត់ក្លាយជាអ្នកដឹកនាំក្នុងស្រុកអេស៊ីព្ទ(ខ.៤៣) ។

ច្បង[ឆ]ឈ្មោះថា ម៉ាន៉ាសេ[ជ] ដោយគិតថាព្រះទ្រង់បានធ្វើឱ្យ
អញភ្លេចសេចក្តីទុក្ខលំបាករបស់អញអស់ទាំងប៉ុន្មានព្រម
ទាំងពួកគ្រួឪពុកអញផង ៥២ហើយកូន១ទៀតគាត់ឱ្យឈ្មោះ
អេប្រាអិម[ឈ] ដោយគិតថា ព្រះទ្រង់បានប្រទានឱ្យអញមាន
កូន[ញ] នៅក្នុងស្រុកនៃសេចក្តីទុក្ខព្រួយរបស់អញ ។
៥៣គ្រានោះឆ្នាំសម្បូរទាំង៧នៅស្រុកអេស៊ីព្ទ ក៏កន្លងផុត
ទៅ ៥៤ឯឆ្នាំអំណត់[ដ]ទាំង៧ក៏ចាប់តាំងផ្តើមឡើង[ឋ]ដូចជា
យ៉ូសែបបានទាយមែន ក៏មានអំណត់នៅគ្រប់ស្រុកទាំងអស់
តែនៅស្រុកអេស៊ីព្ទទាំងមូលមានស្បៀងអាហារវិញ
៥៥កាលជនក្នុងស្រុកអេស៊ីព្ទទាំងអស់បានអត់ឃ្លាន[ឌ]ហើយគេ
ស្រែកសូមអាហារពីផារ៉ោន នោះទ្រង់មានបន្ទូលទៅពួក
សាសន៍អេស៊ីព្ទទាំងអស់ថា ចូរទៅឯយ៉ូសែបទៅហើយធ្វើ
តាមដែលលោកបង្គាប់ចុះ[ឍ] ៥៦នោះមានអំណត់អត់នៅ
ពេញលើផែនដី រួចយ៉ូសែបគាត់បើកគ្រប់ទាំងជង្រុកស្រូវ
លក់ឱ្យពួកសាសន៍អេស៊ីព្ទ[ណ] អំណត់នោះ[ត] កាន់តែខ្លាំងឡើង
នៅស្រុកអេស៊ីព្ទ[ថ] ៥៧គ្រប់ទាំងស្រុកក៏នាំគ្នាចូលមកឯ
យ៉ូសែប[ទ]នៅស្រុកអេស៊ីព្ទ ដើម្បីនឹងទិញស្រូវ ពីព្រោះ
អំណត់នោះជាខ្លាំងណាស់នៅពេញលើផែនដី[ធ] ។

## បងប្រុសរបស់លោកយ៉ូសែបទៅប្រទេសអេស៊ីព្ទ

**៤២** ១រីឯយ៉ាកុប គាត់ឃើញថា ស្រុកអេស៊ីព្ទមានស្រូវ
នោះ[ក] គាត់និយាយទៅពួកកូនថា ហេតុអ្វីបានជាឯងរាល់
គ្នាមើលមុខគ្នាទៅវិញទៅមកដូច្នេះ ២គាត់ប្រាប់ថា នែ
អញបានឮថាស្រុកអេស៊ីព្ទមានស្រូវ ដូច្នេះចូរឯងរាល់គ្នា
ចុះទៅឯណោះ ដើម្បីទិញពីនោះមកសំរាប់យើងចុះ[ខ] ឱ្យ
យើងបានរស់នៅកុំឱ្យស្លាប់[គ] ៣នោះបងយ៉ូសែបទាំង
១០នាក់ ក៏ចុះទៅទិញស្រូវ[ឃ]ឯស្រុកអេស៊ីព្ទ ៤តែយ៉ាកុបមិន
ឱ្យបេនយ៉ាមីន[ង]ជាប្អូនយ៉ូសែប ទៅជាមួយនឹងពួកបងៗទេ
ដោយនឹកខ្លាចថា ក្រែងកើតមានគ្រោះថ្នាក់ដល់វា[ច] ៥ដូច្នេះ
ពួកកូនអ៊ីស្រាអែលក៏ចូលទៅជាមួយនឹងពួកអ្នកទាំងប៉ុន្មាន
ដែលទៅទិញស្រូវ[ឆ] ដ្បិតនៅស្រុកកាណាន[ជ]ក៏មានអំណត់
អត់ដែរ[ឈ] ៦ឯយ៉ូសែប គាត់ជាចៅហ្វាយលើស្រុកនោះ[ញ]
គឺគាត់ហើយ ដែលជាអ្នកលក់ស្រូវឱ្យដល់បណ្តាមនុស្សនៅ
ផែនដី[ដ] ពួកបងគាត់ក៏ចូលទៅក្រាបផ្កាប់មុខដល់ដីចំពោះ
គាត់[ឋ] ៧កាលយ៉ូសែបឃើញពួកបង នោះក៏ស្គាល់គេ តែគាត់
ធ្វើដូចជាអ្នកដទៃនឹងគេវិញ ហើយនិយាយដោយតឹងរ៉ឹង[ឌ]ថា
មកពីណា[ឍ] គេឆ្លើយថា យើងខ្ញុំមកពីស្រុកកាណាន ដើម្បី
នឹងទិញស្បៀងអាហារ ៨យ៉ូសែបស្គាល់ពួកបងជាក់ តែគេ

**៤១:៥១** ឆ លប ៤៨:១៤,១៨,២០ ៤៩:៣ ជ លប ៤៦:២០ ៤៨:១ ២៣ ជន ១:៣៤ ចទ ៣៣:១៧ យស ៤:១២ ១៧:១ ១របា ៧:១៤
**៤១:៥២** ឈ លប ៤៦:២០ ៤៨:១,៥ ៥០:២៣ ជន ១:៣២ ២៦:២៨ ចទ ៣៣:១៧ យស ១៤:៤ ពច ៥:១៤ ១រប ៧:២០ ២រប ៣០:១ ទដ ៦០:៧ យរ ៧:១៥ អប ១:១៩ ញ លប ១៧:៦
**៤១:៥៤** ដ លប ១២:១០ ឋ កច ៧:១១
**៤១:៥៥** ឌ ចទ ៣២:២៤ ២រប ២០:៩ អស ៥១:១៩ យរ ៥:១២ ២៧:៨ ៤២:១៦ ៤៤:២៧ ឍ ខ.៤១ យហ ២:៥
**៤១:៥៦** ណ ខ.៣៦ ត លប ១២:១០ ថ ខ.៣០ **៤១:៥៧** ទ លប ៤២:៥ ៤៧:១៥ ធ លប ១២:១០
**៤២:១** ក កច ៧:១២ **៤២:២** ខ លប ៤៣:២,៤ ៤៤:២៥ គ ខ.១៩,៣៣ លប ៤៣:៨ ៤៧:១៩ ទដ ៣៣:១៨–១៩ **៤២:៣** ឃ ខ.១០ លប ៤៣:២០ **៤២:៤** ង លប ៣៥:១៨ ច ខ.៣៨ **៤២:៥** ឆ លប ៤១:៥៧ ជ ខ.១៣, ២៩ លប ៣១:១៨ ៤៥:១៧ ឈ លប ១២:១០ ចទ ៣២:២៤ កច ៧:១១ **៤២:៦** ញ លប ៤១:៤១ នហ ៥:១៤ ដ លប ៤១:៣៦ ឋ លប ៣៣:៣ **៤២:៧** ឌ ខ.៣០ ឍ លប ២៩:៤
**៤២:៨** ណ លប ៣៧:២

**៤១:៥២** *អេប្រាអិម* ការដាក់ឈ្មោះឱ្យបែបនេះ គឺជាការលេងពាក្យមួយដែលសំដៅលើការប្រទានពររបស់ព្រះ ចំពោះលោកយ៉ូសែប ឱ្យគាត់មានកូន២នាក់(ខ.៥០) ។

**៤១:៥៧** *គ្រប់ទាំងស្រុក* គ្រប់ទាំងស្រុកល្បីល្បាញដែលនៅឆ្ងាយៗ(មជ្ឈិមប្រទេស) ។ អ្នកនិពន្ធបានពិពណ៌នាពីគ្រាអំណត់ នៅសម័យយ៉ូសែប ដូចគ្នានឹងការពិពណ៌នានៅគ្រាទឹកជន់ជិនាន់លោកណូអេដែរ ដែលពេលនោះមានតែគ្រួសារលោកណូអេប៉ុណ្ណោះ ដែលបានទទួលសេចក្តីសង្គ្រោះមកពីព្រះ ហើយលោកណូអេគាត់បានក្លាយជាឪពុកថ្មីសម្រាប់ប្រជាជនអ៊ីស្រាអែល(បន្ទាប់ពីលោកអ័ដាម) ។ ដោយសារការត្រាស់ហៅរបស់ព្រះចំពោះលោកអ័ប្រាហាំ ឱ្យគាត់ចាកចេញពីស្រុកកំណើត បន្ទាប់ពីទឹកជន់ និងមនុស្សដែលរស់នៅឯប៉មបាបិលមក នៅគ្រាមួយព្រះយេហូវ៉ា ទ្រង់គឺជាព្រះដ៏វិសេសសម្រាប់មនុស្សជាច្រើន ហើយឥឡូវនេះព្រះអង្គ គឺជាឪពុកដ៏វិសេសសម្រាប់រាស្ត្ររបស់ទ្រង់ ។ ព្រះយេហូវ៉ាទ្រង់បានសន្យាថា តាមរយៈអ្នកនេះហើយនិងកូនចៅរបស់គេនោះ"គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារឯង"(១២:៣) ។ អ្នកនិពន្ធបានលើកយកចំណុចដ៏សំខាន់ឡើងដោយគាត់បានបង្ហាញថា វិបត្តិសេដ្ឋកិច្ចនេះនិងអាចដោះស្រាយបានតាមរយៈកូនចៅរបស់អ៊ីស្រាអែល ។

**៤២:១–៤៥:២៨** នៅក្នុងជំពូកទាំងនេះ គឺជាការពិពណ៌នាអំពីការជួបជុំនិងការផ្សះផ្សាឡើងវិញរបស់កូនចៅយ៉ាកុប ហើយឥឡូវនេះពួកគេទាំងនោះកំពុងរស់នៅប្រទេសអេស៊ីព្ទ ។

**៤២:២–៣** លោកស្ទេផាន បានយករឿងនេះទៅអធិប្បាយនៅក្នុងព្រះគម្ពីរ កច ៧:១២ ។

**៤២:៤** *យ៉ាកុបមិនឱ្យបេនយ៉ាមីន ជាប្អូនយ៉ូសែប* នាងរ៉ាជែលជាម្តាយរបស់ពួកគេបានស្លាប់(៣៥:១៩)លោកយ៉ាកុបគាត់ក៏បានគិតថា យ៉ូសែបបានស្លាប់ហើយ (៣៧:៣៣) ។ ដោយសារគាត់មិនចង់ឱ្យបាត់បង់កូនជាទីស្រឡាញ់ម្នាក់ទៀតដែលនាងរ៉ាជែលបង្កើតឱ្យគាត់ ដូច្នេះហើយបានជាគាត់មិនចង់ឱ្យបេនយ៉ាមីនទៅជាមួយពួកបងៗរបស់គេ ។

**៤២:៥** *ដ្បិតនៅស្រុកកាណានក៏មានអំណត់អត់ដែរ* ដូចគ្នានឹងសម័យលោកអ័ប្រាហាំដែរ(១២:១០ និងការពន្យល់) ។

**៤២:៨** *យ៉ូសែបស្គាល់ពួកបងជាក់* ទោះបីជាគាត់មិនបានឃើញពួកគេ២១ឆ្នាំ (៣៧:២ ៤១:៤៦,៥៣–៥៤) ហើយនៅគ្រានោះពួកគេពេញវ័យហើយក៏ដោយ ក៏ពេលនេះអត្តចរិតរបស់ពួកគេមិនមានការផ្លាស់ប្តូរប៉ុន្មានឡើយ ។ *តែគេមិនស្គាល់គាត់ទេ* ដោយនៅគ្រាដែលបងៗលក់គាត់ឱ្យធ្វើជាទាសករលោកយូសែបគាត់មានអាយុ១៧ឆ្នាំ (៣៧:២) ពេលនេះគាត់ពេញវ័យហើយបានទទួលមុខតំណែងខ្ពស់មុខខ្ពស់មាត់ នឹងមានអំណាចនៅស្រុកអេស៊ីព្ទ គាត់បានស្លៀកសំលៀកបំពាក់ជាជនជាតិអេស៊ីព្ទនិយាយទៅកាន់បងៗរបស់គាត់តាមរយៈអ្នកបកប្រែ (មើល ខ.២៣) មួយវិញទៀតគាត់បានកោរពុកមាត់តាមលក្ខណៈជាជនជាតិអេស៊ីព្ទ (៤១:១៤) ។

មិនស្គាល់គាត់ទេ[ណ] ៩គាត់ក៏នឹកឃើញពីសប្តិ[ត] ដែលបានយល់
សប្តិពីដំណើរគេ រួចនិយាយទៅគេថា ឯងរាល់គ្នាជាពួក
លបសង្កេតស្រុកទេ[ថ] ឯងបានមកដើម្បីនឹងមើលស្រុកនេះ
ដែលនៅទទេជាយ៉ាងណាហើយ[ទ] ១០តែគេឆ្លើយថា ទេ
លោកម្ចាស់ខ្ញុំអើយ[ធ] យើងខ្ញុំប្របាទបានគ្រាន់តែមកទិញ
ស្បៀងអាហារប៉ុណ្ណោះទេ[ន] ១១យើងខ្ញុំរាល់គ្នាមានឪពុក
តែ១ យើងខ្ញុំប្របាទ[ប]ជាមនុស្សទៀងត្រង់ពិត[ផ] មិនមែនជា
ពួកលបសង្កេតទេ[ព] ១២តែគាត់តបទៅគេថា ទេពិតជាឯង
រាល់គ្នាបានមក ដើម្បីមើលស្រុកដែលនៅទទេ ជាយ៉ាង
ណាហើយ[ភ] ១៣នោះគេឆ្លើយថា យើងខ្ញុំប្របាទ[ម]មានបង
ប្អូន១២នាក់ ជាកូនមានឪពុកតែ១ នៅស្រុកកាណាន[យ]
មើល សព្វថ្ងៃនេះ កូនពៅបាននៅជាមួយនឹងឪពុករបស់
យើងខ្ញុំ ហើយកូន១ទៀតមិននៅទេ[រ] ១៤យ៉ូសែបឆ្លើយតបថា
គឺដូចជាអញបានប្រាប់ឯងរាល់គ្នា ហើយថាឯងរាល់គ្នាជា
ពួកលបសង្កេតស្រុកទេ[ល] ១៥អញនឹងល្បងសាកឯងរាល់គ្នា
មើល ដូច្នេះ គឺអញស្បថនឹងព្រះជន្មផារ៉ោន[វ]ថា ឯងរាល់គ្នា
នឹងមិនបានចេញពីទីនេះឡើយ លើកតែប្អូនពៅឯងបាន
មកឯណេះសិន[ស] ១៦ចូរឯងចាត់គ្នាឯងម្នាក់ឱ្យទៅនាំប្អូន
ពៅមក[ហ] តែត្រូវចងឯងរាល់គ្នាទុកនៅទីនេះ[ឡ] ដើម្បីនឹង
ល្បងសាកមើលចំពោះពាក្យសំដីឯង ឱ្យដឹងជានិយាយពិតឬ
ទេ[អ] បើមិនពិតទេ នោះអញស្បថនឹងព្រះជន្មផារ៉ោនថា
ឯងរាល់គ្នាជាពួកលបសង្កេតស្រុកមែន[ក] ១៧រួចគាត់ឃុំគេ
ទុក[ខ]នៅអស់៣ថ្ងៃ ។

១៨លុះដល់៣ថ្ងៃក្រោយមក នោះយ៉ូសែបគាត់និយាយទៅ
គេថា ចូរធ្វើដូច្នេះចុះ ដើម្បីឱ្យបានរស់នៅ ដ្បិតអញជាអ្នក
គោរពកោតខ្លាចដល់ព្រះ[គ] ១៩បើឯងរាល់គ្នាជាមនុស្ស
ទៀងត្រង់មែន[ឃ] នោះចូរឱ្យបងប្អូនឯងម្នាក់នៅជាប់ចំណាង
ក្នុងគុក[ង]នេះសិន តែឯងរាល់គ្នាឯទៀតត្រូវនាំយកស្រូវទៅ
ឱ្យពួកផ្ទះឯងដែលអត់ចុះ[ច] ២០រួចឱ្យនាំប្អូនពៅឯងមកឯអញ
កុំខាន[ឆ] យ៉ាងនោះនឹងបានដឹងថា ឯងរាល់គ្នានិយាយពិត
ត្រង់មែនហើយ ឯងរាល់គ្នាក៏មិនត្រូវស្លាប់ផង គេក៏ធ្វើ
ដូច្នោះ ២១រួចគេនិយាយគ្នាគេថា ប្រាកដជាយើងមាន
ទោសដោយព្រោះប្អូនយើងហើយ[ជ] ពីព្រោះយើងបាន
ឃើញសេចក្តីទុក្ខព្រួយក្នុងចិត្តវាក្នុងកាលដែលវាអង្វរដល់
យើងនោះ តែយើងមិនបានស្តាប់តាមវាសោះ គឺដោយ
ហេតុនោះឯង បានជាសេចក្តីទុក្ខព្រួយនេះ[ឈ]បានធ្លាក់មក
លើយើងរាល់គ្នាវិញ ២២នោះរូបេនឆ្លើយឡើងថា តើអញ
មិនបានហាមឯងរាល់គ្នាទេឬអីថា កុំឱ្យធ្វើបាបវាឡើយ[ញ]
តែឯងរាល់គ្នាមិនព្រមស្តាប់តាមអញសោះ មើលន៍ឥឡូវ
ឈាមវា[ដ]បានទារ[ឋ]វិញហើយ ២៣គេមិនដឹង[ឌ]ថា យ៉ូសែប
ស្តាប់បានទេ[ឍ] ពីព្រោះមានអ្នកបកភាសាឱ្យ ២៤គាត់ក៏ងាក
បែរចេញពីគេទៅយំ[ណ] រួចត្រឡប់មកនិយាយនឹងគេវិញ
ទើបយកស៊ីម្មានពីពួកគេមកចងនៅមុខគេ[ត] ។

២៥យ៉ូសែបគាត់បង្គាប់ឱ្យច្រកស្រូវឱ្យពេញបាវគេ[ថ]
ហើយដាក់ប្រាក់គេចុះទៅក្នុងបាវរៀងខ្លួនវិញ[ទ] ព្រមទាំងឱ្យ
ស្បៀងអាហារ[ធ]សំរាប់បរិភោគតាមផ្លូវ[ន]ផង នោះក៏បានធ្វើ
ឱ្យគេដូច្នោះ ២៦គេផ្ទុកស្រូវលើលា[ប]ចេញពីនោះទៅ ២៧លុះ
កាលអ្នកម្នាក់បានស្រាយបាវនឹងយកស្រូវឱ្យលាស៊ីនៅត្រង់
ផ្ទះសំណាក់[ផ] នោះស្រាប់តែឃើញប្រាក់របស់ខ្លួននៅក្នុង
មាត់បាវ[ព] ២៨គាត់ក៏ប្រាប់ដល់បងប្អូនថា ប្រាក់ខ្ញុំគេបាន
ប្រគល់មកវិញហើយ មើល មាននៅក្នុងបាវខ្ញុំឯណេះ គេ
មានសេចក្តីតក់ស្លុតគ្រប់គ្នា[ភ] ក៏ងាកបែរមើលគ្នាទាំងភ័យ
ញ័រ[ម] ហើយនិយាយថា តើព្រះបានធ្វើអ្វីដល់យើងដូច្នេះ[យ] ។

២៩លុះគេទៅដល់យ៉ាកុបជាឪពុកនៅស្រុកកាណានហើយ[រ]
នោះក៏រ៉ាយរ៉ាប់ជំរាបគាត់ពីគ្រប់ទាំងការដែលបានកើត
ឡើងដល់គេ[ល]ថា ៣០អ្នកដែលជាចៅហ្វាយនៅស្រុកនោះ

**៤២:៩** ត លប ៣៧:៧ ថ ខ.១៤,១៦, ៣០ ចទ ១:២២ យស ២:១ ៦:២២ ទ ខ.១២ **៤២:១០** ធ លប ៣៧:៨ ន ខ.៣ **៤២:១១** ប ខ.១៣ លប ៤៤:៧,៩,១៦, ១៩,២១,៣១ ៤៦:៣៤ ៤៧:៣ ផ ខ.១៥,១៦, ១៩, ២០,៣៤ ព ខ.៣១ **៤២:១២** ភ ខ.៩ **៤២:១៣** ម ខ.១១ យ ខ.៥ លប ៤៦:៣១ ៤៧:១ រ ខ.២៤,៣២,៣៦ លប ៣៧:៣០,៣៣ ៤៣:៧,២៩,៣៣ ៤៤:៨ យរ ៣១:១៥ **៤២:១៤** ល ខ.៩ **៤២:១៥** វ ១សយ ១៧:៥៥ ស ខ.១១ លប ៤៣:៣,៥,៧ ៤៤:២១,២៣ **៤២:១៦** ហ ខ.១៥ ឡ ខ.១៩ អ ខ.១១ ក ខ.៩ **៤២:១៧** ខ លប ៤០:៤ **៤២:១៨** គ លប ២០:១១ ២២:១២ លវ ១៩:១៤ ២៥:៤៣ ២សយ ២៣:៣ **៤២:១៩** ឃ ខ.១១ង ខ.១៦ ច ខ.២ **៤២:២០** ឆ ខ.១៥ **៤២:២១** ជ លប ៣៧:២៦-២៨ ឈ លប ៤៥:៥ **៤២:២២** ញ លប ៣៧:២១-២២ ដ លប ៤៥:២៤ ឋ លប ៩:៥ **៤២:២៣** ឌ លប ៣៨:១៦ ឍ លប ១១:៧ **៤២:២៤** ណ លប ២៩:១១ ត ខ.១៣ លប ៤៣:១៤,២៣ **៤២:២៥** ថ លប ៤៣:២ ទ ខ.២៧, ៣៥ លប ៤៣:១២,១៨,២១ ៤៤:១,៨ ធ យរ ៤០:៥ ន លប ៤៥:២១,២៣ **៤២:២៦** ប លប ៣២:១៥ ៤៤:១៣ ៤៥:១៧ ១សយ ២៥:១៨ អស ៣០:៦ **៤២:២៧** ផ ពច ១៩:១៩ យប ៣៩:៩ អស ១:៣ ព ខ.២៥ **៤២:២៨** ភ យស ២:១១ ៥:១ ៧:៥ ម មក ៥:៣៣ យ លប ៤៣:២៣ **៤២:២៩** រ ខ.៥ ល លប ៤៤:២៤

**៤២:៩,១៤,១៦** *ឯងរាល់គ្នាជាពួកលបសង្កេតស្រុកទេ* សូមមើល យស ២:១-២៤ ។
**៤២:១០** *លោកម្ចាស់ខ្ញុំអើយ* បងៗលោកយ៉ូសែបបានកោតខ្លាច លោកយ៉ូសែបដោយមិនដឹងខ្លួន (៣៧:៨) ។
**៤២:១៥** *គឺអញស្បថនឹងព្រះជន្មផារ៉ោនថា* រាល់ពាក្យសម្បថជាច្រើន គឺគេតែងតែនិយាយដោយនាមរបស់ស្តេចណាមួយ ឬដោយនូវឈ្មោះអ្នកនិយាយតែម្តង (ទដ ១៦:៤ អម ៨:១៤) ជួនកាលគឺនិយាយដោយនូវព្រះនាមព្រះយេហូវ៉ា (ពច ៨:១៩ ១សយ ១៤:៣៩,៤៥ ១៩:៦) ។
**៤២:២១** *សេចក្តីទុក្ខព្រួយ . . . បានជាសេចក្តីទុក្ខព្រួយនេះបានធ្លាក់មកលើយើងរាល់គ្នា* បងៗរបស់លោកយ៉ូសែបទទួលស្គាល់ថា ពេលនេះគេបានច្រូតនូវអ្វីដែលគេបានព្រោះ (កទ ៦:៧) ។
**៤២:២២** មើលក្នុង ៣៧:២១-២២ និងការពន្យល់ ៣៧:២១ ។
**៤២:២៤** *ទើបយកស៊ីម្មាន* ស៊ីម្មាន គឺជាកូនទី២របស់លោកយ៉ាកុប (សូមមើល ២៩:៣២-៣៣) ត្រូវមកជាប់គុកជំនួសរូបេនដែលជាកូនច្បងវិញ ប្រហែលគាត់ជាអ្នកដែលបានជួយលោកយ៉ូសែបមុនដំបូងនោះ (សូមមើល ៣៧:២១-២២) ។

លោកបាននិយាយមកយើងដោយតឹងរ៉ឹងណាស់ ហើយបានទុក
យើងជាពួកលបសង្កេតស្រុក[ស] ៣១យើងខ្ញុំបានជំរាបលោកថា
យើងខ្ញុំជាមនុស្សទៀងត្រង់ មិនមែនជាពួកលបសង្កេតស្រុក
ទេ[ហ] ៣២ហើយថា យើងខ្ញុំមានបងប្អូន១២នាក់ជាកូននៃឪពុក
តែ១ កូន១មិននៅទៀតទេ ហើយកូនពៅវានៅជាមួយនឹង
ឪពុករបស់ខ្ញុំនៅស្រុកកាណានសព្វថ្ងៃនេះ[ឡ] ៣៣តែអ្នកដែល
ជាចៅហ្វាយនៃស្រុកនោះ លោកនិយាយមកយើងខ្ញុំថា គឺ
យ៉ាងនេះដែលអញនឹងដឹងថា ឯងរាល់គ្នាជាមនុស្សទៀង
ត្រង់មែន ត្រូវឱ្យទុកបងប្អូនឯងម្នាក់នៅនឹងអញសិន រួចនាំ
យកស្រូវសំរាប់ឱ្យពួកគ្រួឯងរាល់គ្នាដែលអត់នោះ ចេញទៅ
ចុះ[អ] ៣៤ហើយនាំប្អូនឯងមកឯអញ នោះអញនឹងដឹងថា ឯង
រាល់គ្នាមិនមែនជាពួកលបសង្កេតស្រុកឡើយ គឺជាមនុស្ស
ទៀងត្រង់ពិត[ក] រួចសឹមអញនឹងលែងឱ្យបងប្អូនឯងម្នាក់នេះ
ដល់ឯងវិញ[ខ] ព្រមទាំងបើកឱ្យឯងរាល់គ្នាចេញចូលបានក្នុង
ស្រុកនេះផង[គ] ។
៣៥កាលគេបានចាក់ស្រូវចេញពីបាវទៅ នោះក៏ឃើញ
កញ្ចប់ប្រាក់របស់គេរៀងខ្លួននៅក្នុងបាវ រួចគេនឹងឪពុកគេ
មានសេចក្ដីភ័យញ័រ[ឃ] ដោយឃើញកញ្ចប់ប្រាក់ទាំងនោះ[ង]
៣៦យ៉ាកុបជាឪពុកនិយាយថា ឯងរាល់គ្នាបានបំបាត់កូនអញ
ទៅគឺយ៉ូសែបមិននៅទៀត[ច] ហើយស៊ីម្មានក៏មិននៅដែរ
ឥឡូវឯងចង់យកបេនយ៉ាមីនទៅទៀត[ឆ]ឬសេចក្ដីទាំងនេះជា
ទំនាស់នឹងអញហើយ[ជ] ៣៧រូបេនឆ្លើយទៅឪពុកថា បើខ្ញុំមិន
នាំវាមកវិញ នោះសូមសំឡាប់កូនប្រុសខ្ញុំទាំង២ចុះ សូមឱ្យ
វាមកខ្ញុំៗ[ឈ] នឹងនាំវាមកជូនលោកឪពុកវិញជាមិនខាន[ញ]
៣៨តែយ៉ាកុបប្រកែកថា កូនអញមិនត្រូវចុះទៅជាមួយនឹង
ឯងរាល់គ្នាទេ ដ្បិតបងវាស្លាប់ទៅហើយ[ដ] នៅសល់តែវា១
ប៉ុណ្ណោះ បើកាលណាវាកើតមានគ្រោះថ្នាក់អ្វី[ឋ]តាមផ្លូវ
ដែលឯងទៅ នោះឯងរាល់គ្នានឹងនាំឱ្យសក់ស្កូវរបស់អញ
ចុះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់[ឌ] ដោយទុក្ខព្រួយ
ហើយ[ឍ] ។

**ការធ្វើដំណើរលើកទីពីរទៅប្រទេសអេស៊ីព្ទ**

**៤៣** ១ឯអំណត់អត់នៅក្នុងស្រុកនោះក៏ខ្លាំងណាស់[ក] ២កាល
គេបានបរិភោគស្រូវដែលនាំយកពីស្រុកអេស៊ីព្ទមកអស់
ហើយ[ខ] នោះឪពុកប្រាប់ថា ចូរទៅទិញស្បៀងអាហារមក
ទៀត[គ] ៣តែយូដា[ឃ]ឆ្លើយទៅឪពុកថា អ្នកនោះបានប្រាប់
យើងខ្ញុំយ៉ាងច្បាស់ថា ឯងរាល់គ្នានឹងខានឃើញមុខអញ
ទៀតលើកតែប្អូនឯងមកជាមួយ[ង] ៤បើលោកឪពុកឱ្យប្អូនទៅ
ជាមួយ នោះយើងខ្ញុំនឹងទៅទិញស្បៀងអាហារយកមកជូន[ច]
៥តែបើលោកឪពុកមិនព្រមឱ្យវាទៅទេ នោះយើងខ្ញុំក៏មិន
ចុះទៅដែរ ពីព្រោះអ្នកនោះបានប្រាប់យើងខ្ញុំថា ឯងរាល់
គ្នាលែងបានឃើញមុខអញទៀតហើយ លើកតែប្អូនឯងមក
ជាមួយ[ឆ] ៦នោះអ៊ីស្រាអែល[ជ]គាត់និយាយថា ហេតុអ្វីបានជា
ឯងរាល់គ្នាប្រព្រឹត្តអាក្រក់[ឈ] នឹងអញដល់ម្ល៉េះ ដោយប្រាប់
អ្នកនោះថា មានប្អូន១ទៀត ៧គេឆ្លើយថាអ្នកនោះបានសាក
សួរយើងខ្ញុំយ៉ាងល្អិតណាស់ ពីដំណើរយើងខ្ញុំ និងញាតិ
សន្តាននៃយើងខ្ញុំថា តើឪពុកឯងរាល់គ្នានៅរស់ទេឬ[ញ] តើ
មានប្អូន១ទៀតឬទេ[ដ] យើងខ្ញុំក៏បានជំរាបលោកតាមពាក្យ
ទាំងនោះទៅ ធ្វើដូចម្ដេចឱ្យយើងខ្ញុំបានដឹងថា លោកនឹង
ប្រាប់ឱ្យនាំប្អូនយើងចុះទៅដូច្នេះ[ឋ] ៨នោះយូដា[ឌ]ក៏អង្វរ
អ៊ីស្រាអែល[ឍ]ជាឪពុកថា សូមឱ្យកូនកំឡោះទៅជាមួយនឹងខ្ញុំ
ចុះ នោះយើងខ្ញុំនឹងរៀបចំទៅ ដើម្បីឱ្យយើងខ្ញុំព្រមទាំង
លោកឪពុក ហើយនិងកូនចៅយើងខ្ញុំទាំងអស់គ្នាបាននៅ
រស់កុំឱ្យស្លាប់[ណ] ៩ខ្ញុំនឹងធានាពីដំណើរវា លោកឪពុកនឹង
ទារវាពីដៃខ្ញុំវិញ[ត] បើខ្ញុំមិននាំវាមកជូនដល់លោកឪពុក ឱ្យ
បាននៅចំពោះមុខលោកឪពុកវិញទេ[ថ] នោះសូមឱ្យខ្ញុំជាប់
មានទោសជាដរាបចុះ[ទ] ១០ដ្បិតបើយើងខ្ញុំមិនបានបង្អង់
នៅ[ធ] នោះប្រាកដជាយើងខ្ញុំ បានទៅមក២សាហើយ
១១អ៊ីស្រាអែល[ន]ជាឪពុក ក៏ប្រាប់ថា បើដូច្នេះចូរធ្វើយ៉ាង
នេះចុះ ចូរយកផលយ៉ាងល្អៗ[ប] ពីស្រុកនេះដាក់ចុះក្នុង
បាវរបស់ឯងរាល់គ្នា យកទៅជូនលោកផង[ផ] គឺជ័រពិដោរ[ព]
និងទឹកឃ្មុំបន្តិច ព្រមទាំងគ្រឿងម្ហូប[ភ] ជ័រល្វីងទេស[ម] គ្រាប់

**៤២:៣០** វ ខ.៧ ស ខ.៩ **៤២:៣១** ហ ខ.១១ **៤២:៣២** ឡ ខ.១៣ **៤២:៣៣** អ ខ.២ **៤២:៣៤** ក ខ.១១ ខ ខ.២៤ គ លប ៣៤:១០ **៤២:៣៥** ឃ លប ៤៣:១៨ ង ខ.២៥ **៤២:៣៦** ច ខ.១៣ ឆ ខ.២៤ ជ យប ៣:២៥ សភ ១០:២៤ រម ៨:៣១ **៤២:៣៧** ឈ លប ៣៩:៤ ញ លប ៤៣:៩ ៤៤:៣២ **៤២:៣៨** ដ លប ៣៧:៣៣ ឋ ខ.៤ ឌ លប ៣៧:៣៥ ឍ លប ៤៤:២៩,៣៤ ៤៨:៧ **៤៣:១** ក លប ១២:១០ **៤៣:២** ខ លប ៤២:២៥ គ លប ៤២:២ **៤៣:៣** ឃ ខ.៨ លប ៤៤:១៤,១៨ ៤៦:២៨ ង លប ៤២:១៥ **៤៣:៤** ច លប ២:២ **៤៣:៥** ឆ លប ៤៤:២៦ ២សយ ៣:១៣ **៤៣:៦** ជ ខ.៨,១១ លប ១៧:៥ ឈ លប ៣៤:៣០ **៤៣:៧** ញ ខ.២៧ លប ៤៥:៣ ដ លប ៤២:១៣ ៤៤:១៩ ឋ លប ៤២:១៥ **៤៣:៨** ឌ ខ.៣ លប ២៩:៣៥ ឍ ខ.៦ ណ លប ៤២:២ ទដ ៣៣:១៨ –១៩ **៤៣:៩** ត ១សយ ២៣:២០ ថ លប ៣៧ភម ១:១៨ –១៩ ទ លប ៤៤:១០, ១៧ **៤៣:១០** ធ លប ៤៥:៩៤ **៣:១១** ន ខ.៦ ប លប ២៤:១០ ផ លប ៣២:១៣ ព លប ៣៧:២៥ អគ ២៧:១៧ ភ នក ៣០:២៣ ១ពវ ១០:២ អគ ២៧:២២ ម លប ៣៧:២៥

**៤២:៣៧** *កូនប្រុសខ្ញុំទាំង២* បង្ហាញពីភាពអាណិតរបស់រូបេន គឺគាត់ជាអ្នកធានានូវសេចក្ដីសុខរបស់បេនយ៉ាមីន (មើល ៣៧:២១) ។

**៤២:៣៨** *ស្ថានឃុំព្រលឹងមនុស្សស្លាប់* សូមមើល ៣៧:៣៥ ។

**៤៣:៣** *តែយូដាឆ្លើយទៅឪពុកថា* ចាប់ពីគ្រានេះតទៅយូដាក្លាយជាអ្នកនាំពាក្យ សម្រាប់ប្អូនៗរបស់គេ (មើល ខ.៨–១០ ៤៤:១៤–៣៤ ៤៦:២៨) ។ ពូជអំបូររបស់គាត់ នឹងក្លាយជាអ្នកដែលមានឋានៈខ្ពស់ជាងគេក្នុងចំណោមបងប្អូនទាំង១២របស់គាត់ (មើល ៤៩:៨–១០) ហើយគាត់ក៏ជាព្ធយុកោព្រះយេស៊ូវដែរ (មថ ១:២–៣,១៦–១៧ លក ៣:២៣,៣៣) ។

**៤៣:៩** យូដាគាត់ចង់បានខ្លួនគាត់ផ្ទាល់ ជាអ្នកការពារសុវត្ថិភាពរបស់បេនយ៉ាមីន ហើយគាត់ពិតជាមានសណ្ដានចិត្តល្អលើសជាងរូបេនទៅទៀត (មើល ៤២:៣៧) ។

**៤៣:១១** *ចូរយកផលយ៉ាងល្អ . . . ទៅជូនលោកផង* គឺជាវប្បធម៌មួយដែលគេតែងតែធ្វើឡើងនៅពេលដែលគេចង់ចូលទៅជិតអ្នកណាម្នាក់ ដែលមានឋានៈ ឬមានមុខងារខ្ពស់ជាង ទាំងអ្នកនយោបាយ (១សយ ១៦:២០) ទាំង

ឈើ និងគ្រាប់ចំបក់ ១២ហើយយកប្រាក់១ជា២[យ] នៅដៃឯង
រាល់គ្នាទៅ ព្រមទាំងប្រាក់ដែលគេដាក់មកនៅមាត់បាវ
នោះផង[រ] យកទៅប្រគល់ឱ្យគេវិញ ក្រែងលោគេច្រឡំ
១៣រួចឱ្យនាំយកប្អូនឯងវិលទៅឯអ្នកនោះចុះ[ល] ១៤សូមព្រះដ៏
មានគ្រប់ទាំងព្រះចេស្តា[វ] បណ្តាលឱ្យអ្នកនោះ អាណិត
មេត្តាដល់ឯងរាល់គ្នា[ស] ដើម្បីឱ្យគេបើកឱ្យបងឯង ហើយ
និងបេនយ៉ាមីនមកវិញដែរ[ហ] ណ្ហើយចុះបើអញត្រូវអត់កូន
នោះក៏ត្រូវតែទ្រាំអត់ទៅចុះ[ឡ] ។
១៥គេក៏យកជំនូនទាំងនោះ និងប្រាក់១ជា២នៅដៃ[អ]
ហើយនាំបេនយ៉ាមីនទៅដែរ រួចគេក្រោកឡើង[ក]ចុះទៅឯ
ស្រុកអេស៊ីព្ទ ទៅឈរនៅចំពោះមុខយ៉ូសែប ១៦កាលយ៉ូ
សែបឃើញបេនយ៉ាមីន[ខ]មកជាមួយ នោះគាត់ប្រាប់ទៅអ្នក
ដំរួតដែលត្រួតមើលផ្ទះគាត់[គ]ថា ចូរនាំមនុស្សទាំងនេះ
ចូលទៅក្នុងផ្ទះ រួចឱ្យសំឡាប់សត្វរៀបម្ហូបម្ហាទៅ ពីព្រោះ
មនុស្សទាំងនេះនឹងបរិភោគ[ឃ]ជាមួយនឹងអញនៅពេលថ្ងៃ
ត្រង់ ១៧អ្នកនោះក៏នាំគេចូលទៅក្នុងផ្ទះតាមបង្គាប់យ៉ូសែប[ង]
១៨គេក៏មានសេចក្តីភិតភ័យ[ច] ពីព្រោះបាននាំចូលទៅក្នុងផ្ទះ
យ៉ូសែប[ឆ]ហើយគេពិគ្រោះគ្នាថា គឺដោយព្រោះប្រាក់ដែល
បានដាក់ចុះក្នុងបាវ[ជ] ឱ្យមកយើងវិញ ពីកាលជាន់មុននោះ
ហើយបានជាគេនាំយើងចូលមកនេះ ដើម្បីឱ្យលោកបានរក
រឿងនឹងយើង[ឈ] ហើយចាប់យើងយកធ្វើជាបាវ[ញ] ព្រមទាំង
សត្វលាផង[ដ] ១៩គេក៏ចូលទៅឯអ្នកដំរួតដែលត្រួតលើផ្ទះ
យ៉ូសែប[ឋ]និយាយនឹងគាត់នៅត្រង់មាត់ទ្វារថា ២០ឱលោក
ម្ចាស់ខ្ញុំអើយ កាលមុននោះយើងខ្ញុំបានចុះមកទិញស្បៀង
អាហារ[ឌ] ២១រួចកាលយើងខ្ញុំបានទៅដល់ទីសំណាក់ នោះ
យើងខ្ញុំបានស្រាយបាវទៅឃើញមានប្រាក់របស់យើងខ្ញុំ
គ្រប់ចំនួននៅក្នុងបាវរៀងខ្លួន ឥឡូវយើងខ្ញុំបានយកប្រាក់
នោះមកវិញ នៅដៃយើងខ្ញុំនេះ[ឍ] ២២ក៏បានយកប្រាក់ផ្សេង
សំរាប់នឹងទិញស្បៀងអាហារនៅដៃយើងខ្ញុំដែរ យើងខ្ញុំ
មិនដឹងជា អ្នកណាបានដាក់ប្រាក់នោះទៅក្នុងបាវទេ ២៣តែ
អ្នកនោះឆ្លើយថា ចូរឱ្យអ្នករាល់គ្នាបានប្រកបដោយ
សេចក្តីសុខចុះ កុំឱ្យខ្លាចឡើយ គឺព្រះនៃអ្នករាល់គ្នា ជាព្រះ
នៃឪពុកអ្នករាល់គ្នា[ណ] ទ្រង់បានប្រទានទ្រព្យមកក្នុងបាវ
របស់អ្នករាល់គ្នាទេ[ត] ឯប្រាក់របស់អ្នករាល់គ្នា គឺខ្ញុំបាន
ទទួលហើយរួចអ្នកនោះនាំស៊ីម្មានចេញមកឯគេ[ថ] ២៤ហើយ
ក៏នាំគេចូលទៅក្នុងផ្ទះយ៉ូសែប[ទ] ទាំងយកទឹកមកឱ្យលាង
ជើង[ធ] រួចគាត់យកចំបើងឱ្យលាគេស៊ីដែរ ២៥ឯគេក៏រៀបចំ
ជំនូន[ន] ចាំយ៉ូសែបមកដល់នៅពេលថ្ងៃត្រង់[ប] ដ្បិតគេបានឮ
ថា ខ្លួនគេត្រូវបរិភោគបាយនៅទីនោះ ។
២៦កាលយ៉ូសែបបានមកដល់ផ្ទះ[ផ] នោះគេយកជំនូនដែល
នៅដៃនាំចូលទៅក្នុងផ្ទះជូនគាត់[ព] ហើយក្រាបផ្កាប់មុខ ដល់
ដីចំពោះគាត់ ២៧គាត់ក៏សួរពីសេចក្តីសុខទុក្ខរបស់គេ ថា
តើលោកតាជាឪពុកអ្នករាល់គ្នាដែលបានប្រាប់ខ្ញុំនោះ
គាត់នៅរស់[ភ]ហើយសុខសប្បាយជាទេឬ[ម] ២៨គេឆ្លើយថា
ឪពុកយើងខ្ញុំជាអ្នកបំរើលោកគាត់[យ]រស់នៅហើយសុខ
សប្បាយជាទេ រួចក៏ឱន[ល]គោរពដល់គាត់[វ] ។
២៩លុះយ៉ូសែបក្រឡេកភ្នែកទៅឃើញបេនយ៉ាមីន ជា
ប្អូនពោះមួយនឹងខ្លួន[ស] នោះក៏សួរថា នេះគឺជាប្អូនពៅដែល
អ្នករាល់គ្នាបានប្រាប់ខ្ញុំឬអី[ហ] ហើយក៏និយាយទៅប្អូនថា កូន
អើយ សូមព្រះអង្គទ្រង់ប្រោសមេត្តាដល់ឯង[ឡ] ៣០យ៉ូសែប

**៤៣:១២** យ ខ.១៥ នក ២២:៤,៧ សភ ៦:៣១ រ លប ៤២:២៥ **៤៣:១៣** ល ខ.៣ **៤៣:១៤** វ លប ១៧:១ ស ចទ ១៣:១៧ ទដ ២៥:៦ ហ លប ៤២:២៤ ឡ ២សយ ១៨:៣៣ នអ ៤:១៦ **៤៣:១៥** អ ខ.១២ ក លប ៤៥:៩,១៣ ខ លប ៤៧:២,៧ មថ ២:១១ **៤៣:១៦** គ លប ៣៥:១៨ ឃ ខ.១៧, ២៤,២៦ លប ៤៤:១,៤,១២ ២សយ ១៩:១៧ អស ២២:១៥ ង ខ.៣១ លក ១៥:២៣ **៤៣:១៧** ច ខ.១៦ **៤៣:១៨** ឆ លប ៤២:៣៥ ជ លប ៤៤:១៤ ឈ លប ៤២:២៥ ញ លប ៣២:១១ ៥០:១៨ ដ លប ៣៤:២៨ **៤៣:១៩** ឋ ខ.១៦ **៤៣:២០** ឌ លប ៤២:៣ **៤៣:២១** ឍ ខ.១៥ លប ៤២:២៥ **៤៣:២៣** ណ លប ៣១:៥ នក ៣:៦ ត លប ៤២:២៨ ថ លប ៤២:២៤ **៤៣:២៤** ទ ខ.១៦ ធ លប ១៨:៤ **៤៣:២៥** ន លប ៣២:១៣ ប ខ.១៦ **៤៣:២៦** ផ ខ.១៦ ព លប ៣២:១៣ មថ ២:១១ ភ លប ៣៣:៣ **៤៣:២៧** ម ខ.៧ យ លប ៣៧:៣ **៤៣:២៨** រ លប ៤៤:២៤,២៧,៣០ ល លប ១៨:២ នក ១៨:៧ វ លប ៣៧:៧ **៤៣:២៩** ស លប ៣៥:១៨ ហ លប ៤២:១៣ ឡ ន ៦:២៥ ទដ ៦៧:១ ១១៩:៥៨ អស ៣០:១៨–១៩ ៣៣:២

ក្នុងជួរកងទ័ព (មើល ១សយ ១៧:១៨) ព្រមទាំងនៅក្នុងសាសនាផងដែរ (មើល ២ពវ ៥:១៥) ។ *ជ័រពិដោរ . . . ជ័រល្វីងទេស* មើល ៣៧:២៥ ។ *ទឹកឃ្មុំ* ទឹកឃ្មុំទាំងនោះ គឺសត្វឃ្មុំជាអ្នកបង្កើតឡើង គេក៏អាចផលិតទឹកឃ្មុំនេះបានដែរ គឺដោយសារគេយកទំពាំងបាយជូរទៅរំងាស់វា ហើយយកទឹកដែលខាប់ល្អ មកលាយជាមួយស្ករ ។ *គ្រាប់ឈើ* នៅក្នុងព្រះគម្ពីរការថ្វាយគ្រាប់ឈើ គឺមានតែកន្លែងនេះទេ ផ្លែរបស់វាមានទំហំតូចៗ ដែលមានដើមកំណើតនៅប្រទេសអាស៊ីមីនីរ ហើយនឹងទឹកដីកាណាន តែនៅក្នុងស្រុកអេស៊ីព្ទវិញ គ្មានដើមឈើនេះឡើយ ។

**៤៣:១៤** *ព្រះដ៏មានគ្រប់ទាំងព្រះចេស្តា* សូមមើល ១៧:១ ៣៥:១ ។ *បើអញត្រូវអត់កូន នោះក៏ត្រូវតែទ្រាំអត់ទៅចុះ* សូមធ្វើការប្រៀបធៀបជាមួយនិងការអត់ធ្មត់នៅក្នុង (នអ ៤:១៦) ។

**៤៣:២១** ពាក្យសំដីដែលបងៗរបស់គាត់ដែលនិយាយទៅចំពោះអ្នកតម្រួតរបស់យ៉ូសែប គឺជាការរៀបរាប់ដ៏លំអិតមួយ (៤២:២៧,៣៥) ។

**៤៣:២៣** *គឺព្រះនៃអ្នករាល់គ្នា . . . ទ្រង់បានប្រទានទ្រព្យមកក្នុងបាវរបស់អ្នករាល់គ្នាទេ* ពួកនាយដំរួតទាំងនោះបានដឹងពីលក្ខណៈរបស់ព្រះ លើសជាងអ្វីដែលពួកបងៗយ៉ូសែបបានដឹងទៅទៀត ។

**៤៣:២៤** សូមមើលការពន្យល់ ១៨:២ ។

**៤៣:២៦** *ក្រាបផ្កាប់មុខដល់ដីចំពោះគាត់* សប្តិរបស់លោកយ៉ូសែបពេលនេះបានក្លាយជាការពិតហើយ (៣៧:៧,៩ ៤២:៦ ៤៣:២៨) ។

**៤៣:២៩** *បេនយ៉ាមីនជាប្អូនពោះមួយនឹងខ្លួន* ទំនាក់ទំនងដ៏វិសេសរវាងយ៉ូសែបនិងបេនយ៉ាមីន គឺបង្ហាញច្បាស់នៅកន្លែងនេះ ។ *សូមឱ្យព្រះប្រោសមេត្តាដល់ឯង* នៅសម័យក្រោយៗមកទៀតនៅពេលដែលគេចង់ឱ្យពរដល់អ្នកណាម្នាក់គេប្រើឃ្លាកន្លែងនេះ (ជន ៦:២៥ ទដ ៦៧:១) ។

**៤៣:៣០** *យ៉ូសែប . . . រកកន្លែងយំ* ជានិច្ចកាលគាត់តែងតែយំដោយព្រោះ

ក៏ប្រញាប់ប្រញាល់ទៅរកកន្លែង[អ]យំ ពីព្រោះគាត់មាន
សេចក្តីក្តួលនឹងប្អូនខ្លាំងណាស់ នោះគាត់ចូលទៅយំ[ក]ក្នុង
បន្ទប់ ៣១រួចលុបមុខចេញមកវិញ ទាំងខំទប់[ខ]ហើយប្រាប់ថា
ចូរលើកម្ហូបមក[គ] ៣២គេក៏លើកមកជូនគាត់ដោយខ្លួន ឱ្យអ្នក
ទាំងនោះដោយខ្លួន ហើយឱ្យពួកសាសន៍អេស៊ីព្ទ ដែល
បរិភោគជាមួយនិងគាត់ ដោយខ្លួនដែរ ពីព្រោះពួក
សាសន៍អេស៊ីព្ទ គេគ្មានច្បាប់នឹងបរិភោគ ជាមួយនឹងពួក
សាសន៍ហេព្រើរទេ[ឃ] ព្រោះជាសេចក្តីស្អប់ខ្ពើមដល់ពួក
សាសន៍អេស៊ីព្ទ[ង] ៣៣ពួកបងប្អូនគាត់ក៏អង្គុយនៅមុខគាត់
ដោយលំដាប់ គឺបងច្បងតាមបងច្បង[ច] ហើយប្អូនពៅ
តាមប្អូនពៅ[ឆ] អ្នកទាំងនោះគេក៏ឆ្ងល់ទាំងអស់គ្នា ៣៤មាន
គេយកចំណែកភោជនាហារ ពីចំពោះគាត់ទៅឱ្យគេគ្រប់
គ្នា តែបេនយ៉ាមីនបាលើសជាងគេ១ជា៥ភាគ[ជ] នោះទាំង
អស់គ្នាក៏បានបរិភោគ[ឈ] ដោយអរសប្បាយជាមួយគ្នាទៅ ។

## ពែងប្រាក់នៅក្នុងបាវ

**៤៤** ១យ៉ូសែបបង្គាប់ទៅអ្នកដែលត្រួតលើផ្ទះខ្លួន[ក]ថា ចូរ
ច្រកស្បៀងអាហារឱ្យពេញបាវរបស់អ្នកទាំងនោះទៅ
តាមដែលគេដឹកនាំទៅបាន រួចយកប្រាក់គេដាក់ទៅក្នុង
មាត់បាវវិញ[ខ] ២ហើយយកពែង[គ]ប្រាក់របស់អញ[ឃ] ដាក់ចុះ
ក្នុងមាត់បាវនៃអ្នកដែលក្មេងជាងគេនោះ ព្រមទាំងប្រាក់ជា
ដំឡៃស្រូវផង អ្នកនោះក៏ធ្វើតាមបង្គាប់យ៉ូសែប ៣លុះភ្លឺ
ឡើងហើយ នោះក៏បញ្ជូនឱ្យអ្នកទាំងនោះទៅ និងលារបស់
គេដែរ[ង] ៤តែកាលគេបានចេញពីទីក្រុងទៅមិនឆ្ងាយប៉ុន្មាន
នោះយ៉ូសែបប្រាប់ទៅអ្នកដែលត្រួតលើផ្ទះខ្លួន[ច]ថា ចូររៀប
ចំដេញតាមមនុស្សទាំងនោះទៅ កាលណាឯងបានទាន់គេ
នោះត្រូវនិយាយយ៉ាងនេះថា ហេតុអ្វីបានជាឯងរាល់គ្នា
ធ្វើការអាក្រក់ស្នងនឹងការល្អដូច្នេះ[ឆ] ៥តើពែងនោះមិន
មែនជាពែង[ជ]ដែលចៅហ្វាយអញផឹក ហើយដែលលោក
ប្រើសំរាប់នឹងទាយទេឬអី[ឈ] ដែលឯងរាល់គ្នាបានធ្វើ ដូច្នេះ
នោះអាក្រក់ណាស់ ។

៦អ្នកនោះក៏ទៅបានទាន់គេ ហើយនិយាយនឹងគេតាម
ពាក្យទាំងនោះ ៧គេប្រកែកឡើងថា ហេតុអ្វីបានជាលោក
ម្ចាស់ខ្ញុំមានប្រសាសន៍ដូច្នេះ យើងខ្ញុំប្រហាទ[ញ]មិនដែលធ្វើ
ដូច្នោះឡើយ[ដ] ៨មើល ដូចជាប្រាក់[ឋ]ដែលយើងខ្ញុំបានឃើញ
នៅមាត់បាវរបស់យើងខ្ញុំ[ឌ] នោះយើងខ្ញុំបានយកពីស្រុក
កាណាន[ឍ]មកជូនលោកវិញហើយដែរ ដូច្នេះធ្វើដូចម្តេចឱ្យ
យើងខ្ញុំបានលួច[ណ]យកប្រាក់ឬមាសពីផ្ទះចៅហ្វាយរបស់
លោកមកបាន ៩បើឃើញមាននៅនឹងរូបអ្នកណាក្នុងពួក
យើងខ្ញុំប្រហាទនេះ[ត] សូមឱ្យអ្នកនោះទទួលស្លាប់ចុះ[ថ] ហើយ
យើងខ្ញុំរាល់គ្នានឹងធ្វើជាបាវរបស់លោកតទៅ[ទ] ១០តែអ្នក
នោះនិយាយថា ដូច្នេះសូមឱ្យបានដូចជាពាក្យអ្នកចុះ បើខ្ញុំ
រកឃើញនៅលើរូបអ្នកណា[ធ] ឱ្យអ្នកនោះត្រូវធ្វើជាបាវខ្ញុំ
ចុះ[ន] តែអ្នកឯទៀតនឹងបានរួចទោសវិញ[ប] ១១នោះគេក៏
ប្រញាប់ប្រញាល់ នឹងដាក់បាវស្រូវចុះមកដី ហើយស្រាយ
ចេញគ្រប់គ្នា ១២រួចអ្នកនោះ[ផ]ជ្រាវរាវរក[ព] ចាប់តាំងពីបង
ច្បងទៅដល់ប្អូនពៅ[ភ] ឃើញមានពែងនោះនៅក្នុងបាវ
របស់បេនយ៉ាមីន[ម] ១៣នោះក៏គេហែកសំលៀកបំពាក់[យ] រួច
ផ្ទុកលា[រ] ត្រឡប់នៅឯទីក្រុងវិញទាំងអស់គ្នា ។

១៤យូដា[ល] និងបងប្អូននាំគ្នាចូលទៅក្នុងផ្ទះយ៉ូសែប[វ] ដែល
នៅផ្ទះនៅឡើយ ក៏ទំលាក់ខ្លួនក្រាបចុះផ្កាប់មុខដល់ដីនៅ

**៤៣:៣០** អ យហ ១១:៣៣,៣៨ ក លប ២៩:១១ **៤៣:៣១** ខ លប ៤៥:១ អស ៣០:១៨ ៤២:១៤ ៦៣:១៥ ៦៤:១២ គ ខ.១៦ **៤៣:៣២** ឃ លប ១៤:១៣ កទ ២:១២ ង លប ៤៦:៣៤ នក ៨:២៦ **៤៣:៣៣** ច លប ៣៥:២៣ ឆ លប ៤២:១៣ ៤៤:១២ **៤៣:៣៤** ជ លប ៣៧:៣ ២៣វ ២៥:៣០ ឈ លក ១៥:២៣ **៤៤:១** ក លប ៤៣:១៦ ខ លប ៤៣:២៥ **៤៤:២** គ ខ.៥,១០, ១២,១៦ ឃ ខ.៨ **៤៤:៣** ង ពច ១៩:៩ **៤៤:៤** ច លប ៤៣:១៦ ឆ ទដ ៣៥:១២ ៣៨:២០ ១០៩:៥ សភ ១៧:១៣ យរ ១៨:២០ **៤៤:៥** ជ ខ.២ ឈ លប ៣០:២៧ ចទ ១៨:១០–១៤ **៤៤:៧** ញ លប ៤២:១១ ដ លប ១៨:២៥ **៤៤:៨** ឋ ខ.២ ឌ លប ៤២:២៥ ៤៣:១៥ ឍ លប ៤២:១៣ ណ លប ៣០ **៤៤:៩** ត លប ៤២:១១ ថ លប ៣១:៣២ ទ ខ.១០ លប ៤៣:១៨ **៤៤:១០** ធ ខ.២ ន ខ.៩, ១៧,៣៣ ប លប ៤៣:៩ **៤៤:១២** ផ លប ៤៣:១៦ ព លប ៣១:៣៤ ភ លប ៤៣:៣៣ ម ខ.២ **៤៤:១៣** យ លប ៣៧:២៩ រ លប ៤២:២៦ **៤៤:១៤** ល លប ៤៣:១៨ វ ខ.១៦ លប ២៩:៣៥ ៤៣:៣ ស លប ៣៣:៣

អារម្មណ៍របស់គាត់ (មើល ៤២:២៤ ៤៥:២,១៤–១៥ ៤៦:២៩) ។

**៤៣:៣២** *ពីព្រោះសសាន៍អេស៊ីព្ទ គ្មានច្បាប់នឹងបរិភោគជាមួយសាសន៍ហេព្រើរទេ* បំរាមនេះ ប្រហែលដោយសារផ្អែកលើច្បាប់សាសនារបស់គេ (នក ៨:២៦) មិនដូចដែលពួកអេស៊ីព្ទ គេបានបដិសេធមិនប្រកបជាមួយពួកអ្នកគង្វាលនោះឡើយ (៤៦:៣៤) ដែលពួកគេបានធ្វើដូច្នេះដោយសារច្បាប់របស់សង្គម ។

**៤៣:៣៤** *តែបេនយ៉ាមីនបានលើសជាងគេ ១ជា៥ភាគ* គឺដោយសារតែគាត់មានម្តាយមួយជាមួយនិងលោកយ៉ូសែប (ខ.២៩ ៤៥:២២) ។

**៤៤:៤** *ទីក្រុង* មិនស្គាល់ថាទីក្រុងនោះឈ្មោះអ្វីពិតប្រាកដឡើយ តែតាមមតិខ្លះគិតថា មានឈ្មោះណូប(មានចម្ងាយប្រមាណជា៣ម៉ែយ ភាគខាងត្បូងទីក្រុងមេរ៉ូ ហើយនឹងទីក្រុងហ្សូន( "ភាគខាងកើតតំបន់ឡៀលតា") ។

**៤៤:៥** *ទាយ* មើលការពន្យល់ ៣០:២៧ ។

**៤៤:៩** *បើឃើញមាននៅនឹងរូបអ្នកណាក្នុងពួកយើងខ្ញុំប្រហាទនេះ សូមឱ្យអ្នកនោះទទួលស្លាប់ចុះ* កាលពីប៉ុន្មានឆ្នាំមុន លោកយ៉ាកុបគាត់បានឆ្លើយចំពោះឡាបាន់នូវចម្លើយដូចគ្នានេះដែរ (មើល ៣១:៣២ និងការពន្យល់) ។

**៤៤:១០** ពួកនាយតម្រួតទាំងនោះបានយល់ព្រមចំពោះសេចក្តីស្នើសុំរបស់ពួកបងៗ លោកយ៉ូសែប ។

**៤៤:១២** *ចាប់តាំងពីបងច្បងទៅដល់ប្អូនពៅ* មានហេតុការណ៍ប្រហាក់ប្រហែលគ្នានេះមួយទៀតបានកើតឡើងនៅ ៣១:៣៣ ។

**៤៤:១៣** *គេក៏ហែកសំលៀកបំពាក់* បង្ហាញពីការឈឺចាប់របស់ពួកគេ (មើល ៣៧:២៩,៣៤) ។

**៤៤:១៤** *ក៏ទំលាក់ខ្លួនក្រាបផ្កាប់មុខដល់ដីចំពោះគាត់* ជាយូរមកហើយ ដែលសុបិន្តរបស់យ៉ូសែបនៅក្នុង ៣៧:៧,៩ បានក្លាយជាការពិតនៅថ្ងៃនេះ (មើល ៤២:៦ ៤៣:២៦,២៨) ។

ចំពោះគាត់[ស] ១៥នោះយ៉ូសែបនិយាយគំរាមទៅគេថា ឯង
រាល់គ្នាបានធ្វើអ្វីដូច្នេះ[ហ] តើមិនដឹងថា មនុស្សយ៉ាងអញ
ចេះចាប់យាមទេឬអី[ឡ] ១៦យូដា[អ]ឆ្លើយឡើងថា យើងខ្ញុំនឹង
ឆ្លើយតបនឹងលោកម្ចាស់នៃយើងខ្ញុំដូចម្ដេចបាន[ក] តើនឹង
និយាយអ្វីឬដោះសាខ្លួនយើងខ្ញុំជាយ៉ាងណាបាន[ខ] ព្រះទ្រង់
បានឃើញសេចក្ដីទុច្ចរិតរបស់យើងខ្ញុំប្របាទហើយ[គ] មើល
យើងខ្ញុំត្រូវធ្វើជាបាវបំរើរបស់លោកម្ចាស់[ឃ] គឺទាំងខ្លួន
យើងខ្ញុំ និងអ្នក១ដែលឃើញមានពែងនៅដៃនោះផង[ង]
១៧តែគាត់ឆ្លើយថា អញមិនធ្វើដូច្នោះទេ[ច]អ្នកណាដែល
បានឃើញមានពែងនៅដៃវា គឺអ្នកនោះឯងដែលត្រូវធ្វើ
ជាបាវរបស់អញ[ឆ] ឯឯងរាល់គ្នាវិញ ត្រូវឡើងត្រឡប់ទៅឯ
ឪពុកឯង ដោយសុខសាន្តចុះ[ជ]។
១៨យូដា[ឈ]គាត់ក៏ចូលទៅជិតអង្វរយ៉ូសែបថា ឱលោក
ម្ចាស់[ញ] ខ្ញុំប្របាទអើយ សូមបើកឱ្យខ្ញុំប្របាទជាបាវលោក
ជំរាបជូនលោកស្ដាប់១ម៉ាត់សិន សូមកុំខឹងក្ដៅ[ដ]នឹងខ្ញុំ
ប្របាទជាអ្នកបំរើលោកឡើយ ពីព្រោះលោកក៏ដូចជា
ផារ៉ោនហើយ ១៩លោកម្ចាស់បានសួរយើងខ្ញុំប្របាទ[ឋ]ថា
តើមានឪពុកមានបងប្អូនឬទេ[ឌ] ២០នោះយើងខ្ញុំបានឆ្លើយ
ជំរាបលោកម្ចាស់ថា យើងខ្ញុំមានឪពុកចាស់ហើយ[ឍ] និងប្អូន
តូច១ដែលកើតមក ក្នុងកាលដែលគាត់ចាស់ដែរ បងវា
បានស្លាប់ទៅ[ណ] ហើយក្នុងកូនពោះមួយនឹងវា នោះនៅ
សល់តែវាម្នាក់ឯងទេ ហើយឪពុកស្រឡាញ់វាណាស់[ត] ២១តែ
លោកមានប្រសាសន៍មកយើងខ្ញុំប្របាទ[ថ]ថា ចូរនាំវាចុះ
មកឯលោកពុំខាន ឱ្យលោកបានឃើញផង[ទ] ២២យើងខ្ញុំក៏
បានជំរាបលោកម្ចាស់វិញ[ធ]ថា កូននោះនឹងឃ្លាតចេញពី
ឪពុកមកមិនបានទេ ដ្បិតបើវាឃ្លាតចេញពីគាត់ នោះគាត់
នឹងស្លាប់ហើយ[ន] ២៣តែលោកបានមានប្រសាសន៍មកយើង
ខ្ញុំប្របាទថា បើប្អូនពៅយើងខ្ញុំមិនចុះមកជាមួយទេ នោះ
យើងខ្ញុំមិនឃើញមុខលោកទៀត[ប] ២៤ដូច្នេះ កាលយើងខ្ញុំ
បានឡើងដល់ឪពុក[ផ]ដែលជាអ្នកបំរើលោក នោះយើងខ្ញុំក៏

**៤៤:១៥** ហ លប ១២:១៨ ឡ លប ៣០:២៧
**៤៤:១៦** អ ខ.១៤ ក ខ.២២,២៤លប ៣៧:៨ ខ ទដ ២៦:៦ ៧៣:១៣ គ ទដ ៤២:១១ ឃ លប ៤៣:១៨ ង ខ.២
**៤៤:១៧** ច លប ១៨:២៥ ឆ ខ.១០ ជ លប ៤៣:៩
**៤៤:១៨** ឈ លប ២៩:៣៥ ញ ខ.១៦ ដ លប ១៨:៣០
**៤៤:១៩** ឋ លប ៤២:១១ ឌ លប ៤៣:៧
**៤៤:២០** ឍ លប ៣៧:៣ ណ លប ៣៧:៣៣ ត លប ៤២:១៣
**៤៤:២១** ថ លប ៤២:១១ ទ លប ៤២:១៥
**៤៤:២២** ធ ខ.១៦ ន លប ៣៧:៣៥
**៤៤:២៣** ប លប ៤២:១៥ ៤៣:៥
**៤៤:២៤** ផ លប ៤៣:២៨ ព លប ៤២:២៩ ភ ខ.១៦
**៤៤:២៥** ម លប ៤២:២
**៤៤:២៦** យ លប ៤៣:៥
**៤៤:២៧** រ លប ៤៣:២៨ ល លប ៤៦:១៩

ជំរាបគាត់តាមពាក្យ[ព]របស់លោកម្ចាស់[ភ] ២៥រួចមកឪពុក
យើងខ្ញុំប្រាប់ថា ចូរទៅទិញស្បៀងអាហារសំរាប់យើង
ទៀត[ម] ២៦តែយើងខ្ញុំបានប្រកែកថា យើងខ្ញុំទៅពុំបានទេ បើ
ប្អូនពៅបានទៅជាមួយ នោះទើបយើងខ្ញុំនឹងទៅបាន ដ្បិត
យើងខ្ញុំនឹងឃើញមុខលោកនោះមិនបានទេ លើកតែប្អូន
ពៅបានទៅជាមួយផង[យ] ២៧ឪពុកយើងខ្ញុំ[រ]ដែលជាអ្នកបំរើ
លោក គាត់មានប្រសាសន៍មកយើងខ្ញុំថា ឯងរាល់គ្នាដឹងថា
ប្រពន្ធអញបានបង្កើតកូនប្រុស២ឱ្យអញ[ល] ២៨១បានឃ្លាត
ចាកពីអញទៅបាត់ហើយ អញក៏គិតថា ប្រាកដជាមានសត្វ
ហែកវាស៊ីមែន[វ] អញមិនដែលឃើញវាទៀតដរាបដល់
សព្វថ្ងៃនេះ[ស] ២៩ឥឡូវបើឯងរាល់គ្នាយកកូននេះពីអញទៅ
ទៀត ហើយចួនជាកើតមានគ្រោះថ្នាក់យ៉ាងណា នោះឯង
រាល់គ្នានឹងនាំឱ្យសក់ស្កូវរបស់អញចុះទៅដល់ស្ថានឃុំ
ព្រលឹងមនុស្សស្លាប់[ហ] ដោយសេចក្ដីទុក្ខព្រួយហើយ[ឡ]
៣០ដូច្នេះ បើកាលណាខ្ញុំប្របាទត្រឡប់ទៅឯឪពុករបស់ខ្ញុំប្រ
បាទ[អ] ជាអ្នកបំរើលោក ហើយក្មេងនេះដែលគាត់ស្រឡាញ់
ដូចជាដួងជីវិត មិនបានឃើញទៅជាមួយនឹងយើងខ្ញុំទេ[ក]
៣១នោះគាត់នឹងស្លាប់ជាពិត[ខ]ដោយមិនឃើញកូននេះ យ៉ាង
នោះយើងខ្ញុំប្របាទ[គ]ឈ្មោះថា នឹងនាំឱ្យសក់ស្កូវរបស់ឪពុក
យើងខ្ញុំជាអ្នកបំរើលោក ចុះទៅឯស្ថានឃុំព្រលឹងមនុស្ស
ស្លាប់[ឃ]ដោយសេចក្ដីទុក្ខព្រួយពិតមែន ៣២ពីព្រោះខ្ញុំប្របាទ
បាននិយាយធានាពីដំណើកូននេះនឹងឪពុកថា បើកាលណា
មិនបាននាំវាមកជូនលោកឪពុកវិញទេ នោះត្រូវឱ្យខ្ញុំ
ប្របាទមានទោសចំពោះលោកឪពុកជាដរាប[ង] ៣៣ដូច្នេះ
សូមឱ្យខ្ញុំប្របាទនៅបំរើលោកម្ចាស់[ច]ជំនួសកូនកំឡោះនេះ
ចុះ[ឆ] ដើម្បីឱ្យវាឡើងទៅវិញ ជាមួយនឹងពួកបងៗ ៣៤ដ្បិតបើ
ក្មេងនេះមិនបានទៅជាមួយហើយ នោះធ្វើដូចម្ដេចឡើយ

**៤៤:២៨** វ លប ៣៧:៣៣ ស លប ៤៥:២៦,២៨ ៤៦:៣០ ៤៨:១១ **៤៤:២៩** ហ លប ៣៧:៣៥ ឡ លប ៤២:៣៨ **៤៤:៣០** អ លប ៤៣:២៨ ក ១សយ ១៨:១ ២សយ ១:២៦ **៤៤:៣១** ខ ខ.២២ គ លប ៤២:១១ ឃ លប ៣៧:៣៥ **៤៤:៣២** ង លប ៤២:៣៧ **៤៤:៣៣** ច ខ.១០ លប ៤៣:១៨ ឆ យហ ១៥:១៣

**៤៤:១៦** *ព្រះទ្រង់បានទតឃើញសេចក្ដីទុច្ចរិតរបស់យើងខ្ញុំប្របាទ* ដូចគ្នានឹងការទទួលស្គាល់របស់ពួកអ្នកតម្រួតរបស់លោកយ៉ូសែបដែរ (៤៣:២៣) យូដានិយាយលើសពីអ្វីដែលគាត់បានដឹងទៅទៀត ។ ម្យ៉ាងទៀតប្រហែលជាគាត់និយាយដល់ព្រឹត្តិការណ៍បច្ចុប្បន្ននេះ និងអំពើបាបដែលគាត់បានប្រព្រឹត្តជាមួយលោកយ៉ូសែប (៤២:២១) ។

**៤៤:១៨** *យូដា . . . អង្វរ* សូមមើល ៤៣:៣ ។ *លោកម្ចាស់ខ្ញុំប្របាទអើយ . . . ខ្ញុំម្ចាស់ជាអ្នកបំរើលោក* សូមមើល ៤២:១០ ។ *ពីព្រោះលោកក៏ដូចជាផារ៉ោនហើយ* ពាក្យនេះហាក់បីដូចជាមានការបំភ្លើសហួសពីការពិតបន្តិច (៤១:៤០,៤៣) ។

**៤៤:២៩,៣១** *ស្ថានឃុំព្រលឹងមនុស្សស្លាប់* សូមមើល ៣៧:៣៥ ។

**៤៤:៣០** *ក្មេងនេះដែលគាត់ស្រឡាញ់ ដូចជាដួងជីវិត* នៅក្នុងភាសាហេព្រើរឃ្លានេះគេនិយាយម្ដងទៀត នៅពេលដែលយ៉ូណាថានបានចងចិត្តជាមួយដាវីឌ "នោះចិត្តយ៉ូណាថានក៏មូលជាប់នឹងចិត្តគាត់" (១សយ ១៨:១) ។

**៤៤:៣៣** *ដូច្នេះខ្ញុំប្របាទ . . . ជំនួសកូនកំឡោះនេះចុះ* បំណងចិត្តរបស់យូដាក្នុងការជំនួសបេនយ៉ាមីន ដូចគ្នានឹងបំណងរបស់គាត់ដែលជួយឱ្យគេលក់យ៉ូសែប ជាជាងសម្លាប់គាត់ (៣៧:២៦-២៧) ។

**៤៤:៣៤** *ខ្ញុំខ្លាចឃើញសេចក្ដីអាក្រក់* លោកយូដាគាត់បាននឹកឃើញពីព្រឹត្តិការណ៍អាក្រក់ដែលកើតឡើងនាពេលមុន (៣៧:៣៤-៣៥) ។

ឱ្យខ្ញុំប្របាទឡើងទៅឯឪពុករបស់ខ្ញុំប្របាទបាន ខ្លាចក្រែង
ខ្ញុំឃើញសេចក្ដីអាក្រក់[ជ]ដែលនឹងកើតដល់ឪពុកខ្ញុំប្របាទ[ឈ]។

### លោកយ៉ូសែបឱ្យគេស្គាល់ខ្លួន

**៤៥** ១យ៉ូសែបខំអត់ទប់ នៅមុខពួកអ្នកទាំងប៉ុន្មាន ដែល
នៅជិតគាត់ពុំបាន[ក] ក៏បន្លឺវាចាថា ចូរឱ្យមនុស្សទាំងអស់
ថយចេញពីអញទៅ[ខ] ដូច្នេះកំពុងដែលយ៉ូសែបថ្លែងឱ្យពួក
បងប្អូនស្គាល់ខ្លួន នោះគ្មានមនុស្សណា១ឈរនៅជិតខាង
ឡើយ ២គាត់ឡើងសំឡេងយំ[គ] ឯពួកសាសន៍អេស៊ីព្ទក៏ឮ
ព្រមទាំងពួក ដំណាក់ផារ៉ោនផង[ឃ] ៣គាត់ប្រាប់ទៅបង
ប្អូនថា ខ្ញុំនេះជាយ៉ូសែប តើឪពុកខ្ញុំនៅរស់ទេឬ[ង] ឯបងប្អូន
គាត់ឆ្លើយមិនបាន[ច] ពីព្រោះគេស្រឡាំងកាំងទាំងអស់គ្នា
នៅមុខគាត់[ឆ] ៤តែយ៉ូសែបនិយាយទៅបងប្អូនថា សូមមកជិត
ខ្ញុំគេក៏ចូលទៅជិត[ជ] រួចគាត់ប្រាប់ថា ខ្ញុំនេះជាយ៉ូសែប
ជាប្អូនអ្នករាល់គ្នាដែលអ្នករាល់គ្នាបានលក់មកនៅស្រុក
អេស៊ីព្ទនេះ[ឈ] ៥ឥឡូវនេះ កុំឱ្យអ្នករាល់គ្នាព្រួយ[ញ] ឬតូចចិត្ត
ដោយបានលក់ខ្ញុំមកទីនេះឡើយ[ដ] ពីព្រោះគឺព្រះទេតើដែល
ទ្រង់ចាត់ខ្ញុំមកជាមុន ដើម្បីនឹងរក្សាជីវិតអ្នករាល់គ្នាទុក[ឋ]
៦ដ្បិតមើលមាន អំណត់នៅលើផែនដី២ឆ្នាំនេះហើយ[ឌ]
ក៏ត្រូវមាន៥ឆ្នាំទៀត ដែលនឹងគ្មានអ្នកណាភ្ជួររាស់ឬច្រូត
កាត់អ្វីឡើយ ៧ព្រះទ្រង់បានចាត់ខ្ញុំឱ្យមកមុនអ្នករាល់គ្នា
ដើម្បីនឹងរក្សាអ្នករាល់គ្នាឱ្យមានសំណល់សល់នៅផែនដី[ឍ]
ហើយនិងជួយសង្គ្រោះជីវិត នៃអ្នករាល់គ្នាដោយសេចក្ដី
ប្រោសប្រោណ យ៉ាងធំ[ណ] ៨ដូច្នេះមិនមែនអ្នករាល់គ្នាឱ្យខ្ញុំមក
ទីនេះទេ គឺជាព្រះវិញទេតើ[ត] ទ្រង់បានតាំងខ្ញុំទុកជាឪពុក[ថ]
ដល់ផារ៉ោន ជាម្ចាស់លើដំណាក់ទ្រង់ទាំងអស់ ហើយជា
ចៅហ្វាយត្រួតត្រាលើស្រុកអេស៊ីព្ទទាំងមូលផង[ទ] ៩ចូរអ្នក
រាល់គ្នាប្រញាប់ឡើង[ធ]ទៅឯឪពុកខ្ញុំ និងជំរាបគាត់ថា
យ៉ូសែបជាកូនលោកឪពុកផ្ដាំមកដូច្នេះថា ព្រះទ្រង់បាន
តាំងខ្ញុំឱ្យធ្វើជាចៅហ្វាយលើស្រុកអេស៊ីព្ទទាំងមូល ដូច្នេះ
សូមអញ្ជើញចុះមកឯខ្ញុំកុំបង្អង់ឡើយ[ន] ១០លោកឪពុកនឹង
បាននៅក្នុងស្រុកកូសែន[ប] ជាស្រុកជិតខ្ញុំនោះ គឺទាំងលោក
ឪពុកនិងកូនចៅរបស់លោកឪពុកទាំងអស់ ហើយនឹងហ្វូង
ចៀមហ្វូងគោ ព្រមទាំងរបស់លោកឪពុកទាំងប៉ុន្មានផង[ផ]
១១នៅស្រុកនោះខ្ញុំនិងចិញ្ចឹមលោកឪពុក[ព] ក្រែងលោក
ឪពុកត្រូវអន្តរាយទៅ គឺទាំងលោកឪពុកនឹងពួកគ្រួលោក
ឪពុក ហើយនិងរបស់លោកឪពុកទាំងអស់ដែរ[ភ] ដ្បិតត្រូវ
មានអំណត់៥ឆ្នាំ[ម]ទៀត ១២មើលភ្នែកបងរាល់គ្នានិងភ្នែក
បេនយ៉ាមីន[យ]ជាប្អូនខ្ញុំ ក៏ឃើញជាក់ថា គឺជាមាត់របស់ខ្លួនខ្ញុំ
នេះហើយដែលនិយាយនិងអ្នករាល់គ្នា[រ] ១៣ត្រូវឱ្យជំរាប
ដល់ឪពុកខ្ញុំ ពីគ្រប់ទាំងសេចក្ដីរុងរឿងរបស់ខ្ញុំនៅស្រុក
អេស៊ីព្ទនេះ[ល] ហើយពីគ្រប់ការទាំងអស់ដែលអ្នករាល់គ្នា
បានឃើញផង ត្រូវឱ្យប្រញាប់ទៅនាំយកឪពុកខ្ញុំចុះមកឯ
ណេះកុំខាន[វ] ១៤នោះគាត់ឱបកបេនយ៉ាមីន ជាប្អូនហើយយំ
បេនយ៉ាមីន[ស]ក៏យំនៅកគាត់ដែរ[ហ] ១៥គាត់ថើប[ឡ]ដល់ពួក

**៤៤:៣៤** ជ លប ៤២:៣៨ ឈ នអ ៨:៦ **៤៥:១** ក លប ៤៣:៣១ ខ ២សយ ១៣:៩ **៤៥:២** គ លប ២៩:១១ ឃ ខ.១៦ កច ៧:១៣ **៤៥:៣** ង លប ៤៣:៧ ច ខ.១៥ ឆ លប ៤៤:២០ យប ២១:៦ ២៣:១៥ មថ ១៧:៦ មក ៦:៤៩–៥០ **៤៥:៤** ជ លប ២៧:២១–២២ ឈ លប ៣៧:២៨ **៤៥:៥** ញ លប ៤២:២១ ដ លប ៤២:២២ ឋ ខ.៧–៨ លប ៥០:២០ យប ១០:១២ ទដ ១០៥:១៧ **៤៥:៦** ឌ លប ៤១:៣០ **៤៥:៧** ឍ ២ពវ ១៩:៤,៣០,៣១ អរ ៩:៨,១៣ អស ១:៩ ១០:២០,២១ ១១:១១,១៦ ៤៦:៣ យរ ៦:៩ ៤២:២ ៥០:២០មីក ៤:៧ ៥:៧ សផ ២:៧ ណ ខ.៥ លប ៤៩:១៨ នក ១៥:២ ១សយ ១៤:៤៥ ២ពវ ១៣:៥ នអ ៤:១៤ អស ២៥:៩ មីក ៧:៧ **៤៥:៨** ត ខ.៥ ថ ពច ១៧:១០ ២ពវ ៦:២១ ១៣:១៤ ទ លប ៤១:៤១ **៤៥:៩** ធ លប ៤៣:១៥ ន លប ៤៣:១០ កច ៧:១៤ **៤៥:១០** ប លប ៤៦:២៨,៣៤ ៤៧:១, ១១,២៧ ៥០:៨ នក ៨:២២ ៩:២៦ ១០:២៤ ៤៧:១ ផ លប ៤៦:៦–៧ **៤៥:១១** ព លប ៤៧:១២ ៥០:២១ ភ ទដ ១០២:១៧ ម លប ៤១:៣០ **៤៥:១២** យ លប ៣៥:១៨ រ មក ៦:៥០**៤៥:១៣** ល លប ៤១:៤១ វ លប ៤៣:១៥ កច ៧:១៤ **៤៥:១៤** ស លប ៣៥:១៨ ហ លប ២៩:១៣ **៤៥:១៥** ឡ លប ២៩:១១ លក ១៥:២០

**៤៥:២** *យំ* សូមមើល ខ.១៤–១៥ និង ៤៣:៣០ ។

**៤៥:៣** *ឯបងប្អូនគាត់មិនឆ្លើយពីព្រោះគេមានសេចក្ដីស្រឡាំងកាំង* ប្រហែលជាពួកគេគិតថា គេកំពុងតែឃើញខ្មោច ឬពួកគេខ្លាចថា យ៉ូសែបនឹងធ្វើការសងសឹកជាមួយពួកគេ ។

**៤៥:៤** *ខ្ញុំនេះជាយ៉ូសែប* សូមមើល ខ.៣ កច ៧:១៣ ។ ពេលនេះលោកយ៉ូសែបគាត់បានបង្ហាញពីទំនាក់ទំនងរបស់គាត់ជាមួយបងប្អូន ។ *ដែលអ្នករាល់គ្នាបានលក់* សូមមើល ៣៧:២៨ ។

**៤៥:៥** *ពីព្រោះគឺព្រះទេតើ ដែលទ្រង់ចាត់ខ្ញុំមកជាមុន* សូមមើល ខ.៧–៩ កច ៧:៩ ហើយប្រៀបធៀប ៥០:២០ ។ ព្រះយេហូវ៉ាទ្រង់បានរៀបចំជីវិតលោកយ៉ូសែប តាមរយៈការច្រណែន នឹងទង្វើដ៏ព្រៃផ្សៃរបស់បងៗគាត់ (សូមមើល កច ២:២៣ ៤:២៨) ។

**៤៥:៦** ឥឡូវនេះលោកយ៉ូសែបមានអាយុ៣៩ឆ្នាំគត់ (មើល ៤១:៤៦,៥៣) ។

**៤៥:៧** *សំណល់* ទោះបីជាគ្មានអ្នកណាម្នាក់បានបាត់បង់ក៏ដោយ ហើយពួកគេបានរួចពីគ្រោះថ្នាក់ដ៏ធំថែមទៀត ដូច្នេះហើយទើបយ៉ូសែបគាត់បានហៅពួកគេថាជាសំណល់ ហើយដោយសារគាត់មានទំនុកចិត្តថា ពួកគេនឹងរស់នៅដើម្បីបង្កើតនគរមួយឡើង ។

**៤៥:៨** *ឪពុក* នេះគឺជាកិត្តិយសដ៏ធំធេងដែលគេបានឱ្យទៅដល់គាត់ដើម្បីត្រួតត្រាលើស្រុកអេស៊ីព្ទ (៤១:៤៣) ព្រមទាំងឱ្យទៅដល់មន្ត្រីផ្សេងៗទៀត ។ មុខដំណែងទាំង៣របស់លោកយ៉ូសែបនៅក្នុងខនេះគឺបញ្ជាក់ពីជនជាតិដើមរបស់អេស៊ីព្ទ ។

**៤៥:៩** *ដូច្នេះអញ្ជើញចុះមកឯខ្ញុំ កុំបង្អង់ឡើយ* លោកយ៉ូសែបគាត់មានចិត្តអន្ទះសារចង់ជួបលោកយ៉ាកុបតាមលទ្ធភាពដែលអាចធ្វើទៅបាន (សូមមើល ខ.១៣) ។

**៤៥:១០** *ស្រុកកូសែន* ស្ថិតនៅភាគខាងកើតនៃដែនដីទន្លេនីល វាជាដែនដីដែលមានដីជាតិល្អ (ខ.១៨) ហើយស្រុកនេះនៅមានកេរ្តិ៍ឈ្មោះរហូតដល់សព្វថ្ងៃនេះ ។

**៤៥:១២** *មាត់របស់ខ្លួនខ្ញុំនេះហើយដែលនិយាយនឹងអ្នករាល់គ្នា* ពេលនេះលោកយ៉ូសែបគាត់និយាយជាមួយបងប្អូនគាត់ផ្ទាល់ មិនមែនដោយសារតាមរយៈអ្នកបកប្រែដូចពីមុននោះឡើយ (សូមមើល ៤២:២៣) ។

**៤៥:១៤** *យំ* សូមមើល ៤៣:៣០ ហើយនិងការពន្យល់ ។

បងៗទាំងអស់[អ] ព្រមទាំងយំនឹងគេផង រួចមកបងប្អូនក៏
និយាយរោះរាយនឹងគាត់[ក] ។
១៦ដំណឹងនោះបានឮទៅដល់ក្នុងដំណាក់ផារ៉ោនថា បង
ប្អូនយ៉ូសែបបានមកដល់ហើយ[ខ] សេចក្ដីនោះក៏គាប់ព្រះ
ទ័យដល់ផារ៉ោន និងមហាតលិក[គ]ទ្រង់[ឃ] ១៧រួចផារ៉ោនទ្រង់
មានបន្ទូលទៅយ៉ូសែបឱ្យប្រាប់ដល់ពួកបងប្អូនថា ត្រូវធ្វើ
ដូច្នេះ គឺឱ្យផ្ទុកសត្វរបស់ឯងរាល់គ្នា[ង] ទៅឯស្រុកកាណាន
ទៅ[ច] ១៨រួចនាំយកឪពុកនិងពួកគ្រួសាររបស់ឯងរាល់គ្នា
មកឯណេះ អញនឹងឱ្យទីកន្លែងដ៏ល្អក្នុងស្រុកអេស៊ីព្ទ[ឆ]ដល់
ឯងរាល់គ្នា នោះឯងរាល់គ្នានឹងបានបរិភោគរបស់ល្អ
បំផុតនៅស្រុកនេះតទៅ[ជ] ១៩ឯងបានទទួលបង្គាប់ហើយ
ដូច្នេះចូរធ្វើយ៉ាងនេះចុះ គឺឱ្យយករទេះ[ឈ]ពីស្រុកអេស៊ីព្ទ
នេះទៅសំរាប់ប្រពន្ធឯងរាល់គ្នាព្រមទាំងកូនតូចៗផង
ហើយបញ្ជិះឪពុកឯងរាល់គ្នានាំចុះមកឯណេះ ២០កុំឱ្យស្ដាយ
របស់ទ្រព្យឯងរាល់គ្នាឡើយ[ញ] ពីព្រោះគ្រប់ទាំងរបស់ល្អ
នៅស្រុកអេស៊ីព្ទទាំងមូល[ដ] ជារបស់ផងឯងរាល់គ្នាហើយ។
២១ពួកកូនអ៊ីស្រាអែលក៏ធ្វើដូច្នោះ ហើយយ៉ូសែបគាត់ឱ្យ
រទេះទៅគេ[ឋ]តាមបង្គាប់ផារ៉ោន ក៏ឱ្យស្បៀងអាហារបរិ
ភោគតាមផ្លូវផង[ឌ] ២២គាត់ឱ្យសំលៀកបំពាក់ពីរបីបន្លាស់[ឍ]
ដល់គ្រប់គ្នា តែគាត់បានឱ្យប្រាក់៣០០ដួង និងសំលៀក
បំពាក់៥បន្លាស់ដល់បេនយ៉ាមីន[ណ] ២៣រួចក៏ផ្ញើទៅជូនឪពុក
យ៉ាងនេះ គឺលា១០[ត]ផ្ទុកសុទ្ធតែរបស់ល្អ[ថ]ពីស្រុកអេស៊ីព្ទ
ហើយលាញី១០ផ្ទុកសុទ្ធតែស្រូវ ព្រមទាំងនំបុ័ងនឹងស្បៀង
សំរាប់ឪពុកមកតាមផ្លូវ[ទ] ២៤គាត់ក៏បញ្ជូនឱ្យបងប្អូនទៅ
ដោយពាក្យបណ្ដាំថា កុំឱ្យឈ្លោះប្រកែកគ្នាតាមផ្លូវណ៎ះ
នោះគេនាំគ្នាចេញទៅ[ធ] ។
២៥គេចេញពីស្រុកអេស៊ីព្ទ[ន] ឡើងទៅដល់យ៉ាកុបជាឪពុក
នៅស្រុកកាណាន[ប] ២៦ក៏ជំរាបថា យ៉ូសែបនៅរស់ទេ គឺវា
ហើយដែលធ្វើជាចៅហ្វាយលើស្រុកអេស៊ីព្ទទាំងមូល[ផ]នោះ
គាត់មានចិត្តភាំងស្លុត ដោយមិនបានជឿទេ[ព] ២៧តែគេ
ជំរាបគាត់តាមគ្រប់ទាំងពាក្យរបស់យ៉ូសែប ដែលបានផ្ដាំ
មក ហើយកាលគាត់ឃើញរទេះទាំងនោះ ដែលយ៉ូសែបឱ្យ
មក[ភ]សំរាប់បញ្ជិះគាត់ទៅ នោះទើបយ៉ាកុបថា ឪពុកបាន
ភ្ញាក់ខ្លួនឡើង ២៨ហើយអ៊ីស្រាអែលនិយាយថា ប៉ុណ្ណេះជឿ
ហើយ[ម] យ៉ូសែបកូនអញនៅរស់មែន អញនឹងទៅឱ្យឃើញ
វាមុនដែលអញស្លាប់[យ] ។

## លោកយ៉ាកុបទៅប្រទេសអេស៊ីព្ទ

**៤៦** ១អ៊ីស្រាអែល[ក]ក៏នាំយករបស់គាត់ទាំងអស់ ធ្វើដំណើរ
ចេញទៅ លុះដល់បៀរ-សេបាហើយ[ខ] នោះគាត់ថ្វាយ
យញ្ញបូជា[គ]ដល់ព្រះនៃអ៊ីសាកជាឪពុកខ្លួន[ឃ] ២ព្រះទ្រង់មាន
បន្ទូលនឹងអ៊ីស្រាអែល[ង] ក្នុងការជាក់ស្ដែងនៅពេលយប់[ច] ថា
យ៉ាកុបៗអើយ គាត់ទូលឆ្លើយថា ព្រះករុណាវិសេសព្រះ
អម្ចាស់អើយ[ឆ] ៣រួចទ្រង់មានបន្ទូលថា អញជាព្រះ គឺជាព្រះ
នៃឪពុកឯង[ជ] កុំឱ្យខ្លាច[ឈ]នឹងចុះទៅឯស្រុកអេស៊ីព្ទឡើយ[ញ]
ដ្បិតនៅស្រុកនោះ អញនឹងបង្កើតនគរ១យ៉ាងធំ[ដ]ពីឯង[ឋ]

អ លប ២៩:១១,១៣ ៤៦:៤ ក ខ.៣ ខ ខ.២ កច ៧:១៣ គ លប ៥០:៧ ឃ លប ៤១:៣៧ **៤៥:១៧** ង លប ៤២:២៦ ច លប ៤២:៥ **៤៥:១៨** ឆ ខ.២០ លប ២០:១៥ ៤៦:៣៤ ៤៧:៦,១១, ២៧ យរ ៤០:៤ ជ អរ ៩:១២ ទជ ៣៧:១៩ អស ១:១៩ **៤៥:១៩** ឈ ខ.២១,២៧ លប ៤៦:៥ ជន ៧:៣-៨ **៤៥:២០** ញ លប ៤៦:៦,៣២ ដ ខ.១៨ **៤៥:២១** ឋ ខ.១៩ ឌ លប ៤២:២៥ **៤៥:២២** ឍ លប ២៤:៥៣ ណ លប ៣៧:៣ ៤១:១៤ ពច ១៤:១២,១៣ ២ពវ ៥:២២ **៤៥:២៣** ត លប ៤២:២៦ ថ លប ២៤:១០ ទ លប ៤២:២៥ **៤៥:២៤** ធ លប ៤២:២១-២២ **៤៥:២៥** ន លប ១៣:១ ប លប ៤២:២៩ **៤៥:២៦** ផ លប ៤១:៤១ ព លប ៤៤:២៨ ១ពវ ១០:៧ **៤៥:២៧** ភ ខ.១៩ **៤៥:២៨** ម លក ១៦:៣១ យ លប ៤៤:២៨ **៤៦:១** ក ខ.៥ ខ លប ២១:១៤ គ លប ៣១:៥៤ ឃ លប ៣១:៤២ **៤៦:២** ង លប ១៧:៥ ច លប ១៥:១ ឆ លប ២២:១ **៤៦:៣** ជ លប ២៨:១៣ ឈ លប ១៥:១ ញ លប ២៦:២ ដ លប ១២:២ ឋ នក ១:៧

**៤៥:១៥** *បងប្អូនក៏និយាយរោះរាយនឹងគាត់* នេះដោយសារតែបងប្អូនរបស់គាត់គិតថា ការចងមិត្តនោះប្រសើរជាជាងធ្វើជាសត្រូវ និងបង្កជម្លោះពីព្រោះនេះជាលើកទី១ហើយ ដែលគេបានជួបគ្នាបន្ទាប់ពីបែកគ្នាអស់រយៈពេល ២០ឆ្នាំ (សូមមើល ៣៧:២ និង ៤៥:៦) ។

**៤៥:១៨** *នោះឯងរាល់គ្នានឹងបានបរិភោគរបស់ល្អបំផុតនៅស្រុកនេះតទៅ* លោកយ៉ូសែបហាក់ដូចជាដកយកពាក្យសំដី ដែលអ៊ីសាកឱ្យពរដល់យ៉ាកុប (សូមមើល ២៧:២៨) ។

**៤៥:២២** *តែគាត់បានឱ្យប្រាក់៣០០ដួង និងសំលៀកបំពាក់៥បន្លាស់ដល់បេនយ៉ាមីន* សូមមើល ៤៣:៣៤ និង ២០:១៦ ។

**៤៥:២៤** *កុំឱ្យឈ្លោះប្រកែកគ្នា* លោកយ៉ូសែបគាត់មិនចង់ពន្យាពេល ការធ្វើដំណើរត្រឡប់ទៅវិញរបស់គេឡើយ (ខ.៩) ហើយគាត់ចង់ឱ្យពួកគេគេចចេញពីជម្លោះដែលបង្កឡើងដូចពេលមុនទៀត ។

**៤៦:១-៤៧:១២** នៅក្នុងជំពូកទាំងនេះ គឺនិយាយពីការធ្វើដំណើររបស់អ៊ីស្រាអែល (យ៉ាកុប) ចូលមកតាំងលំនៅ ក្នុងស្រុកអេស៊ីព្ទ (មើល ១៥:១៣) ។

**៤៦:១** *នាំយក* ប្រហែលជាគាត់រៀបចំទ្រព្យសម្បត្តិដែលគាត់មាន កាលពីនៅហេប្រុន (មើល ៣៥:២៧) ។ *លុះដល់បៀរ-សេបាហើយ នោះគាត់ថ្វាយយញ្ញបូជាដល់ព្រះនៃអ៊ីសាកជាឪពុកខ្លួន* លោកអ័ប្រាហាំនិងអ៊ីសាកពួកគេទាំងពីក៏បានថ្វាយបង្គំព្រះនៅកន្លែងនោះដែរ (សូមមើល ២១:៣៣ ២៦:២-២៥) ។

**៤៦:២** *ព្រះទ្រង់មានបន្ទូលនឹងអ៊ីស្រាអែល ក្នុងការជាក់ស្ដែងនៅពេលយប់* សូមមើល ២៦:២៤ ។ *យ៉ាកុបៗអើយ* សូមមើល ២២:១១ ។ *ព្រះករុណាវិសេស* មើល ២២:១ ។

**៤៦:៣-៤** ព្រះយេហូវ៉ាទ្រង់បានបញ្ជាក់អំពីសេចក្ដីសន្យារបស់ទ្រង់ម្ដងទៀតនៅក្នុងខណៈពេលដែលលោកយ៉ាកុប ហើយនឹងក្រុមគ្រួសាររបស់គាត់ធ្វើដំណើរចាកចេញពីទឹកដីកាណាន ។

**៤៦:៣** *អញជាព្រះ គឺជាព្រះនៃឪពុកឯង កុំឱ្យខ្លាចនឹងចុះទៅឯស្រុកអេស៊ីព្ទឡើយ* ព្រះបានរំឭកសេចក្ដីសន្យាដែលទ្រង់បានសន្យាជាមួយយ៉ាកុប ដែលការសន្យានេះមិនបានបាត់ពាក្យណាមួយនោះឡើយ (២៦:២៤) ។ *អញនឹងបង្កើតនគរមួយយ៉ាងធំពីឯង* ដូចគ្នានឹងសេចក្ដីសន្យាដែលព្រះបានសន្យាជាមួយលោកអ័ប្រាហាំដែរ (មើល ១២:២) *នៅស្រុកនោះ* មើល នក ១:៧ ។

៤អញនឹងចុះទៅឯស្រុកអេស៊ីព្ទជាមួយនឹងឯងដែរ ហើយ
និងនាំឯងឡើងមកវិញជាមិនខាន[ឱ] ឯយ៉ូសែបវានឹងបិទភ្នែក
ឯង[ឲ] ៥រួចយ៉ាកុបក្រោកឡើងចេញពីបៀរ-សេបាទៅ[ណ]
ហើយពួកកូនចៅអ៊ីស្រាអែល[ត] ក៏បញ្ជិះឪពុក និងប្រពន្ធកូន
គេលើរទេះ[ថ]ដែលផារ៉ោនបានផ្ញើមកសំរាប់ នាំយកទៅ
៦គេក៏យកហ្វូងសត្វនិងទ្រព្យសម្បត្តិទាំងប៉ុន្មាន[ទ] ដែលគេ
បាន[ធ]ពីកាលនៅស្រុកកាណាន នាំទៅស្រុកអេស៊ីព្ទ ដែរ
គឺយ៉ាកុបនឹងពូជគាត់ទាំងអស់គ្នា[ន] ៧គាត់បាននាំទាំងកូន
ប្រុស កូនស្រី និងចៅទាំងប៉ុន្មាន ហើយពូជពង្សទាំង
អស់ទៅឯស្រុកអេស៊ីព្ទ[ប]ជាមួយគ្នា[ផ] ។

៨នេះជាបញ្ជីឈ្មោះរបស់ពួកកូនចៅអ៊ីស្រាអែល[ព] ដែល
ចូលទៅក្នុងស្រុកអេស៊ីព្ទ គឺយ៉ាកុបនឹងកូនចៅគាត់ទាំង
ប៉ុន្មាន ឯរូបេនជាកូនច្បងបង្អស់[ភ] ៩ហើយកូនរបស់រូបេន[ម]
គឺហេណុក ប៉ាលូវ[យ] ហេស្រុន និងកើមី[រ] ១០ឯកូនរបស់
ស៊ីម្មាន[ល] គឺយេមូអែល[វ] យ៉ាមីន អូហាត់ យ៉ាគិន សូហារ[ស]
និងសូល ជាកូនរបស់ស្រីសាសន៍កាណានម្នាក់ ១១ឯកូន
របស់លេវី[ហ] គឺគើសុន[ឡ] កេហាត់[អ] និងម្រ៉ារី[ក] ១២ឯកូនរបស់
យូដា[ខ] គឺអេរ[គ] អូណាន់[ឃ] សេឡា ពេរេស[ង] និងសេរ៉ាស[ច]
តែអេរ និង អូណាន់បានស្លាប់នៅស្រុកកាណាន[ឆ]ទៅ ឯកូន
របស់ ពេរេស[ជ] គឺហេស្រុន និងហាមុល[ឈ] ១៣ឯកូនរបស់
អ៊ីសាខារ[ញ] គឺថូឡា ពូវ៉ា[ដ] យ៉ូប[ឋ] និងស៊ីមរ៉ុន ១៤ឯកូនរបស់
សាប់យូល៉ូន[ឌ] គឺសេរ៉េក អេឡូន និងយ៉ាលាល ១៥នោះសុទ្ធ
តែជាកូនចៅរបស់លេអាដែលនាងបានបង្កើតឱ្យយ៉ាកុប
នៅស្រុកប៉ាដាន់-អើរ៉ាម[ឍ] ព្រមទាំងឌីណាជាកូនស្រីផង[ណ]
ពួកកូនប្រុសកូនស្រីទាំងនោះមាន៣៣នាក់ ។

១៦ឯកូនរបស់កាឌ់[ត] គឺសេផុន[ថ] ហាក់គី ស៊ូនី អែសបូន
អេរី អើរ៉ូត នឹងអើរេលី ១៧ឯកូនរបស់អេសើរ[ទ] គឺយីមន៉ា
យីសវ៉ា យីសវី បេរា និងសេរ៉ាជាប្អូនស្រី ឯកូនរបស់បេរា
គឺហេបើរ និងម៉ាលគាល ១៨នោះសុទ្ធតែជាកូនចៅរបស់
ស៊ីលផា[ធ] ជាបាវស្រីដែលឡាបាន់បានឱ្យដល់នាងលេអា[ន]ជា
កូន ហើយនាងបានបង្កើតកូនទាំងនោះឱ្យយ៉ាកុប ទាំងអស់
មាន១៦នាក់ ។

១៩ឯកូនរបស់រ៉ាជែល[ប]ជាប្រពន្ធយ៉ាកុប នោះគឺយ៉ូសែប
និងបេនយ៉ាមីន[ផ] ២០នៅស្រុកអេស៊ីព្ទ យ៉ូសែបមានកូន២គឺ
ម៉ាន៉ាសេ[ព] និងអេប្រាអិម[ភ] ដែលនាងអាសនាត់ ជាកូនប៉ូទី-
ផេរ៉ាជាសង្ឃនៅក្រុងអូនបានបង្កើតឱ្យ[ម,យ] ២១កូនរបស់បេន
យ៉ាមីន[រ] គឺបេឡា បេគើរ អ័សបេល កេរ៉ា ណាម៉ាន អេហ៊ី
រ៉ុស មូភីម ហ៊ូភីម និងអេឌី[ល] ២២នោះសុទ្ធតែជាកូន
ចៅរបស់រ៉ាជែល[វ]ដែលនាងបង្កើតឱ្យយ៉ាកុបទាំងអស់មាន
១៤នាក់ ។

២៣ឯកូនរបស់ដាន់[ស] គឺហ៊ូស៊ីម[ហ] ២៤ឯកូនរបស់ណែប-
ថាលី[ឡ] គឺយ៉ាស៊ាល គូនី យេសើរ និងស៊ីលិម ២៥នោះសុទ្ធ
តែជាកូនចៅរបស់ប៊ីលហា[អ] ជាបាវស្រីដែលឡាបាន់បានឱ្យ
ទៅនាងរ៉ាជែល[ក]ជាកូន នាងបង្កើតកូនទាំងនោះឱ្យយ៉ាកុប
ទាំងអស់មាន៧នាក់ ២៦ពួកអ្នកដែលចូលទៅឯស្រុកអេស៊ីព្ទ
ជាមួយនឹងយ៉ាកុប ជាពួកអ្នកដែលកើតពីគាត់ទាំងប៉ុន្មាន
នោះរួមទាំងអស់មាន៦៦នាក់ ឥតរាប់ប្រពន្ធរបស់កូន

**៤៦:៤** ឱ លប ១៥:១៦ ២៨:១៣ ឲ ខ.២៩ លប ៤៥:១៤-១៥ ៥០:១ **៤៦:៥** ណ លប ២១:១៤ ត ខ.១ ថ លប ៤៥:១៩ **៤៦:៦** ទ លប ៤៥:២០ ធ លប ១២:៥ ន ជន ២០:១៥ ចទ ២៦:៥ យស ២៤:៤ ទដ ១០៥:២៣ អស ៥២:៤ កច ៧:១៥ **៤៦:៧** ប ខ.៦ លប ៤៥:១០ ផ លប ១៣:១០ **៤៦:៨** ព លប ៣៥:២៦ នក ១:១ ជន ២៦:៤ ភ លប ២៩:៣២ **៤៦:៩** ម នក ៦:១៤ ជន ១:២០ ២៦:៧ ១រប ៥:៣ យ ជន ២៦:៥ ១រប ៥:៣ រ ជន ២៦:៦ **៤៦:១០** ល លប ២៩:៣៣ ជន ២៦:១៤ វ នក ៦:១៥ ជន ២៦:១២ ស ជន ២៦:១៣ **៤៦:១១** ហ លប ២៩:៣៤ ជន ៣:១៧ ឡ នក ៦:១៦ ជន ៣:២១ ៤:៣៨ អ នក ៦:១៦ ជន ៣:២៧ ១រប ២៣:១២ ក នក ៦:១៨ ជន ៣:២០,៣៣ ៤:២៩ ២៦:៥៧ ១រប ៦:១៩ **៤៦:១២** ខ បល ២៩:៣៥ គ លប ៣៨:៣ ឃ លប ៣៨:៤ ង លប ៣៨:២៩ ច លប ៣៨:៣០ ឆ លប ៣៨:៧ ជន ២៦:១៩ ជ ១រប ២:៥ មថ ១:៣ ឈ ជន ២៦:២១ **៤៦:១៣** ញ លប ៣០:១៨ ដ ជន ២៦:២៣ ពច ១០:១ ១រប ៧:១ ឋ ជន ២៦:២៤ **៤៦:១៤** ឌ លប ៣០:២០ **៤៦:១៥** ឍ លប ២៥:២០ ២៩:៣១-៣៥ ណ លប ៣០:២១ **៤៦:១៦** ត លប ៣០:១១ ជន ១:២៥ ថ ជន ២៦:១៥ **៤៦:១៧** ទ លប ៣០:១៣ **៤៦:១៨** ធ លប ៣០:១០ ន លប ១៦:១ **៤៦:១៩** ប លប ២៩:៦ ផ លប ៤៤:២៧ **៤៦:២០** ព លប ៤១:៥១ ភ លប ៤១:៥២ ម ជន ២៦:២៨-៣៧ យលប ៤១:៤៥ **៤៦:២១** រ ជន ២៦:៣៨-៤១ ១រប ៧:៦-១២ ៨:១ ល ជន ២៦:៤០ ១រប ៨:៣ **៤៦:២២** វ លប ២៩:៦ **៤៦:២៣** ស លប ៣០:៦ ហ ជន ២៦:៤២ **៤៦:២៤** ឡ លប ៣០:៨ **៤៦:២៥** អ លប ៣០:៨ ក លប ២៥:៦១ **៤៦:២៦** ខ ខ.៥-៧ នក ១:៥ ចទ ១០:២២

**៤៦:៤** *អញនឹងចុះទៅឯស្រុកអេស៊ីព្ទជាមួយនឹងឯងដែរ* ព្រះយេហូវ៉ាទ្រង់នឹងធ្វើដំណើរជាមួយយ៉ាកុប ក្នុងពេលដែលគាត់ធ្វើដំណើរទៅស្រុកអេស៊ីព្ទ ហើយបានគង់នៅជាមួយគេ ដូចគ្នានឹងពេលដែលព្រះបានធ្វើជាមួយគេ ក្នុងកាលដែលពួកគេធ្វើដំណើរទៅហារ៉ាន់ ហើយនឹងនាំគេត្រឡប់វិញដែរ (មើល ២៨:១៥ ១៥:១៦ ៤៨:២១) ។ *វានឹងបិទភ្នែកឯង* ព្រះអង្គចង់មានបន្ទូលអំពីការស្លាប់របស់យ៉ាកុប (៤៩:៣៣-៥០:១) ។

**៤៦:៨** *នេះជាបញ្ជីឈ្មោះរបស់ពួកកូនចៅអ៊ីស្រាអែល ដែលចូលទៅក្នុងស្រុកអស៊ីព្ទ* ត្រូវបាននិយាយម្តងទៀតនៅក្នុង នក ១:១ គឺជាការណែនាំអំពីប្រវិត្តិដើមរបស់ពួកអ៊ីស្រាអែល ។

**៤៦:១៥** *ស្រុកប៉ាដាន់-អើរ៉ាម* សូមមើល ២៥:២០ ។ *មាន៣៣នាក់* នៅក្នុង ខ.៨-១៥ គឺមាន៣៤នាក់ ។ ហើយនៅកន្លែងនេះមានតែ៣៣ ប្រហែលជាអូហាត់ដែលនិយាយក្នុង ខ.១០ គាត់បានត្រឡប់ទៅវិញ ក្នុងខណៈពេលដែលមិនបាននិយាយពីគាត់ក្នុង ជន ២៦:១២-១៣ ១រប ៤:២៤ ។ តាមការរៀបរាប់ពីលក្ខណៈរបស់គាត់ "អូណាត់" គឺគាត់មានលក្ខណៈដូចគ្នា នឹងអ្នកជិតខាងរបស់គាត់ឈ្មោះថា "សូហារ" (មើល នក ៦:១៥) ហើយនៅពេលក្រោយមកទៀតគាត់ក្លាយជាមនុស្សក្នុងអំបូរអូហាត់ ។

**៤៦:២០** មើល ៤១:៤៥។

**៤៦:២៦** *ពួកអ្នកដែលចូលទៅឯស្រុកអេស៊ីព្ទជាមួយនឹងយ៉ាកុប . . . ទាំងអស់មាន៦៦នាក់* ចំនួនសរុបមានត្រឹមតែ៣៣នាក់ប៉ុណ្ណោះ (នៅក្នុង ខ.១៥) ១៦នាក់ (នៅក្នុង ខ.១៨) ១៤នាក់ទៀត (ខ.២២) គឺទាំងអស់មាន៧០នាក់ (ខ.២៧) ។ ៦៦នាក់នេះប្រហែលមកពី អើរ ហើយនិងអូណាស់ដែលអ្នកទាំង២បានស្លាប់ក្នុងទឹកដីកាណាន (ខ.១២) និងមកពី ម៉ាន៉ាសេ និងអេប្រាអិម

យ៉ាកុបទាំងប៉ុន្មានទេ[ខ] ២៧ហើយកូនរបស់យ៉ូសែប ដែល
គាត់បង្កើតនៅស្រុកអេស៊ីព្ទ[គ] នោះមាន២នាក់ ដូច្នេះពួក
គ្រួរបស់យ៉ាកុបទាំងអស់ដែលចុះទៅឯស្រុកអេស៊ីព្ទ នោះ
រួមគ្នាមាន៧០នាក់[ឃ] ។
២៨គាត់ចាត់យូដា[ង]ទៅឯយ៉ូសែបជាមុន ដើម្បីនឹងសួរផ្លូវ
ដែលទៅឯស្រុកកូសែន រួចគេទៅដល់ស្រុកកូសែន[ច]នោះ
២៩ឯយ៉ូសែបគាត់ទឹមរថរបស់គាត់[ឆ]ឡើងទៅទទួលអ៊ីស្រា
អែលជាឪពុកនៅត្រង់កូសែន[ជ] ក៏ចូលទៅឱបកឪពុកហើយ
យំ[ឈ]ជាយូរ[ញ] ៣០អ៊ីស្រាអែល[ដ]និយាយទៅយ៉ូសែបថា ឥឡូវ
នេះ បើអញស្លាប់ក៏ស្លាប់ចុះ ដ្បិតអញបានឃើញមុខឯង
ដែលឯងនៅរស់នៅឡើយ[ឋ] ៣១យ៉ូសែបក៏និយាយទៅបង
ប្អូន និងពួកគ្រួឪពុកទាំងអស់ថា ខ្ញុំនឹងឡើងទៅគាល់
ផារ៉ោនទូលថា ពួកបងប្អូនខ្ញុំ និងគ្រួឪពុកខ្ញុំដែលនៅស្រុក
កាណាន[ឌ]បានមកដល់ខ្ញុំ[ឍ]ហើយ ៣២អ្នកទាំងនោះជាអ្នកធ្លាប់
ឃ្វាលសត្វ[ណ] ពីព្រោះគេមានរបររកស៊ីដោយចិញ្ចឹមហ្វូង
សត្វ[ត] ហើយគេបាននាំទាំងហ្វូងចៀម ហ្វូងគោ និងរបស់គេ
ទាំងអស់មកផង[ថ] ៣៣ដូច្នេះកាលណាផារ៉ោនមានបន្ទូល
ហៅបងប្អូនទៅសួរពីរបររកស៊ី[ទ] ៣៤នោះត្រូវឆ្លើយថា
យើងខ្ញុំជាបាវបំរើ[ធ]ទ្រង់ បានធ្លាប់ឃ្វាលសត្វតាំងតែពីក្មេង
ដរាបមកដល់ឥឡូវនេះ ទាំងយើងខ្ញុំ និងឪពុកយើងខ្ញុំតរៀង
មកផង[ន] នោះដើម្បីឱ្យបងប្អូនបាននៅ[ប]ក្នុងស្រុកកូសែន
នោះ[ផ] ពីព្រោះគ្រប់អស់ទាំងអ្នកគង្វាលសត្វជាទីស្អប់ខ្ពើម
ដល់ពួកសាសន៍អេស៊ីព្ទ[ព] ។

**៤៧** ១យ៉ូសែបក៏ចូលទៅគាល់ផារ៉ោនទូលថា ឪពុកនិង
បងប្អូនទូលបង្គំបានចេញពីស្រុកកាណានមកហើយ[ក] ព្រម
ទាំងនាំយកហ្វូងចៀមហ្វូងគោ និងរបស់ទ្រព្យទាំងអស់មក
ផង មើល គេនៅឯស្រុកកូសែនឯណោះ[ខ] ២គាត់ក៏យកបង
ប្អូន៥នាក់[គ]ទៅថ្វាយផារ៉ោនឱ្យទ្រង់ស្គាល់ ៣នោះផារ៉ោន
ទ្រង់មានបន្ទូលសួរបងប្អូនគាត់ថា ឯងរាល់គ្នាមានរបររក
ស៊ីធ្វើការអ្វី[ឃ] គេក៏ទូលថា យើងខ្ញុំជាបាវបំរើ[ង]ទ្រង់មានរបរ
ជាអ្នកគង្វាលសត្វ[ច] ទាំងយើងខ្ញុំនិងឪពុកយើងខ្ញុំតៗមក ៤គេ
ទូលទ្រង់ថា យើងខ្ញុំសូមចូលមកជ្រកកោននៅក្នុងស្រុក នេះ
ផង[ឆ] ពីព្រោះនៅឯស្រុកកាណាននោះ[ជ] គ្មានស្មៅឱ្យហ្វូង
សត្វរបស់យើងខ្ញុំជាបាវទ្រង់ទេ ដ្បិតនៅស្រុកនោះកើតមាន
អំណត់ជាខ្លាំងណាស់[ឈ] ដូច្នេះសូមឱ្យយើងខ្ញុំជាបាវទ្រង់
បានជ្រកកោននៅស្រុកកូសែនផង[ញ] ៥នោះផារ៉ោនមាន
បន្ទូលទៅយ៉ូសែបថា ឪពុកនិងបងប្អូនអ្នកបានមកឯអ្នក
ហើយ ៦ដូច្នេះស្រុកអេស៊ីព្ទនៅមុខអ្នកស្រាប់ហើយ ចូរឱ្យ
ឪពុកនិងបងប្អូនអាស្រ័យនៅ[ដ]ត្រង់កន្លែងដ៏ល្អបំផុតចុះ[ឋ]ចូរ
ឱ្យគេនៅក្នុងស្រុកកូសែនទៅ បើអ្នកស្គាល់អ្នកណាក្នុងពួក
គេ ដែលប្រសប់វាងវៃ[ឌ] នោះចូរតាំងគេឡើងឱ្យធ្វើជាមេ
គង្វាលលើហ្វូងសត្វរបស់យើងផង[ឍ] ៧យ៉ូសែបក៏នាំយក
យ៉ាកុបជាឪពុកខ្លួន[ណ] ចូលទៅគាល់ផារ៉ោនដែរ ហើយ
យ៉ាកុបក៏សូមពរថ្វាយដល់ផារ៉ោន[ត] ៨រួចទ្រង់មានបន្ទូល
សួរគាត់ថា អាយុរបស់តាបានប៉ុន្មានហើយ ៩យ៉ាកុបទូល
ឆ្លើយថា ចំនួនឆ្នាំដែលទូលបង្គំសិចតនៅ នោះបានតែ
១៣០ឆ្នាំទេ[ថ] អស់ទាំងឆ្នាំអាយុនៃទូលបង្គំបានតិចណាស់
ហើយអាក្រក់ផង[ទ] មិនដល់នឹងចំនួនឆ្នាំអាយុ ដែលពួក
ឰយុកោរបស់ទូលបង្គំបានសិចតនៅនោះទេ[ធ] ១០យ៉ាកុបក៏
សូមពរថ្វាយដល់ផារ៉ោនទៀត[ន] រួចលាទ្រង់ចេញទៅ
១១យ៉ូសែបក៏ឱ្យឪពុកនឹងបងប្អូនអាស្រ័យនៅត្រង់កន្លែងដ៏ល្អ
បំផុតក្នុងស្រុក[ប] គឺនៅត្រង់រ៉ាមសេស[ផ] ហើយគាត់ឱ្យគេមាន

**៤៦:២៧** គ លប ៤១:៤៥ ឃ លប ៣៤:៣០ កច ៧:១៤ **៤៦:២៨** ង លប ៤៣:៣ ច លប ៤៥:១០ **៤៦:២៩** ឆ លប ៤១:៤៣ ជ ខ.១,៣០ លប ៣២:២៨ ៤៧:២៩,៣១ ឈ លប ២៩:១១ ញ ខ.៤ លក ១៥:២០ **៤៦:៣០** ដ ខ.២៩ ឋ លប ៤៤:២៨ **៤៦:៣១** ឌ លប ៤២:១៣ ឍ លប ៤៥:១០ **៤៦:៣២** ណ លប ៤៧:៣ ត លប ៣៧:២ ថ លប ៤៥:២០ **៤៦:៣៣** ទ លប ៤៧:៣ **៤៦:៣៤** ធ លប ៤២:១១ ន លប ៤៧:៣ ប លប ៣៤:១០ ផ លប ៤៥:១០ ព លប ៤៣:៣២ **៤៧:១** ក លប ៤២:១៣ ខ លប ៤៦:៣១ **៤៧:២** គ លប ៤៣:១៥ **៤៧:៣** ឃ លប ៤៦:៣៣ ង លប ៤២:១១ ច លប ៤៦:៣២ **៤៧:៤** ឆ នរ ១:១ ជ លប ១២:១០ ឈ ១ពវ ១៨:៥ យរ ១៤:៥–៦ យអ ១:១៨ ញ លប ៤៦:៣៤ **៤៧:៦** ដ លប ៣៤:១០ ឋ លប ១៣:៩ ៤៥:១៨ ឌ នក ១៨:២១,២៥ ចទ ១:១៣,១៥ ២របា ១៩:៥ ទដ ១៥:២ ឍ លប ៣៩:៤ **៤៧:៧** ណ លប ៤៣:១៥ ត ខ.១០ ២សយ ១៤:២២ ១៩:៣៩ ១ពវ ៨:៦៦ **៤៧:៩** ថ លប ២៥:៧ ទ លប ៣:១៧ ទដ ៣៩:៤ ៨៩:៤៧ ធ យប ៨:៩ ទដ ៣៩:១២ **៤៧:១០** ន ខ.៧ **៤៧:១១** ប លប ៤៥:១០,១៨ ផ នក ១:១១ ១២:៣៧

(ខ.២០) ដែលបានកើតនៅស្រុកអេស៊ីព្ទ(ខ.២៧) ។

**៤៦:២៧** *៧០នាក់* សូមមើល ចទ ១០:២០ ។ តាមវប្បធម៌របស់អ៊ីស្រាអែល ៧០នាក់ គឺជាចំនួនមួយដែលគ្រប់លក្ខណ៍នៅពេលដែលកូនចៅរបស់លោកយ៉ាកុបចូលមកក្នុងទឹកដីអេស៊ីព្ទបើសិនជាអើ និងអូណាស់ មិនបានស្លាប់ (៣៨:៧–១០) ។ ចំនួន៧៥ មាននិយាយក្នុង កច ៧:១៤ ។

**៤៦:២៨** *គាត់ចាត់យូដាទៅឯយ៉ូសែបជាមុន* សូមមើល ៤៣:៣ ។

**៤៦:២៩** *យំ* សូមមើល ៤៣:៣០ នឹងការពន្យល់ ។

**៤៦:៣៤** *អ្នកគង្វាលសត្វជាទីស្អប់ខ្ពើមដល់សាសន៍អេស៊ីព្ទ* មើល ៤៣:៣២ ។

**៤៧:៩** *សំចតនៅ* លោកយ៉ាកុបនិយាយអំពីអាយុជាធម្មតារបស់ពួកឰយុកោ ហើយអាយុពិតរបស់គាត់ ដោយគាត់សង្ឃឹមថា គាត់អាចរង់ចាំរហូតបានសម្រេចនៅក្នុងទឹកដីសន្យា (ចថ ២៦:៥) ។ *មិនដល់និងចំនួនឆ្នាំអាយុ ដែលពួកឰយុកោរបស់ទូលបង្គំបានសំចតនោះទេ* លោកអ័ប្រាហាំគាត់រស់នៅបានត្រឹមតែអាយុ១៧៥ឆ្នាំ (២៥:៧) តែអ៊ីសាកគាត់រស់នៅបាន១៨០ឆ្នាំ (៣៥:២៨) ។

**៤៧:១១** *ត្រង់កន្លែងដ៏ល្អបំផុតក្នុងស្រុក* សូមមើល ៤៥:១០ ។ *រ៉ាមសេស* ទីក្រុងរ៉ាមសេសគឺនិយាយនៅក្នុង នក ១:១១ ១២:៣៧ ជន ៣៣:៣,៥ ។ គេបានដាក់ឈ្មោះឱ្យទីក្រុងនេះ ទៅតាមឈ្មោះរបស់ផារ៉ោន រ៉ាមសេសទី២ ដែលប្រជាជនអេស៊ីព្ទ ពួកគេបានក្លាយជាអ្នកដឹកនាំប្រទេសនៅសម័យក្រោយមកទៀត ។ ពីមុនត្រូវបានគេស្គាល់ថាជាកូសែន (ខ.២៧) ដែលជាស្រុកមួយនៅក្នុងទីក្រុងរ៉ាមសេស ដែលគេធ្លាប់ហៅថា "វាលសូអាន" នៅក្នុង ទដ

កេរ្តិ៍អាករ នៅក្នុងស្រុកអេស៊ីព្ទ ដូចជាផារ៉ោនបានបង្គាប់មក ១២យ៉ូសែបតែងចំណាយស្បៀងអាហារចិញ្ចឹមដល់ឪពុកនិងបងប្អូន ព្រមទាំងពួកផ្ទះឪពុកទាំងអស់តាមគ្រួគេផង[ព] ។

## លោកយ៉ូសែប និងគ្រោះអំណត់

១៣នៅគ្រប់ក្នុងស្រុកនោះគ្មានអ្វីបរិភោគសោះ ដ្បិតអំណត់អត់ជាខ្លាំងណាស់ ដល់ម្ល៉េះបានជាស្រុកអេស៊ីព្ទនិងស្រុកកាណានបានហិនហោចទៅ ដោយព្រោះអំណត់នោះ[ភ] ១៤យ៉ូសែបប្រមូលប្រាក់ដែលមាននៅស្រុកអេស៊ីព្ទ ហើយនៅស្រុកកាណានទាំងអស់ជាដំឡៃនៃស្រូវដែលគេទិញនោះ[ម] ក៏បញ្ចូលទុកក្នុងឃ្លាំងរបស់ផារ៉ោន[យ] ១៥រួចកាលប្រាក់ស្រុកអេស៊ីព្ទ និងស្រុកកាណានបានអស់ហើយ[រ] នោះពួកសាសន៍អេស៊ីព្ទទាំងអស់ក៏មកឯយ៉ូសែប[ល]អង្វរថា សូមចែកស្បៀងអាហារដល់យើងខ្ញុំផង ដ្បិតត្រូវឱ្យយើងខ្ញុំស្លាប់នៅមុខលោក[វ]ដោយព្រោះតែខ្វះប្រាក់ឬអី ១៦យ៉ូសែបក៏ប្រាប់ថា បើគ្មានប្រាក់ ចូរឱ្យហ្វូងសត្វរបស់អ្នករាល់គ្នាមក[ស] នោះខ្ញុំនឹងឱ្យស្បៀងអាហារប្តូរនិងហ្វូងសត្វរបស់អ្នករាល់គ្នាវិញ[ហ] ១៧គេក៏នាំយកហ្វូងសត្វមកឯយ៉ូសែប ហើយគាត់ឱ្យស្បៀងអាហារដល់គេប្តូរនឹងសេះ[ឡ] ហ្វូងចៀម ហ្វូងគោ និងលា[អ]នៅឆ្នាំនោះគាត់ឱ្យស្បៀងអាហារចិញ្ចឹមគេដោយប្តូរនឹងហ្វូងសត្វ ១៨ដល់ផុតពីឆ្នាំនោះទៅ ចូលមកឆ្នាំថ្មីទៀត នោះគេមកឯយ៉ូសែបអង្វរថា យើងខ្ញុំមិនលាក់បាំងនឹងលោកម្ចាស់នៃយើងខ្ញុំទេ ដ្បិតប្រាក់របស់យើងខ្ញុំអស់រលីងហើយ[ក] ឯហ្វូងសត្វទាំងអស់សោតក៏បានទៅលោកម្ចាស់ដែរ[ខ] គ្មានសល់អ្វីនៅមុខលោកម្ចាស់នៃយើងខ្ញុំឡើយ នៅសល់តែខ្លួនយើងខ្ញុំ និងដីរបស់យើងខ្ញុំប៉ុណ្ណោះ ១៩ហេតុអ្វីបានជាត្រូវឱ្យយើងខ្ញុំស្លាប់នៅចំពោះលោក[គ] ព្រមទាំងដីយើងខ្ញុំផង ដូច្នេះសូមទិញយើងខ្ញុំ និងដីយើងខ្ញុំប្តូរនឹងអាហារចុះ[ឃ] នោះយើងខ្ញុំហើយដីយើងខ្ញុំនឹងនៅបំរើផារ៉ោន[ង] សូមចែកពូជមកយើងខ្ញុំ ឱ្យយើងខ្ញុំបានរស់នៅ កុំឱ្យស្លាប់[ច] ហើយកុំឱ្យដីនៅចោលទទេផង ។

២០យ៉ូសែបក៏ទិញដី នៅស្រុកអេស៊ីព្ទទាំងអស់ថ្វាយផារ៉ោន ដ្បិតពួកសាសន៍អេស៊ីព្ទគេលក់ស្រែចំការរៀងខ្លួនពីព្រោះគេអត់ជាខ្លាំង[ឆ] ស្រុកនោះក៏ទៅជារបស់ផងផារ៉ោនទាំងអស់ ២១ឯពួករាស្ត្រគាត់ឱ្យគេចូលទៅនៅក្នុងទីក្រុង[ជ] ពីព្រំស្រុកអេស៊ីព្ទម្ខាងទៅដល់ចុងម្ខាង ២២សល់នៅតែដីរបស់ពួកសង្ឃប៉ុណ្ណោះដែលគាត់មិនបានទិញ ដ្បិតពួកសង្ឃ[ឈ]មានចំណែកមកពីផារ៉ោន លោកឆាន់ចំណែក[ញ] ដែលផារ៉ោនប្រគេន ហេតុនោះមានជាលោកសង្ឃមិនលក់ដីរបស់ខ្លួនទេ ។

២៣យ៉ូសែបប្រកាសដល់ប្រជាជនទាំងឡាយថា នែឥឡូវនេះខ្ញុំបានទិញអ្នករាល់គ្នា[ដ] ព្រមទាំងដីរបស់អ្នករាល់គ្នាថ្វាយផារ៉ោនហើយ នេះជាពូជឱ្យដល់អ្នករាល់គ្នា ចូរយកទៅសាបព្រោះចុះ[ឋ] ២៤ដល់រដូវចំរូត នោះត្រូវឱ្យអ្នករាល់គ្នាយក១ភាគក្នុង៥[ឌ]មកថ្វាយដល់ផារ៉ោនវិញ ហើយ៤ភាគទៀតទុកសំរាប់អ្នករាល់គ្នា គឺទុកជាពូជពង្រោះ និងជាអាហារដល់អ្នករាល់គ្នាចុះ ព្រមទាំងពួកគ្រួអ្នករាល់គ្នាផង ហើយសំរាប់និងចិញ្ចឹមកូនចៅអ្នករាល់គ្នា ២៥គេក៏ឆ្លើយថា លោកបានជួយសង្គ្រោះជីវិតយើងខ្ញុំ ហើយសូមតែឱ្យយើងបានប្រកបដោយគុណរបស់លោកចុះ[ឍ] នោះយើងខ្ញុំនឹងធ្វើជាបាវបំរើដល់ផារ៉ោន[ណ] ២៦យ៉ូសែប ក៏តាំងសេចក្តីនោះពីដំណើរដីស្រុកអេស៊ីព្ទ ទុកជាច្បាប់ដរាបដល់សព្វថ្ងៃនេះថា ត្រូវថ្វាយ១ភាគក្នុង៥[ត]ទៅផារ៉ោន មានតែដីរបស់ពួកសង្ឃប៉ុណ្ណោះទេដែលមិនបានទៅជារបស់ ផងផារ៉ោន[ថ] ។

២៧ឯពួកអ៊ីស្រាអែល គេនៅត្រង់កូសែន[ទ] ក្នុងស្រុកអេស៊ីព្ទ ហើយបានកេរ្តិ៍អាករនៅស្រុកនោះ[ធ] ក៏បង្កើតកូនចំរើនកើនឡើងសន្ធឹក[ន] ២៨យ៉ាកុបគាត់រស់នៅក្នុងស្រុកអេស៊ីព្ទ[ប]១៧ឆ្នាំ នោះអាយុយ៉ាកុបបាន១៤៧ឆ្នាំហើយ[ផ] ២៩វេលាដែលអ៊ីស្រាអែល[ព]ត្រូវស្លាប់[ភ] នោះកាន់តែជិតដល់ គាត់ហៅយ៉ូសែបជាកូនមកផ្តាំថា បើឯងអាណិតដល់អញ[ម] ឥឡូវ នោះចូរដាក់ដៃនៅក្រោមភ្លៅអញ[យ]ស្បថថា ឯងនឹងប្រព្រឹត្តចំពោះអញដោយសប្បុរស[រ]ហើយពិតត្រង់[ល] គឺមិន

នទ៣:៣,៥
**៤៧:១២** ព លប ៤៥:១១
**៤៧:១៣** ភ លប ១២:១០ ៤១:៣០
**៤៧:១៤** ម លប ៤១:៣៦ យ លប ៤១:៣៤ នក ៧:២៣ ៨:២៤ យរ ៤៣:៩
**៤៧:១៥** រ ខ.១៦,១៨ ល លប ៤១:៥៧ វ ខ.១៩ នក ១៦:៣
**៤៧:១៦** ស ខ.១៨, ១៩ ហ ខ.១៥
**៤៧:១៧** ឡ នក ១៤:៩ អ លប ១២:១៦
**៤៧:១៨** ក ខ.១៥ ខ ខ.១៦
**៤៧:១៩** គ ខ.១៥ ឃ ខ.១៦ ងខ.២១, ២៥ ច លប ៤២:២
**៤៧:២០** ឆ លប ១២:១០
**៤៧:២១** ជ ខ.១៩
**៤៧:២២** ឈ ខ.២៦ ញ ចទ ១៤:២៨–២៩
**៤៧:២៣** ដ អស ៥៥:១០ ៦១:១១ ឋ នហ ៥:៣
**៤៧:២៤** ឌ លប ៤១:៣៤
**៤៧:២៥** ឍ លប ៣២:៥ ណ ខ.១៩
**៤៧:២៦** ត លប ៤១:៣៤ ថ ខ.២២
**៤៧:២៧** ទ លប ៤៥:១០,១៨ ធ លប ៣៣:១៩ ន លប ១:២២ ១២:២ ១៧:៦
**៤៧:២៨** ប ទដ ១០៥:២៣ ផ លប ២៥:៧ **៤៧:២៩** ព លប ៤៦:២៩ ភ លប ២៧:២

៣៨:១២,៤៣ (សូមមើលការពន្យល់ លក ៤៤:៤) ។

**៤៧:១៣** *អំណត់អត់ជាខ្លាំងណាស់* បន្ទាប់ពីប្រជាជនបានចំណាយប្រាក់របស់គេទាំងអស់ដើម្បីទិញស្បៀងមក (មើល ខ.១៤–១៥) ពួកគេក៏បានយកហ្វូងសត្វ ដែលគេមានមកដោះដូរយកស្បៀង (មើល ខ.១៦–១៧) ហើយបន្ទាប់មកទៀត គឺជាដីចំការ (មើល ខ.២០) ចុងក្រោយនោះ គឺជាខ្លួនរបស់ពួកគេផ្ទាល់ (មើល ខ.២១) ។

**៤៧:២១** មនុស្សទាំងនោះបានចូលមកក្នុងទីក្រុង ហើយរស់នៅក្នុងរយៈពេលដ៏ខ្លីមួយដរាបណា គេបានផ្តល់គ្រាប់ពូជឱ្យទៅសាបព្រោះ (ខ.២៣) ។

**៤៧:២៦** *ត្រូវថ្វាយ១ភាគក្នុង៥ទៅផារ៉ោន* នៅ ៤១:៣៤ បាននិយាយថា "ក្នុងរវាង៧ឆ្នាំដែលសម្បូរ" នោះត្រូវឱ្យមាននាយតម្រួតនៅក្នុងស្រុកសម្រាប់ហូត១ភាគក្នុង៥ពីអស់ទាំងផលដែលមាននៅក្នុងស្រុកប៉ុន្តែពេលនេះនៅក្នុងស្រុកទាំងអស់គ្មានកន្លែងណាដែលអាចបង្កើតផលសម្រាប់ផារ៉ោនទៀតទេ ។

**៤៧:២៧** *ឯពួកអ៊ីស្រាអែល . . . ក៏បានបង្កើតកូនចំរើនកើនឡើងសន្ធឹក* សូមមើលក្នុង ៤៥:១១–១២ ៤៦:៣ ។

កប់សពអញនៅក្នុង ស្រុកអេស៊ីព្ទនេះឡើយ ៣០ តែកាល
អញបានដេកលក់ទៅ ជាមួយនឹងពួកឰយុកោអញហើយ[រ]
នោះចូរឯងយកសព អញចេញពីស្រុកអេស៊ីព្ទ ទៅកប់នៅ
ក្នុងផ្នូររបស់ពួកឰយុកោទៅ[ស] យ៉ូសែបក៏ទទួលព្រមថា ខ្ញុំ
នឹងធ្វើសំរេចតាមពាក្យរបស់លោកឪពុក ៣១ នោះយ៉ាកុប
ប្រាប់ថា ចូរស្បថឱ្យអញចុះ[ហ] គាត់ក៏ស្បថជូន[ឡ] រួចអ៊ីស្រា
អែល[អ] ក៏ឱនក្រាបចុះនៅលើក្បាលគ្រែ[ក] ។

## លោកម៉ានាសេ និងលោកអេប្រាអឹម

**៤៨** ១ ក្រោយការទាំងនោះមកមានគេជំរាបយ៉ូសែបថា
ឪពុកលោកមានជំងឺឈឺហើយ នោះយ៉ូសែបក៏នាំយក
ម៉ាន៉ាសេ និងអេប្រាអឹម[ក] ជាកូនខ្លួនទាំង២ទៅជាមួយ ២ មាន
គេ ជំរាបយ៉ាកុបថា មើល យ៉ូសែបកូនលោកមកដល់ហើយ
នោះអ៊ីស្រាអែល[ខ] គាត់ខំប្រឹងក្រោកអង្គុយឡើងនៅលើគ្រែ
៣ ហើយនិយាយទៅយ៉ូសែបថា ព្រះដ៏មានគ្រប់ទាំងព្រះ
ចេស្តា[គ] ទ្រង់បានលេចមកឯអញ ត្រង់លូស[ឃ] ក្នុងស្រុក
កាណាន ហើយក៏ប្រទានពរឱ្យអញ[ង] ៤ ដោយបន្ទូលថា មើល
អញនឹងធ្វើឱ្យឯងបង្កើតបានកូនចំរើនជាច្រើនឡើង[ច] ឱ្យ
ឯងបាន ទៅជាពួកច្រើនរួមគ្នាតែ១ អញនឹងឱ្យស្រុកនេះ[ឆ]
ដល់ពូជឯងតទៅ ទុកជាកេរ្តិ៍អាករដល់គេនៅអស់កល្ប
ជានិច្ច[ជ] ៥ រីឯកូនប្រុសឯងទាំង២ ដែលឯងបានបង្កើតនៅ
ស្រុកអេស៊ីព្ទ[ឈ] គ្រាមុនដែលអញមកឯឯងនៅស្រុកនេះគឺ
អេប្រាអឹមនិងម៉ាន៉ាសេ នោះជារបស់ផងអញ[ញ] ដូចជា
រូបេន[ដ] និងស៊ីម្មាន[ឋ] ជារបស់ផងអញដែរ ៦ តែពូជដែលឯង
នឹងបង្កើតក្រោយទៀត នោះនឹងបានជារបស់ផងឯងវិញ
វានឹងត្រូវហៅតាមឈ្មោះបងប្អូនវា ក្នុងចំណែកមរដក
របស់គេ ៧ ឯអញកាលមកពីប៉ាដាន់[ឌ] នោះម្ដាយឯងបាន
ស្លាប់ចោលអញទៅ[ឍ] តាមផ្លូវនៅស្រុកកាណាន ក្នុងកាល
ដែលជិតដល់អេប្រាតាហើយ អញក៏បានកប់សពនៅទីនោះ
តាមផ្លូវអេប្រាតា គឺជាបេថ្លេហិម[ណ] ។
៨ អ៊ីស្រាអែល[ត] គាត់ឃើញកូនយ៉ូសែប[ថ] ក៏សួរថា តើអ្នក

ម លប ៣២:៥ យ លប ២៤:២ រ លប ១៩:១៩ ល លប ២៤:២៧ ពច ១:២៤ ២សយ ២:៦ **៤៧:៣០** វ លប ១៥:១៥ ស លប ២៣:២០ ២៥:៩ ២៩:១៦ ៥០:២៥ នក ១៣:១៩ យស ២៤:៣២ កច ៧:១៥–១៦ **៤៧:៣១** ហ លប ២១:២៣ យស ២:២០ ពច ១៥:១២ ១សយ ២៤:២១ ៣០:១៥ ឡ លប ២៤:៣ អ លប ៤៦:២៩ ក លប ៣២:១០ ហព ៣២:១០ ហព ១១:២១ ១ពវ ១:៤៧

**៤៨:១** ក លប ៤១:៥២ ហព ១១:២១ **៤៨:២** ខ ខ.៨,៩, ១១,១៤,២០ **៤៨:៣** គ លប ១៧:១ ឃ លប ២៨:១៩ ង លប ២៨:១៣ ៣២:២៩ **៤៨:៤** ច លប ១២:២ ១៧:៦ ឆ លប ១២:៧ ២៨:១៣ ជ លប ១៥:៧ **៤៨:៥** ឈ លប ៤១:៥០–៥២ ញ ១របា ៥:១ ដ លប ២៩:៣២ ឋ លប ២៩:៣៣ **៤៨:៧** ឌ លប ២៥:២០ ឍ លប ៤២:៣៨ ណ លប ៣៥:១៩ នរ ១:២ ១សយ ១៦:៤ **៤៨:៨** ត ខ.២ ថ ខ.១០

**៤៧:២៩** *នោះចូរដាក់ដៃនៅក្រោមភ្លៅអញ* សូមមើល ២៤:២ និងការពន្យល់ ។ ការធ្វើរបៀបនេះគឺបញ្ជាក់ពីចំណងមិត្តភាពនៅក្នុងក្រុមគ្រួសាររបស់ពួកគេ ។

**៤៧:៣០** *តែកាលណាអញបានដេកលក់ ទៅជាមួយនឹងពួកឰយុកោអញ* សូមមើល ២៥:៨ ។ *កប់នៅក្នុងផ្នូររបស់ពួកឰយុកោអញទៅ* គឺកប់នៅក្នុងរអាងនាចំការម៉ាក់ពីឡា (៥០:១២–១៣) ។

**៤៧:៣១** *អ៊ីស្រាអែលក៏ឱនក្រាបចុះនៅលើក្បាលគ្រែ* មើល ហព ១១:២១ លោកប៉ុលបានដកស្រង់ឃ្លានេះមកនិយាយ ដើម្បីបញ្ជាក់ប្រាប់ពួកហេព្រើរ សូមមើលការប្រៀបធៀប ៤៨:២ ។

**៤៨:១–២២** នៅក្នុងអត្ថបទនេះនឹងបង្ហាញដល់យើងនូវរបៀបដែលលោកយ៉ូសែបជាកូនដែលជាទីស្រឡាញ់របស់គាត់ជាមួយនាងរ៉ាជែល ហើយបានទទួលអំណាចមរតកជាកូនច្បងនៅក្នុងចំណោមបងប្អូនរបស់គាត់ ។

**៤៨:៣** *ព្រះដ៏មានគ្រប់ទាំងព្រះចេស្តា* សូមមើល ១៧:១ ៣៥:១ ។*លូស* ពីមុនវាមានឈ្មោះថាបេតអែល (២៨:១៩) ។

**៤៨:៥** *រីឯកូនប្រុសឯងទាំង២ . . . នោះជារបស់ផងអញ* លោកយ៉ាកុបបានចិញ្ចឹមកូនរបស់លោកយ៉ូសែបទាំង២នោះទុកដូចជាកូនរបស់គាត់ផ្ទាល់ ។ *អេប្រាអិមនឹងម៉ាន៉ាសេ* សូមមើល ខ.១ ។ ម៉ាន៉ាសេ គឺជាកូនដំបូងរបស់លោកយ៉ូសែប (៤១:៥១) ប៉ុន្តែយ៉ាកុបគាត់ផ្តោតទៅលើអេប្រាអិមជាសំខាន់ ដោយគាត់បានគិតថា គាត់នឹងឱ្យពរដំបូងទៅឱ្យអេប្រាអិម "ដូច្នេះគាត់បានលើកអេប្រាអិមឱ្យធំជាងម៉ាន៉ាសេ" (ខ.២០) ។ *នោះជារបស់ផងអញ . . . ដូចជារូបេននឹងស៊ីម្មានជារបស់ផងអញដែរ* កូនដំបូងរបស់លោកយ៉ូសែបទាំង២គឺអាចមានសិទ្ធិស្មើគ្នា នឹងកូនដំបូងទាំង២របស់លោកយ៉ាកុបហើយរស់នៅជាមួយគ្នាដោយអំណរ (៣៥:២៣) ហើយពួកគេក៏ជួបប្រទះនូវការផ្សងព្រេងដែរ ។ ដោយព្រោះពីដំបូងគេបានធ្វើបាប (៣៥:២២) នោះរូបេនជាកូនជាទីស្រឡាញ់របស់យ៉ាកុប អាចបាត់បង់សិទ្ធិអំណាចជាកូនច្បង នោះគាត់ក៏បានផ្តល់សិទ្ធិជាកូនច្បងឱ្យទៅយ៉ូសែប នឹងកូនប្រុសរបស់លោកយ៉ូសែប (៤៩:៣–៤ ១របា ៥:១–២) ។

**៤៨:៦** *តែពូជដែលឯងនឹងបង្កើតក្រោយទៀត នោះនឹងបានជារបស់ផងឯងវិញ* កូនដែលកើតក្រោយមក គេនិងជំនួសកន្លែងរបស់អេប្រាអិមហើយនឹងម៉ាន៉ាសេដែលលោកយ៉ាកុបបានយកទៅចិញ្ចឹម ។ *វានឹងត្រូវហៅតាមឈ្មោះបងប្អូនវា ក្នុងចំណែកមរតករបស់គេ* ពួកគេអាចនឹងបង្ខូចកិត្តិនាមរបស់អេប្រាអិមនឹងម៉ាន៉ាសេ ដើម្បីឱ្យបានចំណែកមរតករបស់គេ(សម្រាប់ការប្រហាក់ប្រហែលគ្នាក្នុងការបែងចែកមរតក (សូមមើល ៣៨:៨ ចថ ២៥:៥–៦) ។ អំបូររបស់លោកយ៉ូសែប និងត្រូវបែងចែកជា២ គឺ ម៉ាន៉ាសេ ហើយនឹងអេប្រាអិម ប៉ុន្តែលេវី (កូនទី៣របស់យ៉ូសែប) គាត់"មិនបានចំណែកណាមួយដល់ពួកលេវីនៅក្នុងស្រុកនោះទេ" (យស ១៤:៤) ។ ការបែងចែកទៅឱ្យក្រុមទាំងអស់គឺមានការស្មើៗគ្នា លើកលែងតែពួកលេវី ។

**៤៨:៧** *ប៉ាដាន់* នោះគឺជាប៉ាដាន់អើរ៉ាម (សូមមើល ២៥:២០) ។ *ម្តាយឯងបានស្លាប់ចោលអញទៅ* សូមមើល ៣៥:១៦–១៩ ។ ដោយសារបានទទួលការចិញ្ចឹមបីបាច់ពីសំណាក់លោកឪពុករបស់លោកយ៉ូសែបហើយបើសិនជានាងរ៉ាជែលជាម្តាយយ៉ូសែបមិនបានស្លាប់ទៅនោះនាងប្រហែលជាអាចនឹងបង្កើតកូនបានទៀត ដូច្នេះប្រហែលជាអេប្រាអិម ហើយនឹងម៉ាន៉ាសេ ពួកគេបានទទួលកន្លែងជំនួសកូនរបស់លោកយ៉ាកុបដែលនាងរ៉ាជែលបង្កើតឱ្យ (បើសិនជានាងរ៉ាជែលជាម្តាយយ៉ូសែបមិនបានស្លាប់) ។ *អេប្រាអិម* សូមមើល ៣៥:១៦ ។

**៤៨:៨** *អ៊ីស្រាអែល . . . តើអ្នកណានេះ* ប្រហែលដោយសារតែគាត់មិនធ្លាប់

ណានេះ ៩រួចយ៉ូសែបជំរាបឪពុកថា នេះគឺជាកូនដែលព្រះ
បានប្រទានឱ្យខ្ញុំនៅស្រុកនេះ[ទ] គាត់ប្រាប់ថា ចូរនាំវាមក
ណេះ អញនឹងឱ្យពរ[ធ]ដល់វា ១០រីឯអ៊ីស្រាអែល ភ្នែកគាត់
ងងឹតដោយសារចាស់ គាត់មើលមិនឃើញច្បាស់ទេ[ន]
យ៉ូសែបក៏នាំកូនចូលជិត នោះគាត់ក៏ឱបថើបវា[ប,ផ] ១១រួច
គាត់[ព]និយាយទៅយ៉ូសែបថា អញស្មានថាលែងឃើញមុខ
ឯងហើយ[ភ] តែមើលព្រះបានឱ្យអញឃើញទាំងពូជឯងផង[ម]
១២នោះយ៉ូសែបនាំកូនទាំង២ ថយចេញពីក្បាលជង្គង់[យ]
ឪពុកមក រួចក្រាបផ្កាប់មុខចុះដល់ដី[រ] ១៣យ៉ូសែបក៏នាំយក
កូនចូលទៅជិតឪពុកវិញ គឺអេប្រាអិមនៅដៃស្តាំទៅខាង
ឆ្វេងអ៊ីស្រាអែល[ល] ហើយម៉ាន៉ាសេនៅដៃឆ្វេងទៅខាងស្តាំ
អ៊ីស្រាអែល ១៤នោះអ៊ីស្រាអែល[វ]គាត់លូកដៃស្តាំទៅដាក់
លើក្បាលអេប្រាអិម[ស]ដែលជាប្អូន[ហ] ហើយដាក់ដៃឆ្វេងលើ
ម៉ាន៉ាសេវិញ ទោះបើម៉ាន៉ាសេជាកូនច្បងក៏ដោយ គាត់ធ្វើ
ដៃ ដូច្នេះដោយមានគំនិតយល់ជាក់[ឡ] ១៥រួចគាត់ឱ្យពរ[អ]ដល់
យ៉ូសែបថា សូមឱ្យព្រះដែលអ័ប្រាហាំជាជីតានិងអ៊ីសាកជា
ឪពុកអញបានដើរ[ក]នៅចំពោះទ្រង់ ជាព្រះដែលបាន
ចិញ្ចឹមអញ[ខ]គ្រប់១ជីវិតដរាបដល់សព្វថ្ងៃនេះ ១៦គឺជា
ទេវតា[គ] ដែលបានជួយឱ្យអញរួច ពីគ្រប់ទាំងសេចក្តី
អាក្រក់[ឃ] សូមទ្រង់ប្រទានពរ[ង]ដល់ក្មេងទាំង២នេះ[ច] ហើយ
ឱ្យវាបានហៅតាមឈ្មោះអញ តាមឈ្មោះអ័ប្រាហាំជាជីតា
និងអ៊ីសាក[ឆ]ជាឪពុកអញ សូមឱ្យវាបានចំរើនឡើងមានគ្នា
សន្ធឹកនៅលើផែនដី[ជ] ១៧កាលយ៉ូសែបឃើញថាឪពុកដាក់
ដៃស្តាំ[ឈ]លើក្បាលអេប្រាអិម[ញ] នោះគាត់មិនសុខចិត្តឡើយ
ក៏ចាប់ដៃឪពុក ចង់លើកចេញពីក្បាលអេប្រាអិមទៅដាក់
លើក្បាលម៉ាន៉ាសេវិញ ១៨ដោយពាក្យថា មិនត្រូវទេលោក
ឪពុកអើយ ដ្បិតនេះជាកូនច្បង សូមដាក់ដៃស្តាំរបស់លោក
ឪពុកលើក្បាលវាវិញ[ដ] ១៩តែឪពុកមិនព្រមសោះ ក៏និយាយ
ថា អញដឹងហើយ កូនអើយអញដឹងហើយ វានឹងបានត្រឡប់
ជាពួក១ដែរ ហើយនឹងបានធំផង[ឋ] ប៉ុន្តែប្អូននឹងបានធំជាង[ឌ]
ពូជវានឹងត្រឡប់ទៅជានគរ១ដ៏ពោរពេញ[ឍ] ២០នៅថ្ងៃនោះ
[ណ]ឯងគាត់ឱ្យពរ[ត]ដល់ក្មេងទាំង២ថា អ៊ីស្រាអែល[ថ]នឹងឱ្យពរ[ទ]
ដល់មនុស្សដទៃដោយសារឯង ដោយថាសូមព្រះទ្រង់
ប្រោសឱ្យឯងបានដូចជាអេប្រាអិម[ធ] និងម៉ាន៉ាសេ[ន]ចុះដូច្នេះ
គាត់បានលើកអេប្រាអិមឱ្យធំជាងម៉ាន៉ាសេ ២១នោះអ៊ីស្រា
អែល ក៏និយាយទៅយ៉ូសែបថា មើលអញនឹងត្រូវស្លាប់
តែព្រះទ្រង់នឹងគង់នៅជាមួយនឹងឯងរាល់គ្នា[ប] ហើយនិង
នាំឯងរាល់គ្នាត្រឡប់ទៅឯស្រុករបស់ពួកឰយុកោឯងវិញ[ផ]
២២មួយទៀត ក្នុងរបស់ទាំងប៉ុន្មាន ដែលអញបានយកពីដៃ
នៃពួកសាសន៍អាម៉ូរី ដោយដាវ[ព] និងធ្នូរបស់អញ នោះអញ

**៤៨:១២** យ លប ៥០:២៣ យប ៣:១២ រ លប ១៩:១ ៣៣:៣ ៣៧:១០ **៤៨:១៣** ល ទដ ១៦:៨ ៧៣:២៣ ១១០:១ មថ ២៥:៣៣ **៤៨:១៤** វ ខ.២ ស ខ.១៧,១៨ ហ លប ២៥:២៣ ឡ លប ២៩:៣២ ៤១:៥១ **៤៨:១៥** អ លប ២៤:៦០ ក លប ៥:២២ ខ លប ៤៩:២៤ ២សយ ៥:២ ទដ ២៣:១ ៨០:១ អស ៤០:១១ យរ ២៣:៤ **៤៨:១៦** គ លប ១៦:៧ ឃ លប ២៤:៥០ ២សយ ៤:៩ ទដ ៧១:៤ យរ ១៥:២១ ដយ ៣:១៧ ង លប ២៨:៣ ច ១រប ៥:១ អក ៤៧:១៣ ហាព **៤៨:១៧** ឈ ខ.១៣ ញ ខ.១៤ **៤៨:១៨** ដ ខ.១៤ **៤៨:១៩** ឋ លប ១៧:២០ ឌ លប ២៥:២៣ ឍ លប ១២:២ **៤៨:២០** ណ ហាព ១១:២១ ត លប ២៤:៦០ ថ ខ.២ ទ លវ ៩:២២ ជន ៦:២៣ ចទ ១០:៨ ២១:៥ ធ ជន ២:១៨ យរ ៣១:៩ ន លប ៤១:៥១ ជន ២:២០ ១០:២៣ នរ ៤:១១ **៤៨:២១** ប លប ២៦:៣ ផ លប ១៥:១៦ ២៨:១៣ ចទ ៣០:៣ ទដ ១២៦:១ យរ ២៩:១៤ អក ៣៤:១៣

ឃើញកូនរបស់លោកយ៉ូសែបពីមុនមកឬមួយដោយសារពេលនេះពួកគេធំៗអស់ហើយធ្វើឱ្យគាត់ចាំពួកគេមិនច្បាស់ ។

**៤៨:១៣–២០** សូមមើល កច ៦:៦ ។

**៤៨:១៣** *ម៉ាន៉ាសេនៅដៃឆ្វេងទៅខាងស្តាំអ៊ីស្រាអែល* លោកយ៉ូសែបចង់ឱ្យយ៉ាកុបឱ្យពរដល់ម៉ាន៉ាសេ ដែលជាកូនដំបូងរបស់គាត់តាមរយៈការដាក់ដៃស្តាំរបស់យ៉ាកុបលើដៃម៉ាន៉ាសេ ។

**៤៨:១៥** *ឱ្យពរ* គាត់បានឱ្យពរដល់ម៉ាន៉ាសេ ដូចជាអ៊ីសាកឪពុកគាត់បានឱ្យពរដល់គាត់ដែរ (២៧:២៧–២៩) ។ *យ៉ូសែប* នៅកន្លែងនេះគឺប្រើឈ្មោះយ៉ូសែបតំណាងឱ្យអេប្រាអិមហើយនិងម៉ាន៉ាសេ (មើលការពន្យល់ខ.១) ។ *សូមឱ្យព្រះ ដែលអ័ប្រាហាំជាជីតា និងអ៊ីសាក . . . ដើរនៅចំពោះទ្រង់* សូមមើល ៥:២២ ១៧:១ ។ *ចិញ្ចឹម* នៅក្នុងភាសាអង់គ្លេសគេនិយាយថា (Shepherd) ដែលមានន័យថា "អ្នកគង្វាល" ដែលគេប្រើជាទូទៅសម្រាប់អ្នកដែលរស់នៅមជ្ឈឹមបូព៌ាសម័យបុរាណ ជាពិសេសពួកមេស្ញូប៉ូតាមាគេនិយាយពាក្យថា អ្នកគង្វាលនេះគឺសំដៅលើព្រះមហាក្សត្រ ។ វាជាមុខរបរដ៏សំខាន់មួយសម្រាប់មនុស្សគ្រប់គ្នា ។ នៅទីនេះហើយនិងនៅ ៤៩:២៤ គឺនិយាយសំដៅលើព្រះយេហូវ៉ា (សូមមើល ទដ ២៣:១ និងការពន្យល់) ។

**៤៨:១៦** *ទេវតា* សូមមើល ១៦:៧ ។ ទេវតានេះ គឺជាព្រះយេហូវ៉ាផ្ទាល់ដែលបានលេចមកហើយប្រទានពរដល់លោកយ៉ាកុបកាលពីដំបូង (៣២:២៩ និង ៣២:២៤) ។

**៤៨:១៩** *ប៉ុន្តែប្អូននឹងបានធំជាង* សូមមើល ២៥:២៣ ។ ក្នុងអំឡុងដែលនគរបានបែងចែកជា២ (៩៣០–៧២២ មុន គ.ស) កូនចៅរបស់អេប្រាអិមគឺមានអំណាចជាងគេ នៅភាគខាងជើង ។ អេប្រាអិមជានិច្ចកាលគឺគេតែងតែនិយាយសំដៅលើអាណាចក្រខាងជើង (សូមមើល អស ៧:២,៥,៨–៩ ហាស ៩:១៣ ១២:១,៨) ។

**៤៨:២០** *ដូច្នេះគាត់ក៏លើកអេប្រាអិមឱ្យធំជាងម៉ាន៉ាសេ* លោកយ៉ាកុបគឺជាប្អូនដែលបានឈ្លោះប្រកែក ហើយបានទាមទារសិទ្ធិអំណាចជាកូនច្បងពីអេសាវ ហើយគាត់ដែលស្រឡាញ់ចូលចិត្តនាងរ៉ាដែលដែលជាប្អូនជាងស្រឡាញ់លេអាជាបង ដូច្នេះហើយពេលនេះគាត់ក៏ឱ្យពរដល់កូនប្អូនរបស់លោកយ៉ូសែបជាអ្នកដឹកនាំ ហើយឱ្យបានប្រសើរជាងបងដែរ ។

**៤៨:២១** *យ៉ូសែប* សូមមើល ខ.១៥ ។ *អញនឹងត្រូវស្លាប់* ក្រោយមកទៀតលោកយ៉ូសែប ក៏បាននិយាយពាក្យនេះជាមួយបងប្អូនរបស់គាត់ទៀតដែរ (៥០:២៤) ។

**៤៨:២២** *ក្នុងរបស់ទាំងប៉ុន្មាន* នៅក្នុងភាសាហេព្រើរឃ្លានេះគឺនិយាយសំដៅលើទីកន្លែងមួយដែលមានឈ្មោះថា ស៊ីគែម ជាកន្លែងដែលពួកកូនចៅយ៉ូសែបនឹងបញ្ចុះសពរបស់លោកយ៉ូសែបនៅកន្លែងនោះនៅពេលក្រោយមកទៀត (សូមមើល សយ ២៤:៣២ លក ៣៣:១៩ យហ ៤:៥ និងការ

បានចែក១ចំណែកដល់ឯង[ភ]លើសជាងបងប្អូនឯងហើយ[ម]។

**លោកយ៉ាកុបឱ្យពរដល់កូនប្រុសៗរបស់គាត់**

*៤៩:១-២៨ – ចទ ៣៣:១-២៩*

**៤៩** ១យ៉ាកុបក៏ហៅកូនគាត់ទាំងអស់មកប្រាប់ពី ចូរឯង
ប្រមូលគ្នាទាំងអស់មក ដើម្បីអញនឹងប្រាប់ឱ្យដឹងថា ការ
ដែលនឹងកើតដល់ឯងរាល់គ្នានៅជាន់ក្រោយ[ក] ២ចូរប្រជុំគ្នា[ខ]
ស្តាប់ចុះឪពុកកូនយ៉ាកុបអើយ ចូរស្តាប់អ៊ីស្រាអែលជា
ឪពុកនៃឯងរាល់គ្នា[គ]។
៣រូបេនអើយឯងជាកូនច្បង[ឃ] ជាឫទ្ធិ ហើយជាដើម
កំឡាំងរបស់អញ[ង] ឯងមានកិត្តិយស[ច] មានឥទ្ធិឫទ្ធិយ៉ាងឯក
៤តែដែលរំពើកចុះឡើងដូចទឹក[ឆ] នោះឯងមិនបានស្ថិតស្ថេរ
នៅជាប់ទេ ពីព្រោះឯងបានឡើងទៅលើដំណេករបស់
ឪពុកឯង ហើយបានធ្វើឱ្យគ្រែអញទៅជាអាស្រូវបារាយ
ក្នុងកាល ដែលឡើងទៅដេកនោះ[ជ] ។
៥ឯស៊ីម្មាន[ឈ]និងលេវី[ញ]ជាបងប្អូនគ្នា ដាវគេជាគ្រឿង
សាហាវណាស់[ដ] ៦ឱចិត្តអញអើយ កុំឱ្យចូលគំនិតនឹងគេ ឱ
កិត្តិយសរបស់អញអើយ កុំឱ្យចូលក្នុងជំនុំគេឡើយ[ឋ] ដ្បិតគេ
បានសំឡាប់ មនុស្សដោយមោហោចិត្ត[ឌ] ហើយបានប្រហារ
អ្នកដែលជាកំពូល[ឍ]ដោយអំណរចិត្តផង ៧សេចក្ដីកំហឹង[ណ]

**៤៨:២២** ព យស ២៤:៣២ យហ ៤:៥ ភ លប ៣៤:២៦ ម លប ៣៧:៨ **៤៩:១** ក ជន ២៤:១៤ ចទ ៣១:២៩ យរ ២៣:២០ ដយ ២:២៨,៤៥ **៤៩:២** ខ យស ២៤:១ គ ខ.១៦ ,២៨ ទដ ៣៤:១១ **៤៩:៣** ឃ លប ២៩:៣២ ៤១:៥១ ង ចទ ២១:១៧ ទដ ៧៨:៥១ ១០៥:៣៦ ច លប ៣៤:១៩ **៤៩:៤** ឆ អស ៥៧:២០ យរ ៤៩:២៣ ជ លប ២៩:២៩ ៣៤:៥ **៤៩:៥** ឈ លប ២៩:៣៣ ញ លប ២៩:៣៤ ដ លប

របស់គេត្រូវបណ្ដាសា ដ្បិតជាខ្លាំងលើសលុប ហើយ
សេចក្តីឃោរឃៅរបស់គេផង[ត] ពីព្រោះជាសាហាវក្រៃ
លែង អញនឹងញែកគេចេញពីគ្នានៅក្នុងពួកយ៉ាកុប ហើយ
និងកំចាត់កំចាយគេនៅក្នុងពួកអ៊ីស្រាអែល[ថ] ។
៨យូដាអើយ[ទ] ពួកបងប្អូនឯងនឹងសរសើរឯង ដៃឯងនឹង
ចាប់កញ្ចឹងក[ធ] នៃពួកខ្មាំងសត្រូវឯង ពួកកូនឪពុកឯងនឹងឱន
គោរពដល់ឯង[ន] ៩យូដាជាសិង្ហ[ប]ស្ទាវ[ផ] កូនអើយ[ព] ឯងបាន
ឡើងមកពីស៊ីរំពាវា[ភ]បានក្រាបចុះ បានដេកដូចជាសិង្ហ
ហើយដូចជសិង្ហយ៉ាងខ្លាំង នោះតើអ្នកណាហ៊ានដាស់វា
១០ដំបងរាជ្យនឹងមិនដែលឃ្លាតពីយូដា[ម] ឬអំណាចគ្រប់គ្រង
ពីជើងវាឡើយ ដរាបដល់ស៊ីឡូរបានមកដល់[យ]នោះបណ្ដា
ជនទាំងឡាយនឹងចុះចូលចំពោះទ្រង់[រ] ១១ទ្រង់នឹងចងកូន

៣៤:២៥ សភ ៤:១៧ **៤៩:៦** ឋ ទដ ១:១ សភ ១:១៥ អភ:១១ ឌ លប ៣៤:២៦ ឍ ១១:៦,៩ ២សយ:៤ ១របា ១៨:៤ **៤៩:៧** ណ លប ៣៤:៧ ត លប ៣៤:២៥ ថ យស ១៩:១,៩ ២១:១-៤២ **៤៩:៨** ទ លប ២៩:៣៥ ធ ចទ ២៨:៤៨ ន លប ៩:២៥ ១រប ៥:២ **៤៩:៩** ប ចន ២៤:៩ ទដ ៧:២ ១០:៩ អគ ១៩:៥ មីក ៥:៨ ផ អគ ១៩:២ ព វវ ៥:៥ ភ ខ.២៧ ជន ២៣:២៤ យប ៣៨:៣៩ ទដ ១៧:១២ ២២:១៣ ១០៤:២១ **៤៩:១០** ម ជន ២៤:១៧,១៩ ពច ១:១-២ ២០:១៨ ១រប ៥:២ ២៨:៤ ទដ ៦០:៧ ១០៨:៨ យ អគ ២១:២៧ រ ទដ ២:៩ ៧២:៨-១១ ៩៨:៣ ១១០:២ អស ២:៤ ២៦:១៨ ៤២:១,៤ ៤៥:២២ ៤៨:២០ ៤៩:៦ ៥

ពន្យល់) ។ *ដែលអញបានយកពីដៃនៃពួកសាសន៍អាម៉ូរី* ដូចគ្នានឹងព្រឹត្តិការណ៍ដែលកើតឡើង សូមមើល ៣៤:២៥-២៩ ។

**៤៩:២-២៧** ជាញឹកញាប់នៅក្នុងជំពូកនេះ គេហៅថា"ព្រះពររបស់យ៉ាកុប" នៅក្នុងផ្នែកនេះ ជាកំណាព្យវែងជាងគេបំផុតនៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ ។ ព្រះដែលបានតម្រូវទុកជាមុនបែបនេះ មិនមែនសម្រាប់តែកូនចៅទាំង១២ របស់យ៉ាកុបនោះឡើយ ប៉ុន្តែគឺសម្រាប់កូនចៅផ្សេងៗទៀតរបស់គេរៀងៗខ្លួនដែរ (ខ.២៨) ។ សម្រាប់ព្រះពរពិសេសផ្សេងៗទៀតដែលអ្នកនិពន្ធបានលើកឡើងក្នុងគម្ពីរលោកុប្បត្តិ សូមមើល ៩:២៦-២៧ ១៤:១៩-២០ ២៧:២៧-២៩ ២៧:៣៩-៤០ ៤៨:១៥-១៦ ៤៨:២០ ។

**៤៩:៤** *រំពើកចុះឡើង* កូនចៅរបស់រូបេន គេនឹងធ្វើការសម្រេចចិត្តដោយមិនប្រាកដហើយមិនច្បាស់លាស់ (ពច ៥:១៥-១៦) ។ *នោះឯងមិនបានស្ថិតស្ថេរនៅជាប់ទេពីព្រោះឯងបានឡើងលើដំណេករបស់ឪពុកឯង* សូមមើល ៣៥:២២ និងការពន្យល់ ព្រមទាំង ៣៧:២១ ៤៨:៥ ។

**៤៩:៥** *ស៊ីម្មាននឹងលេវីជាបងប្អូនគ្នា* ពួកគេទាំង២នាក់ពោរពេញដោយជម្លោះកំហឹងទាស់ទែងគ្នាយ៉ាងខ្លាំងទៀតផង (សូមមើល ខ.៦-៧ ព្រមទាំង ៣៤:២៥) ។

**៤៩:៧** *អញនឹងញែកគេចេញពីគ្នា* ការនេះបានសម្រេចនៅពេលដែលកូនចៅរបស់ស៊ីម្មានទទួលមរតកពីពួកកូនចៅយូដា (យស ១៩:១ នឹងជំពូក៩) ហើយនិងនៅពេលដែលពួកកូនចៅលេវី បានបែកខ្ញែកទៅតាមទីកន្លែងផ្សេងៗគ្នានិងតំបន់នៅជុំវិញក្រុងនេះដែរ ដែលរស់នៅជា៤៨ក្រុម (សូមមើល ៤:៦ ជន ៣៥:២,៧ យស ១៤:៤ ២១:៤១) ។

**៤៩:៨** សូមប្រៀបធៀបជាមួយ ២៧:២៩,៤០ ៣៧:៧,៩ ។ *យូដាអើយពួកបងប្អូនឯង . . . នឹងឱនគោរពដល់ឯង* សូមមើល ៤៣:៣ ។ ពួកគេទាំងនោះបានក្លាយជាអ្នកដឹកនាំនៅកុលសម្ពន្ធក្នុងប្រទេសអ៊ីស្រាអែលនៃនគរខាងត្បូងនិងនគរខាងជើង ។ លោកយ៉ាកុបបានឱ្យពរដល់យូដានិងយ៉ូសែបច្រើនជាងគេនិងវែងជាងគេ (ខ.៨-១២,ខ.២២-២៦) ។ យូដាគាត់គឺជាកូនទី៤របស់លេអា ដែលនាងបានបង្កើតឱ្យលោកយ៉ាកុប (សូមមើល ២៩:៣៥) ។ រូបេន ស៊ីម្មាន និងលេវីពួកគេបានបាត់បង់សិទ្ធិជាអ្នកដឹកនាំ ដូច្នេះហើយលោកយ៉ាកុបបានផ្តល់សិទ្ធិជាអ្នកដឹកនាំយូដា (កូននាងលេអា) ប៉ុន្តែឱ្យទៅយ៉ូសែប (កូនរ៉ាជែល) ទ្វេរជា២វិញ សូមមើល ១រប ៥:២ ។

**៤៩:៩** *យូដាជាសិង្ហស្ទាវ* សិង្ហគឺជានិមិត្តរូបនៃអំណាច កម្លាំង ហើយនឹងការលើកទឹកចិត្ត ។ នៅសម័យក្រោយមកទៀតយូដា(អ៊ីស្រាអែល)បានប្រើសត្វសិង្ហធ្វើជានិមិត្តសញ្ញារបស់គាត់ (អគ ១៩:២ មីក ៥:៨ ជាពិសេស ជន ២៤:៩) ។ ព្រះយេស៊ូវគ្រីស្ទទ្រង់មានតំណវង្សចេញពីពួកកូនចៅដ៏ច្រើនរបស់យូដា (៤៣:៣) ហើយព្រះអង្គបានហៅខ្លួនព្រះអង្គផ្ទាល់ថា "សត្វសិង្ហដែលកើតពីអំបូរយូដា" (វវ ៥:៥) ។

**៤៩:១០** ទោះបីជាកន្លែងនេះមានការពិបាកក្នុងការបកប្រែនឹងពន្យល់ក៏ដោយ(មើលក្នុងអត្ថបទគម្ពីរ)ក៏ខនេះយើងអាចយល់បានថា ដំបូងគឺត្រូវបានសម្រេចទៅលើដាវីឌ ហើយក្រោយមកទៀតគឺនៅលើព្រះយេស៊ូវផ្ទាល់តែម្តង ។ *ដំបងរាជ្យ* សូមមើល ជន ២៤:១៤ និងការពន្យល់ ។ *ដរាបដល់ស៊ីឡូរបានមកដល់* នៅក្នុង អគ ២១:២៧ បានដកស្រង់ចេញពីឃ្លានេះបានស្ទើរតែទាំងអស់(សូមមើលអត្ថបទទីនោះ) ។ គឺនៅពេលដែលសេដេគាជាស្តេចក្រោយបង្អស់នៅយូដា បានដោះមកុដចេញ (អគ ២១:២៦) ពីក្បាលរបស់គាត់ ពីព្រោះមនុស្សកំណាចដែលមកពីក្រុងយេរូសាឡិម ។

លា[ល]ភ្ជាប់និងដើមទំពាំងបាយជូរ គឺជាកូនរបស់មេលាទ្រង់
ភ្ជាប់និងដើមយ៉ាងល្អបំផុត[វ] ទ្រង់នឹងបោកព្រះពស្ត្រទ្រង់
នឹងស្រាទំពាំងបាយជូរ[ស] ១២ព្រះនេត្រទ្រង់នឹងបានក្រហម
ដូចស្រាទំពាំងបាយជូរ ហើយព្រះទន្តទ្រង់សដូចទឹកដោះ[ហ] ។
១៣សាប់យ៉ូល៉ូន[ឡ]នឹងនៅមាត់សមុទ្រ វានឹងបានជាមាត់
កំពង់សំរាប់នាវា ហើយព្រំស្រុកវានឹងទល់នឹងស្រុកស៊ី
ដូន[អ] ។
១៤អ៊ីសាខារ[ក]វាជាសត្វលាយ៉ាងខ្លាំង ដែលដេកនៅ
កណ្តាលក្រោលចៀម[ខ] ១៥វាឃើញមានទីឈប់សំរាកដែល
ស្រួល ហើយថា ស្រុកនោះល្អ[គ] រួចវាបានឱនស្មាទទួលនឹម[ឃ]
ព្រមទាំងចុះចូលធ្វើការដែលគេបង្ខំឱ្យធ្វើ[ង]។
១៦ដាន់[ច] នឹងជំនុំជំរះពួកវា ទុកដូចជាពូជអំបូរអ៊ីស្រា
អែល១[ឆ] ១៧ដាន់[ជ]នឹងធ្វើជាពស់នៅក្នុងផ្លូវ[ឈ] គឺជាពស់វែក
នៅផ្លូវច្រកដែលចឹកកែងជើងសេះ[ញ] ឱ្យអ្នកជិះធ្លាក់ផ្ងារ
ក្រោយ ១៨ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានរង់ចាំសេចក្តី
សង្គ្រោះ[ដ] របស់ទ្រង់[ឋ] ។
១៩ឯកាឌ់[ឌ]នឹងមាន១ហ្វូងមកប្រជ្រៀតលើវា តែវានឹង
ដេញប្រកិតតាមកែងគេវិញ[ឍ]។
២០ឯអេស៊ើរ[ណ] អាហារវានឹងបានវិសេស[ត] ហើយវានឹង
ផ្គត់ផ្គង់របស់យ៉ាងឆ្ងាញ់ថ្វាយស្តេច[ថ] ។
២១ណែបថាលី[ទ] ជាក្តាន់ដែលគេលែង វានឹងពោល
ពាក្យពិរោះស្តាប់[ធ]។
២២យ៉ូសែប[ន]ជាមែកឈើមានផ្លែ[ប] ជាមែកឈើមានផ្លែ
ដែលដុះនៅជិតរន្ធទឹក ខ្នែងវា[ផ]នឹងវារពាក់លើកំផែង
២៣ពួកពលធ្នូបានធ្វើទុក្ខវាជាខ្លាំង[ព] ទាំងបាញ់ទាំងស្អប់វា
ផង[ភ] ២៤តែធ្នូវានៅតែខ្លាំងពូកែ[ម] ដៃវាក៏មានកំឡាំង[យ]ដោយ
សារ ព្រះហស្តនៃព្រះដ៏មានព្រះចេស្តារបស់យ៉ាកុប[រ] ឯអ្នក
គង្វាល[ល] គឺជាថ្មដារបស់អ៊ីស្រាអែលបានចេញពីនោះមក[វ]
២៥គឺដោយនូវព្រះនៃឪពុកឯង[ស] ដែលទ្រង់នឹងជួយ[ហ]ឯង
ហើយដោយនូវព្រះដ៏មានគ្រប់ទាំងព្រះចេស្តា[ឡ] ដែលទ្រង់
នឹងប្រទានពរដល់ឯង ជាព្រះពរពីលើមេឃ ហើយជាព្រះ

**៤៩:១១** ល ពច ៥:១០ ១០:៤ សក ៩:៩ វ ចទ ៨:៨ ២ពវ ១៨:៣២ ស ចទ ៣២:១៤ អស ៦៣:២ **៤៩:១២** ហ សស ៥:១២ **៤៩:១៣** ឡ លប ៣០:២០ អ លប ១០:១៩ **៤៩:១៤** ក លប ៣០:១៨ ខ ពច ៥:១៦ ទដ ៦៨:១៣ **៤៩:១៥** គ យស ១៩:១៧–២៣ ឃ អក ២៩:១៨ ង ១ពវ ៤:៦ ៥:១៣ ៩:២១ អស ១៤:២ ៣១:៨ **៤៩:១៦** ច លប ៣០:៦ ឆ ខ.២ **៤៩:១៧** ជ ពច ១៨:២៧ ឈ យរ ៨:១៧ អម ៩:៣ ញ ខ.១៩ **៤៩:១៨** ដ លប ៤៥:៧ ទដ ៤០:១–៣ ទដ ១១ ៩:១៦៦,១៧៤ **៤៩:១៩** ឌ លប ៣០:១១ ឍ ខ.១៧ **៤៩:២០** ណ លប ៣០:១៣ ត អស ២៥:៦ ថ យប ២៩:៦ **៤៩:២១** ទ លប ៣០:៨ ធ យប ៣៩:១ **៤៩:២២** ន លប ៣០:២៤ ប លប ១៧:៦ ទដ ១២៨:៣ អគ ១៩:១០ ផ ទដ ៨០:១០ **៤៩:២៣** ព ១របា ១០:៣ ភ លប ២៧:៤១ ៣៧:២៤ **៤៩:២៤** ម យប ២៩:២០ យ ទដ ១៨:៣៤ អស ៦៣:១២ រ ទដ ១៣២:២,៥ អស ១:២៤ ១០:៣៤ ៤៩:២៦ ៦០:១៦ ល លប ៤៨:១៥ វ ចទ ៣២:៤,១៥,១៨,៣១ ១សយ ២:២ ២សយ ២២:៣២ ទដ ១៨:២,៣១ ១៩:១៤ ៧៨:៣៥ ៨៩:២៦ ១៤៤:១ អស ១៧:១០ ២៦:៤ ៣០:២៩ ៤៤:៨ ហព ១:១២ **៤៩:២៥** ស លប ២៨:១៣ ហ នក ១៨:៤ ទដ ២៧:៩

**៤៩:១១** នៅថ្ងៃណាមួយកូនចៅរបស់យូដា គេនឹងបានតាំងលំនៅរបស់គេដោយអំណរ ហើយពួកគេក៏នឹងរស់នៅដោយសុខសាន្ត ។

**៤៩:១៣** ទោះបីជាទឹកដីនេះជារបស់អេស៊ើរ និង ម៉ាន៉ាសេក៏ដោយ កូនចៅរបស់សាប់យូល៉ូន ក៏នៅជិតសមុទ្រមេឌីទែរ៉ាណេ (ប្រហែលមានចម្ងាយ ១០ ម៉ៃយ៍) "ដ្បិតគេនឹងជញ្ជក់ផលបរិបូរពីសមុទ្រ" (ចទ ៣៣:១៩) ។

**៤៩:១៧** *ដាន់នឹងធ្វើជាពស់នៅក្នុងផ្លូវ* អំពើក្បត់របស់ពួកដាន់នឹងប្រាប់យើងនៅក្នុង ពច ១៨:២៧ ។ *ចឹកកែងជើងសេះ* លោកសាំសុន ជាកូនចៅរបស់ដាន់ គឺជាម្នាក់ដែលបានចុះចាញ់ភីលីស្ទីន (ពច ១៤–១៦) ។

**៤៩:១៨** លោកយ៉ាកុប គាត់បានបន្តសុំព្រះពរពីព្រះតាមរយៈសេចក្តីអធិស្ឋាន ហើយសុំជំនួយមកពីព្រះ ។

**៤៩:១៩** *ឯកាឌ់នឹងមាន១ហ្វូងប្រជ្រៀតលើវា* មានទីកន្លែងស្ថិតនៅភាគខាងជើងនៃទន្លេយ័រដាន់ (យស ១៣:២៤,២៧) ។ កូនចៅរបស់កាឌ់បានវាយលុកជាមួយមេសាជាស្តេចសាសន៍ម៉ូអាប់ (២ពវ ៣:៤) ។

**៤៩:២០** *ឯអេស៊ើរអាហារវានឹងបានវិសេស* ដោយសារព្រំប្រទល់នៃស្រែចំការរបស់គេ ដែលស្ថិតនៅក្បែរសមុទ្រមេឌីទែរ៉ាណេពោរពេញទៅដោយដីជាតិគ្រប់យ៉ាងទាំងអស់ (សូមមើល យស ១៩:២៤–៣០) ហើយអាចធានានិងផ្តល់ឱ្យកូនចៅរបស់អេស៊ើរនូវភាពរុងរឿង ។

**៤៩:២១** *ណែបថាលី ជាក្តាន់ដែលគេលែង* ប្រហែលអ្នកនិពន្ធចង់និយាយអំពីសេរីភាពខាងវិញ្ញាណ និងសេរីភាពនៃការចិញ្ចឹមបីបាច់កូនចៅរបស់គេដោយសារពួកគេខ្លះបានបែកគ្នាទៅរស់នៅលើភ្នំ នៅភាគខាងជើងសមុទ្រកាលីឡេ (សូមមើល យស ១៧:១៤–១៨) ។

**៤៩:២២** *មានផ្លែ... មានផ្លែ* វាតំណាងឱ្យឈ្មោះរបស់អេប្រាអិមដែលនឹងបង្កើតផលផ្លែជានិច្ច (សូមមើល ៤១:៥) ហើយគឺជាអំបូរដែលលោកយ៉ាកុបបានថ្លែងទំនាយថា គេនឹងបានធំជាង ម៉ាន៉ាសេដែលជាកូនច្បងរបស់លោកយ៉ូសែប (មើល ៤៨:១៩–២០) ។ *ខ្នែងវានឹងវារពាក់លើកំផែង* កូនចៅរបស់អេប្រាអិម និងពង្រីកកុលសម្ពន្ធរបស់គេថែមទៀត នៅពេលក្រោយ (សូមមើល យស ១៧:១៤–១៨) ។

**៤៩:២៤** *តែធ្នូវានៅតែខ្លាំងពូកែ* ជានិច្ចកាលសង្គ្រាមរបស់ពួកកូនចៅអេប្រាអិម (មើល ពច ៨:១១ ២:១) គឺតែងតែទទួលជ័យជម្នះ (យស ១៧:១៨) ។ *ដោយសារព្រះហស្តនៃព្រះដ៏មានព្រះចេស្តារបស់យ៉ាកុប* នៅកន្លែងនេះអ្នកនិពន្ធចង់បញ្ជាក់អំពីសកម្មភាពដ៏រស់រវើករបស់ព្រះ ក្នុងការជួយសង្គ្រោះ និងប្រោសលោះរាស្ត្ររបស់ទ្រង់ (មើល អស ៤៩:២១៦) ។ *អ្នកគង្វាល* សូមមើល ៤៨:១៥ ។ *ជាថ្មដារបស់អ៊ីស្រាអែល* ការធានាអំពីការ ការពារចំពោះអ៊ីស្រាអែល (ចទ ៣២:៤,១៥,១៨,៣០–៣១) ហើយទំនុកចិត្តចំពោះការការពារនេះជាញឹកញាប់ ត្រូវបានគេនិយាយនៅក្នុងគម្ពីរទំនុកដំកើង (មើល ទដ ១៨:២) នឹងគម្ពីរអេសាយ ។

**៤៩:២៥** *ព្រះចេស្តា* សូម មើល ១៧:១ ។ *ជាព្រះពរពីលើមេឃ ... ពីជីវៅនៅពីក្រោម* ព្រះយេហូវ៉ាទ្រង់បានបង្អុរភ្លៀងពីលើមេឃប្រយោជន៍ឱ្យដីមានដីជាតិល្អ ព្រមទាំងឱ្យមានទឹកនិងរដូវកាលគ្រប់គ្រាន់ដល់គេ ។ *ទាំងផលរបស់ដោះហើយនិងពោះផង* ព្រះពររបស់ព្រះ គឺនឹងកើតដល់គេដោយសារមនុស្សហើយនិងសត្វ ។ សម្រាប់ព្រះពរនិងភាពរុងរឿងរបស់កូនចៅអេប្រាអិម នៅសម័យក្រោយមកទៀត សូមមើល ហស ១២:៨ ។

ពរពីទីជិរៅ ដែលនៅខាងក្រោម[អ] ទាំងផលរបស់ដោះ[ក]
ហើយនិងពោះផង[ខ] ២៦ពររបស់ឪពុកឯង នោះលើសជាង
អស់ទាំងពររបស់ពួកឰយុកោអញ ជាពរធំដល់ព្រំចុង
បង្អស់របស់ភ្នំដ៏នៅកល្បជានិច្ច[គ] ហើយក៏នៅលើក្បាល
យ៉ូសែប[ឃ] គឺនៅលើកំពូលក្បាលនៃអ្នកដែលបានញែក
ចេញពីពួកបងប្អូនវា[ង] ។
២៧បេនយ៉ាមីន[ច] ជាឆ្កែព្រៃដែលហែកស៊ី[ឆ] នៅពេល
ព្រឹក វាខាំស៊ីរំពា[ជ] ហើយដល់ពេលល្ងាចវាចែករបឹប[ឈ]។
២៨នោះជាពូជអំបូរអ៊ីស្រាអែលទាំង១២[ញ] គឺសេចក្តីនេះ
ហើយដែលឪពុកគេបានពោលទុក ក្នុងកាលដែលឱ្យពរ
ដល់គេ គាត់ឱ្យពរដល់គ្រប់គ្នា តាមពរ[ដ]ដែលគួរឱ្យដល់
គេរៀងខ្លួន ។

## ការស្លាប់របស់យ៉ាកុប

២៩គាត់ក៏ផ្តាំថា[ឋ] អញហៀបនឹងបានប្រមូលទៅមូលនឹង
ញាតិអញហើយ[ឌ] ចូរកប់អញនៅជាមួយនឹងជីតាជីដូនអញ[ឍ]
ក្នុងរអាងដែលនៅឯចំការរបស់អេប្រុន ជាសាសន៍ហេត
ទៅ[ណ] ៣០គឺក្នុងរអាងដែលនៅចំការម៉ាក់ពេឡា[ត] ទល់មុខ
និងម៉ាមរេ[ថ]នៅស្រុកកាណាន ដែលអ័ប្រាហាំបានទិញជា
មួយនឹងចំការនោះ ពីអេប្រុនសាសន៍ហេត ទុកសំរាប់ជាទី
កប់ខ្មោច[ទ,ធ] ៣១គឺនៅទីនោះ ដែលគេបានកប់សពអ័ប្រាហាំ[ន]
និងសារ៉ា[ប]ជាប្រពន្ធគាត់ ហើយនៅទីនោះគេបានកប់សព
អ៊ីសាកនិងរេបិកា[ផ]ប្រពន្ធគាត់ ហើយគឺនៅទីនោះដែលអញ
បានកប់សពលេអាដែរ[ព] ៣២ឯចំការនិងរអាងនោះបាន
ទិញពីពួកកូនចៅហេតហើយ[ភ] ៣៣កាលយ៉ាកុបបានផ្តាំដល់
ពួកកូនរួចស្រេចហើយ នោះគាត់លើកជើងដាក់លើគ្រែ
វិញ ហើយក៏ផុតដង្ហើមទៅបានប្រមូលទៅមូលនឹងញាតិ
របស់គាត់[ម]។

**៥០** ១យ៉ូសែបក៏ក្រាបផ្ទប់នៅលើមុខឪពុក ទាំងយំហើយ
ថើបគាត់[ក] ២រួចយ៉ូសែបបង្គាប់គ្រូពេទ្យជាអ្នកបំរើគាត់ឱ្យ
ដាក់បារទសពឪពុក ពួកគ្រូពេទ្យក៏ដាក់បារទសពអ៊ីស្រា
អែលទៅ[ខ] ៣គេរៀបចំឱ្យគាត់ពេញ៤០ថ្ងៃ ដ្បិតគឺគិតរប់ថ្ងៃ
ទាំងនោះ ដែលធ្លាប់ដាក់បារទខ្មោចទាំងប៉ុន្មាន ហើយពួក
សាសន៍អេស៊ីព្ទ គេនាំគ្នាកាន់ទុក្ខអស់៧០ថ្ងៃ[គ] ៤រួចកាលផុត
វេលាដែលគេកាន់ទុក្ខហើយ[ឃ] នោះយ៉ូសែបក៏ផ្តាំដល់ពួក
ដំណាក់ផារ៉ោន[ង]ថា ឥឡូវបើខ្ញុំប្រកបដោយគុណនៃអ្នក
រាល់គ្នា[ច] នោះសូមទូលដល់ផារ៉ោនថា ៥ឪពុកយើងបាន
ឱ្យយើងស្បថ[ឆ]ដោយថា មើល អញត្រូវស្លាប់[ជ] ចូរឯងកប់
សពអញនៅក្នុងផ្នូររបស់អញ ដែលអញបានជីកសំរាប់អញ
[ឈ]នៅស្រុកកាណាន[ញ] ដូច្នេះសូមទ្រង់អនុញ្ញាតឱ្យយើងបាន
ឡើងទៅកប់ខ្មោចរបស់ឪពុកយើង[ដ]ឥឡូវរួចយើងនឹងវិល
ត្រឡប់មកវិញ ៦នោះផារ៉ោនទ្រង់មានបន្ទូលថា ចូរឡើង
ទៅកប់សពឪពុក អ្នកចុះតាមដែលគាត់បានឱ្យអ្នកស្បថ
នោះ ។
៧យ៉ូសែបក៏ឡើងទៅកប់សពឪពុក ហើយពួកមហាតលិក
ផារ៉ោនទាំងអស់[ឋ] នឹងពួកចាស់ទុំនៅដំណាក់ទ្រង់[ឌ]ព្រមទាំង
ពួកចាស់ទុំនៅស្រុកអេស៊ីព្ទទាំងប៉ុន្មានក៏ឡើងទៅជាមួយ
ដែរ ៨ហើយពួកផ្ទះយ៉ូសែប ទាំងបងប្អូនគាត់នឹងពួកផ្ទះ
ឪពុកគាត់ ទាំងអស់ផង[ឍ] សល់នៅតែកូនក្មេងនឹងហ្វូងចៀម
ហ្វូងគោ របស់គេប៉ុណ្ណោះ ដែលទុកឱ្យនៅស្រុកកូសែន[ណ]

ឡ លប ១៧:១ អ លប ២៧:២៨ ក អស ៦៦:១១ ខ ចទ ៧:១៣ ២៨:៤ ទដ ១០៧:៣៨ សភ ១០:២២ **៤៩:២៦** គ ហព ៣:៦ ឃ ១រប ៥:១ អក ៤៧:១៣ ង លប ៣៧:៨ **៤៩:២៧** ច លប ៣៥:១៨ ពច ២០:១២–១៣ ឆ ហព ១:៨ សផ ៣:៣ ជ ខ.៩ ឈ ជន ៣១:១១ ចទ ២:៣៥ យស ៧:២១ ៨:២ ២២:៨ ពច ៨:២៤ **៤៩:២៨** ញ ខ.២ ដ លប ២៧:៤ **៤៩:២៩** ឋ លប ៥០:១៦ ឌ លប ២៥:៨ ឍ លប ១៥:១៥ ៥០:២៥ ២សយ ២:៣២ ១៩:៣៧ ណ លប ២៥:៩ **៤៩:៣០** ត លប ២៣:៩ ថ លប ១៣:១៨ ទ លប ២៣:៤ ធ លប ២៣:២០ **៤៩:៣១** ន លប ២៥:៩ ប លប ២៣:១៩ ផ លប ២៤:៦៧ ព លប ២៣:២០ ២៩:១៦ **៤៩:៣២** ភ លប ១០:១៥ **៤៩:៣៣** ម លប ២៥:៨ កថ ៧:១៥ **៥០:១** ក លប ២៩:១១ ៤៦:៤ **៥០:២** ខ ខ.២៦ ២រប ១៦:១៤ មថ ២៦:១២ មក ១៦:១ យហ ១៩:៣៩–៤០ **៥០:៣** គ លប ៣៧:៣៤ ចទ ១:៣ **៥០:៤** ឃ លប ២៧:៤១ ង ខ.៧ ច លប ៣០:២៧ ៣២:៥ **៥០:៥** ឆ លប ២៤:៣៧ ជ ខ.២៤ ឈ ២សយ ១៨:១៨ ២រប ១៦:១៤ អស ២២:១៦ មថ ២៧:៦០ ញ លប ៤៧:៣១ ដ មថ ៨:២១ **៥០:៧** ឋ លប ៤៥:១៦ ឌ ខ.៤ **៥០:៨** ឍ ខ.១៤ ណ លប ៤៥:១០

**៤៩:២៦** *នៅលើក្បាលយ៉ូសែប . . . បែកចេញពីបងប្អូនវា* សូមមើល ខ.៨ ៤៨:១៩ ។ អេប្រាអិមនិងទទួលបានអំណាចដ៏អស្ចារ្យ ជាពិសេសគឺគេក្លាយជាអ្នកគ្រប់គ្រងនៅនគរខាងជើង (សូមមើល យស ១៦:៩ អស ៧:១–២ ហស ១៣:១) ។

**៤៩:២៧** *បេនយ៉ាមីន ជាឆ្កែព្រៃដែលហែកស៊ី* សូមមើលពីភាពវៃឆ្លាតរបស់អេហ៊ុឌ (ពច ៣:១២–៣០) ហើយនឹងស្តេចសូល (១សយ ១១–១៥) ។ សូមមើល ពច ១៩–២១ ដែលនៅក្នុបទគម្ពីរនោះបាននិយាយពីភាពកាចសាហាវ និងលក្ខណៈផ្សេងៗទៀតរបស់ពួកកូនចៅប៉េនយ៉ាមីន ។

**៤៩:២៨** *ពូជអំបូរអ៊ីស្រាអែលទាំង១២* សូមមើល ខ.២–២៧ ។

**៤៩:២៩** *ចូរកប់អញជាមួយជីតាជីដូនរបស់អញ* សូមមើល ២៥:៨ ។ លោកយ៉ាកុបមិនបានភ្លេចពីទឹកដីដែលពួកឰយុកោគាត់រស់ឡើយ គាត់បានដឹងថាទឹកដីនោះជាទឹកដីដែលព្រះបានសន្យាឱ្យដល់ពួកកូនចៅរបស់គាត់ និងពួកអ៊ីស្រាអែល (មើល ២៣:១៩) ។

**៤៩:៣៣** *បានប្រមូលទៅមូលនឹងញាតិរបស់គាត់* សូមមើល ២៥:៨ ។

**៥០:១** *យំ* សូមមើល ៤៣:៣០ ។

**៥០:២** *គ្រូពេទ្យក៏ដាក់បារទសពអ៊ីស្រាអែលទៅ* តួនាទីនៃអ្នកដាក់បារទប្រហែលជាអាចរកបានកម្រៃខ្ពស់ ដូច្នេះយ៉ូសែបគាត់ត្រូវចំណាយលុយច្រើន ប៉ុន្តែលោកយ៉ូសែបគាត់មិនចង់ឱ្យទាក់ទងជាមួយសាសនាដែលមិនជឿព្រះនោះឡើយ ។

**៥០:៣** *៤០ថ្ងៃ . . . ៧០ថ្ងៃ* ការធ្វើពិធី២បែបនេះប្រហែលចំថ្ងៃដូចគ្នា ។

**៥០:៥** *ឪពុកយើងបានឱ្យយើងស្បថដោយថា* សូមមើល ៤៧:២៩–៣១ ។ *ជីក* ឬ "ទិញ" ការបកប្រែខគម្ពីរនេះ ជាភាសាហេព្រើរនោះសូមមើល ហស ៣:២ (សូមមើល ចទ ២:៦) ។ *ឡើងទៅ* គឺទៅស្រុកហេប្រុនជាកន្លែងដែលមានទីទួលខ្ពស់ជាងគេនៅកូសែន ។

៩ក៏មានរទេះ[ត]និងពួកជិះសេះដង្ហែរជូនគាត់ទៅ ជាហ្វូង
មនុស្សដ៏ច្រើនក្រៃលែង ១០គេទៅដល់លានស្រូវ[ថ]របស់
អ័ថាត់ដែលនៅ ខាងនាយទន្លេយ័រដាន់ នៅទីនោះគេទួញ
ទំនួញជាខ្លាំង[ទ] ហើយយ៉ូសែបក៏កាន់ទុក្ខ[ធ]និងឪពុក[ន]អស់៧
ថ្ងៃ[ប] ១១កាលពួកអ្នកស្រុកនោះ គឺពួកសាសន៍កាណាន[ផ] បាន
ឃើញគេកាន់ទុក្ខនៅត្រង់លានស្រូវអ័ថាត់ដូច្នោះ នោះគេ
និយាយថា នេះជាការកាន់ទុក្ខយ៉ាងខ្លាំងណាស់របស់ពួក
សាសន៍អេស៊ីព្ទ[ព]បានជាគេហៅទីនោះថា អេបិល–មីសរ៉ែម
ដែលនៅខាងនាយទន្លេយ័រដាន់ ១២ពួកកូនចៅយ៉ាកុបក៏
ធ្វើសំរេចដល់គាត់ ដូចជាគាត់បានផ្តាំទុក[ភ] ១៣គឺពួកកូនចៅ
បានដឹកសពគាត់ ទៅដល់ស្រុកកាណាន ហើយបញ្ចុះនៅ
ក្នុងរអាងនាចំការម៉ាក់ពេឡា[ម] ខាងមុខម៉ាមរេ[យ] ដែល
អ័ប្រាហាំបានទិញពីអេប្រុនជាសាសន៍ហេត[រ] ជាមួយនឹង
ចំការនោះ ទុកជាទីកប់ខ្មោចរបស់ផងគាត់[ល] ១៤រួចក្រោយ
ដែលបានបញ្ចុះសពឪពុកហើយ នោះយ៉ូសែបត្រឡប់ទៅ
ឯស្រុកអេស៊ីព្ទវិញ ព្រមទាំងពួកបងប្អូននឹងអស់អ្នកដែល
បានឡើងទៅជាមួយ ដើម្បីនឹង បញ្ចុះសពឪពុកគាត់ផង[វ]។

## លោកយ៉ូសែបធ្វើការបញ្ជាក់ម្តងទៀតដល់ពួកបងប្អូន

១៥កាលពួកបងរបស់យ៉ូសែបឃើញថា ឪពុកបានស្លាប់
ហើយ នោះគេជំនុំគ្នាថា ប្រហែលជាយ៉ូសែបនឹងស្អប់យើង
ហើយ[ស]មុខជាវានឹងសងសឹកចំពោះយើងជាមិនខាន ដោយ
ព្រោះគ្រប់ទាំងការអាក្រក់ដែលយើងបានធ្វើដល់វា[ហ] ១៦រួច
គេចាត់ម្នាក់ឱ្យទៅនិយាយនឹងយ៉ូសែបថា ឪពុកប្អូនបានផ្តាំ
ទុក[ឡ]មុនដែលគាត់ស្លាប់ថា ១៧ចូរឯងរាល់គ្នានិយាយនឹង
យ៉ូសែបដូច្នេះថា សូមអត់ទោសសេចក្តីរំលងនឹងអំពើបាប
របស់ពួកបងឥឡូវ[អ] ដ្បិតគេបានប្រព្រឹត្តអាក្រក់នឹងប្អូនទៅ
ហើយ[ក] ដូច្នេះសូមអត់ទោសពួកអ្នកបំរើរបស់ព្រះនៃឪពុក
ប្អូនឥឡូវ[ខ] កាលយ៉ូសែបបានឮសេចក្តីដែលគេនិយាយនោះ
ក៏យំ[គ] ១៨ហើយពួកបងគាត់ក៏ទៅទំលាក់ខ្លួនក្រាបចុះនៅ
ចំពោះមុខគាត់ដែរ[ឃ] ដោយពាក្យថា មើលយើងខ្ញុំជាអ្នក
បំរើប្អូន[ង] ១៩នោះយ៉ូសែបឆ្លើយតបថា កុំឱ្យខ្លាចឡើយដ្បិត
តើខ្ញុំជាព្រះឬអី[ច] ២០អ្នករាល់គ្នាបានគិតធ្វើអាក្រក់ដល់ខ្ញុំ[ឆ]
តែព្រះទ្រង់សំរេច[ជ]ជាកាល្អវិញ[ឈ] ដើម្បីនឹងសង្គ្រោះដល់
ជីវិតនៃមនុស្សជាច្រើន ដូចជាបានកើតមានសព្វថ្ងៃនេះ[ញ]
២១ដូច្នេះ កុំឱ្យខ្លាចឡើយ ខ្ញុំនឹងចិញ្ចឹមអ្នករាល់គ្នា ហើយនិង
កូនចៅរបស់អ្នករាល់គ្នាដែរ[ដ] គាត់ក៏កំសាន្ត ចិត្តគេហើយ
និយាយស្រទន់[ឋ]នឹងគេ ។

## ការស្លាប់របស់លោកយ៉ូសែប

២២ឯយ៉ូសែបនឹងពួកគ្រួឪពុកគាត់ទាំងប៉ុន្មាន ក៏នៅក្នុង
ស្រុកអេស៊ីព្ទតទៅ យ៉ូសែបគាត់រស់នៅបានអាយុ១១០ឆ្នាំ[ឌ]
២៣គាត់ឃើញកូនចៅ[ឍ]របស់អេប្រាអិម[ណ]ដល់៣ដំណ[ត] ឯកូន

**៥០:៩** ត លប ៤១:៤៣ **៥០:១០** ថ ជន ១៥:២០ នរ ៣:២ ២សយ ២៤:១៨ ១ពវ ២២:១០ ទ ២សយ ១:១៧ ៣:៣៣ ២របា ៣៥:២៥ អគ៣២:១៦ កច ៨:២ ធ លប៣៧:៣៤ ន លប ២៧:៤១ លវ ១០:៦ ប ១សយ ៣១:១៣ យប ២:១៣ អគ ៣:១៥ **៥០:១១** ផ លប ១០:១៨ ព លប ៣៧:៣៤ **៥០:១២** ភ លប ៤៩:២៩ **៥០:១៣** ម លប ២៣:៩ យ លប ១៣:១៨ រ លប ២៥:៩ ល លប ២៣:២០ **៥០:១៤** វ ខ.៨ **៥០:១៥** ស លប ២៧:៤១ ហ ខ.១៧ លប ៩:៥ ៣៧:២៨ សផ ៣:១១ ១ពត ៣:៩

**៥០:១៦** ឡ លប ៤៩:២៩ **៥០:១៧** អ មថ ៦:១៤ ក ខ.១៥ ខ លប ២៨:១៣ គ លប ២៩:១១ **៥០:១៨** ឃ លប ៣៧:៧ ង លប ៤៣:១៨ **៥០:១៩** ច លប ៣០:២ នក ៣២:៣៤ រម ១២:១៩ ហព ១០:៣០ **៥០:២០** ឆ លប ៣៧:២០ **៥០:២០** ជ អស ១០:៧ មីក ៤:១១–១២ ឈ រម ៨:២៨ ញ លប ៤៥:៥ នអ ៤:១៤ **៥០:២១** ដ លប ៤៥:១១ ឋ លប ៣៤:៣ អភ ៤:៣២ **៥០:២២** ឌ លប ២៥:៧ យស ២៤:២៩ **៥០:២៣** ឍ លប ៤៨:១១ ណ លប ៤១:៥២ ត យប

**៥០:១០** *លានស្រូវ* ជានិច្ចកាល ធញ្ញជាតិ គេតែងតែបែនវានៅកន្លែងទំនាបរាបស្មើ ។ លានស្រូវនេះ គឺគេបានសាងឡើងនៅកន្លែងដែលធំហើយមានខ្យល់ ដែលជានិច្ចកាលពួកអ៊ីស្រាអែលគេបានសង់វានៅក្បែរទ្វារក្រុង (សូមមើល ១ពវ ២២:១០) ។ សូមមើល នរ ១:២២ ។

**៥០:១៥** *គេជំនុំគ្នាថា . . . វានឹងសងសឹកចំពោះយើងមិនខាន* ពីមុនលោកអេសាវមានគម្រោងការណ៍ ដើម្បីនឹងសម្លាប់យ៉ាកុបចេញដោយព្រោះតែយ៉ាកុបបានប្រព្រឹត្តអាក្រក់ជាមួយគាត់ បន្ទាប់ពីលោកអ៊ីសាកបានស្លាប់ទៅ (២៧:៤១–៤៥) ។

**៥០:១៧** *កាលយ៉ូសែប . . . នោះក៏យំ* សូមមើល ៤៣:៣០ ។ លោកយ៉ូសែបប្រហែលជាគាត់ធ្លាប់ជួបទុក្ខព្រួយ ដោយសារគាត់បានគិតថា បងប្អូនរបស់គាត់អាចនិងប្រឌិតរឿងរបស់គាត់ ហើយនិយាយប្រាប់ដល់ឪពុករបស់គាត់ ។ ម្យ៉ាងទៀតប្រហែលជាគាត់សោកស្តាយចំពោះការគិតរបស់ពួកគេ លឿនជាងការអត់ទោសដែលគាត់បានអត់ទោសឱ្យគេហើយនោះឡើយ ។

**៥០:១៨** *ហើយពួកបងគាត់ក៏ទៅទំលាក់ខ្លួនក្រាបនៅចំពោះមុខគាត់ដែរ* គឺជាសេចក្តីសម្រេចចុងក្រោយដែលគាត់បានយល់សប្តិឃើញ កាលពីគ្រាមុន (មើល ៣៧:៧,៩) ។ *យើងខ្ញុំជាអ្នកបំរើប្អូន* ពីមុនពួកគេបាននិយាយបែបនេះដែរ តែស្ថិតក្នុងស្ថានការណ៍មិនដូចគ្នាឡើយ (៤៤:៩,៣៣) ។

**៥០:១៩** *ដ្បិតអញជាព្រះឬអី* សូមមើល ៣០:២ ។

**៥០:២០** *ព្រះទ្រង់សំរេចការល្អវិញ* ទង្វើររបស់ពួកគេដែលបានប្រព្រឹត្តលើលោកយ៉ូសែបជាប្អូន គឺព្រះទ្រង់ជាអ្នកបណ្តាលឱ្យមានការនោះកើតមាន ហើយព្រះអង្គទ្រង់ក៏បានរៀបផែនការណ៍ដើម្បីសង្គ្រោះជីវិតគាត់ ក៏ដូចជាជីវិតពួកកូនចៅអ៊ីស្រាអែលទាំងមូល ហើយនឹងប្រជាជនអេស៊ីព្ទ នឹងមនុស្សទូរទាំងនគរ ដែលបានមកទិញស្បៀងនៅស្រុកអេស៊ីព្ទ ក្នុងអំឡុងពេលមានគ្រោះអំណត់អត់ជាខ្លាំង ។ នៅពេលនោះផងដែរ ព្រះយេហូវ៉ាទ្រង់បានបង្ហាញដល់ប្រជាជាតិទាំងឡាយអំពីគោលបំណងរបស់ទ្រង់ថា ជីវិតនឹងការរស់នៅគឺសំខាន់ណាស់ចំពោះព្រះ ហើយព្រះទ្រង់នឹងបង្ហាញដំណោះស្រាយតាមរយៈកូនចៅលោកអ័ប្រាហាំ ។

**៥០:២៣** *គាត់ឃើញកូនចៅរបស់អេប្រាអិមដល់៣តំណ* សូមធ្វើការប្រៀបធៀបជាមួយ និងបទពិសោធន៍របស់លោកយ៉ូប (យប ៤២:១៦) ។ *ម៉ាគារ* ជាកូនច្បងរបស់ម៉ានាសេ នឹងជាឪពុករបស់កាឡាត (យស ១៧:១) ។ នៅសម័យក្រោយមកទៀត ម៉ាគារគាត់បានធ្វើឱ្យអំបូរម៉ានាសេ បានផ្លាស់ប្រែស្ទើរតែទាំងអស់(មើល ពច ៥:១៤) ។ *នោះគាត់ក៏បានកាន់ដាក់នៅលើភ្លៅដែរ* ប្រហែលជាលោកយ៉ូសែបបានចិញ្ចឹមកូនរបស់ម៉ាគារ (សូមមើល ៣០:៣០) ។

ចៅម៉ាគារ[ថ]ជាកូនម៉ានាសេ[ទ] នោះគាត់ក៏បានកាន់ដាក់
នៅលើភ្លៅដែរ[ធ] ។
២៤រួចគាត់និយាយទៅបងប្អូនថា ខ្ញុំហៀបនឹងស្លាប់
ហើយ[ន] តែព្រះទ្រង់នឹងប្រោសអ្នករាល់គ្នាជាមិនខាន[ប]
ហើយនិងនាំអ្នករាល់គ្នាឡើងចេញពីស្រុកអេស៊ីព្ទនេះ ទៅ
ក្នុង[ផ]ដែលទ្រង់បានស្បថថា និងឱ្យដល់អ័ប្រាហាំ[ព] អ៊ីសាក[ភ]
និងយ៉ាកុប[ម] ២៥យ៉ូសែបក៏ឱ្យពួកកូនចៅអ៊ីស្រាអែលស្បថ[យ]
ដោយផ្ដាំថា ព្រះទ្រង់នឹងប្រោសអ្នករាល់គ្នាជាមិនខាន
នោះអ្នករាល់ គ្នាត្រូវយកឆ្អឹងខ្ញុំ[រ]ចេញពីនេះឡើងទៅជា
មួយផង[ល] ២៦យ៉ូសែបគាត់ក៏ស្លាប់ទៅ[វ]អាយុគាត់បាន១១០
ឆ្នាំ[ស] ហើយគេដាក់បារទសពគាត់[ហ]រួចដាក់ចុះក្នុងមឈូស
នៅស្រុកអេស៊ីព្ទ ។

៤២:១៦ ថ ជន២៦:២៩ ២៧:១ ៣២:៣៩, ៤០ ៣៦:១ ចទ ៣:១៥ យស ១៣:៣១ ១៧:១ ពច ៥:១៤ ទ លប ៤១:៥១ ធ លប ៤៨:១២ **៥០:២៤** ន ខ.៥ ប នរ ១:៦ ទដ

៣៥:២ ១០៦:៤ អស ៣៨:១៤ ផ លប ១៥:១៤ ព លប ១៣:១៧ ភ លប ១៧:១៩ ម លប ១២:៧ ១៥:១៦ **៥០:២៥** យ លប ២៤:៣៧ រ លប ៤៩:២៩ ល លប ៤៧:២៩–៣០ ហព ១១:២២ **៥០:២៦** វ នក ១:៦ ស លប ២៥:៧ ហ ខ.២

**៥០:២៤** *បងប្អូន* ពាក្យដែលលោកយ៉ូសែបបានប្រើនៅកន្លែងនេះ ប្រហែលជាពាក្យពេញដោយការគោរពជាជាងប្រើអារម្មណ៍បងប្អូន ។ *ខ្ញុំហៀបនឹងស្លាប់ហើយ* សូមមើល ៤៨:២១ ។ *តែព្រះ . . . ចេញពីស្រុកអេស៊ីព្ទនេះ* លោកយ៉ូសែបគាត់មិនបានភ្លេចសេចក្ដីសន្យារបស់ព្រះឡើយ (ប្រៀបធៀប ១៥:១៦ ៤៦:៤ ៤៨:២១) ដែលបានប្រាប់ពីទំនាក់ទំនងទៅនឹង "ការចាកចេញ" (សូមមើល ហព ១១:២២) ។

**៥០:២៥** សូមមើល ៤៧:២៩–៣១ ដែលនិយាយពីសំណូមពររបស់លោកយ៉ាកុបមានការស្រដៀងគ្នានិងសំណូមពររបស់លោកយ៉ូសែបដែរ ។ *នោះអ្នករាល់គ្នាត្រូវយកឆ្អឹងខ្ញុំចេញពីនេះឡើងទៅជាមួយផង* នៅសតវត្សរ៍ក្រោយមកទៀតលោកម៉ូសេគាត់បានបំពេញសេចក្ដីសម្បថរបស់ពួកព្ធយុកោគាត់ (នក ១៣:១៩) ។ ឆ្អឹងរបស់លោកយ៉ូសែប គឺស្ថិតនៅក្នុងការផ្សងព្រេង "គេក៏ឈប់នៅត្រង់ស៊ីគែម . . . ពីពួកកូនចៅហាម៉ោរ" (យស ២៤:៣២ លក ៣៣:១៩) ។

**៥០:២៦** *យ៉ូសែបគាត់ក៏ស្លាប់ទៅ អាយុគាត់បាន១១០ឆ្នាំ* សូមមើលខ.២២ ។ ពួកព្ធយុកោអេស៊ីព្ទគេតែងតែគិតថា កាលណាអ្នកណាម្នាក់មានអាយុ ១១០ ឆ្នាំ អ្នកនោះគឺបានរស់នៅយ៉ាងពេញលេញនៃអាយុមនុស្ស ហើយប្រជាជនគេគិតថា វាជាព្រះពររបស់ព្រះប្រទានដល់លោកយ៉ូសែប ក្នុងចំណោមមនុស្សផ្សេងៗទៀត ។

# និក្ខមនំ

## សេចក្តីផ្តើម

### ចំណងជើង

គេបានបកប្រែពាក្យ "និក្ខមនំ" ពីពាក្យជាភាសាឡាតាំង អានថា "អ៊ែក្សូដឹស" (Exodus) ដែលមានប្រភពដើមពីពាក្យជាភាសាក្រិក អានថា "អ៊ែក្សូដូស" *Exodos* ជាចំណងជើងដែលត្រូវបានដាក់ឱ្យដោយអ្នកបកប្រែព្រះគម្ពីរនេះដំបូងជាភាសាក្រិក ។ ចំណងជើងនោះមានន័យថា "ការចេញក្រៅ" ឬ "ការចាកចេញដំណើរ" (សូមមើល លក ៩:៣១ ហព ១១:២២) ។ សម័យក្រោយមកទៀត ចំណងជើងនៃព្រះគម្ពីរនេះត្រូវបានដាក់តាមលំនាំដូចនេះ ដោយអ្នកបកប្រែព្រះគម្ពីរទៅជាភាសាឡាតាំង អ្នកនិពន្ធសាសន៍យូដាឈ្មោះភីឡូ "Philo" (នៅសម័យព្រះយេស៊ូវគ្រីស្ទ) និងការបកប្រែព្រះគម្ពីរជាភាសាស៊ីរី ។ ក្នុងព្រះគម្ពីរជាភាសាហេព្រើរ គេបានដាក់ឈ្មោះកណ្ឌគម្ពីរនេះ ដោយយោងទៅលើពាក្យចំនួនពីរ ដែលសរសេរនៅខាងដើមនៃព្រះគម្ពីរនេះ ដែលអានថា "វេអេលេហ សេម៉ូត" (We´elleh shemoth ប្រែថា "នេះជាបញ្ជីឈ្មោះ") ។ ពាក្យនេះក៏មានសរសេរនៅក្នុងព្រះគម្ពីរ លប ៤៦:៨ ផងដែរ ដូចនៅក្នុងព្រះគម្ពីរនេះផងដែរ គឺនិយាយអំពីបញ្ជីឈ្មោះនៃអ្នក "ដែលបានទៅឯស្រុកអេស៊ីព្ទជាមួយលោកយ៉ាកុប" (១:១) ។ ដូចនេះអ្នកនិពន្ធមិនមានបំណងធ្វើឱ្យព្រះគម្ពីរនិក្ខមនំ មានលក្ខណៈដាច់ពីកណ្ឌព្រះគម្ពីរផ្សេងទៀតនោះឡើង គឺបានបន្តការពិពណ៌នាមួយដែលបានចាប់ផ្តើមនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ហើយបញ្ចប់នៅក្នុងព្រះគម្ពីរលេវីវិន័យ ជនគណនា និងចោទិយកថា ។ កណ្ឌគម្ពីរទាំងប្រាំដំបូងរួមបញ្ចូលគ្នា ហៅថា ព្រះគម្ពីរបញ្ចកណ្ឌ (មើលសេចក្តីផ្តើមលោកុប្បត្តិ ត្រង់ចំណុច អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

មានខគម្ពីរមួយចំនួននៅក្នុងកណ្ឌគម្ពីរនិក្ខមនំដែលបញ្ជាក់ថា លោកម៉ូសេបានសរសេរវគ្គមួយចំនួនក្នុងព្រះគម្ពីរនេះ (សូមមើល ១៧:១៤ ២៤:៤ ៣៤:២៧) ។ ម្យ៉ាងទៀត បទគម្ពីរ យស ៨:៣១ បាននិយាយអំពីព្រះគម្ពីរក្រឹត្យវិន័យរបស់លោកម៉ូសេ ដោយក្រឹត្យវិន័យសំដៅទៅលើបទគម្ពីរ នក ២០:២៥ ។ ព្រះគម្ពីរសញ្ញាថ្មីក៏បាននិយាយអំពីការនិពន្ធរបស់លោកម៉ូសេ នូវវគ្គមួយចំនួននៅក្នុងគម្ពីរនិក្ខមនំផងដែរ (មើលឧទាហរណ៍ក្នុង មក ៧:១០ ១២:២៦ និង លក ២:២២-២៣) ។ សរុបមក គេអាចសន្និដ្ឋានថា លោកម៉ូសេមានការទទួលខុសត្រូវមួយផ្នែកធំនៅក្នុងការនិពន្ធព្រះគម្ពីរនិក្ខមនំ ហើយប្រពៃណីដែលប្រកាន់យកទស្សនៈដូចនេះ គឺមានលក្ខណៈត្រឹមត្រូវជាងការអះអាងថា ព្រះគម្ពីរបញ្ចកណ្ឌមានបង្កប់នូវប្រភពបួន (មើលសេចក្តីផ្តើមគម្ពីរលោកុប្បត្តិ ត្រង់ចំណុចអ្នកនិពន្ធ និងកាលបរិច្ឆេទ) ។

### ពង្សាវតា

យោងទៅតាម ១ពវ ៦:១ (មើលការពន្យល់ខនេះ) បើរាប់ចាប់ពីការធ្វើនិក្ខមនំ ឬដំណើរចាកចេញពីស្រុកអេស៊ីព្ទ រហូតដល់ "ឆ្នាំទីបួននៃរាជ្យរបស់ស្តេចសាឡូម៉ូនលើនគរអ៊ីស្រាអែល" គឺមានរយៈពេល ៤៨០ឆ្នាំ ។ ដោយសារឆ្នាំទីបួននៃរាជ្យស្តេចសាឡូម៉ូនប្រហែលជាត្រូវនឹងឆ្នាំ ៩៦៦ មុន គ.ស នោះគេជឿថា ការធ្វើនិក្ខមនំ ប្រហែលជាប្រព្រឹត្តទៅនៅឆ្នាំ ១៤៤៦ មុនគ.ស ។ ការនិយាយអំពីរយៈពេល ៣០០ ឆ្នាំ ក្នុង ពច ១១:២៦ គឺសមស្របនឹងការកំណត់រយៈពេលខាងលើនេះ (មើលសេចក្តីផ្តើមព្រះគម្ពីរពួកចៅហ្វាយ ត្រង់ចំណុច ប្រវត្តិដើម) ។ ម្យ៉ាងទៀត ទោះបីជាគេមិនទាន់ដឹងច្បាស់អំពី រាជ្យវង្សទី១៨ នៃពង្សាវតានៃនគរអេស៊ីព្ទក៏ដោយ ក៏ការស្រាវជ្រាវថ្មីៗច្រើនតែគាំទ្រទស្សនៈដែលថា ស្តេចទាំងពីរអង្គនៃរាជ្យវង្សផារោន ដែលមានស្តេចធូតម៉ូសទី ៣ (Thutmose III) និងអ័ម៉ាន់ហូទិបទី ២ (Amunhotep II) គឺសុទ្ធតែជាស្តេចផារ៉ោន ដ៏មហាជិះជាន់ និងនៃការធ្វើនិក្ខមនំ (មើលការពន្យល់ ២:១៥,២៣ ៣:១០) ។

ម្យ៉ាងទៀត ការនិយាយអំពីឈ្មោះក្រុងរ៉ាមសេសក្នុង ១:១១ ក៏បាននាំឱ្យមនុស្សជាច្រើនសន្និដ្ឋានថា ពួកស្តេចផារ៉ោននៃរាជ្យវង្សទី១៨ ដែលមានស្តេចសេទី ទី១ (Seti I) និងបុត្រាស្តេចនេះ គឺរ៉ាមសេស ទី២ (Ramese II) គឺសុទ្ធតែជាស្តេចផារ៉ោន ដ៏មហាជិះជាន់ និងនៃការធ្វើនិក្ខមនំផងដែរ ។ ជាងនេះទៅទៀត កំណាយនៃបុរាណវិជ្ជាបានផ្តល់ភស្តុតាងនៃការបំផ្លាញទីក្រុងមួយចំនួន នៅតំបន់កាណាន នៅក្នុង សតវត្សទី១៣ មុនគ.ស ហើយគេបានកាត់ស្រាយថា នោះជាភស្តុតាង នៃការចូលវាយលុកដណ្តើមយកទឹកដី សន្យាដោយកងទ័ព ដែលដឹកនាំដោយលោកយ៉ូស្វេ នាសតវត្សរ៍នោះ ។ ដោយយោងទៅលើការពិភាក្សាខាងលើនេះ ក៏ដូចជាការពិភាក្សាដែលស្រដៀងគ្នាផ្សេងទៀត នោះគេអាចកំណត់បានថា ការធ្វើនិក្ខមនំ គឺប្រព្រឹត្តទៅប្រហែលជានៅ ឆ្នាំ ១២៩០ មុនគ.ស (មើលសេចក្តីផ្តើមព្រះគម្ពីរយ៉ូស្វេ ត្រង់ចំណុច ការកំណត់កាលប្រវត្តិសាស្ត្រ) ។

គេមិនទាន់អាចបញ្ជាក់ច្បាស់អំពីអត្តសញ្ញាណ នៃពួកចូលវាយលុកទីក្រុងទាំងនោះនៅឡើយទេ ។ ការចូលវាយលុកទាំងនោះប្រហែលជាទង្វើរបស់កងទ័ពអ៊ីស្រាអែល នៅសម័យក្រោយៗ ឬដោយពួកភីលីស្ទីន ឬក៏ពួកសាសន៍ផ្សេងទៀតដែលរស់នៅក្រៅតំបន់កាណាន ។ ម្យ៉ាងទៀត ភស្តុតាងដែលបានពីកំណាយបុរាណវត្ថុវិទ្យា មិនមានភាពច្បាស់លាស់នៅឡើយ ហើយការធ្វើកំណាយថ្មីៗនេះគឺច្រើនតែដើម្បីកំណត់ឡើងវិញនូវកាលបរិច្ឆេទនៃការចូលវាយលុកទាំងនោះថា នៅក្នុងរាជវង្សទី១៨ នៃនគរអេស៊ីព្ទ ។ ការនិយាយអំពីឈ្មោះរ៉ាមសេស នៅក្នុង ១:១១ អាចបង្ហាញថា ព្រះគម្ពីរនិក្ខមនំមានការរួមចំណែកនៅក្នុងការនិពន្ធ ដោយអ្នកនិពន្ធម្នាក់ទៀត ដែលបានរស់នៅក្រោយសម័យលោកម៉ូសេ ជាច្រើនរយឆ្នាំ ហើយដោយសម្អាងទៅលើការប្រើពាក្យ រ៉ាមសេស នៅក្នុង លប ៤៧:១១ នោះការរួមចំណែកនៅក្នុងការនិពន្ធ ក៏បានកើតមាននៅក្នុងការនិពន្ធព្រះគម្ពីរលោកុប្បត្តិផងដែរ ។

សរុបសេចក្តីមក មិនមានហេតុផលណាមួយដែលអាចកែប្រែ ការកំណត់យក ឆ្នាំ ១៤៤៦ មុនគ.ស ជាឆ្នាំនៃការធ្វើនិក្ខមនំនៃរាស្ត្រអ៊ីស្រាអែល ពីចំណងទាសភាពនៃពួកសាសន៍អេស៊ីព្ទឡើយ ។

**ផ្លូវនៃការធ្វើនិក្ខមនំ**

យ៉ាងហោចណាស់មានការសន្និដ្ឋានបីផ្សេងៗពីគ្នា អំពីផ្លូវនៃការធ្វើនិក្ខមនំរបស់ពួកអ៊ីស្រាអែល ពីក្រុងពីថំ និងក្រុងរ៉ាមសេស (១:១១)។ (១).ផ្លូវនៃតំបន់ខាងជើងដែលកាត់តាមទឹកដីសាសន៍ភីលីស្ទីន (មើល ១៣:១៧) (២).ផ្លូវតំបន់កណ្តាល ដែលឆ្ពោះទៅទិសខាងកើត ហើយឆ្លងកាត់ភ្នំស៊ីណាយទៅឯតំបន់បៀរសេបា ហើយ(៣).គឺជាផ្លូវនៃតំបន់ខាងត្បូងនៅតាមបណ្តោយឆ្នេរសមុទ្រនៃឧបទ្វីបស៊ីណាយ ទៅកាន់ចុងបំផុតនៃភាគអាគ្នេយ៍នៃឧបទ្វីបនោះ ។ ផ្លូវនៃតំបន់ខាងត្បូងគឺមានលក្ខណៈទំនងជាងគេ ព្រោះពួកអ៊ីស្រាអែលបានធ្វើនិក្ខមនំ កាត់តាមតំបន់មួយចំនួនដែលមាននៅតាមផ្លូវនៃតំបន់ខាងត្បូងនោះ ។ តែទោះជាយ៉ាងណាក៏ដោយ គេមិនទាន់អាចកំណត់ទីកន្លែងពិតប្រាកដ ដែលពួកអ៊ីស្រាអែលបានឆ្លងកាត់ "សមុទ្រក្រហម" នៅឡើយទេ (មើលការពន្យល់ ១៣:១៨ ១៤:២)។

**ផ្ទៃរឿង និងវិជ្ជាសិក្សាអំពីព្រះ**

ព្រះគម្ពីរនិក្ខមនំផ្តល់ជាមូលដ្ឋានគ្រឹះផ្នែកខាងវិជ្ជាសិក្សាអំពីព្រះ ដោយនិយាយអំពីការបើកសម្តែងរបស់ព្រះអម្ចាស់ នូវព្រះនាមទ្រង់ លក្ខណៈរបស់ទ្រង់ ការប្រោសលោះរបស់ទ្រង់ ក្រឹត្យវិន័យរបស់ទ្រង់ និងរបៀបដែលត្រូវថ្វាយបង្គំទ្រង់ ។ ព្រះគម្ពីរនេះបានកត់ត្រាអំពីការដែលព្រះបានរើសតាំងលោកម៉ូសេ និងការងារជាបុគ្គលកណ្តាលរបស់លោកម៉ូសេ នៅក្នុងការតាំងសេចក្តីសញ្ញានៅភ្នំស៊ីណាយ និងបានពណ៌នាអំពីការចាប់ផ្តើមនូវការងារពួកសង្ឃនៃពួកអ៊ីស្រាអែល ហើយបកស្រាយអត្ថន័យរបស់តួនាទីនៃពួកហោរា ហើយនិងនិយាយភ្ជាប់អំពីទំនាក់ទំនងដែលមានការតាំងសញ្ញារវាងព្រះអម្ចាស់ និងរាស្ត្ររបស់ទ្រង់តាំងពីរយូរលុងមកហើយ (មើលការពន្យល់ លប ១៧:២) ព្រមទាំងបានប្រាប់អំពីរបៀបដែលទំនាក់ទំនងនោះ មានការតាំងសញ្ញាថ្មីមួយទៀត(គឺសេចក្តីសញ្ញាដែលទ្រង់ប្រទាននៅភ្នំស៊ីណាយ)។

គេអាចសិក្សាស៊ីជម្រៅអំពីលក្ខណៈរបស់ព្រះអម្ចាស់ នៅក្នុង ជំពូក ៣,៦,៣៣-៣៤ ។ បទគម្ពីរទាំងនោះនិយាយផ្តោតទៅលើសេចក្តីពិត និងភាពសំខាន់នៃព្រះវត្តមានដែលទ្រង់មានជាមួយនឹងរាស្ត្ររបស់ទ្រង់ ដូចដែលបានបញ្ជាក់ដោយ ព្រះនាម យ៉ាវេហ (Yahweh, មើលការពន្យល់ ៣:១៤-១៥) និងដោយសិរីល្អដែលទ្រង់បង្ហាញនៅក្នុងចំណោមពួកគេ ។ ប៉ុន្តែ បទគម្ពីរទាំងនោះក៏បាននិយាយផ្តោតផងដែរ ទៅលើលក្ខណៈរបស់ទ្រង់ដូចជា លក្ខណៈយុត្តិធម៌ ពិតត្រង់ មេត្តាករុណា ស្មោះត្រង់ និងបរិសុទ្ធ ។ ដូចនេះ ការស្គាល់ "ព្រះនាមទ្រង់" ក៏ដូចជាការស្គាល់អង្គទ្រង់ និងលក្ខណៈរបស់ទ្រង់ផងដែរ (មើល ៣:១៣-១៥ ៦:៣)។

ព្រះទ្រង់ក៏ជាម្ចាស់នៃប្រវត្តិសាស្ត្រផងដែរ ។ ព្រះទ្រង់បានគ្រប់គ្រងអ្វីៗទាំងអស់ដែលកើតឡើង នៅពេលដែលពួកអ៊ីស្រាអែលកំពុងរងទុក្ខវេទនា ហើយក្នុងពេលដែលសេចក្តីវេទនាទាំងដប់កើតឡើងដល់ពួកសាសន៍អេស៊ីព្ទ ។ ស្តេចផារ៉ោន ពួកសាសន៍អេស៊ីព្ទ និងពួកសាសន៍អ៊ីស្រាអែល សុទ្ធតែបានឃើញអំណាចចេស្តារបស់ព្រះអម្ចាស់ ។ គ្មានព្រះឯណាដូចទ្រង់ឡើយ គឺទ្រង់ "មានពេញដោយភាពបរិសុទ្ធ មានសិរីល្អយ៉ាងអស្ចារ្យ ហើយធ្វើការអស្ចារ្យយ៉ាងសម្បើម" (មើល ១៥:១១ និងការពន្យល់)។

យើងអាចមានទំនុកចិត្តលើទ្រង់ នៅពេលដែលយើងដឹងថា ព្រះអម្ចាស់ទ្រង់នឹកចាំ និងយកព្រះទ័យទុកដាក់ចំពោះរាស្ត្រទ្រង់ (មើល ២:២៤)។ ព្រះទ្រង់បានមានព្រះបន្ទូលសន្យា អស់ជាច្រើនសតវត្សរ៍ ជាមួយនឹងលោកអ័ប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប ហើយសេចក្តីសន្យានេះបានចាប់ផ្តើមមានលទ្ធផល នៅពេលដែលរាស្ត្រអ៊ីស្រាអែលបានរួចពីចំណងទាសភាពរបស់សាសន៍អេស៊ីព្ទ ហើយបានធ្វើដំណើរចាកចេញទៅកាន់ទឹកដីសន្យា ។ ទ្រង់បានបង្ហាញនូវការសម្រេចសេចក្តីសន្យានោះ មួយជំហានទៀត ដោយការតាំងសេចក្តីសញ្ញានៅភ្នំស៊ីណាយជាមួយនឹងរាស្ត្រអ៊ីស្រាអែល (មើល ៣:១៥-១៧ ៦:២-៨ ១៩:៣-៨) ។

ព្រះគម្ពីរនេះក៏បានចែកចាយនូវដំណឹងនៃសេចក្ដីសង្គ្រោះផងដែរ ។ ដោយឡែកគេឃើញពាក្យ "ប្រោសលោះ" ដែលមានថ្នាក់ពាក្យជាកិរិយាស័ព្ទ ត្រូវបានប្រើបទគម្ពីរ ៦:៦ ១៥:១៣ ។ ប៉ុន្តែ គេអាចធ្វើការសិក្សាសំខាន់ៗតាមវិជ្ជាសិក្សាអំពីព្រះ អំពីការប្រោសលោះតាមរយៈការពិពណ៌នាអំពីបុណ្យរំលងនៅក្នុងជំពូក ១២ ការបញ្ជាក់សេចក្ដីសញ្ញាក្នុងជំពូក ២៤ និងការតាំងសញ្ញាជាថ្មីឡើងវិញ របស់ព្រះអម្ចាស់ដោយព្រះគុណទ្រង់ បន្ទាប់ពីពួកអ៊ីស្រាអែលបានក្បត់សេចក្ដីសញ្ញា ដោយងាកទៅថ្វាយបង្គំរូបគោមាស(សូមមើល ៣៤:១-១៤ និងការពន្យល់)។ លោកសាវ័កប៉ុលបានបកស្រាយអំពីការស្លាប់របស់កូនចៀមនៅថ្ងៃបុណ្យរំលងថា ជានិមិត្រដែលរូបបានសម្រេចនៅក្នុងអង្គព្រះគ្រីស្ទ(១កថ ៥:៧)។ ជាការពិតណាស់ លោកយ៉ូហានបាទីស្ទ បានហៅព្រះយេស៊ូវគ្រីស្ទថាជា "កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក"(យហ ១:២៩) ។

គេអាចស្វែងរកមូលដ្ឋានគ្រឹះនៃក្រមសីលធម៌តាមព្រះគម្ពីរ ជាបឋម នៅក្នុងលក្ខណៈរបស់ព្រះអម្ចាស់ ដែលបានបង្ហាញនៅក្នុងព្រះគម្ពីរនិក្ខមនំ ហើយមួយទៀត នៅក្នុងក្រឹត្យវិន័យទាំងដប់ប្រការ(២០:១-១៧) និងសៀវភៅសញ្ញា(២០:២២-២៣:៣៣) ដែលបង្រៀនពួកអ៊ីស្រាអែលអំពីរបៀបអនុវត្តតាមក្រឹត្យវិន័យទាំងនោះ ។

ព្រះគម្ពីរនេះបានបញ្ចប់ ដោយនិយាយតាមវិជ្ជាសិក្សាអំពីព្រះ អំពីការថ្វាយបង្គំព្រះ។ ទោះបីជាពួកអ៊ីស្រាអែលត្រូវចំណាយពេល កិច្ចប្រឹងប្រែង និងប្រាក់កាសច្រើនក៏ដោយ ក៏អត្ថន័យនិងតួនាទីនៃរោងឧបោសថ គឺដើម្បីបង្ហាញអំពី "ព្រះហឫទ័យដែលព្រះទ្រង់មានសម្រាប់មនុស្សលោក" គឺ "ដើម្បីឱ្យពួកគេបានថ្វាយសិរីល្អដល់ទ្រង់ និងមានអំណរចំពោះទ្រង់ជារាងរហូត"។ តាមរយៈរោងឧបោសថនោះ ព្រះនៃសកលលោក ដ៏មានព្រះចេស្ដា មិនចេះប្រែប្រួល និងគ្មានអ្វីអាចប្រៀបផ្ទឹមបាន ទ្រង់យាងមក "គង់ជាមួយ" នឹងរាស្ត្ររបស់ទ្រង់ ព្រមទាំងប្រទាននូវការប្រកបស្និទ្ធស្នាលជាមួយនឹងពួកគេ ដោយព្រះគុណទ្រង់ផងដែរ ។ ព្រះអម្ចាស់ទ្រង់បានធ្វើឱ្យរាស្ត្រទ្រង់មានអំណាចឡើង ហើយរាស្ត្ររបស់ទ្រង់បានធ្វើឱ្យសាសន៍ជិតខាងបានឃើញអំពីអំណាចព្រះចេស្ដាទ្រង់ផងដែរ ។

ទោះជាយ៉ាងណាក៏ដោយ វិជ្ជាសិក្សាអំពីព្រះ គឺមិនគ្រាន់តែមាននៅក្នុងការពិពណ៌នានៃព្រះគម្ពីរនិក្ខមនំប៉ុណ្ណោះទេ ។ គេអាចស្វែងរកវិជ្ជាសិក្សាអំពីព្រះក្នុងព្រះគម្ពីរនេះបានកាន់តែច្រើនថែមទៀត នៅក្នុងសេចក្ដីពិតនៃការដែលព្រះអម្ចាស់ទ្រង់លើកអ្នកបម្រើទ្រង់ គឺលោកម៉ូសេឡើង (១).ដើម្បីឱ្យរំដោះរាស្ត្រទ្រង់ពីចំណងទាសភាពនៃសាសន៍អេស៊ីព្ទ (២).ដើម្បីចាប់ផ្ដើមតាំងនគររបស់ទ្រង់នៅលើលោកិយ ដោយប្រទានដល់ពួកគេនូវសេចក្ដីសញ្ញាដែលទ្រង់តាំងឡើងជាមួយនឹងពួកគេ ជាសាសន៍មួយទាំងមូល (៣).ដើម្បីស្អាងត្រសាលទ្រង់នៅក្នុងនគរអ៊ីស្រាអែល ។ ការប្រោសលោះពីចំណងនោះបាននាំឱ្យមានការញែកជាបរិសុទ្ធ ដោយការតាំងសញ្ញា និងស្អាងត្រសាលរបស់ទ្រង់នៅលើលោកិយ ដែលការទាំងនេះសុទ្ធតែបានធ្វើឡើងតាមរយៈបុគ្គលកណ្ដាមម្នាក់ដែលទ្រង់បានជ្រើសតាំង ហើយព្រះគម្ពីរដែលនិយាយអំពីការប្រោសលោះពីចំណងនេះ បានបើកបង្ហាញអំពីបំណងព្រះហឫទ័យដែលទ្រង់មាននៅក្នុងប្រវត្តិសាស្ត្រ ដែលបានសម្រេច តាមរយៈរាស្ត្រអ៊ីស្រាអែល ហើយនៅទីបញ្ចប់ គឺតាមរយៈអង្គព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ជាបុគ្គលកណ្ដាលដែលធំបំផុត ។

**គម្រោងសង្ខេប :**

I. បញ្ចកថា(ជំពូក ១-២)
- ក. រាស្ត្រអ៊ីស្រាអែលបានទទួលព្រះពរ និងការជិះជាន់(ជំពូក ១)
- ខ. ការរៀបចំឱ្យមានអ្នករំដោះ(ជំពូក ២)
  - ១. ទារកម៉ូសេបានរួចផុតពីសេចក្ដីស្លាប់(២:១-១០)
  - ២. លោកម៉ូសេ រត់គេចចេញពីស្រុកអេស៊ីព្ទ ពេលពេញវ័យ(២:១១-២៥)

II. ព្រះទ្រង់រំដោះរាស្ត្រអ៊ីស្រាអែល(ជំពូក ៣-១៨) ។
- ក. ការត្រាសហៅអ្នករំដោះ(ជំពូក ៣)
- ខ. អ្នករំដោះបដិសេធការត្រាសហៅ ការជម្នះការខ្វះលក្ខណៈសម្បត្តិ(ជំពូក ៤)
- គ. ការរំដោះដែលមិនបានសម្រេច(៥:១-៦:១២)
  - ១. ការគាបសង្កត់មានកាន់តែខ្លាំង(៥:១-២១) ។
  - ២. ព្រះបន្ទូលសន្យាម្ដងទៀតអំពីការសង្គ្រោះ(៥:២២-៦:១២) ។
- ឃ. ការស្គាល់អត្តសញ្ញាណអ្នករំដោះ(៦:១៣-២៧) ។
- ង. ការជំនុំជម្រះ ដោយទម្លាក់សេចក្ដីវេទនា មកលើស្រុកអេស៊ីព្ទ(៦:២៨-១១:១០)

១. អ្នករំដោះចាប់ផ្ដើមបេសកកម្មជាថ្មី (៦:២៨–៧:៧)
២. ការបង្ហាញពីទីសម្គាល់នៃអំណាចព្រះចេស្ដារបស់ព្រះ (៧:៨–១៣)
៣. សេចក្ដីវេទនាទីមួយ : ទឹកត្រឡប់ជាឈាម (៧:១៤–២៤)
៤. សេចក្ដីវេទនាទីពីរ : សត្វកង្កែបច្រើន (៧:២៥–៨:១៥)
៥. សេចក្ដីវេទនាទី៣ : ចៃជាច្រើន (៨:១៦–១៩)
៦. សេចក្ដីវេទនាទី៤ : រុយច្រើន (៨:២០–៣២)
៧. សេចក្ដីវេទនាទី៥ : ជម្ងឺដល់ហ្វូងសត្វ (៩:១–៧)
៨. សេចក្ដីវេទនាទី៦ : ដំបៅពីគុកភ្លើង (៩:៨–១២)
៩. សេចក្ដីវេទនាទី៧ : ការធ្លាក់ព្រឹល (៩:១៣–៣៥)
១០. សេចក្ដីវេទនាទី៨ : សត្វកណ្ដូប (១០:១–២០)
១១. សេចក្ដីវេទនាទី៩ : ងងឹតពេញនគរ (១០:២១–២៩)
១២. សេចក្ដីវេទនាទី១០ : ការសម្លាប់កូនប្រុសច្បងទាំងអស់ (ជំពូក ១១)

ច. ពិធីបុណ្យរំលង (១២:១–២៨)
ឆ. ការធ្វើនិក្ខមនំចេញពីស្រុកអេស៊ីព្ទ (១២:២៩–៥១)
ជ. ការញែកអស់ទាំងកូនច្បង (១៣:១–១៦)
ឈ. ការឆ្លងកាត់សមុទ្រ "ក្រហម" (១៣:១៧–១៥:២១)
១. ការសង្គ្រោះនៅឯ "សមុទ្រក្រហម" (១៣:១៧–១៤:៣១)
២. ទំនុកតម្កើងនៅឯ "សមុទ្រក្រហម" (១៥:១–២១)

ញ. ការធ្វើដំណើរទៅឯភ្នំស៊ីណាយ (១៥:២២–១៨:២៧)
១. ទឹកនៅម៉ារ៉ា (១៥:២២–២៧)
២. នំម៉ាន៉ា និងសត្វក្រួច (ជំពូក ១៦)
៣. ទឹកនៅមេរីបា (១៧:១–៧)
៤. ចម្បាំងជាមួយពួកសាសន៍អាម៉ាលេក (១៧:៨–១៦)
៥. រចនាសម្ព័ន្ធនៃការគ្រប់គ្រងជាមូលដ្ឋាន (ជំពូក ១៨)

III. សេចក្ដីសញ្ញានៅឯភ្នំស៊ីណាយ (ជំពូក ១៩–២៤)

ក. ការរៀបចំមុននឹងតាំងសេចក្ដីសញ្ញា (ជំពូក ១៩)
ខ. ក្រឹត្យវិន័យទាំងដប់ប្រការ (២០:១–១៧)
គ. ការភ័យខ្លាចរបស់ពួកបណ្ដាជនចំពោះព្រះវត្តមានរបស់ព្រះ (២០:១៨–២១)
ឃ. ក្រាំងនៃសេចក្ដីសញ្ញា (២០:២២–២៣:៣៣)
១. បុព្វកថា (២០:២២–២៦)
២. ក្រឹត្យវិន័យស្ដីពីបាវបម្រើ (២១:១–១១)
៣. ក្រឹត្យវិន័យស្ដីពីឃាដកម្ម (២១:១២–១៧)
៤. ក្រឹត្យវិន័យស្ដីពីការធ្វើឱ្យរបួសដល់រូបកាយ (២១:១៨–៣២)
៥. ក្រឹត្យវិន័យស្ដីពីការខូចខាតទ្រព្យសម្បត្តិ (២១:៣៣–២២:១៥)
៦. ក្រឹត្យវិន័យសង្គម (២២:១៦–៣១)
៧. ក្រឹត្យវិន័យស្ដីពីភាពយុត្តិធម៌ និងអ្នកប្រទេសក្រៅ (២៣:១–៩)
៨. ក្រឹត្យវិន័យស្ដីពីឆ្នាំឈប់សម្រាក (២៣:១០–១៩)
៩. សេចក្ដីបញ្ចប់ (២៣:២០–៣៣)

ង. ការយល់ព្រមទទួលសេចក្តីសញ្ញា (ជំពូក ២៤)

IV. ត្រសាលរបស់ព្រះក្នុងពួកសាសន៍អ៊ីស្រាអែល (ជំពូក ២៥–៤០)

ក. សេចក្តីបង្គាប់នៅក្នុងការរៀបចំត្រសាល (ជំពូក ២៥–៣១)

១. ការប្រមូលដង្វាយជាសម្ភារៈសម្រាប់រៀបចំត្រសាល (ជំពូក ២៥:១–៩)

២. ការលម្អរត្រសាល (២៥:១០–៤០)

ក. ហឹបសញ្ញា និងគម្របនៃទីសន្ដោសប្រោស (២៥:១០–២២)

ខ. តុតាំងនំបុ័ងនៅចំពោះព្រះវត្តមានទ្រង់ (២៥:២៣–៣០)

គ. ជើងចង្កៀងស្រោបដោយមាស (២៥:៣១–៤០)

៣. ត្រសាល និងទីលានជុំវិញត្រសាល (២៦:១–២៧:១៩)

ក. វាំងនន និងក្តា (ជំពូក ២៦)

ខ. អាសនាសម្រាប់ដង្វាយដុត (២៧:១–៨)

គ. ទីលាននៃរោងឧបោសថ (២៧:៩–១៩)

៤. ត្រសាលសម្រាប់ផ្ទាល់ខ្លួន (២៧:២០–២៩:៤៦)

ក. លក្ខណៈជាសង្ឃ (២៧:២០–២៨:៥)

ខ. សំលៀកបំពាក់របស់ពួកសង្ឃ (២៨:៦–៤៣)

គ. ក្រុមការងារនៃពួកសង្ឃ (ជំពូក ២៩)

៥. របៀបរៀបចំត្រសាលដែលនៅមានទៀត (ជំពូក ៣០)

ក. អាសនានៃគ្រឿងក្រអូប (៣០:១–១០)

ខ. ការយកពន្ធ ដោយធ្វើជំរឿនប្រជាជន (៣០:១១–១៦)

គ. ចានក្លាំធ្វើពីលង្ហិន (៣០:១៧–២១)

ឃ. ប្រេងសំម្រាប់ចាក់តាំង និងគ្រឿងក្រអូប (៣០:២២–៣៨)

៦. ការចាត់តាំងពួកជាង (៣១:១–១១)

៧. ការប្រារព្ធថ្ងៃឈប់សម្រាក (៣១:១២–១៨)

ឃ. ការបះបោរប្រឆាំងដែលនាំឱ្យព្រះអម្ចាស់ដកព្រះវត្តមានទ្រង់ពីពួកគេ (ជំពូក ៣២–៣៤)

១. រូបកូនគោមាស (៣២:១–២៩)

២. ការសម្រុះសម្រួលពីលោកម៉ូសេ (៣២:៣០–៣៥)

៣. ព្រះទ្រង់គម្រាមថា នឹងយាងចេញ និងការអធិស្ឋានរបស់លោកម៉ូសេ (ជំពូក ៣៣)

៤. ការភ្ជាប់សេចក្តីសញ្ញាឡើងវិញ (ជំពូក ៣៤)

ង. ការស្អាងត្រសាលនៃព្រះអម្ចាស់ (ជំពូក ៣៥–៤០)

១. ការប្រកាសឱ្យសាងសង់ (៣៥:១–១៩)

២. ដង្វាយស្ម័គ្រពីចិត្ត (៣៥:២០–២៩)

៣. លោកបេតសាលាល និងពួកជាងរបស់គាត់ (៣៥:៣០–៣៦:៧)

៤. ការចម្រើននៃការងារ (៣៦:៨–៣៩:៣១)

៥. ការឱ្យពររបស់លោកម៉ូសេ (៣៩:៣២–៤៣)

៦. ការសាងសង់ត្រសាលរបស់ព្រះអម្ចាស់ (៤០:១–៣៣)

៧. ការចាប់ផ្តើមដំណើរការនៃត្រសាលរបស់ព្រះ (៤០:៣៤–៣៨)

# ១

១ នេះជាបញ្ជីឈ្មោះនៃពួកកូនចៅអ៊ីស្រាអែល[ក] ដែល
ចូលមកក្នុងស្រុកអេស៊ីព្ទ ជាមួយនឹងយ៉ាកុប ព្រមទាំង
គ្រួសារគេរៀងខ្លួន ២គឺរូបេន១ ស៊ីម្មាន១ លេវី១ យូដា១
៣អ៊ីសាខារ១ សាប់យូឡូន១ បេនយ៉ាមីន១ ៤ដាន់១ ណែប
ថាលី១ កាឌ់១ និងអេស៊ើរ១[ខ] ៥ពួកអ្នកដែលកើតអំពីយ៉ាកុប
មកទាំងប៉ុន្មាន នោះមានចំនួន៧០នាក់[គ] ឯយ៉ូសែបលោក
បាននៅស្រុកអេស៊ីព្ទហើយ ៦យ៉ូសែបក៏ស្លាប់ទៅ ព្រមទាំង
បងប្អូនលោកទាំងអស់ និងអស់មនុស្សដំណនោះទាំងអស់
ដែរ[ឃ] ៧តែជនជាតិអ៊ីស្រាអែលគេបង្កើតកូនដុះដាលចំរើន
ជាច្រើនឡើង[ង] ក៏បានទៅជាស្តុកស្តម្ភឡើងសន្ធឹក ទាំងនៅ
កុះករពេញក្នុងស្រុកនោះ ។

៨នៅគ្រានោះ មានស្តេចថ្មី១អង្គសោយរាជ្យឡើង នៅ
ស្រុកអេស៊ីព្ទ ស្តេចនោះមិនបានស្គាល់យ៉ូសែបទេ[ច] ៩ទ្រង់
មានបន្ទូលទៅបណ្តារាស្ត្ររបស់ទ្រង់ថា មើល ពួកជនជាតិ
អ៊ីស្រាអែលគេមានគ្នាច្រើន[ឆ] ក៏ស្តុកស្តម្ភជាងពួកយើង
ហើយ[ជ] ១០ចូរយើងប្រព្រឹត្តនឹងគេដោយប្រាជ្ញា[ឈ] ក្រែង
គេចំរើនជាច្រើនឡើង ហើយបើកាលណាកើតមានចំបាំង
នោះគេនឹងចូលទៅខាងពួកខ្មាំងសត្រូវ ដើម្បីច្បាំងនឹង
យើងវិញ រួចចេញពីស្រុកបាត់ទៅ"[ញ] ១១ដូច្នេះគេក៏ដាក់ឱ្យ
មាននាយដំរួត[ដ] សំរាប់នឹងធ្វើទុក្ខដល់ពួកអ៊ីស្រាអែល
ដោយការនឿយលំបាកជាច្រើន[ឋ] ពួកអ៊ីស្រាអែលបាន
កសាងក្រុងពីថំ និងរ៉ាមសេស[ឌ] សំរាប់ជាឃ្លាំងថ្វាយ
ផារ៉ោន[ឍ] ១២ប៉ុន្តែដែលធ្វើទុក្ខគេប៉ុណ្ណា នោះគេក៏ចំរើន
ជាច្រើនទាំងសាយពេញពាសឡើងប៉ុណ្ណោះដែរ ហើយ
សាសន៍អេស៊ីព្ទមានសេចក្តីធុញទ្រាន់ ដោយព្រោះជនជាតិ
អ៊ីស្រាអែល ១៣ក៏ចាប់ប្រើគេឱ្យធ្វើការឱ្យតឹងរ៉ឹង[ណ] ១៤ព្រម
ទាំងធ្វើឱ្យជីវិត គេមានសេចក្តីជូរល្វីង ដោយការលំបាក
វេទនា[ត] គឺប្រើឱ្យធ្វើបាយអនឹងឥដ្ឋ[ថ] ព្រមទាំងការនៅចំការ
គ្រប់មុខផង ឯការដែលគេចាប់ប្រើឱ្យធ្វើទាំងប៉ុន្មាននោះ
សុទ្ធតែជាការយ៉ាងតឹងរ៉ឹងទាំងអស់[ទ] ។

១៥រួចស្តេចស្រុកអេស៊ីព្ទ ទ្រង់ក៏បង្គាប់ដល់ពួកឆ្មប

**១:១** ក លប ៤៦:៨
**១:៤** ខ លប ៣៥:២២ –២៦ ជន ១:២០–៤៣
**១:៥** គ លប ៤៦:២៦
**១:៦** ឃ លប ៥០:២៦ កច ៧:១៥
**១:៧** ង ខ.៩ លប ១២:២ ចទ ៧:១៣ អគ ១៦:៧
**១:៨** ច យរ ៤៣:១១ ៤៦:២
**១:៩** ឆ ខ.៧ ជ លប ២៦:១៦
**១:១០** ឈ លប ១៥:១៣ នក ៣:៧ ១៨:១១ ទដ ៦៤:២ ៧១:១០ ៨៣:៣ អស ៥៣:៣ ញ ទដ ១០៥:២៤–២៥ កច ៧:១៧–១៩
**១:១១** ដ នក ៣:៧ ៥:១០,១៣,១៤ ឋ លប ១៥:១៣ នក ២:១១ ៥:៤ ៦:៦–៧ យស ៩:២៧ ១ពវ ៩:២១ ១រប ២២:២ អស ៦០:១០ ឌ លប ៤៧:១១ ឍ ១ពវ ៩:១៩ ២រប ៨:៤
**១:១៣** ណ ខ.១៤ លប ១៥:១៣–១៤ នក ៥:២១ ១៦:៣ លវ ២៥:៤៣,៤៦, ៥៣ ចទ ៤:២០ ២៦:៦ ១ពវ ៨:៥១ ទដ ១២៩:១ អស ៣០:៦ ៤៨:១០ យរ ១១:៤ **១:១៤** ត ចទ ២៦:៦ អរ ៩:៩ អស ១៤:៣ ថ លប ១១:៣ ទ នក ២:២៣ ៣:៩ ជន ២០:១៥ ១សយ ១០:១៨ ២ពវ ១៣:៤ ទដ ៦៦:១១ ៨១:៦ កច ៧:១៩

**១:១–២:២៥** វគ្គនៃបទគម្ពីរនេះគឺជាបុព្វកថានៃព្រះគម្ពីរនិក្ខមនំ ។ ព្រះគម្ពីរនេះពិពណ៌នាអំពីព្រះពរ ដែលព្រះទ្រង់ប្រទានពរដល់សាសន៍អ៊ីស្រាអែល រហូតដល់ធ្វើឱ្យពួកគេក្លាយជាទីគម្រាមគំហែង ដល់ពួកសាសន៍អេស៊ីព្ទវិញ។ ការសង្កត់សង្កិនមានជាបន្តបន្ទាប់ តែព្រះទ្រង់បានលើកលោកម៉ូសេឡើង ជាអ្នកជួយរំដោះ ។ វគ្គនេះជាដំណាក់កាលនៃការចាប់ផ្តើមតទល់នឹងស្តេចផារ៉ោន និងដើម្បីរំដោះជនជាតិអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ ។

**១:១–៥** ខទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា ព្រះគម្ពីរនិក្ខមនំជាកណ្ឌគម្ពីរដែលសរសេរបន្តពីព្រះគម្ពីរលោកុប្បត្តិ។ មកដល់ចំណុចនេះ សាសន៍អ៊ីស្រាអែលបានរស់នៅក្នុងស្រុកអេស៊ីព្ទ អស់៤៣០ឆ្នាំហើយ (មើល ១២:៤០) ។

**១:១** *នេះជាបញ្ជីឈ្មោះ* គឺពាក្យនេះក៏មានប្រើផងដែរនៅក្នុងការរៀបរាប់នៅក្នុង លប ៤៨:៨ គឺនៅដើមបញ្ជីពូជរបស់លោកយ៉ាកុប ។ *អ៊ីស្រាអែល . . . យ៉ាកុប* ពាក្យថា យ៉ាកុបគឺឈ្មោះពីមុន តែក្រោយមកគាត់មានឈ្មោះថាអ៊ីស្រាអែលវិញ (លប ៣២:២៨ ៣៥:១០ និងការពន្យល់) ។

**១:២–៤** ពួកកូនប្រុសសរបស់នាងលេអា (ពីរូបេន ដល់សាប់យូឡូន) និងរបស់នាងរ៉ាជែល (មានបេនយ៉ាមីន ហើយឈ្មោះយ៉ូសែប គឺមិនបាននិយាយព្រោះបញ្ជីឈ្មោះនេះមានតែ "ឈ្មោះអ្នកដែលទៅស្រុកអេស៊ីព្ទជាមួយនឹងលោកយ៉ាកុបប៉ុណ្ណោះ"ខ.១) មានការរៀបតាមលំដាប់ចុះពីអ្នកនៅខ្ពស់បំផុតហើយនៅខាងមុខឈ្មោះពួកកូនប្រុសរបស់ស្រីបម្រើរបស់នាងរ៉ាជែល និងនាងលេអា ដែលក្នុងនោះនាងប៊ីលហា មានកូនប្រុសឈ្មោះដាន់ និងណែប–ថាលី ស៊ិលផាមានកូន ឈ្មោះកាឌ់ និងអេស៊ើរ (មើល លប ៣៥:២៣–២៦)

**១:៥** *៧០នាក់* មើលការពន្យល់ លប ៤៦:២៧ ។

**១:៦–៧** ចាប់ពីពេលលោកយ៉ូសែបបានស្លាប់ រហូតដល់មានស្តេចមួយអង្គទៀតគ្រងរាជ្យ (ខ.៨) គឺមានរយៈពេលជាង២០០ឆ្នាំ ។

**១:៧** ពាក្យពេចន៍ក្នុងខនេះ គឺដូចព្រះបន្ទូលជាព្រះពរ ដែលព្រះបានប្រទានដល់មនុស្សជាតិ គឺនៅពេលដែលព្រះបានបង្កើតពួកគេ (មើល លប ១:២៨ និងការពន្យល់) ។ ព្រះទ្រង់ប្រទានពរដោយពាក្យដូចនេះ ជាថ្មីម្តងទៀតបន្ទាប់ពីមានទឹកជំនន់ដ៏ធំនៅលើផែនដី (មើល លប ៩:១ និងការពន្យល់ ៩:១–៧) ហើយព្រះពរក៏ផ្តល់បន្តទៀត តាមរយៈព្រះបន្ទូលសន្យាជាការព្រមព្រៀងចំពោះលោកអ័ប្រាហាំ (លប ១៧:២,៦ ២២:១៧) ដល់លោកអ៊ីសាក់ (លប ២៦:៤) និងលោកយ៉ាកុប (លប ២៨:១៤ ៣៥:១១ ៤៨:៤) ។ ព្រះទ័យដ៏ល្អរបស់ព្រះមានចំពោះមនុស្សលោក គឺមាននៅពេលដែលទ្រង់បានបង្កើតមនុស្សមក គឺគេអាចយល់បានតាមរយៈប្រវត្តិសាស្ត្រនៃសាសន៍អ៊ីស្រាអែល គឺមិនមែនតាមសាសន៍អេស៊ីព្ទទេ ។ សូមមើលការពន្យល់ នក ៣៩:៣២ ជន ១:៤៦ ។ *ស្រុក* ដូចជា ស្រុកកូសែន (មើលការពន្យល់ លប ៤៥:១០) ។

**១:៨** មើល កច ៧:១៨ ។ *ស្តេចថ្មី១* គេជឿថាជាស្តេច "អ័ម៉ូស" (Ahmose) គឺជាអ្នកបង្កើតខ្សែរាជវង្សទី១៨ និងជាអ្នកបណ្តេញពួកឈ្លានពានហ៊ីកសូស (សាសន៍ប្រើភាសាស៊ីម៉ាយ ដែលចូលមកគ្រប់គ្រងនគរអេស៊ីព្ទ)។ *មិនបានស្គាល់យ៉ូសែបទេ* មានន័យថា ស្តេចនេះពុំបានដឹង ថាតើលោកយ៉ូសែបបាននាំព្រះពរដ៏អស្ចារ្យប៉ុណ្ណា មកដល់នគរអេស៊ីព្ទជាច្រើនឆ្នាំមកនោះឡើយ ។

**១:១១** *នាយដំរួត* ជាមន្ត្រីរបស់នគរអេស៊ីព្ទ (មើលសេចក្តីផ្តើមត្រង់ចំណុចពង្សាវតារ) ។ *ធ្វើទុក្ខ . . . ដោយការនឿយលំបាក* មើល លប ៤៧:១១ ។ *ផារ៉ោន* ពាក្យនេះមានប្រភពជាភាសាអេស៊ីព្ទ មានន័យថា "ផ្ទះក៏ធំសម្បើម" គឺជាព្រះងារ មិនមែនជាព្រះនាមផ្ទាល់របស់ស្តេចឡើយ ។

**១:១៤** *ធ្វើឱ្យជីវិតគេមានសេចក្តីជូរល្វីង* គេរំឭកបទពិសោធន៍ដ៏ពិតនេះនៅក្នុងបុណ្យរំលង ដោយអាហារ "មានបន្លែល្វីងជូរចត់" (១២:៨)។ *ការនៅចំការគ្រប់មុខ* រាប់ទាំងការបាចទឹកបញ្ចូលស្រែចំការ (ចទ ១១:១០)។

សាសន៍ហេព្រើរ[ធ] ដែល១ឈ្មោះនាងស៊ីប្រា ហើយ១ទៀត
ឈ្មោះនាងពូអាថា ១៦កាលណានាងទៅកាន់ពោះ នៃពួក
ស្រីសាសន៍ហេព្រើរដែលសំរាលកូន នោះក្នុងកាលដែល
គេកំពុងតែសំរាល បើកូននោះប្រុស ចូរសំឡាប់វាទៅ តែ
បើសិនជាស្រី នោះត្រូវទុកឱ្យរស់នៅចុះ[ន] ១៧ប៉ុន្តែឆ្មបទាំង
នោះ ជាអ្នកកោតខ្លាច[ប]ដល់ព្រះ គេមិនបានធ្វើតាមបង្គាប់
នៃស្តេចស្រុកអេស៊ីព្ទនោះឡើយ[ផ] គឺបានទុកកូនប្រុសៗឱ្យ
រស់នៅវិញ ១៨ឯស្តេចស្រុកអេស៊ីព្ទក៏ហៅឆ្មបទាំងនោះមក
សួរថា ហេតុអ្វីបានជាធ្វើយ៉ាងដូច្នេះ គឺដែលទុកកូនប្រុសៗ
ឱ្យរស់នៅនេះ ១៩ឆ្មបទូលឆ្លើយទៅផារ៉ោនថា គឺពីព្រោះ
ពួកស្រីសាសន៍ហេព្រើរមិនមែនដូចជាស្រីសាសន៍អេស៊ីព្ទ
ទេគេ រហ័សណាស់ ដ្បិតឆ្មបមិនទាន់ទាំងមកដល់ផង នោះ
គេបានសំរាលរួចជាមុនទៅហើយ[ព] ២០ដូច្នេះព្រះទ្រង់ក៏
ប្រទានពរដល់ឆ្មបទាំងនោះ[ភ] ឯពួកជនជាតិអ៊ីស្រាអែលគេ
កាន់តែចំរើនជាច្រើនឡើង ត្រឡប់ទៅជាមានកំឡាំងគ្រប់
ជិពូក ២១ហើយដោយព្រោះពួកឆ្មបនោះមានសេចក្តីកោត
ខ្លាច[ម]ដល់ព្រះ បានជាទ្រង់ចំរើនពូជ[យ]ឱ្យគេ ។
២២នោះផារ៉ោនទ្រង់បង្គាប់បណ្តារាស្ត្រថា អស់ទាំង
កូនប្រុសៗដែលកើតមក នោះត្រូវបោះចោលទៅក្នុងទន្លេ
ចេញ[រ] តែកូនស្រីៗទាំងប៉ុន្មានត្រូវទុកឱ្យរស់នៅវិញ[ល]។

## កំណើតរបស់លោកម៉ូសេ

**២** ១មានមនុស្សម្នាក់ក្នុងពូជលេវី[ក] បានទៅយកកូនស្រី
របស់ពួកលេវីម្នាក់ធ្វើជាប្រពន្ធ[ខ] ២នាងចាប់មានផ្ទៃពោះក៏
សំរាលបានកូនប្រុស១ នាងឃើញថាកូននោះថ្លោសល្អ[គ]
ក៏លាក់ទុកនៅបាន៣ខែ[ឃ] ៣លុះដល់លាក់មិនកំបាំងទៀត
នោះក៏យកកូនទូក ដែលធ្វើពីដើមបបុស[ង] មកពរជ័រលាប
ម្រ័ក្សណ៍[ច] រួចដាក់កូនចុះក្នុងទូកនាំយកទៅបណ្តែតនៅ
កណ្តាលគុម្ពត្រែង[ឆ]នាមាត់ទន្លេ ៤ឯបងស្រីរបស់កូននោះ[ជ]
ក៏ឈរមើលពីចំងាយ ចង់ដឹងហេតុដែលនឹងកើតមានយ៉ាង
ដូចម្តេច ។
៥ខណនោះបុត្រីផារ៉ោននាងយាងចុះមក ដើម្បីនឹងស្រង់
ព្រះគង្គាក្នុងទន្លេ ពួកភីលៀងរបស់នាងបាននាំគ្នាដើរលេង
ទៅតាមមាត់ច្រាំង[ឈ] ឯនាងក៏ឃើញកូនទូកនៅនាកណ្តាល
គុម្ពត្រែង ទើបចាត់ភីលៀងម្នាក់ឱ្យទៅនាំយកមក ៦នាង
បើកទៅឃើញកូនតូច ហើយមើល វាស្រែកយំឡើង នាងក៏
មានព្រះទ័យផ្លួចអាណិតដល់វា ដោយមានសវនីយ៍ថា នេះ
ឯងពិតជាកូនរបស់សាសន៍ហេព្រើរហើយ ៧ឯបងស្រីរបស់
កូនតូចក៏ទូលសួរបុត្រីផារ៉ោនថា តើព្រះនាងចង់ឱ្យខ្ញុំម្ចាស់
ទៅរកមេដោះ ពីពួកស្រីសាសន៍ហេព្រើរ មកបំបៅកូននេះ
ឬទេ ៨បុត្រីផារ៉ោនមានសវនីយ៍ថា អើ ទៅចុះ នាងក៏ទៅ
ហៅម្តាយរបស់កូននោះមក ៩បុត្រីផារ៉ោនបង្គាប់ថា ចូរ
យកកូននេះទៅបំបៅឱ្យខ្ញុំចុះ ខ្ញុំនឹងឱ្យប្រាក់ខែដល់អ្នក

**១:១៥** ធ លប ៣៥:១៧
**១:១៦** ន ខ.២២
**១:១៧** ប ខ.២១ សភ ១៦:៦ ផ ១សយ ២២:១៧ ដយ ៣:១៦–១៨ កច ៤:១៨–២០ ៥:២៩
**១:១៩** ព លវ ១៩:១១ យស ២:៤–៦ ១សយ ១៩:១៤ ២សយ ១៧:២០
**១:២០** ភ សភ ១១:១៨ ២២:៨ សស ៨:១២ អស ៣:១០ ហព៦:១០
**១:២១** ម ខ.១៧ យ ១សយ ២:៣៥ ២សយ ៧:១១, ២៧–២៩ ១ពវ ១១:៣៨ ១៤:១០
**១:២២** រ លប ៤១:១ ល ខ.១៦ កច ៧:១៩
**២:១** ក លប ២៩:៣៤ ខ ខ.២ នក ៦:២០ ជន ២៦:៥៩
**២:២** គ លប ៣៩:៦ ឃ ហព ១១:២៣
**២:៣** ង អស ១៨:២ ច លប ៦:១៤ ឆ លប ៤១:២ យប ៨:១១ កច ៧:២១
**២:៤** ជ នក ១៥:២០
**២:៥** ឈ នក ៧:១៥ ៨:២០

**១:១៥** *សាសន៍ហេព្រើរ* មើលការពន្យល់ លប ១៤:១៣ ។

**១:១៦** *ដែលសំរាល* ពាក្យនេះក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យត្រង់ថា "ជាថ្មធំពីរ" ដែលស្ត្រីអង្គុយពីលើ ក្នុងពេលសំរាលកូន ។ *បើកូននោះប្រុស ចូរសំឡាប់វាទៅ* ព្រោះអាចធ្វើអ្នកចម្បាំងដ៏ខ្លាំងពូកែ និងធ្វើជាឪពុក ។

**១:១៧** ចំពោះការប្រើពាក្យដូចនេះនៅក្នុងពួកជិនុំដំបូង សូមមើល កច ៥:២៩ ។ *កោតខ្លាចដល់ព្រះ* មើលការពន្យល់ លប ២០:១១ ។

**១:២២** *បណ្តារាស្ត្រ* ដោយសារស្តេចផារ៉ោនមិនសម្រេចបំណងតាមរយៈពួកឆ្មបនោះបាន នោះស្តេចអង្គនេះនាំពួកសាសន៍អេស៊ីព្ទទាំងអស់ឱ្យចូលរួម ក្នុងការទប់ទល់នឹងការភ័យខ្លាចចំពោះសាសន៍អ៊ីស្រាអែលវិញ ។

**២:១–១០** វគ្គនេះនិយាយអំពីកំណើតលោកម៉ូសេ ។ គាត់កើតនៅក្នុងគ្រាសង្កត់សង្កិន ហើយដោយសារកូនទូកតូចមួយ គាត់បានរួចជីវិតពីបញ្ជាដែលស្តេចផារ៉ោនបង្គាប់ឱ្យសម្លាប់ពួកកូនប្រុសៗដែលកើតមក ។ គាត់បានពេញរូបរាងឡើង ក្នុងរាជវាំងស្តេចផារ៉ោន ។ ដូចនេះ កុមារភាពរបស់លោកម៉ូសេ គឺប្រៀបបាននឹងជីវិតរបស់ពួកអ៊ីស្រាអែល ក្នុងនគរអេស៊ីព្ទ ហើយការនេះក៏បានប្រាប់អំពីការដែលនឹងកើតមក(ការពន្យល់ ខ.២)។

**២:១** *មនុស្សម្នាក់ . . . កូនស្រីរបស់ពួកលេវី* គឺប្រហែលជាលោកអាំរ៉ាម និងយ៉ូកិបិត(ប៉ុន្តែ សូមមើលការពន្យល់ ៦:២០) ។

**២:២** *កូននោះថ្លោសល្អ* ម៉ូសេជាក្មេងមានលក្ខណៈមិនធម្មតា (មើល កច ៧:២០ ហព ១១:២៣) មានលក្ខណៈស្រស់ល្អដល់ព្រះ(មើល កច ៧:២០)។ ការរួចជីវិតរបស់លោកម៉ូសេកាលនៅជាទារក គឺជាការប្រាប់ជាមុនអំពីការរំដោះពួកអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ ដែលព្រះទ្រង់ធ្វើតាមរយៈគាត់ ។

**២:៣** *ដើមបបុស* តាមព្រះគម្ពីរភាសាហេព្រើរ គេធ្វើកូនទូកនោះពីដើមប៉ាពីរើស(Papyrus ដើមម្យ៉ាងដែលដុះនៅក្នុងទឹកដីអេស៊ីព្ទ)។ ការសង្គ្រោះដោយទូកនេះ មាននិយាយតែនៅក្នុងខនេះ និងនៅក្នុងរឿងរបស់លោកណូអេប៉ុណ្ណោះ(មើលការពន្យល់ លប ៦:១៤)។ ទូកម៉ូសេ គឺជាការបំព្រួញទូកពីធំមកតូច ហើយទូកតូចដែលឆ្លងកាត់សមុទ្របានក៏មាននិយាយនៅក្នុង អស ១៨:២ ផងដែរ ។ *ត្រែង* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានប្រភពពីភាសាអេស៊ីព្ទ ដែលជាឈ្មោះ "សមុទ្រក្រហម" (មើលការពន្យល់ ១០:១៩) ។

**២:៥** *បុត្រីផារ៉ោន* ប្រហែលជាព្រះនាងដ៏ល្បីល្បាញ នៃរាជវង្សទី១៨ ដែលក្លាយជាមហាក្សត្រយានីហាតសេស៊ូត(Hatshepsut)។ ក្នុងផ្នែកដំបូងនៃព្រះគម្ពីរនេះ ហើយស្តេចផារ៉ោនការប្រឹងប្រែងរបស់ស្តេចផារ៉ោន ត្រូវបង្អាក់ដោយស្រីៗ: ពួកឆ្មប(១:១៧) ពួកម្តាយនៃពួកអ៊ីស្រាអែល(១:១៩) ម្តាយនិងបងស្រីរបស់លោកម៉ូសេ(ខ.៣–៤,៧–៩) បុត្រីរបស់ទ្រង់(ខនេះ)។

**២:៦** *វាស្រែកយំឡើង* នៅក្នុងព្រះគម្ពីរមានតែកន្លែងនេះប៉ុណ្ណោះ ដែលនិយាយអំពីទារកយំ ។

ម្ដាយក៏យកកូនទៅបំបៅ ១០លុះកូនមានវ័យធំឡើងកាល
ណា ក៏នាំវាទៅថ្វាយដល់បុត្រីផារ៉ោនវិញ ហើយវាបាន
ទៅជាកូនរបស់នាងទៅ នាងក៏ឱ្យឈ្មោះថា ម៉ូសេ ដោយថា
អញ បានស្រង់[ដ]វាពីទឹកមក ។

## លោកម៉ូសេបានភៀសខ្លួនទៅម៉ាឌាន

១១ក្នុងគ្រានោះ កាលម៉ូសេបានពេញក្ដីជាមនុស្សហើយ
នោះលោកចេញទៅឯពួកញាតិសន្ដានខ្លួន[ឋ] ក៏បានឃើញ
ការទុក្ខលំបាករបស់គេ[ឌ] ហើយឃើញសាសន៍អេស៊ីព្ទម្នាក់
កំពុងតែវាយសាសន៍ហេព្រើរម្នាក់ ដែលជាសាច់ញាតិ
១២នោះលោកក្រឡេកមើលណេះ មើលណោះ ឃើញថា
គ្មានអ្នកណាសោះ ក៏សំឡាប់សាសន៍អេស៊ីព្ទនោះ កប់ក្នុង
ខ្សាច់ចោលទៅ ១៣ដល់ថ្ងៃក្រោយទៀត លោកចេញទៅ
ឃើញសាសន៍ហេព្រើរ២នាក់ កំពុងតែប្រឈ្លោះគ្នា ក៏
និយាយនឹងអ្នកដែលធ្វើខុសថា ហេតុអ្វីបានអ្នកវាយគូកន
ដូច្នេះ[ឍ] ១៤អ្នកនោះឆ្លើយតបថា តើអ្នកណាបានតាំងឯង
ឱ្យធ្វើជាចៅហ្វាយ ហើយជាចៅក្រមលើយើងរាល់គ្នា[ណ]
តើគិតសំឡាប់អញដូចជាបានសំឡាប់សាសន៍អេស៊ីព្ទម្នាក់
នោះទៀតឬអី នោះម៉ូសេមានសេចក្ដីភិតភ័យណាស់ ដោយ
គិតថា ការនោះប្រាកដជាគេដឹងហើយ ១៥រីឯផារ៉ោន
កាលទ្រង់បានឮ នោះទ្រង់ក៏រកសំឡាប់[ត]ម៉ូសេ តែលោក
រត់[ថ]ពីចំពោះទ្រង់ចេញទៅឯស្រុកម៉ាឌាន[ទ] ហើយក៏ឈប់
អង្គុយនៅជិតអណ្ដូងទឹក១ ។

**២:១០** ញ ១សយ ១:២០ ដ ២សយ ២២:១៧
**២:១១** ឋ កច ៧:២៣ ហព ១១:២៤-២៦ ឌ នក ១:១១
**២:១៣** ឍ កច ៧:២៦
**២:១៤** ណ លប ១៣:៨ កច ៧:២៧
**២:១៥** ត នក ៤:១៩ ថ លប ៣១:២១ ទ ហព ១១:២៧
**២:១៦** ធ នក ៣:១ ១៨:១ ន លប ២៤:១១ ប លប ៣០:៣៨
**២:១៧** ផ ១សយ ៣០:៨ ទដ ៣១:២ ព លប ២៩:១០
**២:១៨** ភ នក ៣:១ ៤:១៨ ១៨:១,៥,១២ ជន ១០:២៩
**២:២០** ម លប ១៨:២-៥

១៦រីឯសង្ឃនៅស្រុកម៉ាឌាន[ធ]នោះ លោកមានកូនស្រី៧
នាក់ នាងទាំងនោះមកដងទឹក[ន]ទៅចាក់បំពេញ[ប]ស្នូកឱ្យហ្វូង
សត្វរបស់ឪពុកផឹក ១៧តែគង្វាលចៀមគេមកបណ្ដេញនាង
ទាំងនោះវិញ នោះម៉ូសេក៏ក្រោកឡើងជួយរាំងរានាង[ផ]
រួចយកទឹកទៅឱ្យហ្វូងសត្វផឹក[ព] ១៨លុះកាលនាងទាំងនោះ
ទៅដល់រេហួលជាឪពុកខ្លួន[ភ] នោះលោកសួរថា ថ្ងៃនេះដូច
ម្ដេចបានជាឯងរាល់គ្នាត្រឡប់មកជាឆាប់ម្ល៉េះ ១៩នាងទាំង
នោះឆ្លើយឡើងថា មានសាសន៍អេស៊ីព្ទម្នាក់បានជួយ ឱ្យ
យើងខ្ញុំរួចពីកណ្ដាប់ដៃ នៃពួកអ្នកគង្វាល ហើយក៏ដងទឹក
ឱ្យយើងខ្ញុំសំរាប់ហ្វូងសត្វដែរ ២០លោកក៏សួរកូនថា អ្នក
នោះ តើនៅឯណា ហេតុអ្វីបានជាឯងរាល់គ្នាមកចោលគេ
ដូច្នេះ ចូរហៅមកបរិភោគសិន[ម] ២១ឯម៉ូសេលោកក៏សុខចិត្ត
ព្រមនៅជាមួយនឹងរេហួល ហើយរេហួលឱ្យកូនស្រីម្នាក់
ឈ្មោះសេផូរ៉ា[យ] ទៅធ្វើជាប្រពន្ធ ២២នាងបង្កើតបានកូន
ប្រុស១ ដែលម៉ូសេឱ្យឈ្មោះថា គើសំម[រ] ដោយគិតថា
អញជាអ្នកស្នាក់នៅ[ល]ស្រុកដទៃ ។
២៣លុះយូរបន្តិចទៅ[វ]ស្ដេចស្រុកអេស៊ីព្ទទ្រង់សុគតទៅ[ស]
នោះពួកកូនចៅអ៊ីស្រាអែលគេថ្ងូរឡើង ដោយព្រោះការ
ទុក្ខលំបាក[ហ]ហើយក៏អំពាវនាវ[ឡ]ដល់ព្រះ ដោយព្រោះការ

**២:២១** យ នក ៤:២៥ ១៨:២ ជន ១២:១ **២:២២** រ ពច ១៨:៣០ ល លប ២៣:៤ ហព ១១:១៣ **២:២៣** វ កច ៧:៣០ ស នក ៤:១៩ ហ នក ១:១៤ ឡ ខ.២៤ នក ៣:៧,៩ ៦:៥ ជន ២០:១៥-១៦ ចទ ២៦:៨ ពច ២:១៨ ១សយ ១២:៨ ទដ ៥:២ ១៨:៦ ៣៩:១២ ៨១:៧ ១០៣:១ យក ៥:៤

**២:១០** *បានទៅជាកូនរបស់នាងទៅ* ដូចនេះ លោកម៉ូសេបានរៀនសូត្រគ្រប់ទាំងចំណេះវិជ្ជានៃសាសន៍អេស៊ីព្ទ (មើល កច ៧:២២ និងការពន្យល់) ។ អ្នកនិពន្ធបានបង្ហាញអំពីលក្ខណៈសម្បត្តិជាអ្នកការពារយុត្តិធម៌ ដែលលោកម៉ូសេមាន នៅក្នុងខមួយចំនួន (១១-១២,១៣,១៦-១៧) ។ *ម៉ូសេ* ជាឈ្មោះចេញពីប្រភពដើមពីភាសាអេស៊ីព្ទ ដែលមានន័យថា "បានកើត" ហើយជាធាតុផ្សំទី២ នៃព្រះនាមក្នុងវង្សស្ដេចផារ៉ោន ដូចជា អាហម៉ូស (Ahmose, មើលការពន្យល់ ១:៨) ធូតម៉ូស (Thutmose) និងរ៉ាមសេស (Rameses ការពន្យល់ ១:១១) ជាដើម ។ *ស្រង់វាពីទឹកមក* នៅក្នុងភាសាហេព្រើរ ឈ្មោះម៉ូសេ មានសូរសៀងដូចពាក្យ "ស្រង់ពីទឹក" ហើយការនេះបានបញ្ជាក់អំពីការដែលព្រះទ្រង់សង្គ្រោះគាត់ពីទន្លេនីល ។ ដូចនេះឈ្មោះរបស់លោកម៉ូសេ បានរំឭកអំពីការដែលព្រះទ្រង់ប្រើលោកម៉ូសេ នៅក្នុងការសង្គ្រោះរាស្ត្ររបស់ទ្រង់នៅ "សមុទ្រក្រហម" (មើល ១៣:១៧) ។

**២:១១-១៥** មើល កច ៧:២៣-២៩ ហព ១១:២៤-២៧ ។

**២:១១** *ម៉ូសេបានពេញក្ដីជាមនុស្ស* គឺមានអាយុ៤០ឆ្នាំហើយ (កច ៧:២៣) ។

**២:១៤** *តើអ្នកណាបានតាំងឯងឱ្យធ្វើជាចៅហ្វាយ ហើយជាចៅក្រម* អ្នកនិយាយសម្ដីនេះ បានប្រើពាក្យទំនាយ ដែលនឹងសម្រេចក្នុងរយៈពេល៤០ឆ្នាំក្រោយមកទៀត (មើល កច ៧:២៧,៣០,៣៦) ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យចៅក្រម ឬចៅហ្វាយ អាចសំដៅទៅលើ អ្នកជួយរំដោះដូចជាក្នុងគម្ពីរពួកចៅហ្វាយ (មើល កច ៧:៣៥) ហើយច្រើនតែមានន័យថាដូចពាក្យ អ្នកដឹកនាំ ក្នុងគម្ពីរសញ្ញាចាស់ (លប ១៨:២៦ និងការពន្យល់) ។ *ម៉ូសេមានសេចក្ដីភិតភ័យណាស់* មើលការពន្យល់ ហព ១១:២៧ ។

**២:១៥** *ផារ៉ោន* (មើលសេចក្ដីផ្ដើមក្នុងគម្ពីរ) ។ *ស្រុកម៉ាឌាន* គេបានដាក់ឈ្មោះឱ្យស្រុកនេះ តាមឈ្មោះកូនប្អូនរបស់លោកអ័ប្រាហាំ (មើល លប ២៥:២ និងការពន្យល់ លប ៣៧:២៥) ។ ស្រុកម៉ាឌានគឺស្ថិតនៅត្រើយទាំងសងខាងនៃដៃខាងកើតនៃសមុទ្រក្រហម (ឈូងសមុទ្រ អ័កាបា) ។ ស្រុកនេះជាវាលរហោស្ថានស្ងួតហែង គឺផ្ទុយពីលំនៅដំបូងដែលលោកម៉ូសេមានក្នុងរាជវាំង ។ គាត់បានរស់នៅស្រុកម៉ាឌានអស់ ៤០ឆ្នាំ (កច ៧:២៩-៣០) ។

**២:១៦** *សង្ឃនៅស្រុកម៉ាឌាន* គឺលោករេហួល (ខ.១៨) ដែលមានន័យថា "សំឡាញ់នៃព្រះ" ។ ឈ្មោះរបស់គាត់មួយទៀតគឺ យេត្រូ (មើល ៣:១) ដែលអាចជាងារ "ឯកឧត្ដម្ភ" ។

**២:២៣-២៥** ខទាំងនេះធ្វើឱ្យអ្នកអានចាប់អារម្មណ៍ ទៅលើភាពវេទនារបស់ប្រជាជនអ៊ីស្រាអែល ដែលកាលនៅស្រុកអេស៊ីព្ទ ។ ក៏បង្ហាញថាព្រះអម្ចាស់ពិតជាយកចិត្តទុកដាក់ចំពោះរាស្ត្រទ្រង់ ហើយក៏មិនភ្លេចពីសេចក្ដីសញ្ញាដែលទ្រង់បានតាំងជាមួយពួកព្ធយុកោគេ ។ គឺដើម្បីជួយសង្គ្រោះដល់ប្រជាជនអ៊ីស្រាអែល ។ មានពាក្យ៤យ៉ាង ដែលបង្ហាញពីការរងទុក្ខរបស់ប្រជាជនអ៊ីស្រាអែលគឺ : "ថ្ងូរ" "អំពាវនាវ" "ការទុក្ខលំបាក" (ខ.២៣) និង

ទុក្ខលំបាករបស់ខ្លួន នោះទ្រង់ក៏ឮ ២៤ទ្រង់ឮដំងូររបស់គេ
ហើយក៏នឹកចាំ[អ]ពីសេចក្ដីសញ្ញា[ក]ដែលទ្រង់បានតាំងនឹង
អ័ប្រាហាំ និងអ៊ីសាក ហើយនិងយ៉ាកុប ២៥ព្រះទ្រង់ឃើញ
ពួកកូនចៅអ៊ីស្រាអែល ហើយក៏ជ្រាប[ខ]ដល់សេចក្ដីទុក្ខ
របស់គេ ។

## លោកម៉ូសេ និងគុម្ពបន្លាឆេះ

**៣** ១កាលម៉ូសេកំពុងតែឃ្វាលហ្វូងសត្វរបស់យេត្រូ[ក] ជា
ឪពុកក្មេក ដែលជាសង្ឃនៅស្រុកម៉ាឌាន[ខ] នោះលោកនាំ
ហ្វូងសត្វទៅខាងនាយទីរហោស្ថានរហូតដល់ភ្នំ[គ]ព្រះ គឺជា
ភ្នំហូរែប[ឃ] ២នៅទីនោះមានទេវតានៃព្រះយេហូវ៉ា[ង]លេច
មកឯលោកក្នុងអណ្ដាតភ្លើង[ច]នៅកណ្ដាលគុម្ពបន្លា[ឆ] លោក
ក៏មើលទៅឃើញឆេះគុម្ពបន្លា តែឥតបានសុសទេ ៣ម៉ូសេ
នឹកក្នុងចិត្តថា អញនឹងងាកចេញទៅមើលការចំឡែកនេះ
តើហេតុអ្វីបានជាគុម្ពបន្លានេះឆេះមិនសុសដូច្នេះ ៤កាល
ព្រះយេហូវ៉ាទ្រង់ឃើញលោកងាកបែរមក មើលដូច្នេះ
នោះទ្រង់ក៏មានបន្ទូលហៅ[ជ]ពីក្នុងគុម្ពបន្លា[ឈ]ថា ម៉ូសេៗអើយ
រួចលោកទូលឆ្លើយថា ព្រះករុណាវិសេសព្រះអម្ចាស់[ញ]
៥ទ្រង់ក៏បង្គាប់ថា កុំឱ្យមកជិតនេះឡើយ [ដ]ចូរដោះស្បែក
ជើងចេញ ដ្បិតកន្លែងដែលឈរនោះជាដីបរិសុទ្ធ[ឋ] ៦ទ្រង់
មានបន្ទូលទៀតថា អញជាព្រះនៃឰយុកោឯង គឺជាព្រះនៃ
អ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះនៃយ៉ាកុប[ឌ] នោះ
ម៉ូសេក៏ខ្ទប់មុខ[ឍ] ដ្បិតមិនហ៊ានមើលចំទៅព្រះទេ[ណ] ។
៧រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញបានឃើញ[ត]
សេចក្ដីវេទនា[ថ]របស់រាស្ត្រអញ ដែលនៅស្រុកអេស៊ីព្ទ
ហើយ ក៏បានឮពាក្យគេអំពាវនាវដោយព្រោះពួកអ្នកដែល
សង្កត់សង្កិនដែរ ពីព្រោះអញស្គាល់[ទ]សេចក្ដីទុក្ខព្រួយរបស់
គេ[ធ] ៨ដូច្នេះអញបានចុះមក[ន] ដើម្បីនឹងជួយដោះគេឱ្យរួច
ចេញពីកណ្ដាប់នៃពួកសាសន៍អេស៊ីព្ទ អញនឹងនាំគេឡើង
ចេញពីស្រុកនោះ[ប] ទៅឯស្រុកយ៉ាងល្អដ៏ធំទូលាយ ជាស្រុក
ដែលមានទឹកដោះនឹងទឹកឃ្មុំហូរហៀរវិញ[ផ] ជាទីកន្លែង
របស់ផងសាសន៍កាណាន សាសន៍ហេត សាសន៍អាម៉ូរី

**២:២៤** អ លប ៨:១ ក លប ៩:១៥ ១៥:១៥ ១៧:៤ ២២:១៦–១៨ ២៦:៣ ២៨:១៣–១៥ នក ៣២:១៣ ២ពវ ១៣:២៣ ទដ ១០៥:១០,៤២ យរ ១៤:២១ **២:២៥** ខ នក ៣:៧ ៤:៣១ លក ១:២៥ **៣:១** ក នក ២:១៨ ពច ១:១៦ ខ នក ២:១៦ គ នក ៤:២៧ ១៨:៥ ២៤:១៣ ចទ ៤:១១,១៥ ឃ ខ.១២ នក ១៧:៦ ១៩:១–១១,៥ ៣៣:៦ ចទ ១:២,៦ ៤:១០ ៥:២ ២៩:១ ១ពវ ១៩:៨ មឡ ៤:៤ **៣:២** ង លប ១៦:៧ នក ១២:២៣ កច ៥:១៩ ច នក ១៩:១៨ ១ពវ ១៩:១២ ឆ ខ.៤ នក ២:២–៦ ចទ ៣៣:១៦ មក ១២:២៦ លក ២០:៣៧ កច ៧:៣០ **៣:៤** ជ នក ១៩:៣ លវ ១:១ ឈ នក ៤:៥ ញ លប ៣១:១១ ១សយ ៣:៤ អស ៦:៨ **៣:៥** ដ យរ ៣០:២១ ឋ លប ២៨:១៧ កច ៧:៣៣ **៣:៦** ឌ លប ២៤:១២ នក ៤:៥ មថ ២:៣២ មក ១២:២៦ លក ២០:៣៧ កច ៣:១៣ ៧:៣២ ឍ ១ពវ ១៩:១៣ ណ នក ២៤:១១ ៣:២០ ពវ ១២:២២ យប ១៣:១១ ២៣:១៦ ៣០:១៥ អស ៦:៥ **៣:៨** ន លប ១១:៥ កច ៧:៣៤ ប លប ១២:៧ ១៥:១៤ ផ ខ.១៧ នក ១៣:៥ ៣៣:៣ លវ ២០:២៤ ជន ១៣:២៧ ចទ ១:២៥ ៦:៣ ៨:៧–៩ ១១:៩ ២៦:៩ យស ៥:៦

"ដំងូរ" (ខ.២៤) និងព្រះទ្រង់ឆ្លើយតបដោយកិរិយាស័ព្ទបួនដូចជា "ឮ" "នឹកចាំ" (ខ.២៤) "ទតឃើញ" និង "ជ្រាប" (ខ.២៥) ។

**២:២៣** *លុះយូរបន្តិចទៅ* ស្ដេចធូតម៉ូស ទី៣ (Thutmose III, មើលការពន្យល់ ខ.១៥) សប្បាយនឹងការគ្រងរាជ្យដ៏យូរឆ្នាំ ។

**២:២៤** *ពីសេចក្ដីសញ្ញាដែលទ្រង់បានតាំងនិងអ័ប្រាហាំ* មើល លប ១៥:១៧–១៨ ១៧:៧ និងការពន្យល់ ។ *និងអ៊ីសាក* មើល លប ១៧:១៩ ២៦:២៤ ។ *និងយ៉ាកុប* មើល លប ៣៦:១១–១២ ។

**៣:១–១៨:២៧** គឺជាផ្នែកសំខាន់ទីពីរនៃកណ្ឌគម្ពីរ ដែលពិពណ៌នាពីការរំដោះរាស្ត្រអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ និងអំពីការត្រាស់ហៅលោកម៉ូសេ ឬសេចក្ដីវេទនាទាំងដប់ បុណ្យរំលង ឬការធ្វើនិក្ខមនំពីស្រុកអេស៊ីព្ទ ការឆ្លងសមុទ្រក្រហម និងការធ្វើដំណើរទៅភ្នំស៊ីណាយ ។

**៣:១** លោកម៉ូសេបានទទួលការត្រាសហៅពីព្រះ ពីអ្នកឃ្វាលចៀម ទៅជាអ្នកគង្វាលរាស្ត្ររបស់ព្រះវិញ គឺមិនខុសពីស្ដេចដាវីឌ (២សយ ៧:៨) ទេ ។ *លោកយេត្រូ* មើលការពន្យល់ ២:១៦ ។ *ភ្នំហូរែប* មានន័យថា "ទីរហោស្ថាន" ឬ "ទីចោលស្ងាត់" គឺ (១).អាចជាឈ្មោះមួយទៀតរបស់ភ្នំស៊ីណាយ ឬ (២).ឈ្មោះភ្នំមួយទៀតដែលខ្ពស់ជាង នៅក្នុងតំបន់ជិតខាង នៃតំបន់អាគ្នេយ៍នៃឧបទ្វីបស៊ីណាយ ។ តាមទំនៀមទម្លាប់ គេហៅភ្នំហូរែបថា ជាភ្នំរ៉ាស អេស–សាហ្វសាហ្វ (Ras es-Safsaf, "ចុងឈើ") មានកំពស់១៩៨១,២ ម៉ែត្រ ហើយហៅភ្នំស៊ីណាយថា ភ្នំយេបែល មូសា (Jebel Musa" ភ្នំនៃលោកម៉ូសេ") មានកំពស់ ២២៥៥,២៥ ម៉ែត្រតែភ្នំ តែការយល់ដូចនេះមិនទាន់ច្បាស់លាស់ទេ ។

**៣:២** *ទេវតានៃព្រះយេហូវ៉ា* ពាក្យនេះត្រូវបានប្រើជំនួសពាក្យ "ព្រះយេហូវ៉ា" និង "ព្រះអម្ចាស់" ដូចនៅក្នុង ខ.៤ (មើលការពន្យល់នៅ លប ១៦:៧) ។ *លេចមកឯលោកក្នុងអណ្ដាតភ្លើង នៅកណ្ដាលគុម្ពបន្លា* ព្រះអម្ចាស់ទ្រង់បើកសម្ដែងព្រះអង្គទ្រង់ និងព្រះហឫទ័យទ្រង់ ដោយមានភ្លើងមកជាមួយផង (មើល ១៣:២១ ១៩:១៨ ១ពវ ១៨:២៤) ។

**៣:៤** ហោរានីមួយៗដែលពិត សុទ្ធតែបានទទួលការត្រាស់ហៅពីព្រះ (មើលឧទាហរណ៍ក្នុង ១សយ ៣:៤ អស ៦:៨ យរ ១:៤–៥ អគ ២:១–៨ ហស ១:២ អម ៧:១៥ យហ ១:១–២ និងមើលការពន្យល់ ៧:១–២) ។ *ម៉ូសេៗអើយ . . . ព្រះករុណាវិសេស* មើលការពន្យល់ លប ២២:១,១១ ។

**៣:៥** *ដោះស្បែកជើងចេញ* គឺសញ្ញានៃការគោរព និងបន្ទាបខ្លួននៅតំបន់មជ្ឈិមបូព៌ានៅសម័យបូរាណ (មើល យស ៥:១៥) ។ អ្នកកាន់សាសនាអ៊ីស្លាមនៅតែអនុវត្តតាមប្រពៃណីនេះ នៅពេលចូលព្រះវិហាររបស់ខ្លួន ។ *បរិសុទ្ធ* ផែនដីជាទូទៅមិនមានលក្ខណៈបរិសុទ្ធទេ ប៉ុន្តែ ព្រះទ្រង់ធ្វើឱ្យដីនៅកន្លែងនោះបរិសុទ្ធវិញ ដោយព្រះវត្តមានទ្រង់ (មើល លប ២:៣) ។

**៣:៦** មើល ២:២៤ និងការពន្យល់ ។ *មិនហ៊ានមើលចំទៅព្រះទេ* មើលការពន្យល់ លប ១៦:១៣ ៣២:៣០ ។ តែក្រោយមក ក្នុងនាមជាអ្នកបម្រើព្រះ លោកម៉ូសេត្រូវជួបព្រះនៅលើភ្នំស៊ីណាយ (១៩:៣) ហើយទូលសូមឱ្យបានឃើញសេរីល្អនៃទ្រង់ (៣៣:១៨) ។

**៣:៨** *អញបានចុះមក ដើម្បីនឹងជួយដោះគេ* ទ្រង់ក៏អាចយាងចុះមក ដើម្បីជំនុំជម្រះផងដែរ (លប ១១:៥–៩ ១៨:២១) ។ *ស្រុកដែលមានទឹកដោះនឹងទឹកឃ្មុំហូរហៀរវិញ* គេពិពណ៌នាតាមប្រពៃណី និងសុភាសិត អំពីតំបន់ខ្ពង់រាបនៃស្រុកកាណាន ដោយប្រើពាក្យដូចនេះ (ការពន្យល់ អស ៧:១០) ។ *ទឹកឃ្មុំ* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យ "ទឹកឃ្មុំ" គឺសំដៅទៅលើទឹកឃ្មុំ និងទឹក

សាសន៍ពេរិស៊ីត សាសន៍ហេវី[ព] និងសាសន៍យេប៊ូស[ភ]
៩ដូច្នេះមើល ឥឡូវនេះ ពាក្យរបស់ពួកកូនចៅអ៊ីស្រាអែល
ដែលគេអំពាវនាវដល់អញ នោះបានឮហើយ ១ទៀត អញ
បានឃើញការលំបាក ដែលសាសន៍អេស៊ីព្ទសង្កត់សង្កិន[ម]
ដល់គេដែរ ១០ដូច្នេះ ចូរមកឥឡូវ អញនឹងចាត់[យ]ឯងឱ្យទៅ
ឯផារ៉ោន ដើម្បីឱ្យឯងបាននាំរាស្ត្រអញ គឺជាពួកកូនចៅ
អ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទមក[រ] ។
១១នោះម៉ូសេទូលទៅព្រះថា តើទូលបង្គំជាអ្វី[ល] ដែល
ព្រះអង្គឱ្យទូលបង្គំទៅឯផារ៉ោន ហើយឱ្យទូលបង្គំនាំពួក
កូនចៅអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទមកដូច្នេះ ១២ទ្រង់
មានបន្ទូលតបថា អញនឹងនៅជាមួយនឹងឯងជាប្រាកដ[វ]
កាលណាឯងបាននាំគេចេញពីស្រុកអេស៊ីព្ទមក នោះឯង
រាល់គ្នានឹងមកថ្វាយបង្គំព្រះនៅលើភ្នំនេះ នេះហើយនឹង
បានជាទីសំគាល់[ស]ឱ្យឯងដឹងថា អញនេះបានចាត់ឯងទៅ[ហ]
១៣ម៉ូសេក៏ទូលទៅព្រះថា មើល កាលណាទូលបង្គំទៅ
ប្រាប់ពួកកូនចៅអ៊ីស្រាអែលថា ព្រះនៃឰយុកោអ្នករាល់គ្នា
ទ្រង់បានចាត់ខ្ញុំឱ្យមកឯអ្នករាល់គ្នា ហើយគេសួរទូល
បង្គំថា តើព្រះទ្រង់ព្រះនាមជាអ្វី[ឡ] នោះតើត្រូវឱ្យទូលបង្គំ
ប្រាប់គេថាដូចម្តេច ១៤ព្រះទ្រង់មានបន្ទូលទៅម៉ូសេថា
"អញជាព្រះដ៏ពិត" រួចទ្រង់មានបន្ទូលទៀតថា ឯងត្រូវ
ឆ្លើយ ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលដូច្នេះថា ព្រះដ៏ជា
ព្រះ[អ]ទ្រង់បានចាត់ឱ្យខ្ញុំមកឯអ្នករាល់គ្នា ១៥ព្រះទ្រង់ក៏មាន
បន្ទូលនឹងម៉ូសេទៀតថា ចូរនិយាយនឹងពួកកូនចៅអ៊ីស្រា
អែលដូច្នេះថា ព្រះយេហូវ៉ាជាព្រះនៃពួកឰយុកោអ្នករាល់
គ្នា[ក] គឺជាព្រះនៃអ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះនៃ
យ៉ាកុប[ខ] ទ្រង់បានចាត់ឱ្យខ្ញុំមកឯអ្នករាល់គ្នា នោះជាឈ្មោះ
អញ[គ]នៅអស់កល្បជានិច្ច ហើយក៏សំរាប់ជាសេចក្តីរំឭក
ពីអញ ដល់គ្រប់ទាំងដំណរៀងរាបតទៅ[ឃ] ១៦ទៅចុះ ចូរ
ទៅប្រមូលពួកចាស់ទុំ[ង]ជាតិអ៊ីស្រាអែល ប្រាប់គេថា ព្រះ
យេហូវ៉ាជាព្រះនៃឰយុកោអ្នករាល់គ្នា គឺជាព្រះនៃអ័ប្រាហាំ
អ៊ីសាក និងយ៉ាកុប[ច] ទ្រង់បានលេចមកមានបន្ទូលនឹងខ្ញុំថា
អញបានមកប្រោសឯងរាល់គ្នាជាប្រាកដហើយ ក៏បាន
ឃើញ[ឆ] ការដែលគេធ្វើដល់ឯងរាល់គ្នា នៅស្រុកអេស៊ីព្ទ
ដែរ ១៧ហើយអញបានសំរេចថា អញនឹងនាំឯងរាល់គ្នា
ឡើងចេញពីសេចក្តីទុក្ខលំបាកនៅស្រុកអេស៊ីព្ទ[ជ] ទៅក្នុង
ស្រុករបស់សាសន៍កាណាន សាសន៍ហេត សាសន៍អាម៉ូរី
សាសន៍ពេរិស៊ីត សាសន៍ហេវី និងសាសន៍យេប៊ូសវិញ ជា
ស្រុកដែលមានទឹកដោះនឹងទឹកឃ្មុំហូរហៀរ[ឈ] ១៨គេនឹង
ស្តាប់[ញ]តាមឯង ហើយឯងនឹងពួកចាស់ទុំជាតិអ៊ីស្រាអែល
ត្រូវចូលទៅគាល់ស្តេចស្រុកអេស៊ីព្ទទូលថា ព្រះយេហូវ៉ាជា

**៣:៨** យរ ១១:៥ ៣២:២២ អគ ២០:៦ ៣ យស ១១:៣ ៣ច ៣:៣ ២សយ ២៤:៧ ភ លប ១៥:១៨–២១ អរ ៩:១ **៣:៩** ម នក ១:១៤ ជន ១០:៩ **៣:១០** យ នក ៤:១២ យស ២៤:៥ ១សយ ១២:៨ ទដ ១០៥:២៦ កច ៧:៣៤ រ នក ៦:១៣,២៦ ១២:៤១ ,៥១ ២០:២ ចទ ៤:២០ ១សយ ១២:៦ ១ពវ ៨:១៦ មីក ៦:៤ **៣:១១** ល នក ៤:១០ ៦:១២,៣០ ពច ៦:១៥ ១សយ ៩:២១ ១៥:១៧ ១៨:១៨ ២សយ ៧:១៨ ២របា ២:៦ អស ៦:៥ យរ ១:៦ **៣:១២** វ លប ២៦:៣ នក ១៤:២២ រម ៨:៣១ ស ជន ២៦:១០ យស ២:១២ ពច ៦:១៧ ទដ ៨៦:១៧ អស ៧:១៤ ៨:១៨ ២០:៣ យរ ៤៤:២៩ ហ ខ.១ កច ៧:៧ **៣:១៣** ឡ លប ៣២:២៩ **៣:១៦** ង នក ៤:២៩ ១៧:៥ លវ ៤:១៥ ជន ១១:១៦ ១៦:២៥ ចទ ៥:២៣ ១៩:១២ ពច ៨:១៤ នរ ៤:២ សភ ៣១:២៣ អគ ៨:១១ ច លប ២៤:១២ ឆ នក ៤:៣១ ២ពវ ១៩:១៦ ២របា ៦:២០ ទដ ៣៣:១៨ ៦៦:៧ **៣:១៧** ជ លប ១៥:១៦ ៤៦:៤ នក ៦:៦ ឈ ខ.៨ **៣:១៨** ញ នក ៤:១, ៨,៣១ ៦:១២,៣០

ផ្អែមពីរុក្ខរស់ម្យ៉ាង ។ *សាសន៍កាណាន . . . សាសន៍យេប៊ុស* មើលការពន្យល់ លប ១០:៦,១៥–១៦ ១៣:៧ ។ មានការសរសេរបញ្ជីឈ្មោះ តាមរបៀបផ្សេងៗគ្នា គឺមានបញ្ជីមាន២ឈ្មោះ(មើល លប ១៣:៧) ៥ឈ្មោះ (មើល ជន ១៣:២៩) ៦ឈ្មោះ(ក្នុងខនេះ និង ពច ៣:៥)១០ឈ្មោះ(លប ១៥:១៩–២០) ១២ឈ្មោះ(លប ១០:១៥–១៨)។ គេមានប្រពៃណីរាប់ឈ្មោះ៧ ដែលជាចំនួនពេញលេញ(មើលការពន្យល់ លប ៤:១៧–១៨) ។

**៣:១០** *ផារ៉ោន* គឺស្តេចអ័ម៉ាន់ហូទិប ទី២(Amunhotep II មើលសេចក្តីផ្តើមត្រង់ចំណុចពង្សាវតារ)។

**៣:១១** ក្នុងខនេះ លោកម៉ូសេស្មាក់ស្មើរជាលើកទី១(ខ.១៣ ៤:១,១០,១៣)។

**៣:១២** *អញនឹងនៅជាមួយឯង* មើលការពន្យល់ លប ២៦:៣ និង ខ.១៤ ។ *ជាទីសំគាល់* គឺជាការបញ្ជាក់ (មើលការពន្យល់ ៤:៨ លប ១៥:៨) ។

**៣:១៣** ក្នុងខនេះ លោកម៉ូសេមានការស្មាក់ស្មើរ ជាលើកទី២ ។ *តើព្រះទ្រង់ព្រះនាមជាអ្វី* ព្រះអម្ចាស់ទ្រង់មិនទាន់បានបង្ហាញឱ្យលោកម៉ូសេស្គាល់ព្រះនាមទ្រង់នៅឡើយទេ(មើល ខ.៦ ធៀបនឹង លប ១៧:១) ។

**៣:១៤** *អញជាព្រះដ៏ជាព្រះ* គឺជានាមព្រះដែលទ្រង់សព្វព្រះទ័យឱ្យគេស្គាល់ និងថ្វាយបង្គំនៅក្នុងសាសន៍អ៊ីស្រាអែល ជាព្រះនាមដែលបង្ហាញពីលក្ខណៈដែលអាចពឹងពាក់បាន និងស្មោះត្រង់ ហើយទ្រង់សព្វព្រះទ័យឱ្យរាស្ត្រទ្រង់ទុកចិត្តលើទ្រង់ទាំងស្រុងផងដែរ(មើល ខ.១២ និង ៣៤:៥–៧)។ *អញជា* ព្រះយេស៊ូវទ្រង់បានប្រើឃ្លានេះថា ព្រះអង្គទ្រង់ជាព្រះ ហើយសាសន៍យូដាយល់ថា នោះជាការប្រមាថព្រះនាមព្រះ ដែលទោសនេះត្រូវចោលថ្មសម្លាប់(មើល យហ ៨:៥៨–៥៩) ។

**៣:១៥** *ព្រះយេហូវ៉ា* មើលការពន្យល់ ចទ ២៥:៥៨ ។ ព្រះនាមទ្រង់មានន័យថា "ទ្រង់ជា" ឬ "ទ្រង់នឹងនៅជាមួយ" ហើយជាសព្វនាមបុរសទី៣ ដែលប្រែថា "អញនឹងនៅជាមួយ" នៅ ខ.១២ និង "អញជា" នៅ ខ.១៤ ។ យើងប្រើពាក្យថា "ទ្រង់ជា" ហើយព្រះទ្រង់ប្រើពាក្យថា "អញជា"។

**៣:១៦** *ពួកចាស់ទុំ* ក្នុងព្រះគម្ពីរភាសាហេព្រើរ មានន័យថាត្រង់ថា "អ្នកមានពុកចង្ការ" ដែលប្រហែលឆ្លុះបញ្ចាំងអំពីអាយុ ប្រាជ្ញា និងបទពិសោធន៍ និងឥទ្ធិពលច្រើន ជាលក្ខណៈសម្បត្តិដែលពួកចាស់ទុំត្រូវមាន ។ ក្នុងនាមជាមេដឹកនាំគ្រួសារ ឬពូជអំបូរ ចាស់ទុំក៏មានមុខដំណែងដែលទទួលស្គាល់ដោយពួកបាប៊ីឡូន ពួកហេរី និងអេស៊ីព្ទ(មើល លប ៥០:៧) ពួកម៉ូអាប់ និងពួកម៉ាឌាន(មើល ២២:៧)។ ពួកចាស់ទុំក៏មាននាទីជាអាជ្ញាកណ្តាលសម្របសម្រួល និងកាត់ក្តី(មើល ចទ ២២:១៣–១៩) ព្រមទាំងដឹកនាំផ្នែកទ័ព (មើល យស ៨:១០) និងជាអ្នកប្រឹក្សា(មើល ១សយ ៤:៣) ។

**៣:១៨** *សាសន៍ហេព្រើរ* មើលការពន្យល់ លប ១៤:១៣ ។ *ដើរអស់៣ថ្ងៃ* មើលការពន្យល់ លប ២២:៤ ។ *ទីរហោស្ថាន* ព្រះទ្រង់បានជួបជាមួយលោកម៉ូសេ(មើល ខ.១–២) ហើយជួបម្តងទៀតនៅទីនោះ(មើល ខ.១២)។

ព្រះនៃសាសន៍ហេព្រើរ[ដ] ទ្រង់បានមកជួប[ឋ]នឹងយើងខ្ញុំរាល់
គ្នាហើយ ដូច្នេះ សូមឱ្យយើងខ្ញុំរាល់គ្នាទៅក្នុងទីរហោស្ថាន
ចំងាយផ្លូវដើរអស់៣ថ្ងៃ[ឌ] ដើម្បីនឹងថ្វាយយញ្ញបូជា[ឍ] ដល់
ព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំរាល់គ្នា ១៩តែអញដឹងថា
ស្តេចស្រុកអេស៊ីព្ទនឹងមិនព្រមអនុញ្ញាតឱ្យឯងរាល់គ្នាទៅទេ
លើកតែដោយដៃខ្លាំងពូកែ[ណ]ប៉ុណ្ណោះ ២០អញនឹងលើកដៃ
វាយ[ត]ស្រុកអេស៊ីព្ទ ដោយអស់ទាំងការអស្ចារ្យ[ថ] ដែលអញ
នឹងធ្វើនៅកណ្តាលស្រុកនោះ ក្រោយនោះមក ស្តេចនឹង
បើក ឱ្យឯងរាល់គ្នាចេញទៅ[ទ] ២១អញនឹងធ្វើឱ្យជនជាតិបាន
ប្រកបដោយគុណ[ធ]នៃពួកអេស៊ីព្ទ ហើយកាលណាចេញទៅ
នោះឯងរាល់គ្នានឹងមិនទៅដោយដៃទទេឡើយ[ន] ២២គឺគ្រប់
ទាំងស្រីៗនឹងសូមគ្រឿងមាស[ប] គ្រឿងប្រាក់[ផ] និងសំលៀក
បំពាក់ពីអ្នកជិតខាង ហើយពីអ្នកដែលអាស្រ័យនៅផ្ទះជា
មួយគ្នា ហើយឯងរាល់គ្នានឹងបំពាក់ឱ្យកូនប្រុសកូនស្រីឯង
វិញ ដូច្នេះ ឯងរាល់គ្នានឹងបង្ហិន[ព]ពួកសាសន៍អេស៊ីព្ទទៅ[ភ]។

## សញ្ញាសម្រាប់លោកម៉ូសេ

៤ ១តែម៉ូសេប្រកែកថា មើល គេនឹងមិនជឿទូលបង្គំ ឬ
ស្តាប់តាម[ក]ទូលបង្គំទេ គេនឹងថា ព្រះយេហូវ៉ាទ្រង់មិនបាន
លេចមកឯអ្នកទេ ២នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលតបថា
តើមានអ្វីនៅដៃឯងនោះ លោកទូលឆ្លើយថា មានដំបង[ខ]
៣រួចទ្រង់ប្រាប់ថា ចូរបោះទៅដីទៅ លោកក៏បោះទៅ
ហើយដំបងនោះត្រឡប់ទៅជាសត្វពស់[គ] ម៉ូសេក៏រត់ចេញពី
សត្វពស់នោះ ៤តែព្រះយេហូវ៉ាទ្រង់បង្គាប់ថា ចូរលូកដៃ
ទៅចាប់ត្រង់កន្ទុយវា លោកក៏លូកដៃទៅចាប់ រួចពស់
នោះក៏ត្រឡប់ទៅជាដំបងនៅដៃលោកវិញ ៥នេះគឺដើម្បីឱ្យ
គេជឿ[ឃ]ថា ព្រះយេហូវ៉ាដ៏ជាព្រះនៃពួកឰយុកោ ជាព្រះនៃ
អ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះនៃយ៉ាកុប ទ្រង់
បានលេចមកឯឯង ។
៦ព្រះយេហូវ៉ាទ្រង់ក៏បង្គាប់ទៀតថា ចូរឯងដាក់ដៃចូល
ទៅលើទ្រូងឥឡូវចុះ លោកក៏ដាក់ដៃចូលទៅ រួចដកមក
វិញ ឃើញមានកើតឃ្លង់សដូចហិមៈ[ង] ៧រួចទ្រង់ប្រាប់ថា
ចូលដាក់ដៃចូលទៅលើទ្រូងម្តងទៀត លោកក៏ដាក់ចូលទៅ
រួចដកចេញមក ហើយមើល ដៃបានត្រឡប់ទៅដូចជា
ធម្មតាដើមវិញ[ច] ៨ទ្រង់មានបន្ទូលថា បើគេមិនជឿ[ឆ]ឯង
ហើយមិនស្តាប់តាមទីសំគាល់មុន[ជ] នោះគេនឹងជឿដោយ
សារទីសំគាល់ក្រោយនេះដែរ ៩តែបើគេមិនជឿទីសំគាល់
ទាំង២នេះទេ ហើយមិនព្រមស្តាប់តាមឯងផង នោះត្រូវឱ្យ
យកទឹកទន្លេមកចាក់លើដីគោក រួចទឹកដែលឯងយកពីទន្លេ
មក នោះនឹងត្រឡប់ទៅជាឈាម[ឈ]នៅលើដីវិញ ។
១០ម៉ូសេទូលទៅព្រះយេហូវ៉ាថា ឱព្រះអម្ចាស់អើយ ទូល

**៣:១៨** ដ លប ១៤:១៣ ឋ ជន ២៣:៤,១៦ ឌ លប ៣០:៣៦ ឍ នក ៤:២៣ ៥:១,៣ ៦:១១ ៧:១៦ ៨:២០២៧ ៩:១៣ ១០:៩,២៦ **៣:១៩** ណ នក ៤:២១ ៦:៦ ៧:៣ ១០:១ ១១:៩ ចទ ៤:៣៤ ២របា ៦:៣២ **៣:២០** ត នក ៦:១,៦ ៧:៤– ៥៩:១៥ ១៣:៣, ៩,១៤,១៦ ១៥:៦, ១២ ចទ ៤:៣៤ ៥:១៥ ៧:៨ ២៦:៨ ២ពវ ១៧:៣៦ ២របា ៦:៣២ ទដ ១១៨:១៥–១៦ថ នក ៤:២១ ៧:៣ ១១:៩,១០ ១៥:១១ ៣៤:១០ ជន ១៤:១១ ចទ ៣:២៤ ៤:៣៤ ៦:២២ នហ ៩:១០ ទដ ៧១:១៩ ៧២:១៨ ៧៧:១៤ ៧៨:៤៣ ៨៦:១០ ១០៥:២៧ ១០៦:២២ ១៣៥:៩ ១៣៦:៤ យរ ៣២:២០ មីក ៧:១៥ កច ៧:៣៦ ទ នក ១១:១ ១២:៣១–៣៣ **៣:២១** ធ លប ៣៩:២១ ន នក ១១:២ ២របា ៣០:៩ នហ ១:១១ ទដ ១០៥:៣៧ ១០៦:៣៧ ១០៦:៤៦ យរ ៤២:១២ **៣:២២** ប នក ១១:២ ១២:៣៥ អរ ១:៤,៦ ៧:១៦ ទដ ១០៥:៣៧ ផ យប ២៧:១៦–១៧ ព លប ១៥:១៤ អគ ៣៩:១០ ភ អគ ២៩:១០ **៤:១** ក នក ៣:១៨ **៤:២** ខ ខ.១៧,២០ លប ៣៨:១៨ នក ៧:១៩ ៨:៥,១៦ ១៤:១៦,២១ ១៧:៥–៦,៩ ជន ១៧:២ ២០:៨ យស ៨:១៨ ពច ៦:២១ ១សយ ១៤:២៧ ២ពវ ៤:២៩ **៤:៣** គ នក ៧:៨–១២,១៥ **៤:៥** ឃ ខ.៣១ នក ៣:៦ ១៤:៣១ ១៩:៩ **៤:៦** ង លវ ១៣:២,១១ ជន ១២:១០ ចទ ២៤:៩ ២ពវ ៥:១–២៧ ២របា ២៦:២១ **៤:៧** ច ២ពវ ៥:១៤ មថ ៨:៣ លក ១៧:១២–១៤ **៤:៨** ឆ នក ៣:១៨ ជ ខ.៣០ ពច ៦:១៧ ១ពវ ១៣:៣ អស ៧:១៤ យរ ៤៤:២៩ **៤:៩** ឈ នក ៧:១៧–២១

*ថ្វាយយញ្ញបូជា* ការស្នើសូមទៅថ្វាយដង្វាយ ដោយមានពួកមេតម្រួតសាសន៍អេស៊ីព្ទទៅជាមួយ គឺមិនមែនជារឿងប្លែកឡើយ ។

**៣:២០** *ទាំងការអស្ចារ្យ* គឺជាពាក្យទំនាយអំពីសេចក្តីវេទនាដែលព្រះទ្រង់នឹងទម្លាក់មកលើស្រុកអេស៊ីព្ទ(មើល ៧:១៤–១២:៣០)។

**៣:២១–២២** មើល ១១:២–៣ ១២:៣៥–៣៦ ។

**៣:២១** *ហើយកាលណាចេញទៅ នោះឯងរាល់គ្នានឹងមិនទៅដោយដៃទទេឡើយ* ព្រះបានសន្យានិងលោកអ័ប្រាហាំថា បន្ទាប់ពីអ៊ីស្រាអែលបានបម្រើគេអស់រយៈពេល៤០០ឆ្នាំមក គេនឹងចេញមកវិញដោយសម្បត្តិហូរហៀរ(លប ១៥:១៥ និង ទដ ១០៥:៣៧)។ ពួកសាសន៍អ៊ីស្រាអែល ក៏ត្រូវផ្តល់អំណោយដល់ទាសករដែលខ្លួនបានលែងផងដែរ(ចទ ១៥:១២–១៥)។

**៣:២២** *បង្ហិនពួកសាសន៍អេស៊ីព្ទ* គឺបង្ហិនដូចនៅក្នុងសង្គ្រាមវាយកាន់កាប់ ។

**៤:១–១៧** លោកម៉ូសេប្រាប់ហេតុផលពីរយ៉ាង ដែលនាំឱ្យគាត់ស្ទាក់ស្ទើរនៅក្នុងការស្តាប់បង្គាប់តាមការត្រាស់ហៅពីព្រះអម្ចាស់ ដើម្បីសង្គ្រោះសាសន៍អ៊ីស្រាអែល ពីចំណងនៃនគរអេស៊ីព្ទ(មើលការពន្យល់ ៣:១១,១៣)។ ក្នុងវគ្គនេះ គាត់បានបង្ហាញហេតុផល៣យ៉ាងទៀត(ខ.១,១០,១៣ និងការពន្យល់)។ តែព្រះអម្ចាស់ក៏បានបង្ហាញនូវចម្លើយចំនួន៣ ផងដែរ ។ ដូចនេះលោកម៉ូសេគួតែអាចត្រៀមខ្លួន ដើម្បីចេញពីស្រុកម៉ាឌាន ត្រឡប់ទៅកាន់ស្រុកអេស៊ីព្ទវិញបានហើយ(មើល ខ.១៨–១៣) ។

**៤:១** ក្នុងខនេះ លោកម៉ូសេបង្ហាញពីភាពស្ទាក់ស្ទើរជាលើកទីបី (ទោះបីជាព្រះទ្រង់បានផ្តល់នូវការធានាហើយក៏ដោយ ៣:១៨) ។

**៤:២** *ដំបង* គេជឿថា នោះជាឈើច្រត់ដែលមានក្បាលក្ងក់ របស់ពួកង្វាល ។

**៤:៣** *សត្វពស់* មើល ៧:៩–១០ និងការពន្យល់ ។ ភាគច្រើននៅក្នុងប្រវត្តិសាស្ត្ររបស់នគរអេស៊ីព្ទ ស្តេចផារ៉ោនតុបតែងព្រះកេស ដោយពាក់រូបពស់ធ្វើពីលោហៈពាក់នៅខាងមុខ ជានិមិត្តរូបនៃរាជបល្ល័ង្ករបស់ទ្រង់ ។

**៤:៨** *ទីសំគាល់* ជាព្រឹត្តិការណ៍បែបអធិធម្មជាតិ ដែលកើតឡើងដើម្បីបង្ហាញនូវអំណាច ការធានា(មើល យស ២:១២–១៣) ធ្វើបន្ទាល់(មើល អស ១៩:១៩–២០) ធ្វើការព្រមាន(មើល ជន ១៧:១០) ឬបង្កើនជំនឿ ។ មើលការពន្យល់ ៣:១២ ។

**៤:១០** ក្នុងខនេះ លោកម៉ូសេបង្ហាញពីភាពស្ទាក់ស្ទើរ ជាលើកទី៤ ។ *ទូលបង្គំជាអ្នកមិនសូវមានវោហារទេ* គឺមិនសំដៅទៅលើអសមត្ថភាពនៅក្នុងការនិយាយទេ(មើល កច ៧:២២)។ គាត់កំពុងត្អូញត្អែរពីភាពមិនពូកែវោហា និងគំនិតមិនរហ័សនៅក្នុងការនិយាយតទល់នឹងស្តេចផារ៉ោន(មើល

បង្គំជាអ្នកមិនសូវមានវោហារទេ គឺតាំងតែពីដើមរៀងមក
ហើយឥឡូវនេះដែលទ្រង់បានមានបន្ទូលនឹងទូលបង្គំ ជាអ្នក
បំរើទ្រង់ នោះក៏នៅតែគ្មានដដែល ដ្បិតទូលបង្គំមានមាត់
រឹង ហើយអណ្តាតក៏ដំឡាន់ផង[ញ] ១១នោះព្រះយេហូវ៉ា
ទ្រង់មានបន្ទូលនឹងលោកថា តើអ្នកណាបានបង្កើតមាត់
មនុស្ស តើអ្នកណាដែលធ្វើឱ្យគ ឬឱ្យថ្លង់ ឱ្យភ្លឺ ឬឱ្យខ្វាក់នោះ
បើមិនមែនអញជាព្រះយេហូវ៉ាប៉ុណ្ណោះទេ ១២ដូច្នេះ ចូរ
ឯងទៅឥឡូវចុះ[ឌ] អញនឹងនៅជាមួយនឹងមាត់ឯង ព្រមទាំង
បង្រៀនសេចក្តីដែលឯងត្រូវនិយាយផង[ឍ] ១៣នោះម៉ូសេ
ទូលថា ឱព្រះអម្ចាស់អើយ សូមទ្រង់ចាត់អ្នកណាមួយ
តាមព្រះហឫទ័យទ្រង់ចុះ[ណ] ១៤នោះសេចក្តីខ្ញាល់របស់ព្រះ
យេហូវ៉ាក៏ឆួលឡើង[ត]ទាស់នឹងម៉ូសេ ទ្រង់មានបន្ទូលថា
តើអើរ៉ុន ជាពួកលេវី មិនមែនជាបងឯងទេឬអី អញដឹងថា
គាត់ចេះវោហារស្រួលណាស់ ហើយមើល គាត់ក៏ចេញ
មករក[ថ]ឯងដែរ កាលណាឃើញឯងហើយ នោះគាត់នឹង
មានចិត្តអំណរអរ ១៥ឯងត្រូវជំនុំនឹងគាត់ ហើយបញ្ចេះ
ពាក្យសំដីឱ្យគាត់បាននិយាយ[ទ] ឯអញៗនឹងនៅជាមួយនឹង
មាត់ឯង ហើយនិងមាត់គាត់ដែរ ព្រមទាំងបង្រៀនការ
ដែលឯងត្រូវធ្វើផង ១៦គាត់នឹងនិយាយទៅបណ្តាជនជំនួស
ឯង គាត់នឹងធ្វើជាមាត់ឱ្យឯង[ធ] ហើយឯងនឹងបានដូចជា
ព្រះដល់គាត់[ន] ១៧ត្រូវឱ្យឯងយកដំបងនេះ[ប]កាន់នៅដៃ[ផ]
សំរាប់នឹងធ្វើទីសំគាល់[ព]ចុះ ។

## លោកម៉ូសេត្រឡប់ទៅអេស៊ីព្ទវិញ

១៨នោះម៉ូសេក៏ត្រឡប់ទៅឯយេត្រូជាឪពុកក្មេកជំរាបថា
សូមអនុញ្ញាត ឱ្យខ្ញុំត្រឡប់ទៅឯបងប្អូនខ្ញុំ នៅស្រុកអេស៊ីព្ទ
វិញ ដើម្បីនឹងមើល តើគេនៅរស់ឬយ៉ាងណា យេត្រូតបថា
ចូរទៅដោយសុខសាន្តចុះ ១៩ រីឯស្រុកម៉ាឌាន នោះ
ព្រះយេហូវ៉ាទ្រង់បានមានបន្ទូលនឹងម៉ូសេថា ចូរឯងត្រឡប់
ទៅឯស្រុកអេស៊ីព្ទវិញ ដ្បិតពួកអ្នកដែលចង់សំឡាប់[ភ]ឯង
គេស្លាប់អស់ហើយ[ម] ២០ម៉ូសេក៏ប្រមូលយកប្រពន្ធកូន[យ]
បញ្ជិះលើសត្វលា វិលត្រឡប់ទៅឯស្រុកអេស៊ីព្ទវិញ ក៏យក
ទាំងដំបង[រ]របស់ព្រះកាន់នៅដៃផង ២១ព្រះយេហូវ៉ាទ្រង់
មានបន្ទូលនឹងម៉ូសេថា កាលណាឯងត្រឡប់ទៅដល់ស្រុក
អេស៊ីព្ទហើយ នោះកុំឱ្យខាននឹងធ្វើអស់ទាំងការអស្ចារ្យ[ល]
ដែលអញបានដាក់នៅដៃឯងនៅចំពោះមុខផារ៉ោនឡើយ
តែអញនឹងធ្វើឱ្យផារ៉ោនមានចិត្តរឹងទទឹង[វ] នោះទ្រង់មិន
ព្រមបើកឱ្យបណ្តាជនចេញទៅទេ[ស] ២២ឯងត្រូវទូលទៅ
ផារ៉ោនថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា អ៊ីស្រា
អែលជាកូនអញ គឺជាកូនច្បងរបស់អញ[ហ] ២៣ហើយអញ
ប្រាប់ឯងថា ចូរបើកឱ្យកូនអញចេញទៅ[ឡ] ដើម្បីនឹងថ្វាយ
បង្គំអញ[អ] បើឯងមិនព្រមទេ នោះមើល អញនឹងសំឡាប់កូន
ច្បងរបស់ឯងចោល[ក]។
២៤លុះធ្វើដំណើរមកតាមផ្លូវ នោះព្រះយេហូវ៉ាទ្រង់
មកជួបនឹងលោក នៅត្រង់ផ្ទះសំណាក់ចង់សំឡាប់[ខ]លោក
២៥នោះសេផូរ៉ា[គ] នាងយកថ្មយ៉ាងមុត មកកាត់ស្បែកចុង
ស្វាស[ឃ]របស់កូនបោះចោលទៅត្រង់ជើងប្តី ដោយពាក្យថា

**៤:១០** ញ នក ៣:១១ **៤:១១** ដ លក ១:២០,៦៤ ឋ ទដ ៩៤:៩ ១៤៦:៨ មថ ១១:៥ យហ ១០:២១ **៤:១២** ឌ នក ៣:១០ ឍ ខ.១៥–១៦ ជន ២៣:៥ ចទ ១៨:១៥,១៨ អស ៥០:៤ ៥១:១៦ យរ ១:៩ មថ ១០:១៩–២០ មក ១៣:១១ លក ១២:១២ **៤:១៣** ណ យហ ១:១–៣ **៤:១៤** ត ជន ១:១,១០,៣៣ ១២:៩ ១៦:១៥ ២២:២២ ២៤:១០ ៣២:១៣ ចទ ៧:២៥ យស ៧:១ យប ១៧:៨ ថ ខ.២៧ ១សយ ១០:២–៥ **៤:១៥** ទ ខ.៣០ ជន ២៣:៥,១២,១៦ ចទ ១៨:១៨ យស ១:៨ អស ៥១:១៦ ៥៩:២១ យរ ១:៩ ៣១:៣៣ **៤:១៦** ធ នក ៧:១–២ យរ ១៥:១៩ ៣៦:៦ ន ជន ៣៣:១ ទដ ៧៧:២០ ១០៥:២៦ មីក ៦:៤ **៤:១៧** ប ខ.២ ផ ខ.២០ នក ១៧:៩ ព នក ៧:៩–២១ ៨:៥,១៦ ៩:២២ ១០:១២–១៥,២១–២៣ ១៤:១៥–១៨,២៦ ជន ១៤:១១ ចទ ៤:៣៤ ទដ ៧៤:៩ ៧៨:៤៣ ១០៥:២៧ **៤:១៩** ភ នក ២:១៥ម នក ២:២៣ មថ ២:២០ **៤:២០** យ នក ២:២២ ១៨:៣ កច ៧:២៩ រ ខ.២ **៤:២១** ល នក ៣:១៩,២០ វ នក ៧:៣,១៣ ៨:១៥ ៩:១២,៣៥ ១០:១,២០,២៧ ១១:១០ ១៤:៤៨ ចទ ២:៣០ យស ១១:២០ ១សយ ៦:៦ ទដ ១០៥:២៥ អស ៦:១០ ៦៣:១៧ យហ ១២:៤០ រម ៩:១៨ ស នក ៨:៣២ ៩:១៧ **៤:២២** ហ លប ១០:១៥ ចទ ៣២:៦ អស ៩:៦ ៦៣:១៦ ៦៤:៨ យរ ៣:១៩ ៣១:៩ ហស ១១:១ មឡ ២:១០ រម ៩:៤ ២កថ **៤:២៣** ឡ នក ៥:១ ៧:១៦ អ នក ៣:១៨ ក លប ៤៩:៣ នក ១១:៥ ១២:១២,២៩ ជន ៨:១៧ ៣៣:៤ ទដ ៧៨:៥១ ១០៥:២៦ ១៣៥:៨ ១៣៦:១០ **៤:២៤** ខ ជន ២២:២២ **៤:២៥** គ នក ២:២១ ឃ លប ១៧:១៤ យស ៥:២,៣

៦:១២)។ ធៀបនឹងការពណ៌នារបស់លោកប៉ូល ក្នុង ២កថ ១០:១០ ។

**៤:១៣** ក្នុងខនេះ លោកម៉ូសេបង្ហាញពីភាពស្ទាក់ស្ទើរលើកទី៥ ដែលជាលើកចុងក្រោយរបស់លោកម៉ូសេ(មើលការពន្យល់ ៣:១១) ។

**៤:១៤** *សេចក្តីខ្ញាល់របស់ព្រះយេហូវ៉ា ក៏ឆួលឡើងទាស់នឹងម៉ូសេ* មើល ៣៤:៧ ។ *ពួកលេវី* ក្រោមការដឹកនាំរបស់លោកអើរ៉ុន ពួកសង្ឃត្រូវជ្រើសរើសចេញពីពួកលេវី ។

**៤:១៥–១៦** មើលការពន្យល់ ៧:១–២ ។

**៤:១៩** *ពួកអ្នកដែលចង់សំឡាប់ឯងគេស្លាប់អស់ហើយ* គឺរួមទាំងស្តេចធូតម៉ូស ទី៣ ផងដែរ (Thutmose III, មើល ២:១៥,២៣)។

**៤:២០** *កូន* (គឺកូនប្រុសៗ)មានលោកគើសំម(មើល ២:២២) និងលោកអេលាសើរ ។ ឈ្មោះលោកអេលាសើរមាននិយាយនៅក្នុង ១៨:៤ ។

**៤:២១** *ការអស្ចារ្យ* មើល ៣:២០ ។ *អញនឹងធ្វើឱ្យផារ៉ោន* ព្រះទ្រង់បានបណ្តាលឱ្យស្តេចផារ៉ោនមានចិត្តរឹងទទឹង ចំនួន ៩ដង នៅក្នុងគម្ពីរនិក្ខមនំ (មើល ៧:៣ ៩:១២ ១០:១,២០,២៧ ១១:១០ ១៤:៤,៨ យស ១១:២០ រម ៩:១៧–១៨ និងការពន្យល់) មាន៩ម្តងទៀត ដែលស្តេចផារ៉ោនបានរឹងទទឹង(៧:១៣–១៤,២២ ៨:១៥,១៩,៣២ ៩:៧,៣៤–៣៥)។ សូមមើលបន្ថែមនៅត្រង់ចំណុចនៃការធ្វើឱ្យចិត្តរឹង នៅក្នុង រម ១:២៤–២៨ ។

**៤:២២** *គឺជាកូនច្បង* ពាក្យនេះត្រូវបានប្រើដើម្បីបង្ហាញអំពីទំនាក់ទំនងរបស់ពួកអ៊ីស្រាអែលជាមួយនឹងព្រះ (មើល យរ ៣១:៩ ហស ១១:១) ។

**៤:២៣** *សំឡាប់កូនច្បងរបស់ឯងចោល* នៅក្នុងខនេះព្រះទ្រង់មានបន្ទូលជាមុនអំពីសេចក្តីវេទនាទី១០(មើល ១១:៥ ១២:១២) ។

**៤:២៤** *នៅត្រង់ផ្ទះសំណាក់* ប្រហែលជាទីកន្លែងនៅក្បែរទឹក ដែលអ្នកដំណើរអាចស្នាក់នៅពេលយប់ ។ *ចង់សំឡាប់លោក* ដោយព្រោះលោកម៉ូសេ ពុំបានកាត់ស្បែកកូនគាត់ទេ(សូមមើល ១៧:៩–១៤) ។

**៤:២៥** *សេផូរ៉ា . . . កាត់ស្បែកចុងស្វាសរបស់កូន* នាងដឹងថា លោកម៉ូសេនឹងត្រូវស្លាប់ ដោយការដែលព្រះមិនសព្វព្រះទ័យនេះ ដូចនេះ នាងក៏បាន

អ្នកជាប្ដីបានឈ្មោះថាខ្មាយឈាមដល់ខ្ញុំហើយ ២៦រួចទ្រង់
លែងធ្វើលោកទៅ ហើយនាងនិយាយថា អ្នកជាប្ដីបាន
ឈ្មោះថាខ្មាយឈាមហើយ ដោយព្រោះការកាត់ស្បែក
នេះ ។
២៧ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងអើរ៉ុនថា ចូរទៅជួប
នឹងម៉ូសេនៅទីរហោស្ថាន លោកក៏ទៅ បានជួបនៅត្រង់
ភ្នំព្រះ[ង] ហើយថើប[ច]គ្នា ២៨នោះម៉ូសេប្រាប់ទៅអើរ៉ុនពី
គ្រប់ទាំងសេចក្ដីដែលព្រះយេហូវ៉ាបានផ្ដាំ និងគ្រប់ទាំងទី
សំគាល់ដែលទ្រង់បានបង្គាប់មក ២៩ម៉ូសេ និងអើរ៉ុនក៏នាំ
គ្នាទៅប្រមូលពួកចាស់ទុំ[ឆ] នៃពួកកូនចៅអ៊ីស្រាអែល ៣០រួច
ហើយ អើរ៉ុនរ៉ាយរឿងប្រាប់ ពីអស់ទាំងសេចក្ដីដែល
ព្រះយេហូវ៉ាមានបន្ទូលនឹងម៉ូសេ ព្រមទាំងធ្វើអស់ទាំងទី
សំគាល់[ជ]នោះ នៅមុខគេដែរ ៣១បណ្ដាជនទាំងឡាយក៏
ជឿ[ឈ] ហើយកាលគេបានឃើញថា ព្រះយេហូវ៉ាទ្រង់បាន
ប្រោសដល់ពួកកូនចៅអ៊ីស្រាអែល ហើយថា ទ្រង់បានទត
ឃើញ[ញ]សេចក្ដីទុក្ខលំបាករបស់គេ[ដ] នោះក៏នាំគ្នាឱនក្បាល
ថ្វាយបង្គំទ្រង់[ឋ] ។

## ការធ្វើឥដ្ឋអត់ចម្បើង

**៥** ១ក្រោយនោះមក ម៉ូសេ និងអើរ៉ុននាំគ្នាចូលទៅគាល់
ផារ៉ោនទូលថា ព្រះយេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលដូច្នេះថា ចូរឱ្យរាស្ត្រអញចេញ[ក]ទៅថ្វាយ
យញ្ញបូជា[ខ]ដល់អញនៅទីរហោស្ថាន ២តែផារ៉ោនមាន
បន្ទូលឆ្លើយថា តើព្រះយេហូវ៉ាជាអ្នកណា[គ]ដែលអញត្រូវ
ស្ដាប់តាមទ្រង់ និងឱ្យសាសន៍អ៊ីស្រាអែលចេញទៅនោះ
អញមិនស្គាល់ព្រះយេហូវ៉ាទេ ហើយក៏មិនព្រមឱ្យសាសន៍
អ៊ីស្រាអែលចេញទៅឡើយ[ឃ] ៣នោះគេទូលថា ព្រះនៃ
សាសន៍ហេព្រើរ ទ្រង់បានលេចមកឯយើងខ្ញុំហើយ ដូច្នេះ
សូមទ្រង់អនុញ្ញាត ឱ្យយើងខ្ញុំរាល់គ្នា ទៅឯទីរហោស្ថាន
ចំងាយផ្លូវដើរអស់៣ថ្ងៃ[ង] ដើម្បីនឹងថ្វាយយញ្ញបូជាដល់ព្រះ
យេហូវ៉ាជាព្រះនៃយើងខ្ញុំ ខ្លាចក្រែងទ្រង់ស្ទុះមកប្រហារ

**៤:២៧** ង នក ៣:១ ច លប ១៧:១៤ យស ៥:២,៣
**៤:២៩** ឆ នក ៣:១៦
**៤:៣០** ជ ខ.៨
**៤:៣១** ឈ នក ៣:១៨ ញ នក ២:២៥ ដ លប ១៦:១១ ឋ លប ២៤:២៦
**៥:១** ក នក ៤:២៣ ខ នក ៣:១៨
**៥:២** គ ពច ២:១០ យប ២១:១៥ មឡ ៣:១៤ ឃ នក ៣:១៩
**៥:៣** ង លប ៣០:៣៦ ច លវ ២៦:២៥ ជន ១៤:១២ ចទ ២៨:១២ ២សយ ២៨:២១
**៥:៤** ឆ នក ១:១១ ៦:៦-៧
**៥:៥** ជ លប ១២:២
**៥:៦** ឈ លប ១៥:១៣
**៥:៧** ញ លប ១១:៣
**៥:៨** ដ ខ.១៤,១៨ ឋ ខ.១៧ ឌ នក ១០:១១
**៥:១០** ឍ ខ.១៣ នក ១:១១
**៥:១១** ណ ខ.១៩
**៥:១៤** ត ខ.១៦ អស ១០:២៤

យើងរាល់គ្នា ដោយអាសន្នរោគ[ច]ឬដាវផង ៤តែស្ដេចស្រុក
អេស៊ីព្ទទ្រង់មានបន្ទូលថា នែម៉ូសេនិងអើរ៉ុន ហេតុអ្វីបាន
ជាឯងបញ្ឈប់ពួកជនមិនឱ្យធ្វើការដូច្នេះ ចូរឯងរាល់គ្នា
ត្រឡប់ទៅធ្វើការរបស់ឯងវិញទៅ ។
៥ផារ៉ោនទ្រង់ក៏មានបន្ទូលថា មើល ឥឡូវនេះបណ្ដា
ជននៅស្រុកនេះគេមានគ្នាច្រើន[ជ] ហើយឯងមកធ្វើឱ្យគេ
ឈប់ពីការគេចេញដូច្នេះ ៦នៅថ្ងៃនោះឯងផារ៉ោនទ្រង់
បង្គាប់ដល់ពួកមេដំរួត[ឈ] លើជនទាំងឡាយ ហើយនិងពួក
នាយថា ៧ចូរកុំឱ្យចំបើងដល់ជនសំរាប់នឹងធ្វើឥដ្ឋដូចអំពី
ដើមទៀតឡើយ[ញ] ត្រូវឱ្យគេទៅរកចំបើងដោយខ្លួនឯងវិញ
៨តែឯចំនួនឥដ្ឋដែលគេធ្លាប់ធ្វើពីដើមមក[ដ] នោះត្រូវបង្ខំ
ឱ្យគេចេះតែធ្វើទៅទៀតចុះ កុំបន្ថយឱ្យសោះ ដ្បិតគេខ្ជិល
ទេ[ឋ] បានជាស្រែកថា សូមឱ្យយើងរាល់គ្នាទៅថ្វាយយញ្ញ
បូជាដល់ព្រះនៃយើងខ្ញុំ[ឌ] ៩ត្រូវដាក់បន្ទុកឱ្យគេធ្វើរឹតតែធ្ងន់
ឡើង ដើម្បីឱ្យគេខំធ្វើទៅ កុំឱ្យគេទុកចិត្តនឹងពាក្យកំភូត
ឡើយ ។
១០ពួកមេដំរួតលើពួកជន[ឍ] និងពួកនាយ ក៏ទៅប្រាប់ដល់គេ
ថា ផារ៉ោនទ្រង់មានបន្ទូលដូច្នេះថា អញលែងបើកចំបើង
ឱ្យឯងរាល់គ្នាហើយ ១១ចូរទៅរកចំបើងដោយខ្លួន ឯងនៅ
កន្លែងណាដែលរកបានចុះ ប៉ុន្តែការរបស់ឯងរាល់គ្នា
នោះមិនត្រូវបន្ថយ[ណ]សូម្បីដល់បន្តិចបន្តួចឡើយ ១២ដូច្នេះ
បណ្ដាជនទាំងឡាយត្រូវខ្ចាត់ខ្ចាយ ទៅពេញក្នុងស្រុកអេស៊ីព្ទ
ដើម្បីនឹងរករើសជញ្ជ្រាំងមកជំនួសចំបើង ១៣ពួកមេដំរួត
ក៏ពោលបង្ខំថា ចូរឯងរាល់គ្នាធ្វើបង្ហើយ ការរបស់ឯងដូច
ជាបានដាក់ឱ្យធ្វើមករាល់តែថ្ងៃ ឱ្យដូចជាកាលមានចំបើង
ពីដើមមកដែរ ១៤គេក៏វាយ[ត]ពួកមេនៃកូនចៅអ៊ីស្រាអែល
ដែលពួកមេដំរួតរបស់ផារ៉ោន បានតាំងលើបណ្ដាជន
ហើយសួរថា ហេតុអ្វីបានជាពីម្សិលមិញ ហើយថ្ងៃនេះ
ឯងរាល់គ្នាមិនបានធ្វើឥដ្ឋឱ្យគ្រប់ចំនួនដូចអំពីដើមមក ។
១៥នោះពួកមេរបស់កូនចៅអ៊ីស្រាអែល ក៏នាំគ្នាទៅ

---

កាត់ចុងស្វាសរបស់កូនប្រុស ។ *ថ្មយ៉ាងមុត* គឺជាខ្លឹមថ្មម្យ៉ាង ដែលមុតជាង លោហៈនៅសម័យនោះ ដូចនេះងាយស្រួលប្រើនៅក្នុងការកាត់ស្បែកជាង។ (មើល យស ៥:២ និងការពន្យល់) ។

**៤:២៦** *ជាប្ដីបានឈ្មោះថាខ្មាយឈាម* នៅតំបន់មជ្ឈឹមបូព៌ានៅសម័យនោះ មានអ្នកកាត់ស្បែកជាច្រើននាក់ ដោយមូលហេតុផ្សេងៗ តែការកាត់ស្បែក នេះអាចគួរឱ្យខ្លាច និងខ្ពើមដល់នាងសេផូរ៉ា ។

**៤:២៧** *ថើប* មើលការពន្យល់ លប ២៩:១៣ ។

**៤:៣០** *អើរ៉ុនរ៉ាយរឿងប្រាប់ពីអស់សេចក្ដី ដែលព្រះយេហូវ៉ាមានបន្ទូលនឹង ម៉ូសេ* មើលការពន្យល់ ៧:១-២ ។

**៥:១** *ផារ៉ោន* មើលការពន្យល់ ៣:១០ ។

**៥:៦** *ពួកមេដំរួត* គេជឿថា ពួកនេះជាពួកមេតម្រួតសាសន៍អេស៊ីព្ទ ក្នុង ១:១១(មើលការពន្យល់ខនេះ)។ *ពួកនាយ* ពួកនេះជាសាសន៍អ៊ីស្រាអែល ដែលមាននិយាយអំពីការតែងតាំង និងតួនាទីនៅក្នុង ខ.១៤-១៦ ។

**៥:៧** *ចំបើង* គេកាត់ចំបើងខ្លីៗ លាយជាមួយនឹងដីឥដ្ឋ ដើម្បីធ្វើឱ្យឥដ្ឋមាំ ។

**៥:៩** *កំភូត* មើល ៤:២៩-៣១ ។

**៥:១០** *ផារ៉ោនទ្រង់មានបន្ទូលដូច្នេះថា* គឺផ្ទុយនឹងឃ្លាថា "ព្រះយេហូវ៉ាទ្រង់ មានបន្ទូលដូច្នេះថា"(មើល ៤:២២ ៥:១)។ នៅក្នុងខនេះ ស្ដេចផារ៉ោន កំពុងចាប់ផ្ដើមតតាំងនឹងព្រះនៃសាសន៍អ៊ីស្រាអែល ។

**៥:១៥** *ពួកមេ . . . ស្រែកដល់ផារ៉ោនថា* ជួនកាលនៅក្នុងប្រវត្តិសាស្ត្រនៃ សាសន៍អេស៊ីព្ទ គេអនុញ្ញាតិឱ្យពួកទាសករទៅគាល់ស្ដេចផារ៉ោនដោយផ្ទាល់

ស្រែកដល់ផារ៉ោនថា ហេតុអ្វីបានជាទ្រង់ប្រព្រឹត្តនឹងយើង
ខ្ញុំជាពួកបំរើទ្រង់យ៉ាងដូច្នេះ ១៦ដ្បិតគេមិនឱ្យចំបើងដល់
យើងខ្ញុំជាពួកបំរើទ្រង់ទៀត ហើយគេប្រាប់យើងខ្ញុំថា
ចូរខំធ្វើឥដ្ឋទៅ គេក៏វាយយើងខ្ញុំជាពួកបំរើទ្រង់ដែរ តែគឺ
ពួកទ្រង់ទេ ដែលធ្វើខុសនោះ ១៧ទ្រង់ឆ្លើយតបថា ឯង
រាល់គ្នាជាមនុស្សកំជិល គឺឯងខ្ជិលទេ[ថ] បានជានិយាយថា
សូមបើកឱ្យយើងរាល់គ្នាទៅថ្វាយយញ្ញបូជាដល់ព្រះ
យេហូវ៉ា ១៨ដូច្នេះចូរឯងរាល់គ្នាត្រឡប់ទៅធ្វើវិញឥឡូវ
ចុះ[ទ] ដ្បិតគេមិនត្រូវឱ្យចំបើងដល់ឯងរាល់គ្នាទេ តែត្រូវឱ្យ
ឯង ធ្វើឥដ្ឋនោះឱ្យគ្រប់ចំនួនកុំខាន ១៩ឯងពួកមេរបស់កូន
ចៅអ៊ីស្រាអែល កាលគេឮថា មិនត្រូវបន្ថយចំនួនឥដ្ឋដែល
ត្រូវធ្វើរាល់ថ្ងៃដូច្នេះ នោះក៏ឃើញថា ខ្លួនជាមនុស្សជាប់
សេចក្តីវេទនាហើយ ២០គេក៏ចេញពីចំពោះផារ៉ោនមកជួប
នឹងម៉ូសេ ហើយនិងអើរ៉ុន ដែលកំពុងតែឈរចាំ ២១ក៏
និយាយថា សូមឱ្យព្រះយេហូវ៉ាពិចារណាហើយជំនុំជំរះ
អ្នកចុះ[ធ] ដ្បិតអ្នកបានធ្វើឱ្យយើងរាល់គ្នាស្អុយកេរ[ន] នៅ
ចំពោះផារ៉ោន និងពួកមហាតលិកទ្រង់ព្រមទាំងដាក់ដាវ[ប]
នៅដៃគេឱ្យសំឡាប់យើងរាល់គ្នា"[ផ]។

## ព្រះអម្ចាស់សន្យាប្រោសរាស្ត្រអ៊ីស្រាអែល

២២នោះម៉ូសេ គាត់ត្រឡប់ទៅឯព្រះយេហូវ៉ា ទូលថា ឱ
ព្រះអម្ចាស់អើយ ហេតុអ្វីបានជាទ្រង់ធ្វើបាបដល់ពួកបណ្តា
ជននេះដូច្នេះ[ព] តើទ្រង់បានចាត់ទូលបង្គំមកធ្វើអ្វី ២៣ដ្បិត
តាំងតែពីទូលបង្គំចូលទៅទូលផារ៉ោន ដោយនូវព្រះនាម
ទ្រង់ នោះផារ៉ោនចេះតែធ្វើបាបដល់បណ្តាជននេះ ហើយ
ទ្រង់សោត ក៏មិនបានប្រោស[ភ] រាស្ត្រទ្រង់ឱ្យរួចផងដែរ ។

**៥:១៧** ថ ខ.៨
**៥:១៨** ទ លប ១៥:១៣
**៥:២១** ធ លប ១៦:៥ ន លប ៣៤:៣០ ប នក ១៦:៣ ជន ១៤:៣ ២០:៣ ផ នក ១:១៣ ១៤:១១
**៥:២២** ព ជន ១១:១១ ចទ ១:១២ យស ៧:៧
**៥:២៣** ភ យរ ៤:១០ ២០:៧ អគ ១៤:៩

**៦:១** ក នក ៣:២០ ចទ ៥:១៥ ខ នក ៣:២០ គ នក ១១:១ ១២:៣១,៣៣,៣៩
**៦:២** ឃ ខ.៦,៧,៨, ២៩ នក ៣:១៤,១៥ ៧:៥,១៧ ៨:២២ ១០:២ ១២:១២ ១៤:៤,១៨ ១៦:១២ លវ ១១:៤៤ ១៨:២១ ២០:៧ អស ២៥:៣ ៤១:២០ ៤៣:១១ ៤៩:២៣ ៦០:១៦ អគ ១៣:៩ ២៥:១៧ ៣៦:៣៨ ៣៧:៦,១៣ យអ ២:២៧
**៦:៣** ង លប ១៧:១

៦ ១នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ឥឡូវនេះ
ឯងនឹងឃើញការដែលអញធ្វើដល់ផារ៉ោន ដ្បិតដោយដៃ
ខ្លាំងពូកែ[ក] នោះអញនឹងឱ្យរាស្ត្រអញចេញទៅ[ខ] ហើយ
ដោយដៃខ្លាំងពូកែ ផារ៉ោននឹងបណ្តេញគេចេញពីស្រុក
ទៅផង[គ] ។

២ព្រះទ្រង់ក៏មានបន្ទូលទៅម៉ូសេទៀតថា អញជាព្រះ
យេហូវ៉ា[ឃ] ៣អញបានលេចមកឯអ័ប្រាហាំ អ៊ីសាក ហើយ
និងយ៉ាកុបសំដែងចេញជាព្រះដ៏មានគ្រប់ព្រះចេស្តា[ង] ប៉ុន្តែ
គេមិនស្គាល់អញ[ច]ដោយនាមជា "យេហូវ៉ា"[ឆ] របស់អញ
នោះទេ ៤អញក៏បានតាំងសេចក្តីសញ្ញារបស់អញ[ជ]ដល់គេថា
នឹងឱ្យស្រុក[ឈ]កាណានដល់គេ គឺជាស្រុកដែលគេបានស្នាក់
នៅទុកដូចជាអ្នកដទៃ[ញ] ៥អញបានឮដំងូរ[ដ]របស់ពួកកូន
ចៅអ៊ីស្រាអែល ដែលពួកសាសន៍អេស៊ីព្ទចាប់ជាបាវបំរើ
ហើយអញបានរឭកដល់សេចក្តីសញ្ញារបស់អញនោះ[ឋ]
៦ដូច្នេះចូរនិយាយនឹងពួកកូនចៅអ៊ីស្រាអែលថា អញជាព្រះ
យេហូវ៉ា អញនឹងនាំឯងរាល់គ្នាចេញឱ្យរួចពីបន្ទុកនៃពួក
សាសន៍អេស៊ីព្ទ[ឌ] ហើយនឹងជួយឱ្យរួច[ឍ]ពីការបំរើគេ អញ
នឹងលើកដៃអញឡើង[ណ]លោះឯងរាល់គ្នា ដោយការវិនិច្ឆ័យ

ច នក ៣:១៥ ២សយ ៧:២៦ ទដ ៤៨:១០ ៦១:៥ ៦៨:៤ ៨៣:១៨ ៩៩:៣ អស ៥២:៦ ឆ នក ៣:១៤ យហ ៨:៥៨ **៦:៤** ជ លប ៦:១៨ ១៥:១៨ ឈ លប ១២:៧ កច ៧:៥ រម ៤:១៣ កទ ៣:១៦ ហព ១១:៨–១០ ញ លប ១៧:៨ **៦:៥** ដ នក ២:២៣ កច ៧:៣៤ ឋ លប ៩:១៥ **៦:៦** ឌ ខ.៧ នក ៣:៨១២:១៧,៥១ ១៦:១,៦ ១៨:១ ១៩:១ ២០:២ ២៩:៤៦ លវ ២២:២៣ ២៦:១៣ ចទ ៦:១២ ទដ ៨១:១០ ១៣៦:១១ យរ ២:៦ ហស ១៣:៤ អម ២:១០ មីក ៦:៤ ឍ នក ១៥:១៣ ចទ ៧:៨ ៩:២៦ ១របា ១៧:២១ យប ១៩:២៥ ទដ ១៩:១៤ ៣៤:២២ ៧៤:២ ៧៧:១៥ ១០៧:២ អស ២៩:២២ ៣៥:៩ ៤៣:១ ៤៤:២៣ ៤៨:២០ យរ ១៥:២១ ៣១:១១ ៥០:៣៤ ណ នក ៣:១៩,២០ យរ ៣២:២១ កច ១៣:១៧

ដោយមិនបាច់គោរពតាមរដ្ឋបាលការងារទេ ។

**៥:២១** *សូមឱ្យព្រះយេហូវ៉ាពិចារណាហើយជំនុំជំរះអ្នកចុះ* មើល លប ១៦:៥ ៣១:៤៩ និងការពន្យល់ ។ *ស្អុយកេរ* មើលការពន្យល់ ១សយ ១៣:៤ ។

**៦:១** *ដៃ* ជាញឹកញាប់ នៅក្នុងព្រះគម្ពីរ គេប្រើពាក្យនេះ តំណាងអោយអំណាច ។

**៦:២** *អញជាព្រះយេហូវ៉ា* ពាក្យនេះមានសរសេរ ៤ដងនៅក្នុងខនេះដើម្បី : (១).ធ្វើសេចក្តីផ្តើមនៃព្រះបន្ទូល ។ (២).បញ្ជាក់អំពីព្រះបន្ទូលសន្យា អំពីការប្រោសលោះ(ខ.៦) ដោយបង្ហាញភស្តុតាងក្នុង ខ.២–៥។ (៣).និយាយសង្កត់ធ្ងន់ អំពីការដែលព្រះអម្ចាស់ទ្រង់រើសសាសន៍អ៊ីស្រាអែល(ខ.៧)។ (៤).បញ្ជាក់ព្រះបន្ទូលអំពីទឹកដីសន្យា និងបញ្ចប់ព្រះបន្ទូល(ខ.៨)។

**៦:៣** *ព្រះដ៏មានគ្រប់ព្រះចេស្តា* មើលការពន្យល់ លប ១៧:១ ។ *គេមិនបានស្គាល់អញដោយនាមជា"យេហូវ៉ា"* មើលការពន្យល់ ៣:១៤–១៥ ។ ត្រង់ចំណុចនេះ មិនមែនមានន័យថា ពួកព្ធយុកោទាំងនោះ មិនបានស្គាល់ព្រះនាមនៃអម្ចាស់នោះឡើយ គឺពួកគេគ្រាន់តែមិនទាន់បានពិសោធការប្រោសលោះ ដោយនូវព្រះនាមទ្រង់(មើលការពន្យល់ ខ.៦ លប ២:៤)។ ជាការពិតណាស់ ការប្រោសលោះនេះ បានកើតមានចំពោះពួកអ៊ីស្រាអែល ដែលធ្វើនិក្ខមនំពីស្រុកអេស៊ីព្ទ និងកូនចៅរបស់ពួកគេ ។ *ស្គាល់អញ* ព្រះគម្ពីរនេះបានប្រើពាក្យស្គាល់ជាច្រើនដង នៅក្នុងការពិពណ៌នាអំពីសេចក្តីវេទនារបស់សាសន៍អេស៊ីព្ទ(មើល ខ.៧ ៧:១៧ ៨:១០,២២ ៩:១៤,២៩ ១០:២ ១១:៧) និងអំពីការធ្វើនិក្ខមនំ(សូមមើល ១៤:៤,១៨ ១៦:៦,៨,១២ ១៨:១១)។

**៦:៥** *បានរឭកដល់* មើលការពន្យល់ លប ៨:១ ។

**៦:៦** *អញនឹងនាំឯងរាល់គ្នាចេញឱ្យរួចពីបន្ទុក . . . រួចពីការបំរើគេ* កិរិយាស័ព្ទទាំងនេះបានបញ្ជាក់អំពីព្រះនាព្រះអម្ចាស់ថា ទ្រង់ជាព្រះដែលប្រោសលោះរាស្ត្រទ្រង់(មើលការពន្យល់ ខ.៣)។ *លើកដៃអញឡើងលោះឯងរាល់គ្នា* ជាពាក្យប្រៀបប្រដូចអំពីការដែលព្រះទ្រង់ប្រើអំណាចចេស្តានៅក្នុងការប្រោសលោះរាស្ត្រទ្រង់(មើល ចទ ៤:៣៤ ៥:១៥ មើល អស ៥១:៩–១១ និងការពន្យល់ ៥១:៩)។ *ដោយការវិនិច្ឆ័យយ៉ាងធំ* មើល ៧:៤

យ៉ាងធំ[ត] ៧អញនឹងយកឯងរាល់គ្នាទុកជារាស្ត្ររបស់អញ ក៏
នឹងធ្វើជាព្រះដល់ឯងរាល់គ្នា[ថ] នោះឯងនឹងបានដឹង[ទ]ថា
អញនេះជាយេហូវ៉ា គឺជាព្រះនៃឯង ដែលនាំឯងចេញផុត
ពីបន្ទុករបស់សាសន៍អេស៊ីព្ទ ៨អញនឹងនាំឯងរាល់គ្នាចូល
ទៅក្នុងស្រុក[ធ]ដែលអញបានលើកដៃ[ន]ស្បថ[ប]ថា នឹងឱ្យទៅ
អ័ប្រាហាំ អ៊ីសាក ហើយយ៉ាកុប[ផ] អញនឹងឱ្យស្រុកនោះដល់
ឯងរាល់គ្នាទុកជាកេរ្តិ៍អាករវិញ គឺអញនេះហើយជាព្រះ
យេហូវ៉ា[ព] ៩រួចម៉ូសេក៏ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល
តាមពាក្យនោះ ប៉ុន្តែដោយព្រោះសេចក្តីវេទនា និងការ
បំរើយ៉ាងសហ័ស បានជាគេមិនព្រមស្តាប់តាមលោកទេ[ភ]។
១០នោះព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ១១ឱ្យចូលទៅទូល[ម]
ផារ៉ោនជាស្តេចស្រុកអេស៊ីព្ទថា ចូរបើកឱ្យពួកកូនចៅ
អ៊ីស្រាអែលចេញពីស្រុកទៅ[យ] ១២តែម៉ូសេទូលនៅចំពោះ
ព្រះយេហូវ៉ាថា មើល សូម្បីតែពួកកូនចៅអ៊ីស្រាអែលក៏
មិនព្រមស្តាប់[រ]តាមទូលបង្គំទៅហើយ ចំណង់បើផារ៉ោន
ធ្វើដូចម្តេចឱ្យស្តាប់តាមទូលបង្គំបាន បើទូលបង្គំជាអ្នកមិន
សូវចេះវោហារដូច្នេះផង[ល]។

## បញ្ជីពួកមេនៃគ្រួសារ លោកម៉ូសេ និងលោកអើរ៉ុន

១៣នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលប្រាប់ម៉ូសេនិង
អើរ៉ុន ជាសេចក្តីបង្គាប់ដល់ពួកកូនចៅអ៊ីស្រាអែល ហើយ
ដល់ផារ៉ោនជាស្តេចស្រុកអេស៊ីព្ទ ប្រយោជន៍ដើម្បីនឹងនាំ
ពួកកូនចៅអ៊ីស្រាអែល ឱ្យចេញពីស្រុកអេស៊ីព្ទទៅ[វ]។
១៤នេះជាបញ្ជីពួកមេនៃគ្រួសារឪពុកគេទាំងប៉ុន្មាន[ស] ពួក
កូនរូបេនដែលជាកូនច្បងរបស់អ៊ីស្រាអែល គឺហេណុក
ប៉ាលូវ ហេស្រុន និងកើមី នេះឯងជាគ្រួរបស់រូបេន[ហ] ទាំង
ប៉ុន្មាន ១៥ពួកកូនស៊ីម្មាន[ឡ] គឺយេមូអែល យ៉ាមីន អូហាត់
យ៉ាគិន សូហា និងសូលជាកូនរបស់ស្ត្រីសាសន៍កាណាន
ម្នាក់ នេះឯងជាគ្រួស៊ីម្មានទាំងប៉ុន្មាន ១៦នេះឈ្មោះរបស់
ពួកកូនលេវី[អ] តាមពូជដំណរបស់គេតមក គឺគើសុន[ក]
កេហាត់ និងម្រ៉ារី[ខ] ឯលេវីក៏មានអាយុរស់នៅបាន១៣៧ឆ្នាំ
១៧ពួកកូនគើសុន គឺលិបនី ហើយនិងស៊ីម៉ាយ តាមគ្រួគេ[គ]
១៨ពួកកូនកេហាត់[ឃ] គឺអាំរ៉ាម យីតសារ ហេប្រុសន
និងអ៊ូស៊ាល[ង] ឯកេហាត់ក៏មានអាយុរស់នៅបាន១៣៣ឆ្នាំ
១៩ពួកកូនម្រ៉ារី គឺម៉ាស់លី និងមូស៊ី[ច] នេះឯងជាគ្រួរបស់
លេវីតាមពូជដំណរបស់គេតមក ២០ឯអាំរ៉ាម[ឆ] គាត់យក
យ៉ូកិបិត ជាម្តាយមីង ធ្វើជាប្រពន្ធហើយនាងបង្កើតអើរ៉ុន
និងម៉ូសេឱ្យគាត់[ជ] ឯអាំរ៉ាមគាត់មានអាយុរស់នៅបាន១៣៧
ឆ្នាំ ២១ពួកកូនយីតសារ[ឈ] គឺកូរេ នេផេក ហើយស៊ីកគ្រី
២២ពួកកូនអ៊ូស៊ាល គឺមីសាអែល អេលសាផាន[ញ] និងស៊ីតទ្រី
២៣ឯអើរ៉ុនលោកយកនាងអេលីសេបា ជាកូនអ័មីន៉ាដាប់[ដ]
ហើយជាប្អូនណាសូន[ឋ] ធ្វើជាប្រពន្ធ នាងបង្កើតបានណា
ដាប អ័ប៊ីហ៊ូវ[ឌ] អេលាសារ[ឍ] និងអ៊ីថាម៉ារឱ្យលោក[ណ]
២៤ពួកកូនកូរេ[ត] គឺអាស់ស៊ា អែលកាណា និងអេបៀសាប់
នេះឯងជាគ្រួពូជកូរេទាំងប៉ុន្មាន ២៥អេលាសា ជាកូនអើរ៉ុន

**៦:៦** ត នក ៣:២០ ទដ ៩:១៦ ១០៥:២៧ **៦:៧** ថ លប ១៧:៧ នក ៣៤:៩ អក ១១:១៩–២០ រម ៩:៤ ទ ខ.២ ១៣វ ២០:១៣,២៨ អស ៤៣:១០ ៤៨:៧ អក ៣៩:៦ យអ ៣:១៧ **៦:៨** ធ លប ១២:៧ នក ៣:៨ ន លប ១៤:២២ វវ ១០:៥–៦ ប យអ ១១:៥ អក ២០:៦ ផ ទដ ១៣៦:២១–២២ ព លវ ១៨:២១ **៦:៩** ភ លប ៣៤:៣០ នក ២:២៣ **៦:១១** ម ខ.២៩ យ នក ៣:១៨ **៦:១២** រ នក ៣:១៨ ល នក ៤:១០ **៦:១៣** វ នក ៣:១០ **៦:១៤** ស នក ១៣:៣ ជន ១:១ ២៦:៤ ហ លប ២៩:៣២ **៦:១៥** ឡ លប ២៩:៣៣ **៦:១៦** អ លប ២៩:៣៤ ក លប ៤៦:១១ ខ ជន ៣:១៧ យស ២១:៧ ១របា ៦:១,១៦ ល នក ៤:១០

**៦:១៣** វ នក ៣:១០ **៦:១៤** ស នក ១៣:៣ ជន ១:១ ២៦:៤ **៦:១៧** គ ជន ៣:១៨ ១របា ៦:១៧ **៦:១៨** ឃ ជន ៣:២៧ ១របា ២៣:១២ ង ជណ ៣:១៩ ១របា ៦:២,១៨ **៦:១៩** ច ជន ៣:២០, ៣៣ ១របា ៦:១៩ ២៣:១២ **៦:២០** ឆ ១របា ២៣:១៣ ជ នក ២:១–២ ជន ២៦:៥៩ **៦:២១** ឈ ១របា ៦:៣៨ **៦:២២** ញ លវ ១០:៤ ជណ ៣:៣០ ១របា ១៥:៨ ២របា ២៩:១៣ **៦:២៣** ដ រម ៤:១៩,២០ ១របា ២:១០ ឋ ជន ១:៧ ២:៣ មថ ១:៤ ឌ នក ២៤:១ ២៨:១ លវ ១០:១ ឍ លវ ១០:៦ ជន ៣:២,៣២ ១៦:៣៧,៣៩ ចទ ១០:៦ យស ១៤:១ ណ នក ២៨:១ លវ ១០:១២, ១៦ ជន ៣:២ ៤:២៨ ២៦:៦០ ១របា ៦:៣ ២៤:១ **៦:២៤** ត ខ.២១ ជន ១៦:១ ១របា ៦:២២,៣៧

ដំណោះស្រាយរបស់ព្រះអម្ចាស់មានដូចជា ការប្រោសលោះ(សាសន៍អ៊ីស្រាអែល) និងការជំនុំជម្រះ(សាសន៍អេស៊ីព្ទ)។

**៦:៧–៨** *ដែលនាំឯងចេញផុតពីបន្ទុក របស់សាសន៍អេស៊ីព្ទ* ការប្រោសលោះគឺមិនគ្រាន់តែធ្វើឱ្យរួចពីភាពជាទាសករ និងសេចក្តីវេទនាប៉ុណ្ណោះទេ តែថែមទាំងនាំឱ្យមានសេរីភាព និងសេចក្តីអំណរផងដែរ ។

**៦:៧** *អញនឹងយកឯងទុកជារាស្ត្ររបស់អញ ក៏នឹងធ្វើជាព្រះដល់ឯងរាល់គ្នា* នេះជាព្រះបន្ទូលប្រាប់ជាមុន អំពីការតាំងសញ្ញានៅឯភ្នំស៊ីណាយ(មើល ១៩:៥–៦ និងមើល យរ ៣១:៣៣) ។

**៦:៨** មើល លប ២២:១៥–១៧ ។ *អញបានលើកដៃអញស្បថថា* មើលការពន្យល់ លប ១៤:២២ ។

**៦:១២** *ទូលបង្គំជាអ្នកមិនសូវចេះវោហារ* មើលការពន្យល់ ៤:១០ ។

**៦:១៣** *ម៉ូសេ និងអើរ៉ុន* បញ្ជីពង្សាវតារក្សត្រនៅក្នុង ខ.១៤ –២៥ បានប្រាប់អំពីប្រវត្តិលោកម៉ូសេ និងលោកអើរ៉ុន ។ បញ្ជីឈ្មោះនេះនិយាយតែអំពីកូនប្រុសទាំង៣នាក់ដំបូង ក្នុងចំណោមកូនប្រុសលោកយ៉ាកុបទាំង១២នាក់(មាន រូបេន ស៊ីម្មាន និងលេវី) ព្រោះពួកគាត់ចេញពីកុលសម្ព័ន្ធទី៣ ។

**៦:១៦** *ម្រ៉ារី* ឈ្មោះនេះមានប្រភពនៅក្នុងភាសាអេស៊ីព្ទ ដូចឈ្មោះ ពុផាល ភិនេហាស(មើល ខ.២៥) និងម៉ូសេ(មើលការពន្យល់ ២:១០)។ *លេវីក៏មានអាយុរស់នៅបាន១៣៧ឆ្នាំ* មើល ខ.១៨,២០។ ក្នុងព្រះគម្ពីរសញ្ញាចាស់ អ្នកដែលមានអាយុចាប់ពី ១០០ឆ្នាំឡើងទៅ ជាអ្នកមានអាយុច្រើន ។

**៦:២០** *ឯអាំរ៉ាម . . .បង្កើតអើរ៉ុននិងម៉ូសេ* មានហេតុផលដែលគួរជឿថា លោកអាំរ៉ាម និងនាងយ៉ូកិបិត មិនមែនឪពុកម្តាយបង្កើតរបស់លោកអើរ៉ុន និងលោកម៉ូសេទេ តែអាចរាប់ជាព្ធយុកោរបស់ពួកគាត់បាន ។ លោកគេហាក់ ដែលជាឪពុករបស់អាំរ៉ាម(មើល ខ.១៨) បានកើតមុនពេលពួកកូនរបស់លោកយ៉ាកុប(អ៊ីស្រាអែល) ចូលទៅរស់នៅក្នុងនគរអេស៊ីព្ទ(មើល លប ៤៦:១១) ហើយពួកគេ និងពួកកូនចៅបានបន្តរស់នៅទីនោះគឺអស់ ៤៣០ឆ្នាំ(មើល ១២:៤០–៤១)។ លោកម៉ូសេមានអាយុ៨០ឆ្នាំ នៅពេលធ្វើនិក្ខមនំ(មើល ៧:៧) ដូចនេះគាត់បានកើតក្រោយលោកគេហាក់ យ៉ាងហោចណាស់ ៣៥០ ឆ្នាំ(មើល ខ.១៨)។

ក៏យកកូនពូធាលម្នាក់ ធ្វើជាប្រពន្ធ ហើយនាងបង្កើតបាន
ភីនេហាស[ថ] នេះឯងជាពួកមេនៃគ្រួសារឪពុករបស់ពួក
លេវីតាមគ្រួគេ ២៦គឺអើរ៉ុនហើយនិងម៉ូសេនេះ ដែល
ព្រះយេហូវ៉ា ទ្រង់បានបង្គាប់ថា ចូរនាំពួកកូនចៅអ៊ីស្រា
អែលចេញពីស្រុកអេស៊ីព្ទមក[ទ] ទាំងកងៗចុះ[ធ] ២៧គឺជា
អ្នកទាំង២នេះដែលបានទូលនឹងផារ៉ោន[ន] ជាស្តេចស្រុក
អេស៊ីព្ទ ដើម្បីនឹងនាំពួកកូនចៅអ៊ីស្រាអែលចេញពីស្រុក
អេស៊ីព្ទទៅ គឺជាម៉ូសេ ហើយនិងអើរ៉ុននេះឯង[ប] ។

## លោកអើរ៉ុនជាអ្នកនិយាយសម្រាប់លោកម៉ូសេ

២៨នៅថ្ងៃដែលព្រះយេហូវ៉ាបានមានបន្ទូលនឹងម៉ូសេ
នៅស្រុកអេស៊ីព្ទ ២៩នោះទ្រង់បង្គាប់ថា អញជាព្រះ
យេហូវ៉ា[ផ] ចូរឯងទៅទូលផារ៉ោនជាស្តេចអេស៊ីព្ទតាមគ្រប់
សេចក្តីដែលប្រាប់ ៣០តែម៉ូសេទូលប្រកែកនៅចំពោះ
ព្រះយេហូវ៉ាថា មើល ទូលបង្គំមិនសូវចេះវោហារទេ[ព]
ធ្វើដូចម្តេចឡើយឱ្យផារ៉ោនបានស្តាប់តាមទូលបង្គំ ។

**៧** ១រួចមក ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា មើល
អញបានឱ្យឯងធ្វើជាព្រះ[ក]ដល់ផារ៉ោន ហើយអើរ៉ុន
បងឯងនិងជាអ្នកប្រកាសរបស់ឯង[ខ] ២ឯងត្រូវនិយាយគ្រប់
សេចក្តីដែលអញបង្គាប់ ហើយអើរ៉ុនបងឯងត្រូវទូលដល់
ផារ៉ោន ដើម្បីឱ្យស្តេចបានបើកឱ្យពួកកូនចៅអ៊ីស្រាអែល
ចេញពីស្រុកទៅ ៣តែអញនឹងធ្វើឱ្យផារ៉ោនមានចិត្តរឹង
ទទឹង[គ] នោះអញនឹងចំរើនទីសំគាល់ និងការអស្ចារ្យ[ឃ]របស់
អញនៅក្នុងស្រុកអេស៊ីព្ទ ៤តែផារ៉ោននឹងមិនស្តាប់តាម
[ង]ឯងទេ រួចអញនឹងដាក់ដៃអញលើស្រុកអេស៊ីព្ទ ហើយ
និងនាំពួកកងរបស់អញ គឺជារាស្ត្រអញ ជាពួកកូនចៅ
អ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ[ច]ទៅ ដោយការវិនិច្ឆ័យ
យ៉ាងធំ[ឆ] ៥កាលណាអញលើកដៃដាក់លើ[ជ]ស្រុកអេស៊ីព្ទ
ព្រមទាំងនាំពួកកូនចៅអ៊ីស្រាអែល ចេញពីកណ្តាលគេទៅ
នោះពួកសាសន៍អេស៊ីព្ទនឹងដឹងថា អញជាព្រះយេហូវ៉ា
ពិត[ឈ] ៦ឯម៉ូសេនិងអើរ៉ុនលោកក៏ធ្វើតាម ដូចជាព្រះយេហូវ៉ា
បានបង្គាប់មក[ញ] ៧ក្នុងគ្រាដែលទូលនឹងផារ៉ោន នោះម៉ូសេ
លោកបានអាយុ៨០ឆ្នាំ[ដ] ឯអើរ៉ុនមានអាយុ៨៣ឆ្នាំហើយ ។

## ដំបងលោកអើរ៉ុនក្លាយជាពស់

៨ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិងអើរ៉ុន
ថា ៩កាលណាផារ៉ោននិយាយមកឯងថា ចូរឯងសំដែង
បាដិហារិយ៍មកមើល[ឋ] នោះឱ្យឯងប្រាប់អើរ៉ុនថា ចូរយក
ដំបងរបស់បងបោះទៅនៅចំពោះមុខផារ៉ោន ដើម្បីឱ្យ
ដំបងនោះក្លាយទៅជាសត្វពស់ [ឌ] ១០ម៉ូសេ និងអើរ៉ុនក៏ចូល
ទៅគាល់ផារ៉ោន ហើយបានធ្វើតាមបង្គាប់ព្រះយេហូវ៉ា
អើរ៉ុនលោកបោះដំបងទៅនៅមុខផារ៉ោន និងមហាតលិក
ទ្រង់ នោះដំបងក៏ត្រឡប់ជាសត្វពស់ ១១ប៉ុន្តែផារ៉ោនទ្រង់
មានបន្ទូលហៅពួកអ្នកប្រាជ្ញ និងពួកអាបធ្មប់មក[ឍ] ឯពួកគ្រូ
នៅស្រុកអេស៊ីព្ទទាំងនោះ[ណ] គេក៏បានធ្វើដូច្នោះ ដោយ
របៀនរបស់គេដែរ[ត] ១២គេបានបោះដំបងរបស់គេរៀង
ខ្លួន ហើយដំបងទាំងនោះក៏ត្រឡប់ក្លាយជាពស់ទាំងអស់
ដែរ តែដំបងរបស់អើរ៉ុនបានលេបដំបងរបស់អ្នកទាំង
នោះបាត់វិញ ១៣នោះផារ៉ោនកើតមានព្រះទ័យរឹងទទឹង[ថ]
មិនព្រមស្តាប់តាមលោក[ទ]ឡើយ ដូចជាព្រះយេហូវ៉ាបាន
បានមានបន្ទូលប្រាប់ហើយ ។

## សេចក្តីវេទនាដោយឈាម

១៤រួចព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា ផារ៉ោន

**៦:២៥** ថ នហ ២៥:៧,១១ ៣១:៦ យស ២៤:៣៣ ទដ ១០៦:៣០
**៦:២៦** ទ នក ៣:១០ ធ នក ៧:៤ ១២:១៧,៤១,៥១
**៦:២៧** ន នក ៥:១ ប ជន ៣:១ ទដ ៧៧:២០
**៦:២៩** ផ ខ.២
**៦:៣០** ព នក ៣:១១
**៧:១** ក នក ៤:១៦ ខ នក ៤:១៥ កច ១៤:១២
**៧:៣** គ នក ៤:២១ រម ៩:១៨ ឃ នក ៣:២០ ១០:១ កច ៧:៣៦
**៧:៤** ង ខ.១៣,១៦,២២ នក ៨:១៥,១៩ ៩:១២ ១១:៩ ច នក ៦:២៦ ឆ នក ៣:២០
**៧:៥** ជ នក ៣:២០ ទដ ១៣៨:៧ អគ ៦:១៤ ២៥:១៣ ឈ នក ៦:២
**៧:៦** ញ ខ.២,១០,២០
**៧:៧** ដ ចទ ៣១:២ ៣៤:៧ កច ៧:២៣,៣០
**៧:៩** ឋ ចទ ៦:២២ ២ពវ ១៩:២៩ ទដ ៧៨:៤៣ ៨៦:១៧ ១០៥:២៧ ១៣៥:៩ អស ៧:១១ ៣៧:៣០ ៣៨:៧–៨ ៥៥:១៣ យហ ២:១១ ឌ នក ៤:២–៥ **៧:១១** ឍ នក ២២:១៨ ចទ ១៨:១០ ១សយ ៦:២ ២ពវ ២១:៦ អស ២:៦ ៤៧:១២ យរ ២៧:៩ មឡ ៣:៥ ណ កទ ៤១:៨ ២ធថ ៣:៨ ត ខ.២២ នក ៨:៧,១៨ មថ ២៤:២៤ **៧:១៣** ថ នក ៤:២១ ទ ខ.៤

**៦:២៦** *ទាំងកងៗ* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះអាចមានន័យថា ពួកអ៊ីស្រាអែលត្រូវធ្វើជាកងទ័ពរបស់ព្រះយេហូវ៉ា (សូមមើលក្នុង ៧:៤ ១២:១៧,៤១,៥១) ។

**៦:៣០** *មិនសូវចេះវោហារទេ* មើល ខ.១២ និងការពន្យល់ ៤:១០ ។

**៧:១–២** ព្រះមានបន្ទូលទៅកាន់រាស្ត្រទ្រង់ តាមរយៈហោរាទ្រង់ គឺលោកម៉ូសេ ដូចនេះ លោកម៉ូសេទូលស្តេចផារ៉ោនតាមរយៈលោកអើរ៉ុនផងដែរ ។ តួនាទីរបស់ពួកហោរា គឺត្រូវនាំព្រះបន្ទូលព្រះនៅកាន់រាស្ត្រទ្រង់ គឺត្រូវធ្វើជាព្រះឱសរបស់ព្រះ (៤:១៥–១៦) ។

**៧:៤** *ដោយការវិនិច្ឆ័យយ៉ាងធំ* មើលការពន្យល់ ៦:៦ ។

**៧:៧** *នោះម៉ូសេលោកបានអាយុ៨០ឆ្នាំ* មើលការពន្យល់ ២:១១,១៥ ។

**៧:៩–១០** *សត្វពស់* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះខុសពីពាក្យក្នុង ៤:៣ (មើល ទដ ៧៤:១៣, "សត្វសំបើម") ។ ពាក្យ (ប្រែថាសត្វសំមើមផងដែរ) ដែលទាក់ទងនឹងពាក្យនេះ មានក្នុង អគ ២០:៣ សំដៅទៅលើនគរអេស៊ីព្ទ និងស្តេចនៃនគរនេះ ។

**៧:១១** *ពួកអ្នកប្រាជ្ញ . . . ពួកគ្រូ* មើលការពន្យល់ លប ៤១:៨ ។ តាមទំនៀមទម្លាប់ ពួកគ្រូសីលពីរនាក់ដែលប្រឆាំងនឹងលោកម៉ូសេ គឺឈ្មោះ យ៉ានេស និងយ៉ាមប្រេស (មើល ២ធថ ៣:៨ ឈ្មោះយ៉ាងនេស ក៏មានចារក្នុងក្រាំងសមុទ្រស្លាប់នៅសម័យមុនគ.សផងដែរ) ។ *គេក៏បានធ្វើដូច្នោះ ដោយរបៀនរបស់គេដែរ* គឺដោយការថ្លិនភ្នែក ឬអំណាចវិញ្ញាណអាក្រក់ ។

**៧:១២** *ដំបងរបស់អើរ៉ុនបានលេបដំបងរបស់អ្នកទាំងនោះ* គឺបញ្ជាក់ថា ព្រះអម្ចាស់ទ្រង់មានអំណាចលើស្តេចផារ៉ោន និងព្រះរបស់សាសន៍អេស៊ីព្ទ ។

**៧:១៣** *ព្រះទ័យរឹងទទឹង* ចិត្តរឹងទទឹង គឺសំដៅទៅលើការបដិសេធន៍ ដោយចិត្តរឹងទទឹងមិនព្រមទទួលព្រះ និងធ្វើតាមព្រះបន្ទូលរបស់ទ្រង់ (មើលការពន្យល់ ៤:២១) ។

មានចិត្តរឹងរូស[ឆ] មិនព្រមបើកឱ្យបណ្តាជនចេញទៅទេ
១៥ដល់ព្រឹកឡើង ផារ៉ោននឹងចេញមកឯមាត់ទឹក[ន] នោះត្រូវ
ឱ្យឯងទៅឈរនៅមាត់ទន្លេ[ប] ចាំជួបនឹងទ្រង់ចុះ ហើយត្រូវ
យកដំបងដែលបានប្រែទៅជាពស់នោះ កាន់នៅដៃឯងផង
១៦ត្រូវទូលដូច្នេះថា ព្រះយេហូវ៉ាជាព្រះនៃសាសន៍ហេព្រើរ
បានចាត់ទូលបង្គំមកឱ្យទូលទ្រង់ថា ចូរឱ្យរាស្ត្រអញចេញ
ទៅ ដើម្បីនឹងថ្វាយបង្គំ[ផ]អញនៅទីរហោស្ថាន មើល ដរាប
មកដល់ឥឡូវនេះ ទ្រង់មិនព្រមស្តាប់តាមសោះ[ព] ១៧ឯព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ស្តេចនឹងដឹងថា អញជា
ព្រះយេហូវ៉ា[ភ] ដោយសារការនេះ គឺទូលបង្គំនឹងវាយទឹក
ទន្លេ ដោយដំបងនៅដៃទូលបង្គំនេះ នោះទឹកនឹងត្រឡប់ប្រែ
ទៅជាឈាម[ម] ១៨ត្រីនៅក្នុងទន្លេនឹងស្លាប់ទាំងអស់ ទន្លេក៏
នឹងធុំក្លិនស្អុយ[យ] ហើយសាសន៍អេស៊ីព្ទគេនឹងខ្ពើមទឹកទន្លេ
នេះ[រ] ។

១៩នោះព្រះយេហូវ៉ា ទ្រង់បង្គាប់ម៉ូសេឱ្យប្រាប់ដល់អើរ៉ុន
ថា ចូរឱ្យបងយកដំបង[ល] លើកដៃ[វ]ទៅលើទឹកស្រុកអេស៊ីព្ទ
ទាំងអស់ ទាំងទន្លេ ទាំងព្រែក ទាំងបឹង ហើយនិងស្រះ
របស់គេទាំងប៉ុន្មាន ដើម្បីឱ្យបានត្រឡប់ទៅជាឈាម នោះ
នឹងមានឈាមនៅពេញក្នុងស្រុកអេស៊ីព្ទ ទោះនៅក្នុងធុង
ឈើ ឬនៅក្នុងពាងថ្មផង ២០ម៉ូសេនិងអើរ៉ុនក៏ធ្វើដូច្នេះតាម
បង្គាប់ព្រះយេហូវ៉ា[ស] លោកលើកដំបងវាយទឹកទន្លេនៅមុខ
ផារ៉ោន និងពួកមហាតលិកទ្រង់ នោះទឹកទន្លេ[ហ]ក៏ត្រឡប់
ទៅជាឈាមទាំងអស់[ឡ] ២១ត្រីដែលនៅក្នុងទន្លេក៏ស្លាប់
ទឹកទន្លេក៏ធុំក្លិនស្អុយ ហើយសាសន៍អេស៊ីព្ទផឹកទឹកពីទន្លេមិន
បាន ក៏មានឈាមនៅពេញក្នុងស្រុកអេស៊ីព្ទផង ២២ឯពួកគ្រូ[អ]
នៅស្រុកអេស៊ីព្ទក៏ធ្វើដូច្នេះ ដោយរបៀនរបស់គេដែរ[ក]
ហើយផារ៉ោនកើតមានព្រះទ័យ[ខ]រឹងទទឹង មិនព្រមស្តាប់
លោកឡើយ ដូចជាព្រះយេហូវ៉ាបានមានបន្ទូលទុក ២៣ផា
រ៉ោនទ្រង់វិលចូលទៅក្នុងដំណាក់ទ្រង់វិញ មិនបានយក
ចិត្តទុកដាក់នឹងការទាំងនោះទេ ២៤ឯពួកសាសន៍អេស៊ីព្ទក៏
ជីកទីនៅក្បែរទន្លេនឹងរកទឹកផឹក[គ] ដ្បិតគេផឹកទឹកពីទន្លេមិន
បានសោះ ។

## សេចក្តីវេទនាដោយសត្វកង្កែប

២៥ក្រោយដែលព្រះយេហូវ៉ាបានវាយទឹកទន្លេហើយ
៨ បាន៧ថ្ងៃ ១នោះទើបព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹង
ម៉ូសេឱ្យចូលទៅឯផារ៉ោនទូលថា ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ ចូរបើកឱ្យរាស្ត្រអញចេញទៅថ្វាយបង្គំ[ក]អញ
២បើមិនព្រមឱ្យគេទៅទេ នោះមើល អញនឹងធ្វើឱ្យកើត
មានកង្កែប នៅពេញពាសក្នុងអស់ទាំងព្រំស្រុករបស់ឯង[ខ]
៣នោះទន្លេនឹងមានពេញសុទ្ធតែកង្កែបវាររវើកឡើង វា
នឹងលោតចូលទៅក្នុងផ្ទះឯង គឺនៅក្នុងបន្ទប់ដេកលើគ្រែ
ហើយក្នុងផ្ទះពួកបំរើ និងពួករាស្ត្រឯង[គ] ព្រមទាំងនៅក្នុង
ជើងក្រាន និងស្នាចលាយម្សៅរបស់ឯងផង[ឃ] ៤កង្កែបទាំង
នោះនឹងលោតលើឯង លើរាស្ត្រ ហើយលើពួកបំរើរបស់
ឯងទាំងអស់គ្នាដែរ ។

៥នោះព្រះយេហូវ៉ា ទ្រង់បង្គាប់ម៉ូសេឱ្យប្រាប់អើរ៉ុនថា
ចូរឱ្យបងកាន់ដំបង[ង] លើកទៅលើអស់ទាំងទន្លេ ព្រែក
ហើយនិងបឹង ធ្វើឱ្យមានកង្កែប[ច]ឡើងមកលើស្រុកអេស៊ីព្ទ
៦អើរ៉ុនក៏លើកដៃទៅលើទឹក នៃស្រុកអេស៊ីព្ទទាំងប៉ុន្មាន

**៧:១៤** ឆ ខ.២២ នក ៨:១៥,៣២ ៩:៧ ១០:១,២០,២៧
**៧:១៥** ន នក ៨:២០ ប លប ៤១:១
**៧:១៦** ផ នក ៣:១៨ ព ខ.៤
**៧:១៣** ថ នក ៤:២១ ទ ខ.៤
**៧:១៧** ភ នក ៦:២ ១៤:២៥ ម ខ.១៩–២១ នក ៤:៩ វវ ១១:៦ ១៦:៤
**៧:១៨** យ អស ១៩:៦ រ ខ.២១, ២៤ ទដ ១៨:៤៤
**៧:១៩** ល នក ៤:២ វ នក ១៤:២១ ២ពវ ៥:១១
**៧:២០** ស ខ.៦ ហ នក ១៧:៥ ឡ ទដ ៧៨:៤៤ ១០៥:២៩ ១១៤:៣ ហាព ៣:៨
**៧:២២** អ លប ៤១:៨ ក ខ.១១ មថ ២៤:២៤ ខ ខ.១៣, ១៤ នក ៨:១៩ ទដ ១០៥:២៨
**៧:២៤** គ ខ.១៨
**៨:១** ក នក ៣:១២,១៨ ៤:២៣ ៥:១ ៩:១
**៨:២** ខ ទដ ៧៨:៤៥ ១០៥:៣០ វវ ១៦:១៣
**៨:៣** គ នក ១០:៦ ឃ នក ១២:៣៤
**៨:៥** ង នក ៤:២ ៧:៩–២០ ៩:២៣ ១០:១៣,២១–២២ ១៤:២៧ ច នក ៤:១៧

**៧:១៤–១០:២៩** សេចក្តីវេទនាទាំង៩ អាចចែកជាបីក្រុម ដែលមួយក្រុមមានសេចក្តីវេទនាបី(៧:១៤–៨:១៩ ៨:២០–៩:១២ ៩:១៣–១០:២៩) ហើយតាមរយៈសេចក្តីវេទនាដំបូង នៅក្នុងក្រុមនីមួយៗ(មានសេចក្តីវេទនាទី១ ទី៤ និងទី៧) ព្រះស្តេចផារ៉ោនទទួលការព្រមាននៅពេលយាងចុះទន្លេនីល នៅពេលព្រឹក(ខ.១៥ ៨:២០ ៩:១៣) ។

**៧:១៧** *ទឹកទន្លេ . . . នឹងត្រឡប់ប្រែទៅជាឈាម* សូមមើល ទដ ៧៨:៤៤ ១០៥:២៩ ។ មានហេតុផលដែលអាចជឿថា សេចក្តីវេទនាទាំង៩ដំបូង គឺជាគ្រោះមហន្តរាយ ដែលជាបទពិសោធន៍របស់សាសន៍អេស៊ីព្ទ ។ តាមធម្មតា ពួកគេមិនដែលធ្លាប់ជួបគ្រោះមហន្តរាយ ដែលកើតដោយសារការរំដោះរាស្ត្រអ៊ីស្រាអែលដូចនេះទេ ។ នៅសម័យនិក្ខមនំ មានភ្នំភ្លើងមួយយ៉ាងខ្លាំង នៅក្បែរនគរក្រិក ដែលនាំឱ្យមានបាតុភូតធម្មជាតិនៅតំបន់ជិតខាង ជាពិសេសនៅនគរអេស៊ីព្ទ គឺសេចក្តីវេទនាទី១ រហូតដល់ទី១០ ហើយធ្វើឱ្យមានបាតុភូតនៅសមុទ្រ និងនៅទីរហោស្ថានផងដែរ គេជឿថា ទ្រង់ធ្វើឱ្យមានបន្ទុះនោះ ។

**៧:១៩** *ដំបង* លោកអើរ៉ុនធ្វើការអស្ចារ្យនេះ ជួសមុខឱ្យលោកម៉ូសេ(មើល ខ.១៧) ។ *នៅក្នុងធុងឈើ ឬនៅក្នុងពាងថ្មផង* ដោយសារពួកអេស៊ីព្ទជឿលើព្រះដែលធ្វើពីឈើ ដី ឬ ថ្ម(ចទ ២៩:១៦–១៧) ដូចនេះ សេចក្តីវេទនាអាចកើតឡើង ដើម្បីវាយប្រហារមកលើសាសនារបស់ពួកគេ(មើល ១២:១២) ។

**៧:២០** *ទឹកទន្លេ* ការរស់នៅរបស់សាសន៍អេស៊ីព្ទគឺពឹងផ្អែកទៅលើទឹកទន្លេនីល ដូចនេះ ពួកគេលើកតម្កើងទន្លេនេះជាព្រះ ដោយឱ្យព្រះនាមថា"ហាភី" (Hapi) និងច្រៀនបទសរសើរដល់ព្រះនេះ មើលការពន្យល់ ខ.១៩ ។

**៧:២៤** *ជីកទីនៅក្បែរទន្លេនឹងរកទឹកផឹក* គឺចម្រោះទឹក តាមរយៈដីខ្សាច់នៅក្បែរមាត់ទន្លេ ដើម្បីបង្កើតទឹកស្អាត ហើយអាចផឹកបាន ។

**៧:២៥** *បាន៧ថ្ងៃ* សេចក្តីវេទនានីមួយៗ មិនកើតឡើងបន្តគ្នាភ្លាមៗទេ ។

**៨:២** *អញនឹងធ្វើឱ្យកើតមានកង្កែប ពាសពេញក្នុងអស់ព្រំស្រុករបស់ឯង* ពួកអេស៊ីព្ទបានលើកសត្វកង្កែប (ឬគីង្គក់) ជាទេពធីតា ហេក(Heqt) ដោយជឿថា ព្រះនោះអាចជួយស្ត្រីនៅពេលសំរាលកូនបាន ។

**៨:៣** *វាររវើកឡើង* ពួកកង្កែបចេញពីទន្លេនីល ឡើងមកលើគោកទាំងហ្វូងៗ ដោយសាទឹកកខ្វក់ខ្លាំងពេក ដែលត្រីក៏ត្រូវស្លាប់គ្មានសល់ ។

នោះក៏មានកង្កែប[ឆ]ឡើងមកគ្របពេញក្នុងស្រុកអេស៊ីព្ទ
[៧]ឯពួកគ្រូក៏ធ្វើដូច្នោះដោយរបៀនរបស់គេដែរ[ជ] គេបាន
ធ្វើឱ្យមានកង្កែបឡើងមកលើស្រុកអេស៊ីព្ទដូចគ្នា ។
[៨]នោះផារ៉ោនទ្រង់ហៅម៉ូសេ និងអើរ៉ុនមកមានបន្ទូលថា
សូមឱ្យអង្វរ[ឈ]ដល់ព្រះយេហូវ៉ា ឱ្យទ្រង់បន្ថយកង្កែបចេញ
ពីអញ ហើយពីរាស្ត្រអញទៅ នោះអញនឹងឱ្យពួកឯងចេញ
ទៅថ្វាយយញ្ញបូជា[ញ]ដល់ព្រះយេហូវ៉ា [៩]ម៉ូសេក៏ទូលផារ៉ោន
ថា ទ្រង់មានអំណាចស្រាប់ហើយ ដូច្នេះសូមបង្គាប់ទូលបង្គំ
ចុះ តើចង់ឱ្យទូលបង្គំអង្វរជំនួសទ្រង់ និងមហាតលិក ហើយ
និងរាស្ត្រក្នុងពេលណា[ដ] ដើម្បីឱ្យកង្កែបបានត្រូវវិនាស
ចេញពីចំពោះទ្រង់ និងពួកដំណាក់ទ្រង់ទៅ ឱ្យមាននៅតែ
ក្នុងទន្លេវិញ [១០]នោះទ្រង់មានបន្ទូលឆ្លើយថា ថ្ងៃស្អែកចុះ
រួចលោកទូលថា សូមតាមព្រះបន្ទូលទ្រង់ចុះ ដើម្បីឱ្យទ្រង់
បានជ្រាបថា គ្មានអ្នកឯណាឡើយ ដែលស្មើនឹងព្រះ
យេហូវ៉ា ជាព្រះនៃយើងរាល់គ្នា[ឋ] [១១]នោះកង្កែបនឹងថយ
ចេញពីទ្រង់ ពីដំណាក់ទ្រង់ ពីពួកមហាតលិក ហើយពី
រាស្ត្រទ្រង់ទៅ និងមានសល់នៅតែក្នុងទន្លេប៉ុណ្ណោះ
[១២]ម៉ូសេនិងអើរ៉ុនក៏ចេញពីផារ៉ោនទៅ រួចម៉ូសេបាន
អំពាវនាវដល់ព្រះយេហូវ៉ាអំពីរឿងកង្កែប ដែលទ្រង់
បាននាំមកលើផារ៉ោននោះ [១៣]ព្រះយេហូវ៉ាទ្រង់ក៏ធ្វើ
សំរេចតាមពាក្យម៉ូសេ នោះ[ឌ]កង្កែបក៏ស្លាប់អន្តរធាននៅ
ក្នុងផ្ទះ និងក្នុងភូមិ ហើយនៅចំការផង [១៤]គេប្រមូលគរ
ឡើងជាគំនរ រួចក្នុងស្រុកក៏ធុំក្លិនស្អុយពេញ [១៥]តែកាល
ផារ៉ោនឃើញថាបានធូរស្បើយហើយ[ឍ] នោះទ្រង់តាំង
ព្រះទ័យរឹងទទឹងទៀត[ណ] ហើយមិនព្រមស្ដាប់តាមម៉ូសេនិង
អើរ៉ុនឡើយ ដូចជាព្រះយេហូវ៉ាបានមានបន្ទូលមក ។

**៨:៦** ឆ ទដ ៧៨:៤៥ ១០៥:៣០
**៨:៧** ជ នក ៧:១១ មថ ២៤:២៤
**៨:៨** ឈ ខ.២៨ នក ៩:២៨ ១០:១៧ ជន ២១:៧ ១សយ ១២:១៩ ១ពវ ១៣:៦ យរ ៤២:២ កច ៨:២៤ ញ ខ.២៥ នក ១០:៨,២៤ ១២:៣១
**៨:៩** ដ នក ៩:៥
**៨:១០** ឋ នក ៩:១៤ ១៥:១១ ចទ ៣:២៤ ៤:៣៥ ៣៣:២៦ ២សយ ៧:២២ ១ពវ ៨:២៣ ១រប ១៧:២០ ២រប ៦:១៤ ទដ ៧១:១៩ ៨៦:៨ ៨៩:៦ ១១៣:៥ អស ៤០:១៨ ៤២:៨ ៤៦:៩ យរ ១០:៦ ៤៩:១៩ មីក ៧:១៨
**៨:១៣** ឌ យក ៥:១៦-១៨
**៨:១៥** ឍ សស ៨:១១ ណ នក ៧:១៤
**៨:១៦** ត នក ៤:២
**៨:១៧** ថ ទដ ១០៥:៣១
**៨:១៨** ទ នក ៩:១១ ធ នក ៧:១១ ដយ ៥:៨

## សេចក្ដីវេទនាដោយសត្វចៃ

[១៦]រួចព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ឱ្យប្រាប់អើរ៉ុនថា ចូរ
បងលើកដំបង[ត]វាយធូលីដីទៅ ដើម្បីឱ្យបានត្រឡប់ជាចៃ
នៅពេញស្រុកអេស៊ីព្ទ [១៧]នោះក៏ធ្វើដូច្នោះ អើរ៉ុនកាន់ដំបង
លើកវាយធូលីដី ហើយកើតមានចៃ[ថ]នៅលើមនុស្ស ហើយ
និងសត្វ ធូលីដីទាំងអស់ក៏ទៅជាចៃពេញក្នុងស្រុកអេស៊ីព្ទ
[១៨]ឯពួកគ្រូ[ទ]ខំធ្វើដូច្នោះដោយរបៀនរបស់គេដែរ[ធ] ដើម្បី
នឹងបង្កើតចៃ តែធ្វើមិនកើតឡើយ ចៃទាំងនោះនៅលើ
មនុស្ស ហើយនិងសត្វផង [១៩]នោះពួកគ្រូគេទូលផារ៉ោនថា
នេះគឺជាអង្គុលីព្រះហស្ត[ន]របស់ព្រះទេ តែផារ៉ោនមានព្រះ
ទ័យរឹងទទឹង[ប] មិនព្រមស្ដាប់[ផ]តាមគេសោះ ដូចជាព្រះ
យេហូវ៉ាបានមានបន្ទូលទុក ។

## សេចក្ដីវេទនាដោយសត្វរុយ

[២០]រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរ
ក្រោកពីព្រលឹម[ព]ទៅឈរនៅមុខផារ៉ោន មើល ទ្រង់នឹង
ចេញទៅឯមាត់ទឹក នោះត្រូវឱ្យឯងទូលទ្រង់ថា ព្រះយេហូ
វ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរឱ្យរាស្ត្រអញចេញទៅថ្វាយ
បង្គំ[ភ]អញចុះ [២១]បើមិនព្រមឱ្យគេចេញទៅទេ នោះមើល
អញនឹងចាត់រុយទាំងហ្វូងៗឱ្យមកលើឯង លើពួកបំរើឯង
ពួករាស្ត្រឯង ហើយនៅក្នុងផ្ទះទាំងប៉ុន្មានរបស់ឯងរាល់គ្នា
ផង បណ្ដាផ្ទះនៃពួកសាសន៍អេស៊ីព្ទនឹងបានពេញដោយរុយ
ទាំងអស់ ព្រមទាំងដីដែលគេអាស្រ័យនៅដែរ [២២]តែនៅ
ថ្ងៃនោះ អញនឹងញែកស្រុកកូសែន[ម]ដែលរាស្ត្រអញនៅ[យ]

**៨:១៩** ន នក ៧:៥ ១០:៧ ១២:៣៣ ៣១:១៨ ១សយ ៦:៩ នហ ៩:៦ ទដ ៨:៣ ៣៣:៦ លក ១១:២០ ប នក ៧:២២ ផ នក ៧:៤ **៨:២០** ព នក ៧:១៥ ៩:១៣ ភ នក ៣:១៨ **៨:២២** ម លប ៤៥:១០ យ នក ៩:៤,៦,២៦ ១០:២៣ ១១:៧ ១២:១៣ ១៩:៥ ចទ ៤:២០ ៧:៦ ១៤:២ ២៦:១៨ ១ពវ ៨:៣៦ យប ៣៦:១១ ទដ ៣៣:១២ ១៣៥:៤ មឡ ៣:១៧

**៨:១៣** *ព្រះយេហូវ៉ាក៏ធ្វើសំរេចតាមពាក្យម៉ូសេ* ចំពោះព្រឹត្តិការណ៍ ដែលស្រដៀងនឹងការនេះ មើល ខ.៣១ ១សយ ១២:១៨ ១ពវ ១៨:៤២-៤៥ អម ៧:១-៦ ។ *កង្កែបក៏ស្លាប់* ប្រហែលដោយសារឆ្លងបាក់តេរីពីទឹកទន្លេ(មើលការពន្យល់ ខ.៣) ។

**៨:១៥** *រឹងទទឹងទៀត* មើលការពន្យល់ ៧:១៣ ។

**៨:១៦** *ដើម្បីឱ្យបានត្រលប់ជាចៃ* ពាក្យ "ធូលីដី" ប្រហែលសំដៅទៅលើចំនួនដ៏ច្រើនសន្ធឹក(មើលឧទាហរណ៍ក្នុង លប ១៣:១៦) របស់ចៃ ដែលបន្តពូជនៅក្នុងទីវាល ដែលលិចទឹកនៅចុងសទរដូវ ។

**៨:១៩** *អង្គុលីព្រះហស្ត* គឺជាការនិយាយប្រៀបប្រដូច អំពីអំណាចដ៏អស្ចារ្យរបស់ព្រះ(មើល ៣១:១៨ ទដ ៨:៣) ។ ព្រះគ្រីស្ទទ្រង់បណ្ដេញអារក្ស "ដោយសារអង្គុលីព្រះហស្តនៃព្រះ" (លក ១១:២០) ។ សូមធៀបនឹងឃ្លាដែលស្រដៀងគ្នាថា "ព្រះហស្តនៃព្រះយេហូវ៉ា"ក្នុង ៩:៣ ក៏មើល "ព្រះពាហុនៃព្រះយេហូវ៉ា" ក្នុង អស ៥១:៩ និងការពន្យល់ ។

**៨:២០** *ទ្រង់នឹងចេញទៅឯមាត់ទឹក* គឺនៅពេលទ្រង់យាងទៅទន្លេនីល ។ ស្ដេចផារ៉ោនប្រហែលជាទៅទីនោះដើម្បី (១).ថ្វាយបង្គំ នៅទីសក្ការៈបូជា ឬ(២). ដើម្បីស្រង់ទឹក(ដូតទឹក)ដូចព្រះនាងដែលបានធ្វើក្នុង ២:៥(មើល ៧:១៥) ។

**៨:២១** *អញនឹងចាត់រុយទាំងហ្វូងៗឱ្យមកលើឯង* គឺវាទាំងអស់នោះនិងកើនកើតជាទ្វេរឡើងជាច្រើនដែលបែកជាកូនចៅ ហើយហ្វូងសត្វនោះនឹងខាំមនុស្សឬសត្វឱ្យរបួសស្នាម ។

**៨:២២** *អញនឹងញែកស្រុកកូសែន* មើល ៣៣:១៦ ។ ព្រះអម្ចាស់បង្ហាញពី "ភាពដាច់ពីគ្នា" (ខ.២៣) រវាងបណ្ដាជនរបស់លោកម៉ូសេ និងរាស្ត្ររបស់របស់ស្ដេចផារ៉ោន នៅក្នុងសេចក្ដីវេទនានេះ និងសេចក្ដីវេទនាទីប្រាំ(មើល ៩:៤,៦) ទី៧ (មើល ៩:២៦) ទី៩(មើល ១០:២៣) និងទី១០(មើល ១១:៧) ហើយគេជឿថា នៅក្នុងទី៦ និងទី៨ផងដែរ(មើល ៩:១១ ១០:២៦)ដែលបង្ហាញថាព្រះអម្ចាស់ការពាររាស្ត្រទ្រង់ នៅពេលជំនុំជម្រះដល់ស្រុកអេស៊ីព្ទ ។ *ស្រុកកូសែន* មើល លប ៤៥:១០ និងការពន្យល់ ។

មិនឱ្យមានរុយឡើយ ដើម្បីឱ្យឯងដឹង[រ]ថា អញជាព្រះយេ
ហូវ៉ាដ៏នៅកណ្ដាលផែនដីនេះ ២៣អញនឹងផ្ដាច់រាស្ត្រអញ
និងរាស្ត្រឯងឱ្យដាច់ចេញពីគ្នា[ល] ឯទីសំគាល់នេះនឹងកើត
ឡើងនៅវេលាថ្ងៃស្អែក ២៤ព្រះយេហូវ៉ាទ្រង់ក៏ធ្វើដូច្នោះ
មានទាំងហ្វូង ដែលនាំឱ្យវេទនាចិត្ត មកក្នុងដំណាក់ផារ៉ោន
ក្នុងផ្ទះពួកមហាតលិកទ្រង់ ហើយពេញក្នុងស្រុកអេស៊ីព្ទផង
រុយទាំងនោះក៏ធ្វើឱ្យស្រុកខូចខាតទៅ[វ] ។
២៥នោះផារ៉ោន ទ្រង់ហៅ[ស]ម៉ូសេនិងអើរ៉ុនមកប្រាប់ថា
ចូរឯងរាល់គ្នាទៅថ្វាយយញ្ញបូជា ដល់ព្រះនៃឯង នៅក្នុង
ស្រុកនោះចុះ ២៦តែម៉ូសេប្រកែកថា មិនគួរគប្បីនឹងធ្វើ
ដូច្នេះទេ បើធ្វើយ៉ាងនោះ ឈ្មោះថាយើងខ្ញុំនឹងថ្វាយបង្គំ
ដល់ព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំ ដោយយញ្ញបូជាដែល
ជាទីស្អប់ខ្ពើមដល់សាសន៍អេស៊ីព្ទហើយ[ហ] ចុះបើយើងខ្ញុំធ្វើ
យញ្ញបូជានៅចំពោះមុខសាសន៍អេស៊ីព្ទ ដែលគេស្អប់ខ្ពើម
ដូច្នេះ នោះតើគេមិនចោលយើងខ្ញុំនឹងថ្មទេឬអី ២៧យើងខ្ញុំ
នឹងដើរផ្លូវចំនួន៣ថ្ងៃ[ឡ]ទៅក្នុងទីរហោស្ថានវិញ ដើម្បីនឹង
ថ្វាយយញ្ញបូជា[អ] ដល់ព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំ តាម
បង្គាប់របស់ទ្រង់ ២៨នោះផារ៉ោនទ្រង់មានបន្ទូលថា អញ
នឹងបើកឱ្យឯងរាល់គ្នា ចេញទៅថ្វាយយញ្ញបូជាដល់ព្រះ
យេហូវ៉ា ជាព្រះនៃឯងនៅទីរហោស្ថានបាន តែកុំឱ្យទៅ
ឆ្ងាយពេក ចូរសូមអង្វរ[ក]ឱ្យអញផង ២៩ម៉ូសេទូលតប
ថា មើល ទូលបង្គំនឹងចេញពីទ្រង់ទៅ សូមអង្វរដល់ព្រះ
យេហូវ៉ា ឱ្យរុយបានថយចេញពីទ្រង់ ពីពួកមហាតលិក
ហើយពីរាស្ត្ររបស់ទ្រង់ នៅពេលថ្ងៃស្អែក ប៉ុន្តែសូមកុំឱ្យ
តែទ្រង់បញ្ឆោតទៀត[ខ] ដើម្បីនឹងឃាត់បណ្ដាជនមិនឱ្យគេ
ចេញទៅថ្វាយយញ្ញបូជាដល់ព្រះយេហូវ៉ានោះឡើយ ៣០រួច
ម៉ូសេក៏ចេញពីផារ៉ោន ទៅទូលអង្វរដល់ព្រះយេហូវ៉ា[គ]
៣១ហើយព្រះយេហូវ៉ាទ្រង់ក៏ស្ដាប់តាម រុយក៏ថយចេញពី
ផារ៉ោន ពីពួកមហាតលិក ហើយពីរាស្ត្រទ្រង់ទៅ គ្មាន
នៅសល់១សោះ ៣២ប៉ុន្តែ ផារ៉ោនទ្រង់តាំងព្រះទ័យរឹង
ទទឹងឡើងវិញម្ដងនេះទៀត[ឃ] គឺទ្រង់មិនព្រមបើកឱ្យបណ្ដា
ជនចេញទៅឡើយ ។

## សេចក្ដីវេទនាដល់សត្វស្រុក

**៩** ១នោះព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ឱ្យចូលទៅគាល់
ផារ៉ោន ទូលទ្រង់ថា ព្រះយេហូវ៉ាជាព្រះនៃសាសន៍
ហេព្រើរទ្រង់មានបន្ទូលដូច្នេះ ចូរបើកឱ្យរាស្ត្រអញចេញ
ទៅថ្វាយបង្គំ[ក]ដល់អញចុះ ២ដ្បិតបើឯងមិនព្រមឱ្យគេទៅទេ
ហើយចេះតែឃាត់ឃាំងទៀត ៣នោះមើល ព្រះហស្ត[ខ]
នៃព្រះយេហូវ៉ា នឹងនៅលើហ្វូងសត្វទាំងប៉ុន្មានរបស់ឯង
ដែលនៅចំការ គឺទាំងសេះ លា អូដ្ឋ ហើយហ្វូងគោ ហ្វូង
ចៀមផង វានឹងកើតជំងឺអាសន្នជាយ៉ាងវេទនា[គ] ៤តែព្រះ
យេហូវ៉ា ទ្រង់និងញែកហ្វូងសត្វរបស់សាសន៍អ៊ីស្រាអែល
និងហ្វូងសត្វរបស់សាសន៍អេស៊ីព្ទចេញពីគ្នា[ឃ] ដូច្នេះនឹងគ្មាន
ស្លាប់សត្វណា១របស់ពួកកូនចៅអ៊ីស្រាអែលឡើយ ៥ព្រះ
យេហូវ៉ាទ្រង់ក៏ដាក់កំណត់ថា ថ្ងៃស្អែកឡើងព្រះយេហូវ៉ា
ទ្រង់នឹងធ្វើការនេះនៅក្នុងស្រុក ៦លុះដល់ថ្ងៃស្អែក នោះ
ព្រះយេហូវ៉ាទ្រង់ក៏ធ្វើដូច្នោះ ហ្វូងសត្វ[ង]របស់សាសន៍
អេស៊ីព្ទក៏ស្លាប់ទាំងអស់[ច] តែគ្មានស្លាប់សត្វណាមួយក្នុង
ហ្វូងសត្វរបស់កូនចៅអ៊ីស្រាអែលទេ ៧ផារ៉ោនទ្រង់ចាត់គេ
ទៅស៊ើបមើល ក៏ឃើញថា គ្មានសត្វណាមួយក្នុងហ្វូង
សត្វរបស់សាសន៍អ៊ីស្រាអែលដែលបានស្លាប់សោះ ប៉ុន្តែ
ផារ៉ោនមានព្រះទ័យ[ឆ]រឹងចចេសមិនព្រមបើកឱ្យបណ្ដាជន
ទៅទេ[ជ] ។

## សេចក្ដីវេទនាដោយជម្ងឺបូស

៨រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុនថា ចូរឯងកើបយកផេះពីគុកភ្លើងពេញក្នុងក្ដាប់ដៃ
រួចឱ្យម៉ូសេបាចទៅលើមេឃនៅមុខផារ៉ោនទៅ ៩ផេះ

**៨:២២** រ នក ៧:៥ ៩:២៩
**៨:២៣** ល នក ៩:៤,៦ ១០:២៣ ១១:៧ ១២:១៣, ២៣,២៧
**៨:២៤** វ ទដ ៧៨:៤៥ ១០៥:៣១
**៨:២៥** ស ខ.៨ នក ៩:២៧ ១០:១៦ ១២:៣១
**៨:២៦** ហ លប ៤៣:៣២
**៨:២៧** ឡ លប ៣០:៦ អ នក ៣:១៨
**៨:២៨** ក ខ.៨ យរ ៣៧:៣ កច ៨:២៤
**៨:២៩** ខ ខ.១៥ នក ៩:៣០ ១០:១១ អស ២៦:១០
**៨:៣០** គ ខ.១២ នក ៩:៣៣ ១០:១៨
**៨:៣២** ឃ នក ៧:១៤
**៩:១** ក នក ៨:១
**៩:៣** ខ នក ៧:៤ ១សយ ៥:៦ យប ១៣:២១ ទដ ៣២:៤ ៣៩:១០ កច ១៣:១១ គ លវ ២៦:២៥ ទដ ៧៨:៥០ អម ៤:១០
**៩:៤** ឃ ខ.២៦ នក ៨:២៣
**៩:៦** ង ខ.១៩–២១ នក ១១:៥ ១២:២៩ ច ទដ ៧៨:៤៨–៥០
**៩:៧** ឆ នក ៧:២២ ជ នក ៧:១៤ ៨:៣២

**៨:២៣** *ទីសំគាល់* មើល ៤:៨ និងការពន្យល់ ។
**៨:២៦** *ជាទីស្អប់ខ្ពើមដល់សាសន៍អេស៊ីព្ទ* មើល លប ៤៦:៣៤ និងមើល លប ៤៣:៣២ និងការពន្យល់ ។
**៨:៣១** *ហើយព្រះយេហូវ៉ាទ្រង់ក៏ស្ដាប់តាម* មើលការពន្យល់ ខ.១៣ ។
**៩:៣** *ព្រះហស្តនៃព្រះយេហូវ៉ា* មើលការពន្យល់ ៨:១៩ ។ *វានឹងកើតជំងឺអាសន្នជាយ៉ាងវេទនា* គឺជាសត្វរុយ នៃសេចក្ដីវេទនាទី៤ (មើលការពន្យល់ ៨:២១) ដែលអាចនាំបាក់តេរី (មើលការពន្យល់ ៨:១៣) ចម្លងជម្ងឺដល់សត្វដែលគេបញ្ជូនទៅទីវាលវិញ បន្ទាប់ពីទឹកជំនន់បានស្រកហើយ ។ ពួកអេស៊ីព្ទថ្វាយបង្គំរូបព្រះ ដែលមានសណ្ឋានជាសត្វ ឬក្បាលសត្វ ដូចជា ព្រះគោឈ្មោល អ័ភីស (Apis) និងមនេវីស (Mnevis) ព្រះមេគោ អ័ថរ (Hathor) និងព្រះចៀមឈ្មោល ឃ្នូម (Khnum) ។ ដូចនេះព្រះនៃពួកអេស៊ីព្ទទទួលការវាយប្រហារ និងសើចចម្អកទៀត (ការពន្យល់ ៧:១៩) ។ *អូដ្ឋ* មើលការពន្យល់ លប ១២:១៦ ។
**៩:៤** *ញែក* មើលការពន្យល់ ៨:២២ ។
**៩:៥** *ថ្ងៃស្អែកឡើង* គឺជាការនាំឱ្យសាសន៍អេស៊ីព្ទ ដែលកោតខ្លាចដល់ព្រះអម្ចាស់ គឺដើម្បីឱ្យហ្វូងសត្វឱ្យរួចផុតពីគ្រោះអាសន្ន (មើល ខ.២០) ។
**៩:៦** *ហ្វូងសត្វរបស់សាសន៍អេស៊ីព្ទក៏ស្លាប់ទាំងអស់* គឺពួកសត្វស្រុកដែលនៅឯវាល ។ ហើយសត្វស្រុកដែលមានការការពារ បានរួចជីវិត (ខ.១៩,២១) ។
**៩:៨** *ចូរឯងកើបយកផេះ . . . បាចទៅលើមេឃ* ប្រហែលបង្ហាញពីការរាលដាលជម្ងឺបូសដំបៅមានកម្រិតធ្ងន់ ។ *គុកភ្លើង* អាចជាឡឥដ្ឋដែលជានិមិត្តនៃការជាប់ចំណងនៃពួកអ៊ីស្រាអែល (១:១៤ ៥:៧–១៩ និង លប ១៩:២៨) ។

នោះនឹងត្រឡប់ក្លាយជាធូលីយ៉ាងម៉ដ្ដ នៅលើស្រុកអេស៊ីព្ទ
ទាំងមូល ហើយនិងបង្កើតជាបូស[ឈ]ធ្លាយចេញជាដំបៅនៅ
ខ្លួនមនុស្ស ព្រមទាំងសត្វនៅពេញក្នុងស្រុកដែរ ១០ម៉ូសេក៏
យកផេះ ពីគុកភ្លើង ទៅឈរនៅមុខផារ៉ោន ហើយលោក
បាចទៅលើមេឃ រួចផេះនោះបង្កើតជាបូស ក្លាយធ្លាយ
ចេញជាដំបៅ ក៏កើតឡើងនៅសព្វខ្លួនរបស់មនុស្ស ហើយ
និងពួកសត្វផង ១១ឯពួកគ្រូ[ញ]គេឈរនៅមុខម៉ូសេមិនបានទេ
ដោយព្រោះបូសនោះ ពីព្រោះបូសក៏កើតឡើងនៅខ្លួនគេ
ដែរ ដូចជានៅខ្លួននៃសាសន៍អេស៊ីព្ទទាំងអស់គ្នាផង ១២តែ
ព្រះយេហូវ៉ាទ្រង់បណ្ដាលឱ្យព្រះទ័យ[ដ]ផារ៉ោនបានរឹងទទឹង
ទ្រង់មិនព្រមស្ដាប់[ឋ]តាមលោកសោះ ដូចជាព្រះយេហូវ៉ា
បានមានបន្ទូលនឹងម៉ូសេស្រាប់ ។

## សេចក្ដីវេទនាដោយព្រឹល

១៣រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរក្រោក
ពីព្រលឹមទៅឈរនៅមុខផារ៉ោនទូលថា ព្រះយេហូវ៉ាជា
ព្រះនៃសាសន៍ហេព្រើរទ្រង់មានបន្ទូលដូច្នេះ ចូរបើកឱ្យ
រាស្ត្រអញចេញទៅថ្វាយបង្គំ[ឌ]ដល់អញ ១៤ដ្បិតម្ដងនេះ អញ
នឹងដាក់សេចក្ដីវេទនាទាំងអស់ មកទាស់នឹងចិត្តឯង និងពួក
មហាតលិក ហើយនិងរាស្ត្រឯងផង ដើម្បីឱ្យឯងបានដឹង[ឍ]
ថា នៅគ្រប់លើផែនដីគ្មានអ្នកឯណាដូច[ណ]អញឡើយ ១៥ដ្បិត
បើអញបានលើកដៃអញធ្វើឱ្យឯង ហើយនិងរាស្ត្រឯង[ត]កើត
មានជំងឺអាសន្នរោគ ក្នុងពេលឥឡូវ នោះឯងរាល់គ្នានឹង
បានវិនាសបាត់ពីលើផែនដីទៅអស់រលីងហើយ ១៦ប៉ុន្តែ
អញបានទុកឱ្យឯងរស់នៅវិញ ដើម្បី[ថ]ឱ្យឯងបានឃើញឫទ្ធិ
បារមី[ទ]របស់អញ ហើយឱ្យគេបានប្រកាសប្រាប់ពីឈ្មោះ
អញទូទៅគ្រប់លើផែនដី ១៧តើឯងនៅតែដំកើងខ្លួនទាស់
នឹងរាស្ត្រអញ ព្រមទាំងឃាត់មិនឱ្យគេទៅទៀតឬ ១៨មើល
ដល់ថ្ងៃស្អែកវេលាថ្មើរណេះ នោះអញនឹងបង្អុរឱ្យធ្លាក់
ព្រឹលជាយ៉ាងវេទនា[ធ]មកដល់ម្ល៉េះបានជាតាំងពីកំណើត
ស្រុក ដរាបដល់ឥឡូវនេះ នោះមិនដែលមានឱ្យដូចក្នុង
ស្រុកអេស៊ីព្ទឡើយ[ន] ១៩ដូច្នេះចូរចាត់គេឱ្យទៅនាំអស់ទាំង
ហ្វូងសត្វ និងរបស់ឯងទាំងប៉ុន្មានដែលនៅឯវាលចូលមក
ជាប្រញាប់ ដ្បិតអស់ទាំងមនុស្ស និងសត្វទាំងប៉ុន្មាននៅវាល
ដែលមិនបានប្រមូលមកក្នុងផ្ទះ នោះនឹងត្រូវព្រឹលធ្លាក់មក
លើ ស្លាប់ទាំងអស់ ២០នោះពួកមហាតលិកណាមួយរបស់
ផារ៉ោន ដែលកោតខ្លាច[ប]ដល់ព្រះបន្ទូលព្រះយេហូវ៉ា គេក៏
ឱ្យពួកបាវ និងហ្វូងសត្វទាំងប៉ុន្មានរត់ចូលមកជ្រកក្នុងផ្ទះ
ទាំងអស់ ២១ប៉ុន្តែពួកអ្នកដែលមិនយកចិត្តទុកដាក់[ផ]នឹងព្រះ
បន្ទូលព្រះយេហូវ៉ាសោះ គេក៏ទុកឱ្យពួកបាវ និងហ្វូងសត្វ
នៅឯវាលវិញ ។

២២នោះព្រះយេហូវ៉ា ទ្រង់មានបន្ទូលប្រាប់ម៉ូសេថា ចូរ
លើកដៃឡើងទៅលើមេឃ ដើម្បីឱ្យមានព្រឹលធ្លាក់មកពេញ
ក្នុងស្រុកអេស៊ីព្ទ គឺធ្លាក់មកលើទាំងមនុស្សនឹងសត្វ ហើយ
លើគ្រប់ទាំងដំណាំនៅទីវាលក្នុងស្រុកផង ២៣ម៉ូសេ ក៏លើក
ដំបងទៅលើមេឃ នោះព្រះយេហូវ៉ាទ្រង់ចាត់ឱ្យមានផ្គរ[ព]
ហើយនិងព្រឹល[ភ]មក ក៏មានរន្ទះបាញ់ផ្សាយជាភ្លើងនៅលើ
ដី ហើយព្រះយេហូវ៉ាទ្រង់បង្អុរព្រឹលមកលើស្រុកអេស៊ីព្ទ
២៤ក៏មានព្រឹល និងភ្លើងលាយគ្នាជាយ៉ាងវេទនាដល់ម្ល៉េះ
បានជាតាំងពីស្រុកអេស៊ីព្ទកើតឡើងជានគរ នោះមិនដែល
មាននៅក្នុងស្រុកដូច្នោះឡើយ[ម] ២៥នៅគ្រប់ក្នុងស្រុកអេស៊ីព្ទ
ព្រឹលនោះបានធ្លាក់មកត្រូវរបស់ទាំងអស់នៅទីវាល តាំងពី
មនុស្សរហូតដល់សត្វ ក៏ធ្លាក់មកបំផ្លាញអស់ទាំងដំណាំនៅ
វាលដែរ ហើយបំបាក់អស់ទាំងដើមឈើនៅចំការផង[យ]
២៦ឯទីដែលគ្មានព្រឹល នោះមានតែនៅស្រុកកូសែន[រ] ដែល
ជាទីលំនៅរបស់ពួកកូនចៅអ៊ីស្រាអែលប៉ុណ្ណោះ[ល]។

២៧នោះផារ៉ោន ទ្រង់ចាត់ឱ្យទៅហៅម៉ូសេ និងអើរ៉ុន
មកថា ម្ដងនេះអញជាអ្នកមានបាប[វ] គឺជាព្រះយេហូវ៉ា

**៩:៩** ឈ លវ ១៣:១៨,១៩ ចទ ២៨:២៧,៣៥ ២ពវ ២០:៧ យប ២:៧ អស ៣៨:២១ វវ ១៦:២
**៩:១១** ញ នក ៨:១៨
**៩:១២** ដ នក ៤:២១ ឋ នក ៧:៤
**៩:១៣** ឌ នក ៣:១៨
**៩:១៤** ឍ នក ៨:១០ ណ នក ១៥:១១ ១សយ ២:២ ២សយ ៧:២២ ១ពវ ៨:២៣ ១រប ១៧:២០ ទដ ៣៥:១០ ៧១:១៩ ៨៦:៨ ៨៩:៦ អស ៤៦:៩ យរ ១០:៦ មីក ៧:១៨
**៩:១៥** ត នក ៣:២០
**៩:១៦** ថ សភ ១៦:៤ នក ១៤:៤,១៧, ៣១ ទដ ២០:៦ ២៥:១១ ៦៨:២៨ ៧១:១៨ ១០៦:៨ ១០៩:២១ រម ៩:១៧
**៩:១៨** ធ ខ.២៣ យស ១០:១១ ទដ ៧៨:៤៧–៤៨ ១០៥:៣២ ១៤៨:៨ អស ៣០:៣០ អគ ៣៨:២២ ហាក ២:១៧ ន ខ.២៤ នក ១០:៦
**៩:២០** ប សភ ១៣:១៣
**៩:២១** ផ លប ១៩:១៤ អគ ៣៣:៤–៥
**៩:២៣** ព នក ២០:១៨ ១សយ ៧:១០ ១២:១៧ ទដ ១៨:១៣ ២៩:៣ ៦៨:៣៣ ៧៧:១៧ ១០៤:៧ ភ ខ.១៨ វវ ៨:៧ ១៦:២១ **៩:២៤** ម ខ.១៨ **៩:២៥** យ ទដ ១០៥:៣២–៣៣ អគ ១៣:១៣
**៩:២៦** រ ខ.៤ អស ៣២:១៨–២០ ល នក ១០:២៣ ១១:៧ ១២:១៣ អម ៤:៧
**៩:២៧** វ ខ.៣៤ នក ១០:១៦ ជណ ១៤:៤០ ចទ ១:៤១ យស ៧:១១ ពច ១០:១០ ១សយ ១៥:២៤ ២៤:១៧ ២៦:២១

**៩:៩** *បូស* អាចជាជំងឺសើស្បែក(សេចក្ដីវេទនាកើតដល់ហ្វូងសត្វក្នុង ខ.១–៧)មានស្នាមរលៀកពណ៌ខ្មៅ ដែលប្រែជាពងបែក ។ *មនុស្ស ព្រមទាំងសត្វ* សេចក្ដីវេទនានេះ បានកើតឡើងដល់សត្វ ព្រមទាំងសាសន៍អេស៊ីព្ទ ។

**៩:១៦** លោកប៉ុលបានដកស្រង់ខនេះ មកពីពណ៌នាអំពីអំណាចនៃព្រះ(មើល រម ៩:១៧) ។

**៩:១៨** *បង្អុរឱ្យធ្លាក់ព្រឹលជាយ៉ាងវេទនា* ជំនន់នៃទន្លេនីលស្រេក(អាចក្នុងពេលនៃសេចក្ដីវេទនាទាំង៦ដំបូង)នៅចុងរដូវស្លឹកឈើជ្រុះ ។ គឺសំដៅទៅលើដុំទឹកកកតូចៗរាងមូល ដែលពេលនោះគឺនៅខែមករា ឬកុម្ភៈ ដែលមានដើមខ្លូតទេស និងស្រូវឱកចេញផ្កា ប៉ុន្តែ ស្រូវសាលី និងស្រូវអេប៉ូតមិនទាន់ដុះនៅឡើយ(មើល ខ.៣១–៣២) ។

**៩:៩–១២** មើលការពន្យល់ ខ.៦ ។

**៩:១៩** ខនេះជាឧទាហរណ៍នៃសេចក្ដីមេត្តាករុណារបស់ព្រះ ដែលទ្រង់អនុញ្ញាតិឱ្យមានការការពារដល់ទាំងជីវិតមនុស្ស និងជីវិតសត្វ នៅពេលដែលទ្រង់ជំនុំជម្រះ(មើលការពន្យល់ យហ ៤:១១)។

**៩:២៧** *ម្ដងនេះអញជាអ្នកមានបាប* នេះជាលើកទីមួយហើយ ដែលស្ដេចផារ៉ោនទទួលស្គាល់អំពើបាបរបស់ខ្លួន និងសេចក្ដីហិនវិនាសនៃបាបនោះ ។

ដែលសុចរិត[ស] ឯអញនិងរាស្ត្រអញ យើងជាពួកអាក្រក់វិញ
២៨ដូច្នេះសូមឱ្យឯងអង្វរ[ហ]ដល់ព្រះយេហូវ៉ាផង ដ្បិតមានផ្គរ
ជាយ៉ាងខ្លាំង ហើយនិងព្រឹលនេះជាការល្មមហើយ នោះ
អញនឹងឱ្យឯងរាល់គ្នាចេញទៅ[ឡ] ឥតមានឃាត់ឃាំងទៀត
ឡើយ ២៩ម៉ូសេលោកទូលឆ្លើយថា កាលណាទូលបង្គំបាន
ចេញពីក្រុងទៅហើយ ទូលបង្គំនឹងលើកដៃ[អ]ទៅឯព្រះ
យេហូវ៉ា នោះផ្គរនឹងស្ងប់ហើយ និងគ្មានព្រឹលទៀត នេះ
ដើម្បីឱ្យទ្រង់ជ្រាបថា ផែនដី[ក]ជារបស់ផងព្រះយេហូវ៉ា
៣០ប៉ុន្តែទូលបង្គំដឹងថា ទ្រង់នឹងពួកមហាតលិកមិនទាន់ខ្លាច[ខ]
ដល់ព្រះយេហូវ៉ាដ៏ជាព្រះនៅឡើយទេ ៣១ឯដើមខ្លូតទេស
និងស្រូវឱក នោះ[គ]ហិនហោចអស់ ដ្បិតស្រូវឱកកំពុងតែ
បែកគួរ ហើយដើមខ្លូតទេសចេញផ្កាហើយ ៣២តែស្រូវ
សាលី និងស្រូវអេប៉ូត[ឃ]មិនបានខូចទេ ពីព្រោះមិនទាន់ដុះ
នៅឡើយ ៣៣ម៉ូសេក៏ចេញពីចំពោះផារ៉ោនទៅក្រៅទីក្រុង
លើកដៃប្រទូលទៅព្រះយេហូវ៉ា នោះផ្គរលាន់ក៏ស្ងប់ស្ងាត់
ព្រឹលក៏បាត់ទៅ ហើយភ្លៀងក៏រាំង មិនធ្លាក់មកលើដីទៀត
៣៤រួចកាលផារ៉ោនឃើញថា ភ្លៀងនិងព្រឹលហើយនិង
ផ្គរលាន់បានស្ងប់បាត់អស់ហើយ នោះទ្រង់នៅតែធ្វើបាប
ទៀត គឺទ្រង់តាំងព្រះទ័យរឹងទទឹង ព្រមទាំងពួកមហាតលិក
ទាំងអស់គ្នាផង ៣៥ដូច្នេះផារ៉ោនមានព្រះទ័យ[ង]រឹងទទឹង
មិនព្រមបើកឱ្យពួកកូនចៅអ៊ីស្រាអែលចេញទៅទេ ដូចជា
ព្រះយេហូវ៉ាទ្រង់បានមានបន្ទូល ដោយសារម៉ូសេ ។

## សេចក្តីវេទនាដោយសត្វកណ្តូប

**១០** ១រួចព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ចូរទៅគាល់
ផារ៉ោន ដ្បិតអញបានបណ្តាលឱ្យចិត្ត[ក]ទ្រង់និងចិត្តនៃពួក
មហាតលិកទ្រង់រឹងទទឹង ដើម្បីឱ្យអញបានសំដែងអស់ទាំង
ទីសំគាល់របស់អញ[ខ] នៅក្នុងចំណោមពួកគេ ២ហើយឱ្យឯង
បាននិទានប្រាប់ដល់កូនចៅឯង[គ] ពីការដែលអញបានធ្វើ
នៅស្រុកអេស៊ីព្ទ និងពីទីសំគាល់ទាំងប៉ុន្មានដែលអញបាន
សំដែងនៅក្នុងពួកគេ[ឃ] យ៉ាងនោះឯងនឹងបានដឹងថា អញ
នេះជាព្រះយេហូវ៉ាពិត[ង] ៣នោះម៉ូសេនិងអើរ៉ុនក៏ចូលទៅ
គាល់ផារ៉ោនទូលថា ព្រះយេហូវ៉ាជាព្រះនៃសាសន៍
ហេព្រើរ ទ្រង់មានបន្ទូលដូច្នេះ តើឯងនៅតែមិនព្រម
បន្ទាបខ្លួន[ច]នៅមុខអញ ដើម្បីនឹងឱ្យរាស្ត្រអញចេញទៅថ្វាយ
បង្គំ អញដល់កាលណាទៀត ៤បើឯងមិនព្រម[ឆ]ឱ្យរាស្ត្រអញ
ចេញទៅទេ នោះមើល ដល់ថ្ងៃស្អែកអញនឹងនាំហ្វូង
កណ្តូប[ជ]មកក្នុងស្រុក ៥វានឹងមកគ្របពេញដី ទាល់តែមើល
ដីមិនឃើញទៀត ហើយនិងស៊ីអស់ទាំងរបស់ដែលសល់
នៅ[ឈ]អំពីព្រឹល វានឹងស៊ីអស់ទាំងដើមឈើដែលដុះនៅ
ចំការរបស់ឯងរាល់គ្នាផង[ញ] ៦វានឹងចូលពេញក្នុងផ្ទះឯង[ដ]
និងផ្ទះរបស់ពួកបំរើឯង ហើយនិងផ្ទះនៃពួកសាសន៍អេស៊ីព្ទ
ទាំងអស់ដែរ ដល់ម្ល៉េះបានជាឪពុកនិងពួកឰយុកោឯង
រាល់គ្នាមិនដែលឃើញដូច្នោះឡើយ តាំងពីគេកើតឡើង
រហូតដល់ឥឡូវនេះ[ឋ] នោះលោកក៏ថយចេញពីផារ៉ោនទៅ
៧ឯពួកមហាតលិករបស់ផារ៉ោន គេទូលថា តើទុកឱ្យមនុស្ស
នោះធ្វើជាអន្ទាក់[ឌ]ដល់យើងរាល់គ្នាដល់កាលណាទៀត
សូមឱ្យគេចេញទៅថ្វាយបង្គំដល់ព្រះយេហូវ៉ាជាព្រះនៃគេ
ទៅចុះ តើទ្រង់មិនទាន់ជ្រាបថា ស្រុកអេស៊ីព្ទខូចអស់ហើយ
ទេឬអី [ឍ]។
៨មានគេនាំម៉ូសេ និងអើរ៉ុនមកឯផារ៉ោនវិញ នោះទ្រង់
មានបន្ទូលថា ទៅចុះ ទៅថ្វាយបង្គំ[ណ]ព្រះយេហូវ៉ាជាព្រះ
នៃឯងរាល់គ្នាចុះ តើមានអ្នកណាខ្លះដែលទៅ ៩ម៉ូសេទូល

**៩:២៧** ស ទដ ១១:៧ ១១៦:៥ ១១៩:១៣៧ ១២៩:៤ ១៤៥:១៧ យរ ១២:១ បទ ១:១៨ **៩:២៨** ហ នក ៨:៨ កច ៨:២៤ ឡ នក ៨:៨ **៩:២៩** អ ខ.៣៣ ១ពវ ៨:២២,៣៨ យប ១១:១៣ ទដ ៧៧:២ ៨៨:៩ ១៤៣:៦ អស ១:១៥ ក នក ១៩:៥ យប ៤១:១១ ទដ ២៤:១ ៥០:១២ ១កថ **៩:៣០** ខ នក ៨:២៩ **៩:៣១** គ ចទ ៨:៨ រម ១:២២ ២:២៣ ២សយ ១៤:៣០ ១៧:២៨ អស ២៨:២៥ អគ ៤:៩ យអ ១:១១ **៩:៣២** ឃ អស ២៨:២៥ **៩:៣៥** ង នក ៤:២១ **១០:១** ក នក ៤:២១ ខ នក ៣:១៩ ៧:៣ យស ២៤:១៧ នហ ៩:១០ ទដ ៧៤:៩ ១០៥:២៦–៣៦ **១០:២** គ នក ១២:២៦–២៧ ១៣:៨,១៤ ចទ ៤:៩ ៦:២០ ៣២:៧ យស ៤:៦ ទដ ៤៤:១ ៧១:១៨ ៧៨:៤,៥ យអ ១:៣ ឃ ១សយ ៦:៦ ង នក ៦:២ **១០:៣** ច ១ពវ ២១:២៩ ២ពវ ២២:១៩ ២របា ៧:១៤ ១២:៧ ៣៣:២៣ ៣៤:២៧ យប ៤២:៦ អស ៥៨:៣ ដយ ៥:២២ យក ៤:១០ ១ពត ៥:៦ **១០:៤** ឆ នក ៨:២ ៩:២ ជ ចទ ២៨:៣៨ ទដ ១០៥:៣៤ សភ ៣០:២៧ យអ ១:៤ វវ ៩:៣ **១០:៥** ឈ នក ៩:៣២ យអ ១:៤ ញ ខ.១៥ **១០:៦** ដ យអ ២:៩ ឋ នក ៩:១៨ **១០:៧** ឌ នក ២៣:៣៣ ៣៤:១២ ចទ ៧:១៦ ១២:៣០ ២០:១៨ យស ២៣:១៣ ពច ២:៣ ៨:២៧ ១៦:៥ ១សយ ១៨:២១ ទដ ១០៦:៣៦ សស ៧:២៦ ឍ លប ២០:៣ នក ៨:១៩ **១០:៨** ណ នក ៨:៨

---

**៩:២៩** *ទូលបង្គំនឹងលើកដៃទៅ* មើល ១ពវ ៨:២២,៣៨,៥៤ ២របា ៦:១២–១៣ អរ ៩:៥ ទដ ៤៤:២០ ៨៨:៩ ១៤៣:៦ អស ១:១៥ ១ធថ ២:៨ ។ អ្នកបុរាណវត្ថុវិជ្ជាបានរកឃើញរូបចម្លាក់មនុស្សប្រុសលើកដៃអធិស្ឋានទៅលើនៅកន្លែងការរដ្ឋានកំណាយមួយចំនួននៅមជ្ឈឹមបូព៌ា ។

**៩:៣០** មើលការពន្យល់ លប ២:៤ ។

**៩:៣១–៣២** មើលការពន្យល់ ខ.១៨ ។

**១០:២** *ប្រាប់ដល់កូនចៅឯង* ពួកគេបន្តនិយាយរឿងពិតនៃការប្រោសលោះរបស់ព្រះអម្ចាស់ ដល់កូនចៅរបស់ពួកគេពីមួយជំនាន់ទៅមួយជំនាន់ ដើម្បីឱ្យជាតិសាសន៍របស់ពួកគេនៅតែចងចាំរឿងនោះជានិច្ច(មើល ១២:២៦–២៧ ១៣:៨,១៤–១៥ ចទ ៤:៩ ទដ ១៧:១១–២០ ៧៨:៤–៦,៤៣–៥៣)។

**១០:៤** *អញនិងនាំហ្វូងកណ្តូបមក* ក្នុងខែមិនា និងមេសា ខ្យល់បក់ពីទិសខាងកើត(មើល ខ.១៣) ជូនកាលនាំសត្វកណ្តូបទាំងហ្វូងៗពីតំបន់ផ្សេងមក មានចំនួន៥០លានក្បាល ក្នុងមួយគីឡូម៉ែត្រការេ អាចស៊ីបំផ្លាញផលដំណាំអស់១សែនតោនក្នុងមួយយប់ ។ នៅសម័យបុរាណ គេភ័យខ្លាចគ្រោះចង្រៃនៃកណ្តូបណាស់ ហើយវាជានិមិត្តរូបនៃការជំនុំជម្រះដ៏ធ្ងន់ធ្ងរពីព្រះអម្ចាស់ (មើល យអ ១:៤–៧ ២:១–១១ អម ៧:១–៣)។

**១០:៧** *កាលណាទៀត . . .* ពួកមន្ត្រីរបស់ស្តេចផារ៉ោន ប្រើពាក្យនេះ ដែលលោកម៉ូសេបាននិយាយក្នុង ខ.៣ ។ *ស្រុកអេស៊ីព្ទខូចអស់ហើយ* ការបះបោរ និងការមិនស្តាប់បង្គាប់របស់មនុស្ស តែងតែនាំមកនូវសេចក្តីស្លាប់ និងសេចក្តីហិនវិនាសមកលើខ្លួនវិញ ។

ឆ្លើយថា យើងខ្ញុំនឹងទៅទាំងចាស់ទាំងក្មេង ទាំងកូនប្រុស
កូនស្រី ហើយនិងហ្វូងចៀមហ្វូងគោរបស់យើងខ្ញុំទាំងអស់
គ្នា ដ្បិតនេះគឺជាបុណ្យ[ត]ព្រះយេហូវ៉ា សំរាប់យើងខ្ញុំរាល់គ្នា
១០នោះទ្រង់មានបន្ទូលថា សូមឱ្យព្រះយេហូវ៉ាគង់ជាមួយ
នឹងឯងរាល់គ្នា ដូចជាអញបានប្រុងឱ្យឯងរាល់គ្នា និងកូន
ចៅឯងទៅដែរ តែចូរប្រយ័ត្ន ដ្បិតមានគ្រោះនៅខាងមុខ
ឯងរាល់គ្នា ១១ឈប់សិន ចូរឯងរាល់គ្នាចេញទៅតែពួក
ប្រុសៗប៉ុណ្ណោះ ដើម្បីនឹងថ្វាយបង្គំដល់ព្រះយេហូវ៉ាចុះ ដ្បិត
ឯងរាល់គ្នាបានសូមដូច្នេះហើយ រួចគេក៏បណ្តេញលោក
ទាំង២ចេញពីមុខផារ៉ោនទៅ ។
១២នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរ
លើកដៃ[ថ]ឡើងលើស្រុកអេស៊ីព្ទ ដើម្បីឱ្យកើតមានកណ្តូបមក
លើស្រុក ឱ្យវាស៊ីដំណាំទាំងប៉ុន្មានដែលសល់អំពីព្រឹល
មក ១៣ម៉ូសេក៏លើកដំបង[ទ]ទៅលើស្រុកអេស៊ីព្ទ នោះព្រះ
យេហូវ៉ាទ្រង់ធ្វើឱ្យមានខ្យល់ ពីខាងកើត បក់មកលើស្រុក
នោះ អស់១ថ្ងៃ១យប់ លុះដល់ព្រឹកឡើងក៏បក់ដោយទាំង
កណ្តូបមកផង[ធ] ១៤កណ្តូបឡើងមកគ្របលើស្រុកអេស៊ីព្ទទាំង
មូលក៏ទំនៅពេញគ្រប់ទាំងព្រំស្រុក វានាំឱ្យវេទនាណាស់
តាំងពីដើមមក មិនដែលមានកណ្តូបយ៉ាងនោះឡើយ[ន]
ហើយទៅខាងមុខក៏មិនដែលមានទៀតដែរ ១៥ដ្បិតវាមក
គ្របពេញពីលើដី ដល់ម្ល៉េះបានជាស្រុកត្រឡប់ទៅជាងងឹត
វាក៏ស៊ី[ប] ដំណាំទាំងអស់នៅក្នុងស្រុក ហើយនិងអស់ទាំងផ្លែ
ឈើដែលរួចអំពីព្រឹលមក គ្មានសល់ស្លឹកខ្ចីណាមួយនៅ
ដើមឈើ ឬស្មៅនៅវាលគ្រប់ក្នុងស្រុកអេស៊ីព្ទឡើយ ។
១៦នោះផារ៉ោន ទ្រង់ហៅ[ផ]ម៉ូសេ និងអើរ៉ុនមកជា
ប្រញាប់ប្រាប់ថា អញបានធ្វើបាប[ព]នឹងព្រះយេហូវ៉ាជា ព្រះ
នៃឯងរាល់គ្នា ហើយនិងឯងរាល់គ្នាដែរ ១៧ដូច្នេះសូមអត់
ទោស[ភ]ដល់អញក្នុងគ្រានេះម្តងចុះ ហើយសូមអង្វរ[ម] ដល់
ព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ដើម្បីឱ្យទ្រង់បន្ថយ
សេចក្តីស្លាប់នេះចេញពីអញទៅ ១៨លោកក៏ថយចេញពី
ផារ៉ោនទៅ សូមអង្វរដល់ព្រះយេហូវ៉ា[យ] ១៩នោះទ្រង់ក៏ធ្វើ
ឱ្យមានខ្យល់ពីខាងលិចយ៉ាងខ្លាំង បក់កៀរកណ្តូបទំលាក់
ទៅក្នុងសមុទ្រក្រហមអស់ទៅ គ្មានសល់កណ្តូបណាមួយនៅ
គ្រប់ក្នុងស្រុកអេស៊ីព្ទទៀតឡើយ ២០តែព្រះយេហូវ៉ាទ្រង់
បណ្តាលឱ្យផារ៉ោនមានព្រះទ័យរឹងទទឹងដដែល[រ] ហើយ
ផារ៉ោនមិនព្រមបើកឱ្យកូនចៅអ៊ីស្រាអែលចេញទៅទេ ។

## សេចក្តីវេទនាដោយភាពងងឹត

២១រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរលើកដៃ
ទៅលើមេឃ ឱ្យមានងងឹត[ល]នៅលើស្រុកអេស៊ីព្ទ គឺជាងងឹត
ដែលនាំឱ្យស្ទាបរាវ ២២លោកក៏លើកដៃទៅលើ មេឃ
នោះមានងងឹតយ៉ាងក្រាស់ណាស់[វ] នៅពេញក្នុងស្រុកអេ–
ស៊ីព្ទអស់ចំនួន៣ថ្ងៃ ២៣គេមើលគ្នាមិនឃើញសោះក្នុងវេលា
៣ថ្ងៃនោះ ឥតមានអ្នកណាក្រោកពីកន្លែងខ្លួនឡើយ តែនៅ
ក្នុងផ្ទះនៃពួកកូនចៅអ៊ីស្រាអែល នោះមានពន្លឺវិញ[ស]។
២៤ឯផារ៉ោនទ្រង់មានបន្ទូលហៅម៉ូសេមក ប្រាប់ថា ទៅ
ចុះ[ហ] ចូរទៅថ្វាយបង្គំព្រះយេហូវ៉ាចុះ ឱ្យទុកតែហ្វូងចៀម
ហើយនិងហ្វូងគោឯងរាល់គ្នាប៉ុណ្ណោះ ចូរយកទាំងកូន
តូចៗ[ឡ]ទៅជាមួយផង[អ] ២៥តែម៉ូសេប្រកែកថា ទេ ត្រូវឱ្យ
ទ្រង់ប្រទានសត្វ សំរាប់ជាយញ្ញបូជា និងដង្វាយដុត[ក]
មកយើងខ្ញុំ ឱ្យយើងខ្ញុំបានរៀបថ្វាយព្រះយេហូវ៉ា ជាព្រះ
នៃយើងខ្ញុំផង ២៦យើងខ្ញុំត្រូវតែនាំហ្វូងសត្វទៅជាមួយ មិន
ត្រូវឱ្យនៅសល់ សូម្បីតែក្រចកសត្វណាមួយផង ព្រោះយើង
ខ្ញុំត្រូវយកពីហ្វូងសត្វនោះ និងថ្វាយបង្គំដល់ព្រះយេហូវ៉ា
ជាព្រះនៃយើងខ្ញុំ ហើយយើងខ្ញុំមិនទាន់ដឹងជាត្រូវយកអ្វី
ដើម្បីនឹងថ្វាយបង្គំព្រះយេហូវ៉ាដែរ ទាល់តែបានដល់ទី
នោះ ២៧តែព្រះយេហូវ៉ាទ្រង់បណ្តាលឱ្យផារ៉ោន មានព្រះ
ទ័យ[ខ]រឹងទទឹងទៀត ហើយស្តេចមិនព្រមបើកឱ្យគេទៅទេ
២៨ផារ៉ោនក៏មានបន្ទូលទៅលោកថា ថយចេញពីអញទៅ
ចូរប្រយ័ត្ន កុំឱ្យមកនៅមុខអញទៀតឡើយ ដ្បិតបើថ្ងៃណា

**១០:៩** ត នក ៣:១៨ **១០:១២** ថ នក ៧:១៩ **១០:១៣** ទ ខ.២១–២២ នក ៤:១៧ ៨:៥,១៧ ៩:២៣ ១៤:១៥–១៦ ២៦–២៧ ១៧:៥ ជន ២០:៨ ធ ខ.៤ ១ពវ ៨:៣៧ ទដ ៧៨:៤៦ ១០៥:៣៤ អម ៤:៩ ណហ ៣:១៦ **១០:១៤** ន ជយ ២៨:៣៨ ទដ ៧៨:៤៦ អស ៣៣:៤ យអ ១:៤ ២:១–១១,២៥ **១០:១៥** ប ចទ ២៨:៣៨ ទដ ១០៥:៣៤–៣៥ យអ ១:៤ អម ៧:២ មឡ ៣:១១ **១០:១៦** ផ នក ៨:២៥ ព នក ៩:២៧ **១០:១៧** ភ ១សយ ១៥:២៥ ម នក ៨:៨ **១០:១៨** យ នក ៨:៣០ **១០:២០** រ នក ៤:២១ **១០:២១** ល ចទ ២៨:២៩ **១០:២២** វ ទដ ១០៥:២៨ អស ១៣:១០ ៤៥:៧ ៥០:៣ វវ ១៦:១០ **១០:២៣** ស នក ៨:២២ អម ៤:៧ **១០:២៤** ហ នក ៨:៨ ឡ ខ.៨–១០ អ លប ៤៥:១០ **១០:២៥** ក លប ៨:២០ នក ១៨:១២ **១០:២៧** ខ នក ៤:២១

**១០:១០** *ព្រះយេហូវ៉ាគង់ជាមួយនឹងឯងរាល់គ្នា* ស្តេចផារ៉ោនប្រើពាក្យនេះក្នុងន័យផ្សេង ព្រោះនៅចុងខ "ដ្បិតមានគ្រោះនៅខាងមុខឯងរាល់គ្នា"។
**១០:១១** *ចូរឯងរាល់គ្នាចេញទៅតែពួកប្រុសៗប៉ុណ្ណោះ* ស្តេចផារ៉ោនយល់ថា (១).ឯស្ត្រីៗ និងក្មេងៗគួរតែនៅជាចំណាប់ខ្មាំង (២).ជាធម្មតាពួកប្រុសៗធ្វើការថ្វាយបង្គំព្រះច្រើនជាងមនុស្សស្រី ។
**១០:១៣** *ខ្យល់ពីទិសខាងកើត* មើលការពន្យល់ ខ.៤ ។
**១០:១៩** *ទ្រង់ក៏ធ្វើឱ្យមានខ្យល់* ព្រះទ្រង់ប្រើអំណាចនៃធម្មជាតិដែលទ្រង់បង្កើត ដើម្បីសម្រេចបំណងព្រះហឫទ័យទ្រង់នៅក្នុងប្រវត្តិសាស្ត្រ (មើល ខ.៤ ១៤:២១ ទដ ១០៤:៤ និងការពន្យល់ ធៀបនឹង មថ ៨:២៣–២៧)។ *សមុទ្រក្រហម* នៅក្នុងព្រះគម្ពីរភាសាហេព្រើ ពាក្យនេះគឺ យ៉ាម ស៊ូប (Yam Suph, មានន័យថា "សមុទ្រដើមបបុស") ។
**១០:២១** *មានងងឹតនៅលើស្រុកអេស៊ីព្ទ* ព្រះទ្រង់ចាក់សេចក្តីវេទនាទី៩ មកដោយមិនបានឱ្យដល់ស្តេចផារ៉ោនដឹងជាមុន គឺដូចកាលទ្រង់ចាក់សេចក្តីវេទនាទី៣ និងទី៦ ដែរ ។ ភាពងងឹតនេះអាចកើតឡើងពីផ្សែង ឬឧស្ម័នដែលចេញពីបន្ទុះភ្នំភ្លើងនៅសម័យនោះ ក្បែរនគរក្រិក (មើលការពន្យល់ ៧:១៧) ។ ភាពងងឹតនេះ គឺជាការវាយប្រហារមកលើព្រះនៃព្រះអាទិត្យ ព្រះនាម រ៉ា (Ra "ឬរេ "Re) ដែលស្ថិតនៅក្នុងចំណោមព្រះធំៗនៃពួកអេស៊ីព្ទ
**១០:២៨** ក្នុងខនេះ ស្តេចប្រកាសមិនឱ្យលោកម៉ូសេចូលគាល់ទៀតឡើយ ។

ដែលឯងមកនៅមុខអញ នោះឯងនឹងត្រូវស្លាប់ ២៩ម៉ូសេក៏
ទូលឆ្លើយថា បន្ទូលនោះត្រូវណាស់ ទូលបង្គំលែងមក
គាល់[គ]ទ្រង់ទៀតហើយ ។

**១១** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា អញនឹងនាំ
សេចក្តីវេទនា១ទៀតមកលើផារ៉ោន ហើយនិងស្រុកអេស៊ីព្ទ
រួចអំពីនោះស្តេចនឹងឱ្យឯងរាល់គ្នាចេញ[ក]ពីនេះទៅ ហើយ
កាលណាឱ្យទៅ នោះនឹងបង្ខំឱ្យចេញផុតពីនេះទៅទាំងអស់
គ្នាផង[ខ] ២ចូរនិយាយដាក់ត្រចៀកបណ្តាជនទាំងឡាយឥឡូវ
ចុះ ប្រយោជន៍ឱ្យគេទាំងប្រុសទាំងស្រីបានសូមគ្រឿងមាស
គ្រឿងប្រាក់ពីអ្នកជិតខាងរៀងខ្លួន[គ] ៣ព្រះយេហូវ៉ាទ្រង់ក៏
ធ្វើឱ្យពួកជនបានប្រកបដោយគុណ[ឃ]នៃសាសន៍អេស៊ីព្ទ
១ទៀត ម៉ូសេក៏ជាអ្នកធំ[ង]នៃមហាតលិកផារ៉ោន ហើយនិង
បណ្តាជនទាំងឡាយនៅស្រុកអេស៊ីព្ទផង ។

៤ម៉ូសេក៏ទូលថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
ដល់កណ្តាលអធ្រាត្រ[ច]អញនឹងទៅនាកណ្តាលស្រុកអេស៊ីព្ទ[ឆ]
៥នោះអស់ទាំងកូនច្បង[ជ]នៅស្រុកអេស៊ីព្ទនឹងស្លាប់ ចាប់
តាំងពីកូនច្បងរបស់ផារ៉ោនដែលគង់លើបល្ល័ង្ករាជ្យ ចុះ
មកដល់កូនច្បងបាវស្រីដែលនៅខាងក្រោយត្បាល់កិន[ឈ]
ហើយគ្រប់ទាំងកូនច្បងក្នុងហ្វូងសត្វដែរ ៦នោះគេនឹង
ស្រែកទ្រហោយំ[ញ]នៅពេញក្នុងស្រុកអេស៊ីព្ទ ដល់ម្ល៉េះបាន
ជាពីដើមមក មិនដែលមានដូច្នេះឡើយ ហើយទៅមុនទៀត
ក៏មិនដែលមានដែរ ៧ប៉ុន្តែនៅក្នុងពួកកូនចៅអ៊ីស្រាអែល
ចាប់តាំងមនុស្សដល់សត្វ នោះសូម្បីតែឆ្កែ១ក៏នឹងមិនកំរើក
អណ្តាតទាស់នឹងគេឡើយ នេះដើម្បីឱ្យអ្នករាល់គ្នាបានដឹង
ថា ព្រះយេហូវ៉ាទ្រង់រាប់[ដ]សាសន៍អេស៊ីព្ទ និងសាសន៍
អ៊ីស្រាអែលផ្សេងអំពីគ្នា ៨នោះអស់ទាំងពួកមហាតលិកទាំង
នេះ គេនឹងចុះ មកឱនគោរពចំពោះទូលបង្គំដោយថា សូម
លោកអញ្ជើញចេញ[ឋ]ពីនេះទៅ ព្រមទាំងពួកអ្នកដែលតាម
លោកផង ទើបទូលបង្គំក៏ចេញទៅ[ឌ] នោះលោកក៏ថយ
ចេញពីផារ៉ោនទៅទាំងមានចិត្តក្តៅជាខ្លាំង ។

៩ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ផារ៉ោនមិន
ព្រមស្តាប់[ឍ]ឯងទេ គឺដើម្បីឱ្យការអស្ចារ្យ[ណ]របស់អញបាន
ចំរើនឡើងនៅក្នុងស្រុកអេស៊ីព្ទ ១០ម៉ូសេនិងអើរ៉ុនក៏ធ្វើ
អស់ទាំងការអស្ចារ្យនោះនៅចំពោះផារ៉ោន តែព្រះ
យេហូវ៉ាទ្រង់បណ្តាលឱ្យផារ៉ោនមានព្រះទ័យ[ត]រឹងទទឹង
មិនព្រមបើកឱ្យពួកកូនចៅអ៊ីស្រាអែលចេញពីស្រុកទៅទេ។

## ការរំលង

*១២:១៤-២០ – លវ ២៣:៤-៨ ជន ២៨:១៦-២៥ ចទ ១៦:១-៨*

**១២** ១ព្រះយេហូវ៉ា ទ្រង់ក៏មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុននៅស្រុកអេស៊ីព្ទថា ២ខែនេះជាខែដំបូង គឺជាខែ
ដើមឆ្នាំ[ក]សំរាប់ឯងរាល់គ្នា ៣ចូរប្រកាសប្រាប់ដល់ពួកជំនុំ
សាសន៍អ៊ីស្រាអែលទាំងអស់គ្នាថា នៅថ្ងៃ១០ខែនេះ ត្រូវ
ឱ្យគ្រប់គ្នាយកកូនចៀម១[ខ] តាមពួកគ្រួឪពុកខ្លួន គឺកូនចៀម១
សំរាប់គ្រួ១[គ] ៤បើផ្ទះណាមានគ្នាតិចពេក មិនល្មមឱ្យអស់
កូនចៀម១បាន នោះត្រូវចូលជាមួយនឹងអ្នកជិតខាងតាម
ចំនួនមនុស្ស ត្រូវឱ្យរាប់ចំនួនមនុស្សតាមដែលគេបរិភោគ
កូនចៀម១បាន ៥ត្រូវតែយកកូនចៀមឈ្មោលឥតខ្ចោះមាន
អាយុ១ខួប[ឃ] ទោះពីក្នុងហ្វូងចៀមឬហ្វូងពពែក៏បាន ៦រួច

**១០:២៩** គ នក ១១:៨ ហព ១១:២៧ **១១:១** ក នក ៣:២០ ខ នក ៦:១ **១១:២** គ នក ៣:២១,២២ **១១:៣** ឃ លប ៣៩:២១ ង ចទ ៣៤:១១ ២សយ ៧:៩ ៨:១៣ ២២:៤៤ ២៣:១ នអ ៩:៤ ទដ ៨៩:២៧ **១១:៤** ច នក ១២:២៩ យប ៣៤:២០ ឆ នក ១២:២៣ ទដ ៨១:៥ **១:៥** ជ នក ៤:២៣ ឈ អស ៤៧:២ **១១:៦** ញ នក ១២:៣០ សភ ២១:៣១ អម ៥:១៧ **១១:៧** ដ នក ៨:២២ **១១:៨** ឋ នក ១២:៣១-៣៣ ឌ ហព ១១:២៧ **១១:៩** ឍ នក ៧:៤ ណ នក ៣:២០ **១១:១០** ត នក ៤:២១ រម ២:៥ **១២:២** ក ខ.១៨ នក ១៣:៤ ២៣:១៥ ៣៤:១៨ ៤០:២ ចទ ១៦:១ **១២:៣** ខ មក ១៤:១២ ១កថ ៥:៧ គ ខ.២១ **១២:៥** ឃ នក ២៩:១ លវ ១:៣ ៣:១ ៤:៣ ២២:១៨-២១ ២៣:១២ ជណ ៦:១៤ ១៥:៨ ២៨:៣ ចទ ១៥:២១ ១៧:១ ហព ៩:១៤ ១ពត ១:១៩

**១១:១** *ហើយកាលណាឱ្យទៅ* តាមព្រះគម្ពីរភាសាហេព្រើ ការឱ្យទៅនោះ គឺដូចជាការឱ្យកូនក្រមុំទៅ ទាំងមានជំនូនទៅជាមួយផង (លប ២៤:៥៣) ។

**១១:២-៣** មើល ៣:២១-២២ ១២:៣៥-៣៦ ។

**១១:៤** *ម៉ូសេក៏ទូលថា* គឺទូលបន្តពី ១០:២៩ ។

**១១:៥** *អស់ទាំងកូនច្បងនៅស្រុកអេស៊ីព្ទនឹងស្លាប់* សូមមើល ទដ ៧៨:៥១ ១០៥:៣៦ ១៣៥:៨ ១៣៦:១០ ។ ជាគ្រោះមហន្តរាយចុងក្រោយធ្ងន់ធ្ងរជាងគេ ព្រោះផែនការនិងក្តីប្រាថ្នារបស់ឪពុកទាំងឡាយ គឺជាប់ជំពាក់ខ្លាំងជាងគេនឹងកូនច្បង ជាអ្នកដែលត្រូវទទួលចំណែកមរតកទ្វេរដង នៅពេលដែលឪពុកស្លាប់ទៅ (មើល ចទ ២១:១៧ និងការពន្យល់) ។ *បាវស្រីដែលនៅខាងក្រោយត្បាល់កិន* គឺជាការងារដែលទាបបំផុត (អស ៤៧:២) ។

**១១:៧** *ផ្សេងអំពីគ្នា* មើលការពន្យល់ ៨:២២ ។

**១១:៨** *លោកក៏ថយចេញពីផារ៉ោនទៅមានចិត្តក្តៅជាខ្លាំង* លោកម៉ូសេបានជួបការគម្រាមយកជីវិតគាត់ ដូចនេះ ព្រះអម្ចាស់ទ្រង់បានបង្គាប់ឱ្យលោកម៉ូសេប្រកាសដល់ស្តេចផារ៉ោន អំពីការសម្លាប់កូនច្បងរបស់ទ្រង់ ដែលនឹងកើតមានផងដែរ (១០:២៨) ។

**១២:២** *ខែនេះ . . . ខែដំបូង* គឺជាការចាប់ផ្តើមនៃប្រតិទិននៃជំនឿរបស់ពួកអ៊ីស្រាអែល ។ នៅមជ្ឈឹមបូព៌ាបុរាណ ជាធម្មតា គេប្រារព្ធបុណ្យចូលឆ្នាំថ្មីស្របពេលនៃការមកដល់នៃរដូវថ្មី នៃជីវិតក្នុងធម្មជាតិផងដែរ ។ ការកំណត់យកខែនេះ ជាខែទីមួយនៃឆ្នាំថ្មីនៃជំនឿរបស់ពួកអ៊ីស្រាអែល គឺដើម្បីឱ្យពួកគេចងចាំថា ការរស់រាននៃជាតិសាសន៍គេ គឺដោយសារតែការប្រោសលោះរបស់ព្រះអម្ចាស់នៅក្នុងការធ្វើនិក្ខមនំ ។ ខែមានឈ្មោះជាភាសាកាណានថា អាប៊ីប (Abib, មើល ១៣:៤ ២៣:១៥ ៣៤:១៨ ចទ ១៦:១) មានន័យថា "គ្រាប់ខ្ចីរបស់ស្រូវ"។ ក្រោយមក ពួកបាប៊ីឡូនប្រើពាក្យនីសាន (Nisan) វិញ (មើល នហ ២:១ នអ ៣:៧) ។ ប្រតិទិនផ្នែកកសិកម្មរបស់អ៊ីស្រាអែលគឺ ចាប់ផ្តើមក្នុងសរទរដូវ (មើលការពន្យល់ ២៣:១៦) ហើយបានក្លាយជាប្រតិទិនខាងផ្លូវរដ្ឋ នៅសម័យរាជានិយម ។

**១២:៣** *ពួកជំនុំសាសន៍អ៊ីស្រាអែល* ពួកអ៊ីស្រាអែលជួបជុំគ្នាជាពួកជំនុំ ។

**១២:៦** *វេលាថ្ងៃលិច* គឺមានន័យថានៅក្នុងពីរពេល ដែលមានន័យពីរយ៉ាង

ត្រូវទុកវាដល់ថ្ងៃ១៤ខែនេះឯង[ង] នោះពួកជំនុំសាសន៍អ៊ីស្រា
អែលទាំងអស់គ្នាត្រូវសំឡាប់វានៅវេលាថ្ងៃលិច[ច] ៧រួចត្រូវ
យកឈាម[ឆ]វាប្រឡាក់នៅក្របទ្វារទាំងសងខាង ហើយលើ
ធ្នឹមទ្វាររបស់ផ្ទះដែលគេបរិភោគផង ៨ត្រូវឱ្យគេអាំង
សាច់[ជ] យកទៅបរិភោគជាមួយនឹងនំបុ័ងឥតដំបែ[ឈ] ហើយ
និងបន្លែល្វីង[ញ]នៅយប់នោះឯង[ដ] ៩មិនត្រូវបរិភោគឆៅឬ
ស្ងោរទេ គឺត្រូវអាំងវិញ ឱ្យមានជាប់ទាំងក្បាលទាំងជើង
ហើយនិងអាការៈខាងក្នុងផង[ឋ] ១០កុំទុកឱ្យអ្វីនៅសល់ដល់
ព្រឹកឱ្យសោះ បើមានសល់អ្វីដល់ព្រឹក[ឌ] នោះត្រូវដុតចោល
វិញ ១១ហើយត្រូវឱ្យបរិភោគបែបយ៉ាងនេះ គឺដោយ
ក្រវាត់ចង្កេះ ពាក់ស្បែកជើងទាំងកាន់ដំបងនៅដៃ ហើយ
ត្រូវបរិភោគឱ្យរហ័សផង[ឍ] នេះជាដំណើររំលងនៃព្រះ
យេហូវ៉ា ១២ដ្បិត នៅយប់នោះអញនឹងដើរកាត់[ត]ស្រុក
អេស៊ីព្ទ ហើយនិងវាយ[ថ]អស់ទាំងកូនច្បង [ទ]នៅក្នុងស្រុក
ចាប់តាំងពីមនុស្សដល់សត្វ ព្រមទាំងធ្វើទោសដល់អស់ទាំង
ព្រះ[ធ]នៃស្រុកអេស៊ីព្ទផង គឺអញនេះជាព្រះយេហូវ៉ា[ន]
១៣ឈាមនោះនឹង បានជាទីសំគាល់សំរាប់ឯងរាល់គ្នានៅ
ផ្ទះណាដែលឯងរាល់គ្នាអាស្រ័យនៅ កាលណាអញឃើញ
ឈាមនោះ អញនឹងរំលងផុតពី[ប]ឯងរាល់គ្នាទៅ ហើយនឹង
គ្មានសេចក្តីវេទនាណាបំផ្លាញឯងរាល់គ្នា ក្នុងវេលាដែល
អញវាយស្រុកអេស៊ីព្ទនោះឡើយ[ផ] ១៤ថ្ងៃនេះនឹងបានជា
សេចក្តីរំឭក[ព]ដល់ឯងរាល់គ្នា ត្រូវឱ្យឯងរាល់គ្នាកាន់ថ្ងៃនេះ
ជាបុណ្យថ្វាយព្រះយេហូវ៉ា គឺត្រូវកាន់ថ្ងៃនេះទុកជាច្បាប់
ជាដរាប នៅអស់ទាំងដំណរៀងរាបតទៅ ។
១៥ក្នុងរវាង៧ថ្ងៃ ឯងរាល់គ្នាត្រូវតែបរិភោគនំបុ័ងឥត
ដំបែ[ម] ចាប់តាំងពីថ្ងៃដំបូង នោះត្រូវយកដំបែពីផ្ទះចេញ
ដ្បិតអ្នកណាដែលបរិភោគនំបុ័ងមានដំបែ ចាប់តាំងពីថ្ងៃជា
ដំបូងរហូតដល់ថ្ងៃទី៧ អ្នកនោះនឹងត្រូវកាត់[យ]ពីសាសន៍
អ៊ីស្រាអែលចេញ ១៦នៅថ្ងៃដំបូង ឯងរាល់គ្នាត្រូវជំនុំ
បរិសុទ្ធ ហើយដល់ថ្ងៃទី៧ នោះក៏ត្រូវប្រជុំជំនុំបរិសុទ្ធទៀត
នៅថ្ងៃទាំងនោះ មិនត្រូវឱ្យធ្វើការ[រ]អ្វីសោះឡើយ ធ្វើបាន
តែម្ហូបដែលត្រូវបរិភោគប៉ុណ្ណោះ ១៧ត្រូវឱ្យឯងរាល់គ្នា
កាន់បុណ្យនំបុ័ងឥតដំបែនេះ[ល] ដ្បិតគឺនៅថ្ងៃនេះឯង ដែល
អញបាននាំពួកកងរបស់ឯងរាល់គ្នា ចេញពីស្រុកអេស៊ីព្ទ
មក[វ] បានជាត្រូវកាន់ថ្ងៃនេះទុកជាច្បាប់ជាដរាប នៅអស់
ទាំងដំណរៀងរាបតទៅ[ស] ១៨នៅថ្ងៃ១៤ខែដំបូងនោះ[ហ] ពី
ល្ងាច ត្រូវឱ្យឯងរាល់គ្នាបរិភោគនំបុ័ងឥតដំបែ ដរាបដល់
ល្ងាចថ្ងៃ២១ខែនោះ ១៩ក្នុងរវាង៧ថ្ងៃ មិនត្រូវឱ្យមានដំបែ
នៅក្នុងផ្ទះឯងរាល់គ្នាទេ ដ្បិតអ្នកណាដែលបរិភោគអ្វីមាន
ដំបែ អ្នកនោះនឹងត្រូវកាត់[ឡ]ពីពួកជំនុំសាសន៍អ៊ីស្រាអែល

**១២:៦** ង ខ.១៩ លវ ២៣:៥ ជន ៩:១–៣, ៥,១១ យស ៥:១០ ២រប ៣០:២ ច ន ១៦:១២ ចទ ១៦:៤,៦ **១២:៧** ឆ ខ.១៣, ២៣ អគ ៩:៦ **១២:៨** ជ ចទ ១៦:៧ ២រប ៣៥:១៣ ឈ ខ.១៩–២០ នក ១៣:៣ ចទ ១៦:៣–៤ ១កថ ៥:៨ ញ ជន ៩:១១ ដ ខ.១០ នក ១៦:១៩ ២៣:១៨ ៣៤:២៥ លវ ៧:១៥ ជន ៩:១២ **១២:៩** ឋ នក ២៩:១៣,១៧,២២ លវ ៣:៣ **១២:១០** ឌ ខ.៨ នក ១៣:៧ ២៩:៣៤ លវ ២២:៣០ ចទ ១៦:៤ **១២:១១** ឍ ខ.៣៣ ចទ ១៦:៣ អស ៤៨:២០ ៥២:១២ ណ ខ.១៣,២១, ២៧,៤៣ លវ ២៣:៥ ជន ៩:២,៤ ២៨:១៦ ចទ ១៦:១ យស ៥:១០ ២ពវ ២៣:២១,២៣ ២រប ៣០:១ អរ ៦:១៩ អស ៣១:៥ អគ ៤៥:២១ **១២:១២** ត អម ៥:១៧ ថ អម ១០:៣៣ ៣១:៨ ៣៧:៣៦ ទ ខ.២៩ នក ៤:២៣ ១៣:១៥ ធ នក ១៥:១១ ១៨:១១ ជន ៣៣:៤ ២រប ២:៥ ទដ ៩៥:៣ ៩៧:៩ ១៣៥:៥ អស ១៩:១ យរ ៤៣:១៣ ៤៤:៨ ន នក ៦:២ **១២:១៣** ប ខ.១១, ២៣ ហព ១១:២៨ ផ នក ៨:២៣ **១២:១៤** ព នក ១៣:៩ ២៣:១៤ ៣២:៥ ភ ខ.១៧,២៤ នក ១៣:៥,១០ ២៧:២១ លវ ៣:១៧ ១០:៩ ១៦:២៩ ១៧:៧ ២៣:១៤ ២៤:៣ ជន ១៨:២៣ **១២:១៥** ម នក ១៣:៦–៧ ២៣:១៥ ៣៤:១៨ លវ ២៣:៦ ជន ២៨:១៧ ចទ ១៦:៣ ១កថ ៥:៧ យ លប ១៧:១៤ **១២:១៦** រ ជន ២៩:៣៥ **១២:១៧** ល នក ២៣:១៥ ៣៤:១៨ ចទ ១៦:១៦ ២រប ៨:១៣ ៣០:២១ អរ ៦:២២ មថ ២៦:១៧ លក ២២:១ កថ ១២:៣ វ ខ.៤១ នក ៦:៦,២៦ ១៣:៣ លវ ១៩:៣៦ ស លវ ៣:១៧ **១២:១៨** ហ ខ.២ **១២:៩** ឡ លវ ១៧:១៤

(១).ចន្លោះពេលថ្ងៃលិចដល់ថ្ងៃរះ ឬ(២).ចន្លោះពេលថ្ងៃលិច និងពេលព្រលប់ ដែលនាំឱ្យមានការយល់ច្រឡំខ្លះពេលថ្ងៃបុណ្យ ឬថ្ងៃបរិសុទ្ធ ។

**១២:៧** *ឈាម* គឺជានិមិត្តរូបនៃការថ្វាយយញ្ញបូជាជាជំនួសឱ្យជីវិត(សូមមើល លប ៩:៤–៦ លវ ១៧:១១ និងការពន្យល់)។ ដូចនេះ ពួកអ៊ីស្រាអែលបានរួចជីវិតពីការសម្លាប់នោះ ដោយសារយញ្ញបូជានៃឈាមកូនចៀមនោះប៉ុណ្ណោះ(ហព ៩:២២ ១យហ ១:៧)។

**១២:៨** *បន្លែល្វីង* វាគឺជាតិណជាតិល្វីងដែលមានប្រភពនៅស្រុកអេស៊ីព្ទ ។ ពួកគេបរិភោគបន្លែនោះ ដើម្បីរំឭកអំពីសម័យដ៏ជូរចត់នៃការជាប់ជាទាសកនៅស្រុកអេស៊ីព្ទ(មើល ១:១៤ និងការពន្យល់)។ *នំបុ័ងឥតដំបែ* ជានិមិត្តរូបនៃដំណើរដ៏លឿននៃការចាកចេញពីស្រុកអេស៊ីព្ទ(មើល ២:១១, ៣៩ ចទ ១៦:៣ និងមើលការពន្យល់ លប ១៩:៣) ។

**១២:៩** *អាំងវា . . . ទាំងក្បាលទាំងជើង* គឺជាវិធីសាស្ត្រចំអិនសាច់ របស់ពួកគង្វាលចៀម ដែលឃ្វាលហ្វូងចៀងពីកន្លែងមួយទៅកន្លែងមួយទៀត ។

**១២:១១** *ដំណើររំលង* ខ.១៣,២៣,២៧ បានពន្យល់អំពីការនេះថា ព្រះអម្ចាស់ទ្រង់នឹងយាង "រំលង"ផ្ទះ ដែលមានលាបឈាមជាសញ្ញាទេ ។

**១២:១២** *ធ្វើទោសដល់អស់ទាំងព្រះនៃស្រុកអេស៊ីព្ទ* ពួកព្រះមួយចំនួនរបស់ពួកគេបានទទួលការជំនុំជម្រះហើយ(មើលការពន្យល់ ៧:១៩ ៨:២ ៩:៣ ១០:២១) ហើយនៅពេលនេះ ត្រូវជំនុំជម្រះពួកព្រះទាំងអស់ដោយ (១).ធ្វើឱ្យគេដឹងថា ព្រះទាំងនោះមិនអាចការពារពួកអេស៊ីព្ទ ពីការសម្លាប់នោះបានឡើយ (២).សត្វស័ក្តិសិទ្ធនៃពួកព្រះទាំងនេះ ក៏ទទួលការសម្លាប់ដែរ។

**១២:១៣** *ទីសំគាល់* ព្រះទ្រង់ចាក់សេចក្តីវេទនា ជាការជំនុំជម្រះដ៏អស្ចារ្យមកលើស្តេចផារ៉ោន និងពួកអេស៊ីព្ទ(មើល ៤:៣ និងការពន្យល់ ៨:២៣) ដូច្នេះ ទ្រង់បាន"រំលង"ពួកអ៊ីស្រាអែលដែលមានសញ្ញានៃឈាមកូនចៀម។

**១២:១៤** *ត្រូវកាន់ថ្ងៃនេះទុកជាច្បាប់ជាដរាបនៅអស់ទាំងតំណ* ព្រះគម្ពីរទាំងមូលបាននិយាយជាច្រើនដង អំពីការប្រារព្ធពិធីបុណ្យរំលង(មើល ជន ៩:១–៥ យស ៥:១០ ២ពវ ២៣:២១–២៣ ២រប ៣០:១–២៧ ៣៥:១–១៩ អរ ៦:១៩–២២ លក ២:៤១–៤៣ យហ ២:១៣,២៣ ៦:៤ ១១:៥៥–១២:១)។

**១២:១៧** *កាន់បុណ្យនំបុ័ងឥតដំបែ* សូមមើល មក ៨:១៥ និងការពន្យល់ ។ *ពួកកង* មើលការពន្យល់ ៦:២៦ ។

ចេញ ទោះបើជាអ្នកប្រទេសក្រៅ[អ] ឬជាអ្នកស្រុកក្តី ២០មិន
ត្រូវឱ្យបរិភោគអ្វីដែលមានដំបែឱ្យសោះ នៅក្នុងទីលំនៅ
របស់ឯងរាល់គ្នាទាំងប៉ុន្មាន[ក] នោះត្រូវបរិភោគតែនំបុ័ង
ឥតដំបែម៉្យាងប៉ុណ្ណោះ[ខ] ។
២១នោះម៉ូសេក៏ហៅពួកចាស់ទុំសាសន៍អ៊ីស្រាអែលមក
ប្រាប់ថា ចូរទៅយកកូនចៀម តាមគ្រួនៃអ្នករាល់គ្នា ហើយ
សំឡាប់ធ្វើបុណ្យរំលង[គ]ទៅ ២២រួចយកមែកហ៊ីសុប១កញ្ចុំ[ឃ]
ជ្រលក់ចុះក្នុងឈាមនៅក្នុងផើង ប្រឡាក់និងធ្នឹម ហើយនិង
ក្របទ្វារសងខាង ដោយឈាម[ង]ដែលនៅក្នុងផើងនោះ ក្នុង
ពួកអ្នករាល់គ្នាមិនត្រូវឱ្យអ្នកណាមួយចេញទៅក្រៅទ្វារផ្ទះ
ខ្លួនឱ្យសោះ រហូតដល់ព្រឹកឡើង ២៣ពីព្រោះព្រះយេហូវ៉ា
ទ្រង់នឹងយាងកាត់ស្រុក ដើម្បីវាយ[ច]ពួកសាសន៍អេស៊ីព្ទ កាល
ណាទ្រង់ទតឃើញឈាម[ឆ]ប្រឡាក់នៅធ្នឹម ហើយនិងក្រប
ទ្វារទាំងសងខាង នោះទ្រង់នឹងរំលង[ជ]ហួសទ្វារនោះទៅ
មិនឱ្យមេបំផ្លាញ[ឈ]ចូលវាយក្នុងផ្ទះអ្នករាល់គ្នាទេ ២៤ដូច្នេះ
ត្រូវឱ្យអ្នកកាន់របៀបនេះ ទុកជាច្បាប់[ញ]សំរាប់ខ្លួនអ្នករាល់
គ្នា និងកូនចៅតរៀងទៅ ២៥កាលណាអ្នករាល់គ្នាបានចូល
ទៅក្នុងស្រុក[ដ] ដែលព្រះយេហូវ៉ានឹងប្រទានមកតាមសេចក្តី
សន្យាទ្រង់ នោះត្រូវកាន់តាមរបៀបនេះកុំខាន ២៦បើកាល
ណាកូនចៅអ្នករាល់គ្នា[ឋ]សួរថា តើរបៀបនេះមានន័យ
ដូចម្តេច ២៧នោះត្រូវឆ្លើយថា នេះគឺជាយញ្ញបូជានៃបុណ្យ
រំលង[ឌ]ថ្វាយដល់ព្រះយេហូវ៉ា ដែលទ្រង់បានយាងរំលង
ផ្ទះពួកកូនចៅអ៊ីស្រាអែលនៅស្រុកអេស៊ីព្ទ[ឍ] ក្នុងកាលដែល
ទ្រង់បានវាយពួកសាសន៍អេស៊ីព្ទ ហើយបានប្រោសឱ្យពួក
ផ្ទះយើងរាល់គ្នារួច នោះពួកជនជាតិអ៊ីស្រាអែលគេឱន
ក្បាលចុះថ្វាយបង្គំ[ណ] ២៨ហើយនាំគ្នាទៅធ្វើតាមសេចក្តី
ដែលព្រះយេហូវ៉ាបានបង្គាប់[ត]មកម៉ូសេនិងអើរ៉ុន គេក៏ធ្វើ

**១២:១៩** អ ជន ៩:១៤ ១៥:១៤ ៣៥:១៥ ចទ?១:១៦ យស ៨:៣៣
**១២:២០** ក លវ ៣:១៧ ជន ៣៥:២៩ អគ ៦:៦ ខ នក ១៣:៦
**១២:២១** គ ខ.១១ មក ១៤:១២–១៦
**១២:២២** ឃ លវ ១៤:៤,៦ ជន ១៩:១៨ ទដ ៥១:៧ ង ហព ១១:២៨
**១២:២៣** ច អស ១៩:២២ ឆ ខ.៧ វវ ៧:៣ ជ ខ.១៣ ឈ លប ១៦:៧ អស ៣៧:៣៦ យរ ៦:២៦ ៤៨:៨ ១កថ ១០:១០ ហព ១១:២៨
**១២:២៤** ញ ខ.១៤
**១២:២៥** ដ លប ១៥:១៤ នក ៣:១៧
**១២:២៦** ឋ នក ១០:២
**១២:២៧** ឌ ខ.១១ ឍ នក ៨:២៣ ណ លប ២៤:២៦
**១២:២៨** ត ខ.៥០
**១២:២៩** ថ នក ១១:៤ ទ លប ១៩:១៣ ធ នក ៤:២៣ ន នក ៩:៦
**១២:៣០** ប នក ១១:៦

សំរេចការនោះ ។
២៩រីឯនៅកណ្តាលអធ្រាត្រ[ថ]ក្នុងយប់នោះ ព្រះយេហូវ៉ា[ទ]
ទ្រង់ក៏វាយអស់ទាំងកូនច្បង[ធ]នៅស្រុកអេស៊ីព្ទ ចាប់តាំងពី
បុត្រច្បងរបស់ផារ៉ោន ដែលគង់លើបល្ល័ង្ករាជ្យ រហូតដល់
កូនច្បងរបស់អ្នកទោសនៅក្នុងគុក ព្រមទាំងកូនច្បងនៃ
អស់ទាំងសត្វ[ន]ផង ៣០ផារ៉ោនទ្រង់ក៏តើនឡើងទាំងយប់
ព្រមទាំងពួកមហាតលិកទ្រង់ និងពួកសាសន៍អេស៊ីព្ទទាំង
អស់គ្នា នោះក៏ឮសំរែកទ្រហោយំ[ប]នៅក្នុងស្រុកអេស៊ីព្ទ ដ្បិត
គ្មានផ្ទះឯណាមួយដែលមិនមានម្នាក់ស្លាប់នោះទេ ។

## និក្ខមនំ (ការជម្លាស)

៣១ផារ៉ោនទ្រង់មានបន្ទូលហៅម៉ូសេ និងអើរ៉ុនមកទាំង
យប់ប្រាប់ថា ចូរឯងរាល់គ្នាក្រោកឡើងនាំគ្នាចេញពី
កណ្តាលរាស្ត្រអញនេះទៅ ព្រមទាំងកូនចៅអ៊ីស្រាអែល
ទាំងអស់គ្នាផង ចូរទៅថ្វាយបង្គំ[ផ]ដល់ព្រះយេហូវ៉ា ដូចជា
ឯងរាល់គ្នាបានសូមនោះចុះ ៣២ចូរនាំហ្វូងចៀមហ្វូង
គោ[ព]ទៅផង ដូចជាបានសូមហើយ ទៅចុះ ហើយសូមឱ្យ
ពរ[ភ]ដល់អញផង ៣៣ពួកសាសន៍អេស៊ីព្ទក៏បង្ខំពួកអ៊ីស្រា
អែលឱ្យចេញពីស្រុកទៅ[ម]ជាប្រញាប់[យ] ដោយពាក្យថា យើង
ស្លាប់ទាំងអស់គ្នាហើយ[រ] ៣៤ពួកកូនចៅអ៊ីស្រាអែលក៏យក
ម្សៅដែលមិនទាន់ដាក់ដំបែ និងស្នាចសំរាប់លាយម្សៅ[ល]
រុំក្នុងអាវគេលីទៅ ៣៥ក៏ធ្វើតាមបង្គាប់ម៉ូសេ គឺគេសូម
គ្រឿងមាស[វ] គ្រឿងប្រាក់ និងខោអាវពីសាសន៍អេស៊ីព្ទ[ស]
៣៦ហើយព្រះយេហូវ៉ា ទ្រង់ក៏ធ្វើឱ្យពួកកូនចៅអ៊ីស្រាអែល
បានប្រកបដោយគុណ[ហ]នៃសាសន៍អេស៊ីព្ទ ដល់ម្ល៉េះបានជា

**១២:៣១** ផ នក ៨:៨ **១២:៣២** ព នក ១០:៩,២៦ ភ លប ២៧:៣៤ **១២:៣៣** ម ខ.១១ យ នក ៦:១ ១សយ ៦:៦ រលប ២០:៣ នក ៨:១៩ **១២:៣៤** ល នក ៨:៣ **១២:៣៥** វ នក ៣:២៧ ស លប ២៤:៥៣ **១២:៣៦** ហ លប ៣៩:២១

**១២:២១** *កូនចៀម* ព្រះយេស៊ូវជាកូនចៀមថ្ងៃបុណ្យរំលង (១កថ ៥:៧) ដែលត្រូវថ្វាយមួយដងជាសម្រេច (ហព ៧:២៧) ដើម្បីយើងគ្រប់គ្នា ។

**១២:២២** *មែកហ៊ីសុប* គឺសំដៅទៅលើរុក្ខជាតិម៉្យាងដែលមានក្លិនប្រហើរ គឺជាប្រភេទជីអង្កាមម៉្យាង ដែលមានទងត្រង់ (មើល យហ ១៩:២៩) និងផ្កាពណ៌ស ។ ស្លិកវាងាយស្រួលប្រើនៅក្នុងការប្រោះទឹក នៅក្នុងពិធីសម្អាតជាបរិសុទ្ធ (មើល លវ ១៤:៤,៦,៤៩,៥១–៥២) ជន ១៨ ហព ៩:១៩ មើល ទដ ៥១:៧) ។ *ជ្រលក់ចុះក្នុងឈាម* សព្វថ្ងៃនេះពិធីស៊ីលៀងថ្ងៃ គេប្រើជីវ៉ាស៊ុយម៉្យាង ឬបន្លែផ្សេងទៀត ជ្រលក់ក្នុងទឹកអំបិល ជានិមិត្តរូបតំណាងឱ្យចំណីអាហារថ្នាក់ទាប និងទឹកភ្នែក ដែលពួកអ៊ីស្រាអែលមាននៅក្នុងភាពជាទាសកនៅស្រុកអេស៊ីព្ទ ។

**១២:២៣** *រំលងហួស* មើលការពន្យល់ ខ.១១ ។ *មេបំផ្លាញ* តាម ទដ ៧៨:៤ សេចក្តីក្រោធព្រះអម្ចាស់ចំពោះស្រុកអេស៊ីព្ទត្រូវបានបង្ហាញចេញ ដោយ "ពួកទេវតានៃការបំផ្លាញ" ។ ជារឿយៗ ព្រះអម្ចាស់បានប្រើពួកទេវតា ដើម្បីបង្កើតសេចក្តីវេទនាដែលបំផ្លិចបំផ្លាញ (មើល ២សយ ២៤:១៥–១៦ ២ពវ ១៩:៣៥ មើល ១កថ ១០:១០ ដែលទាក់ទងនឹង ជន ១៦:៤១–៤៩) ។

**១២:២៦** *កូនចៅអ្នករាល់គ្នាសួរថា តើរបៀបនេះមានន័យដូចម្តេច* មើល ១៣:១៤ គេត្រូវធ្វើពិធីបុណ្យរំលង ដោយទទួលទានអាហារ ដែលរំឭកពីការប្រោសលោះដល់រាស្ត្រអ៊ីស្រាអែល និងការកសាងជាថ្មីរបស់ពួកគេ ។ សព្វថ្ងៃនៅក្នុងពីធីបុណ្យនេះ កូនពៅនៅក្នុងគ្រួសារពួកយូដា ត្រូវសួរនូវសំណួរនេះ ។

**១២:២៧** *យញ្ញបូជានៃបុណ្យរំលង* មើលការពន្យល់ ខ.២១ ។

**១២:៣១** *ផារ៉ោនទ្រង់មានបន្ទូលហៅម៉ូសេ* ស្តេចផារ៉ោនបានស្បថមិនឱ្យលោកម៉ូសេចូលគាល់ទៀត (មើល ១០:២៨ និងការពន្យល់) តែក្នុងខនេះស្តេចផារ៉ោនបានបន្ទាបខ្លួន ដោយកោះហៅលោកម៉ូសេ និងលោកអើរ៉ុន ។

**១២:៣៥–៣៦** សូមមើល ៣:២១–២២ ១១:២–៣ ។

គេចែកឱ្យតាមដែលសូម យ៉ាងនោះគេក៏បង្ហិនបង្ហោច[ឡ]ដល់
ពួកសាសន៍អេស៊ីព្ទ ។
៣៧ពួកកូនចៅអ៊ីស្រាអែល គេចេញពីស្រុករ៉ាមសេស[អ]
ដើរដោយជើងទៅដល់សិកូត[ក] មានមនុស្សប្រុសៗចំនួន៦
សែននាក់[ខ]ឥតរាប់កូនក្មេងឡើយ ៣៨ក៏មានមនុស្សសន្ធឹក[គ]
គ្រប់បែបឡើងទៅជាមួយដែរ ព្រមទាំងហ្វូងចៀមហ្វូង
គោគេ ជាហ្វូងសត្វមានប្រមាណសន្ធឹកណាស់ ៣៩គេនាំគ្នា
យកម្សៅ ដែលយកពីស្រុកអេស៊ីព្ទមក ទៅដុតធ្វើជានំឥតដំ
បែ ដ្បិតមិនទាន់បានដាក់ដំបែនៅឡើយទេ ពីព្រោះពេល
ដែលគេត្រូវបណ្តេញចេញ[ឃ]ពីស្រុកអេស៊ីព្ទមក នោះឥត
មានឱ្យបង្អែបង្អង់បានទេ បានជាគេមិនបានធ្វើម្ហូបម្ហា
សំរាប់តាមផ្លូវឡើយ ។
៤០រីឯវេលា ដែលពួកកូនចៅអ៊ីស្រាអែលនៅស្រុក
អេស៊ីព្ទ នោះបាន៤៣០ឆ្នាំ[ង] ៤១រួចដល់ផុតពី៤៣០ឆ្នាំនោះ
ទៅ នៅថ្ងៃដដែលនោះឯង ពួកកកកុញរបស់ព្រះយេហូវ៉ា
គេក៏នាំគ្នាចេញ[ច]ពីស្រុកអេស៊ីព្ទទៅ[ឆ] ៤២គឺជាយប់១ដែល
ត្រូវកាន់យ៉ាងសំខាន់ចំពោះព្រះយេហូវ៉ា ដោយព្រោះទ្រង់
បាននាំគេចេញពីស្រុកអេស៊ីព្ទមក យប់នោះឯងជាយប់
ដែលពួកកូនចៅអ៊ីស្រាអែលទាំងអស់ ត្រូវកាន់យ៉ាងសំខាន់
នៅចំពោះព្រះយេហូវ៉ា នៅអស់ទាំងដំណគេតរៀងទៅ[ជ]។

## ច្បាប់សម្រាប់បុណ្យរំលង

៤៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិងអើរ៉ុន
ថា នេះជាច្បាប់សំរាប់បុណ្យរំលង[ឈ] គឺមិនត្រូវឱ្យអ្នក
ប្រទេសក្រៅណា[ញ]បរិភោគបុណ្យនេះឡើយ ៤៤តែអស់ទាំង
បាវបំរើដែលឯងរាល់គ្នាទិញនឹងប្រាក់មក បើកាលណា
បានកាត់ស្បែកឱ្យហើយ[ដ] នោះឱ្យគេបរិភោគទៅបាន ៤៥ឯ
អ្នកប្រទេសក្រៅឬជើងឈ្នួល[ឋ] នោះមិនត្រូវបរិភោគទេ
៤៦ត្រូវឱ្យបរិភោគនៅក្នុងផ្ទះតែ១ មិនត្រូវយកសាច់ចេញ
ទៅក្រៅផ្ទះឡើយ ក៏មិនត្រូវបំបាក់ឆ្អឹងណាមួយផង[ឌ] ៤៧ត្រូវ
ឱ្យពួកជំនុំសាសន៍អ៊ីស្រាអែលទាំងអស់គ្នាធ្វើបុណ្យនេះ
៤៨បើមានអ្នកប្រទេសក្រៅណាមួយ មកនៅជាមួយនឹងឯង
រាល់គ្នា ហើយចង់ធ្វើបុណ្យរំលងនេះថ្វាយព្រះយេហូវ៉ា
ដែរ នោះត្រូវឱ្យពួកប្រុសៗរបស់គេទទួលកាត់ស្បែកសិន
ទើបនឹងចូលមកធ្វើបាន យ៉ាងនោះគេនឹងបានដូចជាអ្នក
ស្រុកដែរ[ឍ] តែអ្នកឯណាដែលមិនបានកាត់ស្បែកសោះ[ណ]
នោះនឹងបរិភោគបុណ្យនេះមិនបានឡើយ ៤៩មានច្បាប់តែ
១ប៉ុណ្ណោះ សំរាប់ពួកអ្នកស្រុក ហើយនិងពួកអ្នកប្រទេស
ក្រៅ[ត] ដែលនៅកណ្តាលឯងរាល់គ្នាដែរ។
៥០ពួកកូនចៅអ៊ីស្រាអែលគេក៏ធ្វើដូច្នេះ តាមដែលព្រះ
យេហូវ៉ាទ្រង់បានបង្គាប់មក[ថ]ម៉ូសេ និងអើរ៉ុន គេបានធ្វើ
សំរេចការទាំងនោះ ៥១ហើយនៅថ្ងៃនោះឯង ព្រះយេហូវ៉ា
ទ្រង់ក៏នាំ ពួកកូនចៅអ៊ីស្រាអែលចេញពីអេស៊ីព្ទ[ទ] ដោយពួក
កងរបស់គេ[ធ]។

## ការញែកកូនច្បង

**១៣** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២នៅក្នុង
ពួកកូនចៅអ៊ីស្រាអែល ត្រូវញែកអស់ទាំងកូនច្បង[ក]ចេញ
ទុកសំរាប់អញ គឺជាកូនណាដែលកើតពីពោះម្តាយមុន
បង្អស់ ទោះមនុស្សឬសត្វក្តី នោះជារបស់ផងអញ ។
៣ម៉ូសេក៏ប្រាប់ដល់បណ្តាជនរាល់គ្នាថា ចូរនឹកចាំពីថ្ងៃ
នេះ គឺពីថ្ងៃដែលអ្នករាល់គ្នាបានចេញពីផ្ទះបាវនៅស្រុក

**១២:៣៦** ឡ នក ៣:២២
**១២:៣៧** អ លប ៤៧:១១ ក នក ១៣:២០ ជន ៣៣:៣–៥ លប ១២:២ នក ៣៨:២៦ ជណ ១:៤៦ ២:៣២ ១១:១៣,២១ ២៦:៥១
**១២:៣៨** គ ជន ១១:៤ យប ៨:៣៥
**១២:៣៩** ឃ នក ៣:២០ ១១:១
**១២:៤០** ង លប ១៥:១៣ កច ៧:៦ កទ ៣:១៧
**១២:៤១** ច នក ៦:២៦ ឆ នក ៣:១០
**១២:៤២** ជ នក ១៣:១០ លវ ៣:១៧ ជណ ៩:៣ ចទ?១៦:១,៦
**១២:៤៣** ឈ ខ.១១ ញ ខ.៤៨ ជន ៩:១៤ ១៥:១៤ ២រប ៦:៣២–៣៣ អស ១៤:១ ៥៦:៣,៦ ៦០:១០
**១២:៤៤** ដ លប ១៧:១២–១៣
**១២:៤៥** ឋ លប ២២:១០
**១២:៤៦** ឌ ជន ៩:១២ ទដ ២២:១៤ ៣៤:២០ ៥១:៨ សភ ១៧:២២ យហ ១៩:៣៦ **១២:៤៨** ឍ ខ.៤៩ លវ ១៩:១៨,៣៤ ២៤:២២ ជន ៩:១៤ ១០:៣២ ណ អគ ៤៤:៧ **១២:៤៩** ត លវ ២៤:២២ ជន ១៥:១៥–១៦,២៩ ចទ ១:១៦ **១២:៥០** ថ ខ.២៨ **១២:៥១** ទ នក ៣:១០ ៦:៦ ធ នក ៦:២៦ **១៣:២** ក ខ.១២, ១៣,១៥ នក ២២:២៩

**១២:៣៦** *បង្ហិនបង្ហោចដល់ពួកសាសន៍អេស៊ីព្ទ* មើលការពន្យល់ ៣:២២ ។
**១២:៣៧** *ចេញពីស្រុករ៉ាមសេស* មើល ១:១១ និងការពន្យល់ លប ៤៧:១១ ។ ការធ្វើដំណើរចេញរបស់រាស្ត្រអ៊ីស្រាអែលបានធ្វើឡើង បន្ទាប់ពីថ្ងៃធ្វើបុណ្យរំលង(ជន ៣៣:៣)។ *មានមនុស្សប្រុសៗចំនួន៦សែននាក់* គឺវាមានចំនួនប្រហែលជា ៦០៣,៥៥០ ទាំងអស់ (៣៨:២៦ មើលសេចក្តីផ្តើម ព្រះគម្ពីរជនគណនាត្រង់ចំណុច បញ្ហាចំបង មើល ជន ១:៤៦ និងការពន្យល់)។
**១២:៣៨** *មានមនុស្សសន្ធឹក* ក៏អាចមានបញ្ចូលទាំងសាសន៍អេស៊ីព្ទ មួយផ្នែកធំទៀតដូចជាបានបង្ហាញក្នុង ៩:២០ ។
**១២:៤១** *ផុតពី៤៣០ឆ្នាំនោះទៅ នៅថ្ងៃដដែល* សូមមើលការពន្យល់ លប ១៥:១៣ កច ៧:៦ ។
**១២:៤៤** មើល លប ១៧:១២–១៣ និងការពន្យល់ ១៧:១០ ។
**១២:៤៦** *មិនត្រូវបំបាក់ឆ្អឹងណាមួយ* មើល ជន ៩:១២ ទដ ៣៤:២០ និងសេចក្តីស្រង់ក្នុង យហ ១៩:៣៦ អំពីព្រះយេស៊ូវគ្រីស្ទ ។
**១២:៤៨** *មិនបានកាត់ស្បែកសោះនោះ និងបរិភោគបុណ្យនេះមិនបានឡើយ* គឺមានតែអ្នកដែលបានញែកខ្លួនជាបរិសុទ្ធ ថ្វាយដល់ព្រះយេហូវ៉ាក្នុងសេចក្តីសញ្ញាប៉ុណ្ណោះ ដែលអាចទទួលបរិភោគអាហារបុណ្យរំលងបាន ហើយពិធីបុណ្យនេះមានន័យតែសម្រាប់ពួកគេប៉ុណ្ណោះ(មើល លប ១៧:៩–១៤)។ ទាក់ទងនឹងការធ្វើពិធីបុណ្យលៀងព្រះអម្ចាស់សូមមើល ១កថ ១១:២៨។
**១៣:២** *ត្រូវញែកអស់ទាំងកូនច្បងចេញទុកសម្រាប់អញ* ព្រះបានរើសសាសន៍អ៊ីស្រាអែលជាកូនច្បង(៤:២២) ហើយបានទុកជីវិតឱ្យពួកកូនច្បងក្នុងសាសន៍អ៊ីស្រាអែល គឺទាំងមនុស្ស ទាំងសត្វ នៅក្នុងសេចក្តីវេទនាទី១០ (១២:១២–១៣)។ ដូចនេះ ពួកកូនច្បងគឺជាដង្វាយសម្រាប់ព្រះ (មើល លប ២:២២–២៣) ។ ព្រះយេស៊ូវជាបុត្រច្បងនៃនាងម៉ារា(មើល លក ២:៧) ដែលបានថ្វាយខ្លួនដល់ព្រះ តាមក្រឹត្យវិន័យនេះ(លក ២:២២–២៣)។

អេស៊ីព្ទមក[ខ] ដ្បិតព្រះយេហូវ៉ាបាននាំអ្នករាល់គ្នាចេញមក
ដោយព្រះហស្តខ្លាំងពូកែហើយ[គ] ដូច្នេះមិនត្រូវឱ្យអ្នកណា
បរិភោគនំបុ័ងមានដំបែទេ[ឃ] ៤គឺនៅថ្ងៃនេះឯងក្នុងខែចេត្រ[ង]
ដែលអ្នករាល់គ្នាបានចេញមក ៥ដូច្នេះកាលណាព្រះយេ
ហូវ៉ា ទ្រង់បាននាំអ្នករាល់គ្នាចូលទៅក្នុងស្រុករបស់សាសន៍
កាណាន[ច] សាសន៍ហេត សាសន៍អាម៉ូរី សាសន៍ហេវី ហើយ
សាសន៍យេប៊ូស[ឆ] ដែលទ្រង់បានស្បថនឹងពួកឰយុកោអ្នក
រាល់គ្នាថា នឹងប្រទានមកអ្នករាល់គ្នា គឺជាស្រុកដែលមាន
ទឹកដោះហើយទឹកឃ្មុំហូរហៀរ[ជ] នោះអ្នករាល់គ្នាត្រូវធ្វើ
បុណ្យនេះ[ឈ]នៅក្នុងខែនេះឯង ៦អ្នករាល់គ្នាត្រូវបរិភោគ
នំបុ័ងឥតដំបែក្នុងរវាង៧ថ្ងៃនោះ ហើយដល់ថ្ងៃទី៧ ត្រូវឱ្យ
មានបុណ្យ[ញ]ថ្វាយព្រះយេហូវ៉ា ៧នៅ៧ថ្ងៃទាំងនោះ ត្រូវឱ្យ
អ្នករាល់គ្នាបរិភោគតែនំបុ័ងឥតដំបែប៉ុណ្ណោះ មិនត្រូវឱ្យ
ឃើញនំបុ័ងមានដំបែនៅនឹងអ្នករាល់គ្នាឡើយ ក៏មិនត្រូវ
ឱ្យឃើញមានដំបែណានៅគ្រប់ក្នុងព្រំស្រុករបស់អ្នករាល់
គ្នាផង ៨ហើយនៅថ្ងៃនោះ អ្នករាល់គ្នាត្រូវប្រាប់ដល់
កូនចៅ[ដ]ថា យើងធ្វើបុណ្យនេះ ដោយព្រោះការដែលព្រះ
យេហូវ៉ាបានប្រោសដល់យើង ក្នុងកាលដែលយើងចេញ
ពីស្រុកអេស៊ីព្ទមក ៩នោះនឹងបានសំរាប់ទីសំគាល់នៅដៃ
អ្នករាល់គ្នា[ឋ] ហើយជាសេចក្ដីរំឭកនៅកណ្ដាលថ្ងាសនៃអ្នក
រាល់គ្នា[ឌ] ដើម្បីឱ្យក្រិត្យវិន័យព្រះយេហូវ៉ាបាននៅក្នុងមាត់
អ្នករាល់គ្នា ដ្បិតព្រះយេហូវ៉ាបាននាំអ្នករាល់គ្នាចេញពី
ស្រុកអេស៊ីព្ទមក ដោយព្រះហស្តយ៉ាងខ្លាំងពូកែហើយ[ឍ]
១០ដូច្នេះរាល់តែឆ្នាំ ដល់កំណត់ហើយ[ណ] ត្រូវឱ្យអ្នករាល់គ្នា
កាន់តាមរបៀបនេះ[ត]”។
១១កាលណាព្រះយេហូវ៉ាបាននាំអ្នករាល់គ្នាចូលទៅ
ក្នុងស្រុករបស់សាសន៍កាណាន[ថ] ដូចទ្រង់បានស្បថនឹងអ្នក
រាល់គ្នា[ទ] នូវពួកឰយុកោ ព្រមទាំងប្រទានស្រុកនោះឱ្យអ្នក
រាល់គ្នាហើយ[ធ] ១២នោះត្រូវឱ្យញែកអស់ទាំងកូនដែលកើត
មុនគេបង្អស់ ថ្វាយដល់ព្រះយេហូវ៉ា ឯកូនច្បងដែលកើតពី
សត្វរបស់អ្នករាល់គ្នា បើជាឈ្មោល នោះសុទ្ធតែជារបស់
ផង ព្រះយេហូវ៉ាទាំងអស់[ន] ១៣ឯអស់ទាំងកូនច្បងរបស់សត្វ
លា[ប] នោះត្រូវថ្វាយកូនចៀម ដើម្បីស្នងនឹងលោះវា តែបើ
មិនចង់លោះទេ នោះត្រូវបំបាក់កវាទៅ[ផ] ហើយអស់ទាំង
កូនច្បងរបស់មនុស្ស ក្នុងពួកកូនចៅនៃអ្នករាល់គ្នា នោះក៏
ត្រូវលោះ[ព]ដែរ[ភ] ១៤រួចដល់ថ្ងៃក្រោយ បើកូនចៅរបស់អ្នក
រាល់គ្នា[ម]សួរថា ការនេះជាអ្វី នោះត្រូវប្រាប់ថា នេះគឺ
ដោយព្រោះព្រះយេហូវ៉ាបាននាំយើងរាល់គ្នា ចេញពីផ្ទះ
បាវបំរើ នៅស្រុកអេស៊ីព្ទមក ដោយព្រះហស្តខ្លាំងពូកែ[យ]
១៥ដ្បិតកាលផារ៉ោនបានតាំងព្រះទ័យរឹងទទឹង មិនព្រមឱ្យ
យើងរាល់គ្នាទៅ នោះព្រះយេហូវ៉ាក៏សំឡាប់អស់ទាំង
កូនច្បងនៅស្រុកអេស៊ីព្ទចោល ចាប់តាំងពីកូនច្បងរបស់
មនុស្ស រហូតដល់កូនច្បងនៃពួកសត្វ ដោយហេតុនោះបាន
ជាអញថ្វាយអស់ទាំងកូនឈ្មោល ដែលកើតមុនបង្អស់ ទៅ
ជាយញ្ញបូជាដល់ព្រះយេហូវ៉ា តែអស់ទាំងកូនច្បងបង្កើត
របស់អញ នោះអញលោះវិញ[រ] ១៦នេះនឹងបានជាទីសំគាល់
នៅលើដៃ និងជាស្លាកនៅកណ្ដាលថ្ងាសអ្នករាល់គ្នា[ល] ដ្បិត
ព្រះយេហូវ៉ា បាននាំយើងរាល់គ្នាចេញពីស្រុកអេស៊ីព្ទ មក
ដោយព្រះហស្តខ្លាំងពូកែ ។

## ការឆ្លងសមុទ្រក្រហម

១៧កាលផារ៉ោនបានឱ្យគេទៅហើយ នោះព្រះទ្រង់មិន
បាននាំគេ តាមផ្លូវកាត់ស្រុករបស់សាសន៍ភីលីស្ទីនទេ ទោះ
បើផ្លូវនោះជិតក៏ដោយ ដ្បិតព្រះទ្រង់មានបន្ទូលថា ខ្លាច

**១៣:៣** ខ ខ.១៤ នក ៧:៤ លវ ២៦:១៣ ជន ១:១ ៩:១ ២២:៥ ២៦:៤ ចទ ៤:៤៥ ៥:៦ ទដ ៨១:១០ ១១៤:១ គ នក ៣:២០ ឃ នក ១២:៨ **១៣:៤** ង នក ១២:២ **១៣:៥** ច នក ១២:២ ឆ នក ៣:៨ ជ នក ៣:៨ ឈ នក ១២:២៥-២៦ **១៣:៦** ញ នក ១២:១៥-២០ **១៣:៨** ដ នក ១០:២ ទដ ៧៨:៥-៦ **១៣:៩** ឋ អស ៤៤:៥ ឌ ខ.១៦ ចទ ៦:៨ ១១:១៨ សភ ៣:៣ មថ ២៣:៥ ឍ នក ៣:២០ **១៣:១០** ណ ទដ ៧៥:២ ១០២:១៣ ត នក ១២:១៤ **១៣:១១** ថ ខ.៥ ទ លប ២២:១៦ ចទ ១:៨ ធ លប ១២:៧ ១៧:១៩ ទដ ១០៥:៤២-៤៥ **១៣:១២** ន លប ៤:៤ លវ ២៧:២៦ ជន ៣:១៣ ១៨:១៥, ១៧ លប ២:២៣ **១៣:១៣** ប ខ.១៥ លវ ២៧:១១ ផ នក ៣៤:២០ អស ៦៦:៣ ព ជន ៣:៤៦-៤៧ ភ ជន ១៨:១៥ **១៣:១៤** ម នក ១០:២ យ នក ២០:២ ចទ ៧:៨ ២៨:៦៨ **១៣:១៥** រ ខ.២ **១៣:១៦** ល ខ.៩

**១៣:៥** មើលការពន្យល់ ៣:៨ ។

**១៣:៩** *សំរាប់ជាទីសំគាល់នៅដៃអ្នករាល់គ្នា ហើយជាសេចក្ដីរំឭកនៅកណ្ដាលថ្ងាស់នៃអ្នករាល់គ្នា* គឺជាន័យធៀប(មើល ខ.១៦ ចទ ៦:៨ ១១:១៨ សភ ៣:៣ ៦:២១ ៧:៣ បស ៨:៦)។ ការកាត់ស្រាយខនេះតាមន័យត្រង់បាននាំឱ្យមានការសសេរបទគម្ពីរ ខ.១-១០ ខ.១១-១៦ ចទ ៦:៤-៩ និង ចទ ១១:១៣-២១ នៅសន្លឹកស្បែកសត្វតូចៗ តាមបទគម្ពីរផ្សេងៗគ្នាដាក់នៅក្នុងប្រអប់ស្បែកសត្វតូចៗពីរ សម្រាប់ពាក់នៅលើថ្ងាស និងដៃខាងឆ្វេង មុនពេលអធិស្ឋានពេលព្រឹក ។ គេហៅប្រអប់ស្បែកសត្វនេះថា "ស្លាក"(មថ ២៣:៥)។ ការអនុវត្តដូចនេះហាក់ដូចជាចាប់ផ្ដើម នៅក្រោយពេលនៃការនិរទេសទៅស្រុកបាប៊ីឡូន ។

**១៣:១៣** *លោះ* មើល ៦:៦ និងការពន្យល់ ។ គឺមានន័យថា "ទទួលបាននូវការដោះលែងដោយការបង់ថ្លៃ"។ *កូនច្បងនៃសត្វលា* ដោយសារសត្វលាមានប្រយោជន៍ដល់សេដ្ឋកិច្ច នៅក្នុងផ្នែកដឹកជញ្ជូន គេអាចរំលោះជីវិតកូនច្បងសត្វលាមួយក្បាលបាន ដោយធ្វើយញ្ញបូជាកូនចៀមមួយក្បាលជំនួស។ *ហើយអស់ទាំងកូនច្បងរបស់មនុស្ស* មនុស្សយើងត្រូវញែកខ្លួនជាបរិសុទ្ធថ្វាយព្រះអម្ចាស់ ដោយការរស់នៅផ្ទាល់ខ្លួនថ្វាយទ្រង់ មិនមែនដោយការស្លាប់នោះទេ(លប ២២:១២ ជន ៣:៣៩-៥១ ធៀបនឹង រម ១២:១ និងការពន្យល់)។

**១៣:១៤** មើលការពន្យល់ ១២:២៦ ។

**១៣:១៦** មើលការពន្យល់ ខ.៩ ។

**១៣:១៧** *តាមផ្លូវកាត់ស្រុករបស់សាសន៍ភីលីស្ទីន* ផ្លូវពីស្រុកកូសែនទៅកាន់ស្រុកកាណាន មានបន្ទាយទាហានពួកអេស៊ីព្ទជាច្រើនកន្លែងតាមផ្លូវ ។

ក្រែងគេឃើញចំបាំង ហើយរសាយចិត្ត រួចត្រឡប់ទៅ
ឯស្រុកអេស៊ីព្ទវិញ[វ] ១៨គឺទ្រង់បាននាំ[ស]គេដើរពង្វាងតាម
ផ្លូវទីរហោស្ថាន ក្បែរសមុទ្រក្រហមវិញ ពួកកូនចៅ
អ៊ីស្រាអែលក៏ឡើងចេញពីស្រុកអេស៊ីព្ទទៅទាំងកាន់គ្រឿង
សស្ត្រាវុធ[ហ] ១៩ម៉ូសេក៏យកឆ្អឹងខ្មោចយ៉ូសែប[ឡ]ទៅជាមួយ
ដែរ ដ្បិតយ៉ូសែបបានចាប់ពួកកូនចៅអ៊ីស្រាអែលឱ្យស្បថ
ដោយថា ព្រះទ្រង់នឹងប្រោសឯងរាល់គ្នាជាមិនខាន នោះ
ត្រូវឱ្យយកឆ្អឹងអញពីទីនេះឡើងទៅជាមួយផង[អ]។
២០គេក៏ចេញពីសិកូត[ក]ទៅដំឡើងត្រសាលនៅឯស្រុក
អេថាម ត្រង់ក្បែរទីរហោស្ថាន[ខ] ២១នៅវេលាថ្ងៃ ព្រះ
យេហូវ៉ាទ្រង់តែងយាងនៅមុខ[គ]គេក្នុងបង្គោលពពក[ឃ]ដើម្បី
នឹងនាំផ្លូវ ហើយនៅវេលាយប់ ទ្រង់យាងក្នុងបង្គោលភ្លើង
ដើម្បីនឹងបំភ្លឺគេ ប្រយោជន៍ឱ្យគេដើរបានទាំងយប់ទាំងថ្ងៃ
២២ហើយបង្គោលពពកដែលសំរាប់ពេលថ្ងៃ និងបង្គោល
ភ្លើងដែលសំរាប់ពេលយប់[ង] នោះមិនបានថយចេញពីគេ
ឡើយ ។

**១៤** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២ចូរប្រាប់
ដល់ពួកកូនអ៊ីស្រាអែល ឱ្យគេបែរទៅដំឡើងត្រសាល
នៅឯមុខ ពីហាហីរ៉ុថ ត្រង់កណ្តាលស្រុកមីកដុល[ក] ហើយ
និងសមុទ្រ ទល់មុខនឹងបាល–សេផុនវិញ[ខ] ត្រូវឱ្យដំឡើង
ត្រសាល ប្រឈមនឹងទីនោះ ដែលនៅជិតមាត់សមុទ្រ
៣ផារ៉ោននឹងនិយាយពីពួកកូនចៅអ៊ីស្រាអែលថា គេបាន
វង្វេងជាប់នៅស្រុកនោះហើយ ទីរហោស្ថានបានបិទគេ
ជិតជុំវិញ ៤នោះអញនឹងបណ្តាលឱ្យផារ៉ោនមានចិត្តរឹង
ទទឹងឡើង[គ] ហើយទ្រង់នឹងដេញតាម[ឃ] តែអញនឹងបានកិត្តិ
សព្ទ[ង] ដោយសារផារ៉ោននឹងពួកទ័ពទ្រង់ទាំងប៉ុន្មាន ហើយ
ពួកសាសន៍អេស៊ីព្ទនឹងដឹងថា អញព្រះជាយេហូវ៉ាពិត"[ច]
គេក៏ធ្វើសំរេចដូច្នោះ ។
៥មានគេទូលដល់ស្តេចស្រុកអេស៊ីព្ទថា ពួកអ៊ីស្រាអែល
បានរត់រួចទៅហើយ[ឆ] នោះផារ៉ោននិងពួកមហាតលិកទ្រង់
ក៏ប្រែគំនិតពីដំណើរគេឡើងវិញ[ជ] ហើយពោលថា តើយើង
បានធ្វើអ្វី និងឱ្យពួកអ៊ីស្រាអែលចេញទៅរួចពីការបំរើ
យើងដូច្នេះ ៦នោះស្រាប់តែទ្រង់ទឹមរាជរថ ព្រមទាំងនាំពួក
ពលទៅជាមួយផង ៧ទ្រង់រើសយករទេះចំបាំងបាន៦០០[ឈ]
ហើយក៏យកអស់ទាំងរទេះចំបាំងនៅស្រុកអេស៊ីព្ទផង គ្រប់
ទាំងរទេះទាំងនោះសុទ្ធតែមានមេទ័ពត្រួតត្រាការ ៨ឯព្រះ
យេហូវ៉ាទ្រង់ក៏បណ្តាលឱ្យផារ៉ោនជាស្តេចអេស៊ីព្ទ មានព្រះ
ទ័យ[ញ]រឹងទទឹងឡើង ហើយស្តេចក៏ដេញតាមពួកកូនចៅ
អ៊ីស្រាអែល តែពួកកូនចៅអ៊ីស្រាអែលគេបានចេញទៅ
ដោយមានជ័យជំនះ[ដ] ៩ពួកសាសន៍អេស៊ីព្ទក៏ដេញតាមទៅ
មានទាំងសេះ[ឋ]ទាំងរាជរថរបស់ផារ៉ោន ទាំងពួកពលសេះ
ហើយនិងពួកពលថ្មើរជើង[ឌ]របស់ទ្រង់ទាំងអស់ បានទាន់[ឍ]
គេនៅត្រង់ទីដំឡើងត្រសាល ក្បែរសមុទ្រដែលជិតនឹងពី
ហាហីរ៉ុថ ទល់មុខបាល–សេផុន[ណ]។

**១៣:១៧** វ នក ១៤:១១ ជន ១៤:១–៤ ចទ ១៧:១៦ ហស ១១:៥ **១៣:១៨** ស នក ១៥:២២ ទដ ១៣៦:១៦ អគ ២០:១០ ហ យស ១:១៤ ៤:១៣ **១៣:១៩** ឡ យស ២៤:៣២ កច ៧:១៦ ហព ១១:២២ អ លប ៥០:២៥–៣០ **១៣:២០** ក នក ១២:៣៧ ខ ជន ៣៣:៦ **១៣:២១** គ នក ៣២:១ ៣៣:១៤ ចទ ២:៧ ៣១:៨ ពច ៤:១៤ ៥:៤ ទដ ៦៨:៧ ៧៧:២០ យរ ២:២ ហព ៣:១៣ ឃ នក ១៤:១៩ ២៤:១៦ ៣៣:៩–១០ ៣៤:៥ ៤០:៣៨ ជន ៩:១៦ ១២:៥ ១៤:១៤ ចទ?១:៣៣ នហ ៩:១២,១៩ ទដ ៧៨:១៤ ៩៩:៧ ១០៥:៣៩ អស ៤:៥ ១កថ ១០:១ **១៣:២២** ង នហ ៩:១៩ **១៤:២** ក ជន ៣៣:៧ យរ ៤៤:១ អគ ២៩:១០ ខ ខ.៩ **១៤:៤** គ នក ៤:២១ ឃ ខ.៨,១៧,២៣ ទដ ៧១:១១ ង នក ៩:១៦ រម ៩:១៧, ២២–២៣ ច នក ៦:២ អគ ៣២:១៥ **១៤:៥** ឆ លប ៣១:២១ ជ ទដ ១០៥:២៥ **១៤:៧** ឈ នក ១៥:៤ **១៤:៨** ញ នក ១១:១០ ដ ជន ៣៣:៣ កច ១៣:១៧ **១៤:៩** ឋ លប ៤៧:១៧ ឌ ខ.៦–៧,២៥ យស ២៤:៦ អស ៤៣:១៧ ឍ នក ១៥:៩ ណ ខ.២

**១៣:១៨** *ផ្លូវទីរហោរស្ថាន* គឺឆ្ពោះទៅខាងត្បូង តាមបណ្តោយឆ្នេរសមុទ្រខាងលិចនៃឧបទ្វីបស៊ីណាយ ។ *សមុទ្រក្រហម* គេបានសន្និដ្ឋានថា ការឆ្លងសមុទ្រនោះ បានធ្វើឡើងនៅតាមតំបន់ ដែលសព្វថ្ងៃគេហៅថា តំបន់ព្រែកជីកស៊ុយអេ គឺរាប់បញ្ចូលចុងខាងជើងនៃតំបន់នេះ (ការពន្យល់ ១៤:២) ។

**១៣:១៩** មើលការពន្យល់ លប ៥០:២៤–២៥ ។

**១៣:២១** *បង្គោលពពក . . . បង្គោលភ្លើង* គឺនិមិត្តសញ្ញានៃព្រះ ដែលរាស្ត្រទ្រង់អាចមើលឃើញ (មើល ១៤:២៤ និងការពន្យល់ ៣:២) ។ ជារឿយៗ ព្រះយេហូវ៉ាបានមាន បន្ទូលទៅកាន់ពួកគេពីបង្គោលទាំងនោះ (មើល ជន ១២:៥–៦ ចទ ៣១:១៥–១៦ ទដ ៩៩: ៦–៧) ។

**១៤:២** *បែរទៅ* គឺការបែរឆ្ពោះទៅរកទិសខាងជើង គឺចាប់ពីកន្លែងដែលគេចេញមក ។ *ពីហាហ៊ីរ៉ុថ* គឺមានទីតាំង "ខាងកើតស្រុកបាលសេផុន" (សូមមើល ជន ៣៣:៧) ។ *មីកដុល* ពាក្យនេះមានន័យថា "ប៉មយាម"។ *មាត់សមុទ្រ* ជាសមុទ្រគេទម្លាប់ហៅថា សមុទ្រក្រហម ក្នុងភាសាហេព្រើរគឺ "យ៉ាមស៊ូប" មានន័យថាសមុទ្រនៃដើមបបុស (មើល ១៣:១៨) ។ ដូចនេះ គេមិនអាចសន្និដ្ឋានថា ការឆ្លងសមុទ្រនោះបានធ្វើឡើងនៅខាងចុងនៃឈូងសមុទ្រស៊ុយអេឡើយ ព្រោះដើមបបុស ឬត្រែងនោះពុំអាចលូតលាស់នៅក្នុងទឹកប្រៃបាននោះទេ ។ ម្យ៉ាងទៀត ដើមបបុស ឬប៉ាពីរើស (Papyrus) របស់សាសន៍អេស៊ីព្ទ មានដុះនៅត្រង់តំបន់បាលសេផុន (Baal Zephon) នៅក្បែតំបន់តាផានេស (Tahpanhes, សូមមើលការពន្យល់ យរ ២:១៦) ជាតំបន់នៅក្បែរបឹង "មែនស្សាលេហ" (Menzaleh) មាននៅខាងកើតនៃស្រុករ៉ាមសេស ចម្ងាយ ៣២ គីឡូម៉ែត្រ ។ ដូចនេះការឆ្លងកាត់សមុទ្រក្រហមបានធ្វើឡើង នៅចុងខាងត្បូងនៃបឹងមែនស្សាលេហ (Menzaleh) ។ *បាល–សេផុន* មានន័យថា "ព្រះបាលនៃតំបន់ខាងជើង" ឬ "ព្រះបាលនៃភ្នំខាងជើង" ហើយក៏ជាឈ្មោះរបស់ព្រះសាសន៍កាណានផងដែរ ។

**១៤:៤** *មានចិត្តរឹង* មើល ខ.៨ និងការពន្យល់ ៤:២១ ។ *អញជាព្រះយេហ៊ូវ៉ាពិត* មើលការពន្យល់ ៦:៣ ។

**១៤:៧** *រទេះចំបាំង* ពួកអេស៊ីព្ទចេះប្រើរទេះចំបាំងតាមពួកកាណាន ហើយបាននាំឱ្យមានការផ្លាសប្តូរនៅក្នុងរបៀបធ្វើសង្គ្រាម ។ រទេះចំបាំងមានប្រសិទ្ធភាពខ្ពស់ នៅតំបន់វាលទំនាប ហើយទឹកដីអេស៊ីព្ទភាគច្រើនមានសណ្ឋានដីដូចនេះ ។ *មេទ័ព* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះជាឯកវចនៈ មានន័យថា អ្នកទី៣ គឺសំដៅលើអ្នកលេខរៀងទីបីក្នុងរទេះចំបាំង។

**១៤:៨** *រឹងទទឹង* មើល ខ.៤ និងការពន្យល់ ។

១០កាលផារ៉ោនចូលទៅជិត នោះពួកកូនចៅអ៊ីស្រាអែល
គេងើបភ្នែកឡើងឃើញពួកសាសន៍អេស៊ីព្ទមកតាម ដូច្នោះ
ក៏មានសេចក្ដីតក់ស្លុតជាខ្លាំង ហើយស្រែក[ត]អំពាវនាវដល់
ព្រះយេហូវ៉ា ១១ព្រមទាំងស្ដីបន្ទោសដល់ម៉ូសេថា តើ
ដោយព្រោះតែគ្មានផ្នូរនៅស្រុកអេស៊ីព្ទឬអី[ថ] បានជាអ្នកនាំ
យើងរាល់គ្នាមក ឱ្យត្រូវស្លាប់នៅទីរហោស្ថាននេះ ដូច្នេះ
ហេតុ អ្វីបានជាអ្នកប្រព្រឹត្តចំពោះយើងរាល់គ្នាយ៉ាងនេះ គឺ
ដែលនាំពួកយើងរាល់គ្នា ចេញពីស្រុកអេស៊ីព្ទមកដូច្នេះ
១២កាលនៅស្រុកអេស៊ីព្ទនៅឡើយ តើយើងរាល់គ្នាមិនបាន
និយាយសេចក្ដីនេះឯងនឹងអ្នកទេឬអីថា កុំមករំខាននឹងយើង
រាល់គ្នាឡើយ ចូរទុកឱ្យយើងនៅបំរើសាសន៍អេស៊ីព្ទចុះ
ដ្បិត ដែលយើងរាល់គ្នាបាននៅបំរើសាសន៍អេស៊ីព្ទ នោះ
វិសេស ជាជាងស្លាប់នៅទីរហោស្ថាននេះ[ទ] ១៣តែម៉ូសេ
ឆ្លើយតបថា កុំខ្លាចអី[ធ] ឈប់សិន ចាំ[ន]មើលសេចក្ដីសង្គ្រោះ
របស់ព្រះយេហូវ៉ា ដែលទ្រង់នឹងប្រោសដល់អ្នករាល់គ្នា
នៅថ្ងៃនេះ ដ្បិតពួកសាសន៍អេស៊ីព្ទដែលអ្នករាល់គ្នាឃើញ
នៅថ្ងៃនេះ នោះនឹងលែងឃើញ[ប]ទៀតជាដរាបទៅ ១៤ព្រះ
យេហូវ៉ាទ្រង់នឹង ច្បាំង[ផ]ជំនួសអ្នករាល់គ្នា ឯអ្នករាល់គ្នានឹង
នៅតែស្ងៀមវិញ[ព] ។

១៥រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា "ឯងអំពាវ
នាវរកអញធ្វើអី[ភ] ចូរប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា
ឱ្យដើរទៅមុខទៅ ១៦ឯឯង ត្រូវលើកដំបង[ម]លូកដៃទៅលើ
សមុទ្រញែកទឹក[យ]ចេញពីគ្នា ដើម្បីឱ្យពួកកូនចៅអ៊ីស្រាអែល
បានដើរតាមដីគោកនៅកណ្ដាលសមុទ្រ ១៧ឯអញៗនឹង
បណ្ដាល ឱ្យពួកសាសន៍អេស៊ីព្ទមានចិត្តរឹងទទឹង[រ]ចូលទៅ
តាមឯងរាល់គ្នា[ល] នោះអញនឹងបានកិត្តិសព្ទដោយឈ្នះ
ផារ៉ោននឹងពួកទ័ពទ្រង់ ហើយនិងអស់ទាំងរទេះចំបាំង
ព្រមទាំងពួកពលសេះទ្រង់ផង ១៨នោះទើបពួកសាសន៍
អេស៊ីព្ទគេនឹងដឹងថា អញជាព្រះយេហូវ៉ាពិត[វ] គឺក្នុងកាល
ដែលអញបានកិត្តិសព្ទដោយឈ្នះផារ៉ោន និងអស់ទាំង
រទេះចំបាំង ហើយនិងពួកពលសេះទ្រង់ដូច្នេះ ។

១៩នោះទេវតានៃព្រះ[ស]ដែលបាននាំមុខពួកអ៊ីស្រាអែល
ទ្រង់ក៏ត្រឡប់ទៅនៅខាងក្រោយវិញ ហើយបង្គោលពពក[ហ]
ក៏ចេញពីមុខទៅនៅខាងក្រោយ[ឡ]ដែរ ២០ពពកនោះស្ថិតនៅ
ជាកណ្ដាលពួកសាសន៍អេស៊ីព្ទ នឹងពួកអ៊ីស្រាអែល ក៏ងងឹត[អ]
ខាងម្ខាង ហើយភ្លឺខាងម្ខាង នៅវេលាយប់ បានជាពួកទាំង
២នោះមិនបានមកជិតគ្នា នៅវេលាយប់នោះឡើយ ២១នោះ
ម៉ូសេក៏លើកដៃ[ក]ទៅលើសមុទ្រ[ខ] ហើយព្រះយេហូវ៉ាទ្រង់
ច្រានផាត់សមុទ្រចេញ ដោយកំឡាំងខ្យល់ពីខាងកើត[គ]ដែល
បក់យ៉ាងខ្លាំងពេញ១យប់នោះ ទ្រង់ធ្វើឱ្យទឹកបានញែក
ចេញពីគ្នា ឱ្យសមុទ្រទៅជាគោក[ឃ]វិញ[ង] ២២រួចពួកកូនចៅ
អ៊ីស្រាអែល គេក៏ចូលទៅនាកណ្ដាលសមុទ្រ[ច] តាមដីគោក
[ឆ]ហើយមានទឹកជាកំផែង[ជ]នៅខាងស្ដាំនឹងឆ្វេងគេ ២៣ពួក
សាសន៍អេស៊ីព្ទក៏ប្រឹងដេញចូលទៅ ត្រង់កណ្ដាលសមុទ្រ
តាមគេ ព្រមទាំងសេះផារ៉ោន និងរទេះចំបាំងហើយទាំង
ពលសេះ[ឈ]ទ្រង់ផង ២៤នៅវេលាយាមព្រឹកព្រះយេហូវ៉ា
ទ្រង់ក៏ទតពីបង្គោលភ្លើង ហើយនិងពពក[ញ] ទៅឃើញពួក
កងពលសាសន៍អេស៊ីព្ទ រួចទ្រង់បណ្ដាលឱ្យពួកពលទ័ព

**១៤:១០** ត នក ១៥:២៥ យស ២៤:៧ នហ ៩:៩ ទដ ៥:២ ៣៤:១៧ ៥០:១៥ ១០៧:៦,២៨ **១៤:១១** ថ នក ៥:២១ ១៦:៣ ១៧:៣ ជណ ១១:១ ១៤:២២ ២០:៤ ២១:៥ ចទ ៩:៧ **១៤:១២** ទ នក ៥:២១ ១៥:២៤ ១៧:២ ទដ ១០៦:៧–៨ **១៤:១៣** ធ លប ១៥:១ ន ១សយ ១២:១៦ ២រប ២០:១៧ ប ខ.៣០ **១៤:១៤** ផ ខ.២៥ នក ១៥:៣ ចទ ១:៣០ ៣:២២ ២០:៤ យស ១០:១៤ ២៣:៣,១០ ២សយ ៥:២៤ ២រប ២០:២៩ នហ ៤:២០ ទដ ២៤:៨ ៣៥:១ អស ៤២:១៣ យរ ៤១:១២ ព ១សយ ១២:១៦ ទដ ៣៧:៧ ៤៦:១០ ១១៦:៧ អស ២៨:១២ ៣០:១៥ សក ២:១៣ **១៤:១៥** ភ យស ៧:១០ **១៤:១៦** ម នក ៤:២ យ ខ.២៧ អស ១០:២៦ **១៤:១៧** រ នក ៤:២១ ល ខ.៤ **១៤:១៨** វ នក ៦:២ អគ ៣២:១៥ **១៤:១៩** ស លប ១៦:៧ អស ៦៣:៩ ហ នក ១៣:២១ ១កថ ១០:១ ឡ អស ២៦:៧ ៤២:១៦ ៤៩:១០ ៥២:១២ ៥៨:៨ **១៤:២០** អ យស ២៤:៧ **១៤:២១** ក នក ៧:១៩ ខ នក ៤:២ យប ២៦:១២ អស ១៤:២៧ ២៣:១១ ៥១:១៥ យរ ៣១:៣៥ កថ ៧:៣៦ គ លប ៤១:៦ នក ១៥:៨ ២សយ ២២:១៦ ១ពវ ១៩:១១ យប ៣៨:១ ៤០:៦ យរ ២៣:១៩ ណាហ ១:៣ ឃ ខ.២២ លប ៨:១ ង ២ពវ ២:៨ ទដ ៧៤:១៣ ៧៨:១៣ ១១៤:៥ ១៣៦:១៣ អស ៦៣:១២ **១៤:២២** ច ខ.១៦ ជន ៣៣:៨ យស ២៤:៦ អស ៤៣:១៦ ៦៣:១១ ១កថ ១០:១ ឆ ខ.២១,២៩ នក ៣:១២ ១៥:១៩ ចទ ៣១:៦–៨ យស ៣:១៦,១៧ ៤:២២ នហ ៩:១១ ទដ ៦៦:៦ ៧៧:១៩ ១០៦:៩ អស ១១:១៥ ៤១:១០ ៤៣:៥ ៤៤:២៧ ៥០:២ ៥១:១០ ៦៣:១៣ យរ ៤៦:២៨ ណាហ ១:៤ ហាព ១១:២៩ ជ នក ១៥:៨ យស ៣:១៣ ទដ ៧៨:១៣ **១៤:២៣** ឈ ខ.៧ **១៤:២៤** ញ នក ១៣:២១ ១កថ ១០:១

**១៤:១៤** *ព្រះយេហូវ៉ាទ្រង់និងច្បាំងជំនួសអ្នករាល់គ្នា* ជាចំណុចដែលពួកគេត្រូវចាំថា ពួកអ៊ីស្រាអែល "មានអាវុធគ្រប់ដៃ"(១៣:១៨) ហើយ "ដង្ហែរក្បួនយ៉ាងក្លាហាន"(ខ.៨) ចេញទៅប្រយុទ្ធមែន តែជ័យជម្នះជារបស់ព្រះម្ចាស់តែប៉ុណ្ណោះ ។

**១៤:១៩** *ទេវតានៃព្រះ* មើលការពន្យល់ ១៦:៧ ។ ត្រង់ចំណុចនេះ ទេវតានៃព្រះជាប់ទាក់ទងនឹងពពក(មើល ១៣:២១) ។

**១៤:២០** *ស្ថិតនៅជាកណ្ដាលពួកសាសន៍អេស៊ីព្ទ និងពួកអ៊ីស្រាអែល* បង្គោលពពក(បញ្ជាក់ពីវត្តមានព្រះយេហូវ៉ា) ការពាររាស្ត្រអ៊ីស្រាអែល(មើល ទដ ១០៥:៣៩) ។

**១៤:២១** *ខ្យល់ពីខាងកើតដែលបក់យ៉ាងខ្លាំង* មើល ១០:១៣ ។ ក្នុង ១៥:៨ បទកំណាព្យតម្កើងព្រះ ហើយថា ខ្យល់"ចេញពីព្រះនាសាទ្រង់" បញ្ជាក់ថា ការអស្ចារ្យកើតឡើង តាមពេល និងការកំណត់របស់ទ្រង់(១៥:១០) ។

**១៤:២២** *គេក៏ចូលទៅនាកណ្ដាលសមុទ្រ តាមដីគោក* គឺជាអ្នកនិពន្ធទំនុកនៅក្នុងវគ្គបន្ទាប់នេះ និងពួកហោរាបានរំឭកពួកអ៊ីស្រាអែល អំពីការដែលព្រះបានធ្វើសម្រាប់ពួកគេ(មើល ទដ ៦៦:៦ ១០៦:៩ ១៣៦:១៣–១៤ អស ៥១:១០ ៦៣:១១–១៣) ។ *ទឹក* មើល ខ.២៩ ។ ទឹកបាន"គរឡើង"(១៥:៨) នៅទាំងសងខាងខ្សែទឹក ។

**១៤:២៤** *នៅវេលាយាមព្រឹក* គឺជាពេលអំណោយផលដល់ការវាយឆ្មក់(មើល យស ១០:៩ ១សយ ១១:១១) ។ *ព្រះយេហូវ៉ាទ្រង់ក៏ទតពីបង្គោលភ្លើង* មើលការពន្យល់ ១៣:២១ ។

សាសន៍អេស៊ីព្ទកោលាហលឡើង[ដ] ២៥រួចក៏ធ្វើឱ្យរបូតកង់
ពីរទេះគេចេញ ឱ្យគេបរដោយពិបាក បានជាពួកសាសន៍
អេស៊ីព្ទនិយាយថា ចូរយើងរាល់គ្នារត់ពីសាសន៍អ៊ីស្រា
អែលនេះចេញ ដ្បិតព្រះយេហូវ៉ាទ្រង់ច្បាំង[ឋ]នឹងយើងជំនួស
គេហើយ[ឌ] ។

២៦ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរឯងលើក
ដៃទៅលើសមុទ្រទៅ ដើម្បីឱ្យទឹកបានហូរត្រឡប់គ្របទៅ
លើពួកសាសន៍អេស៊ីព្ទ ព្រមទាំងរទេះ និងពួកទ័ពសេះគេ
ផង ២៧នោះម៉ូសេក៏លើកដៃទៅលើសមុទ្រ ហើយដល់ព្រឹក
ឡើង ទឹកក៏ហូរប្រសប់ចូលទៅ នៅកន្លែងធម្មតាវិញ[ឍ] ពួក
សាសន៍អេស៊ីព្ទក៏នាំគ្នារត់ចេញពីទឹក ប៉ុន្តែព្រះយេហូវ៉ាទ្រង់
ផ្តួលគេនៅកណ្តាលសមុទ្រទៅ[ណ] ២៨ហើយទឹកក៏ត្រឡប់មក
គ្របលើអស់ទាំងរទេះ និងពួកពលសេះ ហើយនិងពលទ័ព
ផារ៉ោនទាំងអស់ ដែលបានចូលទៅក្នុងសមុទ្រ តាមពួកកូន
ចៅអ៊ីស្រាអែល[ត] គ្មានរួចអ្នកណាមួយសោះឡើយ[ថ] ២៩តែ
ពួកកូនចៅអ៊ីស្រាអែលបានដើរនៅកណ្តាលសមុទ្រតាម
ដីគោកវិញ[ទ] ដោយមានទឹកជាកំផែង[ធ]នៅពីខាងស្តាំ និង
ខាងឆ្វេង ។

៣០ដូច្នេះនៅថ្ងៃនោះឯង ព្រះយេហូវ៉ាទ្រង់បានជួយ[ន]ពួក
អ៊ីស្រាអែល ឱ្យរួចពីកណ្តាប់ដៃនៃពួកសាសន៍អេស៊ីព្ទ ហើយ
ពួកអ៊ីស្រាអែល បានឃើញខ្មោចពួកសាសន៍អេស៊ីព្ទរាយ
នៅតាមឆ្នេរសមុទ្រ ៣១ក៏បានឃើញការយ៉ាងធំ[ប]ដែល
ស្នាដៃនៃព្រះយេហូវ៉ាបានធ្វើដល់សាសន៍អេស៊ីព្ទ នោះគេក៏
មានសេចក្តីកោតខ្លាច[ផ]ដល់ព្រះយេហូវ៉ា ហើយក៏ជឿ[ព]ដល់
ព្រះយេហូវ៉ា ព្រមទាំងដល់ម៉ូសេ ជាអ្នកបំរើទ្រង់ផង ។

### បទចម្រៀងលោកម៉ូសេ និងហោរាម៉ារ៉ាម

**១៥** ១រួចពីនោះមក ម៉ូសេនិង ពួកកូនចៅអ៊ីស្រាអែល ក៏
នាំគ្នាច្រៀង[ក]ទំនុកនេះថ្វាយព្រះយេហូវ៉ាថា ខ្ញុំនឹងច្រៀង[ខ]
ថ្វាយព្រះយេហូវ៉ា ដ្បិតទ្រង់មានជ័យជំនះយ៉ាងឧត្តមទ្រង់
បានផ្តួលទាំងសេះ ទាំងអ្នកជិះ[គ] ទៅក្នុងសមុទ្រ[ឃ] ២ព្រះយេ
ហូវ៉ាទ្រង់ជាកំឡាំង[ង]នៃខ្ញុំ ហើយជាទំនុកដែលខ្ញុំច្រៀង
ផងទ្រង់បានជួយសង្គ្រោះខ្ញុំ[ច] ហើយជាព្រះនៃខ្ញុំ[ឆ] ឯខ្ញុំនឹង
លើកសរសើរ[ជ]ដល់ទ្រង់ គឺជាព្រះនៃឪពុកខ្ញុំៗនឹងដំកើង
ទ្រង់ ៣ព្រះយេហូវ៉ាទ្រង់ជាអ្នកចំបាំង[ឈ] ព្រះនាមទ្រង់ជាព្រះ
យេហូវ៉ា[ញ] ៤ទ្រង់បានបោះអស់ទាំងរទេះ និងពលទ័ព[ដ]របស់
ផារ៉ោនចោលទៅក្នុងសមុទ្រ ឯពួកមេទ័ពជ្រើសរើសទាំង

**១៤:២៤** ដ នក ២៣:២៧ យស ១០:១០ ១សយ ៥:៩ ៧:១០ ១៤:១៥ ២សយ ៥:២៤ ២ពវ ៧:៦ ១៩:៧ **១៤:២៥** ឋ ខ.១៤ ឌ ខ.៩ ចទ ៣២:៣១ ១សយ ២:២ ៤:៨ **១៤:២៧** ឍ យស ៤:១៨ ណ ខ.២៨ នក ១៥:១,២១ ចទ ១:៤០ ២:១ ១១:៤ ទដ ៧៨:៥៣ ១០៦:១១ **១៤:២៨** ត ខ.២៣ នក ១៥:១៩ យស ២៤:៧ ថ ខ.២៧ នក ១៥:៥ ពច ៤:១៦ នហ ៩:១១ **១៤:២៩** ទ ខ.២១ ២២ យស ២៤:១១ ២ពវ ២:៨ ទដ ៧៤:១៥ ធ ទដ ៧៨:១៣ **១៤:៣០** ន ខ.២៩ ១សយ ១៤:២៣ ១របា ១១:១៤ ទដ ៤៤:៧ ១០៦:៨,១០, ២១ អស ៤៣:៣ ៥០:២ ៥១:៩–១០ ៦០:១៦ ៦៣:៨,១១ **១៤:៣១** ប នក ៩:១៦ ទដ ១៤៧:៥ផ នក ២០:១៨ ចទ ៣១:១៣ យស ៤:២៤ ១សយ ៤:២៤ ១សយ ១២:១៨ ទដ ៧៦:៧ ១១២:១ ព នក ៤:៥ ទដ ២២:៤ ៤០:៣ ១០៦:១២ យហ ២:១១ ១១:៤៥ **១៥:១** ក ជន ២១:១៧ ពច ៥:១ ២សយ ២២:១ ១របា ១៦:៩ យប ៣៦:២៤ ទដ ៥៩:១៦ ១០៥:២ វវ ១៥:៣ ខ ពច ៥:៣ ទដ ១៣:៦ ២១:១៣ ២៧:៦ ៦១:៨ ១០៤:៣៣ ១០៦:១២ អស ១២:៥,៦ ៤២:១០ ៤៤:២៣ គ ចទ ១១:៤ ទដ ៧៦:៦ យរ ៥១:២១ ឃ នក ១៤:២៧ **១៥:២** ង ទដ ១៨:១ ៥៩:១៧ ច លប ៤៥:៧ នក ១៤:១៣ ទដ ១៨:២,៤៦ ២៥:៥ ២៧:១ ៦២:២ ១១៨:១៤ អស ១២:២ ៣៣:២ យហ ២:៩ ហព ៣:១៨ឆ លប ២៨:២១ ជ ចទ ១០:២១ ២សយ ២២:៤៧ ទដ ២២:៣ ៣០:១ ៣៤:៣ ៣៥:២៧ ៩៩:៥ ១០៣:១៩ ១០៧:៣២ ១០៨:៥ ១០៩:១ ១១៨:២៨ ១៤៥:១១ ១៤៨:១៤ អស ២៤:១៥ ២៥:១ យរ ១៧:១៤ ដយ ៤:៣៧ **១៥:៣** ឈ នក ១៤:១៤ វវ ១៩:១១ ញ នក ៣:១៥ **១៥:៤** ដ នក ១៤:៦–៧ យរ ៥១:២១

**១៤:២៥** *ព្រះយេហូវ៉ាទ្រង់ច្បាំងនិងយើងជំនួសគេហើយ* មើលការពន្យល់ ខ.១៤ ។

**១៤:២៧** *ព្រះយេហូវ៉ាផ្តួលគេនៅកណ្តាលសមុទ្រទៅ* គឺដូចនៅក្នុងសេចក្តីវេទនាទី៨ ដែលមានសត្វកណ្តូបមក(មើល ១០:១៩) ។

**១៤:៣១** *សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា* មើល លប ២០:១១ ។ *ជឿដល់ព្រះយេហូវ៉ា ព្រមទាំងដល់ម៉ូសេ* គឺសេចក្តីជំនឿដល់ព្រះដ៏មានព្រះចេស្តា និងទុកចិត្តលើការដឹកនាំរបស់លោកម៉ូសេ(ធៀបនឹង ១សយ ១២:១៨ និងការពន្យល់)។ *អ្នកបំរើទ្រង់* ក្នុងខនេះ គឺសំដៅទៅលើអ្នកដឹកនាំជាន់ខ្ពស់ក្នុងការងារបម្រើព្រះអម្ចាស់(ការពន្យល់ ជន ១២:៦–៨ ចទ ៣៤:៥)។ មើលការហៅមុខនាទីរបស់លោកយ៉ូស្វេ(មើល យស ២៤:២៩) ហោរាសាំយូអែល(មើល ១សយ ៣:១០) ស្តេចដាវីឌ(មើល ២សយ ៣:១៨) និងលោកអេលីយ៉ា(មើល ២ពវ ៩:៣៦) ។

**១៥:១–៨** វគ្គនេះជាបទទំនុកតម្កើង អំពីជ័យជម្នះដែលព្រះអម្ចាស់ទ្រង់មានលើស្តេចផារ៉ោន និងកងទ័ពរបស់ទ្រង់ ។ បទនេះបានផ្តោតការសរសើរទៅលើព្រះអម្ចាស់(មើល ខ.១១ និងការពល្យល់) និងព្រះនាមទ្រង់ចំនួនដប់ដង ។ ពីវគ្គដំបូងនៃបទនេះ(ខ.២–៦,៧–១១) បានរៀបរាប់ឡើងវិញអំពី"ការប្រោសលោះ"(១៤:១៣) នៅឯសមុទ្រក្រហម ហើយវគ្គចុងក្រោយ(ខ.១២–១៧) និយាយអំពីហេតុការណ៍ដែលនឹងកើតឡើង និងការចូលវាយកាន់កាប់ទឹកដីកាណាន(ទឹកដីសន្យា) ។

**១៥:១** *ម៉ូសេនិង ពួកកូនចៅអ៊ីស្រាអែលក៏នាំគ្នាច្រៀង* គឺច្រៀងសរសើររួមគ្នាតែមួយ ឱ្យដូចជាសម្លេងនៃមនុស្សតែម្នាក់ ។ *ខ្ញុំនឹងច្រៀងថ្វាយ . . . ទៅក្នុងសមុទ្រ* ឃ្លានេះចាប់ផ្តើមបទកំណាព្យ ដែលបញ្ចប់ដោយ ខ.១៨ ហើយបានរួមគ្នាផ្តោតទៅលើខ្លឹមសារសំខាន់បំផុត(មើល ពច ៥:៣ ទដ ៨៩:១ ១០១:១ ១០៨:១)។ *ខ្ញុំនឹងច្រៀង* គឺជាពាក្យផ្តើមបទសរសើរតម្កើង(មើល ពច ៥:៣ ទដ ៨៩:១ ១០១:១ ១០៨:១)។

**១៥:២–៦** វគ្គនេះរៀបរាប់អំពីជ័យជម្នះ ដែលព្រះអម្ចាស់មានលើស្តេចផារ៉ោន យ៉ាងពិតប្រាកដ ។

**១៥:២** ផ្នែកពាក់កណ្តាលទីមួយ នៃខនេះ បាននិយាយនៅក្នុង ទដ ១១៨:១៤ ផងដែរ (មើល អស ១២:២) ។

**១៥:៣** *ព្រះយេហូវ៉ាទ្រង់ជាអ្នកចំបាំង* មើលការពន្យល់ ១៤:១៤ ។ ជាញឹកញាប់គេរៀបរាប់អំពីលក្ខណៈរបស់ព្រះអម្ចាស់ ជាព្រះមហាក្សត្រដែលដឹកនាំរាស្ត្រក្នុងការធ្វើសង្គ្រាម(មើល ចទ ១:៣០ ពច ៤:១៤ ២សយ ៥:២៤ ២របា ២០:១៧–១៨) ។

**១៥:៤** *ពលទ័ព* មើលការពន្យល់ ១៤:៧ ។

ប៉ុន្មាន ក៏បានលង់ទៅក្នុងសមុទ្រក្រហម ៥អស់ទាំងទីជំរៅ[ឋ]
បានគ្របគេបាត់ គេបានចុះទៅដល់បាតសមុទ្រ ដូចជាថ្ម[ឌ]
៦ឱព្រះយេហូវ៉ាអើយ ព្រះហស្តស្តាំទ្រង់មានឫទ្ធិដ៏វិសេស[ឍ]
ឱព្រះយេហូវ៉ា ព្រះហស្តស្តាំទ្រង់[ណ]បានបោក[ត]ពួកខ្មាំង
សត្រូវខ្ទេចខ្ទីហើយ ៧គឺទ្រង់បានរំលំពួកអ្នកដែលលើកគ្នា
ទាស់នឹងទ្រង់ ដោយឫទ្ធានុភាពដ៏ជាធំរបស់ទ្រង់[ថ] ទ្រង់បាន
បញ្ចេញសេចក្ដីក្រោធនៃទ្រង់[ទ] សេចក្ដីក្រោធនេះបាន
បញ្ឆេះ[ធ]គេដូចជាភ្លើងឆេះជញ្ជ្រាំង ៨ហើយដោយសារ
កំឡាំងខ្យល់ពីព្រះនាសាទ្រង់[ន] នោះទឹកត្រូវគរជាគំនរ
ឡើង[ប] ទឹកធំបានពូនឡើងដូចជាកំផែង[ផ] អស់ទាំងទីជំរៅក៏
បានកកខះនៅនាសមុទ្រ[ព] ៩ឯពួកខ្មាំងសត្រូវ គេនិយាយថា
អញនឹងដេញតាម[ភ] អញនឹងបានទាន់ អញនឹងចែករបឹប[ម]
អញនឹងបំពេញចិត្តដោយសារគេ អញនឹងហូតដាវ ហើយ
ដៃអញនឹងកាប់បំផ្លាញគេ ១០តែទ្រង់បានផ្លុំដោយខ្យល់
ដង្ហើមទ្រង់[យ] នោះសមុទ្រក៏គ្របលើគេវិញ ហើយគេត្រូវ
លិចចុះ ទៅក្នុងទឹកធំដូចជាសំណល់ ១១ឱព្រះយេហូវ៉ាអើយ
តើមានព្រះឯណាឱ្យដូចទ្រង់[ល] តើមានអ្នកឯណាដែលមាន
សេចក្ដីបរិសុទ្ធដ៏វិសេសដូចទ្រង់[វ] ដែលគួរសរសើរដំកើង[ស]
ហើយក៏ធ្វើការអស្ចារ្យផង[ហ] ១២ទ្រង់បានលើក[ឡ]ព្រះហស្ត
ស្តាំឡើង នោះដីក៏ស្រូបគេបាត់ទៅ[អ] ១៣ដោយសារសេចក្ដី
សប្បុរសរបស់ទ្រង់ នោះទ្រង់បាននាំ[ក]រាស្ត្រដែលទ្រង់
លោះ[ខ] គឺបាននាំគេទៅដល់ទីលំនៅបរិសុទ្ធរបស់ទ្រង់
ដោយព្រះបារមី[គ] ១៤គ្រប់ទាំងសាសន៍បានឮ ហើយក៏ញាប់
ញ័រ[ឃ] ឯពួកសាសន៍ភីលីស្ទីន គេកើតមានសេចក្ដីភ័យខ្លាច[ង,ច]
១៥ពួកមេ[ឆ]នៃសាសន៍អេដំម[ជ] មានសេចក្ដីភាន់ភាំង[ឈ] អស់
ទាំងមនុស្សខ្លាំងពូកែក្នុងសាសន៍ម៉ូអាប់ ក៏មានសេចក្ដីភ័យ
ញ័រ ហើយអស់ទាំងមនុស្សដែលនៅស្រុកកាណានក៏ស្លុត
ចិត្ត[ញ] ១៦សេចក្ដីស្ញែងខ្លាច[ដ]នឹងសេចក្ដីថប់បារម្ភក៏គ្របសង្កត់
លើគេទាំងអស់ គេបានទៅជាគ ដូចជាថ្ម[ឋ] ដោយសារ
អំណាចព្រះហស្តទ្រង់ ទាល់តែរាស្ត្រទ្រង់បានទៅហួស ឱ
ព្រះយេហូវ៉ា គឺទាល់តែរាស្ត្រដែលទ្រង់បានលោះ[ឌ] បាន
ទៅបាត់ហើយ[ឍ] ១៧ឱព្រះយេហូវ៉ាអើយទ្រង់នឹងនាំ[ណ] គេចូល
ទៅដាំ[ត]នៅលើភ្នំ[ថ]ជាមរដករបស់ទ្រង់ ជាទីកន្លែងដែល

**១៥:៥** ឋ នក ១៤:២៨ ឌ ខ.១០ នហ ៩:១១ **១៥:៦** ឍ ទដ ១៦:១១ ១៧:៧ ២១:៨ ៦៣:៨ ៧៤:១១ ៧៧:១០ ៨៩:១៣ ៩៨:១ ១១៨:១៥ ១៣៨:៧ ណ នក ៣:២០ យប ៤០:១៤ ត នក ២៤:៨ ១សយ ២:១០ ទដ ២:៩ **១៥:៧** ថ ចទ ៣៣:២៦ ចទ ១៥០:២ ទ ទដ ២:៥ ៧៨:៤៩–៥០ យរ ១២:១៣ ២៥:៣៨ ធ នក ២៤:១៧ ចទ ៤:២៤ ៩:៣ ទដ ១៨:៨ ៥៩:១៣ ហព ១២:២៩ **១៥:៨** ន នក ១៤:២១ ទដ ១៨:១៥ ប យស ៣:១៣ ទដ ៧៨:១៣ អស ៤៣:១៦ ផ នក ១៤:២២ ព ទដ ៤៦:២ **១៥:៩** ភ នក ១៤:៥–៩ ចទ ២៨:៤៥ ទដ ៧:៥ បទ ១:៣ ម ពច ៥:៣០ អស ៩:៣ ៥៣:១២ លក ១១:២២ **១៥:១០** យ យប ៤:៩ ១៥:៣០ អស ១១:៤ ៣០:៣៣ ៤០:៧ រ ខ.៥ នហ ៩:១១ ទដ ២៩:៣ ៣២:៦ ៧៧:១៩ **១៥:១១** ល នក ៨:១០ ទដ ៧៧:១៣ អស ៤៦:៦ វ លវ ១៩:២ ១សយ ២:២ ១របា ១៦:២៩ ទដ ៩៩:៣ ១១០:៣ អស ៦:៣ វវ ៤:៨ ស នក ១៤:៤ ទដ ៤:២ ៨:១ ២៦:៨ អស ៣៥:២ ៤០:៥ ហ នក ៣:២០ **១៥:១២** ឡ នក ៧:៥ អ ជន ១៦:៣២ ២៦:១០ ចទ ១១:៦ ទដ ១០៦:១៧ **១៥:១៣** ក នហ ៩:១២ ទដ ៧៧:២០ ខ នក ៦:៦ យប ៣៣:២៨ ទដ ៧១: ២៣ ១០៦:១០ អស ១:២៧ ៤១:១៤ ៤៣: ១៤ ៤៤:២២–២៤ ៥១:១០ ៦៣:៩ ទត ២:១៤ គ ខ.១៧ ទដ ៦៨:១៦ ៧៦:២ ៧៨:៥៤ **១៥:១៤** ឃ ខ.១៦ នក ២៣:២៧ ចទ ២:២៥ យស ២:៩ ៥:១ ៩:២៤ ១សយ ៤:៧ នក ៨:១៧ ទដ ៤៨:៦ ៩៦:៩ ៩៩:១ ១១៤:៧ អក ៣៨:២០ ង អស ១៣:៨ ច ទដ ៨៣:៧ **១៥:១៥** ឆ លប ៣៦:១៥ ជ ចទ ២:៤ ឈ ជន ២២:៣ ទដ ១១៤:៧ ញ យស ២:៩,២៤ **១៥:១៦** ដ ខ.១៤ លប ៣៥:៥ ឋ ១សយ ២៥:៣៧ ឌ ទដ ៧៤:២ ២ពត ២:១ ឍ ចទ ២:៤ វ **១៥:១៧** ណ នក ២៣:២០ ៣២:៣៤ ៣៣:១២ ត ២សយ ៧:១០ ទដ ៤៤:២ ៨០:៨,១៥ អស ៥:២ ៦០:២១ យរ ២:២១ ១១:១៧ ២៤:៦ អម ៩:១៥ ថ ចទ ៣៣:១៩ ទដ ២:៦ ៣:៤ ១៥:១ ៧៨:៥៤,៦៨ ១៣៣:៣ ដយ ៩:១៦ ២:១ អម ១:១៦ សជ ៣:១១

**១៥:៦** *ព្រះហស្តស្តាំទ្រង់* មើល អស ៤១:១០ និងការពន្យល់ ។
**១៥:៧–៨** ជោគជ័យដ៏អស្ចារ្យនៃព្រះយេហូវ៉ា បានបង្ហាញថាទ្រង់ជាព្រះពិត ដែលគ្មានព្រះនៃលោកិយណាប្រៀបផ្ទឹមបានឡើយ ។
**១៥:៨** មើលការពន្យល់ ១៤:២២ ។ *ដោយសារកំឡាំងខ្យល់ពីព្រះនាសាទ្រង់* មើលការពន្យល់ ១៤:២១ មើល ទដ ១៨:១៥ ផងដែរ ។
**១៥:១០** *តែទ្រង់បានផ្លុំដោយខ្យល់ដង្ហើមទ្រង់* មើលការពន្យល់ ១៤:២១ ។
**១៥:១១** *តើមានព្រះឯណាឱ្យដូចទ្រង់* មើល ទដ ៣៥:១០ ៧១:១៩ ៨៩:៦ ១១៣:៥ មីក ៧:១៨ និងការពន្យល់ ។ ព្រះអម្ចាស់ទ្រង់មិនសព្វព្រះទ័យនឹងព្រះដទៃ (២០:៣ និងការពន្យល់) បានបំបាក់រូបព្រះក្នុងស្រុកអេស៊ីព្ទ និងអ្នកដែលថ្វាយបង្គំរូបព្រះនោះ ។
**១៥:១២–១៧** ព្រះហស្តស្តាំនៃព្រះអម្ចាស់ដ៏មានជ័យជម្នះ ប្រាកដជានឹងរៀបចំរាស្ត្រទ្រង់ ឱ្យបានចូលទទួលទឹកដីសន្យា ។
**១៥:១២** *ដី* គឺសំដៅទៅលើជម្រៅនៃផែនដី (មើល ទដ ៦៣:៩ ៧១:២០) ឬ "ស្ថានឃុំព្រលឹងមនុស្សស្លាប់" (ចទ ៣២:២២) ពីព្រោះទឹកសមុទ្របានលេបត្របាក់ពួកសាសន៍អេស៊ីព្ទ ។
**១៥:១៣** *សេចក្ដីសប្បុរសរបស់ទ្រង់* មើលការពន្យល់ ទដ ៦:៤ ។ *រាស្ត្រដែលទ្រង់លោះ* មើលការពន្យល់ ៦:៦ ។ *ដល់ទីលំនៅបរិសុទ្ធរបស់ទ្រង់* ប្រហែលសំដៅទៅលើកន្លែងថ្វាយបង្គំនៅស្រុកស៊ីឡូរ (មើល យរ ៧:១២) ហើយសំដៅទៅលើព្រះវិហារនៅលើភ្នំស៊ីយ៉ូន (មើល ទដ ៧៦:២) ជាទីកន្លែងដែលព្រះទ្រង់បានជ្រើសរើស (ចទ ១២:១៤,១៨,២៦ ១៤:២៥ ១៦:៧, ១៥–១៦ ១៧:៨,១០ ១៨:៦ ៣១:១១) ដើម្បីដាក់ព្រះនាមទ្រង់ (មើល ចទ ១២:៥,១១,២១ ១៤:២៣–២៤ ១៦:២,៦,១១ ២៦:២)។ ប៉ុន្តែ ឃ្លានេះអាចសំដៅលើទឹកដីសន្យា ដែលខ.១៧ បានហៅថា "ទីលំនៅរបស់ទ្រង់" និង "ទីបរិសុទ្ធដែលព្រះហស្តទ្រង់បានស្អាង"។ *បរិសុទ្ធ* មើលការពន្យល់ ៣:៥ ។
**១៥:១៤–១៥** *ភីលីស្ទីន . . . សាសន៍អេដំម . . . សាសន៍ម៉ូអាប់ . . . កាណាន* គឺជាសត្រូវដ៏មានសក្តានុភាពរបស់រាស្ត្រអ៊ីស្រាអែល ។ ការរៀបរាប់នេះបង្ហាញពីការធ្វើដំណើររបស់ពួកអ៊ីស្រាអែល ពីភ្នំស៊ីណាយទៅទឹកដីសន្យា ។
**១៥:១៥** *ពួកមេ* ពាក្យនេះបានប្រើសំដៅទៅលើស្ដេចអេដំមនៅក្នុងវគ្គមុន (មើល លប ៣៦:១៥–១៩,២១,២៩–៣០,៤០,៤៣) ។
**១៥:១៦** *សេចក្ដីថប់បារម្ភក៏គ្របសង្កត់លើគេទាំងអស់* មើលការពន្យល់ ១របា ១៤:១៧ ។ *បានលោះ* មើលការពន្យល់ ចទ ៣២:៦ ។ នៅក្នុង ទដ ៧៤:២ ពាក្យ "ទិញ" ត្រូវនឹងបរិបទនៃពាក្យ "ប្រោះលោះ" (សូមមើលការពន្យល់ ១៣:១៣) ។
**១៥:១៧** *ជាមរដក* គឺទឹកដីសន្យា (មើល ១សយ ២៦:១៩ ទដ ៧៩:១) ។

ទ្រង់រៀបចំទុកជាទីលំ[ទ]នៅជាទីលំនៅរបស់[ធ]របស់ទ្រង់ ឱ
ព្រះអម្ចាស់អើយ គឺជាទីបរិសុទ្ធដែលព្រះហស្តទ្រង់បាន
សាង ១៨ព្រះយេហូវ៉ា ទ្រង់នឹងសោយរាជ្យ ជារៀងរាបត
ទៅ អស់កល្បជានិច្ច[ន] ១៩ដ្បិតអស់ទាំងសេះរបស់ផារ៉ោន
បានចូលទៅក្នុងសមុទ្រ[ប] នាំយកទាំងរទេះ និងពលរបស់
ទ្រង់ដែលជិះដោយទៅផង ហើយព្រះយេហូវ៉ាទ្រង់បានឱ្យ
ទឹកសមុទ្រត្រឡប់មកគ្របលើគេ តែពួកកូនចៅអ៊ីស្រាអែល
បានដើរកណ្តាលសមុទ្រតាមដីគោកវិញ[ផ] ។
២០ឯហោរា[ព]ម៉ារាម[ភ] ជាបងស្រីរបស់អើរ៉ុន នាងក៏យក
ក្រាប់មកនៅដៃ ហើយបណ្តាស្រីទាំងអស់គ្នាក៏ទៅតាមទាំង
បន្ទរក្រាប់[ម] ហើយលោតកញ្ជ្រៀងកញ្ឆាត់ផង[យ] ២១ម៉ារាម
នាងក៏ទទួលពាក្យឆ្លើយ[រ]នឹងគេថា ចូរច្រៀងថ្វាយព្រះយេ
ហូវ៉ា ដ្បិតទ្រង់មានជ័យជំនះយ៉ាងឧត្តម ទ្រង់បានផ្តួលទាំង
សេះទាំងអ្នកជិះ[ល]ទៅក្នុងសមុទ្រ[វ] ។

## ទឹករបស់ម៉ារ៉ា និងអេលីម

២២ម៉ូសេក៏នាំពួកអ៊ីស្រាអែល ពីសមុទ្រក្រហមទៅហើយ
គេចេញទៅឯទីរហោស្ថាន[ស]ស៊ើរ[ហ] គេដើរក្នុងទីរហោ
ស្ថានអស់៣ថ្ងៃ មិនឃើញមានទឹកសោះ[ឡ] ២៣កាលគេទៅ
ដល់ម៉ារ៉ាហើយ ក៏ផឹកទឹកម៉ារ៉ាមិនបាន ដ្បិតទឹកនោះល្វីង
ណាស់ ហេតុនោះបានជាគេហៅកន្លែងនោះថា ម៉ារ៉ា[អ]
២៤បណ្តាជនក៏ត្អូញត្អែរ[ក]ដាក់ម៉ូសេថា តើយើងមានអ្វីផឹក[ខ]
២៥លោកក៏អំពាវនាវ[គ]ដល់ព្រះយេហូវ៉ា រួចទ្រង់បង្ហាញ
ដើមឈើ១ ឱ្យលោកបោះ[ឃ]ទៅក្នុងទឹក នោះទឹកក៏ត្រឡប់ទៅ
ជាសាបវិញ នៅទីនោះទ្រង់បានតែងជាច្បាប់ និងបញ្ញត្តិ
សំរាប់គេព្រមទាំងល្បង[ង]គេដែរ ២៦ទ្រង់មានបន្ទូលថាបើ
ឯងរាល់គ្នាប្រុងនឹងស្តាប់តាមព្រះយេហូវ៉ា ជាព្រះនៃឯង
ហើយ ធ្វើការត្រឹមត្រូវនៅព្រះនេត្រនៃទ្រង់ ព្រមទាំងផ្ទៀង
ត្រចៀកស្តាប់តាមបញ្ញត្តិទ្រង់ ហើយកាន់តាម[ច]ច្បាប់[ឆ]ទ្រង់
ទាំងប៉ុន្មាន នោះអញនឹងមិនធ្វើឱ្យឯងរាល់គ្នាកើតមានជំងឺ
រោគា[ជ]ណាមួយ ដូចជាអញបានធ្វើឱ្យកើតឡើងដល់ពួក
សាសន៍អេស៊ីព្ទនោះឡើយ ដ្បិតអញនេះជាយេហូវ៉ា គឺជា
ព្រះដែលប្រោស[ឈ]ឯងរាល់គ្នាឱ្យជា ។
២៧គេក៏ទៅដល់អេលីម ជាទីដែលមានក្បាលទឹក១២
មានលម៉ើ៧០ដើមផង ហើយគេក៏ដំឡើងត្រសាល[ញ]នៅ
ទីនោះជិតកន្លែងទឹក ។

## នំម៉ាន៉ា និងសត្វក្រួច

**១៦** ១រួចគេចេញពីអេលីមធ្វើដំណើរទៅ លុះដល់ថ្ងៃ១៥
ខែទី២ តាំងពីចេញពីស្រុកអេស៊ីព្ទមក[ក] នោះពួកជំនុំនៃកូន
ចៅអ៊ីស្រាអែលទាំងអស់គ្នា ក៏ទៅដល់ទីរហោស្ថានស៊ីន[ខ]
ជាទីដែលនៅជាកណ្តាលអេលីម ហើយនិងស៊ីណាយ

**១៥:១៧** ទ ខ.១៣ ទដ ១៣២:១៣–១៤ ធ ទដ ៧៨:៦៩ ១១៤:២ **១៥:១៨** ន លប ២១:៣៣ ទដ ៩:៧ ២៩:១០ ៥៥:១៩ ៦៦:៧ ៨០:១ ១០២:១២ ១៤៥:១៣ បទ ៥:១៩ **១៥:១៩** ប នក ១៤:២៨ ផ នក ១៤:២២ **១៥:២០** ព ពច ៤:៤ ២ពវ ២២:១៤ ២របា ៣៤:២២ នហ ៦:១៤ អស ៨:៣ អក ១៣:១៧ ភ ខ.២១ នក ២:៤ ជន ១២:១ ២០:១ ២៦:៥៩ ១របា ៤:១៧ ៦:៣ ម លប ៣១:២៧ ១សយ ១៨:៦ ទដ ៨១:២ អស ៣០:៣២ យ លប ៤:២១ ពច ១១:៣៤ ២១:២១ ១សយ ១៨:៦ ២សយ ៦:៥,១៤,១៦ ទដ ៣០:១១ ១៤៩:៣ ១៥០:៤ ៦:១៣ យរ ៣១:៤,១៣ **១៥:២១** រ ១សយ ១៨:៧ ល អម ២:១៥ ហក ២:២២ វ នក ១៤:២៧ **១៥:២២** ស ទដ ៧៨:៥២ ហ លប ១៦:៧ ឡ នក ១៧:១,៣ ជន ២០:២,៥ ៣៣:១៤ ទដ ១០៧:៥ **១៥:២៣** អ ជន ៣៣:៨ ជន ១:២០ **១៥:២៤** ក នក ១៤:១២ ១៦:២ ៧:៣ ជណ ១៤:២ យស ៩:១៨ ទដ ៧៨:១៨,៤២ ១០៦:១៣, ២៥ អក ១៦:៤៣ ខ មថ ៦:៣១ **១៥:២៥** គ នក ១៤:១០ ឃ ២ពវ ២:២១ ៤:៤១ ៦:៦ ង លប ២២:១ ពច ៣:៤ យប ២៣:១០ ទដ ៨១:៧ អស ៤៨:១០ **១៥:២៦** ច នក ២៣:២២ ចទ ១១:១៣ ១៥:៥ ២៨:១ យរ ១១:៦ ឆ នក ១៩:៥–៦ ២០:២–១៧ ចទ ៧:១២ ជ ចទ ៧:១៥ ២៨:២៧ ៥៨:៦០ ៣២:៣៩ ១សយ ៥:៦ ទដ ៣០:២ ៤១:៣–៤ ១០៣:៣ ឈ នក ២៣:២៥–២៦ ២ពវ ២០:៥ ទដ ២៥:១១ ១០៣:៣ ១០៧:២០ យរ ៣០:១៧ ហស ១១:៣ **១៥:២៧** ញ ជន ៣៣:៩ **១៦:១** ក នក ១៧:១ ជន ៣៣:១១,១២ ខ នក ៦:៦ ១២:១–២

**១៥:១៨** មើលការពន្យល់ ខ.១ ។

**១៥:២០** *ហោរា* ចំពោះពាក្យដែលនាងម៉ារាម និយាយអំពីអំណោយទានជាហោរារបស់នាង មើល ជន ១២:១–២ (មើលការពន្យល់ ៧:១–២) ។ ក្នុងព្រះគម្ពីរ មានហោរាស្រីឯទៀត ដូចជា នាងដេបូរា (ពច ៤:៤) ប្រពន្ធលោកអេសាយ (មើល អស ៨:៣ និងការពន្យល់) នាងហ៊ុលដា (២ពវ ២២:១៤) នាងណូអឌា (នហ ៦:១៤) នាងអាណា (លក ២:៣៦) កូនស្រីរបស់លោកភីលីព (កច ២១:៩) ។ *ស្រីទាំងអស់គ្នាក៏ទៅតាមទាំងបន្ទរក្រាប់ ហើយលោតកញ្ឆេងផង* ការអបអរសាទដូចនេះ គឺជារឿងធម្មតា បន្ទាប់ពីបានឈ្នះសង្គ្រាមហើយ (មើល ១សយ ១៨:៦ ២សយ ១:២០) ។

**១៥:២១** នាងម៉ារាមបានច្រៀងទំនុកសរសើរអំពីជ័យជម្នះ ទាំងបួនបន្ទាត់នោះឡើងវិញ (មើល ខ.១) ដោយប្តូរទម្រង់កិរិយាស័ព្ទទីមួយ ។

**១៥:២២–១៨:២៧** វគ្គនេះនិយាយអំពីការធ្វើដំណើរនៃពួកអ៊ីស្រាអែល ពីសមុទ្រក្រហមទៅភ្នំស៊ីណាយ (សេចក្តីផ្តើមត្រង់ចំណុច គម្រោងសង្ខេប) ។

**១៥:២២** *ទីរហោស្ថានស៊ើរ* នៅតំបន់ខាងកើត នៃស្រុកអេស៊ីព្ទ (មើល លប ២៥:១៨ ១សយ ១៥:៧) និងតំបន់និរតីនៃឧបទ្វីបស៊ីណាយ ។

**១៥:២៣** *ម៉ារ៉ា* គេជឿថា ជាតំបន់អែន ហាវ៉ារ៉ាហ (Ain Hawarah) បច្ចុប្បន្ន ជាដៃសមុទ្រក្រហម ចម្ងាយ ៨០,៤គ.ម ពីចុងខាងជើងនៃសមុទ្រនេះ

**១៥:២៤** *ត្អូញត្អែរ* នៅក្នុងពេលវិលវល់នៅក្នុងទីរហោស្ថាន ពួកអ៊ីស្រាអែលបានរអ៊ូរទាំទាស់នឹងលោកម៉ូសេ និងអើរ៉ុន ពេលណាពួកគេជួបវិបត្តិ (មើល ១៦:២ ១៧:៣ ជន ១៤:២ ១៦:១១,៤១) ។ តាមការពិត ការនេះក៏ជាការរអ៊ូរទាំទាស់ "ទាស់នឹងព្រះអម្ចាស់" (១៦:៨) ។

**១៥:២៥** *ឱ្យលោកបោះទៅក្នុងទឹក នោះទឹកក៏ត្រឡប់ទៅជាសាបវិញ* ចំពោះហេតុការណ៍ស្រដៀងគ្នា មើល ១ពវ ២:១៩:២២ ។ *ជាច្បាប់ និងបញ្ញត្តិ* ពាក្យនេះសំដៅទៅលើ ខ.២៦ ។ *ល្បង* មើលការពន្យល់ លប ២២:១។

**១៥:២៧** *អេលីម* ស្ថិតនៅខាងត្បូងតំបន់ អែន ហាវ៉ារ៉ាហ (Ain Hawarah មើលការពន្យល់ ខ.២៣) ក្នុងជ្រលងជ្រោះការ៉ានដែល (Gharandel) ដែលសំបូរទឹក ។ *លម៉ើ* អេលីមមានន័យថា "ដើមឈើធំៗ"។

**១៦:១** *ចេញពីអេលីម . . . ដល់ទីរហោស្ថានស៊ីន* មើល ជន ៣៣:១០–១១។ ទីរហោស្ថានស៊ីននៅតំបន់ខាងនិរតីនៃភ្នំស៊ីណាយ (គេជឿថា ពាក្យ "ស៊ីន" បានក្លាយមកពីពាក្យ "ស៊ីណាយ") ។ *ថ្ងៃ១៥ខែ២* គឺមានរយៈពេលមួយខែ

២ហើយពួកជំនុំកូនចៅអ៊ីស្រាអែលទាំងអស់ក៏ត្អូញត្អែរ[ក]នឹង
ម៉ូសេ ហើយនិងអើរ៉ុននៅទីរហោស្ថាននោះ ៣គេនិយាយ
នឹងលោកថា ស៊ូឱ្យយើងបានស្លាប់ដោយព្រះហស្តនៃព្រះ
យេហូវ៉ានៅស្រុកអេស៊ីព្ទ[ឃ] ក្នុងកាលដែលយើងអង្គុយនៅ
ជិតឆ្នាំងសំឡ ហើយបានទទួលទានបាយឱ្យឆ្អែត[ង] នោះជា
ជាង ដ្បិតដែលអ្នកបាននាំយើងមកក្នុងទីរហោស្ថាននេះ
នោះគឺដើម្បីតែសំឡាប់ពួកជំនុំនេះទាំងអស់ដោយអត់
ឃ្លានទេ[ច]។

៤បន្ទាប់នោះមក ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ
ថា មើល អញនឹងបង្អុរភ្លៀងជានំបុ័ងពីលើមេឃ[ឆ]មកឱ្យឯង
រាល់គ្នា ត្រូវឱ្យបណ្តាជនចេញទៅរើសឱ្យល្មមតែ១ថ្ងៃរាល់
៧ថ្ងៃ ដើម្បីឱ្យអញបានល្បងល[ជ]គេមើល តើគេនឹងដើរតាម
ច្បាប់របស់អញឬទេ ៥ដល់ថ្ងៃទី៦ នោះត្រូវឱ្យគេរើស
លើសជាងធម្មតា១ជា២[ឈ] យកទៅរៀបចំទុក ។

៦ម៉ូសេ និងអើរ៉ុន ក៏ប្រកាសប្រាប់ ដល់ពួកកូនចៅអ៊ីស្រា
អែលទាំងអស់ថា "នៅល្ងាចនេះអ្នករាល់គ្នានឹងដឹងថា គឺជា
ព្រះយេហូវ៉ាហើយដែលបាននាំអ្នករាល់គ្នាចេញពីស្រុក
អេស៊ីព្ទមក[ញ] ៧ហើយដល់ព្រឹកឡើង នោះអ្នករាល់គ្នានឹង
ឃើញសិរីល្អ[ដ]របស់ទ្រង់ ដ្បិតទ្រង់បានឮសេចក្ដីដែលអ្នក
រាល់គ្នាត្អូញត្អែរ[ឋ]នឹងទ្រង់ហើយ ឯយើង តើយើងជាអ្វី
ដែលអ្នករាល់គ្នាត្អូញត្អែរនឹងយើងដូច្នេះ[ឌ] ៨ម៉ូសេក៏ប្រាប់
ថា ល្ងាចនេះ ព្រះយេហូវ៉ាទ្រង់នឹងប្រទានសាច់ ឱ្យអ្នករាល់
គ្នាបរិភោគ ហើយដល់ព្រឹកឡើងនឹងប្រទាននំបុ័ងឱ្យចំអែត
ដ្បិត ទ្រង់បានឮពាក្យដំអូញ ដែលអ្នករាល់គ្នាត្អូញ[ឍ]នឹងទ្រង់
ហើយ ឯយើង តើយើងជាអ្វី ដែលអ្នករាល់គ្នាត្អូញត្អែរ
ដូច្នេះ នោះមិនមែនត្អូញត្អែរទាស់នឹងយើងទេ គឺនឹងព្រះ
យេហូវ៉ាវិញ[ណ]។

៩រួចម៉ូសេ លោកប្រាប់អើរ៉ុនឱ្យបង្គាប់ដល់ពួកជំនុំនៃកូន
ចៅអ៊ីស្រាអែលទាំងអស់គ្នាថា ចូរអ្នករាល់គ្នាចូលមកនៅ
ចំពោះព្រះយេហូវ៉ា ដ្បិតទ្រង់បានឮសេចក្ដីដំអូញរបស់អ្នក
រាល់គ្នាហើយ ១០កាលអើរ៉ុនកំពុងតែនិយាយនឹងពួកជំនុំ
កូនចៅអ៊ីស្រាអែលទាំងអស់ នោះគេងាកបែរទៅឯទីរ
ហោស្ថាន ឃើញសិរីល្អ[ត]នៃព្រះយេហូវ៉ាលេចមកក្នុង
ពពក[ថ] ១១ព្រះយេហូវ៉ា ទ្រង់មានបន្ទូលទៅម៉ូសេថា ១២អញ
បានឮសេចក្ដីត្អូញត្អែរ[ទ] របស់ពួកកូនចៅអ៊ីស្រាអែលហើយ
ដូច្នេះចូរប្រាប់គេថា នៅល្ងាចនេះ ឯងរាល់គ្នានឹងបាន
បរិភោគសាច់ លុះដល់ព្រឹកឡើង នោះនឹងចំអែតដោយ
នំបុ័ង ដើម្បីឱ្យឯងរាល់គ្នាបានដឹងថា អញនេះជាយេហូវ៉ា
ជាព្រះនៃឯងរាល់គ្នាពិត[ធ]។

១៣លុះដល់វេលាល្ងាច នោះក៏មានសត្វក្រួច[ន]ហើរមក
គ្របនៅលើទីដំឡើងត្រសាល ហើយដល់ព្រឹកឡើង[ប] ក៏មាន
ទឹកសន្សើមនៅជុំវិញ ១៤កាលទឹកសន្សើមស្ងួតទៅហើយ
នោះឃើញនៅពេញទាំងទីរហោស្ថាន សឹងដ៏មានគ្រាប់
ល្អិតៗ ដែលមើលទៅបែបដូចទឹកសន្សើមកក[ផ] ឡើង
សស្កុសនៅលើដី ១៥កាលពួកកូនចៅអ៊ីស្រាអែលបាន
ឃើញ នោះគេនិយាយគ្នាថា នេះជាអ្វីហ្ន៎ ដ្បិតគេមិនស្គាល់
[ព]ជាអ្វីទេ រួចម៉ូសេប្រាប់ថា នេះគឺជានំបុ័ង[ភ]ដែលព្រះយេ
ហូវ៉ា ទ្រង់ប្រទានមកអ្នករាល់គ្នា ទុកជាអាហារហើយ
១៦នេះហើយជាសេចក្ដីដែលព្រះយេហូវ៉ាបានបង្គាប់មក
គឺឱ្យអ្នករាល់គ្នារើសយកល្មមតែនឹងបរិភោគឆ្អែតគ្រប់គ្នា
ចុះ គឺជា១ខ្ញឹង[ម]ម្នាក់ តាមចំនួនពួកអ្នករាល់គ្នា គ្រប់គ្នាត្រូវ
យកឱ្យល្មមដល់ពួកអ្នកដែលនៅត្រសាលរបស់ខ្លួន ១៧ពួក
អ៊ីស្រាអែលក៏ធ្វើដូច្នោះ ខ្លះរើសបានច្រើនខ្លះបានតិច

**១៦:២** គ នក ១៥:២៤ ១កថ ១០:១០
**១៦:៣** ឃ នក ១៧:៣ ជន ១៤:២ ២០:៣ ង ជន ១១:៤,៣៤ ចទ ១២:២០ ទដ ៧៨:១៨ ១០៦:១៤ យរ ៤៤:១៧ ច លប ៤៧:១៥ ចទ ៨:៣
**១៦:៤** ឆ ខ.១៤–១៥ ចទ ៨:៣ នហ ៩:១៥ ទដ ៧៨:២៤ ១០៥:៤០ យប ៦:៣១ ជ លប ២២:១
**១៦:៥** ឈ ខ.២២ លវ ២៥:២១
**១៦:៦** ញ នក ៦:៦
**១៦:៧** ដ ខ.១០ នក ២៤:១៦ ២៩:៤៣ ៣៣:១៨,២២ ៤០:៣៤ លវ ៩:៦ ជន ១៦:១៩,៤២ ចទ ៥:២៤ ១ពវ
**១៦:១០** ត ខ.៧ យហ ១១:៤ ថ នក ១៣:២១ ៤០:៣៤–៣៥ ១ពវ ៨:១០ ២រប ៧:១ អក ១០:៤
**១៦:១២** ទ ខ.៧ ធ នក ៦:២ ២០:២
**១៦:១៣** ន ជន ១១:៣១ ទដ ៧៨:២៧–២៨ ១០៥:៤០ ១០៦:១៥ ប ជន ១១:៩
**១៦:១៤** ផ ខ.៣១ ជណ ១១:៧–៩ ចទ ៨:៣,១៦ ទដ ១០៥:៤០ **១៦:១៥** ព ចទ ៨:១៦ ភ ខ.៤ នហ ៩:២០ យហ ៦:៣១ **១៦:១៦** ម ខ.៣២,៣៦

បន្ទាប់ពីពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ (មើល ១២:២,៦,២៩,៣១)។
**១៦:២** *ត្អូញត្អែរ* មើលការពន្យល់ ១៥:២៤ ។
**១៦:៣** *ឆ្នាំងសំឡ* បទគម្ពីរ ជន ១១:៥ រៀបរាប់អំពីមុខម្ហូបបន្ថែមទៀត ។
**១៦:៤** *ជានំបុ័ងពីលើមេឃ* ព្រះគ្រីស្ទមានបន្ទូលថា ទ្រង់ជានំបុ័ងដ៏ពិត មកពីស្ថានសួគ៌ (យហ ៦:៣២) "នំបុ័ងនៃព្រះ" (យហ ៦:៣៣) "នំបុ័ងជីវិត" (យហ ៦:៣៥,៤៨) "នំបុ័ងដ៏រស់ដែលមកពីស្ថានសួគ៌" (យហ ៦:៥១) ដែលសុទ្ធតែមានន័យខាងឯវិញ្ញាណ (យហ ៦:៦៣)។ មានការប្រើពាក្យស្រដៀងគ្នាក្នុង ចទ ៨:៣ និងការដកស្រង់របស់ព្រះយេស៊ូវក្នុង មថ ៤:៤ ។ *ចេញទៅរើសឱ្យល្មមតែ១ថ្ងៃរាល់ៗថ្ងៃ* គេជឿថា សេចក្ដីអធិស្ឋានរបស់ព្រះអម្ចាស់មានមូលដ្ឋាននៅក្នុងខនេះ (មថ ៦:១១ លក ១១:៣)។ *ល្បង* មើលការពន្យល់ ១៥:២៥ លប ២២:១ ។
**១៦:៥** *ថ្ងៃទី៦ . . . ១ជា២ យកទៅរៀបចំទុក* ដើម្បីទុកប្រើប្រាស់នៅ "ថ្ងៃទី៧ ជាថ្ងៃឈប់សម្រាក" (ខ.២៦) និង "ថ្ងៃសម្រាក" (ខ.២៣)។ មើល ខ.២៩។
**១៦:៦** *ដឹង* មើលការពន្យល់ ៦:៣ ។
**១៦:៨** *ល្ងាចនេះ . . . សាច់ . . . ព្រឹក . . . នំបុ័ង* មើល ខ.១៣–១៤ ។
**១៦:១០** *សិរីល្អនៃព្រះយេហូវ៉ាលេចមកក្នុងពពក* មើល ២៤:១៥–១៧ ។ មើលការពន្យល់ ១៣:២១ ៤០:៣៤ ទដ ២៦:៨ ។
**១៦:១២** *នៅល្ងាចនេះ* មើលការពន្យល់ ១២:៦ ។
**១៦:១៣** *សត្វក្រួចហើរមក* ចំពោះហេតុការស្រដៀងគ្នា សូមមើល ជន ១១:៣១–៣៣ ។
**១៦:១៤** *គ្រាប់ល្អិតៗ . . . សស្កុសនៅលើដី* មើលការពន្យល់ ខ.៣១ ។
**១៦:១៥** *នេះជាអ្វីហ្ន៎* មើល ខ.៣១ ។

១៨តែកាលគេយកខ្ញឹងមកវាស់ នោះអ្នកដែលរើសបាន
ច្រើនក៏គ្មានលើសទេ ហើយអ្នកណាដែលរើសយកបានតិច
ក៏មិនខ្វះដែរ[យ] គ្រប់គ្នាមានល្មមតែបរិភោគឆ្អែតប៉ុណ្ណោះ
១៩រួចម៉ូសេប្រាប់ថា កុំឱ្យអ្នកណាទុកឱ្យសល់ដល់ព្រឹកឡើយ[រ]
២០តែគេមិនបានស្តាប់តាមទេ ក៏មានអ្នកខ្លះបានទុកនំនោះ
ដល់ព្រឹក នោះក៏មានដង្កូវមានក្លិនស្អុយ[ល] ម៉ូសេក៏ខឹង[វ]នឹងគេ
២១គេក៏តែងតែរើសរាល់តែព្រឹកឱ្យល្មមបរិភោគឆ្អែត គ្រប់
ៗគ្នា លុះដល់ថ្ងៃក្តៅ នំនោះក៏រលាយទៅ ។
២២លុះដល់ថ្ងៃទី៦ គេក៏រើសនំនោះបានចំនួន២ភាគ[ស]គឺ
២ខ្ញឹងគ្រប់គ្នា រួចអស់ទាំងមេលើពួកជំនុំ[ហ]ក៏មកប្តឹងដល់
ម៉ូសេ ២៣តែលោកឆ្លើយថា នោះគឺជាសេចក្តីដែលព្រះយេ
ហូវ៉ាទ្រង់បង្គាប់មកទេ ដ្បិតថ្ងៃស្អែកជាថ្ងៃសំរាក គឺជាថ្ងៃ
ឈប់សំរាកបរិសុទ្ធ[ឡ]ថ្វាយព្រះយេហូវ៉ា អាហារណាដែល
ត្រូវដុត នោះឱ្យដុតចុះ ហើយអាហារណាដែលត្រូវស្ងោរ
ក៏ឱ្យស្ងោរទៅ ឯអាហារដែលសល់ នោះត្រូវទុកដល់ព្រឹក
ឡើងសំរាប់អ្នករាល់គ្នា ២៤គេក៏ទុកដល់ព្រឹកតាមបង្គាប់
ម៉ូសេ តែនំនោះឥតមានធុំក្លិនស្អុយអ្វីទេ ដង្កូវក៏មិនបានកើត
ដែរ ២៥រួចម៉ូសេប្រាប់ថា ត្រូវបរិភោគសំណល់នោះនៅថ្ងៃ
នេះ ដ្បិតជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ា ថ្ងៃនេះអ្នក
រាល់គ្នានឹងរកនៅឯវាលទៀតគ្មានទេ ២៦អ្នករាល់គ្នានឹង
រើសនំនេះបានតែក្នុងរវាង៦ថ្ងៃ លុះដល់ថ្ងៃទី៧ នោះគ្មាន
ទេ ព្រោះជាថ្ងៃឈប់សំរាក[អ] ។
២៧នៅថ្ងៃទី៧ ក៏មានអ្នកខ្លះចេញទៅរើសនំនោះដែរ
តែរកគ្មានសោះ ២៨នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹង
ម៉ូសេថា តើឯងរាល់គ្នាមិនព្រមធ្វើតាមបញ្ញត្តិ ហើយនិង
ច្បាប់អញ[ក]ដល់កាលណាទៀត ២៩មើល ដោយព្រោះព្រះ
យេហូវ៉ាបានប្រទានឱ្យមានថ្ងៃឈប់សំរាក នោះបានជាក្នុង
ថ្ងៃទី៦ ទ្រង់ក៏ប្រទាននំឱ្យល្មមគ្រាន់ដល់២ថ្ងៃ ដូច្នេះចូរ
ឱ្យឯងរាល់គ្នានៅតែកន្លែងឯងចុះ កុំឱ្យអ្នកណាចេញទៅ
ក្រៅនៅថ្ងៃទី៧ឡើយ ៣០ហេតុនោះបណ្តាជនគ្រប់គ្នាក៏
សំរាកនៅថ្ងៃទី៧នោះ ៣១ពួកវង្សអ៊ីស្រាអែលក៏ហៅនំនោះ
ថា "ម៉ាន៉ា"[ខ] នំនោះ មើលទៅមានសណ្ឋានដូចជាគ្រាប់ល្ង
សម្បុរស ហើយមានរសជាតិដូចនំដែលធ្វើពីទឹកឃ្មុំ ។
៣២ម៉ូសេក៏ប្រាប់ថា នេះជាសេចក្តីដែលព្រះយេហូវ៉ា
ទ្រង់បង្គាប់មក គឺឱ្យយកនំនេះដាក់ពេញ១ខ្ញឹង[គ] ទុកសំរាប់
កូនចៅឯងរាល់គ្នាតទៅមុខ ដើម្បីឱ្យគេបានឃើញនំដែល
អញបានឱ្យឯងបរិភោគនៅទីរហោស្ថាន ក្នុងកាលដែល
អញបាននាំឯងចេញពីស្រុកអេស៊ីព្ទមកផង ៣៣នោះម៉ូសេក៏
ប្រាប់ទៅអើរ៉ុនថា ចូរយកផើង១មកដាក់នំម៉ាន៉ា១ខ្ញឹង រួច
យកទៅដាក់នៅចំពោះព្រះយេហូវ៉ាទៅ ដើម្បីទុកដរាបដ៏
អស់ទាំងដំណនៃអ្នករាល់គ្នាតទៅ ៣៤នោះអើរ៉ុនក៏យកនំ
ម៉ាន៉ាទៅទុកនៅមុខសេចក្តីបន្ទាល់[ឃ] តាមព្រះបន្ទូលនៃ
ព្រះយេហូវ៉ាដែលទ្រង់បានបង្គាប់ដល់ម៉ូសេ ៣៥ពួកកូនចៅ
អ៊ីស្រាអែល បានបរិភោគនំម៉ាន៉ានោះ[ង] អស់រវាង៤០ឆ្នាំ[ច]
ទាល់តែបានទៅដល់ស្រុក១ដែលមានមនុស្សនៅ គឺបាន
បរិភោគនំម៉ាន៉ាដរាបទៅដល់ព្រំដែនស្រុកកាណាន[ឆ] ៣៦ឯ

**១៦:១៨** យ ២កថ ៨:១៥
**១៦:១៩** រ ខ.២៣ នក ១២:១០
**១៦:២០** ល ខ.២៤ វ នក ៣២:១៩
**១៦:២២** ស ខ.៥ ហ នក ៣៤:៣១
**១៦:២៣** ឡ លប ២:៣ នក ២០:៨ ចទ ៥:១៣–១៤
**១៦:២៦** អ ខ.២៣
**១៦:២៨** ក យស ៩:១៤ ទដ ៧៨:១០ ១០៦:១៣ ១០៧:១១ ១១៩:១ យរ ៣២:២៣
**១៦:៣១** ខ ខ.១៤
**១៦:៣៣** គ ហព ៩:៤ វវ ២:១៧
**១៦:៣៤** ឃ នក ២៥:១៦,២១,២២ ២៧:២១ ៣១:១៨ ៤០:២០ លវ ១៦:១៣ ជន ១:៥០ ៧:៨៩ ១០:១១ ១៧:៤,១០ ចទ ១០:២ ១ពវ ៨:៩ ២របា ៥:១០
**១៦:៣៥** ង យហ ៦:៣១,៤៩ ច ជន ១៤:៣៣ ៣៣:៣៨ ចទ ១:៣ ២:៧ ៨:២–៤ យស ៥:៦ ពច ៣:១១ នហ ៩:២១ ទដ ៩៥:១០ អម ៥:២៥ ឆ យស ៥:១២

**១៦:១៨** លោកប៉ុលបានដកស្រង់ពីខនេះ ដើម្បីបង្រៀននៅក្នុង ២កថ ៨:១៥ អំពីការដែលគ្រីស្ទបរិស័ទត្រូវចេះចែកចាយគ្នានូវអ្វីដែលខ្លួនមាន ។
**១៦:២៣** *ថ្ងៃឈប់សំរាក* ពាក្យនេះបានប្រើជាលើកដំបូងក្នុងខនេះ ហើយមានទំនាក់ទំនងនឹងថ្ងៃទី៧ ជាថ្ងៃឈប់សម្រាក និងបរិសុទ្ធដែលព្រះទ្រង់មានបន្ទាប់ពីថ្ងៃបង្កើតលោកិយ(មើល លប ២:៣)។
**១៦:២៩** មើលការពន្យល់ ខ.៥ ។
**១៦:៣១** *នំម៉ាន៉ា* តាមសេចក្តីពន្យល់ជាទូទៅ នំម៉ាន៉ា ជាការប្រទានរបស់ព្រះតាមផែនការទ្រង់ ដើម្បីឱ្យពួកគេទទួលនៅវាលរហោស្ថាន ។ (១).តាមអត្ថន័យនៃពាក្យ"ម៉ាន៉ា"ជាភាសាហេព្រើរ ពួកអ៊ីស្រាអែលមិនដែលធ្លាប់ស្គាល់នំនោះពីមុនមកទេ(ម៉ាន៉ាមានន័យថា នេះជាអ្វីហ្នុ៎?)។ (២).តាមរូបរាងនិងរសជាតិនៃនំម៉ាន៉ា អ្នកដែលមិនបាននៅក្នុងចំណោម ពួកគេក៏មិនដែលបានបរិភោគដែរ ។ (៣).ការដែលនំម៉ាន៉ាធ្លាក់ចុះយ៉ាងសន្សឹកសន្សាប់តែមិនមានជារៀងរាល់ថ្ងៃ(ជាទ្វេឡើងនៅថ្ងៃទី៦ ហើយមិនមាននៅថ្ងៃទី៧ ខ.២២,២៧) គឺមិនអាចបកស្រាយតាមបាតុភូតធម្មជាតិ ។ (៤).បរិមាណដែលនំម៉ាន៉ាធ្លាក់មកលើសពីតម្រូវការ នៅកន្លែងដែលពួកគេស្នាក់នៅក្នុងវាលរហោស្ថាន(ខ.៣៥)មានន័យថា មិនមែនជានំដែលកើតតាមធម្មជាតិឡើយ ។ (៥).ការរក្សាទុកនំម៉ាន៉ានោះក្នុងផើង១ សម្រាប់អស់ទាំងដំណតទៅ មានន័យថា ជានំដែលខុសពីនំប្រភេទផ្សេងទៀត(សូមមើល ខ.៣៣ –៣៤)។
**១៦:៣៣** *ផើង* ពាក្យនេះបានប្រាប់ក្នុងគម្ពីរ ហព ៩:៤ ថាផើងនោះគឺគេបានធ្វើឡើងពីពីមាស ។
**១៦:៣៤** *សេចក្តីបន្ទាល់* ពាក្យនេះបានបង្ហើបប្រាប់ជាមុនអំពីការពិពណ៌នានៅក្នុងបទគម្ពីរក្រោយទៀត អំពីបន្ទះថ្មពីរផ្ទាំងដែលមានចារក្រឹត្យវិន័យទាំងដប់ប្រការ ហៅថា "បន្ទះថ្មនៃសេចក្តីបន្ទាល់ទាំងពីរផ្ទាំង"(មើល ៣១:១៨ ៣២:១៥ ៣៤:២៩) ហើយបាននាំឱ្យមានឈ្មោះ"ហឹបនៃទីបន្ទាល់"(សូមមើល ២៥:២២ ២៦:៣៣) ដែលបានផ្ទុកបន្ទះថ្មទាំងពីរផ្ទាំងនោះ នៅខាងក្នុង(២៥:១៦,២១) ជាមួយនឹងផើងនំម៉ាន៉ា(ហព ៩:៤ វវ ២:១៧ និងការពន្យល់) ។
**១៦:៣៥** *បរិភោគនំម៉ាន៉ានោះអស់រវាង៤០ឆ្នាំ . . . ដរាបទៅដល់ព្រំដែនស្រុកកាណាន* នំម៉ាន៉ាក៏ឈប់លែងមានតទៅទៀត គឺក្នុងខណៈដែលសាសន៍អ៊ីស្រាអែល បានធ្វើពិធីថ្ងៃបុណ្យរំលងជាលើកទីមួយ នៅក្នុងទឹកដីកាណាន(សូមមើល យស ៥:១០–១២)។

ខ្ទឹងនោះ[ជ] គឺ១ថាំងមាន១០ខ្ទឹង[ឈ] ។

**១៧** ១ឯពួកជំនុំកូនចៅអ៊ីស្រាអែលទាំងអស់ក៏ចេញពីទី
រហោស្ថានស៊ីន[ក] ធ្វើដំណើរទៅតាមបង្គាប់ព្រះយេហូវ៉ា ក៏
ដំឡើងត្រសាលនៅត្រង់រេផិឌីម[ខ] នៅទីនោះគ្មានទឹក[គ]ឱ្យគេ
ផឹកសោះ ២បានជាគេរករឿងឈ្លោះនឹងម៉ូសេ ដោយពាក្យ
ថា ចូរឱ្យទឹក[ឃ]មកយើងរាល់គ្នាផឹកផង[ង] ម៉ូសេឆ្លើយតបថា
ហេតុអ្វីបានជាអ្នករាល់គ្នារករឿងនឹងខ្ញុំ អ្នករាល់គ្នាចង់
ល្បងលព្រះយេហូវ៉ាធ្វើអី[ច] ៣នៅទីនោះបណ្ដាជនក៏ស្រេក
ទឹក[ឆ]ជាខ្លាំង ហើយគេត្អូញត្អែរ[ជ]ដាក់ម៉ូសេថា ហេតុអ្វីបាន
ជាលោកនាំពួកយើងរាល់គ្នាចេញពីស្រុកអេស៊ីព្ទមក ដើម្បី
សំឡាប់[ឈ]យើង ព្រមទាំងកូនចៅ និងហ្វូងសត្វយើងផង
ដោយស្រេកទឹកដូច្នេះ ៤នោះម៉ូសេក៏ស្រែកអំពាវនាវដល់
ព្រះយេហូវ៉ាថា តើឱ្យទូលបង្គំធ្វើដូចម្ដេចនឹងពួកនេះ គេ
ចង់ចោល[ញ]ទូលបង្គំនឹងថ្មហើយ ៥ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលនឹងម៉ូសេថា ចូរឯងដើរទៅខាងមុខគេ ទាំងនាំពួក
ចាស់ទុំសាសន៍អ៊ីស្រាអែលទៅជាមួយ ហើយយកដំបង[ដ]
ដែលឯងបានវាយទឹកទន្លេនោះ[ឋ]ជាប់នៅដៃផង ៦មើលអញ
នឹងឈរនៅមុខឯងនៅលើថ្មដាហូរ៉េប[ឌ] ត្រូវឱ្យឯងវាយ[ឍ]ថ្ម
នោះ រួចនឹងមានទឹក[ណ]ចេញមកឱ្យគេផឹកហើយ នោះម៉ូសេ
ក៏ធ្វើដូច្នោះ នៅមុខពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែល
៧លោកឱ្យកន្លែងនោះឈ្មោះថា "ម៉ាសា"[ត] ហើយនិង
"មេរីបា"[ថ]ដោយព្រោះពួកកូនចៅអ៊ីស្រាអែលបានរករឿង
ឈ្លោះ ព្រមទាំងល្បងលព្រះយេហូវ៉ាមើលផង ដោយថា
តើព្រះយេហូវ៉ាទ្រង់នៅកណ្ដាលពួកយើងរាល់គ្នាមែនឬ ។

### សាសន៍អាម៉ាលេកត្រូវបរាជ័យ

៨នោះសាសន៍អាម៉ាលេក[ទ]ក៏មក ច្បាំងនឹងពួកអ៊ីស្រាអែល
នៅត្រង់រេផិឌីម[ធ] ៩ហើយម៉ូសេបង្គាប់ដល់យ៉ូស្វេ[ន]ថា ចូរ
ឯងទៅកេណ្ឌរើសមនុស្សមក ហើយចេញទៅតទល់ជាមួយ
នឹងសាសន៍អាម៉ាលេកទៅ ថ្ងៃស្អែកនេះអញនឹងកាន់ដំបង[ប]
ព្រះ ទៅឈរនៅលើកំពូលភ្នំ ១០យ៉ូស្វេក៏ធ្វើដូចជាម៉ូសេបាន
បង្គាប់ លោកទៅច្បាំងនឹងសាសន៍អាម៉ាលេក ឯម៉ូសេ
អើរ៉ុន និងហើរ[ផ] ក៏ឡើងទៅលើកំពូលភ្នំ ១១បើកាលណា
ម៉ូសេលើកដៃឡើងទៅលើ នោះខាងសាសន៍អ៊ីស្រាអែល
មានកំឡាំងជាង[ព] តែបើកាលណាម៉ូសេដាក់ដៃសំរាកចុះ
នោះខាងសាសន៍អាម៉ាលេកមានកំឡាំងជាងវិញ ១២តែ
ម៉ូសេទៅជារួយណាស់ បានជាគេយកថ្មមកដាក់ឱ្យលោក
អង្គុយចុះ រួចអើរ៉ុននិងហើរក៏ឈរទ្រដៃលោកទាំងសង
ខាង ដូច្នេះដៃលោកបាននៅនឹងដដែលដរាបដល់ថ្ងៃលិច[ភ]
១៣យ៉ូស្វេក៏បានឈ្នះអាម៉ាលេក[ម] ព្រមទាំងពលទ័ពគេដោយ
មុខដាវ ១៤រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរ

**១៦:៣៦** ជ ខ.១៦ ឈ លវ ៥:១១ ៦:២០ ជណ ៥:១៥ ១៥:៤ ២៨:៥ **១៧:១** ក នក ១៦:១ ខ ខ.៨ នក ១៩:២ ជន ៣៣:១៥ គ ជន ២០:៥ ២១:៥ ៣៣:១៤ **១៧:២** ឃ ជន ២០:២ ៣៣:១៤ ទដ ១០៧:៥ ង នក ១៤:១២ ច ចទ ៦:១៦ ទដ ៧៨:១៨,៤១ ១០៦:១៤ មថ ៤:៧ ១កថ ១០:៩ **១៧:៣** ឆ នក ១៥:២២ ជ នក ១៥:២៤ ឈ នក ១៤:១១ **១៧:៤** ញ ជន ១៤:១០ ១សយ ៣០:៦ យហ ៨:៥៩ **១៧:៥** ដ នក ៤:២ ១០:១២–១៣ ឋ នក ៧:២០ **១៧:៦** ឌ នក ៣:១ ឍ នក ២០:៨ ណ ជន ២០:១១ ចទ ៨:១៥ ពច ១៥:១៩ ២ពវ ៣:២០ នហ ៩:១៥ ទដ ៧៤:១៥ ៧៨:១៥–១៦ ១០៥:៤១ ១០៨:៣៥ ១១៤:៨ អស ៣០:២៥ ៣៥:៦ ៤៣:១៩ ៤៨:២១ ១កថ ១០:៤ **១៧:៧** ត ចទ ៦:១៦ ៩:២២ ៣៣:៨ ទដ ៩៥:៨ ថ ជន ២០:១៣,២៤ ២៧:១៤ ទដ ៨១:៧ ១០៦:៣២ **១៧:៨** ទ លប ៣៦:១២ ធ ខ.១ **១៧:៩** ន នក ២៤:១៣ ៣២:១៧ ៣៣:១១ ជន ១១:២៨ ២៧:២២ ចទ ១:៣៨ យស ១:១ កថ ៧:៤៥ ប នក ៤:១៧ **១៧:១០** ផ ខ.១០–១២ នក **១៧:១១** ព យស ៥:១៦ **១៧:១២** ភ យស ៨:២៦ **១៧:១៣** ម ខ.៨

**១៧:១** *ធ្វើដំណើរទៅតាមបង្គាប់ព្រះយេហូវ៉ា* ចំពោះទីកន្លែងជាក់លាក់សូមមើល ជន ៣៣:១២–១៤ ។ *រេផិឌីម* គឺនៅក្បែរ តំបន់យេបែលមូសា (មើលការពន្យល់ ៣:១) នៅតំបន់ខាងត្បូងនៃវាលរហោស្ថានស៊ីណាយ ។

**១៧:២** *ល្បងលព្រះយេហូវ៉ា* ពួកអ៊ីស្រាអែលមិនបានឆ្លងកាត់ការល្បងលដោយជោគជ័យ(មើល ១៦:៤) ដោយសារពួកគេល្បងលទ្រង់វិញ ។

**១៧:៣** *ត្អូញត្អែរ* មើលការពន្យល់ ១៥:២៤ ។

**១៧:៤** *ពួកនេះ* ព្រះគម្ពីរហោរាបានប្រើពាក្យនេះជាញឹកញាប់(៣២:៧,៩–១១ ៣៣:១៣) ដើម្បីបញ្ជាក់ពីទំនាក់ទំនងឃ្លាតឆ្ងាយ(មើល អស ៦:៩–១០ និងការពន្យល់ និងមើល ហក ១:២) ។

**១៧:៦** *អញនឹងឈរ . . . លើថ្មដាហូរ៉េប* លោកប៉ុលអាចផ្អែកលើខនេះ ក្នុងការបង្រៀនថា "ព្រះគ្រីស្ទថាជាថ្មដាខាងឯវិញ្ញាណ ដែលតាមពួកអ៊ីស្រា–អែល" (មើល ១កថ ១០:៤ និងការពន្យល់ និងមើល ហព ១១:២៤–២៦)។ *ហូរ៉េប* មើលការពន្យល់ ៣:១ ។ *វាយថ្មនោះរួចនឹងមានទឹកចេញ* នៅសម័យក្រោយៗ មានអ្នកនិពន្ធ និងពួកហោរាធ្វើបទនិពន្ធ អំពីការនេះ (មើល ទដ ៧៨:១៥–១៦,២០ ១០៥:៤១ ១១៤:៨ អស ៤៨:២១)។

**១៧:៧** *ម៉ាសានិងមេរីបា* តាម ហព ៣:៧–៨,១៥ (ដកស្រង់ពី ទដ ៩៥:៧–៨)ពាក្យម៉ាសា មានន័យថា "ល្បងល" ហើយមេរីបា "ប្រឆាំងបះបោរ"។ បទគម្ពីរដែលនិយាយសំដៅទៅលើមេរីបា មានដូចជា ជន ២០:១៣,២៤ ២៧:១៤ ចទ ៣២:៥១ ៣៣:៨ ទដ ៨១:៧ ១០៦:៣២ អគ ៤៧:១៩ ៤៨:២៨ ។

**១៧:៨** *សាសន៍អាម៉ាលេក* មើលការពន្យល់ លប ១៤:៧ ។

**១៧:៩** *យ៉ូស្វេ* ជាឈ្មោះដែលលោកម៉ូសេដាក់ឱ្យលោកហូសេ ដែលជាកូនប្រុសរបស់លោកនុន(មើល ជន ១៣:១៦)។ ពាក្យ "ហូសេ" មានន័យថា "សេចក្ដីសង្គ្រោះ" ហើយ"យ៉ូស្វេ"មានន័យថា"ព្រះអម្ចាស់ទ្រង់សង្គ្រោះ"។ នៅក្នុងភាសាក្រិក ពាក្យ"យ៉ូស្វេ" និងពាក្យ "យេស៊ូវ" គឺមានការសរសេរដូចគ្នា ចំពោះអត្ថន័យ មើលការពន្យល់ មថ ១:២១ ។ លោកយ៉ូស្វេមានអំបូរអេប្រាអិម(ជន ១៣:៨) គឺក្នុងចំណោមពូជអំបូរដែលខ្លាំងៗបំផុតនៃពូជអំបូរទាំង១២(មើលការពន្យល់ លប ៤៨:៦,១៩)។ *ច្បាំងជាមួយសាសន៍អាម៉ាលេក* ជំនាញខាងធ្វើសង្គ្រាមបាននាំឱ្យលោកយ៉ូស្វេអាចដឹកនាំទ័ពចូលវាយកាន់កាប់ស្រុកកាណានបាន នៅ៤០ឆ្នាំក្រោយមកទៀត(មើលបន្ថែមក្នុង ២៤:១៣ ៣៣:១១ ចទ ១:៣៨ ៣:២៨ ៣១:១៤ ៣៤:៩ យស ១:៥)

**១៧:១០** *ហើរ* គឺជាកូនប្រុសលោកកាលែប និងជីតានៃលោកបេតសាលាស (សូមមើល ១រប ២:១៩–២០) ដែលជាអ្នកមានចំណែកនៅ ក្នុងការសង់ត្រសាល(សូមមើល ៣១:២–៥) ។

**១៧:១១** *លើកដៃឡើងទៅលើ* (មើលការពន្យល់ ៩:២៩) ។

កត់[យ]រឿងនេះចុះក្នុងសៀវភៅទុកជាសេចក្តីរំឭក ហើយ
និទានប្រាប់ឱ្យយ៉ូស្វេស្តាប់ ដ្បិតអញនឹងលុប[រ]ឈ្មោះអាម៉ា
លេក[ល] ចេញពីក្រោមមេឃនេះ ឱ្យអស់រលីង មិនឱ្យនឹក
ឃើញទៀតសោះឡើយ ១៥គ្រានោះម៉ូសេក៏ស្អាងអាសនា[វ]
១ដាក់ឈ្មោះ[ស]ថា "យេហូវ៉ា-នីស៊ី" ១៦ដោយថា ព្រះយេ
ហូវ៉ា ដែលគង់លើបល្ល័ង្ក ទ្រង់បានលើកព្រះហស្តស្បថថា
ទ្រង់នឹងច្បាំងនឹងសាសន៍អាម៉ាលេក[ហ] គ្រប់ទាំងដំណតរៀង
ទៅ[ឡ] ។

## លោកយេត្រូ

**១៨** ១រីឯយេត្រូ[ក] ជាសង្ឃនៅស្រុកម៉ាឌាន[ខ] ដែលជាឪពុក
ក្មេកម៉ូសេ កាលបានឮពីអស់ទាំងការដែលព្រះយេហូវ៉ាបាន
ប្រោសដល់ម៉ូសេ និងពួកអ៊ីស្រាអែលជារាស្ត្រទ្រង់ ដោយ
ទ្រង់បាននាំគេចេញពីស្រុកអេស៊ីព្ទមក[គ] ២នោះលោកក៏នាំ
នាងសេផូរ៉ាជាប្រពន្ធម៉ូសេ[ឃ] ដែលបានឱ្យត្រឡប់ទៅផ្ទះវិញ
ទៅជាមួយ ៣ព្រមទាំងកូនរបស់នាងទាំង២ដែរ[ង] គឺ១ឈ្មោះ
គើសំម ដ្បិតម៉ូសេនឹកថា អញនៅប្រទេសក្រៅ[ច] ៤ហើយ១
ទៀតឈ្មោះអេលាសើរ[ឆ] ដ្បិតលោកថា ព្រះនៃឪពុក
អញទ្រង់បានជួយអញ[ជ] ក៏បានដោះអញឱ្យរួចពីដាវរបស់
ផារ៉ោនផង ៥យេត្រូ ឪពុកក្មេកម៉ូសេនិងកូនទាំង២ ព្រម
ទាំងប្រពន្ធម៉ូសេ ក៏នាំគ្នាមកឯលោកនៅទីរហោស្ថាន ត្រង់
កន្លែងដែលដំឡើងត្រសាលនៅ[ឈ]ជើងភ្នំនៃព្រះ ៦យេត្រូ
ក៏ផ្តាំទៅម៉ូសេថា អញ យេត្រូជាឪពុកក្មេកឯងបានមកដល់
ហើយ បាននាំទាំងប្រពន្ធនិងកូនឯងទាំង២មកជាមួយផង
៧ដូច្នេះ ម៉ូសេក៏ចេញទៅទទួលឪពុកក្មេក ក៏ក្រាបសំពះ[ញ]
ហើយថើប[ដ]លោក រួចលោកសាកសួរគ្នាទៅវិញទៅមកពី
សេចក្តីសុខទុក្ខ ហើយនាំគ្នាចូលទៅក្នុងត្រសាល ៨ឯម៉ូសេ
លោកចាប់តាំងរ៉ាយរឿងប្រាប់ឪពុកក្មេក ពីអស់ទាំងការ
ដែលព្រះយេហូវ៉ាទ្រង់បានធ្វើដល់ផារ៉ោន និងសាសន៍
អេស៊ីព្ទ ដោយទ្រង់យល់ដល់ពួកអ៊ីស្រាអែល និងពីសេចក្តី
ទុក្ខលំបាកទាំងប៉ុន្មាន[ឋ] ដែលកើតមានតាមផ្លូវ ហើយដែល
ព្រះយេហូវ៉ាទ្រង់បានជួយ[ឌ]ឱ្យរួចទាំងអស់ ៩យេត្រូក៏មាន
សេចក្តីអំណរ ដោយអស់ទាំងសេចក្តីល្អ[ឍ] ដែលព្រះយេហូវ៉ា
បានប្រោសដល់ពួកអ៊ីស្រាអែល ដោយទ្រង់បានជួយឱ្យគេ
រួចពីកណ្តាប់ដៃនៃពួកសាសន៍អេស៊ីព្ទ ១០ក៏ពោលថា សូម
ឱ្យព្រះយេហូវ៉ា[ណ] បានប្រកបដោយព្រះពរ ជាព្រះដែល
ទ្រង់បានជួយឯងឱ្យរួចពីកណ្តាប់ដៃនៃពួកសាសន៍អេស៊ីព្ទ
និងកណ្តាប់ដៃនៃផារ៉ោន ព្រមទាំងបណ្តាជន ឱ្យរួចពី
ក្រោមអំណាចសាសន៍អេស៊ីព្ទផង ១១ឥឡូវនេះ អញដឹងថា
ព្រះយេហូវ៉ាទ្រង់ធំលើសអស់ទាំងព្រះ[ត] ដ្បិតទ្រង់បានឈ្នះ
ក្នុងអំពើដែលគេបានប្រព្រឹត្ត ដោយព្រហើនចំពោះឯង
រាល់គ្នា[ថ] ១២រួចយេត្រូជាឪពុកក្មេកម៉ូសេ[ទ] លោកយកដង្វៃ
ដុត[ធ]និងយញ្ញបូជា[ន]ទៅថ្វាយដល់ព្រះ ហើយអើរ៉ុននិងពួក
ចាស់ទុំសាសន៍អ៊ីស្រាអែល ក៏មកបរិភោគភោជនាហារ[ប]
ជាមួយនឹងឪពុកក្មេករបស់ម៉ូសេនៅចំពោះ[ផ]ព្រះដែរ ។
១៣ដល់ថ្ងៃស្អែកឡើង ម៉ូសេអង្គុយជំនុំជំរះរឿងឱ្យបណ្តា
ជនទាំងឡាយ ឯបណ្តាជនទាំងអស់ក៏ឈរនៅមុខលោក
តាំងពីព្រឹករហូតដល់ល្ងាច ១៤កាលឪពុកក្មេកម៉ូសេ បាន

**១៧:១៤** យ នក ២៤:៤ ៣៤:២៧ ជន ៣៣:២ ចទ ៣១:៩ យប ១៩:២៣ អស ៣០:៨ យរ ៣៦:២ ៤៥:១ ៥១:៦០ រ នក ៣២:៣៣ ចទ ២៩:២០ យប ១៨:១៧ ទដ ៩:៥ ៣៤:១៦ ១០៩:១៥ អក ១៨:៤ ល ខ.១៣ លប ៣៦:១២ ជន ២៤:៧ ពច ៣:១៣ ១សយ ៣០:១៧-១៨ ទដ ៨៣:៧ **១៧:១៥** វ លប លប ៨:២០ ស លប ២២:១៤ **១៧:១៦** ហ ជន ២៤:៧ ១សយ ១៥:៨,៣២ ១របា ៤:៤៣ នអ?៣:១ ៨:៣ ៩:២៤ ឡ នអ ៩:៥ **១៨:១** ក នក ២:១៨ ខ នក ២:១៦ គ នក ៦:៦ **១៨:២** ឃ នក ២:២១ **១៨:៣** ង នក ៤:២០ កច ៧:២៩ ច នក ២:២២ **១៨:៤** ឆ ១រប ២៣:១៥ ជ លប ៤៩:២៥ ចទ ៣៣:២៩ **១៨:៥** ឈ នក ៣:១ **១៨:៧** ញ លប ១៧:៣ ៤៣:២៨ ដ លប ២៩:១៣ **១៨:៨** ឋ ជន ២០:១៤ នហ ៩:៣២ ឌ នក ១៥:៦,១៦ ទដ ៨១:៧ **១៨:៩** ឍ យស ២១:៤៥ ១ពវ ៨:៦៦ នហ ៩:២៥ ទដ ១៤៥:៧ អស ៦៣:៧ **១៨:១០** ណ លប ៩:២៦ ២៤:២៧ **១៨:១១** ត នក ១២:១២ ១រប ១៦:២៥ ថ នក នក ១:១០ លក ១:៥១ **១៨:១២** ទ នក ៣:១ ធ នក ១០:២៥ ២០:២៤ លវ ១:២-៩ ន លប ៣១:៥៤ នក ២៤:៥ ប លប ២៦:៣០ ផ ចទ ១២:៧

**១៧:១៤** *កត់* មើល ២៤:៤ ៣៤:២៧-២៨ ជន ៣៣:២ ចទ ២៨:៥៨ ២៩:២០ ២១,២៧ ៣០:១០ ៣១:៩,១៩,២២,២៤ មើលសេចក្តីផ្តើមត្រង់ចំណុច អ្នកនិពន្ធ និងកាលបរិច្ឆេទនៃការសរសេរ ។ *ក្នុងសៀវភៅ* គឺជាបន្ទះស្បែកវែង ឬស្លឹកធ្វើពីដើមបាពីរើស (Papyrus) ដែលអ្នកចម្លងសរសេរ (មើល យរ ៣៦:២៣) ដោយស្លាបប៉ាកាម៉្យាង (មើល អស ៨:១) និងទឹកខ្មៅ (មើល យរ ៣៦:១៨) ជួនកាលសរសេរនៅលើទំព័រទាំងសងខាង (មើល អគ ២:១០ វវ ៥:១) ។ បន្ទាប់ពីមូលក្រាំងនោះហើយ គេបិទត្រាពីលើដើម្បីការពារសំណេរ ខាងក្នុង (មើល អស ២៩:១១ ដយ ១២:៤ វវ ៥:១-២,៥,៩) ។ ក្រាំងមានទំហំខុសៗគ្នា (មើល អស ៨:១ វវ ១០:២,៩-១០) ។ ក្រាំងរបស់ពួកអេស៊ីព្ទ មានប្រវែង ដល់ទៅ ៣០,៤៨ ម៉ែត្រ តែក្រាំងព្រះគម្ពីរកម្រមានប្រវែងលើពី៩,១៤ ម៉ែត្រ (មើល លក ៤:១៧) ដូចក្នុងករណីព្រះគម្ពីរអេសាយជាដើម (លក ៤:១៧) ។ ក្នុងការអានក្រាំងនោះ ដៃម្ខាងមូលសន្លឹកក្រាំងចូល ហើយម្ខាងទៀតមូលចេញវិញ (មើល អស ៣៤:៤ អគ ២:២០ លក ៤:១៧,២០ វវ ៦:១៤) ។

**១៨:១** *យេត្រូ ជាសង្ឃនៅស្រុកម៉ាឌាន* សូមមើលការពន្យល់ ២:១៦ ។

**១៨:២** *នាំនាងសេផូរ៉ាជាប្រពន្ធម៉ូសេ* គេជឿថា លោកម៉ូសេបានបញ្ជូននាងសេផូរ៉ា ទៅឯឪពុករបស់នាង ដោយនាំដំណឹងទៅថា ព្រះយេហូវ៉ាបានប្រទានពរដល់ដំណើរបេសកកម្មរបស់គាត់ (មើល ខ.១) ហើយគាត់កំពុងនៅតំបន់ភ្នំស៊ីណាយជាមួយពួកអ៊ីស្រាអែល ។

**១៨:៥** *ភ្នំនៃព្រះ* មើល ៣:១ និងការពន្យល់ ។

**១៨:១១** *ឥឡូវនេះ អញដឹងថាព្រះយេហូវ៉ាទ្រង់ធំលើសអស់ទាំងព្រះ* មើលការទទួលស្គាល់ស្រដៀងគ្នារបស់លោកណាម៉ាន់ ក្នុង ១ពវ ៥:១៥ ។

**១៨:១២** *យក* មានន័យថា "នាំ" សត្វចូលមកធ្វើយញ្ញបូជា (មើល ២៥:២ វវ ១២:៨) តែមិនមែនធ្វើយញ្ញបូជាទេ ។ *បរិភោគភោជនាហារជាមួយ* គឺជាការចងមិត្តភាព (គឺខុសពីការច្បាំងជាមួយនឹងពួកអាម៉ា-លេក ក្នុង ១៧:៨-១៦) ឬជាការតាំងសញ្ញា (មើល លប ៣១:៥៤ នក ២៤:១១) ។

ឃើញអស់ទាំងការដែលលោកធ្វើ សំរាប់ពួកបណ្តាជន
ដូច្នោះ នោះក៏សួរថា តើឯងធ្វើអ្វីដូច្នេះ ហេតុអ្វីបានជា
អង្គុយតែម្នាក់ឯង ហើយបណ្តាជនគេឈរនៅចំពោះមុខ
ឯង តាំងពីព្រឹកទាល់ល្ងាចយ៉ាងនេះ ១៥ម៉ូសេក៏ឆ្លើយទៅ
ឪពុកក្មេកថា ពីព្រោះគេមកឯខ្ញុំ ដើម្បីទូលសួរដល់ព្រះ[ព]
១៦កាលណាគេមានរឿងអ្វី[ភ] នោះគេតែងមកឯខ្ញុំ ហើយខ្ញុំ
វិនិច្ឆ័យឱ្យគេ ព្រមទាំងប្រាប់ឱ្យគេដឹងអស់ទាំងសេចក្តី
បញ្ញត្តិនិងច្បាប់របស់ព្រះផង[ម] ១៧ឪពុកក្មេកម៉ូសេក៏និយាយ
ថា ដែលឯងធ្វើដូច្នោះនោះវាមិនស្រួលទេ ១៨ដ្បិតយ៉ាង
នោះឯងនឹងថយកំឡាំងទៅ ព្រមទាំងកំឡាំងនៃបណ្តាជន
ដែលនៅជាមួយនឹងឯងផង ពីព្រោះការនេះហួសកំឡាំង
ឯងហើយ និងធ្វើតែម្នាក់ឯងមិនបានទេ[យ] ១៩ឥឡូវនេះ
ចូរស្តាប់សិន អញនិងទូលទូន្មានឯងបន្តិច ក៏សូមឱ្យព្រះគង់
ជាមួយនិងឯងផង[រ] គឺឱ្យឯងបានឈរជាជំនួសបណ្តាជន
ទាំងឡាយនៅចំពោះព្រះ ដើម្បីនឹងនាំរឿងគេទាំងប៉ុន្មាន[ល]
ទៅទូលដល់ទ្រង់ ២០ហើយឯងនិងបង្រៀនអស់ទាំងសេចក្តី
បញ្ញត្តិនឹងច្បាប់ដល់គេ ទាំងបង្ហាញផ្លូវដែលគេត្រូវដើរ[ស]
និងការដែលគេត្រូវធ្វើដែរ[ហ] ២១ត្រូវឱ្យឯងរើសមនុស្សប៉ិន
ប្រសប់[ឡ] ដែលមានចិត្តកោតខ្លាច[អ] ដល់ព្រះក្នុងពួកជន ជា
មនុស្សទៀងត្រង់ដែលស្អប់ការសំណូក[ក] ហើយត្រូវតាំង
មនុស្សទាំងនោះឡើង ឱ្យត្រួតត្រា[ខ] លើជនទាំងឡាយ ឱ្យគេ
ធ្វើជាមេលើមនុស្ស១ពាន់នាក់ ជាមេលើ១រយនាក់ ជាមេ
លើ៥០នាក់ ហើយជាមេលើ១០នាក់ផង ២២ឱ្យអ្នកទាំងនោះ
ជំនុំជំរះពួកជនជាដរាប ឯអស់ទាំងរឿងណាធំៗ[គ] នោះ
ត្រូវឱ្យគេនាំមកដល់ឯង តែបើជារឿងតូចៗទេ ត្រូវឱ្យគេ
កាត់សេចក្តីដោយខ្លួនគេចុះ នោះឯងនឹងបានស្រួលជាង
ឯអ្នកទាំងនោះនឹងបានជាជំនួយ[ឃ]ដល់ឯង ២៣បើឯងព្រម
ធ្វើដូច្នោះ ហើយព្រះទ្រង់ក៏បង្គាប់ផង នោះឯងនឹងនៅស្ថិត
ស្ថេរបាន ហើយបណ្តាជននេះនឹងបានទៅដល់កន្លែងគេ
ដោយសុខសាន្តទាំងអស់គ្នាដែរ ។
២៤ម៉ូសេលោកក៏ស្តាប់តាមឪពុកក្មេក ហើយធ្វើតាមពាក្យ
ដែលលោកថាទាំងប៉ុន្មាន ២៥គឺលោករើសយកមនុស្ស
ដែលប៉ិនប្រសប់ក្នុងពួកអ៊ីស្រាអែលទាំងអស់ តាំងឡើងឱ្យ
ធ្វើជាមេត្រួតត្រា[ង]លើបណ្តាជនទាំងឡាយ ជាមេលើមនុស្ស
១ពាន់នាក់ ជាមេលើ១រយនាក់ ជាមេលើ៥០នាក់ ហើយ
ជាមេលើ១០នាក់ដូច្នោះ[ច] ២៦អ្នកទាំងនោះក៏ជំនុំជំរះ[ឆ]ពួក
ជនជាដរាបទៅ គេនាំអស់ទាំងរឿងរ៉ាវណាដែលពិបាកៗ[ជ]
មកដល់ម៉ូសេ តែអស់ទាំងរឿងរ៉ាវណាដែលតូចៗ នោះ
គេកាត់សេចក្តីដោយខ្លួនគេវិញ[ឈ] ២៧រួចម៉ូសេបញ្ជូនឱ្យឪពុក
ក្មេកទៅ នោះលោកក៏ត្រឡប់ទៅស្រុកវិញ[ញ]។

**១៩** ១ដល់ខែទី៣ក្រោយដែលចេញពីស្រុកអេស៊ីព្ទមក[ក]
នៅថ្ងៃនោះឯង ពួកកូនចៅអ៊ីស្រាអែលក៏ទៅដល់ទីរហោ–
ស្ថានស៊ីណាយ[ខ] ២គេបានចេញពីរេផីឌីម[គ]ទៅដល់ទីរហោ–
ស្ថានស៊ីណាយ ហើយនាំគ្នាដំឡើងត្រសាលនៅទីនោះ គេ
តាំងទីលំនៅ ក្នុងទីរហោស្ថានទល់មុខនឹងភ្នំ[ឃ] ៣ចំណែកឯ
ម៉ូសេ លោកក៏ឡើងទៅឯព្រះ[ង] នោះព្រះយេហូវ៉ាទ្រង់មាន
បន្ទូល[ច]ហៅលោកពីលើភ្នំថា ចូរឯងនិយាយនឹងពួកវង្ស
យ៉ាកុប ហើយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ៤ឯង
រាល់គ្នាបានឃើញអស់ទាំងការដែលអញធ្វើដល់សាសន៍

**១៨:១៥** ព ខ.១៩ លប ២៥:២២ **១៨:១៦** ភ នក ២៤:១៤ ម ខ.១៥ លវ ២៤:១២ ជន ១៥:៣៤ ចទ ១:១៧ ២រប ១៩:៧ សភ ២៤:២៣ មឡ ២:៩ **១៨:១៨** យ ជនក ១១:១១,១៤,១៧ ចទ ១:៩,១២ **១៨:១៩** រ នក ៣:១២ ល ខ.១៥ ជន ២៧:៥ **១៨:២០** វ ចទ ៤:១,៥ ៥:១ ទដ ១១៩:១២,២៦,៦៨ ស ទដ ១៤៣:៨ ហ លប ៣៩:១១ **១៨:២១** ឡ លប ៤៧:៦ កច ៦:៣ អ លប ២២:១២ នក ២៣:៨ ចទ ១៦:១៩ ១សយ ១២:៣ ទដ ១៥:៥ សភ ១៧:២៣ ២៨:៨ ២២:១២ ខ ជន ១:១៦ ៧:២ ១០:៤ ចទ ១៦:១៨ អរ ៧:២៥ **១៨:២២** គ លប ២៤:១១ ចទ ១:១៧–១៨ ឃ ជន ១១:១៧ ចទ ១:៩ **១៨:២៥** ង ជន ១:១៦ ៧:២ ១១:១៦ ចទ ១៦:១៨ ច ចទ ១:១៣–១៥ **១៨:២៦** ឆ ចទ ១៦:១៨ ២រប ១៩:៥ អរ ៧:២៥ ជ ចទ ១:៧១ ឈ ខ.២២ **១៨:២៧** ញ ជន ១០:២៩–៣០ **១៩:១** ក នក ៦:៦ ខ ជន ១:១ ៣:១៤ ៣៣:១៥ **១៩:២** គ នក ១៧:១ ឃ ខ.១៧ នក ៣:១ ចទ ៥:២–៤ **១៩:៣** ង នក ២០:២១ ច នក ៣:៤ ២៥:២២ កច ៧:៣៨

**១៨:១៥** *ទូលសួរដល់ព្រះ* ការស្វែងរកព្រះ គឺត្រូវធ្វើនៅកន្លែងថ្វាយបង្គំ (មើល លប ២៥:២២ និងការពន្យល់ និងមើល ជន ២៧:២១) ឬទៅជួបនឹងពួកហោរា (មើល ១សយ ៩:៩ ១ពវ ២២:៨) ។
**១៨:១៦** *សេចក្តីបញ្ញត្តិនិងច្បាប់របស់ព្រះ* ដំណើរការនៃការចងក្រង និងបង្កើតប្រព័ន្ធក្រឹត្យវិន័យដែលមកពីព្រះ សម្រាប់គ្រប់គ្រងសាសន៍ដែលទើបបង្កើតថ្មី អាចបានចាប់ផ្តើមហើយ (១៥:២៥–២៦ និងពន្យល់ លប ២៦:៥) ។
**១៨:២១** *កោតខ្លាចដល់ព្រះ* មើលការពន្យល់ លប ២០:១១ ។
**១៩:១** ការទៅដល់ទីរហោស្ថានស៊ីណាយ គឺជាមហាព្រឹត្តិការណ៍ នៅក្នុងជីវិតនៃជាតិសាសន៍អ៊ីស្រាអែល ។ បន្ទាប់ពីបានរំដោះដោយព្រះអម្ចាស់ពីចំណងនៃពួកអេស៊ីព្ទ និងទទួលបានការថែរក្សា និងព្រះពរពីព្រះអម្ចាស់ ពួកគេបានត្រៀមខ្លួនតាំងសញ្ញាថ្នាក់ជាតិជាមួយព្រះអម្ចាស់ ។
**១៩:២** *រហោស្ថានស៊ីណាយ* មានទីតាំងនៅភាគអាគ្នេយ៍នៃឧបទ្វីបស៊ីណាយ (មើលការពន្យល់ ៣:១) ។ មានការពិពណ៌នាអំពីព្រឹត្តិការណ៍នៅទីកន្លែងនោះ នៅក្នុងព្រះគម្ពីរនិក្ខមនំ លេវីវិន័យ និងជនគណនា ១:១–១០:១០ ។
**១៩:៣–២៤:១៨** វគ្គនេះនិយាយអំពីសេចក្តីសញ្ញា នៅឯភ្នំស៊ីណាយ ។ ការតាំងសញ្ញានេះ គឺជាប្រភេទនៃការតាំងសញ្ញាចុះចូលនឹងការដឹកនាំ ដែលគេនិយមធ្វើនៅតំបន់មជ្ឈឹមបូព៌ាសម័យបុរាណ នៅសហស្សវត្សរ៍ទី២ មុន គ.ស ។ ក្នុងនេះមានព្រះបន្ទូលសន្យាថា ទ្រង់នឹងផ្តល់ការការពារដល់សាសន៍អ៊ីស្រាអែល បើសាសន៍នេះស្មោះត្រង់ចំពោះទ្រង់ ដែលជាម្ចាស់ពួកគេតាមសេចក្តីសញ្ញា ហើយស្តាប់បង្គាប់តាមសេចក្តីសញ្ញា ក្នុងនាមជារាស្ត្រដែលចំណុះឱ្យនគរទ្រង់ ។ នៅពេលក្រោយៗមកទៀត សេចក្តីសញ្ញានេះបានតាំងឡើងជាថ្មី ដូចមាននៅក្នុង ជំពូក ៣៤ ក្នុងកណ្ឌគម្ពីរចោទិយកថាទាំងមូល និងយ៉ូស្វេជំពូក ២៤ ។ មើលការពន្យល់ យរ ៣១:៣២ ។
**១៩:៣** *ពូជវង្សយ៉ាកុប . . . កូនចៅអ៊ីស្រាអែល* មើលការពន្យល់ ១:១ ។
**១៩:៤** *ទ្រឯងរាល់គ្នាលើស្លាប់ឥន្ទ្រីនាំមកឯអញនេះផង* ការពណ៌នានេះគឺត្រូវនឹងលក្ខណៈឥន្ទ្រីមាសញីផងដែរ ។

អេស៊ីព្ទ[ឆ]ហើយ និងការដែលអញបានទ្រឯងរាល់គ្នាលើ
ស្លាបឥន្ទ្រី[ជ]នាំមកឯអញនេះផង[ឈ] ៥ដូច្នេះបើឯងរាល់គ្នា
នឹងស្តាប់តាមអញឥឡូវ[ញ] ហើយកាន់តាមសេចក្ដីសញ្ញា[ដ]
របស់អញ នោះឯងរាល់គ្នានឹងបានដាច់ជារបស់ផងអញ
លើសជាងអស់ទាំងសាសន៍[ឋ] ដ្បិតផែនដីទាំងមូល[ឌ]ជារបស់
ផងអញ ៦ឯងរាល់គ្នានឹងបានធ្វើជានគរដល់អញ ដែលសុទ្ធ
តែជាសង្ឃ[ឍ] ហើយជាសាសន៍បរិសុទ្ធឱ្យអញដែរ[ណ] គឺពាក្យ
ទាំងនេះហើយ ដែលឯងត្រូវប្រាប់ដល់ពួកកូនចៅអ៊ីស្រា
អែល ។

៧នោះម៉ូសេក៏មកវិញ ហៅប្រជុំពួកចាស់ទុំ[ត]ក្នុងបណ្ដាជន
ប្រាប់គេតាមអស់ទាំងពាក្យដែលព្រះយេហូវ៉ាទ្រង់បង្គាប់
មក[ថ] ៨ឯពួកជនទាំងឡាយ គេឆ្លើយឡើងថា យើងខ្ញុំរាល់គ្នា
នឹងធ្វើតាមគ្រប់សេចក្ដី ដែលព្រះយេហូវ៉ាទ្រង់មានបន្ទូល
មក[ទ] នោះម៉ូសេក៏នាំយកពាក្យរបស់គេទៅទូលដល់ព្រះ
យេហូវ៉ាវិញ ៩ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅម៉ូសេថា
មើល អញមកឯងក្នុងពពកយ៉ាងក្រាស់[ធ] ដើម្បីឱ្យបណ្ដាជន
បានឮ ក្នុងកាលដែលអញនិយាយ[ន]នឹងឯង ហើយឱ្យគេបាន
ទុកចិត្ត[ប]នឹងឯងជាដរាប នោះម៉ូសេក៏ទូលដល់ព្រះយេហូវ៉ា
តាមអស់ទាំងពាក្យនៃពួកជន ។

១០ព្រះយេហូវ៉ាទ្រង់បានមានបន្ទូលនឹងម៉ូសេថា ចូល
ទៅឯពួកជន ដើម្បីនឹងញែក[ផ]គេឱ្យបរិសុទ្ធនៅថ្ងៃនេះ
ហើយថ្ងៃស្អែកផង ត្រូវឱ្យគេបោកខោអាវដែរ[ព] ១១ហើយ
រៀបខ្លួនជាស្រេចឱ្យទាន់ថ្ងៃទី៣[ភ] ដ្បិតនៅថ្ងៃទី៣នោះ

**១៩:៤** ឆ ចទ ២៩:២ យស ២៤:៧ ជ ចទ ៣២:១១ ទដ ១០៣:៥ អស ៤០:៣១ យរ ៤:១៣ ៤៨:៤០ វវ ១២:១៤ ឈ ចទ ៣៣:១២ អស ៣១:៥ អក ១៦:៦ **១៩:៥** ញ នក ១៥:២៦ ចទ ៦:៣ ទដ ៧៨:១០ យរ ៧:២៣ ដ លប ១៧:៩ នក ៣:១ ឋ នក ៨:២២ ៣៤:៩ ចទ ៨:១ ទត ២:១៤ ឌ នក ៩:២៩ ១កថ ១០:២៦ **១៩:៦** ឍ អស ៦១:៦ ៦៦:២១ ១ពត ២:៥ ណ លប ១៨:១៩ លវ ១១:៤៤–៤៥ ចទ ៤:៣៧ ៧:៦ ២៦:១៩ ២៨:៩ ២៩:១៣ ៣៣:៣ អស៤:៣ ៦២:១២ យរ ២:៣ អម ៣:២ **១៩:៧** ត នក១៨:១២ លវ ៤:១៥ ៩:១ ជន ១៦:២៥ ថ នក ៤:៣០ ១សយ

ព្រះយេហូវ៉ា ទ្រង់នឹងយាងចុះមក[ម]លើភ្នំស៊ីណាយ[យ] ឱ្យគេ
ឃើញ ១២ត្រូវឱ្យឯងដាក់កំណត់គោលចារិក[រ]នៅជុំវិញ ឱ្យ
បណ្ដាជនគ្រប់គ្នា ដោយប្រាប់ថា ចូរប្រយ័ត្ន កុំឱ្យឡើងទៅ
លើភ្នំឡើយ កុំឱ្យទាំងជាន់ដល់ជើងភ្នំផង ដ្បិតអ្នកណាដែល
ជាន់ដល់ភ្នំ នោះនឹងត្រូវស្លាប់ជាមិនខាន ១៣នឹងគ្មានដៃអ្នក
ណាពាល់ដល់អ្នកនោះទេ គឺអ្នកនោះនឹងត្រូវចោលនឹងថ្ម[ល]
ឬបាញ់នឹងព្រួញវិញ ទោះសត្វឬមនុស្សក្ដីក៏មិនត្រូវរស់ដែរ
កាលណាផ្លុំស្នែង[វ]ឮសូរវែង នោះត្រូវឱ្យគេចូលមកជិតភ្នំ[ស]
១៤ម៉ូសេក៏ចុះពីលើភ្នំមកឯពួកជនរាល់គ្នាវិញ ញែកគេ
ចេញជាបរិសុទ្ធ ហើយគេក៏បោកខោអាវគ្រប់គ្នា[ហ] ១៥រួច
លោកបង្គាប់គេថា ចូរអ្នករាល់គ្នារៀបខ្លួនជាស្រេចឱ្យ
ទាន់ថ្ងៃទី៣ចុះ កុំឱ្យទៅជិត[ឡ]ស្ត្រីឯណាឱ្យសោះ ។

១៦លុះដល់ព្រឹកឡើងថ្ងៃទី៣ នោះក៏មានឮសូរផ្គរ[អ]មាន
ផ្លេកបន្ទោរ និងពពកយ៉ាងក្រាស់[ក]នៅលើភ្នំ ព្រមទាំងឮសូរ

៨:១០ **១៩:៨** ទ នក ២៤:៣,៧ ចទ ៥:២៧ ២៦:១៧ **១៩:៩** ធ ខ.១៦ នក ២០:២១ ២៤:១៥–១៦ ៣៣:៩ ៣៤:៥ ចទ ៤:១១ ២សយ ២២:១០,១២ ២របា ៦:១ ទដ ១៨:១១ ៩៧:២ ៩៩:៧ មថ ១៧:៥ ន ចទ ៤:១២ ,៣៦ យហ ១២:២៩–៣០ ប នក ៤:៥**១៩:១០** ផ ខ.១៤, ២២ លវ ១១:៤៤ ជន ១១:១៨ ១សយ ១៦:៥ យអ ២:១៦ ហព ១០:២២ ព លប ៣៥:២ វវ ២២:១៤ **១៩:១១** ភ ខ.១៦ ម លប ១១:៥ យ ខ.៣,២០ នក ៣:១ ២៤:១៦ ៣១:១៨ ៣៤:២,៤, ២៩,៣២ លវ ៧:៣៨ ២៦:៤៦ ២៧:៣៤ ជន ៣:១ ចទ ១០:៥ នហ ៩:១៣ កទ ៤:២៤–២៥ **១៩:១២** រ ខ.២៣ **១៩:១៣** ល ហព ១២:២០ វ យស ៦:៤ ១របា ១៥:២៨ ទដ ៨១:៣ ៩៨:៦ ស ខ.២១ នក ៣៤:៣ **១៩:១៤** ហ លប ៣៥:២ **១៩:១៥** ឡ ១សយ ២១:៤ ១កថ ៧:៥ **១៩:១៦** អ ១សយ ២:១០ អស ២៩:៦ ក ខ.៩

**១៩:៥** *ដូច្នេះបើ . . . នោះ* សេចក្ដីសញ្ញារវាងព្រះអម្ចាស់និងរាស្ត្រអ៊ីស្រាអែលនៅភ្នំស៊ីណាយ គឺបានបន្តសេចក្ដីសញ្ញារបស់ទ្រង់ ជាមួយនិងលោកអ័ប្រាហាំ និងកូនចៅរបស់គាត់ តាំងពី៦០០ឆ្នាំមុន ។ ការទទួលព្រះពរពីព្រះ គឺតម្រូវឱ្យមានសេចក្ដីជំនឿ ដែលបង្ហាញចេញដោយការស្ដាប់បង្គាប់(មើលការពន្យល់ លប ១៧:៩)។ *សេចក្ដីសញ្ញារបស់អញ* មើលការពន្យល់ លប ៩:៩ ។ *ដាច់ជារបស់ផងអញលើស ជាងអស់ទាំងសាសន៍ . . . ជារបស់ផងអញ* ដូចជាឃ្លានេះដែលបានប្រើសំដៅទៅលើគ្រីស្ទបរិស័ទក្នុង ១ពត ២:៩ ថា ជា "ពូជជ្រើសតាំង" និង "រាស្ត្រដ៏ជាកេរ្ដិ៍អាករ"(សូមមើល ចទ ៧:៦ ១៤:២ ២៦:១៨ ទដ ១៣៥:៤ មទ្ យ ៣:១៧ ធៀបនឹង ទត ២:១៤)។ *ដ្បិតផែនដីទាំងមូលជារបស់ផងអញ* ព្រះអម្ចាស់ជាព្រះអទិករ និងជាម្ចាស់ផែនដី និងរបស់សព្វសារពើ(លប ១៤:១៩,២២ ទដ ២៤:១–២)។

**១៩:៦** *នគរដល់អញ ដែលសុទ្ធតែជាសង្ឃ* រាស្ត្រអ៊ីស្រាអែលត្រូវរួមគ្នាធ្វើជានគររបស់ព្រះ(គឺរាស្ត្រដែលទទួលទ្រង់ជាព្រះមហាក្សត្ររបស់ខ្លួន) គឺដូចពួកសង្ឃដែលត្រូវបានញែកខ្លួនទាំងស្រុង ជាបរិសុទ្ធដើម្បីបម្រើទ្រង់(មើលការពន្យល់ ១២:២–៣ អស ៤២:១–៤ ៤៩:៦)។ *សាសន៍បរិសុទ្ធ* មើល ១ពត ២:៩ ។ រាស្ត្ររបស់ព្រះគឺត្រូវ"ញែកខ្លួន"(មើលការពន្យល់ ៣:៥) ដើម្បីធ្វើតាមព្រះហឫទ័យទ្រង់(មើល ចទ ៧:៦ ១៤:២,២១ ២៦:១៩ អស ៦២:១២) ដោយបុគ្គល ឬជារួម ។

**១៩:៨** *យើងខ្ញុំរាល់គ្នានឹងធ្វើតាមគ្រប់សេចក្ដី ដែលព្រះយេហូវ៉ាទ្រង់មានបន្ទូលមក* ពួកបណ្ដាជនសន្យានិងស្ដាប់តាម នូវព្រះបន្ទូលក្នុងសេចក្ដីសញ្ញា (មើល ២៤:៣,៧ ចទ ៥:២៧) ។

**១៩:៩** *ពពកយ៉ាងក្រាស់* មើល ១៣:២១ និងការពន្យល់ ។ *បណ្ដាជនបានឮក្នុងកាលដែលអញនិយាយ* មើល ចទ ៤:៣៣ ។ *ទុកចិត្តនិងឯងជាដរាប* មើល ១៤:៣១ និងការពន្យល់ ។

**១៩:១០–១១** ការរៀបចំផ្នែកខាងក្រៅដើម្បីជួបព្រះ គឺជានិមិត្តតំណាងឱ្យការញែកនូវផ្នែកខាងក្នុង ដែលព្រះអម្ចាស់បានតម្រូវពីរាស្ត្រទ្រង់ ។

**១៩:១២–១៣** ទីភ្នំទាំងមូលក៏ប្រែក្លាយជាបរិសុទ្ធ ដោយព្រោះវត្តមានពីព្រះអម្ចាស់(មើល ៣:៥ និងការពន្យល់)។ នៅពេលនោះ រាស្ត្រអ៊ីស្រាអែលត្រូវនៅឱ្យឆ្ងាយពីភ្នំនោះ ព្រមទាំងរោងឧបោសថផងដែរ (មើល ជន ៣:១០)។

**១៩:១៥** *កុំឱ្យទៅជិតស្ត្រីឯណាឱ្យសោះ* មិនមែនមានន័យថា ការរួមដំណេកជាអំពើបាបនោះទេ ប៉ុន្តែ ការនេះនឹងធ្វើឱ្យអ្នកចូលរួមក្នុងព្រឹត្តិការណ៍នោះត្រូវប្រែជាមិនស្អាត តាមក្រឹត្យវិន័យវិញ(មើល លវ ១៥:១៨ មើល អស ២១:៤–៥) ។

**១៩:១៦** *មានឮសូរផ្គរមានផ្លេកបន្ទោរ និងពពកយ៉ាងក្រាស់នៅលើភ្នំ ព្រម*

ផ្លុំស្នែងយ៉ាងខ្លាំងក្រៃលែង[ខ] រួចបណ្ដាជនទាំងឡាយ ដែល
នៅក្នុងទីដំឡើងត្រសាល ក៏ញ័ររន្ធត់ទាំងអស់គ្នា[គ] ១៧នោះ
ម៉ូសេលោកនាំគេចេញពីទីដំឡើងត្រសាលទៅជួបនឹងព្រះ
គេឈរដំរៀបគ្នានៅទីជើងភ្នំ[ឃ] ១៨ឯភ្នំស៊ីណាយក៏ហុយ
ផ្សែងឡើងពេញទាំងអស់[ង] ដ្បិតព្រះយេហូវ៉ាទ្រង់យាងចុះ
មកពីលើភ្នំគង់ក្នុងភ្លើង[ច] ផ្សែងនោះហុយឡើងដូចជាផ្សែង
នៃគុកភ្លើង[ឆ] តួភ្នំទាំងមូលក៏កក្រើក[ជ]រំពើកយ៉ាងខ្លាំង ។
១៩កាលឮសូរស្នែងតន្ទើនខ្លាំងឡើង នោះម៉ូសេក៏ទូល
ហើយព្រះទ្រង់មានបន្ទូល[ឈ]ឆ្លើយតប[ញ]មកលោក ២០ព្រះ
យេហូវ៉ា ទ្រង់យាងចុះមកលើកំពូលភ្នំស៊ីណាយ[ដ] ទ្រង់មាន
បន្ទូលហៅម៉ូសេពីលើកំពូលភ្នំ រួចម៉ូសេក៏ឡើងទៅ ២១ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលប្រាប់ថា ចូលឯងចុះទៅហាមដល់
បណ្ដាជនរាល់គ្នាដោយដាច់ខាត ក្រែងគេរំលងចូលមកឯ
ព្រះយេហូវ៉ា ដើម្បីមើល[ឋ] នោះនឹងមានគេជាច្រើនត្រូវ
ស្លាប់[ឌ] ២២ឯពួកសង្ឃដែលចូលមកឯព្រះយេហូវ៉ា[ឍ] នោះ
ត្រូវឱ្យគេញែក[ណ]ខ្លួនចេញជាបរិសុទ្ធដែរ ក្រែងទ្រង់នឹងប្រ
ហារគេ[ត] ២៣ម៉ូសេទូលឆ្លើយទៅព្រះយេហូវ៉ាថា បណ្ដាជន
ទាំងឡាយ នឹងឡើងមកលើភ្នំស៊ីណាយ[ថ]ពុំបាន ដ្បិតទ្រង់
បានហាមផ្ដាច់ហើយ ដោយបន្ទូលថា ចូរដាក់គោលចារិក[ទ]
នៅជុំវិញភ្នំ ហើយញែកចេញជាបរិសុទ្ធផង ២៤តែព្រះយេ
ហូវ៉ាទ្រង់បង្គាប់ថា ទៅៗ ចូរឯងចុះទៅ រួចឡើងមកវិញ
នាំទាំងអើរ៉ុន[ធ] មកជាមួយផង តែកុំបើកឱ្យពួកសង្ឃ និង
ពួកជនទំលាយចូលមកឯព្រះយេហូវ៉ាឡើយ ក្រែងទ្រង់នឹង
ប្រហារគេ[ន] ២៥ដូច្នេះម៉ូសេក៏ចុះទៅប្រាប់ដល់ពួកជនទាំង
ឡាយ ។

**១៩:១៦** ខ ហាព ១២:១៨–១៩ វវ ៤:១ គ លប ៣:១០ ១សយ ១៣:៧ ១៤:១៥ ២៨:៥ ទដ ៩៩:១ ហាព ១២:២១ **១៩:១៧** ឃ ខ.២ ចទ ៤:១១ **១៩:១៨** ង នក ២០:១៨ ទដ ១០៤:៣២ អស ៦:៤ វវ ១៥:៨ ច នក ៣:២ ២៤:១៧ លវ ៩:២៤ ចទ ៤:១១, ២៤,៣៣,៣៦ ៥:៤ ៩:៣ ១ពវ ១៨:២៤, ៣៨១របា ២១:២៦ ២របា ៧:១ទដ ១៨:៨ ហាព ១២:១៨ ឆ លប ១៩:២៨ វវ ៩:២ ជ ពច ៥:៥ ២សយ ២២:៨ ទដ ១៨:៧ ៦៨:៨ អស ២:១៩ ៥:២៥ ៤១:១៥ ៦៤:១ យរ៤:២៤ ១០:១០ មីក ១:៤ ណាហ ១:៥ ហាព ៣:៦,១០

## ក្រឹត្យវិន័យទាំងដប់ប្រការ

*២០:១–១៧ – ចទ ៥:៦–២១*

**២០** ១នោះព្រះទ្រង់មានបន្ទូល[ក]នូវពាក្យទាំងនេះ[ខ]ថា
២អញនេះគឺយេហូវ៉ា ជាព្រះនៃឯង[គ] ដែលបាននាំឯង
ចេញ[ឃ] ពីផ្ទះពួកបាវបំរើនៅស្រុកអេស៊ីព្ទ[ង]មក[ច]។
៣កុំឱ្យមានព្រះឯណាទៀតនៅចំពោះអញឱ្យសោះ[ឆ]។
៤កុំឱ្យឆ្លាក់ធ្វើរូបណាសំរាប់ឯងឱ្យសោះ[ជ] ក៏កុំឱ្យធ្វើរូប
ណាឱ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាង

ហាក ២:៦ **១៩:១៩** ឈ ខ.៩ ចទ ៤:៣៣ នហ ៩:១៣ ញ ទដ ៨១:៧ **១៩:២០** ដ ខ.១១ **១៩:២១** ឋ នក ២៤:១០–១១ ជន ៤:២០ ១សយ ៦:១០ ឌ ខ.១៣ **១៩:២២** ឍ លវ ១០:៣ ណ ១សយ ១៦:៥ ២របា ២៩:៥ យអ ២:១៦ ត ខ.២៤ ២សយ ៦:៧ **១៩:២៣** ថ ខ.១១ ទ ខ.១២ **១៩:២៤** ធ នក ២៤:១,៩ ន ខ.២២ **២០:១** ក ចទ ១០:៤ ខ នហ ៩:១៣ ទដ ១១៩:៩ ១៤៧:១៩ មឡ ៤:៤ **២០:២** គ លប ១៧:៧ នក ១៦:១២ លវ ១៩:២ ២០:៧ អស ៤៣:៣ អក ២០:១៩ ឃ លប ១៥:៧ ង នក ៦:៦ ច នក ១៣:៣ អគ ២០:៦ **២០:៣** ឆ ខ.២៣ នក ៣៤:១៤ ចទ ៦:១៤ ១៣:១០ ២ពវ ១៧:៣៥ ទដ ៤៤:២០ ៨១:៩ យរ១:១៦ ៧:៦,៩ ១១:១៣ ១៩:៤ ២៥:៦ ៣៥:១៥ **២០:៤** ជ ខ.៥,២៣ នក ៣២:៨ ៣៤:១៧ លវ ១៩:៤ ២៦:១ ចទ ៤:១៥–១៩, ២៣ ២៧:១៥ ២សយ ៧:២២ ១ពវ ១៤:៩ ២ពវ ១៧:១២ អស ៤០:១៩ ៤២:៨ ៤៤:៩

*ទាំងឮសូរផ្លុំស្នែងយ៉ាងខ្លាំងក្រៃលែង* ជាញឹកញាប់ ព្រះទ្រង់បង្ហាញព្រះវត្តមានទ្រង់ ដោយបាតុភូតធម្មជាតិ ដែលមានជារូបភាព និងសម្លេងសន្ធិក (មើលឧទាហរណ៍ ១សយ ៧:១០ ១២:១៨ យប ៣៨:១ ៤០:៦ ទដ ១៨:១៣–១៤)។ *ពពកយ៉ាងក្រាស់* មើល ១៣:២១ និងការពន្យល់ ។

**១៩:១៨** *ភ្លើង . . . ផ្សែងនៃគុកភ្លើង* មើល លប ១៥:១៧ និងការពន្យល់ ។

**១៩:២២** *ពួកសង្ឃ* មើល ខ.២៤ ។ កាលមិនទាន់មានពួកសង្ឃនៃគ្រួលោកអើរ៉ុននៅឡើយ(មើល ២៨:១) តួនាទីជាសង្ឃ ត្រូវបានបំពេញដោយពួកចាស់ទុំ(មើលការពន្យល់ ៣:១៦ ៣:១៨ ១២:២១ ១៨:២១) ឬពួកប្រុសៗដែលមានវ័យក្មេងជាងដែលគេបានជ្រើសរើស(មើល ២៤:៥)។ ខនេះប្រហែលជា និយាយបង្ហើបជាមុនអំពី វិន័យរបស់ពួកសង្ឃនៃគ្រួលោកអើរ៉ុន ដែលត្រូវទទួលការតែងតាំងនៅពេលក្រោយមកទៀត ។ *ចូលមកឯព្រះយេហូវ៉ា* គឺជាអ្នកធ្វើយ័ញ្ញបូជា មើល ៤០:៣២ លវ ២១:២៣ ។

**១៩:២៣** ហើយញែកចេញជាបរិសុទ្ធិ មើលការពន្យល់ ៣:៥ ។

**២០:១–១៧** មើល ចទ ៥:៦–២១ មើល មថ ៥:២១,២៧ ១៩:១៧–១៩ មក ១០:១៩ លក ១៨:២០ រម ១៣:៩ អភ ៦:២–៣ យក ២:១០–១១ ។

**២០:១** *ពាក្យទាំងនេះ* ជាពាក្យបច្ចេកទេសដែលមានន័យថា "សេចក្ដីសញ្ញា" ដែលគេប្រើក្នុងតំបន់មជ្ឈឹមបូព៌ាសម័យបុរាណ(ឧទាហរណ៍ : ក្នុងចំណោមសាសន៍ហេត មើល ២៤:៣,៨ ៣៤:២៨)។ ក្រឹត្យវិន័យជាមូលដ្ឋាន ដែលមកពីព្រះដែលរាស្ត្រអ៊ីស្រាអែលបានទទួល មានក្នុង ខ.២–១៧ ដែលខខ្លះបានហៅថា "ក្រឹត្យវិន័យទាំង១០ប្រការ"(៣៤:២៨ ចទ ៤:១៣ ១០:៤) ។

**២០:២** *អញនេះគឺយេហូវ៉ា ជាព្រះនៃឯង ដែលបាននាំឯងចេញ* ក្រឹត្យវិន័យទាំងដប់ប្រការបានឆ្លុះបញ្ចាំងអំពីរបៀបតាំងសញ្ញារបស់ពួកស្ដេចនៅសម័យនោះ(មើលការពន្យល់ លប ១៥:៧) ដែលចាប់ពីមូលដ្ឋានគ្រឹះមកគឺមាន (១).នៅក្នុងបុព្វកថា ស្ដេចដ៏ជាធំបង្ហាញពីអត្តសញ្ញាណរបស់ខ្លួន("អញនេះជាយេហូវ៉ា ជាព្រះនៃឯង") និង(២).ក្នុងការណែនាំអំពីប្រវត្តិសាស្ត្រ ស្ដេចដ៏ជាធំទ្រង់រំឭកអំពីព្រះគុណ ដែលទ្រង់ធ្លាប់មានចំពោះស្ដេច និងរាស្ត្រដែលជាចំណុះ("ដែលបាននាំឯងចេញ . . .") ហើយ(៣).ទ្រង់ប្រកាសតាំងសេចក្ដីសញ្ញា(មើល ចទ ៥:១–៣,៧–២១) ដើម្បីឱ្យស្ដាប់បង្គាប់(ក្នុងករណីនេះ គឺមាន១០ប្រការចាប់ពី ខ.៣–១៧)។ ការតាំងសញ្ញារបៀបនេះ គឺដើម្បីបញ្ជាក់ថា ពួកអ៊ីស្រាអែលបានទទួលព្រះយេហូវ៉ាជាស្ដេចរបស់សាសន៍ពួកគេ ហើយទ្រង់បានទទួលពួកគេជារាស្ត្ររបស់ទ្រង់ ។

**២០:៣** *ចំពោះអញ* ក្នុងព្រះគម្ពីរភាសាហេព្រើរ បទគម្ពីរ លប ១៦:១២ ២៥:១៨ បានប្រើពាក្យ "ទាស់ប្រឆាំងនឹង"។ គ្មានព្រះណាដែលអាចតតាំងនឹងព្រះដ៏ពិត ដែលពួកគេជឿឡើយ ។

**២០:៤** *កុំឱ្យឆ្លាក់ធ្វើរូបណាសម្រាប់ឯងឱ្យសោះ* ពីព្រោះព្រះមានលក្ខណៈដែលគេមិនអាចមើលទ្រង់ឃើញ ដូចនេះការសាងរូបព្រះតំណាងឱ្យអង្គទ្រង់ដើម្បីថ្វាយបង្គំ គឺជាអំពើបាប(មើល ចទ ៤:១២,១៥–១៨)។ ហើយដោយសារគេមិនត្រូវថ្វាយបង្គំរូបព្រះដទៃ(មើល ខ.៥)ការធ្វើរូបឱ្យព្រះទាំងនោះ

ក្រោម ឬនៅក្នុងទឹកដែលទាបជាងដីផង ⁵ក៏កុំឱ្យក្រាប
សំពះនៅចំពោះរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាម[ឈ]
នោះឡើយ ដ្បិតអញដែលជាយេហូវ៉ា ជាព្រះនៃឯង
អញមានសេចក្ដីប្រច័ណ្ឌ[ញ] ក៏ទំលាក់ការទុច្ចរិតរបស់ឪពុក[ដ]
ទៅលើកូនចៅរហូតដល់៣ហើយ៤ដំណផង[ឋ] ចំពោះអស់
អ្នកណាដែលស្អប់អញ ៦តែអញផ្ដល់សេចក្ដីសប្បុរស
ដល់ទាំងពាន់ដំណ[ឌ] នៃពួកអ្នកស្រឡាញ់ ហើយកាន់តាម
បញ្ញត្តិរបស់អញទាំងប៉ុន្មានវិញ ។
៧កុំឱ្យចេញព្រះនាមរបស់ព្រះយេហូវ៉ា ជាព្រះនៃឯងជា
អសារឥតការឡើយ ដ្បិតព្រះយេហូវ៉ាទ្រង់នឹងមិនរាប់ជា
ឥតទោសដល់អ្នកណា ដែលចេញព្រះនាមទ្រង់ ជាអសារ
ឥតការនោះទេ[ឍ] ។
៨ចូរឱ្យនឹងចាំពីថ្ងៃឈប់សំរាក[ណ] ដើម្បីញែកថ្ងៃនោះ
ចេញជាបរិសុទ្ធ ៩ក្នុងរវាង៦ថ្ងៃ នោះត្រូវឱ្យឯងធ្វើអស់
ទាំងការរបស់ឯងចុះ[ត] ១០តែឯថ្ងៃទី៧ នោះគឺជាថ្ងៃឈប់
សំរាក[ថ]ថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ នៅថ្ងៃនោះមិន
ត្រូវធ្វើអ្វីឱ្យសោះ ទោះខ្លួនឯងឬកូនប្រុសកូនស្រីឯងក្ដី ទោះ
បាវប្រុស ឬបាវស្រីឯងក្ដី ទោះសត្វរបស់ឯង ឬអ្នកដទៃ
ដែលនៅផ្ទះឯងក្ដី ១១ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើ
ផ្ទៃមេឃ ផែនដី[ទ] ហើយនិងសមុទ្រ ព្រមទាំងរបស់សព្វសារ
ពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧[ធ] ទ្រង់ឈប់
សំរាក[ន] ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទាន
ពរដល់ថ្ងៃឈប់សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ ។
១២ចូរឱ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយ[ប] ដើម្បីឱ្យបាន
អាយុវែង[ផ]នៅក្នុងស្រុក[ព] ដែលព្រះយេហូវ៉ា ជាព្រះនៃឯង

**២០:៥** ឈ នក ២៣:១៣,២៤ យស ២៣:៧ ពច ៦:១០ ២ពវ ១៧:៣៥ អស ៤៤:១៥,១៧,១៩ ៤៦:៦ ញ នក ៣៤:១៤ ចទ ៤:២៤ យស ២៤:១៩ ណាហ ១:២ ដ លប ៩:២៥ លវ ២៦:៣៩ ឋ នក ៣៤:៧ ជន ១៤:១៨ យរ ៣២:១៨ **២០:៦** ឌ នក ៣៤:៧ ជន ១៤:១៨ ចទ ៧:៩ យរ ៣២:១៨ លក ១:៥០ រម ១១:២៨ **២០:៧** ឍ នក ២២:២៨ លវ ១៨:២១ ១៩:១២ ២២:២ ២៤:១១,១៦ ចទ ៦:១៣ ១០:២០ យប ២:៥,៩ ទដ ៦៣:១១ អស ៨:២១ អគ ២០:៣៩ ៣៩:៧ មថ ៥:៣៣ **២០:៨** ណ នក ១៦:២៣ ៣១:១៣–១៦ ៣៥:៣ លវ ១៩:៣,៣០ ២៦:២ អស ៥៦:២ យរ ១៧:២១–២៧ អគ ២២:៨ **២០:៩** ត នក ២៣:១២ ៣១:១៣–១៧ ៣៤:២១ ៣៥:២–៣ លវ ២៣:៣ លក ១៣:១៤ **២០:១០** ថ លប ២:៣ នក ៣១:១៤ លវ ២៣:៣៨ ជន ២៨:៩ អស ៥៦:២ អក ២០:១២,២០ **២០:១១** ទ លប ១:៣–២:១ ធ លប ២:២ ន នក ៣១:១៧ ហព ៤:៤ **២០:១២** ប លប ៣១:៣៥ ចទ ៥:១៦ មថ ១៥:៤ ១៩:១៩ មក ៧:១០ ១០:១៩ លក ១៨:២០ អភ ៦:២ ផ ចទ ៦:២ អភ ៦:៣ ព ចទ ១១:៩ ២៥:១៥ យរ ៣៥:៧

ក៏ជាអំពើបាបផងដែរ(មើល ចទ ៤:១៩,២៣–២៨)។ ធៀបនឹង យហ ៤:២៣–២៤ និងការពន្យល់ ៤:២៤ ។

**២០:៥** *ព្រះ . . . មានសេចក្ដីប្រច័ណ្ឌ* ព្រះទ្រង់មិនសព្វព្រះទ័យនឹងការដែលនរណាម្នាក់ប្រជែងនឹងទ្រង់ ឬការពុំស្មោះត្រង់ចំពោះទ្រង់ឡើយ ។ តាមធម្មតាការប្រច័ណ្ឌនោះ កើតមានចំពោះរាស្ត្រអ៊ីស្រាអែល ព្រោះពួកគេបានតាំងសញ្ញាជាមួយទ្រង់(គឺប្រៀបបាន នឹងប្ដីប្រពន្ធ) ដែលនាំឱ្យពួកគេក្លាយជាកម្មសិទ្ធិផ្ដាច់មុខរបស់ទ្រង់ ហើយត្រូវស្រឡាញ់ទ្រង់ និងស្មោះត្រង់ចំពោះទ្រង់តែមួយអង្គគត់ ។ ការប្រច័ណ្ឌគឺកើតចេញពីការស្រឡាញ់ផងដែរ ។ ការប្រច័ណ្ឌរបស់ទ្រង់គឺ (១).ជាការតម្រូវឱ្យប្តូរប្តេជចំពោះទ្រង់តែមួយអង្គ(មើល ៣៤:១៤ ចទ ៤:២៤ ៣១:១៦, ២១ យស ២៤:១៩ ទដ ៧៨:៥៨ ១កថ ១០:២២ យក ៤:៥)។ (២).អ្នកដែលទាស់ប្រឆាំងនឹងទ្រង់ត្រូវទទួលការជំនុំជម្រះ(មើល ២៩:២០ ១ពវ ១៤:២២ ទដ ៧៩:៥ អស ៤២:១៣ ៥៩:១៧ អគ ៥:១៣ ១៦:៣៨ ២៣:២៥ ៣៦:៥ ណាហ ១:២ សផ ១:១៨ ៣:៨) និង(៣).បញ្ជាក់ថា រាស្ត្រទ្រង់បានរួច ពីទោសហើយ(មើល ២ពវ ១៩:៣១ អស ៩:៧ ២៦:១១ អរ ៣៩:២៥ យអ ២:១៨ សក ១:១៤ ៨:២)។ *លើកូនចៅរហូតដល់៣ ហើយ៤ដំណរផង ចំពោះអស់អ្នកណាដែលស្អប់អញ* ការបំពានយ៉ាងធ្ងន់ធ្ងរដល់សេចក្ដីសញ្ញាដែលបានតាំងនឹងព្រះ ជាភស្ដុតាងនៃការមិនទទួលទ្រង់ជាស្ដេច ហើយនឹងនាំឱ្យមានសេចក្ដីជំនុំជម្រះមកលើខ្លួន និងគ្រួសារខ្លួនផង (មើលឧទាហរណ៍ក្នុង ជន ១៦:៣១ – ៣៤ យស ៧:២៤ និងការពន្យល់) គឺអស់បី ឬបួនដំណរផង ។ មើលការពន្យល់ ទដ ១០៩:១២ ។ *ស្អប់អញ* តាម បរិបទនៃសេចក្ដីសញ្ញាពាក្យ "ស្អប់" មានន័យថា បដិសេធ ហើយ "ស្រឡាញ់"(ខ.៦ មានន័យថា ស្មោះត្រង់)។

**២០:៦** *ដល់ទាំងពាន់ដំណ នៃពួកអ្នក* សូមមើល ចទ ៧:៩ ១របា ១៦:១៥ ទដ ១០៥:៨ ។ *ដែលស្រឡាញ់ ហើយកាន់តាមបញ្ញត្តិ* មើល ចទ ៥:១០ ៧:៩,១២ និងការពន្យល់ និង នហ ១:៥ ចទ ៩:១៤ យហ ១៤:១៥ ១យហ ៥:៣។ នៅតំបន់មជ្ឈឹមបូព៌ាសម័យបុរាណ នៅក្នុងការតាំងសញ្ញា ពាក្យថា "ស្រឡាញ់" ដល់ស្ដេចដ៏ជាធំ គឺសំដៅទៅលើការស្មោះត្រង់ ចំពោះទ្រង់ទាំងស្រុង ដោយធ្វើការបម្រើតាមបង្គាប់ទ្រង់ ។

**២០:៧** *កុំឱ្យចេញព្រះនាមរបស់ព្រះយេហូវ៉ា* គឺជាការប្រើព្រះនាមទ្រង់ដោយមិនគោរព ឧទាហរណ៍ : ប្រើព្រះនាមទ្រង់ ក្នុងសម្បថដែលមិនពិត (លវ ១៩:១២ និងមើល យរ ៧:៩) ក្នុងការធ្វើជាសាក្សីនៅទីកាត់ទោស ។ ព្រះយេស៊ូវទ្រង់បានបង្រៀនអំពីការធ្វើសម្បថនៅក្នុង មថ ៥:៣៣–៣៧ ។

**២០:៨** មើល ២:៣ ។ *ថ្ងៃឈប់សំរាក* មើលការពន្យល់ ១៦:២៣ ។ *បរិសុទ្ធ* មើលការពន្យល់ ៣:៥ ។

**២០:៩** *៦ថ្ងៃ* ចំនួននេះ គឺមិនទាក់ទងនឹងចំនួនថ្ងៃធ្វើការនៃសម័យទំនើបទេ ។

**២០:១០** *នៅថ្ងៃនោះមិនត្រូវធ្វើអ្វីសោះ* គឺមានហេតុផលពីរយ៉ាង(ហេតុផលទីមួយក្នុងគម្ពីរនេះ ហេតុផលមួយទៀតនៅក្នុងគម្ពីរចោទិយកថា) ដូចជា : (១).បន្ទាប់ពីបានបញ្ចប់ព្រះរាជកិច្ចបង្កើតរបស់សព្វសារពើហើយ ព្រះអម្ចាស់ទ្រង់ "បានឈប់សំរាកនៅថ្ងៃទី៧"(ខ.១១) ហើយរាស្ត្រអ៊ីស្រាអែលក៏ត្រូវអនុវត្តតាមគំរូនេះ នៅក្នុងការបម្រើទ្រង់ (២).រាស្ត្រអ៊ីស្រាអែលត្រូវឈប់សម្រាកពីការងារទាំងអស់ ដើម្បីឱ្យអ្នកបម្រើរបស់ពួកគេបានសម្រាកនៅថ្ងៃនោះផងដែរ គឺដូចដែលព្រះអម្ចាស់ទ្រង់បានដោះបន្ទុករបស់ពួកអេស៊ីព្ទចេញពីរាស្ត្រទ្រង់ ។ ដោយព្រះអម្ចាស់បានរំដោះរាស្ត្រទ្រង់ពីនឹមបន្ទុកធ្ងន់នៃស្រុកអេស៊ីព្ទ(មើល ៥:១៤–១៥) ថ្ងៃឈប់សំរាកនេះ គឺជាថ្ងៃដែលព្រះបានតាំងសញ្ញា នៃសញ្ញារវាងព្រះអម្ចាស់និងរាស្ត្រអ៊ីស្រាអែលនៅឯភ្នំស៊ីណាយ(មើល ៣១:១២–២៧ មើលការពន្យល់ លប ៩:១២)។

**២០:១២** *ឱ្យគោរពប្រតិបត្តិ* (១).គឺឱ្យតម្លៃ និងចាត់ទុកជាសំខាន់យ៉ាងខ្លាំង (សភ ៤:៨)។ (២).មើលថែ(ទដ ៩១:១៥)។ (៣).ផ្ដល់ការគោរព(ចទ ២១:១៨ –២១ ធៀបនឹង អភ ៦:២)។ *ដើម្បីឱ្យអ្នកបានអាយុវែង* គឺជាសេចក្ដីបញ្ញត្តិទី១ដែលភ្ជាប់ជាមួយព្រះបន្ទូលសន្យា(អភ ៦:២) ។មើលការ

ទ្រង់ប្រទានឱ្យ ។
១៣កុំសំឡាប់មនុស្សឱ្យសោះ[ភ]។
១៤កុំឱ្យផិតក្បត់គ្នាឱ្យសោះ[ម]។
១៥កុំឱ្យលួចប្លន់ឱ្យសោះ[យ]។
១៦កុំឱ្យធ្វើជាទីបន្ទាល់ក្លែង[រ] ទាស់នឹងអ្នកជិតខាងខ្លួនឱ្យ
សោះ[ល]។
១៧កុំឱ្យលោភ[វ]ចង់បានផ្ទះអ្នកជិតខាងខ្លួនឱ្យសោះ ក៏កុំឱ្យ
លោភចង់បានប្រពន្ធគេ ឬបាវប្រុសបាវស្រីគេក្ដី ឬគោ លា
ឬរបស់អ្វីផងអ្នកជិតខាងខ្លួនឱ្យសោះ"។
១៨កាលបណ្ដាជនទាំងអស់គ្នា បានឮផ្គរលាន់ និងសូរផ្លុំ
ស្នែង[ស] ហើយឃើញផ្លេកបន្ទោរ និងភ្នំហុយផ្សែងឡើង
ដូច្នេះ[ហ] នោះស្រាប់តែគេញ័ររន្ធត់[ឡ] ហើយក៏ថយទៅឈរ
នៅទីឆ្ងាយវិញ ១៩គេនិយាយនឹងម៉ូសេថា សូមលោកមាន
ប្រសាសន៍មកយើងខ្ញុំរាល់គ្នា តែខ្លួនលោកបានហើយ
យើងខ្ញុំនឹងស្ដាប់លោក សូមកុំឱ្យព្រះមានបន្ទូល[អ]នឹងយើងខ្ញុំ
ឡើយ ក្រែងយើងខ្ញុំត្រូវស្លាប់[ក] ២០ម៉ូសេក៏តបថា កុំខ្លាចអី[ខ]
ដ្បិតព្រះទ្រង់បានយាងមកប្រយោជន៍តែនឹងល្បង[គ]អ្នករាល់
គ្នាទេ ហើយឱ្យអ្នករាល់គ្នាបានកោតខ្លាច[ឃ]ដល់ទ្រង់ ដើម្បី
កុំឱ្យអ្នករាល់ធ្វើអំពើបាបឡើយ[ង] ២១ឯជនទាំងឡាយគេក៏
ឈរនៅទីឆ្ងាយ តែម៉ូសេបានចូលទៅជិតទីងងឹតយ៉ាង
ក្រាស់[ច] ដែលព្រះគង់នៅនោះ ។

## រូបព្រះនិងអាសនា

២២ព្រះយេហូវ៉ាទ្រង់ក៏បង្គាប់ទៅម៉ូសេ ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលដូច្នេះថា ខ្លួនឯងរាល់គ្នាបានឃើញថា
អញបាននិយាយនឹងឯងរាល់គ្នា ពីលើស្ថានសួគ៌មក[ឆ]
២៣ដូច្នេះ មិនត្រូវឱ្យមានព្រះណាទៀត នៅជាមួយនឹងអញ[ជ]
ទោះទាំងព្រះធ្វើពីមាស ឬពីប្រាក់ ក៏មិនត្រូវធ្វើសំរាប់ខ្លួន
ឡើយ[ឈ]។

**២០:១៣** ភ លប ៤:២៣ មថ ៥:២១ ១៩:១៨ មក ១០:១៩ លក ១៨:២០ រម ១៣:៩ យក ២:១១ **២០:១៤** ម លវ ១៨:២០ ២០:១០ ជន ៥:១២,១៣,២៩ សភ ៦:២៩,៣២ មថ ៥:២៨ ១៩:១៨ មក ១០:១៩ លក ១៨:២០ រម ១៣:៩ យក ២:១១ **២០:១៥** យ លវ ១៩:១១,១៣ អគ ១៨:៧ មថ ១៩:១៨ មក ១០:១៩ លក ១៨:២០ រម ១៣:៩ **២០:១៦** រ លវ ១៩:១១ យរ ៩:៣,៥ ល នក ២៣:១,៧ លវ ១៩:១៨ ទដ ៥០:២០ ១០១:៥ ១១៩:២៩ មថ ១៩:១៨ មក ១០:១៩ លក ៣:១៤ ១៨:២០ **២០:១៧** វ លក ១២:១៥ រម ៧:៧ ១៣:៩ អភ ៥:៣ ហព ១៣:៥ **២០:១៨** ស នក ១៩:១៦–១៩ ចទ ៤:៣៦ អភ ៥៨:១ យរ ៦:១៧ អគ ៣៣:៣ ហព ១២:១៨–១៩ វវ ១:១០ ហ នក ១៩:១៨ ឡ លប ៣:១០ នក ១៤:៣១ ១៩:១៦ **២០:១៩** អ យប ៣៧:៤,៥ ៤០:៩ ទដ ២៩:៣–៤ ក ចទ ៥:៥,២៣,២៧ ១៨:១៦ កទ ៣:១៩ **២០:២០** ខ លប ១៥:១ គ លប ២២:១ ឃ ចទ ៤:១០ ៦:២,២៤ ១០:១២ ទដ ១១១:១០ ១២៨:១ សជ ១:៧ សស ១២:១៣ អស ៨:១៣ ង យប ១:៨ ២:៣ ២៨:២៨ សភ ៣:៧ ៨:១៣ ១៤:១៦ ១៦:៦ **២០:២១** ច នក ១៩:៩ ចទ ៥:២២ ទដ ១៨:៩ ៦៨:៤ ៩៧:២ អស ១៩:១ **២០:២២** ឆ ចទ ៥:២៤,២៦ នហ ៩:១៣ **២០:២៣** ជ ខ.៣ ឈ នក ២២:២០ ៣២:៤,៨,៣១ ៣៤:១៧ ចទ ២៩:១៧–១៨ នហ ៩:១៨

ពន្យល់ផងដែរ ចទ ៦:២ ផ្ដល់កិត្តិយសដល់អ្នកដែលមានអំណាច ដែលជាអ្នកសំខាន់ ក្នុងការរក្សាស្ថេរភាពសង្គម ។

**២០:១៣** មើល មថ ៥:២១–២៦ ។ *សំឡាប់មនុស្ស* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះសំដៅទៅលើការធ្វើឃាតដោយគិតទុកជាមុន ។

**២០:១៤** មើល ៥:២៧–៣០ ។ *ផិតក្បត់គ្នា* ជាអំពើបាបដែលទាស់ប្រឆាំងនឹងព្រះ (លប ៣៩:៩) ព្រមទាំងទាស់ប្រឆាំងនឹងប្ដីឬប្រពន្ធផងដែរ ។ អាពាហ៍ពិពាហ៍ជាការប្រសើរដល់គ្រប់គ្នា (មើល ហព ១៣:៤) ។

**២០:១៥** *លួចប្លន់* គឺជាការដកយកនូវអ្វីមួយពីអ្នកដែលបានទទួលការផ្ទុកផ្ដាក់ពីព្រះ នូវរបស់ដែលបាត់នោះ (មើល ២២:១–១៥ និងការពន្យល់) ។

**២០:១៦** *បន្ទាល់ក្លែង* គឺបង្ខូចកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ និងដកហូតនូវសិទ្ធិពីអ្នកនោះ (មើល ទដ ២៤:៤ សភ ៦:១៩ យរ ៥:២ និងការពន្យល់) ។

**២០:១៧** *លោភចង់បាន* គឺជាការចង់បានរបស់អ្វីមួយ ដោយគំនិតអាក្រក់ (មើល មថ ១៥:១៩) ។ ការរំលងក្រឹត្យវិន័យនៅក្នុងចិត្ត គឺស្មើនឹងការរំលងដោយការប្រព្រឹត្ត (សូមមើល មថ ៥:២១–៣០ ធៀបនឹង កល ៣:៥) ។

**២០:១៨–២១** វគ្គនេះជាសេចក្ដីបញ្ចប់នៃការនិយាយ អំពីក្រឹត្យវិន័យទាំង១០ប្រការ ។ ការពិពណ៌នាហាក់ដូចជាមានលំដាប់លំដោយ ខុសពីព្រឹត្តិការណ៍ ព្រោះគេជឿថា ខ.១៨ ជាសេចក្ដីបន្តពី ១៩:២៥ ។ ការប្រកាសក្រឹត្យវិន័យទាំង១០ប្រការបានធ្វើឡើង បន្ទាប់ពីលោកម៉ូសេបានជួបនឹងព្រះ (ខ.២១) ។ អ្នកនិពន្ធនៃព្រះគម្ពីរ ជារឿយៗ មិនបានរៀបរាប់តាមលំដាប់លំដោយនៃកាលបរិច្ឆេទ ដោយសារមូលហេតុផ្សេងៗ ហើយនៅក្នុងវគ្គនេះអាច (១). ដើម្បីញែកក្រឹត្យវិន័យទាំង១០ប្រការឱ្យដាច់ និងឱ្យមានលក្ខណៈខុសពី "បទគម្ពីរនៃសេចក្ដីសញ្ញា" (២៤:៧) ដែលត្រូវនៅបន្ទាប់ (២០:២២–២៣:១៩) ឬ (២). ដើម្បីធ្វើសេចក្ដីបញ្ចប់នៃការនិយាយអំពីក្រឹត្យវិន័យ ដែលមានលោកម៉ូសេ ជាបុគ្គលកណ្ដាល ។

**២០:១៩** មើល ហព ១២:១៩–២០ ។ ពួកអ៊ីស្រាអែលបានស្នើរឱ្យមានបុគ្គលកណ្ដាលម្នាក់ ដែលត្រូវឈរនៅចន្លោះពួកគេនិងព្រះអម្ចាស់ ហើយមុខងារនេះ មានលោកម៉ូសេបំពេញ ហើយជាបន្តបន្ទាប់មកទៀត គឺមានពួកសង្ឃ ពួកហោរា និងពួកស្ដេច ហើយនៅទីបញ្ចប់គឺមានព្រះយេស៊ូវទ្រង់ជាបុគ្គលកណ្ដាលចុងក្រោយ (១ធថ ២:៥) ។

**២០:២០** *កុំខ្លាចអី* មានន័យថា កុំឱ្យគិតថា ព្រះទ្រង់សម្ដែងព្រះចេស្ដាទ្រង់ ដើម្បីធ្វើឱ្យអ្នកភ័យរន្ធត់នោះឡើយ ។ ប៉ុន្តែ ទ្រង់បានយាងមក ដើម្បីតាំងសេចក្ដីសញ្ញាជាមួយនឹងអ្នក ដើម្បីទទួលអ្នកជារាស្ត្រទ្រង់ ។ *ល្បង* មើលការពន្យល់ លប ២២:១ ។ *កោតខ្លាចដល់ទ្រង់* មើលការពន្យល់ លប ២០:១១។

**២០:២២–២៣:១៩** សៀវភៅសញ្ញា (២៤:៧) គឺនិយាយអំពីក្រឹត្យវិន័យទូទៅ ដែលមានមូលដ្ឋានគ្រឹះនៅក្នុងក្រឹត្យវិន័យទាំង១០ប្រការ ។

**២០:២២–២៦** ក្រឹត្យវិន័យនៅក្នុងវគ្គនេះ គឺផ្ដោតទៅលើទំនាក់ទំនងជាមូលដ្ឋាន របស់ពួកអ៊ីស្រាអែលជាមួយនឹងព្រះ (ធៀបនឹង ខ.៣) ។

**២០:២២** *លើស្ថានសួគ៌* កន្លែងដែលទ្រង់សណ្ឋិតនៅ ។ សូម្បីតែនៅកំពូលភ្នំស៊ីណាយ (១៩:២០) ក៏ទ្រង់មានបន្ទូលពីលើស្ថានសួគ៌មកដែរ ។

**២០:២៣** មើល ខ.៣–៤ ។ ខនេះបាននាំឱ្យមានការគត់សម្គាល់ អំពីលក្ខណៈផ្ទុយរវាងព្រះពិតតែមួយនៅឯនគរស្ថានសួគ៌ ដែល "ទ្រង់ធ្វើគ្រប់ការទាំងអស់ ដែលគាប់ព្រះហឫទ័យទ្រង់" (ទដ ១១៥:៣) និងរូបព្រះធ្វើពីប្រាក់ ឬមាសដែលពុំអាចធ្វើអ្វីបានសោះ (មើល ទដ ១១៥:៤–៧ ឬ ទដ ១៣៥:៥–៦,១៥–១៧) ។

២៤ត្រូវឱ្យឯងយកដីស្អាងអាសនា[ញ]ឱ្យអញ ហើយត្រូវ
ថ្វាយដង្វាយដុត[ដ]និងដង្វាយមេត្រី ជាចៀម ហើយនិងគោ
របស់ឯង នៅលើអាសនានោះ ឯអញនឹងមកឱ្យពរ[ឋ]ដល់ឯង
នៅគ្រប់ទីកន្លែងណា ដែលអញតាំងឱ្យមានសេចក្ដីរំឭក
ដល់ឈ្មោះអញ[ឌ] ២៥បើឯងស្អាងអាសនាពីថ្ម ឱ្យអញ នោះកុំ
ឱ្យយកថ្មដាប់ឡើយ ដ្បិតកាលណាឯងយកពន្លាកមកដាប់ថ្ម
នោះឈ្មោះថាឯងបានធ្វើឱ្យថ្មនោះ ទៅជារបស់[ឍ]ដែលមិន
ស្អាតវិញ ២៦ក៏កុំមានថ្នាក់ជណ្ដើរ ដើម្បីឡើងទៅឯអាសនា
អញឡើយ ក្រែងគេឃើញកេរខ្មាស់[ណ]ឯង ។

**២១** ១នេះជាមាត្រាច្បាប់[ក]ទាំងប៉ុន្មាន ដែលឯងត្រូវយក
ទៅដាក់នៅមុខគេ ។

## អ្នកបម្រើសាសន៍ហេព្រើរ

*២១:២-៦ – ចទ ១៥:១២-១៨*

*២១:២-១១ – លវ ២៥:៣៩-៥៥*

២បើឯងទិញបាវជាសាសន៍ហេព្រើរ[ខ] នោះវាត្រូវនៅ
បំរើតែ ៦ឆ្នាំទេ លុះដល់ឆ្នាំទី៧ នោះនឹងរួចចេញទៅទទេ[គ]
ឥតសងអ្វីឡើយ ៣បើវាបានមកតែម្នាក់ឯង នោះនឹងចេញ
ទៅតែម្នាក់ដែរ តែបើមានប្រពន្ធផង នោះប្រពន្ធនឹងចេញ
ទៅជាមួយគ្នា ៤បើប្រពន្ធនោះជាស្ត្រីដែលចៅហ្វាយបានឱ្យ
ហើយនាងបានបង្កើតកូនប្រុសឬស្រីឱ្យវា នោះប្រពន្ធនិង
កូនទាំងប៉ុន្មានជារបស់ផងចៅហ្វាយវាវិញ ឯវាត្រូវចេញ
ទៅតែខ្លួនប៉ុណ្ណោះ ៥តែបើបាវនោះនិយាយថា ខ្ញុំស្រឡាញ់
ចៅហ្វាយខ្ញុំ និងប្រពន្ធកូនខ្ញុំណាស់ ខ្ញុំមិនចង់ចេញទៅទេ[ឃ]
៦នោះចៅហ្វាយត្រូវនាំវាទៅឯចំពោះព្រះ[ង] រួចត្រូវនាំទៅ
ឯទ្វារ ឬបង្គោលទ្វារណាក្តី ហើយយកដែកចោះមកចោះ[ច]
ត្រចៀកវា ដូច្នេះបាវនោះនឹងត្រូវនៅបំរើចៅហ្វាយជា
ដរាបទៅ[ឆ]។

៧បើមនុស្សណាលក់កូនស្រី ឱ្យទៅធ្វើជាបាវបំរើគេ រូប
កូននោះឯងនឹងចេញទៅដូចជាបាវប្រុសពុំបានទេ ៨បើនាង
មិនជាទីពេញចិត្ត ដល់ចៅហ្វាយដែលបានយក នាងហើយ
នោះគាត់នឹងបើកឱ្យគេលោះនាងចេញបាន តែគ្មានច្បាប់
នឹងលក់នាងឱ្យទៅអ្នកប្រទេសក្រៅណា ក្រោយដែលបាន
បញ្ឆោតនាងហើយនោះទេ ៩តែបើគាត់បានយកមកបំរុង
ទុកឱ្យកូនប្រុសវិញ នោះត្រូវប្រព្រឹត្តនឹងនាងតាមធម្មតា
ច្បាប់ជាកូនស្រី ១០បើបានយកសំរាប់ខ្លួនឯងរួចទៅយក
ប្រពន្ធ១ទៀត នោះមិនត្រូវបន្ថយអាហារ ឬសំលៀកបំពាក់
ឬច្បាប់ជាប្តីចេញពីប្រពន្ធដើមសោះឡើយ[ជ] ១១តែបើសិន
ជាគាត់មិនធ្វើតាមសេចក្តីទាំង៣ប្រការនេះដល់នាងទេ
នោះនាងនឹងត្រូវចេញបានទទេ ឥតសងប្រាក់អ្វីឡើយ ។

## ការបង្ករបួសស្នាម

១២អ្នកណាដែលវាយមនុស្សដល់ស្លាប់ នោះនឹងត្រូវ
សំឡាប់ចេញជាមិនខាន[ឈ] ១៣តែបើមិនបានលបវាយទេ គឺ

**២០:២៤** ញ នក ២៧:១ ៤០:២៩ ជណ ១៦:៣៨ ចទ ២៧:៥ យស ៨:៣០ ២ពវ ១៦:១៤ ២រប ៤:១ អរ ៣:២ អគ ៤៣:១៣ ដ លប ៨:២០ នក ១៨:១២ ឋ លប ១២:២ ២២:១៧ ឌ ចទ ១២:៥ ១៦:៦,១១ ២៦:២ ១ពវ ៩:៣ ២ពវ ២ពវ ២១:៤,៧ ២រប ៦:៦ ១២:១៣ អរ ៦:១២ **២០:២៥** ឍ យស ៨:៣១ ១ពវ ៦:៧ **២០:២៦** ណ អគ ៤៣:១៧ **២១:១** ក នក ២៤:៣ ៣៤:៣២ ចទ ៤:១៤ ៦:១ **២១:២** ខ នក ២២:៣ គ ខ.៧ យរ ៣៤:៨,១៤ **២១:៥** ឃ ចទ ១៥:១៦ **២១:៦** ង នក ២២:៨-៩ ចទ ១៧:៩ ១៩:១៧ ២៥:១ ច ទដ ៤០:៦ ឆ យប ៣៩:៩ ៤១:៤ **២១:១០** ជ ១កថ ៧:៣-៥ **២១:១២** ឈ ខ.១៥, ១៧ លប ៤:១៤,២៣ នក ៣១:១៥ លវ ២០:៩,១០ ២៤:១៦ ២៧:២៩ ជន ១:៥១ ៣៥:១៦,៣០-៣១ ចទ ១៣:៥ ១៩:១១ ២២:២២ ២៧:១៦ យប ៣១:១១ សភ ២០:២០ មថ ២៦:៥២

**២០:២៤** *ដីស្អាងអាសនា* អាសនាធ្វើពីដីនេះ គឺដូចជាអាសនាដែលនៅក្នុងរោងឧបោសថ(សូមមើល ២៧:១) ហើយគេបានរកឃើញនៅក្នុងការរុករកនៃក្រុមបុរាណវត្ថុវិទ្យា នៅក្នុងវិហារនៃពួកអ៊ីស្រាអែល(មានចំណាស់តាំងពីសតវត្សរ៍ទី ១០ ឬ ១១ មុនគ.ស) នៅឯក្រុងអើរ៉ាត ក្នុងភាគខាងត្បូងនៃប្រទេសអ៊ីស្រាអែលសព្វថ្ងៃ ។ *ដង្វាយដុត* មើលការពន្យល់ លវ ១:៣ ។ *ដង្វាយមេត្រី* មើលការពន្យល់ លវ ៣:១ ។ *នៅគ្រប់ទីកន្លែងណា* គឺមិនមែននៅទីបរិសុទ្ធមជ្ឈិមនៃក្រុងយេរូសាឡិមនៅសម័យក្រោយមកទៀតទេ តែនៅឯទីកន្លែងបណ្ដោះអាសន្នជាច្រើន សម្រាប់ថ្វាយបង្គំ(សូមមើល យស ៨:៣០-៣១ ពច ៦:២៤ ២១:៤ ១សយ ៧:១៧ ១៤:៣៥ ២សយ ២៤:២៥ ១ពវ ១៨:៣០)។

**២០:២៥** *នោះកុំឱ្យយកថ្មដាប់ឡើយ* សព្វថ្ងៃគេបានរកឃើញអាសនាបូរាណជាច្រើន ដែលមិនធ្វើពីថ្មដាប់(ដែលមានរយៈពេលអាយុកាលផ្សេងៗគ្នា) នៅប្រទេសអ៊ីស្រាអែល ។ *ដ្បិតកាលណាឯងយកពន្លាកមកដាប់ថ្ម... ទៅជារបស់ដែលមិនស្អាត* ប្រហែលដោយសារពួកសាសន៍ដទៃបានធ្វើដូចនេះនៅក្នុងការសាងសង់។

**២០:២៦** *ថ្នាក់ជណ្ដើរ* ជាជណ្ដើរអាសនាដែលចាស់បំផុត ដែលគេរកឃើញក្នុងស្រុកអ៊ីស្រាអែល គឺនៅក្នុងតំបន់មេគីដោ គឺមានអាយុតាំងពី ចន្លោះឆ្នាំ ៣០០០ និង២៥០០ ម.ស មុន គ.ស ។

**២១:១** ខនេះ គឺជាចំណងជើងនៃវគ្គ ២១:២-២៣:១៩ ។

**២១:២-១១** មើល យរ ៣៤:៨-២២ ។ សៀវភៅសញ្ញាបានចាប់ផ្ដើមនិយាយអំពីក្រឹត្យវិន័យសម្រាប់ការគ្រប់គ្រងទាសករមុនគេ គឺខុសពីការរៀបចំច្បាប់ ឬក្រឹត្យវិន័យសាសន៍ដទៃ នៅមជ្ឈឹមបូពាំសម័យបុរាណ ។ ព្រះអម្ចាស់ទ្រង់រៀបចំក្រឹត្យវិន័យស្ដីអំពីទាសករ ឱ្យនៅមុខគេ អាចដើម្បីឆ្លុះបញ្ចាំងពីការប្រោះលោះរាស្ត្រទ្រង់ពីចំណងទាសភាព នៅក្នុងសម័យពេញដោយទុក្ខវេទនានៅនគរអេស៊ីព្ទ ។

**២១:២** *ហេព្រើរ* សូមមើលការពន្យល់ លប ១៤:១៣ ។ *លុះដល់ឆ្នាំទី៧ នោះនឹងរួចចេញទៅទទេ* អ្នកបម្រើព្រះអម្ចាស់ មិនត្រូវធ្វើជាទាសកររបស់អ្នកណាម្នាក់ជារៀងរហូតឡើយ (មើល ២០:១០ និងការពន្យល់)។

**២១:៦** *ចៅហ្វាយ* សូមមើលការពន្យល់ ២២:៨-៩,២៨ ។ *យកដែកចោះមកចោះត្រចៀកវា* មើល ចទ ១៥:១៧ ។ ការធ្វើដូចនេះ គឺដើម្បីបញ្ជាក់ថាពីការស្ម័គ្រចិត្តធ្វើជាបាវបម្រើ(ទដ ៤០:៦-៨ និងការពន្យល់ ៤០:៦)។

**២១:១២-១៥** មើល ២០:១៣ និងការពន្យល់ មើល ជន ៣៥:១៦-៣៤ ចទ ១៩:១-១៣ ២១:១-៩ ២៤:៧ ២៧:២៤-២៥ សយ ២០:១-៩ ។

**២១:១២** មើល លប ៩:៦ និងការពន្យល់ ។

ដោយព្រះបានឱ្យគេស្លាប់ ដោយសារដៃអ្នកនោះនឹងរត់ទៅ
ទីពឹង[ញ]បាន ១៤ប៉ុន្តែបើសិនជាអ្នកណាបានប្រព្រឹត្តដោយចិត្ត
ព្រហើនចំពោះអ្នកជិតខាង ទាំងសំឡាប់ដោយឧបាយកល[ដ]
នោះទោះបើបានចូលទៅទីពឹងដល់អាសនាអញក៏ដោយ
គង់តែត្រូវចាប់នាំចេញទៅសំឡាប់ដែរ[ឋ]។
១៥ឯអ្នកណាដែលវាយឪពុកឬម្តាយខ្លួន នោះត្រូវសំឡាប់
ចោលជាមិនខាន ១៦ហើយអ្នកណាដែលចាប់មនុស្សយក
ទៅលក់[ឌ] ឬទាន់ឃើញកំពុងនៅក្នុងដៃនៅឡើយ នោះត្រូវ
សំឡាប់ចោលជាមិនខាន[ឍ] ១៧ឯអ្នកណាដែលប្រទេចផ្តាសា
ដល់ឪពុកឬម្តាយខ្លួន នោះត្រូវសំឡាប់ចោលចេញជាមិន
ខានដែរ[ណ]។
១៨បើអ្នកណាឈ្លោះគ្នា ហើយអ្នក១បានយកថ្មទៅគប់
អ្នក១ ឬដាល់តប់គេ តែមិនបានជាស្លាប់ទេ គ្រាន់តែឈឺដល់
ដេកនៅគ្រែប៉ុណ្ណោះ ១៩បើសិនជាអ្នករងគ្រោះ នោះ
ក្រោកកាន់ឈើច្រត់ដើរទៅក្រៅបាន នោះអ្នកដែលបាន
វាយនឹងបានរួច តែត្រូវសងបំពេញការគេ ហើយត្រូវមើល
គេ ទាល់តែបានជាស្រឡះដែរ ។
២០បើអ្នកណាវាយបាវប្រុស ឬបាវស្រីខ្លួន ដោយដំបង
ហើយបាវនេះស្លាប់នៅក្រោមដៃខ្លួនភ្លាម នោះត្រូវធ្វើ
ទោសដល់ចៅហ្វាយជាមិនខាន ២១ប៉ុន្តែបើបាវនោះរស់
នៅបាន២ឬ៣ថ្ងៃ នោះមិនត្រូវធ្វើទោសដល់ចៅហ្វាយទេ
ដ្បិតបាវនោះជារបស់ទ្រព្យផងគេហើយ[ត]។
២២បើអ្នកណាឈ្លោះគ្នា ហើយប៉ះទង្គិចលើស្ត្រីមានផ្ទៃ
ពោះឱ្យរលូតកូន តែគ្មានគ្រោះថ្នាក់ទេ នោះត្រូវធ្វើទោស
ជាមិនខាន តាមបន្ទុកដែលប្តីរបស់នាងផ្ទុកលើអ្នកនោះ[ថ]
ហើយត្រូវសងគេតាមដែលចៅក្រមកាត់សំរេចឱ្យ ២៣ប៉ុន្តែ
បើមានគ្រោះថ្នាក់ នោះត្រូវសងជីវិតឱ្យធួននឹងជីវិតវិញ[ទ]
២៤ត្រូវសងភ្នែកឱ្យធួននឹងភ្នែក ធ្មេញឱ្យធួននឹងធ្មេញ[ធ] ដៃឱ្យ
ធួននឹងដៃ ជើងឱ្យធួននឹងជើង ២៥រលាកឱ្យធួននឹងរលាក
របួសឱ្យធួននឹងរបួស ជាំឱ្យធួននឹងជាំដែរ ។
២៦បើអ្នកណាវាយត្រូវភ្នែករបស់បាវប្រុសបាវស្រីខ្លួន
ឱ្យខ្វាក់ នោះត្រូវឱ្យវារួចចេញទៅទទេ ដោយព្រោះភ្នែក
២៧ហើយបើវាយបំបាក់ធ្មេញបាវប្រុសបាវស្រី នោះក៏ត្រូវ
ឱ្យវារួចចេញទៅទទេដែរ ដោយព្រោះធ្មេញ ។
២៨បើគោណាជល់មនុស្សប្រុស ឬស្រី ដល់ស្លាប់ នោះ
ត្រូវចោលគោនោះសំឡាប់នឹងថ្មជាមិនខាន[ន] ហើយមិនត្រូវ
ទាំងស៊ីសាច់វាផង ឯម្ចាស់វាត្រូវរួចខ្លួនវិញ ២៩ប៉ុន្តែបើ
ពីដើមគោនោះធ្លាប់តែជល់គេ ក៏មានគេបានប្រាប់ដល់
ម្ចាស់ហើយ តែម្ចាស់មិនបានឃុំខាំងវា[ប] ហើយវាជល់
មនុស្សប្រុសឬស្រីឱ្យស្លាប់ទៅ នោះឯរូបគោ ត្រូវគេចោល
សំឡាប់នឹងថ្ម ឯម្ចាស់ក៏ត្រូវស្លាប់ដែរ ៣០តែបើគេចាប់ឱ្យ
សងថ្លៃជំនួសជីវិតវិញ នោះត្រូវឱ្យម្ចាស់សងគេតាមដែល
គេបង្គាប់ទាំងអស់ចុះ[ផ] ៣១ទោះបើបានជល់ដល់កូនប្រុសឬ
កូនស្រីក្តី ក៏ត្រូវឱ្យជំនុំជំរះតាមច្បាប់នេះដែរ ៣២តែបើគោ
នោះបានជល់ដល់បាវប្រុសឬបាវស្រីគេវិញ នោះត្រូវសង
តែប្រាក់៣០រៀល[ព]ទៅចៅហ្វាយវាបានហើយ ឯរូបគោ
ត្រូវចោលសំឡាប់នឹងថ្មទៅ ។

**២១:១៣** ញ ជន ៣៥:១០–៣៤ ចទ ៤:៤២ ១៩:២–១៣ យស ២០:៩
**២១:១៤** ដ លប ៤:៨ ជន ៣៥:២០ ២សយ ៣:២៧ ២០:១០ ហប ១០:២៦ ឋ ចទ ១៩:១១–១២ ១ពវ ២:២៨–៣៤
**២១:១៦** ឌ លប ៣៧:២៨ ឍ នក ២២:៤ ចទ ២៤:៧
**២១:១៧** ណ ខ.១២ ចទ ៥:១៦ មថ ១៥:៤ មក ៧:១០
**២១:២១** ត លវ ២៥:៤៤–៤៦
**២១:២២** ថ ខ.៣០
**២១:២៣** ទ លវ ២៤:១៩ ចទ ១៩:២១
**២១:២៤** ធ ខ.២៣ មថ ៥:៣៨
**២១:២៨** ន ខ.៣២ លប ៩:៥
**២១:២៩** ប ខ.៣៦
**២១:៣០** ផ ខ.២២
**២១:៣២** ព លប ៣៧:២៨ សក ១១:១២–១៣ មថ ២៦:១៥ ២៧:៩

**២១:១៣** *មិនបានលបវាយទេ* បទគម្ពីរផ្សេងទៀត ប្រើពាក្យ "មិនដោយចិត្តប៉ង"(ជន ៣៥:១១) "ដោយឥតមានឈ្លបលប"(ជន ៣៥:២២) "មិនមែនជាខ្មាំងសត្រូវ"(ជន ៣៥:២៣)"មិនដែលប៉ងនឹងធ្វើអាក្រក់"(ជន ៣៥:២៣) "និងមិនប្រកបដោយចិត្តប៉ង ក៏មិនបានស្អប់ពីមុនដែរ"(ចទ ១៩:៤)។ *ព្រះបានឱ្យគេស្លាប់* ជាព្រឹត្តិការដែលមនុស្សមិនអាចគ្រប់គ្រងបានទេ(មើល ជន ៣៥:៦–៣២ ចទ ១៩:១–១៣ យស ២០:១–៩ ២១:១៣,១២,២៧,៣២,៣៨)

**២១:១៥** មើល ២០:១២ និងការពន្យល់ ។

**២១:១៦** មើល ២០:១៥ និងការពន្យល់ ។

**២១:១៧** *ប្រទេចផ្តាសា . . . ឪពុកម្តាយ* គឺដាក់ផ្តាសា ដើម្បីឱ្យសេចក្តីហិនវិនាសកើតមានដល់ពួកគាត់ ។

**២១:២០–២១** នៅពេលដែលគេមិនអាចរកភស្តុតាង ដើម្បីបញ្ជាក់ថា ម្ចាស់ទាសករ បានធ្វើមនុស្សឃាតដោយប៉ុនប៉ង នោះម្ចាស់ទាសករត្រូវរួចខ្លួន ។

**២១:២៣–២៥** មើល ចទ ១៩:២១ ។ គេហៅក្រឹត្យវិន័យនេះថា ក្រឹត្យវិន័យនៃការសងសឹក ។ តាមបរិបទនៃវគ្គនេះ ការកំណត់ទោសដូចនេះ គឺដើម្បីឱ្យអ្នកប្រព្រឹត្តខុសបានទទួលទោសឱ្យសមនឹងកម្រិតនៃបទល្មើសរបស់ខ្លួន ។ ព្រះយេស៊ូវបានប្រទានក្រឹត្យវិន័យនៃសេចក្តីស្រឡាញ់ ដែលធ្វើឱ្យបំបាត់នូវការភាន់ច្រឡំ អំពីក្រឹត្យវិន័យនៃការសងសឹងនោះ(មើល មថ ៥:៣៨–៤២)។ មើលការពន្យល់ លវ ២៤:២០ ។

**២១:២៣** *មានគ្រោះថ្នាក់* គឺមកលើម្តាយ ឬកូនរបស់គាត់ ។

**២១:២៦–២៧** គឺជាក្រឹត្យវិន័យដែលមានមនុស្សធម៌ ដល់អ្នកដែលទាក់ទងនឹងការសងសឹក ។

**២១:២៨–៣២** គឺជាក្រឹត្យវិន័យអំពីសត្វគោឈ្មោលដែលបង្ករបួសស្នាម ។

**២១:២៨** *គោនោះសំឡាប់នឹងថ្ម* សត្វគោនោះត្រូវទទួលខុសត្រូវចំពោះជីវិតមនុស្ស ដែលគោនោះបានសម្លាប់(មើល លប ៩:៥ និងការពន្យល់)។

**២១:៣០** *បើគេចាប់ឱ្យសងថ្លៃជំនួសជីវិត* បើក្រុមគ្រួសារអ្នករងគ្រោះមានបំណងចង់ទទួលប្រាក់លោះ ជំនួសការកាត់ទោសសម្លាប់ ។ *នោះត្រូវឱ្យម្ចាស់សងតាមដែលគេបង្គាប់ចុះ* ការបង់ប្រាក់លោះ(ដូចក្នុង ជន ៣៥:៣១) មិនមែនដើម្បីសងជម្ងឺចិត្តដល់គ្រួសារអ្នកស្លាប់ឡើយ ប៉ុន្តែ គឺដើម្បីសង្គ្រោះដល់ជីវិតម្ចាស់គោដែលមិនដឹងអ្វី ។

**២១:៣២** *ប្រាក់៣០រៀល* វាជាមាត្រដ្ឋាននៃតម្លៃលោះខ្លួនពួកទាសករ ។ សាវ័ករបស់ព្រះយេស៊ូវ ឈ្មោះយូដាសអ៊ីស្ការីយ៉ុត ក៏បានទទួលប្រាក់ក្នុងចំនួនដូចនេះផងដែរ នៅក្នុងការបញ្ជូនទ្រង់ ឱ្យទៅគេធ្វើគុត(សូមមើល

៣៣បើអ្នកណាបើកអណ្តូង[ភ] ឬជីកអណ្តូង ហើយមិនបានគ្រប
រួចមានគោ ឬលាធ្លាក់ចុះទៅក្នុងនោះ ៣៤នោះម្ចាស់អណ្តូង
ត្រូវសងប្រាក់ដល់ម្ចាស់វាតាមដំឡៃសត្វ រួចសត្វស្លាប់នោះ
នឹងបានមកម្ចាស់អណ្តូងវិញ ។
៣៥បើគោរបស់អ្នកណាជល់គោគេឱ្យស្លាប់ នោះគេត្រូវ
លក់គោដែលនៅរស់ចែកប្រាក់គ្នា ហើយសាច់គោស្លាប់ ក៏
ត្រូវចែកគ្នាដែរ ៣៦តែបើម្ចាស់ដឹងថា គោនោះធ្លាប់ជល់ពី
ដើមមក ហើយមិនបានបង្ខាំងទុក[ម] នោះត្រូវសងជាគោឱ្យ
ធួននឹងគោជាមិនខាន រួចគោស្លាប់នឹងបានមកខ្លួនវិញ ។

## ការការពារទ្រព្យសម្បត្តិ

**២២** ១បើអ្នកណាលួចគោ ឬចៀមគេ ហើយកាប់សំឡាប់
ឬលក់ទៅ នោះត្រូវសង[ក]គោ៥ឱ្យធួននឹងគោ១ ហើយចៀម
៤ឱ្យធួននឹងចៀម១ ២បើចោរកំពុងតែលួចហើយ[ខ]គេបាន
ទាន់វាយសំឡាប់ទៅ នោះគេគ្មានទោសនឹងឈាមវាទេ[គ]
៣តែបើថ្ងៃរះហើយ នោះត្រូវមានទោសវិញ ដ្បិតនឹងត្រូវ
ចាប់ឱ្យសង[ឃ] បើចោរគ្មានអ្វីសោះ ត្រូវលក់[ង]ខ្លួនវាឱ្យធួន
នឹងរបស់ដែលបានលួចយកនោះ ៤បើរបស់ដែលលួចនោះ
ទោះគោ លា ឬចៀមក្តី ឃើញរស់[ច]នៅដៃវានៅឡើយ
នោះ ត្រូវឱ្យសង១ជា២[ឆ]។
៥បើអ្នកណាធ្វើបំផ្លាញចំការ ឬដំណាំទំពាំងបាយជូរ
របស់គេ ដោយលែងសត្វខ្លួន ឱ្យលុកលុយស៊ីក្នុងដីគេ នោះ
ត្រូវយកផលដំណាំយ៉ាងល្អបំផុតពីស្រែចំការរបស់ខ្លួនទៅ
សង[ជ]គេវិញ ។
៦បើកាលណាមានភ្លើងឆេះ[ឈ]គុម្ពបន្លា ហើយខ្ទាតទៅ
ឆេះដល់ស្នឹមស្រូវ ឬស្រូវមិនទាន់ច្រូត ឬវាលស្មៅក្តី នោះ
អ្នកណាដែលដុតភ្លើង ត្រូវតែសងគេជាមិនខាន [ញ]។
៧បើអ្នកណាផ្ញើប្រាក់ ឬជារបស់អ្វី ទុកនឹងអ្នកជិតខាង[ដ]
ហើយមានចោរលួចពីផ្ទះអ្នកនោះទៅ បើសិនជាគេចាប់
ចោរបាន នោះចោរត្រូវសង១ជា២[ឋ] ៨តែបើរកចោរមិន
ឃើញទេ នោះត្រូវនាំម្ចាស់ផ្ទះទៅឯចៅក្រម[ឌ] ដើម្បីនឹង
ពិចារណាមើល តើអ្នកនោះបានដាក់ដៃលើរបស់ទ្រព្យអ្នក
ជិតខាងឬទេ ។
៩ក្នុងគ្រប់រឿងរំលងច្បាប់អ្វី ទោះពីគោ ពីលា ពីចៀម
ពីខោអាវ ឬពីរបស់ណាបាត់ក៏ដោយ ដែលគេនឹងប្រកាន់
ថា នេះជារបស់ខ្ញុំ នោះរឿងអ្នកទាំងសងខាងត្រូវនាំទៅឯ
ចៅក្រម[ឍ] បើអ្នកណាដែលចៅក្រមបានកាត់ថា មានទោស
អ្នកនោះត្រូវសងគេ១ជា២ ។
១០បើអ្នកណាផ្ញើលា គោ ចៀម ឬសត្វណាទុកនឹងគេ[ណ]
ហើយសត្វនោះស្លាប់ ឬបាក់ជើង ឬមានគេនាំទៅបាត់ ឥត
អ្នកណាឃើញ ១១នោះអ្នកទាំង២ត្រូវស្បថនឹងគ្នា[ត]ដោយនូវ
ព្រះយេហូវ៉ា ដើម្បីឱ្យបានដឹងជាអ្នកនោះ បានដាក់ដៃលើ
របស់ទ្រព្យអ្នកជិតខាងខ្លួនឬទេ ហើយម្ចាស់សត្វនឹងត្រូវរង
សំបថនោះ រួចអ្នកនោះមិនត្រូវសងសំណងទេ ១២ប៉ុន្តែបើ
មានគេលួចសត្វនោះទៅវិញ នោះនឹងត្រូវសងសំណង[ថ] ទៅ
ម្ចាស់ជាពិត ១៣ឬបើត្រូវសត្វណាហែកវា នោះត្រូវយកមក
ធ្វើជាភស្តុតាង ហើយមិនត្រូវសងសំណងពីសត្វណាដែល
ត្រូវហែកហួរនោះទេ[ទ]។
១៤បើអ្នកណាខ្ចីសត្វរបស់គេ ហើយវាបាក់ជើង ឬស្លាប់
ក្នុងកាលដែលម្ចាស់មិនបាននៅជាមួយ នោះត្រូវតែសង
សំណងជាមិនខាន[ធ] ១៥បើម្ចាស់វានៅជាមួយដែរ នោះមិន
ត្រូវសងសំណងទេ បើជាសត្វដែលគេជួល នោះក៏ល្មមនឹង
ថ្លៃឈ្នួលហើយ[ន]។

## ការទទួលខុសត្រូវក្នុងសង្គម

១៦បើអ្នកណាល្បួងលួងលោមស្ត្រីក្រមុំ[ប] ដែលមិនទាន់
មានអ្នកណាដណ្តឹងនៅឡើយ ហើយបានដេកនៅជាមួយនឹង
នាង នោះត្រូវយកនាងធ្វើជាប្រពន្ធទៅ ព្រមទាំងចេញ
បណ្តាការឱ្យផង[ផ] ១៧តែបើឪពុកនាងមិនព្រមឱ្យទៅអ្នក
នោះសោះ នោះត្រូវតែសងថ្លៃតាមបណ្តាការរបស់ស្ត្រី
ក្រមុំវិញ ។

**២១:៣៣** ភ លក ១៤:៥
**២១:៣៦** ម ខ.២៩
**២២:១** ក លវ ៦:១–៧ ២សយ ១២:៦ សភ ៦:៣១ លក ១៩:៨
**២២:២** ខ យប ២៤:១៦ យរ ២:៣៤ ហស ៧:១ មថ ៦:១៩–២០ ២៤:៤៣ គ ជន ៣៥:២៧
**២២:៣** ឃ ខ.១ ង នក ២១:២ មថ ១៨:២៥
**២២:៤** ច ១សយ ១២:៥ ឆ លប ៤៣:១២
**២២:៥** ជ ខ.១
**២២:៦** ឈ ពច ១៥:៥ ញ ខ.១
**២២:៧** ដ ខ.១០ លវ ៦:២ ឋ លប ៤៣:១២
**២២:៨** ឌ នក ២១:៦
**២២:៩** ឍ ខ.៨ ចទ ២៥:១
**២២:១០** ណ ខ.៧
**២២:១១** ត លវ ៦:៣ ១ពវ ៨:៣១ ២របា ៦:២២ ហព ៦:១៦
**២២:១២** ថ ខ.១
**២២:១៣** ទ លប ៣១:៣៩
**២២:១៤** ធ ខ.១
**២២:១៥** ន លវ ១៩:១៣ យប ១៧:៥
**២២:១៦** ប ចទ ២២:២៨ ផ លប ៣៤:១២

មថ ២៦:១៤–១៥ មើល សក ១១:១២–១៣ និងការពន្យល់)។ *រៀល* មើល ការពន្យល់ លប ២០:១៦ ។

**២១:៣៣–៣៦** ក្រឹត្យវិន័យក្នុងវគ្គនេះ គឺស្តីពីការបង្ករបួសស្នាមដល់សត្វ ។

**២២:១–១៥** ក្រឹត្យវិន័យអំពីសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ (មើល ២០:១៥ និងការពន្យល់)។

**២២:២** ការសម្លាប់មនុស្សនៅក្នុងទីងងឹត ដោយមូលហេតុការការពារខ្លួន គឺមិនមានទោស នៃការកំចាយឈាមនោះទេ ។

**២២:៣** ការសម្លាប់ចោរដែលចូលមកនៅពេលថ្ងៃគឺមិនអាចរួចខ្លួនបានទេ។

**២២:៥** *ល្អបំផុត* សំណងគួរតែផ្តោតលើគុណភាព និងបរិមាណដ៏សមរម្យ។

**២២:៦** *គុម្ពបន្លា* ជារឿយៗគេប្រើជារបងការពារចំការ (មក ៧:៤)។

**២២:១១** មើល ២០:៧ និងការពន្យល់។ *ស្បថនឹងគ្នាដោយនូវព្រះយេហូវ៉ា* ចៅក្រមគឺតំណាងរបស់ព្រះក្នុងការកាត់ក្តី (មើល ២១:៦ ២២:៨–៩,២៨ និងការពន្យល់) ។

**២២:១២–១៣** មានក្រឹត្យវិន័យស្រដៀងនឹងក្រឹត្យវិន័យក្នុងវគ្គនេះ ដែលមានអាយុកាលប្រហែលសម័យពួកព្វយុកោរ (មើល លប ៣២:៣៩) ។

**២២:១៦–៣១** *បណ្តាការ* ជាអំណោយពីកូនកម្លោះ មួយសម្រាប់ក្រុមគ្រួសារខាងស្រី (មើល លវ ២៤:៥៣) ក៏ជាប្រពៃណីដែលគេគោរព ជាទម្លាប់របស់ប្រជាជននៅភូមិភាគមជ្ឈឹមបូព៌ារហូតដល់សព្វថ្ងៃ ។

[១៨]កុំទុកឱ្យស្ត្រីដែលជាគ្រូអាបធ្មប់[ព]នៅរស់ឡើយ ។
[១៩]អ្នកណាដែលរួមសង្វាសជាមួយនឹងសត្វ[ភ] នោះត្រូវ
សំឡាប់ចោលជាមិនខាន ។
[២០]អ្នកណាដែលថ្វាយយញ្ញបូជាដល់ព្រះណា[ម] ក្រៅពី
ព្រះយេហូវ៉ាតែ១ នោះនឹងត្រូវបំផ្លាញចេញអស់រលីង[យ]។
[២១]កុំឱ្យធ្វើបាបដល់អ្នកប្រទេសក្រៅ[រ] ក៏កុំឱ្យសង្កត់សង្កិន
គេឡើយ ដ្បិតឯងរាល់គ្នាក៏បាននៅស្រុកអេស៊ីព្ទជាអ្នក
ប្រទេសក្រៅ[ល]ដែរ។
[២២]កុំឱ្យធ្វើទុក្ខដល់ស្ត្រីមេម៉ាយឬកូនកំព្រាណាឡើយ[វ]
[២៣]បើធ្វើទុក្ខដល់គេ ហើយគេអំពាវនាវ[ស]រកអញ នោះអញ
នឹងឮសំរែករបស់គេជាមិនខាន[ហ] [២៤]ហើយសេចក្តីក្រោធ
របស់អញនឹងក្តៅឡើង អញនឹងសំឡាប់ឯងរាល់គ្នាដោយ
ដាវ នោះប្រពន្ធរបស់ឯងរាល់គ្នានឹងត្រឡប់ទៅជាមេម៉ាយ
ហើយកូនឯងនឹងទៅជាកំព្រាដែរ[ឡ]។
[២៥]បើឱ្យរាស្ត្រអញណាមួយ ជាអ្នកទ័លក្រ ដែលនៅជា
មួយនឹងឯង បានខ្ចីប្រាក់ នោះមិនត្រូវប្រព្រឹត្តនឹងគេដូចជា
ម្ចាស់បំណុលទេ ក៏មិនត្រូវយកការពីគេឡើយ[អ]។
[២៦]បើទទួលបញ្ចាំ សំលៀកបំពាក់របស់អ្នកជិតខាង[ក]
នោះត្រូវប្រគល់ទៅគេវិញមុនថ្ងៃលិច [២៧]ដ្បិតជាសំពត់
ដណ្តប់តែ១របស់អ្នកនោះ ជាសំលៀកបំពាក់ខ្លួនគេ តើគេ
នឹងបានអ្វីដណ្តប់ក្នុងកាលដែលទៅដេក[ខ] បើគេអំពាវនាវ
ដល់អញ នោះអញនឹងឮ ដ្បិតអញមានសេចក្តីអាណិតដល់
គេ[គ]។
[២៨]កុំឱ្យប្រមាថមើលងាយដល់ព្រះ[ឃ] ក៏កុំឱ្យជេរប្រទេច[ង]
ដល់ចៅហ្វាយរបស់សាសន៍ឯងឡើយ[ច]។
[២៩]កុំឱ្យបង្អង់នឹងថ្វាយ[ឆ]ផលផ្លែ និងទឹកទំពាំងបាយជូរ
ដំបូងរបស់ឯង១ចំណែកមកអញឡើយ ឯកូនប្រុសៗរបស់
ឯងដែលកើតជាដំបូង នោះក៏ត្រូវថ្វាយដល់អញដែរ[ជ]
[៣០]ហើយទាំងកូនគោកូនចៀមដែលកើតដំបូង[ឈ] នោះត្រូវ
នៅនឹងមេវាអស់៧ថ្ងៃ លុះដល់ថ្ងៃទី៨ នោះត្រូវថ្វាយដល់
អញ[ញ]។
[៣១]ឯងរាល់គ្នាត្រូវបានជាមនុស្សបរិសុទ្ធដល់អញ[ដ] កុំឱ្យ
ស៊ីសាច់ដែលត្រូវសត្វព្រៃហែកនៅឯវាលឡើយ[ឋ] ត្រូវបោះ

**២២:១៨** ព នក ៧:១១ លវ ១៩:២៦, ៣១ ២០:២៧ ចទ ១៨:១១ ១សយ ២៨:៣ ២រប ៣៣:៦ អស ៥៧:៣ **២២:១៩** ភ លវ ១៨:២៣ ២០:១៥ ចទ ២៧:២១ **២២:២០** ម នក ២០:២៣ ៣៤:១៥ លវ ១៧:៧ ជន ២៥:២ ចទ ៣២:១៧ ទដ ១០៦:៣៧ យ លវ ២៧:២៩ ចទ ១៣:៥ ១៧:២–៥ ១៨:២០ ១ពវ ១០:២៥ ២៣:៣០ ២របា ១៥:១៣ **២២:២១** រ នក ២៣:៩ លវ ១៩:៣៣ ២៤:២២ ជន ១៥:១៤ ចទ ១:១៦ ២៤:១៧ អគ ២២:២៩ ល ចទ ចទ ១០:១៩ ២៧:១៩ សក ៧:១០ មឡ ៣:៥ **២២:២២** វ ខ.២៦ ចទ ១០:១៨ ២៤:៦,៩,១២,១៧ យប ២២:៦,៩ ២៤:៣,២១ ទដ ៦៨:៥ ១៤៦:៩ សភ ២៣:១០ អស ១:១៧ យរ ៧:៥,៦ ២១:១២ ២២:៣ អគ ១៨:៥–៩,១២ សក ៧:៩–១០ មឡ ៣:៥ យក ១:២៧ **២២:២៣** ស លក ១៨:៧ ហ ចទ ១០:១៨ ១៥:៩ ២៤:១៥ យប ៣៤:២៨ ៣៥:៩ ទដ ១០:១៤,១៧ ១២:៥ ១៨:៦ ៣៤:១៥ យក ៥:៤ **២២:២៤** ឡ ទដ ៦៩:២៤ ១០៩:៩ បទ ៥:៣ **២២:២៥** អ លវ ២៥:៣៥–៣៧ ចទ ១៥:៧–១១ ២៣:២០ នក ៥:៧។១០ ទដ ១៥:៥ អគ ១៨:៨ **២២:២៦** ក ខ.២២ សភ ២០:១៦ អគ ៣៣:១៥ អម ២:៨ **២២:២៧** ខ ចទ ២៤:១៣,១៧ យប ២២:៦ ២៤:៧ ២៩:១១ ៣១:១៩–២០ អគ ១៨:១២,១៦ គ នក ៣៤:៦ ចទ ៤:៣១ ២រប ៣០:៩ នហ ៩:១៧ ទដ ៩៩:៨ ១០៣:៨ ១១៦:៥ ១៤៥:៨ យអ ២:១៣ យហ ៤:២ **២២:២៨** ឃ នក ២០:៧ ង ២សយ ១៦:៥,៩ ១៩:២១ ១ពវ ២១:១០ ២ពវ ២:២៣ ទដ ១០២:៨ ច សស ១០:២០ កច ២៣:៥ **២២:២៩** ឆ នក ២៣:១៥,១៦,១៩ ៣៤:២០,២៦ លវ ១៩:២៤ ២៣:១០ ជន ១៨:១៣ ២៨:២៦ ចទ ១៨:៤ ២៦:២,១០ ១សយ ៦:៣ នហ ១០:៣៥ សភ ៣:៩ មឡ ៣:១០ ជ នក ១៣:២ ជន ៨:១៦–១៧ លក ២:២៣ **២២:៣០** ឈ នក ៣៤:១៩ ចទ ១៥:១៩ ញ លប ១៧:១២ លវ ១២:៣ ២២:២៧ **២២:៣១** ដ នក ១៩:៦ លវ ១៩:២ ២២:៣១ អរ ៩:២ ឋ លប ៧:២៤ ១៧:១៥ ២២:៨ ចទ ១៤:២១ អគ ៤:១៤ ៤៤:៣១

**២២:១៨** បទគម្ពីរ ចទ ១៨:៩–១២ បានថ្កោលទោសយ៉ាងធ្ងន់ធ្ងរ ចំពោះពួកអាបធ្មប់ ការប្រព្រឹត្តអំពើរបស់ពួកគេ(សូមមើល ១សយ ២៨:៩ អស ៤៧:១២–១៤) ។

**២២:២០** មើល ២០:៣–៥។ ពេលក្រោយមក ព្រះអម្ចាស់បានបង្គាប់ឱ្យពួកអ៊ីស្រាអែលធ្វើការបំផ្លាញទាំងស្រុង ដល់ពួកកាណាដែលថ្វាយបង្គំរូបព្រះ (មើល ចទ ៧:២ ១៣:១៥ ២០:១៧ យស ៦:១៧ ១០:៤០ ១១:១២,២០)។

**២២:២១–២៧** ការមានព្រះទ័យទុក្ខដាក់ និងជំនួយ របស់ព្រះអម្ចាស់សម្រាប់អ្នកក្រ ស្ត្រីមេម៉ាយ ក្មេងកំព្រា និងពួកសាសន៍ដទៃ និយាយរួមគឺអ្នកដែលគ្មានទីពឹង សុទ្ធតែបាននិយាយនៅក្នុងការនិពន្ធរបស់លោកម៉ូសេ(សូមមើល ២១:២៦–២៧ ២៣:៦–១២ លវ ១៩:៩–១០ ចទ ១៤:២៩ ១៦:១១,១៤ ២៤:១៩–២១ ២៦:១២–១៣) អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង(ទដ ១០:១៤, ១៧–១៨ ៦៨:៥ ៨២:៣ ១៤៦:៩) និងពួកហោរា(អស ១:២៣ ១០:២ យរ ៧:៦ ២២:៣ សក ៧:១០ មឡ ៣:៥) ក៏ដូចជាក្នុងការបង្រៀនរបស់ព្រះយេស៊ូវ(សូមមើល មថ ២៥:៣៤–៤៥) និងសាវ័កផងដែរ(សូមមើល រម ១៥:២៦ កទ ២:១០ យក ១:២៧ ២:២–៧) ។

**២២:២៥–២៧** ក្រឹត្យវិន័យក្នុងវគ្គនេះ គឺដោះស្រាយបញ្ហាការប្រាក់(មើល លវ ២៥:៣៥–៣៧ ចទ ១៥:៧–១១ ២៣:១៩–២០ មើល នហ ៥:៧–១២ យប ២៤:៩ ទដ ១៥:៥ សភ ២៨:៨ អគ ១៨:១៣ ២២:១២)។ គេមិនត្រូវយកផលចំណេញពីការប្រាក់ពីអ្នកក្រីក្រទេ ។ ព្រះយេស៊ូវបានបង្រៀនឱ្យមានចិត្តសប្បុរសខ្លាំងជាងនេះទៅទៀត(មើល លក ៦:៣៤–៣៥) ។

**២២:២៦–២៧** អ្នកដែលយកសំលៀកបំពាក់ទៅបញ្ចាំ គឺនៅក្នុងចំណោមអ្នកក្រីក្របំផុត(មើល អម ២:៨ និងការពន្យល់)។

**២២:២៨** *កុំឱ្យ . . . ជេរប្រទេចដល់ចៅហ្វាយរបស់សាសន៍ឯងឡើយ* ព្រោះពួកគេជាអ្នកតំណាងឱ្យព្រះ ។ លោកប៉ុលបានដកស្រង់នូវក្រឹត្យវិន័យនេះមកនិយាយ បន្ទាប់ពីបានជៀលសម្តេចសង្ឃ(មើល កច ២៣:៤–៥)។

**២២:២៩** *ទឹកទំពាំងបាយជូរដំបូង* មើលការពន្យល់ ហក ២:១៦ ។ *កូនប្រុស ៗ . . . ដំបូង* មើលការពន្យល់ ៤:២២ ១៣:២,១៣ និងមើល ១៣:១៥ ។

**២២:៣០** *ហើយទាំងកូនគោ . . . ថ្វាយដល់អញ* មើលការពន្យល់ ១៣:២,១៣ និងមើល ១៣:១២,១៥ ។ *លុះថ្ងៃទី៨ នោះត្រូវថ្វាយដល់អញ* ការថ្វាយកូនច្បង ក៏មានគោលការណ៍ដូចនេះផងដែរ(ការពន្យល់ លប ១៧:១២)។

**២២:៣១** ដោយសាររាស្ត្ររបស់ព្រះ បានរួមគ្នាជា"នគរនៃពួកសង្ឃ" (មើល ១៩:៦ និងការពន្យល់) នោះពួកគេត្រូវប្រព្រឹត្តតាមក្រឹត្យវិន័យ ដែលក្រោយមកមានលក្ខណៈពិសេស សម្រាប់ពួកសង្ឃនៃគ្រួលោកអ៊ើរ៉ុនផងដែរ(មើល លវ ២២:៨)។

ចោលទៅឱ្យឆ្អែវិញ ។

## ក្រឹត្យវិន័យនៃសេចក្ដីយុត្តិធម៌ និងសេចក្ដីមេត្តាករុណា

២៣ ១កុំឱ្យបង្កើតរឿងក្លែងក្លាយឱ្យសោះ[ក] ក៏កុំឱ្យចូលដៃ
នឹងមនុស្សអាក្រក់ ដើម្បីនឹងធ្វើជាទីបន្ទាល់ទុច្ចរិតឡើយ[ខ] ។
២កុំឱ្យតាមពួកមានគ្នាច្រើន[គ] ដើម្បីប្រព្រឹត្តសេចក្ដីអាក្រក់
ហើយកុំឱ្យធ្វើជាទីបន្ទាល់ដល់ពួកក្ដីខាងអ្នកណាដែលមាន
គ្នាច្រើន ដើម្បីនឹងបង្វែរសេចក្ដីយុត្តិធម៌ចេញនោះឡើយ[ឃ]
៣ក៏កុំឱ្យយល់មុខ[ង]ខាងឯអ្នកក្រក្នុងការក្ដីគេដែរ ។
៤បើប្រទះឃើញគោ ឬលា របស់ខ្មាំងសត្រូវ[ច] ដែលវង្វេង
នោះត្រូវឱ្យនាំទៅប្រគល់ដល់ម្ចាស់វិញជាកុំខាន[ឆ] ៥បើ
ឃើញលា[ជ]របស់អ្នកណាដែលស្អប់ឯង វាលុតជង្គង់ចុះ
ដោយសារបន្ទុកធ្ងន់ នោះប្រហែលជាឯងនឹងចង់ធ្វើ
ព្រងើយឥតជួយគេទេ តែមិនត្រូវធ្វើដូច្នោះឡើយ គឺត្រូវ
ជួយដល់គេវិញជាកុំខាន ។
៦កុំឱ្យបង្វែរសេចក្ដីយុត្តិធម៌[ឈ] ក្នុងរឿងក្ដីរបស់អ្នកក្រឱ្យ
សោះ ៧ត្រូវឱ្យចៀសចេញឱ្យឆ្ងាយពីរឿងក្លែងក្លាយ[ញ] ឯ
មនុស្សដែលគ្មានទោស[ដ] និងមនុស្សសុចរិត នោះកុំឱ្យ
សំឡាប់គេឡើយ[ឋ] ដ្បិតឯមនុស្សអាក្រក់ នោះអញមិនដែល
រាប់ជាសុចរិតទេ[ឌ] ៨ក៏កុំឱ្យស៊ីសំណូកឱ្យសោះ[ឍ] ដ្បិតសំណូក
តែងដឹកនាំមនុស្សភ្លឺឱ្យទៅជាខ្វាក់ ហើយក៏បង្ខូចពាក្យរបស់
មនុស្សសុចរិតផង ។
៩កុំឱ្យសង្កត់សង្កិនអ្នកប្រទេសក្រៅឡើយ[ណ] ដ្បិតឯងរាល់
គ្នា ស្គាល់សណ្ឋានចិត្ត របស់អ្នកប្រទេសក្រៅហើយ ដោយ
ធ្លាប់នៅស្រុកអេស៊ីព្ទ ជាអ្នកប្រទេសក្រៅដែរ ។

## ក្រឹត្យវិន័យស្ដីពីថ្ងៃឈប់សម្រាក

១០ក្នុងរវាង៦ឆ្នាំ ត្រូវសាបព្រោះនៅដីឯង ហើយត្រូវ
ច្រូតយកផលផង ១១តែដល់ឆ្នាំទី៧ នោះត្រូវឈប់លែង
ហើយទុកដីឱ្យនៅទំនេរវិញ[ត] ដើម្បីឱ្យពួកមនុស្សទ័លក្របាន
ចិញ្ចឹមជីវិតផង ហើយសំណល់សល់ពីគេ នោះសត្វនៅវាល
ទាំងប៉ុន្មាននឹងបានស៊ី ឯដំណាំទំពាំងបាយជូរ និងដំណាំអូ
លីវរបស់ឯង ក៏ត្រូវធ្វើដូច្នោះដែរ ។
១២ក្នុង៦ថ្ងៃត្រូវធ្វើការរបស់ឯង[ថ] ហើយដល់ថ្ងៃទី៧ ត្រូវ
ឈប់សំរាកវិញ ដើម្បីឱ្យគោ និងលារបស់ឯង បានសំរាក
ផង ហើយដើម្បីឱ្យកូនរបស់បាវស្រីឯង នឹងអ្នកប្រទេសក្រៅ
បានឈប់ដកដង្ហើមសិន[ទ] ១៣ត្រូវឱ្យប្រយ័ត្ន[ធ]និងកាន់តាមអស់
ទាំងសេចក្ដីដែលអញបានប្រាប់ដល់ឯងរាល់គ្នា ហើយកុំឱ្យ
ចេញឈ្មោះរបស់ព្រះដទៃណាឡើយ[ន] ក៏កុំឱ្យឮចេញពីមាត់
ឯងរាល់គ្នាឱ្យសោះ[ប] ។

## បុណ្យទាំងបីប្រចាំឆ្នាំ

១៤ក្នុង១ឆ្នាំត្រូវធ្វើបុណ្យថ្វាយអញ៣ដង[ផ] ១៥ត្រូវធ្វើបុណ្យ
នំបុ័ងឥតដំបែ[ព] គឺដល់កំណត់ក្នុងខែចេត្រ នោះត្រូវធ្វើនំបុ័ង
ឥតដំបែក្នុង៧ថ្ងៃ ដូចជាអញបានបង្គាប់មកហើយ ដ្បិតគឺនៅ
ខែនោះហើយ ដែលឯងរាល់គ្នាបានចេញពីស្រុកអេស៊ីព្ទ
មក[ភ] ហើយមិនត្រូវមកនៅមុខអញដោយដៃទទេឡើយ[ម]
១៦ត្រូវឱ្យធ្វើបុណ្យចំរូត[យ] គឺជាផលដំបូង[រ]អំពីការឯងធ្វើ
ដោយសាបព្រោះនៅដីរបស់ឯង ហើយនិងបុណ្យប្រមូល

**២៣:១** ក លប ៣៩:១៧ មថ ១៩:១៨ លក ៣:១៤ ខ នក ២០:១៦ ចទ ៥:២០ ១៩:១៦-២១ ទដ ២៧:១២ ៣៥:១១ សភ ១៩:៥ កច ៦:១១ **២៣:២** គ យប ៣១:៣៤ ឃ ខ.៣,៦,៩ លវ ១៩:១៥,៣៣ ចទ ១:១៧ ១៦:១៩ ២៤:១៧ ២៧:១៩ ១សយ ៨:៣ **២៣:៣** ង ចទ ១:១៧ **២៣:៤** ច រម ១២:២០ ឆ លវ ៦:៣ ១៩:១១ ចទ ២២:១-៣ **២៣:៥** ជ ចទ ២២:៤ **២៣:៦** ឈ ខ.២ ចទ ២៣:១៦ សភ ២២:២២ **២៣:៧** ញ នក ២០:១៦ អភ ៤:២៥ ដ មថ ២៧:៤ ឋ លប ១៨:២៣ ឌ នក ៣៤:៧ **២៣:៨** ឍ នក ១៨:២១ លវ ១៩:១៥ ចទ ១០:១៧ ២៧:២៥ យប ១៥:៣៤ ៣៦:១៨ ទដ ២៦:១០ សភ ៦:៣៥ ១៥:២៧

១៧:៨ អស ១:២៣ ៥:២៣ មីក ៣:១១ ៧:៣ **២៣:៩** ណ ខ.២ នក ២២:២១ លវ ១៩:៣៣-៣៤ អគ ២២:៧ **២៣:១១** ត លប ២៥:១-៧ នហ ១០:៣១ **២៣:១២** ថ នក ២០:៩ លក ១៣:១៤ ទ លប ២:២-៣ **២៣:១៣** ធ ចទ ៤:៩,២៣ ១ធថ ៤:១៦ ន ខ.៣២ ចទ ១២:៣ យស ២៣:៧ ទដ ១៦:៤ សក ១៣:២ ប ចទ ១៨:២០ យស ២៣:៧ ទដ ១៦:៤ ហស ២:១៧ **២៣:១៤** ផ ខ.១៧ នក ១២:១៤ ៣៤:២៣,២៤ ចទ ១៦:១៦ ១ពវ ៩:២៥ ២រប ៨:១៣ អគ ៤៦:៩ **២៣:១៥** ព នក ១២:១៧ មថ ២៦:១៧ លក ២២:១ កច ១២:៣ ភ នក ១២:២ ម នក ៣៤:២០ ចទ ១៦:១៦ **២៣:១៦** យ លវ ២៣:១៥-២១ ជន ២៨:២៦ ចទ ១៦:៩ ២រប ៨:១៣ រ នក ២២:២៩ ៣៤:២២

**២៣:១-៩** ភាគច្រើននៃក្រឹត្យវិន័យក្នុងវគ្គនេះ គឺទាក់ទងនឹង ២០:១៦ ។

**២៣:១** មើល លវ ១៩:១៦ ចទ ២២:១៣-១៩ ១ពវ ២១:១០-១៣ ។

**២៣:៤-៥** គឺត្រូវប្រព្រឹត្តចំពោះអ្នកដែលជាសត្រូវ ដូចអ្នកដទៃដែរ (មើល ចទ ២២:១-៤ សភ ២៥:២១) ។ ព្រះគ្រីស្ទទ្រង់ក៏បានបង្រៀនឱ្យស្រឡាញ់ខ្មាំងសត្រូវផងដែរ (មថ ៥:៤៤) ។

**២៣:៨** មើល ចទ ១៦:១៩ ។

**២៣:១០-១៣** គឺជាការបន្តក្រឹត្យវិន័យនៅក្នុង ២០:៨-១១ ចទ ៥:១២-១៥ ។

**២៣:១៤-១៩** មើល ៣៤:១៨-២៦ លវ ២៣:៤-៤៤ ជន ២៨:១៦-២៩:៤០ ចទ ១៦:១-១៧ ។

**២៣:១៥** *បុណ្យនំបុ័ងឥតដំបែ* គឺជាពិធីបុណ្យមួយ ចាប់ពីថ្ងៃ១៥រហូតដល់ថ្ងៃ២១គឺជាខែទី១ (ជារឿយៗ ក្នុងពាក់កណ្ដាលខែមិនា រហូតដល់ខែមេសា មើលការពន្យល់ ១២:២) គឺនៅពេលដើមចម្រូតស្រូវឱក គឺជាបុណ្យរំលឹកដល់ការធ្វើនិក្ខមនំនៃពួកអ៊ីស្រាអែល ។

**២៣:១៦** *បុណ្យប្រមូលផល* គេក៏អាចហៅម្យ៉ាងទៀតថា "បុណ្យអាទិត្យទី៧" (៣២:២២) ព្រោះគេធ្វើនៅសប្ដាហ៍ទី៧បន្ទាប់ពីបុណ្យនំបុ័ងឥតដំបែ ។ គេធ្វើបុណ្យនេះនៅថ្ងៃទី៦នៃខែទី៣ (គឺក្នុងចន្លោះពាក់កណ្ដាលខែឧសភាដល់ពាក់កណ្ដាលខែមិថុនា) ក្នុងពេលប្រមូលផលស្រូវសាឡី ។ ក្រោយមកសាសនានៃសាសន៍យូដា បានធ្វើពិធីនេះដើម្បីរំឭកដល់ ការទទួលក្រឹត្យវិន័យនៅភ្នំស៊ីណាយ ទោះបីជាព្រះគម្ពីរសញ្ញាចាស់មិនបានបង្រៀនដូចនេះក៏ដោយ ។ តែគ្រាសញ្ញាថ្មី គេហៅបុណ្យនេះថា "បុណ្យថ្ងៃទី៥០" (កច ២:១ ២០:១៦ ១កថ ១៦:៨ និងមើល លវ ២៣:១៦) ។ *បុណ្យប្រមូលផលចុងឆ្នាំ* ក៏គេអាចហៅថា "បុណ្យបារាំ" (លវ ២៣:៣៤ មើលការពន្យល់ សក

ផល[ល]ដល់ចុងឆ្នាំ ក្នុងកាលដែលឯងបានប្រមូលផលកើត
អំពីការរបស់ឯងធ្វើនៅចំការមក[វ] ១៧គឺក្នុង១ឆ្នាំ ត្រូវឱ្យ
ពួកប្រុសៗ មកនៅចំពោះព្រះយេហូវ៉ា ជាព្រះអម្ចាស់ គ្រប់
៣ដង[ស]។
១៨កុំឱ្យយកឈាមរបស់យញ្ញបូជានៃអញ ថ្វាយជាមួយ
នឹងនំបុ័ងមានដំបែឡើយ[ហ] ហើយមិនត្រូវទុកខ្លាញ់នៃដង្វាយ
នោះតាំងពីល្ងាចដល់ព្រឹកទេ[ឡ]។
១៩ឯចំណែកមុនបង្អស់នៃផលដំបូង[អ] ដែលកើតពីដីរបស់
ឯង នោះត្រូវនាំចូលទៅក្នុងដំណាក់ព្រះយេហូវ៉ា ជាព្រះនៃ
ឯង ។
កុំឱ្យស្ងោរកូនពពែនឹងទឹកដោះរបស់មេវាឡើយ[ក]។
២០មើល អញចាត់ទេវតា១[ខ]ឱ្យនាំមុខឯង ដើម្បីនឹងជួយ
ទំនុកបំរុងឯងតាមផ្លូវ ហើយនិងនាំទៅដល់ទីកន្លែងដែល
អញបានរៀបចំទុកឱ្យ[គ] ២១ចូរប្រយ័ត្ននឹងស្តាប់បង្គាប់តាម[ឃ]
ទ្រង់ កុំឱ្យបណ្តាលឱ្យទ្រង់ខ្ញាល់ឡើយ ដ្បិតទ្រង់មិនអត់
ទោស[ង]ការរំលងរបស់ឯងរាល់គ្នាទេ[ច] ពីព្រោះឈ្មោះ
អញ[ឆ]នៅក្នុងទ្រង់ ២២បើឯងប្រុងស្តាប់បង្គាប់ទ្រង់ ហើយ
ប្រព្រឹត្តតាម[ជ]សេចក្តីដែលអញប្រាប់ទាំងប៉ុន្មាន នោះអញ
នឹងធ្វើជាសត្រូវ[ឈ] ដល់ពួកសត្រូវរបស់ឯង ហើយជាអ្នកត
តាំងនឹងអស់អ្នកដែលតតាំងនឹងឯង ២៣ដ្បិតទេវតាអញនឹង
ទៅមុនឯង ហើយនិងនាំឯងទៅឯពួកសាសន៍អាម៉ូរី សាសន៍
ហេត សាសន៍ពេរិស៊ីត សាសន៍កាណាន សាសន៍ហេវី និង
សាសន៍យេប៊ូស[ញ] ហើយអញនឹងធ្វើឱ្យសាសន៍ទាំងនោះ
សាបសូន្យទៅ ។
២៤កុំឱ្យក្រាបថ្វាយបង្គំឬគោរពប្រតិបត្តិ[ដ]ដល់ព្រះរបស់
គេឱ្យសោះ ក៏កុំឱ្យប្រព្រឹត្តតាមអំពើរបស់គេឡើយ[ឋ] គឺត្រូវឱ្យ
បំផ្លាញ[ឌ]គេអស់រលីងវិញ ព្រមទាំងបំបាក់បំបែករូបព្រះ
គេ[ឍ]ឱ្យខ្ទេចខ្ទីផង ២៥ត្រូវឱ្យឯងរាល់គ្នាគោរពប្រតិបត្តិដល់
ព្រះយេហូវ៉ា ជាព្រះនៃឯងវិញ[ណ] នោះទ្រង់នឹងប្រទានពរ[ត]
ដល់អាហារ និងទឹករបស់ឯង ហើយអញនឹងដកជំងឺរោគា[ថ]
ពីពួកឯងរាល់គ្នាចេញ ២៦នៅក្នុងស្រុកឯង នឹងគ្មានអ្វី
រលូតកូន ឬនៅអារឡើយ[ទ] អញក៏នឹងបំពេញអាយុរបស់ឯង
ឱ្យពោរពេញ[ធ] ២៧អញនឹងចាត់សេចក្តីស្ញែងខ្លាចរបស់
អញ[ន]ទៅមុនឯង ហើយនិងបំផ្លាញ[ប]គ្រប់ទាំងសាសន៍ដែល
ឯងទៅដល់ អញនឹងធ្វើឱ្យអស់ទាំងខ្មាំងសត្រូវឯងត្រូវបែរ
ខ្នងនៅមុខឯង[ផ] ២៨អញនឹងចាត់ឱម៉ាល់[ព]ទៅមុនឯង ដែល
នឹងបណ្តេញសាសន៍ហេវី សាសន៍កាណាន ហើយនិង

**២៣:១៦** ល នក ៣៤:២២ លវ ២៣:៣៤,៤២ ចទ ១៦:១៦ ៣១:១០ អរ ៣:៤ នហ ៨:១៤ សក ១៤:១៦ វ លប ២៣:៣៩ ចទ ១៦:១៣ យរ ៤០:១០ **២៣:១៧** ស ខ.១៤ **២៣:១៨** ហ នក ៣៤:២៥ លវ ២:១១ ឡ នក ១២:៨ **២៣:១៩** អ នក ២២:២៩ ៣៤:២២ ជន ១៨:១២ ក នក ៣៤:២៦ ចទ ១៤:២១ **២៣:២០** ខ លប ១៦:៧ គ នក ១៥:១៧ **២៣:២១** ឃ ចទ ១៨:១៩ យរ ១៣:១៥ ង ចទ ២៩:២០ ២ពវ ២៤:៤ បទ ១:១៧ ច ជន ១៧:១០ ចទ ៩:៧ ៣១:២៧ យស ២៤:១៩ ទដ ២៥:៧ ៧៨:៨,៤០,៥៦ ១០៦:៣៣ ១០៧:១១ ឆ ១យហ ៥:១៦ ឆ នក ៣:១៥ **២៣:២២** ជ នក ១៥:២៦ ឈ លប ១២:៣ អស ៤១:១១ យរ ៣០:២០ **២៣:២៣** ញ ជន ១៣:២៩ ២១:២១ យស ៣:១០ ២៤:៨,១១ អរ ៩:១ ទដ ១៣៥:១១ **២៣:២៤** ដ នក ២០:៥ ឋ លវ ១៨:៣ ២០:២៣ ចទ ៩:៤ ១២:៣០–៣១ យរ ១០:២ ឌ នក ៣៤:១៣ ជន ៣៣:៥២ ចទ ៧:៥ ១២:៣ ពច ២:២ ២ពវ ១៨:៤ ២៣:១៤ ឍ លវ ២៦:១ ចទ ១៦:២២ ១ពវ ១៤:២៣ ២ពវ ៣:២ ១០:២៦ ១៧:១០ ២រប ១៤:៣ អស ២៧:៩ **២៣:២៥** ណ មថ ៤:១០ ត លវ ២៦:៣–១៣ ចទ ៧:១២–១៥ ២៨:១–១៤ ថ នក ១៥:២៦ **២៣:២៦** ទ លវ ២៦:៣–៤ ចទ ៧:១៤ ២៨:៤ មឡ ៣:១១ ធ លប ១៥:១៥ ចទ ៤:១,៤០ ៣២:៤៧ ទដ ៩០:១០ **២៣:២៧** ន លប ៣៥:៥ នក ១៥:១៤ ប នក ១៤:២៤ ចទ ៧:២៣ ផ ២សយ ២២:៤១ ទដ ១៨:៤០ ២១:១២ **២៣:២៨** ព ចទ ៧:២០ យស ២៤:១២

១៤:១៦) ដោយព្រោះរាស្ត្រអ៊ីស្រាអែលបានរស់នៅ បណ្តោះអាសន្នក្នុងជំរុំនៃស្រុកអេស៊ីព្ទ ហើយព្រះបាននាំពួកគេចេញពីស្រុកអេស៊ីព្ទវិញ(មើល លវ ២៣:៤២–៤៣)។ គឺពីថ្ងៃទី១៥រហូតដល់ថ្ងៃទី២២ នៃរយៈពេលក្នុងថ្ងៃទី៧ (ជារៀយៗ គឺប្រហែលពីពាក់កណ្តាលខែកញ្ញា រហូតដល់កណ្តាលខែតុលា) គឺនៅពេលគេប្រមូលផលផ្លែទំពាំងបាយជូរទុក ហើយបុណ្យនេះជាការរំលឹកពីដំណើរវិលវល់នៅក្នុងទីរហោស្ថាន បន្ទាប់ពីការធ្វើនិក្ខមនំ ។ *ចុងឆ្នាំ* គឺជាចុងនៃឆ្នាំធ្វើកសិកម្ម ដែលមានតាំងពីរដូវស្លឹកឈើជ្រុះ(មើលការពន្យល់ ១២:២)។

**២៣:១៧** *ពួកប្រុសៗ* តាមធម្មតា ពួកគេមានក្រុមគ្រួសាររួមដំណើរផងដែរ (មើលឧទាហរណ៍ក្នុង ១សយ ១) ។

**២៣:១៨** *កុំឱ្យយកឈាម . . . នំបុ័ងមានដំបែឡើយ* សូមមើលការពន្យល់ ១២:១៥ ។ *មិនត្រូវទុកខ្លាញ់នៃដង្វាយនោះតាំងពីល្ងាចដល់ព្រឹកទេ* មើល ១២:៩–១០ ។

**២៣:១៩** *ផលដំបូង* គឺជាតំណាងឱ្យផលចម្រូតទាំងមូល ។ ការថ្វាយដង្វាយនៃផលដំបូង គឺដើម្បីបញ្ជាក់ថា ភោគផលគឺបានមកពីព្រះអម្ចាស់ ហើយជាសម្បត្តិទ្រង់ទាំងអស់ ។ *កុំស្ងោរកូនពពែនឹងទឹកដោះរបស់មេវាឡើយ* ដើម្បីបំពេញតាមក្រឹត្យវិន័យនេះ ពួកគ្រូនៃសាសនាយូដា បានបង្កើតច្បាប់ដោយខ្លួនពួកគេ ដោយហាមមិនឱ្យបរិភោគសាច់ និងទឹកដោះគោនៅក្នុងពេលទទួលទានអាហារតែមួយ ។

**២៣:២០** *ទេវតា* មើល ១៤:១៩ និងការពន្យល់ លប ១៦:៧ ។ *ទីកន្លែងដែលអញបានរៀបចំទុកឱ្យ* ដូចជាទឹកដីកាណាន(ព្រះយេស៊ូវមានបន្ទូលស្រដៀងគ្នានឹងការនេះនៅក្នុង យហ ១៤:២–៣) ។

**២៣:២១** *ឈ្មោះ* គឺជាតំណាងឱ្យព្រះវត្តមានរបស់ព្រះ(មើលការពន្យល់ ចទ ១២:៥) ។

**២៣:២២** *បើ* មើលការពន្យល់ ១៩:៥ ។

**២៣:២៣** មើល ៣:៨ និងការពន្យល់ ។

**២៣:២៥–២៦** ចំពោះការនិយាយអំពីព្រះពរតាមសេចក្តីសញ្ញា មើល លវ ២៦:៣–១៣ ចទ ៧:១៣–១៥ ២៨:១–១៤ ៣១:១–១០ ។

**២៣:២៧** *សេចក្តីស្ញែងខ្លាចរបស់អញ* មើលការពន្យល់ ១រប ១៤:១៧ ។

**២៣:២៨** *ឱម៉ាល់* ជួនកាលព្រះអម្ចាស់បានសន្យាបញ្ជូនភ្នាក់ងាររបស់ទ្រង់ គឺសត្វល្អិត ដើម្បីរារាំង ឬបំភ័យពួកសាសន៍កាណាន ដើម្បីឱ្យពួកគេមិនអាចតតាំងនឹងការចូលវាយកាន់កាប់ទឹកដីនោះបាន ។ នៅក្នុងព្រះគម្ពីរភាសារហេព្រើគេមិនទាន់ដឹងច្បាស់ថា សត្វល្អិតនោះជាអ្វីទេ ប៉ុន្តែ ការដែលសំខាន់គេត្រូវផ្តោតការសិក្សាទៅលើលទ្ធផលដែលកើតពីសត្វនោះ ។

សាសន៍ហេត[ភ] ពីមុខឯងចេញ ២៩អញមិនបណ្តេញគេចេញ
ពីមុខឯងក្នុង១ឆ្នាំតែម្តងទេ ក្រែងស្រុកនោះនឹងត្រឡប់ទៅ
ជាស្ងាត់ ហើយកើតមានសត្វព្រៃជាច្រើនឡើង[ម] ធ្វើបាប
ដល់ឯងវិញ ៣០គឺនឹងបណ្តេញគេពីមុខឯងទៅបន្តិចម្តងៗ
ទាល់តែឯងមានគ្នាច្រើន ល្មមនឹងទទួលយក[យ]ស្រុកជាមរ
ដកបាន ៣១នោះអញនឹងដាក់ព្រំស្រុកឱ្យឯងចាប់តាំងពី
សមុទ្រក្រហម ទៅដល់សមុទ្រភីលីស្ទីន ហើយតាំងពីទី
រហោស្ថានរហូតដល់ទន្លេ[រ] ដ្បិតអញនឹងប្រគល់មនុស្សនៅ
ស្រុកនោះ មកក្នុងកណ្តាប់ដៃឯង[ល] ហើយឯងនឹងបណ្តេញ
គេពីមុខឯងចេញ ៣២កុំឱ្យតាំងសេចក្តីសញ្ញា[វ]នឹងគេ ឬនឹង
ព្រះរបស់គេឡើយ ៣៣ក៏មិនត្រូវឱ្យគេនៅក្នុងស្រុករបស់
ឯងដែរ ក្រែងគេនាំឱ្យឯងធ្វើបាបចំពោះអញ ដ្បិតបើឯង
គោរពប្រតិបត្តិដល់ព្រះគេ នោះនឹងត្រឡប់ជាអន្ទាក់[ស]
ដល់ឯងហើយ ។

## ការបញ្ជាក់ការតាំងសេចក្តីសញ្ញា

**២៤** ១ទ្រង់ក៏មានបន្ទូលនឹងម៉ូសេថា ចូរឯង និងអើរ៉ុន[ក]
ព្រមទាំងណាដាប អ័ប៊ីហ៊ូវ[ខ] ហើយនិងពួកចាស់ទុំ[គ]សាសន៍
អ៊ីស្រាអែលទាំង៧០នាក់ ឡើងមកឯព្រះយេហូវ៉ា ហើយឱ្យ
ថ្វាយបង្គំពីចំងាយ ២ត្រូវឱ្យម៉ូសេតែម្នាក់ឯងចូលមកជិត[ឃ]
ព្រះយេហូវ៉ា ចំណែកអ្នកឯទៀតមិនត្រូវឱ្យចូលមកជិតទេ
ហើយពួកបណ្តាជនក៏មិនត្រូវទាំងឡើងមកជាមួយផង ។

៣នោះម៉ូសេក៏ទៅប្រាប់ដល់បណ្តាជន តាមគ្រប់ទាំងព្រះ
បន្ទូលនៃព្រះយេហូវ៉ា ហើយនិងបញ្ញត្តិទាំងនោះ[ង] រួចពួក
ជនទាំងអស់គ្នាក៏ទទួលព្រមថា យើងខ្ញុំរាល់គ្នានឹងធ្វើតាម
អស់ទាំងសេចក្តីដែលព្រះយេហូវ៉ាមានបន្ទូលមក[ច] ។
៤ម៉ូសេក៏កត់[ឆ]អស់ទាំងព្រះបន្ទូលនៃព្រះយេហូវ៉ា រួច
លោកក្រោកពីព្រលឹមទៅស្អាងអាសនា១[ជ]នៅជើងភ្នំ ហើយ
ក៏បញ្ឈរថ្ម១២[ឈ] តាមចំនួនពូជអំបូរសាសន៍អ៊ីស្រាអែល
ទាំង១២ ៥រួចលោកចាត់ពួកកំលោះៗ ជាកូនចៅពួក
អ៊ីស្រាអែលឱ្យទៅថ្វាយដង្វាយដុត[ញ] ហើយនិងសំឡាប់គោ
ឈ្មោលថ្វាយជាដង្វាយមេត្រី[ដ]ដល់ព្រះយេហូវ៉ា ៦លោក[ឋ]ក៏
យកឈាមពាក់កណ្តាល[ឌ] ដាក់ក្នុងផើង ហើយពាក់កណ្តាល
ទៀតប្រោះ[ឍ]ទៅលើអាសនា ៧រួចយកសៀវភៅសញ្ញា[ណ]
មកអានមើលឱ្យបណ្តាជនស្តាប់ គេក៏ឆ្លើយឡើងថា យើងខ្ញុំ
រាល់គ្នានឹងធ្វើតាមគ្រប់អស់ទាំងសេចក្តី ដែលព្រះយេហូវ៉ា
បានមានបន្ទូលមក ហើយនិងស្តាប់បង្គាប់គ្រប់ចំពូកផង[ត]
៨ដូច្នេះម៉ូសេលោកយកឈាមទៅប្រោះលើជនទាំងឡាយ[ថ]

**២៣:២៨** ភ នក ៣៣:២ ៣៤:១១,២៤ ជន ១៣:២៩ ចទ ៤:៣៨ ១១:២៣ ១៨:១២ យស ៣:១០ ២៤:១១ ទដ ៧៨:៥៥ **២៣:២៩** ម ចទ ៧:២២ **២៣:៣០** យ យស ២៣:៥ **២៣:៣១** រ លប ២:១៤ ចទ ៣៤:២ អរ ៤:២០ ល ចទ ៧:២៤ ៩:៣ យស ២១:៤៤ ២៤:១២,១៨ ទដ ៨០:៨ **២៣:៣២** វ លប ២៦:២៨ នក ៣៤:១២ ចទ ៧:២ យស ៩:៧ ពច ២:២ ១សយ ១១:១ ១ពវ ១៥:១៩ ២០:៣៤ អគ ១៧:១៣ **២៣:៣៣** ស នក ១០:៧ **២៤:១** ក នក ១៩:២៤ ខ នក ៦:២៣ គ ខ.៩ ជន ១១:១៦ **២៤:២** ឃ ជន ១២:៦–៨ **២៤:៣** ង នក ២១:១ កទ ៣:១៩ ច នក ១៩:៨ យស ២៤:២៤ **២៤:៤** ឆ នក ១៧:១៤ ជ លប ៨:២០ ឈ លប ២៨:១៨ ចទ ២៧:២ **២៤:៥** ញ លវ ១:៣ ដ លប ៣១:៥៤ **២៤:៦** ឋ នក ១៤:១៥ ៣២:៣១ ទដ ៩៩:៦ ឌ ហព ៩:១៨ ឍ លវ ១:១១ ៣:២,៨,១៣ ៥:៩ មថ ២៦:២៨ **២៤:៧** ណ ២ពវ ២៣:២,២១ ហព ៩:១៩ ត នក ១៩:៨ យរ ៤០:៣ ៤២:៦,២១ ៤៣:២ **២៤:៨** ថ ហប ៩:១៩ ១ពត ១:២

**២៣:៣០** *បន្តិចម្តងៗ* មើល ពច ជំពូក ១ ។

**២៣:៣១** មើល លប ១៥:១៨ ១ពវ ៤:២១ ។ *សមុទ្រក្រហម* គឺនៅឯព្រំប្រទល់ភាគអាគ្នេយ៍(នៅឈូងសមុទ្រ អាកាបា Aqaba សព្វថ្ងៃ មើលការពន្យល់ ១ពវ ៩:២៦)។ *សមុទ្រភីលីស្ទីន* នៅព្រំខាងលិច ។ *ទីរហោស្ថាន* នៅព្រំខាងត្បូង(នៅភ្នំស៊ីណាយភាគឦសាន, សូមមើលការពន្យល់ លប ១៥:១៨)។ *ទន្លេ* នៅព្រំផ្នែកខាងជើង ។

**២៣:៣៣** *អន្ទាក់* ជានិមិត្តសញ្ញានៃភាពហិនវិនាស(មើល ១០:៧ យប ១៨:៩ ទដ ១៨:៥ សភ ១៨:៥ ទដ ១៣:១៤ ២១:៦ អស ២៤:១៧–១៨)។

**២៤:១** *ឡើងមកឯ* ការនេះបានបន្តពី ២០:២១ បន្ទាប់ពីបានផ្អាក ដោយសារសៀវភៅសញ្ញា(២០:២២–២៣:៣៣)។ លោកម៉ូសេ និងអ្នកជំនួយគាត់បានឡើងភ្នំបន្ទាប់ពីព្រឹត្តិការណ៍ដែលកើតឡើងក្នុង ខ.៣–៨ ។ *ណាដាប់ អ័ប៊ីហ៊ូវ* ជាកូនច្បងទាំងពីររបស់លោកអើរ៉ុន ។ លោកណាដាបត្រូវស្នងការងារជាសម្តេចសង្ឃពីលោកអើរ៉ុន តែគាត់ត្រូវស្លាប់ជាមួយលោកអ័ប៊ីហូវ ដោយសារការថ្វាយភ្លើងដទៃ(មើល លវ ១០:២ ជន ៣:៤ និងការពន្យល់)។ *ពួកចាសទុំ . . . ៧០នាក់* ធៀបនឹង ជន ១១:១៦ ប្រហែលជា តំណាងឱ្យកូនចៅទាំង៧០នាក់របស់លោកយ៉ាកុប(១:៥ លប ៤៦:២៧ និងការពន្យល់)។ *ពួកចាស់ទុំ* មើលការពន្យល់ ៣:១៦ ។ *ពីចំងាយ* មើល ២០:២១ ។

**២៤:២** *ម៉ូសេតែម្នាក់ឯង* គឺជាបុគ្គលកណ្តាលរវាងព្រះអម្ចាស់ និងរាស្ត្រអ៊ីស្រាអែល ។ ព្រះយេស៊ូវទ្រង់ធំឧត្តមជាងលោកម៉ូសេ(មើល ហព ៣:១–៦) ហើយ"ជាអ្នកកណ្តាលនៃសេចក្តីសញ្ញាថ្មី"(ហព ១២:២៤)។

**២៤:៣** *ព្រះបន្ទូល* គេជឿថា លោកម៉ូសេប្រើពាក្យនេះ សំដៅទៅលើក្រឹត្យវិន័យទាំង១០ប្រការ(មើល ៣០:១ និងការពន្យល់) ហើយប្រើពាក្យបញ្ញត្តិសំដៅទៅលើសៀវភៅសញ្ញា(២០:២២–២៣:១៩)។ *យើងរាល់គ្នានឹងធ្វើ* មើល ខ.៧ និងមើល ១៩:៨ និងការពន្យល់ ។

**២៤:៤** *ម៉ូសេក៏កត់* មើលការពន្យល់ ១៧:១៤ និងសេចក្តីផ្តើមត្រង់ចំណុច អ្នកនិពន្ធ និងកាលបរិច្ឆេទនៃការសរសេរ ។ *ក៏បញ្ឈរថ្ម១២ តាមចំនួនពូជអំបូរ* មើល យស ៤:៥,២០ ១ពវ ១៨:៣១ ។

**២៤:៥** *ពួកកំលោះៗ ជាកូនចៅពួកអ៊ីស្រាអែល* មើលការពន្យល់ ១៩:២២។

**២៤:៦** *ឈាមពាក់កណ្តាលដាក់ក្នុងផើង . . . ពាក់កណ្តាលទៀត* ការចែកឈាមជាពីរផ្នែកនេះ គឺបង្ហាញពីលក្ខណៈពីរយ៉ាងនៃសេចក្តីសញ្ញា(ខ.៨)គឺៈ ឈាមនៅលើអាសនា តំណាងឱ្យការអត់ទោសពីព្រះ និងការដែលទ្រង់ទទួលដង្វាយ ហើយឈាមក្នុងផើងគឺតំណាងឱ្យចំណងនៃសេចក្តីសញ្ញា ដែលតម្រូវឱ្យពួកគេស្តាប់បង្គាប់(មើល ខ.៣,៧) ។

**២៤:៧** *សៀវភៅសញ្ញា* បានចែងពីសៀវភៅនេះនៅក្នុង ២០:២២–២៣:១៩(មើលការពន្យល់ខនេះ) តែក្នុងខនេះ បាននិយាយបង្ហើបពីក្រឹត្យវិន័យក្នុង ២០:២–១៧ ២៣:២០–២៣ ។ *យើងខ្ញុំរាល់គ្នានឹងធ្វើតាម . . . នឹងស្តាប់បង្គាប់* មើល ខ.៣ មើល ១៩:៨ និងការពន្យល់ ។

**២៤:៨** *ដូច្នេះ* ទាល់តែព្រមស្តាប់បង្គាប់ ទើបពួកគេអាចតាំងសេចក្តីសញ្ញា

ដោយពាក្យថា នេះជាឈាមនៃសេចក្តីសញ្ញា[ទ] ដែលព្រះ
យេហូវ៉ាបានតាំងនឹងអ្នករាល់គ្នា តាមព្រះបន្ទូលទ្រង់ទាំង
នេះ។
៩បន្ទាប់នោះម៉ូសេក៏ឡើងទៅ នាំទាំងអើរ៉ុន ណាដាប
អ័ប៊ីហ៊ូវ ហើយនិងពួកចាស់ទុំ[ធ]សាសន៍អ៊ីស្រាអែលទាំង៧០
នាក់ផង ១០គេក៏បានឃើញ[ន]ព្រះនៃសាសន៍អ៊ីស្រាអែល
ហើយនៅក្រោមព្រះបាទទ្រង់ មានដូចជាកំរាលធ្វើពីត្បូង
កណ្តៀង[ប]ស្រឡះត្រចះដូចផ្ទៃមេឃ[ផ] ១១តែទ្រង់មិនបាន
ដាក់ព្រះហស្តលើពួកកូនចៅអ៊ីស្រាអែលមានត្រកូលខ្ពស់
ទាំងនោះទេ គេបានឃើញ[ព]ព្រះអង្គ រួចក៏នាំគ្នាបរិភោគ
ភោជន៍[ភ]។
១២រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរឡើង
មកឯអញនៅលើភ្នំឱ្យបាននៅឯណោះចុះ អញនឹងឱ្យក្រិត្យ
វិន័យ ហើយនិងសេចក្តីបង្គាប់ទាំងប៉ុន្មានដែលអញបាន
ចារិកទុកនៅបន្ទះថ្ម[ម]ដល់ឯង សំរាប់នឹងបង្រៀនដល់
បណ្តាជន ១៣នោះម៉ូសេ និងយូស្វេ[យ] ជាអ្នកជំនួយការ លោក
ក៏ក្រោកឡើង ហើយម៉ូសេលោកឡើងទៅលើភ្នំ[រ]ព្រះ
១៤លោកបង្គាប់ដល់ពួកចាស់ទុំថា ចូរអ្នករាល់គ្នារង់ចាំយើង
នៅទីនេះចុះ ទំរាំយើងត្រឡប់មកវិញ មើល មានអើរ៉ុននិង
ហ៊ើរ[ល] នៅជាមួយនឹងអ្នករាល់គ្នាហើយ បើអ្នកណាកើត
មានវិវាទទាស់ទែងគ្នា[វ] នោះត្រូវចូរមកសួរលោកចុះ ។
១៥ម៉ូសេក៏ឡើងទៅភ្នំស៊ីណាយ ហើយមានពពក[ស]គ្រប
លើភ្នំ ១៦សិរីល្អ[ហ]នៃព្រះយេហូវ៉ាក៏នៅលើភ្នំ[ឡ] ហើយពពក
ក៏គ្របលើភ្នំពេញចំនួន៦ថ្ងៃ នោះដល់ថ្ងៃទី៧ ទើបទ្រង់
មានបន្ទូលពីកណ្តាលពពកហៅម៉ូសេ[អ] ១៧ឯសិរីល្អនៃព្រះ
យេហូវ៉ា នោះមើលទៅដូចជាភ្លើងឆេះ[ក]នៅលើភ្នំ ចំពោះ
ដល់ភ្នែកនៃពួកកូនចៅអ៊ីស្រាអែល ១៨ម៉ូសេលោកចូលក្នុង
ពពកឡើងទៅភ្នំ ហើយក៏នៅឯណោះអស់៤០[ខ]ថ្ងៃ៤០យប់[គ]។

## ការថ្វាយដង្វាយសម្រាប់រោងឧបោសថ

*២៥:១-៧ – នក ៣៥:៤-៩*

**២៥** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២ចូរ
ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល ឱ្យគេយកដង្វាយមកថ្វាយ
អញ ត្រូវទទួលដង្វាយដែលថ្វាយដល់អញនោះ ពីអស់អ្នក
ណាដែលថ្វាយដោយស្ម័គ្រ[ក]ពីចិត្ត ៣នេះជាដង្វាយដែលឯង
ត្រូវទទួលពីគេ គឺជាមាស ប្រាក់ លង្ហិន ៤ហើយអំបោះ
ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌ក្រហម[ខ] និងអំបោះខ្លូតទេស
យ៉ាងម៉ដ្តព្រម ទាំងរោមពពែ ៥ស្បែកចៀមឈ្មោលជ្រលក់
ពណ៌ក្រហម ស្បែកផ្សោត[គ] និងឈើនាងនួន[ឃ] ៦ប្រេងសំរាប់
ដុត[ង]គ្រឿងក្រអូបសំរាប់ប្រេងចាក់លាប ហើយសំរាប់

**២៤:៨** ទ លវ ២៦:៣ ចទ ៥:២-៣ យស ២៤:២៥ ២ពវ ១១:១៧ យរ ១១:៤,៨ ៣១:៣២ ៣៤:១៣ សក ៩:១១ មថ ២៦:២៨ លក ២២:២០ ហព ៩:២០ **២៤:៩** ធ ខ.១ **២៤:១០** ន លប ១៦:១៣ ជន ១២:៦ អស ៦:១ អក ១:១ ៨:៣ ៤០:២ យហ ១:១៨ ប យប ២៨:១៦ អស ៥៤:១១ អក ១:២៦ ១០:១ ផ វវ ៤:៣ **២៤:១១** ព ខ.១០ នក ៣:៦ ១៩:២១ ភ អក ៤៤:៣ មថ ២៦:២៩ **២៤:១២** ម នក ៣១:១៨ ៣២:១៥-១៦ ៣៤:១,២៨,២៩ ចទ?៤:១៣ ៥:២២ ៨:៣ ៩:៩,១០,១១ ១០:៤ ២កថ ៣:៣ **២៤:១៣** យ នក ១៧:៩ រ នក ៣:១ **២៤:១៤** ល នក ១៧:១០ វ នក ១៨:១៦ **២៤:១៥** ស នក ១៩:៩ មថ ១៧:៥ **២៤:១៦** ហ នក ១៦:៧ លវ ៩:២៣ ជន ១៤:១០ ១សយ ៤:២១,២២ អក ៨:៤ ១១:២២ ឡ នក ១៩:១១ អ ទដ ៩៩:៧ **២៤:១៧** ក នក ១៥:៧ ១៩:១៨ ហព ១២:១៨,២៩ **២៤:១៨** ខ ១ពវ ១៩:៨ គ លប ៧:៤ មថ ៤:២ **២៥:២** ក នក ៣៥:២១,២២,២៦,២៧,២៩ ៣៦:២ ២ពវ ១២:៤ ១របា ២៩:៥,៧,៩ ២របា ២៤:១០ ២៩:៣១ អរ ២:៦៨ នហ ៧:៧០-៧២ ២របា ៨:១១-១២ ៩:៧ **២៥:៤** ខ នក ២៨:៤-៨ **២៥:៥** គ ជន ៤:៦,១០ ឃ ចទ ១០:៣ **២៥:៦** ង នក ២៧:២០ ៣០:២២-៣២ ៣៥:២៨ ៣៩:៣៧ ជន ៤:១៦

បាន ។ *ឈាមនៃសេចក្តីសញ្ញា* មើល មក ១៤:២៤ និងការពន្យល់ ។

**២៤:៩** *ក៏ឡើងទៅ* មើល ខ.១ និងការពន្យល់ ។

**២៤:១០** *បានឃើញព្រះ* តែមិនបានឃើញសេរីរុងរឿងនៃព្រះទាំងស្រុងទេ (មើល ៣៣:២០ មើលការពន្យល់ ៣:៦ លប ១៦:១៣ ជន ១២:៨ អគ ១:២៨)។ *ផ្ទៃមេឃ* ត្បូងកណ្តៀងមានពណ៌ខៀវជានិមិត្តរូបផ្ទៃមេឃ(មើល អស ១:២៦)។

**២៤:១១** *ដាក់ព្រះហស្តលើ* មើល ៩:១៥ ។ *ត្រកូលខ្ពស់* ធៀបនឹង កទ ២:៩ *បរិភោគភោជន៍* ជាការទទួលអាហារខាងឯសេចក្តីសញ្ញា(ធៀបនឹង លប ២៦:៣០ ៣១:៥៤) ដើម្បីអបអរសាទរដល់ការបិទត្រា ដែលបានចែងក្នុង ខ.៣-៨ ។ ពិធីបរិភោគអាហារនេះបានបង្ហើបអំពីលៀងព្រះអម្ចាស់ ដែលនឹងប្រារព្ធឡើង ដើម្បីអបអរសាទរដល់សេចក្តីសញ្ញាថ្មី ដែលព្រះគ្រីស្ទទ្រង់បានបោះត្រាដោយការសុគត(មើល ១កថ ១១:២៥-២៦)។

**២៤:១២** *ចូរឡើងមក* មើលការពន្យល់ ខ.១ ។ *បន្ទះថ្ម* មើលការពន្យល់ ៣១:១៨ ។ *បង្រៀន* គឺបង្រៀនអំពីសេចក្តីបង្គាប់របស់ព្រះអម្ចាស់ ។

**២៤:១៣** *យ៉ូស្វេ ជាអ្នកជំនួយការ* មើលការពន្យល់ ១៧:៩ ។

**២៤:១៤** *ហ៊ើរ* មើលការពន្យល់ ១៧:១០ ។

**២៤:១៧** *សិរីល្អនៃព្រះយេហូវ៉ា* មើល ១៦:១០ ។

**២៤:១៨** *ទៅលើភ្នំ* លោកម៉ូសេមិនបានចុះមកក្រោមទេ គឺត្រូវរង់ចាំទទួលសេចក្តីបង្គាប់អំពីរោងឧបោសថ និងការលម្អរោងនោះ(មើល ៣២:១៥)។ *៤០ថ្ងៃ ៤០យប់* ព្រះយេស៊ូវទ្រង់ក៏បាន(មើលការពន្យល់ ខ.២) តមអាហារក្នុងរយៈពេលដូចគ្នាដែរ (មើល មថ ៤:២)។

**២៥:២** *ដង្វាយ* នៅក្នុងខនេះ គឺដង្វាយស្ម័គ្រពីចិត្ត ។

**២៥:៤** *ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌ក្រហម* ជាពណ៌របស់ក្សត្រ ។ គេផលិតថ្នាំលាបពណ៌ផ្ទៃមេឃ និងពណ៌ស្វាយ ពីពពួកសត្វសមុទ្រដែលមានសម្បក(ខ្ចៅ ខ្យង គ្រុំ ។ល។) ដែលសម្បូរនៅសមុទ្រមេឌីទែរ៉ាណេ ។ មើលការពន្យល់ លប ១០:៦ ។ *ពណ៌ក្រហម* យកចេញពីជាតិស៊ុត និងសាកសពសត្វដង្កូវម្យ៉ាង(Coccus ilicis) ដែលបានភ្ជាប់ខ្លួនវានឹងស្លឹកឈើម្យ៉ាង ។ *អំបោះខ្លូតទេសយ៉ាងម៉ដ្ត* ជាប្រភេទក្រណាត់មានគុណភាពខ្ពស់(ពួករាជវង្សនៃសាសន៍អេស៊ីព្ទច្រើនតែប្រើក្រណាត់នេះ) ស្ទើរតែល្អដូចក្រណាត់សូត ។

**២៥:៥** *ស្បែកចៀមឈ្មោលជ្រលក់ពណ៌ក្រហម* គឺស្បែកដែលក្រោយពីគេបានកោររោមអស់ហើយ ។ *ស្បែកផ្សោត* ពួកវារស់នៅសមុទ្រក្រហម ។ *ឈើនាងនួន* គឺសំដៅទៅលើឈើម្យ៉ាងដែលពណ៌ក្រម៉ៅ និងមាំ ។

**២៥:៦** *គ្រឿងក្រអូប* ត្រូវបានគេប្រើសម្រាប់ការចាក់លាប(ការចាក់ប្រេងតាំង)ដែលបញ្ជាក់ក្នុង ៣០:២៣-២៤ ជាប្រភេទជ័រល្វីងទេស ដើមហ៊ីស៊ុប ដែលផ្សំគ្នានិងផ្កាស្គួត។ ។ គ្រឿងទាំងអស់នេះត្រូវបានគេប្រើក្នុងធូបម្យ៉ាង គឺមានខ្លិនក្រអូបដែលបានបញ្ជាក់ក្នុង ៣០:៣៤ ក៏មានលក្ខណៈដូចជាជ័រឈើ

គ្រឿងដុត[ច] ៧ត្បូងអូនីក្ស ហើយត្បូងគ្រប់យ៉ាង សំរាប់ដាំ
នៅអេផូឌ[ឆ] និងនៅប្រដាប់បាំងទ្រូង[ជ] ៨រួចឱ្យគេស្អាង
ទីបរិសុទ្ធ[ឈ] ដើម្បីឱ្យអញនៅ[ញ]បានកណ្ដាលគេ ៩ត្រូវឱ្យឯង
ធ្វើរោងឧបោសថ និងគ្រឿងប្រដាប់ទាំងប៉ុន្មាន តាមគំរូ[ដ]
ដែលអញបានបង្ហាញឯង ។

## ហឹប

*២៥:១០-២០ – នក ៣៧:១-៩*

១០ត្រូវឱ្យគេធ្វើហឹប១[ឋ]ពីឈើនាងនួន បណ្ដោយ២ហត្ថ
កន្លះ ទទឹង១ហត្ថកន្លះ កម្ពស់១ហត្ថកន្លះ ១១រួចត្រូវស្រោប[ឌ]
ដោយមាសសុទ្ធទាំងក្នុងទាំងក្រៅ ហើយធ្វើកែមមាសនៅ
លើហឹបជុំវិញ ១២ត្រូវឱ្យសិតកងមាស៤សំរាប់ហឹប ដាក់
ភ្ជាប់ នៅគ្រប់ទាំង៤ជ្រុង គឺ២ម្ខាងៗ[ឍ] ១៣ហើយត្រូវយកឈើ
នាងនួនធ្វើជាឈើស្នែង ដោយស្រោបមាសដូចគ្នាដែរ[ណ]
១៤រួចប្រកឈើស្នែង[ត] ទៅក្នុងកងនៅជ្រុងហឹបនោះ សំរាប់
សែងទៅ ១៥ឈើស្នែងនោះ ត្រូវនៅជាប់នឹងកងហឹប មិន
ត្រូវឱ្យដកចេញឡើយ[ថ] ១៦ត្រូវដាក់សេចក្ដីបន្ទាល់[ទ]ដែល
អញនឹងឱ្យឯង នៅក្នុងហឹបនោះ ១៧រួចត្រូវធ្វើទីសន្ដោស[ធ]
ប្រោសពីមាសសុទ្ធបណ្ដោយ២ហត្ថកន្លះ ទទឹង១ហត្ថកន្លះ
១៨ត្រូវយកមាសឆ្លាក់ធ្វើជារូបចេរូប៊ីន២[ន] នៅចុងសងខាង
នៃទីសន្ដោសប្រោសនោះ ១៩គឺធ្វើរូបចេរូប៊ីន១នៅចុងម្ខាង
ហើយចេរូប៊ីន១នៅចុងម្ខាងទៀត ត្រូវធ្វើចេរូប៊ីនទាំង២ឱ្យ
នៅចុងទាំងសងខាង ភ្ជាប់ជាមួយនឹងទីសន្ដោសប្រោស
២០ត្រូវឱ្យចេរូប៊ីន[ប]ទាំង២នោះ ត្រដាងស្លាបពីលើ[ផ]គ្រប់ទី
សន្ដោសប្រោស ហើយត្រូវដាក់ប្រទល់មុខគ្នា ទាំងឈ្ងោក
មើលទីសន្ដោសប្រោស ២១ត្រូវឱ្យដាក់ទីសន្ដោសប្រោស
ទៅលើហឹប[ព] ហើយដាក់សេចក្ដីបន្ទាល់[ភ]ដែលអញនឹងឱ្យ
ដល់ឯងទៅក្នុងហឹបដែរ ២២គឺនៅទីនោះហើយដែលអញ

**២៥:៦** ច នក ៣០:១,៧,៣៥ ៣១:១១ ៣៥:២៨ លវ ១៦:១២ ជន ៤:១៦ ៧:១៤ ២រប ១៣:១១
**២៥:៧** ឆ នក ២៨:៤,៦-១៤ ២៩:៥ ពច ៨:២៧ ហស ៣:៤ ជ លវ ៨:៨
**២៥:៨** ឈ នក ៣៦:១-៥ លវ ៤:៦ ១០:៤,៧ ២១:១២,២៣ ជន ៣:២៨ ហព ៩:១-២ ញ នក ២៩:៤៥ លវ ២៦:១១-១២ ជន ៥:៣ ចទ ១២:១១ ១ពវ ៦:១៣ សក ២:១០ ២កថ ៦:១៦
**២៥:៩** ដ ខ.៤០ នក ២៦:៣០ ២៧:៨

៣១:១១ ៣៩:៣២,៤២,៤៣ ជន ៨:៤ ១រប ២៨:១១,១៩ កច ៧:៤៤ ហព ៨:៥
**២៥:១០** ឋ ចទ ១០:១-៥ ១ពវ ៦:១៩ ហព ៩:៤ **២៥:១១** ឌ ខ.២៤ នក ៣០:៣
**២៥:១២** ឍ ខ.២៦ នក ៣០:៤ **២៥:១៣** ណ ខ.២៨ នក ២៧:៦ ៣០:៥ ៣៧:២៨
**២៥:១៤** ត នក ២៧:៧ ៤០:២០ ១រប ១៥:១៥ **២៥:១៥** ថ ១ពវ ៨:៨ **២៥:១៦** ទ នក ១៦:៣៤ ហព ៩:៤ **២៥:១៧** ធ ខ.២១ លវ ១៦:១៣ រម ៣:២៥ **២៥:១៨** ន នក ២៦:១,៣១ ៣៦:៣៥ ១ពវ ៦:២៣,២៧ ៨:៦ ២រប ៣:១០-១៣ ហព ៩:៥ **២៥:២០** ប លប ៣:២៤ ផ នក ៣៧:៩ ១ពវ ៨:៧ ១រប ២៨:១៨ ហព ៩:៥ **២៥:២១** ព ខ.១០-១៥ នក ២៦:៣៤ ៤០:២០ ចទ ១០:៥ ភ នក ១៦:៣៤ ហព ៩:៤

(ហើយម្សៅក្រអូបនោះយកចេញពីស្នូលផ្កាវីងៗ ដែលកម្រមាន ហើយមានតម្លៃណាស់) ។

**២៥:៧** *ត្បូងគ្រប់យ៉ាង* មើល ២៨:១៧-២០ ។ *អេផូឌ* មើល ២៨:៦ និងការពន្យល់ ។ *ប្រដាប់បាំងទ្រូង* មើល ២៨:១៥-៣០ ។

**២៥:៨** *ទីបរិសុទ្ធ* គឺ "កន្លែងញែកដោយឡែក"។ មើលការពន្យល់ ៣:៥ ។

**២៥:៩** *រោងឧបោសថ* តាមន័យត្រង់គឺជា "កន្លែងសណ្ឋិតនៅ" គេកម្រប្រើពាក្យនេះ សំដៅទៅលើកន្លែងរស់នៅរបស់មនុស្ស ហើយគេប្រើស្ទើរតែគ្រប់ពេល សំដៅទៅលើកន្លែងដែលព្រះអម្ចាស់ទ្រង់គង់នៅក្នុងចំណោមរាស្ត្ររបស់ទ្រង់(មើល ខ.៨ ២៩:៤៥-៤៦ លវ ២៦:១១ អគ ៣៧:២៧ ធៀបនឹង យហ ១:១៤ វវ ២១:៣)។ *គំរូ* មើលការពន្យល់ ខ.៤០ ។

**២៥:១០** *ហឹប* មើល ខ.១៤ ។ តាមព្រះគម្ពីរភាសាហេព្រើរ គេបកប្រែដោយប្រើពាក្យ"ហឹបសញ្ញា"ចាប់ពីខនេះដល់ចប់ព្រះគម្ពីរនិក្ខមនំ(មើលការពន្យល់ ចទ ១០:១-៣) ពាក្យនេះមានលក្ខណៈខុសពីពាក្យដែលប្រើសំដៅទៅលើទូករបស់លោកណូអេ កូនទូកដើមបបុសដែលដាក់ម៉ូសេកាលនៅជាទារក(មើល ២:៣)។ នៅក្នុងសេចក្ដីបង្គាប់ពីការលម្អរោងឧបោសថមានការនិយាយអំពីហឹបសញ្ញាមុន ពីព្រោះវាជានិមិត្តរូបនៃបល្ល័ង្កនៃព្រះ (មើល ១សយ ៤:៤ ២សយ ៦:២) ដ៏ជាមហាក្សត្រ ដែលបានសម្រេចព្រះទ័យយាងមកគង់ក្នុងចំណោមរាស្ត្រទ្រង់(មើលការពន្យល់ ខ.៩) ។

**២៥:១១** *មាសសុទ្ធ* គឺពុំមានដាក់លាយប្រាក់ ឬលោហៈផ្សេងទៀតឡើយ ។

**២៥:១២** *កង* តាមន័យត្រង់គឺជា "ផ្ទះ" ឬ "ការស្នាក់នៅ"។ គេស៊កឈើចូលតាមកងនោះ សម្រាប់សែងហឹបសញ្ញា(មើល ខ.១៤) ។

**២៥:១៦** *សេចក្ដីបន្ទាល់* គឺបន្ទះថ្មពីរដែលចារនូវក្រឹត្យវិន័យទាំង១០ប្រការជាមូលដ្ឋានគ្រឹះនៃការតាំងសញ្ញានៅភ្នំស៊ីណាយ(២០:១-១៧ ៣១:១៨)។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យ "សេចក្ដីបន្ទាល់" មានទំនាក់ទំនងនឹងពាក្យក្នុងភាសាបាប៊ីឡូនគឺ "ការតាំងសេចក្ដីសញ្ញា"។ មើលការពន្យល់ ខ.២២ ១៦:៣៤ ។

**២៥:១៧** *សន្ដោសប្រោស* គឺជាការផ្សះផ្សាដែលធ្វើឡើងដោយព្រះគុណនៃព្រះអម្ចាស់ ដែលបាននាំអ្នកដែលនៅដាច់ពីទ្រង់ ឱ្យបានចូលទៅចំពោះទ្រង់ ហើយសាងទំនាក់ទំនងឡើង ។ ក្នុងគ្រាសញ្ញាចាស់ ការខ្ចាយឈាមនៃសត្វសម្រាប់ថ្វាយជាយញ្ញបូជា គឺដើម្បីលន់តួបាប(មើល ១៧:១១ និងការពន្យល់) ហើយក្នុងគ្រាសញ្ញាថ្មី ព្រះលោហិតនៃព្រះយេស៊ូវ បានខ្ចាយតែមួយដងជាសម្រេច ដើម្បីអត់ទោសបាបដល់មនុស្សដែលលន់តួ(មើល ហព ៩:១២) គឺមិនខុសគ្នាទេ(មើល រម ៣:២៥ ១យហ ២:២ និងការពន្យល់)។ *ទីសន្ដោសប្រោស* មើល លវ ១៦:២ និងការពន្យល់ ។ ហឹបសញ្ញាដែលជានិមិត្តរូបនៃបល្ល័ង្កទ្រង់ ត្រូវតំកល់នៅក្នុងទីសណ្ដោសប្រោស ជាសញ្ញាបញ្ជាក់អំពីសេចក្ដីមេត្តាករុណា ដែលទ្រង់មានចំពោះរាស្ត្រទ្រង់ មានតែទ្រង់ទេដែលសមនឹងទទួលការសរសើរតម្កើង(មើល ទដ ១៣០:៣-៤)។

**២៥:១៨** *រូបចេរូប៊ីន* គេជឿថារូបនេះស្រដៀងនឹងរូបចម្លាក់ដែលលម្អរដៃនៃបល្ល័ង្កស្ដេច(មើលការពន្យល់ ខ.១០)ក្នុងតំបន់ជាច្រើននៅមជ្ឈឹមបូព៌ាសម័យបុរាណ(មើលការពន្យល់ លប ៣:២៤)។ រូបចេរូប៊ីន គឺជានិមិត្តរូបបញ្ជាក់ពីទីកន្លែងដែល "ព្រះទ្រង់គង់លើរាជ្យទ្រង់" នៅក្នុងនគររបស់ទ្រង់នៅក្នុងលោកិយ(មើល ១សយ ៤:៤ ២សយ ៦:២ ២ពវ ១៩:១៥ ទដ ៩៩:១) ព្រះទ្រង់បង្គាប់ និងដឹកនាំលោកម៉ូសេ(មើល ខ.២២ ជន ៧:៨៩) ពីហឹបសញ្ញានោះមក(និមិត្តសញ្ញានៃបល្ល័ង្កទ្រង់)។ នៅសម័យក្រោយមក វត្តមានរបស់ហឹបនោះនៅក្នុងព្រះវិហារនៃក្រុងយេរូសាឡិម បាននាំឱ្យក្រុងនោះក្លាយជារាជធានីរបស់ទ្រង់នៅក្នុងលោកិយ(ទដ ៩:១១ និងការពន្យល់)។

**២៥:២២** *ហឹបនៃទីបន្ទាល់* ត្រូវហៅដូនេះ ព្រោះនៅក្នុងនោះ មានសេចក្ដីបន្ទាល់(មើល ខ.១៦)។ ពាក្យ "ហឹបនៃទីបន្ទាល់" មានន័យដូចពាក្យ "ហឹប

នឹងមកជួបនឹងឯង ហើយនិងនិយាយនឹងឯងពីលើទីសន្ដោស
ប្រោស នៅកណ្ដាលចេរូប៊ីនទាំង២[ម]ដែលនៅលើហឹបនៃ
ទីបន្ទាល់ ដើម្បីប្រាប់[យ]ឯងពីអស់ទាំងសេចក្ដីដែលអញនឹង
បង្គាប់ដល់ពួកកូនចៅអ៊ីស្រាអែល[រ] ។

### តុ

*២៥:២៣–២៩ – នក ៣៧:១០–១៦*

២៣ត្រូវឱ្យធ្វើតុ១[ល]ពីឈើនាងនួន បណ្ដោយ២ហត្ថ ទទឹង
១ហត្ថ ហើយកំពស់១ហត្ថកន្លះ ២៤រួចត្រូវស្រោបដោយ
មាសសុទ្ធ ហើយធ្វើកែមមាសនៅជុំវិញ ២៥ត្រូវធ្វើគែមតុ
កំពស់១ទះ ហើយធ្វើកែមមាសភ្ជាប់នឹងគែមនៅព័ទ្ធជុំវិញ
ទៀត ២៦ត្រូវឱ្យធ្វើកងមាស៤សំរាប់តុដែរ ដាក់ភ្ជាប់ទាំង
៤ជ្រុងនៅត្រង់ជើងតុទាំង៤ ២៧កងទាំងនោះត្រូវនៅជិត
គែមតុ សំរាប់ព្រហាកឈើស្នែងនឹងសែងទៅ ២៨ត្រូវយក
ឈើនាងនួន ស្រោបដោយមាស[វ]ធ្វើជាស្នែងសំរាប់សែងតុ
២៩ត្រូវឱ្យធ្វើថាស ផ្តិល ប៉ាន់ ហើយនិងពែងសំរាប់តុនោះ
ដើម្បីប្រើថ្វាយដង្វាយច្រូច ត្រូវធ្វើពីមាសសុទ្ធទាំងអស់[ស]
៣០ហើយនៅលើតុនោះ[ហ]ត្រូវដាក់នំបុ័ងតាំងទុក នៅមុខអញ
ជានិច្ច ។

### ជើងចង្កៀង

*២៥:៣១–៣៩ – នក ៣៧:១៧–២៤*

៣១រួចត្រូវយកមាសសុទ្ធធ្វើជាជើងចង្កៀង[ឡ] ឯជើងចង្កៀង
នោះត្រូវធ្លាក់ធ្វើឱ្យមានគល់ ដើម នប់ កន្សោម គ្រាប់
ហើយនិងផ្កាភ្ជាប់ជាមួយគ្នា ៣២ត្រូវមានមែក៦បែកចេញ
មកពីគល់ គឺមែក៣ម្ខាងៗ ៣៣នៅមែក១ ត្រូវមាននប់៣រាង
ដូចជាគ្រាប់ចំបក់ មានទាំងកន្សោមគ្រាប់ ហើយនិងផ្កាផង
ឯមែកទាំង៦ដែលបែកចេញពីគល់ជើងចង្កៀងមក នោះក៏
ត្រូវមាននប់៣ រាងដូចជាគ្រាប់ចំបក់ព្រមទាំងកន្សោមគ្រាប់
ហើយនិងផ្កា ដូចគ្នាទាំងអស់ដែរ ៣៤ឯគល់ជើងចង្កៀងត្រូវ
មាននប់៤វិញ រាងដូចជាគ្រាប់ចំបក់ព្រមទាំងកន្សោមគ្រាប់
ហើយនិងផ្កាផង ៣៥នៅក្រោមមែក២ ត្រូវមានកន្សោម
គ្រាប់១ នៅក្រោមមែក២ទៀត ត្រូវមានកន្សោមគ្រាប់១
ហើយនៅក្រោមមែក២ទៀត ត្រូវមានកន្សោមគ្រាប់១ដែរ
មែកទាំង៦ដែលបែកចេញពីជើងចង្កៀងមក នោះត្រូវមាន
ដូចគ្នាគ្រប់ទាំងអស់ ៣៦កន្សោមគ្រាប់ និងមែកទាំងប៉ុន្មាន
នោះ ត្រូវធ្លាក់ធ្វើពីមាសសុទ្ធភ្ជាប់ជាមួយគ្នា[អ] ៣៧ត្រូវធ្វើ
ចង្កៀង៧[ក]សំរាប់ឱ្យគេដាក់នៅលើ ដើម្បីឱ្យមានពន្លឺចេញ
ទៅខាងមុខ ៣៨ឯឃ្នាបប្រឆេះ និងកន្ថោរដាក់កំទេច
សំរាប់ជើងចង្កៀង[ខ] នោះក៏ត្រូវធ្វើពីមាសសុទ្ធទាំងអស់ដែរ
៣៩ត្រូវយកមាសសុទ្ធ១ហាបធ្វើជើងចង្កៀង ហើយនិង
គ្រឿងប្រដាប់ទាំងអស់នោះ ៤០ហើយត្រូវប្រយ័ត្ននឹងធ្វើ
ឱ្យត្រឹមត្រូវតាមគំរូ[គ] ដូចដែលបានបង្ហាញឱ្យឯងឃើញនៅ
លើភ្នំស្រាប់ ។

### រោងឧបោសថ

*២៦:១–៣៧ – នក ៣៦:៨–៣៨*

**២៦** ១រីឯរោងឧបោសថ[ក] នោះត្រូវឱ្យឯងធ្វើពីសំពត់១០

**២៥:២២** ម ជន ៧:៨៩ ១សយ ៤:៤ ២សយ ៦:២ ២២:១១ ២ពវ ១៩:១៥ ១រប ១៣:៦ ២៨:១៨ ទដ ១៨:១០ ៨០:១ ៩៩:១ អស ៣៧:១៦ យ នក ១៩:៣ ២៩:៤២ ៣០:៦,៣៦ លវ ១:១ ១៦:២ ជន ១៧:៤ រ យរ ៣:១៦ **២៥:២៣** ល ខ.៣០ នក ២៦:៣៥ ៤០:៤,២២ លវ ២៤:៦ ជន ៣:៣១ ១ពវ ៧:៤៨ ១រប ២៨:១៦ ២រប ៤:៨,១៩ អក ៤១:២២ ៤៤:១៦ ហព ៩:២ **២៥:២៨** វ ខ.១៣ **២៥:២៩** ស ជន ៤:៧ **២៥:៣០** ហ នក ៣៥:១៣ ៣៩:៣៦ ៤០:៤,២៣ លវ ២៤:៥–៩ ជន ៤:៧ ១សយ ២១:៤–៦ ១ពវ ៧:៤៨ ១រប ២៣:២៩ **២៥:៣១** ឡ នក ២៦:៣៥ ៣១:៨ ៣៥:១៤ ៣៩:៣៧ ៤០:៤,២៤ លវ ២៤:៤ ជន ៣:៣១ ១ពវ ៧:៤៩ ២រប ៤:៧ សក ៤:២ ហព ៩:២ វវ ១:១២ **២៥:៣៦** អ ខ.១៨ ជន ៨:៤ **២៥:៣៧** ក នក ២៧:២១ ៣០:៨ លវ ២៤:៣–៤ ជន ៨:២ ១សយ ៣:៣ ២រប ១៣:១១ **២៥:៣៨** ខ ខ.៣៧ ជន ៤:៩ **២៥:៤០** គ ខ.៩ កច ៧:៤៤ ហព ៨:៥ **២៦:១** ក នក ២៩:៤២ ៤០:២ លវ ៨:១០ ជន ១:៥០ យស ២២:១៩,២៩ ២សយ ៧:២ ១ពវ ១:៣៩ កច ៧:៤៤ ហព ៨:២,៥ ១៣:១០ វវ ២១:៣

សញ្ញា"(ជន ១០:៣៣) ។ *អញនឹងមកជួបឯង* មើលការពន្យល់ ២៧:២១ ។

**២៥:២៦** *កង* មើលការពន្យល់ ខ.១២ ។

**២៥:៣០** *ដាក់នំបុ័ងតាំងទុក* ក្នុងឃ្លានេះ ពាក្យតាំងទុកមានន័យថា "ព្រះវត្តមាននៃព្រះ"(ដូចក្នុង ៣៣:១៤–១៥ អស ៦៣:៩) ។ នំបុ័ងនេះគឺ(មាន ១២ដុំ ហើយដុំនីមួយៗ តំណាងឱ្យពូជអំបូរនីមួយៗនៃពូជអំបូរទាំង១២) ជាតំណាងឱ្យនំបុ័ងដែលថ្វាយអស់កល្បជានិច្ច ដល់ព្រះអម្ចាស់ គឺពួកអ៊ីស្រាអែលបានប្រកាសថា ជាដង្វាយដែលញែកជាបរិសុទ្ធថ្វាយដល់ទ្រង់ ពីផលនៃពលកម្មរបស់ពួកគេ ដែលជាតិសាសន៍ពួកគេទាំងមូលបានទទួលស្គាល់ថា ជាព្រះពរដែលព្រះប្រទាន ។ មើល លវ ២៤:៥–៩ ។

**២៥:៣១** *ដើម នប់ កន្សោម គ្រាប់ ហើយនិងផ្កាភ្ជាប់ជាមួយគ្នា* គឺមានរាងដូចគ្រាប់ចំបក់(មើល ខ.៣៣) ដែលស្ថិតនៅក្នុងចំណោមដើមដែលចេញផ្កាមុនគេ នៅតំបន់មជ្ឈឹមបូព៌ា នៅរដូវផ្ការីក ។ ផ្នែកខ្លះនៃចង្កៀងនៅសម័យនោះមានរាងដូចផ្កា ឬគ្រាប់នៃដើមនោះ ។

**២៥:៣៧** *៧សំរាប់* បង្ហាញពីភាពពេញលេញ ។ *ចង្កៀង* នៅសម័យបុរាណមានសណ្ឋានជាកូនទ្រនាប់ចានធ្វើពីដីឥដ្ឋ ។ ហើយគែមវាភ្ជាប់គ្នាបានជាចង្អូរ ដែលគេអាចដាក់ប្រឆេះ ចាប់ពីកំពូលនោះចុះមកប្រេង ដែលនៅក្នុងចង្កៀងដែលមានរាងដូចកូនទ្រនាប់ចាននោះ(មើលឧទាហរណ៍ នៃចង្កៀងទាំង៧នៅសម័យលោកម៉ូសេ) ។ នៅសំណង់បុរាណបាក់បែកនៃទីក្រុងបៀត–សាន និងទីក្រុងមេគីដោ គេរកឃើញទម្រចង្កៀងធ្វើពីលោហៈ ។ ចង្កៀងនេះត្រូវឆេះពេញមួយយប់ៗនៅក្នុងរោងឧបោសថ ដោយមានពួកសង្ឃជាអ្នកមើល ។ ពួកបណ្ដាជនគឺជាអ្នកផ្គត់ផ្គង់ប្រេងចង្កៀងនោះ ហើយពន្លឺនៃចង្កៀងគឺជាតំណាងឱ្យសិរីល្អនៃព្រះយេហូវ៉ា បានបង្ហាញចេញតាមរយៈការរស់នៅដោយញែកជាបរិសុទ្ធនៃរាស្ត្រអ៊ីស្រាអែល មានន័យថា សិរីល្អនៃពួកអ៊ីស្រាអែល គឺត្រូវស្របតាមសិរីល្អរបស់ព្រះក្នុងរោងឧបោសថ(២៩:៤៣) ។ មើល ២៧:២០–២១ ។

**២៥:៤០** បទគម្ពីរ ហព ៨:៥ បានដកស្រង់ខនេះ ដើម្បីធៀប"ស្រមោល"(សេចក្តីសញ្ញាចាស់)ជាមួយនឹងសេចក្តីពិត(ព្រះគ្រីស្ទនៃសេចក្តីសញ្ញាថ្មី) ។ មើល ហព ១០:១ ។

**២៦:១** *រោងឧបោសថ* មើលការពន្យល់ ២៥:៩ ។ សំណង់ជាមូលដ្ឋានតាមបង្គាប់របស់ព្រះគឺ មានទទឹង ៤,៥៧ ម៉ែត្រ បណ្ដោយ ១៣,៧១ ម៉ែត្រ និង

ផ្ទាំង ដែលត្បាញ ដោយអំបោះខ្លូតទេស វេញយ៉ាងខ្មាញ់
មានពណ៌ផ្ទៃមេឃ ពណ៌ស្វាយ និងពណ៌ក្រហម ព្រម
ទាំងប៉ាក់ជារូបចេរូប៊ីន[ខ] តាមរចនានៃពួកជាងមានស្នាដៃ
២បណ្ដាសំពត់នីមួយៗត្រូវឱ្យមានបណ្ដោយ២៨ហត្ថ ទទឹង៤
ហត្ថស្មើគ្នាទាំងអស់[គ] ៣សំពត់៥ផ្ទាំង ត្រូវដេរភ្ជាប់ជាមួយគ្នា
ហើយសំពត់៥ផ្ទាំងទៀត ក៏ត្រូវដេរភ្ជាប់ជាមួយគ្នាដែរ
៤ត្រូវធ្វើខ្សែក្រវិលមានពណ៌ខៀវតាមជាយសំពត់ទី១ ខាង
ចុងផ្ទាំងត្រង់កន្លែងដែលភ្ជាប់គ្នា ហើយត្រូវធ្វើដូច្នោះ
តាមជាយខាងចុងផ្ទាំង១ទៀត ត្រង់កន្លែងដែលភ្ជាប់គ្នា
ដែរ ៥ត្រូវធ្វើឱ្យមានខ្សែក្រវិល៥០នៅសំពត់ទី១ ហើយ៥០
ទៀតនៅសំពត់ទី២ ត្រូវដាក់ខ្សែក្រវិលទាំងនោះឱ្យស្មើគ្នា
ទាំងអស់ ៦ត្រូវធ្វើទំពក់មាស៥០ ដើម្បីនឹងភ្ជាប់សំពត់ទាំង
២ផ្ទាំងនិងទំពក់នោះ ឱ្យរោងឧបោសថបានជាប់នៅជា
រោងតែ ១[ឃ] ។

៧រួចត្រូវធ្វើសំពត់ ពីរោមពពែ ទុកសំរាប់គ្របពីលើ
រោងឧបោសថ ត្រូវឱ្យធ្វើសំពត់នោះ១១ផ្ទាំង ៨ឱ្យមាន
បណ្ដោយ៣០ហត្ថ ទទឹង៤ហត្ថស្មើគ្នាទាំងអស់[ង] ៩ត្រូវដេរ
សំពត់៥ផ្ទាំងភ្ជាប់ជាមួយគ្នា ហើយ៦ផ្ទាំងទៀតក៏ត្រូវដេរ
ភ្ជាប់ជាមួយគ្នាដែរ ឯសំពត់ទី៦ នោះត្រូវបត់ផាត់ទៅលើ ពី
ខាងមុខត្រសាល ១០ហើយត្រូវធ្វើខ្សែក្រវិល៥០ដាក់តាម
ជាយសំពត់ទី១ ខាងចុងផ្ទាំងត្រង់កន្លែងដែលភ្ជាប់គ្នា
ហើយខ្សែក្រវិល៥០ទៀត តាមជាយសំពត់ទី២ ខាងចុងផ្ទាំង
ត្រង់កន្លែងដែលភ្ជាប់គ្នាដែរ ១១ត្រូវធ្វើទំពក់លង្ហិន៥០
សំរាប់ថ្លក់នឹងខ្សែក្រវិលទាំងនោះ ភ្ជាប់ត្រសាលរួមមក
តែ១[ច] ១២ឯសំពត់ត្រសាលដែលលើសពាក់កណ្ដាលក្នុង១
ផ្ទាំងខាងចុង នោះត្រូវឱ្យសំយាកធ្លាក់ទៅបាំងខាងក្រោយ
រោងឧបាសថវិញ ១៣ហើយសំពត់ដែលសល់១ហត្ថទាំងសង
ខាងតាមបណ្ដោយផ្ទាំងទាំងប៉ុន្មាន នោះត្រូវឱ្យសំយាក
ធ្លាក់ទៅ បាំងរោងឧបោសថទាំងសងខាងដែរ ១៤រួចត្រូវ
ធ្វើគំរប[ឆ]ពីស្បែកចៀមឈ្មោលជ្រលក់ពណ៌ក្រហម សំរាប់
គ្របត្រសាល ហើយនិងគំរបស្បែកផ្សោត ដើម្បីនឹងគ្របពី
លើនោះទៀត[ជ] ។

១៥ត្រូវធ្វើក្ដារ ពីឈើនាងនួន ដាក់បញ្ឈរ សំរាប់ជា
ជញ្ជាំងនៃរោងឧបោសថ ១៦ក្ដារទាំងនោះ ត្រូវឱ្យមាន
បណ្ដោយ១០ហត្ថ ហើយទទឹង១ហត្ថកន្លះ ១៧គ្រប់តែក្ដារ
ត្រូវមានពន្លួញ២ភ្ជាប់តាមជួរជញ្ជាំង ត្រូវធ្វើឱ្យដូចគ្នាទាំង
អស់ សំរាប់រោងឧបោសថ ១៨ត្រូវធ្វើក្ដារ២០សន្លឹកសំរាប់
ខាងត្បូងរោងឧបោសថ ១៩ហើយនៅក្រោមក្ដារ២០សន្លឹក
នោះ ត្រូវធ្វើជើងប្រាក់ចំនួន៤០[ឈ] គឺជើងពីរៗនៅក្រោម
រាល់តែក្ដារសំរាប់ស៊កពន្លួញចូលទៅ ២០ត្រូវធ្វើក្ដារ២០
សន្លឹក សំរាប់រោងឧបោសថនៅទិសខាងជើងទៀត ២១និង
ជើងប្រាក់ចំនួន៤០[ញ] សំរាប់ក្ដារទាំងនោះដែរ គឺជើងពីរៗ
នៅក្រោមគ្រប់តែក្ដារ ២២ហើយត្រូវធ្វើក្ដារ៦សន្លឹកសំរាប់
ចុងរោងឧបោសថនៅទិសខាងលិច ២៣ត្រូវធ្វើក្ដារ២សន្លឹក
សំរាប់ជ្រុងរោងឧបោសថនៅខាងចុង ២៤ក្ដារ២សន្លឹកនោះ
ត្រូវភ្ជាប់គ្នានៅខាងក្រោម និងខាងលើដោយសារកង១
នៅជ្រុងទាំង២ ត្រូវមានក្ដារ២ដូចគ្នា ២៥ដូច្នេះត្រូវមានក្ដារ
៨សន្លឹក ហើយនិងជើងប្រាក់សំរាប់ក្ដារទាំងនោះចំនួនជា
១៦ គឺជើងពីរៗនៅរៀងរាល់តែក្ដារ ២៦ត្រូវធ្វើរនុក៥ពី
ឈើនាងនួន សំរាប់ក្ដារនៅជញ្ជាំងរោងឧបោសថម្ខាង
២៧និងរនុក៥ទៀត សំរាប់ក្ដារជញ្ជាំងរោងឧបោសថម្ខាង
ហើយរនុក៥ សំរាប់ក្ដារជញ្ជាំងនៅឯចុងរោងឧបោសថ
ខាងលិច ២៨ឯរនុកកណ្ដាល ត្រូវឱ្យវែងបង្ហួតពីចុងម្ខាង
ដល់ចុងម្ខាង ២៩ត្រូវស្រោបក្ដារទាំងអស់ដោយមាស ហើយ
ត្រូវធ្វើកងអំពីមាស សំរាប់ព្រហករនុកចូល ទោះទាំងរនុក
នោះក៏ត្រូវស្រោបដោយមាសដែរ ៣០ត្រូវដំឡើងរោង
ឧបោសថ[ដ]តាមគំរូ[ឋ] ដែលបានបង្ហាញ ឱ្យឯងឃើញនៅលើ
ភ្នំ ។

**២៦:១** ខ នក ២៥:១៨
**២៦:២** គ ខ.៨
**២៦:៦** ឃ ខ.១១
**២៦:៨** ង ខ.២
**២៦:១១** ច ខ.៦
**២៦:១៤** ឆ ជន ៣:២៥ ជ ជន ៤:២៥
**២៦:១៩** ឈ ខ.២១, ២៥,៣២ នក ៣៨:២៧
**២៦:២១** ញ ខ.១៩
**២៦:៣០** ដ នក ៤០:២ ជន ៩:១៥ ឋ នក ២៥:៩

៤,៥៧ ម៉ែត្រ ។ នៅផ្នែកខាងក្នុងមានរៀបចំជារាងអង្កាញ់ៗជាជួរៗ(ខ.១–៦) សំពត់គម្របដែលធ្វើពីរោមពពែ(ខ.៧–១៣) ក៏មានគំរបពីផ្ទាំងបន្ថែមទៀតធ្វើពីស្បែកចៀម(ខ.១៤) ។ រោងឧបោសថជាតំណាង ឱ្យរាជរោងរបស់ព្រះ ។ ទំរង់ និងការលម្អរនៃរោងឧបោសថ(ដូចនៅក្នុងព្រះវិហារនៅសម័យក្រោយៗ) ជានិមិត្តរូបតំណាងឱ្យនៃការបង្កើតអ្វីៗរបស់ព្រះអម្ចាស់ ក្នុងលក្ខណៈជាព្រះអាទិករ និងព្រះអម្ចាស់ ។ រោងនោះជាតំណាងឱ្យចំណុចកណ្ដាលនៃសាកលលោក ដែលរាជ្យរបស់ទ្រង់បានចាប់ផ្ដើមពីកន្លែងនោះមក ហើយជាទីប្រសប់នៃផែនដី និងស្ថានសួគ៌ ។ (ពាក្យថា អេម៉ាញូអែល មានន័យថាព្រះអង្គគង់ជាមួយយើងទាំងអស់គ្នា)។ នៅទីនោះ ព្រះទ្រង់ "គង់នៅ" នៅក្នុងចំណោមរាស្ត្ររបស់ទ្រង់(អេម៉ាញូអែល, "ព្រះគង់ជាមួយយើង") ហើយរាស្ត្ររបស់ទ្រង់អាចចូលមកជិតទ្រង់ ។ មានទីបរិសុទ្ធនៅក្នុងចំណោមពួកអ៊ីស្រាអែល គឺមានន័យថា ពួកគេហាក់ដូចជាកំពុងរស់នៅជិតមាត់ទ្វាស្ថានសួគ៌ រង់ចាំការសម្រេចនៃផែនការប្រោសលោះពួកគេ(មើល ខ.៣១–៣៥ លប ៣:២៤ និងការពន្យល់ មើល វវ ២១:១–២២:៦ និងការពន្យល់)។

**២៦:៧** *រោមពពែ* មើលការពន្យល់ ២៥:៤ ។

**២៦:១៤** *ស្បែកចៀមឈ្មោលជ្រលក់ពណ៌ក្រហម សំរាប់គ្របត្រសាល ហើយនិងគំរបស្បែកផ្សោត* មើលការពន្យល់ ២៥:៥ ។

**២៦:១៧** *ពន្លួញ២* តាមន័យត្រង់គឺ "ដៃសម្រាប់កាន់"(មើល ខ.១៩)។

**២៦:១៩** *ជើងប្រាក់ចំនួន៤០* ជើងទាំងអស់សរុបទៅ មានប្រាក់ចំនួន ១០០ ។

៣១ រួចត្រូវធ្វើវាំងនន[ឃ] ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌
ក្រហម ដោយអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ព្រមទាំងប៉ាក់
រូបចេរូប៊ីន[ឃ] ដោយការរចនានៃជាងមានស្នាដៃ ៣២ ហើយ
ត្រូវពាក់វាំងននោះលើសសរនាងនួន៤ ដែលស្រោប
ដោយមាស បញ្ឈរលើជើងប្រាក់៤[ណ] មានទាំងទំពក់មាស
ផង ៣៣ ត្រូវពាក់វាំងននទឹងទំពក់ទាំងនោះ រួចត្រូវយកហឹប
នៃសេចក្តីបន្ទាល់ចូលទៅ ដាក់នៅខាងក្នុងវាំងនន[ត] ហើយ
វាំងននោះនឹងឃាំងទីបរិសុទ្ធ ពីទីបរិសុទ្ធបំផុតឱ្យឯងរាល់
គ្នា[ថ] ៣៤ រួចត្រូវដាក់ទីសន្តោសប្រោសនៅលើ[ទ]ហឹបនៃ
សេចក្តីបន្ទាល់ខាងក្នុងទីបរិសុទ្ធបំផុត ៣៥ ហើយត្រូវដាក់
តុ[ធ]ពីខាងក្រៅវាំងនន ចំហៀងខាងជើង ឯជើងចង្កៀង[ន]
នោះត្រូវដាក់នៅ ពីមុខតុចំហៀងខាងត្បូងក្នុងរោង
ឧបោសថ ។

៣៦ នៅមុខត្រសាល ត្រូវធ្វើរនាំង[ប] ពណ៌ផ្ទៃមេឃ ពណ៌
ស្វាយ ពណ៌ក្រហម ដោយអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់
ហើយត្រូវប៉ាក់ផង[ផ] ៣៧ ត្រូវធ្វើសសរនាងនួន៥ស្រោប
ដោយមាស សំរាប់រនាំងនោះ ត្រូវមានទំពក់មាស ហើយ
ត្រូវសិតជើងលង្ហិន៥ សំរាប់សសរទាំងនោះដែរ ។

## អាសនាសម្រាប់ធ្វើដង្វាយដុត

*២៧:១–៨ – នក ៣៨:១–៧*

**២៧** ១ ត្រូវឱ្យធ្វើអាសនា[ក]ពីឈើនាងនួន បណ្តោយ៥ហត្ថ
ទទឹង៥ហត្ថ ៤ជ្រុងស្មើ ហើយកំពស់៣ហត្ថ ២ ត្រូវធ្វើស្នែង[ខ]
ជាប់នឹងអាសនាគ្រប់ទាំង៤ជ្រុង ហើយត្រូវស្រោបដោយ
លង្ហិន ៣ ត្រូវធ្វើប្រដាប់ដាក់ផេះ ចបចូក ផើង[គ] សម ហើយ
និងជើងក្រានសំរាប់អាសនា[ឃ] ឯប្រដាប់ទាំងនោះ ត្រូវធ្វើពី
លង្ហិនទាំងអស់ ៤ ត្រូវធ្វើប្រទាសលង្ហិនខ្វាស់ក្រឡាគ្នាសំរាប់
អាសនាដែរ ហើយត្រូវធ្វើកងលង្ហិន៤ដាក់នៅគ្រប់ជ្រុង
ប្រទាស ៥ ត្រូវដាក់ប្រទាសពីខាងក្រោមគែមឱ្យជាប់ត្រង់
ពាក់កណ្តាលកំពស់នៃអាសនា ៦ ត្រូវយកឈើនាងនួន ធ្វើជា
ឈើស្នែងសំរាប់សែងអាសនា ហើយស្រោបដោយលង្ហិន
ដែរ[ង] ៧ ត្រូវព្រហកឈើស្នែងនោះទៅក្នុងកង ឱ្យឈើស្នែង
បានជាប់ទាំងសងខាងអាសនាសំរាប់សែងទៅ[ច] ៨ អាសនា
នោះត្រូវធ្វើពីក្តារឱ្យខូង ដូចជាបានបង្ហាញ[ឆ]ឱ្យឯងឃើញ
នៅលើភ្នំ ។

## ទីលាននៃរោងឧបោសថ

*២៧:៩–១៩ – នក ៣៨:៩–២០*

៩ ត្រូវធ្វើទីលាន[ជ]នៃរោងឧបោសថដែរ គឺខាងត្បូងត្រូវ
មានរនាំងធ្វើពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ប្រវែង១
រយហត្ថ សំរាប់បាំងទីលានខាងម្ខាងនោះ ១០ ហើយត្រូវ
មានសសរ២០ និងជើងលង្ហិន២០ ឯទំពក់សសរនឹងគន្លឹះ
នោះត្រូវធ្វើពីប្រាក់ ១១ នៅខាងជើង ត្រូវមានរនាំងប្រវែង

**២៦:៣១** ឃ ជន ៤:៥ ២រប ៣:១៤ មថ ២៧:៥១ លក ២៣:៥១ លក ២៣:៤៥ ហេព ៩:៣ ឃ នក ២៥:១៨ **២៦:៣២** ណ ខ.១៩ **២៦:៣៣** ត នក ២៧:២១ ៣៥:១២ ៤០:៣,២១ លវ ១៦:២ ជន ៣:៣១ ៤:៥ ២រប ៣:១៤ ថ លវ ១៦:២,១៦ ១ពវ ៦:១៦ ៧:៥០ ៨:៦ ២រប ៣:៨ ៥:៧ អគ ៤១:៤ ហេព ៩:២–៣ **២៦:៣៤** ទ នក ២៥:២១ ៣០:៦ ៣៧:៦ លវ ១៦:២ ហេព ៩:៥ **២៦:៣៥** ធ នក ២៥:២៣ ហេព ៩:២ ន នក ២៥:៣១ **២៦:៣៦** ប នក ៣៥:១៥ ៤០:៥,២៨ ផ ទដ ៤៥:១៤ អគ ១៦:១០ ២៦:១៦ ២៧:៧ **២៧:១** ក នក ២០:២៤ ៤០:៦ ១ពវ ៨:៦៤ **២៧:២** ខ នក ២៩:១២ ៣០:២ ៤៣:១៥ អម ៣៧:២៥ លវ ៤:៧ ១ពវ ១:៥០ ២:២៨ ទដ ១១៨:២៧ យរ ១៧:១ អគ ៣:១៤ សក ៩:១៥ **២៧:៣** គ ជន ៧:១៣ ១ពវ ៧:៤០ ៤៥ ២ពវ ១២:១៣ ឃ ជន ៤:១៤ ១រប ២៨:១៧ យរ ៥២:១៨ **២៧:៦** ង នក ២៥:១៣ **២៧:៧** ច នក ២៥:១៤, ២៨ **២៧:៨** ឆ នក ២៥:៩ **២៧:៩** ជ នក ៣៥:១៧ ៤០:៨,៣៣ លវ ៦:១៦,២៦ អគ ៤០:១៤ ៤២:១

**២៦:៣១–៣៥** វាំងននសម្រាប់ចែករោងឧបោសថទៅជាពីរចំណែក គឺជាទីបរិសុទ្ធ និងទីបរិសុទ្ធបំផុត ដែលទីបរិសុទ្ធធំជាងទីបរិសុទ្ធបំផុតពីរដង ។ គេជឿថា ទីបរិសុទ្ធបំផុតមានរាងជាគូប ដោយសារមានទំហំ ៤,៥៧ ម៉ែត្រ គុណនឹង ៤,៥៧ ម៉ែត្រ ហើយគុណ ៤,៥៧ ម៉ែត្រ ហើយបិទដោយវាំងននលម្អរដោយរូបចេរូប៊ីន ហើយតម្កល់តែហឹបនៃសេចក្តីបន្ទាល់ប៉ុណ្ណោះ (ការពន្យល់ ខ.១)។ ទីបរិសុទ្ធតំណាង ឱ្យរាជតំណាក់សម្រាប់ភ្ញៀវ(មើល ២៥:៣០)។

**២៦:៣១** *វាំងនន* សម្រាប់ញែកទីបរិសុទ្ធពីទីបរិសុទ្ធបំផុត(មើល ខ.៣៣)។ គឺគេហៅថាវាំងននសម្រាប់ឃាំង(៣៩:៣៤ ៤០:២១ ជន ៤:៥) ព្រោះជារបាំងនៃហឹបសញ្ញា(២៧:២១ មើលការពន្យល់ ១៦:៣៤ ២៥:២២)។ ពេលដែលព្រះគ្រីស្ទបានសុគត វាំងននៃព្រះវិហាររបស់ស្តេចហេរ៉ូត បានរហែកជាពីរ នាំឱ្យអ្នកជឿអាចចូលទៅក្នុងព្រះវត្តមានព្រះដោយផ្ទាល់(មក ១៥:៣៨ ហេព ៦:១៩–២០ ១០:១៩–២២)។ *ចេរូប៊ីន* មើល ខ.១ និងការពន្យល់ ។ វាំងននៅច្រកចូលទីបរិសុទ្ធពុំមានរូបចេរូប៊ីនទេ(ខ.៣៦)។

**២៦:៣៧** *លង្ហិន* មាសជាជម្រើសនៃលោហៈធាតុដ៏ល្អបំផុត នៅក្នុងរោងឧបោសថ ហើយចាប់ពីជើងវាំងននខាងក្រោមមក ជម្រើសនៃលោហៈដ៏ល្អបំផុតគឺលង្ហិន ។ នៅក្នុងរោងឧបោសថ គ្រឿងលម្អរនៅក្បែរដំណាក់ព្រះ គឺធ្វើពី ឬស្រោបដោយមាសសុទ្ធ(មើល ២៧:២–៦ ៣០:១៨) ហើយគ្រឿងលម្អរដែលនៅឆ្ងាយពីដំណាក់ទ្រង់ធ្វើពី ឬស្រោបដោយលង្ហិន ។ ហើយទម្រនៃរោងឧបោសថ និងបង្គោលទាំង៤ ដែលភ្ជួរវាំងននដែលញែកទីបរិសុទ្ធ និងទីបរិសុទ្ធបំផុត គឺធ្វើពីប្រាក់(មើល ខ.១៩,២១,២៥,៣២)។

**២៧:១** *អាសនា* គឺជាអាសនានៃដង្វាយដុត(មើល លវ ៤:៧,១០,១៨)។ *ឈើនាងនួន* មើលការពន្យល់ ២៥:៥ ។

**២៧:២** *ស្នែង* គឺតំណាងឱ្យបង្គោលនៃជ្រុងទាំងបួន ។ ស្នែងជានិមិត្តរូបនៃជំនួយ និងទីជ្រកកោន(មើល ១ពវ ១:៥០ ២:២៨) ហើយជានិមិត្តរូបនៃអំណាចចាក់ប្រេងតាំងនៃអាសនា ដែលក្នុងនោះ គេចាក់ឈាមខ្លះពីលើស្នែងនៃអាសនា មុននឹងចាក់ឈាមទាំងប៉ុន្មាននៅជើងអាសនានោះ (មើល ២៩:១២ លវ ៤:៧,១៨,២៥,៣០,៣៤ ៨:១៥ ៩:៩ ១៦:១៨) ។

**២៧:៣** *ផើង* គឺសម្រាប់ត្រងឈាមសត្វ ដែលគេសម្លាប់ក្បែរអាសនា ហើយគេប្រោសឈាមនោះនៅជើងអាសនា ។ *សម* មានធ្មេញបី សម្រាប់រៀបចំយ័ញ្ញបូជា ឬចូកយកចំណែករបស់សង្ឃចេញពីទីចំអិន(មើល ១សយ ២:១៣–១៤)។ *ជើងក្រាន* មើល លវ ១០:១ ១៦:១២–១៣)។

**២៧:៤** *ប្រទាល* គឺដាក់នៅកណ្តាលសំណង់ដែលមានរាងដូចប្រអប់។(មើល ខ.៨)។ *កង* មើលការពន្យល់ ២៥:១២ ។

១រយហត្ថ ហើយសសរ២០ និងជើងសសរលង្ហិនដែរ ឯទំពក់សសរ និងគន្លឹះ ក៏ត្រូវធ្វើពីប្រាក់ដូចគ្នា ១២នៅខាងលិច ទទឹងទីលាន នោះត្រូវមានរនាំងប្រវែង៥០ហត្ថ ហើយសសរ១០ និងជើង១០ ១៣ឯនៅខាងកើតទីលាន មានទទឹង៥០ហត្ថដែរ ១៤តែខាងម្ខាងត្រូវមានរនាំងប្រវែង១៥ហត្ថ និងសសរ៣ ហើយនិងជើង៣ ១៥ឯម្ខាងទៀត នោះត្រូវមានរនាំងប្រវែង១៥ហត្ថ និងសសរ៣ ហើយនិងជើង៣ដូចគ្នា ១៦ឯនៅមាត់ទ្វារទីលាន ត្រូវមានរនាំង[ឈ] ប្រវែង ២០ហត្ថ ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌ក្រហម ធ្វើពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ហើយប៉ាក់ផង[ញ] ព្រមទាំងសសរ៤ និងជើង៤ដែរ ១៧អស់ទាំងសសរនៅជុំវិញទីលាន នោះត្រូវមានគន្លឹះនិងទំពក់ធ្វើពីប្រាក់ ហើយនិងជើងធ្វើពីលង្ហិន ១៨ទីលាននោះ ត្រូវឱ្យមានបណ្តោយ១រយហត្ថ និងទទឹង៥០ហត្ថស្មើគ្នារហូត ហើយកំពស់រនាំង៥ហត្ថ ឯរនាំងនោះ ត្រូវធ្វើពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ហើយជើងសសរទាំងប៉ុន្មានត្រូវធ្វើពីលង្ហិន ១៩អស់ទាំងប្រដាប់សំរាប់នឹងប្រើការក្នុងរោងឧបោសថ និងចំរឹងនៃរោងនោះ ហើយចំរឹងទីលាន នោះត្រូវធ្វើពីលង្ហិនទាំងអស់ ។

## ប្រេងសម្រាប់ជើងចង្កៀង

*២៧:២០–២១ – លវ ២៤:១–៣*

២០ត្រូវឱ្យបង្គាប់ដល់ពួកកូនចៅអ៊ីស្រាអែល ឱ្យគេយកប្រេងអូលីវសុទ្ធ[ដ] ដែលធ្វើយ៉ាងសំរាំង សំរាប់នឹងដុតនៅចង្កៀងជាអចិន្ត្រៃយ ២១ឯចង្កៀងនោះ[ឋ] ត្រូវឱ្យអើរ៉ុននឹងកូនលោកថែឱ្យឆេះនៅចំពោះព្រះយេហូវ៉ា ចាប់តាំងពីល្ងាចដល់ព្រឹក នៅខាងក្រៅវាំងននក្នុងត្រសាលជំនុំ[ឌ]ត្រង់មុខទីបន្ទាល់[ឍ] នេះជាច្បាប់សំរាប់អស់កល្បជានិច្ច[ណ] ដល់ពូជដំណនៃពួកកូនចៅអ៊ីស្រាអែលតរៀងទៅ ។

## សំលៀកបំពាក់សម្រាប់ពួកសង្ឃ

**២៨** ១រួចត្រូវឱ្យញែកអើរ៉ុន[ក] បងឯង ព្រមទាំងពួកកូនលោកផង ចេញពីពួកកូនចៅអ៊ីស្រាអែលមក ដើម្បីឱ្យគេបានធ្វើការងារជាសង្ឃនៅមុខអញ[ខ] គឺទាំងអើរ៉ុន និងណាដាប អ័ប៊ីហ៊ូវ[គ] អេលាសារ ហើយនិងអ៊ីថាម៉ារ[ឃ]ជាកូនលោក ។

២ត្រូវឱ្យធ្វើសំលៀកបំពាក់បរិសុទ្ធ[ង] សម្រាប់អើរ៉ុន បងឯង សំរាប់ជាកិត្តិយស ហើយនិងភាពលំអ[ច] ៣ត្រូវប្រាប់ដល់អស់អ្នកណាដែលមានគំនិតវាងវៃ[ឆ] ជាមនុស្សដែលអញបានបំពេញដោយដំរិះ[ជ]សព្វគ្រប់ ឱ្យគេធ្វើសំលៀកបំពាក់ឱ្យអើរ៉ុន ដើម្បីញែកលោកចេញជាបរិសុទ្ធ សំរាប់នឹងធ្វើការងារជាសង្ឃដល់អញ ៤ឯសំលៀកបំពាក់ទាំងប៉ុន្មានដែលគេត្រូវធ្វើ នោះគឺប្រដាប់បាំងទ្រូង១[ឈ] អេផូឌ១[ញ] អាវវែង១[ដ] អាវខ្លី ប៉ាក់១[ឋ] មួក១[ឌ] ហើយនិងខ្សែក្រវាត់១ ៥ត្រូវឱ្យយកមាស សំពត់ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌ក្រហម និងសំពត់ខ្លូតទេសយ៉ាងម៉ដ្ត ដើម្បីធ្វើសំលៀកបំពាក់បរិសុទ្ធទាំងនោះ សំរាប់អើរ៉ុន បងឯង និងឱ្យកូនលោកផង ដើម្បីឱ្យគេបានធ្វើការងារជាសង្ឃដល់អញ[ឍ]។

## អេផូឌ

*២៨:៦–១៤ – នក ៣៩:២–៧*

៦ត្រូវឱ្យធ្វើអេផូឌ[ណ]ពីមាស ហើយពីសំពត់ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌ក្រហម ដែលត្បាញដោយអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ទាំងធ្វើតាមរចនានៃពួកជាងដែលមានស្នា

**២៧:១៦** ឈ នក ៤០:៣៣ ញ នក ៣៦:៣៧
**២៧:២០** ដ នក ២៥:៦
**២៧:២១** ឋ នក ២៥:៣៧ ឌ នក ២៨:៤៣ ២៩:៤២ ៣០:៣៦ ៣៣:៧ លវ ១:១ ឍណ
**២៨:១** ក លវ ៨:៣០ ទដ ៩៩:៦ ហព ៥:៤ ខ លវ ៨:២ ២១:១ ជន ១៨:១–៧ ចទ ១៨:៥ ១សយ ២:២៨ ហព ៥:១ គ នក ៦:២៣ ២៤:៩ ឃ នក ៦:២៣
**២៨:២** ង នក ៣១:៦ ៣៥:១០ ៣៥:១៩ ៣៩:១ លវ ៨:៧–៩,៣០ ១៦:៣២ ជន ២០:២៦–២៨ ច ខ.៤០
**២៨:៣** ឆ នក ៣១:៦ ៣៥:១០,២៥,៣៥ ៣៦:១ ជ នក ៣១:៣ ចទ ៣៤:៩ អស ១១:២ ១កថ ១២:៨ អក ១:១៧
**២៨:៤** ឈ ខ.១៥–៣០ ញ នក ២៥:៧ ដ ខ.៣១–៣៥ ឋ ខ.៣៩ លវ ១០:៥ ឌ ខ.៣៧
**២៨:៥** ឍ នក ២៥:៤ **២៨:៦** ណ នក ២៥:៧

**២៧:១២–១៣** *ខាងលិច . . . ខាងកើត* ទីលាននោះបានចែកជាពីរចំណែកស្មើៗគ្នា ។ គេជឿថា ទីបរិសុទ្ធបំផុតគឺនៅក្នុងចំណុចកណ្តាលក្នុងផ្នែកពាក់កណ្តាលខាងលិច ហើយអាសនានៃដង្វាយដុតនៅចំណុចកណ្តាលក្នុងផ្នែកពាក់កណ្តាលខាងកើត ។

**២៧:១៣–១៤** រោងឧបោសថគឺបែរទៅទិសខាងកើត គឺដូចព្រះវិហារស្តេចសាឡូម៉ូន(មើល អគ ៨:១៦) និងព្រះវិហាររបស់ស្តេចហេរ៉ូឌផងដែរ ។

**២៧:១៨** *៥ហត្ថ* គឺកំពស់ខ្ពស់ល្មមនឹងអាចបិទបាំង មិនឱ្យអ្នកឈរនៅទីលានខាងក្រៅមើលឃើញបាន ដូចនេះ ដើម្បីការពារភាពបរិសុទ្ធ និងភាពឯកជននៃការថ្វាយបង្គំ ដែលនៅខាងក្នុង ។

**២៧:២០** *ប្រេងអូលីវសុទ្ធ ដែលធ្វើយ៉ាងសំរាំង* ចំពោះផ្លែអូលីវដែលមិនទាន់ទុំ គេកិននិងត្បាល់ ។ គេត្រងកាករបស់វា ដោយក្រណាត់ក្នុងកន្ត្រកម៉្យាង ដើម្បីចម្រាញ់យកប្រេងថ្លាល្អដែលដុតទៅមានផ្សែងតិច ឬគ្មានផ្សែង។

**២៧:២១** *ត្រសាលជំនុំ* រោងឧបោសថ គឺមិនមែនជាកន្លែងសម្រាប់រាស្ត្ររបស់ព្រះជួបជុំគ្នាដើម្បីថ្វាយបង្គំរួមគ្នាទេ ប៉ុន្តែ ជាកន្លែងដែលទ្រង់ជួបជាមួយនឹងរាស្ត្រទ្រង់ ដោយការរៀបចំ គឺមិនមែនដោយចៃដន្យទេ(មើល ២៩:៤២–៤៣)។*វាំងននក្នុងត្រសាលជំនុំត្រង់មុខទីបន្ទាល់* មើលការពន្យល់ ២៦:៣១ ។ *ចង្កៀងនោះឆេះ . . . ល្ងាចដល់ព្រឹក* គេអុចចង្កៀងនៅពេលល្ងាច(មើល ៣០:៨) ហើយគេពន្លត់នៅពេលព្រឹកវិញ(១សយ ៣:៣) ។

**២៨:១** *ណាដាប អ័ប៊ីហ៊ូវ* មើលការពន្យល់ ២៤:១ ។ *ឱ្យគេធ្វើការជាសង្ឃនៅមុខអញ* គឺដើម្បី "ថ្វាយដង្វាយ និងយញ្ញបូជាសម្រាប់លោះបាប" និង "ដើម្បីអធ្យាស្រ័យ ដល់មនុស្សល្ងង់ និងមនុស្សវង្វេង"(ហព ៥:១–២)។ តួនាទីដ៏សំខាន់មួយទៀតនៃពួកសង្ឃ គឺអានក្រឹត្យវិន័យរបស់លោកម៉ូសេដល់ពួកបណ្តាជន ហើយរំឭកអំពីកាតព្វកិច្ចដែលពួកគេមានតាមសេចក្តីសញ្ញា(មើល ចទ ៣១:៩–១៣ នហ ៨:២–៣ យរ ១៨:១៨ មទ្បា ២:៥–៨)។

**២៨:២** *សម្រាប់ជាកិត្តិយស ហើយនិង* ឯកសណ្ឋានរបស់ពួកសង្ឃ បានតម្កើងដល់ការងារជាសង្ឃ និងតួនាទីរបស់ពួកសង្ឃថ្នាក់ទាប(មើល ខ.៤០) ក៏ដូចជាសម្តេចសង្ឃដែរ ។

**២៨:៦** *អេផូឌ* ជាអាវគ្មានដៃ ដែលសម្តេចសង្ឃពាក់ពីលើ ។

ដៃ ៧ត្រូវមានមានខ្សែស្មា២ភ្ជាប់នៅចុងអេផូឌទាំងមុខទាំង
ក្រោយ ឱ្យបានជាប់ជាមួយគ្នា ៨ឯខ្សែក្រវ៉ាត់ដែលជាប់នឹង
អេផូឌ[ត] ហើយសំរាប់ចងភ្ជាប់គ្នា នោះត្រូវធ្វើយ៉ាងនោះ
ដែរ គឺធ្វើពីមាស ហើយពីសំពត់ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ
ពណ៌ក្រហម ដែលត្បាញដោយអំបោះខ្លូតទេសវេញយ៉ាង
ខ្មាញ់ ៩រួចត្រូវយកថ្មអូនីក្ស២ដុំ ឆ្លាក់[ថ]ចុះអស់ទាំងឈ្មោះនៃ
ពួកកូនអ៊ីស្រាអែល ១០ត្រូវឱ្យមានឈ្មោះ៦នៅថ្ម១ដុំ
ហើយឈ្មោះ៦នៅថ្ម១ដុំទៀត តាមកំណើតគេគ្រប់គ្នា
១១ត្រូវឆ្លាក់អស់ទាំងឈ្មោះនៃពួកកូនចៅអ៊ីស្រាអែលនៅថ្ម
ទាំង២ដុំនោះ បែបដូចជាជាងចំឡាក់គេឆ្លាក់ធ្វើត្រា ហើយ
ដាំចុះក្នុងគ្រោងមាស ១២ត្រូវដាក់ថ្មទាំង២ដុំនោះនៅលើ
ខ្សែស្មាអេផូឌ[ទ] ទុកជាសេចក្ដីរំឭក[ធ]ដល់អស់ទាំងពួកកូន
ចៅអ៊ីស្រាអែល ដូច្នេះអើរ៉ុននឹងពាក់ឈ្មោះគេនៅលើ
ស្មាទាំង២ ទុកជាសេចក្ដីរំឭកនៅចំពោះព្រះយេហូវ៉ា
១៣ត្រូវឱ្យធ្វើគ្រោងមាសសំរាប់ដាំថ្ម ១៤ហើយខ្សែមាសសុទ្ធ
២ វេញដូចជាខ្សែពួរ រួចភ្ជាប់ខ្សែនឹងគ្រោងមាសនោះ ។

## ប្រដាប់បាំងទ្រូង

*២៨:១៥-២៨ – នក ៣៩:៨-២១*

១៥ត្រូវធ្វើប្រដាប់បាំងទ្រូង[ន]នៃការវិនិច្ឆ័យ ឱ្យត្រូវតាម
រចនានៃពួកជាងដែលមានស្នាដៃ ហើយតាមរបៀបអេផូឌ
ដែរ គឺធ្វើពីមាស ពីសំពត់ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌
ក្រហម ដែលត្បាញដោយអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់
១៦ត្រូវឱ្យបាន៤ជ្រុងស្មើ បត់ជា២ផ្នត់ បណ្ដោយ១ចំអាម
ទទឹង១ចំអាម ១៧ហើយត្រូវដាំត្បូង[ប]៤ជួរនៅប្រដាប់នោះ
ក្នុងជួរទី១ មានត្បូងសាមសី១ ត្បូងទោប៉ុត១ និងបារកេត១
១៨ក្នុងជួរទី២ មានត្បូងមរកដ១ ត្បូងកណ្ដៀង១ និងពេជ្រ១
១៩ក្នុងជួរទី៣ មានត្បូងលេសិម១ ត្បូងទទឹម១ និងត្បូង
ត្របែក១ ២០ក្នុងជួរទី៤ មានត្បូងបេរិល១[ផ] ត្បូងអូនីក្ស១
និងមណីជោតិ១ ត្រូវដាំត្បូងទាំងនេះចុះក្នុងគ្រោងមាស
២១ត្រូវតែមានត្បូង១២ តាមឈ្មោះនៃពួកកូនអ៊ីស្រាអែល
ទាំងប៉ុន្មាន[ព] ហើយត្រូវឆ្លាក់ទាំងអស់បែបដូចជាឆ្លាក់ត្រា ឯ
គ្រប់តែត្បូង ត្រូវចារិកឈ្មោះមួយៗ ក្នុងឈ្មោះពូជអំបូរ
ទាំង១២នោះ[ភ] ២២ហើយត្រូវឱ្យធ្វើខ្សែមាសសុទ្ធវេញដូចជា
ខ្សែពួរដាក់ភ្ជាប់នឹងប្រដាប់បាំងទ្រូង ២៣ត្រូវធ្វើក្រវិលមាស
២ ដាក់ភ្ជាប់នៅចុងសងខាងដែរ ២៤ហើយត្រូវបញ្ចូលខ្សែ
មាស២ក្នុងក្រវិលដែលនៅជាប់ចុងសងខាងនៃប្រដាប់បាំង
ទ្រូង ២៥ហើយចុងខ្សែទាំង២ ត្រូវឱ្យភ្ជាប់នឹងគ្រោងមាស
ដាំត្បូងនៅខ្សែស្មារបស់អេផូឌខាងមុខ ២៦ឯងត្រូវធ្វើក្រវិល
មាស២ទៀត ដាក់ភ្ជាប់នៅជាយខាងក្នុងត្រង់ចុងសងខាង
នៃប្រដាប់បាំងទ្រូង ដែលនៅផ្ទាប់នឹងអេផូឌ ២៧ហើយត្រូវ
ធ្វើក្រវិលមាស២ទៀត ដាក់ភ្ជាប់នៅក្រោម ហើយខាងមុខ
តួគ្រោងនៃខ្សែស្មាភ្ជាប់គ្នា ហើយខាងលើខ្សែអេផូឌដែរ
២៨ត្រូវយកខ្សែខៀវចងក្រវិលនៃប្រដាប់បាំងទ្រូង ភ្ជាប់និង
ក្រវិលអេផូឌ ដើម្បីឱ្យប្រដាប់បាំងទ្រូងបាននៅលើខ្សែ
អេផូឌ កុំឱ្យរបូតចេញពីអេផូឌឡើយ ២៩ដូច្នេះកាលណា
អើរ៉ុនចូលទៅក្នុងទីបរិសុទ្ធ[ម] នោះនឹងពាក់អស់ទាំងឈ្មោះ
នៃពួកកូនអ៊ីស្រាអែល ដែលឆ្លាក់នៅប្រដាប់បាំងទ្រូងនៃ
ការវិនិច្ឆ័យនោះនៅលើទ្រូង សំរាប់ជាសេចក្ដីរំឭកនៅ
ចំពោះព្រះយេហូវ៉ាជានិច្ច ៣០ត្រូវដាក់យូរីមនិងធូមីម[យ] ភ្ជាប់
នៅប្រដាប់បាំងទ្រូងនៃការវិនិច្ឆ័យដែរ ដូច្នេះ អើរ៉ុន
នឹងពាក់លើទ្រូង ក្នុងកាលដែលចូលទៅនៅចំពោះព្រះ
យេហូវ៉ា ហើយការវិនិច្ឆ័យនៃពួកកូនចៅអ៊ីស្រាអែល និង
នៅជាប់លើទ្រូងអើរ៉ុននៅចំពោះព្រះយេហូវ៉ាជានិច្ច ។

## សំលៀកបំពាក់សង្ឃដទៃទៀត

*២៨:៣១-៤៣ – នក ៣៩:២២-៣១*

៣១ឯអាវវែងផងអេផូឌ នោះត្រូវឱ្យធ្វើពីសំពត់ពណ៌ផ្ទៃ
មេឃទាំងអស់ ៣២នៅកណ្ដាលអាវ នោះត្រូវវៀលជាក
ហើយត្រូវមានសំពត់ចំនៅជុំវិញកអាវនោះ បែបដូចជាក

**២៨:៨** ត នក ២៩:៥
**២៨:៩** ថ ៨:៦ អស ៤៩:១៦ ហក ២:២៣
**២៨:១២** ទ ចទ ៣៣:១២ យប ៣១:៣៦ ធ ខ.២៩ នក ៣០:១៦ ជន ១០:១០ ៣១:៥៤ យស ៤:៧ សក ៦:១៤
**២៨:១៥** ន នក ២៥:៧
**២៨:១៧** ប អគ ២៨:១៣ វវ ២១:១៩-២០
**២៨:២០** ផ អគ ១:១៦ ១០:៩ ដយ ១០:៦
**២៨:២១** ព យស ៤:៨ ភ វវ ២១:១២
**២៨:២៩** ម ខ.៤៣ **២៨:៣០** យ លវ ៨:៨ ជន ២៧:២១ ចទ ៣៣:៨ ១សយ ២៨:៦ អរ ២:៦៣ នហ ៧:៦៥

**២៨:៨** *ខ្សែក្រវ៉ាត់* គេជឿថា ខ្សែក្រវ៉ាត់នោះ គឺសម្រាប់ចងផ្នែកខាងមុខ និងខាងក្រោយអេផូឌឱ្យជាប់នឹងខ្លួនសម្ដេចសង្ឃ ។

**២៨:១២** *អើរ៉ុននឹងពាក់ឈ្មោះគេនៅលើស្មាទាំង២* ដើម្បីធ្វើជាសញ្ញាបញ្ជាក់ពីការពិតថា សម្ដេចសង្ឃគឺជាតំណាងឱ្យពួកអ៊ីស្រាអែលទាំងអស់ នៅពេលដែលគាត់បម្រើព្រះក្នុងរោងឧបោសថ ។

**២៨:១៥** *នៃការវិនិច្ឆ័យ* គឺមានន័យថា ត្រូវដាក់យូរីម និងធូមីមភ្ជាប់នៅប្រដាប់បាំងទ្រូងនៃការវិនិច្ឆ័យ (មើលការពន្យល់ ខ.៣០) ។

**២៨:២៩** *អើរ៉ុន... ពាក់អស់ទាំងឈ្មោះ... លើទ្រូង* ដើម្បីតំណាងឱ្យជាតិសាសន៍ទាំងមូលនៅចំពោះព្រះអម្ចាស់ (មើល ខ.១២ និងការពន្យល់) ។

**២៨:៣០** *យូរីម និងធូមីម* គេជឿថា តាមព្រះគម្ពីរភាសាហេព្រើរ ពាក្យទាំងពីរនេះមានន័យថា "បណ្ដាសា និងភាពល្អឥតខ្ចោះ"។ នៅក្នុងភាសាហេព្រើ គេសរសេរពាក្យ *យូរីម* ផ្ដើមដោយព្យញ្ជនៈទី១ ("Aleph" អាលេប) ហើយពាក្យ *ធូមីម* ដោយព្យញ្ជនៈចុងក្រោយ ("Taw" តាវ)។ ឧបករណ៍ទាំងពីរមានអំណាច ហើយជាញឹកញាប់ គេប្រើនៅគ្រាមានវិប័ត្តិ ដើម្បីបញ្ជាក់ពីព្រះហឫទ័យព្រះ (មើល ជន ២៧:២១)។ គេជឿថា បើគេចាប់បានយូរីម (បណ្ដាសា) ចម្លើយគឺ "ទេ" ហើយធូមីម (ភាពឥតខ្ចោះ) គឺ "បាទ"។ ការសម្រេចចិត្តត្រូវតាមព្រះហឫទ័យព្រះ (សភ ១៦:៣៣ និងការ ពន្យល់)។

**២៨:៣១** *អាវវែង* ត្រូវពាក់ពីក្រោមអេផូឌ ។

នៃអាវសឹក ដើម្បីកុំឱ្យអាវនោះរហែកចេញ ៣៣នៅជុំវិញ
ជាយអាវខាងក្រោម[រ] នោះត្រូវធ្វើផ្លែទទឹមពណ៌ផ្ទៃមេឃ
ពណ៌ស្វាយ ពណ៌ក្រហម លាយឆ្លាស់នឹងចង្រ្កង់មាស ៣៤គឺ
ចង្រ្កង់មាស១ ផ្លែទទឹម១ ចង្រ្កង់មាស១ ផ្លែទទឹម១ តាមជុំ
វិញជាយអាវវែងនោះ ៣៥ អើរ៉ុនត្រូវពាក់អាវវែងនោះ
សំរាប់ធ្វើការងាររបស់ខ្លួន ដូច្នេះកាលណាចូលទៅក្នុងទី
បរិសុទ្ធនៅចំពោះព្រះយេហូវ៉ា ឬចេញមកវិញក្តី នោះនឹង
ឮសូរចង្រ្កង់ ហើយលោកមិនត្រូវស្លាប់ទេ ។
៣៦ត្រូវធ្វើស្លាកមាស[ល]សុទ្ធ១ ហើយឆ្លាក់បែបដូចជាឆ្លាក់
ត្រាថា "បរិសុទ្ធដល់ព្រះយេហូវ៉ា"[វ] ៣៧ត្រូវចងស្លាកនោះ
នឹងខ្សែពណ៌ខៀវភ្ជាប់នៅត្រង់មុខមួក នៅលើថ្ងាសអើរ៉ុន
៣៨នោះអើរ៉ុននឹងទទួលអស់ទាំងការកំហុស[ស]ខាងឯរបស់
បរិសុទ្ធទាំងប៉ុន្មាន ដែលពួកកូនចៅអ៊ីស្រាអែលថ្វាយ
ហើយស្លាកនោះនឹងនៅលើថ្ងាសអើរ៉ុន ជាដរាបនៅ
ចំពោះព្រះយេហូវ៉ា ដើម្បីឱ្យទ្រង់បានទទួល[ហ]គេ ។
៣៩ត្រូវឱ្យធ្វើអាវខ្លីពីសំពត់ខ្លូតទេស[ឡ]យ៉ាងម៉ដ្ត និងមួក[អ]ពី
សំពត់ខ្លូតទេសដែរ ហើយខ្សែក្រវាត់ប៉ាក់ផង ។
៤០ឯពួកកូនរបស់អើរ៉ុន[ក] នោះត្រូវឱ្យឯងធ្វើអាវខ្លី និងខ្សែ
ក្រវាត់ ព្រមទាំងឈ្នួតសំរាប់គេដែរ ដើម្បីជាកិត្តិយសនិង
ជាភាពលំអដល់គេ[ខ] ៤១ត្រូវបំពាក់[គ]ឱ្យអើរ៉ុនបងឯងនិងកូន
លោកផង រួចត្រូវចាក់ប្រេងតាំង[ឃ]គេឡើង ហើយញែក
ចេញជាបរិសុទ្ធ ដើម្បីឱ្យបានធ្វើការងារជាសង្ឃដល់អញ[ង]
៤២ត្រូវឱ្យធ្វើខោស្នាប់ភ្លៅ[ច]ពីសំពត់ខ្លូតទេសឱ្យគេ ពីត្រឹម
ចង្កេះ ដល់ពាក់កណ្តាលភ្លៅ សំរាប់បាំងកេរខ្មាសគេ
៤៣អើរ៉ុននិងកូនលោកត្រូវស្លៀកខោនោះ ក្នុងកាលដែល
ចូលទៅក្នុងត្រសាលជំនុំ[ឆ] ឬកាលណាចូលទៅឯអាសនានិង
ធ្វើការងារក្នុងទីបរិសុទ្ធ[ជ] ដូច្នេះគេនឹងគ្មានទោស ហើយមិន
ត្រូវស្លាប់ទេ[ឈ] នេះឯងជាច្បាប់សំរាប់នៅអស់កល្បជានិច្ច[ញ]
ដល់អើរ៉ុន និងពូជដំណររបស់លោកតរៀងទៅ ។

## **ការញែកជាបរិសុទ្ធរបស់ពួកសង្ឃ**

*២៩:១-៣៧ - លវ ៨:១-៣៦*

**២៩** ១នេះជាការដែលឯងត្រូវធ្វើ ដើម្បីនឹងញែក[ក]អ្នក
ទាំងនោះចេញជាបរិសុទ្ធ ឱ្យបានធ្វើការងារជាសង្ឃដល់
អញ គឺត្រូវឱ្យយកគោឈ្មោលស្ទាវ១ និងចៀមឈ្មោល២ដ៏
ឥតខ្ចោះ[ខ] ២ហើយយកម្សៅភោជ្ជសាលីយ៉ាងម៉ដ្ត ធ្វើនំបុ័ង
ឥតដំបែ និងនំឥតដំបែលាយដោយប្រេង ហើយនិងនំក្រៀប
ឥតដំបែប្រោះដោយប្រេង[គ] ៣ត្រូវឱ្យដាក់នំទាំងនោះនៅក្នុង
កញ្ច្រែង រួចនាំយកមកជាមួយនឹងគោឈ្មោល ព្រមទាំង
ចៀមឈ្មោលទាំង២[ឃ] ៤ហើយត្រូវនាំអើរ៉ុននិងកូនលោក
ចូលមកឯទ្វារត្រសាលជំនុំ រួចយកទឹកមកផ្ងូតគេ[ង] ៥ត្រូវយក
សំលៀកបំពាក់[ច]ទាំងប៉ុន្មានមកបំពាក់ឱ្យ គឺអាវខ្លី អាវវែង
នៃអេផូឌ ហើយអេផូឌ និងប្រដាប់បាំងទ្រូងឱ្យអើរ៉ុន ហើយ
យកខ្សែក្រវាត់របស់អេផូឌមកក្រវាត់ឱ្យដែរ[ឆ] ៦ព្រមទាំង
បំពាក់មួក[ជ]លើក្បាល ហើយដាក់ស្លាកនៃសេចក្តីបរិសុទ្ធ[ឈ]
នៅភ្ជាប់នឹងមួកនោះ ៧ត្រូវយកប្រេង[ញ]មកចាក់លើក្បាល
តាំងលោកឡើង ៨រួចត្រូវនាំកូនលោកចូលមកបំពាក់អាវ
ខ្លីឱ្យ[ដ] ៩ព្រមទាំងយកខ្សែក្រវាត់មកក្រវាត់ឱ្យអើរ៉ុន និងកូន
លោកផង[ឋ] រួចជួតឈ្នួតឱ្យគេដែរ នោះការងារជាសង្ឃ
នឹងបានជារបស់ផងគេ ជាច្បាប់សំរាប់នៅអស់កល្បជា
និច្ច[ឌ] គឺយ៉ាងនោះឯងដែលត្រូវតាំងអើរ៉ុន ហើយនិងពួក
កូនលោកឡើង ។

**២៨:៣៣** រ ជន ១២:២៣ ១សយ ១៤:២ ១ពវ ៧:១៨ ៤:៣ យរ ៥២:២២ យអ ១:១២ ហាក ២:១៩ **២៨:៣៦** ល ខ.៣៧ នក ២៩:៦ លវ ៨:៩ វ សក ១៤:២០ **២៨:៣៨** ស លវ ៥:១ ១០:១៧ ១៦:២២ ២២:៩,១៦ ជន ១៨:១ អស ៥៣:៥,៦,១១ អគ ៤:៤-៦ ហព ៩:២៨ ១ពត ២:២៤ ហ លប ៣២:២០ លវ ២២:២០,២៧ ២៣:១១ អស ៥៦:៧ **២៨:៣៩** ឡ ខ.៤ អ អគ ២៩:៦ លវ ១៦:៤ អគ ២៤:១៧,២៣ ៤៤:១៨ **២៨:៤០** ក ខ.៤ នក ២៩:៨-៩ ៣៩:៤១ ៤០:១៤ លវ ៨:១៣ ខ ខ.២ **២៨:៤១** គ នក ៤០:១៣ ឃ នក ២៩:៧ លវ ៦:២០ ១០:៧ ២១:១២ ជណ ៣៥:២៥ ង នក ២៩:៧-៩ ៣០:៣០ ៤០:១៥ លវ ៤:៣ ៦:២២ ៨:១-៣៦ ជណ ៣:៣ ហព ៧:២៨ **២៨:៤២** ច លវ ៦:១០ ១៦:៤,២៣ អគ ៤៤:១៨ **២៨:៤៣** ឆ នក ២៧:២១ ជ ខ.២៩ ឈ នក ៣០:២០,២១ លវ ១៦:១៣ ២២:៩ ជន ១:៥១ ៤:១៥,២០ ១៨:២២ ញ នក ២៧:២១ **២៩:១** ក ខ.២១,៤៤ លវ ២០:៧ យស ៣:៥ ១រប ១៥:១២ ខ អគ ៤៣:២៣ **២៩:២** គ ខ.២៣ លវ ២:១,៤ ៦:១៩-២៣ ជន ៦:១៥ **២៩:៣** ឃ ខ.១៥,១៩ **២៩:៤** ង នក ៤០:១២ លវ ១៤:៨ ១៦:៤ ហព ១០:២២ **២៩:៥** ច នក ២៨:២ ឆ នក ២៨:៨ **២៩:៦** ជ នក ២៨:៣៩ អស ៣:២៣ សក ៣:៥ ឈ នក ២៨:៣៦ **២៩:៧** ញ ខ.២១ នក ២៨:៤១ ៣០:២៥,៣០,៣១ ៣៧:២៩ ៤០:៩ លវ ២១:១០ ១សយ ១០:១ ១ពវ ១:៣៩ ទដ ៨៩:២០ ១៣៣:២ ១៤១:៥ **២៩:៨** ដ នក ២៨:៤ លវ ១៦:៤ **២៩:៩** ឋ នក ២៨:៤០ ឌ នក ២៧:២១ ៤០:១៥ ជន ៣:១០ ១៨:៧ ២៥:១៣ ចទ ១៨:៥ ពច ១៧:៥ ១សយ ២:៣០ ១ពវ ១២:៣១

**២៨:៣៥** យោងតាមទំនៀមទម្លាប់របស់សាសន៍យូដា គេចងករជើងរបស់សម្តេចសង្ឃជាប់នឹងចុងម្ខាងនៃខ្សែពួរ និងចុងខ្សែម្ខាងទៀតចេញមកខាងក្រៅនៃរោងឧបោសថ ។ បើសិនកណ្តឹងជាប់នឹងខ្សែនោះឈប់ឮសូរ ខណៈដែលសង្ឃនោះនៅទីបរិសុទ្ធ នោះគេអាចសន្និដ្ឋានថា សង្ឃនោះបានស្លាប់ហើយ ដោយសាកល្បងទាញខ្សែដែលចងជើងនោះថ្នមៗ ។

**២៨:៣៦** *ទីបរិសុទ្ធដល់ព្រះយេហូវ៉ា* មើល ៣:៥ និងការពន្យល់ ៣៩:៣០ សក ១៤:២០ និងការពន្យល់ ។

**២៨:៣៨** *ទទួលអស់ទាំងការកំហុស* គឺជានិមិត្តរូបមួយ ។

**២៨:៣៩** *អាវខ្លី* ដែលពាក់ពីក្រោមអាវវែង ។

**២៨:៤០** *ដើម្បីជាកិត្តិយសនឹងជាភាពលំអដល់គេ* មើលការពន្យល់ ខ.២ ។

**២៨:៤២-៤៣** មើលការពន្យល់ ២០:២៦ ។

**២៨:៤៣** *ត្រសាលជំនុំ* ២៧:២១ ។

**២៩:១** *ញែកអ្នកទាំងនោះចេញជាបរិសុទ្ធ* មើលការពន្យល់ ១៩:១០-១១ ។ *ដ៏ឥតខ្ចោះ* មើលការពន្យល់ ១២:៥ ។

**២៩:៤** *ត្រសាលជំនុំ* មើលការពន្យល់ ២៧:២១ ។ *រួចយកទឹកមកផ្ងូតគេ* ជាសញ្ញាបញ្ជាក់ពីការសម្អាតភាពមិនស្អាត(ធៀបនឹង ហព ១០:២២) ដូចនេះក៏បញ្ជាក់ពីនៃភាពស្អាត ដែលជាលក្ខណៈដែលពួកគេត្រូវមានផងដែរ ។

**២៩:៧** *យកប្រេងមកចាក់លើ* គឺជានិមិត្តរូបនៃការប្រទានអំណោយទានខាងឯព្រលឹងវិញ្ញាណ ដើម្បីទទួលការងារបម្រើព្រះ(មើល ២៨:៤ អស ៦១:១ និងការពន្យល់) ។

១០រួចត្រូវនាំគោឈ្មោលមក នៅមុខត្រសាលជំនុំ ហើយ
អើរ៉ុននិងកូនលោក ត្រូវដាក់ដៃលើក្បាលគោនោះ[ឍ] ១១ត្រូវ
សំឡាប់គោនោះនៅត្រង់មាត់ទ្វារត្រសាលជំនុំ នៅចំពោះ
ព្រះយេហូវ៉ា[ណ] ១២ហើយយកម្រាមដៃជ្រលក់ចុះក្នុងឈាម
នោះខ្លះប្រឡាក់នៅស្នែង[ត]អាសនា រួចត្រូវចាក់ឈាមទាំង
អស់នៅជើងអាសនា[ថ] ១៣ត្រូវយកខ្លាញ់ទាំងអស់[ទ]ដែលនៅ
ជាប់និងអាការៈខាងក្នុង[ធ] ហើយដុំថ្លើមអង្គញ់ទាំង២ និង
ខ្លាញ់ដែលរុំអង្គញ់នោះ ទៅដុតទាំងអស់នៅលើអាសនា
១៤តែសាច់នឹងស្បែក ហើយនិងលាមកទាំងប៉ុន្មាន[ន] នោះ
ត្រូវយកទៅខាងក្រៅទីដំឡើងត្រសាលដុតនៅទីនោះទៅ[ប]
នោះហើយជាដង្វាយលោះបាប ។
១៥ត្រូវឱ្យយកចៀមឈ្មោល១មក[ផ] ហើយអើរ៉ុននិងកូន
លោកត្រូវដាក់ដៃលើក្បាលចៀមនោះ[ព] ១៦ត្រូវសំឡាប់
ចៀមនោះ យកឈាមទៅប្រោះនៅគ្រប់ជុំវិញលើអាសនា
១៧រួចត្រូវកាប់ជាដុំៗ ហើយលាង[ភ]អាការៈខាងក្នុងទាំង
ប៉ុន្មាន និងជើងផង យកទៅដាក់លើដុំសាច់ហើយនិងក្បាល
១៨រួចដុតទាំងអស់នៅលើអាសនា នោះហើយជាដង្វាយ
ដុតថ្វាយព្រះយេហូវ៉ា គឺជាដង្វាយដុតនិងភ្លើងសំរាប់ជាក្លិន
ឈ្ងុយ[ម]ដល់ព្រះយេហូវ៉ា ។
១៩ត្រូវយកចៀម១ទៀតនោះមក[យ] ហើយត្រូវឱ្យអើរ៉ុន
និងកូនលោកដាក់ដៃលើក្បាល[រ] ២០រួចសំឡាប់យកឈាមខ្លះ
ទៅលាបនៅលើទងត្រចៀកស្តាំអើរ៉ុន ហើយលើទង
ត្រចៀកស្តាំនៃពួកកូនលោកដែរ លើមេដៃស្តាំ ហើយលើ
មេជើងស្តាំទាំងអស់គ្នា[ល] រួចប្រោះឈាមទាំងអស់ទៅគ្រប់
លើអាសនាជុំវិញ[វ] ២១ត្រូវឱ្យយកឈាមខ្លះ[ស]ដែលនៅលើ
អាសនា និងប្រេង[ហ]ទៅប្រោះលើអើរ៉ុន លើសំលៀកបំពាក់
លោក លើពួកកូនលោក និងសំលៀកបំពាក់ពួកកូនលោក
ផង នោះលោកនឹងបានបរិសុទ្ធ ព្រមទាំងសំលៀកបំពាក់
ហើយពួកកូនលោក និងសំលៀកបំពាក់របស់គេដែរ[ឡ]
២២ត្រូវយកខ្លាញ់ចៀមនោះ[អ] ព្រមទាំងកន្ទុយនិងខ្លាញ់ដែល
នៅជាប់ និងអាការៈខាងក្នុង ហើយដុំថ្លើមអង្គញ់ទាំង២
និងខ្លាញ់ ដែលរុំនៅអង្គញ់នោះ ហើយនិងស្មាស្តាំផង ដ្បិត
នេះជាចៀមសំរាប់បុណ្យតាំងជាសង្ឃ ២៣ហើយត្រូវយក
នំបុ័ង១ដុំ នំលាយប្រេង១ និងនំក្រៀប១ ពីនំឥតដំបែដែល
នៅក្នុងកញ្ជ្រែងនៅចំពោះព្រះយេហូវ៉ា ២៤ទៅដាក់នៅបាត
ដៃអើរ៉ុន ហើយបាតដៃនៃកូនលោក គ្រវីនំទាំងនោះទុកជា
ដង្វាយគ្រវីនៅចំពោះព្រះយេហូវ៉ា[ក] ២៥រួចត្រូវយកទាំង
អស់ពីដៃចេញទៅដុតនៅលើដង្វាយ ដែលកំពុងតែថ្វាយ
នៅលើអាសនា សំរាប់ជាក្លិនឈ្ងុយថ្វាយព្រះយេហូវ៉ា នោះ
ហើយជាដង្វាយដុតថ្វាយព្រះយេហូវ៉ា[ខ] ២៦ត្រូវឱ្យយកទ្រូង
ចៀម១នោះ ដែលសំរាប់បុណ្យតាំងអើរ៉ុនជាសង្ឃ ទៅគ្រវី
ទុកជាដង្វាយគ្រវីនៅចំពោះព្រះយេហូវ៉ា នោះនឹងបានជា
ចំណែកដល់ឯង[គ] ២៧ឯទ្រូង និងស្មារបស់ចៀម ដែលសំរាប់
បុណ្យតាំងអើរ៉ុននិងកូនលោកឡើងជាសង្ឃ[ឃ] នោះត្រូវ
ញែកជាបរិសុទ្ធ ដោយយកទ្រូងគ្រវីពីម្ខាងទៅម្ខាង ហើយ
ដោយយកស្មាលើកថ្វាយចុះឡើង ២៨នោះនឹងបានជារបស់
ផងអើរ៉ុន ហើយនិងកូនលោក គឺជាច្បាប់សំរាប់ដៅ
អស់កល្បជានិច្ច ដែលពួកកូនចៅអ៊ីស្រាអែលត្រូវកាន់តាម
ដ្បិតនេះឯងជាដង្វាយលើកចុះឡើង ហើយក្នុងអស់ទាំង
ដង្វាយមេត្រី ដែលពួកកូនចៅអ៊ីស្រាអែលថ្វាយ នោះ
ដង្វាយលើកចុះឡើង ជាដង្វាយសំរាប់ព្រះយេហូវ៉ា[ង]។
២៩ឯអស់ទាំងសំលៀកបំពាក់បរិសុទ្ធ[ច]របស់អើរ៉ុន នឹង
ត្រូវទុកឱ្យពួកកូនចៅលោកតរៀងទៅ ឱ្យគេបានស្លៀកពាក់
ក្នុងកាលដែលបានចាក់ប្រេងតាំងគេឡើងជាសង្ឃដែរ[ឆ]
៣០កូនលោកណាមួយ[ជ]ដែលត្រូវជំនួសលោកក្នុងការងារជា
សង្ឃ នោះត្រូវស្លៀកសំលៀកបំពាក់នោះគ្រប់៧ថ្ងៃ ក្នុង

**២៩:១០** ឍ ខ.១០ លវ ១:៤ ៤:១៥ ១៦:២១ ជន ៨:១២ ណ លវ ១:៥,១១ ៤:២៤ ៦:១៦,២៥ ១៤:១៣ **២៩:១២** ត នក ២៧:២ ថ លវ ៤:៧ ៩:៩ **២៩:១៣** ទ ខ.២២ លវ ១:៨ ៣:៣,៥,៩ ៤:១០ ៦:១២ ៧:៣,៥,៣១ ៩:១០ ជន ១៨:១៧ ១សយ ២:១៥ ១ពវ ៨:៦៤ ២រប ៧:៧ ២៩:៣៥ ៣៥:១៤ អស ៤៣:២៤ អគ ៤៤:១៥ ធ នក ១២:៩ **២៩:១៤** ន ណហ ៣:៦ មឡ ២:៣ ប លវ ៤:១២,២១ ១៦:២៧ ជន ១៩:៣–៥ ហព ១៣:១១ **២៩:១៥** ផ ខ.៣ ព ខ.១០ លវ ៣:២ ២រប ២៩:២៣ **២៩:១៧** ភ លវ ១:៩,១៣ **២៩:១៨** ម លប ៨:២១ ២កថ ២:១៥ **២៩:១៩** យ ខ.៣ រ ខ.១០ **២៩:២០** ល លវ ១៤:១៤,២៥ វ ខ.១៦ លវ ១:៥,១១ ៣:២ **២៩:២១** ស ហព ៩:២២ ហ ខ.៧ ឡ ខ.១

**២៩:២២** អ ខ.១៣ **២៩:២៤** ក លវ ៧:៣០ ៩:២១ ១០:១៥ ១៤:១២ ២៣:១១, ២០ ជន ៨:១១,១៣, ១៥ **២៩:២៥** ខ ខ.១៨ **២៩:២៦** គ លវ ៧:៣១–៣៤ **២៩:២៧** ឃ នក ២២:២៩ លវ ៧:៣១,៣៤ ជន ១៨:១១,១២ ចទ ១៨:៣ **២៩:២៨** ង ខ.២២–២៧ លវ ៧:៣០,៣៤ ១០:១៥ **២៩:២៩** ច នក ២៨:២ លវ ១៦:៤ ឆ ជន ២០:២៨ **២៩:៣០** ជ លវ ៦:២២ ជន ៣:៣ ២០:២៨

**២៩:១០** *នាំគោឈ្មោលមក* គឺជាដង្វាយលោះបាប(មើល ខ.១៤) ដើម្បីសម្អាតអំពើបាបពីមុនមក ដែលលោកអើរ៉ុន និងពួកកូនប្រុសរបស់គាត់មាន (មើល លវ ៤:៣ និងការពន្យល់)។ *រួចដាក់ដៃលើក្បាលគោនោះ* គឺជានិមិត្តរូប (១).សត្វគោនោះក្លាយជាអ្នកទទួលជំនួសវិញ និង (២).គឺដើម្បីផ្ទេរបាបរបស់ពួកគេទាំងអស់ ឱ្យទៅសត្វដែលទទួលរងជំនួសវិញ(មើល លវ ១៦:២០–២២ និងការពន្យល់) ។

**២៩:១២** *ស្នែងអាសនា* មើលការពន្យល់ ២៧:២ ។

**២៩:១៣** *ខ្លាញ់* ភាគច្រើននៃផ្នែកនៃខ្លួនគោ(មើល លវ ៣:៣–៥,១៦)ដែលបានជ្រើសរើសហើយ គេដុតនៅលើអាសនា ជាយ័ញ្ញបូជាដល់ព្រះ ។

**២៩:១៨** *ដុតទាំងអស់* គឺជានិមិត្តរូបនៃការថ្វាយទាំងស្រុងទៅចំពោះព្រះ ។

**២៩:២០** *ទងត្រចៀកស្តាំ* ជានិមិត្តរូបនៃភាពរួសរាន់ ចំពោះព្រះអម្ចាស់ និងព្រះបន្ទូលទ្រង់ ។ *លើមេដៃស្តាំ . . . លើមេជើងស្តាំ* ជានិមិត្តរូបនៃការបម្រើអ្នកដទៃ និងដល់ព្រះអម្ចាស់អស់មួយជីវិត ។

**២៩:២៤** *ដង្វាយគ្រវី* មើលការពន្យល់ លវ ៧:៣០–៣២ ។

**២៩:២៨** *នោះនឹងបានជារបស់ផងអើរ៉ុន ហើយនិងកូនលោក* គេត្រូវចែកខ្លួនសត្វដែលត្រូវថ្វាយជាយ័ញ្ញបូជាទុកមួយចំណែក សម្រាប់ជាអាហារដល់ពួកសង្ឃ និងគ្រួសាររបស់ពួកគាត់(មើល លវ ១០:១៤) ។

**២៩:៣១** *កន្លែងបរិសុទ្ធ* គេជឿថា សំដៅទៅលើទីលាននៃរោងឧបោសថ ។

កាលដែលចូលទៅក្នុងត្រសាលជំនុំ ដើម្បីនឹងធ្វើការងារ
ក្នុងទីបរិសុទ្ធ ។
៣១រួចត្រូវឱ្យយកចៀមឈ្មោល[ឈ] សំរាប់បុណ្យតាំងជា
សង្ឃ ទៅស្ងោរនៅកន្លែងបរិសុទ្ធ[ញ] ៣២នោះអើរ៉ុន ព្រម
ទាំងកូនលោក នឹងបរិភោគសាច់ចៀម ហើយនិងនំបុ័ង[ដ]
ក្នុងកញ្ច្រែងនៅមាត់ទ្វារត្រសាលជំនុំ ៣៣ត្រូវឱ្យគេបរិភោគ
របស់ទាំងនោះ ដែលបានថ្វាយឱ្យធួននឹងបាប ដើម្បីនឹង
តាំងគេជាសង្ឃ ហើយញែកជាបរិសុទ្ធ ឯអ្នកប្រទេសក្រៅ
មិនត្រូវបរិភោគ[ឋ]ឡើយ ដ្បិតរបស់ទាំងនោះជារបស់
បរិសុទ្ធ ៣៤បើសិនជាមានសាច់ពីបុណ្យនោះ ឬនំបុ័ងបាន
សល់នៅដល់ព្រឹកឡើង[ឌ] នោះត្រូវយកសំណល់នោះទៅដុត
នឹងភ្លើងទៅ មិនត្រូវបរិភោគឡើង ដ្បិតជារបស់បរិសុទ្ធ ។
៣៥ត្រូវធ្វើបុណ្យនេះគ្រប់៧ថ្ងៃ ដើម្បីនឹងតាំងអើរ៉ុននិង
ពួកកូនលោកឡើងធ្វើជាសង្ឃ តាមអស់ទាំងសេចក្តីដែល
អញបានបង្គាប់ ៣៦រាល់តែថ្ងៃនោះ[ឍ] ត្រូវថ្វាយគោឈ្មោល
១ជាដង្វាយលោះបាប[ណ]សំរាប់ឱ្យធួននឹងបាប យ៉ាងនោះនឹង
បានសំអាតអាសនា ដោយសារដង្វាយ ដែលសំរាប់ឱ្យធួន
នឹងបាប រួចត្រូវចាក់ប្រេងញែក[ត]អាសនាចេញជាបរិសុទ្ធ
៣៧ក្នុងរវាង៧ថ្ងៃនោះ ត្រូវថ្វាយដង្វាយឱ្យធួននឹងអាសនា
ព្រមទាំងញែកជាបរិសុទ្ធ នោះអាសនានឹងបានបរិសុទ្ធជា
ទីបំផុត ហើយរបស់អ្វីដែលប៉ះនឹងអាសនាក៏នឹងបានជា
បរិសុទ្ធដែរ[ថ] ។
៣៨រីឯដង្វាយ ដែលត្រូវថ្វាយនៅលើអាសនារាល់តែថ្ងៃ
ជានិច្ច[ទ]នោះគឺកូនចៀម២អាយុ១ខួប ៣៩កូនចៀម១ត្រូវថ្វាយ
ក្នុងពេលព្រឹក ហើយ១ទៀតក្នុងពេលល្ងាច[ធ] ៤០ហើយដែល
ថ្វាយកូនចៀមមុនដំបូង នោះត្រូវថ្វាយទាំងម្សៅយ៉ាងម៉ដ្ត១
ភាគក្នុង១០ក្នុង១ថាំង លាយនឹងប្រេងសំរាំង១កំប៉ុង[ន] និង
ដង្វាយច្រួចជាស្រាទំពាំងបាយជូរ១កំប៉ុងផង[ប] ៤១លុះដល់
ល្ងាច[ផ] ត្រូវឱ្យឯងថ្វាយកូនចៀម១ទៀត ព្រមទាំងដង្វាយ
ម្សៅ[ព]និងដង្វាយច្រួចដូចថ្វាយពីព្រឹកដែរ នេះគឺជាដង្វាយ
ដុតសំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា ៤២នេះហើយជា
ដង្វាយដុតជានិច្ច[ភ] ដែលកូនចៅឯងតទៅមុខ[ម] ត្រូវថ្វាយនៅ
មាត់ទ្វារត្រសាលជំនុំ[យ]នៅចំពោះព្រះយេហូវ៉ា ជាកន្លែង
ដែលអញនឹងមកជួបនឹងឯងរាល់គ្នា ដើម្បីនឹងនិយាយជា
មួយនឹងឯង[រ] ៤៣អញនឹងមកជួបនឹងពួកកូនចៅអ៊ីស្រាអែល
នៅទីនោះ ហើយកន្លែងនោះនឹងបានបរិសុទ្ធ ដោយសារ
សិរីល្អនៃអញ[ល] ៤៤អញនឹងញែកត្រសាលជំនុំ ហើយនិង
អាសនាចេញជាបរិសុទ្ធព្រមទាំងអើរ៉ុន និងពួកកូនលោក
ដែរ ដើម្បីឱ្យអ្នកទាំងនោះបានធ្វើការងារជាសង្ឃដល់
អញ[វ] ៤៥យ៉ាងនោះអញនឹងនៅ[ស]កណ្តាលពួកកូនចៅអ៊ីស្រា
អែល ហើយនិងធ្វើជាព្រះឱ្យគេ[ហ] ៤៦ដូច្នេះគេនឹងដឹងថា
អញជាព្រះយេហូវ៉ា ជាព្រះដែលបាននាំគេចេញពីស្រុក
អេស៊ីព្ទមក[ឡ] ដើម្បីឱ្យបាននៅកណ្តាលគេ គឺអញនេះហើយ
ជាយេហូវ៉ា ជាព្រះនៃគេ[អ] ។

## អាសនាសម្រាប់ដុតគ្រឿងក្រអូប

*៣០:១-៥ – នក ៣៧:២៥-២៨*

**៣០** ១ត្រូវឱ្យធ្វើអាសនា១[ក]ពីឈើនាងនួនសំរាប់ដុតគ្រឿង
ក្រអូប[ខ] ២ឱ្យមានបណ្តោយ១ហត្ថ ទទឹង១ហត្ថ៤ជ្រុងស្មើ
ហើយកំពស់២ហត្ថ ឯស្នែងអាសនា[គ]ក៏ត្រូវធ្វើភ្ជាប់នឹងតួ

**២៩:៣១** ឈ លវ ៧:៣៧ ២រប ១៣:៩ ញ លវ ១០:១៤ ជន ១៩:៩ អគ ៤២:១៣ **២៩:៣២** ដ មថ ១២:៤ **២៩:៣៣** ឋ លវ ២២:១០,១៣ **២៩:៣៤** ឌ នក ១២:១០ **២៩:៣៦** ឍ ហព ១០:១១ ណ ខ.៣៣, ៣៧ នក ៣០:១០ លវ ១:៤ ៤:២០ ១៦:១៦ ជណ ៦:១១ ៨:១២,១៩ ១៦:៤៦ ២៥:១៣ ២រប ២៩:២៤ ត នក ៤០:១០ ជណ ៧:១០ **២៩:៣៧** ថ នក ៣០:២៨-២៩ ៤០:១០ អគ ៤៣:២៥ មថ ២៣:១៩ **២៩:៣៨** ទ លវ ២៣:២ ជន ២៨:៣-៨ ១រប ១៦:៤០ ២រប ៨:១៣ អគ ៤៦:១៣-១៥ ដយ ១២:១១ **២៩:៣៩** ធ ជន ២៨:៤,៨ ១ពវ ១៨:៣៦ ២រប ១៣:១១ អរ ៣:៣ ទដ ១៤១:២ ដយ ៩:២១ **២៩:៤០** ន នក ៣០:២៤ ជន ១៥:៤ ២៨:៥ ប លប ៣៥:១៤ លវ ២៣:៣៧ ២ពវ ១៦:១៣ **២៩:៤១** ផ ១ពវ ១៨:២៩,៣៦ ២ពវ ៣:២០ ១៦:១៥ អរ ៩:៤,៥ ទដ ១៤១:២ ដយ ៩:២១ ព លវ ២:១ ៥:១៣ ១០:១២ ជន ៤:១៦ ៦:១៧ ១ពវ ៨:៦៤ អស ៤៣:២៣ **២៩:៤២** ភ អគ ៤៦:១៥ ម នក ៣០:៨,១០,២១,៣១ ៣១:១៣ យ នក ២៦:១ ២៧:២១ រ ខ.៤៣ នក ២៥:២២ ៣៣:៩,១១ ជន ៧:៨៩ **២៩:៤៣** ល នក ៣៣:១៨ ៤០:៣៤ លវ ៩:៦ ១ពវ ៨:១១ ២រប ៥:១៤ ៧:២ ទដ ២៦:៨ ៨៥:៩ អគ ១:២៨ ៤៣:៥ ហក ១:៨ ២:៧ **២៩:៤៥** ស នក ២៥:៨ ជន ៣៥:៣៤ យហ ១៤:១៧ រម ៨:១០ ហ លប ១៧:៧ ២កថ ៦:១៦ **២៩:៤៦** ឡ នក ៦:៦ ១៩:៤-៦ ចទ ៥:៦ ទដ ១១៤:១ ហក ២:៥ អ លប ១៧:៧ **៣០:១** ក នក ៤០:៥,២៦ ជន ៤:១១ ១ពវ ៦:២០ អគ ៤១:២២ ខ នក ២៥:៦ ៣៧:២៩ លក ១:១១ ហព ៩:៤ វវ ៨:៣ **៣០:២** គ នក ២៧:២ វវ ៩:១៣

**២៩:៣៦** *ធួននឹងបាប* ដោយព្រោះអាសនាប្រែជាមិនស្អាត ដោយសារបាបរបស់ពួកបណ្តាជន (មើល លវ ១៦:១៦ ហព ៩:២១-២២) ។

**២៩:៣៧** *បរិសុទ្ធ . . . បរិសុទ្ធ* ត្រូវញែកជាបរិសុទ្ធ ថ្វាយដល់ព្រះអម្ចាស់ (មើលការពន្យល់ ៣:៥) ។

**២៩:៣៨-៣៩** វគ្គនេះនិយាយអំពីការថ្វាយដង្វាយប្រចាំថ្ងៃ នៅពេលព្រឹក និងពេលល្ងាច នៅសម័យដែលពួកយូដាប្រែជំនឿ ជួនកាលគេនៅបន្តអនុវត្តការថ្វាយដង្វាយនេះ (មើល ២ពវ ១៦:១៥) ។

**២៩:៤២-៤៣** *អញនឹងមកជួបនឹងឯង* មើលការពន្យល់ ២៧:២១ ។

**២៩:៤៣** *សិរីល្អអញ* គឺជាតំណាងឱ្យវត្តមាននៃព្រះអម្ចាស់ ដែលគ្របដណ្តប់ហឹបសញ្ញា (សូមមើលការពន្យល់ ២៥:១០ មើល ៤០:៣៤-៣៥ ១ពវ ៨:១០-១៣) ។

**២៩:៤៥-៤៦** *នៅកណ្តាលពួកកូនចៅ* មើលការពន្យល់ ២៥:៩ ។

**២៩:៤៥** *ហើយនិងធ្វើជាព្រះឱ្យគេ* តាមធម្មតា ពាក្យនេះបញ្ជាក់អំពីសារៈសំខាន់នៃព្រះបន្ទូលសន្យា ដែលមាននៅក្នុងសេចក្តីសញ្ញា ដែលបានតាំងនឹងរាស្ត្ររបស់ផងទ្រង់ (មើលការពន្យល់ ៦:៧) ។

**២៩:៤៦** *អញជាព្រះយេហូវ៉ា ជាព្រះដែលបាននាំគេចេញពីស្រុកអេស៊ីព្ទមក* មើលការពន្យល់ ២០:២ ។

**៣០:១** *គ្រឿងក្រអូប* ក្លិនក្រអូបជាផ្សែងដែលចេញពីការដុតគ្រឿងក្រអូប គឺជាតំណាងឱ្យសេចក្តីអធិស្ឋានរបស់រាស្ត្រនៃព្រះ (សូមមើល ទដ ១៤១:២ លក ១:១០ វវ ៥:៨ ៨:៣-៤) ។

អាសនា ៣ត្រូវស្រោបដោយមាសសុទ្ធខាងលើ ហើយនៅ
ចំហៀងជុំវិញ ព្រមទាំងស្នែងផង ហើយត្រូវធ្វើកែមដោយ
មាសព័ទ្ធជុំវិញដែរ[ឃ] ៤នៅពីក្រោមកែមនោះត្រូវធ្វើកង
មាស២[ង]ដាក់ភ្ជាប់នៅសងខាង សំរាប់នឹងព្រហកឈើស្នែង
សែងទៅ ៥ឯឈើស្នែងសោត ក៏ត្រូវធ្វើពីឈើនាងនួន
ស្រោបដោយមាសដែរ[ច] ៦ត្រូវដាក់អាសនានោះនៅមុខវាំង
នន ដែលនៅខាងមុខហឹបនៃសេចក្តីបន្ទាល់[ឆ] គឺនៅមុខទី
សន្តោសប្រោសដែលនៅសេចក្តីបន្ទាល់នោះ ជាកន្លែង
ដែលអញមកជួបនឹងឯង ៧អើរ៉ុនត្រូវដុតគ្រឿងក្រអូប[ជ]លើ
អាសនានោះរាល់តែព្រឹក នៅវេលាដែលកំពុងរៀប
ចង្កៀង ៨ហើយរាល់តែល្ងាច ក្នុងកាលដែលលោកអុជ
ចង្កៀង នោះត្រូវដុតគ្រឿងក្រអូបទៀត នេះគឺជាគ្រឿង
ក្រអូបថ្វាយព្រះយេហូវ៉ា សំរាប់ថ្វាយនៅអស់កល្បជានិច្ច
ដល់អស់ទាំងពូជដំណឯងតទៅ[ឈ] ៩មិនត្រូវថ្វាយគ្រឿង
ក្រអូបដទៃ[ញ] ឬយញ្ញបូជាដុត ឬដង្វាយម្សៅណានៅលើ
អាសនានេះឡើយ ក៏មិនត្រូវច្រួចដង្វាយអ្វីលើអាសនានេះ
ដែរ ១០ក្នុង១ឆ្នាំម្តង[ដ] អើរ៉ុនត្រូវយកឈាមនៃដង្វាយលោះ
បាប[ឋ] ដែលថ្វាយសំរាប់ឲ្យធួននឹងបាបមកប្រឡាក់នៅស្នែង
ឲ្យធួននឹងអាសនានេះផង[ឌ] គឺនៅគ្រប់ទាំងដំណឯងរាល់គ្នា
ត្រូវធ្វើដូច្នេះ ដើម្បីឲ្យធួននឹងអាសនានេះក្នុង១ឆ្នាំម្តងជា
និច្ច[ឍ] ដ្បិតជាការបរិសុទ្ធបំផុតនៅចំពោះព្រះយេហូវ៉ា ។

## ដង្វាយលោះបាបជាប្រាក់

១១រួចព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា ១២កាល
ណារាប់ចំនួន[ណ]ពួកកូនចៅអ៊ីស្រាអែលតាមបញ្ជីគេនោះ
ត្រូវឲ្យគេបង់ប្រាក់ ជាថ្លៃលោះខ្លួន[ត] ថ្វាយព្រះយេហូវ៉ា
គ្រប់ៗគ្នា ដើម្បីកុំឲ្យកើតមានសេចក្តីវេទនាណាមួយ[ថ]នៅ
ក្នុងពួកគេ ក្នុងកាលដែលកំពុងតែរាប់ចំនួនគេនោះឡើយ

**៣០:៣** ឃ នក ២៥:១១ **៣០:៤** ង នក ២៥:១២ **៣០:៥** ច នក ២៥:១៣ **៣០:៦** ឆ នក ២៥:២២ ២៦:៣៤ **៣០:៧** ជ នក ២៥:៦ ៤០:២៧ ជណ ៣:១០ ចទ ៣៣:១០ ១សយ ២:២៨ ១របា ៦:៤៩ ២រប ២:៤ ២៦:១៨ ២៩:៧ **៣០:៨** ឈ នក ២៥:៣៧ ២៩:៤២ **៣០:៩** ញ លវ ១០:១ ជណ ១៦:៧,៤០ **៣០:១០** ដ លវ ១៦:២ ឋ លវ ៩:៧ ១៦:១៨–១៩,៣០ ២៣:២៧,២៨ ២៥:៩ ឌ នក ២៩:១៤ លវ ៤:៣ ៦:២៥ ៧:៧ ៨:២,១៤ ជន ៦:១១ ឍ នក ២៩:៤២ **៣០:១២** ណ នក ៣៨:២៥ ជណ ១:២,៤៩ ៤:២,២៩ ១៤:២៩ ២៦:២ ៣១:២៦ ២សយ ២៤:១ ២ពវ ១២:៤ ត នក ៣៨:២៦ ជន ៣១:៥០ មថ ២០:២៨ ថ ជន ១៤:១២ ចទ

១៣ឯអ្នកដែលឆ្លងទៅខាងពួកអ្នកដែលបានរាប់ហើយ នោះ
ត្រូវបង់ថ្លៃ៥កាក់ម្នាក់គ្រប់ៗគ្នា តាមប្រាក់ដែលប្រើក្នុង
ទីបរិសុទ្ធ[ទ] គឺ១រៀលត្រូវជា១០កាក់ ឯ៥កាក់នេះជាដង្វាយ
ថ្វាយព្រះយេហូវ៉ា ១៤ពួកអ្នកទាំងប៉ុន្មានដែលត្រូវរាប់ក្នុង
បញ្ជី តាំងពីអាយុ២០ឆ្នាំឡើងទៅលើ[ធ] នោះត្រូវបង់ថ្លៃ
ថ្វាយជាដង្វាយដល់ព្រះយេហូវ៉ាគ្រប់ៗគ្នា ១៥អ្នកមានមិន
ត្រូវបង់ឲ្យលើសទៅ ហើយអ្នកក្រក៏មិនត្រូវបង់ឲ្យខ្វះពី៥
កាក់[ន] សំរាប់ជាដង្វាយថ្វាយព្រះយេហូវ៉ា ដើម្បីនឹងលោះខ្លួន
នោះដែរ ១៦ត្រូវឲ្យទទួលប្រាក់លោះខ្លួននោះ[ប] ពីពួកកូនចៅ
អ៊ីស្រាអែល សំរាប់ការងារក្នុងត្រសាលជំនុំ[ផ] ដើម្បីឲ្យបាន
ទុកជាសេចក្តីរំឭក[ព] របស់ពួកកូនចៅអ៊ីស្រាអែលនៅ
ចំពោះព្រះយេហូវ៉ា សំរាប់ជាដង្វាយលោះខ្លួន ។

## ក្លាំសម្រាប់ការលាងសម្អាត

១៧ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ១៨ត្រូវឲ្យធ្វើ
ឲ្យបានក្លាំ[ភ] និងជើងពីលង្ហិន សំរាប់ការលាងសំអាតហើយ
ត្រូវដាក់នៅទីពាក់កណ្តាលត្រសាលជំនុំនឹងអាសនា រួចត្រូវ
ដាក់ទឹកចុះ ១៩នោះអើរ៉ុន និងពួកកូនលោក នឹងលាងដៃ
លាងជើង[ម]នៅត្រង់[យ]នោះ ២០កាលណាគេចូលទៅក្នុង
ត្រសាលជំនុំ ត្រូវឲ្យគេលាងនឹងទឹកនោះ ដើម្បីកុំឲ្យត្រូវ
ស្លាប់[រ] ហើយកាលណាចូលទៅជិតអាសនា ដើម្បីធ្វើការ

២៨:៥៨–៦១ ២សយ ២៤:១៣ ១ពវ ៨:៣៧ **៣០:១៣** ទ ឧ.២៤ នក ៣៨:២៤,២៦ លវ ៥:១៥ ២៧:៣,២៥ ជណ ៣:៤៧ ៧:១៣ ១៨:១៦ អគ ៤:១០ ៤៥:១២ មថ ១៧:២៤ **៣០:១៤** ធ នក ៣៨:២៦ ជណ ១:៣,១៨ ១៤:២៩ ២៦:២ ៣២:១១ ២រប ២៥:៥ **៣០:១៥** ន សភ ២២:២ អភ ៦:៩ **៣០:១៦** ប ឧ.១២ ផ នក ៣៨:២៥–២៨ ២រប ២៤:៥ ព ជន ៣១:៥៤ **៣០:១៨** ភ នក ៣១:៩ ៣៥:១៦ ៣៨:៨ ៣៩:៣៩ ៤០:៧,៣០ ១ពវ ៧:៣៨ ២រប ៤:៦ **៣០:១៩** ម នក ៤០:៣១–៣២ យហ ១៣:១០ យ នក ២៩:៤ ៤០:១២ លវ ៨:៦ ទដ ២៦:៦ ហព ១០:២២ **៣០:២០** រ នក ២៨:៤៣

**៣០:៣** *មាស* មើលការពន្យល់ ២៦:៣៧ ។

**៣០:៤** *កង* មើលការពន្យល់ ២៥:១២ ។

**៣០:៦** *វាំងនន ដែលនៅខាងមុខហឹបនៃសេចក្តីបន្ទាល់* មើលការពន្យល់ ២៥:១៦,២២ ២៦:៣១ ។

**៣០:១០** *ដង្វាយលោះបាប* មើល លវ ១៦:៣៤ និងការពន្យល់ ។ *បរិសុទ្ធបំផុត នៅចំពោះព្រះយេហូវ៉ា* មើល ២៩:៣៧ និងការពន្យល់ ។

**៣០:១២** *រាប់ចំនួនពួកកូនចៅអ៊ីស្រាអែល* ការធ្វើជំរឿនប្រជាជនដូចនេះប្រហែលជាធ្វើឡើងនៅក្នុងឱកាសផ្សេងៗ(នៅចន្លោះពេល) ដើម្បីបញ្ចូលពួកអ៊ីស្រាអែលទៅក្នុងតួនាទីក្នុងរាជការ ដើម្បីបម្រើដល់ព្រះអម្ចាស់(មើល ជន ១:២ ២៦:២) ។ *បង់ប្រាក់ជាថ្លៃលោះខ្លួន* គឺជាក្រឹត្យវិន័យបន្តពីក្រឹត្យវិន័យក្នុង ១៣:១៣,១៥(មើលការពន្យល់ ១៣:១៣) ។ ព្រះគ្រីស្ទបានថ្វាយព្រះជន្មទ្រង់ដើម្បីលោះមនុស្សគ្រប់គ្នា(មើល មថ ២០:២៨ មក ១០:៤៥ និងការពន្យល់ ១ធថ ២:៥–៦) ។

**៣០:១៣** *កាក់* គឺសំដៅទៅលើខ្នាតទម្ងន់ មិនមែនប្រាក់កាក់ទេ(មើលការពន្យល់ លប ២០:១៦)។ *តាមប្រាក់ដែលប្រើក្នុងទីបរិសុទ្ធ* ក្នុងគោលបំណងរក្សាមាត្រដ្ឋានទម្ងន់ ដែលគេប្រើក្នុងរោងឧបោសថ ។ ខ្នាត់ទម្ងន់នេះអាចខុសគ្នាបន្តិចបន្តួចពីខ្នាតដែលគេប្រើនៅទីផ្សារ ។

**៣០:១៤** *តាំងពីអាយុ២០ឆ្នាំឡើងទៅ* គឺជាអាយុសម្រាប់បម្រើក្នុងជួរកងទ័ព (មើល ជន ១:៣)។

**៣០:១៦** *ត្រសាលជំនុំ* មើលការពន្យល់ ២៧:២១ ។ *សំរាប់ជាដង្វាយលោះខ្លួន* មើលការពន្យល់ ២៥:១៧ ។

**៣០:១៨** *ចានក្លាំ* គឺធ្វើពីកញ្ចក់ធ្វើពីលង្ហិន ដែលពួកស្ត្រីសាសន៍អ៊ីស្រាអែលបានធ្វើជាដង្វាយដល់ព្រះអម្ចាស់(សូមមើល ៣៨:៨)។ *សំអាត* មើលការពន្យល់ ២៩:៤ ។

ងារ ឬនឹងថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ា [២១]នោះគេត្រូវលាងដៃលាងជើងដែរ ដើម្បីកុំឱ្យត្រូវស្លាប់ នេះជាច្បាប់[ល]សំរាប់នៅអស់កល្បជានិច្ច ដល់អើរ៉ុននឹងពូជពង្សលោកអស់ទាំងដំណតរៀងទៅ[វ] ។

## ការចាក់ប្រេងតាំង

[២២]ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេទៀតថា [២៣]ចូរឱ្យយកគ្រឿងក្រអូបយ៉ាងវិសេស[ស] គឺជាជ័រល្វីងទេសសុទ្ធ ៥០០ដំឡឹង[ហ] សម្បុរល្វែងក្រអូបពាក់កណ្តាល[ឡ] គឺ២៥០ដំឡឹង ឬសកន្ទាយ២៥០ដំឡឹង[អ] [២៤]និងកំញាន[ក]៥០០ដំឡឹង[ខ] តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ ហើយនឹងប្រេងអូលីវ ៨កំប៉ុង [២៥]ត្រូវលាយចំរុះគ្នាធ្វើជាប្រេងសំរាប់បុណ្យចាក់លាបយ៉ាងបរិសុទ្ធ ដែលបានចំរុះលាយគ្នាតាមវិធីធ្វើនៃអ្នកផ្សំគ្រឿងក្រអូប[គ] ទុកសំរាប់ជាប្រេងចាក់លាបយ៉ាងបរិសុទ្ធ[ឃ] [២៦]ត្រូវយកប្រេងនេះ ចាក់លាប[ង]ត្រសាលជំនុំ ហឹបនៃសេចក្តីបន្ទាល់ [២៧]តុ ហើយនិងគ្រឿងប្រដាប់នៃតុទាំងប៉ុន្មាន ជើងចង្កៀង និងគ្រឿងប្រដាប់នៃចង្កៀងទាំងអំបាលម៉ាន អាសនាគ្រឿងក្រអូប [២៨]អាសនាដង្វាយដុត និងគ្រឿងប្រដាប់នៃអាសនានោះទាំងប៉ុន្មាន ហើយចានក្លាំ និងជើងនៃចាននោះផង [២៩]ត្រូវឱ្យញែករបស់ទាំងនោះ[ច] ចេញជាបរិសុទ្ធជាទីបំផុត ឯរបស់អ្វីដែលប៉ះនឹងរបស់ទាំងនោះៗនិងបានបរិសុទ្ធដែរ[ឆ] [៣០]រួចត្រូវឱ្យចាក់ប្រេងលើអើរ៉ុននិងពួកកូនលោក ព្រមទាំងញែក[ជ]គេចេញជាបរិសុទ្ធ ឱ្យបានធ្វើការងារជាសង្ឃដល់អញ[ឈ] [៣១]ត្រូវឱ្យប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ប្រេងនេះត្រូវទុកជាប្រេងសំរាប់បុណ្យចាក់លាប[ញ]យ៉ាងបរិសុទ្ធដល់អញ នៅអស់ទាំងដំណឯងរាល់គ្នាតទៅ[ដ] [៣២]មិនត្រូវយកប្រេងនេះចាក់លើខ្លួនមនុស្សធម្មតាឡើយ ក៏មិនត្រូវផ្សំគ្រឿងតាមកំណត់នេះនឹងធ្វើឱ្យដូចដែរ ដ្បិតប្រេងនេះជាបរិសុទ្ធ ហើយត្រូវឱ្យឯងរាល់គ្នារាប់ជាបរិសុទ្ធដែរ[ឋ] [៣៣]អ្នកណាដែលនឹងផ្សំធ្វើតាមឱ្យដូច ឬដែលយកទៅចាក់លាបដល់អ្នកប្រទេសដទៃ នោះនឹងត្រូវកាត់កាល[ឌ]ពីសាសន៍ខ្លួនចេញ ។

**៣០:២១** ល នក ២៧:២១ វ នក ២៩:៤២
**៣០:២៣** ស លប ៤៣:១១ ហ លប ៣៧:២៥ ឡ សភ ៧:១៧ ៤:១៤ អ ៤:១៤ អស ៤៣:២៤ យរ ៦:២០
**៣០:២៤** ក ខ.១៣ ខ ទដ ៤៥:៨ អក ២៧:១៩
**៣០:២៥** គ ខ.៣៥ នក ៣៧:២៩ ១របា ៩:៣០ ឃ នក ២៩:៧ ១សយ ៩:១៦
**៣០:២៦** ង នក ៤០:៩ លវ ៨:១០ ជន ៧:១
**៣០:២៩** ច លវ ៨:១០–១១ ឆ នក ២៩:៣៧ លវ ៦:១៨,២៧ មថ ២៣:១៧
**៣០:៣០** ជ នក ២៩:៧ លវ ៨:២, ១២,៣០ ១០:៧ ១៦:៣២ ២១:១០, ១២ ១របា ១៥:១២ ទដ ១៣៣:២ ឈ នក ២៨:៤១
**៣០:៣១** ញ នក ២៩:៧ ដ នក ២៩:៤២
**៣០:៣២** ឋ ខ.២៥,៣៧
**៣០:៣៣** ឌ ខ.៣៨ លប ១៧:១៤
**៣០:៣៤** ឍ ៣:៦
**៣០:៣៥** ណ នក ២៥:៦ ត ខ.២៥

## គ្រឿងក្រអូប

[៣៤]រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរយកគ្រឿងក្រអូបទាំងនេះ[ឍ] គឺពុំសែនទេស សន្ទះក្រអូបហើយកប៊ូរ និងកំញានសុទ្ធស្មើគ្នា [៣៥]ត្រូវផ្សំគ្នាធ្វើជាគ្រឿងក្រអូប[ណ] តាមវិធីធ្វើរបស់អ្នកផ្សំគ្រឿងក្រអូប[ត] ទាំងបង់អំបិលផង នេះជាគ្រឿងក្រអូបស្អាត ហើយបរិសុទ្ធ [៣៦]ត្រូវយកខ្លះលំអិតឱ្យម៉ដ្ត នាំទៅដាក់នៅមុខទីបន្ទាល់ក្នុងត្រសាលជំនុំជាកន្លែងដែលអញមកជួប[ថ] នឹងឯង ត្រូវឱ្យឯងរាល់គ្នារាប់គ្រឿងនេះជាបរិសុទ្ធជាទីបំផុត[ទ] [៣៧]កុំឱ្យផ្សំគ្រឿងតាមកំណត់នេះ និងធ្វើឱ្យដូចគ្រឿងក្រអូបនេះសំរាប់ឯងឡើយ ឯងរាល់គ្នាត្រូវរាប់រឿងនេះជាបរិសុទ្ធ[ធ] សំរាប់តែព្រះយេហូវ៉ាប៉ុណ្ណោះ [៣៨]បើអ្នកណាដែលធ្វើឱ្យដូចនឹងគ្រឿងក្រអូបនេះ ទុកសំរាប់នឹងហិត នោះនឹងត្រូវកាត់កាល[ន]ពីសាសន៍ខ្លួនចេញ ។

## បេតសាលាល និងអូហូលីអាប់

*៣១:២–៦ – នក ៣៥:៣០–៣៥*

**៣១** [១]ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា [២]មើលអញបានហៅបេតសាលាល[ក] ជាកូនយូរី ដែលជាកូនហើរ[ខ] ក្នុងអំបូរយូដា [៣]ហើយអញបានបំពេញគាត់ដោយព្រះវិញ្ញាណនៃព្រះ ឱ្យមានគំនិតវាងវៃ មានយោបល់មាន[គ]ចំណេះចេះធ្វើការគ្រប់មុខទាំងអស់[ឃ] [៤]ឱ្យបានប្រសប់នឹងបង្កើតអស់ទាំងការ គឺឱ្យចេះការខាងគ្រឿងមាស ប្រាក់ ហើយនិងលង្ហិន [៥]ចេះច្នៃត្បូងសំរាប់ដាំ ចេះឆ្លាក់ឈើ និងការគ្រប់មុខទាំងអស់ផង [៦]ហើយអញបានហៅអូហូលីអាប់[ង] កូនអ័ហ៊ីសាម៉ាក់ ជាពូជអំបូរដាន់[ច] ឱ្យមកធ្វើការជាមួយនឹងគាត់ដែរ ឯអស់អ្នកណាដែលចំណានការនោះ អញក៏បានបន្ថែមឱ្យមានដំរិះប្រាជ្ញា[ឆ] ដើម្បីនឹងធ្វើអស់ទាំងរបស់

**៣០:៣៦** ថ នក ២៥:២២ ទ ខ.៣២ នក ២៩:៣៧ លវ ២:៣ **៣០:៣៧** ធ ខ.៣២ **៣០:៣៨** ន ខ.៣៣ **៣១:២** ក នក ៣៦:១,២ ៣៧:១ ៣៨:២២ ១របា ២:២០ ២របា ១:៥ ខ នក ១៧:១០ **៣១:៣** គ នក ២៨:៣ ឃ ១ពវ ៧:១៤ ១កថ ១២:៤ **៣១:៦** ង នក ៣៦:១,២ ៣៨:២៣ ច ១ពវ ៧:១៤ ២របា ២:១៤ ឆ នក ២៨:៣

**៣០:២៩** *បរិសុទ្ធ . . . បរិសុទ្ធ* មើល ២៩:៣៧ និងការពន្យល់ ។
**៣០:៣៣** *ត្រូវកាត់កាលពីសាសន៍ខ្លួនចេញ* មើលការពន្យល់ ១២:១៥ ។
**៣០:៣៤** *គឺពុំសែនទេស សន្ទះក្រអូប ហើយកប៊ូរ* មើលការពន្យល់ ២៥:៦។ *កំញានសុទ្ធស្មើគ្នា* ជាជាតិជ័រយកចេញពីសំបកឈើ ដែលដុះនៅភាគខាងត្បូងនៃតំបន់អារ៉ាប់ ។
**៣១:២** *បេតសាលាល* មានន័យថា "នៅក្រោមម្លប់ ឬការការពារនៃព្រះ"។ *ហើរ* មើលការពន្យល់ ១៧:១០ ។
**៣១:៣** *បានបំពេញគាត់ដោយព្រះវិញ្ញាណនៃព្រះ* សមត្ថភាពនៅក្នុងការធ្វើការងារជាង យ៉ាងប៉ិនប្រសព្វ គឺជាអំណោយទានខាងវិញ្ញាណ ដែលព្រះប្រទានដល់អ្នកដែលត្រូវធ្វើការងារពិសេសអ្វីមួយថ្វាយទ្រង់ ។ *មានគំនិតវាងវៃ* មើល សភ ១:២ និងការពន្យល់ ។
**៣១:៦** *អូហូលីអាប់* គឺមានន័យថា "ព្រះវបិតាដ៏ជាព្រះទ្រង់ជារោងឧបោសថនៃខ្ញុំ"។ ឈ្មោះ បេតសាលាល (សូមមើលការពន្យល់ ខ.២) និងអូហូលីអាប់ គឺសក្តិសមជាឈ្មោះរបស់ពួកមេជាង ដែលធ្វើការនៅក្នុងរោងឧបោសថ ។

ដែលអញបានបង្គាប់ដល់ឯង ៧គឺត្រសាលជំនុំ១[ជ] ហឹបនៃ
សេចក្ដីបន្ទាល់១[ឈ] ទីសន្ដោសប្រោសដែលនៅលើហឹប
នោះ១[ញ] ហើយនិងអស់ទាំងប្រដាប់សំរាប់ត្រសាល ៨គឺតុ[ដ]
និងគ្រឿងប្រដាប់នៃតុ ជើងចង្កៀងមាសសុទ្ធ[ឋ] និងប្រដាប់
របស់ចង្កៀង អាសនាគ្រឿងក្រអូប[ឌ] ៩អាសនាដង្វាយដុត[ឍ]
និងគ្រឿងប្រដាប់នៃអាសនានោះ ចានក្លាំ[ណ]និងជើងនៃចាន
នោះ ១០អស់ទាំងសំលៀកបំពាក់សំរាប់ការងារ[ត] គឺ
សំលៀកពាក់បរិសុទ្ធសំរាប់អើរ៉ុន ជាអ្នកថ្វាយបូជា និងអស់
ទាំងសំលៀកបំពាក់ របស់ពួកកូនលោក ដែលសំរាប់ការ
ងារជាសង្ឃ ១១ប្រេងចាក់លាប[ថ] និងគ្រឿងក្រអូប[ទ] សំរាប់
ទីបរិសុទ្ធផង អ្នកទាំងនោះនឹងធ្វើតាមអស់ទាំងសេចក្ដី
ដែលអញបានបង្គាប់[ធ]ដល់ឯង ។[ន]

## ថ្ងៃឈប់សម្រាក

១២ព្រះយេហូវ៉ាទ្រង់ក៏បង្គាប់ម៉ូសេ ១៣ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា ត្រូវឱ្យឯងរាលគ្នាកាន់អស់ទាំងថ្ងៃ
ឈប់សំរាក[ន]របស់អញជាកុំខាន ដ្បិតនោះជាទីសំគាល់[ប]ដល់
អញ ហើយនិងឯងរាល់គ្នា នៅអស់ទាំងដំណតទៅ[ផ] ដើម្បី
ឱ្យបានដឹងថា អញនេះជាព្រះយេហូវ៉ាដែលញែកឯងរាល់
គ្នាចេញជាបរិសុទ្ធ[ព] ១៤ដូច្នេះត្រូវឱ្យរក្សាថ្ងៃឈប់សំរាក
ទាំងនោះ ដ្បិតថ្ងៃនោះជាថ្ងៃបរិសុទ្ធដល់ឯងរាល់គ្នា អស់
អ្នកណាដែលប្រព្រឹត្តកន្លងចំពោះថ្ងៃនោះ នឹងត្រូវសំឡាប់
ជាមិនខាន[ភ] ឯអ្នកណាដែលធ្វើការអ្វីនៅថ្ងៃនោះ នឹងត្រូវ
កាត់កាលពីសាសន៍របស់ខ្លួនចេញ ១៥ក្នុងរវាង៦ថ្ងៃនោះ
ត្រូវធ្វើការ[ម]បាន តែថ្ងៃទី៧ នោះជាថ្ងៃឈប់សំរាកវិញ គឺ
ជាថ្ងៃបរិសុទ្ធដល់ព្រះយេហូវ៉ា ឯអស់អ្នកណាដែលធ្វើការ
អ្វីនៅថ្ងៃឈប់សំរាក[យ] នោះនឹងត្រូវសំឡាប់ចោលជាមិន
ខាន ១៦ហេតុនោះបានជាត្រូវឱ្យពួកកូនចៅអ៊ីស្រាអែលបាន
ស្មោះត្រង់ដល់ថ្ងៃឈប់សំរាកនោះ[រ] ដើម្បីនឹងកាន់តាមនៅ
អស់កល្បជានិច្ច ១៧នោះហើយជាទីសំគាល់[ល]ដល់អញ
ហើយនិងពួកកូនចៅអ៊ីស្រាអែល ជាដរាបរៀងរាបតទៅ
ដ្បិតព្រះយេហូវ៉ា ទ្រង់បានបង្កើតផ្ទៃមេឃនិងផែនដីក្នុង
រវាង៦ថ្ងៃ លុះដល់ថ្ងៃទី៧ នោះទ្រង់ក៏ឈប់សំរាក ហើយ
បានលំហើយព្រះអង្គវិញ[វ]។[ស]
១៨កាលព្រះបានមានបន្ទូលនឹងម៉ូសេ នៅលើភ្នំស៊ីណាយ
រួចសព្វគ្រប់ហើយ[ហ] នោះទ្រង់ក៏ប្រទានសេចក្ដីបន្ទាល់ដល់
លោក ជាសេចក្ដីដែលទ្រង់បានសរសេរចុះនឹងបន្ទះថ្ម២
ផ្ទាំង[ឡ] ដោយអង្គុលីព្រះហស្ដ[អ]។

## រូបកូនគោមាស

៣២ ១កាលបណ្ដាជនទាំងឡាយបានឃើញថា ម៉ូសេក្រ
ចុះមកពីលើភ្នំវិញដូច្នេះ[ក] នោះគេប្រជុំគ្នាទៅឯអើរ៉ុនជំរាប
ថា សូមលោកធ្វើព្រះសំរាប់យើងរាល់គ្នា ឱ្យបាននាំមុខ[ខ]
យើងផង ដ្បិតឯម៉ូសេ ជាអ្នកដែលនាំយើងចេញពីស្រុក
អេស៊ីព្ទមកនោះ យើងរាល់គ្នាមិនដឹងជាលោកមានគ្រោះ
ថ្នាក់អ្វីទេ[គ] ២រួចអើរ៉ុនតបទៅគេថា ដូច្នេះចូរដោះក្រវិល
មាស[ឃ]ពីត្រចៀកប្រពន្ធ និងកូនប្រុសកូនស្រីឯងរាល់គ្នា
យកមកឱ្យអញ ៣នោះគ្រប់គ្នាក៏ដោះយកទៅប្រគល់ឱ្យ
៤ហើយលោកទទួលយកពីដៃគេទៅចាក់ក្នុងពុម្ព សិតធ្វើជា

**៣១:៧** ជ នក ៣៦:៨–៣៨ ឈ នក ៣៧:១–៥ ញ នក ៣៧:៦ ៤០:២០ **៣១:៨** ដ នក ៣៧:១០–១៦ ឋ នក ៣៧:១៧–២៤ លវ ២៤:៤ ឌ នក ៣៧:២៥–២៨ **៣១:៩** ឍ នក ៣៨:៣ ជន ៤:១៤ ណ នក ៣០:១៨ **៣១:១០** ត នក ២៨:២ **៣១:១១** ថ នក ៣០:២២–៣២ ៣៧:២៩ ទ នក ២៥:៦ ធ នក ២៥:៩ **៣១:១៣** ន នក ២០:៨ ប ខ.៧ អស ៥៦:៤ អគ ២០:១២,២០ ផ នក ២៩:៤២ ព លវ ១១:៤៤ ២០:៨ ២១:៨ អគ ៣៧:២៨ **៣១:១៤** ភ អគ ៣៥:២ ជន ១៥:៣២–៣៦ **៣១:១៥** ម នក ២០:៨–១១ ៣៥:២ លវ ១៦:២៩ ២៣:៣ ជន ២៩:៧ **៣១:១៦** យ នក ២០:៨ **៣១:១៧** រ ខ.១៣ ល លប ២:២–៣ វ លប ២:២ នក ២០:៩ អស ៥៦:២ ៥៨:១៣ ៦៦:២៣ យរ ១៧:២១–២២ អគ ២០:១២,២០ **៣១:១៨** ស នក ១៩:១១ ហ នក ២៤:១២ ២កថ ៣:៣ ហព ៩:៤ ឡ នក ៣២:១៥–១៦ ៣៤:១,២៨ ចទ ៤:១៣ ៩:១០ **៣២:១** ក លប ៧:៤ ចទ ៩:៩–១២ ខ នក ១៣:២១ គ ខ.២៣ កច ៧:៤០ **៣២:២** ឃ ពច ៨:២៤–២៧

**៣១:៧** *ត្រសាលជំនុំ* មើលការពន្យល់ ២៧:២១ ។
**៣១:១៣** *កាន់អស់ទាំងថ្ងៃឈប់សំរាករបស់អញ* សេចក្ដីណែនាំអំពីការសាងសង់រោងឧបោសថ និងអាវនៃសម្ដេចសង្ឃ បានបញ្ចប់ដោយការបញ្ជាក់ដល់រាស្ត្រអ៊ីស្រាអែល អំពីភាពសំខាន់ និងចំបាច់នៃការកាន់ថ្ងៃឈប់សំរាក ទោះបីជាកំពុងធ្វើការងារដ៏សំខាន់នោះក៏ដោយ ។ *បរិសុទ្ធដល់អ្នក* មើល ១៩:៦ ២៩:៣៧ និងការពន្យល់ ។
**៣១:១៤** *កាត់កាលពីសាសន៍របស់ខ្លួនចេញ* មើលការពន្យល់ ១២:១៥ ។
**៣១:១៦–១៧** *សេចក្ដីសញ្ញា . . . ទីសំគាល់* នៅក្នុងការធ្វើការបម្រើ និងសម្រាកនៅក្នុងការងារបម្រើព្រះ ពួកអ៊ីស្រាអែលត្រូវយកគំរូតាមព្រះអម្ចាស់ដែលទ្រង់បានបង្កើតអ្វីៗ ហើយការយកគំរូនេះគឺជាការបង្ហាញនូវទីសំគាល់ថ្មីនៃការតាំងសញ្ញាជាមួយព្រះ (មើលការពន្យល់ លប ៩:១២) ។
**៣១:១៨** *បន្ទះថ្មពីរផ្ទាំង* គឺជាបន្ទះថ្មចម្លង នៃក្រឹត្យវិន័យទាំង១០ប្រការ ។ បន្ទះចម្លងមានពីរច្បាប់ ដែលច្បាប់នីមួយៗ គឺសម្រាប់ភាគីទាំងសងខាងនៃសេចក្ដីសញ្ញា ។ ដោយសារពួកអ៊ីស្រាអែលត្រូវយកបន្ទះចម្លងរបស់ខ្លួន ទៅដាក់នៅចំពោះព្រះ (តាមប្រពៃណី) នោះបន្ទះថ្មទាំងពីរច្បាប់ (របស់ព្រះ និងរបស់រាស្ត្រអ៊ីស្រាអែល) ត្រូវដាក់ក្នុងហឹបសញ្ញាជាមួយគ្នា (មើល ២៥:២១) ។ *សេចក្ដីបន្ទាល់* មើលការពន្យល់ ១៦:៣៤ ២៥:១៦ ។ *សរសេរចុះ . . . ដោយអង្គុលីព្រះហស្ដ* ព្រោះជាសេចក្ដីសញ្ញារបស់ ទ្រង់ (១៩:៥–៦ និងការពន្យល់) ហើយទ្រង់ក៏ជាអ្នកចេញក្រឹត្យវិន័យផងដែរ (២០:១–៧) ។
**៣២:១** *ក្រចុះមក* ព្រោះមានរយៈពេល៤០ថ្ងៃ និង៤០យប់ (មើល ២៤:១៨ និងការពន្យល់) ។ *ពួកគេ* គេជឿថា នោះគឺពួកអ្នកដឹកនាំគ្រូ និងពូជអំបូរ ។ *ដ្បិតឯម៉ូសេ ជាអ្នកដែលនាំយើងចេញពីស្រុកអេស៊ីព្ទមកនោះ* សម្ដីនេះគឺខុសពីព្រះបន្ទូលរបស់ព្រះនៃសេចក្ដីសញ្ញា (មើល ២០:២ និងការពន្យល់) ។
**៣២:២** *ក្រវិលមាស* ជាគ្រឿងលំអដែលរឹបអូសបានមកពីស្រុកអេស៊ីព្ទ (មើល ៣:២១–២២ និងការពន្យល់ ៣:២១ ១១:២–៣ ១២:៣៥–៣៦) ។
**៣២:៤** *សិតធ្វើជារូបកូនគោ* គេយកមាសផែរ ហើយស្រោបពីលើកូនគោធ្វើ

រូប[ង]កូនគោ[ច] រួចគេប្រកាសថា នែ ពួកអ៊ីស្រាអែលអើយ
នេះហើយជាព្រះ[ឆ]នៃឯង ដែលបាននាំឯង ចេញពីស្រុក
អេស៊ីព្ទមក[ជ] ៥កាលអើរ៉ុនបានឃើញរូបគោហើយ នោះក៏
ស្អាងអាសនា១នៅមុខរូបនោះ រួចស្រែកប្រកាសថា នៅ
ថ្ងៃស្អែកនេះនឹងមានបុណ្យ[ឈ]ថ្វាយព្រះយេហូវ៉ា ៦លុះដល់ថ្ងៃ
ស្អែកបណ្ដាជនទាំងឡាយ ក៏ក្រោកឡើងពីព្រលឹម ទៅថ្វាយ
ដង្វាយដុត និងដង្វាយមេត្រី[ញ] ក៏នាំគ្នាអង្គុយស៊ីផឹក[ដ] រួច
ក្រោកឡើងលេងសប្បាយ[ឋ]។
៧ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ទៅ ចូរចុះទៅ
ដ្បិតពួកជននៃឯង ដែលឯងបាននាំចេញពីស្រុកអេស៊ីព្ទ
មក[ឌ] គេបានបង្ខូចចិត្តអស់ហើយ[ឍ] ៨ក៏រហ័សងាកបែរ
ចេញ[ណ]ពីផ្លូវដែលអញបានបង្គាប់គេ ហើយបានសិតធ្វើ
រូប[ត]កូនគោ[ថ] នាំគ្នាក្រាបថ្វាយបង្គំ[ទ]ដល់រូបនោះ រួចបាន
ថ្វាយយញ្ញបូជា ដោយប្រកាសថា នែ ពួកអ៊ីស្រាអែលអើយ
នេះហើយជាព្រះនៃឯង ដែលបាននាំឯងចេញពីស្រុក
អេស៊ីព្ទមក[ធ] ៩ព្រះយេហូវ៉ាទ្រង់ក៏មានបន្ទូលនឹងម៉ូសេថា
អញឃើញបណ្ដាជននេះ ថាជាពួកមនុស្សមានក្បាលរឹង[ន]
១០ដូច្នេះទុកឱ្យអញឥឡូវចុះ[ប] ឱ្យសេចក្ដីក្រោធរបស់អញ
បានឆេះក្ដៅឡើងទាស់នឹងគេ អញនឹងបំផ្លាញ[ផ]គេឱ្យសូន្យ
ទៅ ហើយនិងបង្កើតនគរ១យ៉ាងធំពីឯងវិញ[ព]។
១១នោះម៉ូសេទូលអង្វរ[ភ]ដល់ព្រះយេហូវ៉ា ជាព្រះនៃ
លោកថា ឱព្រះយេហូវ៉ាអើយ ហេតុអ្វីបានជាទ្រង់មាន
សេចក្ដីក្រោធក្ដៅឡើងទាស់នឹងរាស្ត្រទ្រង់ ដែលទ្រង់បាន
នាំចេញពីស្រុកអេស៊ីព្ទមក ដោយព្រះចេស្ដាដ៏ធំ ហើយ
ដោយព្រះហស្តខ្លាំងពូកែដូច្នេះ[ម] ១២ហេតុអ្វីបានជាបើក
ឱកាសឱ្យសាសន៍អេស៊ីព្ទមានពាក្យដំណិះថា គឺព្រះចង់ធ្វើ
អាក្រក់ដល់គេហើយ បានជានាំគេចេញទៅ ដើម្បីនឹង
សំឡាប់នៅទីភ្នំ ហើយនិងបំផ្លាញគេពីផែនដីចេញយ៉ាង
នេះ[យ] សូមទ្រង់បង្វែរសេចក្ដីក្រោធដ៏សហ័សរបស់ទ្រង់
ហើយប្រែព្រះហឫទ័យ ដែលទ្រង់បានគិតធ្វើឱ្យរាស្ត្រទ្រង់
អន្តរាយ[រ]នោះចេញ ១៣សូមទ្រង់នឹកចាំ[ល]ពីអ័ប្រាហាំ អ៊ីសាក
ហើយនិងអ៊ីស្រាអែលជាអ្នកបំរើទ្រង់ ដែលទ្រង់បានស្បថ
នឹងអ្នកទាំងនោះ[វ] ដោយព្រះអង្គទ្រង់ថា អញនឹងចំរើនពូជ
ឯងឱ្យបានដូចជាផ្កាយ[ស]នៅលើមេឃ ឯស្រុកទាំងនេះ[ហ]
ដែលអញបានសន្យានឹងឯងថា នឹងឱ្យដល់ពូជឯង ឱ្យគេបាន
ទទួលទុកជាមរដកជារៀងរាបតទៅ ១៤នោះព្រះយេហូវ៉ា

**៣២:៤** ង នក ២០:២៣ ពច ១៧:៣–៤ អស ៣០:២២ ច ខ.៨, ២៤,៣៥ ចទ ៩:១៦ នហ ៩:១៨ ទដ ១០៦:១៩ កច ៧:៤១ ឆ នក ២០:២៣ អស ៤២:១៧ ជ ១ពវ ១២:២៨ ១៤:៩ ២ពវ ១០:២៩ ១៧:១៦ ២រប ១៣:៨ ហស ៨:៦ ១០:៥ **៣២:៥** ឈ លវ ២៣:២,៣៧ ២ពវ ១០:២០ យអ ២:១៥ **៣២:៦** ញ នក ២០:២៤ ៣៤:១៥ លវ ៣:១ ៤:១០ ៦:១២ ៩:៤ ២២:២១ ជន ៦:១៤ ២៥:២ ចទ ២៧:៧ ពច ២០:២៦ អគ ៤៣:២៧ កច ៧:៤១ ដ ពច ១៩:៤ នរ ៣:៣ ១សយ ១:៩ ២សយ ១១:១១ ១ពវ ១២:២៣ ១៨:៤២ នហ ៨:១២ យប ១:៤ សស ៥:១៨ ៨:១៥ យរ ១៦:៨ ឋ ខ.១៧–១៩ ១កថ ១០:៧ **៣២:៧** ឌ ខ.៤,១១ នក ៣៣:១ ឍ លប ៦:១១–១២ អគ ២០:៨ **៣២:៨** ណ យរ ៧:២៦ ១៦:១២ មឡ ២:៨ ៣:៧ ត នក ២០:៤ ថ ខ.៤ ទ នក ២២:២០ ធ ១ពវ ១២:២៨ អគ ២៣:៨ **៣២:៩** ន នក ៣៣:៣,៥ ៣៤:៩ ចទ ៩:៦,១៣ ១០:១៦ ៣១:២៧ ពច ២:១៩ ២ពវ ១៧:១៤ ២រប ៣០:៨ ៣៦:១៣ នហ ៩:១៦ ទដ ៧៨:៨ សភ ២៩:១ អស ៤៦:១២ ៤៨:៤ យរ ៧:២៦ អគ ២:៤ ហស ៤:១៦ កច ៧:៥១ **៣២:១០** ប ១សយ ២:២៥ យរ ៧:១៦ ១១:១៤ ១៤:១១ ផ នក ២២:២៤ ៣៣:៣,៥ ជន ១៦:២១,៤៥ ចទ ៩:១៤,១៩ ទដ ១០៦:២៣ យរ ១៤:១២ អគ ២០:១៣ ព ជន ១៤:១២ ចទ ៩:១៤ **៣២:១១** ភ ចទ ៩:១៨ ២សយ ២១:១ ២រប ១៥:២ ទដ ៩:១០ ៣៤:៤ ១០៦:២៣ អស ៩:១៣ យរ ១៥:១ ម ខ.១៣ ចទ ៩:២៦ ១សយ ៧:៩ នហ ១:១០ ទដ ១៣៦:១២ **៣២:១២** យ ជន ១៤:១៣–១៦ ចទ ៩:២៨ រ ខ.១៤ នក ៣៣:១៣ **៣២:១៣** ល នក ២:២៤ ៣៣:១៣ វ លប ២២:១៦ ហព ៦:១៣ ស លប ១៥:៥ ២២:១៧ ហ លប ១២:៧

ពីឈើ (ក្រោយមកត្រូវបានដុតចោលវិញ, មើល ខ.២០) ឬយកដុំមាសមកឆ្លាក់ធ្វើរូបកូនគោមាននោះ តែក្រោយមកត្រូវរំលាយចោលនៅក្នុងភ្លើង ។ គេជឿថា រូបកូនគោនោះគឺស្រដៀងនឹងព្រះគោ អ័ពីស (Apis, មើលការពន្យល់ យរ ៤៦:១៥)។ ការធ្វើរូបព្រះកូនគោនេះ គឺបានរំលងក្រឹត្យវិន័យទី ២ (២០:៤–៥ និងការពន្យល់)។ *គេ* គឺពួកអ្នកដឹកនាំក្នុងចំណោមពួកបណ្ដាជន (ការពន្យល់ ខ.១)។ *នេះហើយជាព្រះនៃឯង . . . ចេញពីស្រុកអេស៊ីព្ទ* គឺជាការចម្លក ដោយត្រាប់តាម ២០:២ (ការពន្យល់ ខ.១)។ ជាច្រើនសតវត្សរ៍ក្រោយមក ស្ដេចយេរ៉ូបោមបានស្រង់ពាក្យនេះ នៅពេលតាំងរូបកូនគោមាសចំនួនពីរនៅនគរខាងជើង (១ពវ ១២:២៨–២៩ និងការពន្យល់)។

**៣២:៥** *ស្អាងអាសនានៅមុខរូបនោះ . . . បុណ្យថ្វាយព្រះយេហូវ៉ា* លោកអើរ៉ុនបានដឹងពីលទ្ធផលនៃការធ្វើរូបកូនគោនោះ ដូចនេះគាត់ត្រូវធ្វើឱ្យបានរហ័ស ដើម្បីកុំឱ្យពួកបណ្ដាជនងាកបែរចេញពីព្រះអម្ចាស់ទាំងស្រុង។

**៣២:៦** *ក៏នាំគ្នាអង្គុយស៊ីផឹក . . . សប្បាយ* និមិត្តសញ្ញារបស់សាសន៍ដទៃនាំឱ្យមានការប្រព្រឹត្តតាមជំនឿសាសន៍ដទៃ ។ សាវ័កប៉ុលបានដកស្រង់ឃ្លានេះ លើកឡើងពីការងាកបែររបស់ពួកអ៊ីស្រាអែលទៅរករូបព្រះ (១កថ ១០:៧ និងការពន្យល់)។ តាមព្រះគម្ពីរភាសាហេព្រើរ ពាក្យ "លេងសប្បាយ" ច្រើនតែមានន័យ ទាក់ទងនឹងផ្លូវភេទ (មើល លប ២៦:៨)។ ការសប្បាយដោយអសីលធម៌ច្រើនតែ ទាក់ទងនឹងការថ្វាយបង្គំរូបព្រះ ។

**៣២:៧,៩** *ពួកជននៃឯង . . . បណ្ដាជននេះ* ត្រង់ចំណុចនេះ ព្រះអម្ចាស់ទ្រង់មិនហៅថា "រាស្ត្រអញ" (ដូចក្នុង ៣:១០) ទៀត ដើម្បីបញ្ជាក់ថា ទ្រង់ឈប់ទទួលស្គាល់ពួកគេ ព្រោះការល្មើសនឹងសេចក្ដីសញ្ញា (១៧:៤)។

**៣២:៧** *បង្ខូច* មានន័យថា បានខូច ហើយល្មមនឹងត្រូវសេចក្ដីហិនវិនាស (សូមមើល ខ.១០ លប ៦:១១–១៣) ។

**៣២:៩** *ក្បាលរឹង* គឺដូចជាសត្វគោ ឬសេះដែលធ្វើមិនដឹងមិនឮ (មើល យរ ២៧:១១–១២ និងការពន្យល់ នហ ៣:៥)។

**៣២:១០** *ហើយនិងបង្កើតនគរ១យ៉ាងធំពីឯងវិញ* មានន័យថា ពួកសាសន៍អ៊ីស្រាអែល ដែលជាកូនចៅលោកអ័ប្រាហាំ បានធ្វើបាបទាស់នឹងសេចក្ដីសញ្ញា ដូចនេះ ព្រះទ្រង់ដកមរដកនៃសេចក្ដីសន្យាពីពួកគេ ហើយប្រគល់ដល់លោកម៉ូសេវិញ (លប ១២:២)។

**៣២:១១** *រាស្ត្រទ្រង់* លោកម៉ូសេប្រើពាក្យនេះ តាមព្រះបន្ទូលទ្រង់ដែលទ្រង់ធ្លាប់មាន (មើល ខ.៧ និងការពន្យល់) ដើម្បីលើកឡើងពីទំនាក់ទំនងពិសេសដែលទ្រង់មានជាមួយពួកអ៊ីស្រាអែល និងសេចក្ដីតិះដៀលរបស់ពួកអេស៊ីព្ទ (មើល ខ.១២) ហើយនិងសេចក្ដីសន្យានឹងពួកព្ធយុកោ ។

**៣២:១៤** *ព្រះយេហូវ៉ាទ្រង់ក៏ប្រែ* សូមមើលការពន្យល់ យរ ១៨:៧–១០

ទ្រង់ក៏ប្រែ[ឡ]ព្រះហឫទ័យ លែងគិតធ្វើឱ្យរាស្ត្ររបស់ទ្រង់
អន្តរាយចេញទៅ ។
១៥ម៉ូសេក៏វិលចុះលើភ្នំ មានទាំងបន្ទះថ្មនៃសេចក្តី
បន្ទាល់[អ]២ផ្ទាំងកាន់ជាប់នៅដៃផង[ក] ឯបន្ទះថ្មទាំង២នោះ
សឹងដ៏មានអក្សរ[ខ]ទាំងសងខាង គឺខាងមុខ ហើយខាងខ្នង
១៦ជាការដែលព្រះទ្រង់ធ្វើ ហើយអក្សរដែលមាននៅបន្ទះ
ថ្មទាំង២នោះ ក៏ជាអក្សរដែលទ្រង់ឆ្លាក់ដែរ[គ] ១៧កាល
យ៉ូស្វេ [ឃ]បានឮសូរសំឡេងរបស់បណ្តាជនទាំងឡាយ ដែល
គេនាំគ្នាស្រែកដូច្នោះ នោះក៏ជំរាបម៉ូសេថា មានឮសូរ
ចំបាំងនៅទីដំឡើងត្រសាលហើយ ១៨តែម៉ូសេឆ្លើយថា
តាមដែលអញឮ នោះមិនមែនជាសូរសំរែកពួកដែលឈ្នះ
ឬពួកចាញ់ទេ គឺជាសូរសំឡេងនៃមនុស្សដែលច្រៀងវិញ
ទេតើ ១៩លុះកាលណាលោកបានទៅដល់ជិតទីដំឡើង
ត្រសាល បានឃើញរូបកូនគោនោះ[ង] ហើយឃើញគេកំពុង
តែលោតរាំលេង[ច] នោះម៉ូសេកើតមានសេចក្តីកំហឹងខឹង
ក្តៅជាខ្លាំង[ឆ] ក៏បោះបន្ទះថ្មទាំង២ចេញពីដៃបំបែក[ជ]នៅ
ជើងភ្នំទៅ ២០រួចលោកយករូបកូនគោដែលគេបានធ្វើ
នោះទៅដុត[ឈ]នឹងភ្លើង ក៏កិនឱ្យម៉ដ្ត[ញ]បាចចោលទៅលើ
ទឹក[ដ] ហើយបង្ខំឱ្យពួកកូនចៅអ៊ីស្រាអែលផឹក ២១ម៉ូសេក៏សួរ
អើរ៉ុនថា តើគេបានធ្វើអ្វីដល់បង បានជាបងឱ្យគេធ្វើបាបដ៏
មានទំងន់ដូច្នេះ ២២អើរ៉ុនឆ្លើយថា សូមកុំឱ្យលោកម្ចាស់ខឹង
ក្តៅឡើយ[ឋ] ដ្បិតទាំងខ្លួនលោកក៏គង់ជ្រាបដែរថា មនុស្ស
ទាំងនេះចូលចិត្តតែខាងផ្លូវបាបទេ[ឌ] ២៣គេបានប្រាប់ខ្ញុំថា
ចូរធ្វើព្រះឱ្យយើងរាល់គ្នាទៅ ដែលសំរាប់នាំមុខយើង
ដ្បិតឯម៉ូសេនោះ ដែលបាននាំយើងរាល់គ្នាចេញពីស្រុក
អេស៊ីព្ទមក យើងមិនដឹងជាលោកមានគ្រោះថ្នាក់អ្វីទេ[ឍ]
២៤ខ្ញុំបានឆ្លើយតបថា ដូច្នេះអ្នកណាដែលមានមាស ចូរឱ្យ
ដោះយកមកចុះ គេក៏ប្រគល់មកខ្ញុំ រួចខ្ញុំនាំទៅបោះចុះក្នុង
ភ្លើង ស្រាប់តែកើតបានជារូបកូនគោនេះចេញមក[ណ] ។
២៥កាលម៉ូសេឃើញថា បណ្តាជនទាំងឡាយបានផ្តាច់
សេចក្តីបង្ខាំងចោលហើយ ដ្បិតអើរ៉ុនបានបន្ធូរសេចក្តី
បង្ខាំងដល់គេ ព្រមទាំងបើកឱកាស ឱ្យពួកខ្មាំងសត្រូវបាន
ដៀលត្មះ[ត]ផង ២៦នោះម៉ូសេក៏ទៅឈរនៅមាត់ទ្វារទីដំ
ឡើងត្រសាលប្រកាសប្រាប់ថា អ្នកណាដែលនៅខាងព្រះ
យេហូវ៉ា ចូរឱ្យមកឯអញចុះ នោះពួកកូនចៅលេវីទាំង
អស់ក៏មូលគ្នាមកឯលោក ២៧រួចប្រាប់ថា ព្រះយេហូវ៉ាជា
ព្រះនៃពួកអ៊ីស្រាអែលទ្រង់មានបន្ទូលដូច្នេះ ចូរឱ្យឯង
រាល់គ្នាក្រវាត់ដាវនៅចង្កេះ ដើរទៅមកក្នុងទីដំឡើង
ត្រសាល ពីទ្វារដល់ទ្វារ១ ហើយសំឡាប់បងប្អូននឹង
មិត្រភក្តិ ព្រមទាំងអ្នកជិតខាងខ្លួនទៅ[ថ] ២៨ពួកកូនចៅលេវី
ក៏ធ្វើតាមបង្គាប់ម៉ូសេ ហើយនៅថ្ងៃនោះឯង មានបណ្តា

**៣២:១៤** ឡ ចទ ៩:១៩ ១សយ ១៥:១១ ២សយ ២៤:១៦ ១ពវ ២១:២៩ ១រប ២១:១៦ ១ពវ ២១:២៩ ១រប ២១:១៥ ទដ ១០៦:៤៥ យរ ១៨:៨ ២៦:៣,១៩ អម ៧:៣,៦ យហ ៣:១០ **៣២:១៥** អ នក ៣១:១៨ ហព ៩:៤ ក នក ១៩:១៨ ៣៤:៤,២៩ ចទ ៩:១៥ ខ ២កថ ៣:៣ **៣២:១៦** គ នក ២៤:១២ **៣២:១៧** ខ នក ១៧:៩ **៣២:១៩** ង ចទ ៩:១៦ ច ខ.៦ ១កថ ១០:៧ ឆ អរ ៩:៣ ទដ ១១៩:៥៣,១៥៨ ជ នក ៣៤:១ ចទ ៩:១៧ **៣២:២០** ឈ ចទ ៧:២៥ ១២:៣ យស ៧:១ ២ពវ ២៣:៦ ១កថ ១៤:១២ ញ ២រប ៣៤:៧ មីក ១:៧ ដ ចទ ៩:២១ **៣២:២២** ឋ លប ១៨:៣០ ឌ ចទ ៩:២៤ ២៨:២០ ២ពវ ២១:១៥ អរ ៩:១៣ នហ ៩:២៨ យរ ៤:៤ ៤៤:៣ អគ ៦:៩ **៣២:២៣** ឍ ខ.១ កច ៧:៤០ **៣២:២៤** ណ ខ.៤ **៣២:២៥** ត លប ៣៨:២៣ **៣២:២៧** ថ ជន ២៥:៣,៥ ចទ ៣៣:៩ អគ ៩:៥

មើលផងដែរ ២សយ ២៤:១៦ ទដ ១០៦:៤៥ អម ៧:១–៦ ។

**៣២:១៥** *វិលចុះពីលើភ្នំ* មើលការពន្យល់ ២៤:១៨ ។ *បន្ទះថ្មនៃសេចក្តីបន្ទាល់* មើលការពន្យល់ ៣១:១៨ ។ *សេចក្តីបន្ទាល់* មើលការពន្យល់ ១៦:៣៤ ២៥:១៦ ។ *មានអក្សរទាំងសងខាង* គឺនាំឱ្យបន្ទះថ្មនៃក្រឹត្យវិន័យទាំង១០ប្រការមានលក្ខណៈពិសេស ដែលអាចទទួលស្គាល់ជាឯកសារនៃសេចក្តីសញ្ញា ជាផ្លូវការ ។ នៅក្នុងបទគម្ពីរផ្សេងទៀតក៏មាននិយាយអំពីការសរសេរនៅលើក្រាំងទាំងសងខាងផងដែរ (អរ ២:១០ សក ៥:៣ វវ ៥:១) ហើយបន្ទះថ្ម និងក្រាំងសុទ្ធតែបានកត់ត្រា ទាក់ទងនឹងព្រះវត្តមានរបស់ព្រះនៅក្នុងប្រវត្តិសាស្ត្រ ។

**៣២:១៦** *ជាការដែលព្រះទ្រង់ធ្វើ ហើយអក្សរដែលមាន* មើល ៣១:១៨ ។

**៣២:១៧** *យ៉ូស្វេ* ប្រហែលជាគាត់បានរួមដំណើរមួយកំណាត់ផ្លូវ ជាមួយលោកម៉ូសេ ក្នុងដំណើរឡើងទៅលើភ្នំ (មើល ២៤:១៣) ។

**៣២:១៩** *ដៃបំបែក* ដើម្បីធ្វើបន្ទាល់ទាស់នឹងពួកអ៊ីស្រាអែលថា ពួកគេបានធ្វើរំលងសេចក្តីសញ្ញា ។

**៣២:២០** *ទៅដុតនឹងភ្លើង ក៏កិនឱ្យម៉ដ្តបាចចោល* គេបានធ្វើដូចនេះផងដែរចំពោះអាសនារបស់ស្តេចយេរ៉ូបោម (មើលការពន្យល់ ខ.៤) នៅក្រុងបេត–អែលផងដែរ (មើល ២ពវ ២៣:១៥) ។

**៣២:២១** *ធ្វើបាបដ៏មានទំងន់* មើល លប ២០:៩ និងការពន្យល់ ។

**៣២:២២–២៤** ក្នុងពេលដែលជ្រួលច្របល់ខ្លាំង លោកអើរ៉ុនបានស្តីបន្ទោសដល់ពួកបណ្តាជន (ធៀបនឹង លប ៣:១២–១៣ និងការពន្យល់) ប៉ុន្តែ ព្រះបានឱ្យគាត់ទទួលខុសត្រូវវិញ ។ លោកអើរ៉ុនបានរួចទោសវិញ គឺដោយសារតែការអធិស្ឋានទូលអង្វររបស់លោកម៉ូសេប៉ុណ្ណោះ (ចទ ៩:២០) ។

**៣២:២៥** *ផ្តាច់សេចក្តីបង្ខាំងចោលហើយ* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ គេប្រើពាក្យដូចនេះក្នុង សភ ២៩:១៨ ។ ភាពអនាធិប្បតេយ្យបានកើតមានក្នុងចំណោមពួកបណ្តាជន ដែលមិនស្តាប់បង្គាប់ និងថ្វាយបង្គំព្រះអម្ចាស់ ។

**៣២:២៦** *អ្នកណាដែលនៅខាងព្រះយេហូវ៉ា ចូរឱ្យមកឯអញចុះ* មើល យស ២៤:១៥ ១ពវ ១៨:២១ មថ ៦:២៤ ។ *ទាំងអស់* គឺសំដៅលើមនុស្សមួយជំនាន់ ព្រោះ ចទ ៣៣:៩ ក៏បានបង្ហើបផងដែរថា គេបានសម្លាប់ពួកលេវីមួយចំនួនដែរ ។ *ពួកកូនចៅលេវី* កូនចៅជំនាន់ក្រោយនៃលោកលេវី (លប ២៩:៣៤) ត្រូវបានចាត់ទុកជាសង្ឃតាំងតែពីដើមមក (ចទ ១៨:៦–៨) តែក្នុងដំណាក់កាលខ្លះ ត្រូវស្ថិតនៅក្រោមពួកសង្ឃដែលជាកូនចៅលោកអើរ៉ុនដែលប្អូនលោកម៉ូសេ (៣៨:២១ ជន ៣:៩–១០ ១រប ១៦:៤–៦,៣៧–៤២) ។

**៣២:២៧** *ហើយសំឡាប់បងប្អូន និងមិត្រភក្តិ ព្រមទាំងអ្នកជិតខាងខ្លួន* មើល មថ ១០:៣៧ លក ១៤:២៦ ។

**៣២:២៨** *ពួកកូនចៅលេវីក៏ធ្វើតាមបង្គាប់ម៉ូសេ* ក្រោយមកសេចក្តីឧស្សាហ៍ដែលពួកគេមានសម្រាប់ព្រះ ក៏បានបង្ហាញឱ្យឃើញផងដែរ តាមរយៈលោក

ជនស្លាប់ប្រហែលជា៣ពាន់នាក់ ២៩រួចម៉ូសេប្រាប់ថា ចូរ
អ្នករាល់គ្នាថ្វាយខ្លួនដល់ព្រះយេហូវ៉ានៅថ្ងៃនេះចុះ ដើម្បី
ឱ្យទ្រង់បានប្រទានពរដល់អ្នករាល់គ្នានៅថ្ងៃនេះ ដ្បិតគ្រប់
គ្នាបានទាស់នឹងកូនបង្កើត ព្រមទាំងបងប្អូនហើយ ។
៣០ដល់ថ្ងៃស្អែក ម៉ូសេក៏និយាយនឹងបណ្ដាជនទាំងឡាយ
ថា ឯងរាល់គ្នាបានធ្វើបាបយ៉ាងធ្ងន់ណាស់[ទ] តែអញនឹង
ឡើងទៅឯព្រះយេហូវ៉ាឥឡូវ ប្រហែលជាអញនឹងធ្វើយ៉ាង
ណាឱ្យធួននឹងបាប[ធ] ដើម្បីឱ្យឯងរាល់គ្នាបានរួច ៣១ដូច្នេះ
ម៉ូសេត្រឡប់ទៅឯព្រះយេហូវ៉ាទូលថា បណ្ដាជននេះបាន
ធ្វើបាបធ្ងន់ណាស់ហើយ[ន] គឺគេបានធ្វើព្រះពីមាសសំរាប់
ខ្លួនគេ[ប] ៣២តែឥឡូវនេះ សូមទ្រង់អត់ទោសចំពោះអំពើ
បាបរបស់គេផង[ផ] ពុំនោះសោត សូមលុបឈ្មោះ[ព]ទូលបង្គំ
ពីបញ្ជី[ភ] ដែលទ្រង់បានកត់ទុកចេញដែរ ៣៣តែព្រះយេហូវ៉ា
ទ្រង់មានបន្ទូលតបថា ឯអ្នកណាដែលបានធ្វើបាបនឹងអញ
នោះអញនឹងលុបឈ្មោះ[ម]អ្នកនោះឯងពីបញ្ជីចេញ ៣៤ដូច្នេះ
ចូរទៅឥឡូវ ហើយនាំ[យ]បណ្ដាជននេះទៅឯកន្លែង[រ]ដែល
អញបានប្រាប់ឯងចុះ មើល ទេវតាអញ[ល]នឹងនាំមុខឯង
ប៉ុន្តែនៅថ្ងៃដែលអញនឹងមកជំនុំជំរះ នោះអញនឹងធ្វើ
ទោស[វ]ចំពោះបាបរបស់គេ ៣៥រួចព្រះយេហូវ៉ាទ្រង់ចាត់
សេចក្ដីវេទនាផ្សេងៗមកលើបណ្ដាជន ដោយព្រោះគេ
បានធ្វើរូបកូនគោ[ស]ដែលអើរ៉ុនសិតឱ្យនោះ ។

**៣៣** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ចូរទៅចុះ ឱ្យ
ចេញពីទីនេះឡើងទៅ ព្រមទាំងពួកឯងដែលឯងបាននាំ
ចេញពីស្រុកអេស៊ីព្ទមកផង ទៅឯស្រុកដែលអញបានស្បថ
នឹងឱ្យ[ក]ដល់អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប ដោយពាក្យថា នឹង
ឱ្យស្រុកនោះដល់ពូជឯងតទៅ[ខ] ២អញនឹងចាត់ទេវតា១[គ]ឱ្យ
នាំមុខឯង ហើយនិងបណ្ដេញពួកសាសន៍កាណាន សាសន៍
អាម៉ូរី សាសន៍ហេត សាសន៍ពេរិស៊ីត សាសន៍ហេវី និង
សាសន៍យេប៊ូសចេញ[ឃ] ៣ឯងនឹងឡើងទៅឯស្រុក១ដែល
មានទឹកដោះ ហើយនិងទឹកឃ្មុំហូរហៀរ[ង] តែអញមិនឡើង
ទៅកណ្ដាលពួកឯងទេ ក្រែងអញធ្វើឱ្យឯងវិនាស[ច]តាមផ្លូវ
ដ្បិតឯងរាល់គ្នាជាមនុស្សមានក្បាលរឹង[ឆ] ។
៤កាលពួកជនទាំងឡាយបានឮដំណឹងអាក្រក់នោះហើយ
គេក៏មានចិត្តស្រងូតស្រងាត់[ជ] ឥតមានអ្នកណាមួយពាក់
គ្រឿងលំអអ្វីឡើយ ៥ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ឱ្យប្រាប់
ដល់ពួកកូនចៅអ៊ីស្រាអែលថា ឯងរាល់គ្នាជាមនុស្សមាន
ក្បាលរឹង[ឈ] បើអញឡើងទៅកណ្ដាលឯងរាល់គ្នាតែ១ភ្លែត
នោះនឹងធ្វើឱ្យវិនាសអស់ហើយ[ញ] ដូច្នេះ ចូរឯងរាល់គ្នា
ដោះគ្រឿងលំអពីខ្លួនចេញឥឡូវ ដើម្បីឱ្យអញដឹងជាត្រូវធ្វើ
ដល់ឯងរាល់គ្នាជាយ៉ាងណា ៦នោះពួកកូនចៅអ៊ីស្រាអែល
ក៏ដោះគ្រឿងលំអទាំងអស់ពីខ្លួនចេញត្រង់ភ្នំហូរែប[ដ] ។

## ត្រសាលជំនុំ

៧ម៉ូសេលោកក៏យកត្រសាលទៅដំឡើងនៅទីឆ្ងាយ ក្រៅ

**៣២:៣០** ទ ១សយ ១២:២០ ទដ ២៥:១១ ៨៥:២ ធ លវ ១:៤ ៤:២០,២៦ ៥:៦,១០,១៣ ៦:៧ **៣២:៣១** ន នក ៣៤:៩ ចទ ៩:១៨ ប នក ២០:២៣ **៣២:៣២** ផ ជន ១៤:១៩ ព រម ៩:៣ ភ ទដ ៦៩:២៨ អគ ១៣:៩ ដយ ៧:១០ ១២:១ មឡ ៣:១៦ លក ១០:២០ **៣២:៣៣** ម នក ១៧:១៤ យប ២១:២០ វវ ៣:៥ **៣២:៣៤** យ នក ១៥:១៧ រ នក ៣:១៧ ល នក ១៤:១៩ វ លប ៥០:១៩ ចទ? ៣២:៣៥ ដទ ៨៩:៣២ ៩៤:២៣ ៩៩:៨ ១០៩:២០ អស ២៧:១ យរ ៥:៩ ១១:២២ ២៣:២ ៤៤:១៣,២៩ ហស ១២:២ រម ២:៥–៦

**៣២:៣៥** ស ខ.៤ **៣៣:១** ក នក ១៣:១១ ជន ១៤:២៣ ហត ៦:១៣ ខ លប ១២:៧ **៣៣:២** គ នក ១៤:១៩ ឃ នក ២៣:២៨ **៣៣:៣** ង នក ៣:៨ ច នក ៣២:១០ ឆ នក ៣២:៩ កច ៧:៥១ **៣៣:៤** ជ ជណ ១៤:៣៩ អរ ៩:៣ នអ ៤:១ ទដ ១១៩:៥៣**៣៣:៥** ឈ នក ៣២:៩ ញ នក ៣២:១០ **៣៣:៦** ដ នក ៣:១

ភីនេហាស ដែលជាចៅរបស់លោកអើរ៉ុន(មើល ២៥:៧–១៣)។

**៣២:២៩** *ចូរអ្នករាល់គ្នាថ្វាយខ្លួនដល់ព្រះយេហូវ៉ានៅថ្ងៃនេះចុះ* ដោយព្រោះសេចក្ដីឧស្សាហ៍របស់ពួកលេវី ព្រះបានញែកពួកគេ សម្រាប់ការមើលថែរោងឧបោសថ និងជំនួយការពួកសង្ឃ(មើល ជន ១:៤៧–៥៣ ៣:៥–៩,១២,៤១,៤៥ ៤:២–៣)។

**៣២:៣០** *ធ្វើយ៉ាងណាឱ្យធួននឹងបាប . . . ឯងរាល់គ្នាបានរួច* គឺដោយការអធិស្ឋានទូលអង្វរឱ្យអស់ពីចិត្ត នៅចំពោះព្រះអម្ចាស់ ក្នុងឋានៈជាបុគ្គលកណ្ដាលរវាងព្រះ និងរាស្ត្រអ៊ីស្រាអែល ។ ក៏គ្មានយញ្ញបូជាណាមួយដែលរាស្ត្រអ៊ីស្រាអែល ឬលោកម៉ូសេអាចថ្វាយដើម្បីលោះបាបនោះបានទេ។ តែលោកម៉ូសេបានសុខចិត្តលះបង់ជីវិតរបស់គាត់ ដើម្បីកុំឱ្យព្រះអម្ចាស់បំផ្លាញជាតិសាសន៍របស់គាត់(មីល ខ.៣២) ។ ពះយេស៊ូវដ៏ជាបុគ្គលកណ្ដាលដ៏ធំឧត្ដម្គ បានថ្វាយព្រះជន្មទ្រង់ នៅលើឈើឆ្កាង ដើម្បីលោះបាបរាស្ត្រទ្រង់ ។

**៣២:៣២** *សូមលុបឈ្មោះទូលបង្គំពីបញ្ជី* លោកប៉ុលបានប្រើពាក្យស្រដៀងនឹងពាក្យនេះផងដែរ(មើល រម ៩:៣ និងការពន្យល់)។ *បានកត់ទុកចេញដែរ* មើលការពន្យល់ ៩:៥ ៥១:១ ៦៩:២៨ ។

**៣២:៣៣** *ឯអ្នកណាដែលបានធ្វើបាបនឹងអញ នោះអញនឹងលុបឈ្មោះអ្នកនោះឯងពីបញ្ជីចេញ* សំណើរសូមពលីរបស់លោកម៉ូសេត្រូវបដិសេធន៍ព្រោះអ្នកដែលបានធ្វើបាប ត្រូវទទួលខុសត្រូវចំពោះបាបដែលខ្លួនបានធ្វើនោះ(មើល ចទ ២៤:១៦ អគ ១៨:៤ និងការពន្យល់)។

**៣២:៣៤** *ចូរទៅឥឡូវ ហើយនាំបណ្ដាជន* លោកម៉ូសេបានទទួលការធានាពីព្រះអម្ចាស់ថា ទ្រង់នឹងបន្តតាំងសេចក្ដីសញ្ញារបស់ទ្រង់ ជាមួយនឹងរាស្ត្រអ៊ីស្រាអែលដែលអាត្មានិយម និងបន្តបំពេញសេចក្ដីសន្យាអំពីការប្រទានទឹកដីសន្យានោះទៀត ។ *កន្លែងដែលអញបានប្រាប់ឯង* គឺស្រុកកាណាន(មើល ៣៣:១)។ *ទេវតាអញ* មើល ២៣:២៣ ៣៣:២ ។

**៣៣:២** *សាសន៍កាណាន . . . សាសន៍យេប៊ូស* មើលការពន្យល់ ៣:៨ ។

**៣៣:៣** *ស្រុកដែលមានទឹកដោះ ហើយនិងទឹកឃ្មុំហូរហៀរ* មើលការពន្យល់ ៣:៨ ។ *អញមិនឡើងទៅកណ្ដាលពួកឯង* ព្រះអម្ចាស់បានបញ្ជាក់ដល់រាស្ត្រទ្រង់ ដោយព្រះវត្តមានទ្រង់(មើល ២៣:២១ និងការពន្យល់) តែទ្រង់ដកព្រះវត្តមានទ្រង់មួយរយៈដោយសារអំពើបាបរបស់ពួកគេ ។ *ក្បាលរឹង* មើលការពន្យល់ ៣២:៩ ។

**៣៣:៦** *ដោះគ្រឿងលំអទាំងអស់ពីខ្លួនចេញ* គឺជាសញ្ញាបញ្ជាក់ពីការកាន់ទុក្ខ (មើល អគ ២៦:១៦–១៧) ។

**៣៣:៧** *ត្រសាលជំនុំដែលនៅខាងក្រៅទីដំឡើងត្រសាលនោះ* គឺមិនមែនរោងឧបោសថទេ(ធៀបនឹង ២៧:២១) ដែលបានតាំងនៅកណ្ដាលជំរុំ

ពីទីដំឡើងត្រសាលរបស់គេ ហើយឱ្យមានឈ្មោះថា
"ត្រសាលជំនុំ"[ឋ] ឯអស់អ្នកណាដែលរក[ឱ]ព្រះយេហូវ៉ា គេក៏
ចេញទៅឯត្រសាលជំនុំ ដែលនៅខាងក្រៅទីដំឡើង
ត្រសាលនោះ ៨កាលណាម៉ូសេចេញទៅឯត្រសាលជំនុំ
បណ្ដាជនទាំងអស់ក៏ក្រោកឡើងឈរនៅមាត់ទ្វារត្រសាល
របស់គេរៀងខ្លួន[ឍ] ទាំងមើលតាមលោកទាល់តែបានចូល
ផុតក្នុងត្រសាលជំនុំ ៩គ្រាដែលម៉ូសេចូលផុតទៅហើយ
នោះបង្គោលពពក[ណ]ក៏ចុះមកស្ថិតនៅត្រង់មាត់ទ្វារត្រសាល
ហើយព្រះយេហូវ៉ាទ្រង់មានបន្ទូលសន្ទនា[ត] នឹងម៉ូសេ ១០ឯ
បណ្ដាជនគេឃើញបង្គោលពពកសណ្ឋិតនៅត្រង់មាត់ទ្វារ
ត្រសាលជំនុំ ក៏ក្រោកឡើងថ្វាយបង្គំនៅមាត់ទ្វារត្រសាល
របស់គេរៀងខ្លួន[ថ] ១១ព្រះយេហូវ៉ាទ្រង់មានបន្ទូលប្រទល់
មុខនឹងម៉ូសេ[ទ] ដូចជាមនុស្សនិយាយនឹងសំឡាញ់ខ្លួន រួច
លោកត្រឡប់មកដល់ទីដំឡើងត្រសាលគេវិញ តែយ៉ូស្វេ[ធ]
កូននុន ជាជំនួយការរបស់លោក ដែលនៅកំឡោះនៅ
ឡើយ មិនបានចេញពីត្រសាលជំនុំមកទេ ។

## លោកម៉ូសេ និងសិរីល្អរបស់ព្រះយេហូវ៉ា

១២ម៉ូសេលោកទូលដល់ព្រះយេហូវ៉ាថា មើល ទ្រង់
បង្គាប់មកទូលបង្គំឱ្យនាំបណ្ដាជននេះឡើងទៅ[ន] តែទ្រង់មិន
បានបង្គាប់ឱ្យទូលបង្គំដឹង ជាទ្រង់នឹងចាត់អ្នកណា ឱ្យទៅជា
មួយសោះ ទ្រង់បានមានបន្ទូលថា អញស្គាល់ឯងយ៉ាងជិត
សិទ្ធ[ប] ហើយឯងក៏ប្រកបដោយគុណ[ផ]របស់អញផង ១៣ដូច្នេះ
បើទូលបង្គំប្រកបដោយព្រះគុណនៃទ្រង់ពិតមែន នោះសូម
សំដែងបង្ហាញអស់ទាំងផ្លូវរបស់ទ្រង់ដល់ទូលបង្គំផង[ព] ដើម្បី
ឱ្យទូលបង្គំបានស្គាល់ទ្រង់ ហើយឱ្យទូលបង្គំបានប្រកប
ដោយព្រះគុណនៃទ្រង់ពិត រួចសូមទ្រង់នឹកចាំពីសាសន៍
នេះថាជារាស្ត្ររបស់ទ្រង់ផង[ភ] ១៤នោះព្រះយេហូវ៉ាទ្រង់
មានបន្ទូលឆ្លើយថា វិញ្ញាណអញ[ម]នឹងទៅជាមួយនឹងឯង
ហើយអញនឹងឱ្យឯងបានសំរាក[យ] ១៥ម៉ូសេក៏ទូលថា បើសិន
ណាជាព្រះវិញ្ញាណនៃទ្រង់[រ]មិនយាងទៅជាមួយទេ នោះ
សូមកុំនាំយើងខ្ញុំរាល់គ្នាឡើងចេញពីទីនេះទៅឡើយ ១៦ដ្បិត
តើធ្វើដូចម្ដេចឱ្យដឹងថា ទូលបង្គំ ហើយនិងរាស្ត្រទ្រង់
បានប្រកបដោយព្រះគុណនៃទ្រង់ទៅបាន តើមិនមែន
ដោយទ្រង់យាងទៅ ជាមួយនឹងយើងខ្ញុំទេឬអី[ល] យ៉ាងនោះ
ឯង យើងខ្ញុំ គឺខ្លួនទូលបង្គំ និងរាស្ត្ររបស់ផងទ្រង់ នឹងបាន
មែឱចេញពីអស់ទាំងសាសន៍ឯទៀត ដែលនៅផែនដីនេះ[វ] ។
១៧រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា អញនឹង
ធ្វើតាមសេចក្ដី ដែលឯងបានសូមនេះដែរ[ស] ដ្បិតឯងប្រកប
ដោយគុណនៃអញ ហើយអញក៏ស្គាល់ឯងយ៉ាងជិតសិទ្ធ
ផង[ហ] ១៨លោកទូលឆ្លើយថា សូមទ្រង់មេត្តាបើកឱ្យទូលបង្គំ

**៣៣:៧** ឋ នក ២៧:២១ ឱ លប ២៥:២២ ១ពវ ២២:៥
**៣៣:៨** ឍ ខ.១០ ជន ១៦:២៧
**៣៣:៩** ណ នក ១៣:២១ ១៩:៩ ចទ ៣១:១៥ ១កថ ១០:១ ត នក ២៩:៤២ ៣១:១៨ ទដ ៩៩:៧
**៣៣:១០** ថ ខ.៨
**៣៣:១១** ទ ជន ១២:៨ ចទ ៥:៤ ៣៤:១០ ធ នក ១៧:៩
**៣៣:១២** ន នក ៣:១០ ១៥:១៧ ប ខ.១៧ អស ៤៣:១ ៤៥:៣ ៤៩:១ យហ ១០:១៤–១៥ ២ពត ២:១៩ ផ លប ៦:៨
**៣៣:១៣** ព ទដ ២៥:៤ ២៧:១១ ៥១:១៣ ៨៦:១១ ១០៣:៧ ១៤៣:៨ ភ នក ៣:៧ ចទ? ៩:២៦,២៩ ទដ ៧៧:១៥
**៣៣:១៤** ម នក ១៣:២១ ចទ ៤:៣៧ អស ៦៣:៩ ហាក ១:១៣ ២:៤ យ ចទ ១២:៩,១០ ២៥:១៩ យស ១:១៣ ១១:២៣ ២១:៤៤ ២២:៤ ២៣:១ ១ពវ ៨:៥៦ អស ៦៣:១៤ យរ ៣១:២ មថ ១១:២៨ ហព ៤:១–១១ **៣៣:១៥** រ ខ.៣ នក ៣៤:៩ ២ពវ ១៣:២៣ ១៧:១៨ ២៣:២៧ ២៤:២០ ទដ ៥១:១១ ៨០:៣,៧,១៩ យរ ៧:១៥ ៥២:៣ **៣៣:១៦** ល នក ៣៤:៥ ៤០:៣៤,៣៥ ជន ៩:១៥ ១៤:១៤ វ នក ៣៤:១០ លវ ២០:២៤,២៦ ជន ២៣:៩ ចទ ៤:៧, ៣២,៣៤ ៣២:៩ ៣៣:២៨
**៣៣:១៧** ស នក ៣៤:២៨ ចទ ៩:១៨,២៥ ១០:១០ យក ៥:១៦ ហ លប ៦:៨

របស់ពួកអ៊ីស្រាអែលនោះឡើយ តែជាត្រសាលបណ្ដោះអាសន្ន ដែលពួកបណ្ដាជនអាចទទួលការប្រឹក្សាជាមួយព្រះ រហូតដល់ការងារសាងសង់រោងឧបោសថបានបញ្ចប់ ។

**៣៣:៩** *បង្គោលពពកក៏ចុះមកស្ថិតត្រង់មាត់ទ្វារត្រសាល* ជានិមិត្តរូបតំណាងឱ្យទំនាក់ទំនងរបស់ព្រះជាមួយលោកម៉ូសេ "ដូចមនុស្សនិយាយនឹងសំឡាញ់ខ្លួន" (ខ.១១) ។ ក្រោយមក មានពពកចុះមកសណ្ឋិតពីលើរោងឧបោសថនៅពេលសង់ចប់ហើយ (មើល ៤០:៣៣–៣៤ មើលការពន្យល់ ១៣:៣១) ។

**៣៣:១១** *ព្រះយេហូវ៉ាទ្រង់មានបន្ទូលប្រទល់មុខនឹងម៉ូសេ* ព្រះអម្ចាស់បានទំនាក់ទំនងជាមួយលោកម៉ូសេផ្ទាល់ តែមិនបង្ហាញ "ព្រះភ័ក្ត្រ" ទ្រង់ឱ្យឃើញទេ ។ ក្នុងនាមជាបុគ្គលកណ្ដាលនៃគ្រាសញ្ញាចាស់ លោកម៉ូសេមានលក្ខណៈពិសេសខុសពីពួកហោរាទាំងឡាយ (មើល ជន ១២:៦–៨ ចទ ៣៤:១០ និងការពន្យល់) ។ *តែយ៉ូស្វេ . . . មិនបានចេញពីត្រសាលជំនុំទេ* ប្រហែលជាកិច្ចការរបស់គាត់ត្រូវយាមត្រសាល ក្រែងមានអ្នកលួចចូល ។

**៣៣:១២** *តែទ្រង់មិនបានឱ្យទូលបង្គំដឹង ថាទ្រង់នឹងចាត់អ្នកណាឱ្យទៅជាមួយសោះ* មើលការពន្យល់ ខ.៣។ ចំពោះលោកម៉ូសេ ទេវតាមិនអាចជំនួសឱ្យព្រះវត្តមានទ្រង់បានឡើយ ។ *អញស្គាល់ឯង យ៉ាងជិតស្និទ្ធ* មានន័យថាទ្រង់បានរើស សម្រាប់ការដ៏ពិសេស (យរ ១:៥ និងការពន្យល់) ។

**៣៣:១៣** *សូមសំដែងបង្ហាញផ្លូវរបស់ទ្រង់ដល់ទូលបង្គំ* ពាក្យនេះគឺជាការអធិស្ឋាន ដែលទទួលការឆ្លើយតបនៅក្នុង ៣៤:៦–៧ ។

**៣៣:១៤** *វិញ្ញាណអញនឹងនៅជាមួយនឹងឯង* មានន័យថា ព្រះយេហូវ៉ាមិន "លាក់ព្រះភក្ត្រទ្រង់ពីរាស្ត្រទ្រង់ទេ ប៉ុន្តែ ទ្រង់នឹងធ្វើឱ្យព្រះភក្ត្រទ្រង់ចាំងពន្លឺមកលើរាស្ត្រទ្រង់ (មើល ជន ៦:២៥ សភ ១៣:១ និងការពន្យល់) ។ មើលការពន្យល់ ខ.១២ ផងដែរ ។

**៣៣:១៧** *ដ្បិតឯងប្រកបដោយព្រះគុណនៃអញ* ដូចនេះ ចំពោះព្រះយេស៊ូវវិញ តើព្រះបិតាទ្រង់នឹងឮសេចក្ដីអធិស្ឋានរបស់ទ្រង់ ខ្លាំងជាងអម្បាលម៉ានទៅទៀត (សូមមើល មថ ១៧:៥ ហព ៣:១–៦ ផងដែរ) ។

**៣៣:១៨** *សូមទ្រង់មេតាបើកឱ្យទូលបង្គំឃើញសិរីល្អទ្រង់ផង* គ្រប់ការដែលព្រះអម្ចាស់បានធ្វើសម្រាប់ពួកអ៊ីស្រាអែល ដោយប្រើលោកម៉ូសេ បានធ្វើឱ្យគាត់មានសេចក្ដីក្លាហានយ៉ាងខ្លាំង ។ នៅពេលដែលលោកម៉ូសេបានជួបនឹងព្រះជាលើកដំបូង "គាត់មិនហ៊ានមើលសិរីល្អទ្រង់" ដែលបង្ហាញចេញតែបន្តិចប៉ុណ្ណោះ នៅគុម្ពបន្លា (មើល ៣:៦ និងការពន្យល់) ហើយបានទូលសូមពីព្រះនាមទ្រង់ (៣:១៣) ។ ក្នុងខនេះគាត់បានទូលសូមច្រើនពេក ហើយគាត់ត្រូវស្កប់ចិត្ត ដោយទ្រង់បានប្រកាសពីព្រះនាមទ្រង់យ៉ាងពេញលេញហើយ (មើល ខ.១៩,២២ ៣៤:៥–៧) ។

ឃើញសិរីល្អទ្រង់ផង[ឡ] ១៩រួចទ្រង់មានបន្ទូលតបថា អញនឹង
ឱ្យអស់ទាំងសេចក្តីសប្បុរសរបស់អញដើរកាត់នៅមុខឯង[អ]
ព្រមទាំងប្រកាសពីព្រះនាម[ក] "យេហូវ៉ា" នៅមុខឯងផង
អញនឹងប្រោសដល់អ្នកណាដែលអញចង់ប្រោស ហើយនិង
ផ្សាយសេចក្តីមេត្តាករុណាដល់ អ្នកណាដែលអញចង់ផ្សាយ
ឱ្យ[ខ] ២០ទ្រង់ក៏មានបន្ទូលថា ឯងពុំអាចនឹងមើលមុខអញបាន
ឡើយ ដ្បិតមនុស្សជាតិនឹងឃើញ[គ]អញ ហើយរស់នៅមិន
បានទេ ២១ព្រះយេហូវ៉ាទ្រង់ក៏មានបន្ទូលថា មើល មាន
កន្លែង នេះជាទីនៅជិតអញ ត្រូវឱ្យឯងឈរនៅលើថ្មដានេះ
ចុះ ២២កំពុងដែលសិរីល្អរបស់អញកាត់នៅមុខឯង នោះ
អញនឹងដាក់ឯងទៅក្នុងទីក្រហែងថ្ម១[ឃ] ហើយនិងបាំងឯង
ដោយដៃ[ង]ដរាបដល់អញបានទៅហួស ២៣រួចអញនឹងដកដៃ
អញចេញ ឱ្យបានឃើញអញពីខាងខ្នងវិញ ឥតឃើញមុខ
ឡើយ ។

**បន្ទះថ្មថ្មី**

**៣៤** ១ព្រះយេហូវ៉ាទ្រង់ក៏បង្គាប់ដល់ម៉ូសេថា "ចូរដាប់
បន្ទះថ្ម២ផ្ទាំងឱ្យដូចជាបន្ទះថ្ម២ពីមុន[ក]នោះអញនឹងចារិកចុះ
នូវអស់ទាំងពាក្យ ដូចបានកត់នៅបន្ទះថ្មពីមុននោះ[ខ] ដែល
ឯងបានបំបែកហើយ[គ] ២ចូររៀបចំជាស្រេចឱ្យទាន់ពេល
ព្រលឹម រួចឡើងមកឯលើភ្នំស៊ីណាយនៅពេលព្រឹក[ឃ]
ហើយឈរចំពោះអញនៅលើកំពូលភ្នំ ៣កុំឱ្យអ្នកណាឡើង
មកជាមួយនឹងឯងឡើយ ក៏កុំឱ្យឃើញមានអ្នកណានៅទីណា
លើភ្នំឱ្យសោះ[ង] ក៏មិនត្រូវឱ្យហ្វូងចៀមឬហ្វូងគោមករកស៊ី
នៅមុខភ្នំនេះដែរ ៤នោះលោកក៏ដាប់[ច]បន្ទះថ្ម២ផ្ទាំង ឱ្យដូច
ជាថ្មទាំង២ពីមុននោះ រួចលោកក្រោកពីព្រលឹម ឡើងទៅ
លើភ្នំស៊ីណាយ តាមដែលព្រះយេហូវ៉ាបានបង្គាប់មក ព្រម
ទាំងយកបន្ទះថ្មទាំង២ផ្ទាំងកាន់នៅដៃទៅជាមួយផង[ឆ] ។
៥ព្រះយេហូវ៉ាទ្រង់ក៏យោងចុះមកក្នុងពពក[ជ]ស្ថិតនៅជិត
លោក ព្រមទាំងប្រកាសពីព្រះនាម "យេហូវ៉ា"ផង[ឈ] ៦ទ្រង់
យាងកាត់នៅមុខលោកទាំងប្រកាសថា យេហូវ៉ា គឺ
យេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះហឫទ័យមេត្តាករុណា ហើយ
ទន់សន្តោស[ញ] ទ្រង់យឺតនឹងខ្ញាល់[ដ] ហើយមានសេចក្តី
សប្បុរស[ឋ] និងសេចក្តីទៀងត្រង់ ជាបរិបូរ[ឌ] ៧ទ្រង់មាន
សេចក្តីមេត្តាករុណាដល់មនុស្សទាំងពាន់[ឍ] ក៏អត់ទោស
ចំពោះសេចក្តីទុច្ចរិត សេចក្តីរំលង និងអំពើបាប[ណ] ប៉ុន្តែ
ទ្រង់មិនរាប់មនុស្សមានទោសទុកជាឥតទោសឡើយ[ត] ទ្រង់
ធ្វើទោសចំពោះសេចក្តីទុច្ចរិតរបស់ឪពុក ទៅដល់កូនចៅ
ដល់៣ហើយ៤ដំណាផង[ថ]។
៨នោះម៉ូសេក៏ប្រញាប់ប្រញាល់នឹងឱនខ្លួន ក្រាបចុះដល់
ដីថ្វាយបង្គំ ៩រួចទូលថា "ឱព្រះម្ចាស់អើយ បើសិនជាទូល
បង្គំប្រកបដោយព្រះគុណ[ទ]ទ្រង់ពិត នោះសូមព្រះអម្ចាស់
យាងទៅកណ្តាលយើងខ្ញុំរាល់គ្នា[ធ] ដ្បិតមនុស្សទាំងនេះមាន
ក្បាលរឹងណាស់[ន] ហើយសូមអត់ទោសចំពោះសេចក្តីទុច្ចរិត
និងអំពើបាបរបស់យើងខ្ញុំផង[ប] សូមទទួលយើងខ្ញុំរាល់គ្នា
ទុកជាមរដករបស់ទ្រង់"[ផ]។
១០នោះទ្រង់មានបន្ទូលថា មើល អញតាំងសេចក្តីសញ្ញា[ព]
ថា នៅមុខជនជាតិឯងទាំងអស់គ្នា នោះអញនឹងធ្វើការ

**៣៣:១៨** ឡ នក ១៦:៧ យហ ១:១៤ ១២:៤១ ១ធថ ៦:១៦ វវ ១៥:៨ **៣៣:១៩** អ ១ពវ ១៩:១១ ក នក ៦:៣ ៣៤:៥–៧ ខ រម ៩:១៥ **៣៣:២០** គ លប ១៦:១៣ នក ៣:៦ ចទ ៥:២៦ យហ ១:១៨ **៣៣:២២** ឃ លប ៤៩:២៤ ១ពវ ១៩:៩ ទដ ២៧:៥ ៣១:២០ ៦២:៧ ៩១:១ អស ២:២១ យរ ៤:២៩ ង ទដ ៩១:៤ **៣៤:១** ក នក ២៣:១២ ខ ចទ ១០:២,៤ គ នក ៣២:១៩ **៣៤:២** ឃ នក ១៩:១១ **៣៤:៣** ង នក ១៩:១៣ **៣៤:៤** ច ចទ ១០:៣ ឆ នក ៣២:១៥ **៣៤:៥** ជ នក ១៣:២១ ១៩:៩ ឈ នក ៦:៣ ៣៣:១៩ **៣៤:៦** ញ នក ២២:២៧ ជន ១៤:២០ ទដ ៨៦:១៥ ដ ជន ១៤:១៨ ទដ ៧៨:៣៨ យរ
១៥:១៥ រម ២:៤ ឋ លប ១៩:១៦ ឌ ទដ ៦១:៧ ១០៨:៤ ១១៥:១ ១៣៨:២ ១៤៣:១ បទ ៣:២៣ យក ៥:១១ **៣៤:៧** ឍ នក ២០:៦ ចទ ៥:១០ ណ ១ពវ ៨:៣០ ទដ ៨៦:៥ ១០៣:៣ ១៣០:៤,៨ អស ៤៣:២៥ ដយ ៩:៩ ១យហ ១:៩ ត នក ២៣:៧ យស ២៤:១៩ យប ៧:២០–២១ ៩:២៨ ១០:១៤ មីក ៦:១–១៦ ណហ ១:៣ ថ នក ២០:៥ **៣៤:៩** ទ នក ៣៣:១៣ ជន ១១:១៥ ធ នក ៣៣:១៥ ន នក ៣២:៩ ប ជន ១៤:១៩ ១ពវ ៨:៣០ ២របា ៦:២១ ទដ ១៩:១២ ២៥:១១ យរ ៣៣:៨ ហស ១៤:២ ផ នក ៦:៧ ១៩:៥ ចទ ៤:២០ ៧:៦ ៩:២៦,២៩ ១៤:២ ២៦:១៨ ៣២:៩ ១សយ ១០:១ ២សយ ១៤:១៦ ១ពវ ៨:៥១,៥៣ ទដ ២៨:៩ ៣៣:១២ ៧៤:២ ៧៩:១ ៩៤:១៤ ១០៦:៥,៤០អស ១៩:២៥ ៦៣:១៧ យរ ១០:១៦ ៥១:១៩ មីក ៧:៨១ សក ២:១២ **៣៤:១០** ព លប ៦:១៨ ៩:១៥ ១៥:១៨ ចទ ៥:២–៣

**៣៣:១៩** *សេចក្តីសប្បុរស* គឺជានិស្ស័យ និងលក្ខណៈសម្បត្តិរបស់ព្រះ ។ *ព្រះនាម* គឺជានិមិត្តរូបនៃនិស្ស័យ លក្ខណៈសម្បត្តិ និងអង្គនៃទ្រង់(មើល ទដ ២០:១ យហ ១:១២ ១៧:៦)។ ក្នុងខនេះ ព្រះនាមទ្រង់សម្តែមសេចក្តីមេត្តាករុណា(ព្រះគុណ) និងសេចក្តីអាណិត(ដូចនៅក្នុង ៣៤:៦)។ *និងផ្សាយសេចក្តីមេត្តា ករុណាដល់អ្នកណាដែលអញចង់ផ្សាយឱ្យ* លោកប៉ុលបានដកស្រង់ឃ្លានេះ មកនិយាយនៅក្នុង បទគម្ពីរ រម ៩:១៥ ដើម្បីពន្យល់អំពីលក្ខណៈគ្រប់គ្រងរបស់ព្រះលើអ្វីៗគ្រប់យ៉ាង ។

**៣៣:២០** មើលការពន្យល់ លប ១៦:១៣ និងមើល យហ ១:១៨ ៦:៤៦ ១ធម ១:១៧ ១យហ ៤:១២ ។

**៣៣:២១–២៣** ទ្រង់មានបន្ទូលពីអង្គទ្រង់ តាមបែបមនុស្សលោក ។ ចំពោះការបំពេញព្រះបន្ទូលសន្យារបស់ទ្រង់ សូមមើល ៣៤:៥–៧ ។

**៣៤:១** *បន្ទះថ្មពីរ . . . អញនិងចារិកចុះនូវអស់ទាំងពាក្យ* មើលការពន្យល់ ៣១:១៨ ។ *ទាំងពាក្យ* មើលការពន្យល់ ២០:១ ។

**៣៤:៥** *ព្រះនាម* មើលការពន្យល់ ៣៣:១៩ ។

**៣៤:៦–៧** មើល ៣៣:១៩ និងការពន្យល់ ។ នៅក្នុងបទគម្ពីរផ្សេងទៀតនៃព្រះគម្ពីរសញ្ញាចាស់ ក៏បាននិយាយអំពីការប្រកាសរបស់ព្រះអម្ចាស់អំពីអត្ថន័យ និងលក្ខណៈនៃព្រះនាមទ្រង់ផងដែរ(មើល ជន ១៤:១៨ នហ ៩:១៧ ទដ ៨៦:១៥ ១០៣:៨ ១៤៥:៨ យអ ២:១៣ យហ ៤:២)។ មើលការពន្យល់ ៣:១៤–១៥ ៦:២–៣ ។

**៣៤:៧** *ទាំងពាន់* ឬ "មួយពាត់ដំណ"(សូមមើល ២០:៦)។ *សេចក្តីសុច្ចរិត សេចក្តីរំលង និងអំពើបាប* សូមមើល អស ៥៩:១២ និងការពន្យល់ ។

**៣៤:១០** *តាំងសេចក្តីសញ្ញាថា* គឺការតាំងឡើងវិញនូវសេចក្តីសញ្ញា ដែលមានពីមុនមក(ជំពូក ១៩–២៤)។ មានផ្នែកជាច្រើននៃ ខ.១០–២៦ ដែលជាការដកស្រង់ស្ទើរតែទាំងស្រុង ពីវគ្គមុនៗនៃក្នុងព្រះគម្ពីរនិក្ខមនំ(ធៀបនឹង

អស្ចារ្យ[ភ] ជាការដែលមិនដែលកើតមានយ៉ាងដូច្នោះ នៅ
អស់ទាំងនគរគ្រប់លើផែនដី[ម] ហើយអស់ទាំងសាសន៍ដែល
ឯងនៅកណ្ដាលនោះ គេនឹងឃើញការរបស់ព្រះយេហូវ៉ា
ដ្បិតការដែលអញនឹងប្រោសដល់ឯង នោះជាការគួរស្ញែង
ខ្លាច ១១ចូរប្រយ័ត្ននឹងធ្វើតាមអស់ទាំងសេចក្ដីដែលអញ
បង្គាប់ដល់ឯងនៅថ្ងៃនេះចុះ[យ] មើល អញនឹងបណ្ដេញ
សាសន៍អាម៉ូរី សាសន៍កាណាន សាសន៍ហេត សាសន៍
ពេរិស៊ីត សាសន៍ហេវី និងសាសន៍យេប៊ូសចេញពីមុខឯង[រ]
១២ចូរប្រយ័ត្នកុំឱ្យតាំងសេចក្ដីសញ្ញា[ល]នឹងអ្នកស្រុកដែលឯង
ចូលទៅនោះឡើយ ក្រែងលោត្រឡប់ជាអន្ទាក់[វ]ដល់ឯងវិញ
១៣ត្រូវឱ្យឯងរាល់គ្នារំលំអាសនារបស់គេ ព្រមទាំងបំបាក់
បំបែករូបព្រះ ហើយបំផ្លាញអ្នកតារបស់គេចេញ[ស] ១៤ដ្បិត
មិនត្រូវឱ្យឯងរាល់គ្នាក្រាបថ្វាយបង្គំដល់ព្រះឯណាទៀត
ឡើយ[ហ] ពីព្រោះព្រះយេហូវ៉ា ដែលព្រះនាម[ឡ]ជាព្រះ
ប្រចណ្ឌ ទ្រង់មានព្រះហឫទ័យប្រចណ្ឌពិត[អ] ១៥ក្រែងលោ
ឯងតាំងសេចក្ដីសញ្ញា[ក]នឹងពួកអ្នកស្រុកនោះ ហើយកាល
ណាគេ ទៅផិត[ខ]តាមព្រះរបស់គេ ទាំងថ្វាយយញ្ញបូជាដល់
ព្រះនៃ គេនោះក៏ហៅឯងទៅបរិភោគយញ្ញបូជាដែរ[គ]
១៦ហើយក្រែងឯងនឹងយកកូនស្រីគេមកឱ្យ[ឃ]កូនប្រុសសរប
ស់ឯង រួចកូនស្រីគេទៅផិតតាមព្រះគេ[ង] នោះនឹងទាញនាំ
កូនឯងឱ្យផិតតាមព្រះគេដែរ ១៧កុំឱ្យសិតរូបព្រះសិរាប់ឯង
ឱ្យសោះ[ច]។

១៨លុះដល់កំណត់នៅខែចេត្រ នោះត្រូវឱ្យឯងធ្វើបុណ្យ
នំបុ័ងឥតដំបែ[ឆ] ដោយបរិភោគនំបុ័ងឥតដំបែ[ជ]ក្នុងរវាង៧ថ្ងៃ

**៣៤:១០** ភ នក ៣:២០ ម នក ៣៣:១៦ **៣៤:១១** យ ចទ ៦:២៥ យស ១១:១៥ រ នក ២៣:២៨ **៣៤:១២** ល ពច ២:២ វ នក ១០:៧ **៣៤:១៣** ស នក ២៣:២៤ ជន ៣៣:៥២ ចទ ៧:៥ ១២:៣ ពច ៦:២៦ ១ពវ ១៥:១៣ ២រប ១៥:១៦ ១៧:៦ ៣៤:៣–៤ មីក ៥:១៤ **៣៤:១៤** ហ នក ២០:៣ ឡ អស ៩:៦ អ នក ២០:៥ **៣៤:១៥** ក ខ.១២ ចទ?២៣:៦ អរ ៩:១២ ខ នក ២២:២០ ៣២:៨ ចទ ៣១:១៦ ពច ២:១៧ ២ពវ ១៧:៨ ១រប ៥:២៥ ២រប ១១:១៥ អម ២:៤ គ នក ៣២:៦ ១កថ ៨:៤ **៣៤:១៦** ឃ ចទ ៧:៣ ១៧:១៧ យស ២៣:១២ ពច ៣:៦ ១៤:៣ ១ពវ

ដូចជាអញបានបង្គាប់ឯងហើយ ដ្បិតគឺនៅខែចេត្រនោះ[ឈ]
ហើយ ដែលឯងបានចេញពីស្រុកអេស៊ីព្ទមក ។
១៩អស់ទាំងកូនដែលកើតពីម្ដាយមក មុនគេបង្អស់[ញ]នោះ
ជារបស់ផងអញ ព្រមទាំងកូនច្បងរបស់សត្វឯងទាំងប៉ុន្មាន
ដែលជាឈ្មោលផង ទោះបីជាគោ ឬជាចៀមក្តី ២០ឯកូន
ច្បងរបស់សត្វលា នោះត្រូវឱ្យលោះដោយកូនចៀមជា១
តែបើមិនចង់លោះទេ នោះត្រូវបំបាក់កទៅ[ដ] ឯកូនប្រុស
ច្បងនៃឯង[ឋ] នោះត្រូវលោះជាកុំខាន ហើយមិនត្រូវមក
ដោយដៃទទេនៅមុខអញឡើយ[ឌ]។

២១ក្នុងរវាង៦ថ្ងៃ នោះត្រូវធ្វើការចុះ តែដល់ថ្ងៃទី៧ត្រូវ
ឈប់សំរាកវិញ[ឍ] ទោះបីនៅរដូវភ្ជួររាស់ ឬរដូវច្រូតកាត់
ក្តី[ណ] ក៏ត្រូវឈប់សំរាកដែរ ។

២២ត្រូវធ្វើបុណ្យអាទិត្យទី៧ គឺជាបុណ្យផលដំបូង[ត]ពីចំរូត
ស្រូវសាលី និងបុណ្យប្រមូលផល[ថ] ដល់ចុងឆ្នាំដែរ ២៣អស់
ទាំងប្រុសៗក្នុងពួកឯង គេត្រូវនៅចំពោះព្រះអម្ចាស់៣ដង[ទ]
ក្នុង១ឆ្នាំ គឺមកចំពោះព្រះយេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រា
អែល ២៤ដ្បិតអញនឹងបណ្ដេញអស់ទាំងសាសន៍ដទៃ[ធ]ពីមុខ
ឯងចេញ ហើយនិងវាតព្រំស្រុករបស់ឯងឱ្យធំទូលាយ

១១:១,២ ១៦:៣១ អរ ៩:២ ១០:៣ នហ ១០:៣០ ១៣:២៥,២៦ ង ចទ ៧:៤ ១២:៣១ ២០:១៨ ១ពវ ១១:៤ ២ពវ ២១:៣០–១៥ ទដ ១០៦:៣៤–៤១ មឡ ២:១១ **៣៤:១៧** ច នក ២០:៤ **៣៤:១៨** ឆ នក ១២:១៧ មថ ២៦:១៧ លក ២២:១ កច ១២:៣ ជ នក ១២:១៥ ឈ នក ១២:២ **៣៤:១៩** ញ នក ១៣:២ **៣៤:២០** ដ នក ១៣:១៣ ឋ នក ១៣:២ ឌ នក ២៣:១៥ ចទ ១៦:១៦ អគ ៤៦:៩ **៣៤:២១** ឍ លប ២:២–៣ ណ នហ ១៣:១៥ អស ៥៦:២ ៥៨:១៣ **៣៤:២២** ត ខ.២៦ នក ២៣:១៩ លវ ២:១២,១៤ ៧:១៣ ២៣:១០,១៧ ជន ២៨:២៦ ថ នក ២៣:១ **៣៤:២៣** ទ នក ២៣:១៤ **៣៤:២៤** ធ នក ២៣:២៨

ខ.១៨–២៦ និង ២៣:១៤–១៩ ជាពិសេស) មានលក្ខណៈ ដូចក្រឹត្យវិន័យទាំង ១០ប្រការ ដោយសារមានការបែងចែកជាដប់ផ្នែក (មើល ខ.១៥–១៦)។ *គួរស្ញែងខ្លាច* ពាក្យនេះក៏បានប្រើសំដៅទៅលើសេចក្តីវេទនា ដែលព្រះបានទម្លាក់មកលើស្រុកអេស៊ីព្ទផងដែរ (៣:២០)។ ខនេះ ប្រហែលជាប្រើពាក្យនេះសំដៅលើការអស្ចារ្យ ដែលព្រះទ្រង់បានធ្វើនៅពេលដែលពួកគេវិលវល់នៅទីរហោស្ថាន និងនៅពេលវាយកាន់កាប់ទឹកដីស្រុកកាណាន (ទដ ៩:១ និងការពន្យល់)។

**៣៤:១៣** *រូបព្រះ* គឺរូបព្រះនាងអាសេរ៉ា (Asherah) ដែលជាមហេសីរបស់ព្រះអែល ដែលជាព្រះដែលធំជាងគេ របស់សាសន៍កាណាន ។ រូបព្រះនោះមានសណ្ឋានជាបង្គោលឈើមួយចំនួន ដែលឆ្លាក់ជារូបព្រះស្រីនោះ ហើយគេច្រើនតែដំកល់ នៅក្បែរគ្រឿងថ្វាយបង្គំរបស់សាសន៍ដទៃផ្សេងទៀត (មើលឧទាហរណ៍ ពច ៦:២៥) ។

**៣៤:១៤** *ព្រះនាមជាព្រះប្រចណ្ឌ* មើលការពន្យល់ ២០:៥ ។

**៣៤:១៥** *ទៅផិតតាមព្រះរបស់គេ* ជាពាក្យប្រៀបធៀបដែលបានប្រើជាទូទៅ ក្នុងគម្ពីរសញ្ញាចាស ដែលសំដៅទៅលើភាពមិនស្មោះត្រង់របស់ពួកអ៊ីស្រាអែល ចំពោះព្រះអម្ចាស់នៃសេចក្តីសញ្ញា ដែលតាមពាក្យប្រៀបប្រដូចដទៃទៀត ទ្រង់ជាប្តីនៃជាតិសាសន៍អ៊ីស្រាអែល នៅពេលដែលទ្រង់តាំងសញ្ញាជាមួយនឹងពួកគេ (មើល អស ៥៤:៥–៦ យរ ៣:១៤ ៣១:៣២ ហស ២:២,៧,១៦ ធៀបនឹង យរ ២:១ ៣:១,២០ អគ ១៦:៨,៣២,៤៥ ២៣:៤, ៣៧)។ ភាពមិនស្មោះត្រង់នោះ គឺបានបង្ហាញចេញ តាមរយៈអំពើវិលងជាច្រើន ហើយច្រើនបំផុតគឺតាមរយៈការថ្វាយរូបព្រះ (ថ្វាយបង្គំរូបព្រះ ដើម្បីឱ្យស្ត្រីនឹងសត្វមានកូន ហើយដីមានជីជាត ដើម្បីព្យាបាលរបួស និងជម្ងឺ ដើម្បីសេរីភាព ឬសន្តិសុខជៀសផុតពីខ្មាំងសត្រូវ ដូចនេះមានន័យថា ពួកគេបានចាត់ទុកព្រះដទៃជា "សាហាយរបស់ខ្លួន")។ *បរិភោគយញ្ញបូជាដែរ* ការចូលរួមនៅក្នុងការថ្វាយដង្វាយអាហារដល់ព្រះដទៃ ជាការបន្ថយក្រឹត្យវិន័យ (ធៀបនឹង ១កថ ៨ ១០:១៨–២១)។

**៣៤:១៧** *កុំសិតរូបព្រះសម្រាប់ខ្លួនឯងឱ្យសោះ* គឺលោកអើរ៉ុនបានប្រព្រឹត្តការនេះ នៅពេលមួយគាត់បានសិត (ធ្វើ) រូបកូនគោមាស (មើល ៣២:៤)។

**៣៤:២១** *ទោះបើនៅរដូវភ្ជួររាស់ ឬរដូវច្រូតកាត់ក្តី ក៏ត្រូវឈប់សំរាកដែរ* គឺដូចដែលពួកគេត្រូវឈប់សំរាកក្នុងដំណើរសាងសង់រោងឧបោសថ (មើលការពន្យល់ ៣១:១៣,១៦–១៧)។

**៣៤:២៤** *នោះនឹងគ្មានអ្នកណាលោភចង់បានស្រុករបស់ឯងឡើយ* ព្រះ

ឡើង[ន] កាលណាឯងឡើងមកនៅចំពោះព្រះយេហូវ៉ាជាព្រះនៃឯង៣ដងក្នុង១ឆ្នាំ នោះនឹងគ្មានអ្នកណាលោភចង់បានស្រុករបស់ឯងឡើយ ។

២៥កុំឱ្យថ្វាយឈាមរបស់យញ្ញបូជា ដែលថ្វាយដល់អញជាមួយនឹងនំបុ័ងមានដំបែឡើយ[ប] ឯយញ្ញបូជារបស់បុណ្យរំលង នោះក៏មិនត្រូវទុកឱ្យកន្លងដល់ព្រឹកដែរ[ផ]។

២៦ឯចំណែកមុនបង្អស់នៃផលដំបូង[ព] ដែលកើតពីដីឯង នោះត្រូវនាំចូល ទៅក្នុងដំណាក់ព្រះយេហូវ៉ាជាព្រះនៃឯង ។

កុំឱ្យឯងស្ងោរកូនពពែក្នុងទឹកដោះរបស់មេវាឡើយ[ភ] ។

២៧រួចព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ចូរកត់[ម]ពាក្យទាំងនេះចុះ ដ្បិតអញតាំងសេចក្ដីសញ្ញារបស់អញ[យ]នឹងឯង ហើយនិងពួកអ៊ីស្រាអែលតាមន័យពាក្យទាំងនេះ ២៨លោកក៏នៅទីនោះ ជាមួយនឹងព្រះយេហូវ៉ា អស់៤០ថ្ងៃ ៤០យប់[រ] ឥតមានបរិភោគអ្វីឡើយ[ល] ហើយទ្រង់ក៏ចារិកចុះនូវអស់ទាំងពាក្យនៃសេចក្ដីសញ្ញាទាំង១០ប្រការ នៅលើបន្ទះថ្ម[វ]ទាំង២ផ្ទាំងនោះ[ស]។

## មុខភ្លឺរបស់លោកម៉ូសេ

២៩រួចកាលម៉ូសេបានចុះពីលើភ្នំស៊ីណាយមកវិញ[ហ] ព្រមទាំងកាន់បន្ទះថ្ម នៃសេចក្ដីបន្ទាល់ ទាំង២ផ្ទាំង នៅដៃមកផង[ឡ] នោះកំពុងដែលចុះមក លោកឥតបានដឹងជាស្បែកមុខលោកភ្លឺ[អ] ដោយបានទូលនឹងទ្រង់នោះទេ ៣០លុះអើរ៉ុន និងពួកកូនចៅអ៊ីស្រាអែលទាំងអស់ បានឃើញលោក នោះឃើញស្បែកមុខលោកភ្លឺ ហើយគេខ្លាចមិនហ៊ានទៅជិតលោកឡើយ ៣១តែម៉ូសេហៅគេឱ្យមក នោះអើរ៉ុននិងអស់ទាំងមេពួកជំនុំ[ក]ក៏នាំគ្នាត្រឡប់មកឯលោកវិញ ហើយលោកបាននិយាយនឹងគេ ៣២រួចមកពួកកូនចៅអ៊ីស្រាអែលក៏ចូលមកជិតទាំងអស់គ្នា ហើយលោកបានប្រាប់ពីអស់ទាំងសេចក្ដីដែលព្រះយេហូវ៉ាបានបង្គាប់[ខ]លោកនៅលើភ្នំស៊ីណាយ ៣៣លោកបានយកស្បៃមកបាំងមុខដរាបដល់ឈប់និយាយនឹងគេ ៣៤តែកាលណាម៉ូសេចូលទៅចំពោះព្រះយេហូវ៉ា ដើម្បីទូលនឹងទ្រង់ នោះលោកបកស្បៃចេញវិញ ដរាបដល់ចេញមក លុះចេញមកវិញហើយ នោះក៏ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល តាមអស់ទាំងសេចក្ដីដែលទ្រង់បង្គាប់មក ៣៥ឯពួកកូនចៅអ៊ីស្រាអែលគេបានមើលមុខម៉ូសេ ឃើញស្បែកមុខលោកភ្លឺ[គ] បានជាលោកយកស្បៃមកបាំងមុខទៀត ទាល់តែចូលទៅទូលនឹងទ្រង់វិញ ។

**៣៤:២៤** ន ចទ ១២:២០ ១៩:៨ យប ១២:២៣
**៣៤:២៥** ប នក ២៣:១៨ ផ នក ១២:៨
**៣៤:២៦** ព នក ២២:២៩ ជន ១៨:១២ ភ នក ២៣:១៩
**៣៤:២៧** ម នក ១៧:១៤ យ លប ៦:១៨ ១៥:១៨
**៣៤:២៨** រ លប ៧:៤ មថ ៤:២ លក ៤:២ ល ចទ ៩:៩,១៨ អរ ១០:៦ វ ខ.១ នក ៣១:១៨ ស ចទ ៤:១៣ ១០:៤
**៣៤:១៩** ញ នក ១៣:២
**៣៤:២០** ដ នក ១៣:១៣ ឋ នក ១៣:២ ឌ នក ២៣:១៥ ចទ ១៦:១៦ អគ ៤៦:៩
**៣៤:២១** ឍ លប ២:២–៣ ណ នហ ១៣:១៥ អស ៥៦:២ ៥៨:១៣
**៣៤:២២** ត ខ.២៦ នក ២៣:១៩ លវ ២:១២,១៤ ៧:១៣ ២៣:១០,១៧ ជន

## ក្រឹត្យវិន័យសម្រាប់ថ្ងៃបុណ្យឈប់សម្រាក

**៣៥** ១ម៉ូសេក៏ប្រមូលពួកជំនុំនៃកូនចៅអ៊ីស្រាអែលទាំងអស់មកប្រាប់ថា នេះជាសេចក្ដីដែលព្រះយេហូវ៉ាបានបង្គាប់[ក]មកឱ្យអ្នករាល់គ្នាប្រព្រឹត្តតាម ២គឺក្នុងរវាង៦ថ្ងៃនោះធ្វើការបាន តែដល់ថ្ងៃទី៧ ជាថ្ងៃបរិសុទ្ធសំរាប់អ្នករាល់គ្នាវិញ ថ្ងៃនោះជាថ្ងៃផ្អាកការ គឺជាថ្ងៃឈប់សំរាក[ខ]ដល់ព្រះយេហូវ៉ា អ្នកណាដែលធ្វើការអ្វីនៅថ្ងៃនោះ នឹងត្រូវសំឡាប់ចោល[គ] ៣អ្នករាល់គ្នាមិនត្រូវទាំងបង្កាត់ភ្លើងនៅក្នុងផ្ទះឯណាមួយ ក្នុងថ្ងៃឈប់សំរាកនោះផង[ឃ] ។

## សម្ភារៈសម្រាប់រោងឧបោសថ

*៣៥:៤–៩ – នក ២៥:១–៧*

*៣៥:១០–១៩ – នក ៣៩:៣២–៤១*

៤ម៉ូសេក៏ប្រាប់ដល់ពួកជំនុំនៃពួកកូនចៅអ៊ីស្រាអែល

២៨:២៦ ថ នក ២៣:១៦ **៣៤:៣៣** គ កច ៣:១៣ **៣៤:៣៥** ឃ ខ.២៩ **៣៥:១** ក នក ៣៤:៣២**៣៥:២** ខ លប ២:៣ នក ៣៤:២១ ចទ ៥:១៣–១៤ គ នក ៣១:១៤ **៣៥:៣** ឃ នក ១៦:២៣

អម្ចាស់បានសន្យាថា នឹងការពារទឹកដីកម្មសិទ្ធិរបស់ពួកធ្វើធម្មយាត្រា ទៅចូលរួមពិធីបុណ្យដែលមានការទទួលអាហារទាំងបីដង ជារៀងរាល់ឆ្នាំ ដើម្បីបង្ហាញវត្តមាននៅចំពោះទ្រង់(មើល ចទ ១៦:១៦ និងការពន្យល់)។

**៣៤:២៧** *ចូរកត់ពាក្យទាំងនេះចុះ* គឺដូចដែលគាត់បានធ្វើការកត់ត្រាស្រដៀងគ្នា កាលពីមុន(មើល ២៤:៤) ។

**៣៤:២៨** *ទ្រង់ចារិកចុះ* មើល ខ.១ ។ *ពាក្យនៃសេចក្ដីសញ្ញាទាំង១០ប្រការ* ពាក្យក្រឹត្យវិន័យទាំង១០ប្រការ និងពាក្យនៃសេចក្ដីសញ្ញាគឺមានន័យដូចគ្នា (មើលការព្យល់ ២០:១) ។

**៣៤:២៩** *សេចក្ដីបន្ទាល់* មើលការពន្យល់ ១៦:៣៤ ២៥:១៦ ។ *ស្បែកមុខលោកភ្លឺ* ក្នុងពេលនេះ លោកម៉ូសេ(មើល ៣៣:១៨ និងការពន្យល់) កំពុងតែបញ្ចេញសិរីល្អនៃទ្រង់នៅលើមុខខ្លួនវិញ ។ តាមព្រះគម្ពីរភាសាហេព្រើរ ពាក្យ "ភ្លឺ"គឺទាក់ទងនឹង ពាក្យ "ស្នែង"។ ដូចនេះ មានអ្នកខ្លះយល់ច្រឡំអំពីអត្ថន័យនៃពាក្យនេះ នៅពេលបកប្រែព្រះគម្ពីរជាភាសាឡាតាំងដោយក្រុមវ៉ាហ្គេដ(Vulgate) ជាហេតុនាំឱ្យពួកវិចិត្រករនៅមជ្ឈិមសម័យ នាំគ្នាគូររូបលោកម៉ូសេ មានស្នែងនៅលើក្បាលរបស់គាត់ ។

**៣៤:៣៣** *លោកបានយកស្បៃមកបាំងមុខ* គឺដើម្បីកុំឱ្យពួកគេអាចឃើញការថយចុះនៃពន្លឺនៅលើមុខគាត់ និងឱ្យពួកគេនៅតែបន្តគោរពគាត់ដែលជាតំណាងរបស់ព្រះអម្ចាស់ ។ ចំពោះការនិយាយក្នុងព្រះគម្ពីរសញ្ញាថ្មី អំពីការដែលលោកម៉ូសេបានធ្វើ សូមមើល ២កថ ៣:៧–១៨ និងការពន្យល់ ។

**៣៥:១–៣** ពួកអ៊ីស្រាអែលបានទទួលការរំឭកអំពីសារៈសំខាន់ នៃការកាន់ថ្ងៃឈប់សម្រាកភ្លាមៗ បន្ទាប់ពីបានទទួលការបង្គាប់ អំពីការសង់រោងឧបោសថ និងអំពីសំលៀកបំពាក់សម្ដេចសង្ឃ(មើលការពន្យល់ ៣១:១៣) ហើយក្នុងវគ្គនេះ មុនពេលបំពេញតាមសេចក្ដីបង្គាប់ទាំងនោះ ពួកគេបានទទួលការំឭកនោះម្ដងទៀត ។

**៣៥:៤–៣៩:៤៣** ភាគច្រើននៃអត្ថបទក្នុងវគ្គនេះ ជាការនិយាយឡើងវិញ ឬជូនកាលដកស្រង់ទាំងស្រុងនូវបទគម្ពីរនៃជំពូក ២៥–២៨ ៣០:១–៥ ៣១:១

ទាំងអស់ថា នេះជាសេចក្ដីដែលព្រះយេហូវ៉ាបានបង្គាប់
មក ៥គឺត្រូវឱ្យយកដង្វាយពីរបស់ដែលអ្នករាល់គ្នាមានទាំង
ប៉ុន្មាន មកថ្វាយដល់ព្រះយេហូវ៉ា ត្រូវឱ្យអស់អ្នកណាដែល
ថ្វាយស្ម័គ្រពីចិត្ត យកដង្វាយនេះមកថ្វាយដល់ព្រះយេហូវ៉ា
ចុះ គឺជាមាស ជាប្រាក់ ជាលង្ហិន ៦ជាល័ខពណ៌ផ្ទៃមេឃ
ពណ៌ស្វាយ ពណ៌ក្រហម ខ្លូតទេសយ៉ាងម៉ដ្ត និងរោមពពែ
៧ស្បែកចៀមឈ្មោលជ្រលក់ពណ៌ក្រហម ស្បែកផ្សោត
ឈើនាងនួន ៨ប្រេង[ង]សំរាប់ចង្កៀង គ្រឿងក្រអូបសំរាប់
ប្រេងចាក់លាប និងគ្រឿងក្រអូបសំរាប់ដុត ៩ថ្មអូនីក្ស
ហើយថ្មឯទៀតសំរាប់ដាំអេផូឌ និងប្រដាប់បាំង ទ្រូងផង
១០ឯអស់អ្នកណាដែលមានគំនិតវាងវៃក្នុងពួកឯងរាល់គ្នា
នោះត្រូវឱ្យមកធ្វើអស់ទាំងប្រដាប់ដែលព្រះយេហូវ៉ា
ទ្រង់បានបង្គាប់មកចុះ[ច] ១១គឺជារោងឧបោសថ ព្រមទាំង
ត្រសាលរោងនោះ[ឆ] និងគំរបគ្របលើត្រសាល ហើយអស់
ទាំងទំពក់ ក្ដារ រនុក សសរ និងជើងរបស់រោងនោះ
១២ហឹប[ជ] និងឈើស្នែង ទីសន្ដោសប្រោស វាំងនន[ឈ]សំរាប់
បាំងហឹប ១៣តុ និងឈើស្នែង ព្រមទាំងប្រដាប់តុ[ញ]នោះ
និងនំបុ័ងតាំងទុក ១៤ជើងចង្កៀង[ដ] អស់ទាំងចង្កៀង និង
ប្រដាប់ទាំងប៉ុន្មាន ហើយនិងប្រេងសំរាប់ដុត ១៥អាសនា[ឋ]
សំរាប់ ដុតគ្រឿងក្រអូប និងឈើស្នែងផង ប្រេងចាក់លាប[ឌ]
និងគ្រឿងក្រអូប[ឍ] ព្រមទាំងរនាំងបាំងមាត់ទ្វាររោង
ឧបោសថ[ណ] ១៦អាសនា[ត]សំរាប់ដង្វាយដុត ប្រទាសលង្ហិន
ឈើស្នែង និងអស់ទាំងប្រដាប់អាសនានោះ ចានក្លាំ[ថ] និង
ជើងនៃចាននោះ ១៧រនាំងបាំងទីលាន អស់ទាំងសសរ
និងជើងទាំងប៉ុន្មាន ហើយរនាំងនៅមាត់ទ្វារទីលានផង[ទ]
១៨អស់ទាំងចំរឹងសំរាប់រោងឧបោសថ និងទីលានព្រមទាំង
ខ្សែប៉ុន្មាន[ធ] ១៩អស់ទាំងសំលៀកបំពាក់សំរាប់ការងារក្នុង
ទីបរិសុទ្ធ អស់ទាំងសំលៀកបំពាក់បរិសុទ្ធ[ន]សំរាប់អើរ៉ុន
ជាសង្ឃ និងសំលៀកបំពាក់សំរាប់ពួកកូនលោកដែលធ្វើ
ការងារជាសង្ឃ ២០នោះពួកជំនុំនៃកូនចៅអ៊ីស្រាអែលគេក៏
ចេញពីមុខម៉ូសេទាំងអស់គ្នាទៅ ។

២១ដូច្នេះ អស់អ្នកណាដែលមានសេចក្ដីរំជួលក្នុងចិត្ត
ជាអ្នកដែលមានវិញ្ញាណបណ្ដាលឱ្យថ្វាយស្ម័គ្រពីចិត្តនោះ
ក៏យកដង្វាយមកថ្វាយដល់ព្រះយេហូវ៉ា សំរាប់ការធ្វើត្រ
សាលជំនុំ សំរាប់ការងារក្នុងត្រសាលនោះ ហើយសំរាប់
សំលៀកបំពាក់បរិសុទ្ធទាំងប៉ុន្មាន ២២ឯអស់អ្នកណាដែល
ថ្វាយដោយស្ម័គ្រចិត្ត នោះក៏ចូលមកទាំងប្រុសទាំងស្រី ព្រម
ទាំងយកការ កងជើង កងដៃ កន្លះក និងចិញ្ចៀន ជា
ប្រដាប់មាសគ្រប់មុខ មកថ្វាយជាដង្វាយមាសដល់ព្រះយេ
ហូវ៉ា ២៣អស់អ្នកណាដែលមានល័ខពណ៌ផ្ទៃមេឃ ពណ៌
ស្វាយ ពណ៌ក្រហម[ប] ខ្លូតទេសយ៉ាងម៉ដ្ត និងរោមពពែ
ស្បែកចៀមឈ្មោលជ្រលក់ពណ៌ក្រហម ហើយនិងស្បែក
ផ្សោត គេក៏យករបស់ទាំងនោះមកដែរ ២៤អស់អ្នកណា
ដែលថ្វាយប្រាក់ ឬលង្ហិន ក៏យកដង្វាយនោះមកថ្វាយដល់
ព្រះយេហូវ៉ា អស់អ្នកណាដែលមានឈើនាងនួនសំរាប់នឹង
ធ្វើការអ្វីៗ គេក៏យកឈើនោះមកដែរ ២៥អស់ស្ត្រីណាដែល
ប៉ិនប្រសប់[ផ]នឹងវេញដោយដៃ ក៏យកអំបោះ ពណ៌ផ្ទៃមេឃ
ពណ៌ស្វាយ ពណ៌ក្រហម ហើយនឹងអំបោះខ្លូតទេសយ៉ាង
ម៉ដ្ត ដែលគេបានវេញនោះមកដែរ ២៦អស់ស្ត្រីណាដែល
មានចិត្តបណ្ដាលដោយគេចេះធ្វើ នោះក៏នាំគ្នាវេញរោម
ពពែ ២៧ហើយពួកមេលើបណ្ដាជន[ព]ក៏យកថ្មអូនីក្ស និងថ្មឯ
ទៀត[ភ]សំរាប់ដាំអេផូឌ ហើយនិងប្រដាប់បាំងទ្រូងដែរ
២៨ព្រមទាំងគ្រឿងក្រអូប ប្រេងសំរាប់ចង្កៀង សំរាប់ប្រេង
ចាក់លាប ហើយសំរាប់គ្រឿងក្រអូបផង[ម] ២៩អស់ពួកកូន
ចៅអ៊ីស្រាអែលទាំងប្រុសទាំងស្រី ដែលមានចិត្ត[យ] បណ្ដាល
ឱ្យថ្វាយរបស់អ្វីសំរាប់ការដែលព្រះយេហូវ៉ាទ្រង់បង្គាប់
មកម៉ូសេ នោះក៏យកដង្វាយមកថ្វាយដល់ព្រះយេហូវ៉ា
ដោយស្ម័គ្រពីចិត្ត[រ] ។

## លោកបេតសាលាល និងលោកអូហូលីអាប់

*៣៥:៣០–៣៥ – នក ៣១:២–៦*

៣០រួចមក ម៉ូសេមានប្រសាសន៍នឹងពួកកូនចៅអ៊ីស្រា
អែលថា មើល ព្រះយេហូវ៉ាទ្រង់បានហៅបេតសាលាល
កូនយូរី ដែលជាកូនហើរ ក្នុងពូជអំបូរយូដាមក ៣១ហើយ
ទ្រង់បានឱ្យព្រះវិញ្ញាណនៃព្រះ មកសណ្ឋិតលើគាត់ពោរ
ពេញ ឱ្យគាត់មានគំនិតវាងវៃ មានយោបល់ ហើយឱ្យ
មានចំណេះចេះធ្វើការគ្រប់មុខ[ល] ៣២ឱ្យគាត់បានចេះនឹង
បង្កើតការយ៉ាងប្រសប់ គឺខាងមាស ខាងប្រាក់ ហើយខាង

**៣៥:៨** ង នក ២៥:៦
**៣៥:១០** ច នក ៣១:៦ ៣៩:៤៣
**៣៥:១១** ឆ នក ២៦:១–៣៧ ៣៦:៨–៣៨
**៣៥:១២** ជ នក ២៦:១០–២២ ៣៧:១–៩ ឈ នក ២៦:៣៣
**៣៥:១៣** ញ នក ២៥:២៣–៣០ ៣៧:១០–១៦
**៣៥:១៤** ដ នក ២៥:៣១
**៣៥:១៥** ឋ នក ៣០:១–៦ ៣៧:២៥–២៨ ឌ នក ៣០:២៥ ឍ នក ៣០:៣៤–៣៨ ណ នក ២៦:៣៦
**៣៥:១៦** ត នក ២៧:១–៨ ៣៨:១–៧ ថ នក ៣០:១៨
**៣៥:១៧** ទ នក ២៧:៩ ៣៨:៩–២០
**៣៥:១៨** ធ នក ២៧:១៩ ៣៨:២០
**៣៥:១៨** ធ នក ២៧:១៩ ៣៨:២០
**៣៥:១៩** ន នក ២៨:២
**៣៥:២៣** ប នក ៣៩:១
**៣៥:២៥** ផ នក ២៨:៣
**៣៥:២៧** ព នក ២៥:២ ១រប ២៩:៦ ភ ១រប ២៩:៨
**៣៥:២៨** ម នក ២៥:៦
**៣៥:២៩** យ នក ២៥:២ រ ខ.៤–៩ នក ២៥:១–៧ ៣៦:៣ ២ពវ ១២:៤
**៣៥:៣១** ល ខ.៣៥ ២រប ២:៧,១៤

–១១ (មើលការពន្យល់ក្នុងជំពូកទាំងនេះ) តែដោយប្រើកិរិយាស័ព្ទទម្រង់អតីតកាល ជាជាងអនាគតកាល ហើយនិយាយអំពីប្រធានបទមួយចំនួន រៀបរាងតាមលំដាប់ខុសៗគ្នា ។ ការនិយាយឡើងវិញដូចនេះ គឺជាប្រពៃណីនៃការនិពន្ធផ្នែកអក្សរសាស្ត្រ នៅមជ្ឈឹមបូព៌ាសម័យបុរាណ ដើម្បីឱ្យការពិពណ៌នានោះ មានការដឹតជាប់នៅ ក្នុងចិត្តអ្នកអាន (មើលការពន្យល់ លប ២៤:៣៤–៤៩) ។

**៣៥:៥** *ត្រូវឱ្យអ្នកណាដែលថ្វាយស្ម័គ្រពីចិត្ត* ខនេះ និយាយសង្កត់ធ្ងន់អំពីការធ្វើដោយស្ម័គ្រពីចិត្ត នៅក្នុងការថ្វាយដង្វាយជាសម្ភារៈ និងការបម្រើនៅក្នុងរោងឧបោសថ (សូមមើល ខ.២១–២២,២៦,២៩ ៣៦:២–៣) ។

**៣៥:២១** *ត្រសាលជំនុំ* មើលការពន្យល់ ២៧:២ ។

លង្ហិន ៣៣ព្រមទាំងចេះឆ្នៃត្បូងសំរាប់ដាំ ចេះឆ្លាក់ឈើ
នឹងធ្វើការគ្រប់ទាំងអស់ ៣៤ទ្រង់ក៏ប្រទានឱ្យគាត់ចេះ
បង្រៀន[វ]ដល់គេ គឺខ្លួនគាត់១ និងអូហូលីអាប់[ស] ជាកូនអ័ហ៊ី
សាម៉ាក់ ក្នុងពូជអំបូរដាន់១ដែរ ៣៥ទ្រង់បានប្រទានឱ្យអ្នក
ទាំង២នោះមានគំនិតវាងវៃដ៏ពោរពេញ សំរាប់នឹងចាត់
ចែងអស់ទាំងការ[ហ]ខាងពួកជាងចំឡាក់ និងអ្នករចនា
ផ្សេងៗ ឱ្យបានចេះប៉ាក់ ចេះត្បាញសំពត់ពណ៌ផ្ទៃមេឃ
ពណ៌ស្វាយ ពណ៌ក្រហម និងសំពត់ខ្លូតទេសយ៉ាងម៉ដ្ឋ
សំរាប់នឹងធ្វើការគ្រប់យ៉ាង ព្រមទាំងបង្កើតការថ្មីផង ។

**៣៦** ១ដូច្នេះ បេតសាលាល និងអូហូលីអាប់ ហើយអស់
អ្នកចំណានការ[ក] ដែលព្រះយេហូវ៉ាទ្រង់បានប្រទានឱ្យមាន
គំនិតវាងវៃ ហើយនិងយោបល់ឱ្យចេះធ្វើការគ្រប់មុខ គេ
នឹងធ្វើអស់ទាំងប្រដាប់ ដែលសំរាប់ការងារក្នុងទីបរិសុទ្ធ[ខ]
តាមដែលព្រះយេហូវ៉ាទ្រង់បានបង្គាប់មក ២ម៉ូសេក៏ហៅ
បេតសាលាល[គ]និងអូហូលីអាប់[ឃ] ហើយអស់អ្នកចំណានការ
ដែលព្រះយេហូវ៉ាទ្រង់បានប្រទានឱ្យមានគំនិតវាងវៃ ឱ្យ
មក គឺជាអស់អ្នកណាដែលមានចិត្ត[ង]បណ្តាលឡើង ឱ្យមក
ធ្វើការនោះ ៣ម៉ូសេក៏ប្រគល់អស់ទាំងដង្វាយ[ច] ដែលពួក
កូនចៅអ៊ីស្រាអែលបានយកមកថ្វាយ សំរាប់ការស្អាងទី
បរិសុទ្ធដល់អ្នកទាំងនោះ ហើយរាល់តែព្រឹក គេចេះតែ
យកដង្វាយថ្វាយស្ម័គ្រពីចិត្ត មកជូនម៉ូសេជានិច្ច ៤នោះអស់
អ្នកចំណានការដែលកំពុងតែធ្វើទីបរិសុទ្ធ គេឈប់ធ្វើការ
គ្រប់គ្នា ៥ទៅជំរាបម៉ូសេថា បណ្តាជនគេចេះតែយកដង្វាយ
មក សំរាប់ការធ្វើនេះបានច្រើនហួសប្រមាណ[ឆ] ពីអស់ទាំង
ការដែលព្រះយេហូវ៉ាបានបង្គាប់ឱ្យធ្វើហើយ ៦នោះម៉ូសេ
បង្គាប់ឱ្យគេទៅប្រកាសប្រាប់គ្រប់ ក្នុងទីដំឡើង ត្រសាលថា
កុំឱ្យអ្នកណា ទោះប្រុសឬស្រី ធ្វើការអ្វីទៀត សំរាប់ជា
ដង្វាយដល់ទីបរិសុទ្ធឡើយ ដូច្នេះគេក៏បញ្ឈប់ ពួកជនមិន
ឱ្យយកមកទៀត ៧ដ្បិតមានរបស់គ្រប់គ្រាន់ [ជ]នឹងធ្វើការ
ទាំងនោះហើយ ថែមទាំងសល់ផង ។

### រោងឧបោសថ

*៣៦:៨–៣៨ – នក ២៦:១–៣៧*

៨រួចអស់អ្នកចំណានដែលធ្វើការទាំងនោះ គេក៏ធ្វើ
រោងឧបោសថពីសំពត់១០ផ្ទាំង ដែលត្បាញដោយអំបោះ
ខ្លូតទេសវេញយ៉ាងខ្មាញ់ និងអំបោះពណ៌ផ្ទៃមេឃ ពណ៌
ស្វាយ ពណ៌ក្រហម ទាំងប៉ាក់រូបចេរូប៊ីនតាមរចនានៃជា
មានស្នាដៃ ៩ឯសំពត់១ផ្ទាំងនោះ មានបណ្តោយ២៨ហត្ថ
ហើយទទឹង៤ហត្ថ រាល់តែផ្ទាំងសុទ្ធតែប៉ុនគ្នាទាំងអស់

**៣៥:៣៤** វ នក ៣១:៦ ស ២របា ២:១៤
**៣៥:៣៥** ហ ខ.៣១
**៣៦:១** ក នក ២៨:៣ ខ នក ២៥:៨
**៣៦:២** គ នក ៣១:២ ឃ នក ៣១:៦ ង នក ២៥:២
**៣៦:៣** ច នក ៣៥:២៩
**៣៦:៥** ឆ ២របា ២៤:១៤ ៣១:១០ ២របា ៨:២–៣
**៣៦:៧** ជ ១ពវ ៧:៤៧
**៣៦:១៧** ឈ ខ.១៨
**៣៦:១៨** ញ ខ.១៣

១០គាត់ក៏ដេរ៥ផ្ទាំងភ្ជាប់ជាមួយគ្នា ហើយ៥ទៀតក៏ដេរភ្ជាប់
គ្នាដែរ ១១រួចគាត់ធ្វើខ្សែក្រវិលខៀវតាមជាយសំពត់ នៅ
ចុងផ្ទាំងសំពត់ទី១ ក៏ធ្វើដូចគ្នាតាមជាយសំពត់ នៅចុងផ្ទាំង
ទី២ ១២គាត់ធ្វើខ្សែក្រវិល៥០ តាមជាយសំពត់ទី១ ហើយក៏
ធ្វើខ្សែក្រវិល៥០ នៅចុងផ្ទាំងទី២ដែរ ខ្សែក្រវិលទាំងនោះ
ស្មើគ្នាទាំងអស់ ១៣គាត់ធ្វើទំពក់មាស៥០ ហើយភ្ជាប់ផ្ទាំង
សំពត់ទាំង២ជាមួយគ្នា ដោយសារទំពក់នោះ ដូច្នេះ រោង
ឧបោសថបានភ្ជាប់គ្នាតែ១[ឈ] ។

១៤រួចគាត់ធ្វើសំពត់១១ផ្ទាំង ពីរោមពពែ សំរាប់គ្រប
លើរោងឧបោសថ ១៥សំពត់១ផ្ទាំងនោះ មានបណ្តោយ
៣០ហត្ថ ហើយទទឹង៤ហត្ថ រាល់តែផ្ទាំងសុទ្ធតែប៉ុនគ្នាទាំង
អស់ ១៦គាត់យកសំពត់៥ផ្ទាំង ដេររួមគ្នាជា១ផ្នែក ហើយ៦
ទៀតក៏ដេររួមគ្នាជា១ផ្នែកដែរ ១៧គាត់ធ្វើខ្សែក្រវិល៥០
តាមជាយសំពត់នៅចុងផ្ទាំងទី១ ហើយខ្សែក្រវិល៥០ទៀត
តាមជាយសំពត់ នៅចុងផ្ទាំងទី២ ១៨រួចធ្វើទំពក់លង្ហិន៥០
សំរាប់ភ្ជាប់ត្រសាលឱ្យបានជាប់គ្នាតែ១[ញ] ។

១៩គាត់ក៏ធ្វើគំរបពីស្បែកចៀមឈ្មោលជ្រលក់ពណ៌
ក្រហម សំរាប់គ្របលើត្រសាល ហើយ១ទៀតពីស្បែក
ផ្សោតសំរាប់នឹងគ្របពីលើនោះថែមទៀត ។

២០គាត់ធ្វើក្តារសំរាប់រោងឧបោសថ ជាក្តារឈើនាង
នួនដាក់បញ្ឈរ ២១ក្តារ១សន្លឹក មានបណ្តោយ១០ហត្ថ
ហើយទទឹង១ហត្ថកន្លះ ២២នៅគ្រប់តែក្តារ មានពន្លូញ២
រៀងតាមជួរជញ្ជាំង គាត់ធ្វើអស់ទាំងក្តារសំរាប់រោង
ឧបោសថនោះ ឱ្យដូចៗគ្នា ២៣គឺក្តារ២០សន្លឹកសំរាប់ខាង
ត្បូងរោងឧបោសថ ២៤ក៏ដាក់ជើងធ្វើពីប្រាក់ទាំង៤០ នៅ
ក្រោមក្តារទាំង២០នោះ ក្រោមក្តារ១មានជើង២ សំរាប់
ស៊កពន្លូញទាំង២ដែលនៅចុងក្តារនោះ ២៥គាត់ធ្វើក្តារ២០
ទៀត សំរាប់រោងឧបោសថម្ខាង គឺជាខាងជើង ហើយជើង
ក្តារ៤០ដែរ ២៦រាល់តែក្តារមានជើងពីរៗ ២៧គាត់ធ្វើក្តារ៦
សំរាប់ចុងរោងឧបោសថខាងលិច ២៨ក៏ធ្វើក្តារ២ សំរាប់
ជ្រុងរោងឧបោសថខាងចុង ២៩ក្តារ២សន្លឹកនោះបានជាប់
គ្នាខាងក្រោមនឹងខាងលើដោយសារកង១ គាត់ធ្វើក្តារ
សំរាប់ជ្រុងទាំង២នៅសងខាងនោះឱ្យដូចគ្នា ៣០ដូច្នេះ មាន
ក្តារ៨នឹងជើងប្រាក់១៦ រាល់តែក្តារមានជើងពីរៗ ៣១ក៏
ធ្វើរនុក៥ពីឈើនាងនួន សំរាប់អស់ទាំងក្តារនៅរោង
ឧបោសថម្ខាង ៣២ហើយរនុក៥ទៀត សំរាប់អស់ទាំងក្តារ
នៅចុងរោងឧបោសថម្ខាងទៀត នឹងរនុក៥ទៀតសំរាប់
ក្តារនៅចុងរោងឧបោសថខាងលិច ៣៣ឯរនុកកណ្តាលគាត់

ធ្វើឱ្យភ្ជាប់ក្ដារពីចុងម្ខាងរហូតដល់ចុងម្ខាង ៣៤រួចមក
គាត់ស្រោបក្ដារទាំងនោះ ដោយមាស ក៏ធ្វើកងពីមាស
ដែរ សំរាប់ព្រហករនុក ហើយរនុកទាំងប៉ុន្មាន ក៏ស្រោប
ដោយមាសដូចគ្នា ។
៣៥គាត់ត្បាញធ្វើវាំងនន[ដ]ពីអំបោះពណ៌ផ្ទៃមេឃ ពណ៌
ស្វាយ ពណ៌ក្រហម ហើយពីអំបោះខ្លូតទេសវេញយ៉ាង
ខ្មាញ់ តាមការរចនានៃជាងមានស្នាដៃ ហើយក៏ប៉ាក់ជារូប
ចេរូប៊ីនដែរ ៣៦គាត់ធ្វើសសរ៤ពីឈើនាងនួន ស្រោប
ដោយមាស សំរាប់វាំងនននោះ ហើយមានទំពក់មាសនៅ
សសរទាំងនោះ រួចគាត់សិតជើងប្រាក់៤សំរាប់ទ្រសសរ
ទាំងនោះ ។
៣៧គាត់ក៏ត្បាញធ្វើរនាំង ពីអំបោះមានពណ៌ផ្ទៃមេឃ
ពណ៌ស្វាយ ពណ៌ក្រហម ហើយពីអំបោះខ្លូតទេសវេញ
យ៉ាងខ្មាញ់ ព្រមទាំងប៉ាក់ផង សំរាប់មាត់ទ្វារត្រសាល[ឋ]
៣៨ហើយគាត់ធ្វើសសរ៥ និងទំពក់សំរាប់រនាំងនោះ ឯ
ក្បាច់ក្បាលសសរ និងគន្លឹះទាំងប៉ុន្មាន នោះសុទ្ធតែ
ស្រោបដោយមាសទាំងអស់ ចំណែកជើងទាំង៥ នោះធ្វើពី
លង្ហិនវិញ ។

## ហឹប

*៣៧:១-៩ – នក ២៥:១០-២០*

**៣៧** ១ឯបេតសាលាល[ក]គាត់ធ្វើហឹប[ខ] ពីឈើនាងនួន មាន
បណ្ដោយ២ហត្ថកន្លះ ទទឹង១ហត្ថកន្លះ ហើយកំពស់១ហត្ថ
កន្លះ ២ក៏ស្រោបដោយមាសសុទ្ធ[គ]ទាំងខាងក្នុងខាងក្រៅ
ហើយធ្វើកែមមាសនៅជុំវិញផង ៣គាត់សិតកងមាស៤នៅ
ជ្រុងហឹបទាំង៤ គឺមាន២ម្ខាងៗ ៤ក៏ធ្វើឈើស្នែងពីឈើ
នាងនួន ព្រមទាំងស្រោបមាសផង ៥រួចគាត់ព្រហកឈើ
ស្នែងនោះ ចូលក្នុងកង នៅសងខាងហឹបសំរាប់នឹងសែង
ទៅ ៦គាត់ធ្វើទីសន្ដោសប្រោស[ឃ]ពីមាសសុទ្ធ មានបណ្ដោយ
២ហត្ថកន្លះ ហើយទទឹង១ហត្ថកន្លះ ៧ក៏យកមាសឆ្លាក់ធ្វើ
ចេរូប៊ីន២នៅចុងសងខាងទីសន្ដោសប្រោស ៨គឺចេរូប៊ីន១
នៅចុងខាងនេះ ហើយចេរូប៊ីន១ទៀតនៅចុងខាងនោះ
គាត់បានធ្វើចេរូប៊ីនទាំង២នោះ[ង]នៅចុងសងខាង ជាប់លើ
ទីសន្ដោសប្រោស ៩ឯចេរូប៊ីនក៏ត្រដាងស្លាបគ្រប[ច]ពីលើទី
សន្ដោសប្រោស ហើយប្រទល់មុខគ្នា ឈ្ងោកមើលទី
សន្ដោសប្រោស[ឆ] ។

## តុ

*៣៧:១០-១៦ – នក ២៥:២៣-២៩*

១០គាត់ធ្វើតុ[ជ]ពីឈើនាងនួន មានបណ្ដោយ២ហត្ថ ទទឹង១
ហត្ថ ហើយកំពស់១ហត្ថកន្លះ ១១ក៏ស្រោបមាសសុទ្ធ[ឈ]
ហើយធ្វើកែមមាសនៅជុំវិញ ១២គាត់ក៏ធ្វើកែមកំពស់១ទះ
នៅជុំវិញតុនោះ ហើយនៅកែមនោះក៏ធ្វើកែមមាសនៅ
ជុំវិញដែរ ១៣គាត់សិតកងមាស៤សំរាប់តុ រួចដាក់កងទាំង
នោះភ្ជាប់នឹងជើងតុទាំង៤ នៅគ្រប់ជ្រុង ១៤កងទាំងនោះ[ញ]
នៅជិតកែមតុ សំរាប់នឹងប្រហកឈើស្នែងសែងទៅ ១៥ក៏
ធ្វើឈើស្នែងពីឈើនាងនួន ស្រោបដោយមាសសំរាប់នឹង
សែងតុ ១៦ឯអស់ទាំងប្រដាប់ដែលត្រូវដាក់លើតុ គឺជាថាស
ផ្តិល ប៉ាន់ ហើយនិងពែងដែលសំរាប់នឹងថ្វាយដង្វាយច្រួច
នោះគាត់ធ្វើពីមាសសុទ្ធទាំងអស់ ។

## ជើងចង្កៀង

*៣៧:១៧-២៤ – នក ២៥:៣១-៣៩*

១៧គាត់ក៏យកមាសសុទ្ធឆ្លាក់ធ្វើជើងចង្កៀង[ដ] គឺធ្វើគល់
ដើម នប់ កន្សោមគ្រាប់ ហើយនិងផ្កា ទាំងអស់ជាប់ជាមួយ
គ្នា ១៨មានមែក៦ចេញពីគល់មក មែក៣ចេញខាងម្ខាង
ហើយមែក៣ទៀតចេញខាងម្ខាង ១៩នៅមែក១មាននប់៣
រាងដូចគ្រាប់ចំបក់ មានទាំងកន្សោមគ្រាប់ ហើយនិងផ្កាផង
ហើយនៅមែក១ទៀតមាននប់៣រាងដូចជាគ្រាប់ចំបក់ មាន
ទាំងកន្សោមគ្រាប់ និងផ្កាដែរ មែកទាំង៦ ដែលចេញពី
គល់ជើងចង្កៀងនោះ បានធ្វើដូចគ្នាទាំងអស់ ២០នៅគល់
ជើងចង្កៀង មាននប់៤ រាងដូចជាគ្រាប់ចំបក់ ហើយមាន
ទាំងកន្សោមគ្រាប់និងផ្កាផង ២១នៅក្រោមមែក២ មាន
កន្សោមគ្រាប់១ នៅក្រោមមែក២ទៀត មានកន្សោមគ្រាប់
១ទៀត មែកទាំង៦ដែលចេញពីគល់ជើងចង្កៀង មានដូច
គ្នាទាំងអស់ ២២កន្សោមគ្រាប់ ហើយនិងមែកជើងចង្កៀង
បានធ្វើជាប់គ្នាឆ្លាក់ពីមាសសុទ្ធ[ឋ] ២៣គាត់ក៏ធ្វើចង្កៀងទាំង
៧[ឌ] ព្រមទាំងឃ្នាបប្រឆេះ និងកន្ថោរដាក់កំទេចសំរាប់
ចង្កៀងនោះពីមាសសុទ្ធដែរ ២៤គឺគាត់យកមាសសុទ្ធ១ហាប
មកធ្វើចង្កៀង ហើយនិងប្រដាប់ទាំងប៉ុន្មានសំរាប់ចង្កៀង។

## អាសនាគ្រឿងក្រអូប

*៣៧:២៥-២៨ – នក ៣០:១-៥*

២៥គាត់ក៏ធ្វើអាសនាគ្រឿងក្រអូប[ឍ] ពីឈើនាងនួនមាន

**៣៦:៣៥** ដ នក ៣៩:៣៨ មថ ២៧:៥១ លក ២៣:៤៥ ហេព ៩:៣
**៣៦:៣៧** ឋ នក ២៧:១៦
**៣៧:១** ក នក ៣១:២ ខ នក ៣០:៦ ៣៩:៣៥ ចទ ១០:៣
**៣៧:២** គ ខ.១១,២៦
**៣៧:៦** ឃ នក ២៦:៣៤ ៣១:៧ ហេព ៩:៥
**៣៧:៧** ង អគ ៤១:១៨
**៣៧:៩** ច ហេព ៩:៥ ឆ ចទ ១០:៣
**៣៧:១០** ជ ហេព ៩:២
**៣៧:១១** ឈ ខ.២
**៣៧:១៤** ញ ខ.២៧
**៣៧:១៧** ដ ហេព ៩:២ វវ ១:១២
**៣៧:២២** ឋ ខ.១៧ ជន ៨:៤
**៣៧:២៣** ឌ នក ៤០:៤,២៥
**៣៧:២៥** ឍ នក ៣០:៣៤-៣៦ លក ១:១១ ហេព ៩:៤ វវ ៨:៣

**៣៦:១-៣៨** មើលការពន្យល់ ៣៥:៤-៣៩:៤៣ ។
**៣៧:១-២៩** មើលការពន្យល់ ៣៥:៤-៣៩:៤៣ ។
**៣៧:១** *ឯបេតសាលាលគាត់ធ្វើហឹប* មេជាងមានកិត្តិយស នៅក្នុងការទទួល ការងារស្ការ(មើល ៣១:២-៣ និងការពន្យល់) នូវសម្ភារៈដែលបរិសុទ្ធបំផុតនៅក្នុងចំណោម(មើល ២៥:១០ និងការពន្យល់) ការងារសំណង់ផ្សេងៗទៀតនៃរោងឧបោសថ ។

បណ្ដោយ១ហត្ថ ទទឹង១ហត្ថ៨ជ្រុងស្មើ ហើយកំពស់២ហត្ថ
ក៏មានស្នែង[ណ]ចេញពីអាសនានោះ ២៦គាត់ស្រោបដោយ
មាសសុទ្ធខាងលើ នៅចំហៀងជុំវិញ ព្រមទាំងស្នែងផង
ក៏ធ្វើកែមមាសនៅជុំវិញដែរ ២៧នៅក្រោមកែមនោះ គាត់
ធ្វើកងមាស២[ត]នៅទាំងសងខាង សំរាប់ប្រហកឈើស្នែង
សែងទៅ ២៨ក៏ធ្វើឈើស្នែង ពីឈើនាងនួន ស្រោបដោយ
មាសដែរ[ថ] ។
២៩រួចគាត់ធ្វើប្រេងចាក់លាប ជាប្រេងបរិសុទ្ធ[ទ] និង
គ្រឿងក្រអូប[ធ]យ៉ាងសុទ្ធ ផ្សំតាមវិធីធ្វើរបស់អ្នកផ្សំគ្រឿង
ក្រអូប ។

### អាសនាដង្វាយដុត

*៣៨:១-៧ – នក ២៧:១-៨*

**៣៨** ១គាត់ស្អាងអាសនាដង្វាយដុតពីឈើនាងនួន មាន
បណ្ដោយ៥ហត្ថ ទទឹង៥ហត្ថ ៤ជ្រុងស្មើ ហើយកំពស់៣ហត្ថ
២នៃជ្រុងទាំង៤ គាត់ធ្វើស្នែងចេញពីអាសនា ស្រោបដោយ
លង្ហិន[ក] ៣គាត់ធ្វើប្រដាប់ទាំងប៉ុន្មានសំរាប់អាសនា គឺជា
ប្រដាប់ដាក់ផេះ[ខ] ចបចូក ផើង សម ហើយនិងជើងក្រាន
ដែរ នោះសុទ្ធតែធ្វើពីលង្ហិនទាំងអស់ ៤គាត់ធ្វើប្រទាស
លង្ហិន ខ្នាស់ក្រឡាក្នាសំរាប់អាសនា ក៏ដាក់ប្រទាសពីក្រោម
កែមឱ្យជាប់ត្រង់ពាក់កណ្ដាលរបស់កំពស់អាសនា ៥រួចសិត
ធ្វើកង៤ដាក់នៅប្រទាសលង្ហិនទាំង៤ជ្រុង សំរាប់នឹង
ប្រហកឈើស្នែងសែងទៅ ៦ក៏ធ្វើឈើស្នែងពីឈើនាងនួន
ព្រមទាំងស្រោបដោយលង្ហិន ៧គាត់ប្រហកឈើស្នែងចូល
ក្នុងកងទាំងប៉ុន្មាន នៅសងខាងអាសនាសំរាប់នឹងសែងទៅ
ឯអាសនានោះ គាត់ធ្វើឱ្យខូងពីក្តារ ។

### ចានក្លាំសម្រាប់លាង

៨គាត់ក៏ធ្វើចានក្លាំពីលង្ហិន[គ] ព្រមទាំងជើងនៃចានក្លាំ
ដែរ គឺធ្វើពីកញ្ចក់របស់ស្រីៗ[ឃ] ដែលប្រជុំគ្នានៅមាត់ទ្វារ
ត្រសាលជំនុំ ។

### ទីលាន

*៣៨:៩-២០ – នក ២៧:៩-១៩*

៩គាត់ធ្វើទីលាន ឯនៅខាងត្បូងមានរនាំងក្បាញធ្វើពី
អំបោះខ្លូតទេស វេញយ៉ាងខ្មាញ់ សំរាប់បាំងទីលានប្រវែង
១០០ហត្ថ ១០មានទាំងសសរ២០ដាក់លើជើងលង្ហិន២០ ឯ
ទំពក់សសរ ហើយនិងគន្លឹះ នោះសុទ្ធតែធ្វើពីប្រាក់វិញ
១១នៅខាងជើង មានរនាំងប្រវែង១០០ហត្ថ ហើយសសរ
២០ និងជើងលង្ហិន២០ មានទាំងទំពក់ និងគន្លឹះធ្វើពីប្រាក់
ដែរ ១២នៅខាងលិច មានរនាំង៥០ហត្ថ មានសសរ១០ និង
ជើង១០ មានទាំងទំពក់សសរ និងគន្លឹះធ្វើប្រាក់ដែរ ១៣ឯ
ខាងកើតក៏មានទទឹង៥០ហត្ថដូចគ្នា ១៤តែនៅ១ចំហៀង
មានរនាំងប្រវែង១៥ហត្ថ ហើយមានសសរ៣ និងជើង៣
១៥ឯចំហៀង១ទៀតដែលស្មើនឹងចំហៀងម្ខាងទ្វារទីលាន
នោះមានរនាំងប្រវែង១៥ហត្ថ ហើយមានសសរ៣ និង
ជើង៣ដូចគ្នា ១៦រនាំងទាំងប៉ុន្មានដែលបាំងជុំវិញទីលាន
នោះសុទ្ធតែក្បាញ ធ្វើអំបោះខ្លូតទេស វេញយ៉ាងខ្មាញ់
១៧អស់ទាំងជើងសសរបានធ្វើពីលង្ហិន ឯទំពក់សសរនិង
គន្លឹះទាំងប៉ុន្មាន នោះបានធ្វើពីប្រាក់ ហើយក្បាច់ក្បាល
សសរក៏ស្រោបដោយប្រាក់ទាំងអស់ដែរ អស់ទាំងសសរ
ទីលាន នោះភ្ជាប់គ្នាដោយសារទំពក់ប្រាក់ ១៨រនាំងមាត់
ទ្វារទីលាន ជាសំពត់ប៉ាក់ ក្បាញធ្វើពីអំបោះពណ៌ផ្ទៃមេឃ
ពណ៌ស្វាយ ពណ៌ក្រហម ហើយអំបោះខ្លូតទេសវេញ
យ៉ាងខ្មាញ់ រនាំងនោះមានបណ្ដោយ២០ហត្ថ កំពស់៥ហត្ថ
ស្មើនឹងរនាំងទីលានទាំងអស់ ១៩សសរទាំង៤និងជើងទាំង
៤សំរាប់រនាំងក៏ធ្វើពីលង្ហិន ឯទំពក់និងគន្លឹះនោះបានធ្វើ
ពីប្រាក់វិញ ហើយក្បាច់ក្បាលសសរក៏ស្រោបដោយប្រាក់
ដែរ ២០ចំណែកអស់ទាំងចំរឹង[ង] សំរាប់រោងឧបោសថនិង
ទីលាន សុទ្ធតែធ្វើពីលង្ហិនទាំងអស់ ។

### សម្ភារៈដែលត្រូវប្រើប្រាស់

២១នេះហើយជាបញ្ជីប្រដាប់ប្រដា សំរាប់រោង
ឧបោសថ គឺជារោងនៃសេចក្តីបន្ទាល់[ច] ឯអ៊ីថាម៉ារ[ឆ] ជាកូន
អើរ៉ុនដ៏ជាសង្ឃ គាត់បានទទួលបង្គាប់ម៉ូសេ ដើម្បីនឹង
រាប់ប្រដាប់ទាំងនោះ សំរាប់ការងារនៃពួកលេវី ២២ឯបេត
សាលាល[ជ] កូនយូរី ដែលជាកូនហើរ ក្នុងពូជអំបូរយូដា
គាត់បានធ្វើអស់ទាំងការ ដែលព្រះយេហូវ៉ាបានបង្គាប់មក
ម៉ូសេ ២៣មានទាំងអូហូលីអាប់[ឈ] ជាកូនអ័ហ៊ីសាម៉ាក់ក្នុង
ពូជអំបូរដាន់មកជួយធ្វើការដែរ អ្នកនោះជាអ្នកប្រសប់
ខាងការចំឡាក់ ហើយខាងបង្កើតការថ្មី និងខាងធ្វើសំពត់
ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌ក្រហម និងសំពត់ខ្លូតទេស
យ៉ាងម៉ដ្ត ២៤ឯមាសទាំងប៉ុន្មានដែលគេបានថ្វាយសំរាប់
នឹងប្រើធ្វើអស់ទាំងការស្អាងទីបរិសុទ្ធ[ញ] នោះមានចំនួន
២៩ហាប៧៣០ដំឡឹង តាមទំងន់ដំឡឹងដែលប្រើក្នុងទី

**៣៧:២៥** ណ នក ២៧:២ វវ ៩:១៣
**៣៧:២៧** ត ខ.១៤
**៣៧:២៨** ថ នក ២៥:១៣
**៣៧:២៩** ទ នក ៣១:១១ ធ នក ៣០:១,២៥ ៣៩:៣៨
**៣៨:២** ក ២បរ ១:៥
**៣៨:៣** ខ នក ៣១:៩
**៣៨:៨** គ នក ៣០:១៨ ៤០:៧ ឃ ចទ ២៣:១៧ ១សយ ២:២២ ១ពវ ១៤:២៤
**៣៨:២០** ង នក ៣៥:១៨
**៣៨:២១** ច ជន ១:៥០,៥៣ ៨:២៤ ៩:១៥ ១០:១១ ១៧:៧ ១រប ២៣:៣២ ២រប ២៤:៦ កច ៧:៤៤ វវ ១៥:៥ ឆ ជន ៤:២៨,៣៣
**៣៨:២២** ជ នក ៣១:២
**៣៨:២៣** ឈ នក ៣១:៦ **៣៨:២៤** ញ នក ៣០:១៦

**៣៨:១-៣១** មើលការពន្យល់ ៣៥:៤-៣៩:៤៣ ។

**៣៨:៨** *ពីលង្ហិន . . . កញ្ចក់* កញ្ចក់ធ្វើពីកែវ ពុំទាន់មានគេប្រើនៅសម័យបុរាណទេ ប៉ុន្តែ បន្ទះលង្ហិនដែលគេដុសខាត់ឱ្យរលោង ហើយស្មើខ្លាំង អាចល្មមនឹងឆ្លុះរូបបាន (ធៀបនឹង ១កច ១៣:១២ និងការពន្យល់) ។ *ត្រសាល*

បរិសុទ្ធ[ដ] ២៥ហើយប្រាក់របស់អស់អ្នកក្នុងពួកជំនុំដែល
បានរាប់ដាក់បញ្ជី[ឋ] នោះមានចំនួន១០០ហាប១៧៧៥ដំឡឹង
តាមទំងន់ដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ ២៦គឺជា៥កាក់ដែល
ត្រូវជាកន្លះរៀលម្នាក់គ្រប់ៗគ្នា[ឌ] តាមរៀលសំរាប់ប្រើក្នុង
ទីបរិសុទ្ធ ជាថ្លៃ[ឍ]នៃអស់ទាំងអ្នកដែលមានឈ្មោះក្នុងបញ្ជី
ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ[ណ] ឯចំនួនមនុស្សទាំង
នោះ មាន៦សែន៣ពាន់៥៥០នាក់[ត] ២៧ហើយប្រាក់១០០
ហាបនោះ គេក៏យកទៅសិតធ្វើជើងសសរ[ថ]ទីបរិសុទ្ធ និង
ជើងវាំងននគឺជើង១មាន១ហាបប្រាក់ ឯជើង១០០ នោះ
ត្រូវជា១០០ហាប ២៨គេក៏យកប្រាក់១៧៧៥ដំឡឹងទៅធ្វើជា
ទំពក់ និងគន្លឹះទាំងប៉ុន្មានសំរាប់សសរ ហើយរំលែកខ្លះមក
ស្រោបនៅក្បាច់ក្បាលសសរ រួចថ្លក់ភ្ជាប់គ្នា ២៩ឯលង្ហិន
ដែលគេបានថ្វាយ នោះមានចំនួន៧០ហាប២៤០០ដំឡឹង
៣០លង្ហិននោះគេប្រើសំរាប់ធ្វើជើងសសរ ដែលនៅមាត់
ទ្វារត្រសាលជំនុំ ព្រមទាំងអាសនាលង្ហិន និងប្រទាស
ហើយអស់ទាំងប្រដាប់សំរាប់អាសនានោះ ៣១អស់ទាំង
ជើងនៃទីលាននៅគ្រប់ជុំវិញ ព្រមទាំងជើងទ្វារទីលាន និង
អស់ទាំងចំរឹងសំរាប់រោងឧបោសថ ហើយនិងទីលាននៅ
ជុំវិញដែរ ។

## សំលៀកបំពាក់សង្ឃ

**៣៩** ១គេក៏ប្រើអស់ទាំងសំពត់ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ
ពណ៌ក្រហម[ក] ធ្វើជាសំលៀកបំពាក់សំរាប់ការងារក្នុង
ទីបរិសុទ្ធ[ខ] និងសំលៀកបំពាក់[គ]សំរាប់អើរ៉ុន ដូចជា
ព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ ។

## អេផូឌ

*៣៩:២-៧ – នក ២៨:៦-១៤*

២គេបានធ្វើអេផូឌពីមាស ធ្វើសំពត់ពណ៌ផ្ទៃមេឃ ពណ៌
ស្វាយ ពណ៌ក្រហម ហើយពីសំពត់ត្បាញដោយអំបោះខ្លូត
ទេសវេញយ៉ាងខ្មាញ់ ៣គេក៏ដែមាសយ៉ាងស្តើងហើយកាត់
ជាខ្សែ យកទៅប៉ាក់នៅសំពត់ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ
ពណ៌ក្រហម ហើយនៅសំពត់ខ្លូតទេសយ៉ាងម៉ដ្ត នោះតាម
រចនានៃជាងមានស្នាដៃ ៤ក៏ធ្វើខ្សែស្មាសំរាប់នឹងចងភ្ជាប់
គ្នា នោះអេផូឌទាំងសងខាងបានជាប់គ្នាតែ១ ៥ខ្សែក្រវាត់ក៏
ធ្វើបែបដូចគ្នា ព្រមទាំងដាក់ភ្ជាប់នឹងអេផូឌដែរ គឺបានធ្វើ

**៣៨:២៤** ដ នក ៣០:១៣
**៣៨:២៥** ឋ នក ៣០:១២
**៣៨:២៦** ឌ នក ៣០:១២ ឍ នក ៣០:១៣ ណ នក ៣០:១៤ ត នក ១២:៣៧
**៣៨:២៧** ថ នក ២៦:១៩
**៣៩:១** ក នក ៣៥:២៣ ខ នក ៣៥:១៩ គ ខ.៤១ នក ២៨:២
**៣៩:៧** ឃ លវ ២៤:៧ យស ៤:៧
**៣៩:៨** ង លវ ៨:៨
**៣៩:១៤** ច វវ ២១:១២

ពីមាស ពីសំពត់ពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌ក្រហម
និងសំពត់ត្បាញដោយអំបោះខ្លូតវេញយ៉ាងខ្មាញ់ ដូចជា
ព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ ៦គេច្នៃត្បូងអូនីក្ស រួច
ឆ្លាក់ឈ្មោះពួកកូនអ៊ីស្រាអែលដូចជាគេឆ្លាក់ត្រា ហើយដាំ
ចុះក្នុងគ្រោងមាស ៧យកមកដាក់ភ្ជាប់នៅលើខ្សែស្មា
របស់អេផូឌ សំរាប់ជាទីរំឭក[ឃ]ដល់ពួកកូនចៅអ៊ីស្រាអែល
ដូចជាព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ ។

## ប្រដាប់បាំងទ្រូង

*៣៩:៨-២១ – នក ២៨:១៥-២៨*

៨គេបានធ្វើប្រដាប់បាំងទ្រូង[ង] តាមការរចនានៃជាងមាន
ស្នាដៃ បែបដូចជាធ្វើអេផូឌដែរ គឺពីមាស ពីសំពត់ពណ៌ផ្ទៃ
មេឃ ពណ៌ស្វាយ ពណ៌ក្រហម និងសំពត់ត្បាញដោយ
អំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ៩គេធ្វើជា៤ជ្រុងស្មើបត់ជា
ពីរ មានបណ្តោយ១ចំអាម ទទឹង១ចំអាមជា២ផ្នត់ ១០គេ
ដាំត្បូង៤ជួរ ក្នុងជួរទី១ មានត្បូងសាមសី១ ត្បូងទោប៉័ត១
និងបារកេត១ ១១ក្នុងជួរទី២ មានត្បូងមរកត១ ត្បូង
កណ្តៀង១ និងពេជ្រ១ ១២ក្នុងជួរទី៣ មានត្បូងលេសិម១
ត្បូងទទឹម១ និងត្បូងត្របែក១ ១៣ក្នុងជួរទី៤ មានត្បូង
បេរីល១ ត្បូងអូនីក្ស១ និងកែវមណីជោតិ១ ត្បូងទាំងនេះ
បានដាំចុះក្នុងគ្រោងមាស ១៤មានត្បូង១២តាមចំនួនឈ្មោះ
កូនអ៊ីស្រាអែល គ្រប់តែត្បូងនោះបានឆ្លាក់ ដូចជាគេឆ្លាក់
ត្រាក្នុងត្បូង១ មានឆ្លាក់ចុះឈ្មោះ១ ក្នុងពូជអំបូរទាំង១២[ច]
១៥គេធ្វើខ្សែមាសសុទ្ធ វេញដូចជាខ្សែពួរ ភ្ជាប់នៅប្រដាប់
បាំងទ្រូង ១៦ក៏ធ្វើគ្រោងមាស២ និងក្រវិលមាស២ដាក់
ភ្ជាប់នៅចុងសងខាងប្រដាប់បាំងទ្រូង ១៧ហើយបញ្ចូល
ខ្សែមាស២ ក្នុងក្រវិលមាសទាំង២ដែលនៅចុងសងខាង
ប្រដាប់បាំងទ្រូងនោះ ១៨ឯចុងខ្សែមាសទាំង២ គេក៏ចង
ភ្ជាប់នឹងគ្រោងមាសនៅខ្សែស្មារបស់អេផូឌខាងមុខ ១៩ក៏
ធ្វើក្រវិលមាស២ទៀត ដាក់ភ្ជាប់នៅជាយខាងក្នុង ត្រង់ចុង
សងខាងនៃប្រដាប់បាំងទ្រូងដែលជាប់នឹងអេផូឌ ២០គេក៏
ធ្វើក្រវិលមាស២ទៀត ដាក់ភ្ជាប់ពីក្រោមខាងមុខខ្សែស្មា
ជិតកន្លែងដែលខ្សែស្មា បានភ្ជាប់នឹងអេផូឌ នៅខាងលើអេ
ផូឌ ២១គេក៏យកខ្សែខៀវមកចងប្រដាប់បាំងទ្រូង ភ្ជាប់នឹង
អេផូឌដោយសារក្រវិលទាំងនោះ ដើម្បីឱ្យប្រដាប់បាំងទ្រូង

*ជំនុំ* មើលការពន្យល់ ២៧:២១ ។

**៣៨:២៥** *ចំនួន១០០ហាប ១៧៧៥ដំឡឹង* ដោយសារ ៣០០០ដំឡឹង ត្រូវជា ១ ហាប នោះ ១០០ ហាប ស្មើនឹង ៣០០,០០០ ដំឡឹង ហើយបើថែមចំនួននេះនឹង ១៧៧៥ ដំឡឹង នោះយើងបានចំនួនសរុបដ៏ច្រើនគឺ ៣០១,៧៧៥ ដំឡឹង មានន័យថា ក្នុងចំណោមប្រុសៗ ៦០៣,៥៥០ នាក់ ដែលអាចបម្រើកងទ័ពបាន ក្នុងម្នាក់ទទួលបានកន្លះដំឡឹងពីចំនួនសរុបនោះ ។

**៣៨:២៦** *មនុស្សទាំងនោះ មាន៦សែន៣ពាន់៥៥០នាក់* មើលសេចក្តីផ្តើម ជនគណនាត្រង់ចំណុច បញ្ហាពិសេស ។ខ មើល ជន ១:៤៦ និងការពន្យល់។

**៣៨:២៧** មើលការពន្យល់ ២៦:១៩ ។

**៣៩:១-៤៣** មើលការពន្យល់ ៣៥:៤-៣៩:៤៣ ។

បាននៅលើខ្សែក្រវាត់របស់អេផូឌ កុំឱ្យរបូតចេញឡើយ
ដូចជាព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ ។
២២ គេក៏ធ្វើអាវវែងរបស់អេផូឌ ត្បាញជាសំពត់សុទ្ធតែ
ពណ៌ផ្ទៃមេឃ ២៣ នៅកណ្ដាលអាវវែងនោះមានក ដូចជា
កនៃអាវសឹក ព្រមទាំងមានសំពត់ចំ នៅជុំវិញកផង ដើម្បី
កុំឱ្យអាវវែង នោះរហែកចេញឡើយ ២៤ នៅជុំវិញជាយ
អាវវែង គេធ្វើផ្លែទទឹងពណ៌ផ្ទៃមេឃ ពណ៌ស្វាយ ពណ៌
ក្រហមពីអំបោះវេញយ៉ាងខ្មាញ់ ២៥ ក៏ធ្វើចង្រ្កង់មាសសុទ្ធ
ដាក់លាយ ចំរុះត្រង់កណ្ដាលផ្លែទទឹមនោះ នៅគ្រប់ជុំវិញ
ជាយអាវដែរ ២៦ គឺចង្រ្កង់១ផ្លែទទឹម១ ចង្រ្កង់១ផ្លែទទឹម១
នៅគ្រប់ជុំវិញជាយអាវសំរាប់ការងារ ដូចជាព្រះយេហូវ៉ា
បានបង្គាប់មកម៉ូសេ ។
២៧ គេបានធ្វើអាវខ្លី ត្បាញពីអំបោះខ្លូតទេសយ៉ាងម៉ដ្ត[ឆ]
សំរាប់អើរ៉ុននិងពួកកូនលោក ២៨ ក៏ធ្វើម្ជុក[ជ]ពីសំពត់ខ្លូតទេស
យ៉ាងម៉ដ្ត និងឈ្នួត ពីសំពត់ខ្លូតទេសយ៉ាងម៉ដ្ត សំរាប់ជា
សេចក្ដីលំអ ហើយនិងខោស្នាប់ភ្លៅពីសំពត់ខ្លូតទេសដែរ
គឺសំពត់ធ្វើពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ២៩ ហើយខ្សែ
ក្រវាត់ពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់ ប៉ាក់ជាពណ៌ផ្ទៃ
មេឃ ពណ៌ស្វាយ ហើយពណ៌ក្រហម ដូចជាព្រះយេហូវ៉ា
បានបង្គាប់មកម៉ូសេ ។
៣០ គេបានធ្វើស្លាកមាសសុទ្ធជាមកុដបរិសុទ្ធ ក៏ឆ្លាក់
អក្សរនៅស្លាកនោះដូចជាគេឆ្លាក់ត្រាថា បរិសុទ្ធដល់ព្រះ
យេហូវ៉ា[ឈ] ៣១ រួចគេយកខ្សែខៀវចងស្លាកនោះជាប់នឹង
ម្ជុក[ញ]ខាងលើ ដូចជាព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ ។

## លោកម៉ូសេត្រួតពិនិត្យរោងឧបោសថ

*៣៩:៣២–៤១ – នក ៣៥:១០–១៩*

៣២ ដូច្នេះ អស់ទាំងការស្អាងរោងឧបោសថ និងត្រសាល
ជំនុំ នោះក៏រួចជាស្រេច ពួកកូនចៅអ៊ីស្រាអែលគេបានធ្វើ
អស់ទាំងការ ដែលព្រះយេហូវ៉ាទ្រង់បង្គាប់មកម៉ូសេ បាន
ហើយជាស្រេចទាំងអស់[ដ] ។
៣៣ គេនាំយករោងឧបោសថ[ឋ]មកឯម៉ូសេ គឺទាំងត្រសាល
និងប្រដាប់ត្រសាលទាំងប៉ុន្មាន ហើយអស់ទាំងទំពក់ ក្ដារ
រនុក សសរ និងជើងទាំងប៉ុន្មាន ៣៤ គំរបធ្វើពីស្បែកចៀម
ឈ្មោលជ្រលក់ពណ៌ក្រហម ហើយគំរបធ្វើពីស្បែកផ្សោត
វាំងននសំរាប់ឃាំង ៣៥ ហឹបទីបន្ទាល់[ឌ]និងឈើស្នែងសំរាប់
សែងទីសន្ដោសប្រោស ៣៦ តុ[ឍ]និងគ្រឿងប្រដាប់សំរាប់តុ
ហើយនិងនំបុ័ងតាំងទុក[ណ] ៣៧ ជើងចង្កៀងធ្វើពីមាសសុទ្ធ[ត]
ចង្កៀងទាំងប៉ុន្មាន គឺជាចង្កៀងសំរាប់ដាក់លើជើងនោះ
និងអស់ទាំងគ្រឿងប្រដាប់[ថ]ចង្កៀង ព្រមទាំងប្រេង[ទ]ផង
៣៨ អាសនាមាស[ធ] ប្រេងចាក់លាប[ន] និងគ្រឿងក្រអូប[ប] វនាំង
បាំង[ផ]នៅមាត់ទ្វារត្រសាល ៣៩ អាសនាលង្ហិន[ព] ប្រទាស
លង្ហិន ឈើស្នែងនិងគ្រឿង ប្រដាប់អាសនាទាំងអស់ ព្រម
ទាំងចានក្លាំ[ភ]និងជើងនៃចាននោះ ៤០ វនាំងទីលាន[ម] អស់
ទាំងសសរនិងជើងរបស់សសរ វនាំងសំរាប់បាំងមាត់ទ្វារ
ទីលាន អស់ទាំងខ្សែចំរឹង ហើយគ្រឿងប្រដាប់សំរាប់រោង
ឧបោសថ ហើយសំរាប់ត្រសាលជំនុំទាំងអស់ផង ៤១ និង
សំលៀកបំពាក់[យ] សំរាប់ការងារនៅទីបរិសុទ្ធ អស់ទាំង
សំលៀកបំពាក់បរិសុទ្ធ សំរាប់អើរ៉ុនដ៏ជាសង្ឃ ហើយនិង
សំលៀកបំពាក់ទាំងអស់ សំរាប់ឱ្យពួកកូនលោកធ្វើការងារ
ជាសង្ឃ ។
៤២ ពួកកូនចៅអ៊ីស្រាអែល គេធ្វើអស់ទាំងការនេះ
សំរេច តាមសេចក្ដីដែលព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ
៤៣ ម៉ូសេក៏ពិនិត្យមើលគ្រប់ការទាំងអស់នោះឃើញថា គេ
បានធ្វើដូចជាព្រះយេហូវ៉ាបានបង្គាប់មក[ល] គេបានធ្វើការ
នោះស្រេចទាំងអស់ រួចម៉ូសេក៏ឱ្យពរ[វ]ដល់គេ ។

## ការដំឡើងរោងឧបោសថ

**៤០** ១ រួចព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា ២ នៅ
ថ្ងៃ១កើតខែដំបូង[ក] នោះត្រូវដំឡើង[ខ]រោងឧបោសថផង
ត្រសាលជំនុំ[គ] ៣ ត្រូវដាក់ហឹប[ឃ]នៃសេចក្ដីបន្ទាល់ទៅក្នុង
ត្រសាលនោះ ហើយយកវាំងននមកបាំង ៤ ត្រូវយកតុ[ង] មក

**៣៩:២៧** ឆ លវ ៦:១០ ៨:២ **៣៩:២៨** ជ ខ.៣១ នក ២៨:៤ លវ ៨:៩ អស ៦១:១០ **៣៩:៣០** ឈ អស ២៣:១៨ សក ១៤:២០ **៣៩:៣១** ញ ខ.២៨ **៣៩:៣២** ដ នក ២៥:៩ **៣៩:៣៣** ឋ នក ២៥:៨–៤០ ៣៦:៨–៣៨ **៣៩:៣៥** ឌ នក ៣៧:១ **៣៩:៣៦** ឍ នក ២៥:២៣–៣០ ៣៧:១០–១៦ ណ នក ២៥:៣០ **៣៩:៣៧** ត នក ២៥:៣១ ថ នក ២៥:៣១–៣៩ ទ នក ២៥:៦ **៣៩:៣៨** ធ នក ៣០:១–១០ ន នក ៣០:២២–៣២ ៣៧:២៩ ប នក ៣០:៣៤–៣៨ ៣៧:២៩ ផ នក ៣៦:៣៥ **៣៩:៣៩** ព នក ២៧:១–៨ ៣៨:១–៧ ភ នក ៣០:១៨ **៣៩:៤០** ម នក ២៧:៩–១៩ ៣៨:៩–២០ **៣៩:៤១** យ នក ២៥:៩ **៣៩:៤៣** រ នក ២៥:៩ ៣៥:១០ ល លប ៣១:៥៥ លវ ៩:២២,២៣ ជន ៦:២៣–២៧ ចទ ២១:៥ ២៦:១៥ ២សយ ៦:១៨ ១ពវ ៨:១៤,៥៥ ១របា ១៦:២ ២របា ៣០:២៧ **៤០:២** ក ខ.១៧ នក ១២:២ ជន ៩:១ ខ ខ.៣៤,៣៥ លវ ១:១ ៣:២ ៦:២៦ ៩:២៣ ១៦:១៦ ជន ១:១ ៧:៨៩ ១១:១៦ ១៧:៤ ២០:៦ យស ១៨:១ ១៩:៥១ យរ ៧:១២ **៤០:៣** ឃ នក ២៦:៣៣ **៤០:៤** ង នក ២៥:២៣

**៣៩:៣០** *ស្លាកមាសសុទ្ធ* គឺការបំពាក់ជាផ្លូវការ (២៨:៣៦–៣៧) នូវស្លាកនៅលើឆ្នួតក្បាល ។ *បរិសុទ្ធដល់ព្រះយេហូវ៉ា* មើល ២៨:៣៦ និងការពន្យល់។
**៣៩:៣២** *អស់ទាំងការស្អាងរោងឧបោសថ... ជាស្រេចទាំងអស់* គឺជាការរំឭកអំពីពាក្យពិពណ៌នា អំពីការបញ្ចប់ព្រះរាជកិច្ចបង្កើតរបស់សព្វសារពើ (មើល លប ២:១–៣) ។ ដូចនេះ ចុងបញ្ចប់នៃព្រះគម្ពីរនិក្ខមនំ មានទំនាក់ទំនងនឹងដើមកំណើតនៃលោកិយ (មើល ១:៧ និងការពន្យល់) ហើយទំនាក់ទំនងនេះបានបង្ហាញ ការចាប់ផ្ដើមនៃការរៀបចំស្ថាព្រះហស្ដទ្រង់ ឱ្យមានសណ្ដាប់ធ្នាប់ឡើងវិញ និងជាការចាប់ផ្ដើមនៃការយល់ដឹងអំពីផែនការប្រោសលោះនៃទ្រង់ ក្នុងប្រវត្តិសាស្ត្រមនុស្សលោក (ការពន្យល់ ២៦:១) ។
**៣៩:៤៣** *ម៉ូសេក៏ឱ្យពរដល់គេ* គឺដោយសារភាពស្មោះត្រង់ ដែលពួកគេមាននៅក្នុងការប្រើអំណោយ ឬពេលវេលា និងចំណេះដឹង នៅក្នុងការសាងសង់ និងលម្អរោងឧបោសថ ជាភាពស្មោះត្រង់ដែលសមនឹងទទួលព្រះពរ ។
**៤០:២** *នៅថ្ងៃ១កើតខែដំបូង* រោងឧបោសថបានសង់ឡើងជិតមួយឆ្នាំបន្ទាប់ពីការធ្វើបុណ្យរំលងដំបូង (ខ.១៧ ១២:២ និងការពន្យល់ និង ខ.៦) ។

រៀបតាមរបៀប[ច] ហើយយកជើងចង្កៀង[ឆ]មកទាំងរៀបចំ
អស់ទាំងចង្កៀងផង ៥ត្រូវដាក់អាសនាមាស[ជ]សំរាប់ដុត
គ្រឿងក្រអូបនៅមុខហឹបនៃសេចក្ដីបន្ទាល់ រួចត្រូវបាំង
វនាំងនៅមាត់ទ្វាររោងឧបោសថ ៦ត្រូវដាក់អាសនា[ឈ]
ដង្វាយដុត នៅមុខមាត់ទ្វាររោងឧបោសថ របស់ផងត្រ–
សាលជំនុំ ៧ហើយត្រូវដាក់ចានក្លាំ[ញ]នៅជាកណ្ដាលត្រសាល
ជំនុំ និងអាសនានោះ រួចដាក់ទឹកចុះក្នុងចានក្លាំផង ៨ឯ
ទីលានត្រូវរៀបចំជុំវិញ[ដ] ព្រមទាំងបាំងវនាំងនៅមាត់ទ្វារ
ដែរ ៩ត្រូវយកប្រេងចាក់លាបមកលាប[ឋ]រោងឧបោសថ
និងប្រដាប់ទាំងប៉ុន្មាននៅក្នុងរោងនោះ ទាំងញែកចេញ
ជាបរិសុទ្ធ ព្រមទាំងគ្រឿងប្រដាប់ទាំងប៉ុន្មានផង[ឌ] នោះនឹង
បានបរិសុទ្ធទាំងអស់ ១០ត្រូវលាបប្រេងនៅអាសនាដង្វាយ
ដុត និងគ្រឿងប្រដាប់អាសនានោះទាំងប៉ុន្មាន ទាំងញែក
ចេញជាបរិសុទ្ធ[ឍ] ដូច្នេះអាសនានោះនឹងបានបរិសុទ្ធជាទី
បំផុត ១១ត្រូវលាបប្រេងនៅចានក្លាំ និងជើងនៃចាននោះ
ទាំងញែកចេញជាបរិសុទ្ធ ១២ត្រូវនាំអើរ៉ុននិងពួកកូន
លោកមកជិតទ្វារត្រសាលជំនុំ[ណ] ហើយផ្ងូតអ្នកទាំងនោះ
ដោយទឹក[ត] ១៣រួចយកសំលៀកបំពាក់បរិសុទ្ធ[ថ]មកបំពាក់
អើរ៉ុន ហើយចាក់ប្រេងញែកលោកចេញជាបរិសុទ្ធ[ទ] ដើម្បី
ឱ្យលោកបានធ្វើការងារជាសង្ឃដល់អញ ១៤រួចត្រូវនាំ
ពួកកូនលោកមកបំពាក់អាវខ្លីឱ្យ[ធ] ១៥ហើយចាក់ប្រេងដល់
គេដូចជាបានចាក់ប្រេងឱ្យឪពុកគេដែរ ដើម្បីឱ្យគេបានធ្វើ
ការងារជាសង្ឃដល់អញ បុណ្យចាក់លាបប្រេងនេះនឹង
បានសំរាប់ការងារជាសង្ឃដល់អ្នកទាំងនោះ អស់កល្បជា
និច្ចគ្រប់ទាំងដំណកេតទៅ[ន] ។

១៦ឯម៉ូសេលោកក៏ធ្វើអស់ទាំងការដែលព្រះយេហូវ៉ា
ទ្រង់បង្គាប់មក[ប] លោកធ្វើការនោះសម្រេចទាំងអស់ ១៧នៅ
ថ្ងៃ១កើតក្នុងខែដំបូង[ផ]ឆ្នាំទី២ នោះរោងឧបោសថ[ព] បាន
ដំឡើងរួចជាស្រេច ១៨ម៉ូសេ[ភ]បានដំឡើងរោងឧបោសថ
លោក ដាក់ជើងទាំងប៉ុន្មាន ក៏បញ្ឈរក្ដារ ហើយរៀបរនុក[ម]
ក៏លើកសសរទាំងប៉ុន្មានឡើង ១៩រួចលោកលាត្រសាល
បាំងរោងឧបោសថ ហើយដាក់គំរបពីលើ[យ]ត្រសាលដូចជា
ព្រះយេហូវ៉ាបានបង្គាប់មក[រ] ២០លោកយកសេចក្ដីបន្ទាល់[ល]
មកដាក់ក្នុងហឹប[វ] រួចប្រហាកឈើស្នែងភ្ជាប់នឹងហឹប ហើយ
ដាក់ទីសន្ដោសប្រោសនៅលើ[ស]ហឹបនោះ ២១លោកយក
ហឹបទៅដាក់ក្នុងរោងឧបោសថ ហើយលាវាំងនន[ហ]បាំង
ហឹបនៃសេចក្ដីបន្ទាល់ ដូចជាព្រះយេហូវ៉ា បានបង្គាប់មក[ឡ]
២២លោកដាក់តុ[អ]នៅខាងជើងក្នុងត្រសាលជំនុំត្រង់ខាងមុខ
វាំងនន ២៣រួចរៀបនំបុ័ង[ក]លើតុនៅចំពោះព្រះយេហូវ៉ា
ដូចជាទ្រង់បានបង្គាប់មក[ខ] ២៤លោកក៏ដាក់ជើងចង្កៀង[គ]
ទៅក្នុងត្រសាលជំនុំ ប្រទល់មុខនឹងតុ គឺខាងត្បូង ក្នុងរោង
ឧបោសថ ២៥រួចលោករៀបចំចង្កៀង[ឃ]នៅចំពោះព្រះ
យេហូវ៉ា ដូចជាទ្រង់បានបង្គាប់មក[ង] ២៦លោកដាក់អាសនា
មាស[ច] នៅមុខវាំងននក្នុងត្រសាលជំនុំ ២៧ហើយក៏ដុតគ្រឿង
ក្រអូបនៅលើអាសនានោះ ដូចជាព្រះយេហូវ៉ាបានបង្គាប់
មក[ឆ] ២៨លោកដាក់វនាំង បាំង[ជ]នៅមាត់ទ្វាររោងឧបោសថ
២៩ហើយក៏ដាក់អាសនា[ឈ]ដង្វាយដុតនៅមុខទ្វាររោងឧបោ
សថផងត្រសាលជំនុំ រួចលោកថ្វាយដង្វាយដុតនឹងដង្វាយ
ម្សៅ[ញ] ដូចជាព្រះយេហូវ៉ាទ្រង់បានបង្គាប់មក[ដ] ៣០លោក
ដាក់ចានក្លាំ[ឋ]នៅជាកណ្ដាលត្រសាលជំនុំ ហើយនិងអាសនា
រួចដាក់ទឹកក្នុងចាននោះសំរាប់និងលាងសំអាត ៣១ហើយ
ម៉ូសេ អើរ៉ុន និងពួកកូនអើរ៉ុនក៏លាង[ឌ]ដៃ លាងជើងត្រង់
ចាននោះ ៣២វេលាណាដែលអ្នកទាំងនោះចូលទៅក្នុង
ត្រសាលជំនុំ ឬទៅជិតអាសនា[ឍ] នោះតែងលាងសំអាតសិន
ដូចជាព្រះយេហូវ៉ាបានបង្គាប់មក[ណ] ៣៣លោកដំឡើងវនាំង
នៃទីលាន[ត] នៅជុំវិញរោងឧបោសថ ហើយនិងអាសនា
រួចដាក់វនាំងបាំង[ថ]នៅមាត់ទ្វារទីលាន ដូច្នេះម៉ូសេបានធ្វើ
ការទាំងនោះរួចជាស្រេច ។

## សិរីល្អរបស់ព្រះអម្ចាស់

៣៤នោះពពក[ទ]ក៏គ្របត្រសាលជំនុំ ហើយសិរីល្អ[ធ]នៃព្រះ

**៤០៤** ច នក ២៥:៣០ ឆ នក ២៥:៣១ **៤០:៥** ជ នក ៣០:១ **៤០:៦** ឈ នក ២៧:១ ២ពវ ១៦:១៤ ២របា ៤:១ **៤០:៧** ញ នក ៣០:១៨ **៤០:៨** ដ នក ២៧:៩ **៤០:៩** ឋ នក ៣០:២៦ ឌ ជន ៧:១ **៤០:១០** ឍ នក ២៩:៣៦ **៤០:១២** ណ ជន ៨:៩ ត នក ២៩:៤ ៣០:១៩ **៤០:១៣** ថ នក ២៨:៤១ ទ លវ ៨:១២ **៤០:១៤** ធ នក ២៨:៤០ លវ ១០:៥ **៤០:១៥** ន នក ២៩:៩ **៤០:១៦** ប លប ៦:២២ **៤០:១៧** ផ ខ.២ ព ជន ៧:១ **៤០:១៨** ភ ២របា ១:៣ ម នក ៣៦:២០–៣៤ **៤០:១៩** យ នក ៣៦:១៩ រ លប ៦:២២ **៤០:២០** ល នក ១៦:៣៤ ហព ៩:៤ វ នក ២៥:២១ ស នក ២៥:១៧–២២ ២៦:៣៤ ៣១:៧ **៤០:២១** ហ នក ២៦:៣៣ ឡ លប ៦:២២ **៤០:២២** អ នក ២៥:២៣ **៤០:២៣** ក នក ២៥:៣០ លវ ២៤:៥–៨ ខ លប ៦:២២ **៤០:២៤** គ នក ២៥:៣១ **៤០:២៥** ឃ នក ៣៧:២៣ ង លប ៦:២២ **៤០:២៦** ច នក ៣០:១ **៤០:២៧** ឆ លប ៦:២២ **៤០:២៨** ជ នក ២៦:៣៦ **៤០:២៩** ឈ នក ២០:២៤ ញ នក ២៩:៣៨–៤២ ដ លប ៦:២២ **៤០:៣០** ឋ ខ.៧ នក ៣០:១៨ **៤០:៣១** ឌ នក ៣០:១៩–២១ **៤០:៣២** ឍ នក ៣០:២០ ណ លប ៦:២២ **៤០:៣៣** ត នក ២៧:៩ ៣៨:៩–២០ ថ នក ២៧:១៦ **៤០:៣៤** ទ នក ១៩:១៦ លវ ១៦:២ ជន ៩:១៥–២៣ ១ពវ ៨:១២ ២របា ៥:១៣ អស ៦:៤ អគ ១០:៤ ធ នក ១៦:៧ យហ ១:១៤ ១២:៤១ វវ ១៥:៨

**៤០:៩–១០** *បានបរិសុទ្ធ . . . ជាបរិសុទ្ធទាំងអស់* មើល ៣:៥ ២៩:៣៧ និងការពន្យល់ ។

**៤០:១៦** *ឯម៉ូសេលោកក៏ធ្វើអស់ទាំងការដែលព្រះយេហូវ៉ា ទ្រង់បង្គាប់មក* ការស្ដាប់បង្គាប់របស់លោកម៉ូសេចំពោះព្រះរាជបញ្ជា គឺជាគន្លឹះនៃជំពូកបញ្ចប់នៃព្រះគម្ពីរនិក្ខមនំ (មើល ខ.១៩,២១,២៣,២៥,២៧,២៩,៣២) ។ ពួកបណ្ដាជនបានថ្វាយនូវធនធានទាំងអស់ ហើយបានសាងសង់គ្រប់ផ្នែក ប៉ុន្តែ មានតែលោកម៉ូសេតែម្នាក់គត់ ដ៏ជាអ្នកបម្រើព្រះយេហូវ៉ា ដែលបានទទួលអភ័យឯកសិទ្ធិ នៅក្នុងការស្អាង និងរៀបចំរោងឧបោសថនោះ សម្រាប់ការយាងចូលមកសណ្ឋិត ។

**៤០:៣៣** *ម៉ូសេបានធ្វើការទាំងនោះរួចជាស្រេច* ការពន្យល់ ៣៩:៣២ ។

**៤០:៣៤** នៅពេលដែលសិរីល្អនៃព្រះអម្ចាស់ យាងមកសណ្ឋិតនៅក្នុងរោងឧបោសថ (ធៀបនឹង ១ពវ ៨:១០–១១ និងការពន្យល់ ៨:១០) ការឈានទៅ

យេហូវ៉ាបានស្ថិតនៅពេញក្នុងរោងឧបោសថ ៣៥ ឯម៉ូសេ
លោកចូលទៅក្នុងត្រសាលជំនុំមិនបាន ពីព្រោះពពកនៅពី
លើ ហើយដោយព្រោះសិរីល្អ[ន]នៃព្រះយេហូវ៉ា ដែលនៅ
ពេញក្នុងរោងឧបោសថនោះផង[ប] ៣៦ បើកាលណាពពក
បានឡើង ផុតពីលើរោងឧបោសថ នោះពួកកូនចៅ
អ៊ីស្រាអែល ក៏តែងធ្វើដំណើរដើរទៅជាដរាប ក្នុងគ្រប់
ទាំងវេលា ដែលគេកំពុងតែធ្វើដំណើរនោះ[ផ] ៣៧ តែបើ
កាលណាពពកមិនបានឡើងទេ នោះគេក៏មិនធ្វើដំណើរ
ទៅដែរ ទាល់តែពពកឡើងផុតចេញ ៣៨ ដ្បិតក្នុងអស់ទាំង
ការដំណើរនៃពួកកូនចៅអ៊ីស្រាអែល នោះនៅវេលាថ្ងៃ
តែងមានពពក[ព]នៃព្រះយេហូវ៉ា ស្ថិតនៅលើរោងឧបោសថ
ហើយនៅវេលាយប់ មានភ្លើងវិញ ឱ្យពួកវង្សអ៊ីស្រាអែល
ទាំងអស់គ្នាបានឃើញ ។

**៤០:៣៥** ន នក ១៦:១០ ប ១ពវ ៨:១១ ២រប ៥:១៣–១៤ ៧:២
**៤០:៣៦** ផ ជន ៩:១៧–២៣ ១០:១៣
**៤០:៣៨** ព នក ១៣:២១ ១កថ ១០:១

ដល់ដំណាក់កាលដែលសំខាន់ជាងគេ បានកើតមានចំពោះហេតុការណ៍ដែលបានកើតឡើងជាបន្តបន្ទាប់ គឺរាប់ចាប់តាំងពីកំណើតរបស់លោកម៉ូសេ និងការសង្គ្រោះជីវិតរបស់គាត់នៅក្នុងទន្លេនីល ដែលជាការបង្ហើបប្រាប់ជាមុនអំពីការរំដោះពួកអ៊ីស្រាអែល ពីស្រុកអេស៊ីព្ទ ។ ចាប់ពីដំណាក់កាលនេះតទៅ ពួកអ៊ីស្រាអែលបន្តនាំគ្នាធ្វើដំណើរកាត់វាលរហោស្ថាន ហើយឆ្លងកាត់ប្រវត្តិសាស្ត្រ ដោយមានព្រះទ្រង់គង់ជាមួយតាមរយៈរោងឧបោសថ ហើយដឹកនាំពួកគេទៅកាន់ទឹកដី ដែលទ្រង់បានសន្យាប្រទាន ។
**៤០:៣៨** មើលការពន្យល់ ១៣:២១ ។

## សេចក្តីផ្តើម

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

សូមមើលការពន្យល់ ១:១ និងសេចក្តីផ្តើម លោកុប្បត្តិ ត្រង់ចំណុចអ្នកនិពន្ធ និងកាលបរិច្ឆេទនៃការសរសេរ ។

### ចំណងជើង

ឈ្មោះព្រះគម្ពីរលេវីវិន័យបានមកពីការបកប្រែព្រះគម្ពីរសញ្ញាចាស់ដំបូងមុនគ្រីស្ទសករាជ ហើយឈ្មោះនេះមានការជាប់ទាក់ទងទៅនឹងពួកលេវីដោយផ្ទាល់ ។ ការដាក់ឈ្មោះព្រះគម្ពីរលេវីវិន័យមិនគ្រាន់តែមានទំនាក់ទំនងនឹងពួកលេវីប៉ុណ្ណោះទេ គឺដោយព្រោះបាននិយាយរៀបរាប់ដល់ការបម្រើផ្នែកថ្វាយបង្គំនៅឯរោងឧបោសថ ដែលបានដឹកនាំដោយពួកសង្ឃ ជាកូនរបស់ស្តេចសង្ឃអ៊ើរ៉ុន ដែលមានអ្នកជំនួយជាច្រើនក្នុងពួកលេវី ។ ព្រះគម្ពីរនិក្ខមនំ និយាយពីការសង់រោងឧបោសថ ហើយព្រះគម្ពីរលេវីវិន័យបានឱ្យក្រឹត្យវិន័យ និងច្បាប់នៃការថ្វាយបង្គំ ដែលបានផ្តល់នូវការណែនាំ ក្នុងពិធីលាងសំអាត ក្រឹត្យក្រមសីលធម៌ ថ្ងៃបរិសុទ្ធ ឆ្នាំឈប់សម្រាក និងឆ្នាំសោមនស្ស ។ យ៉ាងហោចណាស់ ក្រឹត្យវិន័យទាំងនេះបានផ្តល់មួយភាគធំ នៅអំឡុងឆ្នាំដែលពួកអ៊ីស្រាអែល បានបោះជំរុំនៅភ្នំស៊ីណាយ ក្រោមការដឹកនាំរបស់លោកម៉ូសេក្នុងការរៀបចំការថ្វាយបង្គំរបស់ពួកអ៊ីស្រាអែល ការគ្រប់គ្រង និងការកេណ្ឌកងទ័ព ។ នៅព្រះគម្ពីរជនគណនា បាននិយាយអំពីប្រវត្តិសាស្ត្រនៃការរៀបចំក្នុងការ ផ្លាស់ប្តូរទីលំនៅ ពីភ្នំស៊ីណាយទៅឯទឹកដីកាណានវិញ ។

### ខ្លឹមសារទេវសាស្ត្រ

លេវីវិន័យគឺជាក្បួនច្បាប់មួយ ដែលអាចជួយដល់ព្រះអម្ចាស់ក្នុងការតាំងរាជ្យ នៅក្នុងចំណោមរាស្ត្ររបស់ទ្រង់ ក្នុងអាណាចក្ររបស់ទ្រង់ ។ ព្រះគម្ពីរលេវីវិន័យនេះ បានពន្យល់ពីរបៀបដែលពួកគេត្រូវធ្វើជារាស្ត្របរិសុទ្ធនៅចំពោះព្រះ ហើយថ្វាយបង្គំទ្រង់ក្នុងន័យបរិសុទ្ធ ។ ភាពបរិសុទ្ធ នៅត្រង់នេះមានន័យថា ត្រូវឱ្យពួកគេផ្តាច់ខ្លួនចេញពីអំពើបាប និងញែកឱ្យដាច់ទៅចំពោះព្រះអម្ចាស់ និងព្រះរាជហឫទ័យ និងសម្រាប់ជាសិរីល្អរបស់ទ្រង់ ។ ដូច្នេះ គំនិតដែលជាគន្លឹះនៅក្នុងព្រះគម្ពីរនេះ គឺភាពបរិសុទ្ធ (មើលការពន្យល់ ១១:៤៤ នក ៣:៥) ។ ភាពបរិសុទ្ធនៅក្នុងន័យខាងឯវិញ្ញាណនៃព្រះគម្ពីរនេះគឺ បង្ហាញខាងឯរាង្គកាយដ៏ល្អឥតខ្ចោះ ។ ដូច្នេះហើយ ទាមទារឱ្យមានសត្វដ៏ល្អឥតខ្ចោះនៅក្នុងការថ្វាយជាយញ្ញបូជាជាច្រើន (ជំពូក ១-៧) និងតម្រូវឱ្យសង្ឃ ដោយគ្មានភាពខូចទ្រង់ទ្រាយ (ជំពូក ៨-១០) ។ ការធ្លាក់ឈាមរដូវរបស់ស្ត្រី (ជំពូក ១-៧) ជំងឺ ការរលាក ឬទំពែកក្បាល (ជំពូក ១៣-១៤) បុរសដែលហូរខ្ទុះ (១៥:១-១៨) ការបញ្ចាក់ពីសកម្មភាពរបស់ស្ត្រីនៅអំឡុងពេលដល់រដូវ (១៥:១៩-៣៣) ហើយទាំងអស់នេះជាសញ្ញានៃភាពមិនស្អាត ហើយវាឈានទៅរកភាពកខ្វក់របស់មនុស្ស ដែលធ្វើឱ្យខូចដល់វិញ្ញាណទាំងមូល ។ ពួកមនុស្សដែលមានជំងឺសើស្បែកត្រូវតែយកពួកគេចេញពីត្រសាលជំនុំ ជាកន្លែងដែលព្រះវត្តមានគង់នៅជាពិសេស ។ ចំណុចនេះផងដែរ លោកអ័ដាម និងនាងអេវ៉ា ក៏ត្រូវបាននិរទេសចេញពីសួនអេដែន ។ ពួកមនុស្សអាចចូលមកក្នុងត្រសាលជំនុំវិញបាន លុះណាតែបានប្រកាសជាថ្មីម្តងទៀតដោយពួកសង្ឃ ។ ទោះជាយ៉ាងណាក៏ដោយ មុនពេលដែលពួកគេចូលក្នុងទីដំឡើងត្រសាលជាថ្មី ពួកគេត្រូវបានបង្គាប់ឱ្យថ្វាយនូវយញ្ញបូជាដ៏បរិសុទ្ធ (និមិត្តរូបពីភាពបរិសុទ្ធ យញ្ញបូជារបស់ព្រះគ្រីស្ទទាំងអស់) ។

ក្រោយពីសេចក្តីសញ្ញានៅភ្នំស៊ីណាយ អ៊ីស្រាអែលគឺជាអាណាចក្ររបស់ព្រះអម្ចាស់មុនគេ និងភាពជាស្តេចរបស់ទ្រង់ ដោយព្រះអម្ចាស់បានបង្កើតប្រព័ន្ធគ្រប់គ្រងនៅគ្រប់ជីវិតពួកអ៊ីស្រាអែល ។ សេចក្តីជំនឿ ការរួបរួម និងជីវិតជាបុគ្គលរបស់ពួកអ៊ីស្រាអែល បានធ្វើឱ្យជីវិតរបស់ពួកគេមានរបៀបរៀបរយ ដើម្បីបង្កើតឱ្យគេធ្វើជារាស្ត្រដ៏បរិសុទ្ធរបស់ព្រះ និងនាំពួកគេទៅដល់ភាពបរិសុទ្ធ ។ ការថ្វាយយញ្ញបូជាត្រូវធ្វើនៅទីបរិសុទ្ធ ជានិមិត្តរូបទាំងភាពបរិសុទ្ធ និងព្រះទ័យរបស់ទ្រង់ ។ ពួកគេត្រូវបានមើលការខុសត្រូវដោយពួកសង្ឃដោយយកចិត្តទុកដាក់ និងដឹកនាំពួកគេឱ្យចូលទៅក្នុងភាពបរិសុទ្ធដោយប្រុងប្រយ័ត្ន និងការបង្រៀនពីអត្ថន័យរបស់វាឱ្យពួកគេយល់ ។

សម្រាប់ព័ត៌មានបន្ថែមពីការថ្វាយយញ្ញបូជា នៅថ្ងៃប្រជុំបរិសុទ្ធ (គឺមាននៅ ជំពូក ១៦ និងការពន្យល់ ១៦:១-៣៤) ។ អត្ថន័យនៃការថ្វាយឈាមជាយញ្ញបូជា សូមមើល ១៧:១១ នក ៩:៤ និងការពន្យល់ ។ សម្រាប់ការជំនួស សូមមើល ១៦:២១ ។

អ្នកខ្លះបានជឿថាយញ្ញបូជានៅគ្រាសញ្ញាចាស់គឺទាមទារឱ្យមានភោគផលចាស់នៃដំណាំកសិកម្ម ដូចដែលពួកគេថ្វាយនូវទ្រព្យរបស់ពួកគេជាដង្វាយក្តីស្រឡាញ់ដល់អាទិទេពរបស់ពួកគេ ។ តែយញ្ញបូជានៅគ្រាសញ្ញាចាស់គឺជាព្រះរាជបញ្ជានៃព្រះអម្ចាស់ ហើយការទទួលអត្ថន័យពីសេចក្តីសញ្ញារបស់ព្រះអម្ចាស់ តាមរយៈការទាក់ទងរបស់ពួកអ៊ីស្រាអែលផ្ទាល់ គឺអ្វីដែលស្រដៀងគ្នានឹងពួកខុសឆ្គង ដែល

គេថ្វាយដែរ ។ ពួកគេបានបញ្ចូលគំនិតនៃការឱ្យអំណោយ ប៉ុន្តែការ នេះមានតម្លៃផ្សេងៗគ្នា ដូចជាការថ្វាយ ការរួបរួម សេចក្ដីស្ងប់ចិត្ត ដង្វាយផ្សេងគ្នាមានន័យផ្សេងគ្នា ដូចជាដង្វាយលោះបាប (សូមមើលការពន្យល់ នក ២៥:១៧) ។

**គម្រោងសង្ខេប**

**I. ដង្វាយសំខាន់ៗប្រាំយ៉ាង (ជំពូក ១–៧)**

ក. ដង្វាយដុត (ជំពូក ១)

ខ. ដង្វាយម្សៅ (ជំពូក ២)

គ. ដង្វាយមេត្រី (ជំពូក ៣)

ឃ.ដង្វាយលោះបាប (៤:១–៥:១៣)

ង.ដង្វាយការរំលង (៥:១៤–៦:៧)

ច.សេចក្ដីបន្ថែមច្បាប់នៃការថ្វាយដង្វាយ (៦:៨–៧:៣៨)

**II. ការកសាង និងបេសកកម្មរបស់លោកអើរ៉ុន និងកូនប្រុសរបស់គាត់ (ជំពូក ៨–១០)**

ក. ការតែងតាំង របស់លោកអើរ៉ុន និងកូនរបស់គាត់ (ជំពូក ៨)

ខ. បេសកកម្មរបស់ពួកសង្ឃ (ជំពូក ៩)

គ. ការស្លាប់របស់ន៉ាដាប និងអ័ប៊ីហ៊ូវ ហើយនិងច្បាប់នៃការបម្រើ (ជំពូក ១០)

**III. ការញែកភាពស្អាត និងភាពមិនស្អាត (ជំពូក ១៥–១៦)**

ក. ម្ហូបអាហារស្អាត និងមិនស្អាត (ជំពូក ១១)

ខ. ភាពបរិសុទ្ធក្រោយពីសម្រាលកូនរួច (ជំពូក ១២)

គ. បទបញ្ញាចំពោះជំងឺសើស្បែក (១៣:១–៤៦)

ឃ. បទបញ្ញាចំពោះជំងឺឃ្លង់ (១៣:៤៧–៥៩)

ង. ការសំអាតរោគសើស្បែក (១៤:១–៣២)

ច. ការសំអាតរោគឃ្លង់ (១៤:៣៣–៥៧)

ឆ. ការហូរខ្ទុះ ដែលជាបុព្វហេតុនៃការមិនស្អាត (ជំពូក ១៥)

**IV. ថ្ងៃបុណ្យឱ្យធួននឹងបាប (ជំពូក ១៦)**

**V. ការរស់នៅជាបរិសុទ្ធ (ជំពូក ១៧–២៦)**

ក. ការហាមមិនឱ្យបរិភោគឈាម (ជំពូក ១៧)

ខ. ការរួមដំណេកខុសច្បាប់ (ជំពូក ១៨)

គ. ច្បាប់ផ្សេងៗក្នុងការរស់នៅជាបរិសុទ្ធ (ជំពូក ១៩)

ឃ. ការកាត់ទោសចំពោះអំពើបាប (ជំពូក ២០)

ង. បទបញ្ញាសម្រាប់ពួកសង្ឃ (២១:១–២២:១៦)

ច. ការទទួលយក និងមិនទទួលយកចំពោះយញ្ញបូជា (២២:១៧–៣៣)

ឆ. ច្បាប់ចំពោះនំបុ័ង និងប្រេងនៅលើអាសនា (២៤:១–៩)

ជ. ការកាត់ទោសចំពោះសេចក្ដីប្រមាថ (២៤:១០–២៣)

ឈ.ឆ្នាំឈប់សម្រាក និងឆ្នាំទី៥០ (ជំពូក ២៥)

ញ.ព្រះពរ និងបណ្ដាសា (ជំពូក ២៦)

**VI. ច្បាប់ចំពោះការថ្វាយដង្វាយលាបំណន់ទៅដល់ព្រះអម្ចាស់ (ជំពូក ២៧)**

## ដង្វាយដុត

**១** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលហៅម៉ូសេ[ក]មក បង្គាប់
លោកពីក្នុងត្រសាលជំនុំ[ខ] ២ឱ្យទៅប្រាប់ដល់ពួកកូនចៅ
អ៊ីស្រាអែលថា បើកាលណាពួកអ្នករាល់គ្នាណាមួយចង់
ថ្វាយដង្វាយដល់ព្រះយេហូវ៉ា[គ] នោះត្រូវតែយកដង្វាយនោះ
មកពីហ្វូងសត្វ ទោះបើជាគោឬចៀមក្ដី[ឃ] ។
៣បើសិនជាដង្វាយរបស់អ្នកនោះជាគោ[ង]ដែលត្រូវដុត
ថ្វាយ[ច] នោះត្រូវយកឈ្មោល១ដ៏ឥតខ្ចោះ[ឆ] គេត្រូវនាំយក
ដង្វាយនោះទៅថ្វាយនៅមាត់ទ្វារត្រសាលជំនុំ[ជ] ឱ្យបានជាទី
គាប់[ឈ]នៅចំពោះព្រះយេហូវ៉ា ៤នោះគេត្រូវដាក់ដៃលើ
ក្បាល[ញ]នៃសត្វទាំងនោះ ហើយទ្រង់នឹងទទួល[ដ]ដង្វាយ[ឋ]
នោះស្នងគេ ដើម្បីឱ្យបានធួននឹងខ្លួនគេ[ឌ] ៥ក៏ត្រូវសំឡាប់[ឍ]
គោស្ទាវនោះ[ណ] នៅចំពោះព្រះយេហូវ៉ា រួចពួកកូនអើរ៉ុន[ត]
ដែលជាពួកសង្ឃ ត្រូវយកឈាមទៅប្រោះនៅជុំវិញ[ថ]លើ
អាសនាដែលនៅមាត់ទ្វារត្រសាលជំនុំ ៦គេត្រូវអារពន្លាត់
ស្បែក[ទ] ហើយកាប់ដង្វាយទៅជាដុំៗ[ធ] ៧រួចពួកកូនអើរ៉ុន
ដ៏ជាសង្ឃនឹងយកភ្លើងមក ដាក់លើអាសនា ហើយបង្គរឧស
នៅលើ ៨រួចរៀបដុំសាច់ ហើយក្បាល និងខ្លាញ់[ប] ពីលើ
ឧស[ផ]ដែលឆេះនៅលើអាសនា ៩តែឯអាការៈខាងក្នុង និង
ជើងទាំងប៉ុន្មាន នោះត្រូវលាងនឹងទឹកចេញ[ព] រួចត្រូវឱ្យ

**១:១** ក នក ៣:៤ ២៥:២២ ខ នក ២៧:២១ ៤០:២ **១:២** គ លវ ៧:១៦, ៣៨ ២២:២១ ២៣:៣៨ ២៧:៩ ឃ លវ ២២:១៨–១៩ ជន ១៥:៣ **១:៣** ង ខ.១០ លវ ២២:២៧ អរ ៨:៣៥ មទ្ឋ ១:៨ ច លប ៨:២០ ឆ ខ.៥ នក ១២:៥ លវ ២២:១៩,២០ ហព ៩:១៤ ១ពត ១:១៩ ជ លវ ៦:២៥ ១៧:៩ ជន ៦:១៦ ចទ ១២:៥–៦,១១ ឈ អស ៥៨:៥ **១:៤** ញ នក ២៩:១០, ១៥ ដ លប ៣២:២០ ឋ ខ.៣ លវ ៤:២៩ ៦:២៥ អគ ៤៥:១៥ ឌ នក ២៩:៣៦ ៣២:៣០ **១:៥** ឍ នក ២៩:១១ លវ ៣:២,៨ ណ ខ.៣ នក ២៩:១ ជន ១៥:៨ ចទ ១៨:៣ ទដ ៥០:៩ ៦៩:៣១ ត លប ៨:២ ១០:៦ ២១:១ ថ នក ២៩:២០ ហព ១២:២៤ ១ពត ១:២ **១:៦** ទ លវ ៧:៨ ធ នក ២៩:១៧ **១:៧** ន ខ.១៧ លប ២២:៩ លវ ៣:៥ ៦:១២ **១:៨** ប ខ.១២ នក ២៩:១៣ លវ ៨:២០ ផ លវ ៩:១៣ **១:៩** ព នក ២៩:១៧

**១:១–៧:៣៨** នៅវគ្គដើមដំបូងនេះគឺជាការរៀបចំដង្វាយសំខាន់ៗ ប្រាំយ៉ាង សម្រាប់ថ្វាយដល់ព្រះយេហូវ៉ាមានដូចជាដង្វាយដុត ដង្វាយគ្រាប់ពូជ ការប្រកបស្និទ្ធស្នាល អំពើបាប និងទោសកំហុស ។

**១:១** នៅក្នុងខនេះបញ្ជាក់ថាបរិបទនៃគម្ពីរលេវីវិន័យ ត្រូវបានប្រទានមកឱ្យលោកម៉ូសេដោយព្រះអម្ចាស់នៅភ្នំស៊ីណាយ (សូមផ្ទៀប នឹង ២៧:៣៤) ។ ចំណុចត្រង់នេះ ក៏មានប្រហែលជាងហាសិបដងដែលនិយាយថា ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅកាន់លោកម៉ូសេ ។ ពួកអ្នកប្រឆាំងក្នុងសម័យទំនើបបានសន្មតយកការប្រតិបត្តិផ្សេងៗទៅតាមអ្វី ដែលមាននៅក្នុងព្រះគម្ពីរនេះ ដែលពួកសង្ឃបានសរសេរក្នុងពេល និងក្រោយពេលដែលលោកម៉ូសេត្រូវគេនិរទេសខ្លួននោះ ។ ការប្រឆាំងនេះគ្មានភស្តុតាងត្រឹមត្រូវទេ ពោលគឺប្រឆាំងនឹងការប្រកាសជាថ្មីម្ដងទៀតរបស់ក្រឹត្យវិន័យលោកម៉ូសេ ដែលប្រឆាំង និងប្រពៃណីពួកយូដាដែលមានក្នុងសម័យសញ្ញាចាស់ និងសញ្ញាថ្មី (រម ១០:៥) ។ រឿងរ៉ាវជាច្រើននៅក្នុងលេវីវិន័យ ត្រូវបានគេរកឃើញថា ជាការពន្យល់ដ៏ល្អនិងសំបូរបែបមួយនៅក្នុងរយៈពេលពីរពាន់ឆ្នាំមុន គ.សមកនេះ ដែលរឿងរ៉ាវទាំងនោះដូចទៅនឹងគម្ពីរទាំងប្រាំកណ្ឌដំបូងរបស់លោម៉ូសេ (មើលសេចក្ដីផ្ដើម លប នៅក្នុងវគ្គអ្នកនិពន្ធ និងកាលបរិច្ឆេទ) ។ *ត្រសាលជំនុំ* នេះជារោងឧបោសថជាទីដែលព្រះអម្ចាស់ជួបនឹងពួកអ៊ីស្រាអែល (មើល នក ២៧:២១) ។

**១:២** *ថ្វាយដង្វាយ* ព្រះគម្ពីរភាសាហេព្រើរប្រើពាក្យដង្វាយនេះក្នុងន័យថា នាំមក និងផ្ដល់ឱ្យ ។ ដង្វាយគឺជាអ្វីមួយដែលមនុស្សនាំយកមកដើម្បីថ្វាយដល់ព្រះអម្ចាស់ (មក ៧:១១) ។

**១:៣** *ដុតថ្វាយ* មើល ៦:៨–១៣ ។ ដង្វាយដុតត្រូវបានគេថ្វាយជារៀងរាល់ព្រឹក និងជារៀងរាល់ល្ងាចសម្រាប់គ្រប់សាសន៍អ៊ីស្រាអែល (នក ២៩:៣០–៤២) ។ ដង្វាយដុតទ្វេរត្រូវបានគេនាំយកមកនៅថ្ងៃឈប់សម្រាក (ជន ២៨:៩–១០) និងថ្ងៃបុណ្យស៊ីលៀង (ជន ២៨–២៩) ។ លើសពីនេះទៅទៀត ពួកគេអាចបូជាដង្វាយដុតជាពិសេសដល់ព្រះអម្ចាស់ ដើម្បីបញ្ជាក់ពីការលះបង់របស់ខ្លួនផងដែរ ។ *ឈ្មោល* ត្រង់នេះបញ្ជាក់ថា សត្វឈ្មោលមានតម្លៃវិសេសវិសាល ដោយព្រោះសត្វនេះមានកម្លាំងខ្លាំង ហើយអាចបន្តពូជបានល្អ ដូចច្នេះពួកគេក៏គិតថាវាជាអំណោយដ៏ប្រសើរសម្រាប់ព្រះ ។ ចំពោះមនុស្សសាមញ្ញ សត្វដែលគេយកទៅថ្វាយនោះ ជាទូទៅគឺចៀម ឬពពែ ប៉ុន្តែចំពោះអ្នកទាំងឡាយណាដែលជាអ្នកមាន គេថ្វាយសត្វ គោ ឬដំរីវិញ ។ ចំណែកឯអ្នកក្រ គេថ្វាយសត្វព្រាប ឬលលក តែសត្វនេះគេថ្វាយមិនទូទៅទេ ។ *ដ៏ឥតខ្ចោះ* សត្វដែលគេយកនោះត្រូវតែបានសំអាតជាមុន (ផ្ទៀប មទ្ឋ ១:៨ ១ពត ១:១៩) ។ គ្រប់ទាំងដង្វាយ អ្នកថ្វាយត្រូវលាដៃរបស់ខ្លួនដាក់លើក្បាលសត្វនោះដើម្បីបញ្ជាក់ពីអត្តសញ្ញាណ រវាងគេនិងសត្វនោះ (១៦:២១) ការស្លាប់របស់សត្វនោះទ្រង់បានទទួលយកជាដង្វាយឱ្យធួននឹងខ្លួនគេ (ខ.៤) ។ ឈាមរបស់សត្វនោះ ស្រក់នៅជាយអាសនា (ក្រៅរោងឧបោសថ ស្ថិតនៅខាងកើតព្រះវិហារ) ជាទីដែលភ្លើងឆេះជាប់ជានិច្ចនៅមួយកន្លែងមិនរលត់ឡើយ (៦:១៣) ។ យញ្ញបូជាទាំអស់ត្រូវបានគេដុត ដែលក្នុងនោះរួមមានទាំងក្បាល ជើង ខ្លាញ់ និងសរីរាង្គខាងក្នុង ។ ពាក្យថា"ហូឡូ" មានន័យថា"ទាំងមូល" ឯ "ខឹស" មានន័យថា "ដុត" ដូច្នេះពាក្យថា "ហូឡូខឹស" ត្រូវបានគេហៅថាយញ្ញបូជាមនុស្សវិញ ។ ទោះជាសត្វគោត្រូវបានគេថ្វាយ ហើយគណៈអធិបតីនៃពួកសង្ឃ ត្រូវរក្សាវាជាសម្ងាត់ ។ ដង្វាយដុតត្រូវថ្វាយជាយញ្ញបូជាធម្មតា ក្នុងអត្ថន័យដ៏ជ្រាលជ្រៅ ដោយសម្ដេចសង្ឃ ។ *មាត់ទ្វារត្រសាលជំនុំ* ជាទីអាសនានៃដង្វាយដុត (នក ៤០:២៩) ។ *ឱ្យបានជាទីគាប់ នៅចំពោះព្រះយេហូវ៉ា* (មើល រម ១២:១ ភល ៤:១៨ និងការពន្យល់) ។

**១:៤** *ដាក់ដៃលើ* មើលការពន្យល់ ខ៣ នក ២៩:១០ ។ *ឱ្យធួននឹងខ្លួនគេ* មើលការពន្យល់ ១៦:២០–២២ ១៧:១១ នក ២៥:១៧ ។

**១:៥** អ្នកថ្វាយបានសម្លាប់សត្វ (ភាពល្អប្រសើររបស់សត្វ ជំនួសឱ្យអំពើបាបរបស់មនុស្ស) ពួកសង្ឃបានធ្វើខាងដើម ។ *ឈាម* មើលការពន្យល់ ១៧:១១ ហព ៩:១៨ ។ *ប្រោះនៅជុំវិញលើអាសនា* មើលការពន្យល់ នក ២៤:៦ ហព ៩:១៩–២១ ។

**១:៦** *ស្បែក* សរីរាង្គទាំងមូលត្រូវបានគេដុតបូជា ប៉ុន្តែលើកលែងស្បែកត្រូវប្រគល់ឱ្យទៅសង្ឃ (៧:៨) ។

**១:៩,១៣,១៧** *ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា* យញ្ញបូជាគ្រាសញ្ញាចាស់បាន

សង្ឃដុតទាំងអស់[ភ]នៅលើអាសនា[ម]ទុកជាដង្វាយដុត[យ] គឺជា
ដង្វាយដែលដុត[រ] សំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[ល]។
១០បើសិនជាដង្វាយរបស់អ្នកនោះ ជាចៀម[វ]ឬពពែ[ស]ដែល
ត្រូវដុតថ្វាយ នោះត្រូវយកឈ្មោល១ដ៏ឥតខ្ចោះ ១១គេត្រូវ
សំឡាប់នៅត្រង់ក្បែរជើងអាសនា[ហ] ចំពោះព្រះយេហូវ៉ា
រួចត្រូវឱ្យពួកកូនអើរ៉ុនដ៏ជាសង្ឃ ប្រោះឈាមនៅជុំវិញលើ
អាសនា[ឡ] ១២គេត្រូវកាប់ឱ្យទៅជាដុំៗ រួចត្រូវឱ្យសង្ឃរៀបចំ
ទាំងអស់ ព្រមទាំងក្បាល និងខ្លាញ់[អ] ពីលើឧសដែលឆេះ
នៅលើអាសនា ១៣តែឯអាការៈខាងក្នុងនឹងជើងទាំងប៉ុន្មាន
នោះត្រូវលាងនឹងទឹកចេញ[ក] រួចត្រូវឱ្យសង្ឃថ្វាយទាំងអស់
នៅលើអាសនា[ខ] ទុកជាដង្វាយដុត[គ] គឺជាដង្វាយដែលដុត[ឃ]
សំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា ។
១៤ឬបើសិនជាដង្វាយ ដែលអ្នកនោះថ្វាយដល់ព្រះ
យេហូវ៉ា ជាសត្វស្លាបដែលត្រូវដុតថ្វាយ នោះត្រូវយកជា
លលក ឬជាព្រាបជំទើរ[ង] ១៥រួចត្រូវឱ្យសង្ឃយកមកដល់
អាសនា ក្តិចបណ្តាច់ក្បាល[ច] ដុតនៅលើអាសនា តែត្រូវ
សំរក់ឈាមនៅខាងអាសនាវិញ[ឆ] ១៦ហើយយកគែព្រមទាំង
បោចស្លាបបោះទៅខាងកើតអាសនា ត្រង់កន្លែងចាក់ ផេះ[ជ]
១៧ត្រូវពុះចំពាក់កណ្តាល ឱ្យមានចំអែងនៅជាប់ទាំងសង
ខាង មិនត្រូវផ្តាច់ចំហៀងចេញពីគ្នាទេ[ឈ] រួចត្រូវឱ្យសង្ឃ
ដុតលើឧស[ញ]ដែលឆេះនៅលើអាសនា ទុកជាដង្វាយដុត
គឺជាដង្វាយដែលដុតសំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា ។

## ដង្វាយម្សៅ

**២** ១បើអ្នកណាចង់ថ្វាយ ជាដង្វាយម្សៅ[ក]ដល់ព្រះយេហូវ៉ា
នោះត្រូវយកម្សៅយ៉ាងម៉ដ្ឋ[ខ]ហើយចាក់ប្រេង[គ,ឃ] ព្រមទាំង
ដាក់កំញានផង[ង] ២ត្រូវឱ្យយកទៅឯពួកកូនអើរ៉ុនដ៏ជាសង្ឃ
ហើយត្រូវឱ្យសង្ឃយកម្សៅយ៉ាងម៉ដ្ឋនោះ១ក្តាប់[ច] ជាមួយ
នឹងប្រេងខ្លះ ព្រមទាំងកំញាន[ឆ]ទាំងអស់ទៅដុត ទុកជា
ទីរំឭក[ជ]នៅលើអាសនា គឺជាដង្វាយដុត[ឈ]សំរាប់ជាក្លិន
ឈ្ងុយដល់ព្រះយេហូវ៉ា[ញ] ៣ឯចំណែកដង្វាយម្សៅដែលសល់
នៅ នោះគឺសំរាប់អើរ៉ុន និងពួកកូនលោក[ដ] ជារបស់បរិសុទ្ធ
បំផុត[ឋ] ក្នុងអស់ទាំងដង្វាយ ដែលដុតថ្វាយព្រះយេហូវ៉ា ។

**១:៩** ភ លប ៦:២២ ម ខ.១៣ នក ២៩:១៨ លវ ៩:១៤ យ ខ.៣ រប ២៣:៨,២៥,៣៦ ជន ២៨:៦,១៩ ល ខ.១៣ លប ៨:២១ លវ ២:២ ៣:៥,១៦ ១៧:៦ ជន ១៨:១៧ ២៨១១–១៣ អភ ៥:២ **១:១០** វ លប ២២:៧ ស ខ.៣ នក ១២:៥ លវ ៣:១២ ៤:២៣, ២៨ ៥:៦ ជន ១៥:១១ **១:១១** ហ នក ២៩:១១ ឡ នក ២៩:២០ **១:១២** អ ខ.៨ **១:១៣** ក នក ២៩:១៧ ខ ខ.៩ គ លវ ៦:២២ ឃ ចទ ១២:២៧

**១:១៤** ង លប ១៥:៩ លក ២:២៤ **១:១៥** ច លវ ៥:៨ ឆ លប ៥:៩ **១:១៦** ជ លវ ៤:១២ ៦:១០ ជន ៤:១៣ **១:១៧** ឈ លប ១៥:១០ ញ ខ.៧ **២:១** ក នក ២៩:៤១ លវ ៦:១៤–១៨ ខ នក ២៩:២,៤០ លវ ៥:១១ គ ជន១៥:៤ ២៨:៥ ឃ នក២៩:២ លវ ៧:១២ ង ខ.២,១៥,១៦ លវ ២៤:៧ នហ ១៣:៩ អស ៤៣:២៣ **២:២** ច លវ ៥:១១ ឆ លវ ៦:១៥ អស ១:១៣ ៦៥:៣ ៦៦:៣ ជ ខ.៩,១៦ លវ ៥:១២ ៦:១៥ ២៤:៧ ជន ៥:២៦ ១៨:៨ ទដ ១៦:៥ ៧៣:២៦ អស ៥៣:១២ ឈ ខ.១៦ ញ លវ ១:៩ **២:៣** ដ ខ.១០ លវ ៦:១៦ ១០:១២,១៣ ឋ នក ៣០:៣៦

ប្រាប់ជាមុនថាព្រះគ្រីស្ទបានថ្វាយអង្គទ្រង់ទុកជាដង្វាយក្រអូប ហើយជាយញ្ញបូជា សម្រាប់ជាក្លិនឈ្ងុយថ្វាយដល់ព្រះ (អភ ៥:២ ធៀបនឹង ភល ៤:១៨) ។

**១:១៤** *សត្វស្លាប* សត្វស្លាបបីប្រភេទនៃយញ្ញបូជាបានលើកឡើងដូចជា ហ្វូងសត្វ (ខ.៣–៩) ហ្វូងចៀម (ខ.១០–១៣) និងសត្វស្លាប (ខ.១៤–១៧) ។ ការបូជាសត្វស្លាបត្រូវបានផ្តល់ដោយពួកអ្នកក្រ (សូមមើល ៥:៧ ១២:៨ លក ២:២៤) ។

**១:១៧** *មិនត្រូវផ្តាច់ចំហៀងចេញពីគ្នា* មើលការពន្យល់ នក ១៥:១០ ។

**២:១** *ដង្វាយម្សៅ* មើលការបញ្ជារបស់ពួកសង្ឃក្នុង ៦:១៤ ៧:៩–១០ ។ ម្សៅនេះធ្វើអំពីគ្រាប់ធញ្ញជាតិ ឬម្សៅម៉ដ្ឋ ។ ប្រសិនបើម្សៅនេះ ត្រូវបានគេយកដុត នោះវាក្លាយទៅជានំបាវាំង ឬនំបន្ទះតូចៗ ដាក់នៅក្នុងចាន ឬឡ និងខ្ទះសំប៉ែត ។ នៅត្រង់នេះវាគ្រាន់តែជាដង្វាយគ្មានឈាម ប៉ុន្តែ ត្រូវអនុលោមទៅតាមដង្វាយដុត (មើលការពន្យល់ ៩:៤ ជន ២៨:៣–៦) ដង្វាយលោះបាប (ជន ៦:១៤–១៥) ហើយនិងដង្វាយមេត្រី (មើល ៩:១៤ ជន ៦:១៧) ។ ចំពោះដង្វាយម្សៅត្រូវថ្វាយទៅជាមួយនឹង គោចៀមឈ្មោល និងកូនចៀមដែរ (ជន ២៨:១២–១៣) ។ ម្សៅមួយក្តាប់ត្រូវបានគេដុត នៅលើអាសនាជាមួយនឹងដង្វាយទាំងអស់នោះ ហើយរបស់ទាំងអស់នោះត្រូវមានចំណែកស្មើៗគ្នាដែលត្រូវដុតដោយគ្មានដំបែ ហើយពួកសង្ឃជាអ្នកទទួលទាន (៦:១៤–១៧) ។ រីឯម្សៅដែលបានដុតនៅលើអាសនានោះវិញ ត្រូវផ្សំជាមួយនឹងប្រេងអូលីវ កំញាន ខ្លាញ់ ជាមួយនឹងគ្រឿងក្រអូប ប៉ុន្តែទាំងអស់នេះមិនត្រូវមានដំបែ ឬទឹកឃ្មុំ ដោយព្រោះរបស់ទាំងពីរនេះ ត្រូវបានគេអនុញ្ញាតដាក់លើអាសនា (ខ.១១–១៣) តែប៉ុណ្ណោះ ។ ពួកអ្នកថ្វាយបង្គំ គឺមិនបរិភោគនំដែលពួកគេនាំយកមកនោះទេ ហើយពួកសង្ឃក៏មិនបរិភោគនំនោះដែរ គឺនំទាំងនោះត្រូវបានគេយកទៅដុតទាំងអស់ (៦:២២–២៣) ។ ព្រះគម្ពីរភាសាហេព្រើរ ពាក្យថាដង្វាយម្សៅមានន័យថា អំណោយ ហើយជានិច្ចកាលមាននៅក្នុង (នក ៤៣:១១) ។ អំណោយដ៏ប្រសើរបញ្ជាក់ពីការលះបង់ដ៏ខ្ពង់ខ្ពស់ របស់យើងចំពោះព្រះ ។ *ម្សៅយ៉ាងម៉ដ្ឋ* ម្សៅនេះគេលាយគ្រប់សារធាតុ ។ *ប្រេង* ប្រេងអូលីវ ជានិច្ចកាលត្រូវបានគេលើកឡើងនៅក្នុងការភ្ជាប់ទំនាក់ទំនងជាមួយនឹងដង្វាយម្សៅស្រាថ្មី ថាជាផលិតផលស្រស់ៗនៃរដូវចម្រូត (ចទ ៧:១៣) ។ ប្រេងនេះត្រូវបានគេយកមកប្រើយ៉ាងច្រើន ក្នុងការចំអិនម្ហូបអាហារ ហើយវាក៏ជាផ្នែកដ៏សក្តិសមមួយនៃអំណោយក្នុងការថ្វាយដង្វាយដល់ព្រះ ។ *គ្រឿងក្រអូប* នៅត្រង់នេះបញ្ជាក់ថា ជ័រកំញាន ជាមេនៃគ្រឿងផ្សំ (សូមមើល នក ៣០:៣៤–៣៥) ។

**២:២,៩,១៦** *ទុកជាទីរំឭក* (១).ដើម្បីរំឭកដល់ពួកអ្នកថ្វាយបង្គំថាគ្រប់របស់ល្អៗគឺមកអំពីព្រះ (ធៀប យក ១:១៧) ។ (២).ដើម្បីឱ្យព្រះអម្ចាស់ទ្រង់បានចងចាំនូវអ្វីដែលពួកគេបានទូលសូម ហើយប្រទានពរដល់អ្នកថ្វាយដង្វាយដែលស្មោះត្រង់ (ធៀប នក ៩:១៣–១៦) ។ សរុបមកទាំងពីរចំណុចខាងលើ គឺមានជាប់ទាក់ទងទៅនឹង ការពន្យល់ ៥:១២ ៦:១៥ ២៤:៧ ។

**២:៣** *បរិសុទ្ធបំផុត* សម្រាប់ហេតុផលនេះ ពួកសង្ឃបានបរិភោគដង្វាយម្សៅដែលពួកគេយកមកថ្វាយ នៅទីបរិសុទ្ធ ហើយមិនបានចម្អែតពួកគេដោយម្ហូបទាំងនោះទេ (៦:១៦–១៨ ខ.១០) ។ *បរិសុទ្ធ* សូមមើល នក ២៩:៣៧ និងការពន្យល់ ។

៤ហើយបើថ្វាយដង្វាយម្សៅ ដែលចំអិននៅក្នុងឡនោះ[ឪ]
ត្រូវថ្វាយជានំឥតដំបែ ធ្វើពីម្សៅយ៉ាងម៉ដ្ត លាយនឹងប្រេង
ឬជានំក្រៀប[ឭ]ឥតដំបែលាបដោយប្រេងក៏បាន[ឮ]។
៥ឬបើថ្វាយដង្វាយម្សៅដែលបានចំអិនក្នុងពុម្ព[ត] នោះ
ត្រូវឱ្យធ្វើពីម្សៅយ៉ាងម៉ដ្តឥតដំបែលាយដោយប្រេង ៦ត្រូវ
បេះនំនោះជាដុំៗ ហើយចាក់ប្រេងពីលើ នេះហើយជា
ដង្វាយម្សៅ ។
៧បើថ្វាយដង្វាយម្សៅដែលចៀននឹងខ្ទះ[ថ] នោះត្រូវឱ្យ
ធ្វើពីម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង ៨ឯដង្វាយម្សៅដែល
បានធ្វើបែបយ៉ាងនេះ នោះត្រូវនាំយកទៅឯព្រះយេហូវ៉ា
ត្រូវប្រគល់ដល់សង្ឃម្នាក់ ហើយត្រូវឱ្យសង្ឃនោះយកទៅឯ
អាសនា ៩រួចត្រូវយក១ចំណែកនៃដង្វាយម្សៅនោះទុកជាទី
រំឭក[ទ] ទៅដុតលើអាសនា គឺជាដង្វាយដុតសំរាប់ជាក្លិន
ឈ្ងុយដល់ព្រះយេហូវ៉ា[ធ] ១០ឯចំណែកដង្វាយម្សៅដែលសល់
នៅ នោះនឹងបានជារបស់សំរាប់អើរ៉ុន និងពួកកូនលោក
វិញ[ន] ជារបស់បរិសុទ្ធបំផុត ក្នុងអស់ទាំងដង្វាយ ដែលដុត
ថ្វាយព្រះយេហូវ៉ា[ប]។
១១រីឯដង្វាយម្សៅណាដែលឯងរាល់គ្នានឹងថ្វាយដល់
ព្រះយេហូវ៉ា នោះមិនត្រូវឱ្យលាយដោយដំបែឡើយ[ផ] ដ្បិត
មិនត្រូវដុតដំបែ ឬទឹកឃ្មុំ ទុកជាដង្វាយដុតថ្វាយដល់ព្រះ
យេហូវ៉ាទេ ១២របស់ទាំង២នោះ ត្រូវថ្វាយដល់ព្រះយេហូវ៉ា
ទុកជាផលដំបូងវិញ[ព] តែមិនត្រូវដុតនៅលើអាសនា សំរាប់
ជាក្លិនឈ្ងុយឡើយ ១៣ហើយអស់ទាំងដង្វាយម្សៅដែលឯង
ថ្វាយ នោះត្រូវបង់អំបិលផង[ភ] ក៏មិនត្រូវឱ្យខាន នឹងដាក់
អំបិលនៃសេចក្ដីសញ្ញា[ម]របស់ព្រះនៃឯង ក្នុងដង្វាយម្សៅ
ឡើយ ត្រូវតែបង់អំបិលចុះក្នុងគ្រប់ទាំងដង្វាយរបស់ឯង ។

**២:៤** ឪ លវ ៧:៩ ២៦:២៦ ឭ លវ ៧:១២ ៨:២៦ ឮ នក ២៩:២ **២:៥** ត លវ ៦:២១ ៧:៩ អគ ៤:៣ **២:៧** ថ លវ ៧:៩ **២:៩** ទ ខ.២ ធ លប ៨:២១ **២:១០** ន ខ.៣ ប អគ ២:៦៣ **២:១១** ផ នក ២៣:១៨ លវ ៦:១៦ **២:១២** ព នក ៣៤:២២ **២:១៣** ភ មក ៩:៤៩ ម ជន ១៨:១៩ ២រប ១៣:៥ អគ ៤៣:២៤ **២:១៤** យ នក ៣៤:២២ ជន ១៥:២០ ចទ ១៦:១៣ ២៦:២ នរ ៣:២ **២:១៥** រ ខ.១ **២:១៦** ល ខ.២ វ ខ.១ ស ជន ៤:១៦ យរ ១៤:១២ **៣:១** ក ខ.៦ នក ៣២:៦ លវ ៧:១១–៣៤ ១៧:៥ ខ នក ១២:៥ **៣:២** គ នក ២៩:១៥ ជន ៨:១០ ឃ លប ១:៥ ង នក ៤០:២ ច នក ២៤:៦ ឆ នក

១៤ហើយបើយកផលដំបូង[យ] មកថ្វាយជាដង្វាយម្សៅដល់
ព្រះយេហូវ៉ា នោះត្រូវថ្វាយគួរស្រូវថ្មីដែលលីង ហើយបុក
ទុកជាដង្វាយផលដំបូង ១៥ត្រូវចាក់ប្រេង ហើយដាក់
កំញាន[រ]ពីលើ នេះហើយដង្វាយម្សៅ ១៦សង្ឃម្នាក់នឹងយក[ល]
ស្រូវបុក១ចំណែកនឹងប្រេងខ្លះ ហើយនិងកំញានទាំងអស់ពី
ដង្វាយនោះ[វ] ដុតថ្វាយទុកជាទីរំឭក នេះជាដង្វាយដុតថ្វាយ
ព្រះយេហូវ៉ា[ស]។

## ដង្វាយមេត្រី

**៣** ១បើសិនជាដង្វាយរបស់អ្នកនោះជាយញ្ញបូជា ដែល
សំរាប់ជាដង្វាយមេត្រី[ក] បើគេថ្វាយគោ ទោះឈ្មោលប
ញីក្ដី នោះត្រូវឱ្យថ្វាយសត្វ១ដែលឥតខ្ចោះ នៅចំពោះព្រះ
យេហូវ៉ា[ខ] ២ត្រូវឱ្យដាក់ដៃលើក្បាលនៃសត្វនោះ[គ] រួច
សំឡាប់[ឃ] នៅមាត់ទ្វារត្រសាលជំនុំ[ង] ហើយត្រូវឱ្យពួកកូន
អើរ៉ុនដ៏ជាសង្ឃប្រោះ[ច] ឈាមនៅជុំវិញ[ឆ]លើអាសនា[ជ]
៣ហើយត្រូវយក ១ចំណែកអំពីយញ្ញបូជា ដែលសំរាប់ជា
ដង្វាយមេត្រីនោះ ទៅដុតថ្វាយព្រះយេហូវ៉ា គឺខ្លាញ់[ឈ]ដែល
រុំអាការៈខាងក្នុង[ញ] និងខ្លាញ់ទាំងអស់ដែលនៅជាប់ខាង
ក្នុង ៤ព្រមទាំងអង្គញ់ទាំង២[ដ] និងខ្លាញ់ដែលនៅជាប់និង
អង្គញ់នោះខាងចង្កេះ ហើយស្រទាប់នៅលើថ្លើមដែល
ត្រូវយកចេញជាមួយនឹងអង្គញ់ផង ៥រួចពួកកូនអើរ៉ុន[ឋ] នឹង
ដុតរបស់ទាំងនោះនៅលើដង្វាយដុត[ឌ] ដែលកំពុងតែឆេះ
លើឧស[ឍ]នៅលើអាសនា[ណ] គឺជាដង្វាយដុតសំរាប់ជាក្លិន
ឈ្ងុយដល់ព្រះយេហូវ៉ា[ត]។

២៩:២០ ជ លវ ១៧:៦ ជន ១៨:១៧ **៣:៣** ឈ នក ២៩:១៣ ញ នក ១២:៩ **៣:៤** ដ ខ.១០ នក ២៩:១៣ លវ ៤:៩ **៣:៥** ឋ លវ ៧:២៩–៣៤ ឌ នក ២៩:១៣,៣៨–៤២ ជន ២៨:៣–១០ ឍ លវ ១:៧ ណ ខ.១១,១៦ ត លវ ១:៩

**២:៤** *ឥតដំបែ* មើលការពន្យល់ នក ១២:៨,១៥ ។

**២:៥** *ពុម្ព* នេះគឺជាឆ្នាំងដីដាក់លើជើងចង្ក្រាន ហើយដុតដោយភ្លើងតែក្រោយមកជាឆ្នាំងដែកវិញ ។

**២:១១** *ទឹកឃ្មុំ* ចំពោះទឹកឃ្មុំត្រូវបានហាមជាដាច់ខាតនៅលើអាសនា ពីព្រោះទឹកឃ្មុំត្រូវបានគេប្រើដើម្បីធ្វើស្រា តែទោះជាយ៉ាងនេះក្ដីក៏មានការលើកឡើងខ្លះថាទឹកឃ្មុំនេះត្រូវបានប្រើក្នុងលទ្ធិសាសនា កាណានដែរ ។

**២:១២** *ផលដំបូង* មើលការពន្យល់ ២៣:១០–១១ នក ២៣:១៦,១៩ ជន ១៥:១៨–២០ ២៦:១–១១ ។

**២:១៣** *អំបិលនៃសេចក្ដីសញ្ញា* មើលការពន្យល់ ជន ១៨:១៩ ។

**៣:១** *ដង្វាយមេត្រី* មើលបទបញ្ញារបស់ពួកសង្ឃបន្ថែមទៀត ៧:១១–២១, ២៨–៣៤ ។ គំនិតមូលដ្ឋានពីរយ៉ាងត្រូវបានរួមបញ្ចូលនៅក្នុងដង្វាយនោះគឺសន្តិភាព និងមេត្រីភាព ។ តាមទម្លាប់នៃការបកប្រែ ពាក្យនេះមានន័យថាដង្វាយសន្តិភាព ហើយឈ្មោះនេះមកពីព្រះគម្ពីរភាសាហេព្រើរថា សាឡូម (shalom) មានន័យថា សន្តិភាព ឬ ទាំងមូល ។ ដង្វាយសន្តិភាព ជាដង្វាយតែមួយគត់ដែលអ្នកថ្វាយបរិភោគមួយផ្នែក ។ ផ្នែកសំខាន់នៃការ បូជាគឺត្រូវមានអំណរជាមួយព្រះ និងពួកសង្ឃ ហើយពួកសង្ឃត្រូវបរិភោគដង្វាយនេះមួយផ្នែក (៧:១៤–១៥ ៣១–៣៤) ។ ការថ្វាយដង្វាយនេះមានភាពដូចគ្នាទៅនឹងពិធីបុណ្យបីរបស់ពួកអ៊ីស្រាអែលផ្សេងៗទៀតដែរ (នក ២៣:១៤–១៧ ជន ២៩:៣៩) ។ ពីព្រោះ មនុស្សភាគច្រើនបានមកឯវិហារ ដើម្បីចែកម្ហូបអាហាររួមគ្នា ។ នៅអ៊ីឡុង របបរាជានិយមសត្វពាហនៈត្រូវបានថ្វាយដោយមនុស្សនិងបន្ថែមចំនួនដោយស្តេច ។ ព្រះវិហារចំនួន ២,០០០ និងចៀម ១២០,០០០ ត្រូវបានផ្ដល់ដោយស្ដេចសាឡូម៉ូនជាដង្វាយមេត្រី ក្នុងរយៈពេល ១៤ ថ្ងៃ (១ពវ ៨:៦៣–៦៥) ។

**៣:២** *ត្រូវឱ្យដាក់ដៃលើក្បាលនៃសត្វនោះ* មើលការពន្យល់ ១:៣ នក ២៩:១០ ។

**៣:៥** *ដុតរបស់ទាំងនោះនៅលើដង្វាយដុត* ដង្វាយដុតនេះត្រូវបានគេដុតជា

៦បើសិនជាដង្វាយ ដែលអ្នកនោះថ្វាយដល់ព្រះយេហូវ៉ា
សិរាប់ជាយញ្ញបូជាខាងឯដង្វាយមេត្រី[ថ] បានយកពីហ្វូង
សត្វតូចវិញ ទោះឈ្មោលឬញីក្តី នោះត្រូវឱ្យថ្វាយសត្វ
១ដែលឥតខ្ចោះ ៧បើគេថ្វាយកូនចៀម[ទ] នោះត្រូវឱ្យយក
មកថ្វាយនៅចំពោះព្រះយេហូវ៉ា[ធ] ៨ត្រូវឱ្យដាក់ដៃលើក្បាល
សត្វនោះ រួចសំឡាប់[ន]នៅមុខត្រសាលជំនុំ ហើយត្រូវឱ្យពួក
កូនអើរ៉ុនប្រោះឈាមនៅជុំវិញលើអាសនា ៩ក៏ត្រូវយក១
ចំណែក អំពីយញ្ញបូជា ដែលសិរាប់ជាដង្វាយមេត្រីនោះ[ប]
ទៅដុតថ្វាយដល់ព្រះយេហូវ៉ា គឺខ្លាញ់ និងកន្ទុយទាំងមូល
ដែលត្រូវកាត់ចេញត្រឹមឆ្អឹងខ្នង និងខ្លាញ់រុំអាការៈខាងក្នុង
ហើយខ្លាញ់ទាំងអស់ដែលនៅជាប់ខាងក្នុង ១០ព្រមទាំង
អង្គញ់ទាំង២ និងខ្លាញ់ដែលនៅជាប់នឹងអង្គញ់នោះខាង
ចង្កេះ ហើយស្រទាប់នៅលើថ្លើម ដែលត្រូវយកចេញជា
មួយនឹងអង្គញ់ផង ១១រួចត្រូវឱ្យសង្ឃដុតរបស់ទាំងនោះ
នៅលើអាសនា[ផ] នេះហើយជាព្រះស្ងោយ[ព]នៃដង្វាយ ដែល
ដុតថ្វាយព្រះយេហូវ៉ា[ភ] ។
១២បើគេថ្វាយពពែ[ម] នោះត្រូវយកមកថ្វាយនៅចំពោះ
ព្រះយេហូវ៉ា ១៣ត្រូវដាក់ដៃលើក្បាល រួចសំឡាប់នៅមុខ
ត្រសាលជំនុំ ហើយពួកកូនអើរ៉ុនត្រូវប្រោះ[យ]ឈាមនៅ
ជុំវិញ[រ]លើអាសនា ១៤ក៏ត្រូវយក១ចំណែកពីដង្វាយនោះ
ថ្វាយជាដង្វាយដុតដល់ព្រះយេហូវ៉ា គឺខ្លាញ់ដែលរុំអាការៈ
ខាងក្នុងនិងខ្លាញ់ទាំងអស់ដែលនៅជាប់ខាងក្នុង ១៥ព្រម
ទាំងអង្គញ់ទាំង២ ហើយខ្លាញ់ដែលនៅជាប់នឹងអង្គញ់នោះ
ខាងចង្កេះ និងស្រទាប់នៅលើថ្លើម ដែលត្រូវយកចេញជា
មួយនឹងអង្គញ់ផង[ល] ១៦រួចត្រូវឱ្យសង្ឃដុតរបស់ទាំងនោះ
នៅលើអាសនា[វ] នេះហើយជាព្រះស្ងោយ[ស]នៃដង្វាយដែល
ដុតថ្វាយសិរាប់ជាក្លិនឈ្ងុយ[ហ] ដ្បិតខ្លាញ់[ឡ]ទាំងនោះជារបស់
ផងព្រះយេហូវ៉ា[អ] ១៧នេះជាច្បាប់នៅអស់កល្បជានិច្ច[ក] ដល់
អស់ទាំងដំណឯងរាល់គ្នាតទៅ[ខ] នៅគ្រប់ទីកន្លែងណា
ដែលឯងរាល់គ្នាតាំងទីលំនៅ[គ] គឺថា មិនត្រូវឱ្យឯងរាល់គ្នា
បរិភោគខ្លាញ់ឬឈាមឡើយ[ឃ] ។

## ដង្វាយលោះបាប

**៤** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា បើអ្នកណាធ្វើបាបឥតដឹង[ក] ដោយពាន
លើបទណាមួយ ដែលព្រះយេហូវ៉ាទ្រង់ហាមមិនឱ្យធ្វើ
ឡើយ ហើយប្រព្រឹត្តខុសត្រង់បទនោះឯង[ខ] ៣បើអ្នកនោះជា
ពួកសង្ឃ[គ]ដែលគេចាក់ប្រេងតាំងឱ្យស្រេចហើយ បានធ្វើ
បាប[ឃ]ជាហេតុនាំឱ្យពួកជនមានទោសផង នោះត្រូវយកគោ
ឈ្មោលស្ទាវ១[ង]ដ៏ឥតខ្ចោះ[ច] មកថ្វាយដល់ព្រះយេហូវ៉ា ទុក
ជាដង្វាយ[ឆ]លោះបាប ឱ្យធួននឹងបាបដែលបានធ្វើនោះ[ជ]
៤ត្រូវនាំគោនោះទៅឯមាត់ទ្វារត្រសាលជំនុំនៅចំពោះ

**៣:៦** ថ ខ.១ លវ ២២:២១ ជន ១៥:៣,៨ **៣:៧** ទ លវ ១៧:៣ ជន ១៥:៥ ២៨:៥,៧,៨ ធ លវ ១៧:៨–៩ ១ពវ ៨:៦២ **៣:៨** ន លវ ១:៥ **៣:៩** ប អស ៣៤:៦ យរ ៤៦:១០ អគ ៣៩:១៩ សផ ១:៧ **៣:១១** ផ ខ.៥ ព ខ.១៦ លវ ២១:៦,១៧ ជន ២៨:២ ភ លវ ៩:១៨ **៣:១២** ម លវ ១:១០ ៤:៣ **៣:១៣** យ នក ២៤:៦ រ លវ ១:៥ **៣:១៥** ល លវ ៧:៤ **៣:១៦** វ ខ.៥ លវ ៧:៣១ ស ខ.១១ ហ លវ ១:៩ ឡ លប ៤:៤ អ ១សយ ២:១៦ **៣:១៧** ក នក ១២:១៤ ២៧:២១ ខ លប ៩:១២ គ នក ១២:២០ ឃ លប ៩:៤ ១៧:១០–១៦ ចទ ១២:១៦ កច ១៥:២០ **៤:២** ក ខ.១៣,២៧ លវ ៥:១៥–១៨ ២២:១៤ ជន ១៥:២៤–២៩ ៣៥:១១–១៥ យស ២០:៣,៩ ហព ៩:៧ ខ ខ.២២ ជន ១៥:២២**៤:៣** គ នក ២៨:៤១ ឃ លប ១៨:២៣ ង ខ.១៤ លវ ៣:១២ ៨:១៤ ១០:១៦ ១៦:៣,៥ ជន ១៥:២៧ ទដ ៦៦:១៥ អគ ៤៣:១៩,២៣ ច នក ១២:៥ ឆ ខ.២៤ នក ៣០:១០ លវ ៥:៦–១៣ ៩:២–២២ ហព ៩:១៣–១៤ ជ ខ.៣២

---

រៀងរាល់ព្រឹក និងល្ងាច ។

**៣:៩** *ខ្លាញ់ និងកន្ទុយ* កូនចៀមនេះនៅតែមានប្រើនៅក្នុងមជ្ឈឹមបូព៌ា ដែលមានកន្ទុយ និងខ្លាញ់ ។

**៣:១១,១៦** *នៅលើអាសនា នេះហើយជាព្រះស្ងោយនៃដង្វាយ* ដង្វាយពួកអ៊ីស្រាអែលគឺមិនមែនព្រះស្ងោយសម្រាប់ព្រះ (មើល អគ ១៦:២០ ធៀប ទដ ៥០:៩–១៣) ។ ប៉ុន្តែ ម្ហូបទាំងអស់នោះជួនកាលត្រូវបានគេហៅថា ព្រះស្ងោយ ដោយធៀបនឹង ២១:៦,៨,១៧,២១ ២២:២៥ ក្នុងន័យថារបស់ទាំងអស់នោះជាដង្វាយ សម្រាប់ព្រះដែលទ្រង់សព្វព្រះទ័យយ៉ាងខ្លាំង ។

**៣:១៦** *ទាំងអស់នោះជារបស់ផងព្រះយេហូវ៉ា* ដង្វាយទាំងអស់នោះតំណាងពីភាពប្រសើរ (មើល ៧:២៣ នក ៤:៣៤ និងការពន្យល់) ។

**៣:១៧** *មិនត្រូវឱ្យឯងរាល់គ្នាបរិភោគខ្លាញ់ ឬឈាមឡើយ* មើលការពន្យល់ ៧:១១ ។

**៤:២** *ធ្វើបាបឥតដឹង* មើលការពន្យល់ ៥:១៣ ផ្ទុយនឹង ជន ១៥:៣០–៣១ ។ មនុស្សបួនថ្នាក់ មានការជាប់ទាក់ទិនទៅនឹងការប្រព្រឹត្តបាប ដោយមិនដឹង (១).សង្ឃដែលបានចាក់ប្រេងតាំង (ខ.៣–១២) (២).ពួកជំនុំអ៊ីស្រាអែល (ខ.១៣–២១) (៣).អ្នកដឹកនាំ (ខ.២២–២៦) និង (៤).ពួកអ្នកស្រុក (ខ.២៧–៣៥) ហព ៩:៧ ។

**៤:៣** *ពួកសង្ឃដែលគេចាក់ប្រេងតាំង* ត្រង់នេះបញ្ជាក់ពីពួកសម្តេចសង្ឃ (មើល ៦:២០,២២) ។ *បាប* ត្រង់នេះប្រាប់ថាពួកសង្ឃទាំងអស់មានបាប លើកលែងតែព្រះយេស៊ូវគ្រីស្ទមួយទេដែលគ្មានបាប (ហព ៥:១–៣ ៧:២៦–២៨) ។ *ពួកជន* នេះជាទំនាក់ទំនងរវាងពួកសង្ឃ និងបណ្តាជន ហើយទំនាក់ទំនងនោះបានចាក់ឫសយ៉ាងជ្រៅនៅក្នុងពួកអ៊ីស្រាអែល (រាស្ត្ររបស់ព្រះ) ដែលថាពួកបណ្តាជនទាំងអស់នោះត្រឡប់ទៅជាមិនបរិសុទ្ធចំពោះព្រះ ដោយព្រោះបាបរបស់ពួកសង្ឃ ។ *ត្រូវយក* ទោះជាដង្វាយដុត ដង្វាយគ្រាប់ពូជ និងដង្វាយមេត្រី (១–៣) ជាដង្វាយស្ម័គ្រពីចិត្តក៏ដោយ ក៏ការថ្វាយដង្វាយលោះបាបមិនអាចអត់បានដែរ (ខ.១៤,២៣,២៨) ។ *ដ៏ឥតខ្ចោះ* យញ្ញបូជាមិនគ្រប់ល័ក្ខណ៍ មិនអាចជំនួសឱ្យភាពមិនគ្រប់ល័ក្ខណ៍របស់មនុស្សបានទេ ។ ទីបំផុតនៃយញ្ញបូជាដែលគ្រប់លក្ខណ៍នោះសម្រាប់លោះបាបរបស់រាស្ត្ររបស់ព្រះនោះគឺ ការសុគតលើឈើឆ្កាងរបស់ព្រះគ្រីស្ទដែលទ្រង់បានថ្វាយព្រះអង្គទ្រង់ ដោយឥតសៅហ្មង (ហព ៩:១៣–១៤ ១ពត ១:១៩) ។ *ដង្វាយលោះបាប* មើលការបង្គាប់បញ្ជារបស់ពួកសង្ឃ ៦:២៤–៣០ ជន ១៥:២២–២៩ ។

**៤:៤** គោលការណ៍៣យ៉ាងក្នុងការថ្វាយដង្វាយឱ្យបានធួននឹងបាប នោះគឺត្រូវបានគេរកឃើញនៅក្នុងខនេះថា (១).ការជំនួស (សត្វគោ) (២).ការ

ព្រះយេហូវ៉ា[ឈ] រួចដាក់ដៃលើក្បាលហើយសំឡាប់នៅ
ចំពោះព្រះយេហូវ៉ាទៅ ៥ត្រូវឱ្យសង្ឃយកឈាម[ញ]នាំចូល
ទៅក្នុងត្រសាលជំនុំ ៦រួចជ្រលក់ម្រាមដៃចុះក្នុងឈាម
រលាស់[ដ]៧ដងនៅចំពោះព្រះយេហូវ៉ា[ឋ] ត្រង់ខាងមុខវាំង
ននទីបរិសុទ្ធ[ឌ] ៧ហើយត្រូវយកឈាមទៅប្រឡាក់នៅស្នែង[ឍ]
អាសនាគ្រឿងក្រអូប ដែលនៅក្នុងត្រសាលជំនុំនៅចំពោះ
ព្រះយេហូវ៉ា រួចត្រូវចាក់ឈាមគោនោះទាំងអស់នាជើង
អាសនា[ណ]ដង្វាយដុត[ត] ដែលនៅមាត់ទ្វារត្រសាលជំនុំ
៨ឯខ្លាញ់គោនោះ ដែលសំរាប់ជាដង្វាយលោះបាប នោះ
ត្រូវយកចេញទាំងអស់ គឺជាខ្លាញ់[ថ] ដែលរុំអាការៈខាងក្នុង
និងខ្លាញ់ទាំងអស់ដែលនៅជាប់ខាងក្នុង ៩ព្រមទាំងអង្គញ់
ទាំង២ និងខ្លាញ់ដែលនៅជាប់នឹងអង្គញ់នោះនៅខាង
ចង្កេះ ហើយស្រទាប់នៅលើថ្លើម ដែលត្រូវយកចេញជា
មួយនឹងអង្គញ់ផង[ទ] ១០ដូចជាបានយកចេញពីគោ[ធ] ដែល
ថ្វាយជាដង្វាយមេត្រី[ន]ដែរ រួចត្រូវឱ្យសង្ឃដុតរបស់ទាំង
នោះ នៅលើអាសនាដង្វាយដុត[ប] ១១ឯស្បែកគោនោះ
និងសាច់ទាំងអស់ ព្រមទាំងក្បាលនិងជើង អាការៈខាងក្នុង
ហើយនិងលាមក[ផ] ១២គឺតួគោនោះទាំងមូល ត្រូវយកចេញ
ទៅក្រៅទីដំឡើងត្រសាល[ព]នៅត្រង់កន្លែងស្អាត[ភ] ដែលចាក់
ផេះ[ម] ហើយដុត[យ]នៅលើឧសត្រង់កន្លែងដែលចាក់ផេះ
នោះ[រ] ។
១៣ឬបើជាពួកជំនុំអ៊ីស្រាអែលទាំងអស់គ្នា ដែលប្រព្រឹត្ត
ការកំហុសអ្វីដោយឥតដឹង[ល] ហើយការនោះបានកំបាំង
នឹងភ្នែកពួកជំនុំ ដែលរំលងចំពោះបញ្ញត្តិណាមួយ ដែល
ព្រះយេហូវ៉ាហាមប្រាមមិនឱ្យធ្វើ ហើយមានទោស ដូច្នោះ
១៤កាលណាគេដឹងពីអំពើបាបដែលបានប្រព្រឹត្តរំលង
ហើយ នោះត្រូវឱ្យពួកជំនុំថ្វាយគោឈ្មោលស្ទាវ១[វ] ទុកជា
ដង្វាយលោះបាប[ស] ត្រូវនាំទៅឯមុខត្រសាលជំនុំ ១៥ហើយ
ត្រូវឱ្យពួកចាស់ទុំ[ហ]ក្នុងពួកជំនុំ ដាក់ដៃ[ឡ]លើក្បាលគោនោះ[អ]
នៅចំពោះព្រះយេហូវ៉ា រួចសំឡាប់នៅចំពោះព្រះ
យេហូវ៉ាទៅ[ក] ១៦នោះត្រូវឱ្យសង្ឃ ដែលគេចាក់ប្រេងតាំង
ឱ្យស្រេចហើយ យកឈាម[ខ]គោនោះទៅក្នុងត្រសាលជំនុំ
១៧ហើយជ្រលក់ម្រាមដៃចុះក្នុងឈាមរលាស់[គ]៧ដង នៅ
ចំពោះព្រះយេហូវ៉ា[ឃ] ត្រង់មុខវាំងនន ១៨រួចយកឈាម[ង]ទៅ

**៤:៤** ឈ ខ.១៥,២៤ លវ ១:៣ ជន ៨:១២ **៤:៥** ញ ខ.១៦ លវ ១៦:១៤ **៤:៦** ដ នក ២៤:៨ ឋ ខ.១៧ លវ ១៦:១៤,១៩ ឌ នក ២៥:៨ **៤:៧** ឍ នក ២៧:២ ណ ខ.៣៤ នក ២៩:១២ លវ ៨:១៥ ត ខ.១៨,៣០ លវ ៥:៩ ៩:៩ ១៦:១៨ **៤:៨** ថ ខ.១៩ **៤:៩** ទ លវ ៣:៤ **៤:១០** ធ លវ ៩:៤ ន នក ៣២:៦ ប នក ២៩:១៣ **៤:១១** ផ នក ២៩:១៤ លវ ៨:១៧ ៩:១១ ជន ១៩:៥ **៤:១២** ព នក ២៩:១៤ លវ ៨:១៧ ៩:១១ ហព ១៣:១១ ភ លវ ៦:១១ ១០:១៤ ជន ១៩:៩ ម លវ ១:១៦ យ លវ ៦:៣០ រ លវ ១៦:៣ **៤:១៣** ល ខ.២ **៤:១៤** វ ខ.៣ ស ជន ១៥:២៤ **៤:១៥** ហ នក ៣:១៦ ១៩:៧ ឡ ២រប ២៩:២៣ អ នក ២៩:១០ លវ ៨:១៤, ២២ ជន ៨:១០ ក ខ.៤ **៤:១៦** ខ ខ.៥ **៤:១៧** គ ជន ១៩:៤, ១៨ ឃ ខ.៦ **៤:១៨** ង លវ ៨:១៥ ១៧:៦ ២របា ២៩:២២

បង្ហាញពីអត្តសញ្ញាណ (ដាក់ដៃលើក្បាល) (៣).ការស្លាប់ដើម្បីជាជំនួស (ការសម្លាប់) ។

**៤:៥** *ឈាម* មើលការពន្យល់ ១៧:១១ ។ នៅត្រង់នេះមានពីរផ្នែក ក្នុងការថ្វាយដង្វាយ ។ ផ្នែកទី១ ចាប់ពីចំណុច ខ.៣–២១ និងចំណុចសំខាន់បន្ថែមទៀតដែលជាប់ទាក់ទិនទៅនឹងការប្រោះឈាម នៅក្នុងរោងឧបោសថនៅទីបរិសុទ្ធក្នុងវាំងនន ឬនៅក្នុងពិធីបុណ្យជំនុំមុតមាំផ្សេងៗ (១៦) ក្នុងការលាក់កំបាំងនូវអំពើបាបរបស់ខ្លួនផ្ទាល់ ។ ដង្វាយលោះបាបនេះមិនតម្រូវឱ្យបរិភោគឡើយ ។ ខ្លាញ់ ក្រលៀន និងសួត ត្រូវបានគេដុតនៅលើអាសនា ប៉ុន្តែ ទីបញ្ចប់ត្រូវយកទៅក្រៅទីដំឡើងត្រសាលវិញ (ខ.១២) ។ ហព ១៣:១១–១៣ បានបញ្ជាក់ពីភាពដូចគ្នានេះយ៉ាងច្បាស់ថាទ្រង់បានរងទុក្ខនៅក្រៅរបងទីក្រុង ដើម្បីលោះបាបមនុស្ស ។ ការទាំងអស់នេះព្រះយេស៊ូវទ្រង់ធ្វើដើម្បីពួកសង្ឃ ពួកចាស់ទុំ និងពួកមនុស្សទាំងអស់ ។ ជាទូទៅសត្វពាហនៈ ត្រូវបានគេយកមកធ្វើជាយញ្ញបូជា ដូចជាសត្វគោជាដើម ប៉ុន្តែដង្វាយលោះបាបនៅថ្ងៃបុណ្យជំនុំមុតមាំ គឺជាសត្វពពែវិញ (១៦:៩) ។ ផ្នែកទី២ នៃដង្វាយលោះបាប (៤:២២–៥:១៣) នៅត្រង់វគ្គនេះគឺសម្រាប់តែពួកចាស់ទុំនិងបុគ្គលផ្ទាល់ៗតែប៉ុណ្ណោះ ។ ផ្នែកខ្លះនៃឈាមបានស្រោចទៅលើអាសនា ហើយផ្នែកដែលនៅសល់ហូរចូលមកខាងជើងអាសនា ។ ខ្លាញ់ត្រូវបានគេដុតនៅលើអាសនា ប៉ុន្តែនៅទីបញ្ចប់នៃការថ្វាយត្រូវបានគេផ្តល់ទៅឱ្យពួកសង្ឃ និងពួកស្ត្រី ដែលជាសាច់ញាតិ ដើម្បីបរិភោគនៅទីបរិសុទ្ធ (៦:២៩–៣០ និង ១០:១៦–២០) ។ ដង្វាយលោះបាបបាននាំយកមកថ្វាយដោយបុគ្គលផ្ទាល់ៗ ដូចជាពពែញី និងចៀម ។ ប្រសិនបើពួកគេជាអ្នកក្រ គឺពួកគេថ្វាយសត្វលលក និងព្រាប (សូមមើល ៥:៧–៨ ១២:៦,៨ ធៀបនឹង លក ២:២៤) ឬម្សៅ ពីរឌិក (៥:១១) ។ ការថ្វាយបានរួមបញ្ចូលទាំងការលន់តួបាប (៥:៥) និងជានិមិត្តរូបនៃការផ្ទេរបាបដោយលាបាតដៃ (សូមមើល ខ.២៩ ១៦:២១) ។ ដោយការផ្ទេរអស់ទាំងអំពើបាបនោះពួកអ៊ីស្រាអែលដែលស្មោះត្រង់ និងបានជាមេត្រីជាមួយនឹងព្រះអម្ចាស់ ។

**៤:៦** *ម្រាមដៃ* ត្រង់នេះបញ្ជាក់ថាជាម្រាមដៃស្តាំ (មើលការពន្យល់ ១៤:១៦) ។ *៧ដង* ចំនួននេះគឺតំណាងឱ្យ ភាពឥតខ្ចោះ និងភាពពេញលេញ (មើលការពន្យល់ នក ៥:៥) ។ *វាំងនន* វាំងននដ៏ធំនេះបានចែក ទីបរិសុទ្ធ និងទីដែលបរិសុទ្ធបំផុតផ្សេងពីគ្នា (នក ២៦:៣៣) ។

**៤:៧,៣០** *ស្នែង* ស្នែងទាំងបួនរបស់អាសនា (មើល នក ៣០:១–៣) គឺជានិមិត្តរូប នៃការប្រោសលោះបាប (នក ៣០:១០) ។

**៤:៨–១០** មើលការពន្យល់ ៣:៣–៥ ។

**៤:១២** *ក្រៅទីដំឡើងត្រសាល* មើលការពន្យល់ ១៣:៤៥–៤៦ ។ មើល ហព ១៣:១១ លវ ៩:១១ ១៦:២៦–២៨ ជន ១៩:៣ អគ ៤៣:២១ ដែលនិយាយអំពីកាលដែលព្រះយេស៊ូវត្រូវគេឆ្កាងនៅក្រៅក្រុងយេរូសាឡិម ។ *ត្រង់កន្លែងស្អាត* នេះជាបញ្ហាស្អាតនិងមិនស្អាតដែលជាទម្លាប់ ឬភាពស្អាតនៅក្នុងសាសនាដែលមិនមែនជាការព្រួយបារម្ភនៃភាពស្អាតរបស់រូបកាយឡើយ (មើលជំពូក ១១–១៥ និងការពន្យល់ មក ៧:១–៤ ) ។

**៤:១៥** *ពួកចាស់ទុំ* មើលការពន្យល់ នក ១:១៦ ។

**៤:១៨** *អាសនា* ត្រង់នេះបង្ហាញពីគ្រឿងក្រអូប (មើល ខ.៧) ។

ប្រឡាក់នៅស្នែងអាសនា ដែលនៅចំពោះព្រះយេហូវ៉ា[ច]
ខាងក្នុងត្រសាលជំនុំ ហើយត្រូវចាក់ឈាមទាំងអស់នាជើង
អាសនា[ឆ]ដង្វាយដុត ដែលនៅមាត់ទ្វារត្រសាលជំនុំ ១៩ឯ
ខ្លាញ់[ជ]គោនោះទាំងប៉ុន្មាន នោះត្រូវយកចេញទៅដុតនៅ
លើអាសនា[ឈ] ២០ត្រូវឱ្យធ្វើនឹងគោនេះដូចជាបានធ្វើ
ចំពោះគោដែលសំរាប់ជាដង្វាយលោះបាបដែរ[ញ] គឺត្រូវធ្វើ
ដូចគ្នាទាំង២ ហើយត្រូវឱ្យសង្ឃថ្វាយឱ្យធួននឹងបាបទាំង
អស់គ្នា នោះនឹងរួចចាកទោសហើយ[ដ] ២១រួចត្រូវឱ្យសង្ឃនាំ
យកគោនោះ ទៅដុតនៅខាងក្រៅទីដំឡើងត្រសាល[ឋ] ដូច
ជាបានដុតគោមុនដែរ នេះគឺជាដង្វាយលោះបាបសំរាប់
ពួកជំនុំ[ឌ] ។
២២បើនាម៉ឺនណាមួយ[ឍ]ធ្វើបាបឥតបានដឹង[ណ] ដោយរំលង
បទណា ដែលព្រះយេហូវ៉ា ជាព្រះនៃខ្លួន ទ្រង់ហាមប្រាម
មិនឱ្យធ្វើ ហើយមានទោសដូច្នោះ ២៣បើសិនជាអ្នកណា
ប្រាប់ឱ្យលោកជ្រាបពីបាបដែលបានប្រព្រឹត្តហើយ នោះ
លោកត្រូវនាំយកពពែឈ្មោល១[ត] ដែលឥតខ្ចោះមកសំរាប់
ជាដង្វាយរបស់ខ្លួន ២៤រួចដាក់ដៃលើក្បាលពពែនោះ
ហើយសំឡាប់នៅកន្លែងដែលគេតែងសំឡាប់សត្វ សំរាប់
ជាដង្វាយដុតនៅចំពោះព្រះយេហូវ៉ាទៅ[ថ]នេះហើយ ជា
ដង្វាយលោះបាប[ទ] ២៥ត្រូវឱ្យសង្ឃយកឈាមនៃដង្វាយ
លោះបាបនោះ ដោយម្រាមដៃ ទៅប្រឡាក់នៅស្នែង
អាសនា[ធ]ដង្វាយដុត ហើយចាក់ឈាមទាំងអស់នៅត្រង់
ជើងអាសនា[ន]ដង្វាយដុតនោះ ២៦ឯខ្លាញ់ទាំងប៉ុន្មាន នោះ
ត្រូវដុតនៅលើអាសនា ដូចជាខ្លាញ់របស់យញ្ញបូជា ដែល
សំរាប់ជាដង្វាយមេត្រីដែរ ហើយត្រូវឱ្យសង្ឃថ្វាយឱ្យធួន[ប]
ចំពោះបាបដែលលោកបានធ្វើ នោះលោកនឹងបានរួចចាក
ទោសហើយ[ផ] ។
២៧ឬបើអ្នកស្រុកណាមួយធ្វើបាបឥតបានដឹង[ព] ដោយ
រំលងបទណា ដែលព្រះយេហូវ៉ាបានហាមប្រាម មិនឱ្យធ្វើ
ហើយមានទោសដូច្នោះ ២៨បើសិនជាអ្នកណាប្រាប់ឱ្យគេ
ដឹងពីបាបដែលបានប្រព្រឹត្តហើយ នោះត្រូវនាំពពែញី១[ភ]
ដែលឥតខ្ចោះមក សំរាប់ជាដង្វាយ[ម] ដោយព្រោះបាបដែល
ខ្លួនបានធ្វើ ២៩រួចដាក់ដៃលើក្បាល[យ]នៃដង្វាយលោះបាប
នោះ[រ] ហើយសំឡាប់ត្រង់កន្លែងដង្វាយដុត[ល] ៣០នោះត្រូវឱ្យ
សង្ឃយកឈាម ដោយម្រាមដៃ ទៅប្រឡាក់នៅស្នែង
អាសនាដង្វាយដុត[វ] ហើយចាក់ឈាមទាំងអស់ត្រង់ជើង
អាសនា ៣១ឯខ្លាញ់ទាំងប៉ុន្មាន នោះត្រូវយកចេញ ដូចជា
យកចេញពីយញ្ញបូជា ដែលសំរាប់ជាដង្វាយមេត្រីដែរ
រួចត្រូវឱ្យសង្ឃដុតនៅលើអាសនា[ស] ទុកជាក្លិនឈ្ងុយដល់
ព្រះយេហូវ៉ា[ហ] ត្រូវឱ្យសង្ឃថ្វាយឱ្យធួន[ឡ]នឹងអ្នកនោះ ដូច្នេះ
អ្នកនោះនឹងរួចចាកទោសហើយ[អ] ។
៣២តែបើសិនជាអ្នកនោះនាំចៀម[ក]មកថ្វាយ សំរាប់
ជាដង្វាយលោះបាបខ្លួនវិញ នោះត្រូវយកញី១ដែលឥត
ខ្ចោះមក[ខ] ៣៣ហើយដាក់ដៃលើក្បាលនៃដង្វាយនោះ រួច
សំឡាប់[គ] ទុកជាដង្វាយលោះបាប ត្រង់កន្លែងដែលគេ
តែងសំឡាប់សត្វ[ឃ]សំរាប់ជាដង្វាយដុត[ង] ៣៤ត្រូវឱ្យសង្ឃម្នាក់
យកឈាមនៃដង្វាយលោះបាបនោះដោយម្រាមដៃ ទៅ
ប្រឡាក់នៅស្នែងអាសនាដង្វាយដុត ហើយចាក់ឈាមទាំង
អស់ត្រង់ជើងអាសនា[ច] ៣៥ឯខ្លាញ់ទាំងប៉ុន្មាននោះត្រូវយក
ចេញដូចជាយកខ្លាញ់ចេញពីកូនចៀមនៃយញ្ញបូជា ដែល
សំរាប់ជាដង្វាយមេត្រីដែរ ហើយត្រូវឱ្យសង្ឃដុតនៅលើ
អាសនា[ឆ] តាមរបៀបដង្វាយទាំងប៉ុន្មាន ដែលដុតថ្វាយព្រះ
យេហូវ៉ា ក៏ត្រូវថ្វាយឱ្យធួននឹងបាប ដែលអ្នកនោះបាន
ប្រព្រឹត្ត ដូច្នេះ អ្នកនោះនឹងរួចចាកទោសហើយ ។
**៥** ១ក្រោយដែលបានទទួលស្បថ ធ្វើជាស្មរបន្ទាល់ហើយ
នោះបើអ្នកណាធ្វើបាប ដោយមិនព្រមឆ្លើយប្រាប់អំពីការ
ដែលខ្លួនបានឃើញឬដឹង[ក] អ្នកនោះឈ្មោះថាមានទោស

**៤:១៨** ច ខ.៧ លវ ៦:៣០ ១០:១៨ ឆ លវ ៥:៩
**៤:១៩** ជ ខ.៨ ឈ ខ.២៦
**៤:២០** ញ នក ២៩:៣៦ ៣២:៣០ រម ៣:២៥ ហព ១០:១០–១២ ដ ខ.២៦,៣១,៣៥ ជន ១៥:២៥
**៤:២១** ឋ ខ.១២ ឌ លវ ១៦:៥,១៥ ២របា ២៩:២១
**៤:២២** ឍ ជន ៣១:១៣ ណ ខ.២
**៤:២៣** ត ខ.៣ លវ ១:១០
**៤:២៤** ថ ខ.៤ ទ ខ.៣ លវ ៦:២៥
**៤:២៥** ធ លវ ១៦:១៨ អគ ៤៣:២០ ២២ ន លវ ៩:៩
**៤:២៦** ប នក ៣២:៣០ ផ លវ ៥:១០ ១២:៨
**៤:២៧** ព ខ.២
**៤:២៨** ភ លវ ៥:៦ អគ ៤០:៣៩ ៤៤:២៧ ម ខ.៣ លវ ១:១០
**៤:២៩** យ ខ.៤,២៤ រ លវ ១:៤ ល លប ៨:២០
**៤:៣០** វ ខ.៧
**៤:៣១** ស ខ.៣៥ ហ លប ៨:២១ ឡ លវ ១:៤ អ ខ.២០
**៤:៣២** ក នក ២៩:៣៨ លវ ៩:៣ ១៤:១០ ខ លវ ១:៣ **៤:៣៣** គ លវ ១:៥ ឃ ខ.២៩ ង លវ ១:៤ **៤:៣៤** ច ខ.៧ **៤:៣៥** ឆ ខ.៣១ **៥:១** ក សភ ២៩:២៤ មថ ២៦:៦៣

**៤:២០** *ដង្វាយលោះបាប* ត្រង់នេះប្រាប់ពីពួកសង្ឃមានបាប មើល ខ.៣ និងការពន្យល់ ។ *នឹងរួចចាកទោស* នៅក្នុង ៤:២០–៦:៧ ជាប្រយោគគន្លឹះ ដែលមានលើកឡើងចំនួន៩ដង សំដៅលើការអត់ទោសដោយព្រះអម្ចាស់ ។
**៤:២៣** *ពពែឈ្មោល១* សត្វដែលមានតម្លៃទាប ត្រូវបានគេថ្វាយក្នុងចំនួនតិច ឬក្នុងកម្រិតសន្សំសំចៃ ។ ដូច្នេះ សត្វគោជាការតម្រូវដល់ពួកសង្ឃដែលមានឋានៈខ្ពស់ (ខ.៣) និងពួកបណ្ដាជន (ខ.១៤) ប៉ុន្តែ ពពែញីសម្រាប់អ្នកដឹកនាំពួកគេ (ខ.២៨) ឬចៀមសម្រាប់ ពួកអ៊ីស្រាអែលសាមញ្ញ (ខ.៣២) ។ ប៉ុន្តែ ប្រសិនបើពួកគេក្រពេក នោះត្រូវថ្វាយសត្វព្រាប ឬលលក និងដង្វាយម្សៅក៏បាន (សូមមើល ៥:៧,១១ និងការពន្យល់ ៥:១១–១២) ។
**៤:២៥** *សង្ឃ* សង្ឃនេះគឺជាអ្នកដែលបានតែងតាំងជាផ្លូវការ ឬក៏មិនទាន់តែងតាំងសម្រាប់ដឹកនាំ និងធ្វើការក្នុងព្រះវិហារ (មើល ខ.៣០,៣៤) ។
**៤:២៨** *ពពែញី* មើលការពន្យល់ ខ.៣២ ។
**៤:២៩** *ដាក់ដៃលើក្បាលនៃដង្វាយលោះបាប* ១:៣ នក ២៩:១០ ។
**៤:៣២** *ចៀម . . . ញី១* មើលការពន្យល់ ខ.៣២ ។
**៤:៣៥** *ខ្លាញ់ . . . សំរាប់ជាដង្វាយមេត្រី* មើលការពន្យល់ ៣:៣–៥ ។
**៥:១–៤** នេះជាគំរូបួនយ៉ាងនៃការធ្វើបាបដោយអត់ដឹង (សូមមើល ៤:២–៣,១៣,២២,២៧) ។

វិញ[ខ] ២ឬបើអ្នកណាប៉ះពាល់នឹងរបស់ស្មោកគ្រោកណាមួយ
ជាខ្មោចសត្វដែលមិនស្អាត ទោះបើជាសត្វព្រៃ សត្វស្រុក
ឬសត្វលូនវារ[គ] ដោយមិនបានដឹង ហើយខ្លួនក៏បានទៅជា
មិនស្អាតដែរ[ឃ] នោះឈ្មោះថាមានទោសហើយ ៣ឬបើបាន
ប៉ះពាល់នឹងសេចក្ដីស្មោកគ្រោករបស់មនុស្ស ទោះបើជា
សេចក្ដីមិនស្អាតយ៉ាងណាក៏ដោយ[ង] ដែលនាំឱ្យខ្លួនមិនស្អាត
បាន[ច]ដោយឥតដឹងខ្លួន បើកាលណាដឹងវិញ នោះមាន
ទោសហើយ ៤ឬបើអ្នកណាស្បថលេងថា[ឆ] នឹងប្រព្រឹត្ត
ការអាក្រក់ឬល្អក្ដី[ជ] ទោះបើសេចក្ដីអ្វីក៏ដោយ ដែលមនុស្ស
នឹងស្បថដោយឥតបើគិត ហើយមិនបានដឹងខ្លួនសោះ បើ
កាលណាដឹងវិញ នោះនឹងមានទោសក្នុងបទណាមួយនោះ
ជាមិនខាន ៥ដូច្នេះ បើអ្នកណាមានទោសក្នុងបទណាមួយ
យ៉ាងនោះ ត្រូវឱ្យលន់តួ[ឈ]ចំពោះអំពើបាបដែលខ្លួនបាន
ប្រព្រឹត្តចុះ ៦ហើយត្រូវនាំយកដង្វាយដែលសំរាប់ការ
រំលងរបស់ខ្លួនមកថ្វាយព្រះយេហូវ៉ា ដោយព្រោះបាប
ដែលបានប្រព្រឹត្ត គឺជាសត្វញី១ពីហ្វូងចៀមឬពពែ[ញ]
សំរាប់ជាដង្វាយលោះបាប[ដ] រួចត្រូវឱ្យសង្ឃថ្វាយឱ្យធួន[ឋ]
នឹងបាបរបស់អ្នកនោះ ។
៧បើសិនជាអ្នកនោះខ្វះខាត គ្មានល្មម[ឌ]នឹងយកកូនចៀម១
បាន[ឍ] នោះត្រូវយកលលក២ ឬព្រាបជិទើរ២[ណ]មកថ្វាយ
ព្រះយេហូវ៉ា ទុកជាដង្វាយសំរាប់ការរំលងរបស់ខ្លួន
ដោយព្រោះបាបដែលបានប្រព្រឹត្តនោះវិញ គឺ១សំរាប់ជា
ដង្វាយលោះបាប ហើយ១សំរាប់ជាដង្វាយដុត ៨ត្រូវឱ្យនាំ
យកសត្វនោះទៅឯសង្ឃ ហើយត្រូវឱ្យសង្ឃថ្វាយ១ ដែល
សំរាប់ជាដង្វាយលោះបាប ជាមុនដំបូងដោយក្ដិចបណ្ដាច់
ក្បាលចេញពីក[ត] តែមិនត្រូវពុះជា២ឡើយ[ថ] ៩រួចប្រោះ[ទ]
ឈាមនៃដង្វាយលោះបាបនោះ នៅចំហៀងអាសនា[ធ]
ហើយត្រូវសិរក់ឈាមដែលសល់ទាំងប៉ុន្មាន នៅជើង
អាសនាវិញ[ន] នេះហើយជាដង្វាយលោះបាប ១០ឯសត្វទី២
នោះត្រូវថ្វាយជាដង្វាយដុតតាមទំលាប់[ប] ដូច្នេះត្រូវឱ្យសង្ឃ
ថ្វាយឱ្យធួន[ផ]នឹងបាបដែលអ្នកនោះបានប្រព្រឹត្ត ហើយអ្នក
នោះនឹងបានរួចចាកទោស[ព] ។
១១បើអ្នកនោះខ្វះខាត[ភ] គ្មានល្មមនឹងយកលលក២ ឬ
ព្រាបជិទើរ២បានទេ[ម] នោះត្រូវយកម្សៅយ៉ាងម៉ដ្ដ[យ]១ខ្ទឹង[រ]
មក ទុកជាដង្វាយលោះបាប ដោយព្រោះអំពើដែលខ្លួនបាន
ប្រព្រឹត្ត តែមិនត្រូវចាក់ប្រេងឬដាក់កំញានទេ ដ្បិតជា
ដង្វាយសំរាប់លោះបាប ១២ត្រូវឱ្យអ្នកនោះនាំយកទៅឯ
សង្ឃ ហើយត្រូវឱ្យសង្ឃយក១ក្ដាប់[ល] ទុកជាទីរំឭកទៅដុត
លើអាសនា[វ] តាមរបៀបដង្វាយដែលដុតថ្វាយព្រះយេហូវ៉ា
នេះហើយជាដង្វាយលោះបាប ១៣ត្រូវឱ្យសង្ឃថ្វាយឱ្យ
ធួន[ស]នឹងអ្នកនោះ ចំពោះការដែលបានប្រព្រឹត្តរំលងក្នុងបទ
ណាមួយនោះ រួចអ្នកនោះនឹងបានរួចចាកទោស ឯម្សៅ
ដែលនៅសល់ នោះត្រូវបានសំរាប់សង្ឃវិញ[ហ] ដូចជាក្នុង
ដង្វាយម្សៅដែរ[ឡ] ។

## ដង្វាយសម្រាប់ការរំលង

១៤ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅម៉ូសេថា ១៥បើអ្នក
ណាប្រព្រឹត្តរំលងច្បាប់ ដោយធ្វើបាបចំពោះរបស់បរិសុទ្ធ
នៃព្រះយេហូវ៉ា ដោយឥតបានដឹង[អ] នោះត្រូវនាំយកដង្វាយ
ដែលសំរាប់ការរំលង[ក]មកថ្វាយដល់ព្រះយេហូវ៉ា គឺជា
ចៀមឈ្មោល១[ខ]ឥតខ្ចោះពីហ្វូងសត្វ តាមដែលគិតថ្លៃប្រាក់
ជាប្រាក់រៀលដែលប្រើក្នុងទីបរិសុទ្ធ សំរាប់ជាដង្វាយ[គ]
ដែលថ្វាយដោយព្រោះការប្រព្រឹត្តរំលង[ឃ] ១៦ហើយត្រូវ

**៥:១** ខ ខ.១៧ នក ២៨:៣៨ លវ ៧:១៨ ១៧:១៦ ១៩:៨ ២០:១៧ ២៤:១៥ ជន ៥:៣១ ៩:១៣ ១៥:៣១ ១៩:២០ ៣០:១៥ **៥:២** គ លវ ១១:១១,២០–៤០ ចទ ១៤:៨ អស ៥២:១១ ឃ ខ.៣ លវ ៧:២១ ១១:៨,២៤ ១៣:៤៥ ជន ១៩:២២ យប ១៥:១៦ ទដ ៥១:៥ អស ៦:៥ ៦៤:៦ អគ ៣៦:១៧ ហក ២:១៣ **៥:៣** ង ជន ១៩:១១–១៦ ច លវ ៧:២០ ១១:២៥ ១៤:១៩ ២១:១ ជន ៥:២ ៩:៦ ១៩:៧ អគ ៤៤:២៥ **៥:៤** ឆ ជន ៣០:៦,៨ ជ អស ៤១:២៣ **៥:៥** ឈ លប ១៦:២១ ២៦:៤០ ជន ៥:៧ យស ៧:១៩ ១ពវ ៨:៤៧ សភ ២៨:១៣ **៥:៦** ញ លវ ១:១០ ៤:៣ ដ លវ ៤:២៨ ឋ នក ៣២:៣០ **៥:៧** ឌ ខ.១១ លវ ១២:៨ ១៤:២១ ២៧:៨ ឍ លវ ១២:៨ ១៤:២២,៣០ ណ លប ១៥:៩ ជន ៦:១០ **៥:៨** ត លវ ១:១៥ ថ លវ ១:១៧ **៥:៩** ទ នក ២៤:៦ ធ លវ ១:១៥ ន លវ ៤:៧ **៥:១០** ប លវ ១:១៤–១៧ ១រប ១៥:១៣ ផ នក ៣២:៣០ ព លវ ៤:២៦ **៥:១១** ភ ខ.៧ ម លវ ១៥:៩ យ លវ ២:១ រ នក ១៦:៣៦ **៥:១២** ល លវ ២:២ វ លវ ២:៩ **៥:១៣** ស នក២:៣០ ហ លវ ២:៣ ឡ នក ២៩:៤១ **៥:១៥** អ លវ ៤:២ ក លវ ២២:១៤ ខ នក ២៩:៣ លវ ៦:៦ ជន ៥:៨ ៦:១៤ ១៥:៦ ២៨:១១ គ នក ៣០:១៣ ឃ ខ.១៦,១៨ លវ ៦:៥,៦ ៧:១៧ ១៤:១២–១៧ ១៩:២១,២២ ជន ៦:១២ ១៨:៩ ១សយ ៦:៣ អរ ១០:១៩ អស ៥៣:១០

**៥:២** *របស់ស្មោកគ្រោក* មើលការពន្យល់ ៤:១២ ។
**៥:៣** *សេចក្ដីស្មោកគ្រោករបស់មនុស្ស* មើលជំពូក ១១–១៥ ។
**៥:៥** *លន់តួ* អ្នកថ្វាយត្រូវតែទទួលស្គាល់នូវបាបរបស់ខ្លួនទៅចំពោះព្រះ ដើម្បីទទួលបាននូវការអត់ទោស (ធៀប ទដ ២៨:១៣ និងការពន្យល់) ។
**៥:៧** *លលក២ . . . ព្រាបជិទើរ២* មើលការពន្យល់ ៤:២៣ ។
**៥:១១** *ម្សៅយ៉ាងម៉ដ្ដ* មើលការពន្យល់ ៤:២៣ ។ ទោះបីជាឈាមមិនត្រូវបានគេប្រើជាមួយនឹងដង្វាយម្សៅនេះក៏ដោយ តែគេដាក់វានៅលើយញ្ញបូជានៃដង្វាយដុតវិញ (ខ.១២) ។ ហប ៩:២២ ប្រហែលជាសំដៅលើស្ថានភាពមួយប៉ុណ្ណោះ ។
**៥:១២** *ទុកជាទីរំឭក* មើលការពន្យល់ ២:២,៩,១៦ ។
**៥:១៥** *របស់បរិសុទ្ធនៃព្រះយេហូវ៉ា* មើលការពន្យល់ នក ៣:៥ ។ *ដង្វាយដែលសំរាប់ការរំលង* មើលការបង្គាប់បញ្ជារបស់ពួកសង្ឃ ៧:១–៦ អស ៥៣:១០ ។ ជាធម្មតាវាត្រូវបានគេហៅថា (ដង្វាយរំលង) ហើយស្ទើរតែដូចទៅនឹង (ដង្វាយលោះបាប) ដែរ (ធៀប ៧:៧) ។ ពាក្យទាំងពីរនេះនៅក្នុងភាសាក្រិក ជួនកាលគេប្រើជំនួសគ្នាដែរ ។ ធាតុសំខាន់ពីរផ្សេងគ្នារវាង ដង្វាយសម្រាប់ការរំលង និងដង្វាយលោះបាប នោះស្ថិតនៅត្រង់ថា ដង្វាយសម្រាប់ការរំលងតម្រូវឱ្យអ្នកដែលប្រព្រឹត្តនូវអំពើ លួច ឬឆក់នោះប្រគល់ឱ្យម្ចាស់ដើមវិញ (ខ.១៦) ហើយត្រូវថ្វាយចៀមឈ្មោល១ ក្នុងចំណោមសត្វទាំងឡាយ ។ ប៉ុន្តែ ចំណែកឯដង្វាយលោះបាបវិញ មិនតម្រូវឱ្យបាបសងដោយបាបរបស់ខ្លួននោះឡើយ ។

សងតាមដីឡៃ[ង]ចំពោះរបស់បរិសុទ្ធដែលខ្លួនបានប្រព្រឹត្ត
រំលងនោះ ព្រមទាំងថែម១ភាគក្នុង៥ផង[ច] ប្រគល់ទៅឱ្យ
សង្ឃ ហើយត្រូវឱ្យសង្ឃថ្វាយចៀមឈ្មោលនោះទុកជា
ដង្វាយដែលថ្វាយដោយព្រោះការរំលង ដើម្បីឱ្យធួននឹង
បាបរបស់អ្នកនោះ រួចនឹងបានរួចចាកទោសហើយ ។
១៧បើអ្នកណាធ្វើបាប ដោយប្រព្រឹត្តការអ្វី ដែលព្រះ
យេហូវ៉ាបានហាមមិនឱ្យធ្វើ ទោះបើមិនបានដឹងក៏ដោយ[ឆ]
គង់តែអ្នកនោះមានទោស ហើយត្រូវទ្រាំទ្រចំពោះសេចក្ដី
ទុច្ចរិតរបស់ខ្លួន[ជ] ១៨ត្រូវឱ្យអ្នកនោះយកចៀមឈ្មោល១
ឥតខ្ចោះពីហ្វូងសត្វ មកប្រគល់ដល់សង្ឃតាមដែលគិតថ្លៃ
សំរាប់ជាដង្វាយដែលថ្វាយដោយព្រោះការរំលង[ឈ]ត្រូវ
ឱ្យសង្ឃថ្វាយឱ្យធួននឹងការកំហុសដែលអ្នកនោះបាន
ប្រព្រឹត្តដោយឥតដឹង រួចអ្នកនោះនឹងបានរួចចាកទោស[ញ]
១៩នេះហើយជាដង្វាយដែលថ្វាយ ដោយព្រោះការប្រព្រឹត្ត
រំលង ដ្បិតពិតជាអ្នកនោះមានទោស នៅចំពោះព្រះ
យេហូវ៉ាមែនហើយ[ដ] ។

**៦** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២បើអ្នកណា
ធ្វើបាប ហើយប្រព្រឹត្តរំលងចំពោះព្រះយេហូវ៉ា[ក] ដោយ
កុហកដល់អ្នកជិតខាងខ្លួន[ខ]ពីរបស់អ្វីដែលគេបានផ្ញើទុក
ឬបញ្ចាំនៅដៃខ្លួន[គ] ឬដែលខ្លួនបានលួច ឬដែលបាន
សង្កត់សង្កិន[ឃ]ដល់អ្នកជិតខាង ៣ឬបានរើសរបស់ដែលគេ
បាត់ហើយកុហកថា មិនឃើញ[ង] ឬស្បថកុហកក្នុងសេចក្ដី
ណាមួយនេះ[ច] ដែលមនុស្សតែងប្រព្រឹត្តទាំងធ្វើបាបដូច្នោះ
៤បើអ្នកនោះបានប្រព្រឹត្ត ហើយមានទោសដូច្នោះ នោះត្រូវ
ឱ្យសង[ឆ]របស់ដែលខ្លួនបានលួច បានកំហែងយក ដែលគេ
បានផ្ញើទុកនឹងខ្លួន ឬរបស់បាត់ដែលខ្លួនបានឃើញ ៥និង
របស់អ្វីដែលខ្លួនប្រកែក ដោយស្បថកុហកថា មិនបានដឹង
គឺត្រូវសង[ជ]ទាំងអស់ ព្រមទាំងបន្ថែម១ភាគក្នុង៥ផង ដល់
ម្ចាស់របស់នោះ ក្នុងថ្ងៃដែលឃើញថា មានទោសដូច្នោះ
ហើយ[ឈ] ៦រួចត្រូវយកដង្វាយដែលថ្វាយដោយព្រោះការ
ប្រព្រឹត្តរំលងរបស់ខ្លួន[ញ] មកប្រគល់ដល់សង្ឃ សំរាប់នឹង
ថ្វាយដល់ព្រះយេហូវ៉ា គឺជាចៀមឈ្មោល១ឥតខ្ចោះពីហ្វូង
សត្វ តាមដែលគិតថ្លៃ ទុកជាដង្វាយដោយព្រោះការរំលង[ដ]
៧ហើយត្រូវឱ្យសង្ឃថ្វាយឱ្យធួន[ឋ]នឹងអ្នកនោះនៅចំពោះ
ព្រះយេហូវ៉ា រួចអ្នកនោះនឹងរួចចាកទោស ចំពោះការអ្វី
ដែលនាំឱ្យខ្លួនមានទោសដោយប្រព្រឹត្តនោះ ។

**ដង្វាយដុត**

៨ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា ៩ចូរបង្គាប់
ដល់អើរ៉ុននិងពួកកូនលោកថា នេះជារបៀបដង្វាយដុត[ឌ] គឺ
ដង្វាយនេះត្រូវតែនៅលើជើងក្រាននៃលើអាសនា ពេញ
១យប់ទាល់ព្រឹក ហើយភ្លើងដែលនៅអាសនាក៏ត្រូវតែឆេះ
នៅជានិច្ចដែរ[ឍ] ១០ឯសង្ឃត្រូវឱ្យពាក់អាវខ្លូតទេស[ណ] ហើយ
ស្លៀកខោខ្លូតទេស[ត] ទៅកើបផេះ[ថ]ដែលភ្លើងបានឆេះ
ដង្វាយនៅលើអាសនា ហើយដាក់នៅក្បែរអាសនាសិន
១១រួចដោះសំលៀកបំពាក់នេះចេញ ស្លៀកពាក់បន្លាស់
ឯទៀត យកផេះចេញទៅក្រៅទីដំឡើងត្រសាលចាក់នៅ
កន្លែងស្អាត[ទ] ១២ឯភ្លើងនៅលើអាសនា នោះត្រូវតែឆេះនៅ
ជានិច្ចឥតរលត់ឡើយ រាល់តែព្រឹកត្រូវឱ្យសង្ឃដាក់ឧស[ធ]
នៅលើនោះ រួចរៀបដង្វាយដុតពីលើ ព្រមទាំងដុតខ្លាញ់
ដង្វាយមេត្រី[ប]ផង ១៣ត្រូវតែមានភ្លើងឆេះនៅជានិច្ចលើ
អាសនា មិនត្រូវឱ្យរលត់ឡើយ ។

**ដង្វាយម្សៅ**

១៤នេះជារបៀបដង្វាយម្សៅ គឺពួកកូនអើរ៉ុនត្រូវថ្វាយ
ដង្វាយនោះ[ផ]នៅចំពោះព្រះយេហូវ៉ា ត្រង់លើអាសនាប៉ែក
ខាងមុខ ១៥ត្រូវយកម្សៅយ៉ាងម៉ដ្ត១ក្ដាប់ជាមួយនឹងប្រេងខ្លះ
ហើយនិងកំញាន[ព]ដែលនៅលើដង្វាយម្សៅនោះ[ភ]ដុតទាំង
អស់ សំរាប់ជាក្លិនឈ្ងុយនៅលើអាសនា ទុកជាទីរំឭក[ម]ដល់
ព្រះយេហូវ៉ា ១៦ឯម្សៅទាំងប៉ុន្មានដែលសល់នៅ[យ] នោះ
អើរ៉ុន និងពួកកូនលោក[រ] ត្រូវបរិភោគ ដោយឥតមាន
ដំបែ[ល]នៅត្រង់កន្លែងបរិសុទ្ធ[វ] គឺត្រូវបរិភោគនៅទីលាន[ស]

**៥:១៦** ង លវ ៦:៤ ច ខ.១៥ លវ ២៧:១៣ ជន ៥:៧
**៥:១៧** ឆ ខ.១៥ ជ ខ.១
**៥:១៨** ឈ លវ ៦:៦ ១៤:១២ ញ ខ.១៥
**៥:១៩** ដ ២ពវ ១២:១៦
**៦:២** ក ជន ៥:៦ ទដ ៧៣:២៧ កច ៥:៤ កល ៣:៩ ខ លវ ១៩:១១ យរ ៩:៤,៥ គ នក ២២:៧ ឃ លវ ៣១:៧
**៦:៣** ង នក ២៣:៤ ច នក ២២:១១
**៦:៤** ឆ លវ ៥:១៦ អគ ៣៣:១៥ លក ១៩:៨
**៦:៥** ជ ជន ៥:៧ ឈ លវ ៥:១៥
**៦:៦** ញ លវ ៥:១៥ ដ ជន ៥:៨
**៦:៧** ឋ នក ៣២:៣០
**៦:៩** ឌ លវ ៧:៣៧ ឍ ខ.១២
**៦:១០** ណ នក ៣៩:២៧ ត នក ២៨:៣៩–៤២,៤៣ ៣៩:២៨ ថ លវ ១:១៦
**៦:១១** ទ លវ ៤:១២
**៦:១២** ធ លវ ១:៧ ន នក ២៩:១៣ ប នក ៣២:៦
**៦:១៤** ផ លវ ២:១ ជន ៦:១៥ ១៥:៤ ២៨:១៣
**៦:១៥** ព លវ ២:១ ភ លវ ២:៩ ម លវ ២:២
**៦:១៦** យ អគ ៤៤:២៩ រ លវ ២:៣ ល លវ ២:១១ វ ខ.២៦ នក ២៩:១១ លវ ១០:១៣ ១៦:២៤ ២៤:៩ ជន ១៨:១០ ស នក ២៧:៩

**៦:៣** *របស់ដែលគេបាត់* មើលការពន្យល់ ចទ ២២ : ១–៣ ។
**៦:៦** *ប្រគល់ដល់សង្ឃ . . .ថ្វាយដល់ព្រះយេហូវ៉ា* នៅត្រង់ចំណុចនេះបញ្ជាក់ថា គ្រប់ទាំងយញ្ញបូជាដែលថ្វាយទៅដល់ព្រះអម្ចាស់ ពួកសង្ឃជាអ្នកតំណាងនាំយករបស់ទាំងនោះទៅចំពោះព្រះអម្ចាស់ ។
**៦:៨–៧:៣៦** នៅត្រង់នេះបង្ហាញពីការបង្គាប់បញ្ជា នៃយញ្ញបូជាដែលទាក់ទងទៅនឹងម្ហូបអាហារដែលបរិភោគដោយពួកសង្ឃនៅក្នុងករណីគេថ្វាយដង្វាយមេត្រីដល់ព្រះអម្ចាស់ ។
**៦:៩** *ដង្វាយដុត* មើលជំពូក៧ ។ ជន ១៥:១–៦ និងការពន្យល់ ។
**៦:១៣** នៅត្រង់នេះបញ្ជាក់ថា ភ្លើងត្រូវឆេះជានិច្ចនៅលើអាសនាដែលបង្ហាញពីការទូលសូមដល់ព្រះអម្ចាស់មិនឈប់ឈរ ក្នុងនាមជារាស្ត្រអ៊ីស្រាអែល ។
**៦:១៤** *ដង្វាយម្សៅ* មើលជំពូក២ និងការពន្យល់ ។
**៦:១៥** *ជាទីរំឭក* មើលការពន្យល់ ២:២,៩,១៦ ។
**៦:១៦** *កន្លែងបរិសុទ្ធ* មើលការពន្យល់ នក ៣:៥ ។

ផងត្រសាលជំនុំ[ហ] [១៧]មិនត្រូវចំអិននំម្សៅនោះដោយលាយនឹង
ដំបែឡើយ អញបានឱ្យម្សៅនោះ ទុកជាចំណែក[ឡ]របស់គេ
ពីដង្វាយដែលដុត[អ]ថ្វាយអញ នេះហើយជារបស់បរិសុទ្ធ
បំផុត[ក] ដូចជាដង្វាយសំរាប់លោះបាប និងដង្វាយដែល
ថ្វាយដោយព្រោះការរំលងដែរ [១៨]អស់ទាំងប្រុសៗ ក្នុងពួក
កូនចៅអើរ៉ុន ត្រូវបរិភោគដង្វាយម្សៅនោះ[ខ] ទុកជា
ចំណែកដល់ខ្លួន[គ]ពីអស់ទាំងដង្វាយដែលដុតថ្វាយព្រះ
យេហូវ៉ា នៅអស់ទាំងដំណតរៀងទៅ[ឃ] ឯអស់អ្នកណា
ដែលពាល់ដង្វាយទាំងនោះក៏នឹងបានបរិសុទ្ធដែរ[ង]។
[១៩]ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា [២០]នេះជា
ដង្វាយដែលអើរ៉ុន និងពួកកូនលោក ត្រូវថ្វាយដល់ព្រះ
យេហូវ៉ា ក្នុងថ្ងៃដែលចាក់ប្រេងតាំងឱ្យ[ច] គឺត្រូវថ្វាយម្សៅ
យ៉ាងម៉ដ្ត[ឆ]១ខ្ញឹង[ជ] សំរាប់ជាដង្វាយម្សៅ[ឈ] ដែលថ្វាយនៅ
ជានិច្ច ត្រូវថ្វាយពាក់កណ្តាលក្នុងពេលព្រឹក ហើយពាក់
កណ្តាលក្នុងពេលល្ងាច [២១]ត្រូវធ្វើដង្វាយនោះលាយនឹង
ប្រេងចាក់ចុះក្នុងពុម្ព[ញ] កាលណាឆ្អិនហើយ នោះត្រូវយក
មកបំបែកជាដុំៗ ថ្វាយជាដង្វាយម្សៅ ទុកជាក្លិនឈ្ងុយដល់
ព្រះយេហូវ៉ា [២២]ឯសង្ឃណាដែលរើសពីក្នុងពួកកូនចៅ
អើរ៉ុន ហើយចាក់ប្រេងតាំងឡើងជំនួសលោក គឺសង្ឃនោះ
ឯង[ដ] ដែលត្រូវថ្វាយដង្វាយនោះ នេះជាច្បាប់សំរាប់អស់
កល្បជានិច្ចនៅ ចំពោះព្រះយេហូវ៉ា ឯដង្វាយនោះត្រូវ
ដុតទៅទាំងអស់វិញ[ឋ] [២៣]គ្រប់ទាំងដង្វាយម្សៅដែលពួកសង្ឃ
ថ្វាយ នោះត្រូវតែដុតទាំងអស់ មិនត្រូវឱ្យបរិភោគឡើយ។

## ដង្វាយលោះបាប

[២៤]ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា [២៥]ចូរប្រាប់
ដល់អើរ៉ុន និងពួកកូនលោកថា នេះជារបៀបដង្វាយដែល
សំរាប់លោះបាប[ឱ] គឺត្រូវតែសំឡាប់ដង្វាយនោះ នៅចំពោះ
ព្រះយេហូវ៉ា[ឍ] ត្រង់កន្លែង[ណ]ដែលសំឡាប់ដង្វាយដុតដែរ
ដង្វាយនោះជាបរិសុទ្ធបំផុត [២៦]ឯសង្ឃណាដែលជាអ្នក
ថ្វាយដោយព្រោះបាប នោះត្រូវបរិភោគដង្វាយនោះ នៅ
ត្រង់កន្លែងបរិសុទ្ធ[ត] គឺនៅទីលាន[ថ]ផងត្រសាលជំនុំ[ទ] [២៧]អ្វីៗ
ដែលប៉ះពាល់នឹងសាច់នោះ ក៏ត្រូវបរិសុទ្ធដែរ[ធ] ហើយបើ
កាលណាឈាមដង្វាយនោះខ្ទាតទៅលើអាវណា ត្រូវលាង
អាវដែលប្រឡាក់នោះ នៅត្រង់កន្លែងបរិសុទ្ធ [២៨]តែថ្លាង
ណា[ន]ដែលប្រើស្ងោរសាច់នោះ ត្រូវតែបំបែកចោល ឬបើ
ជាឆ្នាំងលង្ហិនវិញ នោះត្រូវតែដុសលាងសំអាតក្នុងទឹក
ចេញ [២៩]អស់ទាំងប្រុសៗក្នុងពួកសង្ឃត្រូវបរិភោគដង្វាយ
នោះ[ប] នេះហើយជារបស់បរិសុទ្ធបំផុត[ផ] [៣០]តែឯដង្វាយ
លោះបាប ដែលបានយកឈាមទៅក្នុងត្រសាលជំនុំ ឱ្យបាន
ធួន[ព]នឹងបាបនៅក្នុងទីបរិសុទ្ធ នោះ[ភ]មិនត្រូវបរិភោគឡើយ
គឺត្រូវតែដុតនឹងភ្លើងវិញ[ម]។

## ដង្វាយសម្រាប់ការរំលង

**៧** [១]នេះជារបៀបដង្វាយ ដែលថ្វាយដោយព្រោះការ
រំលង[ក] ជារបស់បរិសុទ្ធបំផុត [២]គឺត្រូវសំឡាប់ដង្វាយដែល
ថ្វាយដោយព្រោះការរំលងនោះ នៅត្រង់កន្លែងដែល
សំឡាប់ដង្វាយដុតដែរ ត្រូវយកឈាមទៅប្រោះនៅជុំវិញ
លើអាសនា [៣]ហើយត្រូវថ្វាយខ្លាញ់ទាំងអស់[ខ] គឺកន្ទុយនិង
ខ្លាញ់ដែលរុំអាការៈខាងក្នុង [៤]ព្រមទាំងអង្គញ់ទាំង២ និង
ខ្លាញ់ដែលនៅជាប់នឹងអង្គញ់នោះខាងចង្កេះ ហើយ
ស្រទាប់នៅលើថ្លើម ដែលត្រូវយកចេញជាមួយនឹងអង្គញ់
ផង[គ] [៥]រួចត្រូវឱ្យសង្ឃដុតថ្វាយនៅលើអាសនា[ឃ] ទុកជា
ដង្វាយដុតថ្វាយដល់ព្រះយេហូវ៉ា នេះហើយជាដង្វាយ
សំរាប់ថ្វាយដោយព្រោះការរំលង [៦]អស់ទាំងប្រុសៗក្នុងពួក
សង្ឃ ត្រូវបរិភោគដង្វាយ[ង]នោះ នៅត្រង់កន្លែងបរិសុទ្ធ
នេះហើយជារបស់បរិសុទ្ធបំផុត[ច] [៧]ឯដង្វាយដែលថ្វាយ
ដោយព្រោះការរំលងនេះ[ឆ] ក៏ដូចជាដង្វាយលោះបាប
ដែរ[ជ]មានរបៀបតែ១ សំរាប់ដង្វាយទាំង២យ៉ាង[ឈ] ឯសង្ឃ
ណាដែលជាអ្នកថ្វាយឱ្យធួននឹងបាប សង្ឃនោះត្រូវបាន
ដង្វាយនោះឯង[ញ] [៨]ហើយសង្ឃណាដែលថ្វាយដង្វាយដុត
របស់អ្នកណា សង្ឃនោះឯងត្រូវបានស្បែករបស់សត្វដែល
ខ្លួនបានដុតថ្វាយ ទុក[ដ]ជារបស់ផងខ្លួន [៩]ឯអស់ទាំងដង្វាយ

**៦:១៦** ហ នក ២៩:៣១ លវ ៨:៣១
**៦:១៧** ឡ ជន ៥:៩ អ អគ ២៩:២៨ លវ ៧:៧ ១០:១៦–១៨ ក ខ.២៩ អគ ៤០:១០ លវ ១០:១២ ២១:២២ ២៤:៩ ជន ១៨:៩,១០
**៦:១៨** ខ ខ.២៩ លវ ២:៣ ៧:៦ ជន ១៨:៩–១០ គ ជន ៥:៩ ឃ លប ៩:១២ ង នក ៣០:២៩
**៦:២០** ច នក ២៨:៤១ ឆ ជន ៥:១៥ ២៨:៥ ជ នក ១៦:៣៦ ឈ នក ២៩:២ លវ ២៣:១៣ ជន ៤:១៦
**៦:២១** ញ លវ ២:៥
**៦:២២** ដ នក ២៨:៤១ ២៩:៣០ ឋ លវ ១:៩
**៦:២៥** ឱ នក ៣០:១០ លវ ៤:២៤ ឍ លវ ១:៣ ណ នក ២៩:១១
**៦:២៦** ត ខ.១៦ ថ នក ២៧:៩ ទ នក ២៧:២១ ៤០:២
**៦:២៧** ធ នក ២៩:៣៧ លវ ១០:១០ អគ ៤៤:១៩ ៤៦:២០ ហក ២:១២
**៦:២៨** ន លវ ១១:៣៣ ១៥:១២ ជន ១៩:១៥
**៦:៣០** ព អគ ៤៥:១៥ ភ លវ ៤:១៨ ម លវ ៤:១២
**៧:១** ក លវ ៥:១៥ អគ ៤០:៣៩ **៧:៣** ខ អគ ២៩:១៣ **៧:៤** គ លវ ៣:១៥ **៧:៥** ឃ នក ២៩:១៣
**៧:៦** ង លវ ៦:១៨ ច អគ ៤២:១៣ **៧:៧** ឆ នក ៣០:១០ ជ លវ ៥:១៥ ឈ ខ.៦ លវ ២:៣ ៦:១៧,២៦ ១៤:១៣ ២ពវ ១២:១៦ ១កច ៩:១៣ ១០:១៨ញ ជន ៥:៨ **៧:៨** ដ លវ ១:៦

**៦:១៨** *នឹងបានបរិសុទ្ធ* មើល នក ២៩:៣៧ និងការពន្យល់ ។
**៦:២៥** *ដង្វាយដែលសំរាប់លោះបាប* មើល ៤:១–៥:១៣ និងការពន្យល់ ។
**៦:២៨** *ថ្លាង* ជាធម្មតាបរិក្ខាផ្ទះបាយ និងគ្រឿងប្រដាប់ផ្សេងៗនៅក្នុងផ្ទះធ្វើពីដីឥដ្ឋ ជាពិសេសនៅពេលដែលគេយកវាទៅដុតក្នុងឡ គេត្រូវលាបពណ៌ ឬដុះខាត់វាឱ្យរលោង ។
**៧:១** *បរិសុទ្ធ* មើលការពន្យល់ នក ៣:៥ ។
**៧:២** *ថ្វាយដោយព្រោះការរំលង* មើល ៥:១៤–៦:៧ និងការពន្យល់ ។ *ត្រង់កន្លែង* ត្រង់នេះបញ្ជាក់ពីទីដែលគេយកដង្វាយទៅថ្វាយ នៅផ្នែកខាងជើងនៃអាសនានៃដង្វាយដុតគឺនៅពីមុខរោងឧបោសថ (១:១១ មើលការពន្យល់)។
**៧:៣** *កន្ទុយនិងខ្លាញ់* មើលការពន្យល់ (៣:៩) ។
**៧:៧–១០** មើល ជន ១៨:៨–២០ ១កថ ៩:១៩ និងការពន្យល់ ។

ម្សៅទាំងប៉ុន្មាន ដែលចំអិននៅក្នុងឡ[ឋ] ចៀននឹងខ្ទះ[ឌ]ឬដុត
ក្នុងពុម្ព[ឍ] នោះនឹងត្រូវបានចំពោះសង្ឃដែលជាអ្នកថ្វាយ
១០តែគ្រប់ទាំងដង្វាយម្សៅលាយនឹងប្រេង ឬទទេ នោះត្រូវ
បានជារបស់ផងពួកកូនអើរ៉ុនគ្រប់គ្នាវិញ ។

## ដង្វាយមេត្រី

១១នេះជារបៀបយញ្ញបូជា ដែលសំរាប់ជាដង្វាយមេត្រី
ថ្វាយព្រះយេហូវ៉ា ១២បើអ្នកណាថ្វាយដង្វាយ ដោយអរព្រះ
គុណ[ណ] នោះត្រូវយកនំ[ត]ឥតដំបែ លាយដោយប្រេង ហើយ
នំក្រៀបឥតដំបែ[ថ] លាបដោយប្រេង និងនំចៀន ធ្វើពីម្សៅ
យ៉ាងម៉ដ្ត[ទ] លាយដោយប្រេង[ធ]មកថ្វាយជាមួយនឹងយញ្ញបូជា
ដែលថ្វាយដោយអរព្រះគុណនោះ ១៣ហើយត្រូវយកនំបុ័ង
មានដំបែ[ន]មក ថែមនឹងនំទាំងនោះសំរាប់ជាដង្វាយរបស់
ខ្លួន ត្រូវថ្វាយទាំងអស់ជាមួយនឹងយញ្ញបូជានៃដង្វាយមេត្រី
ដែលថ្វាយទុកជាសេចក្ដីអរព្រះគុណ[ប] ១៤ត្រូវយកនំ១ ពី
រាល់តែដង្វាយយ៉ាងនោះ សំរាប់ជាដង្វាយលើកចុះឡើង
ថ្វាយព្រះយេហូវ៉ា នំនោះត្រូវបានជារបស់ផងសង្ឃណា
ដែលប្រោះឈាមដង្វាយមេត្រី[ផ] ១៥ឯសាច់នៃយញ្ញបូជារបស់
ដង្វាយមេត្រី ដែលសំរាប់ជាសេចក្ដីអរព្រះគុណ នោះត្រូវ
បរិភោគក្នុងថ្ងៃដែលបានថ្វាយនោះឯង មិនត្រូវទុកឱ្យដល់
ភ្លឺឡើយ[ផ] ១៦តែបើយញ្ញបូជានោះជាដង្វាយលាបំណន់[ព]
ឬជាដង្វាយស្ម័គ្រពីចិត្តវិញ[ភ] នោះត្រូវបរិភោគក្នុងថ្ងៃដែល
ថ្វាយនោះឯង ហើយដល់ស្អែក ក៏នឹងបរិភោគអ្វីដែលនៅ
សល់បានដែរ[ម] ១៧ឯរបស់អ្វីដែលសល់ពីសាច់នៃយញ្ញបូជា
ក្នុងថ្ងៃទី៣ នោះត្រូវដុតនឹងភ្លើងទៅ[យ] ១៨បើអ្នកណា
បរិភោគសាច់នៃយញ្ញបូជាជាដង្វាយមេត្រី[រ]របស់ខ្លួនក្នុង
ថ្ងៃទី៣ យញ្ញបូជានោះឈ្មោះថា ព្រះមិនបានទទួលទេ[ល] គឺ
ទុកដូចជាមិនបានថ្វាយវិញ[វ] ដង្វាយនោះនឹងត្រឡប់ទៅជា
របស់គួរស្អប់ខ្ពើម ឯអស់អ្នកណាដែលបរិភោគ នោះក៏នឹង
ត្រូវមានទោសដែរ[ស]។

១៩ឯសាច់ណាដែលប៉ះពាល់នឹងរបស់អ្វីមិនស្អាត នោះ
មិនត្រូវបរិភោគឡើយ ត្រូវតែដុតនឹងភ្លើងវិញ តែ
សាច់ណាដែលស្អាត នោះអ្នកដែលបរិសុទ្ធនឹងបរិភោគ
បាន ២០បើអ្នកណាដែលជាប់មានសេចក្ដីសៅហ្មងនៅខ្លួន[ហ]
បានបរិភោគសាច់នៃយញ្ញបូជា ជាដង្វាយមេត្រី ដែលជា
របស់ផងព្រះយេហូវ៉ា នោះនឹងត្រូវកាត់កាល់ចេញពី
សាសន៍ខ្លួន[ឡ] ២១ហើយបើអ្នកណាប៉ះពាល់នឹងរបស់មិនស្អាត
អ្វីក៏ដោយ[អ] ទោះបើជាសេចក្ដីស្មោកគ្រោករបស់មនុស្ស
ឬរបស់សត្វដែលមិនស្អាត ឬរបស់ស្មោកគ្រោកណាមួយ
ដែលគួរខ្ពើមឆ្អើម រួចនឹងបរិភោគសាច់នៃយញ្ញបូជា
ដង្វាយមេត្រីរបស់ផងព្រះយេហូវ៉ា អ្នកនោះនឹងត្រូវកាត់
កាល់ចេញពីសាសន៍របស់ខ្លួន ។

## បម្រាមការបរិភោគខ្លាញ់ និងឈាម

២២ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេ ២៣ឱ្យហាមដល់ពួក
កូនចៅអ៊ីស្រាអែលថា កុំឱ្យឯងរាល់គ្នាបរិភោគខ្លាញ់គោ

**៧:៩** ឋ លវ ២:៤ ឌ លវ ២:៧ ឍ លវ ២:៥ **៧:១២** ណ ខ.១៣,១៥ លវ ២២:២៩ ទដ ៥០:១៤ ៥៤:៦ ១០៧:២២ ១១៦:១៧ យរ ៣៣:១១ ត យរ ៤៤:១៩ ថ ជន ៦:១៩ ទ លវ ២:៤ ធ លវ ២:១ **៧:១៣** ន លវ ២៣:១៧ អម ៤:៥ ប ខ.១២ នក ៣៤:២២ **៧:១៥** ផ នក ១២:១០ **៧:១៦** ព លប ២៨:២០ លវ ១:២ ចទ ២៣:២១–២៣ ភ នក ៣៥:២៩ លវ ២២:១៨,២១ ២៣:៣៨ ជន ១៥:៣ ២៩:៣៩ ចទ ១២:៦ ទដ ៥៤:៦ អគ ៤៦:១២ ម លវ ១៩:៥–៨ **៧:១៧** យ នក ១២:១០ លវ ១៩:៦ **៧:១៨** រ ២របា ៣៣:១៦ ល លវ ១៩:៧ វ ជន ១៨:២៧ ស លវ ៥:១ **៧:២០** ហ លវ ៥:៣ ឡ លប ១៧:១៤ លវ ២២:៣–៧ **៧:២១** អ លវ ៥:២

**៧:១១–៣៦** នៅវគ្គនេះជាការបន្ថែមនូវការបង្គាប់បញ្ជាដូចតទៅ (១). ដង្វាយមេត្រីបីយ៉ាង (ដង្វាយអរព្រះគុណ ខ.១២–១៥ ដង្វាយលាបំណន់ ខ.១៦ ដង្វាយស្ម័គ្រពីចិត្ត ខ.១៦) (២).ការហាមប្រាមក្នុងការបរិភោគខ្លាញ់ និងឈាម (ខ.២២–២៧) (៣).ការចែករំលែករបស់ពួកសង្ឃ (ខ.២៨–៣៦) ។

**៧:១២–១៥** ត្រង់វគ្គនេះបង្ហាញពីការដឹងគុណចំពោះព្រះអម្ចាស់ ដែលព្រះទ្រង់បានជួយឱ្យជាពីជំងឺ(ទដ ១១៦:១៧) បញ្ហាផ្សេងៗ (ទដ ១០៧:២២) ឬរួចពីសេចក្ដីស្លាប់ (ទដ ៦៥:១២) និងសម្រាប់ព្រះពរដែលព្រះផ្ដល់ឱ្យ ។

**៧:១៣** *នំបុ័ងមានដំបែ* ការបង្គាប់បញ្ជានេះ មិនជំទាស់នៅត្រង់ចំណុចនៃការហាមប្រាមក្នុង ២:១១ ឬ នក ២៣:១៨ ដែលក្នុងចំណុចទាំងពីរនេះ ដង្វាយមិនត្រូវបានដុតនៅលើអាសនាឡើយ ។

**៧:១៥–១៨** សូមមើល ១៩:៥–៨ ។ នៅវគ្គនេះបានប្រាប់ថា ម្ហូបអាហារត្រូវបរិភោគឱ្យត្រូវតាមពេលកំណត់ (នៅថ្ងៃអរព្រះគុណ គេបរិភោគថ្ងៃនោះតែម្ដង រីឯនៅថ្ងៃដែលគេថ្វាយដង្វាយលាបំណន់ និងស្ម័គ្រពីចិត្តនោះត្រូវបរិភោគនៅថ្ងៃនោះ និងបន្តនៅថ្ងៃបន្ទាប់ទៀត) ។ ហេតុផលមួយទៀតដែលបានកើតមាននៅទីកដីកាណាននោះគឺ ម្ហូបអាហារចាប់ផ្ដើមខូចយ៉ាងលឿន ដូច្នោះហើយពិធីនេះក្លាយជាពិធីដ៏គួរឱ្យស្អប់ខ្ពើម នៅចំពោះព្រះ (ខ.១៨) ។ ដូច្នេះដង្វាយទាំងអស់នោះ គឺមិនបានបរិសុទ្ធនៅចំពោះព្រះឡើយ (១:៣ មើល ២១:១៦–២៣) ។ ការហាមប្រាមក្នុងការបរិភោគនេះបានឆ្លើយតបទៅដល់បុណ្យរំលង (នក ១២:១០) ។

**៧:១៦** *លាបំណន់* មើល ២២:១៨–២៣ ។ ដង្វាយលាបំណន់ គឺជាការសន្យាដ៏មុតមាំរបស់អ្នកថ្វាយ នូវអ្វីដែលខ្លួនបានសន្យាចំពោះព្រះ ។ ការលាបំណន់តែងតែប្រព្រឹត្តទៅជាមួយនឹងការអធិស្ឋាន (មើលការពន្យល់ ទដ ៧:១៧) ។ *ដង្វាយស្ម័គ្រពីចិត្ត* មើលការពន្យល់ ២២:១៨–២៣ ។

**៧:១៩** *របស់អ្វីមិនស្អាត* មើលការពន្យល់ ៤:១២ ។

**៧:២០** *កាត់កាល់ចេញពីសាសន៍ខ្លួន* ចំណុចត្រង់នេះបានប្រាប់ថា ចំពោះមនុស្សដែលលះចោលសេចក្ដីសញ្ញា នោះត្រូវប្រឈមមុខនឹងការជំនុំជម្រះរបស់ព្រះអម្ចាស់ដោយផ្ទាល់ (មើល នក ១៧:១៤)(ខ.២១,២៥,២៧, ១៧:៤,៩–១០,១៤ ១៨:២៩ ១៩:៨ ២០:៣,៥–៦,១៧–១៨ ២៣:២៩) ឆ្លងកាត់ការប្រព្រឹត្ត (មើល ២០:២–៣ នក ៣១:១៤) ឬជួនកាលអាចជាការនិរទេសខ្លួន ។

**៧:២១** *គួរខ្ពើមឆ្អើម* ព្រះអម្ចាស់បានកាត់ទោសសម្រាប់ការធ្វើខុសអ្វីមួយដោយសុក្រិត្យបំផុត (មើលការពន្យល់ ខ.២០ ១៣:២៩ ២០:១៣) ។

**៧:២២–២៧** មើលការពន្យល់ ១៧:១១ ។

ខ្លាញ់ចៀម ឬខ្លាញ់ពពែឡើយ[ក] ២៤ឯខ្លាញ់សត្វណាដែល
ស្លាប់ឯង ឬត្រូវសត្វព្រៃហែកហួរ[ខ] នោះនឹងប្រើធ្វើការអ្វី
ផ្សេងក៏បាន តែមិនត្រូវឱ្យបរិភោគឡើយ ២៥ដ្បិតអ្នកណា
ដែលបរិភោគខ្លាញ់របស់សត្វ ជាសត្វដែលមនុស្សតែង
ធ្លាប់យកមកថ្វាយ ជាដង្វាយដុតដល់ព្រះយេហូវ៉ា អ្នកនោះ
នឹងត្រូវកាត់កាល់ចេញពីសាសន៍របស់ខ្លួន ២៦ហើយមិនត្រូវ
បរិភោគឈាមយ៉ាងណា[គ]នៅក្នុងទីលំនៅរបស់ឯងរាល់
គ្នាណាមួយឡើយ ទោះទាំងឈាមរបស់សត្វហើរ ឬឈាម
នៃសត្វជើង៤ក្តី ២៧អ្នកណាដែលបរិភោគឈាមអ្វីក៏ដោយ
[ឃ]អ្នកនោះនឹងត្រូវកាត់កាល់ចេញពីសាសន៍របស់ខ្លួន ។

## ចំណែករបស់ពួកសង្ឃ

២៨ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេ ២៩ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា អ្នកណាដែលថ្វាយយញ្ញបូជា ជា
ដង្វាយមេត្រីរបស់ខ្លួន ដល់ព្រះយេហូវ៉ា នោះត្រូវយក១
ផ្នែក ពីយញ្ញបូជានោះ មកថ្វាយដល់ព្រះយេហូវ៉ា ៣០ដៃអ្នក
នោះឯង ត្រូវយកដង្វាយដែលសំរាប់ដុតថ្វាយព្រះយេហូវ៉ា
មក គឺត្រូវយកខ្លាញ់ជាមួយនឹងទ្រូងមក ដើម្បីឱ្យបានគ្រវី
ទ្រូងនោះ ទុកជាដង្វាយគ្រវី នៅចំពោះព្រះយេហូវ៉ា[ង]
៣១រួចត្រូវឱ្យសង្ឃដុតខ្លាញ់នៅលើអាសនា[ច] តែឯទ្រូងនោះ
ត្រូវបានជារបស់ផងអើរ៉ុន និងពួកកូនលោក[ឆ] ៣២ឯស្មាស្តាំ
នៃអស់ទាំងយញ្ញបូជា ដែលឯងរាល់គ្នាថ្វាយជាដង្វាយ
មេត្រី នោះត្រូវប្រគល់ដល់សង្ឃទុកជាដង្វាយលើកចុះ
ឡើង[ជ] ៣៣អ្នកណាក្នុងពួកកូនអើរ៉ុនដែលថ្វាយឈាមហើយ
និងខ្លាញ់នៃដង្វាយមេត្រី នោះត្រូវបានស្មាស្តាំជាចំណែក
ដល់ខ្លួន ៣៤ដ្បិតអញបានញែកទ្រូងដែលគ្រវីនិងស្មាដែល
លើកចុះឡើងនោះ[ឈ]ចេញពីយញ្ញបូជា ដែលពួកកូនចៅ

**៧:២៣** ក លវ ១៧:១៣–១៤ ចទ ១៤:៤
**៧:២៤** ខ នក ២២:៣១
**៧:២៦** គ លប ៩:៤
**៧:២៧** ឃ លប ៩:៤
**៧:៣០** ង នក ២៩:២៤
**៧:៣១** ច នក ២៩:១៣ ឆ នក ២៩:២៧
**៧:៣២** ជ នក ២៩:២៧ លវ ១០:១៤,១៥ ជន ៥:៩ ៦:២០ ១៨:១៨
**៧:៣៤** ឈ នក ២៩:២២ លវ ១០:១៥ ជន ៦:២០ ១សយ ៩:២៤
ញ នក ២៩:២៧
**៧:៣៦** ដ លវ ៨:១២,៣០
**៧:៣៧** ឋ លវ ៦:៩ ឌ លវ ៦:១៤ ឍ នក ២៩:៣១
**៧:៣៨** ណ លវ ២៦:៤៦ ជន ៣៦:១៣ ចទ ៤:៥ ២៩:១ ត នក ១៩:១១ ថ លវ ១:២
**៨:២** ក នក ២៨:១ លវ ១:៥ ខ នក ២៨:២,៤,៤៣ ៣៩:២៧ គ នក ៣០:២៣–២៥,៣០ ឃ នក ៣០:១០ ង ខ.១៨,២២ ច នក ២៩:២–៣

អ៊ីស្រាអែលថ្វាយជាដង្វាយមេត្រី ប្រគល់ឱ្យដល់អើរ៉ុនដ៏
ជាសង្ឃ និងពួកកូនលោក[ញ]ទុកជាចំណែកដល់គេពីពួកកូន
ចៅអ៊ីស្រាអែលនៅអស់កល្បជានិច្ចហើយ ៣៥នេះហើយជា
ចំណែករបស់អើរ៉ុន និងជាចំណែករបស់ពួកកូនលោក
ពីអស់ទាំងដង្វាយដែលដុតថ្វាយព្រះយេហូវ៉ា ចាប់តាំង
ពីថ្ងៃដែលបានតាំងគេឱ្យធ្វើការងារជាសង្ឃ ថ្វាយព្រះ
យេហូវ៉ាតទៅ ៣៦គឺជាចំណែកដែលព្រះយេហូវ៉ា បាន
បង្គាប់ឱ្យពួកកូនចៅអ៊ីស្រាអែលប្រគល់ដល់គេ នៅថ្ងៃដែល
បានចាក់លាបប្រេងតាំងឡើង[ដ] នេះហើយជាចំណែករបស់
គេ នៅអស់កល្បជានិច្ច ដល់អស់ទាំងដំណរបស់គេតរៀង
ទៅ ។
៣៧ច្បាប់ទាំងនេះហើយ ជារបៀបនៃដង្វាយដុត[ឋ] ដង្វាយ
ម្សៅ[ឌ] ដង្វាយលោះបាប និងដង្វាយដែលថ្វាយដោយ
ព្រោះការប្រព្រឹត្តរំលង ដង្វាយតាំងជាសង្ឃ[ឍ] ហើយនិង
យញ្ញបូជាជាដង្វាយមេត្រី ៣៨ដែលព្រះយេហូវ៉ាទ្រង់បាន
បង្គាប់ដល់ម៉ូសេ[ណ]នៅលើភ្នំស៊ីណាយ[ត] នៅថ្ងៃដែលទ្រង់
បានបង្គាប់ដល់ពួកកូនចៅអ៊ីស្រាអែល នៅទីរហោស្ថាន
ស៊ីណាយ ឱ្យបានថ្វាយដង្វាយគេដល់ព្រះយេហូវ៉ា[ថ]។

## ការចាក់ប្រេងតាំងលោកអើរ៉ុន និងកូនលោក

*៨:១–៣៦ – នក ២៩:១–៣៧*

**៨** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២ចូរនាំយក
អើរ៉ុន និងពួកកូនលោក[ក] ព្រមទាំងសំលៀកបំពាក់[ខ]ប្រេង
ចាក់តាំង[គ] គោឈ្មោលស្ទាវ១ សំរាប់ជាដង្វាយលោះបាប[ឃ]
ចៀមឈ្មោល២[ង] និងកញ្ច្រែងនំបុ័ងឥតដំបែមកជាមួយផង[ច]

**៧:២៣** *ខ្លាញ់* ការហាមប្រាមមិនឱ្យបរិភោគខ្លាញ់ គឺដូចទៅនឹងឈាមដែរ ប៉ុន្តែមានហេតុផលផ្សេងគ្នា ។ ចំពោះខ្លាញ់នៃដង្វាយមេត្រីគឺសម្រាប់តែព្រះអម្ចាស់ ហើយត្រូវដុតនៅលើអាសនាជានិច្ច (មើល ៣:១៦ និងការពន្យល់)។ គ្មានការបញ្ជាក់ច្បាស់អំពីការហាមប្រាមមិនឱ្យបរិភោគខ្លាញ់សត្វ ដែលបានសម្លាប់ ដូចជាសត្វក្តាន់ ប៉ុន្តែទាំងអស់នេះក៏មានរួមបញ្ចូលនៅក្នុង(មើល ៣:១៧ ចទ ១២:១៥–២២) ។

**៧:២៦** *មិនត្រូវបរិភោគឈាម* មើលការពន្យល់ ១៧:១១ ៣:១៧ ១៩:២៦ នក ៩:៤–៦ ចទ ១២:១៦,២៣–២៥ ១៥:២៣ ១សយ ១៤:៣២–៣៤ អគ ៣៣:២៥ ។

**៧:២៨–៣៦** សូមមើល ១០:១២–១៥ ជន ១៨:៨–២០ ចទ ១៨:១–៥ ។

**៧:៣០–៣២** *ទ្រូង . . . លើកចុះឡើង* ទ្រូងហើយនិងដង្វាយលើកចុះឡើងត្រូវបានគេផ្តល់ឱ្យសង្ឃជាអំណោយលើកដំបូង ថ្វាយដល់ព្រះអម្ចាស់ ជាមួយនឹងកាយវិកាលើកដៃទាំងគូថ្វាយទ្រូង និងដង្វាយលើកចុះឡើង (ខ.៣៤ មើល ៨:២៥–២៩ ៩:២១ ១០:៤–១៥ នក ២៩:២៦–២៧ ជន ៦:២០ ១៨:១១,១៨) ។

**៧:៣៧–៣៨** នេះជាការសង្ខេប ពីជំពូក១ ដល់ជំពូក៧ ។

**៧:៣៧** *ដង្វាយតាំងជាសង្ឃ* មើល៨:១៤–៣៦ នក ២៩:១–៣៥ ។

**៨:១–១០:២០** នៅវគ្គនេះ គឺការតាំងជាសង្ឃ ការស្តាឡើងវិញបេសកកម្មរបស់លោកអើរ៉ុន និងកូនចៅរបស់គាត់ ហើយនិងការស្លាប់របស់លោកណាដាប លោកអ័ប៊ីហ៊ូវ និងការគោរពវិន័យ ។

**៨:២** *សំលៀកបំពាក់* សូមមើល នក ៣៩:១–៣១ ៤០:១២–១៦ ។ សំលៀកបំពាក់នៅត្រង់នេះជារបស់សម្តេចសង្ឃ នក ២៨:៤–៤៣ ។ *ប្រេងចាក់តាំង* មើលការពន្យល់ នក ២៥:៦ ។ ប្រេងត្រូវបានគេចាក់ទៅលើរោងឧបោសថជាវត្ថុដ៏វិសុទ្ធ ហើយសម្រាប់តែងតាំងពួកសង្ឃ (មើល ខ.១០–១២,៣០) ។ ប្រេងនេះផងដែរ ក្រោយមកត្រូវបានគេចាក់ទៅលើអ្នកដឹកនាំ និងស្តេចដែរ (១សយ ១០:១ ១៦:១៣) និងការពន្យល់បន្ថែមទៀត នក ២៩:៧ ។

៣ ហើយប្រជុំពួកជំនុំទាំងអស់គ្នា[ឆ]មកនៅមាត់ទ្វារត្រសាល
ជំនុំ ៤ម៉ូសេក៏ធ្វើតាមដែលព្រះយេហូវ៉ាបង្គាប់មក ឯពួកជំនុំ
គេមូលគ្នានៅមាត់ទ្វារត្រសាលជំនុំ ៥នោះម៉ូសេក៏ប្រាប់
ដល់ពួកជំនុំថា នេះជាសេចក្តីដែលព្រះយេហូវ៉ាទ្រង់បង្គាប់
ឱ្យធ្វើ[ជ] ។
៦ម៉ូសេក៏នាំអើរ៉ុន និងពួកកូនលោក មកផ្ងូតទឹកឱ្យ[ឈ] ៧រួច
បំពាក់អាវខ្លីឱ្យអើរ៉ុន ព្រមទាំងក្រវាត់ខ្សែក្រវាត់ ហើយ
បំពាក់អាវវែងពីលើ ក៏បំពាក់អេផូឌ ហើយចងភ្ជាប់ដោយ
ខ្សែដែលជាប់នឹងអេផូឌនោះផង[ញ] ៨រួចបំពាក់ប្រដាប់បាំង
ទ្រូង ហើយដាក់យូរីម និងធូមីម[ដ] ជាប់នៅប្រដាប់បាំងទ្រូង
ដែរ[ឋ] ៩ក៏បំពាក់មួក[ឌ]នៅលើក្បាល ហើយភ្ជាប់ស្លាកមាស
គឺជាក្បាំងបរិសុទ្ធ[ឍ] ឱ្យជាប់នឹងមួកពីខាងមុខ ដូចជាព្រះ
យេហូវ៉ាបានបង្គាប់មក[ណ]។
១០រួចម៉ូសេយកប្រេង[ត] ទៅចាក់លាប[ថ]រោងឧបោសថ[ទ]
និងគ្រប់របស់ទាំងអស់ ដែលនៅក្នុងរោងនោះ ញែកចេញ
ជាបរិសុទ្ធ ១១ហើយក៏យកទៅប្រោះលើអាសនា៧ដង
លោកចាក់លាបអាសនា និងប្រដាប់អាសនាទាំងប៉ុន្មាន
ព្រមទាំងចានក្លាំ និងជើងនៃចាននោះផង ដើម្បីនឹងញែក
ចេញជាបរិសុទ្ធ[ធ] ១២ក៏ចាក់ប្រេងខ្លះ[ន]លើក្បាលអើរ៉ុន ទាំង
លាបឱ្យបានបរិសុទ្ធ[ប] ១៣រួចលោកនាំយកពួកកូនអើរ៉ុន[ផ]មក
បំពាក់អាវខ្លី[ព] ហើយក្រវាត់ខ្សែក្រវាត់ ព្រមទាំងជួតឈ្នួត
ផង ដូចជាព្រះយេហូវ៉ាបានបង្គាប់មក[ភ]។
១៤បន្ទាប់មក លោកនាំយកគោឈ្មោលស្ទាវ[ម] ដែល
សំរាប់ដង្វាយលោះបាបមក[យ] ហើយអើរ៉ុន និងពួកកូនទាំង
ប៉ុន្មាន ក៏ដាក់ដៃលើក្បាលគោ[រ] ដែលជាដង្វាយនោះ
រួចសំឡាប់ទៅ ១៥នោះម៉ូសេក៏សំអាតអាសនា លោកយក
ឈាម[ល] ដោយម្រាមដៃ ទៅប្រឡាក់លើស្នែងអាសនា[វ]ជុំវិញ
រួចចាក់ឈាមនៅត្រង់ជើងអាសនា[ស] ទាំងញែកជាបរិសុទ្ធ
ដើម្បីឱ្យបានធួននឹងអាសនានោះ[ហ] ១៦លោកយកខ្លាញ់ទាំង
អស់ដែលរុំអាការៈខាងក្នុង ស្រទាប់ថ្លើម ហើយអង្គញ់ទាំង
២ និងខ្លាញ់នៃអង្គញ់នោះ ទៅដុតទាំងអស់នៅលើអាសនា
១៧តែតួគោនោះ និងស្បែក សាច់ ហើយនិងលាមក[ឡ] លោក
ដុតនឹងភ្លើង នៅខាងក្រៅទីដំឡើងត្រសាលវិញ[អ] ដូចជាព្រះ
យេហូវ៉ាបានបង្គាប់មក ។
១៨លោកក៏នាំយកចៀមឈ្មោល[ក] ដែលសំរាប់ជាដង្វាយ
ដុតមក ហើយអើរ៉ុននិងពួកកូនទាំងប៉ុន្មានក៏ដាក់ដៃលើ
ក្បាលចៀមនោះ រួចសំឡាប់ទៅ ១៩នោះម៉ូសេក៏យកឈាម
ទៅប្រោះនៅជុំវិញលើអាសនា ២០រួចកាប់ចៀមនោះជាដុំៗ
ក៏ដុតក្បាលនិងដុំទាំងប៉ុន្មាន ព្រមទាំងខ្លាញ់ផង[ខ] ២១លោក
យកទឹកមកលាងអាការៈខាងក្នុង និងជើងទាំងប៉ុន្មាន ហើយ
ដុតចៀមនោះទាំងអស់នៅលើអាសនា នេះហើយជាដង្វាយ
ដុតសំរាប់ជាក្លិនឈ្ងុយ គឺជាដង្វាយដុតថ្វាយព្រះយេហូវ៉ា
ដូចជាព្រះយេហូវ៉ាបានបង្គាប់មក ។
២២លោកក៏នាំយកចៀមទី២ដែលសំរាប់ពិធីតាំងជា
សង្ឃមក[គ] ហើយអើរ៉ុននិងពួកកូនទាំងប៉ុន្មានក៏ដាក់ដៃលើ
ក្បាលចៀមនោះ រួចសំឡាប់ទៅ[ឃ] ២៣នោះម៉ូសេយកឈាម
ទៅលាបនៅទងត្រចៀកស្តាំ មេដៃស្តាំ និងមេជើងស្តាំ
របស់អើរ៉ុន[ង] ២៤ក៏នាំពួកកូនអើរ៉ុនមក លាបឈាមនៅទង
ត្រចៀកស្តាំ មេដៃស្តាំ និងមេជើងស្តាំដែរ ហើយប្រោះ
ឈាមនៅជុំវិញលើអាសនា[ច] ២៥រួចលោកយកខ្លាញ់[ឆ]កន្ទុយ
និងខ្លាញ់ទាំងអស់ដែលរុំអាការៈខាងក្នុង និងស្រទាប់ថ្លើម
អង្គញ់ទាំង២ និងខ្លាញ់របស់អង្គញ់នោះ ហើយនិងស្មាខាង
ស្តាំមក ២៦រួចយកនំឥតដំបែ១ នំបុ័ងលាបដោយប្រេង១
និងនំក្រៀប១[ជ] ចេញពីកញ្ច្រែងនំបុ័ងឥតដំបែដែលនៅ
ចំពោះព្រះយេហូវ៉ា ទៅដាក់លើខ្លាញ់ ហើយនិងស្មាស្តាំ
នោះ ២៧លោកដាក់ទាំងអស់នៅបាតដៃអើរ៉ុន ហើយនៅ
បាតដៃរបស់ពួកកូន ឱ្យគ្រវីរបស់ទាំងនោះ ទុកជាដង្វាយ

**៨:៣** ឆ ជន ៨:៩
**៨:៥** ជ នក ២៩:១
**៨:៦** ឈ នក ២៩:៤ ៣០:១៩ កច ២២:១៦
**៨:៧** ញ នក ២៨:៤
**៨:៨** ដ នក ២៨:៣០ ឋ នក ២៥:៧
**៨:៩** ឌ នក ៣៩:២៨ ឍ នក ២៨:៣៦ ណ នក ២៨:២ លវ ២១:១០
**៨:១០** ត ខ.២ ថ នក ៣០:២៦ ទ នក ២៦:១
**៨:១១** ធ នក ៣០:២៩
**៨:១២** ន លវ ៧:៣៦ ប នក ៣០:៣០
**៨:១៣** ផ នក ២៨:៤០ ព នក ២៨:៤,៣៩ ៣៩:២៧ ភ លវ ២១:១០
**៨:១៤** ម លវ ៤:៣ យ នក ៣០:១០ រ លវ ៤:១៥
**៨:១៥** ល លវ ៤:១៨ វ លវ ៤:៧ ស ហព ៩:២២ ហ អគ ៤៣:២០
**៨:១៧** ឡ លវ ៤:១១ អ លវ ៤:១២
**៨:១៨** ក ខ.២
**៨:២០** ខ លវ ១:៨
**៨:២២** គ ខ.២ ឃ លវ ៤:១៥
**៨:២៣** ង លវ ១៤:១៤,២៥
**៨:២៤** ច ហព ៩:១៨-២២
**៨:២៥** ឆ លវ ៣:៣-៥ **៨:២៦** ជ លវ ២:៤

**៨:៦** *ផ្ងូតទឹកឱ្យ* នៅត្រង់នេះទឹកគេដាក់នៅចានដែលធ្វើពីសំរឹត (មើល ខ.១១) ដែលដាក់នៅពីមុខរោងឧបោសថ (មើលការពន្យល់ នក ៣០:១៧–២១) ។

**៨:៨** *យូរីម និងធូមីម* សូមមើលការ នក ២៨:៣០ ១សយ ២:២៨ ។

**៨:៩** *ក្បាំងបរិសុទ្ធ* មើលការពន្យល់ នក ៣៩:៣០ ។

**៨:១១** *៧ដង* មើលការពន្យល់ ៤:៦ ។

**៨:១២** *ក៏ចាក់ប្រេងខ្លះលើក្បាលអើរ៉ុន* មើល ទដ ១៣:៣ ។

**៨:១៤** *ដង្វាយលោះបាប* មើល ៤:៣–១១ ។ ដង្វាយដុតសម្រាប់ការថ្វាយបង្គំ (ខ.១៨) និងចៀមឈ្មោលសម្រាប់ពិធីតាំងជាសង្ឃ (ខ.២២) ដែលឈាមរបស់វាបានលាបនៅលើទងត្រចៀកមេដៃ មេជើង សម្តេចសង្ឃ (ខ.២៣) បន្ទាប់ពីកម្មវិធីចប់សព្វគ្រប់ លោកអើរ៉ុនឱ្យពរដល់អ្នកទាំងអស់នោះ (៩:១៥–២១)និងក្រោយមកទៀតលោកក៏ឱ្យពរដល់ពួកគេឱ្យមានសមត្ថភាពជាសង្ឃ ដោយសិរីល្អនៃព្រះអម្ចាស់បានទទួលគេ(៩:២៣–២៤) ។ *ដាក់ដៃលើក្បាល* មើលការពន្យល់ ១:៣ នក ២៩:១០ ។

**៨:១៥** *ឱ្យធួននឹងអាសនា* សូមមើល ១៦:១៦ និង នក ២៩:៣៦ ។

**៨:១៧** *ខាងក្រៅទីដំឡើងត្រសាល* មើលការពន្យល់ ៤:៥,១២ ១៣:៤៥–៤៦ អគ ៤៣:២១ ហព ១៣:១២–១៣ ។

**៨:២៣** នៅត្រង់នេះជាទីសញ្ញាចុងក្រោយរបស់លោកអើរ៉ុន ដែលគាត់បានបញ្ចប់នូវកិច្ចការបម្រើព្រះអម្ចាស់ ក្នុងនាមជាអ្នកតែងតាំង(ធៀប ខ.១៤) ។

**៨:២៧** *ដង្វាយគ្រវី* សូមមើលការពន្យល់ ៧:៣០–៣២ ។

គ្រវីនៅចំពោះព្រះយេហូវ៉ា[ឈ] ២៨បន្ទាប់មក លោកយកពីដៃ
អ្នកទាំងនោះទៅដុតលើដង្វាយដែលនៅលើអាសនា នេះ
ហើយជាដង្វាយសំរាប់ពិធីតាំងជាសង្ឃទុកជាខ្លិនឈ្ងុយ
គឺជាដង្វាយដុតថ្វាយដល់ព្រះយេហូវ៉ា ២៩ម៉ូសេក៏យកទ្រូង
ទៅគ្រវីទុកជាដង្វាយគ្រវីនៅចំពោះព្រះយេហូវ៉ា នេះ
ហើយជាចំណែករបស់ម៉ូសេក្នុងចៀមឈ្មោល[ញ] ដែល
សំរាប់ពិធីតាំងជាសង្ឃ ដូចជាព្រះយេហូវ៉ាបានបង្គាប់មក
៣០រួចម៉ូសេ[ដ]ក៏យកប្រេងលាបនិងឈាមខ្លះ ដែលនៅលើ
អាសនាទៅប្រោះលើអើរ៉ុន លើសំលៀកបំពាក់របស់
លោក[ឋ] ព្រមទាំងលើពួកកូនលោកនិងសំលៀកបំពាក់
របស់ពួកកូននោះផង ហើយញែក[ឌ]អើរ៉ុននិងសំលៀក
បំពាក់ លោកព្រមទាំងពួកកូនលោកនិងសំលៀកបំពាក់
របស់គេចេញជាបរិសុទ្ធទាំងអស់ ។
៣១ម៉ូសេក៏បង្គាប់អើរ៉ុននិងពួកកូនលោកថា ចូរស្ងោរ
សាច់នៅត្រង់មាត់ទ្វារត្រសាលជំនុំ[ឍ] រួចបរិភោគនៅ
ទីនោះចុះ ព្រមទាំងនំបុ័ងដែលនៅក្នុងកញ្ច្រែងនៃពិធីតាំង
ជាសង្ឃផង ដូចជាខ្ញុំបានទទួលបង្គាប់ហើយថា ត្រូវឲ្យ
អើរ៉ុននិងពួកកូនលោកបរិភោគរបស់ទាំងនោះ ៣២ឯ
សាច់ និងនំបុ័ងដែលសល់នៅ នោះត្រូវដុតនឹងភ្លើងទៅ
៣៣ហើយមិនត្រូវឲ្យអ្នករាល់គ្នាចេញពីត្រសាលជំនុំនៅអស់
៧ថ្ងៃ ដរាបដល់អស់ទាំងថ្ងៃ ដែលតាំងអ្នករាល់គ្នាឡើងជា
សង្ឃបានសំរេច ដ្បិតត្រូវធ្វើពិធីតាំងអ្នករាល់គ្នាជាសង្ឃ
ឲ្យគ្រប់៧ថ្ងៃ[ណ] ៣៤ព្រះយេហូវ៉ាទ្រង់បានបង្គាប់ឲ្យធ្វើ[ត] ដូច
ជាបានធ្វើហើយនៅថ្ងៃនេះ ដើម្បីឲ្យធួននឹងអ្នករាល់គ្នា
៣៥ត្រូវឲ្យអ្នករាល់គ្នានៅត្រង់មាត់ទ្វារត្រសាលជំនុំគ្រប់៧
យប់៧ថ្ងៃ ទាំងរក្សាបញ្ញើរបស់ព្រះយេហូវ៉ា[ថ] ដើម្បីកុំឲ្យ
ត្រូវស្លាប់ឡើយ ដ្បិតខ្ញុំបានទទួលបង្គាប់មកយ៉ាងដូច្នេះ
ហើយ ៣៦នោះអើរ៉ុន និងពួកកូនលោកក៏ធ្វើសំរេចគ្រប់ការ
ទាំងអស់ តាមដែលព្រះយេហូវ៉ាបានបង្គាប់មកដោយសារ
ម៉ូសេ ។

## ពួកសង្ឃចាប់ផ្តើមការងារ

៩ ១លុះដល់ថ្ងៃទី៨[ក] ម៉ូសេក៏ហៅអើរ៉ុន និងពួកកូនលោក
មក ព្រមទាំងពួកចាស់ទុំ[ខ]នៃសាសន៍អ៊ីស្រាអែលផង ២រួច
បង្គាប់ដល់អើរ៉ុនថា ចូរយកកូនគោ១ ពីហ្វូងសត្វសំរាប់
ជាដង្វាយលោះបាប និងចៀមឈ្មោល១ឥតខ្ចោះសំរាប់ជា
ដង្វាយដុត មកថ្វាយនៅចំពោះព្រះយេហូវ៉ា ៣ហើយត្រូវ
ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល ឲ្យគេយកពពែឈ្មោល១[គ]
សំរាប់ជាដង្វាយលោះបាប[ឃ] និងកូនគោ១[ង] ហើយកូនចៀម
១[ច] ដែលទាំង២មានអាយុ១ខួប ហើយឥតខ្ចោះសំរាប់ជា
ដង្វាយដុត ៤ព្រមទាំងគោឈ្មោល១[ឆ]និងចៀមឈ្មោល១
សំរាប់ជាដង្វាយមេត្រី[ជ] ដើម្បីនឹងថ្វាយ ជាយញ្ញបូជា នៅ
ចំពោះព្រះយេហូវ៉ា ហើយនិងដង្វាយម្សៅលាយដោយ
ប្រេងផង ដ្បិតនៅថ្ងៃនេះព្រះយេហូវ៉ានឹងលេចមកឯអ្នក
រាល់គ្នា[ឈ] ៥គេក៏នាំយកដង្វាយដែលម៉ូសេបានបង្គាប់ទាំង
ប៉ុន្មាននោះ មកនៅមុខត្រសាលជំនុំ រួចពួកជំនុំទាំងអស់គ្នា
ក៏ចូលមកជិត ឈរនៅចំពោះព្រះយេហូវ៉ា ៦នោះម៉ូសេ
ប្រកាសថា នេះហើយជាសេចក្តីដែលព្រះយេហូវ៉ាបាន
បង្គាប់មកឲ្យអ្នករាល់គ្នាធ្វើតាម យ៉ាងនោះសិរីល្អនៃព្រះ
យេហូវ៉ា[ញ]នឹងលេចមកឲ្យអ្នករាល់គ្នាឃើញ ។
៧ម៉ូសេបង្គាប់ដល់អើរ៉ុនថា ចូរទៅឯអាសនា ហើយថ្វាយ
ដង្វាយលោះបាប និងដង្វាយដុតរបស់បង សំរាប់ឲ្យធួននឹង
ខ្លួន ហើយនិងពួកជនផង[ដ] រួចថ្វាយដង្វាយរបស់ពួកជនឲ្យ
ធួននឹងគេ ដូចជាព្រះយេហូវ៉ាបានបង្គាប់មក[ឋ] ៨អើរ៉ុនក៏ចូល
ទៅឯអាសនា សំឡាប់កូនគោទុកជាដង្វាយលោះបាប[ឌ]
ដែលសំរាប់ខ្លួន ៩ហើយពួកកូនលោកក៏យកឈាមមកជូន[ឍ]
នោះលោកជ្រលក់ម្រាមដៃទៅក្នុងឈាមយកទៅប្រឡាក់
នៅស្នែងអាសនា[ណ] រួចចាក់ឈាមទាំងប៉ុន្មាននៅត្រង់ជើង
អាសនា[ត] ១០ឯខ្លាញ់និងអង្គញ់ទាំង២ ហើយនិងស្រទាប់
ដែលយកពីថ្លើមរបស់សត្វ ដែលសំរាប់ជាដង្វាយលោះ
បាបនោះ លោកក៏ដុតនៅលើអាសនា ដូចជាព្រះយេហូវ៉ា
បានបង្គាប់មកម៉ូសេ ១១តែឯសាច់ និងស្បែក[ថ] នោះបានដុត
នឹងភ្លើង នៅខាងក្រៅទីដំឡើងត្រសាលវិញ[ទ] ១២លោកក៏
សំឡាប់ដង្វាយដុត[ធ] ហើយពួកកូនលោកក៏យកឈាម[ន]មក
ជូន រួចលោកប្រោះឈាមនោះនៅជុំវិញលើអាសនា

**៨:២៧** ឈ ជន ៥:២៥
**៨:២៩** ញ លវ ៧:៣១ -៣៤
**៨:៣០** ដ នក ២៨:១ ឋ នក ២៨:២ ឌ លវ ៧:៣៦
**៨:៣១** ឍ លវ ៦:១៦
**៨:៣៣** ណ លវ ១៤:៨ ១៥:១៣,២៨ ជន ១៩:១១ អគ ៤៣:២៥
**៨:៣៤** ត ហប ៧:១៦
**៨:៣៥** ថ លវ ១៨:៣០ ២២:៩ ជន ៣:៧ ៩:១៩ ចទ ១១:១ ១ពវ ២:៣ អគ ៤៨:១១ សក ៣:៧
**៩:១** ក អគ ៤៣:២៧
ខ លវ ៤:១៥
**៩:៣** គ លវ ៤:៣ ឃ ខ.១៥ លវ ១០:១៦ ង ខ.៨ ច លវ ៤:៣២
**៩:៤** ឆ លវ ៤:១០ ជ នក ៣២:៦ ឈ នក ២៩:៤៣
**៩:៦** ញ នក ១៦:៧
**៩:៧** ដ លវ ១៦:៦ ឋ នក ៣០:១០ ហប ៥:១,៣ ៧:២៧
**៩:៨** ឌ លវ ៤:១-១២ ១០:១៩
**៩:៩** ឍ ខ.១២,១៨ ណ នក ២៩:១២ ត អគ ៤៣:២០
**៩:១១** ថ លវ ៤:១១ ទ លវ ៤:១២
**៩:១២** ធ លវ ១០:១៩ ន ខ.៩

**៨:២៨** *ដុតលើដង្វាយដែលនៅលើអាសនា* មើលការពន្យល់ ៣:៥ ។
**៨:៣១** *ចូរស្ងោរ . . . រួចបរិភោគ* នៅក្នុងខនេះជាការដកស្រង់ចេញពី នក ២៩:៣២ ។
**៩:១** *ថ្ងៃទី៨* នេះជារយៈពេលក្រោយពី ៧ថ្ងៃនៃការតែងតាំង (៨:៣២) ។
**៩:២** *ដង្វាយលោះបាប* មើលការពន្យល់ ៤:៣,៥ ។ *ដង្វាយដុត* មើលការពន្យល់ ១:៣ ។
**៩:៤** *ដង្វាយមេត្រី* មើលការពន្យល់ ៣:១ ។ *ដង្វាយម្សៅ* មើលការពន្យល់ ២:១ ។ *ព្រះយេហូវ៉ានឹងលេចមក* សូមមើល ខ.៦,២៣ និងពន្យល់ នក ១២:៧ ។
**៩:៦,២៣** *សិរីល្អនៃព្រះយេហូវ៉ា* មើលការពន្យល់ នក ១៦:១៧ ៤០:៣៤ ទដ ២៦:៨ អគ ១:១-២៨ ។
**៩:៨** *ទុកជាដង្វាយលោះបាបដែលសំរាប់ខ្លួន* ចំណុចនេះព្រះយេស៊ូវមានភាពផ្ទុយគ្នាទៅនឹង ហប ៧:២៦-២៨ និងការពន្យល់ផ្ទាល់ ។
**៩:១១** *ក្រៅទីដំឡើងត្រសាល* មើលការពន្យល់ ៨:១៧ ។

១៣ពួកកូនក៏យកដង្វាយដុតមកជូនលោកទាំងដុំៗ ព្រមទាំង
ក្បាលផង ហើយលោកដុតទាំងអស់នៅលើអាសនា[ប] ១៤ឯ
អាការៈខាងក្នុងនឹងជើងទាំងប៉ុន្មាន នោះលោកលាងនឹង
ទឹក រួចដុតនៅលើដង្វាយដែលនៅលើអាសនាផង[ផ] ។
១៥បន្ទាប់មក លោកថ្វាយដង្វាយរបស់ពួកជន[ព]លោកយក
ពពែជាដង្វាយលោះបាប ដែលសំរាប់ពួកជនមកសំឡាប់
ថ្វាយដោយព្រោះបាប ដូចជារបៀបនៃសត្វមុនដែរ ១៦រួច
ក៏យកដង្វាយដុត មកថ្វាយតាមរបៀប[ភ] ១៧ហើយលោកក៏
ថ្វាយដង្វាយម្សៅដែរ លោកយក១ក្ដាប់ទៅដុតលើអាសនា
ជាក្ដាប់ផ្សេងពីដង្វាយដុតពេលព្រឹក[ម] ១៨រួចមកលោក
សំឡាប់គោឈ្មោល និងចៀមឈ្មោលទុកជាយញ្ញបូជានៃ
ដង្វាយមេត្រីដែលសំរាប់ពួកជន[យ] ឯពួកកូនលោកក៏យក
ឈាមមកជូន នោះលោកប្រោះនៅជុំវិញលើអាសនា
១៩ពួកកូនក៏ជូនខ្លាញ់គោឈ្មោល និងចៀមឈ្មោល កន្ទុយ
និងខ្លាញ់ដែលជាប់អាការៈខាងក្នុង ព្រមទាំងអង្គញ់ទាំង២
និងស្រទាប់ថ្លើមផង ២០គេដាក់ខ្លាញ់ពីលើទ្រូង រួចអើរ៉ុនក៏
ដុតខ្លាញ់ទាំងនោះ នៅលើអាសនា ២១ហើយគ្រវីទ្រូង
និងស្មាខាងស្ដាំ ទុកជាដង្វាយគ្រវី នៅចំពោះព្រះយេហូវ៉ា[រ]
ដូចជាម៉ូសេបានបង្គាប់មក ។
២២នោះអើរ៉ុនក៏លើកដៃឱ្យពរដល់ពួកបណ្ដាជន[ល]រួចចុះ
មកពីការថ្វាយដង្វាយលោះបាប ដង្វាយដុត និងដង្វាយ
មេត្រី ២៣ម៉ូសេនិងអើរ៉ុនក៏នាំគ្នាចូលទៅក្នុងត្រសាល
ជំនុំ[វ] រួចចេញមកវិញឱ្យពរដល់បណ្ដាជន នោះសិរីល្អនៃ
ព្រះយេហូវ៉ា[ស]ក៏លេចមកឱ្យគេឃើញទាំងអស់គ្នា ២៤ក៏មាន
ភ្លើង[ហ]ចេញពីចំពោះព្រះយេហូវ៉ា មកបញ្ឆេះដង្វាយដុត
និងខ្លាញ់នៅលើអាសនា កាលបណ្ដាជនឃើញដូច្នោះ
នោះគេស្រែកឡើងដោយអំណរ រួចក្រាបផ្កាប់មុខចុះ[ឡ]។

### ការស្លាប់របស់ណាដាប និងអ័ប៊ីហូវ

**១០** ១ឯណាដាប និងអ័ប៊ីហ៊ូវ[ក] ជាកូនអើរ៉ុនទាំង២នាក់ ក៏
យកជើងពានរៀងខ្លួន[ខ]ទៅដាក់ភ្លើង[គ] ហើយរោយគ្រឿង
ក្រអូបពីលើ[ឃ] គឺបានយកភ្លើងដទៃទៅថ្វាយនៅចំពោះព្រះ
យេហូវ៉ា[ង] ដែលទ្រង់ឥតបានបង្គាប់ឡើយ[ច] ២នោះស្រាប់
តែមានភ្លើង[ឆ]ចេញពីចំពោះព្រះយេហូវ៉ាមក បញ្ឆេះអ្នក
ទាំង២នោះ[ជ] ឱ្យស្លាប់នៅចំពោះព្រះយេហូវ៉ាទៅ[ឈ] ៣ម៉ូសេ
ក៏និយាយនឹងអើរ៉ុនថា នេះហើយជាសេចក្ដីដែលព្រះយេ
ហូវ៉ាមានបន្ទូលមកថា ត្រូវឱ្យអស់អ្នកដែលចូលមកជិតអញ
[ញ]បានលើកអញជាបរិសុទ្ធ[ដ] ហើយត្រូវឱ្យអញបានសិរីល្អ
នៅចំពោះមុខជនទាំងឡាយដែរ[ឋ] ដូច្នេះអើរ៉ុនក៏នៅស្ងៀម
៤នោះម៉ូសេ លោកហៅមីសាអែល និងអែលសាផាន[ឌ] ជា
កូនអ៊ូស៊ាល[ឍ] ដែលត្រូវជាមាអើរ៉ុនមកបង្គាប់ថា ចូរមក
សែងយកខ្មោចបងប្អូនឯង ចេញពីមុខទីបរិសុទ្ធទៅខាង
ក្រៅទីដំឡើងត្រសាលទៅ[ណ,ត] ៥គេក៏ចូលទៅចាប់អាវខ្មោច
ទាំងនោះ[ថ] សែងចេញទៅក្រៅទីដំឡើងត្រសាល តាម
បង្គាប់ម៉ូសេ ៦រួចម៉ូសេប្រាប់ដល់អើរ៉ុន ហើយអេលាសារ
និងអ៊ីថាម៉ារ[ទ]ជាកូនលោកថា កុំឱ្យអ្នករាល់គ្នាបើកក្បាល

**៩:១៣** ប លវ ១:៨ **៩:១៤** ផ លវ ១:៩ **៩:១៥** ព លវ ៤:២៧–៣១ **៩:១៦** ភ លប ១:១–១៣ **៩:១៧** ម លវ ៣:៥ **៩:១៨** យ លវ ៣:១–១១ **៩:២១** រ នក ២៩:២៤,២៦ **៩:២២** ល លប ៤៨:២០ នក ៣៩:៤៣ លក ២៤:៥០ **៩:២៣** វ នក ៤០:២ ស នក ២៤:១៦ **៩:២៤** ហ នក ១៩:១៨ ពច ៦:២១ ១៣:២០ ឡ ១ពវ ១៨:៣៩ **១០:១** ក នក ៦:២៣ ២៤:១ ២៨:១ ជន ៣:២–៤ ២៦:៦១ ១រប ៦:៣ ខ ជន ១៦:៤៦ ១ពវ ៧:៥០ ២ពវ ២៥:១៥ ២រប ៤:២២ យរ ៥២:១៩ អគ ៨:១១ គ លប ១៦:១២ ជន ១៦:៧,១៨ អស ៦:៦ ឃ នក ៣០:៩ ង ខ.២ លវ ១៦:១ ច នក ៣០:៩

**១០:២** ឆ ទដ ១០៦:១៨ ជ ជន ១១:១ ១៦:៣៥ ទដ ២:១២ ៥០:៣ អស ២៩:៦ ឈ លប ១៩:២៤ ៣៨:៧ ជន ១៦:៣៥ ១រប ២៤:២ យប ១:១៦ **១០:៣** ញ នក ១៩:២២ ដ នក ៣០:២៩ លវ ២១:៦ ២២:៣២ ជន ១៦:៥ ២០:១៣ អស ៥:១៦ អគ ២៨:២២ ៣៨:១៦ ឋ អគ ១៤:៤ អស ៤៤:២៣ ៤៩:៣ ៥៥:៥ ៦០:២១ **១០:៤** ឌ នក ៦:២២ ឍ នក ៦:១៨ ណ កច ៥:៦,៩,១០ ត នក ២៥:៨ **១០:៥** ថ លវ ៨:១៣ **១០:៦** ទ នក ៦:២៣

**៩:១៧** *ដង្វាយដុតពេលព្រឹក* សូមមើល នក ២៩:៣៨–៤២ ។
**៩:២១** *ដង្វាយគ្រវី* មើលការពន្យល់ ៧:៣០–៣២ ។ *បរិសុទ្ធ* សូមមើល ១១:៤៤ និងការពន្យល់ និងមើលបន្ថែមទៀត ជន ២០:១៣ អស ៥:១៦ អគ ២០:៤១ ២៨:២២,២៥ ៣៦:២៣ ៣៨:១៦ ៣៩:២៧ ។ *បរិសុទ្ធ* សូមមើល សេចក្ដីផ្ដើម ។
**៩:២២** *ពរ* នេះជាការឱ្យពររបស់លោកអើរ៉ុន ដែលមានបីយ៉ាងនៅក្នុង ជន ៦:២៣–២៦ ។ សូមធៀបនឹងការឱ្យពរបីយ៉ាងរបស់ពួកសាវ័ក ដែលមាននៅក្នុង ២កថ ១៣:១៤ ។
**៩:២៣** *សិរីល្អនៃព្រះយេហូវ៉ា* សូមមើល ខ.៦ ធៀបទៅនឹង ការបង្ហាញពីសិរីល្អនៃព្រះចំពោះការសាងសង់រោងឧបោសថ (នក ៤០:៣៤–៣៥) ធៀបនឹងការទទួលយកនូវយញ្ញបូជារបស់ព្រះអម្ចាស់ ក្នុងការដែលស្ដេចសាឡូម៉ូនបានសម្ភោធព្រះវិហារទៅដល់ព្រះ (២រប ៧:១) ។
**៩:២៤** *ក៏មានភ្លើងចេញពីចំពោះព្រះយេហូវ៉ា* សូមមើល ១០:២ ១ពវ ១៨:២៨ ។
**១០:១** *ជើងពាន* ជាភាជន៍ម្យ៉ាងសម្រាប់ដាក់រងើកភ្លើង ដែលគេដុតគ្រឿងក្រអូប (មើល ១៦:១២–១៣ ២រប ២៦:១៩ វវ ៨:៣–៤) ។
**១០:២** *ឱ្យស្លាប់នៅចំពោះព្រះយេហូវ៉ាទៅ* នេះបញ្ជាក់ថា ជាកូនប្រុសច្បងរបស់លោកអើរ៉ុន ដូចដែលបានពិពណ៌នានៅក្នុង នក ៦:២៣ ២៤:១,៩ ២៨:១ ជន ៣:២–៤ ២៦:៦០–៦១ ១រប ៦:៣ ២៤:១–២ ។ ពួកមនុស្សទាំងអស់នៅក្នុងចំណុចនេះត្រូវបានគេដឹងថា សុទ្ធតែបានស្លាប់នៅចំពោះព្រះដោយគ្មានកូនប្រុសទាំងអស់គ្នា ។ ការស្លាប់របស់ពួកគេនីមួយៗ គឺជួបនឹងទុក្ខភ័យ និងមើលទៅហាក់បីដូចជាអាក្រក់ខ្លាំងណាស់ ប៉ុន្តែក៏មិនអាក្រក់ដូចករណីលោក អាន្នានាស និងនាងសាភីរ៉ាដែលជាប្រពន្ធគាត់នោះដែរ ។
**១០:៣** នៅវគ្គនេះលោកម៉ូសេ បានថ្លែងប្រាប់លោកអើរ៉ុន នូវព្រះបន្ទូលរបស់ព្រះយេហូវ៉ា នក ១៤:៤ ១៩:២២ ២៩:១,៤៤ ៣០:២៩ ។ *លើកអញជាបរិសុទ្ធ* មើល ១១:៤៤ និងការពន្យល់ មើលបន្ថែមទៀត ជន ២០:១៣ អស ៥:១៦ អគ ២០:៤១ ២៨:២២,២៥ ៣៦:២៣ ៣៨:១៦ ៣៩:២៧ ។
**១០:៤** *ខាងក្រៅទីដំឡើងត្រសាល* សូមមើលការពន្យល់ ៨:១៧ ។ *បរិសុទ្ធ* សូមមើលសេចក្ដីផ្ដើម ។
**១០:៦** *ហែកសំលៀកបំពាក់* មើល ២១:១០ និងការពន្យល់ លប ៤៤:១៣ ។

ឱ្យនៅទទេឡើយ[ធ] ក៏កុំហែកសំលៀកបំពាក់ខ្លួនដែរ[ន] ក្រែង
លោស្លាប់ ហើយនាំឱ្យព្រះយេហូវ៉ាទ្រង់ខ្ញាល់នឹងពួកជំនុំ
ទាំងអស់គ្នាផង[ប] តែត្រូវឱ្យបងប្អូនអ្នករាល់គ្នា គឺជាពួកវង្ស
អ៊ីស្រាអែលទាំងអស់កាន់ទុក្ខ[ផ] ដោយព្រោះភ្លើងដែលព្រះ
យេហូវ៉ាបានបញ្ឆេះគេវិញ ៧មិនត្រូវឱ្យអ្នករាល់គ្នាចេញ
ពីត្រសាលជំនុំឡើយ[ព] ក្រែងនឹងត្រូវស្លាប់ ដ្បិតប្រេងចាក់
លាបរបស់ព្រះយេហូវ៉ា[ភ]នៅជាប់លើអ្នករាល់គ្នាហើយ គេ
ក៏ធ្វើតាមបង្គាប់របស់ម៉ូសេ ។
៨ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងអើរ៉ុនថា ៩កាលណា
ចូលទៅក្នុងត្រសាលជំនុំ នោះកុំឱ្យឯង ឬពួកកូនឯងផឹក
ស្រាទំពាំងបាយជូរ[ម] ឬគ្រឿងស្រវឹងណាឡើយ[យ] ក្រែងលោ
ស្លាប់ នេះហើយជាច្បាប់នៅអស់កល្បជានិច្ច[រ] ដល់អស់
ទាំងពូជដំណាងឯងតទៅ ១០គឺដើម្បីឱ្យឯងរាល់គ្នាចេះញែក
របស់បរិសុទ្ធចេញពីរបស់ធម្មតា និងរបស់ស្មោកគ្រោក
ចេញពីរបស់ដែលស្អាត[ល] ១១ហើយឱ្យបានបង្រៀន[វ]បញ្ញត្ត
ច្បាប់ទាំងប៉ុន្មាន ដល់ពួកកូនចៅអ៊ីស្រាអែល ជាបញ្ញត្ត
ដែលព្រះយេហូវ៉ា ទ្រង់បានមានបន្ទូលប្រាប់គេដោយសារ
ម៉ូសេ[ស] ។
១២រួចម៉ូសេបង្គាប់ដល់អើរ៉ុន ហើយអេលាសារ និង
អ៊ីថាម៉ារ គឺជាកូនអើរ៉ុនដែលនៅសល់ថា ចូរយកដង្វាយ
ម្សៅ[ហ]ដែលសល់ពីដង្វាយព្រះយេហូវ៉ា ទៅបរិភោគដោយ
ឥតដំបែនៅខាងអាសនាទៅ[ឡ] ដ្បិតដង្វាយនោះ ជារបស់
បរិសុទ្ធបំផុត ១៣ត្រូវឱ្យអ្នករាល់គ្នាបរិភោគដង្វាយនោះ
នៅទីកន្លែងបរិសុទ្ធ[អ] ដ្បិតនេះជាចំណែករបស់បង និង
ពួកកូនរបស់បង ពីដង្វាយទាំងប៉ុន្មានដែលដុតថ្វាយព្រះ
យេហូវ៉ា ពីព្រោះខ្ញុំបានទទួលបង្គាប់មកយ៉ាងដូច្នេះហើយ[ក]
១៤ឯទ្រូង[ខ] ដែលគ្រវី និងស្មាដែលថ្វាយដោយលើកចុះឡើង
នោះត្រូវបរិភោគនៅទីកន្លែងដ៏ស្អាត[គ] គឺទាំងបង ហើយ
និងពួកកូនប្រុសស្រីរបស់បងផង ដ្បិតរបស់ទាំងនោះបាន
ប្រទានមកទុកជាចំណែករបស់បងហើយ និងជាចំណែក

**១០:៦** ធ លវ ១៣:៤៥
២១:១០ ជន ៥:១៨
ន យរ ៤១:៥ មក
១៤:៦៣ ប ជន
១:៥៣ ១៦:២២
យស ៧:១ ២២:១៨
ផ លប ៥០:៣,១០
ជន ២០:២៩
១សយ ២៥:១
**១០:៧** ព នក ២៥:៨
ភ នក ២៨:៤១
**១០:៩** ម លប ៩:២១
នក ២៩:៤០ លវ
២៣:១៣ ជន ១៥:៥
ចទ?២៨:៣៩ អស
៥:២២ ២២:១៣
២៨:១ ២៩:៩
៥៦:១២ យរ ៣៥:៦
ហស ៤:១១ ហព
២:១៥–១៦ យ ជន
៦:៣ ២៨:៧ ចទ
១៤:២៦ ២៩:៦ ពច
១៣:៤ សភ ២០:១
២៣:២៩–៣៥
៣១:៤–៧ អស
២៨:៧ អក ៤៤:២១
មីក ២:១១ លក
១:១៥ អភ ៥:១៨
១ធថ ៣:៣ ទត ១:៧
រ នក ១២:១៤
**១០:១០** ល លប ៧:២
លវ ៦:២៧ ១៤:៥៧
២០:២៥ អគ
២២:២៦
**១០:១១** វ ២របា
១៥:៣ ១៧:៧ អរ
៣:២៥ នហ ៨:៧
មឡ ២:៧ ស ចទ

នៃពួកកូនរបស់បង ពីយញ្ញបូជានៃដង្វាយមេត្រីទាំងប៉ុន្មាន
របស់ពួកកូនចៅអ៊ីស្រាអែលផង ១៥គេត្រូវយកស្មា[ឃ]ដែល
ថ្វាយ ដោយលើកចុះឡើង និងទ្រូងដែលគ្រវី មកជាមួយនឹង
ខ្លាញ់ទាំងប៉ុន្មានដែលសំរាប់ដុតថ្វាយ ដើម្បីនឹងគ្រវី ទុកជា
ដង្វាយគ្រវី[ង] នៅចំពោះព្រះយេហូវ៉ាដង្វាយនោះនិងត្រូវ
បានជារបស់ផងបង ហើយនិងពួកកូនរបស់បងផង តាម
បញ្ញត្តិច្បាប់នៅអស់កល្បជានិច្ច ដូចជាព្រះយេហូវ៉ាបាន
បង្គាប់មក ។
១៦ម៉ូសេក៏ខំរកពពែដែលសំរាប់ជាដង្វាយលោះបាបនោះ[ច]
តែឃើញថា គេបានដុតទៅហើយ នោះលោកក៏ខឹងនឹង
អេលាសារ ហើយនិងអ៊ីថាម៉ារ ជាកូនអើរ៉ុន ដែលនៅ
សល់ ហើយសួរថា ១៧ដែលឃើញថា ដង្វាយលោះបាប
នេះ[ឆ] ជារបស់បរិសុទ្ធបំផុត ហើយថា ទ្រង់បានប្រទានមក
ឯងរាល់គ្នាផង ចុះម្តេចក៏ឯងមិនបានយកទៅបរិភោគក្នុង
ទីបរិសុទ្ធវិញ ដើម្បីនឹងទទួលសេចក្តីទុច្ចរិត[ជ]របស់ពួក
ជំនុំ ប្រយោជន៍ឱ្យបានធួននឹងគេ នៅចំពោះព្រះយេហូវ៉ា
១៨មើល ឥឡូវមិនបានយកឈាមដង្វាយនោះ ទៅក្នុង
ទីបរិសុទ្ធ[ឈ]សោះ គួរតែឯងបានបរិភោគដង្វាយនោះ នៅ
ក្នុងទីបរិសុទ្ធ ឥតខានវិញ ដូចជាអញបានបង្គាប់ហើយ[ញ] ។
១៩នោះអើរ៉ុនឆ្លើយនឹងម៉ូសេថា មើល ថ្ងៃនេះគេបាន
ថ្វាយដង្វាយលោះបាប និងដង្វាយដុតរបស់គេ[ដ] នៅចំពោះ
ព្រះយេហូវ៉ា ហើយក៏កើតមានហេតុយ៉ាងនេះដល់ខ្ញុំ បើសិន
ជាខ្ញុំបានទទួលទានដង្វាយលោះបាបនៅថ្ងៃនេះ នោះតើ
ជាទីគាប់ដល់ព្រះនេត្រព្រះយេហូវ៉ាឬ ២០កាលម៉ូសេបាន
ឮពាក្យដូច្នោះហើយ នោះទើបលោកបានពេញចិត្តវិញ ។

១៧:១០,១១២៤:៨ ២៥:១ ៣៣:១០ សភ ៤:២៧ ហក ២:១១ មឡ ២:៧ **១០:១២** ហ នក ២៩:៤១ ឡ លវ ៦:១៤–១៨ **១០:១៣** អ លវ ៦:១៦ ក អគ ៤៣:១៣ **១០:១៤** ខ ជន ៥:៩ គ នក ២៩:៣១ លវ ៤:១២ **១០:១៥** ឃ លវ ៧:៣៤ ង នក ២៩:២៨ **១០:១៦** ច លវ ៩:៣ **១០:១៧** ឆ លវ ៦:២៤–៣០ អគ ៤២:១៣ ជ នក ២៨:៣៨ **១០:១៨** ឈ លវ ៤:១៨ ៦:២៦ ញ លវ ៦:១៧ **១០:១៩** ដ លវ ៩:១២

**១០:៧** *មិនត្រូវ . . . ចេញពីត្រសាលជំនុំឡើយ* ត្រង់នេះប្រាប់ពីការចូលរួមរបស់អ្នកកាន់ទុក្ខ (មើល ២១:១១–១២) ។

**១០:១០** *ញែករបស់បរិសុទ្ធ ចេញពីរបស់ធម្មតា* ឃ្លានេះប្រាប់ពីរបស់បរិសុទ្ធ (នក ៣:៥) និងរបស់ធម្មតាដែលមិនអាចនៅជាមួយគ្នាបានដោយប្រុងប្រយ័ត្នបំផុត(មើល ២២:២៦ ៤២:២០ ៤៤:២៣ ៤៨:១៤–១៥)។

**១០:១២–១៥** មើល ៧:២៨–៣៦ ជន ១៨:៨–២០ ចទ ១៨:១–៥ ។

**១០:១៨** *មើលឥឡូវ . . . បានបរិភោគដង្វាយនោះ* នៅត្រង់នេះ ដង្វាយលោះបាបមានពីរផ្នែក (១).ឈាមដែលគេប្រោះនៅក្នុងរោងឧបោសថ (២).ឈាមដែលគេប្រោះនៅលើអាសនា ។ បំណែកនៃឈាមទាំងពីរនេះជាទូទៅត្រូវបានគេបរិភោគ (មើលការពន្យល់ ៤:៥) ។ ចំណែកឯលោកម៉ូសេមានសេចក្តីរីករាយនៅពេលដែលគាត់ដឹងថា លោកអើរ៉ុនជាមនុស្សស្មោះត្រង់ ហើយមិនដែលបណ្តែតបណ្តោយខ្លួនឡើយ (ខ.១៩–២០) ។

**១០:១៩** *ហើយក៏កើតមានហេតុយ៉ាងនេះដល់ខ្ញុំ* ឃ្លានេះជាទូទៅសំដៅទៅលើការស្លាប់របស់កូនប្រុសច្បងទាំងពីររបស់លោកអើរ៉ុន (ខ.២) សម្រាប់ការនេះលោកអើរ៉ុន បានកាន់ទុក្ខពួកគេដោយការតមអត់ ឬក៏អ្វីមួយផ្សេងទៀតដែលកើតចំពោះខ្លួនគាត់ ដែលបណ្តាលឱ្យគាត់មិនបរិសុទ្ធ ។

## អាហារស្អាត និងអាហារមិនស្អាត

*១១:១-២៣ – ចទ ១៤:៣-២០*

**១១** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុនថា ២ចូរប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ក្នុង
បណ្តាសត្វទាំងប៉ុន្មានដែលនៅលើផែនដី នោះឯងរាល់
គ្នាត្រូវបរិភោគសត្វយ៉ាងនេះបាន[ក] ៣គឺសត្វណាដែលមាន
ក្រចកឆែកជា២ ហើយដែលទំពាអៀងផង នោះត្រូវ
បរិភោគបាន ៤ប៉ុន្តែក្នុងបណ្តាពួកសត្វដែលទំពាអៀង និង
ពួកសត្វដែលមានក្រចកឆែក នោះមិនត្រូវឱ្យឯងរាល់គ្នា
បរិភោគសត្វទាំងនេះឡើយ[ខ] គឺសត្វអូដ្ឋ១ ដ្បិតវាទំពាអៀង
តែគ្មានក្រចកឆែកទេ ជាសត្វដែលរាប់ជាមិនស្អាតដល់
ឯងរាល់គ្នា ៥ទន្សាយថ្ម១ ដ្បិតវាទំពាអៀង តែគ្មានក្រចក
ឆែកទេ ជាសត្វដែលរាប់ជាមិនស្អាតដល់ឯងរាល់គ្នា
៦ទន្សាយគល់១ ដ្បិតវាទំពាអៀង តែគ្មានក្រចកឆែកទេ
ជាសត្វដែលរាប់ជាមិនស្អាតដល់ឯងរាល់គ្នា ៧ហើយ
ជ្រូក១[គ] ដ្បិតវាក៏មានក្រចកឆែកជា២ តែមិនទំពាអៀងទេ
ជាសត្វដែលរាប់ជាមិនស្អាតដល់ឯងរាល់គ្នាដែរ ៨មិនត្រូវ
ឱ្យបរិភោគសាច់នៃសត្វទាំងនោះឡើយ ក៏មិនត្រូវទាំង
ពាល់ខ្មោចវាផង ដ្បិតជាសត្វដែលរាប់ជាមិនស្អាតដល់ឯង
រាល់គ្នាហើយ[ឃ]។

៩ឯបណ្តាត្រីទាំងប៉ុន្មាននៅក្នុងទឹក ដែលឯងរាល់គ្នា
បរិភោគបាន នោះគឺអស់ទាំងត្រីណាមានព្រុយ ហើយនិង
ស្រកាដែលអាស្រ័យនៅក្នុងទឹក ទោះក្នុងសមុទ្រ ឬក្នុងទន្លេ
ក្តី ត្រីទាំងនោះត្រូវបរិភោគបាន ១០តែក្នុងបណ្តាត្រីដែល
កំរើកក្នុងទឹក និងអស់ទាំងសត្វដែលអាស្រ័យនៅក្នុងទឹក
នោះសត្វណាដែលឥតមានព្រុយនិងស្រកា សត្វនោះត្រូវ
រាប់ជារបស់គួរខ្ពើមដល់ឯងរាល់គ្នាវិញ[ង] ១១ត្រូវឱ្យខ្ពើម
ឆ្អើមចំពោះសត្វទាំងនោះ ហើយមិនត្រូវបរិភោគសាច់វា
ឡើយ ក៏ត្រូវរាប់ខ្មោចវាទុកជារបស់គួរខ្ពើមដែរ[ច] ១២សត្វ
ណានៅក្នុងទឹកដែលគ្មានព្រុយហើយនិងស្រកា នោះជាសត្វ
គួរខ្ពើមឆ្អើមដល់ឯងរាល់គ្នាហើយ[ឆ]។

១៣ឯក្នុងបណ្តាសត្វហើរទាំងប៉ុន្មានក៏ដែរ ត្រូវឱ្យឯង
រាល់គ្នារាប់សត្វទាំងនេះ ជាសត្វគួរខ្ពើមឆ្អើម មិនត្រូវបរិ
ភោគឡើយ ដ្បិតជាសត្វគួរខ្ពើមហើយ គឺខ្លែង១ ស្ទាំង១
ប្រមង់១ ១៤ត្មាត១ ហើយរអាតតាមពូជវា[ជ] ១៥គ្រប់ទាំងក្អែក
តាមពូជវា[ឈ] ១៦អូសទ្រិច១ ខ្លែងស្រាក១ រំពេ១ ហើយ
និងអកតាមពូជវា ១៧មៀម១ ស្មោញ១ គូក១ ១៨ទីទុយ១[ញ]
ទុង១ ក្រៀល១ ១៩កុក១[ដ] ក្រសារតាមពូជវា១[ឋ] កំប្រោយ១
ហើយជ្រើង១[ឌ]។

២០អស់ទាំងសត្វស្លាបមានជើង ដែលវារតោងបាននោះ
ត្រូវរាប់ជាទីខ្ពើមឆ្អើមដល់ឯងរាល់គ្នា[ឍ] ២១ប៉ុន្តែក្នុងពួកសត្វ
មានស្លាបដែលវារតោង ឬដើរដោយជើង នោះឯងរាល់
គ្នាត្រូវបរិភោគបានតែសត្វណា ដែលមានជើងសំរាប់ផ្លោត
នៅដី ២២ក្នុងពូជនោះត្រូវបរិភោគសត្វទាំងនេះបាន គឺ
កណ្តូបតាមពូជវា[ណ] កន្រ្តុលតាមពូជវា ចង្រិតដែកតាមពូជ
វា និងចង្រិតដូងតាមពូជវា ២៣តែអស់ទាំងសត្វស្លាបមាន
ជើង៤ដែលវារតោងបាន នោះឯងរាល់គ្នាត្រូវខ្ពើមឆ្អើម
វិញ ២៤ដ្បិតសត្វទាំងនោះនឹងនាំឱ្យឯងរាល់គ្នាត្រឡប់ទៅជា
មិនស្អាតបាន[ត] អ្នកណាដែលប៉ះពាល់នឹងខ្មោចវានោះទៅ
ជាមិនស្អាតរហូតដល់ល្ងាច[ថ] ២៥ហើយអ្នកណាដែលចាប់
កាន់ខ្មោចវា យកទៅឯណា អ្នកនោះត្រូវបោកសំលៀក
បំពាក់ខ្លួនចេញ[ទ] ហើយនៅជាមិនស្អាតរហូតដល់ល្ងាច[ធ]
២៦គ្រប់ទាំងសត្វណាដែលមានក្រចក តែមិនឆែកជា២ ក៏
មិនទំពាអៀងផង នោះត្រូវរាប់ជាមិនស្អាតដល់ឯងរាល់
គ្នា អស់អ្នកណាដែលប៉ះពាល់នឹងវា នោះក៏មិនស្អាតដែរ
២៧ហើយសត្វណា ដែលមានបាតជើងទន់ ក្នុងពួកសត្វដែល
ដើរជើង៤ នោះត្រូវរាប់ទាំងអស់ជាមិនស្អាតដល់ឯងរាល់
គ្នា អ្នកណាដែលប៉ះពាល់ខ្មោចវា នោះទៅជាមិនស្អាត
រហូតដល់ល្ងាច ២៨អ្នកណាដែលចាប់កាន់ខ្មោចវាយកទៅ

**១១:២** ក កច ១០:១២-១៤
**១១:៤** ខ កច ១០:១៤
**១១:៧** គ អស ៦៥:៤ ៦៦:៣,១៧
**១១:៨** ឃ លវ ៥:២ ហព ៩:១០
**១១:១០** ង ខ.១២
**១១:១១** ច លវ ៥:២
**១១:១២** ឆ ខ.១០
**១១:១៤** ជ លប ១:១១
**១១:១៥** ឈ លប ៨:៧
**១១:១៨** ញ អស ១៣:២១ ១៤:២៣ ៣៤:១១,១៣ សផ ២:១៤
**១១:១៩** ដ សផ ៥:៩ ឋ លប ១:១១ ឌ អស ២:២០
**១១:២០** ឍ កច ១០:១៤
**១១:២២** ណ មថ ៣:៤ មក ១:៦
**១១:២៤** ត លប ៥:២ ថ ខ.២៧-៤០ លវ ១៣:៣ ១៤:៤៦ ១៥:៥ ១៦:២៦ ជន ១៩:៧,១៩
**១១:២៥** ទ ខ.២៨ នក ១៩:១០ លវ ១៣:៦ ១៤:៨,៤៧ ១៥:៥ ១៦:២៦ ជន ៨:៧ ១៩:៧ ធ លវ ១៣:៣៤ ជន ១៩:៨ ៣១:២៤

**១១:១-១៥:៣៣** វគ្គនេះនិយាយពីការបែងចែករវាងរបស់បរិសុទ្ធ និងរបស់មិនបរិសុទ្ធ (មើលការពន្យល់ ១១:២) ។

**១១:២** *ឯងរាល់គ្នាត្រូវបរិភោគសត្វយ៉ាងនេះ* នៅជំពូក១១នេះ គឺដូចគ្នានឹង ចទ ១៤:៣-២១ ប៉ុន្តែមានរៀបរាប់ច្រើនជាង ។ ចំពោះ សត្វដែលអាចឱ្យមនុស្សបរិភោគបាន មានដូចជាសត្វដែលទំពាអៀង ហើយមានក្រចកឆែក (ខ.៣) ។ ឯពពួកសត្វសមុទ្រ គឺយកតែសត្វណាដែលមានព្រុយ និងស្រកាប៉ុណ្ណោះ (ខ.៩) ។ សត្វស្លាបមាននិយាយនៅក្នុង (១៣-២៣) ។ បំណែកផ្សេងៗរវាងអាហារស្អាត និងមិនស្អាត គឺចាស់ ដូចទៅនឹងសម័យលោកណូអេ (នក ៧:២) ។ ហេតុផលសំខាន់សម្រាប់ក្រឹត្យវិន័យ គឺមានការជាប់ទាក់ទងទៅនឹងម្ហូបស្អាត និងមិនស្អាត ជាការថែរក្សាការពារជនជាតិអ៊ីស្រាអែល ជារាស្ត្រដ៏បរិសុទ្ធចំពោះព្រះ (សូមមើល ខ.៤៤ និងការពន្យល់) ។

**១១:៦** *ទន្សាយគល់* សត្វនេះមិនអាចទំពាអៀង ចំណីអាហារដែលវាលេបចូល ហើយយកចេញមកទំពាជាថ្មីម្តងទៀតបានឡើយ ។ ការទំពារបស់សត្វនេះ គ្រាន់តែជាការទំពាមាត់ទទេប៉ុណ្ណោះ ។

**១១:២០** *អស់ទាំងសត្វស្លាប* ទោះបីសត្វស្លាបមានជើង៦ តែមនុស្សនៅសម័យបុរាណប្រហែលជាមិនបានរាប់ថាជាសត្វដែលមានជើងធំពីរ ធម្មតាក្តាន់ញីដែលបានប្រើជើងរបស់វាសម្រាប់លោត ។

ឯណា នោះត្រូវបោកសំលៀកបំពាក់ខ្លួនចេញ ហើយនៅ
ជាមិនស្អាតរហូតដល់ល្ងាច[ន] ដ្បិតសត្វទាំងនោះត្រូវរាប់ជា
មិនស្អាតដល់ឯងរាល់គ្នា ។
២៩ឯក្នុងបណ្ដាពួកសត្វទាំងប៉ុន្មានដែលលូនវារនៅដីសត្វ
ទាំងនេះក៏ត្រូវរាប់ជាមិនស្អាត ដល់ឯងរាល់គ្នាដែរ[ប] គឺស្កា
១ កណ្ដុរ១[ផ] ថ្លែន១ តាមពូជវា ៣០តុកកែ១ ទន្សង១ ជីង
ចក់១ បង្គួយ១ ជាស១ ៣១ក្នុងបណ្ដាសត្វលូនវារទាំងប៉ុន្មាន
ត្រូវរាប់សត្វទាំងនោះជាសត្វមិនស្អាតដល់ឯងរាល់គ្នា
កាលណាវាស្លាប់ហើយ បើអ្នកណាបានប៉ះពាល់ នោះត្រូវ
នៅជាមិនស្អាតរហូតដល់ល្ងាច ៣២បើសត្វណាមួយនោះ
ស្លាប់ ហើយធ្លាក់ទៅប៉ះលើរបស់អ្វី របស់នោះក៏ទៅជាមិន
ស្អាតហើយ ទោះបើជាប្រដាប់ដែលធ្វើពីឈើ ឬសំលៀក
បំពាក់ ឬស្បែក ឬការុងក្ដី[ព] គឺប្រដាប់ណាក៏ដោយដែល
សំរាប់ប្រើ នោះត្រូវតែត្រាំចុះក្នុងទឹក ប្រដាប់នោះត្រូវរាប់
ជាមិនស្អាត រហូតដល់ល្ងាចរួចទើបបានស្អាតវិញ ៣៣ឯគ្រប់
ទាំងប្រដាប់ធ្វើពីដីដែលសត្វណាមួយ នោះធ្លាក់ចូលទៅក្នុង
នោះរបស់ អ្វីដែលនៅក្នុងប្រដាប់នោះ ក៏ទៅជាមិនស្អាត
ហើយ ត្រូវឱ្យបំបែកប្រដាប់នោះចោលចេញ[ភ] ៣៤ឯអាហារ
ណាសំរាប់បរិភោគ ដែលមានទឹកចាក់មកលើ នោះទៅជា
មិនស្អាតហើយ ឬទឹកណាសំរាប់ផឹកដែលនៅក្នុងប្រដាប់
ណាមួយ នោះក៏ទៅជាមិនស្អាតដែរ ៣៥ហើយរបស់អ្វីក៏
ដោយ ដែលកំទេចខ្មោចនៃសត្វទាំងនោះធ្លាក់មកលើ នោះ
ក៏ទៅជាមិនស្អាត ទោះបើជាគុកភ្លើងឬជើងក្រាន នោះត្រូវ
បំបែកចោលចេញ ព្រោះបានទៅជាមិនស្អាត ហើយក៏
ត្រូវរាប់ជាមិនស្អាតដល់ឯងរាល់គ្នាផង ៣៦បើជារន្ធទឹកឬ
អណ្ដូងដែលមានទឹកដក់នៅ នោះជាស្អាតទេ តែទឹកដែល
នៅជុំវិញខ្មោចនោះនឹងត្រូវរាប់ជាមិនស្អាតវិញ ៣៧បើមាន
អ្វីរបស់ខ្មោចនៃសត្វទាំងនោះ ធ្លាក់មកលើពូជអ្វី ដែល
សំរាប់ដាំ ព្រោះពូជនោះនៅជាស្អាតទេ ៣៨តែបើគេបាន
ត្រាំក្នុងទឹកហើយ ស្រាប់តែមានអ្វីរបស់ខ្មោចនោះធ្លាក់មក
លើពូជ នោះត្រូវរាប់ជាស្មោកគ្រោកដល់ឯងរាល់គ្នាវិញ។
៣៩បើសត្វណា ដែលសំរាប់ជាអាហារ ដល់ឯងរាល់គ្នា
បានស្លាប់ទៅ[ម] ហើយមានអ្នកណាប៉ះពាល់នឹងខ្មោចវា[យ]អ្នក
នោះត្រូវនៅជាមិនស្អាតរហូតដល់ល្ងាច ៤០ឯអ្នកណាដែល
បរិភោគសាច់នៃខ្មោចវា[រ] នោះត្រូវបោកសំលៀកបំពាក់
ចេញ រួចនៅជាមិនស្អាតរហូតដល់ល្ងាច[ល] ហើយអ្នកណា
ដែលលើកខ្មោចនោះយកទៅឯណា នោះក៏ត្រូវបោក
សំលៀកបំពាក់ចេញ រួចនៅជាមិនស្អាតរហូតដល់ល្ងាច
ដែរ ។
៤១ឯសត្វទាំងប៉ុន្មានដែលលូនវារនៅដី នោះជាសត្វគួរ
ខ្ពើមឆ្អើម មិនត្រូវឱ្យបរិភោគឡើយ ៤២គឺសត្វណាដែលលូន
នឹងពោះ ឬវារនឹងជើង៤ ឬដែលមានជើងច្រើនជាពួកសត្វ
ដែលលូនវារនៅដី នោះមិនត្រូវបរិភោគឡើយ ដ្បិតសត្វ
ទាំងនោះជាទីគួរខ្ពើមឆ្អើមហើយ ៤៣មិនត្រូវឱ្យឯងរាល់គ្នា
នាំខ្លួនឱ្យទៅជាគួរខ្ពើមឆ្អើមដោយសារសត្វលូនវារណា
មួយឡើយ[វ] ក៏មិនត្រូវឱ្យប្រឡាក់នឹងវាដែរ ដើម្បីកុំឱ្យទៅជា
មិនស្អាតដោយសារវា ៤៤ដ្បិតអញនេះ គឺព្រះយេហូវ៉ា[ស]ជា
ព្រះនៃឯងរាល់គ្នា ដូច្នេះចូរឱ្យឯងរាល់គ្នាញែកខ្លួនចេញ[ហ]
ហើយឱ្យនៅជាបរិសុទ្ធចុះ[ឡ] ដ្បិតអញជាបរិសុទ្ធ[អ]មិនត្រូវឱ្យ
ឯងរាល់គ្នានាំខ្លួនឱ្យទៅជាមិនស្អាត ដោយសារសត្វណា
ដែលលូនវារនៅដីឡើយ[ក] ៤៥ដ្បិតអញជាព្រះយេហូវ៉ាដែល
បាននាំឯងរាល់គ្នាចេញពីស្រុកអេស៊ីព្ទមក[ខ] ដើម្បីនឹងធ្វើជា
ព្រះនៃឯងរាល់គ្នា[គ] ដូច្នេះចូរឱ្យឯងរាល់គ្នាបានបរិសុទ្ធចុះ
ដ្បិតអញបរិសុទ្ធ[ឃ] ។

**១១:២៨** ន ហព ៩:១០
**១១:២៩** ប ខ.៤១ ផ អស ៦៦:១៧
**១១:៣២** ព លវ ១៥:១២ ជន ១៩:១៨ ៣១:២០
**១១:៣៣** ភ លប ៦:២៨
**១១:៣៩** ម លប ១៧:១៥ ២២:៨ ចទ ១៤:២១ អគ ៤:១៤ ៤៤:៣១ យ ខ.៤០ លវ ២២:៤ ជន ១៩:១១
**១១:៤០** រ ខ.៣៩ ល ខ.២៥ លវ ១៤:៨ ១៧:១៥ ២២:៨ អគ ៤៤:៣១ ហព ៩:១០
**១១:៤៣** វ ខ.៤៤ លវ ២០:២៥ ២២:៥
**១១:៤៤** ស នក ៦:២,៧ ២០:២ អស ៤៣:៣ ៥១:១៥ អគ ២០:៥ ហ នក ១៩:១០ លវ ២០:៧ ជន ១៥:៤០ យស ៣:៥ ៧:១៣ ១របា ១៥:១២ ២របា ២៩:៥ ៣៥:៦ ឡ នក ២២:៣១ ចទ ១៤:២ អ នក ៣១:១៣ លវ ១៩:២ ២០:៧ យស ២៤:១៩ ១សយ ២:២ យប ៦:១០ ទដ ៩៩:៣ អភ ១:៤ ១ថន ៤:៧ ១ពត ១:១៥,១៦ ក ខ.៤៣ **១១:៤៥** ខ លវ ២៥:៣៨,៥៥ គ លប ១៧:៧ ឃ នក ១៩:៦ ១ពត ១:១៦

**១១:៣៦** *អណ្ដូងដែលមានទឹកដក់នៅ* នៅត្រង់នេះបញ្ជាក់ពីការការពារ ដោយដាក់ទ្រនាប់ដើម្បីមិនឱ្យទឹកជ្រាបចេញចូលបាន ។ ការដាក់ក្នុងអណ្ដូងនេះជាផ្នែកមួយដ៏សំខាន់ សម្រាប់ពួកអ៊ីស្រាអែលដែលរស់នៅក្នុងតំបន់កាណាន នៅពេលមានភាពរាំងស្ងួត ក្រោយពីចម្បាំង (សូមផ្ទៀប ២របា ២៦:១០) ។

**១១:៤១** *នៅដី* នៅចាប់ពី ខ.២៩–៣០ បានបញ្ជាក់ពីសត្វដែលត្រឡប់ទៅជាមិនស្អាត ។

**១១:៤៤** *ជាបរិសុទ្ធ* នៅចំណុចនេះមាននៅក្នុង ១ពត ១:៦ (មើលការពន្យល់ និងសេចក្ដីផ្ដើម លេវីវិន័យ) ភាពបរិសុទ្ធជាគន្លឹះនៅក្នុងព្រះគម្ពីរលេវីវិន័យ ហើយមានច្រើនជាងគេក្នុងចំណោមកណ្ឌគម្ពីរទាំងអស់ ហើយន័យរបស់វាក៏ផ្សេងៗគ្នាផងដែរ (ខ.៤៥ ១៩:២ ២០:៧,២៦ ២១:៨,១៥, ២២:៩,១៦,៣២) ។ ពួកអ៊ីស្រាអែលទាំងអស់ ត្រូវបានរាប់ជាបរិសុទ្ធនៅចំពោះព្រះ ។ ភាពបរិសុទ្ធពួកគេត្រូវបានបញ្ជាក់នៅគ្រប់ជីវិតពួកគេរាល់ៗរូប ។ ដោយព្រោះព្រះទ្រង់ជាព្រះ ហើយបានបង្កើតរបស់សព្វសារពើរ នោះរាស្ត្ររបស់ទ្រង់ត្រូវតែប្រគល់រូបកាយទៅដល់ទ្រង់ (ផ្ទៀប មថ ៥:៤៨) មើល រម ១២:១ ។ *អញជាបរិសុទ្ធ* ភាពបរិសុទ្ធរបស់ព្រះនេះគឺមាននៅក្នុងព្រះគម្ពីរ ហើយសេចក្ដីយោងគឺ (១).ភាពគ្មានគូប្រៀបរបស់ទ្រង់ (២). ភាពពិតនៃចរិយាធម៌របស់ទ្រង់ ។ ចំណុចទាំងពីរនេះមាននៅក្នុង អស ៦:៣–៥ ។

**១១:៤៥** *នាំឯងរាល់គ្នា . . . ចេញពីស្រុកអេស៊ីព្ទ* ឃ្លានេះមានប្រាំបីដងនៅក្នុងកណ្ឌគម្ពីរ លេវីវិន័យនេះ (១៩:៣៦ ២២:៣៣ ២៣:៤៣ ២៥:៣៨,៤២, ៥៥ ២៦:១៣,៤៥) និងស្ទើរតែ៦០ដងនៅចំណោមព្រះគម្ពីរសញ្ញាចាស់

[៤៦]នេះហើយជាច្បាប់ខាងឯសត្វជើង៤ សត្វហើរនិង
គ្រប់ទាំងសត្វដែលរស់នៅក្នុងទឹក ហើយគ្រប់ទាំងសត្វ
ដែលលូនវារនៅដី [៤៧]ដើម្បីឱ្យចេះសំគាល់សត្វដែលមិន
ស្អាត និងសត្វដែលស្អាត ហើយសត្វដែលបរិភោគបាន
និងសត្វដែលមិនត្រូវបរិភោគឡើយ[ង] ។

## ការសម្អាតខ្លួនបន្ទាប់ពីសំរាលកូន

**១២** [១]ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ [២]ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា បើស្ត្រីណាមានទំងន់ ហើយសំរាល
បានកូនប្រុស នាងនោះត្រូវរាប់ជាមិនស្អាតគ្រប់៧ថ្ងៃ ត្រូវ
រាប់ជាមិនស្អាត ដូចជាក្នុងកាលដែលមានរដូវដែរ[ក] [៣]លុះ
ដល់ថ្ងៃទី៨[ខ] នោះត្រូវកាត់ស្បែកចុងស្វាសរបស់កូនចេញ[គ]
[៤]រួចនាងនោះត្រូវនៅ៣៣ថ្ងៃទៀត ដើម្បីសំអាតខ្លួនពីឈាម
ចេញ មិនត្រូវពាល់របស់បរិសុទ្ធណាមួយឱ្យសោះ ក៏មិន
ត្រូវចូលទៅក្នុងទីបរិសុទ្ធដែរ ទាល់តែថ្ងៃដែលសំអាតខ្លួន
នោះបានសំរេច [៥]បើនាងសំរាលជាកូនស្រីវិញ នោះត្រូវ
ឱ្យនៅជាមិនស្អាតគ្រប់២អាទិត្យដូចជានៅថ្ងៃរដូវនាង រួច
នាងត្រូវនៅ៦៦ថ្ងៃទៀត ដើម្បីសំអាតខ្លួនពីឈាមចេញ
[៦]លុះកាលណាបានសំរេចថ្ងៃសំអាតខ្លួន ដោយព្រោះ
សំរាលកូនប្រុស ឬកូនស្រីហើយ[ឃ] នោះនាងត្រូវយកកូន
ចៀម១អាយុ១ខួប[ង] សំរាប់ជាដង្វាយដុត និងព្រាបជំទើរ១
ឬលលក១ សំរាប់ជាដង្វាយលោះបាបមក ប្រគល់ដល់សង្ឃ
នៅមាត់ទ្វារត្រសាលជំនុំ[ច] [៧]ត្រូវឱ្យសង្ឃថ្វាយសត្វនោះ
នៅចំពោះព្រះយេហូវ៉ា ដើម្បីឱ្យធួននឹងខ្លួននាង នោះ
នាងនឹងបានស្អាត រួចពីឈាមនាងទៅ នេះហើយជារបៀប
ខាងឯស្ត្រីដែលសំរាលកូន ទោះបើជាកូនប្រុសឬស្រីក្តី
[៨]តែបើនាងខ្វះខាតមិនល្មមនឹងយកកូនចៀម១បាន នោះ
ត្រូវយកលលក២ ឬព្រាបជំទើរ២[ឆ] គឺ១សំរាប់ជាដង្វាយដុត
ហើយ១សំរាប់ជាដង្វាយលោះបាប[ជ] ត្រូវឱ្យសង្ឃថ្វាយសត្វ
នោះឱ្យធួននឹងនាង រួចនាងនឹងបានស្អាតវិញ[ឈ] ។

## ក្រឹត្យវិន័យសម្រាប់ជម្ងឺស្បែក

**១៣** [១]ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុនថា [២]បើមនុស្សណាកើតមានពកឬដំបៅ[ក] ឬស្នាមអ៊ី
ក្រហម[ខ]នៅស្បែក ដែលក្លាយទៅជាឃ្លង់នៅក្នុងសាច់[គ]
នោះត្រូវឱ្យគេនាំអ្នកនោះទៅឯអើរ៉ុនដ៏ជាសង្ឃ[ឃ] ឬទៅឯ
កូនណាមួយរបស់លោក ដែលនឹងធ្វើជាសង្ឃក៏បាន [៣]ត្រូវ
ឱ្យសង្ឃពិនិត្យមើលរោគ ដែលនៅក្នុងសាច់អ្នកនោះ បើ
រោមដែលនៅត្រង់ដំបៅបានត្រឡប់ទៅជាស ហើយដំបៅ
នោះមើលទៅដូចជាខូងទាបជាងស្បែក នោះគឺជាឃ្លង់
ហើយ ត្រូវឱ្យសង្ឃពិនិត្យមើល ហើយប្រាប់ថាជាស្មោក
គ្រោក[ង] [៤]តែបើសិនជាស្នាម[ច]ដែលនៅស្បែកនោះសវិញ
មើលទៅមិនមែនខូងទាបជាងស្បែកទេ ហើយបើរោមមិន
បានទៅជាស នោះត្រូវឱ្យសង្ឃបង្ខាំងអ្នកដែលមានរោគ
នោះទុកនៅ៧ថ្ងៃ[ឆ] [៥]រួចដល់ថ្ងៃទី៧[ជ] ត្រូវពិនិត្យមើលម្តង
ទៀត[ឈ] បើមើលទៅស្មានថា រោគនៅតែដដែលមិនបាន

**១១:៤៧** ង លវ ១០:១០
**១២:២** ក លវ ១៥:១៩ ១៨:១៩ អស ៦៤:៦ អគ ១៨:៦ ២២:១០ ៣៦:១៧
**១២:៣** ខ នក ២២:៣០ គ លប ១៧:១០ លក ១:៥៩
**១២:៦** ឃ លក ២:២២ ង នក ២៩:៣៨ លវ ២៣:១២ ជន ៦:១២,១៤ ៧:១៥ ច លវ ៥:៧
**១២:៨** ឆ លប ១៥:៩ លវ ១៤:២២ ជ លវ ៥:៧ លក ២:២២-២៤ ឈ លវ ៤:២៦
**១៣:២** ក ខ.១០,១៩, ២៨,៤៣ ខ ខ.៤, ៣៨, ៣៩ លវ ១៤:៥៦ ខ.៣,៩,១៥ នក ៤:៦ លវ ១៤:៣,៣២ ជន ៥:២ ចទ ២៤:៨ ឃ ចទ ២៤:៨
**១៣:៣** ង ខ.៨,១១, ២០,៣០ លវ ២១:១ ជន ៩:៦ **១៣:៤** ច ខ.២ ឆ ខ.៥,២១,២៦,៣៣,៤៦ លវ ១៤:៣៨ ជន ១២:១៤,១៥ ចទ ២៤:៩ **១៣:៥** ជ លប ១៤:៩ ឈ ខ.២៧,៣២, ៣៤,៥១

ទាំង១៨ កណ្ឌដំបូង ។

**១១:៤៦-៤៧** នៅវគ្គនេះជាសេចក្តីសង្ខេបនៃជំពូក ១១ ។

**១២:២** *មិនស្អាត* ក្នុងន័យនេះភាពមិនស្អាតមកពីឈាម ខ.៤-៥,៧ មិនមែនមកពីសំរាលកូននោះទេ ។ នៅត្រង់នេះមិនបានបញ្ជាក់ច្បាស់ថាហេតុអ្វីបានជារយៈពេលមិនស្អាតក្រោយពីបានបង្កើតកូនប្រុសនោះមានរហូតដល់ ៤០ថ្ងៃ ហើយដែលចំនួននេះតិចជាងពាក់កណ្តាលនៃការបង្កើតកូនស្រីដែលមានចំនួន៨០ថ្ងៃ ឯណោះវិញ ។ *ក្នុងកាលដែលមានរដូវ* មើល ១៥:១៩-២៤

**១២:៣** មើលការពន្យល់ នក ១៧:១០,១២ ។

**១២:៦** *ដង្វាយដុត* មើលការពន្យល់ ១:៣ ។ *ដង្វាយលោះបាប* មើលការពន្យល់ ៤:៣,៥ ។

**១២:៧** នៅឃ្លាចុងក្រោយនៃខនេះ គឺជាការសង្ខេបនៃជំពូក ១២ ។

**១២:៨** នៅត្រង់ខនេះគឺជាការបញ្ជាក់អំពីការអាចជំនួសគ្នាបានចំពោះយញ្ញបូជាដែលអ្នកក្របានថ្វាយដល់ព្រះអម្ចាស់ មើល ១:១៤-១៧ និងការពន្យល់ ១:១៤ និងការពន្យល់បន្ថែម ៥:៧-១០ ១៤:២១-២២ និងការពន្យល់ជាពិសេស លក ២:២៤ (ដង្វាយរបស់នាងម៉ារា ដែលថ្វាយចំពោះព្រះយេស៊ូវគ្រីស្ទ) ។

**១៣:១-៤៦** នៅត្រង់នេះ គឺមានជាប់ទាក់ទងទៅនឹងការចាប់ផ្តើមនៃរោគសញ្ញាជម្ងឺសើស្បែក (ខ.១-៨) និងក្រោយមក (១). សាច់ស្រស់ (ខ.៩-១៧) (២).បូសនៅនាស្បែក (ខ.១៨-២៣) (៣).រលាកភ្លើង (២៤-២៨) (៤).រោគនៅក្បាល ឬចង្កា(ខ.២៩-៣៧) (៥).ស្នាមភ្លឺ(ខ.៣៨-៣៩) និង (៦).ជម្ងឺសើស្បែកនៅលើក្បាលដែលធ្វើឱ្យទំពែក (ខ.៤០-៤៤) ។

**១៣:២** *ស្នាមអ៊ីក្រហមនៅស្បែក* រោគសញ្ញានេះជានិច្ចកាលកើតមាននៅក្នុងជំពូក ១៣-១៤ មើល ២២:៤ ជន ៥:២ ។ វាមិនទំនងថា មនុស្សសម័យបុរាណនឹងយល់ពីការបង្ករោគសញ្ញានេះទេ ហើយការសួរបកមកវិញនោះគឺថា ព្រះគម្ពីភាសរហេព្រើរាបានបកប្រែរថាជា "ជម្ងឺសើស្បែក" ដោយការពិពណ៌នាយ៉ាងល្អថា ជានិមិត្តរូបនៃភាពកខ្វក់ គឺអាចដូចជាផ្សិត (សូមធៀប ខ.៤៧-៥៩) ។ *ក្លាយ* សូមមើល ២២:៤-៨ ជន ៥:២-៤ ចទ ២៤-៩ ។ ចំពោះរោគសញ្ញា ដែលបានរៀបរាប់ខាងលើនេះ ពួកគេផ្លាស់ប្តូរយ៉ាងលឿន(ខ.៦,២៦-២៧,៣២-៣៧) ដែលបង្ហាញថា វាមិនមែនជាជម្ងឺឃ្លង់ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ "ស្នាមអ៊ីក្រហមនៅស្បែក" អាចមានន័យថា "ផ្សិត" (ខ.៤៧ ១៤:៣៤ និងជាពិសេស ១៤:៥៧) ។

**១៣:៤៥-៤៦** នៅវគ្គនេះបញ្ជាក់ថា អ្នកណាដែលមិនស្អាតនោះត្រូវនៅក្រៅ

រាលទៅក្នុងស្បែកទេ នោះត្រូវបង្ខាំងអ្នកនោះនៅ៧ថ្ងៃ
ទៀត ៦រួចដល់ថ្ងៃទី៧ ត្រូវឱ្យសង្ឃពិនិត្យមើលម្តងទៀត
បើរោគអន់ថយហើយ មិនបានរាលក្នុងស្បែកទេ នោះត្រូវ
ប្រកាសថា អ្នកនោះស្អាតវិញ[ញ] គ្រាន់តែជាស្រែងប៉ុណ្ណោះ
រួចអ្នកនោះត្រូវបោកសំលៀកបំពាក់ខ្លួនចេញ[ដ]នោះនឹង
បានស្អាតហើយ[ឋ] ៧តែបើដំបៅរាលធំឡើង នៅក្នុងស្បែក
ក្រោយដែលសង្ឃបានពិនិត្យមើល ព្រមទាំងប្រកាសថា ជា
ស្អាតហើយ នោះត្រូវឱ្យបង្ហាញខ្លួនដល់សង្ឃឱ្យមើលម្តង
ទៀត[ឌ] ៨ត្រូវឱ្យសង្ឃពិនិត្យមើល បើឃើញថា ដំបៅនោះ
បានរាលជាខ្លាំងឡើង នៅក្នុងស្បែកនោះ ត្រូវប្រកាសថា
ជាស្មោកគ្រោកវិញ គឺជាឃ្លង់ហើយ ។
៩កាលណាមានរោគឃ្លង់កើតឡើងដល់មនុស្សណានោះ
ត្រូវតែនាំទៅឯសង្ឃ ១០ត្រូវឱ្យសង្ឃពិនិត្យមើលអ្នកនោះ
បើឃើញមានពកសៗនៅនាស្បែក ដែលបានធ្វើរោមឱ្យ
ទៅជាស ហើយមានសាច់ស្រស់នៅក្នុងពកនោះ ១១នោះគឺ
ជាឃ្លង់ចាស់នៅក្នុងសាច់ហើយ[ឍ] ត្រូវឱ្យសង្ឃប្រាប់ថាជា
ស្មោកគ្រោកមិនបាច់នឹងបង្ខាំងទុកទេ ព្រោះជាស្មោក
គ្រោកហើយ ១២បើកាលណារោគឃ្លង់នោះចេញមកគ្រប់
នៅនាស្បែក ហើយបានរាលពេញខ្លួនអ្នកដែលមានរោគ
នោះ ចាប់តាំងពីក្បាលរហូតដល់ជើង នៅសព្វកន្លែងដែល
សង្ឃមើលឃើញ ១៣នោះត្រូវឱ្យពិនិត្យមើលអ្នកនោះ
បើឃើញថា រោគឃ្លង់បានរាលពេញខ្លួនហើយនោះត្រូវ
ប្រកាសថា អ្នកដែលមានរោគនោះជាស្អាតវិញ ដ្បិតបាន
ត្រឡប់ជាសទាំងអស់ហើយ គឺស្អាតទេ ១៤តែបើកាលណា
ឃើញមានសាច់ស្រស់ នោះស្មោកគ្រោកវិញ ១៥ត្រូវឱ្យ
សង្ឃពិនិត្យមើលសាច់ស្រស់នោះ រួចប្រកាសថា អ្នកនោះ
ស្មោកគ្រោកពិត សាច់ស្រស់នោះស្មោកគ្រោកហើយ គឺជា
ឃ្លង់[ណ] ១៦ឬបើសាច់ស្រស់នោះទៅជាសទៅវិញ អ្នកនោះ
ត្រូវមកឯសង្ឃម្តងទៀត ១៧ត្រូវឱ្យសង្ឃពិនិត្យមើល បើ
ឃើញថារោគនោះបានត្រឡប់ជាសមែន នោះត្រូវប្រកាស
ថា អ្នកដែលមានរោគបានជាស្អាតវិញ[ត] គឺជាស្អាតទេ ។
១៨កាលណាកើតមានបួស[ថ]នៅនាស្បែក ហើយបានសះ

**១៣:៦** ញ ខ.១៣, ១៧,២៣,២៨,៣៤ មថ ៨:៣ លក ៥:១២-១៤ ដ លវ ១១:២៥ ឋ លវ ១១:២៥ ១៤:៨,៩, ២០,៤៨ ១៥:៨ ជន ៨:៧
**១៣:៧** ឌ លក ៥:១៤
**១៣:១១** ឍ នក ៤:៦ លវ ១៤:៨ ជន ១២:១០ មថ ៨:២
**១៣:១៥** ណ ខ.២
**១៣:១៧** ត ខ.៦
**១៣:១៨** ថ នក ៩:៩
**១៣:១៩** ទ ខ.២ ធ ខ.២៤,៤២ លវ ១៤:៣៧
**១៣:២០** ន ខ.២
**១៣:២៣** ប ខ.៦
**១៣:២៥** ផ ខ.១១
**១៣:២៦** ព ខ.៤
**១៣:២៧** ភ ខ.៥
**១៣:២៨** ម ខ.២
**១៣:២៩** យ ខ.៤៣, ៤៤

ទៅ ១៩រួចនៅត្រង់កន្លែងបួសនោះកើតមានពក[ទ]ស[ធ]ឬស្នាម
ក្រហមព្រឿងៗ នោះត្រូវបង្ហាញឱ្យសង្ឃមើល ២០ត្រូវឱ្យ
សង្ឃពិនិត្យមើល បើឃើញស្នាមនោះដូចជាខូងទាបជាង
ស្បែក ហើយរោមបានត្រឡប់ទៅជាស នោះត្រូវប្រកាស
ថា អ្នកនោះស្មោកគ្រោកពិត គឺជាឃ្លង់[ន]ដែលលេចពីបួស
នោះមកហើយ ២១តែបើសង្ឃពិនិត្យមើលទៅមិនឃើញ
មានរោមសសោះ ហើយស្នាមនោះក៏មិនខូងទាបជាង
ស្បែកដែរ គឺចង់ក្រៀមហើយ នោះត្រូវបង្ខាំងអ្នកនោះទុក
នៅ៧ថ្ងៃ ២២បើរោគនោះរាលដាលធំឡើងនៅនាស្បែក
នោះត្រូវប្រកាសថា អ្នកនោះស្មោកគ្រោកពិត គឺជាឃ្លង់
ហើយ ២៣តែបើស្នាមក្រហមនោះនៅនឹងដដែល មិនបាន
រាលដាលទេ គឺគ្រាន់តែជាស្នាមបួសប៉ុណ្ណោះ នោះត្រូវឱ្យ
សង្ឃប្រកាសថា អ្នកនោះស្អាតទេ[ប]។
២៤បើកាលណាស្បែកបានត្រូវរលាកភ្លើង ហើយសាច់
ស្រស់ត្រង់រលាកនោះកើតមានសម្បុរក្រហមព្រឿងៗឬសក្តី
២៥នោះត្រូវឱ្យសង្ឃពិនិត្យមើល បើឃើញថា រោមដែល
នៅត្រង់ស្នាមនោះបានទៅជាសហើយ មើលទៅដូចជាខូង
ទាបជាងស្បែកដែរ នោះគឺជាឃ្លង់ដែលបានលេចមកត្រង់
ស្នាមរលាកនោះ ត្រូវឱ្យសង្ឃប្រកាសថា អ្នកនោះស្មោក
គ្រោកពិត គឺជាឃ្លង់ហើយ ២៦តែបើសង្ឃពិនិត្យមើលទៅ
មិនឃើញមានរោមសនៅត្រង់ស្នាមក្រហមនោះទេ ក៏មិន
ខូងទាបជាងស្បែកដែរ គឺបានក្រៀមហើយនោះត្រូវបង្ខាំង
អ្នកនោះទុកនៅ៧ថ្ងៃ[ផ] ២៧រួចដល់ថ្ងៃទី៧ ត្រូវពិនិត្យមើល
ម្តងទៀត[ព] បើរោគនោះបានរាលដាលធំឡើងនៅនាស្បែក
នោះត្រូវប្រកាសថា អ្នកនោះស្មោកគ្រោកពិត គឺជាឃ្លង់
ហើយ ២៨តែបើស្នាមក្រហមនោះនៅនឹងដដែល មិនបាន
រាលដាលទៅទៀតទេ គឺបានក្រៀមហើយ នោះគឺជាស្នាម
ផ្លួចឡើងត្រង់កន្លែងរលាកទេ ត្រូវឱ្យសង្ឃប្រកាសថា អ្នក
នោះជាស្អាតវិញ នោះគ្រាន់តែជាកំឡាំងដរប៉ុណ្ណោះ[ភ]។
២៩បើកាលណាប្រុស ឬស្រីណា កើតមានរោគនៅក្បាល[ម]
ឬចង្កា ៣០នោះត្រូវឱ្យសង្ឃពិនិត្យមើល បើឃើញដូចជាខូង
ទាបជាងស្បែក មានទាំងរោមឆ្មារលឿងស្លាំងនោះត្រូវ

---

ទីដំឡើងត្រសាល (ក្រៅរោងឧបោសថ) ជាទីដែលពួកអ៊ីស្រាអែលរស់នៅខាងក្នុង ។ ក្រោយមក ពួកមនុស្សមិនស្អាត ត្រូវបានអនុញ្ញាតឱ្យចូលក្នុងបរិវេណព្រះវិហារ ទីនោះហើយដែលពួកគេអាចប្រកបជាមួយនឹងអ្នកដទៃផ្សេងៗបាន ។ ចំណុចនេះវត្តមានព្រះមិនមែននៅក្នុងរោងឧបោសថប៉ុណ្ណោះទេ តែព្រះវត្តមានរបស់ទ្រង់នៅក្នុងទីដំឡើងត្រសាលផងដែរ (ជន ៥:៣ ចទ ២៣:១៤) ។ ដូច្នេះ ពួកមនុស្សមិនស្អាតមិនត្រូវឱ្យចូលក្នុងទីដំឡើងត្រសាលផងដែរ (សូមមើល ៥:១-៤ ១២:១៤-១៥ ហោរាម៉ារាម ៣១:១៩-២៤ និងមើល លវ ១០:៤-៥ ជន ១៥:៣៥ ២ពវ ៧:៣-៤ ២រប ២៦:២១ លោកអ៊ីសា) ។ លទ្ធផលនៃការបែកចេញពីព្រះអម្ចាស់របស់ពួកគេ គឺបានបង្ហាញទៅតាមរយៈទុក្ខសោករបស់ពួកគេ ដោយការបង្ហូរទឹកភ្នែក សំលៀកបំពាក់កណ្តាច សក់មិនស្អាត និងការគ្របបាំងផ្ទៃមុខ (មើល ខ.៤៥) ។

ប្រកាសថា អ្នកនោះស្មោកគ្រោកពិត គឺជាទឹលម៉ូវ ជាឃ្លង់
នៅក្បាល ឬនៅចង្កា ៣១តែបើសង្ឃមើលទៅរោគទឹលម៉ូវ
នោះឃើញថា មិនខូងទាបជាងស្បែកទេ ក៏គ្មានរោមខ្មៅ
ផង នោះត្រូវបង្ខាំងអ្នកដែលមានរោគនោះទុកនៅ៧ថ្ងៃ[យ]
៣២រួចដល់ថ្ងៃទី៧ ត្រូវពិនិត្យមើលម្ដងទៀត[រ] បើឃើញថា
រោគនោះមិនបានរាលដាលទៅទៀតទេ ហើយគ្មានរោម
ដែលលឿងស្លាំងផង ក៏មិនឃើញមានភាពខូងទាបជាង
ស្បែកដែរ ៣៣នោះត្រូវកោរឱ្យអ្នកនោះចេញ តែត្រង់
កន្លែងដែលកើតរោគ នោះមិនត្រូវកោរទេ ហើយត្រូវឱ្យ
សង្ឃបង្ខាំងអ្នកដែលកើតរោគនោះទុកនៅ៧ថ្ងៃ ៣៤រួចដល់
ថ្ងៃទី៧ ត្រូវពិនិត្យមើលម្ដងទៀត[ល] បើរោគនោះមិនបាន
រាលដាលនៅស្បែក ហើយមើលទៅដូចជាមិនខូងទាប
ជាងស្បែកទេ នោះត្រូវឱ្យសង្ឃប្រកាសថា ជាស្អាតវិញ
ហើយអ្នកនោះត្រូវបោកសំលៀកបំពាក់ខ្លួនចេញ នោះនឹង
បានស្អាតហើយ ៣៥តែបើរោគនោះរាលដាលធំឡើងនៅ
នាស្បែក ក្នុងពេលក្រោយដែលអ្នកនោះបានស្អាតហើយ
៣៦នោះត្រូវឱ្យសង្ឃពិនិត្យមើល បើឃើញថា បានរាល
ដាលនៅនាស្បែកមែន នោះមិនបាច់រករោមដែលលឿង
ស្លាំងទេ ដ្បិតជាមនុស្សស្មោកគ្រោកហើយ[វ] ៣៧បើសង្ឃ
មើលទៅស្មានថា រោគនៅជានឹងដដែល ហើយមានរោម
ខ្មៅដុះនៅត្រង់កន្លែងដំបៅ នោះរោគទឹលម៉ូវបានជា
ហើយ គឺជាស្អាតទេ ត្រូវឱ្យសង្ឃប្រកាសថា អ្នកនោះស្អាត
ពិត ។

៣៨បើកាលណាមនុស្សប្រុស ឬស្រីណា កើតមានស្នាម
ភ្លឺៗ គឺជាស្នាមសភ្លឺ ៣៩នោះត្រូវឱ្យសង្ឃពិនិត្យមើល បើ
ឃើញថាស្នាមភ្លឺៗនៅក្នុងស្បែកអ្នកនោះបែបសៗ នោះគឺ
ជាស្រែងដែលបានកើតមកនៅស្បែក អ្នកនោះស្អាតទេ ។

៤០បើអ្នកណាជ្រុះសក់ក្បាលអស់ អ្នកនោះទំពែកហើយ[ស]
តែស្អាតទេ ៤១បើបានជ្រុះសក់ក្បាលត្រង់ចំហៀងខាងមុខ
អ្នកនោះឆកហើយ តែស្អាតទេ ៤២ប៉ុន្តែបើមានដំបៅក្រហម
ព្រឿងៗនៅកន្លែងទំពែកខាងលើ ឬខាងមុខនោះគឺជាឃ្លង់
ដែលចេញមកនៅកន្លែងទំពែកនោះ ទោះខាងលើឬពីមុខ
ក្តី ៤៣ត្រូវឱ្យសង្ឃពិនិត្យមើលអ្នកនោះ បើឃើញថា ពក
ដំបៅនោះមានសម្បុរក្រហមព្រឿងៗនៅកន្លែងដែល
ទំពែកត្រង់ខាងលើឬពីមុខ មើលទៅដូចជាឃ្លង់ដែលកើត
នៅនាស្បែកឯទៀតដែរ ៤៤នោះគឺជាឃ្លង់ហើយ ជាមនុស្ស
ស្មោកគ្រោក ត្រូវឱ្យសង្ឃប្រកាសជាកុំខានថា អ្នកនោះ
ស្មោកគ្រោកពិត ដ្បិតមានរោគនៅលើក្បាលហើយ ។

៤៥ឯមនុស្សណាដែលកើតឃ្លង់ នោះត្រូវឱ្យស្លៀកពាក់
កណ្ដាច[ហ] ហើយនៅក្បាលទទេ ត្រូវគ្របបបូរមាត់ខាងលើ
[ឡ]ហើយស្រែកថា ខ្ញុំស្មោកគ្រោកៗ[អ] ៤៦អ្នកនោះនឹងនៅតែ
ស្មោកគ្រោកជានិច្ច គ្រប់វេលាដែលនៅមានរោគនៅ
ឡើយ អ្នកនោះជាមនុស្សស្មោកគ្រោកពិត ត្រូវឱ្យនៅតែឯង
ហើយមានទីលំនៅជាខាងក្រៅទីដំឡើងត្រសាលផង[ក] ។

## ក្រឹត្យវិន័យអំពីការ កើតរោគឃ្លង់

៤៧ឯសំលៀកបំពាក់ដែលមានរោគឃ្លង់ ទោះបើធ្វើពី
រោមចៀមឬពីខ្លូតទេស ៤៨ទោះបើតាមអំបោះអន្ទង ឬ
អំបោះចាក់ ពីអំបោះខ្លូតទេស និងពីរោមចៀមក្តី ឬកើត
នៅស្បែកឬរបស់អ្វីធ្វើពីស្បែកក្តី ៤៩បើរោគនោះមាន
សម្បុរបៃតងខ្ចី ឬក្រហមព្រឿងនៅក្នុងសំលៀកបំពាក់នោះ
ទោះតាមអំបោះអន្ទងឬតាមអំបោះចាក់ ឬនៅស្បែកនោះ
ឬរបស់អ្វីធ្វើពីស្បែកក្តី នោះគឺជារោគឃ្លង់ហើយ ត្រូវឱ្យ
បង្ហាញដល់សង្ឃ[ខ] ៥០ត្រូវឱ្យសង្ឃពិនិត្យមើល រួចត្រូវយក
របស់ដែលមានរោគនោះ[គ] ទៅបង្ខាំងទុកគ្រប់៧ថ្ងៃ ៥១ដល់
ថ្ងៃទី៧ ត្រូវពិនិត្យមើលម្ដងទៀត[ឃ] បើឃើញថា បានរាល
ដាលធំឡើងនៅសំលៀកបំពាក់នោះ ទោះបើតាមអំបោះ
អន្ទង ឬអំបោះចាក់ ឬនៅស្បែកនោះ ដែលជាស្បែកប្រើធ្វើ
ការអ្វីក៏ដោយ នោះគឺជារោគដែលស៊ីបង្ខូចរបស់នោះ
ស្មោកគ្រោកហើយ[ង] ៥២ត្រូវដុតសំលៀកបំពាក់នោះចោល
ទោះបើធ្វើពីរោមចៀមឬពីខ្លូតទេស ដែលកើតតាមអំបោះ
អន្ទងឬអំបោះចាក់ក្តី ព្រមទាំងរបស់អ្វីធ្វើពីស្បែកដែល
មានរោគនោះផង ដ្បិតរោគនោះ គឺជាឃ្លង់ដែលស៊ីបង្ខូច
ត្រូវដុតនឹងភ្លើងទៅ[ច] ។

៥៣តែបើសង្ឃពិនិត្យមើលទៅឃើញថា រោគនោះមិន
បានរាលដាលឡើងនៅសំលៀកបំពាក់នោះទេ ទោះបើ
តាមអំបោះអន្ទងឬតាមអំបោះចាក់ក្តី ឬនៅរបស់អ្វីដែលធ្វើ
ពីស្បែកនោះដែរ ៥៤នោះត្រូវឱ្យសង្ឃបង្គាប់ឱ្យលាងរបស់
ដែលមានរោគនេះចេញ រួចត្រូវយកទៅបង្ខាំងទុក៧ថ្ងៃ
ទៀត ៥៥ក្រោយដែលបានលាងរួចហើយ នោះត្រូវឱ្យសង្ឃ
ពិនិត្យមើលម្ដងទៀតបើឃើញថា រោគនោះមិនបានប្រែ

**១៣:៣១** រ ខ.៤
**១៣:៣២** ល ខ.៥
**១៣:៣៤** វ ខ.៥
ស លវ ១១:២៥
**១៣:៣៦** ហ ខ.៣០
**១៣:៤០** ឡ លវ ២១:៥ ២ពវ ២:២៣ អស ៣:២៤ ១៥:២ ២២:១២ អគ ២៧:៣១ ២៩:១៨ អម ៨:១០ មីក ១:១៦
**១៣:៤៥** អ លវ ១០:៦ ក អគ ២៤:១៧,២២ មីក ៣:៧ ខ លវ ៥:២
បទ ៤:១៥ លក ១៧:១២
**១៣:៤៦** គ ជន ៥:១-៤ ១២:១៤ ២ពវ ៧:៣ ១៥:៥
**១៣:៤៩** ឃ មក ១:៤៤
**១៣:៥០** ង អគ ៤៤:២៣
**១៣:៥១** ច ខ.៥
ឆ លវ ១៤:៤៤
**១៣:៥២** ជ ខ.៥៥,៥៧

**១៣:៤៧** *រោគឃ្លង់* រោគនេះកើតមាននៅរដូវវស្សារបស់ពួកអ៊ីស្រាអែល (គិតចាប់ពីខែតុលា ដល់ មីនា) នេះហើយជាបញ្ហាមួយនៅតាមឆ្នេរសមុទ្រ កាលីឡេ ដែលសើមខ្លាំងជានិច្ច ។

**១៣:៥៤** *លាង* នេះជាការរៀបចំឱ្យមានលំដាប់លំដោយ ដែលរួមទាំងការលាងសម្អាតផងដែរ (សូមមើល ខ.៣៤,៥៥-៥៦,៥៨) ។

សម្បុរទេ ក៏មិនបានរាលដាលឡើងផង របស់នោះស្មោក
គ្រោកហើយ ត្រូវដុតចោលក្នុងភ្លើងទៅ ដ្បិតជារោគស៊ី
បង្ខូចពិត ទោះបើនៅខាងក្នុងឬខាងក្រៅក្តី ៥៦បើសង្ឃ
ពិនិត្យ មើលឃើញថា រោគនោះចង់ស្រអាប់ហើយ ក្នុង
ពេលក្រោយដែលបានលាងចេញ នោះត្រូវហែកត្រង់ដុំ
នោះពីសំលៀកបំពាក់ ឬពីស្បែកនោះ ពីអំបោះអន្ទង ឬពី
អំបោះចាក់យកចេញ ៥៧រួចបើចេះតែលេចមកនូវសំលៀក
បំពាក់នោះទៀត ទោះតាមអំបោះអន្ទងឬតាមអំបោះចាក់
ឬនៅរបស់អ្វីធ្វើពីស្បែកក្តី នោះគឺជាដំណួចរោគឃ្លង់
ហើយ ត្រូវតែយករបស់ដែលមានរោគនោះទៅ ដុតនឹង
ភ្លើងទៅ ៥៨តែសំលៀកបំពាក់ណា ទោះតាមអំបោះអន្ទង
ឬតាមអំបោះចាក់ក្តី ឬរបស់អ្វីធ្វើពីស្បែកដែលបានលាង
ហើយ បើសិនជារោគនោះចេញជ្រះស្រឡះ នោះត្រូវលាង
ម្តងទៀត រួចនឹងបានស្អាត ៥៩នេះហើយជាច្បាប់ខាងឯ
រោគឃ្លង់ នៅក្នុងសំលៀកបំពាក់ ដែលធ្វើពីរោមចៀម
ឬខ្លូតទេស ទោះបើតាមអំបោះអន្ទង ឬតាមអំបោះចាក់
ឬនៅរបស់អ្វីធ្វើពីស្បែកក្តី ដើម្បីឱ្យចេះសំរេចថា នេះស្អាត
នេះមិនស្អាត ។

## ការសម្អាតពីជម្ងឺស្បែក

**១៤** ១ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា ២នេះជា
ច្បាប់ខាងឯមនុស្សឃ្លង់ នៅថ្ងៃណាដែលញែកគេចេញជា
ស្អាត ត្រូវតែនាំអ្នកនោះទៅឯសង្ឃ[ក] ៣រួចត្រូវឱ្យសង្ឃចេញ
ទៅខាងក្រៅទីដំឡើងត្រសាលពិនិត្យមើល[ខ] បើឃើញថា
មនុស្សឃ្លង់នោះបានជាពិត[គ] ៤នោះត្រូវឱ្យសង្ឃបង្គាប់ ឱ្យ
យកសត្វហើរ២ ដែលរស់ ហើយស្អាត មកសំរាប់អ្នកនោះ
ដែលត្រូវញែកជាស្អាត ព្រមទាំងឈើតាត្រៅ សំពត់
ក្រហម និងមែកហ៊ីសុប[ឃ]ផង[ង] ៥រួចត្រូវបង្គាប់ឱ្យសំឡាប់សត្វ
ហើរ១ នៅក្នុងផើងពីលើទឹកហូរ[ច] ៦ឯសត្វដែលរស់នៅ
នោះត្រូវឱ្យសង្ឃជ្រលក់ទៅក្នុងឈាមនៃសត្វ ដែលបាន
សំឡាប់ពីលើទឹកហូរនោះ ជាមួយនឹងឈើតាត្រៅ សំពត់
ក្រហម ហើយនិងមែកហ៊ីសុប[ឆ] ៧ទៅប្រោះ[ជ]៧ដង[ឈ]លើអ្នក
ដែលត្រូវញែកចេញជាស្អាតពីរោគឃ្លង់ រួចប្រកាសថា ជា
ស្អាតហើយ ឯសត្វដែលរស់នៅ នោះត្រូវលែងនៅឯវាល
ទៅ[ញ] ៨រួចអ្នកដែលត្រូវបានញែកជាស្អាត ត្រូវបោក
សំលៀកបំពាក់ខ្លួន[ដ] ព្រមទាំងកោរសក់ហើយងូតទឹកចេញ[ឋ]
រួចនឹងបានស្អាត[ឌ] ហើយនិងចូលទៅក្នុងទីដំឡើងត្រសាល
បាន[ឍ] តែត្រូវនៅខាងក្រៅត្រសាលរបស់ខ្លួនអស់៧ថ្ងៃ ៩ដល់
ថ្ងៃទី៧[ណ] អ្នកនោះត្រូវកោរសក់[ត] កោរពុកមាត់ និងចិញ្ចើម
ហើយរោមខ្លួនទាំងអស់ចេញ ព្រមទាំងបោកសំលៀក
បំពាក់ ហើយងូតទឹកផង នោះនឹងបានស្អាតហើយ[ថ] ។
១០លុះដល់ថ្ងៃទី៨[ទ] ត្រូវយកកូនចៀមឈ្មោល២ឥតខ្ចោះ
និងចៀមញី[ធ]១ ឥតខ្ចោះអាយុ១ខួបមក ព្រមទាំងម្សៅយ៉ាង
ម៉ដ្ត៣ខ្ទឹង[ន]លាយនឹងប្រេងសំរាប់ជាដង្វាយម្សៅ[ប] ហើយនិង
ប្រេង១កំប៉ុង[ផ] ១១រួចត្រូវឱ្យសង្ឃដែលញែកអ្នកនោះចេញ
ជាស្អាត នាំ[ព]អ្នកនោះមកដាក់ជាមួយនិងដង្វាយនៅចំពោះ
ព្រះយេហូវ៉ា ត្រង់មាត់ទ្វារត្រសាលជំនុំ[ភ] ១២ត្រូវឱ្យសង្ឃយក
កូនចៀមឈ្មោល១ទៅថ្វាយជាដង្វាយ ដោយព្រោះការ
រំលង[ម]ព្រមទាំងប្រេង១កំប៉ុងផង រួចគ្រវីរបស់ទាំងនោះ
ទុកជាដង្វាយគ្រវីនៅចំពោះព្រះយេហូវ៉ា[យ] ១៣ត្រូវសំឡាប់
កូនចៀមឈ្មោលនៅកន្លែង ដែលគេសំឡាប់ដង្វាយលោះ
បាបហើយនិងដង្វាយដុត គឺនៅក្នុងទីបរិសុទ្ធ[រ] ដ្បិតដង្វាយ
ដែលថ្វាយ ដោយព្រោះការរំលង ជារបស់ផងសង្ឃ[ល] ដូច

**១៤:២** ក លវ ១៣:៥៧ ចទ ២៤:៨ មថ ៨:២-៤ មក ១:៤០-៤៤ លក ៥:១២-១៤ ១៧:១៤ **១៤:៣** ខ លវ ១៣:៤៦ គ លវ ១៣:២ **១៤:៤** ឃ នក ១២:២២ ង ខ.៦,៤៩, ៥១,៥២ ជន ១៩:៦ ទដ ៥១:៧ **១៤:៥** ច ខ.៥០ **១៤:៦** ឆ ខ.៤ **១៤:៧** ជ ២ពវ ៥:១០,១៤ អស ៥២:១០,១៤ អស ៥២:១៥ អគ ៣៦:២៥ ឈ ខ.៥១ ញ ខ.៥៣ **១៤:៨** ដ លវ ១១:២៥ ឋ ខ.៩ នក ២៩:៤ លវ ១៥:៥ ១៧:១៥ ២២:៦ ជន ១៩:៧,៨ ឌ ខ.២០ ឍ លវ ១៣:១១ ជន ៥:២,៣ ១២:១៤,១៥ ១៩:២០ ៣១:២៤ ២របា ២៦:២១ **១៤:៩** ណ លវ ១៣:៥ ត ជន ៦:៩ ចទ ២១:១២ ថ លវ ១៣:៦ **១៤:១០** ទ ជន ៦:១០ មថ ៨:៤ មក ១:៤៤ លក ៥:១៤ ធ លវ ៤:៣២ ន ជន ១៥:៩ ២៨:២០ ប លវ ២:១ ផ ខ.១២, ១៥,២១,២៤ **១៤:១១** ព ជន ៦:១៦ ភ ជន ៦:១០ **១៤:១២** ម លវ ៥:១៨ យ នក ២៩:២៤ **១៤:១៣** រ នក ២៩:១១ ល លវ ៦:២៤-៣០ ៧:៧

**១៣:៥៩** នៅវគ្គនេះជាការសង្ខេបនៃជំពូក ១៣ ។

**១៤:១-៣២** នៅត្រង់នេះជាក្បួនព្យាបាលជម្ងឺសើរស្បែកដែលមានបីជំហាន (១).សម្រាប់សប្តាហ៍ទី១ (នៅក្រៅទីដំឡើងត្រសាល ខ.១-៧) (២).សប្តាហ៍ទី២ (នៅក្នុងទីដំឡើងត្រសាល ខ.៨-២០) (៣).សិទ្ធិជា ពិសេសសម្រាប់អ្នកក្រ (ខ.២១-៣២) ។

**១៤:៤** *ហ៊ីសុប* នេះជារុក្ខជាតិម្យ៉ាងដែលគេប្រើនៅក្នុងពិធីលាងសម្អាត (នក ១២:២២) ៥:១៥ ។ *ដង្វាយគ្រវី* មើលការពន្យល់ ៧:៣០-៣២ ។

**១៤:៥** *សំឡាប់* នេះបញ្ជាក់ថាជម្ងឺ និងភាពច្របូកច្របល់ ជានិមិត្តរូបនៃអំពើបាប ហើយមនុស្សជាអ្នកសង ឬសម្អាតឱ្យបានស្អាត ។ ការរៀបរាប់ពីការសំអាតដែលរួមទាំងយញ្ញបូជានោះត្រូវបានសំអាតផងដែរ (មើលការពន្យល់ ១៣:៥៤) ។

**១៤:៦** *ឈើតាត្រៅ . . . សំពត់ . . . ហ៊ីសុប* វត្ថុទាំងបីនេះគេប្រើសម្រាប់លាងសម្អាត ខ.៥១-៥២ ជន ១៩:៦ និងការពន្យល់ ។

**១៤:៧,១៦,៥១** *៧ដង* មើលការពន្យល់ ៤:៦ ។

**១៤:៧** *ស្អាត* ត្រង់នេះប្រហែលសំពត់ និងឈើតាត្រៅ ត្រូវបានគេប្រើដូចជាដើមហ៊ីសុប ដើម្បីប្រោះឈាមសម្រាប់លាងសម្អាត (មើល ទដ ៥១:៧ និងការពន្យល់) ។ លើសពីនេះទៀត យញ្ញបូជាត្រូវបានបញ្ជាក់នៅក្នុង ១០-១៣ ។ *សត្វដែលនៅរស់ នោះត្រូវលែង* សូមធៀប ១៦:២២ និងការពន្យល់ ១៦:៥ ។

**១៤:១០** នៅវគ្គត្រង់នេះមានភាពស្រដៀងគ្នានឹងការសម្អាតនៅក្នុង ជន ៨:៧ និងការពន្យល់ ។

**១៤:១០** *ដង្វាយម្សៅ* មើលការពន្យល់ ២:១ ។

**១៤:១២** *ដង្វាយដោយព្រោះការរំលង* មើល ៥:១៤-៦:៧ និងការពន្យល់ ។

**១៤:១៣** *បរិសុទ្ធបំផុត* មើលការពន្យល់ នក ៣:៥ ។

ជាដង្វាយលោះបាបដែរ ដង្វាយនេះជារបស់បរិសុទ្ធបំផុត
១៤រួចត្រូវឱ្យសង្ឃយកឈាមដង្វាយដែលថ្វាយដោយព្រោះ
ការរំលងនោះ ទៅលាបនៅទងត្រចៀកស្ដាំរបស់អ្នក
ដែលត្រូវញែកចេញជាស្អាត ព្រមទាំងនៅលើមេដៃស្ដាំ
និងមេជើងស្ដាំផង[វ] ១៥ក៏ត្រូវយកប្រេង ពីក្នុងកំប៉ុង ចាក់ទៅ
ក្នុងបាតដៃឆ្វេងខ្លួន[ស] ១៦ហើយជ្រលក់ម្រាមដៃស្ដាំទៅក្នុង
ប្រេង ដែលនៅក្នុងបាតដៃ ប្រោះ៧ដងនៅចំពោះព្រះ
យេហូវ៉ា[ហ] ១៧ឯប្រេងដែលសល់នៅបាតដៃ នោះត្រូវយក
ខ្លះទៅលាបនៅទងត្រចៀកស្ដាំ និងមេដៃស្ដាំ ហើយនិងមេ
ជើងស្ដាំរបស់អ្នកដែលត្រូវញែកជាស្អាតនោះ ត្រង់កន្លែង
ដែលបានលាបឈាមនៃដង្វាយ ដែលថ្វាយ ដោយព្រោះ
ការរំលងដែរ[ឡ] ១៨ហើយប្រេងដែលសល់នៅក្នុងបាតដៃ
របស់សង្ឃ ត្រូវឱ្យចាក់លើក្បាលនៃអ្នកដែលញែកជាស្អាត
ទៅ[អ] រួចត្រូវថ្វាយឱ្យធួននឹងខ្លួនអ្នកនោះ នៅចំពោះព្រះ
យេហូវ៉ា ១៩ត្រូវឱ្យសង្ឃថ្វាយដង្វាយលោះបាប ឱ្យបានធួន
នឹងអ្នក ដែលត្រូវញែកចេញជាស្អាតនោះ ដោយព្រោះ
សេចក្ដីស្មោកគ្រោករបស់ខ្លួន[ក] រួចមកត្រូវសំឡាប់ដង្វាយ
ដុតទៀត ២០ក៏ត្រូវថ្វាយដង្វាយដុត និងដង្វាយម្សៅនៅលើ
អាសនាឱ្យបានធួននឹងអ្នកនោះដែរ[ខ] នោះនឹងបានស្អាត
ហើយ[គ] ។

២១បើអ្នកនោះខ្វះខាត[ឃ]មិនល្មមនឹងយករបស់ទាំងនោះ
បាន[ង] នោះត្រូវយកកូនចៀមឈ្មោល១មក ដោយព្រោះ
ការរំលងសំរាប់នឹងគ្រវីថ្វាយ ដើម្បីឱ្យធួននឹងខ្លួន ព្រមទាំង
ម្សៅយ៉ាងម៉ដ្ឋ១ខ្ញឹង លាយដោយប្រេង សំរាប់ជាដង្វាយ
ម្សៅនិងប្រេង១កំប៉ុង ២២ហើយលលក២ ឬព្រាបជំទើរ២[ច]
តាមកំឡាំងរបស់ខ្លួន គឺ១សំរាប់ជាដង្វាយលោះបាប ហើយ
១សំរាប់ជាដង្វាយដុត[ឆ] ២៣នៅថ្ងៃទី៨អ្នកនោះត្រូវយករបស់
ទាំងនោះមកប្រគល់ដល់សង្ឃ ត្រង់មាត់ទ្វារត្រសាលជំនុំ[ជ]
នៅចំពោះព្រះយេហូវ៉ា[ឈ]សំរាប់ការញែកខ្លួនចេញជា
ស្អាត ២៤ត្រូវឱ្យសង្ឃយកកូនចៀមដែលសំរាប់ថ្វាយដោយ
ព្រោះការរំលង[ញ]និងប្រេង១កំប៉ុង[ដ] ទៅថ្វាយជាដង្វាយ
គ្រវី[ឋ]នៅចំពោះព្រះយេហូវ៉ា ២៥រួចត្រូវសំឡាប់កូនចៀម
ដែលសំរាប់ថ្វាយដោយព្រោះការរំលងនោះ ហើយត្រូវ
យកឈាមនៃដង្វាយ ទៅលាបនៅទងត្រចៀកស្ដាំនៃអ្នក
ដែលត្រូវញែកចេញជាស្អាត ព្រមទាំងនៅមេដៃស្ដាំនិងមេ
ជើងស្ដាំផង[ឌ] ២៦ក៏ត្រូវចាក់ប្រេងទៅ ក្នុងបាតដៃឆ្វេង
របស់ខ្លួន[ឍ] ២៧ហើយប្រោះប្រេងនោះដោយម្រាមដៃស្ដាំ
អស់៧ដងនៅចំពោះព្រះយេហូវ៉ា ២៨រួចត្រូវយកប្រេង
ដែលនៅក្នុងបាតដៃទៅលាបនៅទងត្រចៀកស្ដាំនិង
មេដៃស្ដាំ ហើយនិងមេជើងស្ដាំនៃអ្នកដែលត្រូវញែកចេញ
ជាស្អាត ត្រង់កន្លែងដែលបានលាបឈាមនៃដង្វាយ ដែល
ថ្វាយដោយព្រោះការរំលងដែរ ២៩ឯប្រេងដែលនៅសល់
ក្នុងបាតដៃ នោះត្រូវចាក់ទៅលើក្បាលនៃអ្នកដែលត្រូវ
ញែកជាស្អាត ដើម្បីឱ្យធួននឹងខ្លួនអ្នកនោះនៅចំពោះ
ព្រះយេហូវ៉ា[ណ] ៣០រួចត្រូវឱ្យសង្ឃថ្វាយលលក១ ឬព្រាប
ជំទើរ១ តាមកំឡាំងដែលអ្នកនោះនាំយកមកបាន[ត] ៣១គឺ១
សំរាប់ជាដង្វាយលោះបាប ហើយ១សំរាប់ជាដង្វាយដុត[ថ]
ជាមួយនិងដង្វាយម្សៅផង រួចត្រូវឱ្យសង្ឃថ្វាយ ឱ្យធួននឹង
អ្នក ដែលត្រូវញែកជាស្អាតនោះ នៅចំពោះព្រះយេហូវ៉ា[ទ]
៣២នេះហើយជាច្បាប់ខាងឯអ្នកដែលកើតរោគឃ្លង់[ធ] ដែល
មិនអាចនឹងលូកឈោងដល់ដង្វាយ[ន] សំរាប់ការញែកខ្លួន
ចេញជាស្អាតបាន ។

## ការសម្អាតរោគឃ្លង់

៣៣ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុនថា ៣៤កាលណាឯងរាល់គ្នាបានចូលទៅក្នុងស្រុក
កាណាន[ប] ជាស្រុកដែលអញនឹងឱ្យជាកេរ្តិ៍អាករ ដល់ឯង
រាល់គ្នា[ផ] បើអញធ្វើឱ្យមានរោគឃ្លង់ក្នុងផ្ទះណាមួយនៅ
ស្រុករបស់ផងឯង ៣៥នោះត្រូវឱ្យម្ចាស់ផ្ទះមកប្រាប់ដល់
សង្ឃថា មើលទៅដូចជាមានរោគនៅក្នុងផ្ទះរបស់ខ្ញុំហើយ
៣៦ដូច្នេះ ត្រូវឱ្យសង្ឃបង្គាប់ឱ្យរើអីវ៉ាន់ចេញពីផ្ទះទៅ មុន
ដែលចូលទៅពិនិត្យមើលរោគ ដើម្បីកុំឱ្យរបស់ទាំងអស់
ដែលនៅក្នុងផ្ទះបានទៅជាស្មោកគ្រោកដែរ រួចហើយត្រូវ
ចូលទៅពិនិត្យមើលជាខាងក្រោយ ៣៧ត្រូវឱ្យសង្ឃពិនិត្យ
មើល បើឃើញថា រោគដែលនៅក្នុងជញ្ជាំងផ្ទះនោះមាន
កន្លែងខួង ពណ៌បៃតងស្ទើរ ឬក្រហមប្រឿង[ព] មើលទៅ
ទាបជាងសាច់ជញ្ជាំងហើយ ៣៨នោះត្រូវចេញទៅឯមាត់
ទ្វារ ហើយបិទខ្ទប់ផ្ទះនោះគ្រប់៧ថ្ងៃ[ភ] ៣៩ដល់ថ្ងៃទី៧[ម]
ត្រូវត្រឡប់មកពិនិត្យមើលវិញ បើឃើញថា រោគមិនបាន

**១៤:១៤** វ នក ២៩:២០
**១៤:១៥** ស ខ.២៦
**១៤:១៦** ហ ខ.២៧
**១៤:១៧** ឡ ខ.២៨
**១៤:១៨** អ ខ.៣១ លវ ១៥:១៥
**១៤:១៩** ក ខ.៣១ លវ ៥:៣ ១៥:១៥
**១៤:២០** ខ លវ ១៥:៣០ គ ខ.៨
**១៤:២១** ឃ លវ ៥:៧ ង ខ.២២,៣២
**១៤:២២** ច លវ ៥:៧ ឆ លវ ១៥:៣០
**១៤:២៣** ជ លវ ១៥:១៤,២៩ ឈ ខ.១០,១១
**១៤:២៤** ញ ជន ៦:១៤ ដ ខ.១០ ឋ ខ.១២
**១៤:២៥** ឌ នក ២៩:២០
**១៤:២៦** ឍ ខ.១៥
**១៤:២៩** ណ ខ.១៨
**១៤:៣០** ត លវ ៥:៧
**១៤:៣១** ថ ខ.២២ លវ ៥:៧ ១៥:១៥, ៣០ ទ ខ.១៨,១៩
**១៤:៣២** ធ លវ ១៣:២ ន ខ.២១
**១៤:៣៤** ប លវ ១២:៥ នក ៦:៤ ជន ១៣:២ ផ លប ១៧:៨ ៤៨:៤ ជន ២៧:១២ ៣២:២២ ចទ ៣:២៧ ៧:១ ៣២:៤៩
**១៤:៣៧** ព លវ ១៣:១៩
**១៤:៣៨** ភ លវ ១៣:៤
**១៤:៣៩** ម លវ ១៣:៥

**១៤:១៤** សូមមើលការពន្យល់ ៨:១៤ ។
**១៤:១៨–២១,២៩,៣១** *ធួន* មើលការពន្យល់ ១៦:២០–២២ ១៧:១១ នក ២៥:១៧ និងការពន្យល់ រម ៣:២៥ ។
**១៤:១៩** *ដង្វាយលោះបាប* សូមមើល ៤:១–៥:១៣ និងការពន្យល់ ៤:៣,៥ ។ *ដង្វាយដុត* មើលការពន្យល់ ១:៣ ។
**១៤:២០** *ដង្វាយដុត* សូមមើល ២:១ ។
**១៤:៣៣–៥៣** នៅវគ្គនេះជាការលាងសម្អាតរោគ ហើយស្រដៀងគ្នាច្រើនទៅនឹងការផ្សះផ្សាទំនាក់ទំនងរវាងព្រះអម្ចាស់ និងមនុស្ស ។

រាលដាល ទៅក្នុងជញ្ជាំងទៀតទេ ៤០នោះត្រូវបង្គាប់គេឱ្យ
យកថ្ម ដែលមានរោគនោះ ចេញទៅចោលឯក្រៅទីក្រុង
ត្រង់កន្លែងស្មោកគ្រោកទៅ[ឃ] ៤១រួចត្រូវឱ្យគេកោសផ្ទះនៅ
ខាងក្នុងជុំវិញ ឯផង់ដែលគេកោសចេញនោះ ត្រូវឱ្យនាំ
យកទៅចាក់ឯកន្លែងស្មោកគ្រោក នៅខាងក្រៅទីក្រុង
៤២ហើយត្រូវយកថ្មឯទៀតមកប៉ះជំនួសថ្មចាស់ រួចយកបាយ
អឯទៀតមកបូកវិញ ។
៤៣បើរោគកើតឡើងនៅក្នុងផ្ទះនោះម្តងទៀត ក្នុងពេល
ក្រោយដែលបានយកថ្មទាំងនោះចេញ ព្រមទាំងកោស
ជញ្ជាំង នឹងបូកជាថ្មីហើយ ៤៤នោះត្រូវឱ្យសង្ឃចូលទៅ
ពិនិត្យមើល បើឃើញថារោគនោះបានរាលដាលឡើងនៅ
ក្នុងផ្ទះមែន នោះគឺជាឃ្លង់ស៊ីបង្ខូចហើយ ផ្ទះនោះស្មោក
គ្រោកពិត[រ] ៤៥ត្រូវឱ្យគេរំលំផ្ទះនោះ ព្រមទាំងថ្មនិងឈើ
ហើយនិងបាយអទាំងអស់ចេញ ហើយនាំយកទាំងអស់ទៅ
ចាក់ឯក្រៅទីក្រុង ត្រង់កន្លែងស្មោកគ្រោកទៅ ៤៦ឯអ្នកណា
ដែលចូលទៅក្នុងផ្ទះនោះក្នុងវេលាដែលកំពុងបិទ នោះ
ត្រូវរាប់ជាមិនស្អាតរហូតដល់ល្ងាច[ល] ៤៧បើអ្នកណាដែល
ដេកក្នុងផ្ទះនោះ ត្រូវឱ្យអ្នកនោះបោកសំលៀកបំពាក់ខ្លួន
ចេញ ហើយអ្នកណាដែលបរិភោគនៅក្នុងផ្ទះនោះ ក៏ត្រូវ
បោកសំលៀកបំពាក់ខ្លួនដែរ[វ] ៤៨តែបើសង្ឃចូលទៅពិនិត្យ
មើល ឃើញថា រោគមិនបានរាលដាលឡើងក្នុងផ្ទះ
ក្រោយដែលបានបូកជាថ្មីហើយនោះទេ នោះត្រូវប្រកាស
ថា ផ្ទះនោះស្អាតវិញ[ស] ដ្បិតរោគនោះបាត់ហើយ ។
៤៩ដូច្នេះត្រូវឱ្យយកសត្វស្លាប២ ឈើតាត្រៅ សំពត់
ក្រហម ហើយនិងមែកហ៊ីសុបមកសំរាប់នឹងញែកផ្ទះនោះ
ជាស្អាត[ហ] ៥០ត្រូវសំឡាប់សត្វ១នៅក្នុងផើងពីលើទឹកហូរ[ឡ]
៥១រួចយកឈើតាត្រៅ មែកហ៊ីសុប[អ] និងសំពត់ក្រហម
ជាមួយនឹងសត្វ១ដែលរស់នៅជ្រលក់ទាំងអស់ទៅក្នុងឈាម
របស់សត្វដែលបានសំឡាប់ ហើយក្នុងទឹកហូរនោះដែរ
រួចប្រោះទៅលើផ្ទះ៧ដង[ក] ៥២ដូច្នេះ ផ្ទះនោះនឹងបានញែក
ជាស្អាត ដោយសារឈាមសត្វស្លាប និងទឹកហូរ ហើយ
សត្វដែលនៅរស់ ព្រមទាំងឈើតាត្រៅ មែកហ៊ីសុប
ហើយនិងសំពត់ក្រហមផង ៥៣តែត្រូវលែងសត្វរស់នៅឯ
វាល[ខ] ក្រៅទីក្រុងទៅ គឺយ៉ាងដូច្នោះដែលនឹងធ្វើឱ្យធួននឹង
ផ្ទះនោះ រួចនឹងបានស្អាតហើយ[គ] ។
៥៤នេះហើយជាច្បាប់ខាងឯរោគឃ្លង់គ្រប់យ៉ាង[ឃ] និង
ទឹលម៉ូវ ៥៥ហើយខាងឯឃ្លង់[ង]ដែលកើតនៅសំលៀកបំពាក់
ឬនៅផ្ទះ ៥៦និងខាងឯពក ឬស្នាមដែលសផង[ច] ៥៧ដើម្បីនឹង
បង្រៀនឱ្យដឹង ក្នុងកាលដែលស្មោកគ្រោក ឬក្នុងកាលដែល
ស្អាត នេះហើយជាច្បាប់ខាងឯរោគឃ្លង់[ឆ] ។

## ការហូរខ្ទុះដែលបណ្តាលឱ្យមិនស្អាត

**១៥** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេនិងអើរ៉ុន ២ឱ្យប្រាប់
ដល់ពួកកូនចៅអ៊ីស្រាអែលថា បើមនុស្សណាមានខ្ទុះហូរ
ចេញពីសាច់[ក] នោះរាប់ជាស្មោកគ្រោកហើយដោយព្រោះ
ហូរខ្ទុះនោះ ៣នេះឯងជាសេចក្តីស្មោកគ្រោករបស់អ្នកនោះ
ក្នុងកាលដែលហូរខ្ទុះ ទោះបើកំពុងតែហូរនៅឡើយ ឬ
បាត់ទៅក្តី នោះគង់តែរាប់ជាស្មោកគ្រោកដែរ ៤គ្រប់ទាំង
ដំណេកណាដែលមនុស្សនោះបានដេកនៅ នោះត្រូវស្មោក
គ្រោក ហើយរបស់អ្វីដែលអ្នកនោះអង្គុយចុះ ក៏ត្រូវស្មោក
គ្រោកដែរ ៥បើអ្នកណាពាល់គ្រែរបស់អ្នកនោះ ត្រូវឱ្យ
បោកសំលៀកបំពាក់ខ្លួន[ខ] ហើយងូតទឹកចេញ[គ] រួចនៅជា
ស្មោកគ្រោករហូតដល់ល្ងាច[ឃ] ៦ហើយបើអ្នកណាអង្គុយលើ
របស់អ្វី ដែលមនុស្សហូរខ្ទុះនោះបានអង្គុយនៅ នោះត្រូវ
បោកសំលៀកបំពាក់របស់ខ្លួន ហើយងូតទឹកចេញ រួចនៅ
ជាស្មោកគ្រោករហូតដល់ល្ងាច ៧បើអ្នកណាពាល់សាច់
មនុស្ស[ង]នោះ[ច] ត្រូវឱ្យបោកសំលៀកបំពាក់ខ្លួន ហើយងូតទឹក
ចេញ រួចនៅជាស្មោកគ្រោករហូតដល់ល្ងាច ៨បើមនុស្ស
ដែលហូរខ្ទុះនោះស្តោះ[ឆ]ទៅលើមនុស្សដែលស្អាត អ្នកនោះ
៧៧៧ត្រូវបោកសំលៀកបំពាក់ខ្លួន ហើយងូតទឹកចេញ
រួចនៅជា ស្មោកគ្រោករហូតដល់ល្ងាច
៩គ្រប់ទាំងកែបណាដែល មនុស្សហូរខ្ទុះនោះនឹងជិះ
នោះត្រូវស្មោកគ្រោកដែរ ១០បើ
អ្នកណាពាល់របស់អ្វីដែលបាននៅក្រោមអ្នកនោះ នោះ

**១៤:៤០** យ ខ.៤៥
**១៤:៤៤** រ លវ ១៣:៥១
**១៤:៤៦** ល លវ ១១:២៤
**១៤:៤៧** វ លវ ១១:២៥
**១៤:៤៨** ស លវ ១៣:៦
**១៤:៤៩** ហ ខ.៤ ១ពវ ៤:៣៣
**១៤:៥០** ឡ ខ.៥
**១៤:៥១** អ ខ.៦ ទដ ៥១:៧ ក ខ.៤,៧
**១៤:៥៣** ខ ខ.៧ គ ខ.២០
**១៤:៥៤** ឃ លវ ១៣:២
**១៤:៥៥** ង លវ ១៣:៤៧–៥២
**១៤:៥៦** ច លវ ១៣:២
**១៤:៥៧** ឆ លវ ១០:១០
**១៥:២** ក ខ.១៦,៣២ លវ ២២:៤ ជន ៥:២ ២សយ ៣:២៩ មថ ៩:២០
**១៥:៥** ខ លវ ១១:២៥ គ លវ ១៤:៨ ឃ លវ ១១:២៤
**១៥:៧** ង ខ.១៩ លវ ២២:៥ ច ខ.១៦ លវ ២២:៤
**១៥:៨** ឆ ជន ១២:១៤

**១៤:៤៥** *រំលំ* នៅត្រង់នេះបង្ហាញ ពីការដួលរលំរបស់ផ្ទះដោយសារផ្សិត ការដុះចាក់ជាពុម្ពជាជួរនៃប្រភេទផ្សិតនេះនឹងធ្វើឱ្យកខ្វក់ ដូច្នេះហើយ វានឹងដួលចុះយ៉ាងគំហុក ។

**១៤:៥៤–៥៧** នេះជាការសង្ខេបនៃជំពូក ១៣,១៤ ។

**១៥:១–៣៣** នៅវគ្គនេះនិយាយអំពី (១).ភាពមិនស្អាតរបស់បុរសបណ្តាលមកពីការហូរខ្ទុះ (ខ.២–១៥) ឬការបញ្ចេញទឹកកាម (ខ.១៦–១៨) (២).ភាពមិនស្អាតរបស់ស្ត្រី បណ្តាមកពីធ្លាក់ឈាមរដូវ (ខ.១៩–២៤) ឬរយៈពេលនៃការធ្លាក់ឈាម (ខ.២៥–៣០) (៣).ការសង្ខេប (ខ.៣១–៣៣) ។

**១៥:២** *ខ្ទុះហូរ* ជាទូទៅទាំងរោគតាមទ្វារធំ និងទ្វារតូច (ភាពផ្សេងគ្នានៃផលប៉ះពាល់) ។ ការឆ្លងរោគផ្សេងៗ គឺស្ថិតនៅក្រោមមនុស្សដែលមានជម្ងឺ (ខ.១០) ដែលអ្នកនោះបានអង្គុយនៅខាងលើ (ខ.៤,៦,៩) ឬដាក់ខ្លួនលើដំណេកអ្នកជម្ងឺ (ខ.៤) នេះបញ្ជាក់ថា ខ្ទុះនេះហូរតាមគូថ ឬតាមអង្គជាតិ ។

**១៥:៤** *ដំណេក* ត្រង់នេះបញ្ជាក់ថាជាកន្ទេល (សូមផ្ទៀប អស ១១:១៣) ។

ដែលចាប់លើករបស់ណាមួយនោះ[ជ] ក៏ត្រូវបោកសំលៀក
បំពាក់ខ្លួន ហើយងូតទឹកចេញ រួចនៅជាស្មោកគ្រោករហូត
ដល់ល្ងាច ១១បើមនុស្សហូរខ្ទុះនោះពាល់អ្នកណាឥតលាង
ដៃ អ្នកនោះត្រូវបោកសំលៀកបំពាក់ខ្លួន ហើយងូតទឹកចេញ
រួចនៅជាស្មោកគ្រោករហូតដល់ល្ងាច ១២ឯប្រដាប់ណាធ្វើ
ពីដី[ឈ]ដែលមនុស្សហូរខ្ទុះនឹងចាប់ពាល់ នោះត្រូវបំបែក
ចោលចេញ ហើយគ្រប់ទាំងប្រដាប់ធ្វើពីឈើ[ញ] នោះត្រូវ
លាងនឹងទឹកចេញដែរ ។
១៣បើកាលណាមនុស្ស ដែលហូរខ្ទុះនោះ បានជាស្អាត
ហើយ នោះត្រូវរាប់៧ថ្ងៃ[ដ] ឱ្យបានញែកខ្លួនជាស្អាត រួចត្រូវ
បោកសំលៀកបំពាក់ ហើយងូតក្នុងទឹកដែលហូរ នោះនឹង
បានស្អាតវិញ[ឋ] ១៤លុះដល់ថ្ងៃទី៨ ត្រូវឱ្យយកលលក២ឬ
ព្រាបជំទេរ២[ឌ]ទៅប្រគល់ដល់សង្ឃនៅចំពោះព្រះយេហូវ៉ា
ត្រង់មាត់ទ្វារត្រសាលជំនុំ ១៥ត្រូវឱ្យសង្ឃថ្វាយសត្វនោះ គឺ១
សំរាប់ជាដង្វាយលោះបាប[ឍ]១ទៀតសំរាប់ជាដង្វាយដុត[ណ]
ហើយត្រូវធ្វើឱ្យធួននឹងអ្នកនោះ នៅចំពោះព្រះយេហូវ៉ា
ដោយព្រោះរោគហូរខ្ទុះនោះ[ត] ។
១៦បើសិនជាមនុស្សណាចេញទឹកកាម[ថ]នោះត្រូវឱ្យងូត
ទឹកដុសលាងសាច់ទាំងអស់ចេញ ហើយនៅជាមិនស្អាត
រហូតដល់ល្ងាច[ទ] ១៧ហើយសំលៀកបំពាក់ឬកន្ទេលណា
ដែលប្រឡាក់ដោយទឹកកាមនោះ[ធ] ក៏ត្រូវលាងចេញហើយ
នៅជាមិនស្អាតរហូតដល់ល្ងាចដែរ ១៨ឯស្ត្រីនឹងបុរសណា
ដែលបានសេពសម្ពគ្នាហើយ នោះត្រូវឱ្យងូតទឹកចេញ
ទាំង២នាក់ ហើយនៅជាមិនស្អាតរហូតដល់ល្ងាច ។
១៩បើស្ត្រីណាធ្លាក់ឈាមដោយមានរដូវ[ន]នោះត្រូវនៅជា
មិនស្អាតអស់៧ថ្ងៃ អ្នកណាដែលពាល់ នាងនោះត្រូវនៅ
ជាមិនស្អាតរហូតដល់ល្ងាច ២០គ្រប់ទាំងដំណេកណាដែល
នាងដេកនៅក្នុងកាលដែលមិនស្អាត ហើយគ្រប់របស់អ្វី
ដែលនាងបានអង្គុយចុះ ក៏ត្រូវរាប់ជាមិនស្អាតដែរ ២១ឯអ្នក
ណាដែលពាល់គ្រែរបស់នាង នោះត្រូវឱ្យបោកសំលៀក
បំពាក់ខ្លួន ហើយងូតទឹកចេញ រួចនៅជាមិនស្អាតរហូត
ដល់ល្ងាច[ប] ២២ហើយអ្នក ណាដែលពាល់របស់អ្វីដែលនាង
បានអង្គុយ នោះត្រូវបោកសំលៀកបំពាក់ខ្លួន ហើយងូតទឹក
ចេញ រួចនៅជាមិនស្អាតរហូតដល់ល្ងាច ២៣បើមានអ្វីនៅ
លើគ្រែ ឬនៅលើរបស់ណាដែលនាងបានអង្គុយ ហើយអ្នក
ណាទៅប៉ះពាល់ នោះត្រូវនៅជាមិនស្អាតរហូតដល់ល្ងាច
២៤បើមានបុរសណាទៅរួមដំណេកនឹងនាង ហើយសេចក្តី
ស្មោកគ្រោក[ផ]របស់នាងក៏សៅហ្មងដល់ខ្លួន អ្នកនោះត្រូវ
ស្មោកគ្រោកអស់៧ថ្ងៃ ហើយគ្រប់ទាំងដំណេកណាដែល
បុរសនោះដេកនៅ ក៏ស្មោកគ្រោកដែរ ។
២៥បើស្ត្រីណាធ្លាក់ឈាមជាយូរថ្ងៃខុសរដូវ ឬបើធ្លាក់
ឈាមមកហួសរដូវ[ព]នោះនាងត្រូវជាមិនស្អាតរាល់តែថ្ងៃ
ដែលធ្លាក់ឈាមស្មោកគ្រោកនោះមក ដូចជានៅវេលា
ដែលមានរដូវដែរ ដ្បិតនាងមិនស្អាតហើយ ២៦គ្រប់ទាំង
ដំណេកណាដែលនាងដេកនៅ ក្នុងវេលាដែលធ្លាក់ឈាម
នោះត្រូវទុកដូចជាដំណេក ដែលនាងដេក ក្នុងកាលដែល
មានរដូវដែរ ហើយគ្រប់ទាំងរបស់អ្វីដែលនាងអង្គុយចុះ
នោះត្រូវជាមិនស្អាត ដូចជាសេចក្តីស្មោកគ្រោកនៅរដូវ
នាងដែរ ២៧បើអ្នកណាប៉ះពាល់នឹងរបស់ណាមួយនោះអ្នក
នោះក៏មិនស្អាតដែរ ត្រូវឱ្យបោកសំលៀកបំពាក់ខ្លួន ហើយ
ងូតទឹកចេញ រួចនៅជាមិនស្អាតរហូតដល់ល្ងាច ២៨បើ
កាលណានាងបានស្អាតខ្លួន ពីឈាមនោះហើយ នោះនាង
ត្រូវរាប់ឱ្យគ្រប់៧ថ្ងៃ រួចមកនឹងបានស្អាតវិញ ២៩លុះដល់ថ្ងៃ
ទី៨ត្រូវឱ្យនាងយកលលក២ ឬព្រាបជំទេរ២[ភ] មកប្រគល់
ដល់សង្ឃនៅមាត់ទ្វារត្រសាលជំនុំ ៣០ត្រូវឱ្យសង្ឃថ្វាយ១ជា
ដង្វាយលោះបាប ១ទៀតជាដង្វាយដុត ហើយត្រូវធ្វើឱ្យធួន
នឹងនាងចំពោះព្រះយេហូវ៉ា ដោយព្រោះធ្លាក់ឈាមស្មោក
គ្រោកនោះ[ម] ។
៣១គឺយ៉ាងដូច្នោះហើយ ដែលឯងរាល់គ្នាត្រូវញែកពួក
កូនចៅអ៊ីស្រាអែលចេញពីសេចក្តីស្មោកគ្រោករបស់គេ

**១៥:១០** ជ ជន ១៩:១០
**១៥:១២** ឈ លវ ៦:២៨ ញ លវ ១១:៣២
**១៥:១៣** ដ លវ ៨:៣៣ ឋ ខ.៥
**១៥:១៤** ឌ លវ ១៤:២២
**១៥:១៥** ឍ លវ ៥:៧ ណ លវ ១៤:៣១ ត លវ ១៤:១៨,១៩
**១៥:១៦** ថ ខ.២ ចទ ២៣:១០ ទ ខ.៥ ចទ ២៣:១១
**១៥:១៧** ធ ១សយ ២១:៤
**១៥:១៩** ន ខ.២៤
**១៥:២១** ប ខ.២៧
**១៥:២៤** ផ ខ.១៩ លវ ១២:២ ១៨:១៩ ២០:១៨ អគ ១៨:៦
**១៥:២៥** ព មថ ៩:២០ មក ៥:២៥ លក ៨:៤៣
**១៥:២៩** ភ លវ ១៤:២២
**១៥:៣០** ម លវ ៥:១០ ១៤:២០,៣១ ១៨:១៩ ២សយ ១១:៤ មក ៥:២៥ លក ៨:៤៣

**១៥:១៦** *ទឹកកាម* ជាធម្មតាទឹកកាមនេះបណ្តាលមកពីសកម្មភាពរួមភេទ និងដំណើរនៃការមានរដូវរបស់ស្ត្រីមិនទាមទាឱ្យមានការថ្វាយនូវយញ្ញបូជា ប៉ុន្តែវាគ្រាន់តែជារយៈពេលសម្អាត និងភាពមិនស្អាត ។

**១៥:១៩** *៧ថ្ងៃ* មើល ១២:២ ។ បទបញ្ញត្តិនេះ គឺជាជីវប្រវត្តិនៃ ២អស ១១:៤ (មើលការពន្យល់) ។

**១៥:២០** មើលការពន្យល់ នក ៣១:៣៥ ។

**១៥:២៤** *សៅហ្មងដល់ខ្លួន* នៅក្នុងរយៈពេលមានរដូវរបស់ស្ត្រីមិនត្រូវអនុញ្ញាតឱ្យរួមភេទ ។ នៅក្នុងដំណាក់កាលនេះ ពួកគេមិនត្រូវថ្វាយនូវយញ្ញបូជាដល់ព្រះអម្ចាស់ ប៉ុន្តែភាពមិនស្អាតរបស់ពួកគេត្រូវបញ្ចប់នៅថ្ងៃទី៧ ។

**១៥:២៥** *ធ្លាក់ឈាមជាយូរថ្ងៃ* នៅត្រង់នេះដូចមានជាឧទាហរណ៍ អំពីស្ត្រីនៅក្នុង មថ ៩:២០ (មើលការពន្យល់ មក ៥:២៥) ។ *ហួសរដូវ* នេះជាការដែលស្ត្រីធ្លាក់ឈាមខុសពីធម្មតា ប្រហែលបណ្តាលមកពីជម្ងឺ ហើយពួកគេថ្វាយនូវយញ្ញបូជានៅថ្ងៃទី៨ (ខ.២៨–៣០ និង ខ.១៤–១៥) ។

**១៥:៣១** នៅវគ្គនេះសំដៅលើពួកសង្ឃដែលមានបញ្ហាក់នៅក្នុងកិច្ចសំខាន់ៗក្នុងបទបញ្ញត្តិ ។ ពីព្រោះព្រះអម្ចាស់ មានព្រះវត្តមាននៅក្នុងរោងឧបោសថ ដូច្នេះ ភាពមិនស្អាតទាំងឡាយ ត្រូវបានបង្ហាញដោយការហូរខ្ទុះនៅក្នុង

ដើម្បីកុំឱ្យគេត្រូវស្លាប់ ក្នុងសេចក្តីស្មោកគ្រោករបស់គេ
ដោយមកនាំឱ្យរោងឧបោសថអញ[យ] ដែលនៅកណ្តាលគេ
បានស្មោកគ្រោកដែរ ៣២ នេះហើយជាច្បាប់ខាងឯអ្នកណា
ដែលហូរខ្ទុះ ហើយដែលធ្លាក់ទឹកកាមមក ឱ្យគេបានស្មោក
គ្រោកដូច្នោះ[រ] ៣៣ ហើយខាងឯស្រីឈឺដោយព្រោះមានរដូវ
នឹងខាងឯបុរសណាដែលហូរខ្ទុះ ឬស្ត្រីណា ដែលធ្លាក់
ឈាម ហើយខាងឯអ្នកណា ដែលរួមដំណេកនឹងស្ត្រីជាប់
មានសេចក្តីស្មោកគ្រោកផង[ល] ។

## ថ្ងៃលោះបាប

*១៦:២-៣៤ - លវ ២៣:២៦-៣២ ជន ២៩:៧-១១*

**១៦** ១ ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេ ក្នុងពេល
ក្រោយដែលកូនអើរ៉ុនទាំង២បានត្រូវស្លាប់ ដោយព្រោះ
បានចូលទៅចំពោះទ្រង់[ក] ២ គឺទ្រង់មានបន្ទូលនឹងម៉ូសេថា
ចូរហាមដល់អើរ៉ុនបងឯង កុំឱ្យចូល[ខ]ជារាល់ពេលមកក្នុង
ទីបរិសុទ្ធ[គ]ខាងក្នុងវាំងនន[ឃ] នៅមុខទីសន្តោសប្រោសដែល
នៅលើ[ង]ហឹបនោះឡើយ ក្រែងលោត្រូវស្លាប់ ដ្បិតអញនឹង
លេចមក[ច]ក្នុងពពក[ឆ]នៅលើទីសន្តោសប្រោស ៣ នេះហើយ
ជាច្បាប់ ដែលអើរ៉ុនចូលទៅក្នុងទីបរិសុទ្ធបាន[ជ] គឺដោយ
យកគោឈ្មោលស្ទាវ១មក[ឈ] សំរាប់ជាដង្វាយលោះបាប
និងចៀមឈ្មោល១ សំរាប់ជាដង្វាយដុត[ញ] ៤ ត្រូវឱ្យពាក់
អាវខ្លូតទេសបរិសុទ្ធ[ដ] និងស្លៀកខោស្នាប់ភ្លៅខ្លូតទេស
ព្រមទាំងក្រវាត់ខ្សែក្រវាត់ខ្លូតទេស ហើយពាក់មួកខ្លូតទេស
នៅក្បាល[ឋ] នោះជាសំលៀកបំពាក់បរិសុទ្ធ[ឌ] បានជាត្រូវឱ្យ
ងូតទឹកសិន[ឍ] រួចសឹមស្លៀកពាក់របស់ទាំងនោះជាខាង
ក្រោយ[ណ] ៥ រួចត្រូវយកពពែឈ្មោល២[ត] សំរាប់ជាដង្វាយ
លោះបាប និងចៀមឈ្មោល១ សំរាប់ជាដង្វាយដុតពីពួក

**១៥:៣១** យ លវ ២០:៣ ជន ៥:៣ ១៩:១៣,២០ ២សយ ១៥:២៥ ២ពវ ២១:៧ ទដ ៣៣:១៤ ៧៤:៧ ៧៦:២ អគ ៥:១១ ២៣:៣៨ **១៥:៣២** រ ខ.២ **១៥:៣៣** ល ខ.១៩, ២៤,២៥ **១៦:១** ក លវ ១០:១ **១៦:២** ខ នក ៣០:១០ ហព ៩:៧ គ នក ២៦:៣៣ ហព ៩:២៥ ១០:១៩ ឃ នក ២៦:៣៣ ហព ៦:១៩ ង នក ២៦:៣៤ ច នក ២៥:២២ ឆ នក ៤០:៣៤ ២សយ ២២:១០ **១៦:៣** ជ ខ.៦ លវ ៤:១-១២ ហព ៩:២៤,២៥ ឈ លវ ៤:៣ ញ ខ.៥ **១៦:៤** ដ លវ ៨:១៣ ឋ នក ២៨:៣៩ ឌ ខ.៣២ នក ២៨:៤២ ២៩:២៩,៣០ លវ ២១:១០ ជន ២០:២៦,២៨ ឍ នក ២៩:៤ ហព ១០:២២ ណ អគ ៩:២ ៤៤:១៧-១៨ **១៦:៥** ត ខ.២០ លវ ៤:៣ ២រប ២៩:២៣ ទដ ៥០:៩

ជំពូកទី១៥ ដែលជាលទ្ធផលនៃសេចក្តីស្លាប់ ប្រសិនបើពួកគេចូលទៅក្នុងរោងឧបោសថនោះ ។ អំពើបាបបានបំបែកមនុស្សទាំងអស់នោះ ឱ្យចេញពីភាពបរិសុទ្ធនៃព្រះ និងធ្វើឱ្យពួកគេធ្លាក់ក្នុងសេចក្តីស្លាប់ផងដែរ ប្រសិនបើពួកគេមិនថ្វាយដង្វាយលោះបាប (មើលជំពូកបន្ទាប់) ។

**១៥:៣២-៣៣** នេះជាការសង្ខេបនៃជំពូក ១៥ ទាំងមូល ។

**១៦:១-៣៤** មើល ២៣:២៦-៣២ ២៥:៩ នក ៣០:១០ ជន ២៩:៧-១១ ហព ៩:៧ ត្រង់នេះជាលំដាប់លំដោយនៃពិធីលោះបាបដូចមានខាងក្រោមនេះ : (១). ត្រង់នេះសម្តេចសង្ឃបានទៅក្នុងអាងទឹកនៃទីធ្លារោងឧបោសថ ដើម្បីផ្លាស់សំលៀកបំពាក់ចាស់ និងលុបលាងខ្លួន រួចទៅកាន់ទីបរិសុទ្ធ ដើម្បីពាក់សំលៀកបំពាក់ពិសេស នៅថ្ងៃបុណ្យលោះបាប (ខ.៤) ។ (២). សម្តេចសង្ឃដដែលបានចេញទៅទីខាងក្រៅ ដើម្បីថ្វាយគោជាយញ្ញបូជានៅលើអាសនា ជាដង្វាយដុត ដង្វាយលោះបាបសម្រាប់ខ្លួនគាត់ផ្ទាល់ និងសង្ឃដទៃទៀត (ខ.១១) ។ (៣). សម្តេចសង្ឃ បានចូលទៅទីបរិសុទ្ធបំផុតដែលយកទៅជាមួយនូវឈាមកូនគោ គ្រឿងក្រអូប និងធ្យូងចេញពីអាសនានៃដង្វាយដុត (ខ.១២-១៣) ។ គ្រឿងក្រអូប ត្រូវបានគេដាក់លើធ្យូងដែលកំពុងឆេះ ហើយផ្សែងនៃគ្រឿងក្រអូបនោះបានធ្វើឱ្យពួកគេមើលមិនឃើញហឹបសញ្ញា (៤). សម្តេចសង្ឃបានប្រោះឈាមកូនគោ នៅចំពោះហឹបសញ្ញាលោះបាប (ខ.១៤) ។ (៥). សម្តេចសង្ឃ ចេញទៅខាងក្រៅរោងឧបោសថ ហើយគ្រវែងសត្វពពែពីរ ដើម្បីបង្ហាញ ពីការថ្វាយយញ្ញបូជា និងការទទួលយកនូវអំពើបាប (ខ.៧-៨) ។ (៦). ដង្វាយដុតនៅអាសនា សម្តេចសង្ឃបានសម្លាប់ពពែសម្រាប់ដង្វាយលោះបាបមនុស្ស និងជាលើកទីពីរគាត់បានចូលទៅទីបរិសុទ្ធបំផុតម្តងទៀត ដើម្បីប្រោះឈាមពពែនោះនៅទីបរិសុទ្ធនោះ និងកន្លែងដែលត្រូវលោះបាប (ខ.៥,៩-១៦) ។ (៧). សម្តេចសង្ឃត្រឡប់ទៅទីបរិសុទ្ធ (ត្រូវបានគេហៅថា "រោងជំនុំ" ខ.១៦) និងប្រោះឈាមពពែនៅទីនោះ (ខ.១៦) ។ (៨). សម្តេចសង្ឃត្រឡប់ទៅទីអាសនា នៃដង្វាយដុតដើម្បីប្រោះឈាមកូនគោ (លើខ្លួនគាត់ផ្ទាល់ខ.១១) និងឈាមពពែលើពួកមនុស្ស (ខ.១៥) ។ (៩). ក្នុងពេលដែលគាត់នៅក្នុងទីធ្លានៅឡើយ គាត់បានលាដៃទាំងពីរដាក់លើសត្វពពែទីពីរ នេះជានិមិត្តរូបនៃការផ្លាស់ប្រែបាបរបស់ពួកអ៊ីស្រាអែល ហើយលែងសត្វពពែនោះ ឱ្យចេញទៅទីរហោស្ថាន (ខ.២០-២២) ។ (១០). អ្នកដែលនាំសត្វពពែនោះចេញទៅនៅពេលដែលទៅដល់ទីដៅ នោះត្រូវដុសលាងខ្លួន និងសំលៀកបំពាក់នៅខាងក្រៅទីដំឡើងត្រសាល (ខ.២៦) មុនពេលគេចូលរួមជាមួយនឹងអ្នកឯទៀត ។ (១១). សម្តេចសង្ឃបានដើរចូលមកទីបរិសុទ្ធបំផុតម្តងទៀត ដើម្បីដោះសំលៀកបំពាក់ពិសេសនោះចេញ (ខ.២៣) ។ (១២). សម្តេច-សង្ឃបានចេញទៅទីអាងទឹកដើម្បីដុសលាង និងស្លៀកសំលៀកបំពាក់សង្ឃធម្មតាវិញ (ខ.២៤) ។ (១៣). ជាកិច្ចបញ្ចប់នៃកម្មវិធីបូជា សម្តេចសង្ឃបានចេញពីទីអាសនា ហើយថ្វាយចៀមឈ្មោល (ខ.៣) ជាដង្វាយដុតសម្រាប់ខ្លួនគាត់ផ្ទាល់ និងចៀមឈ្មោលមួយទៀតសម្រាប់មនុស្ស(ខ.២៤) ។ (១៤). នេះជាការបូកសរុប នៃការថ្វាយដង្វាយលោះបាបនៅ ខាងក្រៅទីដំឡើងត្រសាល ជាទីដែលពួកគេបានដុតដង្វាយដុត ហើយទីនោះផងដែរពួកមនុស្សដែលមានរោគបានចូលមកសម្អាត និងដុះលាងសំលៀកបំពាក់ (ខ.២៧-២៨) មុនពួកគេចូលរួមជាមួយមនុស្សឯទៀត ។

**១៦:១** *កូនអើរ៉ុនទាំង២បានត្រូវស្លាប់* សូមមើល ១០:១-៣ ។

**១៦:២** *សន្តោសប្រោស* សូមមើល ២៥:១៧ និងការពន្យល់ ។ ឈាមដែលបានប្រោះលើគម្របហឹបសញ្ញា បានសន្តោសដល់ពួកអ៊ីស្រាអែលឱ្យធួននឹងបាបរបស់ពួកគេ (ខ.២៧-២៨) ។

**១៦:៣** *ក្នុងទីបរិសុទ្ធ* នេះបញ្ជាក់ពីទីដែលបរិសុទ្ធបំផុត (មើល ខ.២) ។ *គោឈ្មោលស្ទាវ* នេះលោកអើរ៉ុន បានធ្វើពិធីលាងសំអាតបាប (៦,១១)។ មុនពេលលោកអើរ៉ុន ចូលទៅទីបរិសុទ្ធបំផុត គាត់ផ្ទាល់បានសំអាតខ្លួនជាស្រេច (ហព ៥:១-៣) តែព្រះយេស៊ូវមិនធ្វើដូច្នេះទេ ដែលទ្រង់ជាសម្តេចសង្ឃដ៏ធំលើយើងទាំងអស់គ្នានិងលោកអើរ៉ុនផងដែរ (ហព ៧:២៦-២៨)។

**១៦:៥** *ពពែឈ្មោល២ សំរាប់ដង្វាយលោះបាប* ពពែមួយធម្មតាជា

ជំនុំកូនចៅអ៊ីស្រាអែល[ថ] ។
៦អើរ៉ុនត្រូវថ្វាយគោឈ្មោល ដែលសំរាប់ជាដង្វាយ
លោះបាបនោះ ទុកជាដង្វាយថ្វាយដោយព្រោះខ្លួន ដើម្បី
ឱ្យបានធួននឹងខ្លួន ហើយនិងពូជពង្សផង[ទ] ៧រួចត្រូវយកពពែ
ឈ្មោលទាំង២នោះ ទៅដាក់នៅចំពោះព្រះយេហូវ៉ាត្រង់
មាត់ទ្វារត្រសាលជំនុំ ៨ហើយចាប់ឆ្នោត[ធ]ពពែទាំង២នោះ
១សំរាប់ព្រះយេហូវ៉ា ១ទៀតសំរាប់បំបរបង់ទៅ[ន] ៩អើរ៉ុន
ត្រូវយកពពែ ដែលចាប់ឆ្នោតត្រូវសំរាប់ព្រះយេហូវ៉ាមក
ថ្វាយទុកជាដង្វាយលោះបាប ១០តែឯពពែដែលចាប់ឆ្នោត
ត្រូវសំរាប់បំបរបង់ទៅ នោះត្រូវយកមកដាក់ទាំងរស់នៅ
ចំពោះព្រះយេហូវ៉ា ដើម្បីឱ្យបានធួននឹងបាប[ប]រួចចាត់គេឱ្យ
នាំយកទៅលែងឯទីរហោស្ថាន ។
១១ត្រូវឱ្យអើរ៉ុននាំគោឈ្មោលនៃដង្វាយលោះបាបដែល
សំរាប់ខ្លួនមកឱ្យធួននឹងខ្លួន ហើយនិងពូជពង្សដែរ[ផ] រួច
សំឡាប់គោនោះថ្វាយដោយព្រោះបាបខ្លួន ១២ត្រូវឱ្យយក
ជើងពានដាក់ពេញដោយរងើកភ្លើង[ព] ពីលើអាសនាដែល
នៅចំពោះព្រះយេហូវ៉ា ហើយយកគ្រឿងក្រអូប[ភ]ដែល
បុកយ៉ាងម៉ដ្ត ចំនួន២ក្តាប់ នាំចូលទៅខាងក្នុងវាំងនន
១៣រួចរោយចុះនៅលើភ្លើងចំពោះព្រះយេហូវ៉ា ដើម្បីឱ្យ
ផ្សែងនៃគ្រឿងក្រអូបនោះហុយឡើង ទៅបាំងទីសន្តោស
ប្រោស ដែលនៅលើ[ម]ហឹបនៃសេចក្តីបន្ទាល់ ក្រែងលោ
ត្រូវស្លាប់[យ] ១៤ហើយត្រូវយកឈាមគោនោះ[រ] ទៅប្រោះ
ដោយម្រាមដៃលើប៉ែកខាងកើត នៃទីសន្តោសប្រោស ឯ
ខាងមុខទីសន្តោសប្រោស ក៏ត្រូវប្រោះឈាមដោយម្រាមដៃ
អស់៧ដងដែរ[ល] ។
១៥រួចអើរ៉ុនត្រូវសំឡាប់ពពែឈ្មោលនៃដង្វាយលោះ
បាបដែលថ្វាយសំរាប់ពួកជន[វ] ហើយយកឈាមនាំចូលទៅ
ខាងក្នុងវាំងនន[ស] ទាំងប្រោះ[ហ]ឈាមពពែនោះដូចជាបាន
ប្រោះឈាមគោឈ្មោលដែរ គឺត្រូវប្រោះឈាមនៅលើទី
សន្តោសប្រោស ហើយនៅខាងមុខដែរ ១៦ដូច្នេះនឹងបាន
ធ្វើឱ្យធួន[ឡ]នឹងទីបរិសុទ្ធ[អ] ដោយព្រោះសេចក្តីស្មោកគ្រោក
របស់ពួកកូនចៅអ៊ីស្រាអែល និងអស់ទាំងសេចក្តីរំលង
របស់គេ គឺអស់ទាំងបាបដែលគេបានប្រព្រឹត្តទាំងប៉ុន្មាន
ត្រូវឱ្យធ្វើដូច្នោះឱ្យបានធួននឹងត្រសាលជំនុំ[ក]ដែលនៅជា
មួយនឹងគេ គឺនៅកណ្តាលអស់ទាំងសេចក្តីស្មោកគ្រោក
របស់គេ ១៧មិនត្រូវឱ្យមានអ្នកណាមួយនៅក្នុងត្រសាលជំនុំ
ក្នុងកាលដែលលោកចូលទៅ ធ្វើឱ្យធួននឹងបាបនៅក្នុង
ទីបរិសុទ្ធឡើយ ដរាបដល់ចេញមកវិញហើយបានធ្វើឱ្យធួន
នឹងខ្លួន ព្រមទាំងពូជពង្ស ហើយនិងពួកជំនុំ នៃសាសន៍
អ៊ីស្រាអែលទាំងអស់គ្នាផង ១៨រួចត្រូវឱ្យលោកចេញទៅ
ឯអាសនា[ខ] ដែលនៅចំពោះព្រះយេហូវ៉ា ដើម្បីនឹងធ្វើឱ្យ
ធួននឹងអាសនានោះ ដោយយកឈាមគោឈ្មោលនិងឈាម
ពពែនោះ ទៅប្រឡាក់នៅស្នែងអាសនាជុំវិញ[គ] ១៩ត្រូវ
ប្រោះឈាមនោះដោយម្រាមដៃអស់៧ដង ទៅលើអាសនា
ព្រមទាំងញែកចេញជាស្អាត ឱ្យបានបរិសុទ្ធ រួចពីអស់ទាំង
សេចក្តីស្មោកគ្រោករបស់ពួកកូនចៅអ៊ីស្រាអែល[ឃ] ។
២០កាលអើរ៉ុនបានធ្វើឱ្យធួននឹងទីបរិសុទ្ធ ព្រមទាំង
ត្រសាលជំនុំ នឹងអាសនារួចហើយ នោះត្រូវនាំពពែ១
ដែលនៅរស់នោះមក[ង] ២១រួចដាក់ដៃទាំង២នៅលើក្បាល
ពពែនោះ[ច] លន់តួ[ឆ]ពីអស់ទាំងសេចក្តីទុច្ចរិត និងអស់ទាំង
សេចក្តីរំលងរបស់ពួកកូនចៅអ៊ីស្រាអែល ពីលើពពែនោះ
គឺអំពើបាបរបស់គេទាំងអស់ ត្រូវដាក់ទាំងអស់លើក្បាល

**១៦:៥** ថ លវ ៤:១៣–២១
**១៦:៦** ទ លវ ៩:៧
**១៦:៨** ធ ជន ២៦:៥៥,៥៦ ៣៣:៥៤ ៣៤:១៣ យស ១៤:២ ១៨:៦ ពច ២០:៩ នហ ១០:៣៤ នអ ៣:៧ ៩:២៤ ទដ ២២:១៨ សភ ១៦:៣៣ ន ខ.១០,២៦
**១៦:១០** ប អស ៥៣:៤–១០
**១៦:១១** ផ ខ.៦, ២៤,៣៣
**១៦:១២** ពលវ១០:១ វវ ៨:៥ ភ នក ២៥:៦ ៣០:៣៤–៣៨
**១៦:១៣** ម នក ២៥:១៧ យ នក ២៨:៤៣
**១៦:១៤** រ លវ ៤:៥ ហព ៩:៧,១៣,២៥ ល លវ ៤:៦
**១៦:១៥** វ លវ ៤:១៣–២១ ហព ៧:២៧ ៩:៧,១២ ១៣:១១
ស ហព ៩:៣ ហ លវ ៤:១៧ ជន ១៩:១៩ អស ៥២:១៥ អក ៣៦:២៥
**១៦:១៦** ឡ នក ២៩:៣៦ រម ៣:២៥ អ នក ២៦:៣៣ ហព ៩:២៥ ក នក ២៩:៤ ៤០:២ **១៦:១៨** ខ លវ ៤:៧ គ លវ ៤:២៥ **១៦:១៩** ឃ អក ៤៣:២០ **១៦:២០** ង ខ.៥ **១៦:២១** ច នក ២៩: ១០ ឆ លវ ៥:៥

ដង្វាយលោះបាប(មើលការពន្យល់ ៤:៣,៥) និងមួយទៀតជាអ្នកទទួលកំហុស ។ គ្មានយញ្ញបូជាណា ដូចយញ្ញបូជារបស់ព្រះយេស៊ូវ ដែលអាចប្រោសលោះបាបបានតែមួយដងគត់ ។ ចៀមមួយត្រូវបានសម្លាប់ ហើយឈាមរបស់វាបានប្រោះនៅទីបរិសុទ្ធបំផុត និងខ្លួនវាទាំងមូលត្រូវបានដុតនៅទីដំឡើងត្រសាល (ខ.១៥,១៧)ជានិមិត្តរូបនៃការបង់ថ្លៃលោះបាបរបស់ព្រះយេស៊ូវ ។ ចៀមទី២ ត្រូវបានគេព្រលែងឱ្យទៅទីឆ្ងាយ និងរែកពុននូវអំពើបាបរបស់ពួកគេ(ខ.២១)ជានិមិត្តរូបនៃការលះចោលអំពើបាបនិងការជាប់មានទោស ។ *ចៀម* សត្វនេះសម្រាប់លោះបាបមនុស្ស នៅក្នុង ខ.៣ សត្វនេះបានលោះបាបដល់សម្តេចសង្ឃ ។ សត្វទាំងពីរ ត្រូវបានគេថ្វាយជាយញ្ញបូជានៅបញ្ចប់ពិធីថ្វាយដង្វាយ (ខ.២៤) ។

**១៦:៦–១០** សូមមើលគម្រោងសង្ខេប ខ.១១–១២ ។

**១៦:១១** *ឱ្យធួននឹងខ្លួន* មើលការពន្យល់ ខ.៣ ។

**១៦:១៣** *ផ្សែងនៃគ្រឿងក្រអូប* ផ្សែងនេះបានបាំងហឹបសញ្ញា ដូច្នេះហើយពួកសម្តេចសង្ឃមិនអាចមើលឃើញ ពីសិរីល្អរបស់ព្រះ ក្រែងលោត្រូវស្លាប់ ។ *សេចក្តីបន្ទាល់* សូមមើល នក ២៥:២២ ។

**១៦:១៤** សូមមើល រម ៣:២៥ និងការពន្យល់ ។ *៧ដង* មើលការពន្យល់ ៤:៦ ។

**១៦:១៦** *ត្រសាលជំនុំ* ពាក្យនេះមាននៅក្នុងខនេះ និង ខ.១៧,២០,៣៣ ហើយពាក្យនេះសំដៅលើទីបរិសុទ្ធ ។

**១៦:២០–២២** នៅវគ្គត្រង់នេះជាការរៀបរាប់ ពីការជិនួសនៃការប្រោសសន្តោស ។ ពួកអ្នកមានបាប បានចូលមកលន់តួបាប ហើយបង្វែរបាបទាំងនោះទៅដល់យញ្ញបូជាសត្វ ដោយការដាក់ដៃលើសត្វនោះ (សូមមើលការពន្យល់ ១:៣ នក ២៩:១០ មើលបន្ថែម លវ ១:៤ ៣:៨ ៤:៤ ធៀប អស ៥៣:៦ យហ ១:២៩ ១ពត ២:២៤) ។

ពពែនោះ រួចប្រគល់ដល់មនុស្សម្នាក់ ដែលប្រុងជាស្រេច
ដើម្បីដឹកវាទៅឯទីរហោស្ថាន ២២ឯពពែនោះត្រូវផ្ទុកអស់
ទាំងសេចក្តីទុច្ចរិតរបស់គេ[ជ] លើខ្លួនចេញទៅឯតំបន់សូន្យ
ស្ងាត់ រួចអ្នកនោះត្រូវលែងវានៅទីរហោស្ថាននោះ ។
២៣រួចអើរ៉ុនត្រូវចូលទៅក្នុងត្រសាលជំនុំវិញ ដោះ
សំលៀកបំពាក់ខ្លូតទេស[ឈ]ដែលបានស្លៀកពាក់ ក្នុងកាល
ដែលចូលទៅក្នុងទីបរិសុទ្ធនោះ ចេញទុកនៅទីនោះ[ញ]
២៤រួចមកត្រូវងូតទឹកត្រង់កន្លែងបរិសុទ្ធ[ដ] ហើយស្លៀកពាក់
ឡើងវិញ[ឋ] ចេញមកថ្វាយដង្វាយដុតរបស់ខ្លួន និងដង្វាយ
ដុតរបស់ពួកជន[ឌ] ដើម្បីឱ្យបានធួននឹងខ្លួន ហើយនិងពួកជន
ផង[ឍ] ២៥ឯខ្លាញ់នៃដង្វាយលោះបាប នោះត្រូវដុតនៅលើ
អាសនា ២៦ចំណែកអ្នកដែលដឹកពពែទៅបំបរបង់នោះ[ណ]
ត្រូវឱ្យបោកសំលៀកបំពាក់ខ្លួន[ត] ហើយងូតទឹកចេញ[ថ] ទើប
នឹងចូលមកក្នុងទីដំឡើងត្រសាលបាន ២៧ឯគោឈ្មោលនៃ
ដង្វាយលោះបាប និងពពែនៃដង្វាយលោះបាបនោះ ដែល
បានយកឈាមចូលទៅក្នុងទីបរិសុទ្ធ ឱ្យធួននឹងបាបនោះ
ត្រូវលើកយកចេញទៅខាងក្រៅទីដំឡើងត្រសាល[ទ] រួចត្រូវ
ដុតទាំងស្បែកទាំងសាច់ និងលាមកទៅ ២៨ឯអ្នកណាដែល
ដុតសត្វទាំង២នោះ ក៏ត្រូវបោកសំលៀកបំពាក់ខ្លួន ហើយ
ងូតទឹកចេញដែរ ទើបចូលមកក្នុងទីដំឡើងត្រសាលបាន[ធ]។
២៩នេះជាច្បាប់សំរាប់ឯងរាល់គ្នានៅអស់កល្បជានិច្ច[ន]គឺ
នៅថ្ងៃ១០ខែអស្សុជ[ប] នោះត្រូវឱ្យឯងរាល់គ្នាបញ្ឈឺចិត្តខ្លួន[ផ]
មិនត្រូវធ្វើការអ្វីឱ្យសោះ[ព] ទោះទាំងអ្នកស្រុក ឬអ្នកប្រទេស
ក្រៅ[ភ] ដែលនៅកណ្តាលឯងរាល់គ្នាផង ៣០ដ្បិតនៅថ្ងៃនោះ
នឹងបានធ្វើឱ្យធួននឹងឯងរាល់គ្នា[ម] ដើម្បីនឹងញែកចេញជា
ស្អាត នោះឯងរាល់គ្នានឹងបានស្អាតពីអំពើបាបទាំងប៉ុន្មាន
នៅចំពោះព្រះយេហូវ៉ា[យ] ៣១នេះជាថ្ងៃឈប់សំរាកសំរាប់
ឯងរាល់គ្នា ត្រូវឱ្យបញ្ឈឺចិត្តខ្លួន[រ]នេះគឺជាច្បាប់នៅអស់
កល្បជានិច្ច[ល] ៣២ឯអ្នកណាដែលគេនឹងចាក់ប្រេងតាំងឡើង
ឱ្យធ្វើជាសង្ឃ[វ]ជំនួសឪពុកខ្លួន សង្ឃនោះត្រូវធ្វើឱ្យធួននឹង
បាប ហើយត្រូវស្លៀកសំលៀកបំពាក់ខ្លូតទេស គឺជា
សំលៀកបំពាក់បរិសុទ្ធនោះ[ស] ៣៣សង្ឃនោះត្រូវធ្វើឱ្យធួន
នឹងទីបរិសុទ្ធបំផុត និងត្រសាលជំនុំ ហើយអាសនា
ព្រមទាំងពួកសង្ឃ ហើយនិងអស់អ្នកទាំងប៉ុន្មានក្នុងជំនុំជន
ផង[ហ] ៣៤នេះហើយជាច្បាប់សំរាប់ឯងរាល់គ្នា នៅអស់
កល្បជានិច្ច[ឡ] ដើម្បីឱ្យបានធួននិងពួកកូនចៅអ៊ីស្រាអែល១
ឆ្នាំម្តង[អ] ដោយព្រោះអស់ទាំងអំពើបាបរបស់គេ លោក
ក៏ធ្វើដូចជា ព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ ។

## បម្រាមចំពោះការបរិភោគឈាម

**១៧** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់អើរ៉ុន
និងពួកកូនលោក[ក] ហើយនិងពួកកូនចៅអ៊ីស្រាអែលទាំង
អស់ថា ព្រះយេហូវ៉ាទ្រង់បានបង្គាប់មកដូច្នេះ ៣គឺបើមាន
អ្នកណាក្នុងពួកវង្សអ៊ីស្រាអែល ដែលសំឡាប់គោ ឬចៀម[ខ]
ឬពពែ[គ]នៅក្នុងទីដំឡើងត្រសាល ឬខាងក្រៅទីដំឡើង
ត្រសាលក្តី ៤ឥតនាំចូលមកឯទ្វារត្រសាលជំនុំ[ឃ] ដើម្បីនឹង
ថ្វាយទុកជាដង្វាយដល់ព្រះយេហូវ៉ានៅមុខរោងឧបោសថ
របស់ទ្រង់[ង] អ្នកនោះនឹងបានរាប់ជាមានទោសនឹងឈាម
ដ្បិតបានកំចាយឈាមហើយ អ្នកនោះត្រូវកាត់កាល់ពី
សាសន៍ខ្លួនចេញ[ច] ៥នេះដើម្បីឱ្យពួកកូនចៅអ៊ីស្រាអែលបាន
នាំអស់ទាំងយញ្ញបូជានៃគេ ដែលតែងថ្វាយនៅវាលមក
ថ្វាយដល់ព្រះយេហូវ៉ានៅមាត់ទ្វារត្រសាលជំនុំវិញ គឺមក

**១៦:២២** ជ នក ២៨:៣៨ អស ៥៣:១២ **១៦:២៣** ឈ នក ២៨:៤២ ញ អក ៤២:១៤ **១៦:២៤** ដ លវ ៦:១៦ ឋ ខ.៣–៥ ឌ ឍ លវ ១:៣ ឍ ខ.១១ **១៦:២៦** ណ ខ.៨ ត លវ ១១:២៥ ថ លវ ១៤:៨ **១៦:២៧** ទ នក ២៩:១៤ **១៦:២៨** ធ ជន ១៩:៨,១០ **១៦:២៩** ន នក ១២:១៤ ប លវ ២៥:៩ ផ ខ.៣១ លវ ២៣:២៧,៣២ ជន ២៩:៧ អស ៥៨:៣ ព នក ៣១:១៥ លវ ២៣:២៨ ភ នក ១២:១៩ **១៦:៣០** ម នក ៣០:១០ យ ទដ ៥១:២ យរ ៣៣:៨ អគ ៣៦:៣៣ សក ១៣:១ អភ ៥:២៦ **១៦:៣១** រ អរ ៨:២១ អស ៥៨:៣,៥ ដយ ១០:១២ ល កច ២៧:៩ **១៦:៣២** វ នក ៣០:៣០ ស ខ.៤ នក ២៨:២ **១៦:៣៣** ហ ខ.១១,១៦–១៨ អគ ៤៥:១៨ **១៦:៣៤** ឡ នក ២៧:២១ អ ហព ៩:៧,២៥ **១៧:២** ក លវ ១០:៦ **១៧:៣** ខ លវ ៣:៧ គ **១៧:៤** ឃ ខ.៩ ១ពវ ៨:៤ ២រប ១:៣ ង ចទ ១២:៥–២១ ច លប ១៧:១៤

**១៦:២៤** *កន្លែងបរិសុទ្ធ* សូមធៀប ៦:២៦ ។ *ដង្វាយដុត . . . ដង្វាយដុត* ចៀមពីរត្រូវបានលើកឡើងនៅក្នុងខ.៣,៥ ។

**១៦:២៥** *ខ្លាញ់នៃដង្វាយលោះបាប* មើល ៤:៨–១០ ។

**១៦:២៧** *ក្រៅទីដំឡើងត្រសាល* មើលការពន្យល់ ៤:១២ ។

**១៦:២៩,៣១** *បញ្ឈឺចិត្តខ្លួន* តាមន័យអក្សរសាស្ត្រថា "បន្ទាបខ្លួន" ឬ"តូចចិត្ត" របស់ខ្លួន ។ ពាក្យនេះត្រូវបានគេប្រើនៅក្នុងពិធីតម (ទដ ៣៥:១៣) ។ ថ្ងៃលោះបាប ជាថ្ងៃតមពិសេសយ៉ាងជាក់លាក់នៅសម័យសញ្ញាចាស់ (មើល ២៣:២៧,២៩,៣២) ។

**១៦:៣០** *នឹងបានធ្វើឱ្យធួននឹងឯងរាល់គ្នា* នៅថ្ងៃបុណ្យលោះបាបនេះសេចក្តីសោកស្តាយរបស់ពួកអ៊ីស្រាអែល ត្រូវបានធានាអះអាងដោយព្រះអម្ចាស់ថានឹងអត់ទោសឱ្យពួកគេ ។

**១៦:៣៤** *១ឆ្នាំម្តង* ពាក្យនេះបង្ហាញភាពផ្ទុយគ្នាទៅនឹង ហព ៩:១១–១០:១៤ ដែលនិយាយពីយញ្ញបូជាតែម្តងគត់របស់ព្រះយេស៊ូវគ្រីស្ទសម្រាប់ទាំងអស់។

**១៧:១–២៦:៤៦** នៅវគ្គត្រង់នេះជួនកាលត្រូវបានគេហៅថា "ច្បាប់បរិសុទ្ធ" ដែលនៅក្នុងជំពូកទាំងនោះដូចទៅនឹង ការរស់នៅជាបរិសុទ្ធ និងការអនុវត្តជាបរិសុទ្ធ ដែលអាចធ្វើឡើងនៅទីកន្លែងផ្សេងគ្នា (សូមមើលការពន្យល់ ១១:៤៤) ។

**១៧:៤** *រោងឧបោសថរបស់ទ្រង់* ចំណុចនេះបង្ហាញពីការលើកលែងដល់ពួកមនុស្សខ្លះ (ឧទាហរណ៍ ចទ ១២:១៥,២០–២១) ក្នុងការដែលសម្លាប់សត្វ ហើយមិនបាននាំមកតាមរោងឧបោសថរបស់ទ្រង់ (ចទ ១២:៦–៧) ។ សានហេរីប ជាស្តេចស្រុកអាសស៊ើរបានបង្ហាញពីការដែលស្តេចអេសេគាល បានឱ្យពួកគេថ្វាយបង្គំតែអាសនា១នៅក្រុងយេរូសាឡិម (២ពវ ១៨:២២) ។ *កាត់កាល់ពីសាសន៍ខ្លួន* មើលការពន្យល់ ៧:២០ ។

**១៧:៥** *មកឯសង្ឃ . . . ដល់ព្រះយេហូវ៉ា* មើលការពន្យល់ ៦:៦ ។

ឯសង្ឃ ដើម្បីនឹងថ្វាយទុកជាយញ្ញបូជានៃដង្វាយមេត្រីដល់
ព្រះយេហូវ៉ា[ឆ] ៦នោះសង្ឃនឹងប្រោះឈាមនៅលើអាសនា[ជ]
នៃព្រះយេហូវ៉ា [ឈ]ត្រង់មាត់ទ្វារត្រសាលជំនុំ ហើយនឹងដុត
ខ្លាញ់ទុកជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ាដែរ[ញ] ៧ដូច្នេះ គេនឹង
មិនថ្វាយយញ្ញបូជារបស់គេចំពោះរូបសត្វ[ដ] ដែលគេផិត
ទៅតាមនោះទៀតឡើយ[ឋ] នេះហើយជាច្បាប់នៅអស់កល្ប
ជានិច្ច[ឌ] សំរាប់គ្រប់ទាំងដំណគេតរៀងទៅ[ឍ] ៨ត្រូវឱ្យប្រាប់
គេថា អស់អ្នកណាក្នុងពួកវង្សអ៊ីស្រាអែល ឬអ្នកប្រទេស
ក្រៅណានៅកណ្តាលគេ ដែលថ្វាយដង្វាយដុត ឬយញ្ញបូជា
៩ឥតនាំមកឯទ្វារត្រសាល[ណ]ជំនុំ[ត] ដើម្បីនឹងថ្វាយដល់ព្រះ
យេហូវ៉ា[ថ] អ្នកនោះត្រូវកាត់កាល់ពីសាសន៍របស់ខ្លួនចេញ។
១០ឯអ្នកណាក្នុងពួកវង្សអ៊ីស្រាអែល ឬអ្នកប្រទេសក្រៅ
ណានៅកណ្តាលគេ ដែលនឹងបរិភោគឈាមអ្វីក៏ដោយ
នោះអញនឹងតាំងមុខទាស់នឹងអ្នកដែលបរិភោគឈាម
នោះ[ទ] ហើយនិងកាត់គេចេញពីសាសន៍របស់ខ្លួន ១១ដ្បិត
ជីវិតនៃរូបសាច់ នោះនៅក្នុងឈាម[ធ] ហើយអញបានឱ្យ
ឈាមដល់ឯងរាល់គ្នា សំរាប់នឹងថ្វាយនៅលើអាសនា
ដើម្បីឱ្យបានធួននឹងជីវិតឯង ដ្បិតគឺជាឈាមនោះឯងដែល
ធួននឹងព្រលឹងបាន[ន] ១២ដោយហេតុនោះបានជាអញហាម
ដល់ពួកកូនចៅអ៊ីស្រាអែលថា កុំឱ្យអ្នកណាក្នុងពួកឯងរាល់
គ្នាបរិភោគឈាមឱ្យសោះ ក៏មិនត្រូវឱ្យពួកប្រទេសក្រៅ
ដែលនៅកណ្តាលឯងរាល់គ្នាបរិភោគដែរ ១៣ឯអ្នកណា
ក្នុងពួកកូនចៅអ៊ីស្រាអែល ឬក្នុងពួកអ្នកប្រទេសក្រៅនៅ
ជាមួយ ដែលដេញចាប់បានសត្វជើង៤ ឬសត្វស្លាប ដែល
បរិភោគបាន ត្រូវឱ្យអ្នកនោះសំរក់ឈាមចោលចេញ រួច
យកដីគ្របវិញ[ប] ១៤ដ្បិតឈាមជាជីវិតនៃអស់ទាំងសត្វ ឈាម
និងជីវិតនោះ គឺតែ១ទេ ដោយហេតុនោះ បានជាអញហាម
ដល់ពួកកូនចៅអ៊ីស្រាអែលថា ឯងរាល់គ្នាមិនត្រូវបរិភោគ
ឈាមនៃសត្វណាមួយឡើយ គឺព្រោះជីវិតនៃសត្វទាំងឡាយ
ជាឈាមនោះឯង អ្នកណាដែលបរិភោគ នោះនឹងត្រូវកាត់
កាល់ចេញជាពិត[ផ] ១៥ហើយអស់អ្នកណាដែលបរិភោគ[ព]
សត្វ ដែលស្លាប់ដោយខ្លួនឯង ឬមានសត្វណា[ភ]ហែកសំឡាប់
ទោះបើអ្នកនោះកើតក្នុងស្រុក ឬជាអ្នកប្រទេសក្រៅក្តី
នោះត្រូវឱ្យបោកសំលៀកបំពាក់ខ្លួនហើយងូតទឹកចេញ[ម]
រួចនៅជាមិនស្អាត រហូតដល់ល្ងាច[យ] នោះទើបនឹងបាន
ស្អាតវិញ ១៦តែបើមិនបានបោក ឬងូតទឹកចេញទេ អ្នក
នោះត្រូវទ្រាំទ្រក្នុងសេចក្តីទុច្ចរិតរបស់ខ្លួនហើយ[រ]។

## ទំនាក់ទំនងផ្លូវភេទដែលខុសច្បាប់

**១៨** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា អញនេះគឺជាយេហូវ៉ា ជាព្រះនៃ
ឯងរាល់គ្នា[ក] ៣មិនត្រូវឱ្យឯងរាល់គ្នាប្រព្រឹត្តតាមអំពើដែល
គេធ្វើនៅស្រុកអេស៊ីព្ទ ជាស្រុកដែលឯងរាល់គ្នាបាន
អាស្រ័យនៅនោះឡើយ ក៏មិនត្រូវឱ្យប្រព្រឹត្តតាមអំពើដែល
គេធ្វើនៅស្រុកកាណាន ជាស្រុកដែលអញនាំឯងរាល់គ្នា
ទៅនៅនោះដែរ កុំឱ្យដើរតាមរបៀបរបស់គេឱ្យសោះ[ខ]
៤ត្រូវឱ្យឯងរាល់គ្នារក្សាបញ្ញត្តិរបស់អញ[គ] ហើយកាន់តាម
អស់ទាំងច្បាប់របស់អញវិញ[ឃ] ដើម្បីនឹងប្រព្រឹត្តតាម អញ
នេះ គឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា[ង] ៥ដូច្នេះ ត្រូវឱ្យឯង

**១៧:៥** ឆ លវ ៣:១ អគ ៤៣:២៧
**១៧:៦** ជ លវ ៤:១៨ ឈ លវ ៣:២ ញ លវ ១:៩
**១៧:៧** ដ នក ២២:២០ ឋ នក ៣៤:១៥ យរ ៣:៦,៩ អគ ២៣:៣ ១កថ ១០:២០ ឌ នក ១២:១៤ ឍ លប ៩:១២
**១៧:៩** ណ លវ ១:៣ ត ខ.៤ ថ លវ ៣:៧
**១៧:១០** ទ លប ៩:៤
**១៧:១១** ធ ខ.១៤ ន ហព ៩:២២
**១៧:១៣** ប លវ ៧:២៦ អគ ២៤:៧ ៣៣:២៥ កច ១៥:២០
**១៧:១៤** ផ លប ៩:៤
**១៧:១៥** ព លប ៧:២៤ ភ នក ២២:៣១ ម លវ ១៤:៨ យ លវ ១១:៤០
**១៧:១៦** រ លវ ៥:១
**១៨:២** ក លប ១៧:៧
**១៨:៣** ខ ខ.២៤–៣០ នក ២៣:២៤ ចទ ១៨:៩ ២ពវ ១៦:៣ ១៧:៨ ១របៈ ៥:២៥
**១៨:៤** គ លប ២៦:៥ ឃ ចទ ៤:១ ១ពវ ១១:១១ យរ ៤៤:១០,២៣ អគ ១១:១២ ង ខ.២

**១៧:៧** *ផិតទៅតាមនោះទៀតឡើយ* មើល នក ៣៤:១៥ និងការពន្យល់ ។

**១៧:១១** *ជីវិតនៃរូបសាច់ នោះនៅក្នុងឈាម* មើលការពន្យល់ នក ៩:៤ ។ ឈាមត្រូវបានគេរក្សាទុកជាយញ្ញបូជា ដ៏ពិសិដ្ឋ ហើយវាជាគំរូនៃការបូជាជីវិតនៃជនរងគ្រោះ ។ ពីព្រោះ ជីវិតត្រូវបានគេបូជា នោះឈាមជា(និមិត្តរូបនៃជីវិត) ហើយវាត្រូវតែទទួលបាននូវការគោរពដ៏ខ្ពង់ខ្ពស់ (នក ៩:៥–៦) ។ ការបរិភោគឈាម គឺត្រូវបានហាមជាដាច់ខាត (មើល ៧:២៦–២៧ ចទ ១២:១៦,២៣–២៥ ១៥:២៣ ១សយ ១៤:៣២–៣៤) ។ *ឈាម . . . ធួន* ការអនុវត្តគ្រប់យញ្ញបូជាដែលរួមបញ្ចូលការប្រោះ ឬការលាបឈាមនៅលើអាសនា ឬនៅក្នុងរោងឧបោសថ (ខ.៦ ១:៥ ៣:២ ៤:៦,២៥ ៧:២)ដូច្នេះការបង្រៀនពីការលោះបាប ជាប់ទាក់ទងទៅនឹងកាជំនួសជីវិតសម្រាប់ជីវិត ។ ឈាមនៅក្នុងសញ្ញាចាស់ គឺជាឈាមរបស់កូនចៀមនៃព្រះអម្ចាស់ ដែលឈាមនោះសម្រាប់រាស្ត្ររបស់ទ្រង់"ការសង្គ្រោះឱ្យរួចពីបាប អស់កល្បជានិច្ច" (ហព ៩:២២) ។

**១៧:១៥** *ស្លាប់ដោយខ្លួនឯង ឬមានសត្វណាហែក* នៅត្រង់នេះប្រសិនបើសាច់សត្វដែលពួកគេនឹងបរិភោគនោះ ពុំទាន់ស្រក់ឈាមអស់ទេ នោះគឺត្រូវហាមជាដាច់ខាតមិនត្រូវឱ្យបរិភោគឡើយ ។

**១៨:១–២០:២៧** នៅចំណុចនេះរាស្ត្ររបស់ព្រះត្រូវទទួលបានការអប់រំដោយផ្ទាល់ៗមកពីព្រះអម្ចាស់ និងចំណាំសីលធម៌ ពីភាពបរិសុទ្ធរបស់ព្រះអម្ចាស់ ។ ដូច្នេះ ការរៀបចំជីវិតរបស់ពួកអ៊ីស្រាអែលមានភាពខុសប្លែកពីពួកកាណាន ដែលការរស់នៅរបស់ពួកគេ គ្មានសីលធម៌ ។ នៅក្នុងជំពូកទី១៨នេះបានគូសបញ្ជាក់ពីការរៀបការ និងទំនាក់ទំនងនៃការរួមភេទ (មើល ខ.២១ និងការពន្យល់) ។ រីឯជំពូកទី១៩វិញ ដែលបានបង្ហាញពីសីលធម៌ ដែលមានចែងនៅក្នុងបទបញ្ញត្តិទាំង១០ប្រការ ។ ជំពូក២០បញ្ជាក់ពីការកាត់ទោសសម្រាប់ការរំលោភលើសីលធម៌របស់ព្រះអម្ចាស់ ។

**១៨:២** នៅជំពូកទី ១៨–២៦ ឃ្លាថា"អញនេះគឺជាយេហូវ៉ា" មាន៤៧ដង ។

**១៨:៣** នៅក្នុងជំពូកនេះ ពួកអ៊ីស្រាអែលត្រូវទទួលការព្រមាន៦ ដងដោយព្រះអម្ចាស់បានហាមពួកគេមិនឱ្យប្រព្រឹត្តដូចសាសន៍ដទៃ (នៅត្រង់នេះមានពីរដង និងមើល ខ.២៤,២៦–២៧,៣០) ។

រាល់គ្នាកាន់តាមអស់ទាំងច្បាប់ និងបញ្ញត្តិទាំងប៉ុន្មានរបស់
អញ[ច] បើអ្នកណាកាន់តាម នោះនឹងរស់នៅដោយសារ
សេចក្តីទាំងនោះឯង[ឆ] អញនេះគឺជាព្រះយេហូវ៉ា ។
៦កុំឱ្យអ្នកណាក្នុងពួកឯងរាល់គ្នាចូលទៅជិតបើកកេរ
ខ្មាសរបស់សាច់ញាតិដែលជិតដិតឡើយ អញនេះជាព្រះយេ
ហូវ៉ា ៧ឯកេរខ្មាសរបស់ឪពុកឯង[ជ] គឺជាកេរខ្មាសម្តាយឯង
នោះកុំឱ្យបើកឱ្យសោះ[ឈ] ដ្បិតគាត់ជាម្តាយឯង មិនត្រូវបើក
កេរខ្មាសគាត់ឡើយ ៨ឯកេរខ្មាសនៃប្រពន្ធរបស់ឪពុកឯង[ញ]
នោះមិនត្រូវបើកឡើយ ដ្បិតគឺជាកេរខ្មាសរបស់ឪពុកឯង
ហើយ[ដ] ៩ឯកេរខ្មាសរបស់បងប្អូនស្រីឯង[ឋ] ទោះបើជាកូន
ខាងឪពុក ឬខាងម្តាយឯង ដែលកើតនៅផ្ទះ ឬនៅឯណា
ទៀតក្តី នោះក៏មិនត្រូវបើកឡើយ[ឌ] ១០ឯកេរខ្មាសរបស់ចៅ
ស្រីខាងកូនប្រុស ឬខាងកូនស្រីឯងនោះមិនត្រូវបើកឡើយ
ដ្បិតគឺជាកេរខ្មាសរបស់ខ្លួនឯងហើយ ១១ឯកេរខ្មាសរបស់
កូនស្រីនៃប្រពន្ធឪពុកឯង ដែលឪពុកឯងបង្កើតមក នោះ
មិនត្រូវបើកឡើយ ដ្បិតនាងនោះជាបងប្អូនស្រីបង្កើត
នឹងឯងហើយ ១២កុំឱ្យបើកកេរខ្មាសរបស់ម្តាយធំឬម្តាយ
មីងខាងឪពុកឯងឡើយ[ឍ] ដ្បិតនាងនោះជាសាច់បង្កើតនឹង
ឪពុកឯង ១៣ក៏កុំឱ្យបើកកេរខ្មាសរបស់ម្តាយធំ[ណ] ឬម្តាយមីង
ខាងម្តាយឯងដែរ ដ្បិតនាងជាសាច់បង្កើតនឹងម្តាយឯង
ហើយ ១៤កុំឱ្យបើកកេរខ្មាសរបស់ឪពុកធំ ឬឪពុកមាខាងឪ
ពុកឯង គឺមិនត្រូវចូលទៅជិតប្រពន្ធគាត់ឡើយ ដ្បិតនាងជា
ម្តាយធំ ឬម្តាយមីងឯងហើយ[ត] ១៥កុំឱ្យបើកកេរខ្មាសរបស់
កូនប្រសាស្រីឯងដែរ[ថ] ដ្បិតនាងជាប្រពន្ធរបស់កូនឯង
ហើយ ដូច្នេះមិនត្រូវបើកកេរខ្មាសរបស់នាងឡើយ[ទ] ១៦កុំឱ្យ
បើកកេរខ្មាសប្រពន្ធរបស់បង ឬប្អូនប្រុសឯងឡើយ[ធ] នោះ
គឺជាកេរខ្មាសរបស់បង ឬប្អូនឯងហើយ ១៧កុំឱ្យបើកកេរ
ខ្មាសរបស់ស្ត្រីណា ហើយនិងកូនស្រីនាងផងនោះឡើយ[ន]
ក៏មិនត្រូវយកចៅស្រីខាងកូនប្រុស ឬខាងកូនស្រីនាង ដើម្បី
នឹងបើកកេរខ្មាសដែរ ដ្បិតនោះជាសាច់ជិតនឹងនាងពេក
គឺជាការអាក្រក់ជួជាតិហើយ ១៨ហើយកុំឱ្យយកប្រពន្ធថែម
ទាំងបង ឬប្អូនស្រីរបស់នាង[ប]ឱ្យបានប្រណាំងប្រជែងនឹង
ប្រពន្ធឯង ដើម្បីនឹងបើកកេរខ្មាសនាងផង កំពុងដែល
ប្រពន្ធនៅរស់នោះឡើយ ។
១៩កុំឱ្យចូលទៅជិតស្ត្រីណា ដើម្បីនឹងបើកកេរខ្មាសនាង
កំពុងដែលមានរដូវ[ផ]នោះឡើយ[ព] ២០ក៏កុំឱ្យសហាយស្មន់នឹង
ប្រពន្ធរបស់អ្នកជិតខាងឯង[ភ] ដែលនឹងនាំឱ្យខ្លួនស្មោក
គ្រោកជាមួយនឹងនាងនោះឡើយ ២១មិនត្រូវឱ្យកូនចៅរបស់
ឯង[ម] ណាមួយចូលកាត់ភ្លើងថ្វាយដល់ព្រះម៉ូឡុកឱ្យសោះ[យ]

**១៨:៥** ច លប ២៦:៥ ឆ ចទ ៤:១ នហ ៩:២៩ អស ៥៥:៣ អគ ១៨:៩ ២០:១១ អម ៥:៤–៦ មថ ១៩:១៧ រម ១០:៥ កទ ៣:១២ **១៨:៧** ជ ខ.៨ លវ ២០:១១ ចទ ២៧:២០ ឈ អគ ២២:១០ **១៨:៨** ញ ១កថ ៥:១ ដ លប ៣៥:២២ លវ ២០:១១ ចទ ២២:៣០ ២៧:២០ **១៨:៩** ឋ ខ.១១ លវ ២០:១៧ ចទ ២៧:២២ ឌ លប ២០:១៧ ចទ ២៧:២២ ២សយ ១៣:១៣អគ ២២:១១ **១៨:១២** ឍ ខ.១៣ លវ ២០:១៩ **១៨:១៣** ណ ខ.១២, ១៤ លវ ២០:២០ **១៨:១៤** ត ខ.១៣ ៣០:១ **១៨:១៥** ថ លប ១១:៣១ ៣៨:១៦ ទ អគ ២២:១១ **១៨:១៦** ធ លវ ២០:២១ មថ ១៤:៤ មក ៦:១៨ **១៨:១៧** ន លវ ២០:១៤ ចទ ២៧:២៣ **១៨:១៨** ប លប ៣០:១ **១៨:១៩** ផ លប ១៥:២៥–៣០ ព លប ១៥:២៤ **១៨:២០** ភ នក ២០:១៤ មថ ៥:២៧,២៨ ១កថ ៦:៩ ហព ១៣:៤ **១៨:២១** ម ចទ ១២:៣១ ១៨:១០ ២ពវ ១៦:៣ ១៧:១៧ ២១:៦ ២៣:១០ ២របា ២៨:១–៤ ៣៣:៦ ទដ ១០៦:៣៧,៣៨ អស ៥៧:៥ យរ ៧:៣០ ១៩:៥ ៣២:៣៥ អក ១៦:២០ មីក ៦:៧ យ លវ ២០:២–៥ ចទ ៩:៤ ១ពវ ១១:៥,៧,៣៣ អស ៥៧:៩ យរ ៣២:៣៥ ៤៩:១ សផ ១:៥

**១៨:៥** *រស់* នេះជាការរស់នៅ ដែលពេញដោយព្រះគុណ ។ បញ្ញត្តិទាំងប៉ុន្មាន ជាផ្លូវនៃការប្រោសលោះ(មើល ចទ ៦:២ ៨:២–៣ ៣០:២០ និងការពន្យល់ ៣២:៤៧ អគ ២១:១១,១៣,២១) និងមិនមែនផ្លូវនៃសេចក្តីសង្គ្រោះ (មើល រម ១០:៥ កទ ៣:១២) ។

**១៨:៦** នេះជាការសង្ខេបនៃការទាស់ប្រឆាំង នឹងសេចក្តីសហាយស្មន់ (ខ.៧–១៨) ។ ការកាត់ទោស សម្រាប់សហាយស្មន់ មាននៅក្នុងជំពូក២០ (ធៀប ១កថ ៥) ។

**១៨:៧** នេះជាការហាមប្រាមមិនឱ្យបើកកេរខ្មាស របស់ឪពុកក្រោយពីគាត់ស្លាប់ទៅនោះ ។

**១៨:៨** *កេរខ្មាសនៃប្រពន្ធរបស់គាត់ឪពុក* នៅត្រង់នេះប្រហែលជាម្តាយផ្សេងទៀតដែលត្រូវជាប្រពន្ធរបស់ឪពុក ដូច្នេះមានន័យថាគាត់មានប្រពន្ធលើសពីមួយឡើងទៅ ។

**១៨:១១** *កូនស្រី* ពាក្យនេះប្រាប់ពីបងប្អូនស្រីរបស់ខ្លួនដែលត្រូវជាកូនរបស់ម្តាយចុងរបស់ខ្លួន ហើយនៅត្រង់នេះផងដែរក៏ប្រាប់ពីសង្គមដែលនិយមប្រពន្ធលើសពី១ឡើងទៅ ។ នាងតាម៉ារ បានតវ៉ាពីការលើកលែងនៃការហាមប្រាម(២សយ ១៣:១២–១៣ ប៉ុន្តែសូមមើលការពន្យល់ទីនោះ) ។

**១៨:១៤** *មីងឯង* សូមមើល ២០:២០ ។ ប្រសិនបើ ឪពុកធំ ឬឪពុកមានៅរស់នោះការរួមដំណេកជាអំពើ សហាយស្មន់ ។ តែប្រសិនបើឪពុកធំ ឬឪពុកមានោះស្លាប់ នោះគេអាចរៀបការជាមួយនឹងនាងនោះបាន ដោយព្រោះនាងដែលជាម្តាយមីងនោះ មិនជាប់សាច់ឈាម ប៉ុន្តែទោះជាយ៉ាងណាក៏នៅតែហាមជាដាច់ខាត ។

**១៨:១៥** សូមធៀបជាមួយ លោកយូដា និងនាងតាម៉ារ (លប ៣៨:១៨) ។

**១៨:១៦** *ប្រពន្ធរបស់បង* នៅត្រង់ចំណុចនេះគឺសំដៅលើច្បាប់នៅពេលមានការលែងលះ ឬនៅពេលបងប្រុសស្លាប់ ។ ចំពោះ ការរៀបការជាមួយស្ត្រីមេម៉ាយដែលជាប្រពន្ធរបស់បងខ្លួន វាមិនមែនជារឿងអសីលធម៌នោះទេ ប៉ុន្តែជាការបំផ្លាញ មរតករបស់បងប្រុសខ្លួន ។ ច្បាប់នៃការរៀបការជាមួយបងស្រីមេម៉ាយ មាននៅក្នុង ចទ ២៥:៥–៦ ដែលចែងអំពីការលើកលែង ។

**១៨:១៧** *កូនស្រី* ពាក្យនេះមានន័យថា កូនចុង ។ ពាក្យថាកូនចុងនេះត្រូវបានទទួលស្គាល់បន្ទាប់ពីមរណភាពរបស់ម្តាយ ។

**១៨:១៨** (សូមធៀប) នេះជាការទទួលខុសត្រូវរបស់លោក យ៉ាកុបជាមួយនាងលេអា និងនាងរ៉ាជែល (លក ២៩:២៣–៣០) ។

**១៨:១៩** សូមមើល អគ ១៨:៦ ២២:១០ ។

**១៨:២០** មើលការពន្យល់ នក ២០:១៤ ។

**១៨:២១** *ម៉ូឡុក* នេះជាព្រះរបស់សាសន៍អាំម៉ូន (មើល ២០:២–៥ ១ពវ ១១:៥ និងការពន្យល់) ការអនុវត្តដ៏អាក្រក់នៃការថ្វាយកូនក្មេងជាយញ្ញបូជា

ក៏កុំឱ្យបង្អាប់ដល់ព្រះនាមព្រះនៃឯងឡើយ[រ] អញនេះជា
ព្រះយេហូវ៉ា[ល] ២២កុំឱ្យរួមដំណេកនឹងប្រុស ដូចជារួមនឹង
ស្រីឡើយ[វ] ដ្បិតនោះជាអំពើគួរខ្ពើមឆ្អើម[ស] ២៣ក៏កុំឱ្យរួម
សង្វាសនឹងសត្វណា ជាការដែលនាំឱ្យស្មោកគ្រោកជាមួយ
នោះឡើយ ហើយស្រីក៏មិនត្រូវឈរនៅមុខសត្វដើម្បីនឹង
រួមសង្វាសជាមួយនោះដែរ ដ្បិតជាការច្របូកច្របល់ដ៏
លាមក[ហ] ២៤កុំឱ្យឯងរាល់គ្នានាំឱ្យខ្លួនស្មោកគ្រោកដោយ
ប្រព្រឹត្តអំពើទាំងនេះណាមួយឡើយ ដ្បិតសាសន៍ដទៃទាំង
ប៉ុន្មាន ដែលអញបណ្តេញចេញពីមុខឯងរាល់គ្នា[ឡ] នោះ
បានស្មោកគ្រោកចំពោះអំពើ ទាំងនេះហើយ[អ] ២៥ហើយ
ស្រុកគេក៏ត្រូវស្មោកគ្រោកដែរ[ក] បានជាអញទំលាក់អំពើ
ទុច្ចរិតរបស់គេទៅលើគេវិញ[ខ] ឯស្រុកក៏ក្អួតគេចេញទៅ
ផង[គ] ២៦ដូច្នេះ ឯងរាល់គ្នាវិញ ត្រូវឱ្យកាន់តាមអស់ទាំង
ច្បាប់ និងបញ្ញត្តិទាំងប៉ុន្មានរបស់អញ[ឃ] ហើយកុំឱ្យប្រព្រឹត្ត
អំពើគួរខ្ពើមឆ្អើមណាមួយនោះឡើយ ទោះទាំងអ្នកស្រុក
ឬពួកប្រទេសក្រៅដែលនៅកណ្តាលឯងរាល់គ្នាផង ២៧ដ្បិត
ពួកអ្នកនៅស្រុកនោះដែលអាស្រ័យនៅមុនឯងរាល់គ្នា គេ
បានប្រព្រឹត្តអស់ទាំងអំពើគួរខ្ពើមឆ្អើមនោះ ហើយស្រុក
របស់គេ ក៏បានត្រូវស្មោកគ្រោកទៅ ២៨ដូច្នេះ បើកាលណា
ឯងរាល់គ្នានាំឱ្យស្រុកនោះទៅជាស្មោកគ្រោកដែរ[ង] នោះ
ក្រែងស្រុកនោះនឹងក្អួតឯងរាល់គ្នាចេញទៀត[ច] ដូចជាបាន
ក្អួតពួកសាសន៍ដទៃដែលនៅមុនឯងរាល់គ្នាចេញផង
២៩ដ្បិតអ្នកណាដែលប្រព្រឹត្តអំពើគួរខ្ពើមឆ្អើមណាមួយ
នោះ អ្នកនោះឯងនឹងត្រូវកាត់កាល់ពីសាសន៍របស់ខ្លួន
ចេញ ៣០ដូច្នេះ ត្រូវឱ្យឯងរាល់គ្នារក្សាបញ្ញើរបស់អញ[ឆ]
ដើម្បីកុំឱ្យប្រព្រឹត្តតាមទំលាប់គួរខ្ពើមទាំងនោះ ដែលគេ
បានប្រព្រឹត្តមុនឯងរាល់គ្នាឡើយ ហើយដើម្បីកុំឱ្យឯងរាល់
គ្នានាំឱ្យខ្លួនស្មោកគ្រោកដោយសារអំពើទាំងនោះផង អញ
នេះ គឺជាយេហូវ៉ាជាព្រះនៃឯងរាល់គ្នាហើយ[ជ] ។

**១៨:២១** រ លវ ១៩:១២
២១:៦ អស ៤៨:១១
អគ ២២:២៦
៣៦:២០ អម ២:៧
មឡ ១:១២
ល នក ៦:២
**១៨:២២** វ លវ
២០:១៣ ចទ២៣:១៨
រម ១:២៧ ១កថ៦:៩
ស លប ១៩:៥
**១៨:២៣** ហ
នក២២: ១៩ លវ
២០:១៥ ចទ
២៧:២១
**១៨:២៤** ឡ ខ.៣,
២៧,៣០ លវ
២០:២៣ អ ចទ
៩:៤ ១៨:១២
**១៨:២៥** ក ជន
៣៥:៣៤ ចទ
២១:២៣ ខ លវ
២០:២៣ ចទ ៩:៥
១២:៣១ ១៨:១២
គ ខ.២៨ លវ
២០:២២ យប
២០:១៥ យរ
៥១:៣៤
**១៨:២៦** ឃ លប
២៦:៥
**១៨:២៨** ង លវ
២០:២២ អរ ៩:១១
បទ ១:១៧ ច ខ.២៥
**១៨:៣០** ឆ លវ
៨:៣៥ ជ ខ.២
**១៩:២** ក ជន ១៤:៥
ទដ ៦៨:២៦
**១៩:៣** ខ នក ១៥:១១
១ពត ១:១៦

**ច្បាប់ផ្សេងៗ**

**១៩** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២ចូរ
ប្រាប់ដល់ពួកជំនុំកូនចៅអ៊ីស្រាអែល[ក]ទាំងអស់គ្នាថា ត្រូវ
ឱ្យឯងរាល់គ្នាបានបរិសុទ្ធ[ខ] ដ្បិតអញនេះដែលជាព្រះ
យេហូវ៉ា ជាព្រះ[គ]នៃឯងរាល់គ្នា អញបរិសុទ្ធ ៣ត្រូវឱ្យឯង
រាល់គ្នាកោតខ្លាចដល់ឪពុកម្តាយឯងរៀងខ្លួន[ឃ] ហើយរក្សា
ថ្ងៃឈប់សំរាករបស់អញដែរ[ង] អញនេះហើយជាយេហូវ៉ា
ជាព្រះនៃឯងរាល់គ្នា[ច] ៤កុំឱ្យឯងរាល់គ្នាបែរទៅតាមរូប
ព្រះឡើយ ក៏កុំឱ្យធ្វើព្រះសិតសំរាប់ឯងរាល់គ្នាផង[ឆ] អញ
នេះជាព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា[ជ] ។
៥កាលណាឯងរាល់គ្នាថ្វាយយញ្ញបូជា នៃដង្វាយមេត្រី
ដល់ព្រះយេហូវ៉ា នោះត្រូវថ្វាយដើម្បីឱ្យទ្រង់បានទទួលឯង
៦ត្រូវតែបរិភោគដង្វាយនោះនៅថ្ងៃដែលថ្វាយហើយនៅ
ថ្ងៃស្អែកក៏បាន តែបើមានអ្វីនៅសល់ដល់ថ្ងៃទី៣ នោះត្រូវ
ដុតនឹងភ្លើងវិញ[ឈ] ៧បើសិនជាបរិភោគដង្វាយនោះនៅថ្ងៃ
ទី៣ នោះជាសេចក្តីខ្ពើមឆ្អើមហើយ ទ្រង់មិនទទួលដង្វាយ
នោះទេ[ញ] ៨ហើយអស់អ្នកណាដែលបរិភោគនោះ និងត្រូវ
ទ្រាំទ្រនឹងសេចក្តីទុច្ចរិតរបស់ខ្លួន[ដ] ដ្បិតអ្នកនោះបានបង្អាប់
ដង្វាយបរិសុទ្ធ[ឋ]របស់ផងព្រះយេហូវ៉ា ហើយអ្នកនោះឯង
នឹងត្រូវកាត់កាល់ពីសាសន៍ខ្លួនចេញ[ឌ] ។
៩កាលណាឯងរាល់គ្នាច្រូតចំរូតនៅស្រែ នោះមិនត្រូវ
ច្រូតឱ្យដល់កៀន[ឍ]ដីរបស់ឯងទាំងអស់ទេ ក៏មិនត្រូវសន្សំ
រើសគួរស្រូវដែលបានជ្រុះនោះផង[ណ] ១០ហើយក៏មិនត្រូវ
សន្សំបេះផ្លែទំពាំងបាយជូរ[ត] ឬរើសផ្លែដែលជ្រុះ[ថ]នៅចំការ
របស់ឯងដែរ ត្រូវទុកសំរាប់ឱ្យពួកអ្នកក្រ និងពួកអ្នកស្នាក់

លវ ១១:៤៤ ២០:២៦ គ នក ២០:២ ឃ នក ២០:១២ ង នក ២០:៨ ច លវ ១១:៤៤ **១៩:៤** ឆ នក ២០:៤ ពច ១៧:៣ ទដ ៩៦:៥ ១១៥:៤–៧ ១៣៥:១៥ ជ លវ១១:៤៤ **១៩:៦** ឈ លវ ៧:១៦–១៧ **១៩:៧** ញ លវ ៧:១៨ **១៩:៨** ដ លវ ៥:១ ឋ លវ ២២:២,១៥,១៦ ជន ១៨:៣២ ឌ លវ ១៧:១៤ **១៩:៩** ឍ ជន ២:២,៣,៧,១៦,១៧ ណ លវ ២៣:១០,២២ ចទ ២៤:១៩–២២ យប ២៤:១០ **១៩:១០** ត ចទ ២៤:២០ ថ ខ.៩

នៅក្នុងទឹកដីស្រុកភីនីស និងទីកន្លែងផ្សេងៗទៀតជុំវិញ ស្រុកនេះទាំងមូល ។ ជាភស្តុតាង ស្តេចម៉ាន៉ាសេ បានថ្វាយបុត្ររបស់ខ្លួន ជាយញ្ញបូជាដល់ព្រះម៉ូឡុក(២រប ៣៣:៦ មើល ២ពវ ២៣:១០) ។ យរ ៣២:២៥ បានជំទាស់នឹងការនេះ ។ *កុំឱ្យបង្អាប់ដល់ព្រះនាមព្រះ* នៅវគ្គនេះទោះជាអ្វីក៏ដោយឱ្យតែការរំលោភលើការបើកសំដែងរបស់ព្រះការនោះ នឹងប្រមាថដល់ព្រះនាមព្រះហើយ (មើលការពន្យល់ ទដ ៥:១១ លវ ១៤:៤៤) ។

**១៨:២២** *រួមដំណេកនឹងប្រុស* សូមមើល ២០:១៣ ។ ការនេះនឹងត្រូវកាត់ទោសសម្រាប់ការរួមភេទដូចគ្នា នោះគឺការស្លាប់ ។

**១៨:២៩** *ខ្ពើមឆ្អើម* មើលការពន្យល់ ៧:២១ ។ *កាត់កាល់ពីសាសន៍របស់ខ្លួន* មើលការពន្យល់ ៧:២០ ។

**១៩:១** មើលការពន្យល់ ១៨:១–២០:២៧ ។

**១៩:២** *បរិសុទ្ធ* មើលការពន្យល់ ១១:៤៤ ។

**១៩:៣–៤** មើល ខ.៣០ មើល នក ២០:៤–៦,៨–១២ និងការពន្យល់ ។

**១៩:៥** *ដង្វាយមេត្រី* មើលការពន្យល់ ៣:១ ។

**១៩:៦** *ថ្ងៃទី៣* មើលការពន្យល់ ៧:១៥–១៨ ។

**១៩:៨** *បរិសុទ្ធរបស់ផងព្រះយេហូវ៉ា* មើលការពន្យល់ នក ៣:៥ ។ *កាត់កាល់ពីសាសន៍ខ្លួនចេញ* មើលការពន្យល់ ៧:១០ ។

**១៩:៩–១០** មើលការពន្យល់ ២៣:២២ និង ចទ ២៤:១៩–២១ ។

វិញ[ទ] អញនេះ គឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ។
១១មិនត្រូវឱ្យឯងរាល់គ្នាលួច[ធ] ឬប្រព្រឹត្តឆបោក ឬកុហក[ន]
គ្នាទៅវិញទៅមកឡើយ[ប] ១២ហើយមិនត្រូវស្បថបំពាន[ផ]
ដោយនូវឈ្មោះអញ[ព] ទាំងបង្អាប់[ភ]ដល់ព្រះនាមព្រះនៃឯង
ឡើយ អញនេះជាព្រះយេហូវ៉ា ១៣មិនត្រូវឱ្យឯងសង្កត់
សង្កិនអ្នកជិតខាង[ម] ឬរឹបជាន់[យ]គេឡើយ[រ] ក៏មិនត្រូវទុកឈ្នួល
របស់ជើងឈ្នួលឯងឱ្យ[ល]នៅដល់ព្រឹកដែរ[វ] ១៤មិនត្រូវដេរ
ប្រមាថចំពោះមនុស្សថ្លង់ ឬធ្វើអ្វីឱ្យមនុស្សខ្វាក់[ស]ដួលនោះ
ឡើយ គឺត្រូវឱ្យកោតខ្លាចដល់ព្រះនៃឯងវិញ[ហ] អញនេះជា
ព្រះយេហូវ៉ា ។
១៥មិនត្រូវឱ្យឯងរាល់គ្នាប្រព្រឹត្តទុច្ចរិត[ឡ] ក្នុងរឿងក្ដី
ឡើយ ក៏មិនត្រូវយល់មុខ[អ]ខាងឯងអ្នកតូច ឬខ្លាចអ្នកធំដែរ[ក]
គឺត្រូវឱ្យជំនុំជំរះអ្នកជិតខាងឯងដោយសុចរិតវិញ[ខ] ១៦មិន
ត្រូវដើរចុះឡើងនិយាយដើមពីគេ[គ]ក្នុងពួកសាសន៍ឯងឡើយ
មិនត្រូវឈរទាស់នឹងឈាមអ្នកជិតខាងឯងដែរ[ឃ] អញនេះ
ជាព្រះយេហូវ៉ា ១៧មិនត្រូវមានចិត្តស្អប់ដល់បងប្អូនឯង
ឡើយ[ង] ក៏កុំឱ្យខាននឹងបន្ទោសដល់អ្នកជិតខាងឯងដែរ[ច]
ដើម្បីកុំឱ្យជាប់មានបាបដោយព្រោះគេ ១៨មិនត្រូវសងសឹក[ឆ]
ឬចងគំនុំគុំគួន[ជ] នឹងពួកកូនចៅរបស់សាសន៍ឯងឡើយ[ឈ]
គឺត្រូវឱ្យស្រឡាញ់[ញ] អ្នកជិតខាងដូចខ្លួនឯងវិញ[ដ] អញនេះ
ជាព្រះយេហូវ៉ា ។
១៩ត្រូវឱ្យឯងរាល់គ្នាកាន់តាមអស់ទាំងច្បាប់របស់អញ[ឋ]
មិនត្រូវឱ្យសត្វឯងជាន់សត្វញីណាខុសពូជគ្នាឡើយ ក៏មិន
ត្រូវព្រោះពូជ២យ៉ាងនៅស្រែចំការឯងដែរ[ឌ] ហើយមិន
ត្រូវស្លៀកពាក់អ្វី ដែលលាយដោយអំបោះ២យ៉ាងឡើយ[ឍ]
២០បើអ្នកណាសេពសម្ពព្ធនឹងស្រីជាបាវបំរើដែលមានគេ
ដណ្ដឹងហើយ[ណ] តែមិនទាន់បានលោះចេញ ឬដែលចៅ
ហ្វាយមិនទាន់លែងឱ្យទៅ នោះគេត្រូវមានទោស តែមិន
ត្រូវដាក់ទោសដល់ស្លាប់ទេ ពីព្រោះមិនសំរេចនឹងចិត្តនាង
ទេ ២១ហើយប្រុសនោះត្រូវយកដង្វាយដោយព្រោះការ
រំលងមកថ្វាយព្រះយេហូវ៉ា ត្រង់មាត់ទ្វារត្រសាលជំនុំ គឺជា
ចៀមឈ្មោល១ សំរាប់ជាដង្វាយដោយព្រោះការរំលង[ត]
២២នោះត្រូវឱ្យសង្ឃថ្វាយចៀមឈ្មោលនៃដង្វាយដោយ
ព្រោះការរំលងនោះនៅចំពោះព្រះយេហូវ៉ា ដើម្បីឱ្យបាន
ធួននឹងបាបរបស់អ្នកនោះ រួចទ្រង់នឹងអត់ទោសចំពោះ
បាបដែលអ្នកនោះបានប្រព្រឹត្ត[ថ] ។
២៣កាលណាឯងរាល់គ្នាបានចូលទៅនៅក្នុងស្រុកហើយ
បានដាំដើមឈើគ្រប់មុខឱ្យមានផ្លែបរិភោគ នោះត្រូវឱ្យ
រាប់ផ្លែឈើនោះ ទុកដូចជាមនុស្ស ដែលមិនកាត់ស្បែក គឺ
ត្រូវរាប់ទុកដូចជាមិនបានកាត់ស្បែកអស់រវាង៣ឆ្នាំ មិន
ត្រូវបរិភោគផ្លែនោះឡើយ ២៤តែដល់ឆ្នាំទី៤ផ្លែឈើទាំង
នោះនឹងបានបរិសុទ្ធវិញ[ទ] សំរាប់នឹងថ្វាយដល់ព្រះយេហូវ៉ា
ដោយអរសប្បាយ ២៥លុះដល់ឆ្នាំទី៥ នោះនឹងបរិភោគបាន
នេះដើម្បីឱ្យដើមឈើទាំងនោះ បានចំរើនផលផ្លែឱ្យឯង
រាល់គ្នា អញនេះ គឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ។
២៦មិនត្រូវឱ្យឯងរាល់គ្នាបរិភោគសាច់ណាដែលជាប់
មានទាំងឈាមផងនោះឡើយ[ធ] មិនត្រូវប្រើរបៀនរបស់គ្រូ
អង្គុយធម៌[ន] ឬមើលនក្ខត្តឫក្សផង[ប] ២៧មិនត្រូវកោរក្រឡឹង
សក់ក្បាលជុំវិញ ឬកាត់ដំរឹមពុកចង្ការរបស់ឯងឡើយ[ផ]

**១៩:១០** ទ ចទ ២៤:១៩,២១ **១៩:១១** ធ នក ២០:១៥ ២៣:៤ លក ៣:១៤ ន នក ២០:១៦ អផ ៤:២៥ ប លវ ៦:២ **១៩:១២** ផ យរ ៥:២ ៧:៩ មទ្ទ ៣:៥ ព នក ៣:១៣ ២០:៧ ចទ ១៨:១៩ សភ ១៨:១០ អស ៤២:៨ យរ ៤៤:១៦,២៦ មថ ៥:៣៣ ភ យរ ៣៤:១៦ **១៩:១៣** ម លវ ២៥:១៤,១៧ យ នក ២០:១៥ រ នក ២២:១៥,២៥–២៧ ល យប ៧:២ ២៤:១២ ៣១:៣៩ អស ១៦:១៤ មឡ ៣:៥ វ ចទ ២៤:១៥ យរ ២២:១៣ មថ ២០:៨ ១ធថ ៥:១៨ យក ៥:៤ **១៩:១៤** ស នក ៤:១១ លវ ២១:១៨ ចទ ២៧:១៨ ហ ខ.៣២ លវ ២៥:១៧,៣៦ **១៩:១៥** ឡ នក ២៣:២ នក ២៣:២, ៦ អ ចទ ២៤:១៧ យប ១៣:៨,១០ ៣២:២១ សភ ២៨:២១ ក យប ៣៤:១៩ ខ នក ២៣:៨ សភ ២៤:២៣ មទ្ទ ២:៩ យក ២:១–៤ **១៩:១៦** គ ទដ ១៥:៣ ៣១:១៣ ៤១:៦ ១០១:៥ យរ ៦:២៨ ៩:៤ អគ ២២:៩ ឃ នក ២៣:៧ ចទ ១០:១៧ ២៧:២៥ ទដ ១៥:៥ អគ ២២:១២ **១៩:១៧** ង ១យហ ២:៩ ច មថ ១៨:១៥ **១៩:១៨** ឆ លប ៤:២៣ រម ១២:១៩ ហព ១០:៣០ ជ ទដ ១០៣:៩ ឈ នក ១២:៤៨ ញ នក ២០:១៦ ដ ខ.៣៤ មថ ៥:៤៣ ១៩:១៦ ២២:៣៩ មក ១២:៣១ លក ១០:២៧ យហ ១៣:៣៤ រម ១៣:៩ កទ ៥:១៤ យក ២:៨ **១៩:១៩** ឋ លប ២៦:៥ ឌ ចទ ២២:៩ ឍ ចទ ២២:១១ **១៩:២០** ណ ចទ ២២:២៣–២៧ **១៩:២១** ត លវ ៥:១៥ **១៩:២២** ថ លវ ៥:១៥ **១៩:២៤** ទ នក ២២:២៩ **១៩:២៦** ធ លប ៩:៤ ន លប ៣០:២៧ អស ៤៤:២៥ ប នក ២២:១៨ ២ពវ ១៧:១៧ **១៩:២៧** ផ លវ ២១:៥ ចទ ១៤:១ ២សយ ១០:៤–៥ យរ ៤១:៥ ៤៨:៣៧ អគ ៥:៥–៥

**១៩:១១–១២** សូមមើល នក ២០:៧,១៥–១៦ និងការពន្យល់ ។

**១៩:១៣** *ឈ្នួលរបស់ជើងឈ្នួលឯង* សូមមើល ចទ ២៤:១៤–១៥ មថ ២០:៨ ។

**១៩:១៧** *ស្អប់ដល់បងប្អូនឯង* សូមមើល ១យហ ២:៩,១១ ៣:១៥ ៤:២០ ។

**១៩:១៨** *ត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង* នេះជាព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ(មថ ២២:៣៩ មក ១២:៣១ លក ១០:២៧) លោកប៉ុល (រម ១៣:៩ កទ ៥:១៤)និងលោកយ៉ាកុប(២:៨) ។ ពួកផារិស៊ីដែលតឹងរ៉ឹងបានបន្ថែម នូវច្បាប់របស់ខ្លួនថា"ស្អប់ខ្មាំងសត្រូវឯង"(មថ ៥:៤៣) ។ ការតបមកវិញរបស់ព្រះគ្រីស្ទ ដែលស៊ីគ្នាជាមួយនឹងការបង្រៀន ក្នុងព្រះគម្ពីរសញ្ញាចាស់ថា "ចូរស្រឡាញ់ខ្មាំងសត្រូវឯង"(មើល ខ.១៧,៣៤) ហើយការនេះក៏ស៊ីគ្នាជាមួយនឹងពួកផារិស៊ីអព្យាក្រឹត្យផងដែរ ។

**១៩:១៩** *មិនត្រូវឱ្យសត្វឯង . . . ព្រោះពូជ . . . ស្លៀកពាក់* ឃ្លានេះបញ្ជាក់ពីការរំលោភលើការដែលព្រះអម្ចាស់បង្កើតផែនដីជាលំដាប់នោះ ។

**១៩:២១–២២** *ដង្វាយដោយព្រោះការរំលង* មើលការពន្យល់ ៥:១៤–៦:៧ និងការពន្យល់ ៥:១៥ ។

**១៩:២៦** *សាច់ណាដែលជាប់មានទាំងឈាម* មើលការពន្យល់ ១៧:១ ។ *នក្ខត្តឫក្ស* មើល ខ.៣១ នក ២២:១៨ ចទ ១៨:១៤ ១សយ ២៨:២៩ ១សយ ៤៧:១២–១៤ ។

**១៩:២៧** *មិនត្រូវកោរក្រឡឹងសក់ក្បាល* នេះជាការហាមប្រាមមួយដែលពួកយូដាបានកាន់តាម ។

28 ក៏មិនត្រូវឆូត[ព] ស្បែកដោយកាន់ទុក្ខមនុស្សស្លាប់ ឬសាក់ខ្លួនផងដែរ អញនេះជាព្រះយេហូវ៉ា ។

29 កុំឱ្យបង្ខូចកូនស្រីឯងដោយធ្វើឱ្យទៅជាស្រីសំផឹងឡើយ[ភ] ក្រែងស្រុកឯងទៅជាសហាយស្មន់គ្រប់គ្នា ហើយបានពេញជាសេចក្ដីអាក្រក់ជួជាតិ[ម] 30 ត្រូវឱ្យរក្សាថ្ងៃឈប់សំរាករបស់អញ[យ] ហើយត្រូវកោតខ្លាចដល់ទីបរិសុទ្ធរបស់អញផង អញនេះជាព្រះយេហូវ៉ា[រ] ។

31 កុំឱ្យឯងរាល់គ្នាបែរទៅតាមពួកគ្រូខាប[ល] ឬគ្រូមន្តគាថាឡើយ[វ] កុំឱ្យពឹងរកគេឱ្យសោះ ក្រែងឯងទៅជាស្មោកគ្រោកដោយសារគេដែរ អញនេះ គឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ។

32 ត្រូវឱ្យឯងក្រោកឡើងឈរនៅមុខ[ស]មនុស្សចាស់សក់ស[ហ] ត្រូវគោរពដល់មនុស្សមានវ័យចំរើន ហើយត្រូវកោតខ្លាចដល់ព្រះនៃឯងដែរ[ឡ] អញនេះជាព្រះយេហូវ៉ា[អ] 33 បើមានមនុស្សប្រទេសក្រៅណាមកស្នាក់នៅក្នុងស្រុកជាមួយនឹងឯង នោះកុំឱ្យធ្វើបាបគេឡើយ 34 ឯអ្នកប្រទេសក្រៅដែលមកស្នាក់នៅក្នុងពួកឯងរាល់គ្នា នោះត្រូវទុកដូចជាកើតនៅស្រុកឯងវិញ[ក] ហើយត្រូវស្រឡាញ់គេដូចជាខ្លួនឯងដែរ[ខ] ដ្បិតឯងរាល់គ្នាពីដើមក៏ជាអ្នកស្នាក់នៅ[គ]ក្នុងស្រុកអេស៊ីព្ទដែរ[ឃ] អញនេះគឺព្រះយេហូវ៉ាជាព្រះនៃឯងរាល់គ្នា ។

35 មិនត្រូវឱ្យឯងរាល់គ្នាប្រព្រឹត្តទុច្ចរិតក្នុងរឿងក្ដី ឬក្នុងការវាស់ ឬថ្លឹង ឬវាល់ឡើយ[ង] 36 ត្រូវឱ្យមានជញ្ជីង[ច] និងកូនជញ្ជីងយ៉ាងត្រឹមត្រូវ ហើយនិងរង្វាល់ត្រឹមត្រូវផងអញនេះ[ឆ,ជ] គឺព្រះយេហូវ៉ាជាព្រះនៃឯងរាល់គ្នា ដែលបាននាំឯងចេញពីស្រុកអេស៊ីព្ទមក[ឈ] 37 ត្រូវឱ្យឯងរាល់គ្នាកាន់អស់ទាំងច្បាប់[ញ] និងបញ្ញត្តិទាំងប៉ុន្មានរបស់អញ[ដ] ព្រមទាំងប្រព្រឹត្តតាមផង អញនេះជាព្រះយេហូវ៉ា ។

**១៩:២៨** ព លវ ២១:៥ ចទ ១៤:១ ១ពវ ១៨:២៨ យរ ១៦:៦ ៤១:៥ ៤៧:៥ **១៩:២៩** ភ លវ ២១:៩ ចទ ២៣:១៨ ម លប ៣៤:៧ លវ ២១:៩ **១៩:៣០** យ នក ២០:៨ រ លវ ២៦:២ **១៩:៣១** ល នក ២២:១៨ ១សយ ២៨:៧–២០ ១រប ១០:១៣ វ លវ ២០:៦ ២ពវ ២១:៦ ២៣:២៤ អស ៨:១៩ ១៩:៣ ២៩:៤ ៤៧:១២ ៦៥:៤ **១៩:៣២** ស ១ពវ ១២:៨ ហ យប ៣២:៤ សភ ២៣:២២ បទ ៥:១២ ១ធថ ៥:១ ឡ ខ.១៤ យប ២៩:៨ អ លវ ២៥:១៧ **១៩:៣៤** ក នក ១២:៤៨ ខ ខ.១៨ គ នក ២២:២១ ឃ នក ២៣:៩ ចទ ១០:១៩ ២៣:៧ ទដ ១៤៦:៩ **១៩:៣៥** ង ចទ ២៥:១៣–១៦ **១៩:៣៦** ច យប ៣១:៦ សភ ១១:១ ហស ១២:៧ មីក ៦:១១ ឆ ពច ៦:១៩ នរ ២:១៧ ១សយ ១:២៤ ១៧:១៧ អគ ៤៥:១០ ជ ចទ ២៥:១៣–១៥ សភ ២០:១០ អគ ៤៥:១១ ឈ នក ១២:១៧ **១៩:៣៧** ញ ២ពវ ១៧:៣៧ ២រប ៧:១៧ ទដ ១១៩:៥ អគ ១៨:៩ ដ លប ២៦:៥

## ការដាក់ទោសបាប

**២០** 1 ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា 2 ត្រូវឱ្យឯងប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល ពីសេចក្ដីនេះទៀតដែរថា បើអ្នកណាក្នុងពួកកូនចៅអ៊ីស្រាអែល ឬក្នុងពួកអ្នកប្រទេសក្រៅ ជាអ្នកអាស្រ័យនៅជាមួយគ្នា ដែលថ្វាយកូនខ្លួនទៅព្រះម៉ូឡុក នោះត្រូវឱ្យពួកបណ្ដាជននៅក្នុងស្រុកសំឡាប់អ្នកនោះចេញ[ក] ដោយចោលនឹងថ្មជាកុំខាន[ខ] 3 អញនឹងតាំងមុខទាស់នឹងអ្នកនោះ ហើយនិងកាត់ចេញពីសាសន៍ខ្លួនទៅ[គ] ពីព្រោះបានឱ្យកូនខ្លួនទៅព្រះម៉ូឡុកទាំងនាំឱ្យ[ឃ]ទីបរិសុទ្ធអញ[ង]ទៅជាស្មោកគ្រោក ហើយបង្អាប់ដល់ឈ្មោះបរិសុទ្ធរបស់អញផង[ច] 4 បើសិនជាបណ្ដាជននៅស្រុកនោះគេធ្មេចភ្នែក ក្នុងកាលដែលអ្នកនោះឱ្យកូនខ្លួនទៅព្រះម៉ូឡុកដូច្នេះ ហើយមិនសំឡាប់អ្នកនោះចោល[ឆ] 5 នោះអញនឹងតាំងមុខទាស់នឹងអ្នកនោះ ព្រមទាំងគ្រួសារគេដែរ ហើយនិងកាត់ចេញពីសាសន៍ខ្លួនទៅ ព្រមទាំងអស់អ្នកដែលផិតទៅតាម ដើម្បីសហាយស្មន់នឹងព្រះម៉ូឡុកនោះផង ។

6 ឯអ្នកណាដែលបែរទៅតាមពួកគ្រូខាប ឬពួកគ្រូមន្តគាថា និងផិតទៅតាមគេ នោះអញនិងតាំងមុខទាស់ចំពោះអ្នកនោះ ហើយនិងកាត់ចេញពីសាសន៍ខ្លួនទៅ[ជ] 7 ដូច្នេះ ចូរឱ្យឯងរាល់គ្នាញែកខ្លួនចេញ[ឈ] ហើយឱ្យបានបរិសុទ្ធចុះ[ញ] ដ្បិតអញនេះគឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា[ដ] 8 ត្រូវឱ្យកាន់អស់ទាំងច្បាប់របស់អញ[ឋ] ព្រមទាំងប្រព្រឹត្តតាមផង អញនេះជា

**២០:២** ក ខ.១០ លប ២៦:១១ នក ១៩:១២ ខ ខ.២៧ លវ ២៤:១៤ ជន ១៥:៣៥,៣៦ ចទ ២១:២១ យស ៧:២៥ **២០:៣** គ ខ.៥,៦ លវ ២៣:៣០ ឃ ទដ ៧៤:៧ ៧៩:១ យរ ៧:៣០ អគ ៥:១១ ង លវ ១៥:៣១ ច លវ ១៨:២១ **២០:៤** ឆ ចទ ១៧:២–៥ **២០:៦** ជ ខ.៣ លវ ១៩:៣១ **២០:៧** ឈ លវ ១១:៤៤ ញ នក ២៩:១ ៣១:១៣ លវ ១១:៤៥ អភ ១:៤ ១ពត ១:១៦ ដ នក ៦:២ **២០:៨** ឋ លប ២៦:៥

**១៩:២៨** នៅក្នុងខនេះបង្ហាញថា កុំឱ្យបង្ខូចរាង្គកាយ ក្រោយពីធ្វើពិធីរបស់ពួកសាសន៍ (មើលការពន្យល់ ២១:៥) ។

**១៩:៣៤** *អ្នកស្នាក់នៅក្នុងស្រុកអេស៊ីព្ទ* (មើលការពន្យល់ ចទ ៥:១៥) ។

**១៩:៣៥** *ប្រព្រឹត្តទុច្ចរិត* នៅក្នុងវប្បធម៌ ដែលរដ្ឋអំណាចគ្មានការគ្រប់គ្រងលើការវាស់ ឬថ្លឹង នោះការបន្លំ ឬបោកប្រាស់នៅក្នុងជំនួញ ដោយក្លែងខ្នាតរង្វាស់ បានកើតឡើងជាធម្មតា(ចទ ២៥:១៣–១៦ សភ ១១:១ និងការពន្យល់ ១៦:១១ និងការពន្យល់ និងមើល ២០:១០,២៣)។ ពួកហោរាបានផ្ដោលទោសចំពោះទង្វើដូចនោះផងដែរ(អម ៨:៥ មីក ៦:១០,២៣) ។

**២០:១–២៧** នៅក្នុងជំពូកនេះ អំពើបាបជាច្រើនបានកត់ចុះទុកនៅក្នុងជំពូក១៨ម្ដងរួចមកហើយ ប៉ុន្តែពេលនេះគឺនិយាយអំពីការកាត់ទោសដ៏ជាក់លាក់១ ។ ព្រះរបស់ពួកអ៊ីស្រាអែល គឺជាព្រះប្រច័ណ្ឌហើយអត់ទ្រាំនិងគ្មានគូប្រជែង(ការពន្យល់ នក ២០:៥) ។ ព្រះទ្រង់តម្រូវឱ្យស្មោះត្រង់ចំពោះទ្រង់ជាដាច់ខាត(ការពន្យល់ ២០:៣)។ មើលការពន្យល់ ១៨:១–២០:២៧។

**២០:២–៥** *ម៉ូឡុក* មើលការពន្យល់ ១៨:២១ ។

**២០:៣** *កាត់ចេញពីសាសន៍ខ្លួនទៅ* មើលការពន្យល់ ៧:២០ ។

**២០:៥** *អស់អ្នកដែលផិត* មើលការពន្យល់ នក ៣៤:១៥ និងការពន្យល់ ។

**២០:៦** *ពួកគ្រូខាប ឬពួកគ្រូមន្តគាថា* ការប្រកបមុខរបរជាគ្រូខាបនិងគ្រូមន្តគាថា គឺជាអំពើបាបដ៏ធ្ងន់ (ខ.២៧)។ សូមមើល ចទ ១៨:១០–១១ ១សយ ៣:២–៣ ។ មានតែព្រះមួយគត់ដែលធ្វើជាគ្រូទាំងពីរនេះដោយឆ្លងតាមរយៈពួកសង្ឃ និងពួកហោរា(សូមមើល អស ៨:១៩–២០ និងការពន្យល់) ។

**២០:៧** *ឱ្យបានបរិសុទ្ធ* មើលការពន្យល់ ១១:៤៤ ។

ព្រះយេហូវ៉ាដែលញែកឯងរាល់គ្នាចេញជាបរិសុទ្ធ[ឌ] ៩ឯ
អស់អ្នកណាដែលបង្អាប់ដល់ឪពុក[ឍ]ម្តាយខ្លួន[ណ] នោះត្រូវ
សំឡាប់ចោលជាមិនខាន[ត] ដ្បិតបានបង្អាប់ដល់ឪពុកម្តាយ
ខ្លួនហើយ ដូច្នេះឈាមគេត្រូវធ្លាក់មកលើគេវិញ[ថ] ។
១០ឯអ្នកណាដែលសហាយស្មន់នឹងប្រពន្ធគេ[ទ] គឺនឹងប្រពន្ធ
របស់អ្នកជិតខាងខ្លួន នោះត្រូវសំឡាប់ចេញទាំងប្រុសទាំង
ស្រីជាមិនខាន[ធ] ១១បើមនុស្សណារួមដំណេកនឹងប្រពន្ធរបស់
ឪពុក នោះឈ្មោះថាបានបើកកេរខ្មាសរបស់ឪពុកហើយ[ន]
ត្រូវសំឡាប់អ្នកទាំង២នោះជាកុំខាន ឈាមគេត្រូវធ្លាក់មក
លើគេវិញ[ប] ១២បើមនុស្សណារួមដំណេកនឹងកូនប្រសាស្រី
របស់ខ្លួន[ផ] នោះត្រូវឱ្យសំឡាប់ចោលទាំង២នាក់ជាកុំខាន
ដ្បិតជាការប្រព្រឹត្តច្របូកច្របល់ដ៏លាមកឈាមគេត្រូវធ្លាក់
មកលើគេវិញ ១៣បើមានប្រុសណារួមដំណេកនឹងប្រុសដូច
ជារួមនឹងស្រី នោះអ្នកទាំង២បានប្រព្រឹត្តអំពើគួរខ្ពើម
ហើយ[ព] ត្រូវសំឡាប់ចេញជាមិនខានឈាមគេត្រូវធ្លាក់មក
លើគេវិញ ១៤បើមនុស្សណាយកទាំងកូនស្រីនិងម្តាយផងធ្វើ
ជាប្រពន្ធ[ភ] នោះជាការអាក្រក់ជួជាតិណាស់ ត្រូវដុតទាំង
អស់គ្នា និងភ្លើង[ម] ដើម្បីកុំឱ្យមានអំពើអាក្រក់ជួជាតិយ៉ាង
នោះនៅកណ្តាលឯងរាល់គ្នាឡើយ[យ] ១៥បើមនុស្សណារួម
សង្វាសនឹងសត្វ[រ] នោះត្រូវឱ្យសំឡាប់ចោលជាកុំខាន[ល]
ហើយទាំងសត្វនោះក៏ត្រូវសំឡាប់ដែរ ១៦បើស្ត្រីណាចូល
ទៅជិតសត្វណា ហើយរួមសង្វាសជាមួយ នោះត្រូវសំឡាប់
ស្ត្រី ព្រមទាំងសត្វនោះផង ត្រូវសំឡាប់ទាំង២កុំខាន ឈាម
គេត្រូវធ្លាក់មកលើគេវិញ ។
១៧បើមនុស្សណាយកបង ឬប្អូនស្រីខ្លួន[វ] ទោះបីជាកូន
ខាងឪពុក ឬខាងម្តាយខ្លួនក្តី ហើយក៏ឃើញកេរខ្មាសនាង
នាងក៏ឃើញកេរខ្មាសរបស់ប្រុសនោះ យ៉ាងនោះជា
ការគួរខ្មាសហើយ អ្នកទាំង២នឹងត្រូវកាត់កាល់ចេញនៅ
ចំពោះមុខ[ស]ពួកកូនចៅសាសន៍របស់ខ្លួន ដោយព្រោះបាន
បើកកេរខ្មាសបងប្អូនស្រីខ្លួន អ្នកនោះត្រូវទ្រាំទ្រនឹង
សេចក្តីទុច្ចរិតរបស់ខ្លួន[ហ] ១៨បើមនុស្សណារួមដំណេកជា
មួយនឹងស្ត្រីដែលមានរដូវ[ឡ] ហើយបើកកេរខ្មាសនាងនោះ
នោះឈ្មោះថា បានសំរាតក្បាលឈាមនាង ហើយនាងក៏
បានបើកក្បាលឈាមខ្លួនដែរ អ្នកទាំង២នោះត្រូវកាត់កាល់
ពីសាសន៍របស់ខ្លួនចេញ[អ] ១៩មិនត្រូវឱ្យបើកកេរខ្មាសម្តាយធំ
ឬម្តាយមីងខាងម្តាយ ឬខាងឪពុកឯងឡើយ[ក] ដ្បិតយ៉ាងនោះ
ឈ្មោះថាបានបកកេរញាតិសន្តានជិតដិតនឹងខ្លួនហើយ អ្នក
ទាំង២នោះនឹងត្រូវទ្រាំទ្រនឹងសេចក្តីទុច្ចរិតរបស់ខ្លួន ២០ឬ
បើមនុស្សណារួមដំណេកជាមួយនឹងប្រពន្ធរបស់ឪពុកធំឬ
ឪពុកមា[ខ] នោះឈ្មោះថាបានបើកកេរខ្មាសរបស់ឪពុកធំ
ឬមាខ្លួនហើយ អ្នកទាំង២នោះនឹងត្រូវទ្រាំទ្រនឹងអំពើបាប
របស់ខ្លួនគេនឹងស្លាប់ទៅឥតមានកូន[គ] ២១បើមនុស្សណាយក
ប្រពន្ធរបស់បងឬរបស់ប្អូនខ្លួន[ឃ] នោះគឺជាការស្មោកគ្រោក
ហើយ អ្នកនោះបានបើកកេរខ្មាសបងឬប្អូនខ្លួន គេនឹងនៅ
ឥតមានកូនឡើយ[ង] ។
២២ដូច្នេះត្រូវឱ្យឯងរាល់គ្នាកាន់អស់ទាំងច្បាប់ និងបញ្ញត្តិ
ទាំងប៉ុន្មានរបស់អញ[ច] ព្រមទាំងប្រព្រឹត្តតាមផង ក្រែង
ស្រុក[ឆ]ដែលអញនាំឯងរាល់គ្នាចូលទៅនៅនោះ បានក្អួត
ឯងចេញដែរ ២៣មិនត្រូវឱ្យដើរតាមអស់ទាំងទំនៀមរបស់
សាសន៍ទាំងប៉ុន្មាន[ជ] ដែលអញបណ្តេញពីមុខឯងរាល់គ្នា
ចេញឡើយ[ឈ] ដ្បិតគេបានប្រព្រឹត្តអំពើទាំងនោះហើយ បាន
ជាអញខ្ពើមឆ្អើមដល់គេ[ញ] ២៤តែអញបានប្រាប់ឯងរាល់គ្នា
ហើយថា ឯងរាល់គ្នានិងទទួលស្រុករបស់គេទុកជាមរដក
អញនឹងឱ្យស្រុកនោះទៅជាកេរ្តិ៍អាករដល់ឯងរាល់គ្នា ជា
ស្រុកដែលមានទឹកដោះ ហើយនិងទឹកឃ្មុំហូរហៀរ[ដ]អញ
នេះ គឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ដែលបានញែកឯង
ចេញពីអស់ទាំងសាសន៍ដទៃហើយ[ឋ] ២៥ដូច្នេះ ត្រូវឱ្យឯង
រាល់គ្នាចេះសំគាល់សត្វជើង៤ដែលស្អាត និងសត្វដែលមិន
ស្អាត[ឌ] ហើយសត្វស្លាបដែលមិនស្អាតនឹងសត្វស្លាបដែល
ស្អាតចុះ មិនត្រូវឱ្យនាំខ្លួនទៅជាស្មោកគ្រោក ដោយសត្វ
ជើង៤ ឬសត្វស្លាប ឬសត្វលូនវារនៅដី ដែលអញបានញែក
ចេញពីឯងរាល់គ្នា ទុកជាមិនស្អាតនោះឡើយ ២៦ត្រូវឱ្យឯង

**២០:៨** ឌ នក ៣១:១៣ នក ២០:១២ **២០:៩** ឍ នក ២០:១២ យរ ៣៥:១៦ មឡ ១:៦ ២:១០ ណ នក ២០:១២ ចទ ២៧:១៦ អគ ២២:៧ ត នក ២១:១៧ ចទ ២១:២០–២១ មថ ១៥:៤ មក ៧:១០ ថ ខ.១១ ចទ ២២:៣០ យស ២:១៩ ២សយ ១:១៦ ៣:២៩ ១ពវ ២:៣៧ អគ ១៨:១៣ ៣៣:៤,៥ **២០:១០** ទ នក ២០:១៤ ចទ ៥:១៨ ២២:២២ យហ ៨:៥ ធ លប ៣៨:២៤ នក ២១:១២ **២០:១១** ន លវ ១៨:៧ ប ខ.៩ លវ ១៨:៨ **២០:១២** ផ លប ១១:៣១ ៣៨:១៦ **២០:១៣** ព លវ ១៨:២២ **២០:១៤** ភ លវ ១៨:១៧ ម លវ ២១:៩ ជន ១៦:៣៩ ពច ១៤:១៥ ១៥:៦ យ លវ ១៨:៨ ចទ ២៧:២៣ **២០:១៥** រ នក ២២:១៩ ល ខ.១០ **២០:១៧** វ លវ ១៨:៩ ស លប ១៧:១៤ ហ លវ ៥:១ **២០:១៨** ឡ លវ ១៥:២៤ អ អគ ១៨:៦ **២០:១៩** ក លវ ១៨:១២ **២០:២០** ខ លវ ១៨:១៣ គ ខ.២១ លប ១៥:២ **២០:២១** ឃ លវ ១៨:១៦ មថ ១៤:៤ មក ៦:១៨ ង ខ.២០ **២០:២២** ច លប ២៦:៥ ឆ លវ ១៨:២៥–២៨ **២០:២៣** ជ លវ ១៨:៣ ឈ លវ ១៨:២៤ ញ លវ ១៨:២៥ **២០:២៤** ដ នក ៣:៨ ជន ១៤:៨ ១៦:១៤ ឋ នក ៣៣:១៦ **២០:២៥** ឌ លវ ១០:១០ ចទ ១៤:៣–២១ កច ១០:១៤

**២០:៨** *ដែលញែកឯងរាល់គ្នាចេញជាបរិសុទ្ធ* មើលការពន្យល់ ពាក្យថា "អញជាព្រះ" ដែលជាចរិកលក្ខណចាប់ពីជំពូក ១៨–២៦ ។
**២០:៩** ធៀបនឹងការកាត់ទោសកូនប្រុសដែលខុស ក្នុង ចទ ២១:២០–២១។
**២០:១០** សូមមើល ១៨:២០ ។ **២០:១២** សូមមើល ១៨:១៥ ។
**២០:១៣** *ខ្ពើម* មើលការពន្យល់ ៧:២១ ។
**២០:១៥–១៦** សូមមើល ១៨:២៣ ។
**២០:១៨** សូមមើល ១៨:១៩ ។
**២០:២០** សូមមើល ១៨:១៤ ។ **២០:២១** សូមមើល ១៨:១៦ និងការពន្យល់។
**២០:២៤** *ទឹកដោះ និងទឹកឃ្មុំហូរហៀរ* គេប្រើឃ្លានេះជាធម្មតា នៅក្នុងព្រះគម្ពីរនិក្ខមនំ ជនគណនា និងចោទិយកថា(មើលការពន្យល់ នក ៣:៨ ចទ ៦:៣ និង យស ៥:៦ យរ ១១:៥ ៣២:២២ អគ ២០:៦,១៥)។
**២០:២៥** មើល ជំពូក ១១ និងការពន្យល់។

រាល់គ្នាបានបរិសុទ្ធដល់អញ[ល] ដ្បិតអញនេះគឺព្រះយេហូវ៉ា
អញបរិសុទ្ធ[ណ] ហើយអញបានញែកឯងរាល់គ្នា ចេញពីអស់
ទាំងសាសន៍ដទៃ[ត] ដើម្បីឱ្យបានជារបស់ផងអញវិញ ។
២៧មនុស្សប្រុសឬស្រីណាដែលធ្វើជាគ្រូខាប[ថ] ឬជាគ្រូមន្ត
គាថា នោះត្រូវសំឡាប់ចោលជាកុំខាន[ទ] ត្រូវចោលគេនឹង
ថ្ម[ធ]ទៅ ឈាមគេត្រូវធ្លាក់លើគេវិញ។

## ក្រឹត្យវិន័យសម្រាប់ពួកសង្ឃ

**២១** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ឱ្យប្រាប់ដល់ពួកសង្ឃ
គឺជាពួកកូនអើរ៉ុន[ក]ថា មិនត្រូវឱ្យអ្នកណាមួយនាំឱ្យខ្លួនសៅ
ហ្មង[ខ] ដោយព្រោះខ្មោចស្លាប់ នៅក្នុងពួកញាតិសន្តាន
របស់ខ្លួនឡើយ[គ] ២លើកតែដោយព្រោះសាច់ញាតិដែលជិត
ដិតចេញ គឺម្តាយ ឬឪពុក[ឃ] ឬកូនប្រុសកូនស្រី ឬបងប្អូនប្រុស
របស់ខ្លួនប៉ុណ្ណោះ ៣ហើយដោយព្រោះបងប្អូនស្រីនៅក្រមុំ
ជាសាច់ជិតដិតដែលមិនទាន់មានប្តី នោះនឹងនាំឱ្យខ្លួនសៅ
ហ្មង ដោយព្រោះខ្មោចនាងនោះបានដែរ[ង] ៤ពួកសង្ឃជា
មេលើសាសន៍របស់ខ្លួន ដូច្នេះមិនត្រូវធ្វើអ្វីនឹងនាំឱ្យខ្លួនសៅ
ហ្មង ឱ្យបានទាបថោកវិញឡើយ ៥មិនត្រូវឱ្យគេធ្វើឱ្យទំពែក
នៅលើក្បាល[ច] ឬកាត់ដំរីមពុកមាត់[ឆ] ឬឆូតស្បែកខ្លួនឡើយ[ជ]
៦ត្រូវឱ្យគេបានបរិសុទ្ធដល់ព្រះនៃខ្លួន[ឈ] ហើយមិនត្រូវ
បង្អាប់ដល់ព្រះនាមព្រះនៃខ្លួនឡើយ[ញ] ដ្បិតគេថ្វាយដង្វាយ
ដុត[ដ] គឺជាព្រះស្ងោយនៃព្រះយេហូវ៉ា[ឋ]ជាព្រះរបស់គេ ហេតុ
នោះបានជាគេត្រូវតែបានបរិសុទ្ធ[ឌ] ៧គេមិនត្រូវយក ស្ត្រី
ណាដែលជាស្រីសំផឹង ឬដែលបានខូចសេចក្តីបរិសុទ្ធ
ហើយ ធ្វើជាប្រពន្ធឡើយ ក៏មិនត្រូវយកស្ត្រីដែលប្តីលែង
ដែរ[ឍ] ដ្បិតគេបរិសុទ្ធដល់ព្រះនៃគេ[ណ] ៨ដូច្នេះត្រូវឱ្យឯង
ញែកគេចេញឱ្យផុត[ត] ដ្បិតគេថ្វាយព្រះស្ងោយរបស់ព្រះ
នៃឯង[ថ] ហើយឯងត្រូវរាប់គេជាបរិសុទ្ធដែរ ដ្បិតអញនេះ
គឺព្រះយេហូវ៉ា ដែលញែកឯងរាល់គ្នាចេញជាបរិសុទ្ធ
អញបរិសុទ្ធ[ទ] ៩បើកូនស្រីរបស់សង្ឃណាម្នាក់បង្ខូចខ្លួន
ដោយធ្វើជាសំផឹង នោះបានបង្អាប់ដល់ឪពុកហើយ ត្រូវតែ
ដុតវានឹងភ្លើងទៅ[ធ]។
១០ឯអ្នកណាដែលធ្វើជាសំដេចសង្ឃ ក្នុងពួកបងប្អូនរបស់
ខ្លួន គឺជាអ្នកដែលគេបានចាក់ប្រេងលើក្បាលតាំងឡើង[ន]
ឱ្យបានស្លៀកសំលៀកបំពាក់បរិសុទ្ធ[ប] នោះមិនត្រូវបើកឱ្យ
នៅក្បាលទទេ ឬហែកសំលៀកបំពាក់របស់ខ្លួនឡើយ[ផ]
១១ក៏មិនត្រូវចូលទៅជិតខ្មោចស្លាប់ណាដែរ[ព] ឬនាំឱ្យខ្លួន
សៅហ្មង[ភ] ដោយព្រោះឪពុក ឬម្តាយខ្លួនឡើយ[ម] ១២មិនត្រូវ
ឱ្យលោកចេញពីទីបរិសុទ្ធ[យ] ឬបង្អាប់ទីបរិសុទ្ធរបស់ព្រះនៃ
ខ្លួនឡើយ ដ្បិតលោកមានប្រេងចាក់លាប[រ]របស់ព្រះនៃខ្លួន
ដែលសំរាប់តាំងឡើងជាសង្ឃ នៅលើក្បាលហើយ អញ
នេះជាព្រះយេហូវ៉ា ១៣ត្រូវឱ្យលោកយកប្រពន្ធដែលនៅជា
ក្រមុំនៅឡើយ[ល] ១៤មិនត្រូវយកស្រីមេម៉ាយ ស្រីប្តីលែង ស្រី
ខូចសេចក្តីបរិសុទ្ធ ឬស្រីសំផឹងឱ្យសោះ គឺត្រូវយកស្រីក្រមុំ
ពីពួកសាសន៍របស់ខ្លួនធ្វើជាប្រពន្ធវិញ ១៥ហើយមិនត្រូវឱ្យ
ពូជពង្សរបស់ខ្លួនទៅជាទាបថោក ក្នុងសាសន៍ខ្លួនឡើយ
ដ្បិតអញនេះជាព្រះយេហូវ៉ា ដែលញែកលោកចេញជា
បរិសុទ្ធ ។
១៦ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេ ១៧ឱ្យប្រាប់ដល់អើ
រ៉ុនថា បើមានអ្នកណាក្នុងពួកកូនចៅឯងនៅអស់ទាំងដំណ
តរៀងទៅដែលវិកលវិការ[វ] នោះមិនត្រូវចូលមកថ្វាយព្រះ
ស្ងោយរបស់ព្រះនៃខ្លួនឡើយ[ស] ១៨ដ្បិតអ្នកណាដែលវិកល
វិការ[ហ] នោះមិនត្រូវចូលមកជិតឡើយ ដូចជាមនុស្សខ្វាក់[ឡ]
ឬខ្ញើច[អ] ឬអ្នកណាដែលមានច្រមុះក្រពិត ឬជើងដៃមិន
ស្មើគ្នា ១៩ឬមនុស្សណាកំពូរជើងដៃ ២០ឬដែលគម ឬតឿ ឬ

**២០:២៦** ល ចទ ១៤:២ ណ ខ.៨ លវ ១៩:២ យស ២៤:១៩ ២ពវ ១៩:២២ ទដ ៩៩:៣ ត នក ៣៣:១៦ **២០:២៧** ថ នក ២២:១៨ ទ លវ ១៩:៣១ ធ ខ.២ លវ ២៤:១៤ **២១:១** ក នក ២៨:១ លវ ១:៥ ខ លវ ៥:៣ ១៣:៣ គ ខ.១១ ជន ៥:២ ៦:៦ ១៩:១១ ៣១:១៩ **២១:២** ឃ ខ.១១ **២១:៣** ង ជន ៦:៦ **២១:៥** ច លវ ១៣:៤០ យរ ៧:២៩ ១៦:៦ ឆ អគ ៥:១ ៤៤:២០ ជ លវ ១៩:២៨ **២១:៦** ឈ ខ.៨ អរ ៨:២៨ ញ លវ ១៨:២១ ដ លវ ៣:១១ ឋ ខ.១៧,២២ លវ ២២:២៥ ឌ នក១៩:២២ លវ ១០:៣ **២១:៧** ឍ ខ.១៣,១៤ ណ អគ ៤៤:២២ **២១:៨** ត ខ.៦ ថ លវ ៣:១១ ទ នក ៣១:១៣ **២១:៩** ធ លប ៣៨:២៤ លវ ១៩:២៩ **២១:១០** ន នក ២៩:៧ ប លវ ៨:៧–៩,១៣ ១៦:៤ ផ លវ ១០:៦ **២១:១១** ព ជន ៥:២ ៦:៦ ៩:៦ ១៩:១១, ១៣,១៤ ៣១:១៩ ភ លវ ១៩:២៨ ម ខ.២ **២១:១២** យ នក ២៥:៨ រ នក ២៨:៤១ **២១:១៣** ល អគ ៤៤:២២ **២១:១៧** វ ខ.១៨,២១,២៣ ស ខ.៦ **២១:១៨** ហ លវ ២២:១៩,២៥ ឡ លវ ១៩:១៤ អ ២សយ ៤:៤ ៩:៣ ១៩:២៦

**២១:១–២២:៣៣** នេះជាការបង្ហាញ ពីការដឹកនាំរបស់សង្ឃ ជាពិសេសអំពីការបំញែកចេញ ពីភាពមិនស្អាត ។

**២១:១** *អ្នកណា . . . ស្លាប់* នេះជាការប៉ះពាល់ខ្លួនសាកសព (ជន ១៩:១១) ឬការចូលមកផ្ទះអ្នកស្លាប់(ជន ១៩:១៤)ដែលធ្វើឱ្យខ្លួនមិនស្អាត ។ សង្ឃតែម្នាក់គត់បានបង្គាប់ដល់ញាតិសន្តានកុំឱ្យខ្លួនសៅហ្មង (ខ.២–៣) និងការបង្គាប់បញ្ជារបស់សម្តេចសង្ឃបានហាមចំពោះការទាំងអស់នោះ ដើម្បីឱ្យពួកគេបានញែកជាបរិសុទ្ធ (ខ.១១–១២) ។

**២១:៥** *ឆូតស្បែកខ្លួន* មើល ១៩:២៧–២៨ ។ ការធ្វើឱ្យមានស្នាមរបួស និងការធ្វើឱ្យខូចទ្រង់ទ្រាយដងខ្លួន ត្រូវបានធ្វើឡើងនៅក្នុងចំណោមពួកសាសន៍ដទៃ ដើម្បីបង្ហាញថា ពួកគេកំពុងកាន់ទុក្ខ ហើយនិងដើម្បីបង្កើនការយកចិត្តទុកដាក់អំពីព្រះរបស់ពួកគេនោះ (សូមមើល ១ពវ ១៨:២៨) ។ សេចក្តីជំនឿរបស់ពួកអ៊ីស្រាអែល មានតិចតួចចំពោះគំនិតនៃការស្លាប់ (សូមមើល គំរូឧទាហរណ៍ ខ.១–៤ នក ៥:២៤ ២សយ ១២:២៣ ហព ១១:១៩) ។

**២១:៨** *ជាបរិសុទ្ធ* មើលការពន្យល់ ១១:៤៤ ។

**២១:៩** សូមមើល នក ៣៨:២៤ និងការពន្យល់ ។

**២១:១១–១២** សូមមើលការពន្យល់ ខ.១ ។

**២១:១៧** *ដែលវិកលវិការ* នៅត្រង់នេះក៏ដូចជាយញ្ញបូជា ដែលតម្រូវឱ្យស្អាតជានិច្ច ដែលពួកសង្ឃធ្វើជាបែបផែនសម្រាប់ការឥតខ្ចោះរបស់ព្រះគ្រីស្ទ (មើល ហព ៩:១១–១៤) ។

មានស្នាមអ្វីនៅភ្នែក ឬកើតទឹលម៉ូវ ឬស្រែង ឬមានពង
ខូច[ក] ២១អ្នកណាដែលវិកលវិការ[ខ]ក្នុងពូជអើរ៉ុនដ៏ជាសង្ឃ
នោះមិនត្រូវចូលមកថ្វាយដង្វាយដុតនៃព្រះយេហូវ៉ាទេ[គ]
អ្នកនោះវិកលវិការហើយ ដូច្នេះមិនត្រូវចូលទៅថ្វាយព្រះ
ស្ងោយរបស់ព្រះនៃខ្លួនឡើយ[ឃ] ២២អ្នកនោះនឹងបរិភោគ
អាហាររបស់ព្រះនៃខ្លួនបាន[ង] ទោះទាំងដង្វាយបរិសុទ្ធ
និងដង្វាយបរិសុទ្ធបំផុតផង ២៣ប៉ុន្តែអ្នកនោះវិកលវិការ
ហើយ[ច] បានជាមិនត្រូវចូលទៅឯវាំងនន ឬជិតអាសនា
ឡើយ ដើម្បីកុំឱ្យបង្អាប់ដល់ទីបរិសុទ្ធរបស់អញ[ឆ] ដ្បិតអញ
នេះ ជាព្រះយេហូវ៉ា ដែលញែកគេចេញជាបរិសុទ្ធ[ជ]
២៤ដូច្នេះម៉ូសេក៏ប្រាប់ដល់អើរ៉ុន និងពួកកូនលោក ហើយ
ដល់ពួកកូនចៅអ៊ីស្រាអែលទាំងអស់គ្នាផង ។

# ២២

១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២ចូរ
ប្រាប់ដល់អើរ៉ុន និងពួកកូនលោក ឱ្យគេរក្សាខ្លួនចំពោះ
ដង្វាយបរិសុទ្ធ[ក] ដែលពួកកូនចៅអ៊ីស្រាអែលថ្វាយដល់អញ
ដើម្បីកុំឱ្យបង្អាប់ដល់ឈ្មោះបរិសុទ្ធរបស់អញឡើយ[ខ] អញ
នេះជាព្រះយេហូវ៉ា[គ] ៣ចូរប្រាប់គេថា អ្នកណាក្នុងពូជឯង
រាល់គ្នា នៅអស់ទាំងដំណតរៀងទៅ ដែលជាប់មានសេច
ក្តីមិនស្អាតណា ក៏ចូលមកឯដង្វាយបរិសុទ្ធ ដែលពួកកូនចៅ
អ៊ីស្រាអែលថ្វាយដល់ព្រះយេហូវ៉ា[ឃ] អ្នកនោះនឹងត្រូវកាត់
ចេញពីមុខអញទៅ[ង] អញនេះជាព្រះយេហូវ៉ា ៤បើមនុស្ស
ណាក្នុងពូជអើរ៉ុនកើតឃ្លង់ ឬហូរខ្ទុះ[ច]នោះមិនត្រូវបរិភោគ
របស់បរិសុទ្ធឡើយ ដរាបដល់បានជាស្អាតសិន ឯអ្នកណា
ដែលពាល់ដល់មនុស្ស ដែលមិនស្អាតដោយសារខ្មោច
ស្លាប់[ឆ] ឬមនុស្សណាដែលទឹកកាមចេញពីខ្លួន ៥ឬអ្នកណា
ដែលពាល់ដល់សត្វលូនវារណា[ជ] ដែលនាំឱ្យខ្លួនមិនស្អាត
ឬដល់មនុស្សណា[ឈ]ដែលសេចក្តីមិនស្អាតរបស់អ្នកនោះ
ឆ្លងមកលើខ្លួនបាន ទោះបើមានសេចក្តីមិនស្អាតយ៉ាងណា
ក៏ដោយ ៦អ្នកដែលពាល់មនុស្សយ៉ាងនោះ នឹងត្រូវនៅជា
មិនស្អាត ញរហូតដល់ល្ងាច[ដ] ហើយមិនត្រូវបរិភោគរបស់
បរិសុទ្ធឡើយ ដរាបដល់បានងូតទឹកជាមុនសិន[ឋ] ៧រួចកាល
ណាថ្ងៃលិចហើយ នោះទើបនឹងបានស្អាត ហើយនិង
បរិភោគរបស់បរិសុទ្ធបាន ដ្បិតនោះជាអាហាររបស់ផង
អ្នកនោះ[ឌ] ៨គេមិនត្រូវបរិភោគសត្វដែលស្លាប់ដោយខ្លួន
ឯង[ឍ] ឬដែលសត្វអ្វីបានហែកហួរ[ណ] ជាការដែលនាំឱ្យខ្លួន
មិនស្អាតនោះឡើយ[ត] អញនេះជាព្រះយេហូវ៉ា[ថ] ៩ដូច្នេះគេ
ត្រូវរក្សាបញ្ញើរបស់អញ[ទ] ក្រែងគេធ្វើឱ្យបញ្ញើនោះទៅជា
អាប់ឱន ហើយគេជាប់មានបាប[ធ] រួចត្រូវស្លាប់[ន]អញនេះជា
ព្រះយេហូវ៉ាដែលញែកគេចេញជាបរិសុទ្ធ[ប] ។

១០មិនត្រូវឱ្យអ្នកដទៃណា បរិភោគដង្វាយបរិសុទ្ធឡើយ
ឯអ្នកណាដែលស្នាក់នៅផ្ទះសង្ឃ ឬអ្នកស៊ីឈ្នួល ក៏មិនត្រូវ
បរិភោគដង្វាយបរិសុទ្ធនោះដែរ[ផ] ១១ប៉ុន្តែបើសង្ឃណាបាន
យកប្រាក់ទៅទិញបាវមក បាវនោះនឹងបរិភោគបាន ហើយ
អស់អ្នកដែលកើតក្នុងផ្ទះនោះផង គេនឹងបរិភោគអាហារ
របស់សង្ឃបាន[ព] ១២បើកូនស្រីរបស់សង្ឃណាបានយកប្ដីជា
អ្នកក្រៅ នាងនោះមិនត្រូវបរិភោគដង្វាយបរិសុទ្ធដែល
លើកថ្វាយចុះឡើងទៀតឡើយ ១៣តែបើកូនស្រីរបស់សង្ឃ
ណាជាមេម៉ាយ ឬដែលប្ដីលែងឥតមានកូន ហើយបាន
ត្រឡប់មកនៅផ្ទះឪពុកខ្លួន ដូចកាលនៅក្រមុំវិញ នាងនោះ
នឹងបរិភោគអាហាររបស់ឪពុកបាន តែមិនត្រូវឱ្យអ្នកដទៃ
ណាបរិភោគទេ ១៤បើអ្នកដទៃណាបរិភោគអ្វីពីដង្វាយ
បរិសុទ្ធដោយឥតដឹង[ភ] ត្រូវឱ្យអ្នកនោះសងរបស់បរិសុទ្ធដល់
សង្ឃវិញ ព្រមទាំងថែម១ភាគក្នុង៥[ម]ផង ១៥គេមិនត្រូវ
ធ្វើឱ្យដង្វាយបរិសុទ្ធ[យ]របស់ពួកកូនចៅអ៊ីស្រាអែល ដែល
បានថ្វាយដល់ព្រះយេហូវ៉ា[រ]ទៅជាអាប់ឱនឡើយ ១៦យ៉ាង
នោះ ជាហេតុនាំឱ្យគេមានសេចក្តីទុច្ចរិត[ល] ដែលនាំឱ្យ
មានទោស[វ] ដោយបានបរិភោគ[ស]ដង្វាយបរិសុទ្ធរបស់គេ
ដូច្នេះដ្បិតអញនេះជាព្រះយេហូវ៉ា ដែលញែកគេចេញជា
បរិសុទ្ធ[ហ] ។

**២១:២០** ក លវ ២២:២៤ ចទ ២៣:១ អស ៥៦:៣ **២១:២១** ខ ខ.១៧ គ លវ ៣:១១ ឃ លវ ២២:១៩ **២១:២២** ង ១កថ ៩:១៣ **២១:២៣** ច ខ.១៧ ឆ នក ២៥:៨ ជ លវ ២០:៨ **២២:២** ក លវ ១៩:៨ ខ នក ២០:៧ មថ ៥:៣៣ គ អគ ៤៤:៨ **២២:៣** ឃ អរ ៨:២៨ ង លវ ៧:២០,២១ ជន ១៩:១៣ **២២:៤** ច លវ ១៥:២០–១៥ ឆ លវ ១១:២៤–២៨, ៣៩ **២២:៥** ជ លវ ១១:២៤–២៨,៤៣ ឈ លវ ១៥:៧ **២២:៦** ញ ហាក ២:១៣ ដ លវ ១១:២៤ ឋ លវ ១៤:៨ **២២:៧** ឌ ជន ១៨:១១ **២២:៨** ឍ លវ ១១:៣៩ ណ នក ២២:៣១ ត លវ ១១:៤០ ថ លវ ១១:៤៤ **២២:៩** ទ លវ ៨:៣៥ ធ នក ២៨:៣៨ ន ខ.១៦ នក ២៨:៤៣ ប លវ ២០:៨ **២២:១០** ផ ខ.១៣ នក ១២:៤៥ ២៩:៣៣ **២២:១១** ព លប ១៧:១៣ នក ១២:៤៤ **២២:១៤** ភ លវ ៤:២ ម លវ ៥:១៥ **២២:១៥** យ លវ ១៩:៨ រ ជន ១៨:៣២ **២២:១៦** ល ជន ១៨:១១ វ នក ២៨:៣៨ ស ខ.៩ ហ លវ ២០:៨

**២១:២៣** *វាំងនន* នៅត្រង់នេះបញ្ជាក់ពីទីបរិសុទ្ធនិងទីបរិសុទ្ធបំផុត (មើល នក ២៦:៣៣) ។

**២១:២៤** មើល ១១:១–៤៦ និងការពន្យល់ ១៣:៤៥–៤៦ ១៥:១–១៨ និងការពន្យល់ ២១:១១ ។

**២២:៥** សូមមើល ១១:២៩–៣១ ។

**២២:៨** សូមមើល ១៧:១៥ និងការពន្យល់ ។

**២២:៩** *ត្រូវស្លាប់ . . . ចេញជាបរិសុទ្ធ* នៅត្រង់នេះជាច្បាប់នៃភាពបរិសុទ្ធគឺដូចពួកសង្ឃ និងពួកមនុស្ស ប៉ុន្តែការកាត់ទោសពួកសង្ឃមានកម្រិតធ្ងន់ជាងដែលពួកគេមានការទទួលខុសត្រូវធំជាង សូមធៀប ណាដាប និងអ័ប៊ីហ៊ូវ (១០:១៣) និងពួកសង្ឃដែលគ្មានជំនឿនៅជំនាន់លោកម៉ាឡាគី (មឡ ១:៦–២:៩) ។ *បរិសុទ្ធ* សូមមើលការពន្យល់ ១១:៤៤ ។

**២២:១៤** *ត្រូវឱ្យអ្នកនោះសង . . . ១ភាគក្នុង៥* សូមធៀប ៥:១៦ និងការពន្យល់ ៥:១៥ ។

**២២:១៦** *បរិសុទ្ធ* មើលការពន្យល់ ១១:៤៤ ។

## ដង្វាយដែលមិនសព្វព្រះទ័យ

១៧ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ១៨ឱ្យប្រាប់ដល់អើរ៉ុន
និងពួកកូនលោក ព្រមទាំងពួកកូនចៅអ៊ីស្រាអែលទាំងអស់
គ្នាថា ឯអស់អ្នកណាក្នុងពួកវង្សអ៊ីស្រាអែល ឬក្នុងពួកអ្នក
សំណាក់នៅជាមួយ[ឡ] ដែលគេនឹងថ្វាយដង្វាយរបស់ខ្លួន[អ]
ទោះជាដង្វាយលាបំណន់[ក] ឬដង្វាយថ្វាយដោយស្ម័គ្រ
ពីចិត្តក្ដី[ខ] ដែលគេនឹងនាំមកថ្វាយជាដង្វាយដុតដល់ព្រះ
យេហូវ៉ា ១៩នោះបើគេចង់ឱ្យទ្រង់ទទួល ត្រូវឱ្យគេថ្វាយសត្វ
ឈ្មោលដ៏ឥតខ្ចោះ[គ]ពីហ្វូងគោ ហ្វូងចៀម ឬហ្វូងពពែក្ដី[ឃ]
២០តែសត្វណាដែលវិកលវិការ[ង] នោះមិនត្រូវឱ្យឯងរាល់គ្នា
ថ្វាយឡើយ ដ្បិតទ្រង់មិនទទួលសត្វយ៉ាងនោះស្នងឯងរាល់
គ្នាទេ[ច] ២១ហើយអ្នកណាដែលថ្វាយយញ្ញបូជា ជាដង្វាយ
មេត្រី[ឆ]ដល់ព្រះយេហូវ៉ា សំរាប់លាបំណន់ ឬជាដង្វាយ
ដោយស្ម័គ្រពីចិត្ត[ជ] ទោះបើគោឬចៀមក្ដី[ឈ] សត្វនោះត្រូវតែ
បានពេញខ្នាតទើបទ្រង់ទទួល[ញ] មិនត្រូវឱ្យមានវិកលវិការ
អ្វីឡើយ[ដ] ២២ឯសត្វដែលខ្វាក់ បាក់ជើង កំបុតជើង ឬ
កើតដំបៅ អង្គែ ឬមានក្រមរ នោះមិនត្រូវថ្វាយដល់ព្រះ
យេហូវ៉ា ឬថ្វាយជាដង្វាយដុតដល់ទ្រង់នៅលើអាសនា
ឡើយ ២៣បើគោឬចៀម មានអវយវៈខ្វះខាតមិនពេញ
លេញ នោះឯងនឹងថ្វាយជាដង្វាយស្ម័គ្រពីចិត្តបាន តែទ្រង់
មិនទទួលសត្វនោះ សំរាប់ជាដង្វាយលាបំណន់ទេ ២៤បើ
សត្វណាមានពងខូច ឬខ្ទាំ ឬបែក ឬក្រៀវ[ឋ] នោះមិនត្រូវឱ្យ
ឯងរាល់គ្នាថ្វាយដល់ព្រះយេហូវ៉ាឡើយ ក៏មិនត្រូវឱ្យធ្វើដូ
ច្នោះនៅក្នុងស្រុកឯងដែរ ២៥មិនត្រូវឱ្យឯងរាល់គ្នាទទួល
សត្វណាយ៉ាងនោះ ពីអ្នកប្រទេសក្រៅ សំរាប់នឹងថ្វាយជា
ព្រះស្ងោយរបស់ព្រះនៃឯងឡើយ[ឌ] ពីព្រោះសត្វទាំងនោះ
មិនពេញខ្នាតទេ គឺមានវិកលវិការហើយ ទ្រង់មិនទទួល
ស្នងឯងរាល់គ្នាឡើយ[ឍ] ។
២៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២៧កាលណា
កូនគោ ឬកូនចៀម ឬកូនពពែ[ណ]កើតមក នោះត្រូវឱ្យវានៅ
ជាមួយនឹងមេអស់៧ថ្ងៃ[ត] រួចតាំងពីថ្ងៃទី៨ទៅមុខ[ថ] នោះនឹង
ទទួល[ទ] សំរាប់ជាដង្វាយដុត ថ្វាយព្រះយេហូវ៉ាបាន ២៨តែ
ទោះបើគោឬចៀមក្ដី នោះមិនត្រូវសំឡាប់ទាំងមេទាំងកូន
នៅថ្ងៃដដែលទេ[ធ] ២៩បើកាលណាឯងរាល់គ្នាថ្វាយយញ្ញ
បូជា ទុកជាដង្វាយអរព្រះគុណ[ន]ដល់ព្រះយេហូវ៉ា នោះត្រូវ
ថ្វាយ បែបឱ្យទ្រង់បានទទួលឯងចុះ ៣០រួចត្រូវតែបរិភោគ
ដង្វាយនោះនៅថ្ងៃនោះឯង មិនត្រូវទុកអ្វីឱ្យនៅដល់ព្រឹក
ឡើយ[ប] អញនេះជាព្រះយេហូវ៉ា[ផ] ៣១ដូច្នេះឯងរាល់គ្នាត្រូវ
កាន់[ព]អស់ទាំងបញ្ញត្តិរបស់អញ ហើយប្រព្រឹត្តតាមផង[ភ]អញ
នេះជាព្រះយេហូវ៉ា ៣២មិនត្រូវឱ្យឯងរាល់គ្នាបង្អាប់ដល់
ឈ្មោះបរិសុទ្ធរបស់អញឡើយ[ម] គឺដើម្បីឱ្យពួកកូនចៅ
អ៊ីស្រាអែល[យ] បានដំកើងអញឡើងជាបរិសុទ្ធអញនេះ គឺ
ព្រះយេហូវ៉ា ដែលញែកឯងរាល់គ្នាចេញជាបរិសុទ្ធ[រ]
៣៣ហើយបាននាំឯងរាល់គ្នាចេញពីស្រុកអេស៊ីព្ទមក[ល] ដើម្បី
ឱ្យបានធ្វើជាព្រះនៃឯងរាល់គ្នា[វ] អញនេះជាព្រះយេហូវ៉ា។

**២៣** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា ឯថ្ងៃបុណ្យទាំងប៉ុន្មាននៃព្រះ
យេហូវ៉ាដែលឯងរាល់គ្នាត្រូវប្រកាសប្រាប់[ក] ទុកជាថ្ងៃជំនុំ
បរិសុទ្ធ បុណ្យអញទាំងនោះ គឺដូច្នេះ[ខ]។

## ថ្ងៃឈប់សម្រាក

៣ត្រូវឱ្យធ្វើការ[គ]ក្នុងរវាង៦ថ្ងៃ តែដល់ថ្ងៃទី៧ នោះជាថ្ងៃ
ឈប់ឱ្យបានសំរាក[ឃ] សំរាប់ប្រជុំជំនុំបរិសុទ្ធវិញ មិនត្រូវ
ឱ្យឯងរាល់គ្នាធ្វើការអ្វីនៅថ្ងៃនោះឡើយ[ង] ដ្បិតជាថ្ងៃឈប់
សំរាករបស់ព្រះយេហូវ៉ានៅក្នុងគ្រប់ទាំងទីលំនៅរបស់ឯង

**២២:១៨** ឡ លវ ១:២ អ ខ.២១ លប ២៨:២០ ជន ១៥:៨ ទដ ២២:២៥ ៧៦:១១ ១១៦:១៨ ក ជន ១៨:១១ ខ លប ៧:១៦ **២២:១៩** គ លវ ១:៣ ២១:១៨–២១ ជន ២៨:១១ ចទ ១៥:២១ ឃ លវ ១:២ **២២:២០** ង លវ ១:៣ ចទ ១៥:២១ ១៧:១ អគ ៤៣:២៣ ៤៥:១៨ ៤៦:៦ មឡ ១:៨ ហព ៩:១៤ ១ពត ១:១៩ ច នក ២៨:៣៨ **២២:២១** ឆ នក ៣២:៦ លវ ៣:៦ ជ លវ ៧:១៦ ឈ លវ ១:២ ញ នក ១២:៥ មឡ ១:១៤ ដ អម ៤:៥ **២២:២៤** ឋ លវ ២១:២០ **២២:២៥** ឌ លវ ២១:៦ ឍ លវ ១:៣ ៣:១ ជន ១៩:២ **២២:២៧** ណ លវ ១:៣ ត នក ២២:៣០ ថ នក ២២:៣០ ទ នក ២៨:៣៨ **២២:២៨** ធ ចទ ២២:៦,៧ **២២:២៩** ន ៧:១២ **២២:៣០** ប លវ ៧:១៥ ផ វ ១១:៤៤ **២២:៣១** ព ចទ ៤:២,៤០ ទដ ១០៥:៤៥ ភ នក ២២:៣១ **២២:៣២** ម លវ ១៨:២១ យ លវ ១០:៣ រ លវ ២០:៨ **២២:៣៣** ល នក ៦:៦ វ លវ ១៧:៧ **២៣:២** ក ខ.៤,៣៧, ៤៤ ជន ២៩:៣៩ អគ ៤៤:២៤ កល ២:១៦ ខ ខ.២១,២៧ **២៣:៣** គ នក ២០:៩ ឃ នក ២០:១០ ហព ៤:៩,១០ ង ខ.៧,២១,៣៥ ជន ២៨:២៦

**២២:១៨** *ដង្វាយដុត* មើលការពន្យល់ ១:៣ ។

**២២:២០–២២** សូមមើល មឡ ១:៨ ។

**២២:២៤** *ខូច ឬខ្ទាំ ឬបែក ឬក្រៀវ* សត្វទាំងប៉ុន្មាននេះមិនត្រូវបានអនុញ្ញាតឱ្យថ្វាយដល់ព្រះអម្ចាស់ឡើយ ។

**២២:២៨** នៅត្រង់វគ្គនេះ ជាការហាមប្រាមដល់មនុស្សក្នុងការថ្វាយយញ្ញបូជា (មើលខ.២៧) ឬការអនុវត្តដែលអាចទៅរួចមានដូចជាសត្វមេដែលត្រូវព្រលែង(ចទ ២២:៦–៧) ។ មួយវិញទៀតនេះប្រហែលជាច្បាប់ប្រពៃណីណាមួយរបស់សាសន៍ដទៃ(មើលការពន្យល់ នក ២៣:១៩) ។

**២២:៣០** *នៅថ្ងៃនោះឯង* នេះជាថ្ងៃបុណ្យរំលង (មើល នក ៣៤:៣៥) ។ ចំពោះដង្វាយមេត្រីត្រូវបានគេរក្សាទុក ដើម្បីបរិភោគនៅថ្ងៃបន្ទាប់ (៧:១៦) ។

**២២:៣២** *បរិសុទ្ធ . . . បរិសុទ្ធ . . . បរិសុទ្ធ* សូមមើល ១១:៤៤ ១៨:២១ និងការពន្យល់ ។ ថ្ងៃឈប់សម្រាកនេះមានជាប់ទាក់ទងជាមួយនឹងបុណ្យប្រចាំឆ្នាំ (នក ២៣:១២) រីឯសត្វចៀមពីរដែលបន្ថែមសម្រាប់ធ្វើជាយញ្ញបូជានៃដង្វាយដុតជារៀងរាល់សប្ដាហ៍នោះមាននៅក្នុង (សូមមើល ជន ២៨:៩–១០) ។

**២៣:២** *ថ្ងៃបុណ្យ* សូមមើល នក ២៣:១៤–១៧ និងការពន្យល់ ៣៤:១៨–២៥ ជន ២៨–២៩ ចទ ១៦:១–១៧ ។ ពាក្យនេះមានចំនួនដូចគ្នាដែលមានបញ្ជាក់យ៉ាងច្បាស់ពីថ្ងៃនិមួយៗ ។

**២៣:៣** *ថ្ងៃឈប់សំរាក* មើលការពន្យល់ នក ១៦:២៣ ២០:៩–១០ ។

រាល់គ្នា ។
៤ឯបុណ្យទាំងប៉ុន្មាននៃព្រះយេហូវ៉ា ជាថ្ងៃប្រជុំជំនុំ
បរិសុទ្ធ ដែលឯងរាល់គ្នាត្រូវប្រកាសប្រាប់នៅពេលកំណត់
នោះដូច្នេះ[ច] ៥គឺនៅថ្ងៃ១៤ក្នុងខែចេត្រ ចាប់តាំងពី
ល្ងាចរហូតដល់ខួបវិញ[ឆ] នោះជាថ្ងៃបុណ្យរំលងផងព្រះ
យេហូវ៉ា[ជ] ៦ហើយនៅថ្ងៃ១៥ក្នុងខែនោះឯង ជាបុណ្យនំបុ័ង
ឥតដំបែ[ឈ]ផងព្រះយេហូវ៉ា ត្រូវឱ្យឯងរាល់គ្នាបរិភោគ
នំបុ័ងឥតដំបែគ្រប់៧ថ្ងៃ[ញ] ៧នៅថ្ងៃដំបូង ត្រូវឱ្យប្រជុំជំនុំ
បរិសុទ្ធ[ដ] មិនត្រូវធ្វើការរកស៊ីឡើយ ៨តែឯងរាល់គ្នាត្រូវ
ថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ាគ្រប់៧ថ្ងៃ[ឋ] ដល់ថ្ងៃទី៧
នោះជាថ្ងៃប្រជុំជំនុំបរិសុទ្ធ មិនត្រូវធ្វើការរកស៊ីឡើយ ។

## ផលដំបូង

៩ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ១០ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា កាលណាឯងរាល់គ្នាបានចូលទៅក្នុង
ស្រុកដែលអញឱ្យដល់ឯង[ឌ] ហើយបានច្រូតចំរូតនៅស្រុក
នោះ[ឍ] នោះត្រូវយកកណ្តាប់[ណ]ដែលជាផលដំបូងពីចំរូតឯង
មកឯសង្ឃ[ត] ១១ត្រូវឱ្យសង្ឃគ្រវីថ្វាយកណ្តាប់នោះ នៅ
ចំពោះព្រះយេហូវ៉ា[ថ] ដើម្បីឱ្យទ្រង់បានទទួល[ទ]ស្នងឯង
រាល់គ្នា គឺនឹងគ្រវីថ្វាយ នៅថ្ងៃក្រោយនៃថ្ងៃឈប់សំរាក
១២ហើយនៅថ្ងៃដែលឯងរាល់គ្នាគ្រវី ថ្វាយកណ្តាប់នោះ
នោះត្រូវយកកូនចៀមឈ្មោល១ឥតខ្ចោះ អាយុ១ខួប[ធ]មក
ថ្វាយជាដង្វាយដុត ដល់ព្រះយេហូវ៉ា[ន] ១៣ឯដង្វាយម្សៅ[ប]
ដែលសំរាប់ថ្វាយជាមួយ នោះត្រូវជាម្សៅយ៉ាងម៉ដ្ត២ខ្ទឹង[ផ]
លាយនឹងប្រេង ទុកជាដង្វាយដុត សំរាប់ជាក្លិនឈ្ងុយដល់
ព្រះយេហូវ៉ា ហើយដង្វាយច្រូច[ព] នោះត្រូវជាស្រាទំពាំង
បាយជូរ២កំប៉ុង[ភ] ១៤ឯឯងរាល់គ្នា មិនត្រូវបរិភោគនំបុ័ង
ឬស្រូវលីង ឬអង្ករថ្មី[ម] ដរាបដល់ថ្ងៃនេះឯង ទាល់តែបាន
យកដង្វាយមកថ្វាយព្រះនៃឯងសិន[យ] នេះហើយជាច្បាប់
សំរាប់ឯងរាល់គ្នា នៅគ្រប់ទីកន្លែងដែលនឹងតាំងទីលំនៅ[រ]
នៅអស់កល្បជានិច្ច ដល់អស់ទាំងដំណតរៀងទៅ[ល] ។

## សប្តាហ៍នៃពិធីបុណ្យ

*២៣:១៥–២២ – ជន ២៨:២៦–៣១ ចទ ១៦:៩–១២*

១៥រួចចាប់តាំងពីថ្ងៃក្រោយនៃថ្ងៃឈប់សំរាកនោះ គឺពី
ថ្ងៃដែលឯងរាល់គ្នាបានយកកណ្តាប់ មកថ្វាយជាដង្វាយ
គ្រវី នោះត្រូវរាប់ពេញជា៧ថ្ងៃឈប់សំរាក ១៦ត្រូវតែរាប់
ទៅដល់ថ្ងៃក្រោយថ្ងៃឈប់សំរាកទី៧នោះ[វ] គឺទាំងអស់ត្រូវ
ជា៥០ថ្ងៃ នោះត្រូវឱ្យឯងរាល់គ្នាថ្វាយដង្វាយម្សៅជាថ្មី
ទៀតដល់ព្រះយេហូវ៉ា ១៧ត្រូវយកនំបុ័ង២ធ្វើពីម្សៅយ៉ាង
ម៉ដ្ត២ខ្ទឹង[ស]ពីផ្ទះឯង មកថ្វាយជាដង្វាយគ្រវី នំបុ័ងនោះត្រូវ
ធ្វើដោយលាយដំបែសំរាប់ជាដង្វាយនៃផលដំបូង[ហ]ថ្វាយ
ព្រះយេហូវ៉ា ១៨ហើយត្រូវយកកូនចៀម៧ឥតខ្ចោះអាយុ១
ខួប និងគោឈ្មោលស្ទាវ១ ហើយនិងចៀមឈ្មោល២មក
ថ្វាយព្រមគ្នានឹងនំបុ័ងនោះ គឺត្រូវដុតសត្វទាំងនោះថ្វាយ
ដល់ព្រះយេហូវ៉ា ព្រមទាំងដង្វាយម្សៅ និងដង្វាយច្រូច
ផង[ឡ] ជាដង្វាយដុតសំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា ១៩ក៏
ត្រូវថ្វាយពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាប និង
កូនចៀមឈ្មោល២អាយុ១ខួប សំរាប់ជាយញ្ញបូជានៃ
ដង្វាយមេត្រីដែរ ២០ត្រូវឱ្យសង្ឃគ្រវីសត្វទាំងនោះ ថ្វាយជា
មួយនឹងនំបុ័ងដែលជាផលដំបូង ទុកជាដង្វាយគ្រវី[អ]នៅ
ចំពោះព្រះយេហូវ៉ា ព្រមទាំងកូនចៀម២នោះដែរ ដង្វាយ
ទាំងនោះ សុទ្ធតែបរិសុទ្ធ ដល់ព្រះយេហូវ៉ា ទុកសំរាប់ពួក
សង្ឃ ២១នៅថ្ងៃនោះឯង ត្រូវប្រកាសប្រាប់ថា ជាថ្ងៃប្រជុំ
ជំនុំបរិសុទ្ធ[ក] មិនត្រូវធ្វើការរកស៊ីឡើយ[ខ] នេះហើយជាច្បាប់
សំរាប់គ្រប់ទីកន្លែង ដែលនឹងតាំងទីលំនៅ នៅអស់កល្បជា
និច្ចដល់អស់ទាំងដំណតរៀងទៅ ។
២២កាលណាឯងរាល់គ្នាច្រូតចំរូត[គ]នៅស្រែចំការរបស់
ឯង នោះមិនត្រូវច្រូតឱ្យដល់គៀនឡើយ ក៏មិនត្រូវសន្សំ
រើសកួរស្រូវដែលជ្រុះចុះដែរ[ឃ] ត្រូវឱ្យទុកសំរាប់ពួកអ្នក
ក្រីក្រ ហើយនិងពួកអ្នកដែលស្នាក់នៅវិញ[ង] អញនេះ គឺ
យេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ។

## បុណ្យផ្លុំត្រែ

*២៣:២៣–២៥ – ជន ២៩:១–៦*

២៣ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២៤ឱ្យលោកប្រាប់ដល់

**២៣:៤** ច នហ ១:១៥
**២៣:៥** ឆ នក ១២:១១ ជ នក ១២:៦
**២៣:៦** ឈ នក ១២:១៩ ញ នក ១២:១៧
**២៣:៧** ដ ខ.៣,៨
**២៣:៨** ឋ លវ ១:៩
**២៣:១០** ឌ ជន ១៥:២,១៨ ឍ លវ ១៩:៩ ណ លវ ១៩:៩ ត នក ២២:២៩ ៣៤:២២ រម ១១:១៦
**២៣:១១** ថ នក ២៩:២៤ ទ នក ២៨:៣៨
**២៣:១២** ធ លវ ១២:៦ ន នក ១២:៥
**២៣:១៣** ប លវ ២:១៤–១៦ ៦:២០ ផ ខ.១៧ លវ ២៤:៥ ជន ១៥:៦ ២៨:៩ ព លប ៣៥:១៤ ភ លវ ១០:៩
**២៣:១៤** ម យស ៥:១១ នរ ២:១៤ ១សយ ១៧:១៧ ២៥:១៨ ២សយ ១៧:២៨ យ នក ៣៤:២៦ រ យរ ២:៣ ល លវ ៣:១៧ ជន ១០:៨ ១៥:២១
**២៣:១៦** វ កច ២:១ ២០:១៦
**២៣:១៧** ស ខ.១៣ ហ នក ៣៤:២២
**២៣:១៨** ឡ ខ.១៣ នក ២៩:៤១ ៣០:៩ ៣៧:១៦ យរ ១៩:១៣ ៤៤:១៨
**២៣:២០** អ នក ២៩:២៤
**២៣:២១** ក ខ.២ នក ៣២:៥ ខ ខ.៣ **២៣:២២** គ លវ ១៩:៩ ឃ លវ ១៩:១០ ចទ ២៤:១៩–២១ នរ ២:១៥ ង រម ២:២

**២៣:៥** *បុណ្យរំលង* មើលការពន្យល់ នក ២៣:១៥ ។ បុណ្យនេះគេធ្វើនៅរដូវចម្រូត ដែលពួកបណ្ដាជនត្រូវនាំមកជាមួយនូវភោគផលដែលខ្លួនច្រូតកាត់រួច(សូមមើល ខ.១០–១១) ។

**២៣:៩–១៤** នៅវគ្គនេះ ជាបុណ្យផលដំបូង (មើល ២៣:១៩ ជន ១៥:២០ នហ ១០:៣៥) ។

**២៣:១៥** *៧ថ្ងៃឈប់សំរាក* មើលការពន្យល់ នក ២៣:១៦ ។

**២៣:១៦** *៥០ថ្ងៃ* ពាក្យនេះបានប្រាប់ពីបុណ្យថ្ងៃទី៥០ (កច ២:១ និងការពន្យល់ ២០:១៦ ១កថ ១៦:៨) អត្ថន័យនៅត្រង់នេះគឺទី "៥០" ។

**២៣:២២** មើលការពន្យល់ ១៩:៩–១០ ។

**២៣:២៤** *ថ្ងៃដំបូងក្នុងខែអស្សុជ* បុណ្យនេះបច្ចុប្បន្នត្រូវបានគេដឹងថាជា

ពួកកូនចៅអ៊ីស្រាអែលថា នៅថ្ងៃដំបូងក្នុងខែអស្សុជនោះ
ជាថ្ងៃឈប់សំរាក សំរាប់ឯងរាល់គ្នា គឺជាបុណ្យផ្លុំត្រែ
រំឭក[ច] ជាថ្ងៃប្រជុំជំនុំបរិសុទ្ធ[ឆ] ២៥មិនត្រូវឱ្យឯងរាល់គ្នា
ធ្វើការរកស៊ីឱ្យសោះ[ជ] តែត្រូវថ្វាយដង្វាយដុតដល់ព្រះ
យេហូវ៉ា[ឈ]។

## ថ្ងៃប្រោសលោះ

*២៣:២៦-៣២-លវ ១៦:២-៣៤ ជន ២៩:៧-១១*

២៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២៧នៅថ្ងៃ១០
ក្នុងខែអស្សុជនេះឯង[ញ] នោះជាថ្ងៃឱ្យបានធួននឹងបាប[ដ]គឺជា
ថ្ងៃប្រជុំជំនុំបរិសុទ្ធដល់ឯងរាល់គ្នា[ឋ] ត្រូវឱ្យឯងរាល់គ្នា
បញ្ឈឺចិត្តខ្លួន ហើយត្រូវថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ា
២៨នៅថ្ងៃនោះ មិនត្រូវធ្វើការរកស៊ីឡើយ[ឌ] ដ្បិតគឺជាថ្ងៃធួន
នឹងបាប សំរាប់នឹងថ្វាយដង្វាយឱ្យធួននឹងខ្លួនឯងរាល់គ្នា
នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង ២៩ឯអស់អ្នកណា
ដែលមិនបញ្ឈឺចិត្តខ្លួននៅថ្ងៃនោះ អ្នកនោះនឹងត្រូវកាត់
កាល់ពីពួកសាសន៍របស់ខ្លួនចេញ[ឍ] ៣០ហើយអស់អ្នកណា
ដែលធ្វើការអ្វីក៏ដោយនៅថ្ងៃនោះ នោះអញនិងធ្វើឱ្យ
វិនាសចេញពីពួកសាសន៍ខ្លួនទៅ[ណ] ៣១មិនត្រូវឱ្យឯងរាល់គ្នា
ធ្វើការយ៉ាងណាឱ្យសោះ នេះហើយជាច្បាប់សំរាប់ឯង
រាល់គ្នានៅគ្រប់ទីកន្លែង ដែលនឹងតាំងទីលំនៅ នៅអស់
កល្បជានិច្ច[ត] ដល់អស់ទាំងដំណតរៀងទៅ ៣២ថ្ងៃនោះត្រូវ
ទុកជាថ្ងៃឈប់ សំរាប់ឱ្យឯងរាល់គ្នាបានសំរាក[ថ] ហើយ
ឯងរាល់គ្នាត្រូវបញ្ឈឺចិត្តខ្លួន គឺនៅពេលល្ងាចថ្ងៃ៩ខែ
នោះឯង ចាប់តាំងពីល្ងាចដរាបដល់ខួបវិញ នោះឯងរាល់
គ្នាត្រូវរក្សាថ្ងៃឈប់សំរាករបស់ឯង[ទ]។

## ថ្ងៃបុណ្យបារាំ

*២៣:៣៣-៤៣ – ជន ២៩:១២-៣៩ ចទ ១៦:១៣-១៧*

៣៣ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ៣៤ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា នៅថ្ងៃ១៥ក្នុងខែអស្សុជ[ធ]នេះ ជាថ្ងៃ
បុណ្យបារាំ[ន]ថ្វាយព្រះយេហូវ៉ាអស់៧ថ្ងៃ ៣៥នៅថ្ងៃដំបូងត្រូវ
ឱ្យឯងរាល់គ្នាប្រជុំជំនុំបរិសុទ្ធ[ប] មិនត្រូវធ្វើការរកស៊ីឡើយ[ផ]
៣៦ក្នុង៧ថ្ងៃនោះ ត្រូវឱ្យឯងរាល់គ្នាថ្វាយដង្វាយដុតទៅព្រះ
យេហូវ៉ា លុះដល់ថ្ងៃទី៨ ជាថ្ងៃប្រជុំជំនុំបរិសុទ្ធ[ព]សំរាប់ឯង
រាល់គ្នា នោះត្រូវថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ា[ភ] នេះជា
ជំនុំដ៏មុតមាំ មិនត្រូវធ្វើការរកស៊ីឱ្យសោះ ។
៣៧នេះហើយ ជាបុណ្យទាំងប៉ុន្មាននៃព្រះយេហូវ៉ា ដែល
ឯងរាល់គ្នាត្រូវប្រកាសប្រាប់ ទុកជាថ្ងៃប្រជុំជំនុំបរិសុទ្ធ
ដើម្បីនឹងថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ា គឺជាដង្វាយដុត១
ដង្វាយម្សៅ១ យញ្ញបូជា១ ហើយនិងដង្វាយច្រួច១[ម] តាម
របៀបបុណ្យរាល់តែថ្ងៃ ៣៨ក្រៅពីអស់ទាំងថ្ងៃឈប់សំរាក[យ]
ផងព្រះយេហូវ៉ា ហើយក្រៅពីដង្វាយដែលឯងរាល់គ្នាថ្វាយ
ទាំងប៉ុន្មាន[រ] ព្រមទាំងបំណន់របស់ឯង និងដង្វាយដែល
ថ្វាយដល់ព្រះយេហូវ៉ាដោយស្ម័គ្រពីចិត្ត[ល]ផង ។
៣៩នៅថ្ងៃ១៥ខែអស្សុជ កាលណាបានប្រមូលផលពីដី
មក នោះត្រូវធ្វើបុណ្យ[វ]ថ្វាយព្រះយេហូវ៉ាអស់៧ថ្ងៃ[ស] ថ្ងៃ
ដំបូង ជាថ្ងៃឈប់សំរាក ហើយនៅថ្ងៃទី៨ ក៏ជាថ្ងៃឈប់
សំរាកដែរ ៤០នៅថ្ងៃដំបូង ត្រូវឱ្យឯងរាល់គ្នាយកមែកពី
ដើមយ៉ាងល្អ ហើយកាត់ធាងលម៉ើ និងមែកឈើញឹកស្និទ្ធ[ហ]
ព្រមទាំងធាងចាកពីមាត់ស្ទឹងផង[ឡ] រួចឱ្យអរសប្បាយឡើង[អ]
អស់៧ថ្ងៃនៅចំពោះព្រះយេហូវ៉ាជាព្រះនៃឯង ៤១ត្រូវឱ្យ
ឯងរាល់គ្នាធ្វើបុណ្យនេះថ្វាយព្រះយេហូវ៉ា អស់៧ថ្ងៃរាល់
តែឆ្នាំ នេះហើយជាច្បាប់ នៅអស់កល្បជានិច្ច អស់ទាំង
ដំណឯងតរៀងទៅ គឺត្រូវធ្វើបុណ្យនេះនៅខែអស្សុជ
៤២ត្រូវឱ្យឯងរាល់គ្នា គឺពួកអ្នកទាំងប៉ុន្មានដែលកើតក្នុង

**២៣:២៤** ច លវ ២៥:៩ ជន ១០:៩,១០ ២៩:១ ៣១:៦ ២ពវ ១១:១៤ ២របា ១៣:១២ ទដ ៩៨:៦ ឆ ខ.២៧,៣៦ អរ ៣:១ **២៣:២៥** ជ ខ.២១ ឈ លវ ១:៩ **២៣:២៧** ញ លវ ១៦:២៩ ដ នក ៣០:១០ ឋ ខ.២,២៤ **២៣:២៨** ឌ ខ.៣១ **២៣:២៩** ឍ លប ១៧:១៤ លវ ៧:២០ ជណ ៥:២ **២៣:៣០** ណ លវ ២០:៣ **២៣:៣១** ត លវ ៣:១៧ **២៣:៣២** ថ លវ ១៦:៣១ ទ នហ ១៣:១៩ **២៣:៣៤** ធ ១ពវ ៨:២ ហក ២:១ ន នក ២៣:១៦ យហ ៧:២ **២៣:៣៥** ប ខ.២ ផ ខ.៣ **២៣:៣៦** ព ខ.២៤ ១ពវ ៨:២ ២របា ៧:៩ នហ ៨:១៨ យហ ៧:៣៧ ភ លវ ១:៩ **២៣:៣៧** ម ខ.១៣ **២៣:៣៨** យ នក ២០:១០ ២របា ២:៤ អគ ៤៥:១៧ រ លវ ១:២ ល លវ ៧:១៦ **២៣:៣៩** វ អស ៦២:៩ ស នក ២៣:១៦ **២៣:៤០** ហ ទដ ១១៨:២៧ ឡ នហ ៨:១៤-១៧ ទដ ១៣៧:២ អស ៤៤:៤ អ ចទ ១២:៧ ១៤:២៦ ២៨:៤៧ នហ ៨:១០ ទដ ៩:២ ៦៦:៦ ១០៥:៤៣ យអ ២:២៦

បុណ្យចូលឆ្នាំរបស់ជនជាតិយូដា (រ៉ូស ហាស្សាណាស់ "ការចាប់ផ្ដើមនៃឆ្នាំ") ប៉ុន្តែការនេះមិនត្រូវបានលើកឡើងនៅក្នុងព្រះគម្ពីរឡើយ(ការលើកឡើងរបស់ពួកហេព្រើរមាននៅក្នុង អគ ៤០:១ និងការពន្យល់) ។ *ត្រែ* ត្រែនេះត្រូវបានគេផ្លុំនៅរៀងរាល់ពេលចាប់ផ្ដើមនៃខែនិមួយៗ (សូមមើល ទដ ៨១:៣ និងការពន្យល់) ។ ជាមួយនឹងការគ្មានប្រតិទិន សម្លេងត្រែឮឆ្លងកាត់ដែនដីទាំងមូល ដែលជាសញ្ញាសំខាន់នៃការចាប់ផ្ដើមរដូវថ្មី ហើយរដូវកសិកម្មចាស់ត្រូវបញ្ចប់ (មើលការពន្យល់ ១៦:២៩)។

**២៣:២៧** *ថ្ងៃឱ្យបានធួននឹងបាប* ចំពោះសេចក្ដីលំអិតនៅត្រង់នេះ សូមមើល ១៦:១-៣៤ ។ លោកអើរ៉ុន បានចូលទៅទីបរិសុទ្ធបំផុតនៅរាល់មួយឆ្នាំម្ដង (១៦:២៩-៣៤) ។ ពួកយូដា សម័យទំនើបបានហៅទីនោះថា "យុម គីបពុ"។ នេះជាថ្ងៃដែលគេដាក់ដោយឡែកពីគេ ឬប្រថ្នូលនៃការប្រោសលោះបាបរបស់ព្រះយេស៊ូវគ្រីស្ទ និងសម្ដេចសង្ឃ(សូមមើល ហព ៩:៧ ១៣:១១-១២ និងការពន្យល់) ។ *បញ្ឈឺចិត្តខ្លួន* សូមមើលការពន្យល់ ១៦:២៩,៣១ ។

**២៣:២៩** *ត្រូវកាត់កាល់ចេញពីសាសន៍របស់ខ្លួន* មើលការពន្យល់ ៧:២០ ។

**២៣:៣៤** *បុណ្យបារាំ* មើលការពន្យល់ នក ២៣:១៦ សក ១៤:១៦ យហ ៧:៣៧-៣៩ ។ ការធ្វើបុណ្យនៅរោងឧបោសថ ជាពីធីបុណ្យទី៣សម្រាប់បុណ្យប្រចាំឆ្នាំនិមួយៗ (សូមមើល នក ១៣:១៤-១៧ ចទ ១៦:១៦ និងការពន្យល់) ។

**២៣:៤២** *បារាំ* ព្រះគម្ពីរភាសាហេព្រើរប្រើពាក្យ "សាក់កុត" (*Sukkot*) ប្រែថា "រោងឧបោសថ" (ដូចក្នុង ខ.៣៤) ហើយនាំឱ្យមានឈ្មោះបុណ្យបារាំ ។ ទោះបីសព្វថ្ងៃនេះ ពួកយូដាដែលនិយមទំនៀមទំលាប់បុរាណ បានសង់រោងតូច(នហ ៨:១៣-១៧) ដើម្បីរំឭកដល់ការដែលពួកគេបានរស់នៅក្នុងរោង

វង្សសាសន៍អ៊ីស្រាអែល អាស្រ័យនៅក្នុងបារាំ[ក]នោះអស់
៧ថ្ងៃ ៤៣ដើម្បីឱ្យអស់ទាំងដំណកូនចៅឯងរាល់គ្នាបានដឹង[ខ]
ថា អញបានឱ្យពួកកូនចៅអ៊ីស្រាអែលនៅក្នុងបារាំដូច្នេះ
ក្នុងកាលដែលអញនាំគេចេញពីស្រុកអេស៊ីព្ទមក អញនេះ គឺ
យេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ៤៤នោះម៉ូសេក៏ប្រាប់ដល់
ពួកកូនចៅអ៊ីស្រាអែល ពីថ្ងៃបុណ្យទាំងប៉ុន្មានរបស់ព្រះ
យេហូវ៉ា ។

## ប្រេង និងនំប៉័ងរៀបនៅចំពោះព្រះអម្ចាស់

*២៤:១-៣ – នក ២៧:២០-២១*

**២៤** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២ចូរប្រាប់
ដល់ពួកកូនចៅអ៊ីស្រាអែល ឱ្យគេយកប្រេងអូលីវសុទ្ធយ៉ាង
សំរាំងមកសំរាប់ចង្កៀង ដើម្បីឱ្យបានឆេះនៅជានិច្ច
៣អើរ៉ុនត្រូវថែទាំងចង្កៀងនោះ ឱ្យឆេះពីល្ងាចរហូតដល់
ព្រឹកជាប្រក្រដី នៅចំពោះព្រះយេហូវ៉ា ត្រង់ខាងក្រៅវាំង
ននដែលបាំងទីបន្ទាល់ក្នុងត្រសាលជំនុំ នេះហើយជាច្បាប់
សំរាប់អស់កល្បជានិច្ច[ក] នៅអស់ទាំងដំណឯងតរៀងទៅ
៤ត្រូវឱ្យលោករៀបចង្កៀង នៅលើជើងចង្កៀងមាសសុទ្ធ[ខ]
នៅចំពោះព្រះយេហូវ៉ាជានិច្ច ។
៥ហើយត្រូវឱ្យយកម្សៅយ៉ាងម៉ដ្តធ្វើនំ១២[គ] គឺថានំនីមួយៗ
ធ្វើពីម្សៅ២ខ្ទឹង[ឃ] ៦ហើយត្រូវដំរៀបនំទាំងនោះជា២ជួរ
ក្នុង១ជួរមាន៦ នៅលើតុមាសសុទ្ធ[ង]ដែលនៅចំពោះព្រះ
យេហូវ៉ា ៧រួចត្រូវដាក់កំញានសុទ្ធ[ច]ពីលើនំទាំង២ជួរនោះ
ឱ្យបាន ទុកជានំប៉័ងរំឭក[ឆ] គឺជាដង្វាយដុតថ្វាយព្រះយេហូវ៉ា
៨រាល់តែថ្ងៃឈប់សំរាក[ជ]ត្រូវឱ្យលោកដំរៀបនំនោះនៅ
ចំពោះព្រះយេហូវ៉ាជានិច្ច[ឈ] ទុកជាដង្វាយនៃពួកកូនចៅ
អ៊ីស្រាអែល នេះហើយជាសេចក្តីសញ្ញាដ៏នៅអស់កល្បជា
និច្ច ៩នំទាំងនោះត្រូវបានជាចំណែកអើរ៉ុននិងពួកកូន
លោក[ញ] គេត្រូវបរិភោគនៅទីកន្លែងបរិសុទ្ធ[ដ] ដ្បិតជារបស់
បរិសុទ្ធបំផុត[ឋ] សំរាប់ពួកលោក ពីក្នុងអស់ទាំងដង្វាយដែល

**២៣:៤២** ក នក ២៣:១៦
**២៣:៤៣** ខ ទដ ៧៨:៥
**២៤:៣** ក នក ១២:១៤
**២៤:៤** ខ នក២៥:៣១
**២៤:៥** គ នក ២៥:៣០ ហព ៩:២ ឃ លវ ២៣:១៣
**២៤:៦** ង នក ២៥:២៣-៣០
**២៤:៧** ច លវ ២:១ ឆ លវ ២:២
**២៤:៨** ជ នក ២៥:៣០ ជន ៤:៧ ១រប ៩:៣២ ២រប ២:៤ ឈ មថ ១២:៥
**២៤:៩** ញ មថ ១២:៤ មក ២:២៦ លក ៦:៤ ដ លវ ៦:១៦ ឋ លវ ៦:១៧
**២៤:១១** ឌ នក ៣:១៥ ឍ នក ២០:៧ ២ពវ ៦:៣៣ យប ១:១១ ណ នក ១៨:២២ ត នក ៣១:២ ជន ១:៤ ៧:២ ១០:១៥ ១៣:២ ១៧:២ យស ៧:១៨ ១ពវ ៧:១៤
**២៤:១២** ថ នក ១៨:១៦
**២៤:១៤** ទ ខ.២៣ លវ ២០:២ ចទ ១៣:៩ ១៧:៥,៧ កច ៧:៥៨

ដុតថ្វាយដល់ព្រះយេហូវ៉ា តាមច្បាប់ដ៏នៅអស់កល្បជានិច្ច។

## ការចោលថ្មសម្លាប់អ្នកជេរប្រមាថព្រះនាមព្រះ

១០នៅគ្រានោះមានកូនប្រុសរបស់ស្ត្រីសាសន៍អ៊ីស្រា
អែលម្នាក់ ដែលឪពុកជាសាសន៍អេស៊ីព្ទ បានចេញទៅ
កណ្តាលជំនុំពួកកូនចៅអ៊ីស្រាអែល ឈ្លោះគ្នានឹងមនុស្ស
សាសន៍អ៊ីស្រាអែលម្នាក់នៅក្នុងទីដំឡើងត្រសាល ១១កូន
របស់ស្ត្រីសាសន៍អ៊ីស្រាអែលនោះក៏ប្រមាថដល់ព្រះនាមនៃ
ព្រះ[ឌ] ព្រមទាំងជេរប្រទេចផង[ឍ] ដូច្នេះគេនាំមកឯម៉ូសេ[ណ] (ឯ
ម្តាយរបស់អ្នកនោះ ឈ្មោះសឡូមិត ជាកូនឌីបរី ក្នុងពូជ
អំបូរដាន់[ត]) ១២ហើយគេឃុំទុក ទាល់តែព្រះយេហូវ៉ាបាន
មានបន្ទូលសំរេចពីដំណើរនោះ[ថ]។
១៣ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា ១៤ចូរ
នាំអ្នក ដែលបានជេរប្រទេចនោះ ចេញទៅឯក្រៅទីដំឡើង
ត្រសាល ហើយអស់អ្នកដែលបានឮ នោះត្រូវដាក់ដៃលើ
ក្បាលវា រួចត្រូវឱ្យពួកជំនុំទាំងអស់គ្នាចោលវានឹងថ្មទៅ[ទ]
១៥ត្រូវឱ្យឯងប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា អស់អ្នក
ណាដែលនឹងជេរប្រទេចដល់ព្រះនៃខ្លួន[ធ]នោះត្រូវទ្រាំទ្រ
នឹងអំពើបាបរបស់ខ្លួនទៅ[ន] ១៦ហើយអ្នកណាដែលប្រមាថ[ប]
ដល់ព្រះនាមព្រះយេហូវ៉ា នោះត្រូវសំឡាប់ជាកុំខានពួក
ជំនុំ[ផ]ទាំងអស់គ្នាត្រូវចោលនឹងថ្មជាកុំខាន ទោះបើជាអ្នក
ប្រទេសក្រៅ ឬអ្នកស្រុកក្តី បើកាលណាគេប្រមាថដល់ព្រះ
នាមព្រះហើយ នោះត្រូវតែសំឡាប់ចេញ ។
១៧ហើយអ្នកណាដែលវាយមនុស្សឱ្យដល់ស្លាប់ នោះ
ត្រូវសំឡាប់ជាកុំខានដែរ[ព] ១៨ឯអ្នកណាដែលវាយសត្វឱ្យ
ដល់ស្លាប់[ភ] នោះនឹងត្រូវសងជីវិតឱ្យធួននឹងជីវិត ១៩បើ
មនុស្សណាធ្វើឱ្យអ្នកជិតខាងខ្លួនមានរបួស នោះគេត្រូវធ្វើ

**២៤:១៥** ធ នក ២២:២៨ ន លវ ៥:១ **២៤:១៦** ប នក ២២:២៨ ផ នក ២១:១២ ១ពវ ២១:១០,១៣ មថ ២៦:៦៦ មក ១៤:៦៤ យហ ១០:៣៣ ១៩:៧ កច ៧:៥៨ **២៤:១៧** ព ខ.២១ លប ៩:៦ នក ២១:១២ ចទ ២៧:២៤ **២៤:១៨** ភ ខ.២១

បារាំ នៅពេលដែលពួកគេចាកចេញពីស្រុកអេស៊ីព្ទ (ខ.៤៣) ។

**២៤:២-៤** សូមមើល នក ២៧:២០-២១ ។

**២៤:៣** *ទីបន្ទាល់* សូមមើលការពន្យល់ នក ២៥:២២ ។ *ត្រសាលជំនុំ* នៅទីនេះជាកន្លែងដែលគេដុតភ្លើងរាល់ៗយប់ ។ *តរៀងទៅ* នេះជាភ្លើងដែលឆេះជាប់ជានិច្ច ប៉ុន្តែពេលថ្ងៃអត់មានឆេះទេ (មើល ១សយ ៣:៣ និងការពន្យល់) ។

**២៤:៧** *កំញានសុទ្ធ* នេះមិនត្រូវបានគេប្រើដូចជាគ្រឿងទេសសម្រាប់នំប៉័ងនោះទេ ប៉ុន្តែបានដុតទាំងគំនរនៅលើតុ និងគំនរដែលនៅអមជួរនំប៉័ងផងដែរ ។ *នំប៉័ងរំឭក* សូមមើលការពន្យល់ ២:២,៩,១៦ ។

**២៤:៨** *នំនោះ* នំនេះជានិច្ចកាលត្រូវបានគេហៅថា "នំប៉័ងវត្តមាន" (សូមមើល នក ២៥:៣០ និងការពន្យល់) ។ វាក៏តំណាងឱ្យអំណោយមកពីពូជអំបូរ១២ និងជានិមិត្តសញ្ញាពីការពិតដែលព្រះអម្ចាស់បានទ្រទ្រង់រាស្ត្ររបស់ទ្រង់ ។ នំប៉័ងទាំងអស់នោះត្រូវបរិភោគដោយពួកសង្ឃ (២៤:៩) ។

**២៤:៩** សូមមើល ១សយ ២១:៤-៦ ។

**២៤:១០** *ឪពុកជាសាសន៍អេស៊ីព្ទ* នេះបញ្ជាក់ថា ជាសាសន៍ដទៃ ។ ចំពោះច្បាប់ យ៉ាងហោចណាស់នៅក្នុងភាពសុភវិនិច្ឆ័យ ស្មើៗគ្នា ទាំងសាសន៍ដទៃ និងជនជាតិអ៊ីស្រាអែលតាំងពីកំណើត (ខ.២២ មើល នក ១២:៤៩) ។

**២៤:១១** *ជេរប្រទេច* សូមមើល នក ២០:៧ និងការពន្យល់ ។

**២៤:១៦** *ព្រះនាម* មើលការពន្យល់ ចទ ១២:៥ ។

**២៤:១៧,២១** សូមមើល នក ៩:៦ និងការពន្យល់ ។

ឱ្យអ្នកនោះមានរបួសដូចគ្នាវិញ ២០ត្រូវបំបាក់ឆ្អឹងឱ្យធួន
នឹងឆ្អឹងដែលបាក់ ភ្នែកឱ្យធួននឹងភ្នែក ធ្មេញឱ្យធួននឹង
ធ្មេញ[ម] ត្រូវធ្វើឱ្យអ្នកនោះមានរបួសដូចជាខ្លួនបានធ្វើគេ
ដែរ ២១បើអ្នកណាសំឡាប់សត្វ នោះត្រូវតែសងគេ[យ] តែ
បើសំឡាប់មនុស្សវិញ នោះត្រូវតែគេសំឡាប់ខ្លួនដែរ[រ]
២២ត្រូវមានច្បាប់តែ១តែម្យ៉ាងប៉ុណ្ណោះ សំរាប់ទាំងអ្នក
ស្នាក់នៅ[ល] និងអ្នកស្រុកផង[វ] ដ្បិតអញនេះ គឺយេហូវ៉ា
ជាព្រះនៃឯងរាល់គ្នា ២៣ដូច្នេះ ម៉ូសេក៏ប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែល ហើយគេក៏នាំអ្នកដែលជេរប្រមាថនោះ
ចេញទៅឯក្រៅទីដំឡើងត្រសាលចោលនឹងថ្មទៅ[ស] ពួកកូន
ចៅអ៊ីស្រាអែលបានធ្វើសំរេច ដូចជាព្រះយេហូវ៉ាទ្រង់បាន
បង្គាប់មកម៉ូសេ ។

## ឆ្នាំឈប់សម្រាក

**២៥** ១ព្រះយេហូវ៉ា ទ្រង់បង្គាប់ដល់ម៉ូសេនៅលើភ្នំស៊ី
ណាយ[ក] ២ឱ្យប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា កាល
ណាឯងរាល់គ្នា ចូលទៅក្នុងស្រុក ដែលអញឱ្យដល់ឯង
នោះដីនៅស្រុកនោះត្រូវមានពេលឈប់សំរាកថ្វាយព្រះ
យេហូវ៉ា ៣គឺត្រូវឱ្យឯងរាល់គ្នាសាបព្រោះនៅស្រែឯង
ហើយថែរក្សាចំការទំពាំងបាយជូររបស់ឯងអស់៦ឆ្នាំ ព្រម
ទាំងប្រមូលផលផ្លែផង[ខ] ៤តែដល់ឆ្នាំទី៧ នោះជាឆ្នាំឈប់
ផ្អាកឱ្យដីបានសំរាកវិញ[គ] គឺជាឆ្នាំឈប់សំរាកថ្វាយព្រះ
យេហូវ៉ាមិនត្រូវឱ្យធ្វើស្រែ ឬលួសកាត់ទំពាំងបាយជូររបស់
ឯងឡើយ[ឃ] ៥ឯមួរស្រូវដែលដុះឯង[ង]ពីចំរូតមុន នោះឯង
មិនត្រូវច្រូតទេ ក៏មិនត្រូវឱ្យបេះផ្លែទំពាំងបាយជូរ[ច] ដែល
មិនបានលួសកាត់ដែរ[ឆ] នោះគឺជាឆ្នាំឈប់សំរាកសំរាប់
ស្រុកឯង ៦ឆ្នាំសំរាក[ជ]នៃស្រុកឯងនឹងចំរើនជាអាហារដល់
ឯង ដល់បាវប្រុសបាវស្រីឯង ជើងឈ្នួល និងអ្នកប្រទេស
ក្រៅដែលស្នាក់នៅជាមួយនឹងឯង ៧ព្រមទាំងហ្វូងសត្វ និង
អស់ទាំងសត្វ[ឈ]ដែលនៅក្នុងស្រុកឯងផង ផលចំរើននោះ
នឹងបានសំរាប់ជាអាហារ ។

## ឆ្នាំសោមនស្ស

*២៥:៨–៣៨ – ចទ ១៥:១–១១*

*២៥:៣៩–៥៥ – នក ២១:២–១១ ចទ ១៥:១២–១៨*

៨ត្រូវឱ្យឯងរាប់ឆ្នាំឈប់សំរាក៧ដង គឺជា៧ឆ្នាំ៧ដង
ត្រូវឱ្យរំលងពេលឆ្នាំឈប់សំរាកអស់៧ ឱ្យបានគ្រប់៤៩ឆ្នាំ
៩រួចត្រូវចាត់ចែងទៅផ្លុំត្រែ[ញ] ឱ្យឮរំពង នៅថ្ងៃ១០ ក្នុងខែ
អស្សុជ[ដ] ដែលត្រូវនឹងថ្ងៃបុណ្យធួននឹងបាប[ឋ]ត្រូវឱ្យគេផ្លុំ នៅ
ពេញក្នុងស្រុកឯង ១០ត្រូវឱ្យឯងរាល់គ្នាញែកឆ្នាំទី៥០នោះ
ទុកជាបរិសុទ្ធ ព្រមទាំងប្រកាសប្រាប់សេចក្តីប្រោសលែង
បាវបំរើ[ឌ] ដល់មនុស្សទាំងអស់នៅពេញក្នុងស្រុកផង ឆ្នាំ
នោះជាឆ្នាំសោមនស្ស[ឍ] ដល់ឯងរាល់គ្នាដែលឯងនឹង
ត្រឡប់ទៅ នៅឯដីរបស់ឯងរាល់គ្នារៀងខ្លួនបាន[ណ] ហើយ
និងត្រឡប់ទៅ នៅនឹងញាតិសន្តានរបស់ខ្លួនវិញ ១១ឆ្នាំទី៥០
នោះនឹងបានជាឆ្នាំសោមនស្ស[ត] ដល់ឯងរាល់គ្នាក្នុងឆ្នាំនោះ
មិនត្រូវឱ្យឯងសាបព្រោះ ឬច្រូចកាត់មួរស្រូវដែលដុះឯង
ឬបេះផ្លែទំពាំងបាយជូរ ដែលមិនបានលួសកាត់ឡើយ[ថ]
១២ដ្បិតនោះគឺជាឆ្នាំសោមនស្សហើយ ត្រូវរាប់ជាឆ្នាំ
បរិសុទ្ធដល់ឯងរាល់គ្នា ហើយឯងនឹងបរិភោគផលចំរើន

**២៤:២០** ម នក ២១:២៤ មថ ៥:៣៨ **២៤:២១** យ ខ.១៨ រ ខ.១៧ **២៤:២២** ល នក ១២:៤៩ ២២:២១ អគ ៤៧:២២ វ ជន ៩:១៤ **២៤:២៣** ស ខ.១៤ **២៥:១** ក នក ១៩:១១ **២៥:៣** ខ នក ២៣:១០ **២៥:៤** គ ខ.៥,៦,២០ លវ ២៦:៣៥ ២រប ៣៦:២១ ឃ អស ៣៦:១៦ ៣៧:៣០ **២៥:៥** ង ២ពវ ១៩:២៩ ច លប ៤០:១០ ជន ៦:៣ ១៣:២០ ចទ ២៣:២៤ នហ ១៣:១៥ អស ៥:២ ឆ ខ.៤,១១ **២៥:៦** ជ ខ.៤ **២៥:៧** ឈ នក ២៣:១១ **២៥:៩** ញ លវ ២៣:២៤ ជន ១០:៨ យស ៦:៤ ពច ៣:២៧ ៧:១៦ ១សយ ១៣:៣ អស ២៧:១៣ សក ៩:១៤

ដ លវ ១៦:២៩ ឋ នក ៣០:១០ **២៥:១០** ឌ អស ៦១:១ យរ ៣៤:៨,១៥,១៧ លក ៤:១៩ ឍ ខ.១១,២៨,៥០ លវ ២៧:១៧,២១ ជន ៣៦:៤ អគ ៤៦:១៧ ណ ខ.២៧ **២៥:១១** ត ខ.១០ ថ ខ.៥

**២៤:២០** *ភ្នែកឱ្យធួននឹងភ្នែក ឆ្អឹងឱ្យធួននឹងឆ្អឹង* មើលការពន្យល់ នក ២១:២៣–៣៥ ។ ត្រង់ចំណុចនេះ គឺបញ្ជាក់ពីគោលការនៃការកាត់ទោសឱ្យសមទៅតាមបទឧក្រិដ្ឋ គឺមិនឱ្យលើស ឬខ្វះឡើយ ។ ក្រឹត្យវិន័យនេះមិនបានទៀមទាឱ្យអ្នកប្រព្រឹត្តខុសសងដល់ជនរងគ្រោះ នូវគ្រាប់ភ្នែក ឬឆ្អឹងរបស់ខ្លួនឡើយ ហើយក៏គ្មានភ័ស្តុតាងក្នុងប្រវត្តិសាស្ត្រណាមួយដែលបញ្ជាក់ពីការនេះដែរ ។ ព្រះយេស៊ូវទ្រង់ហាមមិនឱ្យសងសឹកគ្នាផងដែរ (៥:៣៨–៤២) ។

**២៤:២២** សូមមើលការពន្យល់ ខ.១០ ។

**២៥:៤** *ដីបានសំរាក* សូមមើល នក ២៣:១០–១១ ។ នៅត្រង់នេះពួកអ៊ីស្រាអែល មិនបានដាំដុះនោះទេ ប៉ុន្តែ ជាឆ្នាំឈប់សម្រាក (ទុកដីឱ្យនៅទំនេរ) ដែលបានឱ្យអ្វីមួយ ក្នុងគោលបំណងដូចគ្នា ។ ដីនៅត្រង់នេះ គឺស្ថិតនៅក្នុងឆ្នាំដែលត្រូវទុកឱ្យនៅទំនេរ ដូច្នេះហើយនៅត្រង់នេះជាទម្លាប់របស់ទាសករហេព្រើរដែលបានកំណត់រយៈពេលធ្វើការ៦ឆ្នាំ ប៉ុន្តែនៅត្រង់ នេះក៏មិនច្បាស់ថាជាឆ្នាំដែលត្រូវទុកដីឱ្យនៅទំនេរដែរ (សូមមើល នក ២១:២ និងការពន្យល់) ។ ចទ ១៥:១–១១ បញ្ជាក់ថាបំណុលទាំងប៉ុន្មាន ត្រូវលុបចោលនៅក្នុងឆ្នាំនោះផងដែរ ។ ការខ្វល់ខ្វាយចំពោះអ្នកក្រនៅក្នុងច្បាប់ពួកអ៊ីស្រាអែល (មើល នក ២៣:១១) គឺមិនមានតម្លៃ ។ សូមមើល ២៣:៧, ៣៥ ចទ ៣១:១០ នហ ១០:៣១ ។

**២៥:៩** *ថ្ងៃបុណ្យធួននឹងបាប* មើលការពន្យល់ ១៦:១–៣៤ ២៣:២៧ ។

**២៥:១០** *ឆ្នាំទី៥០* នៅត្រង់នេះប្រហែលជាឆ្នាំឈប់សម្រាក ដែលបន្ថែមនៅឆ្នាំទី៧ ឬប្រហែលដូចជាឆ្នាំទី៤៩ (រាប់ពីឆ្នាំទី១ ដល់ឆ្នាំចុងក្រោយ) ។ តាមឯកសាររបស់ពួកយូដាគឺមានការអនុគ្រោះនៅក្នុងឆ្នាំនេះ ។ *ប្រកាស ប្រាប់. . . ញាតិសន្តាន* សូមមើល ខ.៣៩–៤៣,៤៧–៥៥ ។ សូមធៀបនឹង អស ៦១:១–២ លក ៤:១៦–២១ ។ *ឆ្នាំសោមនស្ស* ពាក្យនេះនៅក្នុងព្រះគម្ពីរភាសាហេព្រើរ គឺដូចគ្នា ឬមានទំនាក់ទំនងនឹងពាក្យ "ស្នែង (របស់ចៀមឈ្មោល)" ឬ "ត្រែ" (មើលឧទាហរណ៏ក្នុង នក ១៩:១៣) ទោះបីនៅក្នុង ខ.៩ ព្រះគម្ពីរភាសាហេព្រើរបានប្រើពាក្យផ្សេង ដែលមានន័យថា "ត្រែ" ក៏ដោយ ។ គេផ្លុំត្រែនៅពេលបញ្ចប់នៃថ្ងៃបុណ្យធួននឹងបាប ដើម្បីប្រកាសការមកដល់នៃឆ្នាំសោមនស្ស (សូមធៀបនឹង ២៣:២៤) ។

អំពីស្រែចំការ ។
១៣នៅឆ្នាំសោមនស្ស[ទ] ត្រូវឱ្យឯងរាល់គ្នាត្រឡប់ទៅ
នៅឯដីរបស់ឯងរៀងខ្លួន ១៤បើកាលណាឯងលក់របស់អ្វី
ឱ្យអ្នកជិតខាងឯង ឬទិញអ្វីពីអ្នកជិតខាងឯងមក នោះមិន
ត្រូវបំបាត់គ្នាទៅវិញទៅមកឡើយ[ធ] ១៥ត្រូវឱ្យទិញពីអ្នកជិត
ខាងឯង រាប់តាមចំនួនឆ្នាំ[ន] ក្រោយឆ្នាំសោមនស្សនោះ
ហើយគេនឹងលក់ឱ្យឯង ដោយរាប់តាមចំនួនរដូវចំរូតដែរ
១៦បើនៅមានច្រើនឆ្នាំទៅទៀត នោះឯងត្រូវបង្កើនថ្លៃ
ឡើង តែបើនៅសល់តិចឆ្នាំវិញ នោះត្រូវបន្ថយថ្លៃចុះតាម
ចំនួនឆ្នាំតិចច្រើនទាំងនោះ[ប] គឺជាចំនួនចំរូតទេដែលគេ
លក់ឱ្យឯង ១៧មិនត្រូវឱ្យឯងរាល់គ្នាបំបាត់គ្នាឡើយ[ផ] ត្រូវតែ
កោតខ្លាចដល់ព្រះនៃឯងវិញ[ព] ដ្បិតអញនេះ គឺយេហូវ៉ា ជា
ព្រះនៃឯងរាល់គ្នា[ភ] ។
១៨ដូច្នេះត្រូវឱ្យកាន់តាមអស់ទាំងច្បាប់អញ[ម] ហើយ
រក្សាសេចក្ដីបញ្ញត្តិរបស់អញទាំងប៉ុន្មាន ព្រមទាំងប្រព្រឹត្ត
តាមផង នោះឯងរាល់គ្នានឹងបាននៅក្នុងស្រុកដោយសុខ
សាន្ត[យ] ១៩ហើយស្រុកនឹងបង្កើតផល[រ]ឱ្យឯងរាល់គ្នាបាន
បរិភោគឆ្អែត ឯងឯងរាល់គ្នានឹងបាននៅដោយសុខសាន្ត[ល]
២០បើឯងរាល់គ្នាសួរថា មើល ក្នុងឆ្នាំទី៧នេះ[វ]យើងមិន
សាបព្រោះ ឬប្រមូលផលអ្វីរបស់យើងសោះ ដូច្នេះតើ
យើងរាល់គ្នានឹងបានអ្វីបរិភោគ ២១នោះគឺអញនឹងផ្ដល់ពរ
របស់អញ[ស]ដល់ឯងរាល់គ្នានៅឆ្នាំទី៦ នៅឆ្នាំនោះនឹង
បង្កើតផលឱ្យល្មមគ្រប់៣ឆ្នាំវិញ[ហ] ២២រួចដល់ឆ្នាំទី៨ ត្រូវ
ឱ្យឯងរាល់គ្នាសាបព្រោះទៅចុះ តែនឹងបរិភោគផលចាស់
ដរាបដល់ឆ្នាំទី៩ ឯងរាល់គ្នាត្រូវបរិភោគផលចាស់នោះ
រហូតដល់បានច្រូតផលថ្មីហើយ[ឡ] ។
២៣មិនត្រូវលក់ដីណា[អ]ឱ្យដាច់ទៅគេឡើយ ដ្បិតស្រុក
នោះជារបស់ផងអញ[ក] ឯងរាល់គ្នាជាអ្នកប្រទេសក្រៅ
ដែលគ្រាន់តែសំណាក់នៅ[ខ] ជាមួយនឹងអញប៉ុណ្ណោះទេ
២៤ហើយនៅក្នុងស្រុក ដែលជាកេរ្តិ៍អាករឯងរាល់គ្នាទាំង
ប៉ុន្មាននោះ ត្រូវបើកច្បាប់ឱ្យលោះ[គ]ដីមកវិញបាន ២៥បើ
សិនជាបងប្អូនឯងធ្លាក់ខ្លួនទៅជាក្រីក្រ ហើយលក់ដីខ្លះ

**២៥:១៣** ទ ខ.១០
**២៥:១៤** ធ លវ ១៩:១៣ ១សយ ១២:៣,៤ ១កថ ៦:៨
**២៥:១៥** ន ខ.២៧ លវ ២៧:១៨,២៣
**២៥:១៦** ប ខ.២៧, ៥១,៥៧
**២៥:១៧** ផ លវ ១៩:១៣ យប ៣១:១៦ សភ ២២:២២ យរ ៧:៥,៦ ២១:១២ ២២:៣,១៥ សក ៧:៩–១០ ១ថន ៤:៦ ព លវ ១៩:១៤ ភ លវ ១៩:៣២
**២៥:១៨** ម លប ២៦:៥ យ ខ.១៩ លវ ២៦:៤,៥ ចទ ១២:១០ ៣៣:២៨ យប ៥:២២ ទដ ៤:៨ យរ ២៣:៦ ៣០:១០ ៣២:៣៧ ៣៣:១៦ អគ២៨:២៦ ៣៤:២៥ ៣៨:១៤
**២៥:១៩** រ លវ ២៦:១៤ ចទ ១១:១៤ ២៨:១២ អស ៥៥:១០ ល ខ.១៨
**២៥:២០** វ ខ.៤
**២៥:២១** ស ចទ ២៨:៨,១២ ទដ ១៣៣:៣ ១៣៤:៣ ១៤៧:១៣ អគ ៤៤:៣០ ហក ២:១៩ មឡ ៣:១០ ហ នក ១៦:៥
**២៥:២២** ឡ លវ ២៦:១០
**២៥:២៣** អ ជន ៣៦:៧ ១ពច ២១:៣ អគ ៤៦:១៨

នោះសាច់សន្តានដែលជិតបំផុត[ឃ] ត្រូវមកលោះ[ង]យកដី
ដែលបានលក់ឱ្យគេហើយនោះវិញ ២៦បើគ្មានអ្នកណានឹង
មកលោះទេ តែអ្នកនោះទៅជាមានឡើងវិញ[ច] ហើយមាន
ល្មមនឹងលោះយកបាន ២៧នោះត្រូវរាប់ចាប់តាំងពីប៉ុន្មាន
ឆ្នាំដែលលក់ដីនោះមក[ឆ] ហើយត្រូវបង្វិលប្រាក់ដែលសល់
នៅប្រគល់ដល់អ្នកដែលទិញ រួចម្ចាស់ដីនឹងទៅនៅឯដី
របស់ខ្លួនវិញ[ជ] ២៨បើអ្នកនោះគ្មានអ្វីល្មមនឹងលោះយកបាន
ទេ នោះដីដែលបានលក់ទៅ នឹងនៅក្នុងកណ្ដាប់ដៃនៃអ្នក
ដែលបានទិញដរាបដល់ឆ្នាំសោមនស្ស លុះដល់ឆ្នាំសោម
នស្សហើយ ដីនោះត្រូវត្រឡប់[ឈ]ទៅម្ចាស់ដើមវិញរួចគាត់
នឹងទៅនៅឯដីរបស់ខ្លួនបាន[ញ] ។
២៩បើមនុស្សណាលក់ផ្ទះ នៅក្នុងទីក្រុង ដែលមាន
កំផែង នោះមានច្បាប់លោះមកវិញក្នុងរវាង១ឆ្នាំ រាប់
តាំងពីថ្ងៃដែលបានលក់មក គឺនៅវេលាពេញ១ឆ្នាំ គេ
មានច្បាប់លោះមកវិញបាន ៣០បើមិនបានលោះវិញក្នុង
រវាង១ឆ្នាំនោះទេ ផ្ទះដែលនៅក្នុងទីក្រុងមានកំផែងនោះ
នឹងបានដាច់ជារបស់ផងអ្នកដែលទិញ ជាដរាបអស់ទាំង
ដំណតរៀងទៅ លុះដល់ឆ្នាំសោមនស្ស ផ្ទះនោះមិនបាន
មកវិញទេ ៣១ឯផ្ទះទាំងប៉ុន្មានដែលនៅអស់ទាំងស្រុកឥត
មានកំផែងព័ទ្ធ នោះត្រូវរាប់ទុកដូចជាស្រែចំការវិញ មាន
ច្បាប់លោះបាន ហើយដល់ឆ្នាំសោមនស្សក៏ត្រូវបានមក
វិញដែរ ៣២ប៉ុន្តែឯត្រង់ទីក្រុងទាំងប៉ុន្មានរបស់ពួកលេវី[ដ]
នោះគេមានច្បាប់នឹងលោះផ្ទះនៅក្នុងទីក្រុងរបស់គេចេះ
តែបានជាដរាប ៣៣បើសិនជាអ្នកណាទិញផ្ទះរបស់ពួកលេវី
ណាមួយ នោះដល់ឆ្នាំសោមនស្ស ផ្ទះដែលបានទិញនោះ
ហើយនិងទីក្រុងរបស់គេនិងបានទៅគេវិញ ដ្បិតអស់ទាំង
ផ្ទះនៅក្នុងទីក្រុងរបស់ពួកលេវី នោះជាកេរ្តិ៍អាកររបស់គេ
នៅក្នុងពួកកូនចៅអ៊ីស្រាអែល ៣៤ឯស្រែចំការទាំងប៉ុន្មាន

ក នក ១៩:៥ ខ លប ២៣:៤ ហព ១១:១៣ **២៥:២៤** គ ខ.២៩, ៤៨ នរ ៤:៧
**២៥:២៥** ឃ ខ.៤៨ នរ ២:២០ យរ ៣២:៧ ង លវ ២៧:១៣, ១៩,៣១ នរ ៤:៤
**២៥:២៦** ច ខ.៤៩ **២៥:២៧** ឆ ខ.១៥ ជ ខ.១០ **២៥:២៨** ឈ លវ ២៧:២៤ ញ ខ.១០ **២៥:៣២** ដ ជន ៣៥:១–៨ យស ២១:២

**២៥:១៣** *ត្រឡប់ទៅឯដីរបស់ឯង* សូមមើល ខ.១០ ។ ព្រះអម្ចាស់បាន ហាមប្រាមការបង្កើនទ្រព្យសម្បត្តិ ដើម្បីធ្វើឱ្យខូចប្រយោជន៍ដល់ពួកអ្នកក្រ ។ ព្រះអម្ចាស់មានបន្ទូលថា "ដីនេះជារបស់អញ" (ខ.២៣) ។ រាស្ត្ររបស់ព្រះ គឺគ្រាន់តែជាអ្នកជួលប៉ុណ្ណោះ (សូមមើល រប ២៩:១៥ ហព ១១:១៣) ។

**២៥:២៤** *លោះដីមកវិញ* ពាក្យនេះមានន័យថា ពួកគេមានសិទ្ធិលោះ ដីរបស់គេវិញ ។

**២៥:២៥** *សាច់សន្តានដែលជិតបំផុត ត្រូវមកលោះយកដី* សូមមើល យរ ៣២:៦–១៥ ។ នៅត្រង់នេះ មានភាពមិនច្បាស់ថាតើ ញាតិសន្តានអាចធ្វើអ្វី ចំពោះ ន៉ាអូមី និងនាងរស់ (នរ ៤:១–៤) ប៉ុន្តែគាត់មានភារកិច្ច ត្រូវ រៀបការជាមួយស្ត្រីមេម៉ាយ និងផ្គត់ផ្គង់គ្រួសារ (សូមមើល ចទ ២៥:៥–១០) ។ ការនោះបូអូស មានឆន្ទៈធ្វើទាំងពីរ (នរ ៤:៩–១០) និងមើល ការពន្យល់ នរ ២:២០ ។

**២៥:៣៣** *ផ្ទះនៅក្នុងទីក្រុងរបស់ពួកលេវី* សូមមើល ជន ៣៥:១–៨ យអ ២១:១–៤២ ។

នៅជុំវិញទីក្រុងរបស់គេ នោះលក់មិនបានទេ ដ្បិតជាកេរ្តិ៍
អាកររបស់ផងគេនៅអស់កល្បជានិច្ច[ឋ]។
៣៥បើបងប្អូនដែលនៅជិតឯង ធ្លាក់ខ្លួនទៅជាក្រ[ឌ]មាន
កំឡាំងដៃខ្សោយ នោះត្រូវឱ្យឯងទប់ទល់ផង[ឍ] ហើយឱ្យនៅ
ជាមួយនឹងឯងដូចជាអ្នកប្រទេសក្រៅ ឬជាអ្នកស្នាក់ដែរ
៣៦មិនត្រូវយកការប្រាក់ ឬគិតកំរៃ[ណ]ពីគេឡើយ គឺត្រូវកោត
ខ្លាចដល់ព្រះនៃឯងវិញ[ត] ដើម្បីឱ្យបងប្អូនបាននៅជាមួយនឹង
ឯងផង ៣៧មិនត្រូវឱ្យគេខ្ចីប្រាក់ ដើម្បីនឹងយកការឡើយ[ថ] ក៏
មិនត្រូវឱ្យអាហារដល់គេ ដោយចង់បានកំរៃដែរ ៣៨អញ
នេះ គឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ដែលបាននាំឯង
ចេញពីស្រុកអេស៊ីព្ទមក ដើម្បីនឹងឱ្យស្រុកកាណាន[ទ]ដល់ឯង
រាល់គ្នា ហើយឱ្យបានធ្វើជាព្រះនៃឯងរាល់គ្នា[ធ]។
៣៩បើបង ឬប្អូនដែលនៅជិតឯង ធ្លាក់ខ្លួនទៅជាក្រ
ហើយលក់ខ្លួនដល់ឯង នោះមិនត្រូវឱ្យឯងប្រើគេទុកដូចជា
បាវបំរើឡើយ[ន] ៤០ត្រូវឱ្យគេនៅជាមួយនឹងឯងទុកដូចជាអ្នក
ស៊ីឈ្នួល[ប] ហើយដូចជាអ្នកស្នាក់នៅវិញ ត្រូវឱ្យគេនៅបំរើ
ឯងដរាបដល់ឆ្នាំសោមនស្ស ៤១រួចគេនឹងចេញពីឯងទៅ
ព្រមទាំងកូនគេផង ដើម្បីនឹងត្រឡប់ទៅឯគ្រួសារ នៅក្នុង
កេរ្តិ៍អាករ[ផ]របស់ពួកឰយុកោគេវិញ[ព] ៤២ដ្បិតអ្នកទាំងនោះ
ជាពួកអ្នកបំរើរបស់អញ ដែលអញបាននាំចេញពីស្រុក
អេស៊ីព្ទមក[ភ] មិនត្រូវឱ្យលក់គេដូចជាលក់ខ្ញុំកំដរទេ ៤៣ក៏មិន
ត្រូវត្រួតត្រាលើគេដោយតឹងរ៉ឹងពេកឡើយ[ម] ត្រូវឱ្យកោត
ខ្លាចដល់ព្រះនៃឯងវិញ[យ] ៤៤តែឯត្រង់បាវបំរើប្រុស ឬស្រី
ដែលឯងនឹងបានទាំងប៉ុន្មាន នោះត្រូវទិញបាវប្រុសស្រី
នោះ អំពីអស់ទាំងសាសន៍ដទៃដែលនៅជុំវិញឯងរាល់
គ្នាវិញ ៤៥ឯងក៏មានច្បាប់នឹងទិញពួកកូនចៅរបស់អ្នក
ប្រទេសក្រៅ ដែលស្នាក់នៅកណ្តាលឯងរាល់គ្នាបានដែរ
ឯងនឹងទិញពួកនោះបាន ព្រមទាំងគ្រួគេ ដែលនៅជា
មួយនឹងឯង ដែលគេបានបង្កើតនៅក្នុងស្រុកឯងរាល់គ្នាផង
ពួកអ្នកទាំងនោះនឹងបានជាកេរ្តិ៍អាករដល់ឯងរាល់គ្នា
៤៦ហើយឯងនឹងទុកអ្នកទាំងនោះ ជាមរដកឱ្យកូនចៅឯងត
ទៅ ដើម្បីឱ្យបានជាកេរ្តិ៍អាករដែរ គឺពីពួកអ្នកទាំងនោះ
ហើយ ដែលឯងរាល់គ្នាត្រូវយកទុកជាបាវបំរើដល់ឯង
តែត្រង់ឯពួកកូនចៅអ៊ីស្រាអែលដែលជាបងប្អូនឯង នោះ

**២៥:៣៤** ឋ ជន ៣៥:២-៥ អគ ៤៨:១៤
**២៥:៣៥** ឌ ចទ ២៤:១៤,១៥ ឍ ចទ ១៥:៨ ទដ ៣៧:២១,២៦ សភ ២១:២៦ លក ៦:៣៥
**២៥:៣៦** ណ នក ២២:២៥ យរ ១៥:១០ ត លវ ១៩:៣២
**២៥:៣៧** ថ នក ២២:២៥
**២៥:៣៨** ទ លប ១០:១៩ ធ លប ១៧:៧
**២៥:៣៩** ន ១ពវ ៥:១៣ ៩:២២ យរ ៣៤:១៤
**២៥:៤០** ប ខ.៥៣
**២៥:៤១** ផ ខ.២៨ ព យរ ៣៤:៨
**២៥:៤២** ភ ខ.៣៨
**២៥:៤៣** ម នក ១:១៣ អគ ៣៤:៤ កល ៤:១ យ លប ៤២:១៨
**២៥:៤៧** រ នហ ៥:៥ យប ២៤:៩
**២៥:៤៨** ល ខ.២៤ វ ខ.២៥
**២៥:៤៩** ស ខ.២៦
**២៥:៥០** ហ ខ.១០ ឡ យប ៧:១ ១៤:៦ អស ១៦:១៤ ២១:១៦
**២៥:៥២** អ ខ.១៦
**២៥:៥៣** ក កល ៤:១
**២៥:៥៤** ខ លវ ១១:៤៥ គ លវ ១១:៤៤
**២៦:១** ក នក ២០:៤ ខ ទដ ៩៧:៧ អស ៤៨:៥ យរ ៤៤:១៩

មិន ត្រូវឱ្យឯងរាល់គ្នាត្រួតត្រាដោយតឹងរ៉ឹងឡើយ ។
៤៧បើមានអ្នកប្រទេសក្រៅ ឬអ្នកដែលស្នាក់នៅជា
មួយនឹងឯងបានទៅជាអ្នកមាន ហើយបងប្អូនឯងម្នាក់ទៀត
ដែលនៅជិតបានធ្លាក់ខ្លួនទៅជាក្រ លក់ខ្លួន[រ]ទៅអ្នកប្រទេស
ក្រៅដែលស្នាក់នៅជាមួយនឹងឯង ឬទៅអ្នកណាក្នុងពូជ
របស់អ្នកប្រទេសក្រៅនោះ ៤៨យ៉ាងនោះមានច្បាប់នឹង
លោះគេមកវិញបាន[ល] ក្រោយដែលលក់ខ្លួនហើយ ដូច្នោះ
គឺបងប្អូនណាមួយ[វ]នឹងលោះគេចេញបាន ៤៩ទោះជាឪពុកធំ
ឬមា ឬក្មួយគេក្តី ឬអ្នកណាក៏ដោយដែលជាសាច់ញាតិជិត
ដិតក្នុងគ្រួសារគេ នោះនឹងលោះបាន ឬបើខ្លួនគេទៅជា
មានវិញ[ស] ក៏នឹងលោះដោយខ្លួនឯងបានដែរ ៥០ត្រូវគិតជា
មួយនឹងអ្នកដែលទិញខ្លួន រាប់តាំងពីឆ្នាំដែលបានលក់ខ្លួន
ទៅរហូតដល់ឆ្នាំសោមនស្ស[ហ] ហើយថ្លៃដែលបានលក់ខ្លួន
នោះ ត្រូវសំរេចតាមចំនួនឆ្នាំដែលបានបំរើនោះ ត្រូវតែ
គិតឈ្នួលដូចជាអ្នកបំរើ[ឡ]វិញ ៥១បើសិនជាសល់នៅច្រើន
ឆ្នាំទៅទៀត នោះត្រូវសងថ្លៃលោះខ្លួន ពីដំឡៃប្រាក់ដែល
បានលក់ខ្លួនទៅតាមចំនួនឆ្នាំនោះ ៥២តែបើសល់នៅតិចឆ្នាំ
និងដល់ឆ្នាំសោមនស្សហើយ នោះត្រូវគិតនឹងចៅហ្វាយ
ហើយសងដំឡៃលោះខ្លួនតាមចំនួនឆ្នាំនោះវិញ[អ] ៥៣ត្រូវ
នៅជាមួយនឹងចៅហ្វាយនោះ ទុកដូចជាជើងឈ្នួល តាម
កំណត់ឆ្នាំ មិនត្រូវឱ្យចៅហ្វាយត្រួតត្រាលើគេដោយតឹងរ៉ឹង
នៅមុខឯងរាល់គ្នាឡើយ[ក] ៥៤បើមិនបានលោះតាមបែប
ណាមួយនេះ នោះគេក៏ត្រូវរួចចេញ ក្នុងឆ្នាំសោមនស្សដែរ
ព្រមទាំងកូនគេផង ៥៥ព្រោះឯពួកកូនចៅអ៊ីស្រាអែលនោះ
ជាបាវរបស់អញដែលអញបាននាំគេចេញពីស្រុកអេស៊ីព្ទ
មកទេ[ខ] អញនេះគឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា[គ]។

## រង្វាន់សម្រាប់ការស្តាប់បង្គាប់

**២៦** ១មិនត្រូវឱ្យឯងរាល់គ្នាធ្វើរូបព្រះ[ក] ឬបញ្ឈររូប
ឆ្លាក់[ខ] ឬបង្គោលថ្ម[គ] សំរាប់គោរពឡើយ ក៏មិនត្រូវឱ្យមាន
ថ្ម[ឃ]ឆ្លាក់ជារូបអ្វីនៅក្នុងស្រុកឯង ដើម្បីនឹងឱនខ្លួនក្រាប
គោរពចំពោះរូបនោះដែរ ដ្បិតអញនេះ គឺយេហូវ៉ា ជាព្រះ
នៃឯងរាល់គ្នាហើយ ២ត្រូវឱ្យឯងរាល់គ្នារក្សាអស់ទាំង
ពេលឈប់សំរាករបស់អញ[ង] ហើយកោតខ្លាចដល់ទីបរិសុទ្ធ

ហព ២:១៨ គ នក ២៣:២៤ ឃ ជន ៣៣:៥២ **២៦:២** ង នក ២០:៨

**២៥:៣៦** *ការប្រាក់* នៅត្រង់ចំណុចនេះ គំនិតសំខាន់គឺមិនចាំបាច់ ក្នុងការមិនយកពន្ធនោះទេ តែជាការជួយអ្នកក្រទៅវិញ ។ ចំពោះច្បាប់ មិនបានហាមប្រាមចំពោះការឱ្យខ្ចីច្រើន ជាការលើកទឹកចិត្តជាការឱ្យទៅវិញ ។
**២៥:៤៣** *កោតខ្លាចដល់ព្រះនៃឯង* សូមមើលការពន្យល់ នក ២០:១១ ។
**២៥:៥៥** *បាវ* ពាក្យនេះមានភាពស្រដៀងទៅនឹង "ខ្ញុំកញ្ជះ" ។
**២៦:១** នេះជាការហាមប្រាមក្នុងការថ្វាយបង្គំរូបព្រះ (សូមមើល នក ២០:៤ និងការពន្យល់) "ការថ្វាយបង្គំដោយវិញ្ញាណ" (យហ ៤:២៤ មើល ចទ ៤:១៥-១៩) ។

របស់អញ[ច] ដ្បិតអញជាព្រះយេហូវ៉ា ។
៣បើឯងរាល់គ្នាដើរតាមអស់ទាំងច្បាប់ ហើយរក្សា
អស់ទាំងបញ្ញត្តិអញ[ឆ] ព្រមទាំងប្រព្រឹត្តតាម ៤នោះអញនឹង
បង្អុរភ្លៀង[ជ]មកតាមរដូវកាល[ឈ] ហើយដីនឹងចំរើនផល ឯ
ដើមឈើទាំងប៉ុន្មាននៅចំការ នោះនឹងបង្កើតផ្លែដែរ[ញ]
៥ការបញ្ជាន់ស្រូវរបស់ឯងរាល់គ្នា នឹងនៅរហូតដល់រដូវ
បេះផ្លែទំពាំងបាយជូរ ហើយការបេះផ្លែទំពាំងបាយជូរនឹង
នៅរហូតដល់រដូវសាបព្រោះទៀត ឯងរាល់គ្នានឹងបាន
អាហារបរិភោគជាបរិបូរ[ដ] ហើយនិងនៅក្នុងស្រុកឯង
ដោយសុខសាន្ត[ឋ] ៦អញនឹងឱ្យមានសេចក្ដីសុខនៅក្នុងស្រុក
នោះ[ឌ] ឯងរាល់គ្នានឹងដេកទៅ[ឍ] ឥតមានអ្នកណាមកបំភ័យ
ឡើយ[ណ] អញនឹងធ្វើឱ្យអស់ទាំងសត្វសាហាវ[ត]បាត់ពីស្រុក
ចេញអស់ ហើយដាវក៏មិនដែលមកក្នុងស្រុកឯងដែរ ៧ឯង
រាល់គ្នានឹងដេញពួកខ្មាំងសត្រូវ[ថ] ហើយគេនឹងដួលដោយ
ដាវនៅមុខឯង ៨ពួកឯងតែ៥[ទ]នឹងដេញគេដល់ទៅ១00នាក់
ហើយពួកឯង១00នឹងដេញគេដល់ទៅ១ម៉ឺននាក់ក៏បាន អស់
ទាំងខ្មាំងសត្រូវឯង នឹងដួលដោយដាវ នៅមុខឯង[ធ] ៩អញ
នឹងជួយទំនុកបំរុងឯងរាល់គ្នា ឱ្យបានបង្កើតកូនចំរើនជា
ច្រើនឡើង[ន] ហើយអញនឹងតាំងសេចក្ដីសញ្ញា[ប]នឹងឯងរាល់
គ្នាដែរ ១០ឯងរាល់គ្នានឹងបរិភោគផលចាស់ដរាបដល់ផល
ថ្មីចូលមក នោះនឹងត្រូវយកផលចាស់ចេញ ឱ្យបានកន្លែង
ដាក់ផលថ្មីវិញ[ផ] ១១អញនឹងតាំងទីលំនៅរបស់អញ[ព]នៅ
កណ្ដាលឯងរាល់គ្នា ឥតដែលមានសេចក្ដីខ្ពើមដល់ឯង
រាល់គ្នាឡើយ[ភ] ១២អញនឹងដើរ[ម]នៅកណ្ដាលពួកឯង ព្រម
ទាំងធ្វើជាព្រះដល់ឯងរាល់គ្នា[យ] ហើយឯងរាល់គ្នានឹងធ្វើ
ជារាស្ត្រដល់អញ[រ] ១៣អញនេះ គឺយេហូវ៉ា ជាព្រះនៃឯង
រាល់គ្នា[ល] ដែលបាននាំឯងចេញពីស្រុកអេស៊ីព្ទមក[វ] ដើម្បី
មិនឱ្យធ្វើជាបាវបំរើរបស់គេទៀត អញបានបំបាក់កាំនឹម
របស់ឯងរាល់គ្នាចេញ[ស] ហើយបាននាំឱ្យដើរដោយត្រង់
ខ្លួនឡើងវិញ ។

## ទោសសម្រាប់ការមិនស្តាប់បង្គាប់

១៤តែបើឯងរាល់គ្នាមិនព្រមស្តាប់តាមអញ ហើយមិន
ប្រព្រឹត្តតាមសេចក្ដីបញ្ញត្តិរបស់អញទាំងនេះ[ហ] ១៥ដោយ
មើលងាយដល់អស់ទាំងច្បាប់អញ ហើយខ្ពើមក្រិត្យក្រម
របស់អញ[ឡ] ដល់ម្ល៉េះបានជាមិនព្រមប្រព្រឹត្តតាមអស់ទាំង
សេចក្ដីបង្គាប់នេះ គឺឯងផ្តាច់សេចក្ដីសញ្ញារបស់អញចេញ
វិញ[អ] ១៦នោះអញនឹងប្រព្រឹត្តចំពោះឯងរាល់គ្នាយ៉ាងដូច្នេះ
គឺនឹងដំរូវសេចក្ដីស្ញែងខ្លាចមកលើឯងរាល់គ្នា ជាជំងឺរីងរៃ
និងគ្រុនក្តៅ[ក] ដែលនឹងធ្វើឱ្យភ្នែកកាន់តែស្រវាំងទៅ ហើយ
នឹងនាំឱ្យមានចិត្តវេទនា[ខ] ឯងរាល់គ្នានឹងសាបព្រោះជា
ការឥតប្រយោជន៍ ដ្បិតខ្មាំងសត្រូវនឹងស៊ីទាំងអស់ទៅ[គ]
១៧អញនឹងតាំងមុខ[ឃ]ទាស់នឹងឯងរាល់គ្នា នោះឯងនឹង
ចាញ់[ង]ពួកខ្មាំងសត្រូវ[ច] ពួកអ្នកដែលស្អប់ឯង គេនឹងត្រួតត្រា
លើឯង[ឆ] ហើយឯងនឹងរត់ទៅឥតមានអ្នកណាដេញតាម
ផង[ជ] ។
១៨បើឯងរាល់គ្នានៅតែមិនស្តាប់តាមអញទៀត[ឈ] នោះ
អញនឹងវាយផ្ចាល[ញ]៧ដងលើសទៅទៀត ដោយព្រោះអំពើ

**២៥:២** ច លវ ១៩:៣០
**២៦:៣** ឆ លប ២៦:៥ នក ២៤:៨ ចទ?៦:១៧ ៧:១២ ១១:១៣,២២ ២៨:១,៩
**២៦:៤** ជ ចទ ១១:១៤ ២៨:១២ ទដ ៦៨:៩ យរ ៥:២៤ ហស ៦:៣ យអ ២:២៣ សក ១០:១ ឈ យប ៥:១០ ទដ ៦៥:៩ ១០៤:១៣ ១៤៧:៨ យរ ៥:២៤ញ នក ២៣:២៦ លវ ២៥:១៩ យប ១៤:៩ ទដ ៦៧:៧
**២៦:៥** ដ ចទ ៦:១១ ១១:១៥ អគ ៣៦:២៩–៣០ យអ ២:១៩,២៦ ឋ លវ ២៥:១៨
**២៦:៦** ឌ ទដ ២៩:១១ ៣៧:១១ ៨៥:៨ ១៤៧:១៤ អស ២៦:៣ ៥៤:១៣ ៦០:១៨ ហក ២:៩ ឍ ទដ ៣:៥ ៤:៨ សភ ៣:២៤ ណ យប ១១:១៨,១៩ អស ១៧:២ យរ ៣០:១០ មីក ៤:៤ សផ ៣:១៣ ត ខ.២២ លប ៣៧:២០
**២៦:៧** ថ ទដ ១៨:៣៧ ៤៤:៥
**២៦:៨** ទ អស ៣០:១៧ធ ចទ ២៨:៧ ៣២:៣០ យស ២៣:១០ ពច ១៥:១៥ ១របា ១២:១៤ **២៦:៩** ន លប ១:២២ ១៧:៦ នហ ៩:២៣ ប លប ១៧:៧ **២៦:១០** ផ លប ២៥:២២ **២៦:១១** ព នក ២៥:៨ ទដ ៧៤:៧ ៧៦:២ អគ ៣៧:២៧ ភ ខ.១៥,៤៣,៤៤ ចទ ៣១:៦ ១សយ ១២:២២ ១ពវ ៦:១៣ ២ពវ ១៧:១៥ **២៦:១២** ម លប ៣:៨ យ លប ១៧:៧ រ នក ៦:៧ យរ ៧:២៣ ១១:៤ ២៤:៧ ៣០:២២ ៣១:១ សក ១៣:៩ ២កថ ៦:១៦ **២៦:១៣** ល លវ ១១:៤៤ វ នក ៦:៦ ១៣:៣ ស អស ១០:២៧ យរ ២:២០ ២៧:២ ២៨:១០ ៣០:៨ អគ ៣០:១៨ ៣៤:២៧ ហស ១១:៤ **២៦:១៤** ហ ចទ ២៨:១៥–៦៨ មឡ ២:២ **២៦:១៥** ឡ ខ.១១ អ លប ១៧:៧ **២៦:១៦** ក ចទ ២៨:២២,៣៥ ទដ ៧៨:៣៣ ខ ខ.៣៩ ១សយ ២:៣៣ ទដ ១០៧:១៧ អគ ៤:១៧ ២៤:២៣ ៣៣:១០ គ ពច ៦:៣–៦ យប ៣១:៨ **២៦:១៧** ឃ លវ ១៧:១០ អគ ១៥:៧ ង ចទ ២៨:៤៨ យស ៧:១២ ពច ២:១៥ ១ពវ ៨:៣៣ ២របា ៦:២៤ ច យស ៧:៤ យរ ១៩:៧ ២១:៧ ឆ ទដ ១០៦:៤១ ជ ខ.៣៦,៣៧ ចទ ២៨:៧,២៥ ទដ ៥៣:៥ សភ ២៨:១ អស ៣០:១៧ **២៦:១៨** ឈ ខ.១៤ ញ ទដ ៩៩:៨ យរ ២១:១៤ អម ៣:១៤

**២៦:៣** *រក្សាអស់ទាំងបញ្ញត្តិអញ* ការប្រព្រឹត្តតាមគឺជាគន្លឹះដើម្បីឱ្យបានព្រះពរ (សូមមើល កឡ ៦:៧–១០ យក ១:២២–២៥) ។ សូមផ្ទៀប ព្រះពរនៃសេចក្ដីសន្យានៅក្នុងខ.៣–១៣ ជាមួយការនោះនៅក្នុង ចទ ២៨:១–១៤ ។

**២៦:៤** *អញនឹងបង្អុរភ្លៀង* នេះជាព្រះពរមួយ សម្រាប់សេចក្ដីស្តាប់បង្គាប់នៃសេចក្ដីសញ្ញានៅភ្នំស៊ីណាយ (សូមមើល ចទ ២៨:១២ មើលបន្ថែម ១១:១៤ អស ៣០:២៣ យរ ១៤:២២ សក ១០:១ និងការពន្យល់) ។ ម្យ៉ាងវិញទៀត បណ្ដាសា នៃការមិនស្តាប់បង្គាប់នោះ ព្រះអម្ចាស់មិនបានបង្អុរទឹកភ្លៀងឱ្យពួកគេ(ខ.១៩ ចទ ២៨:២៣–២៤ មើលបន្ថែម ចទ ១១:១៧ ១ពវ ៨:៣៥ អស ៥:៦ យរ ៣:៣ ១៤:៤ សក ១៤:១៧–១៨ និងការពន្យល់) ។

**២៦:៩** *បង្កើតកូនចំរើនជាច្រើនឡើង* សូមមើល ជន ១:២២ ផ្ទុយគ្នានឹង លវ ២៦:២២ ។

**២៦:១២** *ដើរនៅកណ្ដាល . . . ជាព្រះដល់ឯងរាល់គ្នា* នេះជាសេចក្ដីព្រមព្រៀងដ៏ល្បីល្បាញដែលបានធ្វើឡើង គឺដោយសារលោកហូសេ(១:៩–១០ ២:២៣) ។ សូមមើល យរ ៣១:៣៣ ហព ៨:១០ ។

**២៦:១៤** *បើអ្នករាល់គ្នាមិនព្រមស្តាប់តាមអញ* ឃ្លាបានប្រាប់ពីបណ្ដាសានៃការមិនប្រព្រឹត្តតាមសេចក្ដីបញ្ញត្តិ(សូមមើល ខ.១៤–៣៩) ដែលសេចក្ដីនេះមានច្រើនជាងការគោរពតាមសេចក្ដីបញ្ញត្តិ (ដូចមានក្នុង ខ.៣–១៣ សូមមើល ចទ ២៨:១៥–២៩:២៨ សូមផ្ទៀប ចទ ២៨:១–១៤) ។

**២៦:១៧** សូមមើល ខ.៣៤ និងសេចក្ដីបញ្ជិតបញ្ឈៀង ទៅនឹងការលើកឡើងនៅក្នុង សភ ២៨:១ ។

**២៦:១៨,២១,២៤,២៨** *៧ដងលើសទៅទៀត* ឃ្លានេះប្រាប់ពីការប្រុងប្រយ័ត្ន (សូមផ្ទៀប ការពន្យល់ ៤:៦) ។

បាបរបស់ឯង[ដ] ១៩អញនឹងបំបាក់សេចក្ដីអំនួតដែលឯងអួត
ពីអំណាចខ្លួន[ឋ] ក៏នឹងធ្វើឱ្យមេឃដែលនៅពីលើឯងប្រែទៅ
ដូចជាដែក ហើយដីរបស់ឯងដូចជាលង្ហិន[ឌ] ២០នោះឯង
រាល់គ្នានឹងបង្ហួសកំឡាំងជាការឥតប្រយោជន៍[ឍ] ដ្បិតដី
របស់ឯងនិងមិនបង្កើតផលទេ ហើយដើមឈើដែលនៅ
ស្រុកក៏មិនបានផ្លែផង[ណ] ។
២១បើឯងរាល់គ្នានៅតែដើរទទឹង[ត]នឹងអញ ហើយមិន
ព្រមស្ដាប់តាម នោះអញនឹងនាំឱ្យឯងមានសេចក្ដីវេទនា
៧ដងលើសទៅទៀត[ថ] តាមអំពើបាបរបស់ឯង ២២អញនឹង
ឱ្យសត្វព្រៃ[ទ]មកកណ្ដាលពួកឯង សត្វទាំងនោះនឹងឆក់នាំ
យកកូនចៅឯងទៅ ព្រមទាំងបង្ហិនហ្វូងសត្វរបស់ឯងផង
នឹងធ្វើឱ្យឯងទៅជាមានគ្នាតិច[ធ] ហើយឱ្យអស់ទាំងផ្លូវថ្នល់
របស់ឯងទៅជាសូន្យស្ងាត់[ន] ។
២៣បើឯងរាល់គ្នាមិនទាន់រាង[ប]ដោយព្រោះសេចក្ដីទាំង
នោះទេ គឺនៅតែដើរទទឹងនឹងអញ ២៤នោះអញនឹងដើរ
ទាស់[ផ]នឹងឯងរាល់គ្នាដែរ ហើយនឹងវាយផ្ចាលឲ្យ៧ដងលើស
ទៅទៀត ដោយព្រោះអំពើបាបរបស់ឯង ២៥អញនឹងនាំ
ឱ្យមានដាវ[ព]ជាសេចក្ដីសងសឹក[ភ]នៃសញ្ញាមកលើឯង នោះ
ឯងរាល់គ្នានឹងមូលគ្នា នៅក្នុងក្រុងរបស់ឯងទាំងប៉ុន្មាន
ហើយអញនឹងឱ្យជំងឺអាសន្នរោគ[ម]កើតឡើង នៅកណ្ដាល
ឯងរាល់គ្នាទៀត រួចឯងនឹងត្រូវបញ្ជូនទៅក្នុងកណ្ដាប់ដៃ
នៃពួកខ្មាំងសត្រូវ ២៦កាលណាអញបានផ្ដាច់ស្បៀងអាហារ
ពីឯងរាល់គ្នាចេញ[យ] នោះស្ត្រី១០នាក់នឹងដុតនំបុ័ងឱ្យឯង
នៅក្នុងឡតែ១ ហើយគេនឹងថ្លឹងនំបុ័ងឱ្យឯងបរិភោគឯង
រាល់គ្នានឹងបរិភោគ តែមិនចេះឆ្អែតឡើយ ។
២៧បើយ៉ាងដូច្នេះហើយ ឯងរាល់គ្នានៅតែមិនព្រម
ស្ដាប់តាមអញ[រ] គឺនៅតែដើរទាស់ទទឹងនឹងអញតទៅទៀត
២៨នោះអញនឹងដើរទាស់ទទឹង[ល]និងឯងរាល់គ្នា ដោយ
សេចក្ដីក្រោធ[វ] ហើយនឹងវាយផ្ចាល៧ដងលើសទៅទៀត
ដោយព្រោះអំពើបាបរបស់ឯង[ស] ២៩ឯងរាល់គ្នានឹង
បរិភោគ[ហ] ទាំងកូនប្រុសកូនស្រីរបស់ឯងផង[ឡ] ៣០អញនឹង
បំផ្លាញអស់ទាំងទីខ្ពស់របស់ឯង[អ] ហើយនឹងគាស់រំលំរូប
ព្រះអាទិត្យរបស់ឯង[ក] ព្រមទាំងបោះខ្មោចឯងរាល់គ្នាទៅ
លើរូបព្រះរបស់ឯងទាំងនោះដែរ[ខ] ហើយចិត្តអញនឹង
ខ្ពើម[គ]ឯងរាល់គ្នា ៣១អញនឹងរំលាង[ឃ]អស់ទាំងទីក្រុងឯង
ហើយនឹងធ្វើឱ្យ[ង]ទីបរិសុទ្ធរបស់ឯងទាំងប៉ុន្មានទៅជាសូន្យ
ស្ងាត់[ច] អញនឹងមិនព្រមហិតក្លិននៃគ្រឿងក្រអូបឯងទៀត
ឡើយ[ឆ] ៣២អញនឹងនាំឱ្យស្រុកទៅជាស្ងាត់ឈឹង[ជ] ដល់ម៉្លេះ
បានជាពួកខ្មាំងសត្រូវរបស់ឯងដែលនៅក្នុងស្រុក គេនឹង
មានសេចក្ដីងឿងឆ្ងល់[ឈ] ៣៣ឯឯងរាល់គ្នា អញនឹងកំចាត់
កំចាយ[ញ]ឱ្យទៅនៅគ្រប់ទាំងនគរ[ដ] ហើយនិងហូតដាវ[ឋ]ទៅ
តាមឯងទៀត នោះស្រុកឯងនឹងនៅជាស្ងាត់ឈឹង[ឌ] ហើយ
ទីក្រុងរបស់ឯងទាំងប៉ុន្មាននឹងត្រូវលាញទៅអស់រលីង[ឍ] ។
៣៤ស្រុកនោះនឹងបានសំរាក ក្នុងរវាងប៉ុន្មាន ដែល
កំពុងនៅស្ងាត់ឈឹង[ណ] ហើយឯងរាល់គ្នានៅឯស្រុករបស់
ពួកខ្មាំងសត្រូវឯងដូច្នេះ[ត] គឺស្រុកឯងនឹងបានត្រេកអរឡើង
ដោយមានពេលឈប់សំរាកវិញ ៣៥ក្នុងប៉ុន្មានឆ្នាំដែល
ស្រុកនៅស្ងាត់ឈឹង នោះនឹងបានសំរាកទៅ[ថ]គឺនឹងបំពេញ
ការសំរាក ដែលខានមានពីកាលគួរឈប់សំរាក ក្នុងគ្រា
ដែលឯងរាល់គ្នានៅស្រុកនោះនៅឡើយ ៣៦ឯពួកឯង
ដែលសល់នៅ នោះអញនឹងបណ្ដាលឱ្យមានចិត្តស្រយុត
នៅក្នុងស្រុករបស់ខ្មាំងសត្រូវខ្លួន បើគ្រាន់តែឮសូរស្លឹក
ឈើដែលត្រូវខ្យល់ផាត់ប៉ុណ្ណោះ[ទ] នោះនឹងធ្វើឱ្យរត់ទៅ[ធ]

**២៦:១៨** ដ ខ.២១ **២៦:១៩** ឋ ទដ ១០:៤ ៧៣:៦ អស ១៦:៦ ២៥:១១ ២៨:១–៣ យរ ១៣:៩ ៤៨:២៩ អក ២៤:២១ អម ៦:៨ សផ ៣:១១ ឌ ចទ ២៨:២៣ យប ៣៨:៣៨ **២៦:២០** ឍ ចទ ២៨:៣៨ ទដ ១២៧:១ អស ១៧:១១ ៤៩:៤ យរ ១២:១៣ មីក ៦:១៥ ហក ១:៦ ណ ចទ ១១:១៧ ២៨:២៤ **២៦:២១** ត ខ.៤១ ថ ខ.១៨ លប ៤:១៥ **២៦:២២** ទ លប ៣៧:២០ ធ ចទ ២៨:៦២ យរ ៤២:២ ន យរ ៥:៦ ១៤:១៦ ១៥:៣ ១៦:៤ អក ១៤:១៥ **២៦:២៣** ប យរ ២:៣០ ៥:៣ ៧:២៨ ១៧:២៣ ៣២:៣៣ សផ ៣:២ **២៦:២៤** ផ ២សយ ២២:២៧ **២៦:២៥** ព យរ ៥:១៧ ១៥:៣ ៤៧:៦ អក ១១:៨ ១៤:១៧ ២១:៤ ៣៣:២ ភ យរ ៥០:២៨ ៥១:៦,១១ ម នក ៥:៣ ៩:៣ ជន ១៦:៤៦ ១ពវ ៨:៣៧ ហព ៣:៥ **២៦:២៦** យ ១ពវ ៨:៣៧ ១៨:២ ២ពវ ៤:៣៨ ៦:២៥ ៨:១ ២៥:៣ ទដ ១០៥:១៦ អស ៣:១ ៩:២០ យរ ៣៧:២១

៥២:៦ អក ៤:១៦,១៧ ៥:១៦ ១៤:១៣ ហស ៤:១០ មីក ៦:១៤ **២៦:២៧** រ ខ.១៤ **២៦:២៨** ល ចទ ៧:១០ យប ៣៤:១១ អស ៥៩:១៨ ៦៥:៦–៧ ៦៦:៦ យរ ១៧:១០ ២៥:២៩ យអ ៣:៤ វ ចទ ៣២:១៩ ពច ២:១៤ ទដ ៧៨:៥៩ ១០៦:៤០ ស ខ.១៨ **២៦:២៩** ហ ២ពវ ៦:២៩ យរ ១៩:៩ បទ ៤:១០ អក ៥:១០ ឡ ចទ ២៨:៥៣ **២៦:៣០** អ ចទ ១២:២ ១សយ ៩:១២ ១០:៥ ១ពវ ៣:២,៤ ១២:៣១ ១៣:២,៣២ ២ពវ ១៧:២៩ ២៣:២០ ២របា ៣៤:៣ ទដ ៧៨:៥៨ អក ៦:៣ ១៦:១៦ អម ៧:៩ ក ២របា ៣៤:៤ អស ១៧:៨ ២៧:៩ អក ៦:៦ ខ អស ២១:៩ យរ ៥០:២ អក ៦:១៣ គ ទដ ១០៦:៤០ អម ៦:៨ **២៦:៣១** ឃ នហ ១:៣ អស ១:៧ ៣:៨,២៦ ៦:១១ ២៤:១២ ៦១:៤ យរ ៤:៧ ៩:១១ ២៥:១១ ៣៤:២២ ៤៤:២,៦,២២ អក ៣៦:៣៣ មីក ២:៤ ៣:១២ សផ ២:៥ ៣:៦ ង ២ពវ ២២:១៩ ច ទដ ៧៤:៣–៧ អស ៦៣:១៨ ៦៤:១១ បទ ២:៧ អក ២៤:២១ អម ៧:៩ ឆ អម ៥:២១,២២ ៨:១០ **២៦:៣២** ជ អស ៥:៦ យរ ៩:១១ ១២:១១ ២៥:១១ ២៦:៩ ៣៣:១០ ៣៤:២២ ៤៤:២២ ឈ ១ពវ ៩:៨ ២របា ២៩:៨ អស ៥២:១៤ យរ ១៨:១៦ ១៩:៨ ៤៨:៣៩ អក ៥:១៤ ២៦:១៦ ២៧:៣៥ ២៨:១៩ **២៦:៣៣** ញ យរ ៤០: ១៥ ៥០:១៧ អក ៣៤:៦ យអ ៣:២ ដ ចទ ៤:២៧ ២៨: ៦៤ នហ ១:៨ ទដ ៤៤:១១ ១០៦:២៧ យរ ៤:១១ ៩:១៦ ១៣:២៤ ៣១:១០ អក ៥:១០ ១២:១៥ ១៧:២១២០:២៣ ២២:១៥ សក ៧:១៤ ឋ យរ ៤២:១៦ អម ៩:៤ ឌ អស ៤៩:១៩ យរ ៧:៣៤ ឍ ខ.៣១ ១សយ ១៥:២២ យប ៣៦:១១ យរ ៤០:៣ **២៦:៣៤** ណ អស ១:៧ យរ ៧:៣៤ ២៥:១១ ៤៤:៦ អក ៣៣:២៩ ត ខ.៤៣ ២របា ៣៦:២១ **២៦:៣៥** ថ លវ ២៥:៤ **២៦:៣៦** ទ យប ១៣:២៥ ថ ២ពវ ២៥:៥ ទដ ៥៨:៧ បទ ១:៣,៦ ៤:១៩ អក ២១:៧

**២៦:១៩** *មេឃ . . . ដូចដែក . . . ដី . . . ដូចជាលង្ហិន* សូមមើលការពន្យល់ ចទ ២៨:២៣ ។

**២៦:៣០** *ទីខ្ពស់* សូមមើលការពន្យល់ ១សយ ៩:១២ ។ *រូបព្រះ* ព្រះគម្ពីរភាសាហេព្រើរប្រើពាក្យដែលមានន័យថា "គំនរលាមកសត្វ" ។

**២៦:៣៤** នៅវគ្គត្រង់នេះ ជាការចាក់បំពេញបន្ថែមទៀតនៅក្នុងអំឡុងពេលនៃការនិរទេសរបស់ពួកបាប៊ីឡូន (មើលការពន្យល់ ២របា ៣៦:២០–២១) ។

គេនឹងរត់ទៅ ដូចជារត់ឱ្យរួចពីមុខដាវផង ក៏នឹងដួល
ដោយឥតមានអ្នកណាដេញតាមឡើយ[ន] ៣៧គេនឹងជំពប់ដួល
ប្រគរគ្នា[ប] ដូចជាស្លាប់ដោយមុខដាវ ក្នុងកាលដែលគ្មានអ្នក
ណាដេញតាមផង ហើយឯងរាល់គ្នានឹងគ្មានកំឡាំងឈរ
នៅមុខពួកខ្មាំងសត្រូវឯងសោះ[ផ] ៣៨ឯងរាល់គ្នានឹងត្រូវ
វិនាសទៅ[ព] នៅអស់ទាំងនគរ ហើយស្រុករបស់ពួកខ្មាំង
សត្រូវនឹងលេបបំបាត់ឯងទៅ[ភ] ៣៩ឯពួករាល់គ្នា ដែលសល់
នៅ នោះនឹងស្រងេះស្រងោច នៅក្នុងអំពើទុច្ចរិតរបស់ខ្លួន
នៅនាស្រុកនៃពួកខ្មាំងសត្រូវ ហើយនិងស្រងេះស្រងោច
ទៅ ដោយសេចក្ដីទុច្ចរិតរបស់ពួកព្ធយុកោ[ម]ដែរ[យ]។
៤០នោះគេនឹងលន់តួ[រ]សេចក្ដីទុច្ចរិតរបស់គេ[ល] ហើយ
សេចក្ដីទុច្ចរិតរបស់ពួកព្ធយុកោគេដែរ[វ] គឺជាការរំលង
ដែលគេបានប្រព្រឹត្តនឹងអញ ដោយព្រោះការដែលគេបាន
ដើរទាស់ទទឹងនឹងអញផង ៤១គឺដោយហេតុនោះបានជាអញ
ដើរទាស់ទទឹង[ស]នឹងគេដែរ ហើយបាននាំគេទៅនៅស្រុក
របស់ពួកខ្មាំងសត្រូវ ដូច្នេះបើចិត្តដែលមិនទាន់កាត់ស្បែក
របស់គេ[ហ] បានទទួលចាលចាញ់[ឡ] ហើយគេព្រមទទួល
ទោស[អ]នៃអំពើទុច្ចរិតរបស់គេ ៤២នោះអញនឹងនឹកចាំពី
សេចក្ដីសញ្ញា ដែលអញបានតាំងនឹងយ៉ាកុប[ក] និងសេចក្ដី
សញ្ញាដែលអញបានតាំងនឹងអ៊ីសាក[ខ] ហើយនិងសេចក្ដី
សញ្ញា ដែលអញបានតាំងនឹងអ័ប្រាហាំ[គ] អញក៏នឹងនឹកចាំ
ពីស្រុកនោះដែរ ៤៣ឯស្រុកនោះនឹងត្រូវគេចោលទទេ[ឃ]
ហើយនឹងបានអរចំពោះឆ្នាំឈប់សំរាក កំពុងដែលនៅ
ស្ងាត់ ឥតមាននៅៗឡើយ ហើយគេនឹងព្រមទទួលទោសនៃ
អំពើទុច្ចរិតរបស់ខ្លួន គឺពីព្រោះគេបានមើលងាយ[ង]ដល់
សេចក្ដីបញ្ញត្តិរបស់អញ ហើយចិត្តគេបានខ្ពើមដល់អស់
ទាំងច្បាប់អញដែរ[ច] ៤៤ប៉ុន្តែទោះបើការនោះយ៉ាងដូច្នោះក៏
ដោយ គង់តែអញមិនបោះបង់ចោលគេ ក្នុងកាលដែល
គេនៅស្រុករបស់ខ្មាំងសត្រូវនោះឡើយ[ឆ] ក៏មិនខ្ពើមគេ[ជ]
ដល់ទៅបំផ្លាញចេញអស់រលីង[ឈ] ឬផ្ដាច់សេចក្ដីសញ្ញា[ញ]
ដែលអញបានតាំងនឹងគេនោះដែរ ដ្បិតអញនេះ គឺយេហូវ៉ា
ជាព្រះនៃគេ ៤៥តែដោយយល់ដល់គេ នោះអញនឹងនឹកចាំ[ដ]
ពីសេចក្ដីសញ្ញារបស់ពួកព្ធយុកោ ដែលអញបាននាំចេញ
ពីស្រុកអេស៊ីព្ទមក[ឋ] នៅចំពោះភ្នែកនៃអស់ពួកសាសន៍ដទៃ
ដើម្បីឱ្យបានធ្វើជាព្រះនៃគេ អញនេះជាព្រះយេហូវ៉ា ។
៤៦នេះហើយជាច្បាប់ ក្រិត្យក្រម និងបញ្ញត្តិទាំងប៉ុន្មាន
ដែលព្រះយេហូវ៉ាទ្រង់បានតាំង នឹងពួកកូនចៅអ៊ីស្រាអែល
ត្រង់ភ្នំស៊ីណាយ[ឌ] ដោយសារម៉ូសេ[ឍ]។

## ការលោះរបស់ផងព្រះអម្ចាស់

**២៧** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា កាលណាមនុស្សណាបន់បំណន់[ក] បើ
របស់ដែលសន្យាថ្វាយជាមនុស្ស នោះត្រូវជារបស់ផង
ព្រះយេហូវ៉ាតាមដែលឯងគិតថ្លៃ ៣ឯមនុស្សប្រុសចាប់តាំង
អាយុ២០ឆ្នាំរហូតដល់៦០ឆ្នាំ នោះត្រូវគិតថ្លៃជាប្រាក់៥០
រៀល តាមប្រាក់រៀលដែលប្រើក្នុងទីបរិសុទ្ធ[ខ] ៤បើជា
ស្រីវិញ ត្រូវគិតថ្លៃ៣០រៀល ៥បើមនុស្សនោះមានអាយុ
ចាប់តាំងពី៥ឆ្នាំរហូតដល់២០ឆ្នាំ នោះខាងឯប្រុសត្រូវ
គិតថ្លៃជា២០រៀល[គ] ស្រី១០រៀល ៦បើមានអាយុចាប់តាំង
ពី១ខែរហូតដល់៥ឆ្នាំ[ឃ] នោះខាងឯប្រុសត្រូវគិតថ្លៃជាប្រាក់
៥រៀល ស្រី៣រៀល ៧បើមានអាយុ៦០ឆ្នាំឡើងទៅលើនោះ
ខាងឯប្រុសត្រូវគិតថ្លៃជា១៥រៀល ស្រី១០រៀល ៨តែបើអ្នក
នោះក្រពេក គ្មានល្មមនឹងសង[ង]តាមដំឡៃដែលឯងគិត នោះ

**២៦:៣៦** ន ខ.១៧ **២៦:៣៧** ប យរ ៦:២១ ១៣:១៦ ៤៦:១៦ អគ ៣:២០ ណហ ៣:៣ ផ យស ៧:១២ **២៦:៣៨** ព យប ៤:៩ ៣៦:១២ ទដ ១:៦ អស ១:២៨ យរ ១៦:៤ ៤៤:២៧ ផ ចទ ៤:២៦ **២៦:៣៩** ម នក ២០:៥ អស ១៤:២១ យ ខ.១៦ អស ២៤:១៦ **២៦:៤០** រ លវ ៥:៥ ល ទដ ៣២:៥ ៣៨:១៨ វ នហ ៩:២ ទដ ១០៦:៦ យរ ៣:១២–១៥ ១៤:២០ **២៦:៤១** ស ខ.២១ ហ ចទ ១០:១៦ ៣០:៦ យរ ៤:៤ ៩:២៥,២៦ អគ ៤៤:៧,៩ កច ៧:៥១ ឡ ២រប ៧:១៤ ១២:៦ អគ ២០:៤៣ អ អស ៦:៧ ៣៣:២៤ ៤០:២ ៥៣:៥,៦,១១ **២៦:៤២** ក លប ២៨:១៥ ៣៥:១១–១២ ខ លប ២៦:៥ គ នក ២:២៤ **២៦:៤៣** ឃ ទដ ៦៩:២៥ អស ៦:១១ ៣២:១៤ ៦២:៤ យរ ២:១៥ ៤៤:២

បទ ១:១ អគ ៣៦:៤ ង ជន ១១:២០ ១៤:៣១ ១សយ ៨:៧ ទដ ១០៦:២៤ ច ខ.១១ អគ ២០:១៣ **២៦:៤៤** ឆ ខ.៣៣ ២ពវ ១៧:២០ ២៥:១១ ២របា ៦:៣៦ ៣៦:២០ ជ ខ.១១ រម ១១:២ ឈ ចទ ៤:៣១ យរ ៤:២៧ ៥:១០ ៣០:១១ ញ ពច ២:១ យរ ៣១:៣៧ ៣៣:២៦ ៥១:៥ **២៦:៤៥** ដ ចទ ៤:៣១ ឋ នក ៦:៨ លវ ២៥:៣៨ **២៦:៤៦** ឌ នក ១៩:១១ ឍ លវ ៧:៣៨ ២៧:៣៤ **២៧:២** ក លប ២៨:២០ **២៧:៣** ខ នក ៣០:១៣ **២៧:៥** គ លប ៣៧:២៨ **២៧:៦** ឃ ជន ៣:៤៧ **២៧:៨** ង លវ ៥:១១

**២៦:៤០** *លន់តួសេចក្ដីទុច្ចរិតរបស់គេ* សូមមើលការពន្យល់ សភ ២៨:១៣ ១យហ ១:១៩ ។

**២៦:៤១** *ចិត្តដែលមិនទាន់កាត់ស្បែក* សូមមើលការពន្យល់ នក ១៧:១០ ។

**២៦:៤៤** *មិនបោះបង់ចោលគេ* សូមមើល យរ ៣១:៣៧ ៣៣:២៥–២៦ រម ១១:១–២៩ និងការពន្យល់ ។

**២៦:៤៦** នេះជាសេចក្ដីសង្ខេបឡើងវិញ ដែលជាប់ទាក់ទងជាមួយនឹងជំពូក ១–២៦ ។

**២៧:១–៣៤** ជំពូកចុងបញ្ចប់នេះ ជាការសន្យាថានឹងថ្វាយអ្វីៗដល់ព្រះ នូវអ្នកបម្រើ សត្វពាហនៈ ផ្ទះ ឬដីធ្លី ។ ប៉ុន្តែចំពោះការនេះ ត្រូវបានគេផ្ដល់ជាទឹកប្រាក់ជំនួសវិញ ដែលជាសេចក្ដីតម្រូវនៅឆ្នាំទី៥០ ។ ចំពោះដង្វាយសន្យានេះ គឺជាអំណោយដ៏ពិសេសមួយ (សូមធៀប អែលហាណា ១សយ ១:២៨) និងការឈប់ថ្វាយដង្វាយ ហើយនិងការថ្វាយនូវដង្វាយខាងលើ ។

**២៧:២** *មនុស្សណាបន់បំណន់* នៅត្រង់នេះប្រហែលជាគេប្រគល់អ្នកបម្រើឱ្យទៅធ្វើការនៅព្រះវិហារ ប៉ុន្តែលើសជាងនេះទៅទៀតគឺខ្លួនឯង ឬក៏សមាជិកណាមួយក្នុងគ្រួសារ ។ ចាប់តាំងពីពួកលេវី បានទទួលយកការនេះ នោះអ្នកឯទៀតបានផ្ដល់ជារូបិយវត្ថុដែលមានតម្លៃស្មើវិញ ប៉ុន្តែសូមមើល ១សយ ១:១១ និងការពន្យល់ ។

**២៧:៣,២៥** *ប្រាក់រៀលដែលប្រើក្នុងទីបរិសុទ្ធ* សូមមើលការពន្យល់ នក ៣០:១៣ ។

ត្រូវនាំមកនៅចំពោះមុខសង្ឃ ហើយត្រូវឱ្យសង្ឃគិតថ្លៃ[ច]
តាមកំឡាំងរបស់អ្នកដែលជាប់បំណន់នោះវិញ ។
៩បើជាសត្វវិញ គឺជាសត្វដែលគេតែងថ្វាយជាដង្វាយ
ដល់ព្រះយេហូវ៉ា[ឆ]នោះគ្រប់ទាំងដង្វាយយ៉ាងនោះដែលអ្នក
ណាថ្វាយ ត្រូវញែកទុកជាបរិសុទ្ធសំរាប់ព្រះយេហូវ៉ា[ជ]
១០នឹងផ្លាស់ប្តូរសត្វល្អនិងសត្វអាក្រក់ ឬអាក្រក់និងល្អមិន
បានឡើយ[ឈ] ឬបើសិនជាគេចង់ប្តូរសត្វនិងសត្វយ៉ាងណា
នោះទាំងសត្វដើម និងសត្វដែលយកមកប្តូរ ក៏ត្រូវបាន
ញែក ទុកជាបរិសុទ្ធទាំង២រូប ១១បើជាសត្វណាមិនស្អាត[ញ]
ដែលមិនត្រូវថ្វាយដល់ព្រះយេហូវ៉ាឡើយ នោះត្រូវនាំមក
នៅចំពោះមុខសង្ឃ ១២ត្រូវឱ្យសង្ឃគិតតាមដំឡៃដែលសត្វ
នោះល្អឬអាក្រក់ ហើយដំឡៃណាដែលគិតនោះនឹងត្រូវ
បានដូចជាលោកដ៏ជាសង្ឃគិតឱ្យពិត ១៣តែបើគេចង់លោះ
ចេញវិញ[ដ] នោះត្រូវឱ្យថែម១ភាគក្នុង៥លើដំឡៃដែលឯង
បានគិតនោះទៀត[ឋ] ។
១៤បើមនុស្សណាចង់ញែកផ្ទះខ្លួន ទុកជាបរិសុទ្ធសំរាប់
ព្រះយេហូវ៉ា នោះត្រូវឱ្យសង្ឃគិតតាមដំឡៃផ្ទះនោះដែល
ល្អ ឬអាក្រក់ ហើយដំឡៃណាដែលគិតនោះ នឹងត្រូវបានដូច
ជាសង្ឃគិតឱ្យពិត ១៥តែបើអ្នកដែលបានថ្វាយផ្ទះចង់លោះ
មកវិញ[ឌ] នោះត្រូវឱ្យថែមជាប្រាក់១ភាគក្នុង៥លើសពីថ្លៃ
ដែលបានគិតហើយ រួចផ្ទះនោះនឹងបានជារបស់ផងអ្នក
នោះវិញ ។
១៦បើមនុស្សណាចង់ញែកស្រែ ជាកេរ្តិ៍របស់ខ្លួន១
ចំណែកទុកជាបរិសុទ្ធសំរាប់ព្រះយេហូវ៉ា នោះត្រូវឱ្យឯង
គិតតាមដំឡៃដែលសាបព្រោះបាន បើព្រោះស្រូវ១០ថាំង
នោះត្រូវគិតជាប្រាក់៥០រៀល ១៧បើគេថ្វាយស្រែរបស់
គេចាប់តាំងពីឆ្នាំសោមនស្សមក នោះត្រូវតែមានដំឡៃដូច
ជាឯងគិតនោះជារហូតទៅ ១៨តែបើគេថ្វាយស្រែគេរំលង
ប៉ុន្មានក្រោយពីឆ្នាំសោមនស្សមក[ឍ] នោះត្រូវឱ្យសង្ឃបន្ថយ
ដំឡៃដែលបានគិតហើយ តាមចំនួនឆ្នាំដែលនៅសល់[ណ]
រហូតដល់ឆ្នាំសោមនស្ស១ទៀត ១៩តែបើអ្នកដែលបាន
ថ្វាយស្រែ ចង់លោះមកវិញ[ត] នោះត្រូវថែម១ភាគក្នុង៥
លើសពីដំឡៃដែលឯងបានគិតនោះ រួចស្រែនោះនឹងបាន
ជារបស់ផងអ្នកនោះវិញ ២០បើអ្នកនោះមិនលោះទេ ហើយ
គេលក់ទៅឱ្យម្នាក់ទៀត នោះនឹងលោះវិញពុំបានឡើយ
២១គឺកាលណាដល់ឆ្នាំសោមនស្ស[ថ] ដែលស្រែនោះត្រូវរួច
ចេញ នោះនឹងបានដាច់ជាបរិសុទ្ធសំរាប់ព្រះយេហូវ៉ា[ទ] ដូច
ជាស្រែណាដែលបានថ្វាយដល់ព្រះហើយដែរ[ធ] ពួកសង្ឃ
ត្រូវបានស្រែនោះទុកជាកេរ្តិ៍អាករវិញ ២២បើគេញែកស្រែ
ណាដែលគេបានទិញ ដែលមិនមែនជាកេរ្តិ៍អាករខ្លួន ទុក
ជាបរិសុទ្ធសំរាប់ព្រះយេហូវ៉ា ២៣នោះត្រូវឱ្យសង្ឃគិត
ថ្លៃឱ្យអ្នកនោះ តាមដំឡៃដែលបានគិត រហូតដល់ឆ្នាំ
សោមនស្ស[ន] រួចនៅថ្ងៃនោះ គេត្រូវចេញថ្លៃដែលបាន
គិតនោះ ទុកជារបស់បរិសុទ្ធដល់ព្រះយេហូវ៉ា ២៤លុះដល់
ឆ្នាំសោមនស្ស ស្រែនោះនឹងត្រឡប់បានទៅម្ចាស់ដើមវិញ[ប]
គឺបានទៅអ្នកដែលមានស្រែនោះជាកេរ្តិ៍អាករពីដើម ២៥ឯ
ដំឡៃទាំងប៉ុន្មានដែលបានគិតសំរេច នោះត្រូវគិតតាម
ប្រាក់រៀលប្រើក្នុងទីបរិសុទ្ធ[ផ] គឺ១រៀលត្រូវជា១០កាក់[ព] ។
២៦ឯកូនច្បងដែលកើតក្នុងហ្វូងសត្វទាំងប៉ុន្មាន គឺជា
ផលដំបូងថ្វាយព្រះយេហូវ៉ាស្រាប់[ភ] ហើយគ្មានអ្នកណា
នឹងញែកទុកជាបរិសុទ្ធ សំរាប់ព្រះយេហូវ៉ាបានឡើយ ទោះ
បើជាគោឬចៀមក្តី ដ្បិតសត្វនោះជារបស់ផងព្រះយេហូវ៉ា
ហើយ ២៧បើជាកូនរបស់សត្វដែលមិនស្អាត[ម] នោះត្រូវឱ្យ
គេលោះ តាមដំឡៃដែលឯងគិតសំរេច ហើយត្រូវថែម
១ភាគក្នុង៥លើសទៅទៀត ឬបើគេមិនលោះទេ នោះ
ត្រូវឱ្យលក់ទៅតាមដំឡៃដែលឯងគិតនោះ ។
២៨ប៉ុន្តែឯរបស់ដែលបានថ្វាយដាច់ទៅហើយ គឺដែល
អ្នកណាថ្វាយដាច់[យ]ដល់ព្រះយេហូវ៉ា ពីរបស់ទ្រព្យខ្លួនទាំង
ប៉ុន្មាន ទោះជាមនុស្ស ឬសត្វ ឬស្រែចំការដែលជាកេរ្តិ៍
អាករខ្លួនក្តី នោះនឹងលក់ ឬលោះវិញ មិនបានឡើយ
គ្រប់ទាំងរបស់អ្វីដែលថ្វាយដាច់ហើយ នោះត្រូវទុកជា
បរិសុទ្ធបំផុត[រ]សំរាប់ព្រះយេហូវ៉ា ២៩ឯអ្នកណាក្នុងពួក

**២៧:៨** ច ខ.១២,១៤
**២៧:៩** ឆ លប ២៨:២០ លវ ១:២ ជ ខ.២១,២៦,២៨ នក ៤០:៩ ជន ៦:២០ ១៨:១៧ ចទ ១៥:១៩
**២៧:១០** ឈ ខ.៣៣
**២៧:១១** ញ ខ.២៧ នក ១៣:១៣ ជន ១៨:១៥
**២៧:១៣** ដ លវ ២៥:២៥ ឋ លវ ៥:១៦
**២៧:១៥** ឌ ខ.១៣, ២០
**២៧:១៨** ឍ លវ ២៥:១០ ណ លវ ២៥:១៥
**២៧:១៩** ត លវ ២៥:២៥
**២៧:២១** ថ លវ ២៥:១០ ទ ខ.៩ ធ ខ.២៨ ជន ១៨:១៤ អគ ៤៤:២៩
**២៧:២៣** ន លវ ២៥:១៥
**២៧:២៤** ប លវ ២៥:២៨
**២៧:២៥** ផ នក ៣០:១៣ ព ជន ៣:៤៧ អគ ៤៥:១២
**២៧:២៦** ភ នក ១៣:១២
**២៧:២៧** ម ខ.១១
**២៧:២៨** យ ជន ១៨:១៤ យស ៦:១៧-១៩ រ ខ.៩

**២៧:៩** *ជាបរិសុទ្ធ* សូមមើលការពន្យល់ នក ៣:៥ ។ ចំពោះសត្វដែលត្រូវថ្វាយជាយញ្ញបូជាមិនអាចជំនួសអ្វីផ្សេងទេ (ខ.១០) ។ ពួកមនុស្សនៅជំនាន់លោកម៉ាឡាគីបានជ្រើសរើសសត្វមិនល្អមកថ្វាយទ្រង់ ក្រោយពីពួកគេបានបន់ស្រន់ថានឹងថ្វាយសត្វល្អនោះ (សូមមើល មឡ ១:១៣-១៤ និងការពន្យល់) ។ ប្រសិនបើ សត្វមិនស្អាតត្រូវបានពួកគេថ្វាយ នោះពួកគេអាចលោះបាបបានតែ២០ភាគរយប៉ុណ្ណោះ (ខ.១១-១៣) ។

**២៧:១៨** មើលការពន្យល់ ២៥:១៥ ។

**២៧:២៨** *ថ្វាយដាច់ដល់ព្រះយេហូវ៉ា* ការថ្វាយដាច់អ្វីមួយដល់ព្រះយេហូវ៉ា នោះមានអត្ថន័យជ្រៅជាងការថ្វាយវាសម្រាប់ការបូជា ។ ការថ្វាយអ្វីៗដាច់ដល់ព្រះអម្ចាស់របស់ទាំងអស់នោះវានឹងក្លាយទៅជារបស់ព្រះទាំងស្រុង ។ បាបរបស់អេកានជាបាបដ៏ធំធេង ព្រោះគាត់បានលួចរបស់ដែលគេបានថ្វាយដាច់ដល់ព្រះអម្ចាស់ (យស ៧:១១) ។ ពួកមនុស្សដែលបានថ្វាយ ដល់ការបំផ្លាញ នោះជាទូទៅជាឈ្លើយសឹកនៅទឹកដីកាណាន (សូមផ្ទៀប ១សយ ១៥:៣,១៨) ។

**២៧:២៩** លោកសូលបានធ្វើបាប នៅពេលដែលគាត់មិនបានបំផ្លាញស្រុកអាម៉ាលេក (១សយ ជំពូក ១៥) ។

មនុស្ស ដែលបានថ្វាយដាច់ហើយ នោះនឹងលោះចេញវិញ
មិនបានឡើយ គឺត្រូវនៅរហូតដល់ស្លាប់[ល]។
៣០ហើយផលពីដី១ភាគក្នុង១០[វ] ទោះបើជាផល ដែល
កើតពីដី ឬផ្លែឈើ នោះជារបស់ផងព្រះយេហូវ៉ាហើយ
ត្រូវតែបានទុកជាបរិសុទ្ធ[ស]សំរាប់ទ្រង់ ៣១បើអ្នកណាចង់
លោះ[ហ] អ្វីពី១ភាគក្នុង១០ដែលខ្លួនថ្វាយ នោះត្រូវឱ្យថែម១
ភាគក្នុង៥[ឡ]លើសទៅទៀត ៣២ឯហ្វូងសត្វធំ ឬតូច១ភាគ
ក្នុង១០ គឺសត្វណាក៏ដោយដែលចូលទៅក្រោមដំបង[អ] នោះ
ត្រូវជាដង្វាយ១ភាគក្នុង១០ទុកជាបរិសុទ្ធដល់ព្រះយេហូវ៉ា
៣៣មិនត្រូវឱ្យពិនិត្យមើលពីសត្វនោះល្អ ឬអាក្រក់ទេ ក៏មិន
ត្រូវផ្លាស់ប្តូរដែរ[ក] តែបើចង់ប្តូរវិញ នោះទាំងសត្វដើមនឹង
សត្វដែលយកមកប្តូរ ត្រូវបានបរិសុទ្ធដូចគ្នាសត្វទាំងនោះ
នឹងលោះវិញពុំបានឡើយ[ខ]។
៣៤នេះហើយជាក្រិត្យវិន័យទាំងប៉ុន្មាន ដែលព្រះយេ
ហូវ៉ាបានបង្គាប់មកម៉ូសេ ត្រង់ភ្នំស៊ីណាយ[គ] សំរាប់ពួកកូន
ចៅអ៊ីស្រាអែល[ឃ]។/

**២៧:២៩** ល ចទ ៧:២៦
**២៧:៣០** វ ជន ១៨:២៦ ចទ ១២:៦,១៧ ១៤:២២,២៨ ២រប ៣១:៦ នហ ១០:៣៧ ១២:៤៤ ១៣:៥ មឡ ៣:៨ ស ចទ ៧:៦ អរ ៩:២ អស ៦:១៣
**២៧:៣១** ហ លវ ២៥:២៥ ឡ លវ ៥:១៦ **២៧:៣២** អ ទដ ៨៩:៣២ យរ ៣៣:១៣ អគ ២០:៣៧ **២៧:៣៣** ក ខ.១០ ខ ជន ១៨:២១ **២៧:៣៤** គ នក ១៩:១១ ឃ លវ ៧:៣៨ កច ៧:៣៨

**២៧:៣០** *១ភាគក្នុង១០* ចំនួន១០ (សូមមើល ជន ១៨:២១–២៩ ចទ ១២:៦–១៨ ១៤:២២–២៩ ២៦:១២) ។ ការនេះកើតមានលើពួកអ៊ីស្រាអែលមាន៣ចំណុច (១).១ភាគ១០ទូទៅផ្តល់ទៅដល់ពួកលេវី (ជន ១៨:២១) ហើយពួកនេះបានផ្តល់១ភាគ១០ដល់ពួកសង្ឃ (ជន ១៨:២៦) (២).ដង្វាយ១ភាគ១០ជាប់ទាក់ទងទៅនឹងការថ្វាយម្ហូបអាហារដល់ព្រះអម្ចាស់ដែលពួកអ្នកថ្វាយនិងពួកលេវី (ចទ ១៤:២២–២៧) (៣).ដង្វាយ១ភាគ១០បានផ្តល់ជារៀងរាល់៣ឆ្នាំម្តងទៅដល់ពួកអ្នកក្រ (១៤:២៨–២៩) ។
**២៧:៣៤** *ព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ* សូមមើល ១:១ និងការពន្យល់ ៧:៣៧–៣៨ ២៥:១ ២៦:៤៦ ។

# ព្រះគម្ពីរជនគណនា

## សេចក្ដីផ្ដើម

### ចំណងជើង

ឈ្មោះកណ្ឌគម្ពីរជាភាសាអង់គ្លេស (Septuagint) "ស៊ិបទ្យូជីនថ៌" (ការបកប្រែជាភាសាក្រិកមុនជិនាន់ការកកើតពួកគ្រីស្ទបរិស័ទនៃជិនាន់សញ្ញាចាស់) និងស្ថិតនៅលើគោលការណ៍ជំរឿនស្ថិតិប្រជាជន ដែលយើងប្រទះឃើញមាននៅក្នុងជំពូក ១ និង ២៦ ។ ចំណងជើងរបស់កណ្ឌគម្ពីរនេះជា ភាសាហេព្រើរថា (bemidbar) "បេមីឌបារ" មានន័យថា "ស្ថិតក្នុងទីវាលរហោស្ថាន" មាននិយាយរៀបរាប់ជាច្រើននៅក្នុងមាតិការឿងរបស់ខ្លួន ។ ជនគណនា បង្ហាញពីអត្ថន័យរាប់ចំនួននៃថេរវេលា ៣៨ ឆ្នាំ ដែលជនជាតិអ៊ីស្រាអែលវង្វេងផ្លូវនៅក្នុងទីរហោស្ថាន ក្រោយបន្ទាប់មកទៀត មានការដាក់តាំងឡើងនូវសេចក្ដីសញ្ញា ស៊ីណាយ (សូមប្រៀបធៀប ១:១ ជាមួយនឹង ចទ ១:១) ។

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

កណ្ឌគម្ពីរនេះ ជាទូទៅត្រូវបានគេសន្មតថារបស់លោកម៉ូសេ ។ សេចក្ដីសន្និដ្ឋាននេះ ស្ថិតលើគោលការណ៍ (១) សេចក្ដីថ្លែងរៀបរាប់ ដែលជាប់ពាក់ព័ន្ធទៅនឹងសំណេររបស់លោកម៉ូសេ អំពីសកម្មភាព (ឧទាហរណ៍ ៣៣:១–២ ១៧:១៤ ២៤:៤ ៣៤:២៧) និង (២) ការសន្មតិទុកថា ប្រាំឆ្នាំដំបូងនៃកណ្ឌគម្ពីរទាំងឡាយ ជិនាន់បុណ្យឆ្នាំទីហាសិប (the Pentateuch) "ឌីផិនធេធើក" គ្រប់កណ្ឌគម្ពីរជាក្រុមតែមួយ ចេញមកពីអ្នកនិពន្ធតែមួយ ។ សូមពិនិត្យមើលសេចក្ដីណែនាំនៃកណ្ឌគម្ពីរលោកុប្បត្តិ: អ្នកនិពន្ធ និងកាលបរិច្ឆេទ ។

ទោះបីជាយ៉ាងណាក្ដី វាមិនមែនជាការចាំបាច់ទេ ចំពោះអំណះអំណាងថាកណ្ឌគម្ពីរជនគណនា តាំងពីដើមដល់ចប់ ជាស្នាដៃរបស់លោកម៉ូសេទាំងស្រុងនោះ ។ ភាគផ្នែកខ្លះៗនៃកណ្ឌគម្ពីរ ប្រហែលជាត្រូវបានបូកបន្ថែម ដោយពណ៌នា ឬការកែតម្រូវរបស់អ្នកនិពន្ធតាមថេរៈវេលានៃប្រវត្តិសាស្ត្រអ៊ីស្រាអែលក្រោយៗមកទៀត ។ ឧទាហរណ៍ ការជំទាស់តវ៉ាចំពោះការបន្ទាបខ្លួនរបស់លោកម៉ូសេ (១២:៣) ដែលពិបាកនឹងទាក់ទាញទឹកចិត្ត ប្រសិនជាហូរចេញពីបបូរមាត់ផ្ទាល់របស់គាត់មែននោះ ។ ក៏ប៉ុន្តែវាហាក់បីដូចជាសមហេតុផលដែរ ក្នុងការសន្មតិថា លោកម៉ូសេបានសរសេរនូវដំណើររឿងដ៏មានសារៈសំខាន់នៃកណ្ឌគម្ពីរនេះ ។

### ដំណើររឿង

កណ្ឌគម្ពីរជនគណនា មានទំនាក់ទំនងទៅនឹងប្រវត្តិនៃដំណើររបស់ជនជាតិអ៊ីស្រាអែល ពីភ្នំស៊ីណាយទៅកាន់ទីវាលរាបនៃទឹកដីម៉ូអាប់ នៅព្រំដែនទឹកដីកាណាន ។ ក្បួនច្បាប់ជាច្រើនរបស់កណ្ឌគម្ពីរនេះសម្រាប់រាស្ត្រអ៊ីស្រាអែល និងពួកសង្ឃមានលក្ខណៈប្រហាក់ប្រហែលទៅនឹងដំណើររឿងក្នុងកណ្ឌគម្ពីរនិក្ខមនំ និងចោទិយកថា ។ កណ្ឌគម្ពីរ ជនគណនា និយាយប្រាប់ពីការរទូរទាំ និងការបះបោរនៃរាស្ត្ររបស់ព្រះ និងការវិនិច្ឆ័យទោសជាបន្តបន្ទាប់របស់ពួកគេ ។ ចំពោះអស់អ្នកដែលព្រះបានលោះពីទាសភាពនៅស្រុកអេស៊ីព្ទ និងជាមួយពួកអ្នក ដែលព្រះអង្គបានធ្វើសេចក្ដីសញ្ញានៅឯភ្នំស៊ីណាយ ដែលបានឆ្លើយតបដោយមិនមានសេចក្ដីជំនឿ ដោយសម្ដែងនូវការដឹងគុណ និងការស្ដាប់បង្គាប់ ក៏ប៉ុន្តែពុំមានជំនឿណាបន្តិចសោះ មានអ្នកខ្លះទៀតមិនសម្ដែងនូវការដឹងគុណ និងប្រព្រឹត្តនូវអំពើបះបោរម្ដងហើយម្ដងទៀត ដែលបណ្ដាលឱ្យកើតជាការបដិសេធន៍នូវការទទួលខុសត្រូវរបស់ខ្លួនយ៉ាងសម្បើម ចំពោះការដណ្ដើមយកទឹកដីកាណាន (ជំពូក ១៤) ។ សហគមន៍ ដែលបាត់បង់នូវសេចក្ដីសង្គ្រោះ និងភាគចំណែកនៅក្នុងទឹកដីសន្យា ។ ពួកគេត្រូវបានដាក់ទោសឱ្យរស់នៅពេញមួយជីវិតរបស់ពួកគេ នៅក្នុងទីរហោស្ថាន បានត្រឹមតែកូនចៅរបស់ពួកគេអាចមានកិច្ចសម្រាប់តាមព្រះបន្ទូលសន្យាថា កូនចៅរបស់ពួកគេដោយពិតៗ (សូមមើលខគម្ពីរជំនួយ ហព ៣:៧–៤:១១) ។

### សេចក្ដីបង្រៀនតាមរបៀបទេវសាស្ត្រ

នៅក្នុងដំណើររឿង ដែលរៀបរាប់ពីប្រវត្តិរបស់ការដើរវង្វេងនៅទីរហោស្ថានរបស់រាស្ត្រអ៊ីស្រាអែល ។ កណ្ឌគម្ពីរជនគណនាច្រើនតែមានការរៀបរាប់ជារបៀបទេវសាស្ត្រ ជាសំខាន់ ។ ក្នុងអំឡុងពេលនៃឆ្នាំទីមួយៗ បន្ទាប់ពីការសង្គ្រោះរបស់រាស្ត្រអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ ប្រជាជាតិនោះបានចូលទៅក្នុងសេចក្ដីសញ្ញាជាមួយនឹងព្រះអម្ចាស់នៅឯស៊ីណាយ ដើម្បីឱ្យក្លាយទៅជារាស្ត្រនៃអាណាចក្ររបស់ផងទ្រង់ ក្នុងចំណោមរាស្ត្រអ៊ីស្រាអែលទាំងនោះ ត្រូវបានជ្រើសរើសដោយព្រះ នាពេលបោះត្រសាលរោងឧបោសថ នេះគឺជាប្រវត្តិ ដែលមាននៅក្នុងកណ្ឌគម្ពីរនិក្ខមនំ ។ ដូចជាការរាប់ចំនួននៃកណ្ឌគម្ពីរជនគណនាចាប់ផ្ដើម ព្រះអម្ចាស់ប្រមូលផ្ដុំ

រាស្ត្រអ៊ីស្រាអែលចូលទៅក្នុងត្រសាលទ័ពមួយ ។ ការចាកចេញពីស៊ីណាយ ពួកគេធ្វើដំណើរុលឆ្ពោះទៅមុខដូចជាកងទ័ពរបស់ផងទ្រង់ធ្វើសញ្ច័យ ដោយមានព្រះអម្ចាស់ទ្រង់នាំមុខ ក្នុងការបង្កើតជាអាណាចក្ររបស់ផងទ្រង់នៅក្នុងទឹកដីសន្យា ដែលស្ថិតនៅក្នុងចំណោមប្រជាជាតិនានា ។ កណ្ឌគម្ពីរមានបង្ហាញរូបគំនូរផែនទីពីអត្តសញ្ញាណរបស់អ៊ីស្រាអែល ដែលព្រះអម្ចាស់បានប្រោសលោះរាស្ត្ររបស់ផងទ្រង់ដោយសេចក្តីសញ្ញា និងការងាររបស់ខ្លួនជារាស្ត្របម្រើរបស់ព្រះ ដែលមានតួនាទីក្នុងការបង្កើតអាណាចក្ររបស់ព្រះនៅលើផែនដីនេះ បំណងព្រះហឫទ័យនៃព្រះនៅក្នុងប្រវត្តិសាស្ត្រនេះ គឺត្រូវបានបើកសម្តែងដោយគ្មានការសង្ស័យអ្វីឡើយៈ ដើម្បីរុករានក្នុងឆាកនៃមនុស្សជាតិ ដែលធ្លាក់ស្រុតចុះ និងបណ្តាលឱ្យមានការប្រោសលោះដល់ស្នាព្រះហស្ត ដែលទ្រង់បានបង្កើតឡើងមកនោះដែរ ពោលគឺបេសកកម្មនៃស្នាព្រះហស្តទ្រង់សម្តែងឡើងចំពោះរាស្ត្រទ្រង់គ្រប់ៗគ្នាទាំងអស់ផងដែរ ។

កណ្ឌគម្ពីរជនគណនាក៏បង្ហាញនូវការវាយផ្ចាលដ៏ខ្លាំងក្លារបស់ព្រះទប់ទល់នឹងរាស្ត្រទ្រង់ណាដែលមិនស្តាប់បង្គាប់ ។ ដោយព្រោះតែការបះបោររបស់ពួកគេ (និងជាពិសេសការឆ្លើយបដិសេធរបស់ប្រជាជាតិក្នុងការធានា ដល់ការដណ្តើមយកទឹកដីកាណាន) រាស្ត្រអ៊ីស្រាអែលបានបោះបង់ចោលព្រះបន្ទូលសន្យា នៃសេចក្តីសញ្ញារបស់ផងព្រះ ។ កណ្ឌគម្ពីរទីបួននៃបុណ្យឆ្នាំទីហាសិប (Pentateuch) "ជិនថេធើក" បង្ហាញឱ្យឃើញនូវការពិតជាក់ស្តែងៈ ព្រះទ្រង់បានរក្សាខ្ជាប់នូវសេចក្តីសញ្ញាជាមួយនឹងអាប់រ៉ាម (លប ជំពូក ១៥,១៧) ព្រះអង្គបានប្រោសរាស្ត្ររបស់ទ្រង់ឱ្យរួចពីទាសករ មាននៅក្នុងកណ្ឌគម្ពីរនិក្ខមនំ (នក ជំពូក ១៤-១៥) ព្រះអង្គបាននាំរាស្ត្រអ៊ីស្រាអែលចូលទៅក្នុងសេចក្តីសញ្ញាជាមួយនឹងអង្គទ្រង់ "ឱ្យបានដូចជារបស់ផងទ្រង់" (នក ជំពូក ១៩) សូមពិនិត្យមើលនូវលក្ខណៈពិសេសត្រង់ (នក ១៩:៥) ហើយព្រះអង្គបានសម្តែងឱ្យឃើញនូវសេចក្តីបរិសុទ្ធរបស់ផងទ្រង់ និងព្រះគុណគ្រប់សណ្ឋានទាំងអស់ ចំពោះការចូលទៅក្នុងវត្តមានព្រះអង្គ (លវ ជំពូក ១-៧) ជាមួយគ្នានេះផងដែរ ព្រះអង្គក៏សម្តែងនូវសេចក្តីក្រោធរបស់ផងទ្រង់ដែរ សេចក្តីក្រោធរបស់ផងទ្រង់ក៏បានកើតមានឡើងដល់រាស្ត្រទ្រង់ណាដែលវិលវល់ក្នុងផ្លូវសាច់ឈាម ក៏ដូចជាមានដល់ប្រជាជាតិណាដែលតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះអង្គដូចជនជាតិអេស៊ីព្ទ និងជនជាតិកាណានជាដើម ។

តួយ៉ាងដូចជាលោកម៉ូសេ ទោះបីលោកជាមហាហោរា និងអ្នកបម្រើសំណប់របស់ព្រះអម្ចាស់ ក៏លោកមិនអាចគេចរួចពីសេចក្តីក្រោធរបស់ព្រះបានឡើយ ដោយព្រោះតែគាត់មិនបានស្តាប់បង្គាប់ព្រះ ។ នៅក្នុងជំពូក ២០ ដែលមានកត់ត្រាពីកំហុសឆ្គងរបស់គាត់ ដោយចាប់ផ្តើមពីកំណត់សម្គាល់ត្រង់កន្លែង នាងម៉ារាម បានស្លាប់ (២០:១) និងកំណត់ត្រាពីសេចក្តីស្លាប់របស់អើរ៉ុន (២០:២២-២៩)។ នៅត្រង់ជំពូកនេះ អស់អ្នកដែលចាំយាមជំនាន់ចាស់បុរាណត្រូវបានវិលងផុតតទៅ គឺចំពោះបុព្វបុរសជំនាន់ដើម ដែលព្រះបានប្រើប្រាស់ពួកគាត់ក្នុងការបង្កើតប្រជាជាតិ និងធ្វើពលីកម្មជីវិតរបស់ខ្លួនមុននឹងប្រជាជាតិខ្លួនចូលទៅក្នុងទឹកដីសន្យា ។

មានការលើកឡើងជាសំណួរៈ តើព្រះបានបង់ប្រជាជាតិនោះទាំងស្រុងតែម្តង ឬ (សូមមើល រម ១១:១) តើព្រះបន្ទូលសន្យារបស់ព្រះអង្គជារឿង ដែលកន្លងផុតទៅហើយឬ? មានផ្នែកមួយ ដែលគួរជាទីសម្គាល់ក្នុងចំណោមផ្នែកទាំងឡាយក្នុងព្រះគម្ពីរ គឺជាការរៀបរាប់របស់បាឡាម ដែលជាសាសន៍ដទៃជាអ្នកទទួលនូវព្រះចេស្តារបស់ព្រះ (ជំពូក ២២-២៤) ដែលជាចម្លើយត្រូវបានបង្ហាញនៅត្រង់កន្លែងនេះ ។ ព្រះអម្ចាស់ធ្វើការតាមវិធីប្រកបដោយព្រះហឫទ័យប្រោសប្រណី និងដោយត្រង់ៗក្នុងការបន្តបង្ហាញនូវភាពស្មោះត្រង់ឥតងាករេ ក្នុងបំណងព្រះហឫទ័យរបស់ផងទ្រង់ចំពោះរាស្ត្រព្រះអង្គណាដែលគ្មានភាពស្មោះត្រង់លើព្រះអង្គក៏ដោយ ។

បាឡាម គឺជាសាសន៍ម៉ូអាប់ ឆ្លើយទៅលោកម៉ូសេ ដែលជាអ្នកសំណប់របស់ព្រះ ។ លោកគឺជាហោរា ដែលគេស្គាល់គ្រប់ទាំងសាសន៍ក្នុងការចែកចាយជំនឿដល់សាសន៍ដទៃ ដោយពន្យល់ប្រាប់ថា ព្រះនៃរាស្ត្រអ៊ីស្រាអែល គឺជាព្រះពិតតែមួយ ដែលព្រះអង្គធ្វើគ្រប់ទាំងអស់បានអំណាចចេស្តារបស់ផងទ្រង់លើសពីអំពើមន្តអាគម ឬ អាបធ្មប់ទៅទៀត ។ នៅក្នុងសេចក្តីរៀបរាប់នៅផ្នែកដើមដំបូង នាពេលដែលបាឡាម បានជួបប្រទះដំបូងបំផុតគឺ តួអង្គព្រះពិតតែមួយក្នុងនិម្មិតទាំងឡាយ ហើយការរៀបរាប់ពីការធ្វើដំណើរដោយជិះសត្វលា (ជំពូក ២២) គាត់ចាប់ផ្តើមរៀនធ្វើទំនាក់ទំនងជាមួយនឹងព្រះពិត ដែលជាគ្រឹះរឹងមាំជាងអ្វីៗទាំងអស់ ដែលគាត់ធ្លាប់បានស្គាល់កន្លងមក ។ នៅពេលដែលគាត់ព្យាយាមដាក់បណ្តាសាដល់រាស្ត្រអ៊ីស្រាអែល តាមការចាក់រុកញុះញង់របស់ស្តេចបាឡាក តែបាឡាមពុំអាចនឹងហើបមាត់និយាយដាក់បណ្តាសាទៅតាមចិត្តគាត់បានឡើយ ។ ផ្ទុយទៅវិញ បបូរមាត់របស់គាត់បែរជានិយាយតែព្រះពរដល់រាស្ត្រអ៊ីស្រាអែល និងដាក់បណ្តាសាដល់ខ្មាំងសត្រូវរបស់រាស្ត្រអ៊ីស្រាអែលវិញ (ជំពូក ២៣-២៤) ។

នៅទីអាសនាទំនាយទាំងប្រាំពីររបស់គាត់បាឡាមប្រកាសនូវមហាព្រះពររបស់ព្រះសម្រាប់រាស្ត្រទ្រង់ (សូមមើល ២៣:២០) ។ ថ្វីបើព្រះពរបាននាំមកនូវអំណរភ្លាមៗក៏ដោយ វាក៏អាស្រ័យដោយជំនឿស្មោះស្ម័គ្ររបស់រាស្ត្រព្រះអង្គ ដែលនៅទីបំផុតប្រាកដជាព្រះពររបស់ព្រះ (សូមមើល ២៣:១៩) ។ ហេតុដូច្នេះហើយកណ្ឌគម្ពីរ ជនគណនា បញ្ជាក់ជាថ្មីម្តងទៀតបំណងព្រះហឫទ័យរបស់ព្រះ

ដែលកំពុងតែកើតមានឡើង ។ ទោះបីការវិនិច្ឆ័យរបស់ព្រះទៅលើរាស្ត្រ ដែលបះបោរក៏ព្រះនៅតែមានព្រះហឫទ័យកំណត់ជាស្រេចនឹងនាំរាស្ត្រអ៊ីស្រាអែលចូលទៅក្នុងទឹកដីសន្យាដែរ ។

សេចក្តីបង្រៀនរបស់កណ្ឌគម្ពីរមានសារៈសំខាន់ជាដរាបនៅអស់ទាំងដំណរៀងរាបតទៅ សម្រាប់រាស្ត្រអ៊ីស្រាអែល និងសម្រាប់ពួកជំនុំផងដែរ (សូមមើល រម ១៥:៤ ១កថ ១០:៦,១១) ។ ព្រះទ្រង់សម្តែងឱ្យឃើញនូវសេចក្តីក្រោធរបស់ផងទ្រង់ ដើម្បីទប់ទល់ជាមួយនឹងរាស្ត្រ ដែលប្រព្រឹត្តនូវអំពើបាប ក៏ប៉ុន្តែព្រះគុណរបស់ផងទ្រង់នៅតែបន្តបង្ហូរយ៉ាងពិតប្រាកដដូចជាពន្លឺ និងបំណងព្រះហឫទ័យរបស់ផងទ្រង់ ដែលមានសេចក្តីប្រោសលោះ ដោយនឹងមិនអាចរំលប់រំលាងបាន ។

បញ្ហាពិសេស ។

ចំនួនមនុស្សប្រុសជាច្រើន ដែលជាប់នៅក្នុងកំណែនទ័ពនៃរាស្ត្រអ៊ីស្រាអែល (សូមមើលគំរូតួលេខក្នុង ១:៤៦ ២៦:៥១) ដែលបានធ្វើឱ្យអ្នកបកស្រាយជាច្រើន មានសេចក្តីងឿងឆ្ងល់ ។ ចំនួននៃមនុស្សប្រុសទាំងនោះ បានមកប្រមូលផ្តុំគ្នា ដើម្បីធ្វើសង្គ្រាម មើលទៅហាក់បីដូចជាទាមទារនូវការ ធ្វើជំរឿនស្ថិតិប្រជាពលរដ្ឋសរុបនៅក្នុងចំនួន ដែលលើសពីធម្មតាមានដល់ទៅ ២.០០០.០០០ ឯណោះ ។ ដូចជាចំនួន ដែលមានបង្ហាញឱ្យឃើញយ៉ាងច្រើនសន្ធឹកសន្ធាប់ក្រៃលែងនាសម័យកាលនោះ សំរាប់ទឹកដីស្នាក់នៅ ក៏សំរាប់ការ ធ្វើដំណើរវិលវល់ក្នុងទីរហោស្ថាន និងស្ថិតក្នុងការប្រៀបធៀបជាមួយនឹងទឹកដីកាណានផងដែរ ។ សូមមើលកំណត់សម្គាល់នៅ ជំពូក ៣:៤៣ ។

មានលទ្ធភាពផ្សេងៗដទៃទៀត ដែលត្រូវបានដាក់ស្នើឡើងដើម្បីដោះស្រាយបញ្ហានេះ ។ មានអ្នកខ្លះបាននឹកគិតថាបរិមាណទាំងនោះអាចត្រូវបានធ្វើឱ្យខូចដល់ការផ្លាស់ប្តូរផ្សេងៗ ។ ទោះបីជាយ៉ាងក៏ដោយ ចំពោះអត្ថបទនាពេលបច្ចុប្បន្នមិនបើកចំហរការសម្ងាត់នៃការលំបាកក្នុងការពឹងផ្អែកលើឯកសារ ដោយភ្ជាប់ជាមួយនឹងចំនួនទាំងនោះ ។

បណ្តាអត្ថបទដទៃផ្សេងៗទៀតបានធ្វើការចាប់អារម្មណ៍ថា ក្នុងព្រះគម្ពីរភាសាហេព្រើរ ចំពោះពាក្យ "ពាន់" អាចមានអត្ថន័យខុសគ្នានៅក្នុងកណ្ឌគម្ពីរនេះ ដោយចាប់ពីពាក្យ ដែលមានន័យលាក់កំបាំងលើចំនួនធម្មតា ។ នៅក្នុងបទគម្ពីរមួយចំនួន ជាឧទាហរណ៍មានពាក្យមួយ ដែលជាពាក្យស្ថិតក្នុងលក្ខណៈបច្ចេកទេសសម្រាប់ចំណោមមនុស្ស ដែលអាចស្មើ ឬមិនអាចស្មើនឹង ១.០០០ (ជាឧទាហរណ៍ យស ២២:១៤ "ការបែងចែកតាមត្រកូ" ១សយ ២៣:២៣ "តាមក្រុមពូជអំបូរ") ។ លើសពីនេះទៀត មានអ្នកខ្លះបានធ្វើការសន្និដ្ឋានដោយឡែកៗថា ពាក្យជាភាសាហេព្រើរនេះមានន័យថា "មេ" (លើសពីនេះទៅទៀតមានអ្នកខ្លះបានធ្វើការសន្និដ្ឋានដោយឡែកៗថា ពាក្យជាភាសាហេព្រើរនេះមានន័យថា "មេ" (មានបង្ហាញក្នុងកណ្ឌព្រះគម្ពីរ លក ៣៦:១៥) ។ តាមន័យនេះ ចំនួនជាតួលេខ ៥៣.៤០០ (ជំពូក ២៦:៤៧) មានន័យថា "មេត្រួតត្រា ចំនួន ៥៣ នាក់ និងបូករួមទាំងបុរសចំនួន ៤០០ នាក់ទៀត" ។ ដូចជាដំណើរការមួយដែលនឹងបង្ហាញឱ្យឃើញនូវចំនួនកាត់បន្ថយសរុបដ៏ច្រើន ក៏ប៉ុន្តែវាគ្រាន់តែជាដំណើរការផ្លាស់ប្តូរពីហេតុការណ៍មួយ ទៅហេតុការណ៍មួយទៀត ដែលអត្ថបទជាភាសាហេព្រើរ មានបន្ថែមនូវពាក្យ "ទាំងពាន់ៗ" ក៏ដូចគ្នានេះដែរក្នុងន័យតែមួយ ក៏ឃើញមាន បន្ថែមនូវពាក្យ "ទាំងរយៗ" ប្រើសម្រាប់ចំនួនបូកសរុបដ៏ធំមួយ ។ ទន្ទឹមគ្នានេះដែរ តាមអត្ថន័យនេះនឹងអាចបង្កើតឱ្យមានចំនួនសមាមាត្រ នៃមេត្រួតត្រាចំពោះទ័ពប្រយុទ្ធកំពូលនៃពួកបុរស (៥៩មេត្រួតត្រាលើបុរស ៣០០ នាក់ ក្នុងពូជអំបូរស៊ីមាន) ។

ជម្រើសផ្សេងមួយទៀត ដើម្បីអានពាក្យជាភាសាហេព្រើរជា "ពាន់" ដែលមានអត្ថន័យពីរថាជា "មេត្រួតត្រា"ផង និងថាជា "១.០០០" ផង តែបើថាមានន័យជាមេត្រួតត្រា ចំនួននោះវាតិចជាងតួលេខ ដែលបានលើកឡើង ។ ជាឧទាហរណ៍ពូជដំណនៃពួកកូនចៅរូបេន ចំនួន ៤៦.៥០០ នាក់ (១:២០) គឺត្រូវអានថាមេត្រួតត្រា ចំនួន ៤៥ នាក់ ហើយនិងប្រុសៗ ដែលអាចចេញទៅច្បាំងបានចំនួន ១.៥០០ នាក់ ដូចជាក្នុងពូជអំបូរ ស៊ីម្មាន មានចំនួន ៥៩.៣០០ នាក់ (១:២៣) គឺត្រូវអានថាមានមេត្រួតត្រា ៥៨ នាក់ និងពួកប្រុសៗដែលអាចចេញទៅច្បាំងបានចំនួន ១.៣០០ នាក់ ។ល។ ប៉ុន្តែនៅក្នុងករណីនេះ ដូចជានៅក្នុងរឿងមុនៗ ចំនួនសរុបទាំងអស់ មាននៅក្នុង ១:៤៦ និង ២:៣២ បើពិនិត្យមើលឱ្យមែនទែនទៅឃើញតួលេខ ដែលយោងខាងលើមានលក្ខណៈលំអៀងគ្នា ចំពោះការយល់ (ប្រហែលជារបៀបសរសេរក្រោយៗមកទៀត) ។

ក៏នៅមានរបៀបមួយបែបផ្សេងទៀត ដែលផ្តោតទៅលើចំនួនរាប់ជាតួលេខសញ្ញា ជាជាងរបៀបដ៏ហ្មត់ចត់តាមបែបគណិតវិទ្យា ។ តាមតម្លៃនៃតួលេខជាតួអក្សរក្នុងព្រះគម្ពីរភាសាហេព្រើ bene yisra´el (ពួកជំនុំនៃកូនចៅអ៊ីស្រាអែល ១:២) ដែលស្មើនឹង ៦០៣ (ចំនួនជាកងពាន់នៃពួកប្រុសៗ ដែលអាចច្បាំងបាន ១:៤៦) ប្រហែលជាអាចចេញមកពីចំនួន ដែលស្មើគ្នានៃតួអក្សរភាសាហេព្រើរ ដែលបានសម្តែងឱ្យឃើញច្បាស់ថា "គឺគ្រប់ទាំងមនុស្ស . . . ដែលអាចនឹងចេញទៅច្បាំងបាន" (១:៣) នេះគឺជានិមិត្តសញ្ញាប្រើប្រាស់សម្រាប់ចំនួន (ដែលហៅថា "gematria") ដែលមិនស្គាល់នៅក្នុងព្រះគម្ពីរ (សូមមើលក្នុង វវ ១៣:១៨) ប៉ុន្តែវាមិនដូចនៅក្នុង

កណ្ឌគម្ពីរជនគណនាទេ ដែលនៅក្នុងកណ្ឌគម្ពីរនោះពុំមានតម្រុយនៃការកំណត់ជាអក្សរសាស្ត្រ ដោយចង្អុលបង្ហាញទិសដៅឡើយ ។ (ក៏មានជម្រើសផ្សេងទៀត ដែលជាជម្រើសមួយប្រកបដោយគំនិតលើសពីធម្មតា ឧ. សូមពិនិត្យមើលកំណត់សម្គាល់ នៅក្នុងកណ្ឌគម្ពីរ ១របា ១២:២៣-២៧) ។

នាពេលដែលបញ្ហានៃចំនួនដ៏ច្រើនលើសលុបនោះមិនបានដោះស្រាយ ឱ្យរួចដោយពេញចិត្តពេញថ្លើមនោះទេ ព្រះគម្ពីរធ្វើការចង្អុលបង្ហាញនូវកំណើន ដែលគួរឱ្យកត់សម្គាល់នៃពួកកូនចៅដំណវង្សានុវង្សរបស់លោកយ៉ាកុបក្នុងអំឡុងពេលបួនសតវត្សនៃការឈប់សំចតស្នាក់នៅជាបណ្តោះអាសន្ននៅក្នុងស្រុកអេស៊ីព្ទ (សូមពិនិត្យមើល នក ១:៧-១២) ។ ពួកកូនចៅអ៊ីស្រាអែលក៏បានកើតមានសេចក្តីលំបាកវេទនា ក្នុងនេះមានចំនួនដ៏សន្ធឹកសន្ធាប់ ក៏បានបង្កើតជាការអស្ចារ្យរបស់ព្រះសម្រាប់រាស្ត្ររបស់ផងទ្រង់ ក្នុងអំឡុងពេលដែលពួកគេបានរស់នៅក្នុងទីរហោស្ថាន (សូមពិនិត្យមើលកំណត់ចំណាំនៅត្រង់ ១:៤៦) ។

### រចនាសម្ព័ន្ធ និងគម្រោងសង្ខេប

កណ្ឌគម្ពីរត្រូវបានចែកចេញជាបីផ្នែកសំខាន់ៗ ដោយផ្អែកតាមទីភូមិសាស្ត្ររបស់អ៊ីស្រាអែល ។ រាល់ផ្នែកនីមួយៗ ក្នុងចំណោមនោះ មានផ្នែកពីរលើកមកបង្ហាញឡើងដោយបំបែកជាក្រុមៗទៀតគឺ (១) រាស្ត្រអ៊ីស្រាអែលស្ថិតនៅឯភ្នំស៊ីណាយ ដែលត្រៀមរៀបចំចេញដំណើរទៅឯទឹកដីសន្យា (១:១-១០:១០) បន្តការធ្វើដំណើរពីភ្នំស៊ីណាយទៅកាន់កាដេស (១០:១១-១២:១៦) (២) កូនចៅអ៊ីស្រាអែល នៅឯកាដេសពន្យាពេលរហូតដល់កើតជាលទ្ធផលនៃការបះបោរ (១៣:១-២០:១៣) កូនចៅអ៊ីស្រាអែលបន្តដំណើរពីកាដេសទៅកាន់វាលស្រុកម៉ូអាប់ (២០:១៤-២២:១), (៣)កូនចៅអ៊ីស្រាអែលតម្លើងត្រសាលនៅត្រង់វាលនៃស្រុកម៉ូអាប់ ការប្រមើមើលពីការធ្វើសញ្ជ័យយកទឹកដីសន្យា (២២:២-៣២:៤២) ដែលមានរៀបរាប់ប្រាប់នៅក្នុងសេចក្តីបន្ថែមគ្រប់រឿងរ៉ាវនានា (ជំពូក ៣៣-៣៦) ។

I. រាស្ត្រអ៊ីស្រាអែលនៅឯភ្នំស៊ីណាយរៀបចំចេញដំណើរទៅកាន់ទឹកដីសន្យា (១:១-១០:១០) ។
- ១. ការបញ្ជាឱ្យរាប់ចំនួនមនុស្ស (ជំពូក ១-៤)
  - ក. ចំនួនប្រុសពីពូជអំបូរនីមួយៗ ដែលមកប្រមូលផ្តុំគ្នាចេញទៅច្បាំងបាន ។
  - ខ. ទីកន្លែងដែលពូជអំបូរនីមួយៗ ដំឡើងត្រសាលជុំវិញរោងឧបោសថ ហើយចេញដើរទៅតាមរបៀប(ជំពូក ២)
  - គ. ទីកន្លែងរបស់ពួកលេវី ដើម្បីនឹងធ្វើការងារ ដែលត្រូវខាងរោងឧបោសថ និងចំនួនពួកលេវីព្រមទាំងញែកកូនច្បងក្នុងសាសន៍អ៊ីស្រាអែលចេញ (ជំពូក ៣) ។
  - ឃ. ចំនួនរបស់ពួកលេវីនៅក្នុងការងារបម្រើថ្វាយព្រះអម្ចាស់នៅរោងឧបោសថ (ជំពូក ៤) ។
- ២. ការបញ្ជាឱ្យមានការសម្អាតដល់ពួកកូនចៅអ៊ីស្រាអែល(ជំពូក ៥:១-១០:១០) ។
  - ក. ការល្បងលដើម្បីការសម្អាតនៅក្នុងច្បាប់នៃសេចក្តីប្រច័ណ្ឌ (ជំពូក ៥)
  - ខ. ពួកនាសារីតធ្វើការលាបំណន់ និងការឱ្យពររបស់ពួកកូនចៅអើរ៉ុន (ជំពូក ៦)
  - គ. ពួកមេដាកំពូលលើសាសន៍អ៊ីស្រាអែលទាំង ១២ នៅក្នុងថ្ងៃបុណ្យឆ្លងរោងឱ្យបោសថ (ជំពូក ៧)
  - ឃ. ការអុជចង្កៀង និង ការញែកពួកលេវីចេញ (ជំពូក ៨)
  - ង. ការរៀបចំធ្វើបុណ្យរំលង (៩:១-១៤)
  - ច. ពពកដែលគ្របបាំង និង ត្រែ ២ ធ្វើពីប្រាក់ (៩:១៥-១០:១០)

II. ការធ្វើដំណើរចេញពីស៊ីណាយទៅឯការដេស (១០:១១-១២:១៦)
- ១. ការចាប់ផ្តើមចេញដំណើរ (១០:១១-៣៦)
- ២. ការចាប់ផ្តើមនៃសេចក្តីទុក្ខព្រួយ ភ្លើង និងសត្វក្រួច (ជំពូក ១១)
- ៣. ការប្រឆាំងជំទាស់របស់ម៉ារាម និងអើរ៉ុន (ជំពូក ១២)

III. រាស្ត្រអ៊ីស្រាអែលនៅត្រង់កាដេស ពន្យាពេលរហូតដល់កើតជារឿយៗបះបោរ (១៣:១-២០:១៣)
- ១. អ្នកសង្កេតការណ៍ទាំង ១២ នាក់ និងសេចក្តីរាយការណ៍ច្របូកច្របល់គ្នាអំពីទឹកដីដ៏ល្អ (ជំពូក ១៣)
- ២. ការបះបោររបស់រាស្ត្រអ៊ីស្រាអែលប្រឆាំងនឹងមហាបេសកកម្មរបស់ព្រះ និងការបរាជ័យរបស់ពួកគេ(ជំពូក ១៤)
- ៣. ការប្រមូលផ្តុំច្បាប់សម្រាប់ការថ្វាយដង្វាយ ថ្ងៃឈប់សម្រាក និងរំយោលនៅជាយអាវ (ជំពូក ១៥)
- ៤. ការបះបោររបស់កូរេ និងបក្សពួកខ្លួន (ជំពូក ១៦)

៥. ការដុះពក ប៉ិចឡើងជាពន្លកនៃដំបងរបស់អើរ៉ុនៈ ទីសម្គាល់ទាស់នឹងពួកអ្នកដែលចង់បះបោរ (ជំពូក ១៧)
៦.ការទទួលខុសត្រូវរបស់ពួកសង្ឃ ការរក្សាបញ្ញើនៃអាសនានៅក្នុងត្រសាលជំនុំ និងការរក្សាការងារជាសង្ឃ (ជំពូក ១៨)
៧. គោក្រមុំសម្បុរទង់ដែង និងទឹកញែកជាស្អាត (ជំពូក ១៩)
៨. អំពើបាបរបស់លោកម៉ូសេ (២០:១-១៣)

IV. ការធ្វើដំណើរចេញពីការដេសទៅឯត្រង់វាលនៃស្រុកម៉ូអាប់ (២០:១៤-២២:១)
១. ការទប់ទល់របស់ស្រុកអេដំម (២០:១៤-២១)
២. មរណៈភាពរបស់អើរ៉ុន (២០:២២-២៩)
៣. ការបំផ្លាញចំពោះស្តេចអើរ៉ាត (២១:១-៣)
៤. រូបពស់លង្ហិន (២១:៤-៩)
៥. ចម្រៀងច្រៀងសរសើរអណ្តូង និងដំណើរឆ្ពោះទៅស្រុកម៉ូអាប់ (២១:១០-២០)
៦. ការបរាជ័យរបស់ស្តេចស៊ីហុន និងស្តេចអុក (២១:២១-៣៥)
៧. រាស្ត្រអ៊ីស្រាអែលវិលត្រឡប់ទៅឯស្រុកម៉ូអាប់ (២២:១)

V. រាស្ត្រអ៊ីស្រាអែលនៅត្រង់វាលនៃស្រុកម៉ូអាប់ ស្ថិតក្នុងក្តីសង្ឃឹមក្នុងការចាប់យកទឹកដីសន្យា(២២:២-៣២:៤២)
១. បាឡាកនៃសាសន៍ម៉ូអាប់ជួលបាឡាមឱ្យដាក់បណ្តាសា ដល់ពួកកូនចៅអ៊ីស្រាអែល (២២:២-៤១)
២. បាឡាមឱ្យពរដល់រាស្ត្រអ៊ីស្រាអែល គ្រប់ទាំងប្រាំពីរពាក្យ (ជំពូក ២៣-២៤)
៣. ព្រះបាល-ពេអរ និងការបែរចេញពីជំនឿលើព្រះយេហូវ៉ារបស់រាស្ត្រអ៊ីស្រាអែល (ជំពូក ២៥)
៤. ការរាប់ចំនួនលើកទីពីរ (ជំពូក ២៦)
៥. ការណែនាំសម្រាប់មនុស្សថ្មីជំនាន់ក្រោយៗមកទៀត (ជំពូក ២៧-៣០)
ក. កេរ្តិ៍អាករសម្រាប់ពួកស្រី (២៧:១-១១)
ខ. អ្នកដែលទទួលបានជ័យជម្នះចំពោះមុខលោកម៉ូសេ (២៧:១២-២៣)
គ. ព្រះយេហូវ៉ាទ្រង់បង្គាប់ឱ្យនឹកចាំនឹងថ្វាយដង្វាយដល់ព្រះ (២៨:១-១៥)
ឃ. ព្រះយេហូវ៉ាទ្រង់បង្គាប់ឱ្យនឹកចាំធ្វើពិធីបុណ្យផ្សេងៗ (២៨:១៦-២៩:៤០)
ង. ព្រះយេហូវ៉ាទ្រង់បង្គាប់មកក្នុងការស្បថ (២៨:១៦-២៩:៤០)
ច. ព្រះយេហូវ៉ាទ្រង់បង្គាប់មកក្នុងការស្បថ (ជំពូក ៣០)
៦. ការធ្វើសង្គ្រាមប្រឆាំងនឹងសាសន៍ម៉ាឌាន (ជំពូក ៣១)
៧. ការបោះទីតាំងរបស់ពូជអំបូរមុនឆ្លងកាត់ទន្លេយ័ដាន់ (ជំពូក ៣២)

VI. ដំណាក់កាលនីមួយៗដែលបែកចេញទៅតាមរឿងផ្សេងៗពីគ្នា (ជំពូក ៣៣-៣៦)
១. ដំណាក់កាលនៃការធ្វើដំណើរ (ជំពូក ៣៣)
២. ទឹកដីនៃមរដក (ជំពូក ៣៤-៣៥)
៣. កេរ្តិ៍អាករសម្រាប់ស្ត្រី (ជំពូក ៣៦)

## ការធ្វើជំរឿន

**១** ១នៅថ្ងៃដំបូង ខែពិសាខ[ក] ក្នុងឆ្នាំទី២ ចាប់តាំងពីគេ
ចេញពីស្រុកអេស៊ីព្ទមក[ខ] នោះព្រះយេហូវ៉ាទ្រង់បង្គាប់ដល់
ម៉ូសេ ក្នុងត្រសាលជំនុំ[គ]នៅទីរហោស្ថានស៊ីណាយ[ឃ]ថា ២ចូរ
ឱ្យរាប់ចំនួនពួកជំនុំ[ង] នៃកូនចៅអ៊ីស្រាអែលទាំងអស់ តាម
គ្រួសារ[ច] តាមវង្សានុវង្សរបស់ឪពុកគេ គឺគ្រប់ទាំងមនុស្ស
ប្រុសៗ តាមឈ្មោះគេ[ឆ] ៣ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅ
លើ[ជ] គឺគ្រប់ទាំងមនុស្សក្នុងសាសន៍អ៊ីស្រាអែល ដែលអាច
នឹងចេញទៅច្បាំងបាន[ឈ] នោះឯង ហើយនិងអើរ៉ុន[ញ] ត្រូវ
រាប់គេតាមពួកកងរបស់គេ ៤ហើយត្រូវឱ្យមានម្នាក់ៗពី
គ្រប់ទាំងពូជអំបូរទាំងអស់[ដ] ដែលជាមេក្នុងវង្សានុវង្ស
របស់ឪពុកគេ[ឋ] ឱ្យបានធ្វើការជាមួយនឹងឯង[ឌ] ៥ឯមនុស្ស
ដែលត្រូវឈរជាមួយនឹងឯង នោះមានឈ្មោះ[ឍ]ដូច្នេះ គឺ
អេលីសើរ ជាកូនសេដេអើរ[ណ]ពីពូជអំបូររូបេន១[ត] ៦ស្លូមាល
ជាកូនស៊ូរីសាដាយ[ថ] ពីពូជអំបូរស៊ីម្មាន១[ទ] ៧ណាសូនជាកូន
អ័មីនាដាប់[ធ] ពីពូជអំបូរយូដា១[ន] ៨នេថានេល ជាកូនស៊ូហារ[ប]
ពីពូជអំបូអ៊ីសាខារ១[ផ] ៩អេលាប ជាកូនហេលូន[ព] ពីពូជអំបូរ
សាប់យូល៉ូន១[ភ] ១០ឯពួកកូនចៅយ៉ូសែប គឺអេលីសាម៉ា ជា
កូនអាំមីហ៊ូត[ម] ពីពូជអំបូរអេប្រាអិម១[យ] និងកាម៉ាលាល ជា
កូនផ្ដាសើរ[រ]ពីពូជអំបូរម៉ាន៉ាសេ១[ល] ១១អ័ប៊ីដាន ជាកូនគីដា
ហូនី[វ] ពីពូជអំបូរបេនយ៉ាមីន១[ស] ១២អ័ហ៊ីយេសើរ ជាកូនអាំមី
សាដាយ[ហ] ពីពូជអំបូរដាន់១[ឡ] ១៣ប៉ាគីហ៊ាល ជាកូនអុក្រាន[អ]
ពីពូជអំបូរអេសើរ១[ក] ១៤អេលាសាប់ ជាកូនដេហ៊ូអែល[ខ]
ពីពូជអំបូរកាឌ់១[គ] ១៥អ័ហ៊ីរ៉ា ជាកូនអេណាន់[ឃ] ពីពូជអំបូរ
ណែបថាលី១[ង] ១៦នេះហើយជាពួកអ្នកដែលបានហៅពីពួក
ជំនុំមក សុទ្ធតែជាកំពូល[ច]លើពូជអំបូរនៃពួកឰយុកោ[ឆ]គេ
រៀងខ្លួន គឺជាមេលើទាំងពាន់ៗនៃសាសន៍អ៊ីស្រាអែល[ជ]
១៧ម៉ូសេនិងអើរ៉ុន ក៏យកមនុស្សទាំងនេះ ដែលបានចេញ
ឈ្មោះហើយនោះ ១៨នាំគ្នាទៅហៅពួកជំនុំឱ្យប្រជុំទាំងអស់
នៅថ្ងៃទី១ ក្នុងខែពិសាខនោះឯង[ឈ] ហើយគេក៏ប្រាប់ពី
ក្រសែរបស់ខ្លួនទាំងប៉ុន្មាន[ញ]តាមគ្រួសារតាមវង្សានុវង្ស
របស់ឪពុកគេ[ដ] ឱ្យត្រូវនឹងចំនួនឈ្មោះគេចាប់តាំងពីអាយុ
២០ឆ្នាំឡើងទៅលើ[ឋ]គ្រប់ៗគ្នា ១៩ម៉ូសេបានរាប់[ឌ]ចំនួន
បណ្ដាជនទាំងឡាយនៅទីរហោស្ថានស៊ីណាយ ដូចជាព្រះ

**១:១** ក ខ.១៨ ខ នក ៦:១៤ គ ខ.១៨ ឃ នក ១៩:១
**១:២** ង នក ៣០:១១–១៦ ច ខ.១៨ ឆ ជណ ៣:៤០
**១:៣** ជ នក ៤:១៤ ជន ១៧:៣ ឈ នក ៣០:១៤ ញ ខ.២០ ជន ២៦:២ យស ៥:៤ ១រប ៥:១៨
**១:៤** ដ លវ ២៤:១១ យស ៧:១ ឋ ខ.១៦ ជន ៧:២ ៣០:១ ៣១:២៦ ឌ នក ១៨:២១ ជន ៣៤:១៨ ចទ ១:១៥ យស ២២:១៤
**១:៥** ឍ ជន ១៧:២ ណ ជន ២:១២ ៧:៣៦,៤១ ១០:១៩ ត លប ២៩:៣២ វវ ៧:៥
**១:៦** ថ ជន ២:១២ ៧:៣៦,៤១ ១០:១៩ ទ ខ.២២ ជន ២៥:១៤ ១:៧ ធ នក ៦:២៣ ជន ៧:១២ ជន ៤:២០ ១រប ២:១០ មថ ១:៤ លក ៣:៣២ ន ខ.២៦ លប ២៩:៣៥ ទដ ៧៨:៦៨ ១:៨ ប ជន ២:៥ ៧:១៨ ផ លប ៣០:១៨ ជន ១០:១៥ ១:៩ ព ជន ២:៧ ៧:២៤ ភ ខ.៣០ ជន ១០:១៦ ១:១០ ម ខ.៣២ យ ជន ២:១៨ ៧:៤៨,៥៣ ១០:២២ ១:១០ រ ជន ២:២០ ៧:៥៤ ល ខ.៣៤ ជន ១០:២៣ ១:១១ វ ជន ២:២២ ៧:៦០ ទដ ៦៨:២៧ ស ជន ១០:២៤ ១:១២ ហ ជន ២:២៥ ៧:៦៦ ១០:២៥ ឡ ខ.៣៨ ១:១៣ អ ជន ២:២៧ ៧:៧២ ក ខ.៤០ ជន ១០:២៦ ១:១៤ ខ ជន ២:១៤ ៧:៤២ គ ខ.២៤ ជន ១០:២០ ១:១៥ ឃ ជន ២:២៩ ៧:៧៩ ង ខ.៤២ ជន ១០:២៧ ១:១៦ ច នក ១៨:២៥ ឆ ជន ៣២:២៨ ជ ខ.៤ **១:១៨** ឈ ខ.១ ញ អរ ២:៥៩ ហព ៧:៣ ដ ខ.២ ឋ នក ៣០:១៤
**១:១៩** ឌ នក ៣០:១២ ជន ២៦:៦៣ ៣១:៤៩

---

**១:១** *នៅថ្ងៃដំបូង ខែពិសាខ ក្នុងឆ្នាំទី២* គឺមានរយៈ១៣ខែក្រោយពីការចាកចេញពីប្រទេសអេស៊ីព្ទ នេះហើយគឺជាព្រឹត្តិការណ៍នៅក្នុងគម្ពីរជនគណនាក៏បានចាប់ផ្ដើម ។ ពួកអ៊ីស្រាអែលបានចំណាយពេលក្នុងឆ្នាំមុនៗ នៅត្រង់តំបន់ភ្នំស៊ីណាយ ដើម្បីទទួលក្រឹត្យវិន័យ និងកសាងត្រសាលជំនុំ ។ នៅពេលនេះពួកបណ្ដាជនត្រូវបានពង្រឹងស្មារតីយ៉ាងខ្លាំង ដូចជាកម្លាំងយោធាសម្រាប់ដើរក្បួនដង្ហែរ ។ ព្រឹត្តិការណ៍នៃកំណត់កាលបរិច្ឆេទចាប់ពីការចេញដំណើរពីស្រុកអេស៊ីព្ទ (១ពវ ៦:១ និងការពន្យល់) គឺស្រដៀងគ្នានឹងការកំណត់កាលបរិច្ឆេទរបស់គ្រីស្ទបរិស័ទនាសម័យនេះ ដោយយោងតាមការយាងមកចាប់កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ (មុន គ.ស និងក្រោយ គ.ស) ការចេញដំណើរពីប្រទេសអេស៊ីព្ទ គឺជាសកម្មភាពដ៏អស្ចារ្យ នៃការប្រោសលោះរាស្ត្ររបស់ព្រះចេញពីចំណងនៃទាសករ ។ *ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេ* មានការបញ្ជាក់មួយយ៉ាងច្បាស់ នៅក្នុងចំណោមការបញ្ជាក់នានាដែលបានចែងនៅក្នុងគម្ពីរជនគណនានេះ គឺថាព្រះអម្ចាស់ទ្រង់មានបន្ទូលមកកាន់លោកម៉ូសេដោយផ្ទាល់ ហើយតាមរយៈលោកម៉ូសេមកកាន់ពួកអ៊ីស្រាអែល ។ ចាប់តាំងពីដើមដំបូងរហូតដល់ទីចុងបញ្ចប់ (៣៦:១៣) ពាក្យនេះបានពោលលើសពី១៥០ដង ដោយប្រើមធ្យោបាយជាង២០របៀបផ្សេងៗគ្នា ។ នៅត្រង់ ១២:៦–៨ ព្រះអម្ចាស់បានប្រើលោកម៉ូសេឱ្យធ្វើជាហោរារបស់ទ្រង់ (មើលការពន្យល់ក្នុងខនោះ) ។ *ត្រសាលជំនុំ* គឺជាទីលានប្រជុំ ។ *ទីរហោស្ថានស៊ីណាយ* គឺជាឈ្មោះជាភាសាហេព្រើរ ដែលគេស្គាល់ជាទូទៅមួយនៅក្នុងគម្ពីរជនគណនា ។

**១:២** *ចូរឱ្យរាប់* ត្រង់ចំនុចនេះ ព្រះគម្ពីរភាសាហេព្រើរ ប្រើជាពហុវចនៈ ដែលសំដៅទៅលើក្រុមគ្រួសារលោកម៉ូសេ និងលោកអើរ៉ុនចូលរួមជាមួយគ្នា ដើម្បីបំពេញកាតព្វកិច្ចរួមគ្នា (ខ.៣ "ឯងហើយនិងអើរ៉ុន") ប៉ុន្តែកិច្ចការដែលទទួលខុសត្រូវសំខាន់នោះ គឺលើលោកម៉ូសេ ។ *ចំនួន* ចំណុចសំខាន់នៃការរាប់ចំនួននេះ គឺដើម្បីបង្កើតជាកម្លាំងទាហានពុំមែនជាផ្នែកសង្គមនយោបាយ ឬការដកហូតពន្ធនោះទេ ។

**១:៣** *ដែលអាចចេញទៅច្បាំងបាន* នេះគឺជាការទទួលបានលទ្ធផលនៃការរាប់ចំនួនមនុស្ស ។ ឃ្លានេះមានរហូតដល់ទៅ១៤ដងនៅក្នុងជំពូក១ ហើយនិងមានម្ដងទៀតនៅក្នុង ២៦:២ (មើលការពន្យល់ ២៦:១–៥១) ។

**១:៤** *មានម្នាក់ៗពីគ្រប់ទាំងពូជអំបូរទាំងអស់* នេះហើយគឺជាតំណាងរបស់ពូជអំបូរនីមួយៗក្នុងការជួយដល់លោកម៉ូសេ និងលោកអើរ៉ុនហើយការរាប់ចំនួននោះ គឺជាប់ទាក់ទងទៅនឹងភាពយុត្តិធម៌សម្រាប់មនុស្សទាំងអស់ ។

**១:៥–១៦** ឈ្មោះនៃបុរសទាំងនេះ និងឃើញម្ដងទៀតនៅក្នុងជំពូក ២,៧,១០ ឈ្មោះភាគច្រើនមានជាប់ទាក់ទងទៅនឹងព្រះនាមរបស់ព្រះ ។ ពូជអំបូរលេវីពុំមាននៅក្នុងបញ្ជីឈ្មោះនេះទេ (មើលការពន្យល់ ខ.៤៧–៥៣) ។

**១:១៩** *ម៉ូសេបានរាប់ចំនួនបណ្ដាជនទាំងឡាយនៅទីរហោស្ថានភ្នំស៊ីណាយ* ត្រង់នេះគឺជាសេចក្ដីសង្ខេបតែប៉ុណ្ណោះ ឯសេចក្ដីលំអិត គឺឃើញមាននៅក្នុង ខ.២០–៤៣ ។

យេហូវ៉ាបានបង្គាប់មក ។
[២០]ឯពូជដំណនៃពួកកូនចៅរូបេន[ឍ] ដែលជាកូនច្បង[ណ]
របស់អ៊ីស្រាអែល តាមគ្រួសារ តាមវង្សានុវង្សរបស់ឪពុក
គេ តាមចំនួនឈ្មោះគេរៀងខ្លួន គឺប្រុសៗទាំងប៉ុន្មាន ចាប់
តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាចនឹង
ចេញទៅច្បាំងបានគ្រប់ៗគ្នា [២១]នោះពួកគេដែលបានរាប់
ក្នុងពូជអំបូររូបេន[ត] មានចំនួន៤ម៉ឺន៦ពាន់៥00នាក់ ។
[២២]ឯពូជដំណនៃពួកកូនចៅស៊ីម្មាន[ថ] តាមគ្រួសារតាម
វង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួន គឺ
ប្រុសៗទាំងប៉ុន្មាន ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជា
មនុស្សដែលអាចនឹងចេញទៅច្បាំងបានគ្រប់ៗគ្នា [២៣]នោះ
ពួកគេ ដែលបានរាប់ហើយ ក្នុងពូជអំបូរស៊ីម្មាន មានចំនួន
៥ម៉ឺន៩ពាន់៣00នាក់[ទ] ។
[២៤]ឯពូជដំណនៃពួកកូនចៅកាឌ់[ធ] តាមគ្រួសារ តាមវង្សា
នុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួន ចាប់តាំង
ពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាចនឹងចេញ
ទៅច្បាំងបានគ្រប់ៗគ្នា [២៥]នោះពួកគេដែលបានរាប់ក្នុង
ពូជអំបូរកាឌ់[ន] មានចំនួន៤ម៉ឺន៥ពាន់៦៥0នាក់ ។
[២៦]ឯពូជដំណនៃពួកកូនចៅយូដា[ប] តាមគ្រួសារ តាម
វង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួន ចាប់
តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាចនឹង
ចេញទៅច្បាំងបានគ្រប់ៗគ្នា [២៧]នោះពួកគេដែលបានរាប់
ហើយក្នុងពូជអំបូរយូដា[ផ] មានចំនួន៧ម៉ឺន៤ពាន់៦00នាក់ ។
[២៨]ឯពូជដំណនៃពួកកូនចៅអ៊ីសាខារ[ព] តាមគ្រួសារតាម
វង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួនចាប់
តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាចនឹង
ចេញទៅច្បាំងបានគ្រប់ៗគ្នា [២៩]នោះពួកគេដែលបានរាប់
ហើយ ក្នុងពូជអំបូរអ៊ីសាខារ[ភ] មានចំនួន៥ម៉ឺន៤ពាន់៤00
នាក់[ម] ។
[៣០]ឯពូជដំណនៃពួកកូនចៅសាប់យូល៉ូន[យ]តាមគ្រួសារតាម
វង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួន ចាប់
តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាចនឹង
ចេញទៅច្បាំងបានគ្រប់ៗគ្នា [៣១]នោះពួកគេដែលបានរាប់
ហើយក្នុងពូជអំបូរសាប់យូល៉ូន មានចំនួន៥ម៉ឺន៧ពាន់៤00
នាក់[រ] ។
[៣២]ឯពួកកូនចៅយ៉ូសែប[ល] គឺក្នុងពូជដំណនៃពួកកូនចៅ
អេប្រាអិម[វ] តាមគ្រួសារ តាមវង្សានុវង្សរបស់ឪពុកគេ តាម
ចំនួនឈ្មោះគេរៀងខ្លួន ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅ
លើ ជាមនុស្សដែលអាចនឹងចេញទៅច្បាំងបានគ្រប់ៗគ្នា
[៣៣]នោះពួកគេដែលបានរាប់ហើយក្នុងពូជអំបូរអេប្រាអិម[ស]
មានចំនួន៤ម៉ឺន៥00នាក់ ។
[៣៤]ឯពូជដំណនៃពួកកូនចៅម៉ាន៉ាសេ[ហ] តាមគ្រួសារ
តាមវង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀង
ខ្លួនចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែល
អាចនឹងចេញទៅច្បាំងបានគ្រប់ៗគ្នា [៣៥]នោះពួកគេដែល
បានរាប់ហើយ ក្នុងពូជអំបូរម៉ាន៉ាសេ មានចំនួន៣ម៉ឺន២
ពាន់២00នាក់ ។
[៣៦]ឯពូជដំណនៃពួកកូនចៅបេនយ៉ាមីន[ឡ]តាមគ្រួសារ
តាមវង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួន
ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាច
នឹងចេញទៅច្បាំងបានគ្រប់ៗគ្នា [៣៧]នោះពួកគេដែលបាន
រាប់ហើយ ក្នុងពូជអំបូរបេនយ៉ាមីន[អ] មានចំនួន៣ម៉ឺន៥ពាន់
៤00នាក់ ។
[៣៨]ឯពូជដំណនៃពួកកូនចៅដាន់[ក] តាមគ្រួសារ តាម
វង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួន ចាប់
តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាចនឹង
ចេញទៅច្បាំងបានគ្រប់ៗគ្នា [៣៩]នោះពួកគេដែលបានរាប់
ក្នុងពូជអំបូរដាន់ មានចំនួន៦ម៉ឺន២ពាន់៧00នាក់[ខ] ។

**១:២០** ឍ លប ២៩:៣២ ៤៦:៩ វវ ៧:៥ ណ លប ១០:១៥ **១:២១** ត ជន ២៦:៧ **១:២២** ថ លប ២៩:៣៣ វវ ៧:៧ **១:២៣** ទ ជន ២៦:១៤ **១:២៤** ធ លប ៣០:១១ យស ១៣:២៤–២៨ វវ ៧:៥ **១:២៥** ន លប ៤៦:១៦ ជន ២៦:១៨ ១រប ៥:១១ **១:២៦** ប ឧ.៧ មថ ១:២ វវ ៧:៥ **១:២៧** ផ ជន ២៦:២២ **១:២៨** ព លប ៣០:១៨ វវ ៧:៧ **១:២៩** ភ លប ៣០:១៨ ម ជន ២៦:២៥ **១:៣០** យ លប ៣០:២០ វវ ៧:៨ **១:៣១** រ ជន ២៦:២៧ **១:៣២** ល លប ៤៩:២៦ វ លប ៤១:៥២ **១:៣៣** ស ជន ២៦:៣៧ ១រប ៧:២០ **១:៣៤** ហ លប ៤១:៥១ វវ ៧:៦ **១:៣៦** ឡ លប ៣៥:១៨ ២រប ១៧:១៧ យរ ៣២:៤៤ អប ១:១៩ វវ ៧:៨ **១:៣៧** អ ជន ២៦:៤១ **១:៣៨** ក លប ៣០:៦ ចទ ៣៣:២២ **១:៣៩** ខ ជន ២៦:៤៣

**១:២០–៤៣** សម្រាប់ពូជអំបូរនីមួយៗបានពោលសារឡើងវិញពីរ១ខ តាមរបៀបដូចតទៅ : (១).ឈ្មោះរបស់ពូជអំបូរ (២).ចំនួនពិតប្រាកដ (៣).ឈ្មោះរបស់ពូជអំបូរម្តងទៀត (៤).ចំនួនសរុបរបស់ពូជអំបូរនោះ ។ ចំនួននៃពូជអំបូរនីមួយៗប្រហែលជាមានត្រឹមតែខ្ទង់រយប៉ុណ្ណោះ (ប៉ុន្តែ ពូជអំបូរកាឌ់វិញ មានរហូតដល់ទៅ៤ម៉ឺន៥ពាន់៦៥0នាក់ "ខ.២៥") ។ មានចំនួនពូជអំបូរស្រដៀងគ្នាបួនដែលមានចំនួនដូចគ្នា នៅក្នុងជំពូក ២ ។ ការរាប់ចំនួននេះបានធ្វើឱ្យមនុស្សមួយចំនួនជឿថា វាជានិមិត្តរូបនៃចំនួនរាប់រយដែលត្រូវបានគេដាក់ជាក្រុមៗ មានចំនួនចាប់ពី២00ទៅ ៧00នាក់ ។ មានខ្លះទៀតបានគិតថា ចំនួនទាំងនេះជាចំនួននៃការរស់ឡើងវិញ ដែលមានជាប់ ទាក់ទងទៅនឹងពាក្យក្នុងព្រះគម្ពីរភាសាហេព្រើរគឺ "រាប់ពាន់"។ នៅក្នុងជំពូកនេះ គេប្រើពាក្យនេះ ក្នុងន័យសំដៅលើចំនួនរាប់ពាន់ដើម្បីសម្រេចគោលដៅ ។

**១:៣២–៣៥** ដោយព្រោះតែកូនចៅអំបូរលេវីត្រូវបានរាប់បញ្ចូល (ខ.៤៧) ។ កូនចៅលោកយ៉ូសែបក៏ត្រូវបានរាប់បញ្ចូលដោយយោងតាមពូជដំណរកូនប្រុសរបស់គាត់ទាំងពីរនាក់ អេប្រាអិម (ខ.៣២–៣៣) ហើយនិងម៉ាន៉ាសេ (ខ.៣៤–៣៥) ។ បើយោងតាមប្រពៃណីនៃចំនួនពូជអំបូរទាំង១២ នោះគឺត្រូវបានថែរក្សាមកដល់បច្ចុប្បន្ន ក៏ដូចជាពូជអំបូររបស់លោកយ៉ូសែបមានចំនួនដល់ទៅពីរដង (លប ៤៩:២២–២៦ ចទ ៣៣:១៣–១៧ ២ពវ ២:៩ និងការពន្យល់) ។

៤០ ឯពូជដំណនៃពួកកូនចៅអេស៊ើរ[គ] តាមគ្រួសារ តាម
វង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួនចាប់
តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាចនឹង
ចេញទៅច្បាំងបានគ្រប់ៗគ្នា ៤១ នោះពួកគេដែលបានរាប់
ហើយក្នុងពូជអំបូរអេស៊ើរ[ឃ] មានចំនួន៤ម៉ឺន១ពាន់៥០០
នាក់ ។

៤២ ឯពូជដំណនៃពួកកូនចៅណែបថាលី[ង] តាមគ្រួសារ
តាមវង្សានុវង្សរបស់ឪពុកគេ តាមចំនួនឈ្មោះគេរៀងខ្លួន
ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ជាមនុស្សដែលអាច
នឹងចេញទៅច្បាំងបានគ្រប់ៗគ្នា ៤៣ នោះពួកគេដែលបាន
រាប់ហើយក្នុងពូជអំបូរណែបថាលី[ច] មានចំនួន៥ម៉ឺន៣ពាន់
៤០០នាក់[ឆ] ។

៤៤ នេះហើយជាពួកអ្នកដែលបានកំណត់រាប់ គឺដែល
ម៉ូសេ និងអើរ៉ុន[ជ] ហើយនិងពួកជាកំពូល លើសាសន៍
អ៊ីស្រាអែលទាំង១២នាក់ ដែលម្នាក់ក្នុងពួកវង្សានុវង្ស
របស់ឪពុកគេនីមួយៗបានកំណត់រាប់ ៤៥ ដូច្នេះពួកកូនចៅ
អ៊ីស្រាអែលទាំងប៉ុន្មាន ដែលគេបានរាប់ហើយ តាម
វង្សានុវង្សរបស់ឪពុកគេ ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅ
លើ[ឈ] ជាពួកសាសន៍អ៊ីស្រាអែល ដែលអាចនឹងចេញទៅ
ច្បាំងបានគ្រប់ៗគ្នា[ញ] ៤៦ នោះរួមគ្នាទាំងអស់ មាន៦សែន
៣ពាន់៥៤០នាក់[ដ] ។

៤៧ តែពួកលេវី[ឋ] តាមពូជអំបូរឪពុកគេ នោះមិនបាន
រាប់[ឌ] ជាមួយគ្នាទេ ៤៨ ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូល
នឹងម៉ូសេថា ៤៩ មានតែពូជអំបូរលេវី១ទេ ដែលឯងមិនត្រូវ
រាប់ ក៏មិនត្រូវកំណត់ឱ្យដឹងចំនួនគេ ក្នុងពួកកូនចៅអ៊ីស្រា
អែលឡើយ ៥០ តែត្រូវឱ្យឯងដំរូវពួកលេវីឱ្យត្រួតលើរោង
ឧបោសថ[ឍ] ផងសេចក្ដីបន្ទាល់[ណ] និងគ្រឿងប្រដាប់ទាំង
ប៉ុន្មាន[ត] ហើយនិងរបស់ទាំងអស់សំរាប់រោងនោះ គឺគេ
ហើយដែលត្រូវលីសែងរោងឧបោសថ និងគ្រឿងប្រដាប់
ទាំងប៉ុន្មាន ហើយគេត្រូវធ្វើការងារក្នុងរោងនោះ ព្រម
ទាំងដំឡើងត្រសាលគេនៅជុំវិញផង ៥១ កាលណារោង
ឧបោសថ[ថ] ត្រូវទៅមុខ[ទ] នោះស្រេចនូវពួកលេវីរុះរើចេញ
ហើយកាលណាត្រូវដំឡើងវិញ នោះក៏ស្រេចនូវពួកលេវី
ដែរ[ធ] បើអ្នកដទៃណាដែលចូលទៅជិត នោះនឹងត្រូវស្លាប់[ន]
៥២ ឯពួកកូនចៅអ៊ីស្រាអែល ត្រូវឱ្យគេដំឡើងត្រសាលគេ
រៀងខ្លួន នៅ១ដុំជាមួយនឹងពួកខ្លួន គឺនៅជិតទង់ជ័យរបស់
ខ្លួនគ្រប់គ្នា តាមពួកកងរបស់ខ្លួន[ប] ៥៣ តែឯពួកលេវីត្រូវ
ដំឡើងត្រសាលរបស់ខ្លួន នៅព័ទ្ធជុំវិញរោងឧបោសថ[ផ]
ផងសេចក្ដីបន្ទាល់វិញ ដើម្បីកុំឱ្យមានសេចក្ដីខ្ញាល់មក[ព] លើ
ពួកជំនុំនៃកូនចៅអ៊ីស្រាអែលឡើយ ហើយត្រូវឱ្យគេរក្សា
រោងឧបោសថផងសេចក្ដីបន្ទាល់នោះ[ភ] ៥៤ ពួកកូនចៅ
អ៊ីស្រាអែលក៏ធ្វើតាមគ្រប់សេចក្ដីទាំងប៉ុន្មាន ដែលព្រះ

**១:៤០** គ លប ៣០:១៣ ជន ២៦:៤៤ វវ ៧:៦ **១:៤១** ឃ ជន ២៦:៤៧ **១:៤២** ង លប ៣០:៨ វវ ៧:៦ **១:៤៣** ច ជន ២៦:៥០ ឆ នក ១:១-៤ **១:៤៤** ជ ជន ២៦:៦៤ **១:៤៥** ឈ ខ.៣ ជន ១៤:២៩ ញ ជន ២:៣២ **១:៤៦** ដ នក ១២:៣៧ ២សយ ២៤:៩ **១:៤៧** ឋ ជន ៣:១៧-២០ ឌ ជន ៤:៣,៤៩ **១:៥០** ឍ នក ២៥:៩ ២៦:១ ណ ១៦:៣៤ កច ៧:៤៤ វវ ១៥:៥ ត ជន ៣:៣១ **១:៥១** ថ នក ២៦:១ ទ ជន ៤:៥ ធ ជន ៣:៣៨ ៤:១៥ ន នក ២១:១២ **១:៥២** ប ជន ១០:១៤ ទដ ២០:៥ ២:៤ ៦:៤ **១:៥៣** ផ ជន ២:១០៣:២៣, ២៩,៣៨ ព លប ១០:៦ ជន ១៦:៤៦ ១៨:៥ ចទ ៩:២២ ភ នក ៣៨:២១ ជន ១៨:២-៤

**១:៤៦** *៦សែន៣ពាន់៥៤០នាក់* នេះគឺជាចំនួនដែលត្រូវបានស្លាប់នៅក្នុងវាលរហោស្ថាន លើកលែងតែយ៉ូស្វេ និងកាលែប ។ ការគណនាចំនួននេះគឺពិតប្រាកដ ហើយស្មុគស្មាញ ។ ចំនួនសរុបនេះវាស្មុគស្មាញណាស់ ដោយសារការប្រមាណវិធីមានពីរបែបៈ (១).បញ្ជីវង្សត្រកូលមួយមាន១២ផ្នែក (ខ.២០-៤៣)ដែលមានចំនួនសរុបនៅក្នុង(ខ.៤៦) ។ (២).ក្រុមមនុស្សដែលមានសមាជិក៣នាក់មួយក្រុម រួមគ្នាបានបួនក្រុម ក្នុងមួយក្រុមៗមានចំនួនសរុបរបស់ខ្លួន ហើយបន្ទាប់មកទៀត ទើបមានការបូកសរុបរួមធំ (២:៣-៣២) ។ តួលេខទាំងនេះក៏មាននៅក្នុង នក ១២:៣៧ ៣៨:២៦ ។ ចំនួនដ៏ច្រើននៃបុរសដែលបានចូលធ្វើជាទាហាន ទាំងនេះគឺចេញមកពីចំនួនសរុបទាំងអស់២លាននាក់នៃប្រជាជននៅក្នុងសហគមន៍ទាំងមូល (មើលសេចក្ដីផ្ដើមត្រង់បញ្ហាពិសេស) ។ នៅក្នុង នក ១:៧ បានពិពណ៌នាអំពីការរីកចម្រើននៃប្រជាជនហេព្រើរ ក្នុងរយៈពេលរស់នៅលើទឹកដីប្រទេសអេស៊ីព្ទ៤០០ឆ្នាំ ។ ពួកគេមានចំនួនយ៉ាងច្រើន ដូច្នេះហើយ ទើបពួកគេមានជាប់ទាក់ទងទៅនឹងការគម្រាមកំហែងផ្នែកសុវត្ថិភាពនៅលើទឹកដីអេស៊ីព្ទ (នក ១:៩-១០,២០) ។ ការរីកចំរើនរបស់អ៊ីស្រាអែលដ៏ច្រើននេះ គឺចេញពីមនុស្សតែ៧០នាក់ប៉ុណ្ណោះពីដំបូងក្នុងប្រទេសអេស៊ីព្ទ (នក ១:៥) ។ នេះគឺជាការបង្ហាញអំពីភស្តុតាងនៃព្រះពរដ៏អស្ចារ្យ និងអំពីភាពស្មោះត្រង់របស់ទ្រង់ក្នុងសេចក្ដីសន្យាជាមួយលោកអ័ប្រាហាំ (សូមមើល លប ១២:២ ១៥:៥ ១៧:៤-៦ ២២:១៧) ។

**១:៤៧** ដោយសារពូជអំបូរលេវីមានតួនាទីបម្រើព្រះអម្ចាស់ ផ្នែកពិធីបុណ្យ និងថែរក្សារោងឧបោសថ នោះពួកគេពុំត្រូវបានរាប់បញ្ចូលឡើយ (មើលការពន្យល់នៅត្រង់ ខ.៣២-៣៥) ។

**១:៥០,៥៣** *សេចក្ដីបន្ទាល់* បញ្ញត្តិទាំងដប់ប្រការបានសរសេរនៅលើផ្ទាំងថ្ម (នក ៣១:១៨ ៣២:១៥ ៣៤:២៩) ដែលត្រូវបានគេដាក់នៅក្នុងហឹប (នក ២៥:១៦,២១ ៤០:២០)ដែលត្រូវបានគេហៅថា "ហឹបនៃសេចក្ដីបន្ទាល់" (នក ២៥:២២ ២៦:៣៣,៣៤ និងមើលការពន្យល់ នក ១៦:៣៤ ២៥:១៦,២២) ។

**១:៥១** *បើអ្នកដទៃណា* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ គេច្រើនតែបកប្រែឃ្លានេះថា "មនុស្សចម្លែក" ឬ"សាសន៍ដទៃ" ដូចជានៅក្នុង អស ១:៧ ហស ៧:៩ ។ ដូច្នេះ មានន័យថា ក្រៅពីពូជអំបូរលេវីនោះពួកអ៊ីស្រាអែលបានចាត់ទុកអ្នកនោះ ជាមនុស្សចម្លែកក្នុងការរៀបចំផ្នែកជំនឿនៅក្នុងរោងឧបោសថ (នក ២៩:៣៣ ៣០:៣៣ លវ ២២:១២) ។ *ស្លាប់* សូមមើល ៣:១០,៣៨ ១៨:៧ ១៦:៣១-៣៣ ១សយ ៦:១៩ ។

**១:៥៣** *ត្រសាលរបស់ខ្លួននៅព័ទ្ធជុំវិញ រោងឧបោសថ* មើល ៣:២១-៣៨ ។ *សេចក្ដីខ្ញាល់* ពួកលេវីបានបង្កើតរបងសម្រាប់ការពារកុំឱ្យពូជអំបូរផ្សេងៗចូលកន្លែងហាមឃាត់ ដើម្បីជៀសវាងពីសេចក្ដីក្រោធរបស់ព្រះ ។

**១:៥៤** *ដែលព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ* នេះហើយគឺជាឃ្លានៃសេចក្ដី

យេហូវ៉ា បានបង្គាប់មកម៉ូសេ គេបានធ្វើសំរេចតាមទាំង
អស់ ។

## ការរៀបចំទីដំឡើងត្រសាលនៃពូជអំបូរ

**២** ១ ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុនថា ២ ត្រូវឱ្យពួកកូនចៅអ៊ីស្រាអែលដំឡើងត្រសាល
នៅក្បែរទង់ជ័យរបស់ខ្លួន តាមគោលដំរុយគ្រួរបស់ឪពុក
ខ្លួន[ក] គេត្រូវនៅជុំវិញ ប្រឈមមុខនឹងត្រសាលជំនុំ ។
៣ ឯពួកដែលដំឡើងត្រសាលនៅទិសឯកើតខាងថ្ងៃរះ
នោះត្រូវជាពួកទង់ជ័យរបស់ទីដំឡើងត្រសាលនៃពូជអំបូរ
យូដាតាមពួកកងគេ ហើយអ្នកដែលជាកំពូលលើពួកកូន
ចៅយូដា នោះគឺជាណាសូន ជាកូនអ័មីណាដាប់[ខ] ៤ ឯពួក
កងរបស់លោក នោះមានចំនួន៧ម៉ឺន៤ពាន់៦00នាក់ តាម
ដែលគេកំណត់រាប់ហើយ ៥ ពួកដែលត្រូវដំឡើងត្រសាល
នៅក្បែរលោក នោះត្រូវជាពូជអំបូរអ៊ីសាខារ[គ] ហើយអ្នក
ដែលជាកំពូលលើពួកកូនចៅអ៊ីសាខារ គឺនេថានេលជាកូន
ស៊ូហារ[ឃ] ៦ ឯពួកកងរបស់លោក នោះមានចំនួន៥ម៉ឺន៤
ពាន់៤00នាក់ តាមដែលគេកំណត់រាប់ហើយ ៧ ពួក១ទៀត
ជាពូជអំបូរសាប់យូឡូន ហើយអ្នកដែលជាកំពូលលើពួក
កូនចៅសាប់យូឡូន គឺអេលាបជាកូនហេឡូន[ង] ៨ ឯពួកកង
របស់លោក នោះមានចំនួន៥ម៉ឺន៧ពាន់៤00នាក់ តាម
ដែលគេកំណត់រាប់ហើយ ៩ អស់ពួកអ្នកដែលបានរាប់
ក្នុងទីដំឡើងត្រសាលរបស់ពួកយូដានេះ រួមទាំងអស់មាន
១សែន៨ម៉ឺន៦ពាន់៤00នាក់តាមពួកកងរបស់គេ ពួកនេះជា
អ្នកដើរមុនគេ[ច] ។
១០ ឯខាងត្បូង[ឆ] នោះត្រូវមានទង់ជ័យរបស់ទីដំឡើង
ត្រសាលនៃពួករូបេន តាមពួកកងរបស់គេ ហើយអ្នកដែល
ជាកំពូលលើពួកកូនចៅរូបេន គឺអេលីស៊ើរ ជាកូន
សេដេអ៊ើរ[ជ] ១១ ឯពួកកងរបស់លោក នោះមានចំនួន៤ម៉ឺន
៦ពាន់៥00នាក់ តាមដែលគេកំណត់រាប់ហើយ ១២ ពួក
ដែលដំឡើងត្រសាលនៅក្បែរលោក នោះត្រូវជាពូជអំបូរ
ស៊ីម្មាន[ឈ] ហើយអ្នកដែលជាកំពូលលើពួកកូនចៅស៊ីម្មាន គឺ
ស្លូមាលជាកូនស៊ូរីសាដាយ[ញ] ១៣ ឯពួកកងរបស់លោក នោះ
មានចំនួន៥ម៉ឺន៩ពាន់៣00នាក់ តាមដែលគេកំណត់រាប់
ហើយ ១៤ ពួក១ទៀតជាពូជអំបូរកាឌ់[ដ] ហើយអ្នកដែលជា
កំពូលលើពួកកូនចៅកាឌ់ គឺអេលាសាប់ជាកូនដេហ៊ូអែល[ឋ]
១៥ ឯពួកកងរបស់លោក នោះមានចំនួន៤ម៉ឺន៥ពាន់៦៥0

**២:២** ក ទដ ៧៤:៤ អស ៣១:៩ យរ ៤:២១
**២:៣** ខ នក ៦:២៣
**២:៥** គ ជន ១០:១៥ ឃ ជន ១:៨
**២:៧** ង ជន ១:៩ ១០:១៦
**២:៩** ច ជន ១០:១៤ ពច ១:១
**២:១០** ឆ ន ១:៥៣ ជ ជន ១:៥
**២:១២** ឈ ជន ១០:១៩ ញ ជន ១:៦
**២:១៤** ដ ជន ១០:២០ ឋ ជន ១:១៤ ១០:២០

ផ្ដើមដែលបណ្ដាលឱ្យពួកអ៊ីស្រាអែលមិនស្ដាប់បង្គាប់ នៅពេលក្រោយៗមកទៀត(ក្នុងគម្ពីរជនគណនា) ហើយក៏ជាពាក្យដែលឱ្យអាសូរដល់អ្នកដែលស្ដាប់បង្គាប់ពីដំបូងៗនោះដែរ ។

**២:១-៣៤** នៅក្នុងជំពូកនេះគឺជារចនាសម្ព័ន្ធដែលត្រូវបានរៀបចំដូចតទៅ:

- សេចក្ដីបង្គាប់សង្ខេប (ខ.១-២)
- សេចក្ដីលំអិតនៃការកាប់សម្លាប់ (ខ.៣-៣៣)
- ត្រសាលនៅភាគខាងកើត (ខ.១០-១៦)
- ត្រសាលនៅភាគខាងត្បូង (ខ.១០-១៦)
- ការដំឡើងត្រសាល និងពួកលេវី (ខ.១៧)
- ត្រសាលភាគខាងលិច (ខ.១៨-២៤)
- ត្រសាលភាគខាងជើង (ខ.២៥-៣១)
- ចំនួនសរុបសង្ខេប (ខ.៣២-៣៣)
- សេចក្ដីសន្និដ្ឋានសង្ខេប (ខ.៣៤)

នៅក្នុងជំពូកទី១ បានប្រាប់អំពីការរីកចម្រើននៃជាតិសាសន៍ ហើយនិងបង្ហាញអំពីទំនាក់ទំនងនៃពង្សាវតារយ៉ាងច្បាស់ទៀតផង ។ នៅក្នុងជំពូកទី២ បានប្រាប់អំពីការរៀបចំជាតិសាសន៍មួយឱ្យមានប្រព័ន្ធតាមលំដាប់ ហើយនិងផ្លូវនៃក្បួនដង្ហែរ ហើយនិងទីតាំងនៃជំរុំក៏ត្រូវបានគេបង្កើតឡើង ។ តួលេខនៅក្នុងជំពូកមួយត្រូវបានធ្វើជាគំរូ ហើយចំនួនអ្នកដឹកនាំដែលត្រូវបានដាក់ឈ្មោះម្ដងទៀតនៅត្រង់នេះ ។

**២:២** *ទង់ជ័យរបស់ខ្លួន* មានន័យថាពូជអំបូរនិមួយៗមានទង់ជ័យរបស់ពួកគេរៀងៗខ្លួន ហើយក្រុមនីមួយៗនៃអំបូរនោះក៏មានទង់ជ័យសំគាល់ក្រុមរបស់គេថែមទៀតផង ។ តាមប្រពៃណីរបស់ពួកយូដាបានបង្ហាញថា ទង់ជ័យនៃអំបូរនីមួយៗគឺមានថ្ម១២ដុំដោយផាត់ពណ៌ផ្សេងៗគ្នា តាមការដាក់ឱ្យរបស់សម្ដេចសង្ឃ នៅលើដើមទ្រូងរបស់ពួកគេ(នក ២៨:១៥-២១) ។ តាមប្រពៃណីដដែលនេះបានឱ្យដឹងទៀតថា ក្រុមនិមួយៗនៃពូជអំបូរទាំង១២ ក៏មានបន្ថែមរូបសត្វផ្សេងៗទៀតផង ដូចជាអំបូរយូដាមានរូបសិង្ហ អំបូររូបេនមានរូបមនុស្សប្រុស អំបូរអេប្រាអិមមានរូបគោឈ្មោល ហើយអំបូរដាន់មានរូបសត្វឥន្ទ្រី(មើលការពិពណ៌នារូបសត្វនៅក្នុង អគ ១:១០ វវ ៤:៧)។ ប៉ុន្តែប្រភពប្រពៃណីទាំងនេះ ពុំមានភស្តុតាងច្បាស់លាស់នោះទេ ។

**២:៣-៧** *ពូជអំបូរយូដា . . . ពូជអំបូរអ៊ីសាខារ . . . ពូជអំបូរសាប់យូឡូន* គឺជាកូនទីបួន ទីប្រាំ និងទីប្រាំមួយរបស់លោកយ៉ាកុប ហើយនិងនាងលេអា ។ វាជាការភ្ញាក់ផ្អើលមួយ ក្នុងការដាក់ឈ្មោះពូជអំបូរទាំងបីនេះនៅខាងលើគេនោះ ព្រោះថាលោករូបេនគឺជាកូនច្បងគេរបស់លោកយ៉ាកុប(១:២០) ។ ជំពូកទី១(សូមមើល ខ.២)"ឯផែនដីបានខូចហើយនៅទទេ" ។ តែទោះជាយ៉ាងនេះក៏ដោយ គឺដោយសារតែការបរាជ័យរបស់កូនច្បងទាំងនោះទេ (រូបេន ស៊ីម្មាន និង លេវី "មើល លប ៤៩:៣-៧) យូដាគឺជាកូនប្រុសម្នាក់ដែលបានផ្ដល់មកជាទីសង្ឃឹមនៅក្នុងចំណោមបងប្អូនទាំងអស់ (លក ៤៩:៨) វង្សត្រកូលយូដានេះឯង ដែលព្រះមែស៊ីបានប្រសូតចេញ (លប ៤៩:១០ នរ ៤:១៨-២១ មថ ១:១-១៦) ។

**២:១០-១២** *រូបេន . . . ស៊ីម្មាន* គឺជាកូនប្រុសទីមួយ និងទីពីររបស់លោកយ៉ាកុប ហើយនិងនាងលេអា ។

**២:១៤** *ពូជអំបូរកាឌ់* គឺជាកូនប្រុសច្បងរបស់លោកយ៉ាកុបជាមួយនឹងនាងស៊ីផា(អ្នកបម្រើរបស់នាងលេអា)។ លោកលេវី គឺជាកូនប្រុសទីបីរបស់នាងលេអា តែពុំមែនជាអ្នកចម្បាំងនោះទេ ។ *ដេហ៊ូអែល* មើល លប ១០:៤ ។

នាក់ តាមដែលគេកំណត់រាប់ហើយ ១៦អស់ពួកអ្នកដែល
បានរាប់ក្នុងទីដំឡើងត្រសាលរបស់ពួករូបេននេះ[ឱ] រួមទាំង
អស់មាន១សែន៥ម៉ឺន១ពាន់៤៥០នាក់ តាមពួកកងរបស់គេ
ពួកនេះជាអ្នកដើរបន្ទាប់ ។

១៧លំដាប់នោះមក ត្រូវឱ្យពួកលេវី[ឍ]ចេញដើរទៅជា
កណ្ដាលនៃអស់ទាំងពួក នាំយកទាំងត្រសាលជំនុំទៅផង
គេត្រូវចេញដើរទៅតាមរបៀប ដែលគេនៅក្នុងទីដំឡើង
ត្រសាលមុនក្រោយ គឺគ្រប់គ្នានៅកន្លែងរបស់ខ្លួន តាម
ទង់ជ័យរៀងខ្លួន ។

១៨ឯខាងលិច[ណ] នោះត្រូវមានទង់ជ័យរបស់ទីដំឡើង
ត្រសាលនៃពួកអេប្រាអិម[ត] តាមពួកកងរបស់គេ ហើយ
អ្នកដែលជាកំពូល លើពួកកូនចៅអេប្រាអិម គឺអេលីសាម៉ា
ជាកូនអាំមីហ៊ូត[ថ] ១៩ឯពួកកងរបស់លោក នោះមានចំនួន
៤ម៉ឺន៥០០នាក់ តាមដែលគេកំណត់រាប់ហើយ ២០ឯពួក
ដែលនៅក្បែរលោក នោះត្រូវជាពូជអំបូរម៉ានាសេ[ទ]
ហើយអ្នកដែលជាកំពូល លើពួកកូនចៅម៉ានាសេ គឺកាម៉ា
លាល ជាកូនផ្ដាសើរ[ធ] ២១ឯពួកកងរបស់លោក នោះមាន
ចំនួន៣ម៉ឺន២ពាន់២០០នាក់ តាមដែលគេកំណត់រាប់
ហើយ ២២ពួក១ទៀតជាពូជអំបូរបេនយ៉ាមីន[ន] ហើយអ្នក
ដែលជាកំពូល លើពួកកូនចៅបេនយ៉ាមីន គឺអ័បឺដានជា
កូនគីដាហូនី[ប] ២៣ឯពួកកងរបស់លោក នោះមានចំនួន
៣ម៉ឺន៥ពាន់៤០០នាក់ តាមដែលគេកំណត់រាប់ហើយ
២៤អស់ពួកអ្នក ដែលបានរាប់ក្នុងទីដំឡើងត្រសាល របស់
ពួកអេប្រាអិម[ផ] រួមទាំងអស់ មាន១សែន៨ពាន់១០០នាក់
តាមពួកកងរបស់គេ ពួកនេះជាអ្នកដើរទី៣[ព] ។

២៥ឯខាងជើង[ភ] នោះត្រូវមានទង់ជ័យរបស់ទីដំឡើង
ត្រសាលនៃពួកដាន់ តាមពួកកងរបស់គេ[ម] ហើយអ្នកដែល
ជាកំពូល លើពួកកូនចៅដាន់ គឺអ័ហ៊ីយេសើរ ជាកូន
អាំមីសាដាយ[យ] ២៦ឯពួកកងរបស់លោក នោះមានចំនួន
៦ម៉ឺន២ពាន់៧០០នាក់ តាមដែលគេកំណត់រាប់ហើយ ២៧ពួក
ដែលនៅក្បែរលោក នោះត្រូវជាពូជអំបូរអេសើរ ហើយ
អ្នកដែលជាកំពូល លើពួកកូនចៅអេសើរ គឺប៉ាគីហ៊ាលជា
កូនអុក្រាន[រ] ២៨ឯពួកកងរបស់លោក នោះមានចំនួន៤ម៉ឺន១
ពាន់៥០០នាក់ តាមដែលគេកំណត់រាប់ហើយ ២៩ពួក១ទៀត
ជាពូជអំបូរណែបថាលី[ល] ហើយអ្នកដែលជាកំពូលលើពួក
កូនចៅណែបថាលី គឺអ័ហ៊ីរ៉ា ជាកូនអេណាន[វ] ៣០ឯពួកកង
របស់លោក នោះមានចំនួន៥ម៉ឺន៣ពាន់៤០០នាក់ តាមដែល
គេកំណត់រាប់ហើយ ៣១អស់ពួកអ្នកដែលបានរាប់ក្នុងទី
ដំឡើង ត្រសាលរបស់ពួកដាន់ រួមទាំងអស់មាន១សែន៥ម៉ឺន
៧ពាន់៦០០នាក់ ពួកនេះជាអ្នកដើរខាងក្រោយបង្អស់[ស] តាម
ទង់ជ័យរបស់គេរៀងខ្លួន ។

៣២នេះហើយជាពួកអ្នកដែលបានរាប់ ក្នុងពួកកូនចៅ
អ៊ីស្រាអែល តាមវង្សានុវង្ស នៃពួកព្ឋយុកោគេ[ហ] គឺគ្រប់
បណ្ដាមនុស្សទាំងអស់ ដែលគេបានរាប់ក្នុងទីដំឡើង
ត្រសាលទាំងប៉ុន្មាន តាមពួកកងរបស់គេនោះ រួមទាំងអស់
មាន៦សែន៣ពាន់៥៥០នាក់[ឡ] ៣៣តែឯពូជលេវី នោះគេមិន
បានរាប់ បញ្ចូល[អ]ក្នុងពួកកូនចៅអ៊ីស្រាអែលទេ ដូចជាព្រះ
យេហូវ៉ាបានបង្គាប់មកម៉ូសេ ៣៤ពួកកូនចៅអ៊ីស្រាអែល
ក៏ធ្វើតាមគ្រប់សេចក្ដីទាំងប៉ុន្មាន ដែលព្រះយេហូវ៉ាទ្រង់
បង្គាប់មកម៉ូសេ គឺគេបានដំឡើងត្រសាលរបស់គេ ត្រង់ទង់
ជ័យរបស់ខ្លួន ហើយគ្រប់គ្នាក៏ចេញដំណើរទៅតាមគ្រួសារ
តាមវង្សានុវង្សរបស់ឪពុកគេរៀងខ្លួន ។

### ពូជអំបូរលេវី

**៣** ១នេះជាពូជដំណររបស់អើរ៉ុននិងម៉ូសេ នាគ្រាដែលព្រះ

**២:១៦** ឱ ជន ១០:១៨
**២:១៧** ឍ ជន ១:៥០ ១០:២១
**២:១៨** ណ ជន ១:៥៣ ត លប ៤៨:២០ ថ ជន ១:១០
**២:២០** ទ លប ៤៨:២០ ធ ជន ១:១០
**២:២២** ន ជន ១០:២៤ ប ជន ១:១១
**២:២៤** ផ ជន ១០:២២ ព ទដ ៨០:២
**២:២៥** ភ ជន ១:៥៣ ម ជន ១០:២៥ យ ជន ១:១២
**២:២៧** រ ជន ១:១៣ ១០:២៦
**២:២៩** ល ជន ១០:២៧ វ ជន ១:១៥ ១០:២៧
**២:៣១** ស ជន ១០:២៥ យស ៦:៩
**២:៣២** ហ ជន ១:៤៥ ឡ នក ១២:៣៧
**២:៣៣** អ ជន ១:៤៧ ២៦:៥៧–៦២

**២:១៧** *ត្រសាលជំនុំ* គឺតំណាងឱ្យព្រះវត្តមានរបស់ព្រះអម្ចាស់នៅត្រង់ចំណុចកណ្ដាលនៃត្រសាល (មើលការពន្យល់ ១:១) ។ *ពួកលេវី* នៅក្នុងក្បួនធ្វើដំណើរ គឺពូជអំបូរយូដា និងក្រុមនៃអំបូររូបេនជាអ្នកនាំមុខគេបន្ទាប់មកគឺរោងឧបោសថដោយមានពួកលេវីជាអ្នកនៅការពារជុំវិញ ហើយអ្នកដើរតាមក្រោយមានពួកអេប្រាអិមនិងដាន់ ។

**២:១៨–២២** ជាពូជអំបូររបស់នាងរ៉ាជែល (លោកយ៉ូសែប និងបេនយ៉ាមីន) គឺនៅទិសខាងលិច ។ កូនប្រុសទាំងពីររបស់លោកយ៉ូសែប ម៉ានាសេ និងអេប្រាអិមបានទទួលព្រះពររបស់ព្រះយ៉ាងពិសេសពីលោកយ៉ាកុប ប៉ុន្តែកូនប្រុសប្អូន អេប្រាអិមត្រូវបានផ្ដល់ឱ្យលើសជាងម៉ានាសេ (មើលការពន្យល់ លប ៤៨:៥–២០) ។

**២:២៥** *ដាន់* គឺជាកូនប្រុសទីមួយរបស់នាងប៊ីលហា (អ្នកបម្រើនាងរ៉ាជែល) ។

**២:២៧** *អេសើរ* គឺជាកូនទីពីរស៊ីលផា (អ្នកបម្រើនាងលេអា) ។

**២:២៩** *ណែបថាលី* គឺជាកូនប្រុសទីពីររបស់នាងប៊ីលហា ។

**២:៣២** *៦សែន៣ពាន់៥៥០នាក់* មើលការពន្យល់ ១:៤៦ ។

**២:៣៣** *លេវី* មើលការពន្យល់ ១:៤៧,៥៣ ។

**២:៣៤** *ក៏ធ្វើតាមគ្រប់សេចក្ដីទាំងប៉ុន្មាន ដែលព្រះយេហូវ៉ាទ្រង់បង្គាប់មកម៉ូសេ* មើលពន្យល់ ១:៥៤ ។ ពួកកូនចៅអ៊ីស្រាអែលនៅជំនាន់ក្រោយបានប្រព្រឹត្តផ្ទុយទាំងស្រុងនូវពាក្យបង្គាប់ខាងលើនេះ ។ *ត្រង់ទង់ជ័យរបស់ខ្លួន . . . តាមគ្រួសារ តាមវង្សានុវង្សរបស់ឪពុកគេរៀងខ្លួន* ត្រង់នេះគឺជាការសម្រេចដ៏សំខាន់មួយ សម្រាប់ការរៀបចំ ចំនួនមនុស្សដ៏ច្រើននេះ ដោយពួកគេទើបនឹងចេញពីភាពជាទាសករ ហើយលើសពីនេះទៅទៀតគឺដើម្បីបោសសំអាតភាពគ្មានសណ្ដាប់ធ្នាប់ ។ ចំណុចទាំងនេះគឺជាការតំរាបតាមលំដាប់លំដោយ នៃការបោះជំរុំដែលបណ្ដាលឱ្យលោកបាឡាមពោលសរសើរថា "ឱយ៉ាកុបអើយ ត្រសាលរបស់ឯងទាំងប៉ុន្មានល្អណាស់ហ្ន៎ ហើយទីលំនៅឯងផងឱអ៊ីស្រាអែលអើយ!" (២៤:៥) ។

**៣:១** *អើរ៉ុន និងម៉ូសេ* បើមើលមួយភ្លែតទៅ ការហៅឈ្មោះអើរ៉ុនមុន ហាក់

យេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ[ក] នៅលើភ្នំស៊ីណាយ[ខ]
២ឯឈ្មោះពួកកូនទាំងប៉ុន្មានរបស់អើរ៉ុន នោះគឺណាដាប
ជាកូនច្បង១[គ] អ័ប៊ីហ៊ូវ១ អេលាសារ១ និងអ៊ីថាម៉ារ១[ឃ]
៣នេះហើយជាឈ្មោះរបស់ពួកកូនអើរ៉ុន ដែលគេបានចាក់
ប្រេងតាំងឡើងធ្វើជាសង្ឃ[ង] ហើយបានញែកចេញសំរាប់
នឹងបំរើក្នុងការងារជាសង្ឃ ៤រីឯណាដាប និងអ័ប៊ីហ៊ូវ គេ
បានស្លាប់នៅចំពោះព្រះយេហូវ៉ា[ច] ក្នុងកាលដែលគេថ្វាយ
ភ្លើងដទៃ នៅចំពោះព្រះយេហូវ៉ាត្រង់ទីរហោស្ថាន ស៊ី–
ណាយទៅ[ឆ] គេឥតមានកូនទេ អេលាសារនិងអ៊ីថាម៉ារ[ជ] គេ
បានធ្វើការងារជាសង្ឃ នៅមុខអើរ៉ុនជាឪពុកគេវិញ[ឈ] ។
៥ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ៦ចូរនាំពូជ
អំបូរលេវីមកឱ្យជិត[ញ] ឱ្យគេបានឈរនៅចំពោះមុខអើរ៉ុនដ៏
ជាសង្ឃ ដើម្បីនឹងបំរើដល់លោក[ដ] ៧ត្រូវឱ្យគេរក្សាបញ្ញើ
របស់លោក និងបញ្ញើរបស់ពួកជំនុំទាំងអស់គ្នា[ឋ] នៅមុខ
ត្រសាលជំនុំ ដើម្បីនឹងធ្វើការងារ[ឌ] ដែលត្រូវខាងរោង
ឧបោសថ ៨ត្រូវឱ្យគេរក្សាអស់ទាំងប្រដាប់ប្រដានៃត្រសាល
ជំនុំ ព្រមទាំងបញ្ញើរបស់ពួកកូនចៅអ៊ីស្រាអែលផង ដើម្បី
នឹងធ្វើការងារ ដែលត្រូវខាងរោងឧបោសថ ៩ត្រូវឱ្យឯង
ប្រគល់ពួកលេវី ដល់អើរ៉ុន និងពួកកូនលោក[ឍ] ដ្បិតអញ
បានញែកគេចេញពីពួកកូនចៅអ៊ីស្រាអែល ឱ្យដាច់ទៅ
លោកហើយ ១០ត្រូវឱ្យឯងដំរូវឱ្យអើរ៉ុន[ណ] និងពួកកូនលោក
រក្សាការងារជាសង្ឃរបស់គេ[ត] ហើយអ្នកដទៃណាដែល
ចូលមកជិត នោះនឹងត្រូវសំឡាប់ចោល[ថ] ។
១១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ១២ឯអញ
មើល អញបានយកពួកលេវី[ទ] ចេញពីពួកកូនចៅអ៊ីស្រា
អែល ស្នងអស់ទាំងកូន[ធ] ដែលកើតពីពោះម្តាយមកមុខគេ
បង្អស់ក្នុងពួកគេ បានជាពួកលេវីនោះ ត្រូវបានជារបស់ផង
អញ[ន] ១៣ដ្បិតអស់ទាំងកូនច្បង ជារបស់ផងអញហើយ[ប]
ពីព្រោះ នៅថ្ងៃដែលអញបានវាយអស់ទាំងកូនច្បងនៅ
ស្រុកអេស៊ីព្ទ នោះអញបានញែកអស់ទាំងកូនច្បង ក្នុង
សាសន៍អ៊ីស្រាអែលចេញ ទុកសំរាប់អញ ទាំងមនុស្ស
ហើយនិងសត្វផង ទាំងអស់គ្នាត្រូវបានជារបស់ផងអញពិត
អញនេះជាព្រះយេហូវ៉ា[ផ] ។
១៤ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេ ត្រង់ទីរហោស្ថាន
ស៊ីណាយថា[ព] ១៥ចូររាប់[ភ]ពួកកូនចៅលេវី តាមគ្រួសារ
តាមវង្សានុវង្សរបស់ឪពុកគេ ត្រូវរាប់គ្រប់ទាំងកូនប្រុសៗ
ចាប់តាំងពីអាយុ១ខែឡើងទៅលើ[ម] ១៦ដូច្នេះម៉ូសេក៏រាប់គេ
តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ដូចជាទ្រង់បានបង្គាប់មក ។

**៣:១** ក នក ៦:២៧ ខ នក ១៩:១១ **៣:២** គ ជន ១:២០ ឃ នក ៦:២៣ **៣:៣** ង នក ២៨:៤១ ២៩:៣០ **៣:៤** ច លវ ១០:២ ឆ លវ ១០:១ ជ លវ ១០:៦,១២ជន ៤:២៨ ឈ ១រប ២៤:១ **៣:៦** ញ ចទ ១០:៨ ៣១:៩ ១រប ១៥:២ ដ ជន ៨:៦–២២ ១៨:១–៧ ២រប ២៩:១១ **៣:៧** ឋ ជន ១:៥៣ ៨:១៩ ឌ លវ ៨:៣៥ **៣:៩** ឍ ខ.១២,៤៥ ជន ៨:១៩ ១៨:៦ **៣:១០** ណ នក ៣០:៧ ត នក ២៩:៩ ថ ជន ១:៥១ **៣:១២** ទ នហ ១៣:២៩ មឡ ២:៤ ធ ខ.៤១ ជន ៨:១៦, ១៨ ន ខ.៩ នក ១៣:២ ជន ៨:១៤ ១៦:៩ **៣:១៣** ប នក ១៣:១២ ផ លវ ១១:៤៤ **៣:១៤** ព នក ១៩:១ **៣:១៥** ភ ខ.៣៩ ១:១៩ ម ខ.២២ ជន ១៨:១៦ ២៦:៦២

បីដូចជាមិនតាមលំដាប់សោះ ប៉ុន្តែ ការបញ្ជាក់អត្ថន័យគឺត្រឹមត្រូវ (ខ.២) ។
**៣:៣** *បានចាក់ប្រេងតាំងឡើងធ្វើជាសង្ឃ* បើតាម នក ២៨:៤១ បានកត់ចុះពីសេចក្តីបង្គាប់របស់ព្រះមកលោកម៉ូសេ ឱ្យចាក់ប្រេងតាំងដល់បងប្រុស របស់គាត់ឈ្មោះអើរ៉ុន និងកូនប្រុសៗរបស់គាត់ ឱ្យធ្វើជាសង្ឃរបស់ព្រះ(នក ៣០:៣០ លវ ៨:៣០) ដូច្នេះ ពួកគេមានសិទ្ធិយ៉ាងពិសេសនៅចំពោះព្រះ ។ ស្តេចក៏ត្រូវបានគេចាក់ប្រេងតាំងសម្រាប់បម្រើកិច្ចការយ៉ាងពិសេសដល់ព្រះអម្ចាស់ដូច្នេះដែរ(មើលការពន្យល់ ១សយ ១៦:១៣) ហើយការតែងតាំងផ្សេងៗទៀត ក៏ត្រូវបានចាក់ប្រេងតាំងរបស់នេះដែរ(នក ២៩:៣៦ និងមើលការពន្យល់ លប ២៨:១៨)។ ពាក្យថា "ចាក់ប្រេងតាំង" គឺចេញមកពីព្រះគម្ពីរភាសាហេព្រើរថា មែស៊ី ក្រោយមកក្លាយទៅជាពាក្យជាក់លាក់មួយដែលគេស្គាល់ថា "ព្រះមែស៊ី(ព្រះគ្រីស្ទ)"(មើលការពន្យល់ មថ ១:១៧)។
**៣:៤** *ណាដាប និងអ័ប៊ីហ៊ូវ* មើលការពន្យល់ លវ ១០:១–៣ ។ *ភ្លើងដទៃ* ពាក្យនេះមានន័យថា "ភ្លើងគ្មានអំណាច" ដែលមើលទៅហាក់បីដូចជាចង់បញ្ជាក់ពីឃ្លាពុំសំខាន់ បានជាអ្នកនិយាយរឿងរៀបរាប់ថា វាគ្មានន័យអ្វីសោះ ។ ពួកគេបានប្រើភ្លើងដែលព្រះអម្ចាស់ពុំបានបង្គាប់(លវ ១០:១)។ ភាព សុចរិត បរិសុទ្ធរបស់ព្រះ និងការស្តាប់បង្គាប់គឺចេញពីសង្ឃរបស់ទ្រង់ ។ ក្រោយពេលលោកអើរ៉ុនបានស្លាប់ កូនចៅជំនាន់ក្រោយត្រូវបានផ្តោតទៅលើផ្នែកបម្រើព្រះយ៉ាងសកម្មបំផុត (១សយ ២:១២–១៧,២២–២៥,២៧–៣៦ ៣:១១–១៤ ៤:១–១១)។ ចំពោះការជំនុំជម្រះរបស់ព្រះអម្ចាស់ នៅដើមដំបូងនៃដំណាក់កាលនីមួយៗនៃប្រវត្តិសាស្ត្រនៃការសង្គ្រោះ មើល យស ៧:១–២៦ ៦:៧ កច ៥:១ និងការពន្យល់ ។
**៣:៥–១០** ក្នុងវគ្គនេះពុំមែនជាសេចក្តីរាយការណ៍នៃការស្តាប់បង្គាប់ ដូចនៅក្នុងជំពូក ១–២ នោះទេ ។ សេចក្តីលំអិតបន្ថែមទៀតនៅក្នុងជំពូកទី៨ ។ ភាពខុសគ្នារវាងផ្ទះរបស់សង្ឃលេវី និងលោកអើរ៉ុនត្រូវបានឃើញយ៉ាងច្បាស់នៅក្នុងជំពូកនេះ ដែលមិនគ្រាន់តែដល់ពូជអើរ៉ុននោះទេ គឺដល់ជាតិសាសន៍ទាំងមូល (ខ.៧–៨) ។
**៣:៩** នៅក្នុងខនេះបានបញ្ជាក់ប្រាប់ថា គ្រប់ទាំងផ្នែកបម្រើត្រូវបានប្រគល់ដល់ពូជរបស់លោកអើរ៉ុន (៨:១៦) ។
**៣:១០** *អ្នកដទៃ* មានន័យថា មនុស្សចម្លែក គឺជាអ្នកដែលគ្មានសិទ្ធិចូលកន្លែងហាមឃាត់ ។ ការរៀបចំពិធីបុណ្យផ្សេងៗនៅក្នុងរោងឧបោសថត្រូវបានតែងតាំងដោយព្រះអម្ចាស់ ។ នៅក្នុងខ.១០ បានប្រាប់ឱ្យដឹងថា ពូជពង្សរបស់លោកអើរ៉ុនមានសិទ្ធិចូលក្នុងរោងឧបោសថ តែបើធ្វើមិនត្រឹមត្រូវ នោះក៏ត្រូវស្លាប់ដែរ ចុះទម្រាំបើមនុស្សគ្មានសិទ្ធិ នោះតើនឹងត្រូវទទួលទោសប៉ុណ្ណា (ខ.៣៨ ១៨:១–៧ និងការពន្យល់) ។
**៣:១២–១៣** មើលការពន្យល់ នក ១៣:២ ។
**៣:១២** *ស្នងអស់ទាំងកូន* មានគំរូនៃការអនុវត្តន៍នៅក្នុង លប ២២:១៣ មថ ២០:២៨ និងការពន្យល់) ។
**៣:១៥** *អាយុ១ខែឡើងទៅលើ* ពូជអំបូរលេវីមានតួនាទីផ្សេងពីអំបូរដទៃទៀត នៅក្នុងជំពូក ១–២ លើកលែងតែភេទប្រុសចាប់តាំងពីអាយុ១ខែឡើងទៅ នោះត្រូវបានគេរាប់ មិនចាំបាច់ដល់អាយុ២០ឆ្នាំនោះទេ ។
**៣:១៦** *ដូចជាទ្រង់បានបង្គាប់មក* គឺជាសេចក្តីស្តាប់បង្គាប់របស់លោកម៉ូសេចំពោះសេចក្តីបង្គាប់របស់ព្រះអម្ចាស់ទាំងស្រុង ហើយនិងដោយផ្ទាល់ ។

១៧នេះជាពួកកូនចៅរបស់លេវី[យ] តាមឈ្មោះគេ គឺ
គើសុន១[រ] កេហាត់១[ល] និងម្រ៉ារី១[វ] ១៨ឯឈ្មោះពួកកូនរបស់
គើសុន តាមគ្រួសារគេ គឺលិបនី១ និងស៊ីម៉ាយ១[ស] ១៩ពួក
កូនរបស់កេហាត់ តាមគ្រួសារគេ គឺអាំរ៉ាម១ យីតសារ១
ហេប្រុន១ និងអ៊ូស៊ាល១[ហ] ២០ហើយពួក កូនរបស់ម្រ៉ារី
តាមគ្រួសារគេ[ឡ] គឺម៉ាស់លី១ និងមូស៊ី១[អ] នេះហើយជា
គ្រួសារទាំងប៉ុន្មានរបស់ពួកលេវី តាមវង្សានុវង្សរបស់
ឪពុកគេរៀងខ្លួន ។
២១ដំណអំពីគើសុនមក[ក] នោះកើតមានគ្រួសារលិបនី
និងគ្រួសារស៊ីម៉ាយ[ខ] នេះហើយជាគ្រួសារទាំងប៉ុន្មានរបស់
ពួកគើសុន ២២ឯពួកគេដែលបានរាប់តាមចំនួនពួកប្រុសៗ
ចាប់តាំងពីអាយុ១ខែឡើងទៅលើ នោះមានចំនួន៧ពាន់
៥០០នាក់ ២៣ចំណែកអស់ទាំងគ្រួសាររបស់ពួកគើសុនគេ
ត្រូវដំឡើងត្រសាល នៅខាងលិច គឺខាងក្រោយរោង
ឧបោសថ[គ] ២៤ហើយអ្នកដែលជាកំពូលលើពួកកូនចៅរបស់
ឪពុកពួកគើសុននេះ គឺអេលាសាប់ជាកូនឡាអែល ២៥រីឯ
បញ្ញើដែលផ្ញើទុកនឹងពួកកូនចៅគើសុន នៅក្នុងត្រសាល
ជំនុំ នោះគឺជារោងឧបោសថ[ឃ] ត្រសាល និងគំរប[ង] ហើយ
និងវាំងននដែលនៅមាត់ទ្វារ[ច]ត្រសាលជំនុំ[ឆ] ២៦ព្រមទាំង
រនាំងទីលាន និងរនាំងនៅមាត់ទ្វារទីលាន[ជ]ដែលបាំង
ជុំវិញ នៃរោងឧបោសថ[ឈ] និងអាសនា ហើយនិងខ្សែ[ញ] ទាំង
ប៉ុន្មាន[ដ] សំរាប់ប្រើការនោះដែរ ។
២៧ដំណអំពីកេហាត់មក[ឋ] នោះកើតមានគ្រួសារអាំរ៉ាម
គ្រួសារយីតសារ គ្រួសារហេប្រុន និងគ្រួសារអ៊ូស៊ាល[ឌ]
នេះហើយជាគ្រួសារទាំងប៉ុន្មានរបស់ពួកកេហាត់[ឍ] ២៨តាម
ចំនួនពួកប្រុសៗ ចាប់តាំងពីអាយុ១ខែឡើងទៅលើ[ណ] នោះ
មាន៨ពាន់៦០០នាក់ ជាអ្នករក្សា[ត]ទីបរិសុទ្ធ[ថ] ២៩ចំណែក
អស់ទាំងគ្រួសាររបស់ពួកកេហាត់ គេត្រូវដំឡើងត្រសាល
ខាងត្បូង[ទ] ជាចំហៀងក្បែររោងឧបោសថ ៣០ហើយអ្នក
ដែលជាកំពូលលើពួកកូនចៅ របស់ឪពុកពួកកេហាត់ គឺ
អេលីសាផាន[ធ] ជាកូនអ៊ូស៊ាល ៣១រីឯបញ្ញើដែលផ្ញើទុក
នឹងគេ នោះគឺជាហឹបនៃសេចក្ដីបន្ទាល់[ន] តុ[ប] ជើងចង្កៀង[ផ]
អាសនាទាំង២[ព] និងប្រដាប់ប្រដាទាំងប៉ុន្មាន[ភ]សំរាប់ទី
បរិសុទ្ធ ដែលគេប្រើធ្វើការងារ[ម] ព្រមទាំងវាំងនន[យ]និង
ប្រដាប់វាំងននទាំងប៉ុន្មានដែរ ៣២ឯអេលាសារ[រ] ជាកូន
អើរ៉ុនដ៏ជាសង្ឃ លោកនឹងធ្វើជាមេ នៃពួកអ្នកដែលជា
កំពូលលើពួកលេវីទាំងប៉ុន្មាន ត្រូវឲ្យលោកត្រួតត្រាលើគេ
ឲ្យគេបានរក្សាទីបរិសុទ្ធដែលផ្ញើទុក[ល]នឹងគេ[វ] ។
៣៣ដំណអំពីម្រ៉ារីមក នោះកើតមានគ្រួសារម៉ាស់លី១
និងគ្រួសារមូស៊ី១[ស] នេះហើយជាគ្រួសារទាំងប៉ុន្មានរបស់
ពួកម្រ៉ារី[ហ] ៣៤ឯពួកគេដែលបានរាប់តាមចំនួនពួកប្រុសៗ
ចាប់តាំងពីអាយុ១ខែឡើងទៅលើ[ឡ] នោះមានចំនួន៦ពាន់
២០០នាក់ ៣៥ហើយអ្នកដែលជាកំពូល លើពួកកូនចៅ
របស់ឪពុកពួកម្រ៉ារី គឺស៊ូរីអែល ជាកូនអ័ប៊ីហែល គេ
ត្រូវដំឡើងត្រសាល នៅខាងជើង ជាចំហៀងក្បែររោង

**៣:១៧** យ លប ២៩:៣៤ ៤៦:១១ ជន ១៧ ១រប ១៥:៤ ២៣:៦ ២រប ២៩:១២ រ យស ២១:៦ ល យស ២១:៤ វ នក ៦:១៦ **៣:១៨** ស នក ៦:១៧ **៣:១៩** ហ នក ៦:១៨ **៣:២០** ឡ លប ៤៦:១១ អ នក ៦:១៩ **៣:២១** ក លប ៤៦:១១ ខ នក ៦:១៧ **៣:២៣** គ ជន ២:១៨ **៣:២៥** ឃ នក ២៥:៩ ជន ៧:១ ង នក ២៦:១៤ ច នក ២៦:៣៦ ជន ៤:២៥ ឆ នក ៤០:២ **៣:២៦** ជ នក ២៧:៩ ឈ ខ.៣១ ញ នក ៣៥:១៨ ដ ជន ៤:២៦ **៣:២៧** ឋ លប ៤៦:១១ នក ៦:១៨ ឌ នក ៦:១៨ ១រប ២៦:២៣ ឍ ជន ៤:១៥,៣៧ **៣:២៨** ណ ខ.១៥ ត ជន ៤:៤,១៥ ថ នក ២៥:៨ ៣០:១៣ ២រប ៣០:១៩ ទដ ១៥:១ ២០:២ អគ ៤៤:២៧ **៣:២៩** ទ ជន ១:៥៣ **៣:៣០** ធ នក ៦:២២ **៣:៣១** ន នក ២៥:១០-២២ ចទ ១០:១-៨ ២រប ៥:២ យរ ៣:១៦ ប នក ២៥:២៣ ផ នក ២៥:៣១ ១រប ២៨:១៥ យរ ៥២:១៩ ព ខ.២៦ ភ ជន ១:៥០ ម ជន ៤:១៥ ១៨:៣ យ នក ២៦:៣៣ ជន ៤:៥ **៣:៣២** រ នក ៦:២៣ ល ខ.២៨ វ ជន ៤:១៩ ១៨:៣ **៣:៣៣** ស នក ៦:១៩ ហ លប ៤៦:១១ **៣:៣៤** ឡ ខ.១៥

**៣:២១-៣៨** ពាក្យនៅក្នុង ១:៥៣ "ត្រសាលរបស់ខ្លួន នៅព័ទ្ធជុំវិញរោងឧបោសថផងសេចក្ដីបន្ទាល់វិញ"ត្រូវបានពន្យល់លំអិតដូចខាងក្រោម : (១).ដំណអំពីគើសុននៅខាងលិច (ខ.២១-២៦) ។ (២).ដំណអំពីកេហាត់នៅខាងត្បូង(ខ.២៧-៣២)។ (៣).ដំណអំពីម្រ៉ារីនៅខាងជើង(ខ.៣៣-៣៧)។ (៤).លោកម៉ូសេ លោកអើរ៉ុន និងកូនរបស់ពួកលោកនៅទិសខាងកើត (ខ.៣៨) ។ ពូជអំបូរផ្សេងទៀតនៅតាមក្រោយ ដោយចាប់ផ្ដើមពីអំបូរដែលពេញចិត្តជាងគេបំផុតជាបន្តបន្ទាប់ : (១).ពួកកូនចៅយូដានៅទិសខាងខាងកើត(២:៣) ។ (២).ពួកចៅរូបេននៅទិសខាងត្បូង(២:១០) ។ (៣).ពួកអេប្រាអិមនៅទិសខាងលិច (២:១៨) ។ (៤).ពួកកូនចៅដាន់នៅទិសជើង (២:២៥) ។

**៣:២៤** *អេលាសាប់* មានន័យថា "ព្រះរបស់ខ្ញុំបានបន្ថែមឲ្យទៀត" ។*ឡាអែល* មានន័យថា "ជារបស់ព្រះ" ។

**៣:២៥-២៦** នៅក្នុងរោងឧបោសថមានវាំងននបីប្រភេទ : (១).នៅនឹងមាត់ទ្វារឯទីលាន(ខ.២៦ ៤:២៦) ។ (២).នៅឯងទ្វារចូលទៅត្រសាល(ខ.២៥,៣១ ៤:២៥) ។ (៣).នៅចន្លោះរវាងកន្លែងបរិសុទ្ធបំផុត និងកន្លែងបរិសុទ្ធ (៤:៥) ។

**៣:២៧** *គ្រួសារអាំរ៉ាម* លោកអើរ៉ុនគឺចេញមកពីគ្រួសារអាំរ៉ាម(មើលការពន្យល់ នក ៦:២០) ។ លោកម៉ូសេចេញមកពីគ្រួសារកេហាត់ ។ ពួកកូនចៅគឺជាអ្នកថែរក្សាទីកន្លែងដែលបរិសុទ្ធបំផុត (៤:៤-១៨) ។

**៣:២៨** *៨ពាន់៦០០នាក់* ជាចំនួនសរុបនៃពួកកូនចៅកេហាត់ ។ ពួកកូនចៅលេវីមាន២មុឺន២ពាន់នាក់ (ខ.៣៩) ។ ចំនួនសរុបរបស់ពួកកូនចៅគើសុន៧ពាន់៥០០នាក់ (ខ.២២) ។ ពួកកូនចៅម្រ៉ារីមានចំនួន៦ពាន់២០០នាក់ (ខ.៣៤) ។ មានមនុស្សជាច្រើនបានជឿថាអ្នកសរសេរចម្លងបានសរសេរខុសនៅត្រង់នេះ ចំនួនត្រឹមត្រូវនោះគឺ ៨ពាន់៣០០នាក់ ។

**៣:៣០** *អេលីសាផាន* មានន័យថា "ព្រះរបស់ខ្ញុំបានការពារ"។ *អ៊ូស៊ាល* មានន័យថា "ព្រះជាអ្នកផ្ដល់កម្លាំងដល់ខ្ញុំ"។

**៣:៣៥** *ស៊ូរីអែល* មានន័យថា "ព្រះអម្ចាស់នៃខ្ញុំគឺជាថ្មដា" ។ *អ័ប៊ីហែល* មានន័យថា "ព្រះវរបិតានៃស្ថានសួគ៌ពេញដោយអំណាចចេស្ដា" ។

ឧបោសថ[អ] ៣៦រីឯបញ្ជីដែលផ្ញើទុក[ក]នឹងពួកកូនចៅម្រ៉ារី
នោះគឺអស់ទាំងក្តារ និងរនុក[ខ] ហើយសសរ[គ] និងជើង
សសរទាំងប៉ុន្មាននៃរោងឧបោសថ[ឃ] ហើយប្រដាប់ប្រដា
និងគ្រឿងទាំងប៉ុន្មានសំរាប់ការងារក្នុងរោងនោះ[ង] ៣៧ព្រម
ទាំងសសរទីលាននៅជុំវិញ[ច] ជើងសសរនោះ និងចំរឹង[ឆ]
ហើយខ្សែទាំងប៉ុន្មានផង ។

៣៨ឯពួកអ្នកដែលត្រូវដំឡើងត្រសាល នៅខាងកើត[ជ]ត្រង់
ខាងមុខរោងឧបោសថ គឺនៅមុខត្រសាលជំនុំ[ឈ]ទិសខាង
ថ្ងៃរះ នោះគឺជាម៉ូសេនិងអើរ៉ុន ហើយនិងពួកកូនលោក
ដើម្បីនឹងរក្សាបញ្ជីនៃទីបរិសុទ្ធ[ញ] ដែលផ្ញើទុកនឹងពួកកូន
ចៅអ៊ីស្រាអែល បើអ្នកដទៃណាដែលមកជិត នោះនឹងត្រូវ
សំឡាប់ចោល[ដ] ៣៩ឯពួកលេវីទាំងអស់ ដែលម៉ូសេ និងអើរ៉ុន
បានរាប់[ឋ]តាមបង្គាប់ព្រះយេហូវ៉ា តាមគ្រួសារគេ គឺគ្រប់
ទាំងប្រុសៗ ចាប់តាំងពីអាយុ១ខែឡើងទៅលើ នោះមាន
ចំនួន២ម៉ឺន២ពាន់នាក់[ឌ] ។

៤០ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ចូររាប់អស់
ទាំងកូនប្រុសច្បងក្នុងពួកកូនចៅអ៊ីស្រាអែល ចាប់តាំងពី
អាយុ១ខែឡើងទៅលើ[ឍ] ឱ្យកំណត់រាប់ចំនួនឈ្មោះរបស់
គេ[ណ] ៤១នោះត្រូវយកពួកលេវីសំរាប់អញ ដើម្បីស្នងអស់
ទាំងកូនប្រុសច្បងនៃពួកកូនចៅអ៊ីស្រាអែល[ត] អញនេះជា
ព្រះយេហូវ៉ា[ថ] ហើយនិងហ្វូងសត្វរបស់ពួកលេវី ស្នងអស់
ទាំងកូនច្បងនៃសត្វរបស់កូនចៅអ៊ីស្រាអែលដែរ ៤២ដូច្នេះ
ម៉ូសេក៏រាប់អស់ទាំងកូនប្រុសច្បង នៃពួកកូនចៅអ៊ីស្រាអែល
ដូចជាព្រះយេហូវ៉ាទ្រង់បានបង្គាប់មក ៤៣ឯអស់ទាំងកូន
ប្រុសច្បង ដែលបានរាប់តាមចំនួនឈ្មោះរបស់គេ ចាប់
តាំងពីអាយុ១ខែឡើងទៅលើ[ទ] នោះមានចំនួន២ម៉ឺន២ពាន់
២៧៣នាក់[ធ] ។

៤៤ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ៤៥ចូរយកពួក
លេវី ឱ្យស្នងអស់ទាំងកូនប្រុសច្បង ក្នុងពួកកូនចៅអ៊ីស្រា
អែល ហើយហ្វូងសត្វពួកលេវី ឱ្យស្នងហ្វូងសត្វរបស់គេដែរ
ឯពួកលេវី នោះត្រូវបានជារបស់ផងអញពិត[ន] អញនេះជា
ព្រះយេហូវ៉ា[ប] ៤៦ឯត្រង់មនុស្សទាំង២៧៣នាក់ ក្នុងពួកកូន
ប្រុសច្បង នៃពួកកូនចៅអ៊ីស្រាអែល ដែលលើសពីចំនួន
ពួកលេវី ៤៧នោះត្រូវឱ្យឯងយក៥រៀល[ផ]ក្នុងម្នាក់ៗ ដើម្បី
នឹងលោះ[ព]អ្នកទាំងនោះ ត្រូវយកតាមប្រាក់រៀល[ភ] ដែល
ប្រើក្នុងទីបរិសុទ្ធ គឺ១រៀលត្រូវជា១០កាក់[ម] ៤៨ហើយប្រាក់
សំរាប់លោះ[យ]ពួកអ្នក ដែលលើសជាងពួកលេវី នោះត្រូវឱ្យ
ប្រគល់ដល់អើរ៉ុន និងពួកកូនលោកទៅ[រ] ៤៩ម៉ូសេក៏យក
ប្រាក់ ជាដំឡៃលោះខ្លួន[ល] ពីពួកអ្នកទាំងប៉ុន្មាន ដែលលើស
ពីចំនួនមនុស្សដែលបានលោះ ដោយពួកលេវីនោះហើយ
៥០គឺបានយកប្រាក់នោះ ពីពួកកូនប្រុសច្បង ក្នុងពួកកូន
ចៅអ៊ីស្រាអែល[វ] បាន១ពាន់៣៦៥រៀល[ស]តាមប្រាក់រៀល
ដែលប្រើក្នុងទីបរិសុទ្ធ ៥១រួចម៉ូសេប្រគល់ប្រាក់ ដែលជា
ដំឡៃលោះនោះ ដល់អើរ៉ុន និងពួកកូនលោកតាមព្រះ
បន្ទូលនៃព្រះយេហូវ៉ា ដូចជាទ្រង់បានបង្គាប់មក ។

## ពួកកូនចៅកេហាត់

**៤** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេនិងអើរ៉ុនថា ២ចូរ
រាប់[ក,ខ]ចំនួនពួកកូនចៅកេហាត់ ញែកគេចេញពីពួកកូនចៅ
លេវីទាំងប៉ុន្មាន តាមគ្រួសារ តាមវង្សានុវង្សរបស់ឪពុក
គេ ៣ចាប់តាំងពីអាយុ៣០ឆ្នាំឡើងទៅ រហូតដល់៥០ឆ្នាំ[គ]
គឺអស់អ្នកដែលត្រូវទទួលការងារក្នុងត្រសាលជំនុំបាន ៤ឯ
ក្រសួង[ឃ]របស់ពួកកូនចៅកេហាត់[ង]ក្នុងត្រសាលជំនុំ នោះគឺ
វាំងនន ដែលបិទបាំង យកទៅគ្របលើហិប នៃសេចក្តី

**៣:៣៥** អ ជន ២:២៥
**៣:៣៦** ក ជន ៤:៣២ ខ នក ៣៦:៣៦ គ នក ២៦:២៦-២៩ ឃ នក ២៦:១៥-២៥ ៣៥:២០-២៩ ង ជន ១៨:៣
**៣:៣៧** ច នក ២៧:១០-១៧ ឆ នក ២៧:១៩
**៣:៣៨** ជ ជន ២:៣ ឈ ជន ១:៥៣ ១របា ៩:២៧ ២៣:៣២ ញ ខ.៧ ជន ១៨:៥ ដ ខ.១០ ជន ១:៥១
**៣:៣៩** ឋ ខ.១៥ ឌ ជន ២៦:៦២
**៣:៤០** ឍ ខ.១៥ ណ ជន ១:២
**៣:៤១** ត ខ.១២ ថ លប ១១:៤៤
**៣:៤៣** ទ ខ.១៥ ធ ខ.៣៩
**៣:៤៥** ន ខ.៩ ប លវ ១១:៤៤
**៣:៤៧** ផ លវ ២៧:៦ ព នក ១៣:១៣ ជន ១៨:១៥ ភ នក ៣០:១៣ ម លវ ២៧:២៥
**៣:៤៨** យ ខ.៥១ រ ខ.៥០
**៣:៤៩** ល ខ.៤៨
**៣:៥០** វ ខ.៤១,៤៥ ស ខ.៤៦-៤៨
**៤:២** ក ជន ១:៤៧
**៤:៣** ខ នក ៣០:១២ គ ខ.២៣ ជន ៨:២៥ ១របា២៣:៣,២៤,២៧ អរ ៣:៨
**៤:៤** ឃ ជន ៣:២៨ ង ជន ៧:៩

**៣:៣៨** *ទិសខាងថ្ងៃរះ* គឺជាទិសមួយដែលមានកិត្តិយសបំផុត ប៉ុន្តែលោកម៉ូសេនិងលោកអើរ៉ុនបាននៅទិសនោះ សម្រាប់ធ្វើកិច្ចការទាំងមូល (តំណាងឱ្យពួកកូនចៅអ៊ីស្រាអែល) ។ *បើអ្នកដទៃណា . . . នោះនឹងត្រូវសំឡាប់ចោល* ការដែលធ្វើពិធីនៅក្នុងរោងឧបោសថគឺជាការស្នើសុំសេចក្តីមេត្តាករុណាសម្រាប់បណ្តាជននៅចំពោះព្រះភក្ត្រព្រះ តែបើធ្វើមិនត្រឹមត្រូវនោះនឹងត្រូវមានទោស (ខ.១០ ១:៥១ ១៨:១-៧ និងការពន្យល់) ។

**៣:៤១** *អញនេះជាព្រះយេហូវ៉ា* នេះជាចរិតលក្ខណៈនៃការអះអាងរបស់ព្រះ (មើលការពន្យល់ នក ៣:១៤) ។

**៣:៤៣** *២ម៉ឺន២ពាន់២៧៣នាក់* ចំនួនសរុបនៃបណ្តាជននៅត្រង់នេះហាក់បីដូចជាតិចណាស់ វាគួរតែមានចំនួន២លានឯណោះ ព្រោះចំនួនបណ្តាជនបានកើនជារហូតចាប់តាំងពីចេញដំណើរមក តែអ្នកខ្លះបានយល់ថា នេះជាចំនួនមនុស្សជំនាន់មុនទេ (នក ១២:២២-២៣) ។

**៣:៤៧,៥០** *តាមប្រាក់រៀលដែលប្រើក្នុងទីបរិសុទ្ធ* មើលការពន្យល់ នក ៣០:១៣ ។

**៤:៣** *អាយុ៣០ឆ្នាំឡើងទៅ រហូតដល់៥០ឆ្នាំ* នៅក្នុងជំពូក៣ បានចុះឈ្មោះគ្រប់ទាំងមនុស្សភេទប្រុស មានអាយុពី១ខែឡើងទៅ (៣:១៥) ។ នៅក្នុងជំពូក៤បានចុះឈ្មោះពូជអំបូរលេវី ដើម្បីបម្រើនៅក្នុងរោងឧបោសថ មានចំនួន២ម៉ឺន២ពាន់នាក់ (៣:៣៩) ហើយមានចំនួន៨ពាន់៥៨០នាក់ មានអាយុគ្រប់អាចបម្រើបាន (ខ.៤៨) ។ បើតាម ៨:២៤ បានបណញ្ជាក់ថា អ្នកដែលអាចបម្រើបានគឺមានអាយុ២៥ឆ្នាំ ។

**៤:៤** *នោះគឺខាងឯរបស់បរិសុទ្ធបំផុត* មើលការពន្យល់ ៣:៥ ។ បើតាមធ្លាប់ឮគេនិយាយតៗមកថា ការថែរក្សាកន្លែងសំខាន់បំផុតទាំងនេះគឺត្រូវបានប្រគល់ទៅឱ្យអំបូរកេហាត់ តែត្រូវបានហាមមិនឱ្យប៉ះឡើយ (ខ.១៥) ឬសូម្បីតែមើលក៏មិនបានដែរ (ខ.២០) ក្រែងត្រូវស្លាប់ ។

ខាងឯរបស់បរិសុទ្ធបំផុត[ច] ៥កាលណាពួកជំនុំរៀបដំណើរ
ចេញទៅ[ឆ] នោះអើរ៉ុននិងពួកកូនលោក ត្រូវចូលទៅដោះ
វាំងនន[ជ] ដែលបិទបាំង យកទៅគ្របលើហិប នៃសេចក្ដី
បន្ទាល់[ឈ] ៦រួចត្រូវគ្របដោយស្បែកផ្សោត[ញ] ហើយក្រាល
សំពត់ពណ៌ផ្ទៃមេឃពីលើ ទើបព្រហាកឈើស្នែងចូលទៅ[ដ]
៧ត្រូវឱ្យគេក្រាលសំពត់ពណ៌ផ្ទៃមេឃ នៅលើតុនៃនំបុ័ង
តាំងទុក[ឋ] ហើយដាក់ថាស ចាន ពែង និងប៉ាន់ ដែល
សំរាប់ដង្វាយច្រួច[ឌ] ព្រមទាំងនំបុ័ង ដែលដាក់ជាអចិន្ត្រៃយ
នៅលើតុនោះ[ឍ]ដែរ ៨រួចត្រូវក្រាលសំពត់ពណ៌ក្រហមលើ
របស់ទាំងនោះ ទាំងគ្របដោយស្បែកផ្សោតពីលើទៀត
រួចព្រហាកឈើស្នែងចូលទៅ[ណ] ៩ក៏ត្រូវយកសំពត់ពណ៌ផ្ទៃ
មេឃ គ្របពីលើជើងដែលសំរាប់ដាក់ចង្កៀង ព្រមទាំង
ចង្កៀង ឃ្នាបប្រឆេះ កន្ថោររងកំទេច[ត] និងដបប្រេងទាំង
ប៉ុន្មាន ដែលសំរាប់ការថែចង្កៀងនោះផង ១០រួចត្រូវឱ្យ
គេយកចង្កៀង និងប្រដាប់ទាំងនោះ ដាក់ក្នុងស្បែកផ្សោត
ហើយសឹកឈើស្នែងចូល[ថ] ១១ឯអាសនាមាស[ទ] នោះត្រូវ
ឱ្យក្រាលសំពត់ពណ៌ផ្ទៃមេឃនៅពីលើ ហើយគ្របដោយ
ស្បែកផ្សោត រួចព្រហាកឈើស្នែងចូលដែរ[ធ] ១២ត្រូវយក
ប្រដាប់ប្រដាទាំងអស់[ន] ដែលសំរាប់ប្រើក្នុងទីបរិសុទ្ធ ទៅ
ដាក់ក្នុងសំពត់ពណ៌ផ្ទៃមេឃ ហើយគ្របនឹងស្បែកផ្សោត
រួចសឹកឈើស្នែងចូល[ប] ១៣ត្រូវកាយផេះ[ផ]ពីអាសនា[ព]ចេញ
ហើយក្រាលសំពត់ពណ៌ស្វាយពីលើ ១៤ព្រមទាំងដាក់
ប្រដាប់ប្រដា[ភ]ដែលសំរាប់ប្រើនៅអាសនានោះផង គឺជើង
ពាន[ម] សម[យ] ចបចូក[រ] ផើង[ល] និងអស់ទាំងប្រដាប់ប្រដានៃ
អាសនានោះ រួចត្រូវក្រាលស្បែកផ្សោតពីលើ ហើយ
ព្រហាកឈើស្នែង[វ]ចូល ១៥កាលណាអើរ៉ុន និងពួកកូន
លោកបានគ្របទីបរិសុទ្ធ ព្រមទាំងប្រដាប់ប្រដាទាំងប៉ុន្មាន
ជាស្រេចហើយ ក្នុងវេលាដែលពួកជំនុំរៀបដំណើរចេញ
ទៅ[ស] នោះពួកកូនចៅកេហាត់[ហ] ត្រូវមកលីសែងរបស់ទាំង
នោះ[ឡ] តែមិនត្រូវឱ្យពាល់ដល់របស់បរិសុទ្ធ[អ]ណាមួយឡើយ
ក្រែងត្រូវស្លាប់[ក,ខ] របស់ទាំងនោះជាបន្ទុកលើពួកកូនចៅ
កេហាត់ក្នុងត្រសាលជំនុំ ។

១៦ឯអេលាសារ[គ]ជាកូនអើរ៉ុនដ៏ជាសង្ឃ នោះត្រូវត្រួត
ខាងប្រេងសំរាប់ចង្កៀង[ឃ] គ្រឿងក្រអូប[ង] ដង្វាយម្សៅដែល
ថ្វាយជានិច្ច[ច] និងប្រេងចាក់លាប ហើយត្រូវត្រួតត្រាលើ
រោងឧបោសថទាំងមូលព្រមទាំងប្រដាប់ប្រដានៅក្នុងរោង
នោះទាំងប៉ុន្មាន នឹងទីបរិសុទ្ធ ហើយប្រដាប់ប្រដាសំរាប់
ទីនោះផង ។

១៧ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុនថា ១៨កុំឱ្យកាត់ពូជគ្រួសារកេហាត់ឱ្យបាត់ពីពួកលេវី
ឡើយ ១៩គឺត្រូវធ្វើនឹងគេយ៉ាងនេះវិញ ដើម្បីឱ្យគេរស់
នៅឥតត្រូវស្លាប់ឡើយ ក្នុងកាលដែលគេចូលទៅឯរបស់
ទាំងប៉ុន្មានដែលបរិសុទ្ធបំផុត[ឆ] គឺត្រូវឱ្យអើរ៉ុន និងពួកកូន
លោក[ជ]ចូលទៅដំរូវការងារ និងបន្ទុកឱ្យគេរៀងខ្លួន[ឈ]
២០តែមិនត្រូវឱ្យគេចូលទៅមើល[ញ] កំពុងដែលគ្របរបស់
បរិសុទ្ធទាំងប៉ុន្មានឡើយ ក្រែងត្រូវស្លាប់ ។

## ពួកកូនចៅគើសុន

២១ព្រះយេហូវ៉ា ទ្រង់បង្គាប់ដល់ម៉ូសេថា ២២ចូររាប់
ចំនួននៃពួកកូនចៅគើសុនដែរ តាមគ្រួសារតាមវង្សានុវង្ស
របស់ឪពុកគេ ២៣ត្រូវរាប់គេចាប់តាំងពីអាយុ៣០ឆ្នាំឡើង
ទៅ រហូតដល់៥០ឆ្នាំ[ដ] គឺអស់អ្នកដែលត្រូវទទួលការងារ
ក្នុងត្រសាលជំនុំបាន ២៤ឯក្រសួងរបស់ពួកគ្រួសារ គើសុន
នោះគឺជាការបំរើ និងការលីសែងផង ២៥ត្រូវឱ្យគេសែង
ផ្ទាំងសំពត់ទាំងប៉ុន្មាន ដែលសំរាប់រោងឧបោសថ[ឋ] ព្រម
ទាំងត្រសាលជំនុំ[ឌ] និងគំរប[ឍ]នៃត្រសាល គំរបស្បែកផ្សោត
ដែលគ្របពីលើ ហើយនិងវាំងបាំងមាត់ទ្វារត្រសាលជំនុំ
២៦វាំងទីលាន វាំងបាំងមាត់ទ្វារទីលានដែលនៅព័ទ្ធ[ណ]
ជុំវិញរោងឧបោសថ ហើយនិងអាសនា[ត] និងអស់ទាំងខ្សែ
ប្រដាប់ប្រដា[ថ]សំរាប់ការងារទាំងប៉ុន្មាន ហើយគ្រប់ទាំង
របស់អ្វីផ្សេងៗឯទៀត គឺការនោះឯងដែលគេត្រូវបំរើ
២៧ឯក្រសួងរបស់ពួកកូនចៅគើសុន ក្នុងការលីសែង ឬ
ការងារអ្វីក្ដី នោះស្រេចនៅអើរ៉ុន និងពួកកូនលោក[ទ] គឺ
ត្រូវឱ្យលោកចាត់ចែង[ធ]ការរបស់គេទាំងអស់ ២៨នេះហើយ
ជាក្រសួងនៃអស់ទាំងគ្រួសាររបស់ពួកកូនចៅគើសុន[ន] ក្នុង
ត្រសាលជំនុំ ហើយបញ្ញើដែលផ្ញើទុកនឹងគេ នោះនៅ
ក្រោមបង្គាប់របស់អ៊ីថាម៉ារ[ប] ជាកូនអើរ៉ុនដ៏ជាសង្ឃ ។

## ពួកកូនចៅម្រ៉ារី

២៩ឯពួកកូនចៅម្រ៉ារី នោះត្រូវរាប់[ផ]គេតាមគ្រួសារ
តាមវង្សានុវង្សរបស់ឪពុកគេ[ព] ៣០ចាប់តាំងពីអាយុ៣០ឆ្នាំ

**៤:៤** ច ខ.១៩
**៤:៥** ឆ ជន ១:៥១ ជ នក ២៦:៣១,៣៣ ឈ ១រប ២៣:២៦
**៤:៦** ញ នក ២៥:៥ ដ នក ២៥:១៣–១៥ ១ពវ ៨:៧ ២រប ៥:៨
**៤:៧** ឋ លវ ២៤:៦ ឌ នក ៣៩:៣៦ យរ ៥២:១៩ ឍ នក ២៥:៣០
**៤:៨** ណ នក ២៦:២៦–២៨
**៤:៩** ត នក ២៥:៣៨
**៤:១០** ថ ខ.១២
**៤:១១** ទ នក ៣០:១ ធ នក ៣០:៤
**៤:១២** ន ជន ៣:៣១ ប ខ.១០
**៤:១៣** ផ លវ ១:១៦ ព នក ២៧:១–៨ ជន ៣:៣១
**៤:១៤** ភ នក ៣១:៩ ម នក ២៧:៣ យ ១រប ២៨:១៧ ២រប ៤:១៦ រ ២រប ៤:១១ ល នក ២៧:៣ ជន ៧:៨៤ ២រប ៤:៨ យរ ៥២:១៨ វ នក ២៧:៦
**៤:១៥** ស ខ.៥ ហ ជន ៣:២៧ ឡ ជន ៧:៩ អ ខ.៤ ក នក ២៨:៤៣ ខ ជន ១:៥១ ២សយ ៦:៦,៧
**៤:១៦** គ លវ ១០:៦ ជន ៣:៣២ ឃ នក ២៥:៦ ង នក ២៥:៦ ច ២៩:៤១ លវ ៦:១៤–២៣
**៤:១៩** ឆ ខ.១៥ ជ ខ.២៧ ឈ ជន ៣:៣២
**៤:២០** ញ នក ១៩:២១
**៤:២៣** ដ ខ.៣
**៤:២៥** ឋ នក ២៧:១០–១៨ ឌ ជន ៣:២៥ ឍ នក ២៦:១៤ **៤:២៦** ណ នក ២៧:១៦ ត នក ២៧:៩ ថ ជន ៣:២៦ **៤:២៧** ទ ខ.១៩ ធ ជន ៣:២៥,២៦
**៤:២៨** ន ជន ៧:៧ ប នក ៦:២៣ **៤:២៩** ផ នក ៣០:១២ ព លប ៦:២៣

**៤:៥** *សេចក្ដីបន្ទាល់* មើលការពន្យល់ នក ២៥:២២ ។
**៤:៦** *ផ្សោត* ជាសត្វសមុទ្រមកពីសមុទ្រក្រហម ។
**៤:៧** *តុនៃនំបុ័ងតាំងទុក* មើលការពន្យល់ នក ២៥:៣០ ។
**៤:១៦** *អេលាសារ . . . ជាសង្ឃ នោះត្រូវត្រួតខាង . . .* សង្ឃកាន់តែខ្ពស់កាន់តែនៅជិតទីកន្លែងដ៏បរិសុទ្ធបំផុត ក្នុងនាមជាអ្នក តំណាងឱ្យប្រជាជន ។ បើសង្ឃនោះពុំអាចធ្វើបានទេនោះ បណ្ដាជនពុំអាចថ្វាយបង្គំបានឡើយ ។

ឡើងទៅ រហូតដល់៥០ឆ្នាំ គឺអស់អ្នកដែលត្រូវទទួលការ
ងារក្នុងត្រសាលជំនុំបាន [៣១]នេះជាបញ្ជីដែលផ្ញើទុកនឹង
គេឱ្យលីសែង តាមក្រសួងគេក្នុងត្រសាលជំនុំ គឺក្តាររបស់
រោងឧបោសថ ព្រមទាំងរនុក សសរ ហើយនិងជើង[ភ]
[៣២]សសរទីលានដែលនៅជុំវិញ និងជើង ចំរឹង ខ្សែ[ម]
ព្រមទាំងប្រដាប់ប្រដាទាំងប៉ុន្មាន ហើយនិងរបស់ទាំងអស់
ដែលសំរាប់គាំពារផង ត្រូវឱ្យឯងដំរូវដោយឈ្មោះប្រដាប់
ប្រដា ដែលត្រូវផ្ញើទុកឱ្យគេលីសែង [៣៣]នេះហើយជា
ក្រសួងនៃអស់ទាំងគ្រួសារពួកកូនចៅម្រ៉ារី តាមការងារ
គេទាំងប៉ុន្មានក្នុងត្រសាលជំនុំ ដែលនៅក្រោមបង្គាប់
អ៊ីថាម៉ារ[យ] ជាកូនអើរ៉ុនដ៏ជាសង្ឃ ។

## ការរាប់ចំនួនកូនចៅនៃពួកលេវី

[៣៤]រួចម៉ូសេ អើរ៉ុន និងពួកដែលជាកំពូលលើពួក
ជំនុំទាំងប៉ុន្មាន ក៏រាប់ពួកកូនចៅកេហាត់[រ] តាមគ្រួសារ
តាមវង្សានុវង្សរបស់ឪពុកគេ [៣៥]ចាប់តាំងពីអាយុ៣០ឆ្នាំ
ឡើងទៅ រហូតដល់៥០ឆ្នាំ[ល] គឺអស់អ្នកដែលត្រូវទទួល
ការងារក្នុងត្រសាលជំនុំបាន [៣៦]ហើយពួកគេដែលបាន
រាប់តាមគ្រួសារ នោះមានចំនួន២ពាន់៧៥០នាក់ [៣៧]នេះ
ហើយជាពួកអ្នក ដែលបានរាប់ក្នុងគ្រួសារទាំងប៉ុន្មានរបស់
កេហាត់[វ] គឺអស់អ្នកដែលបំរើក្នុងត្រសាលជំនុំ ដែលម៉ូសេ
និងអើរ៉ុនបានរាប់ តាមព្រះបន្ទូល ដែលព្រះយេហូវ៉ាបាន
បង្គាប់មក ដោយសារម៉ូសេ ។

[៣៨]ឯពួកអ្នកដែលបានរាប់ ក្នុងពួកកូនចៅគើសុន[ស] តាម
គ្រួសារ តាមវង្សានុវង្សរបស់ឪពុកគេ [៣៩]ចាប់តាំងពី
អាយុ៣០ឆ្នាំឡើងទៅ រហូតដល់៥០ឆ្នាំ គឺអស់អ្នកដែលត្រូវ
ទទួលការងារក្នុងត្រសាលជំនុំបាន [៤០]ពួកនោះដែលបាន
រាប់តាមគ្រួសារ តាមវង្សានុវង្សរបស់ឪពុកគេ នោះមាន
ចំនួន២ពាន់៦៣០នាក់ [៤១]នេះហើយជាពួកអ្នកដែលបាន
រាប់ក្នុងគ្រួសារទាំងប៉ុន្មានរបស់ពួកកូនចៅគើសុន គឺអស់
អ្នកដែលបំរើក្នុងត្រសាលជំនុំ ដែលម៉ូសេ និងអើរ៉ុនបាន
រាប់ តាមបង្គាប់ព្រះយេហូវ៉ា ។

[៤២]ឯពួកអ្នកដែលបានរាប់ ក្នុងគ្រួសារទាំងប៉ុន្មានរបស់
ពួកកូនចៅម្រ៉ារី តាមគ្រួសារ តាមវង្សានុវង្សរបស់
ឪពុកគេ [៤៣]ចាប់តាំងពីអាយុ៣០ឆ្នាំឡើងទៅ រហូតដល់
៥០ឆ្នាំ[ហ] គឺអស់អ្នកដែលត្រូវទទួលការងារក្នុងត្រសាលជំនុំ
បាន [៤៤]ពួកនោះដែលបានរាប់តាមគ្រួសារ នោះមាន
ចំនួន៣ពាន់២០០នាក់ [៤៥]នេះហើយជាពួកអ្នកដែលបាន
រាប់ក្នុងគ្រួសារទាំងប៉ុន្មានរបស់ពួកកូនចៅម្រ៉ារី[ឡ] ដែល
ម៉ូសេ និងអើរ៉ុន បានរាប់ តាមព្រះបន្ទូលដែលព្រះយេហូវ៉ា
បានបង្គាប់មក ដោយសារម៉ូសេ ។

[៤៦]ឯអស់អ្នកដែលម៉ូសេ អើរ៉ុន និងពួកជាកំពូល ទាំង
ប៉ុន្មាន លើសាសន៍អ៊ីស្រាអែល បានរាប់[អ]ក្នុងពួកលេវី តាម
គ្រួសារ តាមវង្សានុវង្សរបស់ឪពុកគេ [៤៧]ចាប់តាំងពីអាយុ
៣០ឆ្នាំឡើងទៅ រហូតដល់៥០ឆ្នាំ[ក] គឺអស់អ្នកដែលបាន
ចូលទៅធ្វើការងារ ហើយលីសែងក្នុងត្រសាលជំនុំ [៤៨]នោះ
រួមគ្នាទាំងអស់ មាន៨ពាន់៥៨០នាក់[ខ] [៤៩]ម៉ូសេបានរាប់គេ
តាមបង្គាប់ព្រះយេហូវ៉ា គ្រប់គ្នាតាមក្រសួងការ តាមបន្ទុក
របស់ខ្លួន គឺយ៉ាងនោះហើយដែលលោកបានរាប់[គ]គេ តាម
ដែលព្រះយេហូវ៉ាទ្រង់បានបង្គាប់មក ។

## ការធ្វើឱ្យទីដំឡើងត្រសាលបរិសុទ្ធ

**៥** [១]ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា [២]ចូរបង្គាប់
ដល់ពួកកូនចៅអ៊ីស្រាអែល ឱ្យគេបណ្តេញអស់អ្នកដែល
កើតឃ្លង់[ក] ឬមានហូរខ្ទុះ[ខ] ឬដែលមិនស្អាត[គ]ដោយព្រោះ
ខ្មោចស្លាប់[ឃ] ឱ្យចេញទៅក្រៅទីដំឡើងត្រសាលទៅ [៣]ត្រូវ
ឱ្យទាំងប្រុស ទាំងស្រី ចេញទៅខាងក្រៅទីដំឡើង
ត្រសាលចុះ ដើម្បីកុំឱ្យគេនាំឱ្យទីដំឡើងត្រសាល ជាទី
ដែលអញនៅជាកណ្តាលគេ ទៅជាស្មោកគ្រោកឡើយ[ង]

**៤:៣១** ភ ជន ៣:៣៦
**៤:៣២** ម ជន ៣:៣៧
**៤:៣៣** យ នក ៣៨:២១
**៤:៣៤** រ ខ.២
**៤:៣៥** ល ខ.៣
**៤:៣៧** វ ជន ៣:២៧
**៤:៣៨** ស លប ៤៦:១១
**៤:៤៣** ហ ខ.៣
**៤:៤៥** ឡ ខ.២៩
**៤:៤៦** អ ជន ១:១៩
**៤:៤៧** ក ខ.៣
**៤:៤៨** ខ ជន ៣:៣៩
**៤:៤៩** គ ជន ៣:៣៩
**៥:២** ក លវ ១៣:២ ខ លវ ១៥:២ មថ ៩:២០ គ លវ ១៣:៣ ជន ៩:៦–១០ ឃ លវ ២១:១១
**៥:៣** ង នក ២៩:៤៥ លវ ២៦:១២ ២កថ ៦:១៦

**៥:២** *អ្នកកើតឃ្លង់* មើល លក ៥:១២–១៦ ១៧:១១–១៩ និងការពន្យល់ លវ ១៣:២ ។ *ឬមានហូរខ្ទុះ* មើលការពន្យល់ លវ ១៥:២ ។ ការហូរខ្ទុះនេះ គឺសំខាន់ផ្តោតទៅលើការរួមភេទ និងជម្ងឺរីងរៃ (លក ៨:៤៣–៤៨) ។ ដូច្នេះ មនុស្សណាដែលណាមានជម្ងឺបែបនេះត្រូវចេញពីគេ ដើម្បីឱ្យមនុស្សទាំងអស់នៅក្នុងត្រសាលបាន "ស្អាត" មុនចូលទៅចំពោះព្រះវត្តមានព្រះ ។ *មិនស្អាត* គឺជាពិធីបុណ្យមិនសមរម្យដែលត្រូវបានធ្វើឡើង ដោយសហគមន៍ ហើយអាចធ្វើមិនត្រឹមត្រូវនៅក្នុងរោងឧបោសថ ព្រមទាំងអ្នកចូលថ្វាយបង្គំនោះមិនស្អាត និងមិនបរិសុទ្ធ ។ *ខ្មោចស្លាប់* ត្រូវបានគេចាត់ទុកជារបស់មិនស្អាតដំណើរនៃភាពពុករលួយរូបកាយ និងជម្ងឺគឺជាភស្តុតាងបង្ហាញមកខាងក្រៅយ៉ាងច្បាស់ ។ ជាធម្មតាការប៉ះពាល់រាង្គកាយ មនុស្សមានជម្ងឺទោះស្លាប់ឬរស់ក្តី ក៏ត្រូវចាត់ទុកថាមិនស្អាត ព្រោះអាចឆ្លងជម្ងឺបាន ។ តែទោះជាយ៉ាងណា នៅតែអាចប្រាស្រ័យទាក់ទងគ្នាបាន លុះត្រាតែមនុស្សដែលត្រូវបាន ចាត់ទុកថាមិនស្អាតនោះត្រូវបានសំអាតជាមុនសិន (មើលការពន្យល់ ៦:៦) ប៉ុន្តែចំពោះនៅក្នុងគម្ពីរសញ្ញាថ្មីវិញ ព្រះយេស៊ូវបានប្រាស្រ័យទាក់ទងជាមួយទាំងមនុស្សរស់ និងមនុស្សស្លាប់ (លក ៨:៥៤) ។

**៥:៣** *ទាំងប្រុសទាំងស្រី* ការទាមទារភាពស្អាត គឺសំដៅទៅលើមនុស្សទាំងពីរភេទ ។ បំណងសំខាន់នៃការទាមទារឱ្យស្អាតនេះគឺដើម្បីនឹងអាច ឈរនៅចំពោះមុខព្រះវត្តមានរបស់ព្រះបាន ។ គ្មានភាពមិនស្អាតណាមួយអាចនៅចំពោះព្រះភក្ត្រទ្រង់បាននោះឡើយ ឬថាកន្លែងដែលព្រះគង់នៅនោះគ្មានបាបសោះឡើយ (វវ ២១:២–៣,២៧) ។

៤ដូច្នេះពួកកូនចៅអ៊ីស្រាអែលក៏ធ្វើយ៉ាងនោះ គឺគេឱ្យពួក
អ្នកទាំងនោះចេញទៅក្រៅទីដំឡើងត្រសាលទៅ ដូចជា
ព្រះយេហូវ៉ា ទ្រង់បានមានបន្ទូលនឹងម៉ូសេ ពួកកូនចៅ
អ៊ីស្រាអែលក៏ធ្វើសំរេចដូច្នោះ ។

## ការធ្វើសំណងដើម្បីនឹងលោះបាប

៥ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ឱ្យប្រាប់ដល់ពួកកូនចៅ
អ៊ីស្រាអែលថា ៦បើកាលណាមនុស្សប្រុសឬស្រីនឹងប្រព្រឹត្ត
អំពើបាបទាស់នឹងអ្នកណា ទាំងប្រព្រឹត្តរំលង[ច] ចំពោះ
ព្រះយេហូវ៉ាផង ហើយមានទោសដូច្នោះ[ឆ] ៧នោះត្រូវឱ្យ
លន់តួ[ជ]បាបដែលខ្លួនបានប្រព្រឹត្ត ហើយប្រគល់[ឈ]អ្វីៗនោះ
ទៅវិញទាំងមូល ព្រមទាំងថែម១ភាគក្នុង៥ទៀត ឱ្យដល់
អ្នកដែលខ្លួនមានទោសចំពោះគេផង ៨តែបើគ្មានអ្នកណា
មានច្បាប់នឹងទទួលសំណងដែលខ្លួនសង ដើម្បីនឹងលោះ
បាបខ្លួននោះទេ នោះសំណងដែលសងដល់ព្រះយេហូវ៉ា
ដោយព្រោះទោសខ្លួន និងត្រូវបានជារបស់សង្ឃវិញ ព្រម
ទាំងពពែឈ្មោល[ញ]ដែលសំរាប់ឱ្យធួននឹងបាប ដែលត្រូវ
ថ្វាយឱ្យធួននឹងខ្លួននោះផង[ដ] ៩ហើយគ្រប់ទាំងដង្វាយដែល
ថ្វាយដោយលើកចុះឡើង ពីដង្វាយបរិសុទ្ធនៃពួកកូនចៅ
អ៊ីស្រាអែល ដែលគេនាំយកមកប្រគល់ដល់សង្ឃ នោះត្រូវ
បានជារបស់ផងលោក[ឋ] ១០ហើយអស់ទាំងរបស់អ្វីដែល
មនុស្សណានឹងញែកជាបរិសុទ្ធ គឺរបស់ណាក៏ដោយដែល
មនុស្សនឹងប្រគល់ដល់សង្ឃ នោះត្រូវបានជារបស់ផង
លោកហើយ[ឌ] ។

## ការល្បងចំពោះប្រពន្ធដែលមិនស្មោះត្រង់

១១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ១២ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា បើប្រពន្ធរបស់អ្នកណាបែរចេញទៅ[ឍ]
ប្រព្រឹត្តក្បត់នឹងប្តី ១៣ហើយមានអ្នកណាសេពសម្ពពនឹង
នាង[ណ] តែការនោះនៅកំបាំងនឹងភ្នែកប្តី ឥតអ្នកណាមួយ
ដឹងសោះ គឺនាងបានទៅជាសៅហ្មង ដោយស្ងាត់កំបាំង
ហើយគ្មានអ្នកណាធ្វើបន្ទាល់ទាស់នឹងនាង ក៏គ្មានអ្នកណា
មួយបានទាន់ដែរ ១៤រួចប្តីកើតមានចិត្តប្រចណ្ឌនឹងប្រពន្ធ
ដោយមានសេចក្តីសង្ស័យ ហើយនាងក៏សៅហ្មងមែនឬ
បើប្តីកើតមានចិត្តប្រចណ្ឌ[ត] ដោយមានសេចក្តីសង្ស័យតែ
ប្រពន្ធមិនបានសៅហ្មងទេ ១៥នោះប្តីត្រូវនាំប្រពន្ធខ្លួនទៅ
ឯសង្ឃ ព្រមទាំងយកដង្វាយជាម្សៅឱក[ថ] ១ខ្ញឹង[ទ]សំរាប់
ប្រពន្ធផង មិនត្រូវចាក់ប្រេង ឬដាក់កំញានពីលើទេ ដ្បិតជា
ដង្វាយខាងឯសេចក្តីប្រចណ្ឌ[ធ] ទុកជាដង្វាយរំឭក[ន] សំរាប់
នឹងរំឭកពីអំពើដ៏លាមក ១៦ត្រូវឱ្យសង្ឃនាំនាងនោះមកជិត
ឱ្យឈរនៅចំពោះព្រះយេហូវ៉ា ១៧រួចត្រូវយកទឹកបរិសុទ្ធ
ចាក់ក្នុងចានដី ហើយយកធូលីដីក្នុងរោងឧបោសថដាក់ចុះ
ក្នុងទឹកនោះ ១៨ត្រូវឱ្យសង្ឃឱ្យនាងឈរនៅចំពោះព្រះ
យេហូវ៉ា ហើយបើកក្បាលនៅទទេ[ប] រួចត្រូវដាក់ដង្វាយ
រំឭក គឺជាដង្វាយខាងឯសេចក្តី ប្រចណ្ឌនោះនៅបាតដៃ
នាង[ផ] ហើយសង្ឃត្រូវកាន់ទឹកល្វីង ដែលនាំឱ្យត្រូវបណ្តាសា

**៥:៦** ច លវ ៦:២
ឆ លវ ៥:១៤–៦:៧
**៥:៧** ជ លវ ៥:៥
លក ១៩:៨
ឈ លវ ៥:១៦
**៥:៨** ញ លវ ៥:១៥
ដ លវ ៦:៦,៧
**៥:៩** ឋ លវ ៦:១៧
**៥:១០** ឌ លវ ៧:២៩–៣៤
**៥:១២** ឍ ខ.១៩–២១ នក ២០:១៤
**៥:១៣** ណ នក ២០:១៤
**៥:១៤** ត ខ.៣០ សភ ៦:៣៤ ២៧:៤ ៨:៦
**៥:១៥** ថ លវ ៦:២០
ទ នក ១៦:៣៦ ធ ខ.១៨,២៥ ន អគ ២១:២៣ ២៩:១៦
**៥:១៨** ប លវ ១០:៦ ១កថ ១១:៦ ផ ខ.១៥

**៥:៥–១០** ការតភ្ជាប់គ្នានៃខទាំងនេះ (សំដៅលើការប្រព្រឹត្តខុសរបស់បុគ្គល) ជាមួយនឹងល្បះខាងដើម (សំដៅលើភាពមិនស្អាតនៅក្នុងពិធីបុណ្យ) ប្រហែលជាចង់មានន័យថា ភាពមិនស្អាតដែលមើលឃើញនឹងភ្នែកផ្នែកខាងក្រៅនោះតែងតែមានឥទ្ធិពលទៅផ្នែកខាងក្នុងសហគមន៍កាន់តែខ្លាំង ។

**៥:៨** *ធួននឹងបាប* សូមមើលការពន្យល់ នក ២៥:១៧ លវ ១៧:១១ រម ៣:២៥ ។

**៥:១១–៣១** នៅក្នុងវគ្គនេះម្តងទៀតហើយ បានភ្ជាប់ទៅនឹងល្បះទាំងពីរខាងលើ តែហាក់បីដូចជាផ្តោតទៅលើបាបរបស់បុគ្គលធំទូលាយជាងមុន ។ ដំណើររឿងនៃភាពបរិសុទ្ធ (ស្អាត) បានចាប់ផ្តើមដោយសញ្ញានៅលើខ្លួនប្រាណរបស់បុគ្គល (ខ.១–៤) ក្រោយមកបន្តទៅមនុស្សផ្សេងទៀតតាមរយៈទំនាក់ទំនង (ខ.៥–១០) ហើយរំខានដល់បុរស និងស្ត្រីដែលបានរៀបការ (មើលការពន្យល់ នក ២០:១៤) ។

**៥:១៤** *កើតមានចិត្តប្រចណ្ឌ* ការព្រួយបារម្ភនៅត្រង់នេះ ពុំមែនគ្រាន់តែប៉ះពាល់ដល់អារម្មណ៍របស់ប្តីប៉ុណ្ណោះទេ ប៉ុន្តែនេះគឺជាមូលដ្ឋានចុងក្រោយនៃព្រះវត្តមានរបស់ព្រះនៅក្នុងចំណោមរាស្ត្ររបស់ទ្រង់ (ខ.៣) ។

**៥:១៥–២៨** សកម្មភាពនៅក្នុងខទាំងនេះហាក់បីដូចជាតឹងរឹង និងសាហាវ ហើយលទ្ធផលក៏អាក្រក់ណាស់សម្រាប់ស្ត្រីដែលផិតប្តីដោយកំហឹងរបស់ប្តី ។ ស្ត្រីយ៉ាងនោះត្រូវបានគេនាំទៅឯសង្ឃ (ខ.១៥) ដែលជាកិច្ចចុងក្រោយនៃសេចក្តីមេត្តាករុណា ។

**៥:១៥,១៨** *ដង្វាយរំឭក* ដង្វាយជាម្សៅឱកសម្រាប់រំឭកពីអំពើបាប និងអំពើដ៏លាមក ។

**៥:១៧** *ទឹកបរិសុទ្ធ* ទឹកនេះប្រហែលត្រូវបានគេចាក់ចេញពីចានលង្ហិនមួយ (នក ៣៨:៨) ហើយដាក់ចូលទៅក្នុងចានក្លាំទីលានបរិសុទ្ធ សម្រាប់ឧទ្ទិសថ្វាយដល់ព្រះនៅក្នុងពិធីបុណ្យ ។

**៥:១៨** *បើកក្បាលនៅទទេ* មានន័យថា លាតត្រដាងពីការបើកចំហរនូវកំហុស ហើយព្រមទទួលយកការជំនុំជម្រះ ហើយនិងភាពសោកស្តាយ។ *ទឹកល្វីង ដែលនាំឱ្យត្រូវបណ្តាសា* ឬអាចនិយាយបានថា "អំពើបាបនេះបាននាំឱ្យទឹកល្វីង"។ វាពុំមែនគ្រាន់តែធ្វើឱ្យទឹកមានរសជាតិល្វីងនោះទេ ប៉ុន្តែទឹកនោះបានមានឥទ្ធិពលនាំមកនូវបណ្តាសាដ៏ល្វីងជូចត់ទៀតផង ។ តួនាទីរបស់ព្រះអម្ចាស់នៅក្នុងដំណើរការរឿងនេះ (ខ.១៦,២១,២៥) គឺត្រូវបានបញ្ជាក់ជាដដែលៗដើម្បីបង្ហាញថា ទឹកនេះពុំមែនជាឧបករណ៍នៃមន្តអាគម ហើយក៏ពុំមែនជាពិធីនៃការបំបាត់ភាពតានតឹង នៃផ្នែកចិត្តសាស្ត្រនោះដែរ ។ សេចក្តីសម្រេចធ្វើឡើងដោយគោរពដល់ស្ត្រីៗ ដែលត្រូវបានប្រឈមមុខនឹង ស្ថានភាពតានតឹងនៅក្នុងផ្លូវចិត្តរបស់នាង ហើយការឆ្លើយតបចំពោះផ្លូវចិត្តនេះ ក៏ក្លាយទៅជាទឹកល្វីងវិញ រួចការជំនុំជម្រះព្រះជាអ្នកសម្រេច ។

នោះនៅក្នុងដៃ[ត] ១៩រួចត្រូវឱ្យនាងស្បថ ដោយប្រាប់ថា បើ
គ្មានប្រុសដទៃណាមួយរួមដំណេកនឹងនាង ឬបើនាងមិន
បានបែរទៅឯសេចក្ដីសៅហ្មង[ភ]ដើម្បីនិងក្បត់ប្ដីទេ នោះ
ឱ្យនាងរួចពីទឹកល្វីង ដែលនាំឱ្យត្រូវបណ្ដាសា[ម]នេះចុះ
២០តែបើនាងដែលនៅក្រោមអំណាចប្ដី បានបែរចេញទៅ
រួមដំណេកនឹងប្រុសដទៃណាក្រៅពីប្ដីខ្លួន ឱ្យមានសេចក្ដី
សៅហ្មង[យ]វិញ ២១យ៉ាងនោះសង្ឃត្រូវឱ្យនាងស្បថ[រ] ដោយ
សម្បថដែលនាំឱ្យត្រូវបណ្ដាសា រួចនឹងបញ្ចេញវាចាថា
សូមព្រះយេហូវ៉ា ធ្វើឱ្យនាងទៅជាអ្នករងពាក្យដំនៀល
និងពាក្យប្រមាថនៅក្នុងសាសន៍របស់ខ្លួនចុះ ដោយព្រះ
យេហូវ៉ាទ្រង់ធ្វើឱ្យភ្លៅនាងរលួយ ហើយឱ្យពោះនាង
ហើមប៉ោងឡើង ២២ទឹក[ល]ដែលនាំឱ្យត្រូវបណ្ដាសា[វ]នេះ នឹង
ចូលទៅក្នុងពោះនាង ព្រមទាំងធ្វើឱ្យពោះនាងហើមប៉ោង
ឡើង ហើយឱ្យភ្លៅនាងរលួយទៅ រួចស្ត្រីនោះត្រូវទទួលថា
អាម៉ែន អាម៉ែន[ស] ២៣ត្រូវឱ្យសង្ឃនោះកត់សេចក្ដីបណ្ដាសា
ទាំងនេះចុះក្នុងសៀវភៅ[ហ]ហើយយកទឹកល្វីងមកលុបចេញ
២៤រួចត្រូវឱ្យនាងផឹកទឹកល្វីងដែលនាំឱ្យត្រូវបណ្ដាសាទៅ
ទឹកនោះនឹងចូលទៅក្នុងនាង ត្រឡប់ទៅជាល្វីង ២៥រួចត្រូវ
ឱ្យសង្ឃយកដង្វាយនោះ ដែលត្រូវខាងសេចក្ដីប្រចណ្ឌ ពី
ដៃនាងមកគ្រវីថ្វាយ នៅចំពោះព្រះយេហូវ៉ា[ឡ] ហើយយក
ទៅឯអាសនា ២៦នោះត្រូវឱ្យសង្ឃយកម្សៅពីដង្វាយនោះ[អ]
១ក្ដាប់ ទុកជាសេចក្ដីរំឭកទៅដុតលើអាសនា រួចសឹមឱ្យ
នាងផឹកទឹកនោះ ២៧កាលណាបានឱ្យផឹកទឹករួចហើយ បើ
នាងមានសៅហ្មងមែន ដោយបានក្បត់ប្ដី នោះទឹកដែល
នាំឱ្យត្រូវបណ្ដាសានឹងចូលទៅក្នុងនាង ត្រឡប់ទៅជាល្វីង
ពោះនាងនឹងហើមប៉ោងឡើង ហើយភ្លៅនាងនឹងរលួយ
ទៅ នាងនឹងទៅជាអ្នករងសេចក្ដីដំនៀល[ក]នៅក្នុងសាសន៍
របស់ខ្លួន ២៨តែបើមិនបានសៅហ្មងទេ គឺនាងបរិសុទ្ធស្អាត
វិញ នោះនឹងបានរួច ហើយនិងមានកូនផង ២៩នេះហើយ
ជាច្បាប់ខាងឯសេចក្ដីប្រចណ្ឌ កាលណាស្ត្រីណា ដែលនៅ
ក្រោមអំណាចប្ដី នឹងបែរចេញទៅក្បត់ប្ដីខ្លួនឱ្យមានសៅ
ហ្មង[ខ] ៣០ឬបើមានមនុស្សណាកើតមានចិត្តប្រចណ្ឌ[គ]នឹង
ប្រពន្ធ ដោយមានសេចក្ដីសង្ស័យ នោះត្រូវនាំនាងទៅឱ្យ
ឈរនៅចំពោះព្រះយេហូវ៉ា ហើយត្រូវឱ្យសង្ឃធ្វើសំរេច
តាមច្បាប់នេះគ្រប់ចំពូក ៣១គឺយ៉ាងដូច្នោះ ដែលមនុស្ស
នោះនឹងបានរៀររួច ពីសេចក្ដីទុច្ចរិត តែឯស្ត្រីនោះ ត្រូវ
ទ្រាំទ្រនឹងអំពើ[ឃ]ដ៏លាមករបស់ខ្លួនវិញ ។

## ពួកណាសារីត

៦ ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា កាលណាមនុស្សប្រុសឬស្រីណានឹង
ញែកខ្លួនចេញ[ក] ដោយបន់បំណន់[ខ]របស់ពួកណាសារីតដើម្បី
នឹងញែកខ្លួនចេញថ្វាយព្រះយេហូវ៉ា[គ] ៣នោះត្រូវញែកខ្លួន
ឱ្យផុតចេញពីស្រាទំពាំងបាយជូរ[ឃ] និងគ្រឿងស្រវឹងមិន
ត្រូវបរិភោគទឹកខ្មេះ[ង] ដែលធ្វើពីស្រាទំពាំងបាយជូរ ឬទឹក
ខ្មេះដែលធ្វើពីគ្រឿងស្រវឹងណានីមួយឡើយ ក៏មិនត្រូវផឹក
ទឹកទំពាំងបាយជូរ ឬបរិភោគផ្លែទំពាំងបាយជូរ[ច] ទោះ
ស្រស់ឬក្រៀមផង ៤ក្នុងវេលាដែលញែកខ្លួនចេញដូច្នេះ
នោះមិនត្រូវបរិភោគអ្វី ដែលធ្វើពីទំពាំងបាយជូរឡើយ
ចាប់តាំងពីគ្រាប់ទៅដល់សំបកផង ៥នៅវេលាដែលញែក
ខ្លួនដោយបន់បំណន់នោះមិនត្រូវទាំងឱ្យកាំបិត[ឆ]មកប៉ះសក់
ផង[ជ] ត្រូវឱ្យបានបរិសុទ្ធ ដរាបដល់បានសំរេចកំណត់ដែល
ញែកខ្លួនចេញថ្វាយដល់ព្រះយេហូវ៉ា គឺត្រូវទុកឱ្យសក់ដុះ
វែង ៦នៅវេលាដែលញែកខ្លួនចេញថ្វាយព្រះយេហូវ៉ា
នោះមិនត្រូវទៅជិតខ្មោចស្លាប់ណាមួយឡើយ[ឈ] ៧គឺមិន
ត្រូវឱ្យខ្លួនសៅហ្មង[ញ] ដោយព្រោះឪពុកម្ដាយ ឬបងប្អូន

**៥:១៨** ត ខ.១៩
**៥:១៩** ភ ខ.១២, ២៩ ម ខ.១៨
**៥:២០** យ ខ.១២
**៥:២១** រ យស ៦:២៦ ១សយ ១៤:២៤ នហ ១០:២៩
**៥:២២** ល ទដ ១០៩:១៨ វ ខ.១៨ ស ចទ ២៧:១៥
**៥:២៣** ហ យរ ៤៥:១
**៥:២៥** ឡ លវ ៨:២៧
**៥:២៦** អ លវ ២:២
**៥:២៧** ក អស ៤៣:២៨ ៦៥:១៥ យរ ២៦:៦ ២៩:១៨ ៤២:១៨ ៤៤:១២, ២២ សក ៨:១៣
**៥:២៩** ខ ខ.១៩
**៥:៣០** គ ខ.១៤
**៥:៣១** ឃ លវ ៥:១
**៦:២** ក ខ.៥ លប ២៨:២៣ ខ ខ.៦ គ ពច ១៣:៥ ១៦:១៧
**៦:៣** ឃ លវ ១០:៩ លក ១:១៥ ង នរ ២:១៤ ទដ ៦៩:២១ សភ ១០:២៦ ច លវ ២៥:៥
**៦:៥** ឆ ទដ ៥២:២ ៥៧:៤ ៥៩:៧ អស ៧:២០ អក ៥:១ ជ ១សយ ១:១១
**៦:៦** ឈ លវ ២១:១–៣ ជន ១៩:១១–២២
**៦:៧** ញ ជន ៩:៦

**៥:២១** *ធ្វើឱ្យភ្លៅនាងរលួយ ហើយឱ្យពោះនាងហើមប៉ោងឡើង* នេះគឺជាឃ្លានៃរបៀបប្រើភាសា ដែលនិយាយសំដៅទៅលើការបាត់បង់សមត្ថភាពបង្កើតកូន ("ខ.២២,២៧ ហើយបើមានផ្ទៃពោះក៏ពុំអាចរក្សាកូនបាន") ។

**៦:២** *មនុស្សប្រុស ឬស្រី* សូមមើលក្នុងជំពូក ៣០ ដែលនិយាយអំពីការបន់បំណន់របស់មនុស្សប្រុស និងមនុស្សស្រី ។ *បំណន់របស់ពួកណាសារីត* ក្រុមនេះត្រូវបានញែកសម្រាប់តែបម្រើផ្នែកថ្វាយបង្គំព្រះក្នុងពេលកំណត់ជាក់លាក់ណាមួយ ឬនៅក្នុងឱកាសណាមួយយ៉ាងច្បាស់លាស់ (ពច ១៣:៥ ១សយ ១:១១) ។

**៦:៤** *អ្វីដែលធ្វើពីទំពាំងបាយជូរ* ការហាមនៅត្រង់នេះ ពុំមែនគ្រាន់តែស្រាទំពាំងបាយជូរនោះទេ សូម្បីតែគ្រាប់ និងសំបកទំពាំងបាយជូរក៏ត្រូវហាមដែរ។ មានចំណុចសំខាន់បីដែលពួកណាសារីតត្រូវធ្វើឱ្យបាន ក្នុងអំឡុងពេលញែកខ្លួនបន់បំណន់នោះគឺ (១).ការតមអាហារ (២).ការរក្សាខ្លួនប្រាណ (៣).ទំនាក់ទំនងជាមួយមនុស្សដទៃ ។

**៦:៥** *មិនត្រូវទាំងឱ្យកាំបិតមកប៉ះសក់ផង* មានន័យថា មិនឱ្យកោរសក់ មើលការពន្យល់ ពច ១៣:៥ ។ ដូច្នេះកាលដែលឃើញពួកណាសារីតមានសក់វែង នោះអាចសំគាល់បានថា ពួកគេបានកំពុងតែញែកខ្លួនបន់បំណន់អ្វីមួយដល់ព្រះអម្ចាស់ហើយ (លវ ២១:៥) ។ *ត្រូវឱ្យបានបរិសុទ្ធ* មើលការពន្យល់ នក ៣:៥ ។

**៦:៦** *ខ្មោចស្លាប់* សូមមើលការពន្យល់ ៥:២ ។ ចំពោះពួកណាសារីតវិញកាលណាប៉ះសាកសពនោះត្រូវបានពន្យាពេលក្នុងការញែកខ្លួនថ្វាយព្រះ ទោះជាខ្មោចញាតិមិត្តរបស់ខ្លួនក៏ដោយ (សូមមើល ខ.៧ ដែលផ្ទុយនឹង លវ ២១:១–៣) ។

ប្រុសស្រី ក្នុងកាលដែលគេស្លាប់នោះឡើយ ដ្បិតជាប់ការ
ញែកខ្លួនចេញថ្វាយព្រះហើយ ៨នៅវេលាដែលញែកខ្លួន
ចេញ នោះតែងជាបរិសុទ្ធដល់ព្រះយេហូវ៉ាជានិច្ច ៩បើ
មានមនុស្សណាស្លាប់ភ្លាម១រំពេចនៅជិតខ្លួន ធ្វើឱ្យខូចការ
ញែកខ្លួនចេញ[ដ] នោះត្រូវកោរសក់ចេញក្នុងថ្ងៃដែលបាន
ញែកជាស្អាតវិញ[ឋ] គឺត្រូវកោរសក់នៅថ្ងៃទី៧ ១០រួចដល់
ថ្ងៃទី៨[ឌ] ត្រូវយកលលក២ ឬព្រាបជំទើរ២[ឍ] ទៅប្រគល់
ដល់សង្ឃនៅមាត់ទ្វារត្រសាលជំនុំ[ណ] ១១ត្រូវឱ្យសង្ឃថ្វាយ១
ជាដង្វាយលោះបាប[ត] ហើយ១ទៀតជាដង្វាយដុត[ថ] ដើម្បី
ឱ្យធួននឹងអ្នកនោះ[ទ] ដោយព្រោះកំហុស ដែលបានធ្វើពី
ដំណើរខ្មោចស្លាប់នោះ ព្រមទាំងញែកអ្នកនោះចេញជា
បរិសុទ្ធនៅថ្ងៃនោះឯង ១២រួចត្រូវឱ្យអ្នកនោះបន់កំណត់
ពេលវេលា ដែលញែកខ្លួនចេញថ្វាយព្រះយេហូវ៉ា ជាថ្មី
ទៀត ហើយត្រូវយកកូនចៀម អាយុ១ខួប[ធ] មកសំរាប់ជា
ដង្វាយ ដោយព្រោះការរំលង[ន] ដ្បិតថ្ងៃមុនទាំងប៉ុន្មាន
បានសាបសូន្យហើយ ពីព្រោះបានខូចសេចក្តីបរិសុទ្ធខ្លួន
ហើយ ។

១៣នេះជាច្បាប់នៃពួក ណាសារីត ក្នុងកាលដែលកំណត់
ញែកខ្លួនចេញនោះបានសំរេចហើយ[ប] ត្រូវឱ្យនាំអ្នកនោះ
ទៅឯមាត់ទ្វារត្រសាលជំនុំ[ផ] ១៤ហើយអ្នកនោះត្រូវថ្វាយ
ដង្វាយរបស់ខ្លួន ដល់ព្រះយេហូវ៉ា គឺកូនចៀមឈ្មោល១
ឥតខ្ចោះ[ព]អាយុ១ខួប សំរាប់ជាដង្វាយដុត និងកូនចៀមញី១
ឥតខ្ចោះអាយុ១ខួប សំរាប់ជាដង្វាយលោះបាប[ភ] ហើយ
ចៀមឈ្មោល១[ម]ឥតខ្ចោះ សំរាប់ជាដង្វាយមេត្រី[យ] ១៥និង
កញ្ច្រែង១ផ្ទុកដោយនំបុ័ងឥតដំបែ នំធ្វើពីម្សៅយ៉ាងម៉ដ្ត
លាយដោយប្រេង[រ] នំក្រៀបឥតដំបែប្រោះដោយប្រេង
ហើយដង្វាយម្សៅ[ល] និងដង្វាយច្រួចនោះផង[វ] ១៦រួចត្រូវឱ្យ
សង្ឃយកទាំងអស់[ស]ទៅថ្វាយនៅចំពោះព្រះយេហូវ៉ា[ហ] ព្រម
ទាំងដង្វាយលោះបាប និងដង្វាយដុតរបស់អ្នកនោះ ដែរ[ឡ]
១៧ក៏ត្រូវថ្វាយចៀមឈ្មោល ជាយញ្ញបូជានៃដង្វាយមេត្រី[អ]
ដល់ព្រះយេហូវ៉ា ព្រមទាំងកញ្ច្រែងនំបុ័ងឥតដំបែរផង

**៦:៩** ដ ខ.១៨
ឋ លវ ១៤:៩
**៦:១០** ឌ លវ ១៤:១០
ឍ លវ ៥:៧
ណ លវ ១៤:១១
**៦:១១** ត នក ៣០:១០
ថ លប ៨:២០
ទ នក ២៩:៣៦
**៦:១២** ធ លវ ១២:៦
ន លវ ៥:១៥
**៦:១៣** ប កច
២១:២៦ ផ
លវ ១៤:១១
**៦:១៤** ព នក ១២:៥
ភ ខ.១១ លវ ៤:៣
១៤:១០ ម លវ ៥:១៥
យ លវ ៣:១
**៦:១៥** រ នក ២៩:២
ល លវ ២:១ ៦:១៤
វ លប ៣៥:១៤
**៦:១៦** ស លវ ១:៣
ហ ខ.១០ ឡ ខ.១១
**៦:១៧** អ លវ ៣:១
ក នក ២៩:៤១
ខ លវ ២៣:១៣
**៦:១៨** គ ខ.៩ កច
២១:២៤
**៦:១៩** ឃ លវ ៧:១២
**៦:២០** ង លវ ៧:៣០
ច លវ ២៧:៩
ឆ លវ ៧:៣៤
ជ សស ៩:៧
**៦:២១** ឈ ខ.១៣
ញ ខ.២
**៦:២៣** ដ ចទ ២១:៥
១រប ២៣:១៣
**៦:២៤** ឋ លប ២៨:៣
ចទ ២៨:៣–៦ ទដ

ត្រូវឱ្យសង្ឃថ្វាយដង្វាយម្សៅ[ក] និងដង្វាយច្រួចដែរ[ខ] ១៨នោះ
អ្នកណាសារីតត្រូវកោរសក់ នៃការញែកខ្លួនចេញ[គ]នៅត្រង់
មាត់ទ្វារត្រសាលជំនុំ រួចយកសក់ដែលបានទុកក្នុងវេលា
ញែកខ្លួនចេញនោះ ទៅដាក់លើភ្លើងដែលឆេះនៅក្រោម
យញ្ញបូជានៃដង្វាយមេត្រី ១៩ត្រូវឱ្យសង្ឃយកស្មាចៀមដែល
ស្ងោរឆ្អិនហើយ និងនំឥតដំបែ១ ពីក្នុងកញ្ច្រែង ហើយនិង
នំក្រៀបឥតដំបែ១ មកដាក់នៅដៃនៃអ្នកណាសារីតនោះ
ក្រោយដែលគេបានកោរសក់ហើយ[ឃ] ២០រួចត្រូវឱ្យសង្ឃ
គ្រវីរបស់ទាំងនោះ ទុកជាដង្វាយគ្រវី[ង]នៅចំពោះព្រះ
យេហូវ៉ា នេះជារបស់បរិសុទ្ធ[ច] សំរាប់សង្ឃនោះ ព្រមទាំង
ទ្រូងដែលគ្រវី និងស្មាដែលលើកចុះឡើងផង[ឆ] ក្រោយមក
ទើបអ្នកណាសារីតនោះ នឹងផឹកស្រាទំពាំងបាយជូរបាន[ជ] ។

២១នេះហើយជាច្បាប់ខាងឯពួកណាសារីត[ឈ] ដែលបាន
បន់បំណន់ ហើយខាងឯដង្វាយ ដែលគេត្រូវថ្វាយដល់ព្រះ
យេហូវ៉ា ដោយព្រោះការញែកខ្លួនចេញ ក្រៅពីដង្វាយ
ណាដែលគេយកមកបាន តាមបំណន់ដែលគេបន់នោះ[ញ] គឺ
យ៉ាងនោះដែលត្រូវធ្វើតាមច្បាប់នៃការញែកខ្លួនចេញ ។

## ពររបស់ពួកសង្ឃ

២២ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២៣ឱ្យប្រាប់ដល់អើរ៉ុន
និងពួកកូនលោកថា ត្រូវឱ្យឯងរាល់គ្នាឱ្យពរ[ដ]ដល់ពួកកូន
ចៅអ៊ីស្រាអែលដោយពាក្យយ៉ាងនេះ គឺត្រូវពោលនឹងគេ
ថា ២៤សូមឱ្យព្រះយេហូវ៉ាប្រទានពរ[ឋ] ហើយរក្សាឯង[ឌ]
២៥សូមឱ្យព្រះយេហូវ៉ាធ្វើឱ្យព្រះភក្ត្រទ្រង់ភ្លឺមកដល់ឯង[ឍ]
ព្រមទាំងផ្តល់ព្រះគុណដល់ឯងផង[ណ] ២៦សូមឱ្យព្រះយេហូវ៉ា
ងើប ព្រះនេត្រទ្រង់[ត]មកចំពោះឯង ហើយប្រទានឱ្យឯងបាន
សេចក្តីសុខ[ថ] ២៧គឺយ៉ាងដូច្នោះដែលត្រូវដាក់ឈ្មោះអញ[ទ]
លើពួកកូនចៅអ៊ីស្រាអែល ហើយអញនឹងឱ្យពរដល់គេ ។

២៨:៩ ១២៨:៥ ឌ ១សយ ២:៩ ទដ ១៧:៨ **៦:២៥** ឍ យប ២៩:២៤ ទដ ៤:៦
៣១:១៦ ៨០:៣ ១១៩:១៣៥ ណ លប ៤៣:២៩ ទដ ២៥:១៦ ៨៦:១៦ ១១៩:២៩
**៦:២៧** ត ចទ ២៨:១០ ២សយ ៧:២៣ ២រប ៧:១៤ នហ ៩:១០ យរ ២៥:២៩
អគ ៣៦:២៣

**៦:៩–១២** ចំណុចដែលទាក់ទងទៅនឹង ការផ្គត់ផ្គង់ម្ហូបអាហារដល់ពួកណាសារីតអាចមានជម្រើសបាន ។ នៅត្រង់វគ្គនេះបានដោះស្រាយជាមួយនឹងការដែលនឹងត្រូវកើតឡើងដោយគ្មានគម្រោងនៃជីវិតប្រចាំថ្ងៃ ។

**៦:១៣–២០** ការបំពេញកិច្ចការចប់សព្វគ្រប់របស់ពួកណាសារីត កាន់តែវែងចំណាយកាន់តែច្រើន ហើយចំណាយពេលចំពោះព្រះក៏កាន់តែយូរ ។

**៦:២៤–២៦** ការឱ្យពររបស់លោកអើរ៉ុន ដែលជាសេចក្តីបង្គាប់របស់ព្រះយេហូវ៉ា (ខ.២៧ "គឺយ៉ាងដូច្នេះដែលត្រូវដាក់ឈ្មោះអញលើពួកកូនចៅអ៊ីស្រាអែល ហើយអញនឹងឱ្យពរដល់គេ") ។ ព្រះពរទាំងនេះត្រូវបានលើកយកមកនិយាយម្តងទៀតនៅក្នុង ទដ ៦៧:១ (មើលការពន្យល់នៅទីនោះ) ។ នៅឆ្នាំ១៩៧៩ ផ្នែកសំខាន់នៃខនេះត្រូវបានគេរកឃើញនៅក្នុងរូបផ្នូរខ្មោចនៅក្រុងយេរូសាឡិម ។ ពាក្យទាំងនេះជាភាសាហេព្រើរដែលត្រូវបានសរសេរនៅលើបណ្តោងប្រាក់ពីរ ដែលបានធ្វើនៅក្នុងឆ្នាំ៦០០ មុន គ.ស ។

**៦:២៥** *ធ្វើឱ្យព្រះភក្ត្រទ្រង់ភ្លឺមកដល់ឯង* មានន័យថា ការទទួលបានព្រះពរ ។

**៦:២៦** *សេចក្តីសុខ* ជាភាសាហេព្រើរគឺ "សាឡូម" ដែលសំដៅទៅលើជីវិតពេញបរិបូរ ផ្នែកខាងឯសុខមាលភាព និងសេចក្តីសុចរិត (មើលការពន្យល់ យហ ១៤:២៧) ពុំមែនមានន័យថាគ្មានសង្គ្រាមនោះទេ ។

## ការថ្វាយដង្វាយសំរាប់ឆ្លងបុណ្យអាសនា

**៧** ១រីឯនៅថ្ងៃ ដែលម៉ូសេបានដំឡើងរោងឧបោសថរួច
ជាស្រេច[ក] ហើយបានលាបប្រេង[ខ]ញែកចេញជាបរិសុទ្ធ
ព្រមទាំងប្រដាប់ប្រដាទាំងប៉ុន្មាន[គ] និងអាសនា ហើយ
គ្រឿងនៃអាសនាទាំងប៉ុន្មាន ដោយលាបប្រេង ញែក
ចេញជាបរិសុទ្ធ[ឃ] ២នោះពួកដែលជាកំពូលលើសាសន៍
អ៊ីស្រាអែល[ង] គឺជាពួកមេលើវង្សានុវង្សរបស់ឪពុកគេ បាន
ថ្វាយដង្វាយ អ្នកទាំងនោះជាកំពូលលើពូជអំបូរទាំងប៉ុន្មាន
ដែលបានត្រួតលើការរាប់[ច]ពួកបណ្តាជនទាំងឡាយ ៣គេ
ក៏យកដង្វាយរបស់ខ្លួនមកនៅចំពោះព្រះយេហូវ៉ា គឺរទេះ
ផ្ទុរ៦[ឆ] និងគោ១២ គឺ២នាក់ថ្វាយរទេះ១ ហើយម្នាក់ៗ
ថ្វាយគោមួយៗ គេនាំយកដង្វាយនោះមក នៅមុខរោង
ឧបោសថ ។
៤ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដល់ម៉ូសេថា ៥ចូរ
ទទួលពីគេចុះ ដើម្បីនឹងប្រើសំរាប់ការងារនៃត្រសាលជំនុំ
ត្រូវឱ្យឯងប្រគល់ទៅពួកលេវី តាមក្រសួងរបស់គេរៀង
ខ្លួន ៦ដូច្នេះម៉ូសេក៏ទទួលរទេះទាំងនោះ ព្រមទាំងគោផង
ប្រគល់ឱ្យដល់ពួកលេវី ៧លោកឱ្យរទេះ២ និងគោ២នឹម
ទៅពួកកូនចៅគើសុន[ជ] តាមក្រសួងគេ ៨ហើយរទេះ៤
និងគោ៤នឹម ទៅពួកកូនចៅម្រ៉ារី[ឈ] តាមក្រសួងគេ នៅ
ក្រោមបង្គាប់អ៊ីថាម៉ារ ជាកូនអើរ៉ុន ដ៏ជាសង្ឃ ៩តែមិន
បានឱ្យដល់ពួកកូនចៅកេហាត់ទេ[ញ] ពីព្រោះក្រសួងគេត្រូវ
ខាងទីបរិសុទ្ធ គេត្រូវតែលីសែង[ដ]វិញ ។
១០ពួកដែលជាកំពូលទាំងនោះ[ឋ] ក៏ថ្វាយដង្វាយសំរាប់
បុណ្យឆ្លងអាសនា[ឌ] នៅថ្ងៃដែលលាបប្រេង គឺគេនាំយក
ដង្វាយគេមកនៅមុខអាសនា ១១រួចព្រះយេហូវ៉ាទ្រង់មាន
បន្ទូលនឹងម៉ូសេថា ត្រូវឱ្យពួក ដែលជាកំពូលនេះថ្វាយ
ដង្វាយរបស់គេ ក្នុង១ថ្ងៃម្នាក់ សំរាប់បុណ្យឆ្លងអាសនា ។
១២ឯអ្នកដែលថ្វាយដង្វាយរបស់ខ្លួន ក្នុងថ្ងៃមុនដំបូង
នោះគឺណាសូន[ឍ] ជាកូនអ័មីន៉ាដាប់ ក្នុងពូជអំបូរយូដា
១៣ហើយដង្វាយរបស់លោក គឺជាថាសប្រាក់១[ណ] ទំងន់

**៧:១** ក នក ៤០:១៧ ខ នក ៣០:២៦ គ នក ៤០:៩ ឃ ខ.៨៤,៨៨ នក ៤០:១០ ២របា ៧:៩ **៧:២** ង ជន ១:៥–១៦ ច ជន ១:១៩ **៧:៣** ឆ លប ៤៥:១៩ ១សយ ៦:៧–១៤ ១របា ១៣:៧ **៧:៧** ជ ជន ៤:២៤–២៦ **៧:៨** ឈ ជន ៤:៣១–៣៣ **៧:៩** ញ ជន ៤:៤ ដ ជន ៤:១៥ **៧:១០** ឋ ខ.១ នក ២៩:៣៦ ឌ ២របា ៧:៩ **៧:១២** ឍ ជន ១:៧ **៧:១៣** ណ នក ២៧:៣ ត ខ.៨៥ ថ នក ៣០:១៣ លវ ២៧:៣–៧ ទ លវ ២:១ ជន ៦:១៥ ១៥:៤ **៧:១៤** ធ ខ.២០ ១ពវ ៧:៥០ ២ពវ ២៥:១៤ ២របា ៤:២២ ២៤:១៤ ន ខ.៨៦ ប នក ២៥:៦ **៧:១៥** ផ នក ២៤:៥ ២៩:៣ ជន ២៨:១១ ព លវ ១:៣ **៧:១៦** ភ លវ ៤:៣ **៧:១៧** ម ជន លវ ៣:១ យ ជន ១:៧ **៧:១៨** រ ជន ១:៨ **៧:២០** ល ខ.១៤ **៧:២៤** វ ជន ១:៩

១៣០ដំឡឹង[ត] ចានគោមប្រាក់១ ទំងន់៧០ដំឡឹង[ថ] តាម
ដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ[ទ] ទាំង២ដាក់ពេញដោយម្សៅ
យ៉ាងម៉ដ្ត លាយដោយប្រេង សំរាប់ជាដង្វាយម្សៅ ១៤កូន
ចានមាស១[ធ] ទំងន់១០ដំឡឹង[ន] ដាក់ពេញដោយកំញាន[ប]
១៥គោស្ទាវ១[ផ] ចៀមឈ្មោល១ កូនចៀមឈ្មោល១ អាយុ
១ខួប សំរាប់ជាដង្វាយដុត[ព] ១៦ពពែឈ្មោល១ សំរាប់
ជាដង្វាយលោះបាប[ភ] ១៧ហើយគោឈ្មោល២ ចៀម
ឈ្មោល៥ ពពែឈ្មោល៥ និងកូនចៀមឈ្មោល៥អាយុ១
ខួបសំរាប់ជាដង្វាយមេត្រី[ម] នេះហើយជាដង្វាយរបស់ណា
សូនជាកូនអ័មីន៉ាដាប់[យ] ។
១៨នៅថ្ងៃទី២ នោះនេថានេល ជាកូនស៊ូហារ[រ]ជាកំពូល
លើពូជអំបូរអ៊ីសាខារក៏ថ្វាយ ១៩លោកថ្វាយដង្វាយរបស់
លោក គឺជាថាសប្រាក់១ទំងន់១៣០ដំឡឹងចានគោមប្រាក់១
ទំងន់៧០ដំឡឹង តាមដំឡឹងប្រើក្នុងទីបរិសុទ្ធទាំង២ ដាក់
ពេញដោយម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង សំរាប់ជា
ដង្វាយម្សៅ ២០កូនចានមាស១[ល]ទំងន់១០ដំឡឹង ដាក់ពេញ
ដោយកំញាន ២១គោស្ទាវ១ ចៀមឈ្មោល១ អាយុ១ខួប
សំរាប់ជាដង្វាយដុត ២២ពពែឈ្មោល១ សំរាប់ជាដង្វាយ
លោះបាប ២៣ហើយគោឈ្មោល២ ចៀមឈ្មោល៥ ពពែ
ឈ្មោល៥ និងកូនចៀមឈ្មោល៥ អាយុ១ខួប សំរាប់ជា
ដង្វាយមេត្រី នេះហើយជាដង្វាយរបស់នេថានេលជាកូន
ស៊ូហារ ។
២៤នៅថ្ងៃទី៣ នោះត្រូវជាអេលាប ជាកូនហេឡូន[វ] ជា
កំពូលលើពួកកូនចៅសាប់យូឡូន ២៥ដង្វាយរបស់លោក គឺ
ជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចានគោមប្រាក់១ទំងន់៧០
ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធទាំង២ ដាក់ពេញ
ដោយម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង សំរាប់ជាដង្វាយ
ម្សៅ ២៦កូនចានមាស១ ទំងន់១០ដំឡឹង ដាក់ពេញដោយ
កំញាន ២៧គោស្ទាវ១ ចៀមឈ្មោល១ កូនចៀមឈ្មោល១
អាយុ១ខួប សំរាប់ជាដង្វាយដុត ២៨ពពែឈ្មោល១ សំរាប់

**៧:១–៨៩** មើល នក ជំពូក៤០ ដែលប្រាប់អំពីការដំឡើងត្រសាល និងការបញ្ចប់ដោយរាយការណ៍ពីពពកមកគ្របពីលើ ហើយនិងព្រះវត្តមានរបស់ព្រះមកបំពេញនៅក្នុងរោងឧបោសថ ។

**៧:១២–៧៨** និយាយអំពីអ្នកដឹកនាំរបស់ពូជអំបូរទាំង១២ក្រុមដែលមានឈ្មោះនៅក្នុង ១:៥–១៥ ២:៣–៣២ ។ លំដាប់លំដោយនៃការថ្វាយដង្វាយរបស់ពួកគេដល់ព្រះអម្ចាស់ នោះគឺមានក្បួនដូចការដើរដង្ហែរក្បួនដែរ ។ ដំបូងគឺពូជអំបូរដែលបានសង់ត្រសាលនៅទិសខាងកើត(មានដូចជា យូដា អ៊ីសាខារ និងសាប់យូឡូន ២:៣–៩ ៧:១២,១៨,២៤)។ ទីពីរគឺពូជអំបូរនៃពូជអំបូរដែលបានសង់ត្រសាលនៅទិសខាងត្បូង (រូបេន ស៊ីមាន និងកាឌ់ សូមមើល ២:១០–១៦ ៧:៣០,៣៦,៤២) ។ ទីបីគឺពូជអំបូរនៃពូជអំបូរដែលបានបោះជំរុំនៅទិសខាងលិច (អេប្រាអិម ម៉ាន៉ាសេ និងបេនយ៉ាមីន មើល ២:១៨–២៤ ៧:៤៨,៥៤,៦០) ។ ទីបួន ចុងក្រោយគឺពូជអំបូរដែលបានសង់ត្រសាលនៅទិសខាងជើង (ដាន់ អេស៊ើរ និងណែបថាលី ២:២៥–៣១ ៧:៦៦,៧២,៧៨) ។

**៧:១៧,២៣** *ដង្វាយមេត្រី* មើលការពន្យល់ លវ ៣:១ ។

**៧:១៩** *តាមដំឡឹងប្រើក្នុងទីបរិសុទ្ធ* មើលការពន្យល់ នក ៣០:១៣ ។

ជាដង្វាយលោះបាប ២៩ហើយគោឈ្មោល២ ចៀមឈ្មោល
៥ ពពែឈ្មោល៥ និងកូនចៀមឈ្មោល៥ អាយុ១ខួប
សំរាប់ជាដង្វាយមេត្រី នេះហើយជាដង្វាយរបស់អេលាប
ជាកូនហេលូ៊ន ។
៣០នៅថ្ងៃទី៤នោះត្រូវជាអេលីសើរ ជាកូនសេដេអើរ[ស]
ជាកំពូលលើពួកកូនចៅរូបេន ៣១ដង្វាយរបស់លោក គឺ
ជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចានគោមប្រាក់១ ទំងន់
៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ ទាំង២ ដាក់
ពេញដោយម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង សំរាប់ជា
ដង្វាយម្សៅ ៣២កូនចានមាស១ ទំងន់១០ដំឡឹង ដាក់
ពេញដោយកំញាន ៣៣គោស្ទាវ១ ចៀមឈ្មោល១ កូន
កូនចៀមឈ្មោល១ អាយុ១ខួប សំរាប់ជាដង្វាយដុត
៣៤ពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាប ៣៥ហើយ
គោឈ្មោល២ ចៀមឈ្មោល៥ ពពែឈ្មោល៥ និង
កូនចៀមឈ្មោល៥ អាយុ១ខួប សំរាប់ជាដង្វាយមេត្រី
នេះហើយជាដង្វាយរបស់អេលីសើរ ជាកូនសេដេអើរ ។
៣៦នៅថ្ងៃទី៥នោះត្រូវជាស្លូមាលជាកូនស៊ូរីសាដាយ[ហ]
ជាកំពូលលើពួកកូនចៅស៊ីម្មាន ៣៧ដង្វាយរបស់លោក
គឺជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចានគោមប្រាក់១
ទំងន់៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ ទាំង២
ដាក់ពេញដោយម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង សំរាប់
ជាដង្វាយម្សៅ ៣៨កូនចានមាស១ ទំងន់១០ដំឡឹង ដាក់
ពេញដោយកំញាន ៣៩គោស្ទាវ១ ចៀមឈ្មោល១ កូន
ចៀមឈ្មោល១ អាយុ១ខួប សំរាប់ជាដង្វាយដុត ៤០ពពែ
ឈ្មោល១ សំរាប់ជាដង្វាយលោះបាប ៤១ហើយគោ
ឈ្មោល២ ចៀមឈ្មោល៥ ពពែឈ្មោល៥ និងកូន
ចៀមឈ្មោល៥ អាយុ១ខួប សំព្រប់ជាដង្វាយមេត្រី នេះ
ហើយជាដង្វាយរបស់ស្លូមាល ជាកូនស៊ូរីសាដាយ ។
៤២នៅថ្ងៃទី៦ នោះត្រូវជាអេលាសាប់ ជាកូន
ដេហ៊ូអែល[ឡ] ជាកំពូលលើពួកកូនចៅកាឌ់ ៤៣ដង្វាយ
របស់លោក គឺជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចាន
គោមប្រាក់១ ទំងន់៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទី
បរិសុទ្ធ ទាំង២ដាក់ពេញដោយម្សៅយ៉ាងម៉ដ្ត លាយ
ដោយប្រេង សំរាប់ជាដង្វាយម្សៅ ៤៤កូនចានមាស១
ទំងន់១០ដំឡឹង ដាក់ពេញដោយកំញាន ៤៥គោស្ទាវ១
ចៀមឈ្មោល១ កូនចៀមឈ្មោល១ អាយុ១ខួប សំរាប់
ជាដង្វាយដុត ៤៦ពពែឈ្មោល១ សំរាប់ជាដង្វាយលោះ
បាប ៤៧ហើយគោឈ្មោល២ ចៀមឈ្មោល៥ ពពែ
ឈ្មោល៥ និងកូនចៀមឈ្មោល៥ អាយុ១ខួប សំរាប់
ជាដង្វាយមេត្រី នេះហើយជាដង្វាយរបស់អេលាសាប់ជា
កូនដេហ៊ូអែល ។
៤៨នៅថ្ងៃទី៧ នោះត្រូវជាអេលីសាម៉ា ជាកូនអាំ
មីហ៊ូត[អ] ជាកំពូលលើពួកកូនចៅអេប្រាអិម ៤៩ដង្វាយ
របស់លោក គឺជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចាន
គោមប្រាក់១ ទំងន់៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទី
បរិសុទ្ធ ទាំង២ដាក់ពេញដោយម្សៅយ៉ាងម៉ដ្ត លាយ
ដោយប្រេង សំរាប់ជាដង្វាយម្សៅ ៥០កូនចានមាស១
ទំងន់១០ដំឡឹង ដាក់ពេញដោយកំញាន ៥១គោស្ទាវ១
ចៀមឈ្មោល១ កូនចៀមឈ្មោល១ អាយុ១ខួប សំរាប់
ជាដង្វាយដុត ៥២ពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាប
៥៣ហើយគោឈ្មោល២ ចៀមឈ្មោល៥ ពពែឈ្មោល៥
និងកូនចៀមឈ្មោល៥ អាយុ១ខួប សំរាប់ជាដង្វាយមេត្រី
នេះហើយជាដង្វាយរបស់អេលីសាម៉ា ជាកូនអាំមីហ៊ូត[ក] ។
៥៤នៅថ្ងៃទី៨ នោះត្រូវជាកាម៉ាលា ជាកូនផ្ដាសើរ[ខ]
ជាកំពូលលើពួកកូនចៅម៉ាន៉ាសេ ៥៥ដង្វាយរបស់លោក
គឺជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចានគោមប្រាក់១
ទំងន់៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ ទាំង២
ដាក់ពេញដោយម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង សំរាប់
ជាដង្វាយម្សៅ ៥៦កូនចានមាស១ ទំងន់១០ដំឡឹង ដាក់ពេញ
ដោយកំញាន ៥៧គោស្ទាវ១ ចៀមឈ្មោល១ កូនចៀម
ឈ្មោល១ អាយុ១ខួប សំរាប់ជាដង្វាយដុត ៥៨ពពែ
ឈ្មោល១ សំរាប់ជាដង្វាយលោះបាប ៥៩ហើយគោ
ឈ្មោល២ ចៀមឈ្មោល៥ ពពែឈ្មោល៥ និងកូន
ចៀមឈ្មោល៥ អាយុ១ខួប សំរាប់ជាដង្វាយមេត្រី នេះ
ហើយជាដង្វាយរបស់កាម៉ាលាលជាកូនផ្ដាសើរ ។
៦០នៅថ្ងៃទី៩ នោះត្រូវជាអ័ប៊ីដាន ជាកូនគីដាហូនី[គ]
ជាកំពូលលើពួកកូនចៅបេនយ៉ាមីន ៦១ដង្វាយរបស់លោក
គឺជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចានគោមប្រាក់១
ទំងន់៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធទាំង២
ដាក់ពេញដោយម្សៅយ៉ាងម៉ដ្ត លាយដោយប្រេងសំរាប់
ជាដង្វាយម្សៅ ៦២កូនចានមាស១ ទំងន់១០ដំឡឹង ដាក់
ពេញដោយកំញាន ៦៣គោស្ទាវ១ ចៀមឈ្មោល១ កូនចៀម
ឈ្មោល១ អាយុ១ខួប សំរាប់ជាដង្វាយដុត ៦៤ពពែឈ្មោល
១សំរាប់ជាដង្វាយលោះបាប ៦៥ហើយគោឈ្មោល២ ចៀម
ឈ្មោល៥ ពពែឈ្មោល៥ និងកូនចៀមឈ្មោល៥អាយុ១
ខួប សំរាប់ជាដង្វាយមេត្រី នេះហើយជាដង្វាយរបស់អ័ប៊ី

៧:៣០ ស ជន ១:៥
៧:៣៦ ហ ជន ១:៦
៧:៤២ ឡ ជន ១:១៤
៧:៤៨ អ ជន ១:១០
៧:៥៣ ក ជន ១:១០
៧:៥៤ ខ ជន ១:១០
៧:៦០ គ ជន ១:១១

ដាន ជាកូនគីដាហូនី ។
៦៦នៅថ្ងៃទី១០ នោះត្រូវជាអ័ហ៊ីយេស៊ើរ ជាកូន
អាំមីសាដាយ[យ] ជាកំពូលលើពួកកូនចៅដាន់ ៦៧ដង្វាយ
របស់លោក គឺជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចាន
គោមប្រាក់១ ទំងន់៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទី
បរិសុទ្ធ ទាំង២ដាក់ពេញដោយម្សៅយ៉ាងម៉ដ្ត លាយ
ដោយប្រេង សំរាប់ជាដង្វាយម្សៅ ៦៨កូនចានមាស១ ទំងន់
១០ដំឡឹង ដាក់ពេញដោយកំញាន ៦៩គោស្ទាវ១ ចៀម
ឈ្មោល១ កូនចៀមឈ្មោល១ អាយុ១ខួប សំរាប់ជាដង្វាយ
ដុត ៧០ពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាប ៧១ហើយ
គោឈ្មោល២ ចៀមឈ្មោល៥ ពពែឈ្មោល៥ និងកូន
ចៀមឈ្មោល៥ អាយុ១ខួប សំរាប់ជាដង្វាយមេត្រី នេះ
ហើយជាដង្វាយរបស់អ័ហ៊ីយេស៊ើរ ជាកូនអាំមីសាដាយ ។
៧២នៅថ្ងៃទី១១ នោះត្រូវជាប៉ាគីហ៊ាល ជាកូនអុក្រាន[ង]
ជាកំពូលលើពួកកូនចៅអេស៊ើរ ៧៣ដង្វាយរបស់លោក
គឺជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចានគោមប្រាក់១ ទំងន់
៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ ទាំង២ដាក់
ពេញដោយម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង សំរាប់ជា
ដង្វាយម្សៅ ៧៤កូនចានមាស១ ទំងន់១០ដំឡឹង ដាក់ពេញ
ដោយកំញាន ៧៥គោស្ទាវ១ ចៀមឈ្មោល១ កូនចៀម
ឈ្មោល១ អាយុ១ខួប សំរាប់ជាដង្វាយដុត ៧៦ពពែឈ្មោល
១ សំរាប់ជាដង្វាយលោះបាប ៧៧ហើយគោឈ្មោល២
ចៀមឈ្មោល៥ ពពែឈ្មោល៥ និងកូនចៀមឈ្មោល៥
អាយុ១ខួប សំរាប់ជាដង្វាយមេត្រី នេះហើយជាដង្វាយ
របស់ប៉ាគីហ៊ាលជាកូនអុក្រាន ។
៧៨នៅថ្ងៃទី១២ នោះត្រូវជាអ័ហ៊ីរ៉ា ជាកូនអេណាន់[ច]
ជាកំពូលលើពួកកូនចៅណែបថាលី ៧៩ដង្វាយរបស់លោក
គឺជាថាសប្រាក់១ ទំងន់១៣០ដំឡឹង ចានគោមប្រាក់១
ទំងន់៧០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធទាំង២
ដាក់ពេញដោយម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង សំរាប់ជា
ដង្វាយម្សៅ ៨០កូនចានមាស១ ទំងន់១០ដំឡឹង ដាក់ពេញ
ដោយកំញាន ៨១គោស្ទាវ១ ចៀមឈ្មោល១ កូនចៀម
ឈ្មោល១ អាយុ១ខួប សំរាប់ជាដង្វាយដុត ៨២ពពែឈ្មោល
១ សំរាប់ជាដង្វាយលោះបាប ៨៣ហើយគោឈ្មោល២
ចៀមឈ្មោល៥ ពពែឈ្មោល៥ និងកូនចៀមឈ្មោល៥
អាយុ១ខួប សំរាប់ជាដង្វាយមេត្រី នេះហើយជាដង្វាយ
របស់អ័ហ៊ីរ៉ាជាកូនអេណាន់ ។
៨៤នេះជាដង្វាយរបស់ពួកដែលជាកំពូលលើសាសន៍
អ៊ីស្រាអែល សំរាប់បុណ្យឆ្លងអាសនា នៅថ្ងៃដែលលាប
ប្រេងនោះ[ឆ] រួមទាំងអស់ គឺជាថាសប្រាក់១២ ចានគោម[ជ]
ប្រាក់១២ កូនចានមាស១២[ឈ] ៨៥ឯថាសប្រាក់នីមួយៗ
មានទំងន់១៣០ដំឡឹង ហើយចានគោមនីមួយៗ មានទំងន់
៧០ដំឡឹង បូករួមទាំងក្នុងគ្រឿងទាំងនោះទៅ ត្រូវជា២ពាន់
៤០០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ[ញ] ៨៦ឯកូនចាន
មាស១២ ដែលដាក់ពេញដោយកំញាននោះនីមួយៗ មាន
ទំងន់១០ដំឡឹង តាមដំឡឹងដែលប្រើក្នុងទីបរិសុទ្ធ[ដ] រួមទំងន់
មាសទាំងប៉ុន្មានក្នុងកូនចានទាំងនោះទៅ ត្រូវជា១២០
ដំឡឹង ៨៧ឯសត្វទាំងប៉ុន្មានសំរាប់ជាដង្វាយដុត[ឋ] នោះគឺគោ
ឈ្មោល១២ ចៀមឈ្មោល១២ និងកូនចៀមឈ្មោល១២
អាយុ១ខួប ព្រមទាំងដង្វាយម្សៅនោះផង[ឌ] ហើយពពែ
ឈ្មោល១២ សំរាប់ជាដង្វាយលោះបាប[ឍ] ៨៨ឯសត្វទាំង
ប៉ុន្មានសំរាប់ជាដង្វាយមេត្រី[ណ] នោះគឺគោឈ្មោល២៤
ចៀមឈ្មោល៦០[ត] ពពែឈ្មោល៦០ និងកូនចៀមឈ្មោល
៦០ អាយុ១ខួប នេះហើយជាដង្វាយសំរាប់បុណ្យឆ្លង
អាសនា ក្នុងពេលក្រោយដែលលាបប្រេងហើយ[ថ] ។
៨៩រួចកាលម៉ូសេបានចូលទៅទូលនឹងព្រះ[ទ] ក្នុងត្រសាល
ជំនុំ[ធ] នោះលោកឮសំឡេងមានបន្ទូលមកពីលើទីសន្តោស
ប្រោស[ន] ដែលនៅលើហឹបនៃសេចក្តីបន្ទាល់[ប] គឺពីកណ្តាល
ចេរូប៊ីនទាំង២ ហើយលោកក៏ទូលតបនឹងទ្រង់ ។

## អុជចង្កៀង

**៨** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់អើរ៉ុនថា
កាលណាឯងអុជចង្កៀងទាំង៧ នោះត្រូវឱ្យភ្លឺទៅខាង
មុខជើងចង្កៀង[ក] ៣អើរ៉ុនក៏ធ្វើដូច្នោះ លោកអុជចង្កៀង
ទាំង៧ ឱ្យមានពន្លឺទៅខាងមុខជើងចង្កៀង ដូចជាព្រះយេ
ហូវ៉ាបានបង្គាប់មកម៉ូសេ ៤ឯរបៀបធ្វើជើងចង្កៀងនោះ
គឺធ្វើពីមាស[ខ] មានរចនាក្បាច់ ចាប់តាំងពីគល់រហូតដល់ផ្កា

**៧:៦៦** យ ជន ១:១២
**៧:៧២** ង ជន ១:១៣
**៧:៧៨** ច ជន ១:១៥
**៧:៨៤** ឆ ខ.១,១០ ជ ជន ៤:១៤ ឈ ខ.១៤
**៧:៨៥** ញ ខ.១៣
**៧:៨៦** ដ ខ.១៣
**៧:៨៧** ឋ ខ.១៥ ឌ ខ.១៣ ឍ ខ.១៦
**៧:៨៨** ណ ខ.១៧ ត លប ៣២:១៤ ថ ខ.១,១០
**៧:៨៩** ទ នក ៤០:២ ធ នក ២៩:៤២ ន នក ១៦:៣៤ ទដ ៨០:១ ៩៩:១ ប ជន ៣:៣១
**៨:២** ក នក ២៥:៣៧
**៨:៤** ខ នក ២៥:១៨,៣៦

**៧:៨៤–៨៨** គឺនិយាយអំពីអំណោយសរុបទាំង១២ អំបូរ ។
**៧:៨៩** ចំណុចសំខាន់នៅក្នុងខនេះ គឺទំនាក់ទំនងគ្នាមួយ ត្រូវបានបង្កើតឡើង រវាងព្រះអម្ចាស់ និងហោរារបស់ទ្រង់ ។ *សេចក្តីបន្ទាល់* មើលការ ពន្យល់ នក ២៥:២២ ។
**៨:២** *ខាងមុខជើងចង្កៀង* គឺភ្លឺទៅកន្លែងបរិសុទ្ធនៅក្នុងរោងឧបោសថ (មើល នក ២៥:៣៧ ២៦:៣១–៣៥ និងការពន្យល់ នក ២៧:២១) ។
**៨:៣–២៦** នៅវគ្គនេះបានប្រាប់អំពីភាពស្អាតរបស់ពួកលេវី ហើយត្រូវបានប្រៀបធៀបទៅនឹងពូជអំបូរលោកអើរ៉ុនពីដើមដំបូង និងកូនប្រុសៗរបស់លោកដែលធ្វើជាសង្ឃ (លវ ៨) ។ ពួកលេវីគឺជាអ្នកជំនួយដល់សង្ឃ ហើយភាសាប្រើនៅត្រង់នេះគឺជាការជួយក្នុងពិធីបុណ្យតាមពួកសង្ឃផ្សេងៗគ្នា ។

សុទ្ធតែជាវិចិត្រ ដោយក្បាច់ទាំងអស់ តាមគំរូ[ក]ដែលព្រះ
យេហូវ៉ាបានបង្ហាញមកម៉ូសេ លោកក៏ធ្វើជើងចង្កៀង
យ៉ាងដូច្នោះ ។

## ការញែកពួកលេវីចេញ

៥ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ៦ចូរយកពួក
លេវីពីពួកកូនចៅអ៊ីស្រាអែល ហើយញែកគេចេញជា
ស្អាត[ឃ] ៧គឺត្រូវឱ្យសំអាត[ង]គេយ៉ាងដូច្នេះ ត្រូវប្រោះទឹក
សំអាតបាបទៅលើគេ រួចឱ្យគេកោរសក់ និងរោមនៅ
ខ្លួន[ច]ចេញទាំងអស់ ត្រូវឱ្យបោកសំលៀកបំពាក់[ឆ] ហើយ
សំអាតខ្លួនផង[ជ] ៨រួចត្រូវឱ្យគេយកគោឈ្មោលស្ទាវ១ ព្រម
ទាំងដង្វាយម្សៅ គឺជាម្សៅយ៉ាងម៉ដ្ត លាយដោយប្រេង[ឈ]
ហើយយកគោឈ្មោលស្ទាវ១ទៀត សំរាប់ជាដង្វាយលោះ
បាប[ញ] ៩រួចត្រូវនាំពួកលេវីមកនៅមុខត្រសាលជំនុំ[ដ] ហើយ
ប្រមូលពួកជំនុំនៃកូនចៅអ៊ីស្រាអែលទាំងអស់មក[ឋ] ១០នោះ
ត្រូវនាំពួកលេវីមកនៅចំពោះព្រះយេហូវ៉ា ឱ្យពួកកូនចៅ
អ៊ីស្រាអែលដាក់ដៃលើគេ[ឌ] ១១រួចត្រូវឱ្យអើរ៉ុនថ្វាយពួក
លេវីទុកជាដង្វាយ[ឍ]របស់ពួកកូនចៅអ៊ីស្រាអែលនៅចំពោះ
ព្រះយេហូវ៉ា ដើម្បីឱ្យគេបានធ្វើការងារថ្វាយព្រះយេហូវ៉ា
១២នោះត្រូវឱ្យពួកលេវីដាក់ដៃលើក្បាលគោទាំង២នោះ[ណ]
ហើយត្រូវឱ្យឯងថ្វាយ១ជាដង្វាយលោះបាប[ត]នឹង១ទៀតជាដ
ង្វាយដុត[ថ]ថ្វាយព្រះយេហូវ៉ា ដើម្បីឱ្យធួន[ទ]នឹងពួកលេវី
១៣រួចត្រូវឱ្យឯងនាំពួកលេវីទៅឈរនៅមុខអើរ៉ុន និងពួក
កូនលោក ព្រមទាំងថ្វាយគេទុកជាដង្វាយ[ធ]ដល់ព្រះយេហូវ៉ា
១៤គឺយ៉ាងនេះហើយ ដែលត្រូវឱ្យឯងញែកពួកលេវីចេញពី
ពួកកូនចៅអ៊ីស្រាអែល ហើយពួកលេវីត្រូវបានជារបស់ផង
អញ[ន] ១៥ក្រោយនោះមក គេត្រូវចូលទៅធ្វើការងារក្នុង
ត្រសាលជំនុំ[ប] ត្រូវឱ្យឯងសំអាតគេ ហើយថ្វាយគេជាដង្វាយ

**៨:៥** ក នក ២៥:៩
**៨:៦** ឃ លវ ២២:២ អស ១:១៦ ៥២:១១
**៨:៧** ង ជន ១៩:៩,១៧ ៣១:២៣ ច លវ ១៤:៩ ជន ៦:៩ ចទ ២១:១២ ឆ លប ៣៥:២ លវ ១៤:៨ ជ លប ៣៥:២
**៨:៨** ឈ លវ ២:១ ជន ១៥:៨–១០ ញ លវ ៤:៣
**៨:៩** ដ នក ៤០:១២ ឋ លវ ៨:៣
**៨:១០** ឌ លវ ៣:២ កច ៦:៦
**៨:១១** ឍ នក ២៩:២៤
**៨:១២** ណ នក ២៩:១០ ត លវ ៤:៣ ជន ៦:១១ ថ លវ ១:៣ ទ នក ២៩:៣៦
**៨:១៣** ធ នក ២៩:២៤
**៨:១៤** ន ជន ៣:១២
**៨:១៥** ប នក ៤០:២ ផ នក ២៩:២៤
**៨:១៦** ព ជន ១:២០ ភ ជន ៣:១២
**៨:១៧** ម នក ៤:២៣ យ នក ២២:២៩ រ នក ១៣:២
**៨:១៨** ល ជន ៣:១២
**៨:១៩** វ ជន ៣:៩ ស ជន ៣:៧ ហ ជន ១៦:៤៦

ចុះ[ផ] ១៦ដ្បិតបានថ្វាយគេមកដាច់ជារបស់ផងអញ ពីពួកកូន
ចៅអ៊ីស្រាអែល ហើយអញក៏បានទទួលគេស្នងអស់ទាំងកូន
ដែលកើតពីពោះម្តាយមុនគេបង្អស់[ព] គឺស្នងអស់ទាំងកូន
ច្បង[ភ] នៃពួកកូនចៅអ៊ីស្រាអែល ១៧ដ្បិតអស់ទាំងកូនច្បងនៃ
ពួកកូនចៅអ៊ីស្រាអែលជារបស់ផងអញ ទោះទាំងមនុស្ស
ទាំងសត្វ[ម]ផង គឺនៅថ្ងៃដែលបានវាយអស់ទាំងកូនច្បង នៅ
ស្រុកអេស៊ីព្ទ នោះអញបានញែកគេចេញទុកសំរាប់អញ
ហើយ[យ,រ] ១៨តែអញបានយកពួកលេវី ស្នងអស់ទាំងកូនច្បង
ក្នុងពួកកូនចៅអ៊ីស្រាអែលវិញ[ល] ១៩ហើយបានយកពួកលេវី
ពីពួកកូនចៅអ៊ីស្រាអែល ឱ្យដល់អើរ៉ុន និងពួកកូនលោក[វ]
ដើម្បីនឹងទទួលក្រសួងរបស់ពួកកូនចៅអ៊ីស្រាអែល[ស] ក្នុង
ត្រសាលជំនុំ ហើយឱ្យបានធួននឹងពួកកូនចៅអ៊ីស្រាអែល
ផង[ហ] ដើម្បីកុំឱ្យគេកើតមានសេចក្តីវេទនាណា ក្នុងកាល
ដែលគេចូលទៅជិតទីបរិសុទ្ធនោះឡើយ ។
២០ឯម៉ូសេ និងអើរ៉ុន ហើយពួកជំនុំនៃពួកកូនចៅ
អ៊ីស្រាអែលទាំងអស់គ្នា ក៏ធ្វើដល់ពួកលេវី តាមដែលព្រះ
យេហូវ៉ាបានបង្គាប់មកពីដំណើរគេ គឺបានធ្វើសំរេចតាម
បង្គាប់នោះឯង ២១ពួកលេវីគេសំអាតខ្លួន ព្រមទាំងបោក
សំលៀកបំពាក់របស់គេផង[ឡ] រួចអើរ៉ុនក៏ថ្វាយគេជាដង្វាយ
នៅចំពោះព្រះយេហូវ៉ា ទាំងធ្វើឱ្យធួននឹងគេ[អ] ដើម្បីឱ្យគេ
បានស្អាត[ក] ២២ក្រោយនោះមក ពួកលេវីក៏ចូលទៅធ្វើការ
ងាររបស់ខ្លួន[ខ]ក្នុងត្រសាលជំនុំ នៅមុខអើរ៉ុន និងពួកកូន
លោក ដូចជាព្រះយេហូវ៉ាបានបង្គាប់មកពីដំណើរគេ គឺ
បានធ្វើសំរេចដល់គេយ៉ាងដូច្នោះ ។
២៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ២៤នេះជា
ក្រសួងរបស់ពួកលេវី គឺត្រូវឱ្យគេចូលទៅធ្វើការងារ ក្នុង

**៨:២១** ឡ ខ.៧ លប ៣៥:២ អ ជន ១៦:៤៧ ក ខ.១២ **៨:២២** ខ ខ.១១

**៨:៧** *កោរសក់ និងរោមនៅខ្លួនចេញទាំងអស់* គឺជានិមិត្តរូបនៃការស្អាតយ៉ាងពេញលេញ ដូចជានៅក្នុងករណីពិធីបុណ្យសម្អាតនៃជម្ងឺសើស្បែកដូច្នេះដែរ (មើលការពន្យល់ លវ ១៤:៨) ។

**៨:១០** *ពួកកូនចៅអ៊ីស្រាអែលដាក់ដៃលើគេ* មានន័យថា ពួកលេវីគឺជាអ្នកតំណាងឱ្យជាតិសាសន៍ទាំងមូល ហើយជាតិសាសន៍ទាំងមូលបានទទួលស្គាល់ថាពួកលេវីគឺជាអ្នកតំណាងឱ្យពួកអ៊ីស្រាអែល (ខ.១៦–១៨) ។

**៨:១៦** *ថ្វាយគេមកដាច់ជារបស់ផងអញ* គឺព្រះញែកសម្រាប់ទ្រង់ សូមមើល ៣:៩ និងការពន្យល់ ។

**៨:១៩** *ហើយបានយកពួកលេវី . . . ឱ្យដល់អើរ៉ុន និងពួកកូនលោក* ពួកលេវីត្រូវបានញែកដាច់សម្រាប់បម្រើព្រះអម្ចាស់ (ខ.១៤) ។ តែឥឡូវនេះព្រះអម្ចាស់ទ្រង់បានប្រគល់ពួកលេវីទៅដល់ពួកសង្ឃទុកជាអ្នកជំនួយផ្នែកថ្វាយបង្គំក្នុងរោងឧបោសថ ។ *ហើយឱ្យបានធួននឹងពួកកូនចៅអ៊ីស្រាអែលផង ដើម្បីកុំឱ្យគេកើតមានសេចក្តីវេទនា* ពួកលេវីគឺជារបងសម្រាប់ការពារដល់សហគមន៍កុំឱ្យចូលមកក្នុងតំបន់ហាមឃាត់ នៅកន្លែងស័ក្តិសិទ្ធ (មើលការពន្យល់ ១:៥៣) ។

**៨:២០** *តាមដែលព្រះយេហូវ៉ាបានបង្គាប់មក* មើល ខ.៤,២២ ១:៥៤ ២:៣៤ ៣:១៦,៥១ ៤:៤៩ ៥:៤ ៩:៥,២៣ ។ ការស្តាប់បង្គាប់របស់លោកម៉ូសេ និងពួកអ៊ីស្រាអែលចំពោះបញ្ញត្តិរបស់ព្រះនៅក្នុងពិធីបុណ្យ និងការបរិភោគអាហារផ្សេងៗបានល្អណាស់ តែក្រោយមកវាផ្ទុយស្រឡះដោយពួកបណ្តាជនបែរជារអ៊ូរទាំចំពោះសេចក្តីស្រឡាញ់របស់ព្រះ និងសេចក្តីបង្រៀនរបស់លោកម៉ូសេនោះទៅវិញ ដោយចាប់ផ្តើមពីជំពូក ១១ ទៅ ។

**៨:២៤** *អាយុ២៥ឆ្នាំ* មើលការពន្យល់ ៤:៣ ។ នៅសម័យកាលស្តេចដាវីឌបានបន្ថយអាយុពី២៥មកត្រឹមតែ ២០ វិញ (មើល ១រប ២៣:៣ និងពន្យល់ ខ.២៤,២៧) ។

ត្រសាលជំនុំ[ក] ចាប់តាំងពីអាយុ២៥ឆ្នាំឡើងទៅលើ[ឃ] ២៥ដល់
អាយុ៥០ឆ្នាំ[ង] នោះត្រូវឱ្យគេឈប់ពីក្រសួងរបស់គេចេញ
មិនត្រូវធ្វើការងារនោះទៀតឡើយ ២៦គេនឹងគ្រាន់តែជួយ
បងប្អូនគេ នៅក្នុងត្រសាលជំនុំ ដើម្បីរក្សាបញ្ញើប៉ុណ្ណោះ
តែមិនធ្វើការងារទេ[ច] គឺយ៉ាងនោះហើយ ដែលឯងត្រូវដំរូវ
ការងារដល់ពួលលេវី ។

## បុណ្យរំលង

**៩** ១នៅខែចេត្រ[ក]ក្នុងឆ្នាំទី២ រាប់តាំងពីគេចេញពីស្រុក
អេស៊ីព្ទមក[ខ] នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ
នៅត្រង់ទីរហោស្ថានស៊ីណាយថា ២ត្រូវឱ្យពួកកូនចៅអ៊ីស្រា
អែលធ្វើបុណ្យរំលង[គ]នៅវេលាកំណត់ដែរ[ឃ] ៣គឺនៅថ្ងៃ
ទី១៤ខែនេះឯង[ង] ដល់ល្ងាចត្រូវឱ្យធ្វើបុណ្យនោះនៅវេលា
កំណត់ ត្រូវតែធ្វើតាមរបៀប និងច្បាប់ ហើយបញ្ញត្តិ
នៃបុណ្យនោះគ្រប់ចំពូក[ច] ៤ម៉ូសេក៏បង្គាប់ពួកកូនចៅ
អ៊ីស្រាអែលឱ្យធ្វើបុណ្យរំលង[ឆ] ៥ដូច្នេះ គេក៏ធ្វើបុណ្យនោះ
ត្រង់ទីរហោស្ថានស៊ីណាយ[ជ] នៅថ្ងៃទី១៤ខែចេត្រ[ឈ] នៅ
វេលាពេលល្ងាច តាមគ្រប់ទាំងសេចក្តីដែលព្រះយេហូវ៉ា
បានបង្គាប់មកម៉ូសេ[ញ] គឺពួកកូនចៅអ៊ីស្រាអែលបានធ្វើ
សំរេចយ៉ាងដូច្នោះ ។
៦រីឯមនុស្សខ្លះ គេមានសៅហ្មង[ដ]ដោយខ្មោចស្លាប់ម្នាក់[ឋ]
បានជាគេធ្វើបុណ្យរំលងនៅថ្ងៃនោះមិនបាន គេក៏មកឯ
ម៉ូសេ និងអើរ៉ុន[ឌ] នៅថ្ងៃនោះ ៧រួចជំរាបលោកថា យើង
រាល់គ្នាមានសៅហ្មងដោយខ្មោចស្លាប់ម្នាក់ ហេតុអ្វីបាន
ជាឃាត់ មិនឱ្យយើងខ្ញុំយកដង្វាយមកថ្វាយដល់ព្រះយេហូវ៉ា
នៅពេលកំណត់ជាមួយនឹងពួកកូនចៅអ៊ីស្រាអែលផង[ឍ]
៨នោះម៉ូសេប្រាប់គេថា ចាំសិន ទំរាំខ្ញុំឮសេចក្តីដែលព្រះ
យេហូវ៉ា ទ្រង់បង្គាប់ពីដំណើរអ្នករាល់គ្នាជាយ៉ាងណា[ណ] ។
៩ព្រះយេហូវ៉ាទ្រង់ក៏បង្គាប់ម៉ូសេ ១០ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា បើសិនជាមនុស្សណាក្នុងពួកឯង
រាល់គ្នា ឬក្នុងពូជដំណឯងតទៅ មានសៅហ្មងដោយខ្មោច
ស្លាប់[ត] ឬគេដើរដំណើរទៅឆ្ងាយក្តី ក៏គង់តែត្រូវធ្វើ[ថ]បុណ្យ
រំលងថ្វាយព្រះយេហូវ៉ាដែរ ១១គឺត្រូវឱ្យគេធ្វើនៅពេល
ល្ងាច ក្នុងថ្ងៃទី១៤ ខែពិសាខ[ទ]វិញ ត្រូវឱ្យគេបរិភោគបុណ្យ
នោះជាមួយនឹងនំបុ័ងឥតដំបែ ហើយនឹងបន្លែល្វីង[ធ] ១២មិន
ត្រូវឱ្យទុកអ្វីដល់ព្រឹកឡើយ[ន] ក៏មិនត្រូវបំបាក់ឆ្អឹង ណាមួយឱ្យ
សោះ[ប] គឺត្រូវធ្វើតាមរបៀបបុណ្យរំលងគ្រប់ចំពូក[ផ] ១៣តែឯ
មនុស្សណាដែលស្អាត ឥតមានដំណើរទៅឯណា ហើយ
ខានធ្វើបុណ្យរំលង មនុស្សនោះត្រូវកាត់កាល់ចេញពី
សាសន៍របស់ខ្លួន[ព] ដោយព្រោះមិនបានយកដង្វាយ មក
ថ្វាយដល់ព្រះយេហូវ៉ានៅវេលាកំណត់ មនុស្សនោះនឹង
ត្រូវទ្រាំទ្រក្នុងអំពើបាបរបស់ខ្លួន ១៤បើសិនជាមនុស្ស
ប្រទេសក្រៅ[ភ] ដែលនៅជាមួយនឹងឯងរាល់គ្នា គេចង់ធ្វើ

**៨:២៤** គ នក ៣៨:២១ ឃ ១រប ២៣:៣ **៨:២៥** ង ជន ៤:៣ **៨:២៦** ច ខ.១១ **៩:១** ក នក ៤០:២ ខ ជន ១:១ **៩:២** គ នក ១២:១១ ឃ ខ.៧ **៩:៣** ង នក ១២:៦,៤២ ច នក ១២:២–១១,៤៣–៤៩ លវ ២៣:៥–៨ ចទ ១៦:១–៨ **៩:៤** ឆ ខ.២ នក ១២:១១ **៩:៥** ជ ខ.១ ឈ នក ១២:៦ ញ ខ.៣ **៩:៦** ដ លវ ៥:៣ ១៣:៣ ឋ លវ ២១:១១ ឌ នក ១៨:១៥ ជន ២៧:២ **៩:៧** ឍ ខ.២ **៩:៨** ណ នក ១៨:១៥ លវ ២៤:១២ ជន ១៥:៣៤ ២៧:៥,២១ ទដ ៨៥:៨ **៩:១០** ត ខ.៦ ថ ២រប ៣០:២ **៩:១១** ទ នក ១២:៦ ធ នក ១២:៨ **៩:១២** ន នក ១២:៨ ប នក ១២:៤៦ យហ ១៩:៣៦ ផ ខ.៣ **៩:១៣** ព លប ១៧:១៤ **៩:១៤** ភ នក ១២:១៩,៤៣

**៨:២៦** *គេនឹងគ្រាន់តែជួយ* ពួកលេវីត្រូវបានឱ្យចូលនិវត្តន៍នៅអាយុ៥០ឆ្នាំ (ខ.២៥) ។ ពួកគេនៅតែមានសិទ្ធជួយដល់អ្នកធ្វើការក្មេងៗជំនាន់ក្រោយទៀតបាន តែពុំចាំបាច់ធ្វើការធ្ងន់ៗដូចកាលពីមុននោះឡើយ ។

**៩:១–១៤** នៅក្នុងវគ្គនេះមានបួនចំណុចគឺ (១).បញ្ញត្តិរក្សាបុណ្យរំលង (ខ.១–៥) ។ (២).សំណួរទាក់ទងទៅនឹងពិធីបុណ្យមិនស្អាត (ខ.៦–៨) ។ (៣).ការទទួលខុសត្រូវរបស់ព្រះអម្ចាស់ និងការអនុញ្ញាតឱ្យពន្យាពេលសមស្របណាមួយ តែការជំនុំជម្រះដល់មនុស្សខ្ជីខ្ជានៅតែមាន (ខ.៩–១៣) ។ (៤).ការផ្តល់សិទ្ធិដល់មនុស្សខាងក្រៅចូលក្នុងពិធីបុណ្យរំលង (ខ.១៤) ។ បុណ្យរំលងជាលើកដំបូងបានប្រព្រឹត្តទៅនៅក្នុងប្រទេសអេស៊ីព្ទ (នក ១២) ។ មួយឆ្នាំក្រោយមក នៅលើភ្នំស៊ីណាយ ជាលើកទី២ ដោយព្រោះតែការបះបោររបស់ពួកអ៊ីស្រាអែល និងការជំនុំជម្រះរបស់ព្រះទៅលើពួកគេ (ជំពូក១៤) ។ ក្រោយពីនេះពួកអ៊ីស្រាអែលពុំបានធ្វើបុណ្យរំលងទៀតទេ រហូតដល់បានចូលដល់ទឹកដីសន្យា (មើលការពន្យល់ យស ៥:១០) ។

**៩:១** *នៅខែចេត្រក្នុងឆ្នាំទី២* នៅក្នុងជំពូកនេះគឺជាព្រឹត្តិការណ៍ដែលបានកើតពីមុនៗមកនៅក្នុងការធ្វើជំរឿនលើកដំបូងក្នុងជំពូកមួយ (មើលការពន្យល់ ១:១) ។

**៩:៣** *ដល់ល្ងាច* តាមប្រពៃណីរបស់ពួកយូដាបានចាត់ទុកពេលល្ងាចនេះគឺជាការបញ្ចប់រយៈពេលមួយនៃថ្ងៃកន្លងទៅ ហើយជាការចាប់ផ្តើមនៃថ្ងៃថ្មីបន្តទៅទៀត ។

**៩:៧** *ហេតុអ្វីបានជាឃាត់មិនឱ្យ . . . ថ្វាយដល់ព្រះយេហូវ៉ា . . . ?* ត្រង់នេះគឺទាក់ទងទៅនឹងការថ្វាយបង្គំដល់ព្រះដោយមានចិត្តមិនស្អាត ទើបត្រូវបានជំទាស់ "ដោយវិញ្ញាណ និងសេចក្តីពិត (មើលការពន្យល់ យហ ៤:២៤) ។

**៩:១០** *ក៏គង់តែត្រូវធ្វើបុណ្យ* ការផ្តល់ព្រះគុណរបស់ព្រះដល់បណ្តាជនទាំងមានរយៈពេល១ខែក្រោយពីថ្ងៃធ្វើបុណ្យ (ខ.១១) ដូច្នេះពួកគេពុំអាចប្រកែកថាគ្មានពេលចូលរួមធ្វើពិធីបុណ្យរំលងនេះបាននោះឡើយ ។

**៩:១២** *ក៏មិនត្រូវបំបាក់ឆ្អឹង* ព្រះយេស៊ូវគឺជាកូនចៀមនៃបុណ្យរំលងរបស់យើងទាំងអស់គ្នា (សូមមើល ១កថ ៥:៧ យហ ១:២៩) ត្រូវបានគេឆ្កាងនោះបានបញ្ជាក់មកថា គ្មានបំណែកឆ្អឹងរបស់ទ្រង់ត្រូវបានបំបាក់នោះឡើយ ត្រង់នេះ បានសម្រេចដូចមានចែងនៅក្នុង យហ ១៩:៣៦ នក ១២:៤៦ ទដ ៣៤:២០ ។

**៩:១៣** *ខានធ្វើបុណ្យរំលង . . . ត្រូវកាត់កាលចេញ* នៅក្នុងបទគម្ពីរសញ្ញាថ្មីក៏បានចែងផងដែរ ពីការព្រមានយ៉ាងធ្ងន់ៗក្នុងការដែលខកខានមិនបានចូលក្នុងពិធីលៀងព្រះអម្ចាស់នោះ (១កថ ១១:២៨–៣០ និងមើលការពន្យល់ ១២:១៥) ។

**៩:១៤** *មនុស្សប្រទេសក្រៅ* បើចង់ចូលរួមបុណ្យរំលងត្រូវតែកាត់ស្បែកជាមុនសិន (មើលការពន្យល់ នក ១២:៤៨) ។

បុណ្យរំលងថ្វាយព្រះយេហូវ៉ាដែរ នោះត្រូវឱ្យគេ ធ្វើតាម
របៀប និងបញ្ញត្តិច្បាប់របស់បុណ្យរំលងនេះចុះ មានច្បាប់
តែ១ទេ ដែលសំរាប់ទាំងអ្នកប្រទេសក្រៅ និងអ្នកកើតក្នុង
ស្រុកផង ។

## ពពកគ្របរោងឧបោសថ

១៥ នៅថ្ងៃដែលបានដំឡើង[ម]រោងឧបោសថ នោះពពក[យ]
ក៏មកគ្របរោងឧបោសថ គឺជាត្រសាលនៃសេចក្ដីបន្ទាល់[រ]
ហើយនៅពេលល្ងាច មានភាពដូចជាភ្លើងវិញរហូតដល់
ព្រឹក[ល] ១៦ ក៏មានដូច្នោះនៅជានិច្ច គឺមានពពកគ្របរោង
ឧបោសថ ហើយនៅពេលយប់ មានដូចជាភ្លើងវិញ[វ] ១៧ បើ
កាលណាពពកឡើងផុតពីត្រសាល នោះពួកកូនចៅអ៊ីស្រា–
អែល ក៏ធ្វើដំណើរទៅ[ស] ហើយនៅកន្លែងណាដែលពពក
ឈប់ នោះពួកកូនចៅអ៊ីស្រាអែល ក៏ដំឡើងត្រសាលនៅ
ទីនោះ[ហ] ១៨ ដូច្នេះ គឺតាមបង្គាប់ព្រះយេហូវ៉ា ដែលពួកកូន
ចៅអ៊ីស្រាអែលបានធ្វើដំណើរទៅហើយក៏តាមបង្គាប់ព្រះ
យេហូវ៉ា ដែលគេឈប់ដំឡើងត្រសាលនៅ បើពពកនៅលើ
រោងឧបោសថជាយូរប៉ុណ្ណា នោះគេក៏ចេះតែ[ឡ]នៅជាដរាប
ទៅប៉ុណ្ណោះឯង ១៩ កាលណាពពកនៅលើរោងឧបោសថ
ជាយូរថ្ងៃ នោះពួកកូនចៅអ៊ីស្រាអែលគេក៏រក្សាបញ្ញើ
របស់ព្រះយេហូវ៉ា[អ] ឥតមានធ្វើដំណើរទៅឯណាទេ[ក] ២០ ចួន
កាលពពកនៅលើរោងឧបោសថតែបួនដប់ថ្ងៃ នោះគេក៏
តាំងនៅតាមបង្គាប់ព្រះយេហូវ៉ា រួចដែលចេញដំណើរទៅ
ក៏តាមបង្គាប់ព្រះយេហូវ៉ាដែរ ២១ ហើយចួនកាលពពក
គ្រាន់តែនៅពីល្ងាចដល់ព្រឹក រួចព្រឹកឡើងកាលណាបាន
ឡើងផុតទៅ នោះគេក៏ចេញដំណើរទៅ កាលណាពពក
បានឡើងផុតទៅ ទោះបើជាពេលថ្ងៃឬយប់ក្តី គង់តែគេក៏
ចេញដំណើរទៅដែរ ២២ ឬបើជា២ថ្ងៃឬ១ខែឬ១ឆ្នាំ ដែល
ពពកនៅជាប់លើរោងឧបោសថឥតរើ ទៅឯណានោះពួក
កូនចៅអ៊ីស្រាអែលក៏ចេះតែនៅទីនោះជាដរាប ឥតធ្វើ

**៩:១៥** ម នក ២៦:៣០
យ នក ៣៣:១៦
រ នក ៣៨:២១
ល នក ១៣:២១
**៩:១៦** វ នក ៤០:៣៨
**៩:១៧** ស ខ.២១
ហ ១កថ ១០:១
**៩:១៨** ឡ នក
៤០:៣៧
**៩:១៩** អ លវ ៨:៣៥
ក នក ៤០:៣៧
**១០:២** ក ខ.៨,៩ ជន
៣១:៦ នហ ១២:៣៥
ទដ ៤៧:៥ ៩៨:៦
១៥០:៣ ខ នហ
៤:១៨ យរ ៤:៥,១៩
៦:១ ហស ៥:៨ ៨:១
យអ ២:១,១៥ អម
៣:៦ គ ជន ៣៣:៣
**១០:៤** ឃ នក
១៨:២១
**១០:៥** ង ខ.១៤
**១០:៦** ច ខ.១៨
**១០:៧** ឆ យរ ៤:៥
៦:១ អគ ៣៣:៣ យអ
២:១ ជ ១កថ ១៤:៨
**១០:៨** ឈ លប
៩:១២ ជន ១៥:១៤
៣៥:២៩
**១០:៩** ញ នក ៣:៩
ពច ២:១៨ ៦:៩
១សយ ១០:១៨ ២ពវ
១៣:៤ ទដ ១០៦:៤២
ដ លវ ២៣:២៤
ឋ លប ៨:១ ឌ ២រប
១៣:១២ ទដ ១០៦:៤

ដំណើរទៅឯណាឡើយ តែវេលាណាដែលពពកឡើង
ផុតវិញ នោះទើបគេចេញដំណើរទៅ ២៣ គឺតាមតែបង្គាប់
ព្រះយេហូវ៉ា ដែលគេដំឡើងត្រសាល ហើយក៏តាមបង្គាប់
ព្រះយេហូវ៉ា ដែលគេចេញដំណើរទៅ គេក៏ស្តាប់បង្គាប់
នៃព្រះយេហូវ៉ា តាមដែលទ្រង់មានបន្ទូលមក ដោយសារ
ម៉ូសេ ។

## ត្រែធ្វើពីប្រាក់

**១០** ១ ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ២ ចូរយកប្រាក់
មកផែធ្វើជាត្រែ២[ក]សំរាប់ឯង ត្រូវប្រើត្រែនោះសំរាប់នឹង
ផ្លុំហៅពួកជំនុំ[ខ] ឱ្យមូលគ្នា ហើយនិងសំរាប់ឱ្យបណ្តាជនធ្វើ
ដំណើរទៅ[គ] ៣ កាលណាគេផ្លុំឡើង នោះពួកជំនុំទាំងអស់គ្នា
ត្រូវប្រជុំមកឯឯង ត្រង់មាត់ទ្វារត្រសាលជំនុំ ៤ បើផ្លុំតែម្តង
នោះពួកដែលជាកំពូល[ឃ] គឺជាពួកមេលើសាសន៍អ៊ីស្រា
អែលទាំងប៉ុន្មាន ត្រូវប្រជុំគ្នាមកឯឯង ៥ កាលណាផ្លុំដោយ
សំឡេងរន្ទាន់១ដង នោះពួកដែលដំឡើងត្រសាលខាងកើត
ត្រូវចេញដំណើរទៅ[ង] ៦ ហើយកាលណាផ្លុំដោយសំឡេង
រន្ទាន់ម្តងទៀត នោះពួកដែលដំឡើងត្រសាលនៅខាងត្បូង
ត្រូវចេញដំណើរទៅ[ច] ត្រូវផ្លុំឱ្យមានសំឡេងរន្ទាន់ ដើម្បីឱ្យ
គេធ្វើដំណើរទៅដូច្នេះ ៧ តែកាលណាត្រូវប្រជុំពួកជំនុំ
នោះត្រូវផ្លុំដែរ[ឆ] តែឥតមានសំឡេងរន្ទាន់ទេ[ជ] ៨ ត្រូវឱ្យ
ពួកកូនចៅអើរ៉ុន ដ៏ជាពួកសង្ឃផ្លុំត្រែនោះ ហើយត្រែនោះ
ឯង ជាបញ្ញត្តិច្បាប់ដល់ឯងរាល់គ្នា នៅអស់កល្បជានិច្ច
គ្រប់ទាំងដំណតទៅ[ឈ] ៩ បើកាលណាឯងរាល់គ្នាចេញទៅ
ច្បាំងនឹងពួកខ្មាំងសត្រូវ ដែលមកសង្កត់សង្កិនក្នុងស្រុក
របស់ឯង[ញ] នោះត្រូវផ្លុំត្រែឱ្យមានសំឡេងស្លន់[ដ] ទើបនឹង
មានសេចក្តីនឹករឭក[ឋ]ពីឯងរាល់គ្នា នៅចំពោះព្រះយេហូវ៉ា
ជាព្រះនៃឯង ហើយនិងមានសេចក្តីសង្គ្រោះឱ្យឯងរាល់គ្នា
រួចពីខ្មាំងសត្រូវចេញ[ឌ] ១០ រីឯនៅថ្ងៃអំណរ និងនៅថ្ងៃបុណ្យ
នៅថ្ងៃអំណរ និងនៅថ្ងៃបុណ្យដ៏មុតមាំ របស់ឯងរាល់គ្នា

**៩:១៥** *សេចក្ដីបន្ទាល់* មើលការពន្យល់ នក ២៥:២២ ។ *ពពកក៏មកគ្រប រោងឧបោសថ* មើលការពន្យល់ នក ១៣:២១ ៤០:៣៤ ។ ពពកគឺជានិមិត្តរូបនៃព្រះវត្តមានរបស់ព្រះនៅលើរោងឧបោសថ ពុំមែនជាពពកធម្មតានោះទេ ។ នៅពេលយប់វិញគឺមានបង្គោលភ្លើងជាអ្នកបង្ហាញទិស (សូមមើល ខ.១៧–១៨) ។

**៩:១៨** *តាមបង្គាប់ព្រះយេហូវ៉ា* ការចេញដំណើរ និងការឈប់សម្រាកគឺតាមបង្គាប់របស់ព្រះទាំងអស់ ។

**៩:២៣** *ក៏ស្ដាប់បង្គាប់ព្រះយេហូវ៉ា* ត្រង់នេះគឺបញ្ជាក់ពីអត្តសញ្ញាណនៃព្រះម្តងទៀតដែលមាននៅក្នុងខ.១៥–២៣ ។ លោកម៉ូសេប្រៀបដូចជាភ្នាក់ងាររបស់ព្រះជាអ្នកប្រាប់អំពីនិមិត្តសញ្ញាដូចជាពពក និងបង្គោលភ្លើងតែការគួរឱ្យក្រៀមក្រំនោះគឺពួកបណ្តាជនពុំបានស្តាប់បង្គាប់ព្រះឡើយ (ជំពូក ១១)

**១០:២** *ត្រែ* ជាឧបករណ៍ម្យ៉ាងដែលធ្វើពីលោហៈមានរាងវែង មានកន្លើតគេប្រើវាសម្រាប់ផ្លុំ ដើម្បីបញ្ជា និងដាក់ពិន័យផ្សេងៗ ។

**១០:៣** *ផ្លុំឡើង* កាលណាឮសម្លេងត្រែនេះគឺសម្រាប់ហៅបណ្តាជនមកប្រជុំ និងការចេញដំណើរទៅមុខទៀត (ខ.៥–៦) សម្រាប់ធ្វើសង្គ្រាម (ខ.៩) ហើយនិងសម្រាប់ធ្វើពិធីបុណ្យ (ខ.១០) ។ ដោយសារតែឮសម្លេងត្រែតែមួយ ហើយមានតួនាទីខុសៗនោះ (ខ.៧) ទើបពួកសង្ឃដែលជំនាញខាងភ្លេងបានអភិវឌ្ឍន៍ (ខ.៨) ឱ្យមានត្រែប្រាំពីរសម្លេងប្លែកៗពីគ្នា ដែលបានប្រើនៅក្នុងចម្បាំងនៅក្រុងយេរីខូ (មើលការពន្យល់ យស ៦:៤) ។

**១០:១០** *រីឯ . . . នៅថ្ងៃបុណ្យដ៏មុតមាំរបស់ឯងរាល់គ្នា . . . នោះឯងត្រូវផ្លុំ*

ហើយនៅថ្ងៃចូលខែ[ឃ] នោះឯងត្រូវផ្លុំត្រែ[ណ]ពីលើដង្វាយ
ដុត[ត] និងយញ្ញបូជា នៃដង្វាយមេត្រីរបស់ឯង[ថ] នោះនឹងមាន
សេចក្ដីរំឭកដល់ឯងរាល់គ្នា នៅចំពោះព្រះនៃឯង អញ
នេះហើយ គឺយេហូវ៉ា ជាព្រះនៃឯង[ទ] ។

## សាសន៍អ៊ីស្រាអែលចាកចេញពីទីរហោស្ថានស៊ីណាយ

១១ដល់ថ្ងៃ២០ខែពិសាខ ក្នុងឆ្នាំទី២[ធ] នោះពពកក៏
ឡើង[ន]ផុតពីរោងឧបោសថផងសេចក្ដីបន្ទាល់[ប] ១២រួចពួក
កូនចៅអ៊ីស្រាអែល ក៏ធ្វើដំណើរចេញពីទីរហោស្ថាន
ស៊ីណាយ ដើរទៅតាមរបៀបដែលគេត្រូវដើរមុនក្រោយ
ហើយពពកក៏ឈប់នៅទីរហោរស្ថានប៉ារ៉ាន[ផ] ១៣នៅជាន់
មុនដំបូងនោះ គេចេញដំណើរទៅតាមបង្គាប់ព្រះយេហូវ៉ា
ដោយសារម៉ូសេ[ព] ១៤ឯទី១ នោះមានទង់ជ័យនៃទីដំឡើង
ត្រសាល របស់ពួកកូនចៅយូដា នាំគ្នាចេញទៅតាមពួក
កងគេ[ភ] មានណាសូនជាកូនអ័មីនាដាប់[ម] ត្រួតលើពួកកង
គេ ១៥ហើយនេថានេលជាកូនស៊ូហារ ត្រួតលើពួកកង
របស់ពូជអំបូរ[យ]កូនចៅអ៊ីសាខារ[រ] ១៦និងអេលាប ជាកូន
ហេលូ៉ន[ល] ត្រួតលើពួកកងនៃពូជអំបូរកូនចៅសាប់យូល៉ូន[វ]
១៧នោះបានរុះរោងឧបោសថ ហើយពួកកូនចៅគើសុន
និងពួកកូនចៅម្រ៉ារី ក៏ចេញទៅទាំងលីសែងរោងនោះ[ស]
១៨បន្ទាប់មក មានទង់ជ័យរបស់ទីដំឡើងត្រសាល នៃ
ពួកកូនចៅរូបេន[ហ] នាំគ្នាចេញទៅតាមពួកកងគេ[ឡ] មាន
អេលីសើរ[អ] ជាកូនសេដេអើរ ត្រួតលើពួកកងគេ ១៩ហើយ
ស្លូមាលជាកូនស៊ូរីសាដាយ ត្រួតលើពួកកងរបស់ពូជអំបូរ
កូនចៅស៊ីម្មាន[ក] ២០និងអេលាសាប់ ជាកូនដេហ៊ូអែល
ត្រួតលើពួកកងរបស់ពូជអំបូរកូនចៅកាឌ់[ខ] ២១រួចមក ពួក
កេហាត់[គ]ក៏ចេញទៅទាំងលីសែងទីបរិសុទ្ធ[ឃ] ហើយពួកមុន
នោះក៏ដំឡើងរោងឧបោសថ ឱ្យទាន់គេមកដល់[ង] ២២រួច
មានទង់ជ័យទីដំឡើងត្រសាល នៃពួកកូនចៅអេប្រាអិម[ច]
នាំគ្នាចេញទៅ តាមពួកកងគេ មានអេលីសាម៉ា ជាកូន
អាំមីហ៊ូត[ឆ] ត្រួតលើពួកកងគេ ២៣ហើយកាម៉ាលាលជា
កូនផ្ដាសើរ ត្រួតលើពួកកងរបស់ពូជអំបូរកូនចៅម៉ានាសេ[ជ]
២៤និងអ័ប៊ីដានជាកូនគីដាហូនី ត្រួតលើពួកកង របស់ពូជ
អំបូរកូនចៅបេនយ៉ាមីន[ឈ] ២៥រួចមានទង់ជ័យរបស់ទីដំឡើង
ត្រសាលនៃពួកកូនចៅដាន់ នាំគ្នាចេញទៅតាមពួកកងគេ[ញ]
មានអ័ហ៊ីយេសើរជាកូនអាំមីសាដាយ[ដ] ត្រួតលើពួកកងគេ
ជាខាងក្រោយបង្អស់ ២៦ហើយប៉ាគីហ៊ាល ជាកូនអុក្រាន
ត្រួតលើពួកកងរបស់ពូជអំបូរកូនចៅអេស៊ើរ ២៧និងអ័ហ៊ីរ៉ា
ជាកូនអេណាន់ ត្រួតលើពួកកង របស់ពូជអំបូរកូនចៅ
ណែបថាលី[ឋ] ២៨គឺយ៉ាងនេះហើយដែលពួកកូនចៅអ៊ីស្រា
អែលតែងធ្វើដំណើរទៅ គេចេញដើរទៅតាមពួកកងគេ
រៀងខ្លួន[ឌ] ។
២៩រីឯម៉ូសេលោកជំរាបហូបាប់[ឍ] កូនរេហួល[ណ]សាសន៍
ម៉ាឌាន ដែលជាឪពុកក្មេក[ត]លោកថា យើងខ្ញុំធ្វើដំណើរ
ទៅឯកន្លែង ដែលព្រះយេហូវ៉ាបានមានបន្ទូលថា អញ
នឹងឱ្យស្រុកនេះដល់ឯងរាល់គ្នា[ថ] ដូច្នេះ សូមអញ្ជើញទៅ
ជាមួយនឹងយើងខ្ញុំចុះ នោះនឹងមានប្រយោជន៍ដល់លោក
ឪពុក ដ្បិតព្រះយេហូវ៉ាបានមានបន្ទូលសេចក្ដីយ៉ាងល្អ ពី
ដំណើរសាសន៍អ៊ីស្រាអែល ៣០តែលោកឆ្លើយថា អញ
មិនទៅទេ[ទ] អញនឹងត្រឡប់ទៅឯស្រុកអញវិញ ដើម្បីនៅជា

**១០:១០** ឃ ជន ២៨:១១ ១សយ ២០:៥,២៤ ២ពវ ៤:២៣ ២របា ៨:១៣ ទដ ៨១:៣ អស ១:១៣ អគ ៤៥:១៧ ៤៦:៦ អម ៨:៥ ណ លវ ២៣:២៤ ត លវ ១:៣ ថ លវ ៣:១ ជណ ៦:១៤ ទ លវ ១១:៤៤ **១០:១១** ធ នក ៤០:១៧ ន ជន ៩:១៧ ប នក ៣៨:២១ **១០:១២** ផ លប ១៤:៦ ចទ ១:១ ៣៣:២ **១០:១៣** ព ចទ ១:៦ ១០:១៤ ភ ជន ១:៥២ ២:៣-៩ ម ជន ១:៧ **១០:១៥** យ លវ ២៤:១១ រ ជន ១:៨ **១០:១៦** ល ជន ២:៧ វ ជន ១:៩ **១០:១៧** ស ខ.២១ ជន ៤:២១-៣២ ១០:១៨ ហ ជន ២:១៦ ឡ ជន ២:១០-១៦ អ ជន ១:៥ **១០:១៩** ក ជន ១:៦ **១០:២០** ខ ជន ១:១៤ **១០:២១** គ ជន ២:១៧ឃ ជន ៤:២០ ង ខ.១៧ **១០:២២** ច ជន ២:២៤ ឆ ជន ១:១០ **១០:២៣** ជ ជន ១:១០ **១០:២៤** ឈ ជន ១:១១ **១០:២៥** ញ ជន ២:៣១ ដ ជន ១:១២ **១០:២៦** ឋ ជន ១:១៣ **១០:២៧** ឌ ជន ១:១៥ **១០:២៩** ឍ ពច ៤:១១ ណ នក ២:១៨ ត នក ៣:១ ថ លប ១២:៧ ១៥:១៤ **១០:៣០** ទ មថ ២១:២៩

*ត្រែ* ការធ្វើបែបនេះដើម្បីរៀបចំពួកបណ្ដាជនក្នុងការប្រកបជាមួយនឹងព្រះ ក្រោយមកទៀតស្ដេច ដាវីឌបានបន្ថែមឧបករណ៍ផ្សេងៗទៀតក្នុងពេលថ្វាយបង្គំព្រះ (១របា ២៥) ប៉ុន្តែ ស្ដេចអង្គនេះនៅតែរក្សាត្រែធ្វើអំពីប្រាក់សម្រាប់នាំមុខហឹបនៃសេចក្ដីសញ្ញា (១របា ១៦:៦) ។

**១០:១១-២២:១** នៅវគ្គនេះបានប្រាប់អំពីដំណើររបស់ពួកអ៊ីស្រាអែលដើរឆ្លងកាត់ឧបសគ្គ ដោយប្រព្រឹត្តមិនត្រឹមត្រូវពីភ្នំស៊ីណាយទៅតំបន់កាដេស (១៣:២៦) ទៅស្រុកម៉ូអាប់ ។

**១០:១១-២៨** ទម្រង់បែបបទនៅក្នុងវគ្គនេះមានដូចតទៅ : (១).ខ.១១ តារាងពេលវេលា (២).ខ.១២-១៣ សេចក្ដីផ្ដើមសង្ខេបនៃការតែងតាំង (៣). ខ.១៤-១៧ ការតែងតាំងឱ្យពូជអំបូរយូដាបានធ្វើជាអ្នកដឹកនាំ (២:៣-៩) ។ (៤).ខ.១៨-២១ ការតែងតាំងឱ្យពូជអំបូររូបេនបានធ្វើជាអ្នកដឹកនាំ (២:១០-១៦) ។ (៥).ខ.២២-២៤ ការតែងតាំងឱ្យពូជអំបូរអេប្រាអិមបានធ្វើជាអ្នកដឹកនាំ (២:១៨-២៤) ។ (៦).ខ.២៥-២៧ ការតែងតាំងឱ្យពូជអំបូរដាន់បានធ្វើជាអ្នកដឹកនាំ (២:២៥-៣១) ។ (៧). ខ.២៨ សរុបសេចក្ដីនៃការដើរក្បួនដង្ហែរ ។

**១០:១១** *ថ្ងៃ២០ ខែពិសាខក្នុងឆ្នាំទី២* បន្ទាប់ពី១១ខែនៅក្នុងតំបន់ភ្នំស៊ីណាយ ពួកបណ្ដាជនបានតម្រង់ទិសដៅទៅទឹកដីសន្យា ដោយមានពពកនាំមុខ ។ ពួកអ៊ីស្រាអែលបានចេញដំណើរពីបីខែកន្លងមកហើយ ដោយតម្រង់ទៅវាយដណ្ដើមស្រុកកាណាន ។ *សេចក្ដីបន្ទាល់* មើលការពន្យល់ នក ២៥:២២ ។

**១០:១៤-២៧** ឈ្មោះអ្នកដឹកនាំនៃពូជអំបូរទាំង១២ត្រូវបានឃើញជាលើកទី៤នៅក្នុងបទគម្ពីរនេះ (១:៥-១៥ ២:៣-៣១ ៧:១២-៨៣) ។

**១០:១៤** *ពួកកង* ដូចនៅក្នុង ២:៣,១០,១៨,២៥ ក្រុមនីមួយៗនៃពូជអំបូរទាំងអស់ត្រូវបានបែងចែកជាក្រុម ឬជាកងៗ ។

**១០:២៩** *ហូបាប់ កូនរេហួល* លោកហូបាប់គឺជាបងថ្លៃរបស់លោកម៉ូសេ ។ *រេហួល* គឺជាលោកយេត្រូជាឪពុកក្មេករបស់លោកម៉ូសេ (សូមមើល នក ២:១៨ ៣:១) ។

មួយនឹងញាតិសន្តានរបស់អញ[ន] ៣១តែម៉ូសេអង្វរថា សូម
កុំឱ្យលោកឪពុកចោលយើងខ្ញុំឡើយ ដ្បិតលោកជាអ្នក
ស្គាល់អស់ទាំងទីកន្លែង ដែលយើងខ្ញុំត្រូវដំឡើងត្រសាល
នៅក្នុងទីរហោស្ថាននេះ ដូច្នេះលោកនឹងបានដូចជាភ្នែក
ដល់យើងខ្ញុំ[ន] ៣២បើសិនជាលោកអញ្ជើញទៅជាមួយនឹង
យើងខ្ញុំ នោះការល្អអ្វីដែលព្រះយេហូវ៉ានឹងប្រោសដល់
យើងខ្ញុំយ៉ាងណា[ប] នោះយើងខ្ញុំក៏នឹងផ្ដល់ជូនលោកយ៉ាង
នោះដែរ[ផ]។

៣៣គេក៏ចេញពីភ្នំនៃព្រះយេហូវ៉ា ធ្វើដំណើរទៅ[ព]អស់
៣ថ្ងៃ ហើយហិបនៃសេចក្តីសញ្ញាផងព្រះយេហូវ៉ា[ភ] ក៏ទៅ
មុខគេទាំង៣ថ្ងៃនោះ ដើម្បីនឹងរកទីកន្លែងឱ្យគេឈប់
សំរាក[ម] ៣៤ក៏មានពពកនៃព្រះយេហូវ៉ានៅពីលើគេ នៅ
ពេលថ្ងៃ ចាប់តាំងពីពេលដែលគេចេញដំណើរពីទីដំឡើង
ត្រសាលនោះទៅ[យ] ៣៥រីឯវេលាណាដែលហិបចេញទៅ
នោះម៉ូសេតែងទូលថា ឱព្រះយេហូវ៉ាអើយ សូមក្រោក
ឈរឡើង[រ] ឱ្យពួកខ្មាំងសត្រូវទ្រង់ត្រូវខ្ចាត់ខ្ចាយទៅ[ល] ហើយ
ឱ្យពួកអ្នកដែលស្អប់ទ្រង់ ត្រូវរត់នៅចំពោះទ្រង់[វ][ស] ៣៦លុះ
វេលាដែលហិបឈប់វិញ នោះលោកទូលថា ឱព្រះយេ
ហូវ៉ាអើយ សូមត្រឡប់[ហ]មកឯពួកអ៊ីស្រាអែលទាំងសល់
សែនវិញ[ឡ] ។

## ភ្លើងដែលមកពីព្រះអម្ចាស់

**១១** ១ឯពួកបណ្តាជនគេរទូរទាំ[ក] ហើយសេចក្តីនោះក៏
អាក្រក់ នៅព្រះការណ៏នៃព្រះយេហូវ៉ា[ខ] កាលទ្រង់បានឮ
នោះសេចក្តីខ្ញាល់ទ្រង់ក៏កាត់ឡើង[គ] ហើយភ្លើងនៃទ្រង់បាន
ឆេះនៅកណ្ដាលពួកគេ[ឃ] ទាំងឆេះបំផ្លាញ[ង]នៅចុងបំផុត នៃ
ទីដំឡើងត្រសាលទៅ ២នោះបណ្ដាជនក៏ស្រែករកម៉ូសេ
ហើយលោកអធិស្ឋាន[ច]ដល់ព្រះយេហូវ៉ា[ឆ] រួចភ្លើងបាន
រលត់ទៅ ៣ដូច្នេះគេហៅទីនោះថា តាបេរ៉ា[ជ] ពីព្រោះភ្លើង
នៃព្រះយេហូវ៉ាបានឆេះក្នុងពួកគេ[ឈ] ។

## សត្វក្រួចដែលមកពីព្រះអម្ចាស់

៤រីឯពួកសាសន៍ដទៃ ដែលនៅលាយឡំជាមួយនឹង
ពួកកូនចៅអ៊ីស្រាអែល គេក៏នឹកចង់បានម្ហូបជាខ្លាំងពន់
ពេក[ញ] ហើយពួកកូនចៅអ៊ីស្រាអែលក៏យំ[ដ]ម្ដងទៀតតាមគេ
ដែរ ដោយពាក្យថា តើអ្នកណានឹងឱ្យសាច់មកយើង
បរិភោគ ៥យើងនឹករឭកពីត្រី ដែលយើងបានបរិភោគ
នៅស្រុកអេស៊ីព្ទជាឥតថ្លៃ ហើយពីត្រសក់ ឪឡឹក ខ្ទឹម
ខ្យល់ ខ្ទឹមសំឡ និងខ្ទឹមសផង[ឋ] ៦តែឥឡូវនេះ យើងរីង
ស្ងាប់ហើយ ដ្បិតគ្មានអ្វីសោះ មានតែនំម៉ាន៉ា ដែលនៅ
ចំពោះភ្នែកយើងនេះប៉ុណ្ណោះ[ឌ] ៧រីឯនំម៉ាន៉ានោះ មាន
ភាពដូចជាគ្រាប់ល្ង[ឍ] មានសម្បុរដូចជាកែវមុក្ដា[ណ] ៨ពួក
បណ្ដាជនក៏ចេញទៅរើសយកមក[ត] កិននឹងត្បាល់កិន ឬបុក
ក្នុងត្បាល់បុក រួចចំអិនក្នុងឆ្នាំងធ្វើជានំ ក៏មានរសជាតិ ដូច

**១០:៣០** ធ នក ១៨:២៧
**១០:៣១** ន យប ២៩:១៥
**១០:៣២** ប ទដ ២២:២៧–៣១ ៦៧:៥–៧ ផ ចទ ១២:៤៨ ចទ ១០:១៨
**១០:៣៣** ព ឧ.១២ ចទ ១:៣៣ ភ ចទ ១០:៨ ៣១:៩ យស ៣:៣ ពច ២០:២៧ ២សយ ១៥:២៤ ម យរ ៣១:២
**១០:៣៤** យ ជន ៩:១៥–២៣
**១០:៣៥** រ ២របា ៦:៤១ ទដ ១៧:១៣ ៤៤:២៦ ៩៤:២ ១៣២:៨ ល ពច ៥:៣១ ១សយ ២:១ ទដ ៦៨:១ ៩២:៩ វ ចទ ៥:៩ ៧:១០ ៣២:៤១ ទដ ៦៨:២ អស ១៧:១២–១៤ ស អស ៥៩:១៨
**១០:៣៦** ហ អស ៥២:៨ ៦៣:១៧ ឡ លប ១៥:៥ ២៦:៤ ចទ ១:១០ ១០:២២ នហ ៩:២៣

**១១:១** ក នក ១៤:១១ ១៦:៧ បទ ៣:៣៩ ខ ជន ១២:២ ចទ ១:៣៤ គ នក ៤:១៤ ឃ លវ ១០:២ ង ជន ២១:២៨ ទដ ៧៨:៦៣ អស ២៦:១១ **១១:២** ច ចទ ៩:១៩ ១សយ ២:២៥ ១២:២៣ ទដ ១០៦:២៣ ឆ លប ២០:៧ ជន ២១:៧ ចទ ៩:២០ យហ ២:១ **១១:៣** ជ ចទ ៩:២ ឈ ជន ១៦:៣៥ យប ១:១៦ អស ១០:១៧ **១១:៤** ញ នក ១៦:៣ ដ ឧ.១៨ **១១:៥** ឋ នក ១៦:៣ ជន ២១:៥ **១១:៦** ឌ នក ១៦:១៤ **១១:៧** ឍ នក ១៦:៣១ ណ លប ២:២១ **១១:៨** ត នក ១៦:១៦

**១០:៣១** *នឹងបានដូចជាភ្នែកដល់យើងខ្ញុំ* នៅក្នុង ពច ១:១៦ បានបង្ហាញថា ហូបាប់ បានទទួលសំណូមពររបស់លោកម៉ូសេ ។

**១០:៣៣** *៣ថ្ងៃ* ដោយសារចំនួនមនុស្សច្រើនកុះករពេក ហើយនេះក៏ជាលើកទីមួយនៃការរៀបចំក្បួនដង្ហែរ វាពុំដូចជាក្បួនដង្ហែរធ្វើដំណើរធម្មតានោះទេ (មើលការពន្យល់ លប ២២:៤)។

**១០:៣៥–៣៦** នៅក្នុងខនេះបានពិពណ៌នាពីទាហានរបស់ព្រះអម្ចាស់ជាអ្នកនាំមុខគេ ។

**១០:៣៥** ពាក្យរបស់លោកម៉ូសេនៅក្នុងខនេះ ក្រោយមកត្រូវបានគេប្រើក្នុងការចាប់ផ្ដើមពិធីអបអរសាទរពីជ័យជម្នះក្នុងក្បួនដើរដង្ហែរពីភ្នំស៊ីណាយទៅក្រុងយេរូសាឡិម(ទដ ៦៨:១ និងការពន្យល់ ទដ ៦៨:១–៣) ។

**១១:១** *ពួកបណ្ដាជនគេរទូរទាំ* នៅក្នុងដប់ជំពូកដំបូងនៃគម្ពីរជនគណនាបានបញ្ជាក់ដដែលអំពីការស្ដាប់បង្គាប់របស់លោកម៉ូសេ ហើយនិងពួកបណ្ដាជនទៅចំពោះព្រះអម្ចាស់ ។ ប៉ុន្តែ មានរយៈពេលតែបីថ្ងៃនៅក្នុងក្បួនដង្ហែរនោះពួកគេបែរទៅជារទូរទាំទៅវិញ ។ ពួកគេបានរទូរទាំដដែលនៅក្នុងឆ្នាំដំបូង ក្រោយពីពួកគេឆ្លងកាត់សមុទ្រក្រហមចប់តែបីថ្ងៃប៉ុណ្ណោះ (នក ១៥:២២–២៧) ហើយក្រោយពីហេតុការណ៍នោះមក ពួកគេបានរទូរទាំអំពីនំម៉ាន៉ា(នក ជំពូក១៦) និងការខ្វះខាតទឹក (នក ១៧:១–៧)។ *ភ្លើងនៃទ្រង់* ដោយសេចក្ដីមេត្តាករុណានៃព្រះអម្ចាស់ ភ្លើងនោះពុំបានធ្លាក់ចំត្រសាលទេ ហើយការឆេះនោះក៏មានតិចតួចដែរ ។ ភ្លើងនេះបានកើតឡើងដោយសារផ្លេកបន្ទោរ (១ពវ ១៨:៣៨ និងការពន្យល់ ១៨:២៤) ។

**១១:៤** *ពួកសាសន៍ដទៃ* គឺមិនមែនជាកូនចៅអ៊ីស្រាអែលទេ តែបានចេញពីស្រុកអេស៊ីព្ទមកជាមួយនឹងពួកអ៊ីស្រាអែលវិញ ។ ពួកនេះហើយដែលជាប្រភពនៃការរទូរទាំ និងជាអ្នកដែលបណ្ដាលឱ្យមានបញ្ហានៅក្នុងត្រសាលនោះ ។ *តើអ្នកណានឹង ឱ្យសាច់មកយើងបរិភោគ* បើនៅក្នុង នក ជំពូក១៦ បណ្ដាជនចាប់ផ្ដើមរទូរទាំអំពីការតមអាហារ ហើយបំភ្លេចនូវអ្វីដែលព្រះបានធ្វើចំពោះគេអស់រលីង (សូមមើល ទដ ១០៦:១៤) ។ តាមពិតទៅសាច់ពុំមែនអាហារពិសេសរបស់ពួកគេនោះទេ ក្នុងពេលដែលពួកគេស្ថិតនៅភាពជាទាសករក្នុងប្រទេសអេស៊ីព្ទនោះ ។

**១១:៥** *ត្រី . . . ត្រសក់ . . . ខ្ទឹមស* ដែលណែនាំទៅលើប្រភេទនៃម្ហូបអាហារដែលអាចមាននៅប្រទេសអេស៊ីព្ទ ហើយមានលក្ខណៈផ្ទុយពីការទទួលទាននំម៉ាន៉ានៅទីរហោស្ថាន ។

**១១:៧** *នំម៉ាន៉ា* សូមមើលការពន្យល់នៅ នក ១៦:៣១ ។

ជារសជាតិនៃប្រេងថ្មី ៩នៅវេលាយប់[ថ] កាលទឹកសន្សើម
ធ្លាក់មកលើទីដំឡើងត្រសាល នោះនំម៉ាន៉ាក៏ធ្លាក់មកជា
មួយ ១០ម៉ូសេក៏ឮបណ្ដាជនយំ[ទ] នៅគ្រប់ទាំងគ្រួសារគេ
គឺគ្រប់គ្នានៅមាត់ទ្វារត្រសាលរបស់ខ្លួន នោះសេចក្ដីខ្ញាល់
នៃព្រះយេហូវ៉ាក៏ឆួលឡើងខ្លាំង ហើយម៉ូសេក៏អន់ចិត្ត
ដែរ ១១រួចម៉ូសេទូលដល់ព្រះយេហូវ៉ាថា ហេតុអ្វីបានជា
ទ្រង់ធ្វើទុក្ខ[ធ]ដល់ទូលបង្គំ ជាអ្នកបំរើទ្រង់ដូច្នេះ ហេតុអ្វីបាន
ជាទូលបង្គំមិនបានប្រកបដោយព្រះគុណនៃទ្រង់ គឺទ្រង់
បានផ្ទុកមនុស្សទាំងនេះជាបន្ទុកលើទូលបង្គំវិញ[ន] ១២តើ
ទូលបង្គំជាឪពុក នៃមនុស្សទាំងនេះឬ តើទូលបង្គំបាន
បង្កើតគេមកឬអី បានជាទ្រង់មានបន្ទូលថា ចូរបីគេដូច
ជាមេដោះបីកូនដែលនៅបៅ[ប] នាំទៅឯស្រុកដែលទ្រង់បាន
ស្បថ[ផ]ថា នឹងឱ្យដល់ពួកឰយុកោគេដូច្នេះ[ព] ១៣តើទូលបង្គំ
នឹងបានសាច់ពីណាមក ឱ្យមនុស្សទាំងនេះភបរិភោគបាន
ដ្បិតគេយំតាមទូលបង្គំថា ចូរឱ្យសាច់មកយើងបរិភោគ
ផង ១៤រូបទូលបង្គំតែម្នាក់ឯង និងបីទ្រមនុស្សទាំងនេះ
មិនបានទេ ដ្បិតគេជាបន្ទុកធ្ងន់ហួសកំឡាំងទូលបង្គំហើយ[ម]
១៥បើទ្រង់ប្រព្រឹត្តនឹងទូលបង្គំយ៉ាងដូច្នេះ ហើយបើទូល
បង្គំប្រកបដោយព្រះគុណនៃទ្រង់ពិត នោះសូមសំឡាប់[យ]
ទូលបង្គំទៅវិញចុះ[រ] ដើម្បីកុំឱ្យទូលបង្គំនៅឃើញសេចក្ដី
វេទនា របស់ទូលបង្គំទៀត ។
១៦ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ចូរប្រមូល៧០
នាក់ ពីពួកចាស់ទុំសាសន៍អ៊ីស្រាអែល[ល] ដែលឯងដឹងថា ជា
ចាស់ទុំក្នុងបណ្ដាជន[វ] និងជានាយកត្រួតត្រាលើគេមែន ឱ្យ
គេមកឯអញ ត្រូវនាំគេមកឯត្រសាលជំនុំ[ស] ឱ្យឈរនៅទី
នោះជាមួយនឹងឯង ១៧អញនឹងចុះមកនិយាយនឹងឯង[ហ]
ហើយនឹងចែកព្រះវិញ្ញាណ ដែលសណ្ឋិតលើឯង ទៅដាក់
លើគេផងឡ នោះគេនឹងជួយផ្ទុកនូវបន្ទុកបណ្ដាជននេះ ជា
មួយនឹងឯង ដើម្បីកុំឱ្យឯងត្រូវផ្ទុកតែម្នាក់ឯងឡើយ[អ] ១៨ត្រូវ
ឱ្យឯងប្រាប់ដល់បណ្ដាជនថា ចូរឯងរាល់គ្នាញែកខ្លួនចេញ
ជាបរិសុទ្ធ[ក]ឱ្យទាន់នៅថ្ងៃស្អែក នោះនឹងបានសាច់បរិភោគ
ហើយ ដ្បិតឯងរាល់គ្នាបានយំ[ខ]ដាក់ព្រះកាណ៌នៃព្រះ
យេហូវ៉ាថា តើអ្នកណានឹងឱ្យសាច់មកយើងបរិភោគ ដ្បិត
ដែលយើងនៅស្រុកអេស៊ីព្ទនៅឡើយ នោះស្រួលណាស់គ
ដូច្នេះព្រះយេហូវ៉ាទ្រង់នឹងប្រទានសាច់មក[ឃ] ហើយឯង
រាល់គ្នានឹងបរិភោគផង ១៩មិនមែនត្រឹមតែ១ថ្ងៃ ២ថ្ងៃ ឬ
៥ថ្ងៃ ១០ថ្ងៃ ឬ២០ថ្ងៃប៉ុណ្ណោះទេ ២០គឺឯងរាល់គ្នានឹង
បរិភោគពេញ១ខែវិញ ទាល់តែសាច់នោះចេញតាមរន្ធ
ច្រមុះឯងមក ហើយឯងនឹងធុញទ្រាន់ចំពោះសាច់នោះ[ង] ពី
ព្រោះឯងរាល់គ្នាបានជិនណាយចិត្ត នឹងព្រះយេហូវ៉ា[ច]
ដែលទ្រង់គង់បណ្ដាពួកឯង ហើយបានយំនៅចំពោះទ្រង់
ថា ហេតុអ្វីបានជាយើងរាល់គ្នាចេញពីស្រុកអេស៊ីព្ទមក
ដូច្នេះ[ឆ] ។

**១១:៩** ថ នក ១៦:១៦
**១១:១០** ទ ខ.៤
**១១:១១** ធ លប ៣៤:៣០ ន នក ៥:២២ ១៨:១៨
**១១:១២** ប អស ៤០:១១ ៤៩:២៣ ៦៦:១១,១២ ផ ជន ១៤:១៦ ព លប ១២:៧ នក ១៣:៥
**១១:១៣** ភ នក ១២:៣៧ យហ ៦:៥–៩
**១១:១៤** ម នក ១៨:១៨
**១១:១៥** យ នក ៣២:៣២ រ ១ពវ ១៩:៤ យប ៦:៩ ៧:១៥–១៦ ៩:២១ ១០:១ អស ៣៨:១២ យហ ៤:៣
**១១:១៦** ល នក ៣:១៦ វ នក ១៨:២៥ ស នក ៤០:២
**១១:១៧** ហ នក ១៩:២០ ឡ ខ.២៥, ២៩ ១សយ ១០:៦ ២ពវ ២:៩,១៥ ៣:១២ អស ៣២:១៥ ៤០:៥ ៦៣:១១ យអ ២:២៨ ហក ២:៥ អ នក ១៨:១៨ យរ ១៩:១
**១១:១៨** ១៩:១០ ខ នក ១៦:៧ គ ខ.៥ កច ៧:៣៩ ឃ ទដ ៧៨:២០
**១១:២០** ង ទដ ៧៨:២៩ ១០៦:១៤,១៥ ច លវ ២៦:៤៣ យស ២៤:២៧ ពច ៨:២៣ ១សយ ១០:១៩ យប ៣១:២៨ អស ៥៩:១៣ ហស ១៣:១១ ឆ ខ.៣៣ យប ២០:១៣,២៣

**១១:១០** *នោះសេចក្ដីខ្ញាល់នៃព្រះយេហូវ៉ាក៏ឆួលឡើងខ្លាំង* ត្រង់នេះគឺជាការបដិសេធន៍ម្ហូបអាហារ ដែលជាអំណោយសេចក្ដីមេត្តាករុណាមកពីស្ថានសួគ៌ "អាហារមកពីស្ថានសួគ៌ នក ១៦:៤" ។ ព្រះអម្ចាស់បានមានបន្ទូលថា ការទទួលបាននំម៉ាន៉ា គឺជាការសាកល្បងនៃការស្ដាប់បង្គាប់របស់ពួកគេប៉ុណ្ណោះ(នក ១៦:៤) ។ ចំណុចល្អនៃទិដ្ឋភាពនេះគឺទ្រង់ត្រូវតែប្រទានដល់ពួកគេ(១០:៣២) ហើយពួកបណ្ដាជនត្រូវតែទទួលជាប្រចាំថ្ងៃ ទុកដូចជាអំណោយដោយសេចក្ដីមេត្តាករុណារបស់ព្រះ ហើយជាការសន្យាដ៏បរិបូរដល់ពួកគេ ។ ការបដិសេធន៍នំម៉ាន៉ាគឺមានន័យថាបដិសេធន៍ព្រះដូច្នេះដែរ។ ពួកគេបានបរាជ័យក្នុងការសាកល្បងនេះ ។ *ម៉ូសេក៏អន់ចិត្តដែរ* ទង្វើរបស់ពួកបណ្ដាជនក្នុងការបដិសេធន៍នំម៉ាន៉ាដែលជាការផ្គត់ផ្គង់របស់ព្រះ នេះបានធ្វើឱ្យ លោកម៉ូសេមានបញ្ហាផងដែរ ។ ក្រៅពីទូលសូមឱ្យព្រះអង្គទ្រង់ជ្រាបពីការរទូរទាំរបស់ពួកបណ្ដាជន នោះលោកម៉ូសេបានសួរព្រះអង្គថាហេតុអ្វីក៏ទ្រង់ប្រគល់មនុស្សមិនចេះដឹងគុណដល់អ្នកដឹកនាំបែបនេះ ។

**១១:១១–១៥** នៅក្នុងខទាំងនេះគឺជាសេចក្ដីអធិស្ឋានពីភាពសោកសង្រេងរបស់លោកម៉ូសេចំពោះការរទូរទាំនៃពួកបណ្ដាជន ។

**១១:១២** *តើទូលបង្គំជាឪពុកនៃមនុស្សទាំងនេះឬ* ការបកស្រាយគឺយ៉ាងដូច្នេះថា ព្រះអម្ចាស់បានបង្កើតរាស្ត្រអ៊ីស្រាអែល ដូច្នេះទ្រង់គឺជាអ្នកថែរក្សាហើយ ពួកគេគឺជាសេចក្ដីសន្យារបស់ទ្រង់ ។ លោកម៉ូសេសូមឱ្យព្រះអង្គបន្ធូរភាពតានតឹងនេះ"បន្ទុកនេះធ្ងន់ណាស់សម្រាប់ខ្ញុំ"(ខ.១៤ ១ពវ ១៩) ។ លោកម៉ូសេបានពោលថា សូម្បីតែស្លាប់ក៏លោកសុខចិត្តដែរ(ខ.១៥) ជាជាងបន្តការប្រឈមមុខនឹងការរទូរទាំរបស់ពួកបណ្ដាជនទាំងនេះ ។

**១១:១៦–៣៤** ការឆ្លើយតបរបស់ព្រះអម្ចាស់ទៅនឹងភាពតានតឹងនៃហោរាមានពីរករណី ដោយសេចក្ដីមេត្តា និងបណ្ដាសា : (១).មានសេចក្ដីមេត្តាដល់លោកម៉ូសេក្នុងការទទួលខុសត្រូវ ឥឡូវមានអ្នកដឹកនាំជួយលោក ៧០នាក់ទៀត(ខ.១៦–១៧) ។ (២). មានបណ្ដាសាទៅលើពួកបណ្ដាជនដោយសារតែពួកគេបានរទូរទាំដោយសារសាច់នោះពួកគេបានមានជម្ងឺដោយសារសាច់នោះ(ខ.១៨–៣៤) ។

**១១:១៨** *នោះនឹងបានសាច់បរិភោគហើយ* ការទទួលនំម៉ាន៉ាជាប្រចាំហើយគ្មានសាច់បរិភោគនោះ បានធ្វើឱ្យពួកគេជិទាស់នឹងសេចក្ដីល្អរបស់ព្រះ ។ ពួកគេបានស្រែកទាមទាសាច់ ឥឡូវពួកគេនឹងបានទទួលសាច់មែន តែដោយបរិភោគច្រើនពេកបានធ្វើឱ្យពួកគេមានជម្ងឺទៅវិញ (ខ.២០) ។

**១១:២០** *ឯងរាល់គ្នាបានជិនណាយចិត្តនឹងព្រះយេហូវ៉ា* សាច់រឿងសំខាន់មិនផ្ដោតទៅលើសាច់ទាំងអស់នោះទេ គឺសំដៅទៅលើភាពបរាជ័យក្នុងការបង្ហាញអត្តចរិតខុសឆ្គងចំពោះព្រះ ។

២១រួចម៉ូសេទូលសួរថា បណ្តាមនុស្សដែលទូលបង្គំ
នៅជាមួយនេះ មានពួកថ្មើរជើងចំនួន៦សែននាក់[ជ] ដូច្នេះ
ទ្រង់មានបន្ទូលថា នឹងឱ្យសាច់ដល់គេគ្រប់គ្នា ឱ្យបាន
បរិភោគពេញ១ខែឬ ២២តើត្រូវសំឡាប់ហ្វូងសត្វទាំងធំ
ទាំងតូច ឱ្យល្មមដល់គេឬអី ឬត្រូវប្រមូលត្រីក្នុងសមុទ្រ
ទាំងអស់មក ឱ្យល្មមដល់គេដែរ[ឈ] ២៣នោះព្រះយេហូវ៉ា
ទ្រង់មានបន្ទូលតបនឹងម៉ូសេថា តើព្រះហស្តព្រះយេហូវ៉ា
បានរួញខ្លីឬអី[ញ] ឥឡូវនេះឯងនឹងឃើញពិត បើពាក្យអញ
ថានឹងកើតមកដល់ឯងមែន ឬមិនមែន[ដ] ។
២៤ម៉ូសេក៏នាំយកព្រះបន្ទូល នៃព្រះយេហូវ៉ា ចេញ
ទៅប្រាប់ដល់បណ្តាជន រួចលោកប្រមូលពួកចាស់ទុំនៃ
បណ្តាជន៧០នាក់ មកដាក់ឱ្យឈរនៅជុំវិញត្រសាលជំនុំ
២៥នោះព្រះយេហូវ៉ាទ្រង់យាងចុះមកក្នុងពពក[ឋ] មានបន្ទូល
នឹងលោក[ឌ] រួចក៏ចែកព្រះវិញ្ញាណ[ឍ] ដែលសណ្ឋិតលើ
លោកទៅដាក់លើពួកចាស់ទុំទាំង៧០នាក់នោះផង[ណ] កាល
ព្រះវិញ្ញាណបានសណ្ឋិតលើគេហើយ នោះស្រាប់តែគេ
ទាយទំនាយម្តង[ត] តែមិនបានទាយតទៅមុខទៀតទេ ។
២៦រីឯមានពួកគេ២នាក់វារង់នៅឯទីដំឡើងត្រសាល
១ឈ្មោះអែលដាត ១ទៀតឈ្មោះមីដាត ជាពួកអ្នកដែល
ចុះឈ្មោះរួចហើយ តែមិនបានចេញទៅឯរោងឧបោសថ
ទេ ព្រះវិញ្ញាណក៏សណ្ឋិតលើគេដែរ[ថ]ហើយគេទាយនៅ
ក្នុងទីដំឡើងត្រសាល ២៧នោះមានមនុស្សកំឡោះម្នាក់រត់
ទៅជំរាបម៉ូសេពីរឿងនោះថា អែលដាត និងមីដាត គេ
កំពុងតែទាយនៅក្នុងទីដំឡើងត្រសាល ២៨រួចយ៉ូស្វេ ជា
កូននុន[ទ] ដែលជាអ្នកជំនិត[ធ]របស់ម៉ូសេ តាំងពីកំឡោះមក ក៏
និយាយថា លោកម្ចាស់ខ្ញុំអើយ សូមហាមគេទៅ[ន] ២៩តែ

**១១:២១** ជ នក ១២:៣៧
**១១:២២** ឈ មថ ១៥:៣៣
**១១:២៣** ញ អស ៥០:២ ៥៩:១ ដ ជន ២៣:១៩ ១សយ ១៥:២៩ អគ ១២:២៥ ២៤:១៤
**១១:២៥** ឋ នក ១៩:៩ ជន ១២:៥ ឌ ខ.១៧ ឍ ខ.២៩ ១សយ ១០:៦ ១៩:២៣ ណ កច ២:២៧ ត ខ.២៦ ជន ២៤:២ ពច ៣:១០ ១សយ ១០:១០ ១៩:២០ ២របា ១៥:១
**១១:២៦** ថ ខ.២៥ ១របា ១២:១៨ វវ ១:១០
**១១:២៨** ទ នក ១៧:៩ ជន ១៣:៨ ២៦:៦៥ យស ១៤:១០ ធ នក ៣៣:១១ យស ១:១ ន មក ៩:៣៨–៤០
**១១:២៩** ប ១សយ ១០:៥ ១៩:២០ ២របា ២៤:១៩ យរ ៧:២៥ ៤៤:៤ ១កថ ១៤:៥ ផ ខ.១៧ ព ជន ២៧:១៨
១១:៣១ ភ នក ១៦:១៣ ទដ ៧៨:២៦–២៨

ម៉ូសេឆ្លើយថា តើឯងច្រណែនជំនួសអញឬអី អញសុខ
ចិត្តឱ្យបណ្តាជនទាំងឡាយរបស់ព្រះយេហូវ៉ា ចេះទាយ
ដែរ[ប] ហើយឱ្យព្រះយេហូវ៉ាបានដាក់ព្រះវិញ្ញាណទ្រង់[ផ] លើ
គេគ្រប់គ្នាចុះ[ព] ៣០នោះម៉ូសេ ព្រមទាំងពួកចាស់ទុំសាសន៍
អ៊ីស្រាអែល ក៏នាំគ្នាត្រឡប់ទៅឯទីដំឡើងត្រសាលវិញ ។
៣១នោះព្រះយេហូវ៉ាទ្រង់ធ្វើឱ្យមានខ្យល់បក់នាំសុទ្ធតែ
សត្វក្រួចពីសមុទ្រមក ឱ្យរាចចេញនៅគ្រប់ជុំវិញទីដំឡើង
ត្រសាល[ភ] មានចំងាយដើរ១ថ្ងៃខាងណេះ ហើយ១ថ្ងៃខាង
ណោះ នៅព័ទ្ធជុំវិញ ហើយកំពស់ពីដីឡើងប្រហែលជា២
ហត្ថ ៣២ឯបណ្តាជនទាំងឡាយ គេក៏ក្រោកឡើងឈរចាប់
ក្រួចពេញ១ថ្ងៃ១យប់នោះ ហើយ១ថ្ងៃស្អែកទៀត អ្នកណា
ដែលចាប់បានតិចជាងគេ នោះបានដល់១០ហាប រួចគេ
ហាលសាច់សត្វទាំងនោះ នៅគ្រប់ជុំវិញទីដំឡើងត្រសាល
ទុកសំរាប់ខ្លួនគេ ៣៣តែកាលសាច់នោះ កំពុងដឹកលំនៅនា
ធ្មេញ[ម]មិនទាន់ទំពានៅឡើយ នោះសេចក្តីខ្ញាល់[យ] របស់ព្រះ
យេហូវ៉ា ក៏ឆួលក្តៅឡើងទាស់នឹងគេ ហើយទ្រង់វាយ
បណ្តាជនទាំងឡាយ ដោយសេចក្តីវេទនាយ៉ាងធំ[រ] ៣៤ឯ
ឈ្មោះកន្លែងនោះគេក៏ហៅថា គីប្រុត–ហាតាវ៉ា[ល] ពីព្រោះ
នៅទីនោះ គេបានកប់ខ្មោចនៃពួកអ្នកដែលនឹកប៉ងប្រាថ្នា
នោះ ៣៥រួចបណ្តាជនគេធ្វើដំណើរ ពីគីប្រុត–ហាតាវ៉ា
ទៅដល់ហាសិរ៉ូត[វ] ហើយក៏ឈប់នៅត្រង់ហាសិរ៉ូតនោះ ។

## នាងម៉ារាម និងលោកអើរ៉ុនទាស់នឹងលោកម៉ូសេ

**១២** ១រីឯម៉ារាម[ក] និងអើរ៉ុន គេនិយាយទំនាស់នឹងម៉ូសេ

**១១:៣៣** ម ទដ ៧៨:៣០ យ ជន ១៤:១៨ ចទ ៨:៧ ពច ២:១២ ២ពវ ២២:១៧ ទដ ១០៦:២៩ យរ ៤៤:៣ អគ ៨:១៧ រ ខ.១៨–២០ ទដ ១០៦:១៥ អស ១០:១៦ **១១:៣៤** ល ជន ៣៣:១៦ ចទ ៩:២២ **១១:៣៥** វ ជន ៣៣:១៧ **១២:១** ក នក ១៥:២០

**១១:២១** *មានពួកថ្មើរជើងចំនួន៦សែននាក់* ចំនួនទាំងនេះមាននៅក្នុងកម្លាំងដើរដង្ហែរក្នុងចំណោមមនុស្ស២លាននាក់(មើលការពន្យល់ ១:៤៦) ។ ការលំបាករបស់លោកម៉ូសេក្នុងការផ្តល់សាច់ទៅឱ្យចំនួនដ៏ច្រើនលើសលប់នេះ(ខ.២២) គឺពុំអាចធ្វើទៅកើតនោះទេ ។

**១១:២៣** *តើព្រះហស្តព្រះយេហូវ៉ាបានរួញខ្លីឬអី* អំណាចព្រះចេស្តារបស់ព្រះបានបង្ហាញក្នុង"ឱកាសដែលមនុស្សពុំអាចនឹងធ្វើកើត" ។

**១១:២៥** *ព្រះវិញ្ញាណ* គឺជាអំណាចនៃព្រះវត្តមានរបស់ព្រះ (មើលការពន្យល់ ពច ៣:១០) ។ *គេទាយទំនាយ* ប្រហែលជាពួកគេសម្តែងពីភាពរំភើបរីករាយដែលបានមកដោយបទពិសោធន៍ខាងឯសេចក្តីជំនឿរបស់ខ្លួន (១សយ ១០:៥ ១៨:១០ ១៩:២០,២៤ ១ពវ ១៨:២៩ និងការពន្យល់) ។ *តែមិនបានទាយតទៅមុខទៀតទេ* នៅត្រង់នេះវាហាក់បីដូចជាអំណោយទានបណ្តោះអាសន្នដល់ពួកចាស់ទុំទាំងនោះតែពីដំបូងដើម្បីបញ្ជាក់ពីសមត្ថភាពរបស់ពួកគាត់ថាមានព្រះវិញ្ញាណបានផ្តល់អំណាចដល់អ្នកដឹកនាំទាំងនេះ ។

**១១:២៩** *តើឯងច្រណែនជំនួសអញឬអី* ត្រង់នេះគឺជាការបង្ហាញពីវិញ្ញាណពិតរបស់លោកម៉ូសេ ។ ពុំត្រូវបានគេស្រែកកំហែងឱ្យឈប់នូវការសម្តែងពីអំណោយទាននៃព្រះវិញ្ញាណនៅមុខសាធារណៈនោះឡើយ លោកម៉ូសេបានសម្រេចចិត្តថា គ្រប់ទាំងរាស្ត្ររបស់ព្រះអាចមានអំណោយទានពីព្រះវិញ្ញាណបានទាំងអស់គ្នា(មើលការពន្យល់ យអ ២:២៨ ភល ១:១៥–១៨) ដូចជាលោកអែលដាត និងមីដាតនេះជាដើម ។

**១១:៣១–៣២** ការផ្តល់អាហារដល់មនុស្សប្រាំពាន់នាក់របស់ព្រះយេស៊ូវ (យហ ៦:៥–១៣) និងបួនពាន់នាក់ (មថ ១៥:២៩–៣៩) នៅក្នុងបទគម្ពីរទាំងពីរនេះគឺសម្តែងពីព្រះគុណរបស់ព្រះ តែនៅក្នុងបទគម្ពីរនេះវិញគឺត្រូវបានផ្តល់មកដោយសេចក្តីក្រោធរបស់ព្រះ ។

**១១:៣៤** *គីប្រុតហាតាវ៉ា* នេះគឺជារណ្តៅធំសម្រាប់កប់អស់អ្នកណាដែលទាស់នឹងម្ហូបអាហារដែលព្រះប្រទានមកដោយក្តីមេត្តា ។

**១២:១** *យកស្រីសាសន៍គូស ម្នាក់ធ្វើជាប្រពន្ធ* លោកហាំបានកូនប្រុសម្នាក់ឈ្មោះគូស កូនចៅរបស់គាត់មានឈ្មោះនៅក្នុង លប ១០:៧ ដែលរស់នៅតំបន់អារ៉ាប់ (លប ១០:៧) ហើយកូនរបស់គូសបានបង្កើតកូនម្នាក់ឈ្មោះ

ពីរឿងស្រីសាសន៍គូសដែលលោកបានយក[ខ] ដ្បិតលោក
បានយកស្រីសាសន៍គូសម្នាក់ ធ្វើជាប្រពន្ធ ២គឺគេនិយាយថា
តើព្រះយេហូវ៉ាបានមានបន្ទូលតែនឹងម៉ូសេតែ ម្នាក់ឯង
ឥតបានមានបន្ទូលនឹងយើងដែរទេឬអី[គ] ព្រះយេហូវ៉ាទ្រង់
ក៏ឮពាក្យនោះ[ឃ] ៣(រីឯម៉ូសេលោកសុភាពណាស់[ង]លើស
អស់ទាំងមនុស្សនៅលើផែនដី) ។
៤នោះលោតែព្រះយេហូវ៉ា ទ្រង់មានបន្ទូលមកម៉ូសេ
អើរ៉ុន ហើយនឹងម៉ារាមថា ចូរឯងទាំង៣នាក់ចេញមកឯ
ត្រសាលជំនុំចុះ គេក៏នាំគ្នាចេញទៅ ៥ព្រះយេហូវ៉ាទ្រង់ក៏
ចុះមកក្នុងបង្គោលពពក[ច] ឈរនៅត្រង់មាត់ទ្វារត្រសាល
មានបន្ទូលហៅចំពោះអើរ៉ុន នឹងម៉ារាម រួចគេក៏ចេញមក
៦ទ្រង់មានបន្ទូលដូច្នេះថា ចូរស្តាប់អញចុះ បើមានហោរា
ណានៅក្នុងពួកឯងរាល់គ្នា នោះអញ ដ៏ជាព្រះយេហូវ៉ា
អញនឹងឱ្យ[ឆ]អ្នកនោះស្គាល់អញក្នុងការជាក់ស្តែង[ជ] ហើយ
អញនឹងនិយាយនឹងអ្នកនោះ ដោយការពន្យល់សប្តិ[ឈ] ៧ឯ
ម៉ូសេជាអ្នកបំរើអញ នោះអញមិនធ្វើដូច្នោះទេ[ញ] ព្រោះជា
អ្នកស្មោះត្រង់ក្នុងផ្ទះរបស់អញទាំងមូល[ដ] ៨អញនឹងនិយាយ
ផ្ទាល់មាត់ នឹងលោកយ៉ាងច្បាស់វិញ គឺមិនមែនដោយ
ប្រស្នាទេ[ឋ] លោកនឹងបានឃើញរូបអង្គនៃព្រះយេហូវ៉ាផង[ឌ]
ចុះហេតុអ្វីបានជាឯងហ៊ាននិយាយទំនាស់នឹងម៉ូសេ ជាអ្នក
បំរើអញដូច្នេះ[ឍ]។
៩សេចក្តីខ្ញាល់របស់ព្រះយេហូវ៉ាក៏កាត់ឡើងទាស់នឹង
អ្នកទាំង២នោះ[ណ] រួចទ្រង់យាងបាត់ទៅ[ត] ១០ហើយពពកក៏
ឡើងផុតពីលើត្រសាលទៅដែរ[ថ] នោះមើល ម៉ារាមកើត
ឃ្លង់សដូចហិមៈ[ទ] អើរ៉ុនបែរមកមើលម៉ារាមឃើញថាកើត
ឃ្លង់ដូច្នោះ[ធ] ១១ក៏អង្វរដល់ម៉ូសេថា ឱលោកម្ចាស់ខ្ញុំអើយ
សូមកុំទំលាក់បាបនេះមកលើយើងខ្ញុំ ដោយព្រោះយើងខ្ញុំ
បានប្រព្រឹត្តដោយល្ងង់ខ្លៅ ហើយបានធ្វើបាបនេះ នោះ
ឡើយ[ន] ១២សូមកុំឱ្យម៉ារាមបានដូចជាកូនស្លាប់ ដែលមាន
សាច់រលួយពាក់កណ្តាល ក្នុងកាលដែលចេញពីផ្ទៃម្តាយ
មកនោះឡើយ ១៣ម៉ូសេក៏អំពាវនាវដល់ព្រះយេហូវ៉ាថា
ឱព្រះអង្គអើយ ទូលបង្គំសូមអង្វរទ្រង់ សូមមេត្តាប្រោសឱ្យ

**១២:១** ខ នក ២:២១ **១២:២** គ ជន ១៦:៣ ឃ ជន ១១:១ **១២:៣** ង មថ ១១:២៩ **១២:៥** ច នក ១៣:២១ ជន ១១:២៥ **១២:៦** ឆ ១សយ ៣:៧,២១ ជ លប ១៥:១ ឈ លប ២០:៣ មថ ២៧:១៩ ហព ១:១ **១២:៧** ញ ចទ ៣៤:៥ យស ១:១-២ ទដ ១០៥:២៦ ដ ហព ៣:២,៥ ទដ ១៧:១៥ ១៤០:១៣ អស ៦:១ **១២:៨** ឋ ពច ១៤:១២ ១ពវ ១០:១ ទដ ៤៩:៤ ២០:៤ សភ ១:៦ ដយ ៥:១២ ឌ នក យប ១៩:២៦ ឍ នក ២៤:២ **១២:៩** ណ នក ៤:១៤ ត លប ១៧:២២ **១២:១០** ថ នក ៤០:២ ទ នក ៤:៦ ចទ ២៤:៩ ធ ១៣:១១ ២ពវ ៥:១,២៧ ២របៈ ១៦:១២ ២១:១២-១៥ ២៦:១៩ **១២:១១** ន ២សយ ១៩:១៩ ២៤:១០

**១២:១៤** *មានសេចក្តីខ្មាសនៅអស់៧ថ្ងៃ* នេះគឺជាសកម្មភាពបន្ទោសជាសាធារណៈ(ចទ ២៥:៩) ជាការមួយដែលត្រូវអៀនខ្មាសជាសាធារណៈ ។ រយៈពេល៧ថ្ងៃគឺជាបទដ្ឋាននៃការសំអាតខ្លួន នៅពេលដែលនរណាម្នាក់បានប៉ះនឹងសាកសព (១៩:១១,១៤,១៦) ។
**១២:១៦** *ទីរហោស្ថានប៉ារ៉ាន* គឺជាតំបន់ភាគខាងត្បូងនៃទឹកដីសន្យា ។ ឱកាសវាយដណ្តើមយកទឹកដីរបស់ពួកបណ្តាជនគឺនៅពេលឆាប់ៗនេះឯង ។
**១៣:២** *ចូរចាត់មនុស្សឱ្យទៅសង្កេតមើលក្នុងស្រុកកាណាន* ការដែលចាត់ឱ្យមនុស្សទៅស៊ើបមើលទឹកដីរបស់មនុស្សផ្សេងទៀតនោះគឺជាការអនុវត្តន៍ជាទូទៅមួយនៅក្នុងសម័យបុរាណ (មើលការពន្យល់ យស ២:១-២៤) ។ ចាប់ពី ចទ ១:២២-២៣ វាបានបង្ហាញពីទិសដៅរបស់ព្រះអម្ចាស់នៅត្រង់នេះ គឺជាការឆ្លើយតបទៅនឹងសំណូមពររបស់ពួកបណ្តាជន ។
**១៣:៤-១៥** បញ្ជីឈ្មោះនៅត្រង់នេះ គឺខុសពីឈ្មោះនៅក្នុងជំពូក១-២,៧, ១០ ។ អ្នកដឹកនាំពូជអំបូរទាំងបួនក្រុមដែលមានក្នុងបញ្ជីលើកមុននោះចាស់ហើយ ។ កាតព្វកិច្ចរបស់មនុស្សនៅជំនាន់ក្រោយនេះ គឺក្មេងជាងហើយមានកម្លាំងជាង ប៉ុន្តែ ពួកគេមិនបានទទួលការគោរពពីមិត្តភក្ត្រនោះឡើយ ។
**១៣:៦** ទោះបីជាយ៉ាងណាក៏ដោយ លោកកាលែបពុំមែនជាជនជាតិអ៊ីស្រាអែលនោះទេ គាត់ជាពូជកេណាស (៣២:១២) ហើយពួកកេណាសនេះគឺជាជនជាតិអេដំម (លប ៣៦:៦,៩,១១) ក្រោយមកគាត់ត្រូវបានទាក់ទងជាមួយនឹងពូជអំបូរយូដា (មើលការពន្យល់ ១៤:២៤) ។
**១៣:១៦** *ម៉ូសេក៏ហៅហូសេ ជាកូននុនថា យ៉ូស្វេវិញ* នេះជាសេចក្តីថ្លែងការមួយដែលត្រូវកត់ទុក ដើម្បីប្រព្រឹត្តឱ្យបានកាន់តែប្រសើរឡើងដល់លោកយ៉ូស្វេក្នុងពេលអនាគត ។ អ្នកអានត្រូវបានធ្វើឱ្យចាប់អារម្មណ៍ដល់ចំណុចសំខាន់ថា ឈ្មោះនេះមាននៅក្នុងបញ្ជីឈ្មោះអ្នកចូលទៅស៊ើបអង្កេត និងជាអ្នកចេញដំណើរ ។ ឈ្មោះហូសេមានន័យថា "សេចក្តីសង្គ្រោះ" ឈ្មោះយ៉ូស្វេ មានន័យថា "ព្រះអង្គសង្គ្រោះ"(មើលការពន្យល់ មថ ១:២១) ។
**១៣:១៧-២០** នៅត្រង់នេះគឺជាសេចក្តីណែនាំទូទៅមួយរបស់លោកម៉ូសេដល់ពួកអ្នកដែលចូលទៅស៊ើបអង្កេត ដោយលោកបានតម្រូវការឱ្យរាយការណ៍ពីស្ថានភាពទឹកដីភោគផលប្រជាជន និងទីប្រជុំជនរបស់ពួកគេ ដើម្បីងាយស្រួលបញ្ជូនកម្លាំងទ័ពចូលប្រយុទ្ធ ។
**១៣:២១** *ទៅសង្កេតមើលក្នុងស្រុកនោះ* ការធ្វើដំណើរចូលស៊ើបរបស់អ្នកយកការទាំងនេះបានចាប់ផ្តើមពីភាគខាងត្បូង (ទីរហោស្ថានស៊ីន) រហូតដល់ភាគខាងជើងបំផុត(ស្រុករេហុប ហាម៉ាត "៣៤:៨") ។ ការធ្វើដំណើរ

នៅតាមផ្លូវទៅឯស្រុកហាម៉ាត[ទ] ២២គេឡើងពីខាងត្បូងទៅ
ដល់ហេប្រុន[ធ] នៅស្រុកនោះមានអ័ហ៊ីម៉ាន សេសាយ និង
តាលម៉ាយ[ន] ជាកូនអ័ណាក់[ប] (ឯក្រុងហេប្រុននេះ បាន
សង់៧ឆ្នាំមុនក្រុងសូអាន ដែលនៅស្រុកអេស៊ីព្ទ)[ផ] ២៣រួច
គេមកដល់ជ្រោះអែសកុល[ព] ហើយកាត់ផ្លែទំពាំងបាយជូរ
១ចង្កោមសែងគ្នា២នាក់ ព្រមទាំងផ្លែទទឹម[ភ]និងផ្លែល្វាផង[ម]
២៤គេហៅទីនោះថា ជ្រោះអែសកុល ដោយព្រោះចង្កោម
ទំពាំងបាយជូរ ដែលពួកកូនចៅអ៊ីស្រាអែលបានកាត់នៅ
ទីនោះ ២៥រួចក្រោយមក៤០ថ្ងៃ[យ] គេក៏ត្រឡប់មកពីសង្កេត
មើលស្រុកនោះវិញ[រ] ។

## របាយការណ៍ពីការរុករក

២៦គេត្រឡប់មកដល់ម៉ូសេនិងអើរ៉ុន ព្រមទាំងពួកជំនុំនៃ
កូនចៅអ៊ីស្រាអែលទាំងអស់គ្នា ត្រង់កាដេស[ល]ក្នុងទីរហោ
ស្ថានប៉ារ៉ាន[វ] ក៏ជូនដំណឹងដល់លោក[ស] និងពួកជំនុំទាំង
អស់គ្នា ហើយបង្ហាញផលនៃស្រុកនោះផង[ហ] ២៧គេជំរាប
ថា យើងខ្ញុំបានទៅដល់ស្រុកដែលលោកចាត់យើងខ្ញុំឱ្យទៅ
នោះ ស្រុកនោះមានទឹកដោះ និងទឹកឃ្មុំ[ឡ]ហូរហៀរជា
ប្រាកដមែន នេះនែ ផលរបស់ស្រុកនោះ[អ] ២៨ប៉ុន្តែមនុស្ស
នៅស្រុកនោះ គេខ្លាំងពូកែណាស់ ទីក្រុងរបស់គេមាន
កំផែង ហើយក៏ធំណាស់ផង[ក] ១ទៀតយើងខ្ញុំបានឃើញកូន
ចៅអ័ណាក់[ខ] នៅស្រុកនោះដែរ[គ] ២៩សាសន៍អាម៉ាលេក[ឃ]
គេនៅស្រុកខាងត្បូង ហើយសាសន៍ហេត[ង]សាសន៍យេប៊ូស[ច]
និងសាសន៍អាម៉ូរី[ឆ]គេនៅស្រុកភ្នំ[ជ] ឯខាងសមុទ្រ ហើយនៅ
មាត់ទន្លេយ័រដាន់[ឈ] នោះមានសាសន៍កាណានវិញ[ញ]។

**១៣:២១** ទ ជន ៣៤:៨ យស ១៣:៥ ពច ៣:៣ ១ពវ ៨:៦៥ ២ពវ ១៤:២៥ ១រប ១៣:៥ ២រប ៧:៨ យរ ៥២:៩ អគ ៤៧:១៦,២០ អម ៦:១៤ **១៣:២២** ធ លប ១៣:១៨ ២៣:១៩ ន យស ១៥:១៤ ពច ១:១០ ប ខ.២៨ ចទ ២:១០ ៩:២ យស ១១:២១ ១៥:១៣ ពច ១:២០ ផ ទដ ៧៨:១២,៤៣ អស ១៩:១១,១៣ ៣០:៤ អគ ៣០:១៤ **១៣:២៣** ព លប ១៤:១៣ ភ នក ២៨:៣៣ ម លប ៣:៧ ជន ២០:៥ ចទ ៨:៨ ២ពវ ១៨:៣១ នហ ១៣:១៥ **១៣:២៥** យ លប ៧:៤ រ ជន ១៤:៣៤ **១៣:២៦** ល លប ១៤:៧ វ លប ១៤:៦ ស ជន ៣២:៨ ហ ចទ ១:២៥ **១៣:២៧** ឡ នក ៣:៨ អ ចទ ១:២៥ យរ

៣០ឯកាលែប[ដ] លោកឱ្យបណ្ដាជននៅស្ងៀមចំពោះមុខ
ម៉ូសេ រួចនិយាយថា ចូរយើងឡើងទៅចាប់យកស្រុក
នោះជាប្រញាប់កុំខាន ដ្បិតយើងអាចនឹងយកបានដោយ
ស្រួល ៣១ប៉ុន្តែមនុស្សដែលបានឡើងទៅជាមួយគ្នា គេ
ប្រកែកថា យើងពុំអាចនឹងឡើងទៅទាស់នឹងគេបានទេ
ដ្បិតគេខ្លាំងពូកែជាងយើងណាស់[ឋ] ៣២អ្នកទាំងនោះក៏បង្ក
បង្កើតរឿងអាក្រក់[ឌ]ពីស្រុក ដែលគេបានសង្កេតមើលនោះ
ដោយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ស្រុកដែលយើង
បានដើរកាត់ហើយសង្កេតមើលនោះ ជាស្រុកដែលបង្ហិន
បង្ហោច[ឍ]ដល់ពួកអ្នក ដែលអាស្រ័យនៅ ឯមនុស្សដែល
យើងឃើញទាំងប៉ុន្មាន ក៏សុទ្ធតែមានមាឌធំៗ[ណ] ៣៣នៅ
ស្រុកនោះយើងបានឃើញពួកមនុស្សធំសំបើម[ត] គឺជាកូន
ចៅអ័ណាក់[ថ] ដែលជាពូជមនុស្សមានមាឌធំសំបើមយើង
មើលទៅខ្លួនយើងដូចជាកណ្ដូប[ទ] ទោះបើនៅភ្នែកគេក៏
ដូច្នោះដែរ ។

## បណ្ដាជនបះបោរ

**១៤** ១គ្រានោះពួកជំនុំ នៃពួកកូនចៅអ៊ីស្រាអែល ក៏ឡើង

២:៧ **១៣:២៨** ក ចទ ១:២៨ ៩:១,២ ខ ខ.២២ គ យស ១៤:១២ **១៣:២៩** ឃ លប ១៤:៧ ង លប ១០:១៥ ចទ ៧:១ ២០:១៧ ១ពវ ៩:២០ ១០:២៩ ២ពវ ៧:៦ ច នក ៣:៨ ឆ លប ១០:១៦ ជ ខ.១៨ ឈ លប ១៣:១០ ជន ៣៣:១ ៣២:៥ ចទ ១:១ យស ១:២ ពច ៣:២៨ ទដ ៤២:៦ ញ លប ១០:១៨ **១៣:៣០** ដ ខ.៦ **១៣:៣១** ឋ ចទ ៩:១ យស ១៤:៨ **១៣:៣២** ឌ ជន ១៤:៣៦,៣៧ ឍ អគ ៣៦:១៣,១៤ ណ ចទ ១:២៨ អម ២:៩ **១៣:៣៣** ត លប ៦:៤ ថ ខ.២៨ ចទ ១:២៨ យស ១១:២២ ១៤:១២ ទ សស ១២:៥ អស ៤០:២២

នេះមានចម្ងាយប្រហែល ៤០២,២៥ គ.ម ដោយចំណាយពេលអស់៤០ថ្ងៃក្នុងការធ្វើដំណើរម្ដងៗ (ខ.២៥) ។

**១៣:២២** *ហេប្រុន* នេះគឺជាទីក្រុងដំបូងគេដែលពួកអ្នកស៊ើបការបានចូលនៅក្នុងស្រុកកាណាន ។ តាមកំណត់ត្រាក្នុងគម្ពីរបានដឹងថា ក្រុងហេប្រុននេះបានសង់៧ឆ្នាំមុនក្រុងសូអានដែលនៅស្រុកអេស៊ីព្ទ (មើលការពន្យល់ ទដ ៧៨:១២,៤៣) ។ ចំណុចនេះអាចជាភស្តុតាងមួយបង្ហាញពីភាពអស្ចារ្យពីទំហំ និងកំផែងក្រុងដែលត្រូវបានពួកស្គាល់យ៉ាងច្បាស់ពីពួកព្ទយុកោរបស់ពួកគេកាលពីបួនសតវត្សរ៍មុន(លប ១៣:១៤–១៨ ១៤:១៣ ២៣:២ ២៥:៩ ៣៥:២៧–២៩ ៥០:១៣) ។ *ជាកូនអ័ណាក់* ពូជអំបូរអ័ណាក់ជាមនុស្សមានមាឌធំដែលធ្វើឱ្យមនុស្សដទៃទៀតខ្លាចញញើត(ខ.៣២–៣៣) តែក្រោយមកដោយសេចក្ដីជំនឿលោកកាលែបបានវាយពួកនេះចេញពីទីក្រុងអស់បាត់ទៅ (យស ១៥:១៤ ពច ១:១០) ។

**១៣:២៣** *ជ្រោះអែសកុល* ជ្រោះមួយនេះនៅក្បែរទីក្រុងហេប្រុន ដែលសំបូរទៅដោយចំការទំពាំងបាយ ហើយជាទឹកដីដ៏ល្អដែលព្រះបានប្រទានមកដល់ពួកគេ ។

**១៣:២៦–២៩** ផ្នែកដំបូងនៃអ្នកចូលទៅស៊ើបអង្កេតបានរាយការណ៍ដែរ ប៉ុន្តែ ភាពសំបូរបែបនៅលើទឹកដីនោះ បានធ្វើឱ្យពួកគេមើលទៅមានការភ័យខ្លាចទៅវិញ ដោយឃើញមនុស្សមាឌធំៗបានរស់នៅលើទឹកដីនោះ ។

**១៣:២៦** *កាដេស* មើលការពន្យល់ ១៤:៧ ។

**១៣:២៧** *មានទឹកដោះ និងទឹកឃ្មុំហូរហៀរ* សូមមើលការពន្យល់ នក ៣:៨ ចទ ៦:៣ ។

**១៣:៣០** *កាលែប លោកឱ្យបណ្ដាជននៅស្ងៀម* មានតែលោកកាលែប និងលោកយ៉ូស្វេទេដែលបានរាយការណ៍ដោយសេចក្ដីជំនឿលើព្រះ ។

**១៣:៣២** *បង្កបង្កើតរឿងអាក្រក់ពីស្រុកដែលគេបានសង្កេតមើលនោះ* ទឹកដីសន្យាគឺជាទឹកដីមួយដ៏ល្អ ជាអំណោយដ៏ថ្លៃវិសេសមកអំពីព្រះ ។ បើនិយាយអាក្រក់អំពីរឿងនេះ នោះអ្នកចូលស៊ើបសង្កេតគ្មានជំនឿទាំងនោះកំពុងតែនិយាយអាក្រក់ពីព្រះអម្ចាស់(១០:២៩) ។

**១៣:៣៣** ពាក្យរបស់ពួកគេបានក្លាយទៅជាការលើកតម្កើង និងសរសើរពួកខ្មាំងសត្រូវរបស់ខ្លួនទៅវិញ ។ ពួកកូនចៅអ័ណាក់ធ្លាប់បានគេនិយាយថាជាមនុស្សខ្លាំងពូកែ (លប ៦:៤)"មនុស្សយក្ស មនុស្សមាឌធំ" ដែលគេតែងតែភ័យខ្លាច ។ ការសរសើរគេដោយខ្វះសេចក្ដីជំនឿនេះបាននាំឱ្យពួកគេសម្រេចចិត្តនិយាយយ៉ាងល្ងីល្ងើថា"យើងមើលទៅខ្លួនយើងដូចជាកណ្ដូប" ។

សំឡេងស្រែក ហើយនៅយប់នោះ បណ្ដាជនក៏យំគ្រប់គ្នា[ក]
២ នោះគេរទូរទាំ[ខ]ទាស់នឹងម៉ូសេ ហើយនិងអើរ៉ុន ពួកជំនុំ
ទាំងអស់គ្នានិយាយថា ស៊ូឱ្យយើងបានស្លាប់នៅស្រុក
អេស៊ីព្ទ[គ] ឬនៅក្នុងទីរហោស្ថាននេះវិញ[ឃ] យើងសុខចិត្តឱ្យ
ស្លាប់ទៅជាជាង ៣ តើហេតុអ្វីបានជាព្រះយេហូវ៉ា ទ្រង់នាំ
យើងមកក្នុងកន្លែងនេះ ឱ្យត្រូវស្លាប់ដោយដាវដូច្នេះ[ង]ហើយ
ឱ្យប្រពន្ធកូនយើង[ច]ទៅជារំពាគេផង[ឆ] ចុះបើយើងវិលត្រ
ឡប់ទៅឯស្រុកអេស៊ីព្ទវិញ[ជ] នោះតើមិនមានប្រយោជន៍ជា
ជាងទេឬអី ៤ រួចគេនិយាយគ្នាទៅវិញទៅមកថា ចូរយើង
រើសយកមេម្នាក់ ហើយត្រឡប់ទៅឯស្រុកអេស៊ីព្ទវិញ
ទៅ[ឈ] ។

៥ នោះម៉ូសេ និងអើរ៉ុន លោកទំលាក់ខ្លួនចុះផ្កាប់មុខ[ញ]
នៅចំពោះមុខពួកជំនុំនៃកូនចៅអ៊ីស្រាអែលទាំងអស់គ្នា[ដ]
៦ ហើយយ៉ូស្វេ ជាកូននុន[ឋ] និងកាលែប ជាកូនយេភូនេ
ដែលនៅក្នុងពួកអ្នកដើរសង្កេតមើលស្រុក គេក៏ហែក
សំលៀកបំពាក់ខ្លួន[ឌ] ៧ ព្រមទាំងនិយាយទៅពួកជំនុំ នៃកូន
ចៅអ៊ីស្រាអែលទាំងអស់ថា ស្រុកដែលយើងបានដើរកាត់
សង្កេតមើលនោះ ជាស្រុកល្អក្រៃលែង[ឍ] ៨ បើសិនជាព្រះ
យេហូវ៉ា ទ្រង់សព្វព្រះហឫទ័យនឹងយើងរាល់គ្នា[ណ] នោះ
ទ្រង់នឹងនាំយើង ឱ្យបានចូលទៅក្នុងស្រុកនោះជាមិនខាន
ហើយនិងប្រទានមកយើងផង[ត] គឺជាស្រុកដែលមានទឹក
ដោះ និងទឹកឃ្មុំដ៏ហូរហៀរ[ថ] ៩ កុំឱ្យតែបះបោរ[ទ]នឹងព្រះ
យេហូវ៉ា ឬខ្លាច[ធ]មនុស្សនៅស្រុកនោះប៉ុណ្ណោះ[ន]ដ្បិតគេជា
អាហារសំរាប់យើងរាល់គ្នាទេ ទីពឹងជ្រករបស់គេបានរើ
ចេញទៅបាត់ហើយ ព្រះយេហូវ៉ាក៏គង់នៅ[ប]ខាងយើង[ផ]
រាល់គ្នាដែរ កុំឱ្យខ្លាចគេឡើយ[ព] ១០ ឯពួកជំនុំទាំងអស់ក៏
ប្រាប់គ្នាថា ចូរចោលគេនឹងថ្ម[ភ]ទៅ តែសិរីល្អនៃព្រះ
យេហូវ៉ា[ម]បានលេចមកក្នុងត្រសាលជំនុំ ឱ្យពួកកូនចៅ
អ៊ីស្រាអែលទាំងអស់គ្នាឃើញ ។

១១ ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា តើជន
ទាំងឡាយនេះ និងនៅតែមើលងាយអញ ដល់កាលណា
ទៀត[យ] តើដល់កាលណាទៀតដែលគេនៅតែមិនជឿដល់
អញ[រ] ទោះបើឃើញអស់ទាំងទីសំគាល់[ល] ដែលអញបាន
ធ្វើនៅកណ្ដាលគេជាច្រើនម្ល៉េះផង ១២ ដូច្នេះ អញនឹង
វាយគេ ដោយជំងឺអាសន្នរោគ[វ] ហើយនិងកាត់កាល់គេ
ចោលចេញ រួចអញនឹងបង្កើតសាសន៍១[ស]ដ៏ធំជាង ហើយ
ពូកែជាងពីឯងវិញ[ហ] ។

១៣ តែម៉ូសេទូលទៅព្រះយេហូវ៉ាថា បើដូច្នោះពួក
សាសន៍អេស៊ីព្ទនឹងឮដែរ (ដ្បិតទ្រង់បាននាំបណ្ដាជននេះ
ពីកណ្ដាលគេ ឡើងមកដោយព្រះចេស្ដាទ្រង់)[ឡ] ១៤ នោះគេ
នឹងប្រាប់តៗមក ដល់មនុស្សនៅស្រុកនេះ ដែលបានឮ[អ]ថា
ព្រះយេហូវ៉ាទ្រង់តែងគង់នៅកណ្ដាលពួកជននេះ[ក] ក៏ឮថា
ពួកជននេះតែងឃើញព្រះយេហូវ៉ានៅប្រទល់មុខ[ខ] ហើយ

**១៤:១** ក លប ២៧:៣៨ នក ៣៣:៤ ជន ២៥:៦ ចទ ១:៤៥ ពច ២០:២៣, ២៦ ២សយ ៣:៣២ យប ៣១:២៩ **១៤:២** ខ នក ១៥:២៤ ហព ៣:១៦ គ នក ១៦:៣ ឃ ជន ១១:១ ១៦:១៣ ២០:៤ ២១:៥ **១៤:៣** ង នក ៥:២១ ច ខ.៣១ ឆ លប ៣៤:២៩ ចទ ១:៣៩ ទដ ១០៩:១១ អស ៣៣:៤ អក ៧:២១ ២៥:៧ ២៦:៥ ជ កច ៧:៣៩ **១៤:៤** ឈ នហ ៩:១៧ **១៤:៥** ញ លវ ៩:២៤ ជន ១៦:៤,២២,៤៥ ២០:៦ យស ៥:១៤ ២សយ ១៤:៤ ១របា ២១:១៦ អក ១:២៨ ដ លវ ១៩:២ **១៤:៦** ឋ ជន ១១:២៨ ឌ លប ៣៧:២៩,៣៤ ពច ១១:៣៥ ២សយ ១៣:៣១ ២ពវ ១៩:១ អក ៩:៣ នអ ៤:១ មក ១៤:៦៣ **១៤:៧** ឍ ជន ១៣:២៧ ចទ ១:២៥

**១៤:៨** ណ ចទ ៧:៨ ១០:១៥ ទដ ១៨:១៩ ២២:៨ ៣៧:២៣ ៤១:១១ ៥៦:៩ ១៤៧:១១ សភ ១១:២០ អស ៦២:៤ មឡ ២:១៧ ត ចទ ១:២១ ថ ជន ៣:២៧ **១៤:៩** ទ ចទ ១:២៦ ៩:៧, ២៣,២៤ ធ លប ២៦:២៤ ២របា ៣២:៧ ទដ ១១៨:៦ យរ ៤១:១៨ ៤២:១១ ន ចទ ១:២១ ៧:១៨ ២០:១ ប ហក ២:៤ ផ លប ២១:២២ ចទ ១:៣០ ២របា ១៣:១២ យរ ១៥:២០ ៤៦:២៨ ហក ១:១៣ ព ខ.២៤ **១៤:១០** ភ នក ១៧:៤ ម នក ២៤:១៦ **១៤:១១** យ នក ២៣:២១ ជន ១៥:៣១ ១៦:៣០ ១សយ ២:១៧ អក ៣១:១៤ មឡ ១:១៣ រ ចទ ១:៣២ ទដ ៧៨:២២ ១០៦:២៤ យហ ៣:១៥ ល នក ៣:២០ ៤:១៧ ១០:១ **១៤:១២** វ នក ៥:៣ ៣០:១២ ស នក ៣២:១០ ហ ចទ ៩:១៤ ២៩:២០ ៣២:២៦ ទដ ១០៩:១៣ **១៤:១៣** ឡ នក ៣២:១១–១៤ ទដ ១០៦:២៣ **១៤:១៤** អ នក ១៥:១៤ ក ជន ៥:៣ ១៦:៣ យស ២:៩ ខ ចទ ៥:៤ ៣៤:១០

**១៤:១** *ពួកជំនុំនៃពួកកូនចៅអ៊ីស្រាអែល . . . យំគ្រប់គ្នា* សំដីគួរឱ្យភ័យខ្លាយរបស់អ្នកស៊ើបការគ្មានជំនឿនេះ បានបង្កឱ្យមានសេចក្ដីទុក្ខព្រួយដល់សហគមន៍ទាំងមូល ហើយក៏បណ្ដាលឱ្យពួកបណ្ដាជនបះបោរទាស់ប្រឆាំងនឹងព្រះអម្ចាស់ ។ ពួកគេភ្លេចអស់រលីងនូវការអស្ចារ្យដែលព្រះបានធ្វើសម្រាប់ពួកគេ ។ ពួកគេមើលងាយសេចក្ដីមេត្តាករុណារបស់ទ្រង់ហើយពួកគេបានបដិសេធអំណាចព្រះចេស្ដារបស់ទ្រង់ ដោយសំដែងអាកប្បកិរិយាមិនដឹងគុណថា ពួកគេសុខចិត្តស្លាប់វិញប្រសើរជាង (ខ.២) ។

**១៤:២,២៩** *រទូរទាំ* មើលសេចក្ដីផ្ដើមត្រង់មាតិកា និងសូមមើលការពន្យល់ នក ១៥:២៤ ។

**១៤:៣** *កូនយើង* ដោយសារតែពួកគេប្រឆាំងនឹងព្រះគុណរបស់ព្រះដ៏ខ្លាំងពេក ដូច្នេះមានតែកូនរបស់ពួកគេប៉ុណ្ណោះដែលអាចចូលទឹកដីសន្យាបាន (ខ.៣១–៣៣) ។

**១៤:៨** *មានទឹកដោះ និងទឹកឃ្មុំដ៏ហូរហៀរ* មើលការពន្យល់ ៣:៨ ចទ ៦:៣។

**១៤:៩** *ព្រះយេហូវ៉ាក៏គង់នៅខាងយើងរាល់គ្នា* គ្មានកំផែង គ្មានជញ្ជាំង គ្មានអំណាចអ្វីមកតទល់នឹងរាស្ត្ររបស់ទ្រង់បានឡើយបើទ្រង់នៅជាមួយនឹងគេ ។

**១៤:១០** *សិរីល្អនៃព្រះយេហូវ៉ាបានលេចមក* ការបង្ហាញព្រះវត្តមានរបស់ព្រះយ៉ាងច្បាស់ជាងនេះគឺដើម្បីបង្ហាញពីអំណាចព្រះចេស្ដា និងសេចក្ដីក្រោធរបស់ព្រះ (ខ.២១–២២ និងមើលការពន្យល់ នក ១៦:៧) ។

**១៤:១១** *នៅតែមើលងាយអញ ដល់កាលណាទៀត* ដោយសារការភាន់ច្រឡំសេចក្ដីជំនឿក្នុងអំណាចរបស់ព្រះអម្ចាស់ ជាពិសេសស្ថិតនៅក្នុងគំនិតសង្ស័យ ។ ពួកគេធ្លាប់មានបទពិសោធន៍ជាច្រើនជាមួយនឹងព្រះអម្ចាស់ ប៉ុន្តែនៅមើលស្រាលលើព្រះអង្គទៀត ។

**១៤:១២** *អញនឹងបង្កើតសាសន៍១* ឃ្លានេះជាព្រះបន្ទូលលើកទីពីរចាប់តាំងពីពេលចេញដំណើរមក ។ ព្រះមានបន្ទូលពីការចាប់ផ្ដើមបង្កើតរាស្ត្រដែលស្មោះត្រង់នឹងទ្រង់ ជាមួយនឹងលោកម៉ូសេ (នក ៣២:១០) ។

**១៤:១៣** *ពួកសាសន៍អេស៊ីព្ទនឹងឮដែរ* លោកម៉ូសេបានសម្រេចចិត្តដើម្បីនឹងការពារកិត្តិនាមរបស់ព្រះអម្ចាស់ ។ ពួកសត្រូវនឹងរាស្ត្ររបស់ព្រះនឹងចោទប្រកាន់ថា ព្រះអម្ចាស់គ្មានសមត្ថភាពនឹងរំដោះពួកគេនោះឡើយ ។

ថា ពពករបស់ទ្រង់តែងស្ថិតនៅពីលើគេ[គ] ទ្រង់ក៏យាងនាំ
មុខគេក្នុងបង្គោលពពកនៅវេលាថ្ងៃ និងក្នុងបង្គោលភ្លើង
នៅវេលាយប់[ឃ] ១៥ដូច្នេះ បើទ្រង់សំឡាប់ពួកជនទាំងនេះ
ដូចជាមនុស្សតែម្នាក់ នោះសាសន៍ទាំងប៉ុន្មាន ដែលបានឮ
ល្បីពីទ្រង់គេនឹងដៀលថា ១៦ដោយព្រោះតែព្រះយេហូវ៉ា
ពុំអាចនឹងនាំពួកនោះចូលទៅក្នុងស្រុកដែលទ្រង់បានស្បថ[ង]
ថានឹងឱ្យទៅគេ នោះបានជាទ្រង់ត្រឡប់ជាសំឡាប់គេ នៅ
ក្នុងទីរហោស្ថានវិញ[ច] ១៧ឥឡូវនេះ ទូលបង្គំសូមអង្វរដល់
ទ្រង់ឱ្យព្រះចេស្តានៃព្រះអម្ចាស់បានធំ ដូចជាទ្រង់មាន
បន្ទូលរួចហើយថា ១៨ព្រះយេហូវ៉ាទ្រង់យឺតនឹងខ្ញាល់ ក៏មាន
សេចក្តីមេត្តាករុណាជាបរិបូរ ទ្រង់តែងអត់ទោសនៃសេច
ក្តីទុច្ចរិត និងការរំលង[ឆ] តែមិនមែនរាប់មនុស្សមានទោស
ទុកជាគ្មាននោះឡើយ គឺទ្រង់តែងធ្វើទោសនៃការទុច្ចរិត
របស់ឪពុកទៅដល់កូនចៅទាំង៣ដំណ ហើយ៤ដំណផង[ជ]
១៩ទូលបង្គំសូមអង្វរទ្រង់ សូមអត់ទោសនៃការទុច្ចរិតរបស់
ពួកជននេះ ដោយសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដូច
ជាទ្រង់បានអត់ទោស[ឈ]ដល់គេ[ញ] តាំងពីស្រុកអេស៊ីព្ទ រហូត
មកដល់ទីនេះដែរ[ដ] ។
២០នោះព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា អញអត់ទោស
ឱ្យ[ឋ] តាមពាក្យឯងហើយ ២១ប៉ុន្តែអញស្បថដោយនូវព្រះជន្ម[ឌ]
អញថា ផែនដីទាំងមូលត្រូវបានពេញដោយសិរីល្អ[ឍ] នៃព្រះ
យេហូវ៉ា[ណ] ២២ហើយពិតប្រាកដជាពួកអ្នកទាំងនេះ ដែល
បានឃើញសិរីល្អអញ និងទីសំគាល់ទាំងប៉ុន្មាន[ត] ដែលអញ
បានធ្វើនៅស្រុកអេស៊ីព្ទ ហើយនៅទីរហោស្ថាននេះ[ថ] ២៣គេ
នឹងមិនដែលឃើញស្រុក ដែលអញបានស្បថ[ទ]នឹងឱ្យដល់
ពួកឰយុកោគេ គឺពួកដែលមើលងាយអញនោះ[ធ] គេនឹងមិន
ដែលឃើញស្រុកនោះឡើយ[ន] ដោយព្រោះគេបានល្បងល
អញទាំង១០ដងនេះហើយ ក៏មិនបានស្តាប់ តាមសំឡេងអញ
ផង ២៤តែឯកាលែប[ប] ជាអ្នកបំរើរបស់អញ នោះអញនឹងនាំ
ចូលទៅក្នុងស្រុក ដែលគាត់បានទៅមើលនោះ ហើយពូជ
គាត់នឹងបានស្រុកនោះជាកេរ្តិ៍អាករ[ផ] ពីព្រោះមានវិញ្ញាណ
ផ្សេងសណ្ឋិតលើគាត់ ហើយគាត់ក៏បានប្រព្រឹត្តតាមអញ
គ្រប់ចំពូក[ព] ២៥(រីឯសាសន៍អាម៉ាលេក[ភ] ហើយនិងសាសន៍
កាណាន[ម] គេអាស្រ័យនៅក្នុងវាលច្រកភ្នំនោះ) ដល់ស្អែក
នេះ ចូរឯងរាល់គ្នាវិល[យ]ដើរទៅក្នុងទីរហោស្ថាន តាមផ្លូវ
សមុទ្រក្រហមវិញ[រ] ។
២៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុនថា ២៧តើត្រូវឱ្យអញទ្រាំទ្រនឹងពួកជំនុំអាក្រក់ ដែល
គេរទូរទាំទាស់នឹងអញនេះ ដល់កាលណាទៀត អញ
បានឮពាក្យ ដែលពួកកូនចៅអ៊ីស្រាអែលរទូរទាំទាស់នឹង
អញនោះហើយ[ល] ២៨ចូរប្រាប់គេថា ព្រះយេហូវ៉ាទ្រង់ស្បថ
ដោយនូវព្រះជន្ម[វ]ទ្រង់ថា ពិតប្រាកដជាអញនឹងប្រព្រឹត្តនឹង
ឯងរាល់គ្នា[ស] តាមពាក្យដែលបាននិយាយដាក់ត្រចៀកអញ
នោះជាមិនខាន ២៩គឺខ្មោចរបស់ឯងរាល់គ្នា ជាពួកអ្នក
ដែលគេបានរាប់បញ្ចូលក្នុងបញ្ជី ចាប់តាំងពីអាយុ២០ឆ្នាំ
ឡើងទៅលើ[ហ] ជាមនុស្សដែលបានរទូរទាំទាស់នឹងអញ
នោះ នឹងត្រូវដួល[ឡ]នៅទីរហោស្ថាននេះឯង ដរាបដល់
គ្រប់ចំនួន[អ]នោះ ៣០ពិតប្រាកដជាឯងរាល់គ្នានឹងមិនបានចូល
ទៅក្នុងស្រុកនោះ[ក] ដែលអញបានស្បថ[ខ]ថា និងឱ្យឯងរាល់
គ្នាអាស្រ័យនៅនោះឡើយ ចូលបានតែកាលែប ជាកូន
យេភូនេ[គ] និងយ៉ូស្វេ ជាកូននុនប៉ុណ្ណោះ[ឃ] ៣១ឯអស់ទាំងកូន
តូចៗរបស់ឯងរាល់គ្នា ដែលឯងបានថា វានឹងទៅជារំពា

**១៤:១៥** គ នក ៣៣:១៦ ឃ នក ១៣:២១ **១៤:១៦** ង ជន ១១:១២ ច នក ៣២:១២ យស ៧:៧ **១៤:១៨** ឆ នក ២០:៦ ៣៤:៦ ទដ ១៤៥:៨ យហ ៤:២ យក ៥:១១ ជ នក ២០:៥ **១៤:១៩** ឈ នក ៣៤:៩ ១ពវ ៨:៣៤ ទដ ៨៥:២ ១០៣:៣ ញ ទដ ១០៦:៤៥ ដ ទដ ៧៨:៣៨ **១៤:២០** ឋ នក ៣៤:៦ ទដ ៩៩:៨ ១០៦:២៣ មីក ៧:១៨–២០ **១៤:២១** ឌ ខ.២៨ ចទ ៣២:៤០ ពច ៨:១៩ នរ ៣:១៣ ១សយ ១៤:៣៩ ១៩:៦ អស ៤៩:១៨ យរ ៤:២ អគ ៥:១១ សផ ២:៩ ឍ លវ ៩:៦ ណ ទដ ៧២:១៩ អស ៦:៣ ៤០:៥ ហព ២:១៤ **១៤:២២** ត ខ.១១ ថ នក ១៤:១១ ១៧:៧ ៣២:១ ទដ ៨១:៧ ១កថ ១០:៥ **១៤:២៣** ទ ខ.១៦ នក ៣៣:១ ជន ៣២:១១ ចទ ១:៣៤ ទដ ៩៥:១១ ១០៦:២៦ ធ ខ.១១ ន ហព ៣:១៨ **១៤:២៤** ប ជន ១៣:៦ ផ ជន ២៦:៦៥ ៣២:១២ ទដ ២៥:១៣ ៣៧:៩,១១ ព ខ.៦–៩ ចទ ១:៣៦ យស ១៤:៨,១៤ **១៤:២៥** ភ លប ១៤:៧ ម លប ១០:១៨ យ ចទ ១:៤០ រ នក ២៣:៣១ ជន ២១:៤ ១ពវ ៩:២៦ **១៤:២៧** ល នក ១៦:១២ ចទ ១:៣៤, ៣៥ **១៤:២៨** វ ខ.២១ ស ជន ៣៣:៥៦ **១៤:២៩** ហ ជន ១:៤៥ ឡ ខ.២៣,៣០, ៣២ ជន ២៦:២៥ ៣២:១៣ ១កថ ១០:៥ ហព ៣:១៧ ពច ១:៥ អ នក ៣០:១២ **១៤:៣០** ក ខ.២៩ ខ នក ៦:៨ ចទ ៣២:៤០ នហ ៩:១៥ ទដ ១០៦:២៦ អក ២០:៥ ៣៦:៧ គ ជន ១៣:៦ ឃ ជន ១១:២៨

**១៤:១៧–១៩** នៅក្នុងវគ្គនេះលោកម៉ូសេបានប្តូរពីការការពារកិត្តិនាមទ្រង់ទៅការបង្ហាញពីអត្តសញ្ញាណរបស់ព្រះដោយស្រង់ព្រះបន្ទូលរបស់ទ្រង់ផ្ទាល់ ដែលបញ្ជាក់ពីសេចក្តីស្រឡាញ់និងភាពស្មោះត្រង់របស់ព្រះដល់រាស្ត្ររបស់ទ្រង់ (នក ២០:៦ និងមើលការពន្យល់ នក ៣៤:៦–៧) ។

**១៤:២៣** *ទាំង១០ដងនេះហើយ* ប្រហែលជាត្រូវបានគេរាប់នៅក្នុងបទគម្ពីរដូចតទៅនេះ : (១).នក ១៤:១០–១២ (២).នក ១៥:២២–២៤ (៣).នក ១៦:១–៣ (៤). នក ១៦:១៩–២០ (៥). នក ១៦:២៧–៣០ (៦).១៧:១–៤ (៧).នក ៣២:១–៣៥ (៨).ជន ១១:១–៣ (៩).ជន ១១:១៤–៣៤ (១០). ជន ១៤:៣ ។ ប៉ុន្តែពាក្យ"១០ដងនេះ"ក៏មានន័យថានិយាយច្រើនដងហើយ ។

**១៤:២៤** *កាលែប . . . បានប្រព្រឹត្តតាមអញគ្រប់ជំពូក* លោកកាលែបត្រូវបានជ្រើសរើសយ៉ាងពិសេស ជាគូកននិងលោកយ៉ូស្វេ ទោះជាលោកពុំមែនមានកំណើតជាសាសន៍អ៊ីស្រាអែលក៏ដោយ (មើលការពន្យល់ ១៣:៦) គាត់ជាមនុស្សស្មោះត្រង់នឹងព្រះ (យស ១៤:១០ និងការពន្យល់ ១៣:២២) ។

**១៤:២៨** *អញនឹងប្រព្រឹត្តនឹងឯងរាល់គ្នា តាមពាក្យដែលបាននិយាយដាក់ត្រចៀកអញ* ពួកសាសន៍អ៊ីស្រាអែលបាននាំសេចក្តីជំនុំជម្រះមកលើពួកគេដោយខ្លួនឯង ។ ពួកគេបាននិយាយថា ពួកគេសុខចិត្តស្លាប់នៅក្នុងវាលរហោស្ថាន (ខ.២) ជាជាងស្លាប់ដោយដាវនៅក្នុងស្រុកកាណាន ។ ដូច្នេះហើយបានជាមនុស្សដែលមានអាយុ២០ ឬលើសពីនេះត្រូវបានស្លាប់នៅក្នុងទីរហោស្ថាន (ខ.២៩) លើកលែងតែលោកយ៉ូស្វេ និងកាលែប (ខ.៣០) និងកូនចៅរបស់ពួកគេប៉ុណ្ណោះដែលរួចខ្លួន (ខ.៣១) ។

ដល់គេ នោះអញនឹងនាំវារាល់គ្នាចូលវិញ ហើយវានឹង
បានស្គាល់ស្រុកនោះ ដែលឯងរាល់គ្នាមិនបានទាំងរាប់
អានផង[ង] 32តែចំណែកឯងរាល់គ្នា នោះខ្មោចឯងនឹងត្រូវ
ដួល[ច]នៅក្នុងទីរហោស្ថាននេះ 33ហើយកូនចៅរបស់ឯង
រាល់គ្នា និងដើរសាត់ព្រាត់នៅក្នុងទីរហោស្ថាននេះអស់
៤០ឆ្នាំ[ឆ] ព្រមទាំងទ្រាំទ្រនឹងសេចក្តីកំផិតរបស់ឯងរាល់គ្នា
ដរាបដល់ខ្មោចឯងទាំងប៉ុន្មាន បានរលួយទៅនៅទីរហោ
ស្ថាននេះ 34ឯងរាល់គ្នានឹងត្រូវទ្រាំទ្រចំពោះសេចក្តីទុច្ចរិត
របស់ឯងអស់៤០ឆ្នាំ[ជ] តាមចំនួនថ្ងៃដែលបានដើរសង្កេត
មើលក្នុងស្រុកនោះ[ឈ] គឺជា៤០ថ្ងៃ ក្នុង១ថ្ងៃទុកជា១ឆ្នាំ នោះ
ឯងរាល់គ្នានឹងស្គាល់សណ្ឋានដែលឥតពីអញទៅជាយ៉ាង
ណា 35អញនេះ គឺព្រះយេហូវ៉ា អញបានចេញវាចាហើយ
ពិតប្រាកដជាអញនឹងប្រព្រឹត្ត[ញ]នឹងពួកជំនុំខូចអាក្រក់ ដែល
បានប្រមូលគ្នា ទាស់នឹងអញនេះយ៉ាងដូច្នេះ គឺគេនឹងត្រូវ
ស្លាប់រោយរៀវទៅ នៅក្នុងទីរហោស្ថាននេះ[ដ] ។

36ឯពួកមនុស្សដែលម៉ូសេបានចាត់[ឋ]ទៅសង្កេតមើល
ក្នុងស្រុកនោះ ដែលគេត្រឡប់មកវិញ បណ្តាលឱ្យពួកជំនុំ
ទាំងអស់រទូរទាំ[ឌ]ទាស់នឹងលោក ដោយនាំដំណឹងអាក្រក់[ឍ]
ពីស្រុកនោះ 37ពួកអ្នកនោះឯង ដែលបាននាំដំណឹង
អាក្រក់[ណ]ពីស្រុកនោះមក គេក៏ស្លាប់នៅចំពោះព្រះយេហូវ៉ា
ដោយការប្រហារ[ត]របស់ទ្រង់ទៅ 38ដូច្នេះ ក្នុងពួកមនុស្ស
ដែលបានទៅសង្កេតមើលស្រុកនោះ[ថ] មានតែយ៉ូស្វេជាកូន
នុន និងកាលែបជាកូនយេភូនេប៉ុណ្ណោះទេដែលនៅរស់[ទ] ។

39ម៉ូសេក៏ប្រាប់សេចក្តីទាំងនេះ[ធ] ដល់ពួកកូនចៅអ៊ីស្រា
អែលទាំងប៉ុន្មាន រួចគេយំទួញ[ន]ជាខ្លាំង 40គេភ្ញាក់ពី
ព្រហាមរៀបឡើងទៅឯកំពូលភ្នំ[ប] ដោយពាក្យថា មើល
យើងខ្ញុំដល់នេះហើយ ដូច្នេះ យើងខ្ញុំនឹងឡើងទៅឯកន្លែង
ដែលព្រះយេហូវ៉ាបានសន្យាទុកនោះ ដ្បិតយើងខ្ញុំបានធ្វើ
បាបមែន[ផ] ។

41នោះម៉ូសេតបថា ម្តេចក៏ឯងរាល់គ្នារំលងបង្គាប់
ព្រះយេហូវ៉ាទៀត ធ្វើដូច្នោះមិនកើតទេ[ព] 42កុំឱ្យឡើងទៅ
ធ្វើអី ដ្បិតព្រះយេហូវ៉ាមិនគង់ជាមួយឯងរាល់គ្នាទេ ក្រែង
ឯងរាល់គ្នាចាញ់ពួកខ្មាំងសត្រូវវិញ[ភ] 43ដ្បិតមានសាសន៍
អាម៉ាលេក[ម] និងសាសន៍កាណាន[យ]នៅខាងមុខឯងរាល់គ្នា
នោះហើយ ឯងនឹងត្រូវដួលដោយដាវរបស់គេជាមិនខាន
ព្រះយេហូវ៉ាទ្រង់មិនព្រមគង់នៅជាមួយទេ[រ]ពីព្រោះឯង
បានថយចេញពីព្រះយេហូវ៉ាហើយ 44ប៉ុន្តែគេចេះតែខំ
ឡើងទៅឯកំពូលភ្នំ ដោយអួតអាងវិញ តែឯហឹបនៃសេចក្តី
សញ្ញាផងព្រះយេហូវ៉ា ព្រមទាំងម៉ូសេផង មិនបានចេញ
ពីទីដំឡើងត្រសាលឡើយ 45ដូច្នេះ ពួកសាសន៍អាម៉ាលេក
និងសាសន៍កាណាន ដែលនៅលើភ្នំនោះក៏ចុះមកវាយផ្តួល
ហើយដេញតាមគេ រហូតដល់ស្រុកហោម៉ា ។

**ដង្វាយ**

**15** 1ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ 2ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា កាលណាឯងរាល់គ្នាបានចូលទៅ
ក្នុងស្រុកដែលអញនឹងឱ្យ[ក] ទុកសំរាប់ជាទីលំនៅរបស់ឯង
3ហើយចង់យកសត្វពីហ្វូងគោ ឬពីហ្វូងចៀម[ខ] ដើម្បីនឹង
ថ្វាយជាដង្វាយដុតដល់ព្រះយេហូវ៉ា[គ] ទោះបើជាដង្វាយ
ដុត[ឃ] ឬជាយញ្ញបូជាលាបំណន់ ឬជាដង្វាយថ្វាយដោយស្ម័គ្រ
ចិត្ត[ង] ឬដែលថ្វាយនៅថ្ងៃបុណ្យកំណត់ក្តី[ច] ទុកជាក្លិនឈ្ងុយ
ដល់ព្រះយេហូវ៉ា 4នោះអ្នកណាដែលថ្វាយដង្វាយរបស់ខ្លួន

**១៤:៣១** ង លវ ២៦:៤៣
**១៤:៣២** ច ខ.២៩, ៣៥
**១៤:៣៣** ឆ ខ.៣៤ នក ១៦:៣៥ កច ១៣:១៨ ហព ៣:៩
**១៤:៣៤** ជ ខ.៣៣ ឈ ជន ១៣:២៥
**១៤:៣៥** ញ ជន ២៣:១៩ ដ ខ.៣២
**១៤:៣៦** ឋ ជន ១៣:៤–១៦ ឌ ខ.២ ឍ ជន ១៣:៣២
**១៤:៣៧** ណ ជន ១៣:៣២ ១កថ ១០:១០ ហព ៣:១៧ ត ជន ១៦:៤៩ ៥:៩ ២៦:១ ៣១:១៦ ចទ ៤:៣
**១៤:៣៨** ថ ខ.៣០ ជន ១៣:៤–១៦ ទ ខ.២៤ យស ១៤:៦
**១៤:៣៩** ធ ខ.២៨–៣៥ ន នក ៣៣:៤
**១៤:៤០** ប ខ.៤៥ ជន ១៣:១៧ ផ នក ៩:២៧
**១៤:៤១** ព ២រប ២៤:២០
**១៤:៤២** ភ ចទ ១:៤២
**១៤:៤៣** ម ពច ៣:១៣ យ ខ.៤៥ ជន ១៣:២៩ រ លប ៣៩:២៣ ចទ ៣១:៨ យស ៦:២៧ ពច ១:១៩ ៦:១៦ ១សយ ៣:១៩ ១៨:១៤ ២រប ១:១ **១៥:២** ក លវ២៣:១០ **១៥:៣** ខ លវ ១:២គ ខ.២៤ លវ ១:៩ ឃ លវ ១:៣ ជន ២៨:១៣ ង លវ ៧:១៦ អរ ១:៤ ច លវ ២៣:១,៤៤

**១៤:៣២** មើល ហព ៣:១៧ ។

**១៤:៣៤** ពួកអ្នកចូលស៊ើបសង្កេតបានចំណាយអស់៤០ថ្ងៃ ហើយចំនួននេះក៏ត្រឡប់ជាចំនួននៃសេចក្តីវេទនា៤០ឆ្នាំនៅក្នុងទីរហោស្ថាន ដោយសារតែពួកគេបានកាត់សេចក្តីមិនត្រឹមត្រូវ ។

**១៤:៣៧** *ពួកអ្នកនោះឯង . . . នាំដំណឹងអាក្រក់ . . . ក៏ស្លាប់ដោយការប្រហារ* នេះគឺជាការជំនុំជម្រះទៅលើពួកអ្នកចូលយកការ១០នាក់ទៀត ដែលបានរាយការណ៍អាក្រក់ពីទឹកដីសន្យាមួយរំពេច ។ មនុស្សជំនាន់ក្រោយដែលមានឥទ្ធិពលបានចំណាយជីវិតរបស់ពួកគេនៅក្នុងទីរហោស្ថាន ។

**១៤:៤០** *យើងខ្ញុំនឹងឡើងទៅ* ឥឡូវនេះវាហួសពេលបាត់ទៅហើយ ក្នុងការតាំងចិត្តដើម្បីចូលក្នុងទឹកដីសន្យានោះ ។ ត្រង់នេះពុំមានន័យថា ព្រះពុំបានគង់ជាមួយនឹងពួកគេនោះទេ តែទ្រង់បានជំទាស់នឹងគេ ដោយសារពួកគេត្រូវបានបំផ្លាញ (ខ.៤១) ព្រោះតែការបះបោររបស់ពួកគេ (មើលការពន្យល់ អគ ១៦:៤៣) ។

**១៥:១–៤១** នៅក្នុងជំពូកនេះត្រូវបានចែកជាបីផ្នែក ដែលផ្នែកនីមួយៗដោយ "ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ"(ខ.១,១៧,៣៧) ។ ពួកបណ្តាជនបានជួបប្រទះការជំនុំជម្រះដ៏ធ្ងន់ធ្ងរ ដោយសារតែការមិនស្តាប់បង្គាប់ជាពិសេស ពួកគេបានមើលងាយដល់សេចក្តីបង្គាប់របស់ព្រះ ។

**១៥:២** *កាលណាឯងរាល់គ្នាបានចូលទៅក្នុងស្រុក* ត្រង់នេះគឺជាឃ្លានៃចុងបញ្ចប់របស់ជំពូក១៤ ដែលត្រូវបានលើកយកមកពោលម្តងទៀត ។ សេចក្តីមេត្តាករុណា និងព្រះគុណរបស់ព្រះ តែងតែសំដែងពីសេចក្តីសន្យារបស់ទ្រង់ជាមួយនឹងលោកអ័ប្រាហាំ (លប ១២:៧) ហើយនិងការពន្យារបស់ទ្រង់ថាឱ្យពួកគេចូលទឹកដីសន្យា ។

**១៥:៣–១២** ដង្វាយម្សៅ និងស្រាទំពាំងបាយជូរតែងតែមកជាមួយនឹងដង្វាយដុត ។ ដង្វាយម្សៅតែងតែលាយជាមួយនឹងប្រេង ។ ដង្វាយម្សៅបាន

ដល់ព្រះយេហូវ៉ា ត្រូវតែយកម្សៅយ៉ាងម៉ដ្ត១ខ្ទឹង[ឆ]ថ្វាយជា
ដង្វាយម្សៅ[ជ]លាយដោយប្រេង២កំប៉ុង ៥ហើយយកស្រា
ទំពាំងបាយជូរ[ឈ]២កំប៉ុង សំរាប់ជាដង្វាយច្រួច[ញ]ជាមួយនឹង
ដង្វាយដុតនោះ ឬសំរាប់រាល់តែចៀម[ដ]ក្នុងយញ្ញបូជានោះ
៦ឬបើជាចៀមឈ្មោល[ឋ] នោះត្រូវរៀបម្សៅ[ឌ]យ៉ាងម៉ដ្ត២
ខ្ទឹង[ឍ] លាយនឹងប្រេង៣កំប៉ុង[ណ] សំរាប់ជាដង្វាយម្សៅ
៧ហើយត្រូវថ្វាយស្រាទំពាំងបាយជូរ[ត]៣កំប៉ុងសំរាប់ជា
ដង្វាយច្រួច[ថ]ទុកជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[ទ] ៨កាលណា
រៀបគោឈ្មោល[ធ]សំរាប់ជាដង្វាយដុត ឬយញ្ញបូជាលា
បំណន់[ន] ឬជាដង្វាយមេត្រី[ប]ថ្វាយដល់ព្រះយេហូវ៉ា ៩នោះ
ត្រូវថ្វាយម្សៅយ៉ាងម៉ដ្ត៣ខ្ទឹង[ផ] សំរាប់ជាដង្វាយម្សៅ[ព]លាយ
ដោយប្រេង៤កំប៉ុង ជាមួយនឹងគោឈ្មោលនោះ ១០ឯដង្វាយ
ច្រួច[ភ]នោះត្រូវថ្វាយស្រាទំពាំងបាយជូរ[ម]៤កំប៉ុង សំរាប់ជា
ដង្វាយដុត ទុកជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[យ] ១១គឺយ៉ាងនោះ
ដែលត្រូវធ្វើដល់រាល់តែគោឈ្មោល ពពែឈ្មោល កូន
ចៀមឈ្មោល និងកូនពពែនីមួយៗ ១២តាមចំនួនសត្វដែល
ឯងរៀបថ្វាយ នោះត្រូវតែធ្វើចំពោះសត្វនីមួយៗយ៉ាង
ដូច្នេះតាមចំនួន[រ] ១៣អស់អ្នកដែលកើតក្នុងស្រុក[ល] ត្រូវតែធ្វើ
តាមរបៀបនេះ ក្នុងកាលដែលថ្វាយដង្វាយដុត ទុកជាក្លិន
ឈ្ងុយដល់ព្រះយេហូវ៉ា[វ] ១៤ឬបើមានអ្នកប្រទេសក្រៅណា
ស្នាក់នៅ[ស]ជាមួយនឹងឯងរាល់គ្នា ឬអ្នកណាក៏ដោយ ដែល
នៅកណ្តាលឯងរាល់គ្នាគ្រប់ទាំងដំណាត[ហ] ទៅចង់ថ្វាយ
ដង្វាយ[ឡ]ដុត[អ] ទុកជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា នោះត្រូវឱ្យ
គេធ្វើដូចជាឯងរាល់គ្នាធ្វើដែរ ១៥នៅក្នុងពួកជំនុំ នោះត្រូវ
មានច្បាប់តែ១ សំរាប់ឯងរាល់គ្នា ហើយសំរាប់អ្នក
ប្រទេសក្រៅ ដែលស្នាក់នៅជាមួយដែរ គឺជាច្បាប់ដ៏នៅ
អស់កល្បជានិច្ច នៅអស់ទាំងដំណាតទៅ[ក] នៅចំពោះព្រះ
យេហូវ៉ា ទោះទាំងអ្នកប្រទេសក្រៅ ក៏ដូចជាឯងរាល់គ្នា
ដែរ ១៦ត្រូវឱ្យមានរបៀបតែ១ ហើយច្បាប់តែ១ប៉ុណ្ណោះ
សំរាប់ឯងរាល់គ្នា ហើយនិងពួកអ្នកប្រទេសក្រៅ ដែលនៅ
ជាមួយនឹងឯងដែរ[ខ]។

**១៥:៤** ឆ នក ១៦:៣៦ ជ លវ ៦:១៤
**១៥:៥** ឈ លវ ១០:៩ ញ លប ៣៥:១៤ ដ លវ ៣:៧
**១៥:៦** ឋ លវ ៥:១៥ ឌ ជន ២៨:១២ ២៩:១៤ ឍ លវ ២៣:១៣ ណ អគ ៤៦:១៤
**១៥:៧** ត ខ.៥ ថ លវ ២៣:១៣ ជន ២៨:១៤ ២៩:១៨ ទ លវ ១:៩
**១៥:៨** ធ នក ១២:៥ លវ ១:៥ ន លវ ២២:១៨ ប លវ ៣:៦
**១៥:៩** ផ លវ១៤:១០ ព លវ ២:១
**១៥:១០** ភ លវ ២៣:១៣ ម ជន ២៨:១៤ យ លវ ១:៩
**១៥:១២** រ អរ ៧:១៧
**១៥:១៣** ល លវ ១៦:២៩ វ លវ ១:៩
**១៥:១៤** ស នក ១២:១៩,៤៣ ២២:២១ ហ លវ ៣:១៧ ជន ១០:៨ ឡ លវ ២២:១៨ អ ខ.២៥
**១៥:១៥**ក ខ.១៤,២១
**១៥:១៦** ខ នក ១២:៤៩ លវ ២២:១៨ ជន ៩:១៤
**១៥:១៨** គ លវ ២៣:១០
**១៥:១៩** ឃ យស ៥:១១,១២ ង ជន

១៧ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ១៨ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា កាលណាឯងរាល់គ្នាបានចូលទៅ
ក្នុងស្រុក ដែលអញនាំឯងចូលទៅ[គ] ១៩ហើយឯងនឹង
បរិភោគអាហាររបស់ស្រុកនោះ[ឃ] នោះត្រូវឱ្យថ្វាយដង្វាយ
លើកចុះឡើងដល់ព្រះយេហូវ៉ា[ង] ២០ត្រូវយកម្សៅ ដែល
លាយមុនដំបូង[ច]មកធ្វើជានំ១ ថ្វាយសំរាប់ជាដង្វាយលើក
ចុះឡើង ត្រូវឱ្យថ្វាយដង្វាយនោះ ដូចជាដង្វាយពីលាន
ស្រូវ[ឆ,ជ] ដែលថ្វាយដោយលើកចុះឡើងដែរ ២១នៅអស់
ទាំងដំណាងតទៅ[ឈ] នោះត្រូវយកម្សៅ ដែលលាយមុន
ដំបូងមក[ញ]ថ្វាយជាដង្វាយលើកចុះឡើងដល់ព្រះយេហូវ៉ា ។

## ដង្វាយសម្រាប់ការកំហុសធ្វើដោយអចេតនា

២២បើកាលណាឯងរាល់គ្នាធ្វើខុស ដោយមិនបាន
ប្រព្រឹត្តតាមអស់ទាំងបញ្ញត្តិទាំងនេះ ដែលព្រះយេហូវ៉ា
បានប្រាប់មកម៉ូសេ[ដ] ២៣គឺអស់ទាំងសេចក្តី ដែលព្រះយេ
ហូវ៉ាបានបង្គាប់មក ដោយសារម៉ូសេ ចាប់តាំងពីថ្ងៃដែល
ទ្រង់បានបង្គាប់សេចក្តីនោះមក ដរាបដល់អស់ទាំងដំណ
តរៀងទៅ[ឋ] ២៤បើសិនជាការកំហុសនោះបានធ្វើដោយឥត
ដឹង[ឌ] ឥតមានអ្នកណាមួយក្នុងពួកជំនុំបានដឹងសោះ[ឍ] នោះ
ពួកជំនុំទាំងអស់គ្នា ត្រូវថ្វាយកូនគោឈ្មោល១ ទុកជា
ដង្វាយដុត[ណ] សំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[ត] ព្រម
ទាំងដង្វាយម្សៅ[ថ] និងដង្វាយច្រួច[ទ]តាមរបៀបនោះផង
ហើយពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាបដែរ[ធ]
២៥ត្រូវឱ្យសង្ឃថ្វាយឱ្យធួននឹងពួកជំនុំ នៃកូនចៅអ៊ីស្រាអែល
ទាំងអស់គ្នា នោះនឹងបានអត់ទោសឱ្យគេ[ន] ដ្បិតការនោះ
ជាការកំហុស[ប] តែគេបានយកដង្វាយគេមកហើយ គឺជា
ដង្វាយដុត[ផ] ថ្វាយដល់ព្រះយេហូវ៉ា ព្រមទាំងដង្វាយលោះ
បាបនៅចំពោះព្រះយេហូវ៉ា ដោយព្រោះការកំហុសរបស់

១៨:៨ **១៥:២០** ច លវ ២៣:១៤ ឆ លវ ២:១៤ ជន ១៨:២៧ ជ លប ៥០:១០ **១៥:២១** ឈ លវ ២៣:១៤ ញ អគ ៤៤:៣០ រម ១១:១៦ **១៥:២២** ដ លវ ៤:២ **១៥:២៣** ឋ ខ.២១**១៥:២៤** ឌ ខ.២៥, ២៦ ឍ លវ ៥:១៥ ណ លវ ៤:១៤ ត ខ.៣ ថ លវ ២:១ ទ លវ ២៣:១៣ ជន ៦:១៥ ធ លវ ៤:៣ **១៥:២៥** ន លវ ៤:២០ រម ៣:២៥ ប ខ.២២,២៤ ផ ខ.១៤

កើនឡើងនៅពេលដែលដង្វាយបូជាសត្វបានកើតឡើង (ខ.៦-១២) ។
**១៥:១៤** *អ្នកប្រទេសក្រៅ* នៅក្នុងឱកាសបុណ្យរំលង(មើលការពន្យល់ ៩:១៤) ពួកសាសន៍ដទៃក៏មានបទបញ្ញាដូចសាសន៍អ៊ីស្រាអែលដែរ ។ សាសន៍អ៊ីស្រាអែលដែលមានជីវភាពមធ្យម ជានិច្ចជាកាលតែងតែមានឱកាសប្រាប់គេអំពីជំនឿរបស់ខ្លួន ។ តាមពិតសេចក្តីសន្យារបស់ព្រះដល់លោកអ័ប្រាហាំបានគ្របដណ្តប់ដល់មនុស្សទូទៅ (សូមមើលការពន្យល់ លប ១២:២-៣) ។
**១៥:២០** *ដំបូង . . . នំ១ថ្វាយសំរាប់ជាដង្វាយ* ក្រឹត្យវិន័យនេះរំពឹងថាពួកអ៊ីស្រាអែលនឹង អនុវត្តនៅពេលដែលពួកគេនឹងបានចូលទឹកដីសន្យា ។ នេះគឺជាម្សៅដំបូង ក្រោយពីប្រមូលផល ហើយត្រូវបានគេយកមកធ្វើនំ សម្រាប់ថ្វាយដង្វាយដល់ព្រះអម្ចាស់ ។ ត្រង់នេះបញ្ជាក់ថា គ្រប់ទាំងផលដំបូងគឺជាព្រះពរមកពីព្រះ ត្រូវថ្វាយដល់ព្រះវិញ ។
**១៥:២២** *ធ្វើខុសដោយមិនបានប្រព្រឹត្តតាម* នៅត្រង់នេះប្រហែលជាធ្វើបាបដោយអចេតនា ប៉ុន្តែនៅតែត្រូវការរកដំណោះស្រាយ (មើលការពន្យល់ លវ ៤:២) ។ បាបអចេតនាប្រហែលត្រូវបានប្រព្រឹត្តដោយពួកបណ្តាជនក្នុងសហគមន៍ទាំងមូល(ខ.២២-២៦) ឬអាចជាបុគ្គល (ខ.២៧-២៩) ។

គេ[ព] ២៦នោះពួកជំនុំនៃកូនចៅអ៊ីស្រាអែលទាំងអស់គ្នា និង
ពួកអ្នកដទៃដែលស្នាក់នៅកណ្តាលគេ និងបានរួចចាក
ទោសហើយ ដ្បិតបណ្តាជនទាំងឡាយបានធ្វើបាបនោះ
ដោយឥតដឹងសោះ[ភ] ។

២៧បើសិនជាមានអ្នកណាតែម្នាក់ ធ្វើបាបដោយឥតដឹង[ម]
អ្នកនោះត្រូវថ្វាយពពែញី១ អាយុ១ខួប សំរាប់ជាដង្វាយ
លោះបាប[យ] ២៨ហើយត្រូវឱ្យសង្ឃថ្វាយឱ្យធួន[រ] នឹងអ្នកនោះ
ដែលបានធ្វើខុស នៅវេលាណាដែលគេធ្វើបាបនៅចំពោះ
ព្រះយេហូវ៉ាដោយឥតដឹង ដើម្បីឱ្យបានធួននឹងអ្នកនោះរួច
និងបានអត់ទោសឱ្យគេ[ល] ២៩ត្រូវមានច្បាប់តែ១ សំរាប់អ្នក
ណា ដែលធ្វើការខុសដោយឥតដឹង ទោះបើជាអ្នកកើត
នៅក្នុងពួកកូនចៅអ៊ីស្រាអែល ឬជាអ្នកប្រទេសក្រៅ ដែល
ស្នាក់នៅជាមួយក្តី[វ] ៣០តែឯអ្នកណាដែលធ្វើបាបដោយ
ឥតមានខ្លាច[ស] ទោះបើជាអ្នកស្រុក ឬជាអ្នកស្នាក់នៅក្តី[ហ]
អ្នកនោះឈ្មោះថាប្រមាថដល់ព្រះយេហូវ៉ាហើយ[ឡ] ត្រូវតែ
កាត់អ្នកយ៉ាងនោះចេញពីសាសន៍របស់ខ្លួន[អ] ៣១ពីព្រោះ
បានមើលងាយ[ក] ដល់ព្រះបន្ទូលនៃព្រះយេហូវ៉ា ព្រមទាំង
ប្រព្រឹត្តទទឹងនឹងបញ្ញត្តិទ្រង់ផង[ខ] ត្រូវតែកាត់កាល់អ្នកនោះ
ឱ្យដាច់ចេញជាពិត គេមានទោសជាប់នៅលើខ្លួនហើយ[គ] ។

## ការដាក់ទោសស្លាប់ដល់អ្នកបំពានថ្ងៃឈប់សម្រាក

៣២កាលពួកកូនចៅអ៊ីស្រាអែលនៅក្នុងទីរហោស្ថាន[ឃ]
គេឃើញមនុស្សម្នាក់កំពុងតែរើសឧស នៅថ្ងៃឈប់សំរាក[ង]
៣៣ឯពួកអ្នកដែលឃើញ ក៏នាំទៅឯម៉ូសេ និងអើរ៉ុនហើយ
និងពួកជំនុំទាំងអស់ ៣៤គេឃុំអ្នកនោះទុក ពីព្រោះមិន
ទាន់បានសំដែងឱ្យដឹង ជាត្រូវធ្វើយ៉ាងដូចម្តេចនៅឡើយ[ច]
៣៥នោះព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ត្រូវសំឡាប់
អ្នកនោះចោលទៅជាកុំខាន[ឆ] ត្រូវឱ្យពួកជំនុំទាំងអស់គ្នា
ចោលនឹងថ្ម នៅឯក្រៅទីដំឡើងត្រសាលទៅ[ជ] ៣៦ដូច្នេះ
ពួកជំនុំក៏នាំទៅឯក្រៅទីដំឡើងត្រសាល ចោលនឹងថ្ម[ឈ]ឱ្យ
ស្លាប់ទៅ[ញ] ដូចជាព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ[ដ] ។

## ការធ្វើរំយោលនៅជាយអាវ

៣៧ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ៣៨ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា ត្រូវឱ្យធ្វើរំយោលនៅជាយអាវខ្លួន
នៅអស់ទាំងដំណតរៀងទៅ[ឋ] ហើយត្រូវមានខ្សែពណ៌ផ្ទៃ
មេឃជាប់នឹងរំយោល នៅគ្រប់ទាំងជាយអាវ[ឌ]របស់គេ
៣៩នោះនឹងបានសំរាប់ជារំយោល ឱ្យឯងរាល់គ្នាមើល
ដើម្បីឱ្យនឹកចាំ[ឍ]ពីអស់ទាំងបញ្ញត្តិនៃព្រះយេហូវ៉ា ព្រមទាំង
ប្រព្រឹត្តតាមផង ប្រយោជន៍កុំឱ្យឯងរាល់គ្នារក[ណ]តាមតែ
ចិត្ត[ត]និងភ្នែកឯង ដែលនាំឱ្យឯងផិតទៅតាមនោះឡើយ
៤០គឺឱ្យឯងរាល់គ្នាបាននឹកចាំ ព្រមទាំងប្រព្រឹត្តតាមអស់
ទាំងបញ្ញត្តិរបស់អញ[ថ] ហើយឱ្យបានបរិសុទ្ធសំរាប់ព្រះនៃ
ឯងវិញ[ទ] ៤១អញនេះ គឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា
ដែលបាននាំឯងចេញពីស្រុកអេស៊ីព្ទមក ដើម្បីឱ្យបានធ្វើ
ជាព្រះនៃឯង[ធ] អញនេះគឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា[ន] ។

## លោកកូរេ ដាថាន និងអ័ប៊ីរ៉ាម

**១៦** ១រីឯកូរេ[ក] ជាកូនយីតសារ ដែលជាកូនកេហាត់ក្នុង
ពូជលេវី ព្រមទាំងដាថាន និងអ័ប៊ីរ៉ាម[ខ] ជាកូនអេលាប[គ]
ហើយនិងអូន ជាកូនពេលេត ក្នុងពួកកូនចៅរូបេន ២គេ
លើកគ្នានៅមុខម៉ូសេ[ឃ] ជាមួយនឹងមនុស្ស២៥០នាក់ ក្នុង

**១៥:២៥** ព លវ ៤:៣ **១៥:២៦** ភ ខ.២៤ **១៥:២៧** ម លវ ៤:២៧ យ លវ ៤:៣ ជន ៦:១៤ **១៥:២៨** រ ជន ៨:១២ ២៨:២២ ល លវ ៤:២០ **១៥:២៩** វ នក ១២:៤៩ **១៥:៣០** ស ជន ១៤:៤០–៤៤ ចទ ១:៤៣ ១៧:១៣ ទដ ១៩:១៣ ហ ខ.១៤ ឡ ២ពវ ១៩:៦,២០ អស ៣៧:៦,២៣ អគ ២០:២៧ អ លប ១៧:១៤ យប ៣១:២២ **១៥:៣១** ក ជន ១៤:១១ ខ ១សយ ១៥:២៣,២៦ ២សយ ១១:២៧ ១២:៩ ទដ ១១៩:១២៦ សភ ១៣:១៣ គ លវ ៥:១ អគ ១៨:២០ **១៥:៣២** ឃ ជន ១២:១៦ ង នក ៣១:១៤,១៥ ៣៥:២,៣ **១៥:៣៤** ច ជន ៩:៨ **១៥:៣៥** ឆ នក ៣១:១៤,១៥ ជ លវ ២០:២ លក ៤:២៩ កច ៧:៥៨ **១៥:៣៦** ឈ លវ ២០:២ ញ នក ៣១:១៤ ដ យរ ១៧:២១ **១៥:៣៨**ឋ លវ៣:១៧ ជន ១០:៨ ឌ ចទ ២២:១២ មថ ២៣:៥ **១៥:៣៩** ឍ ចទ ៤:២៣ ៦:១២ ទដ ៧៣:២៧ ណ លវ ១៧:៧ ពច ២:១៧ ទដ ១០៦:៣៩ យរ ៣:២ ហស ៤:១២ ត ទដ ៧៨:៣៧ យរ ៧:២៤ អគ ២០:១៦ **១៥:៤០** ថ លប ២៦:៥ ចទ ១១:១៣ ទដ ១០៣:១៨ ១១៩:៥៦ ទ លវ ១១:៤៤ រម ១២:១ ២២ ១ពត ១:១៥ **១៥:៤១** ធ លប ១៧:៧ ន នក ២០:២ **១៦:១** ក នក ៦:២៤ ពច ១:១១ ខ ខ.២៤ ទដ ១០៦:១៧ គ ជន ២៦:៨ ចទ ១១:៦ **១៦:២** ឃ ជន ២៧:៣

**១៥:៣០** *ដោយឥតមានខ្លាច* គឺជាបាបដោយចេតនា ក្នុងការបដិសេធន៍ ឬមើលងាយការផ្តត់ផ្គង់របស់ព្រះដោយសេចក្តីមេត្តាករុណា នោះហើយដែលត្រូវមានទោសនោះ ។ នេះហើយដែលពួកអ៊ីស្រាអែលមានបទពិសោធន៍នៅក្នុងជំពូក១៤ ហើយត្រូវបានគេលើកយកមកនិយាយជាបុគ្គលនៅក្នុង ខ.៣២–៣៦ ។ *កាត់ . . . ចេញពីសាសន៍របស់ខ្លួន* មើលការពន្យល់ នក ១២:១៥ ។

**១៥:៣២** *កំពុងតែរើសឧសនៅថ្ងៃឈប់សំរាក* ទោសនៃការធ្វើខុសនៅថ្ងៃឈប់សម្រាកគឺស្លាប់ (ខ.៣៦ នក ៣១:១៥ ៣៥:២) ដូចជាអ្នកដែលបានប្រមាថព្រះនោះដែរ (លវ ២៤:១០–១៦) ។ នៅសម័យព្រះយេស៊ូវ ក្នុងថ្ងៃបុណ្យឈប់សម្រាកនេះត្រូវបានកែប្រែចំណុចនេះថា ក្រឹត្យវិន័យពុំត្រូវបានចាត់ទុកឱ្យសំខាន់ជាងសេចក្តីត្រូវការរបស់មនុស្សនោះទេ ។ ព្រះយេស៊ូវបានប្រឈមមុខនឹងពួកផារិស៊ីជាច្រើនដងនៅក្នុងឱកាសបុណ្យឈប់សម្រាកនេះម្តងៗ (មថ ១២:១–១៤) ។ នៅក្នុងចំណុចខាងលើ (ខ.៣២–៣៦) ទាំងនេះហើយ ដែលបណ្តាលឱ្យពួកគេធ្វើគុតដល់ទ្រង់ (មថ ១២:១៤) ។

**១៥:៣៨** *រំយោលនៅជាយអាវខ្លួន* រំយោលនេះគឺសម្រាប់ចងក្រឹត្យវិន័យជាប់ទៅនឹងអាវរបស់ខ្លួន (ខ.៣៩) ដើម្បីឱ្យឆាប់ចាំ និងធ្វើតាម (ចទ ៦:៤–៩) ។

**១៥:៤១** *អញនេះ គឺយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ដែលបាននាំឯងចេញពី* ជាសេចក្តីរំឭកពីការរំដោះរាស្ត្ររបស់ទ្រង់ (មើលការពន្យល់ ២០:២) ។

**១៦:១–៧** កាលពីដំបូងនាងម៉ារាម និងលោកអើរ៉ុនបានដឹកនាំការបះបោរទាស់នឹងការដឹកនាំរបស់លោកម៉ូសេ (ជំពូក ១២) ហើយឥឡូវនេះ លោកកូរេ និងក្រុមរបស់គាត់នាំគ្នាប្រឆាំងនឹងការដឹកនាំរបស់លោកម៉ូសេ និងអើរ៉ុន ។ នៅពេលនេះ លោកកេហាត់មានតួនាទីយ៉ាងខ្ពស់នៅក្នុងរោងឧបោសថ ផ្នែកបម្រើព្រះអម្ចាស់នោះទៅហើយ (៤:១–២០) តែគាត់នៅតែមានចិត្តចង់បានតំណែងខ្ពស់ថែមទៀត បំណងរបស់គាត់គឺចង់បានតំណែង

ពួកកូនចៅអ៊ីស្រាអែល ដែលសុទ្ធតែជាកំពូលលើពួកជំនុំ
ជាមនុស្សរើសតាំងក្នុងពួកគេ ហើយក៏មានល្បីឈ្មោះផង[ង]
៣អ្នកទាំងនោះប្រជុំគ្នាទាស់នឹងម៉ូសេ ហើយនិងអើរ៉ុន
ដោយពាក្យថា អ្នកយកអំណាចលើខ្លួនហួសពេកណាស់
ដ្បិតពួកជំនុំក៏បានបរិសុទ្ធទាំងអស់គ្នាដែរ[ច] ហើយព្រះ
យេហូវ៉ាទ្រង់គង់នៅជាមួយនឹងគេផង[ឆ] ម្ដេចឡើយអ្នកទាំង
២លើកកំពស់ខ្លួន ត្រួតលើពួកជំនុំផងព្រះយេហូវ៉ាដូច្នេះ[ជ]។
៤កាលម៉ូសេបានឮពាក្យនោះ លោកក៏ទំលាក់ខ្លួនចុះ
ក្រាបផ្កាប់មុខ[ឈ] ៥ឆ្លើយនឹងកូរេ ហើយនិងពួកគេថា ព្រឹក
ស្អែកនេះ ព្រះយេហូវ៉ានឹងសំដែងឱ្យស្គាល់អ្នកណាដែលជា
របស់ផងទ្រង់ និងអ្នកណាដែលបរិសុទ្ធ[ញ] ទ្រង់នឹងនាំឱ្យអ្នក
នោះចូលទៅជិតទ្រង់[ដ] គឺជាអ្នកណាដែលទ្រង់នឹងរើស[ឋ]
ទ្រង់នឹងនាំអ្នកនោះឯងឱ្យចូលទៅជិតទ្រង់ ៦ចូរឱ្យកូរេឯង
និងពួកអ្នកនៅជាមួយ[ឌ]ធ្វើដូច្នេះចុះ ឱ្យយកពានគ្រប់គ្នារៀង
ខ្លួនទៅ[ឍ] ៧រួចដល់ស្អែកឡើង ចូរយកភ្លើង[ណ]ដាក់នឹង
ពានទាំងនោះ ហើយរោយកំញាន[ត]ពីលើនៅចំពោះព្រះ
យេហូវ៉ា នោះអ្នកណាដែលព្រះយេហូវ៉ាទ្រង់រើស[ថ] អ្នក
នោះឯងនឹងបានបរិសុទ្ធ[ទ] នែ កូនចៅលេវីអើយ ឯងរាល់
គ្នាយកអំណាចលើខ្លួនហួសពេកណាស់ ៨ម៉ូសេក៏និយាយទៅ
កូរេថា ពួកកូនចៅលេវីអើយ ចូរស្ដាប់សិន ៩ដែល[ធ]ព្រះ
នៃសាសន៍អ៊ីស្រាអែល ទ្រង់បានញែកឯងរាល់គ្នាចេញពី
ពួកជំនុំនៃកូនចៅអ៊ីស្រាអែល ឱ្យបាននាំឯងចូលទៅជិត
ទ្រង់ សំរាប់នឹងធ្វើការងារក្នុងរោងឧបោសថផងព្រះយេ
ហូវ៉ា ហើយឱ្យបានឈរនៅមុខពួកជំនុំ ដើម្បីនឹងធ្វើការ
ងារជូនគេ[ន] ១០ព្រមទាំងនាំឯងរាល់គ្នា និងពួកលេវីជាបង
ប្អូនឯងទាំងអស់មកជិតផង នោះតើឯងរាល់គ្នាស្មានថាជា
ការតូចពេកឬអី បានជារកចង់បានការងារជាសង្ឃថែម
ទៀតដូច្នេះ[ប] ១១ឯអើរ៉ុន តើលោកជាអ្វីដែលឯងរាល់គ្នា
រទូរទាំទាស់នឹងលោកដូច្នេះ គឺឯង និងពួកឯងទាំងនេះ
បានប្រមូលគ្នាទាស់[ផ]នឹងព្រះយេហូវ៉ាវិញទេតើ[ព]។
១២ម៉ូសេក៏ចាត់គេឱ្យទៅហៅដាថាន និងអ័ប៊ីរ៉ាម[ភ] ជា
កូនអេលាបឱ្យមក តែគេប្រកែកថា យើងមិនទៅទេ[ម]
១៣ដែលអ្នកបាននាំយើងចេញពីស្រុក ដែលមានទឹកដោះ
និងទឹកឃ្មុំ[យ]ហូរហៀរមក ដើម្បីនឹងសំឡាប់យើងនៅទី
រហោស្ថាននេះ[រ] តើជាការតូចពេកឬអី បានជាអ្នកត្រូវ
ការចង់លើកខ្លួន ធ្វើជាកំពូលលើយើងទៀត[ល] ១៤១ទៀត
អ្នកមិនបាននាំយើងចូលទៅក្នុងស្រុក ដែលមានទឹកដោះ
និងទឹកឃ្មុំហូរហៀរទេ[វ] ក៏មិនបានឱ្យស្រែចំការ[ស]មកយើង
ទុកជាមរដកផង តើអ្នកចង់ចាក់ពន្លត់ភ្នែកអ្នកទាំងនេះដែរ
ឬអី[ហ] យើងមិនព្រមទៅសោះឡើយ[ឡ]។
១៥ដូច្នេះ ម៉ូសេក៏ខឹងណាស់[អ] ហើយទូលទៅព្រះយេ
ហូវ៉ាថា សូមទ្រង់កុំរាប់អានដង្វាយគេឡើយ ទូលបង្គំមិន
បានយកសត្វលា[ក]របស់គេ សូម្បីតែ១ផង ក៏មិនដែល
ប្រទូសរ៉ាយចំពោះពួកគេណាឡើយ ។
១៦រួចម៉ូសេបង្គាប់ដល់កូរេថា ថ្ងៃស្អែកនេះ ចូរឱ្យ
ឯង និងពួកឯងទាំងប៉ុន្មាន មកនៅចំពោះព្រះយេហូវ៉ាចុះ
គឺឯង និងពួកអ្នកទាំងនោះ ព្រមទាំងអើរ៉ុនផង[ខ] ១៧ចូរឱ្យ
គ្រប់គ្នានាំយកពានរបស់ខ្លួន មករោយកំញានពីលើ គឺត្រូវ
ឱ្យគ្រប់គ្នានាំយកពានរបស់ខ្លួនមក នៅចំពោះព្រះយេហូវ៉ា
ជាពានមានចំនួន២៥០ ទាំងឯង និងអើរ៉ុន ក៏ត្រូវយក
ពានរបស់ខ្លួនមកដែរ[គ] ១៨ដូច្នេះ គេក៏យកពាន[ឃ]មកគ្រប់គ្នា
ព្រមទាំងដាក់ភ្លើង ហើយរោយកំញានពីលើផង រួចឈរ

**១៦:២** ង ជន ១:១៦ ២៦:៩
**១៦:៣** ច ខ.៧ ទដ ១០៦:១៦ ឆ នក ១៩:៦ ជ ជន ១៤:១៤ ឈ ជន ១២:២
**១៦:៤** ញ ជន ១៤:៥
**១៦:៥** ដ លវ ១០:៣ ២ធថ ២:១៩ ឋ យរ ៣០:២១ ឌ ជន ១៧:៥ ទដ ៦៥:៤ ១០៥:២៦ យរ ៥០:៤៤
**១៦:៦** ឍ ខ.៧,១៦ ណ លវ ១០:១ វវ ៨:៣
**១៦:៧** ត លវ ១០:១ ថ នក ៣០:៩ ទ ខ.៦ ធ ខ.៥
**១៦:៩** ន លប ៣០:១៥ ប ជន ៣:៦ ចទ?១០:៨ ១៧:១២ ២១:៥ ១សយ ២:១១ ទដ ១៣៤:១ អគ ៤៤:១១
**១៦:១១** ផ ខ.៤១ ១កថ ១០:១០ ព នក ១៦:៧
**១៦:១២** ភ ខ.១,២៧ ម ខ.១៤
**១៦:១៣** យ ជន ១៣:២៧ រ ជន ១៤:២ ល លប ១៣:៨ កច ៧:២៧,៣៥
**១៦:១៤** វ លវ ២០:២៤ ស នក ២:៥ ២៣:១១ ជន ២០:៥ ១ពវ ៤:២៥ នហ ១៣:១៥ ទដ ១០៥:៣៣ យរ ៥:១៧ សហ ២:១២ យអ ២:២២ ហក ២:១៩ សក ៣:១០ ហ ពច ១៦:២១ ១សយ ១១:២ យរ ៣៩:៧ ឡ ខ.១២ **១៦:១៥** អ នក ៤:១៤ ក ១សយ ១២:៣ **១៦:១៦** ខ ខ.៦ **១៦:១៧** គ អគ ៨:១១ **១៦:១៨** ឃ លវ ១០:១

ជាសង្ឃ ហើយត្រូវបានធ្លាប់គេធ្វើឱ្យខកចិត្តម្ដងរួចទៅហើយពីមុនមក ។ រីឯកូរេត្រូវបានចូលរួមដោយពួករូបេន ដាថាន និងអ័ប៊ីរ៉ាម ព្រមទាំងអ្នកដឹកនាំសាសន៍អ៊ីស្រាអែលប្រហែល២៥០នាក់ផ្សេងទៀតបានចូលរួម ។ ការចោទប្រកាន់របស់ពួកគេម្ដងនេះគឺថា "លោកម៉ូសេបានយកអំណាចលើខ្លួនហួសពេក"(ខ.៣) ហើយគេបន្តទៀតថា "ពួកជំនុំក៏បានបរិសុទ្ធទាំងអស់គ្នាដែរ"(ខ.៣) ។ ការចោទប្រកាន់បានធ្វើឱ្យលោកម៉ូសេឆ្លើយទាំងកំហឹងវិញថា "នែកូនចៅលេវីអើយ! ឯងរាល់គ្នាយកអំណាចលើខ្លួនហួសពេកណាស់ ចូរយកភ្លើងដាក់នឹងពានទាំងនោះ ហើយរោយកំញានពីលើនៅចំពោះព្រះយេហូវ៉ា នោះអ្នកណាដែលព្រះយេហូវ៉ាទ្រង់រើសអ្នកនោះឯងនឹងបានបរិសុទ្ធ"(ខ.៧) ។

**១៦:៣** *ពួកជំនុំក៏បានបរិសុទ្ធទាំងអស់គ្នា* មើលការពន្យល់ នក ៣:៥ ១៩:៦ ។

**១៦:៦** *ពាន* មើលការពន្យល់ លវ ១០:១ "ជើងពាន"។

**១៦:១២** *ដាថាន និងអ័ប៊ីរ៉ាម* គឺជាពួកអ្នកដែលចោទប្រកាន់នឹងលោកម៉ូសេថា គាត់មិនបាននាំយើងរាល់គ្នាចូលទៅក្នុងទឹកដីសន្យានោះទេ ។ ពួកគេនិយាយបង្ខូចដល់គាត់ថា"លោកម៉ូសេនេះបាននាំពួកគេចេញពីទឹកដីដែលសំបូរហូរហៀរដោយទឹកដោះ និងទឹកឃ្មុំ"(ខ.១៣) ។ ការផ្លាស់ប្ដូរដ៏ចម្លែកនេះបានធ្វើឱ្យពួកគេនិយាយថា ការជាប់ទោសជាទាសករនៅអេស៊ីព្ទនោះជាស្ថានសួគ៌របស់ពួកគេទៅវិញ ។

**១៦:១៣–១៤** *មានទឹកដោះ និងទឹកឃ្មុំហូរហៀរ* មើលការពន្យល់ នក ៣:៨ ចទ ៦:៣ ។

**១៦:១៥** *ក៏មិនដែលប្រទូសរ៉ាយចំពោះពួកគេណាឡើយ* សេចក្ដីទូលអង្វររបស់លោកម៉ូសេត្រូវបានគេទទួលស្គាល់ថា ស័ក្ដិសិទ្ធិណាស់ ។

**១៦:១៨–២១** ការល្បងនៅត្រង់នេះគឺដោយភ្លើង ដើម្បីឱ្យដឹងថា តើអ្នកណាខ្លះដែលព្រះអម្ចាស់ទទួលធ្វើជាសង្ឃនៅក្នុងរោងឧបោសថ ។ អ្នកដឹកនាំ

នៅមាត់ទ្វារត្រសាលជំនុំជាមួយនឹងម៉ូសេ ហើយនឹងអើរ៉ុន
១៩ ឯកូរេក៏ប្រមូលពួកជំនុំទាំងអស់គ្នា មកទាស់នឹងលោក
ទាំង២[ង] នៅត្រង់មាត់ទ្វារត្រសាលជំនុំ គ្រានោះសិរីល្អនៃ
ព្រះយេហូវ៉ា[ច]ក៏លេចមក ឱ្យពួកជំនុំទាំងអស់ឃើញ ។
២០ ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេ ហើយនិងអើរ៉ុន
ថា ២១ ចូរឯងដកខ្លួន[ឆ]ពីពួកជំនុំនេះចេញ ដើម្បីឱ្យអញបាន
បំផ្លាញគេទៅជា១រំពេច[ជ] ២២ នោះអ្នកទាំង២ក៏ទំលាក់ខ្លួន
ចុះក្រាបផ្កាប់មុខ[ឈ]ទូលថា ឱព្រះអង្គដ៏ជាព្រះនៃវិញ្ញាណ
គ្រប់ទាំងមនុស្សអើយ[ញ] បើមនុស្សតែម្នាក់ធ្វើបាប[ដ] នោះតើ
ទ្រង់នឹងក្រោធចំពោះពួកជំនុំទាំងអស់គ្នាឬអី[ឋ] ២៣ ព្រះយេ
ហូវ៉ា ទ្រង់មានបន្ទូលតបថា ២៤ ចូរប្រាប់ដល់ពួកជំនុំឱ្យគេ
ថយចេញពីត្រសាលរបស់កូរេ ដាថាន និងអ័ប៊ីរ៉ាមទៅ ។
២៥ រួចម៉ូសេក៏ក្រោកឡើងទៅឯដាថាន និងអ័ប៊ីរ៉ាម
មានទាំងពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែល[ឌ]ដើរតាមទៅ
ដែរ ២៦ លោកអង្វរពួកជំនុំដោយពាក្យថា សូមឱ្យអ្នករាល់
គ្នា ថយចេញពីត្រសាលរបស់មនុស្សអាក្រក់ទាំងនេះទៅ[ឍ]
កុំពាល់របស់អ្វីផងគេឱ្យសោះ ក្រែងត្រូវវិនាសទៅ[ណ] ក្នុង
អំពើបាបទាំងប៉ុន្មានរបស់គេដែរ[ត] ២៧ ដូច្នេះ គេក៏ថយចេញ
ពីកន្លែងជុំវិញត្រសាលរបស់កូរេ ដាថាន និងអ័ប៊ីរ៉ាមទៅ
រីឯដាថាន និងអ័ប៊ីរ៉ាម[ថ] គេក៏ចេញមកឈរនៅមាត់ទ្វារ
ត្រសាលរបស់ខ្លួន[ទ] ព្រមទាំងប្រពន្ធ និងកូនធំតូចទាំងប៉ុន្មាន
របស់គេដែរ[ធ] ២៨ រួចម៉ូសេមានប្រសាសន៍ថា គឺយ៉ាងដូច្នេះ
ដែលឯងរាល់គ្នានឹងដឹង[ន]ថាព្រះយេហូវ៉ាបានចាត់អញ[ប]
មកធ្វើការទាំងនេះ ហើយថា អញមិនបានធ្វើដោយអំពើ
ចិត្តរបស់អញទេ ២៩ គឺបើអ្នកទាំងនេះស្លាប់ តាមដំណើរ
ធម្មតានៃមនុស្សទាំងឡាយ ឬបើគេត្រូវដកជីវិតយកទៅ
តាមភាពធម្មតារបស់មនុស្សផងទាំងពួង នោះព្រះយេហូវ៉ា
មិនបានចាត់អញមកទេ[ផ] ៣០ តែបើសិនជាព្រះយេហូវ៉ា ទ្រង់
ធ្វើការមួយយ៉ាងចំឡែកវិញ ដោយឱ្យដីហា[ព]ឡើងលេបគេ
និងរបស់ផងគេទាំងអស់ទៅ ហើយគេចុះទាំងរស់ទៅក្នុង
ស្ថានឃុំព្រលឹងមនុស្សស្លាប់[ភ] នោះអ្នករាល់គ្នានឹងដឹងពិតថា
គេបានមើលងាយ ដល់ព្រះយេហូវ៉ាហើយ[ម]។
៣១ កាលលោកបានមានប្រសាសន៍ពាក្យទាំងនេះរួច
ហើយ នោះដីក៏ប្រេះឡើងពីក្រោមគេ[យ] ៣២ ហាទទួលយក
គេបាត់ទៅ[រ] ព្រមទាំងពួកផ្ទះគេ និងអស់មនុស្សណាដែល
ជាពួករបស់កូរេ ហើយនិងទ្រព្យសម្បត្តិរបស់គេផង
៣៣ ដូច្នេះ អ្នកទាំងនោះនិងពួកគេទាំងអស់ក៏ចុះទៅឯស្ថាន
ឃុំព្រលឹងមនុស្សស្លាប់ទាំងរស់[ល] រួចដីភ្ជិតពីលើគេទៅ
វិញហើយគេត្រូវវិនាសបាត់អស់ពីពួកជំនុំចេញ ៣៤ ឯពួក
អ៊ីស្រាអែលដែលនៅជុំវិញ កាលគេឮសំរែករបស់អ្នក
ទាំងនោះ ក៏រត់ទាំងអស់គ្នា ដោយនិយាថា ក្រែងដីស្រូប
យើងទៅដែរ ៣៥ ក៏មានភ្លើងចេញពីព្រះយេហូវ៉ា[វ] មក
បញ្ឆេះ[ស]មនុស្ស២៥០នាក់ ដែលកំពុងថ្វាយកំញាននោះ
ដែរ។
៣៦ ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ៣៧ ចូរប្រាប់
ដល់អេលាសារ[ហ] ជាកូនអើរ៉ុនដ៏ជាសង្ឃ ឱ្យរើសពាន[ឡ]ទាំង
នោះពីក្នុងភ្លើងមក ហើយឱ្យវាចភ្លើងទៅខាងនោះទៅ
ដ្បិតពានទាំងនោះជារបស់បរិសុទ្ធ ៣៨ ត្រូវឱ្យយកពានទាំង
ប៉ុន្មានរបស់មនុស្ស ដែលបានធ្វើបាបមានទោសដល់ស្លាប់

**១៦:១៩** ង ខ.៤២ ជន ២០:២ ច នក ១៦:៧ ជន ១៤:១០ ២០:៦ **១៦:២១** ឆ ខ.២៤ ជ លប ១៩:១៤ នក ៣២:១០ **១៦:២២** ឈ ជន ១៤:៥ ញ ជន ២៧:១៦ យប ១២:១០ ២៧:៨ ៣៣:៤ ៣៤:១៤ យរ ៣២:២៧ អគ ១៨:៤ ហព ១២:៩ ដ លប ១៨:២៣ យប ១២:២០ ឋ លវ ១០:៦ **១៦:២៥** ឌ នក ១៩:៧ **១៦:២៦** ឍ អស ៥២:១១ ណ លប ១៩:១៥ ត យរ ៥១:៦ **១៦:២៧** ថ ខ.១២ ទ ខ.៣២ យស ៧:២៤ អស ១៣:១៦ ១៤:២១ ធ នក ៣៣:៨ **១៦:២៨** ន ១ពវ ១៨:៣៦ ប នក ៣:១២ យហ ៥:៣៦ ៦:៣៨ **១៦:២៩** ផ ជន ២៤:១៣ យប ៣១:២ សស ៣:១៩ **១៦:៣០** ព ទដ ១៤១:៧ អស ៥:១៤ ភ ខ.៣៣ លប ៣៧:៣៥ ១សយ ២:៦ យប ៥:២៦ ២១:១៣ ទដ ៩:១៧ ១៦:១០ ៥៥:១៥ អស ១៤:១១ ៥៥:១៥ អស ១៤:១១ ៣៨:១៨ ម ជន ១៤:១១ អគ ២៦:២០ **១៦:៣១** យ អស ៦៤:១–២ អគ ៤៧:១–១២ មីក ១:៣–៤ សក ១៤:៤ **១៦:៣២** រ នក ១៥:១២ **១៦:៣៣** ល ខ.៣០ សស ៩:១០ **១៦:៣៥** វ ជន ១១:១–៣ ២៦:១០ វវ ១១:៥ ស លវ ១០:២ **១៦:៣៧** ហ នក ៦:២៣ ឡ ខ.៦

២៥០នាក់ដែលជាសម្ព័ន្ធមិត្តនឹងពួកកូរេបានឱ្យដឹងថាពួកគេសំខាន់ណាស់ អាចឈរជាមួយនឹងលោកម៉ូសេ និងអើរ៉ុននៅឯទីប្រជុំក្នុងត្រសាល ។ ការបើកសម្តែងពីសិរីល្អរបស់ព្រះគឺប្រាកដច្បាស់ និងភ្លាមៗ(ខ.១៩) ដោយកើតឡើងយ៉ាងទាន់ហន់ដល់ពួកអ្នកប្រឆាំងនឹងព្រះ (ខ.២១) ។ ការជំនុំជម្រះគឺសមនឹងទង្វើ ។ មនុស្សទាំង២៥០នាក់ដែលហ៊ានប្រកាសថាខ្លួនពួកគេជាសង្ឃនៅមុខព្រះយេហូវ៉ាដោយភ្លើងក្នុងជើងពានរបស់ពួកគេ នោះត្រូវស្លាប់ដោយសារភ្លើង(ប្រហែលភ្លើងផ្លេកបន្ទោរ) មកពីព្រះអម្ចាស់(ខ.៣៥) ។

**១៦:១៩,៤២** *សិរីល្អនៃព្រះយេហូវ៉ា* មើលការពន្យល់ នក ១៦:៧ ។

**១៦:២៤** *ថយចេញ* ការជំនុំជម្រះរបស់ព្រះនឹងមានសភាពធ្ងន់ធ្ងរណាស់នៅត្រង់នេះដល់ពួកជំនុំ ប៉ុន្តែទ្រង់ពុំប្រព្រឹត្តនឹងពួកគេយ៉ាងដូច្នេះឡើយ ។ ពួកកូរេខ្លួនឯងទេ ដែលបានចាកចេញពីសង្ឃខុសឆ្គងទាំង២៥០នាក់ ហើយទៅចូលរួមជាមួយនឹងពួកដាថាន និងពួកអ័ប៊ីរ៉ាមដើម្បីបន្តប្រឆាំងនឹងលោកម៉ូសេ ។

**១៦:៣០** *ការមួយយ៉ាងចំឡែក* លោកម៉ូសេមានបំណងធានាពួកបណ្តាជនទាំងនោះឱ្យរួចពីការជំនុំជម្រះរបស់ព្រះ ដែលនឹងត្រូវកើតក្នុងពេលឆាប់ៗខាងមុខនេះ ។ រំពេចនោះផែនដីក៏បើកចំហ លេបពួកអ្នកបះបោរទាំងនេះអស់ទៅ ។ នេះគឺជាសញ្ញានៃសេចក្តីក្រោធរបស់ព្រះ ហើយនិងជាការយល់ព្រមរបស់លោកម៉ូសេ និងលោកអើរ៉ុននោះផងដែរ ។ *ស្ថានឃុំព្រលឹងមនុស្សស្លាប់* មើល ខ.៣៣ និងមើលការពន្យល់ លប ៣៧:៣៥ ។

**១៦:៣២** *ហាទទួលយកគេបាត់ទៅ ព្រមទាំងពួកផ្ទះគេ* ពួកកូនចៅរបស់ពួកកូរេពុំបានស្លាប់ឡើយ (២៦:១១) ប្រហែលជាពួកកូនចៅទាំងនេះពុំបានរួមគំនិតនឹងឪពុកម្តាយរបស់គេនោះទេមើលទៅ ប៉ុន្តែពួកគ្រួសារផ្សេងៗដែលបានចូលរួមនឹងពួកកូរេនោះត្រូវស្លាប់ទាំងអស់ ។

**១៦:៣៧** *ឱ្យរើសពាន* សង្ឃដ៏ពិតប្រាកដបានរើសពានរបស់អ្នកដែលបានស្លាប់ទៅទាំង២៥០នាក់នោះ យកមកធ្វើជាអាសនាធំមួយដើម្បីទុកជាសេចក្តីរំឭកពីពួកល្ងីល្ងើដែលប្រកាសខ្លួនថាជាសង្ឃរបស់ព្រះនោះ(ខ.៤០) ។

នោះ[អ] ទៅផែធ្វើជាបន្ទះ សំរាប់នឹងប៉ានភ្ជាប់នឹងអាសនា[ក]
ដ្បិតគេបានថ្វាយនៅចំពោះព្រះយេហូវ៉ាហើយ ដូច្នេះ
ជារបស់បរិសុទ្ធ ក៏នឹងបានជាទីសំគាល់[ខ]ដល់ពួកកូនចៅ
អ៊ីស្រាអែល ៣៩នោះអេលាសារដ៏ជាសង្ឃ[គ]ក៏រើសយកពាន
លង្ហិនទាំងប៉ុន្មាន ដែលពួកអ្នកត្រូវភ្លើងឆេះ[ឃ]នោះបាន
ថ្វាយ មកផែសំរាប់នឹងប៉ានអាសនា ៤០ទុកជាសេចក្ដីរំឭក
ដល់ពួកកូនចៅអ៊ីស្រាអែល ដើម្បីកុំឱ្យអ្នកដទៃណា ដែល
មិនកើតពីពូជអើរ៉ុនមក បានចូលទៅដុតកំញាន[ង]នៅ
ចំពោះព្រះយេហូវ៉ាឡើយ[ច] ក្រែងលោគេត្រូវស្លាប់ដូចកូរេ
ហើយនិងពួកគេដែរ[ឆ] ដូចជាព្រះយេហូវ៉ាបានបង្គាប់មក
ដោយសារម៉ូសេ ។

៤១លុះដល់ថ្ងៃស្អែកឡើង ពួកជំនុំនៃកូនចៅអ៊ីស្រាអែល
ទាំងអស់គ្នា ក៏រទូរទាំទាស់នឹងម៉ូសេ ហើយនិងអើរ៉ុនថា
លោកបានសំឡាប់ពួកជននៃព្រះយេហូវ៉ា ៤២តែកាលពួក
ជំនុំបានប្រជុំគ្នាទាស់[ជ]នឹងម៉ូសេ ហើយនិងអើរ៉ុនដូច្នេះ នោះ
គេក្រឡេកមើលទៅខាងត្រសាលជំនុំ ឃើញពពកមកគ្រប
លើត្រសាល ហើយសិរីល្អនៃព្រះយេហូវ៉ា[ឈ]ក៏លេចមក
ដែរ ៤៣ឯម៉ូសេ និងអើរ៉ុនក៏ទៅឯត្រង់មុខត្រសាលជំនុំ
៤៤នោះព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ៤៥ចូរឱ្យឯង
ថយចេញពីពួកជំនុំនេះទៅ ដើម្បីឱ្យអញបានបំផ្លាញ[ញ]គេ
ចេញជា១រំពេច តែអ្នកទាំង២ក៏ទំលាក់ខ្លួនចុះក្រាបផ្កាប់
មុខ ៤៦ហើយម៉ូសេប្រាប់ដល់អើរ៉ុនថា ចូរយកពានរបស់
បងទៅ[ដ] ហើយយកភ្លើងពីលើអាសនាមកដាក់ រួចរោយ
កំញាន នាំយកទៅឯពួកជំនុំ[ឋ] ថ្វាយឱ្យធួន[ឌ]នឹងគេជាប្រញាប់
ទៅ ដ្បិតមានសេចក្ដីក្រោធចេញពីចំពោះព្រះយេហូវ៉ា
មក[ឍ] មានមនុស្សកំពុងតែដួលស្លាប់[ណ]ហើយ ។

៤៧ដូច្នេះអើរ៉ុនក៏យកពានទៅតាមបង្គាប់ម៉ូសេ ហើយ
រត់ទៅឯកណ្ដាលពួកជំនុំ នោះឃើញមនុស្សកំពុងតែដួល
ស្លាប់នៅក្នុងពួកគេហើយ[ត] រួចលោករោយកំញានថ្វាយឱ្យ
ធួននឹងគេ ៤៨ក៏ឈរនៅកណ្ដាលពួកមនុស្សស្លាប់ នឹងពួក
មនុស្សរស់ ដូច្នេះការប្រហារជីវិតនោះក៏បាត់ទៅ[ថ] ៤៩រីឯ
ពួកមនុស្សដែលស្លាប់ ដោយការប្រហារជីវិតនោះ មាន
ចំនួន១ម៉ឺន៤ពាន់៧០០នាក់ ទីទៃពីពួកអ្នកដែលត្រូវស្លាប់
ពីដំណើរកូរេ[ទ] ៥០រួចអើរ៉ុនក៏ត្រឡប់ទៅឯម៉ូសេ នៅត្រង់
មាត់ទ្វារត្រសាលជំនុំ ហើយការប្រហារជីវិតបានឈប់
ទ្រឹងនៅ ។

## ដំបងរបស់លោកអើរ៉ុន

**១៧** ១ព្រះយេហូវ៉ា ទ្រង់បង្គាប់ដល់ម៉ូសេថា ២ចូរនិយាយ
នឹងពួកកូនចៅអ៊ីស្រាអែល រួចទទួលយកដំបង[ក]ពីគេ គឺដំបង
មួយៗពីគ្រប់ទាំងវង្សានុវង្ស របស់ពួកឰយុកោគេ ត្រូវយក
ពីពួកអ្នកដែលជាកំពូលលើគេ តាមវង្សានុវង្សនៃពួកឰយុ
កោគេរៀងខ្លួន[ខ] ឱ្យបានដំបង១២ ហើយសរសេរឈ្មោះ
របស់គេរៀងខ្លួន នៅភ្ជាប់នឹងដំបងនីមួយៗ ៣តែត្រូវ
សរសេរឈ្មោះអើរ៉ុន[គ] ភ្ជាប់នៅដំបងរបស់ពួកលេវីវិញ
ដ្បិតត្រូវឱ្យមានដំបង១ សំរាប់គ្រប់ទាំងមេនៃពួកវង្សឰយុ
កោគេ ៤រួចត្រូវដាក់ដំបងទាំងនោះទុកក្នុងត្រសាលជំនុំ[ឃ]
នៅចំពោះមុខនៃសេចក្ដីបន្ទាល់[ង] ត្រង់កន្លែងដែលអញតែង
ជួបនឹងឯង[ច] ៥ឯដំបងរបស់អ្នកណាដែលអញបានរើស[ឆ]
នោះនឹងបានប៉ិចឡើង[ជ] ហើយយ៉ាងនោះអញនឹងបំបាត់
សេចក្ដីរទូរទាំ របស់ពួកកូនចៅអ៊ីស្រាអែល ដែលគេចេះ
តែរទូរទាំ[ឈ]ទាស់នឹងឯង ឱ្យបាត់ចេញពីមុខអញទៅ ។

៦ម៉ូសេក៏ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល រួចអស់ទាំង
អ្នក ដែលជាកំពូលលើគេ ក៏ប្រគល់ដំបង១ម្នាក់មកលោក
រៀងខ្លួន តាមពួកវង្សានុវង្សនៃពួកឰយុកោគេ គឺជាដំបង
ទាំងអស់១២ ហើយដំបងរបស់អើរ៉ុនក៏នៅជាមួយនឹងដំបង
គេដែរ ៧រួចម៉ូសេដាក់ដំបងទាំងនោះទុកនៅចំពោះព្រះ

**១៦:៣៨** អ លវ ១០:១ សក ២០:២ ក នក ២០:២៤ ៣៨:១–៧ ខ ជន ២៦:១០ ចទ ២៨:៤៦ យរ ៤៤:២៩ អគ ១៤:៨ ២ពត ២:៦ **១៦:៣៩** គ ២របា ២៦:១៨ ឃ លវ ២០:១៤ **១៦:៤០** ង នក ៣០:១ ២ពវ ១២:៣ អស ១:១៣ ៦៦:៣ យរ ៤១:៥ ៤៤:៣ ច នក ៣០:៩ ២រប ២៦:១៨ ឆ ជន ៣:១០ **១៦:៤២** ជ ខ.១៩ ឈ នក ១៦:៧ ជន ១៤:១០ **១៦:៤៥** ញ នក ៣២:១០ **១៦:៤៦** ដ លវ ១០:១ ឋ លវ ១០:៦ ឌ នក ២៩:៣៦ ឍ ជន ១:៥៣ ណ លវ ២៦:២៥ ជន ៨:១៩ ទដ ១០៦:២៩ **១៦:៤៧** ត ជន ២៥:៦–៨ **១៦:៤៨** ថ ជន ២៥:៨ ទដ ១០៦:៣០ **១៦:៤៩** ទ ខ.៣២ **១៧:២** ក លប ៣២:១០ នក ៤:២ ខ ជន ១:៤ **១៧:៣** គ ជន ១:៣ **១៧:៤** ឃ នក ៤០:២ ង ខ.៧ នក ១៦:៣៤ ច នក ២៥:២២ **១៧:៥** ឆ ជន ១៦:៥ ជ ខ.៨ ឈ នក ១៦:៧

**១៦:៤១** *ពួកជំនុំនៃកូនចៅអ៊ីស្រាអែលទាំងអស់គ្នា ក៏រទូរទាំទាស់នឹងម៉ូសេ* នៅត្រង់នេះបាននិយាយម្ដងហើយ ដែលពួកបណ្ដាជនទាស់នឹងលោកម៉ូសេ ដោយការចោទប្រកាន់លោកពីរឿងស្លាប់រាស្ត្ររបស់ព្រះ ។ លើកលែងតែមានការអន្តរាគមន៍ពីលោកម៉ូសេនិងលោកអើរ៉ុន (ខ.៤,២២) បើមិនដូច្នោះទេជាតិសាសន៍ទាំងមូលនឹងត្រូវបំផ្លាញ ពីព្រោះតែការបះបោររបស់ពួកបណ្ដាជន (ខ.៤៥) ។

**១៦:៤៩** *ចំនួន១ម៉ឺន៤ពាន់៧០០នាក់ . . . ដែលត្រូវស្លាប់* នេះគឺជាចំនួនពិតប្រាកដដូចដែលស្ថិតិដ៏ច្រើនបានលើកឡើងនៅក្នុងជំពូក១២ ។

**១៧:១–១៣** រឿងនៅក្នុងវគ្គនេះកើតឡើងដោយយោងទៅតាមការជំនុំជម្រះរបស់ព្រះដល់ពួកកូរេ (១៦:១–៣៥) ហើយនិងរឿងនិទានអំពីនិមិត្តរូបអំពីពាន ដែលបន្សល់ទុកក្រោយពួកបះបោរទាំងនោះបានស្លាប់អស់ទៅ (១៦:៣៦–៥០) ។ នៅក្នុងជំពូក១៧ គឺជាចំណុចទីបីនៃសេចក្ដីយល់ព្រមរបស់សង្ឃអើរ៉ុនក្នុងការជំនុំជម្រះដល់ពួកអ្នកបះបោរនោះ ។

**១៧:៣** *តែត្រូវសរសេរឈ្មោះអើរ៉ុន ភ្ជាប់នៅដំបងរបស់ពួកលេវី* ការតម្រូវនេះត្រូវតែធ្វើតាមជាដាច់ខាត ដោយព្រោះតែការគាំទ្រដល់ការបះបោររបស់ពួកកូរេនោះកាន់តែច្រើនឡើងៗ ។ ចំនួនអ្នកដឹកនាំ២៥០នាក់ដែលបានស្លាប់ ដោយសារតែបានចូលរួមជាមួយនឹងពួកកូរេនោះ ប្រហែលមកពីស្ទើរតែគ្រប់អំបូរទាំង១២ ។

**១៧:៤** *នៅចំពោះមុខនៃសេចក្ដីបន្ទាល់* នៅមុខហឹបសេចក្ដីសន្យា ព្រមជាមួយនឹងបញ្ញត្តិទាំង១០ប្រការ ត្រង់នេះប្រហែលជាកន្លែងទីបរិសុទ្ធនៅជិត

យេហូវ៉ា ក្នុងត្រសាលនៃសេចក្ដីបន្ទាល់[ញ] ។
៨លុះថ្ងៃស្អែកឡើង កាលម៉ូសេចូលទៅក្នុងត្រសាលនៃ
សេចក្ដីបន្ទាល់[ដ] នោះឃើញដំបងរបស់អើរ៉ុន[ឋ] ដែលសំរាប់
ពួកវង្សលេវី មានពក ហើយប៉ិចឡើង រួចបែកចេញជា
ផ្កាហើយបង្កើតបានផ្លែចំបក់ទុំ[ឌ] ៩ម៉ូសេក៏យកដំបង[ឍ]
ទាំងនោះពីចំពោះព្រះយេហូវ៉ាចេញមកឯពួកកូនចៅ
អ៊ីស្រាអែលគេក៏មើល ហើយបានយកដំបងរបស់គេរៀង
ខ្លួនទៅ ១០រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរ
ដាក់ដំបងរបស់អើរ៉ុន[ណ] នៅចំពោះមុខនៃសេចក្ដីបន្ទាល់
វិញទៅ ទុកជាទីសំគាល់ទាស់នឹងពួកអ្នកដែលចង់បះបោរ[ត]
ដើម្បីឱ្យសេចក្ដីរទូរទាំរបស់គេ បានផុតចេញពីមុខអញទៅ
ក្រែងលោគេត្រូវស្លាប់ ១១នោះម៉ូសេក៏ធ្វើដូច្នោះ តាម
ដែលព្រះយេហូវ៉ាបានបង្គាប់មក លោកបានធ្វើសំរេច
តាមនោះ ។
១២ពួកកូនចៅអ៊ីស្រាអែល ក៏ពោលចំពោះម៉ូសេថា
មើល យើងរាល់គ្នាស្លាប់ យើងវិនាសហើយ យើងទាំង
អស់គ្នាត្រូវវិនាស[ថ] ១៣ដ្បិតអស់អ្នកណា ដែលចូលទៅជិត
រោងឧបោសថផងព្រះយេហូវ៉ា នោះក៏ត្រូវស្លាប់[ទ] ដូច្នេះ
តើត្រូវឱ្យយើងទាំងអស់គ្នាវិនាសទៅឬអី ។

## ការងាររបស់ពួកសង្ឃ និងពួកលេវី

**១៨** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងអើរ៉ុនថា ត្រូវ
ឱ្យខ្លួនឯង និងកូនចៅឯង ព្រមទាំងពួកវង្សឪពុកឯងទាំង
អស់គ្នា រ៉ាប់រងសេចក្ដីកំហុសដែលអ្នកណាធ្វើក្នុងរោង
ឧបោសថ[ក] ហើយត្រូវឱ្យខ្លួនឯង និងកូនចៅឯងរ៉ាប់រង
សេចក្ដីកំហុស ដែលកើតមកក្នុងការងារជាសង្ឃដែរ ២ឯ
ពួកលេវីជាបងប្អូនឯង គឺជាពូជអំបូរនៃឰយុកោឯង នោះ
ត្រូវនាំមកជិតជាមួយនឹងឯង ឱ្យបានភ្ជាប់ពួកជាមួយគ្នា
ហើយជួយការងារផង តែឯង ហើយនិងកូនចៅឯង ត្រូវ[ខ]
នៅចំពោះមុខត្រសាលនៃសេចក្ដីបន្ទាល់វិញ ៣ត្រូវឱ្យគេ
រក្សា[គ]បញ្ញើរបស់ឯង និងបញ្ញើនៃត្រសាលទាំងមូលដែរ[ឃ]
ប៉ុន្តែមិនត្រូវឱ្យគេចូលទៅជិតប្រដាប់ប្រដាណាមួយរបស់ទី
បរិសុទ្ធ ឬជិតអាសនាឡើយ ក្រែងលោគេត្រូវស្លាប់ ព្រម
ទាំងឯងផង[ង] ៤ត្រូវឱ្យគេនៅជាប់ ធ្វើការជាមួយនឹងឯង
ហើយរក្សាបញ្ញើរបស់ត្រសាលជំនុំ សំរាប់ក្រសួងទាំង
ប៉ុន្មាននៃត្រសាលនោះ តែមិនត្រូវឱ្យអ្នកដទៃណាចូលទៅ
ជិតឯងឡើយ[ច] ៥ឯងត្រូវឱ្យរក្សាបញ្ញើ នៃទីបរិសុទ្ធ និង
បញ្ញើនៃអាសនា[ឆ] ដើម្បីកុំឱ្យមានសេចក្ដីក្រោធមកលើ
ពួកកូនចៅអ៊ីស្រាអែលទៀតឡើយ ៦ឯអញ មើល អញ
បានទទួលយកពួកលេវី ជាបងប្អូនឯង ពីពួកកូនចៅ
អ៊ីស្រាអែល ដែលគេថ្វាយដល់ព្រះយេហូវ៉ា ហើយបាន
ប្រគល់ដល់ឯង[ជ] សំរាប់ធ្វើការងារក្នុងត្រសាលជំនុំ[ឈ] ៧ត្រូវ
ឱ្យឯង និងកូនចៅឯង រក្សាការងារជាសង្ឃរបស់ឯង
សំរាប់ការទាំងអស់ខាងឯអាសនា ហើយខាងក្នុងវាំងនន
ផង[ញ] គឺឯងរាល់គ្នា ដែលត្រូវធ្វើការងារនោះ អញឱ្យការ
ងារជាសង្ឃដល់ឯងរាល់គ្នា ទុកជាអំណោយ[ដ] បើអ្នកដទៃ
ណាដែលចូលទៅជិត នោះនឹងត្រូវស្លាប់[ឋ] ។

**១៧:៧** ញ នក ៣៨:២១
**១៧:៨** ដ ខ.៧ ជន ១:៥០ ឋ ខ.២,១០ ឌ អគ ១៧:២៤ ហាព ៩:៤
**១៧:៩** ឍ ខ.២
**១៧:១០** ណ ខ.៨ ត នក ២៣:២១ ចទ ៩:២៤ ទដ ៦៦:៧ ៦៨:១៨ សភ ២៤:២១
**១៧:១២** ថ ពច ១៣:២២ អស ៦:៥ ១៥:១
**១៧:១៣** ទ ជន ១:៥១
**១៨:១** ក នក ២៨:៣៨
**១៨:២** ខ ជន ៣:១០
**១៨:៣** គ ជន ៣:៣២ ឃ ជន ១:៥១ ង ខ.៧
**១៨:៤** ច ជន ៣:៣៨
**១៨:៥** ឆ ខ.៣ លវ ៦:១២
**១៨:៦** ជ ជន ៣:៩ ឈ ជន ៣:៨
**១៨:៧** ញ ហាព ៩:៣,៦ ដ ខ.២០ នក ២៩:៩ ៤០:១៣ ហាព ៥:៤ ឋ ខ.៣ ជន ៣:១០

អាសនានៃកំញាន (ខ.៧–៨,១០ និងមើលការពន្យល់ នក ២៥:២២) ។

**១៧:៨** *មានពក ហើយប៉ិចឡើង រួចបែកចេញជាផ្កាហើយបង្កើតបានផ្លែចំបក់ទុំ* ព្រះអង្គបានបង្កើតឱ្យមានការសាកល្បង គឺដើម្បីកុំឱ្យអ្នកផ្សេងមានការសង្ស័យលើសកម្មភាពរបស់លោកអើរ៉ុន ។

**១៧:១០** *ចំពោះមុខនៃសេចក្ដីបន្ទាល់* ដំបងរបស់លោកអើរ៉ុនបានចងភ្ជាប់ទៅនឹងផ្ទាំងក្រឹត្យវិន័យរបស់លោកម៉ូសេ (មើលការពន្យល់ នក ២៥:១៦) និងចាននំម៉ាន៉ា (មើល នក ១៦:៣៣–៣៤) ដែលនៅក្បែរហឹបនៃសេចក្ដីសញ្ញា (មើល ហាព ៩:៤) ។ និមិត្តដែលបរិសុទ្ធទាំងនេះគឺស្ថិតនៅខាងមុខព្រះយេហូវ៉ាទុកជាការរំលឹកពីតម្រូវការរបស់ទ្រង់ ជិនួសរាស្ត្ររបស់ទ្រង់ ។

**១៧:១២** *យើងរាល់គ្នាស្លាប់* នៅក្នុងខនេះបានប្រាប់ថា បណ្ដាជនបានដឹងពីលទ្ធផលនៃអំពើបាប ដោយសារការប្រកួតប្រជែងនឹងតួនាទីរបស់លោកអើរ៉ុន ។ សេចក្ដីលំអិតស្ដីអំពីមធ្យោបាយនាំចូលទៅជិតព្រះអម្ចាស់នោះមាននៅក្នុងជំពូក ១៨–១៩ ។

**១៨:១–៧** អើរ៉ុន និង គ្រួសាររបស់គាត់ ត្រូវបានជ្រើសតាំងឡើងដោយព្រះអម្ចាស់ ដើម្បីក្លាយជាសង្ឃដ៏ពិតប្រាកដសម្រាប់ការថ្វាយបង្គំបរិសុទ្ធ ដែលត្រូវប្រឈមមុខនឹងបន្ទុកភារកិច្ចដ៏ធ្ងន់ ។ សេចក្ដីទួញសោកនៃរាស្ត្រអ៊ីស្រាអែលនៅក្នុង ១៧:១២–១៣ គឺជាការពិត អំពើបាបដ៏ធ្ងន់ធ្ងរបានជិទាស់នឹងទីកន្លែងរោងជំនុំដ៏បរិសុទ្ធនៃព្រះអម្ចាស់ ហើយរាស្ត្ររបស់ទ្រង់ទាំងនេះនឹងត្រូវវិនិច្ឆ័យទោសដល់ស្លាប់ ។ សេចក្ដីប្រោសប្រណីនៃព្រះជាម្ចាស់ ដែលបានប្រទានឱ្យនូវការសម្ដែងព្រះគុណរបស់ផងទ្រង់ទៅតាមច្បាប់របស់សង្ឃដ៏ជាក់ស្ដែង (សូមប្រៀបធៀប ទដ ៩៩:៦–៨) ព្រោះថាព្រះគុណរបស់ផងទ្រង់គឺជាសេចក្ដីសង្ឃឹមតែមួយគត់របស់រាស្ត្រទ្រង់សម្រាប់ការរំដោះឱ្យរួចពីការវិនិច្ឆ័យទោស ។

**១៨:២** *ពួកលេវី . . . ត្រូវនាំមក* សង្ឃដែលស្ថិតក្នុងក្រុមគ្រួសារអើរ៉ុន ត្រូវបានជួយដោយអ្នកដទៃទៀតក្នុងពូជអំបូរលេវី ប៉ុន្តែពួកអ្នកដែលជាជំនួយការទាំងនោះមិនត្រូវបានអនុញ្ញាតឱ្យចេញទៅខាងមុខក្នុងពេលដែលពួកគេបំពេញតួនាទីរបស់ពួកគេនោះឡើយ ។ បើពួកគេបានចូលទៅជិតទីបរិសុទ្ធនោះ នឹងមិនត្រឹមតែបណ្ដាលឱ្យពួកគេស្លាប់ប៉ុណ្ណោះទេ ថែមទាំងពួកសង្ឃដែលទទួលខុសត្រូវនៅទីនោះថែមទៀតផង (ខ.៣) ។ *សេចក្ដីបន្ទាល់* សូមមើលសេចក្ដីពន្យល់នៅក្នុង នក ២៥:២២ ។

**១៨:៧** *ការងារជាស្បថដល់ឯងរាល់គ្នាទុកជាអំណោយ* គ្រប់បុរសទាំងអស់ដែលជាសង្ឃ សុទ្ធតែមានអភ័យឯកសិទ្ធិចូលទៅជិត ទីកន្លែងបរិសុទ្ធ និងបម្រើការងារនៅចំពោះមុខព្រះអម្ចាស់ ។ ការងារជាសង្ឃទុកជាអំណោយរបស់ព្រះគុណផងព្រះ ដែលមានចំពោះពួកសង្ឃ និងរាស្ត្រអ៊ីស្រាអែល ។

## ដង្វាយសម្រាប់ពួកសង្ឃ និងពួកលេវី

៨ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងអើរ៉ុនថា ឯអញ
មើល អញបានប្រគល់អស់ទាំងដង្វាយ ដែលថ្វាយដោយ
លើកចុះឡើង ក្នុងដង្វាយទាំងប៉ុន្មានរបស់ពួកកូនចៅអ៊ីស្រា
អែលទុកនឹងឯង អញបានឱ្យដង្វាយទាំងនោះចំពោះឯង
និងពួកកូនចៅឯង[ឌ] ទុកជាកំរៃនៅអស់កល្បជានិច្ច[ឍ] ដោយ
ព្រោះការចាក់ប្រេងតាំងជាសង្ឃ ៩ក្នុងដង្វាយបរិសុទ្ធបំផុត
ទាំងប៉ុន្មាន[ណ] ដែលមិនត្រូវដុត នោះរបស់ទាំងនេះ ត្រូវបាន
ជារបស់ផងឯង គឺគ្រប់ទាំងដង្វាយរបស់គេ ទោះបើជា
ដង្វាយម្សៅ[ត] ឬដង្វាយលោះបាប[ថ] ឬដង្វាយថ្វាយដោយ
ព្រោះការរំលងក្តី[ទ] ដែលគេនឹងថ្វាយដល់អញ នោះជា
បរិសុទ្ធបំផុតសំរាប់ឯង ហើយនិងកូនចៅឯង ១០ត្រូវឱ្យឯង
បរិភោគរបស់ទាំងនោះ នៅកន្លែងបរិសុទ្ធបំផុត គ្រប់ទាំង
ប្រុសៗ ត្រូវបរិភោគចុះ[ធ] គឺជារបស់បរិសុទ្ធដល់ឯង[ន]
១១ហើយនេះជារបស់ផងឯងដែរ គឺអស់ទាំងដង្វាយលើក
ចុះឡើង និងដង្វាយគ្រវី[ប]របស់ផងពួកកូនចៅអ៊ីស្រាអែល
អញឱ្យរបស់ទាំងនោះដល់ឯង និងកូនប្រុសកូនស្រីឯងផង
ទុកជាកំរៃនៅអស់កល្បជានិច្ច[ផ] អស់អ្នកណាដែលស្អាត[ព]
នៅក្នុងផ្ទះឯង នោះនឹងបរិភោគរបស់ទាំងនោះបាន
១២ហើយប្រេងល្អបំផុតទាំងអស់ និងស្រាទំពាំងបាយជូរល្អ
បំផុតទាំងអស់ ព្រមទាំងស្រូវផង[ភ] គឺជាផលដំបូង ដែលគេ
ថ្វាយដល់ព្រះយេហូវ៉ា[ម] នោះអញឱ្យមកឯងទាំងអស់ហើយ[យ]
១៣ឯផលដំបូងពីរបស់ទាំងអស់ នៅក្នុងស្រុកគេ ដែលយក
មកថ្វាយដល់ព្រះយេហូវ៉ា នោះត្រូវបានជារបស់ផងឯង
ដែរ[រ] អស់អ្នកណានៅក្នុងគ្រួសារឯង ដែលស្អាត និង
បរិភោគរបស់ទាំងនោះបាន[ល] ១៤គ្រប់របស់អ្វីដែលថ្វាយ
ដាច់[វ] នៅក្នុងពួកអ៊ីស្រាអែល នោះក៏ជារបស់ផងឯង
១៥គ្រប់ទាំងអស់ដែលកើតពីពោះម្តាយមកមុនគេ ក្នុងគ្រប់
ទាំងដង្វាយដែលត្រូវថ្វាយដល់ព្រះយេហូវ៉ា ទោះមនុស្សឬ
សត្វក្តី នោះត្រូវបានជារបស់ផងឯង[ស] ឯកូនច្បង[ហ]របស់
មនុស្ស នោះត្រូវឱ្យឯងលោះ[ឡ]ចេញវិញជាមិនខាន ព្រម
ទាំងសត្វមិនស្អាតដែលកើតមកមុនបង្អស់ផង[អ] ១៦ហើយ
រូបណាមួយដែលត្រូវលោះចេញ នោះត្រូវឱ្យលោះចាប់
តាំងពីអាយុ១ខែ[ក]តាមដំឡៃដែលឯងសំរេចឱ្យ គឺជាប្រាក់
៥រៀល[ខ]តាមប្រាក់រៀលដែលគេប្រើក្នុងទីបរិសុទ្ធ[គ] (គឺ១
រៀលត្រូវជា១០កាក់)[ឃ] ១៧ប៉ុន្តែមិនត្រូវឱ្យឯងលោះកូនគោ
ឬកូនចៀម ឬកូនពពែ ដែលកើតមកមុនបង្អស់នោះទេ
ដ្បិតជាសត្វបរិសុទ្ធ[ង] ត្រូវឱ្យឯងប្រោះឈាម[ច]សត្វនោះ នៅ
លើអាសនាវិញ ហើយដុតខ្លាញ់[ឆ]ជាដង្វាយដុត សំរាប់ជា
ក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[ជ] ១៨ឯសាច់របស់សត្វទាំងនោះ
ត្រូវបានជារបស់ផងឯង ដូចជាទ្រូងដែលគ្រវី[ឈ] ហើយស្មា
ស្តាំក៏ជារបស់ផងឯងដែរ[ញ] ១៩គឺគ្រប់ទាំងដង្វាយលើកចុះ
ឡើងពីដង្វាយបរិសុទ្ធ[ដ]ទាំងប៉ុន្មាន ដែលពួកកូនចៅអ៊ីស្រា–
អែល នឹងថ្វាយដល់ព្រះយេហូវ៉ា នោះអញបានឱ្យដល់ឯង
និងពួកកូនប្រុសកូនស្រីឯងហើយ ទុកជាកំរៃនៅអស់កល្ប

**១៨:៨** ឌ លវ ២:២ ឍ លវ ៦:១៦ ៧:៦,៣១–៣៤,៣៦ ចទ ១៨:១ ២រប ៣១:៤ **១៨:៩** ណ លវ ៦:១៧ ត លវ ២:១ ថ លវ ៦:២៥ ទ លវ ៥:១៥ **១៨:១០** ធ លវ ៦:១៦ ន លវ ៦:១៧,១៨ **១៨:១១** ប នក ២៩:២៦ លវ ៧:៣០ ជណ ៦:២០ ផ លវ ៧:៣១–៣៤ ព លវ ១៣:៣ ២២:១–១៦ **១៨:១២** ភ ចទ ៧:១៣ ១១:១៤ ១២:១៧ ២៨:៥១ ២ពវ ១៨:៣២ ២រប ៣១:៥ នហ ១០:៣៧ យរ ៣១:១២ អគ ២៣:៤១ ហស ២:៨ យអ ១:១០ ហក ១:១១ ម លប ៤:៣ យ នក ២៣:១៩ ៣៤:២៦ នហ ១០:៣៥ **១៨:១៣** រ នក ២៩:២៧ ល ខ.១១ **១៨:១៤** វ លវ ២៧:២១ ឝ ៦:១៧–១៩ **១៨:១៥** ស នក ១៣:២ ហ លប ១០:១៥ ឡ ជន ៣:៤៦ អ នក ១៣:១៣**១៨:១៦** ក ជន ៣:១៥ ខ លវ ២៧:៦ គ នក ៣០:១៣ ឃ ជន ៣:៤៧ **១៨:១៧** ង លវ ២៧:៩ ច លវ ៣:២ ឆ នក ២៩:១៣ ជ លវ ១:៩ **១៨:១៨** ឈ លវ ៧:៣០ ញ ខ.១១ **១៨:១៩** ដ ២ពវ ១២:៤

**១៨:៨** *កំរៃនៅអស់កល្បជានិច្ច* ពួកសង្ឃទាំងឡាយត្រូវបានផ្គត់ផ្គង់ដោយការងាររបស់ពួកគេនៅក្នុងការងារបម្រើព្រះ (សូមមើល លវ ៦:១៤–៧:៣៦) ចាប់តាំងពីពួកលេវីអស់ទាំងដំណ និងជាពិសេសពួកសង្ឃគ្មានចំណែកនៅក្នុងទឹកដីសន្យា ដែលព្រះបានប្រទានឱ្យឡើយ វាជាវិធីសាស្ត្រមួយដ៏ចាំបាច់សម្រាប់ការបម្រុងទុករបស់ពួកគេ ដែលត្រូវបានពន្យល់ប្រាប់យ៉ាងច្បាស់លាស់រួចទៅហើយ ។ ថ្វីដ្បិតពួកគេមិនត្រូវបានទទួលភាគចំណែកនៅក្នុងទឹកដីសន្យាក៏ពិតមែន ក៏ប៉ុន្តែ ពួកគេត្រូវបានទទួលភាគចំណែកជាមួយនឹងព្រះអម្ចាស់ដោយផ្ទាល់តែម្តង ។

**១៨:១១** *កូនប្រុសកូនស្រីឯង* ដង្វាយជាកំរៃនោះត្រូវបានបង្កើតឡើងមិនមែនសម្រាប់តែពួកសង្ឃប៉ុណ្ណោះទេ ក៏ប៉ុន្តែ សម្រាប់ក្រុមគ្រួសាររបស់គេផងដែរ។ ត្រូវបានហាមដល់សមាជិកក្រុមគ្រួសារណា ដែលមិនស្អាតមិនត្រូវឱ្យចូលរួមក្នុងពិធី និងហាមទទួលទានអំណោយ និងដង្វាយរបស់ពួកកូនចៅអ៊ីស្រាអែលថែមទៀតផង (សូមមើល ខ.១៣) ។ ដង្វាយជាកំរៃសម្រាប់លាងសម្អាត ត្រូវបានធ្វើការបរិយាយប្រាប់នៅក្នុង លវ ២២:៤–៨) ។

**១៨:១២** *ប្រេងល្អបំផុត . . . ស្រាទំពាំងបាយជូរល្អបំផុតទាំងអស់ ព្រមទាំងស្រូវផង* ដោយរាប់តាំងពីផលដំណាំគ្រប់ប្រភេទដ៏ល្អបំផុត ដែលត្រូវបានថ្វាយទៅព្រះអម្ចាស់ ហើយដង្វាយទាំងនេះបានក្លាយទៅជាស្បៀងអាហារសម្រាប់ពួកសង្ឃ និងក្រុមគ្រួសាររបស់ពួកគេ ។ ពួកអ្នកនិពន្ធព្រះគម្ពីរសញ្ញាថ្មីជជែកគ្នាដោយមានលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរថា អស់អ្នកណាដែលបម្រើការងារព្រះបន្ទូលព្រះ នៅក្នុងសម័យបច្ចុប្បន្ននេះ គួរតែត្រូវបានបង់ប្រាក់ឱ្យបានសមរម្យចំពោះការងាររបស់ពួកគេ (សូមមើលឧទាហរណ៍នៅ ១កថ ៩:៣–១០ និងការពន្យល់) ។

**១៨:១៦** *តាមប្រាក់រៀលដែលគេប្រើក្នុងទីបរិសុទ្ធ* សូមមើលការពន្យល់នៅ នក ៣០:១៣ ។

**១៨:១៩** *នៅអស់កល្បជានិច្ច គឺជាសេចក្តីសញ្ញា ដែលតាំងឡើងដោយសារអំបិល* គឺជាកំរៃដែលស្ថិតនៅជារៀងរហូតសម្រាប់ពួកសង្ឃ ។ នៅត្រង់ឃ្លាថា "*សេចក្តីសញ្ញាដែលតាំងឡើងដោយសារអំបិល* " (សូមមើល ២រប ១៣:៥) ស្ថិតនៅក្នុងភាពមិនទាន់ច្បាស់លាស់នៅឡើយ ។ នៅក្នុង លវ ២:១៣ អំបិលដែលត្រូវតែអមដោយដង្វាយម្សៅ ត្រូវបានគេឱ្យឈ្មោះថា "អំបិលនៃសេចក្តីសញ្ញា" ។ ដោយយោងទៅតាម អគ ៤៣:២៤ អំបិលក៏ត្រូវបានគេបាចនៅលើដង្វាយដុត និង នក ៣០:៣៥ ដែលមានរៀបរាប់យ៉ាងពិស្តារថា អំបិលដូចជាគ្រឿងផ្សំម្យ៉ាងដាក់នៅក្នុងធូបពិសេសដែលលាយ

ជានិច្ច គឺជាសេចក្ដីសញ្ញាដែលតាំងឡើង ដោយសារ
អំបិល[ប]ដល់ឯងនឹងពូជឯងនៅចំពោះព្រះយេហូវ៉ា នៅអស់
កល្បជានិច្ច។

២០ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងអើរ៉ុនថា មិនត្រូវ
ឱ្យឯងមានកេរ្ដិ៍អាករ នៅក្នុងស្រុកគេឡើយ ក៏មិនត្រូវមាន
ចំណែកអ្វីជាមួយនឹងគេដែរ[ឪ] គឺអញជាចំណែកដល់ឯង
ហើយជាកេរ្ដិ៍អាកររបស់ឯង[ឮ] ក្នុងពួកកូនចៅអ៊ីស្រាអែល
វិញ ២១ឯពួកកូនចៅលេវី នោះអញបានឱ្យអស់ទាំង
ដង្វាយ ដែលពួកកូនចៅអ៊ីស្រាអែលថ្វាយ១ភាគក្នុង១០[ណ]
ទុកជាមរដក[ត]ដល់គេហើយ ដើម្បីឱ្យបានជាកំរៃនៃការងារ
ដែលគេធ្វើ គឺជាក្រសួងការរបស់ត្រសាលជំនុំ[ថ] ២២ដូច្នេះ
អំពីនេះទៅមុខ មិនត្រូវឱ្យពួកកូនចៅអ៊ីស្រាអែលចូលមក
ជិតត្រសាលជំនុំទៀតឡើយ ក្រែងលោគេធ្វើបាបអ្វី ហើយ
ត្រូវស្លាប់[ទ] ២៣គឺពួកលេវីវិញ ដែលធ្វើការងារក្នុងត្រសាល
ជំនុំ ហើយគេត្រូវតែរ៉ាប់រងសេចក្ដីកំហុសរបស់គេ នេះ
ជាបញ្ញត្តិច្បាប់ដ៏នៅអស់កល្បជានិច្ច[ធ] ដល់អស់ទាំងដំណ
ឯងរាល់គ្នាតរៀងទៅ[ន] តែគេគ្មានកេរ្ដិ៍អាករអ្វី[ប]នៅក្នុងពួក
កូនចៅអ៊ីស្រាអែលទេ[ផ] ២៤ដ្បិតអស់ទាំងដង្វាយ ដែលពួក
កូនចៅអ៊ីស្រាអែលថ្វាយ១ភាគក្នុង១០ដល់ព្រះយេហូវ៉ា[ព]
ទុកជាដង្វាយលើកចុះឡើង នោះអញបានឱ្យដល់ពួកលេវី
ទុកជាមរដកហើយ ហេតុនោះបានជាអញបានប្រាប់គេថា
គេគ្មានកេរ្ដិ៍អាករនៅក្នុងពួកអ៊ីស្រាអែលទេ ។

២៥ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២៦ឱ្យប្រាប់សេចក្ដី
១ទៀតដល់ពួកលេវីថា កាលណាឯងរាល់គ្នាទទួលយក
ដង្វាយ១ភាគក្នុង១០ ពីពួកកូនចៅអ៊ីស្រាអែល ដែលអញ
យកពីគេ ឱ្យដល់ឯងរាល់គ្នា[ភ]ទុកជាមរដក នោះឯងរាល់គ្នា
ត្រូវហូត១ភាគក្នុង១០ ពីដង្វាយ១ភាគក្នុង១០របស់គេ
ទុកជាដង្វាយលើកចុះឡើង ថ្វាយព្រះយេហូវ៉ា[ម] ២៧ដូច្នេះ
ដង្វាយដែលឯងថ្វាយដោយលើកចុះឡើងនោះ នឹងបាន
រាប់[យ]ទុកដូចជាស្រូវ ដែលទើបនឹងបញ្ជាន់នៅទីលាន[រ]
ហើយដូចជាទឹកទំពាំងបាយជូរ[ល] ដែលទើបនឹងគាបដែរ
២៨យ៉ាងនោះឯងរាល់គ្នាក៏នឹងបានថ្វាយដង្វាយលើកចុះ
ឡើងដល់ព្រះយេហូវ៉ា ពីដង្វាយ១ភាគក្នុង១០[វ] ដែលឯង
ទទួលពីពួកកូនចៅអ៊ីស្រាអែលដែរ ត្រូវឱ្យប្រគល់ដង្វាយ
លើកចុះឡើងផងព្រះយេហូវ៉ានោះ ដល់អើរ៉ុនដ៏ជាសង្ឃ
២៩ឯអស់ទាំងដង្វាយដែលឯងរាល់គ្នាទទួលនោះ ត្រូវឱ្យ
រើសយកចំណែកល្អបំផុត សំរាប់នឹងថ្វាយជាដង្វាយទាំង
ប៉ុន្មានរបស់ផងព្រះយេហូវ៉ា គឺជាចំណែកដែលបរិសុទ្ធក្នុង
ដង្វាយទាំងនោះ ៣០ដូច្នេះ ត្រូវឱ្យឯងប្រាប់គេថា បើ
កាលណាឯងរាល់គ្នារើសយកចំណែកល្អបំផុត ពីដង្វាយ
ទាំងនោះ ទៅថ្វាយជាដង្វាយលើកចុះឡើង នោះនឹងបាន
រាប់ទុកដូចជាផលចំរើន ដែលភ្ជាន់នៅទីលាន ហើយ
ដូចជាផលចំរើន ដែលគាបក្នុងឃ្នាបដល់ពួកលេវី ៣១ឯង
រាល់គ្នា ព្រមទាំងគ្រួសាររបស់ឯងផង និងបរិភោគរបស់
ទាំងនោះ នៅកន្លែងណាក៏បាន ដ្បិតជាកំរៃនៃការងារ
ដែលឯងធ្វើក្នុងត្រសាលជំនុំ[ហ] ៣២ដូច្នេះ កាលណាឯងរាល់
គ្នាបានថ្វាយចំណែកល្អបំផុត[ឡ] ជាដ្វាយលើកចុះឡើងហើយ
នោះមិនមានទោសដោយព្រោះរបស់ទាំងនោះទេ[អ] តែមិន
ត្រូវបង្អាប់ដល់ដង្វាយបរិសុទ្ធ[ក]របស់ពួកកូនចៅអ៊ីស្រាអែល
ឡើយ យ៉ាងនោះឯងរាល់គ្នាមិនត្រូវស្លាប់ទេ ។

## ទឹកសម្រាប់លាងសម្អាត

**១៩** ១ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិង
អើរ៉ុនថា ២នេះជាបញ្ញត្តិច្បាប់ដែលព្រះយេហូវ៉ាបាន
បង្គាប់មក គឺថា ចូរប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល ឱ្យគេ

**១៨:១៩** ប លវ ២:១៣ **១៨:២០** ឪ ជន ២៦:៦២ ចទ ១២:១២ ឋ ខ.២៤ ចទ ១០:៩ ១៤:២៧ ១៨:១–២ យស ១៣:៣៣ អគ ៤៤:២៨ **១៨:២១** ណ ខ.២៤ លប ២៨:២២ ជន ៣១:២៨ ចទ ១៤:២៨ ចទ ១៤:២២ នហ ១០:៣៧ ១៣:៥ មឡ ៣:៨ ត លវ ២៧:៣០–៣៣ ហព ៧:៥ ថ ជន ១:៥៣ **១៨:២២** ទ នក ២៨:៤៣ **១៨:២៣** ធ នក ១២:១៤ ២៧:២១ ន ជន ១០:៨ ប ខ.២០ ជន ២៦:៦២ ចទ ១០:៩ ផ អគ ៤៤:១០ **១៨:២៤** ព លវ ២៧:៣០ ចទ ២៦:១២ **១៨:២៦** ភ ខ.២១ ម ខ.២៨ នហ ១០:៣៨ **១៨:២៧** យ លវ ៧:១៨ រ លប ៥០:១០ ចទ ១៥:១៤ ពច ៦:៣៧ នរ ៣:៣,៦,១៤ ១សយ ២៣:១ ល ខ.១២,៣០

**១៨:២៨** វ មឡ ៣:៨ **១៨:៣០** ស ខ.២៧ **១៨:៣១** ហ ខ.២៣ **១៨:៣២** ឡ លវ ២២:១៥ អ ខ.២៩ ក លវ ១៩:៨

ចូលគ្នាសម្រាប់ដុតនៅក្នុងព្រះវិហារ ។ "សេចក្ដីសញ្ញាដែលតាំងឡើងដោយសារអំបិល គឺប្រហែលជាការសរសេរដល់អំបិល ដែលប្រើប្រាស់នៅក្នុងការដុតសាច់ថ្វាយយញ្ញបូជាព្រះជាធម្មតា ដែលអមដោយការបង្កើតឡើងនូវសេចក្ដីសញ្ញា (សូមមើល លប ៣១:៥៤ នក ២៤:៥–១១ ទដ ៥០:៥) ។

**១៨:២៦–៣២** ទោះបីជាពួកលេវីត្រូវបានតែងតាំងជាអ្នកទទួលនូវដង្វាយដប់ហូតមួយ ដែលបានថ្វាយដល់ព្រះអម្ចាស់ តែពួកគេត្រូវបានលើកលែងឱ្យរួចខ្លួនពីដង្វាយដប់ហូតមួយនេះ ។ ប៉ុន្តែពួកលេវីត្រូវថ្វាយដង្វាយលើកចុះឡើងដល់ព្រះយេហូវ៉ាពីដង្វាយ១ភាគ១០ ប្រគល់ដល់អើរ៉ុន (ខ.២៨) ដើម្បីបញ្ជាក់ថា ជាផ្នែកដ៏ល្អបំផុតត្រូវបានថ្វាយជាចំណែករបស់ព្រះអម្ចាស់ (ខ.២៩) ។ ដោយការប្រព្រឹត្តតាមពោរពេញទៅដោយការស្ដាប់បង្គាប់ពួកលេវីអាចនឹងគេចផុតពីការវិនិច្ឆ័យទោសដល់ស្លាប់បាន (ខ.៣២) ។

**១៩:២** *គោក្រហមុំ១សម្បុរទង់ដែង* ជាពាក្យដែលប្រកបដោយលក្ខណៈសម្បត្តិល្អ "ដោយឥតខ្ចោះ ឬមិនអាចរកចាប់កំហុសបាន" ដែលប្រហាក់ប្រហែលទៅនឹងបរិបទនៃការថ្វាយបង្ហុំដោយយញ្ញ នាជំនាន់នៃសញ្ញាចាស់ ។ ក៏ប៉ុន្តែ នេះមិនមែនជាសត្វដែលបូជាយញ្ញឡើយ វាគឺជាគោញីមួយមិនមែនជាគោឈ្មោលឡើយ វាត្រូវបានគេសម្លាប់ មិនមែនបូជាយញ្ញឡើយ ហើយវាត្រូវបានគេសម្លាប់នៅក្រៅត្រសាល មិនមែននៅត្រង់កន្លែងអាសនាឡើយ រីឯផេះរបស់គោក្រមុំសម្បុរទង់ដែងនោះ (ខ.៩) គឺជាចំណុចរួមជាដំបូងចំពោះការនេះ ចំពោះផេះនោះត្រូវបានគេប្រើប្រាស់នៅក្នុងពិធីញែកខ្លួនឱ្យបរិសុទ្ធដោយទឹកក្នុងការសម្អាតឱ្យបានស្អាត ។ ការដុតបូជាសត្វឱ្យឆេះទាំងឈាម និងគ្រឿងក្នុងរបស់វាទាំងអស់ (ខ.៥) ដែលពុំធ្លាប់មានពីមុនមកនៅ

យកគោក្រមុំ១សម្បុរទង់ដែង[ក] ឥតមានស្លាកស្នាម ឥត
ខ្ចោះ[ខ] ដែលមិនទាន់ទឹមនៅឡើយ[គ] ៣នាំវាមកប្រគល់ឱ្យ
អេលាសារ[ឃ]ដ៏ជាសង្ឃ ត្រូវឱ្យលោកនាំយកទៅខាងក្រៅទី
ដំឡើងត្រសាល[ង] រួចត្រូវឱ្យគេសំឡាប់គោនោះ នៅមុខ
លោក ៤ហើយអេលាសារដ៏ជាសង្ឃ លោកត្រូវយក
ឈាមដោយម្រាមដៃ ទៅប្រោះ[ច]៧ដងនៅខាងមុខត្រសាល
ជំនុំ ៥រួចត្រូវឱ្យគេដុតគោនោះនៅមុខលោក ទាំងស្បែក
ទាំងសាច់ ទាំងឈាម និងលាមកផង[ឆ] ៦ត្រូវឱ្យសង្ឃយក
ឈើតាត្រៅ មែកហ៊ីសុប[ជ] និងសំពត់ពណ៌ក្រហម[ឈ] បោះ
ទៅក្នុងភ្លើងដែលកំពុងបញ្ឆេះគោនោះ ៧រួចត្រូវឱ្យសង្ឃ
បោកសំលៀកបំពាក់ខ្លួន ហើយងូតទឹកចេញ[ញ] ក្រោយមក
ទើបនឹងចូលទៅក្នុងទីដំឡើងត្រសាលវិញបាន តែនឹងនៅ
ជាមិនស្អាតរហូតដល់ល្ងាច ៨ឯអ្នកដែលបានដុតគោនោះ
ត្រូវបោកសំលៀកបំពាក់ខ្លួន ហើយងូតទឹកចេញ រួចនៅជា
មិនស្អាតរហូតដល់ល្ងាចដែរ ៩នោះត្រូវឱ្យម្នាក់ដែលស្អាត
ចេញទៅកើបផេះគោនោះ[ដ] យកទៅដាក់ទុកនៅកន្លែង
ស្អាត[ឋ] ខាងក្រៅទីដំឡើងត្រសាល ផេះនោះត្រូវទុកសំរាប់
ពួកកូនចៅអ៊ីស្រាអែល ដើម្បីនឹងធ្វើជាទឹកញែកជាស្អាត[ឌ]
នេះគឺជាដង្វាយលោះបាប[ឍ] ១០ឯអ្នកដែលបានកើបផេះគោ
នោះ[ណ] ត្រូវឱ្យបោកសំលៀកបំពាក់ខ្លួន ហើយនៅជាមិន
ស្អាតរហូតដល់ល្ងាច[ត] នេះហើយជាច្បាប់នៅអស់កល្ប
ជានិច្ច[ថ] សំរាប់ពួកកូនចៅអ៊ីស្រាអែល និងពួកអ្នកប្រទេស
ក្រៅដែលនៅជាមួយនឹងគេដែរ[ទ] ។
១១បើអ្នកណាពាល់ខ្មោច របស់មនុស្សណាដែលស្លាប់[ធ]
នោះត្រូវរាប់ជាមិនស្អាត់អស់៧ថ្ងៃ[ន] ១២ត្រូវឱ្យអ្នកនោះយក
ទឹកនេះមកសំអាតខ្លួននៅថ្ងៃទី៣ រួចដល់ថ្ងៃទី៧[ប]ទើបនឹង
បានស្អាត តែបើមិនបានសំអាតខ្លួននៅថ្ងៃទី៣ទេ នោះដល់
ថ្ងៃទី៧មិនបានរាប់ជាស្អាតដែរ[ផ] ១៣ឯអ្នកណាដែលពាល់
ខ្មោចរបស់មនុស្សស្លាប់[ព] ហើយមិនសំអាតខ្លួនចេញ នោះ
ឈ្មោះថាធ្វើបង្អាប់ដល់រោងឧបោសថផងព្រះយេហូវ៉ា[ភ]
អ្នកនោះឯងនឹងត្រូវកាត់កាល់ពីសាសន៍អ៊ីស្រាអែលចេញ[ម]
ពីព្រោះទឹកដែលញែកជាស្អាតមិនបានប្រោះទៅលើខ្លួន
ឡើយ អ្នកនោះមិនស្អាតទេ[យ] ដ្បិតសេចក្តីសៅហ្មងរបស់អ្នក
នោះនៅជាប់នឹងខ្លួននៅឡើយ ។
១៤បើកាលណាមនុស្សម្នាក់ស្លាប់ នៅក្នុងត្រសាលនេះ
មានច្បាប់ដូច្នេះ គឺអស់អ្នកណា ដែលចូលទៅក្នុង
ត្រសាលនោះ នឹងអស់អ្នកដែលអាស្រ័យនៅក្នុងត្រសាល
នោះ ត្រូវរាប់ជាមិនស្អាតអស់៧ថ្ងៃ ១៥ហើយគ្រប់ទាំង
ឆ្នាំងចំហ[រ] ដែលគ្មានគ្របចងភ្ជាប់ នោះក៏ត្រូវរាប់ជាមិន
ស្អាតដែរ ១៦ឯអ្នកណាដែលពាល់ដល់មនុស្ស ដែលត្រូវគេ
សំឡាប់នឹងដាវចោលនៅវាល[ល] ឬខ្មោចណា ឬឆ្អឹងខ្មោច[វ]
ឬផ្នូរក្តី[ស] នោះត្រូវរាប់ជាមិនស្អាតអស់៧ថ្ងៃ[ហ] ១៧ដូច្នេះ ត្រូវ
ឱ្យគេយកផេះ[ឡ]ដង្វាយលោះបាប ដែលបានដុតនោះទៅ
ដាក់ក្នុងផើង រួចចាក់ទឹក[អ]សំរាប់ដល់មនុស្សមិនស្អាតនោះ
១៨រួចមនុស្សស្អាតម្នាក់ ត្រូវយកមែកហ៊ីសុបជ្រលក់ចុះ[ក] ក្នុង
ទឹកនោះ ទៅរលាស់[ខ]លើត្រសាល និងប្រដាប់ប្រដាទាំង
ប៉ុន្មាន ហើយលើអស់មនុស្ស ដែលនៅក្នុងត្រសាលនោះ

**១៩:២** ក លប ១៥:៩ ហាព ៩:១៣ ខ លវ ២២:១៩–២៥ គ ចទ ២១:៣ ១សយ ៦:៧ **១៩:៣** ឃ ជន ៣:៤ ង នក ២៩:១៤ **១៩:៤** ច លវ ៤:១៧ **១៩:៥** ឆ នក ២៩:១៤ **១៩:៦** ជ ខ.១៨ ទដ ៥១:៧ ឈ លវ ១៤:៤ **១៩:៧** ញ លវ ១១:២៥ ១៤:៨ **១៩:៩** ដ ហាព ៩:១៣ ឋ នក ២៩:៣១ លវ ៤:២១ ឌ ខ.១៣ ជន ៨:៧ ឍ លវ ៣៥:២ **១៩:១០** ណ លវ ១៥:១០ ត លវ ១៤:៤៦ ថ លវ ៣:១៧ ទ លវ ២២:១៨ **១៩:១១** ធ លវ ២១:១ ន លវ ៨:៣៣ ជន ៣១:១៩ **១៩:១២** ប ខ.១៩ ជន ៣១:១៩ ផ ខ.២០ ២របា ២៦:២១ **១៩:១៣** ព លវ ២១:១១ ភ លវ ១៥:៣១ ២រប ៣៦:១៤ ទដ ៧៩:១ ម លវ ៧:២០ ២២:៣ យ ខ.២២ ហក ២:១៣ **១៩:១៥** រ លវ ៦:២៨ **១៩:១៦** ល ជន ៣១:១៩ វ ១ពវ ១៣:២ ២ពវ ២៣:១៤ អគ ៦:៥ ស ២ពវ ២៣:៦ មថ ២៣:២៧ ហ លវ ៥:៣ **១៩:១៧** ឡ ខ.៩ អ ជន ៨:៧ **១៩:១៨** ក ខ.៦ នក ១២:២២ ខ លវ ៤:១៧

ក្នុងជំនាន់សញ្ញាចាស់ ។ ទៅតាមគំរូធម្មតា សម្រាប់ការធ្វើយញ្ញបូជានៃដង្វាយដុត ត្រូវបានរៀបរាប់នៅក្នុង លវ ១:៣–៩ ។ នៅក្នុងការគោរពនីមួយៗ ការសម្លាប់គោក្រមុំសម្បុរទង់ដែង ដែលមានលក្ខណៈផ្សេងគឺសត្វណាជាសត្វញី ត្រូវបានគេនាំយកទៅសម្លាប់នៅខាងក្រៅជំរុំ រីឯពួកសង្ឃត្រូវមានវត្តមាននៅទីនោះ តែមិនចូលរួមក្នុងការសម្លាប់គោនោះឡើយ ម្យ៉ាងវិញទៀតពួកសង្ឃទាំងនោះត្រូវយកឈាមរបស់មេគោក្រហមនោះទៅប្រោះដោយម្រាមដៃរបស់ខ្លួននៅជុំវិញលើអាសនានោះគំរប់ ៧ ដង ចំណែកឯសត្វផ្សេងទៀត ត្រូវបានគេយកទៅដុតទាំងមូល ដោយមិនមានការចាក់កបង្ហូរឈាម ឬលាងសម្អាតអាការៈខាងក្នុងរបស់សត្វនោះឡើយ ។

**១៩:៦** *ឈើតាត្រៅ មែកហ៊ីសុប និងសំពត់ពណ៌ក្រហម* ក៏មានជាប់ទាក់ទងទៅនឹងការសម្អាតរបស់របរនៃផេះរបស់គោញីពណ៌ក្រហមនោះ ។

**១៩:១២** *យកទឹកនេះមកសម្អាតខ្លួន* ផេះដែលបានមកពីគោក្រមុំសម្បុរទង់ដែង ត្រូវបានរក្សាទុកនៅខាងក្រៅត្រសាល ហើយត្រូវបានគេយកទៅដាក់លាយជាមួយនឹងទឹក ដើម្បីផ្តល់ជាមធ្យោបាយនៃការសម្អាត បន្ទាប់ពីពាល់ខ្មោចស្លាប់ ។

**១៩:១៣** *ធ្វើបង្អាប់ដល់រោងឧបោសថផងព្រះយេហូវ៉ា* ការធ្វេសប្រហែសដែលធ្វើតាមតែចិត្តចំពោះការដែលបម្រុងទុកសម្រាប់ការលាងសម្អាត ដែលនាំឱ្យមិនត្រឹមតែការដាក់ទោសទៅលើជននោះទេ ក៏ប៉ុន្តែការធ្វើឱ្យអាប់ឱនដល់រោងឧបោសថរបស់ខ្លួនទៀតផង ។ *ត្រូវកាត់ចេញពីសាសន៍អ៊ីស្រាអែល* សូមមើលការពន្យល់នៅ នក ១២:១៥ ។

**១៩:១៤** *អស់អ្នកដែលអាស្រ័យនៅក្នុងត្រសាលនោះ* អាចនឹងមានឱកាសជាច្រើន ដែលមនុស្សនឹងទៅជាមិនស្អាតនាពេលនោះ មិនមែនដោយព្រោះតែការប៉ះពាល់ទៅលើសពមនុស្សស្លាប់នោះទេ ប៉ុន្តែគ្រាន់តែស្ថិតក្នុងសភាពជាប់ជាសាច់ញាតិសន្តានរបស់បុគ្គលដែលបានស្លាប់ទៅនោះ ។

**១៩:១៨** *មែកហ៊ីសុបជ្រលក់ចុះក្នុងទឹកនោះ ទៅរលាស់លើត្រសាល* នៅត្រង់ខនេះវិធីសាស្ត្រនៃពិធីលាងសម្អាតដោយញែកខ្លួនឱ្យបានបរិសុទ្ធត្រូវបានគេពន្យល់ប្រាប់ ។ ពិធីលាងសម្អាតមនុស្ស ត្រូវតែធ្វើឡើងដោយរលាស់ទឹកទៅលើមនុស្ស ឬ វត្ថុណា ដែលមិនទាន់បាននៅឡើយ ។ អំណាចចេស្តានៃការសម្អាត ដោយព្រះលោហិតនៃព្រះគ្រីស្ទ ដែលមានលក្ខណៈ

និងលើអ្នកដែលបានពាល់ឆ្អឹងខ្មោច ឬមនុស្សដែលគេ
សំឡាប់ ឬខ្មោចណា ឬផ្នូរក្ដី[គ] ១៩ត្រូវឱ្យមនុស្សស្អាតនោះឯង
ប្រោះ[ឃ]ទៅលើមនុស្សមិនស្អាតនៅថ្ងៃទី៣ ហើយនៅថ្ងៃទី៧
ទៀត រួចនៅថ្ងៃទី៧ នោះត្រូវញែកអ្នកនោះចេញជាស្អាត[ង]
ត្រូវឱ្យខ្លួនអ្នកនោះបោកសំលៀកបំពាក់[ច] ហើយងូតទឹក
ចេញរួចដល់ល្ងាចនឹងបានស្អាតវិញ ។
២០បើមនុស្សណាដែលមិនស្អាត មិនបានញែកខ្លួនចេញ
ជាស្អាត អ្នកនោះត្រូវកាត់កាល់ពីពួកជំនុំចេញ ដ្បិតបានធ្វើ
បង្អាប់[ឆ]ដល់ទីបរិសុទ្ធផងព្រះយេហូវ៉ាហើយ[ជ] អ្នកនោះនៅ
ជាមិនស្អាតនៅឡើយ ពីព្រោះទឹកដែលញែកជាស្អាត មិន
បានប្រោះទៅលើខ្លួន[ឈ] ២១នេះត្រូវបានជាបញ្ញត្តិច្បាប់ដល់
គេនៅអស់កល្បជានិច្ច[ញ] ឯអ្នកដែលបានប្រោះទឹកដ៏
ញែកជាស្អាតនោះ ត្រូវឱ្យអ្នកនោះបោកសំលៀកបំពាក់ខ្លួន
ចេញ ហើយអ្នកណាដែលគ្រាន់តែពាល់ទឹកនោះ ក៏ត្រូវ
រាប់ជាមិនស្អាតរហូតដល់ល្ងាចដែរ ២២ហើយគ្រប់ទាំង
អស់ ដែលមនុស្សមិនស្អាត[ដ]នឹងប៉ះពាល់ ក៏ត្រូវរាប់ជា
មិនស្អាតដែរ ឯអ្នកណាដែលប៉ះពាល់ដល់របស់ណា នោះ
ក៏ត្រូវរាប់ជា មិនស្អាតរហូតដល់ល្ងាច ។

**ទឹកចេញពីថ្ម**

**២០** ១រីឯពួកកូនចៅអ៊ីស្រាអែល គឺជាពួកជំនុំទាំងអស់គ្នា
ក៏មកដល់ទីរហោស្ថានស៊ីន[ក] នៅខែចេត្រ ហើយអាស្រ័យ
នៅត្រង់កាដេស[ខ] ឯម៉ារាម[គ]នាងក៏ស្លាប់ ហើយគេបញ្ចុះ
សពនាងនៅទីនោះទៅ ។
២កន្លែងនោះគ្មានទឹក[ឃ]ឱ្យពួកជំនុំផឹកសោះ[ង] ដូច្នេះគេក៏
មូលគ្នាមកទាស់[ច]នឹងម៉ូសេ ហើយនិងអើរ៉ុន ៣គេរករឿង
ឈ្លោះ[ឆ]នឹងម៉ូសេថា ស៊ូឱ្យយើងរាល់គ្នាបានស្លាប់[ជ]ក្នុងកាល
ដែលបងប្អូនយើងស្លាប់ នៅចំពោះព្រះយេហូវ៉ានោះចុះ[ឈ]
៤ហេតុអ្វីបានជាលោកនាំពួកជំនុំផងព្រះយេហូវ៉ាមកក្នុងទី
រហោស្ថាន[ញ] ឱ្យយើងត្រូវស្លាប់នៅទីនេះ ព្រមទាំងហ្វូងសត្វ
របស់យើងផងដូច្នេះ[ដ] ៥ម្ដេចក៏លោកបាននាំយើងរាល់គ្នា
ចេញពីស្រុកអេស៊ីព្ទមក ក្នុងទីហិនហោចនេះធ្វើអីទីនេះមិន
មែនជាកន្លែងដែលនឹងសាបព្រោះទៅបាន ឬដែលមាន
ល្វា មានទំពាំងបាយជូរ ឬទទឹមទេ[ឋ] សូម្បីតែទឹកផឹកក៏គ្មាន
ផង[ឌ] ៦ឯម៉ូសេ និងអើរ៉ុន ក៏ចេញពីពួកជំនុំទៅឯមាត់ទ្វារ
ត្រសាលជំនុំ[ឍ] ទំលាក់ខ្លួនក្រាបផ្កាប់មុខចុះ[ណ] នោះសិរីល្អនៃ
ព្រះយេហូវ៉ា[ត]លេចមកឱ្យឃើញ ៧ហើយទ្រង់មានបន្ទូលនឹង
ម៉ូសេថា ៨ចូរយកដំបងរបស់ឯង[ថ] ហើយប្រជុំពួកជំនុំទៅ គឺ
ឯង និងអើរ៉ុនជាបងឯងផង រួចបង្គាប់ដល់ថ្មដានៅមុខគេ
ឱ្យមានទឹកចេញមកចុះ[ទ]នោះឯងនឹងបាននាំទឹកឱ្យចេញពីថ្ម

**១៩:១៨** គ ខ.១៦ **១៩:១៩** ឃ លវ ១៦:១៤–១៥ ង ជន ៣១:១៩ អគ ៣៦:២៥ ហព ១០:២២ ច លប ៣៥:២ **១៩:២០** ឆ ទដ ៧៤:៧ ជ លវ ១៥:៣១ ឈ ខ.១២ លវ ១៤:៨ **១៩:២១** ញ នក ២៧:២១ **១៩:២២** ដ លវ ៥:២ ១៥:៤–១២ **២០:១** ក ជន ១៣:២១ ខ ខ.១៤ ជន ១៣:២៦ ៣៣:៣៦ ចទ ១:៤៦ ពច ១១:១៧ ទដ ២៩:៨ គ នក ១៥:២០ **២០:២** ឃ នក ១៥:២២ ង នក ១៧:១ ច ជន ១៦:១៩ **២០:៣** ឆ ខ.១៣ លប ១៣:៧ នក ១៧:២ ២១:១៨ ជ នក ៥:២១ ឈ ជន ១៤:២ ១៦:៣១–៣៥ **២០:៤** ញ ជន ១៤:២ ដ នក ១៤:១១ ជន ១៤:៣ ១៦:១៣ **២០:៥** ឋ ជន ១៣:២៣ ១៦:១៤ ឌ នក ១៧:១ **២០:៦** ឍ នក ៤០:២ត ជន ណ ជន ១៤:៥ ១៦:១៩ **២០:៨** ថ នក ៤:២ ១០:១២–១៣ ទ នក ១៧:៦ អស ៤១:១៨ ៤៣:២០ យរ ៣១:៩

ផ្ទុយគ្នាជាពិសេស ("ច្រើនជាង" ហព ៩:១៣–១៤) ដែលប្រកបទៅដោយប្រសិទ្ធិភាពនៅក្នុងការសម្អាត ដោយទឹកនៃផេះរបស់គោក្រមុំសម្បុរទង់ដែង ។

**២០:១–២៩** ជំពូកនេះចាប់ឡើងដោយមរណភាពរបស់ម៉ារាម (ខ.១) ហើយធ្វើសេចក្ដីសន្និដ្ឋានដោយមរណភាពរបស់អើរ៉ុន (ខ.២៨) ដោយរួមទាំងកំណត់ត្រាស្ដីពីជម្លោះជាមួយនឹងសាសន៍អេដំម(ខ.១៤–២១) ហើយនិងស្ថិតនៅចំកណ្ដាលអំពើបាបប្រកបដោយទុក្ខភ័យរបស់លោកម៉ូសេ (ខ.១១–១២) ។ ដូចជាការកើតទុក្ខព្រួយ ដែលនៅពីកាលដើមដំបូងនៃឆ្នាំកន្លងទៅរបស់ពួកកូនចៅអ៊ីស្រាអែលនៅក្នុងទីរហោស្ថានមកម្ល៉េះ ។

**២០:១** *ខែចេត្រ* ឆ្នាំមិនត្រូវបានគេផ្ដល់ឱ្យឡើយ ប៉ុន្តែការប្រៀបធៀបមួយនៅ ខ.២២–២៩ មានបង្ហាញប្រាប់នៅក្នុងជំពូក ៣៣:៣៨ នាំទៅរកសេចក្ដីសន្និដ្ឋាន ដែលនៅក្នុងជំពូកនេះ ចាប់ផ្ដើមឡើងនៅឆ្នាំទី៤០ បន្ទាប់ពីការបម្លាស់ទី (សូមមើលការពន្យល់នៅ ១:១ ៩:១) ។ មនុស្សភាគច្រើនដែលមានអាយុ២០ ឬលើសពីនោះទៀត នាពេលដែលមានការបះបោរនៅឯកាដេស (ជំពូក ១៣–១៤) ដែលនឹងត្រូវបានស្លាប់រួចជាស្រេចទៅហើយ ។ *នៅត្រង់កាដេស* សូមមើលការពន្យល់នៅ លប ១៤:៧ ។ គឺជាទីរហោស្ថានមួយ ដែលមានផ្ទៃធំទូលាយ ដោយបានដើរវង្វេងនៅទីនោះ (សូមមើល ៣២:១៣) ត្រូវបានចាកចេញទៅដោយគ្មានការកត់ត្រាទុក ។ មនុស្សផងទាំងឡាយប្រហែលជាអាចធ្វើដំណើរទៅក្បែរកន្លែងនោះ ដើម្បីស្វែងរកប្រភពទឹក និងគុម្ពរុក្ខជាតិ ក្នុងការទទួលទាននំម៉ាន៉ា ដែលព្រះបានប្រទានឱ្យជាមុនដំបូងនោះ ។ ប៉ុន្តែដំណើរវិលវល់របស់ពួកគេទាំងនោះបាននាំពួកគេឱ្យធ្វើដំណើរត្រឡប់មកឯកណ្ដាលត្រសាលនៅត្រង់កាដេស ទិដ្ឋភាពនេះបង្ហាញពីការបះបោរដ៏ខ្លាំងក្រៃលែងរបស់ពួកគេទាំងនោះ (ជំពូក១៣–១៤) ។ ពួកមនុស្សទាំងនោះបានដើរព័ទ្ធមួយជុំពេញតែម្ដង ដែលទឹកដីសន្យានោះស្ថិតនៅចំពោះមុខគេជាថ្មីម្ដងទៀត ។

**២០:២** *គ្មានទឹក* ៤០ឆ្នាំមុននេះ ព្រះអម្ចាស់បានធ្វើការណែនាំលោកម៉ូសេឱ្យយកដំបង ដែលគាត់ធ្លាប់បានប្រើប្រាស់នោះទៅវាយទន្លេនីល (មើល នក ៧:១៧) ។ ៤០ឆ្នាំក្រោយមកទៀត និងបច្ចុប្បន្ននេះ ពួកកូនចៅអ៊ីស្រាអែលនៅតែប្រព្រឹត្តអំពើរំលងដដែលៗ ។ រីឯពួកកូនចៅនៃប្រជាជាតិ ដែលបះបោរបច្ចុប្បន្ននេះមានបំណងប្រាថ្នាសុខចិត្តស្លាប់ជាមួយនឹងម្ដាយឪពុករបស់ពួកគេ ចំណែកឯម្ដាយឪពុករបស់ពួកគេបានតវ៉ាពីរឿងនំម៉ាន៉ា ដែលធ្លាក់ពីលើមេឃមក ហើយក៏ត្រូវបានបន្តការទាមទារនេះមកដល់កូនចៅរបស់ពួកគេតទៅទៀត ។

**២០:៦** *សិរីល្អនៃព្រះយេហូវ៉ា* សូមមើលការពន្យល់នៅ នក ១៦:៧ ។

**២០:៨** *បង្គាប់ដល់ថ្មដា* លោកម៉ូសេត្រូវបានប្រាប់ឱ្យយកដំបងរបស់គាត់ តាមរយៈដំបងនោះ ដែលព្រះទ្រង់បានបង្កើតការអស្ចារ្យនៅស្រុកអេស៊ីព្ទ និងនៅក្នុងទីរហោស្ថាននាអំឡុងប៉ុន្មានឆ្នាំនេះ ក៏ប៉ុន្តែនៅពេលនេះគាត់គ្រាន់តែនិយាយបង្គាប់ទៅថ្មដានោះ ហើយទឹកក៏ហូរចេញមកក្រោសម្រាប់ឱ្យហ្វូង

មកឱ្យគេហើយ ដូច្នេះ ឯងនឹងឱ្យពួកជំនុំ ព្រមទាំងហ្វូងសត្វ
គេផឹកបាន ៩ម៉ូសេក៏យកដំបង[ធ]ពីចំពោះព្រះយេហូវ៉ា[ន] ដូច
ជា ទ្រង់បានបង្គាប់មក ១០រួចលោក និងអើរ៉ុន ក៏ប្រមូលពួក
ជំនុំ[ប] មកនៅមុខថ្មដា ដោយពាក្យថា ចូរស្តាប់ចុះ ពួក
បះបោរអើយ តើត្រូវឱ្យយើងធ្វើឱ្យទឹកចេញពីថ្មដានេះ
សំរាប់អ្នករាល់គ្នាឬអី[ផ] ១១រួចម៉ូសេលើកដៃឡើងវាយថ្ម
នោះ ដោយដំបងអស់២ដង នោះក៏មានទឹក[ព]ហូរចេញមក
ជាបរិបូរ ឯពួកជំនុំ និងហ្វូងសត្វគេ ក៏នាំគ្នាផឹកទៅ ។
១២តែព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនឹង
អើរ៉ុនថា ពីព្រោះឯងមិនបានជឿអញ ដើម្បីនឹងលើកអញ
ជាបរិសុទ្ធ[ភ] ចំពោះភ្នែកនៃពួកកូនចៅអ៊ីស្រាអែលដូច្នេះ
បានជាឯងនឹងនាំពួកជំនុំនេះចូលទៅក្នុងស្រុក ដែលអញឱ្យ
ដល់គេពុំបានឡើយ[ម] ១៣ទឹកនោះជាទឹកមេរីបា[យ] ពីព្រោះ
ពួកកូនចៅអ៊ីស្រាអែលបានរករឿង[រ]នឹងព្រះយេហូវ៉ា
ហើយទ្រង់បានសំដែងសេចក្តីបរិសុទ្ធរបស់ទ្រង់ ដោយសារ
ទឹកនោះឯង[ល] ។

## ស្រុកអេដំមមិនឱ្យពួកអ៊ីស្រាអែលឆ្លងកាត់

១៤ម៉ូសេក៏ចាត់សារពីកាដេស[វ]ទៅឯស្តេចស្រុកអេដំម[ស]
ទូលថា អ៊ីស្រាអែលជាប្អូនទ្រង់មានវាចាដូច្នេះថា ទ្រង់
ជ្រាប[ហ]ចំពោះការនឿយហត់[ឡ] ដែលកើតមកដល់យើងខ្ញុំ
រាល់គ្នាហើយ ១៥គឺដែលពួកឰយុកោយើងខ្ញុំបានចុះទៅនៅ
ស្រុកអេស៊ីព្ទ[អ] ហើយយើងខ្ញុំក៏បាននៅស្រុកនោះជាយូរ
ឆ្នាំដែរ[ក] ឯពួកសាសន៍អេស៊ីព្ទគេបានធ្វើបាប[ខ]ដល់យើងខ្ញុំ
និងពួកឰយុកោយើងខ្ញុំផង ១៦តែកាលយើងខ្ញុំបានអំពាវ
នាវដល់ព្រះយេហូវ៉ា នោះទ្រង់ក៏ឮសំឡេងយើងខ្ញុំ[គ] ហើយ
ទ្រង់ចាត់ទេវតា១មក[ឃ] នាំយើងខ្ញុំចេញពីស្រុកអេស៊ីព្ទមក[ង]
ឥឡូវនេះ មើល យើងខ្ញុំនៅត្រង់កាដេស ជាទីក្រុងនៅចុង
ព្រំស្រុករបស់ទ្រង់[ច] ១៧ដូច្នេះសូមអនុញ្ញាត ឱ្យយើងខ្ញុំដើរ
កាត់ស្រុករបស់ទ្រង់ផង យើងខ្ញុំនឹងមិនដើរកាត់ស្រែឬ
ចំការទេ ក៏មិនផឹកទឹកអណ្តូងដែរ គឺយើងខ្ញុំនឹងដើរតាមតែ
ផ្លូវថ្នល់របស់ស្តេចវិញ ឥតមានបែរទៅខាងស្តាំឬខាង
ឆ្វេងឡើយ ទាល់តែបានឆ្លងហួសពីព្រំដែនទ្រង់ទៅ[ឆ] ១៨តែ
ស្តេចស្រុកអេដំម[ជ]មានបន្ទូលតបថា មិនត្រូវឱ្យឯងដើរកាត់
ស្រុករបស់យើងឡើយ បើធ្វើដូច្នោះ នោះយើងនឹងយកដាវ
ចេញមកច្បាំងនឹងឯងហើយ[ឈ] ១៩ពួកកូនចៅអ៊ីស្រាអែលគេ
អង្វរថា យើងខ្ញុំរាល់គ្នានឹងគ្រាន់តែដើរតាមថ្នល់ធំទេ បើ

**២០:៩** ធ ជន ១៧:២ ន ជន ១៧:១០ **២០:១០** ប ខ.៨ ផ ទដ ១០៦:៣២,៣៣ **២០:១១** ព នក ១៧:៦ អស ៣៣:២១ **២០:១២** ភ ជន ២៧:១៤ ចទ ៣២:៥១ អស ៥:១៦ ៨:១៣ ម ខ.២៤ ចទ ១:៣៧ ៣:២៧ **២០:១៣** យ នក ១៧:៧ រ ខ.៣ ល លវ ១០:៣ **២០:១៤** វ ខ.១ ស ខ.១៦ លប ២៥:៣០ ៣៦:១៦ ហ លប ២៤:៣ ចទ ៤:៣៩ យស ២:១១ ៩:៩ ឡ នក ១៨:៨ **២០:១៥** អ លប ៤៦:៦ ក លប ១៥:១៣ ខ នក ១:១៤ **២០:១៦** គ លប ១៦:១១ ២១:១៧ នក ២:២៣ ឃ នក ១៤:១៩ ង នក ១២:៤២ ចទ ២៦:៨ ច ខ.១៤,២៣ ជន ៣៣:៣៧ **២០:១៧** ឆ ខ.២០ ជន ២១:២២ ចទ ២:២៧ ពច ១១:១៧ **២០:១៨** ជ ខ.១៤ ឈ ជន ២១:២៣

មនុស្សបានផឹក ។ សូមមើលខប្រៀបធៀប ទដ ១១៤:៨ និងការពន្យល់ ។

**២០:១០** *ចូរស្តាប់ចុះ ពួកបះបោរអើយ* នៅពេលមួយនោះ កំហឹងបានកើនឡើង សេចក្តីក្រេវក្រោធ និងសេចក្តីរសាយចិត្តក្នុងរវាង ៤០ឆ្នាំក៏លេចចេញឡើងនូវការសម្តែងដោយព្រះហឫទ័យអាណិតអាសូរមកវិញ (សូមមើល ទំនុកដំកើង ១០៦:៣៣ និងការពន្យល់) ។

**២០:១១** *លើកដៃឡើងវាយថ្មនោះ ដោយដំបងអស់២ដង* នៅក្នុងការបង្គាប់របស់គាត់ទៅថ្មដានោះ (ខ.៨) ។ ដោយសារតែលោកម៉ូសេមានសកម្មភាពស្ទុះស្ទាយ៉ាងដូច្នេះ ព្រះអម្ចាស់ក៏បានធ្វើកាស្ត្របន្ទោសគាត់ជាខ្លាំង (ខ.១២) និស្ស័យរបស់លោកម៉ូសេ ដែលបានប្រព្រឹត្តខុសឆ្គងនោះ មិនមានបង្ហាញប្រាប់ច្បាស់នៅក្នុងខគម្ពីរនោះទេ ប៉ុន្តែសារៈសំខាន់បំផុតចុងនោះបានលេចចេញ ដោយមានជាប់ពាក់ព័ន្ធដូចជាៈ(១)សកម្មភាពរបស់លោកម៉ូសេ មានចំណុចខ្វះខាតជំនឿរឹងមាំលើព្រះអម្ចាស់ (ខ.១២) ថ្វីបើគាត់បានជឿថាត្រឹមតែពាក្យមួយគត់នោះមិនគ្រប់គ្រាន់ឡើយ ។ (២)ភាពបរិសុទ្ធរបស់ផងព្រះត្រូវបាន ព្រះទ្រង់មានការអាក់អន់ព្រះទ័យចំពោះអំពើប្រញាប់ប្រញាល់របស់លោកម៉ូសេ (ខ.១២) ដោយសារតែគាត់មិនបានគោរពដល់ព្រះវត្តមានរបស់ផងព្រះឱ្យបានត្រឹមត្រូវសោះឡើយ ។

**២០:១២** *ដើម្បីនឹងលើកអញជាបរិសុទ្ធ* សូមមើលការពន្យល់នៅ លវ ១១:៤៤ ។ *បានជាឯងនឹងនាំពួកជំនុំនេះចូលទៅក្នុងស្រុក . . . ពុំបានឡើយ* លទ្ធផលចុងបញ្ចប់នៃសកម្មភាពរបស់លោកម៉ូសេ គឺវាប្រាកដណាស់ៈ ទាំងលោកអើរ៉ុន និងលោកម៉ូសេ មិនបានចូលទៅក្នុងទឹកដីសន្យាឡើយ ។ ចំពោះជំនាន់របស់ពួកគេទាំងនោះ គឺបានត្រឹមតែ លោកយ៉ូស្វេ និងកាលែបប៉ុណ្ណោះទេ ដែលអាចនឹងនៅរស់មានជីវិតបានចូលទៅក្នុងទឹកដីសន្យា ។ រាប់បញ្ចូលទាំងអើរ៉ុនផងដែរ បង្ហាញប្រាប់នូវភាពជាដៃគូរបស់គាត់ជាមួយនឹងបងប្អូនរបស់គាត់នៅក្នុងការវិវាទគ្នាប្រឆាំងទាស់នឹងភាពបរិសុទ្ធរបស់ព្រះ ។

**២០:១៣** *មេរីបា* សូមមើលសេចក្តីពន្យល់អត្ថបទ គម្ពីរសញ្ញាថ្មី ។ មានឈ្មោះតែមួយដូចគ្នា ដែលធ្លាប់មានអស់រយៈកាល៤០ឆ្នាំកន្លងមកមុននោះនាឱកាសទីមួយក្នុងការនាំយកទឹកចេញពីថ្មដានោះ (នក ១៧:៧ កន្លែងដែលគេឱ្យឈ្មោះថា "ម៉ាសា" មានន័យថា "ការសាកល្បង" សូមមើលសេចក្តីពន្យល់មានបង្ហាញប្រាប់នៅត្រង់ខនោះ)។ ទដ ៩៥:៨ (សូមមើលការពន្យល់នៅទីនោះ) ត្អូញត្អែរការបះបោរនៅឯមេរីបា និងម៉ាសា ។ *បានសំដែងសេចក្តីបរិសុទ្ធរបស់ទ្រង់* សូមមើល លវ ១០:៣ ហើយនិងការពន្យល់ ។

**២០:១៤–២១** សេចក្តីរបស់ម៉ូសេ ដើម្បីឆ្លងកាត់ព្រំដែននៃទឹកដីអេដំម ដោយកិច្ចពិភាក្សាប្រកបដោយសេចក្តីសុខសាន្ត និងការបង់ថ្លៃសម្រាប់ការងារជាអ្នកបម្រើ ដែលនាំមកនូវការជួបប្រទះដោយការទាត់ចោលនូវភាពក្រអឺតក្រទម ។

**២០:១៤** *អ៊ីស្រាអែលជាប្អូនទ្រង់* មនុស្សទាំងឡាយនៅក្រុងអេដំមបានជាប់ពូជពីអេសាវជាបងប្រុសរបស់យ៉ាកុប(មើល លប ៣៦:១ និងការពន្យល់)។

**២០:១៧** *ផ្លូវថ្នល់របស់ស្តេចវិញ* ផ្លូវតំបន់ពាណិជ្ជកម្មដ៏សំខាន់ ដែលលាតសន្ធឹងពីជើងទៅត្បូងនៅតាមដងទន្លេយ័រដាន់ ជាផ្លូវដែលលាតសន្ធឹងចាប់ពីប្រទេសអារ៉ាប់ទៅដល់ក្រុងដាម៉ាស់ ។

សិនជាយើងខ្ញុំ ឬហ្វូងសត្វ[ញ] យើងខ្ញុំផឹកទឹករបស់ទ្រង់ នោះ
យើងខ្ញុំនឹងចេញថ្លៃសងថ្វាយទ្រង់[ដ] សូមតែឱ្យយើងខ្ញុំដើរ
កាត់ស្រុកទ្រង់ប៉ុណ្ណោះចុះ ២០តែស្តេចនោះមានបន្ទូលថា
មិនត្រូវឱ្យឯងទៅទេ[ឋ] ហើយស្តេចអេដំម[ឌ]ក៏ចេញមកទាស់
នឹងគេ ព្រមទាំងនាំយកមនុស្សជាច្រើនមកមានអំណាចជា
ខ្លាំង ២១ដូច្នេះ ស្តេចអេដំមមិនព្រមបើកឱ្យពួកអ៊ីស្រាអែល
ដើរកាត់ស្រុកទ្រង់ទេ[ឍ] បានជាពួកអ៊ីស្រាអែលគេបែរចេញ
ពីទ្រង់ទៅ[ណ] ។

## ការស្លាប់របស់លោកអើរ៉ុន

២២ពួកកូនចៅអ៊ីស្រាអែល គឺពួកជំនុំទាំងមូលក៏ធ្វើ
ដំណើរចេញពីស្រុកកាដេស[ត]មកដល់ភ្នំហោរ[ថ] ២៣នោះព្រះ
យេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិងអើរ៉ុននៅភ្នំ
ហោរនោះ ត្រង់ព្រំដែនស្រុកអេដំមថា[ទ] ២៤អើរ៉ុននឹងត្រូវ
បានប្រមូលទៅមូលនឹងពួកឰយុកោហើយ[ធ] ដ្បិតមិនត្រូវ
ចូលទៅក្នុងស្រុក ដែលអញបានឱ្យដល់ពួកកូនចៅអ៊ីស្រា
អែលទេ ពីព្រោះឯងទាំង២នាក់បានចចេសនឹងបង្គាប់អញ[ន]
នៅត្រង់ទឹកមេរីបា[ប] ២៥ដូច្នេះ ឱ្យយកអើរ៉ុន និងអេលាសារ
ជាកូនលោក នាំឡើងទៅលើភ្នំហោរទៅ[ផ] ២៦រួចដោះ
សំលៀកបំពាក់ ពីអើរ៉ុន[ព] យកទៅបំពាក់ឱ្យអេលាសារជា
កូនវិញ នោះអើរ៉ុននឹងត្រូវបានប្រមូលទៅមូលនឹងពួក
ឰយុកោ[ភ] គឺត្រូវស្លាប់នៅទីនោះ ២៧ម៉ូសេក៏ធ្វើដូចជាព្រះ
យេហូវ៉ាបានបង្គាប់មក គេនាំគ្នាឡើងទៅលើភ្នំហោរ[ម] នៅ
ចំពោះភ្នែកនៃពួកជំនុំទាំងអស់គ្នា ២៨នោះម៉ូសេក៏ដោះ

**២០:១៩** ញ នក ១២:៣៨ ដ ចទ ២:៦,២៨
**២០:២០** ឋ ខ.១៧, ១៨ ឌ ខ.១៤
**២០:២១** ឍ ជន ២១:២៣ ណ ជន ២១:៤ ចទ ២:៨ ពច ១១:១៨
**២០:២២** ត ចទ ១:៤៦ ថ ជន ៣៣:៣៧ ៣៤:៧ ចទ ៣២:៥០
**២០:២៣** ទ ខ.១៦
**២០:២៤** ធ លប ២៥:៨ ន ខ.១០ ប នក ១៧:៧
**២០:២៥** ផ ជន ៣៣:៣៨
**២០:២៦** ព នក ២៨:១–៤ ៤០:១៣ លវ ១៦:៤ ភ ខ.២៤ ជន ២៧:១៣ ៣១:២
**២០:២៧** ម ជន ៣៣:៣៨
**២០:២៨** យ នក ២៩:២៩ រ ខ.២៦ ជន ៣៣:៣៨ ចទ ១០:៦ ៣២:៥០
**២០:២៩** ល ចទ

សំលៀកបំពាក់ពីអើរ៉ុន យកទៅបំពាក់ឱ្យអេលាសារ[យ]ជា
កូនវិញ រួចអើរ៉ុនស្លាប់នៅលើកំពូលភ្នំនោះទៅ[រ] ឯម៉ូសេ
និងអេលាសារក៏ចុះពីលើភ្នំមកវិញ ២៩កាលពួកជំនុំទាំង
ប៉ុន្មានបានឃើញថា អើរ៉ុនស្លាប់ហើយ[ល] នោះពូជពង្ស
អ៊ីស្រាអែលទាំងអស់គ្នា ក៏កាន់ទុក្ខនឹងលោក[វ]អស់៣០ថ្ងៃ ។

## ស្តេចអើរ៉ាតត្រូវស្លាប់

**២១** ១រីឯស្តេចអើរ៉ាត[ក] ជាសាសន៍កាណាន ដែលនៅ
ស្រុកខាងត្បូង[ខ] កាលបានឮថា ពួកអ៊ីស្រាអែលមកតាមផ្លូវ
ស្រុកអ័ថារីមហើយ នោះទ្រង់ក៏ចេញមកច្បាំងនឹងគេ ហើយ
ចាប់យកបានខ្លះ ២រួចពួកអ៊ីស្រាអែលគេតាំងសច្ចា[គ]ដល់ព្រះ
យេហូវ៉ា ដោយពាក្យថា បើទ្រង់ប្រគល់សាសន៍នោះមកក្នុង
កណ្តាប់ដៃយើងខ្ញុំ នោះយើងខ្ញុំនឹងបំផ្លាញ[ឃ]ទីក្រុងគេអស់
រលីង ៣ព្រះយេហូវ៉ាទ្រង់ក៏ស្តាប់តាមពាក្យរបស់ពួកអ៊ីស្រា
អែល ហើយប្រគល់ពួកសាសន៍កាណាន[ង]នោះមក រួចពួក
អ៊ីស្រាអែលក៏បំផ្លាញគេ និងទីក្រុងគេទាំងអស់ទៅ[ច] គេហៅ
ទីនោះថា ហោម៉ា[ឆ]។

## ពស់លង្ហិន

៤រួចគេធ្វើដំណើរពីភ្នំហោរ[ជ]ដើរទៅ តាមផ្លូវសមុទ្រ
ក្រហម[ឈ] ដើម្បីនឹងវាងព័ទ្ធស្រុកអេដំម[ញ] តែបណ្តាជនមាន

៣២:៥០ វ លប ២៧:៤១ លវ ១០:៦ ចទ ៣៤:៨ **២១:១** ក ជន ៣៣:៤០ យស ១២:១៤ ខ លប ១២:៩ ជន ១៣:១៧ ចទ ១:៧ ពច ១:៩,១៦ **២១:២** គ លវ ៧:១៦ ឃ ខ.៣ នក ២២:២០ ចទ ២:៣៤ យស ២:១០ ៨:២៦ យរ ២៥:៩ ៥០:២១ **២១:៣** ង លវ ១០:១៨ ច ខ.២ ឆ ជន ១៤:៤៥ **២១:៤** ជ ជន ២០:២២ ឈ ជន ១៤:២៥ ចទ ២:១ ១១:៤ ញ ជន ២០:២១

**២០:២០** *មនុស្សជាច្រើនមក មានអំណាចជាខ្លាំង* ដើម្បីបង្ហាញនូវកម្លាំងទ័ពរបស់អេដំម ដែលបណ្តាលឱ្យពួកកូនចៅអ៊ីស្រាអែល ងាកបែរចេញឆ្ងាយ ដោយមិនប្រថុយប្តូរតតាំងជាមួយនឹងប្រជាជាតិ ដែលត្រូវជាបងប្អូនរបស់ផងព្រះនោះ ។ ពួកកូនចៅអ៊ីស្រាអែលត្រូវបានហាមប្រាមដោយព្រះអម្ចាស់ សូម្បីតែ ដាក់បាតជើងចុះនៅក្នុងស្រុកអេដំមក៏មិនបានផង (សូមមើល ចទ ២:៤–៦) ។

**២០:២២** *ភ្នំហោរ* នៅត្រង់កន្លែងណាមួយ ដែលនៅក្បែរព្រំដែនស្រុកអេដំម (សូមមើល ខ.២៣) ។

**២០:២៤** *ប្រមូលទៅមូលនឹងពួកឰយុកោ* ការនិយាយសម្រាលពាក្យសម្រាប់ការទទួលមរណភាព (សូមមើលឧទាហរណ៍មាននៅក្នុង លប ២៥:៨,១៧ ៣៥:២៩) ។ *ឯងទាំង២នាក់* អើរ៉ុនបានរួមជាមួយនឹងម៉ូសេ នៅក្នុងការបះបោរប្រឆាំងនឹងព្រះ (ខ.១២) ការគំរាមដល់សេចក្តីស្លាប់របស់គាត់បានក្លាយជាប្រផ្នូលមិនល្អដល់សេចក្តីស្លាប់របស់ម៉ូសេផងដែរ (ចទ ជំពូក៣៤) ។

**២០:២៥** *អើរ៉ុន និង អេលាសារ* គ្មានការសង្ស័យអំពីអ្នកស្នងពីអើរ៉ុនឡើយ ហើយក៏ដូចជាគ្មានការសង្ស័យអំពីអ្នកស្នងពីម៉ូសេដែរ (ចទ ជំពូក ៣៤) ។

**២០:២៦–២៨** នាពេលដែលអើរ៉ុន កាលដែលនៅរស់នៅឡើយ សំលៀកបំពាក់របស់គាត់ត្រូវបានយកទៅបំពាក់ឱ្យកូនរបស់គាត់ ត្រឹមតែនៅពេលណាដែលគាត់បានស្លាប់រួចទៅហើយ ។

**២០:២៩** *កាន់ទុក្ខនឹងលោក* មរណភាពរបស់គាត់ (ហើយថាជារបស់លោកម៉ូសេ) បានធ្វើការកត់សម្គាល់ការឆ្លងទៅជំនាន់មួយទៀត ។ ជំនាន់មនុស្សចាស់ ដែលបច្ចុប្បន្នក្រោយមកទៀតប្រហែលជាបានកន្លងផុតបាត់ទៅហើយ នោះក្នុងរវាង៤០ឆ្នាំ បានមានការប្រគល់ឱ្យស្ទើរតែទាំងស្រុងទៅមនុស្សដែលមានអាយុ២០ ឆ្នាំ ឬលើសពីនោះទៀត ។

**២១:១–៣** ការចេញច្បាំងលើកទី១ របស់ពួកជំនុំថ្មីតតាំងនឹងពួកសាសន៍កាណាន ដោយសារតែការបង្កហេតុរបស់ស្តេចអើរ៉ាត ប្រហែលជាស្តេចអង្គនោះបានចេញមកច្បាំងតតាំងវាយលុកនឹងពួកជំនុំអ៊ីស្រាអែល ។ រីឯលទ្ធផលពួកកូនចៅអ៊ីស្រាអែលទទួលបានជ័យជម្នះទាំងស្រុង ពោលគឺ ជាថ្ងៃថ្មីរបស់ពួកគេ ក្រោយពេលដែលពួកកូនចៅជំនាន់មុនបានចាញ់ចម្បាំងជាមួយពួកសាសន៍អាម៉ាឡេក និងសាសន៍កាណាន (១៤:៤១–៤៥) ។

**២១:១** *ស្រុកខាងត្បូង* សូមមើលការពន្យល់នៅ លប ១២:៩ ។

**២១:៣** *ហោម៉ា* ដោយមានការជាប់ពាក់ព័ន្ធជាមួយនឹងការបរាជ័យរបស់ពួកកូនចៅអ៊ីស្រាអែលកាលពីជំនាន់មុននោះ នៅទីកន្លែងដដែលនេះដែលត្រូវបានហៅឈ្មោះកន្លែងនោះថាដូច្នោះទៅ (មើលខប្រៀបធៀប ១៤:៤៥) ។

**២១:៤** ដោយការសម្រេចចិត្តរបស់លោកម៉ូសេ មិនបានជម្រុញឱ្យស្រុក

ចិត្តរវាត ដោយព្រោះផ្លូវនោះ[ដ] ៥ក៏និយាយទាស់នឹងព្រះ[ឋ]
ហើយទាស់នឹងម៉ូសេថា ម្ដេចក៏បាននាំយើងចេញពីស្រុក
អេស៊ីព្ទ[ឌ]មក ឱ្យត្រូវស្លាប់នៅក្នុងទីរហោស្ថាន[ឍ]ដូច្នេះ ដ្បិត
គ្មានអាហារគ្មានទឹកសោះ[ណ] ហើយយើងទ្រាន់ណាយនឹង
នំគំរក់នេះពេកណាស់[ត] ៦នោះព្រះយេហូវ៉ាទ្រង់ចាត់ពស់
ភ្លើង[ថ]មកកណ្ដាលពួកជន ពស់ទាំងនោះក៏ចឹកគេ ហើយ
មានមនុស្សស្លាប់ជាច្រើន[ទ] ៧បណ្ដាជនទាំងឡាយក៏មក
ឯម៉ូសេ[ធ] ជំរាបថា យើងរាល់គ្នាបានធ្វើបាប[ន]ហើយ ដ្បិត
បាននិយាយទាស់នឹងព្រះយេហូវ៉ា ហើយទាស់នឹងលោក
ដែរ ដូច្នេះ សូមលោកអធិស្ឋាន[ប]ដល់ព្រះយេហូវ៉ាផង សូម
ទ្រង់បន្ថយពស់ទាំងនេះចេញពីយើងរាល់គ្នាទៅ នោះម៉ូសេ
ក៏អធិស្ឋាន[ផ]ឱ្យគេ ៨ហើយព្រះយេហូវ៉ាទ្រង់មានបន្ទូលមក
ម៉ូសេថា ចូរធ្វើពស់ភ្លើង១ ភ្ជាប់នៅលើបង្គោល[ព]ទៅ
ដើម្បីកាលណាអស់អ្នកដែលត្រូវពស់ចឹក គេក្រឡេកមើល
ទៅឃើញ នោះនឹងបានរស់នៅ ៩ម៉ូសេក៏ធ្វើរូបពស់១ពី
លង្ហិន[ភ] ដាក់ភ្ជាប់នៅលើបង្គោលនោះ ដូច្នេះ កាលណា
មានពស់ចឹកមនុស្សណា បើអ្នកនោះគ្រាន់តែក្រឡេកមើល
ទៅរូបពស់លង្ហិននោះក៏បានរស់វិញ[ម] ។

## ដំណើរទៅស្រុកម៉ូអាប់

១០ពួកកូនចៅអ៊ីស្រាអែលក៏ធ្វើដំណើរទៅដំឡើងត្រ
សាលនៅត្រង់អូបូត[យ] ១១រួចគេចេញពីអូបូត ទៅដំឡើង
ត្រសាលនៅត្រង់អ៊ីយេ-អាបារីមក្នុងទីរហោស្ថាន ដែល
ជាប់ព្រំដែនខាងកើតនៃស្រុកម៉ូអាប់[រ] ១២ពីទីនោះ គេក៏ធ្វើ
ដំណើរដើរទៅដំឡើងត្រសាល នៅត្រង់ច្រកភ្នំសេរេត[ល]
១៣ហើយចេញពីទីនោះ ដើរទៅដំឡើងត្រសាលឯត្រើយ
ស្ទឹងអើណូនម្ខាង ជាស្ទឹងដែលហូរពីព្រំស្រុកអាម៉ូរីមកតាម
ទីរហោស្ថាន ដ្បិតស្ទឹងអើណូន[វ]ជាព្រំដែននៃស្រុកម៉ូអាប់
នៅជាកណ្ដាលស្រុកម៉ូអាប់ និងស្រុកអាម៉ូរី[ស] ១៤ហេតុនោះ
បានជាមានពាក្យដំណាលក្នុងសៀវភៅ ដែលនិទានពី
ចំបាំង[ហ]ផងព្រះយេហូវ៉ាថា ការដែលទ្រង់ធ្វើនៅក្នុងស៊ូផា
ហើយនៅច្រកភ្នំអើណូន ១៥គឺនៅជំរាលភ្នំដែលជ្រាល
ទៅខាងទីលំនៅអើរ [ឡ]ហើយក៏ជាប់នឹងព្រំស្រុកម៉ូអាប់
១៦ពីទីនោះគេមកដល់បៀរ[អ] គឺជាអណ្ដូង ដែលព្រះយេហូវ៉ា
បានមានបន្ទូលនឹងម៉ូសេថា ចូរប្រមូលពួកបណ្ដាជនឱ្យជុំគ្នា

**២១:៤** ដ ចទ ២:៨ ពច ១១:១៨ **២១:៥** ឋ ទដ ៧៨:១៩ ឌ ជន ១១:២០ ឍ នក ១៤:១១ ជន ១៤:២,៣ ណ ជន ២០:៥ ត ជន ១១:៥ **២១:៦** ថ ខ.៧ ចទ ៨:១៥ ៣២:៣៣ យប ២០:១៤ ទដ ៥៨:៤ ១៤០:៣ យរ ៨:១៧ ទ ១កច ១០:៩ **២១:៧** ធ ទដ ៧៨:៣៤ ហស ៥:១៥ ន ជន ១៤:៤០ ប នក ៨:៨ ១សយ ៧:៨ យរ ២៧:១៨ ៣៧:៣ កច ៨:២៤ ផ ជន ១១:២ **២១:៨** ព យហ ៣:១៤ **២១:៩** ភ ២ពវ ១៨:៤ ម យប ៣:១៤-១៥ **២១:១០** យ ជន ៣៣:៤៣ **២១:១១** រ លប ៣៦:៣៥ ជន ៣៣:៤៤ ចទ ៣៤:៨ យរ ៤០:១១ **២១:១២** ល ចទ ២:១៣,១៤ **២១:១៣** វ ជន ២២:៣៦ចទ ២:២៤ យស ១២:១ ពច ១១:១៣, ១៨ ២ពវ ១០:៣៣ អស ១៦:២ យរ ៤៨:២០ ស លប ១០:១៦ **២១:១៤** ហ ១សយ ១៧:៤៧ ១៨:១៧ ២៥:២៨ **២១:១៥** ឡ ខ.២៨ ចទ ២:៩,១៨ អស ១៥:១ **២១:១៦** អ ជន ២៥:១ ៣៣:៤៩ ពច ៩:២១ អស ១៥:៨

អេដំម ធ្លាក់ចូលទៅក្នុងចម្បាំងឡើយ (សូមមើលការពន្យល់នៅត្រង់ ២០:២០) ពីព្រោះមនុស្សផងទាំងឡាយបានខ្វះសេចក្ដីអំណត់អត់ធន់ជាមួយនឹងគាត់ ហើយទៅតាមទិសដៅដែលព្រះអម្ចាស់បានរៀបចំសម្រាប់ពួកគេ ។ ដោយជ័យជម្នះ ដែលទទួលបានមកដោយរហ័សពេកនោះ ធ្វើឱ្យពួកគេមានទំនុកចិត្តមកលើខ្លួនឯង ។ ពួកគេទាំងអស់គ្នាបានភ្លេចថា ជ័យជម្នះរបស់ពួកគេទៅលើស្ដេចអើរ៉ាត ជាជ័យជម្នះដែលទទួលបានមកដោយការប្រទានពរមកពីព្រះអម្ចាស់ បានសព្វព្រះហឫទ័យឆ្លើយតបចំពោះព្រះបន្ទូលសន្យារបស់ផងទ្រង់ចំពោះពួកកូនចៅអ៊ីស្រាអែលទាំងនោះឡើយ (ខ.២) ឥឡូវនេះពួកគេទាំងអស់គ្នាបានងើបបះបោរប្រឆាំងនឹងព្រះទៅវិញ ។

**២១:៥** *យើងទ្រាន់ណាយនឹងនំគំរក់នេះពេកណាស់* ការកង្វះនូវសេចក្ដីអំណត់អត់ធន់របស់មនុស្សផងទាំងឡាយ(ខ.៤) បាននាំឱ្យពួកគេពោលពាក្យប្រមាថដល់ព្រះអម្ចាស់ ក្នុងការបដិសេធន៍អ្នកបម្រើរបស់ផងទ្រង់គឺលោកម៉ូសេ ហើយក៏ស្អប់"នំបុ័ងពីស្ថានសួគ៌" (នក ៦:៤ និងការពន្យល់) ។ នេះជាភាពល្ងង់ជូរចត់ជាទីបំផុត ចំពោះការរំលោភបំពានជារៀងរាល់លើករបស់ពួកគេទៅលើរឿងនំម៉ាន៉ា (សូមមើលការពន្យល់នៅ ១១:៧) ។ គ្រាន់តែការវាយទៅលើថ្មរបស់លោកម៉ូសេ មានច្រើនដងជាងការដែលកើតមានឡើងទៅទៀត (សូមមើលការពន្យល់នៅត្រង់ ២០:១១) ដូច្នេះ ការមិនគោរពឱ្យតម្លៃរបស់ពួកហ្វូងមនុស្សចំពោះនំបុ័ង ដែលធ្លាក់មកពីស្ថានសួគ៌មានសភាពធ្ងន់ធ្ងរជាងដែលគេគិតទៅទៀត ។ ការបដិសេធន៍នំម៉ាន៉ា ជារឿងមួយដូចគ្នាទៅនឹងការច្រានចោល ទាំងមើលងាយនូវព្រះគុណរបស់ផងព្រះ (សូមមើលការប្រៀបធៀប យហ ៦:៣២-៣៥,៤៨-៥១,៥៨) ។

**២១:៨-៩** នៅក្នុងការឆ្លើយតបចំពោះការលន់តួបាបរបស់បណ្ដាជនទាំងឡាយនៃការរំលងរបស់ខ្លួន (ខ.៧) ព្រះបានកំណត់ទិសដៅដល់លោកម៉ូសេ ដើម្បីធ្វើជារូបសត្វពស់១ ហើយដាក់ភ្ជាប់នៅលើបង្គោល បើអ្នកណាមួយមានពស់ចឹកនោះ គ្រាន់តែក្រឡេកមើលទៅរូបសត្វពស់នោះ ក៏បានរស់ឡើងវិញ ។ សូមមើលការប្រើប្រាស់ក្នុងមុខវិជ្ជា (មុទ្ទវិទ្យា) នៅក្នុងដំណើរហេតុការណ៍កើតមានឡើងក្នុង យហ ៣:១៤-១៥ ។

**២១:១០-១៣** ពួកហ្វូងមនុស្ស ដែលរស់នៅឯជាយក្រុងអេដំម ហើយពួកគេក៏ធ្វើដំណើរទៅកាន់ឯអើណូន គឺជាដងទន្លេមួយ ដែលរីងស្ងួតនារដូវប្រាំងត្រូវបានគេប្រើប្រាស់ជាព្រំដែនរវាងស្រុកម៉ូអាប់ និងតំបន់នៃស្រុកអាម៉ូរី ហើយបានហូរទៅកាន់ទិសខាងលិច ចូលទៅចំណុចកណ្ដាលនៃសមុទ្រស្លាប់ ។

**២១:១២** *សេរេត* សូមមើលការពន្យល់នៅ ចទ ២:១៣ ។

**២១:១៤** *សៀវភៅដែលនិទានពីចំបាំងផងព្រះយេហូវ៉ា* ដែលមានបញ្ជាក់ប្រាប់ត្រឹមតែនៅក្នុងបទគម្ពីរនេះនៃសញ្ញាចាស់ប៉ុណ្ណោះ ។ តែពាក្យនេះពុំមាននៅក្នុងសម័យបច្ចុប្បន្នឡើយ វាអាចសន្មតបានថា ជាការចងក្រងពីបុរាណនៃបទចម្រៀងពីចម្បាំងនៅក្នុងការសរសើរតម្កើងដល់ព្រះអម្ចាស់ (សូមមើលការពន្យល់នៅ ១០:៣ ចំពោះបទភ្លេងនៅក្នុងសង្គ្រាម) ។ សូមមើលខប្រៀបធៀប "សៀវភៅរបស់យ៉ាសើរ" (យស ១០:១៣ និងការពន្យល់ ២សយ ១:១៨) ។

**២១:១៦** *នឹងឱ្យទឹកគេផឹក* ដំណើរនៃការស្វែងរកទឹកត្រូវបានក្លាយជាបញ្ហា

នោះអញនឹងឱ្យទឹកគេផឹក ១៧រួចពួកអ៊ីស្រាអែលគេក៏ច្រៀង
ទំនុកនោះ[ក]ថា "ឱ្យផុសឡើង អណ្តូងអើយ ចូរច្រៀងសរ
សើរអណ្តូងនេះចុះ ១៨ជាអណ្តូងដែលពួកចៅហ្វាយបានជីក
ហើយពួកអ្នកមានត្រកូលខ្ពស់បានជីកនឹងជ្រនីកគេ តាម
ច្បាប់បញ្ញត្តិ" រួចពីទីរហោស្ថាននោះ គេក៏មកដល់ម៉ាថា
ណា ១៩ពីម៉ាថាណា ទៅដល់ណាហាលាលពីណាហាលាល
ទៅដល់បាម៉ូត ២០ហើយពីបាម៉ូត ដែលនៅក្នុងច្រកភ្នំនៅ
ស្រុកម៉ូអាប់ ក៏ទៅដល់កំពូលភ្នំពីសកា[ខ]ដែលបែរទៅខាង
ទីរហោស្ថាន ។

## ការវាយឈ្នះពួកស៊ីហុន និងអុកជាស្តេចស្រុកបាសាន

២១នោះសាសន៍អ៊ីស្រាអែលគេចាត់សារ[គ]ទៅឯស៊ីហុន[ឃ]
ជាស្តេចសាសន៍អាម៉ូរីថា[ង] ២២សូមឱ្យយើងខ្ញុំដើរកាត់ស្រុក
ទ្រង់ផង យើងខ្ញុំនឹងមិនងាកបែរទៅក្នុងស្រែឬចំការទេ ក៏
មិនផឹកទឹកអណ្តូងដែរ យើងខ្ញុំនឹងដើរតាមតែថ្នល់ធំរបស់
ស្តេចប៉ុណ្ណោះ រហូតដល់បានហួសផុតពីដែនស្រុកទ្រង់ទៅ[ច]
២៣តែស៊ីហុន មិនព្រមឱ្យសាសន៍អ៊ីស្រាអែលដើរកាត់ព្រំ
ស្រុកទ្រង់ទេ[ឆ] គឺទ្រង់បានប្រមូលពួកជនទាំងអស់ ចេញទៅ
ឯទីរហោស្ថានទាស់នឹងពួកអ៊ីស្រាអែលវិញ ក៏ច្បាំងវាយ
ពួកអ៊ីស្រាអែល[ជ]នៅត្រង់យ៉ាហាស់[ឈ] ២៤តែពួកអ៊ីស្រាអែល
ប្រហារទ្រង់ដោយមុខដាវទៅ[ញ] ហើយក៏ចាប់យកស្រុក
ទ្រង់[ដ] ចាប់តាំងពីស្ទឹងអើណូន រហូតដល់ស្ទឹងយ៉ាបុក[ឋ] ដែល
ជាព្រំដែនរបស់សាសន៍អាំម៉ូន[ឌ] ឯព្រំដែននៃពួកកូនចៅ
អាំម៉ូននោះមាំណាស់ ២៥ពួកអ៊ីស្រាអែលក៏វាយយកអស់
ទាំងទីក្រុងរបស់ពួកសាសន៍អាម៉ូរី[ឍ] ហើយអាស្រ័យនៅក្នុង
ទីក្រុងទាំងនោះ[ណ] គឺក្នុងក្រុងហែសបូន[ត] និងដំបន់ទាំង
ប៉ុន្មាននៅជុំវិញទីក្រុងនោះ ២៦ឯហែសបូននេះ ជាទីក្រុងនៃ
ស៊ីហុន[ថ]ជាស្តេចសាសន៍អាម៉ូរី[ទ] ដែលបានច្បាំងនឹងស្តេច
សាសន៍ម៉ូអាប់[ធ] ជាស្តេចពីមុន ហើយចាប់យកអស់ទាំង
ស្រុកពីកណ្តាប់ដៃនៃស្តេចនោះ រហូតដល់ស្ទឹងអើណូន[ន]
២៧ហេតុនោះបានជាគេតែងនិយាយ ដោយពាក្យសុភាសិត
ថា "ចូរមកក្នុងហែសបូន ឱ្យទីក្រុងរបស់ស៊ីហុនបានសង់
ឡើង ហើយរៀបជាស្រេចផង ២៨ដ្បិតមានភ្លើងចេញពី
ហែសបូនមក គឺជាអណ្តាតភ្លើងពីទីក្រុងរបស់ស៊ីហុន[ប] ភ្លើង
នោះបានឆេះ[ផ]ក្រុងអើរ[ព]របស់ស្រុកម៉ូអាប់ ព្រមទាំងពួក
ម្ចាស់ទីខ្ពស់របស់ស្ទឹងអើណូន[ភ] ២៩វេទនាដល់ឯង ម៉ូអាប់
អើយ[ម] ឱពួកព្រះកេម៉ូសអើយ[យ] ឯងរាល់គ្នាត្រូវវិនាសហើយ
ដ្បិតព្រះនៃឯងបានបញ្ជូនពួកកូនប្រុសរបស់ខ្លួន ឱ្យត្រូវរត់[រ]
និងពួកកូនស្រីឱ្យទៅជាឈ្លើយ[ល] ដល់ស៊ីហុនជាស្តេច
សាសន៍អាម៉ូរី ៣០យើងបានបាញ់តាមគេ ហែសបូនត្រូវ
វិនាសទៅរហូតដល់ឌីបូន[វ] យើងក៏បានរំលាងស្រុករហូត
ដល់ណូផា គឺទៅដល់មេឌីបាផង[ស]" ៣១ដូច្នេះពួកអ៊ីស្រាអែល
បាននៅក្នុងស្រុករបស់សាសន៍អាម៉ូរីនោះ[ហ] ៣២រួចម៉ូសេ
ចាត់គេទៅសង្កេតមើល[ឡ]ឯក្រុងយ៉ាសេរ[អ] គេក៏ចាប់យកអស់
ទាំងដំបន់នៅជុំវិញ ព្រមទាំងបណ្តេញសាសន៍អាម៉ូរីដែល
នៅស្រុកនោះឱ្យចេញទៅផង ។
៣៣រួចគេបែរឡើងទៅតាមផ្លូវស្រុកបាសានវិញ នោះ
អុកជាស្តេចស្រុកបាសាន[ក,ខ] ព្រមទាំងពួកជនរបស់ទ្រង់ ក៏

**២១:១៧** ក នក ១៥:១
**២១:២០** ខ ជន ២៣:១៤ ចទ ៣:១៧,២៧ ៣៤:១ យស ១២:៣ ១៣:២០
**២១:២១** គ លប ៣២:៣ ឃ ជន ៣២:៣៣ ចទ ១:៤ យស ២:១០ ១២:២,៤ យស ២:១០ ១២:២,៤ ១៣:១០ ពច ១១:១៩–២១ ១ពវ ៤:១៩ នហ ៩:២២ ទដ ១៣៥:១១ ១៣៦:១៩ យរ ៤៨:៤៥ ង នក ២៣:២៣
**២១:២២** ច ជន ២០:១៧
**២១:២៣** ឆ ជន ២០:២១ ជ ជន ២០:១៨ ឈ ចទ ២:៣២ យស ១៣:១៨ ២១:៣៦ ពច ១១:២០ អស ១៥:៤ យរ ៤៨:២១,៣៤
**២១:២៤** ញ ចទ ២:៣៣ ៣:៣ ២៩:៧ ទដ ១៣៥:១០–១១ អម ២:៩ ដ ខ.៣៥ ចទ ៣:៤ ឋ លប ៣២:២២ ជន ៣២:៣៣ ពច ១១:១៣,២២ ឌ លប ១៩:៣៨ ចទ ២:៣៧ យស ១៣:១០
**២១:២៥** ឍ ជន ១៣:២៩ ពច ១០:១១ អម ២:១០ ណ ពច ១១:២៦ ត ខ.៣០ជន ៣២:៣ ចទ ១:៤ ២៩:៧ យស ៩:១០ ១២:២ យស ៩:១០ ១២:២ អស ១៥:៤ ១៦:៨ យរ ៤៨:២,៣៤ **២១:២៦** ថ ខ.២១ ចទ ២៩:៧ ទដ ១៣៥:១១ ទ ជន ១៣:២៩ ធ ខ.១១ ន ខ.១៣ **២១:២៨** ប យរ ៤៨:៤៥ ផ ជន ១១:១ ព ខ.១៥ ភ ជន ២២:៤១ ចទ ១២:២ យស ១៣:១៧ អស ១៥:២ យរ ១៩:៥ **២១:២៩** ម ជន ២៤:១៧ ២សយ ៨:២ ១រប ១៨:២ ទដ ៦០:៨ អស ២៥:១០ យរ ៤៨:៤៦ យ ពច ១០:៦ ១១:២៤ រម ១:១៥ ១ពវ ១១:៧,៣៣ ២ពវ ២៣:១៣ យរ ៤៨:៤៦ រ អស ១៥:៥ ល អស ១៦:២ **២១:៣០** វ ជន ៣២:៣ យស ១៣:៩,១៧ នហ ១១:២៥ អស ១៥:២ យរ ៤៨:១៨,២២ ស យស ១៣:១៦ **២១:៣១** ហ ជន ១៣:២៩ **២១:៣២** ឡ យស ២:១ ៦:២២ ៧:២ ពច ១៨:២ ២សយ ១០:៣ ១រប ១៩:៣ អ ជន ៣២:១,៣,៣៥ យស ១៣:២៥ ២សយ ២៤:៥ ១រប ៦:៨១ អស ១៦:៨ យរ ៤៨:៣២ គ ចទ ១:៤ ៣:១,១០ យស ១២:៤ ១៣:១២,៣១ ១៩:៣៧ **២១:៣៣** ក ជន ៣២:៣៣ ចទ ៣:៣ ៣១:៤ យស ២:១០ ១២:៤ ៣០ ១ពវ ៤:១៩ នហ ៩:២២ ទដ ១៣៥:១១ ១៣៦:២០ ខ ចទ ៣:៤ ៣២:១៤ យស ៩:១០ ១ពវ ៤:១៣

មួយដ៏មាំមួនក្នុងអំឡុងពេល ដែលវង្វេងក្នុងទីរហោស្ថាន (សូមមើលក្នុងជំពូក ២០ នកជំពូក ១៧) ។

**២១:១៧–១៨** ចម្រៀងអំពីអណ្តូងទឹក ក៏អាចចេញមកពីក្នុង "សៀវភៅដែលនិទានពីចំបាំងផងព្រះយេហូវ៉ា" (ខ.១៤) ។

**២១:២១–២៦** ដូចដែលពួកគេបានធ្វើជាមួយនឹងស្រុកអេដំម (២០:១៤–១៩) ពួកកូនចៅអ៊ីស្រាអែលបានស្នើសុំសេរីភាពក្នុងការដើរកាត់ទឹកដីរបស់ពួកសាសន៍អាម៉ូរី ។ នៅពេលដែលស៊ីហុន ជាស្តេចរបស់ពួកគេនោះបានព្យាយាមដើម្បីជួបពួកកូនចៅអ៊ីស្រាអែល ដោយការបង្ហាញនូវកម្លាំង ដែលស្តេចអង្គនោះបានទទួលការឈឺចាប់ការបរាជ័យយ៉ាងដំណំ ។ ទឹកដីនៃពួកសាសន៍អាម៉ូរី បានបញ្ជាក់ប្រាប់ថានៅទីកន្លែងនេះតាមដងទន្លេយ័រដាន់ដែលលាតសន្ធឹងចាប់ពីស្ទឹងអើណូន (នៅឯចំណុចកណ្តាលនៃសមុទ្រស្លាប់) រហូតដល់ស្ទឹងយ៉ាបុក (ខ.២៤) ដែលហូរចាក់ចូលទៅក្នុងទន្លេយ័រដាន់ក្នុងចំងាយ ២៤ ម៉ៃ ភាគខាងជើងសមុទ្រស្លាប់ ។

**២១:២៧–៣០** កំណាព្យពីបុរាណទីបីនេះ នៅក្នុងជំពូកទី២១ ជាបទចម្រៀង របស់ពួកសាសន៍អាម៉ូរីនៅក្នុងការច្រៀងចំអកឡកឡឺយ អំពីជ័យជម្នះរបស់ពួកគេកាលពីពេលមុនទៅលើពួកសាសន៍ម៉ូអាប់ (ខ.២៩) ។ ប្រហែលជាបទ ចម្រៀងនេះច្រៀងអំពីហែសបូន ក៏មានរក្សាទុកនៅក្នុង "សៀវភៅដែល និទានពីចំបាំងផងព្រះយេហូវ៉ា" (ខ.១៤) ។

**២១:៣៣** *បាសាន* ជាតំបន់ព្លៀសាន (ទិសខាងជើងឆៀងខាងកើត) នៃសមុទ្រកាលីឡេ ។

លើកគ្នាចេញមកទាស់នឹងគេ ហើយច្បាំងគ្នានៅត្រង់
អេទ្រ៉ី[គ] ៣៤ នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា
កុំឱ្យខ្លាចគេឡើយ ដ្បិតអញបានប្រគល់ស្តេចនេះមកក្នុង
កណ្ដាប់ដៃឯង ហើយព្រមទាំងរាស្ត្រ និងស្រុករបស់ទ្រង់
ផង ត្រូវឱ្យឯងធ្វើដល់គេ ដូចជាឯងបានធ្វើយដល់ស៊ីហុន
ជាស្តេចសាសន៍អាម៉ូរី ដែលនៅហែសបូននោះដែរ[ឃ]
៣៥ ដូច្នេះគេក៏វាយស្តេចនោះ ព្រមទាំងកូនចៅ និងរាស្ត្រ
ទ្រង់ផងទាល់តែគ្មានសល់១ឡើយ[ង] ហើយគេចាប់យកស្រុក
របស់ទ្រង់ដែរ[ច] ។

## ស្តេចបាឡាកហៅលោកបាឡាម

**២២** ១ ពួកកូនចៅអ៊ីស្រាអែលក៏ធ្វើដំណើរទៅទៀតរួច
ដំឡើងត្រសាលនៅត្រង់វាលនៃស្រុកម៉ូអាប់[ក] នៅត្រើយ
ទន្លេយ័រដាន់[ខ]ខាងនេះ ទល់មុខនឹងយេរីខូរ[គ] ។
២ រីឯបាឡាកជាបុត្រាស៊ីបព័រ[ឃ] ទ្រង់ក៏ឃើញអស់ទាំង
ការដែលពួកអ៊ីស្រាអែលបានធ្វើដល់សាសន៍អាម៉ូរី ៣ ដូច្នេះ
សាសន៍ម៉ូអាប់ក៏ភ័យខ្លាចជាខ្លាំង ហើយមានចិត្តស្រយុត
វន្ធត់[ង] នៅមុខពួកកូនចៅអ៊ីស្រាអែល ដោយព្រោះគេមាន
គ្នាច្រើន ៤ នោះពួកម៉ូអាប់[ច]ក៏និយាយទៅពួកចាស់ទុំនៃ
សាសន៍ម៉ាឌាន[ឆ]ថា ឥឡូវពួកនេះនឹងស៊ីរំលីងរបស់ទាំង
អស់[ជ]នៅជុំវិញយើងរាល់គ្នាហើយ ដូចជាគោស៊ីរំលីងស្មៅ
ខ្ចីនៅវាលដែរ[ឈ] រីឯនៅគ្រានោះ បាឡាកជាបុត្រាស៊ីបព័រ
ទ្រង់ធ្វើជាស្តេចលើសាសន៍ម៉ូអាប់ ៥ ទ្រង់ក៏ចាត់សារទៅ
ឯបាឡាមជាកូនបេអ៊ោរ[ញ] នៅក្រុងពេថោរ ដែលនៅមាត់
ទន្លេ[ដ] ក្នុងស្រុករបស់ពួកកូនចៅសាសន៍ទ្រង់ ដើម្បីនឹងហៅ
មកដោយពាក្យថា មើល មានសាសន៍១ចេញពីស្រុកអេស៊ីព្ទ
មក[ឋ] គេនៅដេរដាសពេញលើផែនដី ត្រង់ទល់មុខនឹង
អញ ៦ ដូច្នេះ ចូរឯងមកឥឡូវ ដើម្បីនឹងដាក់បណ្ដាសា[ឌ] ដល់
សាសន៍នេះឱ្យអញ ដ្បិតគេខ្លាំងពូកែជាងអញណាស់
ប្រហែលជាអញនឹងឈ្នះគេបាន ហើយនិងវាយបណ្ដេញគេ
ចេញពីស្រុកទៅ[ឍ] ដ្បិតអញដឹងថា អ្នកណាដែលឯងឱ្យពរ
នោះបានពរមែន ហើយអ្នកណាដែលឯងដាក់បណ្ដាសា
នោះក៏ត្រូវបណ្ដាសាពិត ។
៧ លំដាប់នោះពួកចាស់ទុំនៃសាសន៍ម៉ូអាប់ និងពួកចាស់
ទុំនៃសាសន៍ម៉ាឌាន គេនាំយករង្វាន់ នៃការទំនាយចេញ
ទៅ[ណ] ក៏មកដល់បាឡាម ហើយរ៉ាយរ៉ាប់ប្រាប់តាមពាក្យ
របស់បាឡាក ៨ រួចគាត់ឆ្លើយថា សូមដេកនៅទីនេះ១យប់
សិន នោះខ្ញុំនឹងឆ្លើយប្រាប់ដល់អ្នករាល់គ្នាតាមដែលព្រះ

**២១:៣៣** គ ចទ ១:៤ ៣:១,១០ យស ១២:៤ ១៣:១២,៣១ ១៩:៣៧ **២១:៣៤** ឃ ចទ ៣:២ **២១:៣៥** ង យស ៩:១០ ច ខ.២៤ **២២:១** ក ជន ២១:១១ ខ ជន ១៣:២៩ យស ២:៧ គ ជន ៣១:១២ ៣៣:៤៨ ចទ ៣២:៤៩ យស ២:១ **២២:២** ឃ ជន ២៣:១–៣ យស ២៤:៩ ពច ១១:២៥ មីក ៦:៥ វវ ២:១៤ **២២:៣** ង នក ១៥:១៥ **២២:៤** ច លប ១៩:៣៧ ឆ លប ២៥:២ ជ ជន ៣២:១៧,១៨,២៩ ឈ យប ៥:២៥ ទដ ៧២:១៦ **២២:៥** ញ ខ.៧ ជន ២៤:២៥ ៣១:៨,១៦ ចទ ២៣:៤ យស ១៣:២២ នហ ១៣:២ មីក ៦:៥ ២ពត ២:១៥ ដ លប ២:១៤ ឋ នក ១៣:៣ **២២:៦** ឌ ខ.១២,១៧ ជន ២៣:៧,១១,១៣ ២៤:៩,១០ ឍ ខ.១១ **២២:៧** ណ លប ៣០:២៧

**២១:៣៥** *គេក៏វាយស្តេចនោះ* ដោយទទួលបានជោគជ័យលើស្តេចអុក នោះកូនចៅអ៊ីស្រាអែលបានត្រួតត្រាតាមដងទន្លេយ័រដាន់ ចាប់ពីស្រុកម៉ូអាប់រហូតដល់ទីកម្ពស់នៃស្រុកបាសាននៅក្នុងបរិវេណនៃភ្នំហើម៉ូន ។ ជ័យជម្នះទៅលើស្តេច ស៊ីហុន និងស្តេចអុក បានក្លាយទៅជាប្រធានបទនៃចម្រៀង (ទដ ១៣៥:១១ ១៣៦:១៩–២០) ហើយបច្ចុប្បន្ននេះបានក្លាយទៅជាពិធីបុណ្យខួប ដ៏ទៀងទាត់មួយចំពោះការងារនៃព្រះអម្ចាស់នៅក្នុងការប្រារព្ធពិធីបុណ្យរំលង ។

**២២:១** *ត្រង់វាលនៃស្រុកម៉ូអាប់* ឥឡូវនេះពួកកូនចៅអ៊ីស្រាអែលបានធ្វើដំណើរត្រឡប់ទៅឯតំបន់នៃដំណាក់របស់ពួកគេវិញ នៅឯខាងនាយទន្លេយ័រដាន់ និងស្ថិតនៅបញ្ឆិតជ្រុងខាងជើងនៃសមុទ្រស្លាប់ ។ ចាប់ពីចំណុចនេះ ពួកគេនឹងធ្វើការវាយលុកទៅលើស្រុកកាណាន ដែលជាទីចាប់ផ្ដើមនៃទីក្រុងយេរីខូ ពីបុរាណកាល ។ ពួកស្រុកម៉ូអាប់មិនបានជឿជាក់ថាពួកកូនចៅអ៊ីស្រាអែលមានបំណងមកលើស្រុករបស់ខ្លួនទេ ។ សេចក្តីភ័យខ្លាចរបស់ពួកស្រុកម៉ូអាប់ នាំមកដល់ចន្លោះដែលគួរឱ្យកត់សម្គាល់មួយនៅក្នុងប្រវត្តិសាស្ត្រនៃពួកកូនចៅអ៊ីស្រាអែលចំពោះរឿងរ៉ាវរបស់បាឡាក និងបាឡាម (ជំពូក ២២–២៤) ។

**២២:៣** *សាសន៍ម៉ូអាប់ក៏ភ័យខ្លាចជាខ្លាំង* បាឡាក ជាស្តេចរបស់ស្រុកម៉ូអាប់មិនបានដឹងថា ពួកកូនចៅអ៊ីស្រាអែលបានមានផែនការប្រឆាំងនឹងខ្លួនទេ ។

**២២:៤** *ក៏និយាយទៅពួកចាស់ទុំសៃាសន៍ម៉ាឌាន* បាឡាកបានចងស្ពានមេត្រីជាមួយនឹងពួកសាសន៍ម៉ាឌាន ដើម្បីទប់ទល់ជាមួយនឹងពួកកូនចៅអ៊ីស្រាអែល (សូមមើល ខ.៧) ។ *ដូចជាគោស៊ីរំលីងស្មៅខ្ចីនៅវាលដែរ* ពាក្យប្រៀបប្រដូចជាសុភាសិតមួយនេះ ជាពិសេសវាត្រូវនឹងមនុស្សទាំងឡាយណា ដែលជាអ្នកគង្វាល ។

**២២:៥** *សារទៅឯបាឡាម* ចាប់តាំងពីបាឡាកបានជឿជាក់ថា គ្មានមធ្យោបាយទ័ពណា ដើម្បីទប់ទល់នឹងពួកកូនចៅអ៊ីស្រាអែលបានទេ គាត់បានស្វែងរកការប្រឆាំងនឹងពួកកូនចៅអ៊ីស្រាអែលតាមរយៈពួកសាសន៍ដទៃដោយប្រើប្រាស់ការទំនាយទៅវិញ (ខ.៦–៧) ហើយក៏ចាត់បញ្ជូនគ្រូទាយទាំងនោះ ដែលធ្លាប់មានឈ្មោះល្បីល្បាញពេញសាកលលោកមក ។ (គ្រូទាយដែលមិនមែនមានជំនឿខាងផ្នែកព្រះគម្ពីរទេ ត្រូវបានបង្ហារនៅក្នុងអត្ថបទភាសាអារ៉ាមមីកពីតំបន់ ឌៀរ អាល់ឡា (Deir ´Alla) ផ្នែកភាគខាងកើត នៃទន្លេយ័រដាន់ បញ្ឆិតទិសខាងជើងនៃទន្លេយ៉ាបុក ដែលមានចុះកាលបរិច្ឆេទក្នុងសតវត្សរ៍ទី៦ មុន គ.ស) ។ *ក្រុងពេថោរ* ស្ថិតនៅក្នុងតំបន់នៃភាគខាងពាយ័ព្យ (ទិសខាងជើងឆៀងខាងលិច) នៃមេសូប៉ូតាមី (North west Mesopotamia) ហើយត្រូវបានគេស្គាល់ថា ជាសិលាចារិកស្ថិតនៅក្នុងស្រុកអាសេ៊ី ។

**២២:៨** *ឆ្លើយប្រាប់ . . . តាមដែលព្រះយេហូវ៉ាមានបន្ទូលមកខ្ញុំ* ភាសានៅត្រង់នេះមាននៅក្នុង ខ.១៨ ("ព្រះយេហូវ៉ាជាព្រះនៃខ្ញុំ") បាននាំទៅរកសេចក្តីជំនឿរបស់បាឡាម ដែលជាអ្នកជឿលើព្រះយ៉ាវេ៎ (Yahweh, មានន័យថាព្រះអម្ចាស់) ព្រះអម្ចាស់នៃពួកអ៊ីស្រាអែល ។ ដោយឈរលើគោលការណ៍នៃការរៀបរាប់ជាបន្តបន្ទាប់ ទោះជាយ៉ាងណាក៏ដោយ វាហាក់ដូច

យេហូវ៉ាមានបន្ទូលមកខ្ញុំ[ត] ដូច្នេះពួកមេនៃសាសន៍ម៉ូអាប់ ក៏
ស្នាក់នៅជាមួយនឹងបាឡាម ៩នោះព្រះទ្រង់យាងមកឯ
បាឡាម[ថ]សួរថា[ទ] តើមនុស្សណានេះ ដែលនៅជាមួយនឹង
ឯង ១០បាឡាមទូលឆ្លើយថា បាឡាកជាបុត្រាសិបព័រ ដែល
ជាស្តេចសាសន៍ម៉ូអាប់ បានចាត់គេមកហៅទូលបង្គំថា
១១មើល សាសន៍នេះដែលចេញពីស្រុកអេស៊ីព្ទមក គេនៅ
ដេរដាសពេញលើផែនដី ឥឡូវចូរឱ្យឯងមកដាក់បណ្តាសា
គេឱ្យអញ ប្រហែលជាអញនឹងអាចច្បាំងជាមួយនឹងគេ
ហើយបណ្តេញគេចេញទៅបាន ១២តែព្រះទ្រង់តបទៅ
បាឡាមវិញថា មិនត្រូវឱ្យឯងទៅជាមួយនឹងគេឡើយ ក៏មិន
ត្រូវដាក់បណ្តាសា ដល់សាសន៍នេះផង ដ្បិតគេជាអ្នកមាន
ពរហើយ[ធ] ១៣បាឡាមក៏ក្រោកឡើងពីព្រលឹម ប្រាប់ដល់ពួក
មេដែលមកពីបាឡាកថា ចូរអ្នករាល់គ្នាត្រឡប់ទៅស្រុក
វិញចុះ ដ្បិតព្រះយេហូវ៉ាទ្រង់មិនព្រមបើកឱ្យខ្ញុំទៅជាមួយ
ទេ ១៤ពួកមេសាសន៍ម៉ូអាប់ក៏ក្រោកវិលត្រឡប់ទៅឯបាឡាក
វិញទូលថា បាឡាមមិនព្រមមកជាមួយនឹងយើងខ្ញុំទេ ។

១៥នោះបាឡាកក៏ចាត់ពួកមេជាច្រើនជាង ជាអ្នកមាន
សក្តិយសខ្ពស់ជាងអ្នកទាំងនោះ ឱ្យទៅទៀត ១៦គេក៏មកដល់
បាឡាមប្រាប់ថា បាឡាកជាបុត្រាសិបព័រ ទ្រង់មានបន្ទូល
ដូច្នេះថា កុំឱ្យមានអ្វីឃាត់ឃាំងឯងមិនឱ្យទៅឯអញនោះ
ឡើយ ១៧ដ្បិតអញនឹងលើកឯងជាធំ[ន] ហើយការអ្វីៗដែល
ឯងប្រាប់ដល់អញ នោះអញនឹងធ្វើសំរេចតាម ដូច្នេះចូរ
ទៅដាក់បណ្តាសា[ប]ដល់សាសន៍នេះឱ្យអញ ១៨តែបាឡាម
ប្រកែកទៅពួកមហាតលិក របស់បាឡាកថា បើសិនជាព្រះ
រាជានឹងប្រទានមាស ហើយនិងប្រាក់ពេញដំណាក់ទ្រង់មក
ខ្ញុំ នោះគង់តែខ្ញុំពុំអាចនឹងរំលងបញ្ញត្តិរបស់ព្រះយេហូវ៉ា
ជាព្រះនៃខ្ញុំ នឹងធ្វើការតិចឬច្រើនទៅបានឡើយ[ផ] ១៩ដូច្នេះ
សូមឱ្យអ្នករាល់គ្នាដេកនៅទីនេះ១យប់សិនចុះ ដើម្បីឱ្យខ្ញុំ
បានដឹងជាព្រះយេហូវ៉ា និងមានបន្ទូលមកខ្ញុំម្តេចទៀត[ព]
២០នៅវេលាយប់នោះ ព្រះទ្រង់ក៏មកឯបាឡាម[ភ]មានបន្ទូល
ថា បើគេបានមកហៅឯង នោះឱ្យឯងក្រោកឡើង ទៅជា
មួយនឹងគេចុះ ប៉ុន្តែត្រូវឱ្យឯងធ្វើសំរេចតាមបង្គាប់អញតែ
ប៉ុណ្ណោះ[ម] ។

## សត្វលារបស់លោកបាឡាម

២១បាឡាមក៏ក្រោកឡើងពីព្រលឹម បំពាក់កែបលើលា
របស់ខ្លួន ចេញទៅជាមួយនឹងពួកមេនៃសាសន៍ម៉ូអាប់
២២នោះសេចក្តីខ្ញាល់[យ]របស់ព្រះក៏កាត់ឡើង ដោយព្រោះ
គាត់ចេញទៅដូច្នោះ ហើយទេវតានៃព្រះយេហូវ៉ា[រ]ក៏មក
ឈរក្នុងផ្លូវ ដើម្បីទាស់ទទឹងនឹងគាត់ ឯគាត់ៗជិះនៅលើលា
មានទាំងអ្នកបំរើ២នាក់ទៅជាមួយផង ២៣លាក៏ឃើញទេវ
តានៃព្រះយេហូវ៉ាឈរនៅត្រង់ផ្លូវ ទាំងកាន់ដាវហូតជា
ស្រេច[ល]នៅព្រះហស្ត នោះលាក៏បែរចេញពីផ្លូវទៅតាម
វាលទៅ ឯបាឡាមគាត់វាយលា[វ] ដើម្បីនឹងទាញញាក់មក
ក្នុងផ្លូវវិញ ២៤នោះទេវតានៃព្រះយេហូវ៉ាក៏ឈរនៅត្រង់
ផ្លូវច្រកនាកណ្តាលចំការទំពាំងបាយជូរ មានកំផែងថ្មនៅ
ជាសងខាង ២៥លាក៏ឃើញទេវតានៃព្រះយេហូវ៉ាទៀត រួច
វាចូលទៅអែបត្បៀតខ្លួននឹងកំផែង គាបជើងបាឡាមនឹងថ្ម
នោះគាត់វាយវាម្តងទៀត ២៦រួចទេវតានៃព្រះយេហូវ៉ាក៏

**២២:៨** ត ខ.១៩
**២២:៩** ថ លប ២០:៣ ទ ខ.២០ ជន ២៣:៥ ២៤:៤,១៦
**២២:១២** ធ លប ១២:២
**២២:១៧** ន ខ.៣៧ ជន ២៤:១១ ប ខ.៦
**២២:១៨** ផ ខ.៣៨ ជន ២៣:១២,២៦ ២៤:១៣ ១ពវ ២២:១៤ ២រប ១៨:១៣ យរ ៤២:៤
**២២:១៩** ព ខ.៨
**២២:២០** ភ លប ២០:៣ ម ខ.៣៥,៣៨ ជន ២៣:៥,១២,១៦, ២៦ ២៤:១៣ ២រប ១៨:១៣
**២២:២២** យ នក ៤:១៤ រ លប ១៦:៧ ពច ១៣:៣,៦,១៣
**២២:២៣** ល យស ៥:១៣ វ ខ.២៥,២៧

ជាការប្រសើរបំផុតដើម្បីទទួលយកបាននូវពាក្យរបស់បាឡាម ក្នុងការប្រកាសប្រាប់ជាអ្នកនាំពាក្យសម្រាប់ព្រះដទៃទៀត ។ បាឡាមត្រូវបានបន្ទោសជាទូទៅ នៅក្នុងបទគម្ពីរសម្រាប់សុជីវធម៌ ក្រមសីលធម៌ និងកំហុសក្នុងសាសនា (សូមមើល ៣១:៧–៨,១៥–១៦ ចទ ២៣:៣–៦ យស ១៣:២២ ២៤:៩–១០ នហ ១៣:១ មីក ៦:៥ ២ពត ២:១៥–១៦ យដ ខ.១១ វវ ២:៤) ។

**២២:៩** ដែលថាព្រះទ្រង់បានមានព្រះបន្ទូលទៅបាឡាម ដែលមិនអាចប្រកែកបាន ប៉ុន្តែ បាឡាមមិនបានយល់ដឹងនៅឡើយទេថា ព្រះនៃសាសន៍អ៊ីស្រាអែល មិនដូចជាពួកទេវតា ដែលគេកសាងឡើងនោះទេ ហើយដែលបាឡាមតែងតែមានគម្រោងការណ៍ប្រឆាំងជានិច្ចនោះ ។

**២២:១២** *គេជាអ្នកមានពរហើយ* ពួកកូនចៅអ៊ីស្រាអែលត្រូវបានទទួលព្រះពរពីព្រះអម្ចាស់ តាមព្រះបន្ទូលសន្យារបស់ផងទ្រង់ មានចំពោះលោកអ័ប្រាហាំ (សូមមើលការពន្យល់នៅ លប ១២:២–៣) ។

**២២:២០** *ទៅជាមួយនឹងគេចុះ* ដែលកើតមានឡើងនូវភាពផ្ទុយគ្នារវាងការអនុញ្ញាតរបស់ផងព្រះបានប្រទានឱ្យ បាឡាមនៅទីនេះ និងការហាមឃាត់ដែលគាត់ត្រូវបានផ្តល់ឱ្យកាលពីពេលមុន (ខ.១២) ហើយបន្ទាប់មកទៀតសេចក្តីខ្ញាល់របស់ផងព្រះអម្ចាស់បានសម្តែងឱ្យឃើញថា ទ្រង់ជិទាស់ប្រឆាំងនឹងបាឡាម នាពេលដែលគាត់កំពុងធ្វើដំណើរទៅនោះ (ខ.២២) ។ ភាពលំបាក គឺងាយយល់ជាទីបំផុត ដូចដែលមានសណ្ឋាននៅក្នុងលក្ខណៈផ្ទុយគ្នារបស់បាឡាម ។ ព្រះបានហាមឃាត់ដល់គាត់ មិនឱ្យចេញទៅដាក់បណ្តាសាដល់ពួកកូនចៅអ៊ីស្រាអែលឡើយ ។ ដែលកាលមុននោះបន្តិចព្រះអង្គបានអនុញ្ញាតឱ្យបាឡាមទៅ ប៉ុន្តែព្រះអង្គទ្រង់តាមជាប់នៅជាមួយ ថាតើបាឡាមធ្វើទៅតាមទិសដៅរបស់ព្រះអម្ចាស់ដែរឬទេ ។ តាមការពិតទៅ បាឡាមមានបំណងរួចស្រេចទៅហើយ ដើម្បីធ្វើទៅតាមបញ្ជារបស់ផងព្រះ ហើយនិងទៅតាមបំណងព្រះហឫទ័យទ្រង់ផង នាពេលដែលប្រឈមមុខជាមួយនឹងពួកហោរារបស់ពួកសាសន៍ដទៃទាំងនោះ ។

**២២:២៣** *លាក៏ឃើញទេវតានៃព្រះយេហូវ៉ា* ក្នុងនាមជាហោរានៃសាសន៍ដទៃបាឡាម មានអ្នកជំនួយការដ៏ពិសេសម្នាក់ ដែលជាសត្វមានញាណដឹង ប៉ុន្តែ សត្វលានោះពុំចេះនិយាយ ដោយវាបានឃើញអ្វី ដែលបាឡាមមិនអាចមើលឃើញ ។

ទៅឈរ នៅត្រង់កន្លែងចង្អៀត១ទៀត ដែលឥតមានផ្លូវ
ណានឹងងាកបែរ ទៅខាងឆ្វេងឬខាងស្តាំបានឡើយ [២៧]លា
ក៏ឃើញទេវតានៃព្រះយេហូវ៉ា រួចវាលុតជង្គង់ក្រាបចុះ
ទាំងបាឡាមនៅលើខ្នង នោះបាឡាមក៏ខឹងក្តៅឡើង[ស]
ហើយវាយវានឹងឈើច្រត់ [២៨]រួចព្រះយេហូវ៉ា ទ្រង់បើក
មាត់លា[ហ] វាក៏និយាយទៅបាឡាមថា តើខ្ញុំបានធ្វើអ្វីដល់
លោក បានជាលោកវាយខ្ញុំ៣ដងហើយនេះ[ឡ] [២៩]បាឡាម
ឆ្លើយទៅលាថា គឺពីព្រោះឯងកៀចនឹងអញណាស់ បើសិន
ជាអញមានដាវនៅដៃឥឡូវ នោះអញនឹងសំឡាប់ឯងចោល
ហើយ[អ] [៣០]សត្វលាតបថា តើខ្ញុំមិនមែនជាលារបស់លោក
ដែលលោកបានជិះមក តាំងពីខ្ញុំជារបស់ផងលោក ដរាប
ដល់សព្វថ្ងៃនេះទេឬអី តើខ្ញុំដែលធ្លាប់ធ្វើយ៉ាងដូច្នេះចំពោះ
លោកដែរឬនោះគាត់ឆ្លើយថា ទេ ។

[៣១]នោះព្រះយេហូវ៉ាទ្រង់បើកបំភ្លឺភ្នែកបាឡាម[ក] ឱ្យ
ឃើញទេវតានៃទ្រង់ ដែលឈរនៅត្រង់ផ្លូវ ទាំងកាន់ដាវ
ហូតជាស្រេចនៅព្រះហស្ត រួចគាត់ឱនក្បាលទំលាក់ខ្លួន
ក្រាបចុះផ្កាប់មុខ [៣២]ទេវតានៃព្រះយេហូវ៉ាក៏សួរគាត់ថា
ហេតុអ្វីបានជាឯងវាយលាដល់ទៅ៣ដងដូច្នេះ មើលអញ
បានចេញមកទាស់នឹងឯង ពីព្រោះឯងមានចិត្តវៀចនៅ
មុខអញ [៣៣]លារបស់ឯងបានឃើញអញ ហើយបានងាក
បែរចេញពីអញ៣ដងនេះហើយ បើវាមិនបានបែរចេញ
ពីអញទេ នោះប្រាកដជាអញបានសំឡាប់ឯងហើយ[ខ] តែទុក
ឱ្យវានៅរស់វិញ [៣៤]នោះបាឡាមក៏ទូលទៅទេវតានៃព្រះ
យេហូវ៉ាថា ទូលបង្គំបានធ្វើបាបហើយ[គ] ពីព្រោះទូលបង្គំ
មិនបានដឹងជាទ្រង់ឈរនៅត្រង់ផ្លូវ ទាស់នឹងទូលបង្គំទេ
ដូច្នេះ បើដំណើរនេះមិនសព្វព្រះហឫទ័យដល់ទ្រង់ នោះ
ទូលបង្គំនឹងត្រឡប់ទៅវិញឥឡូវ [៣៥]តែទេវតានៃព្រះយេហូ
វ៉ាមានបន្ទូលតបថា ចូរទៅជាមួយនឹងគេចុះ ប៉ុន្តែត្រូវឱ្យឯង
និយាយតែពាក្យដែលអញប្រាប់ដល់ឯងប៉ុណ្ណោះ ដូច្នេះ
បាឡាមក៏ទៅជាមួយនឹងពួកមេរបស់បាឡាកទៅ ។

[៣៦]កាលបាឡាក[ឃ]ឮថា បាឡាមមកដល់ហើយ នោះទ្រង់
ក៏ចេញទៅទទួលដល់ទីក្រុង១នៃស្រុកម៉ូអាប់ ដែលនៅមាត់
ស្ទឹងអើណូន[ង] ជាព្រំដែនឆ្ងាយបំផុត [៣៧]បាឡាកមានបន្ទូល
ទៅបាឡាមថា តើអញមិនបានចាត់គេ ឱ្យទៅហៅឯងមក
ទេឬអី ហេតុអ្វីបានជាឯងមិនបានមកឯអញ តើអញមិន
អាចនឹងលើកឯងឱ្យបានជាធំទេឬអី [៣៨]បាឡាមក៏ទូលតបថា
មើល ទូលបង្គំបានមកដល់ទ្រង់ហើយ តែឥឡូវនេះ តើទូល
បង្គំមានអំណាចនឹងនិយាយអ្វីបាន ឯពាក្យណាដែលព្រះ
ទ្រង់សំរេចនៅមាត់ទូលបង្គំ[ច] គឺពាក្យនោះដែលទូលបង្គំនឹង
និយាយវិញ [៣៩]រួចបាឡាមក៏ទៅជាមួយនឹងបាឡាក ដល់ទៅ
គារយ៉ាត់-ហាសូត [៤០]នោះបាឡាកទ្រង់ថ្វាយគោ និងចៀម[ឆ]
ជាយញ្ញបូជា រួចផ្ញើទៅឱ្យបាឡាម និងពួកមេដែល
នៅជាមួយនឹងគាត់ [៤១]ដល់ថ្ងៃស្អែក បាឡាកទ្រង់នាំ
យកបាឡាមឡើងទៅលើអស់ទាំងទីខ្ពស់របស់ផងព្រះបាល[ជ]
ហើយពីទីនោះ គាត់ក៏ឃើញចុងបំផុតនៃពួកសាសន៍អ៊ីស្រា
អែល[ឈ] ។

## លោកបាឡាមថ្លែងទំនាយលើកទី១

**២៣** [១]នោះបាឡាមទូលទៅបាឡាកថា សូមទ្រង់ធ្វើ

**២២:២៧** ស ជន ១១:១ យក ១:១៩
**២២:២៨** ហ ២ពត ២:១៦ ឡ ខ.៣២
**២២:២៩** អ ខ.៣៣ ចទ ២៥:៤ សភ ១២:១០ ២៧:២៣-២៧ មថ ១៥:១៩
**២២:៣១** ក លប ២១:១៩
**២២:៣៣** ខ ខ.២៩
**២២:៣៤** គ លប ៣៩:៩ ជន ១៤:៤០ ១សយ ១៥:២៤,៣០ ២សយ ១២:១៣ ២៤:១០ យប ៣៣:២៧ ទដ ៥១:៤
**២២:៣៦** ឃ ខ.២ ង ជន ២១:១៣
**២២:៣៨** ច ជន ២៣:៥,១៦,២៦
**២២:៤០** ឆ ជន ២៣:១ ១៤:២៩ អគ ៤៥:២៣
**២២:៤១** ជ ជន ២១:២៨ ឈ ជន ២៣:១៣

**២២:២៩** *បើសិនជាអញមានដាវនៅដៃ* ជាទិដ្ឋភាពមួយដែលគួរឱ្យអស់សំណើចនៃគ្រោះកាចរបស់បាឡាម ។ ដោយមានដាវនៅជិតបង្កើយ (សូមមើល ខ.២៣,៣១-៣៣) ប៉ុន្តែសត្វលានោះ ដែលពុំព្រមដើរទៅមុខគ្រាន់តែជាអ្នករងគ្រោះប៉ុណ្ណោះ ។

**២២:៣១** *នោះព្រះយេហូវ៉ាទ្រង់បើកបំភ្លឺភ្នែកបាឡាម* ភាសានេះមានដំណើរទៅតាមទ្រង់ទ្រាយប្រយោគតែមួយដូចគ្នា ដូចដែលមានពាក្យបើកចំហនៅក្នុង ខ.២៨ ។ នៅតាមវិធីខ្លះទៀត ការបើកបំភ្លឺភ្នែករបស់ហោរាសាសន៍ដទៃ ដើម្បីឱ្យបានមើលឃើញនូវសេចក្តីពិតនៃទេវតា ដែលបានធ្វើការអស្ចារ្យដ៏ធំមួយ ។

**២២:៣៥** *និយាយតែពាក្យដែលអញប្រាប់ឯងប៉ុណ្ណោះ* ផលកម្រៃដ៏ធំមួយបានមានឡើង ត្រង់ដែលថា បាឡាមនាពេលនេះបានយកចិត្តទុកដាក់ទៅនឹងភាពដ៏ធ្ងន់ធ្ងរនៃភារកិច្ចនៅចំពោះព្រះភក្ត្រទ្រង់ ហើយគាត់មិនអាចនឹងផ្លាស់ប្តូរព្រះបន្ទូល ដែលព្រះអម្ចាស់បានប្រទានមកគាត់នោះឡើយ (សូមមើល ២៣:១២,២០,២៦) ។

**២២:៣៧** *និយាយតែពាក្យដែលអញប្រាប់ដល់ឯងប៉ុណ្ណោះ* សារធាតុដែលគួរឱ្យអស់សំណើចនៅក្នុងសាច់រឿង ត្រូវបានបង្ហាញឱ្យឃើញថាមិនត្រឹមតែធ្វើឱ្យបាឡាមស្ថិតនៅក្នុងគ្រោះកាចប៉ុណ្ណោះទេ តែក៏ស្ថិតនៅក្នុងស្ថានភាពមួយដែលបាឡាកមិនបានសម្រេចបំណងផងដែរ (សូមមើល ២៣:១១,២៥ ២៤:១០) ។

**២២:៤០** ផ្នែកទាំងឡាយដែលបានផ្តល់ឱ្យទៅបាឡាម ដោយរួមទាំងថ្លើមសត្វផងដែរ នោះសម្រាប់តែពួកព្រះនៃសាសន៍ដទៃ ដែលបាឡាមនោះឯងជាអ្នកជំនាញខាងការថ្វាយថ្លើមទៅពួកទេវតានៃសាសន៍ដទៃ ។ បាឡាមបានបោះបង់ចោលជាបន្តបន្ទាប់នូវសកម្មភាពរបស់គាត់ដូចជាមន្តអាគមអាបធ្មប់ចេញចោលទាំងអស់ ដោយប្តូរមកជាអំណាចចេស្តានៃព្រះបន្ទូលរបស់ផងព្រះ ដែលបានយាងមកសណ្ឋិតនៅលើគាត់ (២៤:១) ។

**២៣:១** *អាសនា៧ . . . គោឈ្មោល៧ និងចៀមឈ្មោល៧* ការថ្វាយយញ្ញបូជាទាំងនេះត្រូវបានរៀបចំឡើងជាផ្នែកមួយសម្រាប់ជាសកម្មភាពរបស់បាឡាមដែលជាសាសន៍ដទៃ ។ រីឯចំនួន៧ (ដែលមានន័យថា ពេញលេញបរិបូណ៌) ត្រូវបានប្រព្រឹត្តទៅដោយការគោរពដ៏ខ្ពង់ខ្ពស់ក្នុងចំណោមប្រជាជននៃតំបន់មេសូប៉ូតាមាក្នុងលក្ខណៈជាទូទៅ ។ សត្វជាច្រើនទៀត ដែលនឹងត្រូវដាក់ធ្វើជាយញ្ញបូជាដោយមានថ្លើមទាំងមូល និងបណ្តាគ្រឿងក្នុងដទៃទៀតផងសម្រាប់ពួកទេវតាដែលនៅតំបន់ភាគពាយ័ព្យនៃមេសូប៉ូតាមា ។

អាសនា៧នៅទីនេះឱ្យទូលបង្គំ ហើយរៀបគោឈ្មោល៧និង
ចៀមឈ្មោល៧[ក]ផង ២បាឡាកទ្រង់ក៏ធ្វើដូចជាបាឡាម
បានថា នោះបាឡាកហើយនិងបាឡាមក៏ថ្វាយគោ និង
ចៀមមួយៗនៅលើអាសនាទាំងនោះ[ខ] ៣រួចបាឡាមគាត់
ទូលទៅបាឡាកថា សូមទ្រង់ឈរនៅជិតដង្វាយទ្រង់នេះចុះ
ទូលបង្គំនឹងទៅ ប្រហែលជាព្រះយេហូវ៉ានឹងយាងមកជួប
នឹងទូលបង្គំ[គ] បើសេចក្ដីណាដែលទ្រង់បង្ហាញមកទូលបង្គំ
នោះទូលបង្គំនឹងនាំមកទូលដល់ទ្រង់ រួចគាត់ក៏ឡើងទៅឯ
ទីខ្ពស់ ៤ឯព្រះទ្រង់ក៏មកជួបនឹងបាឡាម[ឃ] រួចគាត់ទូលទ្រង់
ថា ទូលបង្គំបានរៀបចំអាសនាទាំង៧ ហើយបានថ្វាយ គោ
និងចៀមមួយៗ នៅលើអាសនាទាំងនោះ ៥នោះព្រះ
យេហូវ៉ា ទ្រង់ដាក់ព្រះបន្ទូលនៅក្នុងមាត់បាឡាម[ង,ច] ហើយ
ប្រាប់ថា ចូរត្រឡប់ទៅឯបាឡាកវិញទៅ ហើយត្រូវនិយាយ
ដូច្នេះ[ឆ] ៦គាត់ក៏ត្រឡប់ទៅឯបាឡាក ឃើញទ្រង់កំពុងតែ
ឈរនៅជិតដង្វាយរបស់ទ្រង់នៅឡើយ មានអស់ទាំងមេ
របស់សាសន៍ម៉ូអាប់នៅជាមួយ[ជ] ៧រួចគាត់[ឈ]ចាប់តាំង
បញ្ចេញព្រះបន្ទូល [ញ]ដោយពាក្យថា បាឡាកជាស្ដេចនៃ
សាសន៍ម៉ូអាប់ ទ្រង់បាននាំខ្ញុំពីស្រុកអើរ៉ាមមក[ដ] គឺពីស្រុកភ្នំ
ទិសខាងកើត[ឋ] ដោយប្រាប់ថា ចូរមក ចូរដាក់បណ្ដាសា
ដល់ពួកយ៉ាកុបឱ្យអញ ហើយថា ចូរមក ចូរប្រកួតនឹង
សាសន៍អ៊ីស្រាអែលចុះ[ឌ] ៨តែធ្វើដូចម្ដេចឱ្យខ្ញុំដាក់បណ្ដាសា
ដល់អ្នកណា ដែលព្រះទ្រង់មិនបានដាក់បណ្ដាសាទៅកើត[ឍ]
ហើយធ្វើដូចម្ដេចឱ្យខ្ញុំប្រកួតនឹងអ្នកណា ដែលព្រះយេហូវ៉ា
មិនបានប្រកួតចំពោះគេបាន[ណ] ៩ដ្បិតខ្ញុំបានឃើញគេពីលើ
កំពូលថ្មដា ខ្ញុំបានរំពឹងមើលគេពីលើភ្នំទាំងប៉ុន្មាន[ត] មើល
សាសន៍នេះគេនៅតែដោយពួកគេទេ គេមិនបានរាប់
បញ្ចូល ក្នុងនគរទាំងប៉ុន្មានឡើយ[ថ] ១០តើអ្នកណានឹងរាប់
ធូលីរបស់យ៉ាកុប[ទ]បាន ឬរាប់ចំនួននៃសាសន៍អ៊ីស្រាអែល១
ភាគក្នុង៤បាន សូមតែឱ្យខ្ញុំបានស្លាប់ដូចជាពួកសុចរិតនោះ
ចុះ[ធ] ហើយសូមឱ្យទីបំផុតនៃជីវិតរបស់ខ្ញុំបានដូចជាគេ
ដែរ[ន]។

១១នោះបាឡាកទ្រង់មានបន្ទូលទៅបាឡាមថា តើឯង
បានធ្វើយ៉ាងដូចម្ដេចនឹងអញ គឺអញបាននាំឯងមកឱ្យដាក់
បណ្ដាសាដល់ពួកខ្មាំងសត្រូវរបស់អញ[ប] តែមើល ឯងបាន
ឱ្យពរដល់គេវិញ[ផ] ១២គាត់ទូលឆ្លើយថា តើមិនត្រូវឱ្យទូល
បង្គំប្រយ័ត្ន នឹងនិយាយតែសេចក្ដី ដែលព្រះយេហូវ៉ាទ្រង់
សំរេចនៅក្នុងមាត់ទូលបង្គំទេឬអី[ព]។

## លោកបាឡាមថ្លែងទំនាយលើកទី២

១៣រួចបាឡាកមានបន្ទូលនឹងគាត់ថា ចូរមកជាមួយនឹង
អញ ទៅឯកន្លែង១ទៀត[ភ] ជាកន្លែងដែលល្មមឱ្យឯងមើល
គេឃើញ ឯងនឹងឃើញតែពួកគេខាងចុងបង្អស់ ឥត
ឃើញទាំងអស់ទេ[ម] រួចចូរឯងដាក់បណ្ដាសាគេពីទីនោះឱ្យ
អញ[យ] ១៤នោះទ្រង់នាំគាត់ទៅឯវាលសូភិម នៅលើភ្នំ

**២៣:១** ក ជន ២២:៤០
**២៣:២** ខ ខ.១៤,៣០
**២៣:៣** គ ខ.១៥
**២៣:៤** ឃ ខ.១៦
**២៣:៥** ង នក ៤:១២ អស ៥៩:២១ ច នក ៤:១៥ ឆ ជន ២២:២០
**២៣:៦** ជ ខ.១៧
**២៣:៧** ឈ ជន ២២:៥ យស ២៤:៩ ញ ខ.១៨ ជន ២៤:៣,២១ ២សយ ២៣:១
**២៣:៧** ដ ២ពវ ៥:១ ឋ លប ២៤:១០ ឌ ជន ២២:៦ នហ ១៣:២
**២៣:៨** ឍ ជន ២២:១២ ណ ខ.២០ អស ៤៣:១៣
**២៣:៩** ត ជន ២២:៤១ ថ នក ៣៣:១៦ ចទ ៣២:៨
**២៣:១០** ទ លប ១៣:១៦ ធ ទដ ១៦:៣ ១១៦:១៥ អស ៥៧:១ ន ទដ ៣៧:៣៧ **២៣:១១** ប ជន ២២:៦ ផ ជន ២៤:១០ យស ២៤:១០ នហ ១៣:២**២៣:១២** ព ជន ៨,២០ **២៣:១៣** ភ ខ.២៧ម ជន ២២:៤១ យ ជន ២២:៦ **២៣:១៤** រ ជន ២១:២០ ២៧:១២

**២៣:២** *បាឡាកទ្រង់ក៏ធ្វើដូចជាបាឡាមបានថា* បាឡាមត្រូវបានទទួលបន្ទុកធ្វើការងារនេះ រីឯបាឡាក ឥឡូវនេះបានក្លាយជាអ្នកស្ថិតនៅក្រោមបង្គាប់វិញម្ដង ។

**២៣:៧–២៤:២៤** មានពាក្យពោលទំនាយតាមរបៀបកំណាព្យកាព្យឃ្លាចំនួន ៧ មាននៅក្នុងខទាំងនេះ: វគ្គទី១ មាន៤ខ ដែលមានឃ្លាវែងបន្តិច បានចាប់ផ្ដើមដោយរៀបរាប់ ទុកដូចជាស្ពានចម្លង ហើយត្រូវបានមានចែងជារបៀបកំណាព្យប្រកបដោយលក្ខណះពិរោះយ៉ាងក្រៃលែង (២៣:៧–១០ ២៣:១៨–២៤ ២៤:៣–៩ ២៤:១៥–១៩) ។ វគ្គចុងក្រោយមាន ៣ខ ត្រូវបានបរិយាយដោយសង្ខេប ហើយមានអត្ថន័យពិបាកនឹងយល់ទៀតផង ព្រមទាំងមានរបៀបលំនាំណែងណងពីមួយទៅមួយ (សូមមើល ២៤:២០,២១–២២,២៣–២៤) ។

**២៣:៧** *ព្រះបន្ទូល* ជាភាសាហេព្រើរគឺ"*ម៉ាសាល*" (*mashal*) ជាធម្មតាបកប្រែថា "សុភាសិត" ប៉ុន្តែនៅក្នុងខនេះទៅជាមានន័យថា "ពាក្យទំនាយ" ទៅ វិញ ដើម្បីឱ្យត្រូវទៅតាមអត្ថន័យដ៏សមរម្យវិញ ។ ដោយពាក្យនេះមានលក្ខណះសម្គាល់ការថ្លែងទំនាយរបស់បាឡាមត្រូវបានបង្កើតឡើង គ្មានការពោលទំនាយណាមួយនៃហោរាពិតរបស់ពួកកូនចៅអ៊ីស្រាអែល ត្រូវបានគេពិពណ៌នានៅក្នុងប្រយោគនេះ ។

**២៣:៨** *តែធ្វើដូចម្ដេចឱ្យខ្ញុំដាក់បណ្ដាសាដល់អ្នកណា ដែលព្រះទ្រង់មិនបានដាក់បណ្ដាសាទៅកើត* ដែលថាបាឡាមត្រូវបានជួលឱ្យធ្វើការនេះ ដែលគាត់មិនអាចធ្វើទៅកើត ។ ព្រះទ្រង់បានទប់គាត់ពីការបន្លឺសូរស័ព្ទនូវរាល់ពាក្យបណ្ដាសាដល់កូនចៅរបស់ផងទ្រង់ ដែលជាពូជមនុស្សជាតិជ្រើសរើសក្នុងចំណោមមនុស្សជាតិនានាក្នុងលោកិយយើងនេះ (ខ.៩) ។

**២៣:១០** *សូមតែឱ្យខ្ញុំបានស្លាប់ដូចជាពួកសុចរិតនោះចុះ* ជាសេចក្ដីប៉ងប្រាថ្នាមួយ ដែលមិនបានប្រទានឱ្យ (សូមមើល ៣១:៨,១៦) ។ *សូមឱ្យទីបំផុតនៃជីវិតរបស់ខ្ញុំបានដូចជាគេដែរ* គាត់គឺជាជនម្នាក់ ដែលបានមកដើម្បីដាក់បណ្ដាសា តែផ្ទុយទៅវិញបែរជាមានសេចក្ដីប៉ងប្រាថ្នាចង់ចូលរួមនៅក្នុងការប្រទានព្រះពរដល់ពួកកូនចៅអ៊ីស្រាអែលទៅវិញ ។

**២៣:១៣** *ពួកគេខាងចុងបង្អស់ ឥតឃើញទាំងអស់ទេ* បាឡាកបានមានបំណងកាត់បន្ថយនូវអំណាចចេស្ដាមានដល់ពួកកូនចៅអ៊ីស្រាអែល ដោយធ្វើការជ្រើសរើសទីតាំងត្រង់ចំណុចមួយ ដែលជាកន្លែងអាចមើលឃើញច្បាស់នូវចំនួនដ៏ច្រើនលើសលុបរបស់ពួកកូនចៅអ៊ីស្រាអែលបាន ។ តែដោយសំណាងអាក្រក់របស់បាឡាក ការពោលទំនាយបែរជាពោលសរសើរដូចមាននៅក្នុង ខ.១៨–២៤ ដែលមានច្រើនលើសពីការទទួលព្រះពរនៅគ្រាទីមួយទៅលើពួកកូនចៅអ៊ីស្រាអែលទៅទៀត ។

ពីសកា[វ] ក៏ធ្វើអាសនា៧ ហើយថ្វាយគោនិងចៀមមួយៗនៅ
លើអាសនាទាំងនោះ[ល] ១៥បាឡាមទូលទៅបាឡាកថា សូម
ទ្រង់ឈរនៅជិតដង្វាយទ្រង់នេះចុះ ចាំទូលបង្គំទៅជួបនឹង
ព្រះសិន ១៦ព្រះយេហូវ៉ាទ្រង់ក៏យាងមកជួបនឹងបាឡាម
ហើយដាក់ព្រះបន្ទូលទៅក្នុងមាត់គាត់[វ] រួចប្រាប់ថា ចូរ
វិលត្រឡប់ទៅឯបាឡាកវិញចុះ ហើយត្រូវនិយាយដូច្នេះ
១៧គាត់ក៏មកឯបាឡាក ឃើញទ្រង់កំពុងតែឈរនៅជិត
ដង្វាយរបស់ទ្រង់នៅឡើយ មានទាំងពួកមេនៃសាសន៍
ម៉ូអាប់នៅជាមួយ[ស] រួចបាឡាកសួរថា តើព្រះយេហូវ៉ាមាន
បន្ទូលថាដូចម្តេច ១៨នោះគាត់ចាប់តាំងបញ្ចេញព្រះបន្ទូល
ដោយពាក្យថា[ហ] សូមឈរឡើង ព្រះរាជាអើយ សូមទ្រង់
ស្តាប់សិន ឱបុត្រស៊ីបព័រអើយ សូមផ្ទៀងព្រះស្រោតស្តាប់
ទូលបង្គំចុះ[ឡ] ១៩ព្រះទ្រង់មិនមែនជាមនុស្ស[អ] ទ្រង់មិនចេះ
កុហកឡើយ ក៏មិនមែនជាកូនមនុស្សដែរ ទ្រង់មិនត្រូវការ
នឹងប្រែគំនិតទេ[ក]សេចក្តីដែលទ្រង់មានវាចាហើយ[ខ] តើទ្រង់
មិនធ្វើតាមឬអី ឬសេចក្តីដែលទ្រង់មានបន្ទូល[គ] តើមិន
សំរេចតាមទេឬអី ២០មើល ទូលបង្គំបានទទួលបង្គាប់មកថា
ត្រូវឱ្យពរ[ឃ] ព្រះទ្រង់ក៏បានឱ្យពរ[ង]ហើយ ដូច្នេះទូលបង្គំពុំ
អាចនឹងបំផ្លាស់ទៅបានទេ[ច] ២១ទ្រង់មិនបានឃើញជាពួក
យ៉ាកុបមានសេចក្តីទុច្ចរិតអ្វីទេ[ឆ] ក៏មិនឃើញជាមានសេចក្តី
អាក្រក់ណានៅក្នុងពួកអ៊ីស្រាអែលដែរ[ជ] ព្រះយេហូវ៉ា ជា
ព្រះនៃគេ ទ្រង់គង់នៅជាមួយនឹងគេ[ឈ] ក៏មានឮសំរែកនៃ
ស្តេច[ញ]នៅកណ្តាលពួកគេ ២២ព្រះទ្រង់បាននាំគេចេញពី
ស្រុកអេស៊ីព្ទមក[ដ] គេមានកំឡាំងបែបដូចជាកំឡាំង នៃសត្វ
រមាស[ឋ] ២៣គ្មានមន្តវិជ្ជាការណានឹងដាក់ពួកយ៉ាកុប ឬអំពើ
អំពាន់[ឌ] ណាដាក់សាសន៍អ៊ីស្រាអែលត្រូវទេ លុះដល់កំណត់
នោះ នឹងមានពាក្យដំណាលពីយ៉ាកុប ហើយពីអ៊ីស្រាអែល
ថា យីអើទ្រង់បានធ្វើអ្វីនេះហ្ន៎ ២៤មើលបណ្តាជននេះ
គេក្រោកឡើងដូចជាសិង្ហញី[ឍ] ក៏ឈរឡើងដូចជាសង្ហ
ឈ្មោល[ណ] គេមិនដេកវិញទាល់តែបានស៊ីរំពាហើយ ព្រម
ទាំងផឹកឈាម[ត] នៃពួកដែលបានសំឡាប់ផង ។
២៥នោះបាឡាកមានបន្ទូលទៅបាឡាមថាបើមិនប្រទេច
ផ្តាសាគេទេ នោះក៏មិនត្រូវឱ្យពរគេដែរ ២៦តែបាឡាម
ទូលឆ្លើយថា តើទូលបង្គំមិនបានទូលទ្រង់ទេឬអីថា គ្រប់
ទាំងសេចក្តីដែលព្រះយេហូវ៉ាមានបន្ទូល នោះទូលបង្គំត្រូវ
តែធ្វើតាម[ថ] ។

## លោកបាឡាមថ្លែងទំនាយលើកទី៣

២៧រួចបាឡាកទ្រង់មានបន្ទូលទៅបាឡាមថា ចូរមក
អញនឹងនាំឯងទៅកន្លែង១ទៀត[ទ] ប្រហែលជាព្រះនឹងសព្វ
ព្រះហឫទ័យ ឱ្យឯងដាក់បណ្តាសាដល់គេពីទីនោះឱ្យអញ[ធ]
២៨បាឡាកក៏នាំបាឡាមទៅលើកំពូលភ្នំពេអរ[ន] ដែលបែរ
ទៅខាងឯទីរហោស្ថាន ២៩នោះបាឡាមទូលទៅបាឡាកថា
សូមទ្រង់ធ្វើអាសនា៧នៅទីនេះឱ្យទូលបង្គំ ហើយសូមរៀប
គោ៧ និងចៀម៧ ឱ្យទូលបង្គំទៀត ៣០រួចបាឡាកក៏ធ្វើដូច
ជាបាឡាមបានមានវាចា គឺបានថ្វាយគោ និងចៀមមួយៗ
នៅលើអាសនាទាំងនោះ[ប] ។

២៤ ១កាលបាឡាមបានឃើញថា ព្រះយេហូវ៉ាសព្វព្រះ
ហឫទ័យនឹងឱ្យពរ ដល់សាសន៍អ៊ីស្រាអែលដូច្នោះ[ក] នោះ

**២៣:១៤** ល ខ.២ **២៣:១៦** វ នក ៤:១៥ ជន ២២:៣៨ **២៣:១៧** ស ខ.៦ **២៣:១៨** ហ ខ.៧ ឡ ជន ២២:២ **២៣:១៩** អ យប ៩:៣២ អស ៥៥:៩ ហស ១១:៩ ក ជន ១១:២៣ ខ ១សយ ១៥:២៩ យប ១២:១៣ ៣៦:៥ ទដ ៣៣:១១ ៨៩:៣៤ ១០២:២៧ ១១០:៤ យរ ៤:២៨ ៧:១៦ មឡ ៣:៦ ទត ១:២ ហព ៦:១៨ ៧:២១ យក ១:១៧ គ ២សយ ៧:២៥ ទដ ១១៩:៣៨ **២៣:២០** ឃ ខ.៥,៦ ជន ២៤:១ ង លប ២២:១៧ ជន ២២:១២ ច ខ.៨ យប ៩:១២ **២៣:២១** ឆ ទដ ៣២:២,៥ ៨៥:២ រម ៤:៧–៨ ជ អស ៣៣:២៤ ៤០:២ យរ ៥០:២០ ឈ លប ២៦:៣ នក ២៩:៤៥,៤៦ ចទ ៤:៧ ទដ ៣៤:១៧–១៨ ១៤៥:១៨ សក ២:១០ ញ ចទ ៣២:១៥ ៣៣:៥ ទដ ៨៩:១៥–១៨ អស ៤៤:២ **២៣:២២** ដ ជន ២៤:៨ យស ២:១០ ៩:៩ ឋ ចទ ៣៣:១៧ យប ៣៩:៩ ទដ ២២:២១ ២៩:៦ ៩២:១០ អស ៣៤:៧ **២៣:២៣** ឌ ខ.៣លប ៣០:២៧ ជន ២៤:១ **២៣:២៤** ឍ ជន ២៤:៩ អក ១៩:២ ណហ ២:១១ ណ លប ៤៩:៩ ត អស ៤៩:២៦ **២៣:២៦** ថ ជន ២២:១៨,២០ **២៣:២៧** ទ ខ.១៣ ធ ជន ២៤:១០ **២៣:២៨** ន ជន ២៥:៣,១៨ ៣១:១៦ ចទ ៣:២៩ ៤:៣ យស ២២:១៧ ទដ ១០៦:២៨ ហស ៩:១០ **២៣:៣០** ប ខ.២ **២៤:១** ក ជន ២៣:២០

**២៣:១៩** *ព្រះទ្រង់មិនមែនជាមនុស្ស ទ្រង់មិនចេះកុហកឡើយ* ពាក្យដ៏ប្រសើរឧត្តុង្គឧត្តមទាំងនេះ ពិពណ៌នាអំពីភាពមិនចេះប្រែប្រួលរបស់ព្រះអម្ចាស់ និងភាពស្មោះត្រង់នៃព្រះបន្ទូលផងទ្រង់ ។ លោកបាឡាម គឺជាបុគ្គលដែលផ្ទុយពីព្រះអម្ចាស់ ព្រោះចិត្តរបស់គាត់ប្រែប្រួលជានិច្ច គ្មានការសម្រេចចិត្តច្បាស់លាស់ ហើយនិយាយបង្វែរការពិត ។ លក្ខណៈទាំងនេះជាឧទាហរណ៍បញ្ជាក់ពីភាពផ្ទុយគ្នារវាងព្រះ និងមនុស្ស ។

**២៣:២១** *សំរែកនៃស្តេចនៅកណ្តាលពួកគេ* នោះគឺជាសេចក្តីប្រកាសដ៏ជាក់ស្តែងស្តីអំពីភាពជាស្តេចនៃព្រះអម្ចាស់ នៅក្នុងគម្ពីរប្រាំកណ្ឌដំបូង ដែលបានបង្កើតឡើងដោយបាឡាម គឺជាភាពដែលសមមិនគួរឱ្យជឿទៅបាននោះព្រោះថា ព្រះគឺជាព្រះមហាក្សត្រ ព្រះអង្គអាចប្រើប្រាស់បាឡាមសម្រាប់ការងារចុងបញ្ចប់របស់ផងទ្រង់បាន ពោលគឺរាស្ត្ររបស់ព្រះអង្គនៅក្នុងលក្ខណៈថ្មី និងអស្ចារ្យមួយ ។

**២៣:២២** *សត្វរមាស* (សត្វម្យ៉ាងដូចសេះមានស្នែង១ដុះត្រង់កណ្តាលក្បាល) គឺជាថនិកសត្វម្យ៉ាងពីបុរាណមក ដែលមានកម្លាំងខ្លាំង គេច្រើនជួបប្រទះមានរស់នៅម្តុំក្បែរបូព៌ាប្រទេស (សូមមើលពាក្យនេះមានម្តងទៀតនៅក្នុង ២៤:៨ ផងដែរ) ។

**២៣:២៣** *គ្មានមន្តវិជ្ជាការណានឹងដាក់ពួកយ៉ាកុប* បាឡាមនិយាយពីបទពិសោធន៍ដែលពោរពេញទៅដោយសេចក្តីភ័យខ្លាចរបស់គាត់ ។ គាត់មិនបាននិយាយដាក់បន្ទុកនៃឧបាយកលក្នុងការទប់ទល់នឹងការប្រទានពររបស់ផងព្រះដល់ពួកកូនចៅអ៊ីស្រាអែលនោះទេ ។

**២៣:២៤** *ដូចជាសិង្ហញី* អ៊ីស្រាអែលប្រហែលជាក្រោកឡើងមែន ហើយនិងធ្វើឱ្យសត្រូវរបស់ខ្លួនវិនាស ដូចជាតោញីដេកចាំចាប់រំពាដូច្នោះដែរ (សូមមើល ២៤:៩ លប ៤៩:៩ និងការពន្យល់) ។

**២៤:១** *បានទៅដូចជាជាន់មុន ដើម្បីនឹងរកមន្តវិជ្ជាការទៀតឡើយ* មន្តវិជ្ជា

គាត់មិនបានទៅដូចជាជាន់មុន ដើម្បីនឹងរកមន្តវិជ្ជាការ
ទៀតឡើយ[ខ] គឺគាត់បែរមុខទៅឯទីរហោស្ថានវិញ[គ] ២ក៏
ងើបភ្នែកឡើងឃើញសាសន៍អ៊ីស្រាអែល នៅក្នុងត្រសាល
តាមពូជអំបូរគេរៀងខ្លួន នោះព្រះវិញ្ញាណនៃព្រះក៏មក
សណ្ឋិតលើគាត់[ឃ] ៣ហើយគាត់ចាប់តាំងបញ្ចេញព្រះបន្ទូល
ដោយពាក្យថា នេះពាក្យរបស់បាឡាមជាកូនបេអ៊ើរ គឺជា
ពាក្យនៃមនុស្ស ដែលមើលឃើញច្បាស់ ៤ហើយជាពាក្យ
អស់មនុស្សដែលឮព្រះបន្ទូលនៃព្រះ ជាអ្នកបានឃើញ ព្រះ
ដ៏មានគ្រប់ព្រះចេស្តា ក្នុងការជាក់ស្តែង ហើយជាអ្នកដែល
ក្រាប់ចុះដោយមានភ្នែកបើកឡើង ៥គឺថា ឱយ៉ាកុបអើយ
ត្រសាលរបស់ឯងទាំងប៉ុន្មានល្អណាស់ហ្ន៎[ជ] ហើយទីលំនៅ
ឯងផង ឱអ៊ីស្រាអែលអើយ ៦ទីលំនៅទាំងនោះលយវែង
ទៅ ដូចជាច្រកភ្នំ ក៏ដូចជាច្បារនៅមាត់ទន្លេ[ឈ] ដូចជាដើម
ក្រឹស្នា[ញ]ដែលព្រះយេហូវ៉ាបានដាំ ហើយដូចជាដើមតា
ត្រៅនៅមាត់ទឹក[ដ] ៧និងមានទឹកហៀរហូរពីថាំងគេ ហើយ
ពូជគេនឹងចំរើនផលឡើងដោយមានទឹកច្រើន ស្តេចគេ
នឹងបានខ្ពស់ជាងស្តេចអ័កាក់[ឋ] ហើយនគរគេនឹងបានថ្កើង
ឡើង[ឌ] ៨ព្រះទ្រង់នាំគេចេញពីស្រុកអេស៊ីព្ទមក គេមាន
កំឡាំង ដូចជាកំឡាំងនៃសត្វរមាស គេនឹងស៊ីលេបសាសន៍
ដទៃដែលជាខ្មាំងសត្រូវនឹងគេ ព្រមទាំងបំបាក់ឆ្អឹងឱ្យខ្ទេច[ឍ]
ហើយបាញ់ទំលុះដោយព្រួញផង[ណ] ៩គេបានក្រាបក៏ដេកទៅ
ដូចជាសិង្ហឈ្មោល ហើយដូចជាសិង្ហញីផង[ត] តើអ្នកណា
ហ៊ានដាស់គេឡើង មានពរហើយ អ្នកណាដែលឱ្យពរដល់
ឯង[ថ] តែអស់អ្នកណាដែលដាក់បណ្តាសាឯង នោះត្រូវ
បណ្តាសាវិញ[ទ] ។
១០នោះបាឡាកទ្រង់មានសេចក្តីខ្ញាល់ក្តៅ[ធ]ឡើងដល់
បាឡាម ក៏ទះព្រហស្តសន្ទាប់ទៅ[ន]បាឡាមថា អញបានហៅ
ឯងមក ដើម្បីដាក់បណ្តាសាដល់ខ្មាំងសត្រូវអញ[ប] តែមើល
ឯងបានឱ្យពរដល់គេ[ផ] គ្រប់ទាំង៣ដងនេះវិញ[ព] ១១ដូច្នេះ
ចូរឯងរត់ទៅឯកន្លែងឯងឥឡូវចុះ[ភ] អញបានគិតនឹងលើក
ឯងឱ្យមានសក្តិយសជាធំ[ម]តែមើល ព្រះយេហូវ៉ាបានឃាត់
មិនឱ្យឯងមានសក្តិយសទេ ១២នោះបាឡាមទូលឆ្លើយថា តើ
ទូលបង្គំមិនបានប្រាប់ដល់ពួកអ្នកនាំសារ ដែលទ្រង់បាន
ត្រាស់ប្រើ ឱ្យទៅឯទូលបង្គំទេឬអី ថា[យ] ១៣ទោះបើព្រះរាជា
នឹងប្រទានមាសនិងប្រាក់ពេញដំណាក់ទ្រង់ ដល់ទូលបង្គំ
ក៏ដោយ គង់តែទូលបង្គំពុំអាចនឹងរំលងបញ្ញត្តិផងព្រះ
យេហូវ៉ា ដើម្បីនឹងធ្វើអំពើល្អ ឬអាក្រក់តាមចិត្តទៅបាន
ឡើយ សេចក្តីណាដែលព្រះយេហូវ៉ាទ្រង់មានបន្ទូល[រ] គឺ

**២៤:១** ខ ជន ២៣:២៣ គ ជន ២៣:២៨ **២៤:២** ឃ ជន ១១:២៥,២៦ **២៤:៣** ង ខ.១៥ **២៤:៤** ច ជន ២២:៩ ឆ លប ១៥:១ **២៤:៥** ជ យរ ៤:២០ ៣០:១៨ មឡ ២:១២ **២៤:៦** ឈ លប ២:១០ ញ ទដ ៤៥:៨ ៤:១៤ ដ យប ២៩:១៩ ទដ ១:៣ ១០៤:១៦ អគ ៣១:៥ **២៤:៧** ឋ នក ១៧:៨-១៦ ឌ ចទ ២៨:១ ២សយ ៥:១២ ១រប ១៤:២ ទដ ៨៩:២៧ ១៤៥:១១-១៣ **២៤:៨** ឍ នក ១៥:៦ យរ ៥០:១៧ ណ ២សយ ១៨:១៤ ទដ ៤៥:៥ **២៤:៩** ត ជន ២៣:២៤ ថ លប ១២:២ ទ លប ១២:៣ **២៤:១០** ធ នក ៤:១៤ ន យប ២៧:២៣ ៣៤:៣៧ បទ ២:១៥ អគ ២១:១៤ ២២:១៣ ២៥:៦ ប ជន ២២:៦ ផ ជន ២៣:១១ ចទ ២៣:៥ ព ខ.៣-៩ ជន ២៣:៧-១០,១៨-២៤ **២៤:១១** ភ ខ.១៤, ២៥ ម ជន ២២:១៧ **២៤:១២** យ ជន ២២:១៨ **២៤:១៣** រ ជន ២២:១៨

ការ និងអំពីសិល្ប៍របស់បាឡាមត្រូវបានបង្ហាញប្រាប់នៅត្រង់ខនេះ (សូមមើលការពន្យល់នៅ ២២:៤០ ២៣:១) ។

**២៤:២** *នោះព្រះវិញ្ញាណនៃព្រះ ក៏មកសណ្ឋិតលើគាត់* នេះដែលមិននឹកស្មានថា កើតមានពាក្យសំដីបង្ហាញឱ្យឃើញថា ព្រះទ្រង់បានមានជ័យជម្នះបង្ក្រាបលើពួកហោរានៃសាសន៍ដទៃឡើយ សម្រាប់គោលបំណងរបស់ខ្លួនគាត់នោះ ។ សូមមើលការប្រៀបធៀបនៅ ពច ៣:១០ ។

**២៤:៣-៤** ការណែនាំជាដំបូងប្រកបដោយអត្ថន័យធំទូលាយ នៃសេចក្តីទំនាយពិពណ៌នាអំពីបទពិសោធន៍របស់បាឡាម នៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ ។ ឥឡូវនេះភ្នែករបស់បាឡាមត្រូវបានបើកឡើងហើយ (សូមមើលការពន្យល់នៅ ២២:៣១) ។

**២៤:៦-៧** បាឡាមនិយាយនៅត្រង់ខនេះ ស្ថិតនៅក្នុងលក្ខណៈទូទៅ ប៉ុន្តែមានភាពទូលំទូលាយ ពាក្យបង្កប់ទៅដោយអត្ថន័យពេញទៅដោយព្រះពរ ដែលនឹងមានមកដល់ពួករាស្ត្រអ៊ីស្រាអែល ដែលពួកគេតាំងទីលំនៅនៅក្នុងទឹកដីសន្យា ។ ភាពថ្កុំថ្កើងនៃព្រះពរ ដែលបានមកពីព្រះអម្ចាស់គឺជាភាពស្អិតស្អាលរាក់ទាក់នៃសួនអេដែន ។

**២៤:៧** *អ័កាក់* ជាព្រះនាមស្តេច ដែលសោយរាជ្យក្នុងអំបូរនៃពួកអាម៉ាលេក (សូមមើល ខដែលប្រៀបធៀប ១សយ ១៥:៣២-៣៣) ។ ពាក្យបញ្ជិតបញ្ចៀងនៅត្រង់ខនេះ អាចមានការប៉ះពាល់ដល់ពូជអំបូរអាម៉ាលេក ដែលបានវាយប្រហារពួកកូនចៅអ៊ីស្រាអែល នៅពេលដែលពួកគេបានធ្វើដំណើរចាកចេញពីស្រុកអេស៊ីព្ទមកនោះ (សូមមើល នក ១៧:៨-១៣) ។ ហើយក៏ទទួលបានជ័យជម្នះ នៅពេលដែលពួកគេ បានចូលទៅជិតស្រុកកាណានជាលើកដំបូង (សូមមើល ១៤:៤៥) ។

**២៤:៨** *ព្រះទ្រង់នាំគេចេញពីស្រុកអេស៊ីព្ទមក* ពាក្យទាំងនេះស្ថិតនៅកណ្តាលចំណោមនៃសេចក្តីសង្គ្រោះរបស់ពួកកូនចៅអ៊ីស្រាអែល ត្រូវបានគេរៀបរាប់ដោយនរណាម្នាក់ ដែលជាសាសន៍ដទៃក្នុងនាមជាសត្រូវ (សូមមើលការពន្យល់នៅ ២៣:២១ ២៥:១-១៨) ។

**២៤:៩** *មានពរហើយ អ្នកណាដែលឱ្យពរដល់ឯង . . . នោះត្រូវបណ្តាសាវិញ* តាមការសិក្សាក្នុងទេវវិទ្យាអំពីការប្រទានពរ និងការដាក់បណ្តាសានៅក្នុងព្រះបន្ទូលសន្យា បានធ្វើចំពោះលោកអ័ប្រាហាំ (លប ១២:២-៣ សូមមើលការពន្យល់នៅត្រង់កន្លែងនោះ) ឥឡូវនេះគឺជាផ្នែកមួយនៃសេចក្តីទំនាយចំពោះការប្រទានពរទៅវិញ ។ ប្រហែលជានៅត្រង់ខនេះ ហើយដែលបាឡាមកំពុងតែនិយាយពីហេតុការណ៍ពីមុននោះ ជាថ្មីម្តងទៀតក្នុងការបញ្ជាក់ឡើងវិញពីសេចក្តីប៉ងប្រាថ្នារបស់គាត់ ក្នុងការចូលរួមនៅនៃការប្រទានពរដល់ពួករាស្ត្រអ៊ីស្រាអែល (សូមមើល ២៣:១០-១១ និងការពន្យល់នៅ ២៣:១០) ។

**២៤:១១** *ព្រះយេហូវ៉ាបានឃាត់មិនឱ្យឯងមានសក្តិយសទេ* នៅក្នុងការជិនឆ្អន់របស់គាត់ជាមួយនឹងការខកខានរបស់បាឡាមក្នុងការដាក់បណ្តាសាដល់ពួករាស្ត្រអ៊ីស្រាអែល ឥឡូវនេះបាឡាកបានបញ្ឈប់គាត់ ដោយមិនបានបង់ថ្លៃឱ្យទាំងអស់ ពោលគឺនៅទីចុងបំផុតមានការប្រមាថមើលងាយដល់សេចក្តីលោភលន់របស់គាត់ទៀតផង (សូមមើល ២ពត ២:១៥ និងការពន្យល់) ។

សេចក្តីនោះឯង ដែលទូលបង្គំនឹងថ្លែងទៅ[ល] ១៤មើល ទូល
បង្គំត្រឡប់ទៅឯសាសន៍ទូលបង្គំឥឡូវនេះឯង សូមយាងមក
នេះ ទូលបង្គំនឹងប្រកាសទូលទ្រង់ពីការដែលសាសន៍នេះ
នឹងធ្វើដល់សាសន៍ទ្រង់នៅគ្រាជាន់ក្រោយ[វ] ។

## លោកបាឡាមថ្លែងទំនាយលើកទី៤

១៥រួចគាត់ចាប់តាំងបញ្ចេញព្រះបន្ទូល ដោយពាក្យថា
នេះជាពាក្យរបស់បាឡាមជាកូនបេអ៊ើរ គឺជាពាក្យនៃមនុស្ស
ដែលមើលឃើញច្បាស់ ១៦ជាពាក្យរបស់មនុស្សដែលឮ
ព្រះបន្ទូល[ស]នៃព្រះ ជាអ្នកដែលស្គាល់គំនិតនៃព្រះដ៏ខ្ពស់
បំផុត[ហ] ហើយជាអ្នកដែលបានឃើញព្រះដ៏មានគ្រប់ព្រះ
ចេស្តាក្នុងការជាក់ស្តែង ព្រមទាំងក្រាបចុះដោយមានភ្នែក
បើកឡើង ១៧ខ្ញុំឃើញទ្រង់ តែមិនមែនក្នុងឥឡូវនេះទេ ខ្ញុំ
រំពឹងមើលទ្រង់តែមិនមែននៅជិតទេ[ឡ] និងមានផ្កាយ១
ចេញពីពួកយ៉ាកុប[អ]មក ហើយនិងមានដំបង១កើតពីសាសន៍
អ៊ីស្រាអែលដែរ[ក] ដំបងនោះនឹងវាយអស់ទាំងទីកៀននៃ
សាសន៍ម៉ូអាប់[ខ] ហើយបំបែកបំបាក់អស់ទាំង[គ]ពួកអ្នកដែល
បង្កើតសេចក្តីវឹកវរ ១៨នោះស្រុកអេដំម[ឃ]នឹងត្រឡប់ទៅជា
កេរ្តិ៍អាកររបស់ផងគេ ហើយស្រុកសៀរ[ង]ដែលជាខ្មាំង
សត្រូវគេ នោះនឹងត្រឡប់ទៅជារបស់ផងគេដែរ[ច] គឺ
សាសន៍អ៊ីស្រាអែល[ឆ]នឹងមានជ័យជំនះ ១៩ហើយនិងមាន
ម្នាក់កើតឡើងពីពួកយ៉ាកុប[ជ] ដែលនឹងកាន់កាប់ត្រួតត្រា
អ្នកនោះនឹងរំលាយអស់ទាំងសំណល់ពីទីក្រុងចេញ ។

## លោកបាឡាមថ្លែងទំនាយលើកចុងក្រោយ

២០រួចគាត់ក្រឡេកឃើញសាសន៍អាម៉ាលេក[ឈ] ក៏ចាប់
តាំងបញ្ចេញព្រះបន្ទូលដោយពាក្យថា អាម៉ាលេកជាដើម
ចមនៃនគរទាំងអស់ តែចុងបំផុតរបស់គេ នោះនឹងត្រូវ
សាបសូន្យទៅ[ញ] ។
២១គាត់ក៏ក្រឡេកឃើញសាសន៍កែន[ដ]ដែរ រួចគាត់
បញ្ចេញព្រះបន្ទូល ដោយពាក្យថា ទីលំនៅរបស់ឯងមាំ
ណាស់[ឋ] ឯងមានសំបុកនៅលើថ្មដា ២២ប៉ុន្តែសាសន៍កែន
នឹងត្រូវរោយរៀវទៅ ដរាបដល់សាសន៍អាសស៊ើរ[ឌ]នាំទៅ
ជាឈ្លើយ ។
២៣រួចគាត់បញ្ចេញព្រះបន្ទូលទៀត ដោយពាក្យថា ឱ
គួរអនិច្ចាណាស់ហ្ន៎ តើអ្នកណានឹងរស់នៅ ក្នុងកាលដែល
ព្រះទ្រង់ធ្វើការទាំងនេះ ២៤តែនឹងមាននាវាមកពីស្រុក
គីទីម[ឍ] គេនឹងបន្ទាបបន្ថោកសាសន៍អាសស៊ើរ[ណ] ព្រមទាំង
សាសន៍ហេប៊ើរផង[ត] តែគេនឹងត្រូវវិនាសទៅដែរ[ថ] ២៥នោះ
បាឡាម[ទ]ក៏ក្រោកឡើង ត្រឡប់ទៅឯកន្លែងរបស់គាត់វិញ ឯ
បាឡាកទ្រង់ក៏យាងតាមផ្លូវរបស់ទ្រង់ទៅដែរ ។

**២៤:១៣** ល ជន ២២:២០ **២៤:១៤** វ លប៤៩:១ ជន ៣១:៨,១៦ មីក ៦:៥ **២៤:១៦** ស ជន ២២:៩ ហ លប ១៤:១៨ អស ១៤:១៤ **២៤:១៧** ឡ វវ ១:៧ អ មថ ២:២ ក លប ៤៩:១០ ខ លប ១៩:៣៧ ជន ២១:២៩ ចទ ២៣:៦ អស ១៥:១–១៦:១៤ គ យរ ៤៨:៤៥ **២៤:១៨** ឃ ២សយ ៨:១២ ១រប ១៨:១១ ទដ ៦០:៨ អស ១១:១៤ អម ៩:១២ ង លប ១៤:៦ ចទ ១:៤៤ យស ១២:៧ ១៥:១០ ពច ៥:៤ ច អប ១:២ ឆ លប ៩:២៥ **២៤:១៩** ជ លប ៤៩:១០ មីក ៥:២ **២៤:២០** ឈ លប ១៤:៧ នក ១៧:១៤ ញ ចទ ២៥:១៩ ១៥:២០ ៣០:១៧–២០ ២សយ ៨:១២ ១រប ១៨:១១ **២៤:២១** ដ លប ១៥:១៩ ឋ ទដ ៣៧:២៧ សភ ១:៣៣ អស ៣២:១៨ អក ៣៤:២៧ **២៤:២២** ឌ លប ១០:២២ **២៤:២៤** ឍ លប ១០:៤ ណ ខ.២២ ត លប ១០:២១ ថ ខ.២០ **២៤:២៥** ទ ជន ២២:៥

**២៤:១៤** *នៅគ្រាជាន់ក្រោយ* ពេលវេលាដ៏យូរអង្វែង (ដែលទៅតាមជំនឿលើព្រះមែស៊ី) ជាធម្មតា ត្រូវបានបង្ហាញប្រាប់ដោយពាក្យវោហារស័ព្ទនេះ (សូមមើល ឧទាហរណ៍នៅក្នុង យរ ៤៨:៤៧ និងការពន្យល់) ។

**២៤:១៥–១៦** ដូចដែលនៅក្នុងសេចក្តីទំនាយទីបី (មើល ខ.៣–៤) សេចក្តីណែនាំចំពោះការពោលពាក្យទំនាយទីបួនគឺវែងបន្តិច ដែលជួយរៀបចំដល់អ្នកអានឱ្យមានការភ្ញាក់ផ្អើលលើពាក្យទស្សន៍ទាយ ទៅលើព្រះមែស៊ីនោះ ។ អ្នកដែលប្រោសលោះនាពេលអនាគតរបស់រាស្ត្រអ៊ីស្រាអែលនឹងក្លាយដូចជាផ្កាយមួយដូច្នោះដែរ (សូមមើលខប្រៀបធៀប ២ពត ១:១៩ វវ ២២:១៦) ព្រះអង្គនឹងកាន់ដំបងរាជ្យ ហើយនិងនាំមកនូវជ័យជម្នះទៅលើពួកខ្មាំងសត្រូវនៃរាស្ត្ររបស់ផងទ្រង់ (សូមមើល ខ.១៩) ។

**២៤:២០** *អាម៉ាលេកជាដើមចម* ជាដើមចមដំបូងដើម្បីវាយប្រហារពួករាស្ត្រអ៊ីស្រាអែល ហើយប្រឆាំងនឹងបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ជាមួយនឹងរាស្ត្ររបស់ផងទ្រង់ (សូមមើល នក ១៧:៨–១៣) ។

**២៤:២១** *សាសន៍កែន* ជាឈ្មោះដែលគេស្នើសុំដល់ពូជអំបូរនៃពួកអ្នកដែលធ្វើការងារខាងលោហៈធាតុ ។ នៅក្នុងបណ្តាបទគម្ពីរដទៃទៀត ពូជអំបូរសាសន៍កែននេះបានចងស្ពានមេត្រីនឹងពួកកូនចៅអ៊ីស្រាអែល (សូមមើល ឧទាហរណ៍ ពច ១:១៦ ៤:១១ ១សយ ១៥:៦ និង សេចក្តីពន្យល់) ។ ចាប់តាំងពីឪពុកក្មេករបស់លោកម៉ូសេជាពូជសាសន៍កែន ក៏ប៉ុន្តែពូជសាសន៍កែននេះក៏ផ្សាភ្ជាប់ជាមួយនឹងសាសន៍ម៉ាឌានផងដែរ (សូមមើល នក ២:១៦) វាប្រហែលជាការសំអាងរបស់បាឡាមសំដៅទៅពូជសាសន៍ម៉ាឌាន (សូមមើល ២២:៤,៧) ។ *សំបុក* ជាព្រះគម្ពីរភាសាហេព្រើរ Ekn “*qen*” ជាពាក្យលេងសើច ដោយសំដៅទៅលើពូជសាសន៍កែន ជាភាសាហេព្រើរ កេនី (“*qeni*”) ។

**២៤:២២** *អាសស៊ើរ* ស្រុកអាសស៊ើរ ។

**២៤:២៤** *ស្រុកគីទីម* ប្រហែលជាពួកបុព្វបុរសនៃពូជសាសន៍គីទីមនេះឯងដែលនៅក្នុងស្រុកគីទីមនោះ ។ *គេនឹងបន្ទាបបន្ថោកសាសន៍អាសស៊ើរ ព្រមទាំងសាសន៍ហេប៊ើរផង តែគេនឹងត្រូវវិនាសទៅដែរ* ប្រជាជាតិមួយនឹងងើបឡើង ហើយនិងដណ្តើមកន្លែងមួយផ្សេងទៀត ត្រឹមតែជួបប្រទះនឹងសេចក្តីវិនាសរបស់ខ្លួន ។ ដោយច្រាសមកវិញ ការប្រទានពរដែលកំពុងតែកើតមានឡើងកំណត់ទៅលើតែពួកកូនចៅអ៊ីស្រាអែល ហើយនិងព្រះបន្ទូលសន្យាដ៏ពិតប្រាកដរបស់ពួកគេនៃអនាគតអ្នកដែលប្រោសលោះ ហើយព្រះអង្គនោះនឹងទទួលបានជ័យជម្នះនៅទីបញ្ចប់ (ខ.១៧–១៩) ។

**២៥:១–១៨** វាមិនមែនមានរហូតដល់ ៣១:៨,១៦ ដែលយើងរៀនទៅថា គោលការណ៍អ្នកញុះញង់ របស់អ្នកដែលបោះបង់ជំនឿរបស់ពួកកូនចៅអ៊ីស្រាអែល ដែលនៅក្នុងខត្រង់នេះនិយាយពីបាឡាម (សូមមើលការពន្យល់ ២២:៥,៨) ។ ការបរាជ័យចំពោះការបំផ្លាញអ៊ីស្រាអែល ដោយដាក់បណ្តាសា បាឡាមបានប្រលោមចិត្តពួកកូនចៅអ៊ីស្រាអែលដោយពួកអ្នកស្រុកកាណានរៀបចំពិធីបុណ្យដាក់ដង្វាយភោគផលដល់ព្រះបាលទៅវិញ ។

## សាសន៍ម៉ូអាប់នាំពួកអ៊ីស្រាអែលធ្វើការអាក្រក់

**២៥** ១រីឯពួកអ៊ីស្រាអែលគេនៅស្រុកស៊ីទីម[ក] ហើយបណ្តា
ជនចាប់តាំងសហាយស្មន់[ខ] នឹងពួកកូនស្រី[គ]របស់សាសន៍
ម៉ូអាប់[ឃ] ២ដ្បិតពួកនោះបានហៅបណ្តាជន ទៅឯការថ្វាយ
យញ្ញបូជា[ង]ដល់ព្រះរបស់គេ[ច] ហើយសាសន៍អ៊ីស្រាអែល
ក៏បានបរិភោគ ព្រមទាំងក្រាបសំពះដល់ព្រះនៃសាសន៍
ម៉ូអាប់នោះដែរ ៣គេចូល[ឆ]ពួកខាងព្រះបាល–ពេអរ[ជ] នោះ
សេចក្តីខ្ញាល់នៃព្រះយេហូវ៉ា ក៏ឆួលឡើងទាស់នឹងគេ ៤ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរចាប់យកពួកមេ
នៃបណ្តាជនទាំងអស់[ឈ] មកចងព្យួរហាល[ញ]ថ្ងៃនៅចំពោះ
ព្រះយេហូវ៉ា[ដ]ទៅ ដើម្បីឱ្យសេចក្តីខ្ញាល់ក្តៅ[ឋ]របស់ទ្រង់បាន
បែរពីពួកអ៊ីស្រាអែលចេញ ៥នោះម៉ូសេក៏ប្រាប់ដល់ពួក
ចៅក្រមនៃពួកអ៊ីស្រាអែលថា ចូរអ្នករាល់គ្នាសំឡាប់[ឌ]ពួក
របស់ខ្លួន ដែលចូលពួកខាងព្រះបាល–ពេអរចេញទៅ[ឍ]។
៦ខណៈនោះមានពួកកូនចៅសាសន៍អ៊ីស្រាអែលម្នាក់ នាំ
ស្ត្រីសាសន៍ម៉ាឌាន[ណ]ម្នាក់មកឯបងប្អូនខ្លួន នៅចំពោះមុខ
ម៉ូសេនិងជំនុំនៃកូនចៅអ៊ីស្រាអែលទាំងអស់ ដែលកំពុង
យំ[ត] នៅមាត់ទ្វារត្រសាលជំនុំ ៧កាលភីនេហាស[ថ] ជាកូន
អេលាសារ ដែលជាកូនអើរ៉ុន ដ៏ជាសង្ឃបានឃើញ នោះក៏
ក្រោកឡើងនៅកណ្តាលពួកជំនុំ ចាប់យកលំពែង[ទ]នៅដៃ
៨ចូលទៅក្នុងត្រសាលតាមក្រោយអ្នកនោះ ហើយក៏ចាក់
ទំលុះអ្នកទាំង២នោះទៅ គឺទាំងប្រុសសាសន៍អ៊ីស្រាអែល
និងស្ត្រីនោះផង ត្រូវត្រង់ពោះនាង នោះសេចក្តីវេទនាបាន
បាត់ពីពួកកូនអ៊ីស្រាអែលទៅ[ធ] ៩ឯអស់អ្នកដែលបានស្លាប់
ក្នុងសេចក្តីវេទនានោះ[ន] មានចំនួន២មុឺន៤ពាន់នាក់[ប]។
១០រួចព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា ១១ភីនេ–
ហាសជាកូនអេលាសារ ដែលជាកូនអើរ៉ុនដ៏ជាសង្ឃលោក
បានបំបែរសេចក្តីឃោរឃៅរបស់អញពីពួកកូនចៅអ៊ី–
ស្រាអែលចេញ[ផ] ដោយព្រោះមានសេចក្តីឈឺឆ្អាលជំនួស
អញ[ព] ប្រយោជន៍កុំឱ្យអញបានបំផ្លាញគេក្នុងសេចក្តីប្រចណ្ឌ
របស់អញឡើយ ១២ដូច្នេះចូរប្រាប់ថា អញតាំងសេចក្តី
សញ្ញារបស់អញ[ភ] ឱ្យបានមេត្រីនឹងលោកហើយ ១៣គឺជា
សេចក្តីសញ្ញា ឱ្យបានការងារជាសង្ឃ[ម] នៅជាដរាបតទៅ
សំរាប់លោកនិងពូជលោករៀងតទៅ ពីព្រោះលោកបាន
ឈឺឆ្អាល[យ]នឹងព្រះនៃខ្លួន[រ] ហើយបានធ្វើឱ្យធួន[ល]នឹងពួកកូន

**២៥:១** ក ជន ២១:១៦ យស ២:១ អស ៦៦:១១ យអ ៣:១៨ មីក ៦:៥ ខ យរ ៥:៧ ៧:៩ ៩:២ ១កថ ១០:៨ វវ ២:១៤ គ ជន ៣១:១៦ ឃ លប ១៩:៣៧ **២៥:២** ង នក ៣២:៦ ច នក ២០:៥ ចទ ៣២:៣៨ ១កថ ១០:២០ **២៥:៣** ឆ ចទ ៤:១៩ ពច ២:១៩ ១ពវ ៩:៩ យរ ១:១៦ ៤៤:៣ ជ ជន ២៣:២៨ **២៥:៤** ឈ ជន ៧:២ ១៣:៣ ញ ២សយ ២១:៦ ដ ចទ ៤:៣ ឋ នក ៣២:១២ ចទ ១៣:១៧ យស ៧:២៦ ២ពវ ២៣:២៦ ២របា ២៨:១១ ២៩:១០ ៣០:៨ អរ ១០:១៤ យរ ៤៤:៣ **២៥:៥** ឌ នក ៣២:២៧ ឍ យស ៩:១០ **២៥:៦** ណ លប ២៥:២ ត ជន ១៤:១ ពច ២:៤ រម ១:៩ ១សយ ១១:៤ ២សយ ១៥:៣០ អរ ១០:១ ទដ ១២៦:៦ យរ ៤១:៦ **២៥:៧** ថ នក ៦:២៥ យស ២២:១៣ ពច ២០:២៨ ទ ពច ៥:៨ ១សយ ១៣:១៩,២២ ១ពវ ១៨:២៨ ទដ ៣៥:៣ ៤៦:៩ យអ ៣:១០ មីក ៤:៣ **២៥:៨** ធ ទដ ១០៦:៣០ **២៥:៩** ន ជន ១៤:៣៧ ១កថ ១០:៨ ប ជន ៣១:១៦ **២៥:១១** ផ ទដ ១០៦:៣០ ព នក ២០:៥ ចទ ៣២:១៦,២១ ទដ ៧៨:៥៨ **២៥:១២** ភ អស ១១:៩ ៥៤:១០ អគ ៣៤:២៥ ៣៧:២៦ មទ្ធ ២:៤,៥ **២៥:១៣** ម នក ២៩:៩ យ ១ពវ ១៩:១០ ២ពវ ១០:១៦ រ ខ.១១ ល នក ២៩:៣៦ រម ៣:២៥

**២៥:១** *ស្រុកស៊ីទីម* មានឈ្មោះផ្សេងមួយទៀតសម្រាប់តំបន់របស់ពួករាស្ត្រអ៊ីស្រាអែល ដែលបង្កើតឡើងសម្រាប់ការដណ្តើមយកទឹកដីកាណាន ដែលស្ថិតនៅត្រើយម្ខាងនៃទន្លេយ័រដាន់ទល់មុខគ្នានឹងទីក្រុងយេរីខូពីបុរាណកាលមក (មើល យស ២:១) ។ *សហាយស្មន់* ការស្មោះស្ម័គ្ររបស់ពួករាស្ត្រអ៊ីស្រាអែល ទៅក្នុងការរៀបចំពិធីបុណ្យដាក់ដង្វាយភោគផលដល់ព្រះបាល ដែលមិនត្រឹមតែ ជារឿងជាប់ពាក់ព័ន្ធទៅនឹងអំពើអាក្រក់ខាងសហាយស្មន់ប៉ុណ្ណោះទេ វាក៏បានធ្វើឱ្យបាក់បែកដល់សេចក្តីសញ្ញាជាមួយ នឹងព្រះអម្ចាស់ថែមទៀតផង (សូមមើល នក ២០:៣–៤ និងការពន្យល់) ការថ្វាយបង្គំរូបព្រះដទៃទៀត ដែលនៅផែនដី (ខ.២–៣) និងការសាកល្បងនៃសេចក្តីហិនវិនាសរបស់បណ្តាជន ទៅក្នុងការលាតត្រដាងនៃប្រវត្តិសាស្ត្ររបស់ពួកគេ ។

**២៥:៤** *មកចងព្យួរហាលថ្ងៃ* ការបង្ហាញប្រាប់ក្នុងលក្ខណៈពិសេសមួយចំពោះសាកសពទាំងឡាយ ដែលទុកជាការព្រមានដល់អ្នកដែលបានរួចមានជីវិតរស់នៅផ្សេងទៀត ក្នុងការទទួលផលប៉ះពាល់លើអំពើបាប ។

**២៥:៦** *នាំស្ត្រីសាសន៍ម៉ាឌានម្នាក់មកឯបងប្អូនខ្លួន* ការមើលងាយចំពោះវត្ថុដែលបរិសុទ្ធ និងព្រះបន្ទូលរបស់ព្រះអម្ចាស់ បានបង្ហាញឱ្យឃើញដោយស៊ីមរី (ខ.១៤) និងស្ត្រីដែលគាត់បានស្រឡាញ់នោះឈ្មោះកូសប៊ី (ខ.១៥) ដែលជារឿងមិនអាចប្រឌិតបានឡើយ ។

**២៥:៩** *២មុឺន៤ពាន់នាក់* ចំនួននៃពួកបណ្តាជន ដែលបានស្លាប់ ព្រោះតែការប្រព្រឹត្តល្មើសរបស់ពួកគេទាំងនោះជាក់ស្តែង នៅក្នុងការថ្វាយបង្គំព្រះបាល ចំនួនបណ្តាជនដែលបះបោរ ហើយត្រូវស្លាប់នោះមានចំនួនធំធេងដែលជាពួក"កូរេ" (*Korah*) ហើយនិងបណ្តាជនដែលជាសម្ព័ន្ធ មិត្តរបស់ខ្លួនថែមទៀតផង (១៤.៧00 សូមមើល ១៦:៤៩ និងការពន្យល់) ។ ជាថ្មីម្តងទៀត ចំនួនដ៏ច្រើនលើសលុបនៃបណ្តាជនដែលស្លាប់ ជាការសមល្មមទៅនឹងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃបណ្តាជន ដែលលើកឡើងនៅក្នុងការរាប់ចំនួនលើកទីមួយ (សូមមើល ១:៤៦ និងការពន្យល់) ហើយនិងការរាប់ចំនួននៅលើកទីពីរទៀត (សូមមើល ២៦:៥១) និងការពន្យល់) ។

**២៥:១១** *ដោយព្រោះមានសេចក្តីឈឺឆ្អាលជំនួសអញ* ធៀបនឹង នក ២០:៤–៦ ។ សេចក្តីឈឺឆ្អាលរបស់ភីនេហាសជំនួសឱ្យព្រះអម្ចាស់ បានក្លាយទៅជាឱកាសមួយសម្រាប់ព្រះអង្គរៀបចំតាំងនូវសេចក្តីសញ្ញាជាមួយនឹងគាត់ និងពួកកូនចៅគាត់ ដែលនៅជំណាក្រោយៗមកទៀត ជាសង្ឃ ដ៏ពិតៗរបស់ផងព្រះ (សូមមើលការពន្យល់ លប ៩:៩ និងសូមមើល ខ.១២) និងតារាងស្តីអំពីសេចក្តីសញ្ញាសំខាន់ៗនៅក្នុងសញ្ញាចាស់ ដែលស្ថិតនៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិផងដែរ) ។ កូនប្រុសរបស់អេលាសារនេះប្រឆាំងនឹងអំពើដ៏ស្មោកគ្រោកដែលកើតឡើងជាធម្មតារបស់ពូកគាតគឺ មានណាដាប និងអ័ប៊ីហ៊ូវ (សូមមើល លវ ១០:១–៣ និងការពន្យល់) ។

**២៥:១២** *សេចក្តីសញ្ញា . . . ឱ្យបានមេត្រី* សូមមើលការពន្យល់ប្រៀបធៀបនៅ អស ៥៤:១០ ។

ចៅអ៊ីស្រាអែល[វ] ។
១៤រីឯមនុស្សសាសន៍អ៊ីស្រាអែល ដែលត្រូវស្លាប់ជាមួយ
នឹងស្ត្រី[ស]សាសន៍ម៉ាឌាននោះ គឺឈ្មោះស៊ីមរី ជាកូនសាលូវ
ដែលជាកំពូលលើវង្សានុវង្សរបស់ឪពុក១ ក្នុងពូជអំបូរ
ស៊ីម្មាន[ហ] ១៥ហើយស្ត្រីសាសន៍ម៉ាឌាន ដែលត្រូវស្លាប់នោះ
គឺឈ្មោះកូសប៊ី[ឡ] ជាកូនសើរ ដែលជាមេលើពួកវង្សនៃ
ឪពុក១ ក្នុងសាសន៍ម៉ាឌាន[អ] ។
១៦ព្រះយេហូវ៉ាទ្រង់ក៏មានបន្ទូលនឹងម៉ូសេថា[ក] ១៧ចូរធ្វើ
ទុក្ខ[ខ]ដល់សាសន៍ម៉ាឌាន[គ] ហើយវាយគេចុះ[ឃ] ១៨ដ្បិតគេធ្វើ
ទុក្ខឯងរាល់គ្នាដោយឧបាយកល ដែលគេមកល្បួងលួង
លោមឯងពីដំណើរពេអរនោះ[ង] ហើយពីដំណើរនាងកូសប៊ី
ជាកូននៃអ្នក១ ដែលជាកំពូលលើសាសន៍ម៉ាឌាន ជាអ្នក
ដែលត្រូវស្លាប់នៅថ្ងៃមានសេចក្ដីវេទនា ដោយព្រោះរឿង
ពេអរនោះ ។

## ការធ្វើជំរឿនជាលើកទីពីរ

**២៦** ១កាលក្រោយសេចក្ដីវេទនា[ក]នោះមក ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលនឹងម៉ូសេ ហើយនិងអេលាសារជាកូនអើរ៉ុន
ដ៏ជាសង្ឃថា ២ចូររាប់ចំនួន[ខ]ពួកជំនុំនៃកូនចៅអ៊ីស្រាអែល
ទាំងអស់ ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ តាមវង្សានុ
វង្សរបស់ឪពុកគេ គឺអស់អ្នកក្នុងពួកអ៊ីស្រាអែល ដែលអាច
នឹងចេញទៅច្បាំង[គ]បាន ៣នោះម៉ូសេ និងអេលាសារដ៏ជា
សង្ឃ ក៏ប្រាប់គេនៅត្រង់ស្រុកវាលរបស់ម៉ូអាប់[ឃ] ជិតទន្លេ
យ័រដាន់ ទល់មុខនឹងក្រុងយេរីខូរថា[ង] ៤ត្រូវរាប់ឯងរាល់គ្នា
ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ ដូចជាព្រះយេហូវ៉ា
បានបង្គាប់មកម៉ូសេ ហើយនិងកូនចៅអ៊ីស្រាអែល នៅគ្រា
ដែលបានចេញពីស្រុកអេស៊ីព្ទមកនោះដែរ[ច] ។
៥ឯរូបេនគាត់ជាកូនច្បងរបស់អ៊ីស្រាអែល ហើយពួក
កូនចៅរបស់រូបេន[ឆ] គឺហេណុក១ ដែលជាអ្នកបង្កើត
គ្រួហេណុក[ជ]ប៉ាលូវ១[ឈ] ដែលជាអ្នកបង្កើតគ្រួប៉ាលូវ
៦ហេស្រុន១[ញ] ដែលជាអ្នកបង្កើតគ្រួហេស្រុន កើមី១[ដ] ដែល
ជាអ្នកបង្កើតគ្រួកើមី ៧នោះជាពួកគ្រួនៃរូបេន ឯអស់អ្នក
ដែលបានរាប់ហើយក្នុងពួកគេ នោះមានចំនួន៤ម៉ឺន៣ពាន់
៧៣០នាក់ ៨ឯកូនរបស់ប៉ាលូវ គឺអេលាប ៩ហើយកូនរបស់
អេលាប[ឋ] គឺនេមួល១ ដាថាន១ អ័ប៊ីរ៉ាម១ គឺដាថាន និង

**២៥:១៣** វ ទដ ១០៦:៣១ យរ ៣៣:១៨ **២៥:១៤** ស ខ.៦ ហ ជន ១:៦ **២៥:១៥** ឡ ខ.១៨ អ ជន ៣១:៨ យស ១៣:២១ ហាព ៣:៧ **២៥:១៦** ក ជន ៣១:៧ **២៥:១៧** ខ នក ២៣:២២ ពច ២:១៦-១៨ នហ ៩:២៧ ទដ ៨:២ ២១:៨ ៧៤:២៣ គ ជន ៣១:១-៣ ឃ ចទ ២១:១ ១សយ ១៧:៩,៣៥ ២ពវ ៩:២៧ ១០:២៥ **២៥:១៨** ង ជន ២៣:២៨ **២៦:១** ក ជន ១៤:៣៧ ២៥:៨ **២៦:២** ខ នក ៣០:១១-១៦ គ ជន ១:៣ **២៦:៣** ឃ ខ.៦៣ ជន ៣៣:៤៨ យស ១៣:៣២ ង ជន ២២:១ **២៦:៤** ច នក ៦:១៤ ១៣:៣ **២៦:៥** ឆ ជន ១:២០ ជ លប ៤៦:៩ ឈ ១រប ៥:៣ **២៦:៦** ញ ១រប ៥:៣ ដ លប ៤៦:៩ **២៦:៩** ឋ ជន ១៦:១

**២៥:១៧** *ចូរធ្វើទុក្ខដល់សាសន៍ម៉ាឌាន ហើយវាយគេចុះ* ព្រោះថាសកម្មភាពចូលរួមរបស់ពួកគេ ស្ថិតនៅក្នុងការទាក់ទាញចិត្តរបស់ពួកកូនចៅអ៊ីស្រាអែល ។ ពួកសាសន៍ម៉ាឌាន បានចូលរួមក្នុងសម្ព័ន្ធមិត្តជាមួយនឹងបាឡាក ចាប់តាំងពីការប្រឈមមុខដាក់គ្នានៅគ្រាដំបូងមកម្ល៉េះ (សូមមើល ២២:៤, ៧) ហើយបានក្លាយជាកម្មវត្ថុមួយនៃសង្គ្រាមបរិសុទ្ធមួយ (៣១:១-២៤) ។
**២៦:១-៥១** ការរាប់ចំនួនលើកទីមួយ ចំពោះអស់អ្នកណាដែលបានកោះហៅឱ្យចូលមកប្រមូលផ្ដុំធ្វើជាកងទ័ពចម្បាំង ដើម្បីធ្វើសញ្ជ័យដណ្ដើមទឹកដីត្រូវបានប្រព្រឹត្តទៅកាលពី ៣៨ ឆ្នាំ មុននេះបន្តិច ។ ជំនាន់មនុស្សទីមួយ មានអាយុពី ២០ឆ្នាំឡើងទៅ នោះមានអាយុកាលចាស់ស្លាប់ជិតអស់ទៅហើយ ។ ឥឡូវនេះចូលមកដល់វេលានៃជំនាន់ថ្មីមួយទៀត ដើម្បីធ្វើការរាប់ចំនួនម្ដងទៀត ហើយនិងត្រូវបានធ្វើការប្រមូលផ្ដុំគ្នាឆ្ពោះទៅយុទ្ធនាការ ដែលត្រូវបានទន្ទឹងរង់ចាំមើលដល់ពួកគេទាំងនោះ ។ កាលជំនាន់របស់លោកម៉ូសេត្រូវបានចូលរួមនៅក្នុងកាតព្វកិច្ចនាពេលនេះ ដោយក្មួយរបស់គាត់ឈ្មោះ អេលាសារ អើរ៉ុនត្រូវបានស្លាប់ (សូមមើល ២០:២៨) ។ នៅក្នុងការរាប់ចំនួនលើកទីពីរនេះជាក់ស្ដែងគឺពូជអំបូរនីមួយៗ ដែលមានកំណត់ក្នុងបញ្ជី ។ ឃើញថាចំនួនទាំងឡាយ ភាគច្រើននៃពូជអំបូរ គឺមានកំណើនកើនឡើង ពួកពូជអំបូររូបេន គឺជាពូជអំបូរមួយក្នុងចំណោមពូជអំបូរទាំងឡាយដែលបានបង្ហាញឱ្យឃើញថា មានការថយចុះ ។ ប្រហែលជាមានការថយចុះដ៏តិចតួចនៃចំនួនសមាជិកគ្រួសារ ក្នុងអំឡុងពេលនៃការបះបោររបស់ពួក "កូរេ" (Korah) និងពួកកូនចៅរូបេន ដែលចងសម្ព័ន្ធមេត្រីនឹងគ្នានោះ (សូមមើលការពន្យល់នៅត្រង់ ខ.៩) ។ នៅក្នុងការជ្រៀតជ្រែកអស់រយៈកាលប៉ុន្មានឆ្នាំកន្លងទៅនេះ គ្រួសារនៃពួកអំបូររូបេនបានកើនចំនួនទាន់នឹងចំនួនកាលពីពេលមុន (សូមមើលការពន្យល់នៅត្រង់ ខ.១៤) ។ សូមធ្វើការកត់សំគាល់ទៅលើការប្រៀបធៀប នៃចំនួនទាំងឡាយរបស់ពូជអំបូរនីមួយៗ ចាប់ពីការរាប់ចំនួនកាលពីលើកទីមួយ មកដល់ការរាប់ចំនួននៅលើកទីពីរនេះ :

| *ឈ្មោះពូជអំបូរ* | *ការរាប់ចំនួនលើកទី១* | *ការរាប់ចំនួនលើកទី២* |
|---|---|---|
| រូបេន | ៤៦.៥០០ | ៤៣.៧៣០ |
| ស៊ីម្មាន | ៥៩.៣០០ | ២២.២០០ |
| កាឌ់ | ៤៥.៦៥០ | ៤០.៥០០ |
| យូដា | ៧៤.៦០០ | ៧៦.៥០០ |
| អ៊ីសាខារ | ៥៤.៤០០ | ៦៤.៣០០ |
| សាប់យូល៉ូន | ៥៧.៤០០ | ៦០.៥០០ |
| អេប្រាអិម | ៤០.៥០០ | ៣២.៥០០ |
| ម៉ាន៉ាសេ | ៣២.២០០ | ៥២.៧០០ |
| បេនយ៉ាមីន | ៣៥.៤០០ | ៤៥.៦០០ |
| ដាន់ | ៦២.៧០០ | ៦៤.៤០០ |
| អេស៊ើរ | ៤១.៥០០ | ៥៣.៤០០ |
| ណែបថាលី | ៥៣.៤០០ | ៤៥.៤០០ |
| បូកសរុប | ៦០៣.៥៥០ | ៦០១.៧៣០ |

**២៦:៩** *ដាថាន និងអ័ប៊ីរ៉ាម* ការកត់ត្រាក្នុងបញ្ជីនៃគ្រួសាររបស់រូបេនក្លាយជាឱកាសមួយ ដើម្បីរំឭកដល់អ្នកអាននៅផ្នែកនេះហើយ ដែលភាពពិតប្រាកដ នៃចំនួនរបស់ពួកគេបានមាននៅក្នុងការបះបោររបស់ពួកកូនចៅកូរេ

អ័ប៊ីរ៉ាមនេះហើយ ដែលគេបានហៅមកឯពួកជំនុំ[ឌ] ជាអ្នក
ដែលបានលើកគ្នាទាស់នឹងម៉ូសេ ហើយនឹងអើរ៉ុន ជាមួយ
នឹងពួកកូរេ ក្នុងកាលដែលពួកកូរេ បានលើកគ្នាទាស់ទទឹង
នឹងព្រះយេហូវ៉ា[ឍ] 10 តែដីបានហាឡើង ទទួលស្រូបយក
គេ[ណ]ជាមួយនឹងកូរេទៅ ក្នុងកាលដែលពួកកូរេនោះត្រូវ
ស្លាប់ ហើយក៏មានភ្លើងឆេះមនុស្ស២៥០នាក់ដែរ[ត] ពួកនោះ
ឯងបានត្រឡប់ជាគំរូដល់បណ្ដាជន[ថ] 11 តែឯកូនចៅរបស់
កូរេ[ទ]នោះមិនបានស្លាប់ទេ[ធ] ។

12 ឯពួកកូនចៅស៊ីម្មានតាមគ្រួគេ គឺយេមូអែល១[ន] ជា
អ្នកដែលបង្កើតគ្រួយេមូអែល យ៉ាមីន១ ជាអ្នកដែល
បង្កើតគ្រួយ៉ាមីន[ប] យ៉ាគិន១ ជាអ្នកដែលបង្កើតគ្រួយ៉ាគិន
13 សេរ៉ាស១[ផ] ជាអ្នកដែលបង្កើតគ្រួសេរ៉ាស សូល១ ជាអ្នក
ដែលបង្កើតគ្រួសូល 14 នោះជាពួកគ្រួរបស់ស៊ីម្មាន[ព]មាន
ចំនួន២ម៉ឺន២ពាន់២០០នាក់[ភ] ។

15 ឯពួកកូនចៅកាឌ់តាមគ្រួគេ គឺសេផុន១[ម] ជាអ្នកដែល
បង្កើតគ្រួសេផុន ហាក់គី១ ជាអ្នកដែលបង្កើតគ្រួហាក់គី
ស៊ូនី១ ជាអ្នកដែលបង្កើតគ្រួស៊ូនី 16 អូសនី១ ជាអ្នកដែល
បង្កើតគ្រួអូសនី អេរី១ ជាអ្នកដែលបង្កើតគ្រួអេរី 17 អើរ៉ូត
១ជាអ្នកបង្កើតគ្រួអើរ៉ូត អើរេលី១ ជាអ្នកបង្កើតគ្រួអើរេលី
18 នោះជាពួកគ្រួរបស់កូនចៅកាឌ់[យ] តាមអស់អ្នកដែលបាន
រាប់ក្នុងពួកគេ មានចំនួន៤ម៉ឺន៥០០នាក់ ។

19 ឯពួកកូនចៅយូដា គឺអ៊ើរ១[រ] ហើយនិងអូណាន់១[ល] ឯ
អ៊ើរ ហើយនិងអូណាន់នេះ គេបានស្លាប់ទៅ[វ]នៅស្រុកកា
ណាន 20 ពួកកូនចៅយូដាតាមគ្រួគេ គឺសេឡា១ ជាអ្នក
ដែលបង្កើតគ្រួសេឡា[ស] ពេរេស១[ហ] ជាអ្នកដែលបង្កើត
គ្រួពេរេស សេរ៉ាស១ ជាអ្នកដែលបង្កើតគ្រួសេរ៉ាស[ឡ]
21 ឯកូនរបស់ពេរេស[អ] គឺហេស្រុន១[ក] ជាអ្នកដែលបង្កើត
គ្រួហេស្រុន ហាមុល១ ជាអ្នកដែលបង្កើតគ្រួហាមុល
22 នោះជាពួកគ្រួរបស់យូដា[ខ] តាមអស់អ្នកដែលបានរាប់
ក្នុងពួកគេ មានចំនួន៧ម៉ឺន៦ពាន់៥០០នាក់ ។

23 ឯពួកកូនចៅអ៊ីសាខារតាមគ្រួគេ គឺថូឡា១[គ] ជាអ្នក
ដែលបង្កើតគ្រួថូឡា ពូវ៉ា១ ជាអ្នកដែលបង្កើតគ្រួពូវ៉ា
24 យ៉ាសុប១[ឃ] ជាអ្នកដែលបង្កើតគ្រួយ៉ាសុប ស៊ីមរ៉ុន១ ជា
អ្នកដែលបង្កើតគ្រួស៊ីមរ៉ុន 25 នោះជាពួកគ្រួរបស់អ៊ីសាខារ
[ង]តាមអស់អ្នកដែលបានរាប់ក្នុងពួកគេមានចំនួន៦ម៉ឺន៤ពាន់
៣០០នាក់ ។

26 ឯពួកកូនចៅសាប់យូល៉ូន[ច]តាមគ្រួគេ គឺសេរែត១ ជា
អ្នកដែលបង្កើតគ្រួសេរែត អេឡូន១ ជាអ្នកដែលបង្កើត
គ្រួអេឡូន យ៉ាលាល១ ជាអ្នកដែលបង្កើតគ្រួយ៉ាលាល
27 នោះជាពួកគ្រួរបស់សាប់យូល៉ូន[ឆ] តាមអស់អ្នកដែលបាន
រាប់ក្នុងពួកគេ មាន៦ម៉ឺន៥០០នាក់ ។

28 ឯពួកកូនចៅយ៉ូសែប[ជ]តាមគ្រួគេ គឺម៉ាន៉ាសេ១ និង
អេប្រាអិម[ឈ]១ 29 ពួកកូនចៅម៉ាន៉ាសេ[ញ] គឺម៉ាគារ១[ដ] ជាអ្នក
ដែលបង្កើតគ្រួម៉ាគារ ហើយម៉ាគារក៏បង្កើតកាឡាត[ឋ] ដែល
ជាអ្នកបង្កើតគ្រួកាឡាត 30 ពួកកូនរបស់កាឡាត[ឌ] គឺយេស៊ើរ
១ ជាអ្នកដែលបង្កើតគ្រួយេស៊ើរ[ឍ] ហេលេក១ ជាអ្នកដែល
បង្កើតគ្រួហេលេក 31 អាសរាល១ ជាអ្នកដែលបង្កើត
គ្រួអាសរាល ស៊ីគែម១ ជាអ្នកដែលបង្កើតគ្រួស៊ីគែម
32 សេមីដា១ ជាអ្នកដែលបង្កើតគ្រួសេមីដា ហេភើរ១
ជាអ្នកដែលបង្កើត គ្រួហេភើរ 33 ឯស្លូផិហាត[ណ]ជាកូន

**២៦:៩** ឌ ជន ១:១៦ ឍ ជន ១៦:២ **២៦:១០** ណ នក ១៥:១២ ត ជន ១៦:៣៥ ថ នក ៣:១២ ជន ១៦:៣៨ **២៦:១១** ទ នក ៦:២៤ ធ ជន ១៦:៣៣ ចទ?៥:៩ ២៤:១៦ ២ពស ១៤:៦ ២របា ២៥:៤ អេ ១៨:២០ **២៦:១២** ន លប ៤៦:១០ ប ១របា ៤:២៤ **២៦:១៣** ផ លប ៤៦:១០ **២៦:១៤** ព លប ៤៦:១០ ភ ជន ១:២៣ **២៦:១៥** ម លប ៤៦:១៦ **២៦:១៨** យ លប ៣០:១១ ជន ១:២៥ យស ១៣:២៤-២៨ **២៦:១៩** រ លប ៣៨:៣ ល លប ៣៨:៤ វ លប ៣៨:៧ **២៦:២០** ស លប ៣៨:៥ ហ លប ៣៨:២៩ ឡ យស ៧:១៧ **២៦:២១** អ លប ៣៨:២៩ ក នរ ៤:១៩ ១របា ២:៩ **២៦:២២** ខ ជន ១:២៧ **២៦:២៣** គ លប ៤៦:១៣ **២៦:២៤** ឃ លប ៤៦:១៣ ៨:២ **២៦:២៥** ង លប ៣០:១៨ **២៦:២៦** ច ជន ១:៣០ **២៦:២៧** ឆ លប ៣០:២០ **២៦:២៨** ជ ជន ១:៣២ ៣៦:១ ឈ លប ៤១:៥២ **២៦:២៩** ញ ជន ១:៣៤ ដ លប ៥០:២៣ ឋ ពច ១១:១ **២៦:៣០** ឌ ជន ២៧:១ ៣៦:១ ១របា ៧:១៤,១៧ ឍ យស ១៧:២ ពច ៦:១១ **២៦:៣៣** ណ ជន ២៧:១ ៣៦:២ យស ១៧:៣ ១របា ៧:១៥

(សូមមើល ១៦:១-៧ និងការពន្យល់ ក៏សូមប្រៀបធៀប យដ ខ.១១ និងការពន្យល់) ។

**២៦:១៤** *២ម៉ឺន២ពាន់២០០* ការបាត់បង់ដ៏ធំមួយ ដែលកើតមានឡើងនៅក្នុងពូជអំបូរស៊ីម្មាន (ថយចុះពី ៥៩.៣០០នាក់) ។ ដូចជាឈ្មោះ ស៊ីមរី ត្រូវបានកាត់ចេញពីពូជអំបូរគ្រួសារនៃស៊ីម្មាន (២៥:១៤) ។ ចំនួនភាគច្រើនប្រហែលជា ២៤.០០០នាក់ ដែលត្រូវបានស្លាប់ដោយសាររោគពិស ឬសេចក្ដីវេទនា នាអំឡុងពេលដែលបែកចេញពីក្រុមអំបូរគ្រួសារនៃស៊ីម្មាន សេចក្ដីជំនុំជម្រះបានកើតមានឡើងទើបតែនៅពេលថ្មីៗនេះ ដែលពូជអំបូរនោះពុំទាន់បានមានចំនួនកើនឡើងមកដូចដើមឡើងវិញនៅឡើយ នាអំឡុងពេលនោះ ក៏ដូចជាកើតមានឡើងចំពោះពូជអំបូររូបេនផងដែរ (សូមមើលការពន្យល់នៅ ខ.១-៥១) ។

**២៦:១៩** *អ៊ើរ ហើយនិងអូណាន់* ឈ្មោះទាំងនេះគឺជាឈ្មោះកូនប្រុសលោកយូដា ដែលកូនប្រុសនោះប្រព្រឹត្តនូវអំពើអាក្រក់ ដែលមិនអាចបំភ្លេចទៅបាន ដូច្នេះហើយបានជាពួកគេទាំងពីរនាក់មិនបានទទួលនូវកេរ្ដិ៍មរតកអ្វីសោះឡើយ (សូមមើល លប ៣៨:១-១០) ។

**២៦:២០** *ពេរេស* តាមខ្សែរបស់ដាវីឌ និងព្រះយេស៊ូវ ត្រូវបានចេញពីជំនួរវង្សនៃពូជរបស់គាត់ (ពេរេស) ដែរ (សូមមើល នរ ៤:១៨-២២ និងការពន្យល់ មថ ១:១-៣) ។

**២៦:២៨,៣៥** *ម៉ាន៉ាសេ . . . អេប្រាអិម* ទៅតាមលំដាប់លំដោយនៃពូជអំបូរគឺមានដូចគ្នាទៅនឹងជំពូក១ លើកលែងតែការរៀបបញ្ច្រាសនៃពួកកូនចៅអេប្រាអិម និងម៉ាន៉ាសេ ប្រហែលជាក្នុងពេលនោះ ទំនាក់ទំនងនៃកំណើនដ៏ធំរបស់ពូជអំបូរម៉ាន៉ាសេកើនឡើងច្រើន(សូមមើលការពន្យល់ ខ.១-៥១ សូមមើលផងដែរនៅ ខ.៣៤) ។

**២៦:៣៣** *ស្លូផិហាត . . . កូនស្រី* សូមមើល ២៧:១-១១,៣៦ ។

ហេភើរ គាត់គ្មានកូនប្រុសទេ[ត] មានសុទ្ធតែកូនស្រី នេះ
ជាឈ្មោះកូនស្រីរបស់ស្លូផិហាត គឺម៉ាសឡា១ ណូហា១
ហុកឡា១ មីលកា១ និងធើសា១[ថ] [៣៤]នោះជាពួកគ្រួរបស់
ម៉ានាសេ ពួកអ្នកដែលបានរាប់ក្នុងពួកគេមានចំនួន៥ម៉ឺន២
ពាន់៧០០នាក់[ទ] ។
[៣៥]ឯពួកកូនចៅអេប្រាអិម[ធ]តាមគ្រួគេ គឺស៊ុថេឡា១ ជា
អ្នកដែលបង្កើតគ្រួស៊ុថេឡា បេគើរ១ ជាអ្នកដែលបង្កើត
គ្រួបេគើរ ថាហាន១ ជាអ្នកដែលបង្កើតគ្រួថាហាន [៣៦]ឯ
ពួកកូនចៅស៊ុថេឡា គឺជាអេរ៉ាន ដែលបង្កើតគ្រួអេរ៉ាន
[៣៧]នោះហើយជាពួកគ្រួរបស់កូនចៅអេប្រាអិម[ន] តាមអស់
អ្នកដែលបានរាប់ក្នុងពួកគេ មានចំនួន៣ម៉ឺន២ពាន់៥០០
នាក់ នោះជាពួកកូនចៅយ៉ូសែបតាមគ្រួគេ ។
[៣៨]ឯពួកកូនចៅបេនយ៉ាមីន[ប]តាមគ្រួគេ គឺបេឡា១ ជា
អ្នកដែលបង្កើតគ្រួបេឡា អ័សបេល១ ជាអ្នកដែលបង្កើត
គ្រួអ័សបេល អេហ៊ីរ៉ាម១ ជាអ្នកដែលបង្កើតគ្រួអេហ៊ីរ៉ាម
[៣៩]ស៊ូផាម១ ជាអ្នកដែលបង្កើតគ្រួស៊ូផាម ហ៊ូផាម១ ជាអ្នក
ដែលបង្កើតគ្រួហ៊ូផាម [៤០]ឯកូនរបស់បេឡា នោះគឺ អើឌ១
និងណាម៉ាន១ ឯអើឌ[ផ] ជាអ្នកបង្កើតគ្រួអើឌ និងណាម៉ាន
ជាអ្នកបង្កើតគ្រួណាម៉ាន [៤១]នោះជាពួកកូនចៅរបស់
បេនយ៉ាមីន[ព] តាមគ្រួគេ ពួកអ្នកដែលបានរាប់ក្នុងពួកគេ
នោះមានចំនួន៤ម៉ឺន៥ពាន់៦០០នាក់ ។
[៤២]ឯពួកកូនចៅដាន់[ភ]តាមគ្រួគេ[ម] គឺហ៊ូស៊ីម[យ] ជាអ្នកដែល
បង្កើតគ្រួហ៊ូស៊ីម នោះជាគ្រួរបស់ដាន់តាមគ្រួសារគេ [៤៣]ឯ
ពួកគ្រួហ៊ូស៊ីមទាំងអស់ តាមដែលបានរាប់ក្នុងពួកគេ មាន
ចំនួន៦ម៉ឺន៤ពាន់៤០០នាក់ ។
[៤៤]ឯពួកកូនចៅអេសេរ[រ]តាមគ្រួគេ គឺយីមន៉ា១ ជាអ្នក
ដែលបង្កើតគ្រួយីមន៉ា យីសវី១ ជាអ្នកដែលបង្កើតគ្រួយីសវី
បេរា១ ជាអ្នកដែលបង្កើតគ្រួបេរា [៤៥]ឯកូនរបស់បេរា
នោះហេប៊ើរ១ ជាអ្នកដែលបង្កើតគ្រួហេប៊ើរ ម៉ាលគាល១
ជាអ្នកដែលបង្កើតគ្រួម៉ាលគាល [៤៦]ឯកូនស្រីរបស់អេសេរ
នោះឈ្មោះសេរ៉ា [៤៧]នោះជាពួកគ្រួរបស់កូនចៅអេសេរ[ល]
តាមអស់អ្នកដែលបានរាប់ក្នុងពួកគេ មានចំនួន៥ម៉ឺន៣ពាន់
៤០០នាក់ ។
[៤៨]ឯពួកកូនចៅណែបថាលី[វ]តាមគ្រួគេ គឺយ៉ាស៊ាល១
ជាអ្នកដែលបង្កើតគ្រួយ៉ាស៊ាល គូនី១ ជាអ្នកដែលបង្កើតគ្រួ
គូនី [៤៩]យេសើរ១ ជាអ្នកដែលបង្កើតគ្រួយេសើរ ស៊ីលិម១
ជាអ្នកដែលបង្កើតគ្រួស៊ីលិម [៥០]នោះជាពួកគ្រួរបស់ណែប
ថាលី[ស]តាមគ្រួគេ អស់អ្នកដែលបានរាប់ក្នុងពួកគេ មាន
ចំនួន៤ម៉ឺន៥ពាន់៤០០នាក់[ហ] ។
[៥១]នេះជាចំនួននៃអស់អ្នក ដែលបានរាប់ក្នុងពួកកូនចៅ
អ៊ីស្រាអែល រួមទាំងអស់មាន៦សែន១ពាន់៧៣០នាក់[ឡ] ។
[៥២]ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងម៉ូសេថា [៥៣]ត្រូវឱ្យ
ចែកស្រុកទុកជាមរដក ឱ្យដល់អ្នកទាំងនេះ តាមចំនួន
ឈ្មោះគេ[អ] [៥៤]ឯពួកណាដែលមានគ្នាច្រើន នោះត្រូវចែកឱ្យ
ជាច្រើន ហើយពួកណាមានគ្នាតិច នោះក៏ត្រូវចែកឱ្យតាម
តិចវិញ គ្រប់គ្នាត្រូវទទួលមរដក តាមចំនួន[ក]នៃអស់អ្នក
ដែលបានរាប់ហើយក្នុងពួកគេ[ខ] [៥៥]ប៉ុន្តែស្រុកនោះត្រូវចាប់
ឆ្នោតចែកគ្នា[គ] គេត្រូវស៊ីមរដក តាមឈ្មោះពូជអំបូរនៃ
ឰយុកោគេរៀងខ្លួន [៥៦]គឺដោយចាប់ឆ្នោតដែលត្រូវចែក
មរដកឱ្យដល់គេ តាមដែលមានគ្នាច្រើន និងគ្នាតិច ។
[៥៧]ឯក្នុងពួកលេវី[ឃ] នោះបានរាប់អ្នកទាំងនេះ តាមគ្រួ
គេ គឺគើសុន១ ជាអ្នកដែលបង្កើតគ្រួគើសុន កេហាត់១
ជាអ្នកដែលបង្កើតគ្រួកេហាត់ និងម្រ៉ារី១ ជាអ្នកដែល
បង្កើតគ្រួម្រ៉ារី [៥៨]នេះជាពួកគ្រួរបស់លេវី គឺជាគ្រួលិបនី១
គ្រួហេប្រុន១ គ្រួម៉ាស់លី១ គ្រួម៉ូស៊ី១ គ្រួកូរេ១ ឯកេហាត់
គាត់បង្កើតអាំរ៉ាម[ង] [៥៩]ហើយប្រពន្ធរបស់អាំរ៉ាមឈ្មោះ
យ៉ូកិបិត[ច] ជាកូនលេវី ដែលលេវីបានបង្កើតនៅស្រុកអេស៊ីព្ទ

**២៦:៣៣** ត ជន ២៧:៣ ថ ជន ៣៦:១១
**២៦:៣៤** ទ ជន ១:៣៥
**២៦:៣៥** ធ ជន ១:៣២
**២៦:៣៧** ន ជន ១:៣៣
**២៦:៣៨** ប លប ៤៦:២១ ជន ១:៣៦ ១រប ៨:៤០
**២៦:៤០** ផ លប ៤៦:២១
**២៦:៤១** ព ជន ១:៣៧
**២៦:៤២** ភ ជន ១:៣៨ ម ពច ១៨:១៩ យ លប ៤៦:២៣
**២៦:៤៤** រ ជន ១:៤០
**២៦:៤៧** ល ជន ១:៤១
**២៦:៤៨** វ លប ៣០:៨
**២៦:៥០** ស ជន ១:៤៣ ហ ជន ១:៤២
**២៦:៥១** ឡ នក ១២:៣៧
**២៦:៥៣** អ ខ.៥៥ យស ១១:២៣ ១៤:១ អគ ៤៥:៨
**២៦:៥៤** ក ជន ៣៣:៥៤ ខ ជន ៣៥:៨
**២៦:៥៥** គ លវ ១៦:៨
**២៦:៥៧** ឃ លប ៤៦:១១ **២៦:៥៨** ង នក ៦:២០ **២៦:៥៩** ច នក ២:១

**២៦:៣៤** *៥ម៉ឺន២ពាន់៧០០* កំណើនដែលច្រើនលើសលុបបានកើតមាននៅក្នុងពូជអំបូរម៉ានាសេ (កើនឡើងចាប់ពី ៣២.២០០នាក់) ។ មូលហេតុនៃកំណើននេះគ្មានប្រភពពត៌មានច្បាស់បញ្ជាក់ឡើយ ។

**២៦:៤៦** *កូនស្រី . . . ឈ្មោះសេរ៉ា* ការចុះបញ្ជីចំពោះកូនស្រីទោលតែមួយដែលធ្វើឱ្យមានការចាប់អារម្មណ៍បំផុត ។

**២៦:៥១** *៦សែន១ពាន់៧៣០* ទោះបីជាពួកបណ្ដាជនទាំងអស់បានមានបទពិសោធន៍ឆ្លងកាត់ទីរហោស្ថានអស់រយៈកាលជាច្រើនឆ្នាំកន្លងក៏ដោយ ចំនួនស្ថិតិសរុបរបស់ពួកគេ នៅតែមានចំនួនប្រហាក់ប្រហែលទៅនឹងចំនួនដែលបានរាប់កាលលើកដំបូងមកម្ល៉េះ ។ ហេតុការណ៍ដែលគួរឱ្យកត់សំគាល់គឺត្រូវបានគេគិតថា ជាព្រះពររបស់ព្រះអម្ចាស់នៅក្នុងការសម្រេចទៅតាមព្រះបន្ទូលសន្យាជាច្រើនរបស់ផងព្រះ ក្នុងការប្រទានពរដល់ពួកបណ្ដាជន ដែលជាដំណកូនចៅពីលោកអ័ប្រាហាំកើនមានចំនួនច្រើន តាមរយៈលោកយ៉ាកុប (សូមមើលការពន្យល់នៅ លប ១២:២–៣) ។ ចំនួនសរុបនេះ ហើយនិងផ្នែករបស់ខ្លួន គឺជាកំណត់ត្រាដោយមានគំរូជាទូទៅនៃចំនួនដែលមាននៅក្នុងកណ្ឌគម្ពីរនេះ (សូមមើលការពន្យល់នៅ ១:៤៦) ។

**២៦:៥៣–៥៦** ពូជអំបូរណាដែលមានចំនួនធំៗ និងត្រូវទទួលនូវមរតកច្រើនដែរ ប៉ុន្តែការសម្រេចចិត្តរបៀបនេះ និងត្រូវបានធ្វើឡើងទៅតាមចំនួនដែលត្រូវបានចាប់ឆ្នោត (សូមមើល ខ.៥៦ ៣៣:៥៤) ។

**២៦:៥៧** *ពួកលេវី* ដូចមាននៅក្នុងការរាប់ចំនួនលើកទី១ (ជំពូក៣) ពួកលេវីនេះ ត្រូវបានរាប់បញ្ចូលទៅក្នុងចំនួនដាច់ដោយឡែកពីគេ ។

នាងនោះនឹងអាំរ៉ាមបង្កើតបានអើរ៉ុន១ ម៉ូសេ១[ឆ] និងម៉ារាម[ជ]ដែលជាបងស្រីគេ[ឈ] ៦០ឯអើរ៉ុន លោកបង្កើតបាន ណាដាប១ អ័ប៊ីហ៊ូវ១ អេលាសារ១ និងអ៊ីថាម៉ារ១[ញ] ៦១ឯណាដាប និងអ័ប៊ីហ៊ូវ[ដ]នេះ គេបានស្លាប់ទៅក្នុងកាលដែលយកភ្លើងដទៃ មកថ្វាយនៅចំពោះព្រះយេហូវ៉ា[ឋ] ៦២នោះពួកលេវីដែលបានរាប់ហើយ[ឌ] មានចំនួន២ម៉ឺន ៣ពាន់នាក់[ឍ] គឺជាប្រុសៗទាំងអស់ ចាប់តាំងពីអាយុ១ខែឡើងទៅលើ ដ្បិតគេមិនបានរាប់ក្នុងពួកកូនចៅអ៊ីស្រាអែលទេ ពីព្រោះគេគ្មានចំណែកមរដក[ណ]នៅជាមួយនឹងពួកកូនចៅអ៊ីស្រាអែលឡើយ[ត]។

៦៣នេះហើយជាអ្នកទាំងប៉ុន្មាន ដែលម៉ូសេ និងអេលាសារដ៏ជាសង្ឃ បានរាប់[ថ]នៅត្រង់ស្រុកវាលរបស់ម៉ូអាប់[ទ] ជិតទន្លេយ័រដាន់ ទល់មុខនឹងយេរីខូរ[ធ] ៦៤ប៉ុន្តែក្នុងបណ្ដាអ្នកទាំងនោះ គ្មានអ្នកណាមួយដែលម៉ូសេនិងអើរ៉ុន[ន]ដ៏ជាសង្ឃបានរាប់[ប]នៅត្រង់ទីរហោស្ថានស៊ីណាយនោះទេ ៦៥ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូលពីគេថា វារាល់គ្នានឹងត្រូវស្លាប់នៅទីរហោស្ថានជាមិនខាន[ផ] ដូច្នេះ គ្មានអ្នកណាក្នុងពួកអ្នកទាំងនោះនៅសល់ឡើយ មានតែកាលែប[ព]ជាកូនយេភូនេ១ ហើយនិងយ៉ូស្វេជាកូននុន១ប៉ុណ្ណោះ[ភ]។

### ពួកកូនស្រីស្លូផិហាត

*២៧:១-១១ -ជន ៣៦:១-១២*

**២៧** ១ឯពួកកូនស្រីស្លូផិហាត[ក] ដែលជាកូនហេភើរ១[ខ] ជាកូនកាឡាត១[គ]ជាកូនម៉ាការ១[ឃ]ជាកូនម៉ាន៉ាសេ ក្នុងពួកគ្រួម៉ាន៉ាសេ ដែលគេជាកូនចៅយ៉ូសែប ឯកូនស្រីរបស់គាត់ទាំងនោះមានឈ្មោះដូច្នេះ គឺម៉ាសឡា១ ណូហា១ ហុកឡា១ មីលកា១ និងធើសា១ ២គេក៏នាំគ្នាចូលមកឈរនៅចំពោះមុខម៉ូសេ[ង] និងអេលាសារដ៏ជាសង្ឃ ហើយនៅមុខអស់អ្នកដែលជាកំពូល[ច] លើពួកជំនុំ ត្រង់មាត់ទ្វារត្រសាលជំនុំ[ឆ] ជិរាបថា ៣ឪពុកយើងខ្ញុំបានស្លាប់ទៅ នៅទីរហោស្ថាន[ជ] គាត់មិនមែនជាពួកកូរេ ដែលលើកគ្នាទាស់នឹងព្រះយេហូវ៉ា[ឈ]នោះទេ គឺគាត់បានស្លាប់ដោយព្រោះតែបាបរបស់ខ្លួនវិញ ហើយគាត់គ្មានកូនប្រុសសោះ[ញ] ៤ហេតុអ្វីបានជាត្រូវឱ្យឈ្មោះឪពុកយើងខ្ញុំបាត់ចេញពីពួកគ្រួគាត់ទៅ ដោយព្រោះតែគ្មានកូនប្រុសដូច្នេះ ហេតុនេះសូមឱ្យយើងខ្ញុំបានកេរ្តិ៍អាករ នៅជាមួយនឹងបងប្អូនរបស់ឪពុកយើងខ្ញុំផង ៥នោះម៉ូសេក៏នាំយករឿង[ដ]គេ ទៅទូលដល់ព្រះយេហូវ៉ា[ឋ]។

៦រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ៧ពួកកូនស្រីស្លូផិហាតបាននិយាយត្រូវ ដូច្នេះត្រូវចែកឱ្យគេមានកេរ្តិ៍អាករ[ឌ]នៅជាមួយនឹងពួកបងប្អូនរបស់ឪពុកគេផង ត្រូវឱ្យគេបានមរដករបស់ឪពុកគេចុះ[ឍ] ៨ត្រូវឱ្យឯងប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលដែរថា បើអ្នកណាស្លាប់ទៅឥតមានកូនប្រុស នោះត្រូវឱ្យឯងរាល់គ្នាចែកមរដករបស់អ្នកនោះដល់កូនស្រីគេទៅ ៩បើគ្មានកូនស្រីទេ នោះត្រូវឱ្យមរដកគេដល់បងប្អូនបង្កើត ១០បើគ្មានបងប្អូនបង្កើត នោះត្រូវឱ្យមរដកដល់បងប្អូនរបស់ឪពុកគេ ១១តែបើឪពុកគ្មានបងប្អូន នោះត្រូវឱ្យមរដកគេទៅអ្នកជិតដិតជាងក្នុងគ្រួគេ ឱ្យអ្នកនោះស៊ីវិញ សេចក្ដីនេះត្រូវទុកជាច្បាប់បញ្ញត្តិ[ណ]ដល់ពួកកូនចៅអ៊ីស្រាអែល ដូចជាព្រះយេហូវ៉ាបានបង្គាប់មក ។

### លោកយ៉ូស្វេស្នងលោកម៉ូសេ

១២ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរឱ្យឯងឡើងទៅលើភ្នំ[ត]អាបារីមនេះ[ថ] ហើយមើលទៅស្រុក[ទ]ដែល

**២៦:៥៩** ឆ នក ៦:២០ ជ នក ១៥:២០ ឈ នក ២:៤ **២៦:៦០** ញ នក ៦:២៣ **២៦:៦១** ដ លវ ១០:១-២ ឋ ជន ៣:៤ **២៦:៦២** ឌ ជន ៣:៣៩ ឍ ជន ១:៤៧ ណ ជន ១៨:២៣ ត ជន ២:៣៣ **២៦:៦៣** ថ ជន ១:១៩ ទ ខ.៣ ធ ជន ២២:១ **២៦:៦៤** ន ជន ១:៤៤ ប ជន ១៤:២៩ **២៦:៦៥** ផ ជន ១៤:២៨ ១កថ ១០:៥ ព ជន ១៣:៦ ភ ជន ១១:២៨ **២៧:១** ក ជន ២៦:៣៣ ខ យស ១៧:២,៣ គ ជន ២៦:៣០ ឃ លប ៥០:២៣ ១រប ២:២១ **២៧:២** ង នក ៤០:២,១៧ ច ជន ៩:៦ ឆ ជន ១:១៦ ៣១:១៣ ៣២:២ ៣៦:១ **២៧:៣** ជ ជន ២៦:៦៥ ឈ ជន ១៦:២ ញ ជន ២៦:៣៣ **២៧:៥** ដ លប ២៥:២២ នក ១៨:១៩ ឋ ជន ៩:៨ **២៧:៧** ឌ យប ៤២:១៥ ឍ ខ.៨ យស ១៧:៤ **២៧:១១** ណ ជន ៣៥:២៩ **២៧:១២** ត ជន ២៣:១៤ ថ ជន ៣៣:៤៧ យរ ២២:២០ ទ ចទ ៣:២៣-២៧ ៣២:៥០ ១ពវ ២:១

---

**២៧:១-១១** បុរសម្នាក់ដែលមានសុទ្ធតែកូនស្រី ពុំមានកូនប្រុសឡើយ (សូមមើល ២៦:៣៣) ត្រូវបានពាក់ព័ន្ធទៅនឹងសិទ្ធិនៃការទទួលមរតកនិងស្ថានភាពដែលមិនប្រែប្រួលនៃឈ្មោះរបស់ឪពុកពួកគេ នៅក្នុងទឹកដីនោះ (ខ.៤) សកម្មភាពរបស់ពួកគេបានរត់ទៅប្ដឹងដល់លោកម៉ូសេអេលាសារ និងអ្នកដឹកនាំដទៃទៀតនៅក្នុងសហគមន៍ ដែលពុំធ្លាប់មានពីមុនមក គឺជាការតវ៉ាមួយនៅក្នុងសេចក្ដីជំនុំជម្រះ ។

**២៧:៣** *គាត់បានស្លាប់ដោយព្រោះតែបាបរបស់ខ្លួនវិញ* ករណីពិសេសមួយពីអស់អ្នកដែលបានស្លាប់នៅក្នុងទីរហោស្ថាន (សូមមើល ២៦:៦៤-៦៥) ។ ពួកស្ត្រីដែលមានជំនឿជាក់លាក់ទាំងនេះ បានបន្លឺសម្លេងនៃការយល់ដឹងរបស់ខ្លួនទៅលើលក្ខណៈនៃបទពិសោធន៍នៅទីរហោស្ថាន ហើយនិងការតវ៉ាដើម្បីក្រុមគ្រួសាររបស់ពួកគេ ។

**២៧:៥** *ម៉ូសេក៏នាំយករឿងគេ ទៅទូលដល់ព្រះយេហូវ៉ា* ខនេះបង្ហាញឱ្យឃើញពីរបៀបរឿងក្ដីទៅតាមច្បាប់ ដែលអាចនឹងប្រព្រឹត្តទៅនៅក្នុងពួករាស្ត្រអ៊ីស្រាអែល ។ ច្បាប់ទូទៅត្រូវបានគេប្រកាសឱ្យដឹងរួចជាស្រេចហើយ តែក្រោយមកមានការលើកលែងនូវច្បាប់មួយចំនួន ឬក៏ការគិតពិចារណាក្នុងលក្ខណៈពិសេសមួយ ដែលនឹងធ្លាក់ទៅលើពួកចាស់ទុំ ហើយប្រហែលជាធ្លាក់ទៅលើលោកម៉ូសេខ្លួនឯងនោះតែម្ដង ។ ក្រោយបន្ទាប់មកគាត់ត្រូវតែនៅរង់ចាំសេចក្ដីសម្រេចចិត្តពីព្រះអម្ចាស់ ។ នៅក្នុងករណីនេះ ព្រះអម្ចាស់បានប្រទានមកនូវសេចក្ដីសម្រេចចិត្តមួយ ដែលគួរជាទីពេញចិត្តដល់ស្ត្រីទាំងនោះ ។ នៅជំពូក៣៦ បានផ្ដល់ឱ្យនូវឧបសម្ព័ន្ធចំពោះរឿងរ៉ាវនេះ ។

**២៧:១២-២៣** ការដាក់ប្រៀបធៀបនូវរឿងសំណើរបស់កូនស្រីស្លូផិហាត សម្រាប់ការទទួលកេរ្តិ៍មរតកនៅក្នុងទឹកដីសន្យា (ខ.១-១១) ហើយព្រះបន្ទូលរបស់ព្រះអម្ចាស់ចំពោះលោកម៉ូសេ អំពីសេចក្ដីហាមប្រាមចូលទៅក្នុងទឹកដីសន្យា (មើល ខ.១២-១៤) ជាកំហិត ។ ទឹកដីដែលបម្រុងទុកត្រូវបាន

អញបានឱ្យដល់ពួកកូនចៅអ៊ីស្រាអែល[ធ] ១៣កាលណាឯង
បានឃើញស្រុកនោះហើយ នោះឯងនឹងត្រូវប្រមូលទៅ
មូលនឹងពួកឰយុកោឯង[ន] ដូចជាអើរ៉ុន[ប]បងឯងបានមូល
ទៅដែរ ១៤ពីព្រោះឯងបានធ្វើទាស់ទទឹងនឹងពាក្យអញនៅ
ត្រង់ទីរហោស្ថានស៊ីន[ផ] ក្នុងកាលដែលពួកជំនុំរករឿង
ឈ្លោះ ឯងមិនបានលើកអញជាបរិសុទ្ធ[ព]នៅចំពោះមុខគេ
ត្រង់ទឹកហូរនោះឡើយ (គឺជាទឹកមេរីបា[ភ] នៅស្រុកកាដេស
ក្នុងទីរហោស្ថានស៊ីន) ។

១៥នោះម៉ូសេទូលទៅព្រះយេហូវ៉ាថា ១៦ដូច្នេះ សូមឱ្យ
ព្រះយេហូវ៉ាដ៏ជាព្រះនៃវិញ្ញាណគ្រប់ទាំងមនុស្ស[ម] ទ្រង់ដំរូវ
ឱ្យមានមនុស្សម្នាក់ត្រួតត្រាលើពួកជំនុំទៅ ១៧ជាអ្នកដែល
អាចនឹងចេញចូលនៅមុខគេ ព្រមទាំងនាំគេចេញចូលផង
ដើម្បីកុំឱ្យពួកជំនុំផងព្រះយេហូវ៉ា[យ] ត្រឡប់ដូចជាហ្វូងចៀម
ដែលគ្មានអ្នកគង្វាលឡើយ ១៨រួចព្រះយេហូវ៉ាទ្រង់មាន
បន្ទូលនឹងម៉ូសេថា ចូរនាំយកយ៉ូស្វេកូននុន ជាមនុស្សដែល
មានព្រះវិញ្ញាណសណ្ឋិតលើ[រ]មកហើយដាក់ដៃលើលោក[ល]
១៩ត្រូវដាក់លោកនៅចំពោះមុខអេលាសារដ៏ជាសង្ឃ និង
ពួកជំនុំទាំងអស់គ្នា រួចប្រគល់សេចក្តីបង្គាប់[វ]ដល់លោក
នៅមុខគេ[ស] ២០ព្រមទាំងចែកអំណាចរបស់ឯងទៅលើ
លោកដែរ ដើម្បីឱ្យពួកកូនចៅអ៊ីស្រាអែលបានប្រតិបត្តិ
តាមលោក[ហ] ២១ត្រូវឱ្យលោកឈរនៅចំពោះមុខអេលា
សារដ៏ជាសង្ឃ ដែលនឹងទូលសួរនៅចំពោះព្រះយេហូវ៉ា
ជំនួសលោកដោយសារសេចក្តីសំរេច[ឡ]របស់យូរីម[អ] គឺតាម
បង្គាប់របស់អេលាសារដែលគេត្រូវចេញទៅ ហើយតាម
បង្គាប់លោកគេត្រូវចូលមកវិញ និងយ៉ូស្វេ និងពួកកូន
ចៅអ៊ីស្រាអែលផង គឺជាពួកជំនុំទាំងអស់គ្នា ២២ម៉ូសេក៏ធ្វើ
តាមបង្គាប់ព្រះយេហូវ៉ា លោកនាំយកយ៉ូស្វេទៅដាក់នៅ
ចំពោះមុខអេលាសារដ៏ជាសង្ឃ និងពួកជំនុំទាំងអស់គ្នា
២៣ក៏ដាក់ដៃលើលោក ហើយប្រគល់សេចក្តីបង្គាប់ដល់
លោក[ក] ដូចជាព្រះយេហូវ៉ាបានបង្គាប់មក ។

### ដង្វាយប្រចាំថ្ងៃ

**២៨** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា នៅវេលាកំណត់[ក] នោះត្រូវឱ្យឯងរាល់
គ្នានឹកចាំនឹងថ្វាយដង្វាយដល់អញ គឺជាអាហារ[ខ]របស់អញ
ដែលសំរាប់ដុតទុកជាក្លិនឈ្ងុយដល់អញ[គ]។

៣ត្រូវឱ្យឯងប្រាប់គេទៀតថា នេះជាដង្វាយដុតដែលឯង
រាល់គ្នាត្រូវថ្វាយដល់ព្រះយេហូវ៉ា គឺរាល់តែថ្ងៃត្រូវថ្វាយ
ចៀមឈ្មោល២ឥតខ្ចោះ[ឃ] អាយុ១ខួប ទុកជាដង្វាយដុត
ជានិច្ច[ង] ៤ឯកូនចៀម១ត្រូវថ្វាយនៅពេលព្រឹកហើយ១ទៀត
នៅពេលល្ងាច[ច] ៥ព្រមទាំងម្សៅយ៉ាងម៉ដ្ត១[ឆ]ខ្ញឹងលាយ
ដោយប្រេង[ជ]យ៉ាងសំរាំង២កំប៉ុង ទុកជាដង្វាយម្សៅ[ឈ]
៦នេះជាដង្វាយដុតជានិច្ច[ញ] ដែលបានចាប់តាំងថ្វាយនៅភ្នំ
ស៊ីណាយ[ដ] ទុកជាដង្វាយដុតសំរាប់ជាក្លិនឈ្ងុយដល់ព្រះ
យេហូវ៉ា[ឋ] ៧ហើយត្រូវថ្វាយដង្វាយច្រួចផង[ឌ] គឺជា២កំប៉ុង
សំរាប់កូនចៀម១ ត្រូវច្រួចថ្វាយជាស្រាទំពាំងបាយជូរ
សុទ្ធ[ឍ]ដល់ព្រះយេហូវ៉ានៅក្នុងទីបរិសុទ្ធ[ណ] ៨ឯកូនចៀម១

**២៧:១២** ធ ជន ២០:២៨ **២៧:១៣** ន ជន ២០:១២ ៣១:២ ចទ ៤:២២ ៣១:១៤ ៣២:៥០ ១ពវ ២:១ ប ជន ២០:២៨ **២៧:១៤** ផ ជន ២០:១,២–៥ ព ជន ២០:១២ ភ នក ១៧:៧ **២៧:១៦** ម ជន ១៦:២២ យប ២១:២០ **២៧:១៧** យ ពច ២២:១៧ ២របា ១៨:១៦ អក ៣៤:៥ សក ១០:២ មថ ៩:៣៦ **២៧:១៨** រ លប ៤១:៣៨ ជន ១១:២៥–២៩ ល ខ.២៣ ចទ ៣៤:៩ កច ៦:៦ **២៧:១៩** វ ខ.២៣ ចទ ៣:២៨ ៣១:១៤,២៣ ស ចទ ៣១:៧ **២៧:២០** ហ យស ១:១៦,១៧ **២៧:២១** ឡ លប ២៥:២២ យស ៩:១៤ ទដ ១០៦:១៣ អស ៨:១៩ ហក ១:១៣ មឡ ២:៧ ៣:១ អ នក ២៨:៣០ **២៧:២២** ក ខ.១៩ **២៨:២** ក លវ ២៣:១–៤៤ ខ លវ ៣:១១ គ លវ ១:៩ **២៨:៣** ឃ នក ១២:៥ ង នក ២៩:៣៨អម ៤:៤ **២៨:៤** ច នក ២៩:៣៩ **២៨:៥** ឆ លវ ៦:២០ ជ លវ ២:១ ឈ ជន ២៩:៦ **២៨:៦** ញ លវ ១:៣ ដ នក ១៩:៣ ឋ លវ ១:៩ **២៨:៧** ឌ ជន ៦:១៥ ឍ លវ ១០:៩ ២៣:១៣ ណ លវ ៣:៧ ជន ៣:២៨

បង្កើតឡើងសម្រាប់ភាពមិនទៀងទាត់ នៅក្នុងច្បាប់កេរ្តិ៍មរដកនោះ ក៏ប៉ុន្តែគ្មានទឹកដីដែលបំរុងទុកសម្រាប់លោកម៉ូសេឡើយ ។ អំពើបាបរបស់គាត់នៅត្រង់ទឹកហូរមេរីបា នៅស្រុកកាដេស (២០:១–១៣) ដែលតែងតែស្ថិតនៅខាងមុខគាត់ជានិច្ច ។

**២៧:១៤** *មិនបានលើកអញជាបរិសុទ្ធ* សូមមើល ២០:១២ និងការពន្យល់ ។

**២៧:១៦** *ដំរូវឱ្យមានមនុស្សម្នាក់* ប្រតិកម្មរបស់លោកម៉ូសេ ចំពោះការពោលអះអាងម្តងទៀតលើការដាក់កម្រិតរបស់គាត់ដែលជាសេចក្តីអធិស្ឋានមួយសម្រាប់អ្នកដែលទទួលបានជ័យជម្នះរបស់ផងទ្រង់ ។

**២៧:១៨** *ចូរនាំយកយ៉ូស្វេ* ដូចជាលោកម៉ូសេ និងអើរ៉ុនដែរបានត្រូវការដើម្បីកំណត់អ្នកទទួលបាននូវជ័យជម្នះពិតប្រាកដ ចំពោះអើរ៉ុន មុននឹងមរណភាពរបស់គាត់ (២០:២២–២៩) ដូច្នេះអ្នកដែលទទួលបានជ័យជម្នះរបស់លោកម៉ូសេ ក៏បានត្រូវការដើម្បីបង្កើតឱ្យមានឡើងដែរ ។ យ៉ូស្វេនិងកាលែបគឺជាវីរៈបុរសទាំងពីរនាក់ នៅក្នុងភាពដ៏ខ្មៅងងឹតរបស់ពួកអ្នកលើកដង្វាយប្រចាំថ្ងៃ ដែលបោះបង់ចោលនូវសេចក្តីជំនឿ (ជំពូក ១៣–១៤) ។ វាជាការមួយដែលសក្តិសមល្មមនឹងព្រះអម្ចាស់ធ្វើការជ្រើសរើសម្នាក់ក្នុងចំណោមពួកគេទាំងពីរនោះ (សូមប្រៀបធៀប នក ១៧:៩–១៤ ២៤:១៣ ៣២:១៧ ៣៣:១១) ។

**២៧:២០** *ព្រមទាំងចែកអំណាចរបស់ឯង* អន្តរភាពពីការដឹកនាំរបស់លោកម៉ូសេ ទៅកាន់អ្នកដែលនឹងទទួលបានជោគជ័យណាមួយនឹងមានការលំបាកការផ្លាស់ប្តូរនឹងត្រូវបានប្រព្រឹត្តទៅដោយរលូនបន្តិចម្តងៗ ក្នុងការផ្ទេរអំណាចនាពេលដែលលោកម៉ូសេ កំពុងនៅរស់នៅឡើយ ។

**២៧:២១** *យូរីម* សូមមើលការពន្យល់នៅ នក ២៨:៣០ ១សយ ២:២៨ ។

**២៨:១–២៩:៤០** ជំពូកទាំងនេះធ្វើការសាកល្បងមើលចំពោះគ្រប់ទាំងភាពយល់ជ្រួតជ្រាបពីយញ្ញបូជានៅក្នុងជីវិតរបស់ពួកបណ្តាជន ហើយនិងភាពធំឧត្តមនៃការងាររបស់ពួកសង្ឃ ។ ប្រហែលជាមូលហេតុនៃបទគម្ពីរទាំងនេះនាពេលនេះ គឺដើម្បីផ្តល់ឱ្យនូវភាពជាបន្តបន្ទាប់ចំពោះអន្តរភាព ដែលនឹងជិតកើតមានឡើង ដោយចាប់ពីការដឹកនាំរបស់លោកម៉ូសេ ទៅជាការដឹកនាំរបស់លោកយ៉ូស្វេវិញ (២៧:១២–២៣) ។

ទៀតនោះត្រូវថ្វាយនៅពេលល្ងាច[ត] ព្រមទាំងដង្វាយម្សៅ
នឹងដង្វាយច្រួច ដូចជានៅពេលព្រឹកដែរ[ថ] ទុកជាដង្វាយ
ដុតសំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[ទ] ។

## ដង្វាយក្នុងថ្ងៃឈប់សម្រាក

៩នៅថ្ងៃឈប់សំរាក[ធ] ត្រូវថ្វាយកូនចៀមឈ្មោល២ឥត
ខ្ចោះអាយុ១ខួប[ន] ព្រមទាំងដង្វាយម្សៅយ៉ាងម៉ដ្ត២ខ្ទឹង[ប]
លាយដោយប្រេង[ផ] និងដង្វាយច្រួចផង ១០នេះជាដង្វាយដុត
ដែលត្រូវថ្វាយរាល់តែថ្ងៃឈប់សំរាក[ព] លើសពីដង្វាយដុត
ដែលតែងតែថ្វាយជានិច្ច ព្រមទាំងដង្វាយច្រួច[ភ]នោះផង ។

## ដង្វាយរាល់ដើមខែ

១១ហើយនៅរាល់តែថ្ងៃដើមខែ[ម] នោះត្រូវឱ្យឯងថ្វាយ
ដង្វាយដុតដល់ព្រះយេហូវ៉ាដែរ គឺជាកូនគោឈ្មោល២[យ]
ចៀមឈ្មោល១[រ] កូនចៀមឈ្មោល៧ឥតខ្ចោះអាយុ១ខួប[ល]
១២ព្រមទាំងម្សៅយ៉ាងម៉ដ្ត៣ខ្ទឹង[វ] លាយដោយប្រេងទុកជា
ដង្វាយម្សៅ[ស] ដែលថ្វាយជាមួយនឹងគោ១ ហើយម្សៅយ៉ាង
ម៉ដ្ត២ខ្ទឹង[ហ] លាយដោយប្រេងទុកជាដង្វាយម្សៅ ដែលថ្វាយ
ជាមួយនឹងចៀមឈ្មោល១ ១៣ហើយម្សៅយ៉ាងម៉ដ្ត១ខ្ទឹង[ឡ]
លាយដោយប្រេង ទុកជាដង្វាយម្សៅ[អ] ដែលថ្វាយជាមួយ
នឹងកូនចៀម១ នេះជាដង្វាយដុត[ក]សំរាប់ជាក្លិនឈ្ងុយដល់
ព្រះយេហូវ៉ា[ខ] ១៤ហើយនិងដង្វាយច្រួច[គ]ផង គឺជាស្រាទំពាំង
បាយជូរ៤កំប៉ុង សំរាប់គោ១ និង៣កំប៉ុងសំរាប់ចៀម
ឈ្មោល១ ហើយ២កំប៉ុងសំរាប់កូនចៀម១ នេះជាដង្វាយ
ដែលត្រូវដុតថ្វាយរាល់តែ[ឃ]ខែក្នុងឆ្នាំជានិច្ច ១៥ហើយត្រូវ
ថ្វាយពពែឈ្មោល១[ង]ដល់ព្រះយេហូវ៉ា ទុកជាដង្វាយលោះ
បាប[ច]លើសពីដង្វាយ ដែលតែងដុត[ឆ]ថ្វាយជានិច្ច និងដង្វាយ
ច្រួចនោះផង ។

## បុណ្យរំលង

*២៨:១៦–២៥–នក ១២:១៤–២០ លវ ២៣:៤–៨ ចទ ១៦:១–៨*

១៦លុះដល់១៤ខែចេត្រ នោះគឺជាថ្ងៃបុណ្យរំលង[ជ]ផង
ព្រះយេហូវ៉ា ១៧ដល់ថ្ងៃ១៥ក្នុងខែនោះជាថ្ងៃបុណ្យដែរត្រូវ
ឱ្យបរិភោគនំបុ័ងឥតដំបែ[ឈ]អស់៧ថ្ងៃ[ញ] ១៨នៅថ្ងៃដំបូងនោះ
ត្រូវប្រជុំជំនុំបរិសុទ្ធមិនត្រូវឱ្យឯងរាល់គ្នាធ្វើការរកស៊ីអ្វីឱ្យ
សោះ[ដ] ១៩ត្រូវថ្វាយដង្វាយដុត[ឋ]ដល់ព្រះយេហូវ៉ាវិញ គឺជា
កូនគោឈ្មោល២ ចៀមឈ្មោល១ កូនចៀមឈ្មោល៧
អាយុ១ខួប សុទ្ធតែជាសត្វឥតមានខ្ចោះ[ឌ] ២០ព្រមទាំងដង្វាយ
ម្សៅផង គឺជាម្សៅយ៉ាងម៉ដ្ត៣ខ្ទឹង[ឍ] លាយដោយប្រេង
សំរាប់គោ១ ហើយ២ខ្ទឹង[ណ]សំរាប់ចៀមឈ្មោល១ ២១និង១
ខ្ទឹងសំរាប់កូនចៀមមួយៗ ក្នុងកូនចៀមទាំង៧នោះ[ត]
២២ហើយពពែឈ្មោល១សំរាប់ជាដង្វាយលោះបាប[ថ] ដើម្បី
នឹងថ្វាយឱ្យធួននឹងឯងរាល់គ្នា[ទ] ២៣ត្រូវឱ្យឯងរាល់គ្នាថ្វាយ
ដង្វាយទាំងនេះ ឱ្យលើសពីដង្វាយដុតពេលព្រឹក ជាដង្វាយ
ដែលតែងថ្វាយជានិច្ច ២៤គឺយ៉ាងនោះដែលត្រូវថ្វាយព្រះ
ស្ងោយ ដែលជាដង្វាយដុតរាល់តែថ្ងៃ ក្នុង៧ថ្ងៃនោះ ទុកជា
ក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[ធ] នេះត្រូវថ្វាយឱ្យលើសពីដង្វាយ
ដុត ដែលតែងថ្វាយជានិច្ច ហើយនិងដង្វាយច្រួចនោះផង
២៥លុះដល់ថ្ងៃទី៧ នោះត្រូវឱ្យឯងរាល់គ្នាប្រជុំជំនុំបរិសុទ្ធ
មិនត្រូវឱ្យធ្វើការរកស៊ីអ្វីឱ្យសោះ ។

## បុណ្យអាទិត្យទី៧

*២៨:២៦–៣១ – លវ ២៣:១៥–២២ ចទ ១៦:៩–១២*

២៦មួយទៀត នៅថ្ងៃបុណ្យផលដំបូង[ន] កាលណាឯងរាល់
គ្នាថ្វាយដង្វាយម្សៅថ្មីដល់ព្រះយេហូវ៉ាក្នុងវេលាបុណ្យ
អាទិត្យទី៧[ប] នោះត្រូវឱ្យប្រជុំជំនុំបរិសុទ្ធ មិនត្រូវឱ្យធ្វើការ
រកស៊ីអ្វីឱ្យសោះ[ផ] ២៧ត្រូវឱ្យថ្វាយដង្វាយដុតសំរាប់ជាក្លិន
ឈ្ងុយដល់ព្រះយេហូវ៉ាវិញ[ព] គឺជាកូនគោឈ្មោល២ ចៀម
ឈ្មោល១ និងកូនចៀមឈ្មោល៧ អាយុ១ខួប ២៨ព្រមទាំង
ដង្វាយថ្វាយម្សៅផង គឺម្សៅយ៉ាងម៉ដ្ត៣ខ្ទឹងលាយដោយ
ប្រេងសំរាប់គោឈ្មោល១ ២ខ្ទឹងសំរាប់ចៀមឈ្មោល១[ភ]
២៩នឹង១ខ្ទឹងសំរាប់កូនចៀមមួយៗ ក្នុងកូនចៀមទាំង៧នោះ[ម]
៣០ហើយពពែឈ្មោល១[យ] សំរាប់ឱ្យធួននឹងឯងរាល់គ្នា
៣១ត្រូវឱ្យថ្វាយដង្វាយទាំងនេះឱ្យលើសពីដង្វាយដុត[រ] ដែល

**២៨:៨** ត នក ២៩:៣៩ ថ លវ ៣:៧ ទ ខ.២ លវ ១:៩ **២៨:៩** ធ នក ២០:១០ មថ ១២:៥ ន ខ.៣ ប លវ ២៣:១៣ ផ ខ.៥ **២៨:១០** ព លវ ២៣:៣៧ ភ ខ.៣ **២៨:១១** ម ជន ១០:១០ យ ជន ៧:១៥ រ លវ ៥:១៥ ល លវ ១:៣ **២៨:១២** វ ជន ១៥:៩ ស ជន ១៥:៦ ២៩:៣ ហ ខ.២០ **២៨:១៣** ឡ ខ.២១ អ លវ ៦:១៤ ក ជន ១៥:៣ ខ លវ ១:៩ **២៨:១៤** គ ជន ១៥:៧ ឃ ខ.១១ ២របា ២:៤ អរ ៣:៥ **២៨:១៥** ង ខ.៣, ២៣,២៤ ច ខ.៣០ ឆ លវ ៤:៣ ជន ២៩:១៦,១៩ **២៨:១៦** ជ នក ១២:១១ ២របា ៣០:១៣ ៣៥:១ **២៨:១៧** ឈ នក ១២:១៩ ញ នក ១២:១៥ **២៨:១៨** ដ នក ១២:១៦ **២៨:១៩** ឋ លវ ១:៩ ឌ នក ១២:១៥ **២៨:២០** ឍ លវ ១៤:១០ ណ ខ.១២ **២៨:២១** ត ខ.១៣ **២៨:២២** ថ លវ ៤:៣ រម ៨:៣ ទ ជន ១៥:២៨ **២៨:២៤** ធ លវ ១:៩ **២៨:២៦** ន នក ៣៤:២២ ប នក ២៣:១៦ ផ ខ.១៨ **២៨:២៧** ព ខ.១៩ **២៨:២៨** ភ ខ.១២ **២៨:២៩** ម ខ.១៣ **២៨:៣០** យ ខ.១៥ **២៨:៣១** រ ជន ២៨:១៨

**២៨:១–៨** សូមមើល នក ២៩:៣៨–៤១ លវ ១–៧ និងការពន្យល់ ។
**២៨:៩–១០** ដង្វាយនៅថ្ងៃឈប់សម្រាក ត្រូវបានក្លាយជាដង្វាយបន្ថែមទៅលើដង្វាយប្រចាំថ្ងៃ ។
**២៨:១១–១៥** ពិធីយញ្ញបូជានៅថ្ងៃដើមខែ គឺជាពិធីមួយដែលមានសារៈសំខាន់ណាស់ ។ ពិធីនេះគឺជាពេលក្នុងការប្រារព្ធពិធីបុណ្យ ដោយមានការផ្លុំត្រែនៅក្នុងការថ្វាយបង្គំទៀតផង (សូមមើល ១០:១០ និងការពន្យល់) ។
**២៨:១៦–២៥** សង្ឃបានធ្វើការណែនាំទៅលើការរៀបចំឱ្យបានត្រឹមត្រូវសម្រាប់បុណ្យរំលងនៅក្នុងខែទីមួយនៃឆ្នាំ ។ បុណ្យរំលងក៏មានជាប់ពាក់ព័ន្ធទៅនឹងបុណ្យនំបុ័ងឥតដំបែរ (សូមមើល នក ១២:១៥ និងការពន្យល់នៅត្រង់ ១២:១៧ លវ ២៣:៤–៨) ។ ចំពោះលេខ ៧ (និង ១៤ ជាមេគុណរបស់វា) កើតមានឡើងជាថ្មីម្តងហើយម្តងទៀតនៅក្នុងវគ្គខណ្ឌ ។
**២៨:២៦–៣១** បុណ្យអាទិត្យទី៧ មានដំណើរប្រព្រឹត្តទៅ៥០ថ្ងៃបន្ទាប់ពីបុណ្យនំបុ័ងឥតដំបែ(សូមមើល លវ ២៣:៩–២២) ដោយសារតែចំនួនតួលេខនេះហើយបានជាកើតនូវពាក្យ"បុណ្យថ្ងៃទី៥០"(មានន័យថា "៥០")ត្រូវបាន

តែងថ្វាយជានិច្ច ហើយនិងដង្វាយម្សៅ និងដង្វាយច្រួច
នោះផង សត្វទាំងនោះត្រូវតែបានឥតខ្ចោះទាំងអស់ ។

### ថ្ងៃសម្រាប់ផ្លុំត្រែ

*២៩:១-៦ – លវ ២៣:២៣-២៥*

**២៩** ១នៅថ្ងៃទី១ក្នុងខែអស្សុជ នោះត្រូវឱ្យឯងរាល់គ្នា
ប្រជុំជំនុំបរិសុទ្ធ មិនត្រូវឱ្យធ្វើការរកស៊ីអ្វីឱ្យសោះ[ក] នេះជា
ថ្ងៃសំរាប់ផ្លុំត្រែឱ្យឯងរាល់គ្នា ២ត្រូវឱ្យថ្វាយដង្វាយដុត[ខ]ជា
ក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[គ] គឺជាកូនគោឈ្មោល១ ចៀម
ឈ្មោល១ និងកូនចៀមឈ្មោល៧ឥតខ្ចោះ[ឃ] អាយុ១ខួប[ង]
៣ព្រមទាំងដង្វាយម្សៅ[ច] លាយដោយប្រេង គឺ៣ខ្ទឹងសំរាប់
គោនោះ ២ខ្ទឹងសំរាប់ចៀមនោះ ៤និង១ខ្ទឹងសំរាប់កូន
ចៀមមួយៗក្នុងចៀមទាំង៧នោះ[ឆ] ៥ហើយពពែឈ្មោល១[ជ]
សំរាប់ជាដង្វាយលោះបាបផង ប្រយោជន៍ឱ្យធួននឹងឯង
រាល់គ្នា ៦នេះត្រូវថ្វាយឱ្យលើសពីដង្វាយដុត ដែលតែង
ថ្វាយនៅថ្ងៃចូលខែ[ឈ] និងដង្វាយម្សៅផង[ញ] ហើយលើសពី
ដង្វាយដុត[ដ] ដែលតែងថ្វាយជានិច្ច និងដង្វាយម្សៅ ហើយ
ដង្វាយច្រួចនោះដែរ[ឋ] ត្រូវថ្វាយតាមរបៀបដង្វាយនោះ
ទុកជាដង្វាយដុត សំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[ឌ] ។

### ថ្ងៃលោះបាប

*២៩:៧-១១-លវ ១៦:២-៣៤ ២៣:២៦-៣២*

៧លុះដល់ថ្ងៃ១០ក្នុងខែអស្សុជ ត្រូវឱ្យឯងរាល់គ្នាប្រជុំ
ជំនុំបរិសុទ្ធ ហើយត្រូវបញ្ឈឺចិត្តខ្លួន[ឍ] មិនត្រូវឱ្យធ្វើការអ្វី
ឱ្យសោះ[ណ] ៨ត្រូវថ្វាយដង្វាយដុតទុកជាក្លិនឈ្ងុយដល់ព្រះ
យេហូវ៉ាវិញ គឺកូនគោឈ្មោល១ ចៀមឈ្មោល១ និងកូន
ចៀមឈ្មោល៧ឥតខ្ចោះ អាយុ១ខួប[ត] ៩ព្រមទាំងដង្វាយ
ម្សៅផង ជាម្សៅយ៉ាងម៉ដ្ឋ[ថ] លាយដោយប្រេង គឺ៣ខ្ទឹង
សំរាប់គោនោះ ២ខ្ទឹងសំរាប់ចៀមនោះ[ទ] ១០និង១ខ្ទឹង
សំរាប់កូនចៀមមួយៗ ក្នុងកូនចៀមទាំង៧នោះ[ធ] ១១ហើយ
ពពែឈ្មោល១[ន] សំរាប់ជាដង្វាយលោះបាបផង នេះត្រូវ
ថ្វាយឱ្យលើសពីដង្វាយលោះបាប ដែលតែងថ្វាយឱ្យធួន
នឹងខ្លួន ហើយលើសពីដង្វាយដុត[ប] ដែលតែងថ្វាយជានិច្ច
ព្រមទាំងដង្វាយម្សៅ និងដង្វាយច្រួចនោះដែរ[ផ] ។

### បុណ្យបារាំ

*២៩:១២-៣៩ – លវ ២៣:៣៣-៤៣ ចទ ១៦:១៣-១៧*

១២នៅថ្ងៃ១៥ក្នុងខែអស្សុជ ត្រូវឱ្យឯងរាល់គ្នាប្រជុំជំនុំ
បរិសុទ្ធ មិនត្រូវឱ្យធ្វើការរកស៊ីអ្វីឱ្យសោះ ហើយត្រូវធ្វើ
បុណ្យថ្វាយព្រះយេហូវ៉ាអស់៧[ព]ថ្ងៃ[ភ] ១៣ក៏ត្រូវថ្វាយដង្វាយ
ដុត សំរាប់ជាក្លិនឈ្ងុយដល់ព្រះយេហូវ៉ា[ម] គឺកូនគោឈ្មោល
១៣ ចៀមឈ្មោល២ កូនចៀមឈ្មោល១៤ឥតខ្ចោះ អាយុ១
ខួប[យ] ១៤ព្រមទាំងដង្វាយម្សៅ[រ]ផង ជាម្សៅយ៉ាងម៉ដ្ឋ លាយ
ដោយប្រេង គឺ៣ខ្ទឹងសំរាប់គោមួយៗក្នុងគោទាំង១៣នោះ
២ខ្ទឹងសំរាប់ចៀមឈ្មោលមួយៗក្នុងចៀមទាំង២ ១៥និង
១ខ្ទឹងសំរាប់កូនចៀមមួយៗ ក្នុងកូនចៀមទាំង១៤[ល] ១៦ហើយ
ពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាបផង[វ]នេះឱ្យ
លើសពីដង្វាយដុត ដែលតែងថ្វាយជានិច្ច និងដង្វាយម្សៅ
ហើយដង្វាយច្រួចនោះដែរ[ស]។
១៧នៅថ្ងៃទី២[ហ] ត្រូវថ្វាយកូនគោឈ្មោល១២ ចៀម
ឈ្មោល២ កូនចៀមឈ្មោល១៤ ឥតខ្ចោះ អាយុ១ខួប[ឡ]
១៨ព្រមទាំងដង្វាយម្សៅ[អ] និងដង្វាយច្រួច[ក] សំរាប់គោ ចៀម
និងកូនចៀមទាំងប៉ុន្មាន តាមចំនួន ឱ្យត្រូវតាមរបៀប[ខ]
១៩ហើយពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាបផង[គ]
នេះឱ្យលើសពីដង្វាយដុត[ឃ] ដែលតែងថ្វាយជានិច្ច និង
ដង្វាយម្សៅ ហើយដង្វាយច្រួចនោះដែរ[ង]។
២០នៅថ្ងៃទី៣ ត្រូវថ្វាយគោឈ្មោល១១ ចៀមឈ្មោល
២ កូនចៀមឈ្មោល១៤ឥតខ្ចោះ អាយុ១ខួប[ច] ២១ព្រមទាំង
ដង្វាយម្សៅ និងដង្វាយច្រួចសំរាប់គោ ចៀមនិងកូនចៀម
ទាំងប៉ុន្មាន តាមចំនួន ឱ្យត្រូវតាមរបៀប[ឆ] ២២ហើយពពែ
ឈ្មោល១ សំរាប់ជាដង្វាយលោះបាបផង នេះឱ្យលើស
ពីដង្វាយដុត ដែលតែងថ្វាយជានិច្ច និងដង្វាយម្សៅ ហើយ
ដង្វាយច្រួចនោះដែរ ។

**២៩:១** ក ជន ២៨:១៸
**២៩:២** ខ លវ ១:៩ ជន ២៨:១១ គ ជន ២៨:២ ឃ លវ ១:៣ ជន ២៨:៣ ង ខ.៣៦
**២៩:៣** ច ខ.១៤ ជន ២៨:១២
**២៩:៤** ឆ ជន ២៨:១៣
**២៩:៥** ជ ជន ២៨:១៥
**២៩:៦** ឈ ជន ២៩:១១ ញ ជន ២៨:៣ ដ ជន ២៨:៥ ឋ ជន ២៨:៧ ឌ លវ ១:៩ ជន ២៨:២
**២៩:៧** ឍ កច ២៧:៩ ណ នក ៣១:១៥
**២៩:៨** ត ខ.២
**២៩:៩** ថ ខ.៣,១៨ ទ ជន ២៨:១២
**២៩:១០** ធ ជន ២៨:១៣
**២៩:១១** ន ខ.៥ ជន ២៨:១៥ ប លវ ១៦:៣ ផ ខ.៦
**២៩:១២** ព លវ ២៣:២៤ ភ ១ពវ ៨:២ ១២:៣២
**២៩:១៣** ម ខ.២ ជន ២៨:២ យ ជន ២៨:៣
**២៩:១៤** រ ខ.៣ ជន ១៥:៦
**២៩:១៥** ល ខ.៤ ជន ២៨:១៣
**២៩:១៦** វ ខ.៥ ជន ២៨:១៥ ស ខ.៦
**២៩:១៧** ហ លវ ២៣:៣៦ ឡ ខ.២ ជន ២៨:៣ **២៩:១៨** អ ខ.៩ ក ជន ២៨:៧ ខ ជន ១៥:៤-១២ **២៩:១៩** គ ជន ២៨:១៥ ឃ ជន ២៨:៣ ង ខ.៦ **២៩:២០** ច ខ.១៧ **២៩:២១** ឆ ខ.១៨

បានប្រើប្រាស់នៅក្នុងសញ្ញាថ្មី (សូមមើល កច ២:១ និងការពន្យល់) ។

**២៩:១-៦** បុណ្យផ្លុំត្រែចាប់ផ្តើមការនៅដើមខែទី៧ គឺជាខែដែលមមាញឹកក្នុងការថ្វាយបង្គំព្រះអម្ចាស់ នៅក្នុងពិធីបុណ្យដ៏បរិសុទ្ធ (សូមមើល ២៣:២៣-២៥ សូមមើល តារាងរៀបរាប់ពីពិធីបុណ្យផ្សេងៗនៅក្នុងកណ្ឌលេវីវិន័យ) ។ លុះចំណេរកាលក្រោយមកទៀត នៅក្នុងទំនៀមទម្លាប់របស់ជនជាតិយូដា ពិធីនេះរីកឡើងជាពិធីបុណ្យចូលឆ្នាំថ្មីទៅវិញ ដែលមានឈ្មោះថា "រ៉ូស្ហហាស្ហាណា" (Rosh Hashanah) ។ ត្រែដែលគេយកមកប្រើប្រាស់នោះធ្វើឡើងពីស្នែងសត្វចៀមឈ្មោល ដែលគេឱ្យឈ្មោះថា "ស្ហូហ្វារ" (shophar) ។

**២៩:៧-១១** បុណ្យផ្លុំត្រែ បានបណ្តាលឱ្យមានថ្ងៃឱ្យធួននឹងបាប ជាពេលវេលានៃការលន់តួបាប ដង្វាយលើកចុះឡើង និងសេចក្តីអំណរអរសប្បាយ (សូមមើល លវ ១៦:១-៣៤ និងការពន្យល់ ២៣:២៦-៣២) ។

**២៩:១២-៣៤** នៅក្នុងខែទី៧ ពិធីបុណ្យផ្លុំត្រែប្រព្រឹត្តទៅនៅថ្ងៃទី១ គឺជាថ្ងៃឱ្យធួននឹងបាប ដែលបានកើតឡើងនៅថ្ងៃទី១០ ចំណែកឯបុណ្យបារាំបានចាប់ផ្តើមឡើងនៅថ្ងៃទី១៥ មានរយៈពេល៧ថ្ងៃ (មើល ២៣:៣៣-៤៤) រាល់ថ្ងៃនៃបុណ្យបារាំ មានលំដាប់លំដោយរបស់គេផ្ទាល់ៗខ្លួន ក្នុងការធ្វើ

២៣នៅថ្ងៃទី៤ ត្រូវថ្វាយគោឈ្មោល១០ ចៀមឈ្មោល
២ កូនចៀមឈ្មោល១៤ ឥតខ្ចោះ អាយុ១ខួប ២៤ព្រមទាំង
ដង្វាយម្សៅ និងដង្វាយច្រួចសំរាប់គោ ចៀម និងកូនចៀម
ទាំងប៉ុន្មាន តាមចំនួនឱ្យត្រូវតាមរបៀប ២៥ហើយពពែ
ឈ្មោល១ សំរាប់ជាដង្វាយលោះបាបផង នេះឱ្យលើស
ពីដង្វាយដុត ដែលតែងថ្វាយជានិច្ច និងដង្វាយម្សៅហើយ
ដង្វាយច្រួចនោះដែរ ។
២៦នៅថ្ងៃទី៥ ត្រូវថ្វាយគោឈ្មោល៩ ចៀមឈ្មោល២
កូនចៀមឈ្មោល១៤ ឥតខ្ចោះ អាយុ១ខួប ២៧ព្រមទាំង
ដង្វាយម្សៅ និងដង្វាយច្រួច សំរាប់គោ ចៀម និងកូន
ចៀមទាំងប៉ុន្មាន តាមចំនួន ឱ្យត្រូវតាមរបៀប ២៨ហើយ
ពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាបផង នេះឱ្យ
លើសពីដង្វាយដុត ដែលតែងថ្វាយជានិច្ច និងដង្វាយម្សៅ
ហើយដង្វាយច្រួចនោះដែរ ។
២៩នៅថ្ងៃទី៦ ត្រូវថ្វាយគោឈ្មោល៨ ចៀមឈ្មោល២
កូនចៀមឈ្មោល១៤ ឥតខ្ចោះអាយុ១ខួប ៣០ព្រមទាំង
ដង្វាយម្សៅ និងដង្វាយច្រួចសំរាប់គោ ចៀមនិងកូនចៀម
ទាំងប៉ុន្មាន តាមចំនួន ឱ្យត្រូវតាមរបៀប ៣១ហើយពពែ
ឈ្មោល១ សំរាប់ជាដង្វាយលោះបាបផង នេះឱ្យលើសពី
ដង្វាយដុត ដែលតែងថ្វាយជានិច្ច និងដង្វាយម្សៅ ហើយ
ដង្វាយច្រួចនោះដែរ ។
៣២នៅថ្ងៃទី៧ ត្រូវថ្វាយគោឈ្មោល៧ ចៀមឈ្មោល
២ កូនចៀមឈ្មោល១៤ ឥតខ្ចោះ អាយុ១ខួប ៣៣ព្រមទាំង
ដង្វាយម្សៅ និងដង្វាយច្រួចសំរាប់គោ ចៀម និងកូនចៀម
ទាំងអស់នោះ តាមចំនួន ឱ្យត្រូវតាមរបៀប ៣៤ហើយពពែ
ឈ្មោល១ សំរាប់ជាដង្វាយលោះបាបផង នេះឱ្យលើសពី
ដង្វាយដុត ដែលតែងថ្វាយជានិច្ច និងដង្វាយម្សៅ ហើយ
ដង្វាយច្រួចនោះដែរ ។
៣៥នៅថ្ងៃទី៨ ត្រូវឱ្យឯងរាល់គ្នាប្រជុំជំនុំ[ជ]មុតមាំ មិន
ត្រូវឱ្យធ្វើការរកស៊ីអ្វីឱ្យសោះ ៣៦ត្រូវឱ្យថ្វាយដង្វាយដុត
សំរាប់ជាក្លិនឈ្ងុយ ដល់ព្រះយេហូវ៉ា[ឈ] គឺគោឈ្មោល១
ចៀមឈ្មោល១ កូនចៀមឈ្មោល៧ ឥតខ្ចោះ អាយុ១ខួប[ញ]
៣៧ព្រមទាំងដង្វាយម្សៅ និងដង្វាយច្រួច សំរាប់គោ ចៀម
និងកូនចៀមទាំងនោះ តាមចំនួន ឱ្យត្រូវតាមរបៀប

**២៩:៣៥** ជ លវ ២៣:៣៦
**២៩:៣៦** ឈ លវ ១:៩ ញ ខ.២
**២៩:៣៩** ដ លវ ១:៣ ១រប ២៣:៣១ ២រប ៣១:៣ ឋ ជន ១:៩ ឌ លវ ៧:១៦ ឍ លវ ២៣:២ ណ លវ ៣:១
**៣០:១** ក ជន ១:៤
**៣០:២** ខ ចទ ២៣:២១–២៣ ពច ១១:៣៥ យប ២២:២៧ ទដ ២២:២៥ ៥០:១៤ ៦១:៥,៨ ៧៦:១១ ១១៦:១៤ សក ២០:២៥ សស ៥:៤,៥ អស ១៩:២១ យហ ១:១៦ ២:៩
**៣០:៤** គ ខ.៧
**៣០:៥** ឃ ខ.៨, ១២,១៥
**៣០:៦** ង លវ ៥:៤

៣៨ហើយពពែឈ្មោល១ សំរាប់ជាដង្វាយលោះបាបផង
នេះឱ្យលើសពីដង្វាយដុត ដែលតែងថ្វាយជានិច្ច និងដង្វាយ
ម្សៅ ហើយដង្វាយច្រួចនោះដែរ ។
៣៩ត្រូវឱ្យឯងរាល់គ្នាថ្វាយដង្វាយទាំងនេះ ដល់ព្រះ
យេហូវ៉ា នៅអស់ទាំងថ្ងៃបុណ្យដែលមានកំណត់របស់ឯង[ដ]
ឱ្យលើសពីអស់ទាំងដង្វាយដុត[ឋ] ដង្វាយម្សៅ ដង្វាយច្រួច
និងដង្វាយមេត្រី[ឌ] ដែលឯងរាល់គ្នាថ្វាយ សំរាប់លាបំណន់
[ឍ]និងដង្វាយដែលថ្វាយដោយស្ម័គ្រពីចិត្ត[ណ] ៤០នោះម៉ូសេក៏
ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល តាមគ្រប់ទាំងសេចក្ដី
ដែលព្រះយេហូវ៉ាបានបង្គាប់មក ។

## ការស្បថ

**៣០** ១រួចម៉ូសេនិយាយនឹងពួកមេលើពូជអំបូរកូនចៅអ៊ី
ស្រាអែលទាំងប៉ុន្មានថា[ក] នេះជាសេចក្ដីដែលព្រះយេហូវ៉ា
បានបង្គាប់មក ២គឺបើបុរសណាបន់ដល់ព្រះយេហូវ៉ា ឬនឹង
ស្បថភ្ជាប់ខ្លួនដោយសម្បថណាមួយ អ្នកនោះមិនត្រូវក្បត់
ពាក្យខ្លួនឡើយ គឺត្រូវតែធ្វើតាមសំដីរបស់ខ្លួនគ្រប់ចំពូក[ខ]
៣ឯស្ត្រីវិញ បើកាលណាបន់ដល់ព្រះយេហូវ៉ា ទាំងភ្ជាប់ខ្លួន
ដោយសារបំណន់នោះ កំពុងដែលនៅក្មេងនៅក្នុងបន្ទុក
របស់ឪពុកនៅឡើយ ៤ហើយឪពុកបានឮបំណន់នោះ និង
សេចក្ដីដែលកូនបានបន់ភ្ជាប់ខ្លួនដែរ តែឥតមានថាអ្វីឱ្យទេ
នោះបំណន់របស់នាងនឹងនៅជាយ៉ាងនោះទាំងអស់ ព្រម
ទាំងសេចក្ដីទាំងប៉ុន្មានដែលនាងបានបន់ភ្ជាប់ខ្លួនដែរ[គ] ៥តែ
បើឪពុកឃាត់នាង[ឃ]ក្នុងថ្ងៃដែលបានឮនោះ បំណន់របស់
នាងនិងសេចក្ដីទាំងប៉ុន្មានដែលនាងបានបន់ភ្ជាប់ខ្លួន មិន
បាននៅជាប់ទៀតទេ ហើយព្រះយេហូវ៉ាទ្រង់ក៏នឹងអត់
ទោសឱ្យនាងដែរ ពីព្រោះឪពុកបានឃាត់ហាម ។
៦បើនាងមានប្ដីក្នុងកាលដែលនៅជាប់បំណន់[ង] ឬបានបន់
ភ្ជាប់ខ្លួនដោយពាក្យណាដែលបានចេញពីមាត់ទៅឥតបើ
គិត ៧រួចប្ដីបានដឹង ហើយឥតមានថាអ្វីឱ្យ នោះបំណន់របស់
នាង និងនៅជាប់ជាយ៉ាងនោះ ព្រមទាំងសេចក្ដីណាដែល
នាងបានបន់ភ្ជាប់ខ្លួនដែរ ៨តែបើប្ដី[ច]បានឃាត់នាងក្នុង
ថ្ងៃដែលបានដឹង នោះគាត់បានផ្ដាច់បំណន់នាងហើយ
ព្រមទាំងសេចក្ដីដែលចេញពីមាត់នាង ដោយឥតបើគិត

**៣០:៨** ច លប ៣:១៦

យញ្ញបូជា (សូមមើលការពន្យល់នៅ សក ១៤:១៦) ។

**២៩:៤០** *នោះម៉ូសេក៏ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល* គឺជាការសរុបសេចក្ដីនៃពិធីបុណ្យទាំងឡាយ ដែលជាផ្នែកដ៏មានសារៈសំខាន់មួយនៃការផ្ទេរអំណាចពីលោកម៉ូសេ ទៅលោកយ៉ូស្វេ ។

**៣០:១–១៦** គោលការណ៍បទគម្ពីរសញ្ញាចាស់នៅលើបំណន់ទាំងឡាយ (សូមមើល ចទ ២៣:២១–២៣) ។ បំណន់ មិនមែនជាការដែលគេធ្វើឡើងដោយប្រញាប់ប្រញាល់ (សូមប្រៀបធៀប សស ៥:១–៧) ហើយនិង បំណន់ចំពោះព្រះអម្ចាស់ ត្រូវតែរក្សាឱ្យខាងតែបាន ។

**៣០:៣–៨** នៅក្នុងសង្គមនៃបូព៌ាប្រទេសស្ត្រីទាំងឡាយត្រូវចុះចូលទៅនឹងអំណាចខាងឪពុករបស់ពួកគេ (ខ.៣–៥) ឬខាងប្ដីរបស់ពួកគេ (ខ.៦–៨)

នោះផង ហើយព្រះយេហូវ៉ាទ្រង់នឹងអត់ទោសឱ្យនាង[ឆ] ។
៩តែឯសេចក្តីណាដែលស្ត្រីមេម៉ាយ ឬស្ត្រីប្តីលែងបាន
បន់ភ្ជាប់ខ្លួន នោះនឹងត្រូវនៅជាប់ជាដរាប ១០បើនាងនោះ
បានបន់បំណន់ឬភ្ជាប់ខ្លួនដោយសារសម្បថណាមួយ ក្នុង
កាលដែលនៅក្នុងបន្ទុកប្តីនៅឡើយ ១១ហើយប្តីបានដឹង
តែមិនបានថាអ្វីឱ្យទេ ក៏មិនបានឃាត់ផង នោះអស់ទាំង
បំណន់របស់នាង នឹងត្រូវនៅជាប់ជាយ៉ាងនោះ ព្រមទាំង
សេចក្តីណាដែលបានបន់ភ្ជាប់ខ្លួនដែរ ១២តែបើប្តីនាងបាន
ផ្តាច់បំណន់នោះចេញ ក្នុងថ្ងៃដែលគាត់បានដឹង នោះ
សេចក្តីអ្វីដែលបានចេញពីមាត់នាង ពីដំណើរបំណន់នោះ
ឬសេចក្តីណាដែលនាងបានបន់ភ្ជាប់ខ្លួន[ជ] នោះមិននៅជាប់
ទៀតទេ ដ្បិតប្តីបានផ្តាច់ហើយ ព្រះយេហូវ៉ាទ្រង់ក៏នឹងអត់
ទោសឱ្យនាងដែរ ។
១៣គ្រប់ទាំងបំណន់ ហើយគ្រប់ទាំងសម្បថ ដែលនឹង
សម្បថ ដើម្បីនឹងបញ្ឈឺចិត្តខ្លួន នោះប្តីនឹងតាំងឱ្យនៅជាប់ ឬ
ផ្តាច់ចេញក៏បាន ១៤បើសិនជាប្តីមិនមានថាអ្វីឱ្យនាងតទៅ
ទេ នោះគឺគាត់បានតាំងបំណន់នាងឱ្យនៅជាប់ហើយ ព្រម
ទាំងសេចក្តីណា ដែលនាងបានបន់ភ្ជាប់ខ្លួនទាំងអស់ផង គឺ
គាត់បានយល់ព្រមនឹងសេចក្តីទាំងនោះដែរ ពីព្រោះមិន
បានថាអ្វីឱ្យនាង ក្នុងថ្ងៃដែលគាត់បានដឹងនោះឡើយ ១៥តែ
បើគាត់ បានផ្តាច់បំណន់នោះ[ឈ]ក្នុងកាលដែលបានដឹង នោះ
គាត់ត្រូវរ៉ាប់រងចំពោះទោសរបស់នាងវិញ ។
១៦នេះហើយជាច្បាប់ទាំងប៉ុន្មាន ដែលព្រះយេហូវ៉ាបាន
បង្គាប់មកម៉ូសេ ពីដំណើរប្តីនិងប្រពន្ធ ហើយពីដំណើរ
ឪពុកនិងកូនស្រីដែលនៅក្មេងនៅក្នុងបន្ទុកឪពុកនៅឡើយ ។

### ការសងសឹកនឹងសាសន៍ម៉ាឌាន

៣១ ១ព្រះយេហូវ៉ា ទ្រង់បង្គាប់ដល់ម៉ូសេថា ២ចូរសងសឹក
នឹងសាសន៍ម៉ាឌាន[ក]ឱ្យពួកកូនចៅអ៊ីស្រាអែលចុះ ក្រោយ
នោះមក ឯងនឹងត្រូវប្រមូលទៅមូលនឹងពួកឰយុកោឯង
វិញ[ខ] ៣នោះម៉ូសេក៏ប្រាប់ដល់ពួកបណ្តាជនថា ចូរចាត់ចែង
គ្រឿងចំបាំងឱ្យដល់ពួកអ្នករាល់គ្នាខ្លះ ដើម្បីនឹងទៅច្បាំង
នឹងសាសន៍ម៉ាឌាន ប្រយោជន៍នឹងសំរេចសេចក្តីសងសឹក[គ]
របស់ព្រះយេហូវ៉ាទៅលើគេ ៤ត្រូវឱ្យឯងរាល់គ្នាចាត់
មនុស្ស១ពាន់នាក់ ពីគ្រប់ទាំងពូជអំបូរសាសន៍អ៊ីស្រាអែល
ឱ្យចេញទៅច្បាំង ៥ដូច្នេះ គេក៏កេណ្ឌយក១ពាន់នាក់ ក្នុង
គ្រប់ទាំងពូជអំបូរពីពួកអ៊ីស្រាអែលទាំងពាន់ៗបាន១ម៉ឺន
២ពាន់នាក់ ដែលកាន់គ្រឿងសំរាប់ទៅច្បាំង[ឃ] ៦រួចម៉ូសេ
ចាត់គេទៅច្បាំង[ង] គឺ១ពាន់នាក់ពីគ្រប់ទាំងពូជអំបូរនោះ
មានទាំងភីនេហាស[ច]ជាកូនអេលាសារ ដ៏ជាសង្ឃនាំយក
គ្រឿងប្រដាប់ទីបរិសុទ្ធ[ឆ] និងត្រែ[ជ]សំរាប់ផ្លុំកាន់នៅដៃទៅ
ជាមួយផង ៧គេក៏ច្បាំងនឹងសាសន៍ម៉ាឌាន ដូចជាព្រះ
យេហូវ៉ាបានបង្គាប់មកម៉ូសេ[ឈ] ក៏សំឡាប់ពួកប្រុសៗទាំង
អស់ទៅ[ញ] ៨ព្រមទាំងសំឡាប់ពួកស្តេចសាសន៍ម៉ាឌានជាមួយ
នឹងពួកអ្នកដែលត្រូវស្លាប់ទាំងប៉ុន្មាននោះដែរ គឺអេវី១
រេគេម១ សើរ១ ហើរ១ ហើយនិងរេបា១[ដ] ជាស្តេច

**៣០:៩** ឆ ខ.៥
**៣០:១២** ជ អភ ៥:២២ កល ៣:១៨
**៣០:១៥** ឈ ខ.៥
**៣១:២** ក លប ២៥:២ ខ ជន ២០:២៦
**៣១:៣** គ ពច ១១:៣៦ ១សយ ២៤:១២ ២សយ ៤:៨ ២២:៤៨ ទដ ៩៤:១ ១៤៩:៧ អស ៣៤:៨ យរ ១១:២០ ៤៦:១០ អគ ២៥:១៧
**៣១:៥** ឃ ខ.៦,២១
**៣១:៦** ង ខ.៥ ច នក ៦:២៥ ឆ ជន ១៤:៤៤ ជ ជន ១០:២
**៣១:៧** ឈ ជន ២៥:១៦ ញ ចទ ២០:១៣ ពច ២១:១១ ១ពវ ១១:១៥,១៦
**៣១:៨** ដ យប ១៣:២១

ដែលឪពុក ឬប្តីរបស់នាងជាអ្នកផ្តាច់បំណន់នាង ។

**៣០:៩** *ស្ត្រីមេម៉ាយ ឬស្ត្រីប្តីលែង* ស្ត្រីទាំងនេះនឹងស្ថិតនៅក្នុងការទទួលខុសត្រូវលើបំណន់របស់ខ្លួនជាដរាប បើសិនជាពួកគេបានធ្វើបំណន់ ។

**៣០:១០–១៥** គំរូដទៃទៀត ដែលមានលក្ខណៈស្មុគ្រស្មាញ ដោយមានបង្ហាញនៅក្នុងបំណន់រវាងទំនាក់ទំនងប្តីនិងប្រពន្ធ ។ លក្ខណៈស្មុកស្មាញនេះអាចច្បាស់តែមួយនាទីបញ្ចប់ ។ ដោយយើងអាចធ្វើការសន្មតបានឃើញថា នៅក្នុងសតវត្សក្រោយៗមកទៀត ចូលមកក្នុងជំនាន់សញ្ញាថ្មី ការសម្រេចចិត្តទៅកើតមានឡើងនៅក្នុងករណីនៃកូនស្រីស្លូផិហាត (២៧:១–១១) ។ ករណីមួយទៀត បន្ទាប់ពីកើតមានឡើងរួចហើយ រីឯលទ្ធផលនៅក្នុងការប្រមូលតាមផ្លូវច្បាប់នៅលើបំណន់បានក្លាយជារឿងស្មុកស្មាញជំពាក់វាក់វិន ។ មានព្រះបន្ទូលរបស់ព្រះយេស៊ូវមួយឃ្លា ដែលបានបញ្ចៀសពីការស្មុគ្រស្មាញ ដែលជាប់ពាក់ព័ន្ធទៅនឹងពាក្យសម្បថ (មថ ៥:៣៣–៣៧) ត្រូវបានដាក់ឱ្យរួចពីរឿងនោះ ។

**៣១:១–២៤** ព្រះអម្ចាស់បានប្រកាសសង្គ្រាមទាស់នឹងពួកសាសន៍ ម៉ាឌាន ដូចជាការប្រព្រឹត្តចុងក្រោយរបស់លោកម៉ូសេ មុននឹងគាត់ចប់ជីវិតរស់នៅលើផែនដីនេះទៅ ។ លោកម៉ូសេ មិនបានមានចំណង់លើការច្រណែនសូម្បីតែបន្តិចបន្តួចសោះឡើយ ប្រយោជន៍នឹងសម្រេចទៅតាមសង្គ្រាមនៃ "ការសងសឹករបស់ព្រះយេហូវ៉ា" (ខ.៣) ចំពោះរឿងមួយរបស់សាសន៍ម៉ាឌានមកល្បួងលួងលោមពួកកូនចៅអ៊ីស្រាអែល ដើម្បីឱ្យធ្លាក់ចូលទៅក្នុងរឿងសេចក្តីកំផិតខាងផ្លូវភេទ និងការថ្វាយបង្គំព្រះបាល ដោយព្រោះរឿងពេអរនោះ ។ (សូមមើល ២៥:១៦–១៨ ដែលជាកន្លែងនិយាយបញ្ជាក់អំពីឈ្មោះកូសប៊ី ជាស្ត្រីជនជាតិម៉ាឌាន ព្រះអង្គទ្រង់ក្រោធយ៉ាងខ្លាំងដែលសម្តែងចេញឡើងនៅជំពូក ៣១) ។

**៣១:២** *ត្រូវប្រមូលទៅមូលនឹងពួកឰយុកោឯងវិញ* ក្នុងមរណភាព (សូមមើលការពន្យល់ លប ២៥:៨) ។

**៣១:៤** *មនុស្ស១ពាន់នាក់ ពីគ្រប់ទាំងពូជអំបូរសាសន៍អ៊ីស្រាអែល* បន្ទុកនៃសង្គ្រាមរបស់ព្រះអម្ចាស់ ត្រូវបានចែកឱ្យទៅគ្រប់ទាំងអំបូរសាសន៍ដោយភាគចំណែកស្មើៗគ្នា ។

**៣១:៦** *ភីនេហាស* សេចក្តីខ្នះខ្នែងរបស់គាត់សម្រាប់សេចក្តីគោរពដល់ព្រះអម្ចាស់ ដែលនាំឱ្យគាត់ប្រតិបត្តិ ស៊ីមរី និងកូសប៊ី (២៥:៨) ។ ឥឡូវនេះគាត់ដឹកនាំចូលនៅក្នុងទិដ្ឋភាពសម្រាប់ការបូជានៃការតស៊ូ ដើម្បីបង្ហាញប្រាប់ថា នេះគឺជាសង្គ្រាមរបស់ព្រះអម្ចាស់ ។ *ត្រែ* សូមមើលការពន្យល់នៅ ១០:៣ ។

**៣១:៨** *ក៏បានសំឡាប់បាឡាម* ជំពូក ២៥ មានកង្វះខាតនូវឈ្មោះនេះចំពោះ

សាសន៍ម៉ាឌានទាំង៥អង្គ[ឋ] ក៏បានសំឡាប់បាឡាមជាកូន
បេអ៊ោរ[ឌ]ដោយដាវដែរ[ឍ] ៩ពួកកូនចៅអ៊ីស្រាអែលគេចាប់
យកពួកស្រីៗសាសន៍ម៉ាឌាន[ណ] និងកូនតូចៗទាំងប៉ុន្មាននាំ
ទៅជាឈ្លើយ ក៏យកហ្វូងគោ ហ្វូងចៀម និងទ្រព្យសម្បត្តិ
ទាំងអស់ទុកជារបឹបដែរ[ត] ១០ឯអស់ទាំងទីក្រុងនិងផ្ទះសំបែង
ហើយអស់ទាំងទីដំឡើងត្រសាលទាំងប៉ុន្មាន[ថ] នោះគេក៏ដុត
ដោយភ្លើងទៅ[ទ] ១១រួចយកអស់ទាំងរបឹប ព្រមទាំងសត្វនិង
មនុស្សទាំងប៉ុន្មានដែលគេចាប់បាននោះ[ធ] ១២ហើយនាំពួក
ឈ្លើយ សត្វទាំងនោះ[ន] និងរបឹបទាំងប៉ុន្មានទៅប្រគល់ដល់
ម៉ូសេ និងអេលាសារដ៏ជាសង្ឃ ព្រមទាំងដល់ពួកជំនុំ[ប]នៃ
កូនចៅអ៊ីស្រាអែល នៅត្រង់ទីដំឡើងត្រសាល នាស្រុក
វាលរបស់ម៉ូអាប់ ដែលជិតទន្លេយ័រដាន់ ទល់មុខនឹង
យេរីខូរ[ផ]។
១៣នោះម៉ូសេ អេលាសារដ៏ជាសង្ឃ ហើយនិងពួកដែល
ជាកំពូលលើពួកជំនុំទាំងអស់ ក៏នាំគ្នាចេញទៅទទួលគេ
នៅខាងក្រៅទីដំឡើងត្រសាល ១៤ឯម៉ូសេលោកខឹងនឹងពួក
មេទ័ព[ព] គឺនឹងពួកមេលើ១ពាន់នាក់ ហើយនិងពួកមេលើ
១00នាក់ ដែលមកពីច្បាំងវិញនោះ ១៥លោកសួរគេថា តើ
បានទុកឱ្យស្រីៗទាំងអស់រស់នៅឬអី ១៦មើល គឺវារាល់គ្នា
ហើយ ដែលបាននាំឱ្យពួកកូនចៅអ៊ីស្រាអែលប្រព្រឹត្តរំលង
ទាស់នឹងព្រះយេហូវ៉ា ពីដំណើរពេអរ[ភ] ដោយសារសេចក្តី
ទូន្មានរបស់បាឡាម[ម] ហើយយ៉ាងនោះ ក៏មានសេចក្តីវេទនា
[យ]កើតឡើងក្នុងពួកជំនុំនៃព្រះយេហូវ៉ា ១៧ដូច្នេះ ចូរសំឡាប់
អស់ទាំងប្រុសៗក្នុងពួកក្មេងទាំងប៉ុន្មាន ព្រមទាំងស្រីៗ
ដែលបានស្គាល់ប្រុស ដោយរួមដំណេកហើយ ឥឡូវទៅ[រ]
១៨តែឯពួកក្មេងស្រីៗ ដែលមិនទាន់ស្គាល់ប្រុសណាដោយ
រួមដំណេកនៅឡើយ នោះទុកសំរាប់ឯងរាល់គ្នាវិញចុះ
១៩ត្រូវឱ្យឯងរាល់គ្នានៅខាងក្រៅទីដំឡើងត្រសាល អស់៧

**៣១:៨** ឋ ជន ២៥:១៥ ឌ ជន ២២:៥ ២៤:១៤ ឍ យស ១៣:២២ **៣១:៩** ណ ខ.១៥ ត លប ៣៤:២៩ **៣១:១០** ថ លប ២៥:១៦ ១រប ៦:៥៤ ទដ ៦៩:២៥ អគ ២៥:៤ ទ យស ៦:២៤ ៨:២៨ ១១:១១ ពច ១៨:២៧ **៣១:១១** ធ ខ.២៦ ចទ ២០:១៤ ២រប ២៨:៨ **៣១:១២** ន ខ.៣២, ៥៣ លប ៤៩:២៧ នក ១៥:៩ ប ជន ២៧:២ ផ ជន ២២:១ **៣១:១៤** ព ខ.៤៨ នក ១៨:២១ ចទ ១:១៥ ២សយ ១៨:១ **៣១:១៦** ភ ជន ២៣:២៨ ២៥:១-៩ ម ជន ២២:៥ ២៤:១៤ ២ពវ ២:១៥ យ ជន ១៤:៣៧ **៣១:១៧** រ ចទ ៧:២ ២0:១៦-១៨ ពច ២១:១១ **៣១:១៩** ល ជន ១៩:១៦ វ លវ ២១:១ ស ជន ១៩:១២

ថ្ងៃ ឯអស់អ្នកណាដែលបានសំឡាប់គេ[ល] ឬបានប៉ះពាល់
ខ្មោចណា នោះត្រូវសំអាតខ្លួននៅថ្ងៃទី៣ ហើយនៅថ្ងៃទី៧
ទៀត[វ] គឺទាំងឯងរាល់គ្នា[ស] ហើយនិងពួកឈ្លើយទាំងប៉ុន្មាន
ផង ២០ចំណែកខាងសំលៀកបំពាក់ទាំងប៉ុន្មាន[ហ] និងអស់
ទាំងរបស់ធ្វើពីស្បែក ព្រមទាំងរបស់ធ្វើពីរោមពពែ
ហើយគ្រប់ទាំងរបស់ធ្វើពីឈើ នោះត្រូវឱ្យឯងរាល់គ្នា
សំអាតដោយខ្លួនឯង[ឡ]។
២១ឯអេលាសារដ៏ជាសង្ឃ លោកប្រាប់ដល់ពួកទ័ព
ដែលបានទៅច្បាំងថា[អ] នេះជាបញ្ញត្តិច្បាប់ដែលព្រះ
យេហូវ៉ាបានបង្គាប់មកម៉ូសេថា ២២ឯមាស ប្រាក់ លង្ហិន
ដែក[ក] ស៊ីវិឡាត និងសំណ ២៣គឺគ្រប់ទាំងធាតុអ្វីដែលធន់នៅ
នឹងភ្លើងបាន[ខ] នោះត្រូវឱ្យឯងរាល់គ្នានាំយកទៅដុតភ្លើង
សំអាតទៅ រួចនឹងបានស្អាត ប៉ុន្តែត្រូវឱ្យសំអាតនឹងទឹក
ដែលសំរាប់សំអាតដែរ[គ] ឯអស់ទាំងធាតុអ្វីដែលធន់នៅ
នឹងភ្លើងមិនបាន នោះត្រូវឱ្យលាងនឹងទឹកវិញ ២៤ដល់ថ្ងៃទី៧
ត្រូវឱ្យឯងរាល់ គ្នាបោកសំលៀកបំពាក់ខ្លួនចេញ នោះនឹង
បានស្អាត[ឃ]រួច សឹមចូលមកក្នុងទីដំឡើងត្រសាលចុះ[ង]។

## ការចែករបឹប

២៥ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ២៦ចូរឱ្យឯង
និងអេលាសារដ៏ជាសង្ឃ ហើយនិងពួកមេ[ច]ក្នុងវង្សានុវង្ស
នៃពួកជំនុំរាប់ចំនួនរបឹប គឺទាំងមនុស្ស[ឆ] ហើយនិងសត្វផង
ដែលចាប់បាននោះ[ជ] ២៧រួចបែងចែក[ឈ]របឹបជា២ចំណែក
ឱ្យដល់ពួកទាហានដែលបានទៅច្បាំង នឹងពួកជំនុំទាំងអស់
គ្នា ២៨ហើយត្រូវហូតយកសួយអាករពីពួកទាហានដែល
បានទៅច្បាំងដែរ គឺ១ក្នុង៥00 ទាំងមនុស្ស ទាំងគោ

**៣១:២០** ហ ជន ១៩:១៩ ឡ លវ ១១:៣២ **៣១:២១** អ ខ.៥ **៣១:២២** ក យស ៦:១៩ ២២:៨ **៣១:២៣** ខ ១កថ ៣:១៣ គ ជន ៨:៧ **៣១:២៤** ឃ លវ ១១:២៥ ង លវ ១៤:៨ **៣១:២៦** ច ជន ១:៤ ឆ ជន ១:១៩ ជ ខ.១១,១២ **៣១:២៧** ឈ យស ២២:៨ ១សយ ២៥:១៣ ៣0:២៤

អ្នកផ្តើមគំនិតដ៏សំខាន់ ក្នុងការល្បួងលួងលោមដល់មនុស្សប្រុសសាសន៍អ៊ីស្រាអែលក្លាយទៅជាខូចអស់រលីង ដោយបែរទៅថ្វាយបង្គំព្រះបាលទៅវិញ ។ ប៉ុន្តែនៅត្រង់ខនេះ គាត់ត្រូវបានគេរកឃើញនៅក្នុងចំណោមអ្នកស្លាប់ទាំងប៉ុន្មាននោះ ។ អ្វីដែលបាឡាមមិនអាចប្រតិបត្តិតាមរយៈការប្រព្រឹត្តនូវមន្តអាគម ឬអំពើអាបធ្មប់ (ជំពូក ២២-២៤) គាត់ជិតបានសម្រេចស្ទើរតែទាំងស្រុង ដោយសេចក្តីទូន្មានរបស់គាត់ដល់ពួកសាសន៍ម៉ាឌាន (ខ.១៦) ។

**៣១:៩-១៨** នាពេលដែលពួកកងទ័ពបានសម្លាប់បុរស នៃសាសន៍ម៉ាឌាន ពួកគេបានទុកជីវិតឱ្យស្ត្រីៗ និងកូនក្មេងទាំងឡាយទុកជារបឹប ។ លោកម៉ូសេ ដោយព្រោះថា អ្នកទាំងនោះជាអ្នកដែលគ្មានទោសពៃរ៍អ្វីទាំងអស់ ហើយក៏មិនបានប្រព្រឹត្តនូវពាក្យសម្តី ដែលមិនសមរម្យដែរនៅឯពេអរនោះ) ដែលត្រូវតែបានទុកឱ្យរស់រានមានជីវិតស្ត្រី និងក្មេងៗដែលមានកំហុស (ជាអ្នកដែលធ្វើឱ្យអន្តរាយដល់សិទ្ធិទទួលកេរ្តិ៍មរដក នៃបុរសសាសន៍អ៊ីស្រាអែល) ត្រូវបានគេដាក់ឱ្យរងទណ្ឌកម្មប្រហារជីវិត (ខ.១៥-១៧) ។

**៣១:១៩-២៤** ចាប់តាំងពីមានសង្គ្រាមរបស់ព្រះអម្ចាស់មក បណ្តាជនទាំងពីរភេទ (ខ.១៩-២0) និងគ្រប់របស់ទាំងអស់ (ខ.២១-២៤) ត្រូវតែបានសម្អាតចេញ (សូមមើលខប្រៀបធៀប ១៩:១១-១៣) ។

**៣១:២៦-៣៥** ទិដ្ឋភាពផ្សេងមួយទៀតនៃសង្គ្រាមរបស់ព្រះអម្ចាស់ មានការហិនវិនាសដោយសង្គ្រាម ប្រកបទៅដោយលក្ខណៈត្រឹមត្រូវយុត្តិធម៌ ក្នុងចំណោមមនុស្សទាំងពីរភេទ ដែលបានប្រយុទ្ធតតាំងនៅក្នុងការតស៊ូនោះ ដែលបានរស់នៅក្នុងពួកជំនុំ ដោយប្រកបទៅដោយការមានភាគចំណែកដ៏សមរម្យ ដើម្បីសម្រាប់ថ្វាយដល់ព្រះយេហូវ៉ា ចំពោះអស់អ្នកណាដែលបាន

ទាំងលា ហើយនិងចៀមផង ទុកសំរាប់ព្រះយេហូវ៉ា[ញ]
២៩ត្រូវឱ្យយកពីចំណែកនៃពួកទាហានប្រគល់ដល់អេលា
សារដ៏ជាសង្ឃ ទុកជាដង្វាយលើកចុះឡើងថ្វាយព្រះយេ
ហូវ៉ា ៣០ឯចំណែករបស់ពួកកូនចៅអ៊ីស្រាអែល នោះត្រូវ
ហូតយក១ភាគក្នុង៥០វិញ ទាំងមនុស្ស ទាំងគោ ទាំងលា
ហើយនិងចៀមផង គឺពីគ្រប់សត្វទាំងអស់ ប្រគល់ដល់ពួក
លេវីដែលថែរក្សា បញ្ញើនៃរោងឧបោសថផងព្រះយេ
ហូវ៉ា[ដ] ៣១នោះម៉ូសេ និងអេលាសារ ដ៏ជាសង្ឃ ក៏ធ្វើដូចជា
ព្រះយេហូវ៉ាបានបង្គាប់មក ។

៣២រីឯក្រៅពីរបស់អ្វីៗ[ឋ] ដែលពួកទាហានបានយកនោះ
របឹបទាំងអស់មានចំនួនដូច្នេះ គឺចៀម៦សែន៧ម៉ឺន៥ពាន់
៣៣និងគោ៧ម៉ឺន២ពាន់ ៣៤សត្វលា៦ម៉ឺន១ពាន់ ៣៥ឯមនុស្ស
ស្រីទាំងប៉ុន្មានដែលមិនបានស្គាល់ប្រុសណា ដោយរួមដំ-
ណេកនឹងគ្នា នោះមានចំនួន៣ម៉ឺន២ពាន់នាក់ ៣៦ហើយ
ចំណែក១ ដែលបានចែកឱ្យពួកអ្នកដែលចេញទៅច្បាំង
នោះមានចៀម៣សែន៣ម៉ឺន៧ពាន់៥០០ ៣៧ហើយចៀម
ដែលជាសួយអាករ ទុកសំរាប់ព្រះយេហូវ៉ា[ឌ]នោះមាន៦៧៥
៣៨ឯគោ នោះគេបាន៣ម៉ឺន៦ពាន់ ហើយសួយអាករថ្វាយ
ព្រះយេហូវ៉ាបាន៧២ ៣៩ក្នុងសត្វលា នោះគេបាន៣ម៉ឺន៥០០
ហើយសួយអាករថ្វាយព្រះយេហូវ៉ាបាន៦១ ៤០ឯមនុស្ស
នោះ គេបាន១ម៉ឺន៦ពាន់នាក់ ហើយសួយអាករថ្វាយព្រះ
យេហូវ៉ាបាន៣២នាក់ ៤១ម៉ូសេក៏ប្រគល់សួយអាករទាំងនោះ
ដែលជាដង្វាយលើកចុះឡើងរបស់ព្រះយេហូវ៉ា[ឍ]ដល់
អេលាសារដ៏ជាសង្ឃ ដូចជាព្រះយេហូវ៉ាបានបង្គាប់មក[ណ] ។

៤២ឯ១ចំណែកទៀត ដែលត្រូវបានដល់ពួកកូនចៅ
អ៊ីស្រាអែល គឺជាចំណែកដែលម៉ូសេបានហូតយកពីពួកអ្នក
ដែលទៅច្បាំង ៤៣ឱ្យដល់ពួកជំនុំវិញ នោះមានចៀម៣
សែន៣ម៉ឺន៧ពាន់៥០០ ៤៤គោ៣ម៉ឺន៦ពាន់ ៤៥សត្វលា៣ម៉ឺន
៥០០ ៤៦ហើយមនុស្ស១ម៉ឺន៦ពាន់ ៤៧ម៉ូសេក៏យក១ក្នុង៥០
ទាំងមនុស្សទាំងសត្វពីចំណែករបស់ពួកកូនចៅអ៊ីស្រាអែល
នោះ ប្រគល់ឱ្យដល់ពួកលេវី ដែលថែរក្សាបញ្ញើនៃរោង
ឧបោសថផងព្រះយេហូវ៉ា ដូចជាព្រះយេហូវ៉ាបានបង្គាប់
មក ។

៤៨រួចពួកមេទ័ព[ត]ដែលត្រួតលើពលទ័ពទាំងពាន់ៗ គឺជា
ពួកមេលើ១ពាន់នាក់ ហើយពួកមេលើ១០០នាក់ គេក៏នាំគ្នា
ចូលមកឯម៉ូសេ ជំរាបថា ៤៩យើងខ្ញុំ ជាអ្នកបំរើលោក បាន
រាប់[ថ]ពួកពលទ័ពដែលនៅក្រោមអំណាចយើងខ្ញុំទាំងអស់
ហើយ ឥតមានខ្វះមនុស្សណាមួយក្នុងពួកយើងខ្ញុំឡើយ[ទ]
៥០ហើយយើងខ្ញុំបានយកដង្វាយនេះមកថ្វាយដល់ព្រះ
យេហូវ៉ា ជារបស់ដែលគ្រប់គ្នាចាប់យកបាន គឺជាគ្រឿង
មាស ខ្សែ កងដៃ ចិញ្ចៀន ការ ហើយនិងខ្សែក ដើម្បី
នឹងថ្វាយឱ្យធួននឹងជីវិតយើងខ្ញុំ[ធ]នៅចំពោះព្រះយេហូវ៉ា
៥១ម៉ូសេនឹងអេលាសារដ៏ជាសង្ឃ ក៏ទទួលយកមាសទាំង
នោះពីគេ សុទ្ធតែជាគ្រឿងរចនាទាំងអស់ ៥២ឯមាស
ទាំងអស់ ដែលគេបានថ្វាយ ដោយលើកចុះឡើងដល់ព្រះ
យេហូវ៉ា គឺដែលពួកមេលើ១ពាន់នាក់ និងពួកមេលើ១០០
នាក់បានថ្វាយ នោះមានទំងន់១ម៉ឺន៦ពាន់៧៥០ដំឡឹង
៥៣ដ្បិតពួកទ័ពបានចាប់យករបស់ទាំងនោះ[ន] ទុកសំរាប់ខ្លួន
គេ ៥៤ម៉ូសេនិងអេលាសារដ៏ជាសង្ឃ ក៏ទទួលយកមាសទាំង
នោះពីពួកមេលើ១ពាន់នាក់ ហើយពីពួកមេលើ១០០នាក់
ទៅទុកដាក់ក្នុងត្រសាលជំនុំ[ប] ទុកជាសេចក្តីរំឭក[ផ] សំរាប់
ពួកកូនចៅអ៊ីស្រាអែល នៅចំពោះព្រះយេហូវ៉ា ។

## ពួកសាសន៍នៅម្ខាងនៃទន្លេយ័រដាន់

**៣២** ១ឯពួកកូនចៅរូបេន និងពួកកូនចៅកាឌ់ គេមាន
ហ្វូងសត្វសន្ធឹកណាស់[ក] ដូច្នេះកាលគេបានឃើញស្រុកយ៉ា
សេ៊ើរ[ខ] និងស្រុកកាឡាត[គ]ថា ជាស្រុកស្រួលល្មមឱ្យចិញ្ចឹម
ហ្វូងសត្វបាន[ឃ] ២នោះគេក៏មកជំរាបដល់ម៉ូសេ និងអេលា
សារដ៏ជាសង្ឃ ព្រមទាំងពួកដែលជាកំពូលលើពួកជំនុំ[ឃ]ថា
៣ក្រុងអាថារ៉ូត[ង] ឌីបូន[ច] យ៉ាសេ៊ើរ[ឆ] នីមរ៉ា[ជ] ហែសបូន[ឈ]
អេលាលេ[ញ] សេបាម[ដ] នេបូរ[ឋ] ហើយបេអុន[ឌ] ៤គឺស្រុកនេះ
ឯងដែលព្រះយេហូវ៉ាបានវាយ[ឍ] នៅមុខពួកជំនុំនៃសាសន៍
អ៊ីស្រាអែល ជាស្រុកស្រួលល្មមចិញ្ចឹមហ្វូងសត្វបាន[ណ] ឯ
យើងខ្ញុំប្របាទជាអ្នកមានហ្វូងសត្វហើយ ៥ដូច្នេះបើយើង
ខ្ញុំបានប្រកបដោយគុណនៃលោក នោះសូមប្រគល់ស្រុក
នេះឱ្យបានជាកេរ្តិ៍អាករដល់យើងខ្ញុំប្របាទផង សូមកុំនាំ
យើងឆ្លងទន្លេយ័រដាន់នេះទៅឡើយ[ត] ។

៦ម៉ូសេលោកឆ្លើយទៅពួកកូនចៅកាឌ់ និងពួកកូនចៅ
រូបេនថា តើត្រូវឱ្យបងប្អូនឯងរាល់គ្នាទៅច្បាំង ហើយឯង
រាល់គ្នាអង្គុយព្រងើយនៅទីនេះវិញឬអី ៧ម្តេចក៏ឯងរាល់

**៣១:២៨** ញ ខ.៣៧–៤១ ជន ១៨:២១
**៣១:៣០** ដ ជន ៣:៧ ១៨:៣
**៣១:៣២** ឋ ខ.១២
**៣១:៣៧** ឌ ខ.៣៨–៤១
**៣១:៤១** ឍ ជន ៥:៩ ១៨:៨ ណ ខ.២១,២៨
**៣១:៤៨** ត ខ.១៤
**៣១:៤៩** ថ ជន ១:១៩ ទ យរ ២៣:៤
**៣១:៥០** ធ នក ៣០:១៦
**៣១:៥៣** ន លប ៣៤:២៩ ចទ ២០:១៤
**៣១:៥៤** ប នក ២៧:២១ ៤០:២ ផ នក ២៨:១២
**៣២:១** ក ខ.២៤,៣៦ ពច ៥:១៦ ខ ជន ២១:៣២ គ លប ៣១:២១ ឃ នក ១២:៣៨
**៣២:២** ង លវ ៤:២២ ជន ២៧:២
**៣២:៣** ច ខ.៣៤ យស ១៦:២,៧ ១៨:១៣ ឆ ខ.៣៤ ជន ២១:៣០ ជ ខ.១ ឈ ខ.៣៦ យស ១៣:២៧ ញ ជន ២១:២៥ ដ ខ.៣៧ អស ១៥:៤ ១៦:៩ យរ ៤៨:៣២ ឋ ជន ៣៣:៤៧ ចទ ៣២:៤៩ ៣៤:១ ១រប ៥:៨ ឌ ខ.៣៨ យស ១៣:១៧ អគ ២៥:៩
**៣២:៤** ឍ ជន ២១:៣៤ ណ នក ១២:៣៨
**៣២:៥** ត ជន ១៣:២៩

ទៅប្រយុទ្ធតតាំងនោះ (ខ.២៨) ។
**៣២:១** *ពួកកូនចៅរូបេន និងកូនចៅកាឌ់* ភាពសម្បូរហូរហៀរនៃទឹកដី
ដែលប្រកបទៅដោយជីជាតិ និងមានពោរពេញទៅដោយស្មៅគ្រប់គ្រាន់
សម្រាប់ចិញ្ចឹមសត្វនៅតាមដងទន្លេយ័រដាន់ បានញុំាងឱ្យពួកអ្នកដឹកនាំនៃពូជ
អំបូរទាំងពីរនេះ ធ្វើសំណើថាពួកគេត្រូវបានអនុញ្ញាតឱ្យបោះទីតាំងនៅត្រង់
នោះ ហើយមិនឆ្លងទៅត្រើយម្ខាងទៀតនៃទន្លេយ័រដាន់ទេ តំបន់នេះជា

គ្នាចង់រំសាយចិត្តនៃពួកកូនចៅអ៊ីស្រាអែល មិនឱ្យគេឆ្លង
ទៅក្នុងស្រុក ដែលព្រះយេហូវ៉ាបានប្រទានឱ្យគេដូច្នេះ[ថ]
៨ពួកឪពុកឯងរាល់គ្នាក៏បានធ្វើដូច្នេះដែរ ក្នុងកាលដែល
អញចាត់គេ ពីកាដេស-បារនា ឱ្យទៅសង្កេតមើលស្រុក
នោះ[ទ] ៩ដ្បិតកាលគេឡើងទៅដល់ជ្រោះអែសកុល[ធ] ឃើញ
ស្រុកនោះហើយ នោះគេបានរំសាយចិត្តពួកកូនចៅ
អ៊ីស្រាអែលវិញ ដើម្បីកុំឱ្យចូលទៅក្នុងស្រុកដែលព្រះ
យេហូវ៉ាបានប្រទានឱ្យ ១០ហើយនៅថ្ងៃនោះឯង សេចក្ដី
ខ្ញាល់នៃព្រះយេហូវ៉ាបានកាត់ឡើង[ន] ទ្រង់ក៏ស្បថថា[ប] ១១ក្នុង
ពួកមនុស្សដែលចេញពីស្រុកអេស៊ីព្ទ[ផ]មក ចាប់តាំងពីអាយុ
២០ឆ្នាំឡើង[ព]ទៅលើ នោះគ្មានអ្នកណាមួយ នឹងឃើញស្រុក
ដែលអញបានស្បថ[ភ] និងឱ្យដល់អ័ប្រាហាំ អ៊ីសាក ហើយ
យ៉ាកុប[ម]នោះឡើយ ពីព្រោះគេមិនបានប្រព្រឹត្តតាមអញ
គ្រប់ចំពូក ១២លើកតែកាលែបជាកូនយេភូនេក្នុងពូជ
កេណាល១ និងយ៉ូស្វេជាកូននុន១ប៉ុណ្ណោះ ពីព្រោះអ្នកទាំង
២នោះ បានប្រព្រឹត្តតាមអញគ្រប់ចំពូក[យ] ១៣ដូច្នេះសេចក្ដី
ខ្ញាល់នៃព្រះយេហូវ៉ា ក៏កាត់ឡើងទាស់នឹងសាសន៍អ៊ីស្រា
អែល[រ] ហើយទ្រង់បានធ្វើឱ្យគេដើរវិមវាមនៅក្នុងទីរហោ
ស្ថានអស់៤០ឆ្នាំ ទាល់តែដំណមនុស្ស ដែលបានប្រព្រឹត្ត
អាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ានោះ បានវិនាសទាំង
អស់ទៅ[ល] ១៤ហើយមើល ឯងរាល់គ្នាបានកើតឡើងជា
ដំណាងនៃឪពុកឯង ជាពួកមនុស្សមានបាប ដែលចំរើន
កាន់តែច្រើនឡើង ចង់តែបន្ថែមសេចក្ដីក្រោធដ៏សហ័ស
នៃព្រះយេហូវ៉ា ឱ្យរឹងរឹតតែក្ដៅឡើងទាស់នឹងសាសន៍
អ៊ីស្រាអែលទៅទៀត[វ] ១៥ដ្បិតបើឯងរាល់គ្នាបែរចេញពី
ទ្រង់ នោះទ្រង់នឹងទុកឯងចោលនៅទីរហោស្ថានតទៅ
ហើយឯងរាល់គ្នានឹងធ្វើឱ្យបណ្ដាជនទាំងនេះត្រូវវិនាស
បង់[ស]។
១៦តែគេចូលទៅជិតជិរាបលោកថា យើងខ្ញុំនឹងធ្វើ
ក្រោល[ហ] សំរាប់ហ្វូងសត្វ[ឡ]របស់យើងខ្ញុំ ហើយនិងទីក្រុង
សំរាប់កូនចៅយើងខ្ញុំ ១៧តែខ្លួនយើងខ្ញុំនឹងមានគ្រឿងប្រុង
ជាស្រេច ដើម្បីនឹងជូនមុខពួកកូនចៅអ៊ីស្រាអែល[អ] ទាល់តែ
បាននាំគេ រហូតទៅដល់ទីកន្លែងរបស់គេ[ក] ឯកូនចៅយើងខ្ញុំ
គេនឹងនៅក្នុងទីក្រុងមានកំផែង ដោយខ្លាចដល់មនុស្សនៅ
ស្រុកនេះ ១៨យើងខ្ញុំមិនត្រឡប់មកឯផ្ទះយើងខ្ញុំវិញទេ ដរាប
ដល់ពួកកូនចៅអ៊ីស្រាអែលបានស៊ីមរដករបស់គេរៀងខ្លួន[ខ]
១៩ដ្បិតយើងខ្ញុំរាល់គ្នានឹងមិនស៊ីមរដកជាមួយនឹងគេ នៅ
ត្រើយទន្លេយ័រដាន់ម្ខាងទៀតទេ ពីព្រោះមរដក[គ]របស់ផង
យើងខ្ញុំបានធ្លាក់មកដល់យើងខ្ញុំ នៅត្រើយខាងកើតនេះ
ហើយ[ឃ]។
២០រួចម៉ូសេលោកឆ្លើយឡើងថា បើឯងរាល់គ្នាធ្វើយ៉ាង
នោះ គឺបើឯងនឹងយកគ្រឿងចេញទៅច្បាំងនៅចំពោះព្រះ
យេហូវ៉ា[ង] ២១ហើយពួកឯងគ្រប់គ្នា ដែលមានគ្រឿងចំបាំង
នឹងឆ្លងទន្លេយ័រដាន់នៅចំពោះព្រះយេហូវ៉ា ដរាបដល់ទ្រង់
បានបណ្ដេញពួកខ្មាំងសត្រូវ ពីចំពោះទ្រង់ចេញ[ច] ២២គឺដល់
កាលណាស្រុកនោះបានទទួលចុះចាញ់ នៅចំពោះព្រះ
យេហូវ៉ា នោះឯងរាល់គ្នានឹងត្រឡប់មកវិញ[ឆ] ឥតមាន
ទោសចំពោះព្រះយេហូវ៉ា ឬចំពោះសាសន៍អ៊ីស្រាអែល
ឡើយ ហើយស្រុកនេះក៏នឹងបានជាកេរ្ដិ៍អាករ[ជ]របស់ឯង
រាល់គ្នានៅចំពោះព្រះយេហូវ៉ា[ឈ] ២៣តែបើមិនព្រមធ្វើ
ដូច្នោះទេ នោះនឹងមានបាបចំពោះព្រះយេហូវ៉ាវិញ ហើយ
ត្រូវដឹងជាប្រាកដថា បាបឯងរាល់គ្នានឹងតាមឯងទាន់[ញ]
២៤ចូរសង់ទីក្រុងសំរាប់កូនចៅឯង ហើយនិងក្រោលសំរាប់
ហ្វូងសត្វផង[ដ] ឱ្យធ្វើតាមសេចក្ដីទាំងប៉ុន្មាន ដែលចេញពី
មាត់ឯងនោះចុះ[ឋ] ២៥នោះពួកកូនចៅកាឌ់ និងកូនចៅរូបេន

**៣២:៧** ថ ជន ១៣:២៧-១៤:៤ **៣២:៨** ទ ជន ១៣:៣,២៦ ចទ ១:១៩-២៥ **៣២:៩** ធ ជន ១៣:២៣ ចទ ១:២៤ **៣២:១០** ន ជន ១១:១ ប ជន ១៤:២០-២៣ **៣២:១១** ផ ជន ១:១ ព នក ៣០:១៤ ភ ជន ១៤:២៣ ម ជន ១៤:២៨-៣០ **៣២:១២** យ ជន ១៤:២៤,៣០ **៣២:១៣** រ នក ៤:១៤ ល ជន ១៤:២៨-៣៥ ២៦:៦៤,៦៥ **៣២:១៤** វ ខ.១០ ចទ ១:៣៤ ទដ ៧៨:៥៩ **៣២:១៥** ស ចទ ៣០:១៧-១៨ ២របា ៧:២០ **៣២:១៦** ហ ខ.២៤,៣៦ ១សយ ២៤:៣ ទដ ៥០:៩ ៧៨:៧០ ឡ នក ១២:៣៨ ចទ ៣:១៩ **៣២:១៧** អ ចទ ៣:១៨ យស ៤:១២,១៣ ក ជន ២២:៤ ចទ ៣:២០ **៣២:១៨** ខ យស ២២:១-៤ **៣២:១៩** គ ខ.២២, ២៩ ឃ ជន ២១:៣៣ យស ១២:១ ២២:៧ **៣២:២០** ង ខ.១៧ **៣២:២១** ច ខ.១៧ **៣២:២២** ឆ យស ២២:៤ ជ លវ ១៤:៣៤ ឈ ចទ ៣:១៨-២០ **៣២:២៣** ញ លប ៤:៧ អស ៣:៩ **៣២:២៤** ដ ខ.១,១៦ ឋ ជន ៣០:២

អំណោយទានរបស់ព្រះយេហូវ៉ាប្រទានឱ្យ ដោយការធ្វើសញ្ជ័យឈ្នះ ។

**៣២:៨** *ពួកឪពុកឯងរាល់គ្នាក៏បានធ្វើដូច្នេះដែរ* ការភ័យខ្លាចរបស់លោកម៉ូសេ បានកើតមានឡើងទៅលើការបរាជ័យរបស់ពូជអំបូរទាំងពីរនោះ ចំពោះការស្នាក់នៅជាមួយទាំងពួកជំនុំទាំងមូលតែម្ដង នៅក្នុងការធ្វើសញ្ជ័យយកទឹកដីកាណាន ដែលនឹងក្លាយជាការចាប់ផ្ដើម នៃការបះបោរជាទូទៅមួយប្រឆាំងទាស់នឹង ការចូលទៅក្នុងទឹកដីនោះ ។ វាអាចនឹងដូចជាការបរាជ័យនៅកាដេស (ជំពូក ១៣-១៤) ទាំងស្រុងម្ដងទៀតផងដែរ ។ លើសពីនេះទៅទៀត ការធ្វើសញ្ជ័យយកទឹកដីកាណាន គឺជាបេសកកម្មចំពោះពួកកូនចៅអ៊ីស្រាអែលទាំងស្រុង ។

**៣២:១២** *បានប្រព្រឹត្តតាមអញគ្រប់ជំពូក* សូមមើលការពន្យល់ ១៤:២៤ ។

**៣២:១៧** *ខ្លួនយើងខ្ញុំនឹងមានគ្រឿងប្រុងជាស្រេច* អ្នកដឹកនាំនៃពួកកូនចៅរូបេន និងកាឌ់បានស្វែងរកដើម្បីធានាអះអាងលោកម៉ូសេ ដែលថាពួកគេមិនបានមានបំណង គេចវេះពីភារកិច្ចក្នុងការបម្រើជាកងទ័ពរបស់ព្រះអម្ចាស់នោះទេ នៅក្នុងការធ្វើសញ្ជ័យយកទឹកដីសន្យានោះ ។ ពួកគេនឹងចូលរួមជាមួយនឹងបងប្អូនរបស់ពួកគេនៅក្នុងការប្រយុទ្ធ ប៉ុន្តែពួកគេបានមានបំណងទុកដាក់ក្រុមគ្រួសារ និងហ្វូងសត្វពាហណៈរបស់ពួកគេនៅទ័ពជួរក្រោយ គឺនៅក្នុងទឹកដីដែលពួកគេបានសម្រេចចិត្តធ្វើការជ្រើសរើសរួចស្រេចហើយនោះ ។

**៣២:២៣** *បាបឯងរាល់គ្នានឹងតាមឯងទាន់* កិច្ចព្រមព្រៀងនេះត្រូវបានយល់ព្រម ប៉ុន្តែជាការព្រមានមួយដ៏តឹងរ៉ឹង ប្រសិនបើពួកគេមានការអាក់ខានធ្វើ

ក៏ឆ្លើយឡើងថា យើងខ្ញុំប្របាទនឹងធ្វើដូចជាលោកម្ចាស់
បង្គាប់មក[ឌ] ២៦ប្រពន្ធកូន ហើយនិងហ្វូងគោហ្វូងចៀមរបស់
យើងខ្ញុំទាំងប៉ុន្មាន និងនៅក្នុងអស់ទាំងទីក្រុងនៃស្រុក
កាឡាតនេះ[ឍ] ២៧តែយើងខ្ញុំប្របាទដែលមានគ្រឿងចំបាំង[ណ]
រៀបជាស្រេច យើងខ្ញុំនឹងឆ្លងទៅ នៅចំពោះព្រះយេហូវ៉ា
ដូចជាលោកម្ចាស់បានបង្គាប់មក ។
២៨ដូច្នេះ ម៉ូសេក៏បង្គាប់ដល់អេលាសារ ដ៏ជាសង្ឃ និង
យ៉ូស្វេ ជាកូននុន[ត] ព្រមទាំងពួកមេលើវង្សានុវង្សនៃ
ពូជអំបូរពួកកូនចៅអ៊ីស្រាអែលទាំងប៉ុន្មាន[ថ] ពីដំណើរគេ[ទ]
២៩លោកប្រាប់អ្នកទាំងនោះថា បើសិនជាពួកកូនចៅកាឌ់
និងពួកកូនចៅរូបេន ឆ្លងទន្លេយ័រដាន់ទៅជាមួយនឹងឯង
រាល់គ្នានៅចំពោះព្រះយេហូវ៉ា ដោយគ្រប់គ្នាមានគ្រឿង
ចំបាំងប្រុងជាស្រេច ដូច្នេះកាលណាស្រុកនោះបានចុះ
ចាញ់នៅមុខឯងរាល់គ្នាហើយ[ធ] នោះត្រូវចែកស្រុកកាឡាត
នេះឱ្យដល់គេ ទុកជាកេរ្តិ៍អាករចុះ[ន] ៣០តែបើគេមិនឆ្លង
ទៅ[ប]ជាមួយដោយមានគ្រឿងចំបាំងប្រុងជាស្រេចទេ នោះ
គេត្រូវបានកេរ្តិ៍អាករ នៅកណ្តាលឯងរាល់គ្នា ក្នុងស្រុក
កាណានវិញ[ផ] ៣១ពួកកូនចៅកាឌ់ និងកូនចៅរូបេនក៏ឆ្លើយ
ឡើងថា សេចក្តីដែលព្រះយេហូវ៉ាបានបង្គាប់មកយើងខ្ញុំ
ប្របាទ នោះយើងខ្ញុំនឹងធ្វើតាម[ព] ៣២យើងខ្ញុំនឹងឆ្លងទៅទាំង
មានគ្រឿងសស្ត្រាវុធនៅដៃ[ភ] ចូលទៅក្នុងស្រុកកាណាន
នៅចំពោះព្រះយេហូវ៉ា តែកេរ្តិ៍អាករជាមរដករបស់យើង
ខ្ញុំ និងនៅឯត្រើយទន្លេយ័រដាន់ខាងអាយនេះវិញ[ម]។
៣៣ម៉ូសេលោកក៏ឱ្យនគររបស់ស៊ីហុន ជាស្តេចសាសន៍
អាម៉ូរី[យ] និងនគររបស់អុក ជាស្តេចបាសាន[រ] គឺស្រុកទាំង
មូលតាមចំនួនទីក្រុងគេ រហូតដល់ព្រំប្រទល់ព្រមទាំងទី
ក្រុងនៅព័ទ្ធជុំវិញទាំងប៉ុន្មាន[ល] ដល់ពួកកូនចៅកាឌ់[វ] និងពួក
កូនចៅរូបេន ហើយដល់១ចំហៀងនៃពួកអំបូរម៉ាន៉ាសេ[ស]
ជាកូនយ៉ូសែប ៣៤នោះពួកកូនចៅកាឌ់ក៏សង់ទីក្រុងឌីបូន
អាថារ៉ូត អារ៉ូអើរ[ហ] ៣៥អាត្រូត-សូផាន យ៉ាស៊ើរ[ឡ]
យ៉ុកបិហា[អ] ៣៦បេត-នីមរ៉ា[ក] ហើយនិងបេត-ហារ៉ាន សុទ្ធ
តែទីក្រុងមានកំផែង ព្រមទាំងធ្វើក្រោលសំរាប់ហ្វូងសត្វ
គេផង[ខ] ៣៧ហើយពួកកូនចៅរូបេន គេក៏សង់ក្រុងហែសបូន[គ]
អេលាលេ[ឃ] គារយ៉ា-ថែម[ង] ៣៨នេបូរ[ច] បាល-មេយ៉ូន (ឯទី
ក្រុងទាំងនោះ គេបានផ្លាស់ឈ្មោះចេញ) ហើយស៊ីបម៉ា
ផង[ឆ] គេដាក់ឈ្មោះជាថ្មីដល់ទីក្រុងទាំងប៉ុន្មាន ដែលគេបាន
សង់ឡើងវិញនោះ ៣៩រីឯពួកកូនចៅម៉ាគារ[ជ] ជាកូន
ម៉ាន៉ាសេ គេក៏ទៅវាយយកស្រុកកាឡាត[ឈ] ព្រមទាំងកំចាត់
សាសន៍អាម៉ូរី[ញ] ដែលនៅស្រុកនោះចេញ ៤០ដូច្នេះ ម៉ូសេក៏
ឱ្យស្រុកកាឡាត ទៅម៉ាគារ[ដ]ជាកូនម៉ាន៉ាសេ ហើយគាត់
តាំងទីលំនៅនៅស្រុកនោះទៅ ៤១ឯយ៉ាអ៊ារ[ឋ] ជាកូនម៉ាន៉ា
សេគាត់ក៏ទៅវាយយកអស់ទាំងភូមិនៅស្រុកនោះ ហើយ
គាត់ហៅភូមិទាំងនោះថា ហាវ៉ុត-យ៉ាអ៊ារ[ឌ] ៤២ចំណែក
ណូបាស ក៏ទៅវាយយកក្រុងកេណាត[ឍ] ព្រមទាំងដំបន់របស់
ទីក្រុងនោះទាំងប៉ុន្មាន ហើយដាក់ឈ្មោះថា ក្រុងណូបាស[ណ]
តាមឈ្មោះរបស់ខ្លួន[ត]។

## ដំណាក់ផ្លូវធ្វើដំណើររបស់ពួកកូនចៅអ៊ីស្រាអែល

**៣៣** ១នេះជាផ្លូវទាំងប៉ុន្មាន ដែលពួកកូនចៅអ៊ីស្រាអែល
បានធ្វើដំណើរ[ក]តាមពួកពលគេ ដោយនូវសារម៉ូសេហើយ
និងអើរ៉ុន[ខ] តាំងពីគេចេញពីស្រុកអេស៊ីព្ទមក[គ] ២ម៉ូសេ

**៣២:២៥** ឌ ខ.២៩ យស ១:១៦,១៨ ២២:២ **៣២:២៦** ឍ ខ.១៦,២៤ យស ១:១៤ ១២:២ ២២:៩ ២សយ ២:៩ ១រប ៥:៩ **៣២:២៧** ណ ខ.១៧,២១ **៣២:២៨** ត ជន ១១:២៨ ថ ជន ១:១៦ ទ ខ.២៩ ចទ ៣:១៨-២០ យស ១:១៣ **៣២:២៩** ធ ជន ២២:៤ ន ខ.១៩ **៣២:៣០** ប ខ.២៣ ផ ខ.២៩,៣២ **៣២:៣១** ព ខ.២៩ **៣២:៣២** ភ ខ.១៧ ម ខ.៣០ យស ១២:៦ **៣២:៣៣** យ ជន ២១:២១ ចទ ២:២៦ រ យស ១៣:២៤-២៨ ១សយ ១៣:៧ ល យស ១:១២ វ ខ.១៩ យស ១២:៥ ស ជន ២១:២៤ ៣៤:១៤ ចទ ២:៣៦ យស ១២:៦ **៣២:៣៤** ហ ចទ ២:៣៦ ៣:១២ ៤:៤៨ យស ១២:២ ១៣:៩ ពច ១១:២៦ ១សយ ៣០:២៨ ១រប ៥:៨ យរ ៤៨:១៩

**៣២:៣៥** ឡ ខ.៣ អ ពច ៨:១១ **៣២:៣៦** ក ខ.៣ ខ ខ.១ **៣២:៣៧** គ ជន ២១:២៥ ឃ ខ.៣ ង យស ១៣:១៩ ១រប ៦:៧៦ យរ ៤៨:១,២៣ អគ ២៥:៩ **៣២:៣៨** ច ខ.៣ អស ១៥:២ យរ ៤៨:១,២២ ឆ ខ.៣**៣២:៣៩** ជ លប ៥០:២៣ ឈ ជន ២៦:២៩ ចទ ២:៣៦ ញ លប ១០:១៦ **៣២:៤០** ដ លប ៥០:២៣ ចទ ៣:១៥ **៣២:៤១** ឋ ១ពវ ៤:១៣ ឌ ចទ ៣:១៤ យស ១៣:៣០ ពច ១០:៤ ១រប ២:២៣ **៣២:៤២** ឍ ១រប ២:២៣ ណ ពច ៨:១១ ត ១សយ ១៥:១២ ២សយ ១៨:១៨ ទដ ៤៩:១១ អស ២២:១៦ ៥៦:៥ **៣៣:១** ក នក ១៧:១ ៤០:៣៦ ខ នក ៤:១៦ ៦:២៦ គ ជន ១:១

តាមពាក្យសម្តីរបស់ពួកគេទាំងនោះ ។

**៣២:៣៣** *១ចំហៀងនៃពូជអំបូរម៉ាន៉ាសេ* មានរឿងមួយលេចចេញឡើង បន្ទាប់ពីតម្រូវការសម្រាប់ការតាំងទីលំនៅនៅតាមដងទន្លេយ័រដាន់ ត្រូវបានបង្កើតឱ្យមានឡើងចំពោះពួកកូនចៅនៃពូជអំបូររូបេន និងកាឌ់ ១ចំហៀងនៃពូជអំបូរម៉ាន៉ាសេ ដែលបានរស់នៅជាមួយពួកគេទាំងនោះដែរ ។

**៣៣:១-៤៩** ចំនួនទីកន្លែង (ទីកន្លែងសំខាន់ៗ ឃើញថាមានចំនួន ៤០ កន្លែង នៅចន្លោះវ៉ាមសេស និងស្រុកវាលរបស់ម៉ូអាប់) នៅក្នុងបទបិសោធន៍នាទីរហោស្ថានរបស់ពួកកូនចៅអ៊ីស្រាអែល ត្រូវបានគេកត់ត្រាទុកក្នុងបញ្ជី ។ ដោយសំណាងមិនល្អ ទីកន្លែងភាគច្រើនជាការតាំងបន្ទាយនៅទីរហោស្ថាន មិនមែនជាទីក្រុង ដោយមានអាយុកាលដ៏វែងយូរលង់ ដែលបង្កប់ទៅដោយការរក្សាទុកជាវត្ថុបុរាណបានឡើយ ។ ដូច្នេះពួកគេមានការលំបាកក្នុងស្នាក់នៅ ។ មានទីកន្លែងជាច្រើនទៀត (ជាឧទាហរណ៍នៅក្នុងខ.១៩-២៩) មានមួយចំនួនទៀត ដែលគេមិនបានធ្វើការកត់ត្រាទុកនៅក្នុងកណ្ឌគម្ពីរនិក្ខមនំ និងជនគណនាទេ ។ មួយចំនួនទៀត (ឧទាហរណ៍ តាបេរ៉ា ១១:៣ សូមមើល ២១:១៩) មានរំលងចោលនៅត្រង់នេះ ។ ទិន្នន័យផ្លូវការបង្កើតបានជាសេចក្តីសន្និដ្ឋានដូចតទៅ: ១.លោកម៉ូសេបានធ្វើការកត់ត្រាទុកជាបញ្ជីស្នាមទៅ តាមបញ្ជារបស់ព្រះអម្ចាស់(ខ.២) ។ ២.បញ្ជីគប្បីត្រូវតែមានលក្ខណៈប្រាកដប្រជា ដូចជាការសរុបសេចក្តីឱ្យបានត្រឹមត្រូវទៅតាមដំណាក់កាលនៃការចេញដំណើរទៅ ទោះបីជាមានការលំបាកនៅក្នុងបោះទីតាំងជាច្រើនកន្លែងក៏ដោយ ។ ៣.កត្តាចំនួន៤០កន្លែង នៅចន្លោះវ៉ាមសេស និងស្រុកវាលរបស់ម៉ូអាប់ មានការស្នើសុំនូវរចនាបថ ទៅតាមបញ្ជីនីមួយៗ ដែលអាចជួយរាប់នូវទីកន្លែងទាំងនោះបាន ដោយមិនចាំបាច់ធ្វើការបូក

បានកត់[ឃ]ដំណើរ ដែលគេដើរ[ង]តាមដំណាក់នីមួយៗតាម
បង្គាប់ព្រះយេហូវ៉ា ដូច្នេះអស់ទាំងដំណាក់គេដែលគេដើរ
ដំណើរមក ៣នោះពួកកូនចៅអ៊ីស្រាអែលបានចេញ[ច]ពីរ៉ាម
សេស[ឆ] មកនៅថ្ងៃ១៥ខែចេត្រ គឺបានចេញមកនៅថ្ងៃ
បន្ទាប់ និងបុណ្យរំលង[ជ] ដោយមានជ័យជំនះ[ឈ] នៅភ្នែកនៃ
ពួកសាសន៍អេស៊ីព្ទទាំងអស់គ្នា ៤ក្នុងកាលដែលគេកំពុងតែ
កប់ខ្មោចពួកកូនច្បងរបស់គេ[ញ] ដែលព្រះយេហូវ៉ាបានវាយ
សំឡាប់នៅក្នុងពួកគេ ហើយព្រះយេហូវ៉ាក៏បានធ្វើទោស[ដ]
ដល់អស់ទាំងព្រះរបស់គេដែរ[ឋ]។

៥ពួកកូនចៅអ៊ីស្រាអែល ក៏ចេញពីរ៉ាមសេស មកស្នាក់
នៅត្រង់ស៊ុកូត[ឌ] ៦គេចេញពីស៊ុកូតមកស្នាក់នៅត្រង់ អេថាម
ក្បែរទីរហោស្ថាន[ឍ] ៧គេចេញពីអេថាម ក៏បែរទៅ
ខាងពីហាហេរ៉ុថ ទល់មុខនឹងបាលសេផុន[ណ] រួចស្នាក់នៅ
ត្រង់មុខមីកដុល[ត] ៨គេចេញពីមុខពីហាហេរ៉ុថ[ថ]ដើរឆ្លងទៅ
កណ្ដាលទឹកសមុទ្រ[ទ]ទៅក្នុងទីរហោស្ថាន ក៏ដើរ៣ថ្ងៃទៅក្នុង
ទីរហោស្ថានអេថាម រួចស្នាក់នៅត្រង់ម៉ារ៉ា[ធ] ៩គេចេញពី
ម៉ារ៉ា មកដល់អេលីម ហើយនៅអេលីមនោះ មានរន្ធ
ទឹក១២ និងដើមលម៉ើ៧០ គេក៏ស្នាក់នៅ[ន]ទីនោះ ១០គេចេញ
ពីអេលីម[ប] មកស្នាក់នៅក្បែរសមុទ្រក្រហម ១១គេចេញពី
សមុទ្រក្រហម មកស្នាក់នៅក្នុងទីរហោស្ថានស៊ីន[ផ] ១២គេ
ចេញពីទីរហោស្ថានស៊ីន មកស្នាក់នៅត្រង់ដុបកា ១៣គេ
ចេញដុបកា មកស្នាក់នៅត្រង់អាលូស ១៤គេចេញពីអាលូស
មកស្នាក់នៅរេផិឌីម ជាកន្លែងដែលគ្មានទឹកឱ្យគេផឹក
សោះ[ព] ១៥គេចេញពីរេផិឌីម[ភ] មកស្នាក់នៅត្រង់ទីរហោ
ស្ថានស៊ីណាយ[ម] ១៦គេចេញពីទីរហោស្ថានស៊ីណាយ មក
ស្នាក់នៅត្រង់គីប្រុត-ហាតាវ៉ា[យ] ១៧គេចេញពីគីប្រុត-ហា
តាវ៉ា មកស្នាក់នៅត្រង់ហាសេរ៉ូត[រ] ១៨គេចេញពីហាសេរ៉ូត
មកស្នាក់នៅត្រង់រីតម៉ា ១៩គេចេញពីរីតម៉ា មកស្នាក់នៅ
ត្រង់រីម៉ូន-ពេរេស ២០គេចេញពីរីម៉ូន-ពេរេស មកស្នាក់
នៅត្រង់លិបណា[ល] ២១គេចេញពីលិបណា មកស្នាក់នៅត្រង់
រីសា ២២គេចេញពីរីសាមកស្នាក់នៅត្រង់ កេហេឡាថា
២៣គេចេញពីកេហេឡា មកស្នាក់នៅត្រង់ភ្នំសាភើរ ២៤គេ
ចេញពីភ្នំសាភើរ មកស្នាក់នៅត្រង់ហារ៉ាដា ២៥គេចេញពី
ហារ៉ាដា មកស្នាក់នៅត្រង់ម៉ាកហេឡូត ២៦គេចេញពី
ម៉ាកហេឡូត មកស្នាក់នៅត្រង់តាហាត ២៧គេចេញពីតា
ហាត មកស្នាក់នៅត្រង់តារ៉ាស ២៨គេចេញពីតារ៉ាស
មកស្នាក់ នៅត្រង់មីតកា ២៩គេចេញពីមីតកា មកស្នាក់នៅ
ត្រង់ហាស្មូណា ៣០គេចេញពីហាស្មូណា មកស្នាក់នៅត្រង់
ម៉ូសេរ៉ូត[វ] ៣១គេចេញពីម៉ូសេរ៉ូត មកស្នាក់នៅត្រង់បេនេ-
យ៉ាកាន[ស] ៣២គេចេញពីបេនេ-យ៉ាកាន មកស្នាក់នៅត្រង់
ហោគីតកាត់ ៣៣គេចេញពីហោគីតកាត់ មកស្នាក់នៅត្រង់
យ៉ុតបាថា[ហ] ៣៤គេចេញពីយ៉ុតបាថា មកស្នាក់នៅអាប្រូណា
៣៥គេចេញពីអាប្រូណា មកស្នាក់នៅត្រង់អេស៊ាន-គេប៊េរ[ឡ]
៣៦គេចេញពីអេស៊ាន-គេប៊េរ មកស្នាក់នៅត្រង់ទីរហោ
ស្ថានស៊ីន គឺនៅត្រង់កាដេស[អ] ៣៧គេចេញពីកាដេស មក
ស្នាក់នៅត្រង់ភ្នំហោរ[ក] ជាព្រំប្រទល់ស្រុកអេដំម[ខ]។

៣៨នៅទីនោះអើរ៉ុនដ៏ជាសង្ឃ បានឡើងទៅលើភ្នំហោរ
តាមបង្គាប់ព្រះយេហូវ៉ា ហើយក៏ស្លាប់ទៅ[គ] នៅថ្ងៃដំបូង
ក្នុងខែស្រាពណ៍ នាឆ្នាំទី៤០[ឃ] ក្រោយដែលពួកកូនចៅ
អ៊ីស្រាអែលបានចេញពីស្រុកអេស៊ីព្ទមក[ង] ៣៩កាលអើរ៉ុន
ស្លាប់ទៅនៅលើភ្នំហោរ នោះលោកបានអាយុ១២៣ឆ្នាំ
ហើយ ។

៤០គ្រានោះអើរ៉ាត[ច] ជាស្តេចសាសន៍កាណាន[ឆ] ដែល
អាស្រ័យនៅប៉ែកខាងត្បូង[ជ]នៃស្រុកកាណាន ទ្រង់ក៏ឮថា
ពួកកូនចៅអ៊ីស្រាអែលធ្វើដំណើរមក ។

៤១ឯពួកអ៊ីស្រាអែលក៏ចេញពីភ្នំហោរ មកស្នាក់នៅត្រង់
សាលម៉ូន៉ា ៤២គេចេញពីសាលម៉ូន៉ា មកស្នាក់នៅត្រង់
ពូណូន ៤៣គេចេញពីពូណូន មកស្នាក់នៅត្រង់អូបូត[ឈ] ៤៤គេ
ចេញពីអូបូត មកស្នាក់នៅត្រង់អ៊ីយេ-អាបារីម នៅព្រំ
ប្រទល់ស្រុកម៉ូអាប់[ញ] ៤៥គេចេញពីអ៊ីយេ-អាបារីម មកស្នាក់
នៅត្រង់ឌីបូន-កាឌ់ ៤៦គេចេញពីឌីបូន-កាឌ់ មកស្នាក់
នៅត្រង់អាលម៉ូន-ឌីប្លាថែម ៤៧គេចេញពីអាលម៉ូន-ឌីប្លា

**៣៣:២** ឃ នក ១៧:១៤ ង ខ.១ **៣៣:៣** ច ជន ១០:២ ឆ លប ៤៧:១១ ជ យស ៥:១០ ឈ នក ១៤:៨ **៣៣:៤** ញ នក ៤:២៣ ដ ២រប ២៤:២៤ យរ ១៥:៣ អក ១៤:២១ នក ១២:១២ **៣៣:៥** ឌ នក ១២:៣៧ **៣៣:៦** ឍ នក ១៣:២០ **៣៣:៧** ណ នក ១៤:៩ ត នក ១៤:២ **៣៣:៨** ថ នក ១៤:២ ទ នក ១៤:២២ ធ នក ១៥:២៣ **៣៣:៩** ន នក ១៥:២៧ **៣៣:១០** ប នក ១៦:១ **៣៣:១១** ផ នក ១៦:១ **៣៣:១៤** ព នក ១៥:២២ ១៧:២ **៣៣:១៥** ភ នក ១៧:១ ម នក ១៩:១ **៣៣:១៦** យ ជន ១១:៣៤ **៣៣:១៧** រ ជន ១១:៣៥ **៣៣:២០** ល យស ១០:២៩ ១២:១៥ ១៥:៤២ ២១:១៣ ២ពវ ៨:២២ ១៩:៨ ២៣:៣១ ១រប ៦:៥៧ ២រប ២១:១០ អស ៣៧:៨ យរ ៥២:១ **៣៣:៣០** វ ចទ ១០:៦ **៣៣:៣១** ស ចទ ១០:៦ **៣៣:៣៣** ហ ចទ ១០:៧ **៣៣:៣៥** ឡ ចទ ២:៨ ១ពវ ៩:២៦ ២២:៤៨ **៣៣:៣៦** អ ជន ១៣:២១ **៣៣:៣៧** ក ជន ២០:២២ ខ លប ៣៦:១៦ ជន ២០:១៦ **៣៣:៣៨** គ ជន ២៧:១៣ ឃ នក ៣៥ង ជន ២០:២៥-២៨ **៣៣:៤០** ច ជន ២១:១ ឆ លប ០:១៨ ជ លប ១២:៩ **៣៣:៤៣** ឈ ជន ២១:១០ **៣៣:៤៤** ញ ជន ២១:១១

បន្ថែមទៀតឡើយ ។ ៤. ដូចនៅក្នុងករណីខ្លះនៃពង្សាវតារ នៅក្នុងគម្ពីរបញ្ចកណ្ឌ មានកត្តាសំខាន់ៗពីបុរាណមួយចំនួន ដែលអាចគ្មានភាពច្បាស់លាស់រហូតមកទល់សព្វថ្ងៃនេះ ។ ៥.នៅទីបំផុតការកត់ត្រាទុកជា លក្ខណៈបែបនិទានរឿងអំពីការប្រទានពររបស់ព្រះអម្ចាស់ មកលើរាស្ត្ររបស់ព្រះអង្គសម្រាប់ការពន្យាថេរវេលា នៃបទពិសោធន៍នៅទីរហោស្ថានរបស់ពួកគេ ។ ទោះបីជាសារៈសំខាន់នៃភូមិសាស្ត្រមានលក្ខណៈពិតប្រាកដ ឬមិនពិតប្រាកដក៏ដោយបញ្ជីស្នាម នៃដំណាក់កាលនីមួយៗនៃបទពិសោធន៍របស់រាស្ត្រអ៊ីស្រាអែលនៅក្នុងទីរហោស្ថាន គឺជាឯកសារជាមូលដ្ឋានគ្រឹះ ហើយកត់នូវព្រះបន្ទូលនៃការប្រោសលោះដល់រាស្ត្រទ្រង់ ។

**៣៣:២** *នៅក្បែរសមុទ្រក្រហម* គឺនៅត្រើយម្ខាងទៀតនៃសមុទ្រក្រហម ដែលពួកគេបានឆ្លងមកដល់ ។

**៣៣:៤០** *ប៉ែកខាងត្បូង* សូមមើលការពន្យល់នៅ លប ១២:៩ ។

ថែម មកស្នាក់នៅត្រង់ភ្នំអាបារីម[ដ] នៅមុខភ្នំនេបូរ[ឋ] ៤៨គេ
ចេញពីភ្នំអាបារីម[ឌ] មកស្នាក់នៅត្រង់ស្រុកវាលរបស់
ម៉ូអាប់[ឍ] ជិតទន្លេយ័រដាន់[ណ] ទល់មុខនឹងយេរីខូរ[ត] ៤៩គេ
ដំឡើងត្រសាលរបស់គេនៅក្បែរទន្លេយ័រដាន់ ចាប់តាំងពី
បេត-យេស៊ីម៉ូត[ថ] រហូតដល់អេបិល-ស៊ីទីម[ទ] ក្នុងស្រុកវាល
របស់ម៉ូអាប់ ។
៥០ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ នៅត្រង់ស្រុកវាល
របស់ម៉ូអាប់ ជិតទន្លេយ័រដាន់ ទល់មុខនឹងយេរីខូរ[ធ] ៥១ឱ្យ
ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា កាលណាឯងរាល់គ្នា
ឆ្លងទន្លេយ័រដាន់ ចូលទៅក្នុងស្រុកកាណានហើយ[ន] ៥២នោះ
ត្រូវឱ្យបណ្តេញអស់ទាំងអ្នកស្រុកនោះ ពីមុខឯងចេញ ព្រម
ទាំងបំផ្លាញអស់ទាំងព្រះជារូបឆ្លាក់ ជារូបសិតរបស់គេ
បង់ ហើយរំលាងអស់ទាំងទីខ្ពស់គេផង[ប] ៥៣ឯងរាល់គ្នាត្រូវ
ចាប់យកស្រុកនោះទុកជាកេរ្តិ៍អាករ ហើយអាស្រ័យនៅផង
ដ្បិតអញបានឱ្យទុកជាកេរ្តិ៍អាករដល់ឯងរាល់គ្នាហើយ[ផ]
៥៤ឯងរាល់គ្នាត្រូវទទួលស្រុកនោះ ទុកជាមរដក ដោយចាប់
ឆ្នោត[ព] តាមគ្រួឯងនីមួយៗ[ភ] ពួកណាមានគ្នាច្រើន នោះត្រូវ
បានច្រើន ហើយពួកណាមានគ្នាតិច នោះត្រូវបានតិចវិញ[ម]
បើអ្នកណាចាប់ឆ្នោតត្រូវត្រង់កន្លែងណា នោះត្រូវតែបាន
កន្លែងនោះ ឯងរាល់គ្នាត្រូវស៊ីមរដកតាមពូជអំបូរនៃឰយុ
កោឯង[យ] ៥៥តែបើមិនបានបណ្តេញពួកអ្នកស្រុកនោះពីមុខ
ឯងចេញទេ នោះពួកអ្នកដែលទុកឱ្យនៅ គេនឹងជាម្ជុល[រ]
ដល់ភ្នែកឯង ហើយជាបន្លានៅចំហៀងឯងផង គេនឹងធ្វើ
ទុកឯងនៅក្នុងស្រុកដែលឯងអាស្រ័យនៅនោះ ៥៦ហើយ
អញនឹងធ្វើដល់ឯងរាល់គ្នា ដូចជាអញបានគិតធ្វើដល់គេ
វិញ[ល] ។

## ព្រំដែនស្រុកកាណាន

**៣៤** ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ២ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា កាលណាឯងរាល់គ្នាបានចូលទៅក្នុង
ស្រុកកាណានហើយ[ក] (គឺស្រុកនោះហើយដែលឯងរាល់គ្នា
និងបានទុកជាមរដក[ខ] ជាស្រុកកាណានតាមព្រំដែនទាំង
ប៉ុន្មាន)[គ] ៣នោះដែនស្រុករបស់ឯងខាងត្បូង ត្រូវចាប់តាំង
ពីទីរហោស្ថានស៊ីន[ឃ] ជាប់នឹងស្រុកអេដំម ហើយព្រំស្រុក
ខាងត្បូង នោះត្រូវចាប់តាំងពីចុងសមុទ្រអំបិលទៅទិស
ខាងកើត[ង] ៤រួចត្រូវបត់ទៅខាងត្បូងតាមច្រកចោតឈ្មោះ
អេក្រាប៊ីម[ច] រហូតទៅត្រឹមស៊ីន ហើយចេញទៅខាងត្បូង
កាដេស-បារនា[ឆ] ដល់ទៅហាសា-អាដា រហូតដល់
អាសម៉ូន[ជ] ៥ពីអាសម៉ូនត្រូវបត់ទៅខាងស្ទឹងស្រុកអេស៊ីព្ទ[ឈ]
ទៅទល់នឹងសមុទ្រ ។
៦ឯព្រំដែនខាងលិច នោះមានសមុទ្រធំជាព្រំប្រទល់
សមុទ្រនោះ[ញ]ត្រូវបានជាព្រំស្រុកខាងលិចរបស់ឯងរាល់
គ្នា[ដ] ។
៧ឯព្រំដែនខាងជើង[ឋ] នោះត្រូវឱ្យឯងកាត់ដិរង់ចាប់
តាំងពីសមុទ្រធំទៅដល់ភ្នំហោរ[ឌ] ៨ពីភ្នំហោរត្រូវកាត់
ដិរង់ទៅដល់ទ្វារស្រុកហាម៉ាត[ឍ]រៀងទៅត្រឹមសេដាត់ ៩រួច
ត្រូវចេញទៅតាមស៊ីប្រុន រហូតដល់ហាសា-អេណាន
នោះហើយជាព្រំស្រុករបស់ឯងខាងជើង ។
១០រួចត្រូវឱ្យឯងរាល់គ្នាសំរេចព្រំដែនខាងកើត[ណ] ចាប់
តាំងពីហាសា-អេណានទៅដល់សេផាម ១១ពីសេផាមចុះ
ទៅដល់រីមឡា[ត] ដែលនៅខាងកើតអាយីន[ថ] ហើយចុះទៅ
ទល់និងកៀនសមុទ្រ គេនេសារ៉ែតខាងកើត[ទ] ១២រួចចុះទៅ
តាមទន្លេយ័រដាន់ ទៅទល់នឹងសមុទ្រអំបិល នោះហើយជា
ស្រុករបស់ឯងរាល់គ្នាតាមព្រំប្រទល់ជុំវិញ ។
១៣ម៉ូសេក៏បង្គាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា នេះ
ហើយជាស្រុក ដែលឯងរាល់គ្នាត្រូវទទួល ទុកជាមរដក[ធ]
ដោយចាប់ឆ្នោត[ន] ជាស្រុកដែលព្រះយេហូវ៉ាបានបង្គាប់ថា

**៣៣:៤៧** ដ ជន ២៧:១២ ឋ ជន ៣២:៣ **៣៣:៤៨** ឌ ជន ២៧:១២ ឍ ជន ២៦:៣ ណ លប ១៣:១០ ត ជន ២២:១ យស ១២:៩ **៣៣:៤៩** ថ យស ១២:៣ ១៣:២០ អក ២៥:៩ ទ ជន ២១:១៦ **៣៣:៥០** ធ ខ.៤៨ **៣៣:៥១** ន ជន ៣៤:២ យស ៣:១៧ **៣៣:៥២** ប ៣៤:១៣ លវ ២៦:១ ទដ ១០៦:៣៤-៣៦ **៣៣:៥៣** ផ ចទ ១១:៣១ ១៧:១៤ យស ១:១១ ២១:៤៣ **៣៣:៥៤** ព លវ ១៦:៨ ជន ៣៦:២ ភ ជន ២៦:៥៤ ម ជន ៣៥:៨ យ យស ១៨:១០ **៣៣:៥៥** រ យស ២៣:១៣ ពច ២:៣ ទដ ១០៦:៣៦ អស ៥៥:១៣ អក ២:៦ ២៨:២៤ មីក ៧:៤ ២កថ ១២:៧ **៣៣:៥៦** ល ជន ១៤:២៨ **៣៤:២** ក ជន ៣៣:៥១ ខ លប ១៧:៨ ចទ ១:៧-៨ យស ២៣:៤ ទដ ៧៨:៥៤-៥៥ ១០៥:១១ គ អក ៤៧:១៥

**៣៤:៣** ឃ ជន ១៣:២១ យស ១៥:១-៣ ង លប ១៤:៣ **៣៤:៤** ច យស ១៥:៣ ពច ១:៣៦ ឆ ជន ៣២:៨ ជ យស ១៥:៤ **៣៤:៥** ឈ លប ១៥:១៨ **៣៤:៦** ញ យស ១:៤ ៩:១ ១៥:១២,៤៧ ២៣:៤ អក ៤៧:១០, ១៥ ៤៨:២៨ ដ អក ៤៧:១៩-២០**៣៤:៧** ឋ អក ៤៧:១៥-១៧ ឌ ជន ២០:២២ **៣៤:៨** ឍ ជន ១៣:២១ យស ១៣:៥ **៣៤:១០** ណ យស ១៥:៥ **៣៤:១១** ត ២ពវ ២៣:៣៣ ២៥:៦,២១ យរ ៣៩:៥ ៥២:៩,២៧ ថ យស ១៥:៣២ ២១:១៦ ១របៈ ៤:៣២ ទ ចទ ៣:១៧ យស ១១:២ ១៣:២៧ **៣៤:១៣** ធ យស ១៣:៦ ១៤:១-៥ អស ៤៩:៨ ៦៥:៩ អក ៤៥:១ ន លវ ១៦:៨ យស ១៨:១០ មីក ២:៥

**៣៣:៥០-៣៦:១៣** ជាសេចក្តីថ្លែងការណ៍សង្ខេបមួយ ដែលជាប់ពាក់ព័ន្ធទៅនឹងរឿងនៃទឹកដី និងទ្រព្យសម្បត្តិនៅក្នុងទឹកដីសន្យា ។ នៅត្រង់ខដំបូង និងចុងបញ្ចប់ ពោលគឺពីខមួយទៅខមួយទៀតមានតភ្ជាប់គ្នាដោយសន្ទានកិរិយា និងផ្នែកនៃសំណេរកថាខណ្ឌ ។

**៣៣:៥២** *នោះត្រូវឱ្យបណ្តេញអស់ទាំងអ្នកស្រុកនោះ . . . ព្រមទាំងបំផ្លាញអស់ទាំងព្រះ . . . របស់គេបង់* អ្វីដែលពួករាស្ត្រអ៊ីស្រាអែលបានបំពេញនៅក្នុងសង្គ្រាមតតាំងជាមួយពួកសាសន៍ម៉ាឌាន (ជំពូក ៣១) ដែលនៅពេលឥឡូវនេះត្រូវបានពង្វាតទីរហូតដល់ពួកអ្នកស្រុកកាណានថែមទៀតផង ។ ជាពិសេស អ្វីដែលមានសារៈសំខាន់បំផុតនោះគឺព្រះបន្ទូលបញ្ជាឱ្យបំផ្លាញអស់ទាំងរូបឆ្លាក់ រូបសិតតាមរបៀបប្រព័ន្ធសាសនារបស់ពួកសាសន៍ដទៃនៃពួកសាសន៍កាណានបង់ចោលចេញ ។

**៣៣:៥៤** សូមមើលការពន្យល់នៅ ២៦:៥៣-៥៦ ។

**៣៤:៣-១២** បញ្ជីស្នាមនិយាយពីព្រំដែនទាំងបួន ដែលបង្ហាញនូវទំហំខ្នាតនៃអំណោយទានរបស់ព្រះ ដែលបានប្រទានឱ្យដល់រាស្ត្ររបស់ផងទ្រង់ ។

**៣៤:១៣-១៥** ភាពប្រាកដនិយមថ្មី ដែលថាការតាំងទីលំនៅរបស់ពួកអំបូរសាសន៍រូបេនកាឌ់ និង១ចំហៀងនៃពូជអំបូរម៉ាន៉ាសេ នៅតាមដងទន្លេ

ត្រូវចែកឱ្យដល់ពូជអំបូរទាំង៩ និង១ចំហៀងទៀតនោះ
១៤ពីព្រោះពូជអំបូរនៃកូនចៅរូបេន តាមវង្សានុវង្សរបស់
ឳពុកគេ បានទទួលមរដកគេហើយ ព្រមទាំងពូជអំបូរនៃ
កូនចៅកាឌ់ តាមវង្សានុវង្សរបស់ឳពុកគេ និងពូជអំបូរ
ម៉ាន៉ាសេ១ចំហៀងផង គេសុទ្ធតែទទួលមរដករបស់គេ
ហើយ[ប] ១៥ពូជអំបូរទាំង២ ហើយនិងពូជអំបូរ១ចំហៀង
ទៀតនោះ គេបានទទួលមរដករបស់គេនៅត្រើយទន្លេ
យ័រដាន់ខាងអាយទល់មុខនឹងយេរីខូរខាងកើតនេះ គឺខាង
ទិសថ្ងៃរះ ។

១៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ១៧ឯឈ្មោះ
ពួកអ្នកដែលត្រូវចែកស្រុកនោះ ទុកជាមរដកឱ្យឯងរាល់
គ្នា នោះគឺអេលាសារដ៏ជាសង្ឃ ហើយនិងយ៉ូស្វេ[ផ]ជាកូននុន
១៨ហើយត្រូវយកម្នាក់ៗ ដែលជាកំពូលពីគ្រប់ទាំងពូជអំបូរ
មក[ព] ឱ្យចែកស្រុកទុកជាមរដក[ភ] ១៩ឯឈ្មោះពួកអ្នកទាំង
នោះ[ម] គឺកាលែប[យ] ជាកូនយេភូនេ ពីពូជអំបូរយូដា១[រ]
២០សាំយូអែល ជាកូនអាំមីហ៊ូត ពីពូជអំបូរស៊ីម្មាន១[ល]
២១អេលីដាត ជាកូនគីស្លូន ពីពូជអំបូរបេនយ៉ាមីន១[វ] ២២អ្នក
ដែលជាកំពូល ឈ្មោះប៊ូគី ជាកូនយុគលី ពីពូជអំបូរនៃ
កូនចៅដាន់១ ២៣ឯខាងពួកកូនចៅយ៉ូសែប នោះគឺអ្នកដែល
ជាកំពូលឈ្មោះហានាល ជាកូនអេផូឌ ពីអំបូរនៃកូនចៅ
ម៉ាន៉ាសេ[ស]១ ២៤នឹងអ្នកដែលជាកំពូល ឈ្មោះកេមយួល ជា
កូនស៊ីបតាន ពីពូជអំបូរនៃកូនចៅអេប្រាអិម[ហ]១ ២៥អ្នក
ដែលជាកំពូលឈ្មោះអេលីសាផាន ជាកូនប៉ារណាក ពីពូជ
អំបូរនៃកូនចៅសាប់យូល៉ូន[ឡ]១ ២៦អ្នកដែលជាកំពូលឈ្មោះ
ប៉ាលទាលជាកូនអាស្សាន់ ពីពូជអំបូរនៃកូនចៅអ៊ីសាខារ១
២៧អ្នកដែលជាកំពូល ឈ្មោះអ័ហ៊ីហ៊ូត ជាកូនសេឡូមី ពីពូជ
អំបូរនៃកូនចៅអេស៊ើរ[អ]១ ២៨ហើយអ្នកដែលជាកំពូល
ឈ្មោះពេដាហិល ជាកូនអាំមីហ៊ូត ពីពូជអំបូរនៃពួកកូនចៅ
ណែបថាលី១ ២៩នេះហើយជាពួកអ្នក ដែលព្រះយេហូវ៉ា
បានបង្គាប់ ឱ្យចែកស្រុកកាណាន ទុកជាមរដកដល់ពួកកូន
ចៅអ៊ីស្រាអែល[ក] ។

## ក្រុងសម្រាប់ពួកលេវី

៣៥ ១ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ នៅត្រង់ស្រុកវាល
របស់ម៉ូអាប់ជិតទន្លេយ័រដាន់ទល់មុខនឹងយេរីខូរ[ក] ២ឱ្យប្រាប់
ដល់ពួកកូនចៅអ៊ីស្រាអែល ឱ្យគេចែកទីក្រុងខ្លះក្នុងមរដក
ជាកេរ្តិ៍អាកររបស់គេដល់ពួកលេវីឱ្យនៅផង[ខ] ព្រមទាំង
ដីបន់[គ]នៅជុំវិញទីក្រុងទាំងនោះដែរ ៣ដូច្នេះគេនឹងមានទី
ក្រុងសំរាប់ជាទីលំនៅរបស់គេ និងដីបន់នៅជុំវិញទាំង
ប៉ុន្មាន សំរាប់ហ្វូងសត្វគេ អស់ទាំងរបស់របរនិងសត្វ
ផ្សេងៗទាំងប៉ុន្មានផង[ឃ] ៤ឯដីបន់នៅជុំវិញទីក្រុងទាំងប៉ុន្មាន
ដែលឯងនឹងឱ្យដល់ពួកលេវី នោះត្រូវវាស់ពីកំផែងក្រុង
ទៅ១ពាន់ហត្ថគ្រប់ជុំវិញ ៥រួចត្រូវវាស់ពីខាងក្រៅទីក្រុង
ទៅជា២ពាន់ហត្ថ[ង]នៅទិសខាងកើត ២ពាន់ហត្ថនៅទិស
ខាងត្បូង ២ពាន់ហត្ថនៅទិសខាងលិច ហើយ២ពាន់ហត្ថនៅ
ទិសខាងជើង មានទីក្រុងនៅជាកណ្តាលនោះនឹងបានជា
ដីវាល់សំរាប់ឱ្យគេឃ្វាលហ្វូងសត្វ នៅជុំវិញទីក្រុងទាំង
នោះ[ច] ។

## ទីក្រុងពំនាក់

*៣៥:៦–៣៤–ចទ ៤:៤១–៤៣ ១៩:១–១៤ យស ២០:១–៩*

៦ឯក្នុងទីក្រុងទាំងប៉ុន្មាន ដែលឯងរាល់គ្នាឱ្យដល់ពួក
លេវី នោះត្រូវឱ្យមានទីក្រុងពំនាក់៦ សំរាប់ឱ្យអ្នកណា
ដែលសំឡាប់មនុស្សបានរត់ទៅជ្រកអាស្រ័យ[ឆ]ហើយក្រៅពី
នោះត្រូវឱ្យឯងរាល់គ្នាឱ្យទីក្រុង៤២ទៅគេទៀត ៧អស់ទាំង
ទីក្រុងដែលត្រូវឱ្យដល់ពួកលេវី នោះរួមត្រូវជា៤៨ព្រម
ទាំងដីបន់នៅជុំវិញផង ៨ឯទីក្រុងក្នុងកេរ្តិ៍អាករពួកកូនចៅ
អ៊ីស្រាអែល ដែលឯងរាល់គ្នាត្រូវឱ្យដល់ពួកលេវី នោះត្រូវ
យកយ៉ាងច្រើន ពីពួកណាដែលមានទីក្រុងច្រើន ហើយ
យ៉ាងតិចពីពួកណាដែលមានតិច ត្រូវឱ្យគ្រប់គ្នាចែកទីក្រុង
ទាំងនោះដល់ពួកលេវី តាមមរដកដែលខ្លួនទទួលហើយ[ជ] ។

**៣៤:១៤** ប ជន ៣២:១៩ ចទ ៣៣:២១ យស ១៤:៣ **៣៤:១៧** ផ ជន ១១:២៨ ចទ ១:៣៨ **៣៤:១៨** ព ជន ១:៤ ភ យស ១៤:១ **៣៤:១៩** ម ខ.២៩ យ ជន ២៦:៦៥ រ លប ២៩:៣៥ ចទ ៣៣:៧ ទដ ៦០:៧ **៣៤:២០** ល លប ២៩:៣៣ **៣៤:២១** វ លប ៤៩:២៧ ពច ៥:១៤ ទដ ៦៨:២៧ **៣៤:២៣** ស ជន ១:៣៤ **៣៤:២៤** ហ ជន ១:៣២ **៣៤:២៥** ឡ លប ៣០:២០ **៣៤:២៧** អ ជន ១:៤០ **៣៤:២៩** ក ខ.១៩ **៣៥:១** ក ជន ២២:១ **៣៥:២** ខ លវ ២៥:៣២–៣៤ យស ១៤:៣,៤ គ យស ២១:១–៤២ **៣៥:៣** ឃ ចទ ១៨:៦ យស ១៤:៤ ២១:២ **៣៥:៥** ង យស ៣:៤ ច លវ ២៥:៣៤ ២របា ១១:១៤ ១៣:៩ ២៣:២ ៣១:១៩ ២៣:២ ៣១:១៩ **៣៥:៦** ឆ ខ.១១ យស ២១:១៣ **៣៥:៨** ជ ជន ២៦:៥៤ ៣៣:៥៤

យ័រដាន់បានកើតមានឡើង (សូមមើលជំពូក ៣២) ។

**៣៤:១៦–២៩** បញ្ជីនៃអ្នកដឹកនាំពូជអំបូរថ្មី ត្រូវបានហៅឈ្មោះសារឡើងវិញទៅតាមបញ្ជីឈ្មោះអ្នកដឹកនាំនៃមនុស្សជំនាន់មុនដំបូង (១:៥–១៦) នៅលើកនេះព្រះបន្ទូលសន្យានឹងត្រូវបានគេទទួលស្គាល់ថាមានពិត ។ អ្នកដឹកនាំថ្មីៗទាំងនេះនឹងជួយជ្រោមជ្រែងដល់អេលាសារ និងយ៉ូស្វេនៅក្នុងការបែងចែកទឹកដីយ៉ាងពិតប្រាកដ ។

**៣៤:១៩** *កាលែប . . . យូដា* សូមមើលការពន្យល់នៅ ១៣:៦ ។

**៣៥:១–៥** ចាប់តាំងពីពួកលេវីមិនបានទទួលចំណែកជាមួយនឹងពូជអំបូរដទៃទៀតនៅក្នុងទឹកដីសន្យានោះ (១:៤៧–៥៣) ពួកគេនឹងត្រូវការចាំបាច់នូវទីកន្លែងសម្រាប់រស់នៅជួបជុំក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងសម្រាប់ចិញ្ចឹមហ្វូងសត្វផងដែរ ។ ពួកលេវីត្រូវបានពង្រាយពាសពេញទឹកដី នោះ (សូមមើល លប ៤៩:៥,៧ និងការពន្យល់) មិនមែននៅក្នុងការផ្តាច់ចេញពីការបោះត្រសាលនោះទេ ។ យស ២១ ក៏បានបង្ហាញពីសេចក្តីទៅតាមបញ្ញាដែលមាននៅក្នុងកណ្ឌគម្ពីរនេះ ។

**៣៥:៦–១៥** មានទីក្រុងរបស់ពួកលេវីទាំង៦ ត្រូវបានបោះទីតាំងជាយុទ្ធសាស្ត្រនៅលើទឹកដី: ៣កន្លែង នៅតាមដងទន្លេយ័រដាន់ និង៣កន្លែងទៀតនៅក្នុងទឹកដីកាណានដាច់ដោយឡែក ដែលជាទីក្រុងប្រកបដោយទីជ្រកកោនដ៏រឹងមាំ ជាកន្លែងដែលមនុស្សប្រព្រឹត្តរំលងច្បាប់ ដោយអចេតនាក្នុង

[៩]ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ [១០]ឱ្យប្រាប់ដល់ពួកកូន
ចៅអ៊ីស្រាអែលថា កាលណាឯងរាល់គ្នាបានឆ្លងទន្លេយ័រ
ដាន់ចូលទៅក្នុងស្រុកកាណានហើយ[ឈ] [១១]នោះត្រូវឱ្យជ្រើសរើស
ទីក្រុងខ្លះ ទុកសំរាប់ជាទីក្រុងពំនាក់ ដល់ឯងរាល់គ្នា ដើម្បី
ឱ្យអ្នកណាដែលសំឡាប់មនុស្ស[ញ] មិនប្រកបដោយចិត្តប៉ង[ដ]
បានរត់ទៅជ្រកអាស្រ័យនៅទីនោះបាន [១២]ទីក្រុងទាំងនោះ
នឹងបានសំរាប់ជាទីពំនាក់ ឱ្យឯងរាល់គ្នាបានរួចពីអ្នកដែល
សងសឹកចេញ[ឋ] ដើម្បីកុំឱ្យអ្នកដែលសំឡាប់គេ[ឌ] បានត្រូវ
ស្លាប់ឡើយ ដរាបដល់បានជំនុំជំរះនៅមុខពួកជំនុំហើយ[ឍ]
[១៣]ក្នុងបណ្តាទីក្រុងដែលឯងរាល់គ្នានឹងឱ្យនោះ ត្រូវមាន៦
ទុកជាទីក្រុងពំនាក់សំរាប់ឯងរាល់គ្នា[ណ] [១៤]ត្រូវឱ្យឯងរាល់
គ្នាឱ្យទីក្រុង៣ នៅត្រើយទន្លេយ័រដាន់ខាងអាយ ហើយ
ទីក្រុង៣ទៀតនៅក្នុងស្រុកកាណាន ទីក្រុងទាំង៦នោះ ត្រូវ
ទុកសំរាប់ជាទីពំនាក់អាស្រ័យ [១៥]គឺត្រូវបានសំរាប់ជាទី
ពំនាក់ដល់ពួកកូនចៅអ៊ីស្រាអែល និងពួកអ្នកប្រទេសក្រៅ
ហើយដល់អ្នកណាដែលស្នាក់នៅជាមួយផង ដើម្បីឱ្យអស់
អ្នកណាដែលសំឡាប់មនុស្ស មិនប្រកបដោយចិត្តប៉ង បាន
រត់ទៅជ្រកអាស្រ័យបាន ។

[១៦]តែបើអ្នកនោះបានប្រហារគេ ដោយគ្រឿងដែកអ្វីឱ្យ
ដល់ស្លាប់ អ្នកនោះឈ្មោះថាជាអ្នកសំឡាប់គេហើយ អ្នក
ណាដែលសំឡាប់គេដូច្នេះ នោះត្រូវតែសំឡាប់វិញជាមិន
ខាន[ត] [១៧]ឬបើអ្នកនោះកាន់ថ្មនៅដៃគប់គេ ល្មមឱ្យស្លាប់ទៅ
បាន ហើយគេក៏ស្លាប់ទៅ អ្នកនោះឈ្មោះថាជាអ្នកសំឡាប់
គេហើយ អ្នកណាដែលសំឡាប់គេដូច្នេះ នោះត្រូវតែ
សំឡាប់វិញជាមិនខាន [១៨]ឬបើអ្នកនោះបានប្រហារគេ
ដោយគ្រឿងឈើដែលកាន់នៅដៃ ជាប្រដាប់ល្មមឱ្យស្លាប់
បាន ហើយគេក៏ស្លាប់ទៅ អ្នកនោះឈ្មោះថាជាអ្នកសំឡាប់

**៣៥:១០** ឈ ជន ៣៣:៥១ ចទ ៩:១ យស ១:២,១១
**៣៥:១១** ញ ខ.២២–២៥ ដ នក ២១:១៣
**៣៥:១២** ឋ ខ.១៩ ចទ ១៩:៦ យស ២០:៣ ២សយ ១៤:១១ ឌ ខ.២៦,២៧,២៨ ឍ ខ.២៤,២៥
**៣៥:១៣** ណ ខ.៦,១៤
**៣៥:១៦** ត នក ២១:១២
**៣៥:១៩** ថ ខ.១២ ទ ខ.២១
**៣៥:២០** ធ នក ២១:១៤
**៣៥:២១** ន នក ២១:១៤ ប ខ.១៩
**៣៥:២២** ផ នក ២១:១៣
**៣៥:២៤** ព ខ.១២
**៣៥:២៥** ភ ខ.៣២ ម នក ២៨:៤១ យ នក ២៩:៧

គេហើយ អ្នកណាដែលសំឡាប់គេដូច្នេះ នោះត្រូវតែ
សំឡាប់វិញជាមិនខាន [១៩]ឯអ្នកដែលត្រូវសងសឹកនឹងឈាម[ថ]
នោះត្រូវតែសំឡាប់អ្នកដែលបានសំឡាប់គេនោះវិញ កាល
ជួបប្រទះឃើញអ្នកនោះវេលាណា នោះត្រូវតែសំឡាប់
ចោលចេញ[ទ] [២០]បើសិនជាអ្នកនោះបានប្រហារគេដោយ
ចិត្តស្អប់[ធ] ឬបានលបចោលគេនឹងអ្វីឱ្យដល់ស្លាប់ [២១]ឬបាន
ដាស់គេដោយចិត្តក្នាញ់ឱ្យដល់ស្លាប់ នោះត្រូវតែសំឡាប់អ្នក
ដែលបានវាយគេនោះ ចោលចេញជាមិនខាន[ន] អ្នកនោះ
ឈ្មោះថាបានសំឡាប់គេហើយ ឯអ្នកដែលត្រូវសងសឹកនឹង
ឈាម[ប]នោះត្រូវសំឡាប់អ្នកនោះវិញ ក្នុងវេលាដែលជួប
ប្រទះនោះឯង ។

[២២]តែបើអ្នកនោះ ស្រាប់តែវាយគេ ដោយឥតមានចិត្ត
សំអប់សោះ ឬចោលរបស់អ្វីទៅលើគេ ដោយឥតមាន
ឈ្លបលប[ផ] [២៣]ឬបានទំលាក់ថ្មណាមួយ ទៅលើគេដោយមិន
បានឃើញ ដែលល្មមឱ្យស្លាប់បាន ហើយគេក៏ស្លាប់ទៅ តែ
អ្នកនោះមិនមែនជាខ្មាំងសត្រូវ ហើយក៏មិនដែលប៉ងនឹងធ្វើ
អាក្រក់ដល់គេដែរ [២៤]នោះពួកជំនុំ[ព]ត្រូវជំនុំជំរះអ្នកដែល
បានសំឡាប់គេ និងអ្នកដែលរកសងសឹកនឹងឈាមគេនោះ
តាមមាត្រាច្បាប់ទាំងនេះ [២៥]រួចត្រូវដោះអ្នកដែលបាន
សំឡាប់គេ ចេញពីកណ្តាប់ដៃ នៃអ្នកដែលរកសងសឹក
នឹងឈាមគេនោះ ហើយត្រូវឱ្យអ្នកនោះត្រឡប់ទៅឯក្រុង
ពំនាក់ ដែលបានរត់ទៅជ្រកអាស្រ័យវិញ ត្រូវឱ្យគេនៅ
ក្នុងទីក្រុងនោះ ដរាបដល់សំដេចសង្ឃ[ភ] ដែលបានចាក់
ប្រេងបរិសុទ្ធ[ម]តាំងឡើង លោកសុគតទៅ[យ] [២៦]ប៉ុន្តែបើអ្នក
ដែលសំឡាប់គេ បានចេញមកឯក្រៅព្រំក្រុងពំនាក់ ដែល
ខ្លួនបានរត់ទៅជ្រកអាស្រ័យនោះវេលាណា [២៧]ហើយចួន
ជាអ្នកដែលត្រូវសងសឹកនឹងឈាមបានប្រទះឃើញ នៅ

ការធ្វើឃាដមនុស្ស ហើយគេអាចធ្វើការភៀសខ្លួនពីការដេញតាមសងសឹក យស ជំពូក២០ ដែលមានរៀបរាប់ពីទីកន្លែងទាំងនោះ ដែលត្រូវបានគេធ្វើការជ្រើសរើស ។

**៣៥:១៦–២១** មានការពិពណ៌នាគ្រប់សណ្ឋានអំពីការធ្វើឃាដមនុស្សទៅតាមតែចិត្តខ្លួនឯង ។

**៣៥:២១** *អ្នកដែលត្រូវសងសឹកដោយឈាម* សូមមើលការពន្យល់នៅ យស ២០:៣ ។

**៣៥:២២** *ដោយឥតមានចិត្តសំអប់សោះ* ទីកន្លែងដែលពឹងពំនាក់អាស្រ័យនៅទាំងនោះ ត្រូវបានបង្កើតឡើងសម្រាប់អស់អ្នកណា ដែលប្រព្រឹត្តនូវអំពើមនុស្សឃាដ ដោយអចេតនា ។

**៣៥:២៤** *តាមមាត្រាច្បាប់ទាំងនេះ* ការផ្តល់ឱ្យដ៏សមសួនណាមួយ ដែលស្ថិតនៅក្នុងរឿងរំលោភបំពានច្បាប់ ។ ចំពោះមូលហេតុនេះ ករណីដែលអ្នកសម្លាប់មនុស្សដោយអចេតនា ត្រូវបានគេកំណត់ ដោយការជំនុំជម្រះក្តី ។ លើសពីនោះទៅទៀត ដោយបន្សល់ឱ្យមានការចោទប្រកាន់ ស្ថិតនៅក្នុងទីក្រុងសម្រាប់ទីពំនាក់អាស្រ័យនៅនោះតទៅទៀត រហូតដល់មរណភាពនៃសម្តេចសង្ឃនាជំនាន់នោះ ទើបអាចមានការសម្រុះសម្រួលគ្នាឡើងវិញបាន រវាងអ្នកចោទប្រកាន់ និងអ្នកដែលធ្វើឃាដមនុស្ស ។ ក្នុងករណីណាមួយដែលអ្នកចោទប្រកាន់នោះបានធ្វើការចាកចោលទីក្រុង ដែលជាទីពំនាក់អាស្រ័យនៅ នោះនឹងក្លាយទៅជាការលេងល្បែងដ៏ត្រឹមត្រូវក្នុងការសងសឹកគ្នាទៅវិញទៅមកបាន ។

**៣៥:២៥–២៨** សូមមើលការពន្យល់នៅ យស ២០:៦ ។

**៣៥:២៥** *ត្រូវឱ្យអ្នកនោះត្រឡប់ទៅ* ជាក់ស្តែងដំណើរការកាត់ទោសអ្នកដែលត្រូវគេចោទប្រកាន់នោះ ប្រព្រឹត្តទៅនៅខាងក្រៅទីក្រុងនៃទីពំនាក់អាស្រ័យ ។

ត្រង់ខាងក្រៅព្រំទីក្រុងពំនាក់នោះ ហើយសំឡាប់អ្នកនោះ
ទៅ នោះគ្មានទោសនឹងឈាមអ្នកនោះឡើយ ២៨ពីព្រោះ
ត្រូវតែនៅក្នុងទីក្រុងពំនាក់ ដែលខ្លួនជ្រកអាស្រ័យនោះ
ដរាបដល់សំដេចសង្ឃបានសុគតហើយសិន លុះក្រោយ
ដែលសំដេចសង្ឃនោះសុគតហើយ នោះទើបនឹងត្រឡប់
មកឯស្រុកដែលជាកេរ្តិ៍អាកររបស់ខ្លួនវិញបាន ២៩នេះជា
បញ្ញត្តិច្បាប់ សំរាប់ឯងរាល់គ្នា[រ] នៅគ្រប់ទីលំនៅរបស់
ឯង[ល] នៅអស់ទាំងដំណតរៀងទៅ[វ] ។
៣០អ្នកណាដែលសំឡាប់គេ នោះត្រូវសំឡាប់វិញ ដោយ
ពាក្យរបស់ស្មរបន្ទាល់២ឬ៣នាក់ តែបើមានស្មរបន្ទាល់
តែម្នាក់វិញ នោះនឹងធ្វើបន្ទាល់ទាស់នឹងអ្នកណាឱ្យគេត្រូវ
ស្លាប់មិនបានទេ[ស] ៣១មួយទៀត មិនត្រូវឱ្យឯងរាល់គ្នាទទួល
សំណូកអ្វី[ហ] នឹងលោះជីវិតអ្នកណា ដែលមានទោសជាអ្នក
សំឡាប់គេឡើយ ត្រូវសំឡាប់អ្នកនោះវិញជាកុំខាន ៣២ក៏មិន
ត្រូវទទួលសំណូកអ្វី នឹងលោះអ្នកដែលបានរត់ទៅជ្រក
អាស្រ័យក្នុងទីក្រុងពំនាក់ ឱ្យត្រឡប់មកនៅក្នុងស្រុកវិញ
ដរាបដល់សង្ឃនោះបានសុគតទៅនោះដែរ ៣៣មិនត្រូវឱ្យ
ឯងរាល់គ្នាធ្វើឱ្យស្រុកដែលឯងនៅនោះ ទៅជាស្មោក
គ្រោកឡើយ[ឡ] ដ្បិតឯឈាម នោះរមែងធ្វើឱ្យស្រុកទៅជា
ស្មោកគ្រោក ហើយនិងរកអ្វីឱ្យធួនស្មើនឹងស្រុក ដោយ
ឈាមដែលបានខ្ចាយហើយនោះគ្មានទេ មានតែឈាមនៃ
អ្នក ដែលបានកំចាយឈាមនោះប៉ុណ្ណោះឯង ៣៤ដូច្នេះមិន
ត្រូវឱ្យឯងរាល់គ្នាធ្វើឱ្យស្រុក[អ]ដែលឯងអាស្រ័យនៅ ហើយ
ដែលអញនៅកណ្តាលនោះ[ក] ទៅជាស្មោកគ្រោកឡើយ
ដ្បិតអញនេះជាព្រះយេហូវ៉ា ដែលនៅកណ្តាលពួកកូនចៅ
អ៊ីស្រាអែល ។

## មរដកសម្រាប់ពួកកូនស្រីលោកស្លូផិហាត

*៣៦:១-១២ – ជន ២៧:១-១១*

**៣៦** ១រីឯពួកមេ ជាឪពុកលើអស់ទាំងគ្រួនៃកូនចៅ
កាឡាត[ក] ជាកូនម៉ាការ[ខ] ដែលជាកូនម៉ាន៉ាសេ ក្នុងពួកគ្រួនៃ
កូនចៅយ៉ូសែប[គ]ទាំងប៉ុន្មាន គេក៏ចូលមកជិរាបចំពោះមុខ
ម៉ូសេ និងពួកអ្នកដែលជាកំពូល[ឃ] ជាមេលើវង្សានុវង្ស
របស់ឪពុកនៃកូនចៅអ៊ីស្រាអែលថា ២ព្រះយេហូវ៉ាទ្រង់
បានបង្គាប់មកលោកម្ចាស់យើងខ្ញុំ ឱ្យចែកស្រុកជាមរដក
ដល់ពួកកូនចៅអ៊ីស្រាអែល ដោយចាប់ឆ្នោត[ង] ហើយលោក
ម្ចាស់ យើងខ្ញុំក៏បានទទួលបង្គាប់ព្រះយេហូវ៉ា និងចែក
មរដករបស់ស្លូផិហាត[ច] ជាបងប្អូនយើងខ្ញុំ ដល់ពួកកូនស្រី
គាត់ ៣ដូច្នេះ បើសិនជាស្ត្រីទាំងនោះយកប្តីពីពួកប្រុសៗ ក្នុង
ពូជអំបូរនៃពួកកូនចៅអ៊ីស្រាអែលណាទៀត នោះមរដក
របស់គេនឹងត្រូវហូតចេញពីមរដករបស់ពួកឰយុកោយើងខ្ញុំ
ទៅថែមបញ្ចូលនឹងមរដករបស់ពូជអំបូរណាមួយ ដែលគេ
ចូលនោះវិញ យ៉ាងនោះមរដកគេនឹងត្រូវដកចេញ ពី
ចំណែកមរដករបស់យើងខ្ញុំហើយ ៤រួចដល់ឆ្នាំសោមនស្ស[ឆ]
នៃពួកកូនចៅអ៊ីស្រាអែល នោះមរដករបស់គេនឹងត្រូវរាប់
បញ្ចូលក្នុងមរដករបស់ពូជអំបូរណាដែលគេចូល នោះ
ហើយនិងត្រូវដកចេញ ពីមរដករបស់ពួកឰយុកោនៃពូជ
អំបូរយើងខ្ញុំទៅ ។
៥នោះម៉ូសេលោកប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែល
តាមបង្គាប់នៃព្រះយេហូវ៉ាថា ពូជអំបូរនៃកូនចៅយ៉ូសែប
គេបាននិយាយត្រូវ ៦នេះជាសេចក្តី ដែលព្រះយេហូវ៉ាទ្រង់
បង្គាប់ ពីដំណើរនៃពួកកូនស្រីស្លូផិហាត គឺថា ឱ្យគេយកប្តី
ណា ដែលគេចូលចិត្តចុះ ប៉ុន្តែ ត្រូវយកក្នុងគ្រួសារនៃពូជ

**៣៥:២៩** រ ជន ២៧:១១ ល ជន ១០:៨ វ នក ១២:២០
**៣៥:៣០** ស ចទ ១៧:៦ ១៩:១៥ មថ ១៨:១៦ យហ ៧:៥១
**៣៥:៣១** ហ នក ២១:៣០ យប ៦:២២ ទដ ៤៩:៨ សភ ១៣:៨
**៣៥:៣៣** ឡ លប ៤:១០
**៣៥:៣៤** អ លវ ១៨:២៤,២៥ ក នក ២៩:៤៥
**៣៦:១** ក ជន ២៦:៣០ ខ លប ៥០:២៣ គ ជន ២៦:២៨ ឃ ជន ២៧:២
**៣៦:២** ង ជន ៣៣:៥៤ ច ជន ២៦:៣៣
**៣៦:៤** ឆ លវ ២៥:១០

**៣៥:២៧** *គ្មានទោស* គឺមនុស្សមិនអាចកាត់ទោសបាន តែនៅតែមានបាបទាស់នឹងព្រះ ។ ព្រះទ្រង់ទុកឱកាសឱ្យអ្នកនោះជ្រកនៅទីក្រុងពំនាក់ ។

**៣៥:៣០** *ស្មរបន្ទាល់* ដើម្បីជៀសវាងនូវលទ្ធភាពនៃភាគីដែលគ្មានទោសដោយជាប់នៅក្នុងការចោទប្រកាន់ នឹងត្រូវបានផ្តន្ទាទោសប្រហារជីវិតដោយគ្មានភស្តុតាងគ្រប់គ្រាន់ ។

**៣៥:៣២** ថែមទាំងមិនអនុញ្ញាតឱ្យអ្នកដែលធ្វើឃាដមនុស្សចាកចេញពីទីក្រុងពំនាក់នោះបាន ដោយសារប្រាក់លោះខ្លួននោះឡើយ ។

**៣៥:៣៣** *ដ្បិតឯឈាម នោះរមែងធ្វើឱ្យស្រុកទៅជាស្មោកគ្រោក* អំពើឃាដកម្មមនុស្សឃាដ មិនមែនត្រឹមតែជាបទឧក្រិដ្ឋប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យខូចដល់ភាពបរិសុទ្ធនៃជីវិតរស់នៅថែមទៀតផង មិនតែប៉ុណ្ណោះថែមទាំងធ្វើឱ្យស្មោកគ្រោកដល់ទឹកដីបរិសុទ្ធរបស់ព្រះអម្ចាស់ទៀតផង (សូមប្រៀបធៀប លប ៤:១០-១១ និងការពន្យល់ ) ។

**៣៦:១-១៣** អំណោយដែលគួរឱ្យចាប់អារម្មណ៍ សម្រាប់កិច្ចការអភិវឌ្ឍន៍ទៅថ្ងៃអនាគតរបស់ពួកកូនស្រីស្លូផិហាត (សូមមើល ២៧:១-១១) ។ ចាប់តាំងពីព្រះអម្ចាស់បានធ្វើការណែនាំដល់លោកម៉ូសេមកថា ស្ត្រីអាចគ្រប់គ្រងកេរ្តិ៍មរដករបស់ឪពុកខ្លួនបាន ក៏កើតមានឡើងនូវសំណួរថ្មីៗជាច្រើន ដូចជា តើនឹងមានអ្វីកើតមានឡើងចំពោះទឹកដីរបស់ក្រុមគ្រួសារ ប្រសិនបើកូនស្រីទាំងនេះនឹងរៀបការប្តីក្នុងចំណោមពូជអំបូរណាមួយនោះ? តើនឹងមិនធ្វើឱ្យខូចដល់ចេតនាប្រភពដើមដំបូងនៃការផ្តល់សិទ្ធិដែរឬទេ ? សំណួរទាំងនេះ បាននាំទៅរកការធ្វើសេចក្តីសម្រេចចិត្តថា អាពាហ៍ពិពាហ៍ ដែលនឹងប្រព្រឹត្តទៅ ត្រូវបានឱ្យរក្សាទុកត្រឹមតែបុរសក្នុងពូជអំបូរខ្លួន ប៉ុណ្ណោះ ហេតុដូច្នេះការបែងចែកមរដកក្នុងគ្រួសារនឹងមិន "ផ្ទេរពីពូជអំបូរមួយ ទៅពូជអំបូរមួយទៀតឡើយ" (ខ.៩) ។

**៣៦:៤** *ឆ្នាំសោមនស្ស* សូមមើល លវ ២៥:១០ និងការពន្យល់ ។

អំបូររបស់ឰយុកោខ្លួន ៧យ៉ាងនោះ មរដករ[ជ]របស់ពួកកូន
ចៅអ៊ីស្រាអែល នឹងមិនត្រូវរើចេញ ពីពូជអំបូរ១ទៅពូជ
អំបូរ១ទៀតឡើយ ដ្បិតត្រូវឱ្យពួកកូនចៅអ៊ីស្រាអែល នៅ
ជាប់នឹងមរដករបស់ពូជអំបូរ នៃពួកឰយុកោគេរៀងខ្លួន
៨ហើយគ្រប់ទាំងកូនស្រីណា ដែលស៊ីមរដកក្នុងពូជអំបូរនៃ
ពួកកូនចៅអ៊ីស្រាអែលណាមួយ នោះត្រូវតែយកប្ដីក្នុង
គ្រួសាររបស់ពូជអំបូរនៃពួកឰយុកោខ្លួន[ឈ] ដើម្បីឱ្យពួកកូន
ចៅអ៊ីស្រាអែល បានស៊ីមរដករបស់ពួកឰយុកោគេរៀងខ្លួន
៩ដូច្នេះ មរដកណាមួយ នឹងមិនត្រូវរើចេញ ពីពូជអំបូរ១
ទៅពូជអំបូរ១ទៀតឡើយ ពីព្រោះត្រូវឱ្យពូជអំបូរនៃពួក
កូនចៅអ៊ីស្រាអែល នៅជាប់នឹងមរដករបស់គេរៀងខ្លួន ។

**៣៦:៧** ជ លវ ២៥:២៣
**៣៦:៨** ឈ ១រប ២៣:២២
**៣៦:១១** ញ ជន ២៦:៣៣
**៣៦:១២** ដ ១រប ៧:១៥
**៣៦:១៣** ឋ លវ ៧:៣៨ ២៧:៣៤ ឌ ជន ២២:១

១០នោះពួកកូនស្រីស្លផិហាត ក៏ធ្វើដូចជាព្រះយេហូវ៉ា
បានបង្គាប់មកម៉ូសេ ១១ដ្បិតម័សឡា ធើសា ហុកឡា មីលកា
និងណូហា[ញ] ជាកូនស្រីរបស់ស្លផិហាត គេបានយកប្ដីក្នុងពួក
បងប្អូនរបស់ឪពុកគេគ្រប់គ្នា ១២គេបានយកប្ដីចូលជាតិក្នុង
គ្រួសារពួកកូនចៅម៉ាន៉ាសេ ជាកូនយ៉ូសែបហើយមរដក
របស់គេ ក៏បាននៅជាប់ ក្នុងពូជអំបូររបស់គ្រួឪពុកគេត
ទៅ[ដ] ។
១៣នេះហើយជាសេចក្ដីបញ្ញត្តិ និងច្បាប់ទាំងប៉ុន្មាន
ដែលព្រះយេហូវ៉ាបានបង្គាប់ ដល់ពួកកូនចៅអ៊ីស្រាអែល
ដោយសារម៉ូសេ[ឋ] នៅត្រង់ស្រុកវាលរបស់ម៉ូអាប់ជិតទន្លេ
យ័រដាន់ទល់មុខនឹងយេរីខូរ[ឌ]។/

**៣៦:១០** *ពួកកូនស្រីស្លផិហាត ក៏ធ្វើដូចជាព្រះយេហូវ៉ាបានបង្គាប់មកម៉ូសេ* កណ្ឌគម្ពីរ ជនគណនា ដែលតែងតែបង្ហាញពីការបះបោររបស់រាស្ត្រផង ព្រះ ទាស់នឹងព្រះគុណរបស់ផងទ្រង់ និងការរឹងទទឹងចំពោះបំណងព្រះហឫទ័យរបស់ព្រះអង្គ នាំមកដល់ទីបញ្ចប់នៅសេចក្ដីសម្គាល់មួយប្រកបដោយសេចក្ដីរីករាយ ។ ស្ត្រីដ៏ថ្លៃថ្នូរទាំងនេះ ដែលជាអ្នកជាប់ពាក់ព័ន្ធជាមួយនឹងឈ្មោះឪពុក ហើយនិងទីកន្លែងរបស់ពួកគេនៅក្នុងទឹកដីនោះ ដោយការគោរពដល់ព្រះអម្ចាស់ ។

**៣៦:១១** សូមមើលការពន្យល់នៅត្រង់ ៣៣:៥០–៣៦:១៣ និងសូមប្រៀបធៀប លវ ២៧:៣៤ ។

# ចោទិយកថា

## សេចក្ដីផ្ដើម

## ចំណងជើង

ព្រះគម្ពីរនេះមានឈ្មោះជាភាសាហេព្រើរគឺ "អេឡេ ដេបារីម"(elleh haddebarim, គឺមានន័យថា "នេះជាសេចក្ដីទាំងប៉ុន្មាន") ឬមានឈ្មោះដ៏សាម័ញ្ញមួយទៀត គឺ"ដេបារីម" (debarim,មានន័យថា "សេចក្ដីទាំងប៉ុន្មាន", មើល ១:១)។ ឈ្មោះព្រះគម្ពីរនេះជាភាសាអង់គ្លេសគឺ "យូឌុធ័រ៉ូណូមី" (Deuteronomy, មានន័យថា ការអានក្រឹត្យវិន័យឡើងវិញ) មានប្រភពពីកិច្ចការបកប្រែសេទូជិន (Septuagint, ការបកប្រែព្រះគម្ពីរសញ្ញាចាស់មកជាភាសាក្រិក មុនគ្រីស្ទសករាជ) និងពីឃ្លាជាភាសាឡាតាំង នៅក្នុងព្រះគម្ពីរវ៉ាល់ហ្គេត (Vulgate) នៅក្នុង ចទ ១៧:១៨ ដែលជាភាសាហេព្រើរ មានន័យថា "ការចម្លងក្រឹត្យវិន័យ" (សូមមើលចំណុចរចនាសម្ព័ន្ធ និងគម្រោងសង្ខេប) ។

### អ្នកនិពន្ធ និងការបរិច្ឆេទ

លោកម៉ូសេបានធ្វើការនិពន្ធនូវផ្នែកភាពច្រើននៃព្រះគម្ពីរនេះ (មើល ១:១,៥ ៣១:២៤ និងការពន្យល់)។ ហេតុនេះហើយបានជា នៅក្នុងកណ្ឌគម្ពីរដទៃទៀត មានការចង្អុលបង្ហាញថា លោកម៉ូសេជាអ្នកសរសេរនូវផ្នែកភាគច្រើននៃព្រះគម្ពីរចោទិយកថា និងច្បាប់នៅក្នុងព្រះគម្ពីរបញ្ចកណ្ឌ (សូមមើលឧទាហរណ៍ក្នុង យស ១:៧-៨ ២៣:៦ ១ពវ ២:៣ ៨:៥៣ មឡ ៤:៤ និងការពន្យល់)។ ព្រះគ្រីស្ទក៏បានមានបន្ទូលអំពីក្រឹត្យវិន័យរបស់លោកម៉ូសេ ដែលមានក្នុង ចទ ២៤:១ (មថ ១៩:៧-៨ មក ១០:៣-៥) លោកពេត្រុសក៏បាននិយាយអំពីក្រឹត្យវិន័យរបស់លោកម៉ូសេ ដែលមានក្នុង ចទ ១៨:១៥,១៨-១៩ (កច ៣:២២-២៣) ហើយលោកស្ទេផាន (សូមមើល កច ៧:៣៧-៣៨ និងការពន្យល់) និងលោកប៉ុល (រម ១០:១៩) ក៏បាននិយាយអំពីក្រឹត្យវិន័យរបស់លោកម៉ូសេ ដែលមានក្នុង ចទ ៣២:២១ ផងដែរ ។ ទន្ទឹមនឹងនោះ មានអ្នកនិពន្ធម្នាក់ទៀតបានចូលរួមនៅក្នុងការនិពន្ធព្រះគម្ពីរនេះ ដោយធ្វើការពិពណ៌នាការនិពន្ធរបស់លោកម៉ូសេ នៅក្នុងព្រះគម្ពីរនេះ (មើលបុព្វកថា នៅក្នុង ១:១-៥ និងសេចក្ដីបញ្ចប់ ក្នុងជំពូក ៣៤ មើល ៥:១ ២៧:១, ៩,១១ ២៩:១-២ ៣១:១,៧,៩-១០,១៤-២៥,៣០ ៣២:៤៤-៤៦,៤៨-៥២ ៣៣:១-២)។ មើលសេចក្ដីផ្ដើមនៅគម្ពីរលោកុប្បត្តិ: ត្រង់ចំណុចអ្នកនិពន្ធ និងកាលបរិច្ឆេទ ។

### លក្ខណៈប្រវត្តិសាស្ត្រ

ព្រះគម្ពីរចោទិយកថានិយាយអំពីសម័យកាល ដែលលោកម៉ូសេ និងពួកអ៊ីស្រាអែលកំពុងរស់នៅ ក្នុងទឹកដីនៃស្រុកម៉ូអាប់តាមបណ្ដោយទន្លេយ័រដាន់ដែលហូរចុះទៅសមុទ្រស្លាប់ (១:៥)។ នៅចុងបញ្ចប់នៃបេសកកម្មរបស់គាត់ គឺនៅពេលដែលគាត់ត្រូវផ្ទេរការងារដឹកនាំពួកអ៊ីស្រាអែលឱ្យទៅលោកយ៉ូស្វេ លោកម៉ូសេបានធ្វើសេចក្ដីថ្លែងការ ជាពាក្យជម្រាបលាដល់ពួកគេ ដើម្បីឱ្យពួកគេត្រៀមខ្លួនចូលទឹកដីកាណាន ។ នៅក្នុងសេចក្ដីថ្លែងការទាំងនោះ លោកម៉ូសេបាននិយាយសង្កត់ធ្ងន់ទៅលើក្រឹត្យវិន័យ ដែលពួកគេត្រូវមានជាលក្ខណៈពិសេស នៅពេលដែលពួកគេចូលដីសន្យា ហើយគាត់បានធ្វើសេចក្ដីថ្លែងការទាំងនោះ តាមរបៀបដែលត្រូវនឹងស្ថានភាពនៅពេលនោះ ។ ការពិពណ៌នានៅក្នុងព្រះគម្ពីរលេវីវិន័យ និងជនគណនា មិនបានបង្ហាញពីអារម្មណ៍របស់អ្នកនិពន្ធទេ គឺខុសពីព្រះគម្ពីរ ចោទិយថា ដែលពាក្យពេចន៍របស់លោកម៉ូបោនបង្ហាញញពីអារម្មណ៍នៅមែនក្នុងជម្រៅចិត្តរបស់គាត់ នៅក្នុងការនិយាយសង្កត់ធ្ងន់អំពីកម្មសិទ្ធដាច់មុខដែលព្រះអម្ចាស់ទ្រង់មានលើពួកអ៊ីស្រាអែល ។

### មុខងារពិសេសនៅក្នុងព្រះគម្ពីរបិរសុទ្ធ

គោលដៅនៃសាច់រឿង ដែលបានលាតត្រដាងចាប់ពីព្រះគម្ពីរលោកុប្បត្តិរហូតដល់ព្រះគម្ពីរជនគណនាហាក់ដូចជា និយាយឆ្ពោះទៅរកការចូលកាន់កាប់កាន់កាប់ទឹកដីកាណាន (ដែលមាននិយាយនៅក្នុងព្រះគម្ពីរយ៉ូស្វេ) ដែលជាការសម្រេចនូវព្រះបន្ទូលសន្យា (មើលសេចក្ដីផ្ដើមព្រះគម្ពីរយ៉ូស្វេ ត្រង់ចំណុចចំណងជើង និងផ្ទៃរឿង)។ ប៉ុន្តែ ព្រះគម្ពីរចោទិយកថាបានបង្ហាញពីការបន្តដំណើរការឆ្ពោះទៅមុខតែបន្តិចបន្តួចប៉ុណ្ណោះ ។ នៅចុងបញ្ចប់នៃព្រះគម្ពីរជនគណនា ពួកអ៊ីស្រាអែលកំពុងស្ថិត "នៅវាលស្រុកម៉ូអាប់តាមបណ្ដោយទន្លេយ័រដាន់ដែលមានក្រុងយេរីខូរនៅត្រើយម្ខាងទៀត" (ជន ៣៦:១៣) ហើយនៅចុងបញ្ចប់នៃគម្ពីរចោទិយកថា ពួកគេនៅនៅមានទីតាំងនៅទីនោះនៅឡើយ (ចទ ៣៤:៨) ដោយរង់ចាំឆ្លងទន្លេយ័រដាន់ (មើល យស ១:២)។ ការទាំងអស់ដែលកើតឡើងនៅពេលនោះ គឺជាការផ្ទេរនូវការងាររបស់លោកម៉ូសេ (ដែលជាអ្នកនាំព្រះបន្ទូលព្រះ និងជាតំណាងរបស់រាស្ត្រទ្រង់) ឱ្យទៅលោកយ៉ូស្វេ (ចទ ៣៤:៩ និង យស ១:១-២)។ តែកិច្ចការចុងក្រោយដែលលោកម៉ូសេត្រូវបំពេញនេះ គឺមានសារៈសំខាន់ណាស់ ព្រោះការពិពណ៌នា

អំពីកិច្ចការទាំងនោះនៅក្នុងព្រះគម្ពីរនេះ ជាការបញ្ជាក់អំពីការបញ្ចប់នៃគម្ពីរបញ្ចកណ្ឌ រីឯកណ្ឌគម្ពីរយ៉ូស្វេវិញ (ដែលពិពណ៌នាអំពីការចាប់ផ្ដើមសម្រេចនូវព្រះបន្ទូលសន្យា ដែលព្រះទ្រង់មាននឹងពួកពូយុកោរ ហើយព្រះគម្ពីរនេះបញ្ជាក់ពីការបញ្ចប់នៃការងាររបស់លោកម៉ូសេ, មើល ១៧:១៥–២៣ សយ ២១:៤៣–៤៥) គឺជាសេចក្ដីផ្ដើមនៃបណ្ដាព្រះគម្ពីរហោរាដំបូង ។

ដូច្នេះ ព្រះគម្ពីរចោទិយកថាបានផ្អាកការនិយាយអំពីការប្រោសលោះ ដែលមានដូចជា :

(១).ការដោះពួកអ៊ីស្រាអែលពីចំណងនៃមហាអំណាចក្នុងលោកិយ (នគរអេស៊ីព្ទ) ដើម្បីឱ្យបានទទួលសេរីភាពនៅក្នុងទឹកដីដែលពួកគេអាចរស់នៅជារាស្ដ្រដែលមានសេរីភាព នៅក្រោមការដឹកនាំរបស់ព្រះ ។

(២).ការរំដោះពួកគេឱ្យរួចភាពជាក្រុមមនុស្សតូចតាច នៅក្រោយសម័យប៉មបាបិល (លោកអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប) ហើយឱ្យមានសន្តិសុខ និងការសម្រាក (មើល ចទ ៣:៣០ និងការពន្យល់ និង ១២:១០ ២៥:១៩) ក្នុងទឹកដីសន្យា ។

(៣).ដើម្បីរំដោះចេញពីជីវិតដែលព្រះបានបណ្ដេញចេញពីសួនច្បារអេដែន (លប ៣) ដើម្បីឱ្យមានជីវិតរស់នៅក្នុងទឹកដី ដែលទ្រង់សព្វព្រះទ័យតាំងត្រសាលរបស់ទ្រង់ (យស ២២:១៩) ។

ប៉ុន្តែ ក្នុងការផ្អាកនិយាយដ៏យូរនេះ មុននឹងបន្តការនិយាយអំពីទឹកដីសន្យា លោកម៉ូសេបានរំឭកដល់ពួកអ៊ីស្រាអែលដោយលម្អិតអំពីការដែលពួកគេត្រូវបំពេញថ្វាយព្រះអម្ចាស់ ក្នុងនាមជារាស្ដ្ររបស់ទ្រង់ ដើម្បីឆ្លងទន្លេយ័រដាន់ ចូលទៅកាន់កាប់ទឹកដីសន្យា ហើយទទួល "សេចក្ដីសម្រាក" នៅក្នុងការប្រកបជាមួយនឹងទ្រង់ តាមដែលទ្រង់សន្យា ។ ពាក្យរំឭកនោះ គឺជាពាក្យដែលពួកអ៊ីស្រាអែលត្រូវការឮម្ដងហើយម្ដងទៀត ។ ការអានព្រះគម្ពីរបញ្ចកណ្ឌ នឹងនាំឱ្យពួកគេបានរំឭកឱ្យដឹងខ្លួនសារជាថ្មី អំពីការចូលទឹកដីសន្យា និងសេចក្ដីសម្រាក់នៅក្នុងទឹកដីនោះ ដើម្បីស្ដាប់ព្រះបន្ទូលដែលលោកម៉ូសេបាននាំមកជាលើកចុងក្រោយ (មើល ទដ ៩៥:៧ខ–២២) ។ ហេតុនេះហើយរឿងរ៉ាវប្រវត្តិសាស្ដ្រទាំងអស់ដែលកើតឡើងក្នុងទឹកដីកាណាន ដែលបានរៀបរាប់នៅក្នុងព្រះគម្ពីរពួកហោរាដំបូង គឺមានមូលដ្ឋានគ្រឹះនៅក្នុងព្រះបន្ទូលនោះ ។

**ការបង្រៀនផ្នែកវិជ្ជាសិក្សាអំពីព្រះ និងគោលបំណង**

កណ្ឌគម្ពីរចោទិយកថា មានលក្ខណៈប្រៀបបានទៅនឹងសន្ធិសញ្ញា ដែលពួកស្ដេចនៅតំបន់មជ្ឈិមបូព៌ាបុរាណបានតាំងនៅសម័យសហស្សវត្សរ៍ទី២ មុនគ.ស ដែលក្នុងនោះមានមហាក្សត្រដ៏ជាធំមួយអង្គទ្រង់សន្យាធ្វើជាអ្នកការពាររបស់ពួកអ៊ីស្រាអែល បើពួកគេមានភាពស្មោះត្រង់ចំពោះទ្រង់ ដែលជាព្រះអម្ចាស់នៃសេចក្ដីសញ្ញា ហើយស្ដាប់បង្គាប់តាមសេចក្ដីតម្រូវ ដែលមានក្នុងសេចក្ដីសញ្ញានោះ ក្នុងនាមជារាស្ដ្រដែលចំណុះឱ្យទ្រង់ ។ ការស្ដាប់បង្គាប់នោះនឹងនាំឱ្យទទួលព្រះពរ ប៉ុន្តែការមិនស្ដាប់បង្គាប់នឹងនាំឱ្យបានបណ្ដាសាវិញ (ជំពូក ២៧–៣០) ។ គោលបំណងនៃព្រះគម្ពីរចោទិយកថា គឺដើម្បីរៀបចំរាស្ដ្រជ្រើសតាំងនៃព្រះ ដែលស្ថិតនៅក្នុងជំនាន់ថ្មីឱ្យបានធ្វើជាអ្នកតំណាងនៅនៃនគររបស់ទ្រង់នៅក្នុងទឹកដី ដែលទ្រង់បានសន្យាដោយគ្មានលក្ខខ័ណ្ឌជាមួយនឹងលោកអ័ប្រាហាំ (មើលរចនាសម្ព័ន្ធ និងគម្រោងសង្ខេបខាងក្រោម, មើលការពន្យល់ ៣:២៧ ១៧:១៤,១៨) ។

ព្រះគម្ពីរនេះទាំងមូលបាននិយាយទាក់ទង នឹងទំនាក់ទំនងនៃសេចក្ដីស្រឡាញ់ដែលព្រះអម្ចាស់ទ្រង់មានចំពោះរាស្ដ្រទ្រង់ និងដែលរាស្ដ្រទ្រង់មានចំពោះទ្រង់ដែលជាព្រះដែលគ្រងរាជ្យលើពួកគេ ។ គេបាននិពន្ធកណ្ឌគម្ពីរដទៃៗទៀតនៅក្នុងព្រះគម្ពីរបរិសុទ្ធដោយយោងទៅលើការដែលព្រះគម្ពីរនេះនិយាយសង្កត់ធ្ងន់ខាងវិញ្ញាណ និងការត្រាសហៅឱ្យមានការប្ដេជ្ញាចិត្តទាំងស្រុងនៅក្នុងការថ្វាយបង្គំ និងស្ដាប់បង្គាប់ព្រះអម្ចាស់ ។ ជាពិសេស នៅក្នុងព្រះគម្ពីរជាភាសាហេព្រើ ក្រុមព្រះគម្ពីរហោរាដំបូង (យ៉ូស្វេ ពួកចៅហ្វាយ សាំយ៉ូអែល ពង្សាវតាក្សត្រ) បានប្រើគំរូនៃរចនាបទ និងផ្ទៃរឿងនៃព្រះគម្ពីរចោទិយកថា ។ នៅក្នុងចំណោមព្រះគម្ពីរហោរាបន្ទាប់ព្រះគម្ពីរនេះក៏មានឥទ្ធិពលយ៉ាងខ្លាំង មកលើព្រះគម្ពីរយេរេមាផងដែរ ។

**រចនាសម្ព័ន្ធ និងគម្រោងសង្ខេប**

ព្រះគម្ពីរនេះមានរចនាសម្ព័ន្ធផ្នែកអក្សរសាស្ដ្រ ដែលត្រូវគ្នានឹងលក្ខណៈប្រវត្តិសាស្ដ្រ ។ ព្រះគម្ពីរនេះមានរចនាបទនៃការសរសេរបែបពន្យល់ បែបនិយាយសារឡើងវិញ បែបរំឭក ហើយមានការផ្លាស់ប្ដូររចនាបទពីផ្នែកមួយទៅផ្នែកមួយទៀត ដូចនេះ គេអាចសន្និដ្ឋានថា ព្រះគម្ពីរនេះការរៀបចំការសរសេរពីចំណុចមួយទៅចំណុចមួយទៀត ដោយមិនតឹងរឹង ហើយជួនកាលរៀបរាប់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ដ្រ មិនតាមលំដាប់លំដោយឡើយ (មើល ១០:៣) ។ ប៉ុន្តែ ព្រះគម្ពីរគឺប្រៀបបានទៅនឹងសន្ធិសញ្ញារវាងចក្រភព និងនគរចំណុះ នៅមជ្ឈិមបូព៌ា នៅមុននិងក្នុងសម័យនោះ ដូចនេះ លក្ខណៈនេះបានបញ្ជាក់ថា ព្រះគម្ពីរនេះនិយាយសង្កត់ធ្ងន់ទៅលើសេចក្ដីសញ្ញារវាងព្រះអម្ចាស់ និងរាស្ដ្រទ្រង់ គឺមានន័យថា ព្រះគម្ពីរចោទិយកថា គឺជាឯកសារដែលញ៉ាំងឱ្យសេចក្ដីសញ្ញានៅតែថ្មីជានិច្ច ដូច

ដែលបានបង្ហាញនៅក្នុងគម្រោងសង្ខេបខាងក្រោម ៖

I. បុព្វកថា (១:១–៥)

II. សេចក្តីផ្តើមអំពីប្រវត្តិសាស្ត្រ (១:៦–៤:៤៣)

III. ការប្រកាសសេចក្តីសេចក្តីសញ្ញា (៤:៤៤–២៦:១៩)

ក. មហាព្រះរាជបញ្ញា ៖ ការតម្រូវឱ្យស្មោះត្រង់ជាដាច់ខាត (៤:៤៤–១១:៣២)

១. ព្រះអម្ចាស់នៃសេចក្តីសញ្ញា (៤:៤៤–៥:៣៣)

២. គោលការនៃការជម្រះជាបរិសុទ្ធ (ជំពូក ៦)

៣. គម្រោងចូលកាន់កាប់ទឹកដីកាណាន (ជំពូក ៧)

៤. ការត្រាស់ហៅឱ្យប្តេជ្ញាចិត្តនៅក្នុងទឹកដីថ្មី (ជំពូក ៨)

៥. មេរៀននៃការបំបែកបន្ទះថ្ម (៩:១–១០:១១)

៦. ការត្រាសហៅម្តងទៀតឱ្យប្តេជ្ញាចិត្ត (១០:១២–១១:៣២)

ខ. ការតម្រូវជាបន្ថែមទៀត (ជំពូក ១២–២៦)

១. ការសម្អាតជាបរិសុទ្ធតាមពិធីបុណ្យ (១២:១–១៦:១៧)

២. អ្នកដឹកនាំជាមនុស្ស ក្នុងនគរដ៏បរិសុទ្ធរបស់ព្រះ (១៦:១៨–២១:២១)

៣. ភាពបរិសុទ្ធនៃនគររបស់ព្រះ (២១:២២–២៥:១៩)

៤. ការប្រកាសទទួលស្គាល់ថា ព្រះទ្រង់ជាមហាក្សត្រដ៏ប្រោសលោះ (ជំពូក ២៦)

IV. ការប្រកាសយល់ព្រមអនុវត្តតាមសេចក្តីសញ្ញាណ, បណ្តាសា និងព្រះពរ (ជំពូក ២៧–៣០)

V. ការស្នងការងារដឹកនាំតាមសេចក្តីសញ្ញា (ជំពូក ៣១–៣៤)

ក. ការផ្លាស់ប្តូរអ្នកដឹកនាំ (៣១:១–២៩)

ខ. ទំនុករបស់លោកម៉ូសេ (៣១:៣០–៣២:៤៧)

គ. លោកម៉ូសេឱ្យពរដល់អំបូរទាំងឡាយ (៣២:៤៨–៣៣:២៩)

ឃ. មរណៈភាពរបស់លោកម៉ូសេ និងការស្នងដំណែងដោយលោកយ៉ូស្វេ (ជំពូក ៣៤)

## ព្រះអម្ចាស់បង្គាប់ឱ្យចាកចេញពីភ្នំហោរេប

**១** ១នេះជាសេចក្តីទាំងប៉ុន្មាន ដែលម៉ូសេបានពោលដល់
ពួកអ៊ីស្រាអែលទាំងអស់ ត្រង់កន្លែងឆ្លងទន្លេយ័រដាន់[ក]ក្នុងទី
រហោស្ថាន នាស្រុកវាល[ខ] ទល់មុខនឹងស៊ូភ នៅជាកណ្តាល
ប៉ារ៉ាន[គ] តូផែល ឡាបាន់ ហាសិរ៉ូត និងឌីសាហាប់ ២រីឯពីភ្នំ
ហោរេប[ឃ] តាមផ្លូវភ្នំសៀរ[ង] ទៅដល់កាដេស-បារនា[ច]
នោះ ទាំងអស់មានចំនួនដើរផ្លូវ[ឆ]អស់១១ថ្ងៃ ៣ហើយនៅថ្ងៃ
ទី១ ក្នុងខែមាឃ[ជ]ឆ្នាំទី៤០[ឈ] នោះម៉ូសេរំឭក[ញ]ដល់ពួកកូន
ចៅអ៊ីស្រាអែល តាមគ្រប់ទាំងសេចក្តី ដែលព្រះយេហូវ៉ា
បានបង្គាប់មកគេ ដោយសារលោក ៤គឺពេលក្រោយដែល
អញបានវាយស៊ីហុន[ដ] ជាស្តេចសាសន៍អាម៉ូរី[ឋ] ដែលនៅ
ក្រុងហែសបូន[ឌ] និងអុក[ឍ] ជាស្តេចស្រុកបាសាន ដែលនៅ
ក្នុងអាសថារ៉ូត[ណ] ត្រង់ទីក្រុងអេទ្រី ៥ត្រើយខាងកើតទន្លេ
យ័រដាន់ ក្នុងស្រុកម៉ូអាប់[ត]ហើយ នោះម៉ូសេចាប់តាំង
សំដែងពន្យល់ ពីបណ្តាក្រិត្យវិន័យនេះ ដោយពាក្យថា
៦ព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា[ថ] ទ្រង់មានព្រះបន្ទូល
មកយើង នៅត្រង់ភ្នំហោរេប[ទ]ថា ឯងរាល់គ្នាបាននៅភ្នំ
នេះល្មម[ធ]ប៉ុណ្ណេះហើយ ៧ដូច្នេះ ចូរនាំគ្នាចេញទៅចុះ
ហើយធ្វើដំណើរទៅឯស្រុកភ្នំរបស់សាសន៍អាម៉ូរី និងអស់
ទាំងកន្លែងជិតខាងស្រុកនោះទៅ គឺជាស្រុកវាល[ន] ស្រុកភ្នំ[ប]
ស្រុកទំនាប[ផ] ស្រុកត្បូង ស្រុកក្បែរសមុទ្រ និងស្រុក
របស់សាសន៍កាណាន[ព] ហើយនៅភ្នំល្បាណូន[ភ] រហូតទៅ
ដល់ទន្លេធំ គឺជាទន្លេអើប្រាត[ម] ៨មើល អញបានប្រគល់
ស្រុកនោះ ឱ្យឯងរាល់គ្នាហើយ[យ,រ] ដូច្នេះឱ្យចូលទៅ ទទួល
យកស្រុក ដែលព្រះយេហូវ៉ាបានស្បថ[ល]ថា នឹងឱ្យដល់ពួក
ឰយុកោឯងរាល់គ្នាចុះ គឺថា នឹងឱ្យដល់អ័ប្រាហាំ អ៊ីសាក
និងយ៉ាកុប ហើយនិងពូជដំណាលោកតទៅ ។

## ការចាត់តាំងអ្នកដឹកនាំ

៩នៅវេលានោះ អញបាននិយាយនឹងឯងរាល់គ្នាថា អញ
ពុំអាចនឹងបីទ្រ[វ]ឯងរាល់គ្នាតែម្នាក់ឯងបានទេ[ស] ១០ព្រះ
យេហូវ៉ា ជាព្រះនៃឯងទ្រង់បានចំរើន[ហ]ឯងជាច្រើនឡើង[ឡ]
ហើយមើល សព្វថ្ងៃនេះ ឯងមានគ្នាយ៉ាងសន្ធឹក[អ] ដូចជា
ផ្កាយនៅលើមេឃ[ក] ១១សូមឱ្យព្រះយេហូវ៉ា ជាព្រះនៃពួក
ឰយុកោឯង ចំរើន[ខ]ឱ្យបានគ្នាជាច្រើនលើសជាងឥឡូវនេះ
ជា១ពាន់ដងទៅទៀតចុះ ហើយប្រទានពរ ដូចជាទ្រង់បាន
មានបន្ទូលនឹងឯងរាល់គ្នាដែរ[គ] ១២តែធ្វើដូចម្តេចឱ្យអញតែ
ម្នាក់ឯងទ្រាំទ្រនឹងឯងរាល់គ្នា ដែលជាបន្ទុក ហើយជា
សេចក្តីលំបាកដល់អញដូច្នេះ និងសេចក្តីឈ្លោះប្រកែក

**១:១** ក ជន ១៣:២៩ ចទ ៤:៤៦ ខ ខ.៧ ចទ ២:៨ ៣:១៧ យស ៣:១៦ ៨:១៤ ១១:២ អគ ៤៧:៨ គ ជន ១០:១២ **១:២** ឃ នក ៣:១ ង ជន ២៤:១៨ ច លប ១៤:៧ ចទ ២:១៤ ៩:២៣ យស ១៥:៣ ឆ ខ.១៩ **១:៣** ជ លប ៥០:៣ ចទ ៣៤:៨ យស ៤:១៩ ឈ ជន ១៤:៣៣ ៣២:១៣ ចទ ៨:២ ហព ៣:៧-៩ ញ ចទ ៤:១-២ **១:៤** ដ ជន ២១:២១-២៦ ឋ លប ១០:១៦ ១៤:៧ ឌ ជន ២១:២៥ ឍ ជន ២១:៣៣-៣៥ ចទ ៣:១០ ណ យស ៩:១០ ១២:៤ ១របា ១១:៤៤ **១:៥** ត ជន ២១:១១ **១:៦** ថ ជន ១០:១៣ ទ នក ៣:១ ធ ចទ ២:៣ **១:៧** ន ខ.១៩ ចទ ២:២៤ ៧:១ យស ១០:៥ ប ខ.១ ផ ជន ២១:១ យស ១១:១៦ ១២:៨ ២សយ ២៤:៧ ព លប ១០:១៨ ភ ចទ ១១:២៤ ម លប ២:១៤ **១:៨** យ យស ២៣:១៣ រ ជន ៣៤:២ ល នក ១៣:១១ ជន ១៤:២៣ ហព ៦:១៣-១៤ **១:៩** វ ជន ១១:១៤ ទជ ៣៨:៤ ស នក ១៨:១៨ **១:១០** ហ ខ.១១ អគ ១៦:៧ ឡ ចទ ៧:១៣ អ លប ១៥:៥ អស ៥១:២ ៦០:២២ អគ ៣៣:២៤ ក លប ២២:១៧ ជន ១០:៣៦ **១:១១** ខ ខ.១០ គ ខ.៨ នក ៣២:១៣ ២សយ ២៤:៣ ១របា ២១:៣

**១:១-៥** វគ្គនេះជាបុព្វកថា ដែលនាំឱ្យមានការចាប់ផ្តើមនិយាយអំពីប្រវត្តិសាស្ត្រនៅក្នុងកណ្ឌគម្ពីរនេះទាំងមូល ហើយណែនាំឱ្យយើងស្គាល់លោកម៉ូសេ ដែលជាអ្នកនាំព្រះបន្ទូលព្រះមកដល់រាស្ត្រទ្រង់ ។

**១:១** *ម៉ូសេបានពោល* ស្ទើរតែគ្រប់ផ្នែកទាំងអស់ នៃព្រះគម្ពីរចោទិយកថា គឺជាពាក្យរបស់លោក ម៉ូសេដែលបានថ្លែងនៅពេលខែចុងក្រោយនៃជីវិតគាត់ គឺមុនពេលដែលពួកអ៊ីស្រាអែលឆ្លងទន្លេយ័រដាន់ចូលទឹកដីកាណាន ។ *ស្រុកវាល* គឺរាប់បញ្ចូលទាំងជ្រលងនៃទន្លេយ័រដាន់ (ចាប់ពីសមុទ្រកាលីឡេ រហូតដល់ចុងខាងត្បូងនៃសមុទ្រស្លាប់) ដែលសន្ធឹងឆ្ពោះចុះទៅឈូងសមុទ្រ "អាកាបា" (Aqaba) ។ *ប៉ារ៉ាន . . . ឌីសាហាប់* គឺតម្រៀបគ្នាតាម បណ្តោយផ្លូវពីវាលស៊ីណាយ ដល់ស្រុកម៉ូអាប់ (មើល ជន ១២:១៦ និងការពន្យល់) ។

**១:២** *ហោរេប* ជាឈ្មោះភ្នំស៊ីណាយ ដែលប្រើក្នុងកណ្ឌនេះជាធម្មតា (លើកលែងតែក្នុង ៣៣:២) ។ *កាដេស-បារនា* មើលការពន្យល់ លប ១៤:៧ ជន ២០:១១ ។ *ភ្នំសៀរ* មើលការពន្យល់ លប ៣៦:៨ អគ ៣៥:២ ។

**១:៣** *ឆ្នាំទី៤០* គឺបន្ទាប់ពីការចាកចេញពីអេស៊ីព្ទ ។ ព្រះអង្គបានកាត់ទោសដល់ពួកអ៊ីស្រាអែល ឱ្យដើរវិលវល់នៅវាលរហោស្ថានស៊ីណាយ អស់៤០ឆ្នាំ ព្រោះពួកគេមិនបានចូលទៅទឹកដីកាណាន (ជន ១៤:៣៣-៣៤) កាលនៅកាដេស-បារនា តាមបង្គាប់ទ្រង់ ។ រយៈពេល៤០ឆ្នាំនោះគឺរាប់ចាប់ពីពេលនៅវាលរហោស្ថានស៊ីណាយ និងតាមផ្លូវទៅស្រុកកាដេស ហើយរាប់ទាំងរយៈពេល៣៨ឆ្នាំក្រោយមកទៀត (សូមមើល ២:១៤) ។ មើល ៨:២-៥ ២៩:៥-៦ ជន ១៤:២៩-៣៥ ៣២:១៣ កច ៧:៣៦ ហព ៣:៧-១៩ ។

**១:៤** *ស៊ីហុន . . . អុក* សូមមើលការពន្យល់ ជន ២១:២១-២៦,៣៥ ។ *ក្រុងហែសបូន* មើលការពន្យល់ អស ១៥:៤ ។

**១:៥** *ក្រិត្យវិន័យនេះ* គឺបញ្ញត្តិទាំង១០ប្រការ ដែលព្រះអម្ចាស់ប្រទានមកឱ្យនៅភ្នំស៊ីណាយ និងបានកត់ត្រាទុកក្នុងព្រះគម្ពីរ នក ២០-២៤ លេវីវិន័យ និងជនគណនា ។ ព្រះគម្ពីរចោទិយាកថា បានសង្ខេប និងកាត់ស្រាយក្រឹត្យវិន័យ ហើយមានការតម្រូវតាមស្ថានភាពថ្មីៗ ដែលពួកអ៊ីស្រាអែលនឹងជួបនៅទឹកដីកាណាន ។

**១:៦** *ព្រះយេហូវ៉ាជាព្រះនៃយើង* ព្រះគម្ពីរចោទិយកថា បានប្រើពាក្យនេះផង និងពាក្យ "ព្រះយេហូវ៉ាជាព្រះនៃឯង" ប្រហែល ៣០០ ដង (មើលការពន្យល់ ២៨:៥៨ លប ២:៤ នក ៣:១៤-១៥ ៦:៣,៦ លវ ១៨:២) ។

**១:៧** សូមមើល យស ១:៤ ។ *ស្រុកវាល* មើលការពន្យល់ ខ.១ ។ ការពិពណ៌នាអំពីទឹកដីនេះ គឺស្របតាមការរៀបរាប់អំពីព្រះបន្ទូលសន្យា (មើល ខ.៨) ចំពោះលោកអ័ប្រាហាំនៅក្នុង លប ១៥:១៨-២១ ក្នុង លប ១៥:១៨-២១ និងចំពោះតែពូជរបស់លោកអ៊ីសាក (លប ២៦:២-៤) ហើយបន្តដល់ពូជលោកយ៉ាកុប ( លប ៣៥:១១-១២) ។

**១:៩-១៨** ផ្ទៀបវគ្គនេះនឹង ១៦:១៨-២០ នក ១៨:១៣-២៦ ។

**១:១០** *ដូចជាផ្កាយនៅលើមេឃ* សូមមើល ១០:២២ ២៨:៦២ លប ១៣:១៦ និងការពន្យល់ ១៥:៥ និងការពន្យល់ និង ២២:១៧ ២៦:៤ នក ៣២:១៣ ។

របស់ឯងរាល់គ្នាទៅបាន[ឃ] ១៣ចូរឱ្យឯងរាល់គ្នារើសយក
មនុស្ស[ង]ដែលមានប្រាជ្ញា មានយោបល់ ហើយមានឈ្មោះ
ក្នុងពូជអំបូរឯងរាល់គ្នាមក នោះអញនឹងតាំងគេឱ្យធ្វើជា
មេលើឯងរាល់គ្នា ១៤រួចឯងរាល់គ្នាបានឆ្លើយមកអញថា
សេចក្ដីដែលលោកមានប្រសាសន៍មក នោះស្រួលហើយ
១៥ដូច្នេះ អញក៏បានយក[ច]ពួកមេលើពូជអំបូរឯងរាល់គ្នា
ទាំងប៉ុន្មាន[ឆ] ដែលជាមនុស្ស[ជ]មានប្រាជ្ញា ហើយមានឈ្មោះ
តាំងគេឡើង លើឯងរាល់គ្នា គឺជាមេ[ឈ]លើ១ពាន់នាក់
ជាមេលើ១រយនាក់ ជាមេលើ៥០នាក់ ហើយជាមេលើ១០
នាក់ ព្រមទាំងនាយកផង តាមពូជអំបូររបស់ឯងរាល់គ្នា[ញ]
១៦នៅវេលានោះ អញក៏បានផ្ដាំនឹងពួកចៅក្រមនៃឯង
រាល់គ្នាថា ចូរប្រុងស្ដាប់រឿងក្ដីរបស់ពួកបងប្អូនឯងរាល់
គ្នាចុះ ហើយជំនុំជំរះ[ដ]ដល់បងនឹងប្អូន និងអ្នកដែលស្នាក់
នៅជាមួយនឹងគេ[ឋ] ដោយយុត្តិធម៌[ឌ] ១៧មិនត្រូវឱ្យអ្នករាល់គ្នា
ល្អៀង[ឍ]ទៅខាងណាក្នុងការកាត់ក្ដីឡើយ ត្រូវស្ដាប់អ្នកតូច
ដូចជាអ្នកធំដែរ មិនត្រូវខ្លាចមុខមនុស្សណាឱ្យសោះ[ណ] ដ្បិត
ការវិនិច្ឆ័យនោះស្រេចនៅព្រះវិញ ឯរឿងណាដែល
ពិបាកពេកដល់អ្នករាល់គ្នា នោះត្រូវនាំមកឯខ្ញុំវិញ ខ្ញុំនឹង
ជំនុំជំរះឱ្យ[ត] ១៨នៅវេលានោះ អញក៏បានបង្គាប់ពីគ្រប់ទាំង
សេចក្ដីដែលឯងរាល់គ្នាត្រូវប្រព្រឹត្តតាមដែរ[ថ]។

## ការចាត់ពួកអ្នកស៊ើបការណ៍

១៩រួចយើងរាល់គ្នាក៏ធ្វើដំណើរ ចេញពីភ្នំហោរែបដើរ
កាត់អស់ទាំងទីរហោស្ថានសំបើម[ទ] គួរស្ញែងខ្លាចនោះ
ដែលឯងរាល់គ្នាបានឃើញ តាមផ្លូវទៅឯស្រុកភ្នំរបស់
សាសន៍អាម៉ូរី[ធ] តាមដែលព្រះយេហូវ៉ា ជាព្រះនៃយើង
រាល់គ្នាបានបង្គាប់មក រហូតទៅដល់កាដេស-បារនា[ន]
២០នោះអញបានប្រាប់ថា ឯងរាល់គ្នាបានមកដល់ស្រុកភ្នំ
របស់សាសន៍អាម៉ូរី ដែលព្រះយេហូវ៉ា ជាព្រះនៃយើង
ទ្រង់បានប្រទានមកយើងហើយ ២១មើល ព្រះយេហូវ៉ាជា
ព្រះនៃឯងទ្រង់បានប្រគល់ស្រុកនោះដល់ឯង ដូច្នេះចូរ
ឡើងទៅទទួលយកចុះ[ប] ដូចជាព្រះយេហូវ៉ា ជាព្រះនៃពួក
ឰយុកោឯងបានមានព្រះបន្ទូលប្រាប់មក កុំឱ្យខ្លាចឡើយ[ផ]
ក៏កុំឱ្យរសាយចិត្តឱ្យសោះ[ព]។
២២នោះឯងគ្រប់គ្នា បានចូលមកឯអញ និយាយថា សូម
ឱ្យយើងរាល់គ្នាចាត់មនុស្សឱ្យទៅមុន ដើម្បីនឹងដើរសង្កេត
មើល[ភ]ស្រុកនោះ[ម]ឱ្យយើង ហើយត្រឡប់មកប្រាប់ពីផ្លូវដែល
យើងត្រូវឡើងទៅ ហើយពីអស់ទាំងទីក្រុងដែលយើងត្រូវ
មកដល់ ២៣សេចក្ដីនោះក៏បានគាប់ចិត្តអញណាស់ដែរ
ដូច្នេះអញបានរើសយក[យ]មនុស្ស១២នាក់ក្នុងពួកឯងរាល់គ្នា
គឺម្នាក់ៗពីពូជអំបូរមួយៗ ២៤អ្នកទាំងនោះក៏ចេញទៅ ហើយ
គេឡើងទៅក្នុងស្រុកភ្នំ[រ] រហូតដល់ជ្រោះអែសកុល ទាំង
សង្កេតមើល ២៥គេក៏នាំយកផលផ្លែពីស្រុកនោះ កាន់នៅដៃ
ត្រឡប់មកវិញ ព្រមទាំងប្រាប់ដំណឹង[ល]ដល់យើងថា ស្រុក
ដែលព្រះយេហូវ៉ាជាព្រះនៃយើងរាល់គ្នា ទ្រង់ប្រទានមក
យើង[វ] នោះជាស្រុកល្អណាស់[ស]។

## ការទាស់ទទឹងនឹងបង្គាប់ព្រះអម្ចាស់

២៦ប៉ុន្តែឯងរាល់គ្នា មិនព្រមឡើងទៅទេ[ហ] គឺបានទាស់
ទទឹង[ឡ]នឹងបង្គាប់របស់ព្រះយេហូវ៉ា ជាព្រះនៃឯងវិញ
២៧ហើយបានរទូរទាំ[អ] នៅក្នុងត្រសាលឯងរាល់គ្នាថា ព្រះ
យេហូវ៉ាទ្រង់ស្អប់យើងរាល់គ្នាហើយ បានជាទ្រង់នាំយើង
ចេញពីស្រុកអេស៊ីព្ទមក ដើម្បីនឹងប្រគល់ទៅក្នុងកណ្ដាប់
ដៃនៃសាសន៍អាម៉ូរី ឱ្យបំផ្លាញយើងទៅ ២៨តើយើងនឹង
ឡើងទៅឯណា ដ្បិតបងប្អូនយើងទាំងនេះ បានរំលាយចិត្ត
យើង ដោយពាក្យថា សាសន៍នោះ គេមានមាឌធំខ្ពស់ជាង
យើងរាល់គ្នាណាស់ ឯទីក្រុងរបស់គេក៏ធំណាស់[ក] ហើយ
មានកំផែងខ្ពស់ដល់មេឃផង ១ទៀតយើងបានឃើញពួក
កូនចៅអ័ណាក់[ខ]នៅស្រុកនោះដែរ ២៩នោះអញបានប្រាប់
ដល់ឯងរាល់គ្នាថា កុំឱ្យភ័យស្លុត ឬខ្លាច[គ]គេឡើយ[ឃ] ៣០ដ្បិត

**១:១២** ឃ នក ៥:២២ ១៨:១៨ **១:១៣** ង លប ៤៧:៦ **១:១៥** ច នក ១៨:២៥ ឆ នក ៥:១៤ ជន ១១:១៦ យស ១:១០ ៣:២ ជ លប ៤៧:៦ ឈ ជន ៣១:១៤ ១សយ ៨:១២ ២២:៧ ១ពវ ១៤:២៧ ញ ជន ១:៤ **១:១៦** ដ ១ពវ ៣:៩ ទដ ៧២:១ សភ ២:៩ ឋ នក ១២:១៩,៤៩ ២២:២១ ឌ លប ៣១:៣៧ យហ ៧:២៤ **១:១៧** ឍ នក ១៨:១៦ លវ ១៩:១៥ កច ១០:៣៤ យក ២:១ ណ សភ ២៩:២៥ ត នក ១៨:២៦ **១:១៨** ថ លប ៣៩:១១ **១:១៩** ទ ចទ ២:៧ ៨:១៥ ៣១:១០ ទដ ១៣៦:១៦ យរ ២:២,៦ ហស ១៣:៥ ធ ខ.៧ ន ខ.២ ជន ១៣:២៦ **១:២១** ប ចទ ៩:២៣ ផ ជន ១៤:៩ យស ១:៦,៩,១៨ ២សយ ១០:១២ ទដ ២៧:១៤ ព ចទ ៧:១៨ យស ៨:១ ១០:៨

**១:២២** ភ ជន ១៣:១-៣ ម លប ៤២:៩ **១:២៣** យ ជន ១៣:១-៣ **១:២៤** រ ជន ១៣:២១-២៥ ៣២:៩ **១:២៥** ល ជន ១៣:២៧ វ យស ១:២ ស ជន ១៤:៧ **១:២៦** ហ ជន ១៤:១-៤ ឡ ជន ១៤:៩ **១:២៧** អ ចទ ៩:២៨ ទដ ១០៦:២៥ **១:២៨** ក ជន ១៣:៣២ ខ ជន ១៣:៣៣ ចទ ៩:១-៣ **១:២៩** គ ចទ ៣:២២ ២០:៣ នហ ៤:១៤ ឃ ចទ ៧:១៨ ២០:១ ៣១:៦

**១:១៩-៤៦** មើល ជន ១៣-១៤ និងការពន្យល់ ។

**១:២១** *ដូចជាព្រះយេហូវ៉ា . . . បានមានព្រះបន្ទូលប្រាប់មក* ព្រះបន្ទូលសន្យាពីទឹកដី (ខ.៧) បញ្ជាក់ប្រាប់ម៉ូសេជាថ្មី (ខ.៨) នៅគុំបន្ទាដែលឆេះ (នក ៣:៨,១៧) ។ ឥឡូវព្រះទ្រង់មានបន្ទូលឱ្យពួកអ៊ីស្រាអែលចូលកាន់ ។ *កុំឱ្យខ្លាចឡើយ ក៏កុំឱ្យរសាយចិត្ត* មើល ៣១:៨ យស ១:៩ ៨:១ ១០:២៥ ។

**១:២៣** *១២នាក់* ពួកគេមានឈ្មោះនៅក្នុង ជន ១៣:៤-១៥ ។

**១:២៤** *ជ្រោះអែសកុល* មើលការពន្យល់ក្នុង ជន ១៣:២៣ ។

**១:២៧** *បានរទូរទាំ* មើលការពន្យល់ នក ១៥:២៤ ។ *ទ្រង់ស្អប់យើងរាល់គ្នាហើយ* ពួកបណ្ដាលជនបានប្រើពាក្យនេះ ខុសនឹងលក្ខណៈនៃព្រះគម្ពីរចោទិយកថា ដែលមានខ្លឹមសារសំខាន់ គឺនិយាយអំពីសេចក្ដីស្រឡាញ់របស់ព្រះ (មើលសេចក្ដីផ្ដើម ត្រង់ចំណុចការបង្រៀនអំពីវិជ្ជាអំពីព្រះ និងគោលបំណង) ។

**១:២៨** *កូនចៅអ័ណាក់* គឺជាប្រជាជននៅស្រុកកាណាន កាលពីសម័យមុនដែលគេថា មានមាឌយក្ស (មើល ២:១០,២១ ៩:២ ជន ១៣:៣២-៣៣) ។

**១:២៩** *កុំឱ្យភ័យស្លុត . . . ខ្លាចគេឡើយ* សូមមើលការពន្យល់ អស ៤១:១០,១៣ ៤៣:១-២ ។

ព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ដែលទ្រង់យាងនាំមុខ
ឯង ទ្រង់នឹងច្បាំង[ង]ជំនួសឯង តាមគ្រប់ទាំងការដែលទ្រង់
បានប្រោសដល់ឯងនៅស្រុកអេស៊ីព្ទ ឱ្យឯងបានឃើញជាក់
៣១ហើយនៅក្នុងទីរហោស្ថានផង នោះឯងរាល់គ្នាក៏បាន
ឃើញថា ព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់បានបីទ្រ[ច]ឯង
តាមផ្លូវដែលឯងបានដើរ រហូតមកដល់ទីនេះ ដូចជា
មនុស្សបីកូនរបស់ខ្លួន[ឆ] ៣២តែទោះបើយ៉ាងនោះក៏ដោយ[ជ]
គង់តែឯងនៅតែមិនទុកចិត្ត[ឈ]នឹងព្រះយេហូវ៉ាជាព្រះនៃ
ឯងទៀត ៣៣ដែលទ្រង់បាននាំមុខឯងតាមផ្លូវ ដើម្បីនឹង
រក[ញ]ទីកន្លែងឱ្យឯងដំឡើងត្រសាល គឺដោយភ្លើងនៅពេល
យប់ សំរាប់បង្ហាញផ្លូវដែលឯងត្រូវដើរ ហើយដោយពពក
នៅពេលថ្ងៃ[ដ]ដែរ ។
៣៤ព្រះយេហូវ៉ា ទ្រង់ឮ[ឋ]សូរសំឡេង នៃសេចក្តីដែលឯង
រាល់គ្នាថានោះ រួចទ្រង់ក៏មានសេចក្តីក្រោធ[ឌ] ហើយស្បថ
[ឍ]ថា ៣៥ក្នុងពួកមនុស្សដំណអាក្រក់នេះ នឹងគ្មានអ្នកណាមួយ
ឃើញស្រុកល្អ[ណ] ដែលអញបានស្បថនឹងឱ្យដល់ពួកឰយុកោ
ឯងឡើយ ៣៦ឃើញបានតែកាលែប[ត]ជាកូនយេភូនេប៉ុណ្ណោះ
ហើយអញនឹងឱ្យស្រុកដែលគាត់បានដើរជាន់នោះ ដល់គាត់
នឹងពួកកូនចៅគាត់ ដ្បិតគាត់បានប្រព្រឹត្តតាមព្រះយេហូវ៉ា
គ្រប់ជំពូក[ថ] ៣៧ព្រះយេហូវ៉ាទ្រង់ក៏ខ្ញាល់[ទ]នឹងអញដែរ ដោយ
ព្រោះឯងរាល់គ្នា ទ្រង់មានបន្ទូលថា ក៏មិនត្រូវឱ្យឯងចូល[ធ]
ទៅក្នុងស្រុកនោះដែរ ៣៨ឯយ៉ូស្វេ[ន]ជាកូននុន ដែលឈរនៅ
មុខឯង នោះនឹងចូលទៅវិញ ដូច្នេះ ចូរកំឡាចិត្ត[ប]គាត់ឡើង
ដ្បិតគាត់នឹងធ្វើឱ្យ[ផ]សាសន៍អ៊ីស្រាអែលបានស្រុកនោះជាមរ
ដក[ព] ៣៩ហើយកូនតូចៗរបស់ឯងរាល់គ្នា[ភ] ដែលឯងបានថា
និងទៅជារំពាគេ ព្រមទាំងកូនចៅឯងរាល់គ្នា ដែលសព្វ
ថ្ងៃនេះមិនទាន់ដឹងខុសត្រូវនៅឡើយ[ម] នោះនឹងបានចូលទៅ
វិញ អញនឹងឱ្យស្រុកនោះដល់គេ ហើយគេនឹងបានស្រុក
នោះ ជាកេរ្តិ៍អាករ ៤០តែឥឡូវនេះ ចូរឱ្យឯងរាល់គ្នាធ្វើ
ដំណើរត្រឡប់ទៅក្នុងទីរហោស្ថាន តាមផ្លូវសមុទ្រក្រហម
វិញទៅ[យ] ។
៤១នោះឯងរាល់គ្នាបានឆ្លើយមកអញថា យើងខ្ញុំបានធ្វើ
បាបនឹងព្រះយេហូវ៉ាហើយ ដូច្នេះយើងនឹងឡើងទៅច្បាំង
តាមគ្រប់ទាំងសេចក្តីដែលព្រះយេហូវ៉ា ជាព្រះនៃយើងបាន
បង្គាប់មក រួចឯងរាល់គ្នាបានក្រវាត់គ្រឿងសស្ត្រាវុធ
គ្រប់ៗគ្នា រៀបចំនឹងឡើងទៅឯស្រុកភ្នំនោះដោយក្លៀវក្លា
៤២តែព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអញថា ចូរហាមកុំឱ្យ
គេឡើងទៅច្បាំងឡើយ ដ្បិតអញមិននៅជាមួយនឹងឯងរាល់
គ្នាទេ ក្រែងឯងត្រូវពួកខ្មាំងសត្រូវវាយឈ្នះ[រ] ៤៣ដូច្នេះ
អញក៏ប្រាប់ដល់ឯងរាល់គ្នា តែឯងមិនស្តាប់តាមសោះ គឺ
បានទាស់ទទឹងនឹងបង្គាប់នៃព្រះយេហូវ៉ាវិញ ក៏ឡើងទៅក្នុង
ស្រុកភ្នំនោះ ដោយមានចិត្តអួតអាង ៤៤រួចសាសន៍អាម៉ូរី
ដែលនៅភ្នំនោះ ក៏ចេញមកទាស់នឹងឯង ដេញតាមឯងដូច
ជាឃ្មុំ[ល] ព្រមទាំងវាយផ្ចួលនៅត្រង់ស្រុកសៀរ[វ] រហូតទៅ
ដល់ភ្នំហោម៉ា[ស] ៤៥នោះឯងរាល់គ្នាបានត្រឡប់មកយំ នៅ
ចំពោះព្រះយេហូវ៉ាវិញ[ហ] តែព្រះយេហូវ៉ាទ្រង់មិនបាន
ស្តាប់[ឡ]សំឡេងឯងទេ ក៏មិនបានផ្ទៀងព្រះកាណ៌[អ]ទ្រង់មក
ផង ៤៦ដូច្នេះ ឯងរាល់គ្នា បានអាស្រ័យនៅត្រង់កាដេស[ក]ជា
យូរថ្ងៃ តាមចំនួនថ្ងៃដែលត្រូវនៅទីនោះ ។

**១:៣០** ង នក១៤:១៤ **១:៣១** ច នក ១៩:៤ ចទ ៣២:១០–១២ ទដ ២៨:៩ អស ៤៦:៣–៤ ៦៣:៩ ហស ១១:១៣ ឆ យរ ៣១:៣២ **១:៣២** ជ ជន ១៤:១១ ឈ ចទ ៩:២៣ ទដ ៧៨:២២ ១០៦:២៤ សផ ៣:២ ហព ៣:១៩ យដ១:៥ **១:៣៣** ញ ជន ១០:៣៣ ដ នក ១៣:២១ ជន ៩:១៥–២៣ ទដ ៧៨:១៤ **១:៣៤** ឋ ជន ១១:១ ឌ ជន ៣២:១៤ ឍ ជន ១៤:២៣,២៨–៣០ អគ ២០:១៥ ហព ៣:១១ **១:៣៥** ណ ជន ១៤:២៩ **១:៣៦** ត ជន ១៣:៦ ថ ជន ១៤:២៤ **១:៣៧** ទ ទដ ១០៦:៣២ ធ ជន ២៧:១៣ **១:៣៨** ន ជន ១១:២៨ ប ចទ ៣១:៧ ផ ចទ ៣:២៨ ព យស ១១:២៣ ទដ ៧៨:៥៥ ១៣៦:២១ **១:៣៩** ភ ជន ១៤:៣ម អស ៧:១៥–១៦ **១:៤០** យ នក ១៤:២៧ ពច ១១:១៦ **១:៤២** រ ជន ១៤:៤១–៤៣ **១:៤៤** ល ទដ ១១៨:១២ វ ជន ២៤:១៨ ស ជន ១៤:៤៥ **១:៤៥** ហ ជន ១៤:១ ឡ យប ២៧:៩ ៣៥:១៣ ទដ ១៩:៤១ ៦៦:១៨ សភ ១:២៨ អស ១:១៥ យរ ១៤:១២ បទ ៣:៨ មីក ៣:៤ យហ ៩:៣១ អ ទដ ២៨:១ ៣៩:១២ សភ ២៨:៩ **១:៤៦** ក ជន ២០:១

**១:៣០** *ការដែលទ្រង់បានប្រោសដល់ឯងនៅស្រុកអេស៊ីព្ទ* មើលការពន្យល់ នក ១៤:១–១៥:១៩ ។

**១:៣១** *ទ្រង់បានបីទ្រឯង* ធៀបនឹង អស ៤០:១១ យរ ៣១:១០ អគ ៣៤:១១–១៦ ។

**១:៣៣** *គឺដោយភ្លើងនៅពេលយប់ សំរាប់បង្ហាញផ្លូវដែលឯងត្រូវដើរ ហើយដោយពពកនៅពេលថ្ងៃដែរ* វត្តមានរបស់ព្រះអម្ចាស់នៅលើពពក ដែលនៅលើរោងឧបោសថ ដើម្បីនាំពួកអ៊ីស្រាអែល នៅក្នុងដំណើររបស់ពួកគេនៅទីរហោស្ថាន (មើល នក ១៣:២១ និងការពន្យល់ ៤០:៣៤–៣៨) ។

**១:៣៦** *កាលែប* មើល ជន ១៣:៣០–១៤:៣៨ យស ១៤:៦–១៥ ។ *ប្រព្រឹត្តតាមព្រះយេហូវ៉ាគ្រប់ជំពូក* មើលការពន្យល់ ជន ១៤:២៤ ។

**១:៣៧** *ដោយព្រោះឯងរាល់គ្នា* មើលការពន្យល់ ៣:២៦ ៤:២១ ។ ព្រះអង្គមានសេចក្តីក្រោធចំពោះលោកម៉ូសេ ដែលមិនគោរពដល់ទ្រង់ជាព្រះដ៏បរិសុទ្ធ ដោយវាយថ្មយកទឹកនោះ (មើលការពន្យល់ ជន ២០:៩–១៣) និងការពន្យល់ ២០:១១ ២៧:១២–១៤) ហើយទ្រង់ក៏ខ្ញាល់នឹងពួកអ៊ីស្រាអែលដែលនាំឱ្យគាត់ធ្វើទង្វើនោះផងដែរ ។

**១:៣៩** *មិនទាន់ដឹងខុសត្រូវនៅឡើយ* សូមមើលការពន្យល់ លប ២:៩ អស ៧:១៥ ។

**១:៤១** *ឯងរាល់គ្នា* មើលការពន្យល់ ខ.២៦ ។

**១:៤៣** *បានទាស់ទទឹងនឹងបង្គាប់នៃព្រះយេហូវ៉ាវិញ* គឺដូចពាក្យក្នុងខ.២៦ ។ ពីដំបូងពួកគេបះបោរទាស់នឹងព្រះអម្ចាស់ ដោយប្រឆាំងនឹងព្រះរាជបញ្ជាឱ្យចាប់ផ្តើមចូលទឹកដីសន្យា ហើយក្រោយមកទាស់ប្រឆាំង និងព្រះរាជបញ្ជាមិនឱ្យចូលទឹកដីសន្យា ។ ដូចនេះពួកគេត្រូវទទួលមេរៀនមួយនោះ ។

**១:៤៤** *ឃ្មុំ* មើលការពន្យល់ នក ២៣:២៨ ។

**១:៤៥** *នៅចំពោះព្រះយេហូវ៉ា* គឺនៅឯរោងឧបោសថ ។

## ការវិលវល់នៅក្នុងទីរហោស្ថាន

**២** ១រួចយើងរាល់គ្នាបានវិលទៅធ្វើដំណើរ ក្នុងទីរហោ
ស្ថាន តាមផ្លូវសមុទ្រក្រហមវិញ[ក] ដូចជាព្រះយេហូវ៉ាបាន
បង្គាប់ ក៏ដើរព័ទ្ធភ្នំសៀរអស់ជាយូរថ្ងៃ[ខ] ២ហើយព្រះយេ
ហូវ៉ាទ្រង់មានបន្ទូលមកអញថា ៣ឯងរាល់គ្នាបានដើរជុំវិញ
ភ្នំនេះក៏ល្មមណាស់ហើយ[គ] ដូច្នេះចូរបែរទៅខាងជើងចុះ
៤ហើយបង្គាប់[ឃ]ដល់ពួកបណ្ដាជនថា ឯងរាល់គ្នានឹងត្រូវ
ដើរកាត់ព្រំស្រុករបស់ពួកកូនចៅអេសាវ[ង] ជាបងប្អូននៃឯង
ដែលនៅស្រុកសៀរ[ច] ហើយគេនឹងខ្លាច[ឆ]ឯង ដូច្នេះចូរប្រុង
ប្រយ័ត្នខ្លួនឱ្យមែនទែន ៥កុំឱ្យតនឹងគេឡើយ ដ្បិតអញមិនឱ្យ
ស្រុកគេដល់ឯងរាល់គ្នាទេ សូម្បីឱ្យល្មមគ្រាន់នឹងដាក់បាត
ជើងចុះក៏មិនមានដែរ ពីព្រោះអញបានឱ្យភ្នំសៀរទុកជា
កេរ្ដិ៍អាករដល់អេសាវហើយ[ជ] ៦ត្រូវឱ្យឯងទិញស្បៀង
អាហារពីគេបរិភោគទៅ ក៏ត្រូវទិញទឹកពីគេផឹកដែរ ៧ដ្បិត
ព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់បានប្រទានពរដល់ឯង ក្នុង
គ្រប់ការដែលដៃឯងធ្វើ ទ្រង់ក៏ស្គាល់[ឈ]ផ្លូវដែលឯងបាន
ដើរក្នុងទីរហោស្ថានសំបើមនេះផង[ញ] ព្រះយេហូវ៉ាជាព្រះ
នៃឯង ទ្រង់បានគង់នៅជាមួយនឹងឯង អស់រវាង៤០ឆ្នាំ
នេះ[ដ] ហើយឯងគ្មានខ្វះខាតអ្វីឡើយ[ឋ] ។

៨ដូច្នេះយើងរាល់គ្នាក៏ដើរបង្ហួស ពីពួកកូនចៅអេសាវ
ជាបងប្អូនយើង ដែលនៅស្រុកសៀរ ទៅតាម[ឌ]ផ្លូវស្រុក
វាល[ឍ] តាមអេឡាត និងអេស៊ាន-គេប៊ើរ[ណ] រួចបែរទៅ
តាមផ្លូវទីរហោស្ថានម៉ូអាប់វិញ[ត] ៩ហើយព្រះយេហូវ៉ាទ្រង់
មានបន្ទូលនឹងអញថា កុំឱ្យធ្វើទុក្ខសាសន៍ម៉ូអាប់ឡើយ ក៏កុំឱ្យ
តតាំងនឹងគេដែរ អញមិនឱ្យស្រុកគេដល់ឯងរាល់គ្នាទេ
ពីព្រោះអញបានឱ្យស្រុកអើរ[ថ] ដល់ពួកកូនចៅឡុត[ទ] ទុកជា
កេរ្ដិ៍អាករហើយ ១០(ពីដើមសាសន៍អេមីម[ធ]បាននៅស្រុក
នោះ ជាសាសន៍មានគ្នាច្រើន ហើយមានមាឌធំខ្ពស់ ដូចជា
សាសន៍អ័ណាក់[ន] ១១សាសន៍នោះក៏រាប់ទុកជាមនុស្សគួរ
ស្ញែងខ្លាចដូចសាសន៍អ័ណាក់ដែរ[ប] តែពួកសាសន៍ម៉ូអាប់
បានហៅគេជាសាសន៍អេមីមវិញ ១២សាសន៍ហូរី[ផ]ក៏នៅ
ស្រុកសៀរនោះកាលពីដើម តែពួកកូនចៅអេសាវបាន
បណ្ដេញគេ ព្រមទាំងបំផ្លាញគេពីមុខចេញ ហើយបាននៅ
កន្លែងគេ ដូចជាសាសន៍អ៊ីស្រាអែលបានធ្វើ[ព]នៅក្នុងស្រុក
ដែលព្រះយេហូវ៉ាប្រទានឱ្យគេ ទុកជាកេរ្ដិ៍អាករដែរ)
១៣ឥឡូវនេះ ចូរឯងក្រោកឡើង ឆ្លងស្ទឹង[ភ]សេរេតនេះចុះ
នោះយើងរាល់គ្នាក៏ឆ្លងស្ទឹងសេរេតទៅ ១៤ឯវេលាដែល
យើងរាល់គ្នាបានដើរ ពីកាដេស-បារនា[ម] ដរាបដល់បាន
ឆ្លងស្ទឹងសេរេតនោះ អស់ចំនួន៣៨ឆ្នាំ[យ] ទាល់តែដំណ[រ]
មនុស្សជំនាញក្នុងចំបាំងទាំងនោះ បានសាបសូន្យពីពួក
យើងទៅ ដូចជាព្រះយេហូវ៉ាទ្រង់ស្បថនឹងគេ[ល] ១៥ហើយ
ព្រះហស្តនៃព្រះយេហូវ៉ាក៏បានទាស់នឹងគេដែរ ដើម្បី
នឹងបំផ្លាញ[វ]គេពីពួកយើងទៅ ទាល់តែរោយរៀវបាត់បង់
អស់ ។

១៦កាលពួកអ្នកថ្មីកច្បាំងបានរោយរៀវស្លាប់បាត់ផុតពី
កណ្ដាលពួកបណ្ដាជនទៅ ១៧នោះព្រះយេហូវ៉ាទ្រង់មាន
បន្ទូលមកអញថា ១៨នៅថ្ងៃនេះឯងនឹងដើររំលងព្រំស្រុក
ម៉ូអាប់តាមក្រុងអើរ[ស] ១៩ដូច្នេះកាលណាមកដល់ទល់មុខនឹង
ពួកកូនចៅអាំម៉ូន[ហ] នោះកុំឱ្យធ្វើទុក្ខគេឡើយ ក៏កុំឱ្យតតាំង
នឹងគេដែរ[ឡ] អញមិនឱ្យស្រុកនៃពួកកូនចៅអាំម៉ូនដល់ឯង
ទុកជាកេរ្ដិ៍អាករទេ ដ្បិតអញបានឱ្យស្រុកនោះទុកជាកេរ្ដិ៍
អាករដល់ពួកកូនចៅឡុតហើយ[អ] ២០(ស្រុកនោះក៏រាប់ទុក

**២:១** ក នក ១៤:២៧ ជន ២១:៤ ខ ជន ២៤:១៨
**២:៣** គ ចទ ១:៦
**២:៤** ឃ ជន ២០:១៤–២១ ង លប ៣៦:៨ ច ខ.១ ឆ នក ១៥:១៦
**២:៥** ជ យស ២៤:៤
**២:៧** ឈ ចទ ៨:២–៤ ញ នក ១៣:២១ ចទ ១:១៩ ដ ខ.១៤ ជន ១៤:៣៣ ៣២:១៣ យស ៥:៦ ឋ នហ ៩:២១ អម ២:១០
**២:៨** ឌ ជន ២០:២១ ឍ ចទ ១:១ ណ ជន ៣៣:៣៥ ១ពវ ៩:២៦ ត ជន ២១:៤
**២:៩** ថ ជន ២១:១៥ ទ លប ១៩:៣៨ ទដ ៨៣:៨
**២:១០** ធ លប ១៤:៥ ន ជន ១៣:២២,៣៣
**២:១១** ប លប ១៤:៥
**២:១២** ផ លប ១៤:៦ ព ជន ២១:២៥,៣៥
**២:១៣** ភ ជន ២១:១២
**២:១៤** ម ចទ ១:២ យ ខ.៧ រ ជន ១៤:២៩–៣៥ ល ចទ ១:៣៤–៣៥ យស ៥:៦ **២:១៥** វ ទដ ១០៦:២៦ ពច ១:៥ **២:១៨** ស ជន ២១:១៥ **២:១៩** ហ លប ១៩:៣៨ ឡ ២របា ២០:១០ **២:១៩** អ ខ.៩

**២:១–៣:១១** មើលការពន្យល់ ជន ២០:១៤–២១:៣៥ និងការពន្យល់ ។
**២:១** *សមុទ្រក្រហម* គេជឿថា ពាក្យនេះសំដៅទៅលើឈូងសមុទ្រ"អាកាបា" (មើលការពន្យល់ ១ពវ ៩:២៦) ។ *ភ្នំសៀរ* គឺជាតំបន់ភ្នំ នៅភាគខាងត្បូងសមុទ្រស្លាប់(អេដំម) ។
**២:៥** *អញមិនឱ្យស្រុកគេដល់ឯងរាល់គ្នាទេ* សូមមើលការពន្យល់ ខ.៩,១៩ ។ ព្រះអម្ចាស់បានបង្គាប់លោកម៉ូសេ មិនឆ្លងកាត់ស្រុកនៃសាសន៍អេដំម ម៉ូអាប់ និង អាំម៉ូន ពីព្រោះពួកគេជាប់ខ្សែស្រឡាយនឹងសាសន៍អ៊ីស្រាអែល ។ អ៊ីស្រាអែលបានកាន់កាប់ទឹកដីទាំងនោះ ផ្នែកទឹកដីភាគខាងកើតទន្លេយ័រដាន់ ដែលបានកាន់កាប់ដោយសាសន៍អាំម៉ូន(មើល ខ.២៤ ៣:២) ។ *អញបានឱ្យ* មើលការពន្យល់ ៩,១៩ ។ ព្រះអង្គបានប្រទានឱ្យពូជរបស់អេសាវ (អ្នកស្រុកអេដំម) និងលោកឡុតនៅទឹកដី គឺសម្រាប់រស់នៅដូចជាព្រះបានឱ្យជនជាតិអ៊ីស្រាអែល នូវតំបន់កាន់កាប់ទឹកដីកាណាន ។
**២:៦,២៨** *ជាប្រាក់* មើលការពន្យល់ ១៤:២៥ ។
**២:៨** *អេឡាត និងអេស៊ាន–គេប៊ើរ* ជាបណ្ដាទីក្រុងដែលនៅភាគខាងលើនៃឈូងសមុទ្រអាកាបា ។ ផ្លូវ"អារ៉ាបា" (Arabah,ផ្លូវស្រុកវាល) គឺចេញពីផ្នែកខាងលើនៃឈូងសមុទ្រអាកាបា ឆ្ពោះទៅទិសខាងជើង ហើយទៅតំបន់ខាងកើតនៃស្រុកម៉ូអាប់ ។
**២:១០** *សាសន៍អ័ណាក់* សូមមើលការពន្យល់ ១:២៨ ។
**២:១១** *មនុស្សគួរឱ្យស្ញែងខ្លាច* មើលការពន្យល់ ៣:១១ ។
**២:១២** *សាសន៍ហូរី* សូមមើលការពន្យល់ លប ១៤:៦ ។ *ស្រុកដែលព្រះយេហូវ៉ាប្រទានឱ្យគេ* គឺ(១).នៅតំបន់ត្រើយម្ខាងនៃទន្លេយ័ដាន់(ការពន្យល់ ២:២៤–៣:២០) ឬ(២).ស្រុកកាណាន ឬក៏(៣).មើលពន្យល់ ១៤:១៤ ។
**២:១៣** *សេរេត* ជាខ្សែទឹកដ៏សំខាន់ដែលមានទឹកម្តងម្កាល ចុះទៅចុងខាងត្បូងនៃសមុទ្រស្លាប់ ពីទិសខាងកើតមក ហើយបង្កើតបានជាព្រំប្រទល់រវាងស្រុកអេដំម និងស្រុកម៉ូអាប់ ។
**២:១៤** *៣៨ឆ្នាំ* មើលការពន្យល់ ១:៣ ។

ជាស្រុករបស់ពួករេផែម[ក] ពួកគួរស្ញែងខ្លាចនោះបាននៅ
ស្រុកនោះកាលពីដើម ឯសាសន៍អាំម៉ូនហៅគេថា ជា
សាសន៍សាំស៊ូមីមវិញ [២១]គេជាសាសន៍មានគ្នាច្រើន ហើយ
មានមាឌធំខ្ពស់ដូចជាសាសន៍អ័ណាក់ដែរ[ខ] តែព្រះយេហូវ៉ា
ទ្រង់បានបំផ្លាញគេពីមុខសាសន៍អាំម៉ូនទៅ ហើយសាសន៍
អាំម៉ូនបានបណ្តេញគេចេញ ព្រមទាំងយកកន្លែងរបស់គេ
អាស្រ័យនៅផង [២២]ដូចជាទ្រង់បានធ្វើឱ្យពួកកូនចៅ
អេសាវដែលនៅស្រុកសៀរ[គ] កាលទ្រង់បានបំផ្លាញ
សាសន៍ហូរីពីមុខគេចេញ ហើយគេក៏បណ្តេញសាសន៍
នោះព្រមទាំងយកន្លែងរបស់គេនៅ ដរាបដល់សព្វថ្ងៃនេះ
ដែរ [២៣]នឹងសាសន៍អាវីម[ឃ]ទៀត ដែលនៅដោយភូមិៗ
រហូតដល់ក្រុងកាសា[ង]នោះ ក៏មានសាសន៍កាប់ថោរ[ច]
ដែលចេញពីស្រុកកាប់ថោរ[ឆ]មក បានបំផ្លាញគេទៅ ព្រម
ទាំងយកស្រុករបស់គេនៅផង) ។

## បរាជ័យរបស់ស្តេចស៊ីហុននៃក្រុងហែសបូន

[២៤]ចូរក្រោកឡើងធ្វើដំណើរឆ្លងស្ទឹងអើណូនទៅ[ជ]
មើល អញបានប្រគល់ស៊ីហុនជាសាសន៍អាម៉ូរី[ឈ] ស្តេចក្រុង
ហែសបូន នឹងស្រុកគេមកក្នុងកណ្តាប់ដៃឯងហើយ ចូរចាប់
តាំងយកស្រុកនោះចុះ ហើយច្បាំងនឹង[ញ]គេទៅ [២៥]នៅថ្ងៃ
នេះឯង អញនឹងចាប់តាំងបណ្តាលឱ្យអស់ទាំងសាសន៍
ដែលនៅក្រោមមេឃទាំងប៉ុន្មាន មានសេចក្តីភ័យញ័រ[ដ]
នឹងសេចក្តីកោតខ្លាច[ឋ]ដល់ឯង ដោយគេឮនិយាយពីឯង
ហើយគេនឹងញាប់ញ័រ[ឌ] ព្រមទាំងមានសេចក្តីថប់បារម្ភ
ដោយព្រោះឯង។

[២៦]គ្រានោះ អញបានចាត់សារពីទីរហោស្ថានក្តេម៉ូត[ឍ]
ទៅឯស៊ីហុន[ណ] ជាស្តេចក្រុងហែសបូន ដោយពាក្យមេត្រី[ត]
ថា [២៧]សូមឱ្យយើងខ្ញុំដើរកាត់ស្រុករបស់ទ្រង់ផង យើងខ្ញុំ
នឹងដើរតាមតែថ្នល់ធំប៉ុណ្ណោះ ឥតមានងាកបែរទៅខាង
ស្តាំឬខាងឆ្វេងឡើយ[ថ] [២៨]ឯអាហារនិងទឹកសំរាប់ឱ្យយើង
ខ្ញុំទទួលទាន[ទ] នោះត្រូវឱ្យទ្រង់លក់ឱ្យយើងខ្ញុំចុះ សូមតែឱ្យ
យើងខ្ញុំបានដើរ[ធ]កាត់ស្រុករបស់ទ្រង់ទៅ [២៩]ដូចជាពួកកូន
ចៅអេសាវដែលនៅស្រុកសៀរ និងពួកសាសន៍ម៉ូអាប់
នៅស្រុកអើរ បានបើកឱ្យខ្ញុំដែរ ទាល់តែខ្ញុំឆ្លងហួសទន្លេ
យ័រដាន់ ចូលទៅក្នុងស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃ
យើងខ្ញុំបានប្រទានមកយើងខ្ញុំ [៣០]តែស៊ីហុនជាស្តេចក្រុង
ហែសបូន មិនព្រមបើកឱ្យយើងដើរកាត់ស្រុកទ្រង់ទេ ដ្បិត
ព្រះយេហូវ៉ា[ន] ជាព្រះនៃឯង ទ្រង់បានបណ្តាលឱ្យស្តេចមាន
ព្រះទ័យ[ប] មានព្រះដំរិះរឹងទទឹង[ផ] ដើម្បីនឹងប្រគល់មកក្នុង
កណ្តាប់ដៃនៃឯង[ព] ដូចជាមានហើយសព្វថ្ងៃនេះ [៣១]រួច
ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអញថា មើល អញបានចាប់
តាំងប្រគល់ស៊ីហុន នឹងស្រុកគេមកឯងហើយ ដូច្នេះចូរ
ចាប់តាំងយកស្រុករបស់គេចុះ ដើម្បីឱ្យបានជាមរដក[ភ]
[៣២]នោះស៊ីហុននឹងបណ្តារាស្ត្រទាំងប៉ុន្មានក៏ចេញមកទាស់
នឹងយើង រួចច្បាំងគ្នា[ម]នៅត្រង់យ៉ាហាស់ [៣៣]តែព្រះយេហូវ៉ា
ជាព្រះនៃយើងរាល់គ្នា ទ្រង់បានប្រគល់[យ]ស្តេចមកយើង
ហើយយើងរាល់គ្នាក៏វាយទ្រង់[រ] នឹងពួកកូនចៅទ្រង់ព្រម
ទាំងរាស្ត្រទាំងអស់គ្នាទៅ [៣៤]យើងក៏ចាប់យកអស់ទាំងទី
ក្រុងរបស់ទ្រង់នៅគ្រានោះ ទាំងរំលាងគ្រប់ទីក្រុងទាំងមូល
[ល]ព្រមទាំងមនុស្សប្រុសស្រី និងកូនក្មេងផងគ្មានទុកណាមួយ
ឱ្យនៅសល់ឡើយ [៣៥]យើងបានយកតែហ្វូងសត្វ[វ] ទុកសំរាប់
ខ្លួនយើង ជាមួយនឹងរបឹប[ស] ពីអស់ទាំងក្រុងដែលយើងចាប់
យកនោះ [៣៦]ហើយចាប់តាំងពីក្រុងអារ៉ូអើរ[ហ] ដែលនៅមាត់

**២:២០** ក លប ១៤:៥
**២:២១** ខ ឧ.១០
**២:២២** គ លប ១៤:៦
**២:២៣** ឃ យស ១៣:៣ ១៨:២៣ ២ពវ ១៧:៣១ ង លប ១០:១៩ ច លប ១០:១៤ ឆ យរ ៤៧:៤ អម ៩:៧
**២:២៤** ជ ជន ២១:១៣–១៤ ពច ១១:១៣,១៨ ឈ ចទ ១:៧ ញ ចទ ៣:៦
**២:២៥** ដ លប ៣៥:៥ ចទ ១១:២៥ ឋ យស ២:៩,១១ ១រប ១៤:១៧ ២រប ១៤:១៤ ១៧:១០ ២០:២៩ អស ២:១៩ ១៣:១៣ ១៩:១៦ ឌ នក ១៥:១៤–១៦
**២:២៦** ឍ យស ១៣:១៨ ១រប ៦:៧៩ ណ ចទ ១:៤ ពច ១១:២១–២២ ត ចទ ២០:១០ ពច ២១:១៣ ២សយ ២០:១៩
**២:២៧** ថ ជន ២១:២១–២២
**២:២៨** ទ ចទ ២៣:៤ ធ ជន ២០:១៩
**២:៣០** ន ពច ១៤:៤ ១ពវ ១២:១៥ ប នក៤:២១ រម ៩:១៨ ផ នក ១៤:១៧ ព បទ ៣:៦៥ **២:៣១** ភ លប ១២:៧ **២:៣២** ម ជន ២១:២៣ **២:៣៣** យ នក ២៣:៣១ ចទ ៧:២ ៣១:៥ រ ជន ២១:២៤ **២:៣៤** ល ជន ២១:២ ចទ ៣:៦ ៧:២ ទដ ១០៦:៣៤ **២:៣៥** វ ចទ ៣:៧ ស លប ៣៤:២៩ ៤៩:២៧ **២:៣៦** ហ ជន ៣២:៣៤

**២:២០** *សាសន៍សាំស៊ូមីម* ពាក្យនេះប្រហែលសំដៅទៅលើពួកស៊ូស៊ីមក្នុង លប ១៤:៥ ។

**២:២៣** *សាសន៍អាវីម* អាចជាដើមកំណើតនៃពួកសាសន៍ភីលីស្ទីន (យស ១៣:៣) ។ *សាសន៍កាប់ថោរ* មើលការពន្យល់ លប ១០:១៤ ។

**២:២៤** *អើណូន* សូមមើល ជន ២១:១០–១៣ ។ *ស៊ីហុន . . . ហែសបូន* មើល ១:៤ និងការពន្យល់ ។

**២:២៦** *ទីរហោស្ថានក្តេម៉ូក* មានន័យថា "បណ្តាតំបន់ភាគខាងកើត"។

**២:៣០** *ព្រះនៃឯង ទ្រង់បានបណ្តាលឱ្យស្តេចមានព្រះទ័យ មានព្រះដំរិះរឹងទទឹង ដើម្បីនិងប្រគល់មកក្នុងកណ្តាប់ដៃនៃឯង* ជាញឹកញាប់ព្រះគម្ពីរសញ្ញាចាស់ច្រើនតែថា ព្រះទ្រង់បណ្តាលឱ្យហេតុការអ្វីមួយកើតឡើង គឺមិនបានថា មានកត្តារួមផ្សំដទៃទៀត ដែលដូច ជាស្ថានភាព ឬមនុស្សទេ ។ ស្តេចស៊ីហុនមានចេតនាមិនឱ្យពួកអ៊ីស្រាអែលធ្វើឆ្លងកាត់ តែទឹកដីរបស់ទ្រង់ គឺស្រេចតែព្រះអម្ចាស់ទ្រង់សម្រេច (មើល នក ៤:២១) ។

**២:៣២** *យ៉ាហាស* មើល ជន ២១:២៣ និងការពន្យល់ អស ១៥:៤ ។

**២:៣៤** *រំលាងគ្រប់ទីក្រុងទាំងមូល* ព្រះគម្ពីរភាសាហេព្រើបានប្រើពាក្យដែលមានន័យថា "បំផ្លាញគ្រប់មនុស្ស ឬអ្វីៗដែលអាចបំផ្លាញបាន ។ វត្ថុធ្វើពីមាស ប្រាក់ និងលង្ហិនមិនត្រូវបំផ្លាញទេ តែត្រូវរក្សាទុកថ្វាយព្រះអម្ចាស់វិញ ។ គ្រប់ទាំងជីវិតមនុស្ស ឬអ្វីៗដែលត្រូវបំផ្លាញគឺមានន័យថា ឱ្យព្រះហស្តទ្រង់ជាអ្នកសម្រេច ។ ជួនកាលព្រះទ្រង់ លើកលែងជីវិតសត្វស្រុក និងរបឹបផ្សេងទៀត ទុកសម្រាប់ជារង្វាន់ដល់ពួកទ័ពដែលបានធ្វើថ្វាយទ្រង់ (មើល ឧ.៣៥ ៣:៧ យស ៨:២) ។

**២:៣៦** *ក្រុងអារ៉ូអើរ* មើលការពន្យល់ អស ១៧:២ ។ *ស្រុកកាឡាត* មើល

ស្ទឹងអើណូន[ឃ] និងពីទីក្រុង១ដែលនៅច្រកភ្នំនោះ រហូតដល់
ស្រុកកាឡាត គ្មានក្រុងណាមួយដែលយើង ពុំអាចនឹងយក
បាននោះទេ ដ្បិតព្រះយេហូវ៉ាជាព្រះនៃយើងរាល់គ្នា ទ្រង់
បានប្រគល់[អ]ទាំងអស់មកយើង ៣៧មានតែស្រុករបស់ពួកកូន
ចៅអាំម៉ូនប៉ុណ្ណោះ[ក] ដែលឯងរាល់គ្នាមិនបានចូលទៅជិត
ឡើយ គឺជាស្រុកនៅក្បែរស្ទឹងយ៉ាបុក[ខ] និងទីក្រុងទាំងប៉ុន្មាន
ដែលនៅស្រុកភ្នំនោះ ព្រមទាំងកន្លែងណាដែលព្រះយេ
ហូវ៉ា[គ] ជាព្រះនៃយើងរាល់គ្នា បានហាមប្រាមនោះផង ។

## បរាជ័យរបស់ស្តេចអុកនៃស្រុកបាសាន

**៣** ១នោះយើងក៏បែរឡើង តាមផ្លូវទៅស្រុកបាសាន[ក]
ហើយអុក ជាស្តេចស្រុកបាសាន និងបណ្តារាស្ត្រទ្រង់ទាំង
អស់គ្នា ក៏ចេញមកទាស់នឹងយើង ហើយច្បាំងគ្នានៅត្រង់
អេទ្រី[ខ] ២ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអញថា កុំឱ្យខ្លាច[គ]
គេឡើយ ដ្បិតអញបានប្រគល់គេមកក្នុងកណ្តាប់ដៃឯង
ហើយ ព្រមទាំងរាស្ត្រទាំងប៉ុន្មាន និងស្រុករបស់គេផង ត្រូវ
ឱ្យឯងធ្វើដល់គេ ដូចជាបានធ្វើដល់ស៊ីហុន ជាស្តេចសាសន៍
អាម៉ូរី នៅក្រុងហែសបូនដែរ ៣ដូច្នេះព្រះយេហូវ៉ាជាព្រះ
នៃយើងរាល់គ្នា ទ្រង់ក៏ប្រគល់អុក ជាស្តេចស្រុកបាសាន
នោះ នឹងរាស្ត្រទាំងប៉ុន្មានមកក្នុងកណ្តាប់ដៃនៃយើងដែរ
ហើយយើងបានវាយពួកខាងទ្រង់[ឃ] ទាល់តែគ្មាននៅសល់១
ឡើយ[ង] ៤យើងចាប់យកអស់ទាំងទីក្រុងរបស់ទ្រង់នៅគ្រា
នោះ គ្មានទីក្រុងណាមួយដែលយើងមិនបានចាប់យកពីគេ
នោះទេ[ច] រាប់ទាំងអស់បានទីក្រុង៦០ គឺស្រុកអើកុបទាំងមូល
ដែលជានគរ[ឆ]របស់ស្តេចអុក នៅស្រុកបាសាន[ជ] ៥អស់ទាំង
ទីក្រុងទាំងនោះ សុទ្ធតែមានបន្ទាយមានកំផែងយ៉ាងខ្ពស់
ណាស់នៅព័ទ្ធជុំវិញ ព្រមទាំងទ្វារ និងរនុកផង ក៏ចាប់យក
ទីក្រុងឯទៀតជាច្រើន ដែលឥតមានកំផែងដែរ ៦យើងបាន
រំលាងទីក្រុងទាំងនោះអស់រលីងទៅ ដូចជាបានធ្វើដល់
ស៊ីហុនជាស្តេចក្រុងហែសបូនដែរ គឺបានរំលាង[ឈ]អស់
ទាំងទីក្រុងទាំងមូល ព្រមទាំងមនុស្សប្រុសស្រី និងកូនក្មេង
ផង ៧តែឯសត្វទាំងប៉ុន្មាន[ញ]និងរបឹបនៃទីក្រុងទាំងនោះ
យើងបានយកទុកសំរាប់ខ្លួនយើងវិញ ៨នៅគ្រានោះ យើង
បានយកស្រុកនោះពីអំណាចនៃស្តេចសាសន៍អាម៉ូរីទាំង២
អង្គ[ដ] ដែលនៅខាងកើតទន្លេយ័រដាន់ ចាប់តាំងពីស្ទឹង
អើណូនទៅដល់ភ្នំហើម៉ូន[ឋ] ៩(ឯភ្នំហើម៉ូននេះ ពួកសាសន៍
ស៊ីដូនគេហៅថាភ្នំស៊ីរានវិញ[ឌ] ហើយសាសន៍អាម៉ូរីគេហៅ
ថាភ្នំសេនារ)[ឍ] ១០គឺអស់ទាំងទីក្រុងនៅស្រុកវាល និងស្រុក
កាឡាតទាំងមូល ហើយស្រុកបាសានទាំងអស់ រហូតដល់
សាលកា[ណ]ហើយនិងអេទ្រី គឺជាទីក្រុងទាំងប៉ុន្មាននៅនគរ
របស់ស្តេចអុក ដែលនៅស្រុកបាសាន ១១(មានតែអុកជា
ស្តេចស្រុកបាសានទេ ដែលសល់ពីពួកមនុស្សគួរស្ញែងខ្លាច
នោះ[ត] មើល គ្រែរបស់ទ្រង់បានធ្វើពីដែក ឃើញមាននៅ
ក្រុងរ៉ាបាត[ថ]របស់ផងពួកកូនចៅអាំម៉ូន គ្រែនោះមាន
បណ្តោយ៩ហត្ថ ហើយទទឹង៤ហត្ថ តាមហត្ថរបស់មនុស្ស)។

## ការបែងចែកទឹកដី

១២នៅគ្រានោះ យើងបានចាប់យកស្រុកនោះ ទុកជាកេរ្តិ៍
អាកររបស់យើង អញបានឱ្យស្រុកនោះ ចាប់តាំងពីអារ៉ូ[ទ]
អើរ នៅមាត់ស្ទឹងអើណូន និងស្រុកភ្នំកាឡាត១ចំហៀង
ព្រម ទាំងទីក្រុងនៃស្រុកនោះទាំងប៉ុន្មានដល់ពួករូបេន និង
ពួកកាឌ់ ១៣ឯស្រុកកាឡាតដែលសល់ និងស្រុកបាសាន ជាន
គររបស់ស្តេចអុកទាំងអស់ នោះអញបានឱ្យដល់ពូជអំបូរ
ម៉ាន៉ាសេ[ធ]១ចំហៀង គឺជាស្រុកអើកុបទាំងមូល ដែលជា

**២:៣៦** ឡ ជន ៣២:៣៩ អ ទដ ៤៤:៣
**២:៣៧** ក ជន ២១:២៤ ខ លប ៣២:២២ គ ខ.១៨–១៩
**៣:១** ក ជន ៣២:១៩ ខ ជន ២១:៣៣
**៣:២** គ យស ១០:៨ ២ពវ ១៩:៦ អស ៧:៤
**៣:៣** ឃ ជន ២១:២៤ ង ជន ២១:៣៥
**៣:៤** ច ជន ២១:២៤ ឆ ខ.១៣ ជ ជន ២១:៣៣
**៣:៦** ឈ ចទ ២:២៤
**៣:៧** ញ ចទ ២:៣៥
**៣:៨** ដ ជន ៣២:៣៣ យស ១៣:៨–១២ ឋ ចទ ៤:៤៨ យស ១១:៣,១៧ ១២:១ ១៣:៥ ពច ៣:៣ ១រប ៥:២៣ ទដ ៤២:៦ ៨៩:១២ ១៣៣:៣ ៤:៨
**៣:៩** ឌ ទដ ២៩:៦ ឍ ១រប ៥:២៣ ៤:៨ អគ ២៧:៥
**៣:១០** ណ យស ១២:៥ ១រប ៥:១១
**៣:១១** ត លប ១៤:៥ ថ យស ១៣:២៥ ១៥:៦០ ២សយ ១១:១ ១២:២៦ ១៧:២៧ ១រប ២០:១ យរ ៤៩:២ អគ ២១:២០ ២៥:៥ អម ១:១៤ **៣:១២** ទ ចទ ២:៣៦ **៣:១៣** ធ ចទ ២៩:៨

ការពន្យល់ លប ៣១:២១ ។

**២:៣៧** *ស្ទឹងយ៉ាបុក* មើលការពន្យល់ លប ៣២:២២ ។

**៣:៣** *ទ្រង់ប្រគល់អុក ជាស្តេចស្រុកបាសាននោះ* ដូចនៅក្នុង ២:២៦–៣៧ ។ មើលក្នុង ១:៤ និងការពន្យល់ ។

**៣:៤** *ទីក្រុង៦០* គឺជា"បណ្តាទីក្រុងធំៗដែលមានកំផែង"(១ពវ ៤:១៣)។ គឺបង្ហាញពីទឹកដីដែលគ្រប់គ្រងសម្រាប់មនុស្សជាច្រើនរស់នៅ(មើល ខ.៥) ។ *ស្រុកអើកុប* ជាតំបន់មួយដែលពុំបានបញ្ជាក់ច្បាស់ក្នុងស្រុកបាសាន មើល ខ.១៣–១៤ ១ពវ ៤:១៣ ដែលនៅផ្នែកទិសឦសាន នៃសមុទ្រកាលីឡេ ។

**៣:៦–៧** សូមមើលការពន្យល់ ២:៣៤ ។

**៣:៨** *ភ្នំហើម៉ូន* មានកំពស់ជាង ២,៨០ គីឡូម៉ែត្រ មានកំពូងដណ្តប់ ដោយព្រឹលពេញមួយឆ្នាំ ហើយស្ថិតក្នុងចំណោមភ្នំសំខាន់ៗ និងស្រស់បំព្រងជាងគេនៅស្រុកល្បាណូន ។

**៣:៩** *ភ្នំស៊ីរាន* ជាឈ្មោះមួយទៀតរបស់ភ្នំហើម៉ូន ដែលមាននិយាយនៅក្នុងឯកសាររបស់ពួកកាណាន នៅសម័យលោកម៉ូសេ ។ *ភ្នំសេនារ* ក៏ជាឈ្មោះមួយទៀតរបស់ភ្នំហើម៉ូន ដែលមាននិយាយនៅក្នុងឯកសាររបស់សាសន៍អាសស៊ើរផងដែរ ។

**៣:១០** *សាលកា* គឺជាទីក្រុងមួយដែលជាព្រំប្រទល់ខាងកើតនៃស្រុកបាសាន (មើល យស ១៣:១១) ។

**៣:១១** *គ្រែ . . . ធ្វើពីដែក* គឺជាប្រភេទមឈូសបុរាណម្យ៉ាងដែលធ្វើពីថ្មបាសាល់ពណ៌ខ្មៅ ។ គេបានរកឃើញមឈូសថ្មប្រភេទនេះ នៅស្រុកបាសាន ដែលតាមព្រះគម្ពីរភាសារហេព្រើ គេជឿថា ជាមឈូសដែលធ្វើពីឈើលាយដែក(ការពន្យល់ យស ១៧:១៦)។ *ក្រុងរ៉ាបាតរបស់ផងពួកកូនចៅអាំម៉ូន* ក្រុងរ៉ាបាតគឺជារាជធានីរបស់សាសន៍អាំម៉ូន នៅសម័យបុរាណ (សូមមើល អម ១:១៣–១៤) សព្វថ្ងៃមានឈ្មោះថា ទីក្រុងអាំម៉ានជារាជធានីរបស់រាជាណាចក្រយ័រដាន់ ។

**៣:១២–២០** មើល ជន ៣២ ៣៤:១៣–១៥ និងការពន្យល់ ។

ស្រុកបាសានផង (ស្រុកនោះក៏ហៅជាស្រុករបស់ពួករេ
ផែម[ន] ១៤យ៉ាអ៊ារ[ប]ជាកូនម៉ាន៉ាសេ បានចាប់យកស្រុកអើកុប
ទាំងមូល រហូតដល់ព្រំស្រុកកេស៊ូរី និងស្រុកម៉ាកាធីផង[ផ]
រួចគាត់ហៅស្រុកបាសាននោះ តាមឈ្មោះ[ព]របស់ខ្លួន គឺជា
ហាវ៉ុត-យ៉ាអ៊ារ ដរាបដល់សព្វថ្ងៃនេះ) ១៥ហើយអញបាន
ឱ្យស្រុកកាឡាតដល់ម៉ាគារ[ភ] ១៦ឯពួករូបេន ហើយនិងពួក
កាឌ់ នោះអញបានឱ្យស្រុកដល់គេ ចាប់តាំងពីស្រុកកាឡាត
រហូតដល់ស្ទឹងអើណូន ដែលមានព្រំខណ្ឌនៅជាកណ្ដាល
ស្ទឹងនោះ ហើយរហូតដល់ស្ទឹងយ៉ាបុក[ម] ជាព្រំស្រុកនៃពួក
កូនចៅអាំម៉ូន ១៧ព្រមទាំងស្រុកវាលដែលមានទន្លេយ័រដាន់
ទុកជាព្រំខណ្ឌ[យ] ចាប់តាំងពីសមុទ្រគេនេសារ៉ែត[រ] រហូត
ដល់សមុទ្រអំបិល[ល]ដែលនៅស្រុកវាល[វ] ត្រង់ជើងភ្នំពីសកា
ខាងកើត ។

១៨នៅគ្រានោះ អញបានបង្គាប់ឯងរាល់គ្នាថា ព្រះ
យេហូវ៉ាជាព្រះនៃឯង ទ្រង់បានប្រទាន[ស]ស្រុកនេះដល់ឯង
ទុកជាកេរ្តិ៍អាករ ដូច្នេះត្រូវឱ្យឯងរាល់គ្នា ដែលថ្មើកចំបាំង
ពាក់គ្រឿងសស្ត្រាវុធ ឆ្លងនាំមុខពួកកូនចៅអ៊ីស្រាអែល[ហ]
ជាបងប្អូនឯងទៅ ១៩តែឯប្រពន្ធ[ឡ]កូន និងហ្វូងសត្វ[អ]របស់
ឯង នោះត្រូវទុកឱ្យនៅក្នុងទីក្រុងទាំងប៉ុន្មាន ដែលអញបាន
ឱ្យដល់ឯងវិញ (ដ្បិតអញដឹងថា ឯងរាល់គ្នាមានហ្វូងសត្វ
ច្រើន) ២០ទាល់តែព្រះយេហូវ៉ាទ្រង់បានឱ្យពួកបងប្អូនឯង
បានសេចក្ដីសំរាកដូចជាឯងដែរ ព្រមទាំងចាប់យកស្រុក
ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានប្រទានឱ្យគេនៅ
ខាងនាយទន្លេយ័រដាន់ រួចសឹមឯងរាល់គ្នាត្រឡប់មកនៅ
ក្នុងស្រុកជាកេរ្តិ៍អាករឯងរៀងខ្លួន ដែលអញក៏បានឱ្យដល់
ឯងរាល់គ្នាចុះ ។

## បម្រាមមិនឱ្យលោកម៉ូសេឆ្លងទន្លេយ័រដាន់

២១ហើយនៅវេលានោះ អញក៏បានប្រាប់ដល់យ៉ូស្វេថា
ភ្នែករបស់អ្នកបានឃើញអស់ទាំងការ ដែលព្រះយេហូវ៉ា
ជាព្រះនៃអ្នក ទ្រង់បានធ្វើដល់ស្ដេចទាំង២នេះហើយ ទ្រង់
ក៏នឹងធ្វើដូច្នេះដល់គ្រប់ទាំងនគរដែលអ្នកនឹងឆ្លងចូលទៅ
នោះដែរ ២២មិនត្រូវឱ្យអ្នកខ្លាច[ក]គេឡើយ[ខ]ដ្បិតព្រះយេហូវ៉ា
ជាព្រះនៃអ្នក ទ្រង់នឹងច្បាំង[គ]ជំនួសអ្នក ។

២៣នៅគ្រានោះ អញបានទូលអង្វរ[ឃ]ដល់ព្រះយេហូវ៉ាថា
២៤ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់អើយ ទ្រង់បានចាប់តាំង
សំដែង ឱ្យអ្នកបំរើរបស់ទ្រង់ឃើញតេជានុភាព[ង]នៃទ្រង់
និងព្រះហស្តដ៏មានព្រះចេស្តាផង ដ្បិតតើមានព្រះឯណា[ច]
នៅលើស្ថានសួគ៌ឬនៅផែនដី ដែលអាចនឹងធ្វើឱ្យដូចការ[ឆ]
ទ្រង់បានធ្វើនោះ ឬតាមឫទ្ធិបារមីរបស់ទ្រង់ទាំងប៉ុន្មាន
បាន[ជ] ២៥ទូលបង្គំសូមអង្វរដល់ទ្រង់ សូមឱ្យទូលបង្គំឆ្លងទៅ
ឱ្យបានឃើញស្រុកល្អ[ឈ] នៅខាងនាយទន្លេយ័រដាន់ផង គឺជា
ស្រុកភ្នំល្អនោះ ព្រមទាំងភ្នំល្បាណូនដែរ[ញ] ២៦តែព្រះយេ
ហូវ៉ាទ្រង់មានសេចក្ដីក្រោធនិងអញ ដោយព្រោះឯងរាល់
គ្នា ហើយទ្រង់មិនព្រម[ដ]តាមអញទេ ដោយបន្ទូលថា ណ្ហើយ
កុំឱ្យនិយាយនឹងអញពីរឿងនោះទៀតឡើយ ២៧ចូរឡើងទៅ
លើកំពូលភ្នំពីសកា[ឋ]នេះ រួចក្រឡេកភ្នែកមើលទៅទិស
ខាងលិច ខាងជើង ខាងត្បូង និងខាងកើតទៅ[ឌ] ហើយ
ពិចារណា មើលតែនឹងភ្នែករបស់ឯងប៉ុណ្ណោះ ដ្បិតមិនត្រូវ

**៣:១៣** ន លប ១៤:៥
**៣:១៤** ប ជន ៣២:៤១ ផ យស ១២:៥ ១៣:១១,១៣ ២សយ ១០:៦ ២៣:៣៤ ២ពវ ២៥:២៣ ១រប ៤:១៩ យរ ៤០:៨ ព យស ១៩:៤៧ ទដ ៤៩:១១
**៣:១៥** ភ លប ៥០:២៣ ជន ៣២:៣៩–៤០
**៣:១៦** ម ជន ២១:២៤
**៣:១៧** យ ២សយ ២:២៩ ៤:៧ អគ ៤៧:៨ រ ជន ៣៤:១១ ល លប ១៤:៣ វ ចទ ១:១
**៣:១៨** ស យស ១:១៣ ហ ជន ៣២:១៧
**៣:១៩** ឡ យស ១:១៤ អ ជន ៣២:១៦
**៣:២២** ក ចទ ១:២៩ ខ ចទ ៧:១៨ ២០:១ ៣១:៦ ២រប ៣២:៨ ទដ ២៣:៤ អស ៤១:១០ គ នក ១៤:១៤
**៣:២៣** ឃ ចទ ១:៣៧ ៣១:២ ៣២:៥២ ៣៤:៤ **៣:២៤** ង ចទ ៥:២៤ ១១:២ ៣២:៣ ច នក ៨:១០ ឆ ទដ ៧១:១៦ ១០៦:២ ១:៧ យស ១:៤ ៩:១ ១១:១៧ ១២:៧ ១៣:៥ ពច ៣:៣ ៩:១៥ ១ពវ ៤:៣៣ ១៤៥:១២ ១៥០:២ ជ ២សយ ៧:២២
**៣:២៥** ឈ ចទ ៤:២២ ញ ចទ **៣:២៦** ដ ខ.២៧ ចទ ១:៣៧ ៣១:២ **៣:២៧** ឋ ជន ២១:២០ ឌ លប ១៣:១៤

**៣:១៤** *យ៉ាអ៊ារ . . . ហាវ៉ុត-យ៉ាអ៊ារ* មើលការពន្យល់ ពច ១០:៣ ។ *ស្រុកកេស៊ូរី និងស្រុកម៉ាកាធី* គឺជានគរពីរតូចៗ បើធៀបនឹងនគរផ្សេង ។ តំបន់កេស៊ូរីស្ថិតនៅខាងកើតសមុទ្រកាលីឡេ ចំណែកស្រុកម្អាកាស្ថិតនៅខាងកើតតំបន់មេរ៉ុម(មើល យស ១១:៥)។

**៣:១៥** *ម៉ាគារ* សូមមើលការពន្យល់ លប ៥០:២៣ ។

**៣:១៧** *សមុទ្រគេនេសារ៉ែត* មើលការពន្យល់ មក ១:១៦ ។ ពាក្យ"គីននរ" ជាភាសាហេព្រើរមានន័យថា "ស៊ុង" គឺសមុទ្រកាលីឡេជាបឹងដែលមានរាងដូចស៊ុង ។

**៣:១៨** *ឯងរាល់គ្នា* សំដៅលើពូជអំបូររូបេន និងកាឌ់ និងពូជអំបូរពួកម៉ាន៉ាសេមួយចំហៀង ។

**៣:២០** *សំរាក* គឺមានន័យថា ស្ថិតក្នុងស្ថានភាពសុខសាន្ត គ្មានគំរាមកំហែងឬគៀបសង្កត់ពីបរទេស ហើយពួកគេគឺជាគ្មានជម្លោះផ្ទៃក្នុង ភាពអត់ឃ្លានឬសេចក្ដីមហន្តរាយឡើយ(មើល ១២:៩-១០ ២៥:១៩ មើលការពន្យល់ យស ១:១៣ ១ពវ ៥:៤ ហព ៤:១-១១ ផងដែរ) ។

**៣:២២** *ជាព្រះនៃអ្នកផ្ទាល់* ការពិពណ៌នាអំពីការចូលកាន់កាប់ទឹកសន្យាបាននិយាយសង្កត់ធ្ងន់អំពីសេចក្ដីពិតថា បើគ្មានជំនួយពីព្រះអម្ចាស់ទេ នោះជ័យជម្នះរបស់ពួកអ៊ីស្រាអែល នឹងមិនអានកើតមានបានឡើយ ព្រោះមានតែព្រះចេស្ដានៃទ្រង់ប៉ុណ្ណោះដែលជួយឱ្យពួកគេទទួលជោគជ័យ ។ លោកម៉ូសេបានប្រើសេចក្ដីធានានេះ ដើម្បីពង្រឹងការប្ដេជ្ញាចិត្ត និងសេចក្ដីជំនឿរបស់ពួកគេ(សូមមើល ១:៣០ ២:២១-២៣,៣១ ២០:៤)។

**៣:២៣-២៥** នៅក្នុងវគ្គនេះ លោកម៉ូសេបានទូលអង្វរជាលើកចុងក្រោយសូមការអនុញ្ញាតិចូលទឹកដីសន្យា(មើល ១:៣៧ និងការពន្យល់ ៣១:២)។

**៣:២៦** *ដោយព្រោះឯងរាល់គ្នា* មើលការពន្យល់ ១:៣៧ ។

**៣:២៧** *ចូរឡើងទៅលើភ្នំពីសកា* លោកម៉ូសេបានធ្វើការនេះ បន្ទាប់ពីបានកាត់ស្រាយក្រឹត្យវិន័យដល់សាសន៍អ៊ីស្រាអែល ដើម្បីឱ្យជាតិសាសន៍មួយនេះមានការរៀបចំ នៅទឹកដីសន្យាជានិរន្ត(សូមមើល ២៣:៤៨-៥២ ៣៤:១-

ឱ្យឯងឆ្លង[ឈ]ទន្លេយ័រដាន់នេះទៅទេ[ណ] ២៨ត្រូវឱ្យបង្គាប់[ត]
យ៉ូស្វេវិញ ព្រមទាំងកំឡាចិត្ត[ថ]គាត់ ហើយចំរើនកំឡាំងដល់
គាត់ផង ដ្បិតត្រូវឱ្យគាត់ឆ្លងនាំមុខបណ្ដាជនទាំងនេះទៅ[ទ]
ឱ្យគេបានទទួលស្រុក ដែលឯងនឹងមើលឃើញនោះ ទុកជា
មរដករបស់គេ ២៩ដូច្នេះយើងរាល់គ្នាក៏នៅតែក្នុងច្រកភ្នំ
ទល់មុខនឹងបេត-ពេអរទៀត[ធ]។

## ការបង្គាប់ឱ្យស្ដាប់បង្គាប់

**៤** ១ឥឡូវនេះ ឱពួកអ៊ីស្រាអែលអើយ ចូរស្ដាប់អស់ទាំង
ច្បាប់[ក] និងបញ្ញត្តិ ដែលអញបង្រៀន[ខ]ដល់ឯងរាល់គ្នា
ហើយឱ្យប្រព្រឹត្តតាមចុះ ដើម្បីឱ្យបានរស់នៅ[គ] ហើយឱ្យបាន
ចូលទៅទទួលយកស្រុក ដែលព្រះយេហូវ៉ាជាព្រះនៃពួក
ឰយុកោឯង ទ្រង់ប្រទានមក ២មិនត្រូវឱ្យឯងរាល់គ្នាបន្ថែម
បញ្ចូល[ឃ]អ្វីៗក្នុងសេចក្ដីទាំងប៉ុន្មាន ដែលអញបង្គាប់ដល់
ឯង ឬកាត់ចោល[ង]អ្វីណាមួយឡើយ ដើម្បីឱ្យឯងរាល់គ្នា
បានកាន់តាម[ច] អស់ទាំងបញ្ញត្តិ[ឆ]ផងព្រះយេហូវ៉ា ជាព្រះនៃ
ឯង ដែលអញបង្គាប់មកឯងនេះ ៣ភ្នែកឯងរាល់គ្នាបាន
ឃើញការ ដែលព្រះយេហូវ៉ាទ្រង់ធ្វើ ដោយព្រោះដំណើរ
ព្រះបាល-ពេអរ[ជ] ដ្បិតអស់អ្នកណាដែលបានតាមព្រះបាល
-ពេអរ នោះព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានបំផ្លាញ
គេពីពួកឯងចេញ ៤តែពួកឯងរាល់គ្នា ដែលបាននៅជាប់
នឹងព្រះយេហូវ៉ា ជាព្រះនៃឯង នោះបានរស់នៅដរាបដល់
សព្វថ្ងៃនេះវិញ ៥មើល អញបានបង្រៀន[ឈ]ច្បាប់ហើយនិង
បញ្ញត្តិ[ញ]ដល់ឯងរាល់គ្នា តាមដែលព្រះយេហូវ៉ា ជាព្រះនៃ
អញបានបង្គាប់មក[ដ] ដើម្បីឱ្យឯងបានប្រព្រឹត្តតាម នៅក្នុង
ស្រុកដែលឯងត្រូវចូល[ឋ]ទៅទទួលយក ៦ដូច្នេះចូរឱ្យឯង
រាល់គ្នាកាន់ហើយប្រព្រឹត្តតាម[ឌ]ចុះ ដ្បិតនេះនឹងបានជា
ប្រាជ្ញា[ឍ] ហើយជាយោបល់ដល់ឯងរាល់គ្នា នៅភ្នែកនៃអស់
ទាំងសាសន៍ ដែលនឹងឮថ្លែងពីបញ្ញត្តិច្បាប់ទាំងប៉ុន្មាននេះ
ហើយគេនឹងនិយាយថា ប្រាកដជាសាសន៍នេះមានប្រាជ្ញា
និងយោបល់ពិត[ណ] ៧ដ្បិតតើមានសាសន៍ដ៏ធំណាមួយ[ត] ដែល
មានព្រះគង់នៅជិតគេ[ថ] ដូចជាព្រះយេហូវ៉ា ជាព្រះនៃយើង
ទ្រង់គង់នៅជិត ក្នុងកាលដែលយើងអំពាវនាវរកទ្រង់នោះ
៨ហើយតើមានសាសន៍ដ៏ធំណាមួយ ដែលមានច្បាប់ និង
បញ្ញត្តិ[ទ]ដ៏ត្រឹមត្រូវឱ្យដូចជាក្រិត្យព្រះវិន័យនេះ ដែលអញ
ដាក់នៅមុខឯងរាល់គ្នានៅថ្ងៃនេះដូច្នេះ ។
៩ប៉ុន្តែត្រូវឱ្យឯងរាល់គ្នាប្រយ័ត្ន[ធ]ខ្លួន ហើយរក្សាចិត្តឱ្យ
មែនទែន ក្រែងភ្លេចអស់ទាំងការ ដែលភ្នែកឯងបាន
ឃើញ ហើយក្រែងនៅក្នុងជីវិតឯងការទាំងនោះបានឃ្លាត
ចេញពីចិត្តឯងទៅ ត្រូវឱ្យឯងប្រាប់[ន]ពីការទាំងនោះដល់កូន
ចៅឯង[ប]ឱ្យដឹងតរៀងទៅវិញ ១០គឺពីថ្ងៃដែលឯងបានឈរ
នៅចំពោះព្រះយេហូវ៉ាជាព្រះនៃឯង ត្រង់ភ្នំហោរែប[ផ] ក្នុង
កាលដែលទ្រង់មានបន្ទូលមកអញថា ចូរប្រមូលពួកបណ្ដា
ជនមកឯអញ នោះអញនឹងឱ្យគេឮអស់ទាំងពាក្យរបស់អញ
ដើម្បីឱ្យគេរៀន[ព]ឱ្យចេះកោតខ្លាច[ភ]ដល់អញ នៅគ្រប់១ជីវិត
ដែលគេរស់នៅលើផែនដី[ម] ហើយឱ្យគេបានបង្រៀន[យ]ដល់
កូនចៅគេថែមទៀត ១១នោះឯងរាល់គ្នាបានចូលមកឈរ
នៅជិតជើងភ្នំ[រ] ហើយភ្នំក៏ឆេះឡើងជាភ្លើង[ល] នាំឱ្យស្រអាប់
ពេញផ្ទៃមេឃ ហើយក៏មានពពក និងងងឹតសូន្យសុង
ផង[វ] ១២រួចព្រះយេហូវ៉ាទ្រង់មានបន្ទូល[ស]មកឯងរាល់គ្នាពី

**៣:២៧** ឈ ឧ.២៦ ជន ២០:១២ ចទ ៣២:៥២ ណ ជន ២៧:១២ **៣:២៨** ត ជន ២៧:១៨-២៣ ថ ចទ ៣១:៧ ទ ចទ ១:៣៨ ៣១:៣,២៣ **៣:២៩** ធ ជន ២៣:២៨ ចទ ៤:៤៦ ៣៤:៦ យស ១៣:២០ **៤:១** ក លវ ១៨:៤ ខ ចទ ១:៣ គ លប ១៨:៥ ចទ ៣០:១៥-២០ រម ១០:៥ **៤:២** ឃ ចទ ១២:៣២ យស ១:៧ សភ ៣០:៦ វវ ២២:១៨-១៩ ង យរ ២៦:២ ច លវ ២២:៣១ ឆ ចទ ១០:១២-១៣ សស ១២:១៣ **៤:៣** ជ ជន ២៥:១-៩ ទដ ១០៦:២៨ **៤:៥** ឈ ទដ ៧១:១៧ ១១៩:១០២ យរ ៣២:៣៣ ញ នក ១៨:២០ ដ លវ ២៧:៣៤ ឋ អរ ៩:១១ **៤:៦** ឌ ចទ ២៩:៩ ១ពវ ២:៣ ឍ ចទ ៣០:១៩-២០ ៣២:៤៦-៤៧ ទដ ១៩:៧ ១១៩:៩៨ សភ ១:៧ ២ធថ ៣:១៥ ណ យប ១:១ ២៨:២៨ ទដ ១១១:១០ សភ ២:៥ ៣:៧ ៩:១០ សស ១២:១៣ អគ ៥:៥ **៤:៧** ត ខ.៣២-៣៤ ២សយ ៧:២៣ ថ ជន ២៣:២១ ទដ ៤៦:១ កច១៧:២៧ **៤:៨** ទ ទដ ៨៩:១៤ ៩៧:២ ១១៩:៧, ៦២ ១៤៤,១៦០,១៧២ រម ៣:២ **៤:៩** ធ នក ២៣:១៣ ន លប ១៤:១៤ ១៨:១៩ ចទ ៦:២០-២៥ អភ ៦:៤ ប នក ១០:២**៤:១០** ផ នក ៣:១ ព ចទ ១៤:២៣ ១៧:១៩ ៣១:១២-១៣ ទដ ២:១១ ១១១:១០ ១៤៧:១១ អស ៨:១៣ យរ ៣២:៤០ ភ នក ២០:២០ ម ចទ ១២:១ យ ខ.៩ **៤:១១** រ នក ៣:១ ១៩:១៧ ល នក ១៩:១៨ វ នក ១៩:៩ ទដ ១៨:១១ ៩៧:២ **៤:១២** ស នក ២០:២២ ចទ ៥:៤,២២ មថ ៣:១៧ ហព ១២:១៩

៦)។ *ភ្នំពីសកា* មើលការការពន្យល់ ខ.១៧ ។ *មើលទៅទិសខាងលិចខាងជើងខាងត្បូង និងកើត* លោកម៉ូសេនឹងទឹកដីសន្យាទទួលមរដក តាមរយៈពូជរបស់គាត់ គឺដូចលោកអ័ប្រាហាំដែរ (មើល លប ១៣:១៤) ។

**៣:២៨** *បង្គាប់យ៉ូស្វេ* មើល ៣១:៧-៨ ។

**៣:២៩** *បេត-ពេអរ* មានន័យថា "ផ្ទះ ឬទីបរិសុទ្ធរបស់ព្រះពេអរ" គឺទំនងសំដៅទៅលើកន្លែងថ្វាយបង្គំព្រះបាល-ពេអរ (ជន ២៣:២៨ ២៥:៣,៥)។

**៤:១** *ឱពួកអ៊ីស្រាអែលអើយ ចូរស្ដាប់* ខ្លឹមសារជាចម្បងនៃព្រះគម្ពីរចោទិ-យកថា (មើល ៥:១ ៦:៣-៤ ៩:១ ២០:៣)) និងកណ្ឌនៃព្រះគម្ពីរសញ្ញាចាស់ផ្សេងទៀត (ការពន្យល់ ៦:៤-៩) គឺច្រើនតែនិយាយអំពីការត្រាសហៅរបស់ព្រះអម្ចាស់ ឱ្យរាស្ត្រទ្រង់ស្ដាប់ព្រះសៀង ហើយធ្វើតាម បង្គាប់ទ្រង់ ។

**៤:២** *មិនត្រូវឱ្យឯងរាល់គ្នាបន្ថែម* ការបើកសម្ដែងដែលព្រះទ្រង់បានផ្ដល់ឱ្យ គឺគ្រប់គ្រាន់ល្មមហើយ ។ ពួកគេត្រូវស្ដាប់តាមគ្រប់ពាក្យរបស់ទ្រង់ ហើយការបន្ថែមបន្ថយ ឬធ្វើអ្វីដែលប្រាសចាកនឹងព្រះបន្ទូលទ្រង់ គឺមិនអាចរួចទោសបានឡើយ (១២:៣២ សភ ៣០:៦ កទ ៣:១៥ វវ ២២:១៨-១៩)។

**៤:៤** *នៅជាប់* មើលការពន្យល់ ១០:២០ ។

**៤:៧** *គង់នៅជិតក្នុងកាលដែលយើងអំពាវនាវរកទ្រង់នោះ* ពួកអ៊ីស្រាអែលមានឯកសិទ្ធិចូលចំពោះទ្រង់ ដោយការអធិស្ឋានជានិច្ច ។ រោងឧបោសថដែលនៅកណ្ដាលចំណោមពួកគេ និងសរសរពពកដែលនៅពីលើរោងនោះ គឺជានិមិត្តរូបបញ្ជាក់ពីព្រះវត្តមានទ្រង់នៅទីនោះ (មើល នក ៤០:៣៤-៣៨ ជន ២៣:២១)។

**៤:៩** *ប្រាប់ពីការទាំងនោះដល់កូនចៅឯង* មើល ខ.១០ ៦:៧ ១១:១៩ ទដ ៧៨:៤-៨ ធៀបនឹង នក ១២:២៦-២៧ ។

កណ្ដាលភ្លើងនោះ ឯងរាល់គ្នាក៏បានឮព្រះសូរសៀងនៃ
ព្រះបន្ទូលនោះ តែមិនឃើញរូបអង្គណាសោះ[ហ] គ្រាន់តែឮ
សំឡេងប៉ុណ្ណោះ[ឡ] ១៣ទ្រង់បានមានបន្ទូលប្រាប់ដល់ឯង
រាល់គ្នាពីសេចក្ដីសញ្ញារបស់ទ្រង់[អ] ដែលទ្រង់បានបង្គាប់ឱ្យ
ឯងរាល់គ្នាប្រព្រឹត្តតាម គឺជាក្រិត្យទាំង១០ប្រការ[ក] ហើយ
ទ្រង់ក៏ចារឹកកត់ក្រិត្យទាំងនោះ ចុះនៅបន្ទះថ្ម២ផ្ទាំង ១៤នៅ
វេលានោះ ព្រះយេហូវ៉ាទ្រង់បានបង្គាប់មកអញ ឱ្យ
បង្រៀនអស់ទាំងច្បាប់និងបញ្ញត្តិ[ខ]ដល់ឯង ដើម្បីឱ្យបាន
ប្រព្រឹត្តតាមនៅក្នុងស្រុក ដែលឯងនឹងឆ្លងចូលទៅទទួល
យកនោះ ។

## បម្រាមចំពោះការថ្វាយបង្គំរូបព្រះ

១៥ដូច្នេះចូរឯងរាល់គ្នាប្រយ័ត្នខ្លួនឱ្យមែនទែន[គ] ដ្បិតឯង
មិនបានឃើញរូបអង្គ[ឃ]បែបយ៉ាងណា នៅថ្ងៃដែលព្រះយេ
ហូវ៉ាទ្រង់បានមានបន្ទូលមកឯង ពីកណ្ដាលភ្លើងនៅភ្នំហោ
រែប[ង]នោះទេ ១៦ក្រែងឯងរាល់គ្នាបង្ខូចខ្លួន[ច] ដោយឆ្លាក់ធ្វើ
រូបមានរាង[ឆ]ដូចជាអង្គណា១ផង ទោះជាប្រុសឬស្រីក្តី ១៧ឬ
ជារូបសត្វណាដែលនៅលើផែនដី ឬជារូបសត្វណាដែល
ហើរនៅលើអាកាស[ជ] ១៨ឬរូបសត្វណាដែលលូនវារនៅដី
ឬរូបត្រីណាដែលនៅក្នុងទឹកក្តី ១៩ហើយក្រែងឯងរាល់គ្នា
ងើបភ្នែក មើលទៅលើមេឃវេលាណាឃើញថ្ងៃ[ឈ] ខែ និង
អស់ទាំងផ្កាយ[ញ] គឺគ្រប់ទាំងរបស់ដែលមានជាបរិបូរនៅ
លើមេឃ[ដ] នោះឯងរាល់គ្នាមានសេចក្ដីល្បួង[ឋ]ប្រទាញ
ចេញទៅថ្វាយបង្គំ[ឌ] ហើយគោរពប្រតិបត្តិដល់របស់ទាំង
នោះ ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានប្រទានមក
ឱ្យគ្រប់ទាំងសាសន៍ នៅក្រោមផ្ទៃមេឃវិញ ២០តែព្រះ
យេហូវ៉ាបាននាំយកឯង ចេញពីគុករំលាយដែក[ឍ] នៅស្រុក
អេស៊ីព្ទមក[ណ] ដើម្បីឱ្យបានធ្វើជារាស្ត្រដ៏ជាមរដកទ្រង់[ត] ដូច
ជាសព្វថ្ងៃនេះ ។

**៤:១២** ហ យហ ៥:៣៧ ឡ នក ១៩:៩ **៤:១៣** អ ចទ ៩:៩ រម ៩:៤ ក នក ២៤:១២ **៤:១៤** ខ នក ២១:១ **៤:១៥** គ ឃ យស ២៣:១១ មឡ ២:១៥ ង អស ៤០:១៨ នក ៣:១ ៤១:២២-២៤ **៤:១៦** ច លប ៦:១១-១២ ចទ ៩:១២ ៣១:២៩ ៣២:៥ ពច ២:១៩ ឆ នក ២០:៤-៥ រម ១:២៣ **៤:១៧** ជ រម ១:២៣ **៤:១៩** ឈ ចទ ១៧:៣ ២ពវ ២៣:១១ យប ៣១:២៦ យរ ៨:២ ៤៣:១៣ អក ៨:១៦ ញ លប ១:១៦ ដ លប ២:១ ៣៧:៩ រម ១:២៥ ឋ ចទ ១៣:៥ ឌ ជន ២៥:៣ **៤:២០** ឍ នក ១:១៣ ណ នក ៣:១០ ត លប ១៧:៧ នក ៨:២២ ៣៤:៩ ទត ២:១៤ **៤:២១** ថ ជន ២០:១២ ចទ ១:៣៧ **៤:២២** ទ ជន ២៧:១៣-១៤ ធ ចទ ៣:២៥

២១ព្រះយេហូវ៉ាទ្រង់ក៏ខ្ញាល់នឹងអញ[ថ] ដោយព្រោះឯង
រាល់គ្នាដែរ ហើយទ្រង់ស្បថមិនឱ្យអញឆ្លងទន្លេយ័រដាន់
ចូលទៅក្នុងស្រុកល្អ ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់
ប្រទានមកទុកជាមរដករបស់ឯងនោះទេ ២២គឺអញត្រូវ
ស្លាប់នៅស្រុកនេះ[ទ] អញមិនត្រូវឆ្លងទន្លេយ័រដាន់នេះទៅ
ឡើយ តែឯងរាល់គ្នានឹងឆ្លងទៅ ទទួលយកស្រុកល្អនោះ
វិញ[ធ] ២៣ដូច្នេះចូរប្រយ័ត្នខ្លួនចុះ ក្រែងភ្លេចសេចក្ដីសញ្ញា[ន]
ផងព្រះយេហូវ៉ា ជាព្រះនៃឯង ដែលទ្រង់បានតាំងនឹងពួក
ឯង រួចងាកបែរទៅឆ្លាក់ធ្វើរូប[ប]មានរាងដូចរបស់យ៉ាង
ណា ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់បានហាមប្រាម
មិនឱ្យធ្វើ ២៤ដ្បិតព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ជាភ្លើង
ឆេះបន្សុស[ផ] គឺជាព្រះប្រចណ្ឌ[ព] ។
២៥កាលណាបាននៅស្រុកនោះជាយូរអង្វែង ព្រមទាំង
បង្កើតកូនចៅ ហើយបង្ខូចខ្លួន[ភ]ទៅជាឆ្លាក់ធ្វើរូប[ម]មានរាង
ដូចរបស់ណាមួយ ក៏ប្រព្រឹត្តការអ្វីដែលអាក្រក់[យ]នៅព្រះ
នេត្រព្រះយេហូវ៉ាជាព្រះនៃឯង ជាការដែលបណ្ដាលឱ្យ
ទ្រង់ខ្ញាល់ឡើង ២៦នោះអញអាងដល់ស្ថានសួគ៌ ហើយនិង
ផែនដី ឱ្យធ្វើជាទីបន្ទាល់[រ]ទាស់នឹងឯងរាល់គ្នា[ល]នៅថ្ងៃនេះ
ថា បន្តិចទៀត ឯងរាល់គ្នាត្រូវវិនាសអស់រលីង[វ] ចេញពី
ស្រុកដែលឯងឆ្លងទន្លេយ័រដាន់ ចូលទៅទទួលយកនោះ ជា
មិនខាន និងធ្វើឱ្យនៅយូរអង្វែងតទៅទៀតមិនបាន គឺនឹង
ត្រូវវិនាសទៅទាំងអស់គ្នាវិញ ២៧ព្រះយេហូវ៉ាទ្រង់នឹង
កំចាត់កំចាយ[ស]ឯងរាល់គ្នាទៅ ឱ្យនៅគ្រប់ទាំងសាសន៍ ឯង

**៤:២៣** ន ៥.៩ ប នក ២០:៤ **៤:២៤** ផ នក ១៥:៧ ១៩:១៨ ហព ១២:២៩ ព នក ២០:៥ **៤:២៥** ភ ៥.១៦ ម ៥.២៣ យ ១ពវ ១១:៦ ១៥:២៦ ១៦:២៥,៣០ ២ពវ ១៧:២,១៧ ២១:២**៤:២៦** រ លប ៣១:៥០ សភ ១៤:៥ ល ចទ ៣០:១៨-១៩ ៣១:២៨ ៣២:១ ទដ ៥០:៤ អស ១:២ ៣៤:១ យរ ៦:១៩ មីក ៦:២ វ ចទ ៦:១៥ ៧:៤ **៤:២៧** ស លប ២៦:៣៣ ចទ ២៨:៣៦,៦៤ ២៩:២៨ ១ពវ ៨:៤៦ ២ពវ ១៧:៦ ទដ ៤៤:១១ ១០៦:២៧ យរ ៣:៨ មីក ១:១៦

**៤:១០-១៤** មើល នក ១៩-២៤ និងការពន្យល់ ។

**៤:១២** *តែមិនឃើញរូបអង្គណាសោះ* មើល ៥.១៥ មើលការពន្យល់ នក ២០:៤ "ព្រះទ្រង់ជាវិញ្ញាណ" (យហ ៤:២៤ ធៀបនឹង អស ៣១:៣) ។ *គ្រាន់តែឮសំឡេងប៉ុណ្ណោះ* មើល ៥.៣៦ ៥:២៣-២៦ ជន ៧:៨៩ ១ពវ ១៩:១៣។

**៤:១៣** *បង្គាប់ឱ្យឯងរាល់គ្នាប្រព្រឹត្តតាម គឺក្រិត្យវិន័យ* មើលការពន្យល់ នក ២០:១ ៣៤:២៨ ។ *នៅបន្ទះថ្ម២ផ្ទាំង* មើលការពន្យល់ នក ៣១:១៨ ។

**៤:១៥-១៨** មើលការពន្យល់ នក ២០:៤ ។

**៤:១៩** ធៀបនឹង ១៧:៣ ។ *មានសេចក្ដីល្បួងប្រទាញ* ពួកស្ដេចនៃនគរយូដាបានចាញ់សេចក្ដីល្បួងនោះ នៅសម័យក្រោយមកទៀត(២ពវ ១៧:១៦ ២១:៣,៥ ២៣:៤-៥) ។

**៤:២០** *គុករំលាយ* គឺសំដៅទៅលើអំឡុងពេលនៅនគរអេស៊ីព្ទ ដែលពួកអ៊ីស្រាអែលទទួលរងទុក្ខវេទនា(មើល ១ពវ ៨:៥១ យរ ១១:៤ និងមើល អស ៤៨:១០ និងការពន្យល់) ។

**៤:២១** *ដោយព្រោះឯងរាល់គ្នា* មើលការពន្យល់ ១:៣៧ ។

**៤:២៤** *ជាភ្លើងឆេះបន្សុស* មើល ៩:៣ និង នក ២៤:១៧ អស ៣៣:១៤ និងការពន្យល់ ហើយមើល ហព ១២:២៩ ។ *ជាព្រះប្រចណ្ឌ* មើល ៥:៩ ៦:១៥ និងការពន្យល់ នក ២០:៥ ។

**៤:២៥** *កាលណាបាននៅស្រុកនោះ* ព្រះគម្ពីរចោទិយកថាបង្រៀននូវសេចក្ដីបង្រៀនដ៏សំខាន់មួយគឺ ការបះបោរនៃពួកអ៊ីស្រាអែល នឹងនាំឱ្យទទួលការបណ្ដេញចេញពីទឹកដីនោះ តែការលន់តួបាបរបស់ពួកគេ នឹងនាំមកនូវការស្អាងឡើងវិញ(មើលរូបមន្តនៃព្រះពរ និងបណ្ដាសាក្នុងជំពូក ២៧-២៨) ។

**៤:២៦** *ស្ថានសួគ៌ ហើយនិងផែនដីឱ្យធ្វើជាបន្ទាន់* មើលការពន្យល់ ៣០:១៩ ទដ ៥០:១ អស ១:២ ។

**៤:២៧** *នឹងកំចាត់កំចាយឯងរាល់គ្នា* មើលការពន្យល់ ២៨:៦៤ ។

នឹងនៅមាន[ហ]តែគ្នាតិច ក្នុងគ្រប់ទាំងនគរ ដែលព្រះ
យេហូវ៉ានឹងនាំឯងទៅនៅនោះ ២៨ហើយនៅស្រុកទាំងនោះ
ឯងនឹងគោរពប្រតិបត្តិដល់ព្រះផ្សេងៗ[ឡ] ដែលធ្វើពីឈើ
ឬពីថ្ម[អ] ដោយដៃមនុស្ស ជារូបដែលមិនអាចនឹងមើល
ឃើញស្តាប់ឮ ឬទទួលអាហារ ឬដឹងក្លិនឡើយ[ក] ២៩ប៉ុន្តែនៅ
ទីនោះឯងនឹងស្វែងរក[ខ]ព្រះយេហូវ៉ា ជាព្រះនៃឯង ហើយ
និងឃើញទ្រង់ក្នុងកាលដែលរកទ្រង់អស់ពីចិត្ត[គ] ហើយអស់
ពីព្រលឹងឯងផង[ឃ] ៣០កាលណាឯងកើតមានសេចក្តីវេទនា[ង]
ហើយគ្រប់ទាំងសេចក្តីនេះ បានកើតឡើងដល់ឯង នោះនៅ
គ្រាចុងបំផុត[ច] ឯងនឹងត្រឡប់មក[ឆ]ឯព្រះយេហូវ៉ា ជាព្រះនៃ
ឯងវិញ ហើយនិងស្តាប់តាមព្រះបន្ទូលទ្រង់ ៣១ដ្បិតព្រះ
យេហូវ៉ាជាព្រះនៃឯង ទ្រង់ជាព្រះដ៏មានសេចក្តីមេត្តា
ករុណា[ជ] ទ្រង់មិនខាននឹងប្រោសឯងទេ[ឈ] ក៏មិនបំផ្លាញ[ញ]ឯង
ឬភ្លេច[ដ]សេចក្តីសញ្ញា ដែលទ្រង់បានស្បថនឹងពួកឰយុកោ
ឯងឡើយ ។

## ព្រះអម្ចាស់ទ្រង់ជាព្រះ

៣២ចូរសើបសួរ[ឋ]រកពីអស់ទាំងថ្ងៃកន្លងទៅហើយ ដែល
មានតាំងពីមុនឯងមក គឺចាប់តាំងពីថ្ងៃដែលព្រះទ្រង់បាន
បង្កើតមនុស្សនៅលើផែនដី[ឌ] ហើយពីជើងមេឃម្ខាង ទៅ
ដល់ជើងមេឃម្ខាងផង[ឍ] តើដែលមានការដ៏ធំយ៉ាងនេះ[ណ] ឬ
ដែលមានឮនិយាយពីការយ៉ាងនេះឬអី ៣៣តើដែលមាន
សាសន៍ណាឮព្រះសៀងនៃព្រះ ដែលទ្រង់មានបន្ទូលពី
កណ្តាលភ្លើងមក ដូចជាឯងបានឮ ហើយបានរស់នៅឬទេ[ត]
៣៤ឬតើដែលមានព្រះណាប្រថុយទៅយកសាសន៍១ សំរាប់
អង្គទ្រង់ ពីកណ្តាលសាសន៍១ទៀត[ថ] ដោយសារការល្បង[ទ]
ទីសំគាល់[ធ] និងការអស្ចារ្យ[ន] ដោយចំបាំង ដោយព្រះហស្តដ៏
មានព្រះចេស្តា[ប] និងដោយព្រះពាហុលើកសំរេចហើយ
ដោយការគួរស្ញែងខ្លាចជាធំ[ផ] ដូចជាគ្រប់ទាំងការដែល
ព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់បានធ្វើ ជាប្រយោជន៍ដល់
ឯង នៅស្រុកអេស៊ីព្ទ ឱ្យឯងឃើញផងឬទេ ៣៥ការទាំងនោះ
បានសំដែងមកឱ្យឯងឃើញ ដើម្បីឱ្យឯងបានដឹងថា ព្រះ
យេហូវ៉ាទ្រង់ជាព្រះ ក្រៅពីទ្រង់ នោះគ្មានព្រះឯណាទៀត
ឡើយ[ព] ៣៦ទ្រង់ធ្វើឱ្យឯងឮព្រះសៀងទ្រង់ពីលើមេឃ[ភ] ដើម្បី
នឹងបង្រៀន[ម]ឯង ហើយនៅផែនដី ទ្រង់បានឱ្យឯងឃើញ
ភ្លើងដ៏ធំរបស់ទ្រង់ ឯងក៏បានឮព្រះបន្ទូលទ្រង់ចេញពី
កណ្តាលភ្លើងនោះមក ៣៧ហើយដោយព្រោះទ្រង់បាន
ស្រឡាញ់[យ]ពួកឰយុកោឯង បានជាទ្រង់រើសយកពូជគេតៗ
មក ព្រមទាំងនាំឯងចេញពីស្រុកអេស៊ីព្ទមកនៅចំពោះទ្រង់
ដោយព្រះចេស្តាដ៏ជាធំរបស់ទ្រង់[រ] ៣៨ដើម្បីនឹងបណ្តេញ
អស់ទាំងសាសន៍ដែលធំ ហើយពូកែជាងឯង ពីមុខឯង
ចេញឱ្យបាននាំឯងចូលទៅ ប្រយោជន៍នឹងឱ្យស្រុកគេ ទុក
ជាមរដកដល់ឯង[ល] ដូចជាមានសព្វថ្ងៃនេះ ៣៩ដូច្នេះ ចូរដឹង[វ]
នៅថ្ងៃនេះ ហើយកំណត់ទុកក្នុងចិត្តចុះថា ព្រះយេហូវ៉ាទ្រង់
ជាព្រះនៅលើស្ថានសួគ៌ ហើយនៅផែនដីនេះផង គ្មានព្រះ
ឯណាទៀតសោះឡើយ[ស] ៤០ត្រូវឱ្យឯងរាល់គ្នារក្សា[ហ]អស់
ទាំងបញ្ញត្តិច្បាប់របស់ទ្រង់[ឡ] ដែលអញបង្គាប់ដល់ឯងនៅ

**៤:២៧** ហ អស ១៧:៦ ២១:១៧ អប ១:៥ **៤:២៨** ឡ ចទ ១៣:២ ២៨:៣៦,៦៤ ១សយ ២៦:១៩ យរ ៥:១៩ ១៦:១៣ កច ១៩:២៦ អ ចទ ២៩:១៧ ក ទដ ១១៥:៤–៨ ១៣៥:១៥– ១៨ អស ៨:១៩ ២៦:១៤ ៤៤:១៧–២០ វវ ៩:២០ **៤:២៩** ខ ១សយ ១៣:១២ ២ពវ ១៣:៤ ២រប ៧:១៤ ១៥:៤ ៣៣:១២ ទដ ៧៨:៣៤ ១១៩:៥៨ អស ៤៥:១៩,២២ ៥៥:៦ យរ ២៦:១៩ ដយ ៩:១៣ ហស ៣:៥ អម ៥:៤ គ ១សយ ៧:៣ ១ពវ ៨:៤៨ យរ ២៩:១៣ ឃ ចទ ៦:៥ ៣០:១–៣,១០ **៤:៣០** ង លវ ២៦:៤១ ចទ ៣១:១៧,២១ ទដ ៤:១ ១៨:៦ ៤៦:១ ៥៩:១៦ ១០៧:៦ ច ចទ ៣១:២៩ យរ ២៣:២០ ហស ៣:៥ ហព ១:២ ឆ ចទ ៣០:២ ១ពវ ៨:៤៨ នហ ១:៩ យរ ៣:១,១២,២២ ៤:១ ១៨:១១ យង ២:១២ **៤:៣១** ជ នក ៣៤:៦ នហ ៩:៣១ ទដ ១១១:៤ ឈ ចទ ៣១:៦,៨ យស ១:៥ ១ពវ ៨:៥៧ ១រប ២៨:៩,២០ ទដ ៩:១០ ២៧:៩ ៧១:៩ អស ៤២:១៦ ហព ១៣:៥ ញ លវ ២៦:៤៤ ដ លប ២៦:៤៥ **៤:៣២** ឋ ចទ ៣២:៧ ឌ លប ១:២៧ អស ៤៥:១២ ឍ ចទ ២៨:៦៤ ៣០:១ យរ ៩:១៦ មថ ២៤:៣១ ណ ខ.៧ ២សយ ៧:២៣ **៤:៣៣** ត នក ២០:២២ ចទ ៥:២៤–២៦ **៤:៣៤** ថ នក ១៤:៣០ ទ អស ៧:១២ ធ នក ៤:១៧ ន ចទ ៧:១៩ ២៦:៨ ២៩:៣ ១រប ១៦:១២ ទដ ៩:១ ៤០:៥ យរ ៣២:២០ ប នក ៣០:២០ ចទ ៥:១៥ ៦:២១ ១៥:១៥ ផ នក ១៥:១១ ចទ ៣៤:១២ ទដ ៤៥:៤ ៦៥:៥ **៤:៣៥** ព ខ.៣៩ នក ៨:១០ ចទ ៧:៩៣ ២:៤, ១២ ១សយ ២:២ ១ពវ ៨:៦០ ២ពវ ១៩:១៩ អស ៤៣:១០ មក ១២:៣២ **៤:៣៦** ភ នក ១៩:១៩ ហព ១២:២៥ ម ចទ ៨:៥ **៤:៣៧** យ ចទ ៧:៨ ១០:១៥ ២៣:៥ ៣៣:៣ ទដ ៤៤:៣ យរ ៣១:៣ ហស ១១:១ មឡ ១:២ ២:១១ រ នក ៣:២០ ៣៣:១៤ **៤:៣៨** ល ជន ៣៤:១៤–១៥ ចទ ៧:១ ៩:៥ **៤:៣៩** វ នក ៨:១០ ស ខ.៣៥ នក ១៥:១១ **៤:៤០** ហ លវ ២២:៣១ ឡ ខ.១ លប ២៦:៥ ចទ ៥:២៩ ១១:១ ទដ ១០៥:៤៥ អស ៤៨:១៨

**៤:២៩** *អស់ពីចិត្ត ហើយអស់ពីព្រលឹងឯងផង* បង្ហាញពីការចូលរួម និងការប្តេជ្ញាចិត្តទាំងស្រុង ។ ឃ្លានេះមិនគ្រាន់តែបង្ហាញពីរបៀប ដែលរាស្ត្ររបស់ទ្រង់ត្រូវស្វែងរកទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបង្ហាញពីរបៀបដែលរាស្ត្ររបស់ទ្រង់ត្រូវកោតខ្លាច រស់នៅដោយស្តាប់បង្គាប់ទ្រង់ ស្រឡាញ់ ហើយបម្រើទ្រង់(៦:៥ ១០:១២ ១១:១៣ ១៣:៣ ៣០:៦) ព្រមទាំងពីរបៀបដែលត្រូវប្តេជ្ញាចិត្ត និងស្មោះត្រង់នឹងទ្រង់ឡើងវិញ(២៦:១៦ ៣០:២,១០) ។

**៤:៣១** *សេចក្តីសញ្ញា . . . បានស្បថ* មើលការពន្យល់ លប ២១:២៣ ២២:១៦ នក ១៩:៥ ហព ៦:១៣,១៨ ។ នៅសម័យបុរាណ ភាគីដែលតាំងសញ្ញាជាមួយគ្នា ត្រូវបញ្ជាក់ពីបំណងចិត្តរបស់ខ្លួន ដោយស្បថសូមឱ្យខ្លួនទទួលបណ្តាសាអ្វីមួយ បើមិនធ្វើតាមពាក្យសម្បថទេនោះ(លប ១៥:១៧) ។

**៤:៣៥** *ដើម្បីឱ្យឯងបានដឹងថា* មើល ខ.១០ ។ *ក្រៅពីទ្រង់នោះ គ្មានព្រះឯណាទៀតឡើយ* មើល ខ.៣៩ ៥:៧ ៦:៤ និងការពន្យល់ និង ៣២:៣៩ ។ លោកម៉ូសេបញ្ជាក់ថា ព្រះពិតគឺមានតែមួយទេ(ការពន្យល់ លប ១:១) ។

**៤:៣៧** *ទ្រង់បានស្រឡាញ់* គឺជាឃ្លាដំបូងក្នុងព្រះគម្ពីរចោទិយកថា ដែលនិយាយអំពីសេចក្តីស្រឡាញ់នៃព្រះចំពោះរាស្ត្រទ្រង់(មើលសេចក្តីផ្តើមត្រង់ចំណុចការបង្រៀនផ្នែកវិជ្ជាសិក្សាអំពីព្រះ និងគោលបំណង) ។ មើល ៥:១០ ៧:៩,១៣ ១០:១៥ ២៣:៥ ។ ដោយសារសេចក្តីស្រឡាញ់នៃព្រះចំពោះរាស្ត្រទ្រង់ នោះពួកគេក៏ត្រូវស្រឡាញ់ទ្រង់វិញដែរ (មើលការពន្យល់ ៦:៥) ។

**៤:៣៩** មើល ខ.៣៥ និងការពន្យល់ ។

**៤:៤០** *ដើម្បីឱ្យបានសប្បាយ* មានន័យថា ឯងនឹងបានទទួលផលនៃសេចក្តី

ថ្ងៃនេះ ដើម្បីឱ្យបានសប្បាយ[អ] ព្រមទាំងកូនចៅឯងតរៀង
ទៅផង ហើយឱ្យបានជីវិតយូរអង្វែងតទៅ[ក] នៅក្នុងស្រុក
ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានមកឱ្យឯងបាន
នៅជាដរាប ។

## ទីក្រុងសម្រាប់ជ្រកកោន

*៤:៤១–៤៣ – ជន ៣៥:៦–៣៤ ចទ ១៩:១–១៤ យស ២០:១–១៩*

៤១ នៅគ្រានោះ ម៉ូសេក៏ញែកទីក្រុង៣នៅត្រើយទន្លេយ័រ
ដាន់ ទិសខាងកើត ៤២ សំរាប់ឱ្យអ្នកណាដែលសំឡាប់អ្នក
ជិតខាងខ្លួន មិនប្រកបដោយចិត្តប៉ង[ខ] ហើយដែលមិនបាន
ស្អប់អ្នកនោះពីកាលមុន បានរត់ទៅជ្រកអាស្រ័យនៅទីនោះ
ហើយឱ្យបានរស់នៅដោយរត់ទៅ ជ្រកកោននៅទីក្រុងណា
មួយនោះ ៤៣ ទីក្រុងទាំងនោះ គឺក្រុងបេសើរ១ ដែលនៅទី
រហោស្ថាន នាស្រុកវាល សំរាប់ពួករូបេន និងទីក្រុង
រ៉ាម៉ូត[គ] ១នៅស្រុកកាឡាត សំរាប់ពួកកាឌ់ ហើយទីក្រុង
កូឡាន១ នៅស្រុកបាសាន សំរាប់ពួកម៉ាន៉ាសេ ។

## ការណែនាំអំពីច្បាប់បញ្ញត្តិ

៤៤ នេះគឺជាក្រិត្យវិន័យ ដែលម៉ូសេបានដាក់នៅមុខពួក
កូនចៅអ៊ីស្រាអែល ៤៥ ហើយនេះជាសេចក្តីបន្ទាល់ជាច្បាប់
ហើយជាបញ្ញត្តិទាំងប៉ុន្មាន ដែលម៉ូសេបានប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែល ក្នុងកាលដែលគេចេញពីស្រុកអេស៊ីព្ទ
មក ៤៦ គឺនៅខាងអាយទន្លេយ័រដាន់ ត្រង់ច្រកភ្នំ ទល់មុខនឹង
បេត–ពេអរ ក្នុងស្រុករបស់ស៊ីហុន[ឃ] ជាស្តេចសាសន៍អាម៉ូរី
ដែលនៅក្រុងហែសបូន ជាអ្នកដែលម៉ូសេនិងពួកកូនចៅ
អ៊ីស្រាអែលបានវាយ ពីកាលគេចេញពីស្រុកអេស៊ីព្ទមក
៤៧ គេក៏ចាប់យកស្រុករបស់ស្តេចនោះ និងស្រុករបស់អុក
ជាស្តេចស្រុកបាសាន គឺជាស្តេចសាសន៍អាម៉ូរីទាំង២ ដែល

**៤:៤០** អ ចទ ៥:១៦ ១២:២៥ អស ៣:១០ ក នក២៣:២៦ អភ ៦:២–៣
**៤:៤២** ខ នក ២១:១៣
**៤:៣៤** គ យស ២១:៣៨ ១ពវ ២២:៣ ២ពវ ៨:២៨ ៩:១៤
**៤:៤៦** ឃ ជន ២១:២៦
**៤:៤៨** ង ចទ ២:៣៦ ច ចទ ៣:៩ ឆ ចទ ៣:៨
**៥:១** ក នក ១៨:២០
**៥:២** ខ នក ១៩:៥ យរ ១១:២ ហព ៩:១៥ ១០:១៥–១៧ គ លប ១៧:៩ នក ៣:១
**៥:៣** ឃ ចទ ១១:២–៧ ង ជន ២៦:៦៣–៦៥ ហព ៨:៩
**៥:៤** ច ចទ ៤:១២ ឆ ជន ១៤:១៤ ជ នក ១៩:១៨
**៥:៥** ឈ កទ ៣:១៩ ញ លប ៣:១០ ហព ១២:១៨–២១
**៥:៦** ដ លប ២៦:១ ចទ ៦:៤ ទដ ៨១:១០ ឋ នក ១៣:៣ ២៩:៤៦

នៅត្រើយទន្លេយ័រដាន់ ទិសខាងកើតទុកជារបស់ផងគេ
៤៨ ចាប់តាំងពីក្រុងអារ៉ូអើរ[ង] ដែលនៅមាត់ស្ទឹងអើណូន
រហូតដល់ភ្នំស៊ីអូន[ច] (គឺជាភ្នំហើម៉ូន[ឆ]) ៤៩ ហើយស្រុកវាល
ទាំងមូលដែលនៅត្រើយទន្លេយ័រដាន់ខាងកើត រហូតដល់
សមុទ្រស្រុកវាល ត្រង់ជើងភ្នំពីសកាផង ។

## ក្រឹត្យវិន័យទាំងដប់ប្រការ

*៥:៦–២១ – នក ២០:១–១៧*

**៥** ១ ម៉ូសេក៏ហៅពួកអ៊ីស្រាអែលទាំងអស់គ្នាមកប្រាប់ថា
ឱពួកអ៊ីស្រាអែលអើយ ចូរស្តាប់អស់ទាំងច្បាប់ និងបញ្ញត្តិ[ក]
ដែលអញប្រាប់នៅត្រចៀកឯងរាល់គ្នាក្នុងថ្ងៃនេះចុះ ដើម្បី
ឱ្យបានរៀន ហើយប្រយ័ត្ននឹងប្រព្រឹត្តតាមទាំងអស់ ២ ព្រះ
យេហូវ៉ាជាព្រះនៃយើងរាល់គ្នា ទ្រង់បានតាំងសេចក្តី
សញ្ញា[ខ] នឹងយើងនៅភ្នំហោរែប[គ] ៣ ទ្រង់មិនបានតាំងសេចក្តី
សញ្ញានេះនឹងពួកឰយុកោយើងទេ គឺបានតាំងនឹងខ្លួនយើង
វិញ[ឃ] គឺនឹងយើងរាល់គ្នានេះហើយ ដែលសុទ្ធតែមានជីវិត
រស់នៅសព្វថ្ងៃនេះ[ង] ៤ ព្រះយេហូវ៉ាទ្រង់មានបន្ទូល[ច] ប្រទល់
មុខនឹងឯង[ឆ] ពីកណ្តាលភ្លើង[ជ] នៅលើភ្នំ ៥ (នៅវេលានោះ
អញបានឈរនៅជាកណ្តាល[ឈ] ព្រះយេហូវ៉ានិងឯងរាល់គ្នា
ដើម្បីនឹងបង្ហាញប្រាប់ ពីព្រះបន្ទូលនៃទ្រង់ ដល់ឯងរាល់
គ្នាពីព្រោះឯងបានខ្លាច[ញ] ភ្លើងនោះ ហើយមិនបានឡើង
ទៅលើភ្នំនោះទេ) ។
៦ ទ្រង់មានបន្ទូលថា អញជាព្រះយេហូវ៉ា ជាព្រះនៃឯង
ដែលបាននាំឯងចេញពីផ្ទះបាវបំរើ[ដ] នៅស្រុកអេស៊ីព្ទមក[ឋ] ។
៧ កុំឱ្យមានព្រះឯណាទៀតនៅមុខអញឱ្យសោះ ។
៨ កុំឱ្យឆ្លាក់ធ្វើរូបណាសំរាប់ឯងឱ្យសោះ ក៏កុំឱ្យធ្វើរូប

សញ្ញានោះ ។ ការបញ្ជាក់នេះមាន១០ដង នៅក្នុងព្រះគម្ពីរចោទិយកថា (៥:១៦,២៩ ៦:៣,១៨ ៨:១៦ ១២:២៥,២៨ ១៩:១៣ ២២:៧) ។

**៤:៤១–៤៣** មើល ១៩:១–១៣ ជន ៣៥:៩–២៨ យស ២០ និងការពន្យល់ ។

**៤:៤៣** *ក្រុងបេសើរ និងក្រុងរ៉ាម៉ូត* មើល ១៩:១–១៣ ជន ៣៩:៩–២៨ យស ជំពូក ២០ មើលការពន្យល់ ។

**៥:១** *ឱពួកអ៊ីស្រាអែលអើយ* មើលការពន្យល់ ៤:១ ។

**៥:២** *តាំងសេចក្តីសញ្ញានឹងយើងនៅភ្នំហោរែប* មើលពន្យល់ នក ១៩:៥ ។ ការតាំងសេចក្តីសញ្ញារបស់ព្រះ ជាមួយសាសន៍អ៊ីស្រាអែលនៅភ្នំស៊ីណាយ (ហោរែប) ឥឡូវបានបើកសម្តែងដល់ប្រជាជនអ៊ីស្រាអែល ដែលជាព្រះមហាក្សត្ររបស់ពួកគេ គឺជាក្រឹត្យវិន័យរបស់គេនិងជាផ្លូវជីវិតរបស់ពួកគេ កាលណាគេបាននៅជាប់និងព្រះ នោះទ្រង់និងនាំព្រះពរដល់ប្រជាជនអ៊ីស្រាអែល តែពេលដែលពួកគេបានឃ្លាតឆ្ងាយពីសេចក្តីសញ្ញារបស់ព្រះ នោះក៏បាននាំឱ្យពួកគេទទួលទណ្ឌកម្មម្តងទៀត ក៏ដូចជាបណ្តាសាដែរ (មើល ២៨:១៥–២០ យរ ៣១:៣១–៣៤) ការថ្លែងពីការស្អាងឡើងវិញនូវការតាំងសញ្ញាសារជាថ្មីនេះបានធ្វើអោយសេចក្តីតាំងសញ្ញា នៅឯភ្នំស៊ីណាយនោះមានភាពកាន់តែច្បាស់ ។ ហព ៧:១៨–២២ មើល ហព ៨:៦–១៣ ១០:១៥–១៨ និងមើលជំពូក ១៨ ។

**៥:៣** *ទ្រង់មិនបានតាំងសេចក្តីសញ្ញានោះ និងពួកឰយុកោយើងទេ គឺបានតាំងនឹងខ្លួនយើងវិញ* សេចក្តីតាំងសញ្ញានោះបានធ្វើឡើងចំពោះអ្នកណាដែលមានវត្តមាននៅភ្នំស៊ីណាយ ប៉ុន្តែចាប់តាំងពីពួកគេត្រូវបានតំណាងដល់ជាតិទាំងមូល ក៏បានធ្វើឱ្យពួកគេទទួលជោគជ័យជាច្រើនជំនាន់ផងដែរ ។

**៥:៥** មើល ខ.២៣–២៧ នក ២០:១៨–២១ ។

**៥:៦–២១** ក្រឹត្យវិន័យ១០ប្រការគឺជាសេចក្តីតម្រូវការ តាំងសញ្ញារបស់ព្រះអង្គជាមួយប្រជាជនអ៊ីស្រាអែលនៅលើភ្នំស៊ីណាយ ។ វាស្ទើរតែពុំអាចមានចំពោះប្រវត្តិសាស្ត្រ ដែលនិងត្រូវកើតមានថែមទៀត ។ គេបន្ត ឬកាន់យកគោលការណ៍ជាមូលដ្ឋាន តាមរយៈលោកខាងលិចគេក៏បានសង្ខេបអ្វីដែល

ណាឱ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោម ឬនៅក្នុងទឹកដែលទាបជាងដីនោះផង[ឌ] ៩ក៏កុំឱ្យក្រាបសំពះនៅមុខរបស់ទាំងនោះ ឬគោរពប្រតិបត្តិតាមឡើយ ដ្បិតអញនេះ គឺព្រះយេហូវ៉ាដែលជាព្រះនៃឯង អញជាព្រះប្រចណ្ឌ អញទំលាក់ការទុច្ចរិតរបស់ឪពុក[ឍ]ទៅលើកូនចៅ ដល់៣ហើយ៤ដំណនៃអស់អ្នកដែលស្អប់អញផង[ណ] ១០តែអញផ្តល់សេចក្តីសប្បុរសដល់ទាំងពាន់[ត]ដំណនៃពួកអ្នកដែលស្រឡាញ់ ហើយកាន់តាមបញ្ញត្តិអញទាំងប៉ុន្មានវិញ[ថ]។

១១កុំឱ្យចេញព្រះនាម[ទ]ព្រះយេហូវ៉ា ជាព្រះនៃឯង ជាអសារឥតការឡើយ ដ្បិតព្រះយេហូវ៉ាទ្រង់នឹងមិនរាប់ជាឥតទោស ដល់អ្នកណាដែលចេញព្រះនាមទ្រង់ជាអសារឥតការនោះទេ[ធ]។

១២ចូរកាន់ថ្ងៃឈប់សំរាក ដើម្បីនឹងថែរក្សាឱ្យបានបរិសុទ្ធ[ន] ដូចជាព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានបង្គាប់មកហើយ ១៣ក្នុងរវាង៦ថ្ងៃ នោះត្រូវឱ្យធ្វើអស់ទាំងការរបស់ឯងចុះ ១៤តែដល់ថ្ងៃទី៧[ប] ជាថ្ងៃឈប់សំរាកនៃព្រះយេហូវ៉ា ជាព្រះនៃឯងវិញ នៅថ្ងៃនោះ មិនត្រូវធ្វើការអ្វីឱ្យសោះ ទោះខ្លួនឯង ឬកូនប្រុសកូនស្រីឯង ទោះបាវប្រុសបាវស្រីឯង[ផ]បានសំរាកដូចជាឯងដែរ[ព] ១៥ចូរនឹកចាំថា ឯងក៏ជាបាវបំរើ[ភ]នៅស្រុកអេស៊ីព្ទដែរ តែព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បាននាំចេញពីស្រុកនោះមក ដោយព្រះហស្តដ៏មានព្រះចេស្តា[ម] និងព្រះពាហុលើកសំរេច[យ] ហេតុដូច្នេះបានជាព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានបង្គាប់មកឱ្យឯងកាន់ថ្ងៃឈប់សំរាកនេះ ។

១៦ចូរឱ្យគោរពប្រតិបត្តិដល់ឪពុក[រ]ម្តាយ[ល]ឯង ដូចជាព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានបង្គាប់មក ដើម្បីឱ្យឯងបានអាយុវែង[វ] ហើយបុឱ្យានសប្បាយនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯង បានប្រទានមក ។

**៥:៩** ឍ ជន ២៦:១១ ណ នក ៣៤:៧ ជន ១០:៣៥ ១៤:១៨ **៥:១០** ត នក ៣៤:៧ថ ជន ១៤:១៨ ចទ ៧:៩ នហ ១:៥ យរ ៣២:១៨ ដយ ៩:៤ **៥:១១** ទ ទដ ១៣៩:២០ ធ លប ១៩:១២ ចទ ១០:២០ មថ ៥:៣៣–៣៧ **៥:១២** ន នក ១៦:២៣–៣០ ៣១:១៣–១៧ មក ២:២៧–២៨ **៥:១៤** ប លប ២:២ មថ ១២:២ មក ២:២៧ ហព ៤:៤ ផ យប ៣១:១៣ យរ ៣៤:៩–១១ ព យរ ១៧:២១,២៤ **៥:១៥** ភ លប ១៥:១៣ ម នក ៦:១ ទដ ១០៨:៦ យរ ៣២:២១ យ ចទ ៤:៣៤ **៥:១៦** រ មឡ ១:៦ ល នក ២១:១៧ លវ ១៩:៣ អគ ២២:៧ មថ ១៥:៤ ១៩:១៩ មក ៧:១០ ១០:១៩ លក ១៨:២០ អភ ៦:២–៣ វ ចទ ៤:៤០ ១១:៩ សភ ៣:១–២ **៥:១៧** ស លប ៩:៦ លវ ២៤:១៧ សស

១៧កុំឱ្យសំឡាប់មនុស្សឱ្យសោះ[ស]។

១៨កុំឱ្យផិតគ្នាឱ្យសោះ[ហ]។

១៩កុំឱ្យលួចប្លន់ឱ្យសោះ[ឡ]។

២០កុំឱ្យធ្វើជាទីបន្ទាល់ក្លែង ទាស់នឹងអ្នកជិតខាងឯងឡើយ[អ]។

២១កុំឱ្យលោភ ចង់បានប្រពន្ធរបស់អ្នកជិតខាងឯង ក៏កុំឱ្យចង់បានផ្ទះអ្នកជិតខាងឯង ឬចំការ ឬបាវប្រុសបាវស្រីគេ ឬគោ លា ឬរបស់អ្វីផងអ្នកជិតខាងឡើយ[ក]។

២២សេចក្តីទាំងនេះ ព្រះយេហូវ៉ាទ្រង់បានមានបន្ទូលចេញពីកណ្តាលភ្លើង ពីពពក និងពីងងឹតសូន្យសុង[ខ] នៅលើភ្នំមកពួកជំនុំនៃឯងរាល់គ្នា ដោយសំឡេងយ៉ាងខ្លាំង ហើយមិនបានបន្ថែមអ្វីទៀតសោះ រួចទ្រង់ក៏កត់សេចក្តីទាំងនេះនៅលើបន្ទះថ្ម២ផ្ទាំង[គ] ប្រទានមកអញ ២៣កាលឯងរាល់គ្នាបានឮសំឡេងពីកណ្តាលងងឹតនោះ ក្នុងវេលាដែលភ្នំកំពុងតែឆេះនោះឯងរាល់គ្នាបានមកឯអញ គឺពួកមេនៃពូជអំបូរឯង និងពួកចាស់ទុំ[ឃ]ផង ២៤ដោយពាក្យថា មើល ព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា ទ្រង់បានបង្ហាញឱ្យយើងខ្ញុំ[ង]ឃើញសិរីល្អនៃទ្រង់ ហើយឱ្យបានស្គាល់តេជានុភាព[ច]នៃទ្រង់ យើងខ្ញុំក៏បានឮព្រះសៀងទ្រង់ចេញពីកណ្តាលភ្លើងមក នៅថ្ងៃនេះ យើងខ្ញុំបានឃើញថា ព្រះទ្រង់មានបន្ទូលនឹងមនុស្សហើយថា ទ្រង់មានព្រះជន្មរស់នៅ[ឆ] ២៥ដូច្នេះ តើហេតុដូចម្តេច បានជាយើងរាល់គ្នាត្រូវស្លាប់ឥឡូវនេះ ដ្បិតភ្លើងធំនេះនឹងឆេះបន្សុសយើងរាល់គ្នាអស់រលីងទៅ បើ

៣:៣ យរ ៤០:១៥ ៤១:៣ មថ ៥:២១–២២ ១៩:១៩ មក ១០:១៩ លក ១៨:២០ រម ១៣:៩ យក ២:១១ **៥:១៨** ហ លវ ២០:១០ មថ ៥:២៧–៣០ ១៩:១៨ មក ១០:១៩ លក ១៨:២០ រម ១៣:៩ យក ២:១១ **៥:១៩** ឡ លវ ១៩:១១ មថ ១៩:១៩ មក ១០:១៩ លក ១៨:២០ រម ១៣:៩ **៥:២០** អ នក ២៣:១ មថ ១៩:១៨ មក ១០:១៩ លក ១៨:២០ **៥:២១** ក រម ៧:៧ ១៣:៩ **៥:២២** ខ នក ២០:២១ គ នក ២៤:១២ **៥:២៣** ឃ នក ៣:១៦ **៥:២៤** ង ចទ ៤:៣៤ ៨:៥ ១១:២ អស ៥៣:៤ ច ចទ ៣:២៤ ឆ នក ១៩:១៩

---

ព្រះពិតបានសង្ឃឹមថាប្រជាជនផងទ្រង់ ដែលមានជំនឿ ឬការថ្វាយបង្គំនិងប្រព្រឹត្តតាម សូមមើល នក ២០:២–១៧ ។

**៥:១២** *ដូចជាព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានបង្គាប់មកហើយ* វាមានការខុសគ្នាពីឬចន្លោះខ ដែលមានអត្ថន័យតែមួយក្នុង នក ២០:៨ ។ អនុប្រយោគនេះបានឱ្យប្រជាជននៅមានភាពជាបរិសុទ្ធ ដូចជាក្នុងក្រឹត្យវិន័យ១០ប្រការផងដែរ គឺចំពោះក្រឹត្យវិន័យទាំង១០ប្រការ ហើយមាន៤០ឆ្នាំនៅលើភ្នំស៊ីណាយ (ខ.១៥–១៦) ។

**៥:១៤** *ទោះបាវប្រុស ឬបាវស្រីក្តី* សូមមើល ខ.១៥ និង នក ២០:១០ ។

**៥:១៥** *ចូរនឹកចាំថា* មើលសេចក្តីពន្យល់ ៤:១០ ។

**៥:១៦–២១** ក្នុងគម្ពីរសញ្ញាថ្មីបានបញ្ជាក់ជាញឹកញាប់ចំពោះឃ្លានេះ គឺក្រឹត្យវិន័យ១០ប្រការ សូមមើលខ យោងដែលទាក់ទងគ្នា ។

**៥:១៦** *ហើយឱ្យបានសប្បាយនៅក្នុងស្រុក* វាខុសពីខគម្ពីរដែលស្របន័យគ្នានៅ នក ២០:១២ ខនេះគ្រាន់តែពន្យល់ពីព្រះហឫទ័យ ដែលមានចំពោះប្រជាជនរបស់ទ្រង់មិនគ្រាន់តែជាការកំណត់ជីវិត ដ៏យូលង់នោះទេ (មើលការពន្យល់ ៤:៤០) ។

**៥:២០** មើល ១៩:១៨–១៩ លវ ១៩:១១–១៣ ១ពវ ២១:១០,១៣ ។

**៥:២២** *សេចក្តីទាំងនេះ* "ព្រះបន្ទូល" (មើលការពន្យល់ នក ២០:១) ។ *បន្ទះថ្មពីរផ្ទាំង* មើលការពន្យល់ នក ១៩:៨ ។

**៥:២៥** *យើងរាល់គ្នាត្រូវស្លាប់ឥឡូវនេះ* សូមមើលការពន្យល់ លប ១៦:១៣ ៣២:៣០ ។

សិនជាយើងខ្ញុំឮព្រះសៀងព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំ
ទៀត នោះយើងរាល់គ្នានឹងស្លាប់ហើយ[ជ] ២៦ដ្បិតតើមានអ្នក
ឯណា ក្នុងបណ្តាអស់ទាំងមនុស្ស ដែលឮព្រះសៀងនៃព្រះ
ដ៏មានព្រះជន្មរស់ ដែលទ្រង់មានបន្ទូលពីកណ្តាលភ្លើងមក
ដូចជាយើងខ្ញុំបានឮនេះ ហើយបានរស់នៅដូច្នេះ[ឈ] ២៧សូម
ឱ្យលោក ចូលទៅជិតស្តាប់សេចក្តីទាំងប៉ុន្មាន ដែល
ព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំទ្រង់មានបន្ទូលមក[ញ] រួចសូម
លោកប្រាប់មកយើង ពីគ្រប់ទាំងសេចក្តី ដែលព្រះយេហូវ៉ា
ជាព្រះនៃយើងខ្ញុំ ទ្រង់មានបន្ទូលនឹងលោក នោះយើងខ្ញុំ
ស្តាប់ ហើយប្រព្រឹត្តតាមផង[ដ] ។
២៨ព្រះយេហូវ៉ាទ្រង់ក៏ឮពាក្យរបស់ឯងរាល់គ្នា ក្នុង
កាលដែលឯងបាននិយាយមកអញនោះ រួចទ្រង់មានបន្ទូល
មកអញថា អញបានឮពាក្យរបស់បណ្តាជនទាំងនេះ ដែល
គេនិយាយមកឯងដែរ សេចក្តីទាំងប៉ុន្មានដែលគេបាន
និយាយនោះក៏ស្រួលហើយ[ឋ] ២៩ឱបើសិនជាគេមានចិត្តយ៉ាង
នោះជាដរាបទៅអេះ ដើម្បីឱ្យគេបានកោតខ្លាចដល់អញ[ឌ]
ហើយកាន់តាមគ្រប់ទាំងបញ្ញត្តិ[ឍ] របស់អញប្រយោជន៍ឱ្យគេ
និងពួកកូនចៅគេ បានសប្បាយនៅជារៀងរាបដរាបទៅ[ណ]
៣០ចូរទៅប្រាប់គេ ឱ្យត្រឡប់ទៅឯត្រសាលរបស់គេចុះ
៣១តែឯឯង នោះចូរឈរនៅទីនេះ[ត]ជិតអញវិញ អញនឹង
ប្រាប់អស់ទាំងសេចក្តីបង្គាប់ និងច្បាប់ហើយបញ្ញត្តិទាំង
ប៉ុន្មាន ដែលឯងត្រូវបង្រៀនដល់គេ ដើម្បីឱ្យគេបានប្រព្រឹត្ត
តាម នៅក្នុងស្រុកដែលអញឱ្យដល់គេ ឱ្យគេទទួលយកនោះ
៣២ដូច្នេះត្រូវឱ្យប្រយ័ត្ននឹងធ្វើដូចជាព្រះយេហូវ៉ា ជាព្រះនៃ
ឯងបានបង្គាប់មក[ថ] កុំឱ្យងាកបែរចេញទៅខាងស្តាំ ឬខាង
ឆ្វេងឡើយ[ទ] ៣៣ត្រូវឱ្យប្រព្រឹត្តសព្វគ្រប់តាមអស់ទាំងសេចក្តី
ដែលព្រះយេហូវ៉ាជាព្រះនៃឯងបានបង្គាប់មក[ធ] ដើម្បីឱ្យ
បានរស់នៅ ហើយឱ្យបានសប្បាយ ព្រមទាំងមានអាយុជា
យូរអង្វែងតទៅ[ន] នៅក្នុងស្រុកដែលឯងរាល់គ្នានឹងទទួល
យកនោះ ។

## ចូរស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯង

៦ ១នេះជាសេចក្តីបង្គាប់ ជាច្បាប់ ហើយជាបញ្ញត្តិទាំង
ប៉ុន្មាន ដែលព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់បានបង្គាប់មក
ឱ្យបង្រៀនដល់ឯង ដើម្បីឱ្យឯងបានប្រព្រឹត្តតាម នៅក្នុង
ស្រុកដែលនឹងឆ្លងចូលទៅទទួលយក ២ប្រយោជន៍ឱ្យឯង
បានកោតខ្លាច[ក]ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ហើយកាន់
តាមគ្រប់ទាំងច្បាប់ និងបញ្ញត្តិ[ខ] របស់ទ្រង់ ដែលអញបង្គាប់
ដល់ឯងនេះ នៅអស់១ជីវិតរបស់ឯង[គ]និងកូនចៅឯងតរៀង
ទៅ ហើយឱ្យឯងបានអាយុជាយូរអង្វែងតទៅ[ឃ] ៣ដូច្នេះ
ឱពួកអ៊ីស្រាអែលអើយ ចូរស្តាប់ ហើយប្រយ័ត្ននឹងប្រព្រឹត្ត
តាម[ង]ចុះ ដើម្បីឱ្យបានសប្បាយ ហើយចំរើនគ្នាជាច្រើន
ឡើងយ៉ាងសន្ធឹក[ច] នៅក្នុងស្រុកដែលមានទឹកដោះ ហើយ
និងទឹកឃ្មុំហូរហៀរ[ឆ] ដូចជាព្រះយេហូវ៉ាជាព្រះនៃពួក
ឰយុកោឯង បានសន្យា[ជ]នឹងឯងហើយ ។
៤ចូរស្តាប់ចុះ ឱអ៊ីស្រាអែលអើយ ព្រះយេហូវ៉ាជាព្រះនៃ
យើង គឺព្រះយេហូវ៉ាតែ១អង្គទ្រង់[ឈ] ៥ត្រូវឱ្យឯងស្រឡាញ់[ញ]

**៥:២៥** ជ នក ២០:១៨–១៩ ចទ ១៨:១៦ ហព ១២:១៩
**៥:២៦** ឈ នក ៣៣:២០ ចទ ៤:៣៣ ពច ៦:២២,២៣ ១៣:២២ អស ៦:៥
**៥:២៧** ញ នក ១៩:៨ ដ នក ២៤:៧
**៥:២៨** ឋ ចទ ១៨:១៧
**៥:២៩** ឌ ទដ ៨១:៨,១៣ ឍ យស ២២:៥ ទដ ៧៨:៧ ណ ឧ.៣៣ ចទ ៤:៣,៤០ ១២:២៥ ២២:៧
**៥:៣១** ត នក ២៤:១២
**៥:៣២** ថ ចទ ៤:២៩ ១០:១២ ទ ចទ ១៧:១១,២០ ២៨:១៤ យស ១:៧ ១ពវ ១៥:៥ ២ពវ ២២:២ សភ ៤:២៧
**៥:៣៣** ធ អស ៣:១០ យរ ៧:២៣ ៣៨:២០ លក ១:៦ ន ឧ.២៩
**៦:២** ក នក ២០:២០ ១សយ ១២:២៤ ខ លប ២៦:៥ គ ចទ ៤:៩ ឃ នក ២០:១២
**៦:៣** ង នក ១៩:៥ ច លប ៥:៣៣ ឆន ក ៣:៨ ចទ ៣២:១៣–១៤ ជ នក ១៣:៥ ៣៩ នហ ៩:៦ ទដ ៨៦:១០ អស ៤៤:៦ សក ១៤:៩ ២:១៩ មក ១២:២៩ យហ ១០:៣០ **៦:៤** ឈ ចទ ៤:៣៥,១កថ ៨:៤ អភ ៤:៦ យក ២:១៩ **៦:៥** ញ ចទ ១១:១,២២ មថ ២២:៣៧ មក ១២:៣០ លក ១០:២៧

**៥:២៧** *យើងនឹងស្តាប់ ហើយប្រព្រឹត្តតាមផង* សូមមើល នក ១៩:៨ ។
**៦:២** *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើលការពន្យល់ លប ២០:១១ ។ *អាយុយូរអង្វែង* មើល ៤:៤០ ៥:១៦ និងការពន្យល់ ។ គឺដោយការស្តាប់បង្គាប់ព្រះអង្គនិងរក្សាបញ្ញត្តិទ្រង់ គឺក៏នាំឱ្យប្រជាជនអ៊ីស្រាអែលសប្បាយ និងអាយុជាយូរអង្វែងតទៅ ហើយមនុស្សក្នុងលោកទាំងមូលក៏មានជាតិសាសន៍យើនយូរក្នុងទឹកដីនេះផងដែរ ។
**៦:៣–៤** *ដូច្នេះឱពួកអ៊ីស្រាអែលអើយ* មើលការពន្យល់ ៤:១ ។
**៦:៣** *នៅក្នុងស្រុកដែលមានទឹកដោះ ហើយនិងទឹកឃ្មុំហូរហៀរ* មើលការពន្យល់ នក ៣:៨ គឺឃ្លានេះហើយដែលបានសរសេរចំនួន ១៤ដងគឺព្រះគម្ពីរនិក្ខមនំ រហូតដល់ចោទិយកថា ហើយមានសរសេរ៥ដងនៅព្រះគម្ពីរសញ្ញាចាស់ផ្សេងៗទៀត ។
**៦:៤–៩** មើល ១២:២៩–៣០ មើលគម្ពីរ មថ ២២:៣៧–៣៨ លក ១០:២៧ ផងដែរ ។ អត្ថបទនេះក្នុងគម្ពីរចោទិយកថា ដែលគេបានទទួលស្គាល់លោកសេម៉ា (ហេព្រើរថានេះនែ៎) ដែលសាសន៍យូដាថាលន់តួចំពោះសេចក្តីជំនឿ ហើយទូលអង្វររាល់ថ្ងៃ ឬនៅថ្ងៃបរិសុទ្ធក្នុងសាលាប្រជុំ ។
**៦:៤** *គឺជាព្រះយេហូវ៉ាតែ១អង្គទ្រង់* សេចក្តីពិតបានបើកសម្តែងដល់ជនជាតិអ៊ីស្រាអែលថា មានតែព្រះមួយអង្គគត់ដែលបង្កើត របស់សព្វសារពើ ហើយមានអំណាចគ្រប់គ្រងលើរបស់ ដែលឈរប្រឆាំងយ៉ាងរឹងមាំទៅនិងសាសនាសម័យដើម ឬពួកផ្នែកលោកខាងកើត ។ ហើយគ្រប់ទាំងជាតិជិតខាងសាសន៍អ៊ីស្រាអែលដែលគេ បានទទួលក្រឹត្យក្រមពីព្រះរបស់គេដែលជាកំណត់លើនិស្ស័យរបស់គេ និងផ្លូវរបស់គេ ។ តែប្រជាជនអ៊ីស្រាអែលអាចរស់បាន តាមតម្រះគ្រប់ការ ឬគ្រប់ពេល គឺក្រោមក្រឹត្យវិន័យព្រះមហាក្សត្រ ដែលជាព្រះបរិសុទ្ធ ដែលជាផ្លូវនិងគោលបំណងដ៏សុចរិតឆ្ពោះទៅរកការសង្គ្រោះ ដល់គ្រប់មនុស្សជាតិ គឺឱ្យរួចពីអំពើបាប ការកាត់ទោសផ្សេងៗនិងឱ្យរួចពីវិញ្ញាណអារក្សដែលជាបន្ទុកដ៏ធ្ងន់ ដល់ជីវិតមនុស្សលោក ។
**៦:៥** *ស្រឡាញ់ព្រះយេហូវ៉ា* ទស្សនៈចម្បងជាសេចក្តីស្រឡាញ់ ដែលបង្ហាញផ្តោតទៅលើព្រះមហាក្សត្រមួយអង្គ គឺព្រះមហាក្សត្រ (yahweh) "យ៉ាវេហ" ដូចប្រជាជនអ៊ីស្រាអែល ដែលស្រឡាញ់ព្រះនិងស្រឡាញ់អ្នកជិតខាងផងដែរ (មើល លវ ១៩:១៨) គឺការសាងសេចក្តីស្រឡាញ់ ដែលទ្រង់បានផ្តល់មកឱ្យ (មើល ៤:៣៧ និងការពន្យល់ ៧:៨–៩ ២៣:៥ ១យហ ៤:១៩–២១)

ព្រះយេហូវ៉ា ជាព្រះនៃឯងឱ្យអស់ពីចិត្ត[ដ] អស់ពីព្រលឹង
ហើយអស់ពីកំឡាំងឯង[ឋ] ៦សេចក្ដីទាំងនេះដែលអញបង្គាប់
ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ក្នុងចិត្តឯងចុះ[ឌ] ៧ត្រូវ
ឱ្យប្រិតប្រៀនសេចក្ដីទាំងនេះដល់កូនចៅឯងព្រមទាំង
និយាយដំណាល ក្នុងកាលដែលអង្គុយនៅក្នុងផ្ទះហើយ
ដើរតាមផ្លូវ ក្នុងកាលដែលដេក ហើយក្រោកឡើងផង[ឍ]
៨ត្រូវចងសេចក្ដីទាំងនេះជាប់នៅដៃឯង ទុកជាទីសំគាល់
ហើយត្រូវធ្វើជាស្លាកនៅកណ្ដាលថ្ងាសឯងផង[ណ] ៩ក៏ត្រូវកត់
នៅក្របទ្វារផ្ទះឯង ហើយនៅទ្វារកំផែងរបស់ឯងផង[ត]។

១០កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង បាននាំឯងចូល
ទៅក្នុងស្រុក ដែលទ្រង់ស្បថនឹងអ័ប្រាហាំ អ៊ីសាក និងយ៉ា
កុបជាពួកឰយុកោឯងថា និងប្រទានដល់ឯង គឺជាទីក្រុង
ធំហើយល្អ ដែលឯងមិនបានសង់[ថ] ១១ព្រមទាំងផ្ទះពេញ
ដោយរបស់ល្អគ្រប់មុខ ដែលឯងមិនបានប្រមូលទុកនឹង
ស្រះជីកស្រាប់[ទ] ដែលឯងមិនបានជីក ហើយទាំងចំការ
ទំពាំងបាយជូរ នឹងដើមអូលីវ ដែលឯងមិនបានដាំ រួចឯង
បានបរិភោគឆ្អែត[ធ] ១២នោះចូរប្រយ័ត្នក្រែងភ្លេច[ន]ព្រះ
យេហូវ៉ា ដែលទ្រង់បាននាំឯងចេញពីផ្ទះបាវបំរើ នៅស្រុក
អេស៊ីព្ទមក ១៣ត្រូវឱ្យកោតខ្លាចដល់ព្រះយេហូវ៉ា[ប] ជាព្រះនៃ
ឯង ហើយគោរពប្រតិបត្តិដល់ទ្រង់[ផ] ព្រមទាំងស្បថ[ព]ដោយ
នូវព្រះនាមទ្រង់[ភ] ១៤មិនត្រូវឱ្យឯងរាល់គ្នាទៅតាមព្រះឯ
ណាទៀត ក្នុងពួកព្រះរបស់សាសន៍ទាំងប៉ុន្មានដែលនៅជុំ
វិញឯងឡើយ ១៥ដ្បិតព្រះយេហូវ៉ា ជាព្រះនៃឯង[ម] ដែល
ទ្រង់គង់នៅកណ្ដាលពួកឯង ទ្រង់ជាព្រះប្រចណ្ឌ ក្រែង
សេចក្ដីខ្ញាល់នៃព្រះយេហូវ៉ា ជាព្រះនៃឯង បានក្ដៅឡើង
ទាស់នឹងឯង រួចទ្រង់បំផ្លាញឯងរាល់គ្នាពីលើផែនដីនេះ
ចេញទៅ ។

១៦កុំឱ្យឯងរាល់គ្នាល្បងលព្រះយេហូវ៉ា[យ]ជាព្រះនៃឯង
ដូចជាបានល្បងទ្រង់នៅត្រង់ម៉ាសានោះឡើយ ១៧ត្រូវឱ្យ
កាន់[រ]អស់ពីចិត្ត តាមអស់ទាំងសេចក្ដីបញ្ញត្តិផងព្រះយេហូវ៉ា
ជាព្រះនៃឯង ព្រមទាំងសេចក្ដីបន្ទាល់ នឹងច្បាប់ទាំង
ប៉ុន្មានដែលទ្រង់បានបង្គាប់មក[ល] ១៨ក៏ត្រូវតែប្រព្រឹត្តការ
ទៀងត្រង់ ហើយល្អនៅព្រះនេត្រព្រះយេហូវ៉ា[វ] ដើម្បីឱ្យ
បានសប្បាយ[ស] ហើយឱ្យបានចូលទៅទទួលយកស្រុកដ៏ល្អ
ដែលទ្រង់បានស្បថនឹងពួកឰយុកោឯងថា ១៩ទ្រង់នឹង
បណ្ដេញអស់ទាំងខ្មាំងសត្រូវ[ហ]ពីមុខឯងចេញ ដូចជាព្រះ
យេហូវ៉ាបានសន្យាហើយ ។

២០កាលណាដល់ថ្ងៃក្រោយ កូនឯងសួរ[ឡ]ថា អស់ទាំងទី
បន្ទាល់ នឹងច្បាប់ ហើយបញ្ញត្តិទាំងនេះ ដែលព្រះយេហូវ៉ា
ជាព្រះនៃយើង បានបង្គាប់មក តើមានន័យដូចម្ដេច
២១នោះត្រូវឱ្យឆ្លើយថា ពីដើមយើងរាល់គ្នាជាបាវបំរើ
របស់ផារ៉ោននៅស្រុកអេស៊ីព្ទ តែព្រះយេហូវ៉ាទ្រង់បាន
នាំយើងចេញពីស្រុកអេស៊ីព្ទមក ដោយព្រះហស្តដ៏មាន
ព្រះចេស្ដា[អ] ២២ហើយទ្រង់បានធ្វើទីសំគាល់ នឹងការអស្ចារ្យ
ដ៏ជាធំ ហើយវេទនាផង ដល់ពួកស្រុកអេស៊ីព្ទ នឹងផារ៉ោន
ព្រមទាំងវង្សារបស់ទ្រង់ផង នៅភ្នែកយើងរាល់គ្នា ២៣ក៏
បាននាំយើងចេញពីស្រុកនោះ ដើម្បីនឹងនាំចូលមក ឱ្យ
បានប្រទានស្រុកនេះមកយើង ជាស្រុកដែលទ្រង់បានស្បថ
នឹងពួកឰយុកោយើង ២៤ហើយព្រះយេហូវ៉ាទ្រង់បានបង្គាប់
ឱ្យយើងរាល់គ្នាប្រព្រឹត្តតាមអស់ទាំងច្បាប់ទាំងនោះ ហើយ
ឱ្យកោតខ្លាចដល់ព្រះយេហូវ៉ា ជាព្រះនៃយើង[ក] ដើម្បីឱ្យ
យើងរាល់គ្នាបានសប្បាយជាដរាប ហើយឱ្យទ្រង់បាន
ថែរក្សាទុកជីវិតយើងរាល់គ្នា ដូចជាមានសព្វថ្ងៃនេះ[ខ]

**៦:៥** ដ ១សយ ១២:២៤ ឋ ចទ ៤:២៩ ១០:១២ យស ២២:៥ **៦:៦** ឌ ខ.៨ ចទ ១១:១៨ ៣០:១៤ ៣២:៤៦ ទដ ២៦:២ ៣៧:៣១ ៤០:៨ ១១៩:១១ សភ ៣:៣ អស ៥១:៧ យរ ១៧:១ ៣១:៣៣ អគ ៤០:៤ **៦:៧** ឍ ចទ ៤:៩ ១១:១៩ សភ ២២:៦ អភ ៦:៤ **៦:៨** ណ ខ.៦ នក ១៣:៩ មថ ២៣:៥ **៦:៩** ត ចទ ១១:២០ **៦:១០** ថ លប ១១:៤ ចទ ១២:២៩ ១៩:១ យស ២៤:១៣ ទដ ១០៥:៤៤ **៦:១១** ទ យរ ២:១៣ ធ លវ ២៦:៥ ចទ ៨:១០ ១៤:២៩ ៣១:២០ **៦:១២** ន ចទ ៤:៩,២៣ ២ពវ ១៧:៣៨ ទដ ៤៤:១៧ ៧៨:៧ ១០៣:២ **៦:១៣** ប ទដ ៣៣:៨ ៣៤:៩ ផ ចទ ១៣:៤ ១សយ ៧:៣ យរ ៤៤:១០ មថ ៤:១០ លក ៤:៤ ៤:៨ ព ១សយ ២០:៣ ភ នក ២០:៧ មថ ៥:៣៣

**៦:១៥** ម ចទ ៤:២៤ ៥:៩ **៦:១៦** យ នក ១៧:២ មថ ៤:៧ លក ៤:១២ **៦:១៧** រ លវ ២៦:៣ ល ចទ ១១:២២ ទដ ១១៩:៤,៥៦,១០០, ១៣៤,១៦៨ **៦:១៨** វ ២ពវ ១៨:៦ អស ៣៦:៧ ៣៨:៣ ស ចទ ៤:៤០ **៦:១៩** ហ នក ២៣:២៧ យស ២១:៤៤ ទដ ៧៨:៥៣ ១០៧:២ ១៣៦:២៤ **៦:២០** ឡ នក ១០:២ **៦:២១** អ ចទ ៤:៣៤ **៦:២៤** ក ចទ១០:១២ ៣០:៦ ទដ ៨៦:១១ យរ ៣២:៣៩ ខ ទដ ២៧:១២ ៤១:២ រម ១០:៥

មើលការពន្យល់ ៤:២៩ យស ២២:៥ ។

**៦:៦** *សេចក្ដីទាំងនោះ . . . ត្រូវនៅជាប់ក្នុងចិត្តឯងចុះ* គឺជាលក្ខណៈសម្បត្តិផ្នែក "គឺការតាំងសញ្ញាថ្មី" មើល ៣១:៣១–៣៣ ១កថ ៣:៣ ។

**៦:៨–៩** សាសន៍យូដាជាច្រើនបានយកខគម្ពីរទាំងនេះ បិតដាក់លើថ្ងាសពួកគេនិងនៅលើស្មាឆ្វេងពួកគេ ។ (មើលការពន្យល់ មថ ២៣:៥) ឬបានចារឆ្លាក់លើផ្ទាំងឈើ ឬកំប៉ុងលោហៈ ឬតាមរបងផ្ទះ មើល ១១:១៨–២០ នក ១៣:៩,១៦ នក ១៣:៩ ។

**៦:១០–១២** ពីព្រោះអត្ថបទព្រះគម្ពីរបានផ្ដោតធ្ងន់ទៅលើព្រះនូវអ្វីដែលទ្រង់បានសម្ដែង មើលការពន្យល់ ៤:១០ ។

**៦:១៣** សេចក្ដីដកស្រង់ខ្លះ តាមព្រះយេស៊ូវក្នុងការឆ្លើយតបចំពោះការល្បួងរបស់សាតាំង(មថ ៤:១០ លក ៤:៨) ។ ព្រះយេស៊ូវបានដកស្រង់ចេញពីគម្ពីរចោទិយកថា ក្នុងការឆ្លើយតបទៅចំពោះសេចក្ដីល្បួងពីផ្សេងទៀតផងដែរ (សូមមើល ខ.១៦ ៨:៣) ។ *ឱ្យកោតខ្លាចដល់ព្រះយេហូវ៉ា* មើលការពន្យល់ លប ២០:១១ ។

**៦:១៥** *ទ្រង់ជាព្រះប្រចណ្ឌ* មើល ៤:២៤ ៥:៩ មើល នក ២០:៥ ផងដែរ ។

**៦:១៦** ការដកស្រង់ដែលព្រះយេស៊ូវបានយកចេញពីគម្ពីរ មថ ៤:៧ លក ៤:១២ មើល ខ.១៣ ។ *ដូចជាបានល្បងទ្រង់នៅត្រង់ម៉ាសា* មើលត្រង់ ៩:២២ ៣៣:៨ មើលការពន្យល់ នក ១៧:៧ ។

**៦:២០** មើល នក ១២:២៦ និងការពន្យល់ ។

**៦:២៣** *នាំចេញពីស្រុកនោះ . . . នាំចូលមក* មើល នក ៦:៧–៨ ។

២៥ដូច្នេះបើយើងប្រយ័ត្ននឹងកាន់តាមបញ្ញត្តិទាំងនោះ[គ] នៅ
ចំពោះព្រះយេហូវ៉ា ជាព្រះនៃយើង ដូចជាទ្រង់បានបង្គាប់
មក នោះនឹងបានរាប់ជាសេចក្ដីសុចរិតដល់យើងហើយ[ឃ] ។

## ការដេញសាសន៍ដទៃ

**៧** ១កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង បាននាំឯងចូល
ទៅក្នុងស្រុកដែលត្រូវចូលទៅទទួលយក[ក]នោះ ហើយទ្រង់
បានដេញសាសន៍ជាច្រើន[ខ] ពីមុខឯងចេញ គឺជាសាសន៍
ហេត[គ] សាសន៍គើកាស៊ី[ឃ] សាសន៍អាម៉ូរី[ង] សាសន៍កាណាន
សាសន៍ពេរិស៊ីត[ច] សាសន៍ហេវី[ឆ] និងសាសន៍យេប៊ូស[ជ]ទាំង
៧សាសន៍នោះដែលធំ ហើយពូកែជាងឯង ២កាលណាព្រះ
យេហូវ៉ាជាព្រះនៃឯង បានប្រគល់[ឈ]សាសន៍ទាំងនោះមក
ឯង ហើយឯងបានឈ្នះគេ នោះត្រូវឱ្យបំផ្លាញ[ញ]គេឱ្យអស់
រលីងចេញ[ដ] មិនត្រូវតាំងសញ្ញា[ឋ]នឹងគេ ឬអាណិតមេត្តា
ដល់គេឡើយ[ឌ] ៣ក៏មិនត្រូវរៀបការជាមួយនឹងគេ[ឍ] ឬឱ្យកូន
ស្រីឯង ទៅកូនប្រុសគេ ហើយយកកូនស្រីគេមកឱ្យកូនប្រុស
ឯងនោះដែរ ៤ដ្បិតគេនឹងបង្វែរកូនឯងពីអញចេញ ឱ្យទៅ
គោរពប្រតិបត្តិតាមព្រះដទៃ[ណ] យ៉ាងនោះសេចក្ដីខ្ញាល់នៃ
ព្រះយេហូវ៉ានឹងត្រូវកាត់ឡើងទាស់នឹងឯងរាល់គ្នា ហើយ
ទ្រង់នឹងបំផ្លាញ[ត]ឯងចេញជាឆាប់ ៥ត្រូវឱ្យឯងរាល់គ្នា
ប្រព្រឹត្តនឹងគេយ៉ាងនេះវិញ គឺត្រូវរំលំអាសនារបស់គេ
បំបាក់បំបែកបង្គោល[ថ]ដែលសំរាប់គោរព ហើយបំផ្លាញ
អ្នកតា ព្រមទាំងដុតរូបឆ្លាក់របស់គេនៅក្នុងភ្លើងទៅ[ទ] ៦ដ្បិត
ឯងជាសាសន៍បរិសុទ្ធ[ធ]ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង
ហើយព្រះយេហូវ៉ា ជាព្រះនៃឯង[ន] ទ្រង់បានរើស[ប]យកឯង
ឱ្យបានជារបស់ផងទ្រង់ លើសជាងអស់ទាំងសាសន៍ ដែល
នៅផែនដីផង[ផ] ។
៧ព្រះយេហូវ៉ាទ្រង់មិនបានស្រឡាញ់ឯងរាល់គ្នា ឬរើស
ឯង ដោយព្រោះឯងមានគ្នាច្រើន[ព]ជាងសាសន៍ឯទៀតនោះ
ទេ ដ្បិតឯងរាល់គ្នាជាសាសន៍តិច[ភ]ជាងសាសន៍ទាំងអស់[ម]
៨គឺដោយព្រោះព្រះយេហូវ៉ាទ្រង់ស្រឡាញ់[យ]ឯងរាល់គ្នា
វិញ ហើយដោយព្រោះទ្រង់ចង់កាន់តាមសេចក្ដីសម្បថ[រ]
ដែលទ្រង់បានស្បថនឹងពួកព្ធយុកោឯង បានជាទ្រង់នាំឯង
ចេញមក ដោយព្រះហស្តដ៏មានព្រះចេស្តា[ល] ហើយបាន
លោះ[វ]ឯងពីផ្ទះពួកបាវបំរើ[ស] គឺពីកណ្ដាប់ដៃនៃផារ៉ោន
ជាស្តេចស្រុកអេស៊ីព្ទមក ៩ដូច្នេះចូរដឹងថា ព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់ពិតជាព្រះហើយ[ហ] គឺជាព្រះស្មោះត្រង់[ឡ]
ដែលទ្រង់កាន់ តាមសេចក្ដីសញ្ញា ហើយនិងសេចក្ដី
សប្បុរស[អ]ដរាបដល់ទាំងពាន់ដំណ[ក] របស់ពួកអ្នកដែល

**៦:២៥** គ ទដ ១០៣:១៨ ១១៩:៣៤,៥៥ ឃ ចទ ២៤:១៣ រម ៩:៣១ រម ១០:៣,៥
**៧:១** ក លវ ១៤:៣៤ ចទ ៤:៣៨ ខ ចទ ២០:១៦–១៨ ៣១:៣ គ លប ១៥:២០ ឃ លប ១០:១៦ ង ចទ ១:៧ ច លប ១៣:៧ ឆ លប ១០:១៧ ជ យស ៣:១០
**៧:២** ឈ ចទ ២:៣៣ ញ ចទ ២:៣៤ ដ ជន ៣១:១៧ ចទ ៣៣:២៧ យស ១១:១១ ឋ នក ២៣:៣២ ឌ ខ.១៦ ចទ ១៣:៨ ១៩:១៣ ២៥:១២
**៧:៣** ឍ នក ៣៤:១៥–១៦ យស ២២:១៦ ដយ ៩:៧
**៧:៤** ណ ពច ៣:៦ ត ចទ ៤:២៦
**៧:៥** ថ នក ៣៤:១៣ ចទ ១៦:២១ ទ នក ២៣:២៤
**៧:៦** ធ នក ១៩:៦ លវ ២៧:៣០ ន ចទ ២៦:១៩ ទដ ៣០:៤ ៣៧:២៨ ៥០:៥ ៥២:៩ ប ចទ ១៤:២ ១ពវ ៣:៨ អស ៤១:៩ អគ ២០:៥ ផ លប ១៧:៧ នក ៨:២២ ៣៤:៩ អស ៤៣:១ រម ៩:៤ ទត ២:១៤ **៧:៧** ព លប ២២:១៧ ភ លប ៣៤:៣០ ម ចទ ៤:៣៧ ១០:២២ **៧:៨** យ ចទ ៤:៣៧ ១ពវ ១០:៩ ២របា ២:១១ ទដ ៤៤:៣ រ នក ៣២:១៣ ជន ១៤:៨ រម ១១:២៨ ល នក ៣:២០ វ នក ៦:៦ ស នក ១៣:១៤ **៧:៩** ហ ចទ ៤:៣៥ ឡ ទដ ១៨:២៥ ៣៣:៤ ១០៨:៤ ១៤៥:១៣ ១៤៦:៦ អស ៤៩:៧ យរ ៤២:៥ ហស ១១:១២ ១កថ ១:៩ អ ខ.១២ ១ពវ ៨:២៣ ២របា ៦:១៤ នហ ១:៥ ៩:៣២ ក នក ២០:៦

**៦:២៥** *សេចក្ដីសុចរិត* ជាការបង្ហាញពីមនុស្សដ៏ពិត ដែលមានទំនាក់ទំនងល្អ និងការតាំងសញ្ញា ដែលព្រះបានសម្ដែងតាមរយៈការរស់នៅរាល់តែថ្ងៃសម្រាប់មនុស្សរបស់ព្រះ (សូមមើល ២៤:១៣) ។

**៧:១–៦** ពេលពិនិត្យយ៉ាងប្រុងប្រយ័ត្ននៅក្នុងព្រះគម្ពីរ ១ពវ ១១:១–១៣ អរ ៩:១–២,១០–១២,១៤ ។ គឺបានបញ្ជាក់ពីការហាមឃាត់ពីការរៀបការនិងសាសន៍ដទៃ ម្យ៉ាងវិញទៀតអ្នកខាងក្រៅនោះ ដែលបានដាក់ខ្លួនគេទៅក្រោមក្រឹត្យវិន័យព្រះអង្គ ហើយចុះចូលនឹងសេចក្ដីសញ្ញា និងធ្វើខ្លួនដូចជាសាសន៍អ៊ីស្រាអែល ។ មើល នក ១២:៤៨–៤៩ លវ ១៧:៨–៩ ១៩:៣៣–៣៤ មើលអំពីនាងរ៉ាហាប យស ២ ៦:១៧,២២–២៥ និងនាងរស់គឺគម្ពីរនាងរស់ មើល មថ ១:៥ ។

**៧:១** *សាសន៍ហេត . . . សាសន៍យេប៊ូស* មើល ២០:១៧ ក៏សូមមើលការពន្យល់ លប ១០:៦,១៥–១៨ ១៣:៧ យស ៩:៧ ។ *ទាំង៧សាសន៍* មើលការពន្យល់ នក ៣:៨ ។

**៧:២–៥** *មិនត្រូវតាំងសញ្ញានឹងគេ . . . មិនត្រូវរៀបការជាមួយនឹងគេ . . . គឺត្រូវរំលំអាសនា* គឺប្រជាជនអ៊ីស្រាអែលមិនត្រូវមានទំនាក់ទំនង និងនយោបាយ ឬទំនាក់ទំនងសាសនាជាមួយនឹងអ្នកដែលថ្វាយបង្គំរូបព្រះរបស់ពួកកាណាន (មើល ខ.១៦ ប្រៀបធៀប មឡ ២:១១ និងការពន្យល់) ។

**៧:២** *បំផ្លាញគេឱ្យអស់រលីងចេញ* មើលការពន្យល់ ២:២៤ ។

**៧:៤** *បង្វែរកូនឯងពីអញចេញ . . . ប្រតិបត្តិតាមព្រះដទៃ* ព្រះអង្គបានព្រមានសាជាថ្មីកុំឱ្យរៀបការជាមួយសាសន៍ដទៃ គឺជាការបំបាក់ទឹកចិត្តវិញ ហើយត្រូវទប់ស្កាត់ការលះបង់សេចក្ដីជំនឿលើព្រះ ដែលជាហេតុធ្វើឱ្យមានភាពមិនស្អាត ។ (មើល ១ពវ ១១:១–១១ នហ ១៣:២៥–២៧) ។

**៧:៥** *អាសនា . . . បង្គោល . . . រូបឆ្លាក់* គឺជាវត្ថុសម្រាប់ថ្វាយបង្គំរបស់ពួកកាណាន មើល ១២:៣ ១៦:២១–២២ នក ៣៤:១៣ និងការពន្យល់ ។

**៧:៦** *បរិសុទ្ធ* គឺបានញែកដាច់ចេញពីមនុស្សពុករលួយមិនស្អាត ឬវត្ថុមិនស្អាត ហើយបើកចិត្តចំពោះព្រះ ។

**៧:៨** *ព្រោះព្រះយេហូវ៉ាទ្រង់ស្រឡាញ់ឯង* មើល ៤:៣៧ និងការពន្យល់ ។

**៧:៩,១២** *កាន់តាមសេចក្ដីសញ្ញា* ១ពវ ៨:២៣ នហ ១:៥ ដយ ៩:៤ ប្រៀបធៀប ទដ ៨៩:២៨ ១០៦:៤៥ សេចក្ដីសញ្ញាដែលព្រះបានស្បថដល់ពួកអ៊ីស្រាអែល គឺពុំដែលផុតឡើយ (ព្រះមេត្តាករុណា មើល ទដ ៦:៤ គ្រប់ទាំងដំណើររបស់ទ្រង់ គឺបង្ហាញឱ្យឃើញនូវព្រះបន្ទូលសន្យាដល់ពួកគេ មើល ខ.១៣–១៥ ១៩:២៤ ២៨:១–១៤ ៣០:១–១០ មើល លប ២២:១៧–១៨ លវ ២៦:៣–១៣) គឺទ្រង់នឹងបំពេញនូវការសន្យា ។ ព្រះបន្ទូលសន្យា ដែលទ្រង់នឹងផ្ដល់ឱ្យ"គឺសេចក្ដីសញ្ញានៃភាពសុខសាន្ត" ជន ២៥:១២ អស ៥៤:១០ ។

**៧:៩** *ដឹងថា . . . ជាព្រះនៃឯង* សូមមើល ១១:២៨ ទដ ១០០:៣ និងការពន្យល់ ។ *ដល់ពាន់ដំណ . . . កាន់តាមបញ្ញត្តិរបស់ទ្រង់* សូមមើលការ

ស្រឡាញ់ទ្រង់ ហើយកាន់តាមបញ្ញត្តិរបស់ទ្រង់[ខ] ១០ហើយ
ទ្រង់ក៏សងដល់ពួកអ្នកដែលស្អប់ទ្រង់នៅប្រទល់មុខគេ ដើម្បី
នឹងបំផ្លាញគេចេញ ទ្រង់មិនបង្អង់ដល់អ្នកណាដែលស្អប់
ទ្រង់ឡើយ[គ] គឺទ្រង់នឹងសងគេនៅប្រទល់មុខវិញ ១១ដូច្នេះ
ត្រូវឱ្យឯងកាន់តាមអស់ទាំងសេចក្តីបង្គាប់ និងច្បាប់
ហើយនិងបញ្ញត្តិទាំងប៉ុន្មាន ដែលអញបង្គាប់ឯងនៅថ្ងៃនេះ
ដើម្បីនឹងប្រព្រឹត្តតាមចុះ ។

១២បើសិនណា ជាឯងរាល់គ្នានឹងស្តាប់តាមអស់ទាំងបញ្ញត្តិ
ទាំងនេះ ព្រមទាំងកាន់ខ្ជាប់ ហើយប្រព្រឹត្តតាម នោះព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងកាន់តាមសេចក្តីសញ្ញា នឹង
សេចក្តីសប្បុរសចំពោះឯង ជាសេចក្តីដែលទ្រង់បានស្បថ
នឹងពួកព្ធយុកោនៃឯង[ឃ] ១៣ទ្រង់នឹងស្រឡាញ់ឯង[ង] ព្រមទាំង
ប្រទានពរ ហើយចំរើនឱ្យឯងមានគ្នាច្រើនឡើង[ច] ទ្រង់ក៏នឹង
ប្រទានពរដល់ផលដែលកើតពីពោះឯងមក[ឆ] និងផលពីដី
ឯងផង គឺជាស្រូវ និងទឹកទំពាំងបាយជូរ[ជ] ហើយនិងប្រេង[ឈ]
ព្រមទាំងផលចំរើនពីហ្វូងគោ និងកូនពីហ្វូងចៀមរបស់ឯង
នៅក្នុងស្រុកដែលទ្រង់បានស្បថនឹងពួកព្ធយុកោថា ទ្រង់នឹង
ឱ្យដល់ឯង[ញ] ១៤ឯងនឹងបានពរលើសជាងអស់ទាំងសាសន៍ឯ
ទៀត នៅក្នុងពួកឯងនឹងគ្មានប្រុស ឬស្រី សត្វឈ្មោល ឬញី
ណា នៅជាអារទេ[ដ] ១៥ព្រះយេហូវ៉ាទ្រង់នឹងដកអស់ទាំងជំងឺ
ពីឯងចេញ ហើយទ្រង់មិនឱ្យឯងកើតមានជំងឺ ដ៏អាក្រក់ណា
មួយ[ឋ] របស់ស្រុកអេស៊ីព្ទ[ឌ] ដែលឯងស្គាល់ហើយនោះទេ គឺ
នឹងដាក់ជំងឺទាំងនោះទៅលើពួកអ្នកទាំងប៉ុន្មានដែលស្អប់
ឯងវិញ[ឍ] ១៦ហើយឯងនឹងបានធ្វើឱ្យអស់ទាំងសាសន៍ ដែល
ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រគល់មកឯង[ណ] បានរោយ
រៀវទៅ ភ្នែកឯងមិនត្រូវប្រណីដល់គេឡើយ[ត] ក៏មិនត្រូវ
គោរពប្រតិបត្តិដល់ព្រះគេដែរ[ថ] ដ្បិតនោះនឹងបានជាអន្ទាក់[ទ]
ដល់ឯងវិញ ។

១៧បើសិនជាឯងនឹកក្នុងចិត្តថា សាសន៍ទាំងនេះគេមាន
គ្នាច្រើនជាងអញ ធ្វើដូចម្តេចឱ្យអញចាប់យកស្រុករបស់
គេបាន[ធ] ១៨នោះកុំឱ្យខ្លាចឡើយ[ន] ចូរនឹកតែពីអស់ទាំងការ
ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានធ្វើដល់ផារ៉ោន
ហើយដល់ស្រុកអេស៊ីព្ទទាំងមូលប៉ុណ្ណោះចុះ[ប] ១៩គឺពីការ

**៧:៩** ខ ចទ ៥:១០ **៧:១០** គ លវ ២៦:២៨ ជន ១០:៣៥ ណហ ១:២ **៧:១២** ឃ លវ ២៦:៣–១៣ ចទ ២៨:១–១៤ ទដ ១០៥:៨–៩ មីក ៧:២០ **៧:១៣** ង ទដ ១១:៥ ១៤៦:៨ សភ ១៥:៩ អស ៥១:១ យហ ១៤:២១ ច លប ១៧:៦ នក ១:៧ ចទ ១:១០ ១៣:១៧ ចទ ១:១០ ១៣:១៧ ៣០:៥ ទដ ១០៧:៣៨ ឆ លប ៤៩:២៦ ជ លប ២៧:២៨ ឈ ជន ១៨:១២ ញ ចទ ២៨:៤ **៧:១៤** ដ នក ២៣:២៦ **៧:១៥** ឋ នក ១៥:២៦ ឌ នក ៩:៩ ឍ នក ២៣:២៥ ចទ ៣០:៨–១០ **៧:១៦** ណ ខ.២៤ យស ៦:២ ១០:២៦ ត ខ.២ ថ ពច ៣:៦ អរ ៩:១ ទដ ១០៦:៣៦ ទ ខ.២៥ នក ១០:៧ **៧:១៧** ធ ជន ៣៣:៥៣ **៧:១៨** ន ជន ១៤:៩ ចទ ១:២១,២៩ ប ទដ ១០៥:៥ ១១៩:៥២ **៧:១៩** ផ ទដ ១៣៦:១២ ព ចទ ៤:៣៤ **៧:២០** ភ នក

ល្បងលយ៉ាងធំ ដែលភ្នែកឯងបានឃើញ និងទីសំគាល់
ហើយការអស្ចារ្យទាំងប៉ុន្មាន និងពីព្រះហស្តដ៏មានព្រះ
ចេស្តា[ផ] ហើយនិងព្រះពាហុលើកសំរេច ដែលព្រះយេហូវ៉ា
ជាព្រះនៃឯងបានប្រើ ដើម្បីនឹងនាំឯងចេញមកនោះ គឺ
យ៉ាងនោះដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងធ្វើដល់
គ្រប់អស់ទាំងសាសន៍ ដែលឯងខ្លាចនោះដែរ[ព] ២០មួយទៀត
ព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់នឹងចាត់ឪម៉ាល់[ភ] ទៅកណ្តាល
គេទាល់តែពួកគេដែលសល់នៅហើយពួននឹងឯង បាន
វិនាសចេញអស់ទៅ ២១មិនត្រូវឱ្យឯងភ័យខ្លាច ដោយព្រោះ
គេឡើយ ដ្បិតព្រះយេហូវ៉ា ជាព្រះនៃឯង គឺជាព្រះដ៏ធំ
ហើយគួរស្ញែងខ្លាច[ម] ទ្រង់គង់កណ្តាលពួកឯងហើយ[យ]
២២ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងបណ្តេញសាសន៍
ទាំងនោះ ចេញពីមុខឯងបន្តិចម្តងៗ[រ] មិនត្រូវឱ្យឯងរាល់គ្នា
បំផ្លាញគេទាំងអស់ដោយរហ័សពេកឡើយ ក្រែងសត្វព្រៃ
ចំរើនឡើងដល់ឯងវិញ ២៣ព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់នឹងប្រគល់គេមកឯង ហើយនិងកំចាត់កំចាយគេ ដោយ
សេចក្តីបាក់ភ្លូកយ៉ាងសំបើម ទាល់តែគេវិនាសបាត់អស់
ទៅ[ល] ២៤ហើយទ្រង់នឹងប្រគល់ពួកស្តេច[វ] គេមកក្នុងកណ្តាប់
ដៃឯងដែរ[ស] នោះឯងនឹងធ្វើឱ្យឈ្មោះគេរលាយបាត់ពី
ក្រោមមេឃចេញ និងគ្មានអ្នកណាអាចនឹងឈរនៅមុខឯង
បានឡើយ[ហ] ដរាបដល់ឯងបានបំផ្លាញគេអស់រលីងទៅ[ឡ]
២៥ត្រូវឱ្យឯងដុត[អ] អស់ទាំងរូបព្រះឆ្លាក់របស់គេចេញ មិន
ត្រូវឱ្យស្តាយ[ក] ប្រាក់ ឬមាស ដែលជាប់នៅនឹងរូបទាំងនោះ
ឡើយ ក៏មិនត្រូវយកមកសំរាប់ខ្លួនដែរ ក្រែងលោឯងត្រូវ
ជាប់អន្ទាក់[ខ] យ៉ាងនោះ ដ្បិតរបស់ទាំងនោះជាទីស្អប់ខ្ពើម[គ]
នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង ២៦មិនត្រូវឱ្យឯងនាំ
យករបស់ដែលគួរស្អប់ខ្ពើម មកក្នុងផ្ទះឯងឡើយ ក្រែងឯង
ត្រឡប់ទៅជាត្រូវវិនាស[ឃ] ដូចរបស់ទាំងនោះដែរ ត្រូវឱ្យ

២៣:២៨ **៧:២១** ម ចទ ១០:១៧ នហ ១:៥ ៩:៣២ ទដ ៤៧:២ ៦៦:៣ ៦៨:៣៥ អស ៩:៦ ដយ ៩:៤ យ លប ១៧:៧ យស ៣:១០ **៧:២២** រ នក ២៣:២៨–៣០ **៧:២៣** ល នក ២៣:២៧ យស ១០:១០ **៧:២៤** វ យស ១០:២៤ ទដ ១១០:៥ ស ខ.១៦ ហ នក ២៣:៣១ ចទ១១:២៥ យស ១:៥ ១០:៨ ២៣:៩ ឡ យស ២១:៤៤ **៧:២៥** អ នក ៤:១៤ ៣២:២០ ក នក ២០:១៧ យស ៧:២១ ខ ខ.១៦ គ ចទ ១៧:១ **៧:២៦** ឃ លវ ២៧:២៨–២៩

ពន្យល់ នក ២០:៦ ។

**៧:១២–១៥** ព្រះអម្ចាស់បានបញ្ជាក់យ៉ាងច្បាស់ សូមមើល ២៨:១–១៤ ៣០:១–១០ ។

**៧:១៣** *ស្រូវ និងទឹកទំពាំងបាយជូរ ហើយនិងប្រេង* ព្រះគម្ពីរសញ្ញាចាស់បញ្ជាក់សង្ខេបចំពោះភោគផល ពីដើមទំពាំងបាយជូរ និងប្រេងអូលីវ (សូមមើល ១១:១៤ ១៤:២៣ ១៨:៤ ២៨:៥១) ។

**៧:១៥** *មិនឱ្យឯងកើតមានជំងឺ . . . ជំងឺ* មើលការពន្យល់ ២៨:៦០ ។

**៧:១៨** *ចូរនឹក* មើលការពន្យល់ ៤:១០ ។

**៧:២០** *ឪម៉ាល់* មើលការពន្យល់ នក ២៣:២៨ ។

**៧:២២** *ទ្រង់នឹងបណ្តេញសាសន៍ទាំងនោះចេញ* មើលការពន្យល់ ៣:២២ ។ *សត្វព្រៃចំរើនឡើងដល់ឯងវិញ* ការបណ្តេញសាសន៍កាណានចេញយ៉ាងរហ័ស នាំឱ្យមានសត្វព្រៃចម្រើនឡើង ព្រោះមានសល់ដីវាលជាច្រើន ។

ឯងស្អប់អស់ពីចិត្ត ហើយខ្ពើមរបស់យ៉ាងនោះឱ្យអស់ពីចិត្ត
ដែរ ដ្បិតជារបស់ត្រូវវិនាសទៅ ។

**កុំភ្លេចព្រះអម្ចាស់**

**៨** ១ឯអស់ទាំងសេចក្ដីបង្គាប់ ដែលអញប្រាប់ដល់ឯងរាល់
គ្នានៅថ្ងៃនេះ នោះត្រូវឱ្យឯងកាន់ខ្ជាប់ ហើយប្រព្រឹត្តតាម
ដើម្បីឱ្យបានរស់នៅ[ក] ហើយចំរើនជាច្រើនឡើង ហើយឱ្យ
បានចូលទៅទទួលយកស្រុកដែលព្រះយេហូវ៉ា បានស្បថ
នឹងពួកព្ធយុកោឯង[ខ] ២ត្រូវឱ្យឯងនឹកចាំពីអស់ទាំងការដែល
កើតមានតាមផ្លូវ ដែលព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់បាន
នាំ[គ]ឯងនៅក្នុងទីរហោស្ថាន ក្នុងរវាង៤០ឆ្នាំនេះ ដើម្បីនឹង
បន្ទាបចិត្តឯង ហើយនិងល្បងល[ឃ]ឯងឱ្យដឹងជាសេចក្ដីណា
ដែលនៅក្នុងចិត្តឯង គឺបើនឹងកាន់តាមបញ្ញត្តិទ្រង់ឬទេ
៣ទ្រង់ក៏បានបន្ទាបចិត្ត[ង]ឯងមែន ព្រមទាំងឱ្យឃ្លានផង រួច
បានចិញ្ចឹមឯងដោយនំម៉ាន៉ា[ច] ដែលឯង និងពួកព្ធយុកោឯង
មិនដែលស្គាល់ឡើយ ដើម្បីឱ្យឯងបានដឹង[ឆ]ថា មនុស្សមិន
មែនរស់ដោយសារតែនំបុ័ង[ជ]ប៉ុណ្ណោះទេ គឺរស់ដោយសារ
គ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋ[ឈ]នៃព្រះយេហូវ៉ា
មកដែរ[ញ] ៤សំលៀកបំពាក់ឯងមិនបានសឹកនៅលើខ្លួន
សោះ ហើយជើងឯងក៏មិនបានពុរពងនៅរវាង៤០ឆ្នាំនេះ
ផង[ដ] ៥ក៏ត្រូវនឹកពិចារណាក្នុងចិត្តថា ព្រះយេហូវ៉ា ជាព្រះ
នៃឯង ទ្រង់បានវាយផ្ចាលឯង ដូចជាមនុស្សវាយផ្ចាលកូន
របស់ខ្លួន[ឋ] ៦ដូច្នេះត្រូវឱ្យកាន់តាមអស់ទាំងបញ្ញត្តិរបស់
ព្រះយេហូវ៉ា ជាព្រះនៃឯងដើម្បីនឹងដើរតាមអស់ទាំងផ្លូវ[ឌ]
របស់ទ្រង់ ព្រមទាំងកោតខ្លាចដល់ទ្រង់ផង[ឍ] ៧ដ្បិតព្រះ
យេហូវ៉ាជាព្រះនៃឯង ទ្រង់នាំឯងចូលទៅក្នុងស្រុកដ៏ល្អ[ណ]
ជាស្រុកដែលមានស្ទឹង មានរន្ធទឹក ហើយនិងក្បាលទឹក ហូរ
ចេញនៅក្នុងច្រក ហើយក្នុងភ្នំផង[ត] ៨ជាស្រុកដែលមាន
ស្រូវសាលី និងស្រូវឱក[ថ]ក៏មានទំពាំងបាយជូរ[ទ] មានល្វា[ធ]
និងទទឹម ហើយមានដើមអូលីវ និងទឹកឃ្មុំផង[ន] ៩ជាស្រុក
ដែលឯងនឹងបរិភោគអាហារ[ប] មិនមែនដោយរិតដ្បិតទេ
ឯងនឹងមិនខ្វះខាតអ្វីនៅស្រុកនោះឡើយ[ផ] ឯថ្មនៅស្រុកនោះ
សុទ្ធ តែជាដែក ហើយនៅក្នុងភ្នំនោះនឹងជីករកបានទង់
ដែង[ព] ១០ឯងនឹងបរិភោគទាល់តែឆ្អែត[ភ]ហើយនឹងសរសើរ
ដំកើងដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ដោយព្រោះស្រុក
ដ៏ល្អដែលទ្រង់បានប្រទានមក ។

១១ចូរប្រយ័ត្ន ក្រែងភ្លេច[ម]ព្រះយេហូវ៉ា ជាព្រះនៃឯង
ដោយមិនកាន់តាមអស់ទាំងសេចក្ដីបង្គាប់ នឹងច្បាប់ហើយ
និងបញ្ញត្តិទាំងប៉ុន្មានរបស់ទ្រង់ ដែលអញបង្គាប់ដល់ឯង
នៅថ្ងៃនេះ ១២ហើយកាលណាឯងបានបរិភោគឆ្អែត បាន
សង់ផ្ទះយ៉ាងល្អ[យ] ១៣បានហ្វូងគោ ហ្វូងចៀមចំរើនជាច្រើន
ឡើង បានប្រាក់មាសសំបូរឡើង ហើយគ្រប់ទាំងរបស់ឯង
ក៏បានបរិបូរផង ១៤នោះក្រែងចិត្តឯងបានអួតអាង រួច
ភ្លេច[រ]ព្រះយេហូវ៉ាជាព្រះនៃឯង ដែលទ្រង់បាននាំឯងចេញ
រួចពីផ្ទះបាវបំរើ នៅស្រុកអេស៊ីព្ទមក ១៥ហើយបាននាំឯង
ដើរកាត់ទីរហោស្ថានសំបើមគួរស្ញែងខ្លាច[ល] ដែលមាន
ពស់ភ្លើង[វ] និងខ្យាដំរី មានដីហួតហែង ឥតមានទឹក តែទ្រង់
បានធ្វើឱ្យទឹកចេញពីថ្មយ៉ាងរឹងឱ្យឯង[ស] ១៦ក៏បានចិញ្ចឹមឯង
នៅក្នុងទីរហោស្ថាន ដោយនំម៉ាន៉ា[ហ] ដែលពួកព្ធយុកោឯង

**៨:១** ក ចទ ៤:១ ខ នក ១៩:៥ យប ៣៦:១១ ទដ ១៦:១១ អគ ២០:១៩ **៨:២** គ ចទ ២៩:៥ ទដ ១៣៦:១៦ អម ២:១០ ឃ លប ២២:១ **៨:៣** ង ២រប ៣៦:១២ ទដ ៤៤:៩ សភ ១៨:១២ អស ២:១១ យរ ៤៤:១០ ច នក ១៦:៤ ឆ ១ពវ ៨:៣៦ ទដ ២៥:៥ ៩៤:១២ ១១៩:១៧១ ជ ខ.៩ លប ៣:១៩ យប ២៣:១២ ទដ ១០៤:១៥ សភ ២៨:២១ អស ៥១:១៤ យរ ១០៤:១៥ សភ ២៨:២១ អស ៥១:១៤ យរ ៤២:១៤ ឈ យប ២២:២២ ទដ ១១៩:១៣ ១៣៨:៤ ញ នក ១៦:២–៣ មថ ៤:៤ លក ៤:៤ **៨:៤** ដ ចទ ២៩:៥ នហ ៩:២១ **៨:៥** ឋ ចទ ៤:៣៦ ២សយ ៧:១៤ យប ៥:១៧ ៣៣:១៩ សផ ៣:១១–១២ ហព ១២:៥–១១ វវ ៣:១៩ **៨:៦** ឌ នក ៣៣:១៣ ១ពវ ៣:១៤ ទដ ៨១:១៣ ៩៥:១០ ឍ ចទ ៥:៣៣ **៨:៧** ណ ទដ ១០៦:២៤ យរ ៣:១៩ អគ ២០:៦ ត ចទ ១១:៩–១២ យរ ២:៧ **៨:៨** ថ នក ៩:១៣ ទ លប ៤៩:១១ ធ ជន ១៣:២៣ ១ពវ ៤:២៥ ន ចទ ៣២:១៣ ទដ ៨១:១៦ **៨:៩** ប ខ.៣ ផ ពច ១៨:១០ ព យប ២៨:២**៨:១០** ភ ចទ ៦:១០–១២ **៨:១១** ម ចទ ៤:៩ **៨:១២** យ សភ ៣០:៩ ហស ១៣:៦ **៨:១៤** រ ខ.១១ ទដ ៧៨:៧ ១០៦:២១ **៨:១៥** ល ចទ ១:១៩ ៣២:១០ វ ជន ២១:៦ អស ១៤:២៩ ៣០:៦ ស នក ១៧:៦ ចទ ៣២:១៣ យប ២៨:៩ ទដ ៧៨:១៥ ១១៤:៨ **៨:១៦** ហ នក ១៦:១៤

**៧:២៦** *ត្រឡប់ទៅជាត្រូវវិនាស* មើលការពន្យល់ ២:៣៤ ។

**៨:២** *នឹកចាំ* មើលការពន្យល់ ៤:១០ ។ *ល្បងល* មើល ខ.១៦ លប ២២:១ ។

**៨:៣** *នំម៉ាន៉ា* មើល ខ.១៦ ក៏មើលការពន្យល់ ជន ១១:៧ ។ *មនុស្សមិនមែនរស់ដោយសារតែនំបុ័ងប៉ុណ្ណោះទេ* មើលការពន្យល់ ៦:១៣ ជាអត្ថបទដកស្រង់ព្រះបន្ទូលរបស់ព្រះយេស៊ូវ ក្នុងគ្រាដែលទ្រង់ត្រូវល្បួងដោយអារក្សសាតាំង (មើល មថ ៤:៤ លក ៤:៤) ។ នំបុ័ងជារូបធាតុដែលពុំអាចធានាឱ្យមានជីវិតបានទេ តែអំណោយទានពីព្រះត្រូវសម្រាប់អ្នកណាដែលទុកចិត្ត និងរស់ដោយពឹងលើព្រះបន្ទូល ឬបញ្ញត្តិក៏ដូចជាព្រះបន្ទូលសន្យា (មើល ខ.១ ,១៨) "វិន័យរបស់ព្រះ" (ខ.៥) ដល់មនុស្សរបស់ព្រះ ដែលទ្រង់នាំពួកគេកាត់វាលរហោស្ថាន បង្រៀនពួកគេឱ្យមានជំនឿជាមូលដ្ឋានគ្រឹះដោយមានការបន្ទាបខ្លួន (ខ.១៦ ប្រៀបធៀប ខ.១៤) ។

**៨:៧–៩** ការពណ៌នាយ៉ាងសង្ខេប ចំពោះទឹកដីដែលមាន (សំបូរ) ជាដីពោរពេញដោយជីវជាតិ ជាដីសន្យាដែលនឹងបានចូលទៅដល់នោះ មើលការពន្យល់ ១១:៨–១២ ។

**៨:៩** *ដែក . . . ទង់ដែង* គឺនៅភ្នំនៃស្រុកល្បាណូនភាគខាងត្បូង នៅតំបន់ខាងកើតសមុទ្រកាលីឡេ និងខាងត្បូងសមុទ្រស្លាប់ ដែលសម្បូរទៅដោយរ៉ែដែក ។ ទាំងទង់ដែង និងដែក គឺមានយ៉ាងច្រើននៅត្រង់តំបន់ស្រុកវាលខាងត្បូងសមុទ្រស្លាប់ ។ រ៉ែទង់ដែង មានតាំងពីសម័យស្ដេចសាឡូម៉ូន ឬមុនពេលនោះទៀត ។ ក្រុងសារថានមានទីតាំងត្រង់ជ្រលងទន្លេយ័រដាន់នៅខាងជើងសមុទ្រស្លាប់ គឺជាមណ្ឌលសម្រាប់ការងាររ៉ែ លង្ហិន នៅក្នុងសម័យស្ដេចសាឡូម៉ូន (១ពវ ៧:៤៥–៤៦) ។

**៨:១១** *ក្រែងភ្លេច* មើលការពន្យល់ ៤:១០ ធៀបនិង ៨:១៤,១៩ ។

**៨:១៥** *ទឹកចេញពីថ្មយ៉ាងរឹង* មើល នក ១៧:៦ និងការពន្យល់ ។

**៨:១៦** *ល្បងល* មើល ខ.២ សូមមើលនៅក្នុងគម្ពីរ លប ២២:១ ។

មិនដែលស្គាល់[ឡ] ដើម្បីនឹងបន្ទាបចិត្តឯង ហើយនឹងល្បង
ល[អ]ឯង ប្រយោជន៍នឹងប្រោសឱ្យឯងបានសេចក្ដីល្អដល់ចុង
បំផុត ១៧ហើយក្រែងឯងនឹកក្នុងចិត្តថា[ក] គឺដោយឥទ្ធិឫទ្ធិ
ហើយនិងកំឡាំងដៃនៃអញទេ[ខ] ដែលអញបានទ្រព្យទាំង
នេះ ១៨ត្រូវឱ្យនឹកពីព្រះយេហូវ៉ា ជាព្រះនៃឯងវិញ ដ្បិតគឺ
ទ្រង់ហើយ ដែលប្រទានឱ្យឯងមានឥទ្ធិឫទ្ធិ ឱ្យបានទ្រព្យ
សម្បត្តិ[គ] ដើម្បីនឹងបញ្ជាក់សេចក្ដីសញ្ញា ដែលទ្រង់បានស្បថ
នឹងពួកឰយុកោឯង ដូចជាមានសព្វថ្ងៃនេះ ១៩តែបើឯង
ភ្លេចព្រះយេហូវ៉ា ជាព្រះនៃឯងមែន ហើយទៅប្រព្រឹត្ត
តាមព្រះដទៃ[ឃ] ទាំងគោរពប្រតិបត្តិ ក្រាបថ្វាយបង្គំដល់ព្រះ
នោះវិញ នោះអញធ្វើបន្ទាល់ទាស់នឹងឯងរាល់គ្នានៅថ្ងៃ
នេះថា និងត្រូវវិនាសទៅអស់រលីង[ង] ២០ឯងរាល់គ្នានឹង
ត្រូវវិនាសទៅ ដូចជាសាសន៍ទាំងប៉ុន្មាន[ច] ដែលព្រះ
យេហូវ៉ាទ្រង់កំពុងតែធ្វើឱ្យវិនាស ពីមុខឯងចេញនោះដែរ
ដោយព្រោះឯងរាល់គ្នាមិនបានស្ដាប់តាមព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ជាព្រះនៃឯងឡើយ[ឆ] ។

## មិនមែនដោយសារភាពសុចរិតនៃសាសន៍អ៊ីស្រាអែល

**៩** ១ឱអ៊ីស្រាអែលអើយ ចូរស្ដាប់ចុះ នៅវេលានេះឯង
រាល់គ្នាត្រូវឆ្លងទន្លេយ័រដាន់[ក] ទៅចាប់យកនគរ ដែលធំ
ជាង ហើយពូកែជាងឯង[ខ] ដែលមានទីក្រុងធំ[គ] មានកំផែង
ខ្ពស់ដល់ផ្ទៃមេឃផង[ឃ] ២ជាសាសន៍មានមាឌធំខ្ពស់ គឺជាពួក
កូនចៅអ័ណាក់ ដែលឯងស្គាល់ហើយ ក៏បានឮនិយាយពីគេ
ថា តើអ្នកណាអាចនឹងឈរនៅមុខពួកកូនចៅអ័ណាក់បាន[ង]
៣ដូច្នេះនៅថ្ងៃនេះ ចូរថា គឺព្រះយេហូវ៉ា ជាព្រះនៃឯង
ដែលនាំមុខឯងឆ្លងទៅ[ច] ទ្រង់ឧបមាដូចជាភ្លើងដែលឆេះ
បន្សុស[ឆ] ទ្រង់នឹងបំផ្លាញគេ ហើយបង្ក្រាបគេ នៅមុខឯង
វិញ យ៉ាងនោះឯងនឹងបណ្ដេញគេបាន ព្រមទាំងធ្វើឱ្យគេ
វិនាសទៅយ៉ាងឆាប់រហ័ស[ជ] ដូចជាព្រះយេហូវ៉ាបានសន្យា
នឹងឯងហើយ ៤កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង បាន
បណ្ដេញគេ ពីមុខឯងចេញហើយ នោះកុំឱ្យឯងនឹកក្នុងចិត្ត
ថា[ឈ] ព្រះយេហូវ៉ាទ្រង់បាននាំអញចូលមកចាប់យកស្រុក
នេះ ដោយព្រោះតែអញមានសេចក្ដីសុចរិតនោះឡើយ គឺ
ដោយព្រោះអំពើបាប[ញ]របស់សាសន៍ទាំងនោះទេ[ដ] ដែល
ព្រះយេហូវ៉ាទ្រង់បណ្ដេញគេ ពីមុខឯងចេញទៅនោះ ៥មិន
មែនដោយព្រោះសេចក្ដីសុចរិតរបស់ឯង ឬដោយព្រោះ
ចិត្តឯងទៀងត្រង់[ឋ] ដែលឯងនឹងចូលទៅចាប់យកស្រុកគេ
នោះឡើយ គឺដោយព្រោះអំពើបាប[ឌ]របស់សាសន៍ទាំង
នោះ[ឍ]វិញទេតើ ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់
បណ្ដេញគេពីមុខឯងចេញ[ណ] ដើម្បីនឹងបញ្ជាក់សេចក្ដីដែល
ទ្រង់បានស្បថ[ត]នឹងពួកឰយុកោឯង គឺនឹងអ័ប្រាហាំ និង
អ៊ីសាក ហើយនិងយ៉ាកុប[ថ] ។
៦ដូច្នេះ ចូរដឹងថា ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់
ប្រទានស្រុកដ៏ល្អនេះមកឱ្យឯងបានចាប់យក នោះមិនមែន
ដោយព្រោះសេចក្ដីសុចរិតរបស់ឯងទេ ដ្បិតឯងជាសាសន៍
មានក្បាលរឹងវិញ[ទ] ។

## រូបកូនគោមាស

៧ចូរនឹកចាំ កុំឱ្យភ្លេចឡើយ ថាឯងបានបណ្ដាលឱ្យ[ធ] ព្រះ
យេហូវ៉ា ជាព្រះនៃឯង មានសេចក្ដីក្រោធ នៅត្រង់ទី
រហោស្ថាន ហើយចាប់តាំងពីថ្ងៃដែលឯងចេញពីស្រុក
អេស៊ីព្ទរហូតមកដល់ទីនេះ នោះឯងរាល់គ្នាចេះតែបះ
បោរ[ន]នឹងព្រះយេហូវ៉ាជាដរាប[ប] ៨នៅត្រង់ភ្នំហោរែបក៏
ដែរ ឯងបានបណ្ដាលឱ្យព្រះយេហូវ៉ាមានសេចក្ដីក្រោធ[ផ]
ព្រះយេហូវ៉ាទ្រង់ក៏ខ្ញាល់ ដល់ទៅចង់បំផ្លាញឯងចេញផង[ព]
៩ក្នុងគ្រាដែលអញបានឡើងទៅលើភ្នំ ដើម្បីនឹងទទួលបន្ទះ
ថ្ម ជាបន្ទះមានកត់ចុះសេចក្ដីសញ្ញា[ភ] ដែលព្រះយេហូវ៉ាបាន
តាំងនឹងឯងរាល់គ្នា នោះអញបាននៅលើភ្នំអស់៤០ថ្ងៃ[ម]
៤០យប់ ឥតមានបរិភោគអាហារ ឬផឹកទឹកសោះ[យ] ១០ហើយ
ព្រះយេហូវ៉ាទ្រង់បានប្រទានបន្ទះថ្មទាំង២ផ្ទាំង ដែលសរ
សេរដោយ អង្គុលីព្រះហស្តនៃទ្រង់[រ]នៅថ្មទាំង២នោះមាន
កត់ចុះអស់ទាំងព្រះបន្ទូល ដែលព្រះយេហូវ៉ាបានមានបន្ទូល

**៨:១៦** ឡ នក ១៦:១៥ អ លប ២២:១ **៨:១៧** ក ចទ ៩:៤,៧,២៤ ៣១:២៧ ខ ពច ៧:២ ទដ ៤៤:៣ អស ១០:១៣ **៨:១៨** គ លប ២៦:១៣ ចទ ២៦:១០ ២៨:៤ ១សយ ២:៧ ទដ ២៥:១៣ ១១២:៣ សភ ៨:១៨ ១០:២២ សស ៩:១១ ហស ២:៨ **៨:១៩** ឃ ចទ ៦:១៤ ទដ ១៦:៤ យរ ៧:៦ ១៣:១០ ២៥:៦ ង ចទ ៤:២៦ ៣០:១៨ **៨:២០** ច ២ពវ ២១:២ ទដ ១០:១៦ ឆ អគ ៥:៥–១៧ **៩:១** ក ជន ៣៥:១០ ខ ចទ ៤:៣៨ គ ជន ១៣:២៨ ឃ លប ១១:៤ **៩:២** ង ជន ១៣:២២ យស ១១:២២ **៩:៣** ច ចទ ៣១:៣ យស ៣:១១ ឆ នក ១៥:៧ ១៩:១៨ ហព ១២:២៩ ជ នក ២៣:៣១ **៩:៤** ឈ ចទ ៨:១៧ ញ ២ពវ ១៦:៣ ១៧:៨ ២១:២ អរ ៩:១១ ដ នក ២៣:២៤ លវ ១៨:២១,២៤–៣០ ចទ ១៨:៩–១៤ **៩:៥** ឋ អភ ២:៩ ឌ ចទ ១៨:៩ ឍ លវ ១៨:២៥ ណ ចទ ៤:៣៨ ១១:២៣ ត លប ១២:៧ ថ អគ ៣៦:៣២ **៩:៦** ទ នក ៣២:៩ កច ៧:៥១ **៩:៧** ធ ជន ១១:៣៣ ន នក ២៣:២១ ប នក ១៤:១១**៩:៨** ផ ជន ១៦:៤៦ ១សយ ២៨:១៨ យប ២០:២៨ ទដ ២:១២ ៧:១១ ៦៩:២៤ ១១០:៥ អស ៩:១៩ អគ ២០:១៣ ព នក ៣២:៧–១០ អរ ៩:១៤ ទដ ១០៦:១៩ **៩:៩** ភ ចទ ៤:១៣ ម លប ៧:៤ យ នក ២៤:១២ **៩:១០** រ នក ៣១:១៨ ល ចទ ១០:៤ ១៨:១៦

**៨:១៧–១៨** មើល សក ៤:៦ និងការពន្យល់ ។

**៨:១៨** *ឱ្យនឹក* មើលការពន្យល់ ៤:១០ ។

**៩:១** *ឱអ៊ីស្រាអែល* មើល ៤:១ ។

**៩:២** *កូនចៅអ័ណាក់* មើលការពន្យល់ ១:២៨ ។

**៩:៣** *ភ្លើងដែលឆេះបន្សុស* មើល ៤:២៤ និងការពន្យល់ ។ *ហើយបង្ក្រាបគេនៅមុខឯងវិញ . . . ឯងនឹងបណ្ដេញគេបាន* ព្រះអង្គមិនគ្រាន់តែដឹកមុខជនជាតិអ៊ីស្រាអែលទេ តែទ្រង់ថែមទាំងផ្ដល់ឱ្យមានជ័យជម្នះលើសត្រូវទៀត ។

**៩:៤** *ដោយព្រោះតែអញមានសេចក្ដីសុចរិត* មើល ៧:៨ ។ *ព្រោះអំពើបាបរបស់សាសន៍ទាំងនេះ* មើលការពន្យល់ លប ១៥:១៦ ។

**៩:៦,១៣** *សាសន៍មានក្បាលរឹង* មើល ១០:១៦ ៣១:២៧ សូមមើលការពន្យល់ នក ៣២:៩ ផងដែរ ។

**៩:៧,២៧** *ចូរនឹកចាំ* មើលការពន្យល់ ៤:១០ ។

**៩:៩** *បន្ទះនៃសេចក្ដីសញ្ញា* សូមមើលការពន្យល់ នក ២០:១ ៣៤:២៨ ។

**៩:១០** *បន្ទះថ្មពីរផ្ទាំង . . . ដោយអង្គុលីព្រះហស្ត* សូមមើល នក ៣១:១៨

នឹងឯងរាល់គ្នា ពីកណ្តាលភ្លើងនៅលើភ្នំ នាថ្ងៃដែល
ប្រជុំគ្នានោះ[ល] ១១លុះដល់ផុត៤០ថ្ងៃ៤០យប់នោះហើយ[វ] ព្រះ
យេហូវ៉ាទ្រង់ក៏ប្រទានបន្ទះថ្មទាំង២ផ្ទាំងនោះដល់អញ[ស] គឺ
ជាបន្ទះនៃសេចក្តីសញ្ញា ១២រួចព្រះយេហូវ៉ាមានបន្ទូល
ប្រាប់អញថា ចូរក្រោកឡើង ចុះពីនេះជាប្រញាប់ទៅ ដ្បិត
ពួកជនដែលឯងបាននាំចេញពីស្រុកអេស៊ីព្ទមក គេបាន
បង្ខូចចិត្តអស់ហើយ[ហ] គេរហ័ស[ឡ]នឹងបែរចេញពីផ្លូវដែល
អញបានបង្គាប់គេ ក៏បានសិតធ្វើរូបព្រះសំរាប់គេហើយ
១៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអញទៀតថា អញបាន
រំពឹងមើលឃើញថា សាសន៍នេះ[អ] គេមានក្បាលរឹងទាំងអស់
គ្នា ១៤ឈប់សិន[ក] ចាំអញនឹងបំផ្លាញគេចេញ ព្រមទាំងលុប[ខ]
ឈ្មោះគេពីក្រោមមេឃទៅ[គ] រួចអញនឹងយកឯង បង្កើត
ឡើងជាសាសន៍១ដ៏ខ្លាំងពូកែ ហើយមានគ្នាច្រើនជាងគេ
ទៅទៀត ១៥ដូច្នេះអញបានវិលចុះពីភ្នំមក មានបន្ទះថ្មទាំង
២នៃសេចក្តីសញ្ញា កាន់នៅដៃ ទាំងសងខាងផង ឯភ្នំក៏មាន
សុទ្ធតែភ្លើងឆេះនៅ[ឃ] ១៦អញក៏ក្រឡេកមើលទៅឃើញថា
ឯងរាល់គ្នាបានធ្វើបាបនឹងព្រះយេហូវ៉ា ជាព្រះនៃឯង
ហើយ ដោយបានសិតធ្វើរូបកូនគោ១[ង] ឯងបានប្រញាប់
នឹងងាកបែរចេញពីផ្លូវ ដែលព្រះយេហូវ៉ាបានបង្គាប់មក
ឯងណាស់ ១៧នោះអញបានចាប់យកថ្មទាំង២ផ្ទាំង បោះពី
ដៃអញបំបែកចោលទៅ នៅចំពោះភ្នែកឯងរាល់គ្នា
១៨រួចអញក៏ក្រាប[ច]ចុះនៅចំពោះព្រះយេហូវ៉ា អស់៤០ថ្ងៃ
៤០យប់ដូចជាន់មុន ឥតមានបរិភោគឬផឹកទឹកសោះឡើយ[ឆ]
ដោយព្រោះអស់ទាំងអំពើបាប ដែលឯងរាល់គ្នាបានធ្វើ[ជ]
ដោយប្រព្រឹត្តសេចក្តីដែលអាក្រក់ នៅព្រះនេត្រនៃព្រះ
យេហូវ៉ា ជាការដែលបណ្តាលឱ្យទ្រង់ខ្ញាល់ឡើង ១៩ដ្បិត
អញបានភ័យខ្លាចចំពោះសេចក្តីខ្ញាល់ នឹងសេចក្តីក្រោធ
ដែលព្រះយេហូវ៉ាទ្រង់ឃោរឃៅ ដល់ទៅចង់បំផ្លាញឯង
នោះណាស់[ឈ] ហើយនៅវេលានោះ ព្រះយេហូវ៉ាក៏ស្តាប់
តាមអញ[ញ] ២០ព្រះយេហូវ៉ាទ្រង់ក៏ខ្ញាល់នឹងអើរ៉ុនជាខ្លាំង

**៩:១១** វ លប ៧:៤
ស នក ២៤:១២
**៩:១២** ហ ចទ ៤:១៦
ឡ ពច ២:១៧
**៩:១៣** អ ខ.៦
ចទ ១០:១៦
**៩:១៤** ក នក
៣២:១០ ខ ជន
១៤:១២ គ យរ
៧:១៦
**៩:១៥** ឃ នក
៣២:១៥
**៩:១៦** ង នក ៣២:៤
**៩:១៨** ច នក
៣៤:២៨ ឆ ខ.៩
ជ នក ៣២:៣១
**៩:១៩** ឈ នក
៣២:១៤ ហព
១២:២១ ញ ខ.២៦
នក ៣៤:១០ ជន
១១:២ ១សយ ៧:៩
យរ ១៥:១
**៩:២១** ដ ទដ
១៨:៤២ អស ២៩:៥
៤០:១៥ ឋ នក
៣២:២០ អស ២:១៨
មីក ១:៧
**៩:២២** ឌ ជន
១១:៣៤ ឍ ជន
១:៥៣ ណ ជន
១១:៣ ត នក ១៧:៧
**៩:២៣** ថ ចទ ១:២
ទ ចទ ១:២១
ធ ជន ១៤:៩
ន ចទ ១:៣២ ទដ
១០៦:២៤
**៩:២៤** ប ចទ ៨:១៧
**៩:២៥** ផ លប ៧:៤
៣ ខ.១៨ នក

ដល់ទៅចង់បំផ្លាញលោកដែរ តែអញបានសូមអង្វរឱ្យ
លោកនៅវេលានោះឯង ២១រួចអញបានយករូបកូនគោ
ដែលឯងរាល់គ្នាបានធ្វើ គឺជាអំពើបាបរបស់ឯងនោះ ទៅ
ដុតនឹងភ្លើង រួចផែ ហើយកិនកំទេច ទាល់តែម៉ដ្ត ដូចធូលី
ទៅ[ដ] ក៏បាចសាចធូលីនោះ ទៅក្នុងជ្រោះទឹកដែលហូរចុះ
ពីភ្នំមក[ឋ]។

២២កាលនៅត្រង់តាបេរ៉ា[ឌ] ត្រង់ម៉ាសា[ឍ] ហើយត្រង់គីប្រុត
ហាតាវ៉ា[ណ]នោះឯងរាល់គ្នាក៏បានបណ្តាលឱ្យព្រះយេហូវ៉ា
ក្រោធទៀត[ត] ២៣ហើយកាលព្រះយេហូវ៉ាបានចាត់ឯង ពី
កាដេស-បារនា[ថ] ដោយបន្ទូលថា ចូរឡើងទៅចាប់យក[ទ]
ស្រុកដែលអញបានឱ្យដល់ឯងចុះ នោះក៏បានបះបោរ[ធ]នឹង
បង្គាប់របស់ព្រះយេហូវ៉ា ជាព្រះនៃឯងទៀត ឯងរាល់គ្នា
មិនបានជឿ[ន] ក៏មិនបានស្តាប់តាមព្រះបន្ទូលទ្រង់សោះ
២៤គឺចេះតែមានចិត្តរឹងចចេសចំពោះព្រះយេហូវ៉ាជានិច្ច
តាំងតែពីថ្ងៃដែលអញទើបនឹងស្គាល់ឯងរាល់គ្នាមក[ប]។

២៥យ៉ាងនោះ អញបានក្រាបចុះ នៅចំពោះព្រះយេហូវ៉ា
អស់៤០ថ្ងៃ៤០យប់[ផ] នោះដោយព្រោះព្រះយេហូវ៉ាបានមាន
បន្ទូលថា ទ្រង់នឹងបំផ្លាញឯងរាល់គ្នា[ព] ២៦ហើយអញក៏ទូល
អង្វរដល់ព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់
អើយ សូមកុំបំផ្លាញបណ្តាជននេះ[ភ]ដ៏ជាមរដក[ម]របស់ទ្រង់
ដែលទ្រង់បានលោះ[យ]ដោយឫទ្ធិបារមីទ្រង់ ហើយបាននាំ
ចេញពីស្រុកអេស៊ីព្ទមក ដោយព្រះហស្តដ៏មានព្រះចេស្តា
នោះឡើយ[រ] ២៧សូមទ្រង់នឹកចាំពីអ័ប្រាហាំ អ៊ីសាក និង
យ៉ាកុប ជាអ្នកបំរើទ្រង់វិញ សូមកុំទតចំពោះសេចក្តីរឹង
រូស[ល]របស់សាសន៍នេះ ឬកិរិយាអាក្រក់ ឬអំពើបាបរបស់
គេឡើយ ២៨ក្រែងមនុស្សនៅស្រុក[វ]ដែលទ្រង់បាននាំយើង
រាល់គ្នាចេញមកនោះ គេដំនៀលថា ដោយព្រោះតែព្រះ

៣៣:១៧ **៩:២៦** ភ នក ៣៣:១៣ ម នក ៣៤:៩ យ នក ៦:៦ ចទ ១៥:១៥
២សយ ៧:២៣ ទដ ៧៨:៣៥រ ខ.១៩ នក ៣២:១១ **៩:២៧** ល ខ.៦ នក ៣២:៩
**៩:២៨** វ ចទ ៣២:២៧

មើលការពន្យល់ នក ៨:១៩ ផងដែរ ។

**៩:១១-២១** មើល នក ៣១:១៨-៣២:២០ និងការពន្យល់ ។

**៩:១៤** *លុបឈ្មោះគេចេញពីក្រោមមេឃ* ស្រង់ចេញពីភាសាហេព្រើរដែលឃ្លានេះហើយបានឃើញនឹងប្រើញឹកញាប់នៅក្នុងឆ្នាំទី៩ មុន គ.ស គឺបានចារជាផ្ទាំងសិលាចារឹកនៅលើក្លោងទ្វារចូល ដោយមានន័យថា"បើ . . . មនុស្សណា . . . បានលុបឈ្មោះចេញពី អាស៊ីតាវ៉ាដា គឺចេញពីទ្វារនេះ . . . នោះ ព្រះហឫទ័យរបស់ព្រះនិង លុបឈ្មោះមនុស្សនោះចេញដែរ" ។

**៩:១៩** *ព្រះយេហូវ៉ាក៏ស្តាប់តាមអញ* ជាពេលដែលលោកម៉ូសេអធិស្ឋានទូលអង្វរក្នុងការអធិស្ឋានរួមគ្នាយ៉ាងអស្ចារ្យសម្រាប់ការជួយសង្គ្រោះប្រជាជនអ៊ីស្រាអែល មើល នក ៣២:១១-១៣ និងការពន្យល់ ក៏មើល អរ ៩:៦-១៥ នហ ៩:៥-៣៨ ដយ ៩:៤-១៩)។

**៩:២២** *តាបេរ៉ា* មើល ជន ១១:៣ និងការពន្យល់ ។ *ម៉ាសាគីប្រុត- ហាតាវ៉ា* មើល ជន ១១:៣៤ និងការពន្យល់ ។

**៩:២៣** *ពីកាដេស-បារនា* មើលការពន្យល់ លប ១៤:៧ ជន ២០:១ ។

**៩:២៧** *កុំទត* មើលការពន្យល់ កច ១៧:៣០ ។

**១០:១-៣** *ហឹបឈើ . . . ហឹប . . . នាវនួន* ពាក្យទាំងពីរនេះគឺបានបកប្រែពីភាសាហេព្រើរ ដែលមានន័យថាប្រអប់ ឬហឹបនោះ (សូមមើលការពន្យល់ នក ២៥:១០) ។

យេហូវ៉ាពុំអាចនឹងនាំគេចូលទៅក្នុងស្រុក ដែលទ្រង់សន្យា
នឹងឱ្យដល់គេបាន ហើយដោយព្រោះទ្រង់ស្អប់គេ[ស]បានជា
ទ្រង់នាំគេចេញទៅសំឡាប់ នៅទីរហោស្ថានវិញ[ហ] ២៩ប៉ុន្តែ
គេជារាស្ត្រ[ឡ] ហើយជាមរដក[អ]របស់ផងទ្រង់ ដែលទ្រង់
បាននាំចេញមក ដោយសារព្រះចេស្តាដ៏ធំ ហើយដោយ
ព្រះពាហុលើកសំរេចហើយ[ក]។

## បន្ទះថ្មដូចបន្ទះថ្មទាំង២ជាន់មុន

**១០** ១នៅវេលានោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអញ
ថា ចូរដាប់បន្ទះថ្ម២ផ្ទាំង[ក] ដូចបន្ទះថ្មពីមុន រួចឡើងមកឯ
អញនៅលើភ្នំនេះ ត្រូវឱ្យធ្វើហឹបឈើ១ដែរ ២អញនឹងកត់
ចុះនៅបន្ទះទាំង២នោះ តាមអស់ទាំងសេចក្តី ដែលបានកត់
នៅបន្ទះទាំង២ពីជាន់មុន ដែលបានបំបែកហើយ រួចត្រូវ
ដាក់ទៅក្នុងហឹបនោះ[ខ] ៣ដូច្នេះអញបានធ្វើហឹប១ពីឈើនាង
នួន[គ] ហើយដាប់[ឃ]ថ្ម២ផ្ទាំង ដូចជាថ្មមុន រួចក៏ឡើងទៅលើភ្នំ
មានទាំងថ្ម២ផ្ទាំងនោះកាន់នៅដៃផង ៤នោះទ្រង់ក៏កត់ចុះ
នៅបន្ទះថ្មនោះ តាមសេចក្តីដែលបានកត់ពីលើកមុន គឺជា
ក្រិត្យទាំង១០ប្រការ[ង] ដែលព្រះយេហូវ៉ាបានមានបន្ទូល[ច]ពី
កណ្តាលភ្លើងមកឯងរាល់គ្នា នៅលើភ្នំ ក្នុងថ្ងៃដែលបាន
ប្រជុំគ្នានោះ[ឆ] រួចព្រះយេហូវ៉ាទ្រង់បានប្រទានថ្មទាំង២មក
អញវិញ ៥អញក៏វិលចុះពីភ្នំ[ជ]មកដាក់ថ្មទាំង២ផ្ទាំងទៅក្នុង
ហឹប[ឈ] ដែលអញបានធ្វើ[ញ] ហើយថ្មនោះក៏នៅតែក្នុងហឹប
ដូចជាព្រះយេហូវ៉ាបានបង្គាប់មកអញ[ដ]។
៦ឯពួកកូនចៅអ៊ីស្រាអែល ក៏ចេញពីបៀរ៉ុត–បេនេ–យ៉ា
កាន ទៅដល់ម៉ូសេរ៉ា[ឋ] នៅទីនោះអើរ៉ុនក៏ស្លាប់ទៅ[ឌ] ហើយ
គេបញ្ចុះសពលោកនៅទីនោះ រួចអេលាសារ[ឍ]ជាកូន
លោក បានធ្វើការងារជាសង្ឃជំនួសឡើង[ណ] ៧គេធ្វើ
ដំណើរពីនោះទៅដល់គុតកូថា ហើយពីគុតកូថាទៅដល់
យ៉ុតបាថា ជាស្រុកដែលមានស្ទឹង[ត] ៨នៅគ្រានោះព្រះយេ
ហូវ៉ាបានញែកពូជអំបូរលេវី[ថ]ចេញ ទុកសំរាប់នឹងសែង
ហឹបនៃសេចក្តីសញ្ញាផងទ្រង់[ទ] ហើយឱ្យឈរធ្វើការងារ[ធ]
នៅចំពោះទ្រង់ ព្រមទាំងឱ្យពរ[ន]ដោយនូវព្រះនាមទ្រង់
ដរាបដល់សព្វថ្ងៃនេះ[ប] ៩ដោយហេតុនោះបានជាពួកលេវី
គ្មានចំណែក គ្មានមរដកជាមួយនឹងពួកបងប្អូនគេទេ គឺព្រះ
យេហូវ៉ាទ្រង់ជាមរដករបស់គេវិញ[ផ] ដូចជាព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់បានមានបន្ទូលហើយ ។
១០នោះអញក៏បាននៅលើភ្នំអស់៤០ថ្ងៃ៤០យប់ ដូចជា
កាលមុនដំបូង ហើយព្រះយេហូវ៉ាទ្រង់ក៏ស្តាប់តាមអញនៅ
ជាន់នោះដែរ គឺទ្រង់មិនសព្វព្រះហឫទ័យនឹងបំផ្លាញឯង
ទេ[ព] ១១ទ្រង់មានបន្ទូលមកអញថា ចូរក្រោកឡើងដើរនាំមុខ
បណ្តាជនចុះ ឱ្យគេបានចូលទៅ ចាប់យកស្រុកដែលអញ
បានស្បថនឹងពួកឰយុកោ ថានឹងឱ្យដល់គេ ។

## ចូរកោតខ្លាចដល់ព្រះអម្ចាស់

១២ឥឡូវនេះ ឱអ៊ីស្រាអែលអើយ សេចក្តីដែលព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់ទារចង់បានពីឯង[ភ] នោះគឺឱ្យឯងបាន
កោតខ្លាច[ម]ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង និងដើរ[យ]តាម
គ្រប់ទាំងផ្លូវរបស់ទ្រង់ ហើយឱ្យស្រឡាញ់ទ្រង់[រ] ព្រមទាំង
គោរពប្រតិបត្តិដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ឱ្យអស់
ពីចិត្ត[វ] អស់ពីព្រលឹងឯងផង[ស] ១៣ហើយឱ្យបានកាន់តាម
សេចក្តីបញ្ញត្តិ[ហ]ផងព្រះយេហូវ៉ា និងច្បាប់ទាំងប៉ុន្មានរបស់
ទ្រង់ ដែលអញបង្គាប់ឯងនៅថ្ងៃនេះ សំរាប់ជាសេចក្តីល្អ
ដល់ឯង[ឡ] ១៤មើល ផ្ទៃមេឃ[អក] ហើយអស់ទាំងជាន់ផ្ទៃ
មេឃខាងលើ[គ,ឃ] និងផែនដី ព្រមទាំងរបស់សព្វសារពើ
ដែលនៅស្ថានទាំងនោះ[ង] សុទ្ធតែជារបស់ផង ព្រះយេហូវ៉ា
ជាព្រះនៃឯង ១៥ប៉ុន្តែ ព្រះយេហូវ៉ាទ្រង់បានសព្វព្រះ
ហឫទ័យនឹងស្រឡាញ់[ច] ដល់ពួកឰយុកោឯង ហើយទ្រង់បាន
រើស[ឆ]ពូជគេតរៀងមក គឺឯងរាល់គ្នា ដែលទ្រង់រាប់អាន
លើសជាងអស់ទាំងសាសន៍ ដូចជាមានសព្វថ្ងៃនេះ[ជ]
១៦ដូច្នេះចូរឯងរាល់គ្នាកាត់ស្បែក[ឈ]ចិត្តចេញ[ញ] ហើយកុំ

**៩:២៨** ស ចទ ១:២៧ ហ នក ៣២:១២ យស ៧:៩ **៩:២៩** ឡ នក ៣៣:១៣ អ នក ៣៤:៩ ចទ ៣២:៩ ក ចទ ៤:៣៤ នហ ១:១០ យរ ២៧:៥ ៣២:១៧ **១០:១** ក នក ៣៤:១–២ **១០:២** ខ នក ២៥:១៦,២១ ២របា ៥:១០ ៦:១១ **១០:៣** គ នក ៣៧:១–៩ ឃ នក ៣៤:៤ **១០:៤** ង នក ២៤:១២ ៣៤:២៨ ច នក ២០:១ ឆ ចទ ៩:១០ **១០:៥** ជ នក ១៩:១១ ឈ នក ២៥:១០ ១សយ ៣:៣ ញ នក ២៥:២១ ដ ១ពវ ៨:៩ **១០:៦** ឋ ជន ៣៣:៣០ ឌ ជន ២៧:១៣ ឍ នក ៦:២៣ ណ ជន ២០:២៥–២៨ **១០:៧** ត ជន ៣៣:៣២–៣៤ ទដ ៤២:១ ៥:១២ អស ៣២:២ **១០:៨** ថ ជន ៣:៦ ទ ជន ១០:៣៣ ធ ជន ១៦:៩ ន លប ៤៨:២០ ប ១របា ២៣:២៦ **១០:៩** ផ ជន ១៨:២០

**១០:១០** ព នក ៣៣:១៧ **១០:១២** ភ មីក ៦:៨ ម នក ២០:២០ យ ១ពវ ២:៣ ៣:៣ ៩:៤ រ ចទ ៥:៣៣ ៦:១៣ មថ ២២:៣៧ ១ធថ ១:៥ ល ចទ ១១:១៣ ២៨:៤៧ ទដ ១០០:២ វ ចទ ៦:៥ ទដ ១១៩:២ ស ចទ ៥:៣២ **១០:១៣** ហ ចទ ៤:២ ឡ ចទ ៥:៣៣ ៦:២៤ **១០:១៤** អ ទដ ១៤៨:៤ អស ១៩:១ ហព ៣:៨ ក នហ ៩:៦ យប ៣៥:៥ ទដ ៨:៣ ៨៩:១១ ១០៤:៣ ខ ចទ ៣៣:២៦ គ ទដ ១១៥:១៦ ឃ ១ពវ ៨:២៧ ង នក ១៩:៥ ទដ ២៤:១ កច ១៧:២៤ **១០:១៥** ច ចទ ៤:៣៧ ឆ ទដ ១០៥:៦ ១៣៥:៤ ជ ជន ១៤:៨ រម ១១:២៨ ១ពត ២:៩ **១០:១៦** ឈ លប ១៧:១១ ញ លប ២៦:៤១ ចទ ៣០:៦ យរ ៣២:៣៩

**១០:១** *បន្ទះថ្ម២ផ្ទាំង* មើលការពន្យល់ នក ៣១:១៨ ។
**១០:២** *ដាក់វាទៅក្នុងហឹបនោះ* មើលការពន្យល់ នក ១៦:៣៤ ២៥:១៦ ។
**១០:៣** ព្រឹត្តិការមានជាប់ៗគ្នានេះគឺខុសពីព្រឹត្តិការនៅក្នុងគម្ពីរ នក ៣៤–៣៧ (មើលសេចក្តីផ្តើមក្នុងចោទិយកថា និងគម្រោងសង្ខេប) ។
**១០:៦–៩** ការប្រមើលពីរប្រវត្តិសាស្ត្រឃើញថា ការអធិស្ឋានមានលក្ខណៈទំនាក់ទំនង ដូចការអធិស្ឋានលោកម៉ូសេ ដែលអធិស្ឋានឱ្យអើរ៉ុននិងពួកអ៊ីស្រាអែល (៩:២៦–២៩) ទំនាក់ទំនងនឹងហឹបគឺ (ខ.១–៥) ។
**១០:៨** *សែងហឹប* មើលការពន្យល់ ជន ១:៥០ ។ *ឈរធ្វើការងារ . . . ឱ្យពរដោយនូវព្រះនាមទ្រង់* មើល មីក ៦:៨ និងការពន្យល់ ។ *កោតខ្លាចដល់ព្រះយេហូវ៉ា* មើលការពន្យល់ លប ២០:១១ ។ *ស្រឡាញ់ទ្រង់* មើលការពន្យល់ ៤:២៩,៣៧ ៦:៥ ។
**១០:១៣** *សំរាប់សេចក្តីល្អដល់ឯង* មើល ៦:២៤ និងការពន្យល់ ៦:២ ។
**១០:១៥** *ស្រឡាញ់ដល់ពួកឰយុកោឯង* មើល ៧:៧–៨ និងការពន្យល់ ៧:៨ ។ *ពួកឰយុកោ* ចាស់ព្រឹទ្ធាចារ្យ (គឺទាក់ទងនឹង ខ.២២) ។

ឱ្យនៅក្បាលរឹង[ដ]ទៀតឡើយ ១៧ដ្បិតព្រះយេហូវ៉ាជាព្រះ
នៃឯង ទ្រង់ជាព្រះលើអស់ទាំងព្រះ[ឋ] ហើយជាព្រះអម្ចាស់
លើអស់ទាំងព្រះអម្ចាស់[ឌ] គឺជាព្រះដ៏ធំដែលមានព្រះចេស្តា
ហើយក៏គួរស្ញែងខ្លាច[ឍ]ទ្រង់មិនដែលយោគយល់ខាងអ្នក
ណាសោះ[ណ] ក៏មិនទទួលសំណូកផង[ត] ១៨ទ្រង់សំរេចសេចក្តី
សុចរិត ដល់ពួកកំព្រានឹងពួកមេម៉ាយ[ថ] ក៏ស្រឡាញ់អ្នក
ប្រទេសក្រៅ ទាំងប្រទានឱ្យមានអាហារ និងសំលៀក
បំពាក់ផង[ទ] ១៩ដូច្នេះចូរឱ្យឯងរាល់គ្នាស្រឡាញ់[ធ] អ្នក
ប្រទេសក្រៅចុះ[ន] ដ្បិតឯងរាល់គ្នាក៏ជាពួកអ្នកប្រទេសក្រៅ
ពីកាលនៅស្រុកអេស៊ីព្ទដែរ[ប] ២០ត្រូវឱ្យកោតខ្លាចដល់
ព្រះយេហូវ៉ា ជាព្រះនៃឯង ហើយគោរពប្រតិបត្តិដល់ទ្រង់[ផ]
ព្រមទាំងនៅជាប់នឹងទ្រង់[ព] ហើយស្បថដោយនូវព្រះនាម
ទ្រង់ដែរ[ភ] ២១ទ្រង់ជាទំនុកសរសើរ[ម] ហើយជាព្រះនៃឯង
ទ្រង់បានធ្វើអស់ទាំងការក៏ធំគួរស្ញែងខ្លាចនេះឱ្យឯង ជា
ការ[យ,រ]ដែលភ្នែកឯងបានឃើញហើយ ២២ពួកឰយុកោ
ឯងបានចុះទៅនៅស្រុកអេស៊ីព្ទ មានតែគ្នា៧០នាក់ទេ[ល] តែ
ឥឡូវនេះព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានចំរើនពួកឯង
ឱ្យមានគ្នាសន្ធឹក ដូចជាផ្កាយលើមេឃវិញ[វ] ។

## ត្រូវស្រឡាញ់ និងស្តាប់បង្គាប់ព្រះអម្ចាស់

**១១** ១ដូច្នេះ ត្រូវឱ្យស្រឡាញ់[ក]ដល់ព្រះយេហូវ៉ា ជាព្រះនៃ
ឯង ហើយរក្សាបញ្ញើទ្រង់ ព្រមទាំងច្បាប់ និងបញ្ញត្តិ
ហើយនិងសេចក្តីបង្គាប់ទាំងប៉ុន្មានរបស់ទ្រង់ ជាដរាបទៅ[ខ]
២ហើយនៅថ្ងៃនេះ ត្រូវឱ្យឯងរាល់គ្នាដឹងការដែលពួកកូន
ចៅឯងរាល់គ្នា[គ]មិនបានឃើញ ហើយពុំអាចនឹងដឹងបាន
ឡើយ គឺជាការផ្ចាញ់ផ្ចាលរបស់ព្រះយេហូវ៉ា ជាព្រះនៃ
ឯង[ឃ] និងតេជានុភាពរបស់ទ្រង់[ង] ហើយព្រះហស្តដ៏មានព្រះ
ចេស្តា និងព្រះពាហុ ដែលលើកសំរេចរបស់ទ្រង់ផង[ច]
៣ព្រមទាំងទីសំគាល់ និងការទាំងប៉ុន្មាន ដែលទ្រង់បានធ្វើ
នៅកណ្តាលស្រុកអេស៊ីព្ទ ដល់ទាំងផារ៉ោន ជាស្តេចស្រុក

**១០:១៦** ដ នក ៣២:៩ ចទ ៩:១៣
**១០:១៧** ឋ យស ២២:២២ ទដ ១៣៥:៥ ១៣៦:២ ដយ ២:៤៧ ១១:៣៦ ឌ ទដ ១៣៦:៣ ១ធថ ៦:១៥ ឍ ចទ ៧:២១ ណ ចទ ១:១៧ មឡ ២:៩ ត នក ២៣:៨ លវ ១៩:១៦
**១០:១៨** ថ នក ២២:២១,២២–២៤ ២៣:៩ លវ ១៩:៣៣ ចទ៩៤:៦ អស ១០:២ យរ ៤៩:៦ អស ១០:២ យរ ៤៩:១១ ទ ជន ១០:៣២
**១០:១៩** ធ ចទ ៧:១២ ន នក ២២:២១ ចទ ២៤:១៩ ប លវ ១៩:៣៤ អគ ៤៧:២២–២៣
**១០:២០** ផ មថ ៤:១០ ព ចទ ១១:២២ ១៣:៤ ៣០:២០ យស ២៣:៨ នរ ១:១៤ ២ពវ ១៨:៦ ទដ ១១៩:៣១ អស ៣៨:៣ ភ នក ២០:៧
**១០:២១** ម នក ១៥:២ យ ១សយ ១២:២៤ ទដ ១២៦:២ រ ២សយ ៧:២៣

អេស៊ីព្ទ និងស្រុករបស់ទ្រង់ទាំងមូលដែរ[ឆ] ៤ហើយការ
ដែលទ្រង់បានធ្វើដល់ពួកពលទ័ពនៃសាសន៍អេស៊ីព្ទ ដល់
ទាំងសេះ និងរទេះចំបាំងគេផង[ជ] គឺដែលទ្រង់បានធ្វើឱ្យទឹក
សមុទ្រក្រហម[ឈ]ហូរមកគ្របលើគេ ក្នុងកាលដែលគេដេញ
តាមឯងរាល់គ្នា ហើយព្រះយេហូវ៉ាបានបំផ្លាញគេឱ្យបាត់
ដរាបដល់ដសព្វថ្ងៃនេះ ៥ព្រមទាំងការដែលទ្រង់បាន
ប្រោសដល់ឯងរាល់គ្នា នៅទីរហោស្ថាន រហូតមកដល់ទី
នេះ ៦ហើយនិងការដែលទ្រង់បានធ្វើ[ញ]ដល់ដាថាន និងអ័រ
ប៊ីរ៉ាម ជាកូនអេលាប ពូជរូបេន គឺដែលដីបានប្រេះហា
ឡើង[ដ] ស្រូបគេបាត់ទៅ ព្រមទាំងពួកផ្ទះ និងត្រសាលរបស់
គេ ហើយនិងគ្រប់ទាំងមនុស្ស ក្នុងពួកសាសន៍អ៊ីស្រាអែល
ដែលតាមគេនោះផង ៧ដ្បិតភ្នែកឯងរាល់គ្នាបានឃើញការ
ដ៏ធំ ដែលព្រះយេហូវ៉ាបានធ្វើទាំងអស់ហើយ[ឋ] ៨ដូច្នេះ ត្រូវ
ឱ្យឯងរាល់គ្នាកាន់តាមបញ្ញត្តិ ដែលអញបង្គាប់មក[ឌ]ឯងនៅ
ថ្ងៃនេះគ្រប់ជំពូក ប្រយោជន៍ឱ្យឯងរាល់គ្នាបានខ្លាំងពូកែ
អាចចូលទៅចាប់យកស្រុក ដែលឯងនឹងឆ្លងទៅយកនោះ
បាន[ឍ] ៩ហើយដើម្បីឱ្យបានជីវិតយូរអង្វែងតទៅ[ណ]នៅក្នុង
ស្រុកដែលព្រះយេហូវ៉ា បានស្បថ[ត]នឹងឱ្យដល់ពួកឰយុកោ
ឯង ហើយដល់ពូជគេតរៀងទៅ ជាស្រុកដែលមានទឹក
ដោះ និងទឹកឃ្មុំហូរហៀរ[ថ] ១០ដ្បិតស្រុកដែលឯងចូលទៅ
ចាប់យកនោះ មិនមែនដូចជាស្រុកអេស៊ីព្ទ[ទ] ដែលឯងទើប
នឹងចេញមក ជាស្រុកដែលឯងបានសាបព្រោះ រួចបើក
ទំនប់ ដោយជើងឱ្យទឹកហូរស្រោច ដូចជា នៅច្បារបន្លែ
នោះទេ ១១ឯស្រុកដែលឯងនឹងឆ្លងទៅចាប់យកនេះ គឺជា

**១០:២២** ល លប ៣៤:៣០ ៤៦:២៦ កច ៧:១៤ វ លប ១២:២ ជន ១០:៣៦
**១១:១** ក ចទ ៦:៥ ខ លវ ៨:៣៥ **១១:២** គ ចទ ៣១:១៣ ទដ ៧៨:៦ ឃ ចទ ៥:២៤ ង ចទ ៣:២៤ ច ទដ ១៣៦:១២ **១១:៣** ឆ នក ៧:៨–២១ **១១:៤** ជ នក ១៥:១ ឈ នក ១៤:២៧ ជន ២១:៤ **១១:៦** ញ ជន ១៦:១–៣៥ ទដ ១០៦:១៦–១៨ ដ អស ២៤:១៩ **១១:៧** ឋ ចទ ៥:៣ **១១:៨** ឌ អរ ៩:១០ ឍ ចទ ៣១:៦–៧,២៣ យស ១:៧ **១១:៩** ណ ចទ ៥:១៦ត ចទ ៩:៥ ថ នក ៣:៨ **១១:១០** ទ អស ១១:១៥ ៣៧:២៥

**១០:១៦** *កាត់ស្បែកចិត្តចេញ* មើលការពន្យល់ លប ១៧:១០ ។ *ក្បាលរឹង* មើល ៩:៦,១៣ ៣១:២៧ នក ៣២:៩ ។

**១០:២០** *នៅជាប់នឹង* គឺក៏ដូចជាមនុស្សប្រុសត្រូវគេផ្សំផ្គុំនឹងប្រពន្ធខ្លួន (មើល លប ២:២៤) ក៏ដូចជានាងរស់ "ទាក់ទងនិងនាងន៉ាអូមីដែរ" ។

**១០:២១** *ទ្រង់ជាទំនុកសរសើរ* មើល ទដ ២២:៣ និងការពន្យល់ ។

**១០:២២** *៧០នាក់* មើលការពន្យល់ លប ១០:២,២៦–២៧ មើល នក ១:៥ ផងដែរ ។ *ដូចជាផ្កាយលើមេឃ* មើលការពន្យល់ ១:១០ ។

**១១:១** *ស្រឡាញ់* មើលការពន្យល់ ៦:៥ ។ *រក្សាបញ្ញើ* គឺជាការស្រឡាញ់ និងការស្តាប់បង្គាប់ គឺមានទំនាក់ទំនងនិងអត្ថបទគម្ពីរ (មើល ឱ. ៦:៥–៦ យហ ១៤:១៥ និងការពន្យល់ នក ២០:២) ។

**១១:២–៧** ម៉ូសេបានផ្តង់អារម្មណ៍ស្តាប់ព្រះសូរសៀង ។ មើលក្នុង ៥:៣ គឺមិនមែនជាសង្ឃរបស់ព្រះទេ តែពួកគេគឺបានឃើញការតាំងសញ្ញានៅភ្នំស៊ីណាយ ក៏មិនមែនជាពួកគេដែរ តែពួកគេនោះហើយបានឃើញព្រះអង្គដ៏អស្ចារ្យ ។

**១១:២** *ដឹងការ* មើលការពន្យល់ ៤:១០ ។

**១១:៨–១២** មើលការពន្យល់ ៨:៧–៩ ។

**១១:៩** *ជីវិតយូរអង្វែង* មើលការពន្យល់ ៦:២ ។

**១១:១០** *បើកទំនប់ដោយជើង* ព្រែកធរាសាស្រ្ត ដែលប្រើដោយជើងធាក់រហាត់នាំទឹកពីទន្លេនីល បង្ហូរចូលទៅច្បារបន្លែក្នុងប្រទេសអេស៊ីព្ទ តែផ្ទុយទៅវិញភ្លៀងបាននាំទឹកទៅដល់ស្រុកកាណាន (ខ.១១) ។

ស្រុកមានភ្នំមានច្រក[ធ] ហើយក៏បានស្រោចដោយទឹកភ្លៀង
ពីលើមេឃមកវិញ[ន] ១២ជាស្រុកដែលព្រះយេហូវ៉ា ជាព្រះ
នៃឯងទ្រង់ថែរក្សាព្រះនេត្រ[ប] ព្រះយេហូវ៉ា ជាព្រះនៃឯង
ចេះតែទតមើលស្រុកនោះជានិច្ច តាំងពីដើមឆ្នាំរហូតដល់
ចុងឆ្នាំ ។
១៣បើសិនជាឯងរាល់គ្នានឹងស្តាប់[ផ]អស់ពីចិត្តតាមបង្គាប់
អញ ដែលអញប្រាប់នៅថ្ងៃនេះ ឱ្យបានស្រឡាញ់[ព]ដល់ព្រះ
យេហូវ៉ា ជាព្រះនៃឯង និងគោរពប្រតិបត្តិដល់ទ្រង់ឱ្យអស់
ពីចិត្តអស់ពីព្រលឹងឯង[ភ] ១៤នោះអញនឹងបង្អុរឱ្យមានភ្លៀង[ម]
មកលើស្រុកឯងតាមរដូវកាល គឺជាភ្លៀងខាងដើមរដូវ[យ]
និងខាងចុងរដូវ ដើម្បីឱ្យឯងអាចនឹងច្រូតស្រូវឯង ហើយ
បេះផ្លែទំពាំងបាយជូរ ព្រមទាំងធ្វើប្រេងរបស់ឯងបាន
១៥អញនឹងឱ្យមានស្មៅ[រ]នៅវាល សំរាប់ហ្វូងសត្វឯង ហើយ
ខ្លួនឯង ក៏នឹងបរិភោគឆ្អែតផង[ល] ។
១៦ចូរប្រយ័ត្នចុះ ក្រែងចិត្តឯងរាល់គ្នាត្រូវសេចក្តីល្បួង
ហើយបែរចេញ ទៅគោរពប្រតិបត្តិក្រាបថ្វាយបង្គំដល់ព្រះ
ដទៃ[វ] ១៧រួចសេចក្តីខ្ញាល់[ស]នៃព្រះយេហូវ៉ាឆួលឡើងទាស់
នឹងឯង ហើយទ្រង់បិទ[ហ]ផ្ទៃមេឃ មិនឱ្យមានភ្លៀងឱ្យដីលែង
បង្កើតផល[ឡ] នោះឯងរាល់គ្នានឹងត្រូវវិនាស[អ]បាត់ចេញ
យ៉ាងឆាប់ពីស្រុកដ៏ល្អ ដែលព្រះយេហូវ៉ាប្រទានមកឯង ។
១៨ដូច្នេះ ត្រូវឱ្យរក្សាអស់ទាំងពាក្យអញទាំងនេះទុក នៅ
ក្នុងចិត្ត ក្នុងព្រលឹងឯងចុះ ហើយត្រូវឱ្យចងពាក្យទាំងនេះ
ភ្ជាប់នៅដៃឯងទុកជាទីសំគាល់ និងសំរាប់ជាស្លាកនៅ
កណ្តាលថ្ងាសឯង[ក] ១៩ត្រូវឱ្យបង្រៀនពាក្យទាំងនេះដល់ពួក
កូនចៅឯង[ខ] ដោយនិយាយប្រាប់ក្នុងកាលដែលឯងអង្គុយ
នៅក្នុងផ្ទះ ហើយដើរតាមផ្លូវ ក្នុងកាលដែលដេក ហើយ
ក្រោកឡើងផង[គ] ២០ត្រូវឱ្យកត់ពាក្យទាំងនេះនៅក្របទ្វារផ្ទះ
ហើយនៅទ្វារកំផែងឯងដែរ[ឃ] ២១ដើម្បីឱ្យអាយុឯងនឹង
អាយុកូនចៅឯង បានចំរើនវែងឡើង[ង] ដូចជាអស់ទាំងថ្ងៃ
នៃស្ថានសួគ៌នៅលើផែនដី នៅក្នុងស្រុកដែលព្រះយេហូវ៉ា
បានស្បថថា នឹងឱ្យដល់ពួកឰយុកោឯង[ច] ២២ដ្បិតបើឯង
រាល់គ្នានឹងកាន់តាមបញ្ញត្តិ[ឆ] ដែលអញបង្គាប់ឯងនេះ គ្រប់
ជីពូកអស់ពីចិត្ត ព្រមទាំងប្រព្រឹត្តតាមផង ដោយស្រឡាញ់[ជ]
ដល់ព្រះយេហូវ៉ាជាព្រះនៃឯង ទាំងដើរតាម[ឈ]គ្រប់ទាំងផ្លូវ
ទ្រង់ ហើយនៅជាប់នឹងទ្រង់ ២៣នោះព្រះយេហូវ៉ាទ្រង់នឹង
បណ្តេញ[ញ] អស់ទាំងសាសន៍ទាំងនេះ[ដ] ពីមុខឯងចេញហើយ
ឯងនឹងបានចាប់យកស្រុក របស់សាសន៍ទាំងប៉ុន្មានដែលធំ
ហើយខ្លាំងពូកែជាងឯង[ឋ] ២៤គ្រប់ទីកន្លែងណាដែលជើងឯង
រាល់គ្នានឹងជាន់លើ នោះនឹងបានជារបស់ផងឯងហើយ[ឌ] ឯ
ព្រំស្រុកឯង នោះនឹងបានចាប់តាំងពីទីរហោស្ថាន[ឍ] រហូត
ដល់ភ្នំល្បាណូន ហើយពីទន្លេ គឺជាទន្លេអឺប្រាត រហូត
ដល់សមុទ្រខាងលិច ២៥គ្មានមនុស្សណាមួយនឹងអាចឈរ
នៅមុខឯងរាល់គ្នាបានឡើយ ដ្បិតព្រះយេហូវ៉ា ជាព្រះនៃ
ឯង ទ្រង់នឹងបណ្តាលស្រុកទាំងមូលដែលឯងរាល់គ្នាទៅ
ជាន់នោះ ឱ្យមានសេចក្តីភ័យញ័រ[ណ] ហើយឱ្យស្ញែងខ្លាច
ចំពោះឯងរាល់គ្នា ដូចជាទ្រង់បានមានបន្ទូលនឹងឯង
ហើយ[ត] ។
២៦មើល នៅថ្ងៃនេះ អញដាក់ព្រះពរ[ថ] ហើយនិងសេចក្តី
បណ្តាសា[ទ] សំញែងនៅមុខឯងរាល់គ្នា ២៧បើឯងស្តាប់តាម
អស់ទាំងបញ្ញត្តិរបស់ព្រះយេហូវ៉ា ជាព្រះនៃឯង ដែលអញ
បង្គាប់ដល់ឯងនៅថ្ងៃនេះ នោះនឹងបានពរ[ធ] ២៨តែបើមិន
ស្តាប់តាម[ន]អស់ទាំងបញ្ញត្តិរបស់ព្រះយេហូវ៉ា ជាព្រះនៃឯង
ទេ គឺបែរចេញពីផ្លូវដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ
ទៅតាមព្រះដទៃ[ប]ដែលពីដើមមិនបានស្គាល់វិញ នោះឯង

**១១:១១** ធ អគ ៣៦:៤ ន ចទ ៨:៧ នហ ៩:២៥ **១១:១២** ប ១ពវ ៨:២៩ ៩:៣ **១១:១៣** ផ ចទ ៦:១៧ ព ចទ ១០:១២ ភ ចទ ៤:២៩ យរ ១៧:២៤ **១១:១៤** ម លវ ២៦:៤ កច ១៤:១៧ យ ទដ ១៤៧:៨ យរ ៣:៣ ៥:២៤ យអ ២:២៣ យក ៥:៧ **១១:១៥** រ ទដ ១០៤:១៤ ល លវ ២៦:៥ **១១:១៦** វ ចទ ៤:១៩ ៨:១៩ ២៩:១៨ យប ៣១:៩,២៧ **១១:១៧** ស ចទ ៦:១៥ ៩:១៩ ហ ១ពវ ១៧:១ ២របា ៦:២៦ ៧:១៣ ឡ លវ ២៦:២០ អ ចទ ៤:២៦ ២៨:១២,២៤ **១១:១៨** ក នក ១៣:៩ ចទ ៦:៦–៨ **១១:១៩** ខ នក ១២:២៦ ចទ ៦:៧ ទដ ១៤៥:៤ អស ៣៨:១៩ យរ ៣២:៣៩ គ ចទ ៤:៩–១០ **១១:២០** ឃ ចទ ៦:៩ **១១:២១** ង យប ៥:២៦ សភ ៣:២ ៤:១០ ៩:១១ ច ទដ ៧២:៥

**១១:២២** ឆ ចទ ៦:១៧ ជ ចទ ៦:៥ ឈ ចទ ១០:២០ **១១:២៣** ញ ចទ ៩:៥ ដ នក ២៣:២៨ ឋ ចទ ៩:១ **១១:២៤** ឌ លប ១៥:១៨ ចទ ១:៣៦ ១២:២០ ១៩:៨ យស ១:៣ ១៤:៩ ឍ លប ២:១៤ **១១:២៥** ណ ចទ ២:២៥ ត នក ២៣:២៧ ចទ ៧:២៤ **១១:២៦** ថ ទដ ២៤:៥ ទ លវ ២៧:១៣–២៦ ៣០:១,១៥,១៩ បទ ២:១៧ ដយ ៩:១១ ហក ១:១១ មឡ ២:២ ៣:៩ ៤:៦ **១១:២៧** ធ ចទ ២៨:១–១៤ ទដ ២៤:៥ **១១:២៨** ន ២របា ២៤:២០ យរ ៤២:១៣ ៤៤:១៦ ប ចទ ៤:២៨ ១៣:៦,១៣ ២៩:២៦ ១សយ ២៦:១៩

**១១:១៣** មើលការពន្យល់ ៤:២៩ ។

**១១:១៤** *ភ្លៀងខាងដើមរដូវ* រដូវភ្លៀងនៅប្រទេសអ៊ីស្រាអែល គឺចាប់ពីខែតុលារហូតដល់ខែមេសា ។

**១១:១៧** *បិទផ្ទៃមេឃ* រដូវភ្លៀងជារដូវសំខាន់ មើល ខ.១៤ គឺជាព្រះយេហូវ៉ា ជាអ្នកគ្រប់គ្រងការងារនោះ មិនមែនបានមកដោយព្រះបាល–ពេអ ដែលអ្នកស្រុកកាណានគិតនោះទេ (ប្រៀបធៀបគម្ពីរ យរ ១៤:២២ ហស ២:៨ និងការពន្យល់) ។

**១១:១៨–២០** សូមមើលការពន្យល់ ៦:៨–៩ ។

**១១:២១** *ដូចជាអស់ទាំងថ្ងៃ . . . ផែនដី* គឺថាឱ្យភាពស្ថិតស្ថេរដូចស្ថានព្រះហស្តសព្វថ្ងៃនេះអញ្ចឹង ។

**១១:២២** *នៅជាប់* សូមមើលការពន្យល់ ១០:២០ ។

**១១:២៤** *គ្រប់ទីកន្លែងណាដែលជើងឯងរាល់គ្នានឹងជាន់លើ* មើល ១:៧ និងការពន្យល់ យស ១:៣ ។

**១១:២៦–៣០** ព្រះពរហើយនិងបណ្តាសារបានប្រកាសប្រាប់ នៅលើភ្នំកេរីស៊ីម និងភ្នំអេបាល ត្រូវបានបង្ហាញបញ្ជាក់យ៉ាងលំអិតនៅក្នុងជំពូក ២៧–២៨ ។

**១១:២៨** *ស្គាល់* បទពិសោធន៍ ឬក៏ចំណេះដឹង (មើល ១៣:២,៦,១៣ ២៨:៦៤ ២៩:២៦ ៣២:១៧ មើលការពន្យល់ក្នុង នក ៦:៣) ។

នឹងត្រូវបណ្ដាសាហើយ ។
២៩កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង បាននាំឯងចូល
ទៅក្នុងស្រុកដែលឯងត្រូវទៅចាប់យក នោះត្រូវឱ្យប្រកាស
ប្រាប់ព្រះពរពីលើភ្នំកេរិសីម[ផ] និងសេចក្ដីបណ្ដាសា[ព]ពីលើ
ភ្នំអេបាល[ភ] ៣០(ភ្នំទាំង២នោះនៅត្រើយទន្លេយ័រដាន់ខាង
នាយ គឺទិសខាងថ្ងៃលិច នាស្រុករបស់ពួកសាសន៍កាណាន
ត្រង់ស្រុកវាល ទល់មុខនឹងគីលកាល[ម] ជិតដើមម៉ៃសាក់
របស់ម៉ូរេ[យ]) ៣១ដ្បិតឯងរាល់គ្នាត្រូវឆ្លងទន្លេយ័រដាន់ចូល
ទៅចាប់យក[រ]ស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃឯងបាន
ប្រទាន[ល]មក ឯងរាល់គ្នានឹងយកទុកជារបស់ផងឯងហើយ
និងនៅក្នុងស្រុកនោះផង ៣២ដូច្នេះ ចូរប្រយ័ត្ននឹងប្រព្រឹត្ត
តាមអស់ទាំងច្បាប់ ហើយនិងបញ្ញត្តិទាំងប៉ុន្មាន ដែលអញ
ដាក់នៅមុខឯងរាល់គ្នានៅថ្ងៃនេះចុះ ។

## ទីកន្លែងថ្វាយបង្គំ

**១២** ១នេះជាច្បាប់[ក] និងជាបញ្ញត្តិទាំងប៉ុន្មាន ដែលឯង
រាល់គ្នាត្រូវប្រយ័ត្ននឹងប្រព្រឹត្តតាម នៅក្នុងស្រុកដែលព្រះ
យេហូវ៉ា ជាព្រះនៃពួកព្ធយុកោឯង បានប្រទានឱ្យទទួលយក
រហូតដល់គ្រប់១ជីវិត ដែលឯងរាល់គ្នារស់នៅលើផែនដី[ខ]
២គឺត្រូវឱ្យបំផ្លាញគ្រប់ទីកន្លែងរបស់សាសន៍ដទៃទាំងប៉ុន្មាន
ដែលឯងនឹងបណ្ដេញចេញនោះជាកុំខាន គឺជាកន្លែងដែល
គេបានគោរពប្រតិបត្តិដល់ព្រះគេ នៅលើភ្នំធំតូច[គ] ហើយ
នៅក្រោមគ្រប់ទាំងដើមឈើខ្ចីផង[ឃ] ៣ត្រូវរំលំអាសនាគេ
ព្រមទាំងបំបាក់បំបែក[ង]បង្គោល ដែលសំរាប់គោរព និង
ដុត[ច]អ្នកតា[ឆ]របស់គេ ក៏ត្រូវកាប់រំលំរូបព្រះឆ្លាក់របស់គេ
ហើយរំលាយឈ្មោះ[ជ]ព្រះទាំងនោះពីទីនោះចេញផង ៤តែ
មិនត្រូវធ្វើដូច្នោះដល់ព្រះយេហូវ៉ា ជាព្រះនៃឯងឡើយ[ឈ]
៥គឺត្រូវឱ្យឯងស្វែររកទីលំនៅនៃព្រះយេហូវ៉ា ជាព្រះនៃឯ
នៅកន្លែងណា[ញ] ដែលទ្រង់សព្វព្រះហឫទ័យនឹងរើស ក្នុង
ពូជអំបូរឯងទាំងប៉ុន្មាន សំរាប់ជាកន្លែងដាក់ព្រះនាមទ្រង់[ដ]
ហើយត្រូវឱ្យទៅឯទីនោះវិញ ៦ក៏ត្រូវនាំយកអស់ទាំងដង្វាយ
ដុតយ ញ្ញបូជា ដង្វាយ១ភាគក្នុង១០[ឋ] ដង្វាយលើកចុះឡើង
ដង្វាយលាបំណន់[ឌ] ដង្វាយស្ម័គ្រពីចិត្ត និងកូនកើតដំបូងក្នុង
ហ្វូងគោហ្វូងចៀមឯង ទៅឯទីនោះដែរ[ឍ] ៧ហើយនៅ
ទីនោះ ត្រូវឱ្យឯងរាល់គ្នាបរិភោគនៅចំពោះ[ណ]ព្រះយេ
ហូវ៉ា ជាព្រះនៃឯង ហើយឯង និងពួកគ្រួសារឯង ត្រូវអរ
សប្បាយឡើង[ត] ដោយព្រោះគ្រប់ទាំងរបស់ដែលដៃឯងលូក
ទៅចាប់យក ពីរបស់ទាំងប៉ុន្មានដែលព្រះយេហូវ៉ា ជាព្រះ
នៃឯង បានប្រទានពរដល់ឯងហើយ ៨មិនត្រូវធ្វើដូចជា
យើងធ្វើនៅទីនេះសព្វថ្ងៃ គឺតាមតែគ្រប់គ្នាគិតឃើញថា
ត្រូវនោះទេ[ថ] ៩ដ្បិតឯងរាល់គ្នាមិនទាន់បានចូលដល់សេចក្ដី
សំរាក[ទ] និងមរដក[ធ]ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់
ប្រទានមកនៅឡើយទេ ១០តែកាលណាបានឆ្លងទន្លេយ័រ

**១១:២៩** ផ ពច ៩:៧ ព ចទ ២៧:១២–១៣ យស ៨:៣៣ យហ ៤:២០ ភ ចទ ២៧:៤ យស ៨:៣០ **១១:៣០** ម លប ១២:៦ យ យស ៤:១៩ ៥:៩ ៩:៦ ១០:៦ ១៤:៦ ១៥:៧ ពច ២:១ ២ពវ ២:១ មីក ៦:៥ **១១:៣១** រ ជន ៣៣:៥៣ ល ចទ ១២:១០ យស ១១:២៣ **១២:១** ក ទដ ១១៩:៥ ខ ចទ ៤:៩–១០ ៦:១៥ ១ពវ ៨:៤០ អគ ២០:១៩ **១២:២** គ ជណ ២១:២៨ ឃ ១ពវ ១៤:២៣ ២ពវ ១៧:១០ អស ៥៧:៥ យរ ២:២០ ៣:៦,១៣ **១២:៣** ង ២ពវ ១១:១៨ ច នក ៣២:២០ ឆ នក ៣៤:១៣ ១ពវ ១៤:១៥,២៣ ជ នក ២៣:១៣ **១២:៤** ឈ ខ.៣០ ២ពវ ១៧:១៥ យរ ១០:២ **១២:៥** ញ នក ២០:២៤ ២សយ ៧:១៣ ដ ខ.១១, ១៣ ចទ?១៤:២៣ ១៥:២០ ១៦:២,១១ ១៨:៦ ២៦:២ ១សយ ២:២៩ ១ពវ ៥:៥ ៨:១៦ ៩:៣ ២របា ២:៤ ៦:៦ ៧:១២,១៦ អរ ៦:១២ ៧:១៥ ទដ ២៦:៨ ៧៨:៦៨ សក ២:១២ **១២:៦** ឋ លវ ២៧:៣០ ឌ លប ២៨:២០ ឍ យស ២២:២៧ អស ៦៦:២០ **១២:៧** ណ នក ១៨:១២ ត លវ ២៣:៤០ សស ៣:១២–១៣ ៥:១៨–២០ អស ៦២:៩ **១២:៨** ថ ពច ១៧:៦ ២១:២៥ **១២:៩** ទ នក ៣៣:១៤ ចទ ៣:២០ ទដ ៩៥:១១ មីក ២:១០ ធ ចទ ៤:២១

**១១:៣០** *ទិសខាងលិច* ប្រហែលជាផ្លូវពីជើងទៅត្បូង ដែលបុកឆ្ពោះទៅទន្លេយ័រដាននៅចន្លោះសមុទ្រកាលីឡេ និងសមុទ្រស្លាប់ ។ *ដើមម៉ៃសាក់របស់ម៉ូរេ* សូមមើលការពន្យល់ លប ១២:៦ ។ *ស្រុកវាល* មើលការពន្យល់ ១:១ សាសន៍កាណានដែលរស់នៅទីនោះបានគ្រងទឹកដី ទាំងស្រុកភ្នំកេរីសីម និងអេបាល ។ *ស្រុកគីលបាល* មើល យអ ៤:១៩ និងការពន្យល់ ។

**១២:២** *នៅក្រោមគ្រប់ទាំងដើមឈើខ្ចីផង* មើលការពន្យល់ ១ពវ ១៦:៤ ។

**១២:៣** *រំលំអាសនាគេ . . . បង្គោល . . . និងដុតអ្នកតា* សូមមើលការពន្យល់ ៧:៥ ។

**១២:៤** *ជាព្រះនៃឯងឡើយ* ការមានទម្លាប់យកវត្ថុផ្សេងៗមកដើម្បីថ្វាយបង្គំព្រះ គឺមិនធ្វើសម្រាប់ការថ្វាយបង្គំព្រះយេហូវ៉ា ជាព្រះពិតនោះទេ (ប្រៀបធៀបនឹង ខ.២៩–៣១) ។ វត្ថុអ្វីៗដែលមិនមែនសម្រាប់សរសើរតម្កើងដល់ទ្រង់នោះគឺត្រូវជម្រុះចោលទាំងអស់ (មើល មីក ៥:១០–១៤ និងការពន្យល់) ។

**១២:៥** *នៅទីកន្លែងណា . . . ព្រះហឫទ័យនឹងរើស . . . ដាក់ព្រះនាមទ្រង់* រោងឧបោសថជាទីដែលទ្រង់រើសដើម្បីគង់ ក្នុងពេលធ្វើដំណើរ នៅវាលរហាស្ថាន ឬក្រុងកាណាន លោកប៉ុលបានប្រាប់ថា ទីដែលសមនឹងធ្វើការថ្វាយបង្គំ គឺទឹកដីសន្យា ។ ទីនោះអ្នកស្រុកកាណាន បានធ្វើជាទីថ្វាយបង្គំ សូមមើល ខ.១១,១៤,១៨,២១,២៦ ១៤:២៣–២៤ ។ *ព្រះនាមទ្រង់* មើលការពន្យល់ នក ៣:១៣–១៥ ២៣:២១ ១ពវ ៥:៥ ។

**១២:៦** មើល ខ.១១ ។

**១២:៧** *ឯងរាល់គ្នាបរិភោគនៅ . . . ត្រូវអរសប្បាយឡើង* ព្រះយេហូវ៉ាសព្វព្រះទ័យឱ្យរាស្ត្រទ្រង់សប្បាយ និងមានសេចក្ដីអំណរ នូវភោគផលដែលចេញពីកម្លាំងរបស់ខ្លួនព្រោះវាជាលទ្ធផលនៃព្រះពរ (សូមមើល ខ.១៨ ប្រៀប ធៀប ២:២៤–២៥ និងការពន្យល់ ៥:១៨–២០) ។

**១២:៨** *ដូចជាយើងធ្វើនៅទីនេះសព្វថ្ងៃ* ប្រជាជនអ៊ីស្រាអែលមិនអាចធ្វើតាមបានគ្រប់ទាំងអស់នូវរបៀបវារៈ នៃការថ្វាយយញ្ញបូជាក្នុងពេលដែលពួកគេធ្វើដំណើរ នៅលើវាលរហោស្ថាន ។ ដូចជាលោកម៉ូសេបានណែនាំខ្លះ ពីការថ្វាយបង្គំនិងត្រូវប្រព្រឹត្តបែបសមគួរ (សូមមើល ខ.១០–១៤ និងការពន្យល់ ពច ១៧:៦) ។

**១២:៩** *សេចក្ដីសំរាក* មើលការពន្យល់ ៣:២០ ។

ដាន់ ទៅក្នុងស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់
ប្រទាន[ន]ឱ្យគ្រងជាមរដក ហើយទ្រង់បានប្រទានឱ្យសិរាក[ប]
ពីពួកខ្មាំងសត្រូវនៅជុំវិញ និងឱ្យឯងបាននៅដោយសុខ
សាន្តហើយ ១១ នោះត្រូវនាំយកអស់ទាំងដង្វាយ ដែលអញ
បង្គាប់ឯង ទៅថ្វាយនៅកន្លែងណា ដែលព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់នឹងរើសសំរាប់តាំងព្រះនាមទ្រង់ចុះ[ផ] គឺ
អស់ទាំងដង្វាយដុត យញ្ញបូជា ដង្វាយ១ភាគក្នុង១០ ដង្វាយ
លើកចុះឡើង ហើយគ្រប់ទាំងផលជ្រើសរើស ដែលឯង
បានបន់ ថ្វាយព្រះយេហូវ៉ាផង[ព] ១២ ត្រូវឱ្យឯងរាល់គ្នាអរ
សប្បាយឡើង[ភ] នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង ព្រម
ទាំងកូនប្រុស កូនស្រីឯង និងបាវប្រុសបាវស្រីឯង ហើយ
និងពួកលេវីដែលនៅក្នុងទីក្រុងឯងផង ដ្បិតពួកលេវី[ម]គ្មាន
ចំណែក គ្មានមរដក[យ]នៅជាមួយនឹងឯងទេ ១៣ ចូរប្រយ័ត្ន
កុំឱ្យថ្វាយដង្វាយដុតរបស់ឯងនៅអស់ទាំងទីកន្លែងណា
ដែលឯងប្រទះឃើញនោះឡើយ[រ] ១៤ គឺត្រូវថ្វាយដង្វាយ
ដុតរបស់ឯង នៅកន្លែងដែលព្រះយេហូវ៉ាទ្រង់នឹងរើស[ល]
ក្នុងពូជអំបូរឯងណាមួយវិញ ហើយនៅទីនោះ ឯងត្រូវធ្វើ
តាមគ្រប់ទាំងសេចក្តីដែលអញបង្គាប់មក ។
១៥ ប៉ុន្តែឯងមានច្បាប់នឹងសំឡាប់ ហើយបរិភោគសាច់
នៅគ្រប់ទីក្រុងរបស់ឯងបាន តាមបំណងចិត្ត តាមដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានពរឱ្យ ទោះទាំងអ្នក
ដែលមិនស្អាតនឹងអ្នកដែលស្អាត ក៏បរិភោគបានទាំងអស់
ដូចជាបរិភោគសាច់ឈ្លូស[វ] និងប្រើសដែរ ១៦ ប៉ុន្តែមិនត្រូវ
បរិភោគឈាមឡើយ[ស] ត្រូវឱ្យចាក់[ហ]ចោលទៅដីដូចជាទឹក
វិញ[ឡ] ១៧ តែនៅក្នុងទីលំនៅរបស់ឯង នោះមិនត្រូវបរិភោគ
ដង្វាយ១ភាគក្នុង១០[អ] ដែលហូតពីស្រូវពីទឹកទំពាំងបាយជូរ
ឬពីប្រេង[ក] និងកូនគោកូនចៀមក្នុងហ្វូងសត្វរបស់ឯងដែល
កើតដំបូង ដង្វាយលាបំណន់[ខ] ដង្វាយដែលថ្វាយដោយ
ស្ម័គ្រពីចិត្ត ឬដង្វាយដែលថ្វាយដោយលើកចុះឡើងនោះ
ឡើយ[គ] ១៨ ឯដង្វាយទាំងនោះ ត្រូវឱ្យឯងបរិភោគ[ឃ] នៅ
ចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង ត្រង់កន្លែងដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងរើស[ង]វិញព្រមទាំងកូន
ប្រុសកូនស្រី និងបាវប្រុសបាវស្រីឯង ហើយនិងពួកលេវី
ដែលនៅទីក្រុងឯងផង ហើយត្រូវអរសប្បាយ[ច]នៅចំពោះ
ព្រះយេហូវ៉ា ជាព្រះនៃឯង ដោយព្រោះគ្រប់ទាំងរបស់អ្វី
ដែលឯងលូកដៃទៅចាប់យកបាន ១៩ ចូរប្រយ័ត្ន កុំឱ្យលះ
ចោលពួកលេវីឡើយ[ឆ] រហូតដល់គ្រប់១ជីវិត ដែលឯងរស់
នៅក្នុងស្រុកឯង[ជ] ។
២០ កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង បានវាតព្រំ
ស្រុកឯងឱ្យធំឡើង[ឈ]ដូចជាទ្រង់បានសន្យា[ញ] ហើយឯងនឹក
ក្នុងចិត្ត ដោយមានសេចក្តីប្រាថ្នាចង់បរិភោគសាច់[ដ]ថា
អញចង់ស៊ីសាច់ណាស់ នោះនឹងបរិភោគបានតាមបំណង
ចិត្ត ២១ បើសិនជាកន្លែងដែលព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់រើស សំរាប់នឹងតាំងព្រះនាមទ្រង់[ឋ] នៅឆ្ងាយពីឯងពេក
នោះនឹងសំឡាប់គោឬចៀម ដែលព្រះយេហូវ៉ាបានប្រទាន
មកឯង បានដូចជាអញបានបង្គាប់ហើយ ក៏មានច្បាប់នឹង
បរិភោគនៅក្នុងទីក្រុងឯងបានតាមចិត្តដែរ[ឌ] ២២ ឯងមាន
ច្បាប់នឹងបរិភោគសាច់សត្វទាំងនោះបាន ដូចជាបរិភោគ
ឈ្លូសនឹងប្រើសផង[ឍ] ទោះទាំងអ្នកមិនស្អាតនឹងអ្នកស្អាតក្តីក៏
នឹងបរិភោគបានដូចគ្នា ២៣ ចូរប្រយ័ត្ន កុំឱ្យតែបរិភោគ
ឈាម[ណ]ប៉ុណ្ណោះ ដ្បិតឈាមជាជីវិត ហើយមិនត្រូវឱ្យ
បរិភោគជីវិតជាមួយនឹងសាច់ឡើយ[ត] ២៤ មិនត្រូវបរិភោគ
ឈាមឱ្យសោះ ត្រូវចាក់ចោលទៅដីដូចជាទឹកវិញ[ថ] ២៥ គឺមិន
ត្រូវឱ្យឯងបរិភោគ ដើម្បីឱ្យឯងបានសប្បាយ[ទ] ព្រមទាំងកូន
ចៅឯងតរៀងទៅផង ដោយឯងប្រព្រឹត្តតាមសេចក្តីដែល
ទៀងត្រង់[ធ]នៅព្រះនេត្រព្រះយេហូវ៉ា ២៦ ឯអស់ទាំងដង្វាយ
បរិសុទ្ធ ដែលនៅជាមួយនឹងឯង និងដង្វាយលាបំណន់របស់
ឯង[ន] នោះត្រូវនាំយកទៅថ្វាយ នៅកន្លែងដែលព្រះយេហូវ៉ា
ទ្រង់នឹងរើសវិញ ២៧ ហើយអស់ទាំងដង្វាយដុតរបស់ឯង[ប]
ព្រមទាំងសាច់ និងឈាមផង នោះត្រូវថ្វាយលើអាសនានៃ
ព្រះយេហូវ៉ា ជាព្រះនៃឯង ហើយឈាមនៃយញ្ញបូជារបស់

**១២:១០** ន ចទ ១១:៣១ ប នក ៣៣:១៤
**១២:១១** ផ ខ.៥ ព លវ ១:៣ យស ២២:២៣
**១២:១២** ភ ខ.៧ ម ចទ ២៦:១១–១៣ យ ជន ១៨:២០
**១២:១៣** រ ខ.៥
**១២:១៤** ល ខ.១១
**១២:១៥** វ ខ.២២ ចទ ១៤:៥ ១៥:២២
**១២:១៦** ស លប ៩:៤ កច ១៥:២០ ហ ខ.២៣–២៤ លប ៣៥:១៤ ១របា ១១:១៨ យរ ៧:១៨ ឡ លវ ១៧:១៣ ចទ ១៥:២៣ យហ ១៩:៣៤
**១២:១៧** អ លវ ២៧:៣០ ក ជន ១៨:២១ ខ ខ.២៦ ជន ១៨:១៩ គ ចទ ១៤:២៣ ១៥:២០
**១២:១៨** ឃ ចទ ១៤:២៣ ១៥:២០ ង ខ.៥ ច ខ.៧,១២ ចទ ១៤:២៦ នហ ៨:១០ សស ៣:១២–១៣ ៥:១៨–២០
**១២:១៩** ឆ ខ.១២ ចទ ១៤:២៧ នហ ១៣:១០ ជ មឡ ៣:៨
**១២:២០** ឈ នក ៣៤:២៤ ញ លប ១៥:៨ ចទ ១១:២៤ ដ នក ១៦:៣
**១២:២១** ឋ ចទ ១៤:២៤ ឌ លវ ១៧:៤
**១២:២២** ឍ ខ.១៥ **១២:២៣** ណ លប ៩:៤ លវ ៧:២៦ ត អគ ៣៣:២៥
**១២:២៤** ថ ខ.១៦ **១២:២៥** ទ ចទ ៤:៤០ ធ ខ.២៨ នក ១៥:២៦ ចទ ១៣:១៨ ១ពស ១១:៣៨ ២ពស ១២:២ **១២:២៦** ន ខ.១៧ ជន៥:៩–១០ **១២:២៧** ប លវ ១:១៣

**១២:១១** *រើសសំរាប់តាំងព្រះនាមទ្រង់ចុះ* មើលការពន្យល់ ខ.៥ ។
**១២:១២** *អរសប្បាយឡើង នៅចំពោះព្រះយេហូវ៉ា* សេចក្តីអំណរជាមូលដ្ឋាននៃព្រះពររបស់ព្រះយេហូវ៉ា ក៏ជាលក្ខណៈសំខាន់របស់សាសន៍ហេព្រើរ និងការថ្វាយបង្គំក្នុងទឹកដីសន្យា (ខ.៧,១៨) ។ *ពួកលេវីគ្មានមរដកនៅជាមួយ* មើល ១០:៩ ជន ១៨:១–៨ និងការពន្យល់ ៨:១ ១៨:២០,២៤ ។
**១២:១៣** *កុំឱ្យថ្វាយដង្វាយដុតរបស់ឯងនៅអស់ទាំងទីកន្លែង* យញ្ញបូជា ឬដង្វាយដែលថ្វាយទៅព្រះនៅត្រង់កន្លែងប្រមូលផ្តុំរួមមួយ មិនមែនគ្រប់កន្លែងផ្សេងៗរបស់សាសន៍កាណាន សម្រាប់ថ្វាយបង្គំនោះទេ (សូមមើល ខ.៥) ។
**១២:១៥,២២** *ដែលមិនស្អាត* មើលការពន្យល់ លវ ៤:១២ ។
**១២:១៦,២៤** *មិនត្រូវបរិភោគឈាមឡើយ* សូមមើលការពន្យល់ លប ៩:៤ លវ ១៧:១១ ។

ឯង នោះត្រូវចាក់ទៅលើអាសនានៃព្រះយេហូវ៉ា ជាព្រះ
នៃឯង តែឯសាច់ នោះបរិភោគ[ផ]បាន ២៨ចូរប្រយ័ត្ន
និងស្តាប់តាមគ្រប់ទាំងសេចក្តីនេះ ដែលអញបង្គាប់ដល់ឯង
ដើម្បីឱ្យឯងបានសប្បាយ[ព] ព្រមទាំងកូនចៅឯងតរៀងទៅ
ជាដរាប ដោយបានប្រព្រឹត្តសេចក្តីដែលល្អ ហើយទៀង
ត្រង់នៅព្រះនេត្រព្រះយេហូវ៉ា ជាព្រះនៃឯង ។
២៩កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បានកាត់
បណ្តាច់[ភ]អស់ទាំងសាសន៍ ពីមុខឯងចេញ នៅក្នុងស្រុក
ដែលឯងចូលទៅចាប់យកពីគេ ហើយឯងបានបណ្តេញ
គេអស់ទៅ ព្រមទាំងអាស្រ័យនៅក្នុងស្រុករបស់គេផង[ម]
៣០នោះចូរប្រយ័ត្នក្រែងត្រូវជាប់អន្ទាក់[យ] និងបណ្តោយតាម
គេ ក្រោយដែលគេត្រូវបំផ្លាញពីមុខឯងចេញហើយ ឬ
ក្រែងឯងសើបសួរតាមព្រះគេ ដោយពាក្យថា សាសន៍ទាំង
នេះគោរពប្រតិបត្តិដល់ព្រះគេជាយ៉ាងដូចម្តេច អញចង់
ធ្វើដូចជាគេដែរ[រ] ៣១មិនត្រូវឱ្យធ្វើយ៉ាងដូច្នោះដល់ព្រះ
យេហូវ៉ា ជាព្រះនៃឯងឡើយ ដ្បិតគេប្រព្រឹត្តដល់ព្រះរបស់
គេតាមអស់ទាំងសេចក្តីដែលព្រះយេហូវ៉ាទ្រង់ស្អប់ខ្ពើម[ល]
គេបានទាំងដុតកូនប្រុសកូនស្រីរបស់គេ[វ]ក្នុងភ្លើងថ្វាយដល់
ព្រះគេផង[ស] ៣២អស់ទាំងសេចក្តីណាដែលអញបង្គាប់ដល់
ឯងរាល់គ្នា នោះត្រូវប្រយ័ត្ននឹងប្រព្រឹត្តតាមចុះ មិនត្រូវ
បន្ថែម[ហ]បញ្ចូលអ្វី ឬកាត់ចោលអ្វីឡើយ ។

## ការថ្វាយបង្គំព្រះដទៃ

**១៣** ១បើកាលណាមានហោរាណា[ក] ឬអ្នកណាកើតឡើង
នៅក្នុងពួកឯង ដែលតែងតែយល់សប្តិ[ខ] ហើយអ្នកនោះ
ប្រាប់ទីសំគាល់ ឬពីការអស្ចារ្យណា ២រួចទីសំគាល់[គ] ឬការ
អស្ចារ្យនោះកើតមកមែន តាមដូចជាអ្នកនោះប្រាប់មកឯង
ដោយល្បួងថា ចូរយើងទៅតាមព្រះដទៃ[ឃ] ហើយគោរព
ប្រតិបត្តិដល់ព្រះទាំងនោះវិញ (ជាព្រះដែលឯងមិនបាន
ស្គាល់សោះ) ៣នោះមិនត្រូវឱ្យឯងស្តាប់តាមពាក្យរបស់
ហោរានោះ[ង] ឬអ្នកដែលយល់សប្តិនោះឡើយ[ច] ដ្បិតព្រះយេ
ហូវ៉ា ជាព្រះនៃឯង ទ្រង់គ្រាន់តែល្បួងឯងមើល[ឆ] ឱ្យដឹងជា
ឯងរាល់គ្នាស្រឡាញ់[ជ]ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង អស់
ពីចិត្ត អស់ពីព្រលឹងឯងឬទេ ៤ត្រូវឱ្យដើរតាម[ឈ]តែព្រះយេ
ហូវ៉ា ជាព្រះនៃឯងវិញ ហើយកោតខ្លាចដល់ទ្រង់[ញ] ព្រម
ទាំងកាន់តាមសេចក្តីបញ្ញត្តិទាំងប៉ុន្មានរបស់ទ្រង់ និងស្តាប់
តាមព្រះបន្ទូលទ្រង់ ក៏ត្រូវគោរពប្រតិបត្តិដល់ទ្រង់ ហើយ
នៅជាប់[ដ]នឹងទ្រង់ផង ៥ឯហោរាឬអ្នកយល់សប្តិនោះ
ត្រូវតែសំឡាប់ចោលទៅ[ឋ] ពីព្រោះបានល្បួងឱ្យបះបោរនឹង
ព្រះយេហូវ៉ា ជាព្រះនៃឯង ដែលទ្រង់បាននាំឯងចេញពី
ស្រុកអេស៊ីព្ទមក ព្រមទាំងលោះឱ្យរួចពីផ្ទះពួកបាវបំរើផង
អ្នកនោះចង់តែទាញ[ឌ]ឱ្យឯងរាល់គ្នាបែរចេញពីផ្លូវ ដែល
ព្រះយេហូវ៉ា ជាព្រះនៃឯង បានបង្គាប់ឱ្យដើរតាមនោះទេ
យ៉ាងនោះឯងនឹងបានបំបាត់សេចក្តីអាក្រក់[ឍ]ចេញពីពួកឯង
ទៅ ។
៦បើសិនជាបង ឬប្អូនពោះ១នឹងឯង ឬកូនប្រុសកូនស្រី
ឯង ឬប្រពន្ធ ជាដួងជីវិតរបស់ឯង ឬសំឡាញ់ថ្មើម១ នឹងឯង
បានបបួល[ណ]ដោយសំងាត់ថា ចូរយើងទៅគោរពប្រតិបត្តិ
ដល់ព្រះដទៃវិញ[ត] ជាព្រះដែលឯង ឬពួកឰយុកោឯងមិន
ដែលបានស្គាល់សោះ ៧គឺក្នុងអស់ទាំងព្រះរបស់សាសន៍
ទាំងប៉ុន្មាន ដែលនៅជុំវិញឯង ទោះជិត ឬឆ្ងាយពីឯងក្តី
ចាប់តាំងពីចុងផែនដីម្ខាង ដល់ចុងផែនដីម្ខាង ៨នោះមិន
ត្រូវព្រម ឬស្តាប់តាម[ថ]អ្នកនោះឡើយ ក៏មិនត្រូវឱ្យភ្នែកឯង
អាណិត ឬប្រណី[ទ] ឬបំពួនទុកដែរ ៩ត្រូវតែឯងសំឡាប់វិញកុំ
ខាន[ធ] ត្រូវឱ្យឯងដាក់ដៃ[ន]លើអ្នកនោះជាមុនគេ រួចសឹម
បណ្តាជនទាំងអស់គ្នាជាខាងក្រោយ ដើម្បីនឹងសំឡាប់អ្នក
នោះចោល ១០ត្រូវឱ្យចោលសំឡាប់នឹងថ្ម ដ្បិតជាអ្នករក
ទាញឱ្យឯងបែរចេញពីព្រះយេហូវ៉ា ជាព្រះនៃឯង ដែល
ទ្រង់បាននាំឯងចេញ[ប]ពីផ្ទះបាវបំរើ នៅស្រុកអេស៊ីព្ទមក
១១ដូច្នេះ សាសន៍អ៊ីស្រាអែលទាំងអស់គ្នានឹងឮ រួចកើតមាន
សេចក្តីភ័យខ្លាច[ផ] ហើយលែងប្រព្រឹត្តសេចក្តីអាក្រក់យ៉ាង
នោះនៅក្នុងពួកឯងតទៅ ។

**១២:២៧** ផ លវ ៣:១–១៧ **១២:២៨** ព ចទ ៤:៤០ សស ៨:១២ **១២:២៩** ភ យស ២៣:៤ ម ចទ ៦:១០ **១២:៣០** យ នក ១០:៧ រ ខ.៤ **១២:៣១** ល លវ ១៨:២៥ វ លវ ១៨:២១ ស ២ពវ ៣:២៧ **១២:៣២** ហ ចទ ៤:២ វវ ២២:១៨–១៩ **១៣:១** ក មថ ២៤:២៤ មក ១៣:២២ ២ថន ២:៩ ខ លប ២០:៣ យរ ២៣:២៥ ២៧:៩ ២៩:៨ **១៣:២** គ ចទ ១៨:២២ ១សយ ២:៣៤ ១០:៩ ២ពវ ១៩:២៩ ២០:៩ អស ៧:១១ ឃ ចទ ១១:២៨ **១៣:៣** ង ២ពត ២:១ ច ១សយ ២៨:៦,១៥ ឆ លប ២២:១ ១ពវ ១៣:១៨ ២២:២២–២៣ យរ ២៩:៣១ ៤៣:២ អគ ១៣:៩ ១កថ ១១:១៩ ជ ចទ ៦:៥ **១៣:៤** ឈ ២ពវ ២៣:៣ ២របា ៣៤:៣១ ២យហ ១:៦ ញ ចទ ៦:១៣ ទដ ៥:៧ ដ ចទ ១០:២០

**១៣:៥** ឋ នក ២១:១២ ២២:២០ឌ ខ.១០ ចទ ៤:១៩ ឍ ចទ ១៧:៧,១២ ១៩:១៩ ២៤:៧ ពច២០:១៣ ១កថ ៥:១៣ **១៣:៦** ណ ចទ ១៧:២–៧ ២៩:១៨ ត ចទ ១១:២៨ **១៣:៨** ថ សភ ១:១០ ទ ចទ ៧:២ **១៣:៩** ធ ខ.៥ ន លប ២៤:១៤ **១៣:១០** ប នក ២០:៣ **១៣:១១** ផ ចទ ១៧:១៣ ១៩:២០ ២១:២១

**១២:៣១** *ដុត . . . កូនប្រុសកូនស្រី . . . ថ្វាយដល់ព្រះ* មើល ១៨:១០ មើលការពន្យល់ លវ ១៨:២១ ផងដែរ ។
**១២:៣២** *មិនត្រូវបន្ថែម . . . ឬកាត់ចោលអ្វីឡើយ* មើការពន្យល់ ៤:២ ។
**១៣:១–៥** ការសម្រេចទំនាយចុងក្រោយ គឺជាការល្បងលទំនាយពិតប្រាកដ (១៨:២១–២២) ។ ប៉ុន្តែ បញ្ញត្តិដែលបានផ្តល់មកនៅក្នុងព្រះគម្ពីរនេះ គឺជាការប្រឆាំងនឹងហោរាក្លែងក្លាយ(ប្រៀបធៀប អស ៨:២០) ។
**១៣:៣** *ល្បួង* សូមមើលការពន្យល់ លប ២២:១ ។ *អស់ពីចិត្ត* សូមមើល ៤:២៩ ។
**១៣:៤** *នៅជាប់* មើលការពន្យល់ ១០:២០ ។
**១៣:៥** *ឯហោរាឬ . . . ត្រូវតែសំឡាប់ចោលទៅ* មើល ១៨:២០ យរ ២៨:១៥–១៧ ។ *ឯងនឹងបំបាត់សេចក្តីអាក្រក់ចេញពីពួកឯងទៅ* មើលឡើងវិញក្នុងជំពូក ១៧:៧ ១៩:១៩ ២១:២១ ២២:២១ ២៤:៧ និងសេចក្តីដកស្រង់ពី ១កថ ៥:១៣ ។ គោលបំណង គឺដើម្បីលុបបំបាត់អ្នកដែលជឿលើវិញ្ញាណអារក្ស និងអារក្សខ្លួនវាផ្ទាល់ ។

[១២]បើសិនជាឯងឮនិយាយពីទីក្រុងណាមួយ ដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់បានប្រទានឱ្យឯងនៅ ថា
[១៣]មានមនុស្សទមិលល្មើសខ្លះ[ព] បានចេញពីពួកឯង ទៅនាំ
ប្រទាញពួកអ្នកក្រុងនោះ ដោយពាក្យថា ចូរយើងទៅ
គោរពប្រតិបត្តិដល់ព្រះដទៃវិញ ជាព្រះដែលឯងរាល់គ្នា
មិនបានស្គាល់សោះ [១៤]នោះត្រូវសើបសួររកឱ្យអស់ពីចិត្ត
បើពិតដូច្នោះមែន[ភ] ការនោះត្រូវដូចជាបានឮហើយ ថា
មានគេបានប្រព្រឹត្តការគួរខ្ពើមនោះ នៅក្នុងពួកឯងជាពិត[ម]
[១៥]នោះត្រូវឱ្យកាប់ពួកមនុស្សនៅក្រុងនោះ ដោយមុខដាវ
ជាកុំខាន ទាំងបំផ្លាញគេឱ្យអស់រលីងចេញ[យ] ព្រមទាំង
របស់នៅក្នុងទីក្រុងនោះ និងហ្វូងសត្វផង ដោយមុខដាវ[រ]
[១៦]រួចត្រូវឱ្យប្រមូលអស់ទាំងរបឹប នៅទីក្រុងនោះមកដាក់
នៅនាផ្លូវ ហើយដុតទាំងអស់ចោល ទាំងទីក្រុង[ល]និងរបឹប
ទាំងអស់ថ្វាយព្រះយេហូវ៉ា ជាព្រះនៃឯង[វ] រួចទីក្រុងនោះ
នឹងនៅជាគំនរ[ស]ជាដរាបតទៅ ឥតមានអ្នកណាសង់ឡើង
វិញឡើយ [១៧]ក៏មិនត្រូវមានអ្វីពីរបស់ដែលត្រូវបំផ្លាញទាំង
នោះ នៅក្នុងដៃឯងដែរ ដើម្បីឱ្យព្រះយេហូវ៉ាបានបាត់
សេចក្តីខ្ញាល់ ដ៏ក្តៅក្រហាយចេញ[ហ] បែរមកមានសេចក្តី
មេត្តាករុណា[ឡ] និងសេចក្តីអាណិតអាសូរ[អ]ដល់ឯងវិញ
ព្រមទាំងចំរើនឯងឱ្យច្រើនឡើង[ក] ដូចជាទ្រង់ស្បថ[ខ]នឹងពួក
ឰយុកោឯងផង [១៨]ដោយឯងស្តាប់តាមព្រះបន្ទូលនៃព្រះ
យេហូវ៉ាជាព្រះនៃឯង ដើម្បីនឹងកាន់តាមអស់ទាំងបញ្ញត្តិ
ទ្រង់ ដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ ឱ្យឯងបាន
ប្រព្រឹត្តចំពោះសេចក្តីណាដែលត្រឹមត្រូវ[គ]នៅព្រះនេត្រព្រះ
យេហូវ៉ាជាព្រះនៃឯង ។

## អាហារស្អាត និងអាហារមិនស្អាត

*១៤:៣–២០ – លវ ១១:១–២៣*

**១៤** [១]ឯងរាល់គ្នាជាកូន[ក]ផងព្រះយេហូវ៉ា ជាព្រះនៃឯង
មិនត្រូវឱ្យឯងអារសាច់ ឬកោរចិញ្ចើម ដោយព្រោះខ្មោច
ស្លាប់ឡើយ [២]ដ្បិតឯងជាសាសន៍បរិសុទ្ធ[ខ]ដល់ព្រះយេហូវ៉ា
ជាព្រះនៃឯង[គ] ហើយព្រះយេហូវ៉ាទ្រង់បានរើសឯងពីអស់
ទាំងសាសន៍ដែលនៅផែនដី ទុកជាសាសន៍របស់ផងទ្រង់[ឃ] ។
[៣]មិនត្រូវឱ្យឯងបរិភោគរបស់អ្វី ដែលគួរខ្ពើមឡើយ[ង]
[៤]នេះជាសត្វទាំងប៉ុន្មានដែលបរិភោគបាន[ច] គឺគោ ចៀម
ពពែ[ឆ] [៥]ឈ្លូស ប្រើស ក្តាន់[ជ] រមាំង ទ្រាយ ទន្សោង[ឈ] ហើយ
ពពែភ្នំ [៦]ហើយគ្រប់ទាំងសត្វដែលមានក្រចកឆែក គឺក្រចក
ឆែកដាច់ជា២ ហើយដែលទំពាអៀងផង ក្នុងអស់ទាំងពួក
សត្វនោះនឹងបរិភោគបាន [៧]ប៉ុន្តែក្នុងបណ្តាសត្វដែល
ទំពាអៀង ឬដែលមានក្រចកឆែកនោះ មិនត្រូវឱ្យ
បរិភោគសត្វទាំងនេះឡើយ គឺសត្វអូដ្ឋ ទន្សាយគល់ ទន្សាយ
ថ្ម ពីព្រោះ សត្វទាំងនោះទំពាអៀង តែគ្មានក្រចកឆែកទេ
ជាសត្វមិនស្អាតទាំងអស់ដល់ឯងរាល់គ្នា [៨]ហើយជ្រូកដែរ
ពីព្រោះ មានក្រចកឆែក តែមិនទំពាអៀងទេ នោះមិន
ស្អាតដល់ឯងរាល់គ្នា មិនត្រូវបរិភោគសាច់វាឡើយ ក៏មិន
ត្រូវទាំងពាល់ខ្មោចវាផង[ញ] ។
[៩]ឯបណ្តាសត្វទាំងប៉ុន្មានដែលនៅក្នុងទឹក នោះឯងនឹង
បរិភោគសត្វទាំងនេះបាន គឺសត្វណាដែលមានព្រុយហើយ
មានស្រកាផង [១០]តែមិនត្រូវឱ្យបរិភោគសត្វណាដែលគ្មាន
ព្រុយនឹងស្រកាទេ ដ្បិតជាសត្វមិនស្អាតទាំងអស់ដល់ឯង
រាល់គ្នា ។
[១១]ឯបណ្តាសត្វហើរដែលស្អាត នោះឯងរាល់គ្នានឹងបរិ
ភោគបានគ្រប់យ៉ាង [១២]តែសត្វហើរ ទាំងនេះ នោះមិនត្រូវ
បរិភោគឡើយ គឺខ្លែង ស្ទាំង ប្រមង់ [១៣]ល្អូត រអាត និង
ត្មាត[ដ]តាមពូជវា[ឋ] [១៤]គ្រប់ទាំងក្អែកតាមពូជវា[ឌ] [១៥]អូសទ្រិច
ខ្លែងស្រាក រំពេ និងអកតាមពូជវា [១៦]មៀម គូក ទីទុយ
[១៧]ទុង[ឍ] ក្រៀល ស្មោញ [១៨]កុក និងក្រសារ តាមពូជវា
កំប្រោយ ហើយជ្រើង [១៩]និងអស់ទាំងសត្វដែលវារ ហើយ
ហើរផង នោះជាសត្វមិនស្អាតដល់ឯង មិនត្រូវបរិភោគ

**១៣:១៣** ព ឧ.២,៦ ពច ១៩:២២ ២០:១៣ ១សយ ២:១២ ១០:២៧ ១១:១២ ២៥:១៧ ១ពវ ២១:១០ **១៣:១៤** ភ ពច ២០:១២ ម ចទ ១៧:៤ **១៣:១៥** យ អស ២៤:៦ ៣៤:៥ ៤៣:២៨ ៤៧:៦ បទ ២:៦ ដយ ៩:១១ សក ៨:១៣ មឡ ៤:៦ រ នក ២២:២០ **១៣:១៦** ល ២ពវ ២៥:៩ យរ ៣៩:៨ ៥២:១៣ អគ ១៦:៤១ វ ចទ ៧:២៥,២៦ យស ៦:២៤ ស យស ៨:២៨ អស ៧:១៦ ១៧:១ ២៤:១០ ២៥:២ ២៧:១០ ៣២:១៤,១៩ ៣៧:២៦ យរ ៤៩:២ មីក ១:៦ **១៣:១៧** ហ នក ៣២:១២ ជន ២៥:៤ ឡ លប ៤៣:១៤ អ ចទ ៣០:៣ ក ចទ ៧:១៣ ខ លវ ១២:២ ១៣:១៤ ២៦:២៤ **១៣:១៨** គ ចទ ១២:២៥ **១៤:១** ក ចទ ចទ ១៩:២៨ យហ ១:១២ រម ៨:១៤ ៩:៨ **១៤:២** ខ លប ២៨:១៤ នក ២២:៣១ អស ៦:១៣ មឡ ២:១៥ គ លវ ២០:២៦ រម ១២:១ ឃ នក ៨:២២ ទ ៧:៦ **១៤:៣** ង អគ ៤:១៤ **១៤:៤** ច កច ១០:១៤ ឆ លវ ៧:២៣ **១៤:៥** ជ ចទ ១២:១៥ ឈ យប ៣៩:១ ទដ ១០៤:១៨ **១៤:៨** ញ លវ ៥:២ **១៤:១៣** ដ អស ៣៤:១៥ ឋ លប ១:១១ **១៤:១៤** ឌ លប ៨:៧ **១៤:១៧** ឍ ទដ ១០២:៦ អស ១៣:២១ ១៤:២៣ ៣៤:១១ សផ ២:១៤

**១៣:១៣** *ទមិលល្មើស* សូមមើល ១សយ ១:១៦ ២:១២ ២៥:១៧ ដូចក្នុងភាសាហេព្រើរបានប្រើក្នុង ១សយ ១០:២៧ ៣០:២២ (អ្នកបង្កបញ្ហា) សូមមើល ១ពវ ២១:១០,១៣ ១៣:១៥ បំផ្លាញគេឱ្យអស់ សូមមើលការពន្យល់ ២:៣៤ ។

**១៤:១** *ឯងអារសាច់* គឺជាទំនៀមទម្លាប់សាសនាដទៃ (១ពវ ១៨:២៨) ។ *កោរចិញ្ចើម* ការកោផ្នែកខាងមុខ គឺជាការកាន់ទម្លាប់ (ទំនៀមទម្លាប់) ចំពោះអ្នកដែលកាន់ទុក្ខ ក្នុងសាសន៍កាណាន ។

**១៤:២,២១** *បរិសុទ្ធដល់ព្រះយេហូវ៉ា* មើលការពន្យល់ លវ ១១:៤៤ ។ ច្បាប់វិន័យចំពោះអាហារស្អាត ឬមិនស្អាត គឺជាបំណងដើម្បីញែកប្រជាជនអ៊ីស្រាអែលចេញពីរបស់ទាំងនោះដែលព្រះយេហូវ៉ាបានបញ្ជាថា វាគួរឱ្យស្អប់ខ្ពើម និងជាវិធីមិនល្អ ។

**១៤:២** *សាសន៍បរិសុទ្ធដល់ព្រះយេហូវ៉ា* មើល នក ៣:៥ និងការពន្យល់ ១៩:៦ ។ *ទុកជាសាសន៍របស់ផងទ្រង់* មើលការពន្យល់ ១៩:៥ ។

**១៤:៣–២១** អត្ថបទដែលទាក់ទងនឹងអាហារស្អាត និងអាហាមិនស្អាត គឺបាននិយាយយ៉ាងលំអិតនៅក្នុងគម្ពីរ វវ ១១ (មើលការពន្យល់) ។

**១៤:៧** *មិនស្អាត* មើលការពន្យល់ ៤:១២ ។

ឡើយ ២០តែគ្រប់ទាំងសត្វហើរ ដែលស្អាត នោះនឹងបរិ
ភោគបាន[ណ] ។
២១មិនត្រូវឱ្យឯងរាល់គ្នាបរិភោគសត្វណា ដែលស្លាប់
ដោយខ្លួនឯងឡើយ[ត] ដ្បិតឯងជាសាសន៍បរិសុទ្ធដល់ព្រះ
យេហូវ៉ា ជាព្រះនៃឯង និងឱ្យសត្វនោះដល់អ្នកដទៃដែល
ស្នាក់នៅក្នុងផ្ទះឯង ឱ្យគេបរិភោគបាន ឬនឹងលក់ឱ្យដល់
សាសន៍ដទៃវិញក៏បាន[ថ] ។
មិនត្រូវឱ្យឯងស្ងោរកូនពពែ ក្នុងទឹកដោះរបស់មេវា
ឡើយ[ទ] ។

## ដង្វាយ១ភាគក្នុង១០

២២ត្រូវឱ្យឯងហូតយក១ភាគក្នុង១០[ធ] ពីផលដែលកើតពី
ស្រែចំការឯង រាល់តែឆ្នាំជាកុំខាន ២៣រួចត្រូវបរិភោគ[ន]
ដង្វាយ១ភាគក្នុង១០ ដែលឯងហូតពីទឹកទំពាំងបាយជូរ[ប] ពី
ប្រេង ហើយពីកូនសត្វដែលកើតដំបូង ក្នុងហ្វូងគោហ្វូង
ចៀមឯងទាំងប៉ុន្មាន នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង
ត្រង់កន្លែងដែលទ្រង់នឹងរើស សំរាប់នឹងតាំងព្រះនាម[ផ]ទ្រង់
ដើម្បីឱ្យឯងទំលាប់[ព]ឱ្យមានសេចក្តីកោតខ្លាច[ភ]ដល់ព្រះ
យេហូវ៉ាជាព្រះនៃឯងជាដរាប ២៤តែបើសិនជាផ្លូវនោះ
ឆ្ងាយ ដល់ម្ល៉េះបានជាឯងនឹងនាំយករបស់ទាំងនោះទៅឱ្យ
ដល់មិនបាន ដោយព្រោះកន្លែងដែលព្រះយេហូវ៉ា ជាព្រះ
នៃឯងបានរើសសំរាប់នឹងដាក់ព្រះនាមទ្រង់ នៅឆ្ងាយពីឯង
ក្នុងវេលាដែលព្រះយេហូវ៉ា ជាព្រះនៃឯង បានប្រទានពរ
ហើយ ២៥នោះត្រូវលក់របស់ទាំងនោះយកជា[ម]ប្រាក់វិញចុះ
រួចវេចប្រាក់កាន់ជាប់នៅដៃ នាំយកទៅឯកន្លែងដែលព្រះ
យេហូវ៉ា ជាព្រះនៃឯងបានរើស ២៦ហើយនិងចំណាយ
ប្រាក់នោះ ទិញអ្វីៗតាមប្រាថ្នាបានទោះជាគោ ឬចៀម ឬ
ស្រាទំពាំងបាយជូរ ឬគ្រឿងផឹកណា[យ] ឬរបស់អ្វីក៏ដោយ

**១៤:២០** ណ លប ២០:២៥
**១៤:២១** ត លវ ១១:៣៩ ថ ខ.២ ទ នក ២៣:១៩
**១៤:២២** ធ លប ១៤:២០ លវ ២៧:៣០ ជន ១៨:២១
**១៤:២៣** ន ចទ ១២:១៧,១៨ ប ទដ ៤:៧ ផ ចទ ១២:៥ ព ១ពវ ៣:២ ៣ ចទ ៤:១០ ភ ទដ ២២:២៣ ៣៣:៨ មឡ ២:៥
**១៤:២៥** ម មឡ ២១:១២ យហ ២:១៤
**១៤:២៦** យ លវ ១០:៩ សស ១០:១៦–១៧ រ លវ ២៣:៤០ ចទ ១២:១៨
**១៤:២៧** ល ចទ ១២:១៩ វ ជន ១៨:២០ ២៦:៦២ ចទ ១៨:១–២
**១៤:២៨** ស លវ ២៧:៣០ ហ ចទ ចទ ២៦:១២
**១៤:២៩** ឡ លប ៤៧:២២ អ ជន ២៦:៦២ ក ចទ ១៦:១១ ២៤:១៩–

ដែលឯងគាប់ចិត្ត រួចនឹងបរិភោគនៅចំពោះព្រះយេហូវ៉ា
ជាព្រះនៃឯង នៅទីនោះ ហើយត្រូវអរសប្បាយឡើង[រ] ព្រម
ទាំងពួកគ្រួឯងជាមួយនឹងឯងផង ២៧ឯពួកលេវី[ល] ដែលនៅ
ក្នុងទីក្រុងរបស់ឯង នោះមិនត្រូវលះចោលគេឡើយ ដ្បិត
គេគ្មានចំណែក គ្មានមរដកជាមួយនឹងឯងទេ[វ] ។
២៨ដល់វេលាផុតរាល់តែ៣ឆ្នាំទៅ នោះត្រូវឱ្យយក
ដង្វាយ១ភាគក្នុង១០[ស] ពីរបស់ដែលបានហូតពីផលកើតក្នុង
ឆ្នាំនោះឯង ចេញមកដាក់ទុកនៅត្រង់ទ្វារក្រុងឯងវិញ[ហ]
២៩ដូច្នេះពួកលេវី ដែលគ្មានចំណែក[ឡ] គ្មានមរដក[អ] ជាមួយ
នឹងឯង និងពួកអ្នកដទៃ[ក] ព្រមទាំងកូនកំព្រា និងស្រីមេម៉ាយ
ដែលនៅក្នុងទីក្រុងឯង គេនឹងមកបរិភោគចំអែត[ខ] ដើម្បីឱ្យ
ព្រះយេហូវ៉ា ជាព្រះនៃឯង បានប្រទានពរ[គ]ដល់ឯង ក្នុង
គ្រប់ទាំងការដែលដៃឯងធ្វើ ។

## ឆ្នាំដែលត្រូវលើកលែង

*១៥:១–១១ – លវ ២៥:៨–៣៨*

**១៥** ១ដល់វេលាផុតរាល់តែ៧ឆ្នាំ នោះត្រូវឱ្យមានការ
ប្រោសលែង[ក] ២នេះជារបៀបនៃការប្រោសលែងនោះ គឺ
គ្រប់ទាំងម្ចាស់បំណុលត្រូវតែលើកលែងបំណុល ចំពោះ
អ្នកជិតខាងដែលបានខ្ចីខ្លួន មិនត្រូវឱ្យតឹងទារពីអ្នកជិតខាង
នោះ ឬពីបងប្អូនណាឡើយ ដ្បិតការប្រោសលែងផងព្រះ
យេហូវ៉ា បានប្រកាសប្រាប់ស្រេចហើយ ៣ឯងនឹងទារពីអ្នក
ប្រទេសក្រៅបាន[ខ] តែរបស់អ្វីផងឯងដែលនៅនឹងបងប្អូន
ឯង នោះត្រូវលើកលែងចោលចេញ ៤ប៉ុន្តែនឹងគ្មានអ្នក
ទាល់ក្រនៅជាមួយនឹងឯងឡើយ ដ្បិតព្រះយេហូវ៉ា ជាព្រះ
នៃឯង ទ្រង់នឹងប្រទានពរ[គ]ដល់ឯង នៅក្នុងស្រុកដែលទ្រង់

២១ ទដ ៩៤:៦ អស ១:១៧ ៥៨:៦ ខ ចទ ៦:១១ គ ចទ ១៥:១០ ទដ ៤១:១ សភ ២២:៩ មឡ ៣:១០ **១៥:១** ក ចទ ៣១:១០ នហ ១០:៣១ **១៥:៣** ខ លប ៣១:១៥ ចទ២៣:២០ ២៨:១២ នរ ២:១០ **១៥:៤** គ ចទ ២៨:៨

**១៤:២១** *មិនត្រូវ . . . សត្វណាដែលស្លាប់* ព្រោះវាទាក់ទងនឹងការហាមឃាត់ចំពោះការហូបឈាមសត្វដែលស្លាប់ ឈាមវាមិនហូរចេញទេ (សូមមើល ១២:១៦,២៤ និងការពន្យល់ ៩:៤ លវ ១៧:១១) ។ *មិនត្រូវឱ្យឯងស្ងោរកូនពពែក្នុងទឹកដោះរបស់មេវា* សូមមើល នក ២៣:១៩ ។

**១៤:២២–២៩** មើល ជន ១៨:២១–២៩ សរុបមកយើងឃើញពីផ្នែកតាមគំនិតខាងក្រោម ។

១–ដង្វាយប្រចាំឆ្នាំដូចជាដង្វាយ១០ហូត១របស់អ៊ីស្រាអែល គឺបានពីភោគផលរបស់ពួកគេ ត្រូវយកទៅដាក់នៅសាលាប្រជុំធំ ដើម្បីចែកឱ្យពួកលេវី ។

២–ពេលនោះគ្រប់ទាំងពិធីបុណ្យ គឺប្រជាជនអ៊ីស្រាអែលមានចំណែកក្នុងដង្វាយ១០ហូត១ ។

៣–ដង្វាយក្រៅពីនោះ គឺសម្រាប់បង់ឱ្យពួកលេវី ។

៤–នៅឆ្នាំទី៣ គឺជាឆ្នាំដែលត្រូវថ្វាយ១ភាគក្នុង១០នោះរួចហើយ ត្រូវចែកដល់ពួកលេវី និងពួកកូនកំព្រា ហើយនិងពួកស្ត្រីមេម៉ាយផង ដើម្បីឱ្យពួកទាំងនោះបានបរិភោគចំអែតគ្រប់គ្រាន់ (មើល ២៦:១២) លវ ២៧:៣០ ។

**១៤:២២** *ហូតយក១ភាគក្នុង១០* មើលការពន្យល់ លប ១៤:២០ ២៨:២២ ។

**១៤:២៣** *តាំងនាមទ្រង់* មើលការពន្យល់ ១២:៥ ។

**១៤:២៥** *ប្រាក់* ចំណែកប្រាក់ទាំងនោះមានទម្ងន់ផ្សេងៗគ្នា គឺសម្រាប់ការដោះដូរតែមិនមែនរាងដូចកាក់នោះទេ មើល លប ២០:១៦ ។

**១៥:១** *រាល់តែ៧ឆ្នាំ* មើល នក ២៣:១០–១១ លវ ២៥:១–៧ មើលការពន្យល់ ២៥:៤ ។

**១៥:៣** *ឯងនឹងទារពីអ្នកប្រទេសក្រៅបាន* បំណុលត្រូវបានរួចលែងឱ្យមានអ្នកជិពាក់ ។

**១៥:៤** *គ្មានអ្នកទាល់ក្រនៅជាមួយនឹងឯងឡើយ* ពីព្រោះរង្វាន់ពីព្រះយេហូវ៉ាគឺសម្រាប់អ្នកដែលស្តាប់បង្គាប់ដល់ទ្រង់ (ខ.៤–៦) ពីព្រោះការរៀបចំឱ្យមាន

ប្រទានមក ឱ្យឯងចាប់យកជាមរដកនោះជាមិនខាន 5គឺបើ
ឯងគ្រាន់តែខំប្រឹងស្តាប់តាម[យ]ព្រះយេហូវ៉ា ជាព្រះនៃឯង
ឱ្យអស់ពីចិត្ត ដើម្បីនឹងកាន់ ហើយប្រព្រឹត្តតាមសេចក្តីបញ្ញត្តិ
ដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះគ្រប់ជំពូកប៉ុណ្ណោះ
6ដ្បិតព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងប្រទានពរដល់ឯង
ដូចជាទ្រង់បានសន្យាហើយ នោះឯងនឹងឱ្យសាសន៍ជា
ច្រើនខ្ចីបាន ឥតមានខ្ចីពីគេវិញឡើយ ហើយឯងនឹងត្រួតត្រា
លើសាសន៍ជាច្រើន តែគេមិនត្រូវត្រួតត្រាលើឯងទេ[ង] ។
7តែបើសិនជាមានអ្នកទាល់ក្រណា[ច] នៅជាមួយនឹងឯង
ដែរ ជាបងប្អូនឯងដែលនៅទីក្រុងឯង ក្នុងស្រុកដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង បានប្រទានមក នោះមិនត្រូវឱ្យឯង
តាំងចិត្តរឹង ឬក្តាប់ដៃ[ឆ]នឹងបងប្អូនជាអ្នកក្រនោះឡើយ 8គឺ
ត្រូវឱ្យលាដៃ[ជ]ដល់គេវិញជាកុំខាន ហើយឱ្យគេខ្ចីតាមចិត្ត
ឱ្យល្មមដល់គ្រាទាល់ក្រនោះចុះ 9ចូរប្រយ័ត្ន កុំឱ្យមានគំនិត
អាក្រក់ក្នុងចិត្តឯង ដោយនឹកថា ឆ្នាំទី៧ជាឆ្នាំ ដែលត្រូវ
លើកលែង[ឈ]នោះជិតដល់ហើយ ហើយឯងគន់មើលបងប្អូន
អ្នកក្រនោះ ដោយព្រងើយកន្តើយវិញ[ញ] ឥតមានឱ្យអ្វីដល់គេ
សោះ ក្រែងគេប្តឹងដល់ព្រះយេហូវ៉ាពីឯងនោះនឹងបានរាប់
ជាបាបដល់ឯង[ដ] 10ត្រូវឱ្យឯងចែកដល់គេជាកុំខាន ដោយ
មានចិត្តឥតស្តាយផង[ឋ] ដ្បិតបើប្រព្រឹត្តយ៉ាងដូច្នោះ នោះ
ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងប្រទានពរ[ឌ]ដល់ឯងក្នុង
គ្រប់ទាំងការរបស់ឯង ហើយក្នុងអស់ទាំងការអ្វីដែលឯង
ដាក់ដៃធ្វើផង 11ពីព្រោះពួកទាល់ក្រមិនចេះដែលផុត[ឍ]
ពីក្នុងស្រុកឡើយ ហេតុនេះបានជាអញបង្គាប់ដល់ឯងថា
ត្រូវឱ្យឯងលាដៃដល់បងប្អូន និងពួកអ្នកទាល់ក្រ ហើយ
និងពួកកំសត់ទុរគត នៅក្នុងស្រុកឯងជាកុំខានវិញ[ណ]។

## ការដោះលែងអ្នកបម្រើ

*១៥:១២–១៨ – នក ២១:២–៦*

*១៥:១២–១៨ – លវ ២៥:៣៨–៥៥*

12បើបងប្អូនប្រុសឬស្រីរបស់ឯង ដែលជាសាសន៍ហេ
ព្រើរ គេលក់ខ្លួនមកឯង ក៏បាននៅបំរើឯងអស់៦ឆ្នាំហើយ
នោះដល់ឆ្នាំទី៧ ត្រូវឱ្យលែងគេចេញឱ្យរួចទៅទទេ[ត]
13ហើយកាលណាលែងឱ្យទៅ នោះមិនត្រូវឱ្យគេទៅដោយ
ដៃទទេឡើយ 14គឺត្រូវផ្គត់ផ្គង់ឱ្យគេពីហ្វូងចៀមពីទីលាន
ហើយពី ធុងឃ្នាប[ថ]របស់ឯងដោយសទ្ធាវិញ ត្រូវឱ្យដល់គេ
តាមដែល ព្រះយេហូវ៉ា ជាព្រះនៃឯង បានប្រទានពរដល់
ឯង 15ត្រូវឱ្យឯងនឹកចាំថា ពីដើមឯងក៏ជាបាវបំរើ[ទ]នៅ
ស្រុកអេស៊ីព្ទដែរ តែព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បាន
លោះ[ធ]ឯងមក ហេតុនោះហើយ បានជាអញបង្គាប់ដល់ឯង
ដូច្នេះនៅថ្ងៃនេះ 16ប៉ុន្តែបើសិនជាគេនិយាយនឹងឯងថា
ខ្ញុំមិនព្រមចេញពីអ្នកទៅទេ គឺដោយគេស្រឡាញ់ឯងនឹងផ្ទះ
ឯង ហើយដោយព្រោះគេនៅជាស្រួលនឹងឯងផង 17នោះ
ត្រូវឱ្យយកដែកចោះមក ចោះត្រចៀកគេផ្ទាប់នៅទ្វារ រួច
គេនឹងធ្វើជាបាវបំរើឯងជាដរាបតទៅ ហើយត្រូវឱ្យឯងធ្វើ
ដូច្នោះនឹងបាវស្រីឯងដែរ 18មិនត្រូវឱ្យមានចិត្តពិបាក
ដោយលែងឱ្យគេទៅទទេឡើយ ដ្បិតគេបាននៅបំរើឯង
អស់៦ឆ្នាំហើយ ជាការបំរើលើសជាងការរបស់ជើង
ឈ្នួល១ជា២ផង ដូច្នេះព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹង
ប្រទានពរដល់ឯង ក្នុងគ្រប់ការដែលឯងធ្វើដែរ ។

## កូនសត្វដែលកើតជាដំបូង

19ក្នុងហ្វូងគោហ្វូងចៀមរបស់ឯង[ន] នោះត្រូវញែកអស់
ទាំងកូនឈ្មោល[ប] ដែលកើតជាដំបូងចេញ ទុកជាបរិសុទ្ធ
ថ្វាយព្រះយេហូវ៉ា[ផ] ជាព្រះនៃឯង មិនត្រូវយកកូន ដែល
កើតជាដំបូងពីមេគោឯង ទៅប្រើធ្វើការអ្វី ឬកាត់រោម
របស់កូនដែលកើតជាដំបូង ពីមេចៀមឯងនោះឡើយ[ព]

**១៥:៥** យ នក ១៥:២៦ ចទ ៧:១២ ២៨:១
**១៥:៦** ង ចទ ២៨:១២–១៣,៤៤
**១៥:៧** ច ខ.១១ មថ ២៦:១១ ឆ ១យហ ៣:១៧
**១៥:៨** ជ មថ ៥:៤២ លក ៦:៣៤ កច ២៤:១៧
**១៥:៩** ឈ ខ.១ ញ មថ ២០:១៥ ដ នក ២២:២៣ យប ៥:១៥ យក ៥:៤
**១៥:១០** ឋ ២កថ ៩:៥ ឌ ចទ ១៤:២៩
**១៥:១១** ឍ ខ.៧ ណ មថ ២៦:១១ មក ១៤:៧ យហ ១២:៨
**១៥:១២** ត យរ ៣៤:១៤
**១៥:១៤** ថ ជន ១៨:២៧
**១៥:១៥** ទ នក ១៣:៣ យរ ៣៤:១៣ ធ នក ២០:២ ចទ ៤:៣៤ ៩:២៦ ១៦:១២ ២៤:១៨ យរ ១៦:១៤ ២៣:៧
**១៥:១៩** ន លប ៤:៤ ប នក ១៣:២ ផ លវ ២៧:៩ ព នក ២២:៣០

ថ្ងៃបុណ្យ (ខ.៧–១១) គឺជា"ឆ្នាំនៃការលើកលែងឱ្យរួចពីបំណុល"(មើល ខ.៩) គឺផ្តលឱ្យប្រជាជនអ៊ីស្រាអែលរួចផុតពីបំណុល (សូមមើល លវ ២៥:៨–៣៨) ។

**១៥:៦** *ឯងនឹងឱ្យសាសន៍ជាច្រើនខ្ចីបាន* បើប្រជាជនអ៊ីស្រាអែលពុំបានគោរពតាមបញ្ញត្តិរបស់ព្រះយេហូវ៉ាទេនោះ សេចក្តីពិតនោះពុំបានកើតឡើងទេ (មើល ២៨:៤៣–៤៤) ។

**១៥:១១** *ពីព្រោះពួកទាល់ក្រមិនចេះផុត* សូមមើលពីការថ្លែងរបស់ព្រះយេស៊ូវគ្រីស្ទក្នុង មថ ២៦:១១ ទោះបើជាក្នុងសង្គមមនុស្សដ៏ល្អបំផុតមួយហើយស្ថិតនៅក្រោមក្រឹត្យក្រមច្បាប់ ដ៏ច្បាស់លាស់ក៏ដោយ គឺក៏មានភាពប្រែប្រួលនៃជីវិតហើយលទ្ធផលនៃជីវិត ក៏មានបែបផែនផ្សេងៗដែរ គឺមានមនុស្សដែលប្រែក្លាយជាក្រដុនដាប ។ ដូចជាករណីក្នុងបញ្ញារបស់ព្រះយេហូវ៉ាមានបន្ទូលថាបើអ្នកមានចិត្តសប្បុរស ត្រូវរំលែកចែកទានដល់អ្នកក្រ ។

**១៥:១៥** *នឹកចាំ* មើលការពន្យល់ ៤:១០ ។

**១៥:១៦** *គឺដោយគេស្រឡាញ់ឯង* នក ២១:៥ គឺជាហេតុផលបញ្ជាក់បន្ថែមដែលផ្តល់ឱ្យឃើញ ។ បាវបម្រើគាត់ គឺមានចិត្តចង់នៅនឹងក្រុមគ្រួសារគាត់។

**១៥:១៧** *យកដែកចោះមក ចោះត្រចៀកគេផ្ទាប់នៅទ្វារ* សូមមើលការពន្យល់ នក ២១:៦ ។

**១៥:១៨** *១ជា២* ជាភាសាហេព្រើរ បើអ្នកជាបាវបម្រើបានបម្រើជាច្រើនឆ្នាំ គឺមានន័យថាមួយជាពីរ នោះគឺបានតម្រូវឱ្យរួចពីបំណុលទាំងអស់ ។

**១៥:១៩** *ត្រូវញែក . . . ដែលកើតជាដំបូងវិញ* ដោយព្រោះព្រះយេហូវ៉ាបានជួយសង្គ្រោះប្រជាជនរបស់ទ្រង់ពីភាពចង្រៃនៃសេចក្តីស្លាប់ដែលជាកំណើតដំបូងនៅប្រទេសអេស៊ីព្ទ សូមមើល នក ១២:១២,២៩ ១៣:២ និងការពន្យល់

២០រាល់តែឆ្នាំ ត្រូវឱ្យឯង និងពួកផ្ទះឯងបរិភោគសត្វនោះ
នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង ត្រង់កន្លែងដែលព្រះ
យេហូវ៉ានឹងរើស[ភ] ២១បើសត្វនោះមានស្លាកស្នាមអ្វី[ម] គឺបើ
ខ្ចើច ឬខ្វាក់ ឬមានខ្ចោះអាក្រក់ត្រង់ណាក្តី នោះមិនត្រូវឱ្យ
ឯងថ្វាយជាយញ្ញបូជា ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង
ឡើយ[យ] ២២ឯងនឹងបរិភោគសត្វនោះនៅក្នុងទីក្រុងឯងបាន
ទោះទាំងអ្នកស្អាត និងអ្នកដែលមិនស្អាតផងដូចជាបរិភោគ
ឈ្លូសហើយនិងប្រើសដែរ[រ] ២៣ប៉ុន្តែមិនត្រូវបរិភោគ
ឈាមឡើយ ត្រូវឱ្យចាក់ចោលទៅដី ដូចជាទឹកវិញ[ល]។

## បុណ្យរំលង

*១៦:១-៨ – នក ១២:១៤-២០ លវ ២៣:៤-៨ ជន ២៨:១៦-២៥*

**១៦** ១ចូរចាំកំណត់នៅខែចេត្រ[ក] ដើម្បីនឹងធ្វើបុណ្យ
រំលង[ខ] ថ្វាយព្រះយេហូវ៉ា ជាព្រះនៃឯង ដ្បិតគឺនៅខែចេត្រ
នេះហើយដែលព្រះយេហូវ៉ា ជាព្រះនៃឯង បាននាំឯង
ចេញពីស្រុកអេស៊ីព្ទមកទាំងយប់ ២ត្រូវឱ្យឯងយកសត្វពីហ្វូង
របស់ឯងមក ថ្វាយជាយញ្ញបូជានៃបុណ្យរំលង ដល់ព្រះ
យេហូវ៉ា ជាព្រះនៃឯង ត្រង់កន្លែងដែលទ្រង់នឹងរើស
សំរាប់តាំងព្រះនាមទ្រង់[គ] ៣មិនត្រូវឱ្យបរិភោគនំបុ័ងមាន
ដំបែជាមួយទេ នៅរវាង៧ថ្ងៃនោះ ត្រូវបរិភោគនំបុ័ងឥត
ដំបែវិញ គឺជានំបុ័ងនៃសេចក្តីទុក្ខលំបាក[ឃ] ពីព្រោះឯងបាន
ចេញពីស្រុកអេស៊ីព្ទមក ដោយប្រញាប់ប្រញាល់[ង] ត្រូវធ្វើ
ដូច្នោះ ដើម្បីឱ្យបាននឹកចាំគ្រប់១ជីវិត ពីថ្ងៃដែលឯងបាន
ចេញពីស្រុកអេស៊ីព្ទមក[ច] ៤មិនត្រូវឱ្យឃើញមានដំបែនៅ
ជាមួយក្នុងព្រំស្រុកឯងទាំងអស់នៅវេលា៧ថ្ងៃនោះឡើយ ក៏
មិនត្រូវឱ្យមានសាច់ ដែលឯងថ្វាយជាយញ្ញបូជា នៅ
ពេលល្ងាចក្នុង[ឆ]ថ្ងៃដំបូងនោះ សល់នៅដល់ព្រឹកដែរ[ជ]
៥ឯងគ្មានច្បាប់នឹងថ្វាយយញ្ញបូជានៃបុណ្យរំលង នៅក្នុង
ទីក្រុងដទៃណា ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់
ប្រទានឱ្យឯងនោះទេ ៦គឺត្រូវឱ្យថ្វាយយញ្ញបូជានៃបុណ្យ
រំលង នៅកន្លែងដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹង
រើសសំរាប់នឹងតាំងព្រះនាមទ្រង់វិញ គឺនៅទីនោះដែល
ត្រូវថ្វាយយញ្ញបូជា នៅពេលល្ងាចពីវេលាថ្ងៃលិចទៅ ក្នុង
រដូវដដែល[ឈ] ដែលឯងបានចេញពីស្រុកអេស៊ីព្ទមក ៧ត្រូវ
ឱ្យចំអិន[ញ]សាច់នោះ ហើយបរិភោគនៅកន្លែងដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងរើស លុះដល់ព្រឹកឡើងឯង
នឹងត្រឡប់ទៅឯត្រសាលឯងវិញបាន ៨ត្រូវឱ្យឯងបរិភោគ
នំបុ័ងឥតដំបែអស់៦ថ្ងៃ លុះដល់ថ្ងៃទី៧ នោះត្រូវប្រជុំជំនុំ[ដ]
មុតមាំថ្វាយព្រះយេហូវ៉ា ជាព្រះនៃឯង មិនត្រូវធ្វើការអ្វីឱ្យ
សោះ[ឋ]។

## បុណ្យអាទិត្យទី៧

*១៦:៩-១២ – លវ ២៣:១៥-២២ ជន ២៨:២៦-៣១*

៩រួចត្រូវរាប់ជា៧អាទិត្យទៀត[ឌ] គឺត្រូវរាប់៧អាទិត្យនោះ
ចាប់តាំងពីវេលាដែលទើបនឹងលូកកណ្តៀវទៅច្រូតស្រូវ[ឍ]
១០នោះត្រូវឱ្យធ្វើបុណ្យអាទិត្យទី៧ ថ្វាយព្រះយេហូវ៉ា
ជាព្រះនៃឯង ដោយថ្វាយដង្វាយស្ម័គ្រពីចិត្ត តាមដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់បានប្រទានពរ ១១ហើយឯង
និងកូនប្រុសកូនស្រីឯង ត្រូវអរសប្បាយ[ណ]នៅចំពោះព្រះ
យេហូវ៉ា ជាព្រះនៃឯង ព្រមទាំងបាវប្រុសបាវស្រីឯង
និងពួកលេវី[ត] ដែលនៅទីក្រុងឯង ហើយនិងពួកអ្នកដទៃ[ថ]
ពួកកំព្រា និងពួកស្រីមេម៉ាយ ដែលនៅជាមួយនឹងឯងទាំង
អស់គ្នាផង[ទ] នៅកន្លែងដែលព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់នឹងរើសសំរាប់តាំងព្រះនាមទ្រង់[ធ] ១២ត្រូវឱ្យនឹកចាំថា
ពីដើមឯងជា បាវបំរើនៅស្រុកអេស៊ីព្ទដែរ[ន] ដូច្នេះត្រូវ
ប្រយ័ត្ននឹងប្រព្រឹត្តតាមអស់ទាំងច្បាប់ទាំងនេះចុះ ។

## បុណ្យបារាំ

*១៦:១៣-១៧ – លវ ២៣:៣៣-៤៣ ជន ២៩:១២-៣៩*

១៣ត្រូវឱ្យឯងធ្វើបុណ្យបារាំនៅអស់៧ថ្ងៃ ក្នុងពេល
ក្រោយដែលបានប្រមូលផលពីលាន[ប] និងពីធុងឃ្នាប[ផ] ហើយ
១៤ត្រូវឱ្យឯង និងកូនប្រុសកូនស្រីឯង អរសប្បាយ[ព]នៅ
វេលាបុណ្យរបស់ឯងនោះ ព្រមទាំងបាវប្រុសបាវស្រីឯង

**១៥:២០** ភ លវ ៧:១៥-១៨ ចទ ១២:៥-៧,១៧,១៨ **១៥:២១** ម នក ១២:៥ យ លវ ២២:១៩-២៥ ចទ ១៧:១ មឡ ១:៨,១៣ **១៥:២២** រ ចទ ១២:១៥ **១៥:២៣** ល លប ៩:៤ ចទ ១២:១៦ អគ ៣៣:២៥ **១៦:១** ក នក ១២:២ ខ នក ១២:១១ ២ពវ២៣:២១ មថ ២៦:១៧-២៩ **១៦:២** គ ចទ ១២:៥,២៦ **១៦:៣** ឃ នក ១២:៨,៣៩ ៣៤:១៨ ១កថ ៥:៨ ង នក ១២:១១ ច ចទ ៤:៩ **១៦:៤** ឆ នក ១២:៦ ជ នក ១២:៨ មក ១៤:១២ **១៦:៦** ឈ នក ១២:៤២ **១៦:៧** ញ នក ១២:៨ **១៦:៨** ដ ១៣:៦ លវ ២៣:៨ ឋ មថ ២៦:១៧ លក ២:៤១ ២២:៧ យហ ២:១៣ **១៦:៩** ឌ កច ២:១ ឍ នក ២៣:១៦ **១៦:១១** ណ ចទ ១២:៧ ត ចទ ១២:១២ ថ ចទ ១៤:២៩ ទ នហ ៨:១០ ធ នក ២០:២៤ **១៦:១២** ន ចទ ១៥:១៥ **១៦:១៣** ប លវ ២:១៤ ផ លប ២៧:៣៧ នក ២៣:១៦ **១៦:១៤** ព ឧ.១១

១៣:១៥ ។

**១៥:២១** *បើសត្វនោះមានស្លាកស្នាមអ្វី . . . នោះមិនត្រូវឱ្យឯងថ្វាយជាយញ្ញបូជា* មើលការពន្យល់ លវ ១:៣ ។

**១៥:២២** *មិនស្អាត* មើលការពន្យល់ លវ ៤:១២ ។

**១៥:២៣** មើល ១២:១៦,២៤ និងមើលការពន្យល់ លប ៩:៤ ។

**១៦:១-១៧** មើលការពន្យល់ នក ២៣:១៤-១៩ ៣៤:១៨-២៦ ។

**១៦:១-៨** មើល នក ១២:១-២៨ ១៣:១-១៦ និងការពន្យល់ ។

**១៦:៣,១២** *នឹកចាំ* មើលការពន្យល់ ៤:១០ ។

**១៦:៧** *ត្រសាលឯងវិញ* គឺទៅទីណាដែលពួកគេស្នាក់នៅ ខណៈពេលដែលមានកម្មវិធីបុណ្យ គឺជាទីកន្លែងដែលគេបានរៀបចំជាបណ្តោះអាសន្ន ឬអចន្ត្រៃ ។

**១៦:៨** *ប្រជុំជំនុំមុតមាំ* ពោល គឺការប្រជុំបិទកម្មវិធី មើល លវ ២៣:៣៦ ។

**១៦:៩** *៧អាទិត្យ* ជានិមិត្តរូបចំពោះរយៈពេលពេញទាំងមួយរដូវចំពោះការងារប្រមូលភោគផលស្រូវ (ឬធញ្ញជាតិ) ។

**១៦:១០** *ថ្វាយ . . . តាមដែលព្រះយេហូវ៉ាប្រទានពរ* មើល ឧ.១៧ ប្រៀបធៀប ១កថ ១៦:២ ១កថ ៨:១២ និងការពន្យល់ ។

និងពួកលេវី ហើយនិងអ្នកដទៃ ពួកកូនកំព្រា និងពួកស្រី
មេម៉ាយ ដែលនៅក្នុងទីក្រុងឯងផង ១៥ត្រូវឱ្យធ្វើបុណ្យនេះ
ថ្វាយព្រះយេហូវ៉ា ជាព្រះនៃឯងអស់៧ថ្ងៃ នៅកន្លែងដែល
ព្រះយេហូវ៉ានឹងរើស ដ្បិតព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់
នឹងប្រទានពរដល់ឯង ចំពោះអស់ទាំងផលចំរើនរបស់ឯង
ហើយក្នុងគ្រប់ទាំងការដែលដៃឯងធ្វើ ដូច្នេះឯងនឹងមាន
សេចក្ដីអំណរ[ភ]ជាមិនខាន ។

១៦ត្រូវឱ្យគ្រប់ទាំងប្រុសៗក្នុងពួកឯង មកនៅ[ម]ចំពោះព្រះ
យេហូវ៉ា ជាព្រះនៃឯង ៣ដងក្នុង១ឆ្នាំ ត្រង់កន្លែងដែលទ្រង់
នឹងរើស គឺនៅពេលបុណ្យនំបុ័ងឥតដំបែម្ដង[យ]បុណ្យអាទិត្យ
ទី៧ម្ដង និងបុណ្យបារាំ[រ]ម្ដង ក៏មិនត្រូវមកនៅចំពោះព្រះ
យេហូវ៉ា ដោយដៃទទេដែរ[ល] ១៧ត្រូវឱ្យគ្រប់គ្នាថ្វាយតាម
កំឡាំងរៀងខ្លួន គឺតាមព្រះពរដែលព្រះយេហូវ៉ា ជាព្រះនៃ
ឯងបានប្រទានឱ្យ ។

## ពួកចៅក្រម

១៨ត្រូវឱ្យឯងតាំងពួកចៅក្រម[វ] និងសុភា នៅគ្រប់ទាំងទី
ក្រុង ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានមកឯង
តាមពូជអំបូរឯងទាំងប៉ុន្មាន ត្រូវឱ្យអ្នកទាំងនោះជំនុំជំរះ
បណ្ដាជនដោយយុត្តិធម៌[ស] ១៩មិនត្រូវបង្វែរសេចក្ដីយុត្តិធម៌
ឡើយ[ហ] ក៏មិនត្រូវលំអៀងចិត្តទៅខាងណា[ឡ] ឬស៊ីសំណូកឱ្យ
សោះ[អ] ដ្បិតសំណូកជាការនាំឱ្យបំបិទភ្នែកអ្នកប្រាជ្ញ ហើយក៏
បង្ខូចពាក្យសំដីរបស់មនុស្សសុចរិតផង ២០ត្រូវឱ្យកាត់តាម
តែសេចក្ដីដែលសុចរិតវិញជាកុំខាន ដើម្បីឱ្យឯងបានរស់
នៅ ហើយគ្រងបានស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់ប្រទានឱ្យ ។

## ការថ្វាយបង្គំព្រះដទៃ

២១មិនត្រូវឱ្យតាំងរូបឆ្លាក់ធ្វើពីឈើណាក៏ដោយ[ក] នៅ
ត្រង់អាសនាផងព្រះយេហូវ៉ា ជាព្រះនៃឯង ដែលនឹងស្អាង
សំរាប់ឯងនោះឡើយ[ខ] ២២ក៏មិនត្រូវបញ្ឈរបង្គោលណា[គ]
សំរាប់ឱ្យឯងគោរព គឺជារបស់ដែលព្រះយេហូវ៉ា ជាព្រះ
នៃឯងទ្រង់ស្អប់នោះដែរ ។

**១៦:១៥** ភ យប ៣៨:៧ ទដ ៤:៧ ២៨:៧ ៣០:១១
**១៦:១៦** ម ចទ ៣១:១១ ទដ ៨៤:៧ យ នក ១២:១៧ រ នក ២៣:១៤,១៦ អរ ៣:៤ ល នក ៣៤:២០
**១៦:១៨** វ នក ១៨:២១,២៦ ស លប ៣១:៣៧
**១៦:១៩** ហ នក ២៣:២ ឡ លវ ១៩:១៥ អ នក ១៨:២១ ១សយ ៨:៣
**១៦:២១** ក ចទ ៧:៥ ខ នក ៣៤:១៣ ១ពវ ១៤:១៥ ២ពវ ១៧:១៦ ២១:៣ ២រប ៣៣:៣
**១៦:២២** គ នក ២៣:២៤
**១៧:១** ក នក ១២:៥ លវ ២២:២០ ខ ចទ ៧:២៥ គ ចទ ១៥:២១
**១៧:២** ឃ ចទ ១៣:៦–១១
**១៧:៣** ង នក ២២:២០ ច លប ១:១៦ ឆ លប ២:១ ៣៧:៩ ជ យរ ៧:៣១
**១៧:៤** ឈ ចទ ២២:២០ ញ ចទ ១៣:១២–១៤
**១៧:៥** ដ លវ ២៤:១៤
**១៧:៦** ឋ ជន ៣៥:៣០ ចទ ១៩:១៥ មថ ១៨:១៦

**១៧** ១មិនត្រូវឱ្យឯងថ្វាយគោ ឬចៀមណា ដែលមានស្លាក
ស្នាម[ក] ឬអាក្រក់អ្វី ទៅជាយញ្ញបូជាដល់ព្រះយេហូវ៉ា ជា
ព្រះនៃឯងឡើយ ដ្បិតនោះជាសេចក្ដីស្អប់ខ្ពើម[ខ]ដល់ព្រះ
យេហូវ៉ា[គ] ជាព្រះនៃឯង ។

២នៅក្នុងទីក្រុងណា ដែលព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់ប្រទានមក បើសិនជាឃើញមានមនុស្សប្រុសឬស្រីណា
នៅជាមួយនឹងឯង ដែលប្រព្រឹត្តសេចក្ដីអ្វីអាក្រក់នៅព្រះ
នេត្រព្រះយេហូវ៉ា ជាព្រះនៃឯង ដោយរំលងសេចក្ដី
សញ្ញាទ្រង់[ឃ] ៣ទៅគោរពប្រតិបត្តិ ហើយក្រាបថ្វាយបង្គំ
ដល់ព្រះដទៃ[ង] ឬព្រះអាទិត្យ[ច] ព្រះច័ន្ទ ឬរបស់ដ៏បរិបូរណា
មួយនៅលើមេឃ[ឆ] ដែលអញមិនបង្គាប់ឡើយ[ជ] ៤រួចមានគេ
ប្រាប់ដល់ឯង ឬឯងបានឮក្តី នោះត្រូវឱ្យឯងស៊ើបសួរយ៉ាង
អស់ពីចិត្ត បើឃើញជាត្រូវពិត[ឈ]ដូច្នោះមែនថា មានគេ
ប្រព្រឹត្តការគួរខ្ពើមយ៉ាងនោះ នៅក្នុងសាសន៍អ៊ីស្រាអែល
ហើយ[ញ] ៥នោះត្រូវឱ្យនាំមនុស្សប្រុសឬស្រី ដែលបានប្រព្រឹត្ត
ការអាក្រក់នោះ មកឯទ្វារក្រុងរបស់ឯង ហើយចោល
សំឡាប់នឹងថ្មទៅ ទោះប្រុសឬស្រីក្តី[ដ] ៦ត្រូវឱ្យសំឡាប់អ្នក
ដែលមានទោសដល់ស្លាប់នោះ ដោយមានស្មរបន្ទាល់២
ឬ៣នាក់ តែបើមានតែម្នាក់ទេ នៅមិនល្មមនឹងសំឡាប់គេ
ឡើយ[ឋ] ៧ត្រូវឱ្យស្មរបន្ទាល់ទាំងនោះដាក់ដៃជាមុនគេ ដើម្បី
នឹងសំឡាប់ចោល[ឌ] រួចសឹមឱ្យពួកបណ្ដាជនគ្រប់គ្នាជាខាង
ក្រោយ[ឍ] គឺយ៉ាងដូច្នោះដែលឯងត្រូវបំបាត់សេចក្ដីអាក្រក់[ណ]
ពីពួកឯងចេញ ។

## កន្លែងកាត់ក្តី

៨បើកាលណាមានរឿងណាពិបាកពេក ដែលឯងនឹង
ជំនុំជំរះមិនបាន[ត] ទោះពីឈាមនឹងឈាម ពាក្យបណ្ដឹងដល់
គ្នាទៅវិញទៅមក ការវាយគ្នា[ថ] ជារឿងដែលនាំមានក្តីកើត
ឡើងនៅក្នុងទីក្រុងឯង នោះត្រូវឱ្យឯងក្រោកឡើង ទៅឯ
កន្លែងដែលព្រះយេហូវ៉ាជាព្រះនៃឯងបានរើស[ទ] ៩ហើយ

**១៧:៧** ឌ យហ ៨:៧ ឍ លប ២៤:១៤ កច ៧:៥៨ ណ ចទ ១៣:៥ ១កថ ៥:១៣
**១៧:៨** ត នក ២១:៦ ថ ២រប ១៩:១០ ទ ចទ ១២:៥ ទដ ១២២:៣–៥

**១៦:១៥** *ឯងនឹងមានសេចក្ដីអំណរជាមិនខាន* គឺជាលទ្ធផលដែលព្រះប្រទានពរ (ប្រៀបធៀប យហ ៣:២៩ ១៥:១១ ១៦:២៤ ភល ២:២ ១យហ ១:៤) ។
**១៦:១៦** *៣ដងក្នុង១ឆ្នាំ* គឺជាបុណ្យដែលធ្វើដំណើរទៅជួបជុំគ្នា១ឆ្នាំ មាន៣ដង មើល នក ២៣:១៤,១៧ ។
**១៦:១៨–២០** ប្រៀបធៀប ១:៩–១៨ នក ១៨:១៣–២៦ ។
**១៦:១៩** ប្រជាជនអ៊ីស្រាអែលត្រូវតែធ្វើខ្លួនឱ្យល្អជាងមុន ចំពោះព្រះអង្គក្នុងករណីនេះ មើលការពន្យល់ នក ២៨:៨ ។
**១៦:២១–២២** សូមមើល ៧:៥ ។
**១៧:១** *មានស្លាកស្នាម ឬអាក្រក់អ្វី* មើលការពន្យល់ លវ ១:៣ ។
**១៧:៣** *ក្រាបថ្វាយបង្គំដល់ព្រះដទៃ ឬព្រះអាទិត្យ ព្រះច័ន្ទ* មើលការពន្យល់ ៤:១៩ ។
**១៧:៦** *ស្មរបន្ទាល់២ ឬ៣នាក់* លក្ខណៈបន្ថែមទៀតនៃច្បាប់ គឺមើល ក្នុង នក ៣៥:៣០ (និងការពន្យល់) មើល ១៩:១៥ មថ ១៨:១៦ ។
**១៧:៧** *ត្រូវបំបាត់សេចក្ដីអាក្រក់ចេញពីពួកឯង* មើល ខ.១២ និង ១៣:៥ ។

ចូលទៅសួរដល់ពួកលេវី[ធ] ដ៏ជាសង្ឃ និងចៅក្រម[ន] ដែល
នឹងមានក្នុងគ្រានោះ រួចអ្នកទាំងនោះនឹងបង្ហាញឱ្យឯងចេះ
កាត់សេចក្ដីហើយ[ប] ១០នោះត្រូវឱ្យឯងធ្វើតាមតែពួកអ្នកនោះ
និងបង្ហាញមកឯង ពីកន្លែងដែលព្រះយេហូវ៉ាបាន រើស
ហើយត្រូវប្រយ័ត្ននឹងប្រព្រឹត្តតាម គ្រប់ទាំងសេចក្ដី ដែល
អ្នកទាំងនោះនឹងបង្រៀនដល់ឯងចុះ ១១គឺត្រូវឱ្យឯងកាត់
សេចក្ដីឱ្យត្រូវ ដូចជាច្បាប់ដែលអ្នកទាំងនោះនឹងបង្រៀន
ដល់ឯង ហើយតាមសេចក្ដីយុត្តិធម៌ ដែលអ្នកទាំងនោះនឹង
ប្រាប់ដល់ឯងផង មិនត្រូវឱ្យងាកបែរទៅខាងស្ដាំ ឬខាង
ឆ្វេងចេញពីសេចក្ដី[ផ] ដែលអ្នកទាំងនោះនឹងបង្ហាញនោះ
ឡើយ ១២ឯអ្នកណា ដែលប្រព្រឹត្តតាមតែអំពើចិត្តឥតស្ដាប់[ព]
តាមសង្ឃដែលឈរបំរើ[ភ]ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង
នៅទីនោះ ឬតាមចៅក្រមផង អ្នកនោះនឹងត្រូវទោសដល់
ស្លាប់[ម] ត្រូវឱ្យបំបាត់សេចក្ដីអាក្រក់ពីសាសន៍អ៊ីស្រាអែល
ចេញ[យ] ១៣នោះបណ្ដាជនទាំងឡាយនឹងឮ រួចនឹងខ្លាច
ហើយលែងប្រព្រឹត្តតាមតែអំពើចិត្តទៀត[រ] ។

## ស្ដេច

១៤កាលណាឯងបានទៅដល់ស្រុក ដែលព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់ប្រទានឱ្យ ហើយចាប់យក[ល]បានព្រមទាំង
តាំងទីលំនៅអាស្រ័យនៅផង[វ] រួចជំនុំគ្នាថា យើងនឹងតាំង
ស្ដេចឱ្យសោយរាជ្យលើយើង ដូចជាសាសន៍ទាំងប៉ុន្មាន
ដែលនៅជុំវិញយើងដែរ[ស] ១៥នោះត្រូវតាំង[ហ]អ្នកណាមួយ
ឡើង ឱ្យធ្វើជាស្ដេចតាមដែលព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់នឹងរើស គឺត្រូវលើកម្នាក់ក្នុងពួកបងប្អូនឯង[ឡ]ឱ្យធ្វើជា
ស្ដេចលើឯងចុះ គ្មានច្បាប់នឹងតាំងអ្នកប្រទេសក្រៅណា
ដែលមិនមែនជាបងប្អូន ឯងឱ្យគ្រប់គ្រងលើឯងឡើយ ១៦កុំបី
តែឱ្យស្ដេចនោះចំរើន សេះ[អ]ជាច្រើនសំរាប់ខ្លួន[ក] ឬបណ្ដាល
ឱ្យបណ្ដាជនត្រឡប់ទៅស្រុកអេស៊ីព្ទ[ខ] ដើម្បីឱ្យខ្លួនបានសេះ
ជាច្រើនឡើងនោះឡើយ[គ] ដ្បិតព្រះយេហូវ៉ា ទ្រង់បានមាន
បន្ទូលនឹងឯងរាល់គ្នាថា មិនត្រូវឱ្យឯងរាល់គ្នាត្រឡប់ទៅ
តាមផ្លូវនោះទៀតឱ្យសោះ[ឃ] ១៧ក៏មិនត្រូវឱ្យស្ដេចនោះយក
ភរិយាជាច្រើនដែរ[ង] ដើម្បីកុំឱ្យមានចិត្តងាកបែរចេញទៅ
ឡើយ[ច] ក៏មិនត្រូវប្រមូល[ឆ]ប្រាក់ មាសជាច្រើនលើសលប់
ដែរ[ជ] ។

១៨កាលណាស្ដេចនោះ បានឡើងគង់លើបល្ល័ង្ករាជ្យ[ឈ]
ហើយនោះត្រូវ[ញ]ឱ្យចំឡង[ដ]ក្រិត្យវិន័យ តាមគម្ពីរដែលនៅ
មុខពួកលេវីដ៏ជាសង្ឃ ទុកក្នុងសៀវភៅសំរាប់ខ្លួន ១៩ត្រូវឱ្យ
សៀវភៅនោះនៅជាមួយនឹងខ្លួន ហើយត្រូវមើលរាល់តែ
ថ្ងៃជានិច្ចអស់១ជីវិតផង[ឋ] ដើម្បីនឹងទំលាប់ខ្លួន ឱ្យចេះកោត
ខ្លាចដល់ព្រះយេហូវ៉ា ជាព្រះនៃខ្លួន ប្រយោជន៍ឱ្យបានកាន់
តាមគ្រប់ទាំងសេចក្ដី ដែលនៅក្នុងក្រិត្យវិន័យនៃច្បាប់ទាំង
នេះ ព្រមទាំងប្រព្រឹត្តតាមផង[ឌ] ២០ហើយកុំឱ្យកើតមានចិត្តធំ
លើពួកបងប្អូនខ្លួន ឬងាកបែរចេញពីសេចក្ដីបង្គាប់[ឍ] ទៅ
ខាងស្ដាំ ឬខាងឆ្វេងឡើយ[ណ] នេះគឺដើម្បីឱ្យបានជីវិតជាយូរ
អង្វែង នៅក្នុងនគរខ្លួន ព្រមទាំងកូនចៅរបស់ខ្លួន នៅក្នុង
ពួកសាសន៍អ៊ីស្រាអែលតរៀងទៅ[ត] ។

## ដង្វាយសម្រាប់ពួកសង្ឃនិងពួកលេវី

**១៨** ១ឯពួកលេវីដ៏ជាសង្ឃ គឺពូជអំបូរលេវី[ក]គ្រប់គ្នាមិន
ត្រូវឱ្យគេមានចំណែក ឬមរដក[ខ] ជាមួយនឹងពួកអ៊ីស្រាអែល

**១៧:៩** ធ ចទ ២៤:៨ ២៧:៩ ន នក ២១:៦ ប លប ២៥:២២ ចទ ១៩:១៧ អគ ៤៤:២៤ ហក ២:១១ **១៧:១១** ផ លវ ១០:១១ ចទ ៥:៣២ **១៧:១២** ព ជន ១៥:៣០ ភ ជន ១៦:៩ ម ខ.១៣ លប ១៧:១៤ ចទ ១៣:១១ ១៨:២០ ១៩:២០ ១ពវ ១៨:៤០ យរ ១៤:១៤ ហស ៤:៤ សក ១៣:៣ យ ចទ ១៣:៥ **១៧:១៣** រ ខ.១២ **១៧:១៤** ល ជន ៣៣:៥៣ វ យស ២១:៤៣ ស ១សយ ៨:៥,១៩–២០ ១០:១៩ **១៧:១៥** ហ ១សយ ១៦:៣ ២សយ ៥:៣ ឡ យរ ៣០:២១ **១៧:១៦** អ អស ២:៧ ៣០:១៦ ក ១សយ ៨:១១ ១ពវ ៤:២៦ ៩:១៩ ១០:២៦ ២របា ១:១៤ ទដ ២០:៧ ខ ១ពវ ១០:២៩ អស ៣១:១ យរ ៤២:១៤ គ ១ពវ ១០:២៨ អស ៣១:១ អគ ១៧:១៥ ឃ នក ១៣:១៧ **១៧:១៧** ង នក ៣៤:១៦ ២សយ ៥:១៣ ១២:១១ ១ពវ ១១:៣ ២របា ១១:២១ ច ១ពវ ១១:២ សភ ៣១:៣ ឆ ១ពវ ១០:២៧ ជ ២របា ១:១១ អស ២:៧ **១៧:១៨** ឈ ១ពវ ១:៤៦ ១របា ២៩:២៣ ញ ចទ ៣១:២២,២៤ យស ២៤:២៦ ១សយ ១០:២៥ ដ ២របា ២៣:១១ **១៧:១៩** ឋ ចទ ៤:៩–១០ យស ១:៨ ឌ ចទ ១១:១៣ ១ពវ ៣:៣១១:៣៨ ២ពវ ២២:២ **១៧:២០** ឍ យស ២៣:៦ យប ២៣:១២ ទដ ១១៩:១០២ ណ ចទ ៥:៣២ ១ពវ ៩:៤ ត ១សយ ៨:៥ ១០:២៥ ១ពវ ២:៣ ១របា ២៨:៨ **១៨:១** ក យរ ៣៣:១៨,២១ ខ ជន ១៨:២០ ១កថ ៩:១៣

**១៧:១៤** *ដូចជាសាសន៍ទាំងប៉ុន្មានដែលនៅជុំវិញយើង* លោកយ៉ូស្វេ និងលោកម៉ូសេ មានភាពយុត្តិធម៌ដល់ពួកគេ ដោយបានជ្រើសរើសពីព្រះយេហូវ៉ា ដើម្បីដឹកនាំប្រជាជនអ៊ីស្រាអែលដោយសេចក្ដីជំនឿរបស់ពួកគេ ។ ដូចសំបុត្ររបស់លោកគេឌានបានថ្លែងថា"ព្រះយេហូវ៉ាជាអ្នកដឹកនាំអ្នករាល់គ្នា"(ពច ៨:២៣ និងការពន្យល់) ។ លោកម៉ូសេបានប្រាប់ទុកជាមុនព្រោះប្រជាជនកំពុងរកស្ដេចរបស់ពួកគេ(១សយ ៨:៤–៩)ទឹកដីដ៏វិសេសរបស់ព្រះអម្ចាស់សម្រាប់ពួកគេ (មើលការពន្យល់ ៧:២–៥ ១សយ ៨:១–១២:២៥ និងមើល លវ ២០:២៣) ។ ដូច្នេះលោកម៉ូសេក៏បាននែនាំអំពីការជ្រើសរើសស្ដេចដល់ពួកគេ(ខ.១៤–២០) ។

**១៧:១៦–១៧** រឿងរ៉ាវដ៏អាក្រក់ជាច្រើន ដែលស្ដេចក្រោយនេះបានប្រព្រឹត្តឃោរឃៅតាំងពីដំបូងជាពិសេសជាមួយស្ដេចសាឡូម៉ូន (មើល ១ពវ ៤:២៦ ១០:១៤ –២២ ១១:១–៤) គឺគេមិនឱ្យប្រជាជនអ៊ីស្រាអែលត្រឡប់ទៅអេស៊ីព្ទ (មើល យរ ៤២:១៣–៣៤:៧) ។

**១៧:១៨** *ចំឡងក្រិត្យវិន័យ... ទុកក្នុងសៀវភៅសំរាប់ខ្លួន* ដោយសារទីដែលទទួលចំពោះព្រះយេហូវ៉ា ដែលជាស្ដេចរបស់គាត់ហើយក៏ដូចជាអ្នកនាំផ្លូវតាមក្រឹត្យវិន័យក្នុងការស្ដាប់បង្គាប់ ពីការត្រាសហៅចំពោះសិទ្ធិដឹកនាំពីស្ថានសួគ៌ ។ ការនេះទាមទារនូវបែបបទចំពោះស្ដេចដែលចំណុះរណបនៅក្រោមការអនុវត្តនៃច្បាប់ស្ថានសួគ៌ ក្នុងចំណោមសាសន៍ហេត និងសាសន៍ដទៃទៀតមុនជំនាន់នេះ (មើល ៣១:៩) ។

**១៨:១** *មិនត្រូវឱ្យគេមានចំណែក ឬមរដក* គឺថាពុំមែនជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ ទីក្រុង ឬដីដែលនៅព័ទ្ធជុំវិញទីក្រុងត្រូវញែកដោយឡែក សម្រាប់ការប្រើប្រាស់របស់ពួកលេវី (យស ២១:៤១–៤២) គឺវាដូចជាដង្វាយ១០ហូតមួយ

ឡើយ ត្រូវឱ្យគេបរិភោគដង្វាយ[គ] ដែលដុតថ្វាយព្រះយេ
ហូវ៉ា គឺជាមរដករបស់ទ្រង់វិញ ២មិនត្រូវឱ្យគេមានមរដក
នៅជាមួយនឹងបងប្អូនគេទេ ដ្បិតព្រះយេហូវ៉ាទ្រង់ជាមរដក
[ឃ]របស់គេហើយ ដូចជាទ្រង់បានមានបន្ទូលនឹងគេស្រាប់[ង]
៣នេះជាចំណែក ដែលបណ្តាជនជាពួកអ្នកដែលថ្វាយយញ្ញ
បូជាត្រូវឱ្យដល់ពួកសង្ឃ[ច] ទោះគោ[ឆ]ឬចៀមក្តី នោះត្រូវ ឱ្យ
ស្មា ថ្គាម និងពោះធំផង[ជ] ៤ព្រមទាំងផលដំបូងពីស្រូវ ពី
ទឹកទំពាំងបាយជូរ ពីប្រេង ហើយរោមចៀមរបស់ឯង
ដែលកាត់មុនដំបូងដែរ[ឈ] ៥ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង
ទ្រង់បានរើសគេ[ញ] និងកូនចៅគេ ពីពូជអំបូរឯងទាំងប៉ុន្មាន
ឱ្យបានឈរធ្វើការងារ[ដ] ដោយនៅព្រះនាមព្រះយេហូវ៉ា
ជានិច្ច[ឋ]។

៦បើមានពួកលេវីណាម្នាក់ ចេញពីទីក្រុងឯងណាមួយ
ក្នុងបណ្តាសាសន៍អ៊ីស្រាអែលទាំងអស់ ជាទីលំនៅរបស់គេ
មកដោយបំណងចិត្តដ៏ពោរពេញ ដល់កន្លែងដែលព្រះយេ
ហូវ៉ានឹងរើស[ឌ] ៧នោះគេនឹងធ្វើការងារ ដោយនូវព្រះនាម[ឍ]
ព្រះយេហូវ៉ាជាព្រះនៃគេបានដែរ ដូចជាពួកលេវី ជាបង
ប្អូនគេគ្រប់គ្នា ដែលឈរនៅទីនោះ ចំពោះព្រះយេហូវ៉ា
៨គេនឹងមានចំណែកបរិភោគស្មើគ្នា ក្រៅពីដំឡៃកេរ្តិ៍អាករ
របស់ឪពុក ដែលគេបានលក់ហើយ[ណ]។

## ការគួរស្អប់ខ្ពើម

៩កាលណាឯងបានចូលទៅក្នុងស្រុក ដែលព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់ប្រទានឱ្យ នោះមិនត្រូវរៀនធ្វើតាម[ត]ការ
គួរស្អប់ខ្ពើម[ថ]របស់សាសន៍ទាំងនោះឡើយ ១០នៅក្នុងពួក
ឯង មិនត្រូវឱ្យឃើញមានអ្នកណាមួយ ដែលធ្វើឱ្យកូនប្រុស
ឬកូនស្រីខ្លួនឆ្លងកាត់ភ្លើង[ទ] ឬគ្រូទាយ[ធ] គ្រូគន់គូរនក្ខត្តឫក្ស
គ្រូអង្គុយធម៌ គ្រូអាបធ្មប់[ន,ប] ១១គ្រូសន្ទាប់[ផ] គ្រូខាប គ្រូគាថា
ឬគ្រូអន្ទងខ្មោច[ព]ណាឡើយ ១២ដ្បិតអ្នកណាដែលប្រព្រឹត្ត
ការទាំងនោះ ជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ាណាស់ គឺ
ដោយព្រោះសេចក្តីគួរស្អប់ខ្ពើមយ៉ាងនោះហើយ បានជា
ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បណ្តេញគេពីមុខឯង
ចេញ[ភ] ១៣ត្រូវឱ្យឯងឥតមានសៅហ្មង[ម]ចំពោះព្រះយេហូវ៉ា
ជាព្រះនៃឯងចុះ[យ]។

## ពួកហោរា

១៤ដ្បិតឯសាសន៍ទាំងនោះ ដែលឯងនឹងត្រូវទៅចាប់
យកស្រុករបស់គេ នោះសុទ្ធតែជាអ្នកស្តាប់តាមគ្រូគន់គូរ
នក្ខត្តឫក្ស នឹងគ្រូទាយទំនាយទាំងអស់[រ] តែព្រះយេហូវ៉ាជា
ព្រះនៃឯង ទ្រង់មិនបើកឱ្យឯងប្រព្រឹត្តការយ៉ាងដូច្នោះទេ ។
១៥ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងបណ្តាលឱ្យមាន
ហោរា១កើតឡើង ពីពួកបងប្អូនឯងឱ្យដូចជាអញ[ល] ត្រូវឱ្យ
ឯងរាល់គ្នាស្តាប់តាមអ្នកនោះចុះ ១៦តាមគ្រប់ទាំងសេចក្តី
ដែលឯងបានសូមដល់ព្រះយេហូវ៉ា ជាព្រះនៃឯងត្រង់
ភ្នំហោរែប នៅថ្ងៃដែលប្រជុំនោះថា សូមកុំឱ្យខ្ញុំឮសំឡេង
របស់ព្រះយេហូវ៉ា ជាព្រះនៃខ្ញុំ ឬឃើញភ្លើងដ៏ធំនេះទៀត
ឡើយ ក្រែងខ្ញុំត្រូវស្លាប់[វ] ១៧នោះព្រះយេហូវ៉ា ទ្រង់ក៏មាន
បន្ទូលមកអញថា សេចក្តីដែលគេថា នោះបានថា ត្រូវ
ហើយ ១៨អញនឹងបណ្តាល ឱ្យមានហោរា១[ស]កើតឡើងពី
ពួកបងប្អូនគេ សំរាប់គេ ឱ្យដូចឯង ហើយអញនឹងដាក់
ពាក្យអញ[ហ]ទៅក្នុងមាត់[ឡ]ហោរានោះ អ្នកនោះនឹងប្រាប់

**១៨:១** គ ជន១៨:៨ **១៨:២** ឃ ជន ១៨:២០ ង យស ១៣:១៤ **១៨:៣** ច នក ២៩:២៧ ឆ លវ ១:៥ ជ លវ ៧:២៨–៣៤ ជន ១៨:១២ **១៨:៤** ឈ នក ២២:២៩ ជន ១៨:១២ **១៨:៥** ញ នក ២៨:១ ដ ចទ ១០:៨ ឋ នក ២៩:៩ **១៨:៦** ឌ ជន ៣៥:២–៣ ចទ ១២:៥ **១៨:៧** ឍ ខ.១៩ ១ពវ ១៨:៣២ ២២:១៦ ទដ ១១៩:២៦ **១៨:៨** ណ ជន ១៨:២៤ ២របា ៣១:៤ នហ ១២:៤៤,៤៧ ១៣:១២ **១៨:៩** ត ចទ ៩:៥ ១២:២៩–៣១ ថ លប ១៨:៣ ២ពវ ២១:២ ២របា ២៨:៣ ៣៣:២ ៣៤:៣៣ អរ ៦:២១ ៩:១១ យរ ៤៤:៤ **១៨:១០** ទ លវ ១៨:២១ ធ ១សយ ១៥:២៣ ន នក ៧:១១ ប លវ ១៩:៣១ **១៨:១១** ផ អស ៤៧:៩ ព នក ២២:១៨ ១សយ ២៨:១៣ **១៨:១២** ភ លវ ១៨:២៤ **១៨:១៣** ម លប ៦:៩ ទដ ១១៩:១ យ មថ ៥:៤៨ **១៨:១៤** រ ២ពវ ២១:៦ **១៨:១៥** ល មថ ២១:១១ លក ២:២៥–៣៥ យហ ១:២១ កច ៣:២២ ៧:៣៧ **១៨:១៦** វ នក ២០:១៩ ចទ ៥:២៣–២៧ **១៨:១៨** ស លប ២០:៧ ហ អស ២:៣ ២៦:៨ ៥១:៤ មីក ៤:២ ឡ នក ៤:១២

ឬជាចំណែកនៃការថ្វាយយញ្ញបូជា (មើល ១៤:២២–២៩ លវ ២៧:៣០ និងការពន្យល់ ជន ១៨:២១–២៩) ។

**១៨:៤** *ផលដំបូង* មើល នក ២៣:១៩ និងការពន្យល់ ៣៤:២៦ លវ ២៣:១០–១១ ជន ១៥:១៨–២០ ១៨:១២–១៨ ។

**១៨:៥** មើលការពន្យល់ ២១:៥ ។

**១៨:៩** *ការគួរស្អប់ខ្ពើមរបស់សាសន៍ទាំងនោះ* គឺអ្វីដែលគេកំពុងគោរពតាមនោះ គឺគ្រូមន្តអាគម ឬគ្រូគន់គូរនក្ខត្តឫក្ស ឬគ្រូទាយទំនាយ ។ ដូចក្នុងគម្ពីរសញ្ញាចាស់ គឺពួកសាសន៍កាណានកំពុងតែមានជំនឿ លើការទាំងអស់នេះហើយដែលព្រះយេហូវ៉ាហាមឃាត់ ។ ពួកគេគួតែស្តាប់ដល់ហោរាពិតរបស់ព្រះយេហូវ៉ា (សូមមើល ខ.១៤–២២ អស ៨:១៩–២០) ។

**១៨:១០** *កូនប្រុស ឬកូនស្រីខ្លួនឆ្លងកាត់ភ្លើង* មើល ១២:៣១ ក៏មើលការពន្យល់ លវ ១៨:២១ ។

**១៨:១៥** *មានហោរា១ . . . ឱ្យដូចជាអញ* មើល ៣៤:១០ ខ.១៦ ដូចជាអត្ថបទផ្សេងទៀត(ជាពិសេសសូមមើល ខ.២០–២២) ការបញ្ជាក់ថាមានហោរាមកមួយទៀត គឺមានន័យថានៅភ្នំហោរែប (នក ៣:១) ប្រជាជនបានសុំឱ្យលោកម៉ូសេសម្តែងព្រះបន្ទូលទៅពួកគេ គឺចំពោះអ្វីៗដែលព្រះចង់បើកសម្តែងនោះ(មើល ២០:១៩ និងការពន្យល់) តែឥឡូវលោកម៉ូសេបានឃ្លាតឆ្ងាយពីពួកគេ ហើយប្រាប់ថា និងមានអ្នកនាំព្រះរាជសារម្នាក់ទៀតមកជំនួសគាត់ ។ គឺជាហោរាម្នាក់ដែលមកតាមក្រោយ គឺព្រះម៉ែស៊ីដែលគេកំពុងរង់ចាំ ហើយទទួលការសម្រេចតាមទំនាយ តាមរយៈព្រះយេស៊ូវគ្រីស្ទ (សូមមើល យហ ១:២១,២៥,៤៥ ៥:៤៦ ៦:១៤ ៧:៤០ កច ៣:២២–២៦ ៧:៣៧) ។

**១៨:១៦** មើល នក ២០:១៨–២១ ហព ១២:១៨ និងការពន្យល់ ។

**១៨:១៨** *ពាក្យអញទៅក្នុងមាត់របស់គេ* មើល នក ៤:១៥–១៦ និងសូមមើល

ដល់គេតាមគ្រប់ទាំងសេចក្ដី ដែលអញនឹងបង្គាប់មក[អ]
១៩ដូច្នេះ បើអ្នកណាមិនស្តាប់[ក]តាមពាក្យអញ ដែលហោរា
នោះនឹងពោល ដោយនូវឈ្មោះអញ[ខ] នោះអញនឹងធ្វើ
ទោសដល់គេ[គ] ។

២០ប៉ុន្តែហោរាណាដែលនឹងនិយាយប្រាប់អ្វី តាមតែ
អំពើចិត្ត ដោយនូវឈ្មោះអញ ជាសេចក្ដីដែលអញមិនបាន
បង្គាប់ឱ្យថាសោះ ឬដែលនឹងនិយាយដោយនូវឈ្មោះព្រះ
ដទៃ[ឃ] ហោរានោះនឹងត្រូវស្លាប់[ង] ២១បើឯងគិតក្នុងចិត្តថា
ធ្វើដូចម្តេចឱ្យយើងដឹងជាពាក្យណា ដែលព្រះយេហូវ៉ាមិន
បានមានបន្ទូល ២២[ឌ]គឺកាលណាហោរាណានឹងទាយ ដោយ
នូវព្រះនាមព្រះយេហូវ៉ា នោះបើការនោះមិនឃើញ មាន
មកក៏មិនកើតមកទេ[ច] ពាក្យនោះហើយជាពាក្យដែលព្រះ
យេហូវ៉ាមិនបានមានបន្ទូល[ឆ] ហោរានោះបានពោលតាម
តែអំពើចិត្តរបស់ខ្លួនទេ[ជ]មិនត្រូវឱ្យឯងខ្លាចគេឡើយ ។

## ទីក្រុងសម្រាប់ជ្រកកោន

*១៩:១-១៤-ជន ៣៥:៦-៣៤ ចទ ៤:៤១-៤៣ យស ២០:១-៩*

**១៩** ១កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង បានកាត់
បណ្តាច់អស់ទាំងសាសន៍ទាំងនោះដែលទ្រង់ប្រទាន ស្រុក
គេមកឱ្យឯង ហើយឯងបានបណ្តេញគេទៅ ព្រមទាំងតាំង
ទីលំនៅឯងនៅក្នុងក្រុង និងនៅក្នុងផ្ទះគេ[ក] ២នោះត្រូវ
ញែកទីក្រុង៣ចេញ សំរាប់ឯង នៅកណ្តាលស្រុកដែល
ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានឱ្យចាប់យក ៣ត្រូវ
ឱ្យរៀបចំផ្លូវ ហើយចែកស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃ
ឯង ទ្រង់ប្រទានឱ្យគ្រងជាមរដក ចេញជា៣ផ្នែក ដើម្បីឱ្យ
អស់អ្នកណាដែលសំឡាប់គេ បានរត់ទៅជ្រកនៅឯទីនោះ ។

៤នេះជាច្បាប់ខាងឯអ្នកដែលសំឡាប់គេ ហើយរត់ទៅ
ជ្រកអាស្រ័យនៅទីក្រុងនោះ ដើម្បីនឹងឱ្យរួចជីវិតបាន គឺអ្នក
ណាមួយដែលសំឡាប់អ្នកជិតខាងខ្លួន មិនប្រកបដោយចិត្ត
ប៉ង ក៏មិនបានស្អប់កាលពីមុនដែរ ៥ឧបមា ដូចជាមនុស្ស
ណាម្នាក់ ដែលទៅព្រៃកាប់ឧសជាមួយនឹងអ្នកជិតខាង
ខ្លួនហើយក៏លើកពូថៅឡើង និងកាប់រំលំដើមឈើ ស្រាប់
តែផ្លែរបូតចេញពីដង ទៅត្រូវអ្នកជិតខាងដល់ស្លាប់ ដូច្នេះ
ត្រូវអ្នកនោះរត់ទៅជ្រកអាស្រ័យ នៅទីក្រុងណាមួយនោះ
ឱ្យបានរួចជីវិតចុះ ៦ក្រែងអ្នកដែលត្រូវសងសឹក និងឈាម[ខ]
បានដេញតាមអ្នកដែលសំឡាប់គេឱ្យទាន់ ដោយព្រោះ
ផ្លូវនោះឆ្ងាយ ក្នុងកាលដែលចិត្តកំពុងខឹងក្តៅនៅឡើយ
រួចក៏វាយអ្នកនោះសំឡាប់ទៅ តែអ្នកនោះមិនគួរនឹងស្លាប់
ទេ ពីព្រោះមិនបានស្អប់គេពីដើមឡើយ ៧ហេតុនោះបាន
ជាអញបង្គាប់ថា ចូរញែកទីក្រុង៣សំរាប់ឯងចុះ ៨ហើយ
បើព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់វាតព្រំប្រទល់របស់ឯង
ឱ្យធំឡើង[គ] ដូចជាទ្រង់បានស្បថ[ឃ]នឹងពួកឰយុកោ ហើយ
ទ្រង់ប្រទានស្រុកទាំងអស់ ដែលទ្រង់បានសន្យានឹងឱ្យដល់
ពួកឰយុកោឯង ៩ដោយឯងនឹងកាន់ ហើយប្រព្រឹត្តតាម
សេចក្ដីបញ្ញត្តិ ដែលអញបង្គាប់មក នៅថ្ងៃនេះគ្រប់ជីពូក
ដើម្បីនឹងស្រឡាញ់ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ព្រមទាំង
ដើរតាមផ្លូវទ្រង់[ង]ជាដរាបទៅ នោះត្រូវឱ្យបន្ថែមទីក្រុង៣
ទៀត ១០ដើម្បីកុំឱ្យមានការខ្ចាយឈាម[ច] របស់មនុស្សឥត
ទោសនៅក្នុងស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់
ប្រទានមកទុកជាមរដករបស់ឯង ហើយយ៉ាងនោះ មាន
ឈាមធ្លាក់មកលើឯងនោះឡើយ[ឆ] ។

១១ប៉ុន្តែបើមនុស្សណាមានចិត្តស្អប់ ដល់អ្នកជិតខាងខ្លួន
ហើយលបចាំស្ទុះទៅវាយឱ្យដល់ស្លាប់[ជ] រួចរត់ទៅជ្រកនៅ
ទីក្រុងណាមួយនោះ ១២នោះពួកចាស់ទុំនៃក្រុងរបស់អ្នក
នោះ ត្រូវចាត់គេឱ្យទៅនាំអ្នកនោះមក ហើយប្រគល់ទៅ
ក្នុងកណ្តាប់ដៃនៃអ្នក ដែលត្រូវសងសឹកនឹងឈាមវិញ ដើម្បី
ឱ្យត្រូវស្លាប់ចុះ ១៣មិនត្រូវឱ្យភ្នែកឯងប្រណីឡើយ[ឈ] ត្រូវឱ្យ
បំបាត់ការខ្ចាយឈាមឥតទោស[ញ] ពីពួកអ៊ីស្រាអែលចេញ
វិញ ដើម្បីឱ្យឯងបានសប្បាយតទៅ ។

១៤មិនត្រូវឱ្យឯងបន្ថយគោលចារឹករបស់អ្នកជិតខាង ដែល
គេបានបោះកាលពីដើម នៅដីដែលឯងនឹងគ្រងជាមរដក
ក្នុងស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានឱ្យ
ចាប់យកនោះឡើយ[ដ] ។

## ស្មរបន្ទាល់

១៥មិនត្រូវឱ្យមានស្មរបន្ទាល់តែម្នាក់ ឈរឡើងធ្វើ
បន្ទាល់ពីសេចក្ដីទុច្ចរិត ឬពីអំពើបាបណា ដែលមនុស្សនឹង
ប្រព្រឹត្តយ៉ាងណាក្តីនោះឡើយ គឺដោយស្មរបន្ទាល់២ ឬ៣

**១៨:១៨** អ យហ ៤:២៥-២៦ ១៤:២៤ កច ៣:២២ **១៨:១៩** ក នក ២៣:២១ ខ ខ.៧ លវ ១៩:២១ ២ពវ ២:២៤ គ យស ២២:២៣ កច ៣:២៣ ហព ១២:២៥ **១៨:២០** ឃ នក ២៣:១៣ ង ចទ ១៣:១-៥ ១៧:១២ **១៨:២២** ច ចទ ១៣:២ ១សយ ៣:២០ ឆ ១ពវ ២២:២៨ យរ ២៨:៩ ជ ខ.២០ **១៩:១** ក ចទ ៦:១០-១១ **១៩:៦** ខ ជន ៣៥:១២ **១៩:៨** គ នក ៣៤:២៤ ឃ លប ១៥:៨ ចទ ១១:២៤ **១៩:៩** ង ចទ ៦:៥ **១៩:១០** ច សផ ៦:១៧ យរ ៧:៦ ២៦:១៥ ឆ ចទ ២១:១-៩ **១៩:១១** ជ នក ២១:១២ ១យហ ៣:១៥ **១៩:១៣** ឈ ចទ ៧:២ ញ ចទ ២១:៩ ១ពវ ២:៣១ **១៩:១៤** ដ ចទ ២៧:១៧ យប ២៤:២ សភ ១៦:៦ សភ ១៥:២៥

២២:២៨ ២៣:១០ អស ១:២៣ ហស ៥:១០ **១៩:១៥** ឋ ចទ ១៧:៦ មថ ១៨:១៦២៦:៦០ ២កថ ១៣:១

៧:១-២ យរ ១:៩ ។

**១៨:២០** *ហោរាណាដែលនឹងនិយាយប្រាប់អ្វី* មើលការពន្យល់ ១៣:១-៥ ។ *នោះនឹងត្រូវស្លាប់* មើល យរ ២៨:១៥-១៧ ។

**១៨:២១-២២** មើលការពន្យល់ ១៣:១-៥១ ៩:១-១៣ មើល ៤:៤១-៤៣ ជន ៣៥:៩-២៨ យស ២០ និងការពន្យល់ ។

**១៩:១៤** *គោលចារឹក* គឺដូចជាបង្គោលថ្មដែលត្រូវបានគេបោះបន្តរឡើង ដើម្បីកំណត់ព្រំដី ឬដីទ្រព្យ គឺជាការរំកិលព្រំដីខុសច្បាប់ ព្រោះតែចង់បានជាកម្មសិទ្ធផ្ទាល់ខ្លួន គឺត្រូវគេចាត់ទុកថា វាជាអំពើឧក្រិដ្ឋ (មើល ២៧:១៧) ។

នាក់វិញ ទើបដំណើរនោះនឹងសំរេចបាន[ប] ១៦បើកាលណា
មានស្មរបន្ទាល់ក្លែងក្លាយ[ឌ] ឈរឡើងធ្វើបន្ទាល់ទាស់នឹង
មនុស្សណាពីការកំហុសអ្វី ១៧នោះត្រូវឱ្យទាំង២នាក់ដែល
កើតទាស់ទែងគ្នា បានឈរនៅចំពោះព្រះយេហូវ៉ា ត្រង់
មុខពួកសង្ឃ និងចៅក្រម[ឍ]ដែលមានក្នុងគ្រានោះ ១៨ហើយ
ត្រូវឱ្យពួកចៅក្រមពិនិត្យសួរដោយហ្មត់ចត់[ណ] បើឃើញថា
អ្នកនោះជាស្មរបន្ទាល់ក្លែងក្លាយមែន ហើយបានធ្វើ
បន្ទាល់កោងទាស់នឹងបងប្អូន ១៩នោះត្រូវឱ្យឯងរាល់គ្នា
ប្រព្រឹត្តនឹងអ្នកនោះ ដូចជាអ្នកនោះបានគិតធ្វើដល់បងប្អូន
វិញ[ត] យ៉ាងនោះឯងនឹង បំបាត់សេចក្តីអាក្រក់ពីពួកឯងចេញ
២០ដូច្នេះអ្នកឯទៀតនឹងឮ ហើយកោចខ្លាច[ថ] រួចនឹងលែង
ប្រព្រឹត្តការអាក្រក់យ៉ាង ដូច្នោះ នៅក្នុងពួកឯងតទៅ
២១មិនត្រូវឱ្យភ្នែកឯងប្រណី[ទ] គេឱ្យសោះ ត្រូវធ្វើឱ្យជីវិតធួន
នឹងជីវិត ភ្នែកធួននឹងភ្នែក ធ្មេញធួននឹងធ្មេញ ដៃធួននឹងដៃ
ជើងធួននឹងជើងវិញ[ធ] ។

## ការចេញទៅច្បាំង

**២០** ១បើកាលណាឯងរាល់គ្នាចេញទៅ ច្បាំងនឹងខ្មាំង
សត្រូវ ឃើញសេះ ឃើញរទេះ និងមនុស្សជាច្រើនជាងពួក
ឯង[ក] នោះមិនត្រូវខ្លាចគេ[ខ]ឡើយ[គ] ដ្បិតព្រះយេហូវ៉ា ជាព្រះ
នៃឯង ដែលបាននាំឯងចេញពីស្រុកអេស៊ីព្ទមក ទ្រង់គង់នៅ
ជាមួយ[ឃ]នឹងឯងហើយ ២កាលណាឯងរាល់គ្នាចូលទៅជិត
ដើម្បីតនឹងគេ នោះត្រូវឱ្យសង្ឃចូលមកនិយាយនឹងបណ្តា
ទ័ពថា ៣ចូរស្តាប់ ពួកអ៊ីស្រាអែលអើយ នៅថ្ងៃនេះឯងរាល់
គ្នាចូលទៅតយុទ្ធនឹងខ្មាំងសត្រូវ ដូច្នេះកុំឱ្យមានចិត្តតក់ស្លុត
ឡើយ[ង] ក៏កុំឱ្យខ្លាច ឬញ័ររន្ធត់ ឬភ្ញាក់ផ្អើលនៅមុខគេឱ្យ
សោះ ៤ដ្បិតព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់យាងទៅជា
មួយនឹងឯង[ច] ដើម្បីច្បាំង[ឆ]នឹងពួកខ្មាំងសត្រូវជំនួសឯង
ហើយនិងជួយសង្គ្រោះឯងផង[ជ] ៥នោះត្រូវឱ្យពួកនាយកសួរ
គេថា តើមានមនុស្សណាដែលទើបនឹងសង់ផ្ទះថ្មី ហើយមិន
ទាន់ឡើងនៅ[ឈ]ឬទេ ចូរឱ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ
ក្រែងស្លាប់ក្នុងចំបាំង ហើយមានម្នាក់ទៀតឡើងទៅនៅ
វិញ ៦តើមានមនុស្សណាបានដាំ[ញ]ចំការទំពាំងបាយជូរ
ហើយមិនទាន់បេះផ្លែឬទេ[ដ] ចូរឱ្យអ្នកនោះត្រឡប់ទៅផ្ទះ
វិញចុះ ក្រែងស្លាប់ក្នុងចំបាំង ហើយមានម្នាក់ទៀតបេះផ្លែ
នោះវិញ ៧តើមានមនុស្សណាបានដណ្តឹងប្រពន្ធ ហើយមិន
ទាន់រៀបការនៅឡើយឬទេ ចូរឱ្យអ្នកនោះត្រឡប់ទៅផ្ទះ
វិញចុះក្រែងស្លាប់ក្នុងចំបាំង ហើយមានម្នាក់ទៀតយកនាង
នោះវិញ[ឋ] ៨រួចត្រូវឱ្យពួកនាយកសួរទៀតថា តើមានមនុស្ស
ណាដែលខ្លាច ហើយមានចិត្តតក់ស្លុតឬទេ ចូរឱ្យអ្នកនោះ
ត្រឡប់ទៅផ្ទះវិញចុះ ក្រែងបងប្អូនខ្លួនមានចិត្តរលាយតាម
អ្នកនោះដែរ[ឌ] ៩កាលណាពួកនាយកបានសួរគេសព្វគ្រប់
ហើយ នោះត្រូវតាំងឱ្យមានមេទ័ព សំរាប់ឱ្យត្រួតលើ
បណ្តាទ័ព ។

១០កាលណាឯងចូលទៅជិត រៀបនឹងច្បាំងនឹងទីក្រុង
ណា នោះត្រូវប្រកាសប្រាប់សេចក្តីមេត្រីដល់គេជាមុន[ឍ]
១១បើសិនជាពួកក្រុងនោះឆ្លើយមកថា ចង់មេត្រីនឹងឯង
ហើយគេបើកឱ្យឯងចូល នោះត្រូវឱ្យមនុស្សទាំងប៉ុន្មាន
ដែលឃើញមានក្នុងទីក្រុងនោះ បានចំណុះ[ណ] ហើយបំរើ[ត]
ឯង ១២តែបើគេមិនព្រមចងមេត្រីនឹងឯងទេ គឺបែរជាច្បាំង
តវិញ នោះត្រូវឱ្យឯងឡោមព័ទ្ធទីក្រុងនោះចុះ ១៣ហើយ
កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រគល់ទីក្រុង
នោះមកក្នុងកណ្តាប់ដៃឯង នោះត្រូវឱ្យកាប់ពួកប្រុសៗទាំង
អស់ដោយមុខដាវទៅ[ថ] ១៤តែឯពួកស្រីៗ និងកូនក្មេង ព្រម
ទាំងហ្វូងសត្វ[ទ] ហើយរបស់ទាំងប៉ុន្មាននៅក្នុងក្រុងនោះ[ធ]
ដែលជារបឹបទាំងអស់[ន]នោះត្រូវចាប់យកមកសំរាប់ឯងវិញ

**១៩:១៦** ឌ នក ២៣:១ សក ៦:១៩
**១៩:១៧** ឍ នក ២១:៦
**១៩:១៨** ណ នក ២៣:៧
**១៩:១៩** ត សភ ១៩:៥,៩ ១កថ ៥:១៣
**១៩:២០** ថ ចទ ១៣:១១
**១៩:២១** ទ ខ.១៣ នក ២១:២៤ មថ ៥:៣៨
**២០:១** ក ទដ ២០:៧ អស ៣១:១ ខ ជន ១៤:៩ គ ចទ ៣:២២ ១សយ ១៧:៤៥ ឃ អស ៤១:១០
**២០:៣** ង ១សយ ១៧:៣២ យប ២៣:១៦ ទដ ២២:១៤ អស ៧:៤ ៣៥:៤ យរ ៥១:៤៦
**២០:៤** ច ២របា ២០:១៤-២២ ឆ នក ១៤:១៤ ១របា ៥:២២ នហ ៤:២០ ជ ពច ១២:៤ ១៥:១៨ ទដ ៤៤:៧ ១៤៤:១០
**២០:៥** ឈ នហ ១២:២៧
**២០:៦** ញ យរ៣១:៥ អគ ២៨:២៦ មីក ១:៦ ដ ១កថ ៩:៧
**២០:៧** ឋ ចទ ២៤:៥ សភ ៥:១៨
**២០:៨** ឌ ពច ៧:៣ **២០:១០** ឍ ចទ ២:២៦ លក ១៤:៣១-៣២ **២០:១១** ណ ខ.១៥ ២ពវ ៦:២២ ត ១ពវ ៩:២១ ១របា ២២:២ អស ៣១:៨ **២០:១៣** ថ ជន ៣១:៧ **២០:១៤** ទ យស ៨:២ ២២:៨

**១៩:១៥** មើលការពន្យល់ ១៧:៦ ។

**១៩:១៨** *ស្មរបន្ទាល់ក្លែងក្លាយ* សូមមើល ៥:២០ លវ ១៩:១១-១២ ១ពវ ២១:១០,១៣ ។

**១៩:១៩** *ឯងនឹងបំបាត់សេចក្តីអាក្រក់ពីពួកឯងចេញ* សូមមើលការពន្យល់ ១៣:៥ ។

**១៩:២១** *ជីវិតធួននឹងជីវិត* មើលការពន្យល់ នក ២១:២៣-២៥ លវ ២៤:២០ មើល មថ ៥:៣៨-៤២ ។

**២០:២** *សង្ឃចូលមកនិយាយ* ពួកសង្ឃពេលខ្លះបានហែរហមជាមួយនឹងកងទ័ពពេលដែលពួកគេចូលទៅសមរភូមិប្រយុទ្ធ ។(មើល ឧទាហរណ៍ យស ៦:៤-២១ ២របា ២០:៤-២២) ។

**២០:៣** *ចូរស្តាប់ ពួកអ៊ីស្រាអែលអើយ* មើលការពន្យល់ ៤:១ ។

**២០:៤** មើលការពន្យល់ ៣:២២ ។

**២០:៥-៨** ប្រៀបធៀបនឹងបណ្តាសាក្នុង ២៨:៣០ ។ *ចូរឱ្យអ្នកនោះត្រឡប់ទៅផ្ទះវិញចុះ* ប្រជាជនអ៊ីស្រាអែលមិនបានទុកចិត្ត លើកម្លាំងទ័ពរបស់ខ្លួន តែគេទុកចិត្តលើព្រះយេហូវ៉ាវិញ (២សយ ២៤:១ ទដ ៣០:៦-៧) ចំនួននៃការរួច ខ្លួនពីភារកិច្ចកងទ័ពមានភាពច្រើនសន្ធឹក(មើល ពច ៧:២-៨) ។

**២០:១០-១៥** វគ្គនេះជាច្បាប់ដែលទាក់ទងនឹងសង្គ្រាមប្រឆាំង ជាតិសាសន៍នៅខាងក្រៅទឹកដីសន្យា ។

**២០:១១** *បានចំណុះ ហើយបំរើឯង* ការសម្រេចទំនាយបណ្តាសារក្នុងជិនាន់លោកណូអេលើពួកកាណាន (មើល លប ៩:២៥ និងការពន្យល់) ។

ហើយត្រូវបរិភោគរបឹបរបស់ពួកខ្មាំងសត្រូវ ដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់បានប្រទានមកចុះ [១៥]ត្រូវឱ្យធ្វើ
យ៉ាងដូច្នោះ ដល់គ្រប់ទាំងទីក្រុងដែលនៅឆ្ងាយៗពីឯង[ប]
ដែលមិនមែនជាទីក្រុងរបស់ពួកសាសន៍ទាំងនេះទេ [១៦]តែឯ
អស់ទាំងទីក្រុងរបស់សាសន៍ទាំងនេះ ដែលព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់ប្រទានមកទុកជាមរដក នោះមិនត្រូវទុក
អ្វីដែលមានដង្ហើមឱ្យនៅរស់ឡើយ[ផ] [១៧]ត្រូវឱ្យបំផ្លាញគេ
ឱ្យអស់រលីងវិញ គឺជាសាសន៍ហេត សាសន៍អាម៉ូរី សាសន៍
កាណាន សាសន៍ពេរិស៊ីត សាសន៍ហេវី និងសាសន៍យេប៊ូស
ដូចជាព្រះ យេហូវ៉ា ជាព្រះនៃឯង បានបង្គាប់មក [១៨]ដើម្បី
កុំឱ្យគេបង្ហាត់បង្រៀន ឱ្យឯងប្រព្រឹត្តតាមគ្រប់ទាំងសេចក្ដី
គួរស្អប់ខ្ពើម ដែលគេបានប្រព្រឹត្តដល់ព្រះរបស់គេឡើយ[ព]
បើប្រព្រឹត្តយ៉ាងដូច្នោះ នោះនឹងឈ្មោះថា ឯងរាល់គ្នាបាន
ធ្វើបាប[ភ]នឹងព្រះយេហូវ៉ា ជាព្រះនៃឯងហើយ ។
[១៩]កាលណាឯងឡោមព័ទ្ធទីក្រុងណាជាយូរ ដោយច្បាំង
ដណ្ដើមយក នោះមិនត្រូវកាប់រំលំដើមឈើឡើយ ដ្បិតនឹង
បរិភោគផ្លែឈើនោះបាន ដូច្នេះមិនត្រូវឱ្យកាប់ឡើយ ដ្បិត
តើដើមឈើនៅវាលជាមនុស្សឬអី បានជាត្រូវឱ្យឯងច្បាំង
នឹងវាដែរដូច្នេះ [២០]មានច្បាប់កាប់តែដើមឈើណា ដែល
ដឹងថាបរិភោគផ្លែមិនបានប៉ុណ្ណោះ ត្រូវឱ្យកាប់ដើមឈើ
ទាំងនោះ[ម] យកទៅធ្វើជារបាំងទាស់នឹងទីក្រុងដែលច្បាំង
នឹងឯង ដរាបដល់គេទទួលចុះចាញ់ ។

**២១** [១]បើសិនជាឃើញមានខ្មោចចង្រ្កាង នៅទីវាលក្នុង
ស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានឱ្យចាប់
យក ហើយគ្មានអ្នកណាដឹងជាអ្នកណាបានសំឡាប់ឡើយ[ក]
[២]នោះត្រូវឱ្យពួកចាស់ទុំ និងពួកចៅក្រមរបស់ឯងចេញទៅ
វាស់ចាប់ពីខ្មោចនោះ ទៅដល់ទីក្រុងទាំងប៉ុន្មានដែលនៅជុំ
វិញ [៣]រួចទីក្រុងណាដែលឃើញថា នៅជិតខ្មោចនោះជា
ជាងគេ ត្រូវឱ្យពួកចាស់ទុំនៃក្រុងនោះយកគោស្ទាវ១ ដែល
មិនទាន់បានប្រើការ ឬទឹមនៅឡើយ[ខ] [៤]ដឹកចុះក្នុងទៅក្នុង
ច្រកភ្នំ១ ដែលមានទឹកហូរ ជាកន្លែងមិនដែលភ្ជួររាស់
ឬសាបព្រោះឡើយ ហើយត្រូវបំបាក់កគោនៅត្រង់ច្រក
នោះទៅ [៥]រួចពួកលេវីដ៏ជាសង្ឃត្រូវចូលទៅជិត ដ្បិតគឺអ្នក
ទាំងនោះហើយ ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់បាន
រើសសំរាប់នឹងបំរើទ្រង់ ព្រមទាំងឱ្យពរ[គ]ដោយនូវព្រះ
នាមព្រះយេហូវ៉ា ហើយគ្រប់ទាំងការទាស់ទែងគ្នា និង
របួសទាំងប៉ុន្មាន[ឃ]នោះស្រេចនៅអ្នកទាំងនោះកាត់ឱ្យចុះ
[៦]នោះពួកចាស់ទុំគ្រប់គ្នារបស់ទីក្រុងណាមួយ ដែលជិត
ខ្មោចនោះជាជាងគេ ត្រូវលាងដៃ[ង]ពីលើគោស្ទាវ ដែល
បានបំបាក់កនៅក្នុងច្រកនោះ [៧]ហើយត្រូវថា ដៃយើងខ្ញុំ
រាល់គ្នាមិនបានកំចាយឈាមនេះទេ ហើយភ្នែកយើងខ្ញុំ
ក៏មិនបានឃើញដែរ [៨]ឱព្រះយេហូវ៉ាអើយ សូមអត់ទោស
ដល់អ៊ីស្រាអែល ជារាស្ត្រទ្រង់ ដែលទ្រង់បានលោះផង
សូមកុំឱ្យមានទោសចំពោះឈាមរបស់មនុស្ស ដែលឥត
ទោស បាននៅជាប់កណ្ដាលពួកអ៊ីស្រាអែល ជារាស្ត្រទ្រង់
ឡើយ យ៉ាងនោះទោសពីការកំចាយឈាមនឹងបានអត់ឱ្យ
ហើយ[ច] [៩]ដូច្នេះឯងនឹងបានបំបាត់[ឆ]ការកំចាយឈាម ដែល
ឥតមានទោសពីពួកឯងចេញ ដោយធ្វើការដែលត្រឹមត្រូវ
នៅព្រះនេត្រព្រះយេហូវ៉ា ។

**ការរៀបការជាមួយស្ត្រីជាឈ្លើយ**

[១០]បើកាលណាឯងចេញទៅច្បាំងនឹងពួកខ្មាំងសត្រូវ
ហើយព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រគល់គេមកក្នុង
កណ្ដាប់ដៃឯង[ជ] ឯងក៏បានចាប់គេនាំទៅជាឈ្លើយហើយ[ឈ]
[១១]រួចឃើញមានស្រីណាមានរូបស្រស់ល្អ[ញ] នៅក្នុងពួក
ឈ្លើយនោះ ហើយឯងមានចិត្តប្រតិព័ទ្ធ[ដ] ចង់យកធ្វើជា
ប្រពន្ធ [១២]នោះត្រូវនាំនាងទៅឯផ្ទះឯង ឱ្យនាងកោរសក់[ឋ]
ហើយកាត់ក្រចក [១៣]ព្រមទាំងដោះអាវដែលពាក់ពីកាល
ចាប់បាននោះចេញ រួចត្រូវឱ្យនាងនៅក្នុងផ្ទះឯង ដោយយំ
សោកនឹងឪពុកម្ដាយអស់១ខែគត់[ឌ] ក្រោយនោះមក សឹមឯង
ចូលទៅឯនាង យកគ្នាជាប្ដីប្រពន្ធចុះ [១៤]លុះក្រោយទៅ

ធ ជន ៣១:១១ ន ជន ៣១:៥៣ **២០:១៥** ប ខ.១១ យស ៩:៩ **២០:១៦** ផ នក ២៣:៣១–៣៣ ជន ២១:២–៣ ចទ ៧:២ យស ៦:២១ ១០:១ ១១:១៤ **២០:១៨** ព នក ៣៤:១៦ ភ នក ១០:៧ **២០:២០** ម យរ ៦:៦ **២១:១** ក ជន ២៥:១៧ **២១:៣** ខ ជន ១៩:២ **២១:៥** គ លប ៤៨:២០ នក ៣៩:៤៣ ឃ ចទ ១៧:៨–១១ **២១:៦** ង មថ ២៧:២៤ **២១:៨** ច ជន ៣៥:៣៣–៣៤ **២១:៩** ឆ ចទ ១៩:១៣ **២១:១០** ជ យស ២១:៤៤ ឈ ១ពវ ៨:៤៦ ១របា ៩:១ អរ ៥:១២ យរ ៤០:១ អគ ១:១ ១៧:១២ ដយ ២:២៥ មីក ៤:១០ **២១:១១** ញ លប ៦:២ ដ លប ៣៤:៨ **២១:១២** ឋ លវ ១៤:៩ ជន ៨:៧ ១កថ ១១:៥ **២១:១៣** ឌ ទដ ៤៥:១០

**២០:១៧** *សាសន៍ហេត . . . សាសន៍យេប៊ូស* មើល ៧:១ និងការពន្យល់នៅគម្ពីរ លប ១០:៦,១៥–១៨ ១៣:១៧ យស ៩:៧ ។

**២០:១៩** *មិនត្រូវកាប់រំលំដើមឈើឡើយ* ភាពបរាជ័យចំពោះកងទ័ពក្រោយៗមកទៀតក្នុងការធ្វើតាមនៃច្បាប់របស់ពួកគេ ហើយជួបប្រទះនឹងភាពហិនហោចព្រៃឈើអស់ ។

**២១:៥** *សំរាប់នឹងបំរើ* គឺការធ្វើជាអធិបតីនៅទីថ្វាយបង្គំព្រះ គឺពីខាងមុខព្រះភ័ក្ត្រទ្រង់(មើល ១០:៨ ១៨:៥) ។ *ព្រមទាំងឱ្យពរ* មើល នក ៦:២២–២៧ ។

**២១:៦** *លាងដៃ* ជានិមិត្តសញ្ញាដែលបង្ហាញប្រាប់ពីការគ្មាន ឬរួចពីបាប (ខ.៧ មថ ២៧:២៤) ។

**២១:១០** *បានចាប់ . . . ជាឈ្លើយ* សត្រូវនៅខនេះ គឺចាប់មកពីក្រៅសាសន៍កាណាន(មើល ២០:១៤–១៥,១៧) ។

**២១:១២** *ឱ្យនាងកោរសក់* គឺជាការបញ្ជាក់ប្រាប់ថា នាងត្រូវលាចាកចេញពីជីវិតចាស់របស់នាងមុន ហើយចាប់ផ្ដើមជីវិតថ្មីមួយវិញ ឬជាទស្សនៈបញ្ជាក់ពីការកាន់ទុក្ខ(ខ.១៣ មើល យរ ៤៧:៥ មីក ១:១៦) ឬក៏ជាភាពនៃការបំបាក់មុខ (មើលការពន្យល់ អស ៧:២០) គឺដើម្បីសម្អាតអំពើបាប (លវ ១៤:៨ ២សយ ១៩:២៤) ។

បើមិនចូលចិត្តនឹងនាងវិញ នោះត្រូវបើកឱ្យទៅតាមតែចិត្ត
មិនត្រូវលក់នាង ឬប្រព្រឹត្តនឹងនាងទុកដូចជាបាវបំរើឡើយ
ដ្បិតឯងបានបន្ទាបនាងហើយ[ល]។

### សិទ្ធិរបស់កូនច្បង

១៥បើសិនជាមានអ្នកណាមានប្រពន្ធ២[ឃ] មួយជាទីស្រឡាញ់
ហើយមួយស្អប់វិញ តែទាំង២បានបង្កើតកូនដោយសារ
អ្នកនោះ ហើយកូនច្បងបង្អស់ជាកូនរបស់នាងដែលស្អប់[ង]
១៦ដូច្នោះ នៅថ្ងៃណាដែលចែកមរដកដល់កូន នោះមិន
ត្រូវឱ្យលើកកូនរបស់នាងដែលជាទីស្រឡាញ់ទុកជាកូន
ច្បងជំនួសកូននាង១ជាទីស្អប់ ដែលជាកូនច្បងពិតមែន
នោះឡើយ[ច] ១៧គឺត្រូវទទួលរាប់កូនរបស់នាង ដែលខ្លួន
ស្អប់នោះ ទុកជាកូនច្បងពិត ដោយចែកទ្រព្យសម្បត្តិដល់វា
ឱ្យលើស១ជា២[ទ] ដ្បិតកូននោះជាកូនដំបូងរបស់ខ្លួន[ធ]
អំណាចច្បាប់របស់កូនច្បងត្រូវបានជារបស់ផងវា[ន] ។

### កូនដែលចចេសរឹងរូស

១៨បើអ្នកណាមានកូន[ប]ដែលចចេសរឹងរូស[ផ] មិនព្រមចុះ
ចូលស្តាប់តាមបង្គាប់ឪពុកម្តាយសោះ[ព] ហើយទោះបើឪពុក
ម្តាយវាយស្តីប្រដៅ គង់តែវាមិនចេះរាងចាលដែរ ១៩នោះ
ត្រូវឱ្យឪពុកម្តាយនាំយកទៅ ឯពួកចាស់ទុំនៃទីក្រុងនោះ
នៅត្រង់ទ្វារក្រុងរបស់គេ ២០រួចត្រូវជំរាបដល់ពួកចាស់ទុំ
នៃក្រុងនោះថា កូនយើងខ្ញុំនេះវាចចេស ហើយរឹងរូស មិន
ព្រមស្តាប់បង្គាប់យើងខ្ញុំសោះ វាក៏ល្មោភស៊ីផឹក ហើយ
ស្រវឹងខ្លួបផង ២១នោះត្រូវឱ្យបណ្តាមនុស្សនៅទីក្រុងនោះ
ទាំងប៉ុន្មាន ចោលសំឡាប់វានឹងថ្មទៅ[ភ] យ៉ាងនោះឯងរាល់
គ្នានឹងបំបាត់ការអាក្រក់[ម] ពីពួកឯងចេញ រួចសាសន៍អ៊ីស្រា

**២១:១៤** ល លប ៣៤:២
**២១:១៥** ឃ លប ៤:១៩ ង លប ២៩:៣៣
**២១:១៦** ច ១រប ២៦:១០
**២១:១៧** ទ ២ពវ ២:៩ អស ៤០:២ ៦១:៧ សក ៩:១២ ធ លប ៤៩:៣ ន លប ២៥:៣១ លក ១៥:១២
**២១:១៨** ប ទជ ៣៨:៨ យរ ៥:២៣ សផ ៣:១ ផ សភ ៣០:១៧ ព លប ៣១:៣៥ សភ ១:៨ អស ៣០:១ អភ ៦:១-៣
**២១:២១** ភ លវ ២០:៩ ម ចទ ១៩:១៩ ១កថ ៥:១៣ យ ចទ ១៣:១១
**២១:២២** រ ចទ ២២:២៦ មថ ២៦:៦៦ មក ១៤:៦៤ កច ២៣:២៩
**២១:២៣** ល យស ៨:២៩ ១០:២៧ យហ ១៩:៣១ វ អគ ៣៩:១២ ស ហ
**២២:១** ក នក

អែលទាំងអស់គ្នានឹងបានឮ ហើយនិងមានសេចក្តីកោត
ខ្លាចផង[យ]។
២២បើមានអ្នកណាបានប្រព្រឹត្តអំពើបាប ដែលគួរឱ្យគេ
ស្លាប់[រ] ហើយឯងសំឡាប់ទៅ ដោយព្យួរនៅលើឈើ
២៣នោះមិនត្រូវឱ្យខ្មោចគេ ជាប់នៅលើឈើ រហូតដល់ភ្លឺ
ឡើយ[ល] ត្រូវឱ្យកប់[វ]ទៅនៅថ្ងៃនោះឯងជាកុំខាន ដ្បិតអ្នក
ណាដែលត្រូវព្យួរ នោះជាអ្នកដែលត្រូវព្រះដាក់បណ្តាសា
ហើយ ត្រូវធ្វើយ៉ាងនោះដើម្បីកុំឱ្យ[ហ]ស្រុកដែលព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់ប្រទានមក ទុកជាមរដក បានត្រូវស្មោក
គ្រោកឡើយ ។

**២២** ១បើឯងឃើញគោ ឬចៀមរបស់បងប្អូនវង្វេង នោះ
មិនត្រូវឱ្យគេចចេញឡើយ ត្រូវឱ្យដឹកនាំទៅឯម្ចាស់វិញជា
កុំខាន[ក] ២បើបងប្អូននោះនៅឆ្ងាយពីឯង ឬជាអ្នកដែលឯង
មិនស្គាល់សោះ នោះត្រូវដឹកនាំសត្វទៅឯផ្ទះឯង ទុកចាំ
ទាល់តែគេមករក រួចសឹមប្រគល់ដល់គេវិញ ៣ត្រូវឱ្យឯង
ប្រព្រឹត្តដូច្នោះចំពោះសត្វលា និងសំលៀកបំពាក់ ហើយនិង
គ្រប់របស់ទាំងអស់ ដែលបងប្អូនឯងបានបាត់ ហើយឯង
បានឃើញនោះដែរ មិនត្រូវឱ្យគេចចេញឡើយ ៤ឬបើ
ឃើញលា[ខ] ឬគោរបស់បងប្អូន ដែលដួលតាមផ្លូវនោះ
ក៏មិនត្រូវឱ្យឯងគេចចេញពីគេដែរ គឺត្រូវតែជួយលើកសត្វ
នោះឡើងវិញជាកុំខាន[គ]។
៥រីឯពួកស្ត្រី មិនត្រូវឱ្យគេស្លៀកពាក់ប្រដាប់របស់បុរស
ឡើយ ហើយបុរសក៏មិនត្រូវស្លៀកពាក់ប្រដាប់របស់ស្ត្រី

២៣:៤-៥ សភ ២៧:១០ សក ៧:៩ **២២:៤** ខ នក ២៣:៥ គ ១កថ ៩:៩

**២១:១៤** *បន្ទាប* មានពាក្យនេះ ១២ដងទៀតបើភាសាហេព្រើរវិញពាក្យនេះ គឺពួកប្រុសៗប្រើសម្រាប់បង្ខំស្ត្រីៗឱ្យរួមរក្សជាមួយខ្លួន គឺជាការបន្ថោកនាង (២២:២៤,២៩ លប ៣៤:២ ពច ១៩:២៤ ២០:៥) ។

**២១:១៥** *ប្រពន្ធ២* មើលការពន្យល់ លប ៤:១៩ ២៥:៦ ។

**២១:១៦** *ជាទីស្រឡាញ់* ធ្វើទៅតាមទំនៀមជាជាងការពេញចិត្តពីឪពុកម្តាយ លោកយ៉ាកុប និងស្តេចសាឡូម៉ូន ។

**២១:១៧** *ឱ្យលើស១ជា២* នៅប្រទេសអ៊ីស្រាអែលកូនប្រុសច្បងត្រូវទទួលមរដក១ជា២ក្នុងចំណោមមរដកទាំងអស់ ។ ការអនុវត្តន៍នេះគឺបានសាយភាយពីសម័យបាប៊ីឡូនចាស់ និងពីទម្លាប់របស់ពួកអាសស៊ើរ (មើល ១ពវ ២:៩ និងការពន្យល់) ។

**២១:១៨** *ដែលចចេសរឹងរូស មិនព្រមចុះចូលស្តាប់តាមបង្គាប់* គឺជាការរឹងរូសដ៏អាក្រក់ចំពោះបញ្ញត្តិទី៥ (មើល ៥:១៦ នក ២០:១២ និងការពន្យល់) ។

**២១:២១** *ចោលសំឡាប់វានឹងថ្ម* មើល ៥:១៦ ២៧:១៦ នក ២១:១៥,១៧ ។ *ឯងរាល់គ្នានឹងបំបាត់ការអាក្រក់ ពីពួកឯងចេញ* មើលការពន្យល់ ១៣:៥ ។

**២១:២២** *ឱ្យគេស្លាប់ . . . ដោយព្យួរនៅលើឈើ* គឺអ្នកប្រព្រឹត្តបទល្មើសគឺដំបូងត្រូវប្រហារជីវិតបន្ទាប់មកព្យួរលើឈើ (មើល លប ៤០:១៩) ។

**២១:២៣** *មិនត្រូវឱ្យខ្មោចគេ ជាប់នៅលើឈើ រហូតដល់ភ្លឺឡើយ* ការពន្យាពេលនេះនាំឱ្យមានភាពហួសហេតុ ចំពោះជនឧក្រិដ្ឋ ។ *ដែលត្រូវដាក់បណ្តាសា* ព្រះបានកាត់ទោសជនឧក្រិដ្ឋ ហើយព្យួរនៅលើដើមឈើជាបន្ទាល់ចំពោះការកាត់ទោសពីព្រះ ។ ព្រះគ្រីស្ទបានទទួលរាល់ទណ្ឌកម្មនៃអំពើបាប និងបណ្តាសារបស់យើងទាំងអស់គ្នា (កទ ៣:១៣) ។

**២២:១** *មិនត្រូវឱ្យគេចចេញ* មើល ខ.៣,៤ ។ តាមក្បួនច្បាប់ទេវសាស្ត្រគឺមិនគ្រាន់តែកាត់ទោសដល់ការប្រព្រឹត្តរបស់ឧក្រិដ្ឋជនប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវកាត់ទោសចំពោះមនុស្ស និងសម្បត្តិរបស់គេដែរ ។

**២២:៥** ខនេះបានហាមឃាត់ការរើកដុះដាល ដូចជាការតុបតែងខ្លួនផ្ទុយពីភេទខ្លួន និងការលេងកូនដឹងជាពិសេសសាសនាខុសឆ្គង ។ ព្រះបានបង្កើតឱ្យមានភាពខុសគ្នារវាងបុរស និងស្ត្រីមិនមែនមើលមិនយល់នោះទេ ។ (មើល លវ ១៨:២២ ២០:១៣) ។

ដែរ ដ្បិតអ្នកណាដែលប្រព្រឹត្តដូច្នោះ នោះជាទីស្អប់ខ្ពើម
ដល់ព្រះយេហូវ៉ា ជាព្រះនៃឯងណាស់ ។
[៦]បើកាលណាឯងប្រទះឃើញសំបុកសត្វ ដែលមានកូន
ឬមានពង នៅក្បែរផ្លូវ ទោះនៅលើដើមឈើណា ឬនៅ
លើដីក្តី ហើយមេកំពុងតែក្រាបនៅលើកូន ឬពីលើពង
នោះមិនត្រូវឱ្យឯងយកមេ ជាមួយនឹងកូនផងទេ[ឃ] [៧]គឺត្រូវ
ឱ្យឯងលែងមេទៅជាកុំខាន[ង] ឯកូននោះ ឯងនឹងយកបាន
ដូច្នេះឯងនឹងបានសប្បាយ ហើយបានជីវិតរស់នៅជាយូរ
អង្វែងតទៅ[ច] ។
[៨]កាលណាសង់ផ្ទះថ្មី នោះត្រូវឱ្យធ្វើបង្កាន់ដៃលើដំបូល
ដើម្បីកុំឱ្យមានអ្នកណាធ្លាក់ពីលើនោះទៅក្រោម នឹងនាំឱ្យ
មានទោសចំពោះឈាមគេលើផ្ទះឯងឡើយ[ឆ]។
[៩]មិនត្រូវឱ្យព្រោះពូជ២យ៉ាងខុសគ្នាចំរុះក្នុងចំការឯង
ឡើយ[ជ] ក្រែងផលទាំងអស់ត្រូវខូចខាតទៅ ព្រមទាំងពូជ
ដែលឯងបានព្រោះ និងផលចំរើននោះផង [១០]ក៏មិនត្រូវភ្ជួរ
ដោយទឹមគោជាមួយនឹងលាដែរ[ឈ] [១១]មិនត្រូវឱ្យឯងស្លៀក
ពាក់សំពត់ត្បាញលាយដោយរោមចៀម និងអំបោះខ្លូត
ទេសជាមួយគ្នាឡើយ[ញ]។
[១២]ត្រូវឱ្យឯងធ្វើរំយោល ភ្ជាប់ត្រង់ជាយទាំង៤នៃសំពត់
ដែលឯងស្លៀកផង[ដ]។

## ការបំពាននៅក្នុងអាពាហ៍ពិពាហ៍

[១៣]បើអ្នកណាយកប្រពន្ធ ហើយចូលទៅឯនាង[ឋ] រួចបែរ
ជាស្អប់វិញ [១៤]ហើយចាប់តាំងនិយាយកេរពីនាង ព្រមទាំង
នាំឱ្យនាងមានឈ្មោះអាក្រក់ ដោយពាក្យថា ខ្ញុំបានយកស្ត្រី
នេះ ហើយកាលបានចូលទៅឯវា នោះឃើញថា មិនបរិ
សុទ្ធទេ [១៥]នោះត្រូវឱ្យឪពុកម្តាយនាង នាំយកទីសំគាល់
ពីសេចក្តីបរិសុទ្ធរបស់នាង ទៅឯពួកចាស់ទុំនៃទីក្រុងត្រង់
មាត់ទ្វារក្រុង[ឌ] [១៦]រួចត្រូវឱ្យឪពុកនាងជំរាបដល់ពួកចាស់ទុំ
ថា ខ្ញុំបានឱ្យកូនខ្ញុំទៅធ្វើជាប្រពន្ធរបស់អ្នកនេះ តែគេបែរ
ជាស្អប់វិញ [១៧]ហើយមើល គេបាននិយាយបរិហារកេរពី
នាងថា មិនឃើញនាងបរិសុទ្ធទេ តែមើលមានទីសំគាល់
នេះពីសេចក្តីបរិសុទ្ធរបស់កូនខ្ញុំស្រាប់ នោះត្រូវលាសំពត់
នោះ នៅមុខពួកចាស់ទុំនៃទីក្រុង [១៨]រួចត្រូវឱ្យពួកចាស់ទុំ[ឍ]
នៃក្រុងនោះ ចាប់យកអ្នកនោះទៅវាយផ្ចាលចេញ [១៩]ហើយ
ត្រូវពិន័យលក់អ្នកនោះ១០០រៀល ឱ្យដល់ឪពុកនាង ដោយ
ព្រោះបាននាំបង្ខូចឈ្មោះនាងក្រមុំម្នាក់នៃសាសន៍អ៊ីស្រា
អែល រួចនាងនោះនឹងនៅជាប្រពន្ធរបស់អ្នកនោះតទៅ
គ្មានច្បាប់នឹងលែងនាងឡើយ រហូតដល់គ្រប់១ជីវិត [២០]តែ
បើការនោះពិតមែន[ណ] ហើយរកទីសំគាល់ពីសេចក្តីបរិសុទ្ធ
របស់នាងមិនបាន [២១]នោះត្រូវឱ្យគេនាំនាងចេញទៅឯ
មាត់ទ្វារផ្ទះឪពុក ហើយត្រូវឱ្យមនុស្សនៅក្រុងនោះចោល
សំឡាប់នឹងថ្មទៅ ដ្បិតនាងបានប្រព្រឹត្តការអាស្រូវបារាយ[ត]
ក្នុងពួកអ៊ីស្រាអែល ដោយបានធ្វើឱ្យខូចសេចក្តីបរិសុទ្ធ
កាលនៅក្នុងផ្ទះឪពុករបស់ខ្លួននៅឡើយ គឺយ៉ាងនោះដែល
ត្រូវបំបាត់ការអាក្រក់ពីពួកឯងចេញ ។
[២២]បើដែលឃើញអ្នកណាកំពុងតែរួមដំណេកនឹងស្ត្រី
ដែលមានប្តីហើយ នោះអ្នកទាំង២ត្រូវស្លាប់ គឺទាំងប្រុស
ដែលដេក[ថ]នឹងនាងព្រមទាំងនាងនោះផង[ទ] គឺយ៉ាងនោះ
ដែលឯងត្រូវបំបាត់សេចក្តីអាក្រក់ពីពួកអ៊ីស្រាអែលចេញ ។
[២៣]បើមានស្រីក្រមុំណា ដែលមានគេដណ្តឹងហើយ
ស្រាប់តែមានប្រុសណាប្រទះឃើញនាង នៅក្នុងទីក្រុង
ហើយចាប់យកទៅរួមដំណេកនឹងនាង [២៤]នោះត្រូវឱ្យឯង
រាល់គ្នានាំអ្នកទាំង២ ចេញទៅឯទ្វារក្រុង ចោលសំឡាប់
នឹងថ្មទៅ គឺនាងនោះ ដោយព្រោះនៅក្នុងទីក្រុង តែមិន
បានស្រែកសោះ ហើយមនុស្សប្រុសនោះ ដោយព្រោះបាន
បន្ទាបបន្ថោកប្រពន្ធរបស់អ្នកជិតខាងខ្លួន គឺយ៉ាងនោះដែល
ឯងត្រូវបំបាត់ការអាក្រក់ពីពួកឯងចេញ[ធ] [២៥]ប៉ុន្តែបើមនុស្ស
ប្រុសនោះ បានប្រទះឃើញនាង ដែលមានគេដណ្តឹងហើយ
នៅឯទីវាលវិញ រួចចាប់បង្ខំដេកនឹងនាងទៅ នោះត្រូវ
ស្លាប់តែខាងប្រុសដែលបានដេកនឹងនាងប៉ុណ្ណោះ [២៦]តែឯ
នាងនោះ មិនត្រូវឱ្យធ្វើទោសអ្វីឡើយ នាងគ្មានបាបណា
ដែលគួរឱ្យស្លាប់ទេ ដ្បិតដំណើរនេះបែបដូចជាកាលមនុស្ស
ណាមួយ ស្ទុះទៅសំឡាប់អ្នកជិតខាងខ្លួនដូច្នោះដែរ [២៧]ដ្បិត
ប្រុសនោះឃើញនាងនៅឯទីវាល ហើយនាងដែលមានគេ
ដណ្តឹងបានស្រែកឡើង[ន]ដែរ តែគ្មានអ្នកណានឹងជួយសោះ ។

**២២:៦** ឃ លវ ២២:២៨ **២២:៧** ង លវ ២២:២៨ ច ចទ ៥:២៩ **២២:៨** ឆ យស ២:៨ ១សយ ៩:២៥ ២សយ ១១:២ **២២:៩** ជ លវ ១៩:១៩ **២២:១០** ឈ ២កថ ៦:១៤ **២២:១១** ញ លវ ១៩:១៩ **២២:១២** ដ ជន ១៥:៣៧,៤១ មថ ២៣:៥ **២២:១៣** ឋ ចទ ២៤:១ **២២:១៥** ឌ លប ២៣:១០ **២២:១៨** ឍ នក ១៨:២១ ចទ ១:៩–៨ **២២:២០** ណ ចទ ១៧:៤ **២២:២១** ត លប ៣៤:៧ ៣៨:២៤ លវ ១៩:២៩ ចទ ២៣:១៧–១៨ ១កថ ៥:១៣ **២២:២២** ថ ២សយ ១១:៤ ទ លប ៣៨:២៤ នក ២១:១២ មថ ៥:២៧–២៨ យហ ៨:៥ ១កថ ៦:៩ ហព ១៣:៤ **២២:២៤** ធ ១កថ ៥:១៣ **២២:២៧** ន លប ៣៩:១៤

**២២:៩–១១** មើលការពន្យល់ លវ ១៩:១៩ ។
**២២:១២** *រំយោល* មើលការពន្យល់ ជន ១៥:៣៨ ។
**២២:១៥** *ពួកចាស់ទុំ . . . ត្រង់មាត់ទ្វារក្រុង* មើល ២១:១៩ ២៥:៧ និងមើលការពន្យល់ លប ១៩:១ នក ៤:១ ។
**២២:១៩** *១០០រៀល* គឺជាការផាកពិន័យយ៉ាងធ្ងន់ធ្ងរ គឺជាប្រាក់ដែលលោកម៉ូសេអាចចាយច្រើនក្នុងការទិញស្រូវឱកបានច្រើនណាស់ ហស ៣:២ (យរ ៣២:៩)ក៏ជាតម្លៃលើសតម្លៃកូនក្រមុំពីរដង (មើល ខ.២៩) ។
**២២:២១–២៤** *ត្រូវបំបាត់ការអាក្រក់ពីពួកឯងចេញ* មើល ខ.២២ និងមើលការពន្យល់ ១៣:១០ ។
**២២:២២** មើល លវ ២០:១០ ។

២៨បើមនុស្សប្រុសណាប្រទះឃើញស្រីក្រមុំ ដែលឥត
មានអ្នកណាដណ្ដឹងនៅឡើយ ហើយក៏ចាប់យកទៅរួម
ដំណេក រួចមានគេឃើញ[ប] ២៩នោះអ្នកដែលបានដេក នឹង
នាងត្រូវបង់៥០រៀល ឱ្យដល់ឪពុកនាង រួចនាងនឹងធ្វើជា
ប្រពន្ធតទៅ ពីព្រោះអ្នកនោះបានបន្ទាបបន្ថោកនាងហើយ
គ្មានច្បាប់នឹងលែងនាងឡើយ រហូតដល់គ្រប់១ជីវិត ។
៣០មិនត្រូវឱ្យមនុស្សណាយកប្រពន្ធ របស់ឪពុកខ្លួនឡើយ
ក៏មិនត្រូវបើកសំលៀករបស់ឪពុកខ្លួនដែរ[ផ]។

## ការកាត់ចេញពីពួកជំនុំ

**២៣** ១ឯអ្នកណាដែលត្រូវរបួស[ក]ត្រង់ពង ឬកាត់ស្វាស
ចេញ នោះមិនត្រូវចូលទៅក្នុងពួកជំនុំនៃព្រះយេហូវ៉ា
ឡើយ ២ហើយមិនត្រូវឱ្យកូនសហាយណា ចូលទៅក្នុងពួក
ជំនុំនៃព្រះយេហូវ៉ាដែរ ព្រមទាំងកូនចៅគេរហូតដល់១០
ដំណាផង ។
៣សាសន៍អាំម៉ូន[ខ] ឬសាសន៍ម៉ូអាប់ មិនត្រូវចូលទៅក្នុង
ពួកជំនុំនៃព្រះយេហូវ៉ាឡើយ ព្រមទាំងកូនចៅគេរហូតដល់
១០ដំណាផង[គ] ៤ពីព្រោះកាលឯងរាល់គ្នាចេញពីស្រុកអេស៊ីព្ទ
មក នោះគេមិនបានយកអាហារ និងទឹកមកទទួលឯងតាម
ផ្លូវទេ[ឃ] ហើយគេបានជួលបាឡាម[ង] ជាកូនបេអរមកពី
ពេថោរ នៅស្រុកអើរ៉ាម–ណាហារេម[ច] ដើម្បីនឹងដាក់
បណ្ដាសាដល់ឯង[ឆ] ៥ប៉ុន្តែព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់
មិនព្រមស្ដាប់តាមបាឡាមទេ គឺទ្រង់បានផ្លាស់សេចក្ដី
បណ្ដាសានោះ[ជ] ឱ្យទៅជាពរដល់ឯងវិញ ដ្បិតទ្រង់បាន
ស្រឡាញ់[ឈ]ឯង ៦ដូច្នេះមិនត្រូវឱ្យឯងរកសេចក្ដីសុខ[ញ]ឱ្យគេ
ឬឱ្យគេចំរើនឡើងឡើយ នៅជារៀងរាបតទៅ[ដ]។
៧មិនត្រូវឱ្យស្អប់ខ្ពើម ដល់សាសន៍អេដំម[ឋ]ណាមួយឡើយ
ដ្បិតគេជាបងប្អូននឹងឯង[ឌ] ក៏មិនត្រូវស្អប់ខ្ពើមដល់សាសន៍
អេស៊ីព្ទដែរ ដ្បិតពីដើម ឯងជាពួកប្រទេសក្រៅដែលស្នាក់
នៅស្រុកគេ[ឍ] ៨ឯចៅទួតដែលកើតពីពូជគេនោះនឹងចូលទៅ
ក្នុងពួកជំនុំនៃព្រះយេហូវ៉ាបាន ។

## ការមិនស្អាតនៅក្នុងទីដំឡើងត្រសាល

៩កាលណាឯងទៅបោះទ័ព ទាស់នឹងពួកខ្មាំងសត្រូវ
នោះត្រូវឱ្យរក្សាខ្លួនពីគ្រប់ទាំងសេចក្ដីអាក្រក់[ណ] ១០បើសិន
ជាមានមនុស្សណាក្នុងពួកឯងដែលមិនស្អាត ដោយព្រោះ
ការអ្វីដែលលោតែកើតដល់ខ្លួន នៅពេលយប់ ត្រូវឱ្យអ្នក
នោះចេញទៅក្រៅ មិនត្រូវចូលមកក្នុងទីដំឡើងត្រសាល
ទេ[ត] ១១តែដល់ពេលល្ងាច អ្នកនោះត្រូវងូតទឹកចេញ រួច
កាលណាថ្ងៃលិចហើយ[ថ] នោះនឹងចូលទៅក្នុងទីដំឡើង
ត្រសាលវិញបាន[ទ] ១២ត្រូវឱ្យមានកន្លែងមួយនៅខាងក្រៅទី
ដំឡើងត្រសាល ជាទីសំរាប់នឹងចេញទៅដោះទុក្ខសត្វ
១៣ហើយត្រូវឱ្យមានចបជីក នៅជាមួយនឹងគ្រឿងសស្ត្រាវុធ
របស់ឯងផង ដើម្បីកាលណាឯងចេញទៅបត់ជើង នោះ
នឹងជីកទៅកប់លុបលាមកឯងទៅ ១៤ដ្បិតព្រះយេហូវ៉ាជា
ព្រះនៃឯង ទ្រង់យាង[ធ]នៅកណ្ដាលទីដំឡើងត្រសាលរបស់
ឯង ដើម្បីនឹងជួយសង្គ្រោះឯង ហើយនឹងប្រគល់ពួកខ្មាំង
សត្រូវមកឯង ដូច្នេះទីដំឡើងត្រសាលរបស់ឯងត្រូវតែ
បរិសុទ្ធ[ន] ដើម្បីកុំឱ្យទ្រង់ទតឃើញអ្វីស្មោកគ្រោក នៅក្នុងពួក
ឯង រួចបែរចេញពីឯងទៅនោះឡើយ ។

## ច្បាប់ផ្សេងៗទៀត

១៥ឯបាវបំរើណា ដែលបានរត់រួចពីចៅហ្វាយខ្លួនមក
ពឹងជ្រក[ប]នឹងឯង នោះមិនត្រូវប្រគល់ទៅចៅហ្វាយវិញ
ឡើយ[ផ] ១៦ត្រូវបើកឱ្យនៅជាមួយនឹងឯង នៅកណ្ដាលពួក
ឯង ក្នុងទីក្រុងណាមួយ ដែលអ្នកនោះជ្រើសរើស តាម
បំណងចិត្តចុះ មិនត្រូវឱ្យសង្កត់សង្កិន[ព]គេឡើយ ។

**២២:២៨** ប នក ២២:១៦ **២២:៣០** ផ លប ២៩:២៩ លវ ១៨:៨ ២០:៩ ១កថ ៥:១ **២៣:១** ក លវ ២១:២០ **២៣:៣** ខ លប ១៩:៣៨ គ ខ.៤ នហ ១៣:២ **២៣:៤** ឃ ចទ ២:២៨ ង ជន ២៣:៧ ២ពត ២:១៥ ច លប ២៤:១០ ឆ ខ.៣ **២៣:៥** ជ ជន ២៤:១០ យស ២៤:១០ សភ ២៦:២ ឈ ចទ ៤:៣៧ **២៣:៦** ញ ជន ២៤:១៧ អស ១៥:១ ២៥:១០ យរ ២៥:២១ ២៧:៣ ៤៨:១ អក ២៥:៨ សផ ២:៩ ដ អរ ៩:១២ មថ ៥:៤៣ **២៣:៧** ឋ លប ២៥:៣០ ឌ លប ២៥:២៦ ឍ លវ ១៩:៣៤ **២៣:៩** ណ លវ ១៥:១–៣៣ **២៣:១០** ត លវ ១៥:១៦ **២៣:១១** ថ លវ ១៥:១៦ ទ ១សយ ២១:៥ **២៣:១៤** ធ លប ៣:៨ ន នក ៣:៥ **២៣:១៥** ប ២សយ ២២:៣ ទដ ២:១២ ៧១:១ ផ ១សយ ៣០:១៥ **២៣:១៦** ព នក ២២:២១ ២៣:៦

**២២:២៩** *ត្រូវបង់៥០រៀល* គឺជាតម្លៃដែលស្មើនិងកូនក្រមុំមួយ (មើលការពន្យល់ នក ២២:១៦) ។

**២២:៣០** *ប្រពន្ធរបស់ឪពុកខ្លួន* យោងទៅលើប្រពន្ធអ្នកដទៃជាងម្ដាយរបស់គាត់(សូមមើល ២៧:២០) ។ *មិនត្រូវបើកសំលៀករបស់ឪពុកខ្លួដែរ* (មើលការប្រៀបធៀបនិង ៣:៩ អក ១៦:៨)។

**២៣:១** ប្រទានពរដល់មនុស្សកំរៀវក្នុងគ្រាក្រោយនោះ មើល អស ៥៦:៤–៥ កថ ៨:២៦–៣៩ ។

**២៣:២–៣** *ព្រមទាំងកូនចៅគេរហូតដល់១០ដំណាផង* គឺជាពាក្យអាចមានន័យថា ជារៀងរហូតទៅ ។ ខ.៦ គឺបញ្ជាក់ពីរយះពេលដែលឱ្យមានជីវិត ។

**២៣:៤** *បាឡាមជាកូនបេអរ* មើល ជន ២២:៤–២៤:២៥ និងការពន្យល់ ។

**២៣:៦** សូមមើលការប្រកាសបដិសេធរបស់ហោរា ឯទីរហោស្ថានម៉ូអាប់ និងនៅស្រុកអាំម៉ូន(អស ១៥–១៦ យរ ៤៨:១–៤៩:៦ អស ២៥:១–១១) ។

**២៣:៧** *សាសន៍អេដំម . . . ជាបងប្អូននឹងឯង* សាសន៍អេដំម ជាការកាត់ទោសចំពោះអំពើរំលងរបស់ពួកគេ ដែលធ្វើទុកដល់បងប្រុសយ៉ាកុប (អ៊ីស្រាអែល មើល អម ១:១១ និងការពន្យល់ លប ២៥:២២,២៦) ។

**២៣:៩–១៤** ច្បាប់នៃភាពស្អាតបាត ចំពោះបន្ទាយទាហាននៃប្រជាជនអ៊ីស្រាអែល ។ ជាច្បាប់ធម្មតាសម្រាប់មនុស្សធម្មតា (សូមមើល លវ ១៥ និងការពន្យល់) ។

**២៣:១៤** *ត្រសាលរបស់ឯងត្រូវតែបរិសុទ្ធ* សូម្បីតែព្រះយេហូវ៉ាក៏ទ្រង់បរិសុទ្ធដែរ(មើល លវ ១១:៤៤ និងការពន្យល់) ។

**២៣:១៥** *ឯបាវបំរើណាដែលបានរត់រួច* អ្នកបម្រើក្រៅស្រុក(សាសន៍ដទៃ) ស្វែងរកសេរីភាពក្នុងស្រុកអ៊ីស្រាអែល ។

១៧មិនត្រូវឱ្យមានស្រីសំផឹងណាមួយ ក្នុងពួកកូនស្រី
សាសន៍អ៊ីស្រាអែលឡើយ ក៏មិនត្រូវមានប្រុស[ភ]ណាមួយធ្វើ
ជាកូនជឹង[ម] នៅក្នុងពួកកូនប្រុសសាសន៍អ៊ីស្រាអែលដែរ
១៨មិនត្រូវឱ្យយកថ្លៃឈ្នួលរបស់ការធ្វើសំផឹង ឬថ្លៃឆ្កែមក
ក្នុងដំណាក់ព្រះយេហូវ៉ា ជាព្រះនៃឯង ដើម្បីនឹងថ្វាយ ជា
ដង្វាយលាបំណន់ឡើយ ដ្បិតទាំង២មុខនេះជាសេចក្តីស្អប់
ខ្ពើមដល់ព្រះយេហូវ៉ា ជាព្រះនៃឯង[យ]។
១៩មិនត្រូវឱ្យឯងឱ្យបងប្អូនខ្ចីដោយយកការ ទោះជាខ្ចី
ប្រាក់ ឬស្បៀងអាហារ ឬរបស់អ្វីដែលគេតែងឱ្យខ្ចីដោយ
យកការវិញនោះឡើយ[រ] ២០ឯងនឹងឱ្យអ្នកប្រទេសដទៃខ្ចី[ល]
ដោយយកការបាន តែមិនត្រូវឱ្យបងប្អូនឯងខ្ចីដោយយក
ការឡើយ ដើម្បីឱ្យព្រះយេហូវ៉ា ជាព្រះនៃឯង បានប្រទាន
ពរ[វ]ដល់ឯង ក្នុងគ្រប់ទាំងការដែលឯងដាក់ដៃធ្វើ នៅក្នុង
ស្រុកដែលឯងនឹងចូលទៅចាប់យកនោះ។
២១កាលណាឯងបន់ដល់ព្រះយេហូវ៉ា ជាព្រះនៃឯងនោះ
មិនត្រូវបង្អង់នឹងលាបំណន់នោះទេ[ស] ដ្បិតព្រះយេហូវ៉ា ជា
ព្រះនៃឯង ទ្រង់នឹងទារពីឯងវិញជាមិនខាន យ៉ាងនោះ នឹង
បានរាប់ជាបាបដល់ឯង[ហ] ២២តែបើឯងមិនដែលបន់បំណន់
ទេ នោះគ្មានបាបឡើយ[ឡ] ២៣សេចក្តីណាដែលចេញពីបបូរ
មាត់ឯង នោះត្រូវប្រយ័ត្ននឹងធ្វើតាមគ្រប់ជំពូក គឺឱ្យត្រូវនឹង
បំណន់ ដែលឯងបានបន់ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ជា
ដង្វាយថ្វាយស្ម័គ្រពីចិត្ត ដែលមាត់ឯងបានសន្យាហើយ ។
២៤កាលណាឯងចូលទៅ ក្នុងចំការទំពាំងបាយជូររបស់
អ្នកជិតខាងណា នោះនឹងបរិភោគផលចំអែតតាមចិត្តបាន
ប៉ុន្តែមិនត្រូវបេះដាក់ក្នុងកញ្ជ្រែងឯងទេ ២៥កាលណាដើរ
កាត់ស្រែ ដែលមានស្រូវរបស់អ្នកជិតខាងឯងណា នោះនឹង
បូតគួរស្រូវដោយដៃបាន ប៉ុន្តែមិនត្រូវយកកណ្តៀវទៅ
ច្រូតឡើយ[អ]។

**២៤** ១បើបុរសណាយកប្រពន្ធ រៀបការពេញច្បាប់
ហើយ រួចមកបែរជាមិនចូលចិត្តវិញ[ក] ដោយបានឃើញ
សេចក្តីណា ដែលមិនគប្បីនៅនឹងនាង នោះត្រូវធ្វើសំបុត្រ
លះលែង[ខ] ប្រគល់នៅដៃនាង ហើយឱ្យចេញពីផ្ទះទៅចុះ
២កាលណានាងបានចេញពីផ្ទះអ្នកនោះផុតហើយ នោះនាង
នឹងទៅធ្វើជាប្រពន្ធរបស់ម្នាក់ទៀតបាន ៣រួចបើសិនជាប្តី
ក្រោយនោះស្អប់នាង ហើយធ្វើសំបុត្រលះលែងប្រគល់នៅ
ដៃនាង ឱ្យចេញពីផ្ទះខ្លួនទៅដែរ ឬបើប្តីក្រោយដែលបាន
យកនាងធ្វើជាប្រពន្ធ នោះស្លាប់ទៅ ៤នោះប្តីដើម ដែល
បានបណ្តេញនាងហើយ គ្មានច្បាប់នឹងយកនាងធ្វើជាប្រពន្ធ
វិញ ក្រោយដែលនាងបានសៅហ្មងហើយនោះទេ ដ្បិត
នោះជាសេចក្តីស្អប់ខ្ពើម នៅចំពោះព្រះយេហូវ៉ា មិនត្រូវ
ឱ្យឯងនាំឱ្យស្រុក ដែលព្រះយេហូវ៉ា[គ] ជាព្រះនៃឯង ទ្រង់
ប្រទានមកជាមរដក មានបាបសោះឡើយ ។
៥បើអ្នកណាទើបនឹងយកប្រពន្ធថ្មី មិនត្រូវឱ្យអ្នកនោះ
ចេញទៅច្បាំងឡើយ ក៏មិនត្រូវដាក់បន្ទុកអ្វីឱ្យគេត្រូវរវល់
ដែរ ត្រូវឱ្យនៅទំនេរនៅឯផ្ទះអស់១ឆ្នាំ ដើម្បីនឹងបណ្តាល
ឱ្យនាង ដែលទើបនឹងយកជាប្រពន្ធនោះ មានសេចក្តីរីក
រាយឡើង[ឃ]។
៦មិនត្រូវឱ្យអ្នកណាទទួលបញ្ចាំងថ្មត្បាល់កិន ទោះគ្រប ឬ
ត្បាល់កិន ទោះគ្រប ឬ
តួក្តី ដ្បិតយ៉ាងនោះឈ្មោះថា ទទួលបញ្ចាំទាំងជីវិតគេ
ផង[ង]។
៧បើឃើញអ្នកណាកំពុងតែចាប់អ្នកណាមួយ ក្នុងពួកបង
ប្អូន ជាពួកកូនចៅអ៊ីស្រាអែល យកទៅប្រើទុកដូចជាខ្ញុំបំរើ
ឬលក់ឱ្យដល់គេក្តី នោះអ្នកដែលចាប់លួចយក នឹងត្រូវ
ទោសដល់ស្លាប់[ច] យ៉ាងនោះឯងនឹងបំបាត់ការអាក្រក់ពីពួក
ឯងចេញ[ឆ]។
៨ចូរប្រយ័ត្នខាងឯរោគឃ្លង់ ដើម្បីឱ្យបានខំប្រឹងកាន់
ហើយធ្វើតាមគ្រប់សេចក្តី ដែលពួកលេវី[ជ]ដ៏ជាសង្ឃ និង

**២៣:១៧** ភ ១ពវ ១៤:២៤ ១៥:១២ ២២:៤៦ ២ពវ ២៣:៧ យប ៣៦:១៤ ម លប ៣៨:២១ **២៣:១៨** យ លប ១៩:៥ លវ ២០:១៣ វវ ២២:១៥ **២៣:១៩** រ លវ ២៥:៣៥–៣៧ នហ ៥:២–៧ **២៣:២០** ល លប ៣១:១៥ ចទ ១៥:៣ វ ចទ ១៥:១០ **២៣:២១** ស ជន ៦:២១ ពច ១១:៣៥ ទដ ១៥:៤ ហ ជន ៣០:១–២ យប ២២:២៧ ទដ ៦១:៨ ៦៥:១ ៧៦:១១ អស ១៩:២១ មថ ៥:៣៣ កថ ៥:៣ **២៣:២២** ឡ កថ ៥:៤ **២៣:២៥** អ មថ ១២:១ មក ២:២៣ លក ៦:១ **២៤:១** ក ចទ ២២:១៣ ខ ខ.៣ ២ពវ ១៧:៦ អស ៥០:១ យរ ៣:៨ មឡ ២:១៦ មថ ១:១៩ ៥:៣១ ១៩:៧–៩ មក ១០:៤–៥ **២៤:៤** គ យរ ៣:១ **២៤:៥** ឃ ចទ ២០:៧ **២៤:៦** ង នក ២២:២២ **២៤:៧** ច នក ២១:១៦ ឆ ១កថ ៥:១៣ **២៤:៨** ជ ចទ ១៧:៩ ឈ លវ ១៣:១–៤៦ ១៤:២

**២៣:១៧–១៨** មើលការពន្យល់ លប ៣៨:២១ នក ៣៤:១៥ ១ពវ ១៤:២៤ មីក ១:៧ ។

**២៣:១៨** *សំផឹង* "ជាឆ្កែព្រៃ"ជាភាពមិនបរិសុទ្ធខាងឯវិញ្ញាណ (មើល មថ ៧:៦ ១៥:២៦ វវ ២២:៥ និងការពន្យល់) ។

**២៣:១៩** *ខ្ចីដោយយកការ* សូមមើលការពន្យល់ នក ២២:៥–២៧ លវ ២៣:៣៦ ។

**២៣:២០** *អ្នកប្រទេសដទៃខ្ចីដោយយកការបាន* អ្នកជំនួញបរទេសចូលទៅប្រទេសអ៊ីស្រាអែលដើម្បីទទួលផលប្រយោជន៍ ជាហិរញ្ញវត្ថុ ដូច្នេះត្រូវយកជាការប្រាក់ ។

**២៣:២១–២៣** មើលការពន្យល់ ជន ៣០ សស ៥:១–៧ ។

**២៤:១–៤** ក្នុងកណ្ឌគម្ពីរម៉ូសេ ការលែងលះត្រូវបានហាមឃាត់ និងមានរបៀបរៀបរយ (មើល លវ ២១:៧,១៤ ២២:១៣ ជន ៣០:៩) ។

**២៤:៥** *សេចក្តីរីករាយ* គឺជាសុខភាពដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ ត្រូវបានគេយកចិត្តទុកដាក់បំផុត ។

**២៤:៦** *ថ្មត្បាល់កិន* ប្រើសម្រាប់កិនគ្រាប់ធញ្ញជាតិ ទៅជាម្សៅ ឬអាហារប្រចាំថ្ងៃ ។ (មើលការពន្យល់ ពច ៩:៥៣) ។

**២៤:៧** *ដូចជាខ្ញុំបំរើ* ប្រៀបធៀបនឹង ២៣:១៥ ។

**២៤:៨** *រោគឃ្លង់* មើលការពន្យល់ លវ ១៣:២ ។

បង្រៀនដល់ឯង ត្រូវឱ្យប្រយ័ត្ននឹងធ្វើតាម ដូចជាអញបាន
បង្គាប់ដល់គេគ្រប់ជំពូក[ឈ] ៩ចូរនឹកចាំពីសេចក្តីដែលព្រះយេ
ហូវ៉ា ជាព្រះនៃឯង បានប្រព្រឹត្តនឹងម៉ារាមតាមផ្លូវ ក្នុងគ្រា
ដែលឯងចេញពីស្រុកអេស៊ីព្ទមកចុះ[ញ]។
១០កាលណាឯងឱ្យអ្នកជិតខាងខ្ចីអ្វីៗ នោះមិនត្រូវចូល
តាមគេទៅក្នុងផ្ទះ ដើម្បីនឹងយករបស់បញ្ចាំពីគេនោះ
ឡើយ[ដ] ១១ត្រូវឱ្យឈរនៅខាងក្រៅ ចាំអ្នកដែលឯងបានឱ្យខ្ចី
នោះ យករបស់បញ្ចាំចេញមកឱ្យឯងឯខាងក្រៅវិញ
១២ហើយបើអ្នកនោះជាអ្នកទាល់ក្រ នោះមិនត្រូវឱ្យឯងខាំង
ទុករបស់បញ្ចាំនោះ[ឋ]ទៅដេកឡើយ ១៣លុះដល់ថ្ងៃលិច[ឌ]
ត្រូវឱ្យឯងប្រគល់ទៅគេវិញជាកុំខាន ដើម្បីឱ្យគេបាន
ប្រដាប់ដេកដណ្តប់ខ្លួនដែរ[ឍ] យ៉ាងនោះគេនឹងឱ្យពរដល់ឯង
ហើយការ នោះនឹងបានរាប់ជាសេចក្តីសុចរិតដល់ឯង
នៅចំពោះព្រះ យេហូវ៉ា ជាព្រះនៃឯង[ណ]។
១៤មិនត្រូវឱ្យឯងសង្កត់សង្កិនកូនឈ្នួលឯង ដែលទាល់ក្រ
ហើយកំសត់ទុរគតឡើយ ទោះជាពួកបងប្អូន ឬជាពួកអ្នក
ប្រទេសក្រៅ ដែលនៅក្នុងក្រុង ក្នុងស្រុករបស់ឯងក្តី[ត] ១៥គឺ
ត្រូវបើកប្រាក់ឈ្នួលឱ្យគេ ក្នុងពេលកំណត់កុំខាន កុំឱ្យប្រាក់
នោះនៅនឹងឯងដរាបដល់ថ្ងៃលិចឡើយ ដ្បិតគេទាល់ក្រ[ថ]
ហើយមានចិត្តសង្ឃឹមចង់បានប្រាក់នោះ[ទ] ក្រែងគេអំពាវ
នាវដល់ព្រះយេហូវ៉ាទាស់នឹងឯង នោះនឹងរាប់ជាមានបាប
ដល់ឯងហើយ[ធ]។
១៦មិនត្រូវសំឡាប់ឪពុកដោយព្រោះកូន ឬសំឡាប់កូន
ដោយព្រោះឪពុកឡើយ ដែលត្រូវស្លាប់នោះ គឺដោយ
ព្រោះតែបាបរបស់ខ្លួនទេ[ន]។
១៧មិនត្រូវឱ្យឯងបង្វែរសេចក្តីយុត្តិធម៌[ប] ពីអ្នកប្រទេស
ក្រៅ ឬពីកូនកំព្រាឡើយ[ផ] ក៏មិនត្រូវទទួលបញ្ចាំអាវរបស់
ស្រីមេម៉ាយដែរ ១៨ត្រូវឱ្យនឹកចាំថា ពីដើមឯងជាបាវបំរើ
នៅស្រុកអេស៊ីព្ទដែរ[ព] តែព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់
បានលោះចេញមក ហេតុនោះបានជាអញបង្គាប់ឱ្យឯង
ប្រព្រឹត្តដូច្នេះ ។
១៩កាលណាច្រូតចំរូតនៅស្រែរបស់ឯង បើភ្លេចស្រូវ១
កណ្តាប់នៅឯស្រែ នោះមិនត្រូវត្រឡប់ទៅយកវិញទេ[ភ] ត្រូវ
ទុកសំរាប់អ្នកដទៃ[ម] និងពួកកូនកំព្រា ហើយនិងស្រីមេម៉ាយ
វិញ[យ] ដើម្បីឱ្យព្រះយេហូវ៉ា ជាព្រះនៃឯងបានប្រទានពរ[រ]
ដល់ឯង ក្នុងគ្រប់ការទាំងអស់ ដែលដៃឯងធ្វើ ២០កាលណា
ឯងវាយជំរុះផល ពីដើមអូលីវរបស់ឯងរួចម្តងហើយ នោះ
មិនត្រូវឡើងទៅធ្វើម្តងទៀតទេ[ល] ត្រូវទុកសំរាប់អ្នកដទៃ
និងពួកកូនកំព្រា ហើយនិងស្រីមេម៉ាយវិញ ២១កាលណា
បេះផ្លែទំពាំងបាយជូររបស់ឯងហើយ នោះមិនត្រូវទៅ១
សាទៀត ដើម្បីនឹងបេះចង្កោមដែលនៅសល់ទេ ត្រូវទុក
សំរាប់ពួកអ្នកដទៃ នឹងពួកកូនកំព្រាហើយនឹងស្រីមេម៉ាយ
វិញ ២២ត្រូវឱ្យនឹកចាំថា ពីដើមឯងជាបាវបំរើ នៅស្រុក
អេស៊ីព្ទដែរ ហេតុនោះបានជាអញបង្គាប់ ឱ្យឯងប្រព្រឹត្ត
ដូច្នេះ[វ]។

**២៥** ១បើកាលណាមានមនុស្សកើតរឿងទាស់ទែងគ្នា
ហើយគេប្តឹងផ្តល់ដល់ចៅក្រម[ក]ឱ្យជំនុំជំរះក្តីនោះ[ខ] នោះត្រូវ
ឱ្យចៅក្រមតាំងឱ្យ[គ]អ្នកដែលសុចរិត បានជាសុចរិតចុះ
ហើយកាត់ទោស[ឃ]ដល់អ្នកដែលមានទោសវិញ ២បើអ្នក
មានទោសនោះគួរឱ្យវាយ[ង] នោះចៅក្រមត្រូវឱ្យដេកទៅ
ហើយ ឱ្យគេវាយនៅចំពោះមុខ ត្រូវវាយឱ្យគ្រប់ចំនួនល្មម
នឹងទោសអ្នកនោះ ៣មានច្បាប់នឹងវាយដល់៤០រំពាត់[ច] មិន
ត្រូវឱ្យលើសឡើយ ក្រែងអ្នកដែលជាបងប្អូនឯងនោះ មើល
ទៅដូចជាទាបថោកពេកដល់ឯង[ឆ] ដោយឯងវាយជាច្រើន
លើសប្រមាណ ។
៤មិនត្រូវឃ្លុំមាត់គោដែលកំពុងបញ្ជាន់ស្រូវឡើយ[ជ]។

**២៤:៩** ញ ជន ១២:១០ **២៤:១០** ដ នក ២២:២៥–២៧ **២៤:១២** ឋ នក ២២:២៦ **២៤:១៣** ឌ នក ២២:២៦ ឍ នក ២២:២៧ ណ ចទ ៦:២៥ ទដ ១០៦:៣១ ដយ ៤:២៧ **២៤:១៤** ត លវ ១៩:១៣ ២៥:៣៥–៤៣ ចទ ១៥:១២–១៨ យប ២៤:៤ សភ ១៤:៣១ ១៩:១៧ អម ៤:១ ១ធថ ៥:១៨ **២៤:១៥** ថ លវ ២៥:៣៥ ទ លវ ១៩:១៣ មថ ២០:៨ ធ នក ២២:២៣ វយប ១២:១៩ យក ៥:៤ **២៤:១៦** ន ជន ២៦:១១ យរ ៣១:២៩–៣០ **២៤:១៧** ប នក ២២:២២ យប ៦:២៧ ២៤:៩ ២៩:១២ ទដ ១០:១៨ ៨២:៣ សភ ២៣:១០ អគ ២២:៧ ផ នក ២២:២១ ២៣:២ ចទ ១០:១៨ **២៤:១៨** ព ចទ ១៥:១៥ **២៤:១៩** ភ លវ ១៩:៩ ម ចទ ១០:១៩ ២៧:១៩ អគ ៤៧:២២ សក ៧:១០ មឡ ៣:៥ យ ខ.២០ ចទ ១៤:២៩ រ ចទ ១៤:២៩ សភ ១៩:១៧ ២៨:២៧ សស ១១:១ **២៤:២០** ល លវ ១៩:១០ **២៤:២២** វ ខ.១៨ **២៥:១** ក នក ២១:៦ ខ ចទ ១៧:៨–១៣ ១៩:១៧ កច ២៣:៣ គ ១ពវ ៨:៣២ ឃ នក ២៣:៧ ចទ ១:១៦–១៧ **២៥:២** ង សភ ១០:១៣ ១៩:២៩ លក ១២:៤៧–៤៨ **២៥:៣** ច មថ ២៧:២៦ យហ ១៩:១ ២កថ ១១:២៤ ឆ យរ ២០:២ **២៥:៤** ជ ជន ២២:២៩ ១កថ ៩:៩ ១ធថ ៥:១៨

**២៤:៩,១៨,២០** *ចូរនឹកចាំ* មើលការពន្យល់ ៤:១០ ។

**២៤:១០–១៣** មើការពន្យល់ ៦:២៥ នក ២២:២៦–២៧ ។

**២៤:១៦** *ត្រូវស្លាប់នោះ គឺដោយព្រោះតែបាបរបស់ខ្លួន* មើល អគ ១៨:៤ និង ការពន្យល់ ។

**២៤:១៧–១៨** សូមមើល ១០:១៨–១៩ ក្នុងពេលប្រជាជនអ៊ីស្រាអែលបាន ជួបបញ្ហា ព្រះយេហូវ៉ាបានជួយដល់ពួកគេ ពោលគឺពួកគេពុំបានឆក់យក ប្រជាជនពីអ្នកដទៃក្នុងគ្រាលំបាកទេ ។

**២៤:១៩–២១** មើលការពន្យល់ លវ ១៩:៩–១០ ។

**២៥:៣** *វាយដល់៤០រំពាត់ មិនត្រូវឱ្យលើសឡើយ* ការវាយនោះជារឿងមួយ នៃឧក្រិដ្ឋជន ការដែលធ្វើឱ្យហួសកំរិតដូច្នេះច្បាប់បានហាមផងដែរ ចំពោះ ភាពជាក់ទណ្ឌកម្មក៏សាហាវ ការនេះទាក់ទងនិងបទពិសោធន៍លោកប៉ុល ផងដែរ មើល ២កថ ១១:២៤–២៥ និងការពន្យល់ ។

**២៥:៤** ការងារនេះបានអនុវត្តក្នុងព្រះរាជកិច្ចរបស់ព្រះយេស៊ូវ សូមមើល ១កថ ៩:៩–១០ ១ធម ៥:១៧–១៨ ។ *ឃ្លុំមាត់គោ* មើលការពន្យល់ លប

៥កាលណាមានបងប្អូនបង្កើតនៅជាមួយគ្នា ហើយម្នាក់
ស្លាប់ទៅឥតមានកូន នោះប្រពន្ធរបស់អ្នកដែលស្លាប់ មិន
ត្រូវទៅធ្វើជាប្រពន្ធអ្នកក្រៅណាទេ ត្រូវឱ្យបងឬប្អូនថ្លៃចូល
ទៅឯនាង យកធ្វើជាប្រពន្ធ ហើយត្រូវសំរេចដល់នាង តាម
ការដែលបង ឬប្អូនថ្លៃត្រូវធ្វើ[ឈ] ៦រួចកូនដែលនាងបង្កើត
មុនដំបូង ត្រូវបន្តឈ្មោះរបស់អ្នក ដែលស្លាប់ទៅហើយ
នោះវិញ ដើម្បីកុំឱ្យឈ្មោះគាត់បានលុបចេញពីសាសន៍
អ៊ីស្រាអែលឡើយ[ញ] ៧តែបើអ្នកនោះមិនចូលចិត្តនឹងយក
ប្រពន្ធរបស់គាត់ទេ[ដ] នោះត្រូវឱ្យនាងចូលទៅឯពួកចាស់ទុំ
ត្រង់ទ្វារក្រុង[ឋ]ប្ដឹងថា ប្អូនថ្លៃខ្ញុំមិនព្រមភ្ជាប់ឈ្មោះឱ្យបងខ្លួន
ក្នុងសាសន៍អ៊ីស្រាអែលទេ គាត់មិនចង់សំរេចដល់ខ្ញុំតាម
ការដែលប្អូនថ្លៃត្រូវធ្វើសោះ[ឌ] ៨នោះពួកចាស់ទុំនៃក្រុង
នោះ ត្រូវហៅអ្នកនោះមកនិយាយគ្នា តែបើគាត់នៅតែថា
ខ្ញុំមិនចូលចិត្តយកនាងទេ ៩នោះប្រពន្ធរបស់បងត្រូវចូល
ទៅជិតអ្នកនោះ នៅមុខពួកចាស់ទុំ ដោះស្បែកជើងពីអ្នក
នោះចេញ[ឍ]រួចស្តោះទឹកមាត់ដាក់មុខ[ណ]គេ ហើយនិយាយ
ថា ត្រូវតែប្រព្រឹត្តយ៉ាងដូច្នេះ នឹងមនុស្សណាដែលមិនព្រម
បន្តពូជឱ្យបងខ្លួន ១០រួចនៅក្នុងសាសន៍អ៊ីស្រាអែល គេនឹង
ហៅអ្នកនោះថា ជាគ្រួមនុស្សដែលត្រូវគេដោះស្បែកជើង
ចេញ ។

១១បើកាលណាមនុស្សកំពុងតែប្រវាយគ្នា ហើយប្រពន្ធ
អ្នកមួយចូលមកចង់ជួយដោះប្ដីខ្លួន ពីកណ្ដាប់ដៃនៃអ្នក
ដែលវាយ រួចនាងលូកដៃទៅចាប់ត្រង់កេរខ្មាសរបស់អ្នក
នោះ ១២នោះត្រូវឱ្យកាប់ដៃនាងចេញ មិនត្រូវឱ្យភ្នែក
ឯងមើលប្រណីនាងទេ[ត] ។

១៣នៅក្នុងថង់ឯង មិនត្រូវមានកូនជញ្ជីង២យ៉ាង គឺ១ធ្ងន់
១ស្រាលឡើយ[ថ] ១៤ក៏មិនត្រូវមាន រង្វាល់២យ៉ាង ១ធំ១តូច
នៅក្នុងផ្ទះឯងដែរ ១៥ត្រូវឱ្យមានកូនជញ្ជីងត្រឹមត្រូវពេញ

**២៥:៥** ឈ នរ ៤:១០,១៣ មថ ២២:២៤ មក ១២:១៩ លក ២០:២៨
**២៥:៦** ញ លប ៣៨:៩ នរ ៤:៥,១០
**២៥:៧** ដ នរ ១:១៥ ឋ លប ២៣:១០ ឌ នរ ៤:១-២,៥-៦
**២៥:៩** ឍ យស ២៤:២២ នរ ៤:៧-៨,១១ ណ ជន ១២:១៤ យប ១៧:៦ ៣០:១០ អស ៥០:៦
**២៥:១២** ត ចទ ៧:២
**២៥:១៣** ថ សភ ១១:១ ២០:២៣ មីក ៦:១១
**២៥:១៥** ទ នក ២០:១២
**២៥:១៦** ធ សភ ១១:១
**២៥:១៧** ន លប ៣៦:១២
**២៥:១៨** ប ទដ ៣៦:១ រម ៣:១៨
**២៥:១៩** ផ នក ៣៣:១៤ ហាព ៣:១៨-១៩ ព នអ ៩:១៦ ភ លប ៣៦:១២
**២៦:២** ក នក ២២:២៩ ខ នក ២០:២៤ ចទ ១២:៥

ទំងន់ និងរង្វាល់ត្រឹមត្រូវពេញខ្នាតដែរ ដើម្បីឱ្យឯងមាន
ជីវិតយូរអង្វែងតទៅ[ទ] នៅក្នុងស្រុកដែលព្រះយេហូវ៉ា ជា
ព្រះនៃឯង ទ្រង់ប្រទានឱ្យ ១៦ដ្បិតអស់អ្នកណាដែលធ្វើយ៉ាង
នោះ គឺដែលប្រព្រឹត្តការដ៏ទុច្ចរិត នោះជាទីស្អប់ខ្ពើមដល់
ព្រះយេហូវ៉ា ជាព្រះនៃឯងណាស់[ធ] ។

១៧ចូរនឹកចាំពីការដែលសាសន៍អាម៉ាលេក[ន]បានធ្វើដល់
ឯងតាមផ្លូវ ក្នុងកាលដែលឯងចេញពីស្រុកអេស៊ីព្ទមកនោះ
១៨គឺបានគេមកទាស់នឹងឯងតាមផ្លូវ ក្នុងកាលដែលឯងអស់
កំលាំង ហើយល្វើយ គេបានវាយពួកអ្នកខ្សោយ ដែលដើរ
ខាងក្រោយ ឥតមានកោតខ្លាចដល់ព្រះសោះ[ប] ១៩ដូច្នេះ
កាលណាព្រះយេហូវ៉ា ជាព្រះនៃឯង បានឱ្យឈប់សំរាក[ផ]
ខាងឯពួកខ្មាំងសត្រូវនៅជុំវិញ[ព] ក្នុងស្រុកដែលព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់ប្រទានឱ្យឯងចាប់យកជាមរដកហើយ
នោះត្រូវឱ្យលុបសេចក្តីនឹកចាំចំពោះសាសន៍អាម៉ាលេក[ភ]
ពីក្រោមមេឃចេញ កុំឱ្យឯងភ្លេចនឹងធ្វើការនេះឡើយ ។

### ផលដំបូងនិងដង្វាយមួយភាគក្នុងដប់

**២៦** ១កាលណាឯងបានចូលទៅ ចាប់យកស្រុកដែល
ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានមក ទុកជាមរដក
រួចបានតាំងទីលំនៅជាស្រេចហើយ ២នោះត្រូវឱ្យយកផល
ដំបូងគ្រប់មុខកើតពីដី[ក] ដែលឯងនឹងប្រមូលមកពីស្រែចំការ
ជាផលដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានឱ្យរួច
ដាក់ចុះក្នុងកញ្ជើនាំយកទៅឯកន្លែងដែល ព្រះយេហូវ៉ា
ជាព្រះនៃឯង និងរើសសំរាប់តាំងព្រះនាមទ្រង់ ៣ហើយ
ត្រូវទៅជិវាបសង្ឃ ដែលមាននៅគ្រានោះថា នៅថ្ងៃនេះ
ខ្ញុំសូមទូលដល់ព្រះយេហូវ៉ា ជាព្រះនៃលោកថា ខ្ញុំបានមក
ដល់ស្រុក ដែលព្រះយេហូវ៉ាទ្រង់បានស្បថនឹងពួកព្ធយុកោ
ថានិងឱ្យមកយើងខ្ញុំហើយ ៤នោះត្រូវឱ្យសង្ឃយកកញ្ជើពី
ដៃឯង ទៅដាក់នៅមុខអាសនាផងព្រះយេហូវ៉ា ជាព្រះនៃ

៥០:១០ នរ ១:២២ ។

**២៥:៥-៦** ការមាននិរន្តរភាពតៗគ្នាចំពោះក្រុមគ្រួសារ និងធ្វើការប្រគល់អំណាចគ្រប់គ្រង(ការធ្វើវិមជ្ឈការ)ចំពោះទឹកដីតាមរយៈ ឱ្យមានភាពជាកម្មសិទ្ធផ្ទាល់ខ្លួនដែលជាមូលដ្ឋានគ្រឹះមួយចំពោះសេដ្ឋកិច្ច (សូមមើល លប ៣៨:៨ និងការពន្យល់) ។

**២៥:៧** *តែបើអ្នកនោះមិនចូលចិត្តនឹងយកប្រពន្ធរបស់គាត់ទេ* សូមមើល ខ.៨-១០ ។ សំគាល់មើលពីបទពិសោធន៍ដែលធ្លាប់មាន ជាមួយនិងការប្រែប្រួល ដែលបានពិពណ៌នានៅក្នុង លប ៣៨:១០ នរ ៤:១-១២ ។ *ពួកចាស់ទុំត្រង់ទ្វារក្រុង* សូមមើល ២១:១៩ ២២:១៥ និងការពន្យល់ លប ១៩:១ នរ ៤:១ ។

**២៥:១១-១២** ប្រៀបធៀប នក ២១:២២-២៥ និងការពន្យល់ ។

**២៥:១៣-១៦** មើលការពន្យល់ លវ ១៩:៣៥ ។

**២៥:១៤** *រង្វាល់* គឺទាក់ទងនឹងបរិមាណ ។

**២៥:១៧** *ចូរនឹកចាំ* សូមមើលការពន្យល់ ៤:១០ ។ *អាម៉ាលេក* មើល នក ១៧:៨-១៦ ជន ១៤:៤៥ ១សយ ១៥:២-៣ ៣០:១-២០ ។

**២៥:១៨** *កោតខ្លាចដល់ព្រះ* មើលការពន្យល់ លប ២០:១១ ។

**២៥:១៩** *ឈប់សំរាក* មើលការពន្យល់ ៣:២០ ។

**២៦:១** *មរដក* មើលការពន្យល់ នក ១៥:១៧ ។

**២៦:២** *ផលដំបូង* គឺជាដង្វាយដែលបានពិពណ៌នានៅខនេះ ក៏បានសរសេរតែម្ដងគត់មិនត្រូវច្រឡំនិងដង្វាយប្រចាំឆ្នាំ និងផលដំបូងឡើយ(មើល ១៨:៤ និងការពន្យល់) ។ *កន្លែងដែលព្រះយេហូវ៉ា . . . រើសសំរាប់តាំងព្រះនាមទ្រង់* មើលការពន្យល់ ១២:៥ ។

ឯង ៥រួចត្រូវថ្លែងប្រាប់ នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃ
ឯងថា ព្ធយុកោទូលបង្គំលោកជាសាសន៍អើរ៉ាម[គ] ដែលដើរ
សាត់ព្រាត់[ឃ] លោកបានចុះទៅតាំងទីលំនៅក្នុង ស្រុក
អេស៊ីព្ទ មានគ្នាតែបន្តិចទេ[ង] ហើយនៅស្រុកនោះ បាន
ត្រឡប់ជាសាសន៍១យ៉ាងធំ[ច] ហើយខ្លាំងពូកែ មានគ្នា
ជាច្រើនវិញ ៦ពួកសាសន៍អេស៊ីព្ទបានប្រព្រឹត្តអាក្រក់ដល់
យើងខ្ញុំ ព្រមទាំងធ្វើទុក្ខ[ឆ] ហើយដាក់បន្ទុក ឱ្យធ្វើការមាន
ទំងន់ណាស់ផង[ជ] ៧នោះយើងខ្ញុំបានអំពាវនាវដល់ព្រះ
យេហូវ៉ា ជាព្រះនៃពួកព្ធយុកោយើងខ្ញុំ ហើយទ្រង់បានឮ
សំរែកយើងខ្ញុំ[ឈ] ក៏ឃើញ[ញ]សេចក្តីទុក្ខលំបាក[ដ]និងការនឿយ
ហត់របស់យើងខ្ញុំ ព្រមទាំងការដែលគេសង្កត់សង្កិនដល់
យើងខ្ញុំផង[ឋ] ៨នោះទ្រង់ក៏នាំយើងខ្ញុំចេញពីស្រុកអេស៊ីព្ទ[ឌ]
មក ដោយព្រះហស្តដ៏មានព្រះចេស្តា[ឍ] និងព្រះពាហុលើក
សំរេច ព្រមទាំងធ្វើការគួរស្ញែងខ្លាចដ៏ធំ និងទីសំគាល់
ហើយនិងការអស្ចារ្យផង[ណ] ៩ទ្រង់ក៏បាននាំយើងខ្ញុំចូលមក
ដល់ទីនេះ ហើយបានប្រទានស្រុកនេះ ជាស្រុកដែលមាន
ទឹកដោះ និងទឹកឃ្មុំហូរហៀរដល់យើងខ្ញុំរាល់គ្នា[ត] ១០ឥឡូវ
នេះ ឱព្រះយេហូវ៉ាអើយ មើល ទូលបង្គំបាននាំយកផល
ដំបូងកើតពីដី ដែលទ្រង់បានប្រទានដល់ទូលបង្គំមក[ថ]
ហើយ នោះត្រូវឱ្យឯងដាក់របស់ទាំងនោះ នៅចំពោះ
ព្រះយេហូវ៉ា ជាព្រះនៃឯង រួចក្រាបថ្វាយបង្គំដល់ទ្រង់
១១ហើយត្រូវរីករាយ[ទ]ចំពោះគ្រប់ទាំងរបស់ល្អ ដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់បានប្រទានមកចុះ ព្រមទាំង
ពួកគ្រួឯង និងពួកលេវី[ធ] ហើយនិងពួកអ្នកដែលស្នាក់នៅ
ជាមួយនឹងឯងផង ។

១២កាលណាឯងបានថ្វាយ១ភាគក្នុង១០[ន] ពីផលរបស់ឯង
ទាំងប៉ុន្មាន នៅឆ្នាំទី៣ គឺជាឆ្នាំដែលត្រូវថ្វាយ១ភាគក្នុង
១០[ប]នោះរួចហើយ នោះត្រូវចែកឱ្យដល់ពួកលេវី និងពួក
អ្នកដែលស្នាក់នៅ ព្រមទាំងពួកកូនកំព្រា ហើយនិងពួកស្រី
មេម៉ាយផង ដើម្បីឱ្យអ្នកទាំងនោះបានបរិភោគចំអែតគ្រប់
គ្រាន់ នៅក្នុងទីក្រុងឯងដែរ ១៣នោះត្រូវឱ្យទូលនៅចំពោះ
ព្រះយេហូវ៉ាជាព្រះនៃឯងថា ទូលបង្គំបាននាំយកដង្វាយ
ទាំងអស់ចេញពីផ្ទះទូលបង្គំមក ហើយបានចែកឱ្យដល់ពួក
លេវី និងពួកអ្នកដែលស្នាក់នៅ ព្រមទាំងពួកកូនកំព្រា
និងពួកស្រីមេម៉ាយផង តាមបញ្ញត្តិដែលទ្រង់បានបង្គាបមក
គ្រប់ជីពូកហើយ ទូលបង្គំមិនបានរំលងបញ្ញត្តិទ្រង់ណាមួយ
ឡើយ ក៏មិនបានភ្លេចដែរ[ផ] ១៤ទូលបង្គំមិនបានទទួលទានពី
របស់ទាំងនោះ ក្នុងការដែលកំពុងកាន់ទុក្ខឡើយ ក៏មិនបាន
បង្វែរអ្វី១សំរាប់ការស្មោកគ្រោក[ព] ឬឱ្យអ្វីសំរាប់ខ្មោច
ស្លាប់ដែរ ទូលបង្គំបានស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ា
ជាព្រះនៃទូលបង្គំ ហើយបានធ្វើតាមគ្រប់សេចក្តីទាំងអស់
ដែលទ្រង់បានបង្គាប់មកហើយ ១៥សូមទ្រង់ទតមកពីទី
លំនៅបរិសុទ្ធរបស់ទ្រង់នូវស្ថានសួគ៌[ភ] ហើយប្រទានពរ[ម]
ដល់សាសន៍អ៊ីស្រាអែលជារាស្ត្ររបស់ទ្រង់ ព្រមទាំងដី
ដែលទ្រង់បានប្រទានមកយើងខ្ញុំផង គឺជាស្រុកដែលមាន
ទឹកដោះ និងទឹកឃ្មុំហូរហៀរ ដូចជាទ្រង់បានស្បថនឹងពួក
ព្ធយុកោយើងខ្ញុំហើយ ។

## ត្រូវប្រព្រឹត្តតាមបង្គាប់ព្រះអម្ចាស់

១៦នៅថ្ងៃនេះព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់បង្គាប់មក
ឱ្យឯងប្រព្រឹត្តតាមអស់ទាំងច្បាប់ និងបញ្ញត្តិទាំងនេះ ដូច្នេះ
ត្រូវឱ្យឯងកាន់ ហើយប្រព្រឹត្តតាម ឱ្យអស់ពីចិត្តអស់ពី
ព្រលឹងឯងចុះ[យ] ១៧នៅថ្ងៃនេះឯងបានសុខចិត្តទទួលព្រម
ថាព្រះយេហូវ៉ា ទ្រង់ជាព្រះនៃឯង ហើយថា ឯងនឹងដើរ
តាមផ្លូវទ្រង់ ព្រមទាំងកាន់តាមអស់ទាំងសេចក្តីបង្គាប់នឹង
ច្បាប់ ហើយនិងបញ្ញត្តិរបស់ទ្រង់ទាំងប៉ុន្មាន ក៏នឹងស្តាប់
តាមព្រះបន្ទូលទ្រង់ផង[រ] ១៨ព្រះយេហូវ៉ាទ្រង់ក៏បានទទួល
ព្រមនៅថ្ងៃនេះថា ឯងជារាស្ត្ររបស់[ល]ផងទ្រង់ពិត ដូចជា
ទ្រង់បានសន្យានឹងឯងហើយ ព្រមទាំងប្រាប់ឱ្យឯងកាន់តាម
គ្រប់ទាំងបញ្ញត្តិទាំងប៉ុន្មានរបស់ទ្រង់ ១៩ហើយឱ្យបានលើក
ឯងឡើងជាខ្ពស់ផង[វ] គឺខ្ពស់លើសអស់ទាំងសាសន៍ ដែល
ទ្រង់ បានបង្កើត ដោយមានសេចក្តីសរសើរនិងកេរ្តិ៍ឈ្មោះ
ហើយនិងសេចក្តីថ្កុំថ្កើង[ស] ដើម្បីឱ្យឯងបានធ្វើជារាស្ត្រ

**២៦:៥** គ លប ២៥:២០ ឃ លប ២០:១៣ ង លប ៣៤:៣០ ៤៣:១៣ ច លប ១២:២ **២៦:៦** ឆ ជន ២០:១៥ ជ នក ១:១៣ **២៦:៧** ឈ លប ២១:១៧ ញ នក ៣:៩ ២ពវ ១៣:៤ ១៤:២៦ ដ លប ១៦:១១ ឋ ទដ ៤២:៩ ៤៤:២៤ ៧២:១៤ **២៦:៨** ឌ ជន ២០:១៦ឍ នក ៣:២០ ណ ចទ ៤:៣៤ ៣៤:១១–១២ **២៦:៩** ត នក ៣:៨ **២៦:១០** ថ ចទ ៨:១៨ **២៦:១១** ទ ចទ ១២:១២ ធ ចទ ១៦:១១ **២៦:១២** ន លប ១៤:២០ ប ជន ១៨:២៤ ចទ ១៤:២៨–២៩ ហព ៧:៥,៩ **២៦:១៣** ផ ទដ ១១៩:១៤១, ១៥៣,១៧៦ **២៦:១៤** ព លវ ៧:២០ ហស ៩:៤ **២៦:១៥** ភ ទដ ៦៨:៥ ៨០:១៤ ១០២:១៩ អស ៦៣:១៥ សក ២:១៣ ម នក ៣៩:៤៣ **២៦:១៦** យ ចទ ៤:២៩

**២៦:១៧** រ នក ១៩:៨ ទដ ៤៨:១៤ **២៦:១៨** ល នក ៦:៧ ចទ ៧:៦ **២៦:១៩** វ អស ៦២:៧ សផ ៣:២០ ស ចទ ៤:៧–៨ ២៨:១,១៣,៤៤ ១រប ១៤:២

**២៦:៥** *សាសន៍អើរ៉ាមដែលដើរសាត់ព្រាត់* គឺសំដៅទៅលើលោកយ៉ាកុប ដែលធ្វើដំណើរផ្សងព្រេង ពីរស្រុកកាណានខាងត្បូងទៅកាន់ក្នុងស្រុកអើរ៉ាម(មើលការពន្យល់ លប ១០:២២) ។ (លោកយ៉ាកុប)ត្រឡប់មកវិញ (លប ២៧–៣៥)ហើយក្រោយមក ផ្លាស់ប្តូរទីកន្លែងទៅប្រទេសអេស៊ីព្ទ (មើល លប ៤៦:៣–៧) ។ គាត់ក៏បានរៀបការ ជាមួយស្ត្រីអើរ៉ាម គឺជាប្រជាជន ដែលនិយាយបែបភាសាអើរ៉ាប់ (លប ២២:២៣–២៤ ការពន្យល់ ៣៥:២០ ៣១:២០–២៤ នក ១:៥ ១:៧ មើលការពន្យល់) ។ *មានគ្នាតែបន្តិចទេ . . . ត្រឡប់ជាសាសន៍១យ៉ាងធំ* មើល នក ១:៥ ១:៧ និងការពន្យល់ ។

**២៦:១១** *រីករាយ* មើលការពន្យល់ ១២:១២ ។

**២៦:១២** មើលការពន្យល់ ១៤:២២–២៩ ។

**២៦:១៦** *អស់ពីចិត្តអស់ពីព្រលឹង* មើលការពន្យល់ ៤:២៩ ។

**២៦:១៧** ជាពាក្យបច្ចេកទេសនៃជាសេចក្តីសញ្ញា ដែលបានផ្សារភ្ជាប់ឡើងវិញតាមរយៈពាក្យសម្បថរបស់ប្រជាជនអ៊ីស្រាអែលថា ព្រះយេហូវ៉ាជាព្រះដែលពួកគេត្រូវស្តាប់បង្គាប់ (មើល ៥:២៧ និងការពន្យល់ នក ១៩:៨) ។

បរិសុទ្ធ[ហ]ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ដូចជាទ្រង់បាន
មានបន្ទូលស្រាប់ ។

## អាសនានៅលើភ្នំអេបាល

**២៧** ១នោះម៉ូសេនឹងពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែល ក៏
បង្គាប់ដល់បណ្តាជនថា ចូរកាន់តាមគ្រប់ទាំងបញ្ញត្តិ[ក] ដែល
អញបង្គាប់ដល់ឯងនៅថ្ងៃនេះ ២រួចនៅថ្ងៃដែលឆ្លងទន្លេ
យ័រដាន់[ខ] ចូលទៅក្នុងស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់ប្រទានមកឯង នោះត្រូវឱ្យរៀបថ្ម[គ]ឡើង ហើយបូក
បាយអចុះ[ឃ] ៣ត្រូវចារឹកអស់ទាំងពាក្យក្នុងក្រិត្យវិន័យនេះ
ចុះនៅនឹងថ្មនោះ ក្នុងកាលដែលឆ្លងទៅ ដើម្បីនឹងចូលទៅ
ក្នុងស្រុកដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានឱ្យ
គឺជាស្រុកដែលមានទឹកដោះ និងទឹកឃ្មុំហូរហៀរ[ង] ដូចជា
ព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោឯង បានមានបន្ទូល
ហើយ ៤កាលណាឯងរាល់គ្នាបានឆ្លងទន្លេយ័រដាន់រួច
ហើយ ត្រូវឱ្យរៀបថ្មនោះឡើង នៅលើភ្នំអេបាល[ច] តាម
ដែលអញបង្គាប់នៅថ្ងៃនេះ រួចបូកបាយអផង ៥នៅទីនោះ
ក៏ត្រូវស្អាងអាសនា១[ឆ] ថ្វាយព្រះយេហូវ៉ា ជាព្រះនៃឯង
គឺជាអាសនាធ្វើពីថ្ម មិនត្រូវឱ្យយកដែកពន្លាក[ជ]ទៅដាប់
ឡើយ ៦ត្រូវស្អាងអាសនាផងព្រះយេហូវ៉ា ជាព្រះនៃឯង
ដោយថ្មទាំងមូល ហើយថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ា
ជាព្រះនៃឯង នៅលើអាសនានោះ ៧ព្រមទាំងដង្វាយមេត្រី
ផង[ឈ] រួចត្រូវបរិភោគនៅកន្លែងនោះដោយអរសប្បាយ[ញ]
នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង[ដ] ៨ត្រូវឱ្យឯងចារឹក
អស់ទាំងពាក្យ ក្នុងក្រិត្យវិន័យនេះ ចុះនៅនឹងថ្មទាំងនោះ[ឋ]
ឱ្យច្បាស់ប្រចក្ស[ឌ] ។

ទដ ១៤៨:១៤ អស ៤០:១១ ហ ចទ ៧:៦
**២៧:១** ក ទដ ៧៨:៧
**២៧:២** ខ យស ៤:១ គ នក ២៤:៤ យស ២៤:២៦ ១សយ ៧:១២ ឃ យស ៨:៣១
**២៧:៣** ង នក ៣:៨
**២៧:៤** ច ចទ ១១:២៩
**២៧:៥** ឆ នក ២០:២៤ ជ នក ២០:២៥
**២៧:៧** ឈ នក ៣២:៦ ញ ចទ ១៦:១១ ដ យស ៨:៣១
**២៧:៨** ឋ អស ៨:១ ៣០:៨ ហប ២:២ ឌ យស ៨:៣២
**២៧:៩** ឍ ចទ ១៧:៩ ណ ចទ ២៦:១៨
**២៧:១២** ត ចទ ១១:២៩ ថ លប ៣០:១៨ ទ យស ៨:៣៥
**២៧:១៣** ធ ចទ ១១:២៩
**២៧:១៥** ន នក ២០:៤ ប ១ពវ ១១:៥,៧ ២ពវ ២៣:១៣ អស ៤៤:១៩ ៦៦:៣

## សេចក្តីបណ្តាសាពីភ្នំអេបាល

៩រួចម៉ូសេ និងពួកលេវី[ឍ]ដ៏ជាសង្ឃ ក៏ប្រាប់ដល់ពួកអ៊ីស្រា
អែលទាំងអស់គ្នាថា ចូរនៅស្ងៀម ហើយស្តាប់ចុះ ឱពួក
អ៊ីស្រាអែលអើយ នៅថ្ងៃនេះឯងបានត្រឡប់ជារាស្ត្ររបស់
ព្រះយេហូវ៉ា ជាព្រះនៃឯងហើយ[ណ] ១០ដូច្នេះត្រូវឱ្យស្តាប់
តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ជាព្រះនៃឯងចុះ ព្រមទាំង
ប្រព្រឹត្តតាមអស់ទាំងច្បាប់ និងបញ្ញត្តិទ្រង់ទាំងប៉ុន្មាន ដែល
អញបង្គាប់ដល់ឯងនៅថ្ងៃនេះ ។
១១ហើយនៅថ្ងៃនោះឯង ម៉ូសេក៏ផ្តាំដល់បណ្តាជនទាំង
ឡាយថា ១២កាលណាឯងរាល់គ្នាបានឆ្លងទន្លេយ័រដាន់រួច
ហើយ នោះត្រូវឱ្យពួកទាំងនេះឈរនៅលើភ្នំកេរិស៊ីម[ត]
ដើម្បីនឹងឱ្យពរដល់បណ្តាជន គឺពួកស៊ីម្មាន១ ពួកលេវី១
ពួកយូដា១ ពួកអ៊ីសាខារ១[ថ] ពួកយ៉ូសែប១ និងពួកបេនយ៉ា
មីន១[ទ] ១៣ឯពួកនេះត្រូវឱ្យគេឈរនៅលើភ្នំអេបាល[ធ] ដើម្បី
នឹងដាក់បណ្តាសាវិញ គឺពួករូបេន១ ពួកកាឌ់១ ពួក
អេស៊ើរ១ ពួកសាប់យូល៉ូន១ ពួកដាន់១ នឹងពួកណែប
ថាលី១ ១៤នោះត្រូវឱ្យពួកលេវីចាប់ផ្តើមបន្លឺឡើង ដោយ
ពាក្យជាខ្លាំង ដល់ពួកសាសន៍អ៊ីស្រាអែលទាំងអស់គ្នាថា –
១៥ត្រូវបណ្តាសាហើយ អ្នកណាដែលឆ្លាក់ ឬសិតធ្វើរូប[ន]
ដែលជាទីស្អប់ខ្ពើម[ប]ដល់ព្រះយេហូវ៉ា គឺជារបស់ដែលដៃ
ជាងធ្វើ រួចយកទៅដាក់នៅទីសំងាត់ នោះបណ្តាជនទាំង
ឡាយត្រូវឆ្លើយឡើងថា អាម៉ែន[ផ] ។
១៦ត្រូវបណ្តាសាហើយ អ្នកណាដែលមើលងាយដល់
ឪពុកម្តាយខ្លួន[ព] នោះបណ្តាជនទាំងឡាយត្រូវឆ្លើយឡើងថា
អាម៉ែន ។

ផ ជន ៥:២២ **២៧:១៦** ព លប ៣១:៣៥ នក ២១:១២ ចទ ៥:១៦

**២៦:១៩** *រាស្ត្របរិសុទ្ធដល់ព្រះយេហូវ៉ា* មើលការពន្យល់ នក ១៩:៥ ។
**២៧:២–៨** ការចារសិលាចារឹកជាប់ដោយព្រះបន្ទូល ដើម្បីជាការរំលឹកចងចាំវាជាការទម្លាប់អនុវត្តក្នុងសម័យបូរាណ ។
**២៧:២,៤** *បូកបាយអ* គឺដើម្បីចារឹកនៅលើបាយអនោះ ដែលអាចឃើញច្បាស់បាន (មើល ខ.៨) ។
**២៧:៣,៨** *ទាំងពាក្យក្រិត្យវិន័យនេះ* ជាលក្ខណៈមួយចំណែក (មើលការពន្យល់ នក ២០:១) គឺជាសេចក្តីសញ្ញាដែលជាការប្រកាសឡើងវិញរបស់លោកម៉ូសេ ។
**២៧:៤** *លើភ្នំអេបាល* សូមមើលការពន្យល់ យស ៨:២០ ។
**២៧:៥** *ស្អាង . . . អាសនាធ្វើពីថ្ម* គឺវាខុសពីអាសនានៅឯរោងឧបោសថ ដែលមានទម្រង់ដូចក្នុងការពន្យល់ នក ២០:២៥ ។
**២៧:៩** *ឯងបានត្រឡប់ជារាស្ត្ររបស់ព្រះយេហូវ៉ា* ពាក្យព្រះបន្ទូលដែលជាសេចក្តីសញ្ញាបានបង្ហាញឱ្យឃើញ ។
**២៧:១២** *ពួកទាំងនេះឈរនៅលើភ្នំកេរិស៊ីម* ជាពូជទាំង៦របស់លោកយ៉ាកុបតាមរយៈនាងលេអា និងនាងរ៉ាដែល (មើល លប ៣៥:២៣–២៤) មើល ១១:៣០ និងការពន្យល់ ។ *ភ្នំកេរិស៊ីម* មើលការពន្យល់ ៤:២០ ។ *ឱ្យពរ* ខ.១៥–២៦ ពុំបានឃើញព្រះពរធ្លាក់មកទេ តែជំនួសដោយបណ្តាសា (មើល ២៨:១៥–៦៨) ។
**២៧:១៣** *ឯពួកនេះត្រូវឈរឱ្យគេនៅលើភ្នំអេបាល* ពួករូបេន១ និងពួកសាប់យូល៉ូន១ គឺជាពូជរបស់លោកយ៉ាកុប តាមរយៈបាវបម្រើស្រីនាងស៊ីលផា និងប៊ីលហា (មើល លប ៣៥:២៣,២៥–២៦) ។
**២៧:១៥** *ឆ្លាក់ . . . ធ្វើរូប* ការប្រព្រឹត្តបទល្មើសចំពោះបញ្ញត្តិទី១ និងទី២ (មើលការពន្យល់ ២០:១,៤) មើល ៤:២៨ ៥:៦–១០ ។ *អាម៉ែន* ជាពាក្យបានទទួលយល់ស្រប ឬឯកភាព ឬមានន័យថាឱ្យបានដូច្នេះចុះ ដូចជាសេចក្តីសញ្ញាដែលមានទាំងព្រះពរ និងបណ្តាសា (មើល ខ.១៦–២៦) ។
**២៧:១៦** មើល ៥:១៦ នក ២០:១២ និងការពន្យល់ ។

១៧ត្រូវបណ្ដាសាហើយ អ្នកណាដែលបន្ថយគោលចារឹក
របស់អ្នកជិតខាងខ្លួន[ភ] នោះបណ្ដាជនទាំងឡាយត្រូវឆ្លើយ
ឡើងថា អាម៉ែន ។
១៨ត្រូវបណ្ដាសាហើយ អ្នកណាដែលធ្វើឱ្យមនុស្សខ្វាក់
វង្វេងចេញពីផ្លូវទៅ[ម] នោះបណ្ដាជនទាំងឡាយត្រូវឆ្លើយ
ឡើងថា អាម៉ែន ។
១៩ត្រូវបណ្ដាសាហើយ អ្នកណាដែលបង្វែរសេចក្ដី
យុត្តិធម៌ពីអ្នកដទៃ[យ] និងកូនកំព្រា ហើយនិងស្រីមេម៉ាយ[រ]
នោះបណ្ដាជនទាំងឡាយត្រូវឆ្លើយឡើងថា អាម៉ែន ។
២០ត្រូវបណ្ដាសាហើយ អ្នកណាដែលរួមដំណេកនឹង
ប្រពន្ធរបស់ឪពុកខ្លួន ដ្បិតអ្នកនោះបានបើកសំលៀករបស់
ឪពុកហើយ[ល] នោះបណ្ដាជនទាំងឡាយត្រូវឆ្លើយ ឡើងថា
អាម៉ែន ។
២១ត្រូវបណ្ដាសាហើយ អ្នកណាដែលរួមសង្វាសនឹង
សត្វណាមួយ[វ] នោះបណ្ដាជនទាំងឡាយត្រូវឆ្លើយឡើងថា
អាម៉ែន ។
២២ត្រូវបណ្ដាសាហើយ អ្នកណាដែលរួមដំណេកនឹង
បងប្អូនស្រី ជាកូនរបស់ឪពុក ឬម្ដាយតែមួយ[ស] នោះបណ្ដា
ជនទាំងឡាយត្រូវឆ្លើយឡើងថា អាម៉ែន ។
២៣ត្រូវបណ្ដាសាហើយ អ្នកណាដែលរួមដំណេកនឹង
ម្ដាយក្មេករបស់ខ្លួន[ហ] នោះបណ្ដាជនទាំងឡាយត្រូវឆ្លើយ
ឡើងថា អាម៉ែន ។
២៤ត្រូវបណ្ដាសាហើយ អ្នកណាដែលវាយ[ឡ]អ្នកជិតខាង
ខ្លួនដោយសំងាត់[អ] នោះបណ្ដាជនទាំងឡាយត្រូវឆ្លើយឡើង
ថា អាម៉ែន ។
២៥ត្រូវបណ្ដាសាហើយ អ្នកណាដែលស៊ីសំណូកដើម្បី
នឹងសំឡាប់មនុស្សណាដែលឥតទោស[ក] នោះបណ្ដាជនទាំង
ឡាយត្រូវឆ្លើយឡើងថា អាម៉ែន ។
២៦ត្រូវបណ្ដាសាហើយ អ្នកដែលមិនយកចិត្តទុកដាក់ នឹង
អស់ទាំងពាក្យក្នុងក្រិត្យវិន័យនេះ ព្រមទាំងប្រព្រឹត្តតាមផង[ខ]
នោះបណ្ដាជនទាំងឡាយ ត្រូវឆ្លើយឡើងថា អាម៉ែន[គ] ។

## ព្រះពរសម្រាប់ការស្ដាប់បង្គាប់

២៨ ១បើសិនជាខំប្រឹងស្ដាប់ តាមព្រះបន្ទូលនៃព្រះយេហូ
វ៉ា ជាព្រះនៃឯង ឱ្យអស់ពីចិត្ត ព្រមទាំងប្រយ័ត្ននឹងប្រព្រឹត្ត
តាម[ក]អស់ទាំងបញ្ញត្តិ[ខ]ទ្រង់ ដែលអញបង្គាប់ដល់ឯងនៅថ្ងៃ
នេះ នោះព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងលើកឯង
ឡើងជាខ្ពស់ លើសជាងអស់ទាំងសាសន៍នៅផែនដីទាំង
ប៉ុន្មាន[គ] ២រួចអស់ទាំងពរទាំងនេះនឹងបានផ្សាយមកលើ
ឯង[ឃ] ហើយរត់មករកឯងផង គឺបើឯងនឹងស្ដាប់តាមព្រះ
បន្ទូលនៃព្រះយេហូវ៉ា ជាព្រះនៃឯង ៣ឯងនឹងមានពរ[ង]នៅ
ក្នុងក្រុង ហើយនិងមានពរនៅស្រែចំការដែរ[ច] ៤ផលដែល
កើតពីពោះឯងមក ព្រមទាំងផលកើតពីដីឯង និងផលកើត
ពីសត្វឯង គឺជាសេចក្ដីចំរើនរបស់គោ និងកូនទាំងប៉ុន្មាន
របស់ចៀមឯង នោះនឹងមានពរគ្រប់ទាំងអស់[ឆ] ៥ឯកំប្រោង
និងស្បៀងអាហាររបស់ឯង នោះនឹងមានពរដែរ ៦ឯងនឹង
មានពរក្នុងកាលដែលឯងចូលមក ហើយនិងមានពរក្នុង
កាលដែលចេញទៅផង[ជ] ។
៧ព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យពួកខ្មាំងសត្រូវ[ឈ]ដែលលើក
គ្នាមកទាស់នឹងឯង ត្រូវចុះចាញ់នៅមុខឯង គេនឹងចេញមក
ទាស់នឹងឯងតាមផ្លូវមួយ តែនឹងរត់ទៅតាមផ្លូវ៧វិញ ដើម្បី
ឱ្យរួចពីមុខឯងចេញ[ញ] ៨ព្រះយេហូវ៉ាទ្រង់នឹងបង្គាប់ឱ្យមាន
ពរនៅលើជង្រុកឯង ហើយលើគ្រប់ទាំងការអ្វីដែលឯង
នឹងដាក់ដៃធ្វើ ទ្រង់នឹងប្រទានពរ[ដ]ដល់ឯងនៅក្នុងស្រុក
ដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានមក ៩ទ្រង់នឹង
តាំងឯងសំរាប់ជារាស្ត្របរិសុទ្ធ[ឋ]ដល់ទ្រង់ ដូចជាទ្រង់បាន
ស្បថនឹងឯងហើយ គឺបើឯងនឹងកាន់តាមអស់ទាំងបញ្ញត្តិ[ឌ]
របស់ព្រះយេហូវ៉ា ជាព្រះនៃឯង ព្រមទាំងដើរតាមផ្លូវ
ទ្រង់ផង ១០នោះគ្រប់ទាំងសាសន៍នៅផែនដីនឹងឃើញថា
ឯងជាអ្នកមានឈ្មោះតាមព្រះនាម[ឍ]ព្រះយេហូវ៉ា ហើយគេ

**២៧:១៧** ភ ចទ ១៩:១៤ **២៧:១៨** ម លប ១៩:១៤ **២៧:១៩** យ នក ២២:២១ ចទ ២៤:១៩ រ នក ២៣:២ ចទ ១០:១៨ **២៧:២០** ល លប ៣៤:៥ លវ ១៨:៥ **២៧:២១** វ នក ២២:១៩ **២៧:២២** ស លវ ១៨:៩ **២៧:២៣** ហ លវ ២០:១៤ **២៧:២៤** ឡ លប ៤:២៣ អ នក ២១:១២ **២៧:២៥** ក នក ២៣:៧-៨ លវ ១៩:១៦ **២៧:២៦** ខ លវ ២៦:១៤ ចទ ២៨:១៥ ទដ ១១៩:២១ យរ ១១:៣ កទ ៣:១០ គ យរ ១១:៥

**២៨:១** ក ចទ ១៥:៥ ខ លវ ២៦:៣ គ ជន ២៤:៧ ចទ ២៦:១៩ **២៨:២** ឃ យរ ៣២:២៤ សក ១:៦ **២៨:៣** ង ទដ ១៤៤:១៥ ច លប ៣៩:៥ **២៨:៤** ឆ លប ៤៩:២៥ ចទ ៨:១៨

**២៨:៦** ជ ទដ ១២១:៨ **២៨:៧** ឈ ២របា ៦:៣៤ ញ លវ ២៦:៨,១៧ **២៨:៨** ដ ចទ ១៥:៤ **២៨:៩** ឋ នក ១៩:៦ ឌ លវ ២៦:៣ **២៨:១០** ឍ ជន ៦:២៧ ១ពវ ៨:៤៣ យរ ២៥:២៩ ដយ ៩:១៨

**២៧:១៧** មើលការពន្យល់ ១៩:១៤ ។

**២៧:១៩** មើល ២៤:១៧-១៨ និងការពន្យល់ ។

**២៧:២០** មើល ២២:៣០ លវ ១៨:៨ និងការពន្យល់ ។

**២៧:២១** មើល នក ២២:១៩ និងសូមមើលការពន្យល់ លវ ១៨:២៣ ២០:១៥-១៦ ។

**២៧:២៤-២៥** មើល ៥:១៧ នក ២០:១៣ និងការពន្យល់ ២១:២១ លវ ២៤:១៧,២១ ។

**២៧:២៦** ការដកស្រង់ក្នុង កទ ៣:១០ បានបង្ហាញថា មនុស្សលោកគឺកំពុងទទួលបណ្ដាសា ពីព្រោះតែគ្មានអ្នកណាម្នាក់ដើរតាមច្បាប់របស់ផងទ្រង់បានទាំងស្រុងទេ (ប្រៀបធៀប យក ២:១០ ១យហ ១:៨,១០) ។

**២៨:១-១៤** ព្រះពរទាំងនេះគឺផ្ទុយគ្នានិងបណ្ដាសាក្នុង ខ.១៥-៤៤ (សូមប្រៀបធៀបជាពិសេសក្នុង ខ.៣-៦,១៦-១៩) ។

**២៨:៥,១៧** *ឯកំប្រោង . . . ស្បៀងអាហារ* ប្រើសម្រាប់ដាក់ទុក ឬសម្រាប់បម្រុងទុកអាហារ ជាពិសេសអាហារនោះ គឺនំប៉ុង ។

**២៨:៧** ភាពផ្ទុយគ្នានៅ ខ.២៥ ។

**២៨:៩** *តាំងឯងសំរាប់ជារាស្ត្របរិសុទ្ធ* មើល ៧:៦ និងការពន្យល់ ។

នឹងកោតខ្លាចដល់ឯង ១១ព្រះយេហូវ៉ាទ្រង់ក៏នឹងចំរើនឱ្យ
ឯងមានជាបរិបូរឡើង ដោយផលដែលកើតពីពោះ និង
ផលកើតពីហ្វូងសត្វ[ណ] ហើយនិងផលកើតពីដីឯង នៅក្នុង
ស្រុកដែលព្រះយេហូវ៉ាបានស្បថនឹងពួកឰយុកោថា និងឱ្យ
ដល់ឯង[ត] ១២ព្រះយេហូវ៉ាទ្រង់នឹងបើកឃ្លាំង[ថ]ដ៏វិសេស
របស់ទ្រង់[ទ]ឱ្យដល់ឯង គឺជាផ្ទៃមេឃ ឱ្យមានភ្លៀង[ធ]ធ្លាក់មក
សំរាប់ស្រុកឯងតាមរដូវកាល ហើយនិងឱ្យពរ[ន]ដល់គ្រប់
ទាំងការដែលដៃឯងធ្វើ នោះឯងនឹងឱ្យសាសន៍ជាច្រើនខ្ចី
ឥតមានខ្ចីពីគេវិញឡើយ[ប] ១៣ព្រះយេហូវ៉ាទ្រង់នឹងតាំងឯង
ទុកជាក្បាល មិនមែនជាកន្ទុយឡើយ ឯងនឹងនៅតែពីលើគេ
មិនដែលនៅពីក្រោមទេ គឺបើឯងនឹងស្តាប់តាម[ផ]អស់ទាំង
សេចក្តីបញ្ញត្តិផងព្រះយេហូវ៉ា ជាព្រះនៃឯង ដែលអញ
បង្គាប់ដល់ឯងនៅថ្ងៃនេះ ដើម្បីនឹងកាន់ ហើយប្រព្រឹត្តតាម
ផង[ព] ១៤ឥតមានងាកបែរទៅខាងស្តាំ ឬខាងឆ្វេង[ភ] ចេញ
ពីព្រះបន្ទូលណាមួយ ដែលអញបង្គាប់ដល់ឯងនៅថ្ងៃ
នេះ ដើម្បីនឹងរក ហើយគោរពប្រតិបត្តិតាមព្រះដទៃនោះ
ឡើយ ។

## បណ្តាសាចំពោះការមិនស្តាប់បង្គាប់

១៥ប៉ុន្តែ បើឯងមិនព្រមស្តាប់តាម[ម]ព្រះបន្ទូលនៃព្រះយេ
ហូវ៉ា ជាព្រះនៃឯង ហើយមិនប្រយ័ត្ននឹងប្រព្រឹត្តតាមគ្រប់
ទាំងសេចក្តីបញ្ញត្តិ និងច្បាប់ទាំងប៉ុន្មានរបស់ទ្រង់ ដែល
អញបង្គាប់ដល់ឯងនៅថ្ងៃនេះទេ[យ] នោះអស់ទាំងសេចក្តី
បណ្តាសាទាំងនេះ និងផ្សាយមកលើឯង ហើយរត់មករក
ឯងផង[រ] ១៦គឺឯងនឹងត្រូវបណ្តាសានៅក្នុងទីក្រុង ហើយនៅ
ស្រែចំការដែរ[ល] ១៧ឯកំប្រោង និងស្បៀងអាហាររបស់ឯង
នោះនឹងត្រូវបណ្តាសាវិញ[វ] ១៨ផលដែលកើតពីពោះ និង
ផលកើតពីដីឯង ហើយនិងសេចក្តីចំរើនរបស់ហ្វូងគោ និង
កូនទាំងប៉ុន្មានរបស់ហ្វូងចៀមឯង នោះនឹងត្រូវបណ្តាសា
ទាំងអស់[ស] ១៩ឯងនឹងត្រូវបណ្តាសា ក្នុងកាលដែលឯងចូល
មក ហើយនិងត្រូវបណ្តាសា ក្នុងកាលដែលឯងចេញទៅ
ផង[ហ] ។

២០ព្រះយេហូវ៉ាទ្រង់នឹងចាត់សេចក្តីបណ្តាសា[ឡ] និងសេ
ចក្តីបាក់បប ហើយសេចក្តីបន្ទោស[អ] មកលើឯងក្នុងគ្រប់
ការអ្វីដែលឯងដាក់ដៃធ្វើ ដរាបដល់ត្រូវបំផ្លាញចេញ
ហើយវិនាសអស់ទៅជាឆាប់ផង[ក] ដោយព្រោះអំពើអាក្រក់
របស់ឯង[ខ] ដែលបានលះបង់ចោលអញ ២១ព្រះយេហូវ៉ា
ទ្រង់នឹងធ្វើឱ្យជំងឺអាសន្នរោគនៅជាប់នឹងឯង ដរាបដល់
ឯងរោយរៀវបាត់ចេញពីស្រុក ដែលឯងចូលទៅចាប់យក
នោះអស់ទៅ[គ] ២២ព្រះយេហូវ៉ាទ្រង់នឹងវាយឯងដោយជំងឺ
រីងរៃ[ឃ] និងគ្រុនរងា ហើយដោយកើត ហើម ពិស
និងក្តៅខ្លួនដូចភ្លើង ដោយដាវ និងស្រូវស្កក[ង] ហើយ
ក្រា[ច]ផងសេចក្តីវេទនាទាំងនោះនឹងដេញតាម[ឆ]ឯង ទាល់តែ
វិនាសបាត់អស់រលីងទៅ[ជ] ២៣ឯមេឃពីលើក្បាលឯង នឹង
បានដូចជាលង្ហិន ហើយដីនៅក្រោមឯង នឹងបានដូចជា
ដែក[ឈ] ២៤ព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យមានភ្លៀង[ញ] មកលើ
ស្រុកឯង ជាធូលីនឹងផង់លំអងដី ដែលនឹងធ្លាក់ពីលើមេឃ
មកលើឯង ដរាបដល់ឯងវិនាសបាត់អស់ទៅ ។

២៥ព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យឯងចុះចាញ់[ដ] នៅមុខពួក
ខ្មាំងសត្រូវ ឯងនឹងចេញទៅទាស់នឹងគេតាមផ្លូវ១ តែនឹង
រត់ទៅតាមផ្លូវ៧វិញ[ឋ] ដើម្បីឱ្យរួចពីមុខគេចេញ ហើយឯង
នឹងត្រូវខ្ចាត់ចុះឡើង[ឌ]ក្នុងគ្រប់ទាំងនគរនៅផែនដី[ឍ] ២៦ខ្មោច
របស់ឯងនឹងបានជាអាហារដល់សត្វហើរនៅលើអាកាស[ណ]
និងសត្វព្រៃនៅដី ឥតមានអ្នកណានឹងដេញវាឡើយ[ត] ២៧ព្រះ
យេហូវ៉ាទ្រង់នឹងវាយឯង ដោយបូសដែលកើតនៅស្រុក
អេស៊ីព្ទ[ថ] និងបូសដូងបាត កមហើយនឹងរមាស់ផង ដែលឯង
នឹងមើលមិនចេះជាឡើយ ២៨ព្រះយេហូវ៉ាទ្រង់នឹងវាយឯង
ឱ្យវង្វេងស្មារតី ឱ្យខ្វាក់ភ្នែក ហើយឱ្យមានចិត្តឆ្ងល់ភាំង
២៩ឯងនឹងដើរស្ទាប[ទ]រកផ្លូវទាំងថ្ងៃត្រង់ ដូចជាមនុស្សខ្វាក់
ស្ទាបរាវរកផ្លូវក្នុងទីងងឹតដែរ ហើយឯងនឹងធ្វើការអ្វី តាម
ផ្លូវប្រព្រឹត្តរបស់ឯង ក៏មិនកើតឡើយ គេនឹងសង្កត់សង្កិន

**២៨:១១** ណ លប ៣០:២៧ ត ខ.៤ **២៨:១២** ថ យប ៣៨:២២ ទដ ១៣៥:៧ យរ ១០:១៣ ៥១:១៦ ទ ទដ ៦៥:១១ ៦៨:១០ យរ ៣១:១២ ធ លវ ២៦:៤ ១ពវ ៨:៣៥–៣៦ ១៨:១ ទដ ១០៤:១៣ អស ៥:៦ ៣០:២៣ ៣២:២០ ន អស ៦១:៩ ៦៥:២៣ យរ ៣២:៣៨–៤១ មឡ ៣:១២ ប ខ.៤៤ លវ ២៥:១៩ ចទ ១៥:៣,៦ អគ ៣៤:២៦ **២៨:១៣** ផ យរ ១១:៦ ព ចទ ២៦:១៩ **២៨:១៤** ភ ចទ ៥:៣២ យស ១:៧ **២៨:១៥** ម ១ពវ ៩:៦ ២ពវ ៧:១៩ យ ចទ ២៧:២៦ រ ចទ ២៩:២៧ យស ២៣:១៥ ២របា ១២:៥ ដយ ៩:១១ មឡ ២:២ **២៨:១៦** ល ខ.៣ **២៨:១៧** វ ខ.៥ **២៨:១៨** ស ខ.៤ **២៨:១៩** ហ ខ.៦

**២៨:២០** ឡ ខ.៨,១៥ លវ ២៦:១៦ យរ ៤២:១៨ មឡ ២:២ ៣:៩ ៤:៦ អ ទដ ៣៩:១១ ៧៦:៦ ៨០:១៦ អស ១៧:១៣ ៥១:២០ ៥៤:៩ ៦៦:១៥ អគ ៥:១៥ ក ចទ ៤:២៦ ខ នក ៣២:២២

**២៨:២១** គ លវ ២៦:២៥ ជន ១៤:១២ យរ ២៤:១០ អម ៤:១០ **២៨:២២** ឃ ខ.៤៨ ចទ ៣២:២៤ ង លវ ២៦:១៦ ២ពវ ៨:១ យប ១២:១៥ ទដ ១០៥:១៦ យរ ១៤:១ ហក ១:១១ មឡ ៣:៩ ច ហក ២:១៧ ឆ លវ ២៦:២៥ ជ ចទ ៤:២៦ អម ៤:៩ **២៨:២៣** ឈ លវ ២៦:១៩ **២៨:២៤** ញ លវ ២៦:១៩ ចទ ១១:១៧ ១ពវ ៨:៣៥ ១៧:១ អស ៥:៦ យរ ១៤:១ ហក ១:១០ **២៨:២៥** ដ ១សយ ៤:១០ ទដ ៧៨:៦២ ឋ លវ ២៦:១៧ ឌ ខ.៣៧ ឍ ២របា ២៩:៨ ៣០:៧ យរ ១៥:៤ ២៤:៩ ២៦:៦ ២៩:១៨ ៤៤:១២ អគ ២៣:៤៦ **២៨:២៦** ណ លប ៤០:១៩ ត ទដ ៧៩:២ អស ១៨:៦ យរ ៧:៣៣ ១២:៩ ១៥:២ ១៦:៤ ១៩:៧ ៣៤:២០ **២៨:២៧** ថ ចទ ៧:១៥ **២៨:២៩** ទ លប ១៩:១១ នក ១០:២១ យប ៥:១៤ ១២:២៥ ២៤:១៣ ៣៨:១៥ អស ៥៩:១០

**២៨:១២** *ឃ្លាំង . . . ជាផ្ទៃមេឃ* ចំពោះពាក្យថាផ្ទៃមេឃដូចជាឃ្លាំងនៃទឹកភ្លៀង ព្រឹល និងខ្យល់ មើល យប ៣៨:២២ ទដ ១៣៥:៧ យរ ១០:១៣ ។

**២៨:១៣** *ទុកជាក្បាល មិនមែនជាកន្ទុយឡើយ* ខដែលផ្ទុយគ្នានោះគឺ ខ.៤៤ ។

**២៨:១៦–១៩** ភាពផ្ទុយគ្នាគឺ ខ.៣–៦ (មើលការពន្យល់ ខ.១–៤) ។

**២៨:២៣** *មេឃ . . . លង្ហិន . . . ដី . . . ដែក* គ្មានភ្លៀងណាអាចធ្វើឱ្យផ្ទៃមេឃ ឬអាចធ្លុះដល់ដីទេ សូមមើល ខ.២២ ។

**២៨:២៥** ចំពោះផ្ទៃមេឃគឺ ខ.៧ ។

**២៨:២៧** *បូសដែលកើតនៅស្រុកអេស៊ីព្ទ* មើលការពន្យល់ នក ៩:៩ ។

ឯងជានិច្ច ហើយបំបាត់យករបស់ឯងជាដរាប ឥតមានអ្នក
ណាជួយ[ធ]ឡើយ ៣០ឯងនឹងដណ្ដឹងប្រពន្ធ តែនឹងមានអ្នកឯ
ទៀតរួមដំណេកនឹងនាងវិញ[ន] ឯងនឹងសង់ផ្ទះ តែមិនបាន
ឡើងនៅទេ[ប] ឯងនឹងដាំចំការទំពាំងបាយជូរ តែមិនបាន
ទទួលផលផ្លែទេ[ផ] ៣១គេនឹងសំឡាប់គោឯងនៅចំពោះភ្នែក
ឯង តែឯងមិនបានបរិភោគសោះ គេនឹងកំហែងយកលា
ពីមុខឯងទៅ ឥតប្រគល់មកវិញឡើយ គេនឹងឱ្យហ្វូងចៀម
ឯង ទៅពួកខ្មាំងសត្រូវវិញ ឥតមានអ្នកណានឹងជួយឯងផង
៣២គេនឹងឱ្យកូនប្រុសកូនស្រីឯងដល់សាសន៍ដទៃ[ព] ភ្នែកឯង
នឹងស្រវាំងទៅដោយនឹករឭក ហើយសំឡឹងមើលតាមវា
ជានិច្ច ដៃឯងក៏នឹងគ្មានកំឡាំងសោះ ៣៣សាសន៍១ដែលឯង
មិនស្គាល់ គេនឹងស៊ីបំផ្លាញផលពីដី និងការនឿយហត់របស់
ឯងទាំងអស់ ឯងនឹងត្រូវគេសង្កត់សង្កិនជានិច្ច[ភ] ហើយជិះ
ជាន់ជាដរាប[ម] ៣៤ដល់ម៉្លេះបានជាឯងនឹងវង្វេងស្មារតី
ដោយអស់ទាំងការដែលឯងមើលឃើញនឹងភ្នែក[យ] ៣៥ព្រះ
យេហូវ៉ាទ្រង់នឹងវាយឯងនៅត្រង់ក្បាលជង្គង់ ហើយនៅ
ជើង ឱ្យកើតមានដំបៅអាក្រក់[រ] ចាប់តាំងពីបាតជើងទៅដល់
ក្រយៅក្បាល[ល]ដែលឥតមានអ្នកណាមើលឱ្យជាបានឡើយ។
៣៦ព្រះយេហូវ៉ាទ្រង់នឹងនាំយកឯង ហើយនិងស្តេច[វ]ដែល
ឯងនឹងតាំងឡើងលើឯង ទៅឯនគរ១ទៀត ដែលឯងនឹង
ពួកឰយុកោឯង[ស]មិនដែលបានស្គាល់ នៅស្រុកនោះឯងនឹង
គោរពប្រតិបត្តិដល់ព្រះដទៃ ដែលធ្វើពីឈើ ហើយពីថ្ម[ហ]
៣៧ឯងនឹងត្រឡប់ទៅជាទីអស្ចារ្យ[ឡ] និងជាទីប្រៀបធៀប[អ]
ហើយជាទីដំនៀល[ក] នៅកណ្ដាលគ្រប់អស់ទាំងសាសន៍
ដែលព្រះយេហូវ៉ានឹងនាំឯងទៅនៅនោះ[ខ] ៣៨ឯងនឹងនាំយក
ពូជពង្រោះជាច្រើន ទៅសាបព្រោះនៅក្នុងស្រែឯង តែនឹង
ច្រូតបានតែបន្តិចវិញទេ[គ] ដ្បិតកណ្ដូប[ឃ]នឹងកាត់បំផ្លាញ[ង]ទាំង
អស់ទៅ ៣៩ឯងនឹងដាំចំការទំពាំងបាយជូរ[ច] ហើយខំថែទាំ
រក្សាផង តែមិនបានក្រេបរសរបស់ផ្លែនោះឡើយ ក៏មិន
បានទាំងបេះផង ដ្បិតដង្កូវនឹងស៊ី[ឆ]ទាំងអស់ទៅ[ជ] ៤០ឯងនឹង
មានដើមអូលីវ នៅពេញក្នុងស្រុកឯង តែមិនបានយកប្រេង
មកលាបខ្លួនសោះ ដ្បិតក្តិបនឹងជ្រុះរុះទាំងអស់ទៅ[ឈ] ៤១ឯង
នឹងបង្កើតបានកូនប្រុសកូនស្រី តែមិនបានជារបស់ផងឯង
ទេ ដ្បិតគេនឹងនាំវាទៅជាឈ្លើយ[ញ] ៤២អស់ទាំងដើមឈើ
និងផលកើតពីដីរបស់ឯង នោះនឹងបានជារបស់ផង
កណ្ដូប[ដ]វិញ ៤៣អ្នកប្រទេសក្រៅដែលនៅជាមួយ នឹងឡើង
ទៅជាខ្ពស់ជាងឯងជាដរាប ហើយឯងនឹងចុះទៅជាដទាប
ជាងគេ[ឋ] ៤៤គេនឹងឱ្យឯងខ្ចី តែឯងមិនបានឱ្យគេខ្ចីទេ[ឌ] គេនឹង
ធ្វើជាក្បាល ហើយឯងនឹងទៅជាកន្ទុយវិញ[ឍ]។
៤៥គ្រប់ទាំងសេចក្ដីបណ្ដាសាទាំងនេះ នឹងផ្សាយមកលើ
ឯង ហើយនិងដេញតាមឯងទាន់[ណ]ផង ដរាបដល់ឯងវិនាស
បាត់ទៅ[ត] ដោយព្រោះឯងមិនបានស្តាប់តាមព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ជាព្រះនៃឯង ដើម្បីនឹងកាន់តាមអស់ទាំង
ច្បាប់ និងបញ្ញត្តិទាំងប៉ុន្មានរបស់ទ្រង់ ដែលទ្រង់បាន
បង្គាប់មកឯងនោះ ៤៦សេចក្ដីទាំងនោះនឹងនៅជាប់លើឯង
ហើយលើពូជឯង សំរាប់ជាទីសំគាល់ ហើយជាទីអស្ចារ្យ
នៅអស់កល្បជានិច្ច[ថ]។
៤៧ដោយហេតុតែឯងមិនបានគោរពប្រតិបត្តិ[ទ] ដល់ព្រះ
យេហូវ៉ា ជាព្រះនៃឯង ដោយចិត្តរីករាយសប្បាយ[ធ] នៅ
កណ្ដាលរបស់ដែលមានជាបរិបូរទាំងប៉ុន្មាន ៤៨បានជាឯង
ត្រូវបំរើពួកខ្មាំងសត្រូវ ដែលព្រះយេហូវ៉ានឹងឱ្យមកទាស់
នឹងឯង គឺនឹងបំរើគេទាំងស្រេកឃ្លាន[ន] ទាំងនៅអាក្រាត
ទាំងខ្វះខាតរបស់ទាំងអស់វិញ ហើយទ្រង់នឹងបំពាក់នឹម
ដែក[ប]មកលើកឯង[ផ]ដរាបដល់ឯងបានវិនាសបាត់ទៅ ៤៩ព្រះ
យេហូវ៉ាទ្រង់នឹងនាំសាសន៍១[ព]ពីចំងាយ គឺពីចុងផែនដីមក[ភ]
ដូចជាឥន្ទ្រីហើរ[ម] ជាសាសន៍ដែលឯងស្តាប់ភាសាគេមិន

ធ ពច ៣:៩ ២ពវ ១៣:៥ នអ ៤:១៤ អស ១៩:២០ ៤៣:១១ ហស ១៣:៤ អប ១:២១ **២៨:៣០** ន យប ៣១:១០ ប អស ៦៥:២២ អម ៥:១១ ផ យរ ១២:១៣ **២៨:៣២** ព ខ.៤១ **២៨:៣៣** ភ យរ ៦:៦ ២២:១៧ ម យរ ៥:១៥–១៧ អគ ២៥:៤ **២៨:៣៤** យ ខ.៦៧ **២៨:៣៥** រ ចទ ៧:១៥ វវ ១៦:២ ល យប ២:៧ ៧:៥ ១៣:២៨ ៣០:១៧, ៣០ អស ១:៦ **២៨:៣៦** វ ១សយ ១២:២៥ ស ចទ ៤:២៧ ២ពវ ២៤:១៤ ២៥:៧,១១ ២របា ៣៣:១១ ៣៦:២១ អរ ៥:១២ យរ ១៥:១៤ ១៦:១៣ ២៧:២០ ៣៩:១–៩ ៥២:២៨ បទ ១:៣ ហ ចទ ៤:២៨ **២៨:៣៧** ឡ ខ.២៥ យរ ៤២:១៨ អគ ៥:១៥ អ ទដ ២២:៧ ៣៩:៨ ៤៤:១៣ ៦៤:៨ យរ ១៨:១៦ ៤៨:២៧ មីក ៦:១៦ ក ២របា ៧:២០ អរ ៩:៧ យរ ៤៤:៨ ខ ១ពវ ៩:៧ ទដ ៤៤:១៤ យរ ១៩:៨ ២៤:៩ ២៥:៩,១៨ ២៩:១៨ បទ ២:១៥ **២៨:៣៨** គ លវ ២៦:២០ ទដ ១២៩:៧ អស ៥:១០ យរ ១២:១៣ ហស ៨:៧ មីក ៦:១៥ ហាក ១:៦,៩ ២:១៦ ឃ នក ១០:៤ ង នក ១០:១៥ **២៨:៣៩** ច លវ ១០:៩ ឆ យអ ១:៤ ២:២៥ មឡ ៣:១១ ជ អស ៥:១០ ១៧:១០–១១ សផ ១:១៣ **២៨:៤០** ឈ យរ ១១:១៦ មីក ៦:១៥ **២៨:៤១** ញ ខ.៣២ **២៨:៤២** ដ ខ.៣៨ ពច ៦:៥ ៧:១២ យរ ៤៦:២៣ **២៨:៤៣** ឋ ខ.១៣ **២៨:៤៤** ឌ ខ.១២ ឍ ចទ ២៦:១៩ **២៨:៤៥** ណ នក ១៥:៩ ត ខ.១៥ ចទ ៤:២៥–២៦ **២៨:៤៦** ថ ជន ១៦:៣៨ ទដ ៧១:៧ អស ៨:១៨ ២០:៣ អគ ៥:១៥ សក ៣:៨ **២៨:៤៧** ទ ចទ ១០:១២ ធ លវ ២៣:៤០ នហ ៩:៣៥ **២៨:៤៨** ន យរ ១៤:៣ បទ ៤:៤ ប យរ ២៨:១៣–១៤ បទ ១:១៤ ផ លប ៤៩:៨ **២៨:៤៩** ព លវ ២៦:៤៤ ភ អស ៥:២៦–៣០,២៦ ៧:១៨–២០ ៣៩:៣

**២៨:៣០** មើល ២០:៥–៨ និងការពន្យល់ ៦៥:២១–២២ ។

**២៨:៣៥** មើលការពន្យល់ នក ៦:១១ ។

**២៨:៤៤** មើលការពន្យល់ ខ.១២–១៣ ។

**២៨:៤៩** *ចុងផែនដី* ដែលបញ្ជាក់ពីភាពមិនអាចវាស់បាន គឺមានន័យថា" ឆ្ងាយណាស់"ដែលឆ្ងាយផុតកន្ទុយភ្នែក ។ *ដូចជាឥន្ទ្រីហើរ* ក្រោយមកទៀតក៏បង្ហាញពីនិមិត្តសញ្ញា នៃការថ្លែង ឬអំណាចនៃស្រុកអាសស៊ើរ (មើល ហស ៨:១) និងពួកអ្នកស្រុកបាប៊ីឡូន (មើល យរ ៤៨:៤០ ៤៩:២២) ។ *ជាសាសន៍ដែលឯងស្តាប់ភាសាគេមិនបាន* ការព្រមានរបស់ព្រះយេហូវ៉ាបានសម្តែងតាមរយៈសកម្មភាពនៅស្រុកអាសស៊ើរ និងពួកបាប៊ីឡូនគឺជាអ្នកមានភាសាដែលទំនាក់ទំនង និងភាសាហេព្រើរ ដែលប្រជាជនអ៊ីស្រាអែលភាគច្រើនមិនអាចយល់បាន ។ (មើល អស ២៨:១១ ៣៣:១៩ និងការពន្យល់ ១កថ ១៤:២១) ។

បាន[ឃ] ៥០ជាសាសន៍មានទឹកមុខសាហាវ ឥតមានយល់ដល់
ចាស់[ង] ក៏មិនចេះអាណិតដល់ក្មេងផង ៥១គេនឹងស៊ីផលពីហ្វូង
សត្វឯង និងពីដីឯង ដរាបដល់ឯងវិនាសបាត់ទៅ គេមិន
ទុកឱ្យឯងមានស្រូវ ឬទឹកទំពាំងបាយជូរ[ល] ឬប្រេង[វ] ឬផល
ចំរើនពីហ្វូងគោ ហ្វូងចៀមឯងឡើយ ដរាបដល់គេបាន
បំផ្លាញឯងអស់រលីងទៅ[ស] ៥២គេនឹងចោមព័ទ្ធ[ហ]ច្បាំងនឹង
ឯង នៅក្នុងអស់ទាំងទីក្រុងឯង ដរាបដល់កំផែងខ្ពស់ ហើយ
មាំមួន ដែលឯងយកជាទីពឹងនោះ បានរលំនៅពេញក្នុង
ស្រុកឯង គេនឹងឡោមព័ទ្ធច្បាំងនឹងឯង នៅក្នុងទីក្រុងទាំង
អស់នៅពេញក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់បានប្រទានឱ្យ[ឡ] ៥៣ហើយនៅវេលាគេឡោមព័ទ្ធឯង
ជុំវិញ និងគ្រាដែលមានសេចក្ដីលំបាក ដែលខ្មាំងសត្រូវនឹង
ធ្វើទុក្ខដល់ឯង នោះឯងនឹងបរិភោគផលដែលកើតចេញ
ពីខ្លួនឯង គឺជាសាច់របស់កូនប្រុសកូនស្រីឯង ដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានឱ្យ[អ] ៥៤អ្នកណាដែល
រមែងមានចិត្តថ្នម ហើយស្រទន់ណាស់ក្នុងពួកឯង អ្នកនោះ
ឯងនឹងត្រឡប់ជាមានភ្នែកអាក្រក់ដល់បងប្អូនខ្លួន ដល់
ប្រពន្ធជាទីស្រឡាញ់របស់ខ្លួន ហើយដល់កូនខ្លួនទាំងប៉ុន្មាន
ដែលនៅសល់វិញ ៥៥ដល់ម្ល៉េះបានជាមិនព្រមទាំងចែក
សាច់កូនរបស់ខ្លួន ដែលកំពុងតែបរិភោគ ឱ្យដល់អ្នក
ណាមួយនោះឡើយ ដោយព្រោះគ្មានអ្វីសល់ទៀត គឺក្នុងគ្រា
ដែលខ្មាំងសត្រូវឯង នៅព័ទ្ធជុំវិញនោះ និងវេលាដែលឯង
មានសេចក្ដីលំបាក ដោយគេធ្វើទុក្ខដល់ឯង នៅគ្រប់ទាំង
ទីក្រុងឯងផង[ក] ៥៦ហើយស្ត្រីណាដែលមានចិត្តថ្នម ហើយ
ស្រទន់[ខ]នៅក្នុងពួកឯង ជាស្ត្រីដែលមិនដែលទាំងដាក់បាត
ជើងដល់ដីផង ដោយព្រោះនាងទន់ភ្លន់ហើយថ្នមខ្លួន នាង
នោះនឹងមានភ្នែកអាក្រក់ដល់ប្ដី ជាទីស្រឡាញ់របស់ខ្លួន និង
ដល់កូនប្រុសកូនស្រីខ្លួន[គ] ៥៧ហើយដល់ទាំងកូនខ្ចី ដែល
ទើបនឹងចេញពីផ្ទៃខ្លួនមក ព្រមទាំងដល់កូនដែលនាងនឹង
សំរាលទៀតផង ដ្បិតនាងនឹងបរិភោគវាដោយសំងាត់[ឃ]
ដោយព្រោះគ្មានអ្វីសោះ ក្នុងគ្រាដែលពួកខ្មាំងសត្រូវនៅ
ព័ទ្ធជុំវិញនោះ និងវេលាដែលមានសេចក្ដីលំបាក ដោយគេ
ធ្វើទុក្ខដល់ឯង នៅក្នុងអស់ទាំងទីក្រុងរបស់ឯង ។
៥៨បើឯងមិនព្រមប្រយ័ត្ន នឹងធ្វើតាមអស់ទាំងពាក្យ ក្នុង
ក្រិត្យវិន័យ[ង] ដែលបានកត់ទុកក្នុងគម្ពីរនេះ ដើម្បីឱ្យបាន
កោតខ្លាច[ច]ដល់ព្រះនាម[ឆ]ដ៏មានសិរីល្អ ហើយគួរស្ញែងខ្លាច
នេះ គឺ "ព្រះយេហូវ៉ា ជាព្រះនៃឯង" ៥៩នោះព្រះយេហូវ៉ា
នឹងធ្វើឱ្យសេចក្ដីវេទនារបស់ឯង បានចំឡែកអស្ចារ្យ ព្រម
ទាំងសេចក្ដីវេទនានៃពូជឯងផង គឺជាសេចក្ដីវេទនាយ៉ាងធំ
ហើយជាប់ជាយូរ និងជំងឺគ្រាំគ្រាដែលនៅជាប់ជាយូរដែរ
៦០ទ្រង់នឹងធ្វើឱ្យឯងកើតអស់ទាំងជំងឺរបស់ស្រុកអេស៊ីព្ទ[ជ]
ដែលឯងបានខ្លាចនោះទាំងប៉ុន្មាន ជំងឺទាំងនោះនឹងនៅ
ជាប់នឹងឯង ៦១ព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យឯងកើតគ្រប់ទាំង
ជំងឺ ហើយនិងសេចក្ដីវេទនាទាំងអស់ ដែលមិនបានកត់ទុក
ក្នុងគម្ពីរក្រិត្យវិន័យនេះទៀត[ឈ] ដរាបដល់ឯងបានវិនាស
បាត់អស់រលីងទៅ[ញ] ៦២ហើយទោះបើពីដើមឯងរាល់គ្នា
មានគ្នាច្រើន ដូចជាផ្កាយនៅលើមេឃ[ដ]ក៏ដោយ គង់តែ
នឹងនៅសល់តែបន្តិច[ឋ]ទេ ពីព្រោះឯងមិនបានស្ដាប់តាម
ព្រះបន្ទូលនៃព្រះយេហូវ៉ា ជាព្រះនៃឯង ៦៣នៅគ្រានោះ
ព្រះយេហូវ៉ាទ្រង់នឹងសព្វព្រះហឫទ័យ[ឌ] ធ្វើឱ្យឯងរាល់គ្នា
វិនាស[ឍ] ហើយនិងបំផ្លាញឯងរាល់គ្នាចេញ[ណ] ដូចជាកាលពី
ដើមទ្រង់សព្វព្រះហឫទ័យ[ត] និងប្រោសសេចក្ដីល្អដល់ឯង

យរ ៤:១៦ ៥:១៥ ៦:២២ ២៥:៣២ ៣១:៨ ហាព ១:៦ ម ២សយ ១:២៣ យរ ៤:១៣ ៤៨:៤០ ៤៩:២២ បទ ៤:១៩ អគ ១៧:៣ យ លប ម ២សយ ១:២៣ យរ ៤:១៣ ៤៨:៤០ ៩:២២ បទ ៤:១៩ អគ ១៧:៣ យ លប **២៨:៥០** រ អស ៤៧:៦ **២៨:៥១** ល ទដ ៤:៧ អស ៣៦:១៧ ហាក ១:១១ វ ជន ១៨:១២ ស ខ.៣៣ ពច ៦:៤ **២៨:៥២** ហ ២ពវ ៦:២៤ ឡ យរ ១០:១៨ អគ ៦:១០ សផ ១:១៤–១៦,១៧ **២៨:៥៣** អ ខ.៥៧ លវ ២៦:២៩ ២ពវ ៦:២៨–២៩ បទ ២:២០ **២៨:៥៥** ក ២ពវ ៦:២៩ **២៨:៥៦** ខ អស ៤៧:១ គ បទ ៤:១០ **២៨:៥៧** ឃ ខ.៥៣ **២៨:៥៨** ង ចទ ៣១:២៤ ច ទដ ៩៦:៤ យរ ៥:២២ មឡ ១:១៤ ២:៥ ៣:៥,១៦ ៤:២ ឆ នក ៣:១៥ យស ៧:៩ **២៨:៦០** ជ នក ១៥:២៦ **២៨:៦១** ឈ ចទ ២៩:២១ ៣០:១០ ៣១:២៦ យស ១:៨ ៨:៣៤ ២៣:៦ ២៤:២៦ ២ពវ ១៤:៦ ២២:៨ ២របា ១៧:៩ ២៥:៤ នហ ៨:១,១៨ មឡ ៤:៤ ញ ចទ ៤:២៥–២៦ **២៨:៦២** ដ លប ២២:១៧ ចទ ៤:២៧ ១០:២២ ឋ លវ ២៦:២២ **២៨:៦៣** ឌ សភ ១:២៦ ឍ លប ៦:៧ ណ ទដ ៥២:៥ យរ ១២:១៤ ៣១:២៨ ៤៥:៤ ត ចទ ៣០:៩ ងស

**២៨:៥៣** *សេចក្ដីលំបាក ដែលខ្មាំងសត្រូវនិងធ្វើទុក្ខដល់ឯង* មើល ខ.៥៥,៥៧ បទគម្ពីរបានបង្ហាញដដែលៗ ដោយផ្ដោតទៅលើប្រជាជនអ៊ីស្រាអែលត្រូវទទួលការឈឺចាប់ បើគេនៅតែបដិសេធន៍ ដោយមិនស្ដាប់បង្គាប់ព្រះយេហូវ៉ា ។ *ឯងនិងបរិភោគផលកូនប្រុសកូនស្រីឯង* ចំពោះការបញ្ជាក់ឱ្យកាន់តែច្បាស់ចំពោះរាល់បណ្ដាសានេះ សូមមើល ១ពវ ៦:២៤–២៩ បទ ២:២០ ៤:១០ សក ១១:៩ និងការពន្យល់ ។

**២៨:៥៨** *អស់ទាំងពាក្យក្នុងក្រិត្យវិន័យ* មើលការពន្យល់ ៣១:២៤ ។ *បានកោតខ្លាចដល់ព្រះនាមដ៏មានសិរីល្អ* មើល នក ៣:១៥ ។ មានភាពចម្លែកមួយ គឺជាការដែលបាត់បង់នូវការបញ្ចេញសម្លេង ឱ្យបានត្រឹមត្រូវនូវព្រះនាមទ្រង់ ដែលជាភាសាហេព្រើរ គឺឈ្មោះអង្គទ្រង់ផ្ទាល់ និងសេចក្ដីសញ្ញារបស់ព្រះនាមនៃព្រះអម្ចាស់នៅក្នុងគម្ពីរសញ្ញាចាស់ លប ២:៤ ។ ពាក្យថា "យេហូវ៉ា"គឺជាការប្រកបពាក្យ ដែលគេផ្គុំភ្ជាប់ពីតួអក្សរព្យញ្ជនៈរបស់ព្រះនាមទ្រង់ និងតួរអក្សរជាស្រៈ នៃពាក្យព្រះអម្ចាស់ ពីភាសាហេព្រើរ ។ ពាក្យថា "យ៉ាវេ" (Yahweh) គឺប្រហែលជាការបញ្ចេញដើមដំបូង ។ ព្រះនាមដើមដំបូងពុំបានបញ្ចេញសម្លេងឱ្យបានដូចទេ ។ ពីព្រោះក្រោយមកសាសន៍យូដាបានគិតថា ព្រះនាមទ្រង់បរិសុទ្ធជាទីបំផុតក្នុងការដែលហៅព្រះនាមទ្រង់ ដោយខ្លាចទទួលបទល្មើសបំពាន នក ២០:៧ លវ ២៤:១៦ ។

**២៨:៦០** *ជំងឺរបស់ស្រុកអេស៊ីព្ទ* គឺបាននាំឱ្យប្រទេសអេស៊ីព្ទទទួលជំងឺដ៏កាចសាហាវបំផុត (មើល ៧:១៥ នក ១៥:២៦) ។

**២៨:៦១** *គម្ពីរក្រិត្យវិន័យ* មើលការពន្យល់ ៣១:២៤ ។

**២៨:៦២** *ដូចជាផ្កាយនៅលើមេឃ* សូមមើល ១:១០ និងការពន្យល់ ១:១០ ១៥:៥ ។

ហើយចំរើនឯងរាល់គ្នាឡើងនោះដែរ ឯងរាល់គ្នានឹងត្រូវ
ដកចេញពីស្រុក ដែលឯងនឹងចូលទៅចាប់យកនោះ ៦៤ព្រះ
យេហូវ៉ាទ្រង់នឹងកំចាត់កំចាយឯង[ថ] ឱ្យទៅនៅក្នុងគ្រប់ទាំង
សាសន៍[ទ] ពីចុងផែនដីម្ខាង រហូតដល់ចុងផែនដីម្ខាង[ធ] នៅ
ទីនោះឯងនឹងគោរពប្រតិបត្តិដល់ព្រះដទៃធ្វើពីឈើ ហើយ
និងថ្ម ដែលឯងនិងពួកឰយុកោឯងមិនដែលស្គាល់សោះ[ន]
៦៥នៅក្នុងសាសន៍ទាំងនោះ ឯងនឹងរកសេចក្ដីស្រណុកមិន
បាន ហើយបាតជើងឯងមិនចេះបានសំរាកឡើយ[ប] គឺនៅ
ទីនោះព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យចិត្តឯងញ័ររន្ធត់ ឱ្យភ្នែក[ផ]
ឯងស្រវាំងទៅ ហើយឱ្យមានគំនិតព្រួយលំបាកដែរ[ព]
៦៦ទោះទាំងជីវិតឯង ក៏នឹងគ្មានទីកំណត់ដល់ឯងផង ឯងនឹង
ចេះតែភ័យខ្លាចទាំងយប់ទាំងថ្ងៃ ឥតមានសង្ឃឹមនឹងរស់
នៅឡើយ ៦៧នៅពេលព្រឹកឯងនឹងថា ឱកាលណាបានល្ងាច
ទៅហ្ន៎ ហើយដល់ពេលល្ងាចនោះនឹងថា ឱកាលណាបាន
ព្រឹកឡើងទៅហ្ន៎ គឺដោយព្រោះសេចក្ដីភិតភ័យនៅក្នុងចិត្ត
ឯង ដែលនាំឱ្យឯងខ្លាចនោះ ហើយដោយព្រោះការដែល
ភ្នែកឯងនឹងឃើញផង[ភ] ៦៨ព្រះយេហូវ៉ាទ្រង់នឹងដឹកនាំឯង
ដោយនាវាត្រឡប់ទៅនៅស្រុកអេស៊ីព្ទវិញ តាមផ្លូវដែល
អញបានប្រាប់ឯងថា ឯងនឹងមិនឃើញផ្លូវនោះទៀតឡើយ[ម]
រួចនៅស្រុកនោះ ឯងនឹងខំលក់ខ្លួនទៅឱ្យពួកខ្មាំងសត្រូវ
ដើម្បីនឹងធ្វើជាបាវប្រុសបាវស្រីគេ តែនឹងគ្មានអ្នកណាទិញ
ឯងសោះ ។

៦៩នោះហើយ ជាពាក្យទាំងប៉ុន្មាននៃសេចក្ដីសញ្ញា
ដែលព្រះយេហូវ៉ាទ្រង់បានបង្គាប់ ឱ្យម៉ូសេតាំងនឹងពួកកូន
ចៅអ៊ីស្រាអែល នៅស្រុកម៉ូអាប់[យ] ក្រៅពីសេចក្ដីសញ្ញា
ដែលទ្រង់បានតាំងនឹងគេ នៅភ្នំហោរែបនោះ[រ] ។

## ការរំឭកឡើងវិញនូវសេចក្ដីសញ្ញា

**២៩** ១ម៉ូសេ លោកហៅពួកអ៊ីស្រាអែលទាំងអស់គ្នាមក
ប្រាប់ថា ឯងរាល់គ្នាបានឃើញគ្រប់ទាំងការ ដែលព្រះ
យេហូវ៉ាបានធ្វើនៅស្រុកអេស៊ីព្ទ ដល់ផារ៉ោន និងពួកមហា
តលិក[ក] ហើយនិងស្រុកទ្រង់ទាំងមូល នៅចំពោះភ្នែកឯង
ហើយ ២គឺអស់ទាំងការល្បងយ៉ាងធំ ដែលភ្នែកឯង បាន
ឃើញ ព្រមទាំងទីសំគាល់ និងការអស្ចារ្យដ៏ធំផង[ខ] ៣តែលុះ
មកដល់សព្វថ្ងៃនេះ ព្រះយេហូវ៉ាទ្រង់មិនបានប្រទាន ឱ្យឯង
រាល់គ្នាមានចិត្តយល់ ឬភ្នែកដែលមើលឃើញ ឬត្រចៀក
ដែលស្តាប់ឮនៅឡើយ[គ] ៤អញបាននាំ[ឃ]ឯងរាល់គ្នាក្នុង
ទីរហោស្ថានអស់៤0ឆ្នាំហើយ ឯសំលៀកបំពាក់របស់ឯង
នោះមិនបានរេចនៅលើខ្លួនសោះ ហើយស្បែកជើងឯងក៏
មិនបានសឹកផង[ង] ៥ឯងរាល់គ្នាមិនបានបរិភោគនំបុ័ង ឬផឹក
ស្រាទំពាំងបាយជូរ ឬគ្រឿងស្រវឹងណាសោះ[ច] ដើម្បីឱ្យបាន
ដឹងថា អញនេះជាព្រះយេហូវ៉ាជាព្រះនៃឯង[ឆ] ៦កាលឯង
រាល់គ្នាបានមកដល់ទីនេះ នោះស៊ីហុន[ជ] ជាស្តេចក្រុង
ហេសបូន[ឈ] និងអុក ជាស្តេចស្រុកបាសាន បានចេញមក
ច្បាំងនឹងយើង ហើយយើងក៏បានវាយឈ្នះគេ[ញ] ៧យើងបាន
ចាប់យកស្រុកគេ ក៏ចែកជាមរដក[ដ]ដល់ពួករូបេន ពួកកាឌ់
ហើយនិងពូជអំបូរម៉ាន៉ាសេ១ចំហៀង[ឋ] ៨ដូច្នេះចូរកាន់
ហើយប្រព្រឹត្តតាម[ឌ]អស់ទាំងពាក្យនៃសញ្ញានេះ[ឍ] ដើម្បីឱ្យ
ឯងរាល់គ្នាមានសេចក្ដីចំរើន ក្នុងគ្រប់ទាំងការដែលឯង
ធ្វើ[ណ] ។

៩នៅថ្ងៃនេះ ឯងទាំងអស់គ្នាកំពុងឈរ នៅចំពោះព្រះ
យេហូវ៉ា ជាព្រះនៃឯង គឺទាំងពួកមេ ទាំងពូជអំបូរឯង
ទាំងប៉ុន្មាន និងពួកចាស់ទុំ ហើយនិងពួកនាយករបស់ឯង
រាល់គ្នាផង ជាបណ្ដាសាសន៍អ៊ីស្រាអែលទាំងអស់គ្នា
១០ព្រមទាំងពួកកូនក្មេង និងប្រពន្ធឯង ហើយពួកអ្នកដទៃ
ដែលនៅក្នុងពួកឯង តាំងពីពួកអ្នកកាប់ឧស ទៅដល់អ្នក
ដែលរែកទឹកឱ្យឯងផង[ត] ១១ប្រយោជន៍ឱ្យបានចុះសញ្ញានឹង
ព្រះយេហូវ៉ា ជាព្រះនៃឯង និងសេចក្ដីសំបថ ដែលព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់ស្បថនឹងឯងនៅថ្ងៃនេះ
១២គឺដើម្បីឱ្យទ្រង់បានតាំងឯង ទុកជារាស្ត្ររបស់ទ្រង់[ថ]នៅ
ថ្ងៃនេះ ហើយឱ្យទ្រង់បានធ្វើជាព្រះដល់ឯង[ទ] ដូចជាទ្រង់
បានមានបន្ទូលនឹងឯង ហើយដូចជាទ្រង់បានស្បថនឹងអ័ប្រា
ហាំ និងអ៊ីសាក ហើយនិងយ៉ាកុប ជាពួកឰយុកោឯងដែរ ។

៦២:៥ ៦៥:១៩ យរ ៣២:៤១ សផ ៣:១៧ **២៨:៦៤** ថ ចទ ៤:២៧ អរ ៩:៧ អស ៦:១២ យរ ៣២:២៣ ៤៣:១១ ៥២:២៧ ទ នហ ១:៨ ទដ ៤៤:១១ ៣២:១៧ យរ ១៣:២៤ ១៨:១៧ ២២:២២ ធ ចទ ៤:៣២ យរ ៨:១៩ ន ចទ ១១:២៨ ៣២:១៧ **២៨:៦៥** ប បទ ១:៣ ផ យប ១១:២០ ព លវ ២៦:១៦,៣៦ ហស ៩:១៧ **២៨:៦៧** ភ ខ.៣៤ **២៨:៦៨** ម នក ១៣:១៤ **២៨:៦៩** យ លវ ៧:៣៨ រ នក ៣:១ **២៩:១** ក នក ១៩:៤ **២៩:២** ខ នក ១៩:៤ **២៩:៣** គ ចទ ៤:៣៤ **២៩:៤** ឃ អស ៦:១០ ៣២:៣ ៤៨:៨ យរ ៥:២១ អរ ៥:២១ មថ ៤:១៨ **២៩:៥** ច ចទ ៨:២ ឆ ចទ ៨:៤ **២៩:៦** ជ លវ ១០:៩ ចទ ៨:៣ **២៩:៧** ជន ២១:២៦ ជន ២១:២៥ ២១:២១–២៤, ៣៣–៣៣ **២៩:៨** ដ ទដ ៧៨:៥៥ ១៣៥:១២ ១៣៦:២២ ឋ ជន ៣២:៣៣ ចទ ៣:១២–១៣ **២៩:១០** ឌ ចទ ៤:៦ យស ១:៧ ឍ នក ១៩:៥ ទដ ២៥:១០ ១០៣:១៨ ណ យស ១:៨ ២របា ៣១:២១ **២៩:១១** ត យស ៩:២១, ២៣,២៧ ១របា ២០:៣

**២៨:៦៤** *នឹងកំចាត់កំចាយឯង* គឺជារឿងដែលប្រជាជនអ៊ីស្រាអែលជួបប្រទះបទពិសោធន៍រួចហើយ នៅក្នុងស្រុកអាសស៊ើរ និងបាប៊ីឡូន (នៅក្នុងឆ្នាំ ៥៨៦ មុន គ.ស) ការបំបរបង់ មើល ២ពវ ១៧:៦ ២៥:២១ ។

**២៨:៦៨** *ឯងនឹងមិនឃើញផ្លូវនោះទៀតឡើយ* មើល ១៧:១៦ នក ១៣:១៧ ជន ១៤:៣–៤ ។

**២៩:១** មើលការពន្យល់ ៥:២–៣ ។

**២៩:២** *ភ្នែកឯងបានឃើញ* គឺចំពោះអ្នកដែលមានអាយុតិចជាង ២0ឆ្នាំ (ជន ១៤:២៩) នៅពេលសាសន៍អ៊ីស្រាអែល ដើរតាមអ្នកសើបអង្កេតដោយលបមើលនៅទឹកដីស្រុកកាដេស–បារនា ហើយមិនបានចូលទៅទឹកដីកាណាន ក៏ត្រូវរងនៅបទពិសោធន៍លំបាកក្នុងជីវិត ហើយលោកម៉ូសេក៏បានប្រាប់ដល់ប្រជាជនដែលមានបទពិសោធន៍ (មើល ៥:៣) ។

**២៩:៧–៨** *ក៏ចែកជាមរដក* មើល ៣:១២–១៧ ។

១៣អញតាំងសេចក្តីសញ្ញា[ត] ហើយសំបថនេះ មិនមែនតែ
នឹងឯងរាល់គ្នាប៉ុណ្ណោះ ១៤គឺនឹងពួកអ្នកដែលឈរជាមួយ
នឹងយើងរាល់គ្នានៅទីនេះ នាចំពោះព្រះយេហូវ៉ា ជាព្រះ
នៃយើង នៅថ្ងៃនេះ ព្រមទាំងពួកអ្នកដែលមិននៅឯនេះ
ជាមួយនឹងយើងរាល់គ្នានៅថ្ងៃនេះដែរ[ធ]
១៥(ដ្បិតឯការទាំង
ប៉ុន្មាន ដែលកើតដល់យើងនៅក្នុងស្រុកអេស៊ីព្ទ ហើយតាម
ផ្លូវដែលយើងបានដើរកាត់ កណ្តាលសាសន៍ទាំងប៉ុន្មាន
ហួសមកដល់ទីនេះ នោះឯងរាល់គ្នាដឹងស្រាប់ហើយ
១៦ក៏
បានឃើញការគួរស្អប់ខ្ពើមរបស់គេ នឹងព្រះដែលធ្វើពី
ឈើ ពីថ្ម ប្រាក់ ហើយនិងមាស នៅក្នុងពួកគេនោះដែរ)
១៧ក្រែងនៅក្នុងពួកឯងរាល់គ្នា នៅថ្ងៃនេះមានមនុស្ស
ប្រុស ឬស្រីណា ឬគ្រួណា ឬពូជអំបូរណា ដែលមានចិត្ត
បែរចេញ[ផ]ពីព្រះយេហូវ៉ា ជាព្រះនៃយើង ទៅគោរពប្រតិ
បត្តិដល់ព្រះរបស់សាសន៍ទាំងនោះវិញ ហើយក្រែងនៅ
ក្នុងពួកឯងរាល់គ្នា មានឫសណាដែលបង្កើតជាតិពុល
ហើយនិងស្លែង[ព]
១៨រួចកាលណាអ្នកនោះឮពាក្យនៃសេចក្តី
បណ្តាសានេះ នោះគេនឹងឱ្យពរ[ភ]ដល់ខ្លួននៅក្នុងចិត្តថា អញ
នឹងមានសេចក្តីសុខទេ ទោះបើអញដើរតាមតែសេចក្តីរឹង
ចចេសក្នុងចិត្តអញ[ម] ដើម្បីនឹងបន្ថែមសេចក្តីស្រវឹង ទៅលើ
សេចក្តីសំរេកក៏ដោយ
១៩ព្រះយេហូវ៉ាទ្រង់នឹងមិនអត់ទោស
ដល់អ្នកនោះឡើយ[យ] គឺសេចក្តីខ្ញាល់ ហើយនិងសេចក្តី
ប្រចណ្ឌ[រ]នៃព្រះយេហូវ៉ា និងហុយឡើង[ល]ទាស់នឹងអ្នកនោះ
ហើយគ្រប់ទាំងសេចក្តីបណ្តាសា ដែលបានកត់ក្នុងគម្ពីរ
នេះ នឹងនៅជាប់លើអ្នកនោះដែរ រួចព្រះយេហូវ៉ាទ្រង់នឹង
លុប[វ]ឈ្មោះគេពីក្រោមមេឃចេញ
២០ព្រះយេហូវ៉ាទ្រង់នឹង
ញែកអ្នកនោះ ពីគ្រប់ទាំងពូជអំបូរនៃសាសន៍អ៊ីស្រាអែល
ចេញ ទុកសំរាប់តែសេចក្តីអាក្រក់ប៉ុណ្ណោះ[ស] តាមអស់ទាំង
ពាក្យបណ្តាសានៃសេចក្តីសញ្ញា ដែលកត់ក្នុងគម្ពីរក្រិត្យ
វិន័យនេះ[ហ]។

**២៩:១៣** ត លក ៦:១៨ នក ១៩:៦ លក ១៧:៧ **២៩:១៤** ធ នក ១៩:៥ អស ៥៩:២១ យរ ៣១:៣១ ៣២:៤០ ៥០:៥ អគ ១៦:៦២ ៣៧:២៦ ហាព ៨:៧-៨ **២៩:១៥** ន លប ៦:១៨ កច ២:៣៩ **២៩:១៧** ប នក ២០:២៣ ចទ ៤:២៨ **២៩:១៨** ផ ចទ ១៣:៦ ព ចទ ១១:១៦ ហាព ១២:១៥ **២៩:១៩** ភ ទដ ៧២:១៧ អស ៦៥:១៦ ម ទដ ៣៦:២ **២៩:២០** យ នក ២៣:២១ រ នក ៣៤:១៤ អគ ២៣:២៥ សផ ១:១៨ ល ៧៤:១ ៧៩:៥ ៨០:៤ អគ ៣៦:៥ វ ២ពវ ១៣:២៣ ១៤:២៧ វវ ៣:៥ **២៩:២១** ស ចទ ៣២:២៣ អគ ៧:២៦ ហ ចទ ២៨:៦១ **២៩:២២** ឡ យរ ១៩:៨ ៤៩:១៧ ៥០:១៣ **២៩:២៣** អ លប

២១ឯដំណមនុស្សក្រោយមក គឺកូនចៅឯងរាល់គ្នាដែលនឹង
កើតតពីឯង ហើយពួកអ្នកដទៃដែលមកពីស្រុកឆ្ងាយ កាល
ណាគេឃើញអស់ទាំងសេចក្តីវេទនានៅស្រុកនោះ និងជំងឺ
ទាំងប៉ុន្មានដែលព្រះយេហូវ៉ាបានធ្វើឱ្យឈឺ[ឡ]
២២ហើយ
ឃើញស្រុកនោះសុទ្ធតែស្ពាន់ធ័រ និងអំបិល[អ]ផង ក៏កំពុងតែ
ឆេះ[ក] ឥតដែលបានសាបព្រោះ ឬលូតលាស់ឥតមានស្មៅ
ដុះសោះដូចជាកាលបំផ្លាញក្រុងសូដុំម ក្រុងកូម៉ូរ៉ា[ខ] ក្រុង
អាត់ម៉ា ហើយនិងក្រុងសេបោមដែរ ជាទីក្រុងដែលព្រះ
យេហូវ៉ាបានបំផ្លាញ ដោយសេចក្តីខ្ញាល់ ហើយនិងសេចក្តី
ឃោរឃៅរបស់ទ្រង់[គ]
២៣នោះគ្រប់ទាំងសាសន៍នឹងសួរថា
ហេតុដូចម្តេចបានជាព្រះយេហូវ៉ាបានធ្វើដល់ស្រុកនេះ
យ៉ាង[ឃ] ដូច្នេះ សេចក្តីក្រោធយ៉ាងខ្លាំងដ៏ឆេះក្តៅ បានកើត
ឡើងដោយព្រោះអ្វី
២៤នោះអស់ទាំងសាសន៍នឹងឆ្លើយថា គឺ
ដោយព្រោះតែគេបានបោះបង់ចោលសេចក្តីសញ្ញាផង
ព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេ ដែលទ្រង់បានតាំង
នឹងគេ ក្នុងកាលដែលទ្រង់បាននាំគេចេញពីស្រុកអេស៊ីព្ទ
មកនោះ[ង]
២៥គេបានបែរទៅជាគោរពប្រតិបត្តិថ្វាយបង្គំ
ដល់ព្រះដទៃ ជាព្រះដែលគេមិនបានស្គាល់ គឺជាព្រះដែល
ទ្រង់ក៏មិនបានប្រទានឱ្យគេផង
២៦ហេតុនោះហើយ បានជា
សេចក្តីខ្ញាល់នៃព្រះយេហូវ៉ា បានកាត់ឡើង ទាស់នឹងស្រុក
នេះ ដើម្បីនឹងនាំអស់ទាំងសេចក្តីបណ្តាសា ដែលកត់ក្នុង
គម្ពីរនេះមកលើគេ[ច]
២៧ព្រះយេហូវ៉ាទ្រង់បានរំលើងគេ ពី
ស្រុកចេញ ដោយសេចក្តីខ្ញាល់[ឆ] សេចក្តីឃោរឃៅ ហើយ
និងសេចក្តីក្តៅក្រហាយដ៏ជាខ្លាំងរបស់ទ្រង់ ហើយបាន
បោះគេចោល[ជ]ទៅក្នុងស្រុក១ទៀត ដូចជាមានសព្វថ្ងៃ

១៣:១០ អគ ៤៧:១១ ក អស ១:៧ ៦:១១ ៩:១៨ ៦៤:១០ យរ ១២:១១ ៤៤:២,៦ មីក ៥:១១ ខ លប ១៩:២៤,២៥ សផ ២:៩ មថ ១០:១៥ រម ៩:២៩ គ លប ១៤:៨ **២៩:២៤** ឃ ១ពវ ៩:៨ ២របា ៣៦:១៩ យរ ១៦:១០ ២២:៨-៩ ៥២:១៣ **២៩:២៥** ង ២ពវ ១៧:២៣ ២របា ៣៦:២១ **២៩:២៧** ច ចទ ២៨:១៥

**២៩:៩-១៥** គឺជាការសង្ខេបយ៉ាងច្បាស់ពីសញ្ញាណ នៃការប្រកាសជាថ្មី ចំពោះសេចក្តីសញ្ញា ។

**២៩:១៧** *ព្រះដែលធ្វើពីឈើ ពីថ្ម* មើល លវ ២៦:៣០ ។

**២៩:១៨** *ឫស . . . បង្កើតជាតិពុល ហើយនិងស្លែង* គឺជាជាតិពុលរបស់ព្រះក្លែងក្លាយ ដែលបានបដិសេធដល់ព្រះយេហូវ៉ា (មើល នក ២០:៣-៤ និងការពន្យល់) ។

**២៩:១៩** *ពាក្យនៃសេចក្តីបណ្តាសា* ជាសេចក្តីសញ្ញារបស់ព្រះជាមួយរាស្ត្ររបស់ផងទ្រង់ (ខ.១២-១៤) គឺជាការបញ្ជាក់ពីភាពមិនស្អាត ពីព្រោះទោះជាភាសា និងការប្រើប្រាស់ភាសាគួរឱ្យយល់ពីលក្ខណៈអក្សរសាស្ត្រ (មើល ខ.២០-២១) ។

**២៩:២០** *ព្រះយេហូវ៉ាទ្រង់នឹងមិនអត់ទោសដល់អ្នកនោះឡើយ* គឺមិនផ្ទុយនិងបទគម្ពីរ ២ពត ៣:៩ ទេ (ពីការមិនចង់ឱ្យអ្នកណាម្នាក់ ហិនវិនាសឡើយ) លោកពេត្រុសក៏ពោលដែរថា អ្នកណាដែលបដិសេធចំពោះព្រះមហាក្សត្រ គឺព្រះយេហូវ៉ានោះ និងនាំឱ្យគេទទួលការហិនវិនាសដល់ខ្លួនគេផងដែរ (២ពត ២:១) មើលការពន្យល់ ៣១:២៤ ២ពត ៣:៩ ។ *លុបឈ្មោះគេ* មើល ៩:១៣ និងការពន្យល់ ។

**២៩:២១** *គម្ពីរក្រិត្យវិន័យ* មើលការពន្យល់ ៣១:២៤ ។

**២៩:២៣** *ការបំផ្លាញក្រុងសូដុំម* មើល ១៩:២៤-២៥ ក៏សូមមើល លប ១០:១៩ ១៣:១០ ។

**២៩:២៧** *ក្នុងគម្ពីរនេះ* មើលការពន្យល់ ៣១:២៤ ។

នេះ ២៨ឯអស់ទាំងសេចក្ដីលាក់កំបាំងនោះស្រេចនៅព្រះ
យេហូវ៉ា ជាព្រះនៃយើងរាល់គ្នាទេ[ឈ] តែសេចក្ដីដែលបាន
បើកសំដែងមកទាំងប៉ុន្មាន នោះស្រេចនៅយើងរាល់គ្នា
ហើយនិងកូនចៅយើង ជារៀងរាបដរាបវិញ ដើម្បីឱ្យ
យើងបានប្រព្រឹត្តតាមអស់ទាំងពាក្យក្នុងក្រិត្យវិន័យនេះ[ញ]។

## ការបែរទៅរកព្រះនិងមានភាពចុំរុងចំរើន

**៣០** ១កាលណាគ្រប់ទាំងសេចក្ដីនេះបានមកលើឯង គឺ
ទាំងពរ និងបណ្ដាសា[ក] ដែលអញដាក់នៅមុខឯងរួចនៅ
កណ្ដាលអស់ទាំងសាសន៍ ដែលព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់នឹងដេញឯងទៅនៅ នោះឯងចាប់តាំងនឹករឭកពីការ
ទាំងនោះនៅក្នុងចិត្ត[ខ] ២ហើយឯងវិលត្រឡប់មក[គ] ឯព្រះ
យេហូវ៉ា ជាព្រះនៃឯងវិញ ដោយស្ដាប់តាមព្រះបន្ទូលទ្រង់
តាមគ្រប់ទាំងសេចក្ដី ដែលអញបង្គាប់ឯងនៅថ្ងៃនេះ ព្រម
ទាំងកូនចៅឯងផង ឱ្យអស់ពីចិត្ត[ឃ] អស់ពីព្រលឹង ៣នោះព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងបំផ្លាស់សណ្ឋានឈ្លើយ
របស់ឯង[ង] ព្រមទាំងអាណិតមេត្តា[ច]ដល់ឯង ហើយនិង
ប្រមូល[ឆ]ឯងមកពីគ្រប់ទាំងសាសន៍ ជាកន្លែងដែលទ្រង់បាន
កំចាត់កំចាយ[ជ]ឯងទៅនៅនោះមកវិញ[ឈ] ៤ទោះបើពួកឯង
ដែលត្រូវខ្ចាត់ខ្ចាយនោះ បានទៅនៅដល់ទីបំផុតនៃជើង
មេឃ[ញ]ក៏ដោយ គង់តែព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹង
ប្រមូល[ដ] ហើយនាំយកឯងពីទីនោះមកវិញដែរ[ឋ] ៥ព្រះ
យេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងនាំ[ឌ]ឯងមកក្នុងស្រុកដែល
ពួកឰយុកោឯងបានចាប់យក ហើយឯងនឹងទទួលយកស្រុក
នោះវិញ នោះទ្រង់នឹងប្រោសសេចក្ដីល្អដល់ឯង ហើយនិង
ចំរើនឯងឱ្យមានគ្នាជាច្រើន[ឍ] លើសជាងពួកឰយុកោឯង
ទៅទៀត ៦ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងកាត់ស្បែក
ចិត្តរបស់ឯង ហើយនិងចិត្តរបស់ពូជឯងផង[ណ] ឱ្យបាន
ស្រឡាញ់[ត]ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ឱ្យអស់ពីចិត្ត
អស់ពីព្រលឹង ដើម្បីឱ្យឯងបានរស់នៅ ៧រួចព្រះយេហូវ៉ា
ជាព្រះនៃឯង ទ្រង់នឹងដាក់អស់ទាំងសេចក្ដីបណ្ដាសាទាំង
នេះ[ថ] ទៅលើពួកខ្មាំងសត្រូវ និងលើពួកអ្នកដែលស្អប់ឯង
ដែលគេបានធ្វើទុក្ខឯងវិញ[ទ] ៨នោះឯងនឹងវិលមកឯព្រះ
យេហូវ៉ាវិញ ព្រមទាំងស្ដាប់តាមព្រះបន្ទូលទ្រង់ ហើយ
ប្រព្រឹត្តតាមគ្រប់ទាំងបញ្ញត្តិទ្រង់ ដែលអញបង្គាប់មកនៅ
ថ្ងៃនេះ ៩រួចព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងចំរើនគ្រប់
ទាំងការដែលដៃឯងធ្វើ ឱ្យមានជាបរិបូរ ព្រមទាំងផល
កើតពីពោះឯង និងផលកើតពីហ្វូងសត្វ ហើយនិងផល
កើតពីដីឯងផង[ធ] សំរាប់ជាសេចក្ដីល្អ ដ្បិតព្រះយេហូវ៉ាទ្រង់
នឹងមានសេចក្ដីអំណរ[ន] ដើម្បីប្រោសឱ្យឯងបានសេចក្ដីល្អ
វិញទៀត ដូចជាពីដើមទ្រង់បានមានសេចក្ដីអំណរនឹងពួក
ឰយុកោឯងដែរ ១០គឺបើឯងស្ដាប់តាមព្រះបន្ទូលនៃព្រះ
យេហូវ៉ា ជាព្រះនៃឯង ដើម្បីនឹងកាន់តាមអស់ទាំងច្បាប់
និងបញ្ញត្តិទាំងប៉ុន្មានរបស់ទ្រង់ ដែលបានកត់ទុកក្នុងគម្ពីរ
ក្រិត្យវិន័យនេះ[ប] គឺបើឯងបែរមកឯព្រះយេហូវ៉ា ជាព្រះនៃ
ឯងវិញ ឱ្យអស់ពីចិត្ត អស់ពីព្រលឹងឯង[ផ]។

## ការដាក់សំញែងជីវិត និងសេចក្ដីស្លាប់

១១ដ្បិតសេចក្ដីបញ្ញត្តិ ដែលអញបង្គាប់មកឯងនៅថ្ងៃនេះ
មិនមែនហួសកំឡាំងឯងទេ ក៏មិនមែននៅឆ្ងាយដែរ[ព] ១២គឺ
មិនមែននៅលើស្ថានសួគ៌ ឱ្យឯងបានថា តើអ្នកណានឹង
ឡើងទៅស្ថានសួគ៌[ភ] នាំយកព្រះបន្ទូលមកប្រាប់យើងខ្ញុំ
ដើម្បីឱ្យយើងខ្ញុំបានប្រព្រឹត្តតាមនោះទេ[ម] ១៣ក៏មិនមែននៅ
ត្រើយសមុទ្រខាងនាយ[យ] ឱ្យឯងបានថា តើអ្នកណានឹងឆ្លង
សមុទ្រ ទៅនាំយកព្រះបន្ទូលមកប្រាប់យើងខ្ញុំ ដើម្បីឱ្យយើង
ខ្ញុំបានប្រព្រឹត្តតាមនោះដែរ[រ] ១៤គឺព្រះបន្ទូលនេះនៅជិតឯង
ណាស់ ក៏នៅក្នុងមាត់ឯង និងក្នុងចិត្តឯងផង ដើម្បីឱ្យឯង
អាចប្រព្រឹត្តតាមបាន[ល]។
១៥មើល នៅថ្ងៃនេះ អញបានដាក់សំញែងជីវិត[វ]និងសេច

**២៩:២៨** ឆ ទដ ៧:១១ ជ ១ពវ ១៤:១៥ ២របា ៧:២០ ទដ ៩:៦ ៥២:៥ សភ ២:២២ យរ ១២:១៤ ៣១:២៨ ៤២:១០ អគ ១៩:១២ **២៩:២៩** ឈ កច ១:៧ យហ ៥:៣៩ កច ១៧:១១ ២ធថ ៣:១៦ **៣០:១** ក ចទ ១១:២៦ ខ លវ ២៦:៤០–៤៥ ចទ ៤:៣២ ២៩:២៨ **៣០:២** ឃចទ ៤:៣០ ង ចទ ៤:២៩ ទដ ១១៩:២ **៣០:៣** ច ទដ ១៤:៧ ៥៣:៦ ៨៥:១ ១២៦:៤ យរ ៣០:១៨ ៣៣:១១ អគ ១៦:៥៣ យអ ៣:១ សផ ២:៧ ឆ ចទ ១៣:១៧ ជ លប ១១:៤ ចទ ៤:២៧ ឈ អស ១១:១១ យរ ១២:១៥ ១៦:១៥ ២៤:៦ ២៩:១៤ ៤៨:៤៧ ៤៩:៦ **៣០:៤** ញ ទដ ១៩:៦ ដ អស ១៧:៦ ២៤:១៣ ២៧:១២ ៤០:១១ ៤៩:៥ ៥៦:៨ អគ ២០:៣៤,៤១ ៣៤:១៣ ឋ នហ ១:៨–៩ អស ១១:១២ ៤១:៥ ៤២:១០ ៤៣:៦ ៤៨:២០ ៦២:១១ យរ ៣១:៨,១០ ៥០:២ **៣០:៥** ឌ យរ ២៩:១៤ ឍ ចទ ៧:១៣ **៣០:៦** ណ ចទ ៦:២៤ ១០:១៦ ត ចទ ៦:៥ **៣០:៧** ថ លប ១២:៣ ទ ចទ ៧:១៥ **៣០:៩** ធ យរ ១:១០ ២៤:៦ ៣១:២៨ ៣២:៤១ ៤២:១០ ៤៥:៤ ន ចទ ២៨:៦៣ **៣០:១០** ប ចទ ២៨:៦១ ផ ចទ ៤:២៩ **៣០:១១** ព ទដ ១៩:៨ អស ៤៥:១៩, ២៣ ៦៣:១ **៣០:១២** ភ សភ ៣០:៤ ម រម ១០:៦ **៣០:១៣** យ យប ២៨:១៤ រ រម ១០:៧ **៣០:១៤** ល ចទ ៦:៦ រម ១០:៨

**២៩:២៨** *ដូចជាមានសព្វថ្ងៃ* ករណីនេះគឺចង់និយាយក្នុងគ្រា ដែលជនជាតិអ៊ីស្រាអែលស្ថិតក្នុងសភាពដែលគេបោះបង់ចោល (មើល ខ.២២–២៥) ។
**២៩:២៩** *សេចក្ដីលាក់កំបាំង* ព្រឹត្តិការណ៍ ដ៏លាក់កំបាំងនៃអនាគតរបស់ប្រជាជនអ៊ីស្រាអែល គឺមានទំនាក់ទំនងព្រះពរនិងបណ្ដាសា ប៉ុន្តែវាមានលក្ខណៈធំធេង ។ *សេចក្ដីដែលបានបើកសំដែង* ពីមុនដំបូងគឺជាពាក្យនៃក្រឹត្យវិន័យ ។
**៣០:២,៦,១០** *អស់ពីចិត្ត អស់ពីព្រលឹងឯង* មើលការពន្យល់ ៤:២៩ ។
**៣០:៧** *បណ្ដាសាទាំងនេះ ទៅលើពួកខ្មាំងសត្រូវ* ប្រៀបធៀប លប ១២:៣ ។
**៣០:៩** *ពួកឰយុកោឯងដែរ* ជាចាស់ព្រឹទ្ធាចារ្យ (មើល ខ.២០) ។
**៣០:១០** *គម្ពីរក្រិត្យវិន័យ* មើលការពន្យល់ ៣១:២៤ ។
**៣០:១២,១៤** *គឺមិនមែននៅលើស្ថានសួគ៌ . . . គឺព្រះបន្ទូលនេះនៅជិតឯងណាស់* លោកម៉ូសេប្រកាសថា ការយល់ឬជំនឿនិងការស្ដាប់បង្គាប់ សេចក្ដីសញ្ញា គឺមិនចាំបាច់អ្វីដែលនៅឆ្ងាយពីខ្លួនគេទេ ។ លោកប៉ុលបានសម្ដែងព្រះបន្ទូលនេះ គឺចង់និយាយពីពាក្យថាជំនឿ (រម ១០:៦–១០) ។

ក្ដីល្អ[ស] នៅមុខឯង ព្រមទាំងសេចក្ដីស្លាប់[ហ] និងសេចក្ដីអាក្រក់
ផង[ឡ] [១៦]ដោយអញបង្គាប់ដល់ឯងនៅថ្ងៃនេះ ឱ្យស្រឡាញ់[អ]
ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ដើម្បីនឹងដើរតាមផ្លូវទ្រង់
ហើយនិងកាន់តាមអស់ទាំងសេចក្ដីបង្គាប់ និងច្បាប់ ហើយ
និងបញ្ញត្តិទាំងប៉ុន្មានរបស់ទ្រង់ ប្រយោជន៍ឱ្យឯងបានរស់
នៅ[ក] ហើយចំរើនឡើង ហើយប្រយោជន៍ឱ្យព្រះយេហូវ៉ា
ជាព្រះនៃឯង បានប្រទានពរដល់ឯងនៅក្នុងស្រុកដែល
ឯងនឹងចូលទៅចាប់យកនោះ [១៧]ប៉ុន្តែបើចិត្តឯងបែរចេញ
មិនព្រមស្ដាប់តាម ក៏យល់ព្រមឱ្យគេប្រទាញនាំទៅថ្វាយបង្គំ
ហើយគោរពប្រតិបត្តិតាមព្រះដទៃវិញ [១៨]នោះអញប្រាប់
ឯងរាល់គ្នាដោយត្រង់ នៅថ្ងៃនេះថា ឯងនឹងត្រូវវិនាស
ទៅជាមិនខាន[ខ] គឺឯងមិនបានរស់នៅជាយូរប៉ុន្មាន នៅក្នុង
ស្រុកដែលឯងនឹងឆ្លងទន្លេយ័រដាន់ ចូលទៅចាប់យកនោះ
ទេ [១៩]អញអាងដល់ស្ថានសួគ៌ និងផែនដីឱ្យធ្វើជាបន្ទាល់
ទាស់នឹងឯងរាល់គ្នា[គ] នៅថ្ងៃនេះថា អញបានដាក់សំពែង
ទាំងជីវិត និងសេចក្ដីស្លាប់ ទាំងព្រះពរនឹងសេចក្ដី
បណ្ដាសា[ឃ] នៅមុខឯងរាល់គ្នា ដូច្នេះចូររើសយកជីវិតចុះ
ដើម្បីឱ្យឯង បានរស់នៅ ព្រមទាំងពូជឯងតរៀងទៅផង
[២០]ប្រយោជន៍ ឱ្យបានស្រឡាញ់[ង]ដល់ព្រះយេហូវ៉ា ជាព្រះនៃ
ឯង និងស្ដាប់តាមព្រះបន្ទូលទ្រង់ ហើយនៅជាប់នឹងទ្រង់ត
ទៅ ដ្បិតគឺទ្រង់ហើយជាជីវិតនៃឯង[ច] ហើយជា[ឆ]អាយុវែង
ដល់ឯងដែរ ឱ្យឯងបាននៅក្នុងស្រុក[ជ] ដែលទ្រង់បានស្បថ
នឹងអ័ប្រាហាំ និងអ៊ីសាក ហើយនិងយ៉ាកុប ជាពួកព្វយុកោ
ឯងថា និងឱ្យដល់គេ ។

## លោកយ៉ូស្វេជាអ្នកស្នងលោកម៉ូសេ

**៣១** [១]ម៉ូសេក៏ទៅប្រាប់សេចក្ដីទាំងនេះ ដល់ពួកអ៊ីស្រា
អែលគ្រប់គ្នា [២]រួចលោកមានប្រសាសន៍ថា នៅថ្ងៃនេះអញ
អាយុបាន១២០ឆ្នាំហើយ[ក] អញមិនអាចនឹងចេញចូលទៀត
បានទេ[ខ] ហើយព្រះយេហូវ៉ាក៏មានបន្ទូលមកអញថា មិនត្រូវ
ឱ្យអញឆ្លងទន្លេយ័រដាន់នេះទៅដែរ[គ] [៣]គឺព្រះយេហូវ៉ាជា
ព្រះនៃឯង ទ្រង់នឹងយាង[ឃ]នាំមុខឯង[ង] ទ្រង់នឹងបំផ្លាញ
សាសន៍ទាំងនោះ[ច]ពីមុខឯងចេញ ហើយឯងនឹងចាប់យក
ស្រុកគេបាន ឯយ៉ូស្វេនេះ លោកនឹងនាំឯងឆ្លង[ឆ] ទៅដូចជា
ព្រះយេហូវ៉ាបានមានបន្ទូលហើយ [៤]ព្រះយេហូវ៉ាទ្រង់នឹង
ធ្វើដល់គេ ដូចជាទ្រង់បានធ្វើដល់ស៊ីហុន និងអុក[ជ]ជាស្ដេច
សាសន៍អាម៉ូរី ព្រមទាំងស្រុកគេ ដែលទ្រង់បានបំផ្លាញនោះ
ផង [៥]ព្រះយេហូវ៉ាទ្រង់នឹងប្រគល់[ឈ]គេមកឯងរាល់គ្នា
នោះត្រូវឱ្យឯងធ្វើដល់គេ តាមគ្រប់ទាំងការដែលអញ
បានបង្គាប់ដល់ឯងចុះ [៦]ដូច្នេះចូរមានកំឡាំង ហើយចិត្ត
ក្លាហានឡើង[ញ] កុំឱ្យខ្លាច ឬមានសេចក្ដីភ័យញ័រ[ដ] ចំពោះគេ
ឡើយ ដ្បិតគឺព្រះយេហូវ៉ា ជាព្រះនៃឯង ដែលយាងទៅជា
មួយនឹងឯង[ឋ] ទ្រង់មិនដែលខាននឹងប្រោសឯង[ឌ]ទេ ក៏មិន
ដែលលះចោល[ឍ]ឯងដែរ ។
[៧]ម៉ូសេក៏ហៅយ៉ូស្វេមក ប្រាប់នៅចំពោះមុខនៃសាសន៍
អ៊ីស្រាអែលទាំងអស់គ្នាថា[ណ] ចូរមានកំឡាំងហើយចិត្ត
ក្លាហានចុះ ដ្បិតត្រូវឱ្យឯងទៅជាមួយនឹងបណ្ដាជនទាំង
នេះ ចូរទៅក្នុងស្រុក ដែលព្រះយេហូវ៉ាបានស្បថនឹងពួក
ព្វយុកោថា និងឱ្យដល់គេ[ត] ហើយត្រូវឱ្យគេបានស្រុកនោះ

**៣០:១៥** វ សភ ១០:១៦ ១១:១៩ ១២:២៨ យរ ២១:៨ ស ចទ ២៨:១១ យប ៣៦:១១ ទដ ២៥:១៣ ១០៦:៥ សភ ៣:១–២ ហ លប ២:១៧ ឡ ចទ ១១:២៦ **៣០:១៦** អ ចទ ៦:៥ ក ខ.១៩ ចទ ៤:១ ៣២:៤៧ នហ ៩:២៩ **៣០:១៨** ខ ចទ ៨:១៩ **៣០:១៩** គ ចទ ៤:២៦ ឃ ចទ ១១:២៦ **៣០:២០** ង ចទ ៦:៥ ច ចទ ៤:១ ៨:៣ ៣២:៤៧ ទដ ២៧:១ សភ ៣:២២ យហ ៥:២៦ កច ១៧:២៨ ឆ លប ១២:៧ ជ ទដ ៣៧:៣

**៣១:២** ក នក ៧:៧ ខ ជន ២៧:១៧ ១ពវ ៣:៧ គ ចទ ៣:២៣,២៦ **៣១:៣** ឃ ជន ២៧:១៨ ង ចទ ៩:៣ ច ចទ ៧:១ ឆ ចទ ៣:២៨ **៣១:៤** ជ ជន ២១:៣៣

**៣១:៥** ឈ ចទ ២:៣៣ **៣១:៦** ញ ខ.៧,២៣ យស ១:៦,៩,១៨ ១០:២៥ ១របា ២២:១៣ ២៨:២០ ២របា ៣២:៧ ដ យរ ១:៨,១៧ អគ ២:៦ ឋ លប ២៨:១៥ ចទ ១:២៩ ២០:៤ មថ ២៨:២០ ឌ ទដ ៥៦:៩ ១១៨:៦ ឍ ចទ ៤:៣១ ១សយ ១២:២២ ១ពវ ៦:១៣ ទដ ៩៤:១៤ អស ៤១:១៧ ហព ១៣:៥ **៣១:៧** ណ ខ.២៣ ជន ២៧:២៣ ត យស ១:៦

**៣០:១៦** *ឱ្យស្រឡាញ់ . . . តាមអស់ទាំងសេចក្ដីបង្គាប់* មើលការពន្យល់ ៦:៥ ១១:១ ។

**៣០:១៩** *អញអាងដល់ស្ថានសួគ៌ និងផែនដីឱ្យធ្វើជាបន្ទាល់ទាស់* សេចក្ដីសញ្ញាបូរាណក្រៅពីសម័យចាស់ ដែលមានឈ្មោះព្រះក្លែងក្លាយជាច្រើន សេចក្ដីសញ្ញាក្នុងគម្ពីរចោទិយកថា ត្រូវបានបង្ហាញតាមរយៈ ស្ថានសួគ៌ និងផែនដី (មើល ៣១:២៨ ៣២:១ និងមើលការពន្យល់ ទដ ៥០:១ អស ១:២) ។

**៣០:២០** *នៅជាប់* មើលការពន្យល់ ១០:២០ ដ្បិតទ្រង់ហើយជាជីវិតនៃឯង ។ ពេលដែលពួកគេបានជ្រើសរើសព្រះយេហូវ៉ា គឺជ្រើសរើសជីវិត ។(ខ.១៩) ៣២:៤៦–៤៧ គ្រប់ទាំងព្រះបន្ទូលនៃបញ្ញត្តិនេះ គឺបានបើកសម្ដែងដោយបន្ទូលថា គឺជាជីវិតរបស់គេ ។ បញ្ញត្តិជាព្រះយេហូវ៉ានឹងជីវិត គឺនៅជាមួយគ្នា ។ ពាក្យថា"ជីវិត"ក្នុងអត្ថបទនេះ គឺទាក់ទងទៅនិងគ្រប់ទាំងជីវិតដែលទ្រង់បានបង្កើត(ប្រៀបធៀប លវ ១៨:៥ យហ ១០:១០ និងការពន្យល់) ។

**៣១:២** *មិនអាចនឹងចេញចូលទៀតបាន* គឺជាការមិនទាក់ទងទៅ និងសមត្ថភាពខាងរូបសាច់ទេ (មើល ៣៤:៧) ព្រះយេហូវ៉ាមិនបានអនុញ្ញាត្តឱ្យលោកម៉ូសេ ដឹកនាំប្រជាជនចូលទៅក្នុងទឹកដីកាណានទេ គឺដោយព្រោះតែអំពើបាបរបស់គាត់ (មើល ១:៣៧ ៣:២៣–២៧ ៤:២១–២២,៣២,៤៨–៥២ ជន ២០:២ មើលការពន្យល់) ។

**៣១:៤** *ដូចជាទ្រង់បានធ្វើដល់ស៊ីហុន និងអុក* មើល ២:២៦–៣:១១ និងការពន្យល់ ១:៤ ។

**៣១:៦** *ចូរមានកំឡាំងហើយចិត្តក្លាហានឡើង* ជាការក្រើនរំឭករបស់ព្រះយេហូវ៉ា គឺជារឿយៗធ្វើតាមរយៈអ្នកបម្រើទ្រង់ គឺចំពោះប្រជាជនអ៊ីស្រាអែល (យស ១០:២៥) ចំពោះលោកម៉ូសេ(មើល ខ.៧,២៣ យស ១:៦:៧,៩,១៨) ចំពោះសាឡូម៉ូន ។ (១របា ២២:១៣ ២៨:២០) ដោយទុកចិត្តលើព្រះយេហូវ៉ាហើយស្ដាប់បង្គាប់ទ្រង់ និងបានទទួលជ័យជម្នះ គឺគ្មានឧបស័គ្គ ។ *ទ្រង់មិនដែលខាននឹងប្រោសឯងទេ ក៏មិនដែលលះចោលឯងដែរ* មើល ខ.៨ យស ១:៥ ១ពវ ៨:៥៧ មើលការពន្យល់នៅ លប ២៨:១៥ ។

ទុកជាមរដក ៨គឺព្រះយេហូវ៉ាដែលនឹងយាងនាំមុខ ឯងទៅ[ថ]
ព្រមទាំងគង់ជាមួយនឹងឯង ទ្រង់មិនដែលខាននឹងប្រោស
ឯងឡើយ ក៏មិនដែលលះចោលឯងដែរ[ទ] ដូច្នេះកុំឱ្យខ្លាច
ឬស្រយុតចិត្តឱ្យសោះ ។

## ការអានក្រឹត្យវិន័យ

៩ម៉ូសេក៏កត់ក្រឹត្យវិន័យ[ធ]នេះ ប្រគល់ឱ្យដល់ពួកសង្ឃ
ជាកូនចៅលេវី ដែលគេសែង[ន]ហឹបនៃសេចក្ដីសញ្ញាផង
ព្រះយេហូវ៉ា ហើយដល់ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែល
ទាំងប៉ុន្មានផង ១០រួចលោកបង្គាប់ទៅគេថា លុះដល់ផុត
រាល់តែ៧ឆ្នាំ គឺក្នុងពេលកំណត់នៅឆ្នាំដែលដោះលែង[ប]
នៅវេលាបុណ្យបារាំ[ផ] ១១កាលសាសន៍អ៊ីស្រាអែលទាំង
អស់គ្នា បានលេចមក[ព]នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃ
ឯង ត្រង់កន្លែងដែលទ្រង់នឹងរើសហើយ[ភ] នោះត្រូវឱ្យមើល
ក្រឹត្យវិន័យនេះ[ម] នៅចំពោះមុខគេ ឱ្យបានស្តាប់ទាំងអស់គ្នា
១២ត្រូវឱ្យប្រមូលបណ្ដាជនទាំងប្រុសទាំងស្រី និងកូនក្មេង
ហើយនិងពួកអ្នកដទៃដែលនៅអស់ទាំងទីក្រុងរបស់ឯងមក
ដើម្បីឱ្យគេស្តាប់ ហើយបានរៀន[យ] ព្រមទាំងកោតខ្លាច[រ]
ដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ទាំងប្រយ័ត្ននឹងប្រព្រឹត្តតាម
អស់ទាំងពាក្យក្នុងក្រឹត្យវិន័យនេះ ១៣ហើយឱ្យកូនចៅគេ[ល]
ដែលមិនដឹង បានឮដែរ ហើយបានទំលាប់ កោតខ្លាចដល់
ព្រះយេហូវ៉ា ជាព្រះនៃឯង នៅអស់វេលាណាដែលឯងនៅ
ក្នុងស្រុក ដែលឯងឆ្លងទន្លេយ័រដាន់ទៅចាប់យកនោះនៅ
ឡើយ ។

## ទំនាយពីការមិនស្តាប់បង្គាប់របស់អ៊ីស្រាអែល

១៤ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា មើល ថ្ងៃ
ដែលឯងត្រូវស្លាប់[វ] នោះជិតដល់ហើយ ដូច្នេះចូរហៅ
យ៉ូស្វេ[ស]មក ហើយចូលទៅក្នុងត្រសាលជំនុំ ដើម្បីឱ្យអញ
បានប្រគល់បន្ទុកលើលោក[ហ] នោះម៉ូសេ និងយ៉ូស្វេក៏ចូល
ទៅក្នុងត្រសាលជំនុំ[ឡ] ១៥រួចព្រះយេហូវ៉ាទ្រង់លេចមកក្នុង
ត្រសាល នៅក្នុងបង្គោលពពក ពពកនោះក៏ស្ថិតនៅពី
លើទ្វារត្រសាល[អ] ១៦ទ្រង់មានបន្ទូលនឹងម៉ូសេថា មើលឯង
ត្រូវដេកលក់ទៅជាមួយនឹងពួកព្ធយុកោឯង[ក] ឯបណ្ដាជន
ទាំងនេះ គេនឹងលើកគ្នាផិតទៅ[ខ]តាមព្រះដទៃ ជាព្រះរបស់
ស្រុកដែលគេចូលទៅនៅកណ្ដាលនោះ គេនឹងបោះបង់
ចោល[គ]អញ ព្រមទាំងផ្តាច់សេចក្ដីសញ្ញា ដែលអញបាន
តាំងនឹងគេចេញ ១៧នោះសេចក្ដីកំហឹងរបស់អញនឹងបាន
កាត់ឡើង[ឃ] ទាស់នឹងគេនៅថ្ងៃនោះ រួចអញនឹងបោះបង់
ចោល[ង]គេដែរ ហើយនិងគេច[ច]មុខ[ឆ]ចេញពីគេទៅ នោះគេ
នឹងត្រូវស៊ីបង្ហិន ហើយនិងកើតមានសេចក្ដីអាក្រក់[ជ] និង
សេចក្ដីវេទនាជាច្រើនយ៉ាង ដល់ម្ល៉េះបានជាគេនឹងនិយាយ
នៅថ្ងៃនោះថា សេចក្ដីអាក្រក់ទាំងនេះបានមកលើយើង
ដោយព្រោះ តែព្រះនៃយើង ទ្រង់មិនគង់ក្នុងពួកយើងទេ
តើ[ឈ] ១៨តែនៅថ្ងៃនោះ អញនឹងគេចមុខចេញជាប្រាកដ
ដោយព្រោះសេចក្ដីអាក្រក់ទាំងប៉ុន្មានដែលគេបានប្រព្រឹត្ត
ដោយងាកបែរទៅតាមព្រះដទៃ ១៩ដូច្នេះចូរឯងកត់[ញ]ទំនុក
នេះទុកសំរាប់ឯងរាល់គ្នា ហើយបង្ហាត់បង្រៀនដល់ពួកកូន
ចៅអ៊ីស្រាអែលចុះ ចូរដាក់ទំនុកនេះចុះក្នុងមាត់គេ ដើម្បីឱ្យ
បានធ្វើជាទីបន្ទាល់[ដ]នៃអញ ទាស់នឹងពួកកូនចៅអ៊ីស្រា
អែល ២០ដ្បិតកាលណាអញបាននាំគេចូលទៅក្នុងស្រុកមាន
ទឹកដោះ និងទឹកឃ្មុំហូរហៀរ ដែលអញបានស្បថនឹងពួក
ព្ធយុកោគេ[ឋ] ហើយគេបានបរិភោគឆ្អែតចំរើនសាច់ឡើង
នោះគេនឹងងាកបែរទៅតាមព្រះដទៃវិញ[ឌ] ព្រមទាំងគោរព
ប្រតិបត្តិផង[ឍ] គេនឹងមើលងាយដល់អញ ហើយផ្តាច់សេចក្ដី

**៣១:៨** ថ នក ១៣:២១ ទ លប ២៨:១៥ ចទ ៤:៣១
**៣១:៩** ធ នក ១៧:១៤ ន ខ.២៥ ១របា ១៥:២
**៣១:១០** ប ចទ ១៥:១ ផ នក ២៣:១៦ ចទ ១៦:១៣
**៣១:១១** ព ចទ ១៦:១៦ ភ ចទ ១២:៥ ម យស ៨:៣៤–៣៥ ២ពវ ២៣:២ នហ ៨:២
**៣១:១២** យ ចទ ៤:១០ រ ហក ១:១២ មទ្ឋ ១:៦ ៣:៥,១៦
**៣១:១៣** ល ចទ ១១:២
**៣១:១៤** វ លប ២៥:៨ ជន ២៧:១៣ ស ជន ២៧:២៣ ចទ ៣៤:៩ យស ១:១–៩ ហ ជន ២៧:១៩ ឡ នក ៣៣:៩–១១
**៣១:១៥** អ នក ៣៣:៩
**៣១:១៦** ក លប ១៥:១៥ ខ នក ៣៤:១៥ ចទ ៤:២៥–២៨ ពច ២:១២ គ ពច ១០:៦,១៣ ១ពវ ៩:៩ ១៨:១៨ ១៩:១០ យរ ២:១៣ ៥:១៩ ១៩:៤
**៣១:១៧** ឃ ចទ ៣២:១៦ ពច ២:១៤,២០ ១០:៧ ២ពវ ១៣:៣ ២២:១៣ ទដ ១០៦:២៩,៤០ យរ ៧:១៨ ២១:៥ ៣៦:៧ ង ពច ៦:១៣ ២របា ១៥:៦ ២៤:២០ អរ ៨:២២ ទដ ៤៤:៩ អស ២:៦ ច ចទ ៣២:២០ អស ១:១៥ ៤៥:១៥ ៥៣:៣ ៥៤:៨ ឆ យប ១៣:២៤ ទដ ១៣:១ ២៧:៩ ៣០:៧ ១០៤:២៩ អស ៥០:៦ យរ ៣៣:៥ អគ ៣៩:២៩ មីក ៣:៤ ជ យរ ៤:២០ អគ ៧:២៦ ឈ ជន ១៤:៤២ ហស ៩:១២ **៣១:១៩** ញ ខ.២២ ដ លប ៣១:៥០ **៣១:២០** ឋ ចទ ៦:១០–១២ ឌ ទដ ៤:២ ១៦:៤ ៤០:៤ យរ ១៣:២៥ ដយ ៣:២៨ អម ២:៤ ឍ ចទ ៨:១៩ ១១:១៦–១៧ ណ ខ.១៦

**៣១:៩** *កត់ក្រឹត្យវិន័យនេះប្រគល់ឱ្យដល់ពួកសង្ឃ* គឺជាសេចក្ដីព្រមព្រៀងពីសម័យបុរាណដែលបញ្ជាក់ថា សេចក្ដីព្រមព្រៀងនេះបានដាក់ពីមុខព្រះដែលពួកគេថ្វាយបង្គំនៅឯមជ្ឈមណ្ឌលនៃខាងជាតិសាសន៍ ។ ចំពោះជនជាតិអ៊ីស្រាអែលអត្ថន័យនោះ គឺដាក់ជាប់នៅត្រង់ហឹបនៃសេចក្ដីសញ្ញា (មើលការពន្យល់ ៣៣:៩ នក ១៦:៣៤ ៣១:១៨) ។

**៣១:១០** *រាល់តែ៧ឆ្នាំ* មើល ១៥:៤ និងការពន្យល់ នក ២៣:១០–១១ លវ ២៥:១–៧ ។

**៣១:១១** *ត្រង់កន្លែងដែលទ្រង់នឹងរើសហើយ* មើលការពន្យល់ ១២:៥ ត្រូវឱ្យមើលក្រឹត្យវិន័យនោះនៅចំពោះមុខគេ ។ គឺជាការអានក្រឹត្យវិន័យចំពោះសាសន៍អ៊ីស្រាអែល (ហើយបង្រៀនវាដល់ពួកគេផងដែរ) វាគឺជាភារៈកិច្ចមួយសំខាន់របស់ពួកសង្ឃ (មើល ៣៣:១០ មទ្ឋ ២:៤–៩) ។

**៣១:១២** *កោតខ្លាចដល់ព្រះយេហូវ៉ា* មើលការពន្យល់ លប ២០:១១ ទដ ៣៤:៨–១៤ ។ *ពាក្យក្នុងក្រឹត្យវិន័យនេះ* មើលការពន្យល់ ខ.២៤ ។

**៣១:១៤** *ចូរហៅយ៉ូស្វេមក* សូមមើល ខ.២៣ ប្រៀបធៀប ជន ២៧:១៨–២៣ និងការពន្យល់ ២៧:១៨,២០ ។

**៣១:១៧–១៨** *គេចមុខចេញពីគេ* ៣២:២០ និងការពន្យល់ ទដ ១៣:១ ។

**៣១:១៩** *ឯងកត់ទំនុកនេះទុក . . . ហើយបង្ហាត់បង្រៀន* មើល ខ.២២ ៣១:៣០ ៣២:៤៤ ។

សញ្ញាអញចេញ[ណ] ២១រួចកាលណាគេកើតមានសេចក្ដី
អាក្រក់ និងសេចក្ដីវេទនាជាច្រើនយ៉ាង[ត] នោះទំនុកនេះ
នឹងធ្វើបន្ទាល់ដល់គេ ដ្បិតទំនុកនេះនឹងមិនដែលភ្លេចបាត់
ចេញពីមាត់នៃពូជគេឡើយ ពីព្រោះអញស្គាល់គំនិតដែល
កើតឡើងក្នុងចិត្តគេនៅថ្ងៃនេះហើយ[ថ] តាំងពីមុនដែលអញ
នាំគេចូលទៅក្នុងស្រុក ដែលបានស្បថនឹងគេមក ២២នៅថ្ងៃ
នោះឯង ម៉ូសេក៏កត់[ទ]ទំនុកនេះ ហើយបានបង្ហាត់បង្រៀន
ដល់ពួកកូនចៅអ៊ីស្រាអែល ។
២៣ព្រះយេហូវ៉ាក៏បង្គាប់[ធ]ដល់យ៉ូស្វេជាកូននុនថា ចូរ
មានកំឡាំង ហើយចិត្តក្លាហានចុះ[ន] ដ្បិតត្រូវឱ្យឯងនាំពួក
កូនចៅអ៊ីស្រាអែល ចូលទៅក្នុងស្រុកដែលអញបានស្បថ
នឹងគេ ឯអញក៏នឹងនៅជាមួយនឹងឯង ។
២៤កាលម៉ូសេបានកត់[ប]អស់ទាំងពាក្យ នៃក្រិត្យវិន័យ[ផ]នេះ
ទុកក្នុងសៀវភៅស្រេចហើយ ២៥នោះលោកបង្គាប់ដល់
ពួកលេវី ដែលសែង[ព]ហឹបនៃសេចក្ដីសញ្ញាផងព្រះយេហូ
វ៉ាថា ២៦ចូរយកគម្ពីរក្រិត្យវិន័យនេះ ទៅដាក់នៅត្រង់
ចំហៀងហឹប នៃសេចក្ដីសញ្ញាផងព្រះយេហូវ៉ា ជាព្រះ
នៃឯងរាល់គ្នាទៅ ឱ្យបាននៅទីនោះ សំរាប់ជាទីបន្ទាល់
ទាស់នឹងឯង[ភ] ២៧ដ្បិតអញស្គាល់ចិត្តបះបោរ[ម] និងក្បាល
រឹង[យ]របស់ឯងរាល់គ្នាហើយ មើល កាលអញកំពុងរស់
នៅជាមួយនឹងឯងរាល់គ្នាសព្វថ្ងៃ ម៉េចឯងបានបះបោរនឹង
ព្រះយេហូវ៉ាទៅហើយ ចំណង់បើថ្ងៃក្រោយដែលអញ
ស្លាប់ទៅ នោះតើនឹងលើសជាអំបាលម៉ានទៅទៀត ២៨ចូរ
ទៅប្រមូលពួកចាស់ទុំ ក្នុងពូជអំបូរទាំងប៉ុន្មានរបស់ឯង
រាល់គ្នា និងពួកនាយកទាំងអស់ របស់ឯងរាល់គ្នា មកឯ
អញ ដើម្បីឱ្យអញបានប្រាប់ពាក្យទាំងនេះ ឱ្យគេស្តាប់ ព្រម
ទាំងយកស្ថានសួគ៌ និងផែនដី ជាទីអាងទាស់នឹងគេផង[រ]

**៣១:២១** ត ចទ ៤:៣០ ថ ១របា ២៨:៩ ហស ៥:៣ យហ ២:២៤-២៥
**៣១:២២** ទ ខ.១៩
**៣១:២៣** ធ ខ.៧ ន យស ១:៦
**៣១:២៤** ប ចទ ១៧:១៨ ផ ២ពវ ២២:៨ ព ចទ ២៨:៥៨
**៣១:២៥** ភ ខ.៩
**៣១:២៧** ម នក ២៣:២១ យ ចទ ៩:២៧
**៣១:២៨** រ ចទ ៤:២៦ ៣០:១៩ ៣២:១ យប ២០:២៧ អស ២៦:២១
**៣១:២៩** ល ចទ ៤:១៦ វវ ៩:២០ វ ១ពវ ៩:៩ ២២:២៣ ២ពវ ២២:១៦
**៣២:១** ក យរ ២:១២ ខ ទដ ៤៩:១ មីក ១:២ គ ចទ ៤:២៦
**៣២:២** ឃ ២សយ ២៣:៤ ង ទដ ១០៧:២០ អស ៩:៨ ៥៥:១១ ច មីក ៥:៧ ឆ ទដ ៦៥:១០ ៦៨:៩ ៧២:៦ ១៤៧:៨
**៣២:៣** ជ ទដ ១១៨:១៧ ១៤៥:៦

២៩ដ្បិតអញដឹងថា ក្រោយដែលអញបានស្លាប់ទៅ នោះឯង
រាល់គ្នានឹងបង្ខូចខ្លួនអស់រលីងទៅ[ល] ហើយនិងងាកបែរ
ចេញពីផ្លូវដែលអញបានបង្គាប់ដល់ឯង ដូច្នេះនៅថ្ងៃជាន់
ក្រោយ និងមានសេចក្ដីអាក្រក់[វ]ធ្លាក់មកលើឯងរាល់គ្នា
ដោយព្រោះឯងរាល់គ្នាចូលចិត្តតែធ្វើការដែលអាក្រក់
នៅចំពោះព្រះនេត្រព្រះយេហូវ៉ាប៉ុណ្ណោះ គឺជាការដែល
បណ្ដាលឱ្យទ្រង់មានសេចក្ដីខ្ញាល់ ដោយដៃឯងធ្វើយ៉ាង
នោះ ។

### ទំនុករបស់លោកម៉ូសេ

៣០រួចម៉ូសេក៏ប្រាប់អស់ទាំងពាក្យក្នុងទំនុកនេះ ឱ្យឮទៅ
ដល់ត្រចៀកនៃពួកជំនុំសាសន៍អ៊ីស្រាអែលទាំងអស់គ្នា
រហូតដល់ចប់ ។
**៣២** ១ឱផ្ទៃមេឃអើយ[ក] ចូរផ្ទៀងត្រចៀកចុះ[ខ] ខ្ញុំនឹង
បញ្ចេញវាចា ហើយសូមឱ្យផែនដីស្ដាប់ពាក្យ ដែលចេញ
ពីមាត់ខ្ញុំដែរ[គ] ២គោលលទ្ធិរបស់ខ្ញុំ និងធ្លាក់មកដូចជាភ្លៀង
ហើយពាក្យសំដីខ្ញុំ និងចុះដូចជាទឹកសន្សើម គឺដូចជាភ្លៀង
រលឹម[ឃ] មកលើស្មៅល្បាស់ខ្ចី[ង,ច] ហើយដូចជាភ្លៀង១មេ[ឆ]
មកលើតិណជាតិទាំងឡាយដែរ ៣ពីព្រោះខ្ញុំនឹងប្រកាស[ជ]
ប្រាប់ពីព្រះនាមព្រះយេហូវ៉ា[ឈ] ចូរសរសើរដល់ព្រះនៃ
យើងខ្ញុំថា ទ្រង់ជាព្រះដ៏ធំឧត្ដម[ញ] ៤ទ្រង់ជាថ្មដា[ដ] ការរបស់
ទ្រង់សុទ្ធតែគ្រប់ល័ក្ខណ៍[ឋ] ដ្បិតអស់ទាំងផ្លូវទ្រង់ សុទ្ធតែ
ប្រកបដោយយុត្តិធម៌ ទ្រង់ជាព្រះដ៏ស្មោះត្រង់[ឌ] ឥតមានសេច
ក្ដីទុច្ចរិតណាឡើយ ទ្រង់ក៏ត្រឹមត្រូវ[ឍ] ហើយទៀងត្រង់[ណ] ។
៥គេបានបង្ខូចខ្លួនហើយ សេចក្ដីសៅហ្មងរបស់គេ មិន
មែនជារបស់ពួកកូនទ្រង់ទេ គេជាដំណមនុស្សវៀច ហើយ

ឈ នក ៣៣:១៩ ៣៤:៥-៦ ញ ចទ ៣:២៤ **៣២:៤** ដ លប ៤៩:២៤ ឋ ២សយ ២២:៣១ ទដ ១៨:៣០ ១៩:៧ ឌ ចទ ៤:៣៥ ឍ ទដ ៩២:១៥ ណ លប ១៨:២៥

**៣១:២៣** *ចូរមានកំឡាំង ហើយចិត្តក្លាហានចុះ* មើលការពន្យល់ ខ.៦ ។
**៣១:២៤** *ក្រិត្យវិន័យនេះទុកក្នុងសៀវភៅស្រេចហើយ* គម្ពីរចោទិយកថា គឺមានមកដល់សព្វថ្ងៃនេះ (មើលការពន្យល់ ខ.៩) ។
**៣១:២៦** *ដាក់នៅត្រង់ចំហៀងហឹប នៃសេចក្ដីសញ្ញា* មើល ខ.៩ ។
**៣១:២៧** *ក្បាលរឹង* មើល ៩:៦,១៣ ១០:១៦ មើលការពន្យល់ នក ៣២:៩ ។
**៣១:២៨** *ស្ថានសួគ៌ និងផែនដីជាទីអាង* មើលការពន្យល់ ៣០:១៩ ។
**៣១:២៩** *ដោយដៃឯងធ្វើយ៉ាងនោះ* គឺចង់និយាយពីរូបព្រះដែលគេថ្វាយបង្គំ (មើល ៤:២៨,២៧,១៥ និងការពន្យល់) ។
**៣១:៣០-៣២:៤៤** បទចម្រៀងរបស់លោកម៉ូសេ (មើល នក ១៥:១-១៨ វវ ១៥:៣)ការរៀបចំបទទំនុកចម្រៀង ៣១:៣០ ៣២:៤៤ ។ ហើយចម្រៀងនោះមានគម្រោងសង្ខេបតាមរយៈ (១)ការអំពាវនាវបន្ទាល់នៃសេចក្ដីសញ្ញា និងការពណ៌នាពីសេចក្ដីសញ្ញានៃព្រះអម្ចាស់(៣២:១-៤) (២)ជាបទចោទទាស់និងមនុស្ស (៣២:៥-៦) (៣) ការរំលឹងពីផលនៃសេចក្ដីសញ្ញារបស់ព្រះ ។ (៣២:៧-១៤) (៤) ការមិនស្ដាប់បង្គាប់របស់ប្រជាជនចំពោះលក្ខណៈពិសេសរបស់សេចក្ដីសញ្ញា (៣២:១៥-១៨) (៥) បណ្ដាសាពីសេចក្ដីសញ្ញាចំពោះប្រភេទមនុស្សដែលមិនស្ដាប់បង្គាប់(៣២:១៩-២៧) (៦) ភាពពុំមានអំណាចរបស់រូបព្រះក្លែងក្លាយទាំងអស់ (សូមមើល ៣២:៣៩-៤៣) ។
**៣២:១** *ឱផ្ទៃមេឃអើយចូរផ្ទៀងត្រចៀកចុះ* គឺជាសេចក្ដីចាប់ផ្ដើមដែលស្រដៀងគ្នានឹងគម្ពីរ អស ១:២ និងការពន្យល់ ៣៤:១ មីក ១:៣ ៦:១-២ ។
**៣២:៤** *ទ្រង់ជាថ្មដា* ចង្វាក់ចម្រៀង របស់លោកម៉ូសេដែលសំខាន់ សូមមើល ខ.១៥,១៨,២០-៣១ និងការពន្យល់ លប ៤៩:២៤ ទដ ១៨:២ ។
**៣២:៥** *សេចក្ដីសៅហ្មង . . . គេជាដំណមនុស្សវៀច* មើល ភល ២:១៥ និងការពន្យល់ ។

ក្រវេចក្រវៀន[ត] ៦ឱពួកមនុស្សលីលា[ថ] ហើយឥតប្រាជ្ញា
អើយ[ទ] តើឯងរាល់គ្នាសងគុណ[ធ]ដល់ព្រះយេហូវ៉ាយ៉ាងនោះ
ឬអី តើទ្រង់មិនមែនជាព្រះវរបិតានៃឯង[ន] ដែលបានទិញ
ឯងមកទេឬអី ទ្រង់បានបង្កើតឯង ហើយតាំងឯងឡើងផង[ប]
៧ចូរនឹកចាំពីថ្ងៃចាស់បុរាណ[ផ] ចូរពិចារណាពីអស់ទាំង
ឆ្នាំដ៏មានជាច្រើនដំណតមក[ព]ចូរសួរឪពុកឯងចុះ គាត់នឹង
សំដែងឱ្យឯងដឹង ហើយសួរពួកចាស់ទុំនៃឯងផង គេនឹង
ប្រាប់ដល់ឯង[ភ] ៨កាលព្រះដ៏ខ្ពស់បំផុត[ម] បានចែកមរដកដល់
សាសន៍ទាំងប៉ុន្មាន[យ] គឺកាលទ្រង់បានបំបែកពួកកូនចៅ
អ័ដាមចេញពីគ្នា នោះទ្រង់បានដាក់ព្រំប្រទល់[រ]ឱ្យអស់ទាំង
ប្រជាជន តាមចំនួនអស់ពួកកូនចៅអ៊ីស្រាអែល[ល] ៩ដ្បិតកេរ្តិ៍
អាកររបស់[វ]ព្រះយេហូវ៉ា នោះគឺជារាស្ត្ររបស់ទ្រង់ ហើយ
យ៉ាកុបជាចំណែកមរដកទ្រង់[ស] ១០ទ្រង់ឃើញលោកនៅ
តំបន់ស្ងាត់ ហើយនៅទីរហោស្ថាន[ហ] ជាទីមានសុទ្ធតែ
សូរស័ព្ទគឹកកង[ឡ] នោះទ្រង់បានព័ទ្ធ[អ]លោកជុំវិញ ហើយបាន
ថែទាំ ព្រមទាំងរក្សាលោកទុកដូចជាប្រស្រីព្រះនេត្ររបស់
ទ្រង់[ក] ១១ឧបមាដូចជាសត្វឥន្ទ្រីដែលដាស់តឿនកូននៅសំបុក
[ខ]ក៏ហើរសំរឹងពីលើ រួចត្រដាងស្លាបទទួលកូន ទ្រនៅលើ
ចំអេងឡើង[គ] ១២ព្រះយេហូវ៉ាតែ១ព្រះអង្គ ទ្រង់បាននាំ[ឃ]
លោក[ង] ឥតមានព្រះដទៃណានៅជាមួយឡើយ[ច] ១៣ទ្រង់បាន
បញ្ជិះលោកនៅលើទីខ្ពស់[ឆ]នៃផែនដី លោកបានបរិភោគ
ផលចំរើនពីស្រែចំការ ហើយទ្រង់បានឱ្យលោកជញ្ជក់ទឹក
ឃ្មុំពីថ្មដា[ជ] និងប្រេង[ឈ]ពីថ្មដ៏រឹង ១៤ក៏បានឱ្យបរិភោគខ្លាញ់
ទឹកដោះ និងទឹកដោះសុទ្ធពីហ្វូងសត្វ ព្រមទាំងខ្លាញ់កូន
ចៀម និងចៀមឈ្មោលពូជពីស្រុកបាសាន[ញ] ហើយពពែ
ផង ក៏មានអង្ករភោជ្ជសាលីយ៉ាងត្រសូលផង[ដ] ហើយលោក
បានផឹកឈាមទំពាំងបាយជូរដ៏សុទ្ធ[ឋ] ១៥តែយេស៊ូរុន[ឌ]បាន
ឡើងសាច់ ហើយបានធាត់[ឍ]ឡើងវិញ គេបានចំរើនសាច់
ឡើង បានត្រឡប់ជាក្រាស់មាំហើយ ក៏ធាត់រលីក នោះគេ
បានបោះបង់ចោល[ណ]ព្រះដែលបង្កើតខ្លួនមក ហើយបាន
មើលងាយដល់ថ្មដា[ត]នៃសេចក្តីសង្គ្រោះរបស់ខ្លួន ១៦គេបាន
បណ្តាលឱ្យ ទ្រង់មានសេចក្តីប្រចណ្ឌ[ថ] ដោយសារព្រះដទៃ
ក៏បានចាក់រុក ឱ្យទ្រង់ខ្ញាល់[ទ] ដោយសារការគួរស្អប់ខ្ពើម
១៧គេបានថ្វាយយញ្ញបូជា[ធ]ដល់ពួកអារក្ស[ន] ដែលមិនមែនជា
ព្រះសោះ គឺដល់ព្រះដែលគេមិនបានស្គាល់[ប] ជាព្រះថ្មីដែល
ទើបនឹងកើតឡើង[ផ] ដែលពួកឰយុកោឯងមិនបានកោតខ្លាត
ឡើយ ១៨ឯព្រះដ៏ជាថ្មដាដែលទ្រង់បង្កើតឯង នោះឯងឥត
រវល់វិញ គឺបានបំភ្លេច[ព]ព្រះដែលបានបង្កើតជីវិតឯងមក ។
១៩ព្រះយេហូវ៉ាទ្រង់បានឃើញ ហើយក៏ខ្ពើម[ភ]ដោយ
ព្រោះកិរិយាបង្អុចបង្អាល របស់ពួកកូនប្រុស កូនស្រីទ្រង់[ម]
២០នោះទ្រង់មានបន្ទូលថា អញនឹងគេចមុខ[យ]ចេញពីគេ អញ
នឹងចាំមើលចុងបំផុតរបស់គេជាយ៉ាងណា ដ្បិតគេជាដំណ
មនុស្សវៀចពេកណាស់[រ] ជាកូនចៅដែលមិនមានសេចក្តី
ស្មោះត្រង់សោះ[ល] ២១គេបានបណ្តាលឱ្យអញមានសេចក្តី
ប្រចណ្ឌ[វ] ដោយសាររបស់ដែលមិនមែនជាព្រះ[ស] ក៏បាន
ចាក់រុកអញឱ្យខឹង ដោយសាររបស់ឥតប្រយោជន៍របស់គេ

**៣២:៥** ត ខ.២០ មថ ១៧:១៧ លក ៩:៤១ កច ២:៤០ **៣២:៦** ថ ទដ ៩៤:៨ យរ ៥:២១ ទ ខ.២៨ ធ ទដ ១១៦:១២ ន នក ៤:២២ ២សយ ៧:២៤ ប ខ.១៥ **៣២:៧** ផ ទដ ៤៤:១ ៧៤:២ ៧៧:៥ អស ៥១:៩ ៦៣:៩ ព ចទ ៤:៣២ យប ៨:៨ ២០:៤ ទដ ៧៨:៤ អស ៤៦:៩ឱ ភ នក ១០:២ យប ១៥:១៨ **៣២:៨** ម ទដ ៧:៨ យ លប ១១:៨ កច ៨:១ រ ទដ ៧៤:១៧ ល ជន ២៣:៩ ចទ ៣៣:១២,២៨ យរ ២៣:៦ **៣២:៩** វ ទដ ១៦:៥ ៧៣:២៦ ១១៩:៥៧ ១៤២:៥ យរ ១០:១៦ ស ចទ ៩:២៩ ១សយ ២៦:១៩ **៣២:១០** ហ ចទ ១:១៩ ឡ ចទ ៨:១៥ យប ១២:២៤ ទដ ១០៧:៤០ អ ទដ ៣២:១០ យរ ៣១:២២ ក ទដ ១៧:៨ សផ ៧:២ ហស ១៣:៥ សក ២:៨ **៣២:១១** ខ នក ១៩:៤ គ ទដ ១៧:៨ ១៨:១០–១៩ ៦១:៤ **៣២:១២** ឃ ទដ ១០៦:៩ អស ៦៣:១៣ យរ ៣១:៣២ ង ចទ ៤:៣៥ ច ខ.៣៩ ពច ២:១២ ទដ ១៨:៣១ ៨១:៩ អស ៤៣:១២ ៤៥:៥ **៣២:១៣** ឆ ចទ ៣៣:២៩ ២សយ ២២:៣៤ ទដ ១៨:៣៣ អស ៣៣:១៦ ៥៨:១៤ អគ ៣៦:២ ហព ៣:១៩ ជ ចទ៨:៨ ឈ ចទ ៣៣:២៤ យប ២៩:៦ **៣២:១៤** ញ ជន ២១:៣៣ ដ ទដ ៦៥:៩ ៨១:១៦ ១៤៧:១៤ ឋ លប ៤៩:១១ **៣២:១៥** ឌ ចទ ៣៣:៥,២៦ អស ៤៤:២ ឍ ចទ ៣១:២០ យរ ៥:២៨ ណ ចទ ៣១:១៦ អស ១:៤,២៨ ៥៨:២ ៦៥:១១ យរ ១៥:៦ អគ ១៤:៥ ត លប ៤៩:២៤ **៣២:១៦** ថ ជន ២៥:១១ ១កថ ១០:២២ ទ ចទ ៣១:១៧ ១ពវ ១៤:៩ **៣២:១៧** ធ នក ៣២:៨ ន នក ២២:២០ ១កថ ១០:២០ ប ចទ ២៨:៦៤ ផ ពច ៥:៨ **៣២:១៨** ព ពច ៣:៧ ១សយ ១២:៩ ទដ ៤៤:១៧,២០ ១០៦:២១ យរ ២:៣២ អគ ២៣:៣៥ ហស ៨:១៤ ១៣:៦ **៣២:១៩** ភ លវ ២៦:៣០ ទដ ៧៨:៥៩ ម អម ៦:៨ **៣២:២០** យ ចទ ៣១:១៧,២៩ ទដ ៤:៦ ៤៤:២៤ រ ខ.៥ ល ចទ ៩:២៣ **៣២:២១** វ ជន ២៥:១១ ១កថ ១០:២២ ស ខ.១៧ ១ពវ

**៣២:៧** *ចូរនឹកចាំពីថ្ងៃចាស់បុរាណ* មើលការពន្យល់ ៤:១០ ។

**៣២:៨** *ខ្ពស់បំផុត* គឺជាពាក្យបង្ហាញក្នុងគម្ពីរចោទិយកកថានេះ គឺជាព្រះនាមព្រះអម្ចាស់ (មើល លប ១៤:១៩) ។ គឺសង្កត់ធ្ងន់ទៅលើនាម ព្រះយេហូវ៉ា ដែលជាព្រះមហាក្សត្រលើគ្រប់ទាំងស្នាព្រះហស្តរបស់ផងទ្រង់ ។ *ចែកមរដកដល់សាសន៍ទាំងប៉ុន្មាន* មើល លប ១០ ។ *តាមចំនួនអស់ពួកកូនចៅអ៊ីស្រាអែល* វាអាចនិយាយចំពោះ៧០នាក់ (មើល ១០:២២) គឺជាកូនប្រុសៗរបស់យ៉ាកុប(អ៊ីស្រាអែល)ដែលបានឆ្លងកាត់ទៅអេស៊ីព្ទ (មើល លប ៤៦:២៧ នក ១:៥ មើល ការពន្យល់ លប ១០:២) ។

**៣២:១០** *ជាប្រស្រីព្រះនេត្ររបស់ទ្រង់* គឺចង់និយាយពីរន្ធប្រស្រីដែលជាផ្នែកមួយដ៏ប្រណិតនៃកែវភ្នែកទាំងមូល ក៏ជាផ្នែកសំខាន់ដើម្បីទទួលបាននូវទិដ្ឋភាព ឬរូបភាពដូចនេះហើយយើងត្រូវថែរក្សាវា ។

**៣២:១១** *ត្រដាងស្លាប* មើល លប ១:២ ។

**៣២:១៣** *ជញ្ជក់ទឹកឃ្មុំពីថ្មដា* មើល ទដ ៨២:១៦ នៅស្រុកកាណានឃ្មុំជួនកាលធ្វើសំបុកនៅនិងផ្ទាំងថ្ម(ប្រៀបធៀប អស ៧:១៨–១៩) *ប្រេងពីថ្មដ៏រឹង* ដើមអូលីវជារឿយៗបានដុះតាមជ្រលងភ្នំ ដូចជាភ្នំដើមអូលីវនៅខាងកើតទីក្រុងយេរូសាឡិម ។

**៣២:១៥** *យេស៊ូរុន* មើលការពន្យល់ អស ៤៤:២ ។ *ថ្មដា* សូមមើល ខ.១៨ និងការព ន្យល់ ខ.៤ ។

**៣២:១៧** *ពួកអារក្ស* មើល ទដ ១០៦:៧ និងការពន្យល់ ។

**៣២:២០** *អញនឹងគេចមុខចេញ* មើលការពន្យល់ ៣១:១៧–១៨ ។

**៣២:២១** សេចក្តីដកស្រង់នៅក្នុងគម្ពីរ រម ១០:១៩ ជាការបញ្ជាក់ពីប្រជាជនអ៊ីស្រាអែល ដែលពុំបានយល់ពីដំណឹងល្អ ឬអំពីព្រះគ្រីស្ទ មើល ខ.១៦ ។

ដូច្នេះអញនឹងបណ្ដាលឱ្យគេមានសេចក្ដីប្រចណ្ឌដែរ ដោយ
សារពួកមនុស្សដែលមិនមែនជាសាសន៍ណាទេ ហើយនិង
ចាក់រុកឱ្យគេខឹងដោយសារសាសន៍១ ដែលឥតប្រាជ្ញា[ហ]
២២ដ្បិតភ្លើងនៃសេចក្ដីកំហឹងរបស់អញបានឆួល ឡើង
ហើយ[ឡ] ក៏ឆេះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ទីជ្រៅ
បំផុត[អ] ព្រមទាំងចំរើនឡើងឆេះបន្សុស[ក]ផែនដី[ខ] ហើយ
បង្កាត់ភ្លើងនៅបាតភ្នំទាំងប៉ុន្មានផង[គ] ២៣អញនឹងបង្គរ
សេចក្ដីអាក្រក់[ឃ]ទៅលើគេ អញនឹងបាញ់ព្រួញ[ង]អញអស់
រលីងទៅលើគេ ២៤គេនឹងត្រូវរីងរៃទៅដោយឃ្លាន[ច]
ហើយរោយរៀវទៅ ដោយអំណាចក្ដៅ[ឆ] និងសេចក្ដីហិន
វិនាសដ៏ជូរចត់[ជ] ហើយអញនឹងចាត់សត្វព្រៃទៅខាំគេ[ឈ]
ព្រមទាំងសត្វលូនវារ[ញ]នៅដី[ដ]ឱ្យទៅចឹកផង ២៥ឯខាងក្រៅ
នោះដាវនឹងបង្អត់ ហើយក្នុងបន្ទប់ខាងក្នុង នោះនឹងមាន
សេចក្ដីស្ញែងខ្លាច[ឋ,ឌ]ដល់ទាំងមនុស្សកំឡោះ និងស្រីក្រមុំ
ហើយទាំងកូនដែលនៅបៅដោះ និងមនុស្សសក់ស្កូវផង[ឍ]
២៦អញបានប្រាប់ថា អញនឹងកំចាត់កំចាយ[ណ]គេឱ្យទៅជា
ឆ្ងាយ អញនឹងបំបាត់សេចក្ដីនឹកចាំពីគេចេញពីពួកមនុស្ស
លោកទៅ[ត] ២៧តែអញខ្លាចការបង្អុចបង្អាលរបស់ពួកខ្មាំង
សត្រូវគេ ក្រែងពួកទាស់ទទឹងទាំងនោះ បានមើលងាយ [ថ]
ហើយក្រែងគេថា ដៃយើងបានឈ្នះទេ មិនមែនជាព្រះយេ
ហូវ៉ាដែលធ្វើការទាំងនេះឡើយ[ទ] ២៨ដ្បិតគេជាសាសន៍
ដែលឥតមានសេចក្ដីដំបូន្មាន គេគ្មានយោបល់[ធ]នៅក្នុងខ្លួន
សោះ ។
២៩ឱបើគេមានប្រាជ្ញា ហើយបានយល់សេចក្ដីនេះ[ន] ឱបើ
គេនឹងពិចារណាពីចុងបំផុតរបស់គេទៅអេះ[ប] ៣០ធ្វើដូច
ម្ដេចឱ្យមនុស្សតែម្នាក់ដេញដល់១ពាន់នាក់ ឬ២នាក់ធ្វើឱ្យ
១ម៉ឺននាក់រត់ទៅបាន[ផ] លើកតែព្រះដ៏ជាថ្មដារបស់ពួកនោះ
បានលក់គេ[ព] ឬព្រះយេហូវ៉ាបានប្រគល់គេទៅប៉ុណ្ណោះ[ភ]
៣១ដ្បិតថ្មដារបស់គេ មិនដូចជាថ្មដារបស់យើងនោះទេ[ម]
គឺជាពួកខ្មាំងសត្រូវនឹងយើង ដែលធ្វើបន្ទាល់[យ]ថាដូច្នោះ
ផង ៣២ដ្បិតគល់របស់គេ គឺជាគល់របស់ក្រុងសូដុំម[រ]
ហើយក៏មកពីចំការរបស់ក្រុងកូម៉ូរ៉ា ផ្លែទំពាំងបាយជូរ
របស់គេ ជាផ្លែមានរសពុល[ល] ចង្កោមគេក៏ជូរចត់ដែរ[វ]
៣៣ស្រាទំពាំងបាយជូររបស់គេ ជាពិសរបស់នាគ[ស] ហើយ
ជាពិសសាហាវរបស់ពស់ហនុមានផង ៣៤នេះតើមិនមែន
ដាក់ទុកនឹងអញព្រមទាំងបិទត្រា នៅជាមួយនឹងទ្រព្យ
សម្បត្តិអញទេឬអី[ហ] ៣៥គឺសេចក្ដីសងសឹក[ឡ] និងសេចក្ដីសង
គុណ[អ] នោះស្រេចនៅអញក្នុងកាលដែលជើងគេរអិល
ភ្លាត់[ក] ដ្បិតថ្ងៃដែលគេត្រូវអន្តរាយ នោះជិតមកដល់ ហើយ
ការដែលត្រូវមកលើគេ ក៏មកជាឆាប់ផង[ខ] ៣៦ពីព្រោះព្រះ
យេហូវ៉ា ទ្រង់នឹងកាត់សេចក្ដីឱ្យរាស្ត្រទ្រង់បានរួច[គ] ព្រម
ទាំងអាណិតមេត្តា[ឃ]ដល់ពួកបាវបំរើរបស់ទ្រង់[ង] ក្នុងកាល
ដែលទ្រង់ទតឃើញថា កំឡាំងរបស់គេបាត់អស់រលីង ឥត
មានអ្នកណានៅសល់ឡើយ ទោះទាំងខ្ញុំកំដរ[ច] និងអ្នកជាផង
៣៧នោះទ្រង់នឹងមានបន្ទូលថា អស់ទាំងព្រះរបស់គេ គឺជា
ថ្មដានោះ ដែលគេបានយកជាទីពឹង តើនៅឯណា[ឆ] ៣៨ជា
ព្រះដែលបានទទួលខ្លាញ់នៃយញ្ញបូជារបស់គេ ព្រមទាំង
ផឹកស្រាទំពាំងបាយជូរនៃដង្វាយច្រួចរបស់គេ[ជ] ចូរឱ្យព្រះ
ទាំងនោះក្រោកឡើងជួយឯងចុះ ហើយការពារឯងទៅ
៣៩ដូច្នេះចូរឯងដឹងថា គឺអញនេះហើយដែលជាព្រះ[ឈ] គ្មាន
ព្រះឯណាទៀតក្រៅពីអញឡើយ[ញ] អញជាអ្នកសំឡាប់[ដ]

១៦:១៣,២៦២ពវ ១៧:១៥ ទដ ៣១:៦ យរ ២:៥ ៨:១៩ ១០:៨ ១៦:១៩ យហ ២:៨ ហ រម ១០:១៩ **៣២:២២** ឡ ទដ ៧:១១ អ ជន ១៦:៣១–៣៥ ទដ ១៨:៧–៨ យរ ១៥:១៤ បទ ៤:១១ ក អម ៧:៤ ខ លវ ២៦:២០ គ ទដ ៨៣:១៤ **៣២:២៣** ឃ ចទ ២៩:២១ ង ខ.៤២ ២សយ ២២:១៥ យប ៦:៤ ទដ ៧:១៣ ១៨:១៤ ៤៥:៥ ៧៧:១៧ ១២០:៤ ៤៥:៥ **៣២:២៤** ច លប ២៦:១ ៤១:៥៥ ៤២:៥ ២សយ ២៤:១៣ ១រប ២១:១២ ឆ ចទ ២៨:២២ ជ ទដ ៩១:៦ ឈ លប ៣៧:២០ ញ ខ.៣៣ យប ២០:១៦ ទដ ៥៨:៤ យរ ៨:១៧ អម ៥:១៨–១៩ មីក ៧:១៧ ដ យប ២០:១៦ **៣២:២៥** ឋ អស ២៤:១៧ ឌ យរ ១៤:១៨ បទ ១:២០ អគ ៧:១៥ ២កថ ៧:៥ ឍ ២រប ៣៦:១៧ អស ១៣:១៨ យរ ៤:៣១ បទ ២:២១

**៣២:២៦** ណ ចទ ៤:២៧ ត ជន ១៤:១២ យប ១៨:១៧ ទដ ៣៤:១៦ ៣៧:២៨ ១០៩:១៥ អស ១៤:២០ **៣២:២៧** ថ ចទ ៩:២៦–២៨ ទ ទដ ១៤០:៨ អស ១០:១៣ យរ ៤០:២–៣ **៣២:២៨** ធ អស ១:៣ ៥:១៣ ២៧:១១ យរ ៨:៧ **៣២:២៩** ន ចទ ៥:២៩ ទដ ៨១:១៣ ប អស ៤៧:៧ បទ ១:៩ **៣២:៣០** ផ លវ ២៦:៨ ព ពច ២:១៤ ៣:៨ ៤:២ ១០:៧ ១សយ ១២:៩ ផ ជន ២១:៣៤ ១សយ ២៣:៧ ១០៦:៤១ អស ៥០:១ ៥៤:៦ **៣២:៣១** ម លប ៤៩:២៤ យ នក ១៤:២៥ **៣២:៣២** រ យរ ២៣:១៤ ល យប ៦:៤ ២០:១៦ វ ចទ ២៩:១៨ **៣២:៣៣** ស ខ.២៤ **៣២:៣៤** ហ យប ១៤:១៧ យរ ២:២២ ហស ១៣:១២ **៣២:៣៥** ឡ ខ.៤១ លប ៤:២៤ យរ ៥១:៦ អ លប ៣០:២ នក ៣២:៣៤ ទដ ៥៤:៥ រម ១២:១៩ ហព ១០:៣០ ក ទដ ១៧:៥ ៣៥:៦ ៣៧:៣១ ៣៨:១៦ ៦៦:៩ ៧៣:២,១៨ ៩៤:១៨ ១២១:៣ សភ ៤:១៩ យរ ២៣:១២ ខ អគ ៧:៨–៩ **៣២:៣៦** គ ហព ១០:៣០ ឃ អម ៧:៣ ង លវ ២៦:៤៣–៤៥ ចទ ៣០:១–៣ ពច ២:១៨ ទដ ៩០:១៣ ១០៦:៤៥ ១៣៥:១៤ យអ ២:១៤ ច ១ពវ ១៤:១០ ២១:២១ ២ពវ ៩:៨ **៣២:៣៧** ឆ ពច ១០:១៤ យរ ២:២៨ ១១:១២ **៣២:៣៨** ជ ជន ២៥:១–២ យរ ១១:១២ ៤៤:៨,២៥ **៣២:៣៩** ឈ អស ៤១:៤ ៤៣:១០ ៤៤:៧ ៤៦:៤ ៤៨:១២ ញ ខ.១២ ដ ១សយ ២:៦

**៣២:២២** *កំហឹងរបស់អញ . . . ស្លាប់ទីជ្រៅបំផុត* មើលកាពន្យល់ ៣៧:៣៥ យប ១៧:១៦ ទដ ១៣៨:៨ សភ ២៣:១៤ ២៤:២០ ។

**៣២:២៦** *អញបានប្រាប់ថា អញនឹងកំចាត់កំចាយគេ* មើល ៩:១៤ និងការពន្យល់ ប្រៀបធៀប ២៥:១៩ ។

**៣២:៣០** *ថ្មដារបស់ពួកនោះ* ព្រះនៃអ៊ីស្រាអែល (មើលការពន្យល់ ខ.៤) ។

**៣២:៣១** *ថ្មដារបស់គេ* ជាព្រះដែលជាសត្រូវរបស់សាសន៍អ៊ីស្រាអែល ។

**៣២:៣៤** *ទាំងបិទត្រានៅជាមួយ នឹងទ្រព្យសម្បត្តិអញ* ផែនការរបស់ព្រះយេហូវ៉ាចំពោះអនាគត គឺត្រឹមត្រូវនិងពិតប្រាកដ ។ អំពើបាបនឹងបានកាត់ទោសនៅពេលកំណត់មួយច្បាស់ ។

**៣២:៣៥–៣៦** ផ្នែកសម្រង់នៅគម្ពីរ ហព ១០:៣០ គឺជាការព្រមានប្រឆាំងនិងព្រះរាជបុត្រានៃព្រះ ។

**៣២:៣៩** *គឺអញនេះហើយដែលជាព្រះ* មើល នក ៣:១២–១៥ មើលការពន្យល់ប្រៀបធៀប យហ ៤:២៦ និងការពន្យល់ ។ គ្មានព្រះឯណាទៀតក្រៅពីអញឡើយ សូមមើលការពន្យល់ ៤:៣៥ ។ *អញជាអ្នកសំឡាប់ ហើយជាអ្នក*

ហើយជាអ្នកប្រោសឱ្យរស់[ឋ] អញជាអ្នកវាយឱ្យមានរបួស
ហើយជាអ្នកមើលឱ្យជាផង[ឌ] គ្មានអ្នកណានឹងដោះឱ្យរួច
ពីកណ្តាប់ដៃអញបានឡើយ[ឍ] ៤០ដ្បិតអញលើកដៃអញ[ណ]
ទៅឯស្ថានសួគ៌ ស្បថដោយនូវព្រះជន្មអញដ៏នៅអស់កល្ប
ជានិច្ច[ត]ថា ៤១បើសិនជាអញសំលៀងដាវរបស់អញដ៏ភ្លឺ
ផ្លេកៗ[ថ] ហើយដៃអញចាប់កាន់សេចក្តីយុត្តិធម៌វេលាណា
នោះអញនឹងសងសឹក[ទ]ចំពោះពួកអ្នកដែលតតាំងនឹងអញ
ហើយនិងសងដល់ពួកអ្នកដែលស្អប់អញជាមិនខាន[ធ] ៤២អញ
នឹងធ្វើឱ្យព្រួញអញស្រវឹងដោយឈាម[ន] ហើយឱ្យដាវអញ
ត្របាក់ស៊ីសាច់ផង[ប] គឺដោយឈាមនៃពួកអ្នកដែលត្រូវគេ
សំឡាប់ព្រមទាំងពួកឈ្លើយ ចាប់តាំងពីដើមនៃការសង
សឹកដល់ពួកខ្មាំងសត្រូវជារហូតទៅ ៤៣ឱអស់ទាំងសាសន៍
អើយ ចូរសរសើរដល់រាស្ត្រទ្រង់ចុះ[ផ]ដ្បិតទ្រង់នឹងសងសឹក
ចំពោះឈាមពួកបាវបំរើទ្រង់[ព] គឺនឹងសងដល់ពួកអ្នកដែល
តតាំងនឹងទ្រង់[ភ] ហើយនិងធ្វើឱ្យធួននឹងស្រុកទ្រង់ព្រមទាំង
រាស្ត្រទ្រង់ផង[ម]។
៤៤ម៉ូសេ ព្រមទាំងយ៉ូស្វេ[យ] ជាកូននុន ក៏មកប្រាប់អស់ទាំង
ពាក្យរបស់ទំនុកនេះ ដល់បណ្តាជនទាំងអស់គ្នា ឱ្យបាន
ស្តាប់ ៤៥កាលម៉ូសេបានប្រាប់ពាក្យទាំងនេះ ដល់សាសន៍
អ៊ីស្រាអែលទាំងអស់ស្រេចហើយ ៤៦នោះលោកក៏មាន
ប្រសាសន៍ថា ចូរយកចិត្តទុកដាក់នឹងពាក្យទាំងអស់ ដែល
អញបានប្រាប់ដល់ឯងរាល់គ្នានៅថ្ងៃនេះចុះ[រ] ដើម្បីនឹង
បង្គាប់[ល]ដល់កូនចៅឯងរាល់គ្នា ឱ្យប្រយ័ត្ននិងប្រព្រឹត្តតាម
ដែរ គឺជាអស់ទាំងពាក្យក្នុងក្រិត្យវិន័យនេះ ៤៧នេះមិនមែន
ជាសេចក្តីឥតប្រយោជន៍ដល់ឯងរាល់គ្នាទេ គឺជាជីវិតដល់
ឯងរាល់គ្នាវិញ[វ] ហើយដោយសារសេចក្តីនេះ នោះឯង
រាល់គ្នានឹងបានជីវិតជាយូរអង្វែងតទៅ[ស] នៅក្នុងស្រុក
ដែលឯងរាល់គ្នា និងឆ្លងទន្លេយ័រដាន់ចូលទៅចាប់យក
នោះ ។

## លោកម៉ូសេស្លាប់នៅលើភ្នំនេបូរ

៤៨នៅថ្ងៃនោះឯង ព្រះយេហូវ៉ាទ្រង់ក៏បង្គាប់ដល់ម៉ូសេ
ថា[ហ] ៤៩ចូរឡើងតាមភ្នំអាបារីមនេះ[ឡ] ទៅដល់កំពូលភ្នំ
នេបូរ[អ] ដែលនៅក្នុងស្រុកម៉ូអាប់ ទល់មុខនឹងយេរីខូរ[ក]
ហើយមើលទៅឯស្រុកកាណាន[ខ] ដែលអញឱ្យទុកជាកេរ្តិ៍
អាករ ដល់ពួកកូនចៅអ៊ីស្រាអែលចុះ ៥០រួចស្លាប់[គ]នៅលើភ្នំ
ដែលឯងឡើងនោះទៅ ឯងនឹងបានប្រមូលទៅមូលនឹងពួក
ឰយុកោឯង ដូចជាអើរ៉ុនបងឯងបានស្លាប់[ឃ]នៅលើភ្នំ
ហោរ[ង] ហើយបានប្រមូលទៅមូលនឹងពួកឰយុកោដែរ
៥១គឺដោយព្រោះឯងបានរំលងទាស់នឹងអញ នៅក្នុងពួកកូន
ចៅអ៊ីស្រាអែល ត្រង់ទឹកមេរីបានៅស្រុកកាដេស[ច] ក្នុង
ទីរហោស្ថានស៊ីន[ឆ] ពីព្រោះឯងមិនបានលើកអញជាបរិសុទ្ធ
នៅកណ្តាលពួកកូនចៅអ៊ីស្រាអែលទេ[ជ] ៥២ឯងនឹងមើល
ស្រុកនៅមុខឯងឃើញ[ឈ] តែមិនបានចូលទៅក្នុងស្រុក[ញ]
ដែលអញឱ្យដល់ពួកកូនចៅអ៊ីស្រាអែលនោះទេ ។

## លោកម៉ូសេឱ្យពរដល់អំបូរនៃអ៊ីស្រាអែល

*៣៣:១-២៩ – លប ៤៩:១-២៨*

**៣៣** ១នេះជាពរ[ក]ដែលម៉ូសេ ជាអ្នកសំណប់របស់ព្រះ[ខ]
បានឱ្យដល់ពួកកូនចៅអ៊ីស្រាអែល មុនដែលលោកស្លាប់
២គឺថា ព្រះយេហូវ៉ាទ្រង់បានយាងមកពីភ្នំស៊ីណាយ[គ] ហើយ
បានក្រោកពីភ្នំសៀរ[ឃ]មកឯគេ ទ្រង់បានភ្លឺ[ង]មកពីភ្នំប៉ារ៉ាន[ច]

ឋ ១សយ ២:៦ ២ពវ ៥:៧ ទដ ៦៨:២០ យហ ១១:២៥-២៦ ឌ នក ១៥:២៦ យប ៥:១៨ ១៥:១១ ទដ ១៤៧:៣ អស ៦:១០ ១៩:២២ ៣០:២៦ ៥៣:៥ ៥៧:១៨ យរ ៣៣:៦ ហស ៦:១ មឡ ៤:២ ១ពត ២:២៤ ឍ យប ៩:១២ ១០:៧ ទដ ៧:២ ៥០:២២ អស ៤៣:១៣ ដយ ៤:៣៥ ហស ៥:១៤ **៣២:៤០** ណ លប ១៤:២២ ត លប ២១:៣៣ វវ ១:១៨ **៣២:៤១** ថ ពច ៧:២០ ទដ ៧:១២ ៤៥:៣ អស ២៧:១ ៣៤:៦ ៦៦:១៦ យរ ១២:១២ អគ ២១:៩-១០ ទ ខ.៣៥ ទដ ១៤៩:៧ យរ ៤៦:១០ ណហ ១:២ ធ ទដ ១៣៧:៨ យរ ២៥:១៤ ៥០:២៩ ៥១:២៤,៥៦ **៣២:៤២** ន ខ.២៣ ប ២សយ ២:២៦ យរ ១២:១២ ៤៤:១ ៤៦:១០,១៤ **៣២:៤៣** ផ ទដ ១៣៧:៦ អស ២៥:៩ ៦៥:១៨ ៦៦:១០ រម ១៥:១០ ព ២ពវ ៩:៧ វវ ៦:១០

ភ អស ១:២៤ យរ ៩:៩ ម ទដ ៦៥:៣ ៧៩:៩ **៣២:៤៤** យ ជន ១៣:៨,១៦ **៣២:៤៦** រ ចទ ៦:៦ យហ ១:១៧ ៧:១៩ ល ចទ ៦:៧ **៣២:៤៧** វ ចទ ៣០:២០ ស នក ២៣:២៦ ចទ ៣៣:២៥ អស ៦៥:២២ **៣២:៤៨** ហ ជន ២៧:១២ **៣២:៤៩** ឡ ជន ២៧:១២ អ ជន ៣២:៣ ក ជន ២២:១ ខ លវ ១៤:៣៤ **៣២:៥០** គ លប ២៥:៨ ជន ២៧:១៣ ឃ ជន ២០:២៩ ង ជន ២០:២២ **៣២:៥១** ច អគ ៤៧:១៩ ឆ ជន ១៣:២១ ២០:១១-១៣ ជ ជន ២៧:១៤ **៣២:៥២** ឈ ចទ ៣៤:១-៣ ញ ចទ ៣:២៧ **៣៣:១** ក លប ២៧:៤ ខ យស ១៤:៦ ១សយ ២:២៧ ៩:៦ ១ពវ ១២:២២ ១៣:១ ២ពវ ១:៩-១៣ ៥:៨ យរ ៣៥:៤ **៣៣:២** គ នក ១៩:១៨ ទដ ៦៨:៨ ឃ យស ១១:១៧ ពច ៥:៤ ង ទដ ៥០:២ ៨០:១ ៩៤:១ ច ជន ១០:១២

*ប្រោសឱ្យរស់* មើលការពន្យល់ ១សយ ២:៦-៨ ។

**៣២:៤០** *អញលើកដៃអញ* មើល លប ១៤:២២ និងការពន្យល់ ។

**៣២:៤៣** *ឱអស់ទាំងសាសន៍អើយ . . . រាស្ត្រ* ក្រាំងមួយផ្ទាំងនៃក្រាំងសមុទ្រស្លាប់ បានបន្ថែមឃ្លាឃ្លោងនៅក្នុងគម្ពីរចោទិយកថានេះ គឺមានក្នុង រម ១៥:១០ ហព ១:៦ និងមើលការពន្យល់ ។

**៣២:៤៧** *គឺជាជីវិតឯងរាល់គ្នាវិញ* មើលការពន្យល់ ៣០:២០ ។

**៣២:៥០** *បានប្រមូលទៅមូលនឹងពួកឰយុកោឯង* មើលការពន្យល់ ២៥:៨ ។ *អើរ៉ុនបងឯងបានស្លាប់នៅលើភ្នំហោរ* មើល ១០:៦ ជន ២០:២២-២៩ និងការពន្យល់ ។

**៣២:៥១** *ព្រោះឯងបានរំលងទាស់និងអញ* មើល ១:៣៧ ៣:២៣-២៧ ៤:២១-២២ ៣១:២ ជន ២០:១២ ។ *ត្រង់ទឹកមេរីបានៅស្រុកការដេស ក្នុងទីរហោស្ថានស៊ីន* មើល ៣៣:៨ មើលការពន្យល់ នក ១៧:៧ ជន ២០:១៣ ។

**៣៣:១** *ជាពរ* មើល លប ១២:១-៣ ២២:១៥-១៨ ២៧:២៧-២៩ ២៨:១០-១៥ ។ ការឱ្យពររបស់លោកម៉ូសេ ដល់ពួកកុលសម្ព័ន្ធ (ខ.៦-២៥) សូមប្រៀបធៀបនិងការឱ្យពររបស់លោកយ៉ាកុបដល់កូនប្រុសៗរបស់គាត់ មើលក្នុង លប ៤៩:៣-៣៧ ។ *សំណប់របស់ព្រះ* ជាការបញ្ជាក់បង្ហាញយ៉ាងច្បាស់ជាលើកដំបូង ពីពាក្យចំណងជើងនេះ ។ វាក៏បង្ហាញឱ្យឃើញជាបន្តរបន្ទាប់ទៀតនៅក្នុងគម្ពីរ យស ១៤:៦ (ក៏មើលផងដែរនៃជីវិតលោកម៉ូសេ មើល ទដ ៩០ ជាចំណងជើង) ក្រោយមកទៀតវាបានបង្ហាញ តាមរយៈអ្នកដឹកនាំព្រះបន្ទូលនៃព្រះ (មើល ១សយ ២:២៧) ។

ទ្រង់ក៏បានចេញពីពួកបរិសុទ្ធទាំងសល់សែន[ឆ]មក ឯនៅ
ខាងព្រះហស្តស្តាំទ្រង់ នោះមានភ្លើងដ៏ជាក្រិត្យវិន័យសំរាប់
គេ ៣តែទ្រង់ក៏ស្រឡាញ់[ជ]ដល់រាស្ត្រទ្រង់ដែរ ពួកបរិសុទ្ធ
របស់ទ្រង់ សុទ្ធតែនៅជាប់ក្នុងព្រះហស្តទ្រង់[ឈ] គេបាន
អង្គុយនៅទៀបព្រះបាទ[ញ] ហើយទទួលព្រះបន្ទូលនៃទ្រង់
៤ម៉ូសេបានឱ្យក្រិត្យវិន័យមកយើងរាល់គ្នា[ដ] គឺជាមរដក
សំរាប់ពួកជំនុំនៃយ៉ាកុប[ឋ] ៥លោកជាស្តេច[ឌ]នៅក្នុងពួក
យេស៊ូរុន[ឍ] ក្នុងកាលដែលពួកមេលើរាស្ត្របានប្រមូលគ្នា
ព្រមទាំងពូជអំបូរនៃសាសន៍អ៊ីស្រាអែលទាំងអស់គ្នាផង ។
៦សូមឱ្យរូបេនរស់នៅ កុំឱ្យស្លាប់ឡើយ ក៏កុំឱ្យពួកគេ
មានគ្នាតិចដែរ[ណ]។
៧ឯពួកយូដា[ត] នោះបានពរដូច្នេះថា ឱព្រះយេហូវ៉ាអើយ
សូមស្តាប់ពាក្យរបស់យូដា ហើយនាំគេចូលទៅឯសាសន៍
ខ្លួន សូមឱ្យដៃគេបានល្មមនឹងខ្លួន ហើយសូមទ្រង់ជួយទាស់
ចំពោះពួកតតាំងនឹងគេផង ។
៨ម៉ូសេក៏និយាយពីពួកលេវី[ថ]ថា ឯធូមីមនិងយូរីម[ទ]របស់
ទ្រង់ នោះនៅនឹងពួកអ្នកបរិសុទ្ធរបស់ទ្រង់[ធ] ដែលទ្រង់បាន
ល្បងល[ន]នៅត្រង់ម៉ាសា ហើយទ្រង់បានតនឹងគេត្រង់ទឹក
មេរីបា[ប] ៩គេបាននិយាយពីឪពុកម្តាយគេថា[ផ] ខ្ញុំមិនបាន
ឃើញគាត់ទេ គេក៏មិនបានទទួលស្គាល់ពួកបងប្អូន ឬស្គាល់
ដល់កូនខ្លួនបង្កើតដែរ ដ្បិតគេបានកាន់តាមព្រះបន្ទូលនៃ
ទ្រង់ ព្រមទាំងរក្សាសេចក្តីសញ្ញារបស់ទ្រង់ផង[ព] ១០គេនឹង
បង្រៀនយ៉ាកុប[ភ] ពីអស់ទាំងបញ្ញត្តិរបស់ទ្រង់ ហើយបង្ហាត់
អ៊ីស្រាអែល[ម] តាមក្រិត្យវិន័យទ្រង់ គេនឹងដុតគ្រឿងក្រអូប
នៅចំពោះទ្រង់[យ] ហើយនិងដង្វាយដែលដុតទាំងមូលនៅ
លើអាសនាទ្រង់ដែរ[រ] ១១ឱព្រះយេហូវ៉ាអើយ សូមប្រទាន
ពរដល់អំណាចគេ ហើយទទួលការដែលដៃគេធ្វើ[ល] សូម
បំបាក់ចង្កេះពួកអ្នកដែលលើកគ្នាទាស់នឹងគេ ព្រមទាំង
ពួកអ្នកដែលស្អប់គេដែរ ដើម្បីកុំឱ្យបានក្រោកឡើងវិញ
រួចឡើយ ។
១២ឯចំណែកពួកបេនយ៉ាមីន[វ] នោះក៏ថា អ្នកស្ងួនភ្ងា[ស]ផង
ព្រះយេហូវ៉ា នឹងនៅជិតទ្រង់ដោយសុខសាន្ត[ហ]ទ្រង់គ្រប
បាំងគេជានិច្ច[ឡ] ហើយគេនឹងនៅជាកណ្តាលព្រះអង្សាទាំង
២របស់ទ្រង់[អ]។
១៣ឯពួកយ៉ូសែប[ក] នោះក៏ថា ស្រុកគេមានពរពីព្រះ
យេហូវ៉ា ជារបស់ថ្លៃវិសេសពីលើមេឃ គឺជាទឹកសន្សើម
ហើយពីទីជំរៅនៅខាងក្រោមផង[ខ] ១៤និងផលថ្លៃវិសេស
ដែលកើតដោយសារថ្ងៃ ហើយផលថ្លៃវិសេស ដែលកើត
ដោយសារខែ ១៥ជារបស់ថ្លៃវិសេសនៅភ្នំចាស់បុរាណ[គ]
និងផលថ្លៃវិសេសនៅភ្នំតូចដ៏នៅអស់កល្បជានិច្ច ១៦និង
ផលថ្លៃវិសេស ដែលកើតពីដីដ៏មានជាបរិបូរ ហើយនិង
ព្រះគុណនៃព្រះ ដែលទ្រង់គង់នៅគុម្ពបន្លា[ឃ] សូមឱ្យទាំង
អស់នោះ មកលើក្បាលយ៉ូសែប គឺនៅលើក្រយៅក្បាល
នៃអ្នកដែលត្រូវពង្រាត់ចេញពីពួកបងប្អូនខ្លួន[ង] ១៧ឯកូនគោ
របស់គេដែលកើតជាដំបូង នោះមានស្វាហាប់ណាស់
ស្នែងវាដូចជាស្នែង[ច]នៃទន្សោង[ឆ] វានឹងច្រាន[ជ]សាសន៍ទាំង
ប៉ុន្មាន ដោយសារស្នែងនោះ ទៅដល់ចុងផែនដីបំផុត គឺ
ជាពួកអេប្រាអិមទាំងសល់សែន[ឈ] ហើយនិងពួកម៉ាន៉ាសេ
ទាំងពាន់ទាំងម៉ឺនដែរ[ញ]។
១៨ឯពួកសាប់យូល៉ូន[ដ] នោះក៏ថា ឱសាប់យូល៉ូនអើយ ចូរ
អរសប្បាយក្នុងកាលដែលឯងចេញទៅ ហើយអ៊ីសាខារ[ឋ]
អើយ ចូរអរសប្បាយនៅក្នុងត្រសាលឯងចុះ ១៩គេនឹងហៅ

ឆ ទដ ៨៩:៧ ដយ ៤:១៣ ៧:១០ ៨:១៣ សក ១៤:៥ កច ៧:៥៣ កទ ៣:១៩ ហព ២:២ វវ ៥:១១ **៣៣:៣** ជ ចទ ៤:៣៧ ឈ ចទ ៧:៦ ញ លក ១០:៣៩ វវ ៤:១០ **៣៣:៤** ដ ចទ ៤:២ យហ ១:១៧ ៧:១៩ ឋ ទដ ១១៩:១១១ **៣៣:៥** ឌ នក ១៦:៨ ១សយ ១០:១៩ ទដ ១០:១៦ ១៤៩:២ ឍ ជន ២៣:២១ចទ ៣២:១៥ **៣៣:៦** ណ លប ៣៤:៥ **៣៣:៧** ត លប ៤៩:១០ **៣៣:៨** ថ លប ២៩:៣៤ ទ នក ២៨:៣០ ធ ទដ ១០៦:១៦ ន ជន ១៤:២២ ប នក ១៧:៧ **៣៣:៩** ផ នក ៣២:២៦–២៩ ព ទដ ៦១:៥ មឡ ២:៥ **៣៣:១០** ភ អរ ៧:១០ នហ ៨:១៨ ទដ ១១៩:១៥១ យរ ២៣:២២ មឡ ២:៦ ម លវ ១០:១១ ចទ ១៧:៨–១១ ៣១:៩–១៣ យ នក ៣០:៧ លវ ១៦:១២–១៣ រ ទដ ៥១:១៩ **៣៣:១១** ល ២សយ ២៤:២៣ ទដ ២០:៣ ៥១:១៩ **៣៣:១២** វ លប ៣៥:១៨ ស អស ៦០:៥ ១២៧:២ អស ៥:១ ហ ចទ ៤:៣៧–៣៨ ១២:១០ ៣២:៨ ឡ នក ១៩:៤ អ នក ២៨:១២ **៣៣:១៣** ក លប ៣០:២៤ ខ លប ២៧:២៨ ទដ ១៤៨:៧ **៣៣:១៥** គ ហព ៣:៦ **៣៣:១៦** ឃ នក ៣:២ ង លប ៣៧:៨ **៣៣:១៧** ច ១សយ ២:១០ ២សយ ២២:៣ អគ ៣៤:២១ ឆ ជន ២៣:២២ ជ ១ពវ ២២:១១ ទដ ៤៤:៥ ឈ លប ៤១:៥២ ញ លប ៤១:៥១ **៣៣:១៨** ដ លប ៣០:២០ ឋ លប ៣០:១៨

**៣៣:២** *ភ្នំស៊ីណាយ . . . ភ្នំសៀរ . . . ភ្នំប៉ារ៉ាន* គឺជាភ្នំដែលមានទំនាក់ទំនង ក្នុងពេលដែលទ្រង់ផ្តល់នូវបញ្ញត្តិ(មើល លប ២១:២១ និងការពន្យល់ ពវ ៥:៤–៥ ៣:៣ និងការពន្យល់) *ពួកបរិសុទ្ធ* គឺជាទេវតា ។

**៣៣:៣** *ពួកបរិសុទ្ធ* សំដៅលើប្រជាជនអ៊ីស្រាអែល (មើល ៧:៦ និងការពន្យល់ ១៤:២ ២៦:១៩ ២៨:៩)។

**៣៣:៥** *ជាស្តេច* គឺជាព្រះយេហូវ៉ា មិនមែនជាព្រះមហាក្សត្ររបស់លោកិយទេ ដែលធ្វើជាស្តេចដល់ប្រជាជនអ៊ីស្រាអែល (មើល ពច ៨:២៣ និងការពន្យល់) មើល អស ៤៤:២ ផងដែរ ។

**៣៣:៩** *គេបានកាន់តាមព្រះបន្ទូលនៃទ្រង់* ពួកលេវីបានកាន់តាមទំលាប់ដែលមានច្បាប់នៅនិងហឹបរបស់គេ ដែលមានគម្ពីរក្រឹត្យវិន័យដាក់នៅទីនោះ(មើលការពន្យល់ ៣១:៩) ។

**៣៣:១០** *បង្រៀនយ៉ាកុបអស់ពីបញ្ញត្តិរបស់ទ្រង់* មើលការពន្យល់ ៣៣:១១ ។

**៣៣:១២** *នៅកណ្តាលព្រះអង្សាទាំង២* មើល អស ៤៩:២២ ចទ ៣៣:២៧ ។

**៣៣:១៣** *ឯពួកយ៉ូសែប* លោកម៉ូសេបានប្រទានពរដល់ពួកអេប្រាអិម និងពួកម៉ាន៉ាសេ(ខ.១៧)ក៏មានកូនរបស់លោកយ៉ូសែប និងលោកយ៉ូសែបខ្លួនឯង ។ *ពីលើមេឃ . . . ពីទីជំរៅនៅខាងក្រោម* មើល លប ៤៩:២៥ ។

**៣៣:១៥–១៦** មើល លប ៤៩:២៦ និងការពន្យល់ ។

**៣៣:១៦** *ផលថ្លៃវិសេស* ជាព្រះពរពីព្រះយេហូវ៉ា លោកយ៉ូសែបមានដីនៅទីកណ្តាលនៃទឹកដីកាណាន ដែលពោរពេញដោយជីជាតិ និងភោគផល ។ *ដែលទ្រង់គង់នៅគុម្ពបន្លា* មើល នក ៣:១–៥ ។

អស់ទាំងពួកជនឱ្យទៅឯភ្នំ[ឱ] ដើម្បីនឹងថ្វាយយញ្ញបូជាសុចរិត
នៅទីនោះ[ឃ] ដ្បិតគេនឹងជញ្ជក់ផលបរិបូរពីសមុទ្រ[ណ] និង
ទ្រព្យសម្បត្តិលាក់កំបាំងពីខ្សាច់ ។
២០ឯពួកកាឌ់[ត] នោះក៏ថា សូមសរសើរដល់ព្រះដែល
ទ្រង់ពង្រីកឱ្យកាឌ់បានធំទូលាយ[ថ] គេនៅដូចជាសិង្ហញី
ហើយក៏ហែកដៃ និងក្រយៅក្បាលផង ២១គេបានរើស
យកចំណែកដំបូងសំរាប់ខ្លួន[ទ] ដ្បិតនៅទីនោះមានចំណែក
របស់អ្នកដែលតែងច្បាប់[ធ] គេបានមកជាមួយនឹងពួកមេ
លើបណ្តាជន ក៏បានសំរេចការតាមសេចក្តីសុចរិតនៃ
ព្រះយេហូវ៉ា[ន] ហើយតាមបញ្ញត្តិដែលទ្រង់តាំងនឹងពួកអ៊ី
ស្រាអែល ។
២២ឯពួកដាន់[ប] នោះក៏ថា ដាន់ជាកូនសិង្ហ ដែលបានហក់
ពីស្រុកបាសានមក ។
២៣ចំណែកពួកណែបថាលី[ផ] នោះក៏ថា ឱណែបថាលី
ឯងដែលឆ្អែតដោយព្រះគុណ ហើយពេញដោយព្រះពរ
នៃព្រះយេហូវ៉ាអើយ ចូរឯងចាប់យកស្រុកខាងលិច ហើយ
ខាងត្បូងចុះ ។
២៤ឯពួកអេសើរ[ព] នោះក៏ថា សូមពរដល់អេសើរក្នុង
ពួកកូនទាំងប៉ុន្មាន សូមឱ្យបងប្អូនគេបានទទួលគេ ហើយឱ្យ
គេបានជ្រលក់ជើងក្នុងប្រេងចុះ[ភ] ២៥រនុកឯងនឹងបានសុទ្ធ
តែដែក ហើយនិងលង្ហិន[ម] ហើយសេចក្តីសុខរបស់ឯង នឹង
នៅអស់១ជីវិតឯងដែរ[យ]។
២៦ឱយេស៊ូរុនអើយ[រ] គ្មានអ្នកណាដូចព្រះ ដែលទ្រង់
ជិះ[ល]ផ្ទៃមេឃមកជួយឯង[វ] ហើយលើពពក[ស] ដោយភាពដ៏
ឧត្តមរបស់ទ្រង់នោះទេ[ហ] ២៧ព្រះដ៏គង់នៅអស់កល្បជានិច្ច[ឡ]
ទ្រង់ជាទីលំនៅរបស់ឯង[អ] ហើយព្រះពាហុដ៏នៅជាប់អស់
កល្បជានិច្ច[ក]ក៏ទ្រឯង ទ្រង់បានច្រានពួកខ្មាំងសត្រូវពីមុខ
ឯងចេញ[ខ] ក៏មានបន្ទូលថា ចូរបំផ្លាញគេចុះ[គ]។

**៣៣:១៩** ឱ នក ១៥:១៧ ទដ ៤៨:១ អស ២:៣ ៦៥:១១ ៦៦:២០ យរ ៣១:៦ ឃ ទដ ៤:៥ ៥១:១៩ ណ អស ១៨:៧ ២៣:១៨ ៤៥:១៤ ៦០:៥,១១ ៦១:៦ ហក ២:៧ សក ១៤:១៤
**៣៣:២០** ត លប ៣០:១១ ថ ចទ ៣:១២–១៧
**៣៣:២១** ទ ជន ៣២:១ ៥,៣១–៣២ ធ ជន ៣៤:១៤ ន យស ២២:១–៣
**៣៣:២២** ប លប ៤៩:១៦ ជន ១:៣៨
**៣៣:២៣** ផ លប ៣០:៨
**៣៣:២៤** ព លប ៣០:១៣ ភ លប ៤៩:២០ ចទ ៣២:១៣
**៣៣:២៥** ម នហ ៣:៣ ៧:៣ ទដ ១៤៧:១៣ យ ចទ ៣២:៤៧
**៣៣:២៦** រ ចទ ៣២:១៥ ល ទដ ១៨:១០ ៦៨:៣៣ វ ចទ ១០:១៤ ទដ ១០៤:៣ ស ២សយ ២២:១០ ទដ ១៨:៩ ៦៨:៤ ដយ ៧:១៣ ហ នក ១៥:៧

២៨ឯពួកអ៊ីស្រាអែល គេនៅដោយសុខសាន្ត[ឃ] ហើយ
ក្បាលទឹករបស់យ៉ាកុប នោះនៅតែឯង ក្នុងស្រុកដែល
មានស្រូវ មានទំពាំងបាយជូរ ឯមេឃ នោះក៏ទំលាក់ទឹក
សន្សើមមកដែរ[ង] ២៩ឱអ៊ីស្រាអែលអើយ[ច] ឯងមានពរ
ហើយ តើមានអ្នកឯណាដូចឯង[ឆ] ជាសាសន៍ដែលព្រះ
យេហូវ៉ាបានសង្គ្រោះ[ជ] ទ្រង់ជាខែលជួយឯង[ឈ] ហើយជា
ដាវនៃសិរីល្អរបស់ឯង ពួកខ្មាំងសត្រូវនឹងចុះចូលចំពោះ
ឯង ហើយឯងនឹងជាន់លើទីខ្ពស់ទាំងប៉ុន្មានរបស់គេ[ញ]។

## ការស្លាប់របស់លោកម៉ូសេ

**៣៤** ១នោះម៉ូសេក៏ឡើងពីស្រុកវាលរបស់ម៉ូអាប់ទៅលើ
ភ្នំនេបូរ[ក] គឺដល់កំពូលភ្នំពីសកា[ខ]ដែលទល់មុខនឹងយេរីខូរ[គ]
រួចព្រះយេហូវ៉ាទ្រង់ក៏បង្ហាញ[ឃ]ឱ្យលោកឃើញស្រុកកាឡាត
ទាំងអស់រហូតដល់ស្រុកដាន់[ង] ២ហើយស្រុកណែបថាលី
ស្រុកអេប្រាអិម និងស្រុកម៉ាន៉ាសេ ហើយនិងស្រុកយូដាទាំង
អស់រហូតដល់សមុទ្រខាងលិច[ច] ៣ព្រមទាំងស្រុកខាងត្បូង[ឆ]
និងវាលនៅច្រកភ្នំយេរីខូរ ហើយទីក្រុងលម៉ើ[ជ] រហូតដល់
សូអារ[ឈ] ៤នោះព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងលោកថា
នេះជាស្រុកដែលអញបានស្បថ[ញ]នឹងអ័ប្រាហាំ និងអ៊ីសាក
ហើយនិងយ៉ាកុប[ដ]ថា អញនឹងឱ្យស្រុកនេះ[ឋ]ដល់ពូជឯង
មើលអញបានឱ្យឯងឃើញស្រុកនេះហើយ តែមិនត្រូវឱ្យ

**៣៣:២៧** ឡ នក ១៥:១៨ អស ៤០:២៨ ៥៧:១៥ អ ទដ ៩:៩ ៨៤:១ ៩០:១ ៩១:៩ ក លប ២១:៣៣ ខ នក ៣៤:១១ យស ២៤:១៨ គ ចទ ៧:២ **៣៣:២៨** ឃ នក ៣៣:១៦ លវ ២៥:១៨ ចទ ៣២:៨ ទដ ១៦:៩ សភ ១:៣៣ អស ១៤:៣០ ង ខ.១៣ លប ២៧:២៨ **៣៣:២៩** ច ទដ ១:១ ៣២:១–២ ១៤៤:១៥ ឆ ២សយ ២២:៤៥ ទដ ១៨:៤៤ ៦៦:៣ ៨១:១៥ ជ ចទ ៤:៧ ឈ លប ១៥:១ នក ១៨:៤ ទដ ១០:១៤ ១៨:១ ២៧:១,៩ ៣០:១០ ៥៤:៤ ៧០:៥ ១១៥:៩–១១ ១១៨:៧ អស ៤៥:២៤ ហស ១៣:៩ ហព ៣:១៩ ញ ជន ៣៣:៥២ ចទ ៣២:១៣ **៣៤:១** ក ជន ៣២:៣ ខ ជន ២១:២០ គ ចទ ៣២:៤៩ ឃ ចទ ៣២:៥២ ង លប ១៤:១៤ **៣៤:២** ច នក ២៣:៣១ **៣៤:៣** ឆ លប ១២:៩ ជ ពច ១:១៦ ៣:១៣ ២របា ២៨:១៥ ឈ លប ១៣:១០ **៣៤:៤** ញ លប ២៨:១៣ យស ២១:៤៣ ឋ លប ១២:៧ ឌ ចទ ៣:២៣

**៣៣:១៩** *ផលបរិបូរពីសមុទ្រ និងទ្រព្យសម្បត្តិលាក់កំបាំងពីខ្សាច់* គឺជាការសំអាងទៅលើសម្បត្តិពីសមុទ្រ (មើល លប ៤៩:១៣) ។
**៣៣:២១** *គេបានរើសយកចំណែកដំបូងសំរាប់ខ្លួន* (មើល ៣:១២–២០ និងការពន្យល់) ។
**៣៣:២២** *ដែលបានហក់ពីស្រុកបាសានមក* "គឺមានន័យថា ការដកខ្លួនចេញឱ្យឆ្ងាយពីពួកពស់វែក" ។ តែពេលខ្លះគាត់ខ្លួនឯងក៏ទំនងដូចជាពស់វែកដែរ (មើល លប ៤៩:១៧ និងការពន្យល់) តែតាមប្រវត្តិសាស្ត្រនៃលោកដាន់ដំបូងនោះ គឺគាត់មានភាពកំសាក ។
**៣៣:២៦** *យេស៊ូរុន* មើលការពន្យល់ ៣២:១៥ ។ *ជិះផ្ទៃមេឃមកជួយឯង ហើយលើពពក* មើលការពន្យល់ ទដ ៦៨:៤ ។
**៣៣:២៧** *ព្រះពាហុដ៏នៅជាប់អស់កល្បជានិច្ច* មើល ខ.១២ និងការពន្យល់ ។
**៣៣:២៩** *ខែល* មើលការពន្យល់ លប ១៥:១ ។ ជាន់លើទីខ្ពស់ទាំងប៉ុន្មានរបស់គេ ។ គឺជាការជាន់លើទីខ្ពស់បំផុតរបស់ពួកគេ (មើល មីក ១:៣ និងការពន្យល់ ប្រៀបធៀប ចទ ៣២:១៣) ។
**៣៤:១** *ម៉ូសេក៏ឡើងពីស្រុកវាលរបស់ម៉ូអាប់ទៅលើភ្នំនេបូរ* គឺការស្តាប់បង្គាប់ព្រះយេហូវ៉ា មើលក្នុង ៣២:៤៨–៥២ ។
**៣៤:៣** *ស្រុកខាងត្បូង* មើលការពន្យល់ លប ១២:៩ ។ *រហូតដល់សូអារ* សូមមើល អស ១៥:៥ និងការពន្យល់ ។
**៣៤:៤** *ស្រុកដែលអញបានស្បថ* មើល ១:៨ លប ១២:១ ១៥:១៨ និងការពន្យល់ នក ៣៣:១ ។

ឯងចូលទៅ[ឌ]ទេ ៥ដូច្នេះម៉ូសេជាបាវបំរើផងព្រះយេហូវ៉ា[ឍ]
លោកស្លាប់[ណ]នៅទីនោះក្នុងស្រុកម៉ូអាប់ទៅ តាមព្រះបន្ទូល
នៃព្រះយេហូវ៉ា ៦ហើយទ្រង់ក៏បញ្ចុះសពនៅក្នុងច្រកភ្នំ១នា
ស្រុកម៉ូអាប់ទល់មុខនឹងបេត–ពេអរទៅ[ត] តែលុះមកដល់
សព្វថ្ងៃនេះ គ្មានអ្នកណាដឹងជាផ្នូរលោកនៅឯណាឡើយ[ថ]
៧កាលម៉ូសេស្លាប់ទៅនោះបានអាយុ១២០ឆ្នាំហើយ[ទ] តែ
ភ្នែកលោកមិនខ្សោយ[ធ]ហើយកំឡាំងមិនបានអន់សោះ[ន]
៨ពួកកូនចៅអ៊ីស្រាអែល បានយំសោកនឹងម៉ូសេអស់៣០ថ្ងៃ[ប]
នៅត្រង់ស្រុកវាលរបស់ម៉ូអាប់[ផ] រួចវេលាកាន់ទុក្ខ[ព]នឹង
ម៉ូសេក៏កន្លងផុតទៅ ។
៩ឯយ៉ូស្វេ ជាកូននុន លោកមានចិត្ត[ភ]ពេញដោយប្រាជ្ញា
ពីព្រោះម៉ូសេបានដាក់ដៃលើលោក[ម] ហើយពួកកូនចៅអ៊ី
ស្រាអែលក៏ស្តាប់តាម ព្រមទាំងធ្វើដូចជាព្រះយេហូវ៉ា
ទ្រង់បានបង្គាប់មកម៉ូសេ ១០មិនដែលកើតមានហោរាណា
មួយ[យ]ក្នុងពួកអ៊ីស្រាអែលឱ្យដូចជាម៉ូសេ[រ] ដែលព្រះយេហូវ៉ា
ទ្រង់ស្គាល់ប្រទល់មុខដូច្នេះឡើយ[ល] ១១គឺដោយអស់ទាំង
ទីសំគាល់ និងការអស្ចារ្យទាំងប៉ុន្មាន[វ] ដែលព្រះយេហូវ៉ា
បានចាត់ប្រើលោកឱ្យធ្វើនៅស្រុកអេស៊ីព្ទ ទាស់នឹងផារ៉ោន
និងពួកមហាតលិកទ្រង់[ស] ហើយនិងស្រុកទ្រង់ទាំងមូល
១២ហើយដោយព្រះហស្តដ៏មានព្រះចេស្តា និងការស្ញែង
ខ្លាចយ៉ាងធំ[ហ] ដែលលោកបាន[ឡ]ធ្វើនៅចំពោះភ្នែក នៃពួក
អ៊ីស្រាអែលផង ។/

**៣៤:៥** ឍ ជន ១២:៧ ណ លប ២៥:៨ **៣៤:៦** ត ចទ ៣:២៩ ថ ពច ១:៩ **៣៤:៧** ទ នក ៧:៧ ធ លប ២៧:១ ន លប ១៥:១៥ **៣៤:៨** ប លប ៣៧:៣៤ ចទ ១:៣ ផ ជន ២១:១១ ព ២សយ ១១:២៧ **៣៤:៩** ភ លប ៤១:៣៨ នក ២៨:៣ អស ១១:២ ម ចទ ៣១:១៤ កច ៦:៦ **៣៤:១០** យ លប ២០:៧ រ ចទ១៨:១៥,១៨ ល នក ៣៣:១១ **៣៤:១១** វ ចទ ៤:៣៤ ស នក ១១:៣ **៣៤:១២** ហ ចទ ៤:៣៤ ឡ ហព ៣:១–៦

**៣៤:៥** *បាវបំរើផងព្រះយេហូវ៉ា* ជាពាក្យ ឬចំណងជើងសម្រាប់អ្នកដែលព្រះបានត្រាសហៅគេមកបម្រើការងារក៏ដូចជាសមាជិក នៃសង្ឃហ្លួង ។ ឧទាហរណ៍ ដូចជាលោកអ័ប្រាហាំ (លប ២៦:២៤) លោកម៉ូសេ(នក ១៤:១២) (យស ១:១) លោកយ៉ូស្វេ(យស ២៤:២៩)ដូចជាស្តេចដាវីឌ (២សយ ៣:១៨ ៧:៥)ពួកហោរា(២ពវ ៩:៧) (អស ៤១:៨–៩) ហើយដូចជាស្តេចដទៃ នោះព្រះយេហូវ៉ាបានប្រើគេ ឱ្យអនុវត្តនូវគោលដៅរបស់ទ្រង់ (យរ ២៥:៩) មើលការពន្យល់ នក ១៤:៣១ ។

**៣៤:៧** *បានអាយុ១២០ឆ្នាំហើយ* មើល ៣១:២ គឺចង់បង្ហាញពេលវេលាបីជំនាន់ក្នុងរយៈពេល ៤០ឆ្នាំម្តង ។

**៣៤:៨** *បានយំសោក . . . អស់៣០ថ្ងៃ* មើល លប ៥០:៣ និងការពន្យល់ ។

**៣៤:១០** *មិនដែលកើតមានហោរាណាមួយ ក្នុងពួកអ៊ីស្រាអែលឱ្យដូចជាម៉ូសេ* មើលការពន្យល់ ១៨:៥ ។ *ប្រទល់មុខ* ជន ១២:៨ និងការពន្យល់ ។

**៣៤:១២** រហូតដល់ពេលដែលព្រះគ្រីស្ទយាងមក គឺពុំមានអ្នកណាម្នាក់មានលក្ខណៈដូចជាលោកម៉ូសេទេ(មើល ហព ៣:១–៦) ។ នេះជាទីកន្លែងដែលលោកម៉ូសេបានរស់នៅបម្រើព្រះ និងស្នាក់នៅ (ខ.៦) គឺមានលក្ខណៈផ្ទុយនិងព្រះគ្រីស្ទ"ព្រះរាជបុត្រាដែលមានអំណាចលើគ្រប់ទាំងអស់"(ខ.៦) ។

# ព្រះគម្ពីរយ៉ូស្វេ

## សេចក្ដីផ្ដើម

### ចំណងជើង និងខ្លឹមសារវិជ្ជាអំពីព្រះ

កណ្ឌគម្ពីរយ៉ូស្វេជាផ្ទៃរឿងចម្បាំងដណ្ដើមយកជ័យជម្នះសម្រាប់រាស្ត្ររបស់ព្រះ ក្រោយពីពួកគេបានជាប់ជាទាសកររបស់ពួកអេស៊ីព្ទ និងរយៈពេល៤០ឆ្នាំដែលពួកគេស្ថិតនៅទីរហោស្ថាន ហើយនៅទីបញ្ចប់ពួកគេបានចូលទៅក្នុងទឹកដីសន្យា ។ លោកអ័ប្រាហាំតែងតែផ្លាស់ទីលំនៅ គឺគាត់មិនដែលចាប់យកទឹកដីណាមួយជាកម្មសិទ្ធិរបស់ខ្លួននោះទេ ប៉ុន្តែគាត់បានបន្សល់ទុកនូវសេចក្ដីសញ្ញារបស់ព្រះដល់ពួកគេ ដែលធ្វើឱ្យពួកគេទទួលបានទឹកដីកាណាននេះដោយថៃដន្យ(លប ១៥:១៣,១៦,១៨ ១៧:៨) ។ ដូច្នេះលោកយ៉ូស្វេត្រូវបានគេគោលបំណងយ៉ាងច្បាស់ ដើម្បីបង្វែរទឹកដីសន្យានេះឱ្យក្លាយទៅជារឿងពិតមួយ ។

នៅទីបញ្ចប់នៃកណ្ឌគម្ពីរចោទិយកថា ហើយវាក៏ជាការចាប់ផ្ដើមនៃកណ្ឌគម្ពីរយ៉ូស្វេនេះ គឺក្នុងខណៈដែលពួកអ៊ីស្រាអែលកំពុងជ្រកកោននៅក្នុងទឹកដីខាងកើតនៃទន្លេយ័រដាន់ ។ ការពិពណ៌នានៃសាច់រឿងនេះ គឺចាប់ផ្ដើមឡើងដោយសេចក្ដីបង្គាប់របស់ព្រះអម្ចាស់ឱ្យពួកគេផ្លាស់ទី ហើយឆ្លងកាត់ទន្លេតាមវាលរាំងស្ងួត ។ សាច់រឿងនេះ គឺតភ្ជាប់គ្នាតាមផ្នែកនៃរឿងនិមួយៗដែលទទួលបានជ័យជម្នះនៅតំបន់កណ្ដាល ខាងត្បូង និងខាងលិចទឹកដីកាណាន ដែលបានផ្ដល់ឱ្យពួកអ៊ីស្រាអែលគ្រប់គ្រងតំបន់ជើងភ្នំទាំងអស់ និងស្រុកត្បូង ។ ព្រះគម្ពីរនេះបន្តជាមួយនឹងការរៀបរាប់ និងការបែងចែករាស្ត្រផ្សេងៗ ហើយបញ្ចប់ជាមួយនឹងសេចក្ដីបញ្ជាក់របស់លោកយ៉ូស្វេចំពោះរាស្ត្ររបស់ព្រះអម្ចាស់ ។ ដូច្នេះ ខ្លឹមសារសំខាន់នៃកណ្ឌគម្ពីរនេះ គឺកសាងរាស្ត្រអ៊ីស្រាអែល ដែលទឹកដីនេះព្រះអម្ចាស់ទ្រង់បានសន្យាថានឹងផ្ដល់ឱ្យពួកគេ ដើម្បីបានជាទីសម្រាកនៅផែនដី(១:១៣ ១៥ ២១:៤៤ ២២:៤ ២៣:១ មើលបន្ថែម ចទ ៣:២០ និងការពន្យល់ ១២:៩–១០ ១ពវ ៥:៤ និងការពន្យល់ ៨:៥៦) ។ ដូច្នេះ សេចក្ដីសន្យារបស់ព្រះដ៏ជាព្រះបានសន្យាទៅចំពោះសម្ដេចសង្ឃ និងលោកម៉ូសេចំពោះការជ្រើសរើសរាស្ត្រនៃអាណាចក្ររបស់ទ្រង់ គឺឥឡូវមានភាពត្រឹមត្រូវតាមផ្នែកប្រវត្តិសាស្ត្រ(១:១–៦ ២១:៤៣–៤៥) ។

សាច់រឿងនៅក្នុងកណ្ឌគម្ពីរនេះ ប្រាប់ពីតួអង្គបីដែលដើរតួសំខាន់នៅក្នុងផ្ទៃរឿងនេះ"ព្រះយេហូវ៉ា(រាស្ត្រអ៊ីស្រាអែល)" លោកយ៉ូស្វេអ្នកបម្រើរបស់ទ្រង់ និងរាស្ត្រអ៊ីស្រាអែលផងដែរ (ចំណុចទាំងបីនេះជាចារឹកលក្ខណៈនៃកណ្ឌគម្ពីរយ៉ូស្វេ) ។ ចំណុចទាំងបីនេះ យើងនឹងឃើញនៅក្នុងជំពូក១ ដែលចំណុចទាំងនេះនឹងបង្ហាញយ៉ាងច្បាស់ក្នុងការសម្គាល់ពីតួនាទីដែលពួកគេប្រព្រឹត្តនៅក្នុងជំពូក១នេះជាបន្តបន្ទាប់ ហើយចំណុចនេះផងដែរ បានបង្ហាញដល់អ្នកអានថា វាជាសាច់រឿងចម្បងនៅក្នុងកណ្ឌគម្ពីរនេះទាំងមូល ។

តួនាទីរបស់មនុស្សនៅក្នុងហេតុការណ៍នេះ គឺរៀបរាប់ហើយត្រូវបានពង្រឹងដោយសារខ្លួនគាត់ផ្ទាល់ ។ នៅគ្រាដំបូងនៃជីវិតរបស់លោកយ៉ូស្វេត្រូវបានហៅជាសាមញ្ញថា"ហូសេ" មានន័យថា"សេចក្ដីសង្គ្រោះ" តែក្រោយមកលោកម៉ូសេ បានប្ដូរឈ្មោះនេះទៅជាយ៉ូស្វេវិញមានន័យថា"ព្រះសង្គ្រោះ" (ឬព្រះបានផ្ដល់ជ័យជម្នះឱ្យដល់គាត់) ។ ឈ្មោះដូចគ្នានេះមាននៅក្នុងភាសាក្រិក(មថ ១:២១) ដែលបានដាក់ឱ្យដល់កូនប្រុសច្បងរបស់នាងម៉ារា ដែលបញ្ជាក់ថាខ្លួនគាត់ជាអ្នកបម្រើរបស់ព្រះអម្ចាស់ ដែលនឹងបញ្ចប់នូវបេសកកម្មរបស់ព្រះសម្រាប់រាស្ត្រអ៊ីស្រាអែលនៅក្នុងមធ្យោបាយដំបូងតាមរយៈនាមយ៉ូស្វេនេះជាដំបូង ដែលយកជ័យជម្នះលើអំណាចនៃអំពើបាបនៅក្នុងលោក ហើយនាំរាស្ត្រអ៊ីស្រាអែលចូលក្នុងទីសម្រាកជារហូត (មើល ហព ៤:១–១១ និងការពន្យល់) ។

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

នៅក្នុងការកាត់សេចក្ដីរបស់អ្នកប្រាជ្ញជាច្រើន បានអះអាងថា កណ្ឌគម្ពីរយ៉ូស្វេនេះ មិនត្រូវបានសរសេរនៅឡើយទេក្រោយពីហេតុការណ៍ពិតជាក់ស្ដែង ៨០០ឆ្នាំមកទៀត រហូតដល់ចុងបញ្ចប់ នៃកណ្ឌគម្ពីរពង្សាវតាក្សត្រ ។ ប៉ុន្តែ ហេតុផលចំពោះសំណួរ និងការសន្និដ្ឋានពីកាលបរិច្ឆេទចំពោះការនិពន្ធកណ្ឌគម្ពីរនេះឡើង គឺបញ្ជាក់ថាព្រះគម្ពីរនេះបានសរសេរឡើងមុនហេតុការណ៍ខាងលើបានកើតមានឡើងវិញ ។ ប្រពៃណីសាសន៍យូដាដំបូង បានបញ្ជាក់ថា កណ្ឌគម្ពីរយ៉ូស្វេនេះ បានសរសេរឡើងដោយលោកយ៉ូស្វេផ្ទាល់ដោយលើកលែងតែផ្នែកចុងក្រោយប៉ុណ្ណោះ ដែលនិយាយពីមរណភាពរបស់គាត់ ។

យ៉ាងហោចណាស់ក៏មានឱកាសពីរនៃសំណេរាយការណ៍ ពីសេចក្ដីបង្គាប់បញ្ជារបស់លោកយ៉ូស្វេផ្ទាល់ថា នៅពេលដែលពួកសាសន៍ផ្សេងៗទទួលបាននូវទឹកដីរបស់ពួកគេ នោះគាត់បានចាត់ពួកគេ ឱ្យទៅសរសេរកំណត់សម្គាល់ពីស្រុកទាំងអស់នោះ (១៨:៨) ។ ហើយនៅក្រោយនៃផ្ទៃរឿងនេះ លោកយ៉ូស្វេបានដឹកនាំពួកអ៊ីស្រាអែល នៅក្នុងការមកដល់នៃសេចក្ដីសញ្ញាថ្មីរបស់ព្រះអម្ចាស់ ហើយគាត់បាននិយាយទៅកាន់ពួកគេថា"គាត់នឹងតាំងសេចក្ដីសញ្ញា ហើយនិងដាក់បញ្ញត្តិដល់គេ(២៤:២៥)" ។ ឱកាសផ្សេងទៀត អ្នក

ដែលរៀបរាប់អំពីរឿងនេះ ធ្វើដូចជាគេបានចូលរួមនៅក្នុងហេតុការណ៍នេះតែម្តង គឺគាត់បានប្រើសព្វនាម"យើង" និង"គាត់" (៥:១,៦)។

ជាងនេះទៅទៀត អ្នកនិពន្ធហាក់ដូចជាស្គាល់ឈ្មោះទីក្រុងពីបុរាណដូចជា "យេប៊ូស" (១៥:៨ ១៨:១៦,២៨) សម្រាប់ក្រុងយេរូសាឡិម ក្រុងគារយ៉ាត់-អើបា (១៤:១៥ ១៥:៥៤ ២០:៧ ២១:១១) សម្រាប់ស្រុកហេប្រុន និងស្រុកស៊ីដូនមហិមា (១១:៣ ១៩:២៨) ហើយក្រោយមកក្លាយជាស្រុកស៊ីដូនធម្មតា ។ ក្រុងទីរ៉ុស មិនបានលើកឡើងទេ ហើយប្រហែលដោយព្រោះនៅសម័យលោកយ៉ូស្វេ ក្រុងនេះមិនទាន់អភិវឌ្ឍន៍ជាកំពង់ផែសំខាន់នៅឡើយទេ ។

ប៉ុន្តែប្រសិនបើ ផ្ទៃរឿងនៃកណ្ឌគម្ពីរនេះ បានបញ្ជាក់ពីអ្នកនិពន្ធថា ជារឿងរបស់លោកយ៉ូស្វេផ្ទាល់ នោះចំណុចផ្សេងទៀតក្នុងការសរសេរនេះគឺពេលក្រោយមកទៀត ។ ការរៀបរាប់ពីថ្ងៃដែលនឹងនៅមួយកន្លែងនៅច្រកភ្នំអាយ៉ាឡូន គឺត្រូវបានបង្ហាញភស្តុតាងដោយការលើកឡើងពីប្រភពឯកសារផ្សេងៗ ដូចជា សៀវភៅយ៉ាសើរជាដើម (១០:១៣) ។ នេះជាភាពកម្រមួយ សម្រាប់សាក្សីឃើញដោយផ្ទាល់ភ្នែកចំពោះការអស្ចារ្យដែលសរសេរឡើងយ៉ាងខ្លីបន្ទាប់ពីរឿងនោះបានកើតឡើង ។

វាមើលទៅហាក់ដូចជាទុកចិត្តបានចំពោះការសន្និដ្ឋាន ក្នុងការប្រើប្រាស់នូវឯកសារដំបូងគេ ហើយប្រហែលជាកំណត់យកកាលបរិច្ឆេទដើមដំបូងនៃរបបរាជាធិបតេយ្យ ។ អ្នកផ្សេងទៀតគិតថា តាមរយៈគម្ពីរសាំយូអែល គឺជាប់ទាក់ទិននឹងសាច់រឿងនេះទាំងមូល ប៉ុន្តែ ការពិតយើងនៅតែមិនច្បាស់ថា នរណាជាអ្នកនិពន្ធចុងក្រោយ ឬអ្នកកែសម្រួលនោះទេ ។

## ជីវិតលោក យ៉ូស្វេ

ជីវិតដ៏អស្ចារ្យរបស់លោកយ៉ូស្វេ គឺចាក់បំពេញដោយសេចក្តីភ្ញាក់ផ្អើល ភាពប្រែប្រួល ភាពជោគជ័យ និងសេចក្តីខ្ពង់ខ្ពស់ ។ គាត់ត្រូវបានគេចាត់ទុកថា ជាអ្នកដែលមានសេចក្តីទុកចិត្តលើព្រះយ៉ាងជ្រាលជ្រៅ និង"ជាអ្នកដែលមានព្រះវិញ្ញាណសណ្ឋិតលើ" (ជនឌ ២៧:១៨)។ ក្នុងភាពជាយុវវ័យរបស់លោក គឺរស់ក្នុងភាពជូរល្វីងជាទាសកររបស់ពួកអេស៊ីព្ទ ប៉ុន្តែគាត់ជាស្មរបន្ទាល់ផងដែរ ចំពោះគ្រោះធម្មជាតិ និងការអស្ចារ្យរបស់ពួកអ៊ីស្រាអែលដែលគេចចេញពីទាហានអេស៊ីព្ទ ក្នុងខណៈដែលទឹកសមុទ្របានបើកផ្លូវឱ្យពួកគេ ។ នៅឯភ្នំស៊ីណាយវិញ លោកយ៉ូស្វេបានដឹកនាំពួកទាហានអ៊ីស្រាអែលយកជ័យជម្នះលើពួកសាសន៍អាម៉ាលេក ។ គាត់តែម្នាក់គត់ត្រូវបានអនុញ្ញាតឱ្យទៅជាមួយលោកម៉ូសេក្នុងការឡើងទៅលើភ្នំស៊ីណាយ ជាទីដែលលោកទទួលនូវក្រឹត្យវិន័យ (និក ២៤:១៣-១៤) ។ ហើយគាត់បានឈរលើត្រសាលប្រជុំរបស់លោកម៉ូសេជាបណ្តោះអាសន្ន មុនពេលដែលរោងឧបោសថបានបង្កើតឡើង (និក ៣៣:១១)។

លោកយ៉ូស្វេត្រូវបានគេជ្រើសរើសធ្វើជាអ្នកតំណាងសាសន៍របស់គាត់ផ្ទាល់ (សាសន៍ អេប្រាអិម) នៅពេលដែលអ្នកស៊ើបការទាំង១២ត្រូវបានបញ្ជូនទៅទឹកដីកាណាន ដើម្បីត្រួតពិនិត្យមើលទឹកដីនោះ ។ មានតែលោកយ៉ូស្វេ និងលោកកាលែបទេដែលជាអ្នកតំណាងឱ្យសាសន៍យូដា ដែលបានរៀបចំធ្វើតាមបំណងព្រះហឫទ័យព្រះ និងចាប់យកទឹកដីនេះជាកម្មសិទ្ធិភ្លាមៗ (មើល ១៤:២៦-៣៤) ហើយនៅទីបញ្ចប់ពួកអ៊ីស្រាអែលត្រូវបានកាត់ទោសឱ្យស្លាប់នៅទីរហោស្ថាន ។ ទោះបីលោកម៉ូសេបានស្លាប់នៅក្នុងរយៈពេលដ៏ខ្លីសម្រាប់ទិសដៅរបស់គាត់ ប៉ុន្តែអ្វីៗត្រូវបង្វែរមកឱ្យលោកយ៉ូស្វេជាអ្នកបន្តនូវដំណើរការនេះ ។ សេចក្តីសន្យារបស់ព្រះអម្ចាស់ក្នុងការដឹកនាំ និងការពង្រីកដល់លោកយ៉ូស្វេ គឺដូចនឹងអ្វីដែលលោកម៉ូសេធ្វើអញ្ចឹងដែរ (ចទ ៣១:២៣ ធៀប ហស ១:៥ និងការពន្យល់) ។

លោកយ៉ូស្វេ ត្រូវបានព្រះអម្ចាស់ជ្រើសជាអ្នកបម្រើទ្រង់ (មើល ២៤:២៩ និងការពន្យល់ ចទ ៣៤:៥) ក្នុងការនាំយកនូវកិច្ចការរបស់លោកម៉ូសេមកបញ្ចប់ដើម្បីបង្កើតរាស្ត្រអ៊ីស្រាអែលនៅក្នុងទឹកដីសន្យា ។ ចំពោះការនេះ គឺជាការតែងតាំងជាពិសេសរបស់ព្រះដែលគាត់បានជឿលើ ថាជាអ្នកដឹកនាំនៃពួកពលបរិវារ ជាអ្នកចាត់ចែងក្នុងការបែងចែកទឹកដីរបស់ព្រះ និងជាទូតរបស់ព្រះក្នុងការនាំសេចក្តីសញ្ញារបស់ព្រះអម្ចាស់មកដល់ពួកអ៊ីស្រាអែល ។ កិច្ចការដែលគាត់បានធ្វើទាំងប៉ុន្មាននៅក្នុងសញ្ញាចាស់ ត្រូវបានគេចាត់ទុកថាជាស្រមោលរបស់ព្រះគ្រីស្ទ (មើលការពន្យល់ ៤:១,៦-៨) ។

## ប្រវត្តិសាស្ត្រ

នៅពេលពួកអ៊ីស្រាអែលចាកចេញពីស្រុកអេស៊ីព្ទចូលក្នុងទឹកដីកាណាន ដែលជាមហាអំណាចនៅតំបន់ខាងកើតបានចាប់ផ្តើមចុះខ្សោយ ។ សាសន៍ហេត ក៏ចាប់ផ្តើមចុះខ្សោយនៅគ្រប់ទីកន្លែង ។ ទាំងចក្រភពបាប៊ីឡូន និងពួកអេស៊ីព្ទ នៅតែអាចឈរមាំមួនដោយវត្តមានរបស់ពួកទាហាននៅក្នុងទឹកដីកាណាន ដូច្នេះហើយពួកអាសស៊ើមិនអាចបញ្ជូនទាហានរបស់ពួកគេមកតំបន់នេះរហូតដល់សតវត្សក្រោយៗទៀត ។

ពួកសាសន៍ផ្សេងៗ បានរស់នៅជុំវិញសមុទ្រស្លាប់ ។ ពួកសាសន៍អេដំម បានបដិសេធន៍ចំពោះដំណើរឆ្លងកាត់តំបន់នេះ ដូច្នេះ

ពួកអ៊ីស្រាអែលក៏ធ្វើដំណើរវាងទៅភាគខាងកើតនៃតំបន់នេះវិញ ទោះបើពេលនោះស្តេចស៊ីហុន និងស្តេចអុក បានព្យាយាមបញ្ឈប់ដំណើររបស់ពួកគេក៏ដោយ ប៉ុន្តែ ពួកគេនៅតែអាចវាយផ្តួលហើយចាប់យកទឹកដីនេះដដែល ។ ពួកម៉ូអាប់ត្រូវបានគេបង្ខំក្នុងការឱ្យពួកអ៊ីស្រាអែលធ្វើដំណើរឆ្លងកាត់ និងជ្រកនៅទឹកដីពួកគេនៅឯវាលខ្សាច់ ហើយពួកសាសន៍ម៉ាឌាន ក៏រឹតបន្តឹងចំពោះការហូរចូលរបស់ពួកគេផងដែរ ។

បុរាណវិទូរផ្នែកខាងព្រះគម្ពីរ បានហៅពេលខាងលើនេះ ថាជាយុគសម័យលង្ហិន (១៥៥០–១២០០ មុន គ.ស)។ បច្ចុប្បន្ន តាមវត្ថុដែលបានបន្សល់ទុកតាំងពីបូរាណរបស់ពួកកាណាន គេអាចដឹងថា ពួកគេនៅសម័យនោះមានវប្បធម៌សម្បូរបែប ជាងពួកអ៊ីស្រាអែលទៅទៀត ។ នៅពេលដែលអាណាចក្រ "អ៊ុហ្គារីត" (Ugarit) បុរាណបានដួលរលំ បានឱ្យដឹងថាមុនពេលស្រុតចុះនៃអាណាចក្រនេះ វាមានភាពរឹងមាំ ខាងផ្នែកទ្រព្យសម្បត្តិ គេហដ្ឋាន ពាណិជ្ជកម្ម និងជីវិតខាងសាសនានៃពួកកាណានគ្រប់ៗគ្នា ។ ភាសារបស់ពួកគេ គឺមានភាពជិតស្និទ្ធនឹងភាសាហេព្រើរ ដែលបានត្រឡប់ចូលក្នុងសាច់រឿងផ្សេងៗនៃស្តេចកាលពីបុរាណកាលនោះ និងព្រះរបស់ពួកគេដែលបានបើកសម្តែងឱ្យដឹងថា ពោរពេញទៅដោយសេចក្តីកំផិត គ្រោកគ្រាត អសីលធម៌ ។ លើសពីនេះទៀត វិហារ អាសនា ផ្នូរ និងភាជន៍របស់សាសន៍ដទៃ បានបង្ហាញឱ្យឃើញផងដែរ តាមរយៈវប្បធម៌ និងប្រពៃណីដែលនៅជុំជិតពួកអ៊ីស្រាអែលនោះ ។

ស្ថានីយ៍បុរាណ មេគីដោ បេត–សៀន កេសើ បានបង្ហាញពីភាពរឹងមាំ ដែលពួកអ៊ីស្រាអែលមិនអាចឡោមព័ទ្ធ និងចាប់យកដីក្រុងនេះបាននៅសម័យលោកយ៉ូស្វេ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏នៅមានក្រុងដែលមានភាពរឹងមាំដែលពួកអ៊ីស្រាអែលមិនបានចាប់យក ដូចនេះ ពួកអ៊ីស្រាអែលបានក្លាយទៅជាអ្នកខ្លាំងពូកែ ហើយត្រួតត្រានៅលើទឹកដីនេះ ។ ចាប់ពីក្រុងយេរីខូរទៅដល់ក្រុងអៃយលោកយ៉ូស្វេបានដុតក្រុងហាសោរតែមួយគត់(១១:១៣) ក្នុងបំណងកត់ត្រាហេតុការណ៍នេះ ទៅក្នុងការបំផ្លាញ គំនរក្រុងកាណានបុរាណដែលចំណុចនេះនៅតែជាការចោទសួរនៅឡើយ ។ វាក៏ត្រូវបានគេចងចាំផងដែរថា នៅពេលនោះក៏មានក្រុមផ្សេងៗ បានជាប់ទាក់ទិននឹងតំបន់ទាំងអស់ខាងលើ ក្នុងខណៈដែលពួកអេស៊ីព្ទជាអ្នកដឹកនាំ និងពួកអ្នករស់នៅតាមសមុទ្រ(រួមបញ្ចូលពួកភីលីស្ទីន) ។ វាក៏ថែមទាំងមានការបញ្ចូលគ្នាក្នុងការច្បាំងនៅក្នុងចំណោមពួកកាណាន ហើយក្រោយមកទៀតរហូតដល់សម័យពួកចៅហ្វាយ ។

ទិន្នន័យជាច្រើនដែលគេរកបានពីកំណាយនៃបូរាណវត្ថុវិទ្យា ហាក់ដូចជាបង្កើបប្រាប់ផងដែរថា កាលបរិច្ឆេទនៃការដឹកនាំការចូលវាយកាន់កាប់ទឹកដី ដោយលោកយ៉ូស្វេ គឺប្រហែលជាធ្វើឡើងនៅឆ្នាំ ១២៥០ មុន គស ។ ការបរិច្ឆេទនេះគឺសមស្របនឹងកាលបរិច្ឆេទនៃការធ្វើនិក្ខមនំរបស់ពួកអ៊ីស្រាអែល(ក្នុងរជ្ជកាលស្តេចរ៉ាមសេសទី២ ជាស្តេចដ៏ល្បីល្បាញដែលគ្រប់គ្រងតំបន់ដីសណ្តរនៃទន្លេនីលដែលរាជធានីមានឈ្មោះដូចព្រះនាមស្តេចអង្គនេះ) ដោយសារការធ្វើនិក្ខមនំគឺមានរយៈពេល៤០ឆ្នាំ មុនពេលដែលលោកយ៉ូស្វេដឹកនាំការចូលវាយកាន់កាប់ទឹកដីសន្យា(នក ១:១១)។ កាលបរិច្ឆេទនេះ ក៏សមស្របនឹងកាលបរិច្ឆេទនៃការដឹកនាំរបស់លោកយ៉ូសែបនៅស្រុកអេស៊ីព្ទ កាលពីសម័យមុនផងដែរ ។ ស្តេចហ៊ីកសូស(Hyksos)ដែលមានដើមកំណើតជាសាសន៍ដែលប្រើភាសាអារ៉ាប់ បានគ្រប់គ្រងតំបន់ដីសណ្តរនោះ នៅក្បែរតំបន់កូសែន កាលពី ៤០០ ឆ្នាំ មុនពេលដែលស្តេចរ៉ាមសេស ទី២ គ្រប់គ្រងតំបន់ដីសណ្តរនោះ ។

ម្យ៉ាងវិញទៀត ការកំណត់យក(តាមប្រពៃណី)នូវឆ្នាំប្រហែល ១៤០៦ មុនគ.ស ជាឆ្នាំនៃការចូលវាយកាន់កាប់ ក៏អាចជាការសមហេតុផលផងដែរ ។ ការគៀបសង្កត់ពួកអ៊ីស្រាអែលនៅស្រុកអេស៊ីព្ទ អាចកើតឡើងនៅក្នុងរជ្ជកាលស្តេចអ័ម៉ាន់ហូទិបទី២(Amunhotep II) បន្ទាប់ពីការសុគតនៃបិតាទ្រង់គឺស្តេចធូតមូស ទី៣(Thutmose III) ដែលល្បីឈ្មោះខាងការប្រើទាសករនៅក្នុងការធ្វើសំណង់ធំៗ ។ ការកំណត់យកឆ្នាំ មុនកាលបរិច្ឆេទខាងលើនេះ ក៏សមស្របនឹងកាលបរិច្ឆេទទាំងពីរ នៅក្នុង ពច ១១:២៦ និង ១ពវ ៦:១ ព្រោះតាមការកំណត់នេះ ចាប់ពីសម័យម៉ូសេ ដល់សម័យនៃការចាប់ផ្តើមពង្សាវតានៃពួកស្តេច គឺមានរយៈពេល ១៥០ ឆ្នាំ ។ មើលសេចក្តីផ្តើមព្រះគម្ពីរលោកុប្បត្តិ(ត្រង់ចំណុចអ្នកនិពន្ធ និងកាលបរិច្ឆេទ) ព្រះគម្ពីរនិក្ខមនំ(ត្រង់ចំណុច ពង្សាវតា) ព្រះគម្ពីរពួកចៅហ្វាយ(ត្រង់ចំណុចប្រវត្តិដើម) និងការពន្យល់ ១ពវ ៦:១ ។

**គម្រោងសង្ខេប**

**I. ការចូលក្នុងទឹកដីសន្យា (១:១–៥:១២)**

ក. ការជម្រុញ ចំពោះការធ្វើសឹកសង្គ្រាម(ជំពូក ១)

ខ. ការស៊ើបការណ៍នៅក្រុងយេរីខូរ (ជំពូក ២)

គ. ដំណើរឆ្លងកាត់ទន្លេយ័រដាន់ (ជំពូក ៣–៤)

ឃ. ការប្រសិទ្ធពរជ័យនៅគីលកាល(៥:១–១២)

**II. សង្គ្រាមវាតទីទឹកដី (៥:១៣–១២:២៤)**

ក. សង្គ្រាមដំបូង (១:១៤–៣:១២)

១. ជ័យជម្នះនៅក្រុងយេរីខូរ (៥:១៣–៦:២៧)

២. ភាពបរាជ័យនៃក្រុងអៃយ ដោយព្រោះអំពើបាបរបស់លោកអេកាន (ជំពូក ៧)

៣. ជ័យជម្នះនៅក្រុងអៃយ (៨:១–២៩)

៤. សេចក្តីសញ្ញាថ្មីនៅឯស៊ីគែម (៨:៣០–៣៥)

ខ. ជំរុំនៅភាគខាងត្បូង (ជំពូក ៩–១០)

១. ការយល់ព្រមនៃសេចក្តីសញ្ញានៅក្រុងគីបៀន (ជំពូក ៩)

២. ថ្ងៃដ៏មានរយៈពេលវែងរបស់លោកយ៉ូស្វេ (១០:១–១៥)

៣. សង្គ្រាមវាតទី នៅភាគខាងត្បូង (១០:១៦–៤៣)

គ. ការបោះជុំរុំនៅភាគខាងជើង (ជំពូក ១១)

ឃ. ការវាយបំបាក់ដល់ស្តេចសាសន៍កាណាន (ជំពូក ១២)

**III. ការបែងចែកទឹកដី (ជំពូក ១៣–២១)**

ក. ទឹកដីដែលមិនទាន់ដណ្តើមបាន (១៣:១–៧)

ខ. ទឹកដីដែលប្រកាសផ្តល់ឱ្យដោយលោកម៉ូសេ ដល់ពួកសាសន៍ផ្សេងៗដែលរស់នៅជុំវិញទន្លេយ័រដាន់ (១៣:៨–៣៣)

គ. ការបែងចែកទឹកដីកាណាន (ជំពូក ១៤–១៩)

១. សេចក្តីផ្តើម (១៤–១៩)

២. ទីក្រុងដែលឱ្យដល់លោកកាលែប (១៤:៦–១៥)

៣. ទឹកដីដែលចែកឱ្យដល់លោកយូដា និងលោកយ៉ូសែប "នៅគីលកាល" (ជំពូក ១៥–១៧)

៤. ការចាប់ឆ្នោតចំពោះកូនចៅបេនយ៉ាមីន ស៊ីម្មាន សាប់យូល៉ូន អ៊ីសាខា អេស៊ើរ ណែបថាលី ដាន់ នៅឯស៊ីឡូរ (១៨:១–១៩:៤៨) ។

៥.ទឹកដីដែលផ្តល់ឱ្យលោកយ៉ូស្វេ (១៩:៤៩–៥១)

ឃ. ទឹកដីដែលប្រកាសឱ្យដល់ពួកលេវី (ជំពូក ២០–២១)

១. ក្រុងទាំង៦នៃការជ្រកពួន (ជំពូក ២០)

២. ក្រុងទាំង៤៨ របស់ពួកសង្ឃ (ជំពូក ២១)

**IV. សេចក្តីសន្និដ្ឋាន** ការរួបរួមរបស់ពូជអំបូរទាំងអស់ និងភាពស្មោះត្រង់ចំពោះព្រះអម្ចាស់ (ជំពូក ១៣–២១)

ក. ស្មរបន្ទាល់អាសនានៃទន្លេយ័រដាន់ (ជំពូក ២២)

ខ. ក្តីអវសានរបស់លោកយ៉ូស្វេ (ជំពូក ២៣)

គ. ការមកដល់ជាថ្មីម្តងទៀតនៃសេចក្តីសញ្ញានៅស៊ីគែម (២៤:១–២៨)

ឃ. សេចក្តីមរណៈ និងការបញ្ចុះសពលោកយ៉ូស្វេ (២៤:២៩–៣៣)

## ព្រះអម្ចាស់បង្គាប់លោកយ៉ូស្វេ

**១** ១រីឯក្រោយដែលម៉ូសេ ជាអ្នកបំរើរបស់ព្រះយេហូវ៉ា[ក]
បានស្លាប់ទៅ នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេ[ខ]
កូននុន ជាអ្នកជំនិតរបស់លោកថា ២ម៉ូសេ ជាអ្នកបំរើអញ
បានស្លាប់ទៅហើយ ដូច្នេះចូររៀបចំឆ្លងទន្លេយ័រដាន់[គ,ឃ]
ឥឡូវនេះចុះ ព្រមទាំងបណ្តាមនុស្សទាំងនេះផង ហើយ
ចូលទៅក្នុងស្រុក[ង]ដែលអញឱ្យដល់គេ[ច] គឺដល់ពួកកូនចៅ
អ៊ីស្រាអែល ៣អស់ទាំងទីកន្លែងណា ដែលឯងដាក់ជើង
ជាន់[ឆ] នោះអញនឹងឱ្យដល់ឯងរាល់គ្នា ដូចជាអញបានប្រាប់
ម៉ូសេហើយ[ជ] ៤ឯព្រំប្រទល់របស់ឯងរាល់គ្នា នោះត្រូវចាប់
តាំងពីទីរហោស្ថាន និងភ្នំល្បាណូននេះ[ឈ] រហូតដល់ទន្លេធំ
គឺជាទន្លេអឺប្រាត[ញ] ជាស្រុករបស់សាសន៍ហេត[ដ]ទាំងមូល
ហើយទៅដល់សមុទ្រធំ នៅទិសខាងលិចដែរ[ឋ] ៥និងគ្មាន
អ្នកណាអាចឈរនៅមុខឯង[ឌ] នៅគ្រប់១ជីវិតឯងបានឡើយ
អញនឹងនៅជាមួយនឹង[ឍ]ឯង ដូចជាបាននៅជាមួយនឹងម៉ូសេ
ដែរ អញមិនដែលខាននឹងប្រោសឯង ក៏មិនដែលបោះបង់
ចោល[ណ]ឯងឡើយ ៦ចូរឱ្យមានកំឡាំង[ត]និងចិត្តក្លាហានចុះ[ថ]
ដ្បិតឯងនឹងនាំឱ្យបណ្តាជននេះបានគ្រងស្រុក ដែលអញបាន
ស្បថថានឹងឱ្យដល់ពួកឰយុកោគេ[ទ] ៧ឱ្យឯងគ្រាន់តែមានកំ–
ឡាំងនិងចិត្តក្លាហានប៉ុណ្ណោះ ដើម្បីនឹងកាន់ ហើយប្រព្រឹត្ត
តាម[ធ]ក្រិត្យវិន័យ[ន]គ្រប់ជំពូក ដែលម៉ូសេ[ប]ជាអ្នកបំរើអញ
បានបង្គាប់មក កុំឱ្យងាកបែរចេញទៅខាងស្តាំ ឬខាងឆ្វេង
ឡើយ[ផ] ប្រយោជន៍ឱ្យឯងបានកើតការ នៅកន្លែងណាដែល
ឯងទៅនោះ[ព] ៨កុំឱ្យគម្ពីរក្រិត្យវិន័យនេះ[ភ]ភ្លេចបាត់ពីមាត់
ឯងឡើយ[ម] គឺត្រូវឱ្យនឹកជញ្ជឹង[យ]ទាំងយប់ទាំងថ្ងៃវិញ ដើម្បី
ឱ្យបានកាន់ ហើយប្រព្រឹត្តតាមអស់ទាំងសេចក្តី ដែលកត់ទុក
ក្នុងគម្ពីរនេះឯង ដ្បិតគឺយ៉ាងនោះ ដែលឯងនឹងបានកើត
ការនៅគ្រប់ទាំងផ្លូវឯង ហើយនិងបានចំរើនឡើងផង[រ]
៩តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឱ្យមានកំឡាំង
និងចិត្តក្លាហានចុះ កុំឱ្យខ្លាចឡើយ[ល] ក៏កុំឱ្យស្រយុតចិត្តផង[វ]
ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែង

**១:១** ក នក ១៤:៣១ ចទ ៣៤:៥ វរ ១៥:៣ ខ នក ១៧:៩ **១:២** គ ជន ១៣:២៩ ឃ ជន ៣៥:១០ ង លប ១៥:១៤ ច លប ១២:៧ ចទ ១:២៥ **១:៣** ឆ ចទ ១១:២៤ ជ លប ៥០:២៤ ជន ១៣:២ ចទ ១:៨ **១:៤** ឈ ចទ ៣:២៥ ញ លប ២:១៤ ដ លប ១០:១៥ ២៣:១០ នក ៣:៨ ឋ ជន ៣៤:២–១២ អរ ៤:២០ **១:៥** ឌ ចទ ៧:២៤ ឍ ខ.១៧ លប ២៦:៣ ៣៩:២ ពច ៦:១២ ១សយ ១០:៧ យរ ១:៨ ៣០:១១ ណ លប ២៨:១៥ ចទ ៤:៣១ **១:៦** ត ២សយ ២:៧ ១ពវ ២:២ អស ៤១:៦ យអ ៣:៩–១០ ថ ចទ ១:២១ ៣១:៦ ពច ៥:២១ ទ យរ ៣:១៨ ៧:៧ **១:៧** ធ ចទ ២៩:៩ ១ពវ ២:៣ ៣:៣ ន អរ ៧:២៦ ទដ ៧៨:១០ ១១៩:១៣៦ អស ៤២:២៤ យរ ២៦:៤–៦ ៣២:២៣ ៤៤:១០ បឌ.២, ១៥ ជន ១២:៧ យប ១:៨ ៤២:៧ ផ ចទ ៥:៣២ យស ២៣:៦ ព ខ.៩ ចទ ៤:២ ៥:៣៣ ១១:៨ យស ១១:១៥ **១:៨** ភ ចទ ២៨:៦១ ទដ ១៤៧:១៩ ម នក ៤:១៥ អស ៥៩:២១ យ លប ២៤:៦៣ រ ចទ ២៩:៩ ១សយ ១៨:១៤ ទដ ១:១–៣ អស ៥២:១៣ ៥៣:១០ យរ ២៣:៥ **១:៩** ល ចទ ៣១:៦ យស ១០:៨ ២ពវ ១៩:៦ អស ៣៥:៤ ៣៧:៦ វ ចទ ១:២១ យប ៤:៥

**១:១–១៨** នៅវគ្គនេះព្រះអម្ចាស់បានជ្រើសរើសលោកយ៉ូស្វេជំនួសឱ្យលោកម៉ូសេ (សូមមើល ចទ ៣១:១–៨) ដើម្បីដឹកនាំពួកអ៊ីស្រាអែលឆ្លងកាត់ទន្លេយ័រដាន់ និងទទួលបាននូវទឹកដីសន្យាជាកម្មសិទ្ធិ ។ ព្រះអម្ចាស់បានបញ្ជា និងតែងតាំងដល់គាត់ជាអ្នកដឹកនាំរាស្ត្រទ្រង់ (ខ.១–៩) ។ លោកយ៉ូស្វេជាអ្នកតំណាងព្រះក្នុងការដឹកនាំរាស្ត្រអ៊ីស្រាអែល (ខ.១០–១៥) ។ ដូច្នេះនៅក្នុងកណ្ឌគម្ពីរនេះ បង្កើតនូវចលនា និងតួនាទីដ៏សំខាន់ក្នុងការដឹកនាំពួករាស្ត្រទាំងនោះ ។

**១:១** *ម៉ូសេ ជាអ្នកបំរើរបស់ព្រះយេហូវ៉ាបានស្លាប់ទៅ* ភ្លាមៗនោះជាវេលា និងឱកាសដែលរៀបចំជាមុន ក្នុងការបង្ហាញថាផ្ទៃរឿងនេះនឹងបន្តចាប់ពីការបញ្ចប់របស់ចោទិយកថា ជាមួយនឹងការស្លាប់របស់លោកម៉ូសេ ។ *អ្នកបំរើរបស់ព្រះយេហូវ៉ា* មើលការពន្យល់ នក ១៤:៣១ ចទ ៣៤:៥ ទដ ១៨ ១សយ ៤១:៨–៩ ៤២:១ ។

**១:២** *ទន្លេយ័រដាន់* ការហូរនៃទឹកទន្លេយ័រដាន់ជិតក្រុងយេរីខូរ គឺមិនខ្លាំងទេក្នុងអំឡុងជាច្រើនឆ្នាំនោះ ប៉ុន្តែការជន់លិចនៅចន្លោះរដូវរងារ និងរដូវក្តៅ បានចាក់បំពេញទន្លេក្នុងទំហំដ៏ធំធេង ដែលទទឹងមានប្រវែងរហូតដល់ជាង ១៦០០ម៉ែត្រ ហើយគ្រោះថ្នាក់បំផុតក្នុងការឆ្លងកាត់ ។ *ស្រុកដែលអញឱ្យដល់គេ* ឃ្លានេះជាគោលរឿងនៃគម្ពីរបញ្ចកណ្ឌដំបូង (មើល លប ១២:១ ៥០:២៤ នក ៣:៨ ២៣:៣១ ចទ ១:៨) ។ កណ្ឌគម្ពីរយ៉ូស្វេ ជាប់ទាក់ទងនឹងការបំពេញសេចក្តីសន្យារបស់ព្រះអម្ចាស់ ។

**១:៣–៥** សូមមើល ១១:២៤–២៥ ។

**១:៤** ទំហំទឹកដីសន្យា ចំពោះការផ្លាស់ប្តូរអ៊ីស្រាអែល (ផ្ទៀបអត្ថបទនេះជាមួយនឹង លប ១៥:១៨ និង ចទ ៣៤:១–៤) ប៉ុន្តែទំហំនេះគឺធំធេងដែលកាន់កាប់ដោយស្តេចដាវីឌ និងស្តេចសាឡូម៉ូន ។ ទឹកដីកាណាននេះត្រូវបានគេហៅថា "ហាទិ" រាប់សតវត្សមកហើយ ក្រោយពី "ហាទិ" នេះត្រូវបានដកទៅតំបន់ខាងជើងនោះ ។ ប៉ុន្តែលោកយ៉ូស្វេ បានរៀបចំផែនការដើម្បីធ្វើការវាយប្រហារ គឺគ្រប់ទីកន្លែងនៅក្នុងតំបន់កាណានទាំងមូល (ខ.៣) ។ ជ័យជម្នះរបស់គាត់ បានផ្តល់ឱ្យពូជអំបូរទាំង១២ នៅតំបន់ជើងភ្នំកណ្តាល ។

**១:៥** *អញនឹងនៅជាមួយនឹងឯង* ឃ្លានេះព្រះទ្រង់មានបន្ទូលដោយផ្ទាល់ទៅកាន់លោកយ៉ូស្វេ ដោយទ្រទ្រង់ និងធានាអះអាងចំពោះភាពជោគជ័យរបស់គាត់ ។

**១:៦** *អញបានស្បថថា នឹងឱ្យដល់ពួកឰយុកោ* នេះជាមរដកនៃការរង់ចាំដ៏យូរក្នុងការសន្យាចំពោះកូនចៅលោកអ័ប្រាហាំ (មើល លប ១៥:៧,៨–២១) និងលោកយ៉ាកុប (លប ២៨:១៣) ។

**១:៧** *កាន់ ហើយប្រព្រឹត្តតាម* ឃ្លានេះប្រាប់ថា ភាពជោគជ័យមិនត្រូវបានធានាដោយគ្មានលក្ខខ័ណ្ឌនោះទេ (សូមមើល ចទ ៨:១ ១១:៨–៩ ២២–២៥) ។

**១:៨** *គម្ពីរក្រិត្យវិន័យ* មើល ចទ ២៨:៥៨,៦១ ២៩:១៧,២០–២១ ៣០:១០ ៣១:២៤ ។ *មាត់ . . . នឹកជញ្ជឹង* មើល ទដ ១:២ ។ ការអានអត្ថបទ ឬការជញ្ជឹងគិត គឺកម្រមានភាពស្ងៀមស្ងាត់ណាស់ (មើល នក ១៣:៩ ចទ ៣០:១៤ ទដ ១៩:១៤ ១១៩:១៣ កច ៨:៣០) ។ *ទាំងយប់ទាំងថ្ងៃ* មើល ទដ ១:២ ។

**១:៩** *តើអញមិនបានបង្គាប់ឯងទេឬអី* នេះជាសំណួរបែបលែងវោហាសព្ទដើម្បីបញ្ជាក់ពីភាពមានអំណាចនៃអ្នកនិយាយ ។

ណា ដែលឯងទៅផង[ស] ។
១០នោះយ៉ូស្វេក៏បង្គាប់ដល់ពួកអ្នក ដែលជានាយកលើ
បណ្ដាជនថា[ហ] ១១ចូរទៅឯកណ្ដាលទីដំឡើងត្រសាល[ឡ]
ប្រកាសប្រាប់បណ្ដាជនទាំងឡាយថា ចូរឱ្យត្រៀមស្បៀង
អាហារ[អ]ទៅ ដ្បិតនៅ៣ថ្ងៃ[ក]ទៀតនឹងត្រូវឆ្លងទន្លេយ័រដាន់
នេះ[ខ] ចូលទៅចាប់យក[គ]ស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃ
ឯង ទ្រង់ប្រទានឱ្យហើយ ។
១២យ៉ូស្វេក៏ប្រាប់ដល់ពួករូបេន ពួកកាឌ់ និងពូជអំបូរ
ម៉ាន៉ាសេ[ឃ]១ចំហៀងថា ១៣ចូរនឹកចាំពីពាក្យដែលលោក
ម៉ូសេ ជាអ្នកបំរើរបស់ព្រះយេហូវ៉ា បានបង្គាប់មកឯង
រាល់គ្នាថា គឺព្រះយេហូវ៉ា ជាព្រះនៃឯង ដែលប្រទានឱ្យ
ឯងឈប់សំរាក[ង] ទ្រង់នឹងប្រទានស្រុកនេះដល់ឯងដែរ ១៤ឯ
ប្រពន្ធកូនរបស់ឯងរាល់គ្នា[ច] និងហ្វូងសត្វទាំងប៉ុន្មាន នោះ
ត្រូវនៅក្នុងស្រុកនេះ[ឆ] ដែលលោកម៉ូសេបានឱ្យដល់ឯង
ហើយ គឺខាងកើតទន្លេយ័រដាន់នេះចុះ តែឯងរាល់គ្នា
ដែលជាមនុស្សខ្លាំងពូកែស្ទាត់ជំនាញ ត្រូវឱ្យឆ្លងនាំមុខពួក
បងប្អូនឯងទៅទាំងពាក់គ្រឿងសស្ត្រាវុធ[ជ] ដើម្បីនឹងជួយបង
ប្អូនឯង[ឈ] ១៥ទាល់តែព្រះយេហូវ៉ាបានប្រទានឱ្យគេឈប់
សំរាក ដូចជាឯងដែរ ហើយគេបានចាប់យកស្រុក ដែល
ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់ប្រទានឱ្យ រួចសឹមឯងរាល់
គ្នាត្រឡប់មកនៅក្នុងស្រុក ដែលជាកេរ្ដិ៍អាកររបស់ឯងវិញ
ដើម្បីនឹងចាប់យកស្រុក ដែលលោកម៉ូសេ ជាអ្នកបំរើរបស់
ព្រះយេហូវ៉ា បានឱ្យមកឯង នៅត្រើយទន្លេយ័រដាន់ខាង
កើតនេះ[ញ] ១៦គេក៏ឆ្លើយតបទៅយ៉ូស្វេវិញថា យើងរាល់គ្នា
នឹងធ្វើតាមគ្រប់ទាំងសេចក្ដី ដែលលោកបង្គាប់មកយើង
ហើយនឹងទៅឯកន្លែងណា ដែលលោកចាត់ឱ្យយើងទៅ
ផង[ដ] ១៧យើងរាល់គ្នានឹងស្ដាប់តាមលោក[ឋ] ក្នុងគ្រប់ការ
ទាំងអស់ ដូចជាបានស្ដាប់លោកម៉ូសេដែរ ឱ្យតែព្រះ
យេហូវ៉ា ជាព្រះនៃលោក បានគង់ជាមួយនឹងលោក ដូចជា
ទ្រង់បានគង់ជាមួយនឹងលោកម៉ូសេចុះ ១៨ឯអ្នកណាដែល
ហ៊ានទាស់ទទឹងនឹងបង្គាប់លោក ហើយមិនព្រមស្ដាប់តាម[ឌ]
អស់ទាំងពាក្យ ដែលលោកបង្គាប់មក នោះនឹងត្រូវមាន
ទោសដល់ស្លាប់ ឱ្យតែលោកមានកំឡាំងហើយចិត្តក្លាហាន
ចុះ[ឍ] ។

## នាងរ៉ាហាប និងពួកសង្កេតមើល

**២** ១យ៉ូស្វេ ជាកូននុន លោកចាត់អ្នកស៊ើបការសំងាត់២
នាក់[ក] ឱ្យចេញពីស៊ីទីមទៅ[ខ] ដោយប្រាប់ថា ចូរទៅសង្កេត
មើល[គ]ស្រុកនោះ និងក្រុងយេរីខូរ[ឃ]ផង គេក៏ចេញទៅ

**១:៩** ស ឧ.៧ ចទ ១:៧–៨ យរ ១:៨ **១:១០** ហ ចទ ១:១៥ **១:១១** ឡ យស ៣:២ អ ១សយ ១៧:២២ អស ១០:២៨ ក លប ៤០:១៣ ខ ជន ៣៥:១០ គ ជន ៣៣:៥៣ **១:១២** ឃ ជន ៣២:៣៣ **១:១៣** ង នក ៣៣:១៤ ទដ ៥៥:៦ អស ១១:១០ ២៨:១២ ៣០:១៥ ៣២:១៨ ៤០:៣១ យរ ៦:១៦ ៤៥:៣ បទ ៥:៥ **១:១៤** ច ចទ ៣:១៩ ឆ ជន ៣២:២៦ ជ នក ១៣:១៨ ឈ យស ៤:១២ **១:១៥** ញ ជន ៣២:២០–២២ យស ២២:១–៤ **១:១៦** ដ ជន ២៧:២០ ៣២:២៥ **១:១៧** ឋ ជន ២៧:២០ **១:១៨** ឌ ជន ៣២:២៥ ឍ ចទ ១:២១ ៣១:៦ **២:១** ក ឧ.៤ លប ៤២:៩ ខ ជន ២៥:១ យស ៣:១ យអ ៣:១៨ គ ជន ២១:៣២ ពច ១៨:២ ឃ ជន ៣៣:៤៨

**១:១០** *យ៉ូស្វេក៏បង្គាប់* នៅចំណុចនេះលោកយ៉ូស្វេ បានធ្វើការបញ្ជាទាំងស្រុង ។ *នាយក* ពួកនេះប្រហែលជាសំដៅដល់ពួកអ្នកដែលលោកម៉ូសេបានតែងតាំងលើការបែងចែកនៅក្នុងចំណោមពួកសាសន៍ផ្សេងៗ (នក ១៨:២១ ចទ ១:១៥) ។

**១:១១** *ស្បៀង* នេះជាការត្រៀម ជាស្បៀងអាហារក្នុងក្បួនដង្ហែរបស់ពួកទ័ពនៅថ្ងៃខាងមុខ ។

**១:១២–១៥** នៅវគ្គនេះ ជាការគម្រាមគំហែងពីសំណាក់ស្ដេចពីរអង្គក្នុងដំណើរឆ្លងកាត់ទន្លេយ័រដាន់ ដោយយកជ័យជម្នះនៃពួកទាហាន និងកាន់កាប់ទឹកដីភាគខាងជើងស្រុកម៉ូអាប់ និងភាគខាងកើតទន្លេយ័រដាន ។

**១:១៣,១៥** *ឈប់សំរាក* ពាក្យនេះជាគន្លឹះសំខាន់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ (ការពន្យល់ ចទ ៣:២០ ២សយ ៧:១,១១) រួចផុតពីការរំលោភបំពានព្រំដែនសន្តិភាពជាមួយប្រទេសជិតខាង និងគ្មានការគម្រាមគំហែងអាយុជីវិត សុខុមាលភាព និងទឹកដី (មើល ១ពវ ៥:៤ ៨:៥៦ និងការពន្យល់) ។

**១:១៤** *មនុស្សខ្លាំងពូកែស្ទាត់ជំនាញ* ពួកនេះមានចំនួនជាង២០នាក់ (មើល ជន ១:៣,១៨–៤៥) ដែលពួកគេអាចដោះស្រាយគ្រប់ស្ថានភាពលំបាកក្នុងការធ្វើសង្គ្រាម ។

**១:១៨** *ឯអ្នកណាដែលហ៊ានទាស់ទទឹង* ការដែលបានធ្វើសេចក្ដីសម្បថអំពីភាពស្មោះត្រង់ចំពោះលោកយ៉ូស្វេ នោះពួកគេបានយល់ព្រមចំពោះការកាត់ទោសប្រហាជីវិតសម្រាប់សេចក្ដីទាស់ប្រឆាំងណាមួយ (ឧទាហរណ៍ អំពើបាបរបស់លោកអេកាន ៧:១៥) ។ *មានកំឡាំងហើយចិត្តក្លាហាន* ពាក្យនេះពួកទាហ៊ាននិយាយលើកទឹកចិត្តដល់លោកយ៉ូស្វេ និងការពង្រឹងទាំងនោះចេញមកពីព្រះអម្ចាស់ (មើល ឧ.៦–៧,៩) ។

**២:១–២៤** នៅវគ្គនេះជាបេសកកម្មរបស់អ្នកស៊ើបការណ៍ពីរនាក់ និងជាការរៀបរាប់អំពីនាងរ៉ាហាប ។ ការអនុវត្តន៍របស់ពួកអ្នកស៊ើបការណ៍ និងចារកិច្ច គឺដូចជាការធ្វើសង្គ្រាម (ធៀប ពច ៧:១–១១ ១សយ ២៦:៦–១២) នាងរ៉ាហាបបានត្រឡប់ទៅឯព្រះរបស់ពួកអ៊ីស្រាអែល និងក្លាយជាស្ត្រីល្បីល្បាញ ក្នុងចំណោមសាសន៍ហេព្រើរ ។ ស្ត្រីរូបនេះទទួលបាន កិត្តិយសល្បីរន្ទឺដូចមានរៀបរាប់នៅក្នុងសញ្ញាថ្មី អំពីសេចក្ដីជំនឿរបស់នាង (ហេព ១១:៣១) និងស្នាដៃល្អ (យក ២:២៥) ។ ពេលជួបពួកអ៊ីស្រាអែល ជាលើកដំបូង (រៀបរាប់ដោយពួកអ្នកស៊ើបការណ៍ទាំងពីរ) និងពួកសាសន៍កាណាន (រៀបរាប់ដោយ ស្ត្រីឈ្មោះរ៉ាហាប) លទ្ធផលនៃបេសកកម្មដែលព្រះបានបញ្ជូនពួកទាហ៊ានរបស់ទ្រង់ ស្ថិតក្រោមការបញ្ជារបស់លោកយ៉ូស្វេ (ជំពូក ១) គឺបានបើកសម្ដែងឱ្យឃើញជាមុន សេចក្ដីធានាចំពោះជ័យជម្នះត្រូវបានអះអាងយ៉ាងច្បាស់ (១:៥) ។

**២:១** *ចាត់ . . . ស៊ីទីម* ចំណុចនៃការលុកលុយ គឺតំបន់វាលរាបស្រុកម៉ូអាប់ទល់មុខទន្លេយ័រដាន់ និងក្រុងយេរីខូរ (ជន ៣៣:៤៨–៤៩) ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យ "ស៊ីទីម" មានន័យថា "ដើមនាងនួន" ដែលដុះនៅវាលសោះកក្រោះ។ *ក្រុងយេរីខូរ* ក្រុងនេះជាចំណាប់អារម្មណ៍ដំបូងរបស់ពួកអ្នកស៊ើបការណ៍ ។ ក្រុងនេះព័ទ្ធដោយជញ្ជាំង ហើយជញ្ជាំងនោះអមទៅដោយទឹកចេញយ៉ាងច្រើនដែលមានប្រវែង ៨ គ.ម ខាងកើតទន្លេយ័រដាន់ (មើល

ហើយចូលទៅស្នាក់នៅក្នុងផ្ទះរបស់ស្រីសំផឹងម្នាក់ ឈ្មោះ
រ៉ាហាប[ង] ២ខណនោះ មានគេទូលដល់ស្តេចក្រុងយេរីខូរថា
មើល នៅយប់នេះ មានមនុស្សសាសន៍អ៊ីស្រាអែលខ្លះបាន
ចូលមក ដើម្បីនឹងសង្កេតមើលស្រុកនេះ ៣នោះស្តេចក្រុង
យេរីខូរក៏ចាត់គេឱ្យទៅបង្គាប់រ៉ាហាប[ច]ថា ចូរនាំមនុស្ស
ដែលចូលមកស្នាក់នៅផ្ទះឯងនោះចេញមក ដ្បិតគេបាន
មក ដើម្បីនឹងដើរសង្កេតមើលពេញក្នុងស្រុកនេះ ៤តែនាង
បាននាំយកមនុស្ស២នាក់នោះ[ឆ]ទៅលាក់ទុក[ជ] រួចប្រាប់ថា
មានមនុស្សមកឯខ្ញុំមែន តែខ្ញុំឥតបានដឹងជាមកពីណាទេ
៥លុះជិតដល់ពេលបិទទ្វារក្រុង[ឈ] កាលងងឹតហើយ នោះ
ស្រាប់តែគេចេញបាត់ទៅ ខ្ញុំឥតបានដឹងជាគេទៅឯណាទេ
ដូច្នេះចូរដេញតាមគេជាប្រញាប់ទៅ ដ្បិតមុខជានឹងតាមគេ
ទាន់[ញ] ៦តែនាងបាននាំយកអ្នកទាំង២នោះឡើងទៅឯលើ
ដំបូងផ្ទះវិញ ហើយលាក់ទុកនៅក្នុងគំនរដើមខ្លូតទេស[ដ]
ដែលនាងបានបញ្ឈរនៅលើដំបូលនោះ[ឋ] ៧ដូច្នេះគេក៏
ដេញតាមរកអ្នកទាំង២តាមផ្លូវទៅឯទន្លេយ័រដាន់[ឌ] រហូត
ដល់កន្លែងឆ្លង កាលពួកអ្នកដែលដេញតាម[ឍ] បានចេញទៅ
ផុតហើយ នោះក៏បិទទ្វារក្រុង ។
៨រួចកាលអ្នកទាំង២មិនទាន់ដេកនៅឡើយ នោះនាងក៏
ឡើងទៅឯគេនៅលើដំបូល[ណ] ៩និយាយថា ខ្ញុំដឹងថា ព្រះយេ
ហូវ៉ាបានប្រទានស្រុកនេះ ដល់អ្នករាល់គ្នាហើយ១ទៀត
សេចក្តីស្ញែងខ្លាច[ត]របស់អ្នករាល់គ្នា បានធ្លាក់មកលើយើង
ដែរ ឯអ្នកស្រុកទាំងប៉ុន្មាន គេនឹងរលាយបាត់ចេញពីមុខ
អ្នករាល់គ្នាទៅ ១០ដ្បិតយើងបានឮពីការ ដែលព្រះយេហូវ៉ា
ទ្រង់ធ្វើឱ្យទឹកសមុទ្រក្រហមរីង[ថ]ទៅ នៅមុខអ្នករាល់គ្នា ក្នុង
កាលដែលចេញពីស្រុកអេស៊ីព្ទមក[ទ] ហើយពីការដែលអ្នក
រាល់គ្នាបានធ្វើ ដល់ស្តេចសាសន៍អាម៉ូរី[ធ]ទាំង២អង្គ នៅ
ខាងនាយទន្លេយ័រដាន់នោះដែរ[ន] គឺដល់ស៊ីហុន ហើយនិង
អុក[ប] ដែលអ្នករាល់គ្នាបានបំផ្លាញអស់រលីងទៅ[ផ] ១១កាល
យើងខ្ញុំបានឮ នោះចិត្តយើងខ្ញុំបានរលត់[ព]ទៅភ្លាម គ្មាន
វិញ្ញាណនៅក្នុងមនុស្សណាទៀតសោះ[ភ] ដោយព្រោះអ្នក
រាល់គ្នា[ម] ដ្បិតព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នា[យ] ទ្រង់ជា
ព្រះលើស្ថានសួគ៌ ហើយជាព្រះលើផែនដី[រ]ផង ១២ដូច្នេះខ្ញុំ
សូមអង្វរអ្នក សូមស្បថនឹងខ្ញុំឥឡូវ[ល] ដោយនូវព្រះយេហូវ៉ា
ថា អ្នករាល់គ្នានឹងអាណិតមេត្តា[វ]ដល់ពួកគ្រួឪពុកខ្ញុំ ដូចជា
ខ្ញុំបានអាណិតមេត្តាដល់អ្នកដែរ សូមប្រាប់ទីសំគាល់ដ៏
ប្រាកដច្បាស់មកខ្ញុំផង[ស] ១៣ឱ្យខ្ញុំដឹងថា អ្នករាល់គ្នានឹងទុក
ជីវិតដល់ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ ព្រមទាំងវង្សាគាត់
ដែរ[ហ] ដោយជួយដោះយើងខ្ញុំឱ្យរួចពីស្លាប់ ១៤រួចអ្នកទាំង
២នាក់នោះក៏ឆ្លើយទៅនាងថា បើនាងមិនបំបែកការពី
រឿងយើងនេះ នោះយើងនឹងប្តូរជីវិតជំនួសនាង[ឡ] ហើយ
កាលណាព្រះយេហូវ៉ាទ្រង់ប្រទានស្រុកនេះដល់យើង នោះ
យើងនឹងប្រព្រឹត្តនឹងនាង ដោយសប្បុរសទៀងត្រង់[អ] ។
១៥នាងក៏សំរូតគេដោយខ្សែ[ក]ចុះតាមបង្អួច[ខ]ទៅ ដ្បិតផ្ទះ

**២:១** ង យស ៦:១៧,២៥ ហព ១១:៣១ **២:៣** ច យស ៦:២៣ **២:៤** ឆ ខ.១ យស ៦:២២ ជ យស ៦:១៧ **២:៥** ឈ ពច ៥:៨ ៩:៣៥ ១៦:២ ញ ហព ១១:៣១ **២:៦** ដ ពច ១៥:១៤ សភ ៣១:១៣ អស ១៩:៩ ឋ នក ១:១៧,១៩ យស ៦:២៥ ២សយ ១៧:១៩ **២:៧** ឌ ជន ២២:១ ពច ៣:២៨ ៧:២៤ ១២:៥,៦ អស ១៦:២ ឍ ខ.១៦,២២ **២:៨** ណ ចទ ២២:៨ ពច ១៦:២៧ ២សយ ១៦:២២ នហ ៨:១៦ អស ១៥:៣ ២២:១ យរ ៣២:២៩ **២:៩** ត លប ៣៥:៥ នក ១៥:១៤ **២:១០** ថ លប ៨:១ នក ១៤:២១ យស ៣:១៧ ទដ ៧៤:១៥ ទ ជន ២៣:២២ ធ លប ១០:១៦ ១៤:៧ ន យស ៩:១០ ប ជន ២១:២១ ផ ជន ២១:២ **២:១១** ព លប ៤២:២៨ ភ ចទ ២:២៥ ទដ ០៧:២៦ យហ ១:៥ ម នក ១៤ យស ៥:១ ៧:៥ ២សយ ៤:១ ទដ ២២:១៤ អស ១៣:៧ ១៩:១ យរ ៥១:៣០ ណហ ២:១០ យ ២ពវ ៥:១៥ ១៩:១៥ ដយ ៦:២៦ រ លប ១៤:១៩ ជន ២០:១៤ **២:១២** ល លប ២៤:៨ ៤៧:៣១ វ លប ២៤:១២ នរ ៣:១០ ស ប ២៤:១៤ នក ៣:១២ យស ៤:៦ ១សយ ២:៣៤ ២ពវ ១៩:២៩ **២:១៣** ហ ខ.១៨ យស ៦:២៣ **២:១៤** ឡ ១ពវ ២០:៣៩,៤២ ១ពវ ១០:២៤ អ លប ៤៧:២៩ **២:១៥** ក យរ ៣៨:៦,១១ ខ ខ.១៨,២១ លប ២៦:៨ ពច ៥:២៨ ១សយ ១៩:១២

ការពន្យល់ ៦:១) ។ *ស្រីសំផឹង* លោកយ៉ូសែបភើរ និងប្រភពផ្សេងៗ សំដៅលើស្ត្រីឈ្មោះរ៉ាហាបម្ចាស់ផ្ទះសំណាក់ ។

**២:២** *ស្តេចក្រុងយេរីខូរ* ក្រុងសំខាន់នៅក្នុងទឹកដីកាណាន គឺជាអាណាចក្រតូចៗ ដែលក្រុងទាំងនោះ បានដឹកនាំដោយពួកស្តេចប្រចាំតំបន់នោះ ។

**២:៦** *ដើមខ្លូតទេស* ត្រូវបានគេច្រូតកាត់នៅឯវាល និងពូកជាគំនរនៅលើដំបូលដើម្បីឱ្យវាស្ងួត ។ ដើមនេះត្រូវបានធ្វើឱ្យវាទៅជាអំបោះ សម្រាប់ធ្វើសម្លៀកបំពាក់ ។ ដើមនេះ វាដុះឡើងក្នុងកំពស់ពី១ម៉ែត្រ ទៅ១,២ម៉ែត្រ ។ ការបោះបង្គោលនៅលើដំបូលនេះ វាធ្វើឱ្យទីនេះក្លាយជាកន្លែងលាក់ខ្លួនដ៏ល្អសម្រាប់អ្នកយកការណ៍ទាំងនោះ ។

**២:៨–១៣** ចំណុចនេះមនុស្សជាច្រើន ស្មានថានាងរ៉ាហាបជាអ្នកប្រឆាំងនឹងសាសន៍កាណាន ហើយជាស្រីសំផឹងទៀតផង គឺមិនដែលចាប់អារម្មណ៍នឹងព្រះសោះឡើយ ។ លើសជាងនេះទៀត នាងបានប្រថុយគ្រោះថ្នាក់គ្រប់ទាំងអស់ ដែលនាងបានធ្វើចំពោះព្រះដែលនាងបានស្គាល់តិចតួចបំផុត ។

**២:១១** នាងរ៉ាហាបបានទទួលស្គាល់អ្វីៗដែលពួកអ៊ីស្រាអែលមិនបានស្គាល់ គឺនាងទទួលស្គាល់ព្រះនៃស្ថានសួគ៌ថា មិនមែនជាព្រះធម្មតា ។ ព្រះទ្រង់មានគ្រប់ទាំងអំណាចព្រះចេស្តា ។ ពួកក្រុងយេរីខូរ មានសេចក្តីភិតភ័យពីព្រោះពួកគេបានឮដំណឹង ពីសេចក្តីភ្ញាក់ផ្អើលក្នុងការវាយប្រហារសត្រូវឆ្លងកាត់ទន្លេយ័រដាន់ ។

**២:១២** *អាណិតមេត្តាដល់ពួកគ្រួឪពុកខ្ញុំ* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យ "មេត្តា"មានន័យថា "សេចក្តីស្រឡាញ់" ឬ"សេចក្តីស្រឡាញ់មិនដែលរលត់" និងការសង្ខេបពីសេចក្តីសញ្ញានៃការអនុគ្រោះរបស់ព្រះចំពោះរាស្ត្ររបស់ទ្រង់ និងសេចក្តីស្រឡាញ់របស់មនុស្ស ដែលត្រូវតែបង្ហាញដល់អ្នកឯទៀត ។ នាងរ៉ាហាប បានធ្វើបង្ហាញដល់អ្នកស៊ើបការណ៍ថា នាងជាមិត្តសំឡាញ់នឹងពួកអ៊ីស្រាអែល ហើយនាងក៏សូមឱ្យពួកអ៊ីស្រាអែល ចាត់ទុកនាងដូចជាពួកគេអញ្ចឹងដែរ ។ *ទីសំគាល់ដ៏ប្រាកដ* ពួកអ៊ីស្រាអែលបានស្បថចំពោះនាងអំពីក្រុមគ្រួសារនាងទាំងមូល(ខ.១៤) ។

**២:១៤** *សប្បុរស ទៀងត្រង់* នេះជាបពាក្យនៃការស្បថ ដែលធ្វើឡើងដោយពួកអ្នកស៊ើបការណ៍ (ខ.១២) ។ *ព្រះយេហូវ៉ាទ្រង់ប្រទានស្រុក* សម្តីនាងរ៉ាហាប បានផ្តល់នូវការធានាចំពោះជ័យជម្នះរបស់ពួកអ៊ីស្រាអែលលើក្រុងយេរីខូរ ។

នាងជាប់នឹងកំផែងទីក្រុង ហើយនាងនៅចំពីលើកំផែង
នោះ ១៦ដោយប្រាប់ថា ចូរអ្នកកាត់ដំរង់ឯទៅភ្នំ[គ]សិនទៅ
ក្រែងពួកអ្នកដែលដេញតាម[ឃ] គេជួបប្រទះនឹងអ្នក ត្រូវឱ្យ
ពួននៅទីនោះគ្រប់៣ថ្ងៃ[ង] ដរាបដល់គេត្រឡប់មកវិញ រួច
សឹមទៅតាមផ្លូវរបស់អ្នកចុះ[ច] ១៧អ្នកទាំង២ក៏ប្រាប់នាងថា
យើងនឹងបានរួចពីសេចក្ដីសំបថនេះ[ឆ] ដែលនាងបានចាប់
ឱ្យយើងស្បថហើយ ១៨គឺកាលណាយើងចូលមកក្នុងស្រុក
នេះ នោះនាងត្រូវចងខ្សែក្រហម[ជ]នេះនៅត្រង់បង្អួច[ឈ]
ដែលនាងបានសំរូតយើងចុះមកនេះ ហើយត្រូវប្រមូល
ឪពុកម្ដាយនឹងបងប្អូននាង ព្រមទាំងពួកគ្រួឪពុកនាងទាំង
អស់[ញ]មកនៅជាមួយគ្នា ១៩បើមានអ្នកណាមួយចេញទៅ
ក្រៅទ្វារផ្ទះនាង នោះឈាមរបស់គេនឹងនៅតែលើក្បាល
គេវិញ[ដ] ឯយើងគ្មានទោសទេ តែអ្នកណានៅក្នុងផ្ទះជា
មួយនឹងនាង បើសិនជាមានអ្នកណាពាល់គេ នោះឈាមគេ
នឹងធ្លាក់មកលើយើង[ឋ]វិញ ២០ម៉្យាងទៀតបើនាងបំបែកការ
នេះពីរឿងយើង នោះយើងក៏រួចពីសំបថនេះដែរ[ឌ] ២១នាង
ឆ្លើយតបថា សូមសំរេចដូចជាពាក្យអ្នកចុះ ដូច្នេះនាងក៏ឱ្យ
គេទៅ ហើយគេចេញបាត់ទៅ រួចនាងចងខ្សែក្រហម
នោះ[ឍ]នៅជាប់នឹងបង្អួច[ណ] ។
២២អ្នកទាំង២ក៏ចេញទៅដល់ភ្នំ ហើយស្នាក់នៅទីនោះ
អស់៣ថ្ងៃ[ត] កំពុងដែលពួកអ្នកដេញតាម[ថ] បានពិនិត្យរកគ្រប់
សព្វតាមផ្លូវឥតមានឃើញសោះ ហើយបានត្រឡប់វិលទៅ

**២:១៦** គ លប ១៤:១០ ឃ ខ.៧ ង ខ.២២ ច ហព ១១:៣១
**២:១៧** ឆ លប ២៤:៨
**២:១៨** ជ ខ.២១ ឈ ខ.១៥ ញ ខ.១៣
**២:១៩** ដ លវ ២០:៩ ឋ មថ ២៧:២៥
**២:២០** ឌ លប ២៤:៨ ៤៧:៣១
**២:២១** ឍ ខ.១៨ ណ ខ.១៥
**២:២២** ត ខ.១៦ ថ ខ.៧
**២:២៤** ទ យស ១០:៨ ១១:៦ ពច ៣:២៨ ៧:៩,១៤

វិញ ២៣នោះទើបអ្នកទាំង២បែរចុះពីភ្នំឆ្លងទៅដល់យ៉ូស្វេ
ជាកូននុន ទៅរ៉ាយរ៉ាប់ប្រាប់ពីគ្រប់ការ ដែលបានកើតមក
ដល់គេ ២៤គេជំរាបយ៉ូស្វេថា ព្រះយេហូវ៉ាទ្រង់បានប្រគល់
ស្រុកនោះទាំងមូល មកក្នុងកណ្ដាប់ដៃយើងហើយ[ទ] ពួកអ្នក
ស្រុកនោះទាំងប៉ុន្មាន គេកំពុងតែរលាយចេញ[ធ]ពីមុខយើង
រាល់គ្នាទៅ ។

## ការឆ្លងទន្លេយ័រដាន់

**៣** ១ឯយ៉ូស្វេលោកក្រោកពីព្រលឹម ហើយពួកកូនចៅ
អ៊ីស្រាអែលទាំងអស់ ក៏នាំគ្នាចេញពីស៊ីទីម[ក] ទៅដល់ទន្លេ
យ័រដាន់[ខ] ក៏ស្នាក់នៅទីនោះសិនមុនដែលឆ្លងទៅ ២រួច
ក្រោយ៣ថ្ងៃមក[គ] ពួកនាយក[ឃ]ក៏ដើរកាត់កណ្ដាលទីដំឡើង
ត្រសាល[ង] បង្គាប់ដល់បណ្ដាជនថា ៣កាលណាឯងរាល់គ្នា
ឃើញហឹប នៃសេចក្ដីសញ្ញា[ច] ផងព្រះយេហូវ៉ា ជាព្រះនៃ
ឯង ដែលពួកលេវី[ឆ]ដ៏ជាសង្ឃ[ជ]សែងទៅ នោះត្រូវឱ្យឯង
រាល់គ្នាចេញ ពីទីកន្លែងរបស់ឯង ដើរទៅតាម ៤តែត្រូវ
ដើរឃ្លាតពីហឹបនោះ ចំនួនប្រហែលជា២ពាន់ហត្ថ[ឈ] កុំឱ្យ
ចូលទៅជិតឡើយ ដើម្បីឱ្យឯងបានស្គាល់ផ្លូវ ដែលត្រូវដើរ
ដ្បិតតាំងតែពីមុនមក ឯងរាល់គ្នាមិនដែលដើរតាមផ្លូវនេះ

២០:២៨ ១សយ ១៤:១០ ធ នក ១៥:១៥ **៣:១** ក យស ២:១ ខ លប ១៣:១០ យប ៤០:២៣ **៣:២** គ លប ៤០:១៣ យស ២:១៦ ឃ ចទ ១:១៥ ង យស ១:១១ **៣:៣** ច ជន ១១:៣៣ ឆ ១សយ ៦:១៥ ជ ខ.៨,១៧ ជន ៤:១៥ ចទ ៣១:៩ ១ពវ ៨:៣ **៣:៤** ឈ ជន ៣៥:៥

**២:១៥** *ផ្ទះនាងជាប់នឹងកំផែងទីក្រុង* តាមការសិក្សាផ្នែកបុរាណវត្ថុវិទ្យាបានបញ្ជាក់ថា ពួកមនុស្សនៅក្រុងយេរីខូរ ជួនកាលរស់នៅចូលគ្នាក្នុងមួយភាគបួននៃកំផែងក្រុងនោះ ។ តែទោះជាភស្តុងតាងនេះ បានកំណត់កាលបរិច្ឆេទមុនសម័យលោកយ៉ូស្វេក៏ដោយ តែវានៅតែបំភ្លឺចំពោះខនេះដែរ ។ កំផែងការពារក្រុងយេរីខូរ ប្រហែលរួមបញ្ចូលទាំងរូងជញ្ជាំងដែរ (ជញ្ជាំងប្រហោង និងការបែងចែកជាផ្នែក) ហើយហាងរ៉ានរ៉ាហាបប្រហែលជាទទួលបន្ទប់នេះមួយ ឬលើសពីមួយនៅក្នុងរន្ធនេះមើលទៅ ។

**២:១៦** *កាត់ដំរង់ទៅឯភ្នំ* ទិសនេះទល់មុខនៃច្រកឆ្លងទឹកទន្លេយ័រដាន់ជាទីដែលពួកអ្នកដេញតាមពួកអ្នកស៊ើបការណ៍ចេញទៅផុត (មើល ខ.៧) ។

**២:១៨** *ខ្សែក្រហមនេះនៅត្រង់បង្អួច* មុខងារខ្សែក្រហមនេះ គឺស្រដៀងទៅនឹងការសម្លាប់កូនចៀមនៅថ្ងៃបុណ្យរំលោះបាប ពេលដែលព្រះអម្ចាស់បានទម្លាក់កូនច្បងនៅអេស៊ីព្ទ (សូមមើល នក ១២:១៣,២២–២៣) ។ ពួកជំនុំដំបូងយល់ថា ការចងព្យួរពណ៌ឈាមជានិមិត្តរូបពីការលោះបាបរបស់ព្រះគ្រីស្ទ ។

**២:១៩** *ឈាមគេនឹងធ្លាក់មកលើយើង* ការសន្យាដែលទទួលយកនូវការទទួលខុសត្រូវសម្រាប់ការស្លាប់របស់អ្នកដទៃ ដែលវាជាប់ទាក់ទងការកាត់ទោស ការបរិច្ចាកព្រំដែន និងរដ្ឋ ។

**២:២២** *ចេញទៅដល់ភ្នំ* ភ្នំនេះមានពេញទៅដោយរូងជាច្រើន សម្រាប់ការលាក់ខ្លួន និងការរត់គេចរបស់ពួកអ្នកស៊ើបការណ៍ទាំងពីរនាក់យ៉ាងងាយ ។

**៣:១–៤:២៤** នៅវគ្គនេះការរៀបរាប់លំអិតពីដំណើរឆ្លងកាត់ទន្លេយ័រដាន់ និងកំណត់ត្រានៃបូជនីដ្ឋានទាំង១២ ដែលសង់ឡើងនៅឯគីលកាល ។ សេចក្ដីដ៏សំខាន់ នៅក្នុងការរៀបរាប់នេះ គឺស្ទើតែមិនអាចបញ្ជាក់បាន ដោយព្រោះវាធ្វើឱ្យការឆ្លងកាត់តាមព្រំដែនក្នុងការចូលទៅក្នុងទឹកដីសន្យា និងការអស្ចារ្យនៅក្នុងដំណើរឆ្លងកាត់សមុទ្រក្រហម (នក ១៤–១៥) ។ សេចក្ដីជំនឿរបស់ពួកអ៊ីស្រាអែល ចំពោះព្រះអម្ចាស់ជាបិតានៃពួកគេនៅតែបន្ត និងពង្រឹង ហើយនៅពេលនោះផងដែរ សេចក្ដីភ័យខ្លាចរបស់ពួកកាណានបានកើនឡើងយ៉ាងខ្លាំង (៥:១) ។

**៣:៣** *ហឹបនៃសេចក្ដីសញ្ញា* ហឹបនេះជាទីគោរព ដែលទុកនៅក្នុងរោងឧបោសថ (សូមមើល ២៥:១០–២២) ។ ពីព្រោះហឹបនេះបានបង្ហាញពីបល្ល័ង្ករបស់ព្រះហើយព្រះអម្ចាស់ទ្រង់ផ្ទាល់ បានយាងទៅទន្លេយ័រដាន់ដឹកនាំរាស្ត្ររបស់ទ្រង់ ចូលទៅក្នុងទីសម្រាក (សូមមើល ជន ១០:៣៣–៣៦ ចទ ៣១:៧) ។

**៣:៤** *ឃ្លាតពីហឹបនោះ ចំនួនប្រហែលជា២ពាន់ហត្ថ* នេះជាភស្តុតាងយ៉ាងច្បាស់នៃជួរពួកពលទាហ៊ាន ដែលពួកសង្ឃ និងហឹបសញ្ញាជាអ្នកនាំមុខ ។ ការគោរពចំពោះវត្ថុតំណាងនៃវត្តមានរបស់ព្រះ បានរៀបរាប់ពីចន្លោះរវាងមនុស្ស និងការលីហឹបសញ្ញារបស់ពួកសង្ឃ ។

ទេ ៥យ៉ូស្វេក៏ប្រាប់បណ្ដាជនថា ចូរឯងរាល់គ្នាញែកខ្លួន
ចេញជាបរិសុទ្ធចុះ[ញ] ពីព្រោះថ្ងៃស្អែក ព្រះយេហូវ៉ា ទ្រង់
នឹងធ្វើការអស្ចារ្យ[ដ]នៅក្នុងពួកឯង ៦រួចលោកប្រាប់ដល់ពួក
សង្ឃថា ចូរលើកយកហឹបនៃសេចក្ដីសញ្ញានាំទៅឯមុខ
បណ្ដាជនទៅ នោះគេក៏លើកយកហឹបនៃសេចក្ដីសញ្ញា
សែងនាំមុខបណ្ដាជនទៅ ។
៧ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេថា នៅថ្ងៃនេះ
អញនឹងចាប់តាំងលើកដំកើងឯង[ឋ] នៅមុខពួកអ៊ីស្រាអែល
ទាំងអស់គ្នា ដើម្បីឱ្យគេដឹងថា អញនៅជាមួយនឹងឯង ដូច
ជាបាននៅជាមួយនឹងម៉ូសេដែរ[ឌ] ៨ត្រូវឱ្យឯងបង្គាប់ដល់ពួក
សង្ឃ[ឍ] ដែលសែងហឹបនៃសេចក្ដីសញ្ញា ថាកាលណាទៅ
ដល់មាត់ទឹកទន្លេយ័រដាន់ហើយ នោះត្រូវចុះទៅឈរនៅ
ក្នុងទឹកនោះទៅ ។
៩យ៉ូស្វេក៏ប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ចូរឯង
រាល់គ្នាមកឯនេះ ដើម្បីនឹងស្ដាប់ព្រះបន្ទូលនៃព្រះយេហូវ៉ា
ជាព្រះនៃឯង ១០រួចលោកប្រាប់ថា ឯងរាល់គ្នានឹងដឹង
ដោយសារសេចក្ដីនេះថា ព្រះដ៏មានព្រះជន្មរស់[ណ] ទ្រង់គង់
នៅក្នុងពួកឯង[ត] ហើយថា ទ្រង់នឹងបណ្ដេញសាសន៍កាណាន
សាសន៍ហេត[ថ] សាសន៍ហេវី សាសន៍ពេរីស៊ីត[ទ] សាសន៍គេ
កាស៊ី សាសន៍អាម៉ូរី និងសាសន៍យេប៊ូស[ធ]ចេញពីមុខឯង
រាល់គ្នាទៅជាមិនខាន ១១គឺដោយហឹបនៃសេចក្ដីសញ្ញាផង
ព្រះអម្ចាស់ នៃផែនដីទាំងមូល[ន] នឹងនាំមុខឯងរាល់គ្នាទៅ[ប]
ក្នុងទន្លេយ័រដាន់ ១២ដូច្នេះ ចូររើសយកមនុស្ស១២នាក់[ផ] ពី
ពួជអំបូរសាសន៍អ៊ីស្រាអែលទាំងប៉ុន្មានទៅ គឺម្នាក់ពីពួជ
អំបូរមួយៗ ១៣រួចកាលណាបាតជើងរបស់ពួកសង្ឃ ដែល
សែងហឹបផងព្រះយេហូវ៉ា ដ៏ជាព្រះអម្ចាស់នៃផែនដីទាំង
មូល[ព] បានដាក់ចុះទៅក្នុងទឹកទន្លេយ័រដាន់ហើយ[ភ] នោះទឹក
ទន្លេនឹងត្រូវកាត់ផ្ដាច់[ម] គឺជាទឹកដែលហូរចុះពីលើនឹងកល់
នៅនឹងជាគំនរ[យ] ។
១៤ដូច្នេះ កាលពួកបណ្ដាជនបានចេញពីត្រសាលគេ
ដើម្បីនឹងឆ្លងទន្លេយ័រដាន់ មានទាំងពួកសង្ឃសែងហឹបនៃ
សេចក្ដីសញ្ញា[រ] ទៅខាងមុខ[ល]ផង ១៥ហើយពួកសង្ឃ ដែល
សែងហឹប បានមកដល់ទន្លេយ័រដាន់[វ] ក៏ដាក់ជើងចុះទៅក្នុង
ទឹកនៅមាត់ទន្លេ (ដ្បិតទន្លេយ័រដាន់ឡើងលិច[ស]មាត់ច្រាំង
ទាំងអស់ នៅពេញរដូវចំរូត[ហ]) ១៦នោះទឹកដែលហូរចុះពី
លើមក ក៏ឈប់នៅនឹង ឡើង[ឡ]ជាគំនរ[អ]ពីទីចំងាយត្រង់ក្រុង
អាដាំ ដែលនៅជិតសារថាន[ក] ហើយផ្នែកទឹកដែលហូរចុះ[ខ]
ទៅខាងសមុទ្រស្រុកវាល[គ] គឺជាសមុទ្រអំបិល[ឃ] នោះក៏ហូរ
រីងអស់ទៅ[ង] រួចពួកបណ្ដាជនគេឆ្លងដំរង់ចំទៅឯក្រុង
យេរីខូរ[ច] ១៧ឯពួកសង្ឃ[ឆ] ដែលសែងហឹបនៃសេចក្ដីសញ្ញា

**៣:៥** ញ នក ២៩:១ លវ ១១:៤៤ ដ ពច ៦:១៣ ១រប ១៦:៩,២៤ ទដ ២៦:៧ ៧៥:១ **៣:៧** ឋ យស ៤:១៤ ១រប ២៩:២៥ ឌ យស ១:៥ **៣:៨** ឍ ខ.៣ **៣:១០** ណ ចទ ៥:២៦ ១សយ ១៧:២៦,៣៦ ២ពវ ១៩:៤,១៦ ទដ ១៨:៤៦ ៤២:២ ៨៤:២ អស ៣៧:៤,១៧ យរ ១០:១០ ២៣:៣៦ ដយ ៦:២៦ ហស ១:១០ មថ ១៦:១៦ ត ចទ ៧:២១ ថ លប ២៦:៣៤ ទ យស ១៧:១៥ ២៤:១១ ពច ១:៤ ៣:៥ ធ នក ៣:៨ ២៣:២៣ ចទ ៧:១ យស ៩:១ ១១:៣ ១២:៨ ពច ១៩:១១ ១រប ១១:៤ **៣:១១** ន ខ.១៣ នក ១៩:៥ ចទ ១០:១៤ ប យប ៩:១០ ២៨:២៤ ៤១:១១ ទដ ៥០:១២ ៩៧:៥ សក ៦:៥ប ចទ ៩:៣ **៣:១២** ផ យស ៤:២,៤ **៣:១៣** ព ខ.១១ ភ ខ.១៦ ម យស ៤:៧ យ នក ១៥:២២ អស ១១:១៥ **៣:១៤** រ ទដ ១៣២:៨ ល កច ៧:៤៤–៤៥ **៣:១៥** វ ២ពវ ២:៦ ស យស ៤:១៨ ១រប ១២:១៥ ស ៨:៧ ហ លប ៨:២២ **៣:១៦** ឡ ទដ ៦៦:៦ ៧៤:១៥ ១១៤:៣ អ យប ៣៨:៣៧ ទដ :៧ ក ១ពវ ៤:១២ ៧:៤៦ ខ ខ.១៣ គ ចទ ១:១ ឃ លប ១៤:៣ ង លប ៨:១ ក ១៤:២២ ច ២ពវ ២:៤ **៣:១៧** ឆ ខ.៣

**៣:៥** *ធ្វើការអស្ចារ្យនៅក្នុងពួកឯង* មុនពេលពួកគេជួបប្រជុំគ្នាជាមួយព្រះអម្ចាស់នៅភ្នំស៊ីណាយ ការនេះជាប់ទាក់ទងនឹងការលាងសម្អាតសំលៀកបំពាក់ ក៏ដូចជារាង្គកាយ ហើយនិងការតមមិនរួមភេទ (សូមមើល នក ១៩:១០,១៤–១៥) ។

**៣:៧** *អញនឹងចាប់តាំងលើកដំកើងឯង* នេះជាបំណងទី១នៃការអន្តរាគមន៍របស់ព្រះនៅទន្លេយ័រដាន់ ដែលបានបញ្ជាក់ពីភាពជាអ្នកដឹកនាំរបស់លោកយ៉ូស្វេ ។ តួនាទីរបស់លោកយ៉ូស្វេជាអ្នកបម្រើព្រះ និងត្រូវបានបង្ហាញដើម្បីធ្វើការប្រៀបធៀបនឹងតួនាទីលោកម៉ូសេ ជាមួយនឹងហេតុការណ៍អស្ចារ្យជាច្រើនដូចជាការឆ្លងកាត់សមុទ្រក្រហម ។

**៣:១០** *ឯងរាល់គ្នានឹង ដឹងដោយសារសេចក្ដីនេះ* ព្រះអម្ចាស់នឹងនាំពួករាស្ត្រអ៊ីស្រាអែលឆ្លងកាត់ទន្លេយ័រដាន់ក្នុងខណៈដែលពោរពេញទៅដោយទឹក ហើយការនេះធានាថា ព្រះពិតតែមួយបាននៅជាមួយពួកគេ ហើយទ្រង់នឹងបណ្ដេញពួកសាសន៍កាណានចេញពីទឹកដីពួកគេទៀតផង ។ លក្ខណៈគ្រឹះពីរយ៉ាងត្រូវស្វែងយល់ : (១).តើនរណាជាព្រះពិត ហើយមានព្រះចេស្ដា គឺជាព្រះរបស់ពួកអ៊ីស្រាអែល ឬព្រះដែលពួកសាសន៍កាណានជឿលើនោះ (ព្រះបាល)។ (២).តើនរណាមានសិទ្ធិស្របច្បាប់ចំពោះទឹកដីមួយនេះ? ជាព្រះអម្ចាស់ ឬពួកកាណាន? ព្រះអម្ចាស់បានបង្ហាញ ពីភាពត្រឹមត្រូវ ដែលទ្រង់បានប្រកាសនៅលើទឹកដីនេះ ដោយឆ្លងកាត់ទន្លេយ័រដាន់ដោយពួកទ័ពរបស់ទ្រង់ ។ *សាសន៍កាណាន . . . សាសន៍ពេរីស៊ីត* មើលការពន្យល់ លប ៩:២៥ ១០:៦,១៥–១៦ ១៣:៧ ១៥:១៦ ២៣:៣ នក ៣:៨ ពច ៣:៣ ៦:១០ ។

**៣:១២** *រើសយកមនុស្ស១២នាក់* នៅត្រង់នេះ លោកយ៉ូស្វេ ហាក់បីដូចជាបានស្មានទុកជាមុនពីការណែនាំរបស់ព្រះជាកន្លែងបូជាសព ដែលធ្វើអំពីថ្មនៃហេតុការណ៍ទាំងឡាយ (មើល ៤:២–៣) ។

**៣:១៣** *កាត់ផ្ដាច់* ពាក្យនេះមានន័យថា "ទប់" ឬបញ្ឈប់ការហូរ ។ *កល់នៅនឹងជាគំនរ* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យ "គំនរ" មានក្នុង ខ.១៦ និងកំណាព្យស្ដីអំពីការឆ្លងកាត់សមុទ្រក្រហម (នក ១៥:៨ ទដ ៧៨:១៣) ។ *គំនរ* នៅត្រង់នេះ ព្រះបានប្រើផ្ទាំងរូបរាង្គកាយ (ការបាក់ ច្រាំង) ដើម្បីទប់ទន្លេយ័រដាន់ហើយទីនោះឈ្មោះថា ក្រុងអាដាំ (ខ.១៦) ជិតផ្លូវចូលទន្លេយ៉ាបុក ។

**៣:១៥** *លិចមាត់ច្រាំង* នេះបណ្ដាលមកពីទឹកភ្លៀងនៅរដូវផ្ការីក និងការរលាយទឹកកកនៃភ្នំហើម៉ូន ។ *រដូវចំរូត* រដូវនេះរាប់ចាប់ពីខែ មេសា ដល់ខែឧសភា ។

**៣:១៧** *សង្ឃសែងហឹប . . . ឆ្លងទៅដីស្ងួត* មានន័យថាព្រះអម្ចាស់ ទ្រង់ផ្ទាល់បានគងនៅកន្លែងដែលមានគ្រោះថ្នាក់ ដើម្បីជួយដល់ពួករាស្ត្រអ៊ីស្រាអែលបានឆ្លងទន្លេនោះ ។

ផងព្រះយេហូវ៉ា គេក៏ឈរនឹង នៅដីស្ងួតនាបាតទន្លេយ័រ
ដាន់[ជ] ហើយសាសន៍អ៊ីស្រាអែលទាំងអស់គ្នា ក៏ឆ្លងទៅនៅដី
ស្ងួតដែរ ទាល់តែពួកគេទាំងអស់បានឆ្លងផុតពីទន្លេទៅ[ឈ]។
**៤** ១កាលសាសន៍អ៊ីស្រាអែលទាំងអស់គ្នាបានឆ្លងទន្លេយ័រ-
ដាន់[ក]ផុតហើយ នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលមកយ៉ូស្វេ
ថា ២ចូររើសយកមនុស្ស១២នាក់[ខ]ពីពួកបណ្ដាជន គឺម្នាក់ពី
ពូជអំបូរមួយៗ ៣ហើយបង្គាប់គេថា ចូរឯងរាល់គ្នាយកថ្ម
១២ដុំ[គ] ពីកណ្ដាលទន្លេយ័រដាន់[ឃ] ត្រង់កន្លែងដែលជើងពួក
សង្ឃបានឈរនោះ ទៅជាមួយនឹងឯង ហើយដាក់នៅត្រង់
កន្លែង ដែលឯងនឹងស្នាក់នៅយប់នេះ[ង] ៤នោះយ៉ូស្វេក៏ហៅ
មនុស្ស១២នាក់[ច] មកពីពួកកូនចៅអ៊ីស្រាអែល ដែលគាត់
បានដំរូវជាមុន គឺម្នាក់ពីពូជអំបូរមួយៗ ៥ប្រាប់គេថា ចូរ
ដើរទៅខាងមុខហឹបផងព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា
ដល់កណ្ដាលទន្លេយ័រដាន់[ឆ] ហើយយកថ្ម១ដុំម្នាក់គ្រប់គ្នាលី
ទៅ តាមចំនួនពូជអំបូរពួកកូនចៅអ៊ីស្រាអែល ៦ដើម្បីឱ្យ
បានទុកជាទីសំគាល់[ជ] នៅក្នុងពួកឯងរាល់គ្នា ប្រយោជន៍
ដល់ថ្ងៃក្រោយ កាលណាកូនចៅឯង[ឈ]សួរថា ថ្មទាំងនេះ
មានន័យដូចម្ដេច[ញ] ៧នោះឯងរាល់គ្នានឹងប្រាប់ថា នេះ
ដោយព្រោះទឹកទន្លេយ័រដាន់បានត្រូវកាត់ផ្ដាច់[ដ] នៅខាង
មុខហឹបនៃសេចក្ដីសញ្ញាផងព្រះយេហូវ៉ា គឺកាលហឹបនោះ
បានឆ្លងទន្លេយ័រដាន់ នោះទឹកទន្លេបានត្រូវកាត់ផ្ដាច់ចេញ
ដូច្នេះថ្មទាំងនេះ នឹងបានសំរាប់ជាសេចក្ដីរំឭក[ឋ] ដល់ពួក
កូនចៅអ៊ីស្រាអែលតរៀងទៅ ។
៨ពួកកូនចៅអ៊ីស្រាអែលក៏ធ្វើតាមបង្គាប់យ៉ូស្វេ[ឌ] គេយក
ថ្ម១២ដុំ[ឍ] ពីកណ្ដាលទន្លេយ័រដាន់[ណ] តាមចំនួនពូជអំបូរពួក
កូនចៅអ៊ីស្រាអែល ដូចជាព្រះយេហូវ៉ាបានមានបន្ទូលនឹង
លោក ហើយគេលីថ្មទាំងនោះទៅជាមួយ យកទៅដាក់ត្រង់
កន្លែងដែលគេស្នាក់នៅ ។
៩យ៉ូស្វេក៏ដាក់ថ្ម១២ដុំ[ត]នៅកណ្ដាលទន្លេយ័រដាន់ត្រង់
កន្លែងនៃជើងពួកសង្ឃ ដែលសែងហឹបនៃសេចក្ដីសញ្ញា
បានឈរ ហើយថ្មទាំងនោះក៏តាំងនៅរហូតដល់សព្វថ្ងៃនេះ[ថ]
១០ឯពួកសង្ឃ ជាអ្នកសែងហឹប គេឈរនៅកណ្ដាលទន្លេយ័រ
ដាន់នោះ ដរាបដល់គ្រប់ការ ដែលព្រះយេហូវ៉ាបានបង្គាប់
ដល់យ៉ូស្វេ ឱ្យប្រាប់ដល់បណ្ដាជនបានសំរេច ជាការដែល
ត្រូវនឹងគ្រប់ទាំងសេចក្ដី ដែលលោកម៉ូសេបានបង្គាប់មក
យ៉ូស្វេដែរ ឯពួកជនទាំងឡាយ គេក៏នាំគ្នាឆ្លងទៅដោយ
ប្រញាប់ប្រញាល់ ១១កាលពួកជនបានឆ្លងទៅផុតហើយ
នោះហឹបនៃព្រះយេហូវ៉ានឹងពួកសង្ឃ ក៏ឆ្លងទៅនៅចំពោះ
មុខគេ ១២ឯពួកកូនចៅរូបេន[ទ] និងពួកកូនចៅកាឌ់[ធ] ហើយ
ពូជអំបូរម៉ាន៉ាសេ១ចំហៀង[ន] ក៏ឆ្លងទៅនៅមុខពួកកូនចៅ
អ៊ីស្រាអែល[ប] ទាំងមានគ្រឿងសស្ត្រាវុធពាក់ស្រាប់ ដូចជា
ម៉ូសេបានប្រាប់[ផ] ១៣គឺមានចំនួនប្រហែលជា៤ម៉ឺននាក់
ដែលសុទ្ធតែពាក់គ្រឿងសស្ត្រាវុធរៀបចំនឹងច្បាំង[ព] គេឆ្លង
នៅ[ភ]ចំពោះព្រះយេហូវ៉ា ទៅដល់វាលក្រុងយេរីខូរ ១៤នៅ
ថ្ងៃនោះឯង ព្រះយេហូវ៉ាទ្រង់បានលើកដំកើង[ម]យ៉ូស្វេ នៅ
ចំពោះភ្នែកនៃពួកអ៊ីស្រាអែលទាំងអស់គ្នា ហើយគេក៏កោត
ខ្លាចដល់លោក ដូចជាបានកោតខ្លាចដល់លោកម៉ូសេដែរ
នៅអស់១ជីវិតរបស់លោក ។
១៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេថា ១៦ចូរបង្គាប់
ដល់ពួកសង្ឃ ដែលសែងហឹបនៃសេចក្ដីបន្ទាល់[យ] ឱ្យឡើងពី
ទន្លេយ័រដាន់មក ១៧នោះយ៉ូស្វេក៏បង្គាប់ដល់ពួកសង្ឃថា ចូរ
នាំគ្នាឡើងមក ១៨កាលពួកសង្ឃ ដែលសែងហឹបនៃសេចក្ដី
សញ្ញាផងព្រះយេហូវ៉ា បានឡើងពីកណ្ដាលទន្លេយ័រដាន់ខ្ទះ
ឃ្លា មកដាក់បាតជើងជាន់នៅលើដីគោកហើយ នោះទឹក
ទន្លេយ័រដាន់ ក៏ហូរទំលាក់មកតាមកន្លែងធម្មតាវិញ[រ] ព្រម
ទាំងលិចមាត់ច្រាំងទាំងអស់[ល] ដូចពីកាលមុន ។
១៩រីឯកាលពួកបណ្ដាជនបានឡើងពីទន្លេយ័រដាន់មក
នោះគឺជាថ្ងៃ១០ខែចេត្រ គេក៏ដំឡើងត្រសាលនៅត្រង់

**៣:១៧** ជ យស ៤:៣,៥,៨,៩,១០ ឈ នក ១៤:២២ យស ២:១០
**៤:១** ក ចទ ២៧:២
**៤:២** ខ យស ៣:១២
**៤:៣** គ ខ.២០ ឃ យស ៣:១៧ ង ខ.១៩
**៤:៤** ច យស ៣:១២
**៤:៥** ឆ យស ៣:១៧
**៤:៦** ជ យស ២:១២ ឈ នក ១០:២ ញ ខ.២១ នក ១២:២៦ ១៣:១៤
**៤:៧** ដ យស ៣:១៣ ឋ នក ២៨:១២
**៤:៨** ឌ នក ២៨:២១ ឍ យស ៣:១៧ ណ ខ.២០
**៤:៩** ត លប ២៨:១៨ យស ២៤:២៦ ១សយ ៧:១២ ថ លប ៣៥:២០
**៤:១២** ទ លប ២៩:៣២ ធ លប ៣០:១១ ន លប ៤១:៥១ ប ជន ៣២:២៧ ផ ជន ៣២:២៩
**៤:១៣** ព នក ១៣:១៨ ភ ជន ៣២:១៧
**៤:១៤** ម យស ៣:៧
**៤:១៦** យ នក ២៥:២២
**៤:១៨** រ នក ១៤:២៧ ល យស ៣:១៥

**៤:៦** *ថ្មនេះមានន័យដូចម្ដេច* ថ្មនេះគេតាំងឡើង ដើម្បីរំឭកដល់អ្នកជិនាន់ក្រោយថា មានរឿងអ្វីកើតឡើងនៅកន្លែងនេះ (២៤:២៦ ១សយ ៧:១២) ។

**៤:៩** *យ៉ូស្វេក៏ដាក់ថ្ម១២ដុំ* នៅត្រង់នេះពួកសាសន៍នីមួយៗគេនាំយកថ្មម្នាក់១ដុំទុកជាធ្វើបូជនីដ្ឋានដែលពួកគេយកចេញពីបាតទន្លេ ទៅឯរោងឧបោសថថ្មីនៅគីលកាល ហើយលោកយ៉ូស្វេក៏សង់បូជនីដ្ឋាននៅទីនោះតែម្ដង (ខ.២០) បូជនីដ្ឋាននៅគីលកាលនេះ ជាបូជនីដ្ឋានទីមួយក្នុងចំណោមបូជនីដ្ឋានផ្សេងៗជាច្រើនដែលបានដៅប្រទេសនេះសម្រាប់ការចងចាំ ពីការដែលពួកអ៊ីស្រាអែលចូលមកក្នុងទឹកដីសន្យាមានដូចជា ការដួលរលំក្រុងយេរីខូរ (៦:២៦) ការបង្គរថ្មលើសាកសពលោកអេកាន (៧:២៦) ការបង្គរថ្មលើសាកសពស្ដេចក្រុងអៃយ (៨:២៩) គំនរថ្មដែលសន្ទប់រូងផ្នូរជាទីដែលពួកស្ដេចសាសន៍កាណានកប់នៅទីនេះ (១០:២៧) សេចក្ដីសញ្ញាថ្មីនៅភ្នំអេបាល (៨:៣០–៣១) និងការសង់អាសនានៅទន្លេយ័រដាន់ជាភស្តុតាងទៅដល់សាសន៍ដែលនៅខាងលិចទន្លេយ័រដាន់ ថាទឹកដីខាងកើតទន្លេនេះត្រូវចែកស្មើគ្នានៅចំពោះមុខព្រះអម្ចាស់ (២២:២៦–២៨) ហើយនិងថ្មទីបន្ទាល់ទាស់នឹងពួកសាសន៍ទាំងអស់នោះនៅស៊ីគែម (២៤:២៦–២៧) ។

**៤:១៣** *ប្រហែលជា៤ម៉ឺននាក់* ចំនួននេះហាក់ដូចជាតិចតួចនៅក្នុង ជន ២៦ សម្រាប់ពួកកូនចៅរូបេន កាឌ់ និងពួកកូនចៅម៉ាន៉ាសេមួយចំហៀង ។

**៤:១៤** សូមមើល ៣:៧ និងការពន្យល់ ។

**៤:១៩** *ថ្ងៃ១០ខែចេត្រ* នៅថ្ងៃបុណ្យរំលង កូនចៀមត្រូវបានគេជ្រើសរើស (មើល នក ១២:៣) ។ *គីលកាល* ជាទូទៅដូចគ្នាជាមួយនឹងការបំផ្លាញនៃ

គីលកាល[វ] ក្បែរព្រំក្រុងយេរីខូរខាងកើត ២០ចំណែកថ្មទាំង
១២ដុំនោះ[ស] ដែលគេបានយកចេញពីកណ្ដាលទន្លេយ័រដាន់
នោះយ៉ូស្វេក៏នាំយកមកដាក់បង្គរត្រង់គីលកាល ២១រួច
លោកប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា កាលណាដល់
ថ្ងៃក្រោយ កូនចៅឯងរាល់គ្នាសួរឪពុកថា តើថ្មទាំងនេះ
មានន័យដូចម្ដេច[ហ] ២២នោះត្រូវប្រាប់ឱ្យដឹងថា គឺពួក
អ៊ីស្រាអែលយើង បានឆ្លងទន្លេយ័រដាន់នេះ នៅដីស្ងួត[ឡ]
២៣ពីព្រោះព្រះយេហូវ៉ា ជាព្រះនៃយើង ទ្រង់បានធ្វើឱ្យទឹក
ទន្លេយ័រដាន់រីងទៅ នៅមុខយើង ទាល់តែបានឆ្លងផុតមក
ដូចជាព្រះយេហូវ៉ា ជាព្រះនៃយើង ទ្រង់បានធ្វើឱ្យសមុទ្រ
ក្រហមរីងទៅ នៅមុខយើង ទាល់តែបានឆ្លងផុតមកដែរ[អ]
២៤ដើម្បីឱ្យគ្រប់ទាំងសាសន៍នៅផែនដីបានដឹងថា[ក] ព្រះហស្ត
នៃព្រះយេហូវ៉ាមានព្រះចេស្ដា[ខ] ប្រយោជន៍ឱ្យឯងរាល់គ្នា
បានកោតខ្លាចដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ជាដរាប
តទៅ[គ] ។

## ការកាត់ស្បែកនៅគីលកាល

**៥** ១កាលពួកស្ដេចសាសន៍អាម៉ូរីទាំងប៉ុន្មាន ដែលនៅខាង
លិចទន្លេយ័រដាន់[ក] និងស្ដេចសាសន៍កាណានទាំងប៉ុន្មាន
ដែលនៅក្បែរសមុទ្រ បានឮថា ព្រះយេហូវ៉ាបានធ្វើឱ្យទឹក
ទន្លេយ័រដាន់រីងទៅ នៅមុខពួកកូនចៅអ៊ីស្រាអែល ទាល់
តែបានឆ្លងផុតមកដូច្នេះ នោះគេមានចិត្តរលត់ទៅ[ខ] គ្មាន
វិញ្ញាណនៅសល់ក្នុងគេទៀតឡើយ ដោយព្រោះពួកកូន
ចៅអ៊ីស្រាអែល ។
២នៅគ្រានោះ ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់យ៉ូស្វេថា
ចូរយកថ្មធ្វើជាកាំបិត[គ] រួចកាត់ស្បែក[ឃ]ពួកកូនចៅអ៊ីស្រា
អែល១លើកទៀត ៣នោះយ៉ូស្វេក៏ធ្វើកាំបិតពីថ្ម ហើយកាត់
ស្បែករបស់ពួកកូនចៅអ៊ីស្រាអែល នៅត្រង់ភ្នំហារ៉ាឡូត
៤យ៉ូស្វេបានកាត់ស្បែកគេ ដោយព្រោះហេតុនេះ គឺមនុស្ស
ប្រុសៗ ជាអ្នកថ្មីកច្បាំងទាំងប៉ុន្មាន[ង] ដែលចេញពីស្រុក
អេស៊ីព្ទមក គេបានស្លាប់តាមផ្លូវនៅទីរហោស្ថាន ក្នុងពេល
ក្រោយដែលបានចេញមកពីស្រុកអេស៊ីព្ទ[ច] ៥ដ្បិតប្រុសៗ
ទាំងអស់ដែលចេញមក គេបានកាត់ស្បែកគ្រប់គ្នាហើយ
តែពួកទាំងប៉ុន្មានដែលកើតតាមផ្លូវ នៅទីរហោស្ថាន
ក្រោយដែលបានចេញពីស្រុកអេស៊ីព្ទមក នោះមិនទាន់បាន
កាត់ស្បែកនៅឡើយ ៦ពួកកូនចៅអ៊ីស្រាអែលបានដើរក្នុង
ទីរហោស្ថាន[ឆ]អស់៤០ឆ្នាំ[ជ] ទាល់តែពួកគេគ្រប់គ្នា គឺជាពួក
មនុស្សថ្មីកច្បាំង ដែលចេញពីស្រុកអេស៊ីព្ទមក បានស្លាប់
បាត់អស់ទៅ ពីព្រោះគេមិនបានស្ដាប់តាមព្រះបន្ទូលនៃព្រះ
យេហូវ៉ា ហើយទ្រង់បានស្បថថា មិនឱ្យគេឃើញស្រុក
ដែលទ្រង់បានស្បថនឹងពួកឰយុកោគេថា នឹងឱ្យមកយើង
រាល់គ្នាឡើយ[ឈ] ជាស្រុកដែលមានទឹកដោះនិងទឹកឃ្មុំហូរ

**៤:១៩** វ ចទ ១១:៣០
**៤:២០** ស ខ.៣,៨
**៤:២១** ហ ខ.៦
**៤:២២** ឡ នក ១៤:២២
**៤:២៣** អ នក ១៤:១៩–២២
**៤:២៤** ក ១ពវ ៨:៦០ ១៨:៣៦ ២ពវ ៥:១៥ ទដ ៦៧:២ ៨៣:១៨ ១០៦:៨ អស ៣៧:២០ ៥២:១០ ខ នក ១៥:១៦ ១រប ២៩:១២ ទដ ៤៤:៣ ៨៩:១៣ ៩៨:១ ១១៨:១៥–១៦ គ នក ១៤:៣១
**៥:១** ក ជន ១៣:២៩ ខ លប ៤២:២៨
**៥:២** គ នក ៤:២៥ ឃ លប ១៧:១០, ១២,១៤
**៥:៤** ង ជន ១:៣ ច ចទ ២:១៤
**៥:៦** ឆ ជន ៣២:១៣ យស ១៤:១០ ទដ ១០៧:៤ ជ នក ១៦:៣៥ ឈ ជន ១៤:២៣,២៩–៣៥ ចទ ២:១៤

ក្រុង"ខើបិត–អែល–ម៉ាសជើរ" (khirbet-el-Mafjer) មានចម្ងាយ៣២០០ ម៉ែត្រភាគខាងជើងក្រុងយេរីខូរ ។

**៤:២២** *ពួកអ៊ីស្រាអែលយើង បានឆ្លងទន្លេយ័រដាន់* នេះជាលើកដំបូងដែលលោកយ៉ូស្វេបានប្រកាសប្រាប់ដល់ពួកអ៊ីស្រាអែលថា ទឹកទន្លេនេះនឹងឈប់ហូរ ដូច្នេះហឹបនៃសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ និងអាចសែងឆ្លងទន្លេនេះបាន (ខ.៦–៧) ។ នេះជាព្រឹត្តិការណ៍ជាក់ស្ដែងមួយ ដែលព្រះអម្ចាស់បានឱ្យពួកអ៊ីស្រាអែលឆ្លងទន្លេយ័រដាន់ ដើម្បីយកទឹកដីកាណានជាកន្លែងដែលទ្រង់បង្កើតអាណាចក្រថ្មីរបស់ទ្រង់ ហើយទ្រង់នឹងរាស្ត្រទ្រង់ជាកងទ័ព ។

**៤:២៣** *ទ្រង់បានធ្វើឱ្យទឹកទន្លេយ័រដាន់រីង* ការនេះនៅតែមានរៀបរាប់នៅប្រយោគផ្សេងៗទៀតពីការអស្ចារ្យ ជាមួយនឹងទឹកទន្លេនេះ "ទឹកទន្លេ . . . ឈប់ហូរ" "បង្គគំនរថ្ម"និង"ការទប់ទំនប់" (៣:១៦) ។

**៤:២៤** *ដើម្បីឱ្យគ្រប់ទាំងសាសន៍ . . . បានដឹង* ព្រះអម្ចាស់ទ្រង់បានបើកសម្ដែងពីអំណាចរបស់ទ្រង់ដល់ពួកបណ្ដាជនអ៊ីស្រាអែល នោះធ្វើឱ្យពួកកាណានបានឮពីដំណឹងនេះ (សូមមើល ៥:១) គឺដូចដែលពួកគេបានឮពីដំណើរឆ្លងកាត់សមុទ្រក្រហម និងការវាយផ្ចាលស្ដេចស៊ីហុន និងស្ដេចអុក (២:១០)។ *កោតខ្លាចដល់ព្រះយេហូវ៉ា* ពាក្យនេះប្រាប់ឱ្យពួកគេថ្វាយបង្គំនិងស្ដាប់បង្គាប់ទ្រង់ ។

**៥:១–១២** នៅវគ្គនេះ បានរៀបរាប់ពីពិធីកាត់ស្បែក និងការប្រារព្ធពិធីបុណ្យរំលងបាបដែលប្រព្រឹត្តនៅតាមមូលដ្ឋាននៃសេចក្ដីសញ្ញាពីរយ៉ាងដូចដែលមានសង្ខេបនៅគីលកាល ។ ការទាំងពីរនេះ ជាការរៀបចំដ៏សំខាន់ក្នុងសង្គ្រាមវាតទីទឹកដីសន្យា ។ មានតែរាស្ត្ររបស់ព្រះដែលបូជាខ្លួនទៅដល់ព្រះ (ការកាត់ស្បែក មើលការពន្យល់ លប ១៧:១០) ហើយដែលពួកគេនៅនឹកចាំពីការដែលព្រះបានរំដោះពួកគេឱ្យមានសេរីភាពពីភាពជាទាសកររបស់ពួកអេស៊ីព្ទ ហើយមកធ្វើជារាស្ត្ររបស់ទ្រង់ (មើល ១២:១១,១៧) ហើយអាចទទួលបានទឹកដីកាណាន ជាកម្មសិទ្ធិរបស់ពួកគេ ។

**៥:១** *សាសន៍អាម៉ូរី . . . សាសន៍កាណាន* ពាក្យទាំងពីរអាចជំនួសគ្នាបាន ហើយជាទូទៅឈ្មោះនេះបានរួមបញ្ចូលសាសន៍តូចៗ ដែលរស់នៅក្នុងទឹកដីនេះ ។ អាម៉ូរីមានន័យថា"ពួកអ្នកខាងលិច" ហើយកាណានសំដៅដល់ពួកអ្នករស់នៅតាមបណ្ដោយឆ្នេរសមុទ្រមេឌីទែរ៉ាណេ ។

**៥:២** *ថ្មធ្វើជាកាំបិត* កាំបិតនេះជាលោហធាតុ ប៉ុន្តែកាំបិតធ្វើអំពីថ្មគេប្រើវាសម្រាប់ជាបរិក្ខារៈកាត់ ដូចដែលសម័យទំនើបបានប្រើប្រាស់ និងបង្ហាញ ។ ការកាត់ស្បែកធ្វើឡើងលើកូនប្រុសរបស់លោកអ័ប្រាហាំ (លប ១៧:១០–១១) ដែលពួកគេត្រូវតែធ្វើជាអ្នកបម្រើព្រះអម្ចាស់ ហើយការនេះជាតម្រូវការចំបាច់សម្រាប់បុណ្យរំលង (នក ១២:៤៨) ។

**៥:៦** *៤០ឆ្នាំ* នេះជារយៈពេលដែលពួកគេចាកចេញពីប្រទេសអេស៊ីព្ទ និងការឆ្លងកាត់ទន្លេយ័រដាន់ ។ ៣៨ឆ្នាំបានកន្លងផុតទៅ ក្នុងអំឡុងពេលដែលពួកគេត្រឡប់ទៅឯកាដេស (ជន ១៤:២០–២២ ចទ ២:១៤) ។ *ទឹកដោះនឹងទឹកឃ្មុំ* មើលការពន្យល់ នក ៣:៨ ចទ ៦:៨ ។

ហៀរ[ញ] ៧គឺជាពួកកូនចៅរបស់អ្នកទាំងនោះឯង ដែលទ្រង់
បានបង្កើតឡើងជំនួសគេ ហើយយ៉ូស្វេបានកាត់ស្បែកឱ្យ
ដ្បិតគេមិនទាន់កាត់ស្បែកនៅឡើយ ពីព្រោះមិនបានកាត់
ស្បែកអ្នកណាតាមផ្លូវសោះ ៨ដូច្នេះកាលគេបានកាត់ស្បែក
ប្រុសៗទាំងអស់រួចហើយ នោះក៏នៅនឹងកន្លែងគេ ក្នុង
ទីដំឡើងត្រសាលនោះដរាបដល់សះជា[ដ] ៩ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលនឹងយ៉ូស្វេថា នៅថ្ងៃនេះ អញបានប្រមៀល
សេចក្តីដំនៀលរបស់ស្រុកអេស៊ីព្ទពីឯងចេញ គឺហេតុនោះ
បានជាគេហៅឈ្មោះកន្លែងនោះថា គីលកាល[ឋ] ដរាបដល់
សព្វថ្ងៃនេះ ។
១០ពួកកូនចៅអ៊ីស្រាអែល គេដំឡើងត្រសាលនៅត្រង់
គីលកាលនោះ ហើយនាំគ្នាធ្វើបុណ្យរំលង[ឌ]នៅល្ងាចថ្ងៃ១៤
ខែនោះ[ឍ] ត្រង់វាលក្រុងយេរីខូរ ១១ក្រោយថ្ងៃបុណ្យរំលង
មក នៅថ្ងៃនោះឯង គេក៏បរិភោគផលរបស់ស្រុកនោះ[ណ]
គឺជានំឥតដំបែ[ត]និងគ្រាប់លីង[ថ] ១២រួចក្រោយដែលគេ
បរិភោគផលរបស់ស្រុកនោះ ដល់ថ្ងៃស្អែកឡើងលែងមាន
នំម៉ាន៉ាហើយ ពួកកូនចៅអ៊ីស្រាអែលមិនដែលមាននំម៉ាន៉ា
ទៀតឡើយ គឺក្នុងឆ្នាំនោះឯង គេបានបរិភោគផលរបស់
ស្រុកកាណានវិញ[ទ] ។

## ការដួលរលំនៃក្រុងយេរីខូរ

១៣រីឯក្នុងគ្រាដែលយ៉ូស្វេនៅជិតក្រុងយេរីខូរ នោះ
គាប់ជួនជាលោកងើបភ្នែកឡើង ឃើញមនុស្សម្នាក់[ធ]កំពុង
តែឈរនៅមុខលោក មានទាំងកាន់ដាវហូតជាស្រេច[ន]
លោកក៏ចូលទៅសួរថា តើលោកកាន់ខាងយើងខ្ញុំ ឬខាង
ពួកខ្មាំងសត្រូវ របស់យើងខ្ញុំ ១៤អ្នកនោះឆ្លើយតបថា ទេ
អញបានមកធ្វើជាកំពូល លើពួកពលផងព្រះយេហូវ៉ាវិញ
នោះយ៉ូស្វេក៏ទំលាក់ខ្លួនក្រាបផ្កាប់មុខ[ប]នឹងដី[ផ] ថ្វាយបង្គំសួរ
ថា តើព្រះអម្ចាស់ នៃទូលបង្គំ ចង់មានបន្ទូលដល់ទូលបង្គំ
ជាបាវបំរើទ្រង់ ថាដូចម្តេច ១៥អ្នកដែលជាកំពូលលើពួក
ពលផងព្រះយេហូវ៉ា ក៏ប្រាប់ថា ចូរដោះស្បែកជើងចេញ
ទៅ ដ្បិតកន្លែងដែលឈរនៅនោះ ជាកន្លែងបរិសុទ្ធ[ព] រួច
យ៉ូស្វេក៏ធ្វើតាមដូច្នោះ ។

**៦** ១រីឯទីក្រុងយេរីខូរ[ក] គេបានបិទទ្វារជាប់ទាំងប្រយ័ត្ន
ដោយខ្លាចពួកកូនចៅអ៊ីស្រាអែល ឥតមានអ្នកណាចេញ

**៥:៦** ញ នក ៣:៨
**៥:៨** ដ លប ៣៤:២៥
**៥:៩** ឋ ចទ ១១:៣០
**៥:១០** ឌ នក ១២:១១ ឍ នក ១២:៦
**៥:១១** ណ ជន ១៥:១៩ ត នក ១២:១៥ ថ លវ ២៣:១៤
**៥:១២** ទ នក ១៦:៣៥
**៥:១៣** ធ លប ១៨:២ ន ជន ២២:២៣
**៥:១៤** ប លប ១៧:៣ ផ លប ១៩:១
**៥:១៥** ព លប ២៨:១៧ នក ៣:៥ កច ៧:៣៣
**៦:១** ក យស ២៤:១១

**៥:៩** *ដំនៀលរបស់ស្រុកអេស៊ីព្ទ* ទោះបីខយោងប្រាប់ថា ពួកអ៊ីស្រាអែលជាប់ជាឈ្លើយរបស់ពួកអេស៊ីព្ទក៏ដោយ ប៉ុន្តែវាទំនងជាគំនិតរបស់អ្នកនិពន្ធចំពោះសេចក្តីដំនៀលរបស់ពួកអេស៊ីព្ទដែលថា ពួកគេនឹងព្រះរបស់ពួកគេត្រូវបាក់បែកគ្នានៅទីរហោស្ថាន (សូមមើល ៣២:១២ ជន ១៤:១៣ ចទ ៩:២៨) ។ ប៉ុន្តែដំណើរនៅវាលរហោស្ថាន បានចប់សព្វគ្រប់ហើយ ក៏មានសុវត្ថិភាពនៅក្នុងទឹកដីសន្យា ជារាស្ត្រសំខាន់របស់ទ្រង់ដែលបានលះបង់ដោយការកាត់ស្បែក ហើយសេចក្តីដំនៀលរបស់ពួកអេស៊ីព្ទនោះ បានផុតរលត់បាត់ទៅ ។

**៥:១០** *បុណ្យរំលង* បុណ្យនេះប្រារព្ធឡើងនៅក្នុងខែចេត្រ ជាខែទីមួយនៃឆ្នាំ (នក ១២:២) ។ នៅពេលថ្ងៃរៀបអស្តង្គត នៅថ្ងៃទី១៤ក្នុងខែបុណ្យរំលងនោះ កូនចៀមត្រូវបានគេសម្លាប់ រួចអាំងហើយគេបរិភោគនៅក្នុងយប់នេះតែម្តង (នក ១២:៥-៨) ។ ពួកអ៊ីស្រាអែល មិនបានប្រារព្ធពិធីនេះនៅអំឡុងដែលពួកគេនៅភ្នំស៊ីណាយ និង១ឆ្នាំក្រោយដែលពួកគេបានរំដោះខ្លួនចេញពីភាពជាទាសកររបស់ពួកអេស៊ីព្ទ (ជន ៩:១-៥) ។ សម័យក្រោយៗមកទៀត ពួកគេបានធ្វើសង្គ្រាមនឹងពួកកាណាននៅតាមព្រំដែន ហើយនិងការជម្លៀសកូនចៅពួកគេដែលបានកាត់ទោសនៅវាលរហោស្ថាន (មើល ជន ១៤:២១-២៣,២៩-៣៥) ។ ពួកកូនចៅទាំងនោះ គេប្រារព្ធពិធីបុណ្យរំលងនេះតិចតួចបំផុត ។

**៥:១១** *នំឥតដំបែ* នេះជានំប៉័ង ដែលគេដុតហើយគ្មានដំបែ ។ ហើយនំនេះត្រូវបានគេយកមកបរិភោគនៅថ្ងៃបុណ្យទាំងប្រាំពីក្រោយមកទៀត (នក ១២:១៥ លវ ២៣:៦) ។

**៥:១២** *លែងមាននំម៉ាន៉ា* គឺជាការឆ្លងផុតពីការបរិភោគនំម៉ាន៉ា ហើយទៅបរិភោគផលដែកើតពីដីវិញ (ខ.១១) ដែលបញ្ចប់នៅក្នុងរយៈពេល៤០ឆ្នាំដោយអាស្រ័យទៅលើការប្រទាននៃព្រះអម្ចាស់ជាពិសេសដល់ពួកគេ ។ នំម៉ាន៉ាជាអំណោយដ៏ពិសេសក្នុដំណើរនៅវាលរហោស្ថាន ប៉ុន្តែ ពីពេលនេះទៅពួកគេត្រូវបានព្រះអម្ចាស់ប្រទានម្ហូបអាហារតាមរយៈទឹកដីសន្យាវិញ ។

**៥:១៣-១៥** នៅវគ្គនេះជាការរៀបរាប់ពីការធ្វើសង្គ្រាមនៅក្រុងយេរីខូរ (៥:១៣-៦:២៧) ត្រូវបានចាប់ផ្តើមឡើងដោយពួកស្ថានសួគ៌ ដែលបានហៅខ្លួនគេថា"ពួកបញ្ជាការកងទ័ពព្រះអម្ចាស់" (៥:១៤) ។

**៥:១៣** *យ៉ូស្វេនៅជិតក្រុងយេរីខូរ* ឃ្លានេះពួកទាហានព្រះអម្ចាស់ បានចុះទៅត្រួតពិនិត្យមើលពីបន្ទាយរបស់ពួកកាណាន ប៉ុន្តែពួកអ្នកចម្បាំងផ្សេងទៀតបានរៀបចំជាស្រេចក្នុងឆាកចម្បាំង ។ *មនុស្សម្នាក់កំពុងតែឈរ* បទពិសោធនេះ ត្រូវបានប្រព្រឹត្តឡើងជាច្រើនដងក្នុងការជួបជាមួយព្រះក្នុងលក្ខណ:ជាមនុស្ស ឬជាមួយព្រះយេស៊ូវគ្រីស្ទ ។ ប៉ុន្តែពួកទេវតាត្រូវបានបញ្ជូនទៅនៅក្នុងបេសសកម្មនេះផងដែរ (ពច ៦:១១ ១៣:៣) ហើយពួកទេវតាខ្លះទៀត ជាមេកងបញ្ជាលើកងពលពួកពលបរិវារនៃស្ថានសួគ៌ (ដយ ១០:៥ ២០ ១២:១) ។

**៥:១៤** *អ្នកនោះ* ពាក្យនេះប្រាប់ថា លោកយ៉ូស្វេ និងពួកអ៊ីស្រាអែល ត្រូវតែដឹងពីទីកន្លែងរបស់ពួកគេ គឺមិនមែនព្រះអម្ចាស់នៅខាងពួកគេ ដូច្នេះពួកគេត្រូវតែចូលនៅក្នុងសមរភូមិរបស់ព្រះអម្ចាស់ ។

**៥:១៥** នៅត្រង់នេះលោកយ៉ូស្វេ ត្រូវបានប្រគល់អំណាចឱ្យក្រោមអំណាចរបស់ព្រះអម្ចាស់ក្នុងការធ្វើសង្គ្រាមនៅទឹកដីកាណាន ដូចជាលោកម៉ូសេត្រូវបានប្រគល់អំណាចឱ្យក្នុងការប្រឈមមុខនឹងស្តេចផារ៉ោន (នក ៣:៥) ។ *កន្លែងបរិសុទ្ធ* សូមមើល នក ៣:៥ និងការពន្យល់ ។

**៦:១** *យេរីខូរ* តាមកំណាយផ្នែកបុរាណវិទ្យា បានឱ្យដឹងថា ក្រុងយេរីខូរនេះប្រហែលជាកន្លែងដំបូងរបស់ពួកអ្នកស្រុកកាណាន (ជាទីដែលមនុស្សរស់

ចូលសោះឡើយ ២ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេ
ថា មើល អញបានប្រគល់[ខ]ក្រុងយេរីខូរ ព្រមទាំងស្តេចគេ
និងពួកមនុស្សខ្លាំងពូកែស្ទាត់ជំនាញទាំងប៉ុន្មាន មកក្នុង
កណ្តាប់ដៃឯងហើយ ៣ដូច្នេះត្រូវឱ្យឯងរាល់គ្នា ជាពួកថ្មើរ
ច្បាំង ដើរជុំវិញទីក្រុងអស់៦ថ្ងៃ ក្នុង១ថ្ងៃ១ជុំ ៤ត្រូវឱ្យមាន
សង្ឃ៧រូប កាន់ត្រែស្នែងចៀម[គ]ដើរនាំមុខហឹប រួចដល់ថ្ងៃ
ទី៧ នោះត្រូវឱ្យដើរព័ទ្ធទីក្រុងអស់៧ជុំថែមទៀត ហើយពួក
សង្ឃត្រូវផ្លុំត្រែឡើង[ឃ] ៥កាលណាគេផ្លុំស្នែងចៀម មាន
សំឡេងយ៉ាងវែង[ង] ឮដល់ឯងរាល់គ្នា នោះទាំងអស់គ្នាត្រូវ
ស្រែកឡើង ជាសំរែកយ៉ាងខ្លាំង[ច] ដូច្នេះកំផែងទីក្រុងនឹង
រលំដួលទៅ រួចត្រូវឱ្យបណ្តាជនទាំងអស់ឡើងចំទៅមុខ
រៀងខ្លួន ៦យ៉ូស្វេជាកូននុនក៏ហៅពួកសង្ឃមកប្រាប់ថា ចូរ
យកហឹបនៃសេចក្តីសញ្ញា ហើយឱ្យមានសង្ឃ៧រូបកាន់ត្រែ
ស្នែងចៀម ដើរនាំមុខហឹបនៃព្រះយេហូវ៉ាទៅ[ឆ] ៧លោកក៏
បង្គាប់ដល់ពួកបណ្តាជនថា ចូរនាំគ្នា[ជ]ដើរព័ទ្ធជុំវិញទីក្រុង
ទៅ ឯអស់ពួកអ្នកដែលមានគ្រឿងសស្ត្រាវុធ នោះត្រូវដើរ
នាំមុខហឹប[ឈ]នៃព្រះយេហូវ៉ា ។

៨លុះកាលយ៉ូស្វេបានប្រាប់ដល់ពួកជនរួចអស់ហើយ
នោះសង្ឃទាំង៧ ដែលកាន់ត្រែស្នែងចៀមទាំង៧ នៅ
ចំពោះព្រះយេហូវ៉ា ក៏ដើរទៅទាំងផ្លុំបណ្តើរ រួចហឹបនៃ
សេចក្តីសញ្ញាផងព្រះយេហូវ៉ាក៏តាមគេទៅ ៩ឯពួកដែល
កាន់គ្រឿងសស្ត្រាវុធ គេដើរខាងមុខពួកសង្ឃដែលផ្លុំត្រែ
ក៏មានពួកអ្នកដើរខាងក្រោយ[ញ]ហឹបដែរ ពួកសង្ឃដើរទៅ
ទាំងផ្លុំត្រែបណ្តើរ ១០ឯយ៉ូស្វេក៏បង្គាប់បណ្តាជនថា មិនត្រូវ
ឱ្យឯងរាល់គ្នាស្រែកឡើង ឬឱ្យមានឮសំឡេងឡើយ ក៏មិន
ត្រូវមានពាក្យណាមួយចេញពីមាត់ឯងដែរ ដរាបដល់ថ្ងៃ
ដែលអញប្រាប់ឱ្យស្រែកឡើង នោះទើបត្រូវឱ្យឯងស្រែក
ចុះ[ដ] ១១ដូច្នេះហឹបនៃព្រះយេហូវ៉ា ក៏បានព័ទ្ធជុំវិញទីក្រុង
អស់១ជុំ រួចគេត្រឡប់ចូលមកក្នុងទីដំឡើងត្រសាលវិញ
ហើយឈប់នៅទីនោះ ។

១២ឯយ៉ូស្វេលោកក្រោកឡើងពីព្រលឹម ហើយពួកសង្ឃ
ក៏នាំគ្នាសែងហឹបនៃព្រះយេហូវ៉ា ១៣មានទាំងពួកសង្ឃ៧
រូបនោះ កាន់ត្រែស្នែងចៀម៧ ដើរនាំមុខហឹបនៃព្រះយេ
ហូវ៉ា ទាំងផ្លុំត្រែបណ្តើរផង ឯពួកកាន់គ្រឿងសស្ត្រាវុធ គេ
ក៏ដើរពីខាងមុខ ហើយមានពួកអ្នកខាងក្រោយ ដើរតាម
ហឹបនៃព្រះយេហូវ៉ាដែរ ពួកសង្ឃក៏ដើរទៅទាំងផ្លុំត្រែ
បណ្តើរ ១៤ថ្ងៃទី២នោះ គេដើរជុំវិញទីក្រុង១ជុំ រួចក៏ត្រឡប់
មកក្នុងទីដំឡើងត្រសាលវិញ គេធ្វើយ៉ាងដូច្នេះអស់៦ថ្ងៃ ។

១៥លុះដល់ថ្ងៃទី៧ គេក្រោកឡើងពីព្រលឹម កាលទើប
នឹងភ្លឺស្រាង នោះក៏ដើរព័ទ្ធជុំវិញទីក្រុងបែបដដែលអស់៧
ជុំ ថ្ងៃនោះខុសពីថ្ងៃមុនតែប៉ុណ្ណោះ គឺគេដើរព័ទ្ធទីក្រុងអស់
៧ដងវិញ[ឋ] ១៦លុះបានគ្រប់៧ជុំហើយ កាលពួកសង្ឃបានផ្លុំ
ត្រែ នោះយ៉ូស្វេក៏ប្រាប់ដល់ពួកជនថា ចូរស្រែកឡើង ដ្បិត
ព្រះយេហូវ៉ាទ្រង់បានប្រគល់ទីក្រុងនេះមកឯងរាល់គ្នា
ហើយ[ឌ] ១៧ឯទីក្រុងនេះ ជាទីក្រុងសំរាប់តែបំផ្លាញអស់
រលីងថ្វាយ[ឍ]ព្រះយេហូវ៉ា ហើយនិងគ្រប់ទាំងអស់ដែលនៅ

**៦:២** ខ ខ.១៦ ចទ ៧:២៤ យស៨:១
**៦:៤** គ នក ១៩:១៣ ឃ លវ ២៥:៩
**៦:៥** ង នក ១៩:១៣ ច ខ.២០ ១សយ ៤:៥ ២សយ ៦:១៥ អរ ៣:១១ ១០:១២ ទដ ៤២:៤ ៩៥:១ អស ៨:៩ ៤២:១៣
**៦:៦** ឆ ខ.៤
**៦:៧** ជ នក ១៤:១៥ ឈ ជន ១០:៣៥ ១សយ ៤:៣ ៧:១
**៦:៩** ញ ខ.១៣ ជន ២:៣១ អស ៥២:១២
**៦:១០** ដ ខ.២០ ១សយ ៤:៥ អរ ៣:១១
**៦:១៥** ឋ ១ពវ ១៨:១៤ ២ពវ ៤:៣៥ ៥:១៤
**៦:១៦** ឌ ខ.២
**៦:១៧** ឍ ខ.២១ លវ ២៧:២៨ ចទ ២០:១៧ អស ១៣:៥ ២៤:១ ៣៤:២,៥ មឡ ៤:៦

នៅដោយការបរបាញ់សត្វ អស់រយៈពេលរាប់ពាន់ឆ្នាំ) ។ ការបោះជំរុំលើកដំបូងរាប់ចាប់ពីឆ្នាំ៧000 មុន គ.ស ។ នៅសម័យលោកយ៉ូស្វេ ទីក្រុងជាង២៤ ត្រូវបានកសាងឡើង និងត្រូវបានបំផ្លាញខ្លះទៅវិញ នៅកន្លែងខ្លះក្នុងរយៈពេល ៥000ឆ្នាំមុន គ.ស ។ ក្រុងទាំងអស់នោះ មានអំណាចខ្លាំងក្លាដោយមានជញ្ជាំង២ជាន់ ។ ក្រុងយេរីខូរនេះជាមជ្ឈមណ្ឌលនៃការថ្វាយបង្គំរូបព្រះច័ន្ទ (ក្រុងយេរីខូរ មានន័យថា"ក្រុងព្រះច័ន្ទ") ។ ប្រសិនបើដូច្នោះ ព្រះមិនត្រឹមតែបំផ្លាញក្រុងកាណានប៉ុណ្ណោះទេ តែថែមទាំងសាសនាពួកកាណានទៀតផងដែរ ។

**៦:២** *ព្រះយេហូវ៉ា* ព្រះរាជបញ្ជាព្រះយេហូវ៉ា ដោយគ្មានការសង្ស័យតាមរយៈ"ពួកពលបរិវារពួកទេវតា"(៥:១៤) ដែលពួកនេះដឹកនាំវាយចូលទឹកដីកាណានជាលើកដំបូង ។

**៦:៣** *ដើរជុំវិញទីក្រុងអស់៦ថ្ងៃ* នេះជាសកម្មភាពប្រពៃណី បង្ហាញពីការឡោមព័ទ្ធទីក្រុងទាំងមូល ដែលធ្វើឡើងក្នុងរវាង៦ថ្ងៃ ។

**៦:៤** *ត្រែស្នែងចៀម* ឧបករណ៍នេះមិនមែនជាតន្ត្រី ប៉ុន្តែជាសញ្ញាសម្គាល់វិញ នៅក្នុងបរិបទសាសនា និងទាហាន (ដែលកើតមាននៅក្នុងភារកិច្ចទាំងពីរនេះ) ។ ត្រែត្រូវបានគេផ្លុំនៅក្នុង (ខ.៨) ដូចដែលនៅថ្ងៃទីប្រាំពីរដែលប្រកាសពីវត្តមានរបស់ព្រះអម្ចាស់(មើល ២សយ ៦:១៥ ១រប ១៥:២៨ សក ៩:១៤) ។ *ហឹប* នេះបង្ហាញ អំពីការដែលឡោមព័ទ្ធជុំជិតទីក្រុងរបស់ព្រះអម្ចាស់ ។

**៦:៥** *សំលេងយ៉ាងវែង* នេះជាការចាប់ផ្តើមការវាយប្រហារ តាមផ្នែកចិត្តសាស្រ្ត ក្នុងគោលបំណងធ្វើឱ្យសត្រូវភ័យស្លន់ស្លោ និងច្របូកច្របល់(មើល ពច ៧) ។ នៅក្នុងក្រាំងសមុទ្រស្លាប់ "ចម្បាំងកូននៃពន្លឺ ប្រឆាំងនឹងកូននៃភាពងងឹត" នោះពួកលេវីត្រូវបានគេបង្រៀនឱ្យចេះផ្លុំត្រែព្រមគ្នា ដើម្បីឱ្យសត្រូវចុះចាញ់ហើយខ្លបខ្លាចពួកគេ ។ *បណ្តាជនទាំងអស់ឡើងចំទៅមុខ* នៅត្រង់នេះមិនមែនជាស្នាមប្រេះ ប៉ុន្តែជាការដួលរលំនៃជញ្ជាំងកំផែងដែលផ្តល់ឱ្យមានច្រកចូលជាច្រើននៅគ្រប់ជ្រុង ។

**៦:៧** *ពួកអ្នកដែលមានគ្រឿងសស្ត្រាវុធ* ឃ្លានេះក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យផ្សេងគ្នានឹង ខ.៣ ប៉ុន្តែប្រហែលជាសទិសន័យរបស់វាវិញ ។ នៅត្រង់នេះវាត្រូវបានគេរំពឹងថា ហឹបសញ្ញាបានដឹកនាំពីដំណើរការនេះ ។

**៦:៨–១៤** ឆ្លងតាមរយៈខនេះ ហឹបសញ្ញានៃព្រះអម្ចាស់ គឺបានបង្កើតឱ្យមានចំណុចរួមមួយ (ការទទួលខុសត្រូវ ក្នុងការឆ្លងទន្លេយ័រដាន់) ដើម្បីបំភ្លឺថាព្រះអម្ចាស់ទ្រង់បានឡោមព័ទ្ធទីក្រុង ។

**៦:១៧** នៅវគ្គនេះជាបម្រាមដែលដាក់លើពួកអ្នកស្រុកយេរីខូរ ឱ្យស្ថិតក្រោមបណ្តាសា សេចក្តីស្លាប់ និងទ្រព្យសម្បត្តិនៅក្នុងទីក្រុងទាំងមូលមិនត្រូវបំផ្លាញ

ក្នុងក្រុងនេះផង រស់នៅបានតែនាងរ៉ាហាប ជាស្រីសំផឹង
១[ណ] និងអស់អ្នកដែលនៅក្នុងផ្ទះជាមួយនឹងនាងប៉ុណ្ណោះ ពី
ព្រោះនាងបាននាំអ្នក២នាក់ ដែលយើងបានចាត់មក ទៅ
លាក់បំពួន[ត]ទុក ១៨ឯងរាល់គ្នាត្រូវប្រយ័ត្នតែនឹងរបស់
ដែលសំរាប់បំផ្លាញ[ថ] ក្រែងកាលណាឯងញែករបស់ណា
ទុកសំរាប់នឹងបំផ្លាញ នោះបែរទៅជាយករបស់ណាមួយ
នោះចេញវិញ ហើយដូច្នេះនឹងនាំឱ្យពួកអ៊ីស្រាអែលត្រូវ
បំផ្លាញទាំងអស់គ្នាដែរ[ទ] ព្រមទាំងមានសេចក្ដីវិករវ[ធ]ផង
១៩ប៉ុន្តែឯប្រាក់និងមាសទាំងប៉ុន្មាន ហើយអស់ទាំងប្រដាប់
ប្រដាធ្វើពីលង្ហិន[ន] និងដែក នោះជារបស់បរិសុទ្ធដល់ព្រះ
យេហូវ៉ា ត្រូវនាំយកទាំងអស់ ចូលមកក្នុងឃ្លាំងនៃព្រះយេ
ហូវ៉ាវិញ ២០ដូច្នេះពួកបណ្ដាជនក៏ស្រែកហ៊ោ ហើយពួក
សង្ឃក៏ផ្លុំត្រែឡើង[ប] គឺកាលពួកបណ្ដាជនបានឮសូរត្រែ
នោះគេស្រែកឡើង ជាសំរែកយ៉ាងខ្លាំង[ផ] ស្រាប់តែកំផែង
ក៏រលំដួលទៅ ដើម្បីឱ្យពួកបណ្ដាជនបានឡើងទៅក្នុងទី
ក្រុងចំមុខគេរៀងខ្លួន ហើយគេក៏ចាប់យកទីក្រុងនោះទៅ[ព]
២១គេបានបំផ្លាញ[ភ,ម]គ្រប់ទាំងអស់ ដែលមាននៅក្នុងក្រុង
នោះអស់រលីង គឺទាំងប្រុសហើយនិងស្រី ទាំងក្មេងហើយ
និងចាស់ផង ព្រមទាំងគោ និងចៀម ហើយនិងលាទាំង
អំបាលម៉ានដោយមុខដាវ ។
២២យ៉ូស្វេក៏ប្រាប់ដល់មនុស្ស២នាក់[យ] ដែលបានចូលទៅ
សង្កេតមើល[រ]ស្រុកនោះថា ចូរឱ្យឯងចូលទៅក្នុងផ្ទះស្រី
សំផឹងនោះ ហើយនាំនាង និងរបស់នាងទាំងប៉ុន្មានចេញ
មកក្រៅ ដូចជាឯងបានស្បថនឹងនាងហើយ[ល] ២៣ឯមនុស្ស
កំឡោះ២នាក់ ដែលបានចូលទៅសង្កេតមើលស្រុក ក៏ចូល
ទៅនាំនាងរ៉ាហាប ទាំងឪពុកម្ដាយនាង និងបងប្អូន ហើយ
និងរបស់នាងទាំងប៉ុន្មានចេញមក ព្រមទាំងញាតិសន្តាន
របស់នាងទាំងប៉ុន្មានផង[វ] ដាក់គេឱ្យនៅជាខាងក្រៅទី
ដំឡើងត្រសាល នៃពួកអ៊ីស្រាអែល ២៤រួចក៏ឆួលដុតទីក្រុង
នោះ[ស] និងរបស់នៅទីនោះទាំងអស់ទៅ បានទុកនៅតែ
ប្រាក់និងមាសទាំងប៉ុន្មាន ព្រមទាំងប្រដាប់លង្ហិន ហើយនិង
ដែកប៉ុណ្ណោះ[ហ] ដែលគេយកទៅដាក់ក្នុងឃ្លាំង នៃដំណាក់
ព្រះយេហូវ៉ា[ឡ] ២៥តែឯរ៉ាហាបជាស្រីសំផឹង[អ] និងពួកគ្រួ
ឪពុកនាង ហើយរបស់នាងទាំងប៉ុន្មាន នោះយ៉ូស្វេលោក
បានទុកឱ្យគង់នៅវិញ[ក] ហើយនាងក៏នៅក្នុងពួកអ៊ីស្រាអែល
ជាដរាបដល់សព្វថ្ងៃនេះ ដោយព្រោះនាងបានលាក់បំពួន
ពួកអ្នក ដែលយ៉ូស្វេបានចាត់ទៅសង្កេតមើលក្រុងយេរីខូរ[ខ]
នោះ ។
២៦នៅគ្រានោះ យ៉ូស្វេក៏ប្រកាស ជាពាក្យបណ្ដាសា[គ]ថា
អ្នកណាដែលចាប់ផ្ដើមសង់ក្រុងយេរីខូរនេះឡើងវិញ នោះ
នឹងត្រូវបណ្ដាសាហើយ[ឃ] កាលណាអ្នកនោះដាក់ឫសកំផែង
នោះកូនច្បងរបស់ខ្លួននឹងស្លាប់ទៅ ហើយកាលណាដាក់
ទ្វារចុះ នោះកូនពៅនឹងស្លាប់ទៅ[ង]។
២៧ព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងយ៉ូស្វេ[ច] ហើយក៏ល្បី
ឮឈ្មោះលោកសុសសាយ[ឆ] ពេញគ្រប់ក្នុងស្រុកនោះ ។

### អំពើបាបរបស់លោកអេកាន

**៧** ១ប៉ុន្តែពួកកូនចៅអ៊ីស្រាអែលបានប្រព្រឹត្តរំលងចំពោះ
របស់ដែលសំរាប់បំផ្លាញវិញ[ក] ដ្បិតមានអេកាន[ខ]ជាកូនកើមី
ដែលកើមីជាកូនសាប់ឌីៗជាកូនសេរ៉ាស[គ] ក្នុងពូជអំបូរ
យូដា[ឃ] គាត់បានយករបស់ខ្លះដែលត្រូវបំផ្លាញ ហើយសេច-
ក្ដីខ្ញាល់នៃព្រះយេហូវ៉ាក៏ឆួលឡើង[ង] ទាស់នឹងពួកកូនចៅ
អ៊ីស្រាអែល[ច]។

**៦:១៧** ណ យស ២:១ ត ខ.២៥,២៦ **៦:១៨** ថ យស ៧:១ ១រប ២:៧ ទ យស ៧:១២ ធ យស ៧:២៥,២៦ **៦:១៩** ន ខ.២៤ ជន ៣១:២២ **៦:២០** ប លវ ២៥:៩ ពច ៦:៣៤ ៧:២២ ១ពវ ១:៤១ អស ១៨:៣ ២៧:១៣ យរ ៤:២១ ៤២:១៤ អម ២:២ ផ ខ.៥,១០ ព ហព ១១:៣០ **៦:២១** ភ ខ.១៧ ម ចទ ២០:១៦ **៦:២២** យ លប ៤២:៩ យស ២:៤ រ ជន ២១:៣២ ល យស ២:១៤ ហព ១១:៣១ **៦:២៣** វ យស ២:១៣ **៦:២៤** ស ជន ៣១:១០ ហ ខ.១៩ ឡ ចទ ១៣:១៦ **៦:២៥** អ យស ២:១ ក ពច ១:២៥ ខ ខ.១៧ យស ២:៦ **៦:២៦** គ ១សយ ១៤:២៤ ឃ ជន ៥:២១ ង ១ពវ ១៦:៣៤ **៦:២៧** ច លប ៣៩:២ ជន ១៤:៤៣ ឆ យស ៩:១ ១រប ១៤:១៧ **៧:១** ក យស ៦:១៨ ខ ខ.២៦ ១រប ២:៧ គ យស ២២:២០ ឃ ខ.១៨ ជន ១:៤ ង នក ៤:១៤ ៣២:២០

(ខ.១៩)។ ដោយយោងទៅលើក្រឹត្យវិន័យលោកម៉ូសេ ការហាមប្រាមនេះគឺឆ្លើយតបទៅនឹងសត្វពាហនៈ ឬរបស់មានតម្លៃដែលសល់ពីមនុស្សដែលស្លាប់ទៅ សម្រាប់ថ្វាយជាយញ្ញបូជាដល់ព្រះអម្ចាស់ (លវ ២៧:២៨–២៩)។ អស់អ្នកដែលរស់នៅក្នុងទឹកដីកាណាន ត្រូវទទួលទោសប្រហារជីវិត ដោយសារពួកគេបានថ្វាយបង្គំរូបព្រះ និងសេចក្ដីពុករលួយខាងសីលធម៌ដទៃទៀតដែលកើតពីការថ្វាយបង្គំនោះ(ចទ ២០:១៦–១៨ និងការពន្យល់ ចទ ២:៣៤)។ *នាងរ៉ាហាប . . . ក្នុងផ្ទះ ជាមួយ* ឃ្លានេះបញ្ជាក់ពីការគោរពតាមសេចក្ដីសន្យាចំពោះនាងរ៉ាហាប(២:១៤)។

**៦:២៥** *នាងក៏នៅក្នុងពួកអ៊ីស្រាអែល* ឃ្លានេះបានប្រាប់ពីសេចក្ដីជំនឿរបស់នាងរ៉ាហាបដែលមានចំនួនពីរដងនៅក្នុងសញ្ញាថ្មី(សូមមើល ហព ១១:៣១ យក ២:២៥) ។

**៦:២៦** នេះជាបណ្ដាសាដែលបានសម្រេចនៅក្នុង ១ពវ ១៦:៣៤ ពេលដែលពួកគេសង់ក្រុងយេរីខូរឡើងវិញ ហើយជាលទ្ធផលពួកគេបានបាត់បង់កូនច្បង និងកូនពៅរបស់ពួកគេ ។

**៧:១–២៦** នៅវគ្គនេះទុក្ខភ័យរបស់លោកអេកាន ដែលផ្ទុយគ្នាយ៉ាងខ្លាំងទៅនឹងរឿងរ៉ាវរបស់នាងរ៉ាហាប ។ ដោយព្រោះនាងរ៉ាហាប មានសេចក្ដីក្លាហាន និងស្វាមីភ័ក្ដិ ចំពោះពួកអ៊ីស្រាអែល និងការទទួលស្គាល់ព្រះរបស់នាង នោះធ្វើឱ្យនាងរួចជីវិត ហើយទទួលបានសិទ្ធិជារាស្ត្រអ៊ីស្រាអែល ។ នាងបានលះចោលពួកកាណាន និងព្រះរបស់ពួកគេ ដោយព្រោះតែព្រះអម្ចាស់ និងពួកអ៊ីស្រាអែល ដូច្នេះហើយនាងក៏ត្រឡប់ទៅឯពួកកាណានផងដែរ ។ នៅក្នុងព្រឹត្តិការណ៍បច្ចុប្បន្នរបស់ពួកអ៊ីស្រាអែល(សាសន៍យូដា) ដោយព្រោះភាពមិនស្មោះត្រង់របស់លោកអេកាន ចំពោះព្រះអម្ចាស់ និងពួកអ៊ីស្រាអែល នោះគាត់ត្រូវបានកាត់ទោសប្រហារជីវិតដូចពួកកាណានអញ្ចឹងដែរ ។ លោកអេកាន បានលួចទ្រព្យសម្បត្តិរបស់ព្រះអម្ចាស់ នៅក្នុងទឹកដីកាណាន ហើយដូច្នោះហើយគាត់បាត់បង់នូវមរដកនៅក្នុងទឹកដីសន្យានេះ ។ រឿងរ៉ាវនេះ ជារបៀបមួយដែលអំពើបាបរបស់មនុស្សម្នាក់បាន

២ឯយ៉ូស្វេលោកចាត់មនុស្សពីក្រុងយេរីខូរ ទៅឯក្រុង
អៃយ[ឆ] ដែលនៅជិតបេត-អាវេន[ជ] នៅខាងកើតបេត-
អៃល[ឈ] ដោយពាក្យថា ចូរឡើងទៅសង្កេតមើល[ញ]ស្រុក
នោះ គេក៏ឡើងទៅសង្កេតមើលក្រុងអៃយ ៣រួចត្រឡប់មក
ឯយ៉ូស្វេជំរាបថា មិនចាំបាច់ឱ្យឡើងទៅទាំងអស់គ្នាទេ
សូមឡើងទៅតែមនុស្ស២ឬ៣ពាន់នាក់ប៉ុណ្ណោះ ដើម្បី
នឹងវាយក្រុងអៃយនោះបានហើយ សូមកុំឱ្យបង់កំឡាំងទាំង
អស់គ្នានឹងឡើងទៅឡើយ ដ្បិតគេមានគ្នាតិចទេ ៤ដូច្នេះ
ក៏មានប្រហែលជា៣ពាន់នាក់នាំគ្នាឡើងទៅ តែគេត្រូវរត់
ពីមុខពួកក្រុងអៃយវិញ[ដ] ៥ហើយពួកក្រុងអៃយក៏សំឡាប់អស់
ប្រហែលជា៣៦នាក់[ឋ] គេដេញពួកអ៊ីស្រាអែលពីមុខទ្វារ
ក្រុងទៅ រហូតដល់សេបារិម ទាំងប្រហាររអ្នកទាំងនោះនៅ
ត្រង់ផ្លូវចុះ ដូច្នេះពួកជនទាំងឡាយ ក៏មានចិត្តរលាយ[ឌ]ទៅ
ដូចជាទឹក ។

៦ឯយ៉ូស្វេលោកហែកសំលៀកបំពាក់[ឍ] ហើយទំលាក់
ខ្លួនក្រាបផ្កាប់មុខ[ណ]នឹងដីនៅចំពោះហឹបនៃព្រះយេហូវ៉ា
ទាល់តែល្ងាច[ត] ព្រមទាំងពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែល
ផង[ថ] គេក៏ដាក់ធូលីដី[ទ]នៅលើក្បាលរៀងខ្លួនដែរ ៧រួច
យ៉ូស្វេទូលថា ដល់ហើយ ឱព្រះយេហូវ៉ាជាព្រះអម្ចាស់
អើយ ហេតុអ្វី[ធ]បានជាទ្រង់បាននាំពួកបណ្តាជននេះ ឆ្លង
ទន្លេយ័រដាន់មកដើម្បីនឹងប្រគល់យើងរាល់គ្នា ទៅក្នុង
កណ្តាប់ដៃសាសន៍អាម៉ូរី ឱ្យត្រូវវិនាសដូច្នេះ[ន] គួរតែឱ្យ
យើងរាល់គ្នាបានសុខចិត្ត នៅខាងនាយទន្លេយ័រដាន់វិញ
ជាជាង ៨ឱព្រះអម្ចាស់អើយ ដែលពួកអ៊ីស្រាអែលបែរ
ខ្នងរត់នៅមុខពួកខ្មាំងសត្រូវយ៉ាងនេះ តើត្រូវឱ្យទូលបង្គំថា
ដូចម្តេចវិញ ៩ដ្បិតពួកសាសន៍កាណាន និងមនុស្សនៅស្រុក
នេះទាំងប៉ុន្មានគេនឹងឮ ហើយនិងព័ទ្ធយើងរាល់គ្នាជុំវិញ
រួចគេនឹងកាត់ឈ្មោះយើងរាល់គ្នាពីផែនដីចេញ[ប] នោះ
តើទ្រង់នឹងធ្វើដូចម្តេច សំរាប់ព្រះនាមទ្រង់ដ៏ជាធំ[ផ]។

១០ព្រះយេហូវ៉ាទ្រង់មានបន្ទូលឆ្លើយនឹងយ៉ូស្វេថា ចូរ
ក្រោកឡើង ម្តេចក៏ទំលាក់ខ្លួនក្រាបផ្កាប់មុខដូច្នេះ ១១ពួក
អ៊ីស្រាអែលបានធ្វើបាប[ព]គេបានប្រព្រឹត្តរំលងសេចក្តីសញ្ញា
អញ[ភ] ដែលបានបង្គាប់ដល់គេហើយ គេបានទាំងយករបស់
ដែលញែកទុកសំរាប់នឹងបំផ្លាញទៅ គឺគេបានលួច ហើយ
ក៏កុហកដែរ[ម] ព្រមទាំងយករបស់នោះ ទៅទុកជាមួយនឹង
អីវ៉ាន់របស់គេផង[យ] ១២ដោយហេតុនោះ បានជាពួកកូនចៅ
អ៊ីស្រាអែល ពុំអាចនឹងឈរនៅមុខពួកខ្មាំងសត្រូវគេបាន
ឡើយ[រ] ដែលគេបែរខ្នង[ល,វ]នៅមុខពួកខ្មាំងសត្រូវនោះគឺពី
ព្រោះគេបានត្រឡប់ទៅជាត្រូវបំផ្លាញដែរ[ស] បើឯងរាល់
គ្នាមិនបំផ្លាញរបស់ ដែលសំរាប់បំផ្លាញពីពួកឯងចេញទេ
នោះអញមិននៅជាមួយនឹងឯងរាល់គ្នាទៀតឡើយ[ហ] ១៣ចូរ
ក្រោកឡើងញែកពួកជនចេញជាបរិសុទ្ធចុះ[ឡ] ហើយប្រាប់

**៧:២** ឆ លប ១២:៨ យស ៨:១,២៨ ជ យស ១៨:១២ ១សយ ១៣:៥ ១៤:២៣ ហស ៤:១៥ ៥:៨ ១០:៥ ឈ លប ១២:៨ យស ១២:១៦ ១៦:១ ពច ១:២២ ១សយ ៣០:២៧ ២ពវ ២៣:១៥ យរ ៤៨:១៣ អម ៣:១៤ ៤:៤ ៥:៥-៦ ៧:១០,១៣ ញ ជន ២១:៣២ **៧:៤** ដ លប ២៦:១៧ ចទ ២៨:២៥ **៧:៥** ឋ យស ២២:២០ ឌ លប ៤២:២៨ ទដ ២២:១៤ អស ១៣:៧ អគ ២១:៧ ណហ ២:១០ **៧:៦** ឍ លប ៣៧:២៩ ណ លប ១៧:៣ ១រប ២១:១៦ អគ ៩:៨ ត ពច ២០:២៣ ថ យស ៨:១០ ៩:១១ ២០:៤ ២៣:២ ទ ១សយ ៤:១២ ២សយ ១៣:១៩ ១៥:៣២ នហ ៩:១ យប ២:១២ បទ ២:១០ អគ ២៧:៣០ វវ ១៨:១៩ **៧:៧** ធ ១សយ ៤:៣ ន នក ៥:២២ ជន ១៤:១៦ **៧:៩** ប នក ៣២:១២ ចទ ៩:២៨ ផ ចទ ២៨:៥៨ ១សយ ១២:២២ ទដ ៤៨:១០ ១០៦:៨ យរ ១៤:២១ **៧:១១** ព នក ៩:២៧ ចទ ២៩:២៧ យស ២៤:១៦-២៧ ២ពវ ១៧:៧ ហស ១០:៩ ភ ខ.១៥ យស ៦:១៧-១៩ ២៣:១៦ ពច ២:២០ ១សយ ១៥:២៤ ទដ ៧៨:១០ ម កច ៥:១-២ យ ខ.២១ **៧:១២** រ លវ ២៦:៣៧ ល ទដ ១៨:៤០ ២១:១២ វ លវ ២៦:១៧ ស យស ៦:១៨ ហ ទដ ៨៤:៩ ៦០:១០ **៧:១៣** ឡ លវ ១១:៤៤

ធ្វើឱ្យប្រជាជាតិទាំងមូលធ្លាក់ចូលក្នុងសេចក្តីវេទនា ។ តាមរយៈការរៀបរាប់ខាងលើនេះ (គម្ពីរសញ្ញាចាស់) ពួកអ៊ីស្រាអែលត្រូវបានគេចាត់ទុកថាបានចុះចូលជាមួយនឹងសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ។

**៧:២** *ក្រុងយេរីខូរ ទៅឯក្រុងអៃយ* ក្រុងនេះមានចម្ងាយ ២៤ គ.ម ដោយឆ្លងកាត់ជ្រលងភ្នំរហូតដល់ទីដ៏ខ្ពស់នៃទឹកដីកាណាន ។ ជាយុទ្ធសាស្ត្រក្នុងដំណើរឆ្ពោះទៅមុខដោយចាប់ពីគីលកាលទៅក្រុងអៃយ នោះបាននាំពួកអ៊ីស្រាអែលឆ្លងទន្លេយ័រដាន់ និងផ្តល់ឱ្យពួកគេនូវទិសដៅដែលបានគ្រោងទុកនៅទឹកដីដ៏ខ្ពស់ ។ ពាក្យអៃយ ជាភាសាហេព្រើរមានន័យថា "បំផ្លាញ"។

**៧:៦** *យ៉ូស្វេលោកហែកសំលៀកបំពាក់* នៅត្រង់នេះជាសញ្ញានៃសេចក្តីវេទនា (សូមមើល លប ៣៧:៣៤ និងការពន្យល់ ៤៤:៣ ពច ១១:៣៥) ។ សេចក្តីស្រងាកចិត្តរបស់លោកយ៉ូស្វេ (ដូចនឹងពួកបណ្តាជន) ដូចបានបញ្ជាក់ក្នុងការអធិស្ឋានរបស់គាត់ ដែលបានកើតឡើងពីការទទួលស្គាល់របស់គាត់ដែលថា ព្រះអម្ចាស់មិនបាននៅជាមួយពួកទាហានអ៊ីស្រាអែលនៅក្នុងសមរភូមិ ។ ប្រសិនបើគ្មានព្រះអម្ចាស់ នោះដំណើរផ្សងព្រេងរបស់ពួកអ៊ីស្រាអែលក្នុងការឆ្លងទន្លេយ័រដាន់ នោះពិតជាមិនអាចទៅរួចទេ ។ លើសពីនេះទៀត ពួកកាណាននឹងត្រូវកាត់ទោស ដែលពួកអ៊ីស្រាអែលនិងព្រះរបស់ពួកគេនឹងមិនដែលបរាជ័យឡើយ ។ *ដាក់ធូលីដីនៅលើក្បាលរៀងខ្លួន* សូមមើល យប ២:១២ បទ ២:១០ និងការពន្យល់ ។

**៧:៩** *សំរាប់ព្រះនាមទ្រង់ដ៏ជាធំ* នៅត្រង់នេះជាការប្តឹងរបស់លោកយ៉ូស្វេ ដូចដែលលោកម៉ូសេបានធ្វើក្នុង (ជន ១៤:១៣ ចទ ៩:២៨-២៩) ថាសេចក្តីខ្ពង់ខ្ពស់របស់ព្រះ មាននៅក្នុងភ្នែកនៅគ្រប់ពិភពលោកទាំងមូល ដែលបានបោះភ្ជាប់ចំពោះរាស្ត្ររបស់ទ្រង់ ។

**៧:១១** *អ៊ីស្រាអែលបានធ្វើបាប* នៅត្រង់នេះបញ្ជាក់ថាទាហានដែលជាចោរតែម្នាក់ដែលលួចសម្ភារៈសម្រាប់ថ្វាយដល់ព្រះអម្ចាស់ បានធ្វើឱ្យពួកអ៊ីស្រាអែល ទាំងមូលធ្លាក់ចូលក្នុងអំពើបាប (សូមមើល ២២:២០) ។ *ប្រព្រឹត្តរំលងសេចក្តីសញ្ញាអញ* សូមមើល ខ.១៥ ។ ឃ្លានេះជាការចោទប្រកាន់យ៉ាងចំបង គឺដូចនឹងអ្វីដែលមានថែងនៅក្នុងខនេះស្រាប់ ។

**៧:១២** *របស់ដែលសំរាប់បំផ្លាញ* សូមមើលការពន្យល់ ៦:១៨ ។

**៧:១៣** *ញែកខ្លួនចេញជាបរិសុទ្ធ* នេះជារបៀបនៃការសម្អាតខ្លួន ដែលត្រូវធ្វើឡើងដោយពួកអ៊ីស្រាអែល នៅក្នុងការជួបប្រជុំថ្វាយបង្គំព្រះអម្ចាស់ ។ ដូចដែលនៅមុនពេលបុណ្យប្រជុំមុតមាំ ឬក៏ការជួបជុំជាពិសេសដែលទ្រង់ហៅពួកគេឱ្យចូលមក (មើលការពន្យល់ ៣:៥) ។ នៅត្រង់នេះផងដែរ

គេថា ចូរឱ្យឯងរាល់គ្នាញែកខ្លួនចេញជាបរិសុទ្ធ ឱ្យទាន់
ពេលថ្ងៃស្អែក ដ្បិតព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រា
អែល ទ្រង់មានបន្ទូលថា ពួកអ៊ីស្រាអែលអើយ មានរបស់
ដែលសំរាប់បំផ្លាញនៅក្នុងពួកឯង ហើយឯងពុំអាចនឹង
ឈរនៅមុខពួកខ្មាំងសត្រូវបានឡើយ ទាល់តែបានដក
របស់ដែលសំរាប់បំផ្លាញនោះ ពីពួកឯងចេញ ១៤ដូច្នេះ
ដល់ព្រឹកឡើង ត្រូវឱ្យឯងរាល់គ្នាចូលមក[អ]តាមពូជអំបូរ
របស់ឯង នោះពូជអំបូរណា ដែលព្រះយេហូវ៉ាទ្រង់រើស
យក[ក] និងត្រូវមកតាមគ្រួគេ ហើយគ្រួណាដែលព្រះយេហូ
វ៉ា ទ្រង់រើសយក នោះត្រូវមកតាមពួកគេ ហើយពួកណា
ដែលព្រះយេហូវ៉ាទ្រង់រើសយក នោះត្រូវមកម្នាក់ម្តងៗ
១៥ឯអ្នកណាដែលត្រូវចាប់ ដោយព្រោះបានយករបស់
ដែលសំរាប់បំផ្លាញ[ខ] នោះនឹងត្រូវដុតទៅក្នុងភ្លើង[គ]ព្រម
ទាំងសព្វសារពើរបស់អ្នកនោះផង[ឃ] ពីព្រោះបានប្រព្រឹត្ត
រំលង នឹងសេចក្តីសញ្ញា[ង]នៃព្រះយេហូវ៉ា ហើយបានធ្វើ
ការចំកួតក្នុងពួកអ៊ីស្រាអែល[ច] ។
១៦យ៉ូស្វេក៏ក្រោកពីព្រលឹម នាំពួកអ៊ីស្រាអែលមក តាម
ពូជអំបូរគេ នោះក៏ជាប់ខាងពូជអំបូរយូដា ១៧រួចលោក
ឱ្យគ្រួយូដាទាំងប៉ុន្មានចូលមក ហើយលោកចាប់យកគ្រួ
សេរ៉ាស លោកក៏ឱ្យគ្រួសេរ៉ាស[ឆ]ចូលមកម្នាក់ម្តងៗ នោះ
ជាប់សាប់ឌី ១៨ហើយលោកឱ្យ[ជ]ពួកសាប់ឌីចូលមកម្នាក់
ម្តងៗ នោះជាប់អេកានជាកូនកើមី ដែលកើមីជាកូនសាប់ឌី
ៗជាកូនសេរ៉ាស ក្នុងពូជអំបូរយូដា[ឈ] ១៩យ៉ូស្វេក៏និយាយនឹង
អេកានថា កូនអើយ ចូរសរសើរ[ញ]ដល់ព្រះយេហូវ៉ា ជា
ព្រះនៃសាសន៍អ៊ីស្រាអែល ហើយលន់តួនឹងទ្រង់ទៅ ចូរ
ប្រាប់[ដ]អញពីការដែលឯងបានធ្វើ កុំឱ្យលាក់នឹងអញឡើយ
២០នោះអេកានក៏ឆ្លើយជំរាបយ៉ូស្វេថា ខ្ញុំបានធ្វើបាបនឹងព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលពិតមែន គឺខ្ញុំបានធ្វើ
ការយ៉ាងនេះមួយៗ ២១ដ្បិតខ្ញុំបានឃើញអាវ១យ៉ាងល្អពី
ស្រុកស៊ីណើរ និងប្រាក់២រយរៀលហើយមាស១ដុល ទំងន់
៥០ដំឡឹងនៅក្នុងរបឹប[ឋ] នោះខ្ញុំកើតមានចិត្តលោភចង់បាន
រួចក៏យក[ឌ]ទៅ មើល របស់ទាំងនោះបានកប់នៅក្នុងដី
នាកណ្តាលត្រសាលរបស់ខ្ញុំ ឯប្រាក់នៅជាខាងក្រោម ។
២២ដូច្នេះយ៉ូស្វេចាត់មនុស្សឱ្យទៅ ហើយគេរត់ទៅឯ
ត្រសាលនោះ ឃើញមានរបស់ទាំងនោះកប់ នៅក្នុង
ត្រសាល ហើយប្រាក់ក៏នៅពីក្រោមមែន ២៣រួចគេនាំយក
ពីកណ្តាលត្រសាល ទៅជូនដល់យ៉ូស្វេ និងពួកកូនចៅអ៊ី
ស្រាអែលទាំងអស់ ដាក់នៅចំពោះព្រះយេហូវ៉ា ២៤នោះ
យ៉ូស្វេ និងពួកអ៊ីស្រាអែលទាំងអស់គ្នា ក៏យកអេកាន ជាកូន
សេរ៉ាស និងប្រាក់ អាវ ហើយនិងមាស១ដុលនោះ ព្រម
ទាំងកូនប្រុស[ឍ]កូនស្រី គោ លា ចៀម និងត្រសាល
ហើយរបស់គាត់ទាំងអស់ នាំឡើងទៅដល់ច្រកភ្នំអាគ័រ[ណ]
២៥ហើយយ៉ូស្វេមានប្រសាសន៍ថា ហេតុអ្វីបានជាឯងធ្វើឱ្យ
យើងមានសេចក្តីវេទនាដូច្នេះ[ត] នៅថ្ងៃនេះព្រះយេហូវ៉ា
នឹងធ្វើឱ្យឯងវេទនាវិញ នោះពួកអ៊ីស្រាអែលទាំងអស់គ្នាក៏
ចោលនឹងថ្ម[ថ] ហើយដុតទាំងអស់ក្នុងភ្លើង[ទ] ព្រមទាំងចោល
នឹងថ្មផង ២៦គេដាក់ថ្មបង្គរ[ធ]ឡើងជាគំនរយ៉ាងធំនៅពីលើ

**៧:១៤** អ ១សយ ១០:១៩ ក សភ ១៦:៣៣ **៧:១៥** ខ យស ៦:១៨ គ ចទ ៧:២៥ ២ពវ ២៥:៩ ១របា ១៤:១២ អស ៣៧:១៩ យរ ៤៣:១២ អគ ៣០:១៦ ឃ ១សយ ១៤:៣៩ ង ខ.១១ ច លប ៣៤:៧ **៧:១៧** ឆ ជន ២៦:២០ **៧:១៨** ជ យហ ១:៧ ឈ ខ.១ លវ ២៤:១១ **៧:១៩** ញ នក ១៤:១៧ ១សយ ៦:៥ ទដ ៩៦:៨ អស ៤២:១២ យរ ១៣:១៦ យហ ៩:២៤ ដ លវ ៥:៥ ១សយ ១៤:៤៣ **៧:២១** ឋ លប ៣៤:២៩ ៤៩:២៧ ឌ ចទ ៧:២៥ អភ ៥:៥ ១ធថ ៦:១០ **៧:២៤** ឍ ជន ១៦:២៧ ណ ខ.២៦ យហ ១៥:៧ អស ៦៥:១០ ហស ២:១៥ **៧:២៥** ត យស ៦:១៨ ថ លវ ២០:២ ចទ ១៧:៥ ១ពវ ១២:១៨ ២របា ១០:១៨ ២៤:២១ នហ ៩:២៦ ទ លប ៣៨:២៤ **៧:២៦** ធ ២សយ ១៨:១៧

ក៏ជាការកោះហៅរបស់ព្រះមុនពេលទ្រង់ធ្វើការជំនុំជម្រះពួកគេដែរ ។

**៧:១៤** *ពូជអំបូរណា ដែលព្រះយេហូវ៉ាទ្រង់រើសយក* នៅត្រង់នេះបង្ហាញពីអំបូរច្រើនដែលព្រះទ្រង់លះចោល ហើយព្រះទ្រង់ជ្រើសយកអំបូរមួយក្នុងចំណោមអំបូរទាំងនោះ ូច្នេះហើយការស្វែងរកនេះ គឺមានភាពតូច ង្អៀតរហូតដល់ព្រះទ្រង់បង្ហាញពីទោសកំហុសរបស់ពួកគេ ។ ពួកអំបូរជាច្រើននោះបានចូលមក ដូចជាយូរីម និងធូមីម ចេញពីអេផូឌនៃពួកសម្តេចសង្ឃ (ការពន្យល់ នក ២៨:៣០ ១សយ ២:២៨ និងការពន្យល់ ១សយ ១៤:៤១) ។

**៧:១៥** *ធ្វើការចំកួតក្នុងពួកអ៊ីស្រាអែល* សេចក្តីកើតមានឡើងចំពោះពួកអ៊ីស្រាអែល ក្នុងនាមជារាស្ត្ររបស់ផងព្រះ គឺពួកគេបានប្រមាថដោយបន្ទឹសម្លេងបែបឆ្កួតលីលា (សូមមើល ចទ ២២:២១ ពច ១៩:២៣–២៤ និងការពន្យល់ ២០:៦,១០ ២សយ ១៣:១២) ។

**៧:១៩** *កូនអើយ* ពាក្យនេះលោកយ៉ូស្វេប្រើក្នុងលក្ខណៈជាឪពុក សំដៅដល់អេកាន ។ *ចូរសរសើរដល់ព្រះយេហូវ៉ា* មើលការពន្យល់សេចក្តីផ្តើម ។

**៧:២១** *អាវ១យ៉ាងល្អពីស្រុកស៊ីណើរ* នេះជាវត្ថុមានតម្លៃដែលនាំចូលមកក្នុងស្រុកនេះ ។

**៧:២៣** *ដាក់នៅចំពោះព្រះយេហូវ៉ា* ពាក្យនេះសំដៅដល់ការបែងចែកទ្រព្យសម្បត្តិទាំងអស់ខាងលើ ។

**៧:២៤** *យ៉ូស្វេ និងពួកអ៊ីស្រាអែលទាំងអស់* នៅត្រង់នេះលោកយ៉ូស្វេ និងពួកអ៊ីស្រាអែលទាំងអស់ជាភ្នាក់ងារក្នុងការជំនុំជម្រះពួកកាណាន និងពួកអ្នកដែលប្រព្រឹត្តរំលងសេចក្តីសញ្ញារបស់ព្រះ ។ *របស់គាត់ទាំងអស់* ក្នុងនាមជាមេគ្រួសារ លោកអេកានបានចូលរួម និងនាំយករបស់ដែលគាត់មានទៅធ្វើការជំនុំជម្រះ ។ ការទាំងអស់នេះត្រូវប្រព្រឹត្តឡើងជាគោលការណ៍សាមគ្គីភាព គឺសហគមន៍ទាំងមូលត្រូវមានសមាជិកអ្នកតំណាង (ពិសេសប្រមុខអ្នកដឹកនាំ សហគមន៍នោះតែម្តង) ។

**៧:២៥** *ចោលនឹងថ្ម* ដោយព្រោះតែពួកគេត្រូវបានគេរកឃើញថា ពួកគេជាប់មានទោសដែលបានប្រព្រឹត្តរំលងសេចក្តីសញ្ញារបស់ព្រះដ៏បរិសុទ្ធនោះ (មើល នក ១៩:១៣ លវ ២៤:២៣ ជន ១៥:៣៦) ។ ហើយក្រោយមកទៀតរាង្គកាយទាំងមូលត្រូវបានដុត ដើម្បីសម្អាតដែនដីដែលជាប់មានបាប ។

ដែលនៅដរាបដល់សព្វថ្ងៃនេះ[ន] នោះព្រះយេហូវ៉ា ទ្រង់ក៏
រសាយសេចក្ដីខ្ញាល់ក្តៅទៅ[ប] គឺហេតុនោះបានជាគេហៅ
កន្លែងនោះថា ច្រកភ្នំអាគ័រ[ផ] ដរាបមកដល់សព្វថ្ងៃនេះ ។

## ការបំផ្លាញក្រុងអៃយ

**៨** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេថា កុំឱ្យខ្លាច
ឡើយ[ក] ក៏កុំឱ្យស្រយុតចិត្តដែរ[ខ] ចូរក្រោកឡើង នាំយកពួក
ដែលថ្នឹកច្បាំងទាំងអស់[គ] ទៅជាមួយនឹងឯង ឡើងទៅឯក្រុង
អៃយ[ឃ]ចុះ មើល អញបានប្រគល់[ង]ស្តេចក្រុងអៃយព្រមទាំង
ពួករាស្ត្រ និងទីក្រុង ហើយនិងស្រុករបស់ស្តេចនោះ មក
ក្នុងកណ្តាប់ដៃឯងហើយ ២ដូច្នេះត្រូវឱ្យធ្វើនឹងក្រុងអៃយ
ហើយនិងស្តេចផង ដូចជាបានធ្វើនឹងយេរីខូរ ហើយនិង
ស្តេចគេដែរ ចូរយក[ច]តែរបស់ទាំងប៉ុន្មាន និងហ្វូងសត្វទុក
សំរាប់ជារបឹប ដល់ខ្លួនឯងរាល់គ្នាប៉ុណ្ណោះ[ឆ] ត្រូវឱ្យឯង
បង្កប់ទ័ព[ជ]នៅខាងក្រោយទីក្រុងវិញ ។

៣ដូច្នេះយ៉ូស្វេ និងពួកដែលថ្នឹកច្បាំងទាំងអស់គ្នា ក៏ប្រុង
ប្រៀបរៀបនឹងឡើងទៅឯក្រុងអៃយ លោករើសយកសុទ្ធ
តែមនុស្សខ្លាំងពូកែស្ទាត់ជំនាញ បានចំនួន៣ម៉ឺននាក់ ចាត់
គេទៅទាំងយប់ ៤ដោយបង្គាប់ថា ត្រូវឱ្យឯងរាល់គ្នាទៅ
បង្កប់ខ្លួន នៅខាងក្រោយទីក្រុង កុំឱ្យនៅឆ្ងាយពីទីក្រុងពេក
ឡើយ ត្រូវឱ្យប្រុងប្រៀបជាស្រេចទាំងអស់គ្នា ៥ឯអញ និង
ពួកមនុស្សទាំងប៉ុន្មានដែលនៅជាមួយ យើងនឹងចូលទៅ
ជិតទីក្រុង រួចកាលណាគេចេញមក តនឹងយើងដូចជា
ជាន់មុន នោះយើងនឹងរត់ពីមុខគេចេញទៀត ៦ដូច្នេះគេ
នឹងចេញមកដេញតាមយើង ទាល់តែយើងបានទាញនាំគេ
ឃ្លាតឆ្ងាយពីទីក្រុងទៅ គេនឹងគិតថា យើងរត់ពីមុខគេទៅ
ដូចជាន់មុនទៀត ដោយយើងរត់ពីមុខគេទៅយ៉ាងនោះ
៧នោះត្រូវឱ្យឯងរាល់គ្នាក្រោកឡើង ពីកន្លែងដែលបង្កប់
ខ្លួននោះ ចូលទៅចាប់យកទីក្រុងទៅ ដ្បិតព្រះយេហូវ៉ា ជា
ព្រះនៃឯង ទ្រង់នឹងប្រគល់ក្រុងនោះមកក្នុងកណ្តាប់ដៃឯង[ឈ]
៨រួចកាលណាឯងរាល់គ្នាយកបានទីក្រុងហើយ នោះត្រូវ
ឱ្យបង្កាត់ភ្លើងដុតឡើង[ញ] ត្រូវឱ្យឯងរាល់គ្នាធ្វើតាមព្រះ
បន្ទូលនៃព្រះយេហូវ៉ាចុះ មើល អញបានបង្គាប់[ដ]ឯងរាល់
គ្នាហើយ ៩យ៉ូស្វេក៏ចាត់គេឱ្យទៅហើយគេនាំគ្នាទៅបង្កប់[ឋ]
ខ្លួន នៅកណ្តាលទាំងសងខាងនៃបេត-អែល និងអៃយ គឺ
នៅខាងលិចក្រុងអៃយ តែលោកស្នាក់នៅកណ្តាលពួកជន
ក្នុងយប់នោះវិញ ។

១០លុះថ្ងៃស្អែកឡើង[ឌ] កាលទើបនឹងភ្លឺស្រាងៗ នោះ
យ៉ូស្វេលោកត្រួតត្រាមើលបណ្តាទ័ព រួចលោក និងពួក
ចាស់ទុំនៃសាសន៍អ៊ីស្រាអែល[ឍ] ក៏នាំមុខគេឡើងទៅឯក្រុង
អៃយ ១១ឯពួកអ្នកថ្នឹកច្បាំងទាំងប៉ុន្មាន ដែលនៅជាមួយនឹង
លោក ក៏ឡើងចូលទៅជិតពីខាងមុខទីក្រុង ហើយបោះទ័ព
នៅជាខាងជើង មានវាលច្រកភ្នំនៅកណ្តាលគេ ហើយ
និងទីក្រុង ១២លោកបានរើសយកប្រហែលជា៥ពាន់នាក់
ចាត់ឱ្យទៅបង្កប់ខ្លួន នៅកណ្តាលទាំងសងខាងនៃបេត-
អែលនិងអៃយ ពីខាងលិចទីក្រុងនោះ ១៣ដូច្នេះកាលបាន
ចាត់ពួកបណ្តាទ័ពឱ្យទៅឯកន្លែងគេរៀងខ្លួន គឺពួកពលទ័ព
ដែលត្រូវនៅខាងជើងទីក្រុង និងពួកអ្នកដែលត្រូវបង្កប់ខ្លួន
នៅខាងលិចរួចស្រេចហើយ នោះយ៉ូស្វេក៏ទៅឯកណ្តាល
វាលច្រកភ្នំ នៅវេលាយប់នោះឯង ។

១៤កាលស្តេចក្រុងអៃយបានឃើញដូច្នោះ នោះពួកក្រុង
ទាំងអស់គ្នា ក៏ប្រញាប់ប្រញាល់ក្រោកឡើងពីព្រលឹម ហើយ
ស្តេចនិងរាស្ត្រទាំងអស់ ក៏ចេញទៅឯកន្លែងដែលបាន
កំណត់ទុកជាមុន ដើម្បីច្បាំងនឹងពួកអ៊ីស្រាអែលត្រង់វាល
នោះ[ណ] ឥតដឹង[ត]ជាមានពលបង្កប់ទាស់នឹងគេ នៅជាខាង
ក្រោយទីក្រុងទេ ១៥ឯយ៉ូស្វេនិងពួកអ៊ីស្រាអែលទាំងអស់គ្នា
គេធ្វើដូចជាចាញ់[ថ]នៅមុខអ្នកទាំងនោះ ក៏នាំគ្នារត់ទៅតាម
ផ្លូវទីរហោស្ថានទៅ[ទ] ១៦លំដាប់នោះ មានគេហៅពួកបណ្តា
ជនដែលនៅក្នុងក្រុង ឱ្យប្រមូលមកមូលគ្នាដេញតាមដែរ

**៧:២៦** ន លប ៣៥:២០ ប ជន ២៥:៤ ផ ខ.២៤
**៨:១** ក លប២៦:២៤ ចទ ៣១:៦ ខ ជន ១៤:៩ ចទ ១:២១ គ យស ១០:៧ ឃ យស ៧:២ ៩:៣ ១០:១ ១២:៩ ង យស ៦:២
**៨:២** ច លប៤៩:២៧ ឆ ខ.២៧ ចទ ២០:១៤ ជ ខ.៤,១២ ពច ៩,៤៣ ២០:២៩
**៨:៧** ឈ ពច ៧:៧ ១សយ ២៣:៤
**៨:៨** ញ ពច ២០:២៩-៣៨ ដ ខ.១៩
**៨:៩** ឋ ២រប ១៣:១៣
**៨:១០** ឌ លប ២២:៣ ឍ យស ៧:៦
**៨:១៤** ណ ចទ ១:១ ត ពច ២០:៣៤
**៨:១៥** ថ ពច ២០:៣៦ ទ យស ១៥:៦១ ១៦:១ ១៨:១២

**៧:២៦** *ថ្មបង្គរឡើងជាគំនរ* នេះជាបូជនីដ្ឋានទី៣ នៅក្នុងហេតុការណ៍នៃការវាយដណ្តើមយកទឹកដី (មើលការពន្យល់ ៤:៩) ។

**៨:១-២៩** វគ្គនេះជាចម្បាំងសារជាថ្មីម្តងទៀត និងការវាយយកក្រុងអៃយ ។

**៨:១** *កុំឱ្យខ្លាចឡើយ* ឃ្លានេះបញ្ជាក់ថា ពួកអ៊ីស្រាអែលត្រូវបានសម្អាត ហើយព្រះអម្ចាស់បានធានាម្តងទៀត (សូមមើល ១:៣-៥ ៣:១១-១៣ ៦:២-៥) ។

**៨:២** *ចូរយកតែរបស់ទាំងប៉ុន្មាន* នៅត្រង់នេះព្រះអម្ចាស់បានចាត់ចែងទ្រព្យសម្បត្តិរបស់ពួកកាណាន ទៅដល់ពួកទាហានដែលបានច្បាំងនៅលើសមរភូមិរបស់ទ្រង់ ។ *ឱ្យឯងបង្កប់ទ័ព* ពាក្យនេះជាការបញ្ជាដោយផ្ទាល់របស់ព្រះអម្ចាស់ក្នុងការវាយប្រហារ ។

**៨:១២** *៥ពាន់នាក់* នៅក្នុង ខ.៣ បានលើកឡើងពីចំនួន៣ម៉ឺននាក់ ក្នុងការបង្កប់ខ្លួន ។ ប្រហែលជាលោកយ៉ូស្វេ បានបែងចែកជាពីរក្រុមផ្សេងគ្នា ដើម្បីធានាការងារឱ្យបានជោគជ័យ ។ ឬចេញពីចំនួនដើម ៣០០០០នាក់ ដែលមួយក្រុមមានចំនួន ៥០០០នាក់ ដែលចំនួននេះប្រហែលត្រូវបានជ្រើសរើសទុកជាមុនដើម្បីវាយក្រុងអៃយផ្ទាល់ ក្នុងខណៈដែលទាហាន២៥០០០ នាក់ កំពុងតែឡោមព័ទ្ធក្រុងបេត-អែល (ខ.១៧) ។

**៨:១៣** *ទ័ពដែលត្រូវនៅខាងជើងក្រុង* នៅត្រង់នេះលោកយ៉ូស្វេបានបង្វែរពួកទាហានឱ្យទៅឯភាគខាងជើងនៃទីក្រុង ហើយបន្តិចក្រោយមកពួកគេធ្វើពុតជារត់ទៅទិសខាងកើត ដែលធ្វើយ៉ាងដូច្នេះ គឺបានពន្យាពេលក្នុងការមកដល់នៃពួកកងការពារ ។

រួចគេក៏ដេញតាមយ៉ូស្វេ ហើយត្រូវប្រទាញនាំទៅ[ធ] ឃ្លាត
ឆ្ងាយពីទីក្រុង ១៧គ្មានសល់មនុស្សណាមួយនៅក្នុងក្រុងអៃយ
និងបេត-អែល ដែលមិនបានចេញទៅដេញតាមសាសន៍
អ៊ីស្រាអែលនោះឡើយ គេបានទុកទីក្រុងឱ្យនៅចំហ ដេញ
តាមពួកអ៊ីស្រាអែលទៅ ។
១៨នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេថា ចូរ
លើកលំពែង[ន] ដែលកាន់នៅដៃ[ប] ដំរង់ទៅឯក្រុងអៃយទៅ
ដ្បិតអញប្រគល់មកក្នុងកណ្តាប់ដៃឯងហើយ នោះយ៉ូស្វេក៏
លើកលំពែង[ផ] ដែលកាន់នៅដៃឡើង ដំរង់ទៅឯទីក្រុងនោះ
១៩កាលលោកលើកដៃឡើង នោះពួកទ័ពបង្កប់ក៏ស្ទុះចេញ
ពីកន្លែងគេជាប្រញាប់[ព] រត់ចូលទៅក្នុងទីក្រុងភ្លាម ក៏
ចាប់យក ហើយប្រញាប់ប្រញាល់នឹងបង្កាត់ភ្លើងដុតឡើង[ភ]
២០រួចកាលពួកក្រុងអៃយ បានងាកបែរមើលទៅក្រោយ
ឃើញផ្សែងហុយឡើងពីទីក្រុង ទៅលើមេឃដូច្នោះ[ម] នោះ
គេគ្មានកំឡាំងនឹងរត់ទៅឱ្យរួច ទោះខាងនេះឬខាងនោះ
ឡើយ ឯពួកអ៊ីស្រាអែលដែលកំពុងតែរត់ទៅឯទីរហោ
ស្ថាន គេក៏វិលបែរមកទាស់នឹងពួកអ្នកដែលដេញតាមខ្លួន
វិញ ២១ហើយយ៉ូស្វេ និងពួកអ៊ីស្រាអែលទាំងអស់គ្នា កាល
ឃើញថាពួកទ័ពបង្កប់បានយកទីក្រុង ហើយមានផ្សែងហុយ
ឡើងដូច្នោះ នោះក៏វិលចូលមក[យ] សំឡាប់ពួកក្រុងអៃយវិញ
ដែរ ២២ហើយពួកដែលដុតទីក្រុង ក៏ចេញមកទាស់នឹងគេ
ទៀត ដូច្នេះគេក៏នៅជាកណ្តាលនៃសាសន៍អ៊ីស្រាអែល
ដែលមានខ្លះនៅខាងណេះ ខ្លះនៅខាងណោះ ហើយក៏ផ្ទប់
វាយគេ ទាល់តែគ្មានអ្នកណាមួយនៅសល់ឬរត់រួចបាន
ឡើយ[រ] ២៣ឯស្តេចអៃយ នោះគេចាប់យកបានទាំងរស់[ល] នាំ
ទៅជូនដល់យ៉ូស្វេ ។

២៤កាលពួកអ៊ីស្រាអែលបានសំឡាប់ពួកក្រុងអៃយទាំង
ប៉ុន្មាន នៅវាលស្រែ និងនៅទីរហោស្ថាន ជាកន្លែងដែល
បានដេញតាម ហើយគេបានដួលស្លាប់ ដោយមុខដាវទាំង
អស់គ្នាជាស្រេចហើយ នោះពួកអ៊ីស្រាអែលទាំងប៉ុន្មាន ក៏
ត្រឡប់ចូលទៅវាយទីក្រុងអៃយ ដោយមុខដាវដែរ ២៥ឯពួក
មនុស្សទាំងប្រុសទាំងស្រី ដែលដួលស្លាប់នៅថ្ងៃនោះ មាន
ចំនួនជា១ម៉ឺន២ពាន់នាក់ គឺជាពួកក្រុងអៃយទាំងអស់គ្នា[វ]
២៦ដ្បិតយ៉ូស្វេមិនបានដកដៃ ដែលលើកលំពែង[ស] ឡើងនោះ
មកវិញឡើយ ទាល់តែបានបំផ្លាញ[ហ] ពួកក្រុងអៃយអស់រលីង
ទៅ[ឡ] ២៧ពួកអ៊ីស្រាអែលបានយកតែហ្វូងសត្វ និងរបស់ទាំង
ប៉ុន្មាននៅក្រុងនោះ ទុកជារបឹបសំរាប់ខ្លួនប៉ុណ្ណោះ តាម
ព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលទ្រង់បានបង្គាប់មកយ៉ូស្វេ[អ]
២៨ដូច្នេះយ៉ូស្វេបានដុត[ក] ក្រុងអៃយ[ខ] ធ្វើឱ្យទៅជាគំនរដរាប
តទៅ[គ] គឺជាទីកន្លែងស្ងាត់ដរាបដល់សព្វថ្ងៃនេះ[ឃ] ២៩ឯស្តេច
នៃក្រុងអៃយនោះ លោកបានព្យួរនឹងដើមឈើទាល់តែ
ល្ងាច រួចដល់ថ្ងៃលិច[ង] លោកបង្គាប់ឱ្យគេដាក់ខ្មោចចុះពី
ដើមឈើមក យកទៅបោះចោលនៅមាត់ទ្វារទីក្រុង ហើយ
ក៏ប្រគរគំនរថ្ម[ច] យ៉ាងធំនៅពីលើ ដែលនៅដរាបដល់សព្វ
ថ្ងៃនេះ ។

## ការចម្លងក្រឹត្យវិន័យនៅឯភ្នំ

៣០នៅគ្រានោះ យ៉ូស្វេលោកស្អាងអាសនា១[ឆ] ថ្វាយព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល នៅលើភ្នំអេបាល[ជ]
៣១ដូចជាលោកម៉ូសេ ជាអ្នកបំរើរបស់ព្រះយេហូវ៉ា បាន
បង្គាប់ដល់ពួកកូនចៅអ៊ីស្រាអែល ហើយដូចជាបានកត់ទុក

**៨:១៦** ធ ពច ២០:៣១
**៨:១៨** ន យប ៤១:២៦ ទដ ៣៥:៣ ប នក ៤:២ ១៧:៩-១២ ផ ខ.២៦
**៨:១៩** ព ពច ២០:៣៣ ភ ខ.៨
**៨:២០** ម ពច ២០:៤០
**៨:២១** យ ពច ២០:៤១
**៨:២២** រ ពច ៧:២ យស ១០:១
**៨:២៣** ល ១សយ ១៥:៨
**៨:២៥** វ ចទ ២០:១៦-១៨
**៨:២៦** ស ខ.១៨ ហ ជន ២១:២ ឡ នក ១៧:១២
**៨:២៧** អ ខ.២
**៨:២៨** ក ជន ៣១:១០ ខ យស ៧:២ យរ ៤៩:៣ គ ចទ ១៣:១៦ យស ១០:១ ឃ លប ៣៥:២០
**៨:២៩** ង ចទ ២១:២៣ យហ ១៩:៣១ ច ២សយ ១៨:១៧
**៨:៣០** ឆ នក ២០:២៤ ជ ខ.៣៣ ចទ ១១:២៩

**៨:១៧** *ក្រុងអៃយ និងបេត-អែល* ទោះបីជាក្រុងនីមួយៗមានស្តេចក៏ដោយ ក៏ការចូលរួមនៅក្នុងសកម្មភាពនេះបញ្ជាក់ថា ក្រុងទាំងពីរនេះបានចងសម្ព័ន្ធភាពគ្នាយ៉ាងស្អិតរមួត (១២:៩,១៦) ។

**៨:២៦** *ទាល់តែបានបំផ្លាញ* ជាលើកទីពីរនេះ លោកយ៉ូស្វេបានដាក់បម្រាមបរិសុទ្ធដល់អ្នកស្រុកកាណាន ។

**៨:២៨** *ដុតក្រុងអៃយ* ការនេះគាត់ធ្វើនៅក្រុងយេរីខូរម្តងហើយ (៦:២៤) ហើយក្រោយមកទៀតគឺនឹងដុតក្រុងហាសោរទៀត (១១:១១) ។

**៨:២៩** *ស្តេចនៃក្រុងអៃយ . . . ព្យួរនឹងដើមឈើ* ពួកអ៊ីស្រាអែលមិនត្រូវបានគេប្រហារជីវិតដោយការព្យួរកទេ ។ "ដើមឈើ" សំដៅលើបង្គោលដែលគេព្យួរសាកសពស្តេចក្រុងអៃយ ដោយពួកគេបានចាក់ទំលុះសុះរាង្គកាយ ក្រោយពេលគេធ្វើគត់ទ្រង់នោះ (មើលការពន្យល់ ចទ ២១:២២) ។ *ប្រគរគំនរថ្ម* គំនរនេះជាបូជនីដ្ឋានដើម្បីរំឭកពីចម្បាំង (សូមមើលការពន្យល់ ៤:៩) ។

**៨:៣០-៣៥** វគ្គនេះជាការនិយាយឡើងវិញ ពីសេចក្តីសញ្ញារបស់ព្រះ ដូចដែលលោកម៉ូសេបានបង្គាប់មក (ចទ ១១:២៦ ២៧:១-៨) បានសន្និដ្ឋានពីការពិពណ៌នាពីសង្គ្រាមលើកដំបូង (មើលសេចក្តីផ្តើម និងគម្រោងសង្ខេប) ។ សង្គ្រាមនៅទឹកដីកាណាន ត្រូវបានគេដាក់បញ្ចូលទៅក្នុងភាពសំបូរបែបខាងឯផ្នែកទេវសាស្ត្រ ។ ព្រឹត្តការណ៍ចុងក្រោយ (សូមមើលជំពូក ២៤) គូសបញ្ជាក់ពីភាពជាអ្នកបម្រើរបស់ពួកអ៊ីស្រាអែលដែលមានទំនាក់ទំនងជាមួយនឹងព្រះអម្ចាស់ ។ នៅក្នុងសង្គ្រាមវាតទី និងការដណ្តើមយក ពួកគេត្រូវតែទទួលបានសញ្ជាតិតែមួយ ថាជារាស្ត្រនៃអាណាចក្ររបស់ព្រះ ដែលការស្របទៅនឹងបេសកកម្ម និងការដឹកនាំរបស់ទ្រង់ ។

**៨:៣០** *ភ្នំអេបាល* ភ្នំនេះជាប៉មនៃទីក្រុងស៊ីគែម ដែលលោកអ័ប្រាហាំបានសង់អាសនានៅទីនោះផងដែរ (នក ១២:៦-៧) ។

**៨:៣១** *ដង្វាយដុត* មើលការពន្យល់ លវ ១:១-១៧ ។ *ដង្វាយមេត្រី* សូមមើល លវ ៣:១-១៧ ៧:១១-១៨ ។

ក្នុងគម្ពីរក្រិត្យវិន័យរបស់លោកម៉ូសេដែរ គឺជាអាសនា
ដែលធ្វើពីដុំថ្មទាំងមូល ឥតមានអ្នកណាដាប់ដោយដែក
ឡើយ[ឈ] រួចគេក៏ថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ា នៅលើ
អាសនានោះ ព្រមទាំងដង្វាយមេត្រីផង[ញ] ៣២ នៅទីនោះ
លោកចារឹកថ្មចំឡងក្រិត្យវិន័យរបស់លោកម៉ូសេ ដែល
លោកបានកត់ទុក នៅចំពោះមុខពួកកូនចៅអ៊ីស្រាអែល[ដ]
៣៣ នោះពួកសាសន៍អ៊ីស្រាអែលទាំងអស់គ្នា[ឋ] ទាំងពួកចាស់
ទុំ និងពួកនាយក ហើយពួកចៅក្រម គេក៏ឈរទាំងសងខាង
ហឹប នៅមុខពួកលេវី[ឌ]ដ៏ជាសង្ឃ ដែលសែងហឹបនៃសេចក្តី
សញ្ញាផងព្រះយេហូវ៉ា ទោះទាំងពួកអ្នកប្រទេសក្រៅ និង
ពួកអ្នកស្រុកផង ពួកគេ១ចំហៀងឈរខាងភ្នំកេរិស៊ីម
ហើយ១ចំហៀងឈរខាងភ្នំអេបាល[ឍ]ដូចជាលោកម៉ូសេ ជា
អ្នកបំរើរបស់ព្រះយេហូវ៉ា បានបង្គាប់មកកាលពីមុន ដើម្បី
ឱ្យគេបានឱ្យពរដល់ពួកអ៊ីស្រាអែល ៣៤ រួចមក លោកក៏អាន
មើលអស់ទាំងពាក្យនៃក្រិត្យវិន័យ ទោះទាំងព្រះពរ និង
សេចក្តីបណ្តាសាទាំងប៉ុន្មានផង តាមគ្រប់ទាំងសេចក្តីដែល
បានកត់ទុកក្នុងគម្ពីរក្រិត្យវិន័យ[ណ] ៣៥ ក្នុងគ្រប់ទាំងសេចក្តី
ដែលលោកម៉ូសេបានបង្គាប់មកយ៉ូស្វេ នោះគ្មានពាក្យណា
មួយដែលយ៉ូស្វេមិនបានអានមើល នៅមុខពួកជំនុំសាសន៍
អ៊ីស្រាអែលទាំងអស់គ្នានោះទេ ហើយក៏មានពួកស្រីៗ ពួក
ក្មេងៗ និងពួកអ្នកប្រទេសក្រៅ ដែលនៅជាមួយនឹងគេ
ដែរ[ត]។

## ការបោកបញ្ឆោតនៃពួកក្រុងគីបៀន

៩ ១ ឯពួកស្តេចទាំងប៉ុន្មាន ដែលនៅខាងលិចទន្លេយ័រដាន់
ក្នុងស្រុកភ្នំ[ក]និងស្រុកទំនាប ក្បែរសមុទ្រធំ[ខ] ទល់មុខនឹងភ្នំ
ល្បាណូន[គ] គឺជាស្តេចសាសន៍ហេត សាសន៍អាម៉ូរី សាសន៍
កាណាន សាសន៍ពេរិស៊ីត[ឃ] សាសន៍ហេវី[ង] និងសាសន៍
យេប៊ូស[ច] កាលបានឮ ២ នោះគេក៏ប្រមូលគ្នាទាំងអស់ ដើម្បី
ច្បាំងនឹងយ៉ូស្វេ ហើយនិងសាសន៍អ៊ីស្រាអែល ដោយស្រុះ
ចិត្តគ្នា ។

៣ តែឯពួកទីក្រុងគីបៀន[ឆ] កាលគេបានឮពីការដែល
យ៉ូស្វេបានធ្វើដល់ក្រុងយេរីខូរនិងក្រុងអៃយ[ជ] ៤ នោះគេក៏
ប្រព្រឹត្តដោយឧបាយកល ក្លែងខ្លួនធ្វើជារាជទូតចូលមក
មានទាំងបាវចាស់ៗ ដាក់ផ្ទុកលើលាគេ និងថង់ស្បែក
សំរាប់ស្រាទំពាំងបាយជូរ ជាថង់ស្បែកចាស់ហើយធ្លាយ
បានចងខ្ចីបវិញផង ៥ ក៏ពាក់ស្បែកជើងកញ្ចាស់ប៉ះយ៉ាងញឹក
ហើយស្លៀកពាក់កញ្ចាស់ផង ឯនំបុ័ងដែលយកមកសំរាប់
បរិភោគតាមផ្លូវ នោះសុទ្ធតែស្វិត ហើយដុះផ្សិតអស់រលីង
៦ គេមកដល់យ៉ូស្វេក្នុងទីដំឡើងត្រសាល ត្រង់គីលកាល[ឈ]
និយាយនឹងលោក ព្រមទាំងពួកអ៊ីស្រាអែលថា យើងខ្ញុំបាន
មកពីស្រុកឆ្ងាយ[ញ] ដូច្នេះសូមលោកតាំងសេចក្តីសញ្ញា[ដ]នឹង
យើងខ្ញុំចុះ ៧ តែពួកអ៊ីស្រាអែលឆ្លើយនឹងពួកសាសន៍ហេវី[ឋ]
នោះថា ក្រែងអ្នករាល់គ្នានៅក្នុងស្រុកយើងនេះដែរទេដឹង

**៨:៣១** ឈ នក ២០:២៥ ញ ចទ ២៧:៦-៧ **៨:៣២** ដ ចទ ២៧:៨ **៨:៣៣** ឋ លវ ១៦:២៩ ឌ ចទ ៣១:១២ ឍ ចទ ១១:២៩ យហ ៤:២០ **៨:៣៤** ណ ចទ ២៨:៦១ ៣១:១១ **៨:៣៥** ត នក ១២:៣៨ ចទ ៣១:១២

**៩:១** ក ជន ១៣:១៧ ខ ជន ៣៤:៦ គ ចទ ៣:២៥ ឃ លប ១៣:៧ យស ៣:១០ ង ខ.៧ យស ១១:១៩ ច យស ៣:១០ **៩:៣** ឆ ខ.១៧ យស ១០:១០ ១១:១៩ ១៨:២៥ ២១:១៧ ២សយ ២:១២ ៥:២៥ ២០:៨ ១ពវ ៣:៤ ៩:២ ១របា ៨:២៩ ១៤:១៦ ១៦:៣៩ ២១:២៩ ២របា ១:៣ នហ ៣:៧ អស ២៨:២១ យរ ២៨:១ ៤១:១២ ជ លប ១២:៨ យស ៨:១ **៩:៦** ឈ ចទ ១១:៣០ ញ ខ.២២ ដ លប ២៦:២៨ **៩:៧** ឋ ខ.១ ឌ នក ២៣:៣២

**៨:៣២** *ចារឹកថ្មចំឡង* ពាក្យនេះបញ្ជាក់ថា លោកម៉ូសេបានបង្គាប់ដល់ពួកគេឱ្យបិតថ្មភ្ជាប់គ្នា ហើយបន្ទាប់មកចារឹកអក្សរនៃក្រឹត្យវិន័យនៅលើថ្មនោះ (ចទ ២៧:២-៤) ។ ថ្មនៅត្រង់នេះ ជាបូជនីដ្ឋានទីប្រាំនៅក្នុងទឹកដីនេះ (មើលការពន្យល់ ៤:៩) ។

**៨:៣៣** *អ្នកប្រទេសក្រៅ និងពួកអ្នកស្រុកផង* ពួកអ៊ីស្រាអែលឥឡូវនេះបានរួមបញ្ចូល "មនុស្សផ្សេងទៀត" (នក ១២:២៨) ដែលពួកអ្នកទាំងនោះបានចេញពីអេស៊ីព្ទមក ហើយបញ្ចូលពួកអ្នកដែលចូលរួមក្នុងដំណើរនៅឯទីរហោស្ថានផងដែរ (មើលការពន្យល់ ខ.៣០-៣៥) ។

**៨:៣៤** *ទាំងព្រះពរ និងសេចក្តីបណ្តាសា* សូមមើល ចទ ២៧-២៨ និងការពន្យល់ ។

**៩:១-២៧** នេះជាការរៀបរាប់ពីហេតុការណ៍ ដែលពួកអ្នកទីក្រុងគីបៀនបានបោកបញ្ឆោតដល់អ្នកដឹកនាំពូជអំបូរ និងការតាំងសញ្ញានៃការចុះចូលនឹងពួកអ៊ីស្រាអែល ។ នៅវគ្គនេះ ជាផ្នែកមួយនៅក្នុងចំណោមបីផ្នែកដែលប្រាប់ ពីរបៀបដែលពួកអ៊ីស្រាអែលបានឈានចូលក្នុងភាពជាម្ចាស់ទឹកដីដ៏ធំធេង ។

**៩:១** *ពួកស្តេចទាំងប៉ុន្មាន ដែលនៅខាងលិចទន្លេយ័រដាន់* នៅត្រង់នេះអាណាចក្រឯករាជ្យតូចៗ ដែលពួកស្តេចទាំងនោះមាននៅពាសពេញ ទឹកដីកាណាន ។ ប្រជាជនរស់នៅទីនេះគឺ មកពីគ្រប់តំបន់ (សូមផ្ទៀប ខ.១-២ ជាមួយនឹង នក ១៥:១៩ សូមមើលការពន្យល់ នក ៣:៨) ។

**៩:៣** *គីបៀន* ទីកន្លែងនេះស្ថិតនៅភាគខាងជើងនៃក្រុងយេរូសាឡិម ដែលគេហៅថា អែល-ជីប ហើយបានបង្ហាញ ពីសំណល់លម្អិនទីក្រុងជាមួយនឹងប្រព័ន្ធទឹកដ៏ល្អឥតខ្ចោះ ។ ពួកគីបៀននេះបានចងសម្ព័ន្ធជាមួយនឹងទីក្រុងជិតខាងមួយចំនួនទៀត (ខ.១៧) ប៉ុន្តែវាហាក់ដូចជាមានអំណាចលើសហព័ន្ធទាំងមូល ។

**៩:៤** *ប្រព្រឹត្តដោយឧបាយកល* ការនេះកើតមានឡើងដោយព្រោះតែពួកគេមានសេចក្តីភ័យខ្លាចចំពោះព្រះនៃពួកអ៊ីស្រាអែល នោះពួកគីបៀនបានប្រើល្បិចនេះដើម្បីឱ្យលោកយ៉ូស្វេ ផ្តល់នូវសេចក្តីសញ្ញានៃការចុះចូលដើម្បីឱ្យពួកគេបានរស់នៅក្នុងទឹកដីនេះដែរ ។

**៩:៦** *តាំងសេចក្តីសញ្ញានឹងយើងខ្ញុំចុះ* នៅក្នុងសំណើនេះ ពួកគេត្រូវចុះចូលក្នុងសេចក្តីសញ្ញា ដើម្បីឱ្យបានធ្វើជាសាសន៍អ៊ីស្រាអែល (សូមមើល ខ.១១ ដែលពួកគេបានហៅខ្លួនគេផ្ទាល់ថា ជា"អ្នកបម្រើ" ពាក្យនេះជាភាសាការទូតទៅវិញទេ ដើម្បីឱ្យគេបានរួចខ្លួន) ។ ពួកគេជ្រើសរើសការចុះចូលលើសជាងការស្លាប់ (ខ.២៤)។

**៩:៧** *សាសន៍ហេវី* សាសន៍នេះប្រហែលជា សាសន៍ហូរីដែលជាបំណែក

ដូច្នេះធ្វើដូចម្តេចឱ្យយើងតាំងសញ្ញា[ឌ]នឹងអ្នករាល់គ្នាបាន
៨នោះគេឆ្លើយតបទៅយ៉ូស្វេថា យើងខ្ញុំជាបាវបំរើ[ឍ] លោក
ពិត តែយ៉ូស្វេសួរគេថា តើអ្នករាល់គ្នាជាសាសន៍ណា
ហើយមកពីណា ៩គេក៏ជំរាបថា យើងខ្ញុំប្របាទបានមកពី
ស្រុកឆ្ងាយណាស់[ណ] ដោយព្រោះព្រះនាមព្រះយេហូវ៉ា ជា
ព្រះនៃលោក ដ្បិតយើងខ្ញុំបានឮល្បី[ត] ព្រះនាមទ្រង់ និងពី
អស់ទាំងការ ដែលទ្រង់បានធ្វើនៅស្រុកអេស៊ីព្ទ[ថ] ហើយ
១០ព្រមទាំងការទាំងប៉ុន្មាន ដែលទ្រង់បានធ្វើដល់ស្តេច
សាសន៍អាម៉ូរីទាំង២ នៅត្រើយទន្លេយ័រដាន់ខាងកើត គឺ
ស៊ីហុនជាស្តេចក្រុងហែសបូន[ទ] និងអុកជាស្តេចស្រុក
បាសាន[ធ] នៅទីក្រុងអាសថារ៉ូត[ន] ១១ដូច្នេះពួកចាស់ទុំ និង
ពួកអ្នកស្រុកយើងខ្ញុំទាំងអស់ គេបានប្រាប់យើងខ្ញុំថា ចូរ
យកស្បៀងអាហារជាប់នឹងខ្លួន សំរាប់តាមផ្លូវ ទៅជួបនឹង
លោកជំរាបថា យើងខ្ញុំជាបាវបំរើលោកហើយ ដូច្នេះសូម
តាំងសញ្ញានឹងយើងខ្ញុំចុះ ១២ឯនំបុ័ងយើងខ្ញុំនេះ បានយកពី
ផ្ទះយើងខ្ញុំមកទាំងក្តៅ សំរាប់ជាស្បៀងតាមផ្លូវ តាំងពីថ្ងៃ
ដែលយើងខ្ញុំបានចេញមកឯលោករាល់គ្នា តែឥឡូវនេះ
មើល បានស្វិត ហើយដុះផ្សិតអស់រលីង ១៣ឯថង់ស្បែក
សំរាប់ស្រាទំពាំងបាយជូរទាំងនេះ ក៏ថ្មីសុទ្ធក្នុងកាលដែល
យើងខ្ញុំបានចាក់ចូលពេញនោះដែរ តែមើល ឥឡូវនេះទៅ
ជាកណ្តាចអស់វិញ សំលៀកបំពាក់និងស្បែកជើងយើងខ្ញុំ
នេះសោត ក៏ទៅជាចាស់អស់ ដោយព្រោះផ្លូវឆ្ងាយទាំង
ម្ល៉េះ ១៤នោះពួកអ៊ីស្រាអែលក៏ទទួលបរិភោគពីស្បៀង
អាហារគេ ឥតទូលសួរ[ប]ដល់ព្រះយេហូវ៉ាឡើយ ១៥ដូច្នេះ
យ៉ូស្វេក៏ព្រមចងជាស្ពានមេត្រី[ផ]នឹងគេ ព្រមទាំងតាំងសញ្ញា
ឱ្យគេបាននៅរស់តទៅ[ព] ហើយពួកអ្នកដែលជាកំពូលលើ
ពួកជំនុំក៏ស្បថនឹងគេដែរ ។
១៦លុះដល់ផុត៣ថ្ងៃក្រោយ ដែលបានតាំងសញ្ញានឹងគេ
មក នោះក៏ឮថា ពួកអ្នកនោះជាអ្នកជិតខាង[ភ] ដែលនៅក្នុង
ស្រុកនោះវិញ ១៧ពួកកូនចៅអ៊ីស្រាអែលក៏ធ្វើដំណើរ ទៅ
ដល់ក្រុងទាំងប៉ុន្មានរបស់គេនៅថ្ងៃទី៣ រីឯទីក្រុងទាំងនោះ
គឺគីបៀន១ កេភីរ៉ា១ បៀរ៉ុត១[ម] និងគារយ៉ាត់-យារីម១[យ]
១៨តែមិនបានវាយគេទេ ដ្បិតពួកអ្នកដែលជាកំពូលលើពួក
ជំនុំ បានស្បថ[រ]នឹងគេហើយ ដោយនូវព្រះនាមផងព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល នោះពួកជំនុំទាំង
អស់គ្នាក៏រទូរទាំ[ល] ទាស់នឹងពួកអ្នក ដែលជាកំពូលនោះ
១៩តែពួកនោះនិយាយទៅពួកជំនុំទាំងអស់ថា យើងបាន
ស្បថនឹងគេ ដោយនូវព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែលហើយ ដូច្នេះយើងគ្មានច្បាប់នឹងពាល់គេឡើយ
២០ចូរយើងធ្វើដូច្នេះនឹងគេវិញ ទុកឱ្យគេនៅរស់ចុះ ខ្លាច
ក្រែងមានសេចក្តីក្រោធមកលើយើងរាល់គ្នា ដោយព្រោះ
សំបថ[វ]របស់យើង ២១រួចពួកអ្នកដែលជាកំពូលក៏និយាយ
ទៀតថា ចូរឱ្យគេរស់នៅចុះ[ស] ដូច្នេះគេក៏ត្រឡប់ជាអ្នកកាប់
ឧស ហើយរែកទឹក[ហ] ដល់ពួកជំនុំទាំងអស់គ្នា ដូចជាពួកអ្នក
ដែលជាកំពូលបានប្រាប់ហើយ ។
២២យ៉ូស្វេក៏ហៅគេមកសួរថា ហេតុអ្វីបានជាឯងរាល់
គ្នាបានបញ្ឆោតយើងដូច្នេះ ដោយថា យើងខ្ញុំនៅឆ្ងាយ[ឡ]ពី
លោកណាស់ តែឯងរាល់គ្នានៅជាមួយ[អ]នឹងយើងវិញ
២៣ដូច្នេះឯងរាល់គ្នាត្រូវបណ្តាសាឥឡូវ[ក] ពួកឯងរាល់គ្នា
នឹងមិនដែលរួចពីការជាបាវបំរើឡើយ គឺត្រូវកាប់ឧស

**៩:៧** ១ពវ ៥:១២
**៩:៨** ឍ ២ពវ ១០:៥
**៩:៩** ណ ចទ ២០:១៥ ត ខ.២៤ ថ ជន ២៣:២២
**៩:១០** ទ ជន ២១:២៥ ធ ជន ២១:៣៣ ន ជន ២១:២៤,៣៥ យស ២:១០
**៩:១៤** ប នក ១៦:២៨ ជន ២៧:២១
**៩:១៥** ផ ខ.៣,៧ យស ១០:១,៤ ១១:១៩ ២សយ ២១:២ ២៤:១ ព ខ.២១ ពច ១:២១ ទដ ១០៦:៣៤
**៩:១៦** ភ ខ.២២
**៩:១៧** ម យស ១៨:២៥ ២សយ ៤:២ ២៣:៣៧ យ យស ១៥:៩,៦០ ១៨:១៤,១៥ ពច ១៨:១២ ១សយ ៦:២១ ៧:២ ទដ ១៣២:៦ យរ ២៦:២០
**៩:១៨** រ ខ.១៥ ពច ២១:១,៧,១៨ ១សយ ២០:១៧ ទដ ១៥:៤ ល នក ១៥:២៤
**៩:២០** វ លប ២៤:៨ **៩:២១** ស ខ.១៥ ហ ចទ ២៩:១១ **៩:២២** ឡ ខ.៦ អ ខ.១៦ **៩:២៣** ក លប ៩:២៥

នៃជនជាតិភាគតិចរស់នៅទឹកដីកាណាន ជាប់ទៅនឹងសាសន៍ហ៊ីវ៉ាយ ដែលនៅភាគខាងជើងតំបន់មេសូប៉ូតាមា (សូមមើល ១១:១៩ លប ១០:១៧ ៣៤:២ ៣៦:២ នក ២៣:២៣ ពច ៣:៣ និងមើលការពន្យល់ ហាស ៨:៣០–៣៥)។

**៩:៩** *ឮល្បីព្រះនាមទ្រង់* ការនេះត្រូវបានឮម្តងទៀត ដូចដែលពួកគេបានឮនៅក្រុងយេរីខូរ (សូមមើល ២:១០) ។

**៩:១៤** *ឥតទូលសួរដល់ព្រះយេហូវ៉ា* នៅត្រង់នេះពួកគេមិនបានពិភាក្សាជាមួយនឹងស្តេចរបស់ពួកគេ ថាតើបេសកកម្មរបស់ពួកគេនឹងទៅជាយ៉ាងណានោះឡើយ ។

**៩:១៥** *តាំងសញ្ញាឱ្យគេបាននៅរស់* សេចក្តីសញ្ញានេះ ដើម្បីឱ្យពួកគេរស់នៅហើយបានស្បថដោយអ្នកដឹកនាំពួកសាសន៍គេ គឺថាសេចក្តីសម្បថត្រូវធ្វើឡើងនៅចំពោះព្រះ ។ គ្រប់ពាក្យសម្បថ ត្រូវតែបានយល់ព្រមដោយពួកអ៊ីស្រាអែល (សូមមើល នក ២០:៧ លវ ១៩:១២ ១សយ ១៤:២៤) ។

**៩:១៨** *ពួកជំនុំទាំងអស់គ្នាក៏រទូរទាំ* នៅត្រង់នេះប្រហែលជាពួកគេមានសេចក្តីភ័យខ្លាចពីលទ្ធផល នៃការមិនធ្វើតាមព្រះហឫទ័យព្រះក្នុងការបំផ្លាញពួកកាណានឱ្យអស់ ប៉ុន្តែពួកគេទំនងជារទូរទាំពីព្រោះគេមិនអាចគ្រប់គ្រងក្រុងគីបៀន និងទ្រព្យសម្បត្តិរបស់គេ ។

**៩:២១** *អ្នកកាប់ឧស ហើយរែកទឹក* នេះជាឃ្លាសម្គាល់អំពីអ្នកបម្រើផ្ទះសំបែង (សូមមើល ចទ ១៩:១១) ។

**៩:២៣** *ត្រូវបណ្តាសា* នេះជាការថ្លែងទំនាយរបស់លោកណូអេដែលថាថ្ងៃមួយពួកកាណាននឹងធ្វើជា"អ្នកបម្រើរបស់ពួកសិម" (សូមមើល លប ៩:២៥–២៦) ហើយការនេះបានសម្រេចដូចបទទំនាយនេះផងដែរ ។ *សំរាប់ដំណាក់ព្រះនៃអញជានិច្ច* ឃ្លានេះទំនងជាបញ្ជាក់ពីកិច្ចការដែលពួកគីបៀននឹងបម្រើ"សហគមន៍ទាំងមូល" (ខ.២១) ។ ការថ្វាយបង្គំនៅរោងឧបោសថ (ក្រោយមកនៅវិហារ) ទាមទារឱ្យមានឧសនិងទឹក ដូច្នេះ

ហើយវែកទឹក សំរាប់ដំណាក់ព្រះនៃអញជានិច្ច ២៤គេក៏
ឆ្លើយតបថា គឺដោយព្រោះមានគេប្រាប់[ខ]មកយើងខ្ញុំប្របាទ
ជាប្រាកដថា ព្រះយេហូវ៉ា ជាព្រះនៃលោក ទ្រង់បានបង្គាប់
មកលោកម៉ូសេ ជាអ្នកបំរើទ្រង់ ឱ្យចែកស្រុកនេះទាំងអស់
ដល់លោករាល់គ្នា ហើយបំផ្លាញពួកអ្នកស្រុកនេះទាំងអស់
ពីមុខលោកចេញ ហេតុនោះបានជាយើងខ្ញុំបានប្រព្រឹត្ត
យ៉ាងដូច្នេះ ដោយនឹកភ័យខ្លាចនឹងជីវិតយើងខ្ញុំជាខ្លាំង
ដោយព្រោះលោករាល់គ្នា ២៥ឥឡូវនេះ មើលយើងខ្ញុំនៅ
ក្នុងកណ្តាប់ដៃរបស់លោកហើយ[គ] សូមប្រព្រឹត្តនឹងយើងខ្ញុំ
តាមដែលលោកគិតថាស្រួល ហើយត្រឹមត្រូវ[ឃ]ចុះ ២៦យ៉ូស្វេ
ក៏ធ្វើដូច្នោះនឹងគេ ព្រមទាំងដោះគេឱ្យរួចចេញពីកណ្តាប់
ដៃនៃពួកកូនចៅអ៊ីស្រាអែល ដើម្បីមិនឱ្យគេត្រូវស្លាប់ឡើយ
២៧នៅថ្ងៃនោះឯង យ៉ូស្វេបានដំរូវគេ[ង]ឱ្យធ្វើជាពួកអ្នកកាប់
ឧស ហើយវែកទឹក[ច]ដល់ពួកជំនុំ និងសំរាប់អាសនានៃព្រះ
យេហូវ៉ា នៅគ្រប់កន្លែងណាដែលទ្រង់សព្វព្រះហឫទ័យ
ចង់រើស[ឆ] ដរាបដល់សព្វថ្ងៃនេះ ។

## ថ្ងៃនៅទ្រឹងស្ងៀម

**១០** ១រីឯអ័ដូនី–សេដិក[ក] ជាស្តេចក្រុងយេរូសាឡិម[ខ] កាល
ឮថា យ៉ូស្វេបានវាយយកក្រុងអៃយ[គ] ព្រមទាំងបំផ្លាញអស់
រលីង[ឃ] គឺបានប្រព្រឹត្តចំពោះក្រុងអៃយ និងស្តេចគេ ដូចជា
បានប្រព្រឹត្តចំពោះក្រុងយេរីខូរ និងស្តេចគេដែរ ហើយថា
ពួកក្រុងគីបៀន[ង]បានចងស្ពានមេត្រី[ច]នឹងពួកសាសន៍អ៊ីស្រា–
អែល ក៏នៅជាមួយគ្នាផង ២នោះគេកើតមានសេចក្តីភ័យ
ខ្លាចជាខ្លាំង ដ្បិតក្រុងគីបៀននោះជាក្រុងធំ ដូចជាទីក្រុង
របស់ស្តេចណាមួយដែរ ក៏ធំជាងក្រុងអៃយទៅទៀត ហើយ
ពួកមនុស្សនៅក្រុងនោះ សុទ្ធតែខ្លាំងពូកែផង ៣ដូច្នេះ
អ័ដូនី–សេដិក ជាស្តេចក្រុងយេរូសាឡិម ក៏ចាត់សារឱ្យ
ទៅឯហូហាំ ជាស្តេចនៃក្រុងហេប្រុន[ឆ] និងពារ៉ាម ជា
ស្តេចក្រុងយ៉ារមុត[ជ] យ៉ាភា ជាស្តេចក្រុងឡាគីស[ឈ] ហើយ
ដេបៀរ[ញ] ជាស្តេចក្រុងអេក្លូន[ដ]ថា ៤សូមឡើងមកជួយខ្ញុំផង
យើងរាល់គ្នា និងវាយគីបៀន ដ្បិតគេបានចងស្ពានមេត្រី[ឋ]
នឹងយ៉ូស្វេ ហើយនិងពួកកូនចៅអ៊ីស្រាអែលហើយ ៥ដូច្នេះ
ស្តេចសាសន៍អាម៉ូរី[ឌ]ទាំង៥អង្គ[ឍ] គឺស្តេចក្រុងយេរូសាឡិម១
ស្តេចក្រុងហេប្រុន១ ស្តេចក្រុងយ៉ារមុត១ ស្តេចក្រុងឡា–
គីស១ និងស្តេចក្រុងអេក្លូន១ ក៏ប្រមូលគ្នានាំទាំងពួកពល
ទ័ពគេទាំងអស់ ឡើងទៅបោះទ័ពច្បាំងនឹងក្រុងគីបៀន ។
៦នោះពួកក្រុងគីបៀនក៏ចាត់គេមកឯយ៉ូស្វេ នៅទីដំឡើង
ត្រសាលត្រង់គីលកាល[ណ] ជំរាបថា សូមកុំបង្អង់ដល់ពួកអ្នក
បំរើរបស់លោកឡើយ សូមឡើងមកជាប្រញាប់ដើម្បីនឹង
ជួយសង្គ្រោះយើងខ្ញុំផង ដ្បិតពួកស្តេចសាសន៍អាម៉ូរីទាំង
អស់ ដែលនៅស្រុកភ្នំ គេបានប្រមូលគ្នាមកទាស់នឹងយើង
ខ្ញុំហើយ ៧ដូច្នេះ យ៉ូស្វេក៏ចេញពីគីលកាលឡើងទៅ មាន
ទាំងពួកអ្នកថ្មីកច្បាំង[ត] និងពួកខ្លាំងពូកែស្ទាត់ជំនាញ ទៅជា
មួយផង ៨នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេថា កុំ
ឱ្យខ្លាច[ថ]គេឡើយ ដ្បិតអញបានប្រគល់គេមកក្នុងកណ្តាប់ដៃ
ឯងហើយ[ទ] និងគ្មានអ្នកណាមួយក្នុងពួកគេ អាចឈរនៅមុខ

**៩:២៤** ខ ខ.៩ **៩:២៥** គ លប ១៦:៦ ឃ យរ ២៦:១៤ **៩:២៧** ង នក ១:១១ ច ចទ ២៩:១១ ឆ ចទ ១២:៥ **១០:១** ក ខ.៣ ខ យស ១២:១០ ១៥:៨,៦៣ ១៨:២៨ ពច ១:៧ គ យស ៨:១ ឃ ចទ ២០:១៦ យស ៨:២២ ង យស ៩:៣ ច យស ៩:១៥ **១០:៣** ឆ លប ១៣:១៨ ជ ខ.៥ យស ១២:១១ ១៥:៣៥ ២១:២៩ នហ ១១:២៩ ឈ ខ.៥,៣១ យស ១២:១១ ១៥:៣៩ ២ពវ ១៤:១៩ ២រប ១១:៩ ២៥:២៧ ៣២:៩ នហ ១១:៣០ អស ៣៦:២ ៣៧:៨ យរ ៣៤:៧ មីក ១:១៣ ញ ខ.៣៨ យស ១១:២១:១៣ ១៣:២៦ ១៥:៧,៤៩ ២១:១៥ ពច ១:១១ ១រប ៦:៥៨ ដ ខ.២៣, ៣៤,៣៦ យស ១២:១២ ១៥:៣៩ **១០:៤** ឋ យស ៩:១៥ **១០:៥** ឌ ជន ១៣:២៩ ចទ ១:៧ ឍ ខ.១៦ **១០:៦** ណ ចទ ១១:៣០ **១០:៧** ត យស ៨:១ **១០:៨** ថ ចទ ៣:២ យស ១:៩ ទ យស ២:២៤

ហើយពួកគេត្រូវបម្រើកិច្ចការជាច្រើន ។ ចាប់ពីឥឡូវទៅ គ្រប់កិច្ចការបម្រើត្រូវបានធ្វើដោយពួកគីបៀន ឬពួកគេផ្លាស់ប្តូរវេនគ្នា ។ នៅក្នុងមធ្យោបាយនេះ ពួកគេអាចចូលនៅក្នុងការបម្រើព្រះអម្ចាស់បាន ។ នៅពេលដែលស្តេចសាឡូម៉ូន បានឡើងគ្រងរាជ្យ រោងឧបោសថ និងអាសនានៃដង្វាយដុតត្រូវបម្រើដោយពួកគីបៀន (២របា ១:៣,៥) ។

**៩:២៧** *គ្រប់កន្លែងណាដែលទ្រង់សព្វព្រះទ័យចង់រើស* លោកយ៉ូស្វេបានរើរោងឧបោសថ ទៅឯស៊ីឡូរ ហើយនៅទីនោះរហូតដល់សម័យលោកសាំយូអែល (១សយ ៤:៣) តែក្រោយមកព្រះអម្ចាស់បានជ្រើសក្រុងយេរូសាឡិម (១ពវ ៩:៣) ។

**១០:១–៤៣** ពួកទាហាននៅក្រោមបង្គាប់លោកយ៉ូស្វេ បានការពារក្រុងគីបៀន ហើយប្រហារពួកសម្ព័ន្ធស្តេចអាម៉ូរីនៅភាគខាងត្បូង ពួកយូដានៅខាងត្បូងទីក្រុងហើយនិងនៅតំបន់ "នីហ្គេវ" (negev) ។

**១០:១** *អ័ដូនី–សេដិក* ពាក្យនេះមានន័យថា "ព្រះនៃសេចក្តីសប្បុរស" ។ ស្តេចក្រុងយេរូសាឡិមដំបូង ក៏មាននាមស្រដៀងនឹងពាក្យនេះផងដែរ ។ *យេរូសាឡិម* នេះជាក្រុងយេប៊ូស ។

**១១:២** *ក្រុងធំ* ពាក្យនេះបានបញ្ជាក់ថា ក្រុងគីបៀនមិនគ្រាន់តែមានទំហំធំជាងក្រុងបេត–អែល ឬក្រុងអៃយប៉ុណ្ណោះទេ គឺថែមទាំងនៅជិតក្រុងយេរូសាឡិមទៀតផង ។ *ខ្លាំងពូកែ* ពួកនេះត្រូវបានគេស្គាល់ថា ជាអ្នកចម្បាំងដ៏ពូកែ ។ ប៉ុន្តែពួកគេនៅមានបញ្ញាគ្រប់គ្រាន់ដើម្បីធ្វើឱ្យមានសន្តិភាពជាមួយពួកអ៊ីស្រាអែលផងដែរ ។

**១០:៥** *សាសន៍អាម៉ូរីទាំង៥អង្គ* ឃ្លានេះប្រាប់ពីអ្នកដឹកនាំទាំងប្រាំនាក់នៃផ្នែកសំខាន់នៃទីក្រុងដែលលាតសន្ធឹងតាមបណ្តោយជើងភ្នំនៃប្រទេស ។ ពួកសាសន៍អាម៉ូរីនៃជើងភ្នំនៅត្រង់នេះ បានខ័ណ្ឌទឹកដីកាណានតាមបណ្តោយឆ្នេរសមុទ្រ ។

**១០:៦** *សូមឡើងមក . . . ជួយសង្គ្រោះយើងខ្ញុំផង* ពាក្យនេះជាសេចក្តីអំពាវនាវជាបន្ទាន់សម្រាប់សេចក្តីសង្គ្រោះ របស់ពួកគេទៅដល់បុរសម្នាក់ដែលនាមរបស់គាត់មានន័យថា "ព្រះសង្គ្រោះ" ។ សេចក្តីសញ្ញា ដូចដែលលោកយ៉ូស្វេ បានធ្វើជាមួយពួកគីបៀន នោះជាកាតព្វកិច្ចនៃការដឹកនាំជាតិសាសន៍ឱ្យពួកគេស្គាល់ពីមុខងាររបស់ខ្លួន ប្រសិនបើពួកគេស្ថិតក្រោមការវាយប្រហារ ។

ឯងបានឡើយ[ធ] ៩យ៉ូស្វេក៏ឡើងពីគីលកាលទៅអស់១យប់
ស្រាប់តែមកដល់ភ្លាមក្នុងពេលដែលគេមិនដឹងខ្លួន ១០ព្រះ
យេហូវ៉ាទ្រង់បំបាក់ទ័ពគេ[ន] នៅមុខពួកកូនចៅអ៊ីស្រាអែល[ប]
ហើយលោកបានសំឡាប់គេនៅជិតក្រុងគីបៀន[ផ] ដោយការ
ប្រហារជីវិតយ៉ាងសំបើម ក៏ដេញគេតាមផ្លូវឡើងទៅឯ
បេត-ហូរ៉ុន[ព] ព្រមទាំងវាយគេរហូតទៅដល់អាសេកា[ភ]
ហើយដល់ម៉ាកេដាផង[ម] ១១កំពុងដែលគេរត់ពីមុខសាសន៍
អ៊ីស្រាអែល នៅត្រង់ផ្លូវដែលចុះពីបេត-ហូរ៉ុនទៅ នោះ
ព្រះយេហវ៉ាទ្រង់ក៏ទំលាក់ព្រិលជាដុំយ៉ាងធំៗ[យ] ពីលើមេឃ[រ]
មកលើគេ រហូតដល់អាសេកា ឱ្យគេត្រូវស្លាប់ ឯពួកអ្នក
ដែលស្លាប់នឹងព្រិល នោះមានគ្នាច្រើនជាងអស់អ្នកដែល
ពួកកូនចៅអ៊ីស្រាអែលបានសំឡាប់ដោយដាវទៅទៀត ។
១២រីឯនៅថ្ងៃដែលព្រះយេហូវ៉ា ទ្រង់បានប្រគល់ពួក
សាសន៍អាម៉ូរីនោះ[ល] មកក្នុងកណ្ដាប់ដៃនៃពួកកូនចៅអ៊ីស្រា
អែល នោះយ៉ូស្វេលោកទូលទៅព្រះយេហូវ៉ា នៅមុខពួក
កូនចៅអ៊ីស្រាអែលថា ថ្ងៃអើយ ចូរឈប់ទ្រឹងនៅពីលើក្រុង
គីបៀនចុះ ហើយខែក៏ដែរ ចូរទ្រឹងនៅត្រង់ច្រកភ្នំអាយ៉ា
ឡូនចុះ[វ] ១៣នោះថ្ងៃក៏ឈប់ទ្រឹង[ស] ហើយខែក៏នឹងនៅទាល់តែ
ពួកគេបានសងសឹកនឹងពួកខ្មាំងសត្រូវហើយ ការនោះបាន
កត់ទុកក្នុងសៀវភៅរបស់យ៉ាសើរហើយ[ហ] ថ្ងៃក៏ឈប់នឹង[ឡ]
នៅកណ្ដាលមេឃ ហើយមិនបានចុះ ដោយឆាប់រហ័សអស់
ពេញ១ថ្ងៃ ១៤មិនដែលមានថ្ងៃណាដូចថ្ងៃនោះ ទោះមុនឬ
ក្រោយ ដែលព្រះយេហូវ៉ាបានស្ដាប់តាមមនុស្សដូច្នេះឡើយ
ដ្បិតព្រះយេហូវ៉ាទ្រង់បានច្បាំង[អ]ជំនួសសាសន៍អ៊ីស្រាអែល
១៥រួចយ៉ូស្វេ និងពួកអ៊ីស្រាអែលទាំងអស់គ្នា ក៏ត្រឡប់វិល
មកឯទីដំឡើងត្រសាលនៅគីលកាលវិញ[ក] ។

**ការសម្លាប់ស្ដេចសាសន៍អាម៉ូរីទាំង៥អង្គ**

១៦ឯស្ដេចទាំង៥នោះ ក៏រត់[ខ]ទៅពួនក្នុងរអាងថ្មនៅ
ម៉ាកេដា ១៧ហើយមានគេមកជំរាបយ៉ូស្វេថា បានឃើញ
ស្ដេចទាំង៥នោះ ពួននៅក្នុងរអាងថ្មត្រង់ម៉ាកេដា ១៨រួច
យ៉ូស្វេបង្គាប់ថា ចូរប្រមៀលថ្មយ៉ាងធំទៅសន្ទប់មាត់រអាង
ទៅ ហើយដាក់មនុស្សឱ្យចាំយាមទៅទីនោះចុះ ១៩តែកុំឱ្យ
ឯងរាល់គ្នាបង្អង់ឈប់ឡើយ ឱ្យចេះតែដេញតាមខ្មាំង
សត្រូវទៅ ត្រូវឱ្យវាយពួកគេដែលនៅខាងក្រោយ កុំឱ្យគេ
ចូលទៅក្នុងក្រុងគេបានឡើយ ដ្បិតព្រះយេហូវ៉ា ជាព្រះនៃ
ឯង ទ្រង់បានប្រគល់គេមកក្នុងកណ្ដាប់ដៃឯងហើយ ២០លុះ
យ៉ូស្វេ និងពួកកូនចៅអ៊ីស្រាអែល បានសំឡាប់គេ ដោយ
ការប្រហារជីវិតយ៉ាងសំបើម ទាល់តែគេបានវិនាសអស់
រលីងទៅ[គ] ហើយពួកគេដែលសល់នៅ បានចូលទៅក្នុង
ទីក្រុងមានកំផែងរួចហើយ[ឃ] ២១នោះពួកជនទាំងអស់គ្នាក៏
ត្រឡប់វិលមកឯយ៉ូស្វេវិញ នៅទីដំឡើងត្រសាលត្រង់
ម៉ាកេដា ដោយសុខសាន្ត ឥតមានអ្នកណាបានហើបមាត់
ទាស់នឹងពួកកូនចៅអ៊ីស្រាអែលណាមួយសោះ ។
២២រួចយ៉ូស្វេបង្គាប់ថា ចូរបើកមាត់រអាងចុះ ហើយនាំ
ស្ដេចទាំង៥នោះ ចេញមកឯអញ ២៣គេក៏នាំស្ដេចទាំង៥
នោះ ចេញពីរអាងមកឯលោក គឺជាស្ដេចក្រុងយេរូសា-
ឡិម១ ស្ដេចក្រុងហេប្រុន១ ស្ដេចក្រុងយ៉ារមុត១ ស្ដេចក្រុង
ឡាគីស១ និងស្ដេចក្រុងអេក្លូន១ ២៤កាលគេបាននាំស្ដេច

**១០:៨** ធ ចទ ៧:២៤ **១០:១០** ន នក ១៤:២៤ ប ចទ ៧:២៣ ផ យស ៩:៣ ព យស ១៦:៣,៥ ១៨:១៣,១៤ ២១:២២ ១សយ ១៣:១៨ ១ពវ ៩:១៧ ១រប ៦:៦៨ ៧:២៤ ២រប ៨:៥ ២៥:១៣ ភ យស ១៥:៣៥ ១សយ ១៧:១ ២រប ១១:៩ នហ ១១:៣០ យរ ៣៤:៧ ម ខ.១៦,១៧,២១ យស ១២:១៦ ១៥:៤១ **១០:១១** យ នក ៩:១៨ ទដ ១៨:១២ អស ២៨:២,១៧ ៣២:១៩ អគ ១៣:១១,១៣ រ ពច ៥:២០ **១០:១២** ល អម ២:៩ វ យស ១៩:៤២ ២១:២៤ ពច ១:៣៥ ១២:១២ ១សយ ១៤:៣១ ១រប ៦:៦៩ ៨:១៣ ២រប ១១:១០ ២៨:១៨ **១០:១៣** ស ហព ៣:១១ ហ ២សយ ១:១៨ ឡ អស ៣៨:៨

**១០:១៤** អ ខ.៤២ នក ១៤:១៤ ទដ ១០៦:៤៣ ១៣៦:២៤ អស ៦៣:១០ យរ ២១:៥ **១០:១៥** ក ខ.៤៣ **១០:១៦** ខ ទដ ៦៨:១២ **១០:២០** គ ចទ ២០:១៦ ឃ ២រប ១១:១០ យរ ៤:៥ ៥:១៧ ៨:១៤ ៣៥:១

**១០:៩** *អស់១យប់* ជាចម្ងាយ ៣២ គម ដែលលោកយ៉ូស្វេបានធ្វើដំណើរឡើងតាមជើងភ្នំ ពីភាគខាងកើតនៃក្រុងគីបៀន ។ *ដែលមិនដឹងខ្លួន* លោកយ៉ូស្វេបានធ្វើការវាយប្រហារលើពួកគេតាំងពីព្រឹកព្រលឹម ហើយក៏ប្រហែលជានៅពេលដែលខែបាននៅទ្រឹង (ខ.១២) ។

**១០:១០** *បំបាក់ទ័ព* ពាក្យនេះនៅក្នុងគម្ពីរជាភាសាហេព្រើរមានន័យថា "បំភ័យ ឬធ្វើឱ្យបែកខ្ញាត់ខ្ញាយ" ។

**១០:១១** *ចុះពីបេត-ហូរ៉ុន* ទីនេះស្ថិតនៅបណ្ដោយទីជម្រាល ទៅដល់វាលរាបនៃច្រកភ្នំអាយ៉ាឡូន ហើយឆ្ពោះទៅផ្លូវបែកជាបួននៃទិសខាងកើត និងខាងលិចនៃភាគខាងជើងនៃក្រុងយេរូសាឡិម ។ *ព្រិលជាដុំយ៉ាងធំៗ* នេះជាការប្រើកម្លាំងធម្មជាតិជាគ្រឿងសញ្ញាវុធរបស់ទ្រង់ (សូមមើល ពច ៥:២០ ១សយ ៧:១០ យប ៣៨:២២-២៣ ទដ ១៨:១២-១៤) ។

**១០:១៣** *សៀវភៅរបស់យ៉ាសើរ* នេះជាការរៀបរាប់ជាលើកដំបូងរបស់សង្គ្រាមអ៊ីស្រាអែល (ប្រហែលជាគ្រប់ទម្រង់កំណាព្យទាំងអស់ សូមមើល ២សយ ១:១៨ និង ពច ៥:១-៣១) ប៉ុន្តែឥឡូវវាបាត់បង់អស់ហើយ ។ *ហើយមិនបានចុះ* អ្នកខ្លះជឿថា ព្រះអម្ចាស់បានពន្យាពេលនៅពេលថ្ងៃសម្រាប់ពួកអ៊ីស្រាអែលក្នុងការវាយប្រហារខ្មាំងសត្រូវពួកគេ ។ ចំណែកឯអ្នកផ្សេងទៀត បានលើកឡើងថា ព្រះអាទិត្យនៅតែត្រជាក់ (ប្រហែលជាមេឃស្រទំ) ពេញមួយថ្ងៃ ដែលផ្ដល់ឱ្យការវាយប្រហារនេះបន្តរហូតដល់ថ្ងៃរសៀល ។ ជាការពិតយើងមិនដឹងថាមានអ្វីបានកើតឡើងទេ នៅពេលនោះគឺលើកលែងតែមានអន្តរាគមន៍ពីព្រះអម្ចាស់ប៉ុណ្ណោះ ។

**១០:១៦** *ម៉ាកេដា* ក្រុងនេះនៅជិតនឹងក្រុងអាសេកា (ខ.១០) នៅភាគខាងជើងនៃជើងភ្នំ ជាទីដែលពួកទ័ពរបស់លោកយ៉ូស្វេបានបោះជំរុំនៅទីនោះ ។

**១០:១៩** *ឱ្យចេះតែដេញតាមខ្មាំងសត្រូវទៅ* នៅត្រង់នេះពួកអ្នកចម្បាំងភាគច្រើនការពារទិសខាងត្បូងទីក្រុងត្រូវបានចាប់ខ្លួន និងសម្លាប់ មុនពេលពួកគេអាចចូលមកទីដែលមានសុវត្ថិភាពនៃប៉មរបស់ពួកគេ ។

**១០:២១** *ឥតមានអ្នកណាបានហើបមាត់* នៅត្រង់នេះបញ្ជាក់ថា ពួកគេមិនហ៊ានតវ៉ាប្រឆាំងនឹងពួកអ៊ីស្រាអែលទៀតឡើយ ។

**១០:២៤** *ចូរអ្នករាល់គ្នាមកជាន់កស្ដេចទាំងនេះទៅ* នេះជាភាពអាម៉ាសជា

ទាំងនោះ[ង] ចេញមកដល់យ៉ូស្វេហើយ នោះយ៉ូស្វេក៏ហៅ
ប្រជុំពួកអ៊ីស្រាអែលទាំងអស់គ្នាមក រួចបង្គាប់ដល់ពួកមេ
ទ័ព ដែលបានទៅជាមួយនឹងលោកថា ចូរឯងរាល់គ្នាមក
ជាន់[ច]កស្តេចទាំងនេះទៅ ដូច្នេះគេក៏មកជាន់[ឆ]កស្តេចទាំង
នោះ ២៥ហើយយ៉ូស្វេប្រាប់គេថា កុំឱ្យខ្លាចឡើយ ក៏កុំឱ្យ
ស្រយុតចិត្តផង ត្រូវឱ្យមានកំឡាំង និងចិត្តក្លាហានឡើង[ជ]
ដ្បិតព្រះយេហូវ៉ាទ្រង់នឹងធ្វើយ៉ាងនេះដល់ខ្មាំងសត្រូវទាំង
អស់ ដែលឯងត្រូវតតាំងនឹងគេដែរ ២៦ក្រោយមកយ៉ូស្វេក៏
វាយសំឡាប់ស្តេចទាំងនោះ រួចព្យួរនៅដើមឈើ៥ដើម
ទាល់តែដល់ថ្ងៃល្ងាច ២៧លុះដល់ពេលថ្ងៃហៀបលិច
ហើយ[ឈ] នោះយ៉ូស្វេក៏បង្គាប់ឱ្យគេដាក់ខ្មោចទាំងនោះ ចុះ
ពីដើមឈើមក យកទៅបោះចោលក្នុងរអាងដែលបានពួន
នោះ រួចគេដាក់ថ្មយ៉ាងធំសន្ធប់នៅមាត់រអាង នៅរហូត
មកដល់ថ្ងៃនេះ[ញ]។

២៨នៅថ្ងៃនោះឯង យ៉ូស្វេក៏ចាប់យកក្រុងម៉ាកេដា ហើយ
កាប់សំឡាប់គេដោយមុខដាវ ព្រមទាំងស្តេចគេផង លោក
បានបំផ្លាញគេ និងអស់អ្នក ដែលនៅក្នុងក្រុងនោះ អស់
រលីង ឥតមានឱ្យអ្នកណាមួយនៅសល់ឡើយ[ដ] លោកបាន
ប្រព្រឹត្តនឹងស្តេចក្រុងម៉ាកេដានោះ ដូចជាបានប្រព្រឹត្តនឹង
ស្តេចក្រុងយេរីខូរដែរ[ឋ]។

## ការកាន់កាប់ក្រុងខាងត្បូង

២៩រួចយ៉ូស្វេ និងពួកអ៊ីស្រាអែលទាំងអស់គ្នា ក៏ចេញពី
ក្រុងម៉ាកេដាទៅដល់លិបណា[ឌ] ច្បាំងនឹងក្រុងនោះ ៣០ព្រះ
យេហូវ៉ាទ្រង់ក៏ប្រគល់ក្រុងនោះនឹងស្តេចគេ មកក្នុងកណ្តាប់
ដៃនៃពួកអ៊ីស្រាអែលដែរ ហើយលោកកាប់គេដោយមុខ
ដាវ គឺពួកអ្នកដែលនៅក្នុងក្រុងនោះទាំងអស់ ឥតមានឱ្យ
អ្នកណានៅសល់ឡើយ លោកបានប្រព្រឹត្តនឹងស្តេចក្រុង
នោះ ដូចជាបានប្រព្រឹត្តនឹងស្តេចក្រុងយេរីខូរដែរ ។

៣១លំដាប់នោះ យ៉ូស្វេនិងពួកអ៊ីស្រាអែលទាំងអស់គ្នា
ក៏ចេញពីលិបណាទៅដល់ឡាគីស[ឍ] បោះទ័ពទាស់នឹងក្រុង
នោះ ហើយច្បាំងនឹងគេ ៣២ព្រះយេហូវ៉ាទ្រង់ក៏ប្រគល់ក្រុង
ឡាគីស មកក្នុងកណ្តាប់ដៃនៃពួកអ៊ីស្រាអែលដែរ ហើយ
លោកចាប់យកបាននៅថ្ងៃទី២ រួចកាប់គេដោយមុខដាវ
គឺអស់អ្នកដែលនៅក្នុងក្រុងនោះទាំងប៉ុន្មាន តាមគ្រប់ទាំង
ការ ដែលបានធ្វើដល់ក្រុងលិបណា ៣៣នោះហោរ៉ាម
ជាស្តេចក្រុងកេស៊ើរ[ណ] ក៏ឡើងមកជួយក្រុងឡាគីស តែ
យ៉ូស្វេលោកវាយស្តេចនោះ និងពួករាស្ត្រទ្រង់ទាំងអស់ទៅ
ទាល់តែគ្មានអ្នកណាមួយនៅសល់ឡើយ ។

៣៤រួចមក យ៉ូស្វេនិងពួកអ៊ីស្រាអែលទាំងអស់គ្នាក៏ចេញ
ពីក្រុងឡាគីសទៅដល់អេក្លូន[ត] បោះទ័ពទាស់នឹងក្រុងនោះ
ហើយច្បាំងនឹងគេ ៣៥ក៏ចាប់យកបាននៅថ្ងៃនោះឯង រួច
កាប់គេដោយមុខដាវ ព្រមទាំងបំផ្លាញពួកអ្នកដែលនៅក្រុង
នោះអស់រលីងក្នុងថ្ងៃនោះ ដូចជាបានធ្វើដល់ក្រុងឡាគីស
ដែរ ។

៣៦តមក យ៉ូស្វេ និងពួកអ៊ីស្រាអែលទាំងអស់គ្នា ក៏ចេញ
ពីក្រុងអេក្លូនឡើងទៅដល់ហេប្រុន[ថ] ច្បាំងនឹងគេទៀត
៣៧ហើយចាប់យកក្រុងនោះបាន រួចកាប់គេដោយមុខដាវ
ព្រមទាំងស្តេច និងអស់ទាំងតំបន់គេ ហើយអស់អ្នកដែល
នៅក្រុងនោះផង ឥតមានទុកឱ្យអ្នកណាមួយ[ទ]នៅសល់ឡើយ
តាមគ្រប់ទាំងការ ដែលលោកបានធ្វើដល់ក្រុងអេក្លូនដែរ
លោកបានបំផ្លាញក្រុងនោះ និងពួកអ្នកទាំងប៉ុន្មាន ដែល
នៅក្នុងក្រុងអស់រលីង ។

៣៨រួចយ៉ូស្វេ និងពួកអ៊ីស្រាអែលទាំងអស់គ្នា ក៏បត់ទៅ
ឯក្រុងដេបៀរ ច្បាំងនឹងគេទៀត[ធ] ៣៩លោកចាប់យកក្រុង
នោះ ព្រមទាំងស្តេចគេ និងតំបន់គេទាំងប៉ុន្មានបានរួច ក៏
កាប់គេដោយមុខដាវ ហើយបំផ្លាញពួកអ្នកនៅក្នុងក្រុង
នោះអស់រលីង ឥតមានទុកឱ្យអ្នកណាមួយនៅសល់ឡើយ
លោកបានប្រព្រឹត្តនឹងក្រុងដេបៀរ ហើយនិងស្តេចគេ ដូច
ជាបានប្រព្រឹត្តដល់ក្រុងហេប្រុន ហើយដូចជាបានប្រព្រឹត្ត
នឹងក្រុងលិបណា ព្រមទាំងស្តេចគេដែរ[ន]។

៤០ដូច្នេះយ៉ូស្វេវាយស្រុកនោះទាំងអស់បាន គឺស្រុកភ្នំ
ស្រុកត្បូង ស្រុកទំនាប[ប] ស្រុកជំរាល[ផ] ព្រមទាំងស្តេចគេ
ទាំងប៉ុន្មាន[ព] ឥតមានទុកឱ្យអ្នកណាមួយនៅសល់ឡើយ គឺ
បានបំផ្លាញអស់ទាំងទីក្រុង និងគ្រប់ទាំងអស់ដែលមាន

**១០:២៤** ង ចទ ៧:២៤ ច មឡ ៤:៣ ឆ ២សយ ២២:៤០ ទដ ១១០:១ អស ៥១:២៣
**១០:២៥** ជ ចទ ៣១:៦
**១០:២៧** ឈ ចទ ២១:២៣ ញ លប ៣៥:២០
**១០:២៨** ដ ចទ ២០:១៦ ឋ ខ.៣០, ៣២,៣៥,៣៩ យស ៦:២១
**១០:២៩** ឌ ជន ៣៣:២០
**១០:៣១** ឍ ខ.៣
**១០:៣៣** ណ យស ១២:១២ ១៦:៣,១០ ២១:២១ ពច ១:២៩ ២សយ ៥:២៥ ១ពវ ៩:១៥ ១របា ៦:៦៧
**១០:៣៤** ត ខ.៣
**១០:៣៦** ថ លប ១៣:១៨ យស ១៤:១៣ ១៥:១៣ ២០:៧ ២១:១១ ពច ១៦:៣
**១០:៣៧** ទ ខ.២៨
**១០:៣៨** ធ ខ.៣
**១០:៣៩** ន ខ.២៨
**១០:៤០** ប លប ១២:៩ យស ១២:៨ ១៥:១៩,២១ ១៨:២៥ ១៩:៨ ១សយ ៣០:២៧ ផ ចទ ១:៧ ព ចទ ៧:២៤

សាធារណៈរបស់ពួកសត្រូវជាប្រមុខដឹកនាំនោះ គឺជាទូទៅសង្គ្រាមមាន កម្រិតកំពូលនៅមជ្ឈឹមបូព៌ានាសម័យបុរាណ ។

**១០:២៦** *ព្យួរនៅដើមឈើ៥ដើម* សូមមើលការពន្យល់ ចទ ២១:២២ ។

**១០:២៧** *គេដាក់ថ្មយ៉ាងធំសន្ធប់* នេះជាបូជនីដ្ឋានទីប្រាំមួយ នៅក្នុងទឹកដីដែលព្រឹត្តិការណ៍សង្គ្រាម (មើលការពន្យល់ ៤:៩) ។

**១០:២៨** *បានបំផ្លាញគេ និងអស់អ្នក* នេះជាបម្រាមបរិសុទ្ធ ដែលបានដាក់ទៅលើពួកអ្នកក្រុងម៉ាកេដា មានន័យថាពួកគេត្រូវតែបូជាសេចក្តីស្លាប់របស់គេសម្រាប់អំពើកោងកាចរបស់ពួកគេ ។ អំពើបាបដូចគ្នានេះ បានធ្លាក់ទៅដល់អ្នកផ្សេងទៀតដែលរស់នៅឯក្រុងភាគខាងត្បូង (មើល ខ.២៩–៤២) ។

**១០:៣៣** *ហោរ៉ាម ជាស្តេចក្រុងកេស៊ើរ* ស្តេចនេះ មានអំណាចខ្លាំងបំផុតនៅតំបន់នោះ ។ ក្រុងកេស៊ើរ ជាចុងក្រោយត្រូវបានរឹបអូសដោយពួកអេស៊ីព្ទ ហើយជូនទៅដល់ស្តេចសាឡូម៉ូនជាអំណោយអាពាហ៍ពិពាហ៍ (សូមមើល ១ពវ ៩:១៦) ។

**១០:៣៨** *ដេបៀរ* ក្រុងនេះត្រូវបានគេស្គាល់ថា គារយ៉ាត់–សេភើរ ។

ដង្ហើមឱ្យអស់រលីង ដូចជាព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល បានបង្គាប់មក[ភ] ៤១យ៉ូស្វេបានវាយគេ ចាប់
តាំងពីកាដេស-បារនា[ម] រហូតដល់ក្រុងកាសា[យ] ព្រមទាំង
ស្រុកកូសែនទាំងអស់[រ] រហូតដល់គីបៀនដែរ ៤២លោកបាន
ចាប់យកស្តេចទាំងប៉ុន្មាន និងស្រុករបស់គេក្នុង១គ្រាចំបាំង
នោះ ដ្បិតព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់បានច្បាំង[ល]ជំនួសអ៊ីស្រាអែល ៤៣រួចយ៉ូស្វេនិងពួក
អ៊ីស្រាអែលទាំងអស់គ្នា ក៏ត្រឡប់វិលមកដល់ទីដំឡើង
ត្រសាលនៅគីលកាលវិញ[វ] ។

## ការឈ្នះពួកស្តេចនៅខាងជើង

**១១** ១កាលយ៉ាប៊ីន[ក] ជាស្តេចក្រុងហាសោរ[ខ] បានឮពីការ
ទាំងនោះហើយ នោះក៏ចាត់សារទៅឯយ៉ូបាប់ជាស្តេច
ក្រុងម៉ាដូន និងស្តេចក្រុងស៊ីមរ៉ុន[គ] ស្តេចក្រុងអាកសាប[ឃ]
២ហើយនិងពួកស្តេចដែលនៅខាងជើង[ង] គឺក្នុងស្រុកភ្នំ នៅ
ស្រុកវាល ជាខាងត្បូងសមុទ្រគេនេសារ៉ែត នៅស្រុក
ទំនាប[ច] ហើយនៅស្រុកទំនួលនៃក្រុងដោរ[ឆ]ខាងលិច ៣ទៅ
ឯសាសន៍កាណាន ដែលនៅខាងកើត ខាងលិច និងសាសន៍
អាម៉ូរី សាសន៍ហេត សាសន៍ពេរិស៊ីត[ជ] ហើយសាសន៍
យេប៊ូសដែលនៅស្រុកភ្នំ[ឈ] ហើយនិងសាសន៍ហេវី[ញ] នៅ
ស្រុកមីសប៉ា[ដ] នាជើងភ្នំហើម៉ូន[ឋ] ៤គេក៏នាំពួកពលរបស់គេ
ទាំងប៉ុន្មានចេញមក មានគ្នាសន្ធឹកដូចជាខ្សាច់នៅមាត់
សមុទ្រ មានទាំងសេះ និងរទេះចំបាំងជាច្រើនណាស់[ឌ]
៥ស្តេចទាំងនោះក៏មូលគ្នាមកបោះទ័ព[ឍ] នៅត្រង់ទឹកមេរ៉ុម[ណ]
ដើម្បីច្បាំងនឹងសាសន៍អ៊ីស្រាអែល ។
៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេថា កុំឱ្យភ័យខ្លាច
ដោយព្រោះគេឡើយ ដ្បិតថ្ងៃស្អែក វេលាថ្មើរណេះ អញ
នឹងប្រគល់គេឱ្យស្លាប់ទាំងអស់ នៅមុខ[ត]អ៊ីស្រាអែល ត្រូវឱ្យ
កាប់សរសៃកជើង[ថ]សេះគេ ហើយដុតរទេះចំបាំងដោយ
ភ្លើងផង[ទ] ៧ដូច្នេះយ៉ូស្វេនឹងពួកអ្នកថ្មីកច្បាំងទាំងប៉ុន្មាន
ក៏ទៅទាស់នឹងគេ ត្រង់ទឹកមេរ៉ុម ឥតគេដឹងខ្លួនសោះ ហើយ
ស្ទុះចូលទៅលើគេ ៨ព្រះយេហូវ៉ាទ្រង់ក៏ប្រគល់គេមកក្នុង
កណ្តាប់ដៃនៃពួកអ៊ីស្រាអែល ពួកអ៊ីស្រាអែលបានវាយគេ
ហើយដេញតាម រហូតទៅដល់ក្រុងស៊ីដូនដ៏ជាក្រុងធំ[ធ]
និងដល់ក្រុងមីសរិផូត-ម៉ែម[ន] ហើយនិងដល់វាលច្រកភ្នំ
មីសប៉ាខាងកើត គឺវាយគេទាល់តែគ្មានអ្នកណាមួយនៅ
សល់ឡើយ ៩យ៉ូស្វេបានប្រព្រឹត្តនឹងគេ ដូចជាព្រះយេហូវ៉ា
ទ្រង់បានបង្គាប់មក គឺបានកាប់សរសៃកជើងសេះ ព្រមទាំង
ដុតរទេះចំបាំងរបស់គេផង ។
១០គ្រានោះ យ៉ូស្វេក៏បត់មកចាប់យកក្រុងហាសោរ

**១០:៤០** ភ ចទ ២០:១៦-១៧ **១០:៤១** ម លប ១៤:៧ យ លប ១០:១៩ រ យស ១១:១៦ ១៥:៥១ **១០:៤២** ល ខ.១៤ **១០:៤៣** វ ខ.១៥ យស ៥:៩ ១សយ ៧:១៦ ១០:៨ ១១:១៤ ១៣:១២ **១១:១** ក ពច ៤:២,៧,២៣ ទដ ៨៣:៩ ខ ខ.១០ យស ១២:១៩ ១៥:២៣,២៥ ១៩:៣៦ ពច ៤:២,១៧ ១សយ ១២:៩ ១ពវ ៩:១៥ ២ពវ ១៥:២៩ នហ ១១:៣៣ យរ ៤៩:២៨,៣៣ គ យស ១៩:១៥ ឃ យស ១២:២០ ១៩:២៥ **១១:២** ង ជន ៤៣:១១ ចទ ៣:១៧ យស ១៩:៣៥ ១ពវ ១៥:២០ ច ខ.១៦

ចទ ១:១ យស ១២:១ ១៨:១៨ ឆ យស ១២:២៣ ១៧:១១ ពច ១:២៧ ១ពវ ៤:១១ ១រប ៧:២៩ **១១:៣** ជ យស ៣:១០ ឈ ជន ១៣:១៧ ញ នក ៣:៨ ចទ ៧:១ ពច ៣:៣,៥ ១ពវ ៩:២០ ដ ខ.៨ លប ៣១:៤៩ យស ១៥:៣៨ ១៨:២៦ ពច ១១:១១ ២០:១ ២១:១ ១សយ ៧:៥,៦ ១ពវ ១៥:២២ ២ពវ ២៥:២៣ ឋ ចទ ៣:៨ **១១:៤** ឌ លប ១២:២ ពច ៧:១២ ១សយ ១៣:៥ **១១:៥** ឍ ពច ៥:១៩ ណ ខ.៧ **១១:៦** ត យស ២:២៤ ថ លប ៤៩:៦ ទ ខ.៩ **១១:៨** ធ លប ១០:១៥ ពច ១៨:៧ ន យស ១៣:៦

**១០:៤១** *កាដេស-បារនា រហូតដល់ក្រុងកាសា* នេះជាការកំណត់ព្រំដែនពីទិសខាងត្បូង ទៅទិសខាងជើង កំណត់ដោយភាគខាងលិចនៃតំបន់ ។ *កូសែន* ពាក្យនេះកម្រប្រើនៅតំបន់ភាគខាងលិច ហើយវាមិនមានភាពផ្ទុយគ្នានឹងពាក្យថា "កូសែន" ដែលជាអក្ខរក្រមទីបួនរបស់អេស៊ីព្ទ ហើយពាក្យនេះក៏ជាឈ្មោះក្រុងផងដែរ (១៥:១៥) ។ កូសែន និងគីបៀនបានគូសសញ្ញាខណ្ឌរវាងខាងត្បូងនិងខាងលិច ហើយតំបន់នេះស្ថិតនៅភាគខាងកើតនៃតំបន់ទាំងពីរនេះ ។

**១១:១-២៣** នៅវគ្គនេះមាននៅសល់សង្គ្រាមខ្លះ នៅភាគខាងជើង ។ សង្គ្រាមនៃតំបន់ជើងភ្នំកាលីឡេ គឺត្រូវបានគេវាយប្រហារ ហើយទទួលបានជ័យជម្នះប្រឆាំងនឹងពួកហាសោរ និងសម្ព័ន្ធប្រទេសដទៃនៅភាគខាងជើង ការសន្និដ្ឋានដែលមានដូចខាងក្រោមនៃជ័យជម្នះរបស់លោកយ៉ូស្វេ មាននៅភាគខាងត្បូង និងតំបន់កណ្តាលផងដែរ ។

**១១:១** *យ៉ាប៊ីន ជាស្តេចក្រុងហាសោរ* ឈ្មោះយ៉ាប៊ីននេះប្រហែលជាឈ្មោះតំណវង្ស ហើយឈ្មោះនេះត្រូវបានប្រើដើម្បីប្រឆាំងនឹងថ្ងៃនៃដេបូរ៉ា (សូមមើល ពច ៤:២) ។

**១១:២** *គេនេសារ៉ែត* ពាក្យនេះមានន័យថា "ពិណ" គឺជាសមុទ្រកាលីឡេ ។

**១១:៤** *សន្ធឹកដូចជាខ្សាច់* ឃ្លានេះត្រូវបានគេប្រើក្នុងន័យបញ្ជាក់ពីចំនួនច្រើន (សូមមើលការពន្យល់ លប ២២:១៧) ។

**១១:៥** *ស្តេចទាំងនោះ* នេះជាការប្រមូលផ្តុំរបស់ស្តេចយ៉ាប៊ីនបន្តរហូតទៅដល់ស្រុកវាល (ខ.២) ចាប់ពីជ្រលងទន្លេយ័រដាន់ និងបន្តទៅក្រុងដោរតាមសមុទ្រម៉េឌីទែរ៉ាណេ ខាងត្បូងភ្នំកាមែល ។ *មេរ៉ុម* ក្រុងនេះមានចម្ងាយ ១,២៨ គ.ម ខាងជើងសមុទ្រកាលីឡេ ។

**១១:៦** *សរសៃកជើងសេះគេ* នៅត្រង់នេះពួកអ៊ីស្រាអែលកាត់សរសៃពួ ខាងលើគន្លាក់កជើងសេះរបស់ពួកគេ ដែលសេះទាំងអស់នោះពិការ ដូច្នេះហើយវាមិនអាចបន្តដំណើរទៅមុខទៀតបាន ។ *ដុតរទេះចំបាំង* នេះជាឧបករណ៍នាំមុខគេនៃកាធ្វើសង្គ្រាម ដែលឧបករណ៍នេះពួកទាហានអ៊ីស្រាអែលមិនបានប្រើរហូតដល់សម័យស្តេចសាឡូម៉ូន (២ពវ ៩:២២ ១០:២៦-២៩) ។

**១១:១០** *យ៉ូស្វេ . . . ចាប់យកក្រុងហាសោរ* នៅត្រង់នេះប្រហែលជាជ័យជម្នះដ៏ធំធេងមួយរបស់គាត់ ។ ទោះបីកងទ័ពរបស់ក្រុងហាសោរបានវាយប្រហារត្រង់មេរ៉ុមមុនក៏ដោយ ។ យោងតាមទីតាំងបុរាណវិទ្យាបានឱ្យដឹងថាការបំផ្លាញដ៏ធំធេង ហើយនិងការដុតទីក្រុងកាណានប្រហែលជានៅឆ្នាំ ១៤០០ ឬ ១៣០០ មុនគ.ស ហើយម្តងទៀតប្រហែលនៅឆ្នាំ១២៣០ មុនគ.ស។ ចាប់តាំងពីវិនាសកម្មនៅ ឆ្នាំ១៣០០ មុន គ.ស មក ការនេះប្រហែលជាការឆេះទីក្រុងដែលធ្វើឡើងដោយស្តេចផារ៉ោនទី១ ហើយវិនាសកម្មនេះត្រូវបញ្ចប់ប្រហែលជានៅឆ្នាំ ១៤០០ ឬ ១២៣០ មុន គ.ស នៃសង្គ្រាមរបស់

ហើយកាប់ស្តេចគេដោយដាវ[ប] ឯក្រុងហាសោរ នេះ ពីដើម
ជាក្រុងធំ ត្រួតលើនគរទាំងនោះ ១១ពួកអ៊ីស្រាអែលក៏កាប់
ពួកអ្នកដែលនៅក្នុងក្រុងនោះ ដោយមុខដាវ ព្រមទាំង
បំផ្លាញគេអស់រលីង[ផ] ឥតមានទុកអ្វីៗដែលមានដង្ហើមឱ្យ
នៅសល់ឡើយ[ព] ហើយដុត[ភ]ទីក្រុងហាសោរ នោះចោល
ដែរ ១២ឯទីក្រុងរបស់ស្តេចទាំងនោះ ព្រមទាំងស្តេចគេផង
នោះយ៉ូស្វេចាប់យកបានទាំងអស់ ហើយលោកកាប់គេ
ដោយមុខដាវ ទាំងបំផ្លាញគេអស់រលីង ដូចជាលោកម៉ូសេ
ជាអ្នកបំរើរបស់ព្រះយេហូវ៉ា បានបង្គាប់មក[ម] ១៣តែឯទី
ក្រុងទាំងប៉ុន្មានដែលនៅលើទីទំនួល នោះពួកអ៊ីស្រាអែល
មិនបានដុតទេ លើកតែក្រុងហាសោរ១ ដែលយ៉ូស្វេបាន
ដុតប៉ុណ្ណោះ ១៤ពួកកូនចៅអ៊ីស្រាអែលគេយករបស់ទាំង
អស់ ដែលនៅក្នុងក្រុងទាំងនោះ និងហ្វូងសត្វទុកជារបឹប
សំរាប់ខ្លួនគេ តែឯមនុស្សទាំងប៉ុន្មាន នោះបានកាប់ដោយ
មុខដាវវិញ ទាល់តែបានបំផ្លាញអស់រលីង ឥតមានទុកអ្វីៗ
ដែលមានដង្ហើមឱ្យនៅសល់ឡើយ[យ] ១៥ឯសេចក្តីដែលព្រះ
យេហូវ៉ាបានបង្គាប់មកលោកម៉ូសេ ជាអ្នកបំរើទ្រង់ នោះ
លោកម៉ូសេក៏បង្គាប់ដល់យ៉ូស្វេដែរ ហើយយ៉ូស្វេក៏ធ្វើតាម
ដូច្នោះ លោកមិនបានវៀរបង់ចំពោះអ្វីៗ ក្នុងគ្រប់ទាំង
សេចក្តី ដែលព្រះយេហូវ៉ាទ្រង់បានបង្គាប់ដល់លោកម៉ូសេ
ឡើយ[រ] ។

១៦ដូច្នេះយ៉ូស្វេបានចាប់យកស្រុកនោះទាំងអស់ គឺស្រុក
ភ្នំ[ល] ស្រុកត្បូង ស្រុកកូសែនទាំងអស់ ស្រុកទំនាបហើយ
ស្រុកវាល[វ] ព្រមទាំងស្រុកភ្នំ[ស] ទាំងស្រុកទំនាបរបស់ស្រុក
អ៊ីស្រាអែលផង ១៧ចាប់តាំងពីភ្នំហាឡាក ត្រង់កន្លែងដែល
ឡើងទៅឯភ្នំសៀរ[ហ] រហូតដល់បាល-កាឌ់[ឡ] ដែលនៅ
ក្នុងវាលច្រកភ្នំល្បាណូន[អ] ត្រង់ជើងភ្នំហើម៉ូន[ក] លោកក៏
ចាប់បានស្តេចគេទាំងអស់ ហើយវាយសំឡាប់ចោលទៅ[ខ]
១៨យ៉ូស្វេបានច្បាំងនឹងស្តេចទាំងនោះជាយូរ ១៩គ្មានទីក្រុង
ណាមួយបានចងស្ពានមេត្រី[គ]នឹងពួកកូនចៅអ៊ីស្រាអែល
ឡើយ លើកតែសាសន៍ហេវី[ឃ]ដែលនៅក្រុងគីបៀនប៉ុ-
ណ្ណោះ[ង] ក្រៅពីនោះ ពួកកូនចៅអ៊ីស្រាអែលចាប់យកទាំង
អស់បានដោយច្បាំង ២០ដ្បិតព្រះយេហូវ៉ាទ្រង់បានបណ្តាល
ចិត្តគេឱ្យរឹងទទឹង[ច] ដើម្បីឱ្យគេចេញមកច្បាំងនឹងពួកអ៊ីស្រា-
អែល ប្រយោជន៍ឱ្យទ្រង់បានបំផ្លាញគេអស់រលីងទៅឥត
មានប្រណីឡើយ គឺឱ្យលោកបានបំផ្លាញគេដូចជាព្រះ
យេហូវ៉ាបានបង្គាប់មកលោកម៉ូសេ[ឆ] ។

២១នៅគ្រានោះយ៉ូស្វេក៏ទៅវាយសាសន៍អ័ណាក់[ជ] ឱ្យសូន្យ
បាត់ពីស្រុកភ្នំ ពីក្រុងហេប្រុន ក្រុងដេបៀរ[ឈ] ក្រុងអា-
ណាប[ញ] ពីស្រុកភ្នំរបស់យូដា និងស្រុកភ្នំរបស់អ៊ីស្រាអែល
ទាំងអស់ទៅ គឺលោកបានបំផ្លាញគេ និងទីក្រុងគេអស់
រលីង ២២គ្មានសល់ពួកសាសន៍អ័ណាក់ណាមួយនៅក្នុងស្រុក
របស់ពួកកូនចៅអ៊ីស្រាអែលឡើយ សល់នៅតែក្នុងក្រុង
កាសា[ដ] ក្រុងកាថ[ឋ] និងក្រុងអាសដូឌ[ឌ]ប៉ុណ្ណោះ ២៣ដូច្នេះ
យ៉ូស្វេបានចាប់យកស្រុកទាំងអស់[ឍ] តាមគ្រប់ទាំងសេចក្តី
ដែលព្រះយេហូវ៉ាបានបង្គាប់មកលោកម៉ូសេ រួចលោក
ចែកស្រុកទាំងនោះជាមរដក[ណ] ដល់សាសន៍អ៊ីស្រាអែល
តាមពួកក្នុងពូជអំបូរគេរៀងខ្លួន[ត,ថ] ស្រុកនោះក៏បានស្រាក
ស្រាន្ត[ទ]ពីចំបាំងទៅ[ធ] ។

## បញ្ជីឈ្មោះស្តេចដែលបានយកឈ្នះ

**១២** ១រីឯពួកស្តេចទាំងប៉ុន្មាននៅស្រុកនោះ ដែលពួក
កូនចៅអ៊ីស្រាអែលបានវាយ ហើយចាប់យក[ក]ស្រុកគេនៅ

**១១:១០** ប អស ៣:២៥ យរ ៤១:២ ៤៤:១៨ **១១:១១** ផ ចទ ៧:២ ព ចទ ២០:១៦-១៧ ភ ជន ៣១:១០ **១១:១២** ម ជន ៣៣:៥០-៥២ ចទ ៧:២ **១១:១៤** យ ចទ ២០:១៦ **១១:១៥** រ នក ៣៤:១១ ចទ ៧:២ យស ១:៧ **១១:១៦** ល ជន ១៣:១៧ វ ចទ ១:៧ ស យស ១០:៤១ **១១:១៧** ហ លប ១៤:៦ ជន ២៤:១៨ ចទ ៣៣:២ ឡ យស ១៣:៥ អ ចទ ៣:២៥ យស ១២:៧ ក ចទ ៣:៩ យស ១២:៨ ខ ចទ ៧:២៤ **១១:១៩** គ យស ៩:១៥ ឃ យស ៩:១ ង យស ៩:៣ **១១:២០** ច នក ៤:២១ ១៤:១៧ រម ៩:១៨ ឆ ចទ ៧:១៦ ពច ១៤:៤ **១១:២១** ជ ជន ១៣:២២,៣៣ ឈ យស ១០:៣ ញ យស ១៥:៥០ **១១:២២** ដ លប ១០:១៩ ឋ យស ១២:១៧ ១៩:១៣ ១សយ ៥:៨ ១៧:៤ ១ពវ ២:៣៩ ២ពវ ១៤:២៥ ១រប ៨:១៣ អម ៦:២ ឌ យស ១៥:៤៧ ១សយ ៥:១ អស ២០:១ **១១:២៣** ឍ យស ២១:៤៣-៤៥ នហ ៩:២៤ ណ ចទ ១:៣៨ ១២:៩-១០ ២៥:១៩ យស ១៣:៧ ត ជន ២៦:៥៣ ថ ទដ ១០៥:៤៤ ទ នក ៣៣:១៤ ធ យស ១៤:១៥ **១២:១** ក ទដ ១៣៦:២១

លោកយ៉ូស្វេ ។ ជាថ្មីម្តងទៀត សង្គ្រាមនៃការបំផ្លាញ ត្រូវបានសរុបនៅក្នុង ខ.១១ ទាំងស្រុង ។

**១១:១៣** *ទីទំនួល* ទីនេះជាភ្នំដែលកកើតឡើងដោយកំទិចកំទី នៃការតាំងទីលំនៅជាច្រើននៅកន្លែងមួយ នៅលើទីដ៏ខ្ពស់ផ្សេងទៀត (សូមមើលការពន្យល់ ៧:២ យរ ៣០:១៨) ។

**១១:១៥** *លោកមិនបានវៀរបង់* ជ័យជម្នះរបស់លោកយ៉ូស្វេ អាចជារង្វាស់នៅក្នុងពន្លឺដ៏ជាក់លាក់តាមលំដាប់លំដោយមួយ ដែលព្រះអម្ចាស់ជាអ្នកផ្តល់ឱ្យគាត់ ។ លោកយ៉ូស្វេបានបំពេញយ៉ាងល្អលើសជាងតំបន់ទាំងអស់ ដែលជាចុងក្រោយពួកអ៊ីស្រាអែលបានកាន់កាប់នោះទៅទៀត ។

**១១:១៧** *ភ្នំហាឡាក* នេះជាវាលខ្សាច់ដ៏ធំល្វឹងល្វើយ នៃភាគខាងកើតតំបន់កាដេស ដែលធ្វើឱ្យពួកអ៊ីស្រាអែលមានទឹកដីធំល្វឹងល្វើយ ។ *បាល-កាឌ់* តំបន់នេះជាជ្រលងទន្លេទី១ នៅភាគខាងលិចនៃភ្នំហើម៉ូន ។

**១១:១៨** *ជាយូរ* នេះជាការប៉ាន់ប្រមាណរយៈពេលសង្គ្រាមរបស់លោកយ៉ូស្វេ អាចជាជីវិតរបស់លោកកាលែប គឺរយៈពេល៧ឆ្នាំដែលកន្លងហួសពីការចាប់ផ្តើមសង្គ្រាម(អាយុ ៧៨ ធៀបនឹង ១៤:៧ និង ចទ ២:១៤) រហូតគាត់យកបានស្រុកហេប្រុន(អាយុ ៨៥ សូមមើល ១៤:១០) ។

**១១:២០** *ព្រះយេហូវ៉ា . . . បណ្តាលចិត្តគេឱ្យរឹងទទឹង* សូមមើលការពន្យល់ នក ៤:២១ ៧:១៣ ។

**១១:២១** *សាសន៍អ័ណាក់* សាសន៍នេះត្រូវបានរាយការណ៍ដោយពួកអ្នកស៊ើបការណ៍ទាំង១២នាក់ ថាជាចំនួនមនុស្ស"មានចំនួនច្រើន" (ជន ១៣:៣២) ដែលពួកអ៊ីស្រាអែលមានការភ័យខ្លាចយ៉ាងខ្លាំង ថាពួកគេត្រូវតែឈប់ធ្វើសង្គ្រាមជាមួយពួកនេះ (សូមមើលការពន្យល់ លប ៦:៤)។

**១២:១-២៤** នៅវគ្គនេះជាការសន្និដ្ឋានលើកដំបូងរបស់លោកយ៉ូស្វេ និងជាការសង្ខេបជារួមនៃជ័យជម្នះរបស់ពួកអ៊ីស្រាអែល ហើយនិងទីក្រុងដែលជា

ត្រើយនាយទន្លេយ័រដាន់ទិសខាងកើត[ខ] ចាប់តាំងពីស្ទឹង
អើណូន[គ]ទៅដល់ភ្នំហើម៉ូន[ឃ] និងស្រុកវាលទាំងអស់នៅ
ខាងកើតនោះ[ង] ២គឺស៊ីហុនជាស្តេចសាសន៍អាម៉ូរី[ច]នៅក្រុង
ហែសបូន[ឆ] ដែលសោយរាជ្យលើស្រុកកាឡាត់១ចំហៀង
ចាប់តាំងពីក្រុងអារូអើរ នៅក្បែរមាត់ស្ទឹងអើណូន គឺពី
កណ្តាលស្ទឹងនោះ រហូតដល់ស្ទឹងយ៉ាបុក[ជ] ជាព្រំស្រុកពួក
កូនចៅអាំម៉ូន[ឈ,ញ] ៣និងស្រុកវាលរហូតដល់ខាងកើត
សមុទ្រគេនេសារ៉ែត[ដ] ហើយទៅដល់ខាងកើតសមុទ្រនៅ
វាល គឺជាសមុទ្រអំបិល[ឋ]តាមផ្លូវទៅឯបេត-យេស៊ីម៉ូត[ឌ]
ហើយនៅខាងត្បូងនោះត្រង់ជើងភ្នំពីសកា[ឍ] ៤និងអុកជា
ស្តេចស្រុកបាសាន[ណ] ជាម្នាក់ក្នុងពួកដែលសល់ពីសាសន៍
រេផែម[ត] នៅក្រុងអាសថារ៉ូត[ថ] និងក្រុងអេទ្រី ៥ដែលសោយ
រាជ្យលើស្រុកភ្នំហើម៉ូន និងក្រុងសាលកា[ទ] ហើយនៅស្រុក
បាសាន[ធ] ទាំងមូល រហូតដល់ព្រំស្រុករបស់សាសន៍កេស៊ូរី[ន]
និងសាសន៍ម៉ាកាធី[ប] ហើយលើស្រុកកាឡាត[ផ]១ចំហៀង
ដែរ ទល់នឹងព្រំស្រុករបស់ស៊ីហុន ជាស្តេចក្រុងហែសបូន
៦គឺលោកម៉ូសេ ជាអ្នកបំរើរបស់ព្រះយេហូវ៉ា និងពួកកូន
ចៅអ៊ីស្រាអែល បានវាយយកស្រុកទាំងនោះ[ព] ហើយ
លោកក៏ចែកស្រុកទាំងនោះដល់ពួករូបេន ពួកកាឌ់ និងពូជ
អំបូរ ម៉ាន៉ាសេ១ចំហៀង ទុកជាកេរ្តិ៍អាកររបស់គេ[ភ]។
៧ឯពួកស្តេចទាំងប៉ុន្មាននៅក្នុងស្រុក ដែលយ៉ូស្វេនិង
ពួកកូនចៅអ៊ីស្រាអែលបានវាយ ចាប់យកនៅត្រើយទន្លេ
យ័រដាន់ខាងលិច ចាប់តាំងពីបាល-កាឌ់ នៅវាលច្រកភ្នំ
ល្បាណូន[ម] រហូតដល់ភ្នំហាឡាកត្រង់កន្លែងឡើងទៅឯភ្នំ
សៀរ (ស្រុកនោះយ៉ូស្វេក៏ចែកដល់ពូជអំបូរសាសន៍អ៊ីស្រា
អែល ទុកជាកេរ្តិ៍អាករតាមពួកគេ ៨គឺស្រុកភ្នំ ស្រុកទំនាប
ស្រុកវាល[យ] ស្រុកជិរាល ទីរហោស្ថាន និងស្រុកត្បូង
ជាស្រុករបស់សាសន៍ហេត សាសន៍អាម៉ូរី សាសន៍កាណាន
សាសន៍ពេរិស៊ីត សាសន៍ហេវី និងសាសន៍យេប៊ូស)[រ]
៩នោះគឺស្តេចក្រុងយេរីខូរ១[ល] ស្តេចក្រុងអៃយ[វ]ដែលនៅជិត
បេត-អែល១[ស] ១០ស្តេចក្រុងយេរូសាឡិម១[ហ] ស្តេចក្រុង
ហេប្រុន១ ១១ស្តេចក្រុងយ៉ារមុត១ ស្តេចក្រុងឡាគីស១[ឡ]
១២ស្តេចក្រុងអេក្លូន១[អ] ស្តេចក្រុងកេស៊ើរ១[ក] ១៣ស្តេចក្រុង
ដេបៀរ១[ខ] ស្តេចក្រុងកេឌើរ១ ១៤ស្តេចក្រុងហោម៉ា១[គ]
ស្តេចក្រុងអើរ៉ាត១[ឃ] ១៥ស្តេចក្រុងលិបណា១[ង] ស្តេចក្រុង
អាឌូឡាម១[ច] ១៦ស្តេចក្រុងម៉ាកេដា១[ឆ] ស្តេចក្រុងបេត-
អែល១[ជ] ១៧ស្តេចក្រុងតាពួរ១[ឈ] ស្តេចក្រុងហេភើរ១[ញ]
១៨ស្តេចក្រុងអាផែក១[ដ] ស្តេចក្រុងឡាសារ៉ុន១ ១៩ស្តេចក្រុង
ម៉ាដូន១ ស្តេចក្រុងហាសោរ១[ឋ] ២០ស្តេចក្រុងស៊ីមរ៉ុន-
មេរ៉ុន១ ស្តេចក្រុងអាកសាប១[ឌ] ២១ស្តេចក្រុងតាអាណាក់១[ឍ]
ស្តេចក្រុងមេគីដោ១[ណ] ២២ស្តេចក្រុងកេដេស១[ត] ស្តេចក្រុង
យ៉ុកនាម[ថ] នៅស្រុកកើមែល១[ទ] ២៣ស្តេចក្រុងដោរ[ធ] ដែល
នៅត្រង់ទីទំនួលរបស់ក្រុងដោរ១ ស្តេចក្រុងកូយីម ដែល
នៅគីលកាល១ ២៤និងស្តេចក្រុងធើសា១[ន] រួមទាំងអស់មាន
ស្តេច៣១អង្គ[ប]។

## ទឹកដីដែលត្រូវចាប់យកបន្តទៀត

**១៣** ១ឯយ៉ូស្វេ លោកចាស់ អាយុក៏ច្រើនណាស់ហើយ[ក]
ព្រះយេហូវ៉ាទ្រង់ក៏មានបន្ទូលនឹងលោកថា ឯងចាស់ហើយ
អាយុក៏ច្រើនណាស់ផង ហើយមានសល់នៅស្រុក ដែលត្រូវ

**១២:១** ខ ជន ៣២:១៩ គ ជន ២១:១៣ ឃ ចទ ៣:៨ ង យស ១១:២ **១២:២** ច ជន ៣២:៣៤ យស ១៣:១៦ ឆ ខ.៥ ជន ២១:២១,២៥ យស ១៣:១០ ពច ១១:១៩ ជ លប ៣២:២២ ឈ លប ១៩:៣៨ ញ លប ៣១:២១ ជន ៣២:២៦ ចទ ២:៣៦ ៣:១៥ យស ១៣:១១,២៥ ១៧:១ ២០:៨ ២១:៣៨ ពច ៥:១៧ ៧:៣ ១០:៨ **១២:៣** ដ យស ១១:២ ឋ លប ១៤:៣ ឌ ជន ៣៣:៤៩ យស ១៣:២០ ឍ ជន ២១:២០ **១២:៤** ណ ជន ២១:២១,៣៣ យស ១៣:៣០ ត លប ១៤:៥ ថ ចទ ១:៤ **១២:៥** ទ ចទ ៣:១០ ធ ជន ៣២:៣៣ យស ១៧:១ ២០:៨ ២១:២៧ ២២:៧ ន យស ១៣:២,១៣ ១សយ ២៧:៨ ប ចទ ៣:១៤ ផ ខ.២ **១២:៦** ព ចទ ៣:៨ ភ ជន ៣២:២៩,៣៣ យស ១៣:៨ **១២:៧** ម យស ១១:១៧

**១២:៨** យ ចទ ១:៧ រ យស ៣:១០ ១១:១៧ អរ ៩:១ **១២:៩** ល ជន ៣៣:៤៨ វ លប ១២:៨ យស ៨:១ ស យស ៧:២ ៨:៩ ១៨:១៣ ពច ១:២៣ ៤:៥ ២០:១៨ ២១:២ នហ ១១:៣១ **១២:១០** ហ យស ១០:១ **១២:១១** ឡ យស ១០:៣ **១២:១២** អ យស ១០:៣ ក យស ១០:៣ **១២:១៣** ខ យស ១០:៣ **១២:១៤** គ ជន ១៤:៤៥ ឃ ជន ២១:១ **១២:១៥** ង ជន ៣៣:២០ ច លប ៣៨:១ **១២:១៦** ឆ យស ១០:១០ ជ យស ៧:២ **១២:១៧** ឈ យស ១៥:៣៤ ១៦:៨ ១៧:៨ ញ យស ១១:២២ ១ពវ ៤:១០ **១២:១៨** ដ យស ១៣:៤ ១៩:៣០ ពច ១:៣១ ១សយ ៤:១ ២៩:១ **១២:១៩** ឋ យស ១១:១ **១២:២០** ឌ យស ១១:១ **១២:២១** ឍ យស ១៧:១១ ២១:២៥ ណ ពច ១:២៧ ៥:១៩ ១ពវ ៤:១២ **២:២២** ត យស ១៥:២៣ ១៩:៣៧ ២០:៧ ២១:៣២ ពច ៤:៦,៩ ថ យស ១៩:១១ ២១:៣៤ ទ យស ១៥:៥៥ ១៩:២៦ ១សយ ១៥:១២ ២សយ ២៣:៣៥ **១២:២៣** ធ យស ១១:២ **១២:២៤** ន ១ពវ ១៤:១៧ ១៥:៣៣ ១៦:៨,២៣ ៦:៤ ប ទដ ១៣៥:១១ ១៣៦:១៨ **១៣:១** ក លប ២៤:១ យស ១៤:១០ ២៣:១,២ ១ពវ ១:១

របស់ស្តេចដែលបានវាយប្រហារ ។

**១២:១** *វាយ . . . យ័រដាន់ទិសខាងកើត* ការបង្រួបបង្រួមជាតិ គឺបានលើកឡើងជាថ្មីម្តងទៀត ដោយការរាប់បញ្ចូលនូវទឹកដីទាំងនោះក្នុងការឆ្លងកាត់ទន្លេយ័រដាន់ ។ *ស្ទឹងអើណូន* ស្ទឹងនេះមានព្រំប្រទល់ចាប់ពីស្រុកម៉ូអាប់ទៅទិសខាងត្បូង ។ *ភ្នំហើម៉ូន* ភ្នំនេះជាទីខ្ពស់ដែលកំណត់ចាប់ពីទឹកដីពួកអ៊ីស្រាអែលទៅទិសខាងជើង ។

**១២:៤** *អុកជាស្តេចស្រុកបាសាន* ស្តេចស៊ីហុន និងស្តេចអុក(ខ.២) ត្រូវបានវាយបំបាក់ដោយពួកអ៊ីស្រាអែល ក្រោមការដឹកនាំនៃលោកម៉ូសេ ។ សញ្ញានៃការចងចាំដ៏យូរនៃអំណាចដ៏ខ្លាំងពូកែរបស់ព្រះ (មើល ទដ ១៣៥:១១) ។

**១២:៧** *ចាប់យក . . . យ័រដាន់ខាងលិច* សូមមើល ៩:១ ១១:១៦-១៧ ២៤:១១ លប ១៥:១៨-១៩ ។

**១២:១២** *ស្តេចក្រុងកេស៊ើរ* ស្តេចក្រុងនេះស្ថិតក្រោមការឡោមព័ទ្ធរបស់ស្តេចក្រុងឡាគីស (១០:៣៣) ប៉ុន្តែទីក្រុងមិនត្រូវបានចាប់យកដោយលោកយ៉ូស្វេទេ ចំណែកឯក្រុងអាផែក ក្រុងអាណាក់ ក្រុងមេគីដោ ក្រុងដោរក៏អញ្ចឹងដែរ (ខ.១៨-២៣ សូមមើល ពច ១:២៧-៣១) ។

**១៣:១-៣២** នៅវគ្គនេះនរគស្ថានសួគ៌ ដែលទ្រង់បានវាតទីយកទឹកដីចាប់ផ្តើមគ្រប់គ្រងអាណាចក្ររបស់ទ្រង់ដោយការចាត់ចែងយ៉ាងច្បាស់លើទឹកដីទៅដល់ពួកសាសន៍មួយចំនួនជិពូក ១៣-២១ ដូចឯកសារគ្រប់គ្រង ។

ចាប់យកសន្ទឹកណាស់ទៀត ២នេះជាស្រុកដែលនៅសល់ គឺ
ដែននៃពួកសាសន៍ភីលីស្ទីន[ខ]ទាំងប៉ុន្មាន និងស្រុករបស់
សាសន៍កេស៊ូរី[គ]ទាំងអស់ ៣ចាប់តាំងពីស្ទឹងស៊ីហោ[ឃ] ដែល
ជាព្រំស្រុកអេស៊ីព្ទ រហូតដល់ព្រំក្រុងអេក្រុន[ង]នៅខាងជើង
ដែលរាប់ជាស្រុករបស់សាសន៍កាណាន មានមេសាសន៍
ភីលីស្ទីន៥នាក់ជាអ្នកត្រួតត្រា[ច] គឺជាក្រុងកាសា១ ក្រុងអាស
ដូឌ១[ឆ] ក្រុងអាសកាឡូន១[ជ] ក្រុងកាថ១ ក្រុងអេក្រុន១ ហើយ
និងស្រុករបស់សាសន៍អាវីម[ឈ] ដែលនៅខាងត្បូងនោះដែរ
៤ព្រមទាំងស្រុករបស់សាសន៍កាណានទាំងមូល និងស្រុក
ម៉ារ៉ា ដែលជារបស់ផងក្រុងស៊ីដូនរហូតដល់អាផែក[ញ] និង
ដល់ព្រំស្រុករបស់សាសន៍អាម៉ូរី[ដ] ៥ស្រុករបស់ពួកកេបាល[ឋ]
និងស្រុកល្បាណូនទាំងមូល[ឌ,ឍ]ដែលនៅខាងកើត ចាប់តាំង
ពីបាល-កាឌ់នៅជើងភ្នំហើម៉ូន រហូតដល់ទ្វារចូលស្រុក
ហាម៉ាត[ណ] ៦អស់ទាំងស្រុករបស់ពួកផ្សេងៗដែលនៅស្រុកភ្នំ
ចាប់តាំងពីភ្នំល្បាណូន រហូតដល់មីសរិផូត-ម៉ែម[ត] គឺជា
ស្រុករបស់ពួកក្រុងស៊ីដូនទាំងអស់ អញនឹងដេញពួកសាសន៍
ទាំងនោះ[ថ]ចេញពីមុខពួកកូនចៅអ៊ីស្រាអែលទៅ ចូរឱ្យឯង
ចែកស្រុកទាំងនោះដល់ពួកចៅអ៊ីស្រាអែល ទុកជាមរដក
ចុះ ដូចជាអញបានបង្គាប់ហើយ ៧គឺត្រូវឱ្យចែកស្រុកទាំង
នោះដល់ពូជអំបូរទាំង៩ និងពូជអំបូរម៉ាន៉ាសេ១ចំហៀង
ទុកជាមរដក[ន] ។

## ការបែងចែកទឹកដីភាគខាងកើតនៃទន្លេយ័រដាន់

៨ឯពួករូបេន និងពួកកាឌ់ ព្រមទាំងពូជអំបូរម៉ាន៉ាសេ
១ចំហៀងឯទៀត នោះបានទទួលមរដករបស់គេ ដែល
ម៉ូសេបានចែកឱ្យ នៅត្រើយទន្លេយ័រដាន់ខាងកើតហើយ
តាមដែលម៉ូសេ ជាអ្នកបំរើរបស់ព្រះយេហូវ៉ា បានចែក[ប]
ដល់គេ[ផ] ៩ចាប់តាំងពីអារ៉ូអើរ[ព]ដែលនៅក្បែរស្ទឹងអើណូន
និងទីក្រុងដែលនៅកណ្តាលច្រកភ្នំនោះ គឺស្រុកវាល[ភ]
មេឌីបាទាំងអស់រហូតដល់ក្រុងឌីបូន[ម] ១០និងអស់ទាំងទី
ក្រុងរបស់ស៊ីហុន ជាស្តេចសាសន៍អាម៉ូរី ដែលសោយរាជ្យ
នៅក្រុងហែសបូន[យ] រហូតដល់ព្រំស្រុករបស់ពួកកូនចៅ
អាំម៉ូន[រ] ១១និងស្រុកកាឡាត[ល] ហើយព្រំដែនស្រុករបស់
សាសន៍ កេស៊ូរី និងសាសន៍ម៉ាកាធី ស្រុកភ្នំហើម៉ូនទាំងមូល
ហើយស្រុកបាសានទាំងអស់ រហូតដល់សាលកា[វ] ១២គឺនគរ
របស់អុក នៅស្រុកបាសាន[ស] ដែលសោយរាជ្យនៅក្រុង
អាសថារ៉ូត[ហ] និងក្រុងអេទ្រើ[ឡ] (ជាម្នាក់ក្នុងពួកដែលសល់ពី
សាសន៍រេផែម)[អ] ដ្បិតម៉ូសេបានវាយ បណ្តេញពួកទាំង
នោះចេញ[ក] ១៣តែពួកកូនចៅអ៊ីស្រាអែលមិនបានដេញ
សាសន៍កេស៊ូរី[ខ] និងសាសន៍ម៉ាកា[គ]ធីចេញទេ គឺសាសន៍
កេស៊ូរី និងសាសន៍ម៉ាកាធីនោះ បាននៅកណ្តាលពួក
អ៊ីស្រាអែល ដរាបដល់សព្វថ្ងៃនេះ[ឃ] ១៤មានតែពូជអំបូរ
លេវីប៉ុណ្ណោះទេ ដែលលោកមិនបានចែកមរដកឱ្យគេ ដ្បិត
អស់ទាំងដង្វាយដុតថ្វាយព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល នោះជាមរដករបស់គេហើយ ដូចជាលោក
បានប្រាប់មក[ង] ។
១៥លោកម៉ូសេក៏ឱ្យ១ចំណែក ដល់ពូជអំបូរពួកកូនចៅ
រូបេនតាមគ្រួគេ ១៦ឯដែនស្រុករបស់គេ នោះចាប់តាំងពី
ក្រុងអារ៉ូអើរ[ច] ដែលនៅក្បែរស្ទឹងអើណូន និងទីក្រុងដែល
នៅកណ្តាលច្រកភ្នំនោះ រហូតដល់ផុតស្រុកវាលមេឌីបា[ឆ]
១៧គឺក្រុងហែសបូន និងទីក្រុងទាំងប៉ុន្មាន ដែលនៅស្រុក

**១៣:២** ខ លប ១០:១៤ ពច ៣:៣១ គ យស ១២:៥ **១៣:៣** ឃ ១របា ១៣:៥ អស ២៣:៣ យរ ២:១៨ ង យស ១៥:១១,៤៥ ១៩:៤៣ ពច ១:១៨ ១សយ ៥:១០ ៧:១៤ ច ពច ៣:៣ ១៦:៥,១៨ ១សយ ៦:៤,១៧ អស ១៤:២៩ យរ ២៥:២០ អគ ២៥:១៥ ឆ យស ១១:២២ អម ៣:៩ ជ ពច ១:១៨ ១៤:១៩ ២សយ ១:២០ ឈ ចទ ២:២៣ **១៣:៤** ញ យស ១២:១៨ ដ លប ១៤:៧ ១៥:១៦ អម ២:១០ **១៣:៥** ឋ ១ពវ ៥:១៨ ទដ ៨៣:៧ អគ ២៧:៩ ឌ យស ១១:១៧ ណ ចទ ៣:៨ ត ជន ១៣:២១ ៣៤:៨ ពច ៣:៣ **១៣:៦** ថ យស ១១:៨ ទ ទដ ៨០:៨ ធ ជន ៣៣:៥៤ ៣៤:១៣ **១៣:៧** ន យស ១១:២៣ ទដ ៧៨:៥៥ **១៣:៨** ប យស ១២:៦ ផ យស ១៨:៧ **១៣:៩** ព ខ.១៦ ជន ៣២:៣៤ ចទ ២:៣៦ ពច ១១:២៦ ២សយ ២៤:៥ ភ ខ.១៧,២១ យស ៤៨:៨,២១ ម ជន ២១:៣០ ៣២:៣ អស ១៥:២ យរ ៤៨:១៨,២២ **១៣:១០** យ យស ១២:២ រ ជន ២១:២៤ **១៣:១១** ល យស ១២:២ វ យស ១២:៥ **១៣:៩** ព ខ.១៦ ជន ៣២:៣៤ ចទ ២:៣៦ ពច ១១:២៦ ២សយ ២៤:៥ ភ ខ.១៧,២១ យស ៤៨:៨,២១ ម ជន ២១:៣០ ៣២:៣ អស ១៥:២ យរ ៤៨:១៨,២២ **១៣:១០** យ យស ១២:២ រ ជន ២១:២៤ **១៣:១១** ល យស ១២:២ វ យស ១២:៥ **១៣:១២** ស ចទ ១:៤ ហ យស ១២:៤ ឡ ជន ២១:៣៣ អ លប ១៤:៥ ក ចទ ៣:៨ **១៣:១៣** ខ យស ១២:៥ គ ចទ ៣:១៤ ឃ ចទ ៣:១២ **១៣:១៤** ង ខ.៣៣ ចទ ១៨:១-២ យស ១៤:៣ **១៣:១៦** ច ខ.៩ យស ១២:២ ១សយ ៣០:២៨ ឆ ជន ២១:៣០ អស ១៥:២

**១៣:១** *យ៉ូស្វេ លោកចាស់* នៅត្រង់នេះលោកមានអាយុ ៩០ និង ១០០ឆ្នាំ ។ លោកកាលែប មានអាយុ៨៥ (១៤:១០) ។

**១៣:៣** *ស្ទឹងស៊ីហោ* ស្ទឹងស៊ីហោផ្សេងៗទៀត ប្រាកដជាសំដៅទៅលើដៃទន្លេផ្សេងៗជាច្រើន (សូមមើល ១របា ១៣:៥ អស ២៣:៣ និងការពន្យល់) ។ *ក្រុងអេក្រុន* សូមមើល ១សយ ៥:១ ។ *អ្នកត្រួតត្រា* ពាក្យនេះ ក្នុងព្រះគម្ពីរភាសាហេព្រើរប្រហែលជាសំដៅលើពាក្យក្រិកដែលមានន័យថា អ្នកសង្កត់សង្កិនផងដែរ ។ នៅសម័យសញ្ញាចាស់ ពាក្យនេះត្រូវបានគេប្រើសម្រាប់តែពួកអ្នកដឹកនាំប៉ាលេស្ទីនប៉ុណ្ណោះ ។

**១៣:៥** *កេបាល* ពួកនេះជាម្ចាស់ស្រុកបុរាណដែលពេលបច្ចុប្បន្ននេះពួកគេនៅភាគខាងជើងក្រុង "បៃរូត" (Beirut) ។

**១៣:៩** *ក្រុងអារ៉ូអើរ* ក្រុងនេះលាតសន្ធឹងលើស្ទឹងអើណូន ចាប់ពីព្រំប្រទល់ខាងត្បូងនៃអ៊ីស្រាអែលខាងកើតទន្លេយ័រដាន់ ។ ចាប់ពីក្រុងនេះ ទឹកដីត្រូវបានគេពង្រីកទៅដល់ខាងជើងដោយឆ្លងកាត់ស្រុកកាឡាត និងស្រុកបាសាន រហូតទៅដល់ទីជម្រាលនៃជើងភ្នំហើម៉ូន ដែលពេលមួយនោះទឹកដីអាម៉ូរីនេះត្រូវបានគ្រប់គ្រងដោយស្តេចពីរអង្គគឺស្តេចស៊ីហុន និងស្តេចអុក ។

**១៣:១៤** *ដង្វាយ . . . មរដករបស់គេ* សូមមើលការពន្យល់ ចទ ១៨:១-៨ និងការពន្យល់ ១៨:១ ។

**១៣:១៥** *ម៉ូសេក៏ឱ្យ . . . រូបេន* នៅត្រង់នេះដីដែលនៅខាងកើតសមុទ្រស្លាប់គឺរវាងស្ទឹងអើណូន (ព្រំប្រទល់ ស្រុកម៉ូអាប់) និងហែសបូន (នគររបស់ស្តេចស៊ីហុន) ។

វាល[ជ] គឺក្រុងឌីបូន[ឈ] ក្រុងបាម៉ូត–បាល[ញ] ក្រុងបេត–បាល–
មេយ៉ូន[ដ] ១៨ក្រុងយ៉ាហាស់[ឋ] ក្រុងក្ដេម៉ូត[ឌ] ក្រុងមេផ្អាត[ឍ]
១៩ក្រុងគាយ៉ាថែម[ណ] ក្រុងសិបម៉ា[ត] ក្រុងសេរ៉ែត–ហាសាកា
ដែលនៅលើភ្នំក្នុងវាលច្រកភ្នំ ២០ក្រុងបេត–ពេអរ[ថ] និង
ជីរាលភ្នំពីសកា ហើយក្រុងបេត–យេស៊ីម៉ូត ២១ព្រមទាំង
ទីក្រុងទាំងប៉ុន្មាន ដែលនៅស្រុកវាល[ទ] និងនគរទាំង
មូលរបស់ស៊ីហុន ជាស្ដេចសាសន៍អាម៉ូរី ដែលសោយ
រាជ្យនៅក្រុងហែសបូន ជាអ្នកដែលលោកម៉ូសេបានវាយ
សំឡាប់ជាមួយនឹងពួកមេសាសន៍ម៉ាឌាន[ធ] គឺអេវី១ រេគេម១
ស៊ើរ១ ហ៊ើរ១ និងរេបា១[ន] សុទ្ធតែជាពួកមេរបស់ស្ដេច
ស៊ីហុនដែលនៅក្នុងស្រុកនោះ ២២ឯបាឡាម ជាកូនបេអ៊ោរ[ប]
ដែលជាគ្រូទាយ[ផ] នោះពួកកូនចៅអ៊ីស្រាអែលបានសំឡាប់
ដោយដាវ ជាមួយនឹងអ្នកឯទៀតដែលត្រូវស្លាប់នោះដែរ
២៣ឯទន្លេយ័រដាន់ នោះជាព្រំស្រុករបស់កូនចៅរូបេន នេះ
ហើយជាមរដករបស់រូបេនតាមគ្រួគេទាំងប៉ុន្មាន ព្រមទាំង
ទីក្រុង និងភូមិទាំងប៉ុន្មានផង[ព] ។
២៤លោកម៉ូសេក៏ឱ្យ១ចំណែក ដល់ពូជអំបូរកាឌ់ដែរ គឺ
ដល់ពួកកូនចៅកាឌ់តាមគ្រួគេ ២៥ឯដែនគេ គឺស្រុកយ៉ា–
ស៊ើរ[ភ] និងអស់ទាំងទីក្រុងនៅស្រុកកាឡាត[ម] និងស្រុករបស់
ពួកកូនចៅអាំម៉ូន១ចំហៀង រហូតដល់អារ៉ូអ៊ើរ ដែលទល់
មុខនឹងក្រុងរ៉ាបាត[យ] ២៦ហើយពីហែសបូន[រ] ទៅដល់រ៉ាម៉ាត–
មីសពេ និងបេថូនិម ហើយពីម៉ាហាណែម[ល] ទៅដល់
ព្រំស្រុកដេបៀរ[វ] ២៧ឯនៅវាលច្រកភ្នំ នោះមានក្រុង
បេត–ហារ៉ាម ក្រុងបេត–នីមរ៉ា[ស] ក្រុងស៊ុកូត[ហ] និងក្រុង
សាផូន[ឡ] គឺជាចំណែកដែលសល់ពីនគររបស់ស៊ីហុន ជា
ស្ដេចក្រុងហែសបូន មានទន្លេយ័រដាន់ជាព្រំប្រទល់ រហូត
ដល់ចុងបំផុតនៃសមុទ្រគេនេសារ៉ែត ដែលនៅត្រើយ
ទន្លេយ័រដាន់ខាងកើត[អ] ២៨នេះហើយជាមរដករបស់ពួក
កូនចៅកាឌ់[ក]តាមគ្រួគេទាំងប៉ុន្មាន ព្រមទាំងទីក្រុង និងភូមិ
គេទាំងប៉ុន្មានផង ។

**១៣:១៧** ជ ខ.៩ ឈ ជន ៣២:៣ ញ ជន ២២:៤១ ដ ១រប ៥:៨ យរ ៤៨:២៣ អគ ២៥:៩ **១៣:១៨** ឋ ជន ២១:២៣ ឌ ចទ ២:២៦ ឍ យស ២១:៣៧ យរ ៤៨:២១ **១៣:១៩** ណ ជន ៣២:៣៧ ត ជន ៣២:៣ **១៣:២០** ថ ចទ ៣:២៩ **១៣:២១** ទ ខ.៩ ធ លប ២៥:២ ន ជន ៣១:៨ **១៣:២២** ប ជន ២២:៥ ផ លប ៣០:២៧ ជន ២៣:២៣ **១៣:២៣** ព ១រប ៥:៧ **១៣:២៥** ភ ជន ២១:៣២ យស ២១:៣៩ ម យស ១២:២ យ ចទ ៣:១១ **១៣:២៦** រ ជន ២១:២៥ យស ៤៩:៣ ល លប ៣២:២ វ យស ១០:៣ **១៣:២៧** **ស**ជន ៣២:៣ ហ លប ៣៣:១៧ ឡ ពច ១២:១ ទដ ៤៨:២ អ ជន ៣៤:១១

២៩លោកម៉ូសេក៏ឱ្យ១ចំណែកដល់ពូជអំបូរម៉ាន៉ាសេ១
ចំហៀងដែរ គឺដល់ពូជអំបូរពួកកូនចៅម៉ាន៉ាសេ១ចំហៀង
តាមគ្រួគេ ៣០ឯដែនរបស់គេ នោះគឺជាស្រុកម៉ាហាណែម[ខ]
ស្រុកបាសានទាំងមូល[គ] នគររបស់អុក ជាស្ដេចស្រុកបា–
សានទាំងមូល[ឃ] និងទីក្រុងទាំង៦០ របស់យ៉ាអ៊ារ[ង]ដែលនៅ
ស្រុកបាសាននោះដែរ ៣១ព្រមទាំងស្រុកកាឡាត១ចំហៀង
និងក្រុងអាសថារ៉ូត ហើយក្រុងអេទ្រើជាទីក្រុងដែលនៅក្នុង
នគររបស់អុកនៅស្រុកបាសាន[ច] នេះសុទ្ធតែសំរាប់ពួកកូន
ចៅម៉ាគារ[ឆ] ជាកូនម៉ាន៉ាសេ គឺសំរាប់ពួកកូនចៅម៉ាគារ១
ចំហៀងតាមគ្រួគេ[ជ] ។
៣២នេះហើយជាមរដក ដែលលោកម៉ូសេបានចែកនៅ
ស្រុកវាលរបស់ម៉ូអាប់[ឈ] ត្រើយទន្លេយ័រដាន់ខាងកើតទល់
មុខនឹងយេរីខូរ[ញ] ៣៣តែឯពូជអំបូរលេវី នោះលោកម៉ូសេ
មិនបានចែកមរដក[ដ] ដល់គេទេ ដ្បិតព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែល ទ្រង់ជាមរដក[ឋ]របស់គេហើយ ដូចជា
លោកបានប្រាប់មក[ឌ] ។

## ការបែងចែកទឹកដីភាគខាងលិចនៃទន្លេយ័រដាន់

**១៤** ១ហើយនេះជាមរដក[ក]ដែលពួកកូនចៅអ៊ីស្រាអែល
បានទទួលនៅក្នុងស្រុកកាណាន គឺដែលអេលាសារ[ខ]ដ៏ជា
សង្ឃ និងយ៉ូស្វេជាកូននុន ហើយនិងពួកមេលើវង្សានុវង្ស
របស់ពូជអំបូរពួកកូនចៅអ៊ីស្រាអែល[គ]ទាំងប៉ុន្មាន បាន
ចែក[ឃ]ឱ្យ[ង] ២មរដកទាំងនោះគេបានចែកឱ្យពូជអំបូរ៩ និង
ពូជអំបូរ១ចំហៀងនោះ[ច] ដោយចាប់ឆ្នោត[ឆ] ដូចជាព្រះ
យេហូវ៉ាបានបង្គាប់មកដោយសារលោកម៉ូសេ ៣ដ្បិត

**១៣:២៨** ក លប ៤៦:១៦ ជន ៣២:៣៣ អគ ៤៨:២៧ **១៣:៣០** ខ លប ៣២:២ គ ជន ២១:៣៣ ឃ យស ១២:៤ ង ជន ៣២:៤១ **១៣:៣១** ច ជន ២១:៣៣ ឆ លប ៥០:២៣ ជ យស ១៧:៥ **១៣:៣២** ឈ ជន ២៦:៣ ញ ជន ២២:១ **១៣:៣៣** ដ ជន ២៦:៦២ ឋ ជន ១៨:២០ ឌ ខ.១៤ យស ១៨:៧ អគ ៤៤:២៨ **១៤:១** ក យស ១១:២៣ ទដ ១៦:៦ ១៣៦:២១ ខ នក ៦:២៣ គ យស ២១:១ ឃ ជន ២៦:៥៣ ង ជន ៣៤:១៧–១៨ យស ១៩:៥១ **១៤:២** ច លវ ១៦:៨ ឆ ជន ៣៤:១៣

**១៣:២២** *បាឡាមជាកូនបេអ៊ោរ* ម្នាក់នេះប្រហែលជាមានឥទ្ធិពលខាងឯរូបព្រះ (ជន ២២–២៤) ត្រូវបានសម្លាប់នៅពេលដែលព្រះអម្ចាស់បានកាត់ទោសសាសន៍ម៉ាឌានពីការព្យាយាមលួងលោមពួកអ៊ីស្រាអែល ឱ្យធ្លាក់ក្នុងការគោរពរូបព្រះ និងការរួមភេទដ៏អសីលធម៌ (មើល ជន ២៥ ៣១:៨) ។

**១៣:២៤** *លោកម៉ូសេក៏ឱ្យ . . . កូនចៅកាឌ់* ពួកនេះទទួលបានតំបន់កណ្ដាលដែលចាប់ផ្ដើមពីក្រុងហែសបូននៅភាគខាងត្បូង និងឆ្ពោះទៅតាមបណ្ដោយទន្លេយ័រដាន់ រហូតដល់ចុងបញ្ចប់សមុទ្រកាលីឡេ ។ វារួមបញ្ចូលស្រុកកាឡាតមួយភាគធំ ប៉ុន្តែព្រំដែនពិតប្រាកដគឺ រវាងពួកកូនចៅកាឌ់ និងកូនចៅម៉ាន៉ាសេពាក់កណ្ដាល ដែលពួកគេនៅតែមិនទាន់ច្បាស់ ទោះបីគ្រប់កន្លែងទាំងនោះត្រូវបានគេដាក់ឈ្មោះក៏ដោយ ។

**១៣:២៩** *ម៉ូសេក៏ឱ្យ១ . . . ម៉ាន៉ាសេ១ចំហៀងដែរ* ដីនៅតំបន់ភាគខាងកើត និងភាគខាងជើងសមុទ្រកាលីឡេ ប៉ុន្តែថែមទាំងរួមបញ្ចូលស្រុកកាឡាតផងដែរ ។

**១៤:១–៥** នៅត្រង់នេះជាសេចក្ដីផ្ដើមនៃការបែងចែកទឹកដី នៅស្រុកកាណាន ។

**១៤:១** *អេលាសារដ៏ជាសង្ឃ* គាត់ជាកូនរបស់សម្ដេចសង្ឃអើរ៉ុន ។ អេលាសារជាសម្ដេចសង្ឃ គាត់មានឋានៈខ្ពស់ហើយជាម្ចាស់លើពួកគេ ។ យូរិម និងធូមីម (ការពន្យល់ នក ២៨:៣០ ១សយ ២:២៨) ។

លោកម៉ូសេបានចែកមរដកដល់ពូជអំបូរទាំង២ និង១
ចំហៀងទៀត នៅខាងនាយទន្លេយ័រដាន់[ជ]ហើយ តែមិន
បានចែកឱ្យដល់ពួកលេវីទេ[ឈ] ៤ពីព្រោះពួកកូនចៅយ៉ូសែប
បានចែកជាពូជអំបូរ២ផ្នែកទៅហើយ គឺម៉ាន៉ាសេនិង
អេប្រាអិម[ញ] ដូច្នេះគេមិនបានចែកចំណែកណាដល់ពួក
លេវី នៅក្នុងស្រុកនោះទេ លើកតែទីក្រុងសំរាប់ឱ្យគេនៅ
ប៉ុណ្ណោះ ព្រមទាំងដីនៅជុំវិញទាំងប៉ុន្មានសំរាប់ហ្វូងសត្វ
និងទ្រព្យសម្បត្តិគេផង[ដ] ៥ពួកកូនចៅអ៊ីស្រាអែលក៏ចែក
ស្រុកគ្នា តាមសេចក្តីដែលព្រះយេហូវ៉ាទ្រង់បានបង្គាប់មក
លោកម៉ូសេ[ឋ] ។

## ក្រុងហេប្រុនត្រូវបានទៅលោកកាលែប

៦គ្រានោះ ពួកកូនចៅយូដា ក៏ចូលមកឯយ៉ូស្វេត្រង់
គីលកាល[ឌ] រួចកាលែប ជាកូនយេភូនេ[ឍ] ជាពួកកេណាស
ក៏និយាយនឹងលោកថា លោកជ្រាបសេចក្តីដែលព្រះ
យេហូវ៉ាបានមានបន្ទូលមកលោកម៉ូសេ ជាអ្នកសំណប់
របស់ព្រះ[ណ] ពីដំណើរខ្ញុំ និងលោក[ត] នៅត្រង់កាដេស–
បារនាហើយ[ថ] ៧កាលលោកម៉ូសេ ជាអ្នកបំរើនៃព្រះ
យេហូវ៉ា បានចាត់ខ្ញុំពីកាដេស–បារនា[ទ] ឱ្យទៅសង្កេត
មើលស្រុក[ធ] នោះខ្ញុំមានអាយុ៤០ឆ្នាំហើយ ខ្ញុំក៏បានត្រឡប់
មកវិញ ជំរាបលោកតាមគំនិតខ្ញុំ[ន] ៨ប៉ុន្តែពួកបងប្អូនដែល
ឡើងទៅជាមួយនឹងខ្ញុំ គេបានរំសាយចិត្តពួកបណ្តាជនវិញ[ប]
ឯខ្ញុំបានធ្វើតាមព្រះយេហូវ៉ា ជាព្រះនៃខ្ញុំគ្រប់ជំពូក[ផ] ៩ហើយ
នៅថ្ងៃនោះឯង លោកម៉ូសេក៏ស្បថថា ដីដែលជើងឯងបាន
ជាន់ នោះនឹងត្រូវបានជាមរដកដល់ឯង[ព] និងកូនចៅឯង[ភ]
តរៀងទៅ ដោយព្រោះឯងបានតាមព្រះយេហូវ៉ា ជាព្រះ
នៃអញគ្រប់ជំពូក ១០ឥឡូវនេះ មើល ព្រះយេហូវ៉ាទ្រង់បាន
ទុកឱ្យខ្ញុំរស់នៅ ដូចជាទ្រង់បានមានបន្ទូល[ម] គឺមាន៤៥ឆ្នាំ
នេះហើយ តាំងពីព្រះយេហូវ៉ាបានមានបន្ទូលសេចក្តីនោះ
នឹងលោកម៉ូសេក្នុងកាលដែលពួកអ៊ីស្រាអែល កំពុងដើរ[យ]
ក្នុងទីរហោស្ថាននៅឡើយ ហើយមើល នៅថ្ងៃនេះខ្ញុំមាន
អាយុ៨៥ឆ្នាំហើយ[រ] ១១សព្វថ្ងៃនេះខ្ញុំនៅតែមានកំឡាំង[ល]
ដូចក្នុងកាលដែលលោកម៉ូសេបានចាត់ខ្ញុំឱ្យទៅនោះនៅ
ឡើយ កំឡាំងខ្ញុំឥឡូវនេះក៏ដូចជាកាលពីដើមដែរ សំរាប់[វ]
នឹងទៅច្បាំងទាំងចេញទៅហើយចូលមកវិញផង ១២ដូច្នេះ
សូមឱ្យស្រុកភ្នំនេះ ដែលព្រះយេហូវ៉ាបានមានបន្ទូលនៅ
គ្រានោះ[ស]មកខ្ញុំចុះ ដ្បិតលោកបានឮនៅវេលានោះ ហើយ
ថា មានសាសន៍អ័ណាក់[ហ] នៅស្រុកនោះ ហើយមានទាំង
ទីក្រុងធំៗដែលមានកំផែងផង[ឡ] ប្រហែលជាព្រះយេហូវ៉ា
ទ្រង់នឹងគង់ជាមួយនឹងខ្ញុំទេដឹង ឱ្យខ្ញុំបានបណ្តេញគេចេញ
ទៅដូចជាព្រះយេហូវ៉ាបានមានបន្ទូលហើយ ។

១៣នោះយ៉ូស្វេឱ្យពរ[អ]ដល់កាលែប ជាកូនយេភូនេ[ក]
ហើយក៏ឱ្យក្រុងហេប្រុន[ខ]ទៅគាត់ទុកជាមរដក[គ] ១៤ដូច្នេះ
ក្រុងហេប្រុនបានត្រឡប់ជាមរដករបស់កាលែប ជាកូន
យេភូនេ ដែលជាពួកកេណាស ដរាបដល់សព្វថ្ងៃនេះ
ពីព្រោះគាត់បានធ្វើតាមព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែលគ្រប់ជំពូក[ឃ] ១៥រីឯក្រុងហេប្រុននេះ ពីដើម
មានឈ្មោះជាគារយ៉ាត់–អើបា[ង] ដែលអើបា[ច]នោះជា

**១៤:៣** ជ ជន ៣២:៣៣ ៣៤:១៤ ឈ ជន ៣៥:២ យស ១៣:១៤ **១៤:៤** ញ លប ៤១:៥២ ពច ១:២៩ ដ ជន ៣៥:២–៣ យស ២១:២ **១៤:៥** ឋ ជន ៣៤:១៣ **១៤:៦** ឌ ចទ ១១:៣០ ឍ ជន ១៣:៦ ១៤:៣០ ណ ចទ ៣៣:១ ត ជន ១៣:២៦ ថ ជន ១៤:៣៨ **១៤:៧** ទ យស ១៥:៣ ធ ជន ១៣:១៧ ន ជន ១៣:៣០ ១៤:៦–៩ **១៤:៨** ប ជន ១៣:៣១ ផ ជន ១៤:២៤ ៣២:១២ **១៤:៩** ព ចទ ១១:២៤ ភ ជន ១៤:២៤ **១៤:១០** ម ជន ១១:២៨ ១៤:៣០ យ យស ៥:៦ រ យស ១៣:១ **១៤:១១** ល ចទ ៣៤:៧ វ លប ១៥:១៥

**១៤:១២** ស ជន ១៤:២៤ ហ ជន ១៣:៣៣ ឡ ជន ១៣:២៨ **១៤:១៣** អ យស ២២:៦,៧ ក ១សយ ២៥:៣ ៣០:១៤ ខ លប ២៣:១៩ យស ១០:៣៦ គ ពច ១:២០ ១រប ៦:៥៦ **១៤:១៤** ឃ ជន ១៤:២៤ **១៤:១៥** ង លប ២៣:២ ច យស ១៥:១៣

**១៤:៤** *ម៉ាន៉ាសេនិងអេប្រាអិម* ទាំងពីរនាក់នេះជាកូនរបស់លោកយ៉ូសែប ពីព្រោះលោកយ៉ាកុប បានយកអ្នកទាំងពីរនេះមកចិញ្ចឹមធ្វើជាកូនបង្កើត (លប ៤៨:៥) ហើយពួកគេក៏បំបែកជាពីរសាសន៍ផ្សេងគ្នា ។ ត្រង់នេះហើយដែលធ្វើឱ្យមានជាតិសាសន៍ទាំង១២អំបូរ ដែលក្នុងនោះពួកសាសន៍លេវីមិនចូលរួមបម្រើក្នុងវិស័យនយោបាយឡើយ ។

**១៤:៦–១៥** នៅវគ្គនេះជាកិច្ចការស្រុកហេប្រុន ចំពោះលោកកាលែប គឺយោងទៅតាមការសន្យារបស់លោកម៉ូសេមកចំពោះគាត់ សម្រាប់ការបម្រើដ៏ស្មោះត្រង់ ក្នុងនាមជាសាសន៍អ៊ីស្រាអែលម្នាក់ដែលបានបញ្ជូនទៅរុករកនៅក្នុងទឹកដីសន្យា (សូមមើល ជន ១៤:២៤,៣០ ៣២:១២ និងការពន្យល់ ១៤:២៤) ។ កិច្ចការនៅក្រុងកាណានចំពោះលោកកាលែប (ពួកយូដា) និងលោកយ៉ូស្វេ (អេប្រាអិម) គឺជាការរៀបរាប់ពីការបែងចែកទឹកដីនៃភាគខាងលិចទន្លេយ័រដាន់ (សូមមើល ១៩:៤៩–៥០ និងការពន្យល់ ១៩:៤៩) ។

**១៤:៦** *ព្រះយេហូវ៉ាបានមានបន្ទូល* ពាក្យនេះព្រះទ្រង់បានត្រាស់ហៅលោកកាលែបឱ្យវិលមកវិញ តាមសេចក្តីសន្យានៃទ្រង់ ក្នុងរយៈពេល៣៨ឆ្នាំដំបូងនៅឯកាដេស ពេលនោះហើយគាត់បាននាំមកជាមួយនូវការរាយការណ៍ដ៏ល្អ ពីទឹកដីដែលបានទៅដល់(ជន ១៣:៣០ ១៤:៦–៩ ចទ ១:៣៤–៣៦)។

**១៤:៨** *ធ្វើតាម . . . គ្រប់ជំពូក* សូមមើល ជន ១៤:២៤ និងការពន្យល់ ៣២:១២ ។

**១៤:១២** *ស្រុកភ្នំនេះ* ស្រុកហេប្រុននេះ មានទីតាំងស្ថិតនៅទីខ្ពស់នៃស្រុកយូដាតំបន់ជើងភ្នំ ដែលមានចម្ងាយប្រហែល ១៩.២០០ ម៉ែត្រ ពីក្រុងយេរូសាឡិម ។ *សាសន៍អ័ណាក់* សូមមើលការពន្យល់ ១១:២១ ។

**១៤:១៥** *ស្រុកគារយ៉ាត់–អើបា* ពាក្យនេះមានន័យថា"ក្រុងអើបា"ហើយត្រូវបានគេដាក់ឈ្មោះថា អើបា ។ ហើយពាក្យអើបាដដែលនេះ ជាឪពុករបស់អ័ណាក់(១៥:១៣ ២១:១១) ។ ហើយពាក្យនេះអាចមានន័យថា "ក្រុងទាំងបួន" ប្រហែលជាអាចសំដៅទៅដល់ក្រុងអ័ណាក់ និងពួកកូនចៅទាំងបីទៀត (សូមមើល ១៥:១៤ ជន ១៣:៣២ និងការពន្យល់ ពច ១:២០) ។ *ស្រុកនោះក៏បានស្រាកស្រាន្តពីចំបាំង* ពីព្រោះសាសន៍យូដា និងលោកកាលែបបានធ្វើ

មនុស្សមានមាឌធំជាងគេក្នុងពួកសាសន៍អ័ណាក់ តពីនោះ
មកស្រុកនោះក៏បានស្រាកស្រាន្ត[ឆ]ពីចំបាំងទៅ ។

## ចំណែកសម្រាប់ពួកយូដា

*១៥:១៥-១៩ – ពច ១:១១-១៥*

**១៥** ១ឯចំណែក ដែលបានចែកដល់ពូកអំបូរនៃពួកកូន
ចៅយូដាតាមគ្រួគេទាំងប៉ុន្មាន នោះគឺខាងត្បូងទល់នឹងព្រំ
ស្រុកអេដំម[ក] ហើយនិងទីរហោស្ថានស៊ីន[ខ]ខាងត្បូងបំផុត[គ]
២ព្រំដែនគេខាងត្បូង នោះចាប់តាំងពីចុងឈូងសមុទ្រ
អំបិល[ឃ] ដែលបែរទៅខាងត្បូង ៣ដំរង់ទៅខាងត្បូង[ង] រួច
ឡើងតាមច្រកភ្នំអាក្រាប៊ីមទៅតាមស៊ីន ហើយចេញមក
ខាងត្បូងកាដេស-បារនា[ច] ដំរង់ទៅដល់ហេស្រុន ហើយ
ឡើងទៅឯអាដារ រួចបត់មកដល់ការកា ៤ពីនោះទៅក៏
ដល់អាសម៉ូន[ឆ] រួចចេញទៅ តាមស្ទឹងស្រុកអេស៊ីព្ទ[ជ] ផុត
ត្រឹមសមុទ្រ នេះហើយជាព្រំដែនរបស់ឯងរាល់គ្នានៅ
ខាងត្បូង ។
៥ឯព្រំប្រទល់[ឈ]ខាងកើត នោះគឺជាសមុទ្រអំបិល[ញ]រហូត
ដល់ចុងទន្លេយ័រដាន់ ហើយព្រំប្រទល់[ដ]ខាងជើង នោះ
ចេញពីឈូងសមុទ្រដែលនៅចុងទន្លេយ័រដាន់ ៦ឡើងទៅ
ដល់បេត-ហុកឡា[ឋ] ដំរង់ទៅខាងជើងបេត-អើរ៉ាបា[ឌ] រួច
ក៏ឡើងទៅដល់ថ្មដារបស់បូហាន[ឍ]ជាកូនរូបេន ៧ហើយ
ចេញពីច្រកភ្នំអាកោរ[ណ] ឡើងទៅដល់ដេបៀរ[ត] រួចកាត់
ត្រង់ទៅឯជើង ខាងគីលកាល[ថ] ដែលទល់មុខនឹងផ្លូវដែល
ឡើងទៅឯអាឌូមីម នៅខាងត្បូងស្ទឹង ហើយក៏ទៅតាម
ក្បាលទឹកអេន-សេមែស[ទ] រួចចេញមកត្រង់អេន-រ៉ូកេល[ធ]
៨ពីទីនោះក៏ឡើងតាមច្រកភ្នំបេន-ហ៊ីនណំម[ន] ខាងត្បូងក្រុង
យេប៊ូស[ប] គឺជាក្រុងយេរូសាឡិម[ផ] រួចឡើងទៅដល់កំពូល
ភ្នំដែលនៅខាងលិច ទល់មុខនឹងច្រកភ្នំហ៊ីនណំម[ព] គឺជាចុង
ច្រកភ្នំខាងជើងរបស់ពួករេផែម[ភ] ៩ពីកំពូលភ្នំនោះ ក៏ចុះ
ទៅដល់ក្បាលទឹកណែបត្វា[ម] ដំរង់ទៅតាមទីក្រុងទាំងប៉ុន្មាន
នៅភ្នំអេប្រុន រហូតដល់បាឡា[យ] គឺជាក្រុងគារយ៉ាត់-
យារីម[រ] ១០ពីបាឡា[ល] ក៏បត់ទៅខាងលិចទៅដល់ភ្នំសៀរ[វ]
រួចកាត់ទៅតាមចង្កេះខាងជើងនៃភ្នំយារីម គឺជាកេសាឡូន
ហើយចុះទៅដល់បេត-សេមែស[ស] រហូតដល់ធីមណា[ហ]
១១ពីទីនោះក៏ចេញទៅខាងជើងក្រុងអេក្រុន[ឡ]ដល់ស៊ីក្រុន
ហើយតាមភ្នំបាឡា[អ]ទៅដល់យ៉ាបនាល[ក] រួចផុតត្រឹមសមុទ្រ
១២ឯព្រំប្រទល់ខាងលិច នោះគឺតាមឆ្នេររបស់សមុទ្រធំ[ខ]
នេះហើយជាព្រំស្រុកនៅព័ទ្ធជុំវិញរបស់ពួកកូនចៅយូដា
តាមគ្រួគេទាំងប៉ុន្មាន ។
១៣យ៉ូស្វេក៏ចែកឱ្យដល់កាលែប[គ] ជាកូនយេភូនេ មាន
១ចំណែក ជាមួយនឹងពួកកូនចៅយូដាដែរ តាមដែលព្រះ
យេហូវ៉ាបានបង្គាប់មក គឺគារយ៉ាត់-អើបា[ឃ] ដែលជា
ក្រុងហេប្រុន[ង] (ឯអើបានោះជាឪពុកអ័ណាក់)[ច] ១៤កាលែប
ក៏បណ្តេញកូនរបស់អ័ណាក់[ឆ]៣នាក់ចេញ គឺសេសាយ១
អ័ហ៊ីម៉ាន១ និងតាលម៉ាយ[ជ]១ សុទ្ធតែជាកូនអ័ណាក់[ឈ] ១៥ពី
ទីនោះគាត់ក៏ឡើងទៅ ទាស់នឹងពួកអ្នកស្រុកដេបៀរ រីឯ
ក្រុងដេបៀរនោះ កាលពីដើមមានឈ្មោះជា គារយ៉ាត់
សេភើរ ១៦កាលែបក៏សន្យាថា បើអ្នកណានឹងវាយយក គារ
យ៉ាត់-សេភើរបាន នោះអញនឹងឱ្យអាកសា[ញ] ជាកូនអញ
ទៅធ្វើជាប្រពន្ធអ្នកនោះ ១៧ដូច្នេះអូធ្នាល[ដ] ជាកូនកេណាស

**១៤:១៥** ឆ យស ១១:២៣ ពច ៣:១១ ១ពវ ៤:២៤ ៥:៤ ១រប ២២:៩ **១៥:១** ក ជន ៣៤:៣ ខ ជន ១៣:២១ គ យស ១១:២៣ ពច ៣:១១ ១ពវ ៤:២៤ ៥:៤ ១រប ២២:៩ **១៥:២** ឃ លប ១៤:៣ **១៥:៣** ង ជន ៣៤:៤ ច ចទ ១:២ **១៥:៤** ឆ ជន ៣៤:៤ ជ លប ១៥:១៨ **១៥:៥** ឈ ជន ៣៤:១០ ញ លប :៣ ដ យស ១៨:១៥-១៩ **១៥:៦** ឋ យស ១៨:១៩,២១ ឌ ខ.៦ ១យស ១៨:១៨ ឍ យស ១៨:១៧ **១៥:៧** ណ យស ១០:៣ ត យស ៧:២៤ ត ចទ ១១:៣០ ទ យស ១៨:១៧ ធ យស ១៨:១៦ ២សយ ១៧:១៧ ១ពវ ១:៩ **១៥:៨** ន ២រប ២៨:៣ យរ ១៩:៦ ប ខ.៦៣ សយ ១០:១ យស ១៨:១៦,២៨ ពច ១:២១ ១៩:១០ ២សយ ៥:៦ ១រប ១១:៤ អរ ៩:១ ផ ព ២ពវ ២៣:១០ យរ ៧:៣១ ១៩:២ ភ ២សយ ៥:១៨,២២ ១រប ១៤:៩ អស ១៧:៥ **១៥:៩** ម យស ១៨:១៥ យ ខ.១០,១១,២៩ ២សយ ៦:២ ១រប ១៣:៦ រ យស ៩:១៧ **១៥:១០** ល ខ.៩ វ ជន ២៤:១៨ ស យស ១៩:២២,៣៨ ២១:១៦ ពច ១:៣៣ ១សយ ៦:៩ ១ពវ ៤:៩ ២ពវ ៤:១១ ហ លប ៣៨:១២ **១៥:១១** ឡ យស ១៣:៣ អ ខ.៩ ក យស ១៩:៣៣ **១៥:១២** ខ ជន ៣៤:៦ **១៥:១៣** គ ១សយ ២៥:៣ ៣០:១៤ ឃ លប ២៣:២ ង យស ១០:៣៦ ២១:១២ ១រប ៦:៥៦ ច ជន ១៣:២២ **១៥:១៤** ឆ ជន ១៣:៣៣ ជ ជន ១៣:២២ ឈ ពច ១:១០,២០ **១៥:១៦** ញ ១រប ២:៤៩ **១៥:១៧** ដ ពច ៣:៩,១១ ១រប ៤:១៣ ២៧:១៥

ដំណើរឆ្ពោះទៅលោកយ៉ូស្វេ ដោយជាប់ទាក់ទងនឹងទឹកដីពួកគេ គឺពេលនោះលោកយ៉ូស្វេគឺជាអ្នកដឹកនាំនៅគីលកាលនៅឡើយ ។ នៅត្រង់នេះប្រហែលជាពួកគេបានធ្វើដំណើរទៅទីនោះយ៉ាងឆាប់បំផុត គឺមុនពេលដែលការវាយប្រហាររបស់លោកយ៉ូស្វេបានបញ្ចប់ (មើល ១១:២៣) ។

**១៥:១-៦៣** នៅវគ្គនេះនិយាយអំពីជនជាតិយូដា ជាពួកអ្នកស្រុកដែលរស់នៅតាមមាត់ច្រាំងទន្លេដើម្បីកំណត់ព្រំដែនទឹកដី ។ ដំបូង ពួកអ្នកស្រុកក្រៅត្រូវបានគេចុះបញ្ជី ហើយបន្ទាប់មកបែងចែកទឹកដីនោះទៅដល់កាលែប និងអូធ្នាល ហើយនៅទីបញ្ចប់ក្រុងកាណានបានចែកទៅដល់ពួកយូដា ឯតំបន់និមួយៗ នោះត្រូវបានគេដាក់ឈ្មោះតាមពួកយូដានោះ ។

**១៥:១** *ពូជអំបូរនៃពួកកូនចៅយូដា* សិទ្ធិជាអាទិភាពរបស់ពួកយូដា គឺបានតភ្ជាប់ជាមួយទំនាយរបស់លោកយ៉ាកុប (លប ៤៩:៨-១២) និងបានលើកកំពស់នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ (ពច ១:១-២ ២០:១៨ ២ពវ ១៧:១៨ ទដ ៧៨:៦៨) ។

**១៥:៤** *ព្រំដែនរបស់ឯងរាល់គ្នានៅខាងត្បូង* ឃ្លានេះប្រាប់ពីចំណុចលំអិតដែលគេធ្វើឡើងមានរាងជាខ្សែកោងដោយចាប់ផ្តើមពីផ្នែកទាបនៃជ្រោយសមុទ្រស្លាប់ ហើយចាក់ទៅផ្នែកខាងក្រោមនៃតំបន់កាដេស ទៅជួបនឹងឆ្នេរសមុទ្រមេឌីទែរ៉ាណេ (សូមមើលការពន្យល់ ១៣:៣) ។

**១៥:៥** *ព្រំប្រទល់ខាងជើង* នេះជាព្រំប្រទល់ពួកយូដា ជាមួយនឹងពួកបេនយ៉ាមីនដែលលាតសន្ធឹងឆ្ពោះទៅទិសខាងលិច ចាប់ពីមាត់ទន្លេយ័រដាន់ដោយកាត់តាមច្រក់ភ្នំបេន-ហ៊ីនណំម ហួសតំបន់ធីមណា បន្ទាប់មកទិសខាងលិចឈាងខាងជើង ទៅឆ្នេរសមុទ្រនៃយ៉ាបនាលដែលប្រហែលជាមានចម្ងាយ ១៦ គ.ម ពីភាគខាងត្បូងក្រុងយ៉ុបប៉េ ។

**១៥:៧** *គីលកាល* មើលការពន្យល់ ពច ៣:១៩ ។

**១៥:១៥** *គាត់ក៏ឡើងទៅទាស់... ស្រុកដេបៀរ* មើលការពន្យល់ ១០:៣៨ ។

ដែលកេណាសជាប្អូនកាលែប គាត់ក៏វាយយកបាន នោះ
កាលែបក៏ឱ្យនាងអាកសា ជាកូនខ្លួន ទៅធ្វើជាប្រពន្ធគាត់
ទៅ ១៨កាលនាងបានមកដល់គាត់ហើយ នោះក៏បបួលឱ្យ
សូមដីពីឪពុកនាង ដូច្នេះនាងចុះពីលើសត្វជំនិះ កាលែប
ក៏សួរថា ហេតុអ្វីហ្នឹង ១៩នាងឆ្លើយថា សូមលោកឪពុក
ចែកឱ្យខ្ញុំមួយចំណែកផង ដ្បិតលោកឪពុកបានឱ្យខ្ញុំមាន
ដីខាងត្បូងហើយ[ឋ] ដូច្នេះសូមឱ្យខ្ញុំមានក្បាលទឹកដែរ នោះ
គាត់ក៏ឱ្យក្បាលទឹកខាងលើ ហើយខាងក្រោមទៅនាង[ឌ] ។

២០នេះជាមរដក របស់ពូជអំបូរ នៃពួកកូនចៅយូដា
តាមគ្រួគេទាំងប៉ុន្មាន ២១ឯទីក្រុងទាំងប៉ុន្មានរបស់ពូជ
អំបូរនៃពួកកូនចៅយូដា ដែលនៅខាងត្បូង[ឍ]បំផុត ក្បែរ
ព្រំដែនរបស់អេដំម នោះគឺកាបសៀល[ណ]១ អេឌើរ[ត]១
យ៉ាគើរ១ ២២គីណា១ ឌីម៉ូណា១ អាដាដា១ ២៣កេដេស[ថ]១
ហាសោរ[ទ]១ អ៊ីថ្នាន១ ២៤ស៊ីភ[ធ]១ ថេលែម១ ប្អាឡូត១
២៥ហាសោរ–ហាដាថា១ កេរីយ៉ុត–ហេស្រុន គឺជាក្រុង
ហាសោរ[ន]១ ២៦អាម៉ាម១ សេម៉ា១ ម៉ូឡាដា[ប]១ ២៧ហាសា
–កាដា១ ហែសម៉ូន១ បេត–ផាលែត១ ២៨ហាសា–
ស៊ូអាល[ផ]១ ប្អៀរ–សេបា[ព]១ ប៊ីសយ៉ុតយ៉ា១ ២៩បាឡា[ភ]១
អ៊ីយីម១ អាសែម[ម]១ ៣០អែលថូឡាត[យ]១ កេសៀល១
ហោម៉ា[រ]១ ៣១ស៊ីកឡាក់[ល]១ ម៉ាតម៉ាណា[វ]១ សានសា–
ណា១ ៣២ល្បាអូត១ ស៊ីលហ៊ីម១ អាយិន[ស]១ និងរីម៉ូន[ហ]១
រួមទាំងអស់មាន២៩ក្រុង ព្រមទាំងភូមិទាំងប៉ុន្មានផង ។

៣៣ឯខាងស្រុកទំនាប នោះមានក្រុងអែសថោល[ឡ]១
សូរ៉ាស់[អ]១ អាសណា[ក]១ ៣៤សាណូអា[ខ]១ អេន–កានីន[គ]១
តាពួរ[ឃ]១ អេណាម១ ៣៥យ៉ារមុត[ង]១ អាឌូឡាម[ច]១
សូគរ[ឆ]១ អាសេកា[ជ]១ ៣៦ស្អារ៉ែប[ឈ]១ អាឌីថែម១
កេដេរ៉ា[ញ]១ និងក្តេរ៉ូថែម១ រួមទាំងអស់មាន១៤ក្រុង
ព្រមទាំងភូមិទាំងប៉ុន្មានផង ៣៧ក្រុងសេណាន១
ហាដាសា១ មីកដាល–កាឌ់១ ៣៨ឌីលាន១ មីសប៉ា[ដ]១
យ៉ុកធាល[ឋ]១ ៣៩ឡាគីស[ឌ]១ បូសកាត់[ឍ]១ អេក្លូន[ណ]១
៤០កាបូន១ ឡាម៉ាស១ គីតលីស១ ៤១កេដេរ៉ូត[ត]១ បេត–
ដាកុន[ថ]១ ន៉ាអាម៉ា១ និងម៉ាកេដា[ទ]១ ទាំងអស់មាន១៦
ក្រុង ព្រមទាំងភូមិទាំងប៉ុន្មានផង ៤២ក្រុងលិបណា[ធ]១
អេធើរ១ អាសាន[ន]១ ៤៣យីបថា១ អាសណា[ប]១ នេស៊ីប១

**១៥:១៩** ឋ យស ១០:៤០ ឌ លប ៣៦:២៤
**១៥:២១** ឍ យស ១០:៤០ ណ ២សយ ២៣:២០ ១រប ១១:២២ ត លប ៣៥:២១
**១៥:២៣** ថ យស ១២:២២ ទ យស ១១:១
**១៥:២៤** ធ ខ.៥៥ ១សយ ២៣:១៤ ២រប ១១:៨
**១៥:២៥** ន យស ១១:១
**១៥:២៦** ប យស ១៩:២ ១រប ៤:២៨ នហ ១១:២៦
**១៥:២៨** ផ យស ១៩:៣ ១រប ៤:២៨ ព លប ២១:១៤
**១៥:២៩** ភ ខ.៩ ម យស ១៩:៣ ១រប ៤:២៩
**១៥:៣០** យ យស ១៩:៤ រជន ១៤:៤៥
**១៥:៣១** ល យស ១៩:៥ សយ ២៧:៦ ១រប ៤:៣០ ១២:១ នហ ១១:២៨ វ ១រប ២:៤៩
**១៥:៣២** ស ជន ៣៤:១១ ហ យស ១៩:៧ ពច ២០:៤៥ ២១:១៣ សក ១៤:១០
**១៥:៣៣** ឡ យស ១៩:៤១ ពច ១៣:២៥ ១៦:៣១ ១៨:២ អ ពច ១៣:២ ១៨:១១ ២រប ១១:១០ នហ ១១:២៩ ក ខ.៤៣

៤៤កេឡា[ផ]១ អាក់ស៊ីប[ព]១ និងម៉ារីសា[ភ]១ ទាំងអស់មាន៩ក្រុង
ព្រមទាំងភូមិទាំងប៉ុន្មានផង ៤៥ក្រុងអេក្រុន[ម]១ ព្រមទាំង
ទីដំបន់នឹងភូមិជុំវិញទាំងប៉ុន្មានផង ៤៦ហើយអស់ទាំងទីក្រុង
ដែលនៅខាងក្រុងអាសដូឌ[យ] និងភូមិទាំងប៉ុន្មាន ចាប់តាំងពី
អេក្រុនរហូតដល់សមុទ្រ ៤៧និងក្រុងអាសដូឌ[រ] ព្រមទាំងភូមិ
និងដំបន់ទាំងប៉ុន្មាន ដែលនៅជុំវិញក្រុងកាសា ព្រមទាំង
ភូមិនិងដំបន់ទាំងប៉ុន្មានដែលនៅជុំវិញ រហូតដល់ស្ទឹងស្រុក
អេស៊ីព្ទ[ល] និងសមុទ្រធំ[វ] ដែលជាព្រំប្រទល់របស់ស្រុកនោះ ។

៤៨ឯខាងស្រុកភ្នំនោះមានក្រុងសាមា[ស]១ យ៉ាទារ[ហ]១ សូគរ
[ឡ]១ ៤៩ដាណា១ គារយ៉ាត់–សាណា គឺជាក្រុងដេបៀរ[អ]១
៥០អាណាប[ក]១ អែសធេម៉ូរ[ខ]១ អានីម១ ៥១កូសែន[គ]១
ហូឡូន[ឃ]១ និងគីឡោ[ង]១ ទាំងអស់មាន១១ក្រុង ព្រមទាំង
ភូមិទាំងប៉ុន្មានផង ៥២ក្រុងអារ៉ាប១ ឌូម៉ា[ច]១ អែសអៀន១
៥៣យ៉ានិម បេត–តាពួរ១ អាផែកា១ ៥៤ហិមតា១ គារយ៉ាត់–
អើបា[ឆ] គឺជាក្រុងហេប្រុន១ និងស៊ីរអារ១ ទាំងអស់មាន
៩ក្រុង ព្រមទាំងភូមិទាំងប៉ុន្មានផង ៥៥ក្រុងម៉ាអូន[ជ]១
កើមែល[ឈ]១ ស៊ីភ[ញ]១ យូថា[ដ]១ ៥៦យេសរាល[ឋ]១ យ៉ុកឌាម១
សាណូអា[ឌ]១ ៥៧កាអ៊ីន១ គីបៀរ[ឍ]១ និងធីមណា១ ទាំងអស់
មាន១០ក្រុង ព្រមទាំងភូមិទាំងប៉ុន្មានផង ៥៨ក្រុងហាលហ៊ុល១

**១៥:៣៤** ខ ខ.៥៦ ១រប ៣:១៨ នហ ៣:១៣ ១១:៣០ គ យស ១៩:២១ ២១:២៩ ឃ ខ.៤៣ **១៥:៣៥** ង យស ១០:៣ ច លប ៣៨:១ ឆ ខ.៤៨ ១ពវ ៤:១០ ជ យស ១០:១០ **១៥:៣៦** ឈ ១សយ ១៧:៥២ ១រប ៤:៣១ ញ ១រប ១២:៤ **១៥:៣៨** ដ យស ១១:៣ ឋ ២ពវ ១៤:៧ **១៥:៣៩** ឌ យស ១០:៣ ឍ ២ពវ ២២:១ ណ យស ១០:៣ **១៥:៤១** ត ២រប ២៨:១៨ ថ យស ២២:១ ទ យស ១០:១០ **១៥:៤២** ធ ជន ៣៣:២០ ន យស ១៩:៧ ១សយ ៣០:៣០ ១រប ៤:៣២ ៦:៥៩ **១៥:៤៣** ប ខ.៣៣ **១៥:៤៤** ផ ១សយ ២៣:១–២,១ ១រប ៤:១៩ នហ ៣:១៧,១៨ ព យស១៩:២៩ ពច ១:៣១ មីក ១:១៤ ភ មីក ១:១៥ **១៥:៤៥** ម យស ១៣:៣ **១៥:៤៦** យ យស ១១:២២ **១៥:៤៧** រ យស ១១:២២ ល លប ១៥:១៨ វ ជន ៣៤:៦ **១៥:៤៨** ស ពច ១០:១ ហ យស ២១:១៤ ១សយ ៣០:២៧ ១រប ៦:៥៧ ឡ ខ.៣៥ **១៥:៤៩** អ យស ១០:៣ **១៥:៥០** ក យស ១១:២១ ខ យស ២១:១៤ ១សយ ៣០:២៨ **១៥:៥១** គ យស ១០:៤១ ឃ យស ២១:១៥ យរ ៤៨:២១ ង ២សយ ១៥:១២ **១៥:៥២** ច លប ២៥:១៤ **១៥:៥៤** ឆ លប ៣៥:២៧ **១៥:៥៥** ជ ពច ១០:១២ ១សយ ២៣:២៤,២៥ ២៥:១,២ ១រប ២:៤៥ ឈ យស ១២:២២ ញ ខ.២៤ ដ យស ២១:១៦ **១៥:៥៦** ឋ យស ១៧:១៦ ១៩:១៨ ពច ៦:៣៣ ១សយ ២៥:៤៣ ១ពវ ១៨:៤៥ ១រប ៣:១ ហស ១:៥ ឌ ខ.៣៤ **១៥:៥៧** ឍ យស ១៨:២៨ ២៤:៣៣ ពច ១៩:១២ ២០:៤ ២សយ ២៣:២៩ ១រប ១១:៣១ លប ៣៨:១២

**១៥:១៧** *អូធ្នាល* សូមមើល ពច ៣:៧–១១ សម្រាប់ការវិនិច្ឆ័យនៅក្នុងពួក អ៊ីស្រាអែល ។

**១៥:២១** *ក្រុង . . . ត្បូងបំផុត* ទឹកដីភាគច្រើននៃទឹកដីដំបូងនៃភូមិ២៩ ដែលត្រូវបានបែងចែកទៅជាសាសន៍ស៊ីម្មាន (ធៀបនឹង ១៩:១–៩) ។

**១៥:៣៣** *ស្រុកទំនាប* ស្រុកនេះស្ថិតនៅតំបន់ខ្ពស់នៃយូដាកណ្តាល និងឆ្នេរសមុទ្រប៉ាឡេស្ទីនជាផ្នែកមួយធំដែលមិនត្រូវបានវាតទីដោយពួកអ៊ីស្រាអែលរហូតដល់ជ័យជម្នះរបស់ស្តេចដាវីឌ ។

**១៥:៤៨** *ស្រុកភ្នំ* ស្រុកនេះនៅតំបន់ខ្ពស់ភាគខាងត្បូងនៃក្រុងយេរូសាឡិម ។

បេត–សើរ[ណ]១ កេដោរ[ត]១ ៥៩ម្អារ៉ាត១ បេត–អាណូត១ និង
អែលទិកុន១ ទាំងអស់មាន៦ក្រុង ព្រមទាំងភូមិទាំងប៉ុន្មាន
ផង ៦០ក្រុងគារយ៉ាត់–បាល[ថ] គឺជាក្រុងគារយ៉ាត់–យារីម[ទ]១
និងរ៉ាបាត[ធ]១ ទាំងអស់មាន២ក្រុង ព្រមទាំងភូមិ ទាំងប៉ុន្មាន
ផង ។
៦១ឯខាងទីរហោស្ថាន[ន] នោះមានក្រុងបេត–អើរ៉ាបា[ប]១
មីឌីន១ សេកាកា១ ៦២នីប សាន១ អៀ–ហាមេឡាក់១
និងអេន–កេឌី[ផ]១ ទាំងអស់មាន៦ក្រុង ព្រមទាំងភូមិទាំង
ប៉ុន្មានផង ៦៣រីឯពួកកូនចៅយូដា គេពុំអាច[ព]នឹងបណ្ដេញ
សាសន៍យេប៊ូស[ព] ដែលនៅក្រុងយេរូសាឡិមបានទេ[ភ] ពួក
សាសន៍នោះគេចេះតែនៅជាមួយនឹងពួកកូនចៅយូដា[ម] នៅ
ក្រុងយេរូសាឡិម ដរាបដល់សព្វថ្ងៃនេះ ។

## ចំណែកសម្រាប់ពួកអេប្រាអិម និងម៉ានាសេ

**១៦** ១ឯចំណែកដែលគេបានចែក ដល់ពួកកូនចៅ
យ៉ូសែប នោះចាប់តាំងពីទន្លេយ័រដាន់ត្រង់យេរីខូរ គឺពី
ខាងកើតទឹកក្រុងយេរីខូរ ក៏កាត់ទីរហោស្ថាន[ក] ដែលឡើង
ពីក្រុងយេរីខូរ តាមស្រុកភ្នំទៅដល់ក្រុងបេត–អែល[ខ] ២រួច
ចេញពីក្រុងបេត–អែល ទៅដល់ក្រុងលូស[គ] ក៏បណ្ដោយ
ទៅតាមព្រំស្រុកសាសន៍អើគី[ឃ] រហូតដល់ក្រុងអាថារ៉ូត[ង]
៣ពីទីនោះ ក៏ចុះទៅខាងលិច តាមព្រំស្រុករបស់ពួក
យ៉ាផ្លេទីត ខាងព្រំក្រុងបេត–ហូរ៉ុន[ច]ខាងក្រោម រហូតដល់
ក្រុងកេសើរ[ឆ] រួចក៏ទៅផុតត្រឹមសមុទ្រ ៤ដូច្នេះពួកកូន
ចៅយ៉ូសែប គឺពួកម៉ានាសេ និងពួកអេប្រាអិមបានមរដក
របស់គេហើយ[ជ] ។
៥ឯព្រំស្រុករបស់ពួកកូនចៅអេប្រាអិម តាមគ្រួគេទាំង
ប៉ុន្មាន នោះប៉ែកខាងកើត គឺក្រុងអាថារ៉ូត–អាដើរ[ឈ] ទៅ
ដល់បេត–ហូរ៉ុនខាងលើ[ញ] ៦ពីទីនោះក៏ចេញទៅឯខាងលិច
ត្រង់ខាងជើងក្រុងមីកមេថា[ដ] រួចបត់ទៅខាងកើត រហូត
ដល់ក្រុងត្អាណាត–ស៊ីឡូរ រួចទៅតាមខាងកើតក្រុង
យ៉ាណូហា[ឋ] ៧ពីយ៉ាណូហា[ឌ]ក៏ចុះទៅដល់ក្រុងអាថារ៉ូត[ឍ]
ហើយនិងក្រុងណារ៉ាត រហូតដល់ក្រុងយេរីខូរ ទៅផុតត្រឹម
ទន្លេយ័រដាន់ ៨ហើយពីក្រុងតាពួរ[ណ] ព្រំនោះក៏ទៅខាងលិច
ទៅតាមស្ទឹងខាណា[ត] រួចផុតត្រឹមសមុទ្រ នេះហើយជា
មរដករបស់ពូជអំបូរពួកកូនចៅអេប្រាអិម តាមគ្រួគេទាំង
ប៉ុន្មាន ៩ព្រមទាំងទីក្រុង និងភូមិជុំវិញទាំងប៉ុន្មាន ដែល
សំរាប់ពួកកូនចៅអេប្រាអិម នៅក្នុងមរដករបស់ពួកកូន
ចៅម៉ានាសេនោះផង[ថ] ១០តែគេមិនបានបណ្ដេញពួក
សាសន៍កាណាន ដែលនៅក្រុងកេសើរចេញទេ ពួក
សាសន៍នោះគេនៅជាមួយនឹងពួកអេប្រាអិម ដរាបដល់
សព្វថ្ងៃនេះ ហើយក៏ត្រឡប់ជាអ្នកបំរើដល់ពួកអេប្រាអិម
ទាំងបង្ខំ[ទ] ។

**១៧** ១នេះជាចំណែកដែលគេបានចែកដល់ពូជអំបូរ
ម៉ានាសេ[ក] ដ្បិតគាត់ជាកូនច្បង[ខ]របស់យ៉ូសែប ឯម៉ាគារ[គ]ជា
កូនច្បងរបស់ម៉ានាសេ ហើយជាឪពុករបស់កាឡាត គាត់
បានស្រុកកាឡាត[ឃ] និងស្រុកបាសាន[ង] ដោយព្រោះគាត់ជា
អ្នកថ្នឹកច្បាំង ២រីឯចំណែកដែលបានចែកឱ្យពួកកូនចៅ
ម៉ានាសេឯទៀត[ច] តាមគ្រួគេទាំងប៉ុន្មាន នោះគឺចែកឱ្យពួក
កូនចៅអ័បៀសើរ[ឆ] ពួកកូនចៅហេលេក ពួកកូនចៅ

**១៥:៥៨** ណ ១របា ២:៤៥ ២របា ១១:៧ នហ ៣:១៦ ត ១របា ៤:៣៩ ១២:៧ **១៥:៦០** ថ ខ.៩ ទ យស ៩:១៧ ធ ចទ ៣:១១ **១៥:៦១** ន យស ៨:១៥ ប ខ.៦ **១៥:៦២** ផ ១សយ ២៣:២៩ ២៤:១ អគ ៤៧:១០ **១៥:៦៣** ព យស ១៦:១០ ១៧:១២ ពច ១:២១ ១ពវ ៩:២១ ភ ខ.៨ ម យស ១០:១ រ អគ ៤៨:៧ **១៦:១** ក យស ៨:១៥ ខ យស ១២:៩ **១៦:២** គ លបា ២៨:១៩ ឃ ២សយ ១៥:៣២ ង ខ.៥ ជន ៣២:៣ **១៦:៣** ច យស ១០:១០ ឆ យស ១០:៣៣ **១៦:៤** ជ យស ១៨:៥ **១៦:៥** ឈ ខ.២ យស ១៨:១៣ ញ យស ១០:១០ **១៦:៦** ដ យស ១៧:៧ ឋ ខ.៧ ២ពវ ១៥:២៩ **១៦:៧** ឌ ខ.៦ ឍ ជន ៣២:៣ **១៦:៨** ណ យស ១២:១៧ ត យស ១៧:៩ ១៩:២៨ **១៦:១០** ថ យស ១៥:៦៣ ១៧:១៣ ពច ១:២៨–២៩ ១ពវ ៩:១៦ **១៧:១** ក ចន ១:៣៤ ១របា ៧:១៤ ខ លបា ៤១:៥១ គ លបា ៥០:២៣ ឃ យស ១២:២ ង យស ១២:៥ **១៧:២** ច យស ២២:៧ ឆ ជន ២៦:៣០ ពច ៦:១១,៣៤ ៨:២ ១របា ៧:១៨

**១៥:៦១–៦២** នៅត្រង់នេះបញ្ជាក់ពី"ទីរហោស្ថាន"មានដីឡើងសោះកក្រោះ នៅភាគខាងកើត និងខាងត្បូងក្រុងយេរូសាឡិម ដែលជាប់ព្រំប្រទល់សមុទ្រស្លាប់ ។
**១៥:៦៣** *សាសន៍យេប៊ូស* ជ័យជម្នះដែលពួកយូដា បានឈ្នះលើក្រុងសាសន៍យេប៊ូសនេះ គឺមានកត់ចុះក្នុង ពច ១:៨ ប៉ុន្តែភស្តុតាងចំពោះការនេះមិនបានមានជាលទ្ធផលនៃការច្បាំងយកនេះទេ ។ ទាំងពួកបេនយ៉ាមីន និងពួកយូដាមិនបានជោគជ័យក្នុងការកាន់កាប់បន្ទាយរបស់ពួកសាសន៍យេប៊ូសនៅក្រុងយេរូសាឡិម (ពច ១:២១) ។
**១៦:១–១៧:១៨** ពីរជំពូកនេះនិយាយពីការបែងចែកទឹកដីទៅឱ្យពួក "គ្រួយ៉ូសែប" (អេប្រាអិម និងសាសន៍ម៉ានាសេមួយចំហៀង ដែលបានបោះទីលំនៅខាងលិចទន្លេយ័រដាន់) ។ ការធ្វើតាមពួកយូដា កូនចៅយ៉ូសែបត្រូវបានសិទ្ធិជាអាទិភាព ក្នុងការបែងចែកទឹកដីនេះផងដែរ ។
**១៦:១** *ចំណែកដែលគេបានចែក ដល់ពួកកូនចៅយ៉ូសែប* ព្រំប្រទល់ខាងត្បូងពួកកូនចៅយ៉ូសែប បានប្តូរទៅឯទិសខាងលិចក្រុងយេរីខូរវិញ ហួសក្រុងបេតអែលដោយចុះទៅក្រោមក្រុងកេសើរ និងឆ្នេរសមុទ្រមេឌីទែរ៉ាណេ ។
**១៦:៥** *ព្រំ* ពាក្យនេះប្រាប់ពីព្រំប្រទល់អេប្រាអិមខាងជើង ដោយចាប់ផ្តើមនៅជាយជ្រលងទន្លេយ័រដាន់ ហើយឆ្ពោះទៅជិតភាគខាងលិចនៃក្រុងស៊ីឡូរ ប៉ុន្តែ វាជាភាគខាងត្បូងស៊ីគែម បន្ទាប់មកត្រឡប់ទៅស្ទឹងខាណាចុះទៅក្រោមសមុទ្រមេឌីទែរ៉ាណេ ។
**១៦:១០** *កេសើរ* សូមមើលការពន្យល់ ១០:៣៣ ។ *បំរើដល់ពួកអេប្រាអិមទាំងបង្ខំ* គម្រោងនេះ ត្រូវបានធ្វើឡើងដោយមន្ត្រីរាជការ តែជាទូទៅ គឺជាស្តេច (២សយ ១២:១៣ ១ពវ ៩:១៥,២០–២១) ។
**១៧:១** *ពូជអំបូរម៉ានាសេ . . . កូនច្បងរបស់យ៉ូសែប* ថ្វីបើលោកយ៉ាកុបបានផ្តល់សិទ្ធិជាអាទិភាពទៅដល់ពួកអេប្រាអិម ពេលដែលគាត់បានចិញ្ចឹមកូនប្រុសទាំងពីររបស់លោកយ៉ូសែបក៏ដោយ ប៉ុន្តែគួរចងចាំថាម៉ានាសេ ជាកូនច្បងរបស់លោកយ៉ូសែប (លបា ៤៨:១៤,១៩) ។

អាសរាល[ដ] ពួកកូនចៅស៊ីគែម ពួកកូនចៅហេភើរ[ឈ] និង
ពួកកូនចៅសេមីដា[ញ] នោះសុទ្ធតែជាកូនចៅប្រុសៗរបស់
ម៉ាន៉ាសេ ដែលជាកូនយ៉ូសែប តាមជំនួរវង្ស ៣ឯស្លូផិហាត
ជាកូនហេភើរ[ដ] ដែលហេភើរជាកូនកាឡាតៗ ជាកូនម៉ាគារ
ម៉ាគារ ជាកូនម៉ាន៉ាសេ គាត់គ្មានកូនប្រុសទេ មានសុទ្ធតែ
កូនស្រីទាំងអស់[ថ] ឈ្មោះរបស់កូនស្រីទាំងប៉ុន្មាននោះ គឺ
ម័សឡា១ ណូហា១ ហុកឡា១ មីលកា១ និងធើសា១
៤នាងទាំងនោះក៏មកឯអេលាសារដ៏ជាសង្ឃ និងយ៉ូស្វេជា
កូននុន ហើយនិងពួកអ្នកជាកំពូលទាំងប៉ុន្មាន ជំរាបថា
ព្រះយេហូវ៉ាទ្រង់បានបង្គាប់ដល់លោកម៉ូសេ ឱ្យចែកមរដក
មកយើងខ្ញុំ នៅកណ្តាលពួកបងប្អូនយើងខ្ញុំដែរ ដូច្នេះ
លោកក៏ចែកមរដកឱ្យគេ គឺនៅកណ្តាលពួកបងប្អូនឪពុកគេ
តាមបង្គាប់ព្រះយេហូវ៉ា[ឌ] ៥មាន១០ចំណែកដែលត្រូវបាន
ដល់ពួកម៉ាន៉ាសេ ក្រៅពីស្រុកកាឡាត និងស្រុកបាសាន
ដែលនៅខាងនាយទន្លេយ័រដាន់[ឍ] ៦ពីព្រោះកូនចៅស្រី
របស់ម៉ាន៉ាសេនោះ បានទទួលមរដកនៅកណ្តាលពួកកូន
ចៅប្រុសៗដែរ ហើយស្រុកកាឡាតបានចែកដល់ពួកកូន
ចៅប្រុសរបស់ម៉ាន៉ាសេឯទៀតនោះហើយ ។
៧ឯព្រំដែនរបស់ម៉ាន៉ាសេ នោះចាប់តាំងពីអេស៊ើរ[ណ]
ទៅដល់មិកមេថា[ត] ដែលនៅប្រទល់មុខក្រុងស៊ីគែម[ថ] រួច
បណ្តោយទៅខាងស្តាំ រហូតដល់ពួកអ្នកនៅស្រុកអែន-
តាពួរ ៨ស្រុកតាពួរ[ទ]នោះជារបស់ផងពួកម៉ាន៉ាសេ តែក្រុង
តាពួរ ដែលនៅព្រំស្រុកម៉ាន៉ាសេ ជារបស់ផងពួកកូនចៅ
អេប្រាអិមវិញ ៩ព្រំនោះក៏ចុះទៅដល់ស្ទឹងខាណា[ធ] រួចទៅ
តាមខាងត្បូងស្ទឹងនោះ ទីក្រុងទាំងនោះដែលនៅក្នុងព្រំ
របស់ម៉ាន៉ាសេ ជារបស់ផងពួកអេប្រាអិម តែព្រំស្រុក
ម៉ាន៉ាសេ គឺនៅខាងជើងស្ទឹងនោះវិញ រួចក៏ចុះទៅផុតត្រឹម
សមុទ្រ ១០ឯស្រុកខាងត្បូងជារបស់ផងអេប្រាអិម ហើយ
ខាងជើងជារបស់ផងម៉ាន៉ាសេ មានសមុទ្រជាខាងចុងស្រុក
ស្រុកគេក៏រហូតដល់អេស៊ើរ[ន]ខាងជើង ហើយរហូតដល់
អ៊ីសាខារ[ប]ខាងកើត[ផ] ១១ហើយពួកម៉ាន៉ាសេក៏មានទីក្រុង
នៅក្នុងស្រុកអ៊ីសាខារ[ព] និងស្រុកអេស៊ើរដែរ គឺក្រុងបេត-
សៀន[ភ] និងដំបន់ជុំវិញ ក្រុងយីបលាម[ម] និងដំបន់ជុំវិញ
ព្រមទាំងពួកអ្នកនៅក្រុងដោរ[យ] និងដំបន់ជុំវិញ ពួកអ្នកនៅ
ក្រុងអេន-ដោរ[រ] និងដំបន់ជុំវិញ ពួកអ្នកនៅក្រុងតាណាក[ល]
និងដំបន់ជុំវិញ និងពួកអ្នកនៅក្រុងមេគីដោ[វ] និងដំបន់ជុំវិញ
គឺអស់៣ស្រុក[ស] ១២ប៉ុន្តែពួកកូនចៅម៉ាន៉ាសេ ពុំអាច[ហ]នឹង
បណ្តេញពួកសាសន៍កាណាន ដែលនៅទីក្រុងទាំងនោះ
ចេញបានទេ គឺគេផ្តាច់ចិត្តនឹងនៅជាប់ក្នុងស្រុកទនោះវិញ
១៣តែកាលពួកកូនចៅអ៊ីស្រាអែលបានមានកំឡាំងឡើង
នោះក៏បង្ខំឱ្យពួកសាសន៍កាណាននោះធ្វើការបំរើខ្លួន ឥត
បានបណ្តេញគេអស់រលីងទេ[ឡ]។
១៤ពួកកូនចៅយ៉ូសែបក៏សួរយ៉ូស្វេថា ហេតុអ្វីបានជា
លោកឱ្យយើងខ្ញុំចាប់ឆ្នោត មានចំណែកតែ១ ទុកជាមរដក
ដូច្នេះ ដ្បិតយើងខ្ញុំជាពួកធំណាស់ដែរ ដោយព្រោះព្រះ
យេហូវ៉ាបានប្រទានពរមកយើងខ្ញុំ តាំងពីដើមរៀងមក[អ]
១៥រួចយ៉ូស្វេឆ្លើយតបថា បើឯងជាពួកធំមែន ហើយបើស្រុក
ភ្នំអេប្រាអិម នោះចង្អៀតពេកដល់ឯង នោះចូរឡើង

**១៧:២** ដ ១របា ៧:១៤ ឈ ជន ២៧:១ ញ ១របា ៧:១៩ **១៧:៣** ដ ជន ២៧:១ ថ ជន ២៦:៣៣ **១៧:៤** ឌ ជន ២៧:៥-៧ **១៧:៥** ឍ យស ១៣:៣០-៣១ **១៧:៧** ណ ខ.១០ យស ១៩:២៤,៣១ ៥:១៧ ៦:៣៥ ៧:២៣ ត យស ១៦:៦ ថ លប ២១:២១ ២៤:២៥ ពច ៩:១ **១៧:៨** ទ យស ១២:១៧ **១៧:៩** ធ យស ១៦:៨ **១៧:១០** ន ខ.៧ ប លប ៣០:១៨ ផ អគ ៤៨:៥ **១៧:១១** ព ខ.១០ ភ ខ.១៦ ពច ១:២៧ ១សយ ៣១:១០ ២សយ ២១:១២ ១ពវ ៤:១២ ១របា ៧:២៩ ម ២ពវ ៩:២៧ យ យស ១១:២ រ ១សយ ២៨:៧ ទដ ៨៣:១០ ល យស ១២:២១ វ ១ពវ ៩:១៥ ស អគ ៤៨:៤ **១៧:១២** ហ យស ១៥:៦៣ **១៧:១៣** ឡ ពច ១:២៧-២៨ **១៧:១៤** អ ជន ២៦:២៨-៣៧

**១៧:៣** *ស្លូផិហាត . . . មានសុទ្ធតែកូនស្រី* មើលការពន្យល់ ជន ២៧:១-១១ ៣៦:១-៣ ។

**១៧:៥** *១០ចំណែក* ទឹកដីរបស់ពួកម៉ាន៉ាសេ ជាផ្នែកទី២ នៅក្នុងដែនដីរបស់ពួកយូដា ។ ចំណែក១០ភាគទៀត បានចែកទៅឱ្យបងប្អូនប្រុសទាំងប្រាំ និងចៅស្រីទាំងប្រាំរបស់ស្តេចហេភើរ ។

**១៧:១១** *ក្រុងបេត-សៀន . . . ក្រុងមេគីដោ* ក្រុងទាំងពីរនេះមានអំណាចខ្លាំងក្លាបានរឹតបន្តឹងក្រុងនោះ ដូច្នេះហើយធ្វើឱ្យក្រុងនេះមិនត្រូវបានគេវាតទីយករហូតមកដល់ពេលក្រោយៗមកទៀត ។ នៅពេលដែលស្តេចសូលបានសុគតទៅ នោះជ័យជម្នះរបស់ពួកភីលីស្ទីន បានរឹតចំណងនៃរាង្គកាយរបស់គាត់ផ្ទាល់ទៅនឹងកំផែងក្រុងបេត-សៀន(សូមមើល ១សយ ៣១:១០) ដែលលើកឡើងថា ក្រុងនោះចងសម្ព័ន្ធជាមួយនឹងពួកភីលីស្ទីន ។

**១៧:១៣** *កូនចៅអ៊ីស្រាអែលបានមានកំឡាំងឡើង* នេះសំដៅទៅលើថ្ងៃនៃស្តេចដាវីឌ និងស្តេចសាឡូម៉ូន (សូមមើលការពន្យល់ ១៦:១០) ។

**១៧:១៤** *កូនចៅយ៉ូសែប . . . ធំណាស់* ឃ្លានេះបញ្ជាក់ពីពួកអេប្រាអិម និងពួកម៉ាន៉ាសេ (ខ.១៧) ។ ការបែងចែកទឹកដីទៅដល់ពួកកូនចៅយ៉ូសែបនៅត្រង់នេះ គឺតែមួយចំណែកប៉ុណ្ណោះ (សូមមើល ១៦:១,៤) ថ្វីបើការបែងចែកជាចំណែកតូចៗ ក្រោយមកទៀតត្រូវបានគេពិពណ៌នាដាច់ៗពីគ្នា (១៦:៥-១៧:១១) ។

**១៧:១៥** *ស្រុកភ្នំអេប្រាអិម* នេះជាទឹកដីរបស់ពួកលោកយ៉ូសែប ដែលស្ថិតក្រោមឈ្មោះបងច្បង(សូមមើលការពន្យល់ ខ.១)។ *កាប់ឆ្ការកន្លែងសំរាប់ឯងចុះ* ឃ្លានេះប្រាប់ពីតំបន់មួយនៃទឹកដីកាណាន ដែលនៅតែមានព្រៃក្រាស់នៅឡើយ ហើយពួកអ៊ីស្រាអែលហាក់ដូចជា បង្ហាញផ្លូវដល់ពួកគេពីទឹកដីជាលើកដំបូងដែលមានដីទំនេរសម្រាប់ការដាំដុះ និងទីវាលស្មៅផងដែរ គឺមិនមែនដីដែលមាននៅក្នុងក្រុងនេះប៉ុណ្ណោះទេ តំបន់ដែលពួកកូនចៅលោកយ៉ូសែបកាន់កាប់ គឺមិនមានចំនួនប្រជាជនច្រើនដូចក្រុងដទៃទៀតទេ ។ *សាសន៍ពេរិស៊ីត និងសាសន៍រេផែម* សាសន៍ទាំងពីរនេះត្រូវបានគេស្គាល់ថាជាអ្នកជិតខាងនឹងគ្នា ទោះបីជាកន្លែងផ្សេងទៀត សាសន៍ពេរិស៊ីតនេះត្រូវបានគេនិយាយថា ពួកនេះជាពួកដែលរស់នៅខាងលិចតាមមាត់ទន្លេនៅក្នុងទឹកដីកាណាន (៣:១០ ១២:៨) និង (រីផាត) នៅក្នុងដំណើរនៃការឆ្លងទន្លេយ័រដាន់ក្នុងនគរនៃស្តេចអុក (១២:៤ ១៣:១២) និង (មើល

ទៅឯព្រៃ[ក] របស់សាសន៍ពេរិស៊ីត[ខ] និងសាសន៍រេផែម[គ]
កាប់ឆ្កាកន្លែងសំរាប់ឯងចុះ ១៦តែពួកកូនចៅយ៉ូសែប
ប្រកែកថា ស្រុកភ្នំនេះមិនគ្រាន់ឱ្យយើងខ្ញុំនៅទេមែន ប៉ុន្តែ
ពួកសាសន៍កាណានទាំងអស់ដែលនៅស្រុកវាល គេមាន
សុទ្ធតែរទេះដែក[ឃ] ទោះទាំងពួកដែលនៅក្រុងបេត-
សៀន[ង] ព្រមទាំងដំបន់នៅជុំវិញ និងពួកដែលនៅវាលច្រក
ភ្នំយេសរាលផង[ច] ១៧នោះយ៉ូស្វេក៏និយាយទៅពួកវង្ស
យ៉ូសែប គឺនឹងពួកអេប្រាអិម ហើយនិងពួកម៉ាន៉ាសេថា
ឯងជាពួកធំពិត ហើយក៏មានកំឡាំងសន្ធឹកណាស់ដែរ មិន
ត្រូវឱ្យឯងមានចំណែកតែ១ដូច្នេះទេ[ឆ] ១៨ប៉ុន្តែស្រុកភ្នំនោះ[ជ]
ជារបស់ផងឯងហើយ ទោះបើសុទ្ធតែព្រៃក៏ដោយ គង់តែ
ឯងនឹងកាប់ឆ្កាបាន ហើយឯងនឹងបានផលទាំងប៉ុន្មានពី
ព្រៃនោះផង ដ្បិតទោះបើពួកសាសន៍កាណានមានរទេះ
ដែក[ឈ] និងកំឡាំងក៏ដោយ គង់តែឯងនឹងអាចបណ្តេញគេ
ចេញបាន ។

## ការបែងចែកទឹកដីដែលនៅសល់

**១៨** ១នោះពួកជំនុំនៃកូនចៅអ៊ីស្រាអែលទាំងអស់ក៏ប្រជុំ
គ្នានៅត្រង់ស៊ីឡូរ[ក] ហើយដំឡើងត្រសាលជំនុំ[ខ]នៅទីនោះ
ស្រុកនោះទាំងមូលក៏បានក្រាបចុះចូលនឹងគេ ២តែក្នុងពួក
កូនចៅអ៊ីស្រាអែល នៅមានពូជអំបូរ៧ ដែលមិនទាន់ចែក
ចំណែកមរដកគ្នានៅឡើយ ៣ដូច្នេះយ៉ូស្វេក៏តឿនដល់ពួក
កូនចៅអ៊ីស្រាអែលថា តើឯងធ្វេសប្រហែសនឹងចូលទៅ
ចាប់យកស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោឯង
បានប្រទានមកឯងរាល់គ្នា ដល់កាលណាទៀត ៤ចូរដំរូវ
មនុស្ស៣នាក់ពីគ្រប់ទាំងពូជអំបូរមក នោះអញនឹងចាត់គេ
ឱ្យទៅដើរចុះឡើងក្នុងស្រុក ដើម្បីនឹងសរសេរកំណត់តាម[គ]
ចំណែកមរដកគេគ្រប់គ្នា[ឃ] រួចត្រឡប់មកឯអញវិញ ៥រួច

**១៧:១៥** ក ២សយ ១៨:៦ ខ យស ៣:១០ គ លប ១៤:៥ យស ១៥:៨ ១៨:១៦ ២សយ ៥:១៨ ២៣:១៣ អស ១៧:៥
**១៧:១៦** ឃ ឧ.១៨ ពច ១:១៩ ៤:៣,១៣ ង ឧ.១១ ច យស ១៥:៥៦ ១សយ ២៩:១
**១៧:១៨** ជ ១សយ ១:១ ឈ ឧ.១៦
**១៨:១** ក ឧ.៨ យស ១៩:៥១ ២១:២ ពច ១៨:៣១ ២១:១២, ១៩ ១សយ ១:៣ ៣:២១ ៤:៣ ១ពវ ១៤:២ ទដ ៧៨:៦០ យរ ៧:១២ ២៦:៦ ៤១:៥ ខ ឧ.១០ នក ២៧:២១ ៤០:២ កច ៧:៤៥
**១៨:៤** គ ឧ.៨ ឃ មីក ២:៥
**១៨:៥** ង យស ១៥:១ ច យស ១៦:១-៤
**១៨:៦** ឆ លវ ១៦:៨
**១៨:៧** ជ យស ១៣:៣៣ ឈ យស ១៣:៨
**១៨:៨** ញ ឧ.៤ ដ ឧ.១
**១៨:១០** ឋ ជន ៣៤:១៣ ឌ ឧ.១ យរ ៧:១២ ឍ ជន ៣៣:៥៤ យស ១៩:៥១

ត្រូវឱ្យគេចែកស្រុកនោះជា៧ចំណែក ឯពួកយូដា ត្រូវឱ្យគេ
នៅជាប់ក្នុងដែនស្រុករបស់គេខាងត្បូង[ង] ហើយពួកវង្ស
យ៉ូសែបត្រូវនៅជាប់ក្នុងដែនស្រុករបស់គេខាងជើង[ច]
៦នោះត្រូវឱ្យឯងរាល់គ្នាកំណត់សំគាល់ស្រុក ទាំងចែកជា៧
ចំណែក រួចយកមកឱ្យអញឯណេះ អញនឹងបោះឆ្នោត[ឆ]ឱ្យ
ឯងរាល់គ្នាចាប់ នៅទីនេះចំពោះព្រះយេហូវ៉ា ជាព្រះនៃ
យើងរាល់គ្នា ៧ឯពួកលេវីគេគ្មានចំណែកណានៅជាមួយ
នឹងឯងរាល់គ្នាទេ ដ្បិតការងារជាសង្ឃផងព្រះយេហូវ៉ា
នោះជាមរដករបស់គេហើយ[ជ] ឯពួកកាឌ់ ពួករូបេន និង
ពូជអំបូរម៉ាន៉ាសេ១ចំហៀង នោះបានទទួលមរដក ដែល
លោកម៉ូសេ ជាអ្នកបំរើរបស់ព្រះយេហូវ៉ា បានចែកឱ្យគេ
នៅត្រើយទន្លេយ័រដាន់ខាងកើតហើយ[ឈ] ។
៨ពួកអ្នកនោះក៏រៀបចំចេញទៅ ដោយទទួលបង្គាប់
យ៉ូស្វេ ដើម្បីទៅសរសេរកំណត់ស្រុក គឺលោកបង្គាប់ថា
ចូរដើរចុះឡើងក្នុងស្រុក ហើយសរសេរកំណត់សំគាល់[ញ]
រួចត្រឡប់មកឯអញវិញ នោះអញនឹងបោះឆ្នោតឱ្យឯង
រាល់គ្នាចាប់ ត្រង់ស៊ីឡូរនេះ[ដ] នៅចំពោះព្រះយេហូវ៉ា
៩ដូច្នេះ អ្នកទាំងនោះក៏ចេញទៅដើរចុះឡើងក្នុងស្រុក
ហើយបានសរសេរកំណត់ចែកជា៧ចំណែក តាមទីក្រុង
ស្រុកនោះ ព្រមទាំងកត់ចុះក្នុងសៀវភៅ រួចត្រឡប់មកឯ
យ៉ូស្វេនៅទីដំឡើងត្រសាល ត្រង់ស៊ីឡូរវិញ ១០នោះយ៉ូស្វេក៏
បោះឆ្នោត[ឋ] ឱ្យគ្រប់គ្នាចាប់ នៅត្រង់ស៊ីឡូរ ចំពោះ[ឌ]ព្រះ
យេហូវ៉ា ហើយនៅទីនោះយ៉ូស្វេក៏ចែកស្រុក ឱ្យពួកកូន
ចៅអ៊ីស្រាអែល តាមពួកគេដែរ[ឍ] ។

## ចំណែករបស់ពួកបេនយ៉ាមីន

១១គេចាប់ឆ្នោត ឱ្យពូជអំបូរពួកកូនចៅបេនយ៉ាមីន

ការពន្យល់ លប ១៣:៧ ចទ ២:១១) ។
**១៧:១៦** *ស្រុកវាល* រទេះចម្បាំងនេះមានប្រសិទ្ធភាពនៅវាលទំនាប ។ *រទេះដែក* រទេះនេះធ្វើអំពីដែកសុទ្ធសាត(សូមមើលការពន្យល់ ២សយ ៨:៧) ហើយប្រហែលជាដូចភ្លៅរទេះតែម្តង ។ ការប្រើដែកនេះ គឺជាការអភិវឌ្ឍន៍ថ្មីមួយ ។ ពួកអ៊ីស្រាអែល មិនបានប្រើរទេះនេះ រហូតមកដល់ពេលយូក្រោយទៀត (សូមមើលការពន្យល់ ១១:៦) ។
**១៨:១-១៩:៥១** វគ្គនេះអំបូរទាំងប្រាំពីរនៅតែត្រូវបានបន្តការបែងចែកទឹកដីមានដូចជា អំបូរបេនយ៉ាមីន ស៊ីម្មាន សាប់យូល៉ូន អេសើរ អ៊ីសាខារ ណែបថាលី និងអំបូរដាន់ ដែលជោគវាសនារបស់ពួកគេត្រូវចាប់ឆ្នោតនៅត្រង់ស៊ីឡូរ ។
**១៨:១** *ស៊ីឡូរ* ក្រុងនេះមានចម្ងាយប្រហែល ១៦០ គ.ម ពីភាគខាងជើងនៃក្រុងបេត-អែល ។ *ត្រសាលជំនុំ* នេះជារោងឧបោសថ(សូមមើលការពន្យល់ នក ២៧:២១) និងហឹបនៃសេចក្តីសញ្ញា ។ ក្រុងនេះនៅតែដដែលរហូតដល់សម័យលោកហោរាសាំយូអែល (១សយ ៤:៣) ។
**១៨:៣** *ចាប់យកស្រុក* ចម្បាំងនៅតែបន្តដោយការបោះជំរុំ ដែលតម្រូវឱ្យមានការស្ទាបស្ទង់ ហើយបន្ទាប់មកបែងចែកដោយត្រឹមត្រូវ និងទីបញ្ចប់កាន់កាប់ដីនោះទាំងស្រុង ។ ដូច្នេះត្រូវតែញែកឱ្យដាច់រវាងសង្គ្រាមដណ្តើមទឹកដីជាតិ (យ៉ូស្វេ) និងសង្គ្រាមកាន់កាប់នៃពូជអំបូរ (ពច ជំពូក ១-២) ។
**១៨:៥** *ខាងជើង* ពាក្យនេះសម្គាល់ពីសាច់ញាតិ និងពួកយូដា ។
**១៨:៦** *អញនឹងបោះឆ្នោតឱ្យឯងរាល់គ្នាចាប់* មើលការពន្យល់ ១៤:១ ។
**១៨:៧** *ការងារជាសង្ឃផងព្រះយេហូវ៉ា នោះជាមរដករបស់គេហើយ* សូមមើល ១៣:១៤ និងមើលបន្ថែម ចទ ១៨:១-៨ និងការពន្យល់ ៨:១ ។
**១៨:៩** *កត់ចុះក្នុងសៀវភៅ* នៅត្រង់នេះព្រះគម្ពីរភាសាហេព្រើរមិនបានបញ្ជាក់ច្បាស់លាស់ទេ ។

តាមគ្រួគេទាំងប៉ុន្មាន ហើយដែនស្រុករបស់គេនោះត្រូវជា
កណ្ដាលពួកកូនចៅយូដា និងពួកកូនចៅយ៉ូសែប ១២ឯព្រំ
ខាងជើងរបស់ស្រុកគេ នោះចាប់តាំងពីទន្លេយ័រដាន់ឡើង
ទៅខាងជើងក្រុងយេរីខូរ ដំរង់ទៅខាងលិច តាមស្រុកភ្នំ
រួចចេញមកត្រង់ទីរហោស្ថាន[ណ]បេត-អាវេន[ត] ១៣ពីទីនោះ
ក៏បត់ទៅខាងត្បូង ក្បែរក្រុងលូស[ថ] គឺជាក្រុងបេត-អែល[ទ]
រួចចុះទៅដល់អាថារ៉ូត-អាដើរ[ធ] ជិតភ្នំដែលនៅខាងត្បូង
បេត-ហូរ៉ុនក្រោម ១៤ព្រំខាងលិចនោះក៏ដំរង់ទៅមុខទៀត
រួចបត់ទៅខាងត្បូង ត្រង់ភ្នំដែលប្រទល់មុខនឹងបេត-
ហូរ៉ុន[ន]នោះ ទៅផុតត្រឹមគារយ៉ាត់-បាល គឺគារយ៉ាត់-
យារីម[ប] ដែលជាទីក្រុងរបស់ពួកកូនចៅយូដា នេះហើយ
ជាព្រំខណ្ឌខាងលិច ១៥ឯខាងត្បូងព្រំ នោះចេញពីក្រុង
គារយ៉ាត់-យារីម ដំរង់ទៅខាងលិច ដល់ក្បាលទឹក
ណែបត្វា[ផ] ១៦ក៏ចុះទៅដល់ចុងភ្នំដែលនៅទល់មុខនឹងច្រក
ភ្នំបេន-ហ៊ីនណំម ដែលនៅប៉ែកខាងជើងនៃច្រកភ្នំរបស់
សាសន៍រេផែម[ព] ហើយចុះទៅដល់ច្រកភ្នំហ៊ីនណំម[ភ]នោះ
ដែលនៅខាងត្បូងក្រុងយេប៊ូស រហូតដល់អេន-រ៉ូកែល[ម]
១៧រួចបត់ទៅខាងជើង ដល់អេន-សេមែស ក៏ចេញទៅ
ដល់កេលីឡុត[យ] ដែលនៅទល់មុខនឹងផ្លូវឡើងទៅឯអាឌូមីម[រ]
រួចចុះទៅទៀត ដល់ថ្មដារបស់បូហាន[ល] ជាកូនរូបេន ១៨ក៏
ដំរង់ទៅឯខាងជើង បណ្ដោយតាមស្រុកវាល[វ] រួចចុះទៅ
ដល់ស្រុកវាលនោះ[ស] ១៩ក៏ចេះតែទៅខាងជើងបណ្ដោយ
តាមចំហៀងបេត-ហុកឡា[ហ] ចេញមកផុតត្រឹមឈូងសមុទ្រ
អំបិលខាងជើង[ឡ] ត្រង់ចុងទន្លេយ័រដាន់ខាងត្បូង នេះជាព្រំ
ស្រុកខាងត្បូង ២០ឯទន្លេយ័រដាន់ ជាព្រំប្រទល់ខាងកើត
នេះហើយជាមរដករបស់ពួកកូនចៅបេនយ៉ាមីន តាមគ្រួ
គេទាំងប៉ុន្មាន ព្រមទាំងព្រំដែននៅជុំវិញ[អ]។
២១រីឯទីក្រុងទាំងប៉ុន្មាន របស់ពូជអំបូរពួកកូនចៅបេន
យ៉ាមីនតាមគ្រួគេ នោះគឺយេរីខូរ១ បេត-ហុកឡា[ក]១
អេមាក់-កេស៊ីស១ ២២បេត-អារ៉ាបា[ខ]១ សេម៉ារែម[គ]១
បេត-អែល[ឃ]១ ២៣អាវីម[ង]១ ប៉ារ៉ា១ អូប្រា[ច]១ ២៤កេផា-
អាំម៉ូនី១ អូបនី១ និងកេបា[ឆ]១ ទាំងអស់មាន១២ក្រុង ព្រម
ទាំងភូមិទាំងប៉ុន្មានផង ២៥ក្រុងគីបៀន[ជ]១ រ៉ាម៉ា[ឈ]១
បៀរ៉ុត[ញ]១ ២៦មីសប៉ា[ដ]១ កេភីរ៉ា[ឋ]១ ម៉ូសា១ ២៧រេគែម១
យារពាល១ តារ៉ាឡា១ ២៨សេឡា[ឌ]១ អេលេប១ យេប៊ូស
គឺជាក្រុង[ឍ]យេរូសាឡិម[ណ]១ គីបៀរ[ត]១ និងគារយ៉ាត់១
ទាំងអស់មាន១៤ក្រុង ព្រមទាំងភូមិទាំងប៉ុន្មានផង[ថ] នេះ
ហើយជាមរដករបស់ពួកកូនចៅបេនយ៉ាមីន តាមគ្រួគេ
ទាំងប៉ុន្មាន[ទ]។

## ចំណែករបស់ពូជអំបូរស៊ីម្មាន

*១៩:២-១០ – ១រប ៤:២៨-៣៣*

**១៩** ១គេចាប់ឆ្នោតទី២ឱ្យស៊ីម្មាន គឺឱ្យពូជអំបូរពួកកូនចៅ
ស៊ីម្មានតាមគ្រួគេទាំងប៉ុន្មាន ហើយមរដកគេក៏ត្រូវត្រង់
កណ្ដាលមរដករបស់ពួកកូនចៅយូដា[ក] ២ឯមរដករបស់គេ
គឺជាក្រុងបៀរ-សេបា[ខ]១ សេបា១ ម៉ូឡាដា១[គ] ៣ហាសា-
ស៊ូអាល១[ឃ] បាឡា១ អាសែម១[ង] ៤អែលថូឡាត១[ច] បេធូល១
ហោម៉ា១[ឆ] ៥ស៊ីកឡាក់១[ជ] បេត-ម៉ារកាបូត១ ហាសា-
ស៊ូសា១ ៦បេត-ល្បាអូត១ និងសារូហែន១ ទាំងអស់មាន
១៣ក្រុង ព្រមទាំងភូមិទាំងប៉ុន្មានផង ៧ក្រុងអាយីន១
រីម៉ូន១[ឈ] អេធើរ១ ហើយអាសាន១[ញ] ទាំងអស់មាន៤ក្រុង
ព្រមទាំងភូមិទាំងប៉ុន្មានផង ៨និងស្រុកទាំងអស់ដែលនៅ
ជុំវិញទីក្រុងទាំងនោះ រហូតដល់បាឡាត-បៀរ និងរ៉ាម៉ាត
ដែលនៅស្រុកត្បូង[ដ] នេះហើយជាមរដក របស់ពូជអំបូរ
ពួកកូនចៅស៊ីម្មាន តាមគ្រួគេទាំងប៉ុន្មាន ៩ឯមរដកពួកកូន
ចៅស៊ីម្មាននេះ គឺបានដកយកពីចំណែកពួកកូនចៅយូដា[ឋ]
ដ្បិតចំណែកពួកកូនចៅយូដាធំពេក គេនៅមិនអស់ទេ
ហេតុនោះបានជាពួកកូនចៅស៊ីម្មាន បានមរដករបស់គេ
នៅកណ្ដាលមរដករបស់ពួកយូដា[ឌ]។

**១៨:១២** ណ យស ៨:១៥ ត យស ៧:២ **១៨:១៣** ថ លប ២៨:១៩ ទ យស ១២:៩ ធ ជន ៣២:៣ យស ១៦:៥ **១៨:១៤** ន យស ១០:១០ ប យស ៩:១៧ **១៨:១៥** ផ យស ១៥:៩ **១៨:១៦** ព យស ១៧:១៥ ភ យស ១៥:៨ ម យស ១៥:៧ **១៨:១៧** យ យស ២២:១០ រ យស ១៥:៧ ល យស ១៥:៦ **១៨:១៨** វ យស ១៥:៦ ស យស ១១:២ **១៨:១៩** ហ យស ១៥:៦ ឡ លប ១៤:៣ **១៨:២០** អ ១សយ ៩:១ **១៨:២១** ក យស ១៥:៦ **១៨:២២** ខ យស ១៥:៦ គ ២របា ១៣:៤ ឃ យស ១៦:១ **១៨:២៣** ង ចទ ២:២៣ ច ពច ៦:១១,២៤ ៨:២៧,៣២ ៩:៥ ១សយ ១៣:១៧ **១៨:២៤** ឆ យស ២១:១៧ ១សយ ១៣:៣,១៦ ១៤:៥ ១ពវ ១៥:២២ ២ពវ ២៣:៨ អស ១០:២៩

**១៨:២៥** ជ យស ៩:៣ ឈ យស ១០:៤០ ពច ៤:៥ ១៩:១៣ អស ១០:២៩ យរ ៣១:១៥ ៤០:១ ញ យស ៩:១៧ អរ ២:២៥ នហ ៧:២៩ **១៨:២៦** ដ យស ១១:៣ ឋ យស ៩:១៧ អរ ២:២៥ នហ ៧:២៩ **១៨:២៨** ឌ ២សយ ២១:១៤ ឍ យស ១៥:៨ ណ យស ១០:១ ត យស ១៥:៥៧ ថ យស ៩:១៧ ទ អគ ៤៨:២៣ **១៩:១** ក លប ៤៩:៧ **១៩:២** ខ លប ២១:១៤ ១ពវ ១៩:៣ គ យស ១៥:២៦ **១៩:៣** ឃ យស ១៥: ២៨ ង យស ១៥:២៩ **១៩:៤** ច យស ១៥: ៣០ ឆ ជន ១៤:៤៥ **១៩:៥** ជ យស ១៥:៣១ **១៩:៧** ឈ យស ១៥: ៣២ ញ យស ១៥:៤២ **១៩:៨** ដ យស ១០:៤០ **១៩:៩** ឋ លប ៤៩:៧ ឌ អគ ៤៨:២៤

**១៨:១១** *ចាប់ឆ្នោត... ឱ្យ... កូនចៅបេនយ៉ាមីន* ព្រំប្រទល់ខាងជើងរបស់ពួកកូនចៅបេនយ៉ាមីន គឺដូចនិងព្រំដែនខាងត្បូងនៃពួកអេប្រាអិម ហើយព្រំដែនខាងត្បូងនៃពួកកូនចៅបេនយ៉ាមីន គឺដូចនិងព្រំដែនខាងជើងរបស់ពួកយូដាដែរ (មើលការពន្យល់ ១១:៦) ។ ការរៀបរាប់ពីការបែងចែកទឹកដីរបស់ពួកកូនចៅបេនយ៉ាមីន និងពួកកូនចៅដាន់ ត្រូវបានធ្វើឡើងនៅតំបន់ស៊ីឡូរ ។ ពូជអំបូរទាំងពីរនេះ និងតំបន់ដែលពួកគេបានបែងចែកបានដើរតួយ៉ាងសំខាន់ នៅក្នុងការស្ដាប់បង្គាប់ និងការមិនស្ដាប់បង្គាប់របស់ពួកអ៊ីស្រាអែល ដែលមាននៅក្នុងគម្ពីរពួកចៅហ្វាយ (មើលសេចក្ដីផ្ដើមពួកចៅហ្វាយ ដែលរៀបរាប់ពីលក្ខណអក្សរសាស្ត្រ និងមើលការពន្យល់ ពច ៣:១២-៣៦ ១៣:១-១៦:៣១) ។

**១៨:២៣** *អាវីម១* ជាពួកមនុស្សក្រុងអៃយ ។

**១៩:១** *ចាប់ឆ្នោតទី២ឱ្យស៊ីម្មាន* (១៥:២១ ១រប ៤:២៤-៤២ ពច ១:៣) ។

## ចំណែករបស់ពួកកូនចៅសាប់យូល៉ូន

១០គេចាប់ឆ្នោតទី៣ឱ្យពួកកូនចៅសាប់យូល៉ូន[ល]តាមគ្រួ
គេទាំងប៉ុន្មាន ឯព្រំដែនរបស់មរដកគេ នោះរហូតដល់
សារីឌ[ណ] ១១ព្រំគេឡើងទៅឯខាងលិច រហូតដល់ម៉ារ៉ាឡា
ហើយដល់ដាបាសែត រួចក៏ដំរង់ទៅឯស្ទឹងដែលហូរទៅ
ខាងមុខយ៉ុកនាម[ត] ១២ហើយត្រង់សារីឌ[ថ] ក៏បត់ទៅឯខាង
កើតដល់ព្រំគីស្លូត-តាបោរ រួចក៏ចេញមកត្រង់ដាប្រាត[ទ]
ឡើងទៅដល់យ៉ាភា ១៣ពីទីនោះក៏បណ្តោយទៅឯខាង
កើតតាមគីតា-ហេភើរ[ធ] និងអីតា-កាស៊ីន ហើយនិង
រីម៉ូន[ន] រហូតដល់នេយ៉ា ១៤រួចក៏បត់ទៅឯខាងជើង ដល់
ហាណាថូន ហើយចេញមក ក្នុងច្រកភ្នំយីបថា-អែល[ប]
១៥មានក្រុងកាថាត១ ណាហាឡាល១[ផ] ស៊ីមរ៉ុន១[ព] យីដាឡា
១ និងបេថ្លេហិម១[ភ] ទាំងអស់មាន១២ក្រុង ព្រមទាំងភូមិ
ទាំងប៉ុន្មានផង ១៦ទីក្រុងទាំងនេះ និងភូមិទាំងប៉ុន្មាននៅ
ជុំវិញ នោះជាមរដករបស់ផងពួកកូនចៅសាប់យូល៉ូន[ម]តាម
គ្រួគេទាំងប៉ុន្មាន[យ] ។

១៧គេចាប់ឆ្នោតទី៤ឱ្យពួកអ៊ីសាខារ[រ] គឺឱ្យពួកកូនចៅ
អ៊ីសាខារតាមគ្រួគេ ១៨ឯព្រំដែនរបស់គេ នោះទៅតាម
យេសរាល[ល] គឺសាឡូត ស៊ូណែម[វ] ១៩ហាផារែមស៊ីអូន
អាណាក្រាត ២០រ៉ាប៊ីត គីសយ៉ូន[ស]អាបែស ២១រេមែត អេន
កានីម[ហ] អេន-ហាដា និងបេតផាសេ ២២រួចក៏ដំរង់ទៅឯភ្នំ
តាបោរ[ឡ] ក្រុងសាហាស៊ីម៉ា បេត-សេមែស[អ] ហើយចេញ
ទៅផុតត្រឹមទន្លេយ័រដាន់ ទាំងអស់មាន១៦ក្រុង ព្រមទាំង
ភូមិទាំងប៉ុន្មានផង ២៣ទីក្រុងទាំងនេះ និងភូមិទាំងប៉ុន្មាន
នៅជុំវិញ ជាមរដករបស់ពូជអំបូរពួកកូនចៅអ៊ីសាខារ[ក]
តាមគ្រួគេទាំងប៉ុន្មាន[ខ] ។

## ចំណែករបស់ពួកកូនចៅអេស៊ើរ

២៤គេចាប់ឆ្នោតទី៥ ឱ្យពូជអំបូរពួកកូនចៅអេស៊ើរ[គ]
តាមគ្រួគេ ២៥ឯព្រំដែនរបស់គេ នោះគឺជាក្រុងហេលកាត-
ហាលី បេថែន អាកសាប[ឃ] ២៦អាឡាម្លេក អាម្អាត និង
មីសាល[ង] រួចក៏ដំរង់ទៅឯខាងលិច ដល់ភ្នំកើមែល[ច] រហូត
ដល់ស៊ីហោរ-លីបណាត ២៧ពីទីនោះក៏បត់ទៅឯខាងកើត
ដល់បេត-ដាកុន[ឆ] រហូតដល់ខែត្រសាប់យូល៉ូន[ជ] និងច្រកភ្នំ
យីបថា-អែល[ឈ] រួចទៅឯខាងជើងដល់បេត-អេមែក និង
ណែអ្អល ហើយបណ្តោយទៅតាមខាងឆ្វេងនៃកាបូល[ញ]
២៨ដល់អេប្រុន[ដ] រេហុប[ឋ] ហាំម៉ូន[ឌ] និងខាណា[ឍ] រហូតដល់
ក្រុងស៊ីដូនធំ[ណ] ២៩រួចក៏បត់ទៅដល់រ៉ាម៉ា[ត] និងទីរ៉ុស[ថ]ដ៏ជា
ក្រុងមាំមួន រួចក៏បត់ទៅដល់ហូសា ហើយចេញទៅផុត
ត្រឹមសមុទ្រ[ទ]តាមស្រុកអាកស៊ីប[ធ] ៣០ក៏មានក្រុងអ៊ូម៉ា អាផែក[ន]
និងរេហុបទៀត[ប] ទាំងអស់មាន២២ក្រុង ព្រមទាំងភូមិទាំង
ប៉ុន្មានផង ៣១ទីក្រុងទាំងនេះ និងភូមិនៅជុំវិញទាំងប៉ុន្មាន
ជាមរដករបស់ពូជអំបូរពួកកូនចៅអេស៊ើរ[ផ] តាមគ្រួគេ
ទាំងប៉ុន្មាន ។

## ចំណែករបស់ណែបថាលី

៣២គេចាប់ឆ្នោតទី៦ឱ្យពួកកូនចៅណែបថាលី គឺឱ្យ
ពួកកូនចៅណែបថាលីតាមគ្រួគេ ៣៣ឯព្រំដែនរបស់គេ
នោះចាប់តាំងពីហេឡិប គឺពីដើមម៉ៃសាក់ស្អាណានីម[ព]
តាមអាដាមី-នេកេប និងយ៉ាបនាល[ភ] រហូតដល់ឡាគូមទៅ
ផុតត្រឹមទន្លេយ័រដាន់ ៣៤ពីទីនោះក៏បត់ទៅឯខាងលិចដល់ភ្នំ
អាសណូត-តាបោរ និងហ៊ូកុក[ម] ហើយទៅទល់នឹងស្រុក
សាប់យូល៉ូន[យ]ខាងត្បូង និងស្រុកអេស៊ើរខាងលិច ហើយនិង
ស្រុកយូដានៅត្រង់ទន្លេយ័រដាន់ខាងកើត ៣៥ឯអស់ទាំង
ទីក្រុងមាំមួន នោះគឺស៊ីឌីម១ សេរ១ ហាំម៉ាត១[រ] រ៉ាកាត១
គីនេរ៉ែត១[ល] ៣៦អាដាម៉ា១ រ៉ាម៉ា១[វ] ហាសោរ១[ស] ៣៧កេ
ដែស១[ហ] អេទ្រី១[ឡ] អេន-ហាសោរ១ ៣៨យីរ៉ូន១ មីកដាល
អែល១ ហូរែម១ បេត-អាណាត១[អ] និងបេត-សេមែស១[ក]

**១៩:១០** ល ខ.១៦, ២៧,៣៤ យស ២១:៧,៣៤ ណ ខ.១២ **១៩:១១** ត យស ១២:២២ **១៩:១២** ថ ខ.១០ ទ យស ២១:២៨ ១រប ៦:៧២ **១៩:១៣** ធ យស ១១:២២ ន យស ១៥:៣២ **១៩:១៤** ប ខ.២៧ **១៩:១៥** ផ យស ២១:៣៥ ព យស ១១:១ ភ លប ៣៥:១៩ **១៩:១៦** ម ខ.១០ យ អគ ៤៨:២៦ **១៩:១៧** រ លប ៣០:១៨ **១៩:១៨** ល យស ១៥:៥៦ វ ១សយ ២៨:៤ ១ពវ ១:៣ ២ពវ ៤:៨ **១៩:២០** ស យស ២១:២៨ **១៩:២១** ហ យស ១៥:៣៤ **១៩:២២** ឡ ពច ៤:៦,១២ ៨:១៨ ទដ ៨៩:១២ យរ ៤៦:១៨ អ យស ១៥:១០ **១៩:២៣** ក យស ១៧:១០ ខ លប ៤៩:១៥ អគ ៤៨:២៥ **១៩:២៤** គ យស ១៧:៧ **១៩:២៥** ឃ យស ១១:១ **១៩:២៦** ង យស ២១:៣០ ច យស ១២:២២ ១ពវ ១៨:១៩ ២ពវ ២:២៥ **១៩:២៧** ឆ យស ១៥:៤១ ជ ខ.១០ ឈ ខ.១៤ ញ ១ពវ ៩:១៣ **១៩:២៨** ដ យស ២១:៣០ ១រប ៦:៧៤ ឋ ខ.៣០ ឌន ១៣:២១ យស ២១:៣១ ពច ១:៣១ ឌ ១រប ៦:៧៦ ឍ យស ១៦:៨ ណ លប ១០:១៩ **១៩:២៩** ត យស ១៨:២៥ ថ២សយ ៥:១១ ២៤:៧ អរ ៣:៧ ទដ ៤៥:១២ អស ២៣:១ យរ ២៥:២២ អគ ២៦:២ ទ ពច ៥:១៧ ធ យស ១៥:៤៤ **១៩:៣០** ន យស ១២:១៨ ប ខ.២៨ **១៩:៣១** ផ លប ៣០:១៣ យស ១៧:៧ អគ ៤៨:២ **១៩:៣៣** ព ពច ៤:១១ ភ យស ១៥:១១ **១៩:៣៤** ម ១រប ៦:៧៥ យ ខ.១០ **១៩:៣៥** រ ១រប២:៥ ល យស ១១:២ **១៩:៣៦** វ យស ១៨:២៥ ស យស ១១:១ **១៩:៣៧** ហ យស ១២:២២ ឡ ជន ២១:៣៣ **១៩:៣៨** អ ពច ១:៣៣ ក យស ១៥:១០

**១៩:១០** *ចាប់ឆ្នោតទី៣ឱ្យពួកកូនចៅសាប់យូល៉ូន* ចំពោះសាសន៍នេះបានផ្តល់ឱ្យនូវតំបន់នៅភាគខាងក្រោមពាក់កណ្តាលស្រុកកាលីឡេ រវាងសមុទ្រកាលីឡេ និងសមុទ្រមេឌីទែរ៉ាណេ ។

**១៩:១៧** *ចាប់ឆ្នោតទី៤ឱ្យពួកអ៊ីសាខារ* ពួកនេះត្រូវបានផ្តល់ឱ្យនៅតំបន់មួយនៃទិសនិរតីនៃសមុទ្រកាលីឡេ ចុះទៅក្រោមរហូតជិតដល់ក្រុងបេត-សៀន និងខាងលិចជ្រលងយេសរាល ។ ភ្នំតាបោរ បានបោះព្រំប្រទល់តំបន់នៅជាប់ខាងជើង ។

**១៩:២៤** *ចាប់ឆ្នោតទី៥ ឱ្យពូជអំបូរកូនចៅអេស៊ើរ* ពួកនេះត្រូវបានគេផ្តល់ឱ្យនៅឯតំបន់ឆ្នេរសមុទ្រ គឺចាប់ពីខាងជើងស៊ីដូន ទៅតាមភាគខាងត្បូងនៃតំបន់ភ្នំកាមែល ។

**១៩:៣២** *ចាប់ឆ្នោតទី៦ ឱ្យពួកកូនចៅណែបថាលី* តំបន់នេះភាគច្រើនគឺនៅភាគខាងជើងសមុទ្រកាលីឡេ ដែលរួមបញ្ចូលព្រំប្រទល់ភ្នំអេស៊ើរ និងសាប់យូល៉ូនភាគខាងលិច ។ តំបន់ដែលជាប់ភាគខាងត្បូងបំផុត គឺនៅផ្នែកចុងបំផុតនៃសមុទ្រកាលីឡេ ។

ទាំងអស់មាន១៩ក្រុង ព្រមទាំងភូមិទាំងប៉ុន្មានផង ៣៩ទី
ក្រុងទាំងនេះ និងភូមិនៅជុំវិញទាំងប៉ុន្មាន ជាមរដករបស់
ពូជអំបូរពួកកូនចៅណែបថាលី តាមគ្រួគេទាំងប៉ុន្មាន[ខ] ។

## ចំណែករបស់ពួកកូនចៅដាន់

៤០គេចាប់ឆ្នោតទី៧ឱ្យពូជអំបូរពួកកូនចៅដាន់ តាមគ្រួ
គេ ៤១ឯព្រំដែនមរដករបស់គេ នោះគឺជាក្រុងសូរ៉ាស អែស
ថោល[គ] អ៊ារ-សេមែស ៤២ស្អាឡាប៊ីន អាយ៉ាឡូន[ឃ] យីតឡា
៤៣អេឡូន ធីមណា[ង] អេក្រុន[ច] ៤៤អែលថេគេ គីបថោន[ឆ]
ប្អាឡាត[ជ] ៤៥យេហ៊ូឌ បេនេ-បេរ៉ាក កាថ-រីម៉ូន[ឈ]
៤៦មេយ៉ារកុន រ៉ាកុន ព្រមទាំងដែនស្រុកទល់មុខនឹង
យ៉ុបប៉េ[ញ] ៤៧ឯដែនស្រុក[ដ] របស់ពួកកូនចៅដាន់ នោះក៏
ផ្សាយចេញពីស្រុកគេទៅ ដ្បិតគេឡើងទៅច្បាំងនឹងក្រុង
លេសែម[ឋ] ហើយវាយយកបានដោយមុខដាវ រួចក៏នៅក្នុង
ស្រុកនោះ ទុកជាកេរ្តិ៍អាកររបស់គេ គេដាក់ឈ្មោះ[ឌ] ក្រុង
លេសែមនោះថា ដាន់ តាមឈ្មោះដាន់ជាព្ធយុកោគេ[ឍ]
៤៨ទីក្រុងទាំងនោះ និងភូមិនៅជុំវិញទាំងប៉ុន្មាន ជាមរដក
របស់ពូជអំបូរពួកកូនចៅដាន់[ណ] តាមគ្រួគេទាំងប៉ុន្មាន ។

## ចំណែករបស់លោកយ៉ូស្វេ

៤៩កាលគេបានចែកស្រុក ជាមរដកដល់គ្នា តាមព្រំ
ប្រទល់រួចហើយ នោះពួកកូនចៅអ៊ីស្រាអែលក៏ឱ្យមរដក
ដល់យ៉ូស្វេ ជាកូននុន នៅជាកណ្តាលស្រុកគេដែរ ៥០គេឱ្យ
ទីក្រុងធីម្ន៉ាត-សេរ៉ា[ត] នៅក្នុងភ្នំរបស់ស្រុកអេប្រាអិម ដល់
លោក តាមបង្គាប់ព្រះយេហូវ៉ា ដូចជាលោកបានសូម រួច
លោកក៏សង់ទីក្រុង ហើយតាំងទីលំនៅនៅទីនោះ ។
៥១នេះហើយជាមរដកទាំងប៉ុន្មាន ដែលអេលាសារដ៏
ជាសង្ឃនឹងយ៉ូស្វេ ជាកូននុន ហើយនិងពួកវង្សានុវង្សនៃ
ពូជអំបូរពួកកូនចៅអ៊ីស្រាអែលទាំងប៉ុន្មាន បានចែកដល់
គេ ដោយចាប់ឆ្នោត ចំពោះព្រះយេហូវ៉ា នៅមាត់ទ្វារ
ត្រសាលជំនុំ ត្រង់សីឡូរ ដូច្នេះគេក៏បានសំរេចការចែក[ថ]
ស្រុក[ទ] ហើយជាស្រេច ។

## ទីក្រុងជ្រកអាស្រ័យ

*២០:១-៩ – ជន ៣៥:៩-៣៤ ចទ ៤:៤១-៤៣ ១៩:១-១៤*

**២០** ១ព្រះយេហូវ៉ាទ្រង់បង្គាប់យ៉ូស្វេ ២ឱ្យប្រាប់ដល់ពួក
កូនចៅអ៊ីស្រាអែលថា ត្រូវឱ្យឯងរាល់គ្នាតាំងទីក្រុងពំនាក់
តាមដែលអញបានប្រាប់ឯង ដោយសារម៉ូសេចុះ ៣ដើម្បីឱ្យ
អ្នកណា ដែលសំឡាប់គេ មិនប្រកបដោយចិត្តប៉ង ហើយឥត
ដឹងខ្លួន[ក] បានរត់ទៅជ្រកអាស្រ័យនៅទីនោះ ទីក្រុងទាំង
នោះនឹងបានសំរាប់ជាទីពំនាក់ដល់ឯងរាល់គ្នា ឱ្យបានរួចពី
អ្នកដែលសងសឹកនឹងឈាម[ខ] ៤អ្នកនោះត្រូវរត់ទៅឯទីក្រុង

**១៩:៣៩** ខ អគ ៤៨:៣
**១៩:៤១** គ យស ១៥:៣៣
**១៩:៤២** ឃ យស ១០:១២
**១៩:៤៣** ង លប ៣៨:១២ ច យស ១៣:៣
**១៩:៤៤** ឆ យស ២១:២៣ ១ពវ ១៥:២៧ ១៦:១៥ ជ ១ពវ ៩:១៨ ២រប ៨:៦
**១៩:៤៥** ឈ យស ២១:២៤ ១រប ៦:៦៩
**១៩:៤៦** ញ ២រប ២:១៦ អរ ៣:៧ យហ ១:៣ កច ៩:៣៦
**១៩:៤៧** ដ ពច ១៨:១ ឋ ពច ១៨:៧,១៤ ឌ ចទ ៣:១៤ ឍ ពច ១៨:២៧,២៩
**១៩:៤៨** ណ លប ៣០:៦
**១៩:៥០** ត យស ២៤:៣០ ពច ២:៩ **១៩:៥១** ថ យស ២៣:៤ ទ យស ១៤:១ ១៨:១០ កច ១៣:១៩ **២០:៣** ក លវ ៤:២ ខ ជន ៣៥:១២

**១៩:៤០** *ចាប់ឆ្នោតទី៧ ឱ្យពូជអំបូរពួកកូនចៅដាន់* ដីនៅត្រង់នេះមានរាងស្រួចច្រឮបាច់បញ្ចូលរវាងអេប្រាអិម និងយូដា ហើយនិងបេនយ៉ាមីនខាងលិច (មើលការពន្យល់ ១៨:១១) ។ កំពង់ផែយ៉ុបប៉េជាប់ជាមួយនឹងផ្នែកពាយព្យនៃតំបន់ដាន់ ។

**១៩:៤៧,៤៨** នៅចំណុចនេះពួកកូនចៅដាន់ បានដឹងថាទឹកដីរបស់ពួកគេខ្លះគឺពិបាកក្នុងការកាន់កាប់ ដូច្នេះហើយពួកគេបានជ្រើសរើសការផ្លាស់ប្តូរទៅឯតំបន់មួយនៅខាងលើដងទន្លេយ័រដាន់ ដោយគេដឹងថាទីនេះគឺមានភាពងាយស្រួលក្នុងការកាន់កាប់ ។ នរណាក៏ដោយ ក៏អាចទុកចិត្តលើព្រះអម្ចាស់បាននៅគ្រប់ពេលវេលា ។ សេចក្តីទុកចិត្តរបស់យើង មើលទៅហាក់បីដូចជាមិនអាចទៅរួច នៅពេលដែលសេក្តីជំនឿ និងសេចក្តីក្លាហានរបស់យើងត្រូវបានទទួលការល្បងល ។ ការជឿថាព្រះអម្ចាស់នៃយើង មានភាពអស្ចារ្យគ្រប់គ្រាន់ ក្នុងការដោះស្រាយគ្រប់ស្ថានភាពលំបាករបស់យើង ។

**១៩:៤៩** *ឱ្យមរដកដល់យ៉ូស្វេ* នៅត្រង់នេះជាការរៀបរាប់ពីការបែងចែកទឹកដីសន្យា (ទឹកដីខាងលិចទន្លេយ័រដាន់) ។ កិច្ចការចំពោះលោកកាលែបគឺត្រូវបានគេបរិយាយជាលើកដំបូង (១៤:៦-១៥) ហើយកិច្ចការរបស់លោកយ៉ូស្វេគឺនៅចុងបញ្ចប់ ។ ដូច្នេះ ការបែងចែកមរដកទៅដល់អ្នកបម្រើទាំងពីនាក់របស់ព្រះអម្ចាស់ដែលមិនចេះចុះញ៉ម តាំងពីវាលរហោស្ថាននោះ ត្រូវបានគេដាក់បញ្ចូលជាមួយគ្នា ទាំងការទទួលបានទឹកដីដែលពួកគេបានសូមនោះ (សូមមើល ជន ១៣:៣០ ១៤:៦,២៤,៣០) ។ ការបែងចែករបស់លោកយ៉ូស្វេនៅពេលក្រោយយ៉ាងដូច្នេះ គឺយ៉ាងសមរម្យបំផុត ពីព្រោះគាត់មិនមែនជាស្តេច ឬជនស្រេកឃ្លានសង្គ្រាម ប៉ុន្តែគាត់ជាអ្នកបម្រើរបស់ព្រះ ដែលទ្រង់បានប្រទានអំណាចឱ្យក្នុងការនាំរាស្ត្ររបស់ទ្រង់ ទៅកាន់ទឹកដីសន្យា ។

**១៩:៥០** *ក្រុងធីម្ន៉ាត-សេរ៉ា* ក្រុងនេះមានទីតាំងនៅទិសនិរតីនៃតំបន់អេប្រាអិម ទល់នឹងសមុទ្រ ។ លោកយ៉ូស្វេ បានកប់នៅទីនេះផងដែរ (មើល ២៤:៣០) ។

**២០:១-៩** ការបែងចែកទឹកដីទៅដល់ពួកសាសន៍ទាំងប៉ុន្មានខាងលើ គឺច្បាប់នៃការគ្រប់គ្រងរបស់ព្រះអម្ចាស់ ពេលបន្ទាប់មកទៀតបានផ្តល់នូវប្រព័ន្ធគ្រប់គ្រងមូលដ្ឋានមួយ ជាពិសេសប្រព័ន្ធតុលាការតំបន់ ដើម្បីដោះស្រាយបញ្ហាការកាត់ទោសប្រហារជីវិតចំពោះការធ្វើឃាតមនុស្ស (មើលការពន្យល់ ១៣:១-៣២) ។ ដូច្នេះ នេះជាការប្តឹងឧទរ បានប្តូរពីសាលាក្តីតាមតំបន់ និងការការពារមួយដែលត្រូវបានបង្កើតឡើងដើម្បីប្រឆាំងនឹងការលះចោលសេចក្តីយុត្តិធម៌យ៉ាងប្រថុយប្រថានបំផុតនោះ ។

**២០:២** *តាំងទីក្រុងពំនាក់ តាមដែលអញបានប្រាប់ឯង* ជន ៣៥:៦-៣៤ ។

**២០:៣** *សងសឹកនឹងឈាម* ពាក្យនេះក្នុងព្រះគម្ពីរភាសាហេព្រើរ គេបកប្រែថា "អ្នកលោះដោយសាចញាតិ" (មើល នរ ២:២០ និងការពន្យល់) ឬ "អ្នកលោះ" (មើល ១សយ ៤១:១៤ និងការពន្យល់) ។ ការសងសឹកនេះគឺវាទាក់ទងទៅនឹងតម្រូវការ នៃប្រាក់ឈ្នួល (សូមមើល លវ ២៤:១៧ ជន ៣៥:១៦-២៨) ។

**២០:៤** *ទ្វារក្រុង* នេះជាទីកាត់ក្តីជាទម្លាប់ដែលពួកចាស់ទុំអង្គុយនៅតុលាការ

ណាមួយនោះ ហើយឈរនៅមាត់ទ្វារក្រុង[គ] ប្រកាសប្រាប់
ពីរឿងខ្លួនឱ្យពួកចាស់ទុំ[ឃ]ក្រុងនោះស្ដាប់ រួចគេនឹងទទួល
អ្នកនោះមកក្នុងក្រុង ព្រមទាំងឱ្យមានកន្លែងនៅជាមួយផង
៥បើអ្នកសងសឹកនឹងឈាមដេញតាមមក នោះពួកចាស់ទុំនៃ
ក្រុងនោះមិនត្រូវប្រគល់អ្នកដែលបានសំឡាប់គេ ទៅក្នុង
កណ្ដាប់ដៃរបស់អ្នកនោះឡើយ ពីព្រោះបានវាយអ្នកជិត
ខាងខ្លួនដោយឥតដឹងទេ ក៏មិនបានស្អប់គេពីដើមមកដែរ
៦រួចអ្នកនោះនឹងនៅក្នុងក្រុងពំនាក់ ដរាបដល់បានឈរ
នៅមុខពួកជំនុំ[ង]ឱ្យជំនុំជំរះខ្លួន គឺដល់សំដេចសង្ឃ ដែលមាន
នៅគ្រានោះ បានសុគតទៅ នោះទើបអ្នកដែលបានសំឡាប់
គេ និងត្រឡប់មកនៅក្នុងផ្ទះក្នុងស្រុករបស់ខ្លួន គឺជាកន្លែង
ដែលបានរត់ចោលនោះវិញបាន ។
៧ដូច្នេះគេក៏តាំងក្រុងកេដេស[ច] ក្នុងស្រុកភ្នំ របស់ខែត្រ
ណែបថាលី នៅស្រុកកាលីឡេ១ ក្រុងស៊ីគែម[ឆ] នៅស្រុកភ្នំ
ខែត្រអេប្រាអិម១ ក្រុងគារយ៉ាត់-អើបា[ជ] គឺក្រុងហេប្រុន[ឈ]
នៅស្រុកភ្នំខែត្រយូដា១[ញ] ៨ហើយខាងនាយទន្លេយ័រដាន់ គឺ
ខាងកើតក្រុងយេរីខូរ គេក៏តាំងក្រុងបេស៊ើរ[ដ] ក្នុងទីរហោ
ស្ថាន នៅស្រុកវាល ខែត្រពូជអំបូររូបេន១ និងក្រុងរ៉ាម៉ូត
នៅស្រុកកាឡាត[ឋ,ឌ] ក្នុងខែត្រពូជអំបូរកាឌ់១ ហើយនិងក្រុង
កូឡាន នៅស្រុកបាសាន[ឍ] ក្នុងខែត្រនៃពូជអំបូរម៉ានាសេ១
៩នេះហើយជាទីក្រុងទាំងអំបាលម៉ាន ដែលបានតាំងឡើង
សំរាប់ដល់ពួកកូនចៅអ៊ីស្រាអែល និងពួកអ្នកប្រទេសក្រៅ
ដែលស្នាក់នៅជាមួយនឹងគេ ដើម្បីឱ្យអ្នកណាដែលសំឡាប់
គេ មិនប្រកបដោយចិត្តប៉ង[ណ] បានរត់ទៅជ្រកអាស្រ័យនៅ
ទីនោះ ឥតស្លាប់ដោយដៃនៃអ្នកដែលសងសឹកនឹងឈាម
ទាល់តែបានឈរនៅមុខពួកជំនុំឱ្យជំនុំជំរះហើយ[ត]។

**២០:៤** គ លប ២៣:១០ យរ ៣៨:៧ ឃ យស ៧:៦ **២០:៦** ង ជន ៣៥:១២ **២០:៧** ច យស ១២:២២ ឆ លប ១២:៦ ជ លប ៣៥:២៧ ឈ យស ១០:៣៦ ញ លក ១:៣៩ **២០:៨** ដ យស ២១:៣៦ ១រប ៦:៧៨ ឋ ១រប ៦:៨០ ឌ យស ១២:២ ឍ យស ១២:៥ ១រប ៦:៧១ **២០:៩** ណ លវ ៤:២ ត នក ២១:១៣ **២១:១** ក យស ១៤:១ **២១:២** ខ យស ១៨:១ គ លវ ២៥:៣២ ឃ ជន ៣៥:២-៣ យស ១៤:៤ **២១:៤** ង ជន ៣:១៧ ច ខ.១៩ **២១:៥** ឆ ខ.២៦ **២១:៦** ជ ជន ៣:១៧ ឈ លប ៣០:១៨ ញ យស ១៧:៧ **២១:៧** ដ នក ៦:១៦ ឋ ខ.៤០ ឌ យស ១៩:១០

## ក្រុងសម្រាប់ពួកលេវី

*២១:៤-៣១ - ១រប ៦:៥៤-៨០*

**២១** ១នោះអស់ទាំងមេលើពួកវង្សានុវង្សនៃពូជអំបូរ
លេវី ក៏ចូលមកឯអេលាសារដ៏ជាសង្ឃ និងយ៉ូស្វេ ជាកូន
នុន ហើយនិងពួកមេលើពួកវង្សានុវង្សទាំងប៉ុន្មាន នៃពូជ
អំបូរកូនចៅអ៊ីស្រាអែល[ក] ២នៅត្រង់ស៊ីឡូរ[ខ] ក្នុងស្រុក
កាណានជំរាបថា ព្រះយេហូវ៉ាទ្រង់បានបង្គាប់ ដោយសារ
លោកម៉ូសេ ឱ្យចែកទីក្រុង[គ]ខ្លះដល់យើងខ្ញុំ ទុកជាទីលំនៅ
ព្រមទាំងដីនៅព័ទ្ធជុំវិញទាំងប៉ុន្មាន សំរាប់ហ្វូងសត្វយើងខ្ញុំ
ផង[ឃ] ៣ដូច្នេះពួកកូនចៅអ៊ីស្រាអែលក៏ញែកទីក្រុងទាំង
ប៉ុន្មាននេះ ព្រមទាំងដីនៅជុំវិញ ពីក្នុងមរដករបស់គេ
ឱ្យដល់ពួកលេវី តាមបង្គាប់ព្រះយេហូវ៉ា ។
៤គេចាប់ឆ្នោតឱ្យពួកគ្រួកេហាត់ដែរ[ង] រីឯពួកកូនចៅ
អើរ៉ុនដ៏ជាសង្ឃ ដែលជាពួកលេវីនោះ គេចាប់ឆ្នោតត្រូវទី
ក្រុង១៣ក្នុងពូជអំបូរយូដា ស៊ីម្មាន និងបេនយ៉ាមីន[ច] ៥ឯ
ពួកកូនចៅកេហាត់ដែលសល់ទាំងប៉ុន្មាន គេចាប់ឆ្នោត
ត្រូវទីក្រុង១០ ក្នុងពួកគ្រួនៃពូជអំបូរអេប្រាអិម ដាន់ និង
ម៉ាន៉ាសេ១ចំហៀង[ឆ] ៦ឯពួកកូនចៅគើសុន[ជ] គេចាប់ឆ្នោត
ត្រូវទីក្រុង១៣ ក្នុងពួកគ្រួនៃពូជអំបូរអ៊ីសាខារ[ឈ] អេស៊ើរ[ញ]
ណែបថាលី និងម៉ាន៉ាសេ១ចំហៀង ដែលនៅស្រុក
បាសាន ៧ឯពួកកូនចៅម្រ៉ារី[ដ]តាមគ្រួគេ នោះចាប់ឆ្នោត
ត្រូវទីក្រុង១២[ឋ]ក្នុងពូជអំបូររូបេន កាឌ់ និងសាប់យូល៉ូន[ឌ]
៨ពួកកូនចៅអ៊ីស្រាអែលបានចែកទីក្រុងទាំងនោះ ព្រមទាំង
ដីនៅជុំវិញ ឱ្យដល់ពួកលេវី ដោយចាប់ឆ្នោត ដូចជាព្រះ
យេហូវ៉ាបានបង្គាប់មក ដោយសារលោកម៉ូសេ ។
៩ក្នុងពូជអំបូរពួកកូនចៅយូដានឹងស៊ីម្មាន នោះគេបាន
ឱ្យទីក្រុងទាំងនេះ ដូចជាមានឈ្មោះនៅក្រោមនេះស្រាប់

(សូមមើល នរ ៤:១ និងការពន្យល់ ហើយនិងមើលបន្ថែមនៅក្នុង យប ២៩:៧) ។

**២០:៦** *ពួកជំនុំ* ប្រហែលជាពួកគេបានមកជួបជុំនៅទីក្រុង ទីនោះហើយដែលឧក្រិដ្ឋកម្មបានធ្វើឡើង(មើល ជន ៣៥:២៤-២៥) ។ *សំដេចសង្ឃ ដែលមាននៅគ្រានោះ បានសុគតទៅ* មើល ជន ៣៥:២៥-២៨ និងការពន្យល់ ៣៥:២៤ ។

**២០:៧** *គេក៏តាំងក្រុងកេដេស* ឃ្លានេះជាការលេងពាក្យរបស់ភាសាហេព្រើរ "ពួកគេធ្វើឱ្យក្រុងនេះមានភាពស័ក្ដសិទ្ធ" ហើយទីក្រុងពីរផ្សេងទៀតដែលនៅខាងលិចក្រុងយ័រដាន់ ពួកគេបានធ្វើយ៉ាងដូច្នេះរួចហើយ ។ ក្រុងស៊ីគែម សូមមើល ៨:៣០-៣៥ និងការពន្យល់ លប ១២:៦-៧ ក្រុងហេប្រុន សូមមើល លប ៣២:២ ៤៩:២៩-៣២ ។ ការបែងចែកទីតាំងភូមិសាស្ត្រនៃទីក្រុង គឺមានសារៈសំខាន់ គឺ១ខាងជើង និង១ទៀតនៅតំបន់កណ្ដាលក្រុង និងមួយទៀតនៅភាគខាងត្បូង ។

**២០:៩** *ពួកអ្នកប្រទេសក្រៅ* ឃ្លានេះបានប្រាប់ពីការផ្ដល់នូវការការពារស្មើគ្នារវាងពួកអ៊ីស្រាអែល និងពួកអ្នកប្រទេសក្រៅ(ធៀបនឹង លវ ១៩:៣៣-៣៤ ចទ ១០:១៨-១៩) ។

**២១:១-៤៥** នៅទីបញ្ចប់ពួកលេវី ត្រូវបានគេបែងចែកឱ្យនូវទីក្រុង និងវាលស្មៅដែលនៅជាប់ក្រុងនោះតែម្ដង ចំណែកឯគ្រួសារសម្ដេចសង្ឃត្រូវបានផ្ដល់អាទិភាពក្នុងការទទួលមរដក (សូមមើល ខ.១០) ។

**២១:៤** *គ្រួកេហាត់* ជាកូនប្រុសទាំងបីរបស់លោកលេវី គឺគើសុន កេហាត់ និង ម្រ៉ារី (សូមមើល នក ៦:១៦ ជន ៣:១៧) ។ *អំបូរយូដា ស៊ីម្មាន និងបេនយ៉ាមីន* ពួកនេះត្រូវបានទឹកដីនៅជាប់នឹងក្រុងយេរូសាឡិម ដែលក្រោយមកទីនេះក្លាយជាមានព្រះវិហារ ។ ពួកកេហាត់នេះ បានទទួលក្រុងនៅជិតនឹងពូជអំបូរទាំបីរខាងលើផងដែរ ។

១០គឺសំរាប់ពួកគ្រួកេហាត់ជាកូនអើរ៉ុន ក្នុងពួកកូនចៅលេវី
ដ្បិតគេចាប់ឆ្នោតបានលេខ១ ១១គេឱ្យក្រុងគារយ៉ាត់–
អើបា[ឍ] ដល់ពួកនោះ (ឯអើបា នោះជាឪពុកអ័ណាក់) គឺជា
ក្រុងហេប្រុន[ណ] ក្នុងស្រុកភ្នំរបស់យូដា ព្រមទាំងដីនៅជុំវិញ
ផង ១២តែស្រុកចំការ និងភូមិទាំងប៉ុន្មាននៅជុំវិញទីក្រុង
គេបានឱ្យដល់កាលែប ជាកូនយេភូនេ ទុកជាកេរ្តិ៍អាករ
វិញ[ត] ១៣ដូច្នេះគេបានឱ្យក្រុងហេប្រុននេះ និងដីនៅជុំវិញ
ដល់ពួកកូនចៅអើរ៉ុនដ៏ជាសង្ឃ ទុកជាទីក្រុងពំនាក់[ថ] សំរាប់
អ្នកណាដែលសំឡាប់គេ ព្រមទាំងក្រុងលិបណា[ទ] និងដីនៅ
ជុំវិញ ១៤យ៉ាទារ[ធ] និងដីនៅជុំវិញ អែលធេម៉ូរ[ន] និងដីនៅ
ជុំវិញ ១៥ហូឡូន[ប] និងដីនៅជុំវិញ ដេបៀរ[ផ] និងដីនៅជុំវិញ
១៦អាឃីន[ព] និងដីនៅជុំវិញ យូថា[ភ] និងដីនៅជុំវិញ បេត–
សេមែស[ម] និងដីនៅជុំវិញ គឺអស់ទីក្រុង៩ ក្នុងពូជអំបូរ
ទាំង២នេះ ១៧ក្នុងពូជអំបូរបេនយ៉ាមីន ក៏ឱ្យក្រុងគីបៀន[យ]
និងដីនៅជុំវិញ គេបា[រ] និងដីនៅជុំវិញ ១៨អាន៉ាថោត[ល]
និងដីនៅជុំវិញ អាលម៉ូន និងដីនៅជុំវិញ ទាំងអស់មាន៤
ក្រុង ១៩ទីក្រុង[វ]របស់ពួកកូនចៅអើរ៉ុនដ៏ជាសង្ឃទាំងអស់
មាន១៣ ព្រមទាំងដីនៅជុំវិញផង[ស] ។

២០ឯពួកគ្រួកូនចៅកេហាត់ ជាពួកលេវីដែលនៅសល់
នោះបានទីក្រុងជាចំណែកខ្លួន ក្នុងពូជអំបូរអេប្រាអិម
២១គេឱ្យក្រុងស៊ីគែម[ហ] និងដីនៅជុំវិញ ដល់ពួកនោះ នៅក្នុង
ស្រុកភ្នំអេប្រាអិម ទុកជាទីក្រុងពំនាក់ សំរាប់អ្នកណា
ដែលសំឡាប់គេ ព្រមទាំងក្រុងអេស៊ើរ[ឡ] និងដីនៅជុំវិញ
២២គិបសែម និងដីនៅជុំវិញ និងបេត–ហូរ៉ុន[អ] និងដីនៅ
ជុំវិញ ទាំងអស់មាន៤ក្រុង[ក] ២៣ហើយក្នុងពូជអំបូរដាន់
នោះក៏ឱ្យអែលថ្កេ និងដីនៅជុំវិញ គីបថោន និងដីនៅ
ជុំវិញ[ខ] ២៤អាយ៉ាឡូន[គ] និងដីនៅជុំវិញ កាថ–រីម៉ូន[ឃ] និងដី
នៅជុំវិញ ទាំងអស់មាន៤ក្រុង ២៥ហើយក្នុងពូជអំបូរ
ម៉ាន៉ាសេ១ចំហៀង នោះក៏ឱ្យតាណាក[ង] និងដីនៅជុំវិញ
កាថ–រីម៉ូន និងដីនៅជុំវិញ ទាំងអស់មាន២ក្រុង ២៦ទីក្រុង
របស់ពួកគ្រួកូនចៅកេហាត់ដែលសល់នៅ ទាំងអស់មាន
១០ ព្រមទាំងដីដែលនៅជុំវិញផង[ច] ។

២៧ឯពួកកូនចៅគើសុន ក្នុងពួកគ្រួលេវី នោះគេឱ្យទី
ក្រុងខ្លះ ក្នុងពូជអំបូរម៉ាន៉ាសេ១ចំហៀង គឺក្រុងកូឡាននៅ
ស្រុកបាសាន[ឆ] ជាទីក្រុងពំនាក់ សំរាប់អស់អ្នកណាដែល
សំឡាប់គេ[ជ] ព្រមទាំងដីនៅជុំវិញ ហើយបេ្អសត្រា និងដី
នៅជុំវិញ ទាំងអស់មាន២ក្រុង ២៨ហើយក្នុងពូជអំបូរ
អ៊ីសាខារ[ឈ] នោះក៏ឱ្យគីសយ៉ូន[ញ] និងដីនៅជុំវិញ ដាប្រាត[ដ]
និងដីនៅជុំវិញ ២៩យ៉ារមុត[ឋ] និងដីនៅជុំវិញ អេន–កានីម[ឌ]
និងដីនៅជុំវិញ ទាំងអស់៤ក្រុង ៣០ហើយក្នុងពូជអំបូរ
អេស៊ើរ[ឍ] នោះក៏ឱ្យមីសាល[ណ] និងដីនៅជុំវិញ អាបដូន[ត] និង
ដីនៅជុំវិញ ៣១ហេលកាត និងដីនៅជុំវិញ រេហុប[ថ] និងដី
នៅជុំវិញ ទាំងអស់មាន៤ក្រុង ៣២ហើយក្នុងពូជអំបូរ
ណែបថាលី នោះក៏ឱ្យកេដេស[ទ] ដែលនៅក្នុងស្រុកកាលីឡេ
និងដីនៅជុំវិញ គឺជាទីក្រុងពំនាក់ សំរាប់អស់អ្នកណាដែល
សំឡាប់គេ[ធ] ព្រមទាំងហាម៉ាត–ដោរ និងដីនៅជុំវិញ
ការថាន និងដីនៅជុំវិញ ទាំងអស់មាន៣ក្រុង ៣៣ទីក្រុង
របស់ពួកគើសុន[ន] តាមគ្រួគេ ទាំងអស់មាន១៣ ព្រមទាំងដី
នៅជុំវិញផង ។

៣៤ឯពួកគ្រួកូនចៅម្រ៉ារី គឺជាពួកលេវីដែលនៅសល់
គេបានឱ្យទីក្រុងខ្លះ ក្នុងពូជអំបូរសាប់យូល៉ូន[ប] គឺយ៉ុកនាម[ផ]
និងដីនៅជុំវិញ ការថា និងដីនៅជុំវិញ ៣៥ឌីមណា និង
ដីនៅជុំវិញ ណាហាឡាល[ព] និងដីនៅជុំវិញ ទាំងអស់មាន៤
ក្រុង ៣៦ហើយក្នុងពូជអំបូររូបេន នោះក៏ឱ្យបេស៊ើរ[ភ] និង
ដីនៅជុំវិញ យ៉ាហាស[ម] និងដីនៅជុំវិញ ៣៧កេ្តម៉ូត និងដី
នៅជុំវិញ មេផ្អាត[យ] និងដីនៅជុំវិញ ទាំងអស់មាន៤ក្រុង
៣៨ហើយក្នុងពូជអំបូរកាឌ់ នោះក៏ឱ្យរ៉ាម៉ូត[រ] ដែលនៅស្រុក
កាឡាត[ល] និងដីនៅជុំវិញ ទុកជាទីក្រុងពំនាក់ សំរាប់អ្នក
ណាដែលសំឡាប់គេ ព្រមទាំងម៉ាហាណែម[វ] និងដីនៅ
ជុំវិញ ៣៩ហែសបូន និងដីនៅជុំវិញ យ៉ាស៊ើ[ស] និងដីនៅជុំ
វិញ ទាំងអស់មាន៤ក្រុង ៤០ទីក្រុងទាំងប៉ុន្មាននេះ ជារបស់
ផងពួកកូនចៅម្រ៉ារី តាមគ្រួគេ គឺជាពួកគ្រួលេវីដែល

**២១:១១** ឍ លប ២៣:២ ណ យស ១០:៣៦
**២១:១២** ត យស ១៥:១៣
**២១:១៣** ថ ជន ៣៥:៦ ទ ជន ៣៣:២០
**២១:១៤** ធ យស ១៥:៤៨ ន យស ១៥:៥០
**២១:១៥** ប យស ១៥:៥១ ផ យស ១០:៣
**២១:១៦** ព ជន ៣៤:១១ ភ យស ១៥:៥៥ ម យស ១៥:១០
**២១:១៧** យ យស ៩:៣ រ យស ១៨:២៤ នហ ១១:៣១
**២១:១៨** ល ២សយ ២៣:២៧ ១ពវ ២:២៦ អរ ២:២៣ នហ ៧:២៧ ១១:៣២ អស ១០:៣០ យរ ១:១ ១១:២១ ៣២:៧
**២១:១៩** វ ២របា ៣១:១៥ ស ខ.៤
**២១:២១** ហ យស ១៧:៧ ឡ យស ១០:៣៣
**២១:២២** អ យស ១០:១០ ក ១សយ ១:១
**២១:២៣** ខ យស ១៩:៤៤
**២១:២៤** គ យស ១០:១២ ឃ យស ១៩:៤៥
**២១:២៥** ង យស ១២:២១
**២១:២៦** ច ខ.៥

**២១:២៧** ឆ យស ១២:៥ ជ ជន ៣៥:៦ **២១:២៨** ឈ លប ៣០:១៨ ញ យស ១៩:២០ ដ យស ១៩:១២ **២១:២៩** ឋ យស ១០:៣ ឌ យស ១៥:៣៤ **២១:៣០** ឍ យស ១៧:៧ ណ យស ១៩:២៦ ត យស ១៩:២៨ **២១:៣១** ថ យស ១៩:២៨ **២១:៣២** ទ យស ១២:២២ ធ ជន ៣៥:៦ **២១:៣៣** ន ខ.៦ **២១:៣៤** ប យស ១៩:១០ ផ យស ១២:២២ **២១:៣៥** ព យស ១៩:១៥ **២១:៣៦** ភ យស ២០:៨ ម ចន ២១:២៣ ចទ ២:៣២ ពច ១១:២០ **២១:៣៧** យ យស ១៣:១៨ **២១:៣៨** រ ចទ ៤:៤៣ ល យស ១២:២ វ លប ៣២:២ **២១:៣៩** ស យស ១៣:២៥

**២១:១១** *ក្រុងហេប្រុន* ក្រុងនេះជារបស់លោកកាលែប (សូមមើល ១៤:១៣–១៥) ។ ពួកសង្ឃ និងពួកលេវីត្រូវបានផ្តល់ឱ្យនូវទីកន្លែង ដែលបានចែកឱ្យរស់នៅជាមួយពួកអំបូរដទៃទៀត ។

**២១:២៥** *១ចំហៀង* ចំនួនពាក់កណ្តាលនៃពួកម៉ានាសេនៅស្រុកកាណាន ។

**២១:២៧** *កូនចៅគើសុន* ពួកនេះបានទទួលទីក្រុងនៅភាគខាងជើងពួកអេស៊ើរ ណែបថានី និងអ៊ីសាខារ ។

**២១:៣៤** *កូនចៅម្រ៉ារី* ទីក្រុងទាំង១២របស់ពួកគេ ត្រូវបានពង្រាយនៅក្នុងចំណោមពួកកូនចៅ រូបេន កាឌ់ និងសាប់យូល៉ូន ។

សល់នៅ ឯចំណែករបស់គេ នោះមានទីក្រុង១២[ហ] ។
៤១ដូច្នេះអស់ទាំងទីក្រុងរបស់ពួកលេវី ដែលនៅក្នុង
កេរ្តិ៍អាករនៃពួកកូនចៅអ៊ីស្រាអែល នោះមាន៤៨ ព្រម
ទាំងដីនៅជុំវិញផង[ឡ] ៤២ទីក្រុងទាំងនោះសុទ្ធតែមានដីនៅ
ជុំវិញគ្រប់ៗគ្នា ។
៤៣ដូច្នេះ ឯស្រុកទាំងប៉ុន្មានដែលព្រះយេហូវ៉ាបានស្បថ
ថា និងឱ្យដល់ពួកឰយុកោ[អ] នោះទ្រង់បានប្រទានដល់ពួក
អ៊ីស្រាអែលទាំងអស់ ហើយគេក៏បានចាប់យក[ក] ព្រមទាំង
តាំងទីលំនៅក្នុងស្រុកនោះផង[ខ] ៤៤រួចព្រះយេហូវ៉ាក៏ប្រោស
ឱ្យគេមានសេចក្តីស្រាកស្រាន្ត[គ]នៅព័ទ្ធជុំវិញ តាមគ្រប់ទាំង
សេចក្តី ដែលទ្រង់បានស្បថនឹងពួកឰយុកោគេគ្មានពួកខ្មាំង
សត្រូវ[ឃ]ណាមួយអាចឈរនៅមុខគេបានឡើយ ពីព្រោះ
ព្រះយេហូវ៉ាបានប្រគល់ទាំងអស់[ង] មកក្នុងកណ្តាប់ដៃគេ
ហើយ[ច] ៤៥ឯអស់ទាំងសេចក្តីល្អដែលព្រះយេហូវ៉ា បានមាន
បន្ទូលសន្យា[ឆ]ដល់ពួកវង្សអ៊ីស្រាអែល នោះបានសំរេចគ្រប់
ជំពូក ឥតមានខ្វះណាមួយឡើយ ។

## ពួជអំបូរខាងកើតវិលត្រឡប់

**២២** ១យ៉ូស្វេក៏ហៅពួករូបេន ពួកកាឌ់ និងពូជអំបូរ
ម៉ាន៉ាសេ១ចំហៀងមក មានប្រសាសន៍ថា ២ឯងរាល់គ្នា
បានកាន់តាមគ្រប់ទាំងសេចក្តីដែលលោកម៉ូសេ ជាអ្នកបំរើ
នៃព្រះយេហូវ៉ា បានបង្គាប់មកឯងហើយ[ក] ក៏បានស្តាប់តាម
គ្រប់ទាំងសេចក្តី ដែលអញបានបង្គាប់ដែរ ៣ឯងរាល់គ្នា
មិនបានចោលបងប្អូនឯង ជាយូរមកហើយ ដរាបដល់សព្វ
ថ្ងៃនេះ គឺបានប្រព្រឹត្តតាមសេចក្តីបញ្ញត្តិផងព្រះយេហូវ៉ា
ជាព្រះនៃឯងវិញ ៤ឥឡូវនេះព្រះយេហូវ៉ា ជាព្រះនៃឯង
ទ្រង់បានប្រទានឱ្យបងប្អូនឯងបានសេចក្តីស្រាកស្រាន្ត
ហើយ[ខ] ដូចជាទ្រង់បានមានបន្ទូលនឹងគេ ដូច្នេះចូរវិលទៅ
ឯត្រសាល[គ]របស់ឯងរាល់គ្នា នៅក្នុងស្រុកជាកេរ្តិ៍អាករ
របស់ឯង ដែលលោកម៉ូសេ ជាអ្នកបំរើនៃព្រះយេហូវ៉ា
បានចែកឱ្យឯង ខាងនាយទន្លេយ័រដាន់ចុះ[ឃ] ៥ប៉ុន្តែត្រូវ
ប្រយ័ត្នឱ្យអស់ពីចិត្តនឹងប្រព្រឹត្តតាមបញ្ញត្តិ[ង] ហើយនិងក្រិត្យ
វិន័យ ដែលលោកម៉ូសេ ជាអ្នកបំរើនៃព្រះយេហូវ៉ា[ច] បាន
បង្គាប់មកឯង ដើម្បីនឹងស្រឡាញ់ដល់ព្រះយេហូវ៉ា ជាព្រះ
នៃឯង ទាំងដើរតាមគ្រប់ទាំងផ្លូវរបស់ទ្រង់ ហើយកាន់តាម
បញ្ញត្តិទ្រង់ទាំងប៉ុន្មាន[ឆ] ព្រមទាំងតោងទ្រង់ជាប់ ហើយបំរើ
ទ្រង់អស់ពីចិត្ត អស់ពីព្រលឹងឯង[ជ] ៦យ៉ូស្វេក៏ឱ្យពរ[ឈ]ដល់គេ
ហើយឱ្យគេចេញទៅ រួចគេក៏ត្រឡប់ទៅឯលំនៅរបស់គេ
វិញ ។
៧រីឯពូជអំបូរម៉ាន៉ាសេ១ចំហៀងនោះ លោកម៉ូសេ
បានចែកមរដកឱ្យ នៅខាងស្រុកបាសាន[ញ] តែ១ចំហៀង
ទៀត[ដ] យ៉ូស្វេបានចែកឱ្យជាមួយនឹងបងប្អូនគេ នៅត្រើយ
ទន្លេយ័រដាន់ខាងលិចវិញ មួយទៀតកាលយ៉ូស្វេបានបើកឱ្យ
គេត្រឡប់ទៅឯលំនៅគេវិញ នោះក៏ឱ្យពរ[ឋ] ដោយពាក្យថា
៨សូមឱ្យឯងរាល់គ្នាបានវិលទៅឯលំនៅឯងចុះ ដោយនាំ
យករបស់ទ្រព្យជាច្រើន និងហ្វូងសត្វយ៉ាងសន្ធឹក[ឌ] ព្រមទាំង
ប្រាក់ មាស លង្ហិន ដែក[ឍ] និងសំលៀកបំពាក់ជាច្រើនផង
ចូរចែក[ណ]របឹប[ត]របស់ពួកខ្មាំងសត្រូវ ដល់ពួកបងប្អូនឯងចុះ
៩ដូច្នេះពួកកូនចៅរូបេន ពួកកូនចៅកាឌ់ និងពូជអំបូរ
ម៉ាន៉ាសេ១ចំហៀងនោះ ក៏ចេញចាកពីពួកកូនចៅអ៊ីស្រា
អែល ដែលនៅត្រង់ស៊ីឡូរ[ថ]ក្នុងស្រុកកាណាន វិលទៅឯ

**២១:៤០** ហ ខ.៧ **២១:៤១** ឡ ជន ៣៥:៧ **២១:៤៣** អ ចទ ៣៤: ៤ ក ចទ ១១:៣១ ខ ចទ ១៧:១៤ **២១:៤៤** គ នក ៣៣:១៤ ឃ ចទ ៦:១៩ ង នក ២៣:៣១ ច ចទ ២១:១០ **២១:៤៥** ឆ យស ២៣:១៤ នហ ៩:៨ **២២:២** ក ជន ៣២:២៥ **២២:៤** ខ នក ៣៣:១៤ គ ជន ៣២:២២ ចទ ៣:២០ ឃ ជន ៣២:១៨ យស ១:១៣–១៥ **២២:៥** ង អស ៤៣:២២ មឡ ៣:១៤ ច យស ២៣:១១ ឆ ចទ ៥:២៩ ជ ចទ ៦:៥ **២២:៦** ឈ លប ២៤:៦០ នក ៣៩:៤៣ **២២:៧** ញ ជន ៣២:១៩ យស ១២:៥ ដ យស ១៧:២ ឋ យស ១៤:១៣ លក ២៤:៥០

**២២:៨** ឌ ចទ ២០:១៤ ឍ ជន ៣១:២២ ណ ជន ៣១:២៧ ត លប ៤៩:២៧ ១សយ ៣០:១៦ ២សយ ១:១ អស ៩:៣ **២២:៩** ថ យស ១៩:១ ទ ជន ៣២:២៦

**២១:៤៣–៤៥** នៅវគ្គនេះ ជាការសង្ខេបឡើងវិញ នូវរបៀបដែលព្រះអម្ចាស់បានចាក់បំពេញ នូវសេចក្តីសន្យារបស់ទ្រង់ដែលបានផ្តល់ទឹកដីដល់ពួកអ៊ីស្រាអែល(សូមមើល លប ១៥:១៨–២១) ។ ការកាន់កាប់ទឹកដីនៅមិនទាន់បញ្ចប់នៅឡើយ (មើល ២៣:៤–៥ ពច ១–២) ប៉ុន្តែការបញ្ចុះបញ្ចូលថ្នាក់ជាតិបានធ្វើលើពួកអ៊ីស្រាអែល ហើយជាចុងក្រោយបានបង្កើតជាទឹកដីសន្យានេះឡើង ។

**២១:៤៤** *សេចក្តីស្រាកស្រាន្ត* សូមមើលការពន្យល់ ១:១៣ ។

**២១:៤៥** *បន្ទូលសន្យា* នេះសំដៅលើវត្ថុល្អដែលព្រះយេហូវ៉ា ទ្រង់បានផ្តល់ជាសេចក្តីសញ្ញាដល់រាស្ត្ររបស់ទ្រង់ (មើល ២៣:១៤–១៥ ១ពវ ៨:៥៦ យរ ៣៣:១៤) ។

**២២:១–៣៤** នៅត្រង់នេះ ពូជអំបូរកាឌ់ និងពូជអំបូរម៉ាន៉ាសេ១ចំហៀង ដែលមកពីខាងកើតទន្លេយ័រដាន់ ដែលស្មោះត្រង់ក្នុងការធ្វើសង្គ្រាមត្រូវបានលោកយ៉ូស្វេផ្តល់នូវការសរសើរ និងបញ្ជូនឱ្យវិលត្រឡប់ទៅមាតុភូមិវិញ ។

**២២:២** *គ្រប់ទាំងសេចក្តីដែលលោកម៉ូសេ . . . បង្គាប់មក* ឃ្លានេះប្រាប់ថា លោកម៉ូសេបានបញ្ជាពួកគេ ឱ្យទៅចូលរួមជាមួយនឹងពូជអំបូរផ្សេងទៀតក្នុងការដណ្តើមយកទឹកដីកាណាន (ជន ៣២:១៦–២៧ ចទ ៣:១៨) ។

**២២:៥** *ស្រឡាញ់ដល់ព្រះយេហូវ៉ា . . . បំរើទ្រង់អស់ពីចិត្ត* នេះបញ្ជាក់ថា ទាំងលោកយ៉ូស្វេ និងលោកម៉ូសេបានឃើញថា ការគោរពទៅដល់ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ នោះត្រូវធ្វើដោយក្តីស្រឡាញ់ និងបម្រើដោយអស់ពីដួងចិត្ត និងព្រលឹងរបស់ខ្លួន ។ នៅមជ្ឈឹមបូព៌ាបុរាណពាក្យថា "ស្រឡាញ់" សំដៅលើផ្នែកនយោបាយ ដែលបញ្ជាក់ថា សេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់មានដល់ស្តេចអង្គណាមួយនោះ(សូមមើល ចទ ៦:៥ ១១:១) ។

**២២:៨** *ចែករបឹប . . . ដល់ពួកបងប្អូនឯង* លោកម៉ូសេបានមើលឃើញពីតម្រូវការ និងការចែកគ្នាដ៏សមគួរមួយនៃរបស់របរដែលឈ្នះក្នុងសង្គ្រាម (ជន ៣១:២៥–២៧) ។

ស្រុកកាឡាត[ទ] គឺដល់ស្រុកដែលជាកេរ្តិ៍អាកររបស់គេវិញ
ជាស្រុកដែលបានទទួលយកតាមបង្គាប់ព្រះយេហូវ៉ា ដោយ
សារលោកម៉ូសេ ។
១០កាលគេបានទៅដល់ក្រវល់ស្រុក[ធ]ជិតទន្លេយ័រដាន់
ក្នុងស្រុកកាណាន នោះពួកកូនចៅរូបេន ពួកកូនចៅកាឌ់
នឹងពូជអំបូរម៉ាន៉ាសេ១ចំហៀងនោះ ក៏ស្អាងអាសនា១នៅ
ជិតទន្លេយ័រដាន់ ជាអាសនា[ន]មានភាពយ៉ាងធំ ១១ឯពួកកូន
ចៅអ៊ីស្រាអែលគេឮនិយាយថា ន៍ ពួកកូនចៅរូបេន ពួកកូន
ចៅកាឌ់ និងពូជអំបូរម៉ាន៉ាសេ១ចំហៀងនោះ បានស្អាង
អាសនា១ នៅចុងស្រុកកាណាន ក្នុងក្រវល់ស្រុកជិត
ទន្លេយ័រដាន់ ខាងពួកអ៊ីស្រាអែលយើងនេះហើយ ១២កាល
ពួកកូនចៅអ៊ីស្រាអែលបានឮដូច្នោះ នោះពួកជំនុំទាំងអស់
ក៏ប្រជុំគ្នានៅត្រង់ស៊ីឡូរ[ប] ដើម្បីនឹងឡើងទៅទាស់នឹងគេ ។
១៣ពួកកូនចៅអ៊ីស្រាអែលក៏ចាត់ភីនេហាស[ផ] ជាកូន
អេលាសារ[ព]ដ៏ជាសង្ឃ ទៅឯពួកកូនចៅរូបេន ពួកកូនចៅ
កាឌ់ និងពូជអំបូរម៉ាន៉ាសេ១ចំហៀងនៅស្រុកកាឡាត
១៤ព្រមទាំងមានពួកជាកំពូល១០នាក់ទៅជាមួយផង គឺម្នាក់
ៗក្នុងវង្សនៃពួកឰយុកោ១ របស់គ្រប់ទាំងពូជអំបូរនៃ
សាសន៍អ៊ីស្រាអែល អ្នកទាំងនោះសុទ្ធតែជាមេលើវង្សានុ-
វង្ស នៃពួកអ៊ីស្រាអែលទាំងពាន់ៗ[ភ] ១៥គេក៏ទៅដល់ពួកកូន
ចៅរូបេន ពួកកូនចៅកាឌ់ និងពូជអំបូរម៉ាន៉ាសេ១ចំហៀង
នៅស្រុកកាឡាតប្រាប់ថា ១៦ពួកជំនុំផងព្រះយេហូវ៉ាទាំង
អស់គ្នាសួរដូច្នេះថា តើអំពើរំលងយ៉ាងណានេះ[ម] ដែលឯង
រាល់គ្នាបានធ្វើ ទាស់នឹងព្រះនៃសាសន៍អ៊ីស្រាអែល ដើម្បី
នឹងបែរចេញពីព្រះយេហូវ៉ានៅថ្ងៃនេះ ដោយបានស្អាង
អាសនាសំរាប់ខ្លួន ប្រយោជន៍នឹងប្រព្រឹត្តទាស់ទទឹង[យ]នឹង
ព្រះយេហូវ៉ាដូច្នេះ ១៧ឯអំពើអាក្រក់ដែលយើងបានប្រព្រឹត្ត
ត្រង់ពេអរ[រ] មិនទាន់បានសំអាតខ្លួនដរាបមកដល់សព្វ

**២២:១០** ធ យស ១៨:១៧ ន ខ.១៩, ២៦-២៧ អស ១៩:១៩ ៥៦:៧
**២២:១២** ប យស ១៨:១
**២២:១៣** ផ ជន ២៥:៧ ព ជន ៣:៣២ យស ២៤:៣៣
**២២:១៤** ភ ខ.៣២ ជន ១:៤
**២២:១៦** ម ចទ ៧:៣ ១សយ ១៣:១៣ ១៥:១១ យ ចទ ១២:១៣-១៤
**២២:១៧** រ ជន ២៣:២៨ ២៥:១-៩
**២២:១៨** ល លវ ១០:៦
**២២:១៩** វ នក ២៦:១ ស ខ.១០
**២២:២០** ហ យស ៧:១ ឡ ទដ ៧:១១ អ លវ ១០:៦ ក យស ៧:៥
**២២:២២** ខ ចទ ១០:១៧ គ ទដ ៥០:១ ឃ ១សយ ២:៣ ១៦:៧ ១ពរ ៨:៣៩ ១រប ២៨:៩ ទដ ១១:៤ ៤០:៩ ៤៤:២១ ១៣៩:៤ យរ ១៧:១០
**២២:២៣** ង យរ ៤១:៥

ថ្ងៃនេះ ទោះបើមានសេចក្ដីវេទនាកើតដល់ពួកជំនុំព្រះ
យេហូវ៉ាក៏ដោយ តើការនោះយល់ថាតូចពេកឬអី ១៨បាន
ជាថ្ងៃនេះ ឯងរាល់គ្នាត្រូវការចង់បែរចេញពីព្រះយេហូវ៉ា
ទៀត ចាំមើល បើឯងរាល់គ្នាទាស់ទទឹងនឹងព្រះយេហូវ៉ា
នៅថ្ងៃនេះ នោះដល់ថ្ងៃស្អែក ទ្រង់នឹងមានសេចក្ដីក្រោធ
ទាស់នឹងពួកជំនុំ[ល] នៃសាសន៍អ៊ីស្រាអែលទាំងអស់គ្នាហើយ
១៩ឬបើសិនជាស្រុក ជាកេរ្តិ៍អាកររបស់ឯងរាល់គ្នា ស្មោក
គ្រោក នោះមានតែឆ្លងទៅក្នុងស្រុក ជាកេរ្តិ៍អាកររបស់
ព្រះយេហូវ៉ាវិញ ជាស្រុកដែលតាំងមានរោងឧបោសថ[វ]
ផងព្រះយេហូវ៉ាវិញ ហើយទទួលយកស្រុក១នៅជាមួយ
នឹងយើងផង សូមកុំឲ្យតែបះបោរនឹងព្រះយេហូវ៉ាឡើយ
ក៏កុំឲ្យបះបោរនឹងយើងដែរ ដោយឯងស្អាងអាសនា[ស]១
ក្រៅពីអាសនាផងព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា
នោះ ២០ឯអេកានជាកូនសេរ៉ាស តើមិនបានរំលងខាងឯ
របស់ដែលត្រូវបំផ្លាញទេឬអី[ហ] ហើយមានសេចក្ដីខ្ញាល់[ឡ]
ធ្លាក់មកលើពួកជំនុំ[អ] នៃសាសន៍អ៊ីស្រាអែលទាំងអស់គ្នា
ផង ហើយមនុស្សនោះមិនមែនបានវិនាសទៅ តែម្នាក់ឯង
ដោយព្រោះអំពើអាក្រក់នោះទេ[ក]។
២១ពួកកូនចៅរូបេន ពួកកូនចៅកាឌ់ និងពូជអំបូរម៉ា-
ន៉ាសេ១ចំហៀង ក៏ឆ្លើយទៅពួកមេលើសាសន៍អ៊ីស្រាអែល
ទាំងពាន់ថា ២២ព្រះយេហូវ៉ាដ៏ជាព្រះលើអស់ទាំងព្រះ[ខ] គឺ
ព្រះយេហូវ៉ា[គ] ជាព្រះលើអស់ទាំងព្រះ ទ្រង់ជ្រាបហើយ[ឃ]
ពួកអ៊ីស្រាអែលក៏នឹងដឹងដែរ បើយើងរាល់គ្នាបានស្អាង
អាសនានេះ ដោយបះបោរ ឬរំលងទាស់នឹងព្រះយេហូវ៉ា
២៣ប្រយោជន៍នឹងបែរចេញពីទ្រង់ ឬសំរាប់នឹងថ្វាយដង្វាយ
ដុតនិងដង្វាយម្សៅ[ង] ឬថ្វាយយញ្ញបូជាទុកជាដង្វាយមេត្រី
នោះសូមឲ្យព្រះយេហូវ៉ាហៅយើងខ្ញុំមកឆ្លើយពីការដែល
ប្រព្រឹត្តនៅចំពោះទ្រង់ចុះ បើយ៉ាងនោះមែននោះសូមកុំឲ្យ

**២២:១១** *អ៊ីស្រាអែលគេឮនិយាយថា* នេះជាសេចក្ដីព្រួយបារម្ភអំពីការបោះបង់អាសនា ហើយឈានទៅរកការសន្និដ្ឋានយ៉ាងឆាប់រហ័ស ។ ពួកគេគិតថា អាសនាដែលបានសាងសង់ឡើង គឺជាអាសនាដែលទាស់ទទឹងនិងអាសនាដ៏ពិត ។

**២២:១២** *ប្រជុំគ្នានៅត្រង់ស៊ីឡូរ* នេះជាវត្តមានរបស់ព្រះអម្ចាស់ នៅក្នុងរោងឧបោសថ ។ *ឡើងទៅទាស់នឹងគេ* នេះជាសកម្មភាពនៃការកាន់តាមក្រឹត្យវិន័យ (ធៀប ចទ ១៣:១២-១៨ ពច ២០) ។

**២២:១៦** *តើអំពើរំលង* នេះជាការចោទប្រកាន់ដ៏ធំមួយ ថាពួកគេបានប្រព្រឹត្តអំពើរំលង ហើយទាស់ប្រឆាំងនឹងទ្រង់ទៀត ។

**២២:១៧** *ពេអរ* នេះជាទីដែលពួកអ៊ីស្រាអែលខ្លះ បានចូលរួមក្នុងការថ្វាយបង្គំព្រះបាលរបស់សាសន៍ម៉ូអាប់ នៅត្រង់ពេអរនេះឯង ។

**២២:១៩** *ស្មោកគ្រោក* សេចក្ដីនេះសំដៅលើការថ្វាយបង្គំរបស់ពួកមិនជឿ និងអំពើពុករលួយជាទម្លាប់ ។ *កេរ្តិ៍អាកររបស់ព្រះយេហូវ៉ា* ទឹកដីសន្យាមិនបានរាប់បញ្ចូលទឹកដីដែលគេឆ្លងកាត់នោះទេ ។ កាណាន ជាទឹកដីដែលព្រះអម្ចាស់បានប្រកាសជាពិសេសថា ជារបស់ទ្រង់ ហើយសន្យាថានឹងប្រទានឲ្យដល់ពួកកូនចៅ លោកអ័ប្រាហាំ អ៊ីសាក់ និងយ៉ាកុប ។

**២២:២០** *អេកាន . . . អ៊ីស្រាអែលទាំងអស់* សូមមើលការពន្យល់ ៧:១-២៦ ។

**២២:២២** *ព្រះយេហូវ៉ាដ៏ជាព្រះលើអស់ទាំងព្រះ* គឺព្រះយេហូវ៉ាជាព្រះលើអស់ទាំងព្រះ សូមមើលការពន្យល់ ទដ ៥០:១ ។ ពាក្យនេះត្រូវបានគេនិយាយដដែលៗ ជានាមដ៏ប្រសើរក្នុងសេចក្ដីសម្បថផ្សេងៗ គឺដូចជាការបញ្ជាក់ថាបានបដិសេធយ៉ាងដាច់ខាត ចំពោះកំហុសឆ្គងផ្សេងៗ ។

ព្រះអង្គជួយសង្គ្រោះយើងខ្ញុំនៅថ្ងៃនេះឡើយ[ច] ២៤គឺយើងខ្ញុំ
បានធ្វើការនេះដោយប្រយ័ត្នវិញទេតើ ហើយតាមបំណង
ចិត្ត ដោយនឹកខ្លាចក្រែងវេលាណាទៅមុខ ពួកកូនចៅអ្នក
រាល់គ្នានិយាយចំពោះពួកកូនចៅយើងខ្ញុំថា តើឯងរាល់គ្នា
មានសេចក្ដីប្រកបអ្វីនឹងព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ២៥ដ្បិតព្រះយេហូវ៉ាទ្រង់បានដីរូវទន្លេយ័រដាន់
ទុកជាព្រំខណ្ឌនៅកណ្ដាលយើងនឹងឯងរាល់គ្នា ដែលជា
កូនចៅរូបេន និងកូនចៅកាឌ់ហើយ ដូច្នេះឯងរាល់គ្នា
គ្មានចំណែកនឹងព្រះយេហូវ៉ាទេ យ៉ាងនោះពួកកូនចៅ
របស់អ្នករាល់គ្នា និងបណ្ដាលឱ្យពួកកូនចៅយើងខ្ញុំលែង
កោតខ្លាចដល់ព្រះយេហូវ៉ា ២៦ហេតុនោះបានជាយើង
រាល់គ្នាបាននិយាយគ្នាថា ចូរយើងស្អាងអាសនា១មិនមែន
សំរាប់ថ្វាយដង្វាយ ឬយញ្ញបូជាទេ ២៧គឺទុកគ្រាន់តែជាទី
បន្ទាល់[ឆ] ដល់យើងខ្ញុំ និងអ្នករាល់គ្នា ព្រមទាំងកូនចៅយើង
ទាំងអស់គ្នាតទៅប៉ុណ្ណោះ ដើម្បីឱ្យយើងខ្ញុំបានគោរព
ប្រតិបត្តិនៅចំពោះព្រះយេហូវ៉ា ដោយដង្វាយដុតយញ្ញបូជា
និងដង្វាយមេត្រីរបស់យើងខ្ញុំ[ជ] ប្រយោជន៍ដល់ពេលទៅមុខ
កុំឱ្យកូនចៅរបស់អ្នករាល់គ្នានិយាយនឹងកូនចៅយើងខ្ញុំថា
ឯងគ្មានចំណែកនឹងព្រះយេហូវ៉ាទេនោះឡើយ ២៨ដូច្នេះ
យើងខ្ញុំបានសំរេចថា បើកាលណាគេនឹងនិយាយដូច្នោះមក
យើងខ្ញុំ ឬនឹងពូជដំណយើងខ្ញុំតទៅមុខ នោះយើងខ្ញុំនឹង
ឆ្លើយតបថា មើល នេះជាគំរូពីអាសនាផងព្រះយេហូវ៉ា
ដែលពួកឰយុកោយើងខ្ញុំបានស្អាងទុក មិនមែនសំរាប់ថ្វាយ
ដង្វាយដុត ឬយញ្ញបូជាទេ គឺទុកគ្រាន់តែជាទីបន្ទាល់[ឈ]ដល់
យើងខ្ញុំ និងអ្នករាល់គ្នាប៉ុណ្ណោះ ២៩សូមឱ្យគំនិតយ៉ាងនោះ
ឃ្លាតទៅឆ្ងាយពីយើងខ្ញុំទៅ កុំឱ្យយើងខ្ញុំបះបោរ[ញ]នឹងព្រះ
យេហូវ៉ា ហើយបែរចេញលែងតាមទ្រង់នៅថ្ងៃនេះ ដោយ
ស្អាងអាសនា សំរាប់ដង្វាយដុត ដង្វាយម្សៅ ឬយញ្ញបូជា
ក្រៅពីអាសនាផងព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំ ដែលនៅ
មុខរោងឧបោសថទ្រង់នោះឡើយ[ដ] ។

**២២:២៣** ច ចទ ១២:១១ ១៨:១៩ ១សយ ២០:១៦
**២២:២៧** ឆ លប ២១:៣០ យស ២៣:២៧ អស ១៩:២០ ជ ចទ ១២:៦
**២២:២៨** ឈ លប ២១:៣០
**២២:២៩** ញ យស ២៤:១៦ ដ នក ២៦:១
**២២:៣១** ឋ ២រប ១៥:២
**២២:៣២** ឌ ខ.១៤
**២២:៣៣** ឍ ១រប ២៩:២០ ដយ ២:១៩ លក ២:២៨
**២២:៣៤** ណ លប ២១:៣០
**២៣:១** ក ចទ ១២:៩ យស ២១:៤៤ ខ យស ១៣:១
**២៣:២** គ យ សឲ:៦ ឃ យស ២៤:១ ង យស ១៣:១

៣០កាលភីនេហាសដ៏ជាសង្ឃ ហើយនិងពួកអ្នកដែលជា
កំពូលលើពួកជំនុំ គឺជាពួកមេលើសាសន៍អ៊ីស្រាអែលទាំង
ពាន់ ដែលនៅជាមួយនឹងលោក បានឮពាក្យរបស់ពួក
កូនចៅរូបេន ពួកកូនចៅកាឌ់ និងពួកកូនចៅម៉ាន៉ាសេ
នោះក៏បានពេញចិត្តណាស់ ៣១រួចភីនេហាស ជាកូនអេលា
សារដ៏ជាសង្ឃ លោកមានប្រសាសន៍ទៅពួកកូនចៅរូបេន
ពួកកូនចៅកាឌ់ និងពួកកូនចៅម៉ាន៉ាសេថា នៅថ្ងៃនេះ
យើងដឹងថា ព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងយើងរាល់គ្នា[ឋ]
ពីព្រោះឯងរាល់គ្នាមិនបានប្រព្រឹត្តការរំលង ទាស់នឹងព្រះ
យេហូវ៉ាដូច្នេះទេ ឯងរាល់គ្នាបានជួយពួកកូនចៅអ៊ីស្រា–
អែល ឱ្យរួចពីព្រះហស្តនៃព្រះយេហូវ៉ាវិញ ៣២ដូច្នេះ
ភីនេហាស ជាកូនអេលាសារ ដ៏ជាសង្ឃ និងពួកអ្នកទាំង
ប៉ុន្មាន ដែលជាកំពូលនោះ គេចេញចាកពីពួកកូនចៅរូបេន
និងកូនចៅកាឌ់ នៅស្រុកកាឡាត ក៏វិលត្រឡប់ទៅឯស្រុក
កាណាន ដល់ពួកកូនចៅអ៊ីស្រាអែលវិញទៅ ព្រមទាំងនាំ
ដំណឹងនោះមកប្រាប់គេដែរ[ឌ] ៣៣សេចក្ដីនោះបានពេញចិត្ត
ដល់ពួកកូនចៅអ៊ីស្រាអែល ហើយគេក៏សរសើរដំកើងដល់
ព្រះ[ឍ] រួចក៏លែងគិតពីការឡើងទៅច្បាំង ដើម្បីនឹងបំផ្លាញ
ស្រុកដែលពួកកូនចៅរូបេន និងកូនចៅកាឌ់នៅនោះតទៅ
ទៀត ៣៤ឯពួកកូនចៅរូបេន និងពួកកូនចៅកាឌ់ គេដាក់
ឈ្មោះអាសនានោះថា "ទីបន្ទាល់" ដ្បិតគេថា នេះហើយ
ជាទីបន្ទាល់[ណ]ដល់អ្នករាល់គ្នា ហើយនិងយើងខ្ញុំ ពីព្រះ
យេហូវ៉ា ថាទ្រង់ជាព្រះពិត ។

## ការផ្ដាំផ្ញើរបស់លោកយ៉ូស្វេដល់ថ្នាក់ដឹកនាំអ៊ីស្រាអែល

**២៣** ១លុះពេលក្រោយជាយូរមក កាលព្រះយេហូវ៉ាទ្រង់
បានប្រទានឱ្យពួកអ៊ីស្រាអែល មានសេចក្ដីស្រាកស្រាន្ត[ក]ពី
ខ្មាំងសត្រូវទាំងអស់នៅជុំវិញ ឯយ៉ូស្វេលោកក៏ចាស់ មាន
វ័យចំរើនច្រើនណាស់ហើយ[ខ] ២នោះលោកហៅពួកអ៊ី–
ស្រាអែលទាំងអស់គ្នា ព្រមទាំងពួកចាស់ទុំ ពួកមេ[គ] និងពួក
ចៅក្រម ហើយពួកនាយក[ឃ]របស់គេមកប្រាប់ថា អញចាស់

**២២:២៧** *ទីបន្ទាល់* នេះជាអាសនា សង់ឡើងពីថ្មដែលមិនទាន់កាត់ (មើល ៨:៣១ នក ២០:២៥) ដែលវាជាទីបន្ទាល់នៃការប្ដេជ្ញាក្នុងដំណើរឆ្លងទន្លេយ័រដាន់របស់សាសន៍ផ្សេងៗ ដើម្បីរក្សាភាពខ្ពង់ខ្ពស់របស់ព្រះអម្ចាស់ និងការបន្តថ្វាយបង្គំព្រះអម្ចាស់នៅរោងឧបោសថទៀត ទោះជាពួកគេបានរស់នៅក្រៅទឹកដីសន្យាក៏ដោយ ។ ទីបន្ទាល់នេះ បានចារឹកនូវបូជនីដ្ឋាន៧ ដែលបានចែងនៅក្នុងព្រះគម្ពីរយ៉ូស្វេ ដើម្បីរំលឹកពីការនេះផងដែរ (សូមមើលការពន្យល់ ៤:៩) ។

**២២:៣១** *ឯងរាល់គ្នាបានជួយពួកកូនចៅអ៊ីស្រាអែល* ពាក្យនេះបានការពារនូវការកាត់ទោសដ៏អាក្រក់មួយ ដែលពូជអំបូរផ្សេងៗត្រូវតែទទួលរងនូវការកាត់ទោសពីព្រះអម្ចាស់ (ខ.២០) ។

**២៣:១–១៦** នៅវគ្គនេះ លោកយ៉ូស្វេ និងសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ ហើយនិងការហៅមកវិញ នូវជ័យជម្នះដែលព្រះអម្ចាស់បានផ្ដល់ឱ្យពួកគេ ប៉ុន្តែក៏រំឭកឡើងវិញផងដែរពីពួកដែលពំទាន់បានដែនដីជាកម្មសិទ្ធិ ហើយត្រូវតែស្មោះត្រង់ចំពោះសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ ។ បេសកកម្មរបស់ពួកគេគឺធ្វើជារាស្ត្រនៃអាណាចក្ររបស់ព្រះ ក្នុងពិភពលោកទាំងមូល ។

**២៣:១** *សេចក្ដីស្រាកស្រាន្ត* សូមមើលការពន្យល់ ១:១៣ ។ *មានវ័យចំរើនច្រើនណាស់ហើយ* មកដល់ត្រង់នេះលោកយ៉ូស្វេ មានវ័យ១១០ឆ្នាំហើយ (សូមមើល ២៤:២៩) ។

ហើយ ក៏មានវ័យចំរើនច្រើនណាស់ផង[ង] ៣ឯងរាល់គ្នា
បានឃើញគ្រប់ទាំងការ ដែលព្រះយេហូវ៉ា ជាព្រះនៃឯង
បានធ្វើដល់សាសន៍ទាំងប៉ុន្មាននេះ ដោយព្រោះឯងរាល់គ្នា
ហើយ ដ្បិតគឺជាព្រះយេហូវ៉ាជាព្រះនៃឯង ដែលបានច្បាំង
ជំនួសឯង[ច] ៤មើល អញបានចែក[ឆ]អស់ទាំងនគរដែលសល់
ទាំងនេះដល់ឯង ទុកជាមរដក[ជ]ដល់ពូជអំបូរឯងទាំងប៉ុន្មាន
ចាប់តាំងពីទន្លេយ័រដាន់ និងអស់ទាំងនគរដែលអញបាន
វាយបំផ្លាញចេញហើយ រហូតដល់សមុទ្រធំ[ឈ]ដែលនៅ
ទិសខាងលិច ៥ព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់នឹងច្រានគេ
ពីមុខឯងចេញ[ញ] ហើយនិងបណ្តេញ[ដ]គេពីចំពោះភ្នែកឯង
ទៅ នោះឯងរាល់គ្នានឹងចាប់យកស្រុកគេ ដូចជាព្រះ
យេហូវ៉ា ជាព្រះនៃឯងបានសន្យាហើយ[ឋ] ៦ដូច្នេះចូរសំរេច
ចិត្តនឹងកាន់ ហើយប្រព្រឹត្តតាមគ្រប់ទាំងសេចក្តីដែលបាន
កត់ទុកក្នុងគម្ពីរក្រិត្យវិន័យ[ឌ] របស់លោកម៉ូសេចុះ ដើម្បីកុំឱ្យ
ឯងបែរចេញ ពីសេចក្តីទាំងនោះ[ឍ]ទៅខាងស្តាំ ឬខាង
ឆ្វេងឡើយ[ណ] ៧ប្រយោជន៍កុំឱ្យលាយឡំនឹងសាសន៍ទាំងនេះ
ដែលសល់នៅក្នុងស្រុកឯង ហើយកុំឱ្យឯងដំណាលពីឈ្មោះ
ព្រះរបស់គេ ឬឱ្យអ្នកណាស្បថ[ត]ដោយនូវឈ្មោះព្រះទាំង
នោះ ហើយកុំឱ្យឯងរាល់គ្នាគោរពប្រតិបត្តិក្រាបថ្វាយ
បង្គំ[ថ]ដល់ព្រះគេឡើយ ៨គឺត្រូវឱ្យតោងជាប់នឹងព្រះយេ
ហូវ៉ា[ទ] ជាព្រះនៃឯងរាល់គ្នាវិញ ដូចជាបានធ្វើដរាបដល់
សព្វថ្ងៃនេះ ៩ដ្បិតព្រះយេហូវ៉ាបានបណ្តេញសាសន៍ធំ[ធ]
ហើយពូកែពីមុខឯងរាល់គ្នាចេញ ហើយគ្មានអ្នកណាបាន
អាចនឹងឈរនៅមុខឯងរាល់គ្នា ដរាបដល់សព្វថ្ងៃនេះ[ន]
១០ពួកឯងរាល់គ្នាតែ១នាក់បានដេញតាម១ពាន់នាក់[ប] ដ្បិត
គឺជាព្រះយេហូវ៉ា ជាព្រះនៃឯង ដែលច្បាំងជំនួសឯង[ផ] ដូច
ជាទ្រង់បានមានបន្ទូលនឹងឯងហើយ ១១ដូច្នេះចូរប្រយ័ត្ន[ព]
ខ្លួនឱ្យអស់ពីចិត្ត ដើម្បីនឹងស្រឡាញ់ដល់ព្រះយេហូវ៉ា[ភ] ជា
ព្រះនៃឯង ១២តែបើសិនជាឯងវិលទៅវិញ ទៅភ្ជាប់ញាតិ
ពន្ធ និងសំណល់នៃសាសន៍ទាំងនេះ ដែលនៅជាមួយនឹង
ឯងរាល់គ្នានៅឡើយ ព្រមទាំងយកគ្នាជាប្តីប្រពន្ធ[ម] ក៏ចូល
ទៅឯគេ ហើយគេមកឯងដែរ[យ] ១៣នោះត្រូវដឹងជាប្រាកដ
ថា ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងមិនបណ្តេញ[រ]
សាសន៍ទាំងនេះពីមុខឯងទៀតទេ គឺគេនឹងនៅជាអង្គប់[ល]
ហើយជាអន្ទាក់ដល់ឯងរាល់គ្នា ហើយជារំពាត់នៅចង្កេះ
និងជាបន្លានៅក្នុងភ្នែកឯងវិញ[វ] ទាល់តែឯងរាល់គ្នាវិនាស
បាត់ពីស្រុកល្អនេះ[ស]ទៅ ជាស្រុកដែលព្រះយេហូវ៉ា ជាព្រះ
នៃឯង ទ្រង់បានប្រទានមក ។
១៤មើល នៅថ្ងៃនេះអញនឹងទៅតាមផ្លូវរបស់មនុស្ស
លោកទាំងអស់[ហ] ឯនៅក្នុងចិត្ត ហើយក្នុងវិញ្ញាណរបស់ឯង
នោះក៏ដឹងទាំងអស់គ្នាថា ឯអស់ទាំងសេចក្តីល្អ ដែលព្រះ
យេហូវ៉ា ជាព្រះនៃឯងទ្រង់បានមានបន្ទូលសន្យា[ឡ]ហើយ
នោះគ្មានខ្វះណាមួយសោះ ទាំងអស់បានសំរេចគ្រប់ជំពូក
ឥតមានខ្វះណាមួយឡើយ[អ] ១៥ប៉ុន្តែដែលគ្រប់ទាំងសេចក្តីល្អ
បានសំរេចដល់ឯងរាល់គ្នា ដូចជាព្រះយេហូវ៉ា ជាព្រះនៃ
ឯង បានសន្យា[ក]យ៉ាងណា នោះទ្រង់នឹងនាំអស់ទាំងសេចក្តី
អាក្រក់[ខ] មកលើឯងរាល់គ្នា យ៉ាងនោះដែរ ទាល់តែទ្រង់
បានបំផ្លាញពួកឯង[គ]ពីស្រុកល្អនេះ ដែលព្រះយេហូវ៉ា ជា
ព្រះនៃឯង ទ្រង់បានប្រទានមកនោះចេញទៅ[ឃ] ១៦គឺបើឯង
រាល់គ្នារំលងសេចក្តីសញ្ញាផងព្រះយេហូវ៉ា ជាព្រះនៃឯង
ដែលទ្រង់បានបង្គាប់មក ហើយទៅគោរពប្រតិបត្តិក្រាប
ថ្វាយបង្គំដល់ព្រះដទៃ នោះសេចក្តីខ្ញាល់នៃព្រះយេហូវ៉ានឹង

**២៣:៣** ច នក ១៤:១៤ ចទ ២០:៤ **២៣:៤** ឆ យស ១៩:៥១ ជ ជន ៣៤:២ ទដ ៧៨:៥៥ ឈ ជន ៣៤:៦ **២៣:៥** ញ ខ.១៣ ពច ២:២១ ដ ទដ ៤៤:៥ យរ ៤៦:១៥ ឋ នក ២៣:៣០ **២៣:៦** ឌ ចទ ២៨:៦១ ឍ ចទ ១៧:២០ ណ យស ១:៧ **២៣:៧** ត នក ២៣:១៣ យរ ៥:៧ ១២:១៦ ថ នក ២០:៥ **២៣:៨** ទ ចទ ១០:២០ **២៣:៩** ធ ចទ ១១:២៣ ន ចទ ៧:២៤ **២៣:១០** ប លវ ២៦:៨ ពច ៣:៣១ ផ នក ៤:១៤ **២៣:១១** ព ចទ ៤:១៥ ភ យស ២២:៥ **២៣:១២** ម លវ ៣៤:៩ យ នក ៣៤:១៦ ទដ ១០៦:៣៤–៣៥ **២៣:១៣** រ ខ.៥ ល នក ១០:៧ វ ជន ៣៣:៥៥ ស ចទ ១:៨ ១ពវ ៩:៧ ២ពវ ២៥:២១ **២៣:១៤** ហ ១ពវ ២:២ ឡ ទដ ១១៩:១៤០ ១៤៥:១៣ អ យស ២១:៤៥ **២៣:១៥** ក ១ពវ ៨:៥៦ យរ ៣៣:១៤ ខ ១ពវ ១៤:១០ ២ពវ ២២:១៦ អស ២៤:៦ ៣៤:៥ ៤៣:២៨ យរ ៦:១៩ ១១:៨ ៣៥:១៧ ៣៩:១៦ មឡ ៤:៦ គ យស ២៤:២០ ឃ លវ ២៦:១៧ ចទ ២៨:១៥ យរ ៤០:២ **២៣:១៦** ង ចទ ៤:២៥–២៦

**២៣:៦** *ប្រព្រឹត្តតាមគ្រប់ទាំងសេចក្តី* នេះជាសម្លេងដែលបន្ទរឡើង ដោយការណែនាំរបស់ព្រះអម្ចាស់នៅក្នុងសេចក្តីចាប់ផ្តើម (១:៧–៨ សូមមើល ២២:៥) ។ *គម្ពីរក្រិត្យវិន័យ* សូមមើលការពន្យល់ ១:៨ ។

**២៣:១០** *១នាក់បានដេញតាម១ពាន់នាក់* សូមមើល ពច ១៥:១៥–១៦ ។

**២៣:១១** *ស្រឡាញ់ដល់ព្រះយេហូវ៉ាជាព្រះនៃឯង* ឃ្លានេះប្រាប់យើងឱ្យបានដឹងពីការសង្ខេបឡើងវិញ នូវអ្វីដែលបានរៀបរាប់ខាងលើ (សូមមើលការពន្យល់ ២២:៥) ។

**២៣:១២** *បើសិនជាឯងវិលទៅវិញ* ពាក្យនេះសម្គាល់ពីទឹកដីសន្យា ដែលពួកគេនៅតែមានជំនឿយ៉ាងមុតមាំទៅដល់ព្រះអម្ចាស់ និងការមិនដាច់ចេញពីព្រះ ហើយមិនវិលបែរទៅគោរពរូបព្រះ ដែលនៅជុំវិញពួកគេ ។ ប្រសិនបើពួកអ៊ីស្រាអែល មិនប្រព្រឹត្តចំពោះកិច្ចការដ៏ត្រឹមត្រូវខាងលើនេះទេ នោះពួកគេនឹងត្រូវនិរទេសចេញពីទឹកដីនោះ (ធៀបនឹង ខ.១៣,១៥–១៦ ២ពវ ១៧:៧–៨ ២របា ៧:១៤–២០) ។ *ភ្ជាប់ញាតិពន្ធ . . . យកគ្នាជាប្តីប្រពន្ធ* នៅត្រង់នេះ ព្រះអម្ចាស់បានហាមដល់ការចងសម្ព័ន្ធជាប្តីប្រពន្ធជាមួយនឹងពួកសាសន៍កាណាន ទាំងពួកក្នុងស្រុក និងក្រៅស្រុក ពីព្រោះប្រសិនបើពួកគេយកគ្នាជាប្តីប្រពន្ធ ពួកគេត្រូវតែស្រុះស្រួលគ្នា ហើយគោរពនិងស្មោះត្រង់ដល់ព្រះដូចប្រជាជនអ៊ីស្រាអែលអញ្ចឹងដែរ (សូមមើល នក ៣៤:១៥–១៦ ចទ ៧:២–៤) ។

**២៣:១៣** *ជាអង្គប់ ហើយជាអន្ទាក់* នៅក្នុងឃ្លានេះជាការបន្ទរនៃសេចក្តីព្រមានមួយរបស់លោកយ៉ូស្វេ (សូមមើល នក ២៣:៣៣ ៣៤:១២ ចទ ៧:១៦) ។

**២៣:១៤** *ទៅតាមផ្លូវរបស់មនុស្សលោក* គឺចុះទៅក្នុងផ្នូរ ។

កាត់ឡើងទាស់នឹងឯង ហើយឯងរាល់គ្នានឹងត្រូវវិនាសបាត់
ទៅជាឆាប់ពីស្រុកល្អ ដែលទ្រង់បានប្រទានមកឯង[ង]។

## ការតាំងសញ្ញាជាថ្មីនៅត្រង់ស៊ីគែម

**២៤** ១យ៉ូស្វេក៏ប្រមូល[ក]ពូជអំបូរសាសន៍អ៊ីស្រាអែល ទាំង
អស់មកនៅត្រង់ស៊ីគែម[ខ] ព្រមទាំងហៅ[គ]ពួកចាស់ទុំ[ឃ]នៃ
សាសន៍អ៊ីស្រាអែល[ង] ពួកមេ ពួកចៅក្រម និងពួកនាយកមក
ដែរ នោះគេក៏មកឈរនៅចំពោះព្រះ ២រួចយ៉ូស្វេលោក
រំឭកដល់ជនទាំងឡាយថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា ពួកព្ទយុកោឯង
រាល់គ្នា ពីដើមបាននៅខាងនាយទន្លេ គឺថេរ៉ា ជាឪពុក
អ័ប្រាហាំនិងណាឃរ[ច] គេក៏បានគោរពប្រតិបត្តិដល់ព្រះ
ដទៃដែរ[ឆ] ៣តែអញបានយកអ័ប្រាហាំ ជាពួកព្ទយុកោឯង
ពីខាងនាយទន្លេមក នាំដើរពេញក្នុងស្រុកកាណាន[ជ] អញក៏
ចំរើនពូជឱ្យ[ឈ] ព្រមទាំងឱ្យបង្កើតអ៊ីសាកផង[ញ] ៤រួចអញឱ្យ
អ៊ីសាកបង្កើតយ៉ាកុបនិងអេសាវ[ដ] ឯអេសាវនោះ អញបាន
ឱ្យចាប់យកស្រុកភ្នំសៀរ[ឋ] តែយ៉ាកុបនិងកូនចៅ នោះបាន
ចុះទៅនៅស្រុកអេស៊ីព្ទវិញ[ឌ] ៥អញក៏ចាត់ម៉ូសេ និងអើរ៉ុន[ឍ]
ឱ្យទៅឯស្រុកអេស៊ីព្ទ រួចឱ្យស្រុកនោះកើតមានសេចក្ដី
វេទនា គឺជាការទាំងប៉ុន្មាន ដែលអញបានធ្វើនៅស្រុក
នោះហើយ ក្រោយនោះអញបាននាំឯងរាល់គ្នាចេញមក[ណ]
៦អញបាននាំពួកឪពុកឯង ចេញពីស្រុកអេស៊ីព្ទ មកដល់
សមុទ្រ[ត] រួចពួកសាសន៍អេស៊ីព្ទគេដេញតាមដោយរទេះ
ចំបាំង[ថ] និងទ័ពសេះរហូតដល់សមុទ្រក្រហម[ទ] ៧កាលពួក
ឪពុកឯងបានអំពាវនាវ[ធ]ដល់ព្រះយេហូវ៉ា នោះទ្រង់ដាក់
សេចក្ដីងងឹត[ន]នៅជាកណ្ដាលឯងរាល់គ្នា ហើយនិងពួក
សាសន៍អេស៊ីព្ទ ក៏នាំទឹកសមុទ្រមកគ្របលើគេទៅ[ប] ហើយ
ភ្នែកឯងរាល់គ្នាបានឃើញការទាំងប៉ុន្មាន ដែលអញបាន
ធ្វើនៅស្រុកអេស៊ីព្ទនោះដែរ[ផ] ឯងរាល់គ្នាក៏បាននៅក្នុង
ទីរហោស្ថានអស់កាលជាយូរ[ព] ៨រួចអញបាននាំឯងរាល់គ្នា
មកក្នុងស្រុករបស់សាសន៍អាម៉ូរី[ភ] ដែលនៅខាងនាយ
ទន្លេយ័រដាន់ គេក៏ច្បាំងនឹងឯង តែអញបានប្រគល់គេមក
ក្នុងកណ្ដាប់ដៃឯងវិញ ហើយឯងរាល់គ្នាបានចាប់យក
ស្រុករបស់គេ[ម] អញបានបំផ្លាញគេពីមុខឯងអស់រលីង ៩គ្រា
នោះបាឡាក ជាកូនស៊ីបព័រ[យ] ស្ដេចស្រុកម៉ូអាប់ ក៏លើកទ័ព
មកច្បាំងនឹងសាសន៍អ៊ីស្រាអែល ក៏ចាត់គេឱ្យទៅហៅ
បាឡាមជាកូនបេអរ[រ]មក ឱ្យដាក់បណ្ដាសាដល់ឯង[ល] ១០តែ
អញមិនព្រមស្ដាប់តាមបាឡាមទេ ដូច្នេះគាត់បែរជាឱ្យពរ
ដល់ឯងរាល់គ្នាវិញ[វ] ហើយអញបានដោះឯងពីកណ្ដាប់
ដៃគេចេញ ១១រួចឯងរាល់គ្នាបានឆ្លងទន្លេយ័រដាន់[ស] មក
ដល់ក្រុងយេរីខូរ[ហ] នោះពួកមនុស្សនៅក្នុងក្រុងយេរីខូរក៏
ច្បាំងនឹងឯង មានទាំងសាសន៍អាម៉ូរី សាសន៍ពេរិស៊ីត[ឡ]
សាសន៍កាណាន សាសន៍ហេត សាសន៍គើកាស៊ី សាសន៍
ហេវី និងសាសន៍យេប៊ូស[អ]ច្បាំងនឹងឯងដែរ តែអញបាន
ប្រគល់គេទាំងអស់មកក្នុងកណ្ដាប់ដៃឯងវិញ[ក] ១២អញក៏ចាត់
ឪម៉ាល់[ខ]ឱ្យទៅមុខឯងរាល់គ្នា ហើយវាបានបណ្ដេញ[គ]គេពី
មុខឯងចេញ គឺស្ដេចសាសន៍អាម៉ូរីទាំង២អង្គ មិនមែន
ដោយដាវ ឬធ្នូរបស់ឯងទេ[ឃ] ១៣អញបានឱ្យស្រុក[ង]១ដល់
ឯងរាល់គ្នា ដែលឯងមិនបានប្រកបការអ្វីសោះ ហើយ
ទីក្រុងដែលឯងមិនបានសង់ផង សព្វថ្ងៃឯងរាល់គ្នាបាន
នៅក្នុងទីក្រុងទាំងនោះ ហើយក៏បរិភោគផ្លែទំពាំងបាយជូរ
និងផ្លែអូលីវដែលឯងរាល់គ្នាមិនបានដាំផងដែរ[ច]។
១៤ដូច្នេះ ឥឡូវនេះចូរកោតខ្លាចដល់ព្រះយេហូវ៉ា[ឆ]
ហើយគោរពប្រតិបត្តិដល់ទ្រង់ដោយចិត្តស្មោះត្រង់[ជ] ហើយ

**២៤:១** ក លប ៤៩:២ ខ លប ១២:៦ គ ១សយ ១២:៧ ១ពវ ៨:១៤ ឃ យស ៧:៦ ង យស ២៣:២ **២៤:២** ច លប ១១:២៦ ឆ លប ១១:៣២ **២៤:៣** ជ លប ១២:១ ឈ លប ១:២៨ ១២:២ ញ លប ២១:៣ **២៤:៤** ដ លប ២៥:២៦ ឋ លប ១៤:៦ ជន ២៤:១៨ ឌ លប ៤៦:៥–៦ **២៤:៥** ឍ នក ៣:១០ ណ នក ១២:៥១ **២៤:៦** ត នក ១៤:២២ ថ នក ១៤:៩ ទ នក ១៤:២៣ **២៤:៧** ធ នក ១៤:១០ ន នក ១៤:២០ ប នក ១៤:២៨ ផ នក ១៩:៤ ព ចទ ១:៤៦ **២៤:៨** ភ នក ២៣:២៣ ម ជន ២១:៣១ **២៤:៩** យ ជន ២២:២ រ ជន ២៣:៧ ល ជន ២២:៦ **២៤:១០** វ ជន ២៣:១១ ចទ ២៣:៥ **២៤:១១** ស នក ១៤:២៩ ហ យស ៦:១ ឡ យស ៣:១០អ លប ១៥:១៨–២១ ក នក ២៣:២៣ ចទ ៧:១ **២៤:១២** ខ នក ២៣:២៨ ទដ ៤៤:៣,៦–៧ គ នក ២៣:៣១ ឃ ទដ ១៣៥:១១ **២៤:១៣** ង នក ៦:៨ច ចទ ៦:១០–១១ **២៤:១៤** ឆ ១សយ ១២:១៤ យប ២៣:១៥ ទដ ១៩:៩ ១១៩:១២០ ជ ចទ ១០:១២ ១៨:១៣ ១សយ ១២:២៤ ២កថ ១:១២

**២៤:១–៣៣** នៅវគ្គនេះ មានពេលមួយនោះ លោកយ៉ូស្វេបានកោះប្រជុំដល់ពួកផ្សេងៗទាំងនៅស៊ីគែម ដើម្បីហៅពួកអ៊ីស្រាអែលឱ្យមកតាំងសញ្ញាថ្មីម្ដងទៀត(មើល ៨:៣០–៣៥) ។ នៅត្រង់នេះ វាជាការងារចុងក្រោយលោកយ៉ូស្វេ ក្នុងភាពជាអ្នកបម្រើព្រះ ក្នុងការសម្របសម្រួលច្បាប់ក្រឹត្យវិន័យរបស់ព្រះលើរាស្ត្ររបស់ទ្រង់ ។ នៅចំណុចនេះ លោកយ៉ូស្វេបានធ្វើតាមគំរូលោកម៉ូសេ ដែលការងារគាត់នៅទីបញ្ចប់ ត្រូវបានគេហៅថាជាអ្នកតាំងសញ្ញាជាថ្មី ដូចដែលមានចែងនៅក្នុងព្រះគម្ពីរចោទិយកថាទាំងមូល ។

**២៤:២** *ទ្រង់មានបន្ទូល . . . ដូច្នេះថា* ពាក្យនេះមិនគ្រាន់តែកំណត់ទៅលើអ្នកដឹលនាំដែលសម្រុះសម្រួលនោះទេ គឺគាត់ហានទូលទៅព្រះថែមទៀយ មើល ខ.២–១៣ ។ *ពីដើម* ក្នុងការអនុញ្ញាតនៃកាតាំងសញ្ញាដែលនៅមជ្ឈឹមបូព៌ាបុរាណសម្រាប់ធ្វើការប្រតិបត្តិ (សន្ធិសញ្ញា) គឺជាការនិទាននៃសាចរឿងដ៏ខ្លីមួយ គឺមានទំនាក់ទំនងទៅនឹងការតាំងសញ្ញាកាលពីបុរាណ ។ លោកយ៉ូស្វេបានឮពីចំណុចរួមគ្នានៃការបែងចែក ដូចជាលោកអ័ប្រាហាំបានចាកចេញពីក្រុមគ្រួសាររបស់គាត់ និងដូចជាប្រជាជនអ៊ីស្រាអែលដែលត្រូវដោះលែងចេញពីប្រទេសអេស៊ីព្ទ ឱ្យរស់នៅក្នុងស្រុកកាណានវិញដែរ ។

**២៤:១០** *មិនព្រមស្ដាប់តាមបាឡាមទេ* ការនេះព្រះអម្ចាស់មិនគ្រាន់តែបានបដិសេធសេចក្ដីអធិស្ឋានរបស់បាឡាមប៉ុណ្ណោះទេ តែទ្រង់បានបង្វែរពាក្យបណ្ដាសារបស់បាឡាមឱ្យទៅជាព្រះពរវិញ (មើល ២៣–២៤)។

**២៤:១៤** *ឥឡូវនេះចូរកោតខ្លាចដល់ព្រះយេហូវ៉ា* ឃ្លានេះប្រាប់ថា ឱ្យយើង

ហើយពិតប្រាកដចុះ ចូរលះចោលអស់ទាំងព្រះ[ឈ] ដែលពួក
ព្ធយុកោឯង បានគោរពប្រតិបត្តិនៅខាងនាយទន្លេ ហើយ
នៅស្រុកអេស៊ីព្ទនោះចេញ[ញ] ត្រូវឱ្យឯងរាល់គ្នាគោរព
ប្រតិបត្តិដល់ព្រះយេហូវ៉ាវិញ ១៥តែបើសិនជាឯងរាល់គ្នា
មិនគាប់ចិត្តនឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាទេ នោះ
ចូររើសយកព្រះណា ដែលឯងចង់គោរពប្រតិបត្តិតាម
នៅថ្ងៃនេះចុះ ទោះបើជាព្រះទាំងប៉ុន្មាន ដែលពួក
ព្ធយុកោឯងបានគោរពប្រតិបត្តិនៅខាងនាយទន្លេ ឬអស់
ទាំងព្រះរបស់សាសន៍អាម៉ូរីនេះ[ដ] ដែលឯងរាល់គ្នានៅក្នុង
ស្រុកគេក្តី[ឋ] តែឯអញនឹងពួកគ្រួអញ យើងទាំងអស់គ្នានឹង
គោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ[ឌ] ។
១៦ពួកបណ្តាជនក៏ឆ្លើយឡើងថា សូមឱ្យគំនិត ដែលនឹង
បោះបង់ចោល[ឍ]ព្រះយេហូវ៉ា ដើម្បីទៅគោរពប្រតិបត្តិដល់
ព្រះដទៃនោះ បាននៅឆ្ងាយពីយើងខ្ញុំទៅ ១៧ដ្បិតគឺព្រះ
យេហូវ៉ា ជាព្រះនៃយើងខ្ញុំ ទ្រង់បាននាំយើងខ្ញុំ និងឪពុក
យើងខ្ញុំ ចេញពីផ្ទះពួកបាវបំរើ[ណ] នៅស្រុកអេស៊ីព្ទមក
ហើយបានធ្វើអស់ទាំងទីសំគាល់យ៉ាងធំនោះ[ត] នៅចំពោះ
ភ្នែកយើងខ្ញុំ ក៏បានថែរក្សាយើងខ្ញុំ តាមផ្លូវដែលយើងខ្ញុំ
បានដើរនោះ ហើយនៅកណ្តាលពួកសាសន៍ទាំងប៉ុន្មាន
ដែលយើងខ្ញុំបានដើរកាត់ស្រុកគេផង ១៨ព្រះយេហូវ៉ា ទ្រង់
បានបណ្តេញ[ថ]អស់ទាំងសាសន៍[ទ] ដែលនៅក្នុងស្រុកនេះ ពី
មុខ[ធ]យើងខ្ញុំចេញ ព្រមទាំងសាសន៍អាម៉ូរីផង ដូច្នេះយើង
នឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាដែរ ដ្បិតទ្រង់ជាព្រះ
នៃយើងខ្ញុំ[ន] ។
១៩យ៉ូស្វេក៏ប្រកែកឡើងថា ឯងរាល់គ្នាពុំអាចនឹងគោរព
ប្រតិបត្តិដល់ព្រះយេហូវ៉ាបានទេ ដ្បិតទ្រង់ជាព្រះបរិសុទ្ធ[ប]
ជាព្រះប្រចណ្ឌ[ផ] ទ្រង់មិនអត់ទោស[ព]ការដែលឯងរាល់គ្នា
ប្រព្រឹត្តរំលង[ភ] ឬអំពើបាបរបស់ឯងឡើយ ២០បើសិនជាឯង
រាល់គ្នាលះចោលព្រះយេហូវ៉ា[ម] និងទៅគោរពប្រតិបត្តិ
ដល់ព្រះដទៃ នោះទ្រង់នឹងប្រែ[យ]ទៅជាធ្វើអាក្រក់[រ]ដល់ឯង
រាល់គ្នាវិញ ហើយនិងបំផ្លាញឯងទៅ[ល] ក្រោយដែលទ្រង់
បានធ្វើល្អដល់ឯងហើយផង ២១តែពួកជនគេឆ្លើយថា ទេ
យើងខ្ញុំរាល់គ្នានឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែ១
ប៉ុណ្ណោះ ២២រួចយ៉ូស្វេមានប្រសាសន៍ទៅគេថា ឯងរាល់
គ្នាជាស្មរបន្ទាល់[វ]ទាស់នឹងខ្លួនឯងថា បានរើសយក[ស]ព្រះយេ
ហូវ៉ា ដើម្បីនឹងគោរពប្រតិបត្តិដល់ទ្រង់ ហើយគេក៏ទទួលថា
យើងខ្ញុំជាទីបន្ទាល់[ហ]ពិតមែន ២៣លោកតបថា ដូច្នេះចូរ
ឯងរាល់គ្នាលះចោលអស់ទាំងព្រះដទៃ[ឡ] ដែលមាននៅក្នុង
ពួកឯងចេញទៅ ហើយផ្ទង់ចិត្តដំរង់[អ]ទៅឯព្រះយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែលវិញ ២៤នោះបណ្តាជនទាំង
ឡាយក៏ឆ្លើយទៅយ៉ូស្វេថា យើងខ្ញុំរាល់គ្នានឹងគោរពប្រតិ
បត្តិដល់ព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំពិត ហើយនិងស្តាប់
តាមព្រះបន្ទូលទ្រង់ផង[ក] ២៥ដូច្នេះលោកក៏តាំងសេចក្តី
សញ្ញា[ខ]នឹងគេនៅថ្ងៃនោះ ហើយដាក់ច្បាប់នឹងបញ្ញត្តិ[គ]ឱ្យ
គេ នៅត្រង់ស៊ីគែម[ឃ] ២៦យ៉ូស្វេក៏កត់អស់ទាំងពាក្យទាំងនេះ[ង]
ចុះក្នុងគម្ពីរក្រិត្យវិន័យរបស់ផងព្រះ[ច] រួចយកថ្មយ៉ាងធំ[ឆ]
មកបញ្ឈរនៅទីនោះ ត្រង់ក្រោមដើមម៉ៃសាក់[ជ]ដែលនៅ ។

**២៤:១៤** ឈ ខ.២៣ លប ៣១:១៩ នក ១២:១២ ១៨:១១ ២០:៣ ជន ២៥:២ ចទ ១១:២៨ ពច ១០:១៦ នរ ១:១៥ អស ៥៥:៧ ញ អក ២៣:៣
**២៤:១៥** ដ ពច ៦:១០ នរ ១:១៥ ឋ លប ៣៥:២ ឌ នរ ១:១៦ ២:១២ ១ពវ ១៨:២១ ដយ ៣:១៨
**២៤:១៦** ឍ យស២៩
**២៤:១៧** ណ ពច ៦:៨ ត នក ១០:១
**២៤:១៨** ថ នក ២៣:៣១ ទ ចទ ៣៣:២៧ ធ កច ៧:៤៥ ន លប ២៨:២១
**២៤:១៩** ប លវ ១១:៤៤ ២០:២៦ ផ នក ២០:៥ ព នក ៣៤:៧ ភ នក ២៣:២១
**២៤:២០** ម ១របា ២៨:៩,២០ ២របា ២៤:១៨ យ កច ៧:៤២ រ ១សយ ១២:២៥ ហស ១៣:១១ ល យស ២៣:១៥
**២៤:២២** វ ខ.២៧ នរ ៤:១០ អស ៨:២ ៤៣:១០ ៤៤:៨ យរ ៤២:៥ មឡ ២:១៤ ស ទដ ១១៩:៣០,១៧៣ ហ ចទ ២៥:៩ **២៤:២៣** ឡ ខ.១៤ អ ១ពវ ៨:៥៨ ទដ ១១៩:៣៦ ១៤១:៤ យរ ៣១:៣៣ **២៤:២៤** ក នក ១៩:៨ យរ ៤២:៦ **២៤:២៥** ខ នក ២៤:៨ គ នក ១៥:២៥ ឃ យស ១៧:៧ **២៤:២៦** ង ចទ ១៧:១៨ ច ចទ ២៨:៦១ ៣១:២៤ ឆ លប ២៨:១៨ ចទ ២៧:២ ជ លប ១២:៦ ពច ៤:១១

គោរព បម្រើ និងថ្វាយបង្គំព្រះ (មើលការពន្យល់ លប ២០:១១) ។ *ព្រះដែលពួកព្ធយុកោឯង* មើល ខ.២ ។ នៅត្រង់នេះ លោកយ៉ូស្វេបាន អំពាវនាវដល់ពួកអ៊ីស្រាអែល ឱ្យពួកគេលះចោលអស់ទាំងព្រះដែលពួក ព្ធយុកោបានថ្វាយបង្គំ នៅមេសូប៉ូតាមា និងនៅអេស៊ីព្ទ ។

**២៤:១៥** *តែឯអញ* លោកយ៉ូស្វេ បានធ្វើការប្តេជ្ញាជាសាធារណៈ នៅក្នុងក្តីសង្ឃឹមយ៉ាងមុតមាំថា គាត់គោរពតែព្រះដែលពួកអ៊ីស្រាអែលបានគោរពនោះដែរ ។

**២៤:១៧–១៨** នេះជាការរៀបរាប់ពីហេតុការណ៍ដ៏អស្ចារ្យ ក្នុងការធ្វើនិរទេសខ្លួន ។

**២៤:១៩** *ឯងរាល់គ្នាពុំអាច* ពាក្យនេះបញ្ជាក់ពីសេចក្តីគ្រោះថ្នាក់ដែលបង្កមកពីការទុកចិត្តខ្លួនហួសហេតុពេក ។ *ទ្រង់ជាព្រះបរិសុទ្ធ* សូមមើល លវ ១១:៤៤ និងការពន្យល់ ។ *ជាព្រះប្រចណ្ឌ* មើល នក ២០:៥ អគ ១:១៤ និងការពន្យល់ ។

**២៤:២២** *ស្មរបន្ទាល់* មើល ខ.២៧ ។ ចំណុចនេះប្រាប់ពីផ្នែកធម្មតានៃសេចក្តីសញ្ញាដែលបានតាំងឡើង (មើល ចទ ៣០:១៩) ។

**២៤:២៣** *ព្រះដទៃ* នៅត្រង់នេះ តំណាងឱ្យរូបព្រះដែលធ្វើអំពីឈើ និងលោហៈធាតុ ដែលព្រះទាំងនេះត្រូវតែបោះចោល ឬបំផ្លាញឱ្យអស់ ។

**២៤:២៥** *តាំងសេចក្តីសញ្ញា* សេចក្តីនេះត្រូវបានគេធ្វើការសន្យាថា បានយល់ស្របទៅដល់ការបង្កើតច្បាប់ និងក្រឹត្យវិន័យពីព្រះ ។

**២៤:២៦** *គម្ពីរក្រិត្យវិន័យរបស់ផងព្រះ* នេះទំនងជាបញ្ជីច្បាប់ និងក្រឹត្យវិន័យដែលលោកយ៉ូស្វេបានលើកឡើង សម្រាប់ប្រជាជនរបស់គាត់ (ខ.២៥) ។ *ថ្មយ៉ាងធំ* ថ្មនេះបង្កើតឡើង សម្រាប់ជាបន្ទាល់ពីការតាំងសញ្ញាជាថ្មីរបស់លោកយ៉ូស្វេ ។ ថ្មនេះ ក៏ជាការរឭកជាលើកទី៨ឱ្យពួកអ៊ីស្រាអែលនឹកចាំឡើងវិញ ពីទឹកដីដែលព្រះអម្ចាស់បានប្រទានឱ្យពួកគេ តាមរយៈអ្នកបម្រើរបស់ទ្រង់ (មើលការពន្យល់ ៤:៩) ។ ដូច្នេះទឹកដីសន្យាជាស្មរបន្ទាល់ទាំងមូលរបស់ពួកអ៊ីស្រាអែល គឺរបៀបដែលពួកគេបានទឹកដីជាកម្មសិទ្ធិ និងពីរបៀបដែលពួកគេនៅតែលើដីដែលចាក់បំពេញ ដោយសេចក្តីសញ្ញានោះ ។ *ដើមម៉ៃសាក់* មើលការពន្យល់ លប ១២:១៦ ។

ជិតទីបរិសុទ្ធផងព្រះយេហូវ៉ា ២៧ដោយប្រាប់គេថា មើល
ថ្មនេះ[ឈ]នឹងបានជាទីបន្ទាល់[ញ]ទាស់នឹងយើងរាល់គ្នា ដ្បិតថ្ម
នេះបានឮអស់ទាំងព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលទ្រង់
បានមានបន្ទូលមកយើងរាល់គ្នា ដូច្នេះត្រូវទុកជាទីបន្ទាល់
ទាស់នឹងឯងរាល់គ្នា ក្រែងធ្វើជាមិនស្គាល់[ដ]ព្រះនៃឯង
វិញ[ឋ]។

## លោកយ៉ូស្វេត្រូវបញ្ចុះសពនៅក្នុងទឹកដីសន្យា

*២៤:២៩–៣១ – ពច ២:៦–៩*

២៨នោះយ៉ូស្វេក៏ឱ្យបណ្តាជនទាំងអស់គ្នា ត្រឡប់ទៅឯ
ស្រុក ជាមរដករបស់គេរៀងខ្លួនទៅ[ឌ]។
២៩ក្រោយការទាំងនោះមក យ៉ូស្វេ ជាកូននុន ដែលជា
អ្នកបំរើនៃព្រះយេហូវ៉ា ក៏ស្លាប់ទៅ[ឍ] ចំនួនអាយុរបស់
លោកបាន១១០ឆ្នាំ[ណ] ៣០គេក៏បញ្ចុះសពលោក នៅចុងព្រំដី
ជាមរដករបស់លោកត្រង់ធីម្នាត–សេរ៉ា[ត] ដែលនៅក្នុង
ស្រុកភ្នំអេប្រាអិម ខាងជើងភ្នំកាអាសទៅ[ថ] ៣១ឯសាសន៍
អ៊ីស្រាអែលគេបានគោរពប្រតិបត្តិដល់ព្រះយេហូវ៉ា គ្រប់
១ជីវិតរបស់យ៉ូស្វេ និងជីវិតរបស់ពួកចាស់ទុំ[ទ] ដែលរស់
នៅក្រោយលោក ជាពួកអ្នកបានស្គាល់អស់ទាំងការ ដែល
ព្រះយេហូវ៉ាបានធ្វើសំរាប់ពួកអ៊ីស្រាអែល ។
៣២ឯឆ្អឹងសព្វរបស់យ៉ូសែប[ធ] ដែលពួកកូនចៅអ៊ីស្រាអែល
បាននាំយកពីស្រុកអេស៊ីព្ទមក[ន] គេក៏កប់នៅត្រង់ស៊ីគែម ក្នុង
ដី[ប]ដែលយ៉ាកុបបានទិញពីពួកកូនចៅហាម៉ោរ ជាឪពុក
ស៊ីគែម ថ្លៃជាប្រាក់១០០ដួង ហើយដីនោះក៏ទៅជាមរដក
របស់ពួកកូនចៅយ៉ូសែប ៣៣ឯអេលាសារជាកូនអើរ៉ុន[ផ] ក៏
សុគតទៅដែរ ហើយគេបញ្ចុះសពលោក[ព]នៅឯភ្នំរបស់
ភីនេហាស[ភ] ជាកូនលោក ជាទីដែលបានចែកឱ្យដល់លោក
នៅក្នុងស្រុក[ម]ភ្នំអេប្រាអិម ។/

**២៤:២៧** ឈ លប ២៨:១៨ ហាព ២:១១ ញ ខ.២២ លប ២១:៣០ យស ២២:២៧ ដ យស ៧:១១ ឋ ជន ១១:២០ សភ ៣០:៩
**២៤:២៨** ឌ ពច ២១:២៣,២៤
**២៤:២៩** ឍ ពច ១:១ ណ លប ៥០:២២
**២៤:៣០** ត យស ១៩:៥០ ថ ២សយ ២៣:៣០
**២៤:៣១** ទ យស ៧:៦
**២៤:៣២** ធ ហាព ១១:២២ ន លប ៤៧:២៩–៣០
ប លប ៣៣:១៩ យហ ៤:៥កច ៧:១៦ **២៤:៣៣** ផ យស ២២:១៣ ព យស ១៥:៥៧ ភ នក ៦:២៥ ម ១សយ ៩:៤

**២៤:២៩–៣៣** នៅវគ្គនេះនិយាយពីការបញ្ចុះសពរបស់មនុស្សបីនាក់ ។ ពីព្រោះតែសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅនៅសម័យបុរាណ នោះពួកគេទាំងបីនាក់នេះ ត្រូវបានគេបញ្ចុះនៅក្នុងទឹកដីដែលជាស្រុកកំណើតរបស់ខ្លួន ។ សកម្មភាពទាំងអស់នេះ មិនគ្រាន់តែបានកត់ត្រាទុកនៅក្នុងសេចក្តីសន្និដ្ឋានរឿង និងការបញ្ចប់នៃសម័យកាលប៉ុណ្ណោះទេ តែក៏បានកត់ចំណាំពីហេតុការណ៍ពិត ដែលពួកអ៊ីស្រាអែលបានបញ្ចុះសាកសពទាំងនោះនៅក្នុងមាតុភូមិកំណើតរបស់ពួកគាត់ គឺព្រះអម្ចាស់ជាអ្នកថែរក្សា នូវសេចក្តីសន្យារបស់សេចក្តីតាំងសញ្ញា ។

**២៤:២៩** *១១០ឆ្នាំ* នេះជាសេចក្តីសំខាន់ (មើលការពន្យល់ លប ៥០:២៦) ។

**២៤:៣០** *បញ្ចុះសពលោក . . . ធីម្នាត–សេរ៉ា* សូមមើល ១៩:៥០ និងការពន្យល់ ។

**២៤:៣១** រឿងនេះបានប្រាប់ពីលោកយ៉ូស្វេ គឺជាស្នរបន្ទាល់នៃភាពស្មោះត្រង់របស់ពួកអ៊ីស្រាអែល ។ អ្នកនិពន្ធ បានប្រមើលមើលពីភាពខុសគ្នាខ្លាំងនិងការវិនិច្ឆ័យក្រោយៗមកទៀត ។

**២៤:៣២** *ឆ្អឹងសពរបស់យ៉ូសែប* ការផ្លាស់ប្តូរឆ្អឹងរបស់គាត់ទៅឯស៊ីគែម គឺឥទ្ធិពលនោះ មិនមែនដោយសារតែដីរបស់លោកយ៉ាកុបបានទិញពីហា–ម៉ោរប៉ុណ្ណោះទេ តែតំបន់ស៊ីគែមនេះជាមជ្ឈមណ្ឌលរបស់ពួកសាសន៍ផ្សេងៗ ដែលមានដូចជា ពួកអេប្រាអិម និងពួកម៉ានាសេ ដែលជាកូនប្រុសទាំងពីររបស់លោកយ៉ូសែប ។ ការធ្វើយ៉ាងដូច្នេះ ក៏ជាការបំពេញនូវពាក្យសម្បថដល់លោកយ៉ូសែបមុនពេលគាតស្លាប់ (លប ៥០:២៥ នក ១៣:១៩) ។

**២៤:៣៣** *អេលាសារ* គាត់ជាសម្តេចសង្ឃដែលបម្រើលោកយ៉ូស្វេ ដូចដែលលោកអើរ៉ុនបានបម្រើលោកម៉ូសេអញ្ចឹងដែរ ។

# ពួកចៅហ្វាយ

## សេចក្ដីផ្ដើម

### ចំណងជើង

ការដាក់ចំណងជើងព្រះគម្ពីរថា "ចៅហ្វាយ" គឺមានទំនាក់ទំនងជាមួយអ្នកដឹកនាំជនជាតិអ៊ីស្រាអែល ចាប់តាំងពីគ្រាលោកយ៉ូស្វេ រហូតដល់គ្រាដែលប្រទេសអ៊ីស្រាអែលបានស្ថិតនៅក្នុងគ្រារាជាធិបតេយ្យ ។ គោលការណ៍ចម្បងរបស់គេ គឺបានពិពណ៌នាដ៏ល្អឥតខ្ចោះនៅក្នុង ២:១៦ ដែលបាននិយាយថា" ព្រះយេហូវ៉ាទ្រង់តាំងឱ្យមានពួកចៅហ្វាយ ដែលបានជួយសង្គ្រោះគេ ឱ្យរួចពីកណ្ដាប់ដៃនៃពួកអ្នកដែលបំផ្លាញគេ" ។ នៅក្នុងអំឡុងពេលដែលព្រះយេហូវ៉ាទ្រង់បានអនុញ្ញាតឱ្យមានការគៀបសង្កត់ និងរំដោះគេឱ្យរួចពីពួកខ្មាំងសត្រូវនោះព្រះអម្ចាស់ទ្រង់ផ្ទាល់ជាចៅហ្វាយ និងជាអ្នករំដោះចុងក្រោយរបស់ពួកអ៊ីស្រាអែល (មើល ១១:២៧) ។ នៅក្នុង ៨:២៣ លោកគេឌានបាននិយាយថា "ឯអញនិងកូនចៅអញ មិនត្រូវគ្រងរាជ្យលើឯងរាល់គ្នាទេ គឺព្រះយេហូវ៉ាទេតើ ដែលសោយរាជ្យលើឯងរាល់គ្នាវិញ" ។

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

ទោះបីជាមានការអះអាងថា លោកសាំយ៉ូអែលតាមលក្ខណៈទំលៀមទម្លាប់ជាអ្នកនិពន្ធក៏ដោយ ក៏យើងមិនបានដឹងច្បាស់ថា អ្នកនិពន្ធពិតប្រាកដជានរណាឡើយ ។ វាអាចជាការពិតដែរ ព្រោះថានៅក្នុងព្រះគម្ពីរសាំយ៉ូអែលមានឈ្មោះមនុស្សមួយចំនួនដែលបាននិយាយនៅក្នុងព្រះគម្ពីរចៅហ្វាយ ដូចជាហោរាណាថាន់ និងកាឌ់ ព្រោះអ្នកទាំង២នោះមានទំនាក់ទំនងជាមួយវង្សស្ដេចដាវីឌ ហើយសុទ្ធតែបានកត់ចុះនៅក្នុងសៀវភៅមើលឆុត (សូមមើលក្នុង ១រប ២៩:២៩) ។

កាលបរិច្ឆេទនៃការសរសេរព្រះគម្ពីរចៅហ្វាយ យើងក៏មិនបានដឹងច្បាស់ដែរ គ្រាន់តែដឹងថា កាលបរិច្ឆេទនៃការសរសេរគឺនៅក្នុងអំឡុងពេលរាជាធិបតេយ្យ ។ ព្រោះថាជានិច្ចកាលតែងតែនិយាយថា "នៅគ្រានោះ គ្មានស្ដេចណាសោយរាជ្យក្នុងស្រុកអ៊ីស្រាអែលទេ" (សូមមើល ១៧:៦ ១៨:១ ១៩:១ ២១:២៥) ។ តាមន័យនេះគឺនិយាយថា ព្រះគម្ពីរចៅហ្វាយសរសេរឡើង បន្ទាប់ពីមានការរៀបចំឱ្យមានស្ដេចឡើងវិញ ។ តាមការធ្វើការសង្កេតពិនិត្យបានបញ្ជាក់ថា ពួកសាសន៍យេប៊ូសនៅបន្តគ្រប់គ្រងលើក្រុងយេរូសាឡិម (មើល ១:២១) មុនពេលគ្រាស្ដេចដាវីឌវាយដណ្ដើមយកក្រុងយេរូសាឡិមមកវិញ ប្រហែលជាក្នុងឆ្នាំ១000 មុន គ.ស (មើល ២សយ ៥:៦-១០) ។ ប៉ុន្តែបើតាមការអះអាងថ្មីមួយទៀត ដែលនិយាយពីពួកអ៊ីស្រាអែលនៅក្នុង ជំពូក ១៧-២១ បាននិយាយថា កាលបរិច្ឆេទនៃការសរសេរព្រះគម្ពីរចៅហ្វាយ គឺបន្ទាប់ពីគ្រារាជ្យវង្សស្ដេចដាវីឌ បានរៀបចំរាជ្យវង្សរបស់គេឡើងវិញ (សតវត្សទី១0 មុន គ.ស) ។

### ផ្ទៃរឿង និងវិជ្ជាសិក្សាពីព្រះ ក្នុងព្រះគម្ពីរ

ព្រះគម្ពីរចៅហ្វាយបានពិពណ៌នាពីជីវិតរស់នៅរបស់ពួកកូនចៅអ៊ីស្រាអែល ក្នុងគ្រាដែលពួកគេរស់នៅក្នុងទឹកដីសន្យា ចាប់តាំងពីគ្រាដែលលោកយ៉ូស្វេបានទទួលមរណភាព រហូតដល់គ្រាដែលមានស្ដេចសោយរាជ្យ (រាជាធិបតេយ្យ) នៅក្នុងស្រុកអ៊ីស្រាអែល ។ មួយវិញសោត ព្រះគម្ពីរចៅហ្វាយក៏បាននិយាយពីពួកកូនចៅអ៊ីស្រាអែល ដែលពួកគេតែងតែបោះបង់ចោលព្រះ រករឿងទាស់ប្រឆាំងនឹងព្រះអម្ចាស់ ។ ម្យ៉ាងទៀត ព្រះគម្ពីរនេះបានពិពណ៌នាពីការអំពាវនាវចំពោះព្រះយេហូវ៉ា នៅក្នុងគ្រាដែលពួកគេមានវិបត្តិ ។

សេចក្ដីសន្យាជាច្រើន ដែលព្រះយេហូវ៉ាទ្រង់បានសន្យាជាមួយពួកឰយុកោរបស់គេ ត្រូវបានសម្រេច ព្រោះពេលនេះពួកកូនចៅគេបានឈានជើងមកស្នាក់នៅក្នុងទឹកដីសន្យាដោយជោគជ័យ តាមរយៈលោកយ៉ូស្វេ ជាអ្នកដឹកនាំរបស់គេ (សូមមើល យស ២១:៤៣-៤៥) ។ ទឹកដីរបស់ព្រះអម្ចាស់ ដែលពួកអ៊ីស្រាអែលបានមកស្នាក់នៅ ពួកគេត្រូវតែជាអ្នកជិនួសពួកកាណាន ហើយនិងបំផ្លាញព្រះរបស់គេចេញ ។ ពេលវេលាបានអនុញ្ញាតឱ្យអ៊ីស្រាអែលក្លាយជានគរព្រះ ក្នុងនាមជាអ្នកតំណាងឱ្យរាស្ត្ររបស់ព្រះអម្ចាស់ លើផែនដីទាំងមូល ។

ប៉ុន្តែនៅក្នុងទឹកដីសន្យា ពួកអ៊ីស្រាអែលបានភ្លេចនូវរាល់កិច្ចការទាំងឡាយដែលព្រះយេហូវ៉ា ទ្រង់ជាអ្នកផ្ដល់កំណើត និងរៀបចំសង់ប្រជាជាតិគេនៅក្នុងទឹកដីនោះ ។ ហេតុដូច្នោះហើយ ពួកគេត្រូវបាត់បង់នូវអត្តសញ្ញាណ ក្នុងនាមជារាស្ត្ររបស់ព្រះដែលព្រះអម្ចាស់ទ្រង់បានជ្រើសរើស និងត្រាស់ហៅគេឱ្យធ្វើជាទាហានរបស់ព្រះអង្គ ព្រមទាំងប្រជាពលរដ្ឋដ៏ស្មោះត្រង់នៅក្នុងនគរព្រះ ។ ពួកកូនចៅអ៊ីស្រាអែលបានផ្សារភ្ជាប់ទំនាក់ទំនងរបស់គេ ជាមួយពួកកូនចៅកាណាន តាមរយៈផ្នែកអសីលធម៌ ការថ្វាយបង្គំរូបព្រះ និងគោរពប្រតិបត្តិតាមជំនឿសាសនាផ្សេងៗទៀត ដូចជាពួកកាណានបានគោរពប្រតិបត្តិ ។

តាមរយៈបណ្ដាពួកចៅហ្វាយសំខាន់ៗទាំងឡាយ ដែលមានពួកគេគឺជាអ្នកដឹកនាំមកពីព្រះ នៅក្នុងពួកកូនចៅអ៊ីស្រាអែល ជាពិសេសអ៊ីស្រាអែលបានទទួលស្គាល់ និងសន្យាថា គេនឹងរស់នៅក្រោមការគ្រប់គ្រងមកអំពីព្រះ ។ រាជ្យរបស់ទ្រង់គ្រប់គ្រងលើអ៊ីស្រាអែល គឺមានតាំងពីគ្រានៃការតាំងសញ្ញានៅលើភ្នំស៊ីណាយមកម្ល៉េះ (មើល នក ១៩-២៤) ហើយក្រោយមកទៀត ត្រូវបានកែប្រែជាថ្មីដោយលោកម៉ូសេ នៅវាលទំនាបស្រុកម៉ូអាប់(ចទ ២៩)ហើយនិងលោកយ៉ូស្វេ នៅត្រង់ស៊ីគែម (យស ២៤) ។ អ្នកនិពន្ធ បានចោទប្រកាន់ចំពោះពួកអ៊ីស្រាអែល ដោយព្រោះពួកគេជានិច្ចកាលតែងតែបដិសេធ ចំពោះរាជ្យរបស់ព្រះអម្ចាស់ម្ដងហើយម្ដងទៀត ។ ពួកគេឈប់ធ្វើជាអ្នកចម្បាំង ដោយគោរពប្រតិបត្តិរូបព្រះរបស់ស្រុកកាណាន គេមានជំនឿថារូបព្រះទាំងនោះ គឺជាប្រភពនៃព្រះពរមកលើក្រុមគ្រួសារគេ ។ ចំណុចសំខាន់ដែលតែងតែកើតឡើងនៅក្នុងព្រះគម្ពីរចៅហ្វាយ (មើលគម្រោងមេរៀន) នោះលោកគេខានតែងតែរំឭកពួកអ៊ីស្រាអែលថា ព្រះយេហូវ៉ាគឺជាស្ដេចរបស់គេ(សូមមើល ៨:២៣) ។ ពាក្យតម្លូវដែលតែងតែកើតមាន និងការចោទសួរ គឺបង្ហាញយើងនៅក្នុងជំពូក ១៧-២១ (មើលគម្រោងមេរៀន) គឺដូច្នេះ "នៅគ្រានោះ គ្មានស្ដេចណាសោយរាជ្យ លើស្រុកអ៊ីស្រាអែលទេ ម្ល៉ោះហើយមនុស្សទាំងឡាយ គេតែងប្រព្រឹត្តការដែលខ្លួនគិតឃើញថាត្រឹមត្រូវ"(មើល ១៧:៦) ។ នៅក្នុងអត្ថន័យកន្លែងនេះ គឺចង់និយាយថា លោកិយទាំងមូលត្រូវតែរស់ក្រោមការគ្រប់គ្រងមកអំពីព្រះយេហូវ៉ា(ឧទាហរណ៍ មនុស្សជាតិ) ប៉ុន្តែពួកអ៊ីស្រាអែលគេមិនបានទុកចិត្តចំពោះព្រះ មិនទទួលស្គាល់ព្រះ ហើយមិនស្ដាប់បង្គាប់តាមអ្នកដឹកនាំដែលមកពីទ្រង់នោះឡើយ ។

មានតែផែនការរបស់ព្រះអម្ចាស់ ដែលទ្រង់បានរៀបចំឱ្យមានសាសន៍ដទៃមកឈ្លានពានរាស្ត្រទ្រង់ និងបណ្ដាសា(មើល លវ ២៦:១៤-៤៥ ចទ ២៨:១៥-៦៨) និងការរំដោះពួកគេ នៅពេលដែលគេអំពាវនាវដល់ព្រះនាមរបស់ព្រះ ដែលព្រះអម្ចាស់បានអះអាងអំពីរាជ្យទ្រង់ នៅក្នុងចំណោមបណ្ដាជនអ៊ីស្រាអែលប៉ុណ្ណោះ ដែលធ្វើឱ្យគេងាកមករកព្រះអម្ចាស់វិញ ដើម្បីឱ្យគេបានឈប់សម្រាក(មើល យស ១:១៣) ។

ទោះបីពួកអ៊ីស្រាអែលមិនស្ដាប់បង្គាប់ព្រះក៏ដោយ ពេលមានការឈ្លានពានពីជនប្រទេសក្រៅ ហើយពួកគេបានអំពាវនាវដល់ព្រះអម្ចាស់ ដោយព្រោះការអាក្រក់របស់គេ ព្រមទាំងទទួលបានការរំដោះពេញលេញផងដែរ(មើល ២:១១- ១៩ នហ ៩:២៦-៣១) ព្រះអម្ចាស់ទ្រង់តែងតែស្មោះត្រង់ជានិច្ច ។ ព្រះគុណ និងការអត់ធ្មត់របស់ព្រះអង្គដ៏យូរលង់ មិនមែនជាបញ្ហាចោទសម្រាប់ព្រះអង្គឡើយ។

សូមចងចាំថា នៅក្នុងពេលដែលពួកអ៊ីស្រាអែលធ្លាក់ចុះ ព្រះអម្ចាស់តែងតែរំដោះគេដោយផ្ទាល់ ទោះបីក្នុងសម័យកាលលោកម៉ូសេក្ដី លោកយ៉ូស្វេក្ដី ជាពិសេសគឺនៅក្នុងព្រះគម្ពីរសញ្ញាចាស់ទាំងមូលតែម្ដង ។ ព្រះវិញ្ញាណនៃព្រះអម្ចាស់ ជាអ្នកដែលនាំគេឱ្យមានជ័យជម្នះក្នុងពេលមានសង្គ្រាមជាមួយពួកមានអំណាចទាំងឡាយ ដែលមកយាយីនគររបស់ទ្រង់(សូមមើល ៣:១០ ៦:៣៤ ១១:២៩ ១៣:២៥ ១៤:៦,១៩ ១៥:១៤ ១សយ ១០:៦,១០ ១១:៦ ១៦:១៣) ។ មើលទៅព្រះវិញ្ញាណនៃព្រះអម្ចាស់ បានចាក់បំពេញលើព្រះវិហារ ដោយបន្តការងារសង្គ្រោះដល់រាស្ត្រទ្រង់ តាមរយៈលោកយ៉ូស្វេទី២(ព្រះយេស៊ូវគ្រីស្ទ) ហើយបានផ្ដល់អំណាចឱ្យរាស្ត្ររបស់ព្រះ ក្នុងការប្រកាសដំណឹងល្អពីព្រះអង្គដល់បណ្ដាជនទាំងឡាយ(មើល កច ១:២,៨) ។

## ប្រវត្តិដើម

ការកំណត់ឱ្យដឹងពីពេលវេលាជាក់លាក់នៃកាលបរិច្ឆេទព្រះគម្ពីរចៅហ្វាយ គឺពិតជាពិបាកហើយស្មុគស្មាញណាស់ ។ កាលបរិច្ឆេទ គឺត្រូវបានពឹងផ្អែកលើ ១ពវ ៦:១ ដែលបាននិយាយថា នៅគ្រាដែលពួកកូនចៅអ៊ីស្រាអែលបានចេញពីស្រុកអេស៊ីព្ទមកនោះ មានរយៈពេល៤៨០ឆ្នាំក្នុងឆ្នាំទី៤ នៃរាជ្យស្ដេចសាឡូម៉ូន ។ ហេតុការណ៍នេះអាចនិយាយបានថា នៅគ្រាដែលពួកកូនចៅអ៊ីស្រាអែលបានចាកចេញ គឺប្រហែលជាក្នុងឆ្នាំ ១៤៤៦ មុន គ.ស ហើយព្រឹត្តិការណ៍ក្នុងអំឡុងពេលចៅហ្វាយ ប្រហែលជាឆ្នាំ១៣៨០ មុន គ.ស ហើយនៅពេលគេតែងតាំងស្ដេចសូល ប្រហែលជាឆ្នាំ១០៥០ មុន គ.ស ។ តាមរយៈសុន្ទរកថារបស់លោកយ៉ូណាថាន បាននិយាយថា អ៊ីស្រាអែលបានតាំងលំនៅ នៅត្រង់ក្រុងហែសបូនអស់រយៈពេល៣០០ឆ្នាំ (១១:២៦) ហើយជាទូទៅគេតែងតែយល់ព្រមចំពោះកាលបរិច្ឆេទនេះ ។ តាមមតិមួយចំនួនទៀតនិយាយថា ពួកអ៊ីស្រាអែលបានតាំងលំនៅក្នុងទឹកដីកាណាន មុនឆ្នាំ១២១០ មុនគ.ស ។

## លក្ខណៈអក្សរសាស្ត្រ

បើសិនជាយើងអានយ៉ាងលឿនពីព្រះគម្ពីរចៅហ្វាយ យើងនឹងឃើញមានការបែងចែកជា៣ផ្នែកសំខាន់ៗគឺ (១). បុរេកថា (១:១-៣:៦) (២). សេចក្ដីផ្ដើម(៣:៧-១៦:៣១) (៣). អវសានកថា(១៧-២១) ។ ប៉ុន្តែបើយើងធ្វើការសិក្សាឱ្យលម្អិតបន្តិច គឺមានបញ្ហាស្មុគស្មាញច្រើនជាងនេះទៀត ព្រោះវាមានការលាយឡំជាមួយផ្ទៃរឿងទាំងមូល ។

នៅក្នុងបុរេកថា (១:១–៣:៦) ត្រូវបានគេចែកជា២ផ្នែក ហើយក្នុងផ្នែកនិមួយៗមានគោលបំណងផ្សេងៗពីគ្នា ។ វាមិនមែនជាកាលប្រវត្តិ ហើយក៏មិនមែនជាតារាងនៃពេលវេលាដែលមានភាពជាក់លាក់ដែរ ។ នៅផ្នែកទី១ (១:១–២:៥) គឺនិយាយពីដំណាក់កាលនៃប្រវត្តិសាស្ត្រ ។ ដំណើររឿងនៅក្នុងផ្នែកនេះ ពិពណ៌នាពីការងាររបស់ពួកអ៊ីស្រាអែលនៅក្នុងទឹកដីសន្យា ចាប់តាំងពីគ្រាដែលគេមានជ័យជម្នះលើកដំបូង រហូតដល់គ្រាដែលគេបះបោរជាមួយព្រះអម្ចាស់ ។

ផ្នែកទី២ (២:៦–៣:៦) គឺនិយាយពីទស្សនវិស័យគ្រឹះ ចាប់តាំងពីគ្រាលោកយ៉ូស្វេ រហូតដល់គ្រារាជាធិបតេយ្យ គឺជាពេលដែលគេតែងតែធ្វើការបោះបង់ចោលព្រះម្តងហើយម្តងទៀត ការឈ្លានពាន ការទូលអង្វរចំពោះព្រះនៅគ្រាមានសេចក្តីទុក្ខព្រួយ ហើយនិងព្រះគុណរបស់ព្រះដែលទ្រង់បានរំដោះគេ ។ អ្នកនិពន្ធបានធ្វើការសង្ខេបយ៉ាងខ្លី និងបានពន្យល់យើងពីទំនាក់ទំនងរបស់ព្រះយេហូវ៉ាជាមួយនឹងមនុស្សដែលតែងតែបះបោរជាមួយទ្រង់ ហើយក៏បានធ្វើការណែនាំនូវវាក្យស័ព្ទគ្រឹះខ្លះៗ និងរូបមន្តផ្សេងៗទៀតដែលគាត់នឹងយកមកប្រើ នៅពេលក្រោយ ដូចជាពាក្យថា "ក៏ធ្វើការដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា" ២:១១ (មើល ៣:៧,១២ ៤:១ ៦:១ ១០:៦) "ប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលបំផ្លាញ" ២:១៤ (មើល ៦:១ ១៣:១) ហើយ "ក៏លក់ទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ" ២:១៤ (មើល ៣:៨ ៤:២ ១០:៧) ។

ដោយឡែកនៅក្នុងតួសេចក្តី (៣:៧–១៦:៣១) គឺជាផ្នែកមួយដែលនិយាយពីព្រឹត្តិការណ៍ ដែលតែងតែកើតមានឡើង (បោះបង់ចោលព្រះយេហូវ៉ា ឈ្លានពាន ទុក្ខព្រួយ រំដោះ) ។ នៅក្នុងរឿងនិមួយៗស្ទើរតែដូចគ្នានឹងរឿងមុនដែរ ("នោះពួកកូនចៅអ៊ីស្រាអែលក៏ធ្វើការដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាវិញ" (មើល ៣:៧) ហើយនិងការសន្និដ្ឋានរួម "ដូច្នេះស្រុកក៏បានសុខសាន្តគ្រាន... ឆ្នាំ" (សូមមើល ៣:១១) ។ ផ្ទៃរឿងសំខាន់ដែលបានកើតឡើងដំបូងនោះ (អូធ្នាលៈ សូមមើល ៣:៧–១១) បានផ្តល់ជា "ទម្រង់សេចក្តីរាយការណ៍" ដែលប្រើបន្តបន្ទាប់មកទៀតនៅក្នុងរឿងការឈ្លានពាន ហើយនិងការរំដោះ ។

មាន៥ដំណាក់កាលដែលបានកើតឡើងម្តងហើយម្តងទៀត ហើយនៅក្នុងផ្ទៃរឿងនិមួយៗគឺមានចៅហ្វាយ១:

១. អេហ៊ុឌ (៣:១២–៣០) គាត់គឺជាវីរបុរសតែម្នាក់គត់ដែលចេញពីអំបូរបេនយ៉ាមីន ដែលបានក្លាយជាអ្នករំដោះពួកអ៊ីស្រាអែល ចេញពីការឈ្លានពានរបស់អ្នកនៅតំបន់ខាងកើត ។

២. ដេបូរ៉ា (ជំពូក ៤–៥) គឺជាស្ត្រីដែលបានចេញពីអំបូរ យ៉ូសែប (កូនចៅអេប្រាអិម ដែលរស់នៅភាគខាងលិចទន្លេយ័រដាន់) គឺជាចៅហ្វាយលើពួកអ៊ីស្រាអែលក្នុងអំឡុងពេលដែលពួកអ៊ីស្រាអែល និងពួកកាណានរស់នៅជាមួយគ្នា ក្រោមការគ្រប់គ្រងរបស់ពួកស៊ីរី ។

៣. គេឌាន ហើយនិងអ័ប៊ីម៉ាឡិចជាកូនប្រុសគាត់ (ជំពូក ៦–៩) ពួកគេគឺជាចំណុចស្នូលនៃរឿងទាំងមូល ។ នៅក្នុងមធ្យោបាយជាច្រើន លោកគេឌានគឺជាចៅហ្វាយដែលបានទឹកចាំពីគ្រាលោកម៉ូសេ នៅក្នុងអំឡុងពេលដែលកូនរបស់គាត់ ជាចៅហ្វាយដែលមានសេចក្តីជំនឿដ៏ខ្លាំង ។

៤. យ៉េបថា (១០:៦–១២:៧) គាត់គឺជាម្នាក់ដែលគេបានកាត់ចេញពីសាសន៍ ពីអំបូរយ៉ូសែប (ស្ថិតក្នុងអំបូរម៉ាន៉ាសេ ដែលរស់នៅភាគខាងកើតទន្លេយ័រដាន់) ។ គាត់គឺជាចៅហ្វាយក្នុងគ្រាដែលពួកអ៊ីស្រាអែលទទួលរងការបៀតបៀន ពីពួកមហាអំណាចក្រោមការគ្រប់គ្រងរបស់ស្តេចអាំម៉ូន ។

៥. សាំសុន (ជំពូក ១៣–១៦) គាត់គឺជាវីរបុរសតែម្នាក់គត់ដែលចេញពីអំបូរដាន់ ដែលជាអ្នករំដោះពួកអ៊ីស្រាអែលឱ្យរួចពីការឈ្លានពានរបស់ពួកអ្នកនៅភាគខាងលិច ។

ការបែងចែករឿងនិមួយៗនេះ គឺមានសារៈសំខាន់ណាស់ ។ នៅក្នុងរឿងរបស់គេឌាន (ព្រះយេហូវ៉ាទ្រង់ជាចៅហ្វាយដ៏ល្អ) ហើយអ័ប៊ីម៉ាឡិច (ជាចៅហ្វាយដែលប្រឆាំង) គឺមានការប្រហាក់ប្រហែលគ្នាជាមួយរឿងដេបូរ៉ា ហើយនិងអ្នកដែលគេកាត់ចេញពីសាសន៍ យ៉េបថា ដែលបានបង្ហិលផ្ទៃរឿងនេះ ដោយវីរបុរស អេហ៊ុឌ និងសាំសុន ។ នៅក្នុងស្ថានភាពនេះ រចនាសម្ព័ន្ធរបស់រឿងនេះបានផ្តោតលើស្ថានការណ៍ពិបាកមួយក្នុងអំឡុងពេលគ្រាចៅហ្វាយៈ ពួកអ៊ីស្រាអែលថ្វាយបង្គំរូបព្រះ (បង្ហាញដោយអ័ប៊ីម៉ាឡិច) ការកាត់ទោស ប្រឆាំងរបស់ព្រះអម្ចាស់លើរាស្ត្រទ្រង់ (លោកគេឌានជាអ្នកធ្វើការលើកទឹកចិត្តដល់គេឱ្យងាកចេញ ៨:២៣) ។

អវសានកថា (ជំពូក ១៧–២១) បាននិយាយពីលក្ខណៈនៃយុគសម័យផ្សេងៗគ្នា ដែលពណ៌នាពីសាសនា អសីលធម៌ ពុករលួយ បញ្ហាទាំងនោះ គឺជារឿងផ្ទាល់ខ្លួនរបស់គេម្នាក់ៗ របស់ប្រជាជាតិនិងអំបូរទាំងមូលរបស់គេ ដូចជាអ្វីដែលបាននិយាយនៅក្នុងសេចក្តីផ្តើម គឺមានបែងចែកជា២ផ្នែក ដែលមិនមែនជាប្រវត្តិសាស្ត្រ ហើយក៏មិនមែនជាការពណ៌នាពីពេលវេលាជាក់លាក់របស់ព្រះគម្ពីរចៅហ្វាយដែរ ។ ព្រឹត្តិការណ៍ទាំងនោះគឺមានពេលវេលាខុសគ្នា (មើល ៨:២៣) ។

មានតែពេលវេលាដែលបានកើតឡើងក្នុងបុរេកថាប៉ុណ្ណោះ ដែលអាចមានទំនាក់ទំនងទៅនឹងពេលវេលារាជាធិបតេយ្យ (សូមមើល ក្នុង ១៧:៦ ១៨:១ ១៩:១ ២១:២៥) អ្នកនិពន្ធបានបង្ហាញពីភាពខុសគ្នាក្នុងគ្រាចៅហ្វាយ និងគ្រារាជាធិបតេយ្យ ក្រោមការគ្រប់គ្រងរបស់ស្ដេចដាវីឌ និងរាជ្យវង្សទ្រង់(មើល ១៧:១-២១:២៥) ។ ព្រះគម្ពីរនេះ បាននិយាយពីហេតុការណ៍២ នៅក្នុងនោះព្រះអម្ចាស់ទ្រង់រើសតាំងពូជអំបូរយូដា(១). បណ្ដេញពួកកាណានចេញ (១:១-២) (២). វិន័យរបស់ពួកអ៊ីស្រាអែល (២០:១៨) ។ គំនិតរបស់អ្នកនិពន្ធ គឺអ្នកដឹកនាំទាំងឡាយដែលចេញពីអំបូរយូដា គឺជាអ្នកសង្គ្រោះប្រជាជាតិទាំងមូល ។

នៅក្នុងផ្នែកទី១នៃអវសានកថា (ជំពូក ១៧-១៨) គឺមានទំនាក់ទំនងជាមួយនឹងរឿងរបស់លោកមីកាដែលលោកថ្វាយបង្គំរូបព្រះ ហើយក៏បានប្រាប់យើងអំពីការរីកចម្រើនកេរ្ដិ៍មរតករបស់អំបូរដាន់ នៅក្នុងអំឡុងពេលដែលលោកមីកាកំពុងតែពុករលួយផ្នែកសាសនារបស់គេ ។ នៅក្នុងផ្នែកទី២នៃអវសានកថានេះ(ជំពូក ១៩-២១)បានប្រាប់យើងពីរឿងរ៉ាវដ៏គួរឱ្យកំសត់របស់ពួកលេវី នៅឯគីបៀរក្នុងអំបូរបេនយ៉ាមីន ហើយក៏បានប្រាប់ពីការហ៊ឹកហាត់ និងការប្ដូរទីលំនៅរបស់ពួកគេ ដោយសារតែការបំផ្លាញមនុស្សអាក្រក់នៅក្នុងគីបៀរ ។

នៅក្នុងផ្នែកទាំង២នៃអវសានកថានេះ មានរឿងរ៉ាវដែលស្រដៀងគ្នា២ ឬ ៣ ។

១.នៅក្នុងផ្នែកទាំង២នោះ សុទ្ធតែនិយាយពីទំនាក់ទំនងនៃការធ្វើដំណើរឆ្លងកាត់របស់ពួកលេវី នៅចន្លោះបេថ្លេហិម (ស្រុកយូដា) ហើយនិងពួកអេប្រាអិម ឆ្លងកាត់បេនយ៉ាមីន-ដាន់ ។

២. ទាំង២ផ្នែកនេះ សុទ្ធតែបានផ្ដោតលើពួកអ្នកចម្បាំងទាំង៦០០ ដែលពួកអ្នកទាំងនោះជាអ្នកដឹកនាំអំបូរដាន់ ហើយអ្នកទាំងនោះជាពួកសំណល់របស់អំបូរបេនយ៉ាមីន ។

៣. នៅក្នុងផ្នែកទាំង២នេះ បានបញ្ចប់ដោយការគ្មានអ្វីសោះរបស់ពូជអំបូរ (ដាន់ និងបេនយ៉ាមីន) ។

ពូជអំបូរដាន់និងបេនយ៉ាមីន មិនមែនគ្រាន់តែមានភាពប្រហាក់ប្រហែលគ្នាក្នុងផ្នែកដ៏សំខាន់នៅក្នុងអវសានកថាប៉ុណ្ណោះនោះទេ ប៉ុន្ដែពួកគេក៏ជាទម្រង់នៃពួកអ្នកដែលមានឈ្មោះសំខាន់ទាំងឡាយបាននិយាយក្នុងព្រះគម្ពីរនេះផងដែរ ។ អំបូរបេនយ៉ាមីន ដែលនៅក្នុងផ្នែកអវសានកថា ពួកគេបានព្យាយាមការពារកំហុសដ៏អាក្រក់ផ្នែកសីលធម៌ ត្រូវបានអេហ៊ុឌដែលជាអ្នករំដោះមកពីព្រះអម្ចាស់ ធ្វើការរំដោះពួកគេ(៣:១៥)នៅពេលគេអំពាវនាវដល់ព្រះនាមទ្រង់ ។ ពូជអំបូរដាន់ជាប់ទាក់ទងទៅនឹងកេរ្ដិ៍មរតក ហើយបានប្រព្រឹត្តតាមសាសនា និងថ្វាយបង្គំរូបព្រះ ត្រូវបានលោកសាំសុនជាអ្នករំដោះមកពីព្រះអម្ចាស់ជួយពួកគេឱ្យរួចពីការទាំងនោះ (១៣:២,៥) ។ នៅទីអវសានកថា អំបូរទាំង២នោះបានគោរពតាមសាសនា ហើយនិងអំពើពុករលួយផ្សេងៗនៅក្នុងពួកអ៊ីស្រាអែល ហើយចំពោះអ្នករំដោះណា ដែលខ្លាំងពូកែត្រូវបានអ្នកនិពន្ធលើកមកធ្វើជាចំណុចចម្បងនៅក្នុងព្រះគម្ពីរ(លោកគេឌាន និងស្ដេចអ័ប៊ីម៉្មាឡិច) ។

របៀបនៃការតាក់តែងព្រះគម្ពីរចៅហ្វាយ ចាប់តាំងពីបុរេកថា រហូតដល់ទីអវសានកថា គឺមានទំនាក់ទំនងជាមួយគ្នារហូត ហើយរបៀបនៃការបែងចែកជា៣ផ្នែកនោះ គឺបានពិពណ៌នារឿងរ៉ាវទាក់ទងគ្នាជានិច្ច ដោយបានចាប់ផ្ដើមនិយាយថា "នៅគ្រានោះគ្មានស្ដេចណាសោយរាជ្យស្រុកអ៊ីស្រាអែលឡើយ" ហើយ "មនុស្សទាំងឡាយ គេតែងតែប្រព្រឹត្តការដែលខ្លួនគិតឃើញថាត្រឹមត្រូវ" (សូមមើល ១៧:៦) ។

**គម្រោងសង្ខេប**

I. **បុរេកថា: ចម្បាំងមិនទាន់បានបញ្ចប់ និងការបោះបង់ចោលព្រះ (១:១-៣:៦)**

ក. វគ្គ ទី១: ការធ្លាក់ចុះរបស់ពួកអ៊ីស្រាអែល ក្នុងការសម្អាតទឹកដី(១:១-២:៥)

ខ.វគ្គ ទី២: ទំនាក់ទំនងរបស់ព្រះអម្ចាស់ជាមួយការបះបោររបស់អ៊ីស្រាអែល(២:៦-៣:៦)

II. **ការជិះជាន់ និងការរំដោះ (៣:៧-១៦:៣១)**

***ពួកចៅហ្វាយធំ***

ក. លោកអូធ្នាស វាយឈ្នះស្ដេចស្រុកអើរ៉ាម-ណាហារេម(៣:៧-១១)

ខ. លោកអេហ៊ុឌ វាយឈ្នះស្ដេចស្រុកម៉ូអាប់(៣:១២-៣០)

គ. នាងដេបូរ៉ា វាយឈ្នះពួកកាណាន(ជំពូក ៤-៥)

ឃ. លោកគេឌាន វាយឈ្នះពួកម៉ាឌាន(ជំពូក ៦-៨)

(ស្ដេចអ័ប៊ីម៉្មាឡិច ជាស្ដេចដែលប្រឆាំងនឹងពួកចៅហ្វាយ ជំពូក ៩)

ង. លោកយ៉េបថា វាយឈ្នះស្ដេចស្រុកអាំម៉ូន (១០:៦–១២:៧)

ច. លោកសាំសុន ផ្ដួលរំលំពួកភីលីស្ទីន (ជំពូក ១៣–១៦)

***ចៅហ្វាយតូច***

១. លោកសាំកើរ (៣:៣១)

២. លោកថូឡា (១០:១–២)

៣. លោកយ៉ាអ៊ារ (១០:៣–៥)

៤. លោកអ៊ីបសាន (១២:៨–១០)

៥. លោកអេឡូន (១២:១១–១២)

៦. លោកអាបដូន (១២:១៣–១៥)

III. **ទីអវសានកថា: ការប្រព្រឹត្តតាមសាសនា និងអំពើអសីលធម៌ (ជំពូក ១៧–២១)**

**ក. វគ្គ ទី១ (ជំពូក ១៧–១៨ សូមមើល ១៧:៦ ១៨:១)**

១. អំពើពុករលួយរបស់លោកមីកា (ជំពូក១៧)

២. ពួកកូនចៅដាន់ត្រូវបានបណ្ដេញចេញពីទឹកដី និងកេរ្ដិ៍មរតក (ជំពូក ១៨)

**ខ. វគ្គ ទី២ (ជំពូក ១៩–២១ មើល ១៩:១ ២១:២៥)**

១. អំពើពុករលួយនៅគីបៀរ (ជំពូក ១៩)

២. ពួកបេនយ៉ាមីនបានចាកចេញពីអំបូររបស់គេ (ជំពូក ២០–២១)

## រាស្ត្រអ៊ីស្រាអែលច្បាំងនឹងសាសន៍កាណាន

*១:១១–១៥ យស ១៥:១៥–១៩*

**១** ១រីឯគ្រាក្រោយ ដែលលោកយ៉ូស្វេ បានស្លាប់[ក]ហើយ
នោះពួកកូនចៅអ៊ីស្រាអែលគេទូលសួរព្រះយេហូវ៉ាថា ក្នុង
ពួកយើងខ្ញុំ តើអ្នកណាត្រូវឡើងទៅច្បាំងនឹងពួកសាសន៍
កាណានមុនគេ[ខ,គ] ២ព្រះយេហូវ៉ាទ្រង់មានបន្ទូលឆ្លើយថា
ត្រូវឱ្យពួកយូដា[ឃ]ឡើងទៅចុះ មើល អញបានប្រគល់ស្រុក
នោះមកក្នុងកណ្តាប់ដៃរបស់គេហើយ[ង] ៣នោះពួកយូដាក៏
និយាយទៅពួកស៊ីម្មានជាបងប្អូនថា សូមឡើងទៅឯស្រុកជា
ចំណែកខ្ញុំ ជាមួយនឹងខ្ញុំចុះ ដើម្បីច្បាំងនឹងសាសន៍កាណាន
នោះយើងនឹងទៅឯស្រុក ជាចំណែករបស់បងប្អូន ជាមួយ
នឹងបងប្អូនដែរ ដូច្នេះពួកស៊ីម្មាន[ច]ក៏ព្រមទៅជាមួយ ៤ពួក
យូដាក៏ឡើងទៅ ហើយព្រះយេហូវ៉ាទ្រង់ប្រគល់ពួកសាសន៍
កាណាន និងសាសន៍ពេរិស៊ីត[ឆ] មកក្នុងកណ្តាប់ដៃរបស់គេ
នោះគេប្រហារពួកសាសន៍នោះ អស់១ម៉ឺននាក់ នៅក្រុង
បេសេក[ជ] ៥ក៏ឃើញអ័ដូនី–បេសេក[ឈ]នៅក្រុងនោះ រួច
ច្បាំងនឹងលោក ព្រមទាំងវាយសំឡាប់ពួកសាសន៍កាណាន
និងសាសន៍ពេរិស៊ីតផង ៦ឯអ័ដូនី–បេសេក បានរត់ចេញ
វិញ តែគេដេញតាមចាប់បានមកហើយកាត់មេដៃមេជើង
របស់លោកចេញ ៧ខណនោះអ័ដូនី–បេសេកនិយាយថា
មានស្តេច៧០អង្គដែលរើសអាហារក្រោមតុខ្ញុំ មានទាំងមេ
ដៃមេជើងកាត់ដាច់ដូច្នេះដែរ នេះគឺព្រះបានសងខ្ញុំ[ញ]ដូចជា
ខ្ញុំបានប្រព្រឹត្តនឹងគេហើយ រួចគេនាំលោកទៅឯក្រុង
យេរូសាឡិម[ដ] ហើយលោកស្លាប់ នៅទីនោះទៅ ។
៨ពួកកូនចៅយូដា ក៏ច្បាំងនឹងក្រុងយេរូសាឡិមដែរ[ឋ]
ព្រមទាំងចាប់យកបាន រួចប្រហារគេដោយមុខដាវ ហើយ
ឆួលដុតទីក្រុងចោលផង ៩ក្រោយមកក៏ចុះទៅច្បាំងនឹង
សាសន៍កាណាន ដែលនៅស្រុកភ្នំទាបៗ[ឌ] ស្រុកត្បូង[ឍ] និង

**១:១** ក យស ២៤:២៩ ខ ជន ២:៣–៩ ពច ២០:១៨ ១ពវ ២០:១៤ គ ខ.២៧ លប ១០:១៨ ពច ៣:១–៦ **១:២** ឃ លប ៤៩:១០ ង ខ.៤ ពច ៣:២៨ ៤:៧,១៤ ៧:៩ **១:៣** ច ខ.១៧ **១:៤** ឆ លប ១៣:៧ យស ៣:១០ ជ ១សយ ១១:៨ **១:៥** ឈ ខ.៦,៧ **១:៧** ញ លវ ២៤:១៩ យរ ២៥:១២ ដ យស ១០:១ **១:៨** ឋ ខ.២១ យរ ១៥:៦៣ ២សយ ៥:៦ **១:៩** ឌ ជន ១៣:១៧ ឍ លប ១២:៩ ជន ២១:១ អស ៣០:៦

**១:១–៣:៦** នៅក្នុងសេចក្តីផ្តើមនេះ យើងធ្វើការបែងចែកជា២ផ្នែក: (១). ការធ្លាក់ចុះរបស់ពួកកូនចៅអ៊ីស្រាអែល នៅក្នុងទឹកដីសន្យា ដោយពួកគេបានធ្វើខុសពីអ្វីដែលព្រះយេហូវ៉ា បានបង្គាប់មក (១:១–៣៦) ហើយនិងការស្តីបន្ទោសរបស់ព្រះអង្គ ចំពោះកំហុសឆ្គងរបស់ពួកគេ ដោយគេមិនបានរក្សាភក្តីភាពជាមួយព្រះអង្គ(២:១–៥) (២).សង្ខេបអត្ថបទព្រះគម្ពីរ ៣:៧–១៦:៣១ ដែលនិយាយពីរបៀបដែលពួកកូនចៅអ៊ីស្រាអែល ធ្វើការបះបោរជាមួយព្រះយេហូវ៉ា បន្ទាប់ពីគ្រាដែលលោកយ៉ូស្វេបានទទួលមរណៈភាពមក និងទំនាក់ទំនងរបស់ព្រះអម្ចាស់ជាមួយពួកគេ(២:៦–៣:៦) សូមមើលសេចក្តីផ្តើមព្រះគម្ពីរចៅហ្វាយ ។

**១:១–៣៦** លោកយូដា គឺជាអ្នកដែលបានបានតែងតាំងឱ្យធ្វើជាអ្នកដឹកនាំនៅក្នុងស្រុក(ខ.២ ២០:១៨) ។ គាត់ទទួលបរាជ័យ ដែលផ្ទុយពីភាពរឹងមាំ និងស្វាហាប់របស់គាត់ ហើយបានធ្វើឱ្យគាត់ទទួលយករឿងនេះទាំងជូរចត់ មានតែពួកអេប្រាអិម១ប៉ុណ្ណោះ ដែលទទួលជ័យជម្នះនៅត្រង់បេត–អែល (ខ.២២–២៦) ។

**១:១** *រីឯគ្រាក្រោយ ដែលលោកយ៉ូស្វេ បានស្លាប់ហើយ* នៅក្នុងព្រះគម្ពីរចៅហ្វាយបានប្រាប់អំពីយុគសម័យ នៃការស្លាប់របស់អ្នកដឹកនាំម្នាក់ ដែលស្ថិតនៅក្នុងគ្រានៃការប្រោសលោះ (មើល ១:១) ។ ការស្លាប់របស់លោកយ៉ូស្វេ ប្រហែលជានៅឆ្នាំ ១៣០៩ មុន គ.ស (ប៉ុន្តែ សូមមើលសេចក្តីផ្តើម: ប្រវត្តិដើម) ។ នៅក្នុងអំឡុងពេលដែលគាត់ដឹកនាំ គាត់បានទទួលជ័យជម្នះលើពួកកាណាន ដែលមានបំណងបណ្តេញពួកអ៊ីស្រាអែលចេញពីទឹក ដី ។ នៅចុងក្រោយ គឺអ៊ីស្រាអែលស្ថិតនៅក្នុងទឹកដីកាណាន (សូមមើលការពន្យល់ យស ១៨:៣ ២១:៤៣–៤៥) ។ *ទូលសួរព្រះយេហូវ៉ាថា* ប្រហែលទូលសួរដោយប្រើយូរីម និងធូមីម (សូមមើលការពន្យល់ នក ២៨:៣០ ១សយ ២:២៨) ។ *ឡើងទៅ* ពួកអ៊ីស្រាអែលសំខាន់ៗត្រូវឡើងទៅ ហើយតាំងបន្ទាយនៅត្រង់ គីលកាល នៅក្បែរក្រុងយេរីខូរនាទន្លេយ័រដាន់ (ប្រហែលជាមានចម្ងាយ ៨៨ ម៉ែត ពីទន្លេ) ហើយពួកកាណានបានតាំងបន្ទាយនៅត្រង់ចំណុចកណ្តាល នៅលើភ្នំ(មានចម្ងាយប្រមាណជា២,៥០០–៣,៥០០ ម៉ែតពីខាងលើទន្លេយ័រដាន់)។

**១:២** *ត្រូវឱ្យពួកយូដាឡើងទៅចុះ* មើល ២០:១៨ ។ យូដាគឺជាមនុស្សដំបូងដែលបានតាំងលំនៅ នៅភាគខាងលិចនៃទន្លេយ័រដាន់(យស ១៥) ។ ច្បាប់ក្នុងការដឹកនាំរបស់ពួកយូដា គឺបានសម្រេចតាមការទាយទុកជាមុន និងការឱ្យពររបស់យ៉ាកុប (លប ៤៩:៨–១២ និងការពន្យល់ យស ១៥:១) ។

**១:៣** *ពួកស៊ីម្មាន* លោកយ៉ូស្វេកំណត់ឱ្យទីក្រុងទៅស៊ីម្មាន ក្នុងអំឡុងពេលដែលបានដកយកចំណែកពីយូដា(មើល យស ១៩:១,៩ លប ៤៩:៥–៧) ។

**១:៤** *ពួកសាសន៍កាណាន* មើលការពន្យល់ លប ១០:៦ ។ *សាសន៍ពេរិស៊ីត* មើលការពន្យល់ លប ១៣:៧ ។ *បេសេក* ស្តេចសូលបានរាប់ទ័ពរបស់គាត់នៅត្រង់នេះដែរមុនពេលចេញទៅ យ៉ាបេស–កាឡាត (១សយ ១១:៨ និងការពន្យល់) ។

**១:៥** *អ័ដូនី–បេសេក* មានន័យថា "ព្រះយេហូវ៉ានៃបេសេក" ។

**១:៦** *កាត់មេដៃមេជើងរបស់លោកចេញ* នៅក្នុងតំបន់មជ្ឈឹមបុពាណ៌សម័យបុរាណ គេតែងតែដាក់ទណ្ឌកម្មរបៀបនេះ ដល់ពួកអ្នកទោសជាច្រើន (មើលការពន្យល់ ១៦:២១) ។

**១:៧** *មានស្តេច៧០អង្គ* កាណាន ត្រូវបានបែងចែកជាក្រុងតូចៗជាច្រើន ហើយនៅក្នុងទីក្រុងនិមួយៗត្រូវគ្រប់គ្រងដោយស្តេច១ ។ "ស្តេច៧០អង្គ" ចំនួននេះប្រហែលជានិមិត្តសញ្ញាថា ពួកគេមានគ្នាច្រើន ។ *ដែលរើសអាហារក្រោមតុខ្ញុំ* មានន័យថា ជាអ្នកដែលទទួលភាពអាមាសមុខយ៉ាងខ្លាំងដូចជាអាហារដែលគេឱ្យសត្វ (សូមមើល មថ ១៥:២៧ លក ១៦:២១) ។ *នេះគឺព្រះបានសងខ្ញុំ* មើលការពន្យល់ នក ២១:២៣–២៥ ។

**១:៨** *ច្បាំងនឹងក្រុងយេរូសាឡិម* ទោះបីជាពួកគេវាយបានក្រុងយេរូសាឡិមក៏ដោយ ក៏ពួកគេមិនទាន់គ្រប់គ្រងក្រុងនេះ នាពេលឥឡូវនេះដែរ(ខ.២១)។ ពួកអ៊ីស្រាអែល មិនបានគ្រប់គ្រងលើក្រុងយេរូសាឡិមជានិច្ចនោះឡើយ រហូតដល់គ្រាដែលស្តេចដាវីឌជាអ្នកចាប់បាន នៅក្នុងអំឡុងឆ្នាំប្រហែល ១០០០ មុន គ.ស (២សយ ៥:៦–១០) ។

**១:៩** *ស្រុកត្បូង* មើល ជន ១៣:១៧ ។

ស្រុកទំនាបថែមទៀត ១០រួចច្បាំងនឹងសាសន៍កាណាន
ដែលនៅក្រុងហេប្រុនដែរ[ណ] (រីឯក្រុងហេប្រុននោះ កាល
ពីដើមហៅថា គារយ៉ាត់–អើបា[ត]) ហើយគេប្រហារ
សំឡាប់សេសាយ អ័ហ៊ីម៉ាន និងតាលម៉ាយបង់[ថ]។
១១រួចពីនោះគេក៏ទៅច្បាំងនឹងពួកអ្នកនៅក្រុងដេបៀរ[ទ]
ទៀត (រីឯក្រុងដេបៀរនេះ ពីដើមបានហៅថា គារយ៉ាត់–
សេភើរ) ១២ឯកាលែបគាត់បានសន្យាថា បើអ្នកណាវាយ
យកក្រុងគារយ៉ាត់–សេភើរបាន នោះអញនឹងឱ្យអាកសា
ជាកូនអញ ធ្វើជាប្រពន្ធអ្នកនោះ ១៣ដូច្នេះអូធ្នាល ជាកូន
កេណាស ដែលជាប្អូនកាលែប បានទៅវាយយកបាន
កាលែបក៏ឱ្យនាងអាកសា ទៅធ្វើជាប្រពន្ធគាត់ទៅ ១៤កាល
នាងបានចូលទៅ នោះក៏បបួលប្ដីឱ្យសូមដីពីឪពុក រួចនាង
លោតចុះពីលើលាដែលនាងជិះមក ដូច្នេះ កាលែបសួរថា
ដូចម្តេចហ្នឹង ១៥នាងឆ្លើយថា សូមលោកឪពុកចែកចំណែក
១មកខ្ញុំផង ដ្បិតលោកឪពុកបានឱ្យដីខាងត្បូងដល់ខ្ញុំហើយ
ដូច្នេះសូមចែកឱ្យខ្ញុំមានក្បាលទឹកដែរ កាលែបក៏ឱ្យអស់
ទាំងក្បាលទឹកខាងលើ ហើយខាងក្រោមទៅនាង[ធ]។
១៦ឯពួកសាសន៍កែន[ន] គឺជាកូនចៅរបស់ឪពុកក្មេក[ប]
លោកម៉ូសេ គេចេញពីក្រុងដើមលម៉ើ[ផ] ឡើងទៅក្នុងទី
រហោស្ថានស្រុកយូដា ដែលនៅខាងត្បូងអើរ៉ាត[ព] ជាមួយ
នឹងពួកកូនចៅយូដា ហើយក៏តាំងទីលំនៅនៅជាមួយនឹង
ពួកអ្នកស្រុកនោះ។
១៧នោះពួកយូដាក៏ទៅជាមួយនឹងពួកស៊ីម្មាន[ភ] ជាបងប្អូន
វិញ គេនាំគ្នាវាយសំឡាប់ពួកសាសន៍កាណានដែលនៅ
សេផាត ហើយបំផ្លាញទីក្រុងនោះអស់រលីងទៅ (រីឯទីក្រុង
នោះហៅថា ហោម៉ា)[ម] ១៨ពួកយូដាក៏ចាប់យកក្រុងកាសា[យ]
ព្រមទាំងដែនស្រុក និងអាសកាឡូន[រ] ព្រមទាំងដែនស្រុក
ហើយនិងអេក្រុន ព្រមទាំងដែនស្រុកដែរ ១៩ព្រះយេហូវ៉ា
ទ្រង់គង់ជាមួយ[ល]នឹងពួកយូដា បានជាគេឈ្នះស្រុកភ្នំបាន[វ]
តែគេពុំអាចនឹងបណ្តេញពួកអ្នកដែលនៅវាលច្រកភ្នំចេញ
បានទេ ពីព្រោះពួកនោះមានសុទ្ធតែរទេះដែក[ស] ២០គេក៏ឱ្យ
ក្រុងហេប្រុន[ហ]ដល់កាលែប ដូចជាលោកម៉ូសេបានបង្គាប់
មក នោះគាត់បណ្តេញពួកកូនអ័ណាក់ទាំង៣នាក់ចេញ[ឡ]
២១រីឯពួកកូនចៅបេនយ៉ាមីន គេមិនបាន[អ]បណ្តេញពួក
សាសន៍យេប៊ូស ដែលនៅក្រុងយេរូសាឡិមចេញទេ[ក]
សាសន៍នោះបាននៅជាមួយនឹងកូនចៅបេនយ៉ាមីន នៅក្នុង
ក្រុងយេរូសាឡិម ដរាបដល់សព្វថ្ងៃនេះ ។
២២ឯពួកវង្សយ៉ូសែប[ខ] គេឡើងទៅ ទាស់នឹងបេត–

**១:១០** ណ លប ១៣:១៨ ត លប ៣៥:២៧ ថ ខ.២០ ជន ១៣:២២ យស ១៥:១៤ **១:១១** ទ យស ១០:៣៨ **១:១៥** ធ ជន ១៣:៦ **១:១៦** ន លប ១៥:១៩ ប ជន ១០:២៩ ផ ចទ ៣៤:៣ ពច ៣:១៣ ២របា ២៨:១៥ ព ជន ២១:១ យស ១២:១៤ **១:១៧** ភ ខ.៣ ម ជន ១៤:៤៥ **១:១៨** យ យស ១១:២២ រ យស ១៣:៣ **១:១៩** ល ជន ១៤:៤៣ វ ជន ១៣:១៧ ស យស ១៧:១៦ **១:២០** ហ យស ១០:៣៦ ឡ ខ.១០ យស ១៤:១៣ **១:២១** អ យស ៩:១៥ ១៥:៦៣ ក ខ.៨ **១:២២** ខ ពច ១០:៩

**១:១០** *គារយ៉ាត់–អើបា* សូមមើលការពន្យល់ យស ១៤:១៥ ។

**១:១១–១៥** នៅក្នុងឃ្លានេះ គឺបានដកស្រង់ចេញពី យស ១៥:១៥–១៩ ។ នៅក្នុងព្រះគម្ពីរយ៉ូស្វេគឺពិពណ៌នាពីកេមរដក ជាច្រើនដែលនឹងផ្តល់ឱ្យអំបូរយូដា ។ នៅទីនេះ គឺនិយាយពីជ័យជម្នះរបស់ពួកយូដា ក្នុងការដណ្តើមយកកេរ្តិ៍មរដក របស់ខ្លួនក្នុងអំបូររបស់គេ ។

**១:១១** *ដេបៀរ* សូមមើលការពន្យល់ យស ១០:៣៨ ។

**១:១២** *កាលែប* លោក និងលោកយ៉ូស្វេ គឺជាអ្នកដែលបានរាយការណ៍ពីការទទួលជ័យជម្នះលើស្រុកកាណាន (ជន ១៤:៦–៩) ។ *ជាកូនអញ ធ្វើជាប្រពន្ធអ្នកនោះ* នៅក្នុងឃ្លានេះចង់និយាយថា ដើម្បីជារង្វាន់លើកទឹកចិត្តដល់អ្នកដែលវាយឈ្នះ គឺឱ្យស្រីម្នាក់មកធ្វើជាប្រពន្ធ (មើល ១សយ ១៨:២៥) ។

**១:១៣** *អូធ្នាល* លោកគឺជាចៅហ្វាយដំបូងលើពួកអ៊ីស្រាអែល (សូមមើល ៣:៧–១១) ។

**១:១៦** *ឪពុកក្មេកលោកម៉ូសេ* សូមមើលការពន្យល់ នក ២:១៦ ។

**១:១៧** *នោះពួកយូដា . . . នឹងពួកស៊ីម្មាន* ពេលនេះយូដាបានសម្រេចការប្តេជ្ញាចិត្តរបស់គេហើយ (ខ.៣) ។

**១:១៨** *កាសា . . . អាសកាឡូន . . . អេក្រុន* នេះគឺជាឈ្មោះទីក្រុងទាំង៣ ក្នុងចំណោមទីក្រុងសំខាន់ៗ៥ ដែលគ្រប់គ្រងដោយពួកភីលីស្ទីន ។

**១:១៩** *តែគេពុំអាចនឹងបណ្តេញពួកអ្នកដែលនៅវាលច្រកភ្នំចេញបានទេ* ដោយព្រោះអ៊ីស្រាអែលគេបានប្រព្រឹត្តខុស ហើយមិនស្តាប់បង្គាប់ព្រះ (ចទ ៧:១–៥ ២០:១៦–១៨) ដែលព្រះបានបង្គាប់ឱ្យគេបណ្តេញពួកកាណានចេញ ។ មានកត្តា៥យ៉ាងដែលបណ្តាលឱ្យគេប្រព្រឹត្តរំលងនឹងបញ្ញត្តិព្រះយេហូវ៉ាៈ (១). គ្រឿងសាស្ត្រាវុធរបស់កាណានទំនើបជាង (នៅទីនេះ) ។ (២). អ៊ីស្រាអែលមិនបានស្តាប់បង្គាប់ព្រះ ដោយគេបានតាំងសញ្ញាជាមួយពួកកាណាន (២:១–៣) ។ (៣). ពួកអ៊ីស្រាអែលបានគោរពប្រតិបត្តិដល់ព្រះដទៃ ដែលខុសពីអ្វី ដែលពួកឰយុកោគេបានតាំងសញ្ញាជាមួយព្រះ (២:២០–២១) ។ (៤). ព្រះយេហូវ៉ាទ្រង់ល្បងលអ៊ីស្រាអែលដើម្បីឱ្យគេស្តាប់បង្គាប់ទ្រង់ (២:២២–២៣ ៣:៤) ។ (៥). ព្រះទ្រង់បានផ្តល់ឱ្យអ៊ីស្រាអែលក្លាយ ជាទាហានរបស់ទ្រង់ ដើម្បីឱ្យគេបានទទួលការរីកចម្រើនជំនាញរបស់គេ ក្នុងពេលធ្វើសង្គ្រាមនឹងចេះច្បាំង (៣:១–២) ។ *រទេះដែក* ជាយានដែលធ្វើពីឈើ និងដែកល្អៗដើម្បីធ្វើចម្បាំង ។ ដែកនោះប្រហែលជាភ្លៅរទេះ (មើលការពន្យល់ យស ១៧:១៦) ។

**១:២០** *ដូចជាលោកម៉ូសេបានបង្គាប់មក* មើល ជន ១៤:២៤ ចទ ១:៣៦ យស ១៤:៩–១៤ ។ *អ័ណាក់* សូមមើលការពន្យល់ ជន ១៣:២២ យស ១៤:១៥ ។

**១:២១** *ពួកកូនចៅបេនយ៉ាមីន គេមិនបានបណ្តេញពួកសាសន៍យេប៊ូស* មើលការពន្យល់ ខ.៨ ។ ទីក្រុងយេរូសាឡិមមានព្រំប្រទល់ចន្លោះពួកបេនយ៉ាមីន និងពួកយូដា ប៉ុន្តែពួកបេនយ៉ាមីនជាអ្នកគ្រប់គ្រង (មើល យស ១៨:២៨) ។ *សាសន៍យេប៊ូស* មើលការពន្យល់ លប ១០:១៦ ។

**១:២២** *ពួកវង្សយ៉ូសែប* គឺជាពួកកូនចៅអេប្រាអិម និងម៉ានាសេខាងលិច ។ *បេត–អែល* សូមមើលការពន្យល់ លប ១២:៨ ។ នៅទីនោះ គឺជាទីកន្លែង

អែល[គ] ហើយព្រះយេហូវ៉ាក៏គង់ជាមួយនឹងគេ
២៣គេចាត់មនុស្សឱ្យទៅសង្កេតមើលក្រុងបេត-អែលនោះ (រីឯទីក្រុងនោះ ពីដើមហៅថា លូស)[ឃ]
២៤ពួកឈ្លបនោះគេបានឃើញមនុស្សម្នាក់ចេញពីទីក្រុងមក ហើយក៏សួរថា សូមអ្នកបង្ហាញផ្លូវដែលចូលទៅក្នុងទីក្រុងផង នោះយើងនឹងអាណិតមេត្តាដល់អ្នក[ង]
២៥អ្នកនោះក៏បង្ហាញផ្លូវដល់គេ រួចគេកាប់សំឡាប់ពួកក្រុងនោះដោយមុខដាវ តែគេលែង[ច]អ្នកនោះ ព្រមទាំងគ្រួសារគាត់ឱ្យទៅវិញ
២៦អ្នកនោះក៏ទៅសង់ទីក្រុង១ នៅត្រង់ស្រុកសាសន៍ហេត[ឆ] រួចដាក់ឈ្មោះថាក្រុងលូស[ជ] ឈ្មោះនោះក៏នៅជាប់ដរាបដល់សព្វថ្ងៃនេះ ។
២៧ឯពួកម៉ាន៉ាសេ គេមិនបាន[ឈ]បណ្តេញពួកអ្នកនៅក្រុងបេត-សៀន និងដំបន់នៅជុំវិញ ពួកក្រុងតាណាក និងដំបន់នៅជុំវិញ ពួកក្រុងដោរ[ញ] និងដំបន់នៅជុំវិញ ពួកក្រុងយីបលាម[ដ] និងដំបន់នៅជុំវិញ ឬពួកក្រុងមេគីដោ[ឋ] និងដំបន់នៅជុំវិញចេញទេ គឺពួកសាសន៍កាណាន[ឌ]បានតាំងចិត្តនឹងនៅជាប់ក្នុងស្រុកនោះវិញ
២៨តែលុះកាលសាសន៍អ៊ីស្រាអែលបានមានកំឡាំងឡើង នោះគេក៏ចាប់ពួកសាសន៍កាណានឱ្យធ្វើការបំរើគេ ឥតបានបណ្តេញទាំងអស់ទេ[ឍ] ។
២៩ឯពួកអេប្រាអិម[ណ] គេមិនបានបណ្តេញពួកសាសន៍កាណាន ដែលនៅក្រុងកេស៊ើរដែរ[ត] គឺពួកកាណាននោះបាននៅកេស៊ើរ ជាកណ្តាលពួកគេវិញ[ថ] ។
៣០ឯពួកសាប់យូល៉ូន គេមិនបានបណ្តេញពួកអ្នកក្រុងគីត្រុន ឬពួកអ្នកក្រុងណាហាឡាលចេញទេ គឺពួកសាសន៍កាណាន នៅជាកណ្តាលពួកគេ ហើយក៏ទទួលព្រមធ្វើការបំរើគេ ។
៣១ឯពួកអេស៊ើរ[ទ] គេមិនបានបណ្តេញពួកអ្នកនៅក្រុងអាកូរ ស៊ីដូន[ធ] អាស់ឡាប់ អាក់ស៊ីប[ន] ហេលបា អាផែក[ប] ឬរេហុបចេញទេ[ផ]
៣២គឺពួកអេស៊ើរនៅជាកណ្តាលសាសន៍កាណាន ដែលនៅស្រុកនោះវិញ ពីព្រោះគេមិនបានបណ្តេញសាសន៍នោះចេញទេ ។
៣៣ឯពួកណែបថាលី គេក៏មិនបានបណ្តេញពួកអ្នកដែលនៅក្រុងបេត-សេមែស[ព] ឬពួកក្រុងបេត-អាណាត[ភ]ចេញដែរ គឺគេនៅជាកណ្តាលពួកសាសន៍កាណាន ដែលនៅស្រុកនោះវិញ ប៉ុន្តែពួកអ្នកនៅក្រុងបេត-សេមែស និងបេត-អាណាត បានទទួលព្រមធ្វើការបំរើដល់គេ ។
៣៤ឯពួកកូនចៅដាន់[ម] នោះពួកសាសន៍អាម៉ូរី[យ]បានបង្ខំឱ្យគេទៅនៅស្រុកភ្នំ មិនព្រមឱ្យគេចុះមកនៅវាលច្រកភ្នំឡើយ[រ]
៣៥ឯពួកសាសន៍អាម៉ូរីនោះ បានតាំងចិត្តនឹងនៅជាប់ក្នុងស្រុកភ្នំហេរេស[ល] នៅក្រុងអាយ៉ាឡូន[វ] និងក្រុងស្អាលប៊ីម[ស] ប៉ុន្តែកាលដែលពួកវង្សយ៉ូសែបបានឈ្នះ នោះក៏បង្ក្រាបគេឱ្យទទួលព្រមធ្វើការបំរើវិញ
៣៦ឯព្រំស្រុករបស់សាសន៍អាម៉ូរី នោះចាប់តាំងពីច្រកភ្នំដែលឡើងទៅ[ហ]ឯភ្នំអាក្រាប៊ីម គឺពីថ្មដា[ឡ]ឡើងទៅលើ[អ] ។

## ទេវតានៃព្រះអម្ចាស់នៅបូគីម

**២** ១នៅគ្រានោះ ទេវតានៃព្រះយេហូវ៉ា[ក] បានឡើងពីគីលកាល[ខ] មកដល់បូគីម[គ]ប្រាប់ថា អញបានធ្វើឱ្យឯងរាល់

**១:២២** គ យស ៧:២ **១:២៣** ឃ លប ២៨:១៩ **១:២៤** ង លប ៤៧:២៩ **១:២៥** ច យស ៦:២៥ **១:២៦** ឆ ចទ ៧:១ អគ ១៦:៣ ជ លប ២៨:១៩ **១:២៧** ឈ ១ពវ ៩:២១ ញ យស ១១:២ ដ យស ១៧:១១ ឋ យស ១២:២១ ឌ ខ.១ **១:២៨** ឍ យស ១៧:១២-១៣ **១:២៩** ណ យស ១៤:៤ ពច ៥:១៤ ត យស ១០:៣៣ ថ យស ១៦:១០ **១:៣១** ទ យស ១៧:៧ ធ លប ៤៩:១៣ ន យស ១៥:៤៤ ប យស ១២:១៨ ផ ជន ១៣:២១ **១:៣៣** ព យស ១៥:១០ ភ យស ១៩:៣៨ **១:៣៤** ម ជន ១៣:២៩ ពច ១០:១ ១សយ ៧:១៤ យ លប ៣០:៦ រ ពច ១៨:១ **១:៣៥** ល ពច ៨:១៣ វ យស ១៩:៤២ ស ១ពវ ៤:៩ **១:៣៦** ហ យស ១៥:៣ ឡ ២ពវ ១៤:៧ អស ១៦:១ ៤២:១១ អ ទដ ១០៦:៣៤ **២:១** ក លប ១៦:៧ ខ ចទ ១១:៣០

បុរាណមួយដែលទទួលរងនូវការបំផ្លាញ ក្នុងអំឡុងពេលសតវត្សរ៍ទី១៣ មុន គ.ស ។

**១:២៣** *គេចាត់មនុស្សឱ្យទៅសង្កេតមើល* មើលការពន្យល់ ជន ១៣:២ ។

**១:២៤** *នោះយើងនឹងអាណិតមេត្តាដល់អ្នក* មើល លប ៤៧:២៩ ។

**១:២៥** *តែគេលែងអ្នកនោះ* សូមប្រៀបធៀបនឹងការប្រព្រឹត្តល្អរបស់នាងរ៉ាហាប (យស ៦:២៥) ។

**១:២៦** *ស្រុកសាសន៍ហេត* គឺជាឈ្មោះរបស់អារ៉ាម (ស្រុកស៊ីរី) តាំងពីសម័យកាលដែលមានចម្បាំងដណ្តើមយកទឹកដី (មើលការពន្យល់ លប ១០:១៥) ។

**១:២៧-២៩** សូមមើល យស ១៧:១៦-១៨ ។

**១:២៨** *ចាប់ពួកសាសន៍កាណានឱ្យធ្វើការបំរើគេ* មើលការពន្យល់ យស ១៦:១០ ។

**១:៣៣** *ក្រុងបេត-សេមែស* ទីកន្លែងពិតនោះមិនបានដឹងច្បាស់ឡើយ ។ ឈ្មោះនៃទីក្រុងនេះមានន័យថា "តំណាក់ព្រះអាទិត្យ (ជារូបព្រះ)" ។ នៅទីនោះវាជា បេត-សេមែសនៅក្នុងស្រុកយូដា (មើលការពន្យល់ ខ.៣៥) ។ *ក្រុងបេត-អាណាត* មានន័យថា "តំណាក់របស់អាណាត (ព្រះស្រី) (សូមមើលការពន្យល់ ៣:៣១) ។

**១:៣៤** *ពួកសាសន៍អាម៉ូរី* មើលការពន្យល់ លប ១០:៦ ។ *ពួកកូនចៅដាន់ . . . បង្ខំឱ្យគេទៅនៅស្រុកភ្នំ* ពួកយូដាក៏បានបង្ខំពួកសាសន៍អាម៉ូរីពីមុនមកដែរ (យស ១០:៥-១១) ប៉ុន្តែ ពួកគេក៏នៅមានកម្លាំងគ្រប់គ្រាន់ ក្នុងការទប់ទល់ជាមួយពួកកូនចៅដាន់ដែរ ។ ដោយសារហេតុនេះ បានធ្វើឱ្យពួកគេបានតាំងលំនៅនៅភាគខាងជើង ក្នុងរយៈពេលមួយដ៏ខ្លី (មើលជំពូក ១៨) ។

**១:៣៥** *ភ្នំហេរេស* មានន័យថា "តំណាក់នៃព្រះអាទិត្យ (រូបព្រះ)" ហើយប្រហែលជា បេត-សេមែលនៅក្នុងស្រុកយូដា ដែលគេស្គាល់ថាមានឈ្មោះមួយទៀតគឺ អ៊ារ-សេមែស ដែលមានន័យថា "ទីក្រុងនៃព្រះ (រូបព្រះ)" (មើល យស ១៩:៤១) ។

**១:៣៦** *ព្រំស្រុករបស់សាសន៍អាម៉ូរី* គឺជាព្រំប្រទល់ភាគខាងត្បូងរបស់ពួកគេ (មើល យស ១៥:២-៣) ។

**២:១-៥** ដោយព្រោះតែពួកកូនចៅអ៊ីស្រាអែល គេមិនបានបណ្តេញពួកកាណាន និងអ្នកឯទៀតចេញពីស្រុក ដូចអ្វីដែលព្រះយេហូវ៉ាទ្រង់បានបង្គាប់មក (មើល ១:២៧-៣៦) នោះព្រះអង្គទ្រង់នឹងដកព្រះហស្តទ្រង់ចេញពីពួកកូន

គ្នាឡើងចេញពីស្រុកអេស៊ីព្ទមក[ឃ] ហើយបាននាំចូលមកក្នុង
ស្រុក ដែលអញបានស្បថនឹងឱ្យដល់ពួកព្ធយុកោឯង[ង] អញ
ក៏បានសន្យាថា អញនឹងមិនក្បត់សេចក្ដីសញ្ញារបស់អញ
ចំពោះឯងរាល់គ្នាទេ[ច] ២ឯងរាល់គ្នា មិនត្រូវឱ្យតាំង
សេចក្ដីសញ្ញានឹងពួកអ្នកស្រុកនេះឡើយ[ឆ] គឺត្រូវរំលំអស់
ទាំងអាសនារបស់គេចេញ[ជ] តែឯងរាល់គ្នាមិនបានស្ដាប់
តាមបង្គាប់[ឈ]អញសោះ ហេតុអ្វីបានជាប្រព្រឹត្តដូច្នេះ ៣គឺ
ហេតុនោះបានជាអញថា អញមិនបណ្ដេញគេពីមុខឯង
ចេញទេ[ញ] គេនឹងបានដូចជាបន្លា[ដ]ចាក់នៅចំហៀងឯងវិញ
ហើយព្រះទាំងប៉ុន្មានរបស់គេ និងបានជាអន្ទាក់[ឋ]ដល់ឯង
៤កាលទេវតានៃព្រះយេហូវ៉ា បានប្រាប់សេចក្ដីទាំងប៉ុន្មាន
នេះ ដល់អស់ទាំងពួកកូនចៅអ៊ីស្រាអែលស្រេចហើយ នោះ
គេក៏ឡើងសំឡេងយំ[ឌ] ៥បានជាគេហៅកន្លែងនោះថា
បូគីម[ឍ] រួចគេនាំគ្នាថ្វាយយញ្ញបូជាដល់ព្រះយេហូវ៉ា នៅទី
នោះ ។

## ការមិនស្ដាប់បង្គាប់ និងការបរាជ័យ

*២:៦-៩ – យស ២៤:២៩-៣១*

៦រីឯយ៉ូស្វេ កាលលោកបានឱ្យពួកកូនចៅអ៊ីស្រាអែល
ចេញទៅ នោះគេក៏ទៅទទួលយកស្រុកជាមរដករបស់គេ
រៀងខ្លួន ៧ពួកបណ្ដាជនក៏គោរពប្រតិបត្តិដល់ព្រះយេហូវ៉ា
នៅគ្រប់១ជីវិតរបស់យ៉ូស្វេ និងពួកចាស់ទុំដែលរស់នៅ
ក្រោយលោកដែរ ជាពួកអ្នកដែលបានឃើញគ្រប់ទាំងការ
ដ៏ធំ ដែលព្រះយេហូវ៉ាបានសំរេចឱ្យពួកអ៊ីស្រាអែល[ណ]
៨យ៉ូស្វេ កូននុន[ត] ជាអ្នកបំរើនៃព្រះយេហូវ៉ា លោកក៏ស្លាប់
ទៅ ក្នុងជិនទាន់អាយុបាន១១០ឆ្នាំ ៩រួចគេបញ្ចុះសពលោក
ត្រង់ព្រំដី ជាមរដករបស់លោកនៅធីម្នាត-ហេរេស[ថ] ក្នុង
ស្រុកភ្នំអេប្រាអិម នាខាងជើងភ្នំកាអាសទៅ ១០អស់ទាំង
មនុស្សនៅដំណនោះ ក៏បានមូលទៅជួបជុំនឹងពួកព្ធយុកោ
គេគ្រប់គ្នាដែរ ហើយកើតមានមនុស្ស១ដំណទៀត ក្រោយ
មកជាមនុស្សដែលមិនបានស្គាល់ព្រះយេហូវ៉ា ឬការដែល
ទ្រង់បានសំរេចដល់ពួកអ៊ីស្រាអែលទេ[ទ] ។
១១នោះពួកកូនចៅអ៊ីស្រាអែល ក៏ធ្វើការដ៏លាមកអាក្រក់
[ធ]នៅព្រះនេត្រព្រះយេហូវ៉ា[ន]វិញ គឺគេគោរពប្រតិបត្តិដល់
អស់ទាំងរូបនៃព្រះបាល[ប] ១២គេបានបោះបង់ចោលព្រះ

**២:១** គ ខ.៥ ឃ នក ២០:២ ពច ៦:៨ ង លប ១៧:៨ ច លប ២៦:៤២-៤៤ ចទ ៧:៩
**២:២** ឆ នក ២៣:៣២ ៣៤:១២ ចទ ៧:២ ជ នក ២៣:២៤ ៣៤:១៣ ចទ ៧:៥ ២រប ១៤:៣ ឈ យរ ៧:២៨
**២:៣** ញ យស ២៣:១៣ ដ ជន ៣៣:៥៥ ឋ នក ១០:៧
**២:៤** ឌ លប ២៧:៣៨ ជន ២៥:៦ ២ពវ ១៧:១៣
**២:៥** ឍ ខ.១
**២:៧** ណ ខ.១៧
**២:៨** ត យស ១:១
**២:៩** ថ យស ១៩:៥០ **២:១០** ទ នក ៥:២ កទ ៤:៨ **២:១១** ធ ១ពវ ១៥:២៦ ន ពច ៣:១២ ៤:១ ៦:១ ១០:៦ ប ពច ៣:៧ ៨:៣៣ ១ពវ ១៦:៣១ ២២:៥៣ ២ពវ ១០:១៨ ១៧:១៦

ចៅអ៊ីស្រាអែល ដោយព្រះអង្គមិនព្រមជួយគេទៀតឡើយ ។ នៅក្នុងបរិបទនេះ និងលើកយកតែពាក់កណ្ដាលផ្នែកទី១នៃសេចក្ដីផ្ដើមមកនិយាយតែប៉ុណ្ណោះ ។ ទោះបីជាមិនបានបញ្ជាក់ប្រាប់យើងច្បាស់ពីពេលវេលា ដែលព្រះយេហូវ៉ាទ្រង់បានស្ដីបន្ទោសដល់ពួកអ៊ីស្រាអែលក៏ដោយ ក៏យើងអាចដឹងខ្លះៗថា ប្រហែលជាកើតឡើងនៅគ្រាមួយ មុនពេលមានពួកចៅហ្វាយកើតឡើង ហើយប្រហែលជាមានទំនាក់ទំនងគ្នាជាមួយព្រឹត្តិការណ៍កើតឡើងក្នុងបទគម្ពីរយ៉ូស្វេ ជំពូក៩ (ឬ យស ១៨:១-៣) ។

**២:១** *ទេវតានៃព្រះយេហូវ៉ា* សូមមើលការពន្យល់ក្នុង លប ១៦:៧ ។ តួនាទីរបស់ទេវតានៃព្រះយេហូវ៉ានៅពេលនេះ គឺមានសភាពដូចគ្នានឹងហោរាមួយដែលគេមិនស្គាល់ឈ្មោះនៅក្នុងជំពូក ៦:៨-១០ ហើយក៏ដូចគ្នានឹងព្រះបន្ទូលរបស់ព្រះយេហូវ៉ានៅក្នុង ១០:១១-១៤ ដែលនិយាយពីការបដិសេធចំពោះរាស្ត្រទ្រង់ ។ *គីលកាល* គឺជាទីកន្លែងដំបូងដែលពួកអ៊ីស្រាអែលបានតាំងលំនៅ ក្រោមការដឹកនាំនៃលោកយ៉ូស្វេ (មើល យស ៤:១៩-៥:១២) ។ *ចេញពីស្រុកអេស៊ីព្ទ* នៅក្នុងផ្ទៃរឿងព្រះគម្ពីរនិក្ខមនំ បានបង្ហាញពីតម្រុយខ្លះៗនៃការប្រោសលោះរបស់ព្រះយេហូវ៉ា និងក្ដីស្រឡាញ់របស់ទ្រង់ចំពោះរាស្ត្រទ្រង់ (មើល នក ២០:២) ។ *ដែលអញបានស្បថនឹងឱ្យ* សូមមើល លប ១៥:១៨ និងការពន្យល់ ហព ៦:១៣ ។

**២:២** *មិនត្រូវឱ្យតាំងសេចក្ដីសញ្ញា* បើពួកគេតាំងសញ្ញាមានន័យថា ពួកកូនចៅអ៊ីស្រាអែល បានក្បត់នឹងសេចក្ដីសញ្ញាដែលគេបានតាំងជាមួយព្រះ (មើល នក ២៣:៣២) ។

**២:៦-៣:៦** នៅក្នុងបរិបទនេះ គឺជាផ្នែកទី២នៃសេចក្ដីផ្ដើម ដែលនៅក្នុងបរិបទនេះ នៅបន្តលើកយករឿងនៅក្នុង យស ២៤:២៨-៣១ ។ វាជាគ្រឹះនៃតំណវង្សនៅក្នុងចៅហ្វាយ ៣:៧-១៦:៣១ ដែលបានបង្ហាញថា តំណាក់កាលដំបូងរបស់ពួកអ៊ីស្រាអែលនៅក្នុងទឹកដីសន្យា គឺគេបានបោះបង់ចោលព្រះ ត្រូវគេសង្កត់សង្កិនម្ដងហើយម្ដងទៀត ។ អ្នកនិពន្ធតំណាលពីអ៊ីស្រាអែលថា ពួកគេអាចនឹងទទួលយកការសម្រាក ប្រកបដោយអំណររបស់ព្រះនៅក្នុងទឹកដីសន្យាតែ១គត់ នៅពេលណាគេព្រមស្ដាប់តាម និងរក្សាសេចក្ដីសញ្ញាជាមួយព្រះ ។

**២:៦** *ទទួលយកស្រុកជាមរដក* សូមមើលការពន្យល់ ១:១ ។

**២:៨** *អ្នកបំរើនៃព្រះយេហូវ៉ា* លោកយ៉ូស្វេប្រៀបដូចជាអ្នកតំណាងផ្លូវការណ៍របស់ព្រះយេហូវ៉ា (មើលការពន្យល់ នក ១៤:៣១ ទដ ១៨ អស ៤១:៨-៩ ៤២:១) ។ *១១០ឆ្នាំ* ចំពោះអត្ថបទនៃចំនួននេះ សូមមើលការពន្យល់ លប ៥០:២៦ ។

**២:១០-១៥** ដោយព្រោះតែពួកកូនចៅអ៊ីស្រាអែលបានបោះបង់ចោលព្រះយេហូវ៉ា នោះព្រះអង្គទ្រង់ក៏មិនព្រមជួយគេ ហើយទ្រង់ក៏បោះបង់គេចោលដែរ ។ ព្រះយេហូវ៉ាទ្រង់បាន "លក់" រាស្ត្រដែលទ្រង់បាន "ទិញ" គេមក (សូមមើល នក ១៥:១៦) និងប្រោសលោះ (១៥:១៣ ប្រៀបធៀបជាមួយ ទដ ៧៤:២) ។

**២:១០** *ក៏បានមូលទៅជួបជុំនឹងពួកព្ធយុកោគេ* សូមមើល លប ១៥:១៥ និងការពន្យល់ ២៥:៨ ។ *ជាមនុស្សដែលមិនបានស្គាល់ព្រះយេហូវ៉ា . . . ពួកអ៊ីស្រាអែលទេ* ពួកគេគ្មានបទពិសោធជាមួយព្រះផ្ទាល់ ហើយមិនបានស្គាល់ពីការងាររបស់ព្រះដូចជាពួកព្ធយុកោរបស់គេនោះឡើយ (សូមមើល នក ១:៨) ។

**២:១១** *ធ្វើការដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាវិញ* យើងនឹងឃើញឃ្លាដដែលនេះនៅក្នុង ៣:៧,១២ ៤:១ ៦:១ ១០:៦ ។ *ព្រះបាល* ពួកកាណានគេធ្វើព្រះបាលទាំងនោះមានទម្រង់ផ្សេងៗគ្នា (ខ.១៣) ។

យេហូវ៉ា ជាព្រះនៃពួកឰយុកោគេ ដែលទ្រង់បាននាំគេ
ចេញពីស្រុកអេស៊ីព្ទមក បែរទៅតាមព្រះដទៃ[ផ] ក្នុងពួកព្រះ
របស់សាសន៍ទាំងប៉ុន្មាន ដែលនៅជុំវិញគេ[ព] ព្រមទាំង
ក្រាបថ្វាយបង្គំដល់ព្រះទាំងនោះផង ហើយបានបណ្តាល[ភ]
ឱ្យព្រះយេហូវ៉ាមានសេចក្តីខ្ញាល់[ម] ១៣គេបានបោះបង់
ចោល[យ]ព្រះយេហូវ៉ា ទៅគោរពប្រតិបត្តិតាមព្រះបាល
និងព្រះអាសថារ៉ូតវិញ[រ] ១៤ដូច្នេះព្រះយេហូវ៉ាក៏កើតមាន
សេចក្តីខ្ញាល់[ល] និងពួកអ៊ីស្រាអែល ហើយទ្រង់ប្រគល់[វ]គេ
ទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលបំផ្លាញ[ស]គេ ក៏លក់[ហ]ទៅ
ក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ ដែលនៅជុំវិញដែរ ដល់
ម្ល៉េះបានជាគេពុំអាចនឹងទប់ទល់ នៅមុខពួកខ្មាំងសត្រូវ
បានឡើយ[ឡ] ១៥នៅកន្លែងណាដែលគេចេញទៅ នោះព្រះ
ហស្តនៃព្រះយេហូវ៉ាចេះតែទាស់នឹងគេជាដរាប[អ] ឱ្យគេ
បានសេចក្តីអាក្រក់ ដូចជាព្រះយេហូវ៉ាបានមានបន្ទូល
ហើយក៏ដូចជាព្រះយេហូវ៉ាបានស្បថនឹងគេដែរ ដូច្នេះគេ
មានសេចក្តីវេទនាយ៉ាងខ្លាំង[ក]។

១៦ព្រះយេហូវ៉ាទ្រង់តាំងឱ្យមានពួកចៅហ្វាយ[ខ] ដែល
បានជួយសង្គ្រោះ[គ]គេ ឱ្យរួចពីកណ្តាប់ដៃនៃពួកអ្នកដែល
បំផ្លាញគេ ១៧ប៉ុន្តែគេមិនបានស្តាប់តាមពួកចៅហ្វាយរបស់
គេទេ គឺគេបានផិត[ឃ]ទៅតាមព្រះដទៃ[ង] ព្រមទាំងក្រាបថ្វាយ
បង្គំផង[ច] គេរហ័សណាស់នឹងបែរ[ឆ]ចេញពីផ្លូវរបស់ពួក
ឰយុកោគេ ដែលបានស្តាប់តាមបញ្ញត្តិនៃព្រះយេហូវ៉ាទាំង
ប៉ុន្មាន ឯគេមិនបានប្រព្រឹត្តដូច្នោះទេ[ជ] ១៨កាលព្រះយេហូវ៉ា
បានតាំងឱ្យមានចៅហ្វាយដល់គេ នោះទ្រង់ក៏គង់ជាមួយ
នឹងចៅហ្វាយនោះ ហើយបានជួយសង្គ្រោះ[ឈ]គេឱ្យរួចពី
កណ្តាប់ដៃនៃខ្មាំងសត្រូវ នៅគ្រប់១ជីវិតរបស់ចៅហ្វាយ
នោះ ពីព្រោះព្រះយេហូវ៉ាទ្រង់អាណិតអាសូរ[ញ]ដល់ដំងូរ[ដ]
គេជាខ្លាំង ដោយព្រោះពួកអ្នកដែលសង្កត់សង្កិន ហើយ
ធ្វើទុក្ខ[ឋ]ដល់គេ ១៩តែលុះកាលចៅហ្វាយ១ស្លាប់ទៅ នោះ
គេក៏ត្រឡប់ទៅជាប្រព្រឹត្តលាមកអាក្រក់[ឌ]ជាងពួកឰយុកោ
គេទៅទៀត[ឍ] ដោយដើរតាមព្រះដទៃ ដើម្បីនឹងគោរព
ប្រតិបត្តិ ហើយក្រាបថ្វាយបង្គំដល់ព្រះទាំងនោះ[ណ] គេមិន
បានលះចោលអំពើ ឬចរិត ដែលរឹងចចេស[ត]របស់គេ
ចេញឡើយ ២០នោះសេចក្តីខ្ញាល់[ថ]នៃព្រះយេហូវ៉ាបានកាត់
ឡើងទាស់នឹងពួកអ៊ីស្រាអែល ហើយទ្រង់មានបន្ទូលថា
ដោយព្រោះសាសន៍នេះ បានរំលងសេចក្តីសញ្ញា[ទ] ដែល
អញបានតាំងនឹងពួកឰយុកោគេ ហើយមិនបានស្តាប់តាម

**២:១២** ផ ចទ ៣២:១២ ទដ ១០៦:៣៦ **២:១២** ព ចទ ៣១:១៦ ពច ១០:៦ ភ ជន ១១:៣៣ ម ចទ ៤:២៥ ទដ ៧៨:៥៨ ១០៦:៤០ **២:១៣** យ ១សយ ៧:៣ ១ពវ ១១:៥,៣៣ ២ពវ ២៣:១៣ រ ពច ៣:៧ ៥:៨ ៦:២៥ ៨:៣៣ ១០:៦ ១សយ ៣១:១០ នហ ៩:២៦ ទដ ៧៨:៥៦ យរ ១១:១០ **២:១៤** ល ចទ ៣១:១៧ វ នហ ៩:២៧ ទដ ១០៦:៤១ ស ទដ ៤៤:១០ ៨៩:៤១ អគ ៣៤:៨ ហ ចទ ៣២:៣០ ពច ៣:៨ ឡ ចទ ២៨:២៥ **២:១៥** អ នវ ១:១៣ យប ១៩:២១ ទដ ៣២:៤ ក លប ៣៥:៣ ២សយ ២២:៧ ២រប ១៥:៤ យប ៥:៥ ២០:២២ ទដ ៤:១ ១៨:៦ **២:១៦** ខ នវ ១:១ ១សយ ៤:១៨ ៧:៦,១៥ ២សយ ៧:១១ ១រប ១៧:១០ កច ១៣:២០ គ ១សយ ១១:៣ ទដ ១០៦:៤៣ **២:១៧** ឃ នក ៣៤:១៥ ជន ១៥:៣៩ ង ទដ ៤:២ ច នហ ៩:២៨ ទដ ១០៦:៣៦ ឆ ចទ ៩:១២ ជ ខ.៧ **២:១៨** ឈ ១សយ ៧:៣ ២ពវ ១៣:៥ អស ១៩:២០ ៤៣:៣, ១១ ៤៥:១៥,២១ ៤៩:២៦ ៦០:១៦ ៦៣:៨ ញ ចទ ៣២:៣៦ ដ នក ២:២៣ ឋ ជន ១០:៩ **២:១៩** ឌ លប ៦:១១ ចទ ៤:១៦ ឍ ចទ ៣២:១៧ នហ ៩:២ ទដ ៧៨:៥៧ យរ ៤៤:៣,៩ ណ ពច ៤:១ ៨:៣៣ ត នក ៣២:៩ **២:២០** ថ ចទ ៣១:១៧ យស ២៣:១៦ ទ យស ៧:១១ ២ពវ ១៧:១៥

**២:១៣** *ព្រះបាល* សម្រាប់ពួកកាណាន មានន័យថា "ព្រះអម្ចាស់" ។ ពួកកាណាន និងពួកភេនីស គេនាំគ្នាថ្វាយបង្គំរូបព្រះបាល ដែលត្រូវបានគេស្គាល់ថា ព្រះនោះមានឈ្មោះផ្សេងៗគ្នា ដូចជាអ្នកខ្លះហៅថា កូនរបស់ដ្រាកន (Son of Dagon) ហើយខ្លះទៀតហៅថា ជាកូនរបស់អែល (Son of El) ។ នៅក្នុងស្រុកអើរ៉ាម(ស្រុកស៊ីរី)គេហៅថាហាដាឌ់ ហើយនៅបាប៊ីឡូនគេហៅថា អាដាឌ់ ។ គេជឿថាព្រះបាលនឹងផ្តល់ឱ្យគេនូវភាពសម្បូររុងរឿង ផ្តល់ជីវិត ផ្តល់ឱ្យមានភ្លៀង ហើយគេយករូបគោធ្វើជានិមិត្តរូបរបស់ព្រះបាល ដោយគេគិតថា ជារូបភាពនៃកម្លាំងនិងភាពរុងរឿង (មើល ១ពវ ១២:២៨) ។ គេជឿថា ព្យុះពពក គឺជារទេះដែករបស់ព្រះបាលនោះ ផ្គរលាន់គឺជាសម្លេងរបស់ទ្រង់ ហើយរន្ទះគឺជាលំពែងនិងព្រួញរបស់ព្រះនោះ ។ នៅពេលគេថ្វាយបង្គំព្រះបាល គេតែងតែជាប់ទាក់ទងផ្លូវភេទជាមួយស្ត្រីពេស្យា ហើយពេលខ្លះទៀត គេក៏យកកូនក្មេងមកធ្វើជាយញ្ញបូជាដែរ(មើល យរ ១៩:៥) ។ រឿងរ៉ាវមួយទៀតដែលនិយាយពីលោកអេលីយ៉ា និងអេលីសេ (១ពវ ១៧–២ពវ ១៣) ក៏ដូចគ្នានឹងព្រះគម្ពីរនៅសញ្ញាចាស់ជាច្រើនទៀតដែរ គឺសុទ្ធតែបាននិយាយពីការប្រឆាំងតវ៉ាជាមួយពួកអ្នកដែលគោរពព្រះបាលទាំងនោះ (ទដ ២៩:៣–៩ ៦៨:១–៤, ៣២–៣៤ ៩៣:១–៥ យរ ១០:១២–១៦ ១៤:២២ ហស ២:៨, ១៦–១៧ អម ៥:៨) ។ *ព្រះអាសថារ៉ូត* ជាព្រះស្រី ដូចគ្នានឹងអាសថារ៉ូត (ប្រពន្ធរបស់ព្រះបាល) និងរូបព្រះ(ប្រពន្ធរបស់ព្រះអែល ដែលជាចៅហ្វាយរបស់ព្រះកាណាន) ។ ព្រះអាសថារ៉ូត មានទំនាក់ទំនងជាមួយតារានាពេលល្ងាច ហើយជាព្រះ ដែលមានរូបសម្រស់ល្អឆើត និងតំណាងឱ្យព្រះនៃសង្គ្រាម ។

**២:១៤** *ប្រគល់គេទៅក្នុងកណ្តាប់ដៃ* យើងនឹងឃើញឃ្លានេះម្តងទៀតនៅក្នុង ៦:១ ១៣:១ ។ *លក់ទៅក្នុងកណ្តាប់ដៃ* ឃ្លានេះក៏នឹងលើកមកនិយាយម្តងទៀតនៅក្នុង ៣:៨ ៤:២ ១០:៧ ។

**២:១៦–១៩** ព្រះយេហូវ៉ាទ្រង់តែងតែផ្តល់ព្រះគុណរបស់ទ្រង់ មកលើរាស្ត្រទ្រង់នៅពេលណាដែលគេជួបទុក្ខលំបាក និងការឈឺចាប់ ហើយព្រះអង្គទ្រង់បានចាត់បញ្ជូនអ្នកសង្គ្រោះមក ដើម្បីជួយសង្គ្រោះគេ ប៉ុន្តែជានិច្ចកាលពួកអ៊ីស្រាអែលគេបានភ្លេចព្រះ ។

**២:១៦** *ពួកចៅហ្វាយ* សូមមើលក្នុងសេចក្តីផ្តើម ។ នៅទីនោះបាននិយាយអំពីចៅហ្វាយធំៗ៦ (អូធ្នាល អេហ៊ុឌ ដេបូរ៉ា គេឌាន យ៉ែបថា សាំសុន) និងមានចៅហ្វាយតូចៗ៦នាក់ទៀត(សាំកើរ ថូឡា យ៉ាអ៊ារ អិបសាន អេឡូន និងអាបដូន) ។

**២:១៧** *គឺគេបានផិត* សូមមើល នក ២:២៤ ៣:៩ ៦:៥ និងការពន្យល់ ។

**២:១៨** *ដំងូរ . . . សង្កត់សង្កិន* គឺជាភាសាមួយសម្រាប់ជនជាតិអេស៊ីព្ទប្រើសម្រាប់ជាងារ "ខ្ញុំគេ"(មើល នក ២:២៤ ៣:៩ ៦:៥) ។

**២:២០–២៣** ព្រះយេហូវ៉ា ទ្រង់បានល្បងភាពស្មោះត្រង់នៃពួកអ៊ីស្រាអែល

ពាក្យរបស់អញ ២១បានជាពីនេះទៅមុខ អញលែងបណ្តេញ
សាសន៍ណាមួយ[ធ] ដែលយ៉ូស្វេបានទុកពីកាលស្លាប់ទៅ
នោះ ចេញពីមុខគេឡើយ ២២ដើម្បីឱ្យអញបានល្បងល
អ៊ីស្រាអែលមើល[ន] បើគេនឹងខំប្រឹងដើរតាមផ្លូវរបស់ព្រះ
យេហូវ៉ា ដូចជាពួកឰយុកោគេបានកាន់តាមឬទេ ២៣ដូច្នេះ
ព្រះយេហូវ៉ាទ្រង់បានទុកសាសន៍ទាំងនោះវិញ ឥតបណ្តេញ
ទៅយ៉ាងរហ័សទេ ក៏មិនបានប្រគល់មកក្នុងកណ្តាប់ដៃ
យ៉ូស្វេដែរ[ប]។

**៣** ១រីឯសាសន៍ទាំងប៉ុន្មាន ដែលព្រះយេហូវ៉ាបានទុកនៅ
ដើម្បីនឹងល្បងល[ក]ពួកអ៊ីស្រាអែលដោយសារគេ គឺនឹង
ល្បងលអស់អ្នក ដែលមិនបានស្គាល់អស់ទាំងចំបាំង នៅ
ស្រុកកាណាន ២គឺប្រយោជន៍តែឱ្យអស់ទាំងដំណរ នៃពួក
កូនចៅអ៊ីស្រាអែល បានដឹងប៉ុណ្ណោះ ដើម្បីនឹងបង្រៀនឱ្យ
គេចេះច្បាំង គឺពួកអ្នកដែលមិនបានធ្លាប់ស្គាល់ចំបាំង កាល
ពីមុនមក ៣ឯសាសន៍ទាំងនោះ មានមេនៃសាសន៍ភីលីស្ទីន[ខ]
ទាំង៥[គ] និងសាសន៍កាណានទាំងអស់ សាសន៍ស៊ីដូន និង
សាសន៍ហេវី[ឃ] ជាសាសន៍នៅស្រុកភ្នំល្បាណូន ចាប់តាំងពី
ភ្នំបាល-ហ៊ើម៉ូន[ង] ទៅដល់ទ្វារចូលស្រុកហាម៉ាត[ច] ៤គឺ
សាសន៍ទាំងនោះហើយ ដែលបានទុកសំរាប់នឹងល្បងល[ឆ]
អ៊ីស្រាអែល ឱ្យដឹងជាគេនឹងស្តាប់តាមអស់ទាំងបញ្ញត្តិនៃ
ព្រះយេហូវ៉ា ដែលទ្រង់បានបង្គាប់មកពួកឰយុកោគេ
ដោយសារម៉ូសេឬទេ ៥ដូច្នេះពួកកូនចៅអ៊ីស្រាអែលក៏នៅ[ជ]
ជាមួយនឹងសាសន៍កាណាន សាសន៍ហេត សាសន៍អាម៉ូរី
សាសន៍ពេរិស៊ីត[ឈ] សាសន៍ហេវី និងសាសន៍យេប៊ូស[ញ]
៦ហើយបានយកកូនគេធ្វើជាប្រពន្ធ ព្រមទាំងឱ្យកូនស្រីរបស់
ខ្លួន[ដ] ទៅកូនប្រុសរបស់គេ ហើយគោរពប្រតិបត្តិដល់អស់
ទាំងព្រះរបស់គេដែរ[ឋ,ឌ] ។

## លោកអូធ្នាល

៧ពួកកូនចៅអ៊ីស្រាអែលក៏បានប្រព្រឹត្តសេចក្តីដែល
លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា គេភ្លេចព្រះ
យេហូវ៉ា[ឍ]ជាព្រះនៃខ្លួន ទៅជាគោរពប្រតិបត្តិដល់អស់ទាំង
ព្រះបាល និងព្រះអាសថារ៉ូតវិញ[ណ] ៨ហេតុនោះបានជាព្រះ
យេហូវ៉ាកើតមានសេចក្តីខ្ញាល់នឹងសាសន៍អ៊ីស្រាអែល
ទ្រង់លក់[ត]គេទៅក្នុងកណ្តាប់ដៃនៃគូសាន-រីសាថែម[ថ] ជា
ស្តេចស្រុកអើរ៉ាម-ន៉ាហារេម[ទ] ពួកកូនចៅអ៊ីស្រាអែល ក៏

**២:២១** ធ យស ២៣:៥
**២:២២** ន លប ២២:១ នក ១៥:២៥
**២:២៣** ប ពច ១:១
**៣:១** ក នក ១៥:២៥
**៣:៣** ខ លប ១០:១៤ គ នក ១៥:២៥ ឃ លប ១០:១៧ នក ៣:៨ ង ចទ ៣:៨ ច ជន ១៣:២១
**៣:៤** ឆ នក១៥:២៥
**៣:៥** ជ ទដ ១០៦:៣៥ ឈ យស ៣:១០ ញ យស ១១:៣ អរ ៩:១
**៣:៦** ដ អរ ១០:១៨ នហ ១៣:២៣ មឡ ២:១១ ឋ នក ៣៤:១៦ ចទ ៧:៣-៤ ឌ ចទ ៧:១៦
**៣:៧** ឍ ចទ ៤:៩ ៣២:១៨ ពច ៨:៣៤ ទដ ៧៨:១១,៤២ ១០៦:៧ យរ ២៣:២៧ ណ នក ៣៤:១៣ ពច ២:១១,១៣ ១ពវ ១៦:៣៣ ២រប ៣៤:៧ អស ១៧:៨ **៣:៨** ត ពច ២:១៤ ទដ ៤៤:១២ អស ៥០:១ ៥២:៣ ថ ខ.១០ ទ លប ២៤:១០

ដោយព្រះអង្គទ្រង់ មិនបានបំផ្លាញពួកគេឡើយ ។

**៣:១-៦** នៅក្នុងផ្នែកនេះ អ្នកនិពន្ធបានលើកឡើងអំពីបញ្ជីតំណវង្សរបស់សាសន៍អ៊ីស្រាអែល ដែលព្រះយេហូវ៉ាទ្រង់បានតាំងលំនៅឱ្យគេ ដែលស្ថិតនៅភាគខាងជើង និងភាគខាងត្បូង ដែលទឹកដីនេះនឹងត្រូវគ្រប់គ្រងដោយពួកអ៊ីស្រាអែល បន្ទាប់ពីលោកយ៉ូស្វេបានស្លាប់ទៅ (ខ.១-៤) ។ នៅក្នុងអំឡុងពេលដែលអ៊ីស្រាអែលកាន់កាប់ទឹកដីកាណាននេះ ក៏មានជនជាតិដើមបានរស់នៅជាមួយពួកអ៊ីស្រាអែលដែរ (ខ.៥ ១:២៧-៣៦) ដោយសារកត្តានេះហើយ បានធ្វើឱ្យពួកអ៊ីស្រាអែលព្រមទទួលគោរពលើព្រះដទៃ និងធ្វើតាមសាសនារបស់គេដែរ (ខ.៦) ។

**៣:២** *ដើម្បីនឹងបង្រៀនឱ្យគេចេះច្បាំង* ដូចជាសេចក្តីដែលព្រះយេហូវ៉ាបានធ្វើការតាំងសញ្ញាដែលថា ពួកអ៊ីស្រាអែលគឺជាកងទ័ពរបស់ព្រះអង្គដើម្បីនឹងច្បាំងលើពួកមហាអំណាចនៅលើលោកនេះ ដែលបន្តរស់នៅលើទឹកដីសន្យា ដែលព្រះទ្រង់សន្យាថា និងឱ្យដល់ពួកអ៊ីស្រាអែល ។ ដោយសារកត្តានេះហើយ អ៊ីស្រាអែលត្រូវតែក្លាយជាអ្នកពិសេសរបស់ព្រះយេហូវ៉ា ។

**៣:៣** *មេនៃសាសន៍ភីលីស្ទីនទាំង៥* សូមមើលការពន្យល់ យស ១៣:៣ ។ មេទាំងនោះត្រូវគ្រប់គ្រងស្រុក៥ ។ យូដាបានវាយឈ្នះស្រុក៣ (១:៣) ប៉ុន្តែគ្មានសមត្ថភាពដើម្បីគ្រប់គ្រងលើគេឡើយ ។ *សាសន៍ស៊ីដូន* នៅទីនេះប្រហែលជារាប់បញ្ចូលនឹងពួកអ្នកស្រុកភីនីស ។ *សាសន៍ហេវី* ពួកនេះគេរស់នៅភាគខាងជើងពីពួកកាណាន រហូតដល់ច្រកចូលស្រុកហាម៉ាត (យស ១១:៣ និងការពន្យល់) ។ *ភ្នំបាល-ហ៊ើម៉ូន* គឺមានឈ្មោះតែ១ជាមួយគ្នានឹងភ្នំហ៊ើម៉ូន (១រប ៥:២៣) ។

**៣:៦** *ហើយបានយកកូនគេ . . . ហើយគោរពប្រតិបត្តិដល់អស់ទាំងព្រះរបស់គេដែរ* សូមមើលការពន្យល់ យស ២៣:១២ ។ គ្រោះថ្នាក់របស់ពួកអ៊ីស្រាអែល ដែលរៀបការជាមួយសាសន៍ដទៃ បានបង្ហាញឱ្យយើងឃើញច្បាស់នៅក្នុងរាជ្យស្តេចសាឡូម៉ូន (១ពវ ១១:១-៨) ។

**៣:៧-១១** អ្នកនិពន្ធបានលើកឡើង អំពីភាពជាចៅហ្វាយ របស់តំណវង្សអូធ្នាល ដោយគាត់បានលើកយកមូលដ្ឋានគ្រឹះនៃលក្ខណៈអក្សរសាស្ត្រនៅក្នុងតំណវង្សរបស់ពួកចៅហ្វាយធំៗ មកពន្យល់យើង (ឧទាហរណ៍ការបោះបង់ព្រះចោលម្តងហើយម្តងទៀត ការផ្តួលរំលំអំណាច ការធានា) ។ មិនតែប៉ុណ្ណោះ គាត់បានលើកយកនូវផ្នែកដែលសំខាន់ៗទាំងអស់ ក្នុងផ្នែកនិមួយៗ មកពន្យល់ឱ្យយើងយល់ច្បាស់ពីបំណងចិត្ត (មើលសេចក្តីផ្តើម) ។

**៣:៧** *ប្រព្រឹត្តសេចក្តីដែលលាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា* អំពើនេះបានកើតឡើងម្តងហើយម្តងទៀត សម្រាប់ពួកកូនចៅអ៊ីស្រាអែល (សូមមើល ខ.១២ ៤:១ ៦:១ ១០:៦ ៣១:១) ហើយអ្នកនិពន្ធក៏ធ្លាប់យកឃ្លានេះមកពន្យល់នៅក្នុងសេចក្តីផ្តើមផងដែរ (មើលក្នុងសេចក្តីផ្តើម) ។ *ព្រះបាល* មើលការពន្យល់ ២:១៣ ។ *ព្រះអាសថារ៉ូត* សូមមើលការពន្យល់ ២:១៣ នក ៣៤:១៣ ។

**៣:៨** *គូសាន-រីសាថែម* ប្រហែលមានន័យថា "អំណាចទ្វេរគុណរបស់គូសាន" ឬប្រហែលជា នាមតំណាងឱ្យការបោកបញ្ឆោតរបស់ព្រះនាមស្តេចនោះផ្ទាល់ (មើលការពន្យល់ ១០:៦ ពួកអ៊ីស្រាអែលបានគោរពព្រះជាច្រើន) ។ *អើរ៉ាម-ន៉ាហារេម* សូមមើលការពន្យល់ក្នុង លប ២៤:១០ ។

នៅជាចំណុះស្ដេចគូសាន–រីសាថែមនោះអស់៨ឆ្នាំ ៩រួច
កាលពួកកូនចៅអ៊ីស្រាអែល បានអំពាវនាវ[ធ]ដល់ព្រះយ
ហូវ៉ា នោះទ្រង់ក៏តាំងឱ្យមានអ្នកជួយសង្គ្រោះម្នាក់[ន]ដល់គេ
ដែលបានជួយឱ្យរួច គឺជាអូធ្នាល[ប] ជាកូនកេណាស
ដែលជាប្អូនកាលែប ១០ព្រះវិញ្ញាណនៃព្រះយេហូវ៉ាក៏
សណ្ឋិតនៅលើលោក[ផ] ហើយលោកបានធ្វើជាចៅហ្វាយ
លើពួកសាសន៍អ៊ីស្រាអែល លោកក៏ចេញទៅច្បាំង ហើយ
ព្រះយេហូវ៉ាទ្រង់បានប្រគល់គូសាន–រីសាថែម[ព] ជាស្ដេច
ស្រុកអើរ៉ាម[ភ]–ន៉ាហារេម មកក្នុងកណ្ដាប់ដៃនៃលោក
នោះលោកមានកំឡាំងនឹងឈ្នះស្ដេចគូសាន–រីសាថែមទៅ
១១ដូច្នេះស្រុកក៏បានសុខសាន្ត[ម]ត្រាណ[យ]អស់៤០ឆ្នាំ រួចមក
អូធ្នាលជាកូនកេណាស[រ]បានស្លាប់ទៅ ។

## អេហ៊ុឌ

១២លុះក្រោយមក ពួកកូនចៅអ៊ីស្រាអែល ក៏ប្រព្រឹត្ត
សេចក្ដីដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាទៀត[ល]
រួចព្រះយេហូវ៉ាទ្រង់បានចំរើនកំឡាំងដល់អេគ្លូន ជាស្ដេច
ស្រុកម៉ូអាប់[វ]ឱ្យទាស់នឹងអ៊ីស្រាអែល ពីព្រោះគេបានប្រព្រឹត្ត
សេចក្ដីដ៏លាមកអាក្រក់នៅព្រះនេត្រទ្រង់ ១៣ស្ដេចនោះក៏
ប្រមូលពួកកូនចៅអាំម៉ូន[ស] និងពួកអាម៉ាលេក[ហ]មក រួចចូល
ទៅវាយពួកអ៊ីស្រាអែល ហើយចាប់យកបានទីក្រុងដើម
លម៉ើរបស់គេ[ឡ] ១៤ពួកកូនចៅអ៊ីស្រាអែលក៏នៅជាចំណុះ
អេគ្លូន ជាស្ដេចសាសន៍ម៉ូអាប់[អ]នោះអស់១៨ឆ្នាំ ១៥តែកាល
គេបានអំពាវនាវដល់ព្រះយេហូវ៉ា នោះទ្រង់តាំងឱ្យមាន
អ្នក១ ជាអ្នកជួយសង្គ្រោះ[ក]ដល់គេ គឺអេហ៊ុឌ[ខ] ជាកូនកេរ៉ា
ក្នុងពូជអំបូរបេនយ៉ាមីន ដែលជាអ្នកប្រើការខាងដៃឆ្វេង[គ]
ពួកកូនចៅអ៊ីស្រាអែលបានផ្ញើសួយអាករ[ឃ]ទៅថ្វាយអេគ្លូន
ជាស្ដេចសាសន៍ម៉ូអាប់នោះ ដោយសារលោក ១៦ឯអេហ៊ុឌ[ង]
លោកធ្វើកាំបិត១ មានមុខពីរ ប្រវែង១ហត្ថ សំរាប់ខ្លួន
ហើយសៀតភ្ជាប់នៅចង្កេះខាងស្តាំ ត្រង់ក្រោមអាវ
១៧លោកក៏ចូលទៅថ្វាយសួយអាករ[ច]ដល់អេគ្លូន ជាស្ដេច
សាសន៍ម៉ូអាប់ (រីឯអេគ្លូន នោះជាមនុស្សធាត់ខ្លាំង
ណាស់)[ឆ] ១៨កាលបានថ្វាយសួយអាករជាស្រេច នោះក៏នាំ

**៣:៩** ធ ខ.១៥ ពច ៦:៦,៧ ១០:១០ ១សយ ១២:១០ ទដ ១០៦:៤៤ ១០៧:១៣ ន ចទ ២៨:២៩ នហ ៩:២៧ ប យស ១៥:១៧ **៣:១០** ផ ជន ១១:២៥,២៩ ពច ៦:៣៤ ១១:២៩ ១៣:២៥ ១៤:៦,១៩ ១៥:១៤ ១សយ ១១:៦ ១៦:១៣ ១ពវ ១៨:៤៦ ១រប ១២:១៨ ២រប ២៤:២០ អស ១១:២ ព ខ.៨ ភ លប ១០:២២ **៣:១១** ម ខ.៣០ យស ១៤:១៥ ពច ៥:៣១ ៨:២៨ យ នក ១៦:៣៥ រ យស ១៥:១៧ **៣:១២** ល ពច ២:១១,១៤ វ ១សយ ១២:៩ **៣:១៣** ស លប ១៩:៣៨ ពច ១០:១១ ហ លប ១៤:៧ ឡ ពច ១:១៦ **៣:១៤** អ យរ ៤៨:១ **៣:១៥** ក ខ.៩ ខ ខ.១៦ ពច ៤:១ គ ពច ២០:១៦ ១រប ១២:២ ឃ ខ.១៧,១៨ ២សយ ៨:២,៦ ១ពវ ៤:២១ ២ពវ ១៧:៣ នអ ១០:១ ទដ ៦៨:២៩ ៧២:១០ ៨៩:២២ សស ២:៨ អស ៦០:៥ ហស ១០:៦ **៣:១៦** ង ខ.១៥ **៣:១៧** ច ខ.១៥ ឆ យប ១៥:២៧ ទដ ៧៣:៤

**៣:៩** *អំពាវនាវដល់ព្រះយេហូវ៉ា* នៅគ្រានៃការគ្រប់គ្រងរបស់ចៅហ្វាយនិមួយៗ ពួកអ៊ីស្រាអែលគេតែងតែអំពាវនាវដល់ព្រះយេហូវ៉ា នូវពេលដែលគេជួបការទុក្ខលំបាក និងភ័យអាសន្ន ។(មើលសេចក្ដីផ្ដើម) ។ *អូធ្នាល* មើល ១:១៣ ។

**៣:១០** *ព្រះវិញ្ញាណនៃព្រះយេហូវ៉ាក៏សណ្ឋិតនៅលើលោក* ព្រះវិញ្ញាណនៃព្រះយេហូវ៉ាទ្រង់សណ្ឋិតលើអូធ្នាល ប្រយោជន៍នឹងប្រទានអំណាចឱ្យគាត់ក្នុងការដឹកនាំរាស្ត្រទ្រង់ ដូចអ្វីដែលព្រះយេហូវ៉ាបានធ្វើចំពោះគេឌាន (មើល ៦:៣៤) លោកយែបថា (១១:២៩) លោកសាំសុន (១៤:៦,១៩) និងស្ដេចដាវីឌ (១សយ ១៦:១៣) សូមប្រៀបធៀប ជន ១១:២៥–២៩ ។

**៣:១១** *ស្រុកក៏បានសុខសាន្តត្រាណអស់៤០ឆ្នាំ* ការទទួលស្គាល់ពីភាពជាអ្នកដឹកនាំរបស់គាត់ (មិនមែនតែនៅក្នុងទីនេះទេ គឺមាននៅក្នុង ខ.៣០ ៥:៣១ ៨:២៨) ។ បន្ទាប់ពីលោកគីឌាន គឺនៅមានអ្នកដែល "គ្រប់គ្រងលើអ៊ីស្រាអែលឆ្នាំផ្សេងៗទៀត" (១២:៧ ១៥:២០ ១៦:៣១) សូមមើលសេចក្ដីផ្ដើម ។ *៤០ឆ្នាំ* គឺជាចំនួនឆ្នាំ នៃការតាំងសញ្ញារបស់ព្រះយេហូវ៉ា ចំពោះកូនចៅជំនាន់ក្រោយ (សូមមើលសេចក្ដីផ្ដើម : ប្រវត្តិដើម) ។

**៣:១២–៣០** នៅក្នុងផ្នែកនេះអ្នកនិពន្ធបានលើកយក ពីជ័យជម្នះរបស់អេហុឌលើអេគ្លូនជាស្ដេចស្រុកម៉ូអាប់ ។ អ្នកដែលជំនាញដៃឆ្វេង ដែលចេញពីអំបូរបេនយ៉ាមីន គឺជាវិរៈបុរស់ពិតមែន ។ គាត់បានប្រើកាំបិតមុខពីរដើម្បីរំលំស្ដេចម៉ូអាប់ ដែលបានគ្រប់គ្រងអ៊ីស្រាអែលនៅក្នុងស្រុកកាណានក្បែរក្រុងយេរេខូរ ។

**៣:១២** *ស្រុកម៉ូអាប់* សូមមើលការពន្យល់ក្នុង លប ១៩:៣៦–៣៨ ។

**៣:១៣** *ពួកកូនចៅអាំម៉ូន* សូមមើលការពន្យល់ លប ១៩:៣៣ ។ *ពួកអាម៉ាលេក* ពួកគេ គឺជាកូនចៅរបស់អេសាវ (លប ៣៦:១២,១៦) ដែលរស់នៅស្រុកត្បូង (ជន ១៣:២៩) មើលការពន្យល់ លប ១៤:៧ ។

**៣:១៤** *ពួកកូនចៅអ៊ីស្រាអែល* នៅទីនេះ គឺផ្ដោតទៅលើអំបូរបេនយ៉ាមីន និងអេប្រាអិម ។

**៣:១៥** *ជាអ្នកប្រើការខាងដៃឆ្វេង* ការប្រើដៃឆ្វេង គឺជារឿងមួយគួរឱ្យកត់សម្គាល់នៅក្នុងចំណោមពួកបេនយ៉ាមីន (មើល ២០:១៥–១៦) ពីព្រោះបេនយ៉ាមីនមានន័យថា " កូនប្រុសដែលនៅខាងស្ដាំដៃអញ" ។ តាមរយៈនៃការប្រើដៃឆ្វេង បានធ្វើឱ្យអេហ៊ុឌអាចទទួលជ័យជម្នះលើគូសត្រូវរបស់គាត់ដោយមិននឹកស្មានដល់ (ខ.២១) ។ *សួយអាករ* គេតែង តែថ្វាយសួយអាករនេះជារៀងរាល់ឆ្នាំ ហើយសួយអាករនេះ ប្រហែលជាផលនៃដំណាំផ្សេងៗ (ប្រៀបធៀបជាមួយ ២ពវ ៣:៤) ។

**៣:១៦** *ធ្វើកាំបិត១ មានមុខពីរ* កាំបិតមុខ២នេះ គឺមានការពេញនិយមណាស់នៅពេលដែលគេចង់ចាក់ ហើយវាក៏ជាអវុធ១ដែលពួកអ៊ីស្រាអែល តែងតែប្រើនៅពេលសង្គ្រាម ។

**៣:១៨** *ដាប់ថ្ម* តាមលក្ខណៈអក្សរសាស្ត្រគេនិយាយថា "រោងថ្ម ឬគុហា" នៅក្នុងខណៈពេល ដែលក្នុងព្រះគម្ពីរភាសាហេព្រើរខ្លះសំដៅលើ "ថ្មដាប់" ។ នៅកន្លែងនេះ ប្រហែលជាសំដៅលើ រូបសំណាកថ្មរបស់ស្ដេចអេគ្លូន ដែលតំណាងឱ្យព្រំប្រទល់ដែលគាត់ត្រួតា ។ ពួកអ្នកនៅក្បែរមជ្ឈឹមបុពាណ៏សម័យបុរាណ គេតែងតែសង់រូបសំណាកអ្នកណាម្នាក់ ដែលមានអំណាចដើម្បីកំណត់ព្រំប្រទល់របស់គេ ។ *គីលកាល* ប្រហែលជាទីកន្លែងដែលបាននិយាយនៅក្នុង យស ១៥:៧ ដែលមានទីតាំងនៅលើព្រំប្រទល់បេនយ៉ាមីន និងយូដា ។ វាមិនមែនជាទីកន្លែងដែលល្បីល្បាញនៅប៉ែកខាងកើតពីក្រុង

គ្នាទៅដល់ត្រឹមកន្លែងដាប់ថ្ម ដែលនៅជិតគីលកាល [១៩]រួច
លោកឱ្យពួកអ្នកដែលកាន់នាំសួយអាករមក ត្រឡប់ទៅ
ស្រុកវិញ តែឯខ្លួនលោកៗវិលចូលមកឯស្ដេចទូលថា
បពិត្រព្រះករុណា ទូលបង្គំមានការយ៉ាងសំងាត់នឹងទូល
ដល់ទ្រង់ ដូច្នេះស្ដេចទ្រង់ក៏បង្គាប់ថា ចូរស្ងៀមសិន រួច
អស់អ្នកដែលឈរជិតក៏នាំគ្នាចេញទៅក្រៅអស់ទៅ [២០]ឯ
ស្ដេចទ្រង់គង់នៅតែឯងក្នុងបន្ទប់ខាងលើ ជាកន្លែងសំរាប់
លំហើយអង្គ[ជ] លំដាប់នោះអេហ៊ុឌក៏ចូលទៅជិតទ្រង់ទូល
ថា ទូលបង្គំមានព្រះបន្ទូលនៃព្រះ សំរាប់នឹងទូលដល់ទ្រង់
ស្ដេចក៏ក្រោកចាក[ឈ]ពីព្រះទែនឡើង [២១]នោះអេហ៊ុឌក៏លូក
ដៃឆ្វេងទៅ ដកយកកាំបិត[ញ]ពីចង្កេះខាងស្ដាំ ចាក់ត្រង់ពោះ
នៃស្ដេច [២២]ឯដងកាំបិតក៏មុតកប់ចូលទៅតាមផ្លែផ្លុះចេញ
ទៅខាងក្រោយ រួចខ្លាញ់បិតភ្ជិតទាំងអស់ទៅ លោកឥត
បានដកកាំបិតចេញពីពោះស្ដេចឡើយ [២៣]ស្រេចហើយ
ក៏ចេញមកឯរានខាងមុខ រួចបិទទ្វារបន្ទប់ខាងលើនោះ
ចាក់សោរភ្ជិតទៅ ។

[២៤]កាលលោកបានចេញទៅបាត់ហើយ នោះពួកគាល់
ហៅរបស់ស្ដេចមកឃើញទ្វារចាក់សោរជិតដូច្នោះ ក៏គិត
ថា ប្រាកដជាទ្រង់ផ្ទុំ[ដ]នៅក្នុងបន្ទប់នោះហើយ [២៥]រួចគេនៅ
ចាំទាល់តែមានសេចក្ដីអៀនខ្មាសដល់ខ្លួន[ឋ] តែទ្រង់មិនបាន
បើកទ្វារបន្ទប់នោះសោះ គេក៏យកកូនសោទៅចាក់
បើកទ្វារ នោះឃើញម្ចាស់របស់គេទ្រង់សុគតនៅលើឥដ្ឋ
ហើយ ។

[២៦]ឯអេហ៊ុឌ លោកបានរត់រួចទៅ កំពុងដែលអ្នកទាំង
នោះនៅរារង់បង្អង់ចាំ ក៏បានទៅហួសពីកន្លែងដាប់ថ្មនោះ
ចូលទៅដល់សៃរ៉ា [២៧]លុះដល់ហើយ នោះលោកផ្លុំត្រែ[ឌ]
ឡើងនៅក្នុងស្រុកភ្នំអេប្រាអិម ឯពួកកូនចៅអ៊ីស្រាអែលក៏
ចុះពីស្រុកភ្នំទៅជាមួយ មានលោកជាអ្នកនាំមុខគេ
[២៨]លោកបង្គាប់ថា ចូរមកតាមខ្ញុំចុះ ដ្បិតព្រះយេហូវ៉ាទ្រង់
បានប្រគល់ពួកសាសន៍ម៉ូអាប់[ឍ]ជាខ្មាំងសត្រូវ មកក្នុង
កណ្ដាប់ដៃអ្នករាល់គ្នាហើយ[ណ] ដូច្នេះគេក៏ចុះតាមលោក
ទៅ ចាប់យកទីឆ្លងទន្លេយ័រដាន់[ត]ពីសាសន៍ម៉ូអាប់ ឥតបើក
ឱ្យអ្នកណាមួយឆ្លងសោះឡើយ [២៩]នៅវេលានោះគេ
ប្រហារជីវិតសាសន៍ម៉ូអាប់ អស់ប្រហែលជា១ម៉ឺននាក់ សុទ្ធ
តែជាមនុស្សក្លាហានហើយស្ទាត់ជំនាញគ្រប់គ្នា គ្មានអ្នក
ណាមួយរួចឡើយ [៣០]ដូច្នេះសាសន៍ម៉ូអាប់[ថ]ត្រូវក្រាបចុះ
នៅក្រោមអំណាច នៃពួកអ៊ីស្រាអែល នៅថ្ងៃនោះឯងវិញ
នោះស្រុកក៏បានសុខសាន្តត្រាណ[ទ]អស់៨០ឆ្នាំ ។

## លោកសាំកើរ

[៣១]ក្រោយពីលោកមក មានឈ្មោះសាំកើរ ជាកូន
អ័ណាត[ធ] ដែលយកជន្លួញគោ វាយសំឡាប់ពួកភីលីស្ទីន[ន]
អស់៦០០នាក់[ប] អ្នកនោះក៏ជួយសង្គ្រោះអ៊ីស្រាអែលដែរ ។

## នាងដេបូរ៉ា

**៤** [១]លុះអេហ៊ុឌ[ក]បានស្លាប់ទៅហើយ នោះពួកកូនចៅ
អ៊ីស្រាអែល គេប្រព្រឹត្តសេចក្ដីដែលលាមកអាក្រក់[ខ] នៅ

**៣:២០** ជ អម ៣:១៥ ឈ នហ ៨:៥
**៣:២១** ញ ២សយ ២:១៦ ៣:២៧ ២០:១០
**៣:២៤** ដ ១សយ ២៤:៣
**៣:២៥** ឋ ២ពវ ២:១៧ ៨:១១
**៣:២៧** ឌ លវ ២៥:៩ ពច ៦:៣៤ ៧:១៨ ២សយ ២:២៨ អស ១៨:៣ យរ ៤២:១៤
**៣:២៨** ឍ លប ១៩:៣៧ ណ យស ២:២៤ ពច ១:២ ត ជន ១៣:២៩ យស ២:៧
**៣:៣០** ថ លប ៣៦:៣៥ ទ ខ.១១
**៣:៣១** ធ ពច ៥:៦ ន យស ២៣:១០ ប យស ១៣:២ ពច ១០:១១ ១៣:១ ១សយ ៥:១ ៣១:១ ២សយ ៨:១ យរ ២៥:២០ ៤៧:១
**៤:១** ក ពច ៣:១៥ ខ ពច ២:១៩

យេរីខូរនោះឡើយ ។

**៣:២០** *បន្ទប់ខាងលើ* គឺជាបន្ទប់ដែលគេសង់នៅលើដំបូលផ្ទះ(ខ្មែរយើងប្រហែល "ឡៅតឿ") មើល ២ពវ ៤:១០–១១ ដំបូលរាំង (យរ ២២:១៣–១៤) និងមានបង្អួច(២ពវ ១:២)ដែលអាចផ្ដល់ឱ្យអ្នកដែលទៅលំហែរអង្គនូវផាសុខភាពយ៉ាងគ្រប់គ្រាន់ ។

**៣:២២** *ចេញទៅខាងក្រោយ* គេអាចនិយាយម្យ៉ាងទៀតថា "របស់ដែលនៅក្នុងពោះគាត់បានចេញមកក្រៅ" ។

**៣:២៨** *ចាប់យកទីឆ្លង* តាមរយៈសមត្ថភាពរបស់ពួកអ៊ីស្រាអែលលើសាសន៍ម៉ូអាប់បែបនេះ នោះពួកអ៊ីស្រាអែល អាចបណ្ដេញពួកម៉ូអាប់ចេញពីក្រុងយេរីខូរ ហើយក៏អាចបង្ការ និងទប់ស្កាត់មិនឱ្យពួកសាសន៍ម៉ូអាប់ បញ្ជូនកងទ័ពបន្ថែម ដើម្បីច្បាំងតបជាមួយអ៊ីស្រាអែលវិញដែរ ។

**៣:៣០** *៨០ឆ្នាំ* ចំនួនលេខនិមួយៗ តែងតែលើកមកនិយាយនៅក្នុងព្រះគម្ពីរពួកចៅហ្វាយ(មើលសេចក្ដីផ្ដើម: ប្រវត្តិដើម) ។

**៣:៣១** *សាំកើរ* គាត់គឺជាមនុស្សដំបូង នៅក្នុងចំណោមពួកចៅហ្វាយតូចៗទាំង៦ ដែលបានធ្វើជាចៅហ្វាយលើពួកអ៊ីស្រាអែល ហើយគាត់ក៏ជាមនុស្សដែលមានអាយុកាល ក្នុងអំឡុងកាលជាមួយដេបូរ៉ាដែរ(៥:៦–៧)។ ឈ្មោះរបស់គាត់ គឺតាមលំនាំជនបរទេស ដូច្នេះប្រហែលជាគាត់មិនមែនជាពួកកូនចៅអ៊ីស្រាអែលនោះឡើយ ។ *ជាកូនអ័ណាត* តាមរយៈឈ្មោះឪពុកគាត់ បានធ្វើឱ្យយើងកាន់តែដឹងច្បាស់ថា សាំកើរ គាត់គឺជាអ្នកមកពី បេត–អាណាតនោះវិញ (មើល ១:៣៣) ហើយក្រុមគ្រួសារគាត់ ប្រហែលជាអ្នកគោរពប្រតិបត្តិលើរូបព្រះស្រីឈ្មោះថា អាណាត ។ ព្រះស្រីអាណាតជាប្អូនរបស់ព្រះបាល ដែលតំណាងឱ្យសង្គ្រាម គឺជាអ្នកដែលច្បាំង ដើម្បីព្រះបាល ។ ចំពោះពាក្យថា "កូនអ័ណាត" ប្រហែលចង់មានន័យអំពីពូជនៃអ្នកច្បាំង ដែលមានន័យថា "អ្នកចម្បាំង" ។ *ជន្លួញគោ* គេប្រើសម្រាប់បរទេះគោ ឬសត្វផ្សេងៗ (សូមមើល ១សយ ១៣:២១) ។

**៤:១–៥:៣១** នៅក្នុងវគ្គនេះ អ្នកនិពន្ធបានលើកឡើងអំពីជ័យជម្នះរបស់នាងដេបូរ៉ា លើលោកស៊ីសេរ៉ា(ជាមេបញ្ជាការកងទ័ពកាណាន)។ នៅក្នុងជំពូក៤ អ្នកនិពន្ធលើកឡើងតាមលក្ខណៈអក្សរសាស្ត្រ ហើយនៅក្នុងជំពូក៥ គឺជាចម្រៀង ។ ក្នុងអំឡុងពេលដែលពួកកាណាន ត្រូវបានឈ្លានពានដោយពួកអ្នកនៅខាងជើង នោះពួកអ៊ីស្រាអែលបែរជាគ្មានសមត្ថភាពច្បាំងរួបរួមគ្នា រហូតដល់គ្រាដែលស្ត្រីម្នាក់(ដេបូរ៉ា)បានហៅអ្នកទាំងនោះមកធ្វើជាអ្នកចម្បាំងរបស់ព្រះ ។ ដោយព្រោះពួកអ្នកចម្បាំងអ៊ីស្រាអែលខ្វះនូវសេចក្ដីក្លាហាន នោះសិរីល្អនៃជ័យជម្នះរបស់ព្រះយេហូវ៉ាបានមកសណ្ឋិតនៅលើស្ត្រី (យ៉ាអែល) នាងនោះប្រហែលមិនមែនជាជនជាតិអ៊ីស្រាអែលឡើយ ។

ព្រះនេត្រព្រះយេហូវ៉ាម្ដងទៀត[គ] ២ទ្រង់ក៏លក់គេ[ឃ] ទៅក្នុង
កណ្ដាប់ដៃនៃយ៉ាប៊ីន ជាស្ដេចស្រុកកាណាន ដែលសោយ
រាជ្យនៅហាសោរ[ង] ស្ដេចនោះមានមេទ័ពឈ្មោះស៊ីសេរ៉ា[ច]
ដែលនៅហារ៉ូសែត-កូយីម ៣ឯពួកកូនចៅអ៊ីស្រាអែល
គេនាំគ្នាអំពាវនាវដល់ព្រះយេហូវ៉ា ពីព្រោះស្ដេចនោះ
មានរទេះដែក[ឆ]៩០០ ហើយក៏សង្កត់សង្កិន[ជ]ពួកកូនចៅ
អ៊ីស្រាអែលជាខ្លាំង អស់រវាង២០ឆ្នាំ ។

៤រីឯនៅវេលានោះ មានស្ត្រី ជាហោរា[ឈ]ម្នាក់ ឈ្មោះ
ដេបូរ៉ា[ញ] ជាប្រពន្ធឡាពិដូត នាងបានជំនុំជំរះរឿងរ៉ាវ
របស់សាសន៍អ៊ីស្រាអែល ៥នាងតែងអង្គុយ[ដ]នៅក្រោមដើម
លម៉ើដេបូរ៉ា ដែលនៅជាកណ្ដាលរ៉ាម៉ា[ឋ] និងបេត-អែល[ឌ]
ក្នុងស្រុកភ្នំអេប្រាអិម ពួកកូនចៅអ៊ីស្រាអែលក៏ឡើងទៅ
ឯនាងឱ្យបានជំនុំជំរះរឿងគេ ៦នាងចាត់គេឱ្យទៅហៅ
បារ៉ាក ជាកូនអ័ប៊ីណោម[ឍ] ពីស្រុកកេដេស[ណ]-ណែបថាលី
មក ហើយប្រាប់ថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់បានបង្គាប់ថា ចូរនាំយកមនុស្ស១ម៉ឺននាក់
ពីពួកកូនចៅណែបថាលី[ត] និងសាប់យូល៉ូន[ថ] ចូលទៅឯភ្នំ
តាបោរទៅ[ទ] ៧នោះអញនឹងទាញនាំស៊ីសេរ៉ា ជាមេទ័ព
របស់ស្ដេចយ៉ាប៊ីន[ធ] ព្រមទាំងរទេះនិងពួកពលទាំងប៉ុន្មាន
របស់គេ មកឯឯង នៅត្រង់ស្ទឹងគីសុន[ន] ហើយនិងប្រគល់គេ
មកក្នុងកណ្ដាប់ដៃនៃឯង[ប] ៨បារ៉ាកឆ្លើយតបថា បើលោក
ស្រីអញ្ជើញទៅជាមួយនឹងខ្ញុំផង នោះទើបខ្ញុំទៅ តែបើ
លោកមិនអញ្ជើញទៅជាមួយទេ នោះខ្ញុំក៏មិនទៅដែរ
៩នាងឆ្លើយថា ដូច្នេះខ្ញុំនឹងទៅជាមួយនឹងអ្នកដែរ ប៉ុន្តែអ្នក
នឹងគ្មានឈ្មោះដោយដំណើរដែលអ្នកទៅនោះទេ ដ្បិតព្រះ

**៤:១** គ ពច ២:១១ **៤:២** ឃ ចទ ៣២:៣០ ង យស ១១:១ ច ១សយ ១២:៩ ទដ ៨៣:៩ **៤:៣** ឆ យស ១៧:១៦ ជ ពច ១០:១២ ទដ ១០៦:៤២ **៤:៤** ឈ នក ១៥:០២ ញ ពច ៥:១,៧,១២,១៥ **៤:៥** ដ ១សយ ១៤:២ ២២:៦ ឋ យស ១៨:២៥ ឌ យស ១២:៩ **៤:៦** ឍ ពច ៥:១,១២,១៥ ១សយ ១២:១១ ហព ១១:៣២ ណ យស ១២:២២ ត លប ៣០:៨ ថ ពច ៥:១៨ ៦:៣៥ ទ យស ១៩:២២ **៤:៧** ធ យស ១១:១ ន ខ.១៣ ពច ៥:២១ ១ពវ ១៨:៤០ ទដ ៨៣:៩ ប ពច ១:២

**៤:១-២** សត្រូវពួកអ៊ីស្រាអែលបានមកពីទីកន្លែងផ្សេងៗ (លើកលែងតែពួកកាណាន) ។ ពួកសាសន៍ទាំងនោះមានដូចជាពួកអារ៉ាម ណាហារ៉ែម ពួកម៉ូអាប់ ពួកមេឌី និងពួកអាំម៉ូន ពួកគេទាំងអស់នោះ គឺសុទ្ធសឹងតែជាអ្នកខ្លាំងពូកែក្នុងចម្បាំងចាប់យករបឹប ប៉ុន្តែការបះបោររបស់ពួកកាណាន នៅក្នុងជំពូក ៤-៥ គឺក្នុងគោលបំណង បង្កើតនិងកសាងជនជាតិគេឡើងវិញនៅភាគខាងជើង ។ ពួកភីលីស្ទីន បានធ្វើចម្បាំងជាមួយពួកអ៊ីស្រាអែល ដើម្បីទឹកដីភាគខាងត្បូង និងមជ្ឈមណ្ឌលនៃតំបន់នេះ ។

**៤:២** *យ៉ាប៊ីន* សូមមើល ទដ ៨៣:៩-១០ ។ តាមរយៈឈ្មោះនេះ គេគិតថា ជាងាររបស់ស្ដេច មិនមែនជាឈ្មោះរបស់មនុស្សឡើយ ។ លោកយ៉ូស្វេបានសម្លាប់ស្ដេចមួយអង្គដែលមានឈ្មោះយ៉ាម៊ីននេះដែរ (យស ១១:១,១០) ។ *ហាសោរ* វាគឺជាទីក្រុងដើមរបស់រាជ្យវង្សយ៉ាម៊ីន ហើយប្រហែលវាក្លាយជាកន្លែងសំណល់បាក់បែកមួយ (មើលការពន្យល់ យស ១១:១០) ។ លោកស៊ីសេរ៉ា បានព្យាយាមក្នុងការវាយដណ្ដើមយកទឹកដី ដែលស្ដេចហាសោរកំពុកគ្រប់គ្រងមកវិញ ។ *ស៊ីសេរ៉ា* តាមរយៈឈ្មោះនេះ គេបានដឹងថា គាត់មិនមែនជាសាសន៍កាណានទេ ។

**៤:៣** *៩០០* ចំនួននេះ ប្រហែលជាចំនួនសរុប នៃរទេះចម្បាំងដែលបានមកពីតំបន់ផ្សេងៗ ។ នៅក្នុងសតវត្សរ៍ទី១៥មុន គ.ស ស្ដេចផារ៉ោនថូម៉ូសទី៣ (Pharaoh Thutmos III) បានចាប់ទេះចម្បាំងចំនួន ៩២៤ នៅពេលមានចម្បាំងនៅក្រុងមេគីដោ ។ *កូនចៅអ៊ីស្រាអែល* សំខាន់គឺពួកសាប់យូលូន និងណែបថាលី ប៉ុន្តែពួកម៉ាន៉ាសេភាគខាងលិចអ៊ីសាខារ និងអាសស៊ើរ ក៏ទទួលរងនូវការបេះពាល់ ។

**៤:៤** *ដេបូរ៉ា* មានន័យថា "សត្វឃ្មុំ" ប្រៀបធៀបជាមួយ ចទ ១:៤៤ ។ នាងគឺជាមនុស្សតែម្នាក់គត់នៅក្នុងគ្រាចៅហ្វាយ ដែលគេរាប់ថា "ហោរា" ។ ស្ត្រីផ្សេងទៀតដែលគេហៅថា "ហោរា" នោះគឺម៉ារាម (នក ១៥:២០) ហ៊ុលដា (២ពវ ២២:១៤) ណូអាឌា (នហ ៦:១៤) ហើយនិងអាណ (លក ២:៣៦) ប៉ុន្តែសូមមើល កច ២១:៩ ។

**៤:៥** *ដើមលម៉ើដេបូរ៉ា* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "ទឹកឃ្មុំ" គឺសំដៅលើទឹកឃ្មុំ និងបង្អែម ។ នាងដេបូរ៉ា គឺជាសត្វឃ្មុំដែលបានចែកចាយទឹកទៅគ្រប់ទីកន្លែង មិនមែនតែនៅក្នុងទ្វារក្រុងដែលជាកន្លែងកាត់ក្ដីនោះឡើយ ប៉ុន្តែនាងថែមទាំងធ្វើជាម្លប់ នៃដើមឈើដែលមានឃ្មុំវិញ (សូមមើលការពន្យល់ ១សយ ១៤:២) ។

**៤:៦** *បារ៉ាក* មានន័យថា "រន្ទះ" ដែលចង់និយាយថា គាត់គឺជាម្នាក់ដែលព្រះបានហៅឱ្យធ្វើជា "ដាវ" របស់ទ្រង់ដើម្បីកាត់ក្ដី (ចទ ៣២:៤១) ។ គាត់គឺជាអ្នកដែលមានឈ្មោះថា វិរៈបុរសនៃជំនឿ នៅក្នុងចំណោមអ្នកដឹកនាំល្អ (ហព ១១:៣២) ។ *ស្រុកកេដេស-ណែបថាលី* វាជាទីក្រុង១ដែលទទួលការគាបសង្កត់ដោយពួកកាណាន ។ *ណែបថាលី និងសាប់យូល៉ូន* អ៊ីសាខារ គឺជាសាច់ញ្ញាតិជិតជាងគេ នៅក្នុងពូជអំបូរមិនបានផ្ដោតលើ ឬលើកមកនិយាយនៅកន្លែងនេះទេ ប៉ុន្តែបានបញ្ចូលជាមួយចំនួនមនុស្ស ដែលនឹងត្រូវច្បាំងនៅក្នុងជំពូក ៥:១៥ វិញ ។ ទាំងអស់មានគ្នា ៦ពូជអំបូរ ដែលបានលើកមកនិយាយ ហើយពួកគេទាំងនោះ គឺជាអ្នកធ្លាប់ចូលរួមធ្វើសង្គ្រាមកន្លងមកដែរ ។ *ភ្នំតាបោរ* ភ្នំនោះមានកំពស់ប្រមាណជា ១៣០០ ហ្វីតដែលស្ថិតនៅខាងជើងឈាងខាងកើត ពីកន្លែងដែលគេតាំងបន្ទាយ ។

**៤:៧** តាមរយៈការតាំងបន្ទាយរបស់ពួកអ៊ីស្រាអែលនៅចង្កេះភ្នំតាបោរ គឺដើម្បីការពារពីពួកអ្នកចម្បាំង ហើយព្រះយេហូវ៉ាទ្រង់បានផ្ដល់ឱ្យពួកអ៊ីស្រាអែលនូវយុទ្ធសាស្ត្ររបស់ទ្រង់ ដើម្បីនឹងរៀបចំឱ្យស្ដេចស៊ីសេរ៉ា ចូលក្នុងអន្ទាក់ ។ នៅឯបន្ទាយ ភាពឆ្លាតវៃរបស់ស៊ីសេរ៉ា បានយកច្រកភ្នំយេរេស ដែលមានទីតាំងតាមបណ្ដោយស្ទឹងគីសុន ជាកន្លែង១ ដែលពលទ័ពរបស់គាត់វាយប្រហារ ពីព្រោះកន្លែងនោះមានទីតាំងធំ នោះពួកគេងាយស្រួលក្នុងការធ្វើសង្គ្រាម ប៉ុន្តែគាត់ធ្វើដូច្នេះ ដោយព្រោះគាត់មិនបានស្គាល់ពីអំណាចរបស់ព្រះ ថា ព្រះអង្គមានអំណាចខ្លាំងនោះឡើយ ។ ព្រះយេហូវ៉ាទ្រង់បានច្បាំងជំនួសអ៊ីស្រាអែល តាមរយៈព្យុះ និងទឹកជំនន់ (មើល ៥:២០-២១) ដូចជាទ្រង់បានធ្វើនៅជំនាន់លោក យ៉ូស្វេដែរ (យស ១០:១១-១៤) ។

**៤:៩** *ស្ត្រី* សេចក្ដីអៀនខ្មាស និងការភ័យខ្លាចរបស់បារ៉ាក (ព្រមទាំងអ្នកចម្បាំងជនជាតិអ៊ីស្រាអែលផ្សេងៗទៀតក្ដី) គឺបណ្ដាលមកពីគេខ្វះការទុក

យេហូវ៉ាទ្រង់នឹងលក់ស៊ីសេរ៉ា ទៅក្នុងកណ្តាប់ដៃរបស់ស្ត្រី
វិញ រួចដេបូរ៉ាក៏ក្រោកឡើង ទៅជាមួយនឹងបារ៉ាក ដល់
កេដេស[ផ] [១០]នោះបារ៉ាកក៏ហៅ[ព]ប្រជុំពួកសាប់យូល៉ូន និង
ពួកណែបថាលីទាំងប៉ុន្មាននៅត្រង់កេដេស ពេលនោះមាន
មនុស្សចំនួន១ម៉ឺននាក់ឡើងទៅតាមបារ៉ាក ហើយដេបូរ៉ាក៏
ទៅជាមួយដែរ ។
[១១]រីឯហេប៊ើរ ជាសាសន៍កែន[ភ] ដែលជាពួកកូនចៅ
ហូបាប់[ម]ជាឪពុកក្មេកម៉ូសេ គេបានឃ្លាតចេញពីពួកសាសន៍
កែន មកដំឡើងត្រសាលនៅត្រឹមដើមម៉ៃសាក់[យ]ស្អាណា
នីម[រ] ដែលនៅជិតកេដេស ។
[១២]ខណនោះមានគេទៅជំរាបស៊ីសេរ៉ាថា បារ៉ាកជា
កូនអ័ប៊ីណោមបានលើកទ័ព ឡើងទៅឯភ្នំតាបោរហើយ[ល]
[១៣]នោះស៊ីសេរ៉ាក៏ប្រមូលអស់ទាំងរទេះរបស់លោក គឺជា
រទេះដែក[វ]៩០០ ព្រមទាំងបណ្តាទ័ព ដែលនៅក្នុងអំណាច
ខ្លួន ចាប់តាំងពីហារ៉ូសែត-កូយីម ទៅដល់ស្ទឹងគីសុន[ស]
[១៤]ឯដេបូរ៉ានាងប្រាប់ដល់បារ៉ាកថា ចូរក្រោកឡើង នេះ
ហើយជាថ្ងៃដែលព្រះយេហូវ៉ា ទ្រង់ប្រគល់ស៊ីសេរ៉ាមកក្នុង
កណ្តាប់ដៃអ្នក[ហ] ព្រះយេហូវ៉ាទ្រង់បានចេញនាំមុខអ្នកទៅ
ហើយ[ឡ] ដូច្នេះបារ៉ាកក៏ចុះពីភ្នំតាបោរនាំមនុស្សទាំង១ម៉ឺន
នាក់ទៅ [១៥]ព្រះយេហូវ៉ាទ្រង់ក៏បំបាក់[អ]ទ័ពស៊ីសេរ៉ា និងអស់
ទាំងរទេះរបស់លោក ព្រមទាំងពួកពលទាំងអស់ដោយមុខ
ដាវនៅចំពោះបារ៉ាក ឯស៊ីសេរ៉ាក៏ចុះពីរទេះខ្លួនរត់រួចទៅ
[១៦]តែបារ៉ាកចេះតែដេញតាមរទេះ និងពួកពលគេទៅ
រហូតដល់ហារ៉ូសែត-កូយីម នោះពួកពលទាំងប៉ុន្មានរបស់
ស៊ីសេរ៉ាក៏ស្លាប់ដោយមុខដាវអស់ គ្មានសល់ដល់ម្នាក់
ឡើយ[ក]។
[១៧]រីឯស៊ីសេរ៉ា លោកបានរត់ទៅដល់ត្រសាលរបស់
យ៉ាអែល[ខ]ជាប្រពន្ធហេប៊ើរ សាសន៍កែននោះ[គ] ដ្បិតយ៉ាប៊ីន
ជាស្តេចហាសោរ[ឃ] និងពួកគ្រួហេប៊ើរ ជាសាសន៍កែនបាន
មេត្រីនឹងគ្នា [១៨]យ៉ាអែល[ង]ក៏ចេញមកទទួលស៊ីសេរ៉ា ដោយ
ពាក្យថា អញ្ជើញចូល លោកម្ចាស់អើយ សូមអញ្ជើញចូល
ក្នុងផ្ទះខ្ញុំមក កុំខ្លាចអ្វីឡើយ លោកក៏ចូលទៅក្នុងត្រសាល
ជាមួយនឹងនាង ហើយនាងយកភួយមកគ្របឱ្យ [១៩]លោក
សូមដល់នាងថា សូមឱ្យទឹកមកខ្ញុំផឹកបន្តិចផង ដ្បិតខ្ញុំស្រេក
ណាស់ នោះនាងក៏បើកថង់ស្បែក[ច]ដាក់ទឹកដោះឱ្យលោក
ផឹក រួចគ្របលោកទៅវិញ [២០]លោកអង្វរដល់នាងថា សូម
នាងឈរនៅមាត់ទ្វារត្រសាល បើមានអ្នកណាមកសួររក
ថា មានអ្នកណានៅទីនេះឬទេ នោះសូមឆ្លើយថា គ្មានទេ
រួចលោកក៏ដេកលក់ស៊ប់ទៅ [២១]ឯយ៉ាអែល[ឆ] ជាប្រពន្ធ
ហេប៊ើរ នាងក៏យកចំរឹងត្រសាល១ និងញញួរកាន់នៅដៃ
ដើរថ្នមៗ ចូលទៅឯលោក[ជ] បោះចំរឹងនោះនៅត្រង់តើក

**៤:៩** ផ យស ១២:២២
**៤:១០** ព ២រប ៣៦:២៣ អរ ១:២ អស ៤១:២ ៤២:៦ ៤៥:៣ ៤៦:១១ ៤៨:១៥
**៤:១១** ភ លប ១៥:១៩ ម ជន ១០:២៩ យ យស ២៤:២៦ ពច ៩:៦ រ យស ១៩:៣៣
**៤:១២** ល យស ១៩:២២
**៤:១៣** វ យស ១៧:១៦ ស ខ.៧ ពច ៥:១៩
**៤:១៤** ហ ពច ១:២ ឡ ចទ ៩:៣ ១សយ ៨:២០ ២សយ ៥:២៤ ទដ ៦៨:៧
**៤:១៥**អ យស១០:១០
**៤:១៦** ក នក ១៤:២៨ ទដ ៨៣:៩
**៤:១៧** ខ ខ.១៨,២១, ២២ ពច ៥:៦,២៤ គ លប ១៥:១៩ ឃ យស ១១:១ **៤:១៨** ង ខ.១៧ **៤:១៩** ច លប ១៨:៨ **៤:២១** ឆ ខ.១៧ ជ លប ២:២១ ១៥:១២ ១សយ ២៦:១២ អស ២៩:១០ យហ ១:៥

ចិត្តចំពោះព្រះយេហូវ៉ា ហើយពួកគេក៏ត្រូវទទួលនូវការស្តីបន្ទោសថែម ទៀតដែរ (មើលការពន្យល់ ៩:៥៤) ។

**៤:១១** *ហេប៊ើរ ជាសាសន៍កែន* ពាក្យថា "ហេប៊ើរ"មានន័យថា"សម្ព័ន្ធមិត្រ" ហើយ "សាសន៍កែន" គឺគាត់ចង់បង្ហាញពីអត្តសញ្ញាណរបស់គាត់ថា គាត់គឺជាគ្រួសារជាងដែក ដែលអ្នកនិពន្ធគាត់បានប្រលយនូវសេចក្តីពិតនេះថា គាត់គឺជាសមាជិកនៃពួកអ្នក ដែលបានចងសម្ព័ន្ធមិត្រជាមួយលោកម៉ូសេ នាសម័យកាលមួយ ដែលលោកម៉ូសេបានធ្វើដំណើរពីភាគខាងត្បូងឆ្ពោះទៅភាគខាងជើង ដើម្បីចងសម្ព័ន្ធមិត្រជាមួយ (ខ.១៧) ស្តេចនៃពួកកូនចៅកាណាន ជាអ្នកដែលមានរទេះចម្បាំងជាច្រើន(ខ.៣ និងមើលការពន្យល់ យស ១៧:១៦) ។ ហើយមិនចាំបាច់ឆ្ងល់អំពីគាត់ឡើយ គាត់គឺជាអ្នករៀបចំទម្រង់ទ័ពរបស់ស៊ីសេរ៉ា បារ៉ាក ។ *ពួកសាសន៍កែន* ពួកគេបានតាំងលំនៅនៅភាគខាងត្បូង ដែលមានចម្ងាយមិនឆ្ងាយប៉ុន្មានពីកេដេស ដែលស្ថិតនៅក្នុងស្រុកត្បូង (១:១៦) ។ *ហូបាប់* សូមមើល ជន ១០:២៩ ។

**៤:១៤** *ទ្រង់បានចេញនាំមុខអ្នកឡើងទៅ* ព្រះយេហូវ៉ាទ្រង់បាននាំមុខគេ ដូចព្រះមហាក្សត្រ ទ្រង់បាននាំមុខកងទ័ពរបស់ទ្រង់ នៅពេលដែលចេញទៅច្បាំង(មើល ១សយ ៨:២០)។ នក ១៥:៣ "ព្រះយេហូវ៉ាទ្រង់ជាអ្នកចម្បាំង" យស ១០:១០-១១ ២សយ ៥:២៤ ២រប ២០:១៥-១៧,២២-២៤ ។ *បារ៉ាកក៏ចុះពីភ្នំតាបោរ* ភ្នំនោះគឺជា"រន្ទះ"នៃព្រះយេហូវ៉ា(មើលការពន្យល់ ខ.៦) ដែលជាភ្នំពីបុរាណកាល ហើយព្រះអម្ចាស់ទ្រង់បានវាយពួកទ័ពកាណាននៅត្រង់ភ្នំនោះ ។

**៤:១៥** *បំបាក់ទ័ព* មើលការពន្យល់ ខ.៧ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះក៏ធ្លាប់បានប្រើនៅក្នុងគ្រា ដែលពួកអ៊ីស្រាអែលបានទទួលជ័យជម្នះលើពួកអេស៊ីព្ទ នៅពេលដែលពួកអ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម (នក ១៤:២៤) និងជ័យជម្នះលើពួកភីលីស្ទីននៅត្រង់មីសប៉ា(១សយ ៧:១០) ។

**៤:១៨** *លោកក៏ចូលទៅក្នុងត្រសាល ជាមួយនឹងនាង* តាមទំនៀមទម្លាប់របស់ពួកអ្នកនៅមជ្ឈឹមបូព៌ាសម័យបុរាណ គឺមិនអនុញ្ញាតឱ្យបុរសណាចូលក្នុងត្រសាល ក្រៅពីប្តី និងឪពុកបានឡើយ ។ ប្រហែលជា យ៉ាអែលនាងអនុញ្ញាតឱ្យស៊ើសេរ៉ា ចូលទៅក្នុងកន្លែងដែលគួរសមណាមួយ ។

**៤:១៩** *ថង់ស្បែក* គឺជាថង់ដែលគេធ្វើឡើងសម្រាប់ផ្ទុកវត្ថុរាវ ដែលជានិច្ចកាលគេធ្វើឡើងដោយស្បែកពពែ ឬស្បែកចៀម ។ *ទឹកដោះ* សូមមើលការពន្យល់ ៥:២៥ ។ ឈ្មោះរបស់យ៉ាអែល មានន័យថា "ពពែភ្នំ" នាងបានផ្តល់ឱ្យគាត់នូវទឹកដោះ ដែលទឹកដោះនោះដូចជាទឹកដោះពពែ (នក ២៣:១៩ សភ ២៧:២៧) ។

**៤:២១** *នាងក៏យកចំរឹងត្រសាល* បើតាមច្បាប់នៃការទទួលភ្ញៀវ គឺតែងតែការពារភ្ញៀវពីខ្មាំងសត្រូវ(មើល ១៩:២៣ លប ១៩:៨)។ យ៉ាអែល នាងបានចងចាំអំពី ការចងសម្ព័ន្ធមិត្ររបស់គ្រួសារនាងជាមួយពួកអ៊ីស្រាអែល

ធ្លុះទៅដល់ដីស្លាប់ទៅ[ឈ] ២២រួចមក កាលបារ៉ាកដេញតាម
ស៊ីសេរ៉ា មកដល់ហើយ នោះយ៉ាអែល[ញ] នាងចេញទៅ
ទទួល ដោយពាក្យថា សូមអញ្ជើញមកណេះ ខ្ញុំនឹងបង្ហាញ
មនុស្សដែលលោករកនោះ លោកក៏ចូលទៅជាមួយនឹង
នាង ឃើញស៊ីសេរ៉ាដេកស្លាប់ នៅមានទាំងចំរឹងនៅនា
តើកផង[ដ] ។
២៣ដូច្នេះ ព្រះទ្រង់បានបង្ក្រាប[ឋ]យ៉ាប៊ីន[ឌ] ជាស្តេចស្រុក
កាណាន នៅមុខពួកកូនចៅអ៊ីស្រាអែល នៅថ្ងៃនោះឯង
២៤ហើយពួកកូនចៅអ៊ីស្រាអែលក៏កាន់តែមានកំឡាំងឡើង
ឈ្នះយ៉ាប៊ីន ជាស្តេចស្រុកកាណាន ទាល់តែបានបំផ្លាញគេ
អស់ទៅ[ឍ] ។

## ទំនុករបស់នាងដេបូរ៉ា

៥ ១នៅថ្ងៃនោះ ដេបូរ៉ា[ក] និងបារ៉ាក ជាកូនអ័ប៊ីណោម[ខ]ក៏
ច្រៀងថា[គ] ២ចូរក្រាបថ្វាយបង្គំដល់ព្រះយេហូវ៉ា[ឃ] ដ្បិតពួក
អ្នកនាំមុខបានតាំងខ្លួននាំពួកអ៊ីស្រាអែល ហើយបណ្តាជន
បានប្រគល់[ង]ខ្លួនដោយស្ម័គ្រពីចិត្ត ។
៣ពួកស្តេចអើយ ចូរស្តាប់ ពួកមេត្រួតត្រាអើយ ចូរ
ផ្ទៀងត្រចៀកស្តាប់ចុះ ខ្ញុំនឹងច្រៀង[ច]ថ្វាយព្រះយេហូវ៉ា
ខ្ញុំនឹងច្រៀងសរសើរ ដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល[ឆ] ៤ឱព្រះយេហូវ៉ាអើយ កាលទ្រង់បានយាង
ចេញ[ជ]ពីភ្នំសៀរ[ឈ] កាលទ្រង់បានយាងមកពីវាលស្រុក
អេដំម នោះផែនដីក៏ញ័រឡើង[ញ] ផ្ទៃមេឃក៏ទូទឹម ហើយ
ពពកបានបង្អុរទឹកចុះ[ដ] ៥ភ្នំទាំងប៉ុន្មានក៏រលាយ[ឋ]ទៅនៅ
ចំពោះព្រះយេហូវ៉ា គឺភ្នំស៊ីណាយបានរលាយពីចំពោះ
ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ។
៦នៅជំនាន់សាំកើរ ជាកូនអ័ណាត[ឌ] ក្នុងគ្រាយ៉ាអែល[ឍ]
នោះគេទុកចោលថ្នល់ធំ[ណ] ពួកអ្នកដំណើរទាំងប៉ុន្មានក៏ដើរ
តាមតែផ្លូវច្រកវិញ[ត] ៧ភូមិទាំងប៉ុន្មានក្នុងស្រុកអ៊ីស្រាអែល
ក៏ចោលនៅស្ងាត់ គឺនៅស្ងាត់ច្រៀប ទាល់តែខ្ញុំដេបូរ៉ា
នេះ[ថ]បានតាំងឡើង គឺបានឡើងធ្វើជាម្តាយនៃសាសន
អ៊ីស្រាអែល ៨គេបានជ្រើសរើសព្រះថ្មី[ទ] បានជាកើតមាន
ចំបាំងនៅមាត់ទ្វារក្រុងទាំងប៉ុន្មាន[ធ] គ្រានោះក្នុងសាសន៍

**៤:២១** ឈ ពច ៥:២៦
**៤:២២** ញ ខ.១៧ ដ ពច ៥:២៧
**៤:២៣** ឋ នហ ៩:២៤ ទដ ១៨:៤៧ ៤៤:២ ៤៧:៣ ១៤៤:២ ឌ យស ១១:១
**៤:២៤** ឍ ទដ ៨៣:៩ ១០៦:៤៣
**៥:១** ក ពច ៤:៤ ខ ពច ៤:៦ គ នក ១៥:១ ទដ ៣២:៧
**៥:២** ឃ ខ.៩ ង ២របា ១៧:១៦ ទដ ១១០:៣
**៥:៣** ច នក ១៥:១ ឆ ទដ ២៧:៦
**៥:៤** ជ នក ១៣:២១ ឈ ជន ២៤:១៨ ចទ ៣៣:២ ញ ២សយ ២២:៨ ទដ ១៨:៧ ៧៧:១៨ ៨២:៥ អស ២:១៩,២១ ១៣:១៣ ២៤:១៨ ៦៤:៣ យរ ១០:១០ ៥០:៤៦ ៥១:២៩ យអ ៣:១៦ ណហ ១:៥ ហព ៣:៦ ដ ទដ ៦៨:៨ ៧៧:១៧
**៥:៥** ឋ នក ១៩:១៨ ទដ ២៩:៦ ៤៦:៣ ៧៧:១៨ ១១៤:៤ អស ៦៤:៣
**៥:៦** ឌ ពច ៣:៣១ ឍ ពច ៤:១៧ ណ លវ ២៦:២២ អស ៣៣:៨ ត ទដ ១២៥:៥ អស ៥៩:៨
**៥:៧** ថ ពច ៤:៤
**៥:៨** ទ ចទ ៣២:១៧ ពច ២:១៣ ធ ខ.១១ យស ២:៥

នៅក្នុងគ្រាមុន (នាងប្រហែលជាមិនមែនសាសន៍អ៊ីស្រាអែលឡើយ) ។ នាងបានប្រព្រឹត្តខុសនឹងក្រឹត្យវិន័យ ដោយមិនឱ្យប្តីនាងដឹង ។

**៤:២២** *ស៊ីសេរ៉ាដេកស្លាប់* នៅពេលដែលស៊ីសេរ៉ាបានស្លាប់ទៅ នោះនគររបស់យ៉ាប៊ីនគ្មានអំណាចតទៅទៀតឡើយ ។ ក្នុងស្រុកនោះ "សម្បូរដោយទឹកដោះនិងទឹកឃ្មុំ" ត្រូវបានសង្គ្រោះដោយសារការលើកទឹកចិត្ត និងសេចក្តីជំនឿរបស់ "សត្វឃ្មុំ" (មើលការពន្យល់ ខ.៤ "ដេបូរ៉ាមានន័យថាឃ្មុំ") ព្រមទាំង "ពពែភ្នំ" (មើលការពន្យល់ ខ.១៩) ។

**៥:១–៣១** ដើម្បីរំឭកទៅដល់ជ័យជម្នះលើប្រជាជាតិផ្សេងៗ គេតែងតែច្រៀងចម្រៀង(មើល នក ១៥:១–១៨ ជន ២១:២៧–៣០ ចទ ៣២:២ ១សយ ១៨:៧) ។ សៀវភៅដែលនិទាន ពីចម្បាំងរបស់ព្រះយេហូវ៉ា (ជន ២១:១៤) និងសៀវភៅរបស់យ៉ាសើរ (មើលការពន្យល់ យស ១០:១៣) គឺប្រហែលជាត្រូវបានដាក់បញ្ចូលគ្នា ហើយចងក្រងជាចម្រៀងឡើង ។

ចម្រៀងទាំងអស់នោះ ប្រហែលជាត្រូវបានសរសេរនិងនិពន្ធដោយដេបូរ៉ា ឬសហកាលិករបស់នាង (មើល ខ.៧) ។ អ្នកនិពន្ធបានដកស្រង់នូវចំណុចសំខាន់ៗខ្លះនៃទេវកថាទាំងនោះ (ប្រៀបធៀប នក ១៥:១–១៨ ១សយ ២:១–១០ ២សយ ២២,២៣:១–៧ លក ១:៤៦–៥៥,៦៨–៧៩) ។ ជានិច្ចកាលគេតែងតែច្រៀងនៅមុខបណ្តាជន (ខ.៣) ដើម្បីថ្លែងពីសេចក្តីសប្បុរសរបស់ទ្រង់ និងពីចម្បាំងរបស់ទ្រង់ (ខ.១១) ។ ចម្រៀងទាំងនោះត្រូវបានបែងចែកជាផ្នែកតូចៗ ដែលមានជាអាទិ : (១).គោលបំណងរបស់ចម្រៀង (ទំនុកសរសើរ)និងឱកាសដែលត្រូវច្រៀងចម្រៀងនេះ(ខ.២–៩) (២).ណែនាំដល់ពួកអ៊ីស្រាអែល ពីទង្វើរដែលព្រះយេហូវ៉ាទ្រង់អនុញ្ញាតឱ្យព្រះមហាក្សត្រជំនាន់មុនធ្វើ (ខ.១០–១១ក) (៣).ការលេចឡើងរបស់បណ្តាជនចំពោះដេបូរ៉ា(ខ.១១ខ–១២) (៤).ការជួបជុំគ្នារវាងអ្នកចម្បាំង (ខ.១៣–១៨) (៥).ការតាំងបន្ទាយ(ខ.១៩–២៣) (៦).បង្ហាញពីភាពមានល្បិចកលរបស់យ៉ាអែលចំពោះស៊ីសេរ៉ា (ខ.២៤–២៧) (៧).ការទន្ទឹងរងចាំផ្លូវរបស់ម្តាយស៊ីសេរ៉ាចំពោះស៊ីសេរ៉ា(ខ.២៨–៣០) (៨).សេចក្តីបញ្ចប់នៃចម្រៀង(ខ.៣១) ។

**៥:៤–៥** អ្នកនិពន្ធ គាត់បាននិយាយម្តងទៀតអំពីលក្ខណៈរបស់ព្រះយេហូវ៉ា ដែលទ្រង់បានធ្វើឱ្យមានព្យុះពពក ជាច្រើនឆ្នាំងកន្លងទៅហើយ គឺតាំងពី គ្រាដែលព្រះអម្ចាស់ ទ្រង់បាននាំពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ តាមទីរហោស្ថាន ឆ្ពោះតម្រង់ទៅកាន់ទឹកដីកាណាន(ចទ ៣៣:២ ទដ ៦៨:៧–៨ មីក ១:៣–៣ ទដ ១៨:៧–១៥) ។

**៥:៤** *សៀរ* ភ្នំសៀរ (ស្ថិតនៅក្នុងស្រុកអេដំម) ។ សម្រាប់ឈ្មោះសៀរផ្សេងទៀត (ភ្នំប៉ារ៉ាន) និងភ្នំស៊ីណាយ សូមមើល ចទ ៣៣:២ ។ *ផ្ទៃមេឃក៏ទូទឹម* មើលក្នុង ទដ ៦៨:៧–១០ ។

**៥:៥** *ភ្នំស៊ីណាយ* សូមមើល ទដ ៦៨:៨ ។ រញ្ជួយផែនដី ហើយផ្គរ មានផ្លេកបន្ទោរ គឺកើតមាននៅពេលដែលព្រះយេហូវ៉ាទ្រង់បានលេចមក នៅលើភ្នំស៊ីណាយ (នក ១៩:១៦–១៨) ។

**៥:៦** *សាំកើរ* មើលក្នុងការពន្យល់ ៣:៣១ ។ *ទុកចោលថ្នល់ធំ* ដោយសារតែជាតំបន់ទ័ពខ្មាំងសត្រូវ និងមានការលួចប្លន់ ធ្វើឱ្យផ្លូវថ្នល់គ្មានសុវត្ថិភាព ជាហេតុធ្វើឱ្យគេបោះបង់ចោល(មើលការពន្យល់ ៤:១–២) ។

**៥:៧** *ភូមិទាំងប៉ុន្មាន...ក៏ចោលនៅស្ងាត់* ពួកគេបានធ្វើរបងដើម្បីការពារទីក្រុងទាំងប៉ុន្មាន មុនពេលដែលគេចាកចេញ ។

**៥:៨** *ឥតមានខែលឬលំពែងណាមួយឡើយ* ដោយសារអ៊ីស្រាអែលបាន

អ៊ីស្រាអែល៤ម៉ឺននាក់ ឥតមានខែលឬលំពែង[ន]ណាមួយ
ឡើយ ៩ខ្ញុំមានសេចក្ដីពេញចិត្ត[ប] ចំពោះពួកចៅហ្វាយ
សាសន៍អ៊ីស្រាអែល ដែលនៅក្នុងពួកបណ្ដាជន គេបាន
ប្រគល់ខ្លួនដោយស្ម័គ្រពីចិត្ត សូមឱ្យព្រះយេហូវ៉ាបាន
ព្រះពរ ១០ឱអ្នករាល់គ្នាដែលជិះលាស[ផ] និងអ្នករាល់គ្នា
ដែលអង្គុយលើព្រំវិចិត្រដ៏មានដំឡៃ ហើយអ្នករាល់គ្នា
ដែលដើរតាមផ្លូវអើយ ចូរថ្លែងប្រាប់ចុះ ១១នៅទីឆ្ងាយ
ពីសូរអឺងអាប់នៃពួកប្រមាញ់ធ្នូ នោះគេនឹងប្រជុំត្រង់កន្លែង
ដងទឹក ថ្លែងប្រាប់ពីអំពើសុចរិត[ព]របស់ព្រះយេហូវ៉ា គឺពី
អស់ទាំងអំពើសុចរិត ដែលទ្រង់ប្រោសក្នុងគ្រាដែល
សោយរាជ្យលើសាសន៍អ៊ីស្រាអែល នៅក្នុងគ្រានោះពួក
រាស្ត្រផងព្រះយេហូវ៉ាបានចុះមកដល់អស់ទាំងទ្វារក្រុង[ភ]។
១២ចូរភ្ញាក់[ម] ចូរភ្ញាក់ឡើងចុះ ដេបូរ៉ាអើយ[យ] ចូរភ្ញាក់
ចូរភ្ញាក់ឡើងច្រៀងជាទំនុកទៅ ចូរក្រោកឡើងបារ៉ាក
អើយ[រ] ឱកូនអ័ប៊ីណោមអើយ ចូរនាំពួកឈ្លើយរបស់អ្នកទៅ
ចុះ[ល] ១៣គ្រានោះ ពួកសំណល់នៃបណ្ដាជន បានឈ្នះពួក
ខ្លាំងពូកែ ព្រះយេហូវ៉ាទ្រង់បានយាងចុះមកច្បាំងជំនួសខ្ញុំ
ទាស់នឹងពួកស្ទាត់ជំនាញ ១៤មានពួកអ្នកចុះពីស្រុក
អេប្រាអិមមក[វ] ដែលមានជាប់កំណើតក្នុងសាសន៍អាម៉ា
លេក[ស] គេមកតាមឯង ឱបេនយ៉ាមីន[ហ]អើយ គឺនៅជា
កណ្ដាលនៃពួកជនរបស់ឯងផង មានពួកចៅហ្វាយចុះមក
ពីពួកម៉ាគារ[ឡ] ហើយពីពួកសាប់យូល៉ូន នោះមានអ្នកដែល
ធ្វើជាមេធំបំផុតចេញមក ១៥ពួកអ្នកដែលជាកំពូលលើពួក
អ៊ីសាខារ[អ]ក៏នៅជាមួយនឹងដេបូរ៉ា[ក] ហើយពួកអ៊ីសាខារបាន
តាមបារ៉ាកដែរ[ខ] គេបានទទួលបង្គាប់ចុះទៅក្នុងច្រកភ្នំ
តាមដានជើងលោក រីឯពួករូបេន នៅត្រង់ជ្រោះទឹក នោះ
គេមានចិត្តនឹកសំរេចការយ៉ាងធំ ១៦ហេតុអ្វីបានជាឯងនៅ
តែក្នុងក្រោលចៀម[គ] និងស្ដាប់សូរហួងសត្វឃុំដូច្នេះ[ឃ] នៅ
ត្រង់ជ្រោះទឹករបស់ពួករូបេន នោះគេមានសេចក្ដីនឹក
ពិចារណាក្នុងចិត្តយ៉ាងធំ ១៧ឯពួកកាឡាត[ង]គេបាននៅតែ
ខាងនាយទន្លេយ័រដាន់ ហើយដាន់ ហេតុអ្វីបានជាគេនៅ
តែក្នុងនាវាដូច្នេះ ពួកអេស៊ើរ[ច]ក៏បានអង្គុយនៅតែនឹងមាត់
សមុទ្រ[ឆ] ហើយតាមស្នឹងរបស់គេផង ១៨គឺមានតែពួកសាប់
យូល៉ូន[ជ]ទេ ដែលប្រថុយជីវិតដល់ស្លាប់ និងពួកណែប
ថាលី[ឈ] ដែរ គេបានចូលទៅច្បាំងនៅទីវាលខ្ពស់[ញ]។
១៩ពួកស្ដេចបានមក[ដ]ច្បាំង គឺពួកស្ដេចស្រុកកាណានគេ
មកច្បាំងនៅតាអាណាក ជិតទឹកមេគីដោ[ឋ] តែគេមិនបានយក

**៥:៨** ន ជន ២៥:៧
**៥:៩** ប ខ.២
**៥:១០** ផ លប ៤៩:១១ ពច ១០:៤ ១២:១៤
**៥:១១** ព ១សយ ១២:៧ ដយ ៩:១៦ មីក ៦:៥ ភ ខ.៨
**៥:១២** ម ទដ ៤៤:២៣ ៥៧:៨ អស ៥១:៩,១៧ យ ពច ៤:៤ រ ពច ៤:៦ ល ទដ ៦៨:១៨ អភ ៤:៨
**៥:១៤** វ លប ៤១:៥២ ពច ១:២៩ ស ពច ៣:១៣ ហ ជន ៣៤:២១ ឡ លប ៥០:២៣
**៥:១៥** អ លប ៣០:១៨ ក ពច ៤:៤ ខ ពច ៤:៦
**៥:១៦** គ លប ៤៩:១៤ ឃ ជន ៣២:១
**៥:១៧** ង យស ១២:២ ច យស ១៧:៧ ឆ យស ១៩:២៩
**៥:១៨** ជ លប ៣០:២០ ឈ លប ៣០:៨ ទដ ៦៨:២៧ ញ ពច ៤:៦,១០
**៥:១៩** ដ យស ១១:៥ ពច ៤:១៣ វវ ១៦:១៦ ឋ យស ១២:២១

ចងមិត្តជាមួយពួកកាណាន (៣:៥–៦) ឬដោយសារពួកគេមិនចុះសម្រុងនឹងគ្នា (១សយ ១៣:១៩–២២) ។

**៥:១០** *ជិះលាស* បញ្ជាក់ពីអ្នកមានមុខមាត់ និងមានទ្រព្យសម្បត្តិច្រើន (១០:៤ ១២:១៤) ។

**៥:១១** *សូរអឺងអាប់* គេបានដើរច្រៀងពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីលើកទឹកចិត្តដល់បណ្ដាជន តាមទីកន្លែងផ្សេងៗគ្នា ។

**៥:១២** *ចូរភ្ញាក់ឡើង* គឺជាពាក្យដែលនិយាយដោយការអង្វរ មិនមែនដោយការបែបមានអំណាចនោះឡើយ (ទដ ៤៤:២៣ អយ ៥១:៩) ។ *ចូរនាំពួកឈ្លើយរបស់អ្នកទៅចុះ* ដូចគ្នានឹងការឆ្លើយចំពោះព្រះនៅក្នុង ទដ ៦៨:១៨ និងព្រះយេស៊ូវនៅក្នុង អភ ៤:៨ (សូមមើលខពន្យល់ទាំងនោះ) ។

**៥:១៣–១៨** ពួកអ្នកចម្បាំងរបស់ព្រះ បាននាំគ្នាមកតាំងបន្ទាយ ។ ពូជអំបូរដែលបានចូលរួមមានជាអាទិ : អេប្រាអិម បេនយ៉ាមីន ម៉ានាសេ ("ម៉ាគីរ" គឺទាំងម៉ានាសេខាងលិច និងខាងកើត មើល ចទ ៣:១៥ យស ១៣:២៩–៣១ ១៧:១) សាប់យូលូន (ខ.១៤,១៨) អ៊ីសាខារ (ខ.១៥) ហើយនិងណែបថាលី (ខ.១៨) ។ ជាពិសេស ពួកសាប់យូលូន និងណែបថាលី ពួកគេបានប្រថុយស្លាប់ (ខ.១៨ ៤:១០) ។ រូបេន (ខ.១៥–១៦) កាឌ់ (ខ.១៧) ពួកគេមកពីភាគខាងកើតពីទន្លេយ័រដាន់ ។ ដាន់ និងអេស៊ើរ មកពីតាមបណ្ដោយឆ្នេរ (ខ.១៧) ។ យូដា និងស៊ីម្មានមិនបាននិយាយឡើយ ប្រហែលជាពួកគេបានចងសម្ព័ន្ធមេត្រីជាមួយពួកភីលីស្ទីន ។ ពួកលេវី ក៏មិនបាននិយាយដែរ ព្រោះគេមិនមានទំពគ្រប់គ្រាន់ ។

**៥:១៤** *ជាប់កំណើតក្នុងសាសន៍អាម៉ាលេក* ពួកអាម៉ាលេកខ្លះរស់នៅក្នុងស្រុកភ្នំ ដែលជាស្រុករបស់ពួកអេប្រាអិម (មើល ១២:១៥) ។ *ម៉ាគារ* គឺជាកូនច្បងរបស់ម៉ានាសេ (យស ១៧:១) ។ ទោះបីជាពួកព្ទយុកោរបស់ម៉ាគារបានតាំងលំនៅស្ថាននៅភាគខាងកើត និងខាងលិចនៃទន្លេយ័រដាន់ (ចទ ៣:១៥ យស ១៣:២៩–៣១ ១៧:១ ១រប ៧:១៤–១៩) ក៏ដោយ អ្វីដែលអ្នកនិពន្ធនិយាយនៅកន្លែងនេះ គឺនិយាយសំដៅលើពួកអ្នកដែលរស់នៅភាគខាងលិចនៃទន្លេយ័រដាន់ (ខ.១៧ យស ១៧:៥) ។

**៥:១៨** *ទីវាលខ្ពស់* ប្រហែលជាជាប់ទាក់ទងទៅនឹង លប ៤៩:២១ ជាកន្លែងមួយដែលណែបថាលី បានិយាយថា "ជាក្តាន់ដែលគេលែង"។

**៥:១៩** *មេគីដោ* មេគីដោនិងតាអាណាក គឺជាអ្នកដែលធ្លាប់ត្រួតត្រានៅតំបន់វាលច្រកភ្នំភាគខាងជើងឆៀងខាងកើត ចាប់តាំងពីវាលសារ៉ុន រហូតដល់ភូមិយេសរាល ។ ដោយសារតែមេគីដោ ស្គាល់ច្បាស់ពីតំបន់នោះរួមជាមួយយុទ្ធសាស្ត្រ ដ៏ប៉ិនប្រសប់នោះ"ច្រកភ្នំមេគីដោ"ត្រូវបានក្លាយជាសមរភូមិនាសម័យមុន ។ ស្ដេចផារ៉ោន ថូសម៉ូសទី៣ បានវាយឈ្នះពួកកាណាននៅឆ្នាំ ១៤៦៨ មុន គ.ស ។ តាមប្រវត្តិសាស្ត្រព្រះគម្ពីរបង្ហាញថា តំបន់នេះក៏ត្រូវជួបនូវការឈ្លានពានពីសំណាក់ដេបូរ៉ា និងប៉ារ៉ាកនៅពេលដែលអ្នកទាំង២នោះ ធ្វើការវាយប្រហារជាមួយពួកអ៊ីស្រាអែល ។ នៅក្នុង ខ.១៩ បាននិយាយថា "ទឹកមេគីដោ" ហើយនៅទីនោះ យ៉ូសៀសជាស្ដេចល្អរបស់ស្រុកយូដាបានសុគតនៅកន្លែងនោះ នៅពេលច្បាំងជាមួយព្រះស្ដេចផារ៉ោននេកោទី២ កាលពីឆ្នាំ ៦០៩ មុន គ.ស (២ពវ ២៣:២៩) ។

របឹបដ៏មានដំឡៃអ៊ីសោះ[ឱ] ២០ផ្ទៃមេឃ[ឲ]ក៏បានជួយច្បាំង
ផ្កាយទាំងប៉ុន្មានបានច្បាំងនឹងស៊ីសេរ៉ាពីទីគោចរ ២១ស្ទឹង
គីសុន[ណ]បានហូរនាំយកគេទៅបាត់ គឺស្ទឹងគីសុន ជាស្ទឹងពី
ចាស់បុរាណនោះ ឱព្រលឹងអញអើយ ឯងបានជាន់គេ
ដោយមានកំឡាំងដ៏ខ្លាំង[ត] ២២គ្រានោះឮសូរសន្ធឹកជើងសេះ
ដែលកំពុងតែរត់ គឺដែលពួកខ្លាំងពូកែរត់ទៅ[ថ] ២៣ទេវតា
នៃព្រះយេហូវ៉ាប្រាប់ថា ចូរដាក់បណ្តាសាដល់មេរ៉ូស ចូរ
ដាក់បណ្តាសាដល់ពួកអ្នក ដែលនៅស្រុកនោះ ជាយ៉ាងធ្ងន់
ពីព្រោះគេមិនបានមកជួយការនៃព្រះយេហូវ៉ា គឺជួយទាស់
នឹងមនុស្សខ្លាំងពូកែនោះទេ ២៤យ៉ាអែល[ទ]ជាប្រពន្ធហេប៊ើរ
សាសន៍កែន[ធ] នាងមានពរលើសជាងអស់ទាំងស្ត្រី[ន] នាង
នឹងមានពរលើសជាងគ្រប់អស់ទាំងស្ត្រី ដែលនៅក្នុង
ត្រសាលផង ២៥លោកបានសូមទឹកផឹក តែនាងបានឱ្យទឹក
ដោះវិញ[ប] គឺនាងបានយកខ្លាញ់ទឹកដោះដាក់ក្នុងចានលំអ
មកជូនលោក ២៦នាងបានលូកដៃទៅចាប់យកចំរឹង ហើយ
ដៃស្តាំចាប់យកញញួររបស់ពួកជាង រួចបានវាយស៊ីសេរ៉ា
នឹងញញួរនោះ គឺបានវាយធ្លុះក្បាលលោក នាងវាយទំលុះ
ត្រង់តើក[ផ] ២៧លោកក៏ឱន ក៏ដួល ក៏ដេក នៅទៀបជើងនាង
គឺនៅទៀបជើងនាងដែលលោកឱនដួលចុះ ហើយនៅ
កន្លែងដែលលោកឱននោះ លោកក៏ដួលស្លាប់នៅទីនោះ
ឯង[ព] ។

២៨ម្តាយស៊ីសេរ៉ាបានរង់មើលតាមតារាង ហើយបន្លឺ
វាចាតាមបង្អួច[ភ]ស្តូរថា[ម] ហេតុអ្វីបានជារទេះលោកក្រមក
ដូច្នេះ ហេតុអ្វីបានជាកង់រទេះលោកយឺតដល់ម៉្លេះ ២៩ពួក
ស្ត្រីប្រាជ្ញរបស់នាងក៏ឆ្លើយឡើង អើ នាងក៏ឆ្លើយដោយខ្លួន
ឯងដែរថា ៣០តើគេរកមិនបានរបឹប តើមិនបានចែកគ្នាទេ
ឬអី[យ] គឺជាស្ត្រីក្រមុំម្នាក់ឬ២នាក់គ្រប់គ្នា ឯស៊ីសេរ៉ា តើមិន
បានរបឹបជាអាវជ្រលក់ល័ខ[រ] គឺជាអាវប៉ាក់មានពណ៌ពី
របឹបទាំងប៉ុន្មាន ជាអាវប៉ាក់ទាំងសងខាង ហើយជ្រលក់
ល័ខផង ដែលសំណំនឹងអ្នកចាប់យករបឹបនោះទេឬអី[ល] ។

៣១ឱព្រះយេហូវ៉ាអើយ សូមឱ្យអស់ទាំងខ្មាំងសត្រូវ
របស់ទ្រង់វិនាសទៅដូច្នេះដែរ[វ] តែសូមឱ្យពួកអ្នក ដែល
ស្រឡាញ់ទ្រង់ បានភ្លឺដូចជាថ្ងៃ[ស] ក្នុងកាលដែលរះឡើង
ពេញវង់វិញ[ហ] ។

នោះស្រុកក៏បានសុខសាន្តត្រាណ[ឡ]អស់៤០ឆ្នាំ ។

## គេឌាន

៦ ១រួចមកពួកកូនចៅអ៊ីស្រាអែល គេប្រព្រឹត្តសេចក្តី
ដែលលាមកអាក្រក់នៅព្រះនេត្រព្រះយេហូវ៉ាទៀត[ក] នោះ
ព្រះយេហូវ៉ាទ្រង់ប្រគល់គេទៅក្នុងកណ្តាប់ដៃ នៃសាសន៍
ម៉ាឌានអស់៧ឆ្នាំ[ខ] ២ពួកសាសន៍ម៉ាឌានក៏មានកំឡាំងឡើង
ឈ្នះពួកអ៊ីស្រាអែល[គ] គឺដោយព្រោះតែសាសន៍ម៉ាឌាននោះ
ហើយ បានជាពួកកូនចៅគេធ្វើរូងនៅក្នុងភ្នំ[ឃ] និងរអាង
ហើយនិងទីមាំមួនសំរាប់ខ្លួន[ង] ៣រីឯកាលពួកអ៊ីស្រាអែល
បានសាបព្រោះ នោះពួកសាសន៍ម៉ាឌាន ពួកសាសន៍
អាម៉ាលេក[ច] និងពួកមនុស្ស[ឆ]នៅស្រុកខាងកើត គេឡើងមក

**៥:១៩** ឱ ខ.៣០
**៥:២០** ឲ យស ១០:១១
**៥:២១** ណ ពច ៤:៧ ត យស ១:៦
**៥:២២** ថ យរ ៨:១៦
**៥:២៤** ទ ពច ៤:១៧ ធ លក ១:៤២ ន លប ១៥:១៩
**៥:២៥** ប លប ១៨:៨
**៥:២៦** ផ ពច ៤:២១
**៥:២៧** ព ពច ៤:២២
**៥:២៨** ភ យស ២:១៥ ម សភ ៧:៦
**៥:៣០** យ នក ១៥:៩ ១សយ ៣០:២៤ ទដ ៦៨:១២ រ ទដ ៤៥:១៤ អគ ១៦:១០ ល ខ.១៩ ២សយ ១:២៤
**៥:៣១** វ ជន ១០:៣៥ ស ២សយ ២៣:៤ យប ៣៧:២១ ទដ ១៩:៤ ៨៩:៣៦ អស ១៨:៤ ហ ២សយ ១៨:៣២ ឡ ពច ៣:១១
**៦:១** ក ពច ២:១១ ខ លប ២៥:២

**៦:២** គ ១សយ ១៣:៦ អស ៥:៣០ ៨:២១ ២៦:១៦ ៣៧:៣ ឃ អស ២:១៩ យរ ៤៨:២៨ ៤៩:៨,៣០ ង យប :៨ យរ ៤១:៩ ហព ១១:៣៨ **៦:៣** ច ជន ១៣:២៩ ឆ លប ២៥:៦ អស ១១:១៤ យរ ៤៩:២៨

**៥:២០** *ផ្កាយទាំងប៉ុន្មានបានច្បាំង* ដូចគ្នានឹងសិល្បិ៍សាស្ត្រ របស់អ្នកកវីនិពន្ធព្រះគម្ពីរបាននិយាយថា អំណាចរបស់ផ្ទៃមេឃបានជួយច្បាំងនឹងពួកអ៊ីស្រាអែល(មើលការពន្យល់ ៤:៧ យស ១០:១១ ទដ ១៨:៧–១៥) ។

**៥:២១** *បានហូរនាំយកគេទៅបាត់* មើលការពន្យល់ ៤:៧ ។

**៥:២៣** *មេរ៉ូស* ដោយសារមនុស្សនៅទីនោះ បានបដិសេធមិនព្រមជួយពលទ័ពរបស់ព្រះយេហូវ៉ា ស្រុកទាំងប៉ុន្មានរបស់ពួកអ៊ីស្រាអែល ក្នុងអំបូរណៃបថាលី ត្រូវបានទទួលការបៀតបៀន និងទទួលនូវការវាយប្រហារពីសំណាក់ខ្មាំងសត្រូវ ហើយទីក្រុងផ្សេងៗទៀត ក៏ត្រូវទទួលទណ្ឌកម្មដែរ (មើល ៨:១៥–១៧ ២១:៥–១០) ។

**៥:២៥** *ខ្លាញ់ទឹកដោះ* គឺជាទឹកដោះមិនសុទ្ធ ដែលគេធ្វើឡើងដោយការក្រឡុកទឹកដោះនោះនៅក្នុងថង់ស្បែក ហើយគេយកតែមេទឹកដោះនោះ ។

**៥:២៨** នៅក្នុងតារាងនៃរូបភាពនេះ បានបង្ហាញពីការទន្ទឹងមើលផ្លូវរបស់ម្តាយ ស៊ីសេរ៉ាដោយអន្ទះសារ ។

**៥:៣១** នៅចុងបញ្ចប់នៃចម្រៀង គឺជាសេចក្តីអធិស្ឋាន ដែលនិយាយពីជ័យជម្នះរបស់ពួកកងពលរបស់ព្រះនៅពេលបច្ចុប្បន្ន និងពេលអនាគតរបស់ពួកពលទ័ពរបស់ព្រះយេហូវ៉ា(ជន ១០:៣៥ ទដ ៦៨:១–២) ។ *ខ្មាំងសត្រូវរបស់ទ្រង់ . . . ពួកអ្នកដែលស្រឡាញ់ទ្រង់* មានអាកប្បកិរិយា២បែបដែលបង្ហាញពីមនុស្សដែលគេរងចាំព្រះយេហូវ៉ា ។ ដូចអ្វីដែលព្រះយេហូវ៉ា ទ្រង់បានសន្យាជាមួយពួកព្ទកយុកោនៃពួកអ៊ីស្រាអែល ព្រះអង្គត្រូវការសេចក្តីស្រឡាញ់របស់ពួកគេ(មើល នក ២០:៦) ឱ្យដូចគ្នានឹងស្តេចនៅមជ្ឈឹមបុព៌ាសម័យបុរាណ ត្រូវការសេចក្តីស្រឡាញ់ពីរាស្ត្ររបស់គេដែរ ។

**៦:១** *សាសន៍ម៉ាឌាន* សូមមើលការពន្យល់ លប ៣៧:២៥ នក ២:១៥ ។ នៅពេលដែលពួកនេះគ្មានកំឡាំងទ័ពគ្រប់គ្រាន់ ដើម្បីធ្វើសង្គ្រាមជាមួយអ៊ីស្រាអែលគេបានចងសម្ព័ន្ធមិត្តជាមួយអ្នកជិតខាងរបស់គេ ដូចជាសាសន៍ម៉ូអាប់ (ជន ២២:៤–៦ ២៥:៦–១៨) សាសន៍អាម៉ាលេក និងក្រុមកុលសម្ព័ន្ធផ្សេងៗទៀតដែលនៅភាគខាងកើត (ខ.៣) ។ ជ័យជម្នះរបស់ពួកគេត្រូវបានគេចងចាំនៅក្នុងប្រវត្តិសាស្ត្រហេព្រើរជាយូរ (មើល ទដ ៨៣:៩ អស ៩:៤ ១០:២៦ ហព ៣:៧) ។

**៦:៣** *សាសន៍អាម៉ាលេក* សូមមើលការពន្យល់ លប ១៤:៧ ។ តាមធម្មតាពួកគេគឺជាប្រជាជន ឬជាក្រុមមនុស្សដែលរស់នៅក្នុងស្រុកត្បូង ប៉ុន្តែនៅទីនេះគេបានរួមគ្នាជាមួយពួកសាសន៍ម៉ាឌាន ហើយនិងជាមួយក្រុមមនុស្សផ្សេងទៀត ដែលស្ថិតនៅភាគខាងកើត គឺជាមួយពួកអ្នកដែលមកពីទីរហោរ

ទាស់ ៤ គេមកបោះទ័ពទាស់នឹងអ៊ីស្រាអែល ក៏បំផ្លាញអស់
ទាំងផល[ជ]កើតពីដី រហូតដល់ក្រុងកាសា[ឈ] ឥតមានទុក
ស្បៀងអាហារណា ឱ្យនៅក្នុងស្រុកអ៊ីស្រាអែលឡើយ ទោះ
ទាំងចៀម គោ ឬលាក្តី ៥ ដ្បិតគេឡើងមកទាំងដឹកហ្វូងសត្វ
និងត្រសាលរបស់គេមកដែរ គឺចូលមកមានគ្នាសន្ធឹកដូចជា
កណ្តូប[ញ] ឯខ្លួនគេនិងសត្វអូដ្ឋ[ដ]របស់គេ នោះរាប់មិនអស់
ឡើយ គេមកប្រយោជន៍តែនឹងបំផ្លាញស្រុកប៉ុណ្ណោះ ៦ ឯពួក
កូនចៅអ៊ីស្រាអែលត្រូវទុគ៌តទៅ ដោយព្រោះសាសន៍
ម៉ាឌាន ដូច្នេះគេអំពាវនាវ[ឋ]ដល់ព្រះយេហូវ៉ា ។

៧ កាលពួកកូនចៅអ៊ីស្រាអែល បានអំពាវនាវ[ឌ]ដល់ព្រះ
យេហូវ៉ា ដោយព្រោះសាសន៍ម៉ាឌាន ៨ នោះទ្រង់ក៏ចាត់
ហោរាម្នាក់[ឍ]មកឯគេ ប្រាប់ថា ព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា អញបាននាំ
ឯងរាល់គ្នាឡើងចេញពីស្រុកអេស៊ីព្ទ[ណ] គឺឱ្យចេញពីផ្ទះពួក
បាវបំរើមក[ត] ៩ អញបានដោះឱ្យរួចពីកណ្តាប់ដៃនៃពួក
សាសន៍អេស៊ីព្ទ និងពីកណ្តាប់ដៃនៃអស់អ្នកដែលសង្កត់
សង្កិនឯង[ថ] ក៏បានបណ្តេញគេពីមុខឯងចេញទៅ ហើយបាន
ឱ្យស្រុករបស់គេមកឯងរាល់គ្នាវិញ[ទ] ១០ អញបានប្រាប់ឯង
ថា អញជាព្រះយេហូវ៉ាជាព្រះនៃឯងរាល់គ្នា មិនត្រូវឱ្យឯង
ខ្លាច[ធ]ដល់អស់ទាំងព្រះរបស់សាសន៍អាម៉ូរី[ន] ដែលឯងនៅ
ស្រុកគេនោះឡើយ តែឯងរាល់គ្នាមិនបានស្តាប់តាមបង្គាប់
អញសោះ ។

១១ គ្រានោះ ទេវតានៃព្រះយេហូវ៉ា[ប] ក៏យាងមកគង់នៅ
ក្រោមដើមម៉ៃសាក់នៅត្រង់អូប្រា[ផ] ដែលជារបស់យ៉ូអាស[ព]
ក្នុងគ្រួអ័បៀស៊ើរ[ភ] រីឯគេឌាន[ម] ជាកូន គាត់កំពុងតែបោក[យ]
ស្រូវនៅក្នុងធុងគាបផ្លែទំពាំងបាយជូរ[រ] ដើម្បីលាក់នឹងពួក
ម៉ាឌាន ១២ ទេវតានៃព្រះយេហូវ៉ា ក៏លេចមកឱ្យលោក
ឃើញ ហើយប្រាប់ថា នែ អ្នកពូកែក្លាហានអើយ[ល] ព្រះ
យេហូវ៉ាទ្រង់គង់ជាមួយនឹងឯង[វ] ១៣ តែគេឌានឆ្លើយឡើង
ថា ឱព្រះអម្ចាស់នៃទូលបង្គំអើយ បើសិនជាព្រះយេហូវ៉ា
ទ្រង់គង់នៅជាមួយនឹងពួកទូលបង្គំពិត នោះហេតុអ្វីបាន
ជាការទាំងអស់នេះកើតឡើងដល់ពួកទូលបង្គំដូច្នេះ ឯអស់
ទាំងការអស្ចារ្យ[ស]របស់ទ្រង់ ដែលពួកឰយុកោបានថ្លែង[ហ]
ប្រាប់តមកថា ព្រះយេហូវ៉ាទ្រង់បាននាំយើងខ្ញុំឡើងចេញ
ពីស្រុកអេស៊ីព្ទមក តើការទាំងនោះនៅឯណា ដ្បិតឥឡូវ
នេះព្រះយេហូវ៉ា ទ្រង់បានបោះបង់ចោល[ឡ]ពួកទូលបង្គំ
ព្រមទាំងប្រគល់ទៅក្នុងកណ្តាប់ដៃ នៃពួកម៉ាឌានហើយ
១៤ នោះព្រះយេហូវ៉ាទ្រង់ទតមើលលោក ហើយមានបន្ទូល
ថា ចូរឯងទៅដោយសារកំឡាំងឯងនេះ[អ] ហើយជួយ
សង្គ្រោះ[ក]សាសន៍អ៊ីស្រាអែល ឱ្យរួចពីកណ្តាប់ដៃនៃពួក
ម៉ាឌានចុះ អញបានចាត់ឯងឱ្យទៅហើយ ១៥ រួចលោកទូល
ទ្រង់ថា ឱព្រះអម្ចាស់អើយ ធ្វើដូចម្តេចឱ្យទូលបង្គំជួយ
សង្គ្រោះដល់សាសន៍អ៊ីស្រាអែលបាន មើល ទូលបង្គំជាគ្រួ[ខ]
ក្រជាងគេក្នុងពួកម៉ាន៉ាសេ ហើយទូលបង្គំក៏ជាអ្នកតូចបំផុត

**៦:៤** ជ លវ ២៦:១៦ ចទ ២៨:៣០,៥១ អស ១០:៦ ៣៩:៦ ៤២:២២ ឈ លប ១០:១៩ **៦:៥** ញ ចទ ២៨:៤២ ដ ពច ៨:១០ អស ២១:៧ ៦០:៦ យរ ៤៩:៣២ **៦:៦** ឋ ពច ៣:៩ **៦:៧** ឌ ពច ៣:៩ **៦:៨** ឍ ចទ ១៨:១៥ ១ពវ ២០:១៣,២២ ២ពវ ១៧:១៣,២៣ នហ ៩:២៩ យប ៣៦:១០ យរ ២៥:៥ អគ ១៨:៣០–៣១ ណ ពច ២:១ ត យស ២៤:១៧ **៦:៩** ថ ជន ១០:៩ ទដ ១៣៦:២៤ ទ ទដ ៤៤:២ **៦:១០** ធ នក ២០:៥ ន យស ២៤:១៥ **៦:១១** ប លប ១៦:៧ ផ យស ១៨:២៣ ព ខ.២៩ ពច ៧:១៤ ៨:១៣,២៩

ភ ជន ២៦:៣០ ម ពច ៧:១ ៨:១ ហព ១១:៣២ យ នរ
២:១៧ ៣:២ ១សយ ២៣:១ ១រប ២១:២០ រ នហ ១៣:១៥ អស ១៦:១០
៦៣:៣ បទ ១:១៥ យអ ៣:១៣ **៦:១២** ល យស ១:៥ នរ ២:៤ ១សយ ១០:៧
ទដ ១២៩:៨ វ ពច ១១:១ **៦:១៣** ស យស ៣:៥ ហ ២សយ ៧:២២ ទដ ៤៤:១
៧៨:៣ ឡ ចទ ៣១:១៧ **៦:១៤** អ ហព ១១:៣៤ ក ខ.៣៦ ពច ១០:១ ២ពវ
១៤:២៧ **៦:១៥** ខ អស ៦០:២២

ស្ថានស្រុកម៉ូអាប់ ហើយនិងអាំម៉ូន ។

**៦:៥** *មានគ្នាសន្ធឹកដូចជាកណ្តូប* នៅត្រង់ចំណុចនេះ ប្រៀបប្រដូចទៅនឹងពួកចោរដែលមានគ្នាច្រើន ធ្វើដំណើរកាត់ទីកន្លែងណា ទីនោះនឹងត្រូវហិនហោច (៧:១២ នក ១០:១៣–១៥ យអ ១:៤) ។ *សត្វអូដ្ឋ* នៅក្នុងសញ្ញាចាស់ សត្វអូដ្ឋត្រូវបានគេយកមកប្រើ នៅពេលមានសង្គ្រាម(ប្រៀបធៀប លប ១២:១៦)។

**៦:៧** *អំពាវនាវដល់ព្រះយេហូវ៉ា* ជានិច្ចកាល នៅពេលដែលពួកអ៊ីស្រាអែលមានទុក្ខលំបាក គឺគេតែងតែអំពាវនាវដល់ព្រះយេហូវ៉ា ជាពិសេសក្នុងអំឡុងពេលគ្រាពួកចៅហ្វាយ(មើលសេចក្តីផ្តើម: លក្ខណៈអក្សរសាស្ត្រ) ។

**៦:៨** *ហោរា* មើលការពន្យល់ ២:១ និងរមើល ១០:១១ ។ ហោរាដែលមិនស្គាល់ឈ្មោះនេះ បានស្តីបន្ទោសចំពោះពួកអ៊ីស្រាអែល ព្រោះគេបានភ្លេចព្រះយេហូវ៉ា គឺជាព្រះដែលបានសង្គ្រោះពួកគេចេញពីស្រុកអេស៊ីព្ទ ព្រមទាំងជាអ្នកដែលបានផ្តល់ឱ្យគេនូវទឹកដីដ៏សន្ធឹកសន្ធាប់(មើល ខ.៩–១០) ។

**៦:១០** *សាសន៍អាម៉ូរី* នៅទីនេះប្រហែលជារាប់បញ្ចូលជាមួយនឹងពួកមនុស្សទាំងអស់ដែលបានតាំងលំនៅ នៅក្នុងស្រុកកាណាន(មើលការពន្យល់ លប ១០:១៦) ។

**៦:១១** *ទេវតានៃព្រះយេហូវ៉ា* សូមមើលការពន្យល់ លប ១៦:៧ ។ *អូប្រា* ទីកន្លែងសំខាន់ព្រមទាំងល្បីឈ្មោះ នៅក្នុងទឹកដីអំបូរបេនយ៉ាមីនដែលមានឈ្មោះអូប្រានេះដែរ (សូមមើល យស ១៨:២៣) ។ *គ្រួអ័បៀស៊ើរ* ពួកអ័បៀស៊ើរ(ខ.២៤) ពួកគេមកពីអំបូម៉ាន៉ាសេ(យស ១៧:២) ។

**៦:១២** *អ្នកពូកែក្លាហានអើយ* មើលទៅលោកគេឌានជាអ្នកមានឋានៈខ្ពស់ ហើយប្រហែលជានៅក្នុងវណ្ណៈអភិជន(ខ.២៧) ។

**៦:១៤** *ព្រះយេហូវ៉ាទ្រង់ទត* សូមមើល ខ.២៣ និង លប ១៦:៧ ។ *ចូរឯងទៅ . . . អញបានចាត់ឱ្យឯងទៅហើយ* លោកគេឌានបានសម្រេចក្នុងចិត្តថា នឹងរំដោះពួកអ៊ីស្រាអែល ដូចជាលោកម៉ូសេ បានធ្វើកន្លងមកដែរ (នក ៣:៧–១០) ។

**៦:១៥** *ធ្វើដូចម្តេចឱ្យទូលបង្គំ . . . បាន* សូមប្រៀបធៀបជាមួយការឆ្លើយតបរបស់លោកម៉ូសេ និងលោកយេរេមាចំពោះការត្រាស់ហៅរបស់ព្រះ (នក ៣:១១ ៤:១០ យរ ១:៦–៧ និងការពន្យល់) ។ ជានិច្ចកាល ព្រះយេហូវ៉ាទ្រង់តែងតែត្រាស់ហៅពួកអ្នក ដែលខ្សោយជាជាងពួកអ្នកដែលពូកែឱ្យទៅបម្រើការងារថ្វាយទ្រង់ (ជន ១២:៣ និងការពន្យល់ លក ២៥:២៣ ១សយ ៩:២១) ។

ក្នុងពួកផ្ទះឪពុកទូលបង្គំផង[ក] ១៦ព្រះយេហូវ៉ាទ្រង់មានបន្ទូល
តបថា អញនឹងនៅជាមួយនឹងឯង[ឃ] ឯងនឹងវាយសាសន៍
ម៉ាឌានដូចជាវាយដល់មនុស្សតែម្នាក់ ១៧លោកទូលថា បើ
ទូលបង្គំប្រកបដោយព្រះគុណនៃទ្រង់ នោះសូមទ្រង់សំដែង
ទីសំគាល់[ង]ឱ្យទូលបង្គំបានដឹងផង ថាគឺទ្រង់ហើយដែលមាន
បន្ទូលនឹងទូលបង្គំពិតមែន ១៨សូមទ្រង់កុំថយចេញពីទីនេះ
ឡើយ ដរាបដល់ទូលបង្គំទៅនាំយកដង្វាយរបស់ទូលបង្គំ
មកថ្វាយនៅចំពោះទ្រង់សិន ទ្រង់ក៏ទទួលថា អញនឹងចាំ
ទាល់តែឯងមកវិញ ។
១៩ដូច្នេះ គេឌានក៏ចូលទៅក្នុងផ្ទះ ចាត់ចែងរៀបចំកូន
ពពែ១[ច] និងនំបុ័ងឥតដំបែធ្វើពីម្សៅ១ថាំង[ឆ]ដាក់សាច់ក្នុង
កញ្ច្រែង ហើយក៏ដាក់ទឹកសំឡក្នុងចាន នាំយកមកថ្វាយទ្រង់
នៅត្រង់ដើមម៉ៃសាក់នោះ[ជ] ២០នោះទេវតានៃព្រះក៏មាន
បន្ទូលប្រាប់ថា ចូរយកសាច់ និងនំបុ័ងឥតដំបែនោះ មក
ដាក់នៅលើថ្មនេះ[ឈ] ហើយចាក់ទឹកសំឡពីលើទៅ លោកក៏
ធ្វើតាមដូច្នោះ ២១រួចទេវតានៃព្រះយេហូវ៉ាក៏លូកចុង
ដំបង[ញ] ដែលកាន់នៅព្រះហស្ត ទៅពាល់សាច់ និងនំបុ័ងឥត
ដំបែ នោះក៏មានភ្លើងចេញពីថ្មបញ្ឆេះសាច់ និងនំបុ័ងឥត
ដំបែ[ដ]អស់រលីងទៅ លុះស្រេចហើយ ទេវតានៃព្រះ
យេហូវ៉ា ក៏យាងចេញពីមុខបាត់ទៅ ២២គេឌានក៏បានដឹង
ថា[ឋ] ជាទេវតា នៃព្រះយេហូវ៉ា បានជាលោកទូលថា វរ
ហើយ ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់អើយ ដ្បិតទូលបង្គំបាន
ឃើញទេវតា នៃព្រះយេហូវ៉ានៅប្រទល់មុខ[ឌ] ២៣ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលតបមកថា ចូរឱ្យមានសេចក្ដីសុខចុះ
កុំឱ្យភ័យអី[ឍ] ឯងមិនត្រូវស្លាប់ទេ[ណ] ២៤នោះគេឌានក៏ស្អាង
អាសនា១ ថ្វាយព្រះយេហូវ៉ានៅទីនោះរួចដាក់ឈ្មោះ[ត]ថា
"យេហូវ៉ា-សាឡិម" អាសនានោះក៏នៅត្រង់អូប្រា[ថ]របស់
ផងពួកអ័បៀស៊ើរ ដរាបដល់សព្វថ្ងៃនេះ ។
២៥នៅវេលាយប់នោះឯង ព្រះយេហូវ៉ា ទ្រង់បង្គាប់
លោកថា ចូរនាំយកគោឈ្មោលរបស់ឪពុកឯង គឺជាគោទី
២អាយុ៧ខួបទៅជាមួយ ត្រូវឱ្យឯងរំលំអាសនានៃព្រះបាល
របស់ឪពុកឯងចេញទៅ ព្រមទាំងកាប់បំផ្លាញអ្នកតា[ទ]
ដែលនៅក្បែរទីនោះផង ២៦រួចស្អាងអាសនា១ថ្វាយព្រះ
យេហូវ៉ាជាព្រះនៃឯង តាមរបៀបនៅលើថ្មដានោះ ហើយ
ត្រូវយកគោទី២ថ្វាយជាដង្វាយដុត ដោយដុតនឹងឈើជា
រូបអ្នកតា ដែលឯងបានកាប់នោះ[ធ] ២៧ដូច្នេះគេឌានក៏
នាំយកអ្នកបំរើរបស់ខ្លួន១០នាក់ ទៅធ្វើតាមដូចជាព្រះ
យេហូវ៉ាបានមានបន្ទូលប្រាប់ តែលោកធ្វើនៅពេលថ្ងៃ
មិនបានដោយព្រោះខ្លាចពួកអ្នកផ្ទះរបស់ឪពុកខ្លួន និងពួក
មនុស្ស នៅទីក្រុងនោះ បានជាធ្វើនៅពេលយប់វិញ ។
២៨កាលពួកមនុស្សនៅទីក្រុង បានក្រោកឡើងពីព្រលឹម
ឃើញអាសនានៃព្រះបាលបានរលំហើយ[ន] ឯអ្នកតាក៏បាន
កាប់ចោលផង ហើយគោទី២បានថ្វាយនៅលើអាសនាដែល
បានស្អាងឡើង ២៩នោះគេនិយាយគ្នាទៅវិញទៅមកថា តើ
អ្នកណាបានធ្វើនេះ គេក៏ស៊ើបសួររក រួចមានគេប្រាប់ថា គឺ
គេឌានជាកូនយ៉ូអាស[ប]បានធ្វើការនោះ ៣០ដូច្នេះពួកមនុស្ស
នៅទីក្រុង គេប្រាប់ទៅយ៉ូអាសថា ចូរនាំកូនអ្នកចេញមកឱ្យ
វាស្លាប់ទៅ ដ្បិតវាបានរំលំអាសនានៃព្រះបាល[ផ] ហើយ
កាប់បំផ្លាញរូបអ្នកតាដែលនៅក្បែរទីនោះផង ៣១យ៉ូអាសក៏
ឆ្លើយទៅអស់អ្នកដែលមកទាស់នឹងគាត់ថា តើអ្នករាល់គ្នា
ចង់តវ៉ាជំនួស ហើយគិតជួយសង្គ្រោះព្រះបាលឬអី[ព] ឯអ្នក
ណាដែលចង់តវ៉ាជំនួសព្រះបាល ឱ្យអ្នកនោះត្រូវស្លាប់វិញ
ឥឡូវមុនដែលថ្ងៃរះផង បើនេះជាព្រះពិត នោះចូរឱ្យវា
តវ៉ាដោយខ្លួនវាចុះ ដោយព្រោះគេបានរំលំអាសនាហើយ
៣២ហេតុនោះបានជានៅថ្ងៃនោះឯង គេហៅគេឌានថា
យេរូ-បាល[ភ] ដោយព្រោះពាក្យដែលថា ចូរឱ្យព្រះបាល

**៦:១៥** ក ១សយ ៩:២១ **៦:១៦** ឃ នក ៣:១២ ជន ១៤:៤៣ យស ១:៥ **៦:១៧** ង ខ.៣៦-៣៧ លប ២៤:១៤ នក ៣:១២ ៤:៨ **៦:១៩** ច ពច ១៣:១៥ ឆ លវ ១៩:៣៦ ជ លប ១៨:៧-៨ **៦:២០** ឈ ពច ១៣:១៩ **៦:២១** ញ នក ៤:២ ដ លវ ៩:២៤ **៦:២២** ឋ ពច ១៣:១៦,២១ ឌ លប ៣២:៣០ ពច ១៣:២២ **៦:២៣** ឍ ដយ ១០:១៩ ណ លប ១៦:១៣ ចទ ៥:២៦ **៦:២៤** ត លប ២២:១៤ ថ យស ១៨:២៤ **៦:២៥** ទ ខ.២៦,២៨ ៣០ នក ៣៤:១៣ ពច ២:១៣ **៦:២៦** ធ លប ៨:២០ **៦:២៨** ន ខ.៣០ ១ពវ ១៦:៣២ ២ពវ ២១:៣ **៦:២៩** ប ខ.១១ **៦:៣០** ផ ខ.២៨

**៦:៣១** ព ១សយ ២៤:១៥ ទដ ៤៣:១ យរ ៣០:១៣ **៦:៣២** ភ ពច ៧:១ ៨:២៩,៣៥ ៩:១ ១សយ ១២:១១

**៦:១៧** *សូមទ្រង់សំដែងទីសំគាល់* មើល ខ.៣៦-៤ ។ សូមប្រៀបធៀប ទីសម្គាល់ដែលព្រះយេហូវ៉ា ទ្រង់បានប្រទានឱ្យលោកម៉ូសេ ដើម្បីផ្តល់ទំនុកចិត្តដល់គាត់ ឱ្យគាត់ព្រមទទួលការងារដែលព្រះអម្ចាស់បានឱ្យ (នក ៣:១២ ៤:១-១៧) ។

**៦:២១** *បញ្ឆេះសាច់* ចង់បង្ហាញថា ដង្វាយរបស់គេឌានត្រូវបានព្រះយេហូវ៉ាសព្វព្រះទ័យ (លវ ៩:២៤) ។

**៦:២៣** *ឯងមិនត្រូវស្លាប់ទេ* សូមមើល ១៣:២២ និងការពន្យល់ លប ១៦:១៣ ៣២:៣០ ។

**៦:២៥** *រំលំអាសនា* ការងារដំបូងរបស់លោកគេឌាន គឺរំលំអស់ទាំងអាសនារបស់ព្រះបាល ដែលជាព្រះរបស់ឪពុកគាត់ ក្នុងនាមគាត់ជាទាហានរបស់ព្រះយេហូវ៉ា (ធៀបជាមួយ ២:២ នក ៣៤:១៣ ចទ ៧:៥) ។ *ព្រះបាល* មើលការពន្យល់ ២:១៣ ។ *អ្នកតា* មើលការពន្យល់ ២:១៣ និងរមើល នក ៣៤:១៣ ។

**៦:២៦** *អាសនា* មើល នក ២០:២៥ ។

**៦:៣០** *ឱ្យវាស្លាប់ទៅ* ពួកកូនចៅអ៊ីស្រាអែលគេបោះបង់ព្រះចោលជាញឹកញាប់ ហើយទៅគោរពព្រះបាល ដូច្នេះ នៅពេលមានអ្នកណាម្នាក់មកបំផ្លាញព្រះបាល គេនឹងសម្លាប់ចោល (ផ្ទុយពី ចទ ១៣:៦-១០ ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេឱ្យសម្លាប់ពួកដែលគោរពលើព្រះបាល ដោយចោលនឹងថ្ម) ។

**៦:៣២** *យេរូ-បាល* មើល ២សយ ១១:២១ ។ *ចូរឱ្យព្រះបាលតវ៉ាដោយខ្លួន*

តវ៉ាដោយខ្លួនឯងចុះ គឺពីព្រោះបានរំលំអាសនាគេហើយ ។
៣៣គ្រានោះពួកសាសន៍ម៉ាឌានទាំងប៉ុន្មាន និងពួកអាម៉ា
លេក[ម] ព្រមទាំងពួកមនុស្សនៅស្រុកខាងកើត[យ] ក៏មូលគ្នា
ឆ្លងទន្លេ មកបោះទ័ពនៅត្រង់វាលច្រកភ្នំយេសរាល[រ]
៣៤នោះព្រះវិញ្ញាណនៃព្រះយេហូវ៉ា ទ្រង់យាងមកសណ្ឋិត
លើ[ល]គេឌាន លោកក៏ផ្លុំត្រែឡើង[វ] នោះពួកអ័បៀស៊ើរ[ស]ក៏
មូលគ្នាមកតាមលោក ៣៥រួចលោកចាត់មនុស្សឱ្យទៅគ្រប់
ក្នុងស្រុកម៉ាន៉ាសេ គេក៏មូលគ្នាមកតាមលោកដែរ រួចគាត់
ចាត់មនុស្សឱ្យទៅឯពួកអេស៊ើរ[ហ] ពួកសាប់យូល៉ូន និងពួក
ណែបថាលីទៀត[ឡ] គេក៏មូលមកឯលោកទាំងអស់គ្នា[អ] ។
៣៦ស្រេចហើយ គេឌានទូលដល់ព្រះថា បើសិនជា
ព្រះអង្គទ្រង់សព្វព្រះហឫទ័យនឹងជួយសង្គ្រោះ[ក]ដល់សាសន៍
អ៊ីស្រាអែល ដោយសារដៃរបស់ទូលបង្គំដូចជាទ្រង់បាន
មានបន្ទូលហើយ ៣៧នោះមើល ទូលបង្គំដាក់រោមចៀម
នេះ[ខ]នៅទីលានស្រូវ[គ] ដូច្នេះបើឃើញសន្សើមមាននៅតែ
នឹងរោមចៀមប៉ុណ្ណោះ ហើយដីទាំងអស់ស្ងួតវិញ នោះទូល
បង្គំនឹងដឹង[ឃ]ថា ទ្រង់ជួយសង្គ្រោះដល់សាសន៍អ៊ីស្រាអែល
ដោយសារដៃទូលបង្គំពិតមែន ដូចជាទ្រង់បានមានបន្ទូល
ហើយ ៣៨នោះក៏កើតមានដូច្នោះ លុះថ្ងៃស្អែកឡើងលោក
ក្រោកពីព្រលឹមទៅច្របាច់ពូតរោមចៀមនោះ បានទឹក
សន្សើមពេញ១ចាន ៣៩រួចគេឌានទូលទៅព្រះថា សូមទ្រង់
កុំខ្ញាល់នឹងទូលបង្គំឡើយ ទូលបង្គំនឹងទូលតែម្តងណេះទេ
គឺសូមឱ្យទូលបង្គំសាកដោយរោមចៀមនេះម្តងទៀត[ង] សូម
ឱ្យតែរោមចៀមនេះបានស្ងួតទៅ ហើយឱ្យដីមានទឹក
សន្សើមវិញ ៤០ព្រះទ្រង់ក៏ធ្វើដូច្នោះនៅយប់នោះ គឺរោម
ចៀមនៅជាស្ងួត តែនៅពេញលើដី មានសុទ្ធតែទឹក
សន្សើមវិញ[ច] ។

## លោកគេឌានយកជ័យជម្នះលើពួកម៉ាឌាន

**៧** ១ដូច្នេះ យេរូ–បាល[ក] គឺជាគេឌាន[ខ] និងពួកមនុស្សទាំង
ប៉ុន្មាន ដែលនៅជាមួយនឹងលោក ក៏ក្រោកឡើងពីព្រលឹម
ទៅបោះទ័ពនៅជិតក្បាលទឹកហារ៉ុឌ[គ] ឯពួកម៉ាឌាន[ឃ]បាន
បោះទ័ពនៅពីខាងជើងគេ ជិតភ្នំម៉ូរេ[ង]ត្រង់វាលច្រកភ្នំនោះ
២ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅគេឌានថា ចំនួនមនុស្ស
ដែលនៅជាមួយនឹងឯង មានគ្នាច្រើនពេកណាស់ និងឱ្យ
អញប្រគល់ពួកម៉ាឌានមក ក្នុងកណ្តាប់ដៃគេមិនបានឡើយ
ក្រែងពួកអ៊ីស្រាអែលអួតខ្លួន ទាស់នឹងអញវិញ ដោយថា
អញ[ច]បានជួយសង្គ្រោះខ្លួនអញទេ ៣ដូច្នេះចូរប្រកាសប្រាប់
ដល់ត្រចៀកបណ្តាជនថា អ្នកណាដែលមានសេចក្តីភ័យញ័រ
ចូរឱ្យអ្នកនោះវិលពីភ្នំកាឡាត[ឆ]ត្រឡប់ទៅវិញចុះ នោះមាន
មនុស្សចំនួន២ម៉ឺន២ពាន់នាក់បានត្រឡប់វិលទៅវិញ នៅ
សល់តែ១ម៉ឺននាក់ប៉ុណ្ណោះ ៤រួចព្រះយេហូវ៉ាមានបន្ទូល
ទៅគេឌានទៀតថា បណ្តាមនុស្សនៅតែច្រើនពេក[ជ]នៅ
ឡើយ ដូច្នេះចូរនាំគេចុះទៅឯទឹកទៅអញនឹងល្បងលគេ
ឱ្យឯង អ្នកណាខ្លះដែលអញប្រាប់ឯងថា នេះត្រូវទៅជា
មួយនឹងឯង គឺអ្នកនោះហើយដែលត្រូវទៅ ឯអ្នកណាដែល
អញប្រាប់ឯងថា នេះមិនត្រូវទៅជាមួយទេ អ្នកនោះឯង
ត្រូវនៅវិញ ៥ដូច្នេះលោកក៏នាំគេចុះទៅឯទឹក រួចព្រះ
យេហូវ៉ាទ្រង់មានបន្ទូលប្រាប់ថា បណ្តាអស់អ្នកណាដែល
លិទ្ធទឹកនឹងអណ្តាតដូចជាឆ្កែ នោះត្រូវដាក់ទុកនៅដោយ
ខ្លួន ហើយអស់អ្នកណាដែលលុតជង្គង់ផឹកទឹក នោះក៏ត្រូវ
ដាក់ដោយខ្លួនដែរ ៦ឯពួកមនុស្សដែលលិទ្ធទឹកដោយក្បង់
នឹងដៃ នោះមានចំនួនជា៣០០នាក់[ឈ] ក្រៅពីនោះសុទ្ធតែជា

**៦:៣៣** ម ជន ១៣:២៩ យ លប ២៥:៦ រ យស ១៥:៥៦ អគ ២៥:៤ ហស ១:៥
**៦:៣៤** ល ពច ៣:១០ វ យស ៦:២០ ពច ៣:២៧ ស យស ១៧:២
**៦:៣៥** ហ យស ១៧:៧ ឡ ពច ៤:៦ អ ពច ៧:២៣
**៦:៣៦** ក ខ.១៤
**៦:៣៧** ខ យប ៣១:២០ គ ជន ១៨:២៧ ២សយ ៦:៦ ២៤:១៦ ឃ លប ២៤:១៤
**៦:៣៩** ង លប ១៨:៣២
**៦:៤០** ច នក ៤:៣–៧ អស ៣៨:៧
**៧:១** ក ពច ៦:៣២ ខ ពច ៦:១១ គ ២សយ ២៣:២៥ ឃ លប ២៥:២ ង លប ១២:៦
**៧:២** ច ចទ ៨:១៧ ២កថ ៤:៧
**៧:៣** ឆ ចទ ២០:៨ យស ១២:២
**៧:៤** ជ ១សយ១៤:៦
**៧:៦** ឈ លប ៤:១៤

*ឯងចុះ* មានន័យថា ឱ្យព្រះបាលតវ៉ាជាមួយនឹងលោកគេឌាន ដោយខ្លួនឯងចុះ ។

**៦:៣៣** *ច្រកភ្នំយេសរាល* សូមមើលការពន្យល់ ៥:១៩ ។

**៦:៣៤** *ព្រះវិញ្ញាណ . . . មកសណ្ឋិត* តាមលក្ខណៈអក្សរសាស្ត្រ បាននិយាយថា "ព្រះវិញ្ញាណបានតែងអង្គយ៉ាងភ្លឺចិញ្ចាចបែបនេះ" គឺមានតែ៣ដងប៉ុណ្ណោះ (មើល ១រប ១២:១៨ ២រប ២៤:២០) នៅក្នុងខគម្ពីរទាំងនោះ បាននិយាយថា ព្រះវិញ្ញាណនៃព្រះយេហូវ៉ា បានផ្តល់អំណាចឱ្យមនុស្សជាបណ្តោះអាសន្ន ហើយព្រះអង្គទ្រង់បានធ្វើការងារនេះតាមរយៈទ្រង់ផ្ទាល់ (មើលការពន្យល់ ៣:១០) ។

**៦:៣៥** *ម៉ាន៉ាសេ* គឺម៉ាន៉ាសេខាងលិច ។ *អេស៊ើរ* ពូជអំបូរនេះ កាលពីមុនបានបដិសេធចំពោះការត្រាស់ហៅ ឱ្យធ្វើជាអ្នកចម្បាំងរបស់ព្រះយេហូវ៉ា (មើល ៥:១៧) ។

**៦:៣៩** *កុំខ្ញាល់នឹងទូលបង្គំឡើយ ទូលបង្គំនឹងសូមតែម្តងណេះទេ* សូមប្រៀបធៀបជាមួយលោកអ័ប្រាហាំ នៅក្នុង ១៨:៣២ ។

**៧:១–៨** ដូចជាអ្វីដែលព្រះយេហូវ៉ា ទ្រង់បានបង្គាប់ដល់ពួកអ៊ីស្រាអែលកាលពីមុនព្រះទ្រង់ជាអ្នករៀបចំទ័ពសម្រាប់អ៊ីស្រាអែល ដូច្នេះពួកកូនចៅអ៊ីស្រាអែលត្រូវតែចងចាំថា ជ័យជម្នះទាំងនោះគឺព្រះយេហូវ៉ាទ្រង់ជាអ្នកធ្វើឱ្យគេទទួលជ័យជម្នះនេះ មិនមែនពួកគេផ្ទាល់ជាអ្នកឈ្នះនោះឡើយ ។

**៧:១** *ហារ៉ុឌ* មានន័យថា "ភ័យញ័រ" គឺសំដៅលើការភ័យខ្លាចចំពោះពួកអ៊ីស្រាអែល ឬការភ័យខ្លាចរបស់សាសន៍ម៉ាឌាន (ខ.៣) នៅពេលឃើញពួកគេឌាន (ខ.២) ។ តាមទម្រង់កិរិយាស័ព្ទរបស់ហេព្រើរ ពាក្យនេះមានន័យថា "បំបាក់ទ័ព" ក្នុង ៨:១២ ។ *វាលច្រកភ្នំ* គឺជាវាលច្រកភ្នំយេសរាល ។ *ភ្នំម៉ូរេ* ភ្នំនេះជាមានចម្ងាយប្រហែលជា ៦,៤ គម ពីបន្ទាយអ៊ីស្រាអែល ។

**៧:៣** *ឱ្យអ្នកនោះវិល* អស់អ្នកណាដែលភ័យខ្លាចចំពោះចម្បាំង គឺជាពួកអ្នកដែលមិនអាចចេញទៅជាមួយពលទ័ពរបស់លោកគេឌាន ដើម្បីនឹងបង្ខូចកងទ័ពដទៃទៀតបានទេ នោះត្រូវឱ្យអ្នកទាំងនោះត្រឡប់ទៅវិញ (ចទ ២០:៨) ។ *ភ្នំកាឡាត* ប្រហែល ជាភ្នំដែលគេប្រើនៅកន្លែងផ្សេងទៀត ដែលមានឈ្មោះថាភ្នំគីលបោ ។

អ្នកលុតជង្គង់ផឹកទាំងអស់ ⁷ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ប្រាប់គេឌានថា អញនឹងជួយសង្គ្រោះឯងរាល់គ្នា ហើយ
ប្រគល់ពួកម៉ាឌានមកក្នុងកណ្តាប់ដៃឯង[ញ]ដោយសារមនុស្ស
៣០០នាក់ ដែលក្សង់ទឹកផឹកនេះ ឯមនុស្សឯទៀត នោះត្រូវ
ឱ្យគេត្រឡប់ទៅឯទីកន្លែងរបស់គេវិញទៅ[ដ] ⁸ដូច្នេះគេឌាន
ក៏ឱ្យពួកអ៊ីស្រាអែលត្រឡប់ទៅឯទីលំនៅគេរៀងខ្លួន បាន
ទុកនៅតែពួក៣០០នាក់នោះប៉ុណ្ណោះ ពួកនោះគេក៏យក
ស្បៀងអាហារនិងត្រែរបស់គេទៅ ឯពួកម៉ាឌានគេបាន
បោះទ័ព នៅកន្លែងខាងក្រោមលោក ក្នុងវាលច្រកភ្នំ ។
⁹នៅវេលាយប់នោះឯង ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ប្រាប់លោកថា ចូរក្រោកឡើងចុះទៅឯទីបោះទ័ពរបស់គេ
ទៅ ដ្បិតអញបានប្រគល់គេមកក្នុងកណ្តាប់នៃឯងហើយ[ឋ]
¹⁰តែបើឯងខ្លាចនឹងទៅ នោះឱ្យនាំពូរ៉ា ជាអ្នកបំរើរបស់
ឯង ចុះទៅជាមួយផងចុះ ¹¹ឯងនឹងបានឮសេចក្តីដែលគេ
ថា ហើយលំដាប់នោះឯងនឹងមានកំឡាំងដៃខ្លាំងឡើង អាច
ចុះទៅទាស់នឹងគេបាន ដូច្នេះលោកនឹងពូរ៉ា ជាអ្នកបំរើ ក៏
ចុះទៅដល់ជិតកន្លែងក្រៅបំផុតនៃពួកពលដែលបោះទ័ព
នៅ ¹²រីឯពួកម៉ាឌាននិងពួកអាម៉ាលេក[ឌ] ហើយនិងពួក
មនុស្សពីស្រុកខាងកើត គេនៅរាយដេរដាសក្នុងវាលច្រក
ភ្នំ មានគ្នាច្រើនណាស់ដូចជាកណ្តូប[ឍ] សត្វអូដ្ឋ[ណ]របស់គេ
ក៏មានច្រើនជាពន្លឹកឥតគណនា ដូចជាខ្សាច់ដែលនៅមាត់
សមុទ្រ[ត] ¹³កាលគេឌានមកដល់ហើយ នោះមានមនុស្ស
ម្នាក់កំពុងតែនិយាយសប្តិប្រាប់ដល់គូកនខ្លួនថា មើលអញ
យល់សប្តិឃើញ មាននំបុ័ងម្សៅឱក១ដុំ រមៀលចុះមកក្នុង
ទីបោះទ័ព នៃពួកម៉ាឌានយើងនេះ ក៏មកទង្គិចនឹងត្រសាល
ធ្វើឱ្យរលំផ្ងារឡើងរាបទៅនឹងដី ¹⁴គូកនគេក៏ឆ្លើយឡើង
ថា នោះមិនគឺជាអ្វីទេ គឺជាដាវរបស់គេឌានជាកូនយ៉ូអាស[ថ]
សាសន៍អ៊ីស្រាអែលម្នាក់ ដែលព្រះបានប្រគល់ពួកម៉ាឌាន

**៧:៧** ញ យស ៨:៧ ដ ១សយ ១៤:៦
**៧:៩** ឋ ខ.១៣–១៥ យស ២:២៤ ពច ១:២
**៧:១២** ឌ ជន ១៣:២៩ ឍ ចទ ២៨:៤២ យរ ៤៦:២៣ ណ យរ ៤៩:២៩ ត យស ១១:៤
**៧:១៤** ថ ពច ៦:១១
**៧:១៥** ទ ១សយ ១៥:៣១ ធ ខ.៩
**៧:១៦** ន លប ១៤:១៥ ប ពច ៩:៤៣ ១សយ ១១:១១ ២សយ ១៨:២ ផ លប ២៥:៩ ព ខ.១៩ លប ២៤:១៤ ភ លប ១៥:១៧
**៧:១៨** ម ពច ៣:២៧
**៧:១៩** យ ខ.១៦
**៧:២០** រ លប ១៥:១៧ ល ចទ ៣២:៤១
**៧:២១** វ ២ពវ ៧:៧
**៧:២២** ស យស ៦:២០ ហ ១សយ ១៤:២០ ២របា ២០:២៣ អស ៩:២១ ១៩:២ អគ ៣៨:២១ ហក ២:២២ សក ១៤:១៣ ឡ ហព ៣:១៤

យើងនេះ ព្រមទាំងកងទ័ពយើងទាំងអស់ ទៅក្នុងកណ្តាប់
ដៃគេហើយ ។
¹⁵នោះក៏កើតដូច្នោះមែន កាលគេឌានបានឮរឿងនៃ
សប្តិនោះ និងសេចក្តីសំរាយដូច្នេះ នោះលោកក៏ក្រាបថ្វាយ
បង្គំ[ទ] រួចត្រឡប់មកឯទីបោះទ័ពខាងពួកអ៊ីស្រាអែលប្រាប់
ថា ចូរក្រោកឡើង ដ្បិតព្រះយេហូវ៉ាបានប្រគល់ពួកកង
ទ័ពម៉ាឌាន មកក្នុងកណ្តាប់ដៃឯងរាល់គ្នាហើយ[ធ] ¹⁶លោក
ក៏ចែកពួក៣០០នាក់[ន]ចេញជា៣ពួក[ប] ប្រគល់ត្រែ[ផ]ឱ្យកាន់
គ្រប់ៗគ្នា ព្រមទាំងក្អម[ព] មានចន្លុះ[ភ]នៅខាងក្នុងផង ¹⁷រួច
បង្គាប់ថា ចូរមើលមកអញ ហើយធ្វើតាមអញចុះ គឺកាល
ណាអញទៅដល់ទីបោះទ័ព ដែលនៅខាងក្រៅបំផុត នោះ
ត្រូវឱ្យឯងធ្វើដូចជាអញ ¹⁸គឺកាលណាអញផ្លុំត្រែឡើង ព្រម
ទាំងពួកអ្នកនៅជាមួយនឹងអញ នោះត្រូវឱ្យឯងរាល់គ្នា
ផ្លុំត្រែឡើង[ម] នៅព័ទ្ធជុំវិញទីបោះទ័ពដែរ ហើយបញ្ចេញ
វាចាថា នេះហើយជាដាវផងព្រះយេហូវ៉ា ហើយរបស់ផង
គេឌានដែរ ។
¹⁹ដូច្នេះគេឌាន និងពួក១០០នាក់ដែលនៅជាមួយក៏មក
ដល់ទីបោះទ័ពខាងក្រៅបំផុត នៅវេលាចូលយាមជា
កណ្តាល កាលគេទើបនឹងផ្លាស់យាម នោះក៏ផ្លុំត្រែឡើង
ហើយបំបែកក្អម[យ]ដែលកាន់នៅដៃ ²⁰ពួកទាំង៣បានផ្លុំត្រែ
ហើយបំបែកក្អមគ្រប់គ្នា រួចកាន់ចន្លុះ[រ]នៅដៃឆ្វេង ហើយ
ត្រែនៅដៃស្តាំសំរាប់នឹងផ្លុំ ក៏ស្រែកឡើងថា នេះហើយជា
ដាវ[ល]ផងព្រះយេហូវ៉ា ហើយរបស់ផងគេឌានដែរ ²¹គេក៏
ឈរនឹង នៅត្រង់កន្លែងគេរៀងខ្លួន នៅព័ទ្ធជុំវិញទីបោះ
ទ័ព ឯពួកទ័ពនោះក៏តាំងរត់ ទាំងស្រែកឡើង ហើយខំឱ្យរួច
ផង[វ] ²²នោះពួក៣០០នាក់ក៏ផ្លុំត្រែឡើង[ស] ហើយព្រះយេ
ហូវ៉ា ទ្រង់បណ្តាលឱ្យគេកាប់សំឡាប់គ្នាឯង[ហ]ទៅវិញទៅ
មក[ឡ] នៅពេញក្នុងកំឡុងកងទ័ពរបស់គេ ពួកទ័ពគេក៏រត់

**៧:៦** *ក្សង់* មនុស្សចំនួន៣០០នាក់បានឈរត្រៀមខ្លួន ដើម្បីក្សង់ទឹកផឹក ប្រហែលគេធ្វើរបៀបនេះ តែមួយរយៈពេលខ្លីប៉ុណ្ណោះ ។

**៧:៨–១៤** ព្រះយេហូវ៉ាបានលើកទឹកចិត្តដល់លោកគេឌាន ដោយផ្តល់ឱ្យគាត់នូវកងទ័ពដែលថ្មីកនឹងចម្បាំង ។

**៧:១៣–១៤** ទោះបីជាមានការបើកសម្តែង មានជាញឹកញាប់នៅក្នុងសញ្ញាចាស់ក៏ដោយ ក៏នៅទីនេះ អ្នកដែលត្រូវទទួលសប្តិ និងកាត់ស្រាយ មិនមែនជាសាសន៍អ៊ីស្រាអែលឡើយ ។ ផ្ទុយពីយ៉ូសែបដែលជាអ្នកកាត់ស្រាយសប្តិនៅក្នុងស្រុកអេស៊ីព្ទ (លប ៤០:១–២២ ៤១:១–៣២) និងដានីយ៉ែលជាអ្នកកាត់ស្រាយសប្តិ នៅបាប៊ីឡូន (ដយ ២:១–៤៥ ៤:៤–២៧) ។

**៧:១៣** *មាននំបុ័ងម្សៅឱក១ដុំ* នៅពេលនោះ ម្សៅឱកត្រូវបានគេចាត់ទុកថាជាធញ្ញជាតិមានតម្លៃទាប គឺមានតម្លៃទាបជាងស្រូវសាលីពាក់កណ្តាល (២ពវ ៧:១) វាជានិមិត្តរូបមួយដ៏សក្តិសមសម្រាប់ប្រជាជនអ៊ីស្រាអែលដែលគេគិតថា ពួកអ៊ីស្រាអែលមានចំនួនតិច ហើយជាអ្នកមានសណ្ឋានអន់បំផុត ។

**៧:១៦** *៣ពួក* នោះគឺជាយុទ្ធសាស្ត្រមួយរបស់ពួកអ៊ីស្រាអែលនៅក្នុងសង្គ្រាម (មើល ៩:៤៣ ១សយ ១១:១១ ២សយ ១៨:២) ។ *ត្រែ* គឺជាត្រែធ្វើឡើងពីស្នែង (នក ១៩:១៣) ។

**៧:១៩** *នៅវេលាចូលយាមជាកណ្តាល* ពួកអ៊ីស្រាអែលបែងចែកពេលយប់ជា៣យាម (មើលការពន្យល់ មថ ១៤:២៥) ។ វេលាចូល"ពាក់កណ្តាលយាម" គឺជាពេលមួយបន្ទាប់ពីខ្មាំងសត្រូវចូលដេក ។

**៧:២២** *៣០០នាក់ក៏ផ្លុំត្រែ* ជាទូទៅមានកងទ័ពតិចណាស់ដែល ដែលជាអ្នកកាន់ត្រែនៅពេលចេញទៅធ្វើសង្គ្រាម ។ *កាប់សំឡាប់គ្នាឯងទៅវិញទៅមក*

រហូតដល់បេត-ស៊ីតា ខាងសេរេរ៉ា ហើយរហូតដល់ព្រំ
អេបិល-មហូឡា[អ] ជិតតាបាត ២៣នោះពួកអ៊ីស្រាអែលគេ
ប្រមូលគ្នា[ក]ពីខែត្រណែបថាលី ខែត្រអេស៊ើរ[ខ] និងស្រុក
ម៉ាន៉ាសេទាំងមូល មកដេញតាមពួកម៉ាឌាន[គ] ។
២៤ឯគេឌានក៏ចាត់មនុស្ស ឱ្យទៅពេញក្នុងស្រុកភ្នំអេប្រា
អិម ប្រាប់ថា ចូរនាំគ្នាចុះមក ចាំស្កាត់ផ្លូវសាសន៍ម៉ាឌាន
ត្រង់អស់ទាំងទីឆ្លងទន្លេយ័រដាន់[ឃ] រហូតដល់បេត-បារ៉ា
ទៅ ដូច្នេះពួកអេប្រាអិមទាំងប៉ុន្មាន ក៏មូលគ្នាទៅចាំស្កាត់
ត្រង់ផ្លូវទឹកទាំងអស់ តាមទន្លេយ័រដាន់រហូតដល់បេត-
បារ៉ា ២៥គេចាប់បានមេទាំង២របស់សាសន៍ម៉ាឌាន គឺ
អូរិប១ សៀប១[ង] គេបានសំឡាប់អូរិប[ច] នៅត្រង់ថ្មរបស់
អូរិប ហើយសៀប នៅត្រង់ធុងគាបផ្លែទំពាំងបាយជូរ
របស់សៀប ក៏ដេញតាមពួកម៉ាឌាន[ឆ]ទៅទៀត រួចនាំយក
ក្បាលរបស់អូរិប និងសៀបនោះមកជូនដល់គេឌាន នៅ
ខាងនាយទន្លេយ័រដាន់[ជ] ។

## ស្តេចសេបាស និងសាលមូន៉ា

**៨** ១នោះពួកអេប្រាអិមស្តីលោក[ក]ថា អ្នកបានធ្វើអ្វីនឹងយើង
ដូច្នេះ គឺដែលអ្នកបានទៅច្បាំងនឹងសាសន៍ម៉ាឌាន[ខ]ឥតហៅ
យើងផងនេះ[គ] គេក៏បន្ទោសលោកជាខ្លាំង[ឃ] ២តែលោក
ឆ្លើយថា តើខ្ញុំបានធ្វើអ្វីដែលល្មមប្រៀបផ្ទឹមនឹងការរបស់
អ្នករាល់គ្នាបាន ការបេះសន្សំពេលក្រោយរបស់ពួក
អេប្រាអិម តើមិនមែនវិសេសជាងការបេះជាដំបូងរបស់
ពួកអ័បៀស៊ើរទេឬអី[ង] ៣គឺព្រះបានប្រគល់អូរិបនិងសៀប[ច]
ជាមេលើសាសន៍ម៉ាឌាន មកក្នុងកណ្តាប់ដៃ នៃអ្នករាល់គ្នា
ហើយ ដូច្នេះតើខ្ញុំបានអាចនឹងធ្វើអ្វីដែលល្មមប្រៀបផ្ទឹម
នឹងការរបស់អ្នករាល់គ្នានោះ កាលលោកបាននិយាយ
ពាក្យទាំងនេះរួចហើយ នោះគេក៏អន់ខឹង ។
៤គេឌាននិងពួក៣០០នាក់ ដែលនៅជាមួយក៏មកដល់
ទន្លេយ័រដាន់[ឆ] ហើយឆ្លងទៅទាំងនឿយហត់ តែចេះតែខំ
ដេញតាមគេទៅ ៥លោកសូមដល់ពួកអ្នកនៅសិកូតថា[ជ] សូម
ចែកនំបុ័ងឱ្យដល់ពួកមនុស្ស ដែលមកតាមខ្ញុំផង ដ្បិតគេ
អស់កំឡាំងណាស់[ឈ] ខ្ញុំកំពុងតែដេញតាមសេបាស និង
សាលមូន៉ា[ញ]ជាស្តេចសាសន៍ម៉ាឌាន ៦តែពួកអ្នកជាកំពូល
នៃក្រុងសិកូត[ដ]ឆ្លើយថា តើសេបាស និងសាលមូន៉ាបាន
លុះក្នុងកណ្តាប់ដៃអ្នកហើយឬនៅ បានជាត្រូវឱ្យយើងចែក
នំបុ័ង[ឋ]ដល់ពួកពលរបស់អ្នកដូច្នេះ[ឌ] ៧គេឌានឆ្លើយតបថា
បើដូច្នេះកាលណាព្រះយេហូវ៉ាបានប្រគល់សេបាស និង
សាលមូន៉ា[ឍ] មកក្នុងកណ្តាប់ដៃខ្ញុំហើយ នោះខ្ញុំនឹងខ្វារហែក
សាច់អ្នករាល់គ្នា ដោយបន្លាពីទីរហោស្ថាន ហើយនិង
បន្លាស្អិត ៨រួចលោកឡើងចេញពីទីនោះ ទៅដល់ពេនួល[ណ]
ក៏សូមគេដូចដែលទៀត ឯពួកអ្នកនៅពេនួលនោះ គេឆ្លើយ

**៧:២២** អ ១សយ ៨:១៩ ១ពវ ៤:១២ ១៩:១៦
**៧:២៣** ក ពច ៦:៣៥ ខ យស ១៧:៧ គ ទដ ៨៣:៩
**៧:២៤** ឃ យស ២:៧
**៧:២៥** ង ពច ៨:៣ ទដ ៨៣:១១ ច អស ១០:២៦ ឆ អស ៩:៤ ជ ពច ៨:៤ ទដ ១០៦:៤៣
**៨:១** ក ពច ៦:១១ ខ លប ២៥:២ គ ពច ១២:១ ឃ ២សយ ១៩:៤១
**៨:២** ង ជន ២៦:៣០
**៨:៣** ច ពច ៧:២៥
**៨:៤** ឆ ពច ៧:២៥
**៨:៥** ជ លប ៣៣:១៧ ឈ យប ១៦:៧ ទដ ៦:៦ យរ ៤៥:៣ ញ ខ.៧,១២ ទដ ៨៣:១១
**៨:៦** ដ ខ.១៤ ឋ ១សយ ២៥:១១ ឌ ខ.១៥ **៨:៧** ឍ ខ.៥ **៨:៨** ណ ខ.៩,១៧ លប ៣២:៣០ ១ពវ ១២:២៥

នៅក្នុងស្ថានការណ៍នេះ មានសភាពប្រហាក់ប្រហែលគ្នានឹងពួកសាសន៍អាំម៉ូន ម៉ូអាប់ និងអេដំម(២របា ២០:២៣)ហើយនិងអ្នកឯទៀតនៅភីលីស្ទីនត្រង់ក្រុងគីបៀរ (១សយ ១៤:២០) ។ មើល អគ ៣៨:២១ សក ១៤:១៣ និងការពន្យល់ ពច ៤:១៥ ។ *ខាងសេរេរ៉ា* ខាងត្បូងឆៀងខាងកើត ។

**៧:២៣** *ប្រមូលគ្នា* គឺជាការប្រមូលទ័ពដែលមិនបានច្បាំង ឱ្យវិលត្រឡប់មកវិញ ។

**៧:២៤** *ស្រុកភ្នំអេប្រាអិម* គេឌានត្រូវការជំនួយបន្ថែមពីពួកអេប្រាអិម ដើម្បីស្ទាក់ផ្លូវរបស់សាសន៍ម៉ាឌាន កុំឱ្យឆ្លងចូលទន្លេយ័រដាន់បាន ។ *ទឹកទាំងអស់តាមទន្លេយ័រដាន់* ប្រហែលជាទន្លេនេះឆ្លងកាត់បរិវេណ បេត-សាន ។ ដោយសារពួកអ៊ីស្រាអែលគ្រប់គ្រងលើទន្លេនេះ នោះគេអាចនឹងបណ្តេញសាសន៍ម៉ាឌានបាន(មើលការពន្យល់ ៣:២៨) ។ *បេត-បារ៉ា* ទីកន្លែងពិតប្រាកដនៅកន្លែងណានោះ យើងមិនដឹងច្បាស់ឡើយ ប៉ុន្តែវាត្រូវតែនៅម្តុំទន្លេនេះ ។ លោកគេឌាន បានដេញតាមសត្រូវដែលឆ្លងទន្លេនេះ ហើយគាត់ក៏ត្រឡប់ទៅឯសិកូត ដែលនៅជិតស្ទឹងយ៉ាបុក (៨:៥) ។

**៧:២៥** *អូរិប* មានន័យថា"ក្អែក" (សូមមើល អស ១០:២៦) ។ *សៀប* មានន័យថា"ឆ្កែចចក"។ *ក្បាល* ផ្នែកខ្លះៗនៃសាសពរបស់ជនរងគ្រោះ ដូចជាក្បាល ដៃ (៨:៦) ស្បែកនៃចុងស្វាស (១សយ ១៨:២៥) ត្រូវបានគេកាត់យកមកវិញ ទុកដូចជារូបកាយទាំងមូល ។

**៨:១** *ពួកអេប្រាអិម* ពួកគេមានលក្ខណៈផ្ទុយគ្នាទាំងស្រុងពីគេឌាន ដែលមិនមានចិត្តឆេវឆាវចំពោះកំហឹង ចំពោះអំបូរ(ខ.២-៣) គឺជាយ៉ែបថាដែលលោកបាននាំយកទាំងការអាម៉ាស និងជ័យជម្នះមក (១២:១-៦) ។

**៨:២** *បេះសន្សំ* គឺជាសំណល់នៃធញ្ញជាតិ បន្ទាប់ពីគេប្រមូលផលពីចម្ការរួច (មើលការពន្យល់ នរ ១:២២) ។ នៅទីនេះ គេឌានគាត់បានតម្រូវដូច្នេះថា អេប្រាអិមបានសម្រេចគោលដៅ ហើយមានស្នាដៃជាច្រើន ច្រើនជាងដែលគាត់បានធ្វើទៅទៀត ។ *អ័បៀស៊ើរ* គឺជាពូជអំបូររបស់លោកគេឌាន(មើលការពន្យល់ ៦:១១) ឈ្មោះនេះមានន័យថា "ឪពុក (ព្រះយេហូវ៉ា) នៃទូលបង្គំជាអ្នកជំនួយ" ឬ "ឪពុក (ព្រះយេហូវ៉ា) នៃទូលបង្គំជាអ្នកខ្លាំងពូកែ" ។

**៨:៣** *កាលលោកបាននិយាយពាក្យទាំងនេះរួចហើយ នោះគេក៏អន់ខឹង* "ពាក្យតបឆ្លើយដោយស្រទន់ នោះរមែងរំងាប់សេចក្តីក្រោធទៅ" (សូមមើល សភ ១៥:១)។

**៨:៥** *ស្តេចសាសន៍ម៉ាឌាន* សេបាស និងសាលមូន៉ា អាចជាសាសន៍ម៉ាឌាននៅក្នុងអំបូរផ្សេងៗគ្នា (ជន ៣១:៨) ។

**៨:៦** *ដៃ* សូមមើល ៧:២៥ ។ *បានជាត្រូវឱ្យយើងចែកនំបុ័ង* មហាតលិកនៃស្រុកសិកូត គឺមានការសង្ស័យចំពោះសមត្ថភាពរបស់គេឌាន ដែលអាចយកជ័យជម្នះលើសាសន៍ម៉ាឌានបាន បើសិនជាពួកគេឱ្យអាហារដល់កងទ័ពរបស់គេឌាន ។

**៨:៨** *ពេនួល* គឺជាកន្លែងដែលលោកយ៉ាកុបបានបោកចំបាប់ជាមួយព្រះ (សូមមើល លប ៣២:៣០-៣១) ។

ដូចជាពួកនៅសិកូតដែរ ៩លោកក៏ប្រាប់ដល់មនុស្សនៅ
ពេនួលថា កាលណាខ្ញុំបានមកវិញដោយសុខសាន្ត នោះខ្ញុំ
នឹងរំលំប៉មនេះទៅ[ត]។
១០រីឯសេបាស និងសាលមូន៉ា គេបានចូលទៅក្នុងក្រុង
កើរកូរ មានទាំងកងទ័ពប្រហែលជា១ម៉ឺន៥ពាន់នាក់ នៅ
ជាមួយផង គឺអស់អ្នកទាំងប៉ុន្មានដែលសល់ពីកងទ័ពរបស់
ពួកមនុស្សនៅស្រុកខាងកើត ពីព្រោះទាហានរបស់គេ
១សែន២ម៉ឺននាក់ ដែលកាន់ដាវ បានដួលស្លាប់អស់ហើយ[ថ]
១១ដូច្នេះគេឌានក៏ឡើងតាមផ្លូវរបស់ពួកអ្នក ដែលនៅក្នុង
ត្រសាល ត្រង់ស្រុកខាងកើតណូបាស[ទ] និងយ៉ុកបិហា[ធ] ចូល
ទៅវាយចំពោះពួកទ័ពនោះបាន ដ្បិតគេស្មានថា បានសុខ
សាន្តហើយ ១២ឯសេបាស និងសាលមូន៉ា ក៏រត់រួចទៅ តែ
លោកដេញតាម ចាប់បានស្តេចសាសន៍ម៉ាឌានទាំង២អង្គ
នោះមក ព្រមទាំងបំបាក់ទ័ពគេផង ។
១៣រួចគេឌាន កូនយ៉ូអាស[ន] ក៏ត្រឡប់មកពីចំបាំងតាមផ្លូវ
ដែលឡើងទៅឯភ្នំហេរេស[ប] ១៤លោកចាប់ក្មេងជំទង់ម្នាក់
ក្នុងពួកមនុស្សនៅសិកូតមកសួរ ហើយក្មេងនោះ ក៏កត់
ឈ្មោះពួកអ្នកជាកំពូល និងពួកចាស់ទុំ[ផ]នៃក្រុងសិកូត[ព] បាន
ចំនួន៧៧នាក់ជូនដល់លោក ១៥លោកក៏មកឯពួកអ្នកនៅ
សិកូតប្រាប់ថា មើល នេះហើយជាសេបាស និងសាលមូន៉ា
ដែលឯងរាល់គ្នាបានមើលងាយដល់អញថា តើសេបាស
និងសាលមូន៉ា បានលុះក្នុងកណ្តាប់ដៃអ្នកហើយឬនៅ បាន
ជាត្រូវឱ្យយើងចែកនំបុ័ង ឱ្យដល់ពួកពលរបស់អ្នកដែល
នឿយហត់ដូច្នេះ[ភ] ១៦លោកក៏ចាប់ពួកចាស់ទុំនៃក្រុងសិកូត
និងមនុស្សទាំងប៉ុន្មាននៅក្រុងនោះមកវាយផ្ចាល[ម] ដោយ
បន្លាពីទីរហោស្ថាន និងបន្លាស្អិត ១៧ហើយក៏រំលំប៉មនៅ
ពេនួល[យ] ព្រមទាំងសំឡាប់មនុស្សនៅក្រុងនោះផង[រ]។
១៨លំដាប់នោះលោកសួរសេបាសនិងសាលមូន៉ាថា
ពួកមនុស្សដែលឯងបានសំឡាប់នៅតាបោរនោះ[ល] តើជា
យ៉ាងណា គេឆ្លើយឡើងថា អ្នកទាំងនោះប្រហែលដូចជា
លោកដែរ គ្រប់គ្នាមានលំនាំឫកពា ដូចជាកូនស្តេច

**៨:៩** ត ខ.១៧
**៨:១០** ថ ពច ៦:៥ អស ៩:៤
**៨:១១** ទ ជន ៣២:៤២ ធ ជន ៣២:៣៥
**៨:១៣** ន ពច ៦:១១ ប ពច ១:៣៥
**៨:១៤** ផ នក ៣:១៦ ព ខ.៦
**៨:១៥** ផ ខ.៦
**៨:១៦** ម ១សយ ១៤:១២
**៨:១៧** យ ខ.៨ រ ខ.៩
**៨:១៨** ល យស ១៩:២២
**៨:១៩** វ ជន ១៤:២១
**៨:២១** ស ខ.២៦ អស ៣:១៨
**៨:២៣** ហ នក ១៦:៨ ជន ១១:២០ ១សយ ១២:១២
**៨:២៤** ឡ លប ៣៥:៤ អ លប ៤៩:២៧ ក លប ១៦:១១
**៨:២៦** ខ ខ.២១
**៨:២៧** គ នក ២៥:៧ ពច ១៧:៥ ១៨:១៤ ឃ យស ១៨:២៣

១៩លោកក៏តបថា នោះគឺជាបងប្អូនពោះមួយនឹងអញហើយ
ដូច្នេះ អញស្បថនឹងព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅថា[វ]
បើសិនជាឯងបានទុកជីវិតឱ្យគេរស់នៅ នោះអញមិន
សំឡាប់ឯងទេ ២០ដូច្នេះលោកបង្គាប់ដល់យេធើ ជាកូនច្បង
ខ្លួនថា ចូរក្រោកឡើង សំឡាប់គេចោលទៅ តែក្មេងជំទង់
នោះខ្លាចមិនហ៊ានហូតដាវទេ ពីព្រោះវានៅក្មេងពេក
២១ដូច្នេះសេបាស និងសាលមូន៉ា និយាយឡើងថា ចូរអ្នក
ក្រោកឡើងសំឡាប់យើងដោយខ្លួនអ្នកវិញ ដ្បិតបើមនុស្ស
ជាយ៉ាងណា នោះកំឡាំងក៏យ៉ាងនោះដែរ នោះគេឌានក៏
ក្រោកឡើងទៅសំឡាប់សេបាស និងសាលមូន៉ាចោលទៅ
ព្រមទាំងដោះយកប្រដាប់លំអ[ស]ពីកនៃសត្វអូដ្ឋរបស់គេផង។

## អេផូឌរបស់លោកគេឌាន

២២ឯពួកសាសន៍អ៊ីស្រាអែល គេសូមដល់គេឌានថា
សូមឱ្យលោកគ្រងរាជ្យលើយើងរាល់គ្នាតទៅ ដរាបដល់
កូនចៅលោកផង ដ្បិតលោកបានជួយសង្គ្រោះយើងខ្ញុំឱ្យរួច
ពីកណ្តាប់ដៃនៃពួកម៉ាឌានហើយ ២៣តែគេឌានឆ្លើយទៅគេ
ថា ឯអញនិងកូនចៅអញ មិនត្រូវគ្រងរាជ្យលើឯងរាល់គ្នា
ទេ គឺជាព្រះយេហូវ៉ាទេតើ ដែលសោយរាជ្យ[ហ]លើឯង
រាល់គ្នាវិញ ២៤រួចលោកថា អញសូមដល់ឯងរាល់គ្នាតែ
ប៉ុណ្ណេះ គឺសូមឱ្យឯងរាល់គ្នាឱ្យក្រវិល[ឡ] ដែលចាប់បានជា
របឹបនោះមកអញ[អ] (ពួកខ្មាំងនោះសុទ្ធតែមានក្រវិលមាស
ដ្បិតជាពួកកូនចៅអ៊ីសម៉ាអែល[ក]) ២៥គេក៏ឆ្លើយឡើងថា
យើងខ្ញុំនឹងជូនដល់លោកដោយស្ម័គ្រពីចិត្ត រួចគេក្រដាង
អាវ ហើយគ្រប់គ្នាក៏បោះក្រវិលជារបឹបដែលខ្លួនចាប់បាន
២៦ឯក្រវិលមាសទាំងប៉ុន្មានដែលលោកសូមបាន នោះមាន
ទំងន់ជាមាស១ពាន់៧រយដំឡឹង ឥតរាប់បន្តោក និងអាយ៉ា
ដក់ ហើយនិងសំលៀកបំពាក់ពណ៌ស្វាយ ដែលពួកស្តេច
សាសន៍ម៉ាឌានស្លៀកពាក់ និងខ្សែនៅក[ខ]របស់សត្វអូដ្ឋនោះ
ទេ ២៧ដូច្នេះគេឌានក៏យកទៅធ្វើជាអេផូឌ១[គ] ដាក់នៅក្នុង
ទីក្រុងខ្លួន គឺនៅក្រុងអូប្រា[ឃ] ហើយសាសន៍អ៊ីស្រាអែលទាំង
អស់គ្នាក៏ទៅទីនោះ ដើម្បីនឹងផិតតាម របស់នោះក៏ត្រឡប់

**៨:១៩** *បងប្អូនពោះមួយនឹងអញ* នៅពេលគ្រប់អាយុ ហើយនៅពេលបុរសយកប្រពន្ធច្រើន គឺមានសារៈសំខាន់ផ្សេងគ្នាចំពោះបងប្អូនបង្កើត និងបងប្អូនម្តាយផ្សេងគ្នា ។

**៨:២១** *ដោយខ្លួនអ្នកវិញ* ការសម្លាប់មនុស្សដោយផ្ទាល់ដៃ ប្រហែលជាមិនធម្មតា ឬមានភាពកាចសាហាវណាស់(១សយ ១៧:២៤) ។ *ប្រដាប់លំអ* គឺគេពាក់វានៅលើតែកប៉ុណ្ណោះ ដែលមានទម្រង់ជាខ្សែក ( អស ៣:១៨) ។

**៨:២៣** *អញមិនត្រូវគ្រងរាជ្យលើឯងរាល់គ្នាទេ . . . សោយរាជ្យលើឯងរាល់គ្នាវិញ* លោកគេឌាន ក៏ដូចជាលោកសាំយូអែលដែរ(១សយ ៨:៤–២០)គឺបដិសេធការគ្រប់គ្រង ពីព្រោះគាត់បានទុកឱកាសនេះឱ្យព្រះយេហូវ៉ាទ្រង់ជាអ្នកគ្រប់គ្រងវិញ ។

**៨:២៤** *ក្រវិល* អាចជាក្រវិលដែលគេពាក់នៅច្រមុះ (មើល លប ២៤:៤៧ អគ ១៦:១២) ។ *កូនចៅអ៊ីសម៉ាអែល* ពួកគេជាប់សាច់ញាតិជាមួយពួកម៉ាឌាន(លប ២៥:១–២) ហើយនៅពេលខ្លះ គេហៅខ្លួនគេថា ជាពួកម៉ាឌានដែរ (ខ.២២,២៤ លប ៣៧:២៥–២៨ ៣៩:១) ។

**៨:២៧** *អេផូឌ* ពេលខ្លះវាជាប្រភេទសំលៀកបំពាក់ដ៏បរិសុទ្ធ សម្រាប់សង្ឃ (នក ២៨:៦–៣០ ៣៩:២–៦ លវ ៨:៧) ហើយពេលខ្លះទៀតត្រូវបានពួក

ជាអន្ទាក់[ង] ដល់គេឌាន និងពួកគ្រួរបស់លោក[ច]។

**ការស្លាប់របស់លោកគេឌាន**

២៨ចំណែកឯពួកម៉ាឌាន គេត្រូវក្រាបចុះនៅមុខពួកកូន
ចៅអ៊ីស្រាអែលយ៉ាងដូច្នោះ ឥតមានងើបក្បាល[ឆ]ឡើង
ទៀតឡើយ ហើយនៅជំនាន់គេឌាន ស្រុកនោះក៏បាន
សុខសាន្តត្រាណ[ជ]អស់៤០ឆ្នាំ ។
២៩ឯយេរូ-បាល[ឈ] ជាកូនយ៉ូអាស[ញ] លោកបែរទៅនៅ
ផ្ទះដោយខ្លួន ៣០លោកបង្កើតបានកូនប្រុស៧០នាក់[ដ] ដ្បិត
លោកមានប្រពន្ធជាច្រើន ៣១ឯប្រពន្ធចុង[ឋ]របស់លោក
ដែលនៅស៊ីគែម នាងក៏បានបង្កើតកូនប្រុស១ឱ្យលោកដែរ
លោកដាក់ឈ្មោះថា អ័ប៊ីម៉្មាឡិច[ឌ] ៣២គេឌានជាកូនយ៉ូអាស
ក៏ស្លាប់ទៅ ក្នុងកាលដែលមានអាយុវែងយឺនយូរល្អ[ឍ] គេ
បានបញ្ចុះសពលោកនៅក្នុងផ្នូររបស់យ៉ូអាស ជាឪពុកនៅ
អូប្រា ជាក្រុងរបស់ពួកអ័បៀស៊ើរ ។
៣៣កាលគេឌានបានស្លាប់ហើយ នោះពួកកូនចៅអ៊ីស្រា
អែលក៏ត្រឡប់ទៅ ផិតតាមអស់ទាំងព្រះបាលវិញទៀត[ណ]
គេយកព្រះបាល-បេរីត[ត]ធ្វើជាព្រះរបស់គេ[ថ] ៣៤ឥតបាននឹក
ចាំ[ទ]ពីព្រះយេហូវ៉ា ជាព្រះនៃខ្លួន ដែលទ្រង់បានប្រោសឱ្យ
រួចពីកណ្តាប់ដៃ នៃពួកខ្មាំងសត្រូវទាំងប៉ុន្មានដែលនៅ
ជុំវិញនោះទេ ៣៥ក៏មិនបានដឹងគុណដល់ពួកគ្រួយេរូ-បាល[ធ]
គឺជាគេឌានតាមគ្រប់ទាំងសេចក្តីសប្បុរស ដែលលោកបាន
ផ្តល់ ដល់ពួកអ៊ីស្រាអែលផងដែរ[ន]។

**អ័ប៊ីម៉្មាឡិច**

**៩** ១នោះអ័ប៊ីម៉្មាឡិច[ក]ជាកូនយេរូ-បាល[ខ] ក៏ទៅឯពួកបង
ប្អូនខាងម្តាយខ្លួននៅស៊ីគែម ព្រមទាំងពួកញាតិសន្តាន
របស់ជីតាខ្លួនខាងម្តាយទាំងអស់គ្នា ជំរាបថា ២សូមខ្សឹប
ដាក់ត្រចៀកនៃពួកមនុស្សនៅស៊ីគែមទាំងអស់ថា បើពួក
កូនយេរូ-បាលទាំង៧០នាក់ ឬមនុស្សតែម្នាក់គ្រងរាជ្យ
លើអ្នករាល់គ្នា នោះតើណាវិសេសជាងណា សូមឱ្យអ្នក
រាល់គ្នានឹកចាំយ៉ាងនេះទៀត គឺថាខ្ញុំនេះជាសាច់ឈាមនឹង
អ្នករាល់គ្នាដែរ[គ] ៣ដូច្នេះពួកបងប្អូនខាងម្តាយ ក៏ខ្សឹប
សេចក្តីទាំងនេះដាក់ត្រចៀកពួកមនុស្សនៅស៊ីគែម នោះ
ចិត្តគេក៏ល្អៀងទៅខាងអ័ប៊ីម៉្មាឡិចដោយថា គាត់ជាបងប្អូន
នឹងយើង ៤គេក៏យកប្រាក់៧០រៀល ពីវិហាររបស់ព្រះ
បាល-បេរីត[ឃ]ជូន លោកក៏យកទៅជួលពួកមនុស្សពាល

**៨:២៧** ង នក ១០:៧ ច នក ៣២:២
**៨:២៨** ឆ ទដ ៨៣:២ ជ ពច ៣:១១
**៨:២៩** ឈ ពច ៦:៣២ ញ ពច ៦:១១
**៨:៣០** ដ ពច ៩:២,៥,១៨,២៤ ១២:១៤ ២ពវ ១០:១
**៨:៣១** ឋ លប ២២:២៤ ឌ ពច ៩:១ ១០:១ ២សយ ១១:២១
**៨:៣២** ឍ លប ១៥:១៥
**៨:៣៣** ណ ពច ២:១១,១៣,១៩ ត ពច ៩:៤ ថ ពច ៩:២៧,៤៦
**៨:៣៤** ទ ពច ៣:៧ នហ ៩:១៧
**៨:៣៥** ធ ពច ៦:៣២ ន ពច ៩:១៦

**៩:១** ក ពច ៨:៣១ ខ ពច ៦:៣២ **៩:២** គ លប ២៩:១៤ **៩:៤** ឃ ពច ៨:៣៣

អ្នកមិនជឿព្រះ យកវាទៅថ្វាយដល់រូបព្រះ (១៧:៥ ១៨:១៤,១៧) ។ *ផិត* មើល នក ៣៤:១៥ និងការពន្យល់ ។

**៨:២៨** *៤០ឆ្នាំ* គឺជាចំនួនឆ្នាំ ដែលព្រះយេហូវ៉ាទ្រង់តាំងសញ្ញាថា និងផ្តល់ឱ្យកូនចៅគេសុខសាន្តត្រាណ (មើលសេចក្តីផ្តើម: ប្រវត្តិដើម) ។

**៨:២៩** *យេរូ-បាល* សូមមើល ៦:២៣ និងការពន្យល់ ។

**៨:៣០** *កូនប្រុស៧០នាក់* គឺជាទីសម្គាល់នៃអំណាច និងទ្រព្យសម្បត្តិ (មើល ១២:១៤ ២ពវ ១០:១) ។

**៨:៣១** *ប្រពន្ធចុង* នាងជាស្ត្រីបម្រើនៅក្នុងផ្ទះលោក (៩:១៨ មើលការពន្យល់ លប ១៦:២) ។ *អ័ប៊ីម៉្មាឡិច* នៅកន្លែងផ្សេងទៀត គាត់សម្តែងខ្លួនថាជាវង្សស្តេច (លប ២០:២ ២៦:១ ទដ ៣៤ ចំណងជើង) ហើយឈ្មោះនេះមានន័យថា "ឪពុកនៃខ្ញុំ(ព្រះយេហូវ៉ា)ជាស្តេច" ។ លោកគេឌាន គឺជាឈ្មោះរបស់កូនប្រុសគាត់បាននិយាយថា ព្រះយេហូវ៉ា (នៅទីនេះនិយាយថា "ឪពុក" គឺជា"ព្រះមហាក្សត្រ" ។

**៨:៣២** *អាយុវែងយឺនយូរ* ពាក្យ និងឃ្លានេះគឺមានប្រើតែសម្រាប់លោកអ័ប្រាហាំ (លប ១៥:១៥ ២៥:៨) និងដាវីឌ (១រប ២៩:២៨) ។

**៨:៣៣** *ផិត* មើលក្នុង នក ៣៤:១៥ និងកំណត់សម្គាល់ ។ *ព្រះបាល* សូមមើល ២:១១,១៣ ។ *ព្រះបាល-បេរីត* មានន័យថា "ព្រះនៃការតាំងសញ្ញា" ។ ដូចគ្នានឹងព្រះ ដែលមានឈ្មោះថា អែល-បេរីត ដែលមានន័យថា "ព្រះ(រូបព្រះ)នៃសេចក្តីសញ្ញា" នៅក្នុង ៩:៤៦ ។ នៅកន្លែងនោះបាននិយាយថា មានព្រះវិហារមួយ ដែលជាវិហាររបស់រូបព្រះនោះ (៩:៤) នៅឯស៊ីគែម ។ ពាក្យថា "សេចក្តីសញ្ញា" ដែលគេប្រើនៅក្នុងព្រះនាមរបស់រូបព្រះនេះ ប្រហែលជាសំដៅលើការប្រកាសជាឱឡារិកមួយ នៅពេលដែលពួកកាណានគេធ្វើមហាសន្និបាតមួយរួមគ្នា ដោយកំណត់យកព្រះនេះធ្វើជាព្រះរបស់គេ ដើម្បីថ្វាយបង្គំ ។ នៅមុនពេលដែលលោកយ៉ូស្វេចូលក្នុងទឹកដីកាណាន លោកបានធ្វើការតាំងសញ្ញាជាមួយព្រះ ៣ឬ៤ដងនៅឯស៊ីគែមជិតភ្នំអេបាល(យស ៨:៣០-៣៥ ២៤:២៥-២៧) ។ មើលការពន្យល់ ២:១១ ។

**៩:១-៥៧** នៅក្នុងផ្នែកនេះ គឺជាដំណើររឿងរបស់គេឌាន និងអ័ប៊ីម៉្មាឡិច ដែលជារឿងសំខាន់នៅក្នុងព្រះគម្ពីរចៅហ្វាយទាំងមូល (មើលសេចក្តីផ្តើម : លក្ខណៈអក្សរសាស្ត្រ) ។ អ័ប៊ីម៉្មាឡិច គឺជាម្នាក់ដែលបានព្យាយាមតាំងខ្លួនគាត់ជាស្តេចនៃប្រទេសកាណាន ដែលមានជំនួយមកពីព្រះបាល (ខ.៤) ដែលទង្វើបែបនេះ មានសភាពផ្ទុយពីគេឌាន ជាឪពុករបស់គាត់ (យេរូ-បាល) ដែលគាត់បានប៉ុនប៉ង និងបដិសេធចំពោះព្រះបាល ហើយបានរាប់ថា ព្រះយេហូវ៉ាទ្រង់គឺជាព្រះ ដែលគ្រប់គ្រងលើអ៊ីស្រាអែល ។

**៩:១** *ស៊ីគែម* សូមមើលការពន្យល់ លប ៣៣:១៨ ។

**៩:២** *ពួកមនុស្ស* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះគឺ "បាល" ជាឯកវចនៈ មានន័យថា "ព្រះ" ឬជា "ម្ចាស់" ។ នៅទីនេះ ប្រហែលជាសំដៅលើអភិជន ឬម្ចាស់នៃទឹកដីនៃទីក្រុងនោះ ។ *សាច់ឈាម* ពាក់កណ្តាលជាពួកកាណាន បានធ្វើឱ្យអ័ប៊ីម៉្មាឡិច បានគិតនៅក្នុងចិត្តថា ពួកកាណាននឹងតែងតាំងគាត់ឱ្យគ្រងរាជ្យធ្វើជាស្តេច ជាជាងស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនទាំង៧០នាក់របស់គេឌាន ។ តាមរយៈការប្រមូលបក្សពួករបស់គាត់ និងទំនាក់ទំនងជិតស្និទ្ធ បានធ្វើឱ្យគាត់អាចប្រឆាំងជាមួយពួកអ៊ីស្រាអែល ។

**៩:៤** *ពីវិហារ* វិហារសម័យបុរាណ មានកន្លែងដែលអាចទុកដាក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គេ ។ អ្នកដែលសងបំណុលគេ និងអ្នកដែលគេពិន័យដែលត្រូវសងគេលុះត្រាតែដង្វាយទាំងនោះ ជាផ្នែកមួយរបស់ព្រះវិហារ ។

អនាថា[ង] ឱ្យចុះចូលតាមខ្លួន ៥រួចនាំទៅឯផ្ទះឪពុកនៅក្រុង
អូប្រា សំឡាប់ពួកកូនយេរូ-បាល ដែលជាបងប្អូនខ្លួនទាំង
៧០នាក់[ច] នៅលើថ្មតែ១ នៅសល់តែយ៉ូថាម[ឆ] ជាកូនពៅ
របស់យេរូ-បាលប៉ុណ្ណោះ ដ្បិតគាត់បានពួនខ្លួន[ជ] ៦ដូច្នេះ
ពួកមនុស្សនៅសីគែម និងពួកបន្ទាយមីឡូរ[ឈ]ទាំងអស់ ក៏
មូលមកព្រមគ្នានឹងទៅលើកតាំងអ័ប៊ីម៉្មាឡិច នៅត្រង់ដើម
ម៉ៃសាក់[ញ]ក្នុងបន្ទាយនៅត្រង់សីគែម ឱ្យធ្វើជាស្តេចឡើង ។
៧មានគេនាំដំណឹងនោះ ទៅប្រាប់ដល់យ៉ូថាម[ដ] រួចគាត់
ក៏ទៅឈរនៅលើកំពូលភ្នំកេរិស៊ីម[ឋ] ទាំងបន្លឺវាចាឡើងថា
ឱពួកមនុស្សនៅសីគែមអើយ ចូរស្តាប់ខ្ញុំ ដើម្បីឱ្យព្រះបាន
ស្តាប់អ្នករាល់គ្នាដែរ ៨មានកាល១ថ្ងៃពួកដើមឈើចង់ធ្វើ
បុណ្យចាក់ប្រេង តាំងឱ្យមានស្តេចឡើង ក៏ទៅសូមដល់ដើម
អូលីវថា សូមឱ្យអ្នកសោយរាជ្យលើយើងរាល់គ្នាទៅ ៩តែ
ដើមអូលីវប្រកែកថា តើគួរឱ្យខ្ញុំលះចោលប្រេងខ្ញុំ ដែល
សំរាប់ប្រើនឹងលើកដំកើងព្រះហើយនិងមនុស្សផង ទៅ
រញ្ជួយគ្របពីលើអស់ទាំងដើមឈើឬអី ១០រួចពួកដើមឈើ
ទាំងនោះក៏សូមដល់ដើមល្វាថា សូមឱ្យអ្នកសោយរាជ្យលើ
យើងរាល់គ្នាទៅ ១១តែដើមល្វាប្រកែកថា តើគួរឱ្យខ្ញុំលះ
ចោលរសជាតិផ្អែម និងផលល្អរបស់ខ្ញុំ ទៅរញ្ជួយគ្របពី
លើអស់ទាំងដើមឈើឬអី ១២នោះពួកដើមឈើក៏សូមដល់
ដើមទំពាំងបាយជូរថា សូមឱ្យអ្នកមកសោយរាជ្យលើយើង
រាល់គ្នាទៅ ១៣តែដើមទំពាំងបាយជូរប្រកែកថា តើគួរឱ្យ
ខ្ញុំលះចោលជាតិទឹកផ្លែរបស់ខ្ញុំ[ឱ] ដែលនាំឱ្យទាំងព្រះនិង
មនុស្សផងបានសប្បាយឡើង ដើម្បីទៅរញ្ជួយគ្របពីលើ
អស់ទាំងដើមឈើឬអី ១៤រួចមកដើមឈើទាំងនោះ ក៏ទៅ
សូមដល់គុម្ពបន្លាថា សូមឱ្យអ្នកមកសោយរាជ្យលើយើង
រាល់គ្នាទៅ ១៥នោះគុម្ពបន្លាឆ្លើយឡើងថា បើសិនជាអ្នក
រាល់គ្នាចង់ចាក់ប្រេង តាំងខ្ញុំឱ្យធ្វើជាស្តេចលើអ្នករាល់គ្នា
ពិត នោះចូរឱ្យមកជ្រកនៅក្រោមម្លប់ខ្ញុំចុះ[ឍ] ពុំនោះសោត
និងមានភ្លើងចេញ[ណ]ពីគុម្ពបន្លាមកបញ្ឆេះដល់ទៅអស់ទាំង
ដើមតាត្រៅនៅភ្នំល្បាណូនផង[ត] ។
១៦ឥឡូវនេះបើសិនជាអ្នករាល់គ្នាបានប្រព្រឹត្តដ៏ទៀង
ត្រង់ត្រឹមត្រូវ ដោយបានតាំងអ័ប៊ីម៉្មាឡិចឱ្យធ្វើជាស្តេច បើ
អ្នករាល់គ្នាបានប្រព្រឹត្តល្អនឹងយេរូ-បាល ព្រមទាំងពួកគ្រួ
លោក ហើយបានសងគុណដល់ការដែលដៃលោកធ្វើ
១៧ដ្បិតឪពុកខ្ញុំបានប្រថុយជីវិត[ថ] ច្បាំងជំនួសអ្នករាល់គ្នា
ព្រមទាំងដោះអ្នករាល់គ្នា ឱ្យរួចពីកណ្តាប់ដៃនៃពួកម៉ាឌាន
ផង ១៨ហើយនៅថ្ងៃនេះ អ្នករាល់គ្នាបែរជាលើកគ្នាមក
ទាស់នឹងពួកគ្រួឪពុកខ្ញុំវិញ ព្រមទាំងសំឡាប់កូនរបស់លោក
ទាំង៧០នាក់[ទ] នៅលើថ្មតែ១ ហើយលើកតាំងអ័ប៊ីម៉្មាឡិចជា
កូនរបស់បាវបំរើលោក ឱ្យធ្វើជាស្តេចលើបណ្តាមនុស្សនៅ
សីគែម ដោយព្រោះតែគេជាសាច់ញាតិនិងអ្នករាល់គ្នា
ដូច្នេះ ១៩អើ បើអ្នករាល់គ្នាយល់ឃើញថា បានប្រព្រឹត្តត្រឹម
ត្រូវ ហើយស្មោះត្រង់នឹងយេរូ-បាល ព្រមទាំងពួកគ្រួ
លោកទាំងប៉ុន្មាននៅថ្ងៃនេះ[ធ] នោះចូរឱ្យត្រេកអរសប្បាយ
ចំពោះអ័ប៊ីម៉្មាឡិចចុះ ហើយឱ្យគេបានរីករាយនឹងអ្នករាល់
គ្នាដែរ ២០ពុំនោះសោត សូមឱ្យមានភ្លើងចេញ[ន]ពីអ័ប៊ីម៉្មា-
ឡិច មកបញ្ឆេះពួកមនុស្សនៅសីគែម[ប] និងពួកបន្ទាយមីឡូរ

**៩:៤** ង ៣ច ១១:៣ ១សយ ២៥:២៥ ២របា ១៣:៧ យប៣០:៨
**៩:៥** ច ៣ច ៨:៣០ ឆ ខ.៧,២១,៥៧ ជ វ ១១:២ ២របា ២២:៩
**៩:៦** ឈ ខ.២០ ២ពវ ១២:២០ ញ លប ១២:៦ ៣ច ៤:១១
**៩:៧** ដ ខ.៥ ឋ ចទ ១១:២៩ យហ ៤:២០
**៩:១៣** ឱ លប ១៤:១៨ សស ២:៣ ៤:១០
**៩:១៥** ឍ អស ៣០:២ ណ ខ.២០ ត ចទ ៣:២៥ ១ពវ ៥:៦ ទដ ២៩:៥ ៩២:១២ អស ២:១៣
**៩:១៧** ថ ៣ច ១២:៣ ១សយ ១៩:៥ ២៨:២១ យប ១៣:១៤ ទដ ១១៩:១០៩
**៩:១៨** ទ ៣ច ៨:៣០
**៩:១៩** ធ ខ.១៦
**៩:២០** ន ខ.១៥

ព្រះវិហាររបស់ព្រះបាល-បេរីតប្រហែលជាអាគារដ៏ធំមួយ ដែលរួមអ្នកវត្ថុបុរាណវិទ្យាគេឃើញនៅឯសីគែម ។ *មនុស្សពាលអនាថា* ការជួលអ្នកណាម្នាក់ ដើម្បីឱ្យសម្រេចកិច្ចការរបស់ខ្លួន គឺមានជាធម្មតានៅសម័យបុរាណ ។ លោកយ៉េបថា (១១:៣) ស្តេចដាវីឌ (១សយ ២២:១-២) ព្រះអម្មាស់អាប់សាឡំម (២សយ ១៥:១) អ័ដូនីយ៉ា (១ពវ ១:៥) លោករេសាន (១ពវ ១១:២៣-២៤) និងយេរ៉ូបោម (២របា ១៣:៦-៧) ក៏ត្រូវបានធ្វើការនេះដែរ ។

**៩:៥** *ថ្មតែ១* បងប្អូនទាំង៧០នាក់របស់អ័ប៊ីម៉្មាឡិច ត្រូវបានគេសម្លាប់ដូចជាសត្វដែលគេយកមកថ្វាយជាយញ្ញបូជា (១៣:១៩-២០ ១សយ ១៤:៣៣-៣៤) ។ គាត់បានតែងតាំងខ្លួនជាស្តេច ដោយសារគាត់បានសម្លាប់ពួកអ៊ីស្រាអែលពាក់កណ្តាល ធ្វើជាយញ្ញបូជាសម្រាប់គាត់ (២សយ ១៥:១០,១២ ១ពវ ១:៥,៩ ៣:៤) ។

**៩:៦** *បន្ទាយមីឡូរ* ទម្រង់កិរិយាហេព្រើរ ពាក្យនេះមានន័យថា "បំពេញ" ប្រហែលសំដៅលើការបំពេញ ឬសម្រេចកិច្ចការទាំងប៉ុន្មានលើផែនដី គឺជាការសាងសង់សំណង់អាគារ ។ បន្ទាយមីឡូរ ប្រហែលជាសំដៅលើ "កំផែងមាំមួន" (ខ.៤៦) ។ *ដើមម៉ៃសាក់* សូមមើល យស ២៤:២៥-២៦ និងមើលការពន្យល់ លប ១២:៦ ។

**៩:៧** *កំពូល* ប្រហែលជាទីលយ ដែលគេមើលឃើញទីក្រុង ។

**៩:៨** *ដើមឈើចង់ធ្វើបុណ្យចាក់ប្រេង* រឿងល្បើកនេះ គឺជារឿងដែលគ្មាននៅសម័យនោះ សម្រាប់អ្នកនៅភាគខាងកើត រឿងនេះផ្ទាល់ជារឿងល្បីល្បាញណាស់ ។

**៩:៩-១៣** ដើមអូលីវ ដើមល្វា ហើយនិងដើមទំពាំងបាយជូរ គឺសុទ្ធតែប្រភេទដើមឈើដែលផ្តល់ផ្លែ ហើយមានសារៈសំខាន់ណាស់សម្រាប់មនុស្សនាមជ្ឈឹមបុព៌ាសម័យបុរាណ ។

**៩:១៣** *ព្រះ* ត្រូវបានគេជឿថា ជាព្រះដែលផឹកស្រាទំពាំងបាយជូរដូចមនុស្ស (ប្រៀបធៀប ២៩:៤០) ។

**៩:១៥** *ម្លប់* គឺជាការចំអកឱ្យ ។ ពាក្យថា ការផ្តល់ម្លប់ឱ្យទៅដើមឈើ នោះការសោយរាជ្យ គឺជានិមិត្តសញ្ញាមួយ ដែលបង្ហាញពីទំនៀមទម្លាប់របស់ស្តេចនៅក្នុងការ ការពារបល្ល័ង្ករបស់ទ្រង់ (មើល អស ៣០:២-៣ ៣២:១-២ បទ ៤:២០ ដយ ៤:១២) ។

**៩:២០** *ភ្លើងចេញពី... បញ្ឆេះ* គឺជារឿងដ៏ក្រៀមក្រំមួយពីដំណើរ អ័ប៊ីម៉្មា-ឡិច និងមនុស្សនៅសីគែមថា ពួកគេនឹងបំផ្លាញគ្នាទៅវិញទៅមក ។

ទៅ[ផ] ហើយក៏សូមឱ្យមានភ្លើងចេញពីពួកមនុស្សនៅសីគែម
និងពួកបន្ទាយមីឡូរ មកបញ្ឆេះអ័ប៊ីម៉្មាឡិចដែរ [២១]រួច
យ៉ូថាម[ព]ក៏ដកខ្លួនរត់រួចទៅឯស្រុកបៀរ[ភ] ស្នាក់នៅទីនោះ
ដោយព្រោះខ្លាចអ័ប៊ីម៉្មាឡិចជាបង ។
[២២]អ័ប៊ីម៉្មាឡិចក៏ដែងគ្រប់គ្រង លើពួកអ៊ីស្រាអែលអស់
៣ឆ្នាំ [២៣]លំដាប់នោះព្រះទ្រង់បណ្ដាលឱ្យអ័ប៊ីម៉្មាឡិច និងពួក
មនុស្សនៅសីគែម មានគំនិតអាក្រក់[ម]ដល់គ្នាទៅវិញទៅមក
ពួកមនុស្សនៅសីគែមក៏ប្រព្រឹត្តដោយចិត្តក្បត់ចំពោះអ័ប៊ីម៉្មា
ឡិច [២៤]ដើម្បីឱ្យឈាមនៃពួកកូនយេរ៉ូ–បាលទាំង៧០នាក់[យ]
ដែលអ័ប៊ីម៉្មាឡិច ជាប្អូន បានសំឡាប់[រ]ដោយសាហាវ បាន
ធ្លាក់មកលើ[ល]លោកនិងពួកមនុស្សនៅសីគែម ដែលបាន
ចំរើនកំឡាំងដៃលោក[វ] ឱ្យសំឡាប់បងប្អូនផង [២៥]ដូច្នេះពួក
មនុស្សនៅសីគែម គេក៏បង្កប់មនុស្សនៅលើភ្នំ ឱ្យចាំចាប់
លោក ពួកអ្នកទាំងនោះក៏ប្លន់អស់អ្នកដែលមកតាមផ្លូវនោះ
ហើយមានគេនាំដំណឹងនោះទៅប្រាប់ដល់អ័ប៊ីម៉្មាឡិច ។
[២៦]គ្រានោះកាអាល ជាកូនអេបេឌ[ស] ក៏មកដល់សីគែម
ជាមួយនឹងបងប្អូនគាត់ ហើយពួកមនុស្សនៅសីគែមក៏ទុក
ចិត្តនឹងគាត់ [២៧]គេនាំគ្នាចេញទៅឯចំការ បេះផ្លែទំពាំង
បាយជូររបស់ខ្លួនយកមកគាប[ហ] រួចតាំងអរសប្បាយឡើង
ជាមួយគ្នា នោះក៏ចូលទៅស៊ីផឹកក្នុងវិហារនៃព្រះរបស់គេ[ឡ]
ហើយដាក់បណ្ដាសាដល់អ័ប៊ីម៉្មាឡិច [២៨]កាអាល ជាកូនអេ
បេឌ[អ] បញ្ចេញវាចាថា តើអ័ប៊ីម៉្មាឡិចជាអ្វី[ក] ហើយសីគែម
ជាអ្វី ដែលយើងត្រូវកោតខ្លាចដល់វា តើវាមិនមែនជាកូន
យេរូ–បាល ហើយមេទ័ពរបស់វាមិនមែនឈ្មោះសេប៊ុល
ទេឬអី ដូច្នេះចូរអ្នករាល់គ្នាកោតខ្លាច ដល់ពួកហាម៉ោរ[ខ]
ជាឪពុកសីគែមវិញ តើចង់កោតខ្លាចដល់អ័ប៊ីម៉្មាឡិចធ្វើអី
[២៩]ឱបើជាបណ្ដាជនទាំងនេះនៅក្រោមអំណាចខ្ញុំវិញទៅ
អេះ[គ] នោះខ្ញុំនឹងដកអ័ប៊ីម៉្មាឡិចចេញ រួចគាត់និយាយប្រកួត
នឹងអ័ប៊ីម៉្មាឡិច ដោយពាក្យថា ចូរចំរើនពលទ័ពឯងចេញ
មកល្បងលចុះ[ឃ] ។
[៣០]កាលសេប៊ុល ជាចៅហ្វាយទីក្រុង បានឮពាក្យរបស់
កាអាល ជាកូនអេបេឌដូច្នោះ ក៏កើតមានសេចក្ដីកំហឹង
ឡើង [៣១]រួចលោកចាត់គេឱ្យទៅជំរាបអ័ប៊ីម៉្មាឡិច ដោយ
សំងាត់ថា មើល ឥឡូវកាអាល ជាកូនអេបេឌ និងបងប្អូនវា
បានមកដល់សីគែមហើយ គេញុះញង់ទីក្រុងឱ្យបះបោរ
ទាស់នឹងលោក [៣២]ដូច្នេះ សូមឱ្យលោក និងពួកអ្នកដែល
កាន់ខាងលោក រៀបចំទៅបង្កប់ខ្លួនទាំងយប់[ង] នៅទីវាល
ទៅ [៣៣]រួចដល់វេលាព្រឹក កាលថ្ងៃទើបនឹងរះ នោះសូម
លោកក្រោកឡើង សង្គ្រុញចូលមកឯទីក្រុងតែម្ដង យ៉ាង
នោះ លុះកាលវា និងពួកអ្នកដែលកាន់ខាងវា ចេញទៅ
ច្បាំងនឹងលោក សូមឱ្យលោកប្រព្រឹត្តនឹងវា តាមតែមាន
ឱកាសចុះ[ច] ។
[៣៤]ខណនោះ អ័ប៊ីម៉្មាឡិច និងអស់មនុស្សដែលកាន់ខាង
លោក ក៏ក្រោកឡើងទាំងយប់ នាំគ្នាទៅបង្កប់ខ្លួនជា៤ពួក
ដើម្បីច្បាំងនឹងពួកក្រុងសីគែម [៣៥]ឯកាអាល ជាកូនអេបេឌ
ក៏ចេញទៅឈរនៅមាត់ទ្វារក្រុង[ឆ] រួចអ័ប៊ីម៉្មាឡិច និងពួក
អ្នកដែលនៅជាមួយ ក៏ងើបចេញពីទីបង្កប់ខ្លួនមក[ជ] [៣៦]កាល
កាអាលបានឃើញគេ ក៏ប្រាប់ដល់សេប៊ុលថា មើល មាន
មនុស្សចុះពីភ្នំនោះមកហើយ តែសេប៊ុលឆ្លើយថា នោះគឺ
ជាស្រមោលភ្នំទេ ដែលអ្នកមើលទៅឃើញដូចជាមនុស្ស
វិញ [៣៧]កាអាលក៏ប្រាប់ម្ដងទៀតថា មើល នុ៎ះន៎ មានគេមក
ពីទួលខ្ពស់នោះហើយ ក៏មាន១ពួកទៀតមកតាមផ្លូវដើម
ម៉ៃសាក់មេវនេនីមដែរ [៣៨]នោះសេប៊ុលឆ្លើយថា តើសំដី
ឯងនៅឯណាឥឡូវ ដែលឯងបានថា តើអ័ប៊ីម៉្មាឡិចជាអ្វី
ដែលយើងត្រូវកោតខ្លាចដល់វា គឺមនុស្សទាំងនោះហើយ
ដែលឯងបានមើលងាយទេតើ[ឈ] ដូច្នេះចូរចេញទៅច្បាំង

**៩:២០** ប ខ.៤៥ ផ ខ.៦
**៩:២១** ព ខ.៥ ភ ជន ២១:១៦
**៩:២៣** ម ១សយ ១៦:១៤,២៣ ១៨:១០ ១៩:៩ ១ពវ ២២:២២
**៩:២៤** យ ពច ៨:៣០ រ លប ៩:៦ ជន ៣៥:៣៣ ១ពវ ២:៣២ ល ខ.៥៦–៥៧ វ ចទ ២៧:២៥
**៩:២៦** ស ខ.២៨,៣១,៤១
**៩:២៧** ហ អស ១៦:១០ អម ៥:១១ ៩:១៣ ឡ ពច ៨:៣៣
**៩:២៨** អ ខ.២៦ ក ១សយ ២៥:១០ ខ លប ៣៣:១៩
**៩:២៩** គ ២សយ ១៥:៤ ឃ ខ.៣៨
**៩:៣២** ង យស ៨:២
**៩:៣៣** ច ១សយ ១០:៧
**៩:៣៥** ឆ យស ២:៥ ជ ទដ ៣២:៧ អស ២៨:១៥,១៧ យរ ៤៩:១០
**៩:៣៨** ឈ ខ.២៨–២៩

**៩:២១** *ស្រុកបៀរ* គឺជាឈ្មោះសាមញ្ញ ដែលមានន័យថា "អណ្ដូង" ។
**៩:២២** *ពួកអ៊ីស្រាអែល* សាសន៍អ៊ីស្រាអែលទាំងអស់នោះ គឺសុទ្ធតែជាអ្នកដែលទទួលស្គាល់ពីអំណាចរបស់អ័ប៊ីម៉្មាឡិច នៅឯសីគែម ។
**៩:២៣** *គំនិតអាក្រក់* ប្រហែលជាគំនិតនៃការមិនទុកចិត្ត និងភាពល្ងង់ជូរចត់ ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា "គំនិត" ជានិច្ចកាលត្រូវបានប្រើដើម្បីពិពណ៌នាពីអាកប្បកិរិយា ឬចរិតលក្ខណៈ ។ *ប្រព្រឹត្តដោយចិត្តក្បត់* អ្នកដែលសាងនគរខ្លួនឯងដោយអំពើក្បត់នោះ និងត្រូវវិនាសទៅវិញដោយអំពើក្បត់ដែរ ។
**៩:២៦** *ទុកចិត្តនឹងគាត់* អំពើក្បត់ទើបតែនឹងមាននៅក្នុងអ័ប៊ីម៉្មាឡិច ដូច្នេះហើយបានជាគេត្រូវទទួលឥទ្ធិពល ពីពួកកាអាល ។
**៩:២៧** *នោះក៏ចូលទៅស៊ីផឹក* នៅក្នុងរដូវបេះផ្លែទំពាំងបាយជូរ វាគឺជាឆ្នាំមួយដែលមានសារៈសំខាន់ ហើយរីករាយបំផុត(មើល អស ១៦:៩–១០ យរ ២៥:៣០) ប៉ុន្តែពិធីបុណ្យ និងការស៊ីផឹកនៅក្នុងវិហាររបស់ពួកអ្នកមិនជឿ គឺជាអំពើអាក្រក់ ។
**៩:២៨** *ហាម៉ោរ* ជាអ្នកគ្រប់គ្រងសាសន៍ហេវី ហើយជាអ្នកដែលបានសាងសង់ទីក្រុងសីគែម សូមមើលក្នុង លប ៣៣:១៩ ៣៤:២ យស ២៤:៣២ ។
**៩:៣២** *បង្កប់ខ្លួន* ការពួនស្ទាក់នេះ បានទទួលជោគជ័យ នៅពេលគេស្ទាក់ពួនវាយប្រហារនៅក្រុងគីបៀរ(២០:៣៧) និងក្រុងអៃយ (សូមមើល យស ៨:២) ។
**៩:៣៤** *៤ពួក* ការបែងចែកជាក្រុមៗបែបនេះ គឺងាយស្រួលក្នុងការបង្កប់ខ្លួន ហើយអាចវាយលុកពីច្រើនកន្លែង ដែលជាយុទ្ធសាស្ត្រល្អបំផុត ។
**៩:៣៧** *ទួលខ្ពស់* សូមមើល អគ ៣៨:១២ ។ *ដើមម៉ៃសាក់មេវនេនីម* ប្រហែលជាដើមឈើដែលមានមហិទ្ធឫទ្ធ ហើយសក្តិសិទ្ធ ដែលមានទំនាក់ទំនងទៅនឹងវិហារព្រះបាល–បេរីត (មើលការពន្យល់ លប ១២:៦) ។

នឹងគេឥឡូវនេះចុះ ៣៩ការអាលក៏នាំមុខពួកមនុស្សនៅ
ស៊ីគែមចេញទៅច្បាំងនឹងអ័ប៊ីម៉្មាឡិច ៤០តែអ័ប៊ីម៉្មាឡិច
ប្រដេញគាត់វិញ ហើយគាត់ក៏រត់ពីមុខគេទៅមានមនុស្ស
ជាច្រើនបានដួល ដោយត្រូវរបួស រហូតដល់មាត់ទ្វារ
ទីក្រុង ។
៤១ឯអ័ប៊ីម៉្មាឡិច លោកក៏អាស្រ័យនៅត្រង់អារូម៉ា ហើយ
សេប៊ុលបានបណ្ដេញការអាលនិងបងប្អូនគេ មិនឱ្យនៅ
ស៊ីគែមទៀតទេ ៤២រួចដល់ថ្ងៃស្អែកឡើង បណ្ដាជនក៏
ចេញទៅត្រៀមនៅឯវាល ហើយមានគេទៅជំរាបដល់
អ័ប៊ីម៉្មាឡិច ៤៣នោះអ័ប៊ីម៉្មាឡិចក៏ចែកពួកទ័ពជា៣ផ្នែក[ញ] នាំ
ចេញទៅបង្កប់ខ្លួន[ដ]នៅឯវាល តែកាលលោកក្រឡេកមើល
ទៅឃើញពួកបណ្ដាជន កំពុងចេញពីទីក្រុងមកទៀត នោះ
ក៏ក្រោកស្ទុះចូលទៅវាយគេ ៤៤រួចលោកនិងពួកទ័ព១ផ្នែក
ដែលនៅជាមួយ ក៏រត់ទៅពីខាងមុខ ឈរនៅមាត់ទ្វារក្រុង
ឯពួកទ័ព២ផ្នែកឯទៀត ក៏ស្ទុះចូលទៅវាយពួកដែលនៅ
ឯវាលនោះ ៤៥អ័ប៊ីម៉្មាឡិចបានច្បាំងនឹងពួកទីក្រុងនោះអស់
ពេញ១ថ្ងៃ ក៏ចាប់យកទីក្រុងបាន ហើយសំឡាប់ពួកបណ្ដា
ជនទាំងប៉ុន្មាន រួចរំលំទីក្រុង[ឋ] ព្រមទាំងបាចអំបិល[ឌ]ទៅលើ
ផង ។
៤៦កាលពួកមនុស្ស នៅប៉មស៊ីគែម បានឮដំណឹងនោះ
គេក៏ចូលទៅក្នុងបន្ទាយមានកំផែងមាំមួន[ឍ] ត្រង់វិហារព្រះ
បេរីត ៤៧មានគេជំរាបដល់អ័ប៊ីម៉្មាឡិចថា ពួកមនុស្សនៅ
ប៉មស៊ីគែមបានមូលគ្នាហើយ ៤៨នោះអ័ប៊ីម៉្មាឡិចព្រមទាំង
ពួកទ័ពដែលនៅជាមួយ ក៏ឡើងទៅលើភ្នំសាលម៉ូន[ណ]លោក
យកពូថៅទៅកាប់មែកឈើ១លីទៅ ហើយបង្គាប់ដល់ពួក
មនុស្សដែលនៅជាមួយថា ចូរឯងរាល់គ្នាប្រញាប់នឹងធ្វើ
តាម ដូចជាអញចុះ ៤៩ដូច្នេះ គេក៏កាប់មែកឈើរៀងខ្លួនលី
ទៅតាម រួចដាក់មែកឈើទាំងនោះ នៅត្រង់ជើងបន្ទាយ
ហើយដុតបញ្ឆេះពីលើគេទៅ ដូច្នេះ ពួកមនុស្សដែលនៅ
ប៉មស៊ីគែមទាំងប៉ុន្មាន ក៏ស្លាប់អស់ ទាំងប្រុសទាំងស្រី
មានចំនួនប្រហែលជា១ពាន់នាក់ ។
៥០រួចអ័ប៊ីម៉្មាឡិចក៏ទៅដល់ថេបេស[ត] បោះទ័ពទាស់នឹង
គេ ហើយចាប់យកទីក្រុងបាន ៥១តែនៅក្នុងទីក្រុងនោះ
មានប៉ម១មាំមួនណាស់ ឯពួកមនុស្សនៅក្រុងទាំងអស់គ្នា
ទាំងប្រុសទាំងស្រី គេក៏រត់ទៅជ្រកនៅប៉មនោះ រួចបិទទ្វារ
នាំគ្នាឡើងទៅដល់កំពូល ៥២អ័ប៊ីម៉្មាឡិចក៏មកច្បាំងនឹងទីប៉ម
ហើយចូលទៅដល់មាត់ទ្វារ ដើម្បីនឹងបង្កាត់ភ្លើងដុតចោល
៥៣ខណនោះ មានស្ត្រីម្នាក់យកត្រាបត្បាល់កិន បោះមកលើ
ត្រូវបែកក្បាលអ័ប៊ីម៉្មាឡិចទៅ[ថ] ៥៤ដូច្នេះ លោកហៅ
មនុស្សកំឡោះ ដែលកាន់គ្រឿងសាស្ត្រាវុធរបស់លោក
មកជាប្រញាប់ប្រាប់ថា ចូរឯងហូតដាវមកសំឡាប់អញ
ទៅ[ទ] ដើម្បីកុំឱ្យមានពាក្យដំនៀលថា មានស្រីបានសំឡាប់
អញនេះឡើយ ដូច្នេះមនុស្សកំឡោះនោះ ក៏ចាក់ទំលុះ
លោកសំឡាប់ចោលទៅ ៥៥កាលពួកសាសន៍អ៊ីស្រាអែល
បានឃើញថា អ័ប៊ីម៉្មាឡិចស្លាប់ហើយ នោះគេក៏ត្រឡប់ទៅ
ឯកន្លែងគេរៀងខ្លួនវិញ ៥៦គឺយ៉ាងនោះហើយដែលព្រះ
បានសងអំពើដ៏លាមកអាក្រក់ ដែលលោកបានធ្វើដល់
ឪពុកខ្លួន ដោយសំឡាប់បងប្អូនទាំង៧០នាក់នោះ ៥៧ហើយ
ព្រះទ្រង់ក៏បានទំលាក់សេចក្ដីដ៏លាមកអាក្រក់របស់ពួកអ្នក
នៅស៊ីគែមទាំងប៉ុន្មាន[ធ] មកលើក្បាលគេវិញដែរ ព្រមទាំង
សេចក្ដីបណ្ដាសារបស់យ៉ូថាម[ន] ជាកូនយេរូ–បាលផង ។

### លោកថូឡា

**១០** ១ក្រោយពីអ័ប៊ីម៉្មាឡិចមក[ក] នោះមានថូឡា ជាកូនពូវ៉ា[ខ]

**៩:៤៣** ញ ពច ៧:១៦ ដ យស ៨:២
**៩:៤៥** ឋ ខ.២០ ឌ យរ ៤៨:៩
**៩:៤៦** ឍ ពច ៨:៣៣
**៩:៤៨** ណ ទដ ៦៨:១៤
**៩:៥០** ត ២សយ ១១:២១
**៩:៥៣** ថ ២សយ ១១:២១
**៩:៥៤** ទ ១សយ ៣១:៤ ២សយ ១:៩
**៩:៥៧** ធ ខ.២៤ ទដ ៩៤:២៣ ន ខ.៥
**១០:១** ក ពច ៨:៣១ ខ លប ៤៦:១៣

**៩:៤៣** ពួកទ័ពជាបីផ្នែក មើលការពន្យល់ ៧:១៦ ។
**៩:៤៥** *បាចអំបិលទៅលើ* ដើម្បីបង្ហាញពីការផ្ដន្ទាទោស ឱ្យគ្មានភោគផល លើដីអស់មួយជីវិត និងវិនាសសកម្មដ៏ធ្ងន់ធ្ងរ (ចទ ២៩:២៣ ទដ ១០៧:៣៣–៣៤ យរ ១៧:៦ សភ ២:៩) ។
**៩:៤៦** *កំផែងមាំមួន* ប្រហែលជាកំផែងបេត–មីឡូ ដែលបាននិយាយនៅក្នុង ខ.៦ ។ *ព្រះបេរីត* គឺជាព្រះបាល–បេរីត (ខ.៤)។
**៩:៤៩** *ដុតបញ្ឆេះ* ត្រូវបានសម្រេចនៅក្នុងបណ្ដាសាយ៉ូថាម (ខ.២០) ។
**៩:៥៣** *ស្ត្រី* នៅក្នុងអំឡុងពេលដែលបុរសទាំងឡាយ ត្រូវបានជាអ្នកកាន់ធ្នូព្រួញ និងលំពែង ស្ត្រីក៏បានជួយការពារកំផែងបាន ដោយសារការទម្លាក់ថ្មធំៗមកលើអស់អ្នកណាដែលមកជិត ។ *ត្រាបត្បាល់កិន* សូមមើល ៣:១៦ ។ ត្រាបត្បាល់កិន គឺមានរាងជារង្វង់ ហើយមានរន្ធនៅកណ្ដាលសម្រាប់ប្រមូលគ្រាប់ធញ្ញជាតិនៅពេលស្ត្រីធ្វើការ (នក ១១:៥) ហើយជានិច្ចកាលត្រូវបានគេគិតថា អ្នកដែលប្រើប្រាស់នោះគឺមានឋានៈទាប (១៦:២១) ។ អ័ប៊ីម៉្មាឡិចត្រូវបានសម្លាប់ដោយសារស្ត្រីម្នាក់ ដែលយកថ្មមកទម្លាក់លើ គឺជាការគួរឱ្យអាម៉ាស់បំផុត (៤:២១) ។
**៩:៥៤** *មនុស្សកំលោះ* កាលពីប៉ុន្មានឆ្នាំមុន នៅក្នុងទឹកដីកាណាន ពួកអ៊ីស្រាអែល អ្នកដឹកនាំកងទ័ពជាច្រើន ត្រូវបានសង្គ្រោះដោយសារពួកដែលទៅជាមួយ (១សយ ១៤:៦ ៣១:៤) ប៉ុន្តែមិនមានពួកកំលោះណាមួយ ដែលត្រូវបានលើកមកនិយាយនោះឡើយ រហូតដល់គ្រាស្ដេចដាវីឌ ។ *ស្រីបានសំលាប់អញ* កាលដែលទាហានម្នាក់ត្រូវស្លាប់ដោយសារស្ត្រី គឺជារឿងអាម៉ាស់បំផុត ។ តាមរយៈការស្លាប់របស់អ័ប៊ីម៉្មាឡិច ត្រូវបានគេលើកយកមកនិយាយដំណាលជារឿងយូរអង្វែង (២សយ ១១:២១) ។
**៩:៥៦** *ព្រះបានសង* ព្រះយេហូវ៉ាទ្រង់គឺជាអ្នកគ្រប់គ្រងលើរាល់បញ្ហាទាំងអស់ គឺជាព្រះមហាក្សត្រដ៏ពិតរបស់អ៊ីស្រាអែល នៅចុងបញ្ចប់ព្រះទ្រង់បានធ្វើឱ្យអ័ប៊ីម៉្មាឡិចត្រឡប់ជាខ្សោយ ។
**៩:៥៧** *បណ្ដាសារបស់យ៉ូថាម* សូមមើល ខ.២០ ។

ដែលជាកូនដូដូរ ក្នុងពួកអ៊ីសាខារ[គ] បានតាំងឡើងជួយ
សង្គ្រោះ[ឃ]ដល់ពួកអ៊ីស្រាអែល លោកនៅត្រង់សាមារ[ង]ក្នុង
ស្រុកភ្នំអេប្រាអិម ២ក៏បានគ្រប់គ្រងលើពួកអ៊ីស្រាអែលអស់
២៣ឆ្នាំ រួចស្លាប់ទៅ ហើយគេបញ្ចុះសពនៅត្រង់សាមារ
នោះ ។

## លោកយ៉ាអ៊ារ

៣ក្រោយពីនោះមកមានយ៉ាអ៊ារ[ច] ជាពួកកាឡាត បាន
តាំងឡើង លោកបានគ្រប់គ្រងលើពួកអ៊ីស្រាអែល អស់២២
ឆ្នាំ ៤លោកមានកូនប្រុស៣០នាក់ ដែលមានកូនលា១ម្នាក់
សំរាប់ជិះ[ឆ] គេក៏មានទីក្រុង៣០ ដែលហៅថាហាវ៉ុត-
យ៉ាអ៊ារ[ជ] ដរាបដល់សព្វថ្ងៃនេះ ក្រុងទាំងនោះនៅស្រុក
កាឡាត ៥ឯយ៉ាអ៊ារ[ឈ]ក៏ស្លាប់ទៅ ហើយគេបញ្ចុះសពនៅ
ត្រង់កាម៉ូន ។

## លោកយែបថា

៦គ្រានោះ ពួកកូនចៅអ៊ីស្រាអែល ក៏ប្រព្រឹត្តសេចក្ដី
ដែលលាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាម្តងទៀត[ញ]
គេបានគោរពប្រតិបត្តិដល់អស់ទាំងព្រះបាល ហើយនិង
ព្រះអាសថារ៉ូត[ដ] ព្រមទាំងព្រះរបស់សាសន៍ស៊ីរី[ឋ] សាសន៍
ស៊ីដូន[ឌ] សាសន៍ម៉ូអាប់ សាសន៍អាំម៉ូន[ឍ,ណ] និងសាសន៍
ភីលីស្ទីនផង[ត] គេបោះបង់ព្រះយេហូវ៉ាចោល[ថ] ក៏លែង
គោរពប្រតិបត្តិដល់ទ្រង់ទៅ ៧នោះសេចក្ដីខ្ញាល់[ទ]នៃព្រះ
យេហូវ៉ាក៏កាត់ឡើង ទាស់នឹងពួកអ៊ីស្រាអែល ហើយទ្រង់
លក់គេ[ធ] ទៅក្នុងកណ្ដាប់ដៃនៃពួកភីលីស្ទីន និងពួកកូនចៅ
អាំម៉ូន ៨ពួកទាំងនោះក៏ធ្វើទុក្ខ ហើយសង្កត់សង្កិនពួកកូន
ចៅអ៊ីស្រាអែល ដែលនៅខាងនាយទន្លេយ័រដាន់ ក្នុងស្រុក
របស់ពួកសាសន៍អាម៉ូរី គឺជាស្រុកកាឡាត[ន] ចាប់តាំងពីឆ្នាំ
នោះ រហូតដល់អស់១៨ឆ្នាំតទៅមុខ ៩រួចពួកកូនចៅអាំម៉ូន
ក៏ឆ្លងទន្លេយ័រដាន់ ទៅច្បាំងនឹងពួកយូដា[ប] ពួកបេនយ៉ាមីន
និងពួកវង្សអេប្រាអិមថែមទៀត[ផ] បានជាពួកអ៊ីស្រាអែល
មានសេចក្ដីវេទនាជាខ្លាំង ។
១០គ្រានោះពួកកូនចៅអ៊ីស្រាអែល ក៏អំពាវនាវ[ព]ដល់
ព្រះយេហូវ៉ាថា យើងខ្ញុំរាល់គ្នាបានធ្វើបាប[ភ]នឹងទ្រង់ហើយ
គឺយើងខ្ញុំបានលះចោលព្រះនៃយើងខ្ញុំ ទៅគោរពប្រតិបត្តិ
ដល់អស់ទាំងព្រះបាលវិញ[ម] ១១នោះព្រះយេហូវ៉ាទ្រង់មាន
បន្ទូលតបទៅពួកកូនចៅអ៊ីស្រាអែលថា តើអញមិនបាន
ជួយឯងរាល់គ្នា ឱ្យរួចពីពួកសាសន៍អេស៊ីព្ទ[យ]សាសន៍អាម៉ូរី[រ]
និងពួកកូនចៅអាំម៉ូន[ល] ហើយនិងសាសន៍ភីលីស្ទីនទេឬអី[វ]
១២មួយទៀត ពួកសាសន៍ស៊ីដូន សាសន៍អាម៉ាលេក[ស] និងពួក

**១០:១** គ លប ៣០:១៨ ឃ ពច ៦:១៤ ង យស ១៥:៤៨ **១០:៣** ច ជន ៣២:៤១ **១០:៤** ឆ លប ៤៩:១១ ១ពវ ១:៣៣ ជ ជន ៣២:៤១ **១០:៥** ឈ ជន ៣២:៤១ **១០:៦** ញ ពច ២:១១ ដ ពច ២:១៣ ឋ អគ ២៧:១៦ ឌ លប ១០:១៥ ឍ លប ១៩:៣៨ ណ ជន ២១:២៩ ត លប ២៦:១ ពច ២:១២ ថ ចទ ៣២:១៥ **១០:៧** ទ ចទ ៣១:១៧ ធ ចទ ៣២:៣០ **១០:៨** ន យស ១២:២ **១០:៩** ប ឧ.១៧ ពច ១១:៤ ផ ពច ១:២២ **១០:១០** ព ពច ៣:៩ ភ នក ៩:២៧ ទដ ៣២:៥ យរ ៣:២៥ ៨:១៤ ១៤:២០ ម យរ ២:២៧ **១០:១១** យ នក ១៤:៣០ រ លប ១៤:៧ ល ពច ៣:១៣ វ ពច ៣:៣១ **១០:១២** ស លប ១៤:៧

**១០:១** *ថូឡា ជាកូនពូវ៉ា ដែលជាកូនដូដូរ ក្នុងអំបូរអ៊ីសាខារ* ថូឡា ហើយនិងពូវ៉ា គឺជាកូនចៅរបស់អ៊ីសាខារ (លប ៤៦:១៣ ជន ២៦:២៣ ១របា ៧:១) ។

**១០:៣** *យ៉ាអ៊ារ* ដោយព្រោះ យ៉ាអ៊ារជាពួកកាឡាត (ទឹកដីនោះ ត្រូវបានគ្រប់គ្រងដោយពួកម៉ានាសេ) ហើយដោយព្រោះពួកកូនចៅរបស់ម៉ានាសេមានឈ្មោះដូចៗគ្នា (ជន ៣២:៤១ ចទ ៣:១៤ ១ពវ ៤:១៣) នោះយើងអាចដឹងជាក់ថាយ៉ាអ៊ារ គឺជាកូនចៅម៉ានាសេ ។

**១០:៤** *លោកមានកូនប្រុស៣០នាក់ . . . លា១ម្នាក់ . . . ទីក្រុង៣០* អ្វីៗទាំងនោះ គឺជាតម្រុយមួយដែលបញ្ជាក់ពីទ្រព្យសម្បត្តិដ៏ច្រើនរបស់គាត់ ។

**១០:៦–១២:៧** ឥឡូវនេះ ពួកអ៊ីស្រាអែលត្រូវបានគ្រប់គ្រង ដោយយែបថា ដែលសង្គមមិនបានទទួលស្គាល់ ហើយបានបណ្ដេញចេញពីស្រុក ព្រមទាំងត្រូវបានគេកាត់ចេញពីច្បាប់មិនឱ្យទទួលមរដក ក្នុងអំបូរអ៊ីស្រាអែល ។ អ្នកនិពន្ធបានធ្វើការកំណត់ចំណាំថា នេះគឺជារឿងដ៏គួរឱ្យអៀនខ្មាសមួយសម្រាប់ពួកអ៊ីស្រាអែល ។ កូនចៅរបស់ចៅហ្វាយយែបថាបានត្រិះរិះដំណើររឿង ដេបូរ៉ានៅក្នុងគ្រានៃពួកចៅហ្វាយ (សូមមើល ៤:១–៥:៣១ និងសេចក្ដីផ្ដើម ត្រង់ចំណុចលក្ខណៈអក្សរសាស្ត្រ) ។

**១០:៦** *ព្រះរបស់សាសន៍ស៊ីរី* មេ ឬចៅហ្វាយលើព្រះផ្សេងៗទៀត គឺហាដាឌ់ (ព្រះបាល) ភ្នំអ័ណាតរីម៉ូន ។ *សាសន៍ស៊ីដូន* ពួកសាសន៍ស៊ីដូន គេថ្វាយបង្គំរូបព្រះសំខាន់ៗតែ១ ដូចជាពួកកាណានដែរ (សូមមើលការពន្យល់ ២:១១, ១៣) ។ *សាសន៍ម៉ូអាប់* ព្រះធំជាងគេនៅស្រុកម៉ូអាប់ឈ្មោះកេម៉ូស ។ *សាសន៍អាំម៉ូន* ព្រះធំជាងគេសម្រាប់ពួកអាំម៉ូន គឺម៉ូឡុក (១ពវ ១១:៧) ហើយគេក៏ថ្វាយបង្គំចំពោះដង្វាយ ដែលមនុស្សបានយកមកថ្វាយជាយញ្ញបូជាដែរ (លវ ១៨:២១ ២០:២–៥ ២ពវ ២៣:១០) ។ ព្រះទាំងនេះក៏ត្រូវបានហៅថា ព្រះមីលកូមដែរ (សូមមើល ១ពវ ១១:៥ ២ពវ ២៣:១៣) ទោះបីជាព្រះម៉ូឡុក ឬជាព្រះមីលកូមក៏ដោយ ក៏ពាក្យនេះមកពីពួកកូនចៅសិមដែលមានន័យថា "ស្តេច" ។ *សាសន៍ភីលីស្ទីន* នៅក្នុងអំឡុងពេលដែលពួកភីលីស្ទីននាំគ្នាគោរពលើព្រះសំខាន់ៗរបស់កាណាន នោះមានលេចឡើងនូវព្រះ ដែលមានឈ្មោះថា ដាកុន និងព្រះបាល–សេប៊ូប ។ ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា "ដាកុន" គឺមានន័យដូចគ្នានឹងពាក្យ "ធញ្ញជាតិ" ដែលតំណាងឱ្យព្រះនៃសារពើរុក្ខជាតិ ។ ព្រះនេះត្រូវបានគេគោរពនៅក្នុងស្រុកបាប៊ីឡូន នៅសហសវត្សរ៍ទី២ មុន គ.ស ។ ព្រះបាល–សេប៊ូប ត្រូវបានគេថ្វាយបង្គំនៅក្នុងពួកអេក្រុន (២ពវ ១:១–៣,៦,១៦) ។ ឈ្មោះនេះមានន័យថា "ព្រះនៃចំការ" ត្រូវគេដូរមកវិញដោយព្រះយេហូវ៉ា (យ៉ាវេ៎) ដើម្បីប្រឆាំងចំពោះការថ្វាយបង្គំដល់ព្រះបាល–សេប៊ូប ("ព្រះនៃសន្តិភាព") ឈ្មោះនេះត្រូវបានគេស្គាល់នៅជំនាន់ ពួកកាណានសម័យបុរាណ (សូមមើលការពន្យល់ មថ ១០:២៥ និងមើល ១២:២៤) ។

**១០:៧** *ពួកភីលីស្ទីន* កូនចៅភីលីស្ទីនត្រូវបានគេនិយាយនៅក្នុង ១៣:១ ។

**១០:១១** *ព្រះយេហូវ៉ាទ្រង់មានបន្ទូលតប* មើល ២:១ ។ ព្រះយេហូវ៉ាទ្រង់បានធ្វើការស្ដីបន្ទោសចំពោះពួកអ៊ីស្រាអែល ដោយព្រោះគេបានភ្លេចទ្រង់ក្នុងការដែលទ្រង់បានរំដោះគេចេញពីពួកកាណាន (មើលការពន្យល់ ២:១៦–១៩ ៦:៨) ។

ម៉ាអូន[ហ] បានធ្វើទុក្ខដល់ឯង[ឡ]រាល់គ្នាដែរ តែកាលឯងរាល់
គ្នាបានអំពាវនាវដល់អញ នោះអញបានជួយសង្គ្រោះឯង
ឱ្យរួចពីកណ្តាប់ដៃរបស់គេទៅ ១៣ប៉ុន្តែឯងរាល់គ្នាបាន
បោះបង់ចោល[អ]អញ ទៅគោរពប្រតិបត្តិដល់ព្រះដទៃវិញ[ក]
ដូច្នេះអញមិនជួយសង្គ្រោះឯងរាល់គ្នាទៀតឡើយ ១៤ចូរ
ទៅអំពាវនាវដល់ព្រះទាំងប៉ុន្មាន ដែលឯងរាល់គ្នាបាន
រើសនោះវិញ ត្រូវឱ្យព្រះទាំងនោះជួយសង្គ្រោះ[ខ]ឯង
ក្នុងវេលាដែលមានសេចក្តីវេទនាចុះ[គ] ១៥តែពួកកូនចៅ
អ៊ីស្រាអែលទូលតបនឹងព្រះយេហូវ៉ាថា យើងខ្ញុំរាល់គ្នាមាន
បាបហើយ ដូច្នេះសូមប្រព្រឹត្តនឹងយើងខ្ញុំ តាមតែទ្រង់សព្វ
ព្រះហឫទ័យចុះ[ឃ] សូមតែជួយយើងខ្ញុំឱ្យរួចនៅថ្ងៃនេះកុំ
ខាន ១៦រួចគេយកអស់ទាំងព្រះដទៃរបស់គេចោលចេញ ក៏
បែរមកគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាវិញ[ង] ទ្រង់ក៏មាន
សេចក្តីរំជួល[ច] ដោយព្រោះសេចក្តីវេទនានៃពួកអ៊ីស្រា
អែល[ឆ] ។

១៧គ្រានោះពួកកូនចៅអាំម៉ូន គេមូលគ្នាទៅបោះទ័ព
នៅស្រុកកាឡាត ឯពួកកូនចៅអ៊ីស្រាអែលក៏មូលគ្នាទៅ
បោះទ័ពនៅមីសប៉ា[ជ] ១៨នោះពួកបណ្តាជន និងពួកអ្នកជា
កំពូលរបស់ពួកកាឡាត គេសួរគ្នាទៅវិញទៅមកថា តើអ្នក
ណាហ៊ានចាប់ផ្តើមច្បាំងនឹងពួកកូនចៅអាំម៉ូន អ្នកណា
ដែលហ៊ាន នោះនឹងបានធ្វើជាមេ[ឈ]លើពួកមនុស្សនៅស្រុក
កាឡាតទាំងអស់ ។

**១១** ១ខណនោះមានមនុស្សក្លាហាន ហើយស្ទាត់ជំនាញ
ម្នាក់[ក] ឈ្មោះយែបថា[ខ] ជាកូនដែលកាឡាត[គ]បង្កើតនឹងស្រី
សំផឹងម្នាក់[ឃ] ២ឯប្រពន្ធកាឡាតក៏បានបង្កើតកូនប្រុសខ្លះឱ្យ
គាត់ដែរ កាលពួកកូនរបស់ប្រពន្ធគាត់បានធំឡើងនោះក៏
បណ្តេញយែបថាចេញ ដោយពាក្យថា ឯងមិនត្រូវបាន
ចំណែកមរដក ក្នុងគ្រួឪពុកយើងទេ ដ្បិតឯងជាកូនខាងក្រៅ
៣នោះយែបថាក៏រត់ពីបងប្អូន ចេញទៅនៅឯស្រុកថូបទៅ[ង]
រួចមានពួកមនុស្សអានាថា[ច]មូលមកចូលដៃជាមួយគ្នា គេ
តែងចេញទៅវាយប្លន់ជាមួយនឹងគាត់ ។

៤លុះចំណេរក្រោយមក នោះពួកកូនចៅអាំម៉ូន[ឆ]គេ
ទន្ទ្រានចូលច្បាំងនឹងសាសន៍អ៊ីស្រាអែល ៥ខណដែលគេ
ទន្ទ្រានចូលក្នុងស្រុកអ៊ីស្រាអែល នោះពួកចាស់ទុំនៅស្រុក
កាឡាតក៏ចាត់គេ ឱ្យទៅហៅយែបថា ពីស្រុកថូបមក
៦ដោយអង្វរថា សូមមកធ្វើជាមេទ័ព លើយើងរាល់គ្នា
ដើម្បីនាំយើងចេញទៅច្បាំងនឹងពួកកូនចៅអាំម៉ូន ៧តែ
យែបថាប្រកែកដល់ពួកចាស់ទុំស្រុកកាឡាតថា តើអ្នករាល់
គ្នាមិនបានស្អប់ខ្ញុំ ហើយបណ្តេញចេញពីផ្ទះឪពុកខ្ញុំទេឬអី[ជ]
ហេតុអ្វីបានជាមករកខ្ញុំឥឡូវ ក្នុងគ្រាដែលមានសេចក្តី
វេទនាវិញដូច្នេះ ៨នោះពួកចាស់ទុំស្រុកកាឡាត ឆ្លើយតប
ថា គឺដោយហេតុនោះបានជាយើងរាល់គ្នាមករកអ្នកឥឡូវ
ដើម្បីឱ្យអ្នកបានចេញទៅច្បាំងនឹងពួកកូនចៅអាំម៉ូនជាមួយ
នឹងយើង នោះអ្នកនឹងបានធ្វើជាមេ[ឈ]របស់យើងរាល់គ្នា
គ្រប់គ្រងលើមនុស្សនៅស្រុកកាឡាតទាំងអស់ ៩រួចយែបថា
សួរបញ្ជាក់ដល់ពួកចាស់ទុំស្រុកកាឡាតថា បើអ្នករាល់គ្នា
នាំខ្ញុំត្រឡប់ទៅស្រុកវិញ ច្បាំងនឹងពួកអាំម៉ូន ហើយព្រះ
យេហូវ៉ាទ្រង់ប្រគល់គេមកនៅមុខខ្ញុំ នោះតើខ្ញុំនឹងបានធ្វើ
ជាមេលើអ្នករាល់គ្នាពិតមែនឬ ១០ពួកចាស់ទុំក៏ឆ្លើយថា
យើងស្បថដោយនូវព្រះយេហូវ៉ា ដែលទ្រង់ឮពាក្យយើង
នេះ[ញ]ថា យើងនឹងធ្វើតាមពាក្យអ្នកជាពិតប្រាកដ ១១ដូច្នេះ
យែបថាក៏ទៅជាមួយនឹងពួកចាស់ទុំ[ដ]នៃស្រុកកាឡាតទៅ
ហើយពួកបណ្តាជនក៏លើកឡើងឱ្យធ្វើជាកំពូល ហើយជាមេ

**១០:១២** ហ យស ១៥:៥៥ ឡ ពជ ៤:៣
**១០:១៣** អ ចទ ៣២:១៥ ក យរ ១១:១០ ១៣:១០
**១០:១៤** ខ អស ៤៤:១៧ ៥៧:១៣ គ ចទ ៣២:៣៧ យរ ២:២៨ ១១:១២ ហព ២:១៨
**១០:១៥** ឃ ១សយ ៣:១៨ ២សយ ១០:១២ ១៥:២៦ យប ១:២១ អស ៣៩:៨
**១០:១៦** ង យស ២៤:២៣ យរ ១៨:៨ ច អស ៦៣:៩ ឆ ចទ ៣២:៣៦
**១០:១៧** ជ លប ៣១:៤៩ ពច ១១:២៩
**១០:១៨** ឈ ពច ១១:៨,៩
**១១:១** ក ពច ១២:១ ១សយ ១២:១១ ហព ១១:៣២ ខ ពច ៦:១២ គ ជន ២៦:២៩ ឃ លប ៣៨:១៥
**១១:៣** ង ខ.៥ ២សយ ១០:៦,៨ ច ពច ៩:៤
**១១:៤** ឆ ពច ១០:៩
**១១:៧** ជ លប ២៦:១៦
**១១:៨** ឈ ពច ១០:១៨ **១១:១០** ញ លប ៣១:៥០ អស ១:២ **១១:១១** ដ ១សយ ៨:៤ ២សយ ៣:១៧

**១០:១២** *ពួកម៉ាអូន* មានឈ្មោះដូចគ្នានឹង "មីយ៉ូនីត" (Meunite) ដែលស្ថិតនៅតាមបណ្តោយស្រុកភីលីស្ទីន និងតំបន់អារ៉ាប់ហើយជាសត្រូវរបស់អ៊ីស្រាអែល (២របា ២៦:៧) ។

**១០:១៧** *មីសប៉ា* មានន័យថា "ប៉មចាំយាម" ។ មានទីកន្លែង ៣ឬ៤ បានប្រើឈ្មោះដូចគ្នានេះដែរ ។ បញ្ជារបស់យែបថា គឺស្ថិតនៅត្រង់ទីក្រុង ឬប៉មនៅកាឡាត (១១:១១) ដែលគេហៅថា មីសប៉ា–កាឡាត (១១:២៩) ។ ឈ្មោះនេះប្រហែលដូចគ្នានឹងរ៉ាម៉ាត–មីសពេ (យស ១៣:២៦) ដែលមានចម្ងាយប្រហែលជា ៤៨ គ.ម ភាគខាងជើងបេត–សៀន ។

**១០:១៨** ពួកកាឡាតចង់តស៊ូប្រឆាំងជាមួយសាសន៍អាំម៉ូន ដោយមិនឱ្យដឹងខ្លួន ប៉ុន្តែមិនមានទ័ពគ្រប់គ្រាន់ ។ *ពួកមនុស្ស* ពួកអ្នកថ្មីកនឹងចម្បាំង ។

**១១:១** *បង្កើតនឹងស្រីសំផឹងម្នាក់* ដោយសារមូលហេតុនេះហើយ បានជាលោកយែបថាត្រូវគេកាត់ចេញពីសាសន៍ ។

**១១:៣** *ស្រុកថូប* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះគឺមានន័យថា "ទឹកដីល្អ" ដែលសំដៅលើទឹកដីសន្យា នៅក្នុងគម្ពីរចោទិយកថា ។ ក្រោយមកទៀតពួកថូបបានចូលដៃជាមួយសាសន៍អាំម៉ូន ប្រឆាំងជាមួយដាវីឌ (មើល ២សយ ១០:៦–៨) ។ *មនុស្សអានាថា* មើលការពន្យល់ ៩:៤ ។

**១១:៨** *ជាមេរបស់យើងរាល់គ្នា* ពួកចាស់ទុំស្រុកកាឡាត បានបន្ថែមមេទ័ពម្នាក់ទៀត (យែបថា) នៅពេលដែលគេត្រូវប្រឈមមុខនឹងសង្គ្រាមជាមួយសាសន៍អាំម៉ូន (ខ.៦) ។ ឥឡូវនេះ ពួកចាស់ទុំស្រុកកាឡាត បានសុំឱ្យលោកយែបថាធ្វើជាអ្នកដឹកនាំទី១លើពួកគេ ដើម្បីច្បាំងជាមួយសាសន៍អាំម៉ូន ។ កេម៉ូសក៏ជាក្សត្រលើស្រុកម៉ូអាប់ ឬជាកងទ័ពដែលត្រួតត្រាស្រុក២ ។

**១១:១១** សេចក្តីស្នើសុំរបស់ពួកចាស់ទុំ ត្រូវបានបណ្តាមនុស្សធ្វើការយល់ព្រមចំពោះព្រះយេហូវ៉ា ហើយគេត្រូវធ្វើបន្តបៀបនេះរហូតដល់គ្រាជ្រើសរើសស្តេចសូលគ្រប់គ្រង (១សយ ១២:២០) រេហូបោម (១ពវ ១២:១) និងយេរូបោម (១ពវ ១២:២០) ។ នៅចុងបំផុតនៃការសម្រេចចិត្តរបស់លោកយែបថា គឺគាត់យល់ព្រមជាមួយពួកចាស់ទុំទាំងនោះ ហើយក៏បានធ្វើ

លើគេ រួចយែបថាក៏ទៅថ្លែងអស់ទាំងពាក្យដដែល[ឋ]នោះ
នៅចំពោះព្រះយេហូវ៉ាត្រង់មីសបា[ឌ]។
១២ស្រេចហើយយែបថាចាត់សារ ឱ្យទៅឯស្តេចពួកកូន
ចៅអាំម៉ូនសួរថា តើលោកនិងខ្ញុំ មានរឿងអ្វីនឹងគ្នាបានជា
លោកមកច្បាំងនឹងខ្ញុំនៅស្រុកខ្ញុំដូច្នេះ ១៣ស្តេចនៃពួកកូន
ចៅអាំម៉ូនឆ្លើយទៅពួកទូតរបស់យែបថាថា គឺដោយព្រោះ
សាសន៍អ៊ីស្រាអែល បានដណ្តើមយកស្រុករបស់អញ ចាប់
តាំងពីស្ទឹងអើណូន[ឍ] ទៅដល់ស្ទឹងយ៉ាបុក[ណ] ហើយត្រឹមទន្លេ
យ័រដាន់ ក្នុងកាលដែលគេឡើងពីស្រុកអេស៊ីព្ទមកនោះ
ដូច្នេះ ចូរប្រគល់ស្រុកទាំងនោះមកអញវិញឥឡូវ ដោយ
មេត្រីចុះ ១៤នោះយែបថាក៏ចាត់សារឱ្យទៅឯស្តេចរបស់
ពួកកូនចៅអាំម៉ូនម្តងទៀត ទូលថា ១៥យែបថាទូលយ៉ាង
ដូច្នេះថា សាសន៍អ៊ីស្រាអែលមិនយកស្រុករបស់សាសន៍
ម៉ូអាប់[ត] ឬស្រុករបស់ពួកកូនចៅអាំម៉ូនទេ[ថ] ១៦គឺកាលគេ
ឡើងពីស្រុកអេស៊ីព្ទមក នោះសាសន៍អ៊ីស្រាអែលបានដើរ
កាត់ទីរហោស្ថាន រហូតដល់សមុទ្រក្រហម[ទ] ហើយក៏ទៅ
ដល់កាដេស[ធ] ១៧រួចចាត់សារ[ន]ឱ្យទៅឯស្តេចស្រុកអេដំម
ទូលថា សូមបើកឱ្យយើងខ្ញុំដើកាត់ស្រុកទ្រង់ផង[ប] តែស្តេច
ស្រុកនោះមិនយល់ព្រមតាមសោះ គេក៏ចាត់សារឱ្យទៅឯ
ស្តេចម៉ូអាប់[ផ] ទូលដូច្នោះដែរ តែទ្រង់ក៏មិនយល់ព្រម[ព]ទៀត
បានជាសាសន៍អ៊ីស្រាអែលបង្អង់នៅក្នុងស្រុកកាដេសនោះ
១៨រួចគេដើរតាមទីរហោស្ថានវាងព័ទ្ធស្រុកអេដំម[ភ] និង
ស្រុកម៉ូអាប់ តាមខាងកើត[ម]ស្រុកម៉ូអាប់វិញ ហើយដំឡើង
ត្រសាលនៅខាងនាយស្ទឹងអើណូន[យ] តែគេមិនបានចូលទៅ
ក្នុងព្រំស្រុកម៉ូអាប់សោះ ដ្បិតស្ទឹងអើណូននោះ ជាព្រំខណ្ឌ
នៃស្រុកម៉ូអាប់ ១៩នៅទីនោះសាសន៍អ៊ីស្រាអែលក៏ចាត់
សារ[រ] ឱ្យទៅឯស៊ីហុន ជាស្តេចសាសន៍អាម៉ូរី គឺជាស្តេច
ក្រុងហែសបូន[ល] ដោយពាក្យថា សូមឱ្យយើងខ្ញុំដើរកាត់
ស្រុកទ្រង់ ទៅឯកន្លែងរបស់យើងខ្ញុំផង[វ] ២០តែស្តេចទ្រង់មិន
ទុកចិត្តចំពោះសាសន៍អ៊ីស្រាអែល និងឱ្យគេដើរកាត់ព្រំ
ស្រុករបស់ទ្រង់ទេ ក៏ប្រមូលពួកទ្រង់ទាំងអស់ ទៅបោះទ័ព
នៅត្រង់យ៉ាហាស់ ច្បាំងនឹងសាសន៍អ៊ីស្រាអែលយើង[ស]
២១នោះព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់ក៏
ប្រគល់ស៊ីហុន និងពួកទ្រង់ទាំងប៉ុន្មាន មកក្នុងកណ្តាប់ដៃនៃ
យើង ហើយយើងក៏ប្រហារគេ គឺយ៉ាងនោះហើយដែល
សាសន៍អ៊ីស្រាអែល ចាប់យកស្រុករបស់សាសន៍អាម៉ូរី
ជាពួកអ្នកដែលនៅស្រុកនោះបាន ២២គេចាប់យកបានស្រុក
របស់សាសន៍អាម៉ូរីនោះ ចាប់តាំងពីស្ទឹងអើណូន រហូត
ដល់ស្ទឹងយ៉ាបុក ហើយពីទីរហោស្ថានទៅដល់ទន្លេយ័រ
ដាន់[ហ] ២៣ឥឡូវព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់បានបណ្តេញសាសន៍អាម៉ូរី ពីមុខពួកអ៊ីស្រាអែល ជា
រាស្ត្រទ្រង់ចេញហើយ ដូច្នេះតើត្រូវការអ្វី ឱ្យទ្រង់មកយក
ស្រុកនេះធ្វើអី ២៤ឯស្រុកដែលព្រះកេម៉ូស[ឡ] ជាព្រះនៃទ្រង់
បានប្រទានឱ្យ នោះតើមិនយកជារបស់ផងទ្រង់ទេឬអី
ដូច្នេះពួកណាដែលព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំ ទ្រង់
បណ្តេញពីមុខយើងខ្ញុំទៅ នោះស្រុករបស់គេត្រូវបានជា
របស់ផងយើងខ្ញុំវិញ[អ]ដូច្នោះដែរ ២៥ចុះតើទ្រង់វិសេសជាង
បាឡាកជាកូនស៊ីបព័រ[ក] ស្តេចសាសន៍ម៉ូអាប់ឬអី តើស្តេច
នោះមិនបានតយុទ្ធនឹងសាសន៍អ៊ីស្រាអែលដែរទេឬអី តើ
មិនបានច្បាំងនឹងគេទេឬ[ខ] ២៦ក្នុងរវាង៣០០ឆ្នាំនេះ ដែល
សាសន៍អ៊ីស្រាអែលនៅ[គ]ក្រុងហែសបូន និងដំបន់នៅជុំវិញ
នៅក្រុងអារ៉ូអើរ[ឃ] និងដំបន់នៅជុំវិញ ហើយនៅទីក្រុង
ទាំងប៉ុន្មាន ដែលនៅក្បែរមាត់ស្ទឹងអើណូន នោះហេតុអ្វី

**១១:១២** ឋ នក ១៩:៩ ១សយ ៨:២១ ឌ យស ១១:៣ **១១:១៣** ឍ ជន ២១:១៣ ណ ជន ២១:២៤ **១១:១៥** ត ចទ ២:៩ ថ ចទ ២:១៩ **១១:១៦** ទ ជន ១៤:២៥ ចទ ១:៤០ ធ លប ១៤:៧ **១១:១៧** ន ខ.១៩ លប ៣២:៣ ជន ២០:១៤ ប ជន ២០:១៧ ផ យរ ៤៨:១ ព យស ២៤:៩ **១១:១៨** ភ ជន ២០:២១ ម ចទ ២:៨ យ ជន ២១:១៣ **១១:១៩** រ ខ.១៧ ល យស ១២:២ វ ជន ២១:២១–២២ **១១:២០** ស ជន ២១:២៣ **១១:២២** ហ ជន ២១:២១–២៦ ចទ ២:២៦ **១១:២៤** ឡ ជន ២១:២៩ យស ៣:១០ អ ចទ ២:៣៦ **១១:២៥** ក ជន ២២:២ ខ យស ២៤:៩ **១១:២៦** គ ជន ២១:២៥ ឃ ជន ៣២:៣៤ យស ១៣:៩

ការតាំងសញ្ញាជាវិសាមញ្ញផ្លូវការណ៍មួយ រវាងគាត់នឹងពួកចាស់ទុំ (សូមប្រៀបធៀបនឹង "ការតាំងសញ្ញា" របស់ដាវីឌ ជាមួយពួកអំបូរអ៊ីស្រាអែល ២សយ ៥:៣) ។ នៅក្នុងហេតុការណ៍ផ្សេងៗទៀត យែបថាបានយកឋានៈរបស់គាត់មកទូលនៅ "ចំពោះព្រះយេហូវ៉ា" ដើម្បីអំពាវដល់ព្រះអង្គ ហើយរៀបចំឱ្យមានការតាំងសញ្ញា ដែលធ្វើឡើងដោយពួកចាស់ទុំកាឡាត ។

**១១:១៣** *ស្រុករបស់អញ* មុនពេលដែលពួកអ៊ីស្រាអែលរៀបនឹងឈ្លានពានពួកកាណាន តំបន់នោះត្រូវបានគ្រប់គ្រងដោយស៊ីហុនជាស្តេចស្រុកអាំម៉ូនដែលបានដណ្តើមយកពីពួកសាសន៍ម៉ូអាប់ (ជន ២១:២៩) ។ ពួកសាសន៍អាំម៉ូនមានអំណាចលើសាសន៍ម៉ូអាប់ទាំងមូល ។

**១១:១៤–២៧** លោកយែបថា បានឆ្លើយតបចំពោះគោលនយោបាយសាសន៍ដទៃ ហើយសាររបស់គាត់គឺជាឧទាហរណ៍នៃការទំនាក់ទំនងអន្តរជាតិ នៅសម័យនោះ ។ ភាពយុត្តិធម៌របស់លោកយែបថា អំពីទឹកដីរបស់អ៊ីស្រាអែលថា: (១). អ៊ីស្រាអែលបានយកទឹកដីនេះពីស៊ីហុនសាសន៍អាម៉ូរី មិនមែនយកពីពួកអាំម៉ូនទេ (ខ.១៥–២២) (២). ព្រះយេហូវ៉ាទ្រង់បានប្រគល់ទឹកនេះឱ្យអ៊ីស្រាអែល(ខ.២៣–២៥) (៣). អ៊ីស្រាអែលបានកាន់កាប់ទឹកដីនោះយូរមកហើយ(ខ.២៦–២៧) ។

**១១:១៦** *កាដេស* ជាឈ្មោះតែមួយរបស់កាដេសបាន (សូមមើលការពន្យល់ ជន ២០:១) ។

**១១:២១** *ព្រះយេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រាអែល* សង្គ្រាមមិនមែនតែជាការប្រកួតប្រជែងជាមួយពួកពលទ័ពឡើយ ប៉ុន្តែក៏ស្ថិតនៅក្នុងចំណោមព្រះដែរ (ខ.២៤ នក ១២:១២ ជន ៣៣:៤) ។

**១១:២៤** *កេម៉ូស* គឺជាព្រះរបស់ពួកម៉ូអាប់ ហើយនៅក្នុងសម័យនោះស្តេចអាំម៉ូនគ្រប់គ្រងទឹកដីម៉ូអាប់ ។

**១១:២៥** *បាឡាក* សូមមើល ជន ២២–២៤ ។

**១១:២៦** *៣០០ឆ្នាំ* ចំពោះការទាក់ទងនឹងឃ្លានេះ ដែលនិយាយអំពីពេលវេលានៅក្នុងគម្ពីរចៅហ្វាយ សូមមើល សេចក្តីផ្តើម : ប្រវត្តិដើម ។

បានជាទ្រង់មិនបានចាប់យកស្រុកពីគេមក ក្នុងគ្រានោះ
ទៅ ២៧ដូច្នេះខ្ញុំមិនបានធ្វើបាបនឹងទ្រង់ទេ គឺទ្រង់ទេតើ
ដែលធ្វើខុសនឹងខ្ញុំវិញ ដោយមកច្បាំងនឹងខ្ញុំដូច្នេះ ព្រះយេ
ហូវ៉ាដ៏ជាចៅក្រម[ង] ទ្រង់នឹងជំនុំជំរះ[ច]រឿងរបស់ពួកកូន
ចៅអ៊ីស្រាអែល និងពួកកូនចៅអាំម៉ូននៅថ្ងៃនេះឯង[ឆ]
២៨ប៉ុន្តែស្តេចពួកកូនចៅអាំម៉ូនមិនព្រមស្តាប់ពាក្យ ដែល
យែបថាបានចាត់សារឱ្យមកទូលទ្រង់នោះទេ ។
២៩ខណនោះព្រះវិញ្ញាណ[ជ]នៃព្រះយេហូវ៉ា ទ្រង់ក៏មក
សណ្ឋិតលើយែបថា រួចលោកដើរកាត់ស្រុកកាឡាត និង
ស្រុកម៉ាន៉ាសេ ទៅតាមមីសប៉ា[ឈ]–កាឡាត ហើយពីទី
នោះក៏ដំរង់ទៅឯពួកកូនចៅអាំម៉ូន[ញ] ៣០យែបថាក៏បន់
ព្រះយេហូវ៉ា ដោយពាក្យ[ដ]ថា បើសិនជាទ្រង់ប្រគល់ពួក
កូនចៅអាំម៉ូន មកក្នុងកណ្តាប់ដៃនៃទូលបង្គំពិត ៣១នោះ
អ្វីៗណាដែលចេញពីមាត់ទ្វារផ្ទះទូលបង្គំ មកទទួលទូល
បង្គំ ក្នុងគ្រាដែលទូលបង្គំត្រឡប់ពីពួកកូនចៅអាំម៉ូនមក
វិញ ដោយសុខសាន្ត[ឋ] នោះនឹងបានជារបស់ផងព្រះ
យេហូវ៉ា ហើយទូលបង្គំនឹងថ្វាយជាដង្វាយដុត[ឌ] ៣២ដូច្នេះ
យែបថាក៏ទៅច្បាំងនឹងពួកកូនចៅអាំម៉ូន ហើយព្រះ
យេហូវ៉ាទ្រង់បានប្រគល់គេមកក្នុងកណ្តាប់ដៃរបស់
លោក ៣៣លោកប្រហារជីវិតគេយ៉ាងសំបើម ចាប់តាំងពី
ក្រុងអារ៉ូអើរ មកដល់ក្រុងមីនីត[ឍ] ទាំងអស់បានទីក្រុង២០
ហើយរហូតដល់អេបិល–កេរ៉ាមីមថែមទៀត ពួកកូនចៅ
អាំម៉ូនក៏ត្រូវក្រាបចុះ នៅមុខពួកកូនចៅអ៊ីស្រាអែល ។
៣៤រួចយែបថា លោកត្រឡប់មកដល់ផ្ទះ នៅត្រង់មីស
ប៉ាវិញ នោះមើល ខណនោះកូនស្រីរបស់លោកក៏ចេញ
មកទទួល ទាំងបន្ទរក្រាប់បណ្តើរ[ណ] ហើយលោតកញ្ឆ្វេង[ត]ផង
នាងនោះជាកូនតែ១របស់លោក[ថ] ក្រៅពីនាងនោះ គ្មានកូន
ប្រុស ឬកូនស្រីណាទៀតឡើយ ៣៥កាលលោកក្រឡេកទៅ
ឃើញនាង នោះក៏ហែកអាវ[ទ]ដោយពាក្យថា វរហើយ កូន
អើយ ឯងបានធ្វើឱ្យអញមានចិត្តក្រាបចុះជាខ្លាំងណាស់ ឯង
ជាអ្នកនៅក្នុងពួកដែលនាំឱ្យអញលំបាកចិត្ត ដ្បិតអញបាន
មានវាចានឹងព្រះយេហូវ៉ាហើយ និងថយមកក្រោយវិញពុំ
បានឡើយ[ធ] ៣៦នាងឆ្លើយទៅឪពុកថា លោកឪពុកអើយ
បើលោកបានមានវាចានឹងព្រះយេហូវ៉ាហើយ នោះសូម
ធ្វើដល់ខ្ញុំតាមវាចា[ន] ដែលចេញពីមាត់នោះចុះ ដោយព្រោះ
ព្រះយេហូវ៉ា ទ្រង់បានសងសឹក[ប] នឹងពួកកូនចៅអាំម៉ូនជាខ្មាំង
សត្រូវ[ផ] ជំនួសលោកឪពុកហើយ ៣៧រួចនាងក៏សូមដល់ឪពុក
ថា សូមបើកឱ្យខ្ញុំធ្វើដូច្នេះ គឺទុកខ្ញុំឱ្យនៅក្នុងរវាង២ខែសិន
ដើម្បីឱ្យខ្ញុំបានទៅនៅលើភ្នំ ហើយយំស្តាយភាពជាក្រមុំរបស់
ខ្ញុំ ជាមួយនឹងពួកស្ត្រី ជាមិត្រសំឡាញ់ខ្ញុំ ៣៨នោះឪពុកក៏ឆ្លើយ
ថា ទៅចុះ ហើយលោកបើកឱកាសឱ្យនាងទៅនៅអស់២ខែ
ដូច្នេះនាងក៏ចេញទៅជាមួយនឹងពួកមិត្រសំឡាញ់ទៅ ហើយ
យំស្តាយដល់ភាពជាក្រមុំរបស់នាងនៅលើភ្នំ ៣៩លុះគ្រប់
កំណត់២ខែហើយ នោះនាងក៏ត្រឡប់មកឯឪពុកវិញ ហើយ
លោកបានធ្វើដល់នាងតាមបំណន់របស់ខ្លួនទៅ នាងឥតដែល
បានស្គាល់បុរសណាឡើយ សេចក្តីនោះឯងបានត្រឡប់ទៅជា
ទំលាប់ក្នុងពួកអ៊ីស្រាអែលតទៅ ៤០គឺរាល់តែឆ្នាំពួកកូនស្រី
របស់អ៊ីស្រាអែល គេតែងទៅយំរំឭកពីកូនស្រីរបស់យែបថា
ជាពួកកាឡាតនោះគ្រប់៤ថ្ងៃក្នុង១ឆ្នាំ ។

**១១:២៧** ង លប ១៨:២៥ ច លប ១៦:៥ ឆ ២របា ២០:១២
**១១:២៩** ជ ពច ៣:១០ ឈ លប ៣១:៤៩ ញ ពច ១០:១៧
**១១:៣០** ដ លប ២៨:២០ ជណ ៣០:១០ ១សយ ១:១១ សភ ៣១:២
**១១:៣១** ឋ លប ២៨:២១ ឌ លប ៨:២០ លវ ១:៣ ពច ១៣:១៦
**១១:៣៣** ឍ អគ ២៧:១៧
**១១:៣៤** ណ នក ១៥:២០ ត លប ៣១:២៧ នក ១៥:២០ ថ សក ១២:១០
**១១:៣៥** ទ ជន ១៤:៦ ធ ជន ៣០:២ ចទ ២៣:២១ សស ៥:២,៤,៥
**១១:៣៦** ន លក ១:៣៨ ប ជន ៣១:៣ ផ ២សយ ១៨:១៩

**១១:២៧** *ចៅក្រម* សូមមើល ១សយ ២៤:១៥ ។ ព្រះយេហូវ៉ា ទ្រង់ជាចៅក្រមដ៏ល្អ ហើយជាអ្នកដែលត្រូវបានមនុស្សគ្រប់គ្នា សុំឱ្យព្រះអង្គកាត់ក្តីចុងក្រោយ ។ សារៈសំខាន់នៅក្នុងព្រះគម្ពីរចៅហ្វាយ គឺអ្នកនិពន្ធបានប្រើពាក្យ "ចៅក្រម" ជានាមឯកវចនៈ ដែលមានតែម្តងគត់ នៅកន្លែងនេះ គឺនិយាយថា ព្រះយេហូវ៉ាទ្រង់ជាចៅក្រមរបស់ពួកអ៊ីស្រាអែល ។
**១១:២៩** *ព្រះវិញ្ញាណនៃព្រះយេហូវ៉ា* សូមមើល ៣:១០ ។ នៅក្នុងសញ្ញាចាស់ ព្រះវិញ្ញាណនៃព្រះយេហូវ៉ាទ្រង់បានផ្តល់អំណាចឱ្យមនុស្ស ដើម្បីស្តាប់ និងប្រព្រឹត្តតាម ទំនួលខុសត្រូវដែលព្រះយេហូវ៉ាទ្រង់បានប្រទានឱ្យ ។
**១១:៣០** *បន់ព្រះយេហូវ៉ា* ការបន់ព្រះ ជាការធម្មតាទៅហើយសម្រាប់ពួកកូនចៅអ៊ីស្រាអែល(មើល លប ២៨:២០ ១សយ ១:១១ ២សយ ១៥:៨) ។ នៅក្នុងកន្លែងនេះ លោកយែបថាបានស្វែងរកជោគជ័យនៅក្នុងចម្បាំង ដោយគាត់បានសុំជំនួយមកពីព្រះ ។ លក្ខណៈនៃសម្បថ គឺមានភាពទូលំទូលាយណាស់ ប៉ុន្តែនៅក្នុង ខ.៣១ បាននិយាយថា សេចក្តីសន្យាពីដង្វាយដុតអាចធ្វើឱ្យយែបថាយកកូនស្រីរបស់គាត់ មកថ្វាយជាដង្វាយដុតដើម្បីលាបំណន់ (ខ.៣៩) ។ គេមិនអាច ភ្លេចចំពោះអ្វីដែលគេបន់នោះឡើយ (សូមមើល ជន ៣០:២ ចទ ២៣:២១–២៣ សស ៥:៤–៥) ។
**១១:៣៤** *លោតកញ្ឆ្វេង* នៅពេលដែលត្រឡប់ពីចម្បាំងវិញ ទាំងនាំជ័យជម្នះដ៏ធំបែបនេះ នោះគឺជាទំលៀមទម្លាប់មួយសម្រាប់ស្ត្រីត្រូវតែអបអរសាទរ (សូមមើល នក ១៥:២០ ១សយ ១៨:៦) ។
**១១:៣៥** *ហែកអាវ* ទង្វើរបែបនេះ គឺបង្ហាញចេញពីសេចក្តីទុក្ខសោកយ៉ាងខ្លាំង(មើល លប ៣៧:៣៤ និងការពន្យល់) ។ *ដ្បិតអញបានមានវាចានឹងព្រះយេហូវ៉ា ហើយនិងថយមកក្រោយវិញពុំបានឡើយ* លោកយែបថាបានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំ ចំពោះតួនាទីនៃភាពជាអ្នកដឹកនាំរបស់គាត់លើគូបដិបក្ស និងបច្ចាមិត្រ លោកយែបថាបានធ្វើការតាំងសញ្ញានៅចំពោះព្រះយេហូវ៉ា គាត់នឹងធ្វើតាមអ្វីដែលព្រះយេហូវ៉ាបានបង្គាប់មក (ខ.១១) ឥឡូវនេះកិច្ចព្រមព្រៀងនេះ មិនអាចត្រឡប់វិញបានឡើយ ។
**១១:៣៧** *យំស្តាយភាពជាក្រមុំ* ត្រង់ចំណុចនេះការមិនអាចរៀបការ និងមិនអាចបង្កើតកូន គឺជារឿងជូរចត់សម្រាប់ស្ត្រីសាសន៍អ៊ីស្រាអែល ។
**១១:៣៩** *ទំលាប់ក្នុងពួកអ៊ីស្រាអែល* ដោយសារនៅក្នុងសញ្ញាចាស់មិនបាននិយាយពីទម្លាប់បែបនេះ នោះប្រហែលទម្លាប់នេះជាទម្លាប់តាមតំបន់ទេ ។

## លោកយែបថា និងពួកអេប្រាអិម

**១២** ១ រីឯពួកអេប្រាអិម គេក៏ប្រមូលគ្នា ដើរទៅខាងជើង[ក]
បន្ទោសដល់យែបថា[ខ]ថា ហេតុអ្វីបានជាឯងទៅច្បាំងនឹង
ពួកកូនចៅអាំម៉ូន ឥតហៅយើងឱ្យទៅជាមួយផងដូច្នេះ[គ]
យើងនឹងដុតផ្ទះឯងឥឡូវ ព្រមទាំងឯងនៅក្នុងផង ២ យែបថា
ឆ្លើយទៅគេថា អញហើយនិងពួកអញនេះ មានហេតុទាស់
ទែងនឹងពួកកូនចៅអាំម៉ូនជាខ្លាំង អញក៏បានហៅឯងរាល់
គ្នាដែរ តែឯងមិនបានជួយអញ ឱ្យរួចពីកណ្ដាប់ដៃគេទេ
៣ ដូច្នេះកាលអញឃើញថា ឯងរាល់គ្នាមិនជួយអញទេ នោះ
អញបានប្រថុយជីវិត[ឃ] ចេញទៅច្បាំងនឹងពួកកូនចៅអាំម៉ូន
ហើយព្រះយេហូវ៉ាទ្រង់ក៏បានប្រគល់[ង]គេមកក្នុងកណ្ដាប់ដៃ
នៃអញ ចុះហេតុអ្វីបានជាឯងរាល់គ្នាឡើងមកតនឹងអញនៅ
ថ្ងៃនេះដូច្នេះ ៤ យែបថាក៏ប្រមូលពួកមនុស្សទាំងប៉ុន្មាន
នៅស្រុកកាឡាត[ច] ទៅតស៊ូនឹងពួកអេប្រាអិម ពួកកាឡាត
បានវាយពួកអេប្រាអិម ដោយព្រោះគេថា ពួកកាឡាតឯង
រាល់គ្នានេះ ដែលនៅកណ្ដាលពួកអេប្រាអិម និងពួក
ម៉ាន៉ាសេ ឯងជាពួកដែលរត់ចេញពីពួកអេប្រាអិមទៅទេ[ឆ]
៥ ពួកកាឡាតក៏ចាប់ស្កាត់យកអស់ទាំងផ្លូវឆ្លងទន្លេយ័រដាន់[ជ]
នៅមុខពួកអេប្រាអិម រួចកាលណាមានពួកអេប្រាអិមដែល
រត់រួចបាន គេមកអង្វរថា សូមឱ្យខ្ញុំឆ្លងទៅផង នោះពួក
កាឡាតសួរទៅថា តើឯងជាពួកអេប្រាអិមឬអី បើគេឆ្លើយ
ថាទេ ៦ នោះពួកកាឡាតបង្គាប់ឱ្យគេចេញពាក្យថា "ស៊ីបូ-
លែត" ហើយបើគេថា "ឈីបូលែត"វិញ ដោយគេធ្វើមាត់
ឱ្យចេញខ្យល់នោះមិនត្រូវ នោះក៏ចាប់គេសំឡាប់ទៅ ត្រង់
ផ្លូវឆ្លងទន្លេយ័រដាន់នៅវេលានោះ មានពួកអេប្រាអិម
ដួលស្លាប់ អស់ចំនួន៤ម៉ឺន២ពាន់នាក់ ៧ ឯយែបថាបានគ្រប់
គ្រងលើពួកអ៊ីស្រាអែលអស់៦ឆ្នាំ រួចលោកស្លាប់ទៅ
ហើយគេបញ្ចុះសពនៅក្នុងក្រុង១របស់ស្រុកកាឡាត ។

## លោកអ៊ីបសាន លោកអេឡូន និងលោកអាបដូន

៨ ក្រោយពីលោកមក នោះមានឈ្មោះអ៊ីបសាន ជាអ្នក
ក្រុងបេថ្លេហិម[ឈ]បានធ្វើជាអ្នកគ្រប់គ្រងលើពួកអ៊ីស្រាអែល
៩ លោកមានកូនប្រុស៣០ ហើយបានឱ្យកូនស្រី៣០ ទៅធ្វើជា
ប្រពន្ធរបស់អ្នកដទៃ ក៏នាំយកកូនស្រីដទៃ៣០ មកឱ្យកូន
ប្រុសរបស់ខ្លួនវិញ អ៊ីបសាននេះបានគ្រប់គ្រងលើសាសន៍
អ៊ីស្រាអែលអស់៧ឆ្នាំ ១០ រួចក៏ស្លាប់ទៅ គេបញ្ចុះសពនៅ
ត្រង់បេថ្លេហិម ។

១១ ក្រោយពីលោកនោះមក មានឈ្មោះអេឡូន ជាពួក
សាប់យូល៉ូន បានធ្វើជាអ្នកគ្រប់គ្រងលើសាសន៍អ៊ីស្រាអែល
អស់១០ឆ្នាំ ១២ រួចអេឡូន ជាពួកសាប់យូល៉ូន ក៏ស្លាប់ទៅ
ហើយគេបញ្ចុះសពនៅត្រង់អាយ៉ាឡូន[ញ] ក្នុងស្រុកសាប់
យូល៉ូន ។

១៣ ក្រោយពីលោកមកមានឈ្មោះអាបដូន ជាកូន
ហ៊ីលេល ក្នុងពួកពីរ៉ាថូន[ដ] បានធ្វើជាអ្នកគ្រប់គ្រងលើពួក
អ៊ីស្រាអែល ១៤ លោកមានកូនប្រុស៤០នាក់ ហើយមានចៅ
៣០នាក់[ឋ] ដែលសុទ្ធតែមានកូនលា១ម្នាក់សំរាប់ជិះ[ឌ] អាបដូន
ជាកូនហ៊ីលេល ក្នុងពួកពីរ៉ាថូន បានគ្រប់គ្រងលើសាសន៍
អ៊ីស្រាអែលអស់៨ឆ្នាំ ១៥ រួចក៏ស្លាប់ទៅ ហើយគេបញ្ចុះសព
នៅត្រង់ពីរ៉ាថូនក្នុងស្រុកអេប្រាអិម ជាស្រុកភ្នំរបស់សាសន៍
អាម៉ាលេក[ឍ]។

## កំណើតរបស់លោកសាំសុន

**១៣** ១ លំដាប់នោះពួកកូនចៅអ៊ីស្រាអែល គេប្រព្រឹត្ត

**១២:១** ក យស ១៣:២៧ ខ ពច ១១:១ គ ពច ៨:១
**១២:៣** ឃ ពច ៩:១៧ ង ចទ ២០:៤
**១២:៤** ច ១ពវ ១៧:១ ឆ លប ៤៦:២០ អស ៩:២១ ១៩:២
**១២:៥** ជ យស ២:៧
**១២:៨** ឈ លប ៣៥:១៩
**១២:១២** ញ យស ១០:១២
**១២:១៣** ដ ខ.១៥ ២សយ ២៣:៣០ ១រប ១១:៣១ ២៧:១៤
**១២:១៤** ឋ ពច ៨:៣០ ឌ ពច ៥:១០
**១២:១៥** ឍ ពច ៥:១៤

**១២:១** *ដុតផ្ទះឯង* ពួកភីលីស្ទីនបានប្រព្រឹត្ត ប្រហាក់ប្រហែលគ្នានឹងការដែលគេគំរាមគំហែងដល់ប្រពន្ធសាំសុនដែរ (១៤:១៥ ២០:២៨) ។

**១២:២** *ឆ្លើយ* ជាថ្មីម្ដងទៀត យែបថាបានព្យាយាមដោះស្រាយដោយភាពប៉ិនប្រសព្វរបស់គាត់ (១១:១២,១៤ និងការពន្យល់ ៨:១) ។ *អញក៏បានហៅឯងរាល់គ្នា* គឺដើម្បីចង់ដឹងពីព័ត៌មានថ្មីៗ ។

**១២:៦** *ស៊ីបូលែត* គឺជាពាក្យបែបចំអក ។ មានន័យថា "ជីនន់" (សូមមើល ទដ ៦៩:២,១៥) ។ ពួកអ៊ីស្រាអែលដែលស្ថិតនៅ ភាគខាងកើតនៃទន្លេយ័រដាន់ ការបញ្ចេញសម្លេងខ្លាំងនៅដើមពាក្យ "ស៊ី" តែពួកកាណានមិនបាននិយាយសង្កត់សំលេងនេះឡើយ ។ (លោកពេត្រុសក៏បញ្ចេញសម្លេងខុសដែរ) ។

**១២:៧** *គ្រប់គ្រងលើពួកអ៊ីស្រាអែលអស់៦ឆ្នាំ* គឺជារូបមន្តថ្មីមួយដែលបង្ហាញពីការគ្រប់គ្រងរបស់ពួកចៅហ្វាយ(៣:១១ មើលសេចក្ដីផ្ដើម ត្រង់ចំណុចអក្សរសាស្ត្រ) ។

**១២:៨** *បេថ្លេហិម* ប្រហែលជាក្រុងបេថ្លេហិម ដែលនៅភាគខាងលិចពីសាប់យូល៉ូន(លប ៣៥:១៩ ៤៨:៧ យស ១៩:១៥) ។

**១២:៩** *កូនប្រុស៣០ ហើយបានឱ្យកូនស្រី៣០* សូមមើល ១០:៤ ។

**១២:១១** *អេឡូន* គឺជាម្នាក់ដែលចេញពីពូជអំបូរសាប់យូល៉ូន (លប ៤៦:១៤ ជន ២៦:២៦)។

**១២:១៤** *កូនប្រុស៤០នាក់ ហើយមានចៅ៣០នាក់* សរុបទាំងអស់៧០នាក់ (៨:៣០ ១០:៤) ។

**១២:១៥** *ស្រុកភ្នំរបស់សាសន៍អាម៉ាលេក* សូមមើលការពន្យល់ ៥:១៤ ។ ប្រវត្តិដើមនៃស្រុកនោះមិនបានដឹងច្បាស់ឡើយ ។

**១៣:១–១៦:៣១** សាំសុន (មកពីអំបូរដាន់) ក៏ដូនគ្នានិងអេហ៊ុឌ (មកពីអំបូរបេនយ៉ាមីន) គឺជាមនុស្សដែលមិនចូលចិត្តមានគ្នាច្រើន ដោយគាត់ចូលចិត្តនៅតែម្នាក់ឯងជាវីរៈបុរស ដែលបានយកជ័យជម្នះលើគូបដិបក្សរបស់ខ្លួន ។ ដំណើររឿងរបស់គាត់គឺតមកពីរឿងរបស់អេហ៊ុឌ (សូមមើលការពន្យល់ ៣:១២–៣០) ។ សារៈសំខាន់របស់គាត់គឺ គាត់គឺជាចៅហ្វាយចុងក្រោយរបស់អ៊ីស្រាអែល ។ ដោយសារគាត់បានប្រសូតមកពីផ្ទៃនៃស្ត្រីអារតាមការ

សេចក្ដីដែលលាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាម្ដង
ទៀត ព្រះយេហូវ៉ាទ្រង់ក៏ប្រគល់គេ ទៅក្នុងកណ្ដាប់ដៃនៃ
ពួកភីលីស្ទីន[ក]អស់រវាង៤០ឆ្នាំ[ខ] ។
២គ្រានោះមានមនុស្សម្នាក់នៅត្រង់សូរ៉ាស់[គ] ក្នុងពួកគ្រូ
ដាន់[ឃ] ឈ្មោះម៉ាណូអា[ង] ប្រពន្ធជាស្ត្រីអារ គ្មានកូនសោះ[ច]
៣នោះទេវតានៃព្រះយេហូវ៉ា[ឆ] ក៏លេចមកឱ្យប្រពន្ធគាត់[ជ]
ឃើញ ហើយប្រាប់ថា មើលឥឡូវនេះ ឯងជាស្ត្រីអារគ្មាន
កូន តែឯងនឹងមានទំងន់បង្កើតបានកូនប្រុស១វិញ[ឈ] ៤ដូច្នេះ
ចូរប្រយ័ត្ន កុំឱ្យផឹកស្រាទំពាំងបាយជូរ ឬគ្រឿងស្រវឹងណា
ឡើយ[ញ] ក៏កុំឱ្យបរិភោគអ្វីដែលមិនស្អាតដែរ[ដ] ៥ដ្បិតមើល
ឯងនឹងមានទំងន់ បង្កើតបានកូនប្រុស[ឋ] តែមិនត្រូវយក
កាំបិត[ឌ]កោរសក់វាឡើយ ពីព្រោះកូននោះនឹងធ្វើជាពួក
ណាសារីត[ឍ] ថ្វាយព្រះតាំងពីផ្ទៃម្ដាយមក វានឹងចាប់តាំងជួយ
សង្គ្រោះ[ណ]ដល់សាសន៍អ៊ីស្រាអែល ឱ្យរួចពីកណ្ដាប់ដៃនៃ
ពួកភីលីស្ទីន ៦ដូច្នេះនាងក៏ទៅប្រាប់ដល់ប្ដីថា មានអ្នក
សំណប់របស់ព្រះ[ត]ម្នាក់បានមកឯខ្ញុំ អ្នកនោះមានភាពមើល
ទៅដូចជាទេវតានៃព្រះ[ថ] គួរឱ្យស្ញែងខ្លាច[ទ] តែខ្ញុំមិនបាន
សួរដែលលោកមកពីណាទេ លោកក៏មិនបានប្រាប់ឈ្មោះ
ដល់ខ្ញុំដែរ ៧តែបានប្រាប់ខ្ញុំថា មើល ឯងនឹងមានទំងន់
បង្កើតបានកូនប្រុស១ ឥឡូវនេះកុំឱ្យផឹកស្រាទំពាំងបាយ
ជូរ[ធ] ឬគ្រឿងស្រវឹងណាឡើយ[ន] ក៏កុំឱ្យបរិភោគអ្វីដែលមិន
ស្អាតផង ដ្បិតកូននោះ និងធ្វើជាពួកណាសារីតថ្វាយព្រះ
តាំងពីក្នុងផ្ទៃមក ដរាបដល់ថ្ងៃស្លាប់[ប] ។
៨ដូច្នេះម៉ាណូអា[ផ]ក៏ទូលអង្វរដល់ព្រះយេហូវ៉ាថា ឱព្រះ
អម្ចាស់អើយ សូមឱ្យអ្នកសំណប់របស់ព្រះ[ព] ដែលទ្រង់បាន
ចាត់មកឯយើងខ្ញុំនោះ បានមកម្ដងទៀត ដើម្បីនឹងបង្ហាញ
ឱ្យយើងខ្ញុំដឹងពីការ ដែលត្រូវប្រព្រឹត្តចំពោះកូនដែលត្រូវ
កើតមកនោះ ៩ព្រះទ្រង់ក៏ស្ដាប់តាមពាក្យរបស់ម៉ាណូអា
ទេវតានៃព្រះក៏មកឯនាងម្ដងទៀត ក្នុងកាលដែលនាង
កំពុងអង្គុយនៅចំការ តែម៉ាណូអាជាប្ដី មិនបាននៅជាមួយ

**១៣:១** ក ពច ៣:៣១ ខ ពច ១៤:៤ **១៣:២** គ យស ១៥:៣៣ ឃ ខ.៨ ពច ១៦:៣១ ង លប ៣០:៦ ច លប ១១:៣០ **១៣:៣** ឆ លប ១៦:៧ ជ ខ.១០ ឈ អស ៧:១៤ លក ១:១៣ **១៣:៤** ញ លវ ១០:៩ ដ ខ.១៤ ជន ៦:២-៤ លក ១:១៥ **១៣:៥** ឋ លប ៣:១៥ ឌ ១សយ ១:១១ ឍ ជន ៦:២,១៣ អម ២:១១,១២ ណ ១សយ ៧:១៣ **១៣:៦** ត ខ.៨ ១សយ ២:២៧ ៩:៦ ១ពវ ១៣:១ ១៧:១៨ ថ ជន ២២:២២ ទ ទដ ៦៦:៥ **១៣:៧** ធ យរ ៣៥:៦ ន លវ ១០:៩ ប ១សយ ១:១១,២៨ **១៣:៨** ផ ខ.២៣ ខ.៦

តម្រូវទុករបស់ព្រះយេហូវ៉ា បានធ្វើឱ្យគាត់ត្រូវបានគេយកទៅថ្វាយដល់ទ្រង់តាំងពីកំណើត ហើយព្រះយេហូវ៉ា ទ្រង់ក៏បានប្រទានឱ្យគាត់នូវអំណាចឱ្យគាត់មានជ័យជម្នះលើពួកខ្មាំងសត្រូវរបស់អ៊ីស្រាអែល បានចង់មិត្តភាពជាមួយស្ត្រីសាសន៍ភីលីស្ទីន ដែលពួកគេនឹងនាំឱ្យគាត់វិនាស ហើយបានរំលងការតាំងសញ្ញាជាមួយព្រះយេហូវ៉ា(កាត់ស្បែក) ហើយនិងអំណាចដ៏វិសេសដែលព្រះយេហូវ៉ាទ្រង់បានប្រទានឱ្យគាត់ (ជ័យជម្នះរបស់ពួកសាសន៍កាណាន) នោះពួកអ៊ីស្រាអែលបន្តគោរពប្រតិបត្តិលំរូបព្រះ និងដើរ តាម-ផ្លូវរបស់សាសន៍កាណាន ហើយពួកគេក៏ត្រូវវិនាស (មើលការពន្យល់ នក ៣៤:១៥) ។ ប្រវត្តិរបស់លោកសាំសុន គឺជាប្រវត្តិរបស់សាសន៍អ៊ីស្រាអែលដែលត្រូវបានគេចារជាចម្លាក់ឡើង ។ អ្នកនិពន្ធបានបង្ហាញឱ្យយើងបានដឹងពីអនាគតរបស់អ៊ីស្រាអែលនៅក្នុងការជំនុំជម្រះ ថាភាពមេត្តាករុណារបស់ព្រះមិនដែលថយចេញពីព្រះអង្គនោះឡើយ ចំពោះអ្នកណាដែលមិនបោះបង់ចោលព្រះ ។

**១៣:១-២៥** តាមរយៈកំណើតលោកសាំសុន បានធ្វើឱ្យអ្នកនិពន្ធចង្អុលបង្ហាញនូវរឿងប្រហាក់ប្រហែលគ្នានេះ រវាងអ៊ីស្រាអែលនិងលោកសាំសុន ដើម្បីឱ្យពួកអ្នកអានបានដឹង ។

**១៣:១** *គេប្រព្រឹត្តសេចក្ដីដែលលាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា* សូមមើលការពន្យល់ ៣:៧ ។

**១៣:២** *សូរ៉ាស់* គឺជាទីក្រុងដំបូងដែលបានផ្ដល់ឱ្យទៅយូដា (មើល យស ១៥:៣៣) ប៉ុន្តែ ក្រោយមកទៀតត្រូវបានឱ្យទៅដាន់វិញ (យស ១៩:៤១) ។ វាគឺជាផ្លូវគមនាគមន៍មួយ ដែលធ្វើឱ្យពួកកូនចៅដាន់ ធ្វើការនិរទេសខ្លួនទៅភាគខាងជើង(១៨:២,៨,១១) ។ *គ្រូដាន់* មើល ១:៣៤ និងការពន្យល់ ។ *ស្ត្រីអារគ្មានកូនសោះ* មានសភាពដូចជាសារ៉ា ដែលជាម្ដាយរបស់លោកអ៊ីសាក (លប ១១:៣០ ១៦:១) នាងនិងរេបិកាម្ដាយរបស់លោកយ៉ាកុប (លប ២៥:២១) ប្រៀបធៀបជាមួយនាងហាណា ដែលជាម្ដាយរបស់លោកសាំយូអែល (១សយ ១:២) ហើយនិងនាងអេលីសាបេតជាម្ដាយលោកយ៉ូហានបាទីស្ទ (លក ១:៧) ។

**១៣:៣** *ទេវតានៃព្រះយេហូវ៉ា* សូមមើល លប ១៦:៧ ។ *តែឯងនឹងមានទំងន់បង្កើតបានកូនប្រុស១វិញ* សូមមើលពីសេចក្ដីប្រកាសពីកំណើតរបស់អ៊ីសាក់ (លប ១៨:១០) ។ ប្រៀបធៀបជាមួយ កំណើតអ៊ីសម៉ាអែល (លប ១៦:១១) អេម៉ាញ៉ូអែល(អស ៧:១៤) យ៉ូហានបាទីស្ទ(លក ១:១៣) ហើយនិងកំណើតព្រះយេស៊ូវគ្រីស្ទ(លក ១:៣១) ។

**១៣:៥** *ណាសារីត* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "ការញែកចេញ" ឬ "ថ្វាយចំពោះ"សម្រាប់ទំនាក់ទំនងនៃសម្បថនេះ សូមមើល ជន ៦:១-២១ និងការពន្យល់ ។ ភាពជាណាសារីតរបស់សាំសុន ហាក់បីដូចជាមិនមែនជាការថ្វាយចំពោះព្រះ ដោយស្ម័គ្រពីចិត្តនោះឡើយ ដូចគ្នានឹងពួកអ៊ីស្រាអែល គេបានថ្វាយខ្លួនចំពោះការងាររបស់ព្រះដោយព្រះទ្រង់ជាអ្នកស្បថនឹងព្រះអង្គទ្រង់ផ្ទាល់ ហើយត្រូវថ្វាយទៅព្រះយេហូវ៉ា រហូតដល់ថ្ងៃស្លាប់ (ខ.៧) ។ ដូចគ្នានឹងសេចក្ដីពិតរបស់សាំយូអែលដែរ(១សយ ១:១១) ហើយនិងយ៉ូហានបាទីស្ទ (លក ១:១៥) ។ *វានឹងចាប់តាំង . . . នៃពួកភីលីស្ទីន* ការរំដោះឱ្យរួចពីកណ្ដាប់ដៃនៃសាសន៍ភីលីស្ទីនត្រូវបានបន្តរហូតដល់គ្រាសាំយូអែល(១សយ ៧:១០-១៤) ហើយត្រូវបានបញ្ចប់នៅក្នុងរាជ្យស្ដេចដាវីឌ(២សយ ៥:១៧-២៥ ៨:១)។

**១៣:៦** *អ្នកសំណប់របស់ព្រះ* ជានិច្ចកាលគេតែងតែនិយាយចំពោះពួកហោរា(មើល ចទ ៣៣:១ ១សយ ២:២៧ ៩:៦-១០ ១ពវ ១២:២២) ទោះបីជានៅក្នុង ខ.៣,២១ បានបញ្ជាក់ច្បាស់យ៉ាងណាក៏ដោយ ឃ្លានេះគឺសំដៅលើទេវតានៃព្រះយេហូវ៉ា ។

**១៣:៨** *បង្ហាញឱ្យយើងខ្ញុំដឹងពីការ* នោះមិនមែនជាទម្លាប់ដែលតែងតែកើតឡើងនៅក្នុងរាជ្យវង្សនោះឡើយ ប៉ុន្តែគឺដោយសារទាក់ទងទៅនឹងការត្រាស់ហៅពិសេសរបស់កុមារនោះ ។

នឹងនាងទេ [១០]នោះនាងក៏រត់ទៅជាប្រញាប់ប្រាប់ប្ដីថា មើល
អ្នកដែលបានមកឯខ្ញុំ[ភ]ពីថ្ងៃមុន បានលេចមកឱ្យខ្ញុំឃើញ
ទៀតហើយ [១១]ដូច្នេះ ម៉ាណូអាក៏ក្រោកឡើងដើរតាមប្រពន្ធ
ទៅឯអ្នកនោះសួរថា តើលោកឬអី ដែលបាននិយាយនឹង
នាងនេះ ទេវតាឆ្លើយថា អើ មែនហើយ [១២]ម៉ាណូអាសួរថា
ដូច្នេះកាលណាពាក្យលោកបានសំរេចហើយ នោះតើត្រូវ
ឱ្យយើងខ្ញុំធ្វើតាមរបៀបយ៉ាងណា ហើយប្រព្រឹត្តចំពោះ
កូននោះជាយ៉ាងដូចម្ដេចទៅ [១៣]ទេវតានៃព្រះយេហូវ៉ា
ក៏ឆ្លើយថា ត្រូវឱ្យនាងប្រយ័ត្ន និងប្រព្រឹត្តតាមគ្រប់សេចក្ដី
ដែលអញបានប្រាប់ហើយនោះ [១៤]គឺមិនត្រូវឱ្យបរិភោគអ្វី
ដែលកើតពីដើមទំពាំងបាយជូរឡើយ ក៏មិនត្រូវផឹកស្រា
ទំពាំងបាយជូរ ឬគ្រឿងស្រវឹងណា[ម] ឬបរិភោគអ្វីដែល
មិនស្អាតផង[យ] ត្រូវឱ្យនាងប្រព្រឹត្តតាមគ្រប់ទាំងសេចក្ដី
ដែលអញបានបង្គាប់ហើយ ។
[១៥]គ្រានោះ ម៉ាណូអាទូលទៅទេវតានៃព្រះយេហូវ៉ាថា
យើងខ្ញុំសូមឃាត់លោកបន្តិច ដើម្បីនឹងចាត់ចែងរៀបចំកូន
ពពែ១[រ]ជូនលោក [១៦]តែទេវតានៃព្រះយេហូវ៉ាប្រកែកថា
ទោះបើឯងឃាត់អញ ក៏អញមិនបរិភោគម្ហូបរបស់ឯងដែរ
បើឯងចង់ថ្វាយដង្វាយដុត[ល] នោះត្រូវតែថ្វាយដល់ព្រះ
យេហូវ៉ាវិញ ឯម៉ាណូអាគាត់មិនដឹង[វ]ជាទេវតានៃព្រះ
យេហូវ៉ាទេ [១៧]ក៏សួរថា តើលោកមាននាមដូចម្ដេច[ស] ដើម្បី
កាលណាបានសំរេចដូចជាពាក្យលោក នោះឱ្យយើងខ្ញុំបាន
លើកសរសើរដល់នាមលោកផង [១៨]តែទេវតានៃព្រះ
យេហូវ៉ាឆ្លើយថា ហេតុអ្វីបានជាឯងសួររកឈ្មោះអញ[ហ]
ដ្បិតឈ្មោះអញនេះប្លែកអស្ចារ្យ [១៩]ដូច្នេះម៉ាណូអាគាត់យក
កូនពពែ និងដង្វាយម្សៅមកថ្វាយព្រះយេហូវ៉ានៅលើថ្ម[ឡ]
រួចទេវតាក៏ធ្វើយ៉ាងអស្ចារ្យ ក្នុងខណៈដែលម៉ាណូអានិង
ប្រពន្ធកំពុងមើល [២០]គឺកាលអណ្ដាតភ្លើង[អ]បានឆេះពីលើ
អាសនាឡើង នោះទេវតានៃព្រះយេហូវ៉ាក៏ហោះឡើង
ទៅក្នុងអណ្ដាតភ្លើង ដែលឆេះលើអាសនានោះទៅ ឯ
ម៉ាណូអានិងប្រពន្ធក៏មើល រួចទំលាក់ខ្លួនក្រាបចុះផ្កាប់មុខ
ដល់ដីទាំង២នាក់[ក] ។
[២១]តាំងពីនោះមកទេវតានៃព្រះយេហូវ៉ាមិនបានលេច
មកឱ្យម៉ាណូអា ឬប្រពន្ធគាត់ឃើញទៀតឡើយ ដូច្នេះ
ម៉ាណូអាក៏ដឹង[ខ]ថា ជាទេវតានៃព្រះយេហូវ៉ា [២២]រួចប្រាប់
ប្រពន្ធថា យើងនឹងស្លាប់ជាប្រាកដ[គ] ពីព្រោះយើងបាន
ឃើញ[ឃ]ព្រះហើយ [២៣]តែប្រពន្ធឆ្លើយថា បើសិនជាព្រះ
យេហូវ៉ាទ្រង់សព្វព្រះហឫទ័យនឹងសំឡាប់យើង នោះទ្រង់
មិនបានទទួលដង្វាយដុត និងដង្វាយម្សៅពីដៃយើងដូច្នេះទេ
ក៏មិនបានឱ្យយើងឃើញអស់ទាំងការនេះ ឬប្រាប់សេចក្ដី
យ៉ាងនេះ ឱ្យយើងដឹងនៅវេលានេះដែរ[ង] ។
[២៤]នាងក៏បង្កើតបានកូនប្រុសមួយ ឱ្យឈ្មោះថា សាំសុន[ច]
កូននោះក៏មានវ័យធំឡើង[ឆ] ហើយព្រះយេហូវ៉ាទ្រង់ប្រ-
ទានពរឱ្យ[ជ] [២៥]ព្រះវិញ្ញាណនៃព្រះយេហូវ៉ាក៏ចាប់តាំង
បណ្ដាល[ឈ] គាត់នៅត្រង់ម៉ាហានេ-ដាន់[ញ]ដែលនៅកណ្ដាល
សូរ៉ាស់ ហើយនិងអែសថោល ។

## មង្គលការរបស់សាំសុន

**១៤** [១]សាំសុន[ក]គាត់ចុះទៅឯក្រុងធីមណា[ខ] ហើយនៅ

**១៣:១០** ភ ខ.៣ **១៣:១៤** ម លវ ១០:៩ យ ខ.៤ **១៣:១៥** រ ពច ៦:១៩ **១៣:១៦** ល ពច ១១:៣១ វ ពច ៦:២២ **១៣:១៧** ស លប ៣២:២៩ **១៣:១៨** ហ លប ៣២:២៩ **១៣:១៩** ឡ ពច ៦:២០ **១៣:២០** អ លវ ៩:២៤ ក លប ១៧:៣ **១៣:២១** ខ ពច ៦:២២ **១៣:២២** គ ជន ១៧:១២ ចទ ៥:២៦ ឃ លប ១៦:១៣ នក ៣:៦ ២៤:១០ ពច ៦:២២ **១៣:២៣** ង ទដ ២៥:១៤ **១៣:២៤** ច ពច ១៤:១ ១៥:១ ១៦:១ ហេព ១១:៣២ ឆ ១សយ ២:២១,២៦ ៣:១៩ ជ លក ១:៨០ **១៣:២៥** ឈ ពច ៣:១០ ញ ពច ១៨:១២ **១៤:១** ក ពច ១៣:២៤ ខ លប ៣៨:១២

**១៣:១២** ខនេះគឺជាការប្រកាសពីសេចក្ដីជំនឿ ។ ម៉ាណូអាមិនមែនជាដើមហេតុដែលនាំឱ្យកើតឡើងនូវព្រឹត្តិការណ៍នោះឡើយ ប៉ុន្តែគឺស្ថិតនៅលើពេលវេលា (សូម មើល ខ.១៧) ។

**១៣:១៥** *យើងខ្ញុំសូមឃាត់លោកបន្តិច . . . កូនពពែ១ជូនលោក* គឺជាការរៀបចំអាហារដ៏វិសេសមួយ ។ ការទទួលភ្ញៀវគឺជាទម្លាប់មួយធម្មតាសម្រាប់ពួកអ្នកនៅមជ្ឈិមបូព៌ាសម័យបុរាណ (សូមមើល ៦:១៨–១៩ លប ១៨:១–៨) ។

**១៣:១៧** *តើលោកមាននាមដូចម្ដេច* អត្តសញ្ញាណនៃអ្នកនាំសារ មានសារៈសំខាន់ណាស់ ។ *បានសំរេចដូចជាពាក្យលោក* ការបានសម្រេចទំនាយ គឺជាសញ្ញាមួយដែលបញ្ជាក់ពីភាពស្របច្បាប់នៃពួកហោរា (ចទ ១៨:២១–២២ ១សយ ៩:៦) ។

**១៣:១៨** *អញនេះប្លែកអស្ចារ្យ* ក្នុង អស ៩:៦ ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "អស្ចារ្យ" គឺសំដៅលើម្នាក់ដែលយាងមកគឺ "ព្រះដ៏មានគ្រប់ទាំងព្រះចេស្ដា" ។

**១៣:២២** *យើងនឹងស្លាប់ជាប្រាកដ* មើល ៦:២៣ និងការពន្យល់ លប ១៦:១៣ ៣២:៣០ ។

**១៣:២៤** *សាំសុន* ឈ្មោះនេះមានប្រភពដើមពីភាសាហេព្រើរ ដែលមានន័យថា "ព្រះអាទិត្យ" ឬ"ពន្លឺ" ហើយដែលប្រើនៅទីនេះ គឺដើម្បីបញ្ជាក់ពីសេចក្ដីអំណរពីកំណើតកូននេះ ។ *កូននោះក៏មានវ័យធំឡើង ហើយព្រះយេហូវ៉ា ទ្រង់ប្រទានពរឱ្យ* ប្រៀបធៀប ១សយ ២:២៦ (សាំយូអែល) លក ២:៥២ (ព្រះយេស៊ូវគ្រីស្ទ) ។

**១៣:២៥** *ចាប់តាំងបណ្ដាលគាត់* សូមមើលការពន្យល់ ៣:១០ ១១:២៩ ។ *ម៉ាហានេ–ដាន់* មានន័យថា "ជំរុំរបស់ដាន់" (១៨:១២) ។

**១៤:១–១៦:៣១** តាមលក្ខណៈពិសេសរបស់អក្សរសាស្ត្រ បានសរសេរអំពីភាពប្លែកពីគេរបស់កូនចៅសាំសុន ។ អ្វីដែលគាត់ជួបលើកដំបូងនោះ គឺជាការជួបជាមួយស្ត្រីសាសន៍ភីលីស្ទីន (១៤:១–២០) និងលទ្ធផលរបស់វា (១៥:១–៨) ក៏ដូចគ្នានឹងកូនចៅរបស់គាត់នៅជំនាន់ក្រោយៗទៀតដែរពួកគេក៏បានជួបជាមួយស្ត្រីសាសន៍ភីលីស្ទីនដែរ (១៦:៤–២២) ហើយនិងលទ្ធផលរបស់គេ (១៦:២–៣១) ។ អ្វីដែលបានកើតឡើងជាលើកដំបូងក្នុងជីវិតរបស់គាត់នោះ គឺជាស្រមោលមួយដែលនឹងកើតឡើងនៅក្នុងថ្ងៃចុង

ទីនោះ គាត់ឃើញស្ត្រីម្នាក់ក្នុងពួកស្រីក្រមុំរបស់សាសន៍
ភីលីស្ទីន ២រួចត្រឡប់មកប្រាប់ដល់ឪពុកម្តាយថា ខ្ញុំបាន
ឃើញស្ត្រីម្នាក់នៅធីមណា ក្នុងពួកស្រីក្រមុំរបស់ពួកសាសន៍
ភីលីស្ទីន ដូច្នេះសូមដណ្តឹងនាងនោះឱ្យខ្ញុំឥឡូវ[ក] ៣តែឪពុក
ម្តាយប្រកែកថា ក្នុងពួកស្រីក្រមុំទាំងប៉ុន្មាន ជាវង្សញាតិឯង
ក្នុងសាសន៍អញនេះ តើគ្មានអ្នកណាមួយទេឬអី[ឃ] បានជា
ឯងចង់យកប្រពន្ធពីពួកភីលីស្ទីន ជាមនុស្សដែលមិនកាត់
ស្បែក[ង]វិញ[ច] សាំសុនក៏ឆ្លើយទៅឪពុកថា សូមដណ្តឹងនាង
នោះឱ្យខ្ញុំកុំខាន ពីព្រោះនាងនោះពេញចិត្តខ្ញុំណាស់ ៤ឪពុក
ម្តាយគាត់មិនបានដឹង ជាការនោះកើតមកពីព្រះយេហូវ៉ា
ទេ[ឆ] ដ្បិតទ្រង់រកឱកាសទាស់នឹងពួកភីលីស្ទីន[ជ] រីឯនៅជាន់
នោះ ពួកសាសន៍ភីលីស្ទីនគេកាន់កាប់ត្រួតត្រាលើសាសន៍
អ៊ីស្រាអែល[ឈ]។
៥លំដាប់នោះ សាំសុនក៏ចុះទៅឯធីមណាជាមួយនឹង
ឪពុកម្តាយ លុះបានដល់មកចំការទំពាំងបាយជូរ នៅធីម
ណា នោះឃើញមានសិង្ហស្ទាវ១ ចេញមកគ្រហឹមដាក់គាត់
៦ខណៈនោះ ព្រះវិញ្ញាណនៃព្រះយេហូវ៉ា ក៏មកសណ្ឋិតលើ
គាត់ បណ្តាលឡើងជាខ្លាំង[ញ] ហើយគាត់ចាប់ហែកសិង្ហ
នោះ[ដ] ដូចជាគេហែកកូនពពែ តែគាត់គ្មានអ្វីនៅដៃសោះ
រឿងនោះគាត់មិនបានប្រាប់ដល់ឪពុកម្តាយទេ ៧រួចសាំសុន
ចុះទៅនិយាយនឹងនាងនោះ ហើយនាងក៏ពេញចិត្តដល់គាត់
ណាស់ ៨ក្រោយបន្តិចគាត់ក៏ត្រឡប់មក ដើម្បីនឹងយកនាងធ្វើ
ជាប្រពន្ធ ក៏បែរទៅមើលខ្មោចសិង្ហនោះ ឃើញថាមាន
សំបុកឃ្មុំ ពេញដោយទឹកនៅក្នុងខ្មោចសិង្ហនោះ ៩គាត់ក៏
ច្បាមយកសំបុកឃ្មុំនោះខ្លះ ដើរទៅទាំងបរិភោគតាមផ្លូវ
បណ្តើរ ដរាបដល់មកជួបនឹងឪពុកម្តាយ រួចក៏ជូនគាត់ពិសា
ដែរ តែមិនបានប្រាប់ពីការដែលយកសំបុកឃ្មុំនោះចេញពី
ខ្មោចសិង្ហមកទេ ។
១០ឪពុកគាត់ក៏ចុះទៅឯផ្ទះនៃស្ត្រីនោះ ដល់ហើយ
សាំសុនក៏ចាត់ចែងរៀបជប់លៀង[ឋ] តាមទំនៀមទំលាប់នៃ

**១៤:២** ក លប ២១:២១
**១៤:៣** ឃ លប ២៤:៤ ង លប ៣៤:១៤ ១សយ ១៤:៦ ច នក ៣៤:១៦
**១៤:៤** ឆ ចទ ២:៣០ ជ យស ១១:២០ ឈ ពច ១៣:១ ១៥:១១
**១៤:៦** ញ ពច ៣:១០ ដ ១សយ ១៧:៣៥
**១៤:១០** ឋ លប ២៩:២២

ក្រោយនៃជីវិតគាត់ដែរ ។ តាមរយៈដំណើររឿងរបស់ពួកគេ បានធ្វើឱ្យមានរឿងបន្ទាប់បន្សំ៣សំខាន់ៗ ។ (១). ដើម្បីបានរួចខ្លួន យូដាបានឱ្យសាំសុនទៅសាសន៍ភីលីស្ទីន (១៥:៩–១៧) (២). សេចក្តីសង្គ្រោះរបស់ព្រះចំពោះសាំសុនឱ្យរួចពីខ្មាំងសត្រូវ (១៥:១៨–១៩) (៣). ការនិរទេសខ្លួនរបស់សាំសុនចេញពីក្រុងកាសា ដែលជាទីក្រុងធំរបស់អ្នកស្រុកហេប្រុន (១៦:១–៣) ។

**១៤:១** *ធីមណា* បានបង្ហាញថា ជាថែល បាថាស ( Tell Batah ) ដែលមានទីតាំងនៅស្ទឹង"សូរីក" ( Sorek )ភាគខាងលិច បេតសិមេស ។ តាមបុរាណវិទូរ បាននិយាយថាពួកភីលីស្ទីន គឺជាអ្នករស់នៅក្នុងស្រុកនេះ ។ *ស្ត្រីម្នាក់ក្នុងពួកក្រមុំរបស់សាសន៍ភីលីស្ទីន* ស្ត្រីនោះមិនមែនជាទីពេញចិត្តរបស់ឪពុកម្តាយសាំសុនឡើយ(ខ.៣ ប្រៀបធៀបជាមួយអេសាវ លប ២៦:៣៥ ២៧:៤៦ ២៨:១) ពួកសាសន៍ដទៃមិនត្រូវបានឱ្យរៀបការ ជាមួយនិងពួកកូនចៅអ៊ីស្រាអែលឡើយ ដោយព្រោះពួកគេមិនមែនជាអ្នកគោរពប្រតិបត្តិដល់ព្រះយេហូវ៉ា (នក ៣៤:១១,១៦ ចទ ៧:១,៣ ពច ៣:៥–៦) ។

**១៤:២** *សូមដណ្តឹងនាងនោះឱ្យខ្ញុំឥឡូវ* សូមមើល លប ៣៤:៤ ។ នៅក្នុងភាពជាមេគ្រួសារ ឪពុកជាអ្នកមានសិទ្ធិសម្រេចលើកិច្ចការទាំងអស់នៅក្នុងក្រុមគ្រួសារ រួមទាំងសិទ្ធិជ្រើសប្រពន្ធផងដែរ (មើល ១២:៩ លប ២៤:៣–៩ នហ ១០:៣០) ។

**១៤:៣** *មិនកាត់ស្បែក* ការកាត់ស្បែក មិនមែនជាសេចក្តីសញ្ញាដែលព្រះយេហូវ៉ាបានបង្គាប់ដល់ពួកភីលីស្ទីនឡើយ ហេតុដូច្នេះហើយ ទើបគេមើលងាយដល់ពួកភីលីស្ទីន(មើល ១សយ ១៤:៦) ។ *នាងនោះពេញចិត្តខ្ញុំណាស់* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះគឺមានន័យថា "នាងជាទីគាប់ភ្នែកខ្ញុំណាស់"នៅក្នុង ១៧:៦ ២១:២៥ ។ អ្នកនិពន្ធបានគិតទុកជាមុន នៅក្នុងឃ្លានេះ ដែលនឹងឃើញម្តងទៀត នៅក្នុងជំពូក ១៧–២១ ។

**១៤:៤** *ការនោះកើតមកពីព្រះយេហូវ៉ាទេ* មើល យស ១១:២០ ១ពវ ១២:១៥ ។ ព្រះយេហូវ៉ាបានយកអ្នកមានបាប អ្នកដែលទន់ខ្សោយ ដើម្បីសម្រេចបំណងព្រះហឫទ័យនៃទ្រង់ ហើយដើម្បីនឹងលើកដម្កើងដល់ព្រះនាមទ្រង់ (មើល លប ៤៥:៨ ៥០:២០ ២រប ២៥:២០ កច ២:២៣ ៤:២៨ រម ៨:២៨–២៩) ។

**១៤:៥** *ចំការទំពាំងបាយជូរនៅធីមណា* នៅច្រកភ្នំ "សូរីក" ( Sorek ) "គឺជាទីកន្លែងផ្សេងទៀត ដែលស្ថិតនៅធីមណា" ហើយនិងនៅតំបន់ផ្សេងៗទៀត នោះមិនមែនជាកន្លែងចំការទំពាំងបាយជូររបស់គេឡើយ ។ សម្រាប់អ្នកណាដែលជាប់ក្នុងពួកន៉ាសារីត នោះមិនត្រូវឱ្យដើរកាត់ចំការទំពាំងបាយជូរឡើយ ព្រោះអាចធ្លាក់ទៅក្នុងសេចក្តីល្បួង (ជន ៦:១–៤) ។ *មានសិង្ហស្ទាវ១ចេញមកគ្រហឹមដាក់គាត់* តាមភាសារបស់អ្នកនិពន្ធអាចមានន័យថា "ពួកសាសន៍ភីលីស្ទីនគេនឹងចេញមកគ្រហឹមដាក់គាត់"(មើល ១៥:១៤) ។ *សិង្ហស្ទាវ* នៅភាគខាងត្បូងនៃប្រទេសកាណាន សត្វសិង្ហគឺជាសត្វដែលសំបូរជាងគេ (សូមមើល ១សយ ១៧:៣៤ ២សយ ២៣:២០ ១ពវ ១៣:២៤ ២០:៣៦) ។

**១៤:៦** *ព្រះវិញ្ញាណ . . . មកសណ្ឋិតលើគាត់* សូមមើល ១៣:២៥ ១៤:១៩ ១៥:១៤ និងការពន្យល់ ៣:១០ និងមើល ១១:២៩ នៅកន្លែងនោះបាននិយាយថាព្រះវិញ្ញាណនៃព្រះយេហូវ៉ា ទ្រង់ជាអ្នកធ្វើឱ្យសាំសុនទទួលជ័យជម្នះលើសាសន៍ភីលីស្ទីន ។ ហើយក្រោយមកទៀតស្តេចដាវីឌ (១សយ ១៧:៣៤–៣៧) និងពួកមាន៉ាសេក៏ស្ថិតនៅក្នុងស្ថានការណ៍នេះដែរ (២សយ ២៣:២០) ។

**១៤:៨–៩** *ខ្មោច . . . គាត់ក៏ច្បាមយកសំបុកឃ្មុំនោះខ្លះ* ពេលនេះលោកសាំសុនបានប្រព្រឹត្តរំលងពីច្បាប់ន៉ាសារីត ដោយទៅជិតខ្មោចសិង្ហ (ជន ៦:៦–៧) ដើម្បីឱ្យតែបានបង្អែមសម្រាប់ខ្លួនគាត់ ។

**១៤:១០** *ជប់លៀង* វាគឺជាពិធីជប់លៀងដ៏វិសេសមួយសម្រាប់ពួកអ្នកនៅមជ្ឈឹមបុព៌ាសម័យបុរាណ(សូមមើល លប ២៩:២២) ហើយនៅទីនេះ គឺគេរៀបចំឡើងរយៈពេល៧ថ្ងៃ(ខ.១២ លប ២៩:២៧) ។ ហើយនៅទីនេះប្រហែលជាមានស្រាទំពាំងបាយជូរដែរ បើសិនជាដូច្នេះមែន នោះលោក

ពួកកំឡោះ ១១លុះគេទទួលគាត់ស្រេចហើយ នោះក៏ដំរូវ
មនុស្ស៣០នាក់ ឱ្យមកកំដរគាត់ ១២ឯសាំសុន គាត់និយាយ
ទៅគេថា សូមឱ្យខ្ញុំចោទជាប្រស្នា[ឌ]ដល់អ្នករាល់គ្នាបន្តិច
បើសិនជាអ្នករាល់គ្នារកពាក្យឆ្លើយដោះស្រាយឱ្យខ្ញុំបាន
ក្នុងរវាង៧ថ្ងៃដែលជប់លៀងនេះ[ឍ] នោះខ្ញុំនឹងឱ្យអាវ
ទ្រនាប់ និងសំលៀកបំពាក់១បន្លាស់ម្នាក់ៗ[ណ] ១៣តែបើអ្នក
រាល់គ្នាដោះស្រាយប្រស្នានេះមិនបាន នោះត្រូវឱ្យអ្នករាល់
គ្នាឱ្យអាវទ្រនាប់ និងសំលៀកបំពាក់១បន្លាស់ម្នាក់ដល់ខ្ញុំ
វិញ គេឆ្លើយឡើងថា ដូច្នេះសូមឱ្យអ្នកចោទប្រស្នានោះ
ដល់យើងរាល់គ្នាចុះ ១៤គាត់ក៏ចោទថា "ពីអាហែកស៊ីមាន
ចេញជាចំណី[ត] ហើយមានបង្អែមចេញពីអាខ្លាំងពូកែ" គេ
ខំរកន័យរបស់ប្រស្នានោះ អស់៣ថ្ងៃមិនឃើញសោះ ។
១៥ដល់ថ្ងៃទី៧គេទៅកំហែងប្រពន្ធសាំសុនថា ចូរនាង
លួងលោមប្ដី[ថ] ឱ្យស្រាយប្រស្នាដល់យើងទៅ ប្រយ័ត្នក្រែង
យើងដុតនាង ព្រមទាំងពួកគ្រួឪពុកនាងនឹងភ្លើង[ទ] តើបាន
ហៅយើងមក ដើម្បីនឹងប្លន់យើងឬអី ១៦ដូច្នេះប្រពន្ធសាំសុន
ក៏យំនៅមុខប្ដីថា បងស្អប់ដល់ខ្ញុំហើយ មិនស្រឡាញ់ខ្ញុំទេ[ធ]
បងបានចោទប្រស្នា ដល់ពួកកូនចៅសាសន៍ខ្ញុំ តែមិនបាន
ស្រាយប្រាប់ខ្ញុំសោះ គាត់ឆ្លើយទៅនាងថា អញមិនបាន
ស្រាយប្រាប់ដល់ទាំងឪពុកម្ដាយអញផង ដូច្នេះតើត្រូវ
ស្រាយប្រាប់ដល់ឯងឬអី ១៧នាងក៏យំនៅមុខគាត់ ទាំង៧ថ្ងៃ[ន]
ដែលជប់លៀងនោះ លុះគ្រប់៧ថ្ងៃហើយ នោះគាត់ក៏
ស្រាយប្រាប់ដល់នាង ពីព្រោះនាងបានរំអុកគាត់ណាស់
រួចនាងក៏ទៅស្រាយប្រស្នានោះ ប្រាប់ដល់ពួកកូនចៅ
សាសន៍របស់ខ្លួន ១៨ក្នុងថ្ងៃទី៧មុនដែលថ្ងៃលិច នោះពួក
មនុស្សទាំងប៉ុន្មាននៅក្នុងក្រុង ក៏ឆ្លើយតបមកគាត់ថា តើ
មានអ្វីដែលផ្អែមជាងទឹកឃ្មុំ ហើយតើមានអ្វីដែលខ្លាំងជាង
សត្វសិង្ហ[ប] នោះគាត់ឆ្លើយទៅវិញថា បើសិនជាអ្នករាល់គ្នា
មិនបានភ្ជួរដោយសារគោញីខ្ញុំ នោះអ្នករាល់គ្នារកន័យ
របស់ប្រស្នាខ្ញុំមិនឃើញទេ ១៩រួចព្រះវិញ្ញាណនៃព្រះយេ
ហូវ៉ា ក៏មកសណ្ឋិតលើគាត់បណ្ដាលឡើងជាខ្លាំង[ផ] ហើយ
គាត់ចុះទៅឯអាសកាឡូន[ព]សំឡាប់មនុស្ស៣០នាក់ យកអាវ
ខោរបស់គេ រួចចែកសំលៀកបំពាក់នោះដល់ពួកអ្នក ដែល
បានស្រាយប្រស្នា សាំសុនមានសេចក្ដីកំហឹងក្ដៅឡើង[ភ]
ហើយក៏ត្រឡប់ទៅឯផ្ទះឪពុកវិញ ២០ឯគេក៏លើកប្រពន្ធគាត់
ឱ្យទៅអ្នក១នោះ[ម] ដែលបានកំដរគាត់វិញ ។

## ការសងសឹករបស់លោកសាំសុនចំពោះពួកភីលីស្ទីន

**១៥** ១ក្រោយបន្តិចមក នៅវេលាចំរូតស្រូវសាលី នោះ[ក]
សាំសុន[ខ]ក៏យកកូនពពែ១[គ]ទៅសួរប្រពន្ធគាត់ ដោយគិតថា
អញនឹងចូលទៅឯប្រពន្ធអញនៅក្នុងបន្ទប់[ឃ] តែឪពុកនាង
មិនព្រមឱ្យចូលទៅទេ ២ដោយពាក្យថា អញបានគិតថាឯង
ស្អប់វាហើយ បានជាអញឱ្យវាទៅអ្នកដែលកំដរឯងម្នាក់
វិញ[ង] ឥឡូវប្អូនវាក៏មានរូបស្រស់ល្អជាងវាដែរ ដូច្នេះសូម

**១៤:១២** ឌ ជន ១២:៨ អគ ១៧:២ ២០:៤៩ ២៤:៣ ហស ១២:១០ ឍ លប ២៩:២៧ ណ លប ៤៥:២២ ២ពវ ៥:៥
**១៤:១៤** ត ខ.១៨
**១៤:១៥** ថ ពច ១៦:៥ សស ៧:២៦ ទ លវ ២០:១៤ ពច ១៥:៦
**១៤:១៦** ធ ពច ១៦:១៥
**១៤:១៧** ន នអ ១:៥
**១៤:១៨** ប ខ.១៤
**១៤:១៩** ផ ពច ៣:១០ ព យស ១៣:៣ ភ ១សយ ១១:៦
**១៤:២០** ម ពច ១៥:២,៦ យហ ៣:២៩
**១៥:១** ក លប ៣០:១៤ ខ ពច ១៣:២៤ គ លប ៣៨:១៧ ឃ លប ២៩:២១
**១៥:២** ង ពច ១៤:២០

សាំសុននឹងរំលងពីច្បាប់ន៉ាសារីត (១៣:៤,៧) ។

**១៤:១១** *ឱ្យមកកំដរគាត់* ប្រៀបធៀបនឹង មថ ៩:១៥ ។ ពួកគេប្រហែលបានទទួលខុសត្រូវក្នុងកម្មវិធីមង្គលការ ។

**១៤:១២** *ប្រស្នា* នៅសម័យបុរាណ នៅពេលដែលមានពិធីជប់លៀងវិសេសបែបនេះ គឺគេតែងតែលើកយកប្រស្នាមក ដាក់ឱ្យគ្នាទៅវិញទៅមក ។ *សំលៀកបំពាក់១បន្លាស់ម្នាក់ៗ* មិនមែនត្រឹមតែសំលៀកបំពាក់នោះទេ គឺរួមទាំងប្រាក់ផងដែរ គឺដូចជាអំណោយយ៉ាងច្រើនដែលបាននិយាយនៅក្នុង លប ៤៥:២២ ២ពវ ៥:២២ (សូមមើល សក ១៤:១៤) ។

**១៤:១៤** *អាហែកស៊ី . . . អាខ្លាំងពូកែ* លោកសាំសុន ចង់និយាយសំដៅលើសត្វតោដែលគាត់បានសម្លាប់ ដែលនៅក្នុងសាកសពតោនោះ មានសំបុកឃ្មុំដែលគាត់យកមកបរិភោគ ។ គាត់មានទំនុកចិត្តថា ប្រស្នារបស់គាត់ គឺប្រៀបដូចជាគាត់បានប្រយុទ្ធជាមួយពួកអ្នកប្រាជ្ញភីលីស្ទីន ។ ជាមួយគ្នានោះដែរ អ្នកនិពន្ធក៏បានបង្ហាញពីទុក្ខក្រៀមក្រំរបស់លោកសាំសុន តាមរយៈប្រស្នាគាត់នៅចុងក្រោយនៃជីវិតគាត់ ។ អ្នកនិពន្ធបានបង្ហាញថាលោកសាំសុនគឺជាអ្នក "ហែកស៊ី"(ហែកឃ្មុំស៊ី) ហើយលោកសាំសុន ក៏ជាអាខ្លាំងពូកែ"បានសម្លាប់សត្វតោដែលមានកម្លាំងមហាសាល" ។ នៅចុងបញ្ចប់រឿងនេះអ្នកនិពន្ធបានបង្ហាញអំពីលោកសាំសុនត្រូវជាប់គុក ហើយត្រូវកិនគ្រាប់ធញ្ញជាតិនៅក្នុងគុកនោះ (១៦:២១ ចេញពីអាហែកស៊ី ពួកភីលីស្ទីនមានជាចំណីសម្រាប់បរិភោគ) ហើយនៅក្នុងពិធីជប់លៀងនោះ អ្នកជាប់ចំណងត្រូវគេយកមកដើម្បីអរសប្បាយ (១៦:២៥ ចេញពីអាខ្លាំងពូកែពួកភីលីស្ទីនមានបង្អែម) ។

**១៤:១៦** *មិនស្រឡាញ់ខ្ញុំទេ* នាងដេលីឡាប្រើល្បិចបែបនេះដែរ (១៦:១៥) ។

**១៤:១៨** *តើមានអ្វីដែលផ្អែមជាងទឹកឃ្មុំ ហើយតើមានអ្វីដែលខ្លាំងជាងសត្វសិង្ហ* ពួកសាសន៍ភីលីស្ទីនបានឆ្លើយតបនឹងប្រស្នានេះ តាមរបៀបប្រស្នា ។ *គោញីខ្ញុំ* គឺប្រពន្ធសាំសុន (ខ.១៥) ។ ពេលនោះគោញីមិនបានប្រើសម្រាប់ភ្ជួរឡើយ លោកសាំសុនចង់និយាយថា ពួកគេមិនយុត្តិធម៌ឡើយ ។

**១៤:១៩** *ព្រះវិញ្ញាណ . . . មកសណ្ឋិតលើគាត់* បំណងព្រះហឫទ័យព្រះចំពោះសាំសុន គឺដើម្បីផ្ចាញ់ពួកភីលីស្ទីន ។ *អាសកាឡូន* គឺជាទីក្រុង១ក្នុងចំណោមទីក្រុងសំខាន់ៗទាំង៥របស់ពួកភីលីស្ទីន ។

**១៤:២០** *អ្នក១នោះដែលបានកំដរ* សូមមើល ១៥:២ ។ ប្រហែលជាមនុស្សកម្លោះដែលបានមកជាមួយលោកសាំសុន (ប្រៀបធៀប យហ ៣:២៩) ក្នុងចំណោមអ្នកកំដរទាំង៣០នាក់ (ខ.១១) ។

**១៥:១** *នៅវេលាចំរូតស្រូវសាលី* ប្រហែលជានៅចុងបញ្ចប់នៃខែឧសភា ឬឈានចូលខែមិថុនា (សូមមើល នរ ១:២២) ។ *កូនពពែ* គឺជាអំណោយមួយ ដែលដូចគ្នានឹងលោកយូដា និងតាម៉ារបានធ្វើនៅក្នុង លប ៣៨:១៧ ។

**១៥:២** *ប្អូន* ឪពុកក្មេកលោកសាំសុនមានអារម្មណ៍ថា គាត់គួរតែធ្វើសេចក្ដី

ឱ្យយកប្អូនជំនួសវាចុះ ៣នោះសាំសុននិយាយទៅគេថា ម្តង
ណេះ បើអញធ្វើបាបដល់ពួកភីលីស្ទីន នោះអញគ្មានទោស
ទេ ៤រួចគាត់ចេញទៅចាប់ចចក៣០០[ច] ហើយយកចន្លុះ[ឆ]មក
ចងកន្ទុយជាប់គ្នាមួយគូៗ ដាក់ចន្លុះមួយៗនៅជាកណ្តាលក
ន្ទុយទាំង២នោះ ៥លុះកាលបានអុចចន្លុះ[ជ]ទាំងនោះស្រេច
ហើយ នោះក៏លែងទៅក្នុងស្រូវរបស់ពួកភីលីស្ទីនបញ្ជោះ
ទាំងស្នឹមកណ្តាប់[ឈ] ទាំងស្រូវដែលមិនទាន់ច្រូត ព្រមទាំង
ចំការដើមអូលីវផង ៦ដូច្នេះពួកភីលីស្ទីនសួរថា តើអ្នកណា
បានធ្វើអំពើនេះ គេឆ្លើយថា គឺសាំសុន ជាកូនប្រសាអ្នក
ក្រុងធីមណានោះ ពីព្រោះគេបានលើកប្រពន្ធវាឱ្យទៅអ្នក
កំដររបស់វាវិញ[ញ] នោះពួកភីលីស្ទីនក៏ឡើងទៅដុតសំឡាប់
នាង[ដ]នោះ ព្រមទាំងឪពុកទៅ[ឋ] ៧សាំសុនក៏និយាយគំនុំដល់
គេថា ឯងរាល់គ្នាធ្វើដូច្នេះ អើ មិនអីទេ ចាំមើលថ្ងៃក្រោយ
អញនឹងសងសឹកនឹងឯងម្តងវិញជាសំរេច ៨គាត់ក៏វាយ
សំឡាបគេដោយកំឡាំងកាយស្លាប់យ៉ាងសន្ធឹក រួចភៀស
ខ្លួនចុះទៅនៅក្នុងក្រហែងថ្មដា[ឌ]ឈ្មោះអេតាមទៅ[ឍ]។

៩នោះពួកភីលីស្ទីនគេឡើងទៅ បោះទ័ពក្នុងស្រុកយូដា
រាយរហូតដល់ដំបន់លេហ៊ី[ណ] ១០រួចពួកយូដាសួរថា ហេតុអ្វី
បានជាអ្នករាល់គ្នាឡើងមក ទាស់នឹងយើងដូច្នេះ គេឆ្លើយ
ថា យើងមកប្រយោជន៍តែនឹងចាប់ចងសាំសុនប៉ុណ្ណោះទេ

**១៥:៤** ច បស ២:១៥ ឆ លប ១៥:១៧
**១៥:៥** ជ លប ១៥:១៧ ឈ នក ២២:៦ ២សយ ១៤:៣០–៣១
**១៥:៦** ញ ពច ១៤:២០ ដ លប ៣៨:២៤ ឋ ពច ៤:១៥
**១៥:៨** ឌ អស ២:២១ ឍ ខ.១១
**១៥:៩** ណ ខ.១៤, ១៧,១៩
**១៥:១១** ត ពច ១៤:៤ ទដ ១០៦:៤០–៤២
**១៥:១២** ថ លប ៤៧:៣១
**១៥:១៣** ទ ពច ១៦:១១,១២
**១៥:១៤** ធ ខ.៩ ន ពច ៣:១០ ប យស ២:៦
**១៥:១៥** ផ លប ២៦:៨

ដើម្បីនឹងសងដល់វា ដូចជាវាបានធ្វើយើងហើយ ១១ដូច្នេះ
មានពួកយូដា៣ពាន់នាក់ ចុះទៅដល់ក្រហែងថ្មអេតាមនោះ
និយាយនឹងសាំសុនថា តើឯងមិនដឹងថាពួកភីលីស្ទីនជាម្ចាស់
លើយើងរាល់គ្នាទេឬអី[ត] ឯងបានធ្វើអ្វីដល់យើងដូច្នេះ គាត់
ឆ្លើយតបថា ខ្ញុំគ្រាន់តែបានធ្វើដល់គេ ដូចជាគេបានធ្វើខ្ញុំ
ហើយទេ ១២នោះគេប្រាប់គាត់ថា យើងចុះមកនេះ ដើម្បី
ចងឯងនាំទៅប្រគល់ដល់អំណាចពួកភីលីស្ទីន សាំសុន
ឆ្លើយថា ដូច្នេះចូរស្បថនឹងខ្ញុំ[ថ]ថា ខ្លួនអ្នករាល់គ្នាមិនសំឡាប់
ខ្ញុំទេ ១៣គេក៏ទទួលព្រមថា អើ យើងគ្រាន់តែចងឯងនាំទៅ
ប្រគល់ដល់អំណាចគេប៉ុណ្ណោះ ឯខ្លួនយើងមិនសំឡាប់ឯង
ជាប្រាកដ គេក៏យកខ្សែថ្មី២[ទ]មកចងគាត់ នាំឡើងចេញពីថ្ម
ដានោះទៅ ។

១៤គ្រាដល់លេហ៊ី[ធ]ហើយ កាលពួកភីលីស្ទីនបានឃើញ
គាត់ នោះក៏នាំគ្នាស្រែកឡើង រួចព្រះវិញ្ញាណនៃព្រះ
យេហូវ៉ា ទ្រង់សណ្ឋិតលើគាត់ បណ្តាលឡើងជាខ្លាំង[ន] ឯខ្សែ
ដែលគេចងដៃគាត់ ក៏ត្រឡប់ដូចជាសរសៃខ្លូតទេស[ប] ដែល
ខ្លោចដោយភ្លើងវិញ របេះជ្រុះពីដៃគាត់ចេញអស់ ១៥លុះ
គាត់ឃើញឆ្អឹងថ្គាមស្រស់១របស់សត្វលា នោះក៏លូកដៃទៅ
ចាប់យកមក វាយសំឡាប់មនុស្សអស់១ពាន់នាក់[ផ] ១៦រួច
សាំសុនថ្លែងវាចាថា ដោយសារថ្គាមលា អញវាយសំឡាប់

ព្រៀងតបចំពោះលោកសាំសុន ព្រោះគាត់បានទទួលថ្លៃទឹកដោះ ជាច្រើនពីលោកសាំសុន ។ ទំនាក់ទំនងនៃអាពាហ៍ពិពាហ៍ ដែលមានការប្រហាក់ប្រហែលគ្នានេះដែរ គឺធ្វើឡើងដោយលោកឡាបាន់ និងលោកយ៉ាកុប (លប ២៩:១៦– ២៨) ស្តេចសូល និងដាវីឌ (១សយ ១៨:១៩–២១) ។

**១៥:៥** *បញ្ឆេះ* នៅរដូវចម្រូតស្រូវសាលី (ខ.១) គឺចុងបញ្ចប់នៃរដូវក្តៅ ដូច្នេះហើយបានធ្វើឱ្យវាលស្រែងាយនឹងឆេះភ្លើងណាស់ ។ ការបញ្ឆេះស្រូវនេះ គឺជាស្រមោលមួយដែលបង្ហាញថា លោកសាំសុននឹងបំផ្លាញព្រះវិហារដាកុន (មានន័យថា "ធញ្ញជាតិ") ដែលការបំផ្លាញព្រះវិហារនេះ គឺជាការវិនាសចុងក្រោយរបស់ពួកភីលីស្ទីន (១៦:២៣–៣០ និងការពន្យល់ ១០:៦) ។

**១៥:៧** *សងសឹក* ការសងសឹកគ្នានេះ គឺជាសកម្មភាពមួយដ៏សាមញ្ញសម្រាប់ពួកមនុស្សនៅមជ្ឈិមបូព៌ាសម័យបុរាណ ។ ទីក្រុងពំនាក់ចំនួន៦ ត្រូវបានរៀបចំឡើងដោយសារព្រះយេហូវ៉ា ដើម្បីការពារមិនឱ្យមានការសម្លាប់គ្នាដែលផុសចេញពីការសងសឹក (សយ ២០:១–៩ និងការពន្យល់) ។ លោកសាំសុនសងសឹកចំពោះពួកភីលីស្ទីនណាម្នាក់ដែលគាត់ពេញចិត្ត (មើលការពន្យល់ ១៤:៣ និងមើល អគ ២៤:១៦) លោកសាំសុនបានបង្ហាញពីស្រមោលនៃការសងសឹករបស់គាត់ចំពោះពួកភីលីស្ទីន ដោយព្រោះពួកគេបានធ្វើឱ្យភ្នែកគាត់ត្រឡប់ជាខ្វាក់ (១៦:២៨) ។

**១៥:៩–១៧** សូមមើល ១៤:១–១៦:៣១ ។

**១៥:៩** *លេហ៊ី* មានន័យថា "ឆ្អឹងថ្គាម" ទីក្រុងនេះប្រហែលជាគ្មានឈ្មោះរហូតដល់គ្រាដែលមានព្រឹត្តិការណ៍បែបនេះបានកើតឡើង ។ អ្នកនិពន្ធបានប្រើឈ្មោះនេះ ដោយយោងទៅតាមព្រឹត្តិការណ៍ដែលបានកើតឡើងជាក់ស្តែង តាមលក្ខណៈអក្សរសាស្ត្រហេព្រើរ ។ សម្រាប់ទីកន្លែងណាមួយពិតប្រាកដរបស់លេហ៊ី នោះគេមិនបានដឹងច្បាស់ឡើយ ។

**១៥:១១** *ដូច្នេះមានពួកយូដា៣ពាន់នាក់* មានតែម្តងគត់ដែលនិយាយពីពួកយូដាមានកងទ័ពជាច្រើន ដែលបានចូលរួមជាមួយពួកចៅហ្វាយ (មើលការពន្យល់ ១:២) ។ ពួកមនុស្សដែលមកពីយូដា ម្នាក់ៗ គឺសុទ្ធតែទទួលស្គាល់ពីសេចក្តីអង់អាចរបស់សាំសុន ទោះបីជាពួកគេមានគ្នាច្រើនយ៉ាងណាក៏ដោយ ក៏ពួកគេមិនអាចចាប់លោកសាំសុនចងបានឡើយ លុះត្រាតែមានការយល់ព្រមពីគាត់ (ខ.១២–១៣) ។ *ពួកភីលីស្ទីនជាម្ចាស់លើយើងរាល់គ្នា* ភាគច្រើននៃពួកយូដា គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភីលីស្ទីន ហើយពូជអំបូរយូដា ក៏យល់ព្រមចំពោះការគ្រប់គ្រងរបស់ពួកភីលីស្ទីនមកលើខ្លួនដែរ ។ ពួកគេបានប្រមូលគ្នាជាកងឡើង ដើម្បីចាប់សាំសុនឱ្យពួកភីលីស្ទីនមិនបានគាំទ្រចំពោះលោកសាំសុននោះឡើយ ។ ទង្វើរនេះមានភាពផ្ទុយគ្នានឹងច្បាប់ដែលបានប្រគល់ឱ្យយូដា (១:២ ២០:១៨) ។

**១៥:១៤** *នោះក៏នាំគ្នាស្រែកឡើង* គឺជាសម្រែកបញ្ឆោតពីការធ្វើសង្គ្រាម (មើល ១សយ ១៧:៥២) ។ ពួកគេបានមកទាំងស្រែកដាក់សាំសុន ដូចគ្នានឹងសម្លេងសឹង្ហដែលបានគ្រហឹមដាក់គាត់ (១៤:៥) ។ *ព្រះវិញ្ញាណនៃព្រះយេហូវ៉ា* សូមមើលការពន្យល់ ៣:១០ និងមើល ១១:២៩ ១៤:១៩ ។

**១៥:១៥** *វាយសំឡាប់មនុស្សអស់១ពាន់នាក់* សូមប្រៀបធៀប ជម្លោះសាំកើរដែលបានវាយសម្លាប់ពួកភីលីស្ទីន៦០០នាក់ ដោយសារជន្លួញគោ (មើល ៣:៣១) ។

**១៥:១៨–១៩** សូមមើលការពន្យល់ ១៤:១–១៦:៣១ ។

មនុស្សបានអស់១ពាន់នាក់ ដោយសារថ្គាមនោះមានគំនរ
មនុស្សគរលើគ្នា[ព] ១៧កាលគាត់បានថ្លែងរួចហើយ ក៏បោះ
ឆ្អឹងថ្គាមនោះពីដៃចេញទៅ គេដាក់ឈ្មោះទីនោះថា រ៉ា
ម៉ាត-លេហី[ភ] ១៨ខណនោះគាត់ស្រេកទឹកជាខ្លាំង ហើយក៏
អំពាវនាវដល់ព្រះយេហូវ៉ា[ម]ថា ទ្រង់បានប្រទានឱ្យដៃអ្នក
បំរើទ្រង់ មានជ័យជំនះ[យ]យ៉ាងធំនេះហើយ ឥឡូវនេះ
តើត្រូវឱ្យទូលបង្គំស្លាប់ ដោយស្រេកទឹកហើយធ្លាក់ទៅក្នុង
កណ្ដាប់ដៃនៃពួក ដែលមិនកាត់ស្បែកនេះវិញឬអី ១៩នោះ
ព្រះទ្រង់ធ្វើឱ្យមានទីខ្វងដែលនៅត្រង់លេហី រួចមានទឹក
ចេញមក កាលគាត់បានផឹកទឹកហើយ នោះក៏មានវិញ្ញាណ
ឡើងវិញ[រ] ព្រមទាំងមានកំឡាំងឡើងដែរ ហេតុនោះបាន
ជាគេដាក់ឈ្មោះទីនោះថា អេន-ហាកូរេ ក្បាលទឹកនោះ[ល]
មាននៅត្រង់លេហី ដរាបដល់សព្វថ្ងៃនេះ ២០សាំសុនបាន
ធ្វើជាអ្នកគ្រប់គ្រង លើសាសន៍អ៊ីស្រាអែល នៅគ្រាពួក
ភីលីស្ទីនអស់២០ឆ្នាំ[វ] ។

## លោកសាំសុន និងនាងដេលីឡា

**១៦** ១លំដាប់នោះសាំសុន[ក]ក៏ទៅឯក្រុងកាសា[ខ] នៅទីនោះ
គាត់ឃើញស្រីសំផឹងម្នាក់[គ] ហើយក៏ចូលទៅឯនាង ២មានគេ
ប្រាប់ដល់ពួកក្រុងកាសាថា សាំសុនបានមកហើយ គេក៏ព័ទ្ធ
ទីជុំវិញ លបចាំចាប់គាត់នៅទ្វារក្រុងរហូតទាល់ភ្លឺ[ឃ] គេនៅ
សំងំពេញ១យប់នោះ ដោយសន្យាគ្នាថា ដល់ភ្លឺឡើង[ង]យើង
នឹងសំឡាប់វាចេញ ៣តែសាំសុនគាត់ដេក ទាល់តែដល់ពាក់
កណ្ដាលអធ្រាត្រ រួចក្រោកឡើង ចាប់យកសន្លឹកទ្វារទីក្រុង
កន្ត្រាក់ទាញបង្គោលទាំង២ ព្រមទាំងរនុក លីទាំងអស់ទៅ
លើកំពូលភ្នំ ដែលនៅមុខហេប្រុនទៅ[ច] ។
៤ក្រោយមកទៀត គាត់មានស្រឡាញ់[ឆ]ស្ត្រីម្នាក់ នៅ
ច្រកភ្នំសូរេក នាងនោះឈ្មោះដេលីឡា[ជ] ៥ដូច្នេះពួកមេ
លើសាសន៍ភីលីស្ទីន[ឈ] ក៏ឡើងទៅបបួលនាងថា ចូរលួង
លោម[ញ]វាមើល ដែលវាមានកំឡាំងខ្លាំងម្ល៉េះ[ដ]ពីណាមក
ហើយធ្វើដូចម្ដេចឱ្យយើងឈ្នះវា ដើម្បីនឹងចាប់ចងបង្ក្រាប
វាទៅបាន នោះយើងគ្រប់គ្នានឹងឱ្យប្រាក់១១០០ម្នាក់ដល់
នាង[ឋ] ៦រួចដេលីឡា[ឌ]ក៏ល្បួងសាំសុនថា សូមប្រាប់ខ្ញុំដែល
អ្នកមានកំឡាំងជាខ្លាំងម្ល៉េះពីណាមក តើយកអ្វីនឹងចង
បង្ក្រាបអ្នកបាន ៧នោះសាំសុនឆ្លើយតបថា បើគេយកវល្លិ
ស្រស់៧ដើម ដែលមិនបានហាលឱ្យស្ងួត មកចងអញ នោះ
អញនឹងទៅជាខ្សោយ ដូចជាមនុស្សឯទៀតវិញ ៨ដូច្នេះ
ពួកមេលើសាសន៍ភីលីស្ទីន ក៏យកវល្លិស្រស់៧ដើម ដែល
មិនបានហាលឱ្យស្ងួតមកឱ្យនាង ហើយនាងយកទៅចងគាត់
៩រីឯនៅក្នុងបន្ទប់ខាងក្នុង[ឍ] នោះមានមនុស្សបង្កប់ខ្លួនចាំ
ខណនោះនាងស្រែកថា សាំសុនអើយ ន៎ ពួកភីលីស្ទីនមក
ចាប់អ្នកហើយ[ណ] តែគាត់បណ្ដាច់វល្លិទាំងនោះចេញ ដូច
ជាសរសៃចចូត ដែលត្រូវដាច់ដោយប៉ះនឹងភ្លើង ដូច្នេះ
គ្មានអ្នកណាដឹងជាគាត់មានកំឡាំងប៉ុណ្ណាទេ ។
១០នោះដេលីឡានិយាយនឹងសាំសុនថា មើល បងបាន
បញ្ឆោតខ្ញុំ[ត] ដោយពោលសុទ្ធតែពាក្យភរភូតវិញ ម្ដងនេះ
សូមប្រាប់ដល់ខ្ញុំ តើនឹងយកអ្វីមកចងបងឱ្យជាប់បាន ១១គាត់
ឆ្លើយថា បើគ្រាន់តែចងអញ ដោយពួរថ្មី[ថ] ដែលមិនទាន់

**១៥:១៦** ព យរ ២២:១៩
**១៥:១៧** ភ ខ.៩
**១៥:១៨** ម ពច ១៦:២៨ យ ចទ ២០:៤
**១៥:១៩** រ លប ៤៥:២៧ ១សយ ៣០:១២ អស ៤០:២៩
**១៥:១៩** ល នក ១៧:៦
**១៥:២០** វ ពច ១៦:៣១
**១៦:១** ក ពច ១៣:២៤ ខ លប ១០:១៩ គ លប ៣៨:១៥
**១៦:២** ឃ យស ២:៥ ង ១សយ ១៩:១១
**១៦:៣** ច យស ១០:៣៦
**១៦:៤** ឆ លប ២៤:៦៧ ៣៤:៣ ជ ខ.៦
**១៦:៥** ឈ យស ១៣:៣ ញ នក ១០:៧ ពច ១៤:១៥ ដ ខ.៦,១៥ ឋ ខ.១៨
**១៦:៦** ឌ ខ.៤
**១៦:៩** ឍ ខ.១២ ណ ខ.១៤
**១៦:១០** ត ខ.១៣
**១៦:១១** ថ ពច ១៥:១៣

**១៥:១៩** *រួចមានទឹកចេញមក* ព្រះយេហូវ៉ាទ្រង់បានផ្គត់ផ្គង់ដល់លោកសាំសុន ដូចគ្នានឹងការផ្គត់ផ្គង់ដល់ពួកកូនចៅអ៊ីស្រាអែល នៅទីរហោស្ថានដែរ ។ មើល នក ១៧:១-៧ (ម៉ាសា) និង (មេរីបា) ជន ២០:២-១៣ (មេរីបា) ។

**១៥:២០** *ធ្វើជាអ្នកគ្រប់គ្រង លើសាសន៍អ៊ីស្រាអែល . . . ២០ឆ្នាំ* សូមមើលការពន្យល់ ១២:៧ ។ *២០ឆ្នាំ* ចំនួនឆ្នាំនៅក្នុងគ្រាចៅហ្វាយតែងតែមានការប្រែប្រួល (សូមមើលសេចក្ដីផ្ដើមៈ ប្រវត្តិដើម) ។

**១៦:១-៣** សូមមើលការពន្យល់ ១៤:១-១៦:៣១ ។

**១៦:១** *ក្រុងកាសា* គឺជាកំពង់ផែដ៏សំខាន់សម្រាប់ពួកភីលីស្ទីន ដែលស្ថិតនៅឆ្នេរសមុទ្រមេឌីទែរ៉ាណេ ភាគខាងត្បូងពីស្រុកកាណាន ។ *ស្រីសំផឹង* នៅពេលនោះលោកសាំសុនមានកម្លាំងខ្លាំងក្លា ប៉ុន្តែបែរជាខ្វះសីលធម៌ដែលនាំឱ្យគាត់ជួបនូវការហិនវិនាស ។

**១៦:២** *ភ្លឺឡើង* នៅពេលនោះ គេគិតថា លោកសាំសុនអស់កម្លាំងនឹងលង់លក់ ។

**១៦:៣** *រនុក* ប្រហែលធ្វើឡើងពីលង្ហិន (១ពវ ៤:១៣) ឬពីដែក (ទដ ១០៧:១៦ អស ៤៥:២) ។ *នៅមុខហេប្រុន* គឺនៅចំពីមុខហេប្រុនតែម្ដងដែលមានចំងាយប្រមាណជា៦០,៨គ.ម ពីស្រុកភ្នំ ។ ពីព្រោះហេប្រុន គឺជាទីក្រុងសំខាន់ជាងគេនៅស្រុកយូដា ការនេះមើលទៅហាក់បីដូចជាបង្ហាញពីអ្វីដែលលោកសាំសុនធ្វើចំពោះពួកយូដា នូវអ្វីដែលគេបានធ្វើចំពោះគាត់ (១៥:១១-១៣) ។

**១៦:៤-៣១** សូមមើលការពន្យល់ ១៤:១-១៦:៣១ ។

**១៦:៥** *ពួកមេលើសាសន៍ភីលីស្ទីន* សូមមើលការពន្យល់ ៣:៣ ។ *បង្ក្រាបវា* ពួកភីលីស្ទីនមិនចង់ឱ្យសាំសុនស្លាប់ឆាប់ឡើយ ពួកគេសងសឹកគាត់ដោយធ្វើទារុណកម្មលើគាត់យ៉ាងយូរ ។ *ប្រាក់១១០០ម្នាក់* ប្រាក់ដ៏ច្រើនបែបនេះគឺជាប្រាក់ដែលផ្ដល់ឱ្យជារង្វាន់ ដែលមានការខុសពីធម្មតាក្នុងករនិយាយនៅ ១៧:១០ (មើលការពន្យល់) ដែលប្រាក់សម្រាប់អ្នកបម្រើមានត្រឹមតែ១០ដួងប៉ុណ្ណោះក្នុង១ឆ្នាំ ។ *ប្រាក់* សូមមើលការពន្យល់ លប ២០:១៦ ។

**១៦:៧** *វល្លិស្រស់៧ដើម* នៅសម័យបុរាណ លេខ៧គឺជាចំនួនពិសេស វាជានិមិត្តសញ្ញានៃភាពគ្រប់លក្ខណ៍ ។ សូមចាំថា សក់របស់សាំសុនត្រូវក្រងជា៧កម្រង (ខ.១៣) ។

**១៦:១១** *ពួរថ្មី* ពួកភីលីស្ទីនគេហាក់បីដូចជាមិនបានដឹងថា គេបានធ្វើរបៀបនេះម្ដងរួចទៅហើយ ហើយក៏ត្រូវបរាជ័យ (១៥:១៣-១៤) ។

ប្រើការសោះ នោះអញនឹងទៅជាខ្សោយ ដូចជាមនុស្សឯ
ទៀតវិញ ១២ដូច្នេះ ដេលីឡាក៏យកពួរថ្មីទៅចង រួចស្រែក
ថា សាំសុនអើយ ន៎ ពួកភីលីស្ទីនមកចាប់បងហើយ[ទ]
ឯពួកអ្នកដែលបង្កប់ខ្លួន ក៏នៅចាំឮដ៏បន្ទប់ខាងក្នុង គាត់
បណ្តាច់ពួរនោះចេញពីដៃទៅ គណនាដូចជាអំបោះ១សរ
សៃសុទ្ធ ។

១៣ដេលីឡានិយាយនឹងសាំសុនថា តាំងពីដើមដល់ឥឡូវ
នេះ បងនៅតែបញ្ឆោតខ្ញុំ ដោយនិយាយភូតភរដដែល ចូរ
ប្រាប់មកខ្ញុំ តើត្រូវយកអ្វីចងបងឱ្យជាប់បាន គាត់ឆ្លើយថា
ឱ្យឯងគ្រាន់តែក្រងសក់ក្បាលអញទាំង៧កំរងជាប់ជា១នឹង
អំបោះអន្ទងទៅ ១៤នាងក៏បោះស្នៀតភ្ជាប់នឹងផ្សំថែមទៀត
រួចស្រែកថា សាំសុនអើយ ន៎ ពួកភីលីស្ទីនមកចាប់បង
ហើយ[ធ] នោះគាត់ភ្ញាក់ពីដេកឡើងរដោះស្នៀតចេញពីកី
ជាប់ទាំងអំបោះអន្ទងទៅផង ។

១៥នោះនាងនិយាយនឹងគាត់ថា ធ្វើដូចម្តេចឱ្យបង
និយាយថា បងស្រឡាញ់ដល់ខ្ញុំបាន[ន] បើចិត្តបងទីទៃពីគ្នា
ដូច្នេះ បងបានបញ្ឆោតខ្ញុំគ្រប់៣ដងនេះហើយ[ប] ឥតប្រាប់ពី
ដំណើរដែលបងមានកំឡាំងខ្លាំងទាំងម្ល៉េះពីណាមកសោះ[ផ]
១៦រួចមក ដោយនាងចេះតែរំអុកបង្ខំរាល់តែថ្ងៃ ដោយ
ពាក្យសំដីនាង បានជាគាត់មានចិត្តព្រួយសឹងតែនឹងស្លាប់
១៧ហើយក៏បញ្ចេញប្រាប់អស់អំពីក្នុងចិត្ត[ព]ដល់នាងថា មិន
ដែលមានកាំបិតកោរសក់ក្បាលអញឡើយ ដ្បិតអញជាពួក
ន៉ាសារីត[ភ]ដល់ព្រះតាំងតែពីផ្ទៃម្តាយមក បើកោរសក់អញ
ហើយ នោះកំឡាំងនឹងថយចេញពីអញទៅ ហើយអញនឹង
ទៅជាខ្សោយ ដូចជាមនុស្សឯទៀត ។

១៨កាលដេលីឡាឃើញថា គាត់បានបញ្ចេញប្រាប់អស់
អំពីក្នុងចិត្តដូច្នោះ នោះនាងក៏ចាត់គេ ឱ្យទៅហៅពួកមេ
លើសាសន៍ភីលីស្ទីន[ម]មក ដោយពាក្យថា សូមឡើងមកតែ
ម្តងនេះទៀតចុះ ដ្បិតវាបានបញ្ចេញប្រាប់អស់អំពីក្នុងចិត្ត
ដល់ខ្ញុំហើយ ដូច្នេះពួកមេក៏ឡើងមកឯនាង ព្រមទាំងយក
ប្រាក់នោះមកផង[យ] ១៩ខណនោះនាងបានផ្តេកគាត់ឱ្យលក់
នៅលើភ្លៅ រួចនាងហៅម្នាក់មកឱ្យកោរកំរងទាំង៧ពីលើ
ក្បាលគាត់ចេញ នោះនាងចាប់តាំងធ្វើទុក្ខដល់គាត់ ហើយ
កំឡាំងក៏ថយចេញពីគាត់ទៅ[រ] ២០រួចនាងស្រែកថា សាំសុន
អើយ ន៎ ពួកភីលីស្ទីនមកចាប់បងហើយ[ល] គាត់ក៏ភ្ញាក់ពីដេក
ឡើង នឹកថា អញនឹងចេញទៅរលាស់ខ្លួន ដូចជាសព្វ១ដង
តែគាត់មិនដឹង ជាព្រះយេហូវ៉ាបានថយចេញពីខ្លួនទៅ[វ]
២១លំដាប់នោះពួកភីលីស្ទីន[ស]ក៏មកចាប់គាត់ ចាក់ឱ្យខ្វាក់
ភ្នែក[ហ] រួចនាំចុះទៅឯក្រុងកាសា[ឡ] ដល់ហើយក៏យកច្រវាក់
លង្ហិនមកដាក់គាត់ រួចគាត់ត្រូវបង្វិលត្បាល់កិន[អ]នៅក្នុងគុក
២២ប៉ុន្តែ ក្រោយដែលគេបានកោរ នោះសក់ក៏ចាប់តាំង
លាស់ឡើងវិញ ។

## ការស្លាប់របស់លោកសាំសុន

២៣គ្រានោះពួកមេសាសន៍ភីលីស្ទីន ក៏ប្រមូលគ្នាដើម្បី
នឹងថ្វាយយញ្ញបូជាយ៉ាងឧឡារិកដល់ដាកុន[ក] ជាព្រះនៃគេ
ហើយនាំគ្នាសប្បាយឡើង ដោយថា ព្រះនៃយើងបាន
ប្រគល់សាំសុន ជាខ្មាំងសត្រូវមកក្នុងកណ្តាប់ដៃយើងហើយ
២៤កាលពួកបណ្តាជនបានឃើញគាត់ នោះគេសរសើរដល់
ព្រះរបស់គេ[ខ]ដោយថា ព្រះនៃយើងបានប្រគល់ខ្មាំងសត្រូវ
មកក្នុងកណ្តាប់ដៃយើងហើយ[គ] គឺជាអ្នកដែលបានបំផ្លាញ
ស្រុកយើង ព្រមទាំងសំឡាប់ពួកយើងជាច្រើនផងនោះ
២៥កាលចិត្តគេបានសប្បាយឡើង[ឃ]ហើយនោះគេប្រាប់ថា
ចូរនាំសាំសុនមកឡកឡឺយឱ្យយើងមើលលេង គេក៏ទៅហៅ

**១៦:១២** ទ ខ.១៤
**១៦:១៤** ធ ខ.៩,២០
**១៦:១៥** ន ពច ១៤:១៦ ប ជន ២៤:១០ ផ ខ.៥
**១៦:១៧** ព ខ.១៨ មីក ៧:៥ ភ ជន ៦:២
**១៦:១៨** ម យស ១៣:៣ ១សយ ៥:៨ យ ខ.៥
**១៦:១៩** រ សភ ៧:២៦–២៧
**១៦:២០** ល ខ.១៤ វ ជន ១៤:៤២ យស ៧:១២ ១សយ ១៦:១៤ ១៨:១២ ២៨:១៥
**១៦:២១** ស យរ ៤៧:១ ហ ជន ១៦:១៤ ឡ លប ១០:១៩ អ យប ៣១:១០ អស ៤៧:២
**១៦:២៣** ក ១សយ ៥:២ ១រប ១០:១០
**១៦:២៤** ខ ដយ ៥:៤ គ ១សយ ៣១:៩ ១រប ១០:៩

**១៦:១៣** សាំសុនមើលងាយចំពោះពួកភីលីស្ទីន ដែលជាសត្រូវរបស់ខ្លួន ។ *កំរងជាប់ជា១នឹងអំបោះអន្ទង* ប្រហែលជាអំបោះសម្រាប់ត្បាញ ។

**១៦:១៩–២០** *ហើយកំឡាំងក៏ថយចេញពីគាត់ទៅ . . . ជាព្រះយេហូវ៉ាបានថយចេញពីខ្លួនទេ* ប្រភពនៃកម្លាំងដ៏មហាសាលរបស់លោកសាំសុន គឺមកពីព្រះយេហូវ៉ាប៉ុណ្ណោះ ។

**១៦:២០** *តែគាត់មិនដឹង* ពាក្យនេះ បានប្រាប់យើងអំពីរឿងដ៏ក្រៀមក្រំ ដែលមាននៅក្នុងសញ្ញាចាស់ ។ លោកសាំសុនមិនបានដឹងថា គាត់កំពុងតែក្បត់ចំពោះការត្រាស់ហៅនោះឡើយ ។ គាត់បានអនុញ្ញាតឱ្យស្ត្រីសាសន៍ភីលីស្ទីន ចងគាត់ដោយខ្សែរពួរដែលបង្ហាញពីការតាំងសញ្ញា ព្រមទាំងការប្រសិទ្ធិយ៉ាងវិសេស រវាងព្រះអម្ចាស់ព្រះយេហូវ៉ា ហើយនិងរូបគាត់ ។ ជ័យជម្នះរបស់ព្រះ ដែលមាននៅក្នុងសាំសុនត្រូវបានបាត់បង់ ដោយសារប្រពន្ធដែលផិតក្បត់របស់គាត់ ។

**១៦:២១** *ចាក់ឱ្យខ្វាក់ភ្នែក* ទង្វើដ៏ព្រៃផ្សៃបែបនេះ គឺគេតែងតែធ្វើឡើងសម្រាប់អ្នកទោសនៅក្នុងសង្គ្រាម (សូមមើល ១សយ ១១:២ ២ពវ ២៥:៧ និងការពន្យល់ ពច ១:៦) ។ *រួចនាំចុះទៅឯក្រុងកាសា* គេបាននាំសាំសុនទៅឯកាសាទាំងឈឺចាប់ ហើយគ្មានកម្លាំងនៅក្នុងខ្លួន ជាកន្លែងប្រភពដើមនៃកម្លាំងរបស់គាត់ (ខ.១–៣) ។ *រួចគាត់ត្រូវបង្វិលត្បាល់កិន* សូមមើលការពន្យល់ ៩:៥៣ និងមើល ១៤:១៤ ។

**១៦:២២** *នោះសក់ក៏ចាប់តាំង* អ្នកនិពន្ធបានណែនាំ នូវសេចក្តីពិតមួយតាមរយៈជីវប្រវត្តិលោកសាំសុន និងការសន្និដ្ឋានរួមចុងក្រោយសម្រាប់សាំសុន គឺព្រះយេហូវ៉ាទ្រង់មិនបានបោះបង់ចោលរាស្ត្ររបស់ទ្រង់នោះឡើយ ទោះបីជាពេលខ្លះគេធ្វើខុសចំពោះព្រះអង្គក៏ដោយ ។

**១៦:២៣** *ដាកុន* សូមមើលការពន្យល់ ១០:៦ ១៥:៥ ។ *ព្រះនៃយើងបានប្រគល់* តាមធម្មតាគេកំណត់បែបនេះ នៅពេលណាដែលគេទទួលជ័យជម្នះលើរាស្ត្ររបស់ព្រះ ។

**១៦:២៥** *ឡកឡឺយឱ្យយើងមើល* សូមមើលការពន្យល់ ១៤:១៤ ។

សាំសុនចេញពីក្នុងគុកមក ហើយគាត់ក៏ឡកត្លុកនៅមុខគេ
គេដាក់គាត់នៅជាកណ្ដាលនៃសសររោង ២៦នោះសាំសុន
សូមដល់ក្មេង ដែលដឹកដៃគាត់ថា សូមបើកឱ្យខ្ញុំពាល់សសរ
ដែលទ្ររោងនេះ ដើម្បីឱ្យខ្ញុំបានផ្អែកទៅលើបន្តិច ២៧រីឯ
រោងនោះមានពេញណែន ដោយមនុស្សទាំងប្រុសទាំងស្រី
ពួកមេសាសន៍ភីលីស្ទីនទាំងអស់ ក៏ប្រជុំគ្នានៅទីនោះដែរ
ហើយមានមនុស្សទាំងប្រុសទាំងស្រី ប្រហែលជា៣ពាន់
នាក់ទៀត នៅមើលសាំសុនពីលើដំបូល[ង] កំពុងដែលគាត់
ឡកត្លុក ២៨គ្រានោះសាំសុនអំពាវនាវដល់ព្រះយេហូវ៉ា[ច]
ទូលថា ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់អើយ សូមទ្រង់នឹកចាំ
ពីទូលបង្គំ ឱព្រះអង្គអើយ សូមចំរើនកំឡាំងឱ្យទូលបង្គំ
តែម្តងណេះចុះ ដើម្បីឱ្យទូលបង្គំបានសងសឹក[ឆ] ដល់ពួក
សាសន៍ភីលីស្ទីន ដោយព្រោះភ្នែកទូលបង្គំទាំង២តែម្តង
២៩នោះសាំសុនក៏ចាប់សសរទាំង២ ដែលទ្រនៅជាកណ្ដាល
រោងនោះ ដោយដៃស្តាំម្ខាង ហើយដោយដៃឆ្វេងម្ខាង
៣០រួចគាត់ថា សូមឱ្យខ្ញុំស្លាប់ជាមួយនឹងពួកភីលីស្ទីនចុះ
នោះគាត់ប្រឹងរួបយោលខ្លួនពេញកំឡាំង ហើយរោងនោះ
បានរលំមកលើពួកមេ ព្រមទាំងបណ្តាជនទាំងប៉ុន្មាន
ដែលនៅក្នុងទីនោះផង ដូច្នេះពួកមនុស្សដែលគាត់ធ្វើឱ្យ
ស្លាប់ ក្នុងកាលដែលគាត់ស្លាប់ទៅ នោះមានច្រើនជាងពួក
អ្នក ដែលគាត់បានសំឡាប់ពីកាលនៅរស់ទៅទៀត ៣១ឯបង
ប្អូន និងពួកគ្រួឪពុកគាត់ទាំងអស់ គេចុះទៅសែងខ្មោចគាត់
ឡើងមក ក៏បញ្ចុះនៅក្នុងទីកប់ខ្មោចរបស់ម៉ាណូអា[ជ] ជា
ឪពុក នៅជាកណ្ដាលសូរ៉ាហ និងអែសថោល គាត់បានធ្វើ
ជាអ្នកគ្រប់គ្រង[ឈ] លើសាសន៍អ៊ីស្រាអែលអស់២០ឆ្នាំ[ញ] ។

**១៦:២៥** ឃ ពច ៩:២៧ ១៩:៦,៩,២២ នរ ៣:៧ នអ ១:១០
**១៦:២៧** ង យស ២:៨
**១៦:២៨** ច ពច ១៥:១៨ ឆ យរ ១៥:១៥
**១៦:៣១** ជ ពច ១៣:២ ឈ នរ ១:១

## រោងព្រះរបស់មីកា

**១៧** ១រីឯនៅស្រុកភ្នំអេប្រាអិម នោះមានបុរសម្នាក់

១សយ ៤:១៨ ៧:៦ ញ ពច ១៥:២០

**១៦:២៧** *លើដំបូល* ព្រះវិហារនោះមានគ្រប់លក្ខណៈប្រហែលជាត្រូវតែមានដំបូលយ៉ាងធំដែលបើកចំហរ ហើយអាចឱ្យមនុស្សអង្គុយមើលការប្រកួតពានរង្វាន់ក្នុងរយៈពេលដ៏ខ្លីមួយ ។

**១៦:២៨** *ដើម្បីឱ្យទូលបង្គំបានសងសឹក . . . ភ្នែកទូលបង្គំទាំង២តែម្តង* សូមមើលការពន្យល់ ១៥:៧ ។

**១៦:៣០** *រួបយោលខ្លួន* លោកសាំសុន បានរំយោលខ្លួនលើសសរទាំង២ ដែលមានសសរគ្រឹះជាថ្មរឹងមាំរបស់ពួកគេ ។ ពួកអ្នកបុរាណវិទូរបានធ្វើការស្រាវជ្រាវនៅព្រះវិហារភីលីស្ទីននៅ "ថែល កាស៊ីល" (Tell Qasile) ហើយពួកគេរកឃើញសសរគ្រឹះនៃព្រះវិហារនេះចំនួន២ ។ *នោះមានច្រើនជាងពួកអ្នក* កាលពីលើកមុន លោកសាំសុនបានសម្លាប់មនុស្សប្រមាណជា១,០០០នាក់ (មើល ១៥:១៥ ១៤:១៩ ១៥:៨) ។ នៅគ្រាចុងក្រោយនៃជីវិតលោកសាំសុនពេល លោកមានកម្លាំងឡើងវិញ ដើម្បីបង្ហាញដល់ពួកភីលីស្ទីនថា ការដែលពួកគេស្មានថារូបព្រះរបស់គេមានជ័យជម្នះលើព្រះយេហូវ៉ា នោះជាការយល់ខុសហើយ ។ *ក្នុងកាលដែលគាត់ស្លាប់ទៅ* បើសិនជាពួកន៉ាសារីត បានប្រព្រឹត្តល្មើសចំពោះការមិនកាត់សក់ ដោយព្រោះជាការប្រសិទ្ធិពិសេសថ្វាយព្រះបានត្រឡប់ជា "ស្មោកគ្រោក" ដោយព្រោះបានកាត់សក់ចេញ នោះពួកន៉ាសារីតត្រូវតែប្រសិទ្ធិខ្លួនទៅឯព្រះម្តងទៀតបាន ក្នុងអំឡុងពេលដែលគាត់បានញែកចេញ ។ ការប្រព្រឹត្តរំលងថ្ងៃមុននោះព្រះយេហូវ៉ាទ្រង់មិនបានរាប់ឡើយ ពីព្រោះគេបានប្រព្រឹត្តរំលងក្នុងអំឡុងពេលដែលញែកខ្លួន ។ "រួចត្រូវឱ្យអ្នកនោះបន់កំណត់ពេលវេលាដែលញែកខ្លួនចេញថ្វាយព្រះយេហូវ៉ាជាថ្មីទៀត ហើយត្រូវយកកូនចៀមអាយុ១ខួបមក សម្រាប់ជាដង្វាយ ដោយព្រោះការរំលង ដ្បិតថ្ងៃមុនទាំងប៉ុន្មានបានសាបសូន្យហើយ ពីព្រោះបានខូចសេចក្តីបរិសុទ្ធខ្លួនហើយ" ជន (៩:១២) ។ នៅពេលដែលសក់លោកសាំសុនត្រូវបានកាត់ ដោយសារនាងដេលីឡា នោះព្រះយេហូវ៉ាបានបង្ហាញថា លោកសាំសុនគឺជាអ្នកប្រព្រឹត្តរំលងដោយខ្លួនគាត់ផ្ទាល់ ហើយព្រះអង្គមិនបានទទួលគាត់ឡើយ ។ ប៉ុន្តែនៅពេលដែលសក់លោកសាំសុនចាប់ផ្តើមដុះជាថ្មី (ខ.២២ និងការពន្យល់) នោះសាំសុនក៏ចាប់ផ្តើមប្រសិទ្ធិខ្លួនជាថ្មីនៅចំពោះព្រះយេហូវ៉ា ។ ទោះបីជាលោកសាំសុនគ្មានចៀមយកមកថ្វាយព្រះយេហូវ៉ា ទុកជាដង្វាយដោយព្រោះការរំលងក៏ដោយ ក៏គាត់បានយកជីវិតរបស់គាត់ថ្វាយដល់ព្រះយេហូវ៉ា ដោយធ្វើជាទ័ពចម្បាំងលើសាសន៍ភីលីស្ទីន ហើយគាត់ក៏ត្រូវស្លាប់ដែរ ។

**១៦:៣១** *គេចុះទៅសែងខ្មោចគាត់ឡើងមក* ក្រុមគ្រួសាររបស់គាត់មានសេរីភាព ក្នុងការយកសាកសពគាត់ដើម្បីបញ្ចុះ ដើម្បីជាការរំឭកថាពួកភីលីស្ទីនមិនអាចប្រព្រឹត្តអាក្រក់បានទៀតឡើយ (ផ្ទុយពីសាកសពរបស់ស្តេចសូល ១សយ ៣១:៩–១០) ។ *គ្រប់គ្រងលើសាសន៍អ៊ីស្រាអែលអស់២០ឆ្នាំ* សូមមើលការពន្យល់ ១២:៧ ។ *២០ឆ្នាំ* ចំនួននៃការគ្រប់គ្រប់ គឺតែងតែមានការប្រែប្រួលនៅគ្រាពួកចៅហ្វាយ (មើលសេចក្តីផ្តើម ត្រង់ប្រវត្តិដើម) ។

**១៧:១–២១:២៥** មានព្រឹត្តិការណ៍២ ដែលបានកើតឡើងនៅចុងបញ្ចប់នៃព្រះគម្ពីរចៅហ្វាយនេះ(សូមមើល សេចក្តីផ្តើម: លក្ខណៈអក្សរសាស្ត្រ) ។ ព្រឹត្តិការណ៍ទាំងនោះ បានបង្ហាញពីពេលវេលានៃហេតុការណ៍ដ៏ជាក់លាក់មួយនាសម័យមុន ក្នុងអំឡុងពេលព្រះគម្ពីរចៅហ្វាយ (សូមមើលការពន្យល់ ១៨:៣០ និងមើល ២០:១,២៨) ។ ពួកគេបានលើកយកពីពិធីក្នុងសាសនា និងអំពើអសីលធម៌ផ្សេងៗទៀត មកធ្វើការពន្យល់យើង ដែលការនេះតែងតែកើតឡើង ជាញឹកញាប់ណាស់សម្រាប់ពួកកូនចៅអ៊ីស្រាអែល នៅគ្រានោះគ្មានស្តេចណាសោយរាជ្យនៅស្រុកអ៊ីស្រាអែលទេ ម្ល៉ោះហើយ មនុស្សទាំងឡាយគេតែងតែប្រព្រឹត្តការដែលខ្លួនគិតឃើញថាត្រឹមត្រូវ (១៧:៦ ២១:២៥ ។

**១៧:១–១៨:៣១** នៅក្នុងជំពូកនេះ គឺនិយាយពីព្រឹត្តិការណ៍ ដែលកើតចេញពីការពុករលួយ និងការថ្វាយបង្គំរូបព្រះ ក្នុងចំណោមពួកកូនចៅអ៊ីស្រាអែល ដោយសារការនិយាយប្រាប់របស់លោកមីកា អំពីទីកន្លែងថ្វាយបង្គំនៅក្នុងតំបន់នៃ ស្រុកអេប្រាអិម ហើយពួកលេវីបានបន្ថែមក្នុងកូនចៅលោកម៉ូសេ ។ នៅពេលដែលពួកគេមានគ្នាកាន់តែច្រើនឡើង ការថ្វាយបង្គំព្រះរបស់ពួកអ្នកជឿនេះត្រូវបានគ្រប់គ្រងដោយពូជអំបូរដាន់ ដែលពួកគេជាអ្នកទទួលនូវមរដក និងការនិរទេសទៅព្រំប្រទល់អ៊ីស្រាអែលភាគខាងជើង ។

ឈ្មោះ មីកា[ក] ២គាត់និយាយប្រាប់ម្ដាយថា ប្រាក់១១០០
ដែលគេបានយកពីម៉ែទៅ ហើយម៉ែបានដាក់បណ្ដាសា
ពីរឿងនោះនៅត្រចៀកខ្ញុំ មើលប្រាក់នោះនៅនឹងខ្ញុំទេ គឺខ្ញុំ
ហើយដែលយក ដូច្នេះម្ដាយនិយាយថា សូមពរពីព្រះ
យេហូវ៉ាដល់ឯង[ខ]ជាកូន ៣គាត់ក៏ប្រគល់ប្រាក់១១០០នោះ
ដល់ម្ដាយវិញ រួចម្ដាយនិយាយថា អញថ្វាយប្រាក់នេះដល់
ព្រះយេហូវ៉ាពីដៃខ្លួនអញសំរាប់កូន ដើម្បីនឹងសិតរូប១[គ]
ហើយឆ្លាក់ធ្វើជារូប១ ដូច្នេះ ហ៏ អញប្រគល់ឱ្យឯង ៤តែ
គាត់ប្រគល់ប្រាក់នោះដល់ម្ដាយវិញ នោះម្ដាយក៏យកប្រាក់
២០០ទៅឱ្យជាងស្មិត ជាងក៏ឆ្លាក់ធ្វើរូប១ និងរូបសិត១[ឃ]
រូបនោះតាំងនៅក្នុងផ្ទះមីកា ៥ឯមីកានេះ គាត់មានរោង
ព្រះ១[ង] ហើយក៏ធ្វើអេផូឌ[ច] និងរូបព្រះ១[ឆ] រួចញែក[ជ]កូនគាត់
ម្នាក់ ទុកជាសង្ឃដល់ខ្លួន[ឈ] ៦នៅគ្រានោះ គ្មានស្ដេចណា
សោយរាជ្យ នៅស្រុកអ៊ីស្រាអែលទេ[ញ] ម្លោះហើយ មនុស្ស
ទាំងឡាយ គេតែងតែប្រព្រឹត្តការដែលខ្លួនគិតឃើញថា
ត្រឹមត្រូវ[ដ] ។
៧រីឯនៅក្រុងបេថ្លេហិម ស្រុកយូដា[ឋ] នោះមានមនុស្ស
កំឡោះម្នាក់ក្នុងគ្រួយូដា ដែលជាពួកលេវី[ឌ] គាត់មាន
ទីលំនៅអាស្រ័យនៅទីនោះ ៨គាត់ក៏ចេញពីបេថ្លេហិម នៅ
ស្រុកយូដានោះ ដើម្បីនឹងទៅស្នាក់នៅទីណាដែលរកបាន
កំពុងដែលធ្វើដំណើរទៅ នោះក៏មកដល់ផ្ទះមីកា នៅស្រុក
ភ្នំអេប្រាអិម ៩មីកាសួរគាត់ថា អ្នកមកពីណា គាត់ឆ្លើយថា
ខ្ញុំជាពួកលេវី ពីបេថ្លេហិម ស្រុកយូដា[ឍ] ខ្ញុំស្វែងរកទីណា
ដែលខ្ញុំនឹងស្នាក់នៅបាន ១០នោះមីកាឆ្លើយតបថា ដូច្នេះ
ចូរនៅជាមួយនឹងខ្ញុំ ធ្វើជាឪពុក[ណ]ហើយជាសង្ឃ[ត]ដល់ខ្ញុំចុះ
ខ្ញុំនឹងបើកប្រាក់ឱ្យ១០ដួងក្នុង១ឆ្នាំ ព្រមទាំងសំលៀកបំពាក់
១សំរាប់ ហើយបាយផង ដូច្នេះអ្នកនោះក៏ចូលទៅ ១១ហើយ
សុខចិត្តនៅជាមួយនឹងមីកា ដែលរាប់គាត់ ទុកដូចជាកូនខ្លួន
បង្កើតណាមួយ ១២មីកាក៏ញែក[ថ]ចេញទុកជាសង្ឃ[ទ]ដល់ខ្លួន
ហើយគាត់នៅក្នុងផ្ទះមីកាទៅ ១៣មីកានឹកថា ឥឡូវនេះ អញ
ដឹងថាព្រះយេហូវ៉ាទ្រង់នឹងផ្ដល់សេចក្ដីល្អដល់អញ ពីព្រោះ
អញមានពួកលេវីម្នាក់ធ្វើជាសង្ឃដល់អញហើយ[ធ] ។

## ពួជអំបូរដាន់តាំងលំនៅនៅឡាអ៊ីស

**១៨** ១នៅគ្រានោះ គ្មានស្ដេចនៅស្រុកអ៊ីស្រាអែលទេ[ក]
រីឯពួជអំបូរដាន់នៅវេលានោះ គេរកស្រុកតាំងជាទីលំនៅ
ទុកជាកេរ្ដិ៍អាកររបស់គេ ដ្បិតតាំងពីដើមរៀងមក គេមិន

**១៧:១** ក ពច ១៨:២,១៣ **១៧:២** ខ នរ ២:២០ ៣:១០ ១សយ ១៥:១៣ ២៣:២១ ២សយ ២:៥ **១៧:៣** គ នក ២០:៤ **១៧:៤** ឃ នក ៣២:៤ អស ១៧:៨ **១៧:៥** ង អស ៤៤:១៣ អគ ៨:១០ ច ពច ៨:២៧ ឆ លប ៣១:១៩ ជ ជន ១៦:១០ ឈ នក ២៩:៩ **១៧:៦** ញ ពច ១៨:១ ១៩:១ ២១:២៥ ដ ចទ ១២:៨ **១៧:៧** ឋ លប ៣៥:១៩ មថ ២:១ ឌ ពច ១៨:៣ **១៧:៩** ឍ នរ ១:១ **១៧:១០** ណ លប ៤៥:៨ ត ពច ១៨:១៩ **១៧:១២** ថ ជន ១៦:១០ ទ ពច ១៨:៤ **១៧:១៣** ធ ជន ១៨:៧ **១៨:១** ក ពច ១៧:៦

**១៧:២** *ប្រាក់១១០០* សូមមើលកាពន្យល់ ១៦:៥ ។ *ដាក់បណ្ដាសាពីរឿងនោះ* ការភ័យខ្លាចចំពោះបណ្ដាសានេះ បានបណ្ដាលឱ្យគាត់ប្រគល់ប្រាក់ដែលលួចនោះមកឱ្យម្ដាយវិញ ។ *សូមពរពីព្រះយេហូវ៉ាដល់ឯងជាកូន* គឺជាពរមួយដែលគាត់បានឱ្យជំនួសបណ្ដាសា ។

**១៧:៣** *ម្ដាយ . . . កូន* ពួកគេថ្វាយបង្គំព្រះនៃសាសន៍អ៊ីស្រាអែល តាមរបៀបសាសន៍ដទៃ ដូច្នេះពួកគេថ្វាយបង្គំរូបព្រះ ដែលខុសពីក្រឹត្យវិន័យរបស់ព្រះអម្ចាស់ (សូមមើល នក ២០:៤,២៣ ចទ ៤:១៦) ។ *ឆ្លាក់ធ្វើជារូប១* រូបនោះប្រហែលធ្វើឡើងពីឈើស្រោបប្រាក់ ។ រូបព្រះប្រហែលធ្វើឡើងដោយប្រាក់រឹង ឬក៏លោហៈដែលមានតម្លៃថោក ដែលស្រោបដោយប្រាក់ ។

**១៧:៤** *ជាងស្មិត* គឺជាម្នាក់ដែលចេះធ្វើរូបព្រះ ដូចដែលបាននិយាយនៅក្នុងកម្ពីរកិច្ចការ ១៩:២៤ (ប្រៀបធៀប អស ៤០:១៩ យរ ១០:៩) ដែលនៅក្នុងកន្លែងនោះ ភាសាហេព្រើរនិយាយថា ជាងទង ។

**១៧:៥** *អេផូឌ* សូមមើល ៨:២៧ និងការពន្យល់ នក ២៨:៦ ។ *រូបព្រះ* គឺជាព្រះដែលថែរក្សា ដែលប្រើសម្រាប់ជាការទស្សទាយ (សូមធៀបជាមួយ អគ ២១:២១ សក ១០:២) ។ រូបព្រះទាំងនោះ ពេលខ្លះមានសណ្ឋានជាមនុស្ស (១សយ ១៩:១៣) ។

**១៧:៦** *គ្មានស្ដេច* សូមមើល ១៨:១ ១៩:១ ២១:២៥ ប្រហែលជាព្រះគម្ពីរចៅហ្វាយសរសេរឡើង បន្ទាប់ពីមានការរៀបចំឱ្យមានស្ដេច (សូមមើលសេចក្ដីផ្ដើម: អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។ *គេតែងតែប្រព្រឹត្តការ ដែលខ្លួនគិតឃើញថាត្រឹមត្រូវ* នៅក្នុងលក្ខណៈនេះ ពួកអ៊ីស្រាអែលគេបានបែកចេញពីសេចក្ដីសញ្ញារបស់ព្រះ (សូមមើល ចទ ១២:៨) ។

**១៧:៧** *ពួកលេវី* ឈ្មោះរបស់គេគឺយ៉ូណាថាន (មើល ១៨:៣០ និងការពន្យល់) ។ *បេថ្លេហិមស្រុកយូដា* មិនមែនជាទីក្រុង១ក្នុងចំណោមទីក្រុងទាំង៤៨របស់ពួកលេវីនោះទេ (យស ២១) ។

**១៧:៨** *ក៏ចេញពីបេថ្លេហិម* ការធ្លាក់ចុះរបស់ពួកអ៊ីស្រាអែលក្នុងការប្រព្រឹត្តតាមក្រឹត្យវិន័យ ប្រហែលជាធ្វើឱ្យពួកគេមានការខ្វះខាតស្បៀងសម្រាប់ឧបត្ថម្ភពួកលេវី ពួកគេត្រូវដើរត្រាច់ចរគ្មានពុំនឹង ។

**១៧:១០** *ឪពុក* រឿងរ៉ាវនៃការគោរព និងឱ្យតម្លៃនេះ ក៏មាននិយាយនៅក្នុងគ្រាលោកអេលីយ៉ា (២ពវ ២:១២) និងលោកអេលីសេដែរ (២ពវ ៦:២១ ១៣:១៤) សូមមើល លប ៤៥:៨ មថ ២៣:៩ ។ *ប្រាក់ឱ្យ១០ដួង* សូមមើលអត្ថបទពន្យល់របស់គម្ពីរ ។ ប្រាក់រង្វាន់ទាំងនោះ គឺសម្រាប់រយៈពេល១ឆ្នាំ ដូច្នេះចំនួនប្រាក់ដ៏ច្រើន ដែលនិយាយនៅក្នុង ១៦:៥ ១៧:២ នោះ គឺជាប្រាក់រង្វាន់ដ៏វិសេសមួយនៅក្នុងសម័យនោះ ។ គេផ្ដល់ឱ្យជាប្រាក់សំលៀកបំពាក់ និងអាហារដែលការទាំងនោះ គឺហួសពីអ្វីដែលពួកលេវីខ្លួន ឯងរកបានទៅទៀត (ខ.១១) ។ ដូច្នេះ វត្ថុទាំងនោះគឺជាឫសគល់នៃការសម្រេចចិត្តរបស់គាត់ ព្រោះក្រោយមកទៀតគាត់បានទទួលយកនូវជំនូនដ៏ច្រើនជាងនេះទៀត (១៨:១៩–២០) ។

**១៧:១២** *ញែក* ការព្យាយាមធ្វើជាទីសការៈស្របច្បាប់ ហើយបានផ្ដល់ឱ្យគេនូវកិត្តិនាម ប្រហែលជាលោកមីកាត្រូវផ្ដល់តួនាទីនេះឱ្យកូនគាត់ (ខ.៥) ។

**១៨:១** *គេរកស្រុកតាំងជាទីលំនៅ* ចំណែកមរដករបស់ពួកកូនចៅដាន់ គឺស្ថិតនៅក្នុងភាគខាងលិចនៃស្រុកយូដា និងអេប្រាអិម (យស ១៩:៤១–៤៦) ប៉ុន្តែ ដោយសារពួកគេមានការជំពាក់បំណុលជាមួយសាសន៍អាម៉ូរីត (ពច ១:៣៤) ហើយនិងពួកភីលីស្ទីន ដូច្នេះពួកដាន់មិនអាចតាំង លំនៅក្នុងទឹកដីនោះបានឡើយ (មើលការពន្យល់ ១៣:២) ។

ទាន់បានទទួលកេរ្តិ៍អាករ របស់គេ ក្នុងពូជអំបូរអ៊ីស្រាអែល
ទាំងប៉ុន្មាននៅឡើយទេ[ខ] ២ដូច្នេះពួកកូនចៅដាន់[គ] ក៏រើស
ពួកគេ៥នាក់[ឃ] ដែលសុទ្ធតែជាមនុស្សខ្លាំងពូកែ ពីក្រុង
សូរ៉ាស់ និងក្រុងអែសថោល ចាត់ឱ្យទៅសង្កេតមើល[ង]ស្រុក
ដោយពាក្យថា ចូរទៅពិនិត្យមើលស្រុកទៅ[ច] គេក៏ចូលមក
ក្នុងស្រុកភ្នំអេប្រាអិមដល់ផ្ទះមីកា[ឆ] ហើយដេកនៅទីនោះ
អស់១យប់ ៣តែគ្រាដែលមកជិតដល់ផ្ទះមីកាហើយនោះគេ
ឮ ហើយក៏ស្គាល់សំឡេងរបស់មនុស្សកំឡោះ ជាពួកលេវី
នោះ[ជ] រួចក៏ចូលទៅសួរគាត់ថា តើអ្នកណាបាននាំអ្នកមក
នេះ អ្នកធ្វើជាអ្វីនៅទីនេះ ហើយមានអ្វីនៅឯណេះ ៤គាត់
ឆ្លើយថា មីកាបានប្រព្រឹត្តនឹងខ្ញុំយ៉ាងនេះមួយៗ គាត់បាន
ជួលខ្ញុំ ឱ្យធ្វើជាសង្ឃដល់គាត់[ឈ] ៥នោះគេប្រាប់ដល់គាត់ថា
ដូច្នេះសូមឱ្យអ្នកទូលសួរព្រះមើល[ញ] ដើម្បីឱ្យយើងរាល់គ្នា
ដឹងជាផ្លូវដែលយើងទៅនេះនឹងបានកើតការឬទេ ៦សង្ឃ
នោះឆ្លើយតបថា សូមអញ្ជើញទៅដោយសុខសាន្តចុះ[ដ]
ព្រះយេហូវ៉ាទ្រង់ជ្រាបផ្លូវ ដែលអ្នករាល់គ្នាទៅនោះ
ហើយ ។

៧នោះពួក៥នាក់[ឋ]នាំគ្នាចេញទៅ ក៏បានទៅដល់ក្រុងឡា
អ៊ីស[ឌ] នៅស្រុកនោះគេឃើញមានពួកមនុស្ស ដែលនៅ
ដោយសុខសាន្ត តាមរបៀបសាសន៍ស៊ីដូន គឺរម្យទម ហើយ
សុខសាន្ត[ឍ] ដ្បិតនៅស្រុកនោះ គ្មានអ្នកណាមានអំណាច
នឹងធ្វើឱ្យគេមានសេចក្តីខ្មាស ក្នុងការអ្វីឡើយ គេនៅឆ្ងាយ
ពីសាសន៍ស៊ីដូន[ណ] ឥតប្រកបនឹងអ្នកណាមួយផង ៨រួចពួក
ទាំង៥នាក់ក៏ត្រឡប់ទៅឯបងប្អូនគេ ដែលនៅសូរ៉ាស់និង
អែសថោលវិញ បងប្អូនគេក៏សួរថា យ៉ាងម៉េចទៅ ៩គេ
ប្រាប់ថា ចូររៀបចំឡើង លើកគ្នាទៅច្បាំងនឹងគេទៅ ដ្បិត
យើងបានឃើញស្រុកគេល្អណាស់ តើនៅព្រងើយដូច្នេះ
ធ្វើអី កុំឱ្យខ្ជិលនឹងចូលទៅចាប់យកស្រុកនោះឡើយ[ត]
១០កាលណាចូលទៅដល់ នោះនឹងឃើញពួកមនុស្ស ដែល
នៅដោយសុខសាន្ត ស្រុកនោះក៏ធំទូលាយដែរ ដ្បិតព្រះ
បានប្រគល់ស្រុកនោះ មកក្នុងកណ្តាប់ដៃយើងហើយ គឺជា
កន្លែងមិនចេះខ្វះអ្វី[ថ] ដែលនៅផែនដីនេះ[ទ] ។

១១គ្រានោះមានមនុស្ស៦០០នាក់[ធ]ពីវង្សដាន់[ន] ដែលនៅ
ត្រង់សូរ៉ាស់ និងអែសថោល គេលើកគ្នាចេញទៅទាំងមាន
គ្រឿងសឹក ១២ក៏ឡើងទៅបោះទ័ព នៅត្រង់គារយ៉ាត់-យា
រីម[ប]ក្នុងស្រុកយូដា ហេតុនោះបានជាគេឱ្យឈ្មោះទីនោះថា
ម៉ាហានេ-ដាន់[ផ] ដរាបដល់សព្វថ្ងៃនេះ ទីនោះនៅខាង
ក្រោយគារយ៉ាត-យារីម ១៣ពីទីនោះគេចូលទៅក្នុងស្រុក
ភ្នំអេប្រាអិម ហើយក៏មកដល់ផ្ទះមីកា[ព] ។

១៤ឯពួក៥នាក់ ដែលបានទៅសង្កេតមើលស្រុកឡា
អ៊ីស[ភ] គេក៏ផ្តើមនិយាយទៅបងប្អូនគេថា តើអ្នករាល់គ្នាដឹង
ថា នៅផ្ទះនេះមានអេផូឌ[ម]និងរូបព្រះ ព្រមទាំងរូបឆ្លាក់និង
រូបសិតផងឬទេ[យ] ដូច្នេះចូរពិចារណាមើល តើត្រូវធ្វើដូច
ម្តេច ១៥គេក៏បែរចូលទៅក្នុងផ្ទះមនុស្សកំឡោះជាពួកលេវី

**១៨:១** ខ យស ១៩:៤៧ ពច ១:៣៤ **១៨:២** គ លប ៣០:៦ ឃ ខ.១៧ ង ជន ២១:៣២ ច យស ២:១ ឆ ពច ១៧:១ **១៨:៣** ជ ពច ១៧:៧ **១៨:៤** ឈ ពច ១៧:១២ **១៨:៥** ញ លប ២៥:២២ ពច ២០:១៨,២៣,២៧ ១សយ ១៤:១៨ ២សយ ៥:១៩ ២ពវ ១:២ ៨:៨ **១៨:៦** ដ ១ពវ ២២:៦ **១៨:៧** ឋ ខ.១៧ ឌ យស ១៩:៤៧ ឍ លប ៣៤:២៥ ណ ខ.២៨ យស ១១:៨ **១៨:៩** ត ជន ១៣:៣០ ១ពវ ២២:៣ **១៨:១០** ថ ចទ ៨:៩ ទ ១រប ៤:៤០ **១៨:១១** ធ ខ.១៦, ១៧ ន ពច ១៣:២ **១៨:១២** ប យស ៩:១៧ ផ ពច ១៣:២៥ **១៨:១៣** ព ពច ១៧:១ **១៨:១៤** ភ យស ១៩:៤៧ ម ពច ៨:២៧ យ លប៣១:១៩

**១៨:២** *ចាត់ឱ្យទៅសង្កេតមើលស្រុក* មើល ១:២៣ និងមើលការពន្យល់ ជន ១៣:២ ។

**១៨:៣** *ស្គាល់សំឡេង* ប្រហែលជាគេស្គាល់គាត់ដោយសារ គ្រាមភាសា ឬក៏សំនៀងរបស់គាត់ ។

**១៨:៥** *ទូលសួរព្រះ* ការទូលសួរនេះ គឺតាមវិធីទំនាយមួយ ។ ប្រហែលជាគេប្រើអេផូឌ និងព្រះនៃឪពុក (មើលការពន្យល់ ១៧:៥) ដើម្បីទាយ ។ ព្រះអម្ចាស់ទ្រង់បានបង្ហាញឱ្យគេបានដឹងហើយ អំពីបំណងព្រះហឫទ័យរបស់ព្រះអង្គ តាមរយៈគេរមដកជាច្រើនដែលព្រះអង្គផ្តល់ឱ្យពួកគេពីមុនមក (យស ១៤-២០) ។ ពួកគេបានស្វែងរកតាមវិធីទំនាយ ក្រែងលដំណើររបស់គេបានទទួលជោគជ័យ ។

**១៨:៦** *សូមអញ្ជើញទៅដោយសុខសាន្តចុះ* ពួកលេវីបានឱ្យពរដល់ពួកគេ ដែលពាក្យនោះ គឺជាការចង់បាននឹងចង់ឮរបស់ពួកគេ ។ ទោះបីជាយ៉ាងណាក៏ដោយ គាត់ត្រូវតែមានការប្រុងប្រយត្ន័ ចំពោះ ការប្រើព្រះនាមព្រះយេហូវ៉ា ដើម្បីឱ្យជាពរនិងអំណាចដល់នរណាម្នាក់ដែលគួរឱ្យជឿ ។

**១៨:៧** *ឡាអ៊ីស* ពួកគេបានចំណាយពេលធ្វើដំណើរ ឆ្ពោះទៅភាគខាងជើង ដែលមានចម្ងាយប្រមាណជា ១៦០ គម ពីទីក្រុងសូរ៉ាស់ និងក្រុងអែលថោល (ខ.២) ។ នៅក្នុង យស ១៩:៤៧ ទីក្រុងឡាអ៊ីសនេះមានឈ្មោះថា ទីក្រុងលេសែម ។ បន្ទាប់ពីពួកកូនចៅដាន់ច្បាំងបានក្រុងនេះត្រូវបានប្តូរឈ្មោះជាថ្មីម្តងទៀត គឺឱ្យឈ្មោះថាក្រុងដាន់ (ខ.២៩) ហើយទីក្រុងនេះត្រូវបានពួកកូនចៅអ៊ីស្រាអែលមកតាំងជាលំនៅ ក្រោយដែលចេញពីស្រុកគេមក (២០:១ ១សយ ៣:២០ ២សយ ៣:១០) ។ តាមរយៈអណ្តូងដែលមាននៅទីនោះបានបង្ហាញថា ពួកកូនចៅអ៊ីស្រាអែលបានមកតាំងលំនៅក្នុងតំបន់នេះក្នុងអំឡុងពេលសតវត្សរ៏ទី១២មុន គ.ស ហើយនោះគឺជាការតាំងលំនៅដំបូងរបស់ពួកកូនចៅអ៊ីស្រាអែល ដែលគេរស់នៅក្នុងត្រសាល ឬខ្ទមដែលមានរយៈពេលបណ្តោះអាសន្នប៉ុណ្ណោះ ។ ការតាំងលំនៅបែបនេះត្រូវបានធ្វើបន្តរហូតដល់គ្រាអាស៊ីកាន់កាប់វិញ ប៉ុន្តែទីក្រុងនេះ ត្រូវបានគេបំផ្លាញនិងកសាងឡើងវិញជាច្រើនដង ។ *សាសន៍ស៊ីដូន* គឺជាមនុស្សដែលមានសន្តិភាព ហើយបានចងស្ពានមេត្រី តាមរយៈការរៀបការ ជាមួយពួកមែឌីទៃរ៉ាណេ ។ *ឥតប្រកបនឹងអ្នកណាមួយផង* ពួកគេហាក់បីដូចជាមិនមានការព្យាបាទ ពីអ្នកដែលមានអំណាចផ្សេងៗឡើយ ដូច្នេះហើយ បានជាធ្វើឱ្យពួកគេមានសេចក្តីសុខ ។

**១៨:១១** *៦០០នាក់* ដូចគ្នានឹងអ្នកដឹកនាំក្នុងពូជអំបូរដាន់ដែរ ពួកគេបានចាត់តំណាងពូជអំបូរម្នាក់ឱ្យចូលទៅក្នុងតំបន់ភាគខាងជើង ។ សូមប្រៀបធៀបមនុស្ស៦០០នាក់ដែលជាសំណល់របស់ពូជអំបូរបេនយ៉ាមីន (២០:៤៧) ។

នោះ គឺក្នុងផ្ទះរបស់មីកា ហើយក៏សាកសួរពីសេចក្ដីសុខ
ទុក្ខ ១៦ឯពួកកូនចៅដាន់[រ] ទាំង៦០០នាក់ ដែលមានគ្រឿង
សឹក គេឈរចាំនៅឯមាត់ទ្វារ ១៧ពួក៥នាក់ដែលបានទៅ
សង្កេតមើលស្រុក ក៏ឡើងចូលទៅក្នុងផ្ទះ យកទាំងរូបឆ្លាក់
និងអេផូឌ ព្រមទាំងរូបព្រះ និងរូបសិតផង[ល] ឯសង្ឃនោះ
គាត់ ឈរនៅមាត់ទ្វារជាមួយនឹងមនុស្ស៦០០នាក់[វ] ដែល
មានគ្រឿងសឹក ១៨កាលអ្នកទាំង៥បានចូលទៅក្នុងផ្ទះមីកា
យក[ស]រូបឆ្លាក់ និងអេផូឌ ព្រមទាំងរូបព្រះ[ហ] និងរូបសិត
ដូច្នោះ នោះគាត់សួរថា អ្នករាល់គ្នាធ្វើអ្វីដូច្នេះ ១៩តែគេ
ប្រាប់គាត់ថា ចូរនៅឱ្យស្ងៀមទៅ[ឡ] ហើយយកដៃខ្ទប់មាត់
ចុះ សូមទៅជាមួយនឹងយើងធ្វើជាឪពុក ហើយជាសង្ឃដល់
យើងវិញ[អ] ដែលអ្នកធ្វើជាសង្ឃដល់ពួកគ្រួ[ក]មនុស្សតែម្នាក់
នេះ នោះតើវិសេសជាងធ្វើជាសង្ឃដល់ពូជអំបូរ១ គឺដល់
វង្ស១ទាំងមូលនៃសាសន៍អ៊ីស្រាអែលឬអី ២០សង្ឃនោះ
មានចិត្តអំណរឡើង រួចក៏យកអេផូឌ និងរូបព្រះ ព្រមទាំង
រូបឆ្លាក់ផង ទៅជាមួយនឹងគេទៅ ។
២១ដូច្នេះគេបែរចេញទៅ ហើយគេឱ្យកូនក្មេង និងហ្វូង
សត្វ ហើយនិងអីវ៉ាន់ទាំងប៉ុន្មានដើរខាងមុខ ២២កាលបាន
ឃ្លាតឆ្ងាយពីផ្ទះមីកាហើយ នោះពួកអ្នកនៅផ្ទះជិតខាងមីកា
ក៏ប្រជុំគ្នាដេញតាមពួកកូនចៅដាន់ឱ្យទាន់ ២៣គេស្រែកហៅ
ពួកកូនចៅដាន់ ឯអ្នកទាំងនោះក៏ងាកបែរមកសួរមីកាថា
ឯងមានហេតុអ្វីបានជាប្រមូលគ្នាច្រើនដល់ម្ល៉េះ ២៤គាត់
ឆ្លើយថា អ្នករាល់គ្នាបាននាំយក[ខ]ព្រះទាំងប៉ុន្មាន ដែលខ្ញុំ
បានធ្វើ ព្រមទាំងសង្ឃរបស់ខ្ញុំមក តើខ្ញុំនៅមានអ្វីទៀត
ចុះដូចម្ដេចបានជាអ្នករាល់គ្នាសួរខ្ញុំថា តើឯងមានហេតុអ្វី
ដូច្នេះ ២៥នោះពួកកូនចៅដាន់ឆ្លើយតបថា កុំឱ្យមានឮ
សំឡេងឯង មកក្នុងពួកយើងឡើយ ក្រែងលោមានពួក
មួរម៉ៅ ស្ទុះទៅលើឯងរាល់គ្នាបំផ្លាញជីវិតឯងទៅ ព្រម
ទាំងជីវិតនៃពួកគ្រួឯងផង ២៦រួចពួកកូនចៅដាន់ ក៏ទៅតាម
ផ្លូវគេទៅ ឯមីកា កាលឃើញថាគេមានកំឡាំងជាងខ្លួន[គ]
នោះគាត់ក៏វិលត្រឡប់មកផ្ទះវិញ ។
២៧ពួកអ្នកទាំងនោះគេនាំយករបស់ដែលមីកាបានធ្វើ
នឹងសង្ឃរបស់គាត់ ទៅដល់ក្រុងឡាអ៊ីសជាទីដែលមាន
មនុស្សរម្យទម[ឃ] ហើយសុខសាន្តនៅ រួចគេសំឡាប់ពួកអ្នក
ក្រុងនោះដោយមុខដាវ ព្រមទាំងយកភ្លើងឆួលដុត[ង]ទីក្រុង
ផង[ច] ២៨ឥតមានអ្នកណាមកជួយគេឡើយ ពីព្រោះទីនោះ
នៅឃ្លាតឆ្ងាយពីក្រុងស៊ីដូន[ឆ] ហើយពួកនោះមិនប្រកបគ្នា
នឹងអ្នកណាផង ក្រុងនោះនៅក្នុងវាលច្រកភ្នំ ដែលនៅជិត
បេត-រេហុប[ជ] រួចហើយពួកកូនចៅដាន់បានសង់ទីក្រុង
នោះឡើងវិញ ទុកជាទីលំនៅរបស់គេ ២៩ក៏ដាក់ឈ្មោះថា
ដាន់[ឈ] តាមឈ្មោះដាន់ជាព្ធយុកោគេ ដែលអ៊ីស្រាអែល
បានបង្កើត តែកាលពីដើម ក្រុងនោះឈ្មោះឡាអ៊ីសវិញ[ញ]
៣០ពួកកូនចៅដាន់ក៏តាំងរូបឆ្លាក់នោះសំរាប់ខ្លួនគេ ហើយ
យ៉ូណាថាន ជាកូនគើសំម[ដ] ក្នុងពូជអំបូរម៉ាន៉ាសេ ព្រមទាំង
កូនចៅគាត់ធ្វើជាសង្ឃដល់ពូជអំបូរដាន់តទៅ ដរាបដល់
ថ្ងៃដែលពួកស្រុកនោះត្រូវគេនិរទេសទៅ ៣១គេបានតាំង
រូបឆ្លាក់ដែលមីកាធ្វើនោះ[ឋ] ទុកសំរាប់ពួកគេ អស់១អំឡុង
ដែលដំណាក់នៃព្រះ[ឌ]នៅត្រង់ស៊ីឡូរ[ឍ]។

**១៨:១៦** រ ខ.១១ **១៨:១៧** ល លប ៣១:១៩ មីក ៥:១៣ វ ខ.១១ **១៨:១៨** ស ខ.២៤ អស ៤៦:២ យរ ៤៣:១១ ៤៨:៧ ៤៩:៣ ហស ១០:៥ ហ លប ៣១:១៩ **១៨:១៩** ឡ យប ១៣:៥ ២១:៥ ២៩:៩ ៤០:៤ អស ៥២:១៥ មីក ៧:១៦ អ ពច ១៧:១០ ក ជន ២៦:៤២ **១៨:២៤** ខ.១៧,១៨ **១៨:២៦** គ ២សយ ៣:៣៩ ទដ ១៨:១៧ ៣៥:១០ **១៨:២៧** ឃ លប ៣៤:២៥ ង ជន ៣១:១០ ច លប ៤៩:១៧ យស ១៩:៤៧ **១៨:២៨** ឆ ខ.៧ លប ១០:១៩ ច ជន ១៣:២១ **១៨:២៩** ឈ លប ១៤:១៤ ញ យស ១៩:៤៧ ១៣រ ១៥:២០ **១៨:៣០** ដ នក ២:២២ **១៨:៣១** ឋ ខ.១៧ ឌ ពច ១៩:១៨ ២០:១៨ ឍ យស ១៨:១ យរ ៧:១៤

**១៨:១៩** *ឪពុក* សូមមើលការពន្យល់ ១៧:១០ ។ *ដល់ពូជអំបូរ១ គឺដល់វង្ស១* គឺមានតែអំបូរ១ដែលមកពីវង្សរបស់ដាន់ប៉ុណ្ណោះដែលនិយាយថា ហ៊ូស៊ីម (ជន ២៦:៤២ ហើយនៅក្នុង លប ៤៦:២៣ ត្រូវបានគេស្គាល់ថាហ៊ូស៊ីម) ។ ពួកកូនចៅ ដាន់បានសុំកម្លាំងទ័ព និងសម្ភារៈផ្សេងៗទៀតពីពួកលេវី ។
**១៨:២១** *ដើរខាងមុខ* គឺដើម្បីការពារគាត់ ក្រែងមានការវាយប្រហារពីមីកានិងគូកនរបស់គេ (សូមប្រៀបធៀប លប ៣៣:២-៣ ដែលនិយាយពីលោកយ៉ាកុប និងលោកអេសាវ) ។
**១៨:២៤** *អ្នករាល់គ្នាបាននាំយកព្រះទាំងប៉ុន្មាន* លោកមីកាមានការព្រួយបារម្ភ ចំពោះការបាត់បង់រូបព្រះ ដែលព្រះនោះមិនអាចជួយខ្លួនឯងបានឡើយ ។ *តើខ្ញុំនៅមានអ្វីទៀត* គឺជាការឈឺចាប់របស់អ្នកដែលមានសេចក្ដីជំនឿចំពោះរូបព្រះ ដែលមិនអាចជួយខ្លួនឯងបាន ។
**១៨:២៨** *បេត-រេហុប* ប្រហែលមានឈ្មោះដូចគ្នានឹងរេហុប ដែលមាននិយាយនៅក្នុង ជន ១៣:២១ (មើល ២សយ ១០:៦,៨) ។
**១៨:២៩** *ក៏ដាក់ឈ្មោះថា ដាន់* សម្រាប់ទីតាំងរបស់ទីក្រុងនេះ ។
**១៨:៣០** *យ៉ូណាថាន* ពួកលេវីនៅកន្លែងនេះបានសម្ដែងថា យ៉ូណាថាន ជាកូនគើសំមៗជាកូនលោកម៉ូសេ (មើល នក ២:២២ ១៨:៣ ១របា ២៣:១៤-១៥) ។ នៅក្នុងការខិតខំប្រឹងប្រែងទប់ស្កាត់ ចំពោះការមើលងាយមើលថោក ដោយសារឈ្មោះរបស់លោកម៉ូសេ ក្រោយមកទៀត អ្នកនិពន្ធបាននិយាយសំដៅលើឈ្មោះនេះ ដោយការមើលងាយហើយក៏បាននិយាយពីលោកម៉ាន៉ាសេវិញ (សូមមើលអត្ថបទគម្ពីរ) ។ បើសិនជាលោកយ៉ូណាថានជាចៅលោកម៉ូសេ នោះព្រឹត្តិការណ៍នៅក្នុងគម្ពីរនេះ គឺកើតឡើងនៅក្នុងអំឡុងពេលមុនគ្រាពួកចៅហ្វាយ (សូមមើលការពន្យល់ ២០:១, ២៨) ។ *ពួកស្រុកនោះត្រូវគេនិរទេសទៅ* ថ្ងៃដែលនិរទេសពិតប្រាកដនោះ មិនបានដឹងឡើយ (សូមមើល ខ.៧) ។
**១៨:៣១** *អស់១អំឡុងដែលដំណាក់នៃព្រះនៅត្រង់ស៊ីឡូរ* សូមមើល យស ១៨:១ ។ សម្រាប់ការបំផ្លាញទីក្រុងស៊ីឡូរ សូមមើលក្នុង ទដ ៧៨:៦០ យរ ៧:១២,១៤ ២៦:៦ ។ តាមពួកអ្នកបុរាណវិទ្យា ដែលធ្វើការនៅស៊ីឡូរ បាននិយាយថា ទីក្រុងនេះត្រូវបានបំផ្លាញ ប្រហែលនៅក្នុងឆ្នាំ ១០៥០ មុន គ.ស ហើយទីក្រុងនេះ ត្រឡប់ជាគ្មានអ្នកតាំងលំនៅអស់ពេលជាច្រើនសតវត្សរ៍ ។

## ពួកលេវីម្នាក់ និងប្រពន្ធចុងរបស់គាត់

**១៩** ១នៅវេលានោះ ក្នុងគ្រាដែលគ្មានស្តេចនៅស្រុក
អ៊ីស្រាអែល នោះមានពួកលេវីម្នាក់ ដែលនៅស្រុកភ្នំ
អេប្រាអិម[ក]ម្ខាង បានយកស្ត្រីម្នាក់ពីបេថ្លេហិម ស្រុកយូដា
មកធ្វើជាប្រពន្ធចុង[ខ] ២នាងនោះក៏ផិតចេញពីប្តី រួចទៅឯ
ផ្ទះឪពុកនាង នៅឯបេថ្លេហិមស្រុកយូដាវិញ នាងបាននៅ
ទីនោះអស់៤ខែ ៣នោះប្តីនាងរៀបចំចេញទៅតាម និយាយ
លួងលោម ដើម្បីនឹងនាំនាងមកវិញ បាននាំទាំងបំរើម្នាក់
និងលា២ទៅជាមួយផង ដល់ហើយនាងក៏នាំបំរើចូលនៅ
ក្នុងផ្ទះឪពុក កាលឪពុកបានឃើញ នោះក៏ទទួលដោយ
អំណរ ៤រួចគាត់នៅជាមួយបាន៣ថ្ងៃ ដោយឪពុកក្មេកបាន
ឃាត់សិន ហើយក៏ស៊ីផឹក[គ]ជាមួយគ្នាព្រមទាំងដេកនៅទី
នោះផង ៥ដល់ថ្ងៃទី៤គេក៏ក្រោកឡើងពីព្រលឹម តែកាល
គាត់ចង់ធ្វើដំណើរចេញទៅ នោះឪពុកនាងឃាត់ថា ចាំ
បរិភោគចំរើនកំឡាំងសិន[ឃ] រួចសឹមទៅចុះ ៦ដូច្នេះគេក៏
អង្គុយស៊ីផឹកជាមួយគ្នា រួចឪពុកនាងនិយាយថា សូមឲ្យ
សំរេចចិត្តនៅ១យប់នេះសិន ឲ្យបានសប្បាយឡើង[ង] ៧អ្នក
នោះក្រោកឡើងចង់ទៅ តែឪពុកក្មេកចេះតែបង្ខំ បានជា
គាត់ដេកនៅទីនោះ១យប់ទៀត ៨ដល់ថ្ងៃទី៥គាត់ក្រោក
ពីព្រលឹម រៀបធ្វើដំណើរទៅ តែឪពុកនាងឃាត់ថា ចូរ
នៅលំហើយចិត្តសិន ហើយបង្អង់ដល់ថ្ងៃរសៀលបន្តិច
នោះគេក៏បរិភោគជាមួយគ្នា ៩រួចកាលគាត់ក្រោកឡើង
រៀបធ្វើដំណើរទៅ នាំទាំងប្រពន្ធ និងអ្នកបំរើរបស់គាត់
ផង នោះឪពុកក្មេកឃាត់ថា ឥឡូវថ្ងៃរសៀលទាបហើយ
ដូច្នេះ សូមឲ្យនៅ១យប់នេះទៀតចុះ មើល ថ្ងៃជិតលិច
ហើយ ចូរដេកឯណេះចុះ ដើម្បីឲ្យចិត្តឯងបានសប្បាយ
ឡើង រួចដល់ស្អែកសឹមធ្វើដំណើរតាមផ្លូវឯង ត្រឡប់ទៅ
ផ្ទះវិញពីព្រលឹមទៅ ។
១០តែគាត់មិនព្រមបង្អង់នៅយប់នោះទៀតទេ ក៏ក្រោក
ឡើងចេញដំណើរទៅ បានទៅដល់ទន្ទឹមនឹងក្រុងយេប៊ូស[ច]
(គឺក្រុងយេរូសាឡិម) នាំទាំងសត្វលា២ដែលចងកែប និង
នាងជាប្រពន្ធចុងទៅជាមួយផង ១១កាលមកជិតក្រុង
យេប៊ូស នោះថ្ងៃទន្ទាបណាស់ហើយ ដូច្នេះអ្នកបំរើគាត់
បបួលថា សូមលោកអញ្ជើញបែរចូលទៅក្នុងទីក្រុងរបស់
សាសន៍យេប៊ូស[ឆ]នេះស្នាក់នៅសិន ១២តែចៅហ្វាយឆ្លើយ
ថា យើងមិនព្រមបែរចូលទៅក្នុងទីក្រុងរបស់សាសន៍ដទៃ
ដែលមិនជាពួកកូនចៅសាសន៍អ៊ីស្រាអែលឡើយ យើងនឹង
ស្រូតទៅឲ្យដល់គីបៀរវិញ ១៣រួចគាត់និយាយនឹងអ្នកបំរើ
ថា ចូរយើងស្រូតទៅឲ្យដល់ទីណាមួយនោះ ដើម្បីនឹងដេក
នៅ ទោះបើជានៅគីបៀរ ឬនៅរ៉ាម៉ា[ជ]ក្តី ១៤ដូច្នេះគេដើរ
បង្ហួសតាមផ្លូវទៅ កាលគេជិតនឹងដល់គីបៀរ ជាទីក្រុង
របស់ពួកបេនយ៉ាមីនហើយ[ឈ] នោះថ្ងៃលិចទៅ ១៥ហើយគេ
ក៏ងាកបែរចូលទៅក្នុងគីបៀរ ដើម្បីនឹងដេកនៅទីនោះ[ញ]
គេចូលទៅអង្គុយ នៅក្បែរផ្លូវក្នុងទីក្រុងនោះ[ដ] ដោយព្រោះ
គ្មានអ្នកណាទទួលឲ្យស្នាក់នៅក្នុងផ្ទះឡើយ ។
១៦ខណនោះ[ឋ] មានបុរសចាស់ម្នាក់ត្រឡប់មកពីធ្វើ
ការនៅស្រែក្នុងវេលាល្ងាច អ្នកនោះជាមនុស្សស្រុកភ្នំ
អេប្រាអិម[ឌ] តែគាត់នៅក្រុងគីបៀរ ឯមនុស្សនៅក្រុងនោះ
សុទ្ធតែជាពួកបេនយ៉ាមីនវិញ ១៧គាត់ងើបភ្នែកឡើងឃើញ
អ្នកដំណើរម្នាក់ កំពុងតែអង្គុយនៅក្បែរផ្លូវ ក៏សួរថា តើ

**១៩:១** ក ខ.១៦,១៨ ខ នរ ១:១
**១៩:៤** គ ខ.៦,៨ នក ៣២:៦
**១៩:៥** ឃ ខ.៨ លប ១៨:៥
**១៩:៦** ង ពច ១៦:២៥
**១៩:១០** ច លប ១០:១៦ យស ១៥:៨
**១៩:១១** ឆ លប ១០:១៦ យស ៣:១០
**១៩:១៣** ជ យស ១៨:២៥
**១៩:១៤** ឈ យស ១៥:៥៧ ១សយ ១០:២៦ ១១:៤ ១៣:២ ១៥:៣៤ អស ១០:២៩
**១៩:១៥** ញ លប ២៤:២៣ ដ លប ១៩:២
**១៩:១៦** ឋ ទដ ១០៤:២៣ ឌ ខ.១

**១៩:១–២១:២៥** នៅក្នុងជំពូកនេះ គឺជាព្រឹត្តិការណ៍ទី២ នៅក្នុងសេចក្តីផ្តើម (សូមមើលការពន្យល់ ១៧:១–១៨:៣១) ។ នៅក្នុងជំពូកនេះបង្ហាញពីការអាក្រក់របស់ពួកកូនចៅអ៊ីស្រាអែល តាមរយៈការប្រាប់ពីការអាក្រក់របស់គីបៀរដែលការអាក្រក់នេះត្រូវបានគេយកមកដំណាល នៅក្នុងសម័យក្រោយមកទៀត (ហស ៩:៩ ១០:៩) ។ ទោះបីជាទីក្រុងនេះបាននិយាយថាជាក្រុងកំសោយ ដូចជាទីក្រុងរបស់ពួកកូនចៅកាណានក៏ដោយ ក៏វាតំណាងឲ្យពួកកូនចៅបេនយ៉ាមីន នៅគ្រាចុងក្រោយ ដែលគេបានទាស់ប្រឆាំងចំពោះព្រះអម្ចាស់ ដោយសារពួកកូនចៅអ៊ីស្រអែលដែរ ហើយនៅចុងក្រោយពួកគេត្រូវបំផ្លាញ ។

**១៩:១–៣០** រឿងរ៉ាវទាំងឡាយរបស់ពួកអ៊ីស្រាអែល ដែលរស់នៅក្នុងទីក្រុង នេះ (គីបៀរ) គឺរំឭកយើងពីទង្វើរបស់អ្នកនៅក្នុងក្រុងសូដុំម (សូមមើល លប ១៩) ។

**១៩:១** *ពួកលេវី* មិនមែនជាពួកលេវី នៅក្នុងជំពូក ១៧–១៨ នោះឡើយ ។ មនុស្សនេះគាត់គ្មានឈ្មោះទេ ។ *ប្រពន្ធចុង* មើលការពន្យល់ លប ២៥:៦ ។

**១៩:៣** *ទទួលដោយអំណរ* ការបែកគ្នារបស់ប្រពន្ធចុងពីពួកលេវីម្នាក់ នោះគឺជាបញ្ហាអាម៉ាស់នៅក្នុងក្រុមគ្រួសារ ដូច្នេះឪពុកក្មេករបស់គាត់ក៏ទទួលគាត់សេចក្តីអំណរ នៅពេលអ្នកទាំងពីជួបគ្នាវិញ ។

**១៩:១០** *យេប៊ូស* សូមមើល ១:២១ និងការពន្យល់ លប ១០:១៦ ។

**១៩:១២** *ទីក្រុងរបស់សាសន៍ដទៃ* ពួកលេវីមានការភ័យខ្លាចថា និងមិនបានទ្រព្យសម្បត្តិ ហើយអាចមានគ្រោះថ្នាក់ថែមទៀត នោះគឺដោយសារតែទីក្រុងនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាសន៍យេប៊ូស ។

**១៩:១៤** *គីបៀរ ជាទីក្រុងរបស់ពួកបេនយ៉ាមីន* គឺជាគីបៀរនៅក្នុងស្រុកយូដា (យស ១៥:២០,៥៧) និងគីបៀរនៅក្នុងស្រុកភ្នំអេប្រាអិម (យស ២៤:៣៣) ។ វាគឺជាទីក្រុងខាងនយោបាយ នៃអាណាចក្ររបស់ស្តេចសូល ហើយត្រូវបានហៅថា គីបៀរជាស្រុករបស់សូលនៅក្នុង ១សយ ១១:៤ ១សយ ១៣:១៥ ។

**១៩:១៥** *ទទួលឲ្យស្នាក់នៅក្នុងផ្ទះ* សូមមើលការពន្យល់ ១៣:១៥ លប ១៨:២ ។

អ្នកអញ្ជើញទៅណា ហើយមកពីណា[ឍ]
១៨គាត់ឆ្លើយឡើងថា យើងខ្ញុំប្របាទធ្វើដំណើរមកពីបេថ្លេហិមស្រុកយូដា ដើម្បីនឹងទៅឯស្រុកភ្នំអេប្រាអិមម្ខាង ខ្ញុំប្របាទជាអ្នកស្រុកនោះឯង ហើយបានទៅឯបេថ្លេហិមស្រុកយូដា ឥឡូវនេះទៅឯដំណាក់ព្រះយេហូវ៉ា[ណ] តែគ្មានអ្នកណាទទួលខ្ញុំប្របាទឱ្យចូលក្នុងផ្ទះគេសោះ
១៩ខ្ញុំប្របាទមានចំបើងនិងស្មៅ[ត] សំរាប់លា[ថ] ហើយមាននំបុ័ងនិងស្រាទំពាំងបាយជូរ[ទ]សំរាប់ខ្លួន និងនាងស្រីនេះ ព្រមទាំងអ្នកកំឡោះ ដែលនៅជាមួយនឹងយើងខ្ញុំប្របាទនេះផង យើងខ្ញុំមិនមានខ្វះអ្វីទេ
២០អ្នកនោះឆ្លើយឡើងថា សូមឱ្យអ្នកបានសេចក្ដីសុខសាន្តចុះ តែសូមឱ្យគ្រប់របស់ដែលអ្នកត្រូវការបានជាភារៈលើខ្ញុំវិញ កុំឱ្យតែដេកនៅផ្លូវឡើយ
២១ដូច្នេះអ្នកនោះក៏នាំគាត់ចូលទៅក្នុងផ្ទះ ដាក់ស្មៅឱ្យលាស៊ី រួចគេក៏លាងជើង ហើយបរិភោគជាមួយគ្នាទៅ[ធ] ។
២២រីឯកាលគេកំពុងតែតាំងចិត្តឱ្យអរសប្បាយឡើង[ន] នោះមើល មានពួកមនុស្សទុរជនខ្លះ[ប]នៅទីនោះ គេមកព័ទ្ធផ្ទះ គោះទ្វារ ហៅតាជាម្ចាស់ផ្ទះនោះថា ចូរនាំមនុស្សដែលបានមកក្នុងផ្ទះតាចេញមកឥឡូវ ដើម្បីឱ្យយើងបានស្គាល់វា[ផ]
២៣ដូច្នេះម្ចាស់ផ្ទះក៏ចេញទៅអង្វរថា ទេបងប្អូនអើយ សូមកុំធ្វើអាក្រក់ដូច្នេះឡើយ ដ្បិតអ្នកនេះបានចូលមកជ្រកនៅផ្ទះខ្ញុំ កុំឱ្យប្រព្រឹត្តការដ៏លាមកយ៉ាងនេះឱ្យសោះ
២៤មើល នេះនៃកូនក្រមុំរបស់ខ្ញុំ[ព] និងប្រពន្ធរបស់អ្នកនេះ ខ្ញុំនឹងនាំចេញមកឥឡូវ ឱ្យអ្នករាល់គ្នាបានបន្ទាបនាងចុះ ហើយប្រព្រឹត្តនឹងនាងតាមតែចិត្ត សូមកុំឱ្យតែប្រព្រឹត្តអំពើដ៏លាមកដល់ម៉្លេះនឹងមនុស្សនេះឡើយ
២៥ប៉ុន្តែមនុស្សទាំងនោះមិនព្រមស្ដាប់គាត់ទេ បានជាប្ដីរបស់នាងនោះ គាត់នាំនាងចេញទៅប្រគល់ឱ្យគេទៅ រួចគេក៏ស្គាល់នាងគ្រប់គ្នា ហើយធ្វើបាបនាងទាល់តែភ្លឺ ទើបលែងឱ្យមកវិញ
២៦ដូច្នេះកាលថ្ងៃទើបនឹងភ្លឺស្រាងឡើង នាងក៏មកដួលនៅមាត់ទ្វារផ្ទះរបស់តានោះ គឺជាផ្ទះដែលប្ដីនៅ ។
២៧លុះព្រឹកឡើងភ្លឺច្បាស់ហើយ ប្ដីនាងក៏ក្រោកបើកទ្វារចេញទៅ ដើម្បីនឹងធ្វើដំណើរតទៅ នោះឃើញប្រពន្ធចុងបានដួលនៅមាត់ទ្វារផ្ទះ ដាក់ដៃនៅលើក្របទ្វារ ហើយ
២៨គាត់ហៅថា នែ ចូរក្រោកឡើងយើងទៅ តែនាងមិនឆ្លើយសោះ ដូច្នេះគាត់ក៏លើកព្រនរដាក់លើលា នាំត្រឡប់ទៅឯលំនៅខ្លួនទៅ
២៩កាលគាត់បានចូលដល់ទៅក្នុងផ្ទះហើយ នោះគាត់យកកាំបិត[ភ] មកកាត់ខ្មោចរបស់នាងនោះចេញជា១២កំណាត់ ផ្ញើទៅគ្រប់ក្នុងស្រុកអ៊ីស្រាអែល[ម]
៣០រួចពួកអ្នកទាំងប៉ុន្មានដែលបានឃើញ ក៏និយាយគ្នាថា មិនដែលឃើញមានគេធ្វើអំពើយ៉ាងដូច្នេះទេ ចាប់តាំងពីថ្ងៃដែលពួកកូនចៅអ៊ីស្រាអែល ឡើងចេញពីស្រុកអេស៊ីព្ទ[យ] ដរាបដល់សព្វថ្ងៃនេះ ដូច្នេះចូរពិចារណា ហើយពីគ្រោះគ្នាចុះ រួចសំរេចសេចក្ដីទៅ[រ] ។

**១៩:១៧** ឍ លប ២៩:៤
**១៩:១៨** ណ ពច ១៩:៣១
**១៩:១៩** ត លប ២៤:២៥ ថ លប ៤២:២៧ ទ លប ១៤:១៨
**១៩:២១** ធ លប ២៤:៣២–៣៣ លក ៧:៤៤
**១៩:២២** ន ពច ១៦:២៥ ប ចទ ១៣:១៣ ផ លប ១៩:៤–៥ ពច ២០:៥ រម ១:២៦–២៧
**១៩:២៣** ព លប ១៩:៦ ភ លប ៣៤:៧ លវ ១៩:២៩ យស ៧:១៥ ពច ២០:៦ រម ១:២៧
**១៩:២៤** ម លប ១៩:៨
**១៩:២៥** យ ពច ២០:៥ រ ១សយ ៣១:៤
**១៩:២៩** ល លប ២២:៦ វ ពច ២០:៦ ១សយ ១១:៧
**១៩:៣០** ស ហស ៩:៩ ហ ពច ២០:៧ សភ ១៣:១០

**១៩:១៨** *ដំណាក់ព្រះយេហូវ៉ា* បើសិនជាយើងធ្វើការសង្កេតពិនិត្យមើលឱ្យបានច្បាស់ យើងឃើញថា ពួកលេវីមានគម្រោងការណ៍ដើម្បីទៅស៊ីឡូរ (មើល ១៨:៣១ យស ១៨:១) ដើម្បីរៀបចំដង្វាយអរព្រះគុណព្រះយេហូវ៉ា ឬដង្វាយលោះបាបសម្រាប់ខ្លួនគាត់ និងប្រពន្ធចុងគាត់ ។

**១៩:២១** *រួចគេក៏លាងជើង* គឺជាភស្តុតាង ក្នុងការទទួលភ្ញៀវ របស់មនុស្សនៅក្នុងតំបន់មជ្ឈឹមបូព៌ានាសម័យបុរាណ ។ អ្នកដំណើរ តែងតែពាក់ស្បែកជើង ព្រោះផ្លូវថ្នល់មានធូលីដីច្រើន (សូមមើល លប ១៨:៤ ២៤:៣២ ៤៣:២៤ លក ៧:៤៤ យហ ១៣:៥–១៤) ។

**១៩:២២** *ទុរជន* ក្នុងព្រះគម្ពីរភាសាហេព្រើរ ឃ្លានេះសំដៅលើមនុស្សខិលខូច ឬទមិលល្មើស (មើលការពន្យល់ ចទ ១៣:១៣) ហើយនៅកន្លែងផ្សេងទៀតសំដៅលើមនុស្សគោរពប្រតិបត្តិរូបព្រះ (សូមមើល ចទ ១៣:១៣) ពួកប្រមឹក (១សយ ១:១៦) និងមនុស្សដែលប្រឆាំងបះបោរ ឬមិនស្គាល់ព្រះ (១សយ ២:១២) ។ សម្រាប់មនុស្សទុរជន នៅក្នុងខគម្ពីរនេះ គឺសំដៅលើមនុស្សដែលរួមភេទជាមួយមនុស្សដែលមានភេទដូចគ្នា ។ *ចូរនាំមនុស្សដែលបានមកក្នុងផ្ទះតាចេញមកឥឡូវ* ការរួមភេទដែលខុសពីសីលធម៌របស់ក្រុមមនុស្សទុរជននោះ គឺជាគំរូអាក្រក់មួយដែលកូនចៅជំនាន់ក្រោយទៀត គេក៏យកគំរូតាម "មនុស្សទាំងឡាយគេតែងតែប្រព្រឹត្តការ ដែលខ្លួនគិតឃើញថាត្រឹមត្រូវ" ១៧:៦ ២១:២៥ ។ មានសំណូមពរឱ្យយកមនុស្សចេញមកក្រៅ ដូចគ្នានេះដែរគឺពួកអ្នកនៅក្រុងសូដំម (លប ១៩:៥) ។ ការរួមភេទជាមួយមនុស្សដែលមានភេទដូចគ្នានេះ គឺជានិច្ចកាលមាននៅក្នុងពួកកូនចៅកាណាន ។

**១៩:២៣** *សូមកុំធ្វើអាក្រក់ដូច្នេះឡើយ* គាត់និយាយដូច្នេះ ដោយព្រោះតែមនុស្សទុរជនទាំងនោះ តែងតែធ្វើអ្វីតាមតែចិត្តឯង មិនស្គាល់ថាអ្វីដែលខុសហើយអ្វីដែលត្រឹមត្រូវនោះឡើយ(មើល លប ១៩:៧ ២សយ ១៣:១២ រម ១:២៧) ។

**១៩:២៤** *នេះនៃកូនក្រមុំរបស់ខ្ញុំ និងប្រពន្ធរបស់អ្នកនេះ* ពួកអ្នកដែលប្រព្រឹត្តការអាក្រក់បែបនេះ មិនមែនតែមនុស្សនៅគីបៀរនោះឡើយ ប៉ុន្តែក៏មានមនុស្សអាក្រក់ដែលមានបំណងក្បត់ ដោយចង់បានស្ត្រីនោះផ្សេងៗទៀតដែរ ។ សូមប្រៀបធៀប លប ១៩:៨ កន្លែងនោះលោកឡុតបានឱ្យកូនស្រីទាំងរបស់គាត់ ទៅមនុស្សនៅក្រុងសូដំម ។

**១៩:២៥** *ប្រគល់ឱ្យគេ* នៅក្នុងកន្លែងនេះ តាមព្រះគម្ពីរភាសាហេព្រើរគឺនិយាយថា ប្រគល់ឱ្យទាំងបង្ខំចិត្ត ។

**១៩:២៩** *កាត់ខ្មោចរបស់នាង* ការកាត់សព ផ្ញើឱ្យពួកកូនចៅអ៊ីស្រាអែលទាំង១២អំបូរនោះ គឺគាត់មានបំណងពញ្ញាក់ស្មារតីពួកអ៊ីស្រាអែល ឱ្យក្រោកឡើងពីការប្រព្រឹត្តអាក្រក់ផ្សេងៗ ហើយដល់ពេលដែលគេម្នាក់ៗត្រូវតែមានទំនួលខុសត្រូវលើកិច្ចការរបស់គេ ។

## ពួកកូនចៅអ៊ីស្រាអែលច្បាំងនឹងពួកកូនចៅបេនយ៉ាមីន

**២០** ១នោះពួកកូនចៅអ៊ីស្រាអែល[ក]ទាំងប៉ុន្មានក៏ចេញពី
ស្រុកគេមក ចាប់តាំងពីក្រុងដាន់ រហូតដល់ក្រុងបៀរ–
សេបា[ខ] ព្រមទាំងស្រុកកាឡាតផង ហើយពួកជំនុំបានប្រជុំ
គ្នា[គ]ដូចជាមនុស្សតែម្នាក់[ឃ]នៅចំពោះព្រះយេហូវ៉ា ត្រង់
មីសប៉ា[ង] ២ឯពួកមេទ័ពក្នុងបណ្ដាជនទាំងប៉ុន្មាន គឺជាមេទ័ព
នៃពូជអំបូរសាសន៍អ៊ីស្រាអែលទាំងអស់ គេក៏ចេញមុខ
ឡើង ក្នុងជំនុំពួកបណ្ដាជននៃព្រះ មានពលថ្មើរជើង ដែល
កាន់ដាវ៤សែននាក់[ច] ៣(រីឯពួកកូនចៅបេនយ៉ាមីន គេក៏ឮ
ថា ពួកកូនចៅអ៊ីស្រាអែលបានឡើងមកដល់មីសប៉ាដែរ)
ពួកកូនចៅអ៊ីស្រាអែលសួរថា សូមប្រាប់ឱ្យយើងដឹង ជា
អំពើដ៏លាមកនេះបានកើតមកជាយ៉ាងណា ៤នោះពួកលេវី
ជាប្ដីនាង ដែលគេបានសំឡាប់នោះ គាត់ឆ្លើយថា ខ្ញុំនិង
ប្រពន្ធចុងរបស់ខ្ញុំ បានចូលទៅក្នុងគីបៀរ[ឆ] ជាទីក្រុងរបស់
ពួកបេនយ៉ាមីន ដើម្បីនឹងស្នាក់នៅ[ជ] ៥ស្រាប់តែពួកមនុស្ស
នៅគីបៀរ គេលើកគ្នាទាំងយប់ មកព័ទ្ធផ្ទះដែលខ្ញុំនៅទាស់
នឹងខ្ញុំ គេគិតសំឡាប់ខ្ញុំ[ឈ] ក៏បានចាប់បង្ខំប្រពន្ធចុងរបស់ខ្ញុំ
ហើយនាងបានស្លាប់ទៅ[ញ] ៦ដូច្នោះហើយ ខ្ញុំបានយកខ្មោច
នាងមកកាត់ជាកំណាត់ៗផ្ញើទៅគ្រប់ក្នុងស្រុក ដែលជា
មរដករបស់សាសន៍អ៊ីស្រាអែល[ដ] ដោយព្រោះការប្រព្រឹត្ត[ឋ]
ដ៏អាសអាភាស ហើយលាមករបស់គេ ក្នុងពួកអ៊ីស្រាអែល
យើងនេះ ៧ដូច្នេះអ្នករាល់គ្នាជាពួកកូនចៅអ៊ីស្រាអែល
ទាំងអស់គ្នាអើយ សូមបញ្ចេញគំនិតរបស់អ្នករាល់គ្នាមក
ហើយសំរេចសេចក្ដីចុះ[ឌ]។

៨គ្រានោះមនុស្សទាំងឡាយក៏ក្រោកឡើងព្រមគ្នា ដូច
ជាមនុស្សតែម្នាក់ ដោយពាក្យថា ក្នុងពួកយើងគ្មានអ្នកណា
មួយនឹងត្រឡប់ទៅទីលំនៅខ្លួន ឬចូលទៅក្នុងផ្ទះខ្លួនវិញ
ឡើយ ៩គឺយើងនឹងធ្វើដល់ពួកគីបៀរយ៉ាងដូច្នេះ យើងនឹង
ឡើងទៅទាស់នឹងគេ ដោយចាប់ឆ្នោត[ឍ] ១០យើងនឹងយក
១០នាក់ក្នុង១០០ ហើយ១០០នាក់ក្នុង១ពាន់ និង១ពាន់នាក់
ក្នុង១ម៉ឺន ពីគ្រប់ទាំងពូជអំបូរនៃសាសន៍អ៊ីស្រាអែល ដើម្បី
ទៅរកស្បៀងអាហារសំរាប់យើង ប្រយោជន៍ឱ្យយើងទៅ
ធ្វើដល់ពួកគីបៀរ របស់ពួកបេនយ៉ាមីន តាមអំពើដ៏លាមក
ទាំងប៉ុន្មាន ដែលគេបានប្រព្រឹត្តក្នុងពួកអ៊ីស្រាអែលយើង
នេះ ១១ដូច្នេះពួកអ៊ីស្រាអែលទាំងអស់គ្នា ក៏មូលគ្នាដូចជា
មនុស្សតែម្នាក់[ណ] ទាស់នឹងទីក្រុងនោះ ។

១២ពូជអំបូរសាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន ក៏ចាត់សារ
ឱ្យទៅគ្រប់ក្នុងពូជអំបូរបេនយ៉ាមីនសួរថា តើអំពើអាក្រក់
យ៉ាងណានេះ ដែលបានកើតមកក្នុងពួកអ្នករាល់គ្នា[ត]
១៣ដូច្នេះចូរប្រគល់ពួកមនុស្សគំរក់នោះ[ថ] ដែលនៅក្រុង
គីបៀរមក ឱ្យយើងរាល់គ្នាបានសំឡាប់គេចោលទៅដើម្បី
នឹងបំបាត់សេចក្ដីអាក្រក់ពីពួកអ៊ីស្រាអែលចេញ[ទ] តែពួកកូន
ចៅបេនយ៉ាមីន មិនព្រមស្ដាប់តាមពួកកូនចៅអ៊ីស្រាអែល
ជាបងប្អូនគេទេ ១៤ហើយក៏ចេញពីទីក្រុងគេទាំងប៉ុន្មាន ទៅ
មូលគ្នាត្រង់គីបៀរ ដើម្បីនឹងចេញទៅតតាំងនឹងពួកកូនចៅ
អ៊ីស្រាអែល ១៥នៅថ្ងៃនោះគេរាប់ពួកកូនចៅបេនយ៉ាមីន

**២០:១** ក ពច ២១:៥ ខ លប ២១:១៤ ១សយ ៣:២០ ២សយ ៣:១០ ១៧:១១ ២៤:១៥ ១ពវ ៤:២៥
**២០:១** គ ១សយ ៧:៥ ឃ ខ.១១ ១សយ ១១:៧ ង យស ១១:៣
**២០:២** ច ១សយ ១១:៨
**២០:៤** ឆ យស ១៥:៥៧ ជ លប ២៤:២៣
**២០:៥** ឈ ពច ១៩:២២ ញ ពច ១៩:២៥–២៦
**២០:៦** ដ ពច ១៩:២៩ ឋ ពច ១៩:២៣ ២សយ ១៣:១២
**២០:៧** ឌ ពច ១៩:៣០
**២០:៩** ឍ លវ ១៦:៨
**២០:១១** ណ ខ.១
**២០:១២** ត ចទ ១៣:១៤
**២០:១៣** ថ ចទ ១៣:១៣ ទ ចទ ១៣:៥ ១កថ ៥:១៣

**២០:១–៤៨** គ្រប់ទាំងអំបូរអ៊ីស្រាអែលទាំងអស់ (លើកលែងតែពួកយ៉ាបេស–កាឡាត មើល ២១:៨–៩) គឺត្រូវបានហៅមកប្រជុំ ដើម្បីពិភាក្សាពីអំពើអាក្រក់របស់ពួកអ្នកនៅកាឡាត ។ ដោយមានការទូលសួរដល់ព្រះយេហូវ៉ា នោះពួកអ៊ីស្រាអែលបាននាំគ្នាទៅច្បាំងជាមួយពួកយ៉ាបេស និងពួកបេនយ៉ាមីនក្នុងនាមជាអ្នកចម្បាំងរបស់ព្រះយេហូវ៉ា (សូមមើល យស ២២:១១– ៣៤) ហើយគេបានតាំងព្រះយេហូវ៉ាជាស្ដេចរបស់គេ ។

**២០:១** *ពីក្រុងដាន់ រហូតដល់ក្រុងបៀរ–សេបា* គឺជារបៀបនិយាយអំពីពួកកូនចៅអ៊ីស្រាអែលទាំងអស់ចាប់តាំងពីភាគខាងជើង (ដាន់) រហូតដល់ភាគខាងត្បូង (បៀរ–សេបា) ។ សូមមើល ១សយ ៣:២០ ២សយ ៣:១០ ២៤:២ ១រប ២១:២ ២រប ៣០:៥ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការប្រើឃ្លាប្រយោគនេះ មិនមែនមានន័យថា ព្រឹត្តិការណ៍ទាំងឡាយដែលមាននៅក្នុងជំពូកនេះ កើតឡើងបន្ទាប់ពីការផ្លាស់ប្ដូរទីកន្លែងរបស់ពួកដាន់មកភាគខាងជើងនោះឡើយ (១៨:២៧–២៩) ប៉ុន្តែគឺចង់បង្ហាញអំពីទស្សនៈវិស័យរបស់អ្នកនិពន្ធ ក្នុងអំឡុងពេលសរសេរព្រះគម្ពីរចៅហ្វាយ (ព្រះគម្ពីរចៅហ្វាយប្រហែលសរសេរឡើង បន្ទាប់ពីការឡើងគ្រងរាជ្យរបស់ស្ដេចដាវីឌ (សូមមើលសេចក្ដីផ្ដើមៈ និពន្ធ និងកាលបរិច្ឆេទ) ។ នៅទីកន្លែងនេះគឺនិយាយសំដៅលើសកម្មភាពនៃការហ៊ឹកហាត់របស់ពួកអ៊ីស្រាអែល (លើកលែងតែយ៉ាបេស–កាឡាតៈ សូមមើល ២១:៨–៩) ដើម្បីទាស់ប្រឆាំងជាមួយពួកកាឡាត និងពួកបេនយ៉ាមីនទាំងអស់ ។ *ដូចជាមនុស្សតែម្នាក់* សូមប្រៀបធៀប ខ.៨,១១ ១សយ ១១:៧ ។ *ប្រជុំគ្នា . . . មីសប៉ា* គឺជាកន្លែងដែលពូជអំបូរនិមួយៗប្រមូលផ្ដុំគ្នាដើម្បីប្រជុំនៅចំពោះព្រះយេហូវ៉ា ដូចគ្នានឹងសម័យកាលនៃរាជ្យស្ដេចសូលដែរ (១សយ ៧:៥–១៧ ១០:១៧) ។

**២០:៩** *ឆ្នោត* ការចាប់ឆ្នោត គឺជាវិធីសាមញ្ញមួយ ដើម្បីស្វែងរកបំណងព្រះបូទ័យរបស់ព្រះ (សូមមើលការពន្យល់ នក ២៨:៣០ និងមើល យហ ១:៧ កច ១:២៦) ។

**២០:១០** *យក១០នាក់* ការគាំទ្រដល់នាយទាហានដែលមានគ្នាច្រើនបែបនេះ ដើម្បីឱ្យការទទួលស្គាល់ និងមានប្រសិទ្ធិភាព ។ ម្នាក់ត្រូវមានភារៈកិច្ចទទួលខុសត្រូវចំពោះការផ្គត់ផ្គង់ស្បៀង ហើយ៩នាក់ទៀតជាអ្នកច្បាំងពីខាងមុខ ។

**២០:១៣** *ដូច្នេះចូរប្រគល់ពួកមនុស្សគំរក់នោះ* តម្រូវការរបស់ពួកអ៊ីស្រាអែល គឺមិនត្រូវបានឆ្លើយតបឡើយ ។ ពួកគេគ្រាន់តែចង់ធ្វើការព្រមានដល់អ្នកណា ដែលប្រព្រឹត្តការអាក្រក់ប៉ុណ្ណោះ ។ *មនុស្សគំរក់* មើលការពន្យល់ ចទ ១៣:១៣ ។ *សំឡាប់ចោល* អំពើបាបរបស់មនុស្សនៅគីបៀរ គឺសមតែស្លាប់ហើយ ដូច្នេះពួកអ៊ីស្រាអែលត្រូវតែព្រមានដល់គេ (ចទ ១៣:៥ ១៧:៧ ១៩:១៩–២០) ។

ដែលចេញពីទីក្រុងរបស់គេ ឃើញមាន២ម៉ឺន៦ពាន់នាក់
ដែលកាន់ដាវ ក្រៅពីពួកគីបៀរ ៧០០នាក់ ដែលជាមនុស្ស
ជ្រើសរើសគ្រប់គ្នា ១៦ក្នុងពួកគេទាំងនោះ មានមនុស្ស
ជ្រើសរើស៧០០នាក់ ដែលប្រើការខាងដៃឆ្វេង[ធ]គ្រប់គ្នា
អាចបាញ់ដោយក្រួស ត្រូវដល់សក់១សរសៃបានឥតខុស
ឡើយ ។

១៧ឯពួកអ៊ីស្រាអែល ដែលក្រៅពីពួកបេនយ៉ាមីន នោះ
មាន៤សែននាក់ដែលកាន់ដាវ សុទ្ធតែជាមនុស្សស្ទាត់
ចំបាំង ១៨ពួកកូនចៅអ៊ីស្រាអែលក៏ក្រោកឡើង ដើរទៅឯ
បេត–អែល[ន] ដើម្បីនឹងទូលសួរដល់ព្រះ[ប]ថា ក្នុងពួកយើង
ខ្ញុំរាល់គ្នា តើអ្នកណាត្រូវឡើងទៅច្បាំង[ផ]នឹងពួកកូនចៅ
បេនយ៉ាមីនមុនគេ[ព] នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលឆ្លើយ
ថា ចូរឱ្យពួកយូដា[ភ]ទៅមុនគេចុះ ។

១៩ដូច្នេះ ពួកកូនចៅអ៊ីស្រាអែល ក៏ក្រោកឡើងពី
ព្រលឹម ទៅបោះទ័ពទាស់នឹងគីបៀរ ២០គេចេញទៅច្បាំង
នឹងពួកបេនយ៉ាមីន ក៏ដំរៀបទ័ពទាស់នឹងគេនៅមុខទីក្រុង
២១ឯពួកកូនចៅបេនយ៉ាមីន គេក៏ចេញពីគីបៀរ មកបំផ្លាញ
ពួកអ៊ីស្រាអែល[ម] អស់២ម៉ឺន២ពាន់នាក់ ឱ្យស្លាប់ចង្រ្កាងនៅ
លើដីក្នុងថ្ងៃនោះឯង ២២តែបណ្តាទ័ពខាងពួកអ៊ីស្រាអែល
គេតាំងចិត្តឡើងទៅដំរៀបទ័ពម្តងទៀត នៅកន្លែងដដែល
ដូចថ្ងៃមុន ២៣ឯពួកកូនចៅអ៊ីស្រាអែល ក៏ឡើងទៅយំ
នៅចំពោះព្រះយេហូវ៉ា[យ] រហូតដល់ល្ងាច[រ] ទាំងទូលសួរ[ល]
ទ្រង់ថា តើត្រូវឱ្យទូលបង្គំចេញទៅច្បាំង[វ]នឹងពួកកូនចៅ
បេនយ៉ាមីនជាបងប្អូនទូលបង្គំម្តងទៀតឬទេ នោះព្រះ
យេហូវ៉ាទ្រង់មានបន្ទូលឆ្លើយថា ចូរឡើងទៅច្បាំងនឹង
គេចុះ ។

២៤ពួកកូនចៅអ៊ីស្រាអែល ក៏ចូលទៅជិតទីពួកកូន
ចៅបេនយ៉ាមីននៅថ្ងៃទី២ ២៥ហើយនៅថ្ងៃនោះឯង ពួក

**២០:១៦** ធ ពច ៣:១៥
**២០:១៨** ន យស ១២:៩ ពច ១៨:៣១ ប ពច ១៨:៥ ផ ខ.២៣, ២៨ ព ពច ១:១ ភ លប ៤៩:១០
**២០:២១** ម ខ.២៥
**២០:២៣** យ ជន ១៤:១ រ យស ៧:៦ ល ពជ ១៨:៥ វ ខ.១៨
**២០:២៥** ស ខ.២១
**២០:២៦** ហ ជន ១៤:១ ឡ ២សយ ១២:២១ អ លវ ១:៣ ក នក ៣២:៦ ខ ពច ២១:៤
**២០:២៧** គ ពច ១៨:៥ ឃ ជន ១០:៣៣
**២០:២៨** ង ជន ២៥:៧ ច ចទ ១៨:៥ ឆ យស ២:២៤
**២០:២៩** ជ យស ៨:២,៤
**២០:៣១** ឈ យស ៨:១៦ ញ យស ១៦:១
**២០:៣២** ដ ខ.៣៩

បេនយ៉ាមីន បានចេញពីគីបៀរមកតតាំងគ្នា គេបំផ្លាញពួក
កូនចៅអ៊ីស្រាអែល[ស] អស់ចំនួន១ម៉ឺន៨ពាន់នាក់ ឱ្យនៅ
ចង្រ្កាងលើដី ពួកទាំងនោះសុទ្ធតែជាអ្នកកាន់ដាវ ២៦នោះ
ពួកកូនចៅអ៊ីស្រាអែល និងបណ្តាទ័ពទាំងអស់ ក៏ឡើងទៅ
ឯបេត–អែល អង្គុយយំនៅទីនោះចំពោះព្រះយេហូវ៉ា[ហ]
ព្រមទាំងតម[ឡ]ក្នុងថ្ងៃនោះរហូតដល់ល្ងាច គេក៏ថ្វាយដង្វាយ
ដុត[អ] និងដង្វាយមេត្រី[ក]នៅចំពោះព្រះយេហូវ៉ាដែរ[ខ] ២៧រួច
គេទូលសួរដល់ព្រះយេហូវ៉ា[គ] (ដ្បិតក្នុងគ្រានោះហឹបនៃ
សេចក្តីសញ្ញារបស់ព្រះ[ឃ]ក៏នៅទីនោះ ២៨ហើយភីនេហាស
ជាកូនអេលាសារ[ង] ជាពូជអើរ៉ុន លោកឈរនៅមុខហឹប
នៅជាន់នោះដែរ)[ច] គឺគេសួរថា តើត្រូវឱ្យទូលបង្គំចេញ
ទៅតតាំង នឹងពួកកូនចៅបេនយ៉ាមីន ជាបងប្អូនទូលបង្គំ
ម្តងទៀតឬត្រូវឈប់វិញ ព្រះយេហូវ៉ាទ្រង់មានបន្ទូលឆ្លើយ
ថា ចូរឡើងទៅចុះ ដ្បិតថ្ងៃស្អែកនេះ អញនឹងប្រគល់គេមក
ក្នុងកណ្តាប់ដៃឯងរាល់គ្នាហើយ[ឆ]។

២៩ពួកអ៊ីស្រាអែលគេបង្កប់ទ័ព[ជ] នៅព័ទ្ធជុំវិញគីបៀរ
៣០រួចឡើងទៅទាស់នឹងពួកបេនយ៉ាមីន នៅថ្ងៃទី៣ទៀត
គេដំរៀបទ័ពទាស់នឹងគីបៀរដូចកាលជាន់មុន ៣១ឯពួក
កូនចៅបេនយ៉ាមីន គេក៏ចេញមក[ឈ]តតាំងគ្នា ហើយត្រូវ
ប្រទាញទៅឃ្លាតឆ្ងាយពីទីក្រុង គេចាប់តាំងសំឡាប់ពួក
អ៊ីស្រាអែល ដូចជាសព្វ១ដង ទាំងអស់ចំនួនប្រហែលជា
៣០នាក់ គឺតាមផ្លូវដែលឡើងទៅឯបេត–អែល[ញ]១ និងផ្លូវ
ដែលទៅឯគីបៀរ១ ព្រមទាំងនៅវាលផង ៣២ដូច្នេះពួក
កូនចៅបេនយ៉ាមីននិយាយគ្នាថា យើងវាយសំឡាប់គេ
បានដូចជាន់មុនទៀត[ដ] តែពួកកូនចៅអ៊ីស្រាអែលនិយាយ
ប្រាប់គ្នាថា ចូរយើងរត់នាំប្រទាញគេមកក្នុងផ្លូវឃ្លាតឆ្ងាយ
ពីទីក្រុងទៅ ៣៣នោះពួកអ៊ីស្រាអែលទាំងប៉ុន្មាន ក៏ងើបពី
កន្លែងរៀងខ្លួនទៅដំរៀបទ័ពនៅត្រង់បាល–តាម៉ារ ឯពួក

**២០:១៦** *ដៃឆ្វេង* លោកអេហ៊ុឌ ជាកូនចៅពួកបេនយ៉ាមីន ក៏ជាអ្នកដែលប្រើការដៃឆ្វេងដែរ (៣:១៥) ។ *បាញ់ដោយក្រួស* សូមធៀបនឹង សក ៩:១៥ ។ ការបាញ់ដោយក្រួសគឺជាអាវុធដ៏មានប្រសិទ្ធិភាពណាស់ ដូចជាស្តេចដាវីឌបានបាញ់កូលីយ៉ាតដែរ (១សយ ១៧:៤៩) ។ គ្រាប់ក្រួស១ មានទម្ងន់ប្រមាណជា ០,៥គីឡូក្រាម ឬច្រើនជាងនេះ ហើយល្បឿននៃការគ្រវែងបាន ចាប់ពី ១៤៤,៨ គម ទៅ១៦០,៩ គម ក្នុង១ម៉ោង (៩០–១០០ម៉ៃយ) ។ *ខុស* នៅក្នុងព្រះគម្ពីរភាសាហេព្រើបកប្រែថា អំពើបាប ។

**២០:១៨** *បេត–អែល* នៅក្នុងអំឡុងពេលនេះ ហឹបនៃសេចក្តីសញ្ញាហើយនិងសម្តេចសង្ឃភីនេហាសគឺស្ថិតនៅក្នុងបេត–អែល (មើល ខ.២៦–២៨) ។ *ទូលសួរដល់ព្រះ* ប្រហែលជាសង្ឃជាអ្នកទូលសួរ ដោយការប្រើយូរីម និងធូមីម (សូមមើលការពន្យល់ នក ២៨:៣០ និងមើល ១សយ ២:២៨) ។ *ក្នុងពួកយើងខ្ញុំ . . . មុនគេ* សូមមើល ១:១–៣៦ ។ *យូដា* សូមមើលការពន្យល់ ១:២ ។

**២០:២១** *២ម៉ឺន២ពាន់នាក់* គួរឱ្យមានការចាប់អារម្មណ៍ពីជ័យជម្នះរបស់ពួកកូនចៅបេនយ៉ាមីន ព្រោះពួកគេមានគ្នាត្រឹមតែ ២ម៉ឺន៦ពាន់នាក់ប៉ុណ្ណោះ (ខ.១៥) ។ ដូច្នេះ ពួកគេម្នាក់ៗ ស្មើរតែអាចសម្លាប់បានពួកអ៊ីស្រាអែលម្នាក់ដែរ ។

**២០:២៧** *ហឹប* នៅក្នុងព្រះគម្ពីរចៅហ្វាយ ពាក្យថា"ហឹប" គឺមាននិយាយតែម្តងប៉ុណ្ណោះ ។

**២០:២៨** *ភីនេហាស* គាត់គឺជាសង្ឃម្នាក់ដែលធ្វើការនៅក្នុងរោងឧបោសថនៅក្នុងដើមសម័យកាលពួកចៅហ្វាយ (សូមមើល ខ.១ ១៨:៣០) ។

**២០:២៩** *បង្កប់ទ័ព* សូមមើល ៩:៣២ យស ៨:២ ។

ទ័ពបង្កប់របស់ពួកអ៊ីស្រាអែល ក៏ស្ទុះចេញពីកន្លែងគេ[ឋ]
នៅត្រង់វាលស្មៅរបស់គីបៀរដែរ ៣៤មានពួកមនុស្ស
ជ្រើសរើសពីសាសន៍អ៊ីស្រាអែល ទាំងអស់ចំនួន១ម៉ឺននាក់
ចូលទៅទាស់នឹងគីបៀរ ហើយចំបាំងនោះក៏ផាសំបើម
ខ្លាំងណាស់ តែពួកបេនយ៉ាមីន ឥតដឹង[ឌ]ខ្លួន ជាមានសេចក្ដី
អន្តរាយជិតដល់គេទេ[ឍ] ៣៥ព្រះយេហូវ៉ាក៏ប្រហារពួក
បេនយ៉ាមីន[ណ]នៅមុខពួកអ៊ីស្រាអែល ហើយនៅថ្ងៃនោះឯង
ពួកកូនចៅអ៊ីស្រាអែល គេបំផ្លាញពួកបេនយ៉ាមីនអស់ចំនួន
២ម៉ឺន៥ពាន់១រយនាក់ សុទ្ធតែជាអ្នកដែលកាន់ដាវ ។
៣៦ដូច្នេះពួកកូនចៅបេនយ៉ាមីន ក៏ឃើញថាខ្លួនគេចាញ់
ហើយ ពីព្រោះពួកអ៊ីស្រាអែលបានថយចេញ[ត]ពីពួកបេន
យ៉ាមីន ដោយទុកចិត្តនឹងពួកទ័ពបង្កប់[ថ] ដែលគេបានដាក់ឱ្យ
ទាស់នឹងក្រុងគីបៀរ ៣៧ពួកទ័ពបង្កប់ក៏ម្នីម្នាស្ទុះចូលទៅក្នុង
ក្រុងគីបៀរជាប្រញាប់ គេដំរង់ទៅមុខ វាយសំឡាប់ពួក
ក្រុងនោះទាំងអស់ដោយមុខដាវ[ទ] ៣៨ឯបណ្ដាពួកទ័ព និងទ័ព
បង្កប់ គេបានសន្យាគ្នានឹងទីសំគាល់នេះ គឺត្រូវឱ្យដុតភ្លើង
ធ្វើផ្សែង[ធ]ឱ្យហុយឡើងយ៉ាងក្រាស់ ចេញពីទីក្រុង[ន] ៣៩ដូច្នេះ
ពួកអ៊ីស្រាអែលបានបែរមុខចេញពីចំបាំង ហើយពួក
បេនយ៉ាមីនចាប់តាំងកាប់សំឡាប់ពួកគេ អស់ប្រហែលជា
៣០នាក់ ដោយស្មានថា វាយសំឡាប់បាន ដូចជាក្នុងចំបាំង
ជាន់មុន[ប] ៤០តែលុះកាលភ្លើងឆេះហុយផ្សែងចេញពីទីក្រុង
ឡើង នោះពួកបេនយ៉ាមីន គេបែរមើលទៅក្រោយឃើញ
ទីក្រុងទាំងមូលហុយសុទ្ធតែផ្សែងទៅលើមេឃ[ផ] ៤១នោះពួក
អ៊ីស្រាអែលត្រឡប់បែរមកវិញ[ព] ហើយពួកបេនយ៉ាមីនក៏
ភាំងស្លុត ដោយឃើញថា សេចក្ដីអន្តរាយមក[ភ]ដល់គេ
ហើយ ៤២ដូច្នេះ គេក៏បែរខ្នងនៅមុខ ពួកអ៊ីស្រាអែល
ប្រាសរត់ទៅតាមផ្លូវទីរហោស្ថានទៅ តែពួកដែលវាយគេ
ចេះតែដេញតាមយ៉ាងប្រកិត ហើយពួកទ័ពដែលចេញពី
ទីក្រុង ក៏បំផ្លាញគេ នៅត្រង់កណ្ដាល ៤៣គេព័ទ្ធពួក
បេនយ៉ាមីនជុំវិញ ព្រមទាំងដេញតាមហើយជាន់គេនៅ
ក្រោមជើងដោយងាយ រហូតដល់ទល់មុខ និងគីបៀរទិស
ខាងកើត ៤៤នោះមានពួកបេនយ៉ាមីន១ម៉ឺន៨ពាន់នាក់បាន
ដួលស្លាប់ សុទ្ធតែជាមនុស្សក្លាហាន[ម] ៤៥រួចគេបែររត់ទៅ
ខាងទីរហោស្ថាន ដល់ថ្មដាឈ្មោះរីម៉ូន[យ] ហើយពួកម្ខាងក៏
វាយសំឡាប់ម្នាក់ៗ រៀងតាមផ្លូវ អស់៥ពាន់នាក់ទៀត ព្រម
ទាំងដេញប្រកិតតាមទៅដល់គីដូម រួចសំឡាប់បាន២ពាន់
នាក់ថែមទៀត ៤៦បានជាពួកបេនយ៉ាមីន[រ]ដែលដួលស្លាប់
នៅថ្ងៃនោះ រួមទាំងអស់មាន២ម៉ឺន៥ពាន់នាក់ សុទ្ធតែជា
អ្នកក្លាហានដែលកាន់ដាវគ្រប់គ្នា ៤៧ប៉ុន្តែ មាន៦០០នាក់
បានងាកបែររត់ទៅខាងទីរហោស្ថានដល់ថ្មដារីម៉ូន ក៏ជ្រក
នៅក្នុងថ្មដានោះអស់៤ខែ ៤៨រួចពួកអ៊ីស្រាអែលគេវិល
ត្រឡប់ទៅក្រោយ សំឡាប់ពួកកូនចៅបេនយ៉ាមីនដោយមុខ
ដាវ គឺសំឡាប់ទាំងពួកអ្នកនៅទីក្រុងទាំងអស់ និងពួកសត្វ
ហើយនិងរបស់អ្វីៗ ដែលប្រទះឃើញទាំងអស់ផង រួចគេ
ដុតទីក្រុងទាំងប៉ុន្មាន ដែលគេប្រទះឃើញដែរ[ល]។

### អ្នកត្រូវធ្វើជាប្រពន្ធពួកបេនយ៉ាមីន

**២១** ១រីឯពួកបណ្ដាជន ជាសាសន៍អ៊ីស្រាអែល គេបាន
ស្បថ[ក]នៅត្រង់មីសប៉ា[ខ]ថា មិនត្រូវឱ្យមានអ្នកណាមួយ ក្នុង
ពួកយើងរាល់គ្នា ឱ្យ[គ]កូនស្រីរបស់ខ្លួនទៅធ្វើជាប្រពន្ធ
ពួកបេនយ៉ាមីនឡើយ ២គេក៏មកដល់បេត-អែល អង្គុយ
នៅទីនោះចំពោះព្រះដរាបដល់ល្ងាច ព្រមទាំងបន្លឺសំឡេង

**២០:៣៣** ឋ យស ៨:១៩
**២០:៣៤** ឌ យស ៨:១៤ ឍ ខ.៤១
**២០:៣៥** ណ ១សយ ៩:២១
**២០:៣៦** ត យស ៨:១៥ ថ យស ៨:២
**២០:៣៧** ទ យស ៨:១៩
**២០:៣៨** ធ យស ៨:២០ ន យស ៨:៤-៨
**២០:៣៩** ប ខ.៣២ ទដ ៧៨:៩
**២០:៤០** ផ យស ៨:២០
**២០:៤១** ព យស ៨:២១ ភ ខ.៣៤
**២០:៤៤** ម ១សយ ១០:២៦ ទដ ៧៦:៥
**២០:៤៥** យ យស ១៥:៣២
**២០:៤៦** រ ១សយ ៩:២១
**២០:៤៨** ល ពច ២១:២៣
**២១:១** ក យស ៩:១៨ ខ យស ១១:៣ គ ខ.១៨,២២

**២០:៣៣** *បាល-តាម៉ារ* សម្រាប់ទីកន្លែងពិតប្រាកដ មិនដឹងច្បាស់ឡើយ ។
**២០:៣៥** *២ម៉ឺន៥ពាន់១រយ* ប្រហែលជាពួកកូនចៅបេនយ៉ាមីន ១០០០នាក់ត្រូវបានសម្លាប់ ក្នុងពេលសង្គ្រាម២លើកដំបូង(មើល ខ.២១) ។
**២០:៣៦ខ-៤៥** នៅក្នុងខទាំងនេះ គឺជាការពិពណ៌នាលំអិតអំពីរឿងរ៉ាវដែលកើតមាននៅក្នុង ខ.២៩-៣៦ក ។
**២០:៤៦** *២ម៉ឺន៥ពាន់នាក់* ចំនួនទាំងអស់មាន២ម៉ឺន៥ពាន់១រយនាក់ (មើល ខ.៣៥) ។
**២០:៤៧** *៦០០នាក់* បើសិនជាពួកគេទាំងនោះមិនបានគេចរត់ចេញទេ នោះពូជអំបូរនៃពួកកូនចៅបេនយ៉ាមីនទាំងអស់ត្រូវវិនាសសាបសូន្យ ។ ពួកដានក៏មានគ្នា៦០០នាក់ដែរ នៅពេលគេចេញទៅឡាអ៊ីស ។
**២១:១-២៥** ការសម្លាប់ពួកកូនចៅបេនយ៉ាមីន ដែលជាបងប្អូនរបស់គេ គឺដោយសារពួកកូនចៅអ៊ីស្រាអែលចង់បង្ហាញពីភាពក្លាហានរបស់គេ ទើបធ្វើឱ្យមានការបាត់បង់ដូច្នេះ ។ មានតែពួកកូនចៅបេនយ៉ាមីន៦០០នាក់ប៉ុណ្ណោះ ដែលអាចមានជីវិត ។ ពួកកូនចៅអ៊ីស្រាអែលគេសម្រេចចិត្តផ្ដល់ប្រពន្ធឱ្យពួកកូនចៅបេនយ៉ាមីន ដើម្បីឱ្យពូជអំបូរគេរីកចម្រើនឡើងវិញ ។ បន្ទាប់ពីសោកវិនាសកម្មនេះ មកមនុស្សជាច្រើននៅយ៉ាបេស-កាឡាត ដែលជាកូនចៅអ៊ីស្រាអែលចំនួន៤០០នាក់ ដែលមិនទាន់ស្គាល់ប្រុសណាឱ្យទៅរៀបការជាមួយពួកកូនចៅបេនយ៉ាមីន ៤០០នាក់ដែរ ។ រយៈពេលដ៏ខ្លីក្រោយមកទៀត សំណល់របស់ពួកកូនចៅបេនយ៉ាមីន បានយកប្រពន្ធពីស្ត្រីដែលនៅស៊ីហុន នៅពេលនោះហើយដែលពួកបេនយ៉ាមីនចាប់ផ្ដើមបង្កើតពូជអំបូរគេឡើងវិញ។
**២១:១** *ស្បថ* ពាក្យសម្បថនេះ គឺគេបាននិយាយដោយនូវព្រះនាមព្រះយេហូវ៉ា ហើយពាក្យសម្បថបែបនេះ គេមិនដែលស្បថពីមុនមកនោះទេ ប៉ុន្តែពាក្យសម្បថនេះ ក្លាយជាបណ្ដាសាដល់ខ្លួនវិញ បើសិនជារំលងពាក្យសម្បថនេះ(ខ.១៨ កច ២៣:១២-១៥) ។
**២១:២** *បេត-អែល* សូមមើល ២០:១៨,២៦-២៧ ។ *បន្លឺសំឡេងយំ* កាលពីគ្រាមុនពួកអ៊ីស្រាអែលយំ ពីព្រោះចាញ់សង្គ្រាមជាមួយពួកបេនយ៉ាមីន (២០:២៣,២៦) ។ ពេលនេះពួកអ៊ីស្រាអែលគេយំដោយព្រោះ ការធ្វើ

យំជាខ្លាំងថា ៣ឱព្រះយេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រាអែល
អើយ ហេតុអ្វីបានជាសេចក្តីនេះកើតមកក្នុងសាសន៍អ៊ីស្រា-
អែល ឱ្យត្រូវបាត់[ឃ]ពូជអំបូរ១ក្នុងសាសន៍យើងខ្ញុំនៅថ្ងៃនេះ
ដូច្នេះ ៤ដល់ថ្ងៃស្អែកគេក៏ក្រោកឡើងពីព្រលឹម គេស្អាង
អាសនា១នៅទីនោះ រួចថ្វាយដង្វាយដុត និងដង្វាយមេត្រី[ង]
៥នោះគេសួរគ្នាថា ក្នុងពូជអំបូរសាសន៍អ៊ីស្រាអែល[ច]
ទាំងប៉ុន្មាន តើអ្នកណាខ្លះដែលមិនបានឡើងមកប្រជុំឯ
ព្រះយេហូវ៉ា គេសួរដូច្នោះពីព្រោះបានស្បថយ៉ាងធ្ងន់
ពីដំណើរអ្នកណាដែលមិនឡើងមកឯព្រះយេហូវ៉ា ត្រង់
មីសប៉ានោះថា អ្នកនោះនឹងត្រូវស្លាប់ជាពិតប្រាកដ ៦ហើយ
ពួកកូនចៅអ៊ីស្រាអែល ក៏នឹកស្តាយពួកបេនយ៉ាមីន ជាបង
ប្អូនគេដោយពាក្យថា នៅថ្ងៃនេះពូជអំបូរមួយបានកាត់
ចេញពីសាសន៍អ៊ីស្រាអែលហើយ ៧ធ្វើដូចម្តេចឱ្យយើង
រកប្រពន្ធឱ្យពួកគេ ដែលនៅសល់បាន ដ្បិតយើងបានស្បថ[ឆ]
នឹងព្រះយេហូវ៉ាថា យើងមិនឱ្យកូនស្រីរបស់យើងទៅធ្វើជា
ប្រពន្ធគេឡើយ ។

៨ដូច្នេះគេសួរថា ក្នុងពូជអំបូរអ៊ីស្រាអែលទាំងប៉ុន្មាន
តើមានពួកណាមិនបានឡើងមកឯព្រះយេហូវ៉ា ត្រង់មីសប៉ា
នោះឃើញថា គ្មានអ្នកណាបានឡើងមកពីយ៉ាបេស-
កាឡាត ដើម្បីនឹងប្រជុំក្នុងពួកជំនុំទេ ៩ដ្បិតកាលគេបាន
រាប់បណ្តាជនទៅ នោះមិនឃើញអ្នកណាពីពួកយ៉ាបេស-
កាឡាត[ជ]ណាមួយបាននៅទីនោះសោះ ១០ដូច្នេះពួកជំនុំ ក៏
ចាត់មនុស្ស១ម៉ឺន២ពាន់នាក់ ក្នុងពួកក្លាហាន ឱ្យទៅឯណោះ
ដោយបង្គាប់ថា ចូរទៅសំឡាប់ពួកអ្នកនៅយ៉ាបេស-
កាឡាតនោះ ដោយមុខដាវទៅ ព្រមទាំងស្រីៗនិងពួកក្មេង
ផង ១១ត្រូវឱ្យអ្នករាល់គ្នាធ្វើដូច្នេះ គឺត្រូវសំឡាប់ពួក
ប្រុសៗ[ឈ]ទាំងអស់ទៅ ព្រមទាំងពួកស្រីៗ ដែលបានស្គាល់
ប្រុសហើយផង[ញ] ១២ក្នុងពួកអ្នកនៅយ៉ាបេស-កាឡាតនោះ
ឃើញមានស្រីក្រមុំ៤០០នាក់ ដែលមិនទាន់បានស្គាល់ប្រុស
ណាដោយរួមដំណេកជាមួយនៅឡើយ គេក៏នាំស្រីទាំង
នោះ មកឯទីដំឡើងត្រសាល នៅត្រង់ស៊ីឡូរ[ដ] ដែលនៅក្នុង
ស្រុកកាណាន ។

១៣នោះពួកជំនុំទាំងអស់គ្នា ក៏ចាត់គេឱ្យទៅនិយាយ
នឹងពួកកូនចៅបេនយ៉ាមីន ដែលនៅថ្មដារីម៉ូននោះ[ឋ] ដោយ
ប្រកាសជាសេចក្តីមេត្រី[ឌ]នឹងគ្នាទៅវិញទៅមក ១៤ដូច្នេះពួក
បេនយ៉ាមីនក៏វិលត្រឡប់មកវិញនៅគ្រានោះ រួចពួកជំនុំ
ប្រគល់ស្ត្រីទាំងប៉ុន្មាន ដែលបានទុកឱ្យរស់នៅ ក្នុងពួកស្ត្រី
យ៉ាបេស-កាឡាតនោះឱ្យដល់គេ តែមិនទាន់បានល្មមឱ្យគេ
នៅឡើយ ១៥ពួកបណ្តាជនក៏នឹកស្តាយដល់ពួកបេនយ៉ាមីន[ឍ]
ដោយព្រះយេហូវ៉ាបានធ្វើឱ្យបាត់ពួក១ ក្នុងពូជអំបូរ
សាសន៍អ៊ីស្រាអែលទាំងប៉ុន្មានចេញ ។

១៦ពួកចាស់ទុំក្នុងពួកជំនុំក៏សួរគ្នាថា ធ្វើដូចម្តេចឱ្យយើង
រកប្រពន្ធឱ្យពួកគេដែលនៅសល់បាន ដ្បិតពួកស្ត្រីក្នុង
ពួកបេនយ៉ាមីនបានវិនាសអស់ហើយ ១៧គេឆ្លើយថា ត្រូវ
ឱ្យមានកេរ្តិ៍អាករឱ្យពួកអ្នក ដែលបានរួចជីវិតក្នុងពួក
បេនយ៉ាមីនផង ដើម្បីកុំឱ្យមានពូជអំបូរណាមួយ ត្រូវរលុប
ចេញពីសាសន៍អ៊ីស្រាអែលឡើយ[ណ] ១៨ប៉ុន្តែខ្លួនយើងរាល់
គ្នា គ្មានច្បាប់នឹងឱ្យកូនយើងទៅធ្វើជាប្រពន្ធគេទេ (ដ្បិត
ពួកកូនចៅអ៊ីស្រាអែលបានស្បថ[ត]ថា ត្រូវបណ្តាសាហើយ
អ្នកណាដែលឱ្យ[ថ]កូនទៅធ្វើជាប្រពន្ធរបស់ពួកបេនយ៉ាមីន)
១៩រួចគេប្រាប់ថា មើល រាល់តែឆ្នាំគេតែងធ្វើបុណ្យថ្វាយ
ព្រះយេហូវ៉ា នៅត្រង់ស៊ីឡូរ[ទ] ដែលនៅខាងជើងបេត-
អែល[ធ] ហើយខាងកើតផ្លូវ ដែលឡើងពីបេត-អែលទៅឯ
ស៊ីគែម[ន] និងខាងត្បូងល្បូណា ២០ដូច្នេះគេបង្គាប់ដល់ពួកកូន

**២១:៣** ឃ ខ.៦,១៧
**២១:៤** ង ៣ច ២០:២៦
**២១:៥** ច ៣ច ២០:១
**២១:៧** ឆ យស ៩:១៨
**២១:៨** ជ ១សយ ១១:១ ៣១:១១ ២សយ ២:៤ ២១:១២ ១រប ១០:១១
**២១:១១** ឈ ជណ ៣១:៧
ញ ចន ៣១:១៧-១៨
**២១:១២** ដ យស ១៨:១
**២១:១៣** ឋ យស ១៥:៣២ ឌ ចទ ២:២៦
**២១:១៥** ឍ ខ.៦
**២១:១៧** ណ ខ.៣
**២១:១៨** ត យស ៩:១៨ ថ ខ.១
**២១:១៩** ទ យស ១៨:១ ធ យស ១៦:១ ន យស ១៧:៧

សង្គ្រាមប្រឆាំងជាមួយពួកបេនយ៉ាមីន ដែលធ្វើឱ្យពួកគេស្ទើរតែផុតពូជទៅហើយ (មើល ខ.៣) ។

**២១:៥** *មិនបានឡើងមក* ពូជអំបូរនិមួយៗត្រូវមានទំនួលខុសត្រូវចំពោះគ្នាទៅវិញទៅមក (សូមមើលការពន្យល់ ៥:១៣-១៨) ។ អ្នកណាដែលមិនបានមកចូលរួម ជានិច្ចកាលត្រូវគេកាត់ចេញពីសាសន៍ ឬដាក់ទណ្ឌកម្ម (៥:១៥-១៧,២៣) ។ *ស្បថយ៉ាងធ្ងន់* បញ្ហាដ៏ស្មុគស្មាញសម្រាប់ប្រជាជនអ៊ីស្រាអែល គឺពួកគេបានស្បថម្តងទៀត គឺអ្នកដែលមិនបានមកចូលរួមប្រជុំ ។

**២១:១០** *១ម៉ឺន២ពាន់នាក់* គេយក១ពាន់នាក់ក្នុងពូជអំបូរនិមួយៗ (ជន ៣១:៦) ។

**២១:១១** *សំឡាប់ពួកប្រុសៗ* ការព្រមានដល់ពួកយ៉ាបេស-កាឡាត មើលទៅហាក់បីដូចជាព្រៃផ្សៃណាស់ ប៉ុន្តែចំណងនៃការតាំងសញ្ញារវាងពូជអំបូរនិមួយៗ គឺមានសារៈសំខាន់ណាស់ ។ ទោះបីជាស្ថានភាពខ្លះមិនបានធ្វើការព្រមានក៏ដោយ (៥:១៥-១៧) ។ មូលហេតុនៃចម្បាំងកន្លែងនេះ គឺដោយសារការបដិសេធន៍របស់ពួកបេនយ៉ាមីន មិនព្រមងាកចេញពីចម្បាំងដែលជាហេតុធ្វើឱ្យពួកអ៊ីស្រាអែលស្បថ (ខ.៥) ។

**២១:១២** *ក្នុងស្រុកកាណាន* តាមឃ្លានេះ បញ្ជាក់ថា ពួកស្ត្រីៗទាំងនោះត្រូវបានគេនាំមកពីភាគខាងកើត ដោយឆ្លងកាត់ទន្លេយ័រដាន់ ។

**២១:១៩** *បុណ្យថ្វាយព្រះយេហូវ៉ា* ការពួកស្នាក់នៅក្នុងចំការទំពាំងបាយជូរ (ខ.២០) គឺហាក់ដូចជាចង់និយាយថា ជាពេលបុណ្យរោងឧបោសថ (មើល ១សយ ១:៣) នៅកន្លែងនោះ គឺជាកន្លែងដែលគេរៀបចំធ្វើពិធីបុណ្យ ។ *ខាងជើងបេត-អែល . . . ខាងត្បូងល្បូណា* នៅក្នុងការពិពណ៌នាពីទីតាំងលំអិតរបស់ស៊ីហុន អាចនិយាយបានថា រឿងរ៉ាវទាំងនេះត្រូវបានសរសេរឡើងនៅក្នុងអំឡុងពេលជម្លោះនៅស៊ីហុន ហើយប្រហែលជាបន្ទាប់ពីស្តេចអាផែក បានបំផ្លាញក្រុងនេះ (១សយ ៤:១-១១) ។

ចៅបេនយ៉ាមីនថា ចូរឯងរាល់គ្នាទៅបង្កប់ខ្លួនក្នុងចំការ
ទំពាំងបាយជូរទៅ
២១ចាំមើល បើពួកស្រីក្រមុំនៅស៊ីឡូរ
ចេញមកលេង[ប] នោះចូរឯងរាល់ចេញពីចំការទំពាំងបាយ
ជូរ ទៅចាប់យកពួកស្រីក្រមុំស៊ីឡូរទាំងនោះ ធ្វើជាប្រពន្ធ
គ្រប់ៗគ្នាចុះ រួចត្រឡប់ទៅឯស្រុកនៅបេនយ៉ាមីនវិញទៅ
២២បើកាលណាឪពុក ឬបងប្អូនស្ត្រីទាំងនោះមកប្តឹងយើង
នោះយើងនឹងអង្វរថា សូមអាណិតមេត្តាដល់គេឱ្យយើងផង
ដ្បិតយើងទៅច្បាំងនោះមិនបានទុកប្រពន្ធឱ្យគេគ្រប់គ្នាទេ
មួយទៀត មិនមែនជាអ្នករាល់គ្នា ដែលឱ្យ[ផ]ស្ត្រីទាំងនោះ
ទៅគេដែរ បើអ្នករាល់គ្នាបានធ្វើដូច្នេះ នោះមានទោស
មែន
២៣ពួកកូនចៅបេនយ៉ាមីនក៏ធ្វើដូច្នោះ គេចាប់យកជា
ប្រពន្ធ១ម្នាក់គ្រប់គ្នាតាមចំនួនគេ ពីពួកក្រមុំដែលកំពុង
លេង[ព] រួចនាំជិរត់យកទៅឯស្រុកជាមរដក[ភ]របស់គេទៅក៏
សង់ទីក្រុងឡើងវិញ ហើយក៏តាំងទីលំនៅផង[ម]
២៤នៅគ្រា
នោះពួកកូនចៅអ៊ីស្រាអែល ក៏ចេញពីទីនោះត្រឡប់ទៅឯ
ពូជអំបូរ និងគ្រួសាររបស់គេរៀងខ្លួន គឺវិលទៅឯស្រុក
ជាមរដករបស់គេគ្រប់ៗគ្នាទៅ ។
២៥នៅគ្រានោះឯង គ្មានស្តេចនៅស្រុកអ៊ីស្រាអែលទេ
គឺមនុស្សទាំងឡាយតែប្រព្រឹត្តការអ្វី តាមដែលគេយល់
ឃើញថាត្រឹមត្រូវគ្រប់គ្នា[យ] ។

**២១:២១** ប នក ១៥:២០
**២១:២២** ផ ខ.១ ខ.១,១៨
**២១:២៣** ព ខ.២១ ភ យស ២៤:២៨ ម ពច ២០:៤៨
**២១:២៥** យ ចទ ១២:៨

**២១:២១** *ធ្វើជាប្រពន្ធគ្រប់ៗគ្នាចុះ* នៅពេលដែលពួកបេនយ៉ាមីន បានប្រពន្ធដោយប្រើប្រាស់វិធីនេះ នោះពូជអំបូរផ្សេងៗទៀត គេមិនឱ្យកូនស្រីគេទៅធ្វើជាប្រពន្ធឡើយ (មើល ខ.២២) ។

**២១:២២** *បើកាលណាឪពុក . . . មកប្តឹង* ការមកប្តឹងបែបនេះ វាជាទំនៀមទម្លាប់មួយទៅហើយ សម្រាប់បងប្អូនរបស់ស្ត្រីក្រមុំទាំងនោះ នៅពេលដែលប្អូនត្រូវបានគេចាប់ ដើម្បីបំពេញចិត្ត (លប ៣៤:៧–៣១ ២សយ ១៣:២០–៣៨) ។ វាមានសារៈសំខាន់ណាស់ ដែលបងជាអ្នកមានទំនួលខុសត្រូវចំពោះប្អូនស្រីរបស់ខ្លួន នៅក្នុងក្រុមគ្រួសារ ។

**២១:២៤** *វិលទៅឯស្រុក* នាយទាហានទាំងនោះ ប្រហែលបានចាកចេញពីស្រុកយ៉ាងតិចក៏៥ខែដែរ (មើល ២០:៤៧) ។

**២១:២៥** *គ្មានស្តេចណានៅស្រុកអ៊ីស្រាអែលទេ* សូមមើលសេចក្តីផ្តើមត្រង់ចំណុច អ្នកនិពន្ធ និងកាលបរិច្ឆេទ ព្រមទាំង ១៧:៦ ។

# ព្រះគម្ពីរនាងរស់

## សេចក្តីផ្តើម

### ចំណងជើង

ការដាក់ចំណងជើងព្រះម្ពីរថា "នាងរស់" គឺបន្ទាប់ពីបានរកឃើញនូវអត្តចរិតដ៏ប្រពៃរបស់ស្រ្តីសាសន៍ម៉ូអាប់ម្នាក់ ដែលត្រូវជាយាយទួតរបស់ស្តេចដាវីឌ ហើយជាព្ធយុកោរបស់ព្រះយេស៊ូវគ្រីស្ទ (៤:២១-២២ មថ ១:១,៥) ។ នៅក្នុងព្រះគម្ពីរផ្សេងទៀត ដែលនិយាយពីឈ្មោះរបស់ស្រ្តី គឺជាព្រះគម្ពីរនាងអេសធើរ ។

### ប្រវត្តិដើម

ដំណើររឿងនៅក្នុងព្រះគម្ពីរនាងរស់នេះ គឺបានកើតឡើងនៅក្នុងសម័យព្រះគម្ពីរចៅហ្វាយដែរ ។ ពេលវេលាដែលសរសេរព្រះគម្ពីរចៅហ្វាយ គឺក្នុងអំឡុងពេលដែលពួកអ៊ីស្រាអែលបានបោះបង់ព្រះចោល ហើយទៅគោរពលើរូបព្រះពេលមានសង្គ្រាម ជាពិសេសទទួលការឈ្លានពានពីប្រទេសក្រៅ ។ ព្រះគម្ពីរនាងរស់ គឺគិតទៅលើពេលវេលាដែលប្រទេសអ៊ីស្រាអែល និងប្រទេសម៉ូអាប់មានសន្តិភាព និងបានមេត្រីជាមួយគ្នា (ខុសពី ពច ៣:១២-៣០) ។ ដូចគ្នានឹង ១សយ ១-២ បានផ្តល់នូវលំដាប់មិត្តភាពជិតស្និទ្ធ ដែលមានរយៈពេលខ្លីរបស់ពួកកូនចៅអ៊ីស្រាអែល ។ នៅក្នុងព្រះគម្ពីរនេះក៏បានពិពណ៌នាអំពីមនោរម្យភាព ទុកសម្រាប់ឱ្យពួកអ្នកសំណល់ដែលមានសេចក្តីជំនឿដ៏ពិត ក្នុងអំឡុងពេលពួកចៅហ្វាយ ដែលជាយុគសម័យកាលមួយដ៏ខ្មៅងងឹត ។

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

ព្រះគម្ពីរនាងរស់ មិនត្រូវបានស្គាល់ឈ្មោះរបស់អ្នកនិពន្ធនោះទេ ។ តាមទំនៀមទម្លាប់របស់ពួកសាសន៍យូដា លោក "សាំយូអែល" ជាអ្នកនិពន្ធ ព្រោះព្រះគម្ពីរនេះបាននិយាយអំពីស្តេចដាវីឌ (៤:១៧,២២) ។ ចំណែកឯកាលបរិច្ឆេទនៃការសរសេរវិញក៏មិនច្បាស់លាស់ដែរ ។ ជាងនេះទៅទៀត លក្ខណៈអក្សរសាស្ត្ររបស់ពួកហេព្រើរនៅក្នុងព្រះគម្ពីរនេះ គឺបញ្ជាក់ថា ព្រះគម្ពីរនាងរស់ត្រូវបានសរសេរឡើងក្នុងអំឡុងពេល ប្រទេសអ៊ីស្រាអែលស្ថិតក្នុងរបបរាជាធិបតេយ្យ ។

### ផ្ទៃរឿង និងវិជ្ជាសិក្សាអំពីព្រះ

សារៈសំខាន់នៃសេចក្តីជំនឿ សេចក្តីស្រឡាញ់របស់មនុស្ស ដែលមានទំនាក់ទំនងជាមួយមនុស្សនិងមនុស្សផងគ្នា នៅក្នុងនគរព្រះនោះគឺជាអំណាចដែលមិនអាចគួសបញ្ជាក់បាន ។ អ្នកនិពន្ធបានយកចិត្តទុកដាក់លើចរិតមិនឆេវឆាវរបស់នាងរស់ និងក្តីអាណិតអាសូររបស់នាងចំពោះនាងន៉ាអូមី (១:១៦-១៧ ២:១១-១២ ៣:១០ ៤:១៥) និងសេចក្តីសប្បុរសរបស់លោកបូអូស ដែលមានចំពោះស្រ្តីមេម៉ាយទាំង២នោះ (ជំពូក ២-៤) ។ គាត់បានពណ៌នា ដោយលើកយកឧទាហរណ៍ពីការងារក្នុងជីវិតរបស់ពួកគេប្រចាំថ្ងៃដែលបានសម្រេចតាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់ (មើល លវ ១៩:១៨ ហើយប្រៀបធៀប ២:១២ ជាមួយ ៣:៩) ។ ជីវិតរស់នៅរាល់ថ្ងៃនោះ គឺជាព្រះពររបស់ព្រះអម្ចាស់ ដែលព្រះអង្គទ្រង់មានមេត្តាករុណា ។

វាប្រហែលជាធ្វើឱ្យយើងមានការភ្ញាក់ផ្អើលជាមិនខាន ព្រោះម្នាក់ដែលតំណាងឱ្យសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់នោះ បានប្រាប់ឱ្យយើងឃើញច្បាស់ គឺជាស្រ្តីសាសន៍ម៉ូអាប់ ។ ពេលនេះ សេចក្តីស្មោះត្រង់របស់នាងចំពោះពួកសាសន៍អ៊ីស្រាអែលត្រូវបានសម្រេចតាមរយៈការរៀបការ និងភាពអាណិតអាសូរចំពោះម្តាយក្មេករបស់នាង ។ ការទាំងនោះបានបង្ហាញថា នាងជាកូនស្រីពិតប្រាកដនៅក្នុងអំបូរអ៊ីស្រាអែល និងជាព្ធយុកោដ៏មានតម្លៃរបស់ស្តេចដាវីឌ មិនមែនដោយសារឈាមជ័រ ឬកំណើតនោះឡើយ ប៉ុន្តែគឺដោយសារតែការចុះចូលបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ តាមរយៈ"ការស្តាប់បង្គាប់ តាមសេចក្តីជំនឿ" (មើល រម ១:៥) ។ ដូចជាអ្វីដែលមាននៅក្នុងពួកព្ធយុកោស្តេចដាវីឌ ព្រះគម្ពីរនាងរស់ គឺជាផ្នែកមួយដែលនិយាយអំពីសេចក្តីសង្គ្រោះ ។ សេចក្តីសង្គ្រោះ គឺជាចំណុចស្នូលគ្រប់អស់ទាំងមនុស្ស ។ នៅក្នុងទម្រង់ភាសាហេព្រើរពាក្យនេះមាន២៣ដង ។ ព្រះគម្ពីរនេះនាងរស់បាននិយាយពីប្រវត្តិរឿង នៃការប្រែប្រួលរបស់នាងន៉ាអូមី ចាប់តាំងពីគ្រាដែលនាងជួបការលំបាកព្រាត់ប្រាស់ រហូតដល់គ្រាដែលនាងទទួលបានសុភមង្គលពេញលេញដោយការខិតខំប្រឹងប្រែង និងតាមរយៈព្រះពររបស់ព្រះអម្ចាស់ផ្តល់មកនាង ដោយសារនាងរស់ និងន៉ាអូមីបានចាប់ផ្តើមដោយទទេ ហើយបញ្ចប់ដោយភាពពោរពេញ (១:១២ ៣:១៧ សូមមើលការពន្យល់ ១:១,៣,៥-៦,២១-២២ និងមើល ៣:៧ ៤:១៥) ពីភាពក្រខ្សត់ (១:១-៥) មកឯភាពបរិបូរណ៍ និងសេចក្តីសង្ឃឹម (៤:១៣-១៧) ។ ដូចគ្នាជាមួយពួកអ៊ីស្រាអែលដែរ ពួកគេបានចាប់ផ្តើមចេញពីប្រជាជាតិមួយ ដែលមានភាពក្រខ្សត់ នៅក្នុងអំឡុងពេលដែលលោកអេលីបានស្លាប់ទៅ (១សយ ៤:១៨) ហើយទទួលបានសន្តិភាពពេញ

លេញ និងមានទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹកសន្ធាប់មុនពេលរាជ្យស្តេចសាឡូម៉ូន (១ពវ ៤:២០-៣៤ ៥:៤) តាមរយៈការខិតខំរបស់ស្តេចដាវីឌជាកូនចៅដ៏ពិតរបស់នាងរស់ ហើយនិងលោកបូអូស ។ អ្នកនិពន្ធក៏បានរំឭកពួកអ៊ីស្រាអែលថា ក្នុងអំឡុងពេលយុគសម័យកាលស្តេចដាវីឌ គឺជាតម្រុយនៃការគ្រប់គ្រងរបស់ព្រះអម្ចាស់លើពួកអ៊ីស្រាអែល ដែលព្រះអង្គបានផ្តល់ឱ្យគេមានសន្តិភាព និងការសម្រាកដ៏ពិតនៅក្នុងព្រះយេស៊ូវគ្រីស្ទជា "ជំនួរវង្ស" ស្តេចដាវីឌ (មថ ១:១) ហើយនិងការប្រោសលោះរបស់ទ្រង់ នោះព្រះពរដែលបានសន្យាអំពីនគរព្រះត្រូវបានសម្រេច ។

**លក្ខណៈអក្សរសាស្ត្រនៅក្នុងព្រះគម្ពីរ**

អក្សរសាស្ត្រនៅក្នុងព្រះគម្ពីរនាងរស់ គឺជារឿងដ៏ខ្លីមួយរបស់ពួកហេព្រើរ ដែលនិយាយអំពី "ការប៉ិនប្រសប" ។ នៅក្នុងចំណោមបណ្តារឿងទាំងឡាយនៅក្នុងព្រះគម្ពីរនេះ ជារឿងដ៏ល្អឯក ប្រៀបដូចជាគ្រឿងអលង្ការដ៏មានតម្លៃ ។

ភាពសក្តិសមមានពេញផ្ទៃរឿងទាំងមូល (សូមមើលគម្រោងសង្ខេប) គឺជាការផ្លាស់ប្តូរចេញពីគ្រួសារដ៏សាមញ្ញ ដែលពេញដោយទុក្ខព្រួយ (មើល ១:១-៥ នៅក្នុងព្រះគម្ពីរភាសាហេព្រើរ មាន៧១ដង) តាមរយៈវគ្គទាំង៤នេះ បានធ្វើឱ្យមានការសន្និដ្ឋានមួយដែលបានទទួលនូវភាពធូរស្បើយ ពោរពេញ និងសេចក្តីសង្ឃឹមដែលមានជាតំណាក់កាលដូចៗគ្នា (មើល ៤:១៣-១៧ មាន៧១ដងនៅក្នុងព្រះគម្ពីរភាសាហេព្រើរ) ។ ដោយសារភាពចាំបាច់ត្រូវតែបង្វែរសាច់រឿងនៅក្នុងកណ្តាលផ្ទៃរឿងនេះតែម្តង (មើលការពន្យល់ ២:២០) ។

ការចាប់ផ្តើម វគ្គនិមួយៗក្នុងចំណោមវគ្គទាំង៤នោះ គឺជាទីសម្គាល់១ដែលបង្ហាញពីគ្រឹះនៃការវិវឌ្ឍន៍ (១:៦ ការវិលត្រឡប់ ២:១ ការជួបជុំជាមួយបូអូស ៣:១ ស្វែងរកទីជម្រកសម្រាប់នាងរស់ ៤:១ ការសម្រេចចិត្តមកអង្គុយនៅទ្វារទីក្រុង) ក្នុងអំឡុងពេលដែលវគ្គនិមួយៗ មានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នាធ្វើជាស្ពានឱ្យអ្នកអានបានដឹងថា តើអ្វីដែលត្រូវធ្វើ ហើយអ្វីដែលមិនត្រូវធ្វើ (សូមមើលការពន្យល់ ១:២២ និងមើល ២:២៣ ៣:១៨ ៤:១២) ។ ផ្ទុយមកវិញ វាក៏ត្រូវបានធ្លាប់មានប្រសិទ្ធិភាព : ការសប្បាយចិត្ត (អត្ថន័យ "ន៉ាអូមី") និងភាពល្វីងជូរចត់ (១:២០) ទទេនិងពោរពេញ (១:២១) ហើយមនុស្សរស់ និងមនុស្សស្លាប់ (២:២០) ។ នៅក្នុងរឿងនេះក៏បានបង្ហាញពីភាពខុសគ្នាផងដែរ គឺរវាងនាងរស់ និងនាងន៉ាអូមី ។ ម្នាក់ជាក្មេងសាសន៍ដទៃ ជាស្ត្រីមេម៉ាយទាល់ក្រ នៅក្នុងពេលដែលម្នាក់ទៀតស្ថិតក្នុងវ័យកណ្តាល មានកេរ្តិ៍ឈ្មោះនៅក្នុងអំបូរអ៊ីស្រាអែលនៅក្នុងសហគមន៍របស់ខ្លួន ។

នៅក្នុងស្ថានភាពដែលប្រែប្រួលបែបនេះ ពេលវេលានិងកាលៈទេសៈទាំងអស់នោះ មានភាពខុសគ្នាខ្លះៗ ។ លទ្ធផលដ៏ប្រពៃមួយ ទាំងភាពស្កប់ចិត្ត ដែលជាការបើកបង្ហាញ ដើម្បីឱ្យយើងបានយល់ ។ អ្នកនិពន្ធព្រះគម្ពីរនាងរស់បានផ្តល់ឱ្យអ្នកអានបានដឹងតាំងពីដើម ពីស្មារតីមិននឹងនរ នៅក្នុងកណ្តាលរឿង គឺចាប់តាំងពីពេលដែលនាងរស់មានការផ្លាស់ប្រែពីភាពទទេ មកឯភាពពោរពេញឈ្មោះរបស់នាងនៅក្នុងអំបូរស្តេចដាវីឌបញ្ជាក់ថា គ្រប់សាសន៍ទាំងអស់ក្លាយជារាស្ត្រដែលរស់នៅក្នុងនគរស្តេចដាវីឌ ដែលជាបុត្រដ៏ឧត្តម ។

តាមរយៈការតស៊ូខ្លួនឯង និងតាមរយៈនាងរស់និងលោកបូអូស (មើលផ្ទៃរឿង និងលក្ខណៈវិជ្ជាសិក្សាអំពីព្រះ) ។ ដំណើររបស់នាង ឬភាពរុងរឿងឡើងវិញរបស់នាងន៉ាអូមី ដំបូងគឺស្ថិតនៅក្នុងពេលដែលនាងវិលត្រឡប់ពីស្រុកម៉ូអាប់ មកឯទឹកដីសន្យា និងភូមិបេថ្លេហិម (ផ្ទះនៃអាហារ សូមមើល ១:១) ។

**គម្រោងសង្ខេប**

**១. សេចក្តីផ្តើម : ភាពបាត់បង់របស់នាងន៉ាអូមី (១:១-៥)**

**២. ការវិលត្រឡប់របស់នាងន៉ាអូមីពីស្រុកម៉ូអាប់ (១:៦-២២)**

ក. នាងរស់ទទូចតាមជាប់ជាមួយនាងន៉ាអូមី (១:៦-១៨)

ខ. នាងរស់និងនាងន៉ាអូមីធ្វើដំណើរទៅបេថ្លេហិម (១:១៩-២២)

**៣. ការជួបគ្នារវាងនាងរស់ និងលោកបូអូសនៅក្នុងវាលស្រែ (ជំពូក ២)**

ក. ការចាប់ផ្តើមធ្វើការរបស់នាងរស់ (២:១-៧)

ខ. លោកបូអូសចាប់ផ្តើមបង្ហាញពីភាពសប្បុរសចំពោះនាងរស់ (២:៨-១៦)

គ. នាងរស់ធ្វើដំណើរត្រឡប់មកឯនាងន៉ាអូមីវិញ (២:១៧-២៣)

**៤. នាងនាអូមីបញ្ជូននាងរស់ទៅទីលានបញ្ជាន់ស្រូវរបស់បូអូស (ជំពូក៣)**

ក. នាងនាអូមីបង្គាប់នាងរស់ (៣:១-៥)

ខ. លោកបូអូសសន្យាថា នឹងធ្វើជាអ្នកលោះ (៣:៦-១៥)

គ. នាងរស់បានត្រឡប់មកឯនាងនាអូមីវិញ (៣:១៦-១៨)

**៥. លោកបូអូសបានសម្រេចសេចក្ដីសន្យា (៤:១-១២)**

ក. លោកបូអូសបានប្រឈមមុខជាមួយសាច់ញាតិដែលមិនស្គាល់ឈ្មោះ (៤:១-៨)

ខ. លោកបូអូសបានទិញកម្មសិទ្ធិនាងនាអូមី ហើយបានប្រកាសរៀបការជាមួយនាងរស់ (៤:៩-១២)

**៦. សន្និដ្ឋានរួម : នាងនាអូមីបានសម្រេចបំណង (៤:១៣-១៧)**

**៧. អវសានកថា : ជិន្នូរវង្សស្ដេចដាវីឌ (៤:១៨-២២)**

## នាងន៉ាអូមី និងនាងរស់

**១** [១]រីឯនៅក្នុងគ្រា ដែលពួកចៅហ្វាយ កំពុងកាន់កាប់ត្រួត
ត្រា [ក]នោះក៏កើតមានអំណត់អត់នៅក្នុងស្រុក[ខ] ពេលនោះ
មានបុរសម្នាក់ ជាអ្នកនៅក្រុងបេថ្លេហិម-យូដា[គ] គាត់បាន
នាំទាំងប្រពន្ធ និងកូនប្រុសទាំង២នាក់ ទៅស្នាក់នៅ[ឃ]ឯ
ស្រុកម៉ូអាប់[ង] [២]មនុស្សនោះឈ្មោះអេលីម៉ាលេច[ច]ប្រពន្ធ
ឈ្មោះន៉ាអូមី ឯកូនទាំង២ មួយឈ្មោះម៉ាឡូន ហើយ១
ឈ្មោះគីលីយ៉ូន[ឆ] សុទ្ធតែជាពួកអេប្រាតា[ជ] ដែលនៅក្រុង
បេថ្លេហិម[ឈ]-យូដា គេក៏ដល់ទៅស្រុកម៉ូអាប់ តាំងទីលំនៅ
នៅស្រុកនោះ [៣]ឯអេលីម៉ាលេច ជាប្ដីន៉ាអូមី គាត់ស្លាប់ទៅ
នៅសល់តែនាង ហើយនិងកូនទាំង២នាក់ [៤]កូនទាំង២ក៏
យកប្រពន្ធ ពីពួកក្រមុំស្រីសាសន៍ម៉ូអាប់[ញ]នោះ នាង១ឈ្មោះ
អ័រប៉ា ហើយ១ទៀតឈ្មោះនាងរស់[ដ] ម៉ាឡូន និងគីលីយ៉ូនក៏
នៅស្រុកនោះប្រហែលជា១០ឆ្នាំ [៥]រួចគេស្លាប់[ឋ]ទៅទាំង២
នាក់[ឌ] នៅសល់តែន៉ាអូមីម្នាក់ឯង ឥតទាំងកូនទាំងប្ដីផង ។
[៦]ន៉ាអូមី និងកូនប្រសា[ឍ]ទាំង២ក៏ប្រុងប្រៀប ដើម្បីនឹង
ចេញពីស្រុកម៉ូអាប់[ណ]ត្រឡប់វិលទៅវិញ ដ្បិតនៅក្នុងស្រុក
ម៉ូអាប់នោះ គាត់បានឮថា ព្រះយេហូវ៉ាទ្រង់បានយាងមក
ប្រោសប្រទានឱ្យរាស្ត្រ[ត]ទ្រង់មានអាហារ[ថ] [៧]ដូច្នេះគាត់ក៏
ចេញពីលំនៅខ្លួន នាំទាំងកូនប្រសាស្រីទាំង២ ដើរទៅតាម
ផ្លូវ ដើម្បីនឹងត្រឡប់ទៅឯស្រុកយូដាវិញ [៨]គាត់និយាយទៅ
កូនប្រសាទាំង២ថា ចូរឯងត្រឡប់ទៅឯផ្ទះម្ដាយឯងវិញ[ទ]
រៀងខ្លួនចុះ សូមឱ្យព្រះយេហូវ៉ាផ្តល់សេចក្តីសប្បុរស[ធ]ដល់
ឯង ដូចជាឯងបានប្រព្រឹត្តនឹងខ្មោចប្ដីឯង[ន] ហើយនិងអញ
ដែរ [៩]សូមឱ្យព្រះយេហូវ៉ាប្រោសមេត្តា ឱ្យឯងបានសេចក្ដី
ស្រាកស្រាន្ត[ប]នៅក្នុងផ្ទះរបស់ប្ដី១ទៀតរៀងខ្លួនចុះ រួចគាត់
ក៏ថើប[ផ]នាងទាំង២ ហើយគេឡើងសំឡេងយំទាំងអស់គ្នា[ព]
[១០]តែនាងទាំង២ប្រកែកថា ទេ យើងខ្ញុំនឹងទៅនៅក្នុង
សាសន៍របស់អ្នកម្ដាយ ជាមួយនឹងអ្នកម្ដាយដែរ [១១]នោះ
ន៉ាអូមីនាងឃាត់ថា ចូរវិលទៅវិញចុះ កូនស្រីអើយ ហេតុអ្វី
បានជាចង់តាមអញទៅធ្វើអី តើនៅមានកូនក្នុងពោះអញ

**១:១** ក ពច ២:១៦-១៨ ខ លប ១២:១០ ២ពវ ៦:២៥ ទដ ១០៥:១៦ ហក ១:១១ គ លប ៣៥:១៩ ឃ លប ៤៧:៤ ង លប ៣៦:៣៥ **១:២** ច ខ.៣ នរ ២:១ ៤:៣ ឆ ខ.៥ នរ ៤:៩ ជ លប ៣៥:១៦ ឈ លប ៣៥:១៩ ១សយ ១៦:១៨ **១:៤** ញ ១ពវ ១១:១ ២រប ២៤:២៦ អរ ៩:២ នហ ១៣:២៣ ដ ខ.១៤ នរ ៤:១៣ មថ ១:៥ **១:៥** ឋ ខ.២ ឌ ខ.៨ នរ ២:១១ **១:៦** ឍ លប ១១:៣១ ៣៨:១៦ ណ លប ៣៦:៣៥ ត លប ៥០:២៤ នក ៤:៣១ យរ ២៩:១០ សផ ២:៧ ថ ទដ ១៣២:១៥ មថ ៦:១១ **១:៨** ទ លប ៣៨:១១ ធ លប ១៩:១៩ ២ទត ១:១៦ ន ខ.៥ **១:៩** ប នរ ៣:១ ផ លប ២៧:២៧ ២៩:១១ ព លប ២៧:៣៨ ជន ៥:៦

**១:១** *រីឯនៅក្នុងគ្រា ដែលពួកចៅហ្វាយ កំពុងកាន់កាប់ត្រួតត្រា* ប្រហែលជានៅក្នុងអំឡុងឆ្នាំ ១៣៨០ ដល់ ១០៥០ មុន គ.ស (សូមមើលសេចក្តីផ្តើម ព្រះគម្ពីរ ចៅហ្វាយ : ប្រវត្តិដើម) ។ អ្នកនិពន្ធ បានបង្ហាញប្រាប់នៅក្នុងព្រះគម្ពីរ ចៅហ្វាយរួចមកហើយថា គ្រានោះពួកអ៊ីស្រាអែលគេបានបោះបង់ព្រះចោល អសីលធម៌ និងការឈ្លានពានពីអ្នកដទៃ ។ *អំណត់* មិនបាននិយាយពីអំណត់នៅក្នុងគ្រាពួកចៅហ្វាយទេ ។ *ក្រុងបេថ្លេហិម-យូដា* គឺជាស្រុកកំណើតរបស់ស្តេចដាវីឌ (១សយ ១៦:១៨) ។ បេថ្លេហិម (មានន័យថា "ផ្ទះនៃអាហារ") គឺទទេ ។

**១:២** *អេលីម៉ាលេច* ឈ្មោះនេះមានន័យថា "ព្រះនៃខ្ញុំទ្រង់ជាមហាក្សត្រ" (សូម ពច ៨:២៣) ។ *ន៉ាអូមី* មានន័យថាជាទីគាប់ចិត្ត ។ *ពួកអេប្រាតា* អេប្រាតា គឺជាឈ្មោះរបស់ភូមិភាគ១ស្ថិតក្នុងតំបន់បេថ្លេហិម (សូមមើល ៤:១១ លប ៣៥:១៩ ១៧:១២ មីក ៥:២) ។

**១:៣** *អេលីម៉ាលេច ជាប្ដីន៉ាអូមីគាត់ស្លាប់ទៅ* នៅពេលដែលប្ដីស្លាប់ទៅ នាងន៉ាអូមីចាប់ផ្តើមទទេគ្មានអ្វីសោះ (មើល ខ.២១) ។

**១:៤** *កូនទាំង២ក៏យកប្រពន្ធ* ពួកគេត្រូវតែរៀបការ ដើម្បីបន្តវង្សត្រកូលដែលជាទីសង្ឃឹមរបស់គ្រួសារ ។ *ក្រមុំស្រីសាសន៍ម៉ូអាប់* សូមមើល លប ១៩:៣៦-៣៧ ។ ការរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីសាសន៍ម៉ូអាប់ មិនត្រូវបានហាមឃាត់ឡើយ ទោះបីជាពួកគេ ឬកូនចៅគេ១០តំណរមិនអនុញ្ញាតិឱ្យចូលក្នុងពួកជំនុំនៃព្រះយេហូវ៉ាក៏ដោយ (ចទ ២៣:៣) ។ *នាងរស់* ឈ្មោះក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យថា "មិត្តភាព" ។ នាងរស់គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំង៥នៅក្នុងម៉ាថាយ ដែលនិយាយអំពីតំណរវង្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ អ្នកផ្សេងទៀតដូចជា តាម៉ារ រ៉ាហាប ហើយនិងម៉ារា (សូមមើល មថ ១:៣,៥-៦,១៦) ។ *ម៉ាឡូន* ជាប្ដីនាងរស់ (សូមមើល ៤:១០) ។ ឈ្មោះរបស់គាត់មានន័យថា "មនុស្ស ឬសត្វខ្សោយ" ។

**១:៥** *នៅសល់តែន៉ាអូមីម្នាក់ឯង* ពេលនេះក្រៅពីកូនប្រសាស្រីទាំង២របស់នាងដែលជាស្ត្រីសាសន៍ដទៃ គ្មានកូនសោះ នោះន៉ាអូមីនាងគ្មានអ្វីទៀតឡើយព្រោះប្ដី និងកូនប្រុសទាំង២របស់នាងបានស្លាប់ហើយ ។

**១:៦-២២** នៅក្នុងវគ្គ១នេះ បានសម្ដែងឱ្យឃើញពីការហិនវិនាសរបស់នាងន៉ាអូមី ។

**១:៦** *ព្រះយេហូវ៉ាទ្រង់បានយាងមកប្រោសប្រទានឱ្យរាស្ត្រទ្រង់មានអាហារ* ព្រះយេហូវ៉ាទ្រង់ គឺជាព្រះដែលគ្រប់គ្រងលើហេតុការណ៍ផ្សេងៗ (នៅក្នុងកន្លែងនេះ ខ.១៣,២១ ២:២០ ៤:១២-១៥) ។ *អាហារ* បេថ្លេហិម (ផ្ទះនៃអាហារ) ពេលនេះមានអាហារគ្រប់គ្រាន់ ។ *ប្រុងប្រៀប ដើម្បីនឹងចេញពីស្រុកម៉ូអាប់ត្រឡប់វិលទៅវិញ* ដោយសារនាងន៉ាអូមីគ្មានអ្វីសោះ នោះនាងសម្រេចចិត្តទៅកន្លែងថ្មី នៅក្នុងទឹកដីសន្យា ។

**១:៨** *ចូរឯងត្រឡប់ទៅឯផ្ទះម្ដាយឯងវិញរៀងខ្លួនចុះ* ភាពក្រៀមក្រំរបស់នាងន៉ាអូមីបានកើតឡើងដដែលៗ នៅពេលដែលនាងជម្រុញឱ្យកូនប្រសានាង ធ្វើដំណើរវិលត្រឡប់ទៅឯស្រុកកំណើតរបស់គេ នៅក្នុងស្រុកម៉ូអាប់វិញ (ទីនេះហើយ ខ.១១-១២,១៥) ដោយនាងគ្មានអ្វីឱ្យទៅកូនប្រសានាងទាំង២ឡើយ ។

**១:១១** *តើនៅមានកូន . . . ប្ដីដល់ឯងបានឬអី* នាងន៉ាអូមី បាននិយាយចំពោះក្រឹត្យវិន័យរបស់ជនជាតិអ៊ីស្រាអែល (ចទ ២៥:៥-៦) អំពីច្បាប់រៀបការជាមួយបងថ្លៃស្រី (សូមមើលការពន្យល់ លប ៣៨:៨ និងមើល ចទ ២៥:៥-១០ មក ១២:១៨-២៣) ដែលនៅក្នុងគម្ពីរទាំងនោះបានប្រាប់ឱ្យការពារស្ត្រីមេម៉ាយ ហើយត្រូវបន្តការរៀបការ ដើម្បីបន្តវង្សត្រកូល ។

ទៀត ដែលនឹងធ្វើជាប្ដីដល់ឯងបានឬអី[ភ] ១២ចូរវិលទៅវិញ
ទៅ កូនស្រីអើយ ដ្បិតអញចាស់ហួសកំណត់នឹងយកប្ដីហើយ
បើសិនជាអញនិយាយថា អញមានសង្ឃឹមហើយ បើអញ
មានប្ដីនៅយប់នេះឯង ហើយនិងបង្កើតបានកូនប្រុស ១៣នោះ
តើឯងនឹងនៅចាំទាល់តែវាធំឡើងឬអី[ម] បើយ៉ាងនោះ តើ
ឯងនឹងបង្អង់នៅឥតមានប្ដីឬអី កុំឡើយ កូនស្រីអើយ អញ
មានចិត្តព្រួយជាខ្លាំង[យ] ដោយព្រោះឯង ពីព្រោះព្រះហស្ត
នៃព្រះយេហូវ៉ា បានលូកមកទាស់នឹងអញហើយ[រ] ១៤នោះ
គេក៏ឡើងសំឡេងយំ[ល]ម្តងទៀត រួចអ័រប៉ានាងថើបលា
ម្តាយ[វ]ទៅ[ស] តែនាងរស់នៅជាប់នឹងគាត់វិញ[ហ] ១៥រួចគាត់
និយាយទៅនាងរស់ថា មើល ប្អូនថ្លៃឯង[ឡ]បានត្រឡប់ទៅ
ឯសាសន៍ ហើយនិងព្រះរបស់វាវិញហើយ[អ] ដូច្នេះចូរឱ្យ
ឯងវិលទៅតាមប្អូនថ្លៃឯងចុះ ១៦តែនាងឆ្លើយថា សូមកុំ
ទទូចឱ្យខ្ញុំទៅចោលអ្នកម្តាយ[ក] និងវិលទៅវិញ លែងតាម
អ្នកម្តាយនោះឡើយ ដ្បិតកន្លែងណាដែលអ្នកម្តាយអញ្ជើញ
ទៅ នោះ[ខ]ខ្ញុំក៏នឹងទៅតាម ហើយកន្លែងដែលអ្នកម្តាយ
ស្នាក់នៅ នោះខ្ញុំក៏នឹងនៅដែរ សាសន៍របស់អ្នកម្តាយនឹង
បានជាសាសន៍របស់ខ្ញុំ[គ] ហើយព្រះរបស់អ្នកម្តាយនឹងបាន
ជាព្រះរបស់ខ្ញុំដែរ[ឃ] ១៧អ្នកម្តាយស្លាប់នៅកន្លែងណា
នោះខ្ញុំក៏ចង់ស្លាប់នៅកន្លែងនោះដែរ ព្រមទាំងឱ្យគេកប់ខ្ញុំ
នៅទីនោះផង បើសិនជាខ្ញុំឃ្លាតចាកចេញពីអ្នកម្តាយទៅ
ដោយហេតុអ្វី ក្រៅពីសេចក្ដីស្លាប់តែមួយ[ង] នោះសូមឱ្យ
ព្រះយេហូវ៉ាប្រព្រឹត្តនឹងខ្ញុំយ៉ាងដូច្នោះចុះ ហើយលើសទៅ
ទៀតផង[ច] ១៨កាលគាត់ឃើញថា នាងផ្តាច់ចិត្តនឹងទៅតាម
ដូច្នោះហើយ នោះគាត់ក៏លែងនិយាយទៅ[ឆ]។
១៩រួចទាំង២នាក់ក៏នាំគ្នា ទៅដល់ក្រុងបេថ្លេហិម[ជ] កាល
បាន ចូលទៅក្នុងក្រុងបេថ្លេហិមហើយ នោះពួកអ្នកស្រុក
ទាំងអស់គ្នា ក៏មានសេចក្ដីរំជួល[ឈ]ពីដំណើរគាត់ ដោយ
ពាក្យថា នេះតើជាន៉ាអូមីមែនឬអី ២០គាត់ឆ្លើយថា កុំហៅ
ខ្ញុំថាន៉ាអូមីឡើយ ត្រូវហៅថាម៉ារ៉ាវិញ ដ្បិតព្រះដ៏មាន
គ្រប់ទាំងព្រះចេស្តា[ញ] ទ្រង់បានប្រព្រឹត្តនឹងខ្ញុំដោយជូរល្វីង
ណាស់[ដ] ២១ខ្ញុំបានចេញទៅទាំងពោរពេញ តែព្រះយេហូវ៉ា
បាននាំខ្ញុំឱ្យត្រឡប់វិលមកដោយទទេវិញ[ឋ] ចុះហេតុអ្វីបាន
ជាអ្នករាល់គ្នាហៅឈ្មោះខ្ញុំថា ន៉ាអូមី ជាអ្នកដែលព្រះ
យេហូវ៉ាបានធ្វើបន្ទាល់ទាស់[ឌ]នឹងខ្ញុំ ហើយព្រះដ៏មានគ្រប់
ទាំងព្រះចេស្តាបានធ្វើទុក្ខខ្ញុំដូច្នេះ ២២គឺយ៉ាងនោះហើយ
ដែលន៉ាអូមីបានវិលពីស្រុកម៉ូអាប់មកវិញ[ឍ] មានទាំងនាង
រស់ជាសាសន៍ម៉ូអាប់ កូនប្រសាខ្លួន[ណ] មកជាមួយផងគេមក
ដល់ក្រុងបេថ្លេហិម នៅដើមរដូវចំរូត[ត]ស្រូវឱក[ថ]។

**១:១១** ភ លប ៣៨:១១ ចទ ២៥:៥ **១:១៣** ម លប ៣៨:១១ យ ខ.២០ នក ១:១៤ ១៥:២៣ ១សយ ៣០:៦ រ ពច ២:១៥ យប ៤:៥ **១:១៤** ល ខ.៩ វ នរ ២:១១ ៣:១ មីក ៧:៦ ស លប ៣១:២៨ ហ ចទ ១០:២០ **១:១៥** ឡ ចទ ២៥:៧ អ យស ២៤:១៤ **១:១៦** ក ២ពវ ២:២ ខ លប ២៤:៥៨ គ ទដ ៤៥:១០ ឃ យស ២៤:១៥ **១:១៧** ង ១សយ ៣:១៧ ១៤:៤៤ ២០:១៣ ២៥:២២ ២សយ ៣:៩,៣៥ ២សយ ១៩:១៣ ១ពវ ២:២៣ ១៩:២ ២០:១០ ២ពវ ៦:៣១ ច ២សយ ១៥:២១

**១:១៨** ឆ កច ២១:១៤ **១:១៩** ជ ពច ១៧:៧ ឈ មថ ២១:១០ **១:២០** ញ លប ១៥:១ ១៧:១ ទដ ៩១:១ ដ ខ.១៣ **១:២១** ឋ យប ១:២១ ឌ យប ៣០:១១ ទដ ៨៨:៧ អស ៥៣:៤ **១:២២** ឍ នរ ២:២,៦,២១ ៤:៥,១០ ណ លប ១១:៣១ ត នក ៩:៣១ លវ ១៩:៩ ថ ២សយ ២១:៩

**១:១២** *ដ្បិតអញចាស់ហួសកំណត់* ន៉ាអូមីនាងគ្មានសមត្ថភាពបង្កើតកូនទៀតទេ ហើយសូម្បីតែផ្ទៃនាងក៏ទទេដែរ ។

**១:១៣** *ព្រះហស្តនៃព្រះយេហូវ៉ា . . . ទាស់នឹងអញហើយ* សូមមើលការពន្យល់ ខ.៥–៦ និងមើល ខ.២០–២១ ។

**១:១៤** ការចាកចេញរបស់អ័រប៉ា គឺចាកចេញទាំងស្មោះត្រង់ និងអាល័យដូចជានាងរស់ធ្វើចំពោះម្តាយក្មេករបស់នាងដែរ ។

**១:១៥** *ព្រះរបស់វា* គឺជាចៅហ្វាយលើអស់ទាំងព្រះរបស់សាសន៍ម៉ូអាប់ ដែលមានឈ្មោះថាកេម៉ូស ។

**១:១៦** ខនេះគឺការពិពណ៌នាអំពីភាពស្មោះត្រង់ និងក្តីស្រឡាញ់បានបង្ហាញពីអត្តចរិតដ៏ពិតរបស់នាងរស់ ។ សេចក្តីសន្យា និងការប្តេជ្ញា ចិត្តរបស់នាងគឺបានក្លាយជាការពិត ទោះបីជាមិនសង្ឃឹមថា និងបានអ្វីក្រៅពីរស់នៅជាមួយនាងន៉ាអូមី ជាម្តាយក្មេកនាងក៏ដោយ ។ សម្រាប់សម្តីប្រហាក់ប្រហែលគ្នានេះ សូមមើល ២សយ ១៥:២១ ។

**១:១៧** *សូមឱ្យព្រះយេហូវ៉ាប្រព្រឹត្តនឹងខ្ញុំយ៉ាងដូច្នោះចុះ ហើយលើសទៅទៀតផង* សូមមើលការពន្យល់ ១សយ ៣:១៧ ។ នាងរស់ មិនមែនជាសាសន៍អ៊ីស្រាអែលទេ ប៉ុន្តែ នាងបានស្បថជាមួយម្តាយក្មេកដោយនូវព្រះនាមព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ហើយទទួលស្គាល់ថាព្រះយេហូវ៉ាជាព្រះនៃនាង (សូមមើល ខ.១៦) ។

**១:២០** *ន៉ាអូមី . . . ម៉ារ៉ាវិញ* សូមមើលអត្ថបទគម្ពីរ ។ នៅក្នុងតំបន់មជ្ឈឹមបូព៌ាសម័យបុរាណ ឈ្មោះរបស់មនុស្សម្នាក់ៗ ជានិច្ចកាលគឺមានអត្ថន័យណាស់ ។ ជម្រើសរបស់នាងន៉ាអូមី ក្នុងការប្តូរឈ្មោះ និងការពន្យល់របស់នាង គឺបានបង្ហាញពីការពិបាកចិត្តនិងទុក្ខក្រៀមក្រំ ទោះបីជាព្រះយេហូវ៉ា ទ្រង់ទាស់ប្រឆាំងក៏ដោយ ។ *គ្រប់ទាំងព្រះចេស្តា* សូមមើលការពន្យល់ លប ១៧:១ ។

**១:២១** *ពោរពេញ . . . ទទេវិញ* ពាក្យទាំងនោះមានសារៈសំខាន់ណាស់ព្រោះវាជាចំណុចស្នូលនៅក្នុងផ្ទៃរឿងទាំងមូលនៃព្រះគម្ពីរ ដែលបានប្រាប់យើងអំពីរបៀបនៃភាពទទេរបស់នាងន៉ាអូមី បានពោរពេញឡើងវិញដោយរបៀបណា ។

**១:២២** *នាងរស់ ជាសាសន៍ម៉ូអាប់* ពីរ ឬបីដង អ្នកនិពន្ធតែងតែនិយាយអំពីនាងរស់ដែលជាស្ត្រីសាសន៍ដទៃ (២:២,៦,២១ ៤:៥,១០ មើល ២:១០) ។ *រដូវចំរូត* ចម្រូតស្រូវឱកនៅស្រុកកាណានសម័យបុរាណ គឺក្នុងអំឡុងពេលខែមេសានិងខែឧសភា (ស្រូវឱកច្រូតមុនស្រូវសាលី២ឬ៣សប្តាហ៍ មើល ២:២៣) ។ តំណាក់កាលនៃការច្រូតស្រូវនេះមាន: (១).គេច្រូតស្រូវដែលទុំ ហើយនៅឈរត្រង់ដោយប្រើកណ្តៀវដៃ (ចទ ១៦:៩ ២៣:២៥ យរ ៥០:១៦ យអ ៣:១៣) ហើយជានិច្ចកាល គឺពួកប្រុសៗជាអ្នកច្រូត ។ (២).ត្រូវប្រមូលស្រូវដែលច្រូតបាននោះមកចងជាកណ្តាប់ ដែលភារៈកិច្ចចងកណ្តាប់នេះ គឺជាតួនាទីរបស់ពួកស្ត្រីៗ ។ (៣).រើសកួរស្រូវ ឧទាហរណ៍ប្រមូលកួរស្រូវដែលជ្រុះនៅពីក្រោយ (២:៧) ។ (៤).ដឹកកណ្តាប់មកទី

## នាងរស់ជួបលោកបូអូស

**២** ១ឯន៉ាអូមី គាត់មានសាច់ញាតិ[ក]ខាងប្ដីម្នាក់ ឈ្មោះ
បូអូស[ខ] ជាអ្នកមានស្តុកស្តម្ភ[គ]នៅក្នុងគ្រួសារ អេលីម៉ាលេច[ឃ]
២គ្រានោះ នាងរស់ ជាសាសន៍ម៉ូអាប់[ង] នាងនិយាយនឹង
ន៉ាអូមីថា ឥឡូវនេះ សូមបើកឱ្យខ្ញុំទៅឯស្រែ ដើម្បីនឹងរើស
សន្សំស្រូវ[ច] តាមអ្នកណាដែលអាណិតមេត្តាដល់ខ្ញុំ[ឆ] រួចគាត់
ប្រាប់ថា ទៅចុះ កូនអើយ ៣នាងក៏ទៅរើសសន្សំក្នុងស្រែ
តាមពួកអ្នកច្រូត[ជ] ហើយគាប់ជួនជានាងទៅក្នុងស្រែ១របស់
បូអូស ដែលជាសាច់ញាតិនឹងអេលីម៉ាលេច[ឈ] ៤ឯបូអូស
គាត់ចេញពីបេថ្លេហិម មកនិយាយនឹងពួកអ្នកចំរូតថា សូម
ព្រះយេហូវ៉ាគង់ជាមួយនឹងអ្នករាល់គ្នា[ញ] គេឆ្លើយឡើងថា
សូមព្រះយេហូវ៉ាប្រទានពរដល់លោក[ដ] ៥រួចបូអូសសួ
ទៅអ្នកបំរើ ដែលគាត់តាំងឱ្យត្រួតត្រាលើពួកចំរូតនោះថា
នាងនេះជាកូនអ្នកណា ៦អ្នកបំរើនោះឆ្លើយថា នោះគឺជា
ស្ត្រីសាសន៍ម៉ូអាប់[ឋ] ដែលមកពីស្រុកម៉ូអាប់ ជាមួយនឹង
ន៉ាអូមី ៧នាងក៏សូមដល់យើងខ្ញុំថា សូមឱ្យខ្ញុំរើសសន្សំ[ឌ]តាម
ពួកអ្នកចំរូតផង ដូច្នេះនាងបានមក ហើយបាននៅតាំងតែ
ពីព្រលឹមរហូតដល់ពេលនេះ លើកតែកាលនាងសំរាក
នៅផ្ទះ១ភ្លែត[ឍ]ប៉ុណ្ណោះ ។
៨ដូច្នេះបូអូសប្រាប់នាងរស់ថា ចូរស្តាប់ខ្ញុំ នាងអើយ
កុំឱ្យនាងចេញពីស្រែនេះ ទៅរើសសន្សំក្នុងស្រែឯណាទៀត
ឡើយ ចូរនៅតែក្នុងទីនេះជិតពួកស្រីៗរបស់ខ្ញុំនេះហើយ
៩ចូរឱ្យភ្នែកនាងមើលតែស្រែ ដែលពួកនេះកំពុងច្រូត
ហើយដើរតាមគេចុះ ខ្ញុំបានហាមដល់ពួកកំឡោះ មិនឱ្យគេ
ពាល់នាងទេ បើកាលណានាងស្រេកទឹក ឱ្យទៅឯក្អម ផឹក
ទឹកដែលពួកកំឡោះបានដងហើយចុះ ១០នោះនាងក៏ទំលាក់
ខ្លួនក្រាបចុះផ្កាប់មុខនឹងដី[ណ] ដោយពាក្យថា ហេតុអ្វីបានជា
លោកប្រោសមេត្តា ដោយអាណិតដល់ខ្ញុំ[ត]ជាសាសន៍ដទៃ[ថ]
ដូច្នេះ ១១បូអូសឆ្លើយទៅនាងថា គេបានប្រាប់ដល់ខ្ញុំ ពីគ្រប់
ទាំងកិរិយា ដែលនាងបានប្រព្រឹត្តនឹងម្តាយក្មេក[ទ] តាំងពីប្តី
នាងស្លាប់ចោលទៅ[ធ] ហើយពីនាងបានលះចោលឪពុក
ម្តាយ និងស្រុកកំណើតរបស់នាង មកឯសាសន៍នេះ ដែល

**២:១** ក នរ ៣:២ សភ ៧:៤ ខ នរ ១:២ គ ១សយ ៩:១ ១ពវ ១១:២៨ ឃ នរ ៤:២១ ១រប ២:១២ មថ ១:៥ លក ៣:៣២
**២:២** ង នរ ១:២២ ច លវ ១៩:៩ ២៣:២២ ឆ លប ៦:៨ ១៨:៣
**២:៣** ជ ខ.១៤ ២ពវ ៤:១៨ យរ ៩:២២ អម ៩:១៣ ឈ ខ.១
**២:៤** ញ ពច ៦:១២ លក ១:២៨ ២ថន ៣:១៦ ដ លប ២៨:៣ ជន ៦:២៤
**២:៦** ឋ នរ ១:២២
**២:៧** ឌ លប ៣៧:៧ លវ ១៩:៩ ឍ ២សយ ៤:៥
**២:១០** ណ លប ១៩:១ ១សយ ២០:៤១ ត ខ.១៩ ទដ ៤១:១ ថ លប ៣១:១៥ ចទ ១៥:៣ **២:១១** ទ នរ ១:១៤ ធ នរ ១:៥

លានចម្រូត ជានិច្ចកាលគេប្រើដោយសត្វលា ហើយពេលខ្លះទៀតដោយរទេះ (អម ២:១៣) ។ (៥).គេត្រូវបញ្ជាន់ ឬបែនស្រូវនោះ ដោយប្រើគោ (ចទ ២៥:៤ ហស ១០:១១) ប៉ុន្តែមានពេលខ្លះទៀតគេបញ្ជាន់ដោយប្រដាប់មានធ្មេញ (អស ៤១:១៥ អម ១:៣) ឬមួយទៀតគេបញ្ជាន់ដោយកង់រទេះ (អស ២៨:២៨) ។ (៦).គេត្រូវអុំស្រូវដោយប្រើចង្អេរបន្ទាប់ពីបញ្ជាន់ហើយ (យរ ១៥:៧) ដើម្បីឱ្យខ្យល់ដែលបក់មកនាពេលរសៀលដែលមានរយៈពេលប្រមាណជា ២ ឬ ៣ ម៉ោងនោះ បានបក់យកអង្កាមចេញ (ទដ ១:៤) ។ (៧).រែងនៅក្នុងកញ្ច្រែង (អម ៩:៩) ដើម្បីប្រមូលសំណល់ផ្សេងៗ ។ (៨).ត្រូវប្រមូលគ្រាប់ស្រូវនោះយកមកផ្ទះ ដើម្បីរក្សាទុក (លប ៤២–៤៤) ។ ទាំងការបញ្ជាន់នៅទីលាន និងការអុំគឺមានការពិបាកណាស់ ត្រូវការកន្លែងដែលរលីង ហើយទូលាយគ្មានថ្មឬដីឥដ្ឋឡើយ ហើយត្រូវមានការប្រុងប្រយ័ត្នចំពោះទីកន្លែង ដោយឱ្យមានពន្លឺគ្រប់គ្រាន់ ហើយមានខ្យល់ចេញចូលគ្រប់គ្រាន់ ។ *ដើមរដូវ* នាងន៉ាអូមីនិងនាងរស់មកបេថ្លេហិម ដើម្បីឱ្យនាងបានពោរពេញឡើងវិញ នៅមុននេះនាងធ្លាប់ពោរពេញម្តងមកហើយ ។ ទាក់ទងទៅនឹងចម្រូតស្រូវឱកនេះ គឺជាការរៀបចំមួយ ដើម្បីឱ្យអ្នកអានបានដឹងទិដ្ឋភាពនៃទីលានចម្រូតនាពេលក្រោយទៀត (សូមមើលសេចក្តីផ្តើមៈត្រង់លក្ខណៈអក្សរសាស្ត្រ) ។

**២:១–២៣** គឺជាវគ្គទី២ ដែលបានសម្តែងថា តើនាងរស់ និងលោកបូអូសបានធ្វើអ្វីដើម្បីផ្តល់ឱ្យនាងន៉ាអូមីមានសង្ឃឹមឡើងវិញ ។

**២:១** *សាច់ញាតិ* គឺជាទីសម្គាល់នៃសេចក្តីសង្ឃឹមសម្រាប់នាងន៉ាអូមី (សូមមើលការពន្យល់ ខ.២០) ។ *បូអូស* ឈ្មោះរបស់គាត់ប្រហែលជាមានន័យថា "នៅក្នុងទ្រង់ គឺជាកម្លាំង" ។ លោកបូអូសក៏ជាតំណវង្សរបស់ព្រះយេស៊ូវគ្រីស្ទផងដែរ (មថ ១:៥ លក ៣:៣២) ។

**២:២** *សូមបើកឱ្យខ្ញុំទៅឯស្រែ* ទោះបីនាងរស់ជាស្ត្រីសាសន៍ដទៃ ហើយនៅក្មេងក៏ដោយ តែនាងបានស្ម័គ្រចិត្តទៅវាលស្រែដើម្បីច្រូត ដោយព្រោះនាងចង់មានទំនួលខុសត្រូវក្នុងការចិញ្ចឹមម្តាយក្មេករបស់នាង ។ នៅក្នុង ៣:១ នាងន៉ាអូមី មានតួនាទីជាអ្នកចិញ្ចឹមបីបាច់នាងរស់វិញ ។ *រើសសន្សំស្រូវ* នៅក្នុងច្បាប់លោកម៉ូសេ បានណែនាំដល់ម្ចាស់ដីទាំងឡាយ ឱ្យទុកកួរស្រូវខ្លះ ដែលជ្រុះដើម្បីឱ្យពួកអ្នកក្រសាសន៍ដទៃ ស្ត្រីមេម៉ាយ និងពួកក្មេងកំព្រាបានរើស តាមសេចក្តីត្រូវការរបស់ពួកគេ (មើល លវ ១៩:៩ ២៣:២២ ចទ ២៤:១៩) ។

**២:៣** *គាប់ជួន* គឺជាផែនការរបស់ព្រះអម្ចាស់ ដែលបណ្តាលឱ្យនាងទៅរើសកួរស្រូវក្នុងស្រែ (ខ.១៩–២០) ។

**២:៤** ការផ្លាស់ប្តូរនូវពាក្យជូនពរជាមួយគ្នារវាងលោកបូអូស និងអ្នកចម្រូតរបស់គាត់ នោះគឺបញ្ជាក់ថា លោកបូអូសគឺជាមនុស្សម្នាក់ដែលស្រឡាញ់ព្រះអម្ចាស់ ហើយពេញដោយព្រះវិញ្ញាណនៃព្រះ ។

**២:៩** *ហើយដើរតាមគេចុះ* តាមទម្លាប់ពួកបុរសទាំងឡាយជាអ្នកច្រូតដើមស្រូវ ហើយស្ត្រីជាអ្នកដើរតាមពីក្រោយដើម្បីចងជាកណ្តាប់ ។ ដូច្នេះនាងរស់អាចរើសយកសំណល់ ដែលគេជ្រុះនៅពីក្រោយ (សូមមើលការពន្យល់ ១:២២) ។ *មិនឱ្យគេពាល់នាងទេ* ពាក្យនេះបានចេញពីមាត់របស់លោកបូអូសដោយផ្ទាល់ ដែលជាការបញ្ជាក់ថា លោកបូអូសនឹងលើកនាងរស់ឡើង ព្រមទាំងថែរក្សា និងផ្គត់ផ្គង់ដល់នាង ។

**២:១១** *ពីគ្រប់ទាំងកិរិយា ដែលនាងបានប្រព្រឹត្តនឹងម្តាយក្មេក* នៅក្នុងការប្តេជ្ញាចិត្តរបស់នាងរស់ ហើយនាងបានសន្យាថា នាងនឹងថែរក្សាម្តាយក្មេកដ៏កំសត់របស់នាងនៅក្នុងផ្ទៃរឿងនេះ គឺជារឿងស្នូលនៅក្នុងព្រះគម្ពីរទាំងមូល ។

មិនបានស្គាល់[ន]កាលពីដើមផង[ប] ១២សូមព្រះយេហូវ៉ាប្រទាន
រង្វាន់ដល់នាង ហើយឱ្យនាងបានទទួលបំណាច់ដ៏ពោរ
ពេញ ពីព្រះយេហូវ៉ា[ផ] ជាព្រះនៃសាសន៍អ៊ីស្រាអែល[ព]
ដែលនាងបានមកជ្រកក្រោមស្លាប[ភ]ទ្រង់ចុះ[ម] ១៣រួចនាង
និយាយថា ឱលោកម្ចាស់ខ្ញុំអើយ សូមលោកមេត្តាប្រោស
ដល់ខ្ញុំផង[យ] ទោះបើខ្ញុំមិនមែនដូចជាពួកស្រីបំរើរបស់
លោកណាមួយក៏ដោយ គង់តែលោកបានកំសាន្តចិត្តខ្ញុំ
ហើយ ព្រមទាំងនិយាយនឹងខ្ញុំជាអ្នកបំរើលោក ដោយ
សប្បុរសដែរ ។
១៤លុះដល់ពេលបាយ បូអូសប្រាប់នាងថា អញ្ជើញមក
ហូប[រ] ហើយជ្រលក់អាហារទៅក្នុងទឹកខ្មេះចុះ នាងក៏អង្គុយ
នៅខាងពួកអ្នកចំរូត[ល] ឯគេក៏ហុចលាជ[វ]មកឱ្យនាងដែរ
ហើយនាងបានបរិភោគទាល់តែឆ្អែត ក៏យកខ្លះទុកដែរ[ស]
១៥កាលនាងបានក្រោកឡើងទៅរើសទៀត នោះបូអូស
ប្រាប់ដល់ពួកកំឡោះរបស់គាត់ថា ចូរបើកឱ្យនាងរើស
យកក្នុងគំនរកណ្តាប់ស្រូវផងចុះ[ហ] កុំឱ្យបន្ទោសនាងឡើយ
១៦ហើយហូតគួរខ្លះពីកណ្តាប់ចេញ ទុកឱ្យនាងរើស កុំឱ្យស្តី
ថា[ឡ]ដល់នាងឡើយ ។
១៧ដូច្នេះ នាងក៏រើសសន្សំនៅក្នុងស្រែនោះ រហូតដល់
ល្ងាច រួចនាងបែន[អ]ស្រូវដែលបានរើសនោះ បានស្រូវឱក
ប្រហែលជា១ថាំង[ក] ១៨នាងលើកទូលនាំយកទៅឯទីក្រុង ឯ
ម្តាយក្មេកក៏ឃើញស្រូវដែលនាងរើសយកមកនោះ រួច
នាងបញ្ចេញម្ហូប ដែលសល់[ខ]ពីនាងចំអែត ជូនដល់ម្តាយ
ក្មេក ១៩គាត់ក៏សួរនាងថា នៅថ្ងៃនេះ ឯងបានរើសសន្សំ
នៅទីណា តើឯងបានធ្វើការនៅកន្លែងណា សូមពរដល់
អ្នកណានោះ ដែលបានអាណិតមេត្តាដល់ឯង[គ] ដូច្នេះនាងក៏
រៀបរាប់ប្រាប់ម្តាយក្មេក ពីដំណើរដែលនាងបានធ្វើនៅទី
ណានោះ ដោយពាក្យថា មនុស្សនោះដែលខ្ញុំបានទៅធ្វើ
ការជាមួយនៅថ្ងៃនេះ លោកឈ្មោះ បូអូស ២០នោះគាត់
និយាយទៅកូនប្រសា[ឃ]ថា សូមឱ្យលោកបានពរពីព្រះ
យេហូវ៉ាចុះ[ង] ដោយព្រោះលោកមិនខាននឹងប្រព្រឹត្តដោយ
សប្បុរស[ច] ដល់ទាំងមនុស្សរស់និងមនុស្សស្លាប់ផង រួច
ន៉ាអូមីនិយាយថា លោកនោះជាសាច់ញាតិជិតដិតនឹងយើង
ហើយ[ឆ] លោកជាអ្នក១ដែលមានច្បាប់នឹងលោះឱ្យយើង
បាន[ជ] ២១នាងរស់ជាសាសន៍ម៉ូអាប់[ឈ]នោះ ក៏ឆ្លើយឡើងថា
ចាស លោកមានប្រសាសន៍នឹងខ្ញុំដែរថា ត្រូវឱ្យនាងនៅ
ជាប់តែនឹងពួកកំឡោះរបស់ខ្ញុំនេះ ដរាបដល់ច្រូតចំរូតទាំង
ប៉ុន្មានរបស់ខ្ញុំហើយ ២២នោះន៉ាអូមីនិយាយទៅនាងរស់
ជាកូនប្រសាថា កូនអើយ បើឯងចេញទៅជាមួយនឹងពួកស្រី
របស់លោក មិនឱ្យមានអ្នកណាជួបនឹងឯងនៅស្រែឯទៀត
នោះស្រួលហើយ ២៣ដូច្នេះនាងក៏នៅជាប់ជាមួយនឹងពួក
ស្រីរបស់បូអូសនោះ ទាំងខំរើសសន្សំទាល់តែចំរូតនៃស្រូវ
ឱក[ញ] និងស្រូវភោជ្ជសាលី[ដ] បានហើយ នាងក៏នៅជាមួយ
នឹងម្តាយក្មេក ។

**២:១១** ន អស ៥៥:៥ ប នរ ១:១៦–១៧
**២:១២** ផ ១សយ ២៤:១៩ ២៦:២៣,២៥ ទដ ១៨:២០ សភ ២៥:២២ យរ ៣១:១៦ ព យស ២៤:១៥ ភ ទដ ១៧:៨ ៣៦:៧ ៥៧:១ ៦១:៤ ៦៣:៧ ៩១:៤ ម ទដ ៧១:១
**២:១៣** យ លប ១៨:៣
**២:១៤** រ លប ៣:១៩ ល ខ.៣ វ លវ ២៣:១៤ ស ខ.១៨
**២:១៥** ហ លប ៣៧:៧ លវ ១៩:៩
**២:១៦** ឡ លប ៣៧:១០
**២:១៧** អ ពច ៦:១១ ក លវ ១៩:៣៦
**២:១៨** ខ ខ.១៤
**២:១៩** គ ខ.១០
**២:២០** ឃ លប ១១:៣១ ង ពច ១៧:២ ១សយ ២៣:២១ ច លប ១៩:១៩ ឆ លវ ២៥:២៥ ជ នរ ៣:៩,១២ ៤:១,១៤ **២:២១** ឈ នរ ១:២២ **២:២៣** ញ នក ៩:៣១ ដ លប ៣០:១៤ ១សយ ៦:១៣

**២:១២** *ជ្រកក្រោមស្លាបទ្រង់* គឺជារូបភាព១ ដែលបណ្តាហ្វូងបក្សីបានការពារកូនរបស់គេ ដោយស្លាប (សូមមើល មថ ២៣:៣៧ និងការពន្យល់ នរ ៣:៩) ។
**២:១៣** *ជាអ្នកបំរើលោក* គឺជាពាក្យគួរសមមួយដែលសំដៅលើខ្លួននាងផ្ទាល់ ប្រៀបដូចជាអ្នកបម្រើ ។
**២:១៥** *ប្រាប់ដល់ពួកកំឡោះរបស់គាត់* លោកបូអូសបានចេញទៅឆ្ងាយ ដូច្នេះ ពាក្យបណ្តាំរបស់គាត់ត្រូវតែជាការពិត ដែលថា ការងាររបស់នាងរស់ និងធ្វើឱ្យនាងមានភាពបរិបូរណ៍ (មើល ៣:១៥) ។
**២:១៧** *បែន* សូមមើលការពន្យល់ ១:២២ ។ នៅក្នុងដំណើររឿងរបស់នាងរស់ គឺដូចគ្នាជាមួយនឹងដំណើររឿងរបស់លោកគេឌានដែរ (មើល ពច ៦:១១) ស្រូវដែលគេមាននេះតិចទេ ដែលគេអាចយកវាមកបែនដោយដៃ ដោយវាយជាមួយនឹងដំបង ឬព្រនង់ ។ *១ថាំង* សូមមើលអត្ថបទគម្ពីរ ។ នាងអាចរើសគួរស្រូវបាន១ថាំងក្នុងមួយថ្ងៃ ដែលចំនួននោះជាចំនួនច្រើនខុស ប្លែកពីធម្មតា ។
**២:២០** *លោកមិនខាននឹងប្រព្រឹត្តដោយសប្បុរស* នៅក្នុង ៣:១០ បាននិយាយថា លោកបូអូសបានឱ្យតម្លៃនាងរស់ដូចគ្នានឹងពេលនេះដែរ ។ *លោកនោះជាសាច់ញាតិ . . . លោះឱ្យយើងបាន* ការប្រោសលោះ គឺជាគំនិតស្នូលនៅក្នុងព្រះគម្ពីរនាងរស់ទាំងមូល (មើលសេចក្តីផ្តើម: ផ្ទៃរឿងនិងវិទ្យាសិក្សាអំពីព្រះ) ។ សាច់ញាតិដែលនឹងលោះ គឺជាអ្នកដែលមានទំនួលខុសត្រូវ និងថែរក្សាចំពោះសេចក្តីត្រូវការ នៃសមាជិកគ្រួសាររបស់ខ្លួនដូចជាផ្តល់កេរ្តិ៍មតក ដល់បងប្អូនដែលបានស្លាប់ (ចទ ២៥:៥–១០) លោះយកដីដែលក្រុមគ្រួសារបានលក់ឱ្យអ្នកប្រទេសក្រៅ (លវ ២៥:២៥–២៨) លោះសាច់ញាតិដែលបានលក់ឱ្យទៅអ្នកធ្វើជាអ្នកបម្រើ (លវ ២៥:៤៧–៤៩) ហើយសងសឹកចំពោះអ្នកណាដែលសម្លាប់សាច់ញាតិរបស់ខ្លួន (មើល ជន ៣៥:១៩–២១) ។ "អ្នកសងសឹក" ហើយ "សាច់ញាតិដែលលោះ" គឺបកប្រែតែមួយ ។ នៅពេលដែលនាងន៉ាអូមីបានដឹងពីហេតុការណ៍ ដែលបានកើតឡើងពេលថ្ងៃ នាងមានអំណរនិងក្លាហានណាស់ ដោយព្រោះពេលនេះនាងមានសង្ឃឹមឡើងវិញ ហើយសេចក្តីសង្ឃឹមនេះ បានចង្អុលបង្ហាញពីផ្ទៃរឿងទាំងមូល (មើលសេចក្តីផ្តើម: លក្ខណៈអក្សរសាស្ត្រ) ។
**២:២៣** *ទាល់តែចំរូតនៃស្រូវឱក និងស្រូវភោជ្ជសាលី បានហើយ* នៅក្នុងឃ្លានេះ គឺបានបង្ហាញឱ្យយើងបានដឹងអំពីទីលានៃចម្រូត ហើយនិងទិដ្ឋភាពនៃចម្រូតលើកក្រោយទៀត (មើលសេចក្តីផ្តើម: លក្ខណៈអក្សរសាស្ត្រ) ។

## នាងរស់និងលោកបូអូសនៅទីលានបោកស្រូវ

**៣** ១គ្រានោះនាអូមី ជាម្ដាយក្មេក[ក] និយាយទៅនាងថា កូន
អើយ គួរឱ្យអញរកទីសំរាក[ខ]ឱ្យឯងដែរ ដើម្បីឱ្យឯងបាន
ស្រួលវិញ ២ឯបូអូស ដែលឯងបាននៅជាមួយនឹងពួកស្រី
របស់លោក នោះជាសាច់ញាតិ[គ]នឹងយើងហើយ មើល នៅ
យប់នេះឯង លោកនឹងរោយស្រូវឱកនៅទីលាន[ឃ] ៣ដូច្នេះ
ចូរឯងងូតទឹក[ង] រួចលាបគ្រឿងក្រអូប[ច] ហើយតែងខ្លួន[ឆ]
ចូលទៅឯទីលាននោះចុះ តែកុំឱ្យលោកស្គាល់ឯងឡើយ
ដរាបដល់លោកបានស៊ីផឹកហើយ[ជ] ៤លុះដល់កាលណា
លោកសំរាន្ត នោះត្រូវឱ្យឯងកំណត់ចំណាំកន្លែងរបស់
លោក រួចចូលទៅបើកភួយ ពីខាងចុងជើងលោកចូលដេក
ទៅ នោះលោកនឹងប្រាប់ឱ្យឯងដឹងពីការដែលត្រូវធ្វើដូច
ម្ដេច ៥នាងក៏ជំរាបគាត់ថា ខ្ញុំនឹងធ្វើតាមគ្រប់ទាំងសេចក្ដី
ដែលអ្នកម្ដាយមានប្រសាសន៍មកនោះ[ឈ] ។
៦នាងក៏ចុះទៅឯទីលាន[ញ] ធ្វើតាមគ្រប់ទាំងសេចក្ដីដែល
ម្ដាយក្មេកបានបង្គាប់មក ៧កាលបូអូសបានស៊ីផឹកមានចិត្ត
រីករាយឡើង[ដ] នោះលោកក៏ទៅដេកនៅចុងគំនរកណ្ដាប់
ស្រូវ[ឋ] រួចនាងលបចូលទៅ បើកភួយពីខាងចុងជើងលោក
ដេកទៅ ៨លុះដល់ពេលកណ្ដាលអធ្រាត្រ នោះលោកក៏នឹក
ខ្លាច ហើយភ្ញាក់ប្រែខ្លួនមក ឃើញមានស្ត្រីម្នាក់ ដេកនៅ
ត្រង់ចុងជើងរបស់ខ្លួន ៩លោកសួរថា អ្នកណានេះ នាង
ឆ្លើយថា ខ្ញុំឈ្មោះរស់ ជាបាវស្រីរបស់លោក សូម
បណ្ដោយភួយ[ឌ]លោកមកដណ្ដប់ឱ្យបាវស្រីផង ដ្បិតលោក
ជាអ្នកមានច្បាប់នឹងលោះបាន[ឍ] ១០លោកតបថា នាងអើយ
សូមឱ្យនាងបានប្រកបដោយពរនៃព្រះយេហូវ៉ាចុះ[ណ] នាង
បានសំដែងទឹកចិត្តដ៏សប្បុរស នៅជាន់ក្រោយនេះ វិសេស
ជាងមុនណាស់[ត] ដោយនាងមិនបានទៅតាមកំលោះៗ ទោះ
ក្របូមានផង ១១ឥឡូវនេះ នាងអើយ កុំឱ្យខ្លាចឡើយ ខ្ញុំនឹង
ធ្វើសំរេចឱ្យនាង តាមគ្រប់ទាំងសេចក្ដីដែលនាងនិយាយ
នេះ ដ្បិតមនុស្សទាំងអស់នៅទីក្រុងខ្ញុំនេះដឹងហើយថា នាង
ជាស្ត្រីល្អត្រឹមត្រូវណាស់[ថ] ១២ឯខ្ញុំៗមានច្បាប់នឹងលោះមែន[ទ]
ប៉ុន្តែមានម្នាក់ទៀត ដែលជាសាច់ញាតិជិតជាង[ធ]ខ្ញុំទៅទៀត
១៣ដូច្នេះ ចូរបង្អង់នៅយប់នេះសិន ចាំដល់ព្រឹកឡើង បើគេ
ចង់សំរេចនឹងនាង[ន] តាមច្បាប់ជាសាច់ញាតិជិតដិតគ្នា
នោះចូរឱ្យគេសំរេចចុះ តែបើអ្នកនោះមិនព្រមទេ នោះខ្ញុំ

**៣:១** ក នរ ១:១៤ ខ នរ ១:៩ **៣:២** គ នរ ២:១ ឃ លវ ២:១៤ ជន ១៨:២៧ ពច ៦:១១ **៣:៣** ង ២សយ ១២:២០ ២ពវ ៥:១០ ទដ ២៦:៦ ៥១:២ អស ១:១៦ យរ ៤:១៤ អគ ១៦:៩ ច ២សយ ១៤:២ អស ៦១:៣ ឆ លប ៤១:១៤ ជ នក ៣២:៦ សស ២:៣ យរ ១៥:១៧ **៣:៥** ឈ អភ ៦:១ កល ៣:២០ **៣:៦** ញ ជន ១៨:២៧ **៣:៧** ដ ពច ១៩:៦,៩,២២ ១សយ ២៥:៣៦ ២សយ ១៣:២៨ ១ពវ ១:៧ នអ ១:១០ ឋ ២របា ៣១:៦ ៧:២ ៥០:២៦ ហក ២:១៦ **៣:៩** ឌ អគ ១៦:៨ ឍ នរ ២:២០ **៣:១០** ណ ពច ១៧:២ ត យស ២:១២ **៣:១១** ថ សភ ១២:៤ ១៤:១ ៣១:១០ **៣:១២** ទ នរ ២:២០ ធ នរ ៤:១ **៣:១៣** ន ចទ ២៥:៥ នរ ៤:៥ មថ ២២:២៤

**៣:១–១៨** នៅក្នុងវគ្គទី៣នេះ នាអូមីបានផ្ដួចផ្ដើមគំនិតដល់នាងរស់ ដោយមានសង្ឃឹម ។

**៣:២** *នៅយប់នេះឯង លោកនឹងរោយស្រូវឱក* សូមមើលការពន្យល់ ១:២២ ។ តាមទំនៀមទម្លាប់នៅរដូវចម្រូតម្ចាស់ស្រែ ហើយនិងពួកអ្នកចម្រូតរបស់គេ តែងតែនាំគ្នាមកគេងនៅក្បែរទីលានរោយស្រូវ ដើម្បីការពារស្រូវរបស់គេកុំឱ្យចោរមកលួច ។

**៣:៣** នាងរស់ត្រូវបានណែនាំឱ្យរៀបខ្លួនដូចជាកូនក្រមុំដែរ (មើល អគ ១៦:៩–១២) ។ *ចូលទៅឯទីលាននោះចុះ* នៅក្នុងទីលានបញ្ជាន់ស្រូវ គឺជាកន្លែងមួយដែលពួកប្រុសៗជាមិត្តសម្លាញ់ប្រកបគ្នា យ៉ាងសប្បាយ (សូមមើល ខ.១៤) ។ *ស៊ីផឹក* នៅក្នុងរដូវចម្រូត គឺជារដូវមួយ ដែលគេរៀបចំពិធីជប់លៀងឡើង (មើល អស ៩:៣ ១៦:៩–១០ យរ ៤៨:៣៣) ។

**៣:៤** *រួចចូលទៅបើកភួយពីខាងចុងជើង* ទោះបីជាការណែនាំរបស់នាងនាអូមី ប្រហែលជានឹងត្រូវកើតឡើងនៅចំពោះមុខនាពេលនេះ ដែលនាងនាអូមីគិតថា វាជាការត្រឹមត្រូវផ្នែកសីលធម៌នោះ លោកបូអូស និងនាងរស់មិនដែលមានការសង្ស័យឡើយ (មើល ខ.១១) ។ ដំបូន្មានរបស់នាងនាអូមីចំពោះនាងរស់ គឺបានបញ្ជាក់ពីគោលបំណង និងតួនាទីច្បាស់លាស់របស់លោកបូអូស ដែលជាសាច់ញាតិ ។ ទង្វើរបស់នាងរស់ គឺសុំលោកបូអូសរៀបការជាមួយ ។ នាងតាម៉ារជាម្ដាយរបស់ពេរេស (៤:១២) ក៏បានរៀបការជាមួយប្អូនថ្លៃរបស់ខ្លួន (ឬសាច់ញាតិ ដែលលោះ) ដែរ (សូមមើល លប ៣៨:១៣–៣០) ។

**៣:៩** *សូមបណ្ដោយភួយលោកមកដណ្ដប់ឱ្យបាវស្រីផង* សំណូមពររបស់នាង គឺបញ្ជាក់ពីគោលបំណងរៀបការ (មើល អគ ១៦:៨) ។ វប្បធម៌បែបនេះក៏នៅមានប្រព្រឹត្ត នៅក្នុងតំបន់ខ្លះៗនៃតំបន់មជ្ឈិមបូព៌ាផងដែ ។ ជាមួយនឹងការប្រើពាក្យយ៉ាងប៉ិនប្រសព្វរបស់នាងរស់ ធ្វើមកលើលោកបូអូសបែប ហើយឆ្លើយតបតាមកតញ្ញូកិច្ចរបស់គាត់យ៉ាងសមស្រប ។ នៅឯទីលានចម្រូតបូអូស បានឱ្យពរដល់នាងដោយនូវព្រះហស្តរបស់ព្រះអម្ចាស់ "ដែលនាងបានមកជ្រកក្រោមស្លាបទ្រង់ "(២:១២) ។ ឥឡូវនេះនៅឯទីលានចម្រូត នាងរស់សុំឱ្យគាត់បណ្ដោយ "ស្លាប" (ភួយ) មកដណ្ដប់លើរាង្គកាយនាង ។ លោកបូអូសមាននាទីជាស្លាប់របស់ព្រះអម្ចាស់ ដែលគ្របដណ្ដប់ការពារលើនាងរស ។

**៣:១០** *ចិត្តដ៏សប្បុរស . . . វិសេសជាងមុន* សូមមើល ២:១១–១២ និងការពន្យល់ ២:២០ ។

**៣:១១** *នាងជាស្ត្រីល្អត្រឹមត្រូវណាស់* សូមមើល សភ ៣១:១០ ។ ពាក្យនេះនៅក្នុងសញ្ញាចាស់ គឺមានតែនៅត្រង់នោះម្ដងទៀតប៉ុណ្ណោះ ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា "ស្ត្រីល្អត្រឹមត្រូវ" គឺមានន័យដូចគ្នានឹងការពិពណ៌នាអំពីបូអូសនៅក្នុង ២:១ ដែរ ។ អ្នកនិពន្ធចង់និយាយថាទាំងនាងរស់ ទាំងលោកបូអូស គឺមានតម្លៃដូចគ្នា ។

**៣:១២** *ប៉ុន្តែ . . . ញាតិជិតជាងខ្ញុំទៅទៀត* ទំនាក់ទំនងរវាងលោកបូអូស និងប្ដីរបស់នាងរស់ (លោកម៉ាឡូន) យ៉ាងដូចម្ដេច នោះគ្មាននរណាបានដឹងច្បាស់ឡើយ ប៉ុន្តែសម្រាប់អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធ គឺត្រូវតែរៀបការជាមួយស្ត្រីមេម៉ាយនោះ ។ នាងនាអូមីបានណែនាំនាងរស់ឱ្យទៅលោកបូអូស ពីព្រោះគាត់បានបង្ហាញពីទឹកចិត្តប្រោសប្រណីដល់នាងរស់រួចមកហើយ ។

**៣:១៣** *ខ្ញុំស្បថនឹងព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅដូច្នេះហើយ* លោក

នឹងសំរេចជាសាច់ញាតិជិតដិតនឹងនាងវិញ ខ្ញុំស្បថនឹងព្រះ
យេហូវ៉ាដ៏មានព្រះជន្មរស់នៅ[ប] ដូច្នេះហើយ ចូរដេកនៅ
ទីនេះ[ផ] រហូតដល់ព្រឹកចុះ ។
១៤នាងក៏ដេកនៅត្រង់ចុងជើងលោក ទាល់តែព្រឹក រួច
ក្រោកឡើងមុនពេលដែលមើលគ្នាស្គាល់ ដ្បិតលោកបាន
ហាមថា កុំឱ្យអ្នកណាដឹងថា មានស្ត្រីមកក្នុងទីលាននេះ[ព] ឱ្យ
សោះ[ភ] ១៥រួចលោកប្រាប់ថា ចូរយកក្រមា[ម] ដែលនាងបង់
នោះ មកត្រដាងកាន់ទៅ នាងក៏ត្រដាង នោះលោកវាល់
ស្រូវឱក៦រង្វាល់ ដាក់ឱ្យនាងទូល រួចនាងក៏ចូលទៅក្នុង
ទីក្រុងវិញ ១៦កាលបានមកដល់ម្តាយក្មេកនោះគាត់សួរថា
តើឯងឬអី កូនអើយ នាងក៏រៀបរាប់ប្រាប់ ពីគ្រប់ទាំង
សេចក្តីដែលលោកបានប្រព្រឹត្តដល់នាង ១៧ហើយនាង
និយាយថា លោកឱ្យស្រូវឱកមកខ្ញុំ៦រង្វាល់នេះ ដោយ
ពាក្យថា កុំឱ្យនាងត្រឡប់ទៅឯម្តាយក្មេកវិញ ដោយដៃទទេ
ឡើយ ១៨ដូច្នេះនាអូមីប្រាប់ថា កូនអើយ ចូរឯងនៅស្ងៀម
ចាំមើលការនោះនឹងទៅជាយ៉ាងណា ដ្បិតនៅថ្ងៃនេះ
លោកមិនឈប់ខានទេ ទាល់តែបានបង្ហើយការនោះជា
ស្រេច[យ] ។

## លោកបូអូសរៀបការជាមួយនាងរស់

**៤** ១រីឯបូអូស លោកឡើងទៅអង្គុយនៅត្រង់ទ្វារ[ក] ទីក្រុង
លំដាប់នោះសាច់ញាតិជិតដិត[ខ] ដែលបូអូសបាននិយាយ
នោះ[គ] គាត់ក៏មកដល់បូអូសហៅថា នែ បងអើយ សូមបែរ
មកអង្គុយនៅទីនេះសិន ដូច្នេះគាត់ក៏បែរចូលមកអង្គុយ ២ឯ
បូអូសលោកហៅយកពួកចាស់ទុំ[ឃ] ក្នុងក្រុងនោះចំនួន១០
នាក់មកជិរាបថា សូមអង្គុយនៅទីនេះចុះ គេក៏អង្គុយនៅ[ង]
៣រួចលោកនិយាយទៅសាច់ញាតិជិតដិតនោះថា ន៉ាអូមី
ដែលបានវិលត្រឡប់មក ពីស្រុកម៉ូអាប់វិញ គាត់ចង់លក់ដី១
ក្បាលរបស់អេលីម៉ាលេច ជាបងប្អូនយើង[ច] ៤ហើយខ្ញុំបាន
គិតថា ត្រូវជំរាបឱ្យបងដឹងដែរ ដូច្នេះសូមឱ្យបងទិញដីនោះ
នៅចំពោះពួកអ្នកដែលអង្គុយនៅទីនេះ ហើយនៅមុខពួក
ចាស់ទុំនៃសាសន៍យើងចុះ បើបងចង់លោះដីនោះ សូម
លោះទៅ តែបើមិនចង់លោះទេ សូមប្រាប់ឱ្យខ្ញុំបានដឹងផង
ដ្បិតក្រៅពីបង[ឆ] នោះគ្មានអ្នកណាទៀតមានច្បាប់នឹងលោះ
បានទេ មានតែខ្ញុំដែលជាអ្នកបន្ទាប់បងប៉ុណ្ណោះ អ្នកនោះ
ឆ្លើយឡើងថា ខ្ញុំព្រមលោះដែរ ៥បូអូសជិរាបថា នៅថ្ងៃ
ណាដែលបងទិញដីនោះពីន៉ាអូមី នោះត្រូវទិញពីនាងរស់
ជាសាសន៍ម៉ូអាប់[ជ] ប្រពន្ធរបស់បងប្អូនយើង ដែលស្លាប់
នោះដែរ ដើម្បីនឹងបង្កើតឈ្មោះអ្នកនោះ នៅក្នុងមរដក
គាត់ឡើងវិញ[ឈ] ៦អ្នកនោះឆ្លើយឡើងថា ខ្ញុំនឹងលោះសំរាប់
ខ្លួនខ្ញុំមិនបានទេ[ញ] ក្រែងខ្ញុំបង្ខូចមរដករបស់ខ្ញុំទៅ ដូច្នេះចូរ
អ្នកយកច្បាប់របស់ខ្ញុំនឹងលោះចុះ ដ្បិតខ្ញុំលោះមិនបានទេ[ដ] ។

**៣:១៣** ប ជន ១៤:១២ ហស ៤:១៥ ផ នរ ៤:៦
**៣:១៤** ព ជន ១៨:២៧ ភ នរ ១៤:១៦ ២កថ ៨:២១
**៣:១៥** ម អស ៣:២២
**៣:១៨** យ ទដ ៣៧:៣–៥
**៤:១** ក លប ១៨:១ ២៣:១០ ខ នរ ២:២០ គ នរ ៣:១២
**៤:២** ឃ នក ៣:១៦ ង ចទ ២៥:៧
**៤:៣** ច លវ ២៥:២៥ នរ ១:២
**៤:៤** ឆ លវ ២៥:២៥ យរ ៣២:៧–៨
**៤:៥** ជ នរ ១:២២ ឈ លប ៣៨:៨ នរ ៣:១៣
**៤:៦** ញ លវ ២៥:២៥ នរ ៣:១៣ ដ ចទ ២៥:៧

បូអូសបានស្បថនឹងខ្លួនគាត់ ដោយនូវព្រះនាមព្រះយេហូវ៉ា (ធៀបនឹង ១:១៧) ថានឹងជួយលោះដល់ក្រុមគ្រួសារ និងផ្តល់កិត្តិយសដល់នាងរស់តាមរយៈការរៀបការ ។

**៣:១៥** លោកបូអូសបានរួចផុតពីបន្ទុកក្រឹត្យវិន័យ ហើយគាត់បានផ្គត់ផ្គង់ស្រូវឱ្យនាង ដែលនៅក្នុងទីលាន (មើល ២:១៥) ។

**៣:១៧** *ដោយដៃទទេ* នៅត្រង់ចំណុចនេះគឺនិយាយម្តងទៀតពីទទេ–ពោរពេញ (មើល ២:២១) ។

**៣:១៨** *ចាំមើល* នៅក្នុង ៤:១ ព្រះគម្ពីរភាសាហេព្រើរ ប្រើពាក្យដែលមានន័យថា "អង្គុយ" ។ ពាក្យទាំងនេះ គឺជាការរៀបចំរបស់ អ្នកនិពន្ធដើម្បីឱ្យយើងបានដឹងពីទិដ្ឋភាពនៃរឿងក្រោយទៀត ដែលនិយាយថា "លោកបូអូសអង្គុយនៅទ្វារក្រុង" ។

**៤:១–១២** គឺជាវគ្គទី៤ និយាយពីលោកបូអូសបានបំពេញសេចក្តីសន្យាចំពោះនាងរស់ ។

**៤:១** *ទ្វារទីក្រុង* នៅឯ "សាលាក្រុង" របស់ពួកអ៊ីស្រាអែលជិនាន់មុន ។ គឺជាកន្លែងជំនួញធម្មតា ហើយក៏ជាកន្លែងដែលងាយស្រួលស្វែងរក (មើល ខ.៩–១២ និងការពន្យល់ លប ១៩:១) ។ *បង* គឺជាសាច់ញាតិម្នាក់ទៀតដែលគេមិនបានបញ្ចេញឈ្មោះ ។

**៤:២** *ពួកចាស់ទុំក្នុងក្រុងនោះចំនួន១០នាក់* ការមកប្តឹងដែលមានគ្នាច្រើនបែបនេះ គឺតម្រូវទៅតាមច្បាប់ ។

**៤:៣** *លក់ដី១ក្បាល* សូមមើល ២:២០ ។ នៅក្នុងកន្លែងមានការកាត់ស្រាយ២យ៉ាង ដែលគួរឱ្យសមហេតុផល ។ (១).នាងន៉ាអូមីជាម្ចាស់ដី ប៉ុន្តែ ដោយសារតែនាងទាល់ក្រដូច្នេះហើយ នាងត្រូវបង្ខំចិត្តលក់ដីនោះ។ វាជាតួនាទីរបស់សាច់ញាតិ ក្នុងការលោះដីនោះមកវិញ ។ (២).នាងន៉ាអូមីមិនមែនជាម្ចាស់ដីនេះទេ ហើយដីនោះលោកអេលីម៉ាលេចបានលក់មុនពេលដែលក្រុមគ្រួសាររបស់នាងន៉ាអូមី វិលត្រឡប់មកពីម៉ូអាប់វិញ ប៉ុន្តែតាមច្បាប់នាងមានសិទ្ធិទិញដីនោះយកមកវិញ ។ ដោយសារនាងគ្មានប្រាក់សម្រាប់ទិញដីនោះយកមកវិញដោយខ្លួនឯង ដូច្នេះមានតែការពឹងពាក់លើសាច់ញាតិរបស់នាង ក្នុងការទិញដីនោះមកឱ្យនាងវិញប៉ុណ្ណោះ ។ នោះគឺជាសិទ្ធិនៃការលោះ ដែលនាងន៉ាអូមីបាន "លក់" ។ *ជាបងប្អូន* និយាយឱ្យទូលំទូលាយជាងនេះទៀតគឺ "សាច់ញាតិ" ។

**៤:៥** *ប្រពន្ធរបស់បងប្អូនយើង ដែលស្លាប់នោះដែរ . . . នៅក្នុងមរដកគាត់ឡើងវិញ* ឥឡូវនេះ លោកបូអូសបាននិយាយអំពីតួនាទីមួយទៀតរបស់គាត់ គឺត្រូវរៀបចំកេរ្តិ៍មរដកសម្រាប់នាងរស់ ។ តាមច្បាប់អាពាហ៍ពិពាហ៍ជាមួយបងថ្លៃស្រី (លវ ២៥:៥–៦ និងការពន្យល់ លវ ២៥:២៥) នោះកូនបងរបស់នាងរស់ត្រូវដាក់ឈ្មោះរបស់ម៉ាឡូន ដើម្បីមិនឱ្យបាត់ពីវង្សត្រកូល និងពីកេរ្តិ៍មរដក ។

**៤:៦** *ខ្ញុំនឹងលោះសំរាប់ខ្លួនខ្ញុំមិនបានទេ* ពីព្រោះគាត់ព្រួយបារម្ភថា បើសិនជាគាត់មានកូនជាមួយនាង ហើយកូននោះគឺជាអ្នកទទួលយកនូវមរដក

៧រីឯនៅស្រុកអ៊ីស្រាអែល កាលពីដើមចំណែកខាងឯការលោះឬប្ដូរ[ឋ] ដើម្បីនឹងសំរេចគ្រប់ទាំងការ នោះត្រូវឱ្យម្នាក់ដោះស្បែកជើង[ឌ] ឱ្យដល់ម្នាក់ទៀត ការយ៉ាងនោះ ទុកជាទីបន្ទាល់[ឍ] ឱ្យបានសំរេចការនៅក្នុងស្រុកអ៊ីស្រាអែល[ណ] ៨ដូច្នេះអ្នកដែលមានច្បាប់លោះនោះ ក៏និយាយទៅបូអូសថា ចូរទិញដីនោះសំរាប់ខ្លួនអ្នកចុះ រួចក៏ដោះស្បែកជើងរបស់ខ្លួនចេញ[ត] ៩នោះបូអូសក៏ប្រកាសដល់ពួកចាស់ទុំ និងមនុស្សទាំងនោះថា នៅថ្ងៃនេះសូមអ្នករាល់គ្នាចាំជាសាក្សី[ថ]ថា ខ្ញុំបានទិញទាំងអស់ដែលជារបស់អេលីម៉ាលេច និងរបស់គីលីយ៉ុន ហើយម៉ាឡូនពីន៉ាអូមីហើយ ១០មួយទៀត ខ្ញុំបានទិញនាងរស់ សាសន៍ម៉ូអាប់[ទ] ជាប្រពន្ធរបស់ម៉ាឡូន មកធ្វើជាប្រពន្ធខ្ញុំដែរ ដើម្បីនឹងបង្កើតឈ្មោះរបស់ម៉ាឡូននោះ[ធ] នៅក្នុងមរដកគាត់ឡើងវិញ ប្រយោជន៍កុំឱ្យឈ្មោះគាត់ ត្រូវកាត់ចេញពីពួកបងប្អូន និងពីទ្វារទីលំនៅរបស់គាត់ឡើយ[ន] អ្នករាល់គ្នាជាទីបន្ទាល់នៅថ្ងៃនេះឯង[ប] ១១ដូច្នេះ ពួកអ្នកដែលនៅត្រង់ទ្វារ[ផ]ក្រុង និងពួកចាស់ទុំក៏ឆ្លើយឡើងថា យើងទាំងអស់គ្នាជាទីបន្ទាល់ពិត[ព] សូមព្រះយេហូវ៉ាប្រោសឱ្យស្រីដែលចូលមកក្នុងផ្ទះអ្នក បានដូចជានាងរ៉ាជែលនិងនាងលេអា[ភ] ដែលទាំង២នោះ បានបង្កើតពួកគ្រួអ៊ីស្រាអែលឡើងដែរ ក៏សូមឱ្យអ្នកបានចំរើនឡើងក្នុងស្រុកអេប្រាតា[ម] ហើយមានល្បីឈ្មោះក្នុងក្រុងបេថ្លេហិមផង[យ] ១២សូមឱ្យអ្នកបានបង្កើតគ្រួសារឡើង អំពីពូជដែលព្រះយេហូវ៉ានឹងប្រទានដល់អ្នក ដោយសារស្ត្រីនេះ ឱ្យបានដូចជាគ្រួរបស់ពេរេស[រ] ជាកូនដែលនាងតាម៉ារ[ល] បានបង្កើតឱ្យយូដាដែរ ។

**៤:៧** ឋ លវ ២៥:២៤ ឌ ខ.៨ ឍ អស ៨:១-២, ១៦,២០ ណ ចទ ២៥:៧-៩ **៤:៨** ត ចទ ២៥:៩ **៤:៩** ថ អស ៨:២ យរ ៣២:១០,៤៤ **៤:១០** ទ នរ ១:២២ ធ ចទ ២៥:៥ ន ចទ ២៥:៦ ប យស ២៤:២២ **៤:១១** ផ លប ២៣:១០ ព ចទ ២៥:៩ ភ លប ៤:១៩ ២៩:១៦ ម លប ៣៥:១៦ យ នរ ១:១៩ **៤:១២** រ លប ៣៨:២៩ ល លប ៨:៦,២៤

## ដំណវង្សរបស់ស្ដេចដាវីឌ

*៤:១៨-២២ - ១រប ២:៥-១៥ មថ ១:៣-៦ លក ៣:៣១-៣៣*

១៣ដូច្នេះ បូអូសបានយកនាងរស់ធ្វើជាប្រពន្ធ ក៏ចូលទៅឯនាង ហើយព្រះយេហូវ៉ាទ្រង់ប្រោសឱ្យនាងមានទំងន់[វ] បង្កើតបានកូនប្រុស១[ស] ១៤នោះពួកស្រីៗ[ហ] គេនិយាយនឹងន៉ាអូមីថា សូមឱ្យព្រះយេហូវ៉ា[ឡ] ដែលទ្រង់មិនបានទុកអ្នកឱ្យឥតមានសាច់ញាតិជិតដិតនៅថ្ងៃនោះ[អ] បានប្រកបដោយ

**៤:១៣** វ លប ៨:១ ស លប ២៩:៣២ ៣០:៦ លក ១:៥៧ **៤:១៤** ហ លក ១:៥៨ ឡ លប ២៤:២៧ អ នរ ២:២០

តែម្នាក់ឯង នោះទ្រព្យសម្បត្តិទាំងប៉ុន្មានដែលគាត់មាន និងត្រូវឱ្យទៅក្រុមគ្រួសារអេលីម៉ាលេច (មើលការពន្យល់ លប ៣៨:៩) ។ នៅក្នុងស្ថានការណ៍បែបនេះ គាត់បានគិតថា គ្មាននរណាសក្តិសមជាងលោកបូអូសទៀតឡើយ ។ ការបដិសេធរបស់សាច់ញាតិ ដែលគាត់មានសិទ្ធិលោះយ៉ាងស្របច្បាប់នេះ បានបង្ហាញយើងអំពីសេចក្តីសប្បុរសរបស់លោកបូអូស ក្នុងការទន្ទឹងរងចាំរបស់ស្ត្រីទាំង២នោះ ដូចគ្នានឹងការវិលត្រឡប់របស់នាងអ័រប៉ាទៅឯក្រុម គ្រួសាររបស់គេវិញ ជាឱកាសនាងរស់បានបង្ហាញពីការអាណិតអាសូរ ចំពោះនាងន៉ាអូមីដែរ ។

**៤:៧** *នោះត្រូវឱ្យម្នាក់ដោះស្បែកជើង ឱ្យដល់ម្នាក់ទៀត* របៀបនៃការផ្ទេរសិទ្ធិពីអ្នកណាម្នាក់ ទៅឱ្យអ្នកណាម្នាក់ទៀត ដែលមានលក្ខណៈជាផ្លូវការ គឺត្រូវឱ្យអ្នកនោះដោះស្បែកជើងខ្លួនចេញ ហើយត្រូវយកទៅពាក់ឱ្យអ្នកដែលត្រូវទទួលតំណែងថ្មីនោះ (ប្រៀបធៀប អម ២:៦ ៨:៦) ។

**៤:៩** *សាក្សី* តួនាទីរបស់សាក្សី គឺត្រូវបញ្ជាក់ប្រាប់ពីគ្រប់ទាំងអស់នៅចំពោះមុខច្បាប់ ។

**៤:១០** *បង្កើតឈ្មោះរបស់ម៉ាឡូន* សូមមើល ចទ ២៥:៦ ។

**៤:១១** *រ៉ាជែលនិងនាងលេអា . . . បង្កើតពួកគ្រួអ៊ីស្រាអែលឡើងដែរ* ប្រៀបធៀបជាមួយ ចទ ២៥:៩ ។ ពួកអ៊ីស្រាអែលដែលកើតចេញពីនាងរស់ គឺជាប់មានទំនាក់ទំនងជាកូនចៅរបស់យ៉ាកុប (អ៊ីស្រាអែល) ដែលបង្កើតឡើងដោយនាងរ៉ាជែល និងនាងលេអា ជាសាសន៍អ៊ីស្រាអែលដែលបានសាងជាថ្មីឡើងវិញ ដោយស្ដេចដាវីឌ ដោយព្ធយុកោរបស់ទ្រង់ គឺនាងរស់និងលោកបូអូស (មើល ១សយ ៤) ។ ពួកគេក៏ជាសេចក្តីសញ្ញាដែលព្រះយេហូវ៉ាទ្រង់បានតាំងសញ្ញាថា "សង់" ស្ដេចដាវីឌឡើង និងពូជពង្សរបស់គេ (២សយ ៧:២៧-២៩) ។ *ស្រុកអេប្រាតា* សូមមើលការពន្យល់ ១:២ ។

**៤:១២** *ពេរេស ជាកូនដែលនាងតាម៉ារ បានបង្កើតឱ្យយូដា* លោកពេរេស គឺជាព្ធយុកោរបស់លោកបូអូស (ខ.១៨-២១ មថ ១:៣ លក ៣:៣៣) ។ គាត់បានបង្កើតសម្រាប់យូដា តាមរយៈរបៀបនៃការរៀបការជាមួយបងថ្លៃ (មើល លប ៣៨:២៧-៣០ និងមើលការពន្យល់ នរ ១:១១) ។ ដូច្នេះហើយលោកពេរេស គឺជាប្រភពនៃព្រះពរមួយក្នុងអំឡុងពេលលោកបូអូស ដែលពួកចាស់ទុំបានឱ្យពរដល់លោកបូអូស ។ មួយវិញទៀត លោកពេរេសគឺជាអ្នកដែលបានធ្វើឱ្យអំបូរយូដាបានស្ថិតស្ថេរក្នុងអ៊ីស្រាអែលផងដែរ ។ ដូច្នេះការប្រទានពរ របស់ចាស់ទុំតាមរយៈកូនចៅនាងរស់ នឹងធ្វើឱ្យលោកបូអូសរឹងមាំឡើង ហើយពូជពង្សរបស់លោកបូអូស ក៏នឹងបានដូចជាពេរេសដែរ សេចក្តីសន្យានេះបានសម្រេចនៅក្នុងគ្រានៃស្ដេចដាវីឌ និងវង្សានុវង្សរបស់ទ្រង់ ។ ជាមួយគ្នានោះដែរនៅក្នុង ខ.១២ បានបង្ហាញយើងយ៉ាងខ្លី ដែលទាក់ទងទៅនឹងសេចក្តីបញ្ចប់ព្រះគម្ពីរនាងរស់នេះ ។

**៤:១៣-១៧** គឺជាសេចក្តីបញ្ចប់នៃរឿងរ៉ាវទាំងឡាយ ក្នុងព្រះគម្ពីរនាងរស់ដែលមានលក្ខណៈដូចគ្នា នៅក្នុងសេចក្តីផ្តើម (១:១-៥): (១).នៅក្នុងចំណុចទាំង២នេះ សម្រាប់ព្រះគម្ពីរភាសាហេព្រើរ គឺមានចំនួននៃពាក្យគឺដូចគ្នា ។ (២).ទាំង២ផ្នែកនេះគឺបានសង្កត់ធ្ងន់លើឃ្លានិមួយៗដែលមានទម្រង់ខ្លី ។ (៣).ចំណុចទាំង២ គឺសុទ្ធតែបានផ្តោតលើន៉ាអូមី (៤).នៅក្នុងសេចក្តីផ្តើម បាននិយាយពីភាពទទេរ ហើយនៅក្នុងសេចក្តីបញ្ចប់គឺនិយាយពីភាពពោរពេញរបស់នាងន៉ាអូមី ។

**៤:១៣** *ព្រះយេហូវ៉ាទ្រង់ប្រោសឱ្យនាងមានទំងន់* មើលការពន្យល់ ១:៦ ។

**៤:១៤** *សាច់ញាតិជិតដិត* នោះគឺ លោកអូបិឌជាកូនរបស់នាង ដូចនៅក្នុង ខ.១៥-១៧ បានបង្ហាញយ៉ាងច្បាស់ ។ *សូមឱ្យលោកបានល្បី* ពាក្យជូនពរនេះ គឺមានលក្ខណៈដូចគ្នានឹងសម្តីរបស់បូអូសនៅក្នុង ខ.១១ ដែរ ។

ព្រះពរ សូមឱ្យលោកបានល្បីទូទៅក្នុងពួកអ៊ីស្រាអែល
១៥កូននេះនឹងបានសំរាប់ជាទីតាំងជីវិតរបស់អ្នកឡើងវិញ
ហើយនិងចិញ្ចឹមអ្នក ក្នុងកាលដែលចាស់ផង ដ្បិតកូនប្រសា
ស្រី[ក]ដែលស្រឡាញ់អ្នក ហើយក៏វិសេសដល់អ្នក ជាជាងកូន
ប្រុស៧នាក់ផង[ខ] នាងបានបង្កើតវាមក ១៦ន៉ាអូមីក៏យកកូន
តូចមកបីបម ហើយថែរក្សា ១៧ឯពួកស្រីជាអ្នកជិតខាង
គេក៏ ដាក់ឈ្មោះកូននោះថា អូបិឌ ដោយថា មានកូនប្រុស១
កើតមកឱ្យន៉ាអូមី នោះហើយជាឪពុកអ៊ីសាយ[គ] ដែលជា
ឪពុកដាវីឌ[ឃ]។

១៨នេះហើយជាពង្សាវតាររបស់ពេរេស[ង] គឺពេរេស
បង្កើតហេស្រុន[ច] ១៩ហេស្រុនបង្កើតរ៉ាម។បង្កើតអ័មីន៉ា
ដាប់[ឆ] ២០អ័មីន៉ាដាប់បង្កើតណាសូន[ជ]។បង្កើតសាលម៉ូន
២១សាលម៉ូនបង្កើតបូអូស។[ឈ]បង្កើតអូបិឌ ២២អូបិឌបង្កើត
អ៊ីសាយ។បង្កើតដាវីឌ។/

**៤:១៥** ក លប ១១:៣១ ខ ១សយ ១:៨, ២:៥ យប ១:២ **៤:១៧** គ ខ.២២ ១សយ ១៦:១,១៨ ១៧:១២,១៧,៥៨ ១របា ២:១២,១៣ ទដ ៧២:២០ ឃ ១សយ ១៦:១៣ ១របា ២:១៥ **៤:១៨** ង លប ៣៨:២៩ ច ជន ២៦:២១ **៤:១៩** ឆ នក ៦:២៣ **៤:២០** ជ ជន ៧:១២ **៤:២១** ឈ ជន ២:១

**៤:១៥** *ហើយក៏វិសេសដល់អ្នក ជាងកូនប្រុស៧នាក់ផង* សូមមើល ១សយ ១:៨ ។ នៅពេលនោះចំនួន៧ គឺជាចំនួនមួយដែលគ្រប់លក្ខណ៍ ។ ដូច្នេះ ការមានកូនប្រុស៧ គឺជាការសង្ខេបព្រះពរទាំងអស់នៅក្នុងគ្រួសាររបស់ពួកអ៊ីស្រាអែល (មើល ១សយ ២:៥ យប ១:២ ៤២:១៣) ។ ការអាណិតអាសូររបស់នាងរស់មកលើន៉ាអូមី គឺជាការគោរពដ៏ខ្ពង់ខ្ពស់មួយ ។
**៤:១៦** *ក៏យកកូនតូចមកបីបម* គឺជានិមិត្តរូបនៃការទទួលយកមកចិញ្ចឹម (សូមមើលការពន្យល់ លប ៣០:៣) ។
**៤:១៧** *មានកូនប្រុស១កើតមកឱ្យន៉ាអូមី* គឺបង្កើតឡើងដោយសារនាងរស់នៅក្នុង១ជីវិតនាងន៉ាអូមី នោះនឹងមិនខានមានកូនទៀតឡើយ ក្នុងការទទួលមរដកពីលោកម៉ាឡូន ។ *អូបិឌ* ឈ្មោះនេះមានន័យថា "បម្រើ" ដែលមានទម្រង់ពេញថា "បាវបម្រើព្រះអម្ចាស់" ។
**៤:១៨–២២** មើល ១របា ២:៥–១៥ មថ ១:៣–៦ លក ៣:៣១–៣៣ ។ ដូចគ្នានឹងតំណវង្សនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ៥:៣–៣២ ១១:១០–២៦ នៅក្នុងតំណវង្សនេះ មានឈ្មោះមនុស្ស១០នាក់ (មើលការពន្យល់ លប ៥:៥) ។ វាបានធ្វើឱ្យយើងដឹងពីសម័យកាលស្តេចដាវីឌ ដែលមានខុសគ្នាយ៉ាងខ្លាំងរវាងគ្រាពួកចៅហ្វាយ ដែលបាននិយាយនៅក្នុង ១:១ ។ នៅទីបញ្ចប់ពួកកូនចៅអ៊ីស្រាអែល បានចូលមករស់នៅក្នុងទឹកដីសន្យា (មើល ១ពវ ៥:៤) ។ សារៈសំខាន់របស់វា គឺគ្រាន់តែនាងន៉ាអូមីបានជួបប្រទះភាពទទេទៅឯភាពពោរពេញ តាមរយៈនាងរស់ និងលោកបូអូសនោះព្រះយេហូវ៉ា ទ្រង់បាននាំពួកកូនចៅអ៊ីស្រាអែលពីទីមិនបានសម្រាកមកឯទីសម្រាក តាមរយៈឮយុកោរបស់គេ គឺស្តេចដាវីឌ ។ ហើយតំណវង្សនេះ គឺជាតំណវង្សរបស់ព្រះយេស៊ូវ "ជាវង្សហ្លួងដាវីឌ" (មើល មថ ១:១) ដែលជាហោរាចុងក្រោយ នាំរាស្ត្ររបស់ព្រះមកឯទីសម្រាកចុងក្រោយ (សូមមើលសេចក្តីផ្តើមយ៉ូស្វេ: ចំណងជើង និងខ្លឹមសាសិក្សាវិទ្យាអំពីព្រះ និង ហព ៣:៧–៤:១១ និងការពន្យល់) ។

# សាំយូអែលទី១

## សេចក្តីផ្តើម

### ចំណងជើង

គេបានដាក់ឈ្មោះព្រះគម្ពីរសាំយូអែលទី១ និងទី២ តាមឈ្មោះមនុស្សម្នាក់ដែលព្រះបានប្រើដើម្បីតាំងនគរអ៊ីស្រាអែលឡើង ។ ហោរាសាំយូអែលមិនត្រឹមតែជាអ្នកចាក់ប្រេងតាំងដល់ស្តេចសូល និងស្តេចដាវីឌដែលជាស្តេច២អង្គដំបូងរបស់ពួកអ៊ីស្រាអែលប៉ុណ្ណោះនោះទេ ប៉ុន្តែគាត់ក៏បានផ្តល់អត្ថន័យទៅចំពោះអ្នកដឹកនាំថ្មីរបស់ព្រះអម្ចាស់ ដែលគ្រប់គ្រងលើពួកអ៊ីស្រាអែលថែមទៀត ។ ការគ្រប់គ្រងរបស់ហោរាសាំយូអែល ធៀបបានទៅនឹងអ្នកតំណាងរបស់ព្រះក្នុងប្រវត្តិសាស្ត្ររបស់ពួកអ៊ីស្រាអែលក្នុងអំឡុងពេលនេះ មានលក្ខណៈដូចគ្នានឹងលោកម៉ូសេដែរ (សូមមើល ទដ ៩៩:៦ យរ ១៥:១) ។ ក្នុងអំឡុងពេលដែលគាត់ដឹកនាំពួកអ៊ីស្រាអែល បានផ្តល់សេចក្តីសញ្ញាដ៏អស់កល្បភ្ជាប់ពីអ្នកដឹកនាំ ដែលមាននៅក្នុងគ្រាចៅហ្វាយរហូតដល់គ្រារាជាធិបតេយ្យនេះ ច្រើនជាងអ្នកឯទៀតៗ ។

ជាដំបូងព្រះគម្ពីរសាំយូអែលទី១និងទី២ជាសៀវភៅតែមួយ ។ ការបកប្រែ "សេបទូជិន"(Septuagint, ការបកប្រែព្រះគម្ពីរសញ្ញាចាស់ជាភាសាក្រិក មុនសម័យគ្រីស្ទបរិស័ទ) បានធ្វើការបែងចែកព្រះគម្ពីរនេះជាពីរផ្នែក ។ ក្រោយមកមានបន្តនូវក្នុងការបែងចែកនេះទៀត ដោយ "លោកយេរ៉ូម"(Jerome, នៅក្នុងការបកប្រែព្រះគម្ពីរមកជាភាសាឡាតាំង ដែលហៅថាព្រះគម្ពីរវ៉ាលហ្គេត "Vulgate" ប្រហែលជានៅឆ្នាំ ៤០០ គ.ស) ហើយការបកប្រែព្រះគម្ពីរនៅសម័យទំនើបក៏បានបន្តការបែងចែកនេះផងដែរ ។ គេបានដាក់ចំណងជើងរបស់ព្រះគម្ពីរនេះផ្សេងៗពីគ្នា ពីសម័យមួយទៅសម័យមួយទៀត គឺមានដូចជា "ព្រះគម្ពីរអាណាចក្រ ទី១ និងទី២" (ដោយក្រុមសេបទូជិន) និង "ពង្សាវតារក្សត្រ ទី១ និង ទី២" (នៅក្នុងព្រះគម្ពីរវ៉ាលហ្គេត) ហើយនិង "សាំយូអែល ទី១ និងទី២" (នៅក្នុងទំនៀមទម្លាប់ពួកហេព្រើរ និងការបកប្រែសម័យទំនើបភាគច្រើន)។

### លក្ខណៈអក្សរសាស្ត្រ អ្នកនិពន្ធ និងកាលបរិច្ឆេទ

មានសំណួរជាច្រើនដែលជាប់ទាក់ទងទៅនឹងលក្ខណៈអក្សរសាស្ត្រ អ្នកនិពន្ធ និងកាលបរិច្ឆេទនៃការសរសេរព្រះគម្ពីរសាំយូអែលទី១-២ ។ តាមលក្ខណៈដ៏ពិតប្រាកដ និងជាក់លាក់ដែលមាននៅក្នុងព្រះគម្ពីរនេះបានលើកឡើងដូច្នេះថា ព្រះគម្ពីរនេះត្រូវបានចងក្រងជាមួយនឹងឯកសារដើម ដែលអ្នកនិពន្ធបានលាយបញ្ចូលជាមួយនឹងរបៀបនៃការតាក់តែងរបស់គាត់ ។

ដោយសារព្រះគម្ពីរនេះ មិនបានចង្អុលបង្ហាញយើងអំពីអត្តសញ្ញាណរបស់វា នោះយើងមិនអាចដឹងថា នរណាជាអ្នកនិពន្ធនោះឡើយ ។ ទោះបីជាបែបនេះក៏ដោយ ក៏គេអាចដឹងខ្លះៗបានដែរថា អ្នកនិពន្ធនោះប្រាកដជាអ្នកដែលបានកត់ត្រាអំពីជីវិតរស់នៅ និងពេលវេលារបស់ហោរាសាំយូអែល ស្តេចសូល ហើយនិងស្តេចដាវីឌ ។ ឯកសារយោងដ៏ពិតប្រាកដ ដែលមាននៅក្នុងព្រះគម្ពីរនេះផ្ទាល់ គឺវាមានតែនៅក្នុងប្រភពមួយប៉ុណ្ណោះ (សៀវភៅរបស់លោកយ៉ាសើរ ២សយ ១:១៨) ប៉ុន្តែ អ្នកនិពន្ធព្រះគម្ពីរបាក្សត្រ គឺសំដៅលើមនុស្ស៤នាក់ផ្សេងទៀតដែលបានជាប់ទាក់ទងនឹងសម័យកាលពេលនេះ (បញ្ជីពង្សាវតាររបស់ស្តេចដាវីឌ ២រប ២៧:២៤ កត់ទុកក្នុងសៀវភៅរបស់ហោរាសាំយូអែលជាអ្នកមើលឆុត ក្នុងសៀវភៅរបស់ហោរាណាថាន់ និងសៀវភៅរបស់ហោរាកាឌ់ ជាអ្នកមើលឆុត ១រប ២៩:២៩) ។

### មាតិកា និងផ្ទៃរឿង : ជំនួរវង្ស និងសេចក្តីសញ្ញា

ព្រះគម្ពីរសាំយូអែលទី១មានទំនាក់ទំនងជាមួយនឹងការដែលព្រះអម្ចាស់បង្កើតប្រព័ន្ធនយោបាយ សម្រាប់ប្រទេសអ៊ីស្រាអែលដែលមានស្តេចមនុស្សជាអ្នកគ្រប់គ្រង ។ កាលពីគ្រាមុន អ្នកនិពន្ធបានពណ៌នាអំពីការប្រែប្រួលនៅក្នុងរចនាសម្ព័ន្ធ (ការសោយរាជ្យរបស់ព្រះលើរាស្ត្ររបស់ទ្រង់) ដែលមានសារៈសំខាន់នេះ គាត់បានពណ៌នាយ៉ាងក្បោះក្បាយអំពីមាតិកាដ៏ស្មុកស្មាញនេះ ។ ព្រឹត្តិការណ៍ខាងក្រោមនេះ នឹងបង្ហាញប្រាប់ពីប្រវត្តិសាស្ត្រ និងប្រវត្តិដើមនៃវិជ្ជាសិក្សាអំពីព្រះក្នុងព្រះគម្ពីរ សម្រាប់ជាការចាប់ផ្តើមរបស់រាជាធិបតេយ្យ :

១. *កំណើត យុវភាព និងការត្រាស់ហៅសាំយូអែល* (ជំពូក ១-៣) ។ នៅក្នុងព្រះគម្ពីរភាគច្រើនជាប់ទាក់ទងនឹងយុគ្គសម័យកាល នៃស្តេច២អង្គដំបូងរបស់ពួកអ៊ីស្រាអែលគឺស្តេចសូល និងស្តេចដាវីឌ ។ សារៈសំខាន់របស់វាគឺ អ្នកនិពន្ធមិនបានជ្រើសរើសកំណើតរបស់មនុស្សដែលមាននៅក្នុងរឿងនិទាននោះទេ ប៉ុន្តែគាត់លើកយកពីកំណើតរបស់អ្នកដឹកនាំ និងអ្នកចាក់ប្រេងតាំងរបស់គេ គឺជាហោរាសាំយូអែលលើកមកនិយាយវិញ ។ អ្នកនិពន្ធបានភ្ជាប់ជាមួយការគ្រប់គ្រងរបស់ហោរាសាំយូអែលក្នុងព្រឹត្តិការណ៍ទាំងអស់នោះ ។ មើល

ទៅគាត់ហាក់បីដូចជានិយាយនៅក្នុងភាពប៉ិនប្រសប់មួយថា សាច់និងឈាម គឺក្លាយជាវត្ថុបន្ទាប់បន្សំចំពោះព្រះបន្ទូល និងវិញ្ញាណ នៅក្នុងរឿងការស្ថាបនាជិន្នូរវង្ស ។ នៅក្នុងហេតុផលនៃជំពូក ១-៣ នេះអាចក្លាយជាការគំហើញពីទំនាក់ទំនងទាំងមូលដែលនឹងកើតឡើង មិនដូចព្រះគម្ពីរចៅហ្វាយ ឬដូចអ្វីដែលបាននិយាយនៅដើមដំបូងរហូតដល់ចុងបញ្ចប់នៃព្រះគម្ពីរសាំយូអែលទី១-២នោះឡើយ ។ ជិន្នូរវង្សគឺត្រូវផ្តល់កំណើត ហើយក្រោយមកទៀតត្រូវបានទទួលការអប់រំតាមរយៈសម្តី និងកិច្ចការរបស់ហោរាសាំយូអែល ។ ទោះបីជាយ៉ាងណាក៏ដោយព្រឹត្តិការណ៍នៃកំណើតរបស់ហោរាសាំយូអែល គឺជាគោលរឿងនៃកិច្ចការរបស់ព្រះអម្ចាស់ពេញសៀវភៅនេះតែម្តង ។

២. *ការរៀបរាប់ "ហឹបសញ្ញា" (ជំពូក ៤-៦)* ។ នៅក្នុងជំពូកនេះ ប្រាប់យើងអំពីរបៀបដែលពួកភីលីស្ទីនចាប់យកហឹបនៃសេចក្តីសញ្ញារបស់ព្រះ បន្ទាប់មកព្រះអម្ចាស់ទ្រង់បានដាក់ទណ្ឌកម្ម ដោយបំផ្លាញទីក្រុងសំខាន់ៗរបស់ពួកភីលីស្ទីន និងរបៀបដែលហឹបសញ្ញានៃព្រះបានត្រឡប់ទៅស្រុកអ៊ីស្រាអែលវិញ ។ ការរៀបរាប់នោះ បានបង្ហាញប្រាប់អំពីសេចក្តីចំកួតរបស់ពួកកូនចៅអ៊ីស្រាអែលថា ហឹបសញ្ញារបស់ព្រះអម្ចាស់ គឺជាទ្រព្យធន ដែលអាចធានារាប់រងពីជ័យជម្នះរបស់ពួកគេ លើខ្មាំងសត្រូវដោយស្វ័យប្រវត្តិ ។ ពួកគេក៏មានការកោតខ្លាចចំពោះអំណាចរបស់ព្រះ (យ៉ាវេ៍ គឺជាព្រះនៃពួកអ៊ីស្រាអែល) និងឧត្តមភាពរបស់ទ្រង់លើព្រះដាកុន ជាព្រះនៃពួកភីលីស្ទីន ពួកភីលីស្ទីនបានបង្ខំចិត្តសារភាពកំហុស ដែលគេបានទាស់ប្រឆាំងជាមួយអំណាចរបស់ព្រះអម្ចាស់ តាមរយៈនៃការផ្ញើហឹបសញ្ញារបស់ព្រះអម្ចាស់ឱ្យពួកអ៊ីស្រាអែលវិញ ។

៣. *សាំយូអែលជាចៅក្រម និងជាអ្នករំដោះ (ជំពូក ៧)* ។ នៅពេលដែលហោរាសាំយូអែលបានហៅពួកអ៊ីស្រាអែលឱ្យប្រែចិត្ត និងថ្វាយខ្លួនជាថ្មីទៅចំពោះព្រះអម្ចាស់ នោះព្រះដ៏មានគ្រប់ទាំងព្រះចេស្តាបានជួយធ្វើអន្តរាគមន៍ ហើយនិងផ្តល់ឱ្យពួកអ៊ីស្រាអែលមានជ័យជម្នះលើពួកភីលីស្ទីន ។ នៅក្នុងការរៀបរាប់នេះ បានបញ្ជាក់ថែមទៀតពីសិទ្ធិអំណាចរបស់ហោរាសាំយូអែលធៀបដូចជាសង្ឃរបស់ព្រះ ។ ក្នុងពេលជាមួយគ្នានោះដែរ ការនោះបានផ្តល់ជាភស្តុតាងរបស់ព្រះអម្ចាស់ដែលបានការពារ និងប្រទានពរដល់រាស្ត្ររបស់ទ្រង់ក្នុងពេលដែលពួក គេបានទុកចិត្តទាំងស្រុងទៅលើព្រះអម្ចាស់ ហើយនិងរស់នៅដោយការស្តាប់បង្គាប់ចំពោះសេចក្តីសញ្ញាដែលជាកាតព្វកិច្ចរបស់ពួកគេ ។

គ្រប់ទាំងអស់នៃសេចក្តីពិតដែលមាននៅក្នុង ជំពូក ១-៧ ធៀបដូចជាអារម្ភកថាដ៏មានសារៈសំខាន់សម្រាប់ការរៀបរាប់នៅក្នុងជំពូក ៨-១២ ដែលនៅក្នុងជំពូកទាំងនោះបានពិពណ៌នាពីការស្ថាបនាជិន្នូរវង្សនៅក្នុងអ៊ីស្រាអែល ។ អ្នកនិពន្ធបានតាក់តែងរឿងនៅក្នុងជំពូក ៨-១២ ប្រកបដោយភាពប៉ិនប្រសព្វ ដើម្បីបង្ហាញឱ្យឃើញច្បាស់ពីជម្លោះដ៏ខ្លាំក្លាផ្នែកវិជ្ជាសិក្សាអំពីព្រះ ក្នុងប្រវត្តិសាស្ត្រទាំងនោះ ។ នៅក្នុងជំពូកទាំងអស់នោះ ជាញឹកញាប់ពួកអ្នកប្រាជ្ញបានធ្វើសេចក្តីអធិប្បាយដ៏ខ្លី ពីការប្រឈមមុខចំពោះភាពតានតឹងក្នុងការទន្ទឹងរងចាំ ឱ្យមានស្តេចគ្រប់គ្រងលើប្រទេសរបស់គេ : (១).ហោរាសាំយូអែលត្រូវបានព្រះអម្ចាស់បង្គាប់ឱ្យជ្រើសរើសស្តេចសម្រាប់ពួកគេ (សូមមើល ៨:៧,៩,២២ ៩:១៦-១៧ ១០:២៤ ១២:១៣) (២).សំណូមពររបស់ពួកគេ ដែលទាមទារឱ្យមានស្តេច គឺជាអំពើបាបមួយដែលគេបានបដិសេធន៍ចំពោះព្រះអម្ចាស់ (សូមមើល ៨:៧ ១០:១៩ ១២:១២,១៧,១៩-២០) ។ ជម្លោះទាំងអស់នោះមើលទៅហាក់បីដូចជាការឆ្ពោះទៅរករាជាធិបតេយ្យ ដែលត្រូវតែយល់ដឹងនៅក្នុងបរិបទនៃសេចក្តីសញ្ញារបស់ពួកអ៊ីស្រាអែល និងព្រះអម្ចាស់ ។

លោកម៉ូសេ បានប្រមើលមើលពីបំណងប្រាថ្នារបស់ពួកអ៊ីស្រាអែលដែលចង់បានស្តេចសោយរាជ្យលើគេ (ចទ ១៧:១៤-២០) ប៉ុន្តែ ជិន្នូរវង្សអ៊ីស្រាអែលត្រូវ តែយល់ព្រមឱ្យព្រះជាអ្នកគ្រប់គ្រងលើរាស្ត្ររបស់ទ្រង់ ទុកដូចជាស្តេចដ៏ធំឧត្តមរបស់ពួកគេ ។ ជិន្នូសមកវិញ នៅពេលដែលពួកចាស់ទុំសុំឱ្យហោរាសាំយូអែលតាំងឱ្យមានស្តេច(សូមមើល ៨:៥,១៩-២០) ពួកគេបានបដិសេធន៍ការសោយរាជ្យរបស់ព្រះអម្ចាស់លើពួកគេ ។ បំណងប្រាថ្នាដែលគេចង់បានស្តេច គឺគ្រាន់តែដើម្បីឱ្យបានដូចជាប្រទេសជិតខាងខ្លួនប៉ុណ្ណោះ ដើម្បីដឹកនាំពួកគេក្នុងចម្បាំង ហើយឱ្យមានទំនុកចិត្តលើសុវត្ថិភាពនៅក្នុងប្រទេស និងសហគមន៍របស់គេប៉ុណ្ណោះ ។ ម្យ៉ាងទៀតព្រះអម្ចាស់ទ្រង់មិនគ្រាន់តែបានសន្យាថា នឹងធ្វើជាអ្នកការពាររបស់ពួកគេប៉ុណ្ណោះនោះឡើយ ប៉ុន្តែព្រះអម្ចាស់ទ្រង់ក៏បានបំភ្លឺបង្ហាញពីអំណាចរបស់ព្រះអង្គនៅពីក្រោយពួកគេថែមទៀត ដើម្បីឱ្យគេបានដឹងជាក់ស្តែងដូចជាការរៀបរាប់ ពីហឹបសញ្ញា ថែមទាំងជ័យជម្នះដ៏ធំដែលគេបានឈ្នះលើពួកភីលីស្ទីន ក្រោមការដឹកនាំរបស់ហោរាសាំយូអែល (ជំពូក ៧) ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ព្រះអង្គបានណែនាំឱ្យហោរាសាំយូអែលតាំងឱ្យមានស្តេចសម្រាប់ពួកគេដែរ ។ តាមរយៈការកំណត់ទុកជាមុនរបស់ព្រះអម្ចាស់ នោះស្តេចសូលត្រូវបាននាំមកឯហោរាសាំយូអែល ហើយគាត់បានចាក់ប្រេងតាំងឱ្យទ្រង់ធ្វើជាស្តេចដោយផ្ទាល់ (៩:១-១០:១៦) ។ ចំណែរកាលក្រោយមកទៀតហោរាសាំយូអែលបានប្រមូលបណ្តាជនទាំងអស់ឱ្យមកជួបជុំគ្នានៅត្រង់

មីសប៉ាជាកន្លែងមួយដែលលោកទូន្មានគេម្តងទៀតចំពោះអំពើបាបដែលគេចង់បានស្តេច (សូមមើល ១០:១៨-១៩) គាត់ធ្វើជាប្រធានលើអ្នកដែលចាប់ឆ្នោតជ្រើសរើសស្តេច ។ សន្លឹកឆ្នោតបានធ្លាក់ទៅលើសូល ហើយគេក៏បានតាំងគាត់ឱ្យធ្វើជាស្តេចស្របច្បាប់ ក្នុងនាមជាអ្នកដែលព្រះបានជ្រើសរើស (១០:២៤) ។ ស្តេចសូលមិនទាន់ធ្វើជាស្តេចភ្លាមៗនោះទេ តែគាត់បានត្រឡប់ទៅផ្ទះដើម្បីធ្វើការ នៅឯទីវាល (សូមមើល ១១:៥,៧) ។ នៅពេលដែលពួកយ៉ាបេស-កាឡាត ទទួលការគំរាមកំហែងពីណាហាសជាសាសន៍អាំម៉ូន ស្តេចសូលមានឱកាសហើយប្រមូលទ័ពព្រមទាំងនាំពួកអ៊ីស្រាអែលមានជ័យជម្នះក្នុងចម្បាំង ។ ជ័យជម្នះរបស់គាត់ គឺជាគ្រាចុងក្រោយរបស់ព្រះអម្ចាស់ដែលយល់ស្របចំពោះការ តាំងសូលឱ្យធ្វើជាស្តេច(ធៀបជាមួយ ១០:២៤ ១១:១២-១៣) ហើយជាឱកាសមួយសម្រាប់គាត់ដែលត្រូវទទួលការតែងតាំងជាស្តេចនៅ គីលកាល (សូម មើល ១១:១៤-១២:២៥) ។

សំនួរដែលនៅតែត្រូវការដំណោះស្រាយ វាមិនច្រើននោះឡើយទោះបីជាពួកអ៊ីស្រាអែលអាចនឹងមានស្តេចមួយអង្គក៏ដោយ (វាបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់ជាអ្នកប្រទានឱ្យពួកគេមានស្តេច) ប៉ុន្តែគេចង់ដឹងរបៀបដែលពួកគេរក្សាទុកសេចក្តីសញ្ញារបស់ពួកគេជាមួយនឹងព្រះអម្ចាស់ (ឧទាហរណ៍ការបង្ការចំពោះទេវាធិបតេយ្យ) ព្រោះឥឡូវនេះគេមានស្តេចហើយ ។ បញ្ហាទាំងអស់នេះត្រូវបានដោះស្រាយ នៅពេលដែលសាំយូអែលបានហៅបណ្តាជនឱ្យប្រែចិត្ត និងថ្វាយខ្លួនជាថ្មីទៅចំពោះព្រះអម្ចាស់ ពីភក្តីភាពរបស់គេក្នុងឱកាសតែងតាំងសូលជាស្តេច (សូមមើល ១០:២៥) ។ ស្តេចដែលគ្រប់គ្រងលើអ៊ីស្រាអែល មិនមែនជាការស្វ័យរាជដោយសារសិទ្ធនឹងអំណាចរបស់គាត់នោះឡើយ គាត់គឺជាម្នាក់ដែលកាន់តាមច្បាប់របស់ព្រះ និងធ្វើតាមសម្តីរបស់ហោរា (សូមមើល ១០:២៥ ១២:២៣) ។ ការនេះមិនគ្រាន់តែជាសេចក្តីពិតសម្រាប់តែសូលម្នាក់ប៉ុណ្ណោះនោះឡើយ ប៉ុន្តែគឺសម្រាប់អស់ទាំងស្តេចដែលនឹងសោយរាជ្យនៅលើប្រទេសអ៊ីស្រាអែលនាថ្ងៃអនាគតផងដែរ ។ ស្តេចត្រូវតែធ្វើជាឧបករណ៍នៃការគ្រប់គ្រងរបស់ព្រះលើរាស្ត្ររបស់ទ្រង់ ហើយបណ្តាជននិងស្តេច ត្រូវតែទទួលស្គាល់ព្រះអម្ចាស់ទុកដូចជាមហាក្សត្ររហូតដល់គ្រាចុងបំផុតរបស់ពួកគេ (មើល ១២:១៤-១៥) ។

មិនយូរប៉ុន្មាន សូលគាត់បានសម្តែងពីការមិនពេញចិត្តក្នុងការចុះចូលចំពោះសេចក្តីតម្រូវការនៃកិច្ចការងាររបស់គាត់ (ជំពូក ១៣-១៥) ។ នៅពេលដែលគាត់មិនស្តាប់បង្គាប់ចំពោះការបង្ហាត់បង្រៀនរបស់ហោរាសាំយូអែល ក្នុងការរៀបចម្បាំងទាស់ប្រឆាំងជាមួយពួកសាសន៍ភីលីស្ទីន(១៣:១៣)ហើយក្នុងពេលដែលគាត់បដិសេធន៍បំផ្លាញពួកសាសន៍អាម៉ាលេកឱ្យអស់ដែលព្រះបង្គាប់ឱ្យគាត់ធ្វើតាមរយៈហោរាសាំយូអែល (ជំពូក ១៥) គាត់ត្រូវបានបញ្ឈប់ពីការងារជាឧបករណ៍នៃការគ្រប់គ្រងរបស់ព្រះអម្ចាស់លើរាស្ត្ររបស់ទ្រង់ ។ គាត់បដិសេធន៍ចំពោះសេចក្តីតម្រូវការនៃកិច្ចការងាររបស់គាត់ ជាហេតុធ្វើឱ្យគាត់ទទួលការបដិសេធមិនឱ្យធ្វើជាស្តេចទៀត (សូមមើល ១៥:២៣) ។

សំណល់ប៉ុន្មានទៀតដែលមាននៅក្នុងព្រះគម្ពីរ១សាំយូអែល(ជំពូក ១៦-៣១)គឺបានពីពណ៌នាពីការជ្រើសរើសរបស់ព្រះអម្ចាស់ចំពោះដាវីឌឱ្យគាត់ក្លាយជាអ្នកស្នងរាជ្យពីស្តេចសូល ហើយនិងពីពណ៌នាពីដំណើរផ្លូវដ៏សែនឆ្ងាយ ដែលដាវីឌបានរៀបចំឡើងគ្រងរាជ្យ ទោះបីជាការដឹកនាំរបស់សូល ក្លាយជាការប្រឆាំងជាលក្ខណៈធម្មជាតិក៏ដោយ ក៏ដាវីឌគាត់បានបដិសេធការដណ្តើមរាជ្យពីសូលតាមរយៈការប្រើអំណាច និងកម្លាំង ប៉ុន្តែគាត់បានទុកកិច្ចការទាំងនោះក្នុងព្រះហស្តនៃព្រះអម្ចាស់វិញ ។ ស្តេចសូលចាញ់សង្គ្រាមជាមួយពួកភីលីស្ទីន ដោយសារការខ្លាចក្រែងពួកភីលីស្ទីនចាប់គាត់បាន គាត់សុខចិត្តសម្លាប់ខ្លួនឯង ។ បុត្រាទាំង៣របស់ស្តេចសូល រួមទាំងមិត្តសំឡាញ់របស់ដាវីឌ ឈ្មោះយ៉ូណាថាន ពួកគេត្រូវបានស្លាប់នៅកន្លែងតែមួយក្នុងទីចម្បាំង (សូមមើល ជំពូក ៣១) ។

### ពង្សាវតារក្សត្រ

ទោះបីជាការរៀបរាប់ក្នុង១-២សាំយូអែល បានភ្ជាប់ជាមួយនឹងសេចក្តីថ្លែងការណ៍ខ្លះៗ ជាមួយពង្សាវតារក៏ដោយ(ឧទាហរណ៍ ១សយ ៦:១ ៧:២ ៨:១,៥ ១៣:១ ២៥:១ ២សយ ២:១០-១១ ៥:៤-៥ ១៤:២៨ ១៥:៧) ទិន្នន័យទាំងនោះមិនទាន់គ្រប់គ្រាន់ដើម្បីស្ថាបនាការ ពណ៌នាពីពង្សាវតារ ដែលជាព្រឹត្តិការណ៍ចម្បងក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល ក្នុងអំឡុងពេលនោះបានឡើយ ។ លើកលែងតែទិន្នន័យដែលស្តីពីកំណើតរបស់ដាវីឌ និងយុគសម័យកាលនៃការគ្រប់គ្រងរបស់គាត់ប៉ុណ្ណោះ ដែលអាចកំណត់យកជាការបានខ្លះៗ (សូមមើល ២សយ ៥:៤-៥) សម្រាប់កំណើតរបស់អ្នកផ្សេងៗទៀតគ្រាន់តែជាការប៉ាន់ប្រមាណប៉ុណ្ណោះ ។ បញ្ហាទិន្នន័យពង្សាវតារលើអាយុកាលរបស់សូលក្នុងអំឡុងពេលដែលគាត់ធ្វើជាស្តេច និងរយៈវេលានៃការគ្រប់គ្រងរបស់គាត់ (សូមមើលអត្ថបទគម្ពីរ ១សយ ១៣:១) គឺជាធនធានមួយមិនគ្រប់គ្រាន់ ដែលទាក់ទងទៅនឹងពេលវេលាជាក់លាក់ពីកំណើត និងពេលនៃការគ្រងរាជ្យរបស់គាត់ ។ គ្មានព័ត៌មានណាមួយដែលអាចឱ្យយើងដឹងពីពេលវេលានៃកំណើតរបស់សាំយូអែល (១សយ ១:២០) ឬពេលដែលគាត់ស្លាប់នោះឡើយ (២៥:១) ។ ឆាកជីវិតរបស់គាត់ប្រហែលដូចគ្នានឹងឆាកជីវិតរបស់សាំសុន (រស់នៅក្នុងជំនាន់ជាមួយគ្នា) ហើយនិងអូបិឌជាកូនប្រុសនាងរស់នៅជាមួយនឹងបូអូស ដែលជាជីតារបស់ស្តេចដាវីឌ ។ ការនេះចង់និយាយដូច្នេះថា គាត់បានរស់នៅលើផែនដីនេះរយៈពេល

យ៉ាងយូរ ក្នុងអំឡុងពេលដែលពួកចាស់ទុំអ៊ីស្រាអែលសុំគាត់តាំងឱ្យមានស្តេចគ្រប់គ្រងលើពួកគេ (សូមមើល ៨:១,៥) ។ នៅមានកត្តាដែលជាធនធានមិនច្បាស់លាស់មួយទៀត អំពីពង្សាវតារគឺ ជានិច្ចកាលអ្នកនិពន្ធគាត់មិនបានចាត់ចែងចាត់ចែងដោយប្រិតប្រៀនអំពីពង្សាវតារ នោះឡើយ ។ តែនៅកន្លែងនេះ ហាក់បីដូចជាការពិតដែរ នៅក្នុង ២សយ ជំពូក ៧ បាននិយាយអំពីការដាក់បញ្ចូលពង្សាវតារបន្ទាប់ពីដាវីឌបានច្បាំងដណ្តើមទឹកដី ដែលបាននិយាយនៅក្នុង ២សយ ៨:១-១៤ (សូមមើល ២សយ ៧:១ ៨:១) ។ រឿងរ៉ាវអំណត់អត់ដែលព្រះអម្ចាស់បានចាត់បញ្ជូនមកក្នុងអំឡុងពេលរាជ្យដាវីឌ ដោយព្រោះការរំលោភបំពានរបស់សូលដែលបានសម្លាប់ពួកគីបៀនគឺរកឃើញក្នុង ២សយ ២៤:១-១៤ សូម្បីតែពង្សាវតារបានកើតឡើង មុនពេលដែលការក្បត់របស់អាប់សាឡុំមក៏បានកត់ចុះក្នុង ២សយ ១៥-១៨ (សូមមើល ២សយ ២១:១-៤ ផងដែរ) ។ កាលបរិច្ឆេទខាងក្រោមនេះ គឺជាការប៉ាន់ស្មានពីពង្សាវតារទុកជាគម្រោងនៃពេលវេលារបស់សាំយូអែល សូល និងដាវីឌ ។

| | |
|---|---|
| ១១០៥ មុន គ.ស | កំណើតរបស់សាំយូអែល (១សយ ១:២០) |
| ១០៨០ មុន គ.ស | កំណើតរបស់ស្តេចសូល |
| ១០៥០ មុន គ.ស | សូលត្រូវបានចាក់ប្រេងតាំងឱ្យធ្វើជាស្តេច (១សយ ១០:១) |
| ១០៤០ មុន គ.ស | កំណើតរបស់ដាវីឌ |
| ១០២៥ មុន គ.ស | ដាវីឌត្រូវបានចាក់ប្រេងតាំងឱ្យក្លាយជាអ្នកស្នងរាជ្យបន្ទាប់ពីសូល (១សយ ១៦:១-១៣) |
| ១០១០ មុន គ.ស | ការស្លាប់របស់សូល និងការចាប់ផ្តើមរាជ្យរបស់ដាវីឌលើពួកយូដានៅហេប្រុន (១សយ ៣១:៤-៦ ២សយ ២:១,៤,១១) ។ |
| ១០០៣ មុន គ.ស | ដាវីឌ ចាប់ផ្តើមគ្រប់គ្រងលើពួកអ៊ីស្រាអែលទាំងអស់ និងការចាប់បានក្រុងយេរូសាឡិម (២សយ ៥) ។ |
| ៩៩៣-៩៩២ មុន គ.ស | សង្គ្រាមរបស់ដាវីឌ (២សយ ៨:១-១៤) ។ |
| ៩៩១ មុន គ.ស | កំណើតរបស់សាឡូម៉ូន (២សយ ១២:២៤) ។ |
| ៩៨០ មុន គ.ស | ជំរឿនរបស់ដាវីឌ (២សយ ២៤:១-៩) ។ |
| ៩៧០ មុន គ.ស | ចុងបញ្ចប់នៃរាជ្យស្តេចដាវីឌ (២សយ ៥:៤-៥ ១ពវ ២:១០-១១) ។ |

**គម្រោងអត្ថបទ**

**I. ប្រវត្តិសាស្ត្រនៃការចាប់ផ្តើមតែងតាំងជំនួរវង្សនៅក្នុងប្រទេសអ៊ីស្រាអែល (ជំពូក ១-៧)**

ក. កំណើតសាំយូអែល យុវវ័យ និងការត្រាស់ហៅសាំយូអែលឱ្យធ្វើជាហោរា (ជំពូក ១-៣)

ខ. ពួកភីលីស្ទីនវាយឈ្នះពួកអ៊ីស្រាអែល ហឹបសញ្ញានៃព្រះត្រូវបានគេចាប់យក និងផ្ញើមកវិញ (ជំពូក ៤-៧)

**II. ការចាប់ផ្តើមជំនួរវង្សនៅអ៊ីស្រាអែលក្រោមការដឹកនាំរបស់សាំយូអែល (៨:១-១៦:១៣)**

ក. ការលើសូលឡើង (ជំពូក ៨-១២)

១. អំពើបាបរបស់បណ្តាជនក្នុងការចង់បានស្តេច (ជំពូក ៨)

២. លោកសាំយូអែលបានចាក់ប្រេងតាំងសូលជាលក្ខណៈបុគ្គល (ជំពូក ៩:១-១០:១៦)

៣. សូលត្រូវបានជ្រើសរើសឱ្យធ្វើជាស្តេចជាផ្លូវការ (ជំពូក ១០:១៧-២៧)

៤. សូលសម្រេចចិត្តពិតប្រាកដដើម្បីធ្វើស្តេច (ជំពូក ១១:១-១៣)

៥. ការតែងតាំងសូលរាជ្យរបស់ស្តេចសូលជាថ្មីម្តងទៀត (ជំពូក ១១:១៤-១២:២៥)

ខ. ការធ្លាក់ចុះជំនួរវង្សរបស់ស្តេចសូល (ជំពូក ១៣:១-១៦:១៣)

**III. ការស្ថាបនាជំនួរវង្សនៅអ៊ីស្រាអែល (ជំពូក ១៦:១៤-៣១:១៣)**

ក. ការលើកដាវីឌឡើង (ជំពូក ១៦:១៤-២៧:១២)

១. លោកដាវីឌក្លាយជាអ្នកបម្រើរបស់ស្តេចសូល (ជំពូក ១៦:១៤-១៧:៥៨)

២. លោកដាវីឌចាកចោលស្តេចសូល (ជំពូក ១៨-១៩)

៣. យ៉ូណាថានការពារដាវីឌ ពីស្តេចសូល (ជំពូក ២០)

៤. ដាវីឌនៅតែបន្តគេចចេញពីសូល (ជំពូក ២១:១-២២:៥)

៥. ស្តេចសូលបានសម្លាប់ពួកសង្ឃនៅក្រុងណូប (ជំពូក ២២:៦–២៣)
៦. លោកដាវីឌបានជួយសង្គ្រោះប្រជាជននៅក្រុងកៃឡា (ជំពូក ២៣:១–៦)
៧. ស្តេចសូលនៅតែបន្តតាមចាប់ដាវីឌ (ជំពូក ២៣:៧–២៩)
៨. លោកដាវីឌបានទុកជីវិតឱ្យសូល (ជំពូក ២៤)
៩. លោកដាវីឌប៉ុនប៉ងយកជីវិតណាបាល(ជំពូក ២៥)
១០. លោកដាវីឌបានទុកជីវិតឱ្យសូលម្តងទៀត(ជំពូក ២៦)
១១. លោកដាវីឌទៅធ្វើជាអ្នកបម្រើស្តេចអ័គីស (ជំពូក ២៧)

ខ. ចុងបញ្ចប់នៃរាជ្យរបស់ស្តេចសូល (ជំពូក ២៨–៣១)

**VI. ការបង្រួបបង្រួមជិន្នូរវង្សនៅអ៊ីស្រាអែល (២សយ ១–២០)**

ក. ការសោកស្តាយរបស់ដាវីឌ ចំពោះស្តេចសូល និងព្រះអម្ចាស់យ៉ូណាថាន (ជំពូក ១)
ខ. ដាវីឌក្លាយជាស្តេចលើស្រុកយូដា (ជំពូក ២–៤)
គ. ដាវីឌក្លាយជាស្តេចលើប្រទេសអ៊ីស្រាអែលទាំងមូល (ជំពូក ៥:១–៥)
ឃ. ដាវីឌច្បាំងដណ្តើមក្រុងយេរូសាឡិម (ជំពូក ៥:៦–២៥)
ង. ដាវីឌនាំយកហឹបនៃព្រះទៅក្រុងយេរូសាឡិម (ជំពូក ៦)
ច. ព្រះអម្ចាស់ទ្រង់បានសន្យាជាមួយស្តេចដាវីឌថានឹងឱ្យជិន្នូរវង្សដ៏នៅអស់កល្ប (ជំពូក ៧)
ឆ. វិបុលកម្ម នៃនគររបស់ស្តេចដាវីឌ (ជំពូក ៨)
ជ. សេចក្តីស្មោះត្រង់របស់ស្តេចដាវីឌចំពោះសេចក្តីសញ្ញាដែលបានតាំងជាមួយយ៉ូណាថាន(ជំពូក ៩)
ញ. ស្តេចដាវីឌប្រព្រឹត្តសេចក្តីកំផិត និងកំចាយឈាម (ជំពូក ១០–១២)
ដ. ស្តេចដាវីឌបាត់បង់អាំណូនជាកូនប្រុសរបស់គាត់ (ជំពូក ១៣–១៤)
ឋ. ស្តេចដាវីឌបាត់បង់អាប់សាឡុំមជាកូនប្រុសរបស់គាត់ (១៥–២០)

**V. ការសញ្ជឹងគិតចុងក្រោយលើរាជ្យដាវីឌ (២សយ ២១–២៤)**

## កំណើតរបស់លោកសាំយូអែល

១ ១រីឯនៅរ៉ាម៉ាថែម[ក]–សូភិម[ខ] ក្នុងស្រុកភ្នំ[គ]អេប្រាអិម[ឃ]
នោះមានមនុស្សម្នាក់ឈ្មោះអែលកាណា[ង] ជាកូនយេរ៉ូហាំ។
ជាកូនអេលីហ៊ូវ។ ជាកូនថូហ៊ូវ។ ជាកូនស៊ូភ អ្នកនោះជា
ពួកអេប្រាតា ២គាត់មានប្រពន្ធ២[ច] មួយឈ្មោះហាណា មួយ
ទៀតឈ្មោះពេនីណា ឯពេនីណានាងមានកូន តែនាង
ហាណាគ្មានកូនទេ ៣រាល់តែឆ្នាំ[ឆ]គាត់តែងឡើងពីក្រុង
ខ្លួនទៅឯស៊ីឡូរ[ជ] ដើម្បីនឹងថ្វាយបង្គំ[ឈ] ហើយថ្វាយយញ្ញបូជា
ដល់ព្រះយេហូវ៉ានៃពួកពលបរិវារ រីឯនៅទីនោះមាន
ហុបនី និងភីនេហាស ជាកូនអេលីទាំង២នាក់[ញ] ធ្វើជាសង្ឃ
នៃព្រះយេហូវ៉ា ៤លុះដល់ថ្ងៃដែលអែលកាណាថ្វាយយញ្ញ
បូជា[ដ]របស់ខ្លួន នោះក៏ចែកចំណែកដល់ពេនីណាជាប្រពន្ធ
និងដល់កូនប្រុសកូនស្រីរបស់នាងទាំងអស់គ្នា[ឋ] ៥តែបាន
ចែកដល់ហាណា១ជា២វិញ[ឌ] ដ្បិតគាត់ស្រឡាញ់ហាណា
ជាង តែព្រះយេហូវ៉ាទ្រង់បានបង្ខាំងផ្ទៃនាង[ឍ] ៦គូវិវាទ
របស់នាងក៏រុកគួននាងជាខ្លាំង ចង់ឱ្យនាងកើតសេចក្ដី
កំហឹង ដោយព្រោះព្រះយេហូវ៉ាបានបង្ខាំងផ្ទៃ[ណ] ៧ហើយ
ដែលគាត់ឡើងទៅរាល់តែឆ្នាំដូច្នោះ នោះពេនីណាក៏តែង
តែរុកគួននាង កំពុងដែលធ្វើដំណើរ ឡើងទៅឯដំណាក់
នៃព្រះយេហូវ៉ា បានជាហាណា នាងយំ ហើយមិនបរិភោគ
ទេ[ត] ៨នោះអែលកាណា ជាប្ដីសួរថា ហាណាអើយ ហេតុអ្វី
បានជានាងយំ ហើយមិនបរិភោគដូច្នេះ ម្ដេចក៏នាងកើត
ទុក្ខ តើខ្ញុំមិនវិសេសដល់នាង ជាជាងមានកូនប្រុស១០នាក់
ទេឬអី[ថ] ។
៩ដូច្នេះ ក្រោយដែលគេបានបរិភោគនៅត្រង់ស៊ីឡូរ
រួចហើយ នោះនាងហាណាក៏ក្រោកឡើង រីឯអេលីដ៏ជា

**១:១** ក យស ១៨:២៥ ខ ១សយ ៩:៥ គ យស ១៧:១៧–១៨ ឃ យស ២១:២០–២២ ង ១របា ៦:២៧,៣៤ **១:២** ច លប ៤:១៩ **១:៣** ឆ ខ.២១ នក ២៣:១៤ ១សយ ២:១៩ ២០:៦,២៩ លក ២:៤១ ជ យស ១៨:១ ឈ ចទ ១២:៥–៧ ញ ១សយ ២:៣១ ១៤:៣ **១:៤** ដ លវ ៧:១៥–១៨ ចទ ១២:១៧–១៨ ឋ លប ២៩:៣៤ **១:៥** ឌ លប ៣៧:៣ ឍ លប ១១:៣០ ២៩:៣១ **១:៦** ណ លប ១៦:៤**១:៧** ត ២សយ ១២:១៧ ទដ ១០២:៤ **១:៨** ថ នរ ៤:១៥

**១:១** *រ៉ាម៉ាថែម* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ឈ្មោះនេះមាននិយាយតែក្នុងកន្លែងនេះប៉ុណ្ណោះ ហើយនៅកន្លែងផ្សេងទៀតគឺឈ្មោះថារ៉ាម៉ា (មើល ខ.១៩ ២:១១ ៧:១៧ ១៩:១៨ ២៥:១) ។ ឈ្មោះនេះប្រហែលជាភូមិអើរីម៉ាថេ (មើល មថ ២៧:៥៧ និងការពន្យល់ យហ ១៩:៣៨) ។ *សូភិម* សូមមើលអត្ថបទគម្ពីរយើងមិនបានប្រាកដថា តើឈ្មោះនេះសំដៅលើមនុស្ស ឬទីកន្លែងនោះឡើយ បើសិនជាសំដៅលើមនុស្ស នោះព្ធយុកោរបស់គាត់គឺចេញពីអំបូរស៊ូភ (សូមមើលនៅក្នុងខបន្ទាប់ទៀត និងមើល ១របា ៦:៣៤–៣៥) ។ បើសិនជាសំដៅលើទីកន្លែងវិញ គឺសំដៅលើតំបន់ទូទៅនៅក្នុងស្រុករ៉ាម៉ាថែម (មើល ៩:៥) ។ *ពួកអេប្រាតា* ទោះបីជានៅទីនេះអែលកាណានិយាយថា ជាពួកអ៊ើប្រាតាក៏ដោយ គាត់ប្រហែលជាពួកលេវីដែលក្រុមគ្រួសាររបស់គាត់ជាគ្រួរបស់អំបូរកេហាត់ ដែលរស់នៅក្នុងស្រុកអេប្រាអិម (មើល យស ២១:២០–២១ ១របា ៦:២២–២៧) ។
**១:២** *គាត់មានប្រពន្ធ២* សូមមើលការពន្យល់ លប ៤:១៩ ១៦:២ ២៥:៦ ។
**១:៣** *រាល់តែឆ្នាំគាត់តែងឡើងពីក្រុងខ្លួន* ក្នុង១ឆ្នាំ៣ដង ពួកប្រុសៗជនជាតិអ៊ីស្រាអែលទាំងអស់ ត្រូវតែឡើងមកឯព្រះយេហូវ៉ានៅក្នុងតំណាក់ទ្រង់ (មើល នក ២៣:១៤–១៩ ៣៤:២៣ ចទ ១៦:១៦–១៧) ។ បុណ្យដែលបាននិយាយនៅទីនេះប្រហែលជាបុណ្យបារាំ ដែលពិធីបុណ្យនេះ មិនគ្រាន់តែរំឭកដល់ព្រះយេហូវ៉ា ដែលទ្រង់បានថែរក្សាការពារពួកអ៊ីស្រាអែល នៅក្នុងទីរហោស្ថាន នាពេលដែលពួកគេធ្វើដំណើរមកក្នុងទឹកដីកាណាននោះឡើយ (មើល លវ ២៣:៤៣) ប៉ុន្តែ មូលហេតុនៃការធ្វើបុណ្យនេះគឺមានច្រើនណាស់ ជាពិសេសនោះគឺដើម្បីអរសប្បាយ និងជប់លៀងអរព្រះគុណចំពោះព្រះអម្ចាស់ ដែលទ្រង់បានប្រទានពរដល់ផលដំណាំក្នុង១ឆ្នាំកន្លងមក (មើល ចទ ១៦:១៣–១៥) ។ នៅក្នុងឱកាសនៃពិធីបុណ្យនេះនាងហាណាកាន់តែមានសេចក្ដីទុក្ខលំបាកខ្លាំងឡើង ព្រោះនាងជាស្ត្រីអារ ។ *ព្រះយេហូវ៉ានៃពួកពលបរិវារ* តាមទំលៀមទម្លាប់ គេតែងតែនិយាយថា "ព្រះយេហូវ៉ានៃពួកពលបរិវារ" គឺជាងាររបស់ព្រះមហាក្សត្រ ។ នេះគឺជាលើកទី១ហើយ ដែលព្រះនាមរបស់ព្រះអម្ចាស់ត្រូវបានគេហៅបែបដូច្នេះ ។ ឥឡូវនេះ នៅក្នុងប្រទេសអ៊ីស្រាអែលចាប់ផ្ដើមមានស្ដេចគ្រប់គ្រងពិតប្រាកដហើយ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យថា "ពួកពលបរិវារ" អាចសំដៅលើ (១).ពួកមនុស្ស (មើល នក ៧:៤ ទដ ៤៤:៩) ។ (២).ជារូបកាយរបស់ស្ថានសួគ៌ ដូចជាព្រះអាទិត្យ ព្រះច័ន្ទ តារា (មើល លប ២:១ "របស់សព្វសារពើផង" ចទ ៤:១៩ អស ៤០:២៦) ។ (៣).ពួកអ្នកដែលនៅស្ថានសួគ៌ដូចជាទេវតាជាដើម (យស ៥:១៤ ១ពវ ២២:១៩ ទដ ១៤៨:២) ។ ចំពោះងារដែលនិយាយថា "ព្រះយេហូវ៉ានៃពួកពលបរិវា" នោះប្រហែលនិយាយសំដៅទូទៅ ដែលថាព្រះយេហូវ៉ាទ្រង់ជាអធិបតេយ្យភាពគ្រប់គ្រងលើអំណាចទាំងអស់ ដែលមាននៅក្នុងលោកិយនេះ (តាមការបកប្រែរបស់គម្ពីរសញ្ញាចាស់និយាយថា "ព្រះយេហូវ៉ានៃពួកពលបរិវា") នៅក្នុងការបង្កើតរាជ្យរបស់ទ្រង់ឡើង ក្នុងប្រទេសអ៊ីស្រាអែល នោះនាមរបស់ទ្រង់បានក្លាយជានាមដ៏វិសេសមួយ ដែលមាននាមថាព្រះយេហូវ៉ានៃពួកពលទ័ព ហើយព្រះអង្គក៏ជាពលទ័ពនៃស្ថានសួគ៌ (ប្រៀបធៀប ចទ ៣៣:២ យស ៥:៤ ទដ ៦៨:១៧ ហប ៣:៨) មិនតែប៉ុណ្ណោះព្រះអង្គជាពលសាសន៍របស់អ៊ីស្រាអែល (១សយ ១៧:៤៥) ។ *ស៊ីឡូរ* គឺជាទីក្រុងដែលស្ថិតនៅក្នុងស្រុកអេប្រាអិម ដែលនៅចន្លោះបេតអែលនិងស៊ីគែម ហើយជាកន្លែងដែលគេបានដាក់ហឹបនៃសេចក្ដីសញ្ញានៅកន្លែងនោះ (សូមមើល ៤:៣ យស ១៨:១ និងការពន្យល់ ពច ២១:១៩) ។
**១:៤** *យញ្ញបូជា* នៅទីនេះ គឺសំដៅលើការថ្វាយដង្វាយមេត្រី ។ យញ្ញបូជានេះមានទាំងការបរិភោគអាហារ ដើម្បីប្រកបជាមួយនឹងព្រះអម្ចាស់ដែរ ។ មិនតែប៉ុណ្ណោះគឺដើម្បីអរព្រះគុណចំពោះសេចក្ដីសប្បុរសរបស់ទ្រង់ (មើល លវ ៧:១១–១៨) ។
**១:៥** *ព្រះយេហូវ៉ាទ្រង់បានបង្ខាំងផ្ទៃនាង* ព្រះយេហូវ៉ាទ្រង់ជាអ្នកផ្ដល់ឱ្យនរណាម្នាក់មានកូនបាន (មើល លប ១៨:១០ ២៩:៣១ ៣០:២,២២) ។
**១:៦** *គូវិវាទរបស់នាង* សូមមើល លប ១៦:៤ ។
**១:៨** *ជាជាងមានកូនប្រុស១០នាក់* មើល ២:៥ និងការពន្យល់ នរ ៤:១៥ ។
**១:៩** *ព្រះវិហារ* ព្រះវិហារនិងព្រះវិហារ ៣:៣ និយាយពីព្រះវិហារនៃ

សង្ឃ លោកកំពុងនៅលើទីអង្គុយរបស់លោក ជិតសសរ
ទ្វារនៃព្រះវិហារព្រះយេហូវ៉ា[ទ] ១០ខណៈនោះ នាងមាន
សេចក្ដីជូរល្វីងក្នុងចិត្តណាស់[ធ] ក៏អធិស្ឋានដល់ព្រះយេហូវ៉ា
ទាំងយំអណ្ដឺតអណ្ដក ១១រួចនាងបន់[ន]ថា ឱព្រះយេហូវ៉ា
នៃពួកពលបរិវារអើយ[ប] បើសិនជាទ្រង់នឹងក្រឡេកព្រះ
នេត្រមកទតចំពោះសេចក្ដីទុក្ខលំបាករបស់ខ្ញុំម្ចាស់ ជាស្រី
បំរើទ្រង់ ហើយនឹកចាំ[ផ]មិនដាច់ពីខ្ញុំម្ចាស់ ដើម្បីនឹងប្រោស
ប្រទានឱ្យខ្ញុំម្ចាស់ ជាស្រីបំរើទ្រង់ បានកូនប្រុស១ នោះខ្ញុំ
ម្ចាស់នឹងថ្វាយវាដល់ព្រះយេហូវ៉ាគ្រប់១ជីវិត[ព] ហើយមិន
ដែលមានកាំបិតកោរ[ភ]សក់វាឡើយ ។
១២គ្រាកំពុងដែលនាងនៅអធិស្ឋាន ចំពោះព្រះយេហូវ៉ា
នៅឡើយ នោះអេលីក៏ចំណាំមើលមាត់នាង ១៣ឯហាណា
នាងនឹកតែក្នុងពោះ មានបបូរមាត់ផ្លូចៗ តែឥតឮសំឡេង
នាងឡើយ បានជាអេលីស្មានថាជានាងស្រវឹងហើយ
១៤ទើបសួរថា តើនាងនៅតែស្រវឹងដល់កាលណាទៀត ចូរ
លះចោលស្រាពីខ្លួននាងចេញទៅ ១៥តែហាណា ឆ្លើយតប
ថា ទេ ព្រះគុណម្ចាស់អើយ ខ្ញុំជាស្ត្រីមានចិត្តព្រួយជាខ្លាំង
ទេ[ម] ខ្ញុំមិនបានផឹកស្រាទំពាំងបាយជូរ ឬគ្រឿងស្រវឹងណា
ឡើយ គឺខ្ញុំបានប្លុងចិត្ត[យ]ទៅចំពោះព្រះយេហូវ៉ាទេតើ
១៦សូមកុំរាប់ខ្ញុំជាអ្នកបំរើលោក ទុកជាស្ត្រីអាក្រក់ឡើយ
ដ្បិតដែលខ្ញុំបានចេញវាចា ដរាបដល់ឥឡូវនេះ នោះកើត
តែពីសេចក្ដីទុក្ខព្រួយរបស់ខ្ញុំ និងការរុកកួនដ៏ហួសកំណោះ
ប៉ុណ្ណោះទេ[រ] ១៧នោះអេលីឆ្លើយថា ដូច្នេះ សូមអញ្ជើញ
ទៅប្រកបដោយសេចក្ដីសុខចុះ[ល] សូមឱ្យព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់ប្រោសឱ្យបានសំរេចដល់នាង តាមសេច
ក្ដីដែលបានសូមពីទ្រង់ចុះ[វ] ១៨រួចនាងសូមថា ដូច្នេះ សូម
ឱ្យខ្ញុំ ជាអ្នកបំរើលោក បានប្រកបដោយគុណនៃលោក
ម្ចាស់ផង[ស] នោះនាងក៏បាត់ទឹកមុខព្រួយ ហើយចេញទៅ
បរិភោគភោជន៍វិញ[ហ] ។
១៩លុះព្រលឹមស្រាងឡើង គេក៏នាំគ្នាទៅថ្វាយបង្គំនៅ
ចំពោះព្រះយេហូវ៉ា រួចត្រឡប់ទៅផ្ទះនៅរ៉ាម៉ាវិញ[ឡ] ឯ
អែលកាណា ក៏ស្គាល់ហាណាជាប្រពន្ធ ហើយព្រះយេហូវ៉ា
ទ្រង់នឹកចាំ[អ]ពីនាង ២០លុះដល់នាងហាណាមានទំងន់គ្រប់ខែ
ហើយ នោះក៏សំរាលបានកូនប្រុស១[ក] នាងឱ្យឈ្មោះ[ខ]ថា
សាំយូអែល[គ] ដោយថា អញបានសូមវាពីព្រះយេហូវ៉ាមក ។

## នាងហាណាថ្វាយសាំយូអែលដល់ព្រះ

២១ឯអែលកាណា ជាប្ដីនាង ព្រមទាំងពួកគ្រួគាត់ទាំង
អស់ ក៏នាំគ្នាឡើងទៅថ្វាយយញ្ញបូជា តាមដែលធ្លាប់ថ្វាយ
ដល់ព្រះយេហូវ៉ារាល់តែឆ្នាំ[ឃ] ហើយនិងលាបំណន់របស់

**១:៩** ទ ១សយ ៣:៣ **១:១០** ធ យប ៣:២០ ៧:១១ ១០:១ ២១:២៥ ២៣:២ ២៧:២ អស ៣៨:១៥ យរ ២០:១៨ **១:១១** ន ពច ១១:៣០ ប លប ១៧:១ ទដ ២៤:១០ ៤៦:៧ អស ១:៩ ផ លប ៨:១ ព ពច ១៣:៧ ភ ជន ៦:១-២១ ពច ១៣:៥ លក ១:១៥ **១:១៥** ម ២ពវ ៤:២៧ យ ទដ ៤២:៤ ៦២:៨ បទ ២:១៩ **១:១៦** រ ទដ ៥៥:២ **១:១៧** ល ជន ៦:២៦ ១សយ ២០:៤២ ២ពវ ៥:១៩ កច ១៥:៣៣ វ លប ២៥:២១ ទដ ២០:៣-៥ **១:១៨** ស លប ១៨:៣ នរ ២:១៣ ហ រម ១៥:១៣ **១:១៩** ឡ យស ១៨:២៥ អ លប ៨:១ ២៩:៣១ **១:២០** ក លប ១៧:១៩ ២៩:៣២ ៣០:៦ ខ នក ២:១០ មថ ១:២១ គ ១សយ ៧:៥ ១២:២៣ ១របៈ ៦:២៧ យរ ១៥:១ ហព ១១:៣២ **១:២១** ឃ ខ.៣

ព្រះយេហូវ៉ាដែលទីបរិសុទ្ធ និងរោងឧបោសថ ។ ជាមួយគ្នានោះដែរ ព្រះវិហារនៃព្រះយេហូវ៉ាក៏អាចហៅថា "ដំណាក់នៃព្រះយេហូវ៉ា" ដែរ (មើល ខ.៧ ៣:១៥) ហើយ "ត្រសាលជំនុំ" (២:២២) ដែលព្រះយេហូវ៉ាតែងតែហៅថា "គ្រួសារឯង" (២:៣២) ។ សេចក្ដីបញ្ជាក់ដែលនិយាយថា រោងឧបោសថជា "ដំណាក់" និង "ព្រះវិហារ" ថែមទាំងមានកន្លែងដេក និងមានទ្វារ (៣:២,១៥) បានផ្ដល់ចំណាប់អារម្មណ៍ថា នៅក្នុងសម័យកាលនោះ រោងឧបោសថ គឺជាផ្នែកមួយដែល មានទំហំធំទូលាយជាងពេលនេះ មានអាគារខ្ទាត់ខ្ទែងដែលមានលក្ខណៈ ជាអចិន្ត្រៃយ៍ដែលជាផ្នែកនៃ "ព្រះវិហារ" (ប្រៀបធៀប យរ ៧:១២ និងការពន្យល់ ខ.១៤ ២៦:៦) ។

**១:១១** *បន់* សូមមើល លប ២៨:២០-២២ ជន ២១:២ ទដ ៥០:១៤ និងការពន្យល់ ៧៦:១១ ១១៦:១៤,១៨ ១៣២:២-៥ សភ ២០:៥ និងការពន្យល់ ៣១:២) ។ របៀបដែលស្ត្រីបន់ គឺមាននិយាយនៅក្នុង ជន ៣០ ។ *នឹកចាំ* ការនឹកចាំគឺជាភាសាមួយសាមញ្ញ ជាងការនឹកឃើញរបស់នាងហាណា ។ វាបានបង្ហាញពីសកម្មភាពធុរៈកិច្ចរបស់នាង (សូមមើល ខ.១៩-២០ និងការពន្យល់ លប ៨:១) ។ *ជាស្រីបំរើទ្រង់* អត្ថន័យរបស់ឃ្លានេះ គឺចង់និយាយថា ខ្ញុំម្ចាស់ (សូមមើល លប ១៨:២) ។ *ហើយមិនដែលមានកាំបិតកោរសក់វាឡើយ* នាងហាណានបាន ស្ម័គ្រចិត្តធ្វើសេចក្ដីសម្បថជាមួយព្រះអម្ចាស់ ជំនួសកូននាងនូវអ្វីដែលព្រះអង្គទាមទារពីលោកសាំយូអែល (មើល ពច ១៣:៥ និងការពន្យល់) ។ ការរក្សាសក់ឱ្យនៅវែង នោះគឺជានិមិត្តរូបមួយ ដែលបង្ហាញពីការបម្រើព្រះអម្ចាស់ ហើយសេចក្ដីសម្បថបែបនេះ មានតែពួកន៉ាសារីតមួយប៉ុណ្ណោះ ដែលជានិច្ចកាលសេចក្ដីសម្បថនេះកម្រមានពេលកំណត់ណាស់ ទំនងជាអស់មួយជីវិត (សូមមើល ជន ៦:១-២១ និងការពន្យល់) ។

**១:១៣** *ស្រវឹង* កំហុសរបស់អេលី គឺគាត់នឹកស្មានថា នៅថ្ងៃនោះក៏មិនខុសប្លែកពីធម្មតាដែរ ដែលអ្នកស្រវឹងអាចចូលទៅក្នុងព្រះវិហារបាន ។ ចំពោះឯកសារដែលបង្ខូចពិធីបុណ្យនេះ គឺមាននិយាយនៅក្នុង ពច ១៧-២១ ។

**១:១៥** *គ្រឿងស្រវឹង* ការសរសេររឿងនេះ គឺចេញពីពួកមេសូប៉ូតាមាតាំងពីអំឡុងឆ្នាំប្រហែល ២៥០០ មុន គ.ស ។ ប្រហែលជាការបិតស្រា ឬគ្រឿងស្រវឹង គឺជាឧស្សាហកម្មដ៏ចម្បង ។

**១:១៦** *អាក្រក់* សូមមើលការពន្យល់ ចទ ១៣:១៣ ។

**១:២១** *ថ្វាយយញ្ញបូជា . . . រាល់តែឆ្នាំ* សូមមើលការពន្យល់ ខ.៣-៤ ។ *បំណន់របស់គាត់* ការបន់ទៅចំពោះព្រះអម្ចាស់ នោះវាជាលក្ខណៈធម្មតាមួយសម្រាប់ពួកអ្នកស្រឡាញ់ព្រះអម្ចាស់នៅក្នុងសញ្ញាចាស់ ហើយជានិច្ចកាលតែងតែភ្ជាប់មកជាមួយនូវដង្វាយ នៃការអរព្រះគុណ និងដង្វាយនៃការសរសើរ (មើល ទដ ៥០:១៤ ៥៦:១២ ១១៦:១៧-១៨) ។ លោកអែលកាណាមិនមានការសង្ស័យអ្វីឡើយ រាល់តែឆ្នាំគាត់តែងតែបន់ចំពោះព្រះ ដើម្បីសុំឱ្យព្រះអម្ចាស់ទ្រង់ប្រទានពរដល់ផលដំណាំ និងហ្វូងសត្វរបស់

គាត់ទៅ[ង] [២២]តែហាណាមិនបានទៅទេ ដោយប្រាប់ប្ដីថា
ចាំដល់កូនលែងដោះសិន នោះខ្ញុំនឹងនាំវាទៅ ឱ្យឈរ[ច]នៅ
ចំពោះព្រះយេហូវ៉ា ហើយឱ្យនៅទីនោះជាប់ជាដរាបទៅ
[២៣]នោះអែលកាណាជាប្ដីឆ្លើយថា ចូរធ្វើតាមដែលនាង
គិតឃើញថាត្រូវចុះ ចូរនៅចាំទាល់តែវាលែងដោះសិន
សូមតែឱ្យព្រះយេហូវ៉ាបានសំរេចតាម[ឆ]ព្រះបន្ទូលទ្រង់
ប៉ុណ្ណោះ ដូច្នេះនាងក៏នៅបំបៅកូន ទាល់តែបានផ្ដាច់ដោះ[ជ]
ហើយ [២៤]លុះបានផ្ដាច់ដោះស្រេចហើយ នោះនាងក៏
នាំយកកូនឡើងទៅជាមួយ ព្រមទាំងគោឈ្មោលស្ទាវ៣[ឈ]
ម្សៅ១ថាំង ហើយនិងថង់ស្បែកដាក់ស្រាទំពាំងបាយជូរ១
នាំទៅឯដំណាក់នៃព្រះយេហូវ៉ានៅត្រង់ស៊ីឡូរ ឯកូននោះ
នៅក្មេងណាស់ [២៥]រួចគេសំឡាប់គោឈ្មោល ហើយនាំកូន
ទៅឯអេលី [២៦]ជំរាបថា ឱព្រះគុណម្ចាស់ខ្ញុំអើយ ខ្ញុំស្បថ
ដោយនូវព្រលឹងលោកដែលនៅរស់ ព្រះគុណម្ចាស់ខ្ញុំ
អើយ ខ្ញុំនេះហើយ ជាស្រីដែលបានឈរអធិស្ឋានដល់
ព្រះយេហូវ៉ា នៅទីនេះជិតលោក [២៧]គឺខ្ញុំបានអធិស្ឋាន[ញ]សូម
ឱ្យបានកូននេះ ហើយព្រះយេហូវ៉ាទ្រង់ក៏ប្រោសឱ្យបាន
សំរេចដល់ខ្ញុំ ដូចពាក្យសំណូមនោះមែន [២៨]ដូច្នេះខ្ញុំសូម
ប្រគល់វាដល់ព្រះយេហូវ៉ា[ដ] ទុកជារបស់ផងទ្រង់រហូត
ដល់អស់ជីវិត រួចគេនាំគ្នាថ្វាយបង្គំដល់ព្រះយេហូវ៉ានៅ
ទីនោះ ។

## សេចក្ដីអធិស្ឋានរបស់នាងហាណា

**២** [១]លំដាប់នោះ ហាណាក៏អធិស្ឋានថា[ក] ចិត្តខ្ញុំម្ចាស់រីក
រាយសាទរ[ខ]ចំពោះព្រះអង្គ ស្នែង[គ]ខ្ញុំម្ចាស់បានថ្កើង[ឃ]ឡើង
ដោយនូវព្រះយេហូវ៉ា មាត់ខ្ញុំម្ចាស់បានបង្រួបលើគូវិវាទ
របស់ខ្ញុំ[ង]ម្ចាស់ ដោយព្រោះខ្ញុំម្ចាស់មានសេចក្ដីអំណរ

**១:២១** ង លប ២៨:២០ ជន ៣០:២ ចទ ១២:១១
**១:២២** ច នក ១៣:២ លក ២:២២
**១:២៣** ឆ លប ២៥:២១ ជ លប ២១:៨
**១:២៤** ឈ ជន ១៥:៨-១០
**១:២៧** ញ ១សយ ២:២០ ទដ ៦៦:១៩-២០
**១:២៨** ដ ៣ច ១៣:៧
**២:១** ក លក ១:៤៦-៥៥ ខ ទដ ១៣:៥ ៣៣:២១ សក ១០:៧ គ ទដ ១៨:២ ៨៩:១៧,២៤ ១៤៨:១៤ ឃ ទដ ៦:៨ ង ជន ១០:៣៥ ទដ ៦:១០

គាត់ព្រមទាំងលាបំណន់របស់គាត់នៅក្នុងពិធីបុណ្យបារាំ (មើលការពន្យល់ ខ.៣) ។

**១:២២** *លែងដោះ* តាមវប្បធម៌មួយសម្រាប់អ្នកនៅមជ្ឈឹមបូព៌ាប្រទេស គេតែងតែចិញ្ចឹមក្មេងរហូតអាយុ៣ឆ្នាំ ឬលើសពីនេះ ។

**១:២៣** *ព្រះបន្ទូលទ្រង់* មិនបានដឹងថា ពេលមុនព្រះអង្គមានបន្ទូលពីអ្វីឡើយ ដរាបណាឃ្លានេះនិយាយសំដៅពីអ្វី ដែលលោកអេលីនិយាយនៅក្នុង ខ.១៧ ។ ក្រាំងសមុទ្រក្រហមឈ្មោះថា "សិបធូជីន" (Septuagint) (សិបធូជីន គឺជាការបកប្រែព្រះគម្ពីរសញ្ញាចាស់ មកជាភាសាក្រិកដំបូង មុនគ្រីស្ទសករាជ) និងការបកប្រែរបស់ស៊ីរេក (Syriac) បានដោះស្រាយបញ្ហានេះដោយការអានថា "ពាក្យរបស់អ្នក" ប៉ុន្តែ ពាក្យថា "ព្រះបន្ទូលទ្រង់" ប្រហែលសំដៅលើពេលការពីមុន ដែលមិនបានឮព្រះបន្ទូលពីព្រះអម្ចាស់ ។

**១:២៦** *លោកដែលនៅរស់* គឺជាការនិយាយតាមរបៀបទម្លាប់មួយ ដែលអ្នកណាម្នាក់បង្ហាញពីសេចក្ដីពិតរបស់ខ្លួន ចំពោះអ្នកណាម្នាក់ផ្សេងទៀត ។

**១:២៧** *ខ្ញុំបានអធិស្ឋានសូមឱ្យបានកូននេះ* កំណើតលោកសាំយូអែល គឺដូចគ្នានិងកំណើតរបស់ស្ដេចដែលត្រូវគ្រប់គ្រងលើអ៊ីស្រាអែល ។ ហាណានាងបានសុំកូនក្នុងពេលដែលនាងមានបញ្ហា ដូច្នេះអ៊ីស្រាអែលក៏សុំឱ្យមានស្ដេចគ្រប់គ្រងលើពួកគេ នៅពេលគេមានបញ្ហាដែរ ហើយចម្រៀងរបស់នាងហាណាស្របពេលកំណើតលោកសាំយូអែល (២:១-១០) បានក្លាយជាចម្រៀងមួយដែលអ៊ីស្រាអែល បានច្រៀងនៅក្នុងពិធីឆ្លងរាជ្យស្ដេចដាវីឌ ។

**១:២៨** *ប្រគល់* មានភាពមិនធម្មតា នៅក្នុងការប្រើប្រាស់ភាសាហេព្រើរនៅទីនេះ គឺដូចគ្នានឹងភាសាហេព្រើរដែលប្រើទៅលើឈ្មោះសូល ។ អ្នកនិពន្ធបានធ្វើការណែនាំចំពោះឈ្មោះសូលថា គាត់គឺជាម្នាក់ដែលពួកកូនចៅអ៊ីស្រាអែលបាន "សុំ" ហើយក៏ជាម្នាក់ដែលព្រះអម្ចាស់ "ប្រទានមក" ដើម្បីឱ្យបម្រើដល់ព្រះអម្ចាស់ ដែលគ្រប់ទាំងស្ដេចនៅប្រទេសអ៊ីស្រាអែល គួរតែធ្វើជា "ស្ដេចសូល" នៅពេលក្រោយទៀត ។

**២:១-១០** សេចក្ដីអធិស្ឋានរបស់នាងហាណា គឺមាន២ផ្នែកស្មើៗគ្នា (ខ.១-៥,៦-១០) ។ នៅក្នុងផ្នែកដែលមានសារៈសំខាន់ទាំង២នេះ មានភាពស្ទួនគ្នារវាងបរិបទទី១ និងបរិបទទី២ ដែលគេផ្ដោតលើការសរសើររបស់នាងហាណា ពីការគោរពចំពោះព្រះអម្ចាស់ដែលទ្រង់បាន "លើកតម្កើង" ចំពោះ "ស្នែង" របស់នាង ទៅជាការរីករាយសាទរចំពោះព្រះអម្ចាស់ដែលទ្រង់ និង "លើកថ្កើង" ចំពោះ "ស្នែង" នៃអ្នកដែលទ្រង់បានចាក់ប្រេងតាំងឱ្យផង ។

**២:១** *អធិស្ឋាន* សេចក្ដីអធិស្ឋានរបស់នាងហាណា (ខ.១-១០) គឺជាចម្រៀងនៃការសរសើរតម្កើង និងការអរព្រះគុណចំពោះព្រះអម្ចាស់ (សូមមើល ទដ ៧២:២០ កន្លែងដែលទំនុករបស់ស្ដេចដាវីឌ បាននិយាយថា "ពាក្យអធិស្ឋាន") ។ ទំនុកនៃចម្រៀងនេះ ពេលខ្លះវាគឺជា "ទំនុកនៃការសរសើររបស់សញ្ញាចាស់" ពីព្រោះវាមានភាពប្រហាក់ប្រហែលគ្នានៅនឹង "ទំនុកនៃការសរសើរនៅក្នុងសញ្ញាថ្មី" (ចម្រៀងនាងម៉ារា លក ១:៤៦-៥៥) ។ ជាមួយគ្នានោះផងដែរ វាក៏មានភាពដូចគ្នាទៅនឹង "ការប្រសិទ្ធិពរ" (ចម្រៀងរបស់សាការី លក ១:៦៧-៧៩) ។ ចម្រៀងនៃការសរសើររបស់នាងហាណា និងឃើញមានជាច្រើននៅក្នុងទំនុកចម្រៀងរបស់ស្ដេចដាវីឌ ដែលជិតចុងបញ្ចប់នៃព្រះគម្ពីរ (២សយ ២២) ។ បទចម្រៀងទាំង២នេះ បានបង្ហាញពីគំនិតស្នូលនៃការរៀបរាប់ ហើយបរិបទរបស់គេគឺជាគោលសំខាន់របស់ព្រះអម្ចាស់ ដែលការរៀបរាប់នេះមានទំនាក់ទំនងជាមួយគ្នា ដោយគេបានបញ្ចូលវិជ្ជាសិក្សាអំពីព្រះ ទៅក្នុងទំនុកនៃការសរសើរ ។ នាងហាណា បាននិយាយតាមរបៀបការថ្លែងទំនាយនេះ ពីពេលវេលា ដែលពួកអ៊ីស្រាអែលប្រហែលឈានចូលដល់តំណាក់កាលជាប្រវត្តិសាស្ត្រថ្មី ដែលនឹងរៀបចំឱ្យមានស្ដេច តាមរយៈលោកសាំយ៉ូអែលជាកូនប្រុសរបស់នាង ។ *រីករាយសាទរចំពោះព្រះអង្គ* ប្រភពនៃអំណរដ៏អស្ចារ្យរបស់នាងហាណា មិនមានដោយសារកូនប្រុសនោះឡើយប៉ុន្តែ គឺដោយសារព្រះអង្គដែលទ្រង់ បានឆ្លើយតបចំពោះសេចក្ដីអធិស្ឋានរបស់នាងវិញ ។ *ស្នែងខ្ញុំម្ចាស់បានថ្កើងឡើង* ប្រៀបធៀបនឹង ចទ ៣៣:១៧ ទដ ៧៥:៤ និងការពន្យល់ ៩២:១០ ១១២:៩ លក ១:៦៩ និងការពន្យល់ ។ ការ

ចំពោះសេចក្តីសង្គ្រោះរបស់ទ្រង់ ២គ្មានព្រះណាបរិសុទ្ធ[ច]
ដូច[ឆ]ព្រះយេហូវ៉ាឡើយ ដ្បិតក្រៅពីទ្រង់ គ្មានព្រះឯណា
ទៀតសោះ ក៏គ្មានព្រះឯណាដែលទុកជាថ្មដា[ជ] ឱ្យដូចព្រះ
នៃយើងខ្ញុំដែរ ៣កុំឱ្យពោលពាក្យអំនួតដ៏លើសលប់ដូច្នេះ
ទៀត កុំឱ្យមានសេចក្តីឃ្មើសឃ្មោងចេញពីមាត់ឯងឡើយ[ឈ]
ពីព្រោះព្រះយេហូវ៉ាទ្រង់ជាព្រះដែលជ្រាបទាំងអស់[ញ] គឺ
ទ្រង់ហើយ ដែលថ្លឹង[ដ]អស់ទាំងអំពើ[ឋ] ៤ធ្នូនៃពួកខ្លាំងពូកែ
បានបាក់ហើយ[ឌ] តែពួកអ្នកដែលល្វើយ បានក្រវាត់ឡើង
ដោយកំឡាំងវិញ[ឍ] ៥ពួកអ្នកដែលពីដើមឆ្អែត គេបានទៅ
ជាស៊ីឈ្នួលចិញ្ចឹមជីវិត តែពួកអ្នកដែលពីដើមអត់ឃ្លាន[ណ]
គេបានឆ្អែតវិញ បានជានាងស្រីអារ[ត]បង្កើតកូនបាន៧
ហើយនាងដែលមានកូនច្រើនបានរីងរៃទៅ ៦ឯសេចក្តី
ស្លាប់ ហើយនិងជីវិត[ថ] នោះស្រេចនៅព្រះយេហូវ៉ា ទ្រង់នាំ
ចុះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយក៏នាំឡើងមក
វិញដែរ[ទ] ៧ឯការក្រ ហើយនិងមាន នោះ[ធ]ស្រេចនៅព្រះ
យេហូវ៉ា គឺទ្រង់ដែលបន្ទាបទៅ ហើយគឺទ្រង់ដែលលើក
ឡើងដែរ[ន] ៨ទ្រង់លើក[ប]មនុស្សក្រីក្រ[ផ]ពីធូលីដី[ព] ហើយស្រង់
មនុស្សកំសត់ទុរគត[ភ]ពីគំនរលាមកឡើង ឱ្យគេបានអង្គុយជា
មួយនឹងពួកត្រកូលខ្ពស់ ហើយឱ្យគេគ្រងមរដក ជាបល្ល័ង្ក
ឧត្តុង្គឧត្តម[ម] ដ្បិតអស់ទាំងសសរ[យ]នៃផែនដីជារបស់ផង
ព្រះយេហូវ៉ា ហើយទ្រង់បានដាក់លោកីយនៅលើសសរ
ទាំងនោះ ៩ទ្រង់នឹងគាំពារជើង[រ]នៃពួកអ្នកបរិសុទ្ធរបស់
ទ្រង់[ល] តែពួកអាក្រក់នឹងត្រូវស្ងៀមស្ងាត់នៅក្នុងទីងងឹតវិញ[វ]
ដ្បិតមនុស្សមិនមែនឈ្នះដោយនូវកំឡាំង[ស]បានទេ ១០ឯពួក
អ្នកដែលតតាំងនឹងព្រះយេហូវ៉ា នោះនឹងត្រូវខ្ទេចខ្ទីទៅ[ហ]
ទ្រង់នឹងបញ្ចេញផ្គរលាន់[ឡ]ពីលើមេឃមកទាស់នឹងគេព្រះ
យេហូវ៉ាទ្រង់នឹងជំនុំជំរះ[អ] រហូតដល់អស់ទាំងចុងផែនដី

**២:២** ច នក ១៥:១១ លវ ១១:៤៤ ឆ នក ៨:១០ ងស ៤០:២៥ ៤៦:៥ ជ លប ៤៩:២៤ នក ៣៣:២២ ចទ ៣២:៣៧ ២សយ ២២:២,៣២ ២៣:៣ ទដ ៣១:៣ ៧១:៣ **២:៣** ឈ ទដ ១៧:១០ ៣១:១៨ ៧៣:៨ ៧៥:៤ ៩៤:៤ ញ យស ២២:២២ ដ សភ ១៦:២ ២៤:១១–១២ ឋ ១សយ ១៦:៧ ១ពវ ៨:៣៩ ១រប ២៨:៩ ២រប ៦:៣០ សភ ១៥:១១ យរ ១១:២០ ១៧:១០ **២:៤** ឌ ២សយ ១:២៧ ទដ ៣៧:១៥ ៤៦:៩ ៧៦:៣ ឍ យប ១៧:៩ អស ៤០:៣១ ៤១:១ ៥២:១ ៥៧:១០ **២:៥** ណ លក ១:៥៣ ត ទដ ១១៣:៩ អស ៥៤:១ យរ ១៥:៩ **២:៦** ថ ចទ ៣២:៣៩ ទ អស ២៦:១៩ អគ ៣៧:៣,១២ **២:៧** ធ ចទ ៨:១៨ ន យប ៥:១១ ៤០:១២ ទដ ៧៥:៧ អស ២:១២ ១៣:១១ ២២:១៩ ដយ ៤:៣៧ **២:៨** ប ទដ ១១៣:៧–៨ ផ យក ២:៥ ព ១ពវ ១៦:២ ភ ទដ ៧២:១២ ១០៧:៤១ ១៤៥:១៤ ១៤៦:៨ មថ ២៣:១២ ម ២សយ ៧:៨ យប ៣៦:៧ អស ២២:២៣ អគ ២១:២៦ យ យប ១៥:៧ ៣៨:៤ ទដ ១០៤:៥ សភ ៨:២៩ អស ៤០:១២ យរ ១០:១២ **២:៩** រ ទដ ៩១:១២ ១២១:៣ សភ ៣:២៦ ល សភ ២:៨ វ យប ១០:២២ អស ៥:៣០ ៨:២២ ៥៩:៩ ៦០:២ យរ ១៣:១៦ អម ៥:១៨, ២០ សផ ១:១៤–១៥ មថ ៨:១២ ស ១សយ ១៧:៤៧ ទដ ៣៣:១៦–១៧ សក ៤:៦ **២:១០** ហ នក ១៥:៦ ឡ នក ១៩:១៦ ១សយ ៧:១០ ១២:១៧ ២សយ ២២:១៤ យប ៣៧:៤,៥ ៣៨:១ ទដ ១៨:១៣ ២៩:៣ អស ៦៦:៦ អ ទដ ៩៦:១៣ ៩៨:៩ មថ ២៥:៣១–៣២

---

ដែលព្រះអម្ចាស់លើកស្នែងនរណាម្នាក់ឡើង គឺមានន័យថាបានទទួលការដោះលែងពីការអាម៉ាស់ ឱ្យមានកិត្តិយស ហើយរឹងប៉ឹង ។

**២:២** *គ្មានព្រះណាបរិសុទ្ធ ដូចព្រះយេហូវ៉ាឡើយ* មើល លវ ១១:៤៤ និងការពន្យល់ ។ *ដ្បិតក្រៅពីទ្រង់គ្មានព្រះឯណាទៀតសោះ* មើល ២សយ ៧:២២ ២២:៣២ ចទ ៤:៣៥ និងការពន្យល់ អស ៤៥:៦ ។ *ថ្មដា* គឺជាការប្រៀបធៀបពិពណ៌នាអំពីកម្លាំង និងភាពស្ថិតស្ថេរ អំពីព្រះអម្ចាស់ជាព្រះនៃអ៊ីស្រាអែលថា ទ្រង់នឹងការពារពួកគេ សុវត្ថិភាពនឹងមិនដែលចាកចេញពីពួកគេឡើយ (មើល ២សយ ២២:២ និងការពន្យល់ ទដ ១៩:១៤ អស ១៧:១០ និងការពន្យល់) ។

**២:៣** *អំនួតដ៏លើសលប់ . . . សេចក្តីឃ្មើសឃ្មោង* ចរិតមារយាទលក្ខណៈរបស់ភីនេហាស គឺពោរពេញដោយអំនួត (ព្រមទាំងអ្នកផ្សេងៗទៀត ដែលមាននៅក្នុងការរៀបរាប់នៃព្រះគម្ពីរសាំយូអែល ១–២ ដូចជាកូនរបស់អេលីពួកភីលីស្ទីន ស្តេចសូល លោកណាបាល លោកកូលីយ៉ាត លោកអាប់សាឡុម លោកសាំមា និងលោកសេបា) ។ *ព្រះយេហូវ៉ាទ្រង់ជាព្រះដែលជ្រាបទាំងអស់* សូមមើល ១៦:៧ ១ពវ ៨:៣៩ ទដ ១៣៩:១–៦ និងការពន្យល់ យហ ២:២៤–២៥ ។

**២:៤–៥** នៅក្នុងគំរូលំដាប់នៃឧទាហរណ៍នេះ គឺបានទាញយកពីជីវិតប្រចាំថ្ងៃ ដែលនាងហាណាបង្ហាញថា ជាញឹកញាប់ព្រះអម្ចាស់តែងតែជំទាស់ទៅនឹងសេចក្តីសង្ឃឹមតាមលក្ខណៈធម្មជាតិ ហើយព្រះអម្ចាស់បានធ្វើឱ្យមានការភ្ញាក់ផ្អើលដែលមិននឹកស្មានដល់ ដូចដែលមាននៅក្នុងរឿងនេះស្រាប់ ។

**២:៥** *បង្កើតកូនបាន៧* សូមមើល ១:៨ និងការពន្យល់ នរ ៤:១៥ ។

**២:៦–៨** នាងហាណាបាននិយាយថា ជីវិតនិងសេចក្តីស្លាប់ មានហើយនិងក្រ គឺស្រេចតែព្រះយេហូវ៉ា ដែលទ្រង់ជាអធិបតេយ្យភាព ។ វគ្គនៃរឿងទាំងអស់ គឺបានបង្ហាញនៅក្នុងការរៀបរាប់នេះស្រាប់ (សូមមើល ចទ ៣២:៣៩ ១ពវ ១៧:២០–២៤ ២ពវ ៤:៣២–៣៥ យហ ៥:២១ ១១:៤១–៤៤) ។

**២:៦** *ស្ថានឃុំព្រលឹងមនុស្សស្លាប់* សូមមើលការពន្យល់ក្នុង លប ៣៧:៣៥ ។

**២:៨** *សសរនៃផែនដី* សសរគឺជារូបភាពដ៏សាមញ្ញមួយនៅក្នុងសញ្ញាចាស់ សម្រាប់ធ្វើជាគ្រឹះដ៏រឹងមាំរបស់ផែនដី (ជាដីគោកដែលមនុស្សរស់នៅ មិនមែនជាផ្កាយព្រះភពនោះឡើយ លប ១:១០) ។ ឃ្លានេះមិនបានបង្រៀនពីលក្ខណៈពិសេសណាមួយ ពីទ្រឹស្តីនៃរចនាសម្ព័ន្ធរបស់ផែនដីនោះឡើយ (សូមមើល យប ៩:៦ ៣៨:៦ ទដ ២៤:២ និងការពន្យល់ ៧៥:៣ ១០៤:៥ សក ១២:១) ។

**២:៩** *គាំពារជើង* នៅសម័យបុរាណ ភាគច្រើននៃប្រជាជនអ៊ីស្រាអែលតែងតែដើរដោយថ្មើរជើង ដែលនៅលើផ្លូវនោះសម្បូណ៌ទៅដោយថ្ម និងប្រកបដោយគ្រោះថ្នាក់ (មើល ទដ ៩១:១១–១២ ១២១:៣) ។ *ពួកអ្នកបរិសុទ្ធ* គឺជាមនុស្សដែលមានចិត្តស្មោះត្រង់ចំពោះព្រះអម្ចាស់ ។ ពាក្យដើមនៃព្រះគម្ពីរភាសាហេព្រើរពាក្យនេះអាចប្រើបានទាំងព្រះអម្ចាស់ និងរាស្ត្ររបស់ទ្រង់នៅក្នុង ២សយ ២២:២៦ ដើម្បីចង្អុលបង្ហាញពីចរិតលក្ខណៈនៃការទំនាក់ទំនងរបស់ពួកគេចំពោះគ្នាទៅវិញទៅមក ។ ជាមួយគ្នានោះដែរពាក្យថា "ពួកអ្នកបរិសុទ្ធ" នេះក៏អាចមានន័យថា "ពួកអ្នកដែលកោតខ្លាចដល់ព្រះ" (សូមមើល ទដ ១២:១ ៣២:៦) និង "អ្នកដែលស្មោះត្រង់" (សភ ២:៨) សូមមើល ទដ ៤:៣ និងការពន្យល់ ។

**២:១០** *ជំនុំជំរះ* ព្រះអម្ចាស់ទ្រង់នឹងជំនុំជម្រះតាមច្បាប់ដ៏សុចរិតរបស់ទ្រង់ (មើល ទដ ៩៦:១៣ ៩៨:៩) ។ *រហូតដល់អស់ទាំងចុងផែនដី* គឺមានន័យថា

ហើយទ្រង់នឹងប្រទានអំណាច[ក]ដល់ស្តេចនៃទ្រង់ ព្រមទាំង
ដំកើងស្នែង[ខ]នៃអ្នកដែលទ្រង់បានចាក់ប្រេងតាំងឱ្យផង
១១រួចពីនោះហើយ អែលកាណាក៏ត្រឡប់វិលទៅឯផ្ទះ
នៅរ៉ាម៉ាវិញ[គ] តែឯកូនតូចបាននៅធ្វើការងារ[ឃ]ថ្វាយព្រះ
យេហូវ៉ា នៅចំពោះអេលីដ៏ជាសង្ឃ ។

**កូនគំរក់របស់លោកអេលី**

១២[ង]រីឯពួកសង្ឃ ជាកូនរបស់អេលី គេជាមនុស្សគំរក់
អាក្រក់ ឥតស្គាល់[ង]ដល់ព្រះយេហូវ៉ាទេ ១៣ឯទំលាប់ដែល
គេប្រព្រឹត្ត[ច]ចំពោះបណ្តាជន នោះគឺដូច្នេះ បើមានអ្នកណា
ថ្វាយយញ្ញបូជា នោះអ្នកបំរើរបស់សង្ឃតែងយកសមមាន
ធ្មេញ៣មកកាន់នៅដៃ ក្នុងពេលដែលគេកំពុងស្ងោរសាច់[ឆ]
១៤ហើយចាក់ចុះទៅក្នុងខ្ទះ ឬថ្លាង ឬឆ្នាំង រួចសង្ឃក៏យក
សាច់ទាំងអស់ដែលជាប់នឹងសមនោះមក គេធ្វើដូច្នោះដល់
ពួកអ៊ីស្រាអែលទាំងប៉ុន្មាន ដែលមកឯស៊ីឡូរ ១៥មួយទៀត
មុនដែលគេដុតខ្លាញ់ នោះអ្នកបំរើរបស់ពួកសង្ឃ ក៏មក
និយាយនឹងមនុស្សដែលថ្វាយយញ្ញបូជាថា ចូរឱ្យសាច់ដែល
សំរាប់អាំងដល់ពួកសង្ឃមក ដ្បិតលោកមិនយកសាច់ស្ងោរ
ពីឯងទេ លោកយកតែសាច់ឆៅវិញ ១៦បើសិនជាអ្នកនោះ
ឆ្លើយឃាត់ថា ចាំឱ្យដុតខ្លាញ់[ជ]មុនសិន រួចសឹមយកតាមចិត្ត
ចុះ នោះគេឆ្លើយឡើងថា ទេ ត្រូវតែឱ្យមកឥឡូវនេះ បើ
មិនដូច្នោះ អញនឹងយកទាំងបង្ខំ ១៧ដូច្នេះបាបរបស់មនុស្ស
កំឡោះទាំងនោះ មានទំងន់ខ្លាំងណាស់នៅចំពោះព្រះយេ
ហូវ៉ា ដ្បិតគេបានមើលងាយដល់ដង្វាយនៃព្រះយេហូវ៉ា[ឈ] ។
១៨ឯសាំយូអែល ជាក្មេងតូចនោះ ក៏តែងពាក់អេផូឌ[ញ]
ធ្វើពីសំពត់ខ្លូតទេស ដើម្បីសំរេចការងារ[ដ]នៅចំពោះ

**២:១០** ក ទដ ១៨:១ ២១:១ ៥៩:១៦ ខ ចទ ៣៣:១៧ ទដ ៨៩:២៤ លក ១:៦៩ **២:១១** គ យស ១៨:២៥ ឃ ខ.១៨ ជន ១៦:៩ ១សយ ៣:១ **២:១២** ង យរ ២:៨ ៩:៦ **២:១៣** ច ចទ ១៨:៣ ឆ លវ ៧:៣៥–៣៦ **២:១៦** ជ លវ ៣:៣,១៤–១៦ ៧:២៩–៣៤ **២:១៧** ឈ ខ.២២,២៩ ជន ១៤:១១ យរ ៧:២១ អក ២២:២៦ មឡ ២:៧–៩ **២:១៨** ញ ខ.១១ដ ខ.២៨ ១សយ ២:១៨ ២៣:៩ ២សយ ៦:១៤ ១របា ១៥:២៧

គ្រប់អស់ទាំងប្រជាជាតិ និងមនុស្សទាំងអស់ (មើល ចទ ៣៣:១៧ អស ៤៥:២២) ។ *ស្តេចនៃទ្រង់* សេចក្តីអធិស្ឋានរបស់នាងហាណានៅទីនេះ គឺជាការថ្លែងទំនាយ ពីការតាំងរាជ្យរបស់ទ្រង់ឡើងនៅលើពួកអ៊ីស្រាអែល និងជាសមិទ្ធិកម្មដំបូង អំពីព្រះមែស៊ី នៅក្នុងរាជ្យដាវីឌ (លក ១:៦៩) ។ នៅទីបំផុតការសង្ឃឹមទុករបស់នាងត្រូវបានសម្រេច នៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទ និងជ័យជម្នះរបស់ទ្រង់លើខ្មាំងសត្រូវរបស់ព្រះអម្ចាស់ ។ *ដំកើងស្នែង* សេចក្តីសង្ឃឹមពីការ "តម្កើង/ថ្កើងឡើង" ស្នែងនៃព្រះមហាក្សត្រ គឺបានសម្រេចដូចអ្វី ដែលជាការសង្ឃឹមទុករបស់នាងហាណាមែន (សូមមើល ខ.១) ។ ពាក្យថាស្នែង ប្រហែលជាបានដកស្រង់ចេញពីចម្រៀង ហើយវាជាផ្នែកមួយដែលមានសារៈសំខាន់ នៅក្នុងផ្ទៃរឿងទាំងមូល ។ *ចាក់ប្រេងតាំង* អត្ថន័យដំបូងនៅក្នុងព្រះគម្ពីរ គឺសំដៅលើការចាក់ប្រេងតាំងរបស់ព្រះអម្ចាស់ ឧទាហរណ៍ ព្រះអម្ចាស់បានចាក់ប្រេងតាំងដល់ស្តេច (សង្ឃក៏ត្រូវបានចាក់ប្រេងតាំង ឱ្យធ្វើជាអ្នកបម្រើរបស់ព្រះអង្គដែរ សូមមើល នក ២៨:៤១ លវ ៤:៣) ។ ជានិច្ចកាលពាក្យនេះក៏មានន័យដូចគ្នា នឹងពាក្យថា "មហាក្សត្រ" (ដូចជានៅទីនេះជាដើម) ហើយក៏ជាវាក្យស័ព្ទគ្រឹះសម្រាប់ជាគំនិតដល់ព្រះមែស៊ីដែរ ។ "ចាក់ប្រេងតាំង" និង "ព្រះមែស៊ី" គឺជាការបកប្រែចេញពីព្រះគម្ពីរភាសាហេព្រើរនូវពាក្យតែ១ ។ នៅក្នុងការបកប្រែភាសាក្រិកចេញពីភាសាហេព្រើរពាក្យនេះមានន័យថា "គ្រីស្ទ័រ" ដែលក្លាយមកពីភាសាអង់គ្លេស គឺពាក្យថា "ព្រះគ្រីស្ទ" (សូមមើលការពន្យល់ក្នុង មថ ១:១៧) ។ ព្រះមហាក្សត្រ (ចេញមកពីអំបូរយូដា) គឺជាការថ្លែងទំនាយដំបូងរបស់លោកយ៉ាកុប (លប ៤៩:១០) ។

**២:១១** *ធ្វើការងារ* ការងារជាអ្នកបម្រើរបស់ក្មេងនោះ ប្រហែលជាអ្នកជំនួយដល់សង្ឃ ។ *ថ្វាយព្រះយេហូវ៉ា* គឺធ្វើការងារនៅក្នុងតំណាក់នៃព្រះ (មើល ១:២៤) ។

**២:១២** *មនុស្សគំរក់អាក្រក់* សូមមើល ១:១៦ និងការពន្យល់ ។ *ឥតស្គាល់* តាមលក្ខណៈអក្សរសាស្ត្រ និយាយថា "មិនស្គាល់" ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ការដែលប្រើពាក្យ "ស្គាល់" មិនមែនប្រើសម្រាប់ពួកបញ្ញវ័ន្តនិងអ្នកដែលពូកែខាងទ្រឹស្តីនោះទេ តែវាគឺសំដៅលើទំនាក់ទំនងជាមួយព្រះអម្ចាស់ ហើយទទួលព្រះអង្គឱ្យគង់នៅក្នុងជីវិត ។ វគ្គនេះជានិច្ចកាលតែងតែមានការព្រមព្រៀង ដោយគ្មានការលាក់បាំងនោះឡើយ (មើល យរ ៣១:៣៤ ហស ២:២០ និងការពន្យល់) ។

**២:១៣–១៦** តាមការប្រមើលនៅក្នុង ខ.១៣–១៤ គឺជាការពិពណ៌នាពីរបៀបនៃការប្រព្រឹត្ត ដែលគួរទទួលយកបាន គឺដែលកំណត់ឱ្យដង្វាយមេត្រីមួយផ្នែកជាចំណែករបស់សង្ឃ (មើល លវ ៧:៣១–៣៦ ១០:១៤–១៥ ចទ ១៨:១–៥) តាមទម្លាប់ដែលបានសន្មត់ទុក ដោយផ្អែកលើការកំណត់ដោយការស្មានថា ការចាក់នឹងសមទាំងនោះ អាចចៃដន្យល្អ ក្នុងការទទួលចំណែកដោយយុត្តិធម៌ ។ ខ.១៥–១៦ ពិពណ៌នាពីរបៀបដែលកូនរបស់អេលីប្រព្រឹត្តអាក្រក់ ។

**២:១៥** *មុនដែលគេដុតខ្លាញ់* ខ្លាញ់ដែលដុតនៅលើអាសនា នោះគឺជាចំណែករបស់ព្រះអម្ចាស់ ដែលទ្រង់ទទួលយកមុនគេ (មើល លវ ៣:១៦ និងការពន្យល់ ៤:១០,២៦,៣១,៣៥ ៧:៣០–៣១ ១៧:៦) ។ *អាំង* ពីព្រោះសាច់ស្ងោរ គឺជាទម្រង់នៃការចំអិនសម្រាប់ជាចំណែករបស់សង្ឃ នៅក្នុងលក្ខណៈពិសេសណាមួយ តាមក្រឹត្យវិន័យតែប៉ុណ្ណោះ មិនមែនទូទៅឡើយ (មើល ជន ៦:១៩–២០) ។ ចំណែកនៃសាច់អាំងនេះ គឺគ្មានកន្លែងណាសម្តែងប្រាប់ពីការហាមឃាត់មិនឱ្យធ្វើ នៅក្នុងក្រឹត្យវិន័យនោះឡើយ ប៉ុន្តែគឺសម្រាប់តែលក្ខណៈ ពិសេសក្នុងពិធីបុណ្យរំលងតែប៉ុណ្ណោះ (មើល នក ១២:៨–៩ ចទ ១៦:៧) ។ នៅក្នុងឃ្លានេះមើលទៅដូចជាចង់និយាយថា សម្រាប់ពួកសង្ឃ ដែលយកចំណែករបស់គេមកដុតជាយញ្ញបូជា នោះមិនស្របច្បាប់ឡើយ ។

**២:១៦** *យកទាំងបង្ខំ* ចំណែករបស់សង្ឃ គឺជាការថ្វាយដោយស្ម័គ្រពីចិត្តនៃពួកអ្នកដែលមកថ្វាយយញ្ញបូជា (មើល លវ ៧:២៨–៣៦ ចទ ១៨:៣) ។

**២:១៨** *ឯសាំយូអែល* នៅចន្លោះជំពូក ២:១២ និង ៤:១ អ្នកនិពន្ធបានណែនាំអំពីភាពផ្ទុយគ្នា ពីការវៃឆ្លាតរបស់លោកសាំយូអែល និងកូនរបស់លោកអេលី ។ *អេផូឌ* គឺជាសំលៀកបំពាក់របស់សង្ឃ សម្រាប់ពួកអ្នកធ្វើការថ្វាយព្រះអម្ចាស់ នៅក្នុងទីបរិសុទ្ធរបស់ទ្រង់ (មើល ២២:១៨ ២សយ ៦:១៤) ។ សំលៀកបំពាក់របស់លោកសាំយូអែល គឺដូចគ្នា និងអេផូតដែលជាសំលៀក

ព្រះយេហូវ៉ា ១៩ហើយម្តាយក៏ធ្វើអាវតូច១ យកមកឱ្យរាល់
តែឆ្នាំ[ឋ] ក្នុងកាលដែលនាងឡើងមកជាមួយនឹងប្តី ដើម្បី
ថ្វាយយញ្ញបូជាដែលត្រូវថ្វាយរាល់តែឆ្នាំ ២០នោះអេលី
លោកឱ្យពរដល់អែលកាណា និងប្រពន្ធផងថា សូមព្រះ
យេហូវ៉ាប្រទានឱ្យអ្នកបានពូជពង្ស ដោយសារស្រីនេះ
ជំនួសកូននេះ ដែលនាងបានសូម[ឌ]ពីទ្រង់ រួចគេក៏ត្រឡប់
វិលទៅផ្ទះវិញ ២១ក្រោយមក ព្រះយេហូវ៉ាទ្រង់ក៏ប្រោស
ប្រទានឱ្យនាងហាណា[ឍ]មានទំងន់បង្កើតបានកូនប្រុស៣កូន
ស្រី២ទៀត ឯសាំយូអែលជាក្មេងតូចនោះ ក៏មានវ័យធំ
ឡើង[ណ]នៅចំពោះព្រះយេហូវ៉ា ។
២២រីឯអេលី លោកចាស់ណាស់ហើយ លោកក៏បានឮ
ពីការទាំងប៉ុន្មាន[ត] ដែលពួកកូនខ្លួនបានប្រព្រឹត្តដល់ពួក
អ៊ីស្រាអែលទាំងអស់ ព្រមទាំងអំពើ ដែលគេតែងដេកនឹង
ពួកស្រីៗ[ថ] ជាអ្នកធ្វើការងារនៅមាត់ទ្វារត្រសាលជំនុំផង
២៣ដូច្នេះលោកសួរថា ហេតុអ្វីបានជាឯងប្រព្រឹត្តអំពើយ៉ាង
នេះ ដ្បិតអញបានឮបណ្តាជននិយាយ ពីអំពើអាក្រក់របស់
ឯងនេះ ២៤កុំឡើយ កូនអើយ ដ្បិតសេចក្តីដែលអញឮគេ
និយាយនោះមិនល្អទេ យ៉ាងនោះឯងនាំឱ្យរាស្ត្ររបស់ព្រះ
យេហូវ៉ាប្រព្រឹត្តរំលងហើយ ២៥បើមនុស្សម្នាក់ធ្វើបាបនឹង

**២:១៩** ឋ ១សយ ១:៣
**២:២០** ឌ ១សយ ១:២៧
**២:២១** ឍ លប ២១:១ ណ ពជ ១៣:២៤ លក ១:៨០ ២:៤០
**២:២២** ត ខ.១៧ ថ នក ៣៨:៨
**២:២៥** ទ នក ៤:២១ យស ១១:២០ ធ នក ៣២:១០ ជណ ១១:២ ១សយ ៣:១៤ ១ពវ ១៣:៦ យប ៩:៣៣ ទដ ១០៦:៣០ អស ១:១៨ ២២:១៤ យរ ១៥:១ ហព ១០:២៦
**២:២៦** ន ពច ១៣:២៤ លក ២:៥២ ប សភ ៣:៤
**២:២៧** ផ ចទ ៣៣:១ ពច ១៣:៦
**២:២៨** ព នក ២៨:១

ម្នាក់ទៀត នោះមានព្រះទ្រង់ជំនុំជំរះដល់អ្នកនោះ តែបើ
មនុស្សធ្វើបាបនឹងព្រះយេហូវ៉ាវិញ នោះតើមានអ្នកណា
នឹង[ទ]ជួយអង្វរ[ធ]ឱ្យអ្នកនោះបាន ប៉ុន្តែគេមិនព្រមស្តាប់តាម
ឪពុកទេ ព្រោះព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យនឹង
ប្រហារជីវិតគេចោល ២៦ឯសាំយូអែល ជាក្មេងនោះក៏ចេះ
តែមានវ័យចំរើនធំឡើង[ន] ជាទីគាប់ព្រះហឫទ័យដល់ព្រះ
យេហូវ៉ា ព្រមទាំងគាប់ចិត្តដល់មនុស្សលោកកាន់តែច្រើន
ឡើងផង[ប] ។

## ទំនាយទាស់នឹងគ្រួរបស់លោកអេលី

២៧គ្រានោះ មានអ្នកសំណប់របស់ព្រះ[ផ]មកឯអេលី
ពោលថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលយ៉ាងដូច្នេះ តើអញ
មិនបានលេចមក ឱ្យពួកវង្សនៃឰយុកោឯងឃើញ ពីកាល
ដែលគេនៅក្នុងដំណាក់ផារ៉ោន នៅស្រុកអេស៊ីព្ទទេឬអី
២៨តើអញមិនបានរើស[ព]យកគេ ពីពូជអំបូរសាសន៍អ៊ីស្រា–
អែលទាំងប៉ុន្មាន មកធ្វើជាសង្ឃដល់អញ ឱ្យបានពាក់
អេផូឌ[ភ] ឡើងទៅឯអាសនាអញ ដើម្បីនឹងដុតគ្រឿងក្រអូប[ម]
នៅមុខអញ ព្រមទាំងចែកដង្វាយទាំងប៉ុន្មាន[យ]ដែលពួក
កូនចៅអ៊ីស្រាអែលដុតថ្វាយ ឱ្យដល់ពួកគ្រួឰយុកោឯងផង

ភ ១សយ ២២:១៨ ២៣:៦,៩ ៣០:៧ ម នក ២០:៧ យ លវ ៧:៣៥–៣៦

បំពាក់របស់សម្តេចសង្ឃដែរ (មើលការពន្យល់ ខ.២៨ ប្រៀបធៀប នក ៣៩:១–៧) ។

**២:១៩** *អាវតូច១* គឺជាអាវដែលគ្មានដៃ ហើយវែងដល់ក្បាលជង្គង់សម្រាប់ពាក់ពីលើអាវក្នុង តែនៅពីខាងក្នុងអេផូឌ ។ *រាល់តែឆ្នាំ* សូមមើលការពន្យល់ ១:៣ ។

**២:២២** *ដេកនឹងពួកស្រីៗ ជាអ្នកធ្វើការងារ* សូមមើល នក ៣៨:៨ នៅទីនេះគ្មានអ្វីដែលសំអាងថា ជាពួកស្ត្រីដែលមាននិយាយនៅក្នុងសញ្ញាចាស់នោះឡើយ ។ កិច្ចការងារបម្រើរបស់ពួកគេ គឺមិនច្រឡំជាមួយនឹងពួកលេវីទាំងនោះឡើយ គឺបាននិយាយនៅក្នុងកណ្ឌគម្ពីរបញ្ចកណ្ឌ (កណ្ឌទាំង៥ដំបូង) តាំងពីដំបូងមកម្ល៉េះ (សូមមើល ជន ១:៥០ ៣:៦–៨ ៨:១៥ ១៦:៩ ១៨:២–៣) ។ អំពើអសីលធម៌របស់កូនអេលី គឺរំឮកពីរឿងរបស់ពួកកាណាន ដែលប្រព្រឹត្តសេចក្តីកំផឹតនៅក្នុងសាសនារបស់គេ ដោយស្រីសំផឹង ដែលអំពើទាំងនោះ មិនគាប់ព្រះហឫទ័យចំពោះព្រះអម្ចាស់ឡើយ (មើល ចទ ២៣:១៧–១៨) ។

**២:២៣** *លោកសួរ* លោកអេលីបានដាក់ទណ្ឌកម្មដល់កូនប្រុសគាត់ ប៉ុន្តែគាត់មិនបានបញ្ឈប់ការងាររបស់គេពីតំណាក់របស់ទ្រង់ឡើយ ។

**២:២៥** *ព្រះយេហូវ៉ា* លោកអេលីបាន ធ្វើការអះអាងថា នៅពេលអ្នកណាម្នាក់ធ្វើបាបនឹងម្នាក់ទៀត នោះមានអ្នកទី៣ជាអ្នកដោះស្រាយរឿងរបស់គេ (ទោះបីជាជំនុំជំម្រះដោយព្រះអម្ចាស់ ឬអ្នកតំណាងរបស់ទ្រង់ក៏ដោយ សូមមើលការពន្យល់ នក ២២:៨–៩) ប៉ុន្តែ គេធ្វើបាបជាមួយព្រះអម្ចាស់ នោះគ្មានអ្នកណាដោះស្រាយជាមួយគេឡើយ ។ *ព្រះយេហូវ៉ាទ្រង់សព្វព្រះឫទ័យនឹងប្រហារជីវិតគេចោល* នេះគឺជាសេចក្តី អធិប្បាយដ៏សង្ខេបរបស់អ្នកនិពន្ធក្នុងការរៀបរាប់ប៉ុណ្ណោះ មិនមែនព្រះអម្ចាស់មានចេតនា ក្នុងការប្រហារជីវិតកូនប្រុសរបស់លោកអេលីនោះឡើយ ប៉ុន្តែ គ្រាន់តែបង្ហាញថា ការព្រមានរបស់លោកអេលីនោះវាហួសពេលទៅហើយ ។ កូនប្រុសរបស់លោកអេលីបានប្រព្រឹត្តអំពើបាបនោះជាយូរមកហើយ ដែលការជំនុំជម្រះរបស់ព្រះមកលើពួកគេ គឺព្រះអង្គធ្វើឡើងដោយមានការតាំងព្រះទ័យរបស់ទ្រង់រួចមកហើយដែរ ។

**២:២៦** *វ័យចំរើនធំឡើង ជាទីគាប់ព្រះហឫទ័យដល់ព្រះយេហូវ៉ា ព្រមទាំងគាប់ចិត្តដល់មនុស្សលោកកាន់តែច្រើនឡើងផង* សូមប្រៀបធៀបជាមួយការពណ៌នារបស់លោកលូកា អំពីព្រះយេស៊ូវគ្រីស្ទ (លក ២:៥២) ។

**២:២៧** *អ្នកសំណប់របស់ព្រះ* ជានិច្ចកាលគឺគេតែងតែដាក់ឈ្មោះរបៀបនេះចំពោះពួកហោរា (មើល ៩:៦,៩–១០ ចទ ៣៣:១ យស ១៤:៦ ១ពវ ៣១:១ ១៧:២៤ ២ពវ ៤:៩) ។ *ពួកវង្សនៃឰយុកោឯង* គឺនិយាយសំដៅលើលោកអើរ៉ុន ។

**២:២៨** *មកធ្វើជាសង្ឃដល់អញ* ការងាររបស់សង្ឃមាន៣យ៉ាងដែលបានផ្តោតនៅទីនេះ ។ (១). *ឡើងទៅឯអាសនាអញ* ដើម្បីចាត់ចែងរៀបចំពិធីយញ្ញបូជានៅលើអាសនាដង្វាយដុត ក្នុងទីធ្លានៃរោងឧបោសថ ។ (២). *ដុតគ្រឿងក្រអូប* គឺដុតនៅលើអាសនានៃគ្រឿងក្រអូប ដែលស្ថិតនៅក្នុងទីបរិសុទ្ធបំផុត (នក ៣០:១–១០) ។ (៣). *ពាក់អេផូឌ* មើល ខ.១៨ នៅទីនេះប្រហែលជាសំដៅលើអេផូឌដ៏ពិសេសរបស់សម្តេចសង្ឃ(នក ២៨:៦–១៤) ប្រដាប់បាំងដើមទ្រូងនៃការវិនិច្ឆ័យ ដែលមានដាក់យូរីម និងធូមីមត្រូវភ្ជាប់ទៅនឹងអេផូឌ ។ យូរីមនិងធូមីម គឺប្រើដើម្បីទាយទំនាយពីការវិនិច្ឆ័យ និងការដឹកនាំរបស់ព្រះអម្ចាស់ ដែលស្ថិតនៅក្រោមការថែរក្សាពីសំណាក់

ទេឬអី ២៩ បើដូច្នេះ ហេតុអ្វីបានជាឯងរាល់គ្នាជាន់ឈ្លី
យញ្ញបូជា និងដង្វាយរបស់អញទាំងប៉ុន្មាន[រ] ដែលអញបាន
បង្គាប់ឱ្យថ្វាយនៅក្នុងដំណាក់អញ ដោយរាប់អានកូនឯង
ជាជាងអញវិញ[ល] ដើម្បីនឹងធ្វើឱ្យខ្លួនធាត់ធំ ដោយសារ
ចំណែកវិសេសជាងគេក្នុងអស់ទាំងដង្វាយនៃសាសន៍អ៊ីស្រា
អែល ជារាស្ត្ររបស់អញដូច្នេះ ៣០ ហេតុនោះ ព្រះយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលថា អញបាន
សន្យាឱ្យពួកគ្រួឯង និងវង្សព្ធយុកោឯង បានដើរនៅមុខ
អញជាដរាបទៅ[វ] តែឥឡូវនេះ ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលយ៉ាងនេះវិញថា សូមឱ្យគំនិតនោះបានឆ្ងាយចេញ
ពីអញទៅ ដ្បិតអស់អ្នកណាដែលលើកដំកើងអញ នោះអញ
នឹងដំកើង[ស]អ្នកនោះឡើងដែរ ហើយអ្នកណាដែលមើល
ងាយ[ហ]ដល់អញ នោះអញក៏មិនរាប់អានដល់គេដែរ[ឡ]
៣១ មើល នឹងមានគ្រាមកដល់ នោះអញនឹងកាត់អំណាច
របស់ឯងចេញ ព្រមទាំងអំណាចនៃពួកវង្សព្ធយុកោឯង
ដែរ រហូតដល់គ្មានមនុស្សចាស់នៅក្នុងជិន្ធូរវង្សឯងឡើយ[អ]
៣២ នៅកណ្តាលគ្រប់ទាំងការចំរើន ដែលព្រះទ្រង់នឹង
ប្រោសប្រទានដល់សាសន៍អ៊ីស្រាអែល នោះឯងនឹងឃើញ
មានទុក្ខវេទនា[ក]កើតដល់ពួកគ្រួសារឯងវិញ ហើយនិងគ្មាន
មនុស្សចាស់នៅក្នុងជិន្ធូរវង្សឯងជាដរាបទៅ[ខ] ៣៣ អញមិន
កាត់ពួកឯងទាំងអស់ចេញពីអាសនាអញទេ ចំណែកអ្នក
ដែលអញមិនកាត់ចេញ នោះនឹងបានសំរាប់នាំឱ្យស្រវាំង
ដល់ភ្នែកឯង ហើយនិងបញ្ឈឺចិត្តឯងវិញ ឯពូជដែលចំរើន
នៅក្នុងគ្រួឯង[គ] គេនឹងស្លាប់ទៅ ពីកាលកំពុងនៅពេញវ័យ
៣៤ នេះជាទីសំគាល់[ឃ]ដល់ឯង ជាការដែលត្រូវកើតដល់
ហុបនី និងភីនេហាស កូនឯងទាំង២ គឺគេនឹងស្លាប់[ង]ទៅ
ទាំង២នាក់នៅថ្ងៃតែ១[ច] ៣៥ រួចអញនឹងបង្កើតឱ្យមានសង្ឃ១
ដែលស្មោះត្រង់ដល់អញ[ឆ] ជាអ្នកដែលនឹងធ្វើតាមចិត្តតាម
គំនិតអញវិញ ហើយអញនឹងបង្កើតឱ្យអ្នកនោះមានគ្រួដ៏រឹង
ប៉ឹង អ្នកនោះនឹងដើរនៅចំពោះអ្នកដែលអញចាក់ប្រេង
តាំងឱ្យ[ជ] ជារៀងរាបដរាបទៅ ៣៦ គ្រានោះពួកអ្នកដែល
នៅសល់ពីពួកគ្រួឯង គេនឹងមកលុតក្រាបចំពោះអ្នកនោះ
ដើម្បីឱ្យបានប្រាក់ ហើយនិងនំបុ័ង ដោយពាក្យថា[ឈ] សូមឱ្យ
ខ្ញុំបានធ្វើការងារនៃពួកសង្ឃណាមួយ ដើម្បីឱ្យបានអាហារ
បរិភោគផង[ញ]។

**២:២៩** រ ឧ.១២–១៧ ល ចទ ១២:៥ **២:៣០** វ នក ២៩:៩ ស ទដ ៥០:២៣ ៩១:១៥ សភ ៨:១៧ ហ អស ៥៣:៣ ណហ ៣:៦ មឡ ២:៩ ឡ យរ ១៨:១០ **២:៣១** អ ១សយ ៤:១១–១៨ ២២:១៦ **២:៣២** ក ១សយ ៤:៣ ២២:១៧–២០ យរ ៧:១២,១៤ ខ ១ពវ ២:២៦–២៧ **២:៣៣** គ យរ ២៩:៣២ មឡ ២:១២ **២:៣៤** ឃ ចទ ១៣:២ ង ១សយ ៤:១១ ច ១ពវ ១៣:៣ **២:៣៥** ឆ ២សយ ៨:១៧ ២០:២៥ ១ពវ ១:៨,៣២ ៤:៤ ១រប ១៦:៣៩ ២៩:២២ អគ ៤៤:១៥–១៦ ជ ១សយ ៩:១៦ ១០:១ ១៦:១៣ ២សយ ២:៤ ១២:៧ ២៣:១ ១ពវ ១:៣៤ ទដ ៨៩:២០ **២:៣៦** ឈ អគ ៤៤:១០–១៤ ញ ១សយ ៣:១២ ១ពវ ២:២៧

សម្តេចសង្ឃ(មើលការពន្យល់, និងមើល នក ២៨:៣០ ១សយ ២៣:៩–១២ ៣០:៧–៨)។

**២:៣០** *អញបានសន្យា* សូមមើល នក ២៩:៩ លវ ៨–៩ ជន ១៦–១៧ ២៥:១៣ ។ *សូមឱ្យគំនិតនោះបានឆ្ងាយចេញពីអញទៅ* នេះមិនមែនមានន័យថា សេចក្តីសន្យារបស់សង្ឃចំពោះពួកគ្រួអើរ៉ុន ត្រូវបានលុបចោលនោះឡើយ ប៉ុន្តែដោយសារលោកអេលី និងពួកផ្ទះគាត់នឹងត្រូវបណ្តេញចេញពីភាគកម្មនៃឯកសិទ្ធិនេះ ដោយសារតែអំពើបាបរបស់ពួកគេ ។ *ដ្បិតអស់អ្នកណាដែលលើកដំកើងអញ នោះអញនឹងដំកើងអ្នកនោះឡើងដែរ* សូមមើល ឧ.២៩ ។ អភ័យឯកសិទ្ធិខាងវិញ្ញាណ គឺផ្តល់ឱ្យគេនូវទំនួលខុសត្រូវ និង កាតព្វកិច្ច មិនត្រូវបានទទួលការបញ្ឈប់ ឬបដិសេធបាននោះឡើយ (សូមមើល ២សយ ២២:២៦–២៧) ។

**២:៣១** *អំណាច . . . អំណាច* តាមលក្ខណ:អក្សរសាស្ត្រគឺ "ដៃ . . . ដៃ " ដែលដៃ គឺជានិមិត្តរូបនៃអំណាច ។ "ដៃ"របស់អេលី និងពួកសង្ឃនៅក្នុងគ្រួរបស់គាត់នឹងកាត់ចេញ (ផ្ទុយពីស្តេចដាវីឌ ២សយ ២២:៣៥) ។ *គ្មានមនុស្សចាស់នៅក្នុងជិន្ធូរវង្សឯងឡើយ* គឺជាការថ្លែងទំនាយពីការសម្លាប់រង្គាលអំពីសង្ឃ នៅក្នុងគ្រួសាររបស់លោកអេលី ក្នុងពេលដែលកូនប្រុសគាត់បានស្លាប់ (៤:១១) និងការសម្លាប់រង្គាលមកលើកូនចៅរបស់គាត់ពីសំណាក់ស្តេចសូល នៅឯក្រុងណូប (២២:១៨–១៩) ព្រមទាំងការបណ្តេញលោកអ័បៀថើរចេញពីតំណែងជាសង្ឃ (១ពវ ២:២៦–២៧) ។

**២:៣២** *ទុក្ខវេទនាកើតដល់ពួកគ្រួសារឯង* រួមទាំងការចាប់យកហឹបសញ្ញា ដោយពួកភីលីស្ទីន (៤:១–១១) ការបំផ្លាញស្តេចស៊ីហុន (យរ ៧:១៤) និងការតាំងរោងឧបោសថនៅក្រុងណូប (២១:១–៦ និងការពន្យល់) ។

**២:៣៣** នៅក្នុងកន្លែងនេះប្រហែលជាសំដៅទៅលើលោកអ័បៀថើរ ដែលស្តេចសាឡូម៉ូនបានបណ្តេញគាត់ចេញពីតំណែងជាសង្ឃ (សូមមើល ១ពវ ២:២៦–២៧) បន្ទាប់ពីគាត់បរាជ័យក្នុងការប៉ុនប៉ងឱ្យស្តេចអ័ដូនីយ៉ា មានជ័យជម្នះលើស្តេចដាវីឌ ។

**២:៣៤** *ជាទីសំគាល់ដល់ឯង* ការស្លាប់របស់លោកហុបនីនិងលោកភីនេហាស(៤:១១) គឺអនុលោមទៅតាមការថ្លែងទំទាយជាយូរមកហើយ ។ ដូច្នេះហើយការថ្លែងទំនាយរបស់ហោរា គឺមិនមានអ្វីដែលខុសនោះឡើយ (មើល ១០:៧–៩ ១ពវ ១៣:៣ និងការពន្យល់ យរ ២៨:១៥–១៧ លក ១:១៨–២០,៦៤) ។

**២:៣៥** *អញនឹងបង្កើតឱ្យមានសង្ឃ១ដែលស្មោះត្រង់ដល់អញ* គឺបានសម្រេចលើលោកសាដុក ដែលការងារបម្រើរបស់គាត់ដូចជាសង្ឃក្នុងអំឡុងពេលស្តេចដាវីឌសោយរាជ្យ (មើល ២សយ ៨:១៧ ១៥:២៤,៣៥ ២០:២៥) ហើយគាត់ក៏ជាអ្នកជំនួសកន្លែងលោកអ័បៀថើរ ក្នុងនាមជាសម្តេចសង្ឃក្នុងគ្រាស្តេចសាឡូម៉ូន (មើល ១ពវ ២:៣៥ ១រប ២៩:២២) ។ *អញនឹងបង្កើតឱ្យអ្នកនោះមានគ្រួដ៏រឹងប៉ឹង* តាមលក្ខណ:អក្សរសាស្ត្រនិយាយថា "ធ្វើឱ្យគាត់ក្លាយជាអ្នកស្មោះត្រង់" ។ សង្ឃដែលការពារភាពស្មោះត្រង់ និងប្រទានឈ្មោះថា "ស្មោះត្រង់" (ឱ.ស្ថិតស្ថេរ) ដល់គ្រួសារនៃសង្ឃ ។ សូមមើលពាក្យដូចគ្នានេះដែរ ដែលនិយាយចំពោះស្តេចដាវីឌ (២៥:២៨ "តាំងជិន្ធូរវង្ស" មើល ២សយ ៧:១៦ ១ពវ ១១:៣៨) ។ ជិន្ធូរវង្សរបស់លោកសាដុក គឺលោកអ័សារា និងក្លាយជាអ្នកបន្តតំណែងរបស់គាត់ (១ពវ ៤:២) ហើយនៅតែបន្តរហូតដល់គ្រានិរទេស និងត្រឡប់មកវិញ (មើល ១រប ៦:៨–១៥ អរ ៣:២) ។

## ព្រះអម្ចាស់ត្រាស់ហៅលោកសាំយូអែល

៣ ១រីឯសាំយូអែល ក្មេងនោះ ក៏ធ្វើការងារ[ក]ថ្វាយព្រះ
យេហូវ៉ា នៅចំពោះមុខអេលី ក្នុងគ្រានោះ ព្រះបន្ទូលនៃ
ព្រះយេហូវ៉ាកាន់តែក្រទៅ[ខ] ឯការជាក់ស្តែងក៏មិនសូវមាន
ជាញឹកញយដែរ[គ] ២នៅគ្រានោះឯង មានពេល១ដែល
អេលីដេកនៅដំណេករបស់លោក (សម័យនោះភ្នែក[ឃ]
លោកបានចាប់តាំងងងឹតទៅ មើលអ្វីមិនឃើញឡើយ[ង])
៣ហើយសាំយូអែលក៏ដេក នៅក្នុងព្រះវិហារ[ច]ព្រះយេហូវ៉ា
ដែរ ជាកន្លែងដែលមានហឹប[ឆ]នៃព្រះ ក្នុងកាលដែល
ចង្កៀង[ជ]នៃព្រះមិនទាន់រលត់នៅឡើយ ៤នោះព្រះយេហូវ៉ា
ទ្រង់ហៅមកសាំយូអែល ហើយសាំយូអែលតបថា ប្របាទ[ឈ]
៥រួចក៏រត់ទៅឯអេលីសួរថា ខ្ញុំមកហើយ លោកមានការអី
តែអេលីឆ្លើយទៅថា អញគ្មានហៅឯងទេ ចូរទៅដេក
វិញទៅ សាំយូអែលក៏ទៅដេកវិញ ៦នោះព្រះយេហូវ៉ា ទ្រង់
ហៅម្តងទៀតថា នែសាំយូអែល រួចសាំយូអែល ក្រោក
ឡើង ទៅឯអេលីសួរថា ខ្ញុំមកហើយ លោកមានការអី តែ
អេលីឆ្លើយថា កូនអើយ អញគ្មានហៅឯងទេ ចូរទៅដេក
វិញទៅ ៧ឯសាំយូអែលមិនទាន់ស្គាល់[ញ]ព្រះយេហូវ៉ានៅ
ឡើយទេ ព្រះបន្ទូល[ដ]នៃទ្រង់ក៏មិនទាន់បានសំដែង[ឋ]មកឱ្យ
ដឹងដែរ ៨រួចព្រះយេហូវ៉ាទ្រង់ហៅម្តងទៀត ជាគំរប់៣ដង
ថា នែសាំយូអែលអើយ នោះសាំយូអែល ក៏ក្រោកឡើង
ទៅឯអេលីសួរថា ខ្ញុំមកហើយ លោកមានការអី ដូច្នេះ
អេលីក៏យល់ឃើញថា គឺជាព្រះយេហូវ៉ាហើយ ដែលបាន
ហៅក្មេងនេះ ៩លោកក៏ប្រាប់ដល់សាំយូអែលថា ចូរឯង
ដេកទៅ បើឮសូរហៅម្តងទៀត នោះត្រូវឆ្លើយថា បពិត្រ
ព្រះយេហូវ៉ាអើយ សូមទ្រង់មានបន្ទូលមកចុះ ដ្បិតទូលបង្គំ
ជាអ្នកបំរើទ្រង់ ប្រុងស្តាប់ហើយ ដូច្នេះសាំយូអែលបានទៅ
ដេកនៅដំណេកខ្លួនវិញទៅ ។
១០លំដាប់នោះ ព្រះយេហូវ៉ាទ្រង់យាងមកឈរហៅ
ដូចជាជាន់មុនថា សាំយូអែល នែសាំយូអែលអើយ[ឌ] នោះ
សាំយូអែលទូលឆ្លើយថា សូមទ្រង់មានបន្ទូលមកចុះ ដ្បិត
ទូលបង្គំ ជាអ្នកបំរើទ្រង់ប្រុងស្តាប់ហើយ ១១ដូច្នេះព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា មើល អញរៀបនឹងធ្វើការ១
នៅក្នុងសាសន៍អ៊ីស្រាអែល ដែលនឹងធ្វើឱ្យខ្ទរដល់ត្រចៀក
ទាំងសងខាង នៃអស់អ្នកណាដែលឮ[ឍ] ១២នៅថ្ងៃនោះ
អញនឹងសំរេចទាស់នឹងអេលី តាមគ្រប់ទាំងការ[ណ]ដែល
អញ បាននិយាយពីពួកគ្រួលោកហើយ ចាប់តាំងពីដើម
ដរាបដល់ចុងផង ១៣ដ្បិតអញបានប្រាប់លោកហើយថា
អញនឹងជំនុំជំរះពួកគ្រួលោកជាដរាបទៅ ដោយព្រោះ
អំពើដ៏លាមកដែលលោកបានដឹងពីពួកកូនលោក ជាការ
ដែលនាំឱ្យគេត្រូវបណ្តាសា ហើយលោកមិនបានហាម
ឃាត់[ត]ដល់គេទេ ១៤គឺដោយហេតុនោះ បានជាអញស្បថ
ដល់ពួកគ្រួអេលីថា ទោះបើយកយញ្ញបូជា ឬដង្វាយណា
មកថ្វាយក៏ដោយ គង់តែមិនបានធួន[ថ]នឹងអំពើដ៏លាមកដែល
ពួកគ្រួលោកបានប្រព្រឹត្តដែរ នៅជាដរាបតទៅ ។
១៥ស្រេចហើយ សាំយូអែលក៏ដេកដល់ព្រឹក រួចបើក

**៣:១** ក ១សយ ២:១១ ខ ទដ ៧៤:៩ បទ ២:៩ អក ៧:២៦ គ អម ៨:១១
**៣:២** ឃ ១សយ ៤:១៥ ង លប ២៧:១
**៣:៣** ច នក ២៥:៣១-៣៨ លវ ២៤:១-៤ ឆ ១សយ ១:៩ ជ ចទ ១០:១-៥ ១ពវ ៦:១៩ ៨:១
**៣:៤** ឈ លប ២២:១ នក ៣:៤
**៣:៧** ញ ១សយ ២:១២ ដ យរ ១:២ ឋ ជន ១២:៦ អម ៣:៧
**៣:១០** ឌ នក ៣:៤
**៣:១១** ឍ ២ពវ ២១:១២ យប ១៥:២១ យរ ១៩:៣
**៣:១២** ណ ១សយ ២:២៧-៣៦
**៣:១៣** ត ១ពវ ១:៦
**៣:១៤** ថ ១សយ ២:២៥

**៣:១** *រីឯសាំយូអែល ក្មេងនោះ* សូមមើល ២:១១,១៨ ។ ពេលនេះ លោកសាំយូអែល មិនមែននៅក្មេងទៀតឡើយ (មើល ២:២១,២៦) ។ *ព្រះបន្ទូលនៃព្រះយេហូវ៉ាកាន់តែក្រទៅ* មើល សភ ២៩:១៨ និងការពន្យល់, និងមើល អម ៨:១១ ។ នៅ ពច ២:២៧-៣៦ ដែលផ្នែកមួយនៃកណ្ឌគម្ពីរហោរា គឺមានតែហោរា២នាក់ប៉ុណ្ណោះដែលលើកមកនិយាយ (ពច ៤:៤ ៦:៨) និងអ្នកដែលនាំឱ្យប្រទេសផ្លាស់ប្រែ៥នាក់ (ពច ២:១-៣ ៦:១១-២៦ ៧:២-១១ ១០:១១-១៤ ១៣:៣-២១) ។ ដូចគ្នានឹង ២រប ១៥:៣ ដែលបាននិយាយសំដៅលើអំឡុងពេលនោះ ។ *ការជាក់ស្តែង* ប្រៀបធៀប លប ១៥:១ ។

**៣:៣** *ចង្កៀងនៃព្រះមិនទាន់រលត់នៅឡើយ* គឺសំដៅលើជើងចង្កៀងមាសដែលឈរទល់មុខនឹងតុនំបុ័ងតាំងទុក (មើល នក ២៥:៣១-៤០) នៅក្នុងទីបរិសុទ្ធ ។ ចង្កៀងនោះត្រូវដុតជារៀងរហូត ប៉ុន្តែនៅទៀបភ្លឺ គេអាចចូលមកឯចង្កៀងនេះម្តងទៀត នៅពេលណាប្រេងចង្កៀងនោះ ប្រហែលជាស្រអាប់ ឬរលត់ (នក ២៧:២០-២១ ៣០:៧-៨ លវ ២៤:៣-៤ ២រប ១៣:១១ សភ ៣១:១៨) ។ ចង្កៀងដែលគេអនុញ្ញាតឱ្យយកចេញមុនពេលព្រឹកនោះ គឺជាការរំលោភបំពានចំពោះច្បាប់ ដែលមាននិយាយនៅបញ្ចកណ្ឌ ។ *ព្រះវិហារ* សូមមើលការពន្យល់ ១:៩ ។

**៣:៤** *ប្របាទ* សូមមើលការពន្យល់ លប ២២:១ ។

**៣:៥** *អញគ្មានហៅឯងទេ* កំហុសរបស់លោកអេលីក្នុងការទទួលស្គាល់ពីការត្រាស់ហៅរបស់ព្រះចំពោះលោកសាំយូអែលនៅពេលនោះ អាចនិយាយថាគាត់គ្មានភាពស្និទ្ធស្នាលជាមួយព្រះអម្ចាស់ទៀតឡើយ ។

**៣:៧** *មិនទាន់ស្គាល់ព្រះយេហូវ៉ា* គឺមិនទាន់មានបទពិសោធន៍ពីការបើកសម្តែងរបស់ព្រះអម្ចាស់ដោយផ្ទាល់ជាមួយគាត់ឡើយ (សូមមើល នក ១:៨ ពាក់កណ្តាលខចុងក្រោយ) ។

**៣:១០** *សាំយូអែល នែសាំយូអែលអើយ* មើលការពន្យល់ លប ២២:១១ ។

**៣:១១-១៤** ការបើកសម្តែងលើកដំបូងរបស់ព្រះអម្ចាស់ ចំពោះលោកសាំយូអែល គឺជាការសង្ខេបនូវព្រះរាជសារដែលលោកអេលីបានទទួលពី "អ្នកសំណប់របស់ព្រះ" (២:២៧-៣៦) ដូច្នេះហើយ តាមរយៈការធានាអះអាងទាំងនោះបញ្ជាក់ថា ក្មេងប្រុសនោះ គឺបានទទួលការបើកសម្តែងមកពីព្រះមែន ។

**៣:១១** *ខ្ទរដល់ត្រចៀកទាំងសងខាង* សូមមើលការពន្យល់ យរ ១៩:៣ ។

**៣:១៣** *ត្រូវបណ្តាសា* សូមមើល លវ ២៤:១៤-១៦ ។

**៣:១៥** *ទ្វារដំណាក់នៃព្រះយេហូវ៉ា* សូមមើលការពន្យល់ ១:៩ ។ *ការជាក់ស្តែង* សូមមើលការពន្យល់ ខ.១,១១-១៤ ។

ទ្វារដំណាក់នៃព្រះយេហូវ៉ា តែខ្លាចមិនហ៊ានជំរាបពីការ
ជាក់ស្តែងនោះដល់អេលីទេ ១៦ដូច្នេះអេលីហៅសាំយូអែល
មកថា សាំយូអែល កូនអើយ សាំយូអែល ឆ្លើយថា ប្របាទ
១៧រួចអេលីសួរថា ព្រះទ្រង់បានមានបន្ទូលនឹងឯងយ៉ាងដូច
ម្តេចខ្លះ សូមកុំលាក់[ទ]នឹងអញឡើយ បើឯងលាក់ការអ្វីនឹង
អញ ពីគ្រប់ទាំងសេចក្តីដែលទ្រង់បានមានបន្ទូលនឹងឯង
នោះសូមឱ្យព្រះធ្វើដល់ឯងដូច្នោះដែរ ហើយលើសទៅ
ទៀតផង[ធ] ១៨សាំយូអែលក៏ជំរាបដល់លោកទាំងអស់ ឥត
មានលាក់អ្វីឡើយ រួចអេលីនិយាយថា នោះគឺជាព្រះ
យេហូវ៉ាហើយ សូមឱ្យទ្រង់សំរេចតាមតែទ្រង់គិតឃើញ
ថាល្អចុះ[ន] ។
១៩សាំយូអែលកាន់តែធំឡើង[ប] ព្រះយេហូវ៉ាទ្រង់ក៏គង់
នៅជាមួយ[ផ] ហើយមិនឱ្យពាក្យទំនាយណាមួយ[ព]របស់លោក
ជ្រុះធ្លាក់បាត់ឡើយ ២០ឯសាសន៍អ៊ីស្រាអែលទាំងអស់គ្នា
ចាប់តាំងពីក្រុងដាន់ រហូតដល់បៀរ–សេបា[ភ]ក៏ដឹងថា
សាំយូអែលបានតាំងឡើងជាហោរានៃព្រះយេហូវ៉ាហើយ[ម]
២១ក្រោយមក ព្រះយេហូវ៉ាទ្រង់តែងលេចមកនៅត្រង់
ស៊ីឡូរទៀត ដ្បិតបានសំដែង[យ]មកឱ្យសាំយូអែលស្គាល់ នៅ
ត្រង់ស៊ីឡូរ ដោយសារព្រះបន្ទូលនៃទ្រង់ ហើយពាក្យសំដី
របស់សាំយូអែលក៏ឮ ផ្សាយទៅដល់សាសន៍អ៊ីស្រាអែល
ទាំងអស់គ្នា ។

## ពួកភីលីស្ទីនកាន់កាប់ហឹបសញ្ញា

**៤** ១រីឯសាសន៍អ៊ីស្រាអែល គេលើកគ្នាចេញទៅច្បាំងនឹង
ពួកសាសន៍ភីលីស្ទីន បោះទ័ពនៅជិតអេបេន–អេសើរ[ក]
ឯពួកភីលីស្ទីន ក៏បោះទ័ពនៅត្រង់អាផែក[ខ] ២ពួកភីលីស្ទីន
គេដំរៀបទ័ពប្រទល់នឹងអ៊ីស្រាអែល រួចកាលគេបានចូល
ប្រឡូកតដៃគ្នា នោះពួកអ៊ីស្រាអែលបាក់ចាញ់នៅមុខគេ
ហើយគេវាយសំឡាប់ពលទ័ពនៅវាល អស់ប្រហែលជា
៤ពាន់នាក់ ៣ដូច្នេះកាលពួកពលបានចូលមកក្នុងទីបោះ
ទ័ពវិញ នោះពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលជំនុំគ្នាថា
ហេតុអ្វី[គ]បានជាព្រះយេហូវ៉ាទ្រង់វាយយើង នៅចំពោះមុខ

**៣:១៧** ទ ១ពង្សាវតារក្សត្រ ២២:១៤ យរ ២៣:២៨ ៣៨:១៤ ៤២:៤ ធ នរ ១:១៧ **៣:១៨** ន ពច ១០:១៥ **៣:១៩** ប លប ២១:២២ ជណ ១៤:៤៣ ផ ពច ១៣:២៤ ព ១សយ ៩:៦ **៣:២០** ភ ពច ២០:១ ម ចទ ១៨:២២ អគ ៣៣:៣៣ **៣:២១** យ ជន ១២:៦ **៤:១** ក ១សយ ៥:១ ៧:១២ ខ យស ១២:១៨ ១សយ ២៩:១ ១ពង្សាវតារក្សត្រ ២០:២៦ **៤:៣** គ យស ៧:៧

**៣:១៧** *សូមឱ្យព្រះធ្វើដល់ឯងដូច្នោះដែរ ហើយលើសទៅទៀត* គឺជាទម្រង់នៃបណ្តាសា (មើល ១៤:៤៤ ២០:១៣ ២៥:២២ ២សយ ៣:៩,៣៥ ១៩:១៣ នរ ១:១៧ ១ពវ ២:២៣ ២ពវ ៦:៣១) ជាធម្មតា ព្រះអង្គតែងតែជំទាស់ជាមួយគេដោយផ្ទាល់ ប៉ុន្តែ នៅទីនេះព្រះអម្ចាស់ទ្រង់ជំទាស់ជាមួយលោកសាំយូអែល តាមរយៈលោកអេលីវិញ បើសិនជាលោកសាំយូអែលបានលាក់អ្វីដែលព្រះអម្ចាស់ទ្រង់មានបន្ទូល (មើលការពន្យល់ ១៤:២៤) ។

**៣:១៨** *សូមឱ្យទ្រង់សំរេចតាមតែទ្រង់គិតឃើញថាល្អចុះ* លោកអេលីបានថ្វាយបង្គំនៅចំពោះព្រះយេហូវ៉ា ក្នុងកាលដែលគាត់ព្រមទទួលស្គាល់ថាការជំនុំជម្រះគឺប្រកបដោយយុត្តិធម៌ (មើល នក ៣៤:៥–៧) ។

**៣:១៩** *ព្រះយេហូវ៉ាទ្រង់ក៏គង់នៅជាមួយ* ស្តេចដាវីឌក៏បានមានបន្ទូលបែបដូច្នោះដែរ (សូមមើល ១៦:១៨ និងការពន្យល់) ។ *ហើយមិនឱ្យពាក្យទំនាយណាមួយរបស់ លោកជ្រុះធ្លាក់បាត់ឡើយ* ដោយសារគ្មានពាក្យណាមួយរបស់លោកសាំយូអែលបង្ហាញថា មិនអាចពឹងពាក់បាន នោះគាត់ត្រូវបានគេទទួលស្គាល់ថា ជាហោរាដែលបានទាយដោយនូវព្រះបន្ទូលរបស់ព្រះអម្ចាស់ (សូមមើល ខ.២០–២១ ៩:៦) ។

**៣:២០** *ពីក្រុងដាន់រហូតដល់បៀរ–សេបា* ការតាំងសញ្ញានេះ តែងតែមាននិយាយនៅក្នុងគម្ពីរសាំយូអែល ពង្សាវតារក្សត្រ និងរបាក្សត្រ ។ ឃ្លានេះជានិច្ចកាលតែងតែពណ៌នាពីព្រំប្រទល់របស់ទឹកដីសន្យា ។ ដាន់ គឺជាទីក្រុងមួយដែលស្ថិតនៅភាគខាងជើង ដែលមានចម្ងាយយ៉ាងឆ្ងាយពីបៀរ–សេបា ដែលស្ថិតនៅភាគខាងត្បូង ។

**៣:២១** *តែងលេចមកនៅត្រង់ស៊ីឡូរ* ព្រះយេហូវ៉ាតែងតែលេចមកឯពួកអ៊ីស្រាអែល នៅត្រង់ស៊ីឡូរ ប៉ុន្តែបន្ទាប់ពីព្រឹត្តិការណ៍ដែលមាននៅក្នុងជំពូក ៤–៦ ព្រះអម្ចាស់មិនបានលេចមកឯគេនៅត្រង់នេះទៀតឡើយ (មើល យរ ៧:១២–១៤ ២៦:៦) ។ *ពាក្យសំដីរបស់សាំយូអែល . . . សាសន៍អ៊ីស្រាអែលទាំងអស់គ្នា* ធៀបនឹង ៣:១ ។

**៤:១** *អេបេន–អេសើរ* ពាក្យនេះមានន័យថា"ថ្មដានៃសេចក្តីជំនួយ" ទីតាំងពិតប្រាកដនៃទីកន្លែងនេះ មិនបានដឹងពិតប្រាកដឡើយ ប៉ុន្តែប្រហែលជាមានចម្ងាយជិតគ្នា ពីភាគខាងកើតនៃក្រុងអាផែក ។ សូមកុំច្រឡំចំពោះទីតាំងថ្មដែលមានឈ្មោះថា អេបេន–អេសើរមួយទៀត ដែលសម័យក្រោយមកហោរាសាំយូអែលជាអ្នកបង្កើតឡើងនៅចន្លោះមីសប៉ា និងសេ៊ន (មើល ៧:១២) ដើម្បីរំឭកពីជ័យជម្នះដែលគាត់បានឈ្នះលើពួកភីលីស្ទីន ។ *អាផែក* ទីក្រុងនេះប្រហែលជាមានចម្ងាយ ១៩,៣០ គម ភាគខាងជើងនៃឆ្នេរសមុទ្រក្នុងទីក្រុងយ៉ុបប៉េ ។ វត្តមានរបស់ពួកភីលីស្ទីន នៅក្នុងទីក្រុងដែលស្ថិតនៅឯនាយនៃភាគខាងជើងនេះ គឺដើម្បីបង្ហាញពីការគ្រប់គ្រងរបស់ពួកគេ លើអំបូរអ៊ីស្រាអែល ក្នុងទឹកដីកាណាន (ខ.៩ ពច ១៥:១១) ។

**៤:៣** *ហេតុអ្វីបានជាព្រះយេហូវ៉ាទ្រង់វាយយើង* ពួកចាស់ទុំទាំងនោះបានដឹងថា ភាគច្រើននៃការវាយរបស់គេ គឺបណ្តាលមកពីការមិនពេញព្រះទ័យរបស់ព្រះអម្ចាស់ ជាជាងមកពីអំណាចពួកកងទ័ពភីលីស្ទីន ។ ពួកសាសន៍ជិតខាងដែលមិនជឿលើព្រះអម្ចាស់របស់ពួកអ៊ីស្រាអែល ក៏មានជំនឿដែរថា ចម្បាំងទាំងឡាយ គឺស្ថិតនៅលើរូបព្រះជាអ្នកសម្រេច ។ *ដើម្បីឱ្យនៅកណ្តាលពួកយើង . . . នៃពួកខ្មាំងសត្រូវ* ពួកចាស់ទុំសាសន៍អ៊ីស្រាអែលបានបញ្ជូនហឹបនៃសេក្តីសញ្ញាមក គឺដើម្បីឱ្យវត្តមានរបស់ព្រះអម្ចាស់បាននៅជាមួយពួកគេក្នុងពេលដែលគេមានចម្បាំងជាមួយពួកភីលីស្ទីន ។ ពួកគេបានគិតដោយត្រឹមត្រូវថា នៅទីនេះគេបានភ្ជាប់ទំនាក់ទំនងរវាងវត្តមានរបស់ព្រះអម្ចាស់ជាមួយបណ្តាជន ហើយនិងហឹបសញ្ញា (ធៀបនឹង ខ.៤) ពួកគេបាននឹកចាំពីវត្តមានរបស់ហឹបសញ្ញា នៅពេលដែលគេមានជ័យជម្នះយ៉ាងធំនាពេលអតិតកាល (មើល ជន ១០:៣៣–៣៦ យស ៣:៣,១១,១៤–១៧ ៦:៦,១២–២០) ប៉ុន្តែពួកគេមានជំនឿដែលមិនត្រឹមត្រូវថា វត្តមានរបស់ព្រះអម្ចាស់នៅក្នុងហឹបនោះ ជាអ្នកធានាចំពោះពួកគេជាជាងអ្វីដែលជាអ្នកធ្វើឱ្យគេសំរេចចិត្តដោយសេរីទៅវិញ ។ ពួកគេបានផ្តោតសំខាន់ទៅ

ពួកភីលីស្ទីនក្នុងថ្ងៃនេះដូច្នេះ ចូរយើងនាំយកហឹបនៃ
សញ្ញា[យ]របស់ព្រះយេហូវ៉ា ពីស៊ីឡូរ[ង]មកឯយើង ដើម្បីឱ្យ
នៅកណ្តាលពួកយើង[ច] ហើយជួយសង្គ្រោះយើង ពីកណ្តាប់
ដៃនៃពួកខ្មាំងសត្រូវ ៤នោះគេក៏ចាត់ឱ្យទៅឯស៊ីឡូរ នាំយក
ហឹបនៃសេចក្តីសញ្ញា ផងព្រះយេហូវ៉ានៃពួកពលបរិវារ
ដែលនៅកណ្តាលចេរូប៊ីន[ឆ] ពីទីនោះមក ឯហុបនី និង
ភីនេហាស ជាកូនអេលីទាំង២ ក៏នៅទីនោះ ជាមួយនឹង
ហឹបនៃសេចក្តីសញ្ញារបស់ព្រះដែរ ។
៥កាលហឹបនៃសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា បាន
មកដល់ក្នុងទីបោះទ័ពហើយ នោះស្រាប់តែពួកអ៊ីស្រាអែល
ទាំងអស់គ្នា គេស្រែកឡើងជាខ្លាំង[ជ] ដល់ម្ល៉េះបានជាឮខ្ទរ
ខ្ទារនៅផែនដី ៦លុះពួកភីលីស្ទីនបានឮសូរសព្ទសំរែក
ដូច្នោះ ក៏សួរគ្នាថា តើសូរសព្ទសំរែកជាខ្លាំងដល់ម្ល៉េះ
នៅទីបោះទ័ពរបស់ពួកសាសន៍ហេព្រើរ[ឈ]ជាយ៉ាងណាហ្ន៎
នោះក៏យល់ឃើញថា ហឹបនៃព្រះយេហូវ៉ាបានមកដល់
ទីបោះទ័ពហើយ ៧ដូច្នេះ ពួកភីលីស្ទីនមានសេចក្តីភ័យ[ញ]
ដោយថា ព្រះបានយាងមកក្នុងទីបោះទ័ពគេហើយ រួចក៏ថា
វរហើយ យើងរាល់គ្នា ដ្បិតកាលពីដើមមិនដែលមាន
ដូច្នេះឡើយ ៨វរហើយ យើងរាល់គ្នា តើមានអ្នកណា
នឹងជួយយើង ឱ្យរួចពីកណ្តាប់ដៃនៃព្រះដ៏ខ្លាំងពូកែទាំងនេះ
គឺព្រះទាំងប៉ុន្មាននេះហើយ ដែលបានវាយ[ដ]ពួកសាសន៍
អេស៊ីព្ទនៅទីរហោស្ថាន ដោយសេចក្តីវេទនាគ្រប់យ៉ាង[ឋ]
៩ឱពួកភីលីស្ទីនអើយ ចូរខំប្រឹងឡើង ហើយសំរេចខ្លួន
ឱ្យពេញជាមនុស្សចុះ ដើម្បីកុំឱ្យយើងត្រូវធ្លាក់ទៅជាបាវ
បំរើនៃពួកហេព្រើរ ដូចជាគេ[ឌ]បានធ្វើជាបាវបំរើដល់
យើងនោះឡើង ចូរសំរេចខ្លួនឱ្យពេញជាមនុស្ស ហើយត
ដៃនឹងគេចុះ ១០ដូច្នេះពួកភីលីស្ទីនក៏ចូលតដៃគ្នា ហើយ
ពួកអ៊ីស្រាអែលត្រូវចាញ់ដៃ[ឍ] រត់ទៅឯត្រសាលវិញរៀង
ខ្លួន ក៏មានមនុស្សស្លាប់យ៉ាងសន្ធឹក គឺពួកពលថ្មើរជើង
ខាងអ៊ីស្រាអែលបានដួលស្លាប់អស់ចំនួន៣ម៉ឺននាក់ ១១ឯ
ហឹបរបស់ព្រះ គេក៏ចាប់នាំយកទៅ ចំណែកហុបនី និង
ភីនេហាស ជាកូនអេលីទាំង២ ក៏ស្លាប់ដែរ[ណ]។

## ការស្លាប់របស់លោកអេលី

១២នៅថ្ងៃនោះឯង មានពួកបេនយ៉ាមីន[ត]ម្នាក់រត់ពីទី
ចំបាំង ទៅឯស៊ីឡូរ មានសំលៀកបំពាក់រហែករហួរ
ហើយមានដី[ថ]នៅលើក្បាលផង ១៣កាលគាត់ចូលទៅដល់
នោះ អេលី[ទ]កំពុងអង្គុយទន្ទឹងចាំនៅមាត់ផ្លូវ ដ្បិតលោកមាន
ចិត្តភ័យញ័រ ដោយព្រោះហឹបនៃព្រះជាខ្លាំង កាលអ្នកនោះ
បានចូលមកប្រាប់ដំណឹងដល់ពួកទីក្រុង នោះគេស្រែក
ឡើងទាំងអស់គ្នា ១៤ឯអេលី ក៏ឮសូរសព្ទសំរែកនោះ
ហើយសួរថា តើសូរសព្ទអឺងកងដែលឮមកនេះ ដោយ
ហេតុអ្វី ដូច្នេះអ្នកនោះក៏ចូលមកជាប្រញាប់ ជំរាបដល់
អេលី ១៥រីឯអេលី លោកមានអាយុ៩៨ឆ្នាំហើយ ភ្នែក[ធ]
លោកក៏ជិត មើលអ្វីមិនឃើញឡើយ ១៦អ្នកនោះជំរាបថា

**៤:៣** យ យស ៦:៧
ង យស ១៨:១
១សយ ២:៣២ ច
២រប ១៣:៨
**៤:៤** ឆ លប ៣:២៤
នក ២៥:២២
**៤:៥** ជ យស
៦:៥,១០
**៤:៦** ឈ លប
១៤:១៣
**៤:៧** ញ នក ១៥:១៤
**៤:៨** ដ នក ១២:៣០
១សយ ៥:១២
ឋ វវ ១១:៦
**៤:៩** ឌ ពច ១៣:១
**៤:១០** ឍ ចទ
២៨:២៥
**៤:១១** ណ ទដ
៧៨:៦៤ យរ ៧:១២
**៤:១២** ត អគ
២៤:២៦ ៣៣:២១
ថ យស ៧:៦
២សយ ១:២
**៤:១៣** ទ ខ.១៨
**៤:១៥** ធ ១សយ
៣:២

លើសញ្ញារបស់ពួកអ្នកមិនជឿ ដោយគេគិតថាព្រះអម្ចាស់ ទ្រង់បានផ្តល់សញ្ញានៃវត្តមានរបស់ទ្រង់ ហើយព្រះហឫទ័យរបស់ព្រះអម្ចាស់អាចទទួលតាមរយៈសញ្ញាជាច្រើនដោយស្វ័យប្រវត្តិ ។

**៤:៤** *នៅកណ្តាលចេរូប៊ីន* នៅចុងទាំងសងខាងនៃទីសន្តោសប្រោសនិមួយៗ ដែលគ្របពីលើហឹបនៃសេចក្តីសញ្ញា នោះគឺជាចេរូប៊ីនដែលធ្វើពីមាស ហើយស្លាបទាំងពីររបស់ចេរូប៊ីននោះ លាតត្រដាងពីលើហឹបនៃសេចក្តីសញ្ញា (សូមមើល នក ២៥:១៧–២២) ។ ព្រះវត្តមានរបស់ព្រះអម្ចាស់ដែលគង់នៅជាមួយរាស្ត្រទ្រង់ គឺស្ថិតនៅចន្លោះចេរូប៊ីនទាំងពីរនោះ ដូច្នេះទីសន្តោសដែលគ្របពីលើហឹបនៃសេចក្តីសញ្ញានោះ នឹងបានដូចជាបល្ល័ង្ករបស់ព្រះរាជានៃសាសន៍អ៊ីស្រាអែល (សូមមើល ២សយ ៦:២ ទដ ៨០:១ ៩៩:១ និងការពន្យល់ នក ២៥:១៨) ។ *ហុបនី និងភីនេហាស* ពួកគេទាំងពីរនាក់ជាសង្ឃអាក្រក់ (មើល ២:១២) ដែលមិនបានបង្ខាំងពួកកងទ័ពដែលមកទាំងមិនគួរសម ដើម្បីប្រើប្រាស់ហឹបនៃសេចក្តីសញ្ញានោះឡើយ ប៉ុន្តែពួកគេទាំងពីរ បានរួមដំណើរយកហឹបនៃសេចក្តីសញ្ញានោះទៅឯទីបោះទ័ពជាមួយពួកកងទ័ពទាំងនោះដែរ ។

**៤:៦** *សាសន៍ហេព្រើរ* សូមមើលការពន្យល់ លប ១៤:១៣ ។

**៤:៧** *ព្រះបានយាងមកក្នុងទីបោះទ័ព* ពួកសាសន៍ភីលីស្ទីន ក៏ព្រមទទួលស្គាល់ព្រះនៃសាសន៍អ៊ីស្រាអែល តាមរយៈអត្តសញ្ញាណនៃវត្តមានរបស់ទ្រង់ដែរ (មើលការពន្យល់ ខ.៣) ។

**៤:៨** *ព្រះដ៏ខ្លាំងពូកែទាំងនេះ* ពួកសាសន៍ភីលីស្ទីនទាំងនោះ គឺគ្រាន់តែមានគំនិតគិតបែបពហុទេពនិយម (ជឿលើព្រះច្រើន) តែប៉ុណ្ណោះ ។ *សាសន៍អេស៊ីព្ទ . . . គ្រប់យ៉ាង* សូមមើលការពន្យល់ ៦:៦ ។

**៤:១១** *ហឹបរបស់ព្រះគេក៏ចាប់យកទៅ* នៅក្នុងឃ្លានេះ គឺកើតឡើងចំនួន៥ដង (នៅទីនេះ ខ.១៧,២១–២២) ហើយវាជាចំនុចសំខាន់នៅក្នុងអក្សរសាស្ត្រនេះ ។ ព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលទ្រង់មានបន្ទូល មើល ៣:១១ ត្រូវបានសម្រេចនៅក្នុងព្រឹត្តិការណ៍ដ៏អាក្រក់បែបនេះ ។ *ហុបនីនិងភីនេហាស . . . ក៏ស្លាប់ដែរ* សម្រេចតាមទំនាយក្នុង ២:៣៤ ៣:១២ ។

**៤:១២** *មានសំលៀកបំពាក់រហែករហួរ ហើយមានដីនៅលើក្បាល* គឺជាទីសម្គាល់នៃសេចក្តីសោយសោក និងទុក្ខវេទនា ហើយអ្នកនាំសារនៅទីនេះ គឺគាត់បាននាំនូវដំណឹងអាក្រក់ (មើល ២សយ ១:២ ១៣:១៩ ១៥:៣២) ។

**៤:១៣** *ដ្បិតលោកមានចិត្តភ័យញ័រ ដោយព្រោះហឹបនៃព្រះ* លោកអេលីមានវិញ្ញាណនៃការទុក្ខព្រួយ ដោយគាត់បានដឹងថា គ្រោះថ្នាក់នឹងកើតឡើងដោយព្រោះអំពើបាប និងភាពព្រហើន ដែលគេបានយកហឹបសញ្ញានៃព្រះចូលទៅក្នុងទីបោះទ័ព ។ លោកអេលីហាក់បីដូចជាមានការព្រួយបារម្ភចំពោះហឹបសញ្ញា ជាជាងព្រួយបារម្ភចំពោះកូនរបស់គាត់ទៅ (សូមមើល ខ.១៨) ។

គឺខ្ញុំនេះដែលចេញមកពីទីចំបាំង ខ្ញុំបានរត់រួចនៅថ្ងៃនេះ
ឯងអេលីសួរថា កូនអើយ ចុះតើយ៉ាងដូចម្ដេចទៅ ១៧អ្នក
ដែលនាំដំណឹងមកក៏ឆ្លើយថា ពួកអ៊ីស្រាអែលយើងបានរត់
ពីចំពោះពួកភីលីស្ទីនចេញ មានពលទ័ពខាងយើងស្លាប់[ន]
អស់សន្ធឹក ហើយហុបនី និងភីនេហាស កូនលោកទាំង២
ក៏ស្លាប់ទៅដែរ ឯហឹបនៃព្រះ គេក៏បានចាប់យកទៅហើយ[ប]
១៨កាលអ្នកនោះដំណាលពីហឹបនៃព្រះដូច្នោះ នោះស្រាប់
តែអេលី លោកផ្ងារធ្លាក់ចុះពីជើងម៉ា ជាទីដែលលោក
អង្គុយនៅត្រង់មាត់ទ្វារនោះ បាក់កស្លាប់ទៅ ដ្បិតមានអាយុ
ច្រើន ហើយក៏ធ្ងន់ផង លោកបានគ្រប់គ្រង[ផ]លើសាសន៍
អ៊ីស្រាអែលអស់៤០ឆ្នាំ[ព] ។
១៩រីឯកូនប្រសាលោក ជាប្រពន្ធភីនេហាស នាងមាន
ទំងន់ជិតសំរាលហើយ កាលឮដំណឹងពីគេចាប់យកហឹប
នៃព្រះ និងពីឪពុកក្មេក ហើយនិងប្ដីខ្លួនបានស្លាប់ហើយ
ដូច្នោះ នោះស្រាប់តែនាងចាប់ឈឺពោះ ហើយឱនខ្លួន
សំរាលកូនមកភ្លាម ២០កាលនាងជិតផុតជីវិតទៅ នោះពួក
ស្រីដែលឈរនៅជិតនាង ក៏ប្រាប់ថា កុំខ្លាចអ្វីឡើយ ដ្បិត
នាងបានកូនប្រុសហើយ តែនាងមិនបានឆ្លើយសោះ ក៏មិន
រវល់ផង ២១នាងដាក់ឈ្មោះកូននោះថា អ៊ីកាបូឌ[ភ] ដោយ
ពាក្យថា សិរីល្អ[ម]បានចេញពីពួកអ៊ីស្រាអែលបាត់ហើយ
គឺដោយព្រោះគេបានចាប់យកហឹបនៃព្រះទៅ ហើយដោយ
ព្រោះឪពុកក្មេក និងប្ដីនាងផង ២២នាងនិយាយថា សិរីល្អ[យ]
បានចេញពីពួកអ៊ីស្រាអែលបាត់ហើយ ពីព្រោះគេបានចាប់
យកហឹបនៃព្រះទៅ[រ] ។

## ហឹបសញ្ញានៅក្រុងអាសដូឌ និងក្រុងអេក្រុន

**៥** ១រីឯពួកភីលីស្ទីន គេចាប់យកបានហឹបនៃព្រះ រួចក៏នាំ
យកចេញពីអេបេន-អេស៊ើរ[ក] ទៅឯក្រុងអាសដូឌទៅ[ខ]
២ហើយគេយកទៅដាក់ក្នុងវិហារនៃព្រះដាកុន[គ] គឺនៅក្បែរ
ព្រះនោះ ៣លុះស្អែកឡើង កាលពួកក្រុងអាសដូឌបានក្រោក
ឡើងពីព្រលឹម នោះក៏ឃើញព្រះដាកុនបានដួល[ឃ]ផ្កាប់
មុខដល់ដី នៅចំពោះហឹបនៃព្រះយេហូវ៉ា រួចគេលើកព្រះ

**៤:១៧** ន ១សយ ២២:១៨ ទដ ៧៨:៦៤ ប ទដ ៧៨:៦១ **៤:១៨** ផ ពច ២:១៦ ១៦:៣១ ព ១សយ ២:៣១ **៤:២១** ភ លប ៣៥:១៨ ម នក ២៤:១៦ ទដ ១០៦:២០ យរ ២:១១ អគ ១:២៨ ៩:៣ ១០:១៨ **៤:២២** យ នក ២៤:១៦ ទដ ៧៨:៦១ រ យរ ៧:១២ **៥:១** ក ១សយ ៤:១ ខ យស ១១:២២ ១៣:៣ **៥:២** គ ពច ១៦:២៣ អស ២:១៨ ១៩:១ ៤៦:១ **៥:៣** ឃ អស ៤០:២០ ៤១:៧ ៤៦:៧ យរ ១០:៤

**៤:១៨** *បាក់កស្លាប់ទៅ* ការស្លាប់របស់លោកអេលីបានបង្ហាញអំពីចុងបញ្ចប់នៃយុគសម័យកាលមួយ ដែលបានចាប់ផ្ដើមតាំងពីគ្រាដែលលោកយ៉ូស្វេបានទទួលមរណៈភាព និងពួកចាស់ទុំដែលបានបម្រើព្រះអម្ចាស់ជាមួយនឹងគាត់ (សូមមើល យស ២៤:២៩,៣១) ។ អសមត្ថភាពក្នុងការបង្ខាំងពួកកូនចៅអ៊ីស្រាអែល ឬកូនប្រុសរបស់គាត់ឱ្យគេចចេញពីផ្លូវអាក្រក់របស់គេ និងភាពទន់ខ្សោយ ព្រមទាំងភាពងងឹតដោយសារវ័យចំណាស់ សង្ស័យដ៏ចំណាស់នោះ គឺជានិមិត្តសញ្ញាពីវ័យទ្រុឌទ្រោម ដែលនឹងទទួលរងនូវការហិនវិនាសយ៉ាងឆាប់ ។ ជាមួយគ្នានោះផងដែរ យុគសម័យកាលគាត់មានភាពផ្ទុយគ្នាទាំងស្រុងជាមួយសម័យកាលស្ដេចដាវីឌ វាជាគំនិតចម្បងដែលគេយកចិត្តទុកដាក់នៅក្នុងអក្សរសាស្ត្រនេះ ។ *ធ្ងន់* ពត៌មានតិចតួចនេះមិនគ្រាន់តែជួយប្រាប់យើងថា ហេតុអ្វីបានជាការធ្លាក់របស់លោកអេលីបណ្ដាលឱ្យស្លាប់ប៉ុណ្ណោះនោះឡើយ ប៉ុន្តែថែមទាំងបានបញ្ជាក់ថា ការស្លាប់របស់គាត់ដែលបាននិយាយតាំងពីគ្រាមុនថែមទៀត "ដោយរាប់អានកូនឯងជាជាងអញវិញ ដើម្បីនឹងធ្វើឱ្យខ្លួនធំធាត់ (២:២៩)" ។ *លោកបានគ្រប់គ្រងលើសាសន៍អ៊ីស្រាអែលអស់៤០ឆ្នាំ* នៅទីនេះអេលីត្រូវបានរាប់បញ្ចូលជាមួយពួកចៅហ្វាយ (មើល ២សយ ៧:១១ ពច ២:១៦-១៩ នរ ១:១) ដែលបានបម្រើក្នុងនាមជាអ្នកដឹកនាំរបស់អ៊ីស្រាអែល រវាងអំឡុងពេលការស្លាប់របស់លោកយ៉ូស្វេ ហើយនិងពួកចាស់ទុំដែលរស់នៅក្នុងសម័យកាលគាត់ ដែលជាអ្នករៀបចំឱ្យមានស្ដេច ។ ការគ្រប់គ្រងរបស់ លោកអេលី៤០ឆ្នាំ គឺអាចស្ទួនឆ្នាំគ្នាជាមួយពួកចៅហ្វាយខ្លះៗ ដូចជាលោកយែបថា និងលោកសាំសុនជាដើម ។

**៤:២១** *សិរីល្អបានចេញ* សិរីល្អរបស់អ៊ីស្រាអែល គឺជាព្រះរបស់សាសន៍អ៊ីស្រាអែល មិនមែនជាហឹបនៃសេចក្ដីសញ្ញានោះទេ (មើល ១៥:២៩ ហព ៩:៥ និងការពន្យល់) ហើយការបាត់បង់ហឹបសញ្ញាមិនមែនមានន័យថាព្រះអម្ចាស់ទ្រង់បោះបង់រាស្ត្រទ្រង់នោះឡើយ ដ្បិតអីព្រះអម្ចាស់ទ្រង់មិនបានប្រថាប់នៅនឹងហឹបនៃសេចក្ដីសញ្ញានោះ ជារៀងរហូតនោះឡើយ (មើល យរ ៣:១៦-១៧) ។ ប៉ុន្តែការបាត់ហឹបនៃសេចក្ដីសញ្ញាពីអ៊ីស្រាអែល គឺជាសញ្ញានៃការឃ្លាតគ្នា ពីទំនាក់ទំនងរបស់ព្រះអម្ចាស់ជាមួយរាស្ត្រទ្រង់ ហើយវាសម្ដែងពីកំហុសដ៏ធ្ងន់របស់គេ ដោយបានគិតថា ទោះបីជាពួកគេមានភាពកម្សោយក៏ដោយ ក៏គេមានកម្លាំងគ្រប់គ្រាន់ដើម្បីបង្ខំព្រះអម្ចាស់ទៅតាមចិត្តរបស់គេ ព្រោះកាន់កាប់ហឹបនៃសេចក្ដីសញ្ញានោះ ។

**៥:១** *អាសដូឌ* គឺជាទីក្រុងដ៏សំខាន់មួយក្នុងចំណោមទីក្រុងទាំង៥របស់ពួកភីលីស្ទីន (យស ១៣:៣) ។ ទីក្រុងអាសដូឌមានទីតាំងស្ថិតនៅក្បែរសមុទ្រមេឌីទែរ៉ាណេ ដែលមានចម្ងាយប្រមាណ ៥៦,៣១ គម ភាគខាងលិចពីក្រុងយេរូសាឡិម (មើលការពន្យល់ អស ២០:១) ។

**៥:២** *ព្រះដាកុន* នៅក្នុងវគ្គសិក្សាអំពីព្រះ ពួកកាណានគេគិតថាជាកូនប្រុស (ឬប្អូន) របស់ព្រះអែល ហើយជាឪពុករបស់ព្រះបាល ។ ព្រះដាកុនជាព្រះមួយរបស់ពួកភីលីស្ទីន ដែលគេគោរពថ្វាយបង្គំនៅក្នុងវិហារកាសា (ពច ១៦:២១,២៣,២៦) នៅអាសដូឌ (ទីនេះ) និងបេត-សាន (៣១:១០-១២ ១រប ១០:១០) ។ ការផ្លាស់ប្ដូររបស់ព្រះនេះ គឺត្រូវបានផ្សព្វផ្សាយពាសពេញពិភពលោក ក្នុងសម័យកាលពីបុរាណ ដោយចាប់ផ្ដើមពីមេសូប៉ូតាមារហូតដល់អារ៉ាម និងតំបន់នៅក្នុងស្រុកកាណាន ព្រមទាំងបានបញ្ជាក់ក្រៅព្រះគម្ពីរអំពីពេលវេលានៃការផ្លាស់ប្ដូរនោះថា នៅក្នុងអំឡុងកាលសហសវត្សរ៍ទី៣ មុន គ.ស ។ ធម្មជាតិជាក់លាក់ពីការថ្វាយបង្គំព្រះដាកុនមិនបានដឹងច្បាស់ឡើយ អ្នកខ្លះបានគិតថា ដាកុនគឺជា"ព្រះត្រី" ។ ឈ្មោះរបស់ព្រះនេះ មានទំនាក់ទំនងជាមួយនឹងពាក្យនៅក្នុងព្រះគម្ពីរភាសាព្រើរ "ធញ្ញជាតិ" (មើលការពន្យល់ ពច ១០:៦) ។

**៥:៣** *ព្រះដាកុនបានដួលផ្កាប់មុខ* ពួកភីលីស្ទីនបានយកហឹបនៃសេចក្ដីសញ្ញាមកដាក់បន្ទាប់រូបព្រះដាកុន ដើម្បីសម្ដែងពីឧត្ដមភាពរបស់ដាកុនលើព្រះនៃសាសន៍អ៊ីស្រាអែល ប៉ុន្តែនិមិត្តរូបនោះត្រូវបានផ្ទុយទៅវិញ នៅពេល

ដាកុន ទៅដាក់នៅកន្លែងដើមវិញ ៤លុះដល់ថ្ងៃស្អែកទៀត
កាលគេក្រោកពីព្រលឹម នោះក៏ឃើញព្រះដាកុនបានដួល
ផ្កាប់មុខដល់ដី នៅចំពោះហឹបនៃព្រះយេហូវ៉ាទៀត ហើយ
ក្បាល និងដៃទាំង២នៃព្រះដាកុន ក៏បាក់ដាច់[ង] នៅលើក្រប
ទ្វារ សល់នៅតែតួព្រះដាកុនប៉ុណ្ណោះ ៥ដោយហេតុនោះ
បានជាពួកសង្ឃរបស់ព្រះដាកុន និងពួកអ្នកដែលចូលទៅ
ក្នុងវិហារនៃព្រះដាកុន គេមិនដែលជាន់លើក្របទ្វារនៃ
វិហារព្រះដាកុន នៅក្រុងអាសដូឌ ដរាបដល់សព្វថ្ងៃ
នេះ[ច] ។

៦ឯព្រះហស្តនៃព្រះយេហូវ៉ា[ឆ] ក៏សង្កត់លើពួកក្រុង
អាសដូឌយ៉ាងធ្ងន់ ទ្រង់បំផ្លាញ[ជ]គេ ហើយវាយគេដោយ
រោគឫសដូងបាត នៅក្រុងអាសដូឌ និងស្រុកជុំវិញទាំង
អស់[ឈ] ៧កាលពួកអាសដូឌឃើញថា កើតមានយ៉ាងដូច្នោះ
នោះគេជំនុំគ្នាថា មិនត្រូវឱ្យហឹបនៃព្រះរបស់សាសន៍
អ៊ីស្រាអែលនៅជាមួយនឹងយើងទៀតឡើយ ដ្បិតព្រះហស្ត
នៃទ្រង់សង្កត់លើយើងរាល់គ្នាធ្ងន់ណាស់ ហើយលើព្រះ
ដាកុន ជាព្រះនៃយើងដែរ ៨ដូច្នេះគេក៏ចាត់ឱ្យទៅ ប្រមូល
ពួកមេ[ញ] នៃសាសន៍ភីលីស្ទីនទាំងប៉ុន្មានមកជំនុំគ្នាថា តើ
ត្រូវឱ្យយើងធ្វើដូចម្តេចនឹងហឹបព្រះរបស់សាសន៍អ៊ីស្រា
អែលនេះ គេឆ្លើយថា ចូរនាំយកទៅឯក្រុងកាថទៅ[ដ] ដូច្នេះ
គេក៏នាំយកហឹបនៃព្រះរបស់សាសន៍អ៊ីស្រាអែល ទៅឯ
ទីនោះ ៩កាលគេបាននាំយកទៅឯណោះហើយ នោះព្រះ
ហស្តនៃព្រះយេហូវ៉ាក៏ទាស់នឹងទីក្រុងនោះ ដោយសេចក្តី
វេទនាយ៉ាងខ្លាំងដែរ[ឋ] ទ្រង់វាយពួកក្រុងនោះទាំងតូចទាំង
ធំ ឱ្យកើតមានឫសដូងបាតទាំងអស់គ្នា ១០ដូច្នេះ គេក៏នាំយក
ហឹបនៃព្រះទៅឯក្រុងអេក្រុនទៀត[ឌ] កាលបានដល់អេក្រុន
ហើយ ពួកក្រុងនោះស្រែកឡើងថា គេបានយកហឹបនៃព្រះ
របស់សាសន៍អ៊ីស្រាអែលមកឯយើង ដើម្បីនឹងសំឡាប់យើង
និងពួកយើងផងហើយ ១១នោះគេចាត់ឱ្យទៅប្រមូលពួក
មេ[ឍ]នៃសាសន៍ភីលីស្ទីនទាំងប៉ុន្មាន មកជំនុំគ្នាថា ចូរផ្ញើហឹប
នៃព្រះរបស់សាសន៍អ៊ីស្រាអែលទៅវិញទៅ ឱ្យបានត្រឡប់
ទៅឯកន្លែងដើមវិញ ដើម្បីកុំឱ្យយើង និងពួកយើងត្រូវស្លាប់
ទាំងអស់គ្នាដូច្នេះឡើយ ពីព្រោះកើតមានសេចក្តីវេទនា
ដ៏នាំឱ្យស្លាប់សន្ធឹក នៅពេញក្នុងទីក្រុង ដ្បិតព្រះហស្តនៃ

**៥:៤** ង អគ ៦:៦ មីក ១:៧
**៥:៥** ច សជ ១:៩
**៥:៦** ឆ នក ៩:៣ កច ១៣:១១ ជ ២សយ ៦:៧ ទដ ៧៨:៦៦ ឈ នក ១៥:២៦ ១សយ ៦:៥
**៥:៨** ញ ពច ១៦:១៨ ដ យស ១១:២២
**៥:៩** ឋ នក ១៤:២៤
**៥:១០** ឌ យស ១៣:៣
**៥:១១** ឍ ខ.៨

ដែលព្រះដាកុនរលំដួលបាត់អំណាចពីទីសក្ការបូជា នៅចំពោះហឹបនៃសេចក្តីសញ្ញាទៅវិញ ។

**៥:៤** *ក្បាល និងដៃទាំង២ក៏បាក់ដាច់* សឱ្យឃើញថា ព្រះអម្ចាស់ទ្រង់បានទាស់ប្រឆាំងជាមួយព្រះដាកុន ។ នៅមជ្ឈឹមបូព៌ាសម័យបុរាណ ក្បាលហើយនិងដៃស្តាំរបស់ពួកសត្រូវដែលបានសម្លាប់ ត្រូវនាំមកជំរុំអ្នកដែលសម្លាប់បាន ទុកជាជ័យភ័ណ្ឌនៃសង្គ្រាម (១របា ១០:១០) ហើយនិងដើម្បីរាប់ចំនួនសព (ប្រៀបធៀប ១៨:២៧ និងការពន្យល់) ។

**៥:៥** *សព្វថ្ងៃនេះ* គឺជាពេលនៃការសរសេរព្រះគម្ពីរសាំយូអែលទី១–២ (មើលសេចក្តីផ្តើម: លក្ខណៈអក្សរសាស្ត្រ អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។ *ជាន់លើក្របទ្វារ* មើលទៅ គេបានចាត់ទុកក្របទ្វារជាសម្បត្តិអធិធម្មជាតិ ពីព្រោះវាជាប់ទាក់ទងជាមួយផ្នែកផ្សេងៗនៃរូបកាយព្រះដាកុន ដែលបានដួលផ្កាប់មុខនោះ ។ នៅក្នុង សផ ១:៩ វិញ បានសំដៅលើគំនិតទូទៅ ហើយបានផ្សព្វផ្សាយលើពិភពលោកទាំងមូលពីគំនិតរបស់ពួកអ្នកមិនជឿ ដែលថាក្របទ្វារ គឺជាតំណាក់នៃវិញ្ញាណ ។

**៥:៦** *ព្រះហស្តនៃព្រះយេហូវ៉ា* ការជ្រួតជ្រាបពីបុព្វហេតុសំខាន់ៗនៅក្នុងដំណើររឿងហឹបសញ្ញានេះ ភាពសមមូលរបស់វា បានកើតឡើងចំនួន ៨ដង (ទីនេះនិង ខ.៧,៩,១១ ៦:៣,៥,៩ ៧:១៣ ហើយប្រៀបធៀប ៤:៨) ។ *យ៉ាងធ្ងន់* បំណែកដៃរបស់ព្រះដាកុន បានធ្លាក់លើក្របទ្វារ (ខ.៤) ប៉ុន្តែព្រះអម្ចាស់ទ្រង់បានបង្ហាញដោយសេចក្តីពិត និងកម្លាំងដ៏ខ្លាំងពីព្រះហស្តរបស់ទ្រង់ ដោយទ្រង់បាននាំជម្ងឺ (មើលការពន្យល់ ៦:៤) មកលើពួកអ្នកនៅក្នុងក្រុងអាសដូឌ និងពួកអ្នកនៅជុំវិញតំបន់នោះទាំងមូល (មើល ខ.៩,១១) ។ ព្រះអម្ចាស់ទ្រង់មិនអាចបញ្ឆោតបានដោយរាស្ត្រទ្រង់ឡើយ (មើលការពន្យល់ ៤:៣) ហើយព្រះអម្ចាស់ទ្រង់ក៏មិនបានអនុញ្ញាតឱ្យពួកភីលីស្ទីនមានគំនិតគិតថា គេមានជ័យជម្នះលើពួកអ៊ីស្រាអែល ព្រមទាំងចាប់យកហឹបនៃសេចក្តីសញ្ញាបាន ដើម្បីបង្ហាញពីអំណាចរបស់ព្រះពួកគេថា មានជ័យជម្នះលើព្រះរបស់ពួកអ៊ីស្រាអែលដែរ ។ *ឫសដូងបាត* គឺជាជម្ងឺមួយក្នុងចំណោមការតាំងសញ្ញាជាច្រើន ដែលនឹងត្រូវដាក់ទោសពួកកូនចៅអ៊ីស្រាអែលនៅពេលណាគេមិនស្តាប់បង្គាប់ព្រះអម្ចាស់ (មើល ចទ ២៨:៥៨–៦០) ។ នៅទីនេះព្រះអម្ចាស់ទ្រង់បានដាក់ទោសលើពួកភីលីស្ទីនវិញ (មើល ខ.៩) ។

**៥:៨** *ពួកមេ* គឺពួកមេដែលគ្រប់គ្រងលើទីក្រុងធំៗទាំង៥របស់ពួកភីលីស្ទីន (សូមមើល ៦:១៦ យស ១៣:៣ ពច ៣:៣) ។ *ចូរនាំយកទៅឯក្រុងកាថទៅ* គឺជាភស្តុតាងមួយដែលបញ្ជាក់ថា ពួកចាស់ទុំនៃសាសន៍ភីលីស្ទីនមិនបានចែកចាយពីគំនិតរបស់ពួកអ្នកអាសដូឌ ដែលពួកគេជាអ្នកមានទំនាក់ទំនងដោយផ្ទាល់រវាងបញ្ហាដែលបានកើតឡើងនៅអាសដូឌ និងវត្តមានពីហឹបនៃសេចក្តីសញ្ញា មើលទៅពួកគេហាក់បីដូចជាមានការមន្ទិលសង្ស័យចំពោះហេតុការណ៍ដែលបានកើតឡើងដល់ពួកគេ ថាកើតឡើងដោយគាប់ជួនទៅវិញ (៦:៩) ។ ការយកហឹបនៃសេចក្តីសញ្ញាទៅក្រុងកាថ (មានចម្ងាយ ១៩,៣០ គម ភាគខាងត្បូងពីក្រុងអាសដូឌ) គឺគ្រាន់តែជាការសាកល្បងប៉ុណ្ណោះ ។

**៥:១០** *ក្រុងអេក្រុន* គឺជាក្រុងមួយដែលស្ថិតនៅឯនាយភាគខាងជើង ក្នុងចំណោមទីក្រុងទាំង៥របស់ពួកភីលីស្ទីន (មើល យស ១៣:៣) ដែលស្ថិតនៅចម្ងាយប្រមាណជា ១៧,៦៩ គម ភាគខាងជើងក្រុងអាសដូឌ ហើយនៅជាប់នឹងព្រំប្រទល់ប្រទេសអ៊ីស្រាអែល ។

**៥:១១** *ចូរផ្ញើហឹបនៃព្រះរបស់សាសន៍អ៊ីស្រាអែលទៅវិញទៅ* បន្ទាប់ពីទីក្រុងចំនួន៣ត្រូវបានបំផ្លាញដោយគ្រោះធម្មជាតិ នៅពេលហឹបនៃសេចក្តីសញ្ញាមកដល់ នោះចិត្តគំនិតរបស់ពួកគេមានការសង្ស័យខ្លះៗថា ហឹបនៃសេចក្តីសញ្ញា គឺជាមូលហេតុនៃការហិនវិនាស និងគ្រោះធម្មជាតិចំពោះពួកគេ ។

ព្រះសង្កត់លើគេជាយ៉ាងធ្ងន់ ១២ឯពួកមនុស្សដែលមិនបាន
ស្លាប់ទេ[ណ] នោះក៏កើតមានឫសដូងបាតវិញ ហើយសូរ
សំរែកនៅទីក្រុងនោះ ក៏ឮរហូតដល់ផ្ទៃមេឃ ។

## ហឹបសញ្ញានាំទៅឯអ៊ីស្រាអែលវិញ

**៦** ១រីឯហឹបនៃព្រះយេហូវ៉ា បានស្ថិតនៅស្រុកភីលីស្ទីន
អស់៧ខែ ២ឯពួកភីលីស្ទីន គេហៅពួកសង្ឃ និងពួក
គ្រូទាយ[ក]មកសួរថា តើត្រូវឱ្យយើងធ្វើដូចម្តេចចំពោះហឹប
នៃព្រះយេហូវ៉ានេះ ចូរបង្ហាញឱ្យយើងដឹងជាត្រូវធ្វើដូច
ម្តេចផង ដើម្បីនឹងផ្ញើទៅឯកន្លែងដើមវិញ ៣គេឆ្លើយថា
បើអ្នករាល់គ្នាផ្ញើហឹបនៃព្រះ របស់សាសន៍អ៊ីស្រាអែលទៅ
វិញ នោះកុំឱ្យផ្ញើទៅដោយទទេឡើយ[ខ] គឺត្រូវផ្ញើដង្វាយ[គ]
ដោយព្រោះការរំលង ទៅឯព្រះរបស់គេផង នោះអ្នក
រាល់គ្នានឹងបានជាហើយ ក៏នឹងដឹងជាមានហេតុអ្វី ដែលនាំ
ឱ្យព្រះហស្ត[ឃ]នៃព្រះយេហូវ៉ា នៅជាប់នឹងអ្នករាល់គ្នាដូច្នេះ
ដែរ ៤គេក៏សួរថា តើដង្វាយយ៉ាងណា ដែលយើងត្រូវផ្ញើ
ទៅថ្វាយទ្រង់នោះ ពួកនោះប្រាប់ថា គឺរូបឫសដូងបាត៥
ធ្វើពីមាស និងកណ្តុរមាស៥ តាមចំនួន[ង]ពួកមេនៃសាសន៍
ភីលីស្ទីន ដ្បិតអ្នករាល់គ្នា និងពួកមេរបស់អ្នករាល់គ្នា ក៏
កើតមានសេចក្តីវេទនា[ច]តែ១ ៥ដូច្នេះ ត្រូវឱ្យអ្នករាល់គ្នាធ្វើ
ជារូបឫសដូងបាត[ឆ] និងរូបកណ្តុរ ដែលបានបំផ្លាញស្រុក
រួចសរសើរ[ជ]ដល់ព្រះនៃសាសន៍អ៊ីស្រាអែលទៅ ប្រហែល
ជាទ្រង់នឹងសំរាលព្រះហស្តចេញពីអ្នករាល់គ្នា និងពីព្រះ
ហើយពីស្រុករបស់អ្នករាល់គ្នាទេដឹង ៦ហេតុអ្វីបានជាអ្នក
រាល់គ្នាតាំងចិត្តរឹងរូស[ឈ] ដូចជាពួកសាសន៍អេស៊ីព្ទ និង
ផារ៉ោនដូច្នេះ កាលក្រោយដែលទ្រង់បានធ្វើការអស្ចារ្យ[ញ]
ក្នុងពួកគេ នោះតើគេ[ដ]មិនបានបើកឱ្យពួកអ៊ីស្រាអែលចេញ
ទៅបាត់ទេឬអី ៧ដូច្នេះ ចូរធ្វើរទេះ[ឋ]១ថ្មី ហើយយកគោ
ញី២ ដែលបំបៅកូន ឥតដែលមានអ្នកណាយកនឹមមក
ទឹមនៅឡើយ[ឌ] រួចឱ្យទឹមនឹងរទេះនោះ ហើយដេញកូនពី
វាឱ្យទៅផ្ទះវិញ ៨នោះត្រូវយកហឹបនៃព្រះយេហូវ៉ាដាក់
លើរទេះទៅ ហើយដាក់គ្រឿងមាសទាំងប៉ុន្មាន ដែល
អ្នករាល់គ្នាថ្វាយនោះ ទៅក្នុងប្រអប់ដាក់ខាងហឹប រួច
លែងវាឱ្យនាំទៅវិញចុះ ៩ចាំមើល បើសិនជាវាឡើងតាម
ផ្លូវ ដែលនាំទៅឯបេត-សេមែស[ឍ] ក្នុងដែនស្រុករបស់គេ
នោះគឺជាទ្រង់ហើយ ដែលបានធ្វើឱ្យយើងកើតមានសេចក្តី
អាក្រក់យ៉ាងធំនេះ តែបើមិនដូច្នោះ នោះយើងនឹងដឹងថា
មិនមែនព្រះហស្តនៃទ្រង់ដែលបានវាយយើងទេ គឺជាគ្រោះ
របស់យើងវិញ ។

១០គេក៏ធ្វើដូច្នោះ គឺគេយកគោញី២ដែលបំបៅកូន នាំ
មកទឹមនឹងរទេះ រួចបង្ខាំងកូនទុកនៅក្នុងក្រោលវិញ
១១ហើយយកហឹបនៃព្រះយេហូវ៉ា មកដាក់លើរទេះ ព្រម
ទាំងប្រអប់ ដែលមានរូបកណ្តុរមាស និងរូបឫសដូងបាត
របស់គេផង ១២រួចគោនោះក៏ចេញដំរង់តាមផ្លូវទៅឯបេត
-សេមែស គឺទៅតាមថ្នល់តែ១នោះទាំងរោទ៍បណ្តើរ ឥត
មានងាកបែរទៅខាងស្តាំឬខាងឆ្វេងឡើយ ឯពួកមេនៃ
សាសន៍ភីលីស្ទីន គេក៏ដើរតាមរហូតដល់ព្រំស្រុកបេត-

**៥:១២** ណ ១សយ ៤:៨
**៦:២** ក នក ៧:១១ អស ៤៤:២៥
**៦:៣** ខ នក ២២:២៩ ៣៤:២០ គ លវ ៥:១៥ ឃ ខ.៩
**៦:៤** ង យស ១៣:៣ ច ២សយ ២៤:២៥
**៦:៥** ឆ ១សយ ៥:៦-១១ ជ យស ៧:១៩ វវ ១៤:៧
**៦:៦** ឈ នក ៤:២១ ញ នក ១០:២ ដ នក ១២:៣៣
**៦:៧** ឋ ២សយ ៦:៣ ១រប ១៣:៧ ឌ ជន ១៩:២
**៦:៩** ឍ យស ១៥:១០ ២១:១៦

**៦:២** *សង្ឃនិងពួកគ្រូទាយ* ពួកអ្នកជំនាញខាងផ្នែកសាសនា (សង្ឃ) ហើយ និងពួកអ្នក ដែលយល់ដឹងពីចំណេះអាថ៌កំបាំង តាមរយៈការកាត់ស្រាយពីប្រផ្នូល (ពួកគ្រូទាយ) ត្រូវបានសុំពិគ្រោះយោបល់ (ចទ ១៨:១០ អស ២:៦ អគ ២១:២១) ។

**៦:៣** *ដង្វាយដោយព្រោះការរំលង* ពួកសង្ឃនិងពួកគ្រូទាយ បានសំណូមពរថា នៅពេលដែលផ្ញើហឹបសញ្ញាទៅវិញ ត្រូវយកទាំងដង្វាយទៅជាមួយផង ដើម្បីជាទីសម្គាល់ព្រមទទួលការរំលង ក្នុងកាលដែលពួកគេចាប់យកហឹបនៃសេចក្តីសញ្ញាមកពីពួកអ៊ីស្រាអែល និងព្រមសងជម្ងឺចិត្តចំពោះការរំលងនេះ ឱ្យសមនឹងភាពធំឧត្តមរបស់ព្រះអម្ចាស់ (មើល ខ.៥) ។ សម្រាប់ដង្វាយដោយព្រោះការរំលងនៅក្នុងពួកអ៊ីស្រាអែល មើល លវ ៥:១៤-៦:៧ ។

**៦:៤** *រូបឫសដូងបាត៥ធ្វើពីមាស* គឺជារូបដែលទាក់ទងទៅនឹងរោគសញ្ញានៃជម្ងឺ (សូមមើល ៥:៦) ។ *កណ្តុរមាស៥* ព្រោះស្រុករបស់គេត្រូវបានបំផ្លាញដោយសារសត្វកណ្តុរ (ខ.៥) ។ ការបកប្រែព្រះគម្ពីរសញ្ញាចាស់មកជាភាសាក្រិកដំបូង មុនគ្រីស្ទសករាជ "សេបទូជីន" (Septuagint) បានដាក់បញ្ចូលនូវពត៌មាននេះ តាំងពីដើមដំបូងនៃការរៀបរាប់នេះ (មើល ៥:៦) ដូច្នេះហើយសត្វកណ្តុរហាក់បីដូចជាអាចយកឈ្នះលើជម្ងឺទាំងនោះបាន ។

**៦:៥** *ដូច្នេះ ត្រូវឱ្យអ្នករាល់គ្នាធ្វើ... សរសើរដល់ព្រះនៃសាសន៍អ៊ីស្រាអែល* គេធ្វើរូបដែលធ្វើពីមាសទាំងនោះ គឺដោយសារគេទទួលស្គាល់ថា ជម្ងឺនិងសត្វកណ្តុរដែលមាននៅក្នុងស្រុកគេ គឺដោយសារព្រះហស្តនៃព្រះរបស់ពួកអ៊ីស្រាអែល (មើលការពន្យល់ ខ.៣) ។

**៦:៦** *ចិត្តរឹងរូស* មើលការពន្យល់ នក ៤:២១ ចទ ២:៣ យស ១១:២០ ។ *ពួកសាន៍អេស៊ីព្ទ និងផារ៉ោន* ជម្ងឺផ្សេងៗដែលកើតមានឡើងដល់ពួកអេស៊ីព្ទក្នុងអំឡុងពេលព្រះគម្ពីរនិក្ខមនំ គឺបានធ្វើឱ្យមានការចងចាំពីសំណាក់បណ្តាប្រទេសដែលនៅជុំវិញនោះ (មើល ៤:៨ យស ២:១០) ។

**៦:៧** *ឥតដែលមានអ្នកណាយកនឹមមកទឹមនៅឡើយ* គឺជាគោដែលមិនមានការហ្វឹកហាត់ក្នុងការអូសទាញរទេះនៅឡើយ ។ *ដេញកូនពីវាឱ្យទៅផ្ទះវិញ* កម្រនឹងមានសត្វគោណាដែលព្រមចាកចេញពីកូន ដែលកំពុងតែបៅដោះនោះឡើយ ។

**៦:៩** *បេត-សេមែស* គឺជាទីក្រុងមួយដែលនៅជាប់នឹងព្រំប្រទល់ស្រុកភីលីស្ទីន ដែលជាកម្មសិទ្ធិពួកយូដា (យស ១៥:១០) ។ *គឺជាគ្រោះ* សូមមើលការពន្យល់ ៥:៨ ។

**៦:១២** *រួចគោនោះក៏ចេញដំរង់តាមផ្លូវ* គឺមានន័យថា ព្រះអម្ចាស់ទ្រង់ជា

សេមែស ១៣គ្រានោះ ពួកអ្នកនៅបេត-សេមែស គេកំពុង
តែច្រូតស្រូវ[ណ]នៅវាលច្រកភ្នំ លុះងើបភ្នែកឡើង ក៏អរ
សប្បាយ ដោយឃើញហឹបនៃព្រះមកវិញ ១៤រទេះក៏មកដល់
ក្នុងចំការរបស់យ៉ូស្វេ ជាអ្នកនៅបេត-សេមែសនោះ
ហើយឈប់នៅទីនោះ ជាកន្លែងដែលមានថ្ម១ធំ ដូច្នេះ គេ
ពុះបំបែករទេះ ហើយថ្វាយគោនោះជាដង្វាយដុត[ត]ដល់ព្រះ
យេហូវ៉ា ១៥ពួកលេវី[ថ]គេយកហឹបនៃព្រះយេហូវ៉ា និងប្រអប់
ដែលមានគ្រឿងមាសទាំងប៉ុន្មាន ចុះមកដាក់លើថ្មធំនោះ[ទ]
រួចពួកបេត-សេមែស[ធ]ក៏ថ្វាយដង្វាយដុត និងយញ្ញបូជា
ដល់ព្រះយេហូវ៉ានៅថ្ងៃនោះឯង ១៦កាលពួកមេនៃសាសន៍
ភីលីស្ទីនទាំង៥នាក់បានឃើញហើយ នោះគេនាំគ្នាត្រឡប់
ទៅឯក្រុងអេក្រុនវិញ នៅថ្ងៃនោះដែរ ។
១៧ឯរូបឫសដូងបាតធ្វើពីមាស ដែលពួកភីលីស្ទីន គេ
ថ្វាយដល់ព្រះយេហូវ៉ា ទុកជាដង្វាយដោយព្រោះការរំលង
នោះគឺ១[ន]ពីក្រុងអាសដូឌ ១ពីក្រុងកាសា ១ពីក្រុងអាស
កាឡូន ១ពីក្រុងកាថ ហើយ១ពីក្រុងអេក្រុន ១៨ក៏មានរូប
កណ្ដុរមាស តាមចំនួនទីក្រុងនៃសាសន៍ភីលីស្ទីន ដែលជា
របស់ផងមេទាំង៥នាក់នោះដែរ គឺទាំងក្រុងមានកំផែង
និងភូមិនៅស្រុកស្រែទាំងប៉ុន្មានផង ពីគ្រប់ក្នុងស្រុក
ភីលីស្ទីនរហូតដល់ថ្មធំ ជាទីដែលគេបានដាក់ហឹបនៃ
ព្រះយេហូវ៉ានោះ ឯថ្មនោះក៏នៅក្នុងចំការរបស់យ៉ូស្វេ
ជាអ្នកនៅបេត-សេមែស ដរាបដល់សព្វថ្ងៃនេះ ។
១៩ព្រះយេហូវ៉ាទ្រង់ប្រហារ[ប]ពួកបេត-សេមែសដែរ ពី
ព្រោះគេបានបើកមើល[ផ]ទៅក្នុងហឹបនៃព្រះយេហូវ៉ា ទ្រង់
ប្រហារជីវិតគេអស់៧០នាក់ ក្នុង៥ម៉ឺននាក់ នោះគេក៏យំ
សោក ដោយព្រោះព្រះយេហូវ៉ាបានវាយសំឡាប់គេអស់ជា
ច្រើនដូច្នេះ ២០ពួកបេត-សេមែសនិយាយឡើងថា តើមាន
អ្នកឯណាអាចនឹងឈរ[ព]នៅចំពោះព្រះយេហូវ៉ា ជាព្រះដ៏
បរិសុទ្ធ[ភ]នេះបាន តើទ្រង់ត្រូវចេញពីយើងខ្ញុំឡើងទៅឯ
អ្នកណាវិញ ២១រួចគេចាត់មនុស្ស ឱ្យទៅឯពួកគារយ៉ាត់-
យារីម[ម]ប្រាប់ថា ពួកភីលីស្ទីនបាននាំយកហឹបនៃព្រះយេហូ
វ៉ាមកវិញហើយ ដូច្នេះសូមអ្នករាល់គ្នាចុះទៅ នាំឡើង
**៧** ទៅឯអ្នករាល់គ្នាវិញចុះ ១នោះពួកគារយ៉ាត់-យារីម
ក៏មកនាំយកហឹប[ក]នៃព្រះយេហូវ៉ា ឡើងទៅដាក់នៅក្នុងផ្ទះ
របស់អ័ប៊ីន៉ាដាប់[ខ] ដែលនៅលើភ្នំ ក៏ញែកអេលាសារជាកូន
ចេញសំរាប់ថែរក្សាហឹបនៃព្រះយេហូវ៉ា ។

**៦:១៣** ណ លប ៣០:១៤ នរ ២:២៣ ១សយ ១២:១៧
**៦:១៤** ត ១សយ ១១:៧ ២សយ ២៤:២២ ១ពវ ១៩:២១
**៦:១៥** ថ យស ៣:៣ ទ ខ.១៨ ធ យស ២១:១៦
**៦:១៧** ន យស ១៣:៣
**៦:១៩** ប ២សយ ៦:៧ ផ នក ១៩:២១
**៦:២០** ព ២សយ ៦:៩ ទដ ១៣០:៣ មឡ ៣:២ វវ ៦:១៧ ភ លវ ១១:៤៥
**៦:២១** ម យស ៩:១៧
**៧:១** ក យស ៦:៧ ខ ២សយ ៦:៣ ១របា ១៣:៧

នាំពួកវា (មើល ខ.៧ និងការពន្យល់) ។

**៦:១៣** *ច្រូតស្រូវ* ពេលវេលានៃការច្រូតស្រូវ គឺស្ថិតនៅអំឡុងពេលពាក់កណ្ដាលខែ មេសា រហូតដល់ពាក់កណ្ដាលខែមិថុនា ។

**៦:១៤-១៥** ការវិលត្រឡប់មកវិញរបស់ហឹបនៃសេចក្ដីសញ្ញា នៅត្រង់បេត-សេមែល គឺត្រូវបានប្រកាសជាដំណឹង ពីព្រោះទីក្រុងនោះ គឺជាទីក្រុងរបស់ពួកសង្ឃ (យស ២១:១៣-១៦) ។

**៦:១៧** *ដង្វាយដោយព្រោះការរំលង* សូមមើលការពន្យល់ ខ.៣ ។

**៦:១៨** *ថ្មនោះក៏នៅក្នុង* គឺទុកដើម្បីឱ្យកូនចៅជំនាន់ក្រោយបានដឹងពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅកន្លែងនោះ ។ *ដរាបដល់សព្វថ្ងៃនេះ* គឺជាសម័យកាលនៃការសរសេរព្រះគម្ពីរសាំយូអែលទី១-២ (សូមមើលសេចក្ដីផ្ដើមៈលក្ខណៈអក្សរសាស្ត្រ អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។

**៦:១៩** *៧០នាក់* ការបន្ថែមចំនួន៥ម៉ឺននាក់ទៅក្នុងការសរសេរភាសាហេព្រើរ ហាក់បីដូចជាកំហុសរបស់ពួកអ្នកដែលចម្លង និងបោះពុម្ពពីព្រោះការបូកបញ្ចូលនោះ មិនបានតាមក្បួនវេយ្យាករណ៍ឡើយ (គ្មានធ្នាក់) ។ មួយវិញទៀតទីក្រុងដ៏តូចមួយនេះ មិនអាចមានមនុស្សរស់ដ៏ច្រើនបែបនេះបានឡើយ ។ *មើលទៅក្នុងហឹបនៃព្រះយេហូវ៉ា* ពួកមនុស្សនៅបេត-សេមែស (ពួកលេវី និងសង្ឃក្នុងចំណោមពួកគេ) ត្រូវបានព្រះអម្ចាស់ទ្រង់ជំនុំជម្រះដោយព្រោះគេមិនគោរពចំពោះព្រះអម្ចាស់ ដោយចង់ដឹងចង់ឃើញហឹបសញ្ញាព្រះយេហូវ៉ា ។ ពីព្រោះព្រះអម្ចាស់ទ្រង់បានភ្ជាប់ទំនាក់ទំនងព្រះវត្តមានទ្រង់យ៉ាងជិតស្និទ្ធិ ទៅនឹងហឹបនៃសេចក្ដីសញ្ញា ពួកគេត្រូវបានព្រះអម្ចាស់ដាក់ទោសដោយមានកិត្តិយស (មើល ២សយ ៦:៧ ជន ៤:១៥,១៧-២០) ។ ទោះបីជាយ៉ាងណាក៏ដោយ សកម្មភាពនេះគឺមានការខុសគ្នាទាំងស្រុងពីការស្មានរបស់ចាស់ទុំដែលគិតថា ព្រះអម្ចាស់បានអនុញ្ញាតឱ្យពួកគេយកហឹបសញ្ញានោះ ទៅដាក់ក្នុងវាលបោះទ័ព ដើម្បីប្រឆាំងជាមួយពួកភីលីស្ទីន ការជំនុំជម្រះនោះគឺផ្ទុយពីពេលនេះ គឺជាការជំនុំជម្រះដោយអំណាច (មើលការពន្យល់ ៤:៣) ។

**៦:២០** *ជាព្រះដ៏បរិសុទ្ធ* សូមមើល ២:២ ការពន្យល់ ។ *តើទ្រង់ត្រូវចេញពីយើងខ្ញុំឡើងទៅឯអ្នកណាវិញ* ពួកអ្នកស្រុកនៅក្នុងបេត-សេមែសត្រូវប្រឈមមុខនឹងការជំនុំជម្រះមកពីព្រះ ដូចពួកអ្នកដែលនៅក្រុងអាសដូឌ ក្រុងកាថ ក្រុងអេក្រុនដែរ (មើល ៥:៨-១០) ។

**៦:២១** *គារយ៉ាត់-យារីម* មានទីតាំងស្ថិតនៅប្រមាណជា ១៤,៤៨ គ.ម ភាគខាងលិចពីក្រុងយេរូសាឡិម ។

**៧:១** *ផ្ទះរបស់អ័ប៊ីន៉ាដាប់* ក្នុងអំឡុងពេលដែលហឹបព្រះយេហូវ៉ាត្រូវបានគង់នៅក្នុងផ្ទះអ័ប៊ីន៉ាដាប់ គឺមិនសូវជាមានអំណាចនោះឡើយ រហូតដល់ពេលដែល ស្ដេចដាវីឌបាននាំយកទៅក្រុងយេរូសាឡិម (២សយ ៦:២-៣) ។ មួយវិញទៀតត្រសាលជំនុំ (ហើយអាសនាដង្វាយដុត) បានគេចផុតពីការបំផ្លាញរបស់ស៊ីឡូរ (យរ ៧:១២,១៤ ២៦:៦) ។ ប្រហែលជាវាត្រូវបានផ្លាស់ទីតាំងលើកដំបូង គឺទៅក្រុងណូប (២១:១-៩) ។ នៅក្នុងស្ដេចដាវីឌ និងស្ដេចសាឡូម៉ូន ហឹបសញ្ញានេះត្រូវបានគេនាំមកទុកនៅក្រុងគីបៀន ដែលមានចម្ងាយ ប្រមាណជា ៨,០៤ គ.ម ភាគខាងជើងក្រុងយេរូសាឡិម (១ពវ ៣:៤ ១របា ១៦:៣៩ ២១:២៩ ២របា ១:៣,១៣) ។ ពួកអ្នកគីបៀនបានហាមឃាត់ពួកអ្នកបម្រើមិន ឱ្យចូលទៅក្នុងទីបរិសុទ្ធរបស់ព្រះអម្ចាស់ឡើយ (យស ៩:២៣, ២៧) ។ បន្ទាប់ពីស្ដេចសាឡូម៉ូនបានសាងសង់ព្រះវិហាររួចរាល់ហើយ ទ្រង់បាននាំយកហឹបសញ្ញា និងត្រសាលជំនុំមក

## លោកសាំយូអែលធ្វើឱ្យពួកភីលីស្ទីនចុះចាញ់នៅមីសប៉ា

២ចាប់តាំងពីថ្ងៃ ដែលហឹបបានតាំងនៅត្រង់គារយ៉ាត់
យារីម[គ] នោះបានយូរណាស់ គឺអស់កំណត់២០ឆ្នាំ ហើយ
ពូជពង្សអ៊ីស្រាអែលទាំងអស់គ្នា ក៏នឹកស្រណោះដល់ព្រះ
យេហូវ៉ា[ឃ] ។
៣នៅវេលានោះ សាំយូអែលប្រាប់ដល់ពួកវង្សអ៊ីស្រា
អែលទាំងអស់ថា បើអ្នករាល់គ្នាវិលត្រឡប់[ង]មកឯព្រះ
យេហូវ៉ាវិញដោយអស់ពីចិត្ត នោះត្រូវយក[ច]អស់ទាំងព្រះ
ដទៃ និងរូបព្រះទាំងប៉ុន្មាន[ឆ]ពីពួកអ្នករាល់គ្នាចេញ ហើយ
បាញ់ចិត្តដំរង់ចំពោះព្រះយេហូវ៉ា ព្រមទាំងគោរពប្រតិ
បត្តិ[ជ]ដល់ទ្រង់តែ១[ឈ] នោះទ្រង់នឹងជួយដោះ[ញ]អ្នករាល់គ្នា ឱ្យ
រួចចេញពីកណ្តាប់ដៃនៃពួកភីលីស្ទីន ៤ដូច្នេះពួកកូនចៅ
អ៊ីស្រាអែលក៏យកព្រះបាល និងរូបព្រះទាំងប៉ុន្មានចោល
ចេញ វិលមកគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែ១វិញ ។
៥សាំយូអែល[ដ]ក៏ប្រាប់ថា ចូរឱ្យប្រមូលពួកអ៊ីស្រាអែល
ទាំងអស់មកឯមីសប៉ា[ឋ]ចុះ ខ្ញុំនឹងអធិស្ឋាន[ឌ]ដល់ព្រះយេហូវ៉ា
ឱ្យអ្នករាល់គ្នា ៦គេក៏ប្រជុំគ្នានៅត្រង់មីសប៉ា[ឍ] រួចដងទឹក
យកទៅចាក់[ណ]នៅចំពោះព្រះយេហូវ៉ា ហើយតមនៅថ្ងៃ
នោះ ដោយថា យើងរាល់គ្នាបានធ្វើបាបនឹងព្រះយេហូវ៉ា
ហើយ នោះសាំយូអែលក៏វិនិច្ឆ័យ[ត]រឿងរបស់ពួកកូនចៅ
អ៊ីស្រាអែលនៅត្រង់មីសប៉ា ៧លុះពួកភីលីស្ទីនឮថា ពួកកូន
ចៅអ៊ីស្រាអែលបានប្រជុំគ្នានៅមីសប៉ាដូច្នោះ នោះពួកមេ
នៃសាសន៍ភីលីស្ទីនក៏ឡើងមកទាស់នឹងគេ កាលពួកកូនចៅ
អ៊ីស្រាអែលបានដឹង នោះគេភ័យខ្លាច[ថ]នឹងពួកភីលីស្ទីន
៨ហើយក៏អង្វរសាំយូអែលថា សូមកុំឱ្យលោកឈប់លែង
អំពាវនាវ[ទ]ដល់ព្រះយេហូវ៉ាជាព្រះនៃយើងរាល់គ្នាឡើយ
ដើម្បីឱ្យទ្រង់ជួយសង្គ្រោះយើងរាល់គ្នា ឱ្យរួចពីកណ្តាប់ដៃ
នៃពួកភីលីស្ទីន ៩ដូច្នោះ សាំយូអែល[ធ]ក៏យកកូនចៀមដែល
នៅបៅ មកដុតទាំងមូលថ្វាយដល់ព្រះយេហូវ៉ា ហើយ
អំពាវនាវដល់ទ្រង់ឱ្យពួកអ៊ីស្រាអែល នោះព្រះយេហូវ៉ា
ទ្រង់ក៏យល់ព្រមតាម[ន] ១០កាលសាំយូអែលកំពុងតែថ្វាយ

**៧:២** គ ១រប ១៣:៥ ទដ ១៣២:៦ ឃ ១រប ១៣:៣ **៧:៣** ង ចទ ៣០:១០ ២ពវ ១៨:៥ ២៣:២៥ យរ ២៤:៧ ច លប ៣១:១៩ យស ២៤:១៤ ឆ ពច ២:១២–១៣ ១សយ ១២:១០ ៣១:១០ ជ យអ ២:១២ ឈ ចទ ៦:១៣ មថ ៤:១០ លក ៤:៨ ញ ពច ២:១៨ **៧:៥** ដ ១សយ ១:២០ ទដ ៩៩:៦ យរ ១៥:១ ឋ យស ១១:៣ ពច ២១:៥ ១សយ ១០:១៧ ឌ ខ.៨ លប ២០:៧ ចទ ៩:៩១

**៧:៦** ឍ យស ១១:៣ ណ បទ ២:១៩ ត ពច ២:១៦ ១៦:៣១ **៧:៧** ថ ១សយ ១៧:១១ **៧:៨** ទ ខ.៥ នក ៣២:៣០ ជន ២១:៧ ១សយ ១២:១៨,២៣ ១ពវ ១៨:២៤ អស ៣៧:៤ យរ ១៥:១ ២៧:១៨ **៧:៩** ធ ទដ ៩៩:៦ ន នក ៣២:១១ ចទ ៩:១៩

រក្សាទុកក្នុងព្រះវិហារនោះ (១ពវ ៨:៣–៦ និងការពន្យល់ ៨:៤) ។

**៧:២** *គឺអស់កំណត់២០ឆ្នាំ* ប្រហែលជា២០ឆ្នាំចន្លោះពីពេលដែលហឹបនៃសេចក្ដីសញ្ញាបានវិលត្រឡប់មកអ៊ីស្រាអែលវិញ ហើយត្រូវបានប្រជុំហៅដោយហោរាសាំយូអែល នៅត្រង់មីសប៉ា (មើល ខ.៥) ។

**៧:៣** *រូបព្រះ* គឺជារូបព្រះទូទៅ ដែលនៅកន្លែងផ្សេងៗនៅមជ្ឈឹមបូព៌ាសម័យបុរាណ ។ ទោះបីជាយ៉ាងណាក៏ដោយ រូបព្រះទាំងនោះ ជាព្រះនៃសេចក្ដីស្រឡាញ់ សម្បូរសប្បាយ ហើយជាព្រះនៃសង្គ្រាម ត្រូវបានគេគោរពតាមរបៀប និងដោយមនុស្សផ្សេងៗគ្នា ក្នុងនោះមានពួកកាណានដែរ (មើលការពន្យល់ ពច ២:១៣) ។ ការគោរពថ្វាយបង្គំចំពោះរូបព្រះតែងតែរាប់បញ្ចូលជាមួយព្រះបាល (មើល ខ.៤ ១២:១០ ពច ២:១៣ ១០:៦) នៅក្នុងការអនុញ្ញាតិជាមួយការប្រព្រឹត្តជាមួយនឹងពិធីសាសនារបស់គេ ដើម្បីបញ្ចូលគ្នារវាងព្រះប្រុស និងព្រះស្រី ។

**៧:៥** *មីសប៉ា* សូមមើល ២ពវ ២៥:២៣ ។ មីសប៉ាគឺជាទីក្រុងមួយក្នុងចំណោមទីក្រុងផ្សេងៗទៀតរបស់អំបូរបេនយ៉ាមីន (យស ១៨:២៦) ដែលមានចម្ងាយប្រមាណជា ១២,០៦ គ.ម ភាគខាងជើងពីក្រុងយេរូសាឡិម ។ នៅទីនេះពួកសាសន៍អ៊ីស្រាអែលបានរួសរាន់ប្រជុំមូលគ្នា ដើម្បីដាក់វិន័យប្រឆាំងជាមួយពួកបេនយ៉ាមីន (មើល ពច ២០:១ ២១:១) បន្ទាប់ពីមានការរំលោភបំពាន និងការកាប់សម្លាប់ប្រពន្ធចុងរបស់អ្នកត្រេចចរលេវី នៅគីបៀរ ពីសំណាក់អំបូរបេនយ៉ាមីន ។ មានឈ្មោះ២ ឬ៣ទៀត ដែលមានឈ្មោះដូចគ្នានេះដែរ (មើល ២២:៣ លប ៣១:៤៩ យស ១១:៣,៨ ១៥:៣៨) ។ *ខ្ញុំនឹងអធិស្ឋាន* សូមមើល ៧:៨–៩ ៨:៦ ១២:១៧–១៩,២៣ ១៥:១១ ។ ហោរាសាំយូអែល ក៏ដូចជាលោកម៉ូសេដែរត្រូវបានគេនឹកចាំពួកគាត់ គឺជាអ្នកអធិស្ឋានទូលអង្វរដ៏ពូកែ (មើល ទដ ៩៩:៦ យរ១៥:១) ។ ពួកគាត់ទាំង២នាក់ត្រូវបានព្រះអម្ចាស់តម្រូវទុកជាមុន ឱ្យធ្វើជាអ្នកសម្របសម្រួលការគ្រប់គ្រងរបស់ព្រះអម្ចាស់លើរាស្ត្រទ្រង់ ជាអ្នកតំណាងរបស់ព្រះអម្ចាស់ចំពោះពួកអ៊ីស្រាអែល ហើយក៏ជាអ្នកនាំពាក្យរបស់ប្រជាជនអ៊ីស្រាអែលទៅឯព្រះអម្ចាស់ផងដែរ ។

**៧:៦** *រួចដងទឹកយកទៅចាក់នៅចំពោះព្រះយេហូវ៉ា* ការដងទឹកយកទៅចាក់នៅចំពោះព្រះយេហូវ៉ាបែបនេះ មិនបានបង្ហាញពីទំនាក់ទំនង ឬសំដៅលើពិធីបុណ្យអ្វីនៅក្នុងព្រះគម្ពីរសញ្ញាចាស់នោះឡើយ ។ វាបានកើតឡើងគ្រាន់តែជានិមិត្តសញ្ញាពីការលាងសម្អាតចិត្តរបស់អ្នកណាម្នាក់ នៅក្នុងការស្តាយក្រោយ និងការបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ប៉ុណ្ណោះ ។ សម្រាប់ទំនាក់ទំនងនឹងសំនួនវោហាស៍នេះ សូមមើល ១:១៥ ទដ ៦២:៨ បទ ២:១៩ និងការពន្យល់ ។ *សាំយូអែលក៏វិនិច្ឆ័យ* សូមមើល ខ.១៥ និងការពន្យល់ ៤:១៨ ។

**៧:៨** *សូមកុំឱ្យលោកឈប់លែងអំពាវនាវដល់ព្រះយេហូវ៉ាជាព្រះនៃយើងរាល់គ្នា* ហោរាសាំយូអែលត្រូវបានហៅចេញពីក្នុងចំណោមបណ្ដាជនដើម្បីឱ្យធ្វើជាអ្នកនាំព្រះបន្ទូលព្រះអម្ចាស់ ទៅចំពោះរាស្ត្ររបស់ទ្រង់ជាហោរាដែលបានផ្ដល់អភ័យឯកសិទ្ធិ ឱ្យចូលទៅក្នុងទីប្រជុំកំពូលរបស់ព្រះអម្ចាស់តែមួយគត់ (១ពវ ២២:១៩ និងការពន្យល់) ។ អភ័យឯកសិទ្ធិនៃការចូលទៅចំពោះព្រះអម្ចាស់នេះ គឺប្រៀបដូចជាអ្នកសម្របសម្រួលការគ្រប់គ្រងរបស់ព្រះអម្ចាស់លើរាស្ត្រទ្រង់ ហើយដោយតាមរយៈកាតព្វកិច្ចដ៏ពិសេសនេះ គាត់ត្រូវតែធ្វើជាអំពាវនាវសម្រាប់រាស្ត្រទ្រង់ ដូចអ្វីដែលលោកម៉ូសេបានធ្វើ (នក ៣២:១១–១៤ ៣៤:៨–៩ ជន ១៤:១៣–១៩) ហើយក៏ដូចជាលោកអេសាយ (២ពវ ១៩:៤) លោកយេរេមា (យរ ៧:១៦ ១៥:១ និងការពន្យល់) ព្រមទាំងលោកអេម៉ុស (អម ៧:២–៣,៥–៦) ។

**៧:១០** *ព្រះយេហូវ៉ាទ្រង់ធ្វើឱ្យមានផ្គរលាន់ ជាយ៉ាងខ្លាំង* ព្រះអម្ចាស់ទ្រង់បានសន្យានឹងរាស្ត្ររបស់ទ្រង់ថា ព្រះអង្គទ្រង់នឹងធ្វើជាអ្នកការពារគេនៅ

ដង្វាយដុត នោះពួកភីលីស្ទីនចូលមកដល់ជិត ដើម្បីច្បាំង
នឹងពួកអ៊ីស្រាអែលហើយ តែនៅថ្ងៃនោះ ព្រះយេហូវ៉ាទ្រង់
ធ្វើឱ្យមានផ្គរលាន់[ប] ជាយ៉ាងខ្លាំង[ផ]ត្រង់ពីលើពួកភីលីស្ទីន
ឱ្យគេបាក់ទ័ពខ្ចាត់ខ្ចាយចេញ ហើយគេត្រូវពួកអ៊ីស្រាអែល
កាប់សំឡាប់ 11 ពួកអ៊ីស្រាអែលក៏ចេញពីមីសប៉ា ដេញតាម
ពួកភីលីស្ទីនទៅ ទាំងប្រហារជីវិតគេរហូតដល់បេត-
ការ ។

12 នោះសាំយូអែល លោកយកថ្ម[ព] ដាក់នៅកណ្ដាល
មីសប៉ា និងសេ៊ន ហើយក៏ហៅថ្មនោះ ឈ្មោះថា អេបេន-
អេស៊ើរ[ភ] ដោយថា ព្រះយេហូវ៉ាទ្រង់បានជួយយើងខ្ញុំដរាប
ដល់ឥឡូវនេះ 13 ដូច្នេះ ពួកភីលីស្ទីនត្រូវទទួលចុះចាញ់[ម] គេ
មិនបានទន្ទ្រានចូលមក ក្នុងដែនស្រុកអ៊ីស្រាអែលទៀត
ហើយព្រះហស្តនៃព្រះយេហូវ៉ាក៏ទាស់នឹងពួកភីលីស្ទីន នៅ
គ្រប់១ជីវិតសាំយូអែល 14 ឯអស់ទាំងទីក្រុងណាដែលពួក
ភីលីស្ទីនបានចាប់យកពីពួកអ៊ីស្រាអែលទៅ នោះក៏បាន
ប្រគល់មកអ៊ីស្រាអែលវិញ ចាប់តាំងពីក្រុងអេក្រុន[យ]រហូត
ដល់ក្រុងកាថ ហើយគ្រប់ដែនស្រុកនោះ ពួកអ៊ីស្រាអែល
ក៏បានដោះឱ្យរួចពីកណ្ដាប់ដៃនៃពួកភីលីស្ទីនដែរ នៅជាន់
នោះសាសន៍អ៊ីស្រាអែល និងសាសន៍អាម៉ូរី មានសេចក្ដី
មេត្រីនឹងគ្នា[រ] ។

15 ឯសាំយូអែល[ល] លោកគ្រប់គ្រង[វ]លើសាសន៍អ៊ីស្រា
អែលអស់[ស]១ជីវិត 16 លោកតែងដើរវង់ ពីបេត-អែល[ហ]
ទៅដល់គីលកាល[ឡ] ហើយនឹងមីសប៉ារាល់តែឆ្នាំ ក៏វិនិច្ឆ័យ[អ]
រឿងរបស់ពួកអ៊ីស្រាអែលនៅកន្លែងទាំងនោះ 17 រួច
ត្រលប់មករ៉ាម៉ា[ក]វិញ ដ្បិតផ្ទះលោកនៅត្រង់រ៉ាម៉ានោះ
គឺនៅទីនោះ ដែលលោកតែងវិនិច្ឆ័យ[ខ]រឿងរបស់ពួក
អ៊ីស្រាអែលជានិច្ច ហើយលោកក៏ស្អាងអាសនា១[គ]ថ្វាយ
ព្រះយេហូវ៉ា នៅទីនោះដែរ ។

## ពួកអ៊ីស្រាអែលស្នើឱ្យមានស្តេច

**៨** 1 លុះកាលសាំយូអែលចាស់ហើយ នោះលោកតាំង[ក]
កូនឡើង ឱ្យធ្វើជាអ្នកគ្រប់គ្រង លើសាសន៍អ៊ីស្រាអែល
តទៅ 2 រីឯកូនច្បងរបស់លោកឈ្មោះយ៉ូអែល ហើយកូន
បន្ទាប់ឈ្មោះអ័ប៊ីយ៉ា[ខ] អ្នកទាំង២នោះ ជាអ្នកវិនិច្ឆ័យការណ៍
នៅត្រង់បៀរ-សេបា[គ] 3 តែគេ[ឃ]មិនបានដើរតាមគន្លង
របស់ឪពុកទេ គឺបានងាកបែរ[ង]ទៅរកកំរៃវិញ ទាំងស៊ី[ច]
សំណូក ហើយបង្វែរ[ឆ]សេចក្ដីយុត្តិធម៌ចេញផង ។

4 នៅគ្រានោះពួកចាស់ទុំ[ជ]នៃសាសន៍អ៊ីស្រាអែលទាំង
ប៉ុន្មាន ក៏ប្រជុំគ្នាមកឯសាំយូអែលនៅត្រង់រ៉ាម៉ា[ឈ] 5 គេ
ជំរាប មើល ឥឡូវលោកចាស់ហើយ ឯពួកកូនលោក គេ

**៧:១០** ប នក ៩:២៣ ១សយ ២:១០ ផ លប ៣៥:៥ នក ១៤:២៤ **៧:១២** ព លប ២៨:២២ ចទ ២៧:២ យស ៤:៩ ភ ១សយ ៤:១ **៧:១៣** ម ពច ១៣:១,៥ **៧:១៤** យ យស ១៣:៣ រ ពច ១:៣៤ **៧:១៥** ល ខ.៦ ១សយ ១២:១១ វ ពច ២:១៦ ស ពច ២:១៨ **៧:១៦** ហ លប ១២:៨ ឡ យស ១០:៤៣ ១សយ ១០:៨ អម ៥:៥ អ ខ.៦ អម ១៣:២០ **៧:១៧** ក យស ១៨:២៥ ១សយ ៨:៤ ១៥:៣៤ ១៩:១៨ ២៥:១ ២៨:៣ ខ ខ.៦ គ ១សយ ៩:១២ ១៤:៣៥ ២០:៦ ២សយ ២៤:២៥ **៨:១** ក ចទ ១៦:១៨-១៩ **៨:២** ខ ១របា ៦:២៨ គ លប ២២:១៩ ១ពវ ១៩:៣ អម ៥:៤-៥ **៨:៣** ឃ ១សយ ២:១២ ង នហ ៩:២៩ យប ៣៤:២៧ ទដ ១៤:៣ ៥៨:៣ អស ៥៣:៦ ច នក ២៣:៨ ១សយ ១២:៣ ឆ នក ២៣:២ **៨:៤** ជ ពច ១១:១១ ១សយ ១១:៣ ឈ ១សយ ៧:១៧

ពេលណាដែលគេស្ដាប់បង្គាប់ចំពោះសេចក្ដីសញ្ញា ដែលគេបានតាំងជាមួយព្រះអម្ចាស់ (នក ២៣:២២ ចទ ២០:១-៤ ២សយ ៥:១៩-២៥ យស ១០:១១-១៤ ពច ៥:២០-២១ ២ពវ ៧:៦ ១៩:៣៥ ២របា ២០:១៧,២២) ។

**៧:១២** *អេបេន-អេស៊ើរ* សូមមើលការពន្យល់ ៤:១ ។

**៧:១៣** *គេមិនបានទន្ទ្រានចូលមក ក្នុងដែនស្រុកអ៊ីស្រាអែលទៀត* មានអ្នកកាត់ស្រាយខ្លះឃើញមានភាពផ្ទុយគ្នារវាងសេចក្ដីថ្លែងការនេះ ទៅនឹងសេចក្ដីអះអាងក្រោយៗទៀតចំពោះពួកភីលីស្ទីននៅក្នុង ៩:១៦ ១០:៥ ១៣:៣,៥ ១៧:១ ២៣:២៧ ។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្ដីថ្លែងការនេះ គឺគ្រាន់តែបង្ហាញថា ពួកភីលីស្ទីនមិនបានវាយតបវិញភ្លាមនោះទេ តែប៉ុណ្ណោះ (មើល ២ពវ ៦:២៣-២៤ សម្រាប់ស្ថានភាពប្រហាក់ប្រហែលគ្នានេះ) ។

**៧:១៤** *សាសន៍អាម៉ូរី* សូមមើលការពន្យល់ លប ១០:១៦ ។

**៧:១៥** គឺជាសេចក្ដីសង្ខេបចំពោះសេចក្ដីថ្លែងការ ដែលបានផ្ដល់ជាស្នាមគំនូសនៅចុងបញ្ចប់នៃបញ្ជីរឿងរបស់អ្នកនិពន្ធ ដែលនិយាយអំពីការងាររបស់ហោរាសាំយូអែលក្នុងនាមជាអ្នកដឹកនាំរបស់ពួកអ៊ីស្រាអែល (ខ.៦) ។

**៧:១៦** *ពីបេត-អែលទៅដល់គីលកាល ហើយនិងមីសប៉ា* គឺជាការធ្វើដំណើរនៅក្នុងតំបន់ដែលនៅជិតៗប៉ុណ្ណោះ ។ *វិនិច្ឆ័យរឿងរបស់ពួកអ៊ីស្រាអែល* សូមមើលការពន្យល់ ៤:១៨ ។

**៧:១៧** *រ៉ាម៉ា* សូមមើលការពន្យល់ ១:១ ។

**៨:១-១២:២៥** សូមមើលសេចក្ដីផ្ដើមៈ មាតិកា និងផ្ទៃរឿង ។

**៨:១** *លុះកាលសាំយូអែលចាស់ហើយ* ប្រហែលជា២០ឆ្នាំបន្ទាប់ពីគាត់ទទួលបានជ័យជម្នះនៅត្រង់មីសប៉ា (មើល ៧:១១) នៅក្នុងពេលនោះហោរាសាំយូអែលប្រហែលជាមានអាយុកាល៦៥ឆ្នាំ (មើលសេចក្ដីផ្ដើមៈ ពង្សាវតារក្សត្រ) ។

**៨:២** *យ៉ូអែល* មានន័យថា"ព្រះយេហូវ៉ាទ្រង់ជាព្រះ"។ *អ័ប៊ីយ៉ា* មានន័យថា "ព្រះយេហូវ៉ាទ្រង់ជាឪពុកទូលបង្គំ" ។ ថ្វីបើឈ្មោះរបស់ពួកគេយ៉ាងនេះក៏ដោយ ក៏កូនទាំង២របស់គាត់ "មិនបានដើរតាមគន្លងផ្លូវរបស់គាត់" ដែរ (ខ.៣) ។ *បៀរ-សេបា* មានចម្ងាយប្រមាណជា ៦៤,៣៦ គ.ម ភាគខាងត្បូងឈៀងខាងលិចក្រុងយេរូសាឡិម (មើល លប ២១:៣១) ។

**៨:៣** *ស៊ីសំណូក* ធៀបនឹង ១២:៣ ។ ការកាត់ក្ដីដោយស៊ីសំណូកត្រូវបានហាមឃាត់ជាដាច់ខាត នៅក្នុងក្រឹត្យវិន័យនៃគម្ពីរបញ្ញត្ត (សូមមើល នក ២៣:៨ និង ចទ ១៦:១៩) ។

**៨:៥** *តាំងឱ្យមានស្តេច១អង្គ សំរាប់នឹងគ្រប់គ្រងលើយើងរាល់គ្នា* ពួកចាស់ទុំទាំងនោះបានសម្អាងលើហេតុផល នៃអាយុកាលរបស់ហោរាសាំយូអែល និងកិរិយាមិនត្រឹមត្រូវរបស់កូនគាត់ មកធ្វើជាលេសសម្រាប់ក្នុងការសំណូមពរឱ្យមានស្តេចគ្រប់គ្រងលើពួកគេ ។ វាអាចនឹងកើតឡើងនៅក្នុងពេលខាងមុខ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយមូលដ្ឋានគ្រឹះនៃសំណូមពរនោះ គឺជាការប្រាថ្នាដើម្បីឱ្យបានដូចជាបណ្ដាប្រជាជាតិនៅជុំវិញរបស់គេ ដែលមានស្តេចគ្រប់គ្រង ព្រោះការមានស្តេចគឺជានិមិត្តសញ្ញា

មិនប្រព្រឹត្តតាមគន្លងរបស់លោកទេ ដូច្នេះ សូមលោកតាំង
ឱ្យមានស្ដេច១អង្គ[ញ] សំរាប់នឹងគ្រប់គ្រង[ដ]លើយើងរាល់គ្នា
ដូចជាសាសន៍ឯទៀត[ឋ]ដែរ ៦តែដំណើរដែលគេសូមឱ្យ
តាំងស្ដេច[ឌ]ឡើងសំរាប់គ្រប់គ្រងលើគេ នោះមិនគាប់ចិត្ត[ឍ]
ដល់សាំយូអែលទេ ហើយលោកក៏អធិស្ឋានដល់ព្រះ
យេហូវ៉ា ៧ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងលោកថា ចូរ
ស្ដាប់[ណ]តាមគ្រប់ទាំងសេចក្ដី ដែលពួកបណ្ដាជនសូម
ដល់ឯងចុះ ដ្បិតគេមិនបានបោះបង់ចោលឯងទេ[ត] គឺបោះ
បង់ចោលអញវិញ ដើម្បីមិនឱ្យអញធ្វើជាស្ដេចលើគេ
ទៀត[ថ] ៨គេប្រព្រឹត្តនឹងឯង ដូចជាបានប្រព្រឹត្តនឹងអញ ចាប់
តាំងពីថ្ងៃ ដែលអញបាននាំគេឡើងចេញពីស្រុកអេស៊ីព្ទមក
ដរាបដល់សព្វថ្ងៃនេះដែរ គឺគេបានបោះបង់ចោល[ទ]អញ
បែរទៅគោរពប្រតិបត្តិដល់ព្រះដទៃវិញ ៩ដូច្នេះ ចូរឯង
ស្ដាប់តាមគេឥឡូវនេះចុះ ប៉ុន្តែត្រូវឱ្យឯងប្រកែកនឹងគេ
យ៉ាងម៉ឺងម៉ាត់ដែរ ដោយពន្យល់បង្ហាញ[ធ]ដល់គេ ពីសណ្ឋាន
ដែលមានស្ដេចសោយរាជ្យលើគេនោះជាយ៉ាងណា ។
១០សាំយូអែលក៏ប្រាប់[ន]គ្រប់ទាំងព្រះបន្ទូល នៃព្រះ
យេហូវ៉ា ដល់ពួកបណ្ដាជន ដែលបានសូមឱ្យលោកតាំង
ស្ដេចឡើងឱ្យគេនោះ ១១ដោយពាក្យថា ឯសណ្ឋានរបស់
ស្ដេចដែលសោយរាជ្យលើអ្នករាល់គ្នា នោះនឹងបានដូច្នេះ
គឺស្ដេចនោះនឹងយក[ប]កូនប្រុសៗរបស់អ្នករាល់គ្នា ដំរូវទុក
សំរាប់ទ្រង់ ឱ្យនៅ[ផ]នឹងរាជរថ ហើយនិងពលសេះរបស់
ទ្រង់ គេនឹងត្រូវរត់នៅមុខរាជរថរបស់ទ្រង់[ព] ១២ទ្រង់នឹង
ដំរូវខ្លះ ឱ្យធ្វើជាមេលើ១ពាន់នាក់ និងជាមេលើ[ភ]៥០នាក់
ហើយខ្លះឱ្យភ្ជួរស្រែច្រូតចំរូត ខ្លះទៀតឱ្យធ្វើគ្រឿងសស្ត្រា
វុធ និងប្រដាប់សំរាប់រាជរថទ្រង់ ១៣ទ្រង់នឹងយកកូនស្រីៗ
របស់អ្នករាល់គ្នា ឱ្យធ្វើជាអ្នកអប់គ្រឿងក្រអូប ជាអ្នក
ដាំបាយ ហើយដុតនំ ១៤ទ្រង់នឹងយកស្រែចំការ និងដំណាំ
អូលីវ[ម]របស់អ្នករាល់គ្នា[យ] គឺរបស់ណាដែលល្អបំផុតផង
ចែកឱ្យដល់ពួកមហាតលិកទ្រង់[រ] ១៥ក៏នឹងយក១ភាគក្នុង១០[ល]
ពីស្រូវ ហើយពីទំពាំងបាយជូររបស់អ្នករាល់គ្នា ចែកឱ្យ
ដល់ពួកអ្នកបំរើនិងពួកបាវផង ១៦ទ្រង់នឹងយកបាវប្រុស
បាវស្រីរបស់អ្នករាល់គ្នា ព្រមទាំងពួកកំឡោះដែលល្អ
បំផុត និងសត្វលារបស់អ្នករាល់គ្នា ទៅប្រើឱ្យធ្វើការ
របស់ទ្រង់វិញ ១៧ទ្រង់នឹងយក១ភាគក្នុង១០ពីហ្វូងសត្វអ្នក
រាល់គ្នា ហើយអ្នករាល់គ្នានឹងធ្វើជាខ្ញុំកំដររបស់ទ្រង់ ១៨នៅ
ថ្ងៃនោះអ្នករាល់គ្នានឹងអំពាវនាវដល់ព្រះយេហូវ៉ា ដោយ
ព្រោះស្ដេចដែលអ្នករាល់គ្នានឹងរើសនោះ តែទ្រង់មិន
ព្រមស្ដាប់តាម[វ]អ្នករាល់គ្នានៅថ្ងៃនោះទេ[ស] ១៩ប៉ុន្តែពួក
បណ្ដាជនមិនព្រម[ហ]ស្ដាប់តាមសាំយូអែលឡើយ ដោយ
ប្រកែកថា ទេ ត្រូវតែមាន[ឡ]ស្ដេច[អ]លើយើងរាល់គ្នាវិញ
២០ដើម្បីឱ្យយើងបានដូចសាសន៍ឯទៀតដែរ[ក] ហើយឱ្យស្ដេច
នៃយើងបានគ្រប់គ្រងលើយើង ព្រមទាំងនាំមុខយើងចេញ

**៨:៥** ញ ឧ.១៩ ចទ ១៧:១៤–២០ ១សយ ១០:១៩ ១២:១២, ១៣ ហស ១៣:១១ ដ ១សយ ៣:២០ ឋ ឧ.២០ **៨:៦** ឌ ហស ១៣:១០ ឍ ១សយ ១២:១៧ ១៥:១១ ១៦:១ **៨:៧** ណ ឧ.២២ ១សយ ១២:១ ត ជន ១១:២០ ថ នក ១៦:៨ **៨:៨** ទ ១សយ ១២:១០ ២ពវ ២១:២២ យរ ២:១៧ **៨:៩** ធ ឧ.១១–១៨ ចទ ១៧:១៤–២០ ១សយ ១០:២៥ **៨:១០** ន នក ១៩:៧ **៨:១១** ប ១សយ ១៤:៥២ ផ លប ៤១:៤៦ ព ចទ ១៧:១៦ ២សយ ១៥:១ ១ពវ ១:៥ ២រប ១:១៤ ៩:២៥ ៣:៧ **៨:១២** ភ ចទ ១:១៥ **៨:១៤** ម ១ពវ ២១:៧,១៥ មីក ២:២ យ អគ ៤៦:១៨ រ ២ពវ ២២:១២ **៨:១៥** ល លប ៤១:៣៤ ១សយ ១៧:២៥ **៨:១៨** វ ១សយ ២៨:៦ យប ២៧:៩ ៣៥:១២,១៣ ទដ ១៨:៤១ ៦៦:១៨ សភ ១:២៨ អស ១:១៥ ៥៨:៤ ៥៩:២ យរ ១៤:១២ អគ ៨:១៨ មីក ៣:៤ ស ១សយ ១០:២៥ ១ពវ ១២:៤ **៨:១៩** ហ សភ ១:២៤ អស ៥០:២ ៦៦:៤ យរ ៧:១៣ ៨:១២ ១៣:១០ ៤៤:១៦ ឡ កច ១៣:២១ អ ឧ.៥ **៨:២០** ក ឧ.៥

ពីអំណាចដ៏អស្ចារ្យ និងការរួបរួមរបស់ប្រជាជាតិនោះ ដែលអាចនាំពួកគេឱ្យទទួលជ័យជម្នះក្នុងចម្បាំង (មើល ឧ.២០ ១០:១៩ ១២:១២ និងសេចក្ដីផ្ដើម: មាតិកា និងផ្ទៃរឿង) ។

**៨:៧** *ចូរស្ដាប់តាមគ្រប់ទាំងសេចក្ដី ដែលពួកបណ្ដាជនសូមដល់ឯងចុះ* ការប្រមើលទុកជាមុនអំពីស្ដេចដែលនឹងត្រូវគ្រប់គ្រងលើអ៊ីស្រាអែល គឺបាននិយាយ និងណែនាំរួចទៅហើយនៅក្នុងបទគម្ពីរបញ្ញកណ្ឌ (សូមមើល លប ៤៩:១០ ជន ២៤:៧,១៧ ចទ ១៧:១៤–២០) ដូច្នេះហើយហោរាសាំយូអែលត្រូវតែមានទំនុកចិត្ត និងធ្វើតាមសំណូមពររបស់បណ្ដាជន (មើល ឧ.៩, ២២) ។ *ដ្បិតគេមិនបានបោះបង់ចោលឯងទេ គឺបោះបង់ចោលអញវិញ* ធៀបនឹង ពច ៨:២៣ ។ បំណងប្រាថ្នារបស់ពួកគេ គឺចង់បានស្ដេចដែលបដិសេធន៍ចំពោះសេចក្ដីសញ្ញារបស់គេ ជាមួយនិងព្រះអម្ចាស់ដែលព្រះទ្រង់ផ្ដាល់បានសន្យាថា នឹងធ្វើជាអ្នកសង្គ្រោះ និងអ្នករំដោះពួកគេ ។ នៅក្នុងសំណូមពរ ដែលចង់ឱ្យមានស្ដេច "ដើម្បីឱ្យយើងបានដូចសាសន៍ឯទៀត" (ឧ.២០) ពួកគេបានបោះបង់ចោលសេចក្ដីសញ្ញា និងបដិសេធន៍ព្រះអម្ចាស់ដែលជាព្រះរបស់គេ (មើល ១២:១២ ជន ២៣:២១ ចទ ៣៣:៥) បំភ្លេចចោលនូវការការពាររបស់ទ្រង់ចំពោះពួកគេពីអតីតកាល (មើល ១០:១៨ ១២:៨–១១) ។

**៨:៩,១១** *ពីសណ្ឋានដែលមានស្ដេចសោយរាជ្យ . . . មុខរាជរថរបស់ទ្រង់* ការពិពណ៌នា ពីការប្រើប្រាស់គោលនយោបាយអចិន្ត្រៃយ៍ នៃស្ដេចសាសន៍កាណាន (សូមមើល ឧ.១១–១៧) ហោរាសាំយូអែលបានរំឭកដល់ពួកបណ្ដាជនដែលមានភារកិច្ចប្រាស្រ័យទាក់ទងជាមួយស្ដេច ដែលពួកគេបានជ្រើសរើសនោះ ។

**៨:១១** *រាជរថ* សូមមើល យស ១១:៦ និង ចទ ១៧:១៦ និងការពន្យល់ ១៧:១៦–១៧ ។

**៨:១៥** *១ភាគក្នុង១០* បំណែករបស់ស្ដេច គឺត្រូវបានច្រើនជាង១ភាគក្នុង ១០ ដែលបណ្ដាជនអ៊ីស្រាអែលបានថ្វាយទៅឯព្រះអម្ចាស់ (លវ ២៧:៣០–៣២ ជន ១៨:២៦ ចទ ១៤:២២,២៨ ២៦:១២) ។ តាមពិតសេចក្ដីតម្រូវការរបស់ស្ដេច គឺត្រូវមានភាពដូចគ្នានឹងអ្វីដែលពួកអ៊ីស្រាអែលបានថ្វាយទៅព្រះដែលជាស្ដេចដ៏ធំឧត្តមរបស់គេ (មនុស្ស ដំណាំដាំដុះ និងហ្វូងសត្វ) រួមទាំងបណ្ដាជនទាំងអស់ទៀតផង (ឧ.១៧) ។

**៨:១៨** *នឹងអំពាវនាវ . . . ដោយព្រោះស្ដេចដែលអ្នករាល់កគ្នានឹងរើស* សូមមើល ១ពវ ១២:៤ យរ ២២:១៣–១៧ ។

ទៅច្បាំងក្នុងចំបាំងយើងផង ២១សាំយូអែលក៏ស្ដាប់អស់
ទាំងពាក្យរបស់ពួកបណ្ដាជនទាំងឡាយ រួចទៅទូល[ខ]ដល់
ព្រះយេហូវ៉ាវិញ ២២ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹង
សាំយូអែលថា ចូរស្ដាប់តាម[គ]ពាក្យគេចុះ ហើយតាំងឱ្យ
មានស្ដេចសោយរាជ្យឡើងលើគេទៅ នោះសាំយូអែល
ក៏ប្រាប់ដល់ពួកអ៊ីស្រាអែលថា ចូរឱ្យអ្នករាល់គ្នាត្រឡប់
ទៅឯទីក្រុងរបស់អ្នករាល់គ្នារៀងខ្លួនទៅ ។

## លោកសាំយូអែលចាក់ប្រេងតាំងឱ្យលោកសូល

**៩** ១រីឯមានពួកបេនយ៉ាមីនម្នាក់[ក] ឈ្មោះគីស[ខ] ជាកូន
អ័បៀល ដែលអ័បៀលជាកូនសេរ៉ោៗជាកូនបេកូរ៉ាៗជា
កូនអ័ភីយ៉ាៗជាកូនពួកបេនយ៉ាមីនម្នាក់ អ្នកនោះជាមនុស្ស
មានចិត្តក្លាហាន[គ] ២គាត់មានកូនកំឡោះម្នាក់ ឈ្មោះសូល
ដែលមានរូបឆោមល្អណាស់[ឃ] ក្នុងបណ្ដាពួកកូនចៅអ៊ីស្រា
អែល គ្មានអ្នកណាល្អជាងទេ[ង] គាត់មានមាឌខ្ពស់ជាង[ច]
គេទាំងអស់ ឯពួកគេមានកំពស់ ត្រឹមតែស្មារបស់គាត់ទេ
៣សម័យនោះហ្វូងលា[ឆ]របស់គីស ជាឪពុកសូល បានវង្វេង
បាត់ទៅ នោះគីសនិយាយទៅសូល ជាកូនថា ចូរឯង និង
បាវម្នាក់នាំគ្នាទៅរកហ្វូងលាទៅ ៤ដូច្នេះ គាត់បានដើរកាត់
ស្រុកភ្នំ[ជ]អេប្រាអិម និងស្រុកសាលីសា[ឈ] តែរកហ្វូងលា[ញ]មិន
ឃើញសោះ រួចនាំគ្នាដើរកាត់ស្រុកសាលីម តែមិនឃើញ
នៅស្រុកនោះដែរ ក៏ដើរកាត់ស្រុកបេនយ៉ាមីនទៀត តែ
រកមិនឃើញសោះឡើយ ។

៥លុះកាលបានទៅដល់ស្រុកស៊ូភ[ដ]ហើយ នោះសូល
និយាយទៅបាវដែលទៅជាមួយថា ឥឡូវនេះចូរយើងវិល
ត្រឡប់ទៅវិញ ក្រែងឪពុកអញលែងគិតពីហ្វូងលា ដោយ
ព្រួយចិត្ត[ឋ]នឹងយើង ៦បាវនោះឆ្លើយថា មើល មានអ្នក
សំណប់របស់ព្រះម្នាក់[ឌ]នៅក្រុងនេះ ជាអ្នកដែលគេរាប់
អានគ្រប់គ្នា ឯអស់ទាំងសេចក្ដីណា[ឍ]ដែលលោកថា នោះ
រមែងកើតមកជាមិនខាន ដូច្នេះសូមយើងទៅឯណោះចុះ
ប្រហែលជាលោកនឹងប្រាប់យើង ពីផ្លូវដែលត្រូវទៅបាន
៧តែសូលឆ្លើយថា បើសិនជាយើងទៅ តើយើងមានអ្វី
យកទៅជូនលោក ដ្បិតអាហារក្នុងសំពាយរបស់យើង អស់
រលីងហើយ គ្មានអ្វី[ណ]នឹងយកទៅជូនដល់អ្នកសំណប់របស់
ព្រះនោះទេ តើនៅមានអ្វីដែរឬទេ ៨បាវឆ្លើយជំរាបទៅ
សូលម្ដងទៀតថា មើល ខ្ញុំមានប្រាក់២កាក់នៅដៃខ្ញុំនឹងជូន
ដល់លោក ឱ្យលោកបង្ហាញផ្លូវយើង ៩(កាលពីដើម នៅ
ស្រុកអ៊ីស្រាអែល កាលណាមនុស្សម្នាក់ទៅសួរ[ត]ដល់ព្រះ
នោះគេតែងនិយាយថា ចូរយើងទៅឯអ្នកមើលឆុត ដ្បិត
អ្នកដែលសព្វថ្ងៃនេះហៅថា ហោរា នោះពីដើមគេហៅថា

**៨:២១** ខ ពច ១១:១១ **៨:២២** គ ខ.៧ **៩:១** ក យស ១៨:១១–២០ ខ ១សយ ១៤:៥១ ១រប ៨:៣៣ ៩:៣៩ នអ ២:៥ កច ១៣:២១ គ នរ ២:១ **៩:២** ឃ លប ៣៩:៦ ង ១សយ ១០:២៤ ច ១សយ ១០:២៣ **៩:៣** ឆ ខ.២០ ១សយ ១០:១៤,១៦ **៩:៤** ជ យស ២៤:៣៣ ឈ ២ពវ ៤:៤២ ញ ១សយ ១០:២ **៩:៥** ដ ១សយ ១:១ ឋ ១សយ ១០:២ **៩:៦** ឌ ចទ ៣៣:១ ពច ១៣:៦ ឍ ១សយ ៣:១៩ **៩:៧** ណ លប ៣២:២០ ១ពវ ១៣:៧ ១៤:៣ ២ពវ ៤:៤២ ៥:៥,១៥ យរ ៤០:៥ **៩:៩** ត លប ២៥:២២

**៨:២០** *ដើម្បីឱ្យយើងបានដូចសាសន៍ឯទៀតដែរ* សូមមើល ខ.៥,៧ ។

**៩:១–១១:១៥** ការស្ថាបនារបស់ព្រះអម្ចាស់ចំពោះស្ដេចសូល ឱ្យធ្វើជាស្ដេចលើពួកអ៊ីស្រាអែល គឺចំណាយពេលវេលា៣ដំណាក់កាលផ្សេងៗគ្នា ។ សូលត្រូវបាន (១).ទទួលការចាក់ប្រេងតាំងដោយហោរាសាំយូអែល (៩:១–១០:១៦) (២).ជ្រើសរើសដោយវិធីបោះឆ្នោត (១០:១៧–២៧) ហើយ (៣).ត្រូវអបអរសាទរជាផ្លូវការណ៍ (១១:១–១៥) ។

**៩:១** *ជាមនុស្សមានចិត្តក្លាហាន* អ្នកនោះគឺជាស្ដេចសូល (ខ.២) និងស្ដេចដាវីឌដែលពួកគេម្នាក់ៗ សុទ្ធតែជាប់ខ្សែលោហិតពីពួកព្ធយុកោ ដែលជាមាសជិកគួរឱ្យកត់សម្គាល់នៅក្នុងសហគមន៍របស់ពួកគេ (មើល នរ ២:១ ៤:២១–២២) ។

**៩:២** *គាត់មានមាឌខ្ពស់ជាងគេទាំងអស់* ជាលក្ខណៈសម្បត្តិទូទៅរបស់ស្ដេច (សូមមើល ១០:២៣) ។

**៩:៣** *ហ្វូងលា . . . បានវង្វេងបាត់* សូលប្រៀបដូចជាអ្នកឃ្វាលសត្វលា ដែលត្រូវបញ្ជូនដើម្បីឱ្យរកលា ដែលបានវង្វេងចេញពីផ្ទះ ។ ប្រហែលជានិមិត្តរូបអំពីស្ដេចសូលនិងបណ្ដាជនដែលបះបោរជាអ្នកសូមឱ្យមានស្ដេច (ធៀបនឹង អស ១:៣) ។ ស្ដេចដាវីឌប្រៀបដូចជាអ្នកគង្វាលដែលឃ្វាលហ្វូងសត្វរបស់ឪពុកគាត់ (១៦:១១–១៣) ហើយក្រោយមកទៀត គាត់គឺជារូបភាពនៃអ្នកគង្វាល ដែលឃ្វាលលើហ្វូងសត្វរបស់ព្រះ (២សយ ៥:២ ៧:៧–៨ ទដ ៧៨:៧០–៧២) ។

**៩:៥** *ស្រុកស៊ូភ* ប្រហែលជាស្ថិតនៅក្នុងតំបន់រ៉ាម៉ា (មើល ខ.៦ ១:១) ។

**៩:៦** *បាវនោះឆ្លើយថា* តាមចរិតរបស់លោកសូលគាត់ពុំបានដឹងថា លោកសាំយូអែលជាហោរាឡើយ ។ *ក្រុងនេះ* ប្រហែលស្ថិតនៅស្រុករ៉ាម៉ា (សូមមើល ៧:១៧) ដែលជាស្រុកកំណើតរបស់សូល ដែលគាត់ទើបតែវិលត្រឡប់មកវិញ (មើល ខ.១២) ។ *អ្នកសំណប់របស់ព្រះ* មើលការពន្យល់ ២:២៧ នៅទីនេះសំដៅលើហោរាសាំយូអែល ។ *អស់ទាំងសេចក្ដីណាដែលលោកថា នោះរមែងកើតមកជាមិនខាន* មើល ៣:១៩ និងការពន្យល់ ។

**៩:៧** *តើយើងមានអ្វីយកទៅជូនលោក* ឧទាហរណ៍ផ្សេងៗទៀតពីអំណោយដែលជូនដល់ពួកហោរា គឺមាននិយាយនៅក្នុង ១ពវ ១៤:៣ ២ពវ ៤:៤២ ៥:១៥–១៦ ៨:៨–៩) ។ ទោះបីជាហោរាសាំយូអែលបានទទួលយកអំណោយដែលជាហ្វូងសត្វក៏ដោយ ក៏ការនិយាយនេះមិនច្បាស់ដែរ ហោរាអេលីសេបានបដិសេធចំពោះអំណោយរបស់លោកណាម៉ាន់ (២ពវ ៥:១៦) ហោរាក្លែងក្លាយ តែងចង់បានអ្វីដែលគេជូន (១ពវ ២២:៦,៨,១៨ យរ ២៨ មីក ៣:៥,១១) ។

**៩:៨** *ប្រាក់២កាក់* មាស ឬប្រាក់ គឺជារូបិយវត្ថុនាសម័យមុន (សូមមើល ១៣:២១ យប ២៨:១៥) ។

**៩:៩** *ដ្បិតអ្នកដែលសព្វថ្ងៃនេះហៅថា ហោរា នោះពីដើមហៅថា អ្នកមើលឆុតវិញ* ភាពខុសគ្នារវាងហោរា និងអ្នកមើលឆុត នោះវាមិនសំខាន់ឡើយ ។ បណ្ដាជនបានឱ្យឈ្មោះថាហោរា គឺក្នុងអំឡុងកាលនៃការសរសេរព្រះគម្ពីរសាំយូអែលទី១–២ ហើយនៅក្នុងសម័យកាលស្ដេចសូលគេហៅថា អ្នកមើលឆុត ។ នេះមិនមែនមានន័យថា "ហោរា" មិនត្រូវបានគេ

អ្នកមើលឆុតវិញ)[ថ] ១០ដូច្នេះសូលក៏ឆ្លើយតបទៅបាវថា អើ
ស្រួលហើយ ចូរយើងទៅចុះ នោះគេក៏ទៅឯក្រុងនោះ
ជាកន្លែងដែលអ្នកសំណប់របស់ព្រះអាស្រ័យនៅ ។
១១កំពុងដែលគេដើរតាមផ្លូវឡើងទៅឯទីក្រុង នោះ
គេជួបប្រទះនឹងពួកស្រីក្រមុំៗ ដែលចេញមកដង[ទ]ទឹក ហើយ
ក៏សួរថា តើអ្នកមើលឆុតនៅទីនេះឬអី ១២នាងទាំងនោះ
ឆ្លើយថា ចាស មែនហើយ មើល លោកបានដើរទៅខាង
មុខនុ៎ះ អញ្ជើញទៅជាប្រញាប់ទៅ ដ្បិតថ្ងៃនេះលោកទើប
នឹងមកដល់ទីក្រុង ពីព្រោះបណ្ដាជនគេត្រូវថ្វាយយញ្ញបូជា[ធ]
នៅលើទីខ្ពស់នៅថ្ងៃនេះ[ន] ១៣កាលណាអ្នកចូលទៅក្នុង
ទីក្រុង នោះអ្នកនឹងឃើញលោកហើយ មុនដែលលោក
ឡើងទៅពិសានៅលើទីខ្ពស់នោះ ដ្បិតពួកបណ្ដាជនមិន
បរិភោគឡើយ ទាល់តែលោកអញ្ជើញទៅដល់ ពីព្រោះ
គឺលោកហើយ ដែលត្រូវឱ្យពរ[ប]ដល់យញ្ញបូជានោះ ទើប
ពួកភ្ញៀវបរិភោគជាខាងក្រោយ ដូច្នេះអញ្ជើញអ្នកឡើង
ទៅចុះ ដ្បិតថ្មើរណេះ អ្នកនឹងរកលោកឃើញ ១៤ដូច្នេះ គេ
ក៏ឡើងទៅឯទីក្រុង កាលគេកំពុងតែចូលទៅ នោះមើល
សាំយូអែលក៏ចេញមកនៅប្រទល់មុខ ដើម្បីនឹងឡើងទៅឯ
ទីខ្ពស់ ។
១៥រីឯ១ថ្ងៃមុនដែលសូលបានមកដល់ នោះព្រះយេហូវ៉ា
ទ្រង់បានមានបន្ទូលប្រាប់សាំយូអែលថា ១៦ដល់ថ្ងៃស្អែក
ពេលថ្មើរណេះ អញនឹងចាត់មនុស្សម្នាក់ពីស្រុកបេន
យ៉ាមីនមកឯឯង ត្រូវឱ្យឯងចាក់ប្រេងតាំង[ផ]អ្នកនោះឱ្យ
គ្រប់គ្រង[ព]លើពួកអ៊ីស្រាអែល ជារាស្ត្រអញចុះ អ្នកនោះ
នឹងជួយសង្គ្រោះ[ភ]រាស្ត្រអញ ឱ្យរួចពីកណ្ដាប់ដៃនៃពួក
ភីលីស្ទីន[ម] ដ្បិតអញបានក្រឡេកមើលទៅរាស្ត្រអញ ពីព្រោះ
សំរែក[យ]របស់គេបានឮមកដល់អញហើយ ១៧ដូច្នេះ កាល
សាំយូអែលបានឃើញសូល នោះព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា នេះហើយ[រ]ជាមនុស្សដែលអញបានប្រាប់ឯង គឺ
អ្នកនេះឯង ដែលត្រូវសោយរាជ្យលើរាស្ត្ររបស់អញ
១៨គ្រានោះ សូលបានចូលទៅជិតសាំយូអែល នៅត្រង់
កណ្ដាលទ្វារក្រុងសួរថា សូមលោកប្រាប់ខ្ញុំ តើផ្ទះគ្រូដែល
មើលឆុតនៅឯណា ១៩នោះសាំយូអែលឆ្លើយថា គឺខ្ញុំនេះ
ហើយជាអ្នកមើលឆុត ចូរអ្នកឡើងទៅឯទីខ្ពស់មុនខ្ញុំចុះ ដ្បិត
ត្រូវឱ្យអ្នកបរិភោគជាមួយនឹងខ្ញុំនៅថ្ងៃនេះ រួចដល់ព្រឹក
ឡើង ខ្ញុំនឹងឱ្យអ្នកអញ្ជើញទៅ ហើយនិងប្រាប់ពីគ្រប់ទាំង
សេចក្ដីដែលអ្នកប៉ងក្នុងចិត្តដែរ ២០ឯហ្វូងលា[ល]ដែលបាន
វង្វេងបាត់៣ថ្ងៃមកហើយ នោះកុំឱ្យធុរៈឡើយ ដ្បិតបាន
ឃើញហើយ ១ទៀត តើសេចក្ដីប៉ងប្រាថ្នា[វ]របស់សាសន៍
អ៊ីស្រាអែលសំរេចលើអ្នកណា តើមិនសំរេចលើអ្នក និង
ពួកគ្រួឪពុកអ្នកទេឬអី ២១តែសូលឆ្លើយថា តើខ្ញុំមិនមែនជា

**៩:៩** ថ ២សយ ១៥:២៧ ២៤:១១ ២ពរ ១៧:១៣ ១រប ៩:២២ ២១:៩ ២៦:២៨ ២៩:២៩ ២រប ១៩:២ អស ២៩:១០ ៣០:១០ អម ៧:១២ **៩:១១** ទ លប ២៤:១១,១៣ **៩:១២** ធ ជន ២៨:១១–១៥ ១សយ ៧:១៧ ន លវ ២៦:៣០ **៩:១៣** ប មថ ១៤:១៩ ១កថ ១០:១៦ ១ធថ ៤:៣–៥ **៩:១៦** ផ នក ៣០:២៥ ១សយ ២:៣៥ ១២:៣ ១៥:១ ២៦:៩ ២ពវ ១១:១២ ទដ ២:២ ព ២សយ ៧:៨ ១ពវ ៨:១៦ ១រប ៥:២ ភ នក ៣:៧–៩ ម ១សយ ២៣:៤ ២សយ ៣:១៨ យ លប ១៦:១១ ទដ ១០២:១ **៩:១៧** រ ១សយ ១៦:១២ **៩:២០** ល ខ.៣ វ ១សយ ១២:១៣ អរ ៦:៨ អស ៦០:៤–៩ ដយ ២:៤៤ ហក ២:៧ មឡ ៣:១

ស្គាល់នៅក្នុងសម័យកាលស្ដេចសូលឡើយ ឬពាក្យថា "អ្នកមើលឆុត" មិន ត្រូវបានគេស្គាល់ក្នុងសម័យកាលក្រោយនោះឡើយ (មើល អស ៣០:១០) ។ ពាក្យទាំងនេះ គឺមានការនិយមប្រើប្រាស់ណាស់ ។

**៩:១១** *ពួកស្រីក្រមុំៗដែលចេញមកដងទឹក* ជានិច្ចកាល គឺពួកស្រីក្រមុំទាំងនោះមកដងទឹកនៅពេលល្ងាចព្រោះវាត្រជាក់ (សូមមើល លប ២៤:១១) ។

**៩:១២** *ទីខ្ពស់* បន្ទាប់ពីការចូលមករស់នៅក្នុងទឹកដីសន្យា ជានិច្ចកាល ពួកកូនចៅអ៊ីស្រាអែល គេតែងតែប្រព្រឹត្តតាមទម្លាប់របស់ពួកកាណាន គឺគេបានសង់អាសនា នៅលើទីខ្ពស់ ។ (នៅពេលនេះ ទីបរិសុទ្ធមិនបានលើកយកមកនិយាយ ហើយក៏គ្មានមុខងារឡើយ ព្រោះហឹបនៃសេចក្ដីសញ្ញាមិនបាននៅក្នុងរោងឧបោសថនោះឡើយ ដោយសារស្ដេចស៊ីហុនបានបំផ្លាញ មិនតែប៉ុណ្ណោះសោត បន្ទាប់ពីការស្លាប់របស់កូនលោកអេលីទៅ ពួកសង្ឃនិងក្រុមគ្រួសាររបស់គេនៅតែគ្មានសកម្មភាព) ។ នៅសម័យកាលក្រោយមកទៀតការថ្វាយបង្គំព្រះអម្ចាស់នៅលើទីខ្ពស់ទាំងនោះ ត្រូវបានគេឱ្យពួកអ្នកមិនជឿចូលរួមថ្វាយបង្គំព្រះជាមួយពួកអ៊ីស្រាអែលដែរ ហើយហេតុផលទាំងនោះត្រូវបានហាមឃាត់ (មើល ១ពវ ៣:២) ។

**៩:១៣** *គឺលោកហើយ ដែលត្រូវឱ្យពរដល់យញ្ញបូជានោះ* លោកសាំយូអែលគឺជាប្រធានលើការថ្វាយយញ្ញបូជាសាច់ទាំងនោះ (មើល ១:៤ ២:១៣–១៦) នៅពេលដែលគាត់អធិស្ឋាន ហើយការនេះប្រហែលជាដូចគ្នានឹងព្រះគម្ពីរសញ្ញាថ្មីដែរ (មថ ២៦:២៦–២៧ យហ ៦:១១,២៣ ១ធថ ៤:៣–៥) ។

**៩:១៦** *ចាក់ប្រេងតាំងអ្នកនោះឱ្យ* សង្ឃក៏ទទួលការចាក់ប្រេងតាំងដែរ (មើល នក ២៩:៧ ៤០:១២–១៥ លវ ៤:៣ ៨:១២) ប៉ុន្តែចាប់តាំងពីកន្លែងនេះមក នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជានិច្ចកាលគឺគេតែងតែចាក់ប្រេងតាំងដល់ស្ដេចវិញដូចជា "ទ្រង់បានចាក់ប្រេងតាំងឱ្យ" (មើលការពន្យល់ ២:១០ និងមើល ២៤:៦ ២៦:៩,១១,១៦ ២សយ ១:១៤,១៦ ១៩:២១ ប្រៀបធៀប ទដ ២:២ ប៉ុន្តែ សូមមើល សក ៤:១៤) ។ ទទួលនូវការចាក់ប្រេងតាំង គឺជានិមិត្តសញ្ញានៃការញែកខ្លួន ទៅចំពោះព្រះអម្ចាស់សម្រាប់កិច្ចការងារពិសេសណាមួយ ហើយព្រះអម្ចាស់ទ្រង់ជាអ្នកផ្គត់ផ្គង់ដល់អ្នកបម្រើទាំងនោះ (មើល ១០:១,៦ ១៦:១៣ អស ៦១:១) ។ *គ្រប់គ្រង* ពាក្យនេះនៅក្នុងព្រះគម្ពីរភាសាហេព្រើរ (មើល ១០:១ ១៣:១៤ ២៥:៣០) គឺសំដៅលើអ្នកណាម្នាក់ដែលទទួលការតែងតាំងមកពីព្រះអម្ចាស់ ដើម្បីឱ្យធ្វើជាអ្នកដឹកនាំលើប្រជារាស្ត្ររបស់ទ្រង់ (ដូចគ្នានឹងការបកប្រែនៅក្នុងព្រះគម្ពីរភាសាហេព្រើរ "អ្នកនាំមុខ" នៅក្នុង ២សយ ៥:២ ៧:៨ ១រប ១១:២ ១៧:៧) ។ វាមានការនិយមប្រើប្រាស់ ដើម្បីឱ្យមានភាពងាយស្រួលចំពោះការបកប្ររវាងអ្នកដឹកនាំនៅក្នុងព្រះគម្ពីរចៅហ្វាយ និងពង្សាវតារក្សត្រ ។ *ពួកភីលីស្ទីន* សូមមើលការពន្យល់ ៧:១៣ ។

**៩:២០** *សេចក្ដីប៉ងប្រាថ្នារបស់សាសន៍អ៊ីស្រាអែល* សំដៅលើសេចក្ដីប៉ងប្រាថ្នារបស់ពួកអ៊ីស្រាអែល ដែលគេចង់បានស្ដេច ។

**៩:២១** *អំបូរតូចជាងគេ . . . តូចទាបជាងអស់ទាំងគ្រួ* ដើមកំណើតរបស់

ពួកបេនយ៉ាមីនជាពូជអំបូរតូចជាងគេ[ស] ក្នុងបណ្ដាសាសន៍
អ៊ីស្រាអែលទេឬអី ហើយពួកគ្រួខ្ញុំ តើមិនមែនជាតូចទាប
ជាង[ហ]អស់ទាំងគ្រួ ក្នុងពូជអំបូរបេនយ៉ាមីនដែរទេឬអី[ឡ]
ដូច្នេះ ហេតុអ្វីបានជាលោកមានប្រសាសន៍នឹងខ្ញុំយ៉ាង
នេះ ។
២២សាំយូអែលក៏នាំយកសូល និងអ្នកបំរើ ចូលទៅក្នុង
រោងជំនុំ ឱ្យអង្គុយនៅទីលេខ១ក្នុងពួកភ្ញៀវ ដែលមាន
ចំនួនប្រហែលជា៣០នាក់ ២៣រួចលោកប្រាប់ទៅអ្នកធ្វើ
បាយថា ចូរយកចំណែក១ ដែលអញបានប្រគល់ឱ្យឯង
ដោយប្រាប់ថា ចូរទុកដោយខ្លួននោះមក ២៤ដូច្នេះអ្នក
ធ្វើបាយ ក៏យកស្មា[អ] និងសាច់ដែលនៅជាប់នោះ មកដាក់
នៅមុខសូល រួចសាំយូអែលប្រាប់ថា មើល នេះជារបស់
ដែលបានបំរុងទុកឱ្យអ្នក អញ្ជើញពិសាចុះ ដ្បិតបានបំរុង
ទុកដល់ពេលកំណត់សំរាប់អ្នក ចាប់តាំងពីខ្ញុំបានអញ្ជើញ
ពួកជនមក ដូច្នេះ សូលក៏បរិភោគជាមួយនឹងសាំយូអែល
នៅថ្ងៃនោះ ។
២៥កាលគេបានចុះពីទីខ្ពស់មកក្នុងទីក្រុងវិញ នោះ
សាំយូអែលនិងសូលក៏និយាយគ្នានៅលើដំបូល[ក]ផ្ទះ ២៦រួច
ក្រោកឡើងពីព្រលឹមស្រាង លុះដល់ថ្ងៃរះ នោះសាំយូ–
អែលហៅសូលទៅលើដំបូលផ្ទះប្រាប់ថា នែ ខ្ញុំឱ្យអ្នក
អញ្ជើញទៅហើយ នោះសូលក្រោកឡើង ហើយគាត់នឹង
សាំយូអែលក៏ដើរចេញទៅក្រៅទាំង២នាក់ ២៧កាលគេ
កំពុងតែចុះទៅជិតដល់ទីចុងក្រុងហើយ នោះសាំយូអែល
ប្រាប់សូលថា ចូរប្រាប់ដល់អ្នកបំរើរបស់អ្នកឱ្យដើរទៅ
ខាងមុខយើងទៅ (វាក៏ទៅ) តែឯអ្នក ចូរឈប់សិន ដើម្បីឱ្យ
ខ្ញុំបានប្រាប់ឱ្យ អ្នកដឹងពីព្រះបន្ទូលនៃព្រះ ។

**១០** ១នោះសាំយូអែលក៏យកដប[ក]ប្រេង ចាក់ទៅលើ
ក្បាលសូល រួចថើបគាត់ដោយពាក្យថា ឯព្រះយេហូវ៉ា
តើទ្រង់មិនបានចាក់ប្រេងតាំង[ខ]អ្នក ឱ្យធ្វើជាអ្នកគ្រប់គ្រង
លើមរដកទ្រង់ទេឬអី[គ] ២នៅថ្ងៃនេះ កាលណាអ្នកចេញពីខ្ញុំ
ទៅ នោះនឹងជួបប្រទះនឹង២នាក់ នៅត្រង់ផ្នូររ៉ាជែល[ឃ]
ដែលនៅភូមិសេលសា ក្នុងព្រំស្រុកបេនយ៉ាមីន គេនឹង
ប្រាប់អ្នកថា សត្វលាដែលអ្នករក នោះបានឃើញហើយ
តែឥឡូវឪពុកអ្នកបានលែងគិតពីលា[ង] ដោយថប់ព្រួយ[ច]នឹង
អ្នកវិញ ដោយថា តើត្រូវធ្វើដូចម្តេចឱ្យបានកូនអញមកវិញ
៣រួចអ្នកនឹងចេញពីទីនោះ ទៅដល់ដើមម៉ៃសាក់នៅតាបោរ
នៅទីនោះនឹងមានមនុស្ស៣នាក់ ដែលកំពុងតែឡើងទៅឯ
ព្រះ នៅបេត–អែល[ឆ] មកជួបនឹងអ្នកម្នាក់កាន់កូនពពែ៣
មួយទៀតកាន់នំបុ័ង៣ដុំ ហើយម្នាក់ទៀតកាន់ថង់ស្បែកដាក់
ស្រាទំពាំងបាយជូរ ៤គេនឹងជំរាបសួរដល់អ្នក ហើយនឹង
ជូននំបុ័ង២ដុំ[ជ]មកអ្នក ដែលអ្នកត្រូវទទួលពីដៃគេ ៥ក្រោយ

**៩:២១** ស ទដ ៦៨:២៧ ហ នក ៣:១១ មថ ២:៦ ១កថ ១៥:៩ ឡ ពច ៦:១៥ ២០:៣៥,៤៦ ១សយ ១៨:១៨
**៩:២៤** អ លវ ៧:៣២–៣៤
**៩:២៥** ក ចទ ២២:៨ យស ២:៨ មថ ២៤:១៧ លក ៥:១៩
**១០:១** ក ១សយ ១៦:១ ២ពវ ៩:១,៣,៦ ខ នក ២៩:៧ ១សយ ៩:១៦ ១ពវ ១:៣៩ គ នក ៣៤:៩ ២សយ ២០:១៩ ទដ ៧៨:៦២,៧១
**១០:២** ឃ លប ៣៥:២០ ង ១សយ ៩:៤ ច ១សយ ៩:៥
**១០:៣** ឆ លប ៣៥:៧–៨
**១០:៤** ជ ខ.២៧
១សយ ១៦:២០ សភ ១៨:១៦

ស្តេចសូល គឺចេញមកពីចំណោមអ្នកដែលបន្ទាបខ្លួនជាងគេនៅក្នុងពួកអ៊ីស្រាអែល (លោកបេនយ៉ាមីន គឺជាកូនពៅរបស់លោកយ៉ាកុប ហើយពូជអំបូរនេះត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅក្នុងអំឡុងពេលគ្រាពួកចៅហ្វាយ សូមមើល ពច ២០:៤៦–៤៨) ។ ការលើកឡើងរបស់គាត់ឱ្យធ្វើជាស្តេចបានបង្ហាញថា ព្រះអម្ចាស់"លើកតម្កើង"អ្នកណាម្នាក់ដែលទ្រង់នឹងលើក (២:៧) ដែលវាជាចំណុចសំខាន់មួយ នៅក្នុងចំណោមចំណុចសំខាន់ផ្សេងៗទៀតនៅក្នុងព្រះគម្ពីរសាំយូអែល ។ ព្រះអម្ចាស់បានប្រើអ្នកដែលគ្មានអំណាច ដើម្បីលើកឱ្យមានអំណាចនៅក្នុងនគររបស់ទ្រង់នៅលើផែនដីដែលបញ្ហានេះ វាជារឿងយ៉ាងសាមញ្ញនៅក្នុងព្រះគម្ពីរសេចក្តីពិតមួយគឺនគររបស់ទ្រង់ មិនមែនជាលោកីយនេះឡើយ ។

**៩:២៤** *ស្មា* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះសំដៅទៅលើស្មា ភ្លៅតែងតែបម្រុងទុកសម្រាប់ថ្វាយដល់ព្រះអម្ចាស់ (មើល នក ២៩:២២,២៧ លវ ៧:៣២–៣៣,៣៥ ជន ៦:២០ ១៨:១៨) ។ ការពិពណ៌នាពីការថ្វាយបំណែកសត្វចំពោះស្តេចសូល គឺដើម្បីសម្គាល់ពីការគោរព និងការប្រមើលថា គាត់ចាប់ផ្តើមទទួលការចាក់ប្រេងតាំងរបស់ព្រះអម្ចាស់ ។

**៩:២៥** *លើដំបូលផ្ទះ* នៅកន្លែងនោះ គេអាចទទួលយកខ្យល់អាកាសដ៏ត្រជាក់នាពេលល្ងាច (មើល ខ.១១ ២សយ ១១:២ និងការពន្យល់) ហើយនៅកន្លែងនោះស្តេចសូលក៏អាចគេងនៅយប់នោះបានដែរ (មើល ខ.២៦) ។

**១០:១** *ប្រេង* ប្រហែលជាប្រេងអូលីវ (សូមមើល នក ៣០:២២–៣៣) ។ *តើទ្រង់មិនបានចាក់ប្រេងតាំងអ្នក* សូមមើល ៩:១៦ ។ *អ្នកគ្រប់គ្រង* សូមមើល ៩:១៦ ។ *មរដកទ្រង់* "អ៊ីស្រាអែលជារាស្ត្រអញ"(៩:១៦) ។ មរដករបស់ព្រះអម្ចាស់រាប់បញ្ចូលទាំងមនុស្ស (សូមមើល នក ៣៤:៩) ហើយនិងទឹកដី (សូមមើល នក ១៥:១៧) ។ បន្ទាប់ចេញពីហោរាសាំយូអែល សូលទទួលនូវទីសម្គាល់៣ (មើល ខ.២–៧) ដើម្បីឱ្យបានសម្រេចតាមពាក្យដែលហោរាសាំយូអែលបាននិយាយ និងដើម្បីធានាថា គាត់គឺជាអ្នកដែលព្រះអម្ចាស់ចាក់ប្រេងតាំងធ្វើជាស្តេច ។

**១០:២** *ផ្នូររ៉ាជែល* នាងរ៉ាជែល គឺជាប្រពន្ធជាទីស្រឡាញ់របស់លោកយ៉ាកុប ។ នាងបានទទួលមរណៈភាពក្នុងពេល ដែលនាងធ្វើដំណើរទៅបេថ្លេហិមស្របពេលកំណើតរបស់លោកបេនយ៉ាមីន ។ ផ្នូររបស់នាងត្រូវបានគេធ្វើឡើង និងធ្វើជាកំណត់សម្គាល់នៅលើទឹកដីនោះ (លប ៣៥:២០ និងការពន្យល់) ។

**១០:៣** *ដើមម៉ៃសាក់* គឺជាដើមឈើដ៏ធំដែលជានិច្ចកាលដុះឡើងដេរដាសស្រួលចំណាំសម្រាប់ធ្វើធម្មយាត្រា និងអ្នកដំណើរផ្សេងៗទៀត (មើល លប ១២:៦ និងការពន្យល់) ។ *បេត–អែល* មានចម្ងាយប្រមាណជា ១៦,៩ គ.ម ភាគខាងជើងក្រុងយេរូសាឡិម (សូមមើលការពន្យល់ លប ១២:៨) ។

**១០:៥** *ភ្នំព្រះ* ភ្នំនោះស្ថិតនៅស្រុកកំណើតរបស់ស្តេចសូល (មើល ខ.២៦ ១១:៤) ដែលមានទីតាំងស្ថិតនៅក្នុងទឹកដីអំបូរបេនយ៉ាមីន (យស ១៨:២៨ ពច ១៩:១២–១៤ ។ ជាញឹកញាប់ត្រូវបានហៅថា"ភ្នំ"ឬ "ស្រុកបេនយ៉ាមីន"

នោះអ្នកនឹងទៅដល់ភ្នំ[ឈ]ព្រះ ជាកន្លែងដែលមានបន្ទាយ
របស់ពួកភីលីស្ទីន[ញ] រួចកាលណាអ្នកទៅដល់ទីក្រុងហើយ
នោះនឹងជួបនឹងពួកហោរា[ដ]ដែលចុះពីទីខ្ពស់មក[ឋ] មានគេ
កាន់ទាំងពិណ ក្រាប់[ឌ] ខ្លុយ[ឍ] និងស៊ីង[ណ]នាំមុខផង ហោរា
ទាំងនោះនឹងទាយ[ត] ៦នោះព្រះវិញ្ញាណ[ថ]នៃព្រះយេហូវ៉ា
នឹងមកសណ្ឋិតលើអ្នក បណ្ដាលជាខ្លាំង អ្នកនឹងទាយជាមួយ
នឹងគេដែរ ហើយអ្នកនឹងបានប្រែ[ទ]ទៅជាមនុស្សថ្មីវិញ
៧កាលណាទីសំគាល់ទាំងនេះបានកើតមកដល់អ្នកហើយ
នោះត្រូវឱ្យអ្នកធ្វើតាមទំនង[ធ]នៅឱកាសនោះចុះ[ន] ដ្បិតព្រះ
ទ្រង់គង់ជាមួយ[ប]នឹងអ្នកហើយ ៨រួចត្រូវឱ្យអ្នកចុះទៅដល់
គីលកាល[ផ]មុនខ្ញុំ ខ្ញុំនឹងចុះទៅឯអ្នក ដើម្បីនឹងថ្វាយដង្វាយដុត
ហើយនិងយញ្ញបូជា ជាដង្វាយមេត្រី ចូរអ្នកអង់ចាំខ្ញុំ៧[ព]ថ្ងៃ
ទាល់តែខ្ញុំបានទៅដល់អ្នក នោះខ្ញុំនឹងបង្ហាញពីការដែលអ្នក
ត្រូវធ្វើ ។

## លោកសូលត្រូវលើកឡើងជាស្ដេច

៩ដូច្នេះក៏កើតមកយ៉ាងនោះមែន កាលសូលបានបែរ
ចេញពីសាំយូអែលទៅ នោះព្រះទ្រង់បំផ្លាស់បំប្រែ[ភ]ចិត្ត
គាត់ ហើយទីសំគាល់ទាំងនោះ[ម] ក៏កើតមក[យ]នៅថ្ងៃនោះឯង
១០កាលគេទៅដល់ភ្នំហើយ នោះមើល មានពួកហោរា មក
ជួបនឹងគាត់ ហើយព្រះវិញ្ញាណ[រ]នៃព្រះទ្រង់មកសណ្ឋិតលើ
គាត់បណ្ដាលឡើងជាខ្លាំង រួចគាត់ទាយនៅកណ្ដាលពួក
នោះ[ល] ១១កាលពួកអ្នកដែលស្គាល់គាត់ពីមុន បានឃើញ
គាត់ទាយ ជាមួយនឹងពួកហោរាដូច្នោះ នោះគេនិយាយ
គ្នាថា តើមានកើតអ្វី[វ]ដល់កូនគីសនេះ តើសូលជាពួកហោរា
ដែរឬអី[ស] ១២រួចម្នាក់ដែលនៅទីនោះក៏ឆ្លើយឡើងថា តើ
ពួកហោរាមានអ្នកណាជាឪពុក សេចក្ដីនោះក៏ត្រឡប់ទៅ
ជាពាក្យទំនឹមទំនៀមថា តើសូលជាពួកហោរាដែរឬអី[ហ]
១៣កាលគាត់ឈប់ទាយ[ឡ]ហើយ នោះក៏ឡើងទៅឯទីខ្ពស់ ។
១៤ឯមា[អ]របស់សូលក៏សួរដល់គាត់ និងអ្នកបំរើថា តើ
ឯងបានទៅឯណា គាត់ឆ្លើយថា បានទៅរកហ្វូងលា[ក]
តែកាលយើងខ្ញុំរកវានៅទីណាមិនឃើញ នោះក៏ទៅឯ
លោកសាំយូអែល ១៥រួចមារបស់សូលសួរថា ចូរប្រាប់
ដល់អញ តើលោកសាំយូអែលមានប្រសាសន៍នឹងឯងដូច
ម្ដេចខ្លះ ១៦នោះសូលឆ្លើយជំរាបមាថា លោកបានប្រាប់
យើងខ្ញុំជាច្បាស់ថា លា[ខ]បានឃើញហើយ តែត្រង់ឯការ
តាំងរាជ្យដែលសាំយូអែលបានប្រាប់ នោះគាត់មិនបាន
ជំរាបដល់មាទេ ។
១៧នៅគ្រានោះ សាំយូអែលប្រមូលពួកកូនចៅអ៊ីស្រា–

**១០:៥** ឈ ខ.២៦ ១សយ ១១:៤ ១៥:៣៤ ញ ១សយ ១៣:៣ ដ ជន ១១:២៩ ១ពវ ២០:៣៥ ២ពវ ២:៣,១៥ ៤:១ ៦:១ ៩:១ អម ៧:១៤ ឋ លវ ២៦:៣០ ឌ លប ៣១:២៧ យរ ៣១:៤ ឍ ១ពវ ១:៤០ អស ៣០:២៩ ណ ១សយ ១៦:១៦ ១៨:១០ ១៩:៩ ២ពវ ៣:១៥ ទដ ៩២:៣ ត ខ.១០ ១សយ ១៩:២០ ១របា ២៥:១ ១កថ ១៤:១
**១០:៦** ថ ជន ១១:២៥ ទ ខ.៩
**១០:៧** ធ ២សយ ៧:៣ ១ពវ ៨:១៧ ១របា ២២:៧ ២៨:២ ២របា ៦:៧ សស ៩:១០ ន ពច ៩:៣៣ ប យស ១:៥ លក ១:២៨ ហព ១៣:៥

**១០:៨** ផ យស ៤:២០ ១០:៤៣ ១សយ ៧:១៦ ១១:១៤–១៥ ព ១សយ ១៣:៨ **១០:៩** ភ ខ.៦ ម ចទ ១៣:២ យ ខ.៧ **១០:១០** រ ជន ១១:២៥ ១សយ ១១:៦ ល ខ.៥–៦ **១០:១១** វ មថ ១៣:៥៤ យហ ៧:១៥ ស ខ.១២ ១សយ ១៩:២៤ ២ពវ ៩:១១ យរ ២៩: ២៦ ហស ៩:៧ **១០:១២** ហ ខ.១១ **១០:១៣** ឡ ១សយ ១៩:២៣ **១០:១៤** អ ១សយ ១៤:៥០ ក ១សយ ៩:៣ **១០:១៦** ខ ១សយ ៩:៣

(១៣:២,១៥) ប៉ុន្តែមានចំនួន៣ដងដែលនិយាយថា "ស្រុករបស់ស្ដេចសូល" (១១:៤ ១៥:៣៤ ២សយ ២១:៦) ។ ការនិយាយរបៀបនេះ (ប្រើនៅតែទីនេះ) ប្រហែលជារបៀបដែលហោរាសាំយូអែលប្រើ ដើម្បីរំឭកស្ដេចសូលថា ទឹកដីកាណាន គឺជារបស់ព្រះមិនមែនជារបស់ពួក ភីលីស្ទីនទេ (មើល ចទ ៣២:៤៣ អស ១៤:២ ហស ៩:៣) ។ *ពួកហោរា* គឺជាក្រុមហោរាដែលរស់នៅក្នុងសម័យកាលហោរាសាំយូអែល (រួមទាំងកូនចៅរបស់ពួកហោរា ដែលរស់ក្នុងសម័យកាលហោរាអេលីយ៉ា និងអេលីសេ សូមមើល ១ពវ ២០:៣៥) ។ ការកើតឡើងនៃក្រុមហោរានេះ គឺដើម្បីបង្កើតទំនាក់ទំនងដ៏តូចមួយរបស់ ក្រុមមនុស្សដែលរួមគ្នាក្នុងវិញ្ញាណដែលទនខ្សោយ ដើម្បីធ្វើការជាមួយគ្នា នៅក្នុងពិធីសាសនាយ៉ាងសប្បាយរីករាយរបស់គេ ។ *ពិណ . . . ស៊ីង* គឺជាសកម្មភាពផ្ទាល់ខ្លួន ឬជាក្រុមរបស់ពួកហោរាដែលពេលខ្លះគេជូនដំណើរ ដោយមានប្រដាប់ភ្លេង (២ពវ ៣:១៥ ១របា ២៥:១) ។ *ហោរាទាំងនោះ* នៅទីនេះ (និង ខ.៦,១០–១១,១៣) លេចឡើងដើម្បីសរសើរតម្កើងដល់ព្រះ ដែលផុសចេញពីវិញ្ញាណនៃព្រះ (ជន ១១:២៤–៣០) ។

**១០:៦** *ប្រែទៅជាមនុស្សថ្មីវិញ* វិញ្ញាណរបស់ព្រះ ធ្វើឱ្យសូលអាចក្លាយជាស្ដេចរបស់ពួកអ៊ីស្រាអែល ។

**១០:៧** *ធ្វើតាមទំនងនៅឱកាសនោះចុះ* ស្ដេចសូលគឺអាចឆក់យកឱកាសផ្សេងៗនៅក្នុងស្ថានការណ៍នេះ ដើម្បីបង្ហាញពីភាពជាអ្នកដឹកនាំរបស់ទ្រង់តាមច្បាប់បាន (មើល ១១:៤–១១) ។

**១០:៨** *ត្រូវឱ្យអ្នកចុះទៅដល់គីលកាលមុនខ្ញុំ* នៅក្នុងពេលអនាគត ដែលមិនជាក់លាក់នេះ ប្រហែលគេបានពិភាក្សាកាលពីពេលមុនមកហើយ (មើល ៩:២៥) សូលត្រូវទៅគីលកាល ហើយត្រូវរង់ចាំរយៈពេល៧ថ្ងៃ ដើម្បីរងចាំដំណើររបស់ហោរាសាំយូអែល (មើល ១៣:៧–១៤) ។ *គីលកាល* សូមមើលការពន្យល់ យស ៤:១៩ ។

**១០:១១** *តើសូលជាពួកហោរាដែរឬអី* មើលការពន្យល់ ១៩:២៤ ។ ការពណ៌នាពីការភ្ញាក់ផ្អើល ចំពោះចរិតរបស់សូល ពីសំណាក់ពួកអ្នកដែលបានស្គាល់គាត់ពីមុន ហើយអ្នកផ្សេងៗទៀតដែលពិពណ៌នាពីការប៉ុនប្រសប់របស់គាត់ (មើលការពន្យល់ ៩:៣,៦) ។

**១០:១២** *អ្នកណាជាឪពុក* អ្នកខ្លះយល់ពីសំណួរនោះថា គឺជាការពណ៌នាពីការមើលងាយរបស់ពួកហោរាទូទៅ អ្នកខ្លះទៀតថាជាការថ្លែងមិនចំក្នុងការទទួលស្គាល់ថា គាត់ជាហោរាមកពីព្រះ ដូច្នេះហើយអាចនឹងក្លាយជាចំណែកដល់អ្នកណាដែលជាហោរាមកពីព្រះ ។ ទោះបីជាយ៉ាងណាក៏ដោយ ពេលខ្លះហោរាគេហៅថា"ឪពុក" (២ពវ ២:១២ ៦:២១ ១៣:១៤) អ្នកនិយាយប្រហែលជាមានគោលបំណងមើលងាយចំពោះសាំយូអែល ឬចំអកឱ្យសូល ។

**១០:១៧** *នៅគ្រានោះ សាំយូអែលប្រមូលពួកកូនចៅអ៊ីស្រាអែល* បន្ទាប់ពីមានការជ្រើសរើសជាលក្ខណៈឯកជន និងចាក់ប្រេងតាំងឱ្យសូលធ្វើជាស្ដេច

អែលមកប្រជុំគ្នានៅចំពោះព្រះយេហូវ៉ាត្រង់មីសប៉ា[គ] ១៨រួច
ប្រាប់ដល់ពួកបណ្ដាជនទាំងឡាយថា ព្រះយេហូវ៉ា ជាព្រះ
នៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលយ៉ាងដូច្នេះថា អញ
បាននាំពួកអ៊ីស្រាអែល ឡើងចេញពីស្រុកអេស៊ីព្ទមក ក៏បាន
ជួយឯងរាល់គ្នាឱ្យរួចពីកណ្ដាប់ដៃនៃសាសន៍អេស៊ីព្ទ ហើយ
ពីកណ្ដាប់ដៃនៃពួកនគរទាំងប៉ុន្មាន ដែលសង្កត់សង្កិន[ឃ]ឯង
១៩តែនៅថ្ងៃនេះ ឯងរាល់គ្នាបានបោះបង់ចោល[ង]ព្រះនៃ
ឯង ដែលទ្រង់បានជួយសង្គ្រោះ[ច]ឯង ឱ្យរួចពីគ្រប់ទាំង
គ្រោះថ្នាក់ និងសេចក្ដីវេទនារបស់ឯង ឥឡូវនេះឯងរាល់
គ្នាបានទូលទ្រង់ថា សូមតាំងស្ដេច[ឆ]ឱ្យសោយរាជ្យលើ
យើងរាល់គ្នាវិញ[ជ] ដូច្នេះ ចូរឯងរាល់គ្នាឈរ[ឈ]នៅចំពោះ
ព្រះយេហូវ៉ា តាមពូជអំបូរ តាមពួកឯងទាំងពាន់ៗចុះ
២០សាំយូអែល ក៏ឱ្យពូជអំបូរ នៃសាសន៍អ៊ីស្រាអែលទាំង
អស់ចូលមក ហើយព្រះទ្រង់រើសយកពូជអំបូរបេនយ៉ាមីន
២១រួចលោកឱ្យពូជអំបូរនោះចូលមកតាមគ្រួគេ ហើយ
រើស[ញ]យកបានគ្រួម៉ាទ្រី ត្រូវលើរូបសូលជាកូនគីស តែ
កាលគេរកគាត់ នោះមិនឃើញសោះ ២២ដូច្នេះគេទូល
សួរ[ដ]ដល់ព្រះយេហូវ៉ាទៀតថា តើឈ្មោះនោះដែលត្រូវមក
មែនឬ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល វាកំពុងតែ
ពួននៅក្នុងអីវ៉ាន់ ២៣គេក៏រត់ទៅនាំគាត់ចេញពីទីនោះមក
កាលគាត់ឈរឡើងនៅកណ្ដាលពួកជន នោះគាត់មាន
កំពស់ផាង[ឋ]គេទាំងអស់ ឯបណ្ដាជនទាំងឡាយបានត្រឹមតែ
ស្មារបស់គាត់ទេ ២៤នោះសាំយូអែលប្រាប់ដល់បណ្ដាជន
ថា ចូរមើល អ្នកនេះដែលព្រះយេហូវ៉ាទ្រង់បានតាំងឡើង[ឌ]
ថាគ្មានអ្នកណា ក្នុងពួកបណ្ដាជន ឱ្យដូចជា[ឍ]គាត់ទេ បណ្ដា
ជនទាំងឡាយក៏បន្លឺវាចាឡើងថា ជយោ[ណ]ព្រះករុណា ។
២៥គ្រានោះ សាំយូអែលក៏ប្រាប់ពន្យល់[ត] ដល់ពួក
បណ្ដាជនពីរបៀប[ថ]នគរ[ទ] ហើយលោកកត់ក្នុងសៀវភៅ
យកទៅដាក់នៅចំពោះព្រះយេហូវ៉ា ស្រេចហើយ លោក
ឱ្យពួកបណ្ដាជនត្រឡប់ទៅឯផ្ទះគេរៀងខ្លួនវិញទៅ ២៦ឯ
សូលលោកក៏ទៅឯលំនៅរបស់លោកនៅគីបៀរដែរ[ធ]មាន
ទាំងពួកអ្នកដែលព្រះបានបណ្ដាលចិត្តគេ[ន] ទៅជាមួយផង
២៧តែមានពួកពាលអនាថា[ប]ខ្លះនិយាយថា ធ្វើដូចម្ដេចឱ្យ
អ្នកនោះជួយសង្គ្រោះយើងបាន គេក៏មើលងាយដល់លោក
ហើយមិនបានយកភស្តុភារអ្វី[ផ]មកជូនលោកទេ តែលោក
ឥតរវល់ឡើយ ។

**១០:១៧** គ ១សយ ៧:៥
**១០:១៨** ឃ នក ១:១៤ ជន ១០:៩
**១០:១៩** ង ជន ១១:២០ ចទ ៣៣:៥ ច ទដ ៧:១០ ១៨:៤៨ ៦៨:២០ ១៤៥:១៩ ឆ ១សយ ៨:៥-៧ ជ ចទ ១៧:១៤ ឈ យស ៧:១៤
**១០:២១** ញ នអ ៣:៧ សភ ១៦:៣៣
**១០:២២** ដ លប ២៥:២២ ពច ១៨:៥
**១០:២៣** ឋ ១សយ ៩:២
**១០:២៤** ឌ ចទ ១៧:១៥ ២សយ ២១:៦ ឍ ១សយ ៩:២ ណ ១ពវ ១:២៥,៣៤,៣៩ ២ពវ ១១:១២
**១០:២៥** ត ១សយ ៨:៩ថ ចទ ១៧:១៤-២០ ១សយ ៨:១១-១៨ ២ពវ ១១:១២ ទ ១សយ ១១:១៤ **១០:២៦** ធ ខ.៥ ពច ១៩:១៤ ន ពច ២០:៤៤ **១០:២៧** ប ចទ ១៣:១៣ ១សយ ២០:៧ ផ ខ.៤ ១ពវ ១០:២៥ ២របា ១៧:៥ ៣២:២៣ ទដ ៦៨:២៩

មក (៩:១៥-១៧,២០-២១,២៧ ១០:១) ហោរាសាំយូអែលបានហៅបណ្ដាជនមកប្រជុំ (ដើម្បីឱ្យព្រះអម្ចាស់បានជ្រើសរើសស្ដេចសូលនៅចំពោះមុខបណ្ដាជន) (ខ.២១) និងដើម្បីប្រាប់ពីកិច្ចការងាររបស់ស្ដេច (ខ.២៥) ។ *មីសប៉ា* សូមមើល ៧:៥ ។

**១០:១៨** *អញបាននាំពួកអ៊ីស្រាអែល* ព្រះអម្ចាស់ទ្រង់បានមានបន្ទូលតាមរយៈហោរាសាំយូអែលដើម្បីបញ្ជាក់ដល់បណ្ដាជនអ៊ីស្រាអែលឱ្យបានដឹងថា ទ្រង់គឺជាអ្នកដែលបាននាំពួកគេ នៅក្នុងប្រវត្តិសាស្ត្រ ។ ព្រះអម្ចាស់ទ្រង់បាននាំពួកគេចេញពីប្រទេសអេស៊ីព្ទ និងរំដោះគេឱ្យរួចផុតពីខ្មាំងសត្រូវទាំងប៉ុន្មាន ក្នុងអំឡុងពេលនៃគ្រាពួកចៅហ្វាយ ។ ទោះបីជាពេលខ្លះពួកចៅហ្វាយទាំងនោះអះអាងថា គេជាអ្នករំដោះពួកអ៊ីស្រាអែលក៏ដោយ (ពច ៣:៩,១៥,៣១ ៦:១៤ ១០:១ ១៣:៥) នោះគ្រាន់តែជាសេចក្ដីពិតទី២ប៉ុណ្ណោះ ពីព្រោះពួកគេ គឺជាឧបករណ៍នៃការរំដោះរបស់ព្រះប៉ុណ្ណោះ (សូមមើល ពច ២:១៨) ព្រះអម្ចាស់ទ្រង់គឺជាអ្នកចាត់បញ្ជូនពួកគេ (មើល ១២:១១ ពច ៦:១៤) ។

**១០:១៩** *ឯងរាល់គ្នាបានបោះបង់ចោលព្រះនៃឯង* មើលការពន្យល់ ៨:៧ ។

**១០:២០** *ព្រះទ្រង់រើសយកពូជអំបូរបេនយ៉ាមីន* ធ្វើតាមរបៀបចាប់ឆ្នោត (មើល ១៤:៤១-៤២ យស ៧:១៦-១៨) ។ គេប្រើយូរីម និងធូមីមដើម្បីឱ្យបានដឹងថា អ្នកណាត្រូវបានជ្រើសរើស (សូមមើលការពន្យល់ ២:២៨ នក ២៨:៣០) ។

**១០:២៣** *គាត់មានកំពស់ផាងគេទាំងអស់* សូមមើលការពន្យល់ ៩:២ ។

**១០:២៤** *ជយោព្រះករុណា* សូមមើលការពន្យល់ ទដ ៦២:៤ ។

**១០:២៥** *របៀបនគរ* ហោរាសាំយូអែលបានចាប់យកជំហានទី១នេះ ដើម្បីដោះស្រាយបញ្ហាតានតឹង ដ៏មានសារៈសំខាន់ រវាងបំណងប្រាថ្នាខុសដែលពួកអ៊ីស្រាអែលគេចង់បានស្ដេច (ហើយនិងការយល់ខុសរបស់ពួកគេ ពីការគ្រប់គ្រងរបស់ស្ដេច និងតួនាទីដែលត្រូវធ្វើ) និងអ្នកដែលព្រះអម្ចាស់ជ្រើសរើសសម្រាប់ពួកគេ (សូមមើលសេចក្ដីផ្ដើម: មាតិកានិងផ្ទៃរឿង) ។ នេះគឺជាការពិពណ៌នាប្រាប់ពីកិច្ចការងារ ហើយនិងបុព្វសិទ្ធិរបស់ពួកកូនចៅអ៊ីស្រាអែលថា ស្ដេចគឺសម្រាប់ជាប្រយោជន៍ និងកម្រៃដល់ទាំងបណ្ដាជន ហើយសម្រាប់ទាំងស្ដេចដែលបានជ្រើសរើសនោះផងដែរ ។ កិច្ចការនេះមានការបម្រុងទុកជាមុនដើម្បីបញ្ជាក់ឱ្យអ៊ីស្រាអែល ដែលមកពីបណ្ដាពូជអំបូរផ្សេងៗបានដឹង និងធានាថា អំណាចនៃការគ្រប់គ្រងរបស់ស្ដេចនៅលើពួកអ៊ីស្រាអែល គឺត្រូវយល់ព្រមបន្តឱ្យការគ្រប់គ្រងរបស់ព្រះអម្ចាស់លើពួកអ៊ីស្រាអែលថា ព្រះជាស្ដេចដ៏ធំរបស់គេ (សូមមើលការពន្យល់ ចទ ១៧:១៤-២០) ។ *សៀវភៅ* សូមមើល នក ១៧:១៤ ។ *ដាក់នៅចំពោះព្រះយេហូវ៉ា* ប្រៀបធៀប នក ៣១:៩ ។ ឯកសារដែលស្របច្បាប់ដែលនិយាយពីការគ្រប់គ្រងរបស់ស្ដេច ក្រោមការដឹកនាំពីសេចក្ដីសញ្ញារបស់ព្រះអម្ចាស់បណ្ដា ជនបានយកមកទុកក្នុងទីបរិសុទ្ធរបស់ព្រះ (នៅក្នុងរោងឧបោសថអាសនានៃព្រះវិហារ) ។

**១០:២៧** *ពួកពាលអនាថា* មើលការពន្យល់ ២:១២ និងមើល ចទ ១៣:១៣ ។ *ធ្វើដូចម្ដេចឱ្យអ្នកនោះជួយសង្គ្រោះយើងបាន* ផ្ដោតលើមនុស្សនៅតែបន្តបោះបង់ចោលព្រះ ហើយគិតថា សុខសន្តិភាពរបស់ប្រជាជាតិស្ថិតនៅលើស្ដេចនៃមនុស្ស (មើលការពន្យល់ ខ.១៨ និងមើល ៨:២០) ។

## ស្តេចសូលរំដោះក្រុងយ៉ាបេស

**១១** ១សម័យនោះ ណាហាស[ក] ជាសាសន៍អាំម៉ូន ក៏ឡើង
មកបោះទ័ពទាស់នឹងក្រុងយ៉ាបេស–កាឡាត[ខ] ឯពួកមនុស្ស
នៅយ៉ាបេសទាំងប៉ុន្មាន គេនិយាយនឹងណាហាសថា ដូច្នេះ
សូមឱ្យតាំងសេចក្តីសញ្ញា[គ]នឹងយើងខ្ញុំចុះ នោះយើងខ្ញុំនឹង
ចំណុះចំពោះលោក ២តែណាហាសជាសាសន៍អាំម៉ូនឆ្លើយ
ថា លុះត្រាតែ[ឃ]ឱ្យអញចាក់[ង]ភ្នែកខាងស្តាំរបស់ឯងរាល់គ្នា
ឱ្យខ្វាក់ នោះទើបអញនឹងព្រមតាំងសេចក្តីសញ្ញានឹងឯង
រាល់គ្នា ដើម្បីនឹងយកការនោះទុកសំរាប់ជាសេចក្តី
ដំនៀល[ច]ដល់សាសន៍អ៊ីស្រាអែល ៣នោះពួកចាស់ទុំ[ឆ]នៅ
ក្រុងយ៉ាបេសក៏អង្វរថា សូមមេត្តាបង្អង់ឱ្យយើងខ្ញុំបាន៧ថ្ងៃ
សិន ដើម្បីនឹងចាត់គេឱ្យទៅប្រាប់គ្រប់ក្នុងកំឡុងស្រុក
អ៊ីស្រាអែល រួចបើគ្មានអ្នកណានឹងមកជួយ[ជ]យើងខ្ញុំទេ នោះ
យើងខ្ញុំនឹងចេញមកចុះចូល[ឈ]នឹងលោក ៤ដូច្នេះ ពួកអ្នក
ទាំងនោះ ក៏មកថ្លែងប្រាប់ដល់បណ្តាមនុស្ស នៅត្រង់
គីបៀរ[ញ] ជាស្រុករបស់សូល ឱ្យស្តាប់ នោះគេឡើងសំឡេង
យំ[ដ]គ្រប់គ្នា ៥ខណនោះ សូលកំពុងតែកៀងហ្វូងគោមកពី
វាលក៏សួរថា តើមានកើតហេតុភេទអ្វី បានជាយំដូច្នេះ
នោះគេជំរាបលោកតាម ពាក្យនៃពួកមនុស្សនៅយ៉ាបេស
សព្វគ្រប់ ។
៦កាលលោកបានឮហើយ នោះព្រះវិញ្ញាណ[ឋ]នៃព្រះ
ទ្រង់មកសណ្ឋិតលើលោក បណ្តាលឡើងជាខ្លាំង ហើយ
សេចក្តីកំហឹងរបស់លោកក៏ឆួលឆេះឡើង ៧លោកយកគោ
១នឹម[ឌ]មកកាប់ជាកង់ៗផ្ញើទៅគ្រប់ក្នុងកំឡុងស្រុកអ៊ីស្រា
អែល[ឍ] ដោយសារពួកអ្នកទាំងនោះ ដោយពាក្យថា អ្នក
ណា[ណ]ដែលមិនចេញមកតាមសូល ហើយនិងសាំយូអែល
នោះនឹងត្រូវធ្វើដូច្នេះ ដល់គោរបស់អ្នកនោះដែរ ដូច្នេះ
សេចក្តីស្ញែងខ្លាចពីព្រះយេហូវ៉ា ក៏ធ្លាក់មកលើពួកជនគ្រប់
គ្នា ហើយគេស្រុះចិត្តគ្នាចេញមក ដូចជាមនុស្សតែម្នាក់[ត]
៨ឯសូលលោករាប់[ថ]គេនៅត្រង់បេសេក[ទ] នោះឃើញមាន
ពួកកូនចៅអ៊ីស្រាអែលចំនួន៣សែននាក់ ហើយពួកយូដា
៣ម៉ឺននាក់ ៩រួចប្រាប់ដល់ពួកអ្នកដែលនាំដំណឹងមកនោះ
ថា ចូរអ្នករាល់គ្នាទៅប្រាប់ដល់ពួកយ៉ាបេស–កាឡាតថា
ថ្ងៃស្អែកនេះដល់ថ្ងៃពេញកំដៅ នោះអ្នករាល់គ្នានិងបាន
រួចហើយ ពួកនោះក៏ទៅប្រាប់ដល់បណ្តាមនុស្សដែលនៅ
យ៉ាបេស ហើយគេកើតមានសេចក្តីអំណរឡើងជាខ្លាំង
១០ដូច្នេះពួកមនុស្សនៅយ៉ាបេស គេប្រាប់ដល់ពួកសាសន៍
អាំម៉ូនថា ថ្ងៃស្អែកនេះយើងខ្ញុំនឹងចេញមក[ធ]ឯអ្នករាល់គ្នា
ហើយ ដើម្បីឱ្យអ្នករាល់គ្នាបានប្រព្រឹត្តនឹងយើងខ្ញុំតាមតែ
ចិត្តចុះ ១១លុះដល់ថ្ងៃស្អែកឡើង សូលលោករៀបពលទ័ព
ជា៣កង[ន] ចូលទៅដល់ទីបោះទ័ពរបស់គេនៅវេលាយាម
ព្រឹក ហើយវាយសាសន៍អាំម៉ូន[ប]នោះ ដរាបដល់ថ្ងៃក្តៅ
ឯពួកអ្នកដែលនៅសល់ក៏ត្រូវខ្ចាត់ខ្ចាយទៅ ដល់ម្ល៉េះបានជា
គ្មាន២នាក់នៅជាមួយគ្នាឡើយ ។

## លោកសូលបានតាំងឡើងជាស្តេច

១២ស្រេចហើយ បណ្តាជនគេជំរាបដល់សាំយូអែលថា
អ្នកណា[ផ]ដែលថា តើត្រូវឱ្យសូលសោយរាជ្យលើយើងឬអី

**១១:១** ក លប ១៩:៣៨ ១សយ ១២:១២ ២សយ ១០:២ ១៧:២៧ ១រប ១៩:១ ខ ពច ២១:៨ ១សយ ៣១:១១ ២សយ ២:៤,៥ ២១:១២ គ នក ២៣:៣២ យរ ៣៧:១ **១១:២** ឃ លប ៣៤:១៥ ង ជន ១៦:១៤ ច ១សយ ១៧:២៦ **១១:៣** ឆ ១សយ ៨:៤ ជ ពច ២:១៦ ឈ ខ.១០ **១១:៤** ញ ១សយ ១០:៥,២៦ ដ លប ២៧:៣៨ ជន ២៥:៦ **១១:៦** ឋ ពច ៣:១០ **១១:៧** ឌ ១សយ ៦:១៤ ឍ ពច ១៩:២៩ ណ ពច ២១:៥ ត ពច ២០:១ **១១:៨** ថ ពច ២០:២ ទ ពច ១:៤ **១១:១០** ធ ខ.៣ **១១:១១** ន ពច ៧:១៦ ប លប ១៩:៣៨ **១១:១២** ផ ចទ ១៣:១៣ លក ១៩:២៧

**១១:១** *សាសន៍អាំម៉ូន* ពួកសាសន៍អាំម៉ូនទាំងនោះ គឺជាកូនចៅជំនាន់ក្រោយរបស់លោកឡុត(លប ១៩:៣៦–៣៨ និងការពន្យល់, និងមើល ចទ ២:១៩) ហើយពួកគេរស់នៅភាគខាងកើតនៃទន្លេយ័រដាន់ និងភាគខាងត្បូងនៃស្ទឹងយ៉ាបុក (មើល ចទ ២:៣៧ យស ១២:២) ។ ពីមុនពួកអាំម៉ូនប៉ុនប៉ងគ្រប់គ្រង និងតាំងលំនៅលើទឹកដីមរដករបស់អ៊ីស្រាអែល គឺមាននិយាយនៅក្នុង ពច ៣:១៣ ១១:៤–៣៣ ។ ពួកភីលីស្ទីនបានព្យាបាទពួកអ៊ីស្រាអែលនៅភាគខាងលិច ជាហេតុធ្វើឱ្យពួកសាសន៍អាំម៉ូនមានឱកាសប្រឆាំង ជាមួយពួកអ៊ីស្រាអែលភាគខាងកើត ដោយគិតស្មានថា ជាការគ្មានទោស ។ *យ៉ាបេស–កាឡាត* គឺជាទីក្រុង១ ដែលស្ថិតនៅភាគខាងកើតទន្លេយ័រដាន់ ។

**១១:២** *លុះត្រាតែឱ្យអញចាក់ភ្នែកស្តាំរបស់ឯងរាល់គ្នាឱ្យខ្វាក់* នោះគឺជារបៀបដែលនាំឱ្យអាម៉ាសមុខ១ផ្សេងទៀត (មើលការពន្យល់ ពច ១៦:២១) ការបាត់បង់ភ្នែកស្តាំ អាចបំផ្លាញទាហានដែលមានសមត្ថភាព ។

**១១:៤** *ស្រុករបស់សូល* មើល ១០:២៦ និងការពន្យល់ ១០:៥ ។ គ្រួសារដែលជិតស្និទ្ធិ គ្មានការសង្ស័យចំពោះការតាំងលំនៅរបស់លោកយ៉ាបេសដើម្បីស្វែងរកជំនួយពីពូជអំបូរបេនយ៉ាមីនឡើយ (សូមមើល ពច ២១:១២–១៤) ។

**១១:៥** *ខណះនោះ សូលកំពុងតែកៀងហ្វូងគោមកពីវាល* បន្ទាប់ពីសូលត្រូវបានជ្រើសឱ្យធ្វើជាស្តេចនៅត្រង់មីសប៉ាមក(១០:១៧–២៥) គាត់បានត្រឡប់មកផ្ទះវិញ (១០:២៦) ដើម្បីបន្តកិច្ចការងារផ្ទាល់ខ្លួនរបស់គាត់ដូចសព្វដង និងដើម្បីរង់ចាំការដឹកនាំរបស់ព្រះអម្ចាស់នៅក្នុងជំហានបន្ទាប់ទៀត ក្នុងការតែងតាំងគាត់ឱ្យគង់លើបល្ល័ង្ក (មើលការពន្យល់ ខ.១៥ ១០:៧) ។

**១១:៦** *ព្រះវិញ្ញាណនៃព្រះ ទ្រង់មកសណ្ឋិតលើលោក បណ្តាលឡើងជាខ្លាំង* សូមមើល ១០:៦,១០ ។ សម្រាប់អំណោចទាន ដែលប្រហាក់ប្រហែលគ្នា នៃអ្នករំដោះរបស់អ៊ីស្រាអែល ពីកម្លាំងដែលប្លែកពីធម្មតា ដែលមកពីវិញ្ញាណព្រះអម្ចាស់នោះ មើល ១១:២៩ និងការពន្យល់, និងមើល ពច ១៤:៦,១៩ ១៥:១៤ ។

**១១:៧** *កាប់ជាកង់ៗផ្ញើទៅគ្រប់ក្នុងកំឡុងស្រុកអ៊ីស្រាអែល* សូមមើល ពច ១៩:២៩ និងការពន្យល់ សម្រាប់រឿងប្រហាក់ប្រហែលគ្នានេះ ។

**១១:៨** *បេសេក* មានទីតាំងស្ថិតនៅភាគខាងជើងនៃតំបន់ស៊ីគែម ហើយនៅភាគខាងលិចទន្លេយ័រដាន់ ប៉ុន្តែនៅក្នុងតំបន់យ៉ាបេស–កាឡាត ។

**១១:១១** *វេលាយាមព្រឹក* ស្ថិតនៅយាមទី៣ (ម៉ោង ២:០០–៦:០០ ព្រឹក សូមមើលការពន្យល់ មថ ១៤:២៥) ។

ចូរនាំអ្នកទាំងនោះមក ឱ្យយើងសំឡាប់ចោលចេញ ១៣តែ
សូលប្រកែកថា នៅថ្ងៃនេះមិនត្រូវឱ្យសំឡាប់អ្នកណាទេ[ព]
ដ្បិតថ្ងៃនេះ ព្រះយេហូវ៉ាបានប្រោសឱ្យមានសេចក្ដី
សង្គ្រោះ[ភ] នៅក្នុងសាសន៍អ៊ីស្រាអែល ។
១៤នោះសាំយូអែលប្រាប់ដល់បណ្ដាជនទាំងឡាយ
ថា ចូរឱ្យយើងរាល់គ្នាទៅឯគីលកាល[ម] ដើម្បីនឹងតាំងនគរ
ឡើងជាថ្មីទៀត[យ] ១៥ដូច្នេះគេក៏ទៅឯគីលកាល[រ]ទាំងអស់គ្នា
ហើយនៅទីនោះ គេតាំងសូលឡើងឱ្យធ្វើជាស្តេច[ល] នៅ
ចំពោះព្រះយេហូវ៉ា រួចគេថ្វាយយញ្ញបូជា ជាដង្វាយមេត្រី
នៅចំពោះព្រះយេហូវ៉ា ហើយនៅទីនោះ សូល និងពួក
អ៊ីស្រាអែលទាំងអស់គ្នា ក៏មានសេចក្ដីអំណរអរសប្បាយ
ឡើងជាខ្លាំង ។

**១១:១៣** ព ២សយ ១៩:២២ ភ ១សយ ១៩:៥ ១រប ១១:១៤ **១១:១៤** ម យស ១០:៤៣ ១សយ ១០:៨ **១១:១៤** យ ១សយ ១០:២៥ **១១:១៥** រ យស ៥:៩ ២សយ ១៩:១៥ ល ១សយ ១២:១ **១២:១** ក ១សយ ៨:៧ ខ ១សយ ១១:១៥ **១២:២** គ ១សយ ៨:៥ ឃ ១សយ ៨:៣ **១២:៣** ង ១សយ ៩:១៦ ២៤:៦ ២៦:៩,១១ ២សយ ១:១៤ ១៩:២១ ទដ ១០៥:១៥ ច ជន ១៦:១៥

## លោកសាំយូអែលថ្លែងដល់ពួកអ៊ីស្រាអែល

**១២** ១លំដាប់នោះ សាំយូអែលប្រាប់ដល់ពួកអ៊ីស្រាអែល
ទាំងអស់គ្នាថា មើល ខ្ញុំបានស្ដាប់[ក]តាមគ្រប់ទាំងសេចក្ដី
ដែលអ្នករាល់គ្នាបានសូមដល់ខ្ញុំហើយ ខ្ញុំបានតាំងឱ្យមាន
ស្តេច[ខ]លើអ្នករាល់គ្នា ២ឥឡូវនេះ មើល ស្តេចទ្រង់យាង
នៅមុខអ្នករាល់គ្នា[គ] ឯខ្ញុំៗចាស់ហើយ សក់ខ្ញុំក៏ស្កូវផង
ហើយមើល កូនខ្ញុំ[ឃ]នៅជាមួយនឹងអ្នករាល់គ្នាដែរ ខ្ញុំបាន
ដើរនៅមុខអ្នករាល់គ្នាតាំងតែពីក្មេង ដរាបដល់ថ្ងៃនេះ
៣ខ្ញុំនៅទីនេះស្រាប់ ចូរធ្វើបន្ទាល់ទាស់នឹងខ្ញុំនៅចំពោះ
ព្រះយេហូវ៉ា ហើយនៅមុខអ្នកដែលទ្រង់បានចាក់ប្រេង
តាំងឱ្យនេះចុះ[ង] តើខ្ញុំបានយកគោរបស់អ្នកណា ឬយកលា[ច]

**១១:១៣** *ព្រះយេហូវ៉ាទ្រង់បានប្រោសឱ្យមានសេចក្ដីសង្គ្រោះដល់សាសន៍អ៊ីស្រាអែល* សូលគាត់បានទទួលស្គាល់ អ្នករំដោះដ៏ពិតរបស់អ៊ីស្រាអែល (សូមមើលការពន្យល់ ១០:១៨) ។ ជ័យជម្នះ បានគួបផ្សំជាមួយការលន់តួរបស់ស្តេចសូល គឺជាត្រារបស់ព្រះអម្ចាស់ដែលទ្រង់បានដៅលើសូលថា សូល គាត់ជាមនុស្សដែលព្រះអម្ចាស់បានរើសតាំងឱ្យធ្វើជាស្តេច ។

**១១:១៤** *ចូរយើងរាល់គ្នាទៅឯគីលកាល ដើម្បីនឹងតាំងនគរឡើងជាថ្មីទៀត* ហោរាសាំយូអែល បានដឹងជាមុនថា ពេលនេះជាពេលដែលសក្តិសមសម្រាប់បណ្ដាជន ដើម្បីឱ្យគេបានបង្ហាញភក្ដីភាពរបស់គេជាថ្មីនូវចំពោះព្រះអម្ចាស់ នគរដែលគាត់និយាយនេះ ជារបស់ព្រះ មិនមែនជារបស់សូលឡើយ ។ ហោរាសាំយូអែលបានហៅបណ្ដាជនមកប្រជុំ ដើម្បីសាងសង់សេចក្ដីសញ្ញានៃការទំនាក់ទំនង រវាងព្រះអម្ចាស់ហើយនិងបណ្ដាជនឡើងវិញ ។ គាត់ត្រូវការធ្វើពិធីតែងតាំងការគ្រប់គ្រងរបស់សូល ក្នុងចរិតមាយាទត្រឹមត្រូវ ដើម្បីបង្ហាញថា គាត់ជាអ្នកបន្តការគ្រប់គ្រងរបស់ព្រះ គឺជាស្តេចដ៏ធំរបស់អ៊ីស្រាអែល ដែលគ្មានថ្ងៃដួលរលំអន់ថយ ឬក៏ប្រព្រឹត្តល្មើសនៅក្នុងយុគ្គសម័យកាលថ្មីនៃរបបរាជានោះឡើយ (សូមមើលសេចក្ដីផ្ដើម: មាតិការ និងផ្ទៃរឿង) ។ នៅក្នុង ខ.១៤–១៥ គឺជាសេចក្ដីសង្ខេបពីការប្រជុំនៅត្រង់គីលកាល ហើយនិងអារម្ភកថា បន្ថែមទៀតអំពីការប្រជុំនៅក្នុងជំពូក១២ ។ *គីលកាល* មានទីតាំងនៅភាគខាងកើតក្រុងយេរីខូរក្បែរទន្លេយ័រដាន់ ។ វាជាកន្លែងដ៏ល្អ និងសក្តិសមសម្រាប់ពួកអ៊ីស្រាអែលបង្ហាញពីភក្ដីភាពរបស់គេ ចំពោះព្រះអម្ចាស់ឡើងវិញ (សូមមើល យស ៤:១៩–៥:១០ ១០:៧–១៥) ។

**១១:១៥** *គេតាំងសូលឡើងធ្វើជាស្តេច នៅចំពោះព្រះយេហូវ៉ា* សូលបានទទួលការចាក់ប្រេងតាំងជាលក្ខណៈឯកជនម្ដងទៅហើយ តាមរយៈហោរាសាំយូអែលនៅត្រង់រ៉ាម៉ា (១០:១) ហើយក៏ទទួលជ្រើសរើសជាស្តេចនៅត្រង់មីសប៉ា (១០:១៧–២០) ។ នៅក្នុងវិបត្តិ សម័យក្រោយមកទៀតជាមួយពួកអាំម៉ូន(ខ.១–១៣) ភាពជាអ្នកដឹកនាំរបស់គាត់ មិនបានឃើញមានការទទួលស្គាល់ជាផ្លូវការណ៍ ពីអំណាចជាស្តេចឡើយ ប៉ុន្តែគេទទួលស្គាល់ថាជាទ័ពដែលទទួលបាននូវជ័យជម្នះវិញ ។ ឥឡូវនេះ នៅត្រង់គីលកាល សូលត្រូវប្រកាសតែងតាំងថា ជាស្តេចរើសតាំងរបស់ព្រះ ។ *ដង្វាយមេត្រី* ប្រភេទនៃដង្វាយនេះគឺមានសារៈសំខាន់ តាំងពីពេលធ្វើពិធីតាំងសញ្ញានៅភ្នំស៊ីណាយមកម្ល៉េះ (នក ២៤:៥,១១) ។ ទង្វើបែបនេះគឺបង្ហាញពីទំនាក់ទំនង និងការរួបរួម ព្រមទាំងសន្តិភាពរវាងព្រះអម្ចាស់ហើយនិងរាស្ត្រទ្រង់ នៅក្នុងអំឡុងពេលដែលរាស្ត្រទ្រង់រស់នៅក្នុងភាពចុះសម្រុងនឹងគ្នាជាមួយនឹងកាតព្វកិច្ចក្នុងសេចក្ដីសញ្ញា (មើល លវ ៧:១១–២១ ២២:២១–២៣) ។ *សេចក្ដីអំណរ . . . ជាខ្លាំង* សេចក្ដីអំណរ គឺជាការពណ៌នាពីបណ្ដាជនចំពោះអ្នកណាម្នាក់ដែលបានធ្វើការប្ដេជ្ញាចិត្តជាថ្មីជាមួយព្រះ ឬការលន់តួរនូវចំពោះព្រះអម្ចាស់ (សូមមើល ១២:១៩) ហើយនិងតែងតាំងស្តេច ។

**១២:២** *យាងនៅមុខអ្នករាល់គ្នា* តាមលក្ខណៈអក្សរសាស្ត្រនិយាយថា "ជាអ្នកនាំមុខអ្នករាល់គ្នា" នៅក្នុងរូបអារម្មណ៍នៃព្រះគម្ពីរភាសាហេព្រើរប្រហែលជាស្តេច និងអ្នកនាំមុខគឺជាអ្នកគង្វាលមនុស្ស(មើល ២សយ ៥:២ អគ ៣៤:២៣ ហើយធៀបនឹងការពន្យល់ ទដ ២៣:១ មីក ២:១២–១៣ ហើយនិងពី ព្រះយេស៊ូវនៅក្នុង យហ ១០:៣–៤,១១,១៤–១៥,២៧) ។

**១២:៣** *ចូធ្វើបន្ទាល់ទាស់នឹងខ្ញុំ* គឺនិយាយតាមភាសាកាត់ក្តី ។ នៅពេលដែលហោរាសាំយូអែលណែនាំ និងបង្ហាញពីស្តេចថ្មីទៅចំពោះប្រជាជន គាត់បានស្វះស្វែងបង្កើត ការការពារពីសេចក្ដីជំនឿ និងភាពស្មោះត្រង់របស់គាត់នាអតីកាល ចំពោះសេចក្ដីសញ្ញា ដែលគាត់មានតួនាទីជាអ្នកគ្រប់គ្រងលើប្រជាជាតិ ។ គោលបំណងរបស់គាត់គឺ ដើម្បីឱ្យខ្លួនគាត់ផ្ទាល់បានរួចពីការចោទប្រកាន់ និងដើម្បីធ្វើជាគំរូដល់ស្តេចសូលអំពីទំនួលខុសត្រូវថ្មីរបស់លោក ។ *តើខ្ញុំបានយកគោរបស់អ្នកណា ឬយកលារបស់អ្នកណា* សូមមើល នក ២០:១៧ ២២:១,៤,៩ ។ ហោរាសាំយូអែលមិនបានប្រើឋានៈរបស់គាត់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនដូចជាកូនប្រុសរបស់លោកនោះឡើយ (សូមមើល ៨:៣ និងការពន្យល់, ធៀបនឹង ជន ១៦:១៥) ។ *តើខ្ញុំបានបំភាន់បំបាត់ ឬសង្កត់សង្កិនអ្នកណា* សូមមើល លវ ១៩:១៣ ចទ ២៤:១៤ ។ *តើខ្ញុំបានទទួលសំណូកពីដៃអ្នកណា* ចំពោះការទទួលសំណូកនោះគឺខុសពី ៨:៣ សូមមើល នក ២៣:៨ ចទ ១៦:១៩ ។

របស់អ្នកណា តើខ្ញុំបាន[ឆ]បំភាន់បំបាត់ឬសង្កត់សង្កិនអ្នកណា
តើខ្ញុំបានទទួល[ជ]សំណូកពីដៃអ្នកណា ដើម្បីឱ្យខ្ញុំធ្មេចភ្នែក
នោះខ្ញុំនឹងសងដល់អ្នករាល់គ្នាវិញ[ឈ] ៤តែគេឆ្លើយឡើងថា
លោកមិនដែលបំភាន់បំបាត់ ឬសង្កត់សង្កិនយើងខ្ញុំឡើយ ក៏
មិនដែលទទួលសំណូកពីដៃអ្នកណាដែរ ៥រួចលោកមាន
ប្រសាសន៍ថា នៅថ្ងៃនេះព្រះយេហូវ៉ាទ្រង់ជាទីបន្ទាល់[ញ]
ទាស់នឹងអ្នករាល់គ្នាហើយ ឯអ្នកដែលទ្រង់បានចាក់ប្រេង
តាំងឱ្យ ក៏ជាទីបន្ទាល់ដែរថា អ្នករាល់គ្នាមិនបានឃើញ
មានអ្វី[ដ] នៅក្នុងដៃខ្ញុំសោះឡើយ នោះគេទទួលថា ទ្រង់ជា
ទីបន្ទាល់មែនហើយ[ឋ]។
៦នោះសាំយូអែលថ្លែងប្រាប់ដល់ពួកជនថា គឺព្រះ
យេហូវ៉ាដែលបានតាំងម៉ូសេ និងអើរ៉ុនឡើង ព្រមទាំងនាំ[ឌ]
ពួកឰយុកោអ្នករាល់គ្នាឡើងពីស្រុកអេស៊ីព្ទមក ៧ដូច្នេះ
ឥឡូវនេះ ចូរឱ្យអ្នករាល់គ្នាឈរ[ឍ]នឹងនៅ ដើម្បីឱ្យខ្ញុំបាន
រំឭកអ្នករាល់គ្នាបន្តិច នៅចំពោះ[ណ]ព្រះយេហូវ៉ា ពីគ្រប់
ទាំងការសុចរិត[ត] ដែលទ្រង់បានប្រព្រឹត្តនឹងអ្នករាល់គ្នា
ហើយនិងពួកឰយុកោអ្នករាល់គ្នា ៨គឺកាលយ៉ាកុប[ថ]បាន
ចូលទៅនៅស្រុកអេស៊ីព្ទ ហើយពួកឰយុកោនៃអ្នករាល់គ្នា
បានអំពាវនាវ[ទ]ដល់ព្រះយេហូវ៉ា នោះទ្រង់ក៏ចាត់[ធ]ម៉ូសេ
និងអើរ៉ុន ឱ្យទៅនាំពួកឰយុកោ នៃអ្នករាល់គ្នាចេញពីស្រុក
អេស៊ីព្ទមក ព្រមទាំងឱ្យគេមានទីលំនៅនៅទីនេះ ៩ប៉ុន្តែគេ
បានភ្លេចចោល[ន]ព្រះយេហូវ៉ាជាព្រះនៃគេវិញ រួចទ្រង់បាន
លក់គេ[ប] ទៅក្នុងកណ្ដាប់ដៃនៃស៊ីសេរ៉ា[ផ] ជាមេទ័ពនៃក្រុង
ហាសោរ[ព] ហើយទៅក្នុងកណ្ដាប់ដៃនៃពួកភីលីស្ទីន[ភ] និង
ទៅក្នុងកណ្ដាប់ដៃនៃស្ដេចសាសន៍ម៉ូអាប់[ម] ដែលបានមក
ច្បាំងនឹងគេ ១០គេក៏អំពាវនាវ[យ]ដល់ព្រះយេហូវ៉ាថា យើង
ខ្ញុំបានធ្វើបាបហើយ ដ្បិតយើងខ្ញុំបានបោះបង់ចោល[រ]ព្រះ
យេហូវ៉ា បែរទៅគោរពប្រតិបត្តិដល់ព្រះបាល និងរូបព្រះ
ទាំងប៉ុន្មាន[ល] តែឥឡូវនេះ សូមទ្រង់ជួយឱ្យយើងខ្ញុំរួចពី
កណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់យើងខ្ញុំចុះ នោះយើងខ្ញុំ
នឹងគោរពប្រតិបត្តិដល់ទ្រង់វិញ ១១នោះព្រះយេហូវ៉ាទ្រង់
ក៏ចាត់យេរូ-បាល[វ] បេដាន[ស] យ៉ែបថា[ហ] និងសាំយូអែល[ឡ]
មកប្រោសឱ្យអ្នករាល់គ្នារួច ពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ
របស់អ្នករាល់គ្នា ដែលនៅជុំវិញទៅ នោះអ្នករាល់គ្នាក៏
បាននៅដោយសុខសាន្តត្រាណ ១២តែកាលបានឃើញ
ណាហាស[អ] ជាស្ដេច[ក]នៃពួកកូនចៅអាំម៉ូន មកទាស់នឹងអ្នក
រាល់គ្នា នោះអ្នករាល់គ្នាបានសូមដល់ខ្ញុំថា ទេ ត្រូវឱ្យ
មានស្ដេចសោយរាជ្យ[ខ]លើយើងរាល់គ្នាដែរ ប៉ុន្តែគឺព្រះ
យេហូវ៉ា ជាព្រះនៃអ្នករាល់គ្នា ដែលជាស្ដេចលើអ្នករាល់

**១២:៣** ឆ នក ២០:១៧ កច ២០:៣៣ ជ នក ១៨:២១ ១សយ ៨:៣ ឈ លវ ២៥:១៤ **១២:៥** ញ លប ៣១:៥០ ដ កច ២៣:៩ ២៤:២០ ឋ នក ២២:៤ **១២:៦** ឌ នក ៣:១០ មីក ៦:៤ **១២:៧** ឍ យស ២៤:១ ណ អស ១:១៨ ៣:១៤ យរ ២:៩ ២៥:៣១ អគ ១៧:២០ ២០:៣៥ មីក ៦:១-៥ ត ពច ៥:១១ **១២:៨** ថ លប ៤៦:៦ ទ នក ២:២៣ ធ នក ៣:១០ ៤:១៦ **១២:៩** ន ចទ ៣២:១៨ ពច ៣:៧ ប ចទ ៣២:៣០ ផ ពច ៤:២ ព យស ១១:១ ភ ពច ១០:៧ ម ពច ៣:១២ **១២:១០** យ ពច ៣:៩ រ ១សយ ៨:៨ ល ១សយ ៧:៣ **១២:១១** វ ពច ៦:៣២ ស ពច ៤:៦ ហ ពច ១១:១ ឡ ១សយ ៧:១៥ **១២:១២** អ ១សយ ១១:១ ក ១សយ ៨:៥ ខ ១សយ ២៥:៣០ ២សយ ៥:២ ១រប ៥:២

**១២:៦** *នោះសាំយូអែលថ្លែងប្រាប់ដល់ពួកជន* ឥឡូវនេះ ហោរាសាំយូអែលបានត្រឡប់មកនិយាយអំពីរឿងដែលពួកជនសូមចង់បានស្ដេច គាត់មានគំនិតថា ពួកគេនឹងបំពានលើសេចក្ដីសញ្ញា និងបោះបង់ព្រះចោល ។ *គឺជាព្រះយេហូវ៉ា* លោកសាំយូអែល បានសង្កត់ធ្ងន់ថា កាលពីអតីតកាល ព្រះយេហូវ៉ា ទ្រង់បានប្រទានឱ្យគេនូវអ្នកដឹកនាំដ៏សំខាន់ល្អៗជាច្រើនដល់ប្រជាជាតិរបស់គេ ។

**១២:៧** *ដើម្បីឱ្យខ្ញុំបានរំឭកអ្នករាល់គ្នាបន្តិច* ពាក្យបច្ចេកទេសនេះ គឺនិយាយពីបណ្ដឹង ដូចជានៅក្នុង ឧ.២-៥ ប៉ុន្តែឥឡូវនេះ ទំនាក់ទំនងរបស់ក្រុមទាំងនោះ គឺមានការផ្ទុយគ្នា ។ នៅក្នុងសម័យកាលហោរាសាំយូអែល គឺមានការរីកចម្រើន បណ្ដាជនគឺជាចុងចោទ ហើយព្រះអម្ចាស់ទ្រង់ជាចៅក្រម ។ *គ្រប់ទាំងការសុចរិត ដែលទ្រង់បានប្រព្រឹត្តនឹងអ្នករាល់គ្នា* ទង្វើនៃការប្រព្រឹត្តទាំងនោះ (សូមមើល ឧ.៨-១១) មិនមែនគ្រាន់តែបំភ្លឺបង្ហាញពីសេចក្ដីសញ្ញាដ៏ភក្ដីភាពរបស់ព្រះអម្ចាស់ចំពោះរាស្ត្រទ្រង់ ពីសម័យកាលមុនប៉ុណ្ណោះនោះទេ ប៉ុន្តែព្រះអម្ចាស់ទ្រង់ក៏បានសង្គ្រោះពួកគេពីការបោះបង់ចោលព្រះនាពេលនេះផងដែរ ។

**១២:៩-១១** គឺជាសេចក្ដីសង្ខេបអំពីសេចក្ដីទុក្ខព្រួយដែលកើតឡើងម្ដងហើយម្ដងទៀត ដែលបណ្ដាលមកពីការបោះបង់ចោលព្រះ ព្រះអម្ចាស់ទ្រង់ដាក់ទណ្ឌកម្មដល់គេ គេក៏អំពាវនាវទៅព្រះ ហើយព្រះអម្ចាស់ទ្រង់ក៏បានស្ដាប់គេ ដែលសកម្មភាពបែបនេះ មាននៅក្នុងសម័យកាលពួកចៅហ្វាយ (សូមមើល ពច ២:១០-១៥ និងការពន្យល់ និងសេចក្ដីផ្ដើមរបស់ព្រះគម្ពីរចៅហ្វាយៈ ផ្ទៃរឿង និងវិជ្ជាអំពីព្រះក្នុងព្រះគម្ពីរ) ។

**១២:៩** *ភ្លេចចោលព្រះយេហូវ៉ាជាព្រះនៃគេ* ហេតុការណ៍នេះអាចបណ្ដាលមកពីការមានះខុសរបស់ពួកអ៊ីស្រាអែល (មើល ហស ២:១៣ និងការពន្យល់) ។

**១២:១០** *គោរពប្រតិបត្តិដល់ព្រះបាល និងរូបព្រះទាំងប៉ុន្មាន* មើលការពន្យល់ ៧:៣ ពច ២:១៣ ។

**១២:១១** *មកប្រោសអ្នករាល់គ្នា* ព្រះអម្ចាស់ទ្រង់បានជួយពួកអ៊ីស្រាអែលឱ្យរួចពីពួកខ្មាំងសត្រូវម្ដងហើយម្ដងទៀត ក្នុងអំឡុងពេលហោរាសាំយូអែល (សូមមើល ៧:៣,៨,១០,១២) ហើយក៏បានបង្ហាញជាថ្មីទៀតនៅពេលអ៊ីស្រាអែលចង់បានស្ដេច ។

**១២:១២** *តែកាលបានឃើញណាហាស . . . មកទាស់នឹងអ្នក* នៅក្នុងពេលដែលពួកភីលីស្ទីន និងពួកអាំម៉ូនរួមដៃគ្នាទាស់ប្រឆាំងអ៊ីស្រាអែល ដោយពួកភីលីស្ទីនជាអ្នកវាយប៉ែកខាងលិច (៩:១៦) ហើយពួកសាសន៍អាំម៉ូន ជាអ្នកវាយនៅប៉ែកខាងកើត (១១:១-៣) នោះពួកអ៊ីស្រាអែលបានស្វែងរកសុវត្ថិភាពចេញពីស្ដេចរបស់គេ ។ *ទេត្រូវឱ្យមានស្ដេចលើយើងរាល់គ្នា . . . លើអ្នករាល់គ្នាវិញ* ពួកកូនចៅអ៊ីស្រាអែលគេចង់បានស្ដេច ហើយទុកចិត្តលើការដឹកនាំរបស់មនុស្ស ហើយបន្ទបដិសេធន៍ភាពជាស្ដេចរបស់ព្រះអម្ចាស់ ហើយមិនបានទុកចិត្តលើការថែរក្សារបស់ទ្រង់ទាំងសេចក្ដី

គ្នាវិញ ១៣ដូច្នេះ មើល ស្តេចនេះហើយ[គ] ដែលអ្នករាល់គ្នា
បានរើស ហើយបានសូម[ឃ]នោះ មើល ព្រះយេហូវ៉ាទ្រង់
បានតាំងស្តេចឱ្យសោយរាជ្យលើអ្នករាល់គ្នាហើយ ១៤បើ
សិនជាអ្នករាល់គ្នានឹងកោតខ្លាច[ង] ហើយគោរពប្រតិបត្តិ
ដល់ព្រះយេហូវ៉ា ព្រមទាំងស្តាប់តាមព្រះបន្ទូលនៃទ្រង់ ឥត
ទាស់ទទឹង[ច]នឹងសេចក្តីបញ្ញត្តិណាមួយ ហើយទាំងខ្លួនអ្នក
រាល់គ្នា និងស្តេចដែលសោយរាជ្យលើអ្នករាល់គ្នា និងដើរ
តាមព្រះយេហូវ៉ាជាព្រះនៃអ្នក នោះបានល្អហើយ ១៥ប៉ុន្តែ
បើអ្នករាល់គ្នាមិនព្រមស្តាប់តាមព្រះយេហូវ៉ាទេ គឺទាស់
ទទឹង[ឆ]នឹងសេចក្តីបញ្ញត្តិរបស់ទ្រង់វិញ នោះព្រះហស្តនៃ
ព្រះយេហូវ៉ានឹងបានទាស់នឹងអ្នករាល់គ្នា ដូចជាបានទាស់
នឹងពួកព្ធយុកោនៃអ្នករាល់គ្នាដែរ ១៦ដូច្នេះ ចូរអ្នករាល់គ្នា
ឈរនឹងនៅ[ជ] ចាំមើល[ឈ]ការដ៏ធំ ដែលព្រះយេហូវ៉ាទ្រង់នឹង
ធ្វើនៅចំពោះភ្នែកអ្នករាល់គ្នាចុះ ១៧នៅរដូវនេះ តើមិន
មែនជាចំរូត[ញ]នៃស្រូវភោជ្ជសាលីទេឬអី តែខ្ញុំនឹងអំពាវ
នាវ[ដ]ដល់ព្រះយេហូវ៉ា ឱ្យទ្រង់បានធ្វើឱ្យមានផ្គរលាន់[ឋ] និង
ទឹកភ្លៀងមក[ឌ] នោះអ្នករាល់គ្នានឹងដឹង ហើយឃើញជាក់ថា
ទោសរបស់អ្នករាល់គ្នាជាធ្ងន់ក្រៃលែង[ឍ] នៅព្រះនេត្រ
ព្រះយេហូវ៉ា ដោយបានសូមស្តេច ឱ្យសោយរាជ្យលើអ្នក
រាល់គ្នានេះ ១៨នោះសាំយូអែលក៏អំពាវនាវដល់ព្រះយេ–
ហូវ៉ា[ណ] ហើយទ្រង់ធ្វើឱ្យមានផ្គរលាន់និងទឹកភ្លៀងធ្លាក់ចុះ
មកនៅថ្ងៃនោះឯង ដូច្នេះបណ្តាជនទាំងឡាយក៏កោត
ខ្លាច[ត]ដល់ព្រះយេហូវ៉ា ហើយដល់សាំយូអែលជាខ្លាំង ។
១៩រួចបណ្តាជនក៏សូមដល់សាំយូអែលថា សូមឱ្យលោក
មេត្តាអង្វរ[ថ]ដល់ព្រះយេហូវ៉ា ជាព្រះនៃលោក ឱ្យយើងខ្ញុំ
ផង ដើម្បីកុំឱ្យយើងខ្ញុំត្រូវស្លាប់[ទ]ឡើយ ដ្បិតយើងខ្ញុំបាន
បន្ថែមការអាក្រក់នេះ ក្នុងអំពើបាបរបស់យើងខ្ញុំទាំង
ប៉ុន្មានហើយ ដោយបានសូមស្តេចសំរាប់យើងខ្ញុំនេះ
២០សាំយូអែលឆ្លើយថា កុំឱ្យខ្លាចឡើយ អ្នករាល់គ្នាបាន
ប្រព្រឹត្តការអាក្រក់ទាំងនេះ[ធ]មែន ប៉ុន្តែកុំឱ្យតែបែរចេញ
ពីព្រះយេហូវ៉ាទៀត គឺត្រូវឱ្យគោរពប្រតិបត្តិដល់ទ្រង់ ឱ្យ
អស់ពីចិត្តចុះ ២១កុំឱ្យបែរចេញឡើយ ដ្បិតយ៉ាងនោះ
អ្នករាល់គ្នានឹងវង្វេងទៅតាមការឥតអំពើ[ន] ដែលគ្មាន
ប្រយោជន៍[ប] ជាការដែលមិនចេះជួយឱ្យរួចផង សុទ្ធតែជា
ការឥតអំពើទាំងអស់ ២២ដ្បិតព្រះយេហូវ៉ាទ្រង់មិនបោះ
បង់ចោល[ផ]រាស្ត្រទ្រង់ឡើយ ដោយព្រោះទ្រង់យល់[ព]ដល់
ព្រះនាម[ភ]ទ្រង់ដ៏ជាធំ ពីព្រោះព្រះយេហូវ៉ាបានសព្វព្រះ
ហឫទ័យ និងយក[ម]អ្នករាល់គ្នា ធ្វើជារាស្ត្ររបស់ទ្រង់
២៣មួយទៀត ចំណែកឯខ្លួនខ្ញុំវិញ សូមកុំឱ្យខ្ញុំធ្វើបាបចំពោះ

**១២:១៣** គ ១សយ ៨:៥ ឃ ១សយ ៩:២០ **១២:១៤** ង យស ២៤:១៤ ច យរ ៤:១៧ បទ ១:១៨ **១២:១៥** ឆ លវ ២៦:១៦ យស ២៣:២០ អស ១:២០ យរ ៤:១៧ ២៦:៤ **១២:១៦** ជ នក ១៤:១៤ ឈ នក ១៤:១៣ **១២:១៧** ញ លប ៣០:១៤ ១សយ ៦:១៣ ដ ១ពវ ១៨:៤២ យក ៥:១៨ ឋ នក ៩:២៣ ១សយ ២:១០ ឌ លប ៧:១២ នក ៩:១៨ យប ៣៧:១៣ សផ ២៦:១ ឍ ១សយ ៨:៦–៧ **១២:១៨** ណ ទដ ៩៩:៦ ត លប ៣:១០ នក ១៤:៣១ **១២:១៩** ថ នក ៨:៨ ១សយ ៧:៨ យរ ៣៧:៣ យក ៥:១៨ ១យហ ៥:១៦ ទ ចទ ៩:១៩ **១២:២០** ធ នក ៣២:៣០ **១២:២១** ន អស ៤០:២០ ៤១:២៤, ២៩ ៤៤:៩ យរ ២:៥,១១ ១៤:២២ ១៦:១៩ យហ ២:៨ ហព ២:១៨ កច ១៤:១៥ ប ចទ ១១:១៦ **១២:២២** ផ លវ ២៦:១១ ចទ ៣១:៦ ព ទដ ២៥:១១ ១០៦:៨ អស ៤៨:៩,១១ យរ ១៤:៧ ដយ ៩:១៩ ភ យស ៧:៩ ២សយ ៧:២៣ យហ ១៧:១២ ម ចទ ៧:៧ ១ពត ២:៩

ស្មោះត្រង់របស់ទ្រង់ក្នុងអំឡុងគ្រា ព្រះគម្ពីរនិក្ខមនំ រហូតដល់គ្រាព្រះគម្ពីរចៅហ្វាយ (សូមមើល ៨:៧ និងការពន្យល់) ។

**១២:១៣** *ព្រះយេហូវ៉ាទ្រង់បានតាំងស្តេចឱ្យសោយរាជ្យ* ទោះបីជាអំពើបាបរបស់បណ្តាជនគឺជាការចង់បានស្តេចក៏ដោយ ក៏ព្រះអម្ចាស់ទ្រង់បានជ្រើសជិនូរវង្ស ដើម្បីដាក់បញ្ចូលក្នុងរចនាសម្ព័ន្ធរបបទេវាធិបតេយ្យរបស់ទ្រង់ដែរ (នគររបស់ទ្រង់) ។ នគររបស់ទ្រង់ត្រូវបានប្រទានមកដោយសារទ្រង់សម្រាប់រាស្ត្រទ្រង់ ហើយមានតួនាទីជាឧបករណ៍របស់ទ្រង់ ដែលគ្រប់គ្រងលើពួកគេ (សូមមើលសេចក្តីផ្តើម : មាតិកា និងផ្ទៃរឿង) ។

**១២:១៤** *បើសិនជាអ្នករាល់គ្នា . . .* ហោរាសាំយូអែលរៀបរាប់អំពីសេចក្តីសញ្ញាដោយមានលក្ខខណ្ឌ (សូមមើល នក ១៩:៥–៦ ចទ ៨:១៩ ១១:១៣–១៥,២២–២៣ ២៨:១,១៥ ៣០:១៧–១៨ យស ២៤:២០) ទៅចំពោះពួកអ៊ីស្រាអែលដែលរស់នៅក្នុងយុគសម័យកាលថ្មី ដែលកំពុងធ្វើដំណើរចូលរបបរាជាធិបតេយ្យ ។ *ហើយទាំងខ្លួនអ្នករាល់គ្នា . . . នោះបានល្អហើយ* ពួកអ៊ីស្រាអែល និងស្តេចរបស់គេគឺបំភ្លឺបង្ហាញថា ទោះបីជាគេមានស្តេចក៏ដោយ ក៏គេត្រូវតែទទួលស្គាល់ព្រះអម្ចាស់ថា ជាស្តេចរបស់គេដែរ ។ នៅក្នុងយុគសម័យកាលថ្មី ដែលជាកន្លែងសក្តានុភាពសម្រាប់បែងចែកពូជស្តេច រវាងព្រះអម្ចាស់ និងស្តេចពូជពង្សអ៊ីស្រាអែល ទៅចំពោះព្រះអម្ចាស់ត្រូវតែធ្វើឡើងដោយគ្មានការរំលោភបំពាន ។

**១២:១៦** *ចាំមើលការដ៏ធំ* សូមមើល ខ.២៤ ។ ហោរាសាំយូអែលបានហៅបណ្តាជនមកដើម្បីឱ្យធ្វើការអង្កេតមើល ដូចជាព្រះអង្គទ្រង់ផ្ទាល់ធ្វើនិទស្សន៍ចំពោះអាទិភាពអំណាច និងសេចក្តីស្មោះត្រង់ដ៏ស្ថិតស្ថេរ ព្រមទាំងសេចក្តីពិតដែលមាននៅក្នុងពាក្យសម្តីហោរាសាំយូអែល ។

**១២:១៧** *ចំរូតនៃស្រូវភោជ្ជសាលី* សូមមើលការពន្យល់ ៦:១៣ ។

**១២:១៨** *កោតខ្លាចដល់ព្រះយេហូវ៉ា ហើយដល់សាំយូអែល* សូមមើល នក ១៤:៣១ និងការពន្យល់ ។

**១២:១៩** *សូមឱ្យលោកមេត្តាអង្វរដល់ព្រះយេហូវ៉ា ជាព្រះនៃលោក* ការចោទប្រកាន់របស់ហោរាសាំយូអែល (ខ.៦–១៥) គឺបញ្ចូលជាមួយការគួរឱ្យភ័យខ្លាចនៃផ្គរលាន់ និងទឹកភ្លៀងនៅក្នុងអំឡុងពេល (ខ.១៦–១៨) ជាការជម្រុញទឹកចិត្តឱ្យបណ្តាជនសារភាពកំហុសរបស់ពួកគេ ហើយនិងសុំឱ្យហោរាសាំយូអែលអំពាវនាវដល់ព្រះយេហូវ៉ាជិនួសពួកគេ ។

**១២:២០** *កុំឱ្យតែបែរចេញពីព្រះយេហូវ៉ាទៀត* ជាថ្មីម្តងទៀត ហោរាសាំយូអែលបានផ្តោតលើចំណុចសំខាន់នៃការជិទាស់ប្រឆាំង នៅជុំវិញនគរអ៊ីស្រាអែល ។

**១២:២១** *តាមការឥតអំពើដែលគ្មានប្រយោជន៍* ការមិនទាស់ប្រឆាំងជាមួយព្រះអម្ចាស់នឹងឱ្យយើងមានជីវិតរស់នៅ ឬមានសុវត្ថិភាព (មើល នក ២០:៣ និងការពន្យល់) ។

ព្រះយេហូវ៉ា ដោយលែងអធិស្ឋាន[យ]ឱ្យអ្នករាល់គ្នានោះ
ឡើយ គឺខ្ញុំនឹងបង្ហាត់បង្រៀន[រ]ដល់អ្នករាល់គ្នា ឱ្យបានចេះ
ប្រព្រឹត្តតាមផ្លូវល្អ ហើយទៀងត្រង់វិញ ២៤សូមឱ្យតែអ្នក
រាល់គ្នាបានកោតខ្លាច[ល]ដល់ព្រះយេហូវ៉ា ហើយគោរព
ប្រតិបត្តិដល់ទ្រង់ ដោយស្មោះត្រង់[វ] ហើយអស់អំពីចិត្តផង
ប៉ុណ្ណោះ ដ្បិតចូរពិចារណា[ស]មើលការដ៏ធំវិសេស[ហ]ទាំង
ម្ល៉េះ ដែលទ្រង់បានប្រោសដល់អ្នករាល់គ្នាហើយ ២៥ប៉ុន្តែ
បើសិនណាជាអ្នករាល់គ្នាចេះតែ[ឡ]ប្រព្រឹត្តសេចក្តីអាក្រក់
ទៀត នោះអ្នករាល់គ្នា ព្រមទាំងស្តេច[អ]នៃអ្នករាល់គ្នា នឹង
ត្រូវរោយរៀវវិនាសទៅ[ក]ទាំងអស់គ្នាវិញ គ្រានោះសូល
សោយរាជ្យបាន១ឆ្នាំហើយ ។

## លោកសាំយូអែលស្តីបន្ទោសស្តេចសូល

**១៣** ១លុះកាលសូលសោយរាជ្យលើសាសន៍អ៊ីស្រាអែល
បាន២ឆ្នាំ ២នោះទ្រង់រើសពួកមនុស្ស ក្នុងសាសន៍អ៊ីស្រា
អែល បានចំនួន៣ពាន់នាក់ ក្នុងពួកនោះ មាន២ពាន់នាក់[ក]
នៅជាមួយនឹងទ្រង់នៅត្រង់មីកម៉ាស[ខ] និងលើភ្នំបេត-អែល
ហើយ១ពាន់នាក់ទៀត នៅជាមួយនឹងយ៉ូណាថាន នៅត្រង់
គីបៀរ[គ] ក្នុងស្រុកបេនយ៉ាមីន ឯបណ្តាជនដែលសល់នៅ
នោះទ្រង់បានឱ្យគេត្រឡប់ទៅផ្ទះរៀងខ្លួនវិញ ៣គ្រានោះ
យ៉ូណាថានក៏វាយបន្ទាយ[ឃ]របស់ពួកភីលីស្ទីន ដែលនៅត្រង់
កេបា[ង] ហើយសាសន៍ភីលីស្ទីន ក៏បានឮដំណឹង នោះសូល
ទ្រង់ផ្លុំត្រែឡើង[ច] នៅពេញក្នុងស្រុកដោយថា ចូរឱ្យពួក
សាសន៍ហេព្រើរស្តាប់ចុះ ៤ដូច្នេះពួកអ៊ីស្រាអែលទាំងអស់
គ្នាក៏ឮថា សូលបានវាយបន្ទាយរបស់ពួកភីលីស្ទីនហើយ
គេក៏ដឹងថា ពួកភីលីស្ទីនស្អប់ខ្ពើម[ឆ] ដល់សាសន៍អ៊ីស្រាអែល
ដែរ នោះបណ្តាជនទាំងឡាយ គេមូលគ្នាទៅឯសូលនៅ
ត្រង់គីលកាល ។

៥ឯពួកភីលីស្ទីន គេក៏មូលគ្នាមក[ជ] ដើម្បីច្បាំងនឹងពួក
អ៊ីស្រាអែលដែរ មានទាំងរទេះចំបាំង៣ម៉ឺន ពលសេះ
៦ពាន់ ហើយនិងពលថ្មើរជើងសន្ធឹកណាស់ ដូចជាខ្សាច់[ឈ]
ដែលនៅមាត់សមុទ្រ គេនាំគ្នាឡើងមក បោះទ័ពនៅត្រង់
មីកម៉ាស[ញ] ខាងកើតបេត-អាវេន[ដ] ៦កាលពួកទ័ពខាង
អ៊ីស្រាអែលឃើញថា ខ្លួនអស់ផ្លូវហើយ ពីព្រោះបណ្តាទ័ព
មានសេចក្តីកង្វល់ជាខ្លាំង នោះក៏រត់ទៅជ្រកពួន[ឋ]ក្នុងរអាង
ក្នុងព្រៃញាតស្បាត ក្នុងកន្លៀតថ្ម និងក្នុងអណ្តូង ហើយនៅ
លើទីខ្ពស់ទាំងប៉ុន្មាន[ឌ] ៧រីឯពួកហេព្រើរខ្លះ គេក៏ឆ្លងទន្លេ
យ័រដាន់ ទៅឯស្រុកកាឌ់[ឍ] ហើយនិងស្រុកកាឡាតទៅ តែ
សូលទ្រង់នៅត្រង់គីលកាលនៅឡើយ ហើយបណ្តាទ័ពក៏
តាមទ្រង់ទាំងញាប់ញ័រ[ណ] ។

៨ទ្រង់ក៏រង់ចាំនៅ៧ថ្ងៃ[ត] តាមកំណត់ដែលសាំយូអែល
បានសន្យា តែសាំយូអែលមិនបានមកដល់គីលកាលទេ
ហើយបណ្តាជនក៏ខ្ចាត់ខ្ចាយចេញពីទ្រង់អស់ទៅ ៩ដូច្នេះ

**១២:២៣** យ ជន ១១:២ ១សយ ១:២០ ៧:៨ រម ១:៩-១០ រ ១ពវ ៨:៣៦ ទដ ២៥:៤ ៣៤:១១ ៨៦:១១ ៩៤:១២ សភ ៤:១១ **១២:២៤** ល ចទ ៦:២ សស ១២:១៣ វ ចទ ៦:៥ យស ២៤:១៤ ស យប ៣៤:២៧ អស ៥:១២ ២២:១១ ២៦:១០ ហ ចទ ១០:២១ **១២:២៥** ឡ ១សយ ៣១:១-៥ អ ចទ ២៨:៣៦ ក យស ២៤:២០ ១ពវ ១៤:១០ **១៣:២** ក ខ.១៥ ខ ខ.៥,១១,២៣ នហ ១១:៣១ អស ១០:២៨ គ ពច ១៩:១៤ **១៣:៣** ឃ ១សយ ១០:៥ ង យស ១៨:២៤ ច លវ ២៥:៩ ពច ៣:២៧ **១៣:៤** ឆ លប ៣៤:៣០ **១៣:៥** ជ ១សយ ១៧:១ ឈ យស ១១:៤ វវ ២០:៨ ញ ខ.២ ដ យស ៧:២ **១៣:៦** ឋ ១សយ ១៤:១១,២២ ឌ ពច ៦:២ អគ ៣៣:២៧ **១៣:៧** ឍ ជន ៣២:៣៣ ណ លប ៣៥:៥ នក ១៩:១៦ **១៣:៨** ត ១សយ ១០:៨

**១២:២៣** *ដោយលែងអធិស្ឋានឱ្យអ្នករាល់គ្នានោះឡើយ* សូមមើល ៧:៨ និងការពន្យល់ ។ *ខ្ញុំនឹងបង្ហាត់បង្រៀនដល់អ្នករាល់គ្នា ឱ្យបានចេះប្រព្រឹត្តតាមផ្លូវល្អ ហើយទៀងត្រង់វិញ* ហោរាសាំយូអែល មិនបានបង្ហាត់ពួកគេតាមច្បាប់ហោរារបស់ទ្រង់ នៅពេលដែលគាត់ណែនាំស្តេចថ្មីដល់បណ្តាជន ។ គាត់នៅតែបន្តការសុំអង្វរ ជំនួសបណ្តាជនទាំងនោះ (មើល ខ.១៩ ៧:៨-៩) និងបង្ហាត់គេពីកាតព្វកិច្ចនៅពេលគេតាំងសញ្ញា (សូមមើល ចទ ៦:១៨ ១២:២៨) ។ ស្តេចសូល និងស្តេចទាំងអស់នៅថ្ងៃក្រោយ គឺជាប្រធានបទមួយដែលទទួលការ បង្ហាត់តាមរយៈអ្នកកង្វាលរបស់ព្រះអម្ចាស់ ។

**១២:២៤** *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើលការពន្យល់ លប ២០:១១ ទដ ១៥:៤ ១១១:១០ សភ ១:៧ ។ ហោរាសាំយូអែលបានធ្វើការសង្ខេបពីកិច្ចការងាររបស់ពូជស្តេច នៅចំពោះព្រះអម្ចាស់ ទុកដូចជាការដឹងគុណចំពោះការដ៏ធំដែលព្រះអម្ចាស់បានធ្វើចំពោះពួកគេ ។

**១២:២៥** *អ្នករាល់គ្នា ព្រមទាំងស្តេចនៃអ្នករាល់គ្នា និងត្រូវរោយរៀវវិនាសទៅទាំងអស់គ្នាវិញ* កាលណាប្រជាជាតិទាំងអស់នៅតែមានះ បំពានសេចក្តីសញ្ញា ពួកគេទាំងអស់នឹងត្រូវវិនាសសាបសូន្យ ។

**១៣:១** *២ឆ្នាំ* ចំនួនទាំងនោះ តែងតែ ប្រាប់ពីចំនួននៃការគ្រប់គ្រងរបស់ស្តេច (សូមមើល ២សយ ២:១០ ៥:៤ ១ពវ ១៤:២១ ២ពវ ៨:២៦) ។

**១៣:២** *មីកម៉ាស* ស្ថិតនៅភាគខាងត្បូងឆៀងខាងកើត នៃតំបន់បេត-អែល ហើយនៅភាគខាងជើង ឆៀងខាងកើតតំបន់គីបៀរ (ខ.២៣) ។ *យ៉ូណាថាន* គឺជាបុត្រច្បងរបស់សូល (មើល ១៤:៤៩ ៣១:២) នៅទីនេះគឺជាលើកទីមួយហើយដែលនិយាយពីទ្រង់ ។

**១៣:៣,៧** *ពួកសាសន៍ហេព្រើរ* សូមមើលការពន្យល់ លប ១៤:១៣ ។

**១៣:៣** *គីបៀរ* មានទីតាំងប្រទល់មុខជ្រោះ និងភាគខាងត្បូងមីកម៉ាស ។

**១៣:៤** *បន្ទាយ* គឺជាការប្រៀបធៀប (មើលក្នុង ២សយ ១០:៦ ១៦:២១ លប ៣៤:៣០ នក ៥:២១) ។ *គីលកាល* សូមមើល ១១:១៤ ។ តាមរយៈការណាត់គ្នាកាលពីគ្រាមុន ស្តេចសូលត្រូវតែរង់ចាំហោរាសាំយូអែលនៅត្រង់កន្លែងនេះ (សូមមើលការពន្យល់ ខ.៨ ១០:៨) ។

**១៣:៥** *រទេះចំបាំង៣ម៉ឺន* ពួកកូនចៅអ៊ីស្រាអែលគ្មានរទេះចម្បាំងឡើយ រហូតដល់គ្រាស្តេចសាឡូម៉ូន (សូមមើល ១ពវ ៤:២៦) ។ *ពលរសេះ៦ពាន់* សូមមើលការពន្យល់ ១ពវ ២២:៣៤ ។

**១៣:៨** *តាមកំណត់ដែលសាំយូអែលបានសន្យា* មើលការពន្យល់ ១០:៨ ។ ស្តេចសូលបានដឹងថា ការបង្ហាត់របស់ហោរាសាំយូអែលកាលពីពេលមុន គឺបានសំដៅលើការជួបជុំគ្នានៅត្រង់គីលកាល ។ *បណ្តាជនក៏ខ្ចាត់ខ្ចាយចេញ* ក្រោយពីការរង់ចាំហោរាសាំយូអែលអស់រយៈពេល៧ថ្ងៃ នៅលើទីខ្ពស់បានធ្វើឱ្យទាហានអ៊ីស្រាអែលមានការភ័យខ្លាច ចំពោះខ្មាំងសត្រូវរបស់គេ ដូច្នេះហើយទើបគេនាំគ្នាខ្ចាត់ខ្ចាយពីស្តេចសូលទៅ ។

ទ្រង់មានបន្ទូលថា ចូរយកដង្វាយដុតនោះមកឯខ្ញុំ ព្រមទាំង
ដង្វាយមេត្រីផង រួចទ្រង់ក៏ថ្វាយ[ថ]ដង្វាយដុតនោះទៅ ១០តែ
កាលដុតថ្វាយរួចហើយ នោះមើល សាំយូអែល[ទ]ក៏មកដល់
ហើយសូលទ្រង់ចេញទៅទទួល ដើម្បីនឹងគោរព[ធ]ដល់
លោក ១១ប៉ុន្តែសាំយូអែលទូលសួរថា តើបានធ្វើអ្វីហ្នឹង
សូលទ្រង់ឆ្លើយថា ដោយព្រោះខ្ញុំឃើញថា បណ្តាទ័ពបាន
ខ្ចាត់ខ្ចាយចេញពីខ្ញុំទៅ ហើយលោកក៏មិនបានអញ្ជើញមក
នៅវេលាកំណត់ ហើយពួកភីលីស្ទីនបានប្រមូលគ្នាមក
នៅមីកម៉ាសផង[ន] ១២នោះបានជាខ្ញុំនឹកថា ពួកភីលីស្ទីន
នឹងចុះមកលើខ្ញុំ នៅគីលកាល[ប]ឥឡូវនេះហើយ ខ្ញុំក៏ឥត
ទាន់បានសូមអង្វរ ដល់ព្រះយេហូវ៉ាផង[ផ] ដូច្នេះខ្ញុំបានបង្ខំ
ខ្លួនឱ្យថ្វាយដង្វាយនេះទៅ ១៣សាំយូអែលឆ្លើយថា ទ្រង់បាន
ប្រព្រឹត្តនេះវរគំនិតហើយ[ព] ទ្រង់មិនបានរក្សាបញ្ញត្តិរបស់
ព្រះយេហូវ៉ា ជាព្រះនៃទ្រង់ ដែលបានបង្គាប់[ភ]មកទេ ដ្បិត
ព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ នឹងតាំងឱ្យទ្រង់សោយ
រាជ្យលើសាសន៍អ៊ីស្រាអែល ជារៀងរាបដរាបទៅ[ម] ១៤តែ
ឥឡូវនេះ រាជ្យទ្រង់[យ]មិនបាននៅតទៅទៀតទេ ដ្បិតព្រះ
យេហូវ៉ាទ្រង់រកបានមនុស្សម្នាក់ទៀត ដែលត្រូវនឹងព្រះ
ហឫទ័យទ្រង់[រ] ហើយទ្រង់បានតាំង[ល]អ្នកនោះ ឱ្យធ្វើជាអ្នក
គ្រប់គ្រង[វ] លើពួករាស្ត្រទ្រង់វិញ ពីព្រោះព្រះករុណាមិន
បានកាន់តាម[ស]សេចក្តី ដែលព្រះយេហូវ៉ាបានបង្គាប់មក

**១៣:៩** ថ ចទ ១២:៥-១៤ ២សយ ២៤:២៥ ១ពវ ៣:៤ **១៣:១០** ទ ១សយ ១៥:១៣ ធ ១សយ ២៥:១៤ **១៣:១១** ន ខ.២ **១៣:១២** ប យស ១០:៤៣ ផ ចទ ៤:២៩ ទដ ១១៩:៥៨ យរ ២៦:១៩ **១៣:១៣** ព ២រប ១៦:៩ ភ ខ.១៤ យស ២២:១៦ ១សយ ១៥:២៣,២៤ ២សយ ៧:១៥ ១រប ១០:១៣ **១៣:១៣** ម ទដ ៣២:៥ **១៣:១៤** យ ១សយ ១៥:២៨ ១៨:៨ ២៤:២០ ១រប ១០:១៤ រ កច ៧:៤៦ ១៣:២២ ល ២សយ ៦:២១ វ ១សយ ២៥:៣០ ២សយ ៥:២ ទដ ១៨:៤៣ អស ១៦:៥ ៥៥:៤ យរ ៣០:៩

សោះ ១៥រួចសាំយូអែលក៏ក្រោកឡើង ដើរចាកចេញពី
គីលកាល ទៅឯគីបៀរ[ហ] នៅស្រុកបេនយ៉ាមីនទៅ[ឡ]។

## ពួកអ៊ីស្រាអែលគ្មានអាវុធ

១៦លំដាប់នោះ សូលទ្រង់ក៏រាប់ពួកបណ្តាទ័ព ដែលនៅ
ជាមួយនឹងទ្រង់បានប្រហែលជា៦០០នាក់ រួចសូល និង
យ៉ូណាថាន ជាបុត្រាទ្រង់ ព្រមទាំងពួករាស្ត្រដែលនៅជា
មួយ ក៏នៅត្រង់កេបា[អ] ក្នុងស្រុកបេនយ៉ាមីន តែឯពួក
ភីលីស្ទីន គេបោះទ័ពនៅត្រង់មីកម៉ាស ១៧គ្រានោះមាន
ពួកទ័ពបំផ្លាញ[ក]៣ពួក ចេញពីទីបោះទ័ពរបស់ពួកភីលីស្ទីន
មក គឺ១ពួកចេញតាមផ្លូវ ដែលទៅឯអូប្រា[ខ] នៅស្រុក
ស៊ូអាល ១៨មួយទៀតចេញតាមផ្លូវបេត-ហូរ៉ុន[គ] ហើយ១
ទៀតចេញតាមផ្លូវព្រំប្រទល់ នៅមុខវាលច្រកភ្នំសេបោម[ឃ]
ខាងឯទីរហោស្ថាន ។
១៩រីឯនៅគ្រប់ក្នុងស្រុកអ៊ីស្រាអែល នោះគ្មានជាងដែក[ង]
ឡើយ ដ្បិតពួកភីលីស្ទីនបានជំនុំគ្នាថា ក្រែងពួកហេព្រើរ
ធ្វើដាវ ឬលំពែងសំរាប់ខ្លួន[ច] ២០ដូច្នេះ ពួកអ៊ីស្រាអែលទាំង
អស់គ្នា តែងចុះទៅឯពួកភីលីស្ទីន ដើម្បីនឹងសំលៀងដែក

អក ៣៤:២៣-២៤ ៣៧:២៤ ដយ ៩:២៥ ហស ៣:៥ មីក ៥:២ ស ១សយ ១៥:២៦ ១៦:១ ២សយ ១២:៩ ១ពវ ១៣:២១ ហស ១៣:១១ **១៣:១៥** ហ ១សយ ១៤:២ ឡ ខ.២ **១៣:១៦** អ យស ១៨:២៤ **១៣:១៧** ក ១សយ ១៤:១៥ ខ យស ១៨:២៣ **១៣:១៨** គ យស ១០:១០ ឃ នហ ១១:៣៤ **១៣:១៩** ង លប ៤:២២ ច ជន ២៥:៧

**១៣:៩** *រួចទ្រង់ក៏ថ្វាយដង្វាយដុត* តាមពិតដង្វាយនោះ គឺជាហោរាសាំយូអែលទេដែលបានសន្យាថា និងថ្វាយដង្វាយនោះ (មើល ១០:៨) មុនពេលដែលពួកអ៊ីស្រាអែលចូលក្នុងទីបោះទ័ព (មើល ៧:៩) ហើយហោរាសាំយូអែលក៏បានប្រាប់ស្តេចសូល ឱ្យរង់ចាំដំណើរមកដល់របស់លោក ព្រមទាំងការបង្ហាត់បង្ហាញដល់សូលទីនោះ ។

**១៣:១៣** *ទ្រង់បានប្រព្រឹត្តនេះវរគំនិតហើយ* អំពើចំកួតលីលានិងទម្រង់អំពើបាប (សូមមើល ២៦:២១ ២សយ ២៤:១០ ២រប ១៦:៩ អស ៣២:៦) នៃការប្រព្រឹត្តរបស់ស្តេចសូល គឺទ្រង់បានគិតថា ទ្រង់អាចខែងរ៉ែងពីជោគវាសនារបស់ពួកអ៊ីស្រាអែល ក្នុងការទាស់ប្រឆាំងជាមួយពួកភីលីស្ទីន ដោយមិនបានយកចិត្តទុកដាក់ ចំពោះការបង្ហាត់បង្រៀនរបស់ហោរាសាំយូអែល ដែលគាត់ជាអ្នកកង្វាលរបស់ព្រះអម្ចាស់ ។ *ទ្រង់មិនបានរក្សាបញ្ញត្តិរបស់ព្រះយេហូវ៉ា . . . ដែលបានបង្គាប់មក* ស្តេចសូលត្រូវតែទទួលស្គាល់ថា គ្រប់ទាំងអស់នៃពាក្យសម្តីដែលចេញពីមាត់ហោរាសាំយូអែល គឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ (មើល ៣:២០ ១៥:១ នក ២០:១៨-១៩ និងការពន្យល់ ៧:១-២) ។ នៅក្នុងអំឡុងពេល ដែលគាត់មិនបានស្តាប់បង្គាប់ហោរាសាំយូអែល ស្តេចសូលបានរំលោភបំពានលើគ្រឹះនៃសេចក្តីត្រូវការរបស់ទេវរាជ្យនៃទ្រង់ ។ នគររបស់ទ្រង់ (សូល) មិនបានពឹងផ្អែកលើក្រឹត្យវិន័យរបស់ទ្រង់ និងពួកហោរាឡើយ (សូមមើលការពន្យល់ ១២:១៤,២៣ ១៥:១១) ។

**១៣:១៤** *រាជ្យទ្រង់មិនបាននៅតទៅទៀតទេ* បុត្ររបស់ស្តេចសូលនឹងមិនបានគ្រងរាជ្យទៀតទេ នៅទីនេះគ្មានអ្នកបន្តរាជ្យរបស់ទ្រង់ទៀតឡើយ (ផ្ទុយជាមួយដាវីឌ ២សយ ៧:១១-១៦) ។ នៅទីនេះ មានការប្រហាក់ប្រហែលគ្នាទៅនឹងព្រះបន្ទូល ដែលព្រះអម្ចាស់បានមានបន្ទូលមកកាន់លោកអេលី (២:៣០ ៣៥ និងការពន្យល់) ។ *ដ្បិតព្រះយេហូវ៉ាទ្រង់រកបានមនុស្សម្នាក់ទៀត . . . លើពួករាស្ត្រទ្រង់វិញ* នៅក្នុងព្រះគម្ពីរសញ្ញាថ្មី លោកប៉ុលបានដកស្រង់ព្រះរាជសារត្រង់កន្លែងនេះដើម្បីពន្យល់ (កច ១៣:២២) ។ *ឱ្យធ្វើជាអ្នកគ្រប់គ្រង* សូមមើលការពន្យល់ ៩:១៦ ។

**១៣:១៦** *៦០០នាក់* ការយឺតយាវរយៈពេល៧ថ្ងៃបានធ្វើឱ្យអ្នកចម្បាំងរបស់ស្តេចសូលថយចុះ (មើល ខ.២,៤,៦-៨,១១) ។

**១៣:១៧** *ពួកទ័ពបំផ្លាញ* គោលបំណងរបស់ពួកអនិមិត្ត ភីលីស្ទីនទាំងនោះមិនមែនមានបំណងចាប់ពួកកូនចៅអ៊ីស្រាអែលដែលនៅ ក្នុងទីបោះទ័ពនោះឡើយ ប៉ុន្តែគឺដើម្បីប្លន់យកទឹកដី និងប្រព្រឹត្តអសីលធម៌ប៉ុណ្ណោះ ។

**១៣:១៨** *ច្រកភ្នំសេបោម* មានទីតាំងស្ថិតនៅភាគខាងកើត ឆ្ពោះតម្រង់ទៅជ្រលងយ័រដាន់ ។

**១៣:១៩** *គ្មានជាងដែក* ពួកសាសន៍ភីលីស្ទីនមានការផ្តាច់មុខលើផ្នែកបច្ចេកទេសផលិតផលដែក ដែលជំនួសឱ្យពួកកូនចៅអ៊ីស្រាអែល ក្នុងអំឡុងពេលដែលជួបប្រទះនូវគុណវិបត្តិដ៏ធ្ងន់ធ្ងរ គ្មានអាវុធសម្រាប់ធ្វើសង្គ្រាម ។

**១៣:២០** *សំលៀងដែក* សូមមើលការពន្យល់ អស ២:៤ ។

ផាល ចបកាប់ ពូថៅ ហើយនិងកណ្ដៀវរបស់គេរៀងខ្លួន
២១គេមានតែដែកឆាបសំរាប់សំលៀង កណ្ដៀវ ចបកាប់
និងពូថៅ ហើយសំរាប់សំរួចសមចូក និងជន្លួញប៉ុណ្ណោះទេ
២២ដូច្នេះ នៅថ្ងៃចំបាំង នោះគ្មានអ្នកណាមួយ ខាងសូល
និងយ៉ូណាថាន[ឆ] ដែលមានដាវ ឬលំពែង[ជ]កាន់នៅដៃឡើយ
ឃើញមានតែសូល ហើយនិងយ៉ូណាថាន ជាបុត្រាទ្រង់
ប៉ុណ្ណោះ ២៣ឯពួកបន្ទាយ១នៃសាសន៍ភីលីស្ទីន គេចេញទៅ
ស្កាត់ផ្លូវ ដែលកាត់[ឈ]ភ្នំត្រង់មីកម៉ាស[ញ]។

**លោកយ៉ូណាថានលើកទ័ពវាយពួកភីលីស្ទីន**

**១៤** ១ថ្ងៃ១យ៉ូណាថាន ជាបុត្រាសូល ប្រាប់ដល់មនុស្ស
កំឡោះ ដែលកាន់គ្រឿងសស្ត្រាវុធរបស់លោកថា ចូរ
យើងឆ្លងទៅឯបន្ទាយរបស់ពួកភីលីស្ទីន ដែលនៅខាង
នាយនោះ តែលោកមិនបានទូលដល់បិតាឱ្យជ្រាបទេ ២ឯ
សូលទ្រង់នៅ[ក]ត្រង់ចុងក្រុងគីបៀរ[ខ] ក្រោមដើមទទឹម[គ]ដែល
នៅមីករ៉ូន[ឃ] មានទាំងពួកទ័ពនៅជាមួយ ប្រហែលជា៦០០
នាក់ផង ៣ព្រមទាំងអ័ហ៊ីយ៉ា ជាកូនអ័ហ៊ីទូប[ង] បងអ៊ីកាបូឌ[ច]
ដែលជាកូនភីនេហាស។ ជាកូនអេលី[ឆ]ដ៏ជាសង្ឃនៃព្រះ
យេហូវ៉ា នៅត្រង់ស៊ីឡូរ[ជ] ដែលលោកពាក់អេផូឌដែរ គេ
ឥតបានដឹងជាយ៉ូណាថានទៅទេ ៤រីឯនៅកណ្ដាលច្រកភ្នំ
ដែលយ៉ូណាថានចង់ឆ្លង[ឈ] ទៅឯបន្ទាយរបស់ពួកភីលីស្ទីន
នោះមានថ្មដាស្រួចអមទាំងសងខាងផ្លូវ ១ឈ្មោះបូសេស
ហើយ១ទៀតឈ្មោះសេនេ ៥មួយនៅខាងជើងទល់មុខនឹង
មីកម៉ាស ហើយ១នៅខាងត្បូងទល់មុខនឹងកេបា[ញ]។
៦យ៉ូណាថានក៏ប្រាប់ដល់មនុស្សកំឡោះ ដែលកាន់គ្រឿង
សស្ត្រាវុធរបស់លោកថា ចូរយើងឆ្លងទៅឯបន្ទាយនៃពួក
មិនកាត់ស្បែក[ដ]នោះ ប្រហែលជាព្រះយេហូវ៉ាទ្រង់នឹងជួយ
យើងទេដឹង ដ្បិតគ្មានអ្វី[ឋ]ឃាត់ឃាំងដល់ព្រះយេហូវ៉ា ដែល
ទ្រង់នឹងជួយសង្គ្រោះ ដោយសារមនុស្សច្រើន[ឌ] ឬតិច[ឍ]

**១៣:២២** ឆ ១រប ៩:៣៩ ជ ជន ២៥:៧ ១សយ ១៤:៦ ១៧:៤៧ សក ៤:៦ ឈ ១សយ ១៤:៤ ញ ខ.២
**១៤:២** ក ពច ៤:៥ ខ ១សយ ១៣:១៥ គ នក ២៨:៣៣ ឃ អស ១០:២៨
**១៤:៣** ង ១សយ ២២:១១,២០ ច លប ៣៥:១៨ ឆ ១សយ ១:៣ ជ ទដ ៧៨:៦០
**១៤:៤** ឈ ១សយ ១៣:២៣
**១៤:៥** ញ យស ១៨:២៤
**១៤:៦** ដ ពច ១៤:៣ ១សយ ១៧:២៦,៣៦ ៣១:៤ យរ ៩:២៦ អគ ២៨:១០ ឋ ១សយ ១៣:២២ ១ពវ ១៩:១២ មថ ១៩:២៦ ហព ១១:៣៤ ឌ ពច ៧:៤ ឍ ទដ ៣៣:១៦
**១៤:១០** ណ យស ២:២៤ ត លប ២៤:១៤
**១៤:១១** ថ លប ១៤:១៣ ទ ១សយ ១៣:៦
**១៤:១២** ធ ពច ៨:១៦ ន ១សយ ១៧:៤៦ ២សយ ៥:២៤

នោះទេ ៧ឯអ្នកដែលកាន់គ្រឿងសស្ត្រាវុធរបស់លោក ក៏
ឆ្លើយថា សូមសំរេចតាមតែលោកចុះ ចង់បែរទៅខាង
ណាក៏តាមតែចិត្ត មើល ខ្ញុំនៅជាមួយនឹងលោកស្រាប់
៨ដូច្នេះយ៉ូណាថានប្រាប់ថា មើល យើងនឹងឆ្លងទៅឯមនុស្ស
ទាំងនោះ រួចសំដែងខ្លួនយើងឱ្យគេឃើញ ៩បើគេនិយាយ
នឹងយើងដូច្នេះថា ចូរចាំយើងចុះមកឯឯងសិន នោះយើង
នឹងឈរវង់នៅឥតឡើងទៅឯគេឡើយ ១០តែបើគេថា
ចូរឡើងមកឯយើងចុះ នោះយើងនឹងឡើងទៅ ដ្បិតច្បាស់
ជាព្រះយេហូវ៉ាបានប្រគល់គេ មកក្នុងកណ្ដាប់ដៃយើង
ហើយ[ណ] នេះឯងនឹងបានជាទីសំគាល់[ត]ដល់យើង ១១ដូច្នេះ
អ្នកទាំង២ក៏សំដែងខ្លួន ឱ្យពួកបន្ទាយនៃសាសន៍ភីលីស្ទីន
ឃើញ រួចគេនិយាយថា មើល ពួកហេព្រើរ[ថ] ចេញពីរូង
ដែលគេពួន[ទ]នៅនោះហើយ ១២គេក៏និយាយទៅយ៉ូណាថាន
និងអ្នកដែលកាន់គ្រឿងសស្ត្រាវុធរបស់លោកថា ចូរឡើង
មកឯយើងចុះ យើងនឹងបង្ហាញឱ្យឯងដឹង[ធ] នោះយ៉ូណាថាន
ប្រាប់ដល់អ្នកកាន់គ្រឿងសស្ត្រាវុធរបស់លោកថា ចូរឯង
ឡើងមកតាមក្រោយអញមក ដ្បិតព្រះយេហូវ៉ាទ្រង់បាន
ប្រគល់គេ មកក្នុងកណ្ដាប់ដៃ[ន]នៃអ៊ីស្រាអែលហើយ ១៣រួច
យ៉ូណាថានក៏ប្រតោងឡើង ហើយអ្នកដែលកាន់គ្រឿង
របស់លោកក៏ឡើងតាមក្រោយទៅ ឯពួកនោះក៏ដួលនៅ
មុខយ៉ូណាថាន ហើយអ្នកដែលកាន់គ្រឿងរបស់លោកក៏
សំឡាប់គេជាក្រោយ ១៤រីឯក្នុងកាលដែលយ៉ូណាថាន និង
អ្នកដែលកាន់គ្រឿងសស្ត្រាវុធរបស់លោក បានសំឡាប់គេ
ជាមុនដំបូង នោះបានស្លាប់អស់ប្រហែលជា២០នាក់ នៅ
លើដីចំនួន១ងារ ។

**ពួកអ៊ីស្រាអែលដេញតាមពួកភីលីស្ទីន**

១៥នោះក៏មានការញាប់ញ័រ[ប]កើតឡើង ក្នុងទីបោះទ័ព

**១៤:១៥** ប លប ៣៥:៥ នក ១៤:២៤ ១៩:១៦ ២ពវ ៧:៥–៧

**១៣:២២** *គ្មានអ្នកណាមួយ . . . មានដាវ ឬលំពែងកាន់នៅដៃឡើយ* អាវុធរបស់ពួកអ៊ីស្រាអែល គឺធ្នូ ព្រួញ ហើយនិងដង្ហក់ ។

**១៤:១** *នៅខាងនាយ* ពួកភីលីស្ទីនបានតាំងបន្ទាយនៅភាគខាងជើង ហើយអ៊ីស្រាអែលនៅខាងត្បូង ។

**១៤:២** *ក្រុងគីបៀរ* ស្ដេចសូលបានវាយម្តងទៀត ចាប់តាំងពីកេបា (១៣:៣) រហូតដល់គីបៀរ ។ *ក្រោមដើមទទឹម* បង្ហាញពីទម្លាប់របស់ពួកអ្នកដឹកនាំអ៊ីស្រាអែលជំនាន់មុន គេតែងតែប្រជុំគ្នានៅក្រោមដើមឈើដែលល្បី (មើល ចទ ២២:៦ ពច ៤:៥) ។

**១៤:៣** *អ័ហ៊ីយ៉ា* ជាបង និងជាជំនាន់មុនរបស់អ័ហ៊ីម៉ាលេក ជាកូនអ័ហ៊ីទូប (២១:១ ២២:៩,១១) ឬជាឈ្មោះមួយទៀតរបស់អ័ហ៊ីម៉ាលេក ។ *ពាក់អេផូឌ* សូមមើលការពន្យល់ ២:២៨ ។ *បងអ៊ីកាបូឌ* សូមមើល ៤:២១ ។

**១៤:៦** *ពួកមិនកាត់ស្បែកនោះ* គឺជាពាក្យពេចន៍នៃការមើលងាយ (សូមមើល ១៧:២៦,៣៦ ៣១:៤ ២សយ ១:២០ ពច ១៤:៣ ១៥:១៨) ដែលការកាត់ស្បែកនេះ ចង្អុលបង្ហាញពីទំនាក់ទំនងសេចក្ដីសញ្ញារបស់ពួកកូនចៅអ៊ីស្រាអែលចំពោះព្រះអម្ចាស់ (មើល លប ១៧:១០ និងការពន្យល់) ។ *ដោយសារមនុស្សច្រើនឬតិច* មើលការពន្យល់ ១៧:៤៧ ។ សេចក្ដីក្លាហានរបស់លោកយ៉ូណាថានធ្វើដោយសេចក្ដីជំនឿ (ធៀបនឹង ហព ១១:៣២–៣៤) ដែលយើងឃើញមាននៅក្នុងសេចក្ដីសន្យារបស់ព្រះអម្ចាស់ (មើល ៩:១៦) ។

**១៤:១០** *ជាទីសំគាល់ដល់យើង* សូមមើល ពច ៦:៣៦–៤០ អស ៧:១១ ។

**១៤:១១** *ពួកហេព្រើរ* សូមមើល ខ.២១ ៤:៦ ១៣:៣,៧ និងការពន្យល់ លប ១៤:១៣ ។

ដែលនៅវាលនឹងនៅក្នុងពួកបណ្ដាទ័ពទាំងប៉ុន្មាន ឯពួកអ្នក
នៅក្នុងបន្ទាយ និងពួកទ័ពបំផ្លាញ[ផ] គេក៏ញ័ររន្ធត់ដែរ
ហើយផែនដីក៏កក្រើកឡើង ដូច្នេះ គេមានសេចក្ដីញ័ររន្ធត់
ជាខ្លាំងក្រៃលែង ។
16 ឯពួកយាមល្បាតខាងសូល ដែលនៅក្រុងគីបៀរ ក្នុង
ស្រុកបេនយ៉ាមីន គេក៏មើលទៅ[ព]ឃើញបណ្ដាពលបែក
ខ្ញែកពីគ្នាខ្ចាត់ខ្ចាយ ខ្លះទៅខាងនេះ ខ្លះទៅខាងនោះ
17 ដូច្នេះ សូលមានបន្ទូលទៅពួកអ្នក ដែលនៅជាមួយថា
ចូររាប់មើល តើអ្នកណាដែលបានចេញពីយើងទៅនោះ
កាលគេបានរាប់ទៅ នោះឃើញបាត់យ៉ូណាថាន និង
អ្នកដែលកាន់គ្រឿងរបស់លោកផង 18 នោះសូលទ្រង់
មានបន្ទូលទៅអ័ហ៊ីយ៉ាថា ចូរយក[ភ]ហឹប[ម]នៃព្រះមកឯណេះ
(ដ្បិតនៅវេលានោះ ហឹបនៃព្រះបាននៅជាមួយនឹងពួកទ័ព
អ៊ីស្រាអែល) 19 កាលសូលកំពុងតែមានបន្ទូលនឹងសង្ឃ
នៅឡើយ នោះសូរអឺងកងដែលឮពីទីបោះទ័ពរបស់ពួក
ភីលីស្ទីនក៏កាន់តែខ្លាំងឡើង ដូច្នេះ សូលប្រាប់ដល់សង្ឃ[យ]
ថា ចូរដកដៃមកវិញ 20 រួចទ្រង់នឹងពួកអ្នកដែលនៅជា
មួយទាំងប៉ុន្មានក៏មូលគ្នាទៅឯទីចំបាំង ហើយឃើញមាន
ការច្របូកច្របល់យ៉ាងសំបើម ដោយកំពុងតែកាប់ចាក់[រ]គ្នា
គេ 21 រីឯពួកហេព្រើរដែលនៅជាមួយនឹងពួកភីលីស្ទីន
ហើយបានឡើងមកក្នុងទ័ពជាមួយនឹងគេ នោះក៏បែរមក[ល]
ខាងពួកអ៊ីស្រាអែល ដែលនៅជាមួយនឹងសូល ហើយនិង
យ៉ូណាថានវិញ 22 កាលពួកអ៊ីស្រាអែលទាំងប៉ុន្មាន ដែល
ពួននៅ[វ] ស្រុកភ្នំអេប្រាអិមបានឮថា ពួកភីលីស្ទីនរត់ដូច្នោះ
នោះគេក៏ដេញតាមច្បាំងយ៉ាងប្រកិតដែរ 23 ដូច្នេះ ព្រះ
យេហូវ៉ា ទ្រង់បានជួយសង្គ្រោះ[ស]ពួកអ៊ីស្រាអែល នៅថ្ងៃ
នោះឯង ហើយចំបាំងច្បាំងគ្នានោះក៏ឆ្លងទៅ រហូតដល់
បេត-អាវេនវិញ[ហ] ។

## លោកយ៉ូណាថានបរិភោគទឹកឃ្មុំ

24 នៅថ្ងៃនោះ ពួកអ៊ីស្រាអែលមានសេចក្ដីវេទនា
ណាស់ ដ្បិតសូលទ្រង់បានឱ្យគេស្បថ[ឡ]ថា អ្នកណាដែល
បរិភោគអ្វីមុនពេលល្ងាច គឺដល់កាលណាអញបានសង
សឹកនឹងខ្មាំងសត្រូវហើយ នោះនឹងត្រូវបណ្ដាសា ហេតុនោះ
បានជាក្នុងពួកគេ គ្មានអ្នកណាមួយហ៊ានបរិភោគអ្វីឡើយ
25 គេក៏បានដល់ទៅក្នុងព្រៃ នោះឃើញមានសំណុំទឹកឃ្មុំ
នៅលើដី 26 ដ្បិតកាលគេចូលទៅ នោះឃើញសំណុំទឹកឃ្មុំ
ធ្លាក់ចុះមក តែគ្មានអ្នកណាហ៊ានលូកដៃចាប់ដាក់ដល់មាត់

**១៤:១៥** ផ ១សយ ១៣:១៧
**១៤:១៦** ព ២សយ ១៨:២៤ ២ពវ ៩:១៧ អស ៥២:៨ អគ ៣៣:២
**១៤:១៨** ភ ១សយ ៣០:៧ ម ពច ១៨:៥
**១៤:១៩** យ ជន ២៧:២១
**១៤:២០** រ ពច ៧:២២ អគ ៣៨:២១ សក ១៤:១៣
**១៤:២១** ល ១សយ ២៩:៤
**១៤:២២** វ ១សយ ១៣:៦
**១៤:២៣** ស នក ១៤:៣០ ហ យស ៧:២
**១៤:២៤** ឡ យស ៦:២៦

**១៤:១៥** *ដីក៏កក្រើកឡើង* សូមមើល ៧:១០ ២សយ ២២:១២-១៦ យស ១០:១១-១៤ ទដ ៧៧:១៨ សម្រាប់ការអស្ចារ្យរបស់ព្រះអម្ចាស់ពេលក្រោយៗទៀតក្នុងពេលដែលព្រះអង្គរំដោះពួកកូនចៅអ៊ីស្រាអែល ។

**១៤:១៨** *ចូរយកហឹបនៃព្រះមកឯណេះ* ស្ដេចសូលស្វែងរកបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ មុនពេលចូលទៅក្នុងទីបោះទ័ពរបស់ពួកភីលីស្ទីន (សូមមើល ជន ២៧:២១ ចទ ២០:២-៤) ។ នៅទីនេះសិបធូជីន (ការបកប្រែគម្ពីរសញ្ញាចាស់របស់ជនជាតិក្រិកមុនជំនាន់គ្រីស្ទបរិស័ទ) ប្រហែលជាបានរក្សាទុកនូវអត្ថបទដើម នូវមូលហេតុដូចតទៅ: (១).នៅក្នុង ៧:១ ហឹបសញ្ញានៃព្រះស្ថិតក្នុងការយ៉ាត់-យារីម ដែលជាស្រុក១របស់ពួកភីលីស្ទីន ហើយគេបានដាក់ហឹបសញ្ញានៅទីនេះ រហូតដល់គ្រាស្ដេចដាវីឌនាំមកក្រុងយេរូសាឡិម (២សយ ៦) ប៉ុន្តែអេផូឌត្រូវបានតម្កល់ទុកនៅក្នុងជំរុំរបស់ស្ដេចសូលនៅឯក្រុងគីបៀរ (មើល ខ.៣) ។ (២).គ្មានកន្លែងណាទៀតនៅក្នុងព្រះគម្ពីរសញ្ញាចាស់បាននិយាយថា ហឹបសញ្ញានៃព្រះធ្លាប់ប្រើជាការកំណត់ពីបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ឡើយ ប៉ុន្តែអេផូឌ (ជាមួយយូរីមនិងធូមីម) ត្រូវបានប្រើដើម្បីទាយពីបំណងព្រះទ័យនៃព្រះវិញ (សូមមើលការពន្យល់ ២៣:៩ ៣០:៧ ២:១៨,២៨) ។ សេចក្ដីបញ្ជាចំពោះសង្ឃ គឺឱ្យដកដៃគាត់ចេញ (មើល ខ.១៩) ។

**១៤:១៩** *ចូរដកដៃមកវិញ* បញ្ឈប់កិច្ចការងារជាសង្ឃ ។ កិច្ចការងារបន្ទាន់ដែលត្រូវធ្វើ ស្ដេចសូលបានសម្រេចចិត្តថា ត្រូវរង់ចាំព្រះបន្ទូលរបស់ព្រះដែលអាចធ្វើឱ្យកងទ័ពរបស់ទ្រង់មហន្តរាយ ។

**១៤:២៣** *ដូច្នេះព្រះយេហូវ៉ាទ្រង់បានសង្គ្រោះពួកអ៊ីស្រាអែល* អ្នកនិពន្ធបានសន្មត់ពីជ័យជម្នះរបស់ព្រះ មិនមែនជាជ័យជម្នះរបស់ស្ដេចសូល ឬលោកយ៉ូណាថានឡើយ (សូមមើល ខ.៦,១០,១២,១៥ ១១:១៣) ។

**១៤:២៤-៤៦** តាមរយៈជ័យជម្នះដ៏ធំ ដែលព្រះអម្ចាស់ទ្រង់បានផ្ដល់ឱ្យអ្នកនិពន្ធបាននិទានពីសកម្មភាពរបស់ស្ដេចសូល ដោយបានលើកយកពីកង្វះសមត្ថភាពធ្វើជាស្ដេច ។ សេចក្ដីចំកួតរបស់គាត់ គឺបានកើតឡើងមុនពេលដែលចូលទៅក្នុងទីចម្បាំង (មើល ខ.២៤ និងការពន្យល់) ដោយគាត់បាននាំ "ការឈឺចាប់" ឱ្យពួកទាហានដូចអ្វីដែលលោកយ៉ូណាថានបាននិយាយថា "នាំឱ្យស្រុកយើងមានវេទនាហើយ" (មើល ខ.២៩) ទំនងជានាំឱ្យគេមានជ័យជម្នះ (ធៀបនឹង យស ៧:២៥ ១ពវ ១៨:១៧-១៨) ។ នៅក្នុងសម័យក្រោយមកទៀតពេលដែលទទួលការរារាំងមិនឱ្យយកផលប្រយោជន៍នៃសង្គ្រាម ដោយព្រះអម្ចាស់ទ្រង់បានបដិសេធមិនឆ្លើយតបចំពោះគេ (ខ.៣៧) ស្ដេចសូលបាន ចោទប្រកាន់ចំពោះលោកយ៉ូណាថានថា ជាដើមចមនៃបញ្ហាទោះបីជាលោកយ៉ូណាថាន ជាមនុស្សដែលអ្នកដទៃគិតថា គាត់ជាអ្នកដែលធ្វើឱ្យពួកគេមានជ័យជម្នះក៏ដោយ (ខ.៤៥) ។

**១៤:២៤** *បណ្ដាសា* បម្រាមរបស់ស្ដេចសូល "ហាមពួកទាហានដោយពាក្យសម្បថ" (ខ.២៨) ទាំងនោះ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរហើយគ្រោះថ្នាក់មួយពីព្រោះពាក្យសម្បថ គឺជាប់ទាក់ទងជាមួយព្រះអម្ចាស់ រួមទាំងទីបន្ទាល់ផងដែរ (មើល នក ២០:៧ លវ ១៩:១២) ដើម្បីធ្វើការប្ដេជ្ញាចិត្ត (មើល លប ២១:២៣-២៤ ២៤:៣-៤) ឬជាសកម្មភាពនៃការហាមឃាត់ ។ *អញបានសងសឹកនឹងខ្មាំងសត្រូវហើយ* ភាគច្រើននៃជម្លោះរបស់ស្ដេចសូលជាមួយពួកភីលីស្ទីន គឺជារឿងផ្ទាល់ខ្លួន (មើលការពន្យល់ ១៥:១២) ជាងការដែលច្បាំងសម្រាប់កិត្តិយសរបស់ព្រះអម្ចាស់ និងដើម្បីសុវត្ថិភាពសម្រាប់រាស្ត្រទ្រង់ ។

ឡើយ ពីព្រោះគេខ្លាចពាក្យសំបថនោះ ២៧តែយ៉ូណាថាន
ឥតបានឮ ក្នុងកាលបិតាបង្គាប់គេ ដោយពាក្យសំបថទេ
បានជាលោកលូកចុងដំបងដែលកាន់នៅដៃទៅចាក់សំណុំ
ឃ្មុំ[អ] យកមកបរិភោគទៅ ស្រាប់តែភ្នែកលោកក៏ស្វាងឡើង
២៨នោះមានម្នាក់ជំរាបថា បិតាលោកបានហាមយើងខ្ញុំ
ដោយពាក្យសំបថថា អ្នកណាដែលបរិភោគអ្វីនៅថ្ងៃនេះ
នោះនឹងត្រូវបណ្តាសា រីឯពួកបណ្តាទ័ពទាំងប៉ុន្មានគេ
ហេវខ្លាំងណាស់ ២៩ដូច្នេះ យ៉ូណាថានមានវាចាថា បិតា
អញបាននាំឱ្យស្រុកយើងមានវេទនា[ក] ហើយ មើល អញបាន
ស្វាងភ្នែកឡើងដោយសារតែភ្លក់ទឹកឃ្មុំបន្តិចនេះ ៣០ចុះ
ចំណង់បើពួកទ័ពបានបរិភោគរបឹបរបស់ពួកខ្មាំងសត្រូវ
តាមចិត្តនៅថ្ងៃនេះ នោះតើនឹងវិសេសជាជាងអំបាលម៉ាន
ទៅទៀត យ៉ាងនោះនឹងបានប្រហារជីវិតពួកភីលីស្ទីន រឹត
តែច្រើនលើសទៅទៀត ។
៣១នៅថ្ងៃនោះឯង គេក៏វាយពួកភីលីស្ទីន ចាប់តាំងពី
មីកម៉ាស[ខ] រហូតដល់អាយ៉ាឡូន[គ] ហើយពួកបណ្តាទ័ពគេ
ល្វើយខ្លាំងណាស់ ៣២ដូច្នោះគេក៏ស្ទុះទៅលើរបឹប[ឃ] ចាប់
យកចៀម គោ និងកូនគោ ទៅសំឡាប់នៅលើដី ហើយ
បរិភោគសាច់ទាំងជាប់មានឈាមផង[ង] ៣៣ខណនោះមាន
គេទូលដល់សូលថា មើល ឥឡូវពួកទ័ពគេធ្វើបាបនឹង
ព្រះយេហូវ៉ាហើយ ដោយបរិភោគសាច់ដែលជាប់ទាំង
ឈាម[ច]ផង នោះទ្រង់មានបន្ទូលថា ឯងរាល់គ្នាបានប្រព្រឹត្ត
ល្មើសហើយ ដូច្នេះចូរប្រមៀលថ្ម១យ៉ាងធំមកឯអញឥឡូវ
៣៤រួចទ្រង់បង្គាប់ថា ចូរទៅក្នុងពួកទ័ពប្រាប់គេឱ្យដឹកនាំ
យកគោនិងចៀមមកឯអញ ដើម្បីនឹងសំឡាប់បរិភោគនៅ
ទីនេះវិញ កុំឱ្យធ្វើបាបនឹងព្រះយេហូវ៉ា ដោយបរិភោគ
សាច់ដែលជាប់ទាំងឈាម[ឆ]ដូច្នេះឡើយ ដូច្នេះនៅយប់
នោះគ្រប់គ្នាក៏ដឹកនាំគោរបស់ខ្លួនទៅសំឡាប់នៅទីនោះ

**១៤:២៧** អ ខ.៤៣ ទដ ១៩:១០ សភ ១៦:២៤ ២៤:១៣
**១៤:២៩** ក យស ៧:២៥ ១ពវ ១៨:១៨
**១៤:៣១** ខ ខ.៥ គ យស ១០:១២
**១៤:៣២** ឃ ១សយ ១៥:១៩ នរ ៩:១០ ង លប ៩:៤
**១៤:៣៣** ច លប ៩:៤
**១៤:៣៤** ឆ លវ ១៩:២៦
**១៤:៣៥** ជ ១សយ ៧:១៧
**១៤:៣៦** ឈ លប ២៥:២២ ពច ១៨:៥
**១៤:៣៧** ញ ១សយ ២៨:៦,១៥ ២សយ ២២:៤២ ទដ ១៨:៤១
**១៤:៣៨** ដ យស ៧:១១
**១៤:៣៩** ឋ ជន ១៤:២១ ២សយ ១២:៥ យប ១៩:២៥ ទដ ១៨:៤៦ ៤២:២ ឌ ខ.៤៤ ឍ យស ៧:១៥
**១៤:៤១** ណ កច ១:២៤ ត សភ ១៦:៣៣
**១៤:៤២** ថ យហ ១:៧

៣៥ឯសូលទ្រង់ក៏ស្អាងអាសនា[ជ]១ថ្វាយព្រះយេហូវ៉ា នោះ
ឯងជាអាសនាមុនដំបូង ដែលទ្រង់បានស្អាងថ្វាយព្រះ
យេហូវ៉ា ។
៣៦លំដាប់នោះសូលទ្រង់មានបន្ទូលថា ចូរយើងចុះ
ទៅទាំងយប់តាមពួកភីលីស្ទីន ដើម្បីនឹងវាយគេរហូតដល់
ភ្លឺ កុំឱ្យយើងទុកគេឱ្យសល់ដល់ម្នាក់ឡើយ គេទទូលថា សូម
ទ្រង់សំរេច តាមដែលយល់ថាស្រួលចុះ នោះសង្ឃមាន
វាចាថា ចូរយើងរាល់គ្នាមូលមកឯ[ឈ]ព្រះនៅទីនេះសិន
៣៧សូលទ្រង់ក៏ទូលសួរដល់ព្រះថា តើត្រូវឱ្យទូលបង្គំចុះទៅ
តាមពួកភីលីស្ទីនឬអី តើទ្រង់នឹងប្រគល់គេមកក្នុងកណ្តាប់
ដៃពួកអ៊ីស្រាអែលឬទេ តែនៅថ្ងៃនោះព្រះទ្រង់មិនបាន
ឆ្លើយតប[ញ]មកសោះ ៣៨ដូច្នេះ សូលទ្រង់ប្រាប់ថា ចូរមក
ឯណេះ ពួកអ្នកដែលជាមេលើរាស្ត្រអើយ ដើម្បីនឹង
ពិចារណាមើល ឱ្យដឹងជាកើតមានបាប[ដ]យ៉ាងណានៅថ្ងៃ
នេះ ៣៩ដ្បិតយើងស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្ម
រស់[ឋ] ដែលទ្រង់បានជួយសង្គ្រោះពួកអ៊ីស្រាអែលថា ទោះ
បើបាបនោះ នៅលើរូបយ៉ូណាថាន[ឌ] ជាកូនយើងក៏ដោយ
គង់តែវានឹងត្រូវស្លាប់ទៅជាប្រាកដ[ឍ] ក្នុងពួកពលទ័ពគ្មាន
អ្នកណា១ឆ្លើយឡើងសោះ ៤០រួចទ្រង់មានបន្ទូលទៅពួក
អ៊ីស្រាអែលថា ចូរឯងរាល់គ្នានៅជាម្ខាង ហើយយើងនិង
យ៉ូណាថាន ជាកូនយើង នឹងនៅជាម្ខាង ពួកពលទ័ពទូល
ឆ្លើយថា សូមទ្រង់សំរេចតាមព្រះទ័យចុះ ៤១ដូច្នោះសូល
ក៏ទូលដល់ព្រះយេហូវ៉ាថា ឱព្រះនៃសាសន៍អ៊ីស្រាអែល
អើយ សូមឱ្យ[ណ]យើងខ្ញុំដឹងការខុសត្រូវ[ត]នេះ នោះគេចាប់
ឆ្នោតត្រូវលើរូបយ៉ូណាថាន ហើយនិងសូល តែឯពួក
បណ្តាទ័ពគេរួចខ្លួនវិញ ៤២រួចសូលទ្រង់ប្រាប់ថា ដូច្នេះ
ចូរចាប់ឆ្នោត[ថ]ឱ្យយើង ហើយនិងយ៉ូណាថាន ជាកូនយើង
ទៀត នោះឆ្នោតក៏ត្រូវលើរូបយ៉ូណាថាន ។

**១៤:៣១** *អាយ៉ាឡូន* មានទីតាំងស្ថិតនៅភាគខាងលិច ក្បែរព្រំប្រទល់ពួកភីលីស្ទីន (មើល យស ១០:១២) ។

**១៤:៣៣** *បរិភោគសាច់ដែលជាប់ទាំងឈាម* ពួកកូនចៅអ៊ីស្រាអែលមិនបានអនុញ្ញាតិឱ្យបរិភោគសាច់ដែលជាប់ឈាមនោះឡើយ (មើល លប ៩:៤ លវ ១៧:១០-១១ ១៩:២៦ ចទ ១២:១៦,២៤ អគ ៣៣:២៥ កច ១៥:២០) ។ *ប្រព្រឹត្តល្មើស* សូមមើល មឡ ២:១០-១១ ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរ គេបានបកប្រែថា "ក្បត់" (ទដ ៧៨:៥៧) "កំផិត" (យរ ៣:៧-៨,១០-១១) ហើយនិង "ចិត្តក្បត់" (អស ៤៨:៨) ។

**១៤:៣៥** *នោះឯងជាអាសនាមុនដំបូង ដែលទ្រង់បានស្អាងថ្វាយព្រះយេហូវ៉ា* នៅកន្លែងផ្សេងទៀត គឺនិយាយពីកង្វះចំណាប់អារម្មណ៍ផ្ទាល់ខ្លួន (មើលការពន្យល់ ៩:៣,៦ ១០:១១) ។

**១៤:៣៦** *សង្ឃ* គឺលោកអ័ហ៊ីយ៉ា (មើល ខ.៣) ។

**១៤:៣៧** *សូលទ្រង់ក៏ទូលសួរដល់ព្រះ* ការដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះ គឺត្រូវប្រើអេផូឌដែលមានយូរីម និងធូមីម (មើល ខ.៣ និងការពន្យល់ ខ.១៨) ។ *ព្រះទ្រង់មិនបានឆ្លើយតបមកសោះ* ការដែលព្រះទ្រង់មិនឆ្លើយតបចំពោះសំណួររបស់ស្តេចសូល ពីព្រោះការស្បថនៅក្នុងទីបោះទ័ព គឺជាការរំលោភបំពាន ។

**១៤:៣៩,៤៥** *ព្រះយេហូវ៉ាដ៏មានព្រះជន្មរស់* ពាក្យនេះគឺជាទម្រង់នៃពាក្យសម្បថ (មើលការពន្យល់ ខ.២៤ ១៩:៦ លប ៤២:១៥ ហស ៤:១៥ និងការពន្យល់) ។

**១៤:៤១** *ចាប់ឆ្នោត* សូមមើល ១០:២០-២១ យស ៧:១៤-១៨ សភ ១៦:៣៣ ។

៤៣លំដាប់នោះ សូលមានបន្ទូលទៅយ៉ូណាថានថា
ចូរប្រាប់ដល់អញ តើឯងបានធ្វើអ្វី[ទ] យ៉ូណាថានទូលថា
ទូលបង្គំបានគ្រាន់តែភ្លក់ទឹកឃ្មុំ[ធ]បន្តិច ដោយចុងដំបងដែល
ទូលបង្គំកាន់នៅដៃប៉ុណ្ណោះ មើល ទូលបង្គំត្រូវស្លាប់ដែរ
ហ្ន៎ ៤៤សូលមានបន្ទូលថា ឱយ៉ូណាថានអើយ បើឯងមិន
ត្រូវស្លាប់ជាពិតប្រាកដ នោះសូមឱ្យព្រះទ្រង់ធ្វើដល់អញ
ដូច្នោះ[ន] ហើយលើសទៅទៀតផង[ប] ៤៥តែពួកបណ្ដាទ័ព
ទូលសួរដល់សូលថា ឯយ៉ូណាថានដែលបាននាំឱ្យមាន
សេចក្ដីសង្គ្រោះក្នុងពួកអ៊ីស្រាអែលយ៉ាងធំដល់ម្ល៉េះ តើ
លោកត្រូវស្លាប់ឬអី មិនត្រូវឱ្យបានដូច្នោះឡើយ យើងខ្ញុំ
ស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់ថា មិនត្រូវឱ្យ
មានសក់[ផ]១សរសៃជ្រុះពីក្បាលរបស់លោកផង ដ្បិតការ
ដែលលោកបានធ្វើនៅថ្ងៃនេះ នោះគឺបានធ្វើជាមួយនឹង
ព្រះទេតើ ដូច្នេះ ពួកបណ្ដាទ័ពបានជួយដោះ[ព]យ៉ូណាថាន
មិនឱ្យស្លាប់ឡើយ ៤៦នោះសូលទ្រង់ក៏លែងដេញតាមពួក
ភីលីស្ទីន ហើយពួកភីលីស្ទីន គេវិលទៅឯកន្លែងគេរៀង
ខ្លួនទៅ ។

៤៧រីឯកាលក្រោយ ដែលសូលបានទទួលគ្រងរាជ្យ
លើសាសន៍អ៊ីស្រាអែល នោះទ្រង់ក៏ច្បាំងនឹងខ្មាំងសត្រូវ
នៅគ្រប់ទីកន្លែងជុំវិញ គឺច្បាំងនឹងសាសន៍ម៉ូអាប់[ភ] និងពួក
កូនចៅអាំម៉ូន[ម] និងសាសន៍អេដំម[យ] និងស្ដេចទាំងប៉ុន្មាននៃ
ស្រុកសូបា[រ] ហើយនិងពួកភីលីស្ទីនផង ឯទិសទីណាដែល
ទ្រង់បែរទៅ នោះក៏ចេះតែបានឈ្នះជាដរាប ៤៨ទ្រង់ក៏
ប្រព្រឹត្តដោយក្លាហាន បានទាំងវាយពួកអាម៉ាលេក[ល]
ហើយជួយដោះពួកអ៊ីស្រាអែល ឱ្យរួចពីកណ្ដាប់ដៃនៃពួក
អ្នកទាំងប៉ុន្មានដែលបំផ្លាញគេ ។

## គ្រួសាររបស់ស្ដេចសូល

៤៩រីឯបុត្រារបស់សូល នោះគឺយ៉ូណាថាន១ យីសវី១
និងម៉ាលគី-ស៊ូអា១[វ] ឯបុត្រីទាំង២អង្គ នោះគឺនាងបងព្រះ
នាមជាម្រ៉ាប ហើយប្អូនព្រះនាមជាមីកាល[ស] ៥០ឯជាយា
របស់ទ្រង់ព្រះនាមជាអ័ហ៊ីណោម ជាកូនអ័ហ៊ីម៉ាស ហើយ
មេទ័ពរបស់ទ្រង់ឈ្មោះអ័ប៊ីនើរ[ហ] ជាកូននើរដែលជាមា
របស់សូល[ឡ] ៥១ដ្បិតគីស[អ] ដែលជាបិតារបស់សូល ហើយ
នើរដែលជាឪពុកអ័ប៊ីនើរ នោះទាំង២នាក់ជាកូនអ័បៀល។

៥២នៅអស់១ជីវិតរបស់សូល នោះចេះតែមានចំបាំង
ច្បាំងនឹងពួកភីលីស្ទីនជាខ្លាំង ហើយកាលណាសូលទ្រង់
ឃើញមនុស្សណាខ្លាំងពូកែ ឬក្លាហាន នោះទ្រង់ក៏យក[ក]
អ្នកនោះមកក្នុងពលទ័ពរបស់ទ្រង់ ។

## ព្រះអម្ចាស់បដិសេធស្ដេចសូល

**១៥** ១គ្រានោះ សាំយូអែលទូលទៅសូលថា ព្រះ
យេហូវ៉ាទ្រង់បានចាត់ទូលបង្គំមក ឱ្យចាក់ប្រេងតាំង[ក]ទ្រង់
ឡើងជាស្ដេចលើអ៊ីស្រាអែល ជារាស្ត្រទ្រង់ ដូច្នេះ សូម
ទ្រង់ស្ដាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ាឥឡូវនេះចុះ ២ព្រះ
យេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលដូច្នេះថា អញ
នឹកចាំពីការ ដែលពួកអាម៉ាលេក[ខ] ធ្វើដល់ពួកអ៊ីស្រាអែល
ហើយ គឺពីការដែលគេបានឈររាំងផ្លូវ ក្នុងកាលដែល

**១៤:៤៣** ទ យស ៧:១៩ ធ ខ.២៧
**១៤:៤៤** ន ខ.៣៩ ប នរ ១:១៧
**១៤:៤៥** ផ ១ពវ ១:៥២ មថ ១០:៣០ ព ២សយ ១៤:១១
**១៤:៤៧** ភ លប ១៩:៣៧ ម លប ១៩:៣៨ ២សយ ១២:៣១ យ ១សយ ២១:៧ រ ២សយ ៨:៣ ១០:៦ ២៣:៣៦
**១៤:៤៨** ល លប ៣៦:១២ ជន ១៣:២៩ ពច ៣:១៣ ១សយ ១៥:២,៧ ២៧:៨ ២៨:១៨ ៣០:១៣ ២សយ ១:១៣ ១រប ៤:៤៣
**១៤:៤៩** វ ១សយ ៣១:២ ១រប ៨:៣៣ ស លប ២៩:២៦
**១៤:៥០** ហ ២សយ ២:៨ ៣:៦ ១ពវ ២:៥ ឡ ១សយ ១០:១៤
**១៤:៥១** អ ១សយ ៩:១
**១៤:៥២** ក ១សយ ៨:១១

**១៥:១** ក ១សយ ៩:១៦ **១៥:២** ខ លប ១៤:៧ ១សយ ១៤:៤៨ ២សយ ១:៨

**១៤:៤៤** គឺជាទម្រង់នៃបណ្ដាសា (មើល ខ.២៤ ៣:១៧ និងការពន្យល់) ។

**១៤:៤៥** *ដ្បិតការដែលលោកធ្វើនៅថ្ងៃនេះ នោះគឺបានធ្វើជាមួយនឹងព្រះ* ពួកទ័ពរបស់ស្ដេចសូលបានទទួលស្គាល់ថា ព្រះទ្រង់ជាអ្នកប្រទានឱ្យអ្នកណាម្នាក់មានជីវិតរស់នៅ ។

**១៤:៤៧-៤៨** គឺសេចក្ដីសង្ខេប ពីជ័យជម្នះរបស់ពួកទាហានរបស់ស្ដេចសូល លើពួកអ្នកនៅខាងកើត (សាសន៍ម៉ូអាប់ និងពួកអាំម៉ូន) ខាងត្បូង (សាសន៍អេដំម) ខាងជើង (ពួកសូបា) និងពួកខាងលិច (ពួកភីលីស្ទីន) ។

**១៤:៤៧** *អាំម៉ូន* សូមមើល ចទ ២:១៩-២១,៣៧ ។

**១៤:៤៨** *ពួកអាម៉ាលេក* សូមមើលការពន្យល់ ១៥:២ ។

**១៤:៤៩** *បុត្រារបស់សូល* សូមមើល ៣១:២ ១រប ៩:៣៩ និងការពន្យល់ ។ *ជាម្រ៉ាប . . . ជាមីកាល* សូមមើល ១៨:១៧,២០ ១៩:១១-១៧ ២៥:៤៤ ២សយ ៦:១៦-២៣ ។

**១៤:៥០** *អ័ហ៊ីណោម* នាងជាភរិយារបស់ស្ដេចសូល ។ ស្រីស្នំរបស់ស្ដេចសូលឈ្មោះរីប៉ាមាននិយាយនៅក្នុង ២សយ ៣:៧ ២១:៨-១១ ។

**១៤:៥២** *នៅអស់១ជីវិតរបស់សូល* រួមទាំសាច់ញាតជិតស្និទ្ធដែលនៅជិតនាន់ស្ដេចសូល ។ *ទ្រង់ក៏យកអ្នកនោះមកក្នុងពលទ័ពរបស់ទ្រង់* ស្ដេចសូលបានបង្ខំកពលទ័ពយ៉ាងពិសេសដើម្បីខ្លួនទ្រង់ ហើយស្ដេចដាវីឌក៏ប្រព្រឹត្តដូចគ្នានេះដែរ (២២:២ ២៣:១៣ ២៥:១៣ ២៧:២-៣ ២៩:២ ៣០:១,៩-១០ ២សយ ២:៣ ៥:៦ ៨:១៨ ១៥:១៨ ២៣:៨-៣៩) ។

**១៥:១-៣៥** នៅក្នុងផ្នែកនេះ គឺនិយាយពីការបដិសេធចំពោះស្ដេចសូល ។ ទោះបីជាមិនដឹងពីពេលវេលាដ៏ជាក់លាក់ក៏ដោយ ក៏មានតម្រុយឱ្យយើងដឹងថា ព្រឹត្តិការណ៍នេះកើតឡើងបន្ទាប់ពីជម្លោះនៅក្នុង ១៤:៤៧ គឺទាក់ទងទៅនិងពេលដែលពួកគេមានសន្តិភាព និងសុវត្ថិភាព ។ ពេលនោះប្រហែលជាដាវីឌត្រូវបានទទួលការចាក់ប្រេងតាំង (១៦:១-១៣) ក្នុងរយៈពេលយ៉ាងខ្លីបន្ទាប់ពីសូលត្រូវបានគេបដិសេធ (ខ.២៣,២៦,២៨) ក្នុងអំឡុងឆ្នាំ ១០២៥ មុន គ.ស ។

**១៥:២** *ពួកអាម៉ាលេក* ពួកចរកជននោះ គឺជាកូនចៅរបស់អេសាវ (សូមមើល លប ៣៦:១២,១៦) ជានិច្ចកាលពួកគេ តែងតែរស់នៅស្រុកត្បូង និងតំបន់ស៊ីណាយ (សូមមើល ២៧:៨ ៣០:១ ២សយ ១៧:១-១៥ លក ៤:៧ និងការពន្យល់ នក ១៧:៨ ជន ១៣:២៩) ។ *ធ្វើដល់ពួកអ៊ីស្រាអែល* សូមមើល ១៤:៤៨ នក ១៧:៨-១៥ ជន ១៤:៤៣,៤៥ ចទ ២៥:១៧-១៩ សូមប្រៀបធៀប ចទ ៣:១៣ ៦:៣-៥,៣៣ ៧:១២ ១០:១២) ។

អ៊ីស្រាអែលឡើងចេញពីស្រុកអេស៊ីព្ទមក ៣ដូច្នេះចូរទៅ
វាយពួកសាសន៍អាម៉ាលេកឥឡូវចុះ ព្រមទាំងបំផ្លិចបំផ្លាញ
គេទាំងប៉ុន្មានឱ្យអស់រលីងទៅ[គ] កុំត្រាប្រណីដល់គេឡើយ
គឺត្រូវឱ្យសំឡាប់ទាំងប្រុសទាំងស្រី ទាំងកូនក្មេង និងកូន
ដែលនៅបៅផង ទាំងគោ ចៀម និងអូដ្ឋ ហើយនិង
លាដែរ ។
៤ដូច្នេះ សូលទ្រង់ក៏កេណ្ឌប្រមូលបណ្ដាជន ហើយ
គណនារាប់គេនៅត្រង់ថេលែម ឃើញមានពលថ្មើរជើង
ចំនួន២សែននាក់ នឹងពួកយូដា១ម៉ឺននាក់ទៀត ៥រួចសូល
ទ្រង់ក៏នាំទៅឯទីក្រុងរបស់ពួកអាម៉ាលេក ហើយបង្កប់ពល
នៅវាលច្រកភ្នំ ៦ទ្រង់ប្រាប់ដល់ពួកសាសន៍កែនថា[ឃ] ចូរ
អ្នករាល់គ្នាថយចុះចេញពីកណ្ដាលពួកអាម៉ាលេកទៅ
ក្រែងត្រូវស្លាប់ជាមួយនឹងគេដែរ ដ្បិតអ្នករាល់គ្នាបាន
សំដែងសេចក្ដីសប្បុរស ដល់ពួកកូនចៅអ៊ីស្រាអែលទាំង
ប៉ុន្មាន ក្នុងកាលដែលគេឡើងចេញពីស្រុកអេស៊ីព្ទមក នោះ
ពួកសាសន៍កែនក៏ថយចេញពីកណ្ដាលពួកអាម៉ាលេកទៅ
៧រួចសូលទ្រង់វាយពួកអាម៉ាលេក[ង]នោះ ចាប់តាំងពី
ហាវីឡា រហូតដល់ស៊ើរ[ច] ដែលនៅទល់មុខនឹងស្រុក
អេស៊ីព្ទ ៨ក៏ចាប់បានអ័កាក់[ឆ] ជាស្ដេចសាសន៍អាម៉ាលេក
មកទាំងរស់[ជ] តែកាប់រំលីងពួកជនដោយមុខដាវ ៩ឯអ័កាក់
នោះសូល និងពួកទ័ពបានទុកឱ្យនៅ[ឈ]វិញ ព្រមទាំងសត្វ
ដែលល្អៗក្នុងហ្វូងចៀម ហ្វូងគោ និងសត្វដែលធាត់ៗ
ហើយកូនចៀម និងរបស់ដែលល្អទាំងប៉ុន្មានផង គេមិន
ព្រមបំផ្លាញឱ្យអស់រលីងទេ តែឯសត្វណាដែលស្គមស្គាំង
មានដំឡៃតិច នោះគេបានបំផ្លាញចេញទាំងអស់វិញ ។
១០ខណនោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងសាំយូអែល
ថា ១១អញស្ដាយណាស់[ញ]ដែលបានតាំងសូលឡើង ឱ្យធ្វើ
ជាស្ដេច ដ្បិតបានងាកបែរចេញ[ដ]លែងតាមអញហើយ ក៏
មិនបានធ្វើតាមបង្គាប់របស់អញសោះ[ឋ] នោះសាំយូអែលក៏
ក្ដៅចិត្ត[ឌ] ហើយលោកអំពាវនាវដល់ព្រះយេហូវ៉ាអស់ពេញ
១យប់ ១២រួចក្រោកឡើងពីព្រលឹម ដើម្បីនឹងទៅជួបនឹង
សូលក្នុងព្រឹកនោះ មានគេជំរាបសាំយូអែលថា សូលទ្រង់
បានយាងមកដល់កើមែលហើយ[ឍ] មើល ទ្រង់បានដំឡើង
គោល[ណ]ជាគ្រឿងចំណាំទុក រួចយាងវិលចុះទៅឯគីលកាល

**១៥:៣** គ ខ.៩,១៩ លប ១៤:២៣ យស ៦:១៧ ១សយ ២២:១៩ ២៧:៩ ២៨:១៨ នអ ៣:១៣ ៩:៥
**១៥:៦** ឃ លប ១៥:១៩ ជន ២៤:២២ ពច ១:១៦ ១សយ ៣០:២៩
**១៥:៧** ង ១សយ ១៤:៤៨ ច លប ១៦:៧
**១៥:៨** ឆ នក ១៧:៨–១៦ ជន ២៤:៧ ជ យស ៨:២៣
**១៥:៩** ឈ ខ.៣
**១៥:១១** ញ លប ៦:៦ នក ៣២:១៤ ដ យស ២២:១៦ ឋ យប ២១:១៤ ៣៤:២៧ ទដ ២៨:៥ អស ៥:១២ ៥៣:៦ យរ ៤៨:១០ អក ១៨:២៤ ឌ ខ.៣៥ ១សយ ៨:៦ **១៥:១២** ឍ យស ១៥:៥៥ ណ ជន ៣២:៤២

**១៥:៣** *បំផ្លិចបំផ្លាញគេទាំងប៉ុន្មានឱ្យអស់រលីងទៅ* សូមមើលអត្ថបទគម្ពីរ ចទ ១៣:១២–១៨ និងការពន្យល់ លវ ២៧:២៨–២៩ យស ៦:១៧–១៨ ។ ស្ដេចសូលត្រូវបានព្រះផ្ដល់ឱកាសឱ្យគាត់ធ្វើជាស្ដេច ដើម្បីបង្ហាញពីភក្ដីភាពចំពោះព្រះអម្ចាស់ តាមរយៈការស្ដាប់បង្គាប់ និងធ្វើតាមការងារដែលព្រះផ្ដល់ឱ្យ ។

**១៥:៤** *ថេលែម* ប្រហែលជាឈ្មោះតែមួយ អំពីថេលែម ដែលនិយាយនៅក្នុង យស ១៥:២៤ ដែលមានទីតាំងស្ថិតនៅភាគខាងត្បូងនៃស្រុកយូដា ។ *ពលថ្មើរជើង* ពួកគេចេញពីអំបូរខាងជើង (សូមមើល ១១:៨) ។

**១៥:៥** *ទីក្រុងរបស់ពួកអាម៉ាលេក* ជំរុំដែលពួកអាម៉ាលេកបានតាំង គឺប្រហែលជាស្ថិតនៅរវាងថេលែម និងកាដេស–បារនា ប្រហែលជាតំណាក់ស្ដេចរបស់គេ ។

**១៥:៦** *សាសន៍កែន* ពួកចរកជននៃតំបន់ស៊ីណាយនេះ មានទំនាក់ទំនងជិតស្និទ្ធជាមួយពួកម៉ាដាយ ។ លោកម៉ូសេបានរៀបការជាមួយស្ត្រីសាសន៍កែន (សូមមើល នក ២:១៦,២១–២២ ជន ១០:២៩ ពច ១:១៦ ៤:១១) ហើយពួកសាសន៍កែនខ្លះ បានចូលរួមដំណើរជាមួយពួកអ៊ីស្រាអែលនៅពេលដែលពួកកូនចៅអ៊ីស្រាអែល ចូលមករស់នៅក្នុងទឹកដីកាណាន (មើល ២៧:១០ ពច ១:១៦ ៤:១៧–២៣ ៥:២៤ ១របា ២:៥៥) ។

**១៥:៧** *ហាវីឡា រហូតដល់ស៊ើរ* ពួកពូជពង្សរបស់អ៊ីសម៉ាអែល បានតាំងលំនៅ នៅក្នុងតំបន់នេះ(សូមមើល លប ២៥:១៨) ។ ទីតាំងពិតប្រាកដនៃតំបន់ហាវីឡា មិនបានដឹងច្បាស់ឡើយ ។ ស៊ើរស្ថិតនៅភាគខាងកើតជាប់ព្រំប្រទល់នឹងស្រុកអេស៊ីព្ទ (មើល ២៧:៨ លប ១៦:៧ ២០:១) ។

**១៥:៨** *អ័កាក់ ជាស្ដេចសាសន៍អាម៉ាលេក* នៅសម័យក្រោយមកទៀត ពួកកូនចៅរបស់គេ បានសង្កត់សង្កិនពួកអ៊ីស្រាអែល (មើលការពន្យល់ នអ ៣:១) ។ *ពួកជន* គ្រប់ទាំងអស់នៃពួកសាសន៍អាម៉ាលេកដែលប្រយុទ្ធជាមួយពួកអ៊ីស្រាអែល ។ ប៉ុន្តែ ក៏មានពួកអាម៉ាលេកខ្លះនៅរស់ដែរ (សូមមើល ២៧:៨ ៣០:១,១៨ ២សយ ១:៨,១៣ ៨:១២ ១របា ៤:៤៣) ។

**១៥:៩** នៅពេលដែលពួកកូនចៅអ៊ីស្រាអែលបដិសេធ មិនស្ដាប់តាមបង្គាប់ព្រះអម្ចាស់(មើល ខ.៣)សង្គ្រាមសាសនារបស់គេប្រឆាំងជាមួយពួកសាសន៍អាម៉ាលេកដែលអាក្រក់លាមក ពួកអ៊ីស្រាអែលបានឆ្លៀតឱកាសយកផលសម្រាប់ខ្លួន ដូចគ្នានឹងអេកាន ក្នុងសម័យកាលដែលពួកអ៊ីស្រាអែលច្បាំងជាមួយសាសន៍កាណានដែរ(មើល យស ៧:១) ។ ពួកគេបានបំផ្លាញតែរបស់ណាដែលមានតម្លៃតិច និងសត្វណាដែលស្គមប៉ុណ្ណោះ នោះគឺជាអំពើគួរឱ្យស្អប់ខ្ពើម (មឡ ១:៧–១២) មិនអាចអត់ឱនឱ្យបានឡើយ (មើល ខ.១៩) ដោយបានតវ៉ា និងដោះសារទុកសម្រាប់ថ្វាយយញ្ញបូជានៅចំពោះព្រះអម្ចាស់ (មើល ខ.១៥,២១) ។

**១៥:១១** *ស្ដាយ* សូមមើល ខ.២៩ ។ *ដ្បិតបានងាកបែរចេញលែងតាមអញហើយ* ស្ដេចសូលបានរំលោភបំពាន់លើសេចក្ដីតម្រូវការគ្រឹះ ការងារជាស្ដេចរបស់ទ្រង់ (មើលការពន្យល់ ១២:១៤–១៥) ។

**១៥:១២** *កើមែល* មានចម្ងាយប្រមាណជា ១១,២៦ គ.ម ភាគខាងត្បូងហេប្រុន (មើល ២៥:២ យស ១៥:៥៥) ។ *ដំឡើងគោល ជាគ្រឿងចំណាំ* កិត្តិយសផ្ទាល់ខ្លួនរបស់ស្ដេចសូលនៅកន្លែងនេះ មានភាពផ្ទុយគ្នាជាមួយការបន្ទាបខ្លួនរបស់ទ្រង់ បន្ទាប់ពីគាត់ទទួលជ័យជម្នះលើពួកសាសន៍អាំម៉ូន (មើលការពន្យល់ ១១:១៣ ធៀបជាមួយ ខ.១៧ ២សយ ១៨:១៨) ។ *គីលកាល* ស្ដេចសូលបានត្រឡប់មកកន្លែងដែលគាត់ទទួលការតែងតាំង និងណែនាំពីការងាររបស់គាត់ (មើល ១១:១៤–១៥) ។ ទីកន្លែងនេះ ក៏ជាកន្លែងមួយ ដែលគាត់បាននិយាយប្រាប់ថា គាត់នឹងគ្មានរាជវង្សរបស់ទ្រង់

វិញ ១៣ដូច្នេះ សាំយូអែលក៏ទៅឯទ្រង់ ទ្រង់ទទួលដោយ
បន្ទូលថា សូមឱ្យលោកបានប្រកបដោយពរពីព្រះយេហូវ៉ា
ខ្ញុំបានធ្វើសំរេច តាមព្រះបន្ទូលនៃព្រះយេហូវ៉ាហើយ
១៤តែសាំយូអែលទូលឆ្លើយថា ចុះដូចម្តេចបានជាឮសូរ
សត្វចៀម ហើយនិងគោរោទ៍នៅត្រចៀកទូលបង្គំដូច្នេះ
១៥សូលទ្រង់ឆ្លើយថា គេបាននាំសត្វទាំងនោះពីសាសន៍
អាម៉ាលេកមក ដ្បិតពួកទ័ពបានទុកសត្វដែលល្អៗក្នុងហ្វូង
ចៀម ហ្វូងគោ សំរាប់ថ្វាយយញ្ញបូជាដល់ព្រះយេហូវ៉ាជា
ព្រះនៃលោក ក្រៅអំពីនោះយើងបានបំផ្លាញអស់រលីង
ហើយ ១៦នោះសាំយូអែលទូលថា ឈប់សិន ទូលបង្គំនឹង
ទូលទ្រង់ពីសេចក្តី ដែលព្រះយេហូវ៉ាបានមានបន្ទូលមក
ទូលបង្គំពីយប់មិញនេះ ទ្រង់ក៏ឆ្លើយថា ដូច្នេះសូមមាន
ប្រសាសន៍ចុះ ។
១៧សាំយូអែលក៏ទូលថា ក្នុងកាលដែលទ្រង់នៅថោក
ទាប[ត]ដល់ព្រះនេត្រនៃអង្គទ្រង់ នោះតើព្រះមិនបានតាំង
ទ្រង់ឡើង ឱ្យធ្វើជាមេលើពូជអំបូរអ៊ីស្រាអែលទាំងប៉ុន្មាន
ទេឬអី គឺព្រះយេហូវ៉ាបានចាក់ប្រេងតាំងទ្រង់ឡើង ជា
ស្តេចលើអ៊ីស្រាអែលហើយ ១៨ព្រះយេហូវ៉ាក៏បានចាត់
ទ្រង់ឱ្យទៅដោយថា ចូរទៅចុះ ចូរទៅបំផ្លាញសាសន៍
អាម៉ាលេកកំបាបនោះឱ្យអស់រលីងទៅ ត្រូវឱ្យច្បាំងនឹងគេ
ដរាបដល់វិនាសបាត់ទាំងអស់ចេញ ១៩ដូច្នេះហេតុអ្វីបាន
ជាទ្រង់មិនបានស្តាប់តាមព្រះយេហូវ៉ាសោះ គឺបានស្ទុះទៅ
ចាប់យករបឹប[ថ] ហើយធ្វើការអាក្រក់នៅព្រះនេត្រនៃព្រះ
យេហូវ៉ាវិញ ២០តែសូលទ្រង់ឆ្លើយប្រកែកថា ខ្ញុំបានស្តាប់
តាម[ទ]ព្រះបន្ទូល នៃព្រះយេហូវ៉ាហើយ គឺបានដើរតាមផ្លូវ
ដែលទ្រង់ចាត់ខ្ញុំនោះ មើល ខ្ញុំបាននាំទាំងអ័កាក់ជាស្តេច
នៃសាសន៍អាម៉ាលេកមកផង ឯពួកសាសន៍អាម៉ាលេកទាំង
ប៉ុន្មាន នោះបានបំផ្លាញអស់រលីងហើយ ២១ប៉ុន្តែពួកទ័ព
បានចាប់យករបឹប ជាចៀម និងគោដែលជាសំខាន់ៗក្នុង
របស់ទាំងប៉ុន្មាន ដែលត្រូវបំផ្លាញនោះមក ដើម្បីនឹងថ្វាយ
ជាយញ្ញបូជាដល់ព្រះយេហូវ៉ា ជាព្រះនៃលោកនៅត្រង់គីល
កាល ២២សាំយូអែលទូលឆ្លើយថា តើព្រះយេហូវ៉ាទ្រង់សព្វ
ព្រះហឫទ័យនឹងដង្វាយដុត ហើយនិងយញ្ញបូជា ឱ្យស្មើនឹង
ការស្តាប់តាមទ្រង់ឬអី មើល ដែលស្តាប់បង្គាប់នោះវិសេស
លើសជាងយញ្ញបូជា[ធ] ហើយដែលផ្ទៀងត្រចៀក នោះក៏
វិសេសជាងខ្លាញ់នៃចៀមឈ្មោលទៅទៀត ២៣ឯសេចក្តីរឹង
ទទឹង នោះក៏ជាបាបដូចជាការមន្តវិជ្ជា[ន]ដែរ ហើយសេចក្តី
ចចេសសោត ក៏ដូចជាអំពើអាក្រក់ណាមួយ ហើយនិងការ

**១៥:១៧** ត នក ៣:១១
**១៥:១៩** ថ លប ១៤:២៣ ១សយ ១៤:៣២
**១៥:២០** ទ ១សយ ២៨:១៨
**១៥:២២** ធ ទដ ៤០:៦–៨ ១:១៦ សភ ២១:៣ អស ១:១១–១៥ យរ ៧:២២ ហស ៦:៦ អម ៥:២៥ មីក ៦:៦–៨:៥ មក ១២:៣៣
**១៥:២៣** ន ចទ ១៨:១០

បន្តគ្រប់គ្រងទៀតទេ ពីព្រោះគាត់មិនបានស្តាប់បង្គាប់ចំពោះព្រះអម្ចាស់ឡើយ (សូមមើល ១៣:១៣–១៤) ។

**១៥:១៣** *ខ្ញុំបានធ្វើសំរេច តាមបន្ទូលរបស់ព្រះយេហូវ៉ាហើយ* នៅទីនេះ និង ខ.២០ ស្តេចសូលគ្មានភាពស្មោះដូចអ្វី ដែលបាននិយាយនឹងហោរាសាំយូអែលឡើយ ។

**១៥:១៥** *ពួកទ័ព . . . ដែលល្អៗ . . . សំរាប់ថ្វាយយញ្ញបូជា* ស្តេចសូលប៉ុនប៉ងផ្លាស់ប្តូរទំនួលខុសត្រូវរបស់គាត់ មកដាក់លើទាហាន ហើយចោទប្រកាន់អំពើរបស់ពួកគេ ដោយគាត់បាននិយាយតាមរបៀបនៃអ្នកជឿលើព្រះ ។ *ព្រះយេហូវ៉ាជាព្រះនៃលោក* ស្តេចសូលនិយាយថា"នៃលោក" ជំនួសពាក្យថា "នៃខ្ញុំ" នៅទីនេះ និង ខ.២១,៣០ គឺបញ្ជាក់ថាគាត់ប្តូរព្រះ (សូមមើល ១២:១៩) ទោះបីជាការស្តាប់បង្គាប់ និងមានចេតនាលើកព្រះនាមរបស់ព្រះអម្ចាស់ តាមរយៈការថ្វាយយញ្ញបូជាក៏ដោយ ។

**១៥:១៧** *ក្នុងកាលដែលទ្រង់នៅថោកទាបដល់ព្រះនេត្រនៃអង្គទ្រង់* សូមមើល ៩:២១ ១០:២២ ។

**១៥:២២** នៅក្នុងកន្លែងនេះ ហោរាសាំយូអែលមិនបាននិយាយថា យញ្ញបូជាមិនសំខាន់នោះឡើយ ប៉ុន្តែគាត់ចង់មានន័យថា យញ្ញបូជាសំខាន់គឺនៅពេលដែលធ្វើដោយការស្តាប់បង្គាប់ និងផ្តង់អារម្មណ៍ទៅចំពោះព្រះអម្ចាស់ (មើល ទដ ៥១:១៦–១៧ អស ១:១១–១៧ ហស ៦:៦ អម ៥:២១–២៤ មីក ៦:៦–៨) ។ *ខ្លាញ់នៃចៀមឈ្មោល* ខ្លាញ់នៃយញ្ញបូជារបស់សត្វ គឺសម្រាប់ព្រះអម្ចាស់ (សូមមើល ២:១៥ និងការពន្យល់, និងមើល នក ២៣:១៨ លវ ៣:១៤–១៦ ៧:៣០) ។

**១៥:២៣** *សេចក្តីរឹងទទឹង* ហោរាសាំយូអែលបានចោទប្រកាន់ស្តេចសូលពីបទរំលោភបំពានលើសេចក្តីសញ្ញាដែលមានលក្ខខណ្ឌ ដែលព្រះអម្ចាស់បានដាក់ឱ្យទ្រង់ នៅក្នុងអំឡុងពេលដែលទ្រង់ឡើងធ្វើជាស្តេច (សូមមើល ១២:១៤–១៥)។ *ក៏ជាបាបដូចជាមន្តវិជ្ជាដែរ* មន្តវិជ្ជា ជាអំពើទាស់ប្រឆាំងនឹងព្រះអម្ចាស់ (មើល លវ ១៩:២៦ ចទ ១៨:៩–១២) ដែលស្តេចសូលខ្លួនឯងត្រូវតែទទួលយកនូវទណ្ឌកម្មនេះ (សូមមើល ២៨:៣,៩) ។ *ដោយព្រោះទ្រង់បានបោះបង់ចោល លែងតាមព្រះបន្ទូលនៃព្រះយេហូវ៉ាហើយ* ស្តេចសូលជាស្តេចដែលបានគិតថា គំនិតទ្រង់ខ្ពស់ជាងការត្រាស់បង្គាប់របស់ព្រះអម្ចាស់ ដែលបានបញ្ឈប់គាត់ពីការងារធ្វើជាអ្នកគ្រប់គ្រងលើរាស្ត្ររបស់ទ្រង់ និងជាអ្នកប្រព្រឹត្តល្មើសលើភាពជាស្តេចរបស់គាត់ ។ *ព្រះយេហូវ៉ាបានបោះបង់ចោលទ្រង់ មិនឱ្យធ្វើជាស្តេចទៀតទេ* ការជំនុំជម្រះនៅទីនេះ គឺនិយាយសំដៅទៅលើការជំនុំជម្រះដែលបាននិយាយពីមុនមកហើយ (មើលការពន្យល់ ១៣:១៤) ។ ឥឡូវនេះស្តេចសូលត្រូវបានបញ្ឈប់ពីការងារ មិនឱ្យគាត់ធ្វើជាស្តេចទៀតឡើយ ។ ទោះបីជាទ្រង់មិនទាន់ត្រូវបានបញ្ឈប់ភ្លាមៗដូចដែលឃើញនៅក្នុងជំពូក ១៦–៣១ នេះពិតមែនក៏ដោយ ក៏ការនេះនឹងកើតឡើងនៅពេលដែលទ្រង់សុគតដែរ បុត្រាទ្រង់មិនអាចគ្រងរាជ្យជំនួសបានឡើយ ។ ការទាំងអស់នោះ រាប់បញ្ចូលទាំងវិញ្ញាណនៃព្រះអម្ចាស់ ដែលបានថយចេញពីសូលទៅដែរ (សូមមើល ១៦:១៤) និងការដែលបុត្រាទ្រង់យ៉ូណាថាន និងមីកាលបានបោះបង់ទ្រង់ចោល ហើយមកស្រឡាញ់លោកដាវីឌ (សូមមើល ១៨:១–៤,២០ ១៩:១១–១៧) រួមទាំងការមិនចុះសម្រុង ជាមួយមន្ត្រីអ្នកមុខអ្នកការរបស់គាត់ទៀត

ថ្វាយបង្គំដល់រូបព្រះដែរ ឥឡូវនេះ ព្រះយេហូវ៉ាបានបោះ
បង់ចោលទ្រង់ មិនឱ្យធ្វើជាស្តេចទៀត ដោយព្រោះទ្រង់
បានបោះបង់ចោល លែងតាម[ប]ព្រះបន្ទូលនៃព្រះយេហូវ៉ា
ហើយ ។
២៤នោះសូលទ្រង់ឆ្លើយទៅសាំយូអែលថា ខ្ញុំមានបាប[ផ]
ហើយ ពីព្រោះខ្ញុំបានរំលង[ព]សេចក្តីបង្គាប់នៃព្រះយេហូវ៉ា
និងពាក្យរបស់លោកផង ដោយខ្លាច[ភ]ដល់ពួកជន ហើយ
បានស្តាប់តាមគេវិញ ២៥ដូច្នេះ សូមឱ្យលោកអត់ទោស[ម]ខ្ញុំ
ឥឡូវ ហើយវិលមកខាងខ្ញុំវិញទៀត ដើម្បីឱ្យខ្ញុំបានថ្វាយ
បង្គំដល់ព្រះយេហូវ៉ាផង ២៦តែសាំយូអែលប្រកែកថា ទូល
បង្គំមិនព្រមវិល ទៅកាន់ខាងទ្រង់ទៀតទេ ពីព្រោះទ្រង់
បានបោះបង់ចោល[យ]ព្រះបន្ទូលនៃព្រះយេហូវ៉ាហើយ ព្រះ
យេហូវ៉ាក៏បានបោះបង់ចោលទ្រង់ មិនឱ្យធ្វើជាស្តេចលើ
សាសន៍អ៊ីស្រាអែលដែរ ២៧រួចកាលសាំយូអែលបែរខ្លួន
រៀបនឹងចេញទៅ នោះសូលចាប់ជាយអាវ[រ]លោក ហើយ
អាវក៏រហែក[ល] ២៨ដូច្នេះសាំយូអែលទូលទ្រង់ថា នៅថ្ងៃនេះ
ព្រះយេហូវ៉ាបានផ្តាច់[វ]នគរ[ស]អ៊ីស្រាអែល ពីទ្រង់ចេញ
ហើយក៏បានប្រទានឱ្យដល់អ្នកជិតខាង ដែលល្អជាងទ្រង់
វិញ[ហ] ២៩១ទៀត ព្រះដ៏ជាកំឡាំងនៃសាសន៍អ៊ីស្រាអែល
ទ្រង់មិនចេះកុហក[ឡ] ឬប្រែប្រួល[អ]ឡើយ ដ្បិតទ្រង់មិនមែនជា
មនុស្សដែលចេះប្រែប្រួលទេ ៣០នោះសូលមានបន្ទូលថា ខ្ញុំ
បានធ្វើបាប[ក] ប៉ុន្តែ សូមលើកមុខ[ខ]ខ្ញុំនៅចំពោះមុខពួក
ចាស់ទុំនៃសាសន៍ខ្ញុំនេះ ហើយនៅមុខសាសន៍អ៊ីស្រាអែល
ទាំងអស់គ្នាផង សូមមកខាងខ្ញុំវិញ ដើម្បីឱ្យខ្ញុំបានថ្វាយបង្គំ
ដល់ព្រះយេហូវ៉ាជាព្រះនៃលោកដែរ ៣១ដូច្នេះសាំយូអែល
បានវិលមកខាងសូលវិញ ហើយសូលទ្រង់ក៏ថ្វាយបង្គំដល់
ព្រះយេហូវ៉ា ។
៣២លំដាប់នោះសាំយូអែលប្រាប់ថា ចូរនាំអ័កាក់ ជា
ស្តេចនៃសាសន៍អាម៉ាលេកមកឯនេះ អ័កាក់ក៏ដើរមកឯ
លោកងង្ហើល ដោយនឹកក្នុងចិត្តថា ប្រាកដជាសេចក្តីជូរ
ល្វីងនៃសេចក្តីស្លាប់បានកន្លងហួសហើយ ៣៣តែសាំយូ-
អែលមានប្រសាសន៍ថា ដាវឯងបានធ្វើឱ្យពួកស្រីៗទៅជា
ឥតកូន ដូច្នេះម្តាយឯងក៏នឹងឥតកូនយ៉ាងនោះដែរ[គ] រួច
សាំយូអែលក៏កាប់អ័កាក់កំទេច នៅចំពោះព្រះយេហូវ៉ា
ត្រង់គីលកាលទៅ ។
៣៤រួចសាំយូអែលវិលទៅឯរ៉ាម៉ាវិញទៅ[ឃ] ហើយសូល
ទ្រង់ឡើងទៅឯលំនៅទ្រង់នៅគីបៀរ[ង] ជាស្រុករបស់ទ្រង់
វិញដែរ ៣៥ឯសាំយូអែល[ច]លោកលែងមកសួរសូលទៀត
រហូតដល់លោកស្លាប់ តែសាំយូអែលសោកស្តាយ[ឆ]នឹង
សូលណាស់ ឯព្រះយេហូវ៉ាទ្រង់ស្តាយ[ជ]ដែលទ្រង់បានតាំង
សូលឡើង ឱ្យធ្វើជាស្តេចលើសាសន៍អ៊ីស្រាអែលផង ។

**១៥:២៣** ប ១សយ ១៣:១៣ **១៥:២៤** ផ នក ៩:២៧ ជន ២២:៣៤ ទដ ៥១:៤ ព ១សយ ១៣:១៣ **១៥:២៤** ភ សភ ២៩:២៥ ងស ៥១:១២–១៣ យរ ៤២:១១ **១៥:២៥** ម នក ១០:១៧ **១៥:២៦** យ ជន ១៥:៣១ ១សយ ១៣:១៤ ១ពវ ១៤:១០ **១៥:២៧** រ ១សយ ២៨:១៤ ល ១បវ ១១:១១,៣១ ១៤:៨ ២ពវ ១៧:២១ **១៥:២៨** វ ១សយ ២៨:១៧ ស ១សយ ១៣:១៤ ហ ២សយ ៦:២១ ៧:១៥ **១៥:២៩** ឡ ទដ ១:២ អ ជន ២៣:១៩ ហាព ៧:២១ **១៥:៣០** ក ជន ២២:៣៤ ខ អស ២៩:១៣ យហ ១២:៤៣ **១៥:៣៣** គ នអ ៩:៧–១០ យរ ១៨:២១ **១៥:៣៤** ឃ ១សយ ៧:១៧ ង ពច ១៩:១៤ ១សយ ១០:៥ **១៥:៣៥** ច ១សយ ១៩:២៤ ឆ ខ.១១ ១សយ ១៦:១ ជ លប ៦:៦

ផង (មើល ២២:១៧) ។

**១៥:២៤** ការលន់តួររបស់ស្តេចសូល គឺជាការនិយាយដោះសារបង្ហាញថា គាត់គ្មានកំហុស និងដើម្បីឱ្យរួចពីការស្តីបន្ទោសប៉ុណ្ណោះ (ផ្ទុយពីការលន់តួររបស់ស្តេចដាវីឌ សូមមើល ២សយ ១២:១៣ និងការពន្យល់ ទដ ៥១:៤) ។ កាលពីគ្រាមុន (មើល ខ.១៥,២១) ស្តេចសូលបានព្យាយាមការពារកំហុសទាហានខ្លួន ។

**១៥:២៥** *វិលមកខាងខ្ញុំវិញទៀត* កង្វល់ព្រួយដ៏ធំរបស់ស្តេចសូល មិនមែនជាការថ្វាយបង្គំព្រះអម្ចាស់នោះទេ ប៉ុន្តែដើម្បីជៀសវាងពីការបែកបាក់ជាមួយហោរាសាំយូអែល ពីព្រោះការបែកបាក់គ្នានោះ និងរំលាយសិទ្ធិអំណាចភាពជាស្តេចរបស់គាត់ (មើល ខ.៣០) ។

**១៥:២៨** *អ្នកជិតខាង* អ្នកជិតខាងនោះ គឺជាដាវីឌ (សូមមើល ២៨:១៧ ១៣:១៤) ។

**១៥:២៩** *ដ៏ជាកំឡាំងនៃសាសន៍អ៊ីស្រាអែល* នៅក្នុង ទដ ១០៦:២០ យរ ២:១១ ហស ៤:៧ ព្រះអម្ចាស់ត្រូវបានគេហៅថា "សិរីល្អ" (សូមមើល ៤:២១ ហាព ៩:៥ និងការពន្យល់) ធៀបជាមួយ ២សយ ១:១៩ ទដ ៨៩:១៧ អស ១៣:១៩ ។ *ទ្រង់មិនចេះកុហក ឬប្រែប្រួលឡើយ* សូមមើល ជន ២៣:១៩ មឡ ៣:៦ និងការពន្យល់, និងមើល ទដ ១១០:៤ យរ ៤:២៨ ។ នៅក្នុងប្រយោគនៃ ការនិយាយទាំងនោះ វាមិនមានជម្លោះជា មួយគ្នារវាង ខ.១១,៣៥ នោះឡើយ ដែលព្រះអម្ចាស់ទ្រង់បានមានបន្ទូលថាអញ "ស្តាយណាស់" ដែល បានតាំងសូលឡើងធ្វើជាស្តេច ។

**១៥:៣១** *ដូច្នេះសាំយូអែលបានវិលមកខាងសូលវិញ* គឺគោលបំណងរបស់ហោរាសាំយូអែល ដែលគាត់បានយល់ព្រមចំពោះសំណូមពររបស់ស្តេចសូល មិនមែនដើម្បីលើកកិត្តិយសរបស់ស្តេចសូលនោះឡើយ ប៉ុន្តែគឺដើម្បីធ្វើតាមព្រះបន្ទូលព្រះ ដែលទ្រង់នឹងធ្វើចំពោះស្តេចអ័កាក់ ដើម្បីបញ្ជាក់ដល់សូលអំពីកិច្ចការងាររបស់ទ្រង់ ។

**១៥:៣៤** *រ៉ាម៉ា* គឺជាផ្ទះរបស់សាំយូអែល (សូមមើល ៧:១៧ និងការពន្យល់ ១:១) ។ *ជាស្រុករបស់ទ្រង់* សូមមើល ១០:៥ ។

**១៥:៣៥** *សាំយូអែលសោកស្តាយនឹងសូល* ហោរាសាំយូអែលសោកស្តាយចំពោះស្តេចសូល បើសិនជាគាត់នឹងស្លាប់ (មើលការប្រើពាក្យ "សោកស្តាយ" នៅក្នុង ៦:១៩) ។ ទោះបីជាគាត់នៅមានសេចក្តីស្រឡាញ់ចំពោះស្តេចសូលក៏ដោយ (សូមមើល ខ.១១ និង ១៦:១) ក៏ហោរាសាំយូអែលមិនអាចទាក់ទងជាមួយស្តេចសូលទៀតឡើយ ពីព្រោះព្រះអម្ចាស់ទ្រង់បានបដិសេធមិនឱ្យស្តេចសូលធ្វើជាស្តេចទៀតឡើយ ។ ស្តេចសូលនឹងមករកហោរាសាំយូអែលនៅឱកាសក្រោយម្តងទៀត (សូម មើល ១៩:២៤)។

## លោកសាំយូអែលចាក់ប្រេងតាំងលោកដាវីឌ

**១៦** ១គ្រានោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅសាំយូ–
អែលថា តើឯងនៅតែសោកស្តាយ[ក]នឹងសូលដល់កាលណា
ទៀត ដ្បិតអញលែងឱ្យ[ខ]ធ្វើជាស្តេចលើអ៊ីស្រាអែលហើយ
ដូច្នេះ ចូរបំពេញប្រេង[គ]ក្នុងស្នែងរបស់ឯងចេញទៅ អញ
នឹងចាត់ឯងទៅឯអ៊ីសាយ[ឃ]នៅបេថ្លេហិម ដ្បិតអញបាន
រើស[ង]ម្នាក់ក្នុងពួកកូនគាត់ ឱ្យធ្វើជាស្តេចរបស់អញ ២តែ
សាំយូអែលប្រកែកថា ធ្វើដូចម្តេចឱ្យទូលបង្គំទៅបាន ដ្បិត
បើសូលបានឮ នោះទ្រង់នឹងសំឡាប់ទូលបង្គំហើយ នោះ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូរយកគោក្រមុំ១នាំទៅជា
មួយផងដោយថា ខ្ញុំបានមក ដើម្បីនឹងថ្វាយយញ្ញបូជាដល់
ព្រះយេហូវ៉ា ៣រួចចូរហៅអ៊ីសាយមកក្នុងការថ្វាយយញ្ញ
បូជាដែរ នោះអញនឹងបង្ហាញ[ច]ឱ្យឯងដឹងជាត្រូវធ្វើយ៉ាង
ណា ត្រូវឱ្យឯងចាក់ប្រេង[ឆ]ដល់អ្នកណា ដែលអញនឹងប្រាប់
ឯង ដើម្បីញែកចេញឱ្យអញ ៤ដូច្នេះ សាំយូអែលក៏ធ្វើដូចជា
ព្រះយេហូវ៉ាទ្រង់បានមានបន្ទូលមក លោកបានទៅដល់
បេថ្លេហិម[ជ] ឯពួកចាស់ទុំនៅទីក្រុងនោះ គេចេញមកទទួល
លោកដោយភ័យញ័រ[ឈ] ហើយសួរថា លោកអញ្ជើញមក
ដោយមេត្រីទេឬអី[ញ] ៥លោកឆ្លើយថា ដោយមេត្រីទេ ខ្ញុំបាន
មកដើម្បីនឹងថ្វាយយញ្ញបូជាដល់ព្រះយេហូវ៉ា ដូច្នេះចូរអ្នក
រាល់គ្នាញែកខ្លួន[ដ]ជាបរិសុទ្ធចុះ រួចមកបរិភោគយញ្ញបូជា
ជាមួយគ្នា លោកក៏ញែកអ៊ីសាយ និងពួកកូនគាត់ចេញជា
បរិសុទ្ធ ហើយហៅគេមកបរិភោគយញ្ញបូជាទាំងអស់គ្នា ។

៦កាលបានចូលមកដល់ នោះលោកក៏ក្រឡេកមើល
ទៅអេលាប[ឋ] ដោយគិតថា នេះប្រាកដជាអ្នកដែលព្រះយេ
ហូវ៉ាចាក់ប្រេងតាំងឱ្យ បានមកនៅចំពោះទ្រង់ហើយ ៧តែ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា កុំឱ្យមើលតែឫកពាខាង
ក្រៅ ឬកំពស់ខ្លួននោះឡើយ ដ្បិតអញមិនទទួលអ្នកនេះទេ
ពីព្រោះព្រះទ្រង់មិនទតចំពោះសេចក្តី ដែលមនុស្សលោក
ពិចារណាមើលទេ ឯមនុស្សលោក តែងមើលតែឫកពា
ខាងក្រៅប៉ុណ្ណោះ[ឌ] តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្ត
វិញ[ឍ] ៨រួចអ៊ីសាយហៅអ័ប៊ីន៉ាដាប់[ណ]មក ឱ្យដើរនៅមុខ
សាំយូអែល តែលោកមានប្រសាសន៍ថា ព្រះយេហូវ៉ាទ្រង់
មិនរើសយកអ្នកនេះទេ ៩នោះអ៊ីសាយឱ្យសាំម៉ា[ត]ដើរកាត់
មុខលោកទៀត តែលោកថា ព្រះយេហូវ៉ាទ្រង់ក៏នឹងរើស
យកអ្នកនេះដែរ ១០អ៊ីសាយក៏ឱ្យកូនទាំង៧នាក់ដើរនៅមុខ
សាំយូអែល តែលោកមានប្រសាសន៍ថា ព្រះយេហូវ៉ាទ្រង់
មិនរើសយកអ្នកទាំងនេះឡើយ ១១ហើយសួរថា អ្នកមានកូន
តែប៉ុណ្ណោះ[ថ]ទេឬអី គាត់ឆ្លើយថា នៅមានកូនពៅ១ទៀត វា
កំពុងតែឃ្វាលចៀម[ទ] លោកមានប្រសាសន៍ទៅអ៊ីសាយថា
ចូរចាត់គេឱ្យទៅនាំវាមក ដ្បិតបើវាមិនទាន់មកដល់ នោះ
យើងមិនអង្គុយនៅតុឡើយ ១២ដូច្នេះគាត់[ធ]ក៏ចាត់គេឱ្យទៅ
ហៅមក រីឯកូននោះមានថ្ពាល់ក្រហមហើយភ្នែកស្រស់ល្អ
ក៏មានរូបជាទីពេញចិត្ត[ន] នោះព្រះយេហូវ៉ាទ្រង់មានបន្ទូល

**១៦:១** ក ១សយ ៨:៦ ១៥:៣៥ ខ ១សយ ១៣:១៤ គ ១សយ ១០:១ ឃ នរ ៤:១៧ ង ២សយ ៥:២ ៧:៨ ១ពវ ៨:១៦ ១រប ១២:២៣ ទដ ៧៨:៧០ កច ១៣:២២ **១៦:៣** ច នក ៤:១៥ ឆ ចទ ១៧:១៥ **១៦:៤** ជ លប ៤៨:៧ លក ២:៤ ឈ ១សយ ២១:១ **១៦:៤** ញ ១ពវ ២:១៣ ២ពវ ៩:១៧ **១៦:៥** ដ នក ១៩:១០,២២ **១៦:៦** ឋ ១សយ ១៧:១៣ ១រប ២:១៣ **១៦:៧** ឌ ទដ ១៤៧:១០ ឍ ១សយ ២:៣ ២សយ ៧:២០ ទដ ៤៤:២១ ១៣៩:២៣ វវ ២:២៣ **១៦:៨** ណ ១សយ ១៧:១៣ **១៦:៩** ត ១សយ ១៧:១៣ ២សយ ១៣:៣ ២១:២១ **១៦:១១** ថ ១សយ ១៧:១២ ទ លប ៣៧:២ ២សយ ៧:៨ **១៦:១២** ធ ១សយ ៩:១៧

**១៦:១** *ព្រះយេហូវ៉ា ទ្រង់មានបន្ទូលទៅសាំយូអែល* ប្រហែលជានៅក្នុងអំឡុងឆ្នាំ ១០២៥ មុន គ.ស (សូមមើលការពន្យល់ ១៥:១–៣៥) ។ សម្រាប់ពង្សាវតាររបស់លោកអ៊ីសាយ សូមមើល នរ ៤:១៨–២២ មថ ១:៣–៦ ។ *បេថ្លេហិម* គឺជាទីក្រុងដែលមានចម្ងាយប្រមាណជា ៨.០៤ គ.ម នៅភាគខាងត្បូងក្រុងយេរូសាឡិម ដែលពីមុនគេស្គាល់ថា ក្រុងអេប្រាតា (សូមមើល លប ៣៥:១៦ និងការពន្យល់) ។ នៅសម័យក្រោយមកទៀត គេបានប្តូរឈ្មោះវាមកជា "ក្រុងរបស់ហ្លួងដាវីឌ" (មើល លក ២:៤) ហើយក៏ជាទីកន្លែងដែលព្រះមែស៊ីប្រសូតនៅទីនោះដែរ (មើល មីក ៥:២ មថ ២:១ លក ២:៤–៧) ។ *អញបានរើសម្នាក់ក្នុងពួកកូនគាត់ ឱ្យធ្វើជាស្តេច* សូមមើលការពន្យល់ ១៣:១៤ ១៥:២៨ ។

**១៦:២** *ដ្បិតបើសូលបានឮ នោះទ្រង់នឹងសំឡាប់ទូលបង្គំ* ផ្លូវពីរ៉ាម៉ា (ជាកន្លែងដែលហោរាសាំយូអែលបានទៅ ១៥:៣៤) ទៅបេថ្លេហិម គឺត្រូវឆ្លងកាត់ស្រុករបស់ស្តេចសូល ។ ស្តេចសូលក៏បានដឹងដែរថា ព្រះអម្ចាស់ទ្រង់នឹងជ្រើសរើសអ្នកផ្សេងឱ្យធ្វើជាស្តេចជំនួសទ្រង់ (មើល ១៥:២៨) ។ ហោរាសាំយូអែលមានការភ័យខ្លាចថា សេចក្តីច្រណែន និងបញ្ហាឱ្យស្តេចសូលមានកំហឹង និងប្រព្រឹត្តអាក្រក់បាន ។ នៅពេលក្រោយមកទៀតឧប្បត្តិហេតុនេះ (មើល ១៨:១០–១១ ១៩:១០ ២០:៣៣) នឹងបង្ហាញថា សេចក្តីភ័យខ្លាចរបស់ហោរាសាំយូអែល នោះគឺជាហេតុផលដ៏ល្អ ។ *ដោយថា ខ្ញុំបានមក ដើម្បីនឹងថ្វាយយញ្ញបូជាដល់ព្រះយេហូវ៉ា* ការឆ្លើយតបនេះ វាជាការពិត ប៉ុន្តែមិនទាន់បានសម្រេចនៅឡើយទេ ហើយវាគ្រាន់តែជាការបោកបញ្ឆោតដល់ស្តេចសូលតែប៉ុណ្ណោះ ។

**១៦:៣** *ចាក់ប្រេង* សូមមើល ខ.១,១៣ និងការពន្យល់ ៩:១៦ ។

**១៦:៦** *អេលាប* ជាកូនច្បងរបស់លោកអ៊ីសាយ (មើល ១៧:១៣) ។

**១៦:៧** *ឫកពាខាងក្រៅ ឬកំពស់ខ្លួន* ហោរាសាំយូអែលគាត់មិនបានផ្តោតលើឫកពាខាងក្រៅ ដូចដែលគាត់ធ្លាប់ផ្តោតលើឫកពារបស់សូលនោះឡើយ (សូមមើល ៩:២ ១០:២៣–២៤) ។ *ក្នុងចិត្ត* ព្រះយេហូវ៉ាទ្រង់សព្វព្រះទ័យនឹងចរិតលក្ខណៈខាងក្នុងរបស់មនុស្ស (១ពវ ៨:៣៩ ១រប ២៨:៩ លក ១៦:១៥ យហ ២:២៥ កច ១:២៤) ។

**១៦:៨** *អ័ប៊ីន៉ាដាប់* គឺជាកូនប្រុសទី២របស់លោកអ៊ីសាយ (សូមមើល ១៧:១៣) ។

**១៦:៩** *សាំម៉ា* គឺជាកូនប្រុសទី៣របស់លោកអ៊ីសាយ (មើល ១៧:១៣) ។

**១៦:១១** *វាកំពុងតែឃ្វាលចៀម* ព្រះអម្ចាស់ទ្រង់បានជ្រើសរើសម្នាក់ដែលជាអ្នកឃ្វាលចៀម (មើលការពន្យល់ ៩:៣ ២សយ ៧:៧–៨ ទដ ៧៨:៧១–៧២) ។

ថា ឱ្យចូលទៅចាក់ប្រេងឱ្យចុះ ដ្បិតគឺអ្នកនេះហើយ
១៣ សាំយូអែលក៏យកស្នែងដែលដាក់ប្រេង[ប]នោះ ទៅចាក់
លើដាវីឌ នៅកណ្ដាលពួកបងៗទាំងប៉ុន្មាន ចាប់តាំងពីថ្ងៃ
នោះតទៅ ព្រះវិញ្ញាណនៃព្រះយេហូវ៉ា[ផ] ក៏សណ្ឋិតលើ
ដាវីឌ[ព] ស្រេចហើយសាំយូអែលលោកក្រោកឡើងទៅឯ
រ៉ាម៉ាវិញ ។

## លោកដាវីឌបម្រើស្ដេចសូល

១៤ គ្រានោះ ព្រះវិញ្ញាណនៃព្រះយេហូវ៉ា ក៏ដកថយ
ចេញ[ភ]ពីសូលទៅ ហើយព្រះយេហូវ៉ាទ្រង់ចាត់វិញ្ញាណ
អាក្រក់១[ម]ឱ្យមកបំភ័យទ្រង់[យ] ១៥ នោះពួកមហាតលិករបស់
សូលទូលថា មើល មានវិញ្ញាណអាក្រក់ពីព្រះមកបំភ័យ
ទ្រង់ហើយ ១៦ ដូច្នេះសូមឱ្យព្រះអម្ចាស់នៃយើងខ្ញុំ បង្គាប់ដល់
យើងខ្ញុំ ជាពួកអ្នកបំរើរបស់ទ្រង់ ដែលនៅចំពោះទ្រង់នេះ
ឱ្យរកមនុស្សម្នាក់ដែលប្រសប់ចាប់ស៊ុងមក[រ] ដើម្បីកាលណា
វិញ្ញាណអាក្រក់ពីព្រះ បានមកសណ្ឋិតលើទ្រង់ នោះគេនឹង
ចាប់លេងឡើង ឱ្យទ្រង់បានធូរព្រះទ័យថយទៅ ១៧ សូលក៏
មានបន្ទូលទៅពួកអ្នកបំរើថា ដូច្នេះ ចូរទៅរកមនុស្ស
ម្នាក់ដែលចេះលេងពិរោះឱ្យយើង ហើយនាំវាមកចុះ
១៨ ខណនោះ មានមនុស្សកំឡោះម្នាក់ ទូលឆ្លើយថា ទូល
បង្គំបានឃើញម្នាក់ ជាកូនរបស់អ៊ីសាយ[ល] ក្នុងពួកក្រុង
បេថ្លេហិម ជាអ្នកប្រសប់ក្នុងការលេងភ្លេងណាស់ ជា
មនុស្សខ្លាំងពូកែមានចិត្តក្លាហាន[វ] ហើយជំនាញក្នុងចំបាំង
ក៏មានវោហារអធិប្បាយ ព្រមទាំងរូបឆោមស្រស់ល្អផង
ព្រះយេហូវ៉ាទ្រង់ក៏គង់ជាមួយ[ស]នឹងអ្នកនោះ ១៩ ដូច្នេះ សូល
ទ្រង់ចាត់គេឱ្យទៅឯអ៊ីសាយប្រាប់ថា សូមឱ្យដាវីឌជាកូន
អ្នកដែលកំពុងតែឃ្វាលចៀម មកឯយើង[ហ] ២០ អ៊ីសាយ
ក៏យកលា១ផ្ទុកដោយនំបុ័ង[ឡ] ថង់ស្បែកពេញដោយស្រា
ទំពាំងបាយជូរ និងកូនពពែ១ ផ្ញើទៅជាមួយនឹងដាវីឌ ជា

**១៦:១២** ន លប ៣៩:៦
**១៦:១៣** ប ១សយ ២:៣៥ ២សយ ២២:៥១ ផ ១សយ ១៨:១២ ព ១សយ ១១:៦
**១៦:១៤** ភ ពច ១៦:២០ ម ខ.២៣ ពច ៩:២៣ ១សយ ១៨:១០ យ ២សយ ៧:១៥
**១៦:១៦** រ ខ.២៣ ១សយ ១០:៥,៦ ២រប ២៩:២៦–២៧ ទដ ៤៩:៤
**១៦:១៨** ល នរ ៤:១៧ វ ២សយ ១៧:៨ ស លប ៣៩:២ ១សយ ១៧:៣២–៣៧ ២០:១៣ ១រប ២២:១១ មថ ១:២៣ **១៦:១៩** ហ ១សយ ១៧:១៥ **១៦:២០** ឡ លប ៣២:១៣ ១សយ ១០:៤

**១៦:១៣–១៤** នៅក្នុងខទាំង២នេះ មិនមែនគ្រាន់តែនិយាយអំពីវិញ្ញាណរបស់ព្រះអម្ចាស់បានថយចេញពីសូលទៅកាន់ដាវីឌនោះឡើយ ប៉ុន្តែក៏និយាយអំពីប្រសិទ្ធិភាពរបស់ព្រះអម្ចាស់ ចំពោះការផ្លាស់ប្ដូររបស់សូលតាមរយៈដាវីឌ ជាស្ដេចលើស្រុកអ៊ីស្រាអែល ។

**១៦:១៣** *នៅកណ្ដាលពួកបងៗ* ការចាក់ប្រេងតាំងលើស្ដេចដាវីឌ នៅក្នុងចំណោមសាក្សីតិចតួចបែបនេះ គឺបានផ្ដល់ជាទំនុកចិត្តមួយ ប៉ុន្តែនៅថ្ងៃអនាគត ក៏ត្រូវការសាក្សីជាច្រើនដើម្បីបង្ហាញថា ហោរាសាំយូអែលបានចាក់ប្រេងតាំងឱ្យដាវីឌធ្វើជាស្ដេច ហើយគាត់មិនបានច្បាំងដណ្ដើមការងាររបស់សូលនោះឡើយ ។ *ព្រះវិញ្ញាណនៃព្រះយេហូវ៉ាក៏សណ្ឋិតលើដាវីឌ* សូមមើល ១០:៥–៦,១០ ១១:៦ ១៤:៦,១៩ ពច ១៥:១៤ ។ នេះជាលើកដំបូងហើយដែលបាននិយាយពីលោកដាវីឌនៅក្នុងព្រះគម្ពីរសាំយូអែលទី១ ។

**១៦:១៤–១៧:៥៨** វគ្គ២បន្ទាប់ទៀតនេះ ដាវីឌត្រូវបានណែនាំទៅមនុស្សក្នុងដំណាក់របស់ស្ដេចសូល និងចំពោះពួកអ៊ីស្រាអែលថា លោកដាវីឌជាអ្នកលេងភ្លេងដ៏វិសេស និងជាអ្នកពូកែខាងចម្បាំង ។ តាមរយៈអំណោយទានទាំង២នេះ អាចធ្វើឱ្យគាត់ក្លាយជាមនុស្សដ៏ល្បីនៅក្នុងប្រទេសអ៊ីស្រាអែល ដែលអាចដឹកនាំប្រជាជាតិទាំងមូលឱ្យបានពេញជាព្រះវិញ្ញាណ និងគោលនយោបាយក្នុងប្រទេសដ៏មានប្រសិទ្ធិភាព(មើល ២សយ ២២ ២៣:១–៧) ។ ជាមួយគ្នានោះដែរ ដោយសារតែដាវីឌគាត់មានអំណោយទាន ទាំង២នេះ បានធ្វើឱ្យស្ដេចសូលមកពឹងពាក់លើដាវីឌ ។

**១៦:១៤** *ព្រះវិញ្ញាណនៃព្រះយេហូវ៉ា ក៏ដកថយចេញពីសូលទៅ* សូមធៀបជាមួយ ពច ១៦:២០ ។ ការដែលព្រះវិញ្ញាណបានថយចេញពីស្ដេចសូល ហើយទៅគង់នៅជាមួយដាវីឌ (មើល ខ.១៣) គឺមានភាពផ្ទុយគ្នាទៅនឹងជីវិតរស់របស់គេយ៉ាងខ្លាំង ។ *ព្រះយេហូវ៉ាទ្រង់ចាត់វិញ្ញាណអាក្រក់* នៅក្នុងប្រយោគនេះ និងប្រយោគមួយទៀតដែលមានការប្រហាក់ប្រហែលគ្នាដែលនិយាយថា វិញ្ញាណអាក្រក់គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអម្ចាស់ ហើយវាធ្វើការនៅក្នុងអំឡុងពេលដែលព្រះអម្ចាស់ជាអ្នកកំណត់ និងអនុញ្ញាតប៉ុណ្ណោះ (សូមមើល ១ពវ ២២:១៩–២៣ យប ១:១២ ២:៦ ២សយ ២៤:១ និងការពន្យល់) ។ វិញ្ញាណអាក្រក់នោះនៅតែបន្តការធ្វើទោសចំពោះការមិនស្ដាប់បង្គាប់របស់ស្ដេចសូល (មើល ខ.១៥–១៦,២៣ ១៨:១០ ១៩:៩) ។ *បំភ័យទ្រង់* ការទន់ជ្រាយរបស់ស្ដេចសូលបានធ្វើឱ្យគាត់ខូចចិត្តច្រណែនប្រព្រឹត្តរំលងបញ្ញត្តិ គឺកើតឡើងដោយសារតែការបដិសេធន៍ឈប់ឱ្យគាត់ធ្វើជាស្ដេច (មើល ១៣:១៣–១៤ ១៥:២២–២៦ ១៨:៩ ២០:៣០–៣៣ ២២:១៦–១៨) ហើយនិងសតិសម្បជញ្ញៈរបស់ដាវីឌដែលរីកចម្រើន ប៉ុន្តែវិញ្ញាណអាក្រក់ក៏មានទំនាក់ទំនងជាមួយចិត្តវិទ្យាដែលប្លែកៗ (មើល ១៨:១០–១២ ១៩:៩–១០) ។

**១៦:១៦** *ទ្រង់បានធូរព្រះទ័យ* ភាពសក្តិសិទ្ធិ លើវិញ្ញាណអាក្រក់ដែលកើតឡើងដោយសារការលេងភ្លេង ជានិច្ចកាលគេតែងតែទទួលស្គាល់ថាជាបាតុភូតចម្លែកមួយ (សូមមើល ២ពវ ៣:១៥) ។ ភាពសក្តិសិទ្ធរបស់ភ្លេងដែលមិនគួរឱ្យជឿនេះ វាអាចជាការមួយដែលកើតដើម្បីបង្ហាញថា ព្រះវិញ្ញាណនៃព្រះ គឺកំពុងតែរស់នៅ និងមានសកម្មភាពនៅក្នុងភ្លេងរបស់ដាវីឌ ដើម្បីបង្ក្រាបវិញ្ញាណអាក្រក់ជាបណ្ដោះអាសន្ន(សូមមើល ខ.២៣) ។

**១៦:១៨** *ព្រះយេហូវ៉ាទ្រង់ក៏គង់ជាមួយអ្នកនោះ* សម្ដីបែបនេះ លោកសាំយូអែលក៏បាននិយាយដែរ (សូមមើល ៣:១ និងការពន្យល់) ។ ផ្អែកលើសេចក្ដីពិត គឺព្រះអម្ចាស់គង់នៅជាមួយដាវីឌ (សូមមើល ១៧:៣៧ ១៨:១២, ១៤,២៨ ២សយ ៥:១០) គឺសំខាន់ជាងអ្វីៗទាំងអស់ ដែលស្ដេចដាវីឌមាននៅក្នុងពេលនោះទៀត ។

**១៦:១៩** *សូមឱ្យដាវីឌជាកូនអ្នក . . . មកឯយើង* ស្ដេចសូលមិនបានដឹងថាមនុស្សដែលទ្រង់អញ្ជើញមកក្នុងដំណាក់របស់ទ្រង់នោះ គឺជាមនុស្សដែលព្រះអម្ចាស់ទ្រង់បានរើសសម្រាប់ជំនួសកន្លែងទ្រង់នោះទេ ។ នៅក្នុងមធ្យោបាយនេះហើយដែលដាវីឌត្រូវបានជ្រើសតាំងឡើង ដើម្បីឱ្យមានទំនាក់ទំនងជាមួយស្ដេចសូល ហើយទ្រង់ក៏ត្រូវបានចាប់ផ្ដើមណែនាំដល់ពួកអ៊ីស្រាអែលដែរ ។

កូនថ្វាយដល់សូល ២១ដាវីឌក៏មកឯសូល ហើយឈរបំរើ
នៅចំពោះទ្រង់[អ] ក៏ជាទីគាប់ដល់ព្រះទ័យទ្រង់ណាស់ ហើយ
បានធ្វើជាអ្នកកាន់គ្រឿងសស្ត្រាវុធរបស់ទ្រង់ ២២រួចសូល
ចាត់គេឱ្យទៅប្រាប់អ៊ីសាយថា សូមឱ្យដាវីឌឈរបំរើ
នៅមុខយើងចុះ ពីព្រោះយើងពេញចិត្តនឹងវាណាស់
២៣ដូច្នេះ កាលណាវិញ្ញាណអាក្រក់ពីព្រះបានមកសណ្ឋិត
លើសូល នោះដាវីឌក៏យកស៊ុំងមកចាប់លេងថ្វាយ រួច
សូលទ្រង់បានធូរ ហើយស្រួលឡើងវិញ វិញ្ញាណអាក្រក់[ក]
ក៏ថយចេញពីទ្រង់ទៅ ។

## លោកដាវីឌនិងលោកកូលីយ៉ាត

**១៧** ១នៅគ្រានោះ ពួកភីលីស្ទីន គេលើកទ័ពមកដើម្បី
ច្បាំង ក៏មូលគ្នា[ក]នៅត្រង់សូគរ ជាស្រុករបស់ពួកយូដា
ហើយបោះទ័ពនៅកណ្តាលសូគរ[ខ] និងអាសេកា[គ] ត្រង់
អេភេស-ដាំមីម ២ឯសូលនិងពួកទ័ពអ៊ីស្រាអែល គេប្រមូល
គ្នាបោះទ័ពនៅច្រកភ្នំអេឡា[ឃ] ក៏ដំរៀបពល ដើម្បីច្បាំងនឹង
ពួកភីលីស្ទីន ៣ពួកភីលីស្ទីនគេឈរលើភ្នំម្ខាង ហើយពួក
អ៊ីស្រាអែលគេក៏ឈរលើភ្នំម្ខាង មានវាលច្រកភ្នំនៅជា
កណ្តាល ៤លំដាប់នោះ មានទាហានម្នាក់ឈ្មោះកូលីយ៉ាត[ង]
ដែលនៅក្រុងកាថ វាចេញពីពួកភីលីស្ទីនមក អ្នកនោះមាន
កំពស់៦ហត្ថ១ចំអាម ៥ពាក់មួកលង្ហិន ហើយពាក់អាវក្រោះ
ធ្វើពីលង្ហិន មានទំងន់៥ពាន់ដំឡឹង ៦ក៏មានស្រោមលង្ហិន
ស្រោបជើង ហើយមានប្រដាប់លង្ហិន[ច]បាំងពីខាងខ្នងដែរ
៧ឯដងលំពែងរបស់វា នោះប្រៀបដោយផ្សំនៃដំបាញ[ឆ]
ហើយផ្លែធ្វើពីដែក ទំងន់៦០០ដំឡឹង មានអ្នកកាន់ខែល[ជ]
ដើរពីមុខ ៨វាឈរស្រែកមកខាងពួកទ័ពអ៊ីស្រាអែលថា
ម្តេចក៏ឯងរាល់គ្នាចេញមកដំរៀបទ័ពសំរាប់ច្បាំងដូច្នេះ
តើអញមិនមែនជាសាសន៍ភីលីស្ទីន ហើយឯងរាល់គ្នាជា
ខ្ញុំរបស់សូលទេឬអី ចូររើស[ឈ]ម្នាក់ឱ្យចុះមកច្បាំងនឹងអញ
មើល ៩បើវាអាចនឹងតដៃសំឡាប់អញបាន នោះយើងនឹង
ធ្វើជាបាវបំរើឯង តែបើអញឈ្នះ ហើយសំឡាប់វាបាន
នោះឯងរាល់គ្នាត្រូវធ្វើជាបាវបំរើយើងវិញ ១០វាប្រកួត[ញ]
នឹងពួកទ័ពអ៊ីស្រាអែលថា នៅថ្ងៃនេះ ចូរឱ្យមនុស្សម្នាក់
ចេញមកតនឹងអញលមើលចុះ[ដ] ១១កាលសូលនិងពួក
អ៊ីស្រាអែលទាំងអស់ បានឮពាក្យរបស់សាសន៍ភីលីស្ទីន
នោះនិយាយដូច្នោះ គេក៏មានគំនិតវិលវល់ ហើយភ័យខ្លាច
ជាខ្លាំង ។
១២រីឯដាវីឌ ជាកូនរបស់ពួកអេប្រាតា[ឋ]ម្នាក់ នៅ
បេថ្លេហិម[ឌ]-យូដា ឈ្មោះអ៊ីសាយ[ឍ] ឯអ៊ីសាយមានកូនប្រុស
៨[ណ]នាក់ ហើយនៅជំនាន់ស្តេចសូល គាត់ចាស់ណាស់ មាន
វ័យកន្លងហើយ ១៣កូនប្រុសច្បងរបស់អ៊ីសាយ៣នាក់បាន
តាមសូលទៅច្បាំង កូនទាំង៣នាក់ ដែលទៅច្បាំងនោះ គឺ
ច្បងបង្អស់ឈ្មោះអេលាប[ត] បន្ទាប់មកឈ្មោះអ័ប៊ីន៉ាដាប់[ថ]
ហើយទី៣ឈ្មោះសាំម៉ា[ទ] ១៤អ្នកទាំង៣នោះបានតាមសូល
ទៅ ឯដាវីឌគាត់ជាកូនពៅ ១៥ក៏តែងធ្លាប់ទៅមកពីសូល
ទៅឯឪពុកនៅបេថ្លេហិមដើម្បីឃ្វាល[ធ]ចៀម[ន] ១៦រីឯសាសន៍
ភីលីស្ទីនម្នាក់នោះ វាចេះតែចូលមកជិត ទាំងព្រឹកទាំង
ល្ងាច ក៏ប្រកាសខ្លួនដូច្នោះអស់រវាង៤០ថ្ងៃ ។
១៧នៅគ្រានោះអ៊ីសាយប្រាប់ដាវីឌជាកូនថា ចូរឯង

**១៦:២១** អ លប ៤១:៤៦ **១៦:២៣** ក ខ.១៤ ពច ៩:២៣ **១៧:១** ក ១សយ ១៣:៥ ខ យស ១៥:៣៥ ២រប ២៨:១៨ គ យស ១០:១០,១១ **១៧:២** ឃ ១សយ ២១:៩ **១៧:៤** ង ១សយ ២១:៩ ២សយ ២១:១៩ **១៧:៦** ច ខ.៤៥ ១សយ ១៨:១០ **១៧:៧** ឆ ២សយ ២១:១៩ ១រប ១១:២៣ ២០:៥ ជ ខ.៤១ **១៧:៨** ឈ ២សយ ២:១២-១៧ **១៧:១០** ញ ខ.២៦,៤៥ ២សយ ២១:២១ **១៧:១០** ដ ខ.២៣ **១៧:១២** ឋ លប ៣៥:១៦ ៤៨:៧ ទដ ១៣២:៦ ឌ លប ៣៥:១៩ ឍ នរ ៤:១៧ ណ ១សយ ១៦:១១ **១៧:១៣** ត ១សយ ១៦:៦ ថ ១សយ ១៦:៨ ទ ១សយ ១៦:៩ **១៧:១៥** ធ លប ៣៧:២ ន ១សយ ១៦:១៩

**១៦:២១** *ជាទីគាប់ដល់ព្រះទ័យទ្រង់ណាស់ ហើយបានធ្វើជាអ្នកកាន់គ្រឿងសស្ត្រាវុធរបស់ទ្រង់* ប្រហែលជាសំដៅលើពេលក្រោយ គឺបន្ទាប់ពីដាវីឌទទួលជ័យជម្នះលើយក្សកូលីយ៉ាតរួចហើយ (សូមមើល ១៨:២) ។

**១៧:១** *សូគរ* មានចម្ងាយប្រមាណជា ២៤,១៣ គ.ម ភាគខាងលិចនៃភូមិបេថ្លេហិម (សូមមើល ២រប ២៨:១៨) ក្បែរព្រំប្រទល់ប្រទេសភីលីស្ទីន ។ *អាសេកា* មានចម្ងាយជាង ១.៦០ គ.ម នៅទិសពាយ័ព្យពីតំបន់ (ខាងជើងឈៀងខាងលិច) សូគរ ។

**១៧:២** *ច្រកភ្នំអេឡា* ច្រកភ្នំនេះស្ថិតនៅចន្លោះរវាងអាសេកា និងសូគរ ។

**១៧:៤** *ទាហាន* នៅប្រទេសក្រិកសម័យបូរាណ ទាហានរបស់ពួកភីលីស្ទីនប្រហែលជាត្រូវតែជាប់សាច់ញាត្តិ ពេលខ្លះការសម្រេចចិត្តលើបញ្ហាធ្វើសង្គ្រាម គឺធ្វើតាមរយៈការជ្រើសរើសទាហានដែលធ្លាប់ប្រយុទ្ធគ្នារវាងកងទ័ពទាំងសងខាង ។

**១៧:១១** *សូលនិងពួកអ៊ីស្រាអែលទាំងអស់ . . . ភ័យខ្លាចជាខ្លាំង* កងទ័ពដែលមានមាឌធំរបស់ពួកអ៊ីស្រាអែល(សូមមើល ៩:២ ១០:២៣) ឥឡូវនេះបែរជាភ័យខ្លាចចំពោះទ័ពភីលីស្ទីន ។ ការភ័យខ្លាចរបស់ស្តេចសូល និងកងទ័ពអ៊ីស្រាអែល (សូមមើល ខ.២៤,៣២) គឺកើតឡើងពីការបាត់បង់សេចក្តីជំនឿលើសេចក្តីសន្យារបស់ព្រះអម្ចាស់ ដែលទ្រង់បានតាំងជាមួយពួកគេ (សូមមើល នក ២៣:២២ ចទ ៣:២២ ២០:១-៤) ។ សេចក្តីភ័យខ្លាចនេះក៏បានបង្ហាញទៀតថា ពួកអ៊ីស្រាអែលបានស្វែងរកសុវត្ថិភាពផ្ទាល់ខ្លួនរបស់គេតាមរយៈស្តេចនៅក្នុងលោកិយ (មិនបានទុកចិត្តលើព្រះទាំងស្រុងទេ) ដែលបានចាញ់ និងដួលចុះទៅហើយ ។ ដោយផ្អែកលើគ្រឹះនៃសេចក្តីសន្យារបស់ព្រះអម្ចាស់ ដែលទ្រង់បានតាំងសញ្ញាជាមួយគេ ពួកអ៊ីស្រាអែលមិនត្រូវភ័យខ្លាចចំពោះខ្មាំងសត្រូវឡើយ ប៉ុន្តែត្រូវតែទុកចិត្តព្រះវិញ (សូមមើល ២សយ ១០:១២ នក ១៤:១៣-១៤ ជន ១៤:៩ យស ១០:៨ ២រប ២០:១៧) ។

**១៧:១២** *ពួកអេប្រាតា* សូមមើលការពន្យល់ នរ ១:២ ។

**១៧:១៥** *ធ្លាប់ទៅមកពីសូល ទៅឯឪពុកនៅបេថ្លេហិមដើម្បីឃ្វាលចៀម* ដោយសារតែដាវីឌមិនទាន់មានការងារជាអចិន្ត្រៃយ៍ នៅក្នុងវាំងនៅឡើយ (១៦:២១-២៣) ប៉ុន្តែ គ្រាន់តែធ្វើការងារណាដែលមិនសូវសំខាន់ប៉ុណ្ណោះ ។ ទំនាក់ទំនងរវាងជំពូក១៦ និង ១៧ មើលការពន្យល់ ខ.៥៥ ។

យកលាជ[ប]១ថាំង[ផ] និងនំបុ័ង១០ដុំនេះទៅ ឱ្យដល់ពួកបងឯង
នៅឯទីបោះទ័ពជាប្រញាប់ទៅ ១៨ហើយនាំយកទឹកដោះ
ខ:១០ផែននេះ ទៅជូនដល់មេទ័ពរបស់វាទៅ រួចចូរមើល
ដែលបងឯង[ព]សុខសប្បាយ ឬយ៉ាងណា ហើយនាំយករបស់
អ្វី១ ជាគ្រឿងសំគាល់ពីវាមកវិញ ១៩ចំណែកសូល និងអ្នក
ទាំង៣នោះ ព្រមទាំងពួកអ៊ីស្រាអែលទាំងអស់ គេនៅច្រក
ភ្នំអេឡា កំពុងតែច្បាំងនឹងពួកភីលីស្ទីន ២០ដូច្នេះ ដាវីឌក៏
ក្រោកពីព្រលឹមប្រគល់ចៀមទុកនឹងអ្នកគង្វាលម្នាក់ រួចយក
អីវ៉ាន់ចេញទៅ ដូចជាឪពុកបានបង្គាប់ ក៏បានទៅដល់ទី
បោះទ័ព ក្នុងកាលដែលពួកពលកំពុងតែចេញទៅឯទី
ចំបាំង ទាំងស្រែកសំរែកសង្គ្រាម ២១ហើយពួកអ៊ីស្រាអែល
និងពួកភីលីស្ទីន គេដំរៀបទ័ពប្រទល់គ្នា រៀបនឹងតដៃ
ហើយ ២២ដាវីឌក៏ប្រគល់អីវ៉ាន់ទុកនឹងអ្នកដែលរក្សាអីវ៉ាន់
របស់ពួកទ័ព[ភ] រួចរត់ចូលទៅក្នុងចំណោមទ័ព ដើម្បីនឹង
ជិរាបសួរដល់ពួកបង ២៣គ្រាដែលកំពុងតែនិយាយនឹងពួក
បង នោះមើល ទាហានរបស់សាសន៍ភីលីស្ទីនម្នាក់នោះ
ពីក្រុងកាថ ឈ្មោះកូលីយ៉ាត ក៏ចេញពីខាងទ័ពភីលីស្ទីន
មកប្រកាសជាពាក្យដដែល[ម]ទៀត ហើយដាវីឌក៏បានឮ
២៤កាលពួកអ៊ីស្រាអែលទាំងប៉ុន្មាន បានឃើញអ្នកនោះ
គេក៏រត់ពីវាទៅ ដោយភ័យខ្លាចជាខ្លាំង ២៥រួចពួកអ៊ីស្រា
អែលនិយាយគ្នាថា បានឃើញមនុស្សនោះ ដែលឡើងមក
ឬទេ វាបានឡើងមក ដើម្បីប្រកួតនឹងសាសន៍អ៊ីស្រាអែល
យើងនេះជាប្រាកដ បើអ្នកណាសំឡាប់វាបាន នោះស្តេច
នឹងប្រទានទ្រព្យសម្បត្តិដ៏វិសេស ដល់អ្នកនោះ ព្រមទាំងឱ្យ
ព្រះរាជបុត្រី[យ]ទ្រង់ផង ក៏នឹងប្រោសប្រណី ដល់គ្រួឪពុក
របស់អ្នកនោះ ឱ្យរួចពន្ធ[រ]ក្នុងសាសន៍អ៊ីស្រាអែលតទៅ

**១៧:១៧** ប លវ ២៣:១៤ ផ លវ ១៩:៣៦
**១៧:១៨** ព លប ៣៧:១៤
**១៧:២២** ភ យស ១:១១
**១៧:២៣** ម ខ.៨–១០
**១៧:២៥** យ ១សយ ១៨:១៧ រ ១សយ ៨:១៥
**១៧:២៦** ល ១សយ ១១:២ វ ១សយ ១៤:៦ ស ខ.១០ ហ ចទ ៥:២៦ យស ៣:១០ ២ពវ ១៨:៣៥
**១៧:២៨** ឡ លប ២៧:៤១ សភ ១៨:១៩
**១៧:៣២** អ ចទ ២០:៣ ទដ ១៨:៤៥ អស ៧:៤ យរ ៤:៩ ៣៨:៤ ដយ ១១:៣០
**១៧:៣៣** ក ជន ១៣:៣១

២៦ដូច្នេះ ដាវីឌក៏សួរដល់ពួកអ្នកដែលឈរនៅជិតថា ឯអ្នក
ណាដែលនឹងសំឡាប់សាសន៍ភីលីស្ទីននេះ ហើយដកសេចក្តី
ដំនៀល[ល]ពីអ៊ីស្រាអែលចេញ នោះនឹងបានដូចម្តេចខ្លះ ដ្បិត
តើសាសន៍ភីលីស្ទីនដែលឥតកាត់ស្បែកនេះជាអ្វី[វ] បានជា
ហ៊ានប្រកួត[ស]នឹងពលទ័ពនៃព្រះដ៏មានព្រះជន្មរស់[ហ]ដូច្នេះ
២៧គេក៏ឆ្លើយប្រាប់តាមពាក្យដដែលនោះថា អ្នកណាដែល
នឹងសំឡាប់វាបាន នោះនឹងបានដូច្នេះឯង ។
២៨គ្រាដែលដាវីឌកំពុងនិយាយនឹងគេ នោះអេលាប
ជាបងបង្អស់ក៏ឮ ហើយកើតមានសេចក្តីកំហឹង[ឡ]ទាស់នឹង
ប្អូនថា ឯងបានចុះមកធ្វើអី តើបានប្រគល់ហ្វូងចៀមតូច
នោះ ដែលនៅទីរហោស្ថានទុកនឹងអ្នកណា អញស្គាល់
សេចក្តីអំនួត និងសេចក្តីអាក្រក់ ដែលនៅក្នុងចិត្តឯងហើយ
ដ្បិតឯងបានចុះមកដើម្បីឱ្យតែបានមើលចំបាំងទេ ២៩តែ
ដាវីឌឆ្លើយថា តើខ្ញុំមានធ្វើអី ខ្ញុំគ្រាន់តែនិយាយ១ម៉ាត់
ទេតើ ៣០រួចក៏បែរចេញពីបងទៅសួរម្នាក់ទៀត តាមពាក្យ
ដដែលនោះ ហើយគេឆ្លើយប្រាប់ដូចជាពាក្យមុន ។
៣១កាលគេបានឮពាក្យ ដែលដាវីឌនិយាយដូច្នោះ នោះ
គេនាំដំណឹងទៅក្រាបទូលដល់សូល រួចទ្រង់ចាត់គេឱ្យទៅ
ហៅដាវីឌមក ៣២ដាវីឌទូលដល់សូលថា សូមកុំឱ្យអ្នក
ណាស្លុតចិត្ត[អ]ដោយព្រោះវាឡើយ ទូលបង្គំជាបាវបំរើ
របស់ទ្រង់នឹងសូមចេញទៅតយុទ្ធនឹងសាសន៍ភីលីស្ទីននោះ
៣៣តែសូលទ្រង់មានបន្ទូល[ក]ថា ឯងនឹងចេញទៅតយុទ្ធនឹង
សាសន៍ភីលីស្ទីននោះមិនបានទេ ដ្បិតឯងនៅក្មេងណាស់
ឯគេជាមនុស្សស្ទាត់ចំបាំងតាំងតែពីក្មេងមកហើយ ៣៤នោះ
ដាវីឌដំណាលរឿងទូលសូលថា ពីដើមដែលទូលបង្គំជា
បាវបំរើទ្រង់ ធ្លាប់ឃ្វាលចៀមរបស់ឪពុកនោះ វេលាណា

**១៧:២៤** *ភ័យខ្លាចជាខ្លាំង* សូមមើលការពន្យល់ ខ.១១ ។

**១៧:២៥** *ស្តេចនឹងប្រទានទ្រព្យសម្បត្តិដ៏វិសេស* មើល ៨:១៤ ២២:៧ *ព្រមទាំងឱ្យព្រះរាជបុត្រីទ្រង់ផង* សូមមើល ១៨:១៧–២៧ ធៀបជាមួយ យស ១៥:១៦ ។

**១៧:២៦,៣៦** *ឥតកាត់ស្បែក* សូមមើលការពន្យល់ ១៤:៦ ។

**១៧:២៦** *ដ្បិតតើសាសន៍ភីលីស្ទីន . . . ជាអ្វី* ដាវីឌបានយល់ពីដំណើររឿងនេះយ៉ាងច្បាស់ គាត់ក៏បានចេញពីស្តេចសូល និងពួកអ៊ីស្រាអែលទាំងអស់នៅក្នុងទីវាលចម្បាំងទៅម្ខាង ។ ដោយសារតែពួកភីលីស្ទីនបានវាយលុក និងការពួនក្រាបរបស់សូល និងទាហានរបស់ទ្រង់នោះការមកដល់នៃនគរព្រះនៅក្នុងលោកិយតាមរយៈ មធ្យោបាយរបស់ព្រះអម្ចាស់ចំពោះអ៊ីស្រាអែលគឺស្ថិតក្នុងជិវិរបស់ពួកទាហាន ។ ដាវីឌហាក់បីដូចជាមានទំនុកចិត្តថា នឹងធ្វើបាន ។ ដាវីឌគឺជាម្នាក់ដែលមានតម្លៃជាងស្តេចសូល ឬអ្នកផ្សេងៗទៀត នៅទីនេះធ្វើឱ្យគាត់សាកសមនឹងទទួលការបំពាក់មកុដនៅក្នុងប្រទេសអ៊ីស្រាអែល ។

**១៧:២៨** *កើតមានសេក្តីកំហឹង* កំហឹងរបស់លោកអេលាបប្រហែលជាកើតឡើងដោយសារការច្រណែនចំពោះប្អូន ។

**១៧:៣២** *សូមកុំឱ្យអ្នកណា . . . តយុទ្ធនឹងសាសន៍ភីលីស្ទីន* ដាវីឌមានទំនុកចិត្តថា កម្លាំងរបស់គាត់មិនអាចយកឈ្នះលើទាហានភីលីស្ទីនបានឡើយ (ខ.៣៧,៤៧) ប៉ុន្តែគឺដោយសារតែអំណាច និងកម្លាំងដ៏រស់នៃព្រះអម្ចាស់វិញ ដែលកិត្តិយសរបស់ទ្រង់ត្រូវបានពួកភីលីស្ទីនបំពានលើ ហើយដែលសេចក្តីសន្យារបស់ទ្រង់ត្រូវបានពួកអ៊ីស្រាអែលមើលងាយវិញ ។

**១៧:៣៣** *មិនបានទេ* ស្តេចសូលមិនបានដឹងពីអំណាចរបស់ព្រះឡើយ (សូមមើល ខ.៣៧, ៤៧) ។

**១៧:៣៤** *សិង្ហ ឬខ្លាឃ្មុំ* សម្រាប់សត្វសិង្ហ និងខ្លាឃ្មុំនៅស្រុកកាណានក្នុងសម័យកាលនោះ សូមមើល ២សយ ១៧:៨ ២៣:២០ ពច ១៤:៥–១១ ១ពវ ១៣:២៤–២៦ ២ពវ ២:២៤ អម ៣:១២ ៥:១៩ ។

ដែលមានសិង្ហ[ខ] ឬខ្លាឃ្មុំ មកចាប់យកកូនចៀមពីហ្វូងទៅ
៣៥ទូលបង្គំក៏ដេញតាមប្រហារវា ដោះចៀមនោះឱ្យរួច
ចេញពីមាត់វាមក បើកាលណាវាស្ទុះមកលើទូលបង្គំ នោះ
ទូលបង្គំបានចាប់[គ]វាត្រង់ពុកចង្កាវាយសំឡាប់ទៅ ៣៦ទូល
បង្គំជាបាវបំរើទ្រង់ បានប្រហារទាំងសត្វសិង្ហ[ឃ] និងខ្លាឃ្មុំ
ផង ដូច្នេះ សាសន៍ភីលីស្ទីន ដែលឥតកាត់ស្បែកនេះ នឹង
បានដូចជាសត្វ១នោះដែរ ដ្បិតវាបានប្រកួតនឹងពលទ័ពនៃ
ព្រះដ៏មានព្រះជន្មរស់ហើយ ៣៧ដាវីឌក៏ទូលទៀតថា ឯព្រះ
យេហូវ៉ា ជាព្រះដែលបានជួយ[ង]ទូលបង្គំ ឱ្យរួចពីក្រចក
សិង្ហ[ច] និងខ្លាឃ្មុំ ទ្រង់ក៏នឹងជួយឱ្យរួចពីកណ្ដាប់ដៃសាសន៍
ភីលីស្ទីននោះដែរ ខណនោះ សូលមានបន្ទូលថា ដូច្នេះ ចូរ
ទៅចុះ សូមឱ្យព្រះយេហូវ៉ាគង់ជាមួយ[ឆ]នឹងឯង ៣៨ទើប
ស្ដេចបំពាក់គ្រឿងរបស់ទ្រង់[ជ]ឱ្យដាវីឌ គឺមួកលង្ហិននៅ
លើក្បាល និងអាវក្រោះដែរ ៣៩នោះដាវីឌក៏ក្រវាត់ដាវ
ពីលើគ្រឿងប្រដាប់នោះ ហើយខំដើរល្បងមើល ដ្បិតមិន
ដែលបានលម្ដងសោះ រួចទូលទៅសូលថា ទូលបង្គំនឹងពាក់
គ្រឿងទាំងនេះទៅមិនបានទេ ដ្បិតទូលបង្គំមិនដែលលម្ដង
ឡើយ ដូច្នេះ ដាវីឌក៏ដោះគ្រឿងទាំងនោះចេញ ៤០រួចយក
តែដំបងរបស់ខ្លួនមកកាន់នៅដៃ ហើយរើសក្រួសរលីងៗ
ចំនួន៥ដុំពីក្នុងទឹកជ្រោះដាក់ចុះក្នុងយាម គឺក្នុងប្លោករបស់
ខ្លួន ហើយកាន់ខ្សែដង្ហក់នៅដៃ ដើរដំរង់ចូលទៅឯសាសន៍
ភីលីស្ទីននោះ។

៤១ចំណែកសាសន៍ភីលីស្ទីននោះ ក៏ដើរចូលមកឯដាវីឌ
មានទាំងអ្នកកាន់ខែលដើរពីមុខ[ឈ]ផង ៤២កាលវាក្រឡេក
ឃើញដាវីឌ នោះក៏តាំងចិត្តមើលងាយ[ញ] ដោយព្រោះដាវីឌ
នៅក្មេង មានថ្ពាល់ក្រហម ហើយមានរូបឆោមស្រស់ល្អ[ដ]
៤៣រួចវានិយាយទៅដាវីឌថា តើអញជាឆ្កែឬអី[ឋ] បានជាឯង
មកឯអញទាំងកាន់ដំបងដូច្នេះ ហើយក៏ប្រទេចផ្ដាសាដល់
ដាវីឌដោយនូវព្រះរបស់វា ៤៤រួចប្រាប់ថា ចូរមកឯអញចុះ
អញនឹងឱ្យសាច់ឯង ដល់សត្វហើរលើអាកាស[ឌ] និងសត្វព្រៃ
ផង[ឍ] ៤៥ដាវីឌឆ្លើយតបទៅវិញថា ចំណែកឯងបានមកឯ
អញ ទាំងកាន់ដាវកាន់លំពែង ហើយនិងដែកព្ចួយ[ណ]ផង តែ
ឯអញវិញ អញមកឯងដោយនូវព្រះនាម[ត]របស់ព្រះយេហូ–
វ៉ា នៃពួកពលបរិវារ គឺជាព្រះនៃពួកពលសាសន៍អ៊ីស្រា
អែល ដែលឯងបានប្រកួតនឹងគេនោះ[ថ] ៤៦នៅថ្ងៃនេះ
ព្រះយេហូវ៉ានឹងប្រគល់[ទ]ឯង មកក្នុងកណ្ដាប់ដៃនៃអញ
ហើយ អញនឹងវាយឯង ហើយនិងកាត់យកក្បាលឯងទៅ
នៅថ្ងៃនេះ អញនឹងឱ្យខ្មោច[ធ]នៃពួកទ័ពភីលីស្ទីនដល់សត្វ
ហើរនៅលើអាកាស និងដល់សត្វព្រៃនៅផែនដីវិញ ដើម្បី
ឱ្យផែនដី[ន]ទាំងមូលបានដឹងថា មានព្រះនៅខាងពួកអ៊ីស្រា
អែលពិត[ប] ៤៧ហើយឱ្យជំនុំមនុស្សទាំងនេះ បានដឹងថា
ព្រះយេហូវ៉ា ទ្រង់មិនជួយសង្គ្រោះ[ផ] ដោយសារដាវ[ព]
ឬលំពែងទេ ដ្បិតចំបាំង[ភ]នេះស្រេចនៅព្រះយេហូវ៉ាវិញ
គឺទ្រង់នឹងប្រគល់ឯងរាល់គ្នាមកក្នុងកណ្ដាប់ដៃនៃយើង
៤៨កាលសាសន៍ភីលីស្ទីនម្នាក់នោះបានចូលមកជិត ដើម្បី
ជួបនឹងដាវីឌហើយ នោះដាវីឌក៏ប្រញាប់ប្រញាល់រត់ចូល
ទៅខាងគេ ដើម្បីជួបគ្នា ៤៩ទើបលូកដៃទៅក្នុងយាម ចាប់

**១៧:៣៤** ខ យបប ១០:១៦ អស ៣១:៤ យរ ៤៩:១៩ ហស ១៣:៨ អម ៣:១២ **១៧:៣៥** គ ពច ១៤:៦ **១៧:៣៦** ឃ ១របា ១១:២២ **១៧:៣៧** ង ១រប ១:១០ ច ២ធថ ៤:១៧ ឆ ១សយ ១៦:១៨ ១៨:១២ **១៧:៣៨** ជ លប ៤១:៤២ **១៧:៤១** ឈ ខ.៧ **១៧:៤២** ញ ទដ ១២៣:៣–៤ សភ ១៦:១៨ ដ ១សយ ១៦:១២ **១៧:៤៣** ឋ ១សយ ២៤:១៤ ២សយ ៣:៨ ៩:៨ ២ពវ ៨:១៣ **១៧:៤៤** ឌ លប ៤០:១៩ វវ ១៩:១៧ **១៧:៤៤** ឍ ២សយ ២១:១០ យរ ៣៤:២០ **១៧:៤៥** ណ ខ.៦ ត ចទ ២០:១ ២រប ១៣:១២ ១៤:១១ ៣២:៨ ទដ ២០:៧–៨ ១២៤:៨ ហព ១១:៣២–៣៤ ថ ខ.១០ **១៧:៤៦** ទ ១សយ ១៤:១២ ធ ចទ ២៨:២៦ ន យស ៤:២៤ អស ១១:៩ ប ១ពវ ១៨:៣៦ ២ពវ ៥:៨ ១៩:១៩ អស ៣៧:២០ **១៧:៤៧** ផ ១សយ ១៤:៦ ២រប ១៤:១១ យរ ៣៩:១៨ ព ហស ១:៧ ភ នក ១៤:១៤ ជន ២១:១៤ ១សយ ២:៩ ២រប ២០:១៥ ទដ ៤៤:៦–៧

**១៧:៣៧** *ជាព្រះដែលបានជួយទូលបង្គំ* សេចក្ដីសង្ឃឹមលើព្រះអម្ចាស់ គឺជាសេចក្ដីសំខាន់សម្រាប់ស្ដេចដ៏ពិតប្រាកដ (មើលការ ១០:១៨ ១១:១៣) ។ នៅទីនេះសេចក្ដីជំនឿរបស់ដាវីឌ គឺវាផ្ទុយគ្នាទាំងស្រុងជាមួយការបាត់បង់សេចក្ដីជំនឿរបស់ស្ដេចសូល (សូមមើល ១១:៦–៧ សម្រាប់ការមិនកោតខ្លាចព្រះរបស់ស្ដេចសូលកាលពីគ្រាមុន) ។ *សូលមានបន្ទូលថា ដូច្នេះចូរទៅចុះ* ឥឡូវនេះស្ដេចសូលបានពឹងផ្អែកទាំងស្រុងទៅលើដាវីឌ មិនមែនគ្រាន់តែដើម្បីឱ្យគាត់បានជាពីជម្ងឺប៉ុណ្ណោះនោះឡើយ ប៉ុន្តែគឺទាំងសុវត្ថិភាពនគររបស់ទ្រង់ថែមទៀត ។ *សូមឱ្យព្រះយេហូវ៉ាគង់ជាមួយនឹងឯង* សូមមើល ១៦:១៨ ។

**១៧:៤០** *យកតែដំបងរបស់ខ្លួន* ចំណាត់តាំងអ្នកគង្វាលថ្មីរបស់ព្រះអម្ចាស់សម្រាប់ធ្វើជាអ្នកគង្វាលលើរាស្ត្រទ្រង់ (សូមមើល ២សយ ៥:២ ៧:៧ ទដ ៧៨:៧២) គឺបានចេញទៅដោយតំណាងឱ្យសង្គ្រាមរបស់ព្រះអម្ចាស់ នឹងបំភ័យដល់ហ្វូងមនុស្សដែលជាខ្មាំងសត្រូវ ។ *ក្រួស* សូមមើល ពច ២០:១៦ ។ តាមធម្មតា គេរើសក្រួសនៅជុំវិញខ្លួនគេហើយរលីង និងមានទំហំធំជាងបាល់ដែលគេលេងក្នុងកីឡាបេហ្សប៊ល ។ *ខ្សែដង្ហក់* សម្រាប់ការសម្លាប់របស់លោកបេនយ៉ាមីនដោយប្រើខ្សែដង្ហក់ មើលការពន្យល់ ពច ២០:១៦ ។

**១៧:៤៣** *តើអញជាឆ្កែឬអី* សូមមើល ២សយ ៩:៨ និងការពន្យល់ ។

**១៧:៤៥** *ដោយនូវព្រះនាមរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ* កម្លាំងរបស់ដាវីឌ គឺសង្ឃឹមពឹងលើព្រះអម្ចាស់ (សូមមើល ទដ ៩:១០) ។ *ដោយនូវព្រះនាមរបស់ព្រះយេហូវ៉ា* មើលការពន្យល់ នក ៣:១៣–១៤ ចទ ១២:១១ ។

**១៧:៤៦** *ដើម្បីឱ្យផែនដីទាំងមូលបានដឹង* ជ័យជម្នះដែលដាវីឌបានធ្វើការរំពឹងទុកជាមុននេះ នឹងបានបង្ហាញដល់គ្រប់គ្នាឱ្យបានដឹងថា ព្រះរបស់ពួកអ៊ីស្រាអែលជាព្រះដែលមានវត្តមាន ហើយមានដោយអំណាចព្រះចេស្ដា (សូមមើល នក ៧:១៧ ៩:១៤,១៦,២៩ ចទ ៤:៣៤–៣៥ យស ២:១០–១១ ៤:២៣–២៤ ១ពវ ៨:៥៩–៦០ ១៨:៣៦–៣៩ ២ពវ ៥:១៥ ១៩:១៩) ។

**១៧:៤៧** *ចំបាំងនេះស្រេចនៅព្រះយេហូវ៉ា* ទាំងកងទ័ពអ៊ីស្រាអែល និងកងទ័ពភីលីស្ទីន នឹងបានឃើញពីកំហុសឆ្គងនៃការទុកចិត្តចំពោះការដឹកនាំរបស់មនុស្សដែលចង់បាននូវសុវត្ថិភាពផ្ទាល់ខ្លួន ឬសម្រាប់ប្រជាជាតិរបស់គេ(សូមមើល ២:១០ ១៤:៦ ២រប ១៤:១១ ២០:១៥ ទដ ៣៣:១៦–២២ ៤៤:៦–៧ សស ៩:១១ ហស ១:៧ សក ៤:៦) ។

យកគ្រួស១គ្រាប់បាញ់ទៅ ត្រូវចំត្រង់ថ្ងាសនៃសាសន៍
ភីលីស្ទីននោះទ្រុឌចូលទៅក្នុងថ្ងាស ហើយវាដួលផ្កាប់មុខ
នៅដីទៅ ។
៥០ដូច្នេះ ដាវីឌបានឈ្នះសាសន៍ភីលីស្ទីនម្នាក់នោះ
ដោយសារតែខ្សែដង្ហក់[ម] និងគ្រួស១គ្រាប់ប៉ុណ្ណោះ គឺបាន
ប្រហារសាសន៍ភីលីស្ទីននោះឱ្យស្លាប់ទៅ ដោយឥតមាន
កាន់ដាវនៅដៃឡើយ ៥១រួចក៏រត់ទៅឈរនៅលើវា ចាប់
ហូតយកដាវ[យ]របស់វាចេញពីស្រោមមកសំឡាប់វាទៅ
ព្រមទាំងកាត់បណ្តាច់[រ]ក្បាលចេញ កាលពួកទ័ពភីលីស្ទីន
បានឃើញថា ទាហានដំណាងរបស់គេបានស្លាប់ហើយ
នោះគេក៏រត់អស់រលីងទៅ ៥២ឯពួកអ៊ីស្រាអែលនិងពួក
យូដា ក៏ក្រោកឡើងស្រែកហ៊ោទាំងអស់គ្នា ដេញតាមពួក
ភីលីស្ទីនទៅក្នុងវាលច្រកភ្នំ រហូតដល់ទ្វារក្រុងអេក្រុន
ហើយពួកភីលីស្ទីនដែលត្រូវរបួស គេក៏ដួលតាមផ្លូវដែល
ទៅឯស្អារ៉ែម[ល] រហូតដល់ក្រុងកាថ និងក្រុងអេក្រុន[វ]
៥៣នោះពួកកូនចៅអ៊ីស្រាអែល គេវិលត្រឡប់ពីដេញតាម
ពួកភីលីស្ទីនមកវិញ ចូលប្លន់ទីបោះទ័ពរបស់គេ ៥៤ចំណែក
ដាវីឌក៏យកក្បាលនៃសាសន៍ភីលីស្ទីននោះ នាំទៅដល់ក្រុង
យេរូសាឡិមឯគ្រឿងប្រដាប់វាទាំងប៉ុន្មាន នោះក៏យកទៅ
ទុកនៅក្នុងត្រសាលរបស់ខ្លួន ។
៥៥រីឯកាលសូលទ្រង់ឃើញដាវីឌ[ស]ចេញទៅទាស់នឹង
សាសន៍ភីលីស្ទីន នោះក៏សួរអ័ប៊ីនើរជាមេទ័ពទ្រង់ថា
អ័ប៊ីនើរអើយ តើក្មេងនោះជាកូនអ្នកណា អ័ប៊ីនើរ[ហ]ទូល
ឆ្លើយថា ឱព្រះករុណាអើយ ទូលបង្គំស្បថដោយនូវព្រះជន្ម
ទ្រង់ដ៏រស់នៅថា ទូលបង្គំមិនដឹងសោះឡើយ ៥៦ស្តេចក៏
បង្គាប់ថា ចូរស៊ើបសួរមើល តើក្មេងជំទង់នេះជាកូនអ្នក
ណា ៥៧ដូច្នេះ កាលដាវីឌបានត្រឡប់មកពីសំឡាប់សាសន៍
ភីលីស្ទីនវិញ នោះអ័ប៊ីនើរក៏នាំចូលមកនៅចំពោះសូល
មានទាំងក្បាលនៃសាសន៍ភីលីស្ទីននោះកាន់នៅដៃ ៥៨សូល
ទ្រង់សួរថា អ្នកកំឡោះអើយ តើឯងជាកូនអ្នកណា នោះ
ដាវីឌទូលឆ្លើយថា ទូលបង្គំជាកូនរបស់អ៊ីសាយ[ឡ]ជាអ្នកបំរើ
ទ្រង់ ដែលនៅក្រុងបេថ្លេហិម ។

## ស្តេចសូលច្រណែននឹងដាវីឌ

**១៨** ១លុះកាលដាវីឌទូលទៅសូលរួចហើយ នោះចិត្ត
យ៉ូណាថាន[ក]ក៏មូលជាប់នឹងចិត្តគាត់ ហើយយ៉ូណាថានបាន
ស្រឡាញ់[ខ]ដាវីឌទុកដូចជាខ្លួនលោកដែរ[គ] ២នៅថ្ងៃនោះ
សូលទ្រង់ក៏ទទួលដាវីឌ មិនឱ្យត្រឡប់ទៅឯផ្ទះឪពុកវិញ
ទៀតទេ ៣ខណនោះ យ៉ូណាថានបានតាំងសញ្ញា[ឃ]នឹងដាវីឌ
ពីព្រោះលោកស្រឡាញ់ដាវីឌ ដូចជាខ្លួនរបស់លោក
៤លោកក៏ដោះអាវ[ង]ដែលលោកពាក់ ប្រគល់ឱ្យដល់ដាវីឌ
ព្រមទាំងសំលៀកបំពាក់របស់លោក និងដាវ ធ្នូ ហើយនិង
ខ្សែក្រវាត់ផង[ច] ៥គ្រានោះ ដាវីឌត្រាច់ទៅគ្រប់ទីកន្លែងតាម
ដែលសូលទ្រង់ប្រើ ហើយក៏តែងប្រព្រឹត្តដោយប្រាជ្ញា[ឆ] រួច

**១៧:៥០** ម ១សយ ២៥:២៩
**១៧:៥១** យ ១សយ ២១:៩ ២២:១០ រ ហព ១១:៣៤
**១៧:៥២** ល យស ១៥:៣៦ វ យស ១៥:១១
**១៧:៥៥** ស ១សយ ១៦:២១ ហ ១សយ ២៦:៥
**១៧:៥៨** ឡ នរ ៤:១៧
**១៨:១** ក ១សយ ១៩:១ ២០:១៦ ៣១:២ ២សយ ៤:៤ ខ ២សយ ១:២៦ គ លប ៤៤:៣០
**១៨:៣** ឃ ១សយ ២០:៨,១៦,១៧,៤២ ២២:៨ ២៣:១៨ ២៤:២១ ២សយ ២១:៧
**១៨:៤** ង លប ៤១:៤២ ច ២សយ ១៨:១១
**១៨:៥** ឆ ខ.៣០

---

**១៧:៥១** *កាត់បណ្តាច់ក្បាលចេញ* សូមមើល ៥:៤ ៣១:៩ និងការពន្យល់ ។ *គេក៏រត់អស់រលីង* ភាគច្រើននៃពួកភីលីស្ទីន បានឃើញទាហានដែលប្រៀបបានទៅព្រះរបស់គេបានដួលចុះ ប៉ុន្តែពួកគេមិនបានរក្សាចំពោះសេចក្តីស្នើសុំរបស់លោកកូលីយ៉ាតកាលពីគ្រាមុននោះឡើយ (សូមមើល ខ.៩) ។
**១៧:៥៤** *នាំទៅដល់ក្រុងយេរូសាឡិម* នៅពេលនេះ ពួកអ៊ីស្រាអែលមិនទាន់វាយបានទីក្រុងយេរូសាឡិមទេ ។ ប្រហែលជាដាវីឌ ត្រូវរក្សាក្បាលកូលីយ៉ាតទុកជាជ័យភ័ណ្ឌនៃជ័យជម្នះ ហើយនាំយកលលាដ៏ក្បាលនេះទៅក្រុងយេរូសាឡិមជាមួយគាត់ នៅពេលដែលពួកអ៊ីស្រាអែលដណ្តើមក្រុងនេះបានមកវិញ (សូមមើល ២សយ ៥:៦–៩) ឬមួយគាត់បានតាំងក្បាលកូលីយ៉ាតដើម្បីបង្ហាញដល់ពួកអ្នកស្រុកពីការរឹងទទឹងរបស់ពួកគេ ទុកជាការព្រមាន និងបង្ហាញពីសមត្ថភាពរបស់ព្រះនៃសាសន៍អ៊ីស្រាអែល ។
**១៧:៥៥** *តើក្មេងនោះជាកូនអ្នកណា* មើលទៅវាមិនមែនអ្វីដែលខុសគ្នាឡើយរវាង ខ.៥៥–៥៨ និង ១៦:១៦–២៣ ។ នៅក្នុងអំឡុងពេលនេះ ប្រហែលជាគ្មានដំណោះស្រាយអ្វីឡើយ ដាវីឌមិនបានប្រចាំការនៅក្នុងដំណាក់ស្តេចសូលជាអចិន្ត្រៃយ៍នោះឡើយ (មើល ខ.១៥ ១៨:២ និងការពន្យល់ ១៦:២១) ដូច្នេះហើយ ការគិតរបស់ស្តេចសូលចំពោះដាវីឌ និងក្រុមគ្រួសារគាត់ប្រហែលជាតិចតួចបំផុត ។
**១៨:១** នៅក្នុងខនេះដាវីឌបាននិយាយទៅស្តេចសូលអស់រយៈពេលយ៉ាងយូរ ហើយប្រហែលជាគាត់បានពន្យល់អំពីសកម្មភាព និងទង្វើដែលគាត់បានទុកចិត្ត ជឿដល់ព្រះអម្ចាស់ ដូច្នេះហើយបានជាយ៉ូណាថានស្រឡាញ់ និងមានចំណាប់អារម្មណ៍ចំពោះដាវីឌ ។ មិត្តភាពរបស់ពួកគេនៅស្ថិតស្ថេរយូរអង្វែង ទោះបីជាពេលដែលគាត់បានដឹងថា ដាវីឌជាអ្នកជំនួសកន្លែងបិតារបស់គាត់ក៏ដោយ ។
**១៨:២** *សូលទ្រង់ក៏ទទួលដាវីឌ* សូមមើលការពន្យល់ ១៧:១៥ ។
**១៨:៣** *យ៉ូណាថានបានតាំងសញ្ញានឹងដាវីឌ* ដើមគំនិតនេះ គឺចេញពីលោកយ៉ូណាថាន ។ ពេលវេលាដែលពួកគេព្រមព្រៀងគ្នានេះ មិនបានដឹងច្បាស់ឡើយ (សូមមើល ១៩:១ ២០:៨,១២–១៦,៤១–៤២ ២៣:១៨) ប៉ុន្តែ អាចកើតឡើងនៅពេលដែលគេបានធ្វើការសន្យាជាមួយគ្នាទៅវិញទៅមក ។ យ៉ូណាថានបានទទួលដាវីឌ និងឱ្យមានសិទ្ធិស្មើគ្នា ។
**១៨:៤** *ដោះអាវដែលលោកពាក់ ប្រគល់ឱ្យដល់ដាវីឌ* លោកយ៉ូណាថានបានបង្ហាញពីសច្ចាប័ននៅក្នុងសេចក្តីសញ្ញា ដោយប្រគល់អាវទុកជានិមិត្តរូបនៃខ្លួនគាត់ទៅចំពោះដាវីឌ ។ ទង្វើរបស់គាត់បង្ហាញថា គាត់ព្រមទទួលស្គាល់ថា ដាវីឌនឹងក្លាយជាអ្នកជំនួសកន្លែងស្តេចសូល ដែលជាបិតារបស់គាត់ដោយជោគជ័យ (សូមមើល ២០:១៤–១៥,៣១ ២៣:១៧) ហើយវាក៏បញ្ជាក់ទៀតថា លោកយ៉ូណាថានបានឱ្យដល់ដាវីឌ "ទោះបីជាដាវគាត់ ធ្នូគាត់ ហើយនិងខ្សែ ក្រវ៉ាត់គាត់" (សូមធៀប ១៣:២២) ។

មកសូលទ្រង់តាំងគាត់ឡើង ឱ្យត្រួតត្រាលើពួកទាហាន[ជ]
នោះពួកបណ្តាជន និងពួកមហាតលិករបស់សូល គេមាន
សេចក្តីពេញចិត្តជាខ្លាំង ។
៦ក្រោកាលដែលគេត្រឡប់វិលមក គឺនៅវេលាដែល
ដាវីឌមកពីសំឡាប់សាសន៍ភីលីស្ទីនម្នាក់នោះវិញហើយ
នោះពួកស្រីទាំងឡាយ ក៏នាំគ្នាចេញពីទីក្រុងរបស់សាសន៍
អ៊ីស្រាអែលទាំងប៉ុន្មាន មកទទួលស្តេចសូលដោយអំណរ
ព្រមទាំងច្រៀង និងលោតកញ្ឆេង[ឈ] ហើយបន្ទរក្រាប់[ញ]
និងប្រដាប់ភ្លេងផ្សេងៗ ៧កំពុងដែលគេលេងភ្លេង នោះក៏
ច្រៀងឆ្លើយឆ្លងគ្នាទៅវិញទៅមក[ដ] ដោយពាក្យថា សូល
ទ្រង់បានសំឡាប់ទាំងពាន់ ហើយដាវីឌទាំងម៉ឺន[ឋ] ៨ដូច្នេះ
សូលទ្រង់មានសេចក្តីខ្ញាល់ជាខ្លាំង ដោយពាក្យនោះនាំឱ្យ
បង្អាក់ដល់ព្រះទ័យទ្រង់ ហើយទ្រង់មានបន្ទូលថា គេបាន
រាប់ជា១ម៉ឺនដល់ដាវីឌ តែអញបានត្រឹមតែពាន់ទេ ដូច្នេះ
វានៅខ្វះតែសោយរាជ្យប៉ុណ្ណោះទេ[ឌ] ៩ចាប់តាំងពីថ្ងៃនោះ
មក សូលទ្រង់ចេះតែរំពៃមើលដាវីឌ ដោយព្រះនេត្រដ៏
អាក្រក់[ឍ] ។
១០លុះថ្ងៃស្អែកឡើង នោះវិញ្ញាណអាក្រក់[ណ]ពីព្រះក៏មក
សណ្ឋិតលើសូល បណ្តាលឡើងជាខ្លាំង ហើយទ្រង់វក់
ដោយសេចក្តីក្រោធនៅកណ្តាលដំណាក់ មានទាំងដែក
ពួយ[ត]នៅព្រះហស្តផង ឯដាវីឌក៏ចាប់លេងភ្លេង[ថ]ឡើងដូច
កាលសព្វ១ដង[ទ] ១១ខណនោះ សូលទ្រង់ក៏ពួយដែកពួយទៅ
ដោយនឹកថា[ធ] អញនឹងចាក់ទំលុះដាវីឌភ្ជាប់នឹងជញ្ជាំង តែ
លោកគេចផុតចេញ[ន]ពីចំពោះទ្រង់ទៅអស់វារៈ២ដង[ប]

**១៨:៥** ជ ២សយ ១៨:១១ **១៨:៦** ឈ នក ១៥:២០ ២សយ ១:២០ ញ ទដ ៦៨:២៥ **១៨:៧** ដ នក ១៥:២១ ឋ ១សយ ២១:១១ ២៩:៥ ២សយ ១៨:៣ **១៨:៨** ឌ ១សយ ១៣:១៤ ១សយ ១៥:៨ **១៨:៩** ឍ ១សយ ១៩:១ **១៨:១០** ណ ពច ៩:២៣ ១សយ ១៦:១៤ ត ១សយ ១៧:៦ ថ ១សយ ១០:៥ ទ ១សយ ១៦:២១ ១៩:៧ **១៨:១១** ធ ខ.២៥ ១សយ ២០:៧,៣៣ ន ១សយ ១៩:១០ ប ទដ ១៣២:១ **១៨:១២** ផ ខ.២៩ ព ១សយ ១៦:១៣ ភ យស ១:៥ ១សយ ១៧:៣៧ ២០:១៣ ១រប ២២:១១ ម ពច ១៦:២០

១២ដូច្នេះ សូលទ្រង់ក៏ខ្លាច[ផ]ដល់ដាវីឌ ដ្បិតព្រះយេហូវ៉ា[ព]ទ្រង់
គង់នៅជាមួយ[ភ]នឹងលោក តែបានថយចេញ[ម]ពីទ្រង់វិញ
១៣ហេតុដូច្នោះ សូលទ្រង់ក៏ដកហូតដាវីឌចេញ ហើយដំរូវ
ឱ្យធ្វើជាមេទ័ពលើ១ពាន់នាក់វិញ រួចដាវីឌក៏តែងនាំមុខ[យ]
បណ្តាទ័ពចេញចូល[រ] ១៤លោកចេះតែប្រព្រឹត្តដោយប្រាជ្ញា[ល]
ក្នុងគ្រប់ទាំងផ្លូវរបស់លោក ហើយព្រះយេហូវ៉ាទ្រង់គង់ជា
មួយ[វ]ផង ១៥កាលសូលទ្រង់ឃើញថា ដាវីឌប្រព្រឹត្តដោយ
ប្រាជ្ញា ដូច្នោះ នោះទ្រង់កោតខ្លាចដល់លោក ១៦តែពួក
អ៊ីស្រាអែល និងពួកយូដាទាំងប៉ុន្មាន គេជិតចិត្តស្រឡាញ់
ដល់ដាវីឌពីព្រោះលោកជាអ្នកនាំមុខគេចេញចូល[ស] ។
១៧នៅគ្រានោះ សូលមានបន្ទូលទៅដាវីឌថា មើលអញ
នឹងឱ្យនាងម្រ៉ាបជាកូនច្បង[ហ]របស់អញ ទៅធ្វើជាប្រពន្ធ
ឯង[ឡ] ឱ្យតែឯងបានធ្វើជាអ្នកក្លាហាន សំរាប់អញ ហើយ
ច្បាំងចំបាំង[អ]នៃព្រះយេហូវ៉ាចុះ ពីព្រោះសូលមានបំណង[ក]
ថា កុំឱ្យដៃអញធ្វើវាឡើយ ទុកឱ្យដៃនៃពួកភីលីស្ទីនធ្វើវិញ
ចុះ ១៨ដាវីឌទូលឆ្លើយនឹងសូលថា តើទូលបង្គំជាអ្វី[ខ] ឬជីវិត
ទូលបង្គំវិសេសយ៉ាងណា ឬគ្រួនៃឪពុកទូលបង្គំជាអ្វីនៅក្នុង
ពួកអ៊ីស្រាអែល បានជាសព្វព្រះទ័យឱ្យទូលបង្គំធ្វើជាកូន
ប្រសានៃទ្រង់ព្រះករុណាដូច្នេះ[គ] ១៩តែដល់វេលាដែលត្រូវ
ឱ្យនាងម្រ៉ាប[ឃ]ជាបុត្រីសូលទៅដាវីឌ នោះត្រឡប់ទៅជា
បានលើកទៅឱ្យធ្វើជាប្រពន្ធរបស់អ័ទ្រីអែល ជាពួកមហូឡា

**១៨:១៣** យ ជន ២៧:១៧ រ ២សយ ៥:២ **១៨:១៤** ល លប ៣៩:៣ វ លប ៣៩:២ ជន ១៤:៤៣ ២សយ ៧:៩ **១៨:១៦** ស ២សយ ៥:២ **១៨:១៧** ហ ១សយ ១៧:២៥ ឡ លប ២៩:២៦ អ ជន ២១:១៤ ក ខ.២៥ ១សយ ២០:៣៣ **១៨:១៨** ខ នក ៣:១១ ១សយ ៩:២១ គ ខ.២៣ **១៨:១៩** ឃ ២សយ ២១:៨

**១៨:៥** *តាមដែលសូលទ្រង់ប្រើ* សូលបានប្រើដាវីឌក្នុងអំឡុងពេលដែលមានយុទ្ធនាការតស៊ូ ។

**១៨:៦** *ពួកស្រីទាំងឡាយ . . . និងប្រដាប់ភ្លេង* មើល នក ១៥:២០ និងការពន្យល់ ។

**១៨:៧** *ដាវីឌទាំងម៉ឺន* សូមមើល ២១:១១ ២៩:៥ ។ យោងទៅតាមការអនុលោមសាមញ្ញរបស់កវីនិពន្ធហេព្រើរ នេះគឺជារបៀបដែលស្ត្រីទាំងនោះនិយាយថា "សូលនិងដាវីឌបានសម្លាប់ទាំងពាន់" (តាមធម្មតាចំនួន ១0000 ត្រូវបានគេប្រើនឹងចាត់ទុកថា ប្រហាក់ប្រហែលគ្នានឹង១000ដែរ សូមមើល ចទ ៣២:៣0 ទដ ៩១:៧ និងការពន្យល់ ដយ ៧:១0 មីក ៦:៧ រួមទាំងនៅក្នុងពួកកវីនិពន្ធកាណាន ដែលគេរកឃើញនៅ "យូហ្គារីត" (Ugarit) ជាទីក្រុងបុរាណដែលស្ថិតនៅភាគខាងជើងនៃប្រទេសអាសស៊ើរ ។ វាគឺជាចំនួននៃការបរាជ័យរបស់ស្តេចសូល និងសេចក្តីច្រណែនឈ្នានីសរបស់គាត់ចំពោះដាវីឌ ដោយគិតក្នុងផ្លូវខុស និងការអាក់អន់ចិត្តរបស់គាត់ (មើល ខ.៨) ។

**១៨:១០** *វិញ្ញាណអាក្រក់ពីព្រះ* មើលការពន្យល់ ១៦:១៤ ។ *វក់ដោយសេចក្តីក្រោធ* ពេលខ្លះនៅក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះគេប្រើសំដៅលើការ "មិនអាចគ្រប់គ្រងលើខ្លួនបាន" (មើលការពន្យល់ ១ពវ ១៨:២៩) ហើយជាការយល់ឃើញយ៉ាងល្អនៅក្នុងវិញ្ញាណ គឺក្នុងបរិបទ (មើលការពន្យល់ ១0:៥) ។ *ដូចកាលសព្វ១ដង* សូមមើល ១៦:២៣ ។

**១៨:១២** *ព្រះយេហូវ៉ាទ្រង់គង់នៅជាមួយនឹងលោក* សូមមើល ១៦:១៨ ។ *បានថយចេញពីទ្រង់វិញ* សូមមើល ១៦:១៤ ។

**១៨:១៣** *ដកហូតដាវីឌចេញ* បំណងចិត្តរបស់ទ្រង់គឺគាត់សង្ឃឹមថា ដាវីឌនឹងត្រូវគេសម្លាប់នៅក្នុងសង្គ្រាម (សូមមើល ខ.១៧,២១,២៥ ១៩:១) ប៉ុន្តែលទ្ធផលត្រូវបានគេស្រែកអបអរសាទរយ៉ាងខ្លាំង ចំពោះជ័យជម្នះរបស់ដាវីឌ (សូមមើល ខ.១៤,១៦,៣0) ។

**១៨:១៤** *ព្រះយេហូវ៉ាគង់នៅជាមួយ* សូមមើល ១៦:១៨ ។

**១៨:១៧** *ជាកូនច្បងរបស់អញ* ដាវីឌមានសិទ្ធិទទួលយកបុត្ររបស់ស្តេចសូលមកធ្វើជាប្រពន្ធ ពីព្រោះគាត់សម្លាប់កូលីយ៉ាតបាន (មើល ១៧:២៥) ។ ស្តេចសូលមិនបានរក្សាសេចក្តីសន្យាឡើយ ហើយឥឡូវនេះគាត់បានដាក់លក្ខខណ្ឌដល់ដាវីឌថែមទៀត គឺលុះត្រាតែគាត់ធ្វើជាអ្នកក្លាហានសម្រាប់ទ្រង់ ។ នៅក្នុងគំនិតនេះស្តេចសូលគិតថា ដាវីឌនឹងត្រូវស្លាប់ជាមិនខាន ។ *ចំបាំងនៃព្រះ* សូមមើល ២៥:២៨ ។

វិញ[ង] ២០ឯមីកាល[ច] ជាបុត្រីសូល នាងប្រតិព័ទ្ធស្រឡាញ់ដល់
ដាវីឌណាស់ ហើយមានគេនាំដំណឹងទៅក្រាបទូលដល់សូល
ការនោះក៏គាប់ព្រះទ័យដល់ទ្រង់[ឆ] ២១ដោយបំណងថា អញ
នឹងឱ្យនាងទៅវាចុះ ដើម្បីឱ្យបានជាអន្ទាក់[ជ]ដល់វា ហើយឱ្យ
ដៃនៃពួកភីលីស្ទីនបានទាស់នឹងវា ដូច្នោះសូលមានបន្ទូល
ទៅដាវីឌថា នៅថ្ងៃនេះឯងនឹងធ្វើជាកូនប្រសាអញ ដោយ
សារនាងបន្ទាប់នេះវិញ ។

២២សូលទ្រង់ក៏បង្គាប់ដល់ពួកមហាតលិកថា ចូរនិយាយ
ប្រលោមដាវីឌដោយសំងាត់ថា មើល ស្តេចទ្រង់សព្វព្រះ
ទ័យនឹងលោកណាស់ ហើយពួកមហាតលិកទាំងអស់គ្នាក៏
ស្រឡាញ់ដល់លោកដែរ ដូច្នេះ សូមលោកធ្វើជាកូន
ប្រសារបស់ស្តេចទៅ ២៣ពួកមហាតលិកក៏ថ្លែងសេចក្តីទាំង
នោះប្រាប់ដល់ត្រចៀកដាវីឌ តែលោកឆ្លើយថា អ្នករាល់
គ្នាស្មានថា ដែលធ្វើជាកូនប្រសារបស់ស្តេច[ឈ] នោះជាការ
ងាយឬ ឯខ្ញុំជាមនុស្សក្រីក្រ ហើយស្តេចមិនសូវរាប់អានផង
២៤នោះពួកមហាតលិក ក៏នាំសេចក្តីទៅក្រាបទូលដល់ទ្រង់
អំពីដាវីឌបាននិយាយយ៉ាងនោះ ២៥រួចសូលទ្រង់បង្គាប់ថា
ចូរឯងរាល់គ្នាទៅនិយាយនឹងដាវីឌដូច្នេះចុះ ថាស្តេចមិន
ចង់បានបណ្តាការអ្វីទេ[ញ] ទ្រង់សព្វព្រះទ័យ ចង់បានតែ
ស្បែកនៃស្រោមចុងស្វាស របស់ពួកភីលីស្ទីន១០០ប៉ុណ្ណោះ
ដើម្បីឱ្យបានសងសឹក[ដ]នឹងពួកខ្មាំងសត្រូវទ្រង់ តែគំនិត[ឋ]
សូលទ្រង់គិតតែឱ្យដាវីឌបានស្លាប់ដោយដៃពួកភីលីស្ទីនទេ
២៦ដូច្នេះកាលពួកមហាតលិក បាននាំសេចក្តីទៅប្រាប់ដល់
ដាវីឌវិញហើយ នោះលោកក៏សុខចិត្តនឹងធ្វើជាកូនប្រសា
របស់ស្តេចដែរ ឯពេលកំណត់ដែលត្រូវយកមកមិនទាន់
សំរេចនៅឡើយ ២៧បានជាដាវីឌក្រោកឡើងចេញទៅ
ព្រមទាំងនាំពួកកងរបស់លោកទៅផង រួចសំឡាប់ពួក
ភីលីស្ទីនបាន២០០នាក់ ហើយលោកនាំយកស្បែកស្រោម
ចុងស្វាសរបស់គេ មកថ្វាយស្តេចគ្រប់ចំនួននោះ ដើម្បីឱ្យ
បានធ្វើជាកូនប្រសាស្តេច នោះសូលទ្រង់ប្រទាននាង
មីកាល[ឌ] ជាបុត្រី ទៅធ្វើជាប្រពន្ធលោកទៅ ២៨សូលទ្រង់
ក៏យល់ឃើញ ហើយជ្រាបថា ព្រះយេហូវ៉ាទ្រង់គង់ជាមួយ
នឹងដាវីឌ ឯនាងមីកាល[ឍ]ជាបុត្រីសូល ក៏ប្រតិព័ទ្ធស្រឡាញ់
ដល់លោក ២៩ដូច្នេះ សូលទ្រង់ខ្លាច[ណ]ដាវីឌរឹតតែខ្លាំងឡើង
ទៀត ក៏ធ្វើជាអ្នកសត្រូវនឹងលោកជាដរាបទៅ ។

៣០នៅគ្រានោះ ពួកមេសាសន៍ភីលីស្ទីន គេចេះតែ
ទន្ទ្រានចូលមក តែវេលាណាដែលគេចូលមក នោះដាវីឌ
ក៏តែងប្រព្រឹត្តដោយប្រាជ្ញា[ត] លើសជាងអស់ពួកមេទ័ពទាំង
ប៉ុន្មាននៃស្តេច ដល់ម្ល៉េះបានជាគេទុកចិត្តពឹងដល់ឈ្មោះ
លោកណាស់ ។

## ស្តេចសូលតាមសម្លាប់លោកដាវីឌ

**១៩** ១គ្រានោះ សូលទ្រង់បង្គាប់ដល់យ៉ូណាថាន[ក]ជាបុត្រា
ទ្រង់ និងពួកមហាតលិកទាំងប៉ុន្មាន ឱ្យសំឡាប់[ខ]ដាវីឌចោល
តែយ៉ូណាថានជាបុត្រាសូល លោកមានចិត្តស្រឡាញ់ដាវីឌ
ណាស់ ២បានជាលោកប្រាប់ដល់ដាវីឌថា សូលជាបិតាខ្ញុំរក
សំឡាប់អ្នក ដូច្នេះ ដល់ព្រឹកឡើងសូមឱ្យអ្នកប្រយ័ត្នខ្លួន ត្រូវ
ឱ្យពួននៅក្នុងទីសំងាត់[គ]ណាមួយទៅ ៣នោះខ្ញុំនឹងចេញទៅ
ឈរជាមួយនឹងបិតាខ្ញុំក្នុងវាលជិតកន្លែងណាដែលអ្នកពួន
នោះ រួចខ្ញុំនឹងស្នើការ[ឃ]ពីដំណើរអ្នកចំពោះបិតាខ្ញុំ បើខ្ញុំ
ឃើញហេតុជាយ៉ាងណា នោះខ្ញុំនឹងប្រាប់ដល់អ្នក ៤ដូច្នេះ
យ៉ូណាថានក៏ដំណាល[ង]សេចក្តីយ៉ាងល្អពីដំណើរដាវីឌ ទូល

**១៨:១៩** ង ពច ៧:២២
**១៨:២០** ច ខ.២៨ លប ២៩:២៦ ឆ ខ.២៩
**១៨:២១** ជ នក ១០:៧ ចទ ៧:១៦
**១៨:២៣** ឈ ខ.១៨
**១៨:២៥** ញ លប ៣៤:១២ ដ ទដ ៨:២ ៤៤:១៦ យរ ២០:១០ ឋ ខ.១១,១៧ ខ.១៧
**១៨:២៧** ឌ ២សយ ៣:១៤ ៦:១៦
**១៨:២៨** ឍ ខ.២០
**១៨:២៩** ណ ខ.១២
**១៨:៣០** ត ខ.៥
**១៩:១** ក ១សយ ១៨:១ ខ ១សយ ១៨:៩
**១៩:២** គ ១សយ ២០:៥,១៩
**១៩:៣** ឃ ១សយ ២០:១២
**១៩:៤** ង ១សយ ២០:៣២ ២២:១៤ សភ ៣១:៨,៩ យរ ១៨:២០

**១៨:២០** *មីកាល . . . ប្រតិព័ទ្ធស្រឡាញ់ដល់ដាវីឌណាស់* មើល ខ.២៨ និងការពន្យល់ ។

**១៨:២១** *ឯងនឹងធ្វើជាកូនប្រសាអញ ដោយសារនាងបន្ទាប់* សម្រាប់ឱ្យកូនច្បង សូមមើល ១៧:២៥ ។

**១៨:២៥** *មិនចង់បានបណ្តាការអ្វីទេ* ជាធម្មតាថ្លៃបណ្តាកាគឺជាតួនាទីរបស់កូនប្រុសដែលត្រូវបង់ទៅឱ្យឪពុកកូនក្រមុំ (សូមមើល លប ៣៤:១២ នក ២២:១៦) ទុកជាការសងជម្ងឺចិត្តចំពោះការបាត់បង់កូនស្រីគាត់ និងត្រូវធានាចិញ្ចឹមប្រសិនជាត្រូវមេម៉ាយ ។ ស្តេចសូលបានទាមទារឱ្យដាវីឌធ្វើជាអ្នកក្លាហានសម្រាប់ទ្រង់ ជំនួសថ្លៃបណ្តាការ និងការធានាចំពោះបុត្រីទ្រង់វិញ ពីព្រោះទ្រង់សង្ឃឹមហើយសង្ឃឹមទៀតថា ដាវីឌនឹងត្រូវ "ចាញ់" (សូមមើល ខ.១៧,២១) ។

**១៨:២៨** *ព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងដាវីឌ* មើលការពន្យល់ ១៦:១៨ ។ *មីកាល . . . ស្រឡាញ់ដល់លោក* ការអនុគ្រោះរបស់ព្រះចំពោះដាវីឌ មិនមែនគ្រាន់តែជួយឱ្យគាត់ទទួលស្នាដៃក្នុងសង្គ្រាមឡើយ ប៉ុន្តែថែមទាំងបានធ្វើឱ្យនាងមីកាលស្រឡាញ់ដល់ដាវីឌ ហើយឥឡូវនេះរួមទាំងលោកយ៉ូណាថានថែមទៀត ។ អ្វីៗគ្រប់យ៉ាងដែលសូលស្វែងរកដើម្បីទាស់ប្រឆាំងជាមួយដាវីឌ បានក្លាយជាគុណសម្បត្តិដ៏ល្អដល់ដាវីឌវិញ ។

**១៨:២៩** *សូលទ្រង់ខ្លាចដាវីឌរឹតតែខ្លាំងឡើង* ស្តេចសូលបានដឹងថា ព្រះហស្តនៃព្រះអម្ចាស់បាននៅជាមួយលោកដាវីឌ មិនបានធ្វើឱ្យទ្រង់មានការសោកស្តាយ និងទទួលយកមកធ្វើជាជោគវាសនាខ្លួនគាត់នោះឡើយ(សូមមើល ១៥:២៦) ប៉ុន្តែធ្វើឱ្យគាត់ច្រណែន និងភ័យខ្លាចចំពោះដាវីឌវិញ ។

**១៩:១** *សូលទ្រង់បង្គាប់ដល់យ៉ូណាថាន . . . ឱ្យសំឡាប់ដាវីឌ* ឥឡូវនេះស្តេចសូល បានបោះបង់ចោលនូវការប៉ុនប៉ងយកជីវិតលោកដាវីឌដោយផ្ទាល់ (សូមមើល ១៨:១៣,១៧,២១,២៥) ហើយទ្រង់បានបង្កើនកម្លាំងបន្ថែមទៀត ដើម្បីតាមដាវីឌពីការរត់គេចចេញពីដំណាក់ និងបម្រើទ្រង់ (សូមមើល ខ.១២,១៨ ២០:៤២) ។

**១៩:៤** *យ៉ូណាថានក៏ដំណាលសេចក្តីយ៉ាងល្អពីដំណើរដាវីឌ* យ៉ូណាថានគាត់មិនអនុញ្ញាតឱ្យមហិច្ឆតាផ្ទាល់ខ្លួន បង្កការអាក្រក់ឡើយ ពីព្រោះគាត់

ដល់សូលជាបិតាថា សូមកុំឱ្យបិតាធ្វើបាប[ច]ដល់ដាវីឌ ជាអ្នក
បំរើទ្រង់ឡើយ ដ្បិតគាត់មិនបានធ្វើខុសនឹងបិតាទេ ហើយ
ការដែលគាត់ធ្វើសោត នោះសុទ្ធតែមានប្រយោជន៍ដល់
បិតាទាំងអស់ផង [៥]គាត់បានប្រថុយជីវិត[ឆ] ទៅវាយពួក
ភីលីស្ទីន ហើយព្រះយេហូវ៉ាទ្រង់បានប្រោសឱ្យមានជ័យ
ជំនះជាធំ[ជ]ដល់ពួកអ៊ីស្រាអែលទាំងអស់គ្នា បិតាក៏បានឃើញ
ហើយមានសេចក្ដីអំណរដែរ ចុះហេតុអ្វីបានជាចង់ធ្វើបាប
នឹងឈាមដែលឥតមានទោសវិញ[ឈ] ដោយសំឡាប់គាត់
ឥតហេតុដូច្នេះធ្វើអី [៦]នោះសូលទ្រង់ក៏ស្ដាប់តាមពាក្យ
យ៉ូណាថាន ព្រមទាំងចេញវាចាស្បថដោយនូវព្រះយេហូវ៉ា
ដ៏មានព្រះជន្មរស់នៅថា វាមិនត្រូវស្លាប់ទេ [៧]រួចមក
យ៉ូណាថានហៅដាវីឌមក ប្រាប់សេចក្ដីទាំងនោះដល់លោក
ក៏នាំដាវីឌទៅឯសូល រួចលោកនៅចំពោះទ្រង់ ដូចកាល
ពីដើមវិញ[ញ] ។
[៨]សម័យនោះ កើតមានចំបាំងម្ដងទៀត ហើយដាវីឌក៏
ចេញទៅច្បាំងនឹងពួកភីលីស្ទីន ប្រហារសំឡាប់ជីវិតគេ
យ៉ាងសំបើម គេក៏រត់ពីមុខលោកទៅ ។
[៩]រីឯកាលសូលកំពុងតែគង់ក្នុងដំណាក់ មានទាំងដែក
ពួយនៅព្រះហស្ត នោះវិញ្ញាណអាក្រក់[ដ]ដែលមកពីព្រះ
យេហូវ៉ាក៏សណ្ឋិតលើទ្រង់ ឯដាវីឌលោកកំពុងតែលេង
ភ្លេង[ឋ] [១០]ស្រាប់តែសូលទ្រង់រកពួយដាវីឌភ្ជាប់នឹងជញ្ជាំង
ដោយដែកពួយ តែលោកគេច[ឌ]ផុតចេញពីចំពោះសូលទាន់
ហើយដែកពួយនោះត្រូវជញ្ជាំងវិញ ដូច្នេះដាវីឌក៏រត់រួច
នៅយប់នោះឯង [១១]ឯសូលទ្រង់ចាត់គេឱ្យទៅឯផ្ទះដាវីឌ
ដើម្បីនឹងចាំយាម[ឍ] ហើយនិងសំឡាប់លោកដល់ព្រឹកឡើង[ណ]
តែមីកាល ជាប្រពន្ធដាវីឌប្រាប់លោកថា បើអ្នកមិនរត់
ទៅឱ្យរួចជីវិតនៅវេលាយប់នេះទេ នោះស្អែកឡើងអ្នក
នឹងត្រូវស្លាប់ហើយ [១២]ដូច្នេះមីកាលបានសំរូតបញ្ចុះដាវីឌ
តាមបង្អួច[ត]ទៅ ហើយលោកក៏រត់ចេញរួច [១៣]ឯមីកាលនាង
យករូប១[ថ]ទៅផ្ដេកនៅលើគ្រែ ហើយយកខ្នើយរោមពពែ
ដាក់កើយក្បាល ព្រមទាំងដណ្ដប់ភួយផង [១៤]លុះកាលសូល
ទ្រង់ចាត់គេឱ្យទៅចាប់ដាវីឌ នោះនាងប្រាប់[ទ]ថាលោកឈឺ
[១៥]រួចសូលទ្រង់ចាត់គេ ឱ្យទៅមើលដាវីឌដោយប្រាប់ថា
ចូរសែងនាំយកវាទាំងដេកនៅលើគ្រែ មកឱ្យអញបាន
សំឡាប់ចេញ [១៦]តែកាលពួកនោះបានទៅដល់ នោះឃើញ
មានតែរូបផ្ដេកនៅគ្រែ ហើយនិងខ្នើយរោមពពែដាក់កើយ
ក្បាលទេ [១៧]ដូច្នេះសូលទ្រង់សួរមីកាលថា ម្ដេចក៏ឯង
បញ្ឆោតអញ ហើយទុកឱ្យសត្រូវអញរួចទៅដូច្នេះ មីកាល
ទូលឆ្លើយថា គាត់បានកំហែងខ្ញុំម្ចាស់ថា ចូរឱ្យអញទៅ ចង់
ឱ្យអញសំឡាប់ឯងឬ ។
[១៨]រីឯដាវីឌ លោករត់រួចទៅដល់សាំយូអែល នៅឯ
រ៉ាម៉ា[ធ] ហើយជំរាបពីសេចក្ដីទាំងប៉ុន្មាន ដែលសូលបានធ្វើ
ដល់ខ្លួន រួចលោក និងសាំយូអែលក៏នាំគ្នាទៅនៅឯណាយ៉ូត
[១៩]មានគេទូលដល់សូលថា មើល ដាវីឌនៅត្រង់ណាយ៉ូត
ដែលនៅស្រុករ៉ាម៉ា [២០]នោះសូលទ្រង់ក៏ចាត់គេឱ្យទៅចាប់
តែកាលគេឃើញពួកហោរា[ន]កំពុងតែទាយ និងសាំយូអែល
ឈរធ្វើជាមេលើគេ នោះព្រះវិញ្ញាណនៃព្រះ ទ្រង់ក៏មក
សណ្ឋិតលើ[ប]ពួកអ្នកដែលសូលចាត់ឱ្យទៅនោះ ហើយគេ
ក៏ទាយដែរ[ផ] [២១]កាលដំណឹងនោះបានឮទៅដល់សូល នោះ
ទ្រង់ចាត់១ពួកឱ្យទៅទៀត តែអ្នកទាំងនោះក៏ទាយដែរ
សូលទ្រង់ចាត់ពួកមនុស្សឱ្យទៅអស់វារៈជាគំរប់៣ដង តែ
គេទាយដូចគ្នាទាំងអស់ [២២]ពេលនោះទ្រង់ក៏យាងទៅឯ
រ៉ាម៉ា ដោយព្រះអង្គទ្រង់វិញ កាលបានដល់ទៅអណ្ដូង១នៅ
ត្រង់សេគូវ នោះទ្រង់សួរគេថា តើសាំយូអែលនិងដាវីឌនៅ
ឯណា គេឆ្លើយថា លោកនៅឯណាយ៉ូត ក្នុងស្រុករ៉ាម៉ា
[២៣]ទ្រង់ក៏យាងទៅឯណាយ៉ូត ស្រុករ៉ាម៉ានោះ ស្រាប់
តែព្រះវិញ្ញាណនៃព្រះក៏មកសណ្ឋិតលើទ្រង់ ហើយទ្រង់
យាងទៅទាំងទាយ[ព]បណ្ដើរ រហូតដល់ណាយ៉ូតនៅស្រុក

**១៩:៤** ច ១សយ ២៥:២១ សភ ១៧:១៣
**១៩:៥** ឆ ពច ៩:១៧ ១២:៣ ជ ១សយ ១១:១៣ ឈ លប ៣១:៣៦ ចទ ១៩:១០–១៣
**១៩:៧** ញ នក ១សយ ១៨:២,១៣
**១៩:៩** ដ ពច ៩:២៣ ឋ ១សយ ១០:៥
**១៩:១០** ឌ ១សយ ១៨:១១
**១៩:១១** ឍ ទដ ៥៩ ណ ពច ១៦:២
**១៩:១២** ត យស ២:១៥ កច ៩:២៥ ២កថ ១១:៣៣
**១៩:១៣** ថ លប ៣១:១៩
**១៩:១៤** ទ នក ១:១៩ យស ២:៤
**១៩:១៨** ធ ១សយ ៧:១៧
**១៩:២០** ន ជន ១១:២៩ ប ជន ១១:២៥ ផ ១សយ ១០:៥
**១៩:២៣** ព ១សយ ១០:១៣

បានដឹងពីសេចក្ដីពិតដែលមាននៅក្នុងដាវីឌ (សូមមើលការពន្យល់ ខ.៥ ១៤:៦ ១៧:១១ ១៨:១) ។

**១៩:៥** *ព្រះយេហូវ៉ាទ្រង់ប្រោសឱ្យមានជ័យជំនះយ៉ាងធំ* សូមមើលការពន្យល់ ១០:១៨ ១២:១១ ១៤:២៣ ។

**១៩:៦** *សូលទ្រង់ក៏ស្ដាប់តាមពាក្យយ៉ូណាថាន ព្រមទាំងចេញវាចាស្បថ* សូមមើល ១៤:២៤,៤៤ ស្ដេចសូលមិនបានរក្សាសម្បថកាលពីគ្រាមុនឡើយ (សូមមើលការពន្យល់ ១៤:៣៩) ។

**១៩:៩** *វិញ្ញាណអាក្រក់ដែលមកពីព្រះ* មើលការពន្យល់ ១៦:១៤ ធៀប ១៨:១០–១១ ។

**១៩:១០** *ដែកពួយ* សូមមើល ១៨:១០–១១ ២០:៣៣ ។

**១៩:១២** *តាមបង្អួច* សម្រាប់ការគេចចេញដែលមានការប្រហាក់ប្រហែលគ្នានេះ សូមមើល យស ២:១៥ កច ៩:២៥ ។

**១៩:១៣,១៦** *រូប១* សូមមើលការពន្យល់ លប ៣១:១៩ ។

**១៩:១៨** *រ៉ាម៉ា* គឺជាស្រុករបស់ហោរាសាំយូអែល (សូមមើល ៧:១៧ និងការពន្យល់ ១:១) ។ *ណាយ៉ូត* មានន័យថា "តាំងលំនៅ" ឬ "ដំណាក់" ។ វយ្យស័ព្ទនេះ គឺចង់និយាយសំដៅទៅលើពីដំណាក់ជាច្រើនខ្ទាត់ខ្ទែងនៅឯរ៉ាម៉ា ដែលជាកន្លែងរបស់ពួកហោរាធ្វើការ (សូមមើល ខ.១៩–២០,២២–២៣) ។

**១៩:២០** *ពួកហោរា* សូមមើល ១០:១៥ និងការពន្យល់ ។ *កំពុងទាយ* សូមមើលការពន្យល់ ១០:៥ ១៨:១០ ។

រ៉ាម៉ា ២៤ទ្រង់ដោះ[ភ]ព្រះពស្ត្រចេញ ហើយក៏ទាយនៅមុខ
សាំយូអែល[ម] រួចដេកអាក្រាតនៅដីពេញ១ថ្ងៃ១យប់នោះ
ហេតុនោះបានជាគេសួរថា តើសូលជាពួកហោរាដែរ
ឬអី[យ] ។

## លោកដាវីឌ និងលោកយ៉ូណាថាន

**២០** ១រីឯដាវីឌ លោករត់ចេញពីណាយ៉ូតនៅស្រុករ៉ាម៉ា
នោះ ទៅឯយ៉ូណាថានសួរថា តើខ្ញុំបានធ្វើអ្វី ខ្ញុំមានទោស[ក]
ជាយ៉ាងណា ឬបានធ្វើបាបដូច្នេះខ្លះនៅចំពោះបិតាអ្នក
បានជាទ្រង់រកសំឡាប់ខ្ញុំដូច្នេះ[ខ] ២យ៉ូណាថានឆ្លើយថា សូម
កុំឱ្យបានដូច្នេះឡើយ អ្នកមិនត្រូវស្លាប់ទេ មើល បិតាខ្ញុំមិន
ដែលធ្វើការអ្វីទោះធំឬតូចក្តី ដែលមិនប្រាប់ដល់ខ្ញុំនោះទេ
ចុះមានទំនងអ្វីឱ្យទ្រង់លាក់ការនេះនឹងខ្ញុំវិញ ការនោះមិន
ត្រូវទេ ៣ប៉ុន្តែដាវីឌនិយាយដោយស្បថ[គ]ថា បិតាអ្នកជ្រាប
ច្បាស់ថា ខ្ញុំជាទីគាប់ចិត្តដល់អ្នកបានជាទ្រង់នឹកថា កុំឱ្យ
យ៉ូណាថានដឹងឡើយក្រែងទាស់ចិត្ត ប៉ុន្តែខ្ញុំស្បថដោយនូវ
ព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ ហើយដោយនូវព្រលឹង
អ្នកដែលរស់នៅដែរថា ពិតប្រាកដជាខ្ញុំ និងសេចក្តីស្លាប់
នៅឃ្លាតតែ១ជំហានពីគ្នាទេ ៤នោះយ៉ូណាថាននិយាយ
នឹងដាវីឌថា ការអ្វីដែលចិត្តអ្នកប្រាថ្នាចង់បាន នោះខ្ញុំនឹង
សំរេចឱ្យ ៥ដាវីឌឆ្លើយថា មើល ថ្ងៃស្អែកនេះ ជាថ្ងៃចូលខែ
ហើយ[ឃ] ត្រូវឱ្យខ្ញុំអង្គុយបរិភោគភោជនាហារជាមួយនឹង
ស្តេចជាមិនខាន តែសូមអនុញ្ញាតឱ្យខ្ញុំទៅពួនលាក់[ង]ខ្លួននៅ
វាល ដរាបដល់ល្ងាចថ្ងៃទី៣វិញ ៦បើបិតាអ្នកសួររកខ្ញុំ
នោះសូមទូលថា ដាវីឌបានសូមច្បាប់[ច]ទូលបង្គំ ដោយអស់
ពីចិត្ត ដើម្បីនឹងទៅឯបេថ្លេហិម[ឆ]ជាទីក្រុងរបស់គាត់ហើយ

**១៩:២៤** ភ ២សយ ៦:២០ អស ២០:២ ម ១សយ ១៥:៣៥ យ ១សយ ១០:១១
**២០:១** ក ១សយ ២៤:៩ ខ ១សយ ២២:២៣ ២៣:១៥ ២៤:១១ ២៥:២៩ ទដ ៤០:១៤ ៥៤:៣ ៦៣:៩ ៧០:២
**២០:៣** គ ចទ ៦:១៣
**២០:៥** ឃ ជន ១០:១០ ង ១សយ ១៩:២
**២០:៦** ច ខ.២៨ ឆ ១សយ ១៧:៥៨ ជ ១សយ ១:៣
**២០:៧** ឈ ១សយ ១០:២៧ ២៥:១៧ ញ ១សយ ១៨:១១
**២០:៨** ដ ១សយ ១៨:៣ ឋ ២សយ ១៤:៣២
**២០:១២** ឌ ១សយ ១៩:៣
**២០:១៣** ឍ នរ ១:១៧ ណ ១សយ ១៦:១៨ ១៨:១២

ដ្បិតត្រូវកំណត់ដែលពួកញាតិគាត់ទាំងប៉ុន្មានថ្វាយយញ្ញ
បូជា ដែលតែងថ្វាយក្នុង១ឆ្នាំម្តង[ជ] ៧បើទ្រង់មានបន្ទូល
យ៉ាងនេះថា អើ ដូច្នេះ ខ្ញុំជាអ្នកបំរើរបស់អ្នកនឹងបាន
សេចក្តីសុខ តែបើសិនជាទ្រង់ក្រោធវិញ[ឈ] នោះត្រូវដឹងថា
បានសំរេច[ញ]នឹងធ្វើអាក្រក់ដល់ខ្ញុំហើយ ៨ដូច្នេះ សូម
ប្រព្រឹត្តនឹងខ្ញុំ ជាបំរើរបស់អ្នកដោយសប្បុរសផង ដ្បិតអ្នក
បាននាំខ្ញុំឱ្យចុះសញ្ញា[ដ]នៃព្រះយេហូវ៉ាជាមួយគ្នាហើយ តែ
បើមានសេចក្តីទុច្ចរិតណានៅខ្លួនខ្ញុំវិញ នោះសូមឱ្យអ្នក
សំឡាប់[ឋ]ខ្ញុំចុះ ដ្បិតគ្មានទំនងឱ្យអ្នកនាំខ្ញុំទៅឯបិតាអ្នកទេ
៩យ៉ូណាថានឆ្លើយថា សូមឱ្យសេចក្តីនេះឋយឆ្ងាយពីអ្នក
ទៅ បើសិនជាខ្ញុំដឹងពិតប្រាកដថា បិតាខ្ញុំបានសំរេចនឹង
ធ្វើអាក្រក់ដល់អ្នក នោះតើខ្ញុំមិនបានប្រាប់ដល់អ្នកទេឬអី
១០រួចដាវីឌនិយាយនឹងយ៉ូណាថានថា បើបិតាអ្នកឆ្លើយនឹង
អ្នកដោយគ្រោតគ្រាត នោះតើអ្នកណានឹងប្រាប់ដល់ខ្ញុំ
១១យ៉ូណាថានឆ្លើយតបថា ចូរយើងចេញទៅឯវាលសិន
នោះក៏នាំគ្នាចេញទៅទាំង២នាក់ ។
១២ដល់ហើយ យ៉ូណាថានមានវាចាថា សូមឱ្យព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ធ្វើជាសាក្សីចុះ ដល់
ស្អែកឡើងពេលថ្មើរនេះ ឬខានស្អែកក្តី កាលណាខ្ញុំបាន
ស្ទង់[ឌ]ការនឹងបិតាខ្ញុំ ហើយឃើញថា មានសេចក្តីល្អណា
សំរេចដល់អ្នក នោះខ្ញុំនឹងចាត់គេឱ្យមកប្រាប់ដល់អ្នក ១៣តែ
បើសិនជាបិតាខ្ញុំសព្វព្រះទ័យ និងធ្វើអាក្រក់ដល់អ្នកវិញ
ហើយខ្ញុំមិនបានប្រាប់ឱ្យអ្នកដឹង ដើម្បីបើកឱ្យអ្នកទៅដោយ
សុខសាន្ត នោះសូមព្រះយេហូវ៉ាធ្វើដល់ខ្ញុំយ៉ាងដូច្នោះចុះ
ហើយលើសទៅទៀតផង[ឍ] សូមព្រះយេហូវ៉ាគង់ជាមួយ[ណ]

**១៩:២៤** *នៅដីពេញ១ថ្ងៃ១យប់* ស្តេចសូលមានការអាក់អន់ចិត្តយ៉ាងខ្លាំង ដោយសារអំណាចព្រះវិញ្ញាណនៃព្រះអម្ចាស់ដែលបានការពារ ទប់ស្កាត់អាយុជីវិតរបស់ដាវីឌ ពីការចង់បានរបសទ្រង់ ។ ការមិនបានសម្រេចបំណងរបស់ទ្រង់ និងការគ្មានសមត្ថភាព ដែលទ្រង់ចង់បានជីវិតដាវីឌ ការដែលលោកយ៉ូណាថានធ្វើឱ្យគាត់ខកបំណង ការបោកបញ្ឆោតរបស់នាងមីកាលរួមទាំងភាពវៃឆ្លាតរបស់ដាវីឌ ទាំងអស់នេះហើយបានធ្វើឱ្យស្តេចសូលមកដល់ទ្រង់មកផ្ទឹនៅកន្លែងនេះ ។ *តើសូលជាពួកហោរាដែរឬអី* នេះជាឱកាសលើកទី២បន្ថែមលើកទី១ (មើល ១០:១១ និងការពន្យល់) ។ ការកើតឡើងម្តងទៀតនេះ គឺដើម្បីបញ្ជាក់ពីរបៀបដែលវិញ្ញា-ណរបស់ស្តេចសូលជាជនចម្លែកនោះថា គឺជាការបើកសម្តែងមកពីព្រះ ។

**២០:១** *ណាយ៉ូតនៅស្រុករ៉ាម៉ា* សូមមើលការពន្យល់ ១៩:១៨ ។

**២០:៣** *ព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ* មើលការពន្យល ១៤:៣៩, ៤៥ ។

**២០:៥** *ជាថ្ងៃចូលខែ* រាល់ខែនិមួយៗនៅក្នុងឆ្នាំតែងតែមានទំនាក់ទំនងជាមួយព្រះអម្ចាស់ តាមរយៈការនាំយកដង្វាយដ៏វិសេសមកថ្វាយជាយញ្ញបូជានៅចំពោះព្រះអម្ចាស់ (សូមមើល ជន ២៨:១១–១៥) និងបុណ្យផ្លុំត្រែ (សូមមើល ជន ១០:១០ ទដ ៨១:៣) ។ បញ្ញត្តិនេះ ជាប់ទាក់ទងជាមួយនឹងការឈប់សម្រាកពីការងាររកស៊ី ជាពិសេសនៅដើមខែទី៧ (សូមមើល លវ ២៣:២៤–២៥ ជន ២៩:១–៦ ២ពវ ៤:២៣ អស ១:១៣ អម ៨:៥) ។

**២០:៦** *ថ្វាយក្នុង១ឆ្នាំម្តង* សម្តីរបស់ដាវីឌចង់បង្ហាញថា វាគឺជាទម្លាប់របស់គ្រួសារដែលត្រូវកាន់តាមបញ្ញត្តិថ្ងៃចូលខែជាមួយគ្នាក្នុង១ឆ្នាំម្តង ។ ថ្ងៃចូលខែនេះ មិនមានកន្លែងណាទៀតនៅក្នុងសញ្ញាចាស់បាននិយាយឡើយ ។

**២០:៨** *ចុះសញ្ញា* សូមមើលការពន្យល់ ១៨:៣ ។

**២០:១១** *ចូរយើងចេញទៅឯវាលសិន* ទង្វើរបស់លោកយ៉ូណាថាន គឺដើម្បីជួយសង្គ្រោះដាវីឌ ។ លោកកាអ៊ីន ក៏បាននិយាយទៅកាន់លោកអេបិលនូវពាក្យពេចន៍ដូចគ្នាដែរ ប៉ុន្តែគឺដើម្បីសម្លាប់ (សូមមើល លប ៤:៨) ។

**២០:១៣** *នោះសូមព្រះយេហូវ៉ាធ្វើដល់ខ្ញុំយ៉ាងដូច្នោះចុះ ហើយលើសទៅទៀតផង* គឺជាពាក្យបណ្តាសា (សូមមើល ៣:១៧) ។ *សូមព្រះយេហូវ៉ាគង់*

នឹងអ្នក ដូចជាទ្រង់បានគង់ជាមួយនឹងបិតាខ្ញុំដែរ ១៤ឯខ្លួន
ខ្ញុំកំពុងដែលនៅរស់នៅឡើយ នោះសូមឱ្យអ្នកសំដែង
សេចក្ដីសប្បុរស[ត]នៃព្រះយេហូវ៉ាដល់ខ្ញុំ មិនមែនឱ្យតែខ្ញុំរួច
ស្លាប់ប៉ុណ្ណោះ ១៥គឺឱ្យអ្នកចុះកិច្ចសន្យាថា មិនផ្ដាច់សេចក្ដី
សប្បុរសរបស់អ្នកពីពួកវង្សខ្ញុំ[ថ] ជារៀងរាបតទៅ ក្នុងកាល
ដែលព្រះយេហូវ៉ា បានដកពួកខ្មាំងសត្រូវទាំងប៉ុន្មានរបស់
អ្នកពីផែនដីចេញនោះផង ១៦គឺយ៉ាងនោះហើយ ដែល
យ៉ូណាថាន[ទ]បានចុះសញ្ញា[ធ]នឹងពួកវង្សរបស់ដាវីឌ ក៏ថែម
ពាក្យនេះថា បើដាវីឌរំលងបទណា នោះសូមព្រះយេហូវ៉ា
ទ្រង់នឹងសងការនោះ ដោយសារដៃនៃពួកខ្មាំងសត្រូវរបស់
ដាវីឌវិញចុះ[ន] ។
១៧រួចយ៉ូណាថានបានឱ្យដាវីឌស្បថ[ប]ម្ដងទៀត ដោយ
ព្រោះសេចក្ដីស្រឡាញ់ដែលលោកមានដល់ដាវីឌ ដ្បិត
លោកមានចិត្តស្រឡាញ់ដល់ដាវីឌ ទុកដូចជាខ្លួនលោក
១៨យ៉ូណាថានក៏និយាយថា ថ្ងៃស្អែកជាថ្ងៃចូលខែហើយ
មុខជាគេនឹងយល់ឃើញថាខ្វះអ្នកដែរ ដោយកៅអីរបស់
អ្នកនៅទំនេរ[ផ] ១៩លុះបានផ្អាកនៅអស់៣ថ្ងៃហើយ នោះត្រូវ
ឱ្យអ្នកចុះទៅឯកន្លែង ដែលអ្នកបានពួន[ព]ពីជាន់មុននោះជា
ប្រញាប់ទៅ គឺត្រូវទៅអែបនៅត្រង់ថ្មដាអេសែល ២០ខ្ញុំនឹង
បាញ់ព្រួញ[ភ]៣ឱ្យត្រូវត្រង់ថ្មដានោះ ធ្វើដូចជាខំបាញ់ឱ្យត្រូវ
ស្នាមអ្វីមួយ ២១រួចខ្ញុំនឹងចាត់ក្មេងជិទង់ម្នាក់ ឱ្យទៅដោយថា
ចូរទៅរកព្រួយមក ហើយបើខ្ញុំនិយាយទៅក្មេងនោះថា
មើល ព្រួញនៅខាងអាយឯងឯណេះ ចូររើសយកមក នោះ
ខ្ញុំស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់ថា គ្មាន
ហេតុអ្វីនឹងនាំឱ្យអន្តរាយទេ មានតែសេចក្ដីមេត្រីដល់អ្នក
ប៉ុណ្ណោះ ២២តែបើខ្ញុំនិយាយទៅក្មេងនោះថា មើល ព្រួញ
នៅខាងនាយឯងឯណោះ[ម] នោះត្រូវឱ្យអ្នកអញ្ជើញទៅចុះ
ដ្បិតព្រះយេហូវ៉ាទ្រង់បានឱ្យអ្នកទៅហើយ ២៣ឯដំណើរ
ដែលយើងបានសំរេចគ្នា នោះមានព្រះយេហូវ៉ា ទ្រង់គង់
នៅជាកណ្ដាល[យ]អ្នក ហើយនិងខ្ញុំរៀងរាបតទៅស្រាប់
ហើយ ។
២៤ដូច្នេះ ដាវីឌក៏ទៅពួននៅឯទីវាល លុះដល់ថ្ងៃចូល
ខែ[រ]ហើយ នោះស្ដេចទ្រង់ក៏គង់សោយព្រះស្ងោយ ២៥ទ្រង់
ក៏គង់នៅលើអាសនៈត្រង់ជិតជញ្ជាំង ដូចជាសព្វ១ដង ឯ
យ៉ូណាថានលោកឈរនៅ ហើយអ័ប៊ីនើរអង្គុយនៅក្បែរ
សូល តែឯកន្លែងរបស់ដាវីឌនៅជាទំនេរវិញ[ល] ២៦ប៉ុន្តែនៅ
ថ្ងៃនោះ សូលទ្រង់មិនបានមានបន្ទូលអ្វីសោះ ដោយស្មាន
ថា មានការអ្វីកើតឡើងហើយ ប្រាកដជាវាមិនស្អាតទេ[វ]
២៧លុះស្អែកឡើង ក្រោយថ្ងៃចូលខែ គឺជាថ្ងៃទី២ កន្លែង
ដាវីឌក៏នៅតែទំនេរទៀត នោះសូលទ្រង់មានបន្ទូលសួរ
យ៉ូណាថានជាបុត្រាទ្រង់ថា ហេតុអ្វីបានជាកូនអ៊ីសាយមិន
បានមកបរិភោគភោជនាហារ ពីថ្ងៃម្សិលមិញ ហើយថ្ងៃ
នេះផង ២៨យ៉ូណាថានទូលឆ្លើយថា ដាវីឌបានអង្វរ សូមឱ្យ
ទូលបង្គំ បើក[ស]ឱ្យគាត់ទៅឯបេថ្លេហិមហើយ ២៩ដោយថា
សូមអនុញ្ញាតឱ្យខ្ញុំទៅ ដ្បិតពួកគ្រួរបស់យើងខ្ញុំ គេនាំគ្នា
ថ្វាយយញ្ញបូជា[ហ]នៅក្នុងទីក្រុង ហើយបងខ្ញុំបានផ្ដាំឱ្យខ្ញុំទៅ
ដូច្នេះ បើអ្នកអាណិតមេត្តាដល់ខ្ញុំ នោះសូមឱ្យខ្ញុំទៅសួរបង
ប្អូនខ្ញុំបន្តិច គឺដោយហេតុនោះបានជាគាត់មិនបានមក

**២០:១៤** ត លប ៤០:១៤
**២០:១៥** ថ ១សយ ២៤:២១ ២សយ ៩:៧
**២០:១៦** ទ ១សយ ១៨:១ ធ ១សយ ១៨:៣ ន យស ២២:២៣
**២០:១៧** ប យស ៩:១៨ ១សយ ១៨:៣
**២០:១៨** ផ ខ.២៥
**២០:១៩** ព ១សយ ១៩:២
**២០:២០** ភ ២ពវ ១៣:១៥
**២០:២២** ម ខ.៣៧
**២០:២៣** យ លប ៣១:៥០
**២០:២៤** រ ជន ១០:១០
**២០:២៥** ល ខ.១៨
**២០:២៦** វ លវ ៧:២០-២១
**២០:២៨** ស ខ.៦
**២០:២៩** ហ លប ៨:២០

*ជាមួយនឹងអ្នក ដូចជាទ្រង់បានគង់នៅជាមួយនឹងបិតាខ្ញុំដែរ* គឺចង់មានន័យថា លោកយ៉ូណាថាន ព្រមទទួលដាវីឌឱ្យធ្វើជាស្ដេច ។

**២០:១៤** *ខ្ញុំរួចស្លាប់ប៉ុណ្ណោះ* វាគឺជារឿងពិតនៅក្នុងសម័យកាលមុនសម្រាប់ការគ្រប់គ្រងដំបូងរបស់ស្ដេចថ្មី ក្នុងការការពារដំណែងរបស់ខ្លួនតាមរយៈ ការសម្លាប់ពួកអ្នកដែលដណ្ដើមទាមទាររាជ្យបល្ល័ង្កពីស្ដេចដែលមានឋានៈខ្ពស់ជាង (១ពវ ១៥:២៩ ១៦:១១ ២ពវ ១០:៧ ១១:១) ។

**២០:១៥** *មិនផ្ដាច់សេចក្ដីសប្បុរសរបស់អ្នកពីពួកវង្សខ្ញុំ* សំណូមពរនេះ គឺពឹងផ្អែកលើសេចក្ដីសញ្ញាដែលយ៉ូណាថាន និងដាវីឌបានតាំងកាលពីគ្រាមុន (មើលការពន្យល់ ១៨:៣) ហើយនិងការប្រព្រឹត្តដោយការគោរពនៅសម័យក្រោយៗទៀត នៅក្នុងទំនាក់ទំនងរបស់ដាវីឌ និងកូនយ៉ូណាថានឈ្មោះថា លោកមភីបូសែត (សូមមើល ២សយ ៩:៣,៧ ២១:៧) ។

**២០:១៦** *សូមឱ្យព្រះយេហូវ៉ាទ្រង់នឹងសងការនោះ ដោយសារដៃនៃពួកខ្មាំងសត្រូវរបស់ដាវីឌវិញចុះ* យ៉ូណាថានបានចូលជាមួយដាវីឌរួចរាល់ហើយ ដើម្បីឱ្យមកបំផ្លាញពួកខ្មាំងសត្រូវរបស់គាត់ រួមទាំងសូលដែលជាបិតារបស់ខ្លួនផង ។

**២០:១៧** *ស្បថម្ដងទៀត* សូមមើល ខ.១៤-១៥,៤២ ១៨:៣ ។ *ស្រឡាញ់ដល់ដាវីឌទុកដូចជាខ្លួនលោក* សូមមើល ១៨:៣ ២សយ ១:២៦ ។

**២០:១៨** *ថ្ងៃចូលខែ* សូមមើលការពន្យល់ ខ.៥ ។

**២០:១៩** *ឯកន្លែងដែលអ្នកបានពួន* ប្រហែលជាសំដៅទៅកន្លែងដែលបាននិយាយនៅក្នុង ១៩:២ ។

**២០:២១** *ព្រះយេហូវ៉ាដ៏មានព្រះជន្មរស់* មើលការពនយល់ ១៤:៣៩,៤៥ ។

**២០:២៣** *ដំណើរដែលយើងបានសំរេចគ្នា* សូមមើល ខ.១៤-១៧ ។ *មានព្រះយេហូវ៉ា ទ្រង់គង់នៅកណ្ដាលអ្នក ហើយនិងខ្ញុំ* ពួកគេកំពុងតែអំពាវនាវសុំឱ្យព្រះអម្ចាស់ធ្វើជាសាក្សី និងជាចៅក្រមរបស់ពួកគេថា អ្វីដែលគេបានយល់ព្រមជាមួយគ្នា គេនឹងធ្វើតាម ។

**២០:២៥** *អ័ប៊ីនើរ* គឺជាជីដូនមួយរបស់ស្ដេចសូល ហើយជាមេបញ្ជាការកងទ័ពរបស់ទ្រង់ដែរ (សូមមើល ១៤:៥០) ។

**២០:២៦** *ប្រាកដជាវាមិនស្អាតទេ* មើលការពន្យល់ ១៦:៥ ផ្ទៀបនឹង លវ ៧:១៩-២១ ១៥:១៦ ចទ ២៣:១០ ។

**២០:២៧,៣០-៣១** *កូនអ៊ីសាយ* ជាការនិយាយមើលងាយចំពោះដាវីឌ (សូមមើល ២២:៧-៩,១៣ ២៥:១០ ប្រៀបធៀបជាមួយ ២សយ ១៦:១០ អស ៧:៤) ។

បរិភោគជាមួយនឹងបិតាទេ ។
៣០ ខណនោះ សូលទ្រង់ក៏កើតមានសេចក្ដីខ្ញាល់នឹង
យ៉ូណាថាន ហើយបន្ទោសថា នែ អាកូនម្ទោម្ទះ ហើយរឹង
ចចេសអញដឹងហើយថា ដែលឯងបានរើសយកកូនអ៊ីសាយ
នេះ ទុកជាមិត្រសំឡាញ់ នោះនឹងបានជាសេចក្ដីខ្មាសដល់
ឯង ហើយជាសេចក្ដីខ្មាសដល់កេរខ្មាសរបស់ម្ដាយឯង
ថែមទៀត ៣១ ដ្បិតដែលកូនអ៊ីសាយនេះរស់នៅផែនដី ដរាប
ណា នោះឯងមិនបានខ្ជាប់ខ្ជួនឡើយ ហើយរាជ្យ[ឡ]ឯងក៏មិន
បានតាំងឡើងដែរ ដូច្នេះ ចូរឱ្យគេទៅនាំយកវាមកឯអញ
ឥឡូវនេះ ដ្បិតវាគួរស្លាប់ហើយ ៣២ តែយ៉ូណាថានទូលទាស់
ថា ហេតុអ្វី[អ]បានជាគាត់ត្រូវស្លាប់ តើបានធ្វើអ្វី[ក]ខ្លះ ៣៣ នោះ
សូលទ្រង់ពួយដែកពួយទៅ ដើម្បីប្រហារយ៉ូណាថាន ដោយ
ហេតុនោះ លោកក៏បានជ្រាបថា បិតាបានសំរេច[ខ]ព្រះទ័យ
នឹងសំឡាប់ដាវីឌហើយ ៣៤ ដូច្នេះយ៉ូណាថានក៏ក្រោកពីតុ
ឡើង ដោយមានសេចក្ដីកំហឹងជាខ្លាំង ហើយនៅថ្ងៃទី២
នោះ លោកមិនបានបរិភោគអ្វីសោះ ដោយមានសេចក្ដីឈឺ
ឆ្អាលចំពោះដាវីឌ ហើយពីព្រោះបិតាបានធ្វើឱ្យមាន
សេចក្ដីខ្មាសផង ។
៣៥ លុះដល់ព្រឹកឡើង យ៉ូណាថានក៏ចេញទៅឯវាលតាម
ពេលដែលបានសន្យានឹងដាវីឌ ហើយមានក្មេងម្នាក់ទៅជា
មួយផង ៣៦ លោកក៏ប្រាប់ដល់ក្មេងនោះថា ចូរឯងរត់ទៅ
យកព្រួញ ដែលអញនឹងបាញ់ឥឡូវនេះមក កាលក្មេងនោះ
កំពុងរត់ទៅ នោះលោកបាញ់ព្រួញ១ទៅខាងនាយវា
៣៧ តែកាលក្មេងបានរត់ទៅដល់កន្លែង ដែលព្រួញធ្លាក់នោះ
យ៉ូណាថានស្រែកទៅតាមថា នៅខាងនាយ[គ]ឯងឯណោះ

**២០:៣១** ឡ ១សយ ២៣:១៧ ២៤:២០
**២០:៣២** អ ១សយ ១៩:៤ មថ ២៧:២៣ ក លប ៣១:៣៦
**២០:៣៣** ខ ១សយ ១៨:១១,១៧
**២០:៣៧** គ ខ.២២
**២០:៤១** ឃ លប ៣៣:៣ នរ ២:១០ ១សយ ២៤:៨ ២៥:២៣ ២សយ ១:២
**២០:៤២** ង ១សយ ១:១៧ កច ១៥:៣៣ ច លប ៤០:១៤ ២សយ ១:២៦ សភ ១៨:២៤ ឆ អស ៤៨:១ ជ លប ៣១:៥០ ១សយ ១៨:៣ ឈ ២សយ ៩:១
**២១:១** ក ១សយ ២២:៩,១៩ នហ ១១:៣២ អស ១០:៣២ ខ ១សយ ១៦:៤

៣៨ រួចយ៉ូណាថានក៏ស្រែកទៅតាមវាម្ដងទៀតថា ឱ្យឆាប់ៗ
ប្រញាប់ឡើង កុំឱ្យឈប់ឡើយ ដូច្នេះ ក្មេងនោះក៏រើសព្រួញ
រួចត្រឡប់មកឯចៅហ្វាយវិញ ៣៩ តែឥតបានដឹងការអ្វីឡើយ
មានតែយ៉ូណាថាន ហើយនិងដាវីឌប៉ុណ្ណោះ ដែលដឹងការ
នោះ ៤០ រួចយ៉ូណាថានលោកប្រគល់គ្រឿងបាញ់ទៅក្មេង
ដោយប្រាប់ថា ចូរយកទៅក្នុងទីក្រុងចុះ ៤១ កាលបានទៅផុត
ហើយ នោះដាវីឌក្រោកឡើងពីទីខាងត្បូងនោះ មកក្រាប
ផ្កាប់មុខនឹងដី[ឃ]អស់៣ដង រួចក៏ឱបគ្នាថើបដោយយំទាំង២
នាក់ ទាល់តែដាវីឌបានហូរទឹកភ្នែកខ្លាំងជាង ៤២ នោះ
យ៉ូណាថានមានប្រសាសន៍ដល់ដាវីឌថា អញ្ជើញអ្នកទៅឱ្យ
ប្រកបដោយសេចក្ដីសុខចុះ[ង] ដ្បិតយើងទាំង២នាក់បាន
ស្បថគ្នា[ច] ដោយនូវព្រះនាមព្រះយេហូវ៉ាហើយថា ព្រះ
យេហូវ៉ា[ឆ] ទ្រង់នឹងគង់កណ្ដាល[ជ]ខ្ញុំហើយនិងអ្នក ហើយ
កណ្ដាលពូជខ្ញុំ និងពូជរបស់អ្នកជាដរាបតទៅ[ឈ] នោះដាវីឌ
ក៏ក្រោកឡើងចេញទៅ ឯយ៉ូណាថានលោកក៏ត្រឡប់វិល
ចូលទៅក្នុងទីក្រុងវិញ ។

### លោកដាវីឌ នៅក្រុងណូប

**២១** ១ ដាវីឌក៏ទៅឯអ័ហ៊ីម៉ាលេកដ៏ជាសង្ឃ នៅត្រង់ណូប[ក]
ឯអ័ហ៊ីម៉ាលេក ក៏ចេញមកទទួលទាំងភ័យញ័រ[ខ]ហើយសួរថា
ហេតុអ្វីបានជាលោកអញ្ជើញមកតែម្នាក់ឯង ឥតមានអ្នក
ណាមកជាមួយផងដូច្នេះ ២ ដាវីឌឆ្លើយថា ស្ដេចទ្រង់បាន
បង្គាប់ការមកខ្ញុំ ដោយថា កុំឱ្យអ្នកណាដឹងអ្វីពីដំណើរ ដែល
អញចាត់ឯងឱ្យទៅធ្វើនោះ ឬពីសេចក្ដីដែលអញបានបង្គាប់
ដល់ឯងឡើយ ឯខ្ញុំបានដំរូវឱ្យពួកកំឡោះៗនៅចាំត្រង់

---

**២០:៣០** *អាកូនម្ទោម្ទះ . . . ជាសេចក្ដីខ្មាសដល់កេរខ្មាស់របស់ម្ដាយឯង* គឺជាសំនួនវោហស័ក្នុងព្រះគម្ពីរភាសាហេព្រើរ សំដៅលើអត្តចរិតលោកយ៉ូណាថានមិនមែនម្ដាយគាត់ឡើយ ។

**២០:៣១** *ឯងមិនបានខ្ជាប់ខ្ជួនឡើយ ហើយរាជ្យឯងក៏មិនបានតាំងឡើងដែរ* ឥឡូវនេះស្ដេចសូលជឿថា ដាវីឌនឹងឈ្នះលើទ្រង់ បើសិនជាដាវីឌមិនត្រូវបានសម្លាប់ (សូមមើលការពន្យល់ ១៨:១៣,១៧,២៩ ១៩:១) ហើយនិងការអសមត្ថភាព របស់គាត់ក្នុងការមិនបានដឹងអំពីការមិនបានខ្វល់ខ្វាយរបស់លោកយ៉ូណាថានក្នុង ការស្នងរាជ្យបន្តពីគាត់នោះឡើយ ។

**២០:៣៣** *ពួយដែកពួយ* សូមមើល ១៨:១១ ១៩:១០ ។

**២០:៤១** *ក្រាបផ្កាប់មុខនឹងដីអស់៣ដង* គឺជានិមិត្តរូបនៃការចុះចូល និងការគោរព (សូមមើល លប ៣៣:៣ និងការពន្យល់ ៤២:៦) ។

**២០:៤២** *យើងទាំង២នាក់បានស្បថគ្នា* សូមមើល ខ.១៤–១៥,២៣ ១៨:៣ ។ *ទីក្រុង* គឺជាទីក្រុងគីបៀរ (សូមមើល ១០:២៦) ។

**២១:១** *ណូប* គឺជាទីក្រុងដែលស្ថិតនៅទិសឦសាននៃក្រុងយេរូសាឡិម និងភាគខាងត្បូងនៃក្រុងគីបៀរ ជាកន្លែងមួយដែលរោងឧបោសថត្រូវបានតាំងជាថ្មី បន្ទាប់ពីត្រូវទទួលការបំផ្លាញពីសំណាក់ស្ដេចស៊ីហុន (សូមមើល ៤:៣ យរ ៧:១២) ។ ទោះបីជាមិនបាននិយាយថា មានការប៉ុនប៉ងយកហឹបសញ្ញាមកក្នុងកន្លែងបរិសុទ្ធនេះក្ដី (សូមមើលការពន្យល់ ៧:១) សម្ដេចសង្ឃអ័ហ៊ីម៉ាលេក និងពួកសង្ឃ៨៥នាក់ទៀត (សូមមើល ២២:១៦–១៨) ព្រមទាំងអេផូឌ (ខ.៩) ហើយនំប៉័ងបរិសុទ្ធ (ខ.៦) ត្រូវស្ថិតនៅទីនោះ ។ *អ័ហ៊ីម៉ាលេកដ៏ជាសង្ឃ* សូមមើលការពន្យល់ ១៤:៣ ។ ចាប់តាំងពីជំពូក ២២:១០,១៥ គឺនិយាយពីគោលបំណងរបស់ដាវីឌដែលមកក្រុងណូប ដើម្បីស្វែងរកការបង្ហាញផ្លូវរបស់ព្រះអម្ចាស់ តាមរយៈការប្រើយូរីម និងធូមីម (សូមមើលការពន្យល់ ២:២៨ នក ២៨:៣០) ។

**២១:២** នៅកន្លែងនេះមិនបានបញ្ជាក់ច្បាស់ឡើយថា ហេតុអ្វីបានជាលោកដាវីឌកុហកដល់អ័ហ៊ីម៉ាលេកនោះឡើយ ។ ប្រហែលជាដើម្បីការពារលោកអ័ហ៊ីម៉ាលេក មិនឱ្យជាប់ទាក់ជាមួយនឹងការរត់គេចរបស់លោកដាវីឌដោយសារស្ដេចសូល ។ បើសិនជាដូច្នេះមែន នោះយុទ្ធសាស្ត្ររបស់គាត់មិន

កន្លែង១នោះ ៣ដូច្នេះ តើមានអ្វីខ្លះនៅក្នុងបន្ទុកលោកដែរ
សូមឱ្យនំបុ័ង៥ដុំ ដែលនៅក្នុងបន្ទុកលោកនោះមកខ្ញុំ ឬ
របស់អ្វីក៏ដោយ ដែលលោកមានផង ៤សង្ឃឆ្លើយតបថា
ខ្ញុំគ្មាននំបុ័ងធម្មតានៅក្នុងបន្ទុករបស់ខ្ញុំទេ មានតែនំបុ័ង[គ]
បរិសុទ្ធ[ឃ]ប៉ុណ្ណោះ បើពួកកំឡោះនោះបានតម[ង]តែស្រី
ប៉ុណ្ណោះ នោះបានហើយ ៥រួចដាវីឌឆ្លើយកាត់ថា នេះគឺ
គេបានបង្អត់យើងជាស្រេច តាំងតែពីខ្ញុំចេញធ្វើដំណើរ
បាន៣ថ្ងៃមកហើយ បានជាពួកខ្ញុំបានបរិសុទ្ធទាំងអស់គ្នាទេ
ឯនំបុ័ងនេះក៏ជានំបុ័ងធម្មតា[ច]ម្យ៉ាងដែរ ទោះបើបានញែក
ជាបរិសុទ្ធ[ឆ] ក្នុងចាននៅថ្ងៃនេះឯងក៏ដោយ ៦ដូច្នេះសង្ឃក៏
ឱ្យនំបុ័ងបរិសុទ្ធទៅលោក[ជ] ដ្បិតនៅទីនោះគ្មាននំបុ័ងណា
ផ្សេងទៀតឡើយ មានតែនំបុ័ងតាំងទុកប៉ុណ្ណោះ គឺជានំបុ័ង
ដែលបានយកចេញពីចំពោះព្រះយេហូវ៉ាមក ដើម្បីនឹងដាក់
នំបុ័ងក្តៅ នៅថ្ងៃដែលគេយកនំបុ័ងចាស់នោះចេញ ។
៧នៅថ្ងៃនោះឯង ក៏មានពួកអភិបាលម្នាក់របស់សូល
នៅទីនោះត្រូវឃាត់ទុកនៅចំពោះព្រះយេហូវ៉ា គាត់នោះ
ឈ្មោះដូអេក[ឈ]ជាសាសន៍អេដំម[ញ] ធ្វើជាមេដំរួតលើពួក
គង្វាលសត្វរបស់សូល ៨ឯដាវីឌក៏សួរអ័ហ៊ីម៉ាលេកថា
នៅទីនេះមានលំពែង ឬដាវ ក្នុងបន្ទុកលោកឬទេ ដ្បិតខ្ញុំ
មិនបានជាប់ដាវ ឬគ្រឿងសស្ត្រាវុធមកជាមួយទេ ពីព្រោះ
ការរបស់ស្តេចនេះ ជាការប្រញាប់ណាស់ ៩សង្ឃឆ្លើយថា
មានតែដាវ[ដ]របស់កូលីយ៉ាត[ឋ] ជាសាសន៍ភីលីស្ទីន ដែល
លោកបានសំឡាប់ នៅក្នុងច្រកភ្នំអេឡា[ឌ]ប៉ុណ្ណោះ បានរុំនឹង
សំពត់ ដាក់នៅខាងក្រោយអេផូឌ បើលោកត្រូវការ សូម
យកចុះ ដ្បិតគ្មានអ្វីទៀតនៅទីនេះទេ នោះដាវីឌឆ្លើយថា
គ្មានដាវណាដូចដាវនោះទេ ដូច្នេះ សូមឱ្យមកខ្ញុំចុះ។

## លោកដាវីឌនៅក្រុងកាថ

១០នៅថ្ងៃនោះឯង ដាវីឌក៏ចេញរត់ទៅ[ឍ]ឯអ័គីស ជា
ស្តេចក្រុងកាថដោយខ្លាចសូល ១១នោះពួកមហាតលិក
របស់អ័គីសទូលថា អ្នកនេះ តើមិនមែនជាដាវីឌ ជាស្តេចនៃ
ស្រុកនោះទេឬអី តើគេមិនបានច្រៀងឆ្លើយឆ្លងគ្នាពី
ដំណើរអ្នកនេះ ទាំងលោតកញ្ឆេងផងថា សូលបានសំឡាប់
ទាំងពាន់ ហើយដាវីឌទាំងម៉ឺនទេឬអី[ណ] ១២ដាវីឌក៏កំណត់ទុក
ពាក្យទាំងនោះ នៅតែក្នុងចិត្ត ហើយមានសេចក្តីភ័យដោយ
ព្រោះអ័គីស ជាស្តេចក្រុងកាថជាខ្លាំង ១៣ដូច្នេះ លោក
ផ្លាស់ភាពប្រព្រឹត្ត[ត]នៅមុខគេ ទាំងក្លែងធ្វើជាឆ្កួតនៅ
កណ្តាលពួកគេ គឺធ្វើជាគូរវាសនៅនាទ្វារ ហើយបង្ហៀរ
ទឹកមាត់លើពុកចង្កា ១៤នោះអ័គីសមានបន្ទូលទៅពួក
មហាតលិកថា មើល ឯងរាល់គ្នាឃើញថា មនុស្សនេះឆ្កួត
ដែរ ម្តេចក៏នាំវាមកឯអញធ្វើអី ១៥តើអញខ្វះមនុស្សឆ្កួត ឬអី
បានជាឯងរាល់គ្នានាំអានេះមកឱ្យឆ្កួតនៅចំពោះមុខ
អញទៀត តើគួរឱ្យវាចូលមកក្នុងដំណាក់អញឬអី ។

## លោកដាវីឌ នៅរអាងអាឌូឡាម និងក្រុងមីសប៉ា

**២២** ១ដូច្នេះដាវីឌក៏ចេញពីទីនោះ ភៀសខ្លួនទៅឯរអាង[ក]
អាឌូឡាម[ខ] កាលពួកបងប្អូន និងពួកគ្រួរបស់ឪពុកលោក
ទាំងប៉ុន្មានបានដឹង នោះគេក៏នាំគ្នាចុះទៅឯលោកនៅទី
នោះដែរ ២ហើយអស់អ្នកណាដែលមានសេចក្តីវេទនា និង

**២១:៤** គ លវ ២៤:៨-៩ ឃ មថ ១២:៤ ង នក ១៩:១៥ លវ ១៥:១៨
**២១:៥** ច ចទ ២៣:៩-១១ យស ៣:៥ ២សយ ១១:១១ ឆ ១ថន ៤:៤
**២១:៦** ជ នក ២៥:៣០ ១សយ ២២:១០ មថ ១២:៣-៤ មក ២:២៥-២៨ លក ៦:១-៥
**២១:៧** ឈ ១សយ ២២:៩,២២ ញ ១សយ ១៤:៤៧ ទដ ៥២
**២១:៩** ដ ១សយ ១៧:៥១ ឋ ១សយ ១៧:៤ ឌ ១សយ ១៧:២
**២១:១០** ឍ ១សយ ២៥:១៣ ២៧:២
**២១:១១** ណ ១សយ ១៨:៧
**២១:១៣** ត ទដ ៣៤
**២២:១** ក ទដ ៥៧, ១៤២ ខ លប ៣៨:១

បានសម្រេចទេ (សូមមើល ២២:១៣-១៩) ។

**២១:៤** *នំបុ័ងបរិសុទ្ធ* គឺជា "នំបុ័ងតាំងទុក" (សូមមើល ខ.៦ នក ២៥:៣០ និងការពន្យល់) ដែលបានតម្កល់ទុកនៅក្នុងទីបរិសុទ្ធនៃរោងឧបោសថ ហើយនៅពេលក្រោយ គេបានតម្កល់ទុកនៅក្នុងព្រះវិហារ ទុកជាដង្វាយនៃការអរព្រះគុណដល់ព្រះអម្ចាស់ ចំពោះការដែលព្រះអង្គបានផ្គត់ផ្គង់នំបុ័ងប្រចាំថ្ងៃដល់ពួកគេ ។ *បើពួកកំឡោះនោះបានតមតែស្រីប៉ុណ្ណោះ នោះបានហើយ* ទោះបីជានំបុ័ងទាំងនោះ អាចបរិភោគបានតែពួកសង្ឃក៏ដោយ (សូមមើល លវ ២៤:៩) ក៏ពេលនេះលោកអ័ហ៊ីម៉ាលេកបានឱ្យទៅដាវីឌ និងពួកកំឡោះរបស់គាត់នៅក្នុងលក្ខខណ្ឌមួយថា ពួកគេត្រូវតែធ្វើពិធីសម្អាត (មើល នក ១៩:១៥ លវ ១៥:១៨) ។ ព្រះយេស៊ូវទ្រង់បានលើកយកហេតុកាណ៌នេះមកពន្យល់អំពីគោលការណ៍ពិធីនោះថា ច្បាប់របស់ពិធីនោះមិនអាចយកជាច្បាប់នគរបានឡើយ (សូមមើល មថ ១២:៣-៤) ។ ព្រះយេស៊ូវទ្រង់ក៏បានបង្រៀនទៀតដែរថា វាជាច្បាប់នឹងធ្វើការល្អ និងសង្គ្រោះជីវិត (លក ៦:៩) ដូចជាការអាណិតអាសូរ និងមេត្តាករុណាទើបជាសេចក្តីពិតរបស់ក្រឹត្យវិន័យ ។

**២១:៥** *បានជាពួកខ្ញុំបានបរិសុទ្ធទាំងអស់គ្នា* ធ្វើដូច្នេះដើម្បីឱ្យពួកគេបានបរិសុទ្ធនៅចំពោះព្រះអម្ចាស់ (មើលការពន្យល់ នក ៣:៥) ។

**២១:៩** *ដាវរបស់កូលីយ៉ាត* សូមមើលការពន្យល់ ១៧:៥៤ ។ *អេផូឌ* មើលការពន្យល់ ២:២៨ ។

**២១:១០** *អ័គីស* សូមមើលការពន្យល់ ទដ ៣៤ ចំណងជើង ។ ការប្រើឈ្មោះនេះប្រហែលជាតាមទម្លាប់តៗគ្នា ដែលពួកអ្នកគ្រប់គ្រងភីលីស្ទីនបានប្រើ (សូមមើលការពន្យល់ ១ពវ ២:៣៩) ។ ឈ្មោះនេះដូចជាងាររបស់ស្តេចអេក្រុន២ ឬ៣នាក់ នៅក្នុងសតវត្សរ៍ក្រោយៗទៀត (ដូចដែលបានបញ្ជាក់នៅក្នុងប្រវត្តិសាស្ត្រស្តេចស៊ីរី អេសារហាដោន និងអ័ស្នាផារដែលបានកត់ទុកក្នុងសិលាចារិក ដែលគេរកឃើញនៅក្រុងអេក្រុនក្នុងឆ្នាំ១៩៩៦) ។ *ក្រុងកាថ* មើល ៥:៨ ។

**២១:១១** សូមមើល ២៩:៥ ១៨:៧ ។ *ស្តេចនៃស្រុក* គឺជាការតាក់តែងងាររបស់ដាវីឌថាជា "ស្តេច" ពីសំណាក់ពួកភីលីស្ទីន ប្រហែលជាការបំភ្លើសពីជ័យជម្នះ និងប្រជាប្រិយភាពរបស់លោកដាវីឌនៅក្នុងចំណោមពួកអ៊ីស្រាអែល ។

**២២:១** *រអាងអាឌូឡាម* សូមមើល ២សយ ២៣:១៣ លប ៣៨:១ និងការពន្យល់, និងមើល យស ១២:១៥ ១៥:៣៥ ។

អស់អ្នកណាដែលជាប់បំណុល ហើយនិងអស់ អ្នកណាដែល
មានសេចក្ដីជូរជ្រេញក្នុងចិត្ត គេក៏ទៅមូលជុំគ្នា[គ]នៅឯ
លោកមានចំនួនប្រហែលជា៤00នាក់ នៅជាមួយនឹងលោក
ហើយលោកធ្វើជាមេលើគេ ។
[៣]ពីទីនោះ ដាវីឌក៏ចេញទៅឯមីសប៉ា នៅស្រុកម៉ូអាប់
លោកទូលសូមស្ដេចម៉ូអាប់ថា សូមទ្រង់អនុញ្ញាតឱ្យឪពុក
ម្ដាយរបស់ទូលបង្គំ មកនៅអាស្រ័យនឹងទ្រង់ផង ដរាបដល់
ទូលបង្គំបានដឹងជាព្រះទ្រង់នឹងប្រព្រឹត្តដល់ទូលបង្គំជាយ៉ាង
ណា [៤]លោកក៏នាំយកឪពុកម្ដាយទៅគាល់នៅចំពោះស្ដេច
ម៉ូអាប់[ឃ] រួចគេអាស្រ័យនៅជាមួយនឹងទ្រង់អស់កំណត់
ពេលដែលដាវីឌនៅក្នុងទីពំនួន [៥]ឯហោរាកាឌ់[ង]ក៏ជំរាប
លោកថា កុំឱ្យនៅក្នុងទីពំនួននេះឡើយ សូមទៅឯស្រុក
យូដាវិញទៅ នោះដាវីឌក៏ចេញទៅអាស្រ័យនៅឯព្រៃ
ហារេក[ច] ។

## ស្ដេចសូលសម្លាប់ពួកសង្ឃនៅក្រុងណូប

[៦]ឯសូលទ្រង់ក៏ឮថា មានគេបានឃើញដាវីឌនិងពួក
មនុស្សដែលនៅជាមួយនឹងលោក គ្រានោះសូលទ្រង់កំពុង
គង់[ឆ]នៅក្រោមដើមម៉ែសាក់[ជ] ត្រង់គីបៀរនៅស្រុករ៉ាម៉ា
មានទាំងលំពែងនៅព្រះហស្ត ហើយពួកមហាតលិកទ្រង់
ឈរព័ទ្ធជុំវិញផង [៧]ទ្រង់មានបន្ទូលទៅពួកមហាតលិក[ឈ]
ដែលឈរជុំវិញនោះថា នែ ពួកបេនយ៉ាមីនអើយ ចូរស្ដាប់
អញ តើកូនអ៊ីសាយនោះនឹងចែកស្រែចំការឱ្យដល់ឯងគ្រប់
គ្នាឬ តើវានឹងតាំងឯងទាំងអស់ឱ្យធ្វើជាមេទ័ពលើ១ពាន់
នាក់ ហើយលើ១00នាក់ឬអី [៨]បានជាឯងទាំងអស់គ្នាបាន
រួមគំនិត[ញ]គិតក្បត់អញដូច្នេះ ហើយគ្មានអ្នកណាមួយប្រាប់
ឱ្យអញដឹង ក្នុងកាលដែលកូនអញបានចុះសញ្ញា[ដ]នឹងកូន
អ៊ីសាយនោះ[ឋ] ក៏គ្មានអ្នកណាមួយក្នុងពួកឯងដែលឈឺឆ្អាល[ឌ]
នឹងអញសោះ ឬបង្ហាញឱ្យដឹង ជាកូនអញបានពន្យុះអ្នកបំរើ
របស់អញ ឱ្យលបចាំទាស់នឹងអញ ដូចជាសព្វថ្ងៃនេះ
ផង [៩]នោះដូអេក[ឍ] ជាសាសន៍អេដំម ដែលឈរជិតពួក
មហាតលិករបស់សូល ក៏ទូលឆ្លើយឡើងថា ទូលបង្គំបាន
ឃើញកូនអ៊ីសាយមកឯអ័ហ៊ីម៉ាលេក ជាកូនអ័ហ៊ីទូប[ណ] នៅ
ត្រង់ណូប[ត] [១០]ហើយលោកបានទូលសួរ[ថ]ដល់ព្រះយេហូវ៉ា
ឱ្យវា ក៏បានឱ្យអាហារ[ទ]និងដាវ[ធ]របស់កូលីយ៉ាតជាសាសន៍
ភីលីស្ទីនទៅវាផង ។
[១១]នោះស្ដេចក៏ចាត់គេ ឱ្យទៅនាំអ័ហ៊ីម៉ាលេក ជាសង្ឃ
ដែលជាកូនអ័ហ៊ីទូប និងពួកគ្រួឪពុកលោកទាំងអស់ដែល
នៅត្រង់ណូបមក គេក៏មកឯស្ដេចទាំងអស់គ្នា [១២]រួចសូល
មានបន្ទូលទៅគេថា ចូរស្ដាប់ចុះ កូនអ័ហ៊ីទូបឯង លោកក៏
ទូលឆ្លើយថា ព្រះករុណាវិសេសព្រះបពិត្រ [១៣]រួចសូលទ្រង់
សួរថា ហេតុអ្វីបានជាឯង និងកូនអ៊ីសាយបានរួមគំនិត[ន]
ទាស់និងអញដូច្នេះ ដោយឯងបានឱ្យអាហារនិងដាវដល់វា
ហើយទូលសួរព្រះឱ្យវាផង ដើម្បីឱ្យវាបានលើកគ្នាមកលប
ចាំទាស់និងអញ ដូចជាសព្វថ្ងៃនេះ [១៤]អ័ហ៊ីម៉ាលេកទូល

**២២:២** គ ១សយ ២៣:១៣ ២៥:១៣ ២សយ ១៥:២០
**២២:៤** ឃ លប ១៩:៣៧
**២២:៥** ង ២សយ ២៤:១១ ១របា ២១:៩ ២៩:២៩ ២របា ២៩:២៥ ច ២សយ ២៣:១៤
**២២:៦** ឆ ពច ៤:៥ ជ លប ២១:៣៣
**២២:៧** ឈ ចទ ១:១៥
**២២:៨** ញ ខ.១៣ ដ ១សយ ១៨:៣ ឋ ២សយ ២០:១ ឌ ១សយ ២៣:២១
**២២:៩** ឍ ១សយ ២១:៧ ណ ១សយ ១៤:៣ ត ១សយ ២១:១
**២២:១០** ថ លប ២៥:២២ ១សយ ២៣:២ ទ ១សយ ២១:៦ ធ ១សយ ១៧:៥១
**២២:១៣** ន ខ.៨

**២២:២** *៤00នាក់នៅជាមួយនឹងលោក* លោកដាវីឌ ជាពួកមន្ត្រីក្រៅផ្លូវការណ៍ គាត់បានចូលរួមនៅក្នុងកាលៈទេសៈដែលស្រដៀងគ្នានេះដែរ ដូច្នេះហើយ បានជាគាត់ចាប់ផ្ដើមបង្កើតពង្រឹងកម្លាំងទ័ពរបស់គាត់ កត្តាទាំងនេះហើយ គឺជាគ្រឹះដែលទ្រទ្រង់គាត់ ឱ្យធ្វើជាស្ដេចនៅឆ្នាំបន្ទាប់ទៀត (សូមមើលការពន្យល់ ១៤:៥២) ។

**២២:៣** *សូមទ្រង់អនុញ្ញាតឱ្យឪពុកម្ដាយរបស់ទូលបង្គំមកនៅអាស្រ័យនឹងទ្រង់ផង* ស្ដេចស្រុកម៉ូអាប់ ពិតជាយល់ព្រមចងមិត្តជាមួយលោកដាវីឌ ពីព្រោះស្ដេចសូលបានធ្វើសង្គ្រាមទាស់ប្រឆាំងជាមួយពួកម៉ូអាប់ (មើល ១៤:៤៧) ហើយលោកយាយទួតរបស់លោកដាវីឌ ជាសាសន៍ម៉ូអាប់ (សូមមើល នរ ៤:៥,១៣,២២) ។

**២២:៤** *ទីពំនួន* ប្រហែលជាសំដៅលើប៉ម ឬបន្ទាយ ប៉ុន្តែភាគច្រើនគឺសំដៅលើកន្លែងភូមិសាស្ត្រមួយដែលងាយស្រួលលាក់ខ្លួន (សូមមើល ២៣:១៤ ២សយ ៥:១៧ ២៣:១៤) ។

**២២:៥** *ហោរាកាឌ់* ឥឡូវនេះស្ដេចក៏មានហោរាមកបម្រើដែរ។ នៅសម័យកាលក្រោយមកទៀត សង្ឃម្នាក់ក៏បានមកឯទ្រង់ (មើល ខ.២0) និងបានបំពេញនូវមូលដ្ឋានគ្រឹះនៃពលបរិវារ ហើយពួកគេបានភាសខ្លួនចេញពីការត្រួតត្រារបស់ស្ដេចសូល ។ នេះគឺជាបុគ្គលិកលក្ខណៈដំបូងរបស់ពួកហោរាដែលបានជួយដាវីឌឱ្យបានក្លាយជាអ្នកលេងភ្លេងក្នុងវិហារ (២របា ២៩:២៥) ជាអ្នកដែលសរសេរប្រវត្តិសាស្ត្រក្នុងអំឡុងពេលស្ដេចដាវីឌ (មើល ១របា ២៩:២៩) ហើយជាអ្នកទូលអង្វរជំនួសដាវីឌ ក្នុងពេលដែលព្រះអម្ចាស់ទ្រង់ខ្ញាល់ចំពោះអំពើបាបរបស់គាត់ (មើល ២សយ ២៤:១១–២៥) ។ *ព្រៃហារេក* ស្ថិតនៅក្នុងតំបន់អំបូរយូដា ។

**២២:៦** *ដើមម៉ែសាក់* សូមមើល លប ២១:៣៣ ។ *គីបៀរ* មើលការពន្យល់ ១0:៥ ។

**២២:៧–៩,១៣** *កូនអ៊ីសាយ* សូមមើលការពន្យល់ ២0:២៧,៣0–៣១ ។

**២២:៧** *ពួកបេនយ៉ាមីន* សូលគឺជាពួកបេនយ៉ាមីន (មើល ៩:១–២ ១0:២១) ដែលបានខែងរ៉ែងចំពោះមុខតំណែងជាមន្ត្រីរបស់គាត់ ដោយលើកយកអំបូរស្ដេចមកនិយាយ ។ ស្ដេចដាវីឌចេញពីអំបូរយូដា (មើលការពន្យល់ ១៦:១ ២សយ ២:៤) ។ *នឹងចែកស្រែចំការឱ្យដល់ឯងគ្រប់គ្នាឬ* ស្ដេចសូលមានការ ប្រាកដច្បាស់ចំពោះអ្វីដែលសាំយូអែលបានព្រមានទ្រង់ថា គាត់អាចនឹងធ្វើ ត្រឡប់ដូចជាស្ដេចនៃនគរផ្សេងៗទៀត (មើល ៨:១៤) ។ ទង្វើរបស់ទ្រង់ដូច ជាផ្ទុយពីសេចក្ដីសញ្ញាអំពីភាពជាស្ដេច (សូមមើលការពន្យល់ ៨:៧ ១0:២៥) ។ *ធ្វើជាមេទ័ពលើ១ពាន់នាក់ ហើយលើ១00នាក់ឬអី* សូមមើល ៨:១២ ។

**២២:១០** *លោកបានទូលសួរដល់ព្រះយេហូវ៉ាឱ្យវា* សូមមើលការពន្យល់ ២១:១ ។

ឆ្លើយថា នៅក្នុងពួកមហាតលិកទ្រង់ទាំងប៉ុន្មាន តើមានអ្នក
ឯណា[ប]ដែលស្មោះត្រង់ដូចដាវីឌ ជាកូនប្រសាទ្រង់ ដែល
ស្តាប់បង្គាប់ទ្រង់ ហើយក៏មានកេរ្តិ៍ឈ្មោះក្នុងដំណាក់ទ្រង់
ផងនោះ ១៥ដូច្នេះនៅថ្ងៃនេះ ដែលទូលបង្គំបានទូលសួរ
ដល់ព្រះ នោះតើបានទូលសួរឱ្យលោកឬអី សូមឱ្យសេចក្តី
នោះនៅឆ្ងាយពីទូលបង្គំទៅ កុំឱ្យទ្រង់ព្រះករុណាប្រចាប់
ទូលបង្គំ ជាបាវបំរើរបស់ទ្រង់ ឬអ្នកណាមួយក្នុងពួកគ្រួឪពុក
ទូលបង្គំដូច្នេះឡើយ ដ្បិតទូលបង្គំជាបាវបំរើទ្រង់ មិនបាន
ដឹងអ្វីពីរឿងទាំងនេះ ទោះច្រើន ឬតិចនោះទេ ១៦តែស្តេច
ទ្រង់មានបន្ទូលថា អ័ហ៊ីម៉ាលេកឯងត្រូវស្លាប់ជាពិតប្រាកដ
គឺឯងហើយ និងពួកគ្រួឪពុកឯងទាំងអស់គ្នាផង[ផ] ១៧រួចស្តេច
ក៏បង្គាប់ដល់ពួកដំរួតដែលឈរនៅជុំវិញថា ចូរឯងរាល់គ្នា
សំឡាប់ពួកសង្ឃរបស់ព្រះយេហូវ៉ាចោលទៅ ពីព្រោះគេ
បានចូលដៃនឹងដាវីឌហើយ គេបានដឹងថាវារត់ តែមិនបាន
ប្រាប់ដល់អញសោះ តែពួកដំរួតរបស់ស្តេច គេមិនព្រម[ព]
លើកដៃទៅសំឡាប់ពួកសង្ឃនៃព្រះយេហូវ៉ាឡើយ ១៨នោះ
ស្តេចទ្រង់បង្គាប់ដល់ដូអេកថា ចូលឯងទៅសំឡាប់ពួក
សង្ឃ[ភ]ទៅ ដូច្នេះដូអេក ជាសាសន៍អេដំម ក៏ស្ទុះទៅលើពួក
សង្ឃសំឡាប់ ស្លាប់អស់៨៥នាក់នៅថ្ងៃនោះ សុទ្ធតែជាអ្នក
ពាក់អេផូឌធ្វើពីអំបោះខ្លូតទេស[ម] ១៩ឯក្រុងណូប[យ]ជាទីក្រុង
របស់ពួកសង្ឃនោះ វាក៏ប្រហារដោយមុខដាវ[រ]ដែរ គឺទាំង
ប្រុស ទាំងស្រី ទាំងក្មេង និងកូនដែលនៅបៅ ទាំងគោ
ទាំងលា ហើយនិងចៀមផង ។

២០តែមានម្នាក់ឈ្មោះអ័បៀថើរ[ល] ជាកូនអ័ហ៊ីម៉ាលេក
ដែលជាកូនអ័ហ៊ីទូប[វ] បានរត់រួចទៅដល់ដាវីឌ[ស] ២១ជំរាបពី
ដំណើរដែលសូលបានសំឡាប់ពួកសង្ឃនៃព្រះយេហូវ៉ាអស់
ហើយ ២២នោះដាវីឌមានប្រសាសន៍ទៅអ័បៀថើរថា នៅ
ថ្ងៃនោះ កាលខ្ញុំឃើញដូអេក[ហ] ជាសាសន៍អេដំម នៅទីនោះ
ខ្ញុំបានដឹងថា វានឹងទូលពិតដល់សូលជាមិនខាន ដំណើរ
នេះខ្ញុំបាននាំឱ្យពួកគ្រួឪពុកអ្នក ត្រូវស្លាប់ទាំងអស់គ្នាហើយ
២៣ដូច្នេះ ចូរអ្នកនៅជាមួយនឹងខ្ញុំចុះ កុំភ័យខ្លាចឡើយ
ដ្បិតអ្នកដែលស្វែងរកជីវិត[ឡ]ខ្ញុំ ក៏រកជីវិតអ្នកដែរ តែនៅជា
មួយនឹងខ្ញុំនេះ អ្នកនឹងបានសេចក្តីសុខវិញ ។

**២២:១៤** ប ១សយ ១៩:៤ **២២:១៦** ផ ១សយ ២:៣១ **២២:១៧** ព នក ១:១៧ **២២:១៨** ភ ១សយ ៤:១៧ ម ១សយ ២:១៨,៣១ **២២:១៩** យ ១សយ ២១:១ រ ១សយ ១៥:៣ **២២:២០** ល ១សយ ២៣:៦,៩ ៣០:៧ ២សយ ១៥:២៤ ២០:២៥ ១ពវ ១:៧ ២:២២,២៦,២៧ ៤:៤ ១រប ១៥:១១ ២៧:៣៤ វ ១សយ ១៤:៣ ស ១សយ ២:៣២ **២២:២២** ហ ១សយ ២១:៧ **២២:២៣** ឡ ១សយ ២០:១ **២៣:១** ក យស ១៥:៤៤ ខ ជន ១៨:២៧ ពច ៦:១១ **២៣:២** គ ខ.៤,១២ ១សយ ២២:១០ ៣០:៨ ២សយ ២:១ ៥:១៩,២៣ ទដ ៥០:១៥

## ស្តេចដាវីឌសង្គ្រោះក្រុងកៃឡា

**២៣** ១គ្រានោះ មានគេមកជំរាបដាវីឌថា ឥឡូវពួក
ភីលីស្ទីន គេមកច្បាំងនឹងក្រុងកៃឡា[ក]គេកំពុងតែប្លន់យក
ស្រូវពីលានទាំងប៉ុន្មានហើយ[ខ] ២ដូច្នេះ ដាវីឌក៏ទូលសួរ[គ]
ព្រះយេហូវ៉ាថា តើត្រូវឱ្យទូលបង្គំទៅវាយពួកភីលីស្ទីន
នោះឬទេ ព្រះយេហូវ៉ាទ្រង់មានបន្ទូលឆ្លើយថា ចូរទៅ
វាយពួកភីលីស្ទីន ហើយជួយសង្គ្រោះពួកកៃឡាចុះ ៣តែពួក
មនុស្សរបស់ដាវីឌ គេនិយាយឡើងថា មើល នៅក្នុងស្រុក
យូដានេះ យើងមានសេចក្តីភ័យខ្លាចទៅហើយ ចំណង់
បើយើងទៅដល់កៃឡា ទាស់នឹងពួកពលទ័ពនៃសាសន៍
ភីលីស្ទីន នោះតើនឹងភ័យជាជាងអំបាលម៉ានទៅទៀត
៤ដាវីឌក៏ទូលសួរ[ឃ]ដល់ព្រះយេហូវ៉ាម្តងទៀត ហើយទ្រង់
មានបន្ទូលឆ្លើយថា ចូររៀបចំចុះទៅឯកៃឡាចុះ ដ្បិតអញ
នឹងប្រគល់ពួកភីលីស្ទី[ង]នោះ មកក្នុងកណ្តាប់ដៃឯងហើយ[ច]
៥នោះដាវីឌ និងពួកលោក ក៏ទៅឯកៃឡាច្បាំងនឹងពួក
ភីលីស្ទីន ហើយចាប់យកបានហ្វូងសត្វរបស់គេ ព្រមទាំង
ប្រហារសំឡាប់គេយ៉ាងសំបើម គឺយ៉ាងនោះហើយដែល
ដាវីឌបានជួយសង្គ្រោះដល់ពួកអ្នកនៅកៃឡា ៦រីឯកាល
អ័បៀថើរ[ឆ] ជាកូនអ័ហ៊ីម៉ាលេក បានរត់ទៅឯដាវីឌនៅ
ត្រង់កៃឡា នោះលោកក៏យកអេផូឌ[ជ]១ ជាប់ទៅជាមួយ
ដែរ ។

**២៣:៤** ឃ ខ.២ ង ១សយ ៩:១៦ ច យស ៨:៧ **២៣:៦** ឆ ១សយ ២២:២០ ជ ១សយ ២:២៨

**២២:១៧** *គេបានដឹងថាវារត់* ចំនួនពិតប្រាកដនៃពួកសង្ឃដែលដឹងថាលោកដាវីឌរត់ មិនបានដឹងច្បាស់ឡើយ ។ លោកដាវីឌខ្លួនឯងផ្ទាល់មិនបានប្រាប់ពួកគេឡើយ (សូមមើល ២១:២-៣,៨) ។

**២២:១៨** *ពាក់អេផូឌធ្វើពីអំបោះខ្លូតទេស* សូមមើលការពន្យល់ ២:១៨ ។

**២២:១៩** *ឯក្រុងណូប . . . វាក៏ប្រហារដោយមុខដាវ* ដូច្នេះសម្តីដែលពួកហោរាបានទាយអំពីការទាស់ប្រឆាំងចំពោះផ្ទះរបស់លោកអេលី នោះបានសម្រេចហើយ (មើល ២:៣១ និងការពន្យល់) ។

**២២:២០** *តែមានម្នាក់ឈ្មោះអ័បៀថើរ . . . បានរត់រួចទៅដល់ដាវីឌ* មើល ខ.៥ ។ លោកអ័បៀថើរបានយកអេផូឌទៅជាមួយគាត់ (សូមមើល ២៣:៦) ហើយក្រោយមកទៀតគាត់បាន"ទូលសូមដល់ព្រះ"សម្រាប់ដាវីឌ (មើល ២៣:២ និងការពន្យល់, និងមើល ២៣:៤,៩ ៣០:៧-៨ ២សយ ២:១ ៥:១៩,២៣) ។ គាត់មានតួនាទីដូចជាសម្តេចសង្ឃ រហូតដល់គ្រាដែលស្តេចសាឡូម៉ូនបានផ្លាស់គាត់ចេញ ដោយព្រោះគាត់បានចូលរួមបះបោរជាមួយលោកអ័ដូនីយ៉ា (សូមមើល ១ពវ ២:២៦-២៧) ។

**២៣:១** *ក្រុងកៃឡា* មានចម្ងាយប្រមាណជា ៥,៤០គ.ម ភាគខាងត្បូងឆៀងខាងកើតនៃរអាងអាឌូឡាម ។

**២៣:២,៤** *ទូលសួរព្រះយេហូវ៉ា* លោកដាវីឌបានទូលសួរតាមរយៈសម្តេចសង្ឃអ័បៀថើរប្រើយូរីម និងធូមីម (មើល ខ.៦,៩ និងការពន្យល់ ២:២៨) ។

**២៣:៥** *ជួយសង្គ្រោះដល់ពួកអ្នកនៅកៃឡា* ព្រះអម្ចាស់ប្រើលោកដាវីឌឱ្យទៅជួយជាជាងប្រើស្តេចសូល ដើម្បីសង្គ្រោះពួកកូនចៅអ៊ីស្រាអែល ជា"អ្នកគង្វាល" ដូច្នេះហើយ ជាថ្មីម្តងទៀតលោកដាវីឌក្លាយជាអ្នកការពារលើ"ហ្វូងសត្វ"របស់ស្តេចសូល ។

## ស្តេចសូលដេញតាមលោកដាវីឌ

៧ មានគេទូលដល់សូលថា ដាវីឌបានចូលទៅក្នុងក្រុង
កៃឡាហើយ ដូច្នេះសូលមានបន្ទូលថា ព្រះទ្រង់បាន
ប្រគល់[ឈ]វាមកក្នុងកណ្ដាប់ដៃអញ ដ្បិតវាទាល់ផ្លូវរួចហើយ
ដោយចូលទៅក្នុងទីក្រុងដែលមានទ្វារនិងរនុកផង[ញ] ៨ រួច
សូលទ្រង់ក៏ហៅបណ្ដាទ័ពទាំងឡាយ ឱ្យប្រជុំគ្នាធ្វើចំបាំង
ដើម្បីនឹងចុះទៅឡោមព័ទ្ធចាប់ដាវីឌ ហើយនិងពួកលោក
នៅកៃឡានោះ ៩ ឯដាវីឌក៏ជ្រាបថា សូលគិតការអាក្រក់
ទាស់នឹងខ្លួនដែរ បានជាលោកជំរាបដល់អ័បៀថើរ[ដ]ដ៏ជា
សង្ឃថា សូមយកអេផូឌមក[ឋ] ១០ រួចដាវីឌទូលថា ឱព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលអើយ ទូលបង្គំជា
បាវបំរើទ្រង់ បានឮប្រាកដថា សូលចង់មកដល់កៃឡា ដើម្បី
នឹងរំលាងបំផ្លាញក្រុងនេះ ដោយព្រោះទូលបង្គំហើយ
១១ ដូច្នេះ តើពួកមនុស្សនៅកៃឡានេះ នឹងប្រគល់ទូលបង្គំ
ទៅក្នុងកណ្ដាប់ដៃសូលឬអី តើសូលនឹងចុះមកតាម ដូចជា
ទូលបង្គំជាបាវទ្រង់បានឮនោះឬអី ឱព្រះយេហូវ៉ា ជាព្រះ
នៃសាសន៍អ៊ីស្រាអែលអើយ សូមទ្រង់ប្រាប់ឱ្យទូលបង្គំជា
បាវបានដឹងផង នោះព្រះយេហូវ៉ាទ្រង់ឆ្លើយថា នឹងចុះ
មកមែន ១២ រួចដាវីឌទូលសួរថា តើពួកកៃឡានឹងប្រគល់[ឌ]
ទូលបង្គំ ហើយនិងពួកទូលបង្គំនេះ ទៅក្នុងកណ្ដាប់ដៃនៃ
សូលដែរឬអី នោះព្រះយេហូវ៉ាទ្រង់ឆ្លើយថា គេនឹងប្រគល់
ឯងទៅមែន ១៣ ដូច្នេះ ដាវីឌហើយនិងពួកលោក[ឍ]ដែលមាន
ចំនួនប្រហែលជា៦០០នាក់ គេក៏ឡើងចេញពីកៃឡា ទៅឯ
កន្លែង១ទៀត ហើយមានគេទូលដល់សូលថា ដាវីឌបានរត់
ពីកៃឡាទៅបាត់ហើយ នោះទ្រង់ក៏លែងគិតទៅ ១៤ ឯដាវីឌ
លោកអាស្រ័យនៅទីពំនួនក្នុងទីរហោស្ថាន[ណ] ក៏នៅតែក្នុង
ស្រុកភ្នំនៃទីរហោស្ថានស៊ីភ[ត]នោះ ចំណែកសូលទ្រង់ចេះ
តែរក[ថ]លោករាល់តែថ្ងៃជានិច្ច តែព្រះទ្រង់មិន[ទ]ប្រគល់
លោកទៅក្នុងកណ្ដាប់ដៃនៃស្តេចឡើយ ។
១៥ ដាវីឌក៏ឃើញថា សូលទ្រង់បានចេញមករកជីវិតខ្លួន
ដែរ បានជាលោកនៅជាប់តែក្នុងព្រៃនៅទីរហោស្ថានស៊ីភ
នោះ[ធ] ១៦ ឯយ៉ូណាថាន ជាបុត្រាសូល ក៏ចេញទៅឯដាវីឌនៅ
ក្នុងព្រៃ ជួយចំរើនឱ្យមានសេចក្ដីសង្ឃឹម[ន]ក្នុងព្រះឡើង
១៧ លោកមានប្រសាសន៍ថា កុំឱ្យខ្លាចឡើយ ដ្បិតដៃរបស់
បិតាខ្ញុំនឹងរាវរកអ្នកមិនឃើញទេ អ្នកនឹងបានធ្វើជាស្តេច[ប]
លើសាសន៍អ៊ីស្រាអែល ហើយខ្ញុំនឹងបានជាបន្ទាប់របស់អ្នក
ដំណើរនេះ បិតាខ្ញុំក៏បានជ្រាបដែរ ១៨ នោះអ្នកទាំង២ក៏ចុះ
សញ្ញា[ផ]គ្នានៅចំពោះព្រះយេហូវ៉ា រួចដាវីឌក៏នៅតែក្នុង
ព្រៃនោះទៅ តែយ៉ូណាថានលោកវិលទៅឯលំនៅរបស់
លោកវិញ ។
១៩ គ្រានោះពួកស្រុកស៊ីភ[ព]ឡើងទៅឯសូល នៅត្រង់
គីបៀរទូលថា ដាវីឌបានពួននៅស្រុកយើងខ្ញុំ [ភ]ក្នុងទីពំនួន
នៃភ្នំហាគីឡា[ម] ដែលនៅត្រង់ព្រៃ ខាងត្បូងទីរហោស្ថាន
២០ ដូច្នេះ បពិត្រព្រះករុណា សូមទ្រង់យាងចុះទៅ ដូចជា
ទ្រង់សព្វព្រះហឫទ័យចង់ទៅស្រាប់ ឯត្រង់ការចាប់បញ្ជូន[យ]
វាមកក្នុងព្រះហស្តទ្រង់ នោះស្រេចនៅយើងខ្ញុំចុះ ២១ សូល
ឆ្លើយថា សូមព្រះយេហូវ៉ាប្រទានពរ[រ]ដល់អ្នករាល់គ្នាដោយ
ព្រោះមានសេចក្ដីឈឺឆ្អាល[ល]នឹងយើង ២២ ដូច្នេះសូមឱ្យអ្នក
រាល់គ្នាទៅស៊ើបសួររក ឱ្យប្រាកដច្បាស់ជាងនេះទៅទៀត
ដើម្បីឱ្យបានដឹង ហើយឃើញពិត ដែលវានៅត្រង់ណា
ហើយអ្នកណាមួយដែលបានឃើញវានៅទីនោះផង ដ្បិត
គេប្រាប់យើងថា វាឆ្លាតណាស់ ២៣ ដូច្នេះ ចូរទៅមើលឱ្យ
ដឹងគ្រប់កន្លែងណាដែលវាធ្លាប់ពួននៅ រួចត្រឡប់មក
ប្រាប់យើងវិញឱ្យពិតប្រាកដ នោះយើងនឹងចេញទៅជា
មួយនឹងអ្នករាល់គ្នា ហើយបើវានៅក្នុងស្រុក នោះយើងនឹង
ជ្រាវរក[វ]វា ក្នុងពួកយូដាទាំងពាន់ៗ ទាល់តែឃើញ ។
២៤ គេក៏ក្រោកឡើង ទៅឯស្រុកស៊ីភមុនសូល តែដាវីឌ
និងពួកលោកនៅក្នុងទីរហោស្ថានម៉ាអូន[ស] ដែលនៅស្រុក
វាលខាងត្បូងទីរហោស្ថាននោះវិញ[ហ] ២៥ ឯសូលនិងពួកទ្រង់
ក៏ទៅរក ហើយមានគេមកជំរាបដល់ដាវីឌ ដូច្នេះលោកចុះ

**២៣:៧** ឈ ចទ ៣២:៣០ ញ ទដ ៣១:២១
**២៣:៩** ដ ១សយ ២២:២០ ឋ ១សយ ២:១៨
**២៣:១២** ឌ ខ.២០
**២៣:១៣** ឍ ១សយ ២២:២
**២៣:១៤** ណ ទដ ៥៥:៧ ត យស ១៥:២៤,៥៥ ថ ទដ ៥៤:៣–៤ ទ ទដ ៣២:៧
**២៣:១៥** ធ ១សយ ២០:១
**២៣:១៦** ន ១សយ ៣០:៦ ទដ ១៨:២ ២៧:១៤
**២៣:១៧** ប ១សយ ២០:៣១
**២៣:១៨** ផ ១សយ ១៨:៣ ២សយ ៩:១
**២៣:១៩** ព ១សយ ២៦:១ ភ ទដ ៥៤ ម ១សយ ២៦:៣
**២៣:២០** យ ខ.១២
**២៣:២១** រ នរ ២:២០ ២សយ ២:៥
**២៣:២២** ល ១សយ ២២:៨
**២៣:២៣** វ លប ៣១:៣៦
**២៣:២៤** ស យស ១៥:៥៥ ហ ១សយ ២៦:១

**២៣:៩** *សូមយកអេផូឌមក* សូមមើលការពន្យល់ ខ.២ ។

**២៣:១៣** *មានចំនួនប្រហែលជា៦០០នាក់* ចំនួនមនុស្សរបស់លោកដាវីឌរីកចម្រើនគួរឱ្យគត់សម្គាល់ (មើលការពន្យល់ ២២:២) ។

**២៣:១៤** *អាស្រ័យនៅទីពំនួន ក្នុងទីរហោស្ថាន* ជាកន្លែងមួយដែលពិបាកនឹងទៅ (មើលការពន្យល់ ២២:៤) ។ *ទីរហោស្ថានស៊ីភ* ស្ថិតនៅភាគខាងត្បូងតំបន់ហេប្រុន ។ *ព្រះទ្រង់មិនប្រគល់លោកទៅក្នុងកណ្ដាប់ដៃនៃស្តេចឡើយ* ការការពាររបស់ព្រះអម្ចាស់លើលោកដាវីឌ នៅទីនេះ ផ្ទុយពីការគិតរបស់ស្តេចសូលនៅក្នុង ខ.៧ ។

**២៣:១៧** *អ្នកនឹងបានធ្វើជាស្តេចលើសាសន៍អ៊ីស្រាអែល* សូមមើលការពន្យល់ ១៨:៤ ២០:១៣,១៦,៣១ ។ *ហើយខ្ញុំនឹងបានជាអ្នកបន្ទាប់របស់អ្នក* សេចក្ដីស្រឡាញ់របស់លោកយ៉ូណាថាន និងការគោរពចំពោះលោកដាវីឌគ្មានទីសម្គាល់ណាបង្ហាញថា យ៉ូណាថានតូចចិត្ត ឬច្រណែននោះឡើយ (មើលការពន្យល់ ១៨:៣ ១៩:៤) ។ នេះគឺជាកំណត់ត្រាចុងក្រោយនៃការប្រជុំរបស់យ៉ូណាថាន និងដាវីឌ ។ *បិតាខ្ញុំក៏បានជ្រាបដែរ* សូមមើល ១៨:៨ និងការពន្យល់ ២០:៣១ ។

**២៣:១៨** *ក៏ចុះសញ្ញាគ្នា* មើលការពន្យល់ ១៨:៣ និងមើល ២០:១៤–១៥ ។

**២៣:១៩** *ទីពំនួន* ជាកន្លែងមួយដែលពិបាកនឹងទៅ (មើលការពន្យល់ ២២:៤) ។

ទៅឯថ្មដា អាស្រ័យនៅក្នុងទីរហោស្ថានម៉ាអូន លុះកាល
សូលបានជ្រាប នោះក៏ដេញតាមលោក ទៅក្នុងទីរហោ–
ស្ថានម៉ាអូននោះដែរ [២៦]សូល[ឃ]បានយាងនៅខាងភ្នំម្ខាង
ហើយដាវីឌនិងពួកលោកនៅខាងភ្នំម្ខាង ដាវីឌក៏ប្រញាប់
នឹងរត់ចេញទៅ ដោយខ្លាចសូល ដ្បិតសូលហើយនិងពួក
ទ្រង់ គេឡោមព័ទ្ធលោក និងពួកលោកទាំងប៉ុន្មាន ដោយ
ប៉ងនឹងចាប់ខ្លួន [២៧]ខណនោះ មានអ្នកនាំដំណឹងមក ទូល
ដល់សូលថា សូមទ្រង់យាងទៅជាប្រញាប់ ដ្បិតពួកភីលីស្ទីន
បានចូលលុកលុយក្នុងស្រុកហើយ [២៨]នោះសូលទ្រង់ក៏លែង
ដេញតាមដាវីឌ ត្រឡប់វិលទៅច្បាំងនឹងពួកភីលីស្ទីនវិញ
ហេតុនោះបានជាគេហៅទីនោះថា សេឡា–ហាម៉ាលេកុត
[២៩]រួចដាវីឌក៏ចាកចេញពីទីនោះ ទៅអាស្រ័យនៅក្នុង
ទីពំនួន[អ]ទាំងប៉ុន្មានដែលនៅស្រុកអេន–កេឌីវិញ[ក] ។

## លោកដាវីឌទុកជីវិតឱ្យស្តេចសូល

**២៤** [១]កាលសូល ទ្រង់បានត្រឡប់ពីដេញតាមពួកភីលីស្ទីន
មកវិញ នោះមានគេទូលទ្រង់ថា ឥឡូវនេះដាវីឌនៅត្រង់
ទីរហោស្ថានអេន–កេឌី[ក] [២]ដូច្នេះសូលទ្រង់ក៏យកមនុស្ស
ដែលជ្រើសរើស ពីក្នុងពួកអ៊ីស្រាអែលទាំងប៉ុន្មាន មាន

**២៣:២៦** ឡ ទដ ១៧:៩
**២៣:២៩** អ ១សយ ២៤:២២ ក យស ១៥:៦២ ២រប ២០:២ ១:១៤
**២៤:១** ក យស ១៥:៦២
**២៤:២** ខ ១សយ ២៦:២
**២៤:៣** គ ទដ ៥៧, ១៤៧ ឃ ពច ៣:២៤
**២៤:៤** ង ១សយ ២៥:២៨–៣០ ច ២សយ ៤:៨ ឆ ខ.១០,១១
**២៤:៥** ជ ១សយ ២៦:៩ ២សយ ២៤:១០
**២៤:៦** ឈ លប ២៦:១១ ១សយ ១២:៣

ចំនួន៣ពាន់នាក់ ចេញទៅរក[ខ]ដាវីឌ និងពួកលោកនៅលើ
ភ្នំថ្មពពែព្រៃ [៣]ក៏យាងមកដល់ក្រោលចៀម ដែលនៅ
តាមផ្លូវ ជាកន្លែងដែលមានរអាង[គ]១ ហើយទ្រង់ចូលទៅ
ផ្ទំ[ឃ]នៅក្នុងរអាងនោះ រីឯដាវីឌ និងពួកលោកគេនៅក្នុង
ទីជ្រៅនៃរអាងនោះដែរ [៤]ខណនោះ ពួកខាងដាវីឌជំរាប
ថា មើល នេះហើយជាថ្ងៃដែលព្រះយេហូវ៉ាទ្រង់បានមាន
បន្ទូល[ង]នឹងលោកថា ទ្រង់នឹងប្រគល់ពួកខ្មាំងសត្រូវមកក្នុង
កណ្តាប់ដៃនៃលោក នោះលោកនឹងធ្វើសំរេចតាមតែចិត្ត
បាន[ច] ដូច្នេះដាវីឌក៏ក្រោកឡើងលបចូលទៅថ្នមៗ កាត់[ឆ]
ផ្តាច់ជាយព្រះពស្ត្ររបស់សូលចេញ [៥]តែបន្ទាប់នោះមក
នោះដាវីឌក៏មានសេចក្តីឈឺចិត្តស្តាយ[ជ] ដោយព្រោះបាន
កាត់ជាយព្រះពស្ត្ររបស់សូល [៦]រួចនិយាយនឹងពួកខ្លួនថា
សូមព្រះយេហូវ៉ាទ្រង់ឃាត់កុំឱ្យខ្ញុំប្រព្រឹត្តដូច្នេះ ដល់ចៅ
ហ្វាយរបស់ខ្ញុំ ដែលទ្រង់បានចាក់ប្រេងតាំង[ឈ]ឱ្យ គឺដែលខ្ញុំ
នឹងលើកដៃទាស់នឹងទ្រង់ឡើយ ដ្បិតព្រះយេហូវ៉ាបានចាក់
ប្រេងតាំងទ្រង់ហើយ [៧]គឺដោយពាក្យយ៉ាងនោះឯង ដែល
ដាវីឌបានឃាត់ពួកខ្លួន មិនឱ្យគេលើកគ្នាទាស់នឹងសូល
ឡើយ រួចមក សូលក្រោកឡើងចេញពីរអាងយាងតាមផ្លូវ

**២៣:២៩** *ស្រុកអេន–កេឌី* សូមមើលការពន្យល់ បស ១:១៤ ។

**២៤:១–២៦:២៥** នៅក្នុងវគ្គនិមួយៗ ក្នុងជំពូកនេះ បាននិយាយអំពីការងារសាកល្បងរបស់លោកដាវីឌនៅក្នុងទីរហោស្ថាន ជាអ្នកដែលព្រះបានចាក់ប្រេងតាំង (មើល ១៦:១–១៣ ធៀបនឹង ចទ ៨ ដែលនិយាយពីការល្បងលរបស់ពួកអ៊ីស្រាអែលនៅក្នុងទីរហោស្ថាន មថ ៤:១–១១ ការល្បងលចំពោះព្រះយេស៊ូវនៅក្នុងទីរហោស្ថាន) ។ នៅក្នុងព្រឹត្តិការណ៍ទាំង៣បានផ្តល់ឱកាសឱ្យដាវីឌនូវអំណាច ហើយប្រើប្រាស់អំណាចនោះដើម្បីបន្សុទ្ធជីវិតផ្ទាល់ខ្លួនរបស់គាត់ (ទទួលរងការសងសឹកខុសចំពោះគាត់) ជាជាងការបម្រើព្រះ និងពួកអ៊ីស្រាអែល ។ ការបរាជ័យចំពោះការសាកល្បង នៃការល្បងលនេះ អាចនឹងក្លាយជាការដកសិទ្ធិអំណាចរបស់លោកដាវីឌដូចគ្នានឹងការដកសិទ្ធិរបស់ស្តេចសូលចេញពីការងារ ដែលព្រះអម្ចាស់បានដៅចំណាំទុកជាស្តេចលើពួកអ៊ីស្រាអែល ។

នៅក្នុងចំណោម៣ជំពូកទាំងនោះ បានបញ្ចប់ដោយការប្រឈមមុខ២រវាងស្តេចសូលនិងលោកដាវីឌ ។ ស្ថានការណ៍បានប្រែក្រឡាស់ ហើយពេលនេះ លោកដាវីឌបានផ្តល់សេចក្តីមេត្តាករុណាដល់ស្តេចសូល ។ នៅក្នុងវគ្គទាំង២នេះ (ជំពូក ២៤,២៦) បានចែកដាច់ពីគ្នា (ជំពូក ២៥) លោកដាវីឌបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយណាបាល ជាពួកយូដាដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ជាអ្នកដែលលោកដាវីឌថែរក្សា"ហ្វូងសត្វ និងមនុស្ស" របស់គាត់ដូចគ្នានឹងអ្វីដែលពួកគេបានថែរក្សា "ហ្វូងសត្វ" របស់ស្តេចសូលពីការឈ្លានពានពីសំណាក់ពួកភីលីស្ទីន ។ ចំណុចសំខាន់នៅក្នុងវគ្គនេះ គឺនិយាយអំពីលោកណាបាល ដែលគាត់ប្រៀបបានទៅនិងស្តេចសូលជាអ្នកប្រព្រឹត្តការ"កំណាច"ហើយជាអ្នកដែលព្រះអម្ចាស់ទ្រង់នឹងទម្លាក់ចុះក្នុងពេលឆាប់ៗនេះ (មើល ២សយ ២៥:៣៨ ធៀបនឹង ២៦:១០ ២៨:១៩ ៣១:៤) ។

**២៤:១–២២** ស្តេចសូលទទួលភាពមេត្តាករុណាពីលោកដាវីឌ ពេលដែលស្តេចសូលរកលោកដាវីឌឃើញក្នុងរអាង ។

**២៤:៤** *នេះហើយជាថ្ងៃដែលព្រះយេហូវ៉ា ទ្រង់បានមានបន្ទូលនឹងលោក* មនុស្សរបស់លោកដាវីឌ មិនបានកត់ត្រាចុះកាលពីគ្រាមុន នូវអ្វីដែលព្រះអម្ចាស់ទ្រង់បានបើកសម្តែងនៅទីនេះឡើយ ។ ប្រហែលជាការកាត់ស្រាយផ្ទាល់ខ្លួនរបស់គេចំពោះការចាក់ប្រេងតាំងដល់លោកដាវីឌ ដើម្បីជំនួសស្តេចសូល (សូមមើល ១៦:១៣–១៤) ឬមួយជាការធានាចំពោះលោកដាវីឌថា គាត់អាចរស់នៅនិងគេចផុតពីការសងសឹករបស់ស្តេចសូល ហើយក្រោយមកទៀតលោកដាវីឌបានក្លាយជាស្តេច (មើល ២០:១៤–១៥ ២៣:១៧) ។ *ទ្រង់នឹងប្រគល់ពួកខ្មាំងសត្រូវមកក្នុងកណ្តាប់ដៃនៃលោក* មើលទៅហាក់បីដូចជានិយាយទៅកាន់មនុស្សរបស់លោកដាវីឌ (សូមមើល ២៦:៨) ។ អ្វីដែលលោកដាវីឌបាននិយាយទៅកាន់ស្តេចសូលនៅក្នុង ខ.១០ វាផ្ទុយគ្នាទៅនឹងអ្វីដែលអ្នកនិពន្ធបាននិយាយនៅក្នុង ២៣:១៤ ។ *កាត់ផ្តាច់ជាយព្រះពស្ត្ររបស់សូលចេញ* ប្រហែលជាលោកដាវីឌបង្ហាញពីនិមិត្តរូបនៃការដកហូតសិទ្ធិជាស្តេចរបស់សូលចេញ ប្តូរមកឱ្យគាត់វិញ (សូមមើល ខ.១១ ធៀបនឹង ១៥:២៧–២៨ ១៨:៤) ។

**២៤:៦** *ដ្បិតព្រះយេហូវ៉ាបានចាក់ប្រេងតាំងទ្រង់ហើយ* សូមមើល ខ.១០ ២៦:៩,១១,១៦,២៣ ២សយ ១:១៤,១៦ ។ ដោយសារតែភាពជាស្តេចរបស់ស្តេចសូលបានអនុម័តឡើងដោយផ្អែកលើគុណធម៌ នៃការចាក់ប្រេងតាំងរបស់ទ្រង់ (សូមមើល ៩:១៩) លោកដាវីឌបានសម្រេចចិត្តថា នឹងមិនដណ្តើមអំណាចពីស្តេចសូលឡើយ ប៉ុន្តែគ្រាន់តែបញ្ឈប់តួនាទីរបស់គាត់ដែលព្រះអម្ចាស់ទ្រង់ជាអ្នកផ្តល់ឱ្យ (សូមមើល ខ.១២,១៥ ២៦:១០) ។

ទ្រង់ទៅ ។
៨ឯដាវីឌ ក៏ក្រោកឡើងចេញពីរអាង តាមក្រោយស្រែក
ទូលដល់សូលថា បពិត្រព្រះរាជា ជាម្ចាស់នៃទូលបង្គំអើយ
រួចកាលសូលបែរទតមកក្រោយ នោះដាវីឌក៏ក្រាបចុះផ្កាប់
មុខដល់ដីថ្វាយបង្គំទូលថា[ញ] ៩ហេតុអ្វីបានជាទ្រង់ស្តាប់[ដ]តាម
ពាក្យរបស់មនុស្សដែលថា ដាវីឌរកធ្វើឲ្យវិនាស[ឋ]ដល់ទ្រង់
ដូច្នេះ ១០មើល ថ្ងៃនេះឯងព្រះនេត្រទ្រង់ឃើញជាយ៉ាង
ណាហើយ ដែលព្រះយេហូវ៉ាបានប្រគល់ទ្រង់មកក្នុង
កណ្តាប់ដៃនៃទូលបង្គំ នៅក្នុងរអាងភ្នំនេះក៏មានអ្នកខ្លះប្រាប់
ឲ្យទូលបង្គំសំឡាប់ទ្រង់ចោល តែទូលបង្គំបានប្រណី[ឌ]ដល់
ទ្រង់វិញ ដោយថា ទូលបង្គំមិនព្រមលើកដៃទាស់នឹងចៅ
ហ្វាយនៃទូលបង្គំទេ ដ្បិតព្រះយេហូវ៉ាបានចាក់ប្រេងតាំង
ទ្រង់ហើយ ១១មួយទៀត បពិត្រព្រះបិតាអើយ សូមទតមើល
មកនេះ នេះនែ ជាយព្រះពស្ត្ររបស់ទ្រង់នៅក្នុងដៃទូលបង្គំ
ឯណេះ ដូច្នេះដោយព្រោះទូលបង្គំបានគ្រាន់តែកាត់[ឍ]ជាយ
ព្រះពស្ត្រទ្រង់ តែមិនបានសំឡាប់ទ្រង់ទេ នោះសូមពិចារ
ណា ហើយជ្រាបថា គ្មានសេចក្តីអាក្រក់[ណ]ណា ឬការក្បត់[ត]
ណា នៅដៃទូលបង្គំឡើយ ទូលបង្គំក៏មិនបានធ្វើបាប[ថ]ដល់
ទ្រង់ដែរ ទោះបើទ្រង់លបចង់ចាប់[ទ]យកជីវិតទូលបង្គំក៏
ដោយ[ធ] ១២ដូច្នេះ សូមឲ្យព្រះយេហូវ៉ាទ្រង់ជំនុំជំរះ[ន]រឿង
យើងខ្ញុំទាំង២ចុះ ហើយសូមឲ្យព្រះយេហូវ៉ាសងសឹក[ប]នឹង
ទ្រង់ជំនួសទូលបង្គំផង តែទូលបង្គំមិនព្រមលូកដៃទៅដាក់
លើទ្រង់ឡើយ ១៣ដូចជាមានពាក្យសុភាសិតពីបូរាណថា
"មនុស្សកំណាច តែងបញ្ចេញសុទ្ធតែសេចក្តីកំណាច[ផ]"
ប៉ុន្តែទូលបង្គំមិនព្រមលូកដៃទៅដាក់លើទ្រង់ឡើយ ១៤តើ
ស្តេចនៃសាសន៍អ៊ីស្រាអែលបានចេញមករកអ្នកណា តើ
ទ្រង់ដេញតាមអ្នកណា គឺតាមតែឆ្កែស្លាប់[ព] ឬជាចៃវិញទេ
តើ[ភ] ១៥ដូច្នេះសូមឲ្យព្រះយេហូវ៉ាធ្វើជាចៅក្រម[ម] ជំនុំជំរះ[យ]
រឿងរបស់យើងខ្ញុំទាំង២នេះចុះ សូមទ្រង់ទតមើល ព្រម
ទាំងជួយដោះសា[រ]ទូលបង្គំ ហើយជួយ[ល]ឲ្យទូលបង្គំរួច[វ]ពី
កណ្តាប់ព្រះហស្តនៃស្តេចផង ។
១៦លុះកាលដាវីឌបានទូលសេចក្តីទាំងនេះរួចហើយ
នោះសូលទ្រង់សួរថា ឱដាវីឌកូនអើយ នេះជាសំឡេងឯង
ឬអី[ស] រួចទ្រង់ក៏ឡើងសំឡេងយំ ១៧ហើយមានបន្ទូលថា ឯង
សុចរិតជាងអញ[ហ] ដ្បិតអញបានធ្វើការអាក្រក់ដល់ឯង[ឡ] តែ
ឯងបានស្នងការល្អដល់អញវិញ[អ] ១៨នៅថ្ងៃនេះឯងបាន
សំដែងបែបយ៉ាងណា ដែលឯងបានប្រព្រឹត្តល្អដល់អញ
ដោយព្រោះកាលព្រះយេហូវ៉ាបានប្រគល់[ក]អញ ទៅក្នុង
កណ្តាប់ដៃឯង នោះឯងមិនបានសំឡាប់អញទេ ១៩ដ្បិតបើ
អ្នកណាជួបប្រទះនឹងខ្មាំងសត្រូវខ្លួនហើយ នោះតើនឹងឲ្យរួច
ទៅដោយសុខសាន្តឬ ដូច្នេះ សូមព្រះយេហូវ៉ាទ្រង់ប្រោស[ខ]
សេចក្តីល្អដល់ឯង ស្នងនឹងការដែលឯងបានប្រព្រឹត្តចំពោះ
អញនៅថ្ងៃនេះចុះ ២០អញក៏ដឹងហើយថា ឯងនឹងបានសោយ
រាជ្យ[គ]ជាមិនខាន ហើយនគរ[ឃ]របស់សាសន៍អ៊ីស្រាអែលនឹង
បានតាំងឡើង នៅក្នុងកណ្តាប់ដៃឯងផង ២១ដូច្នេះ សូមឯង
ស្បថ[ង]នឹងអញ ដោយនូវព្រះយេហូវ៉ាឥឡូវនេះចុះ ថា កាល
ណាអញអស់ជីពជន្មទៅហើយ នោះឯងនឹងមិនកាត់វង្ស
របស់អញចេញឡើយ ក៏មិនបំផ្លាញឈ្មោះអញ ឲ្យបាត់ពីពួក
វង្សនៃបិតាអញចេញដែរ[ច] ២២នោះដាវីឌក៏ស្បថថ្វាយសូល
រួចសូលទ្រង់វិញត្រឡប់ទៅឯដំណាក់ទ្រង់វិញទៅ តែដាវីឌ
និងពួកលោក គេនាំគ្នាឡើងទៅឯទីពំនួនវិញ[ឆ] ។

## លោកដាវីឌ លោកណាបាល និងនាងអ័ប៊ីកែល

**២៥** ១រីឯសាំយូអែលលោកក៏ស្លាប់ទៅ[ក] នោះពួកជន

**២៤:៨** ញ ១សយ ២០:៤១
**២៤:៩** ដ ១សយ ២៦:១៩ ឋ ១សយ ២០:១
**២៤:១០** ឌ ខ.៤
**២៤:១១** ឍ ខ.៤ ណ ទដ ៧:៣ ត ១សយ ២៥:២៨ ថ ទដ ៣៥:៧ ទ លប ៣១:៣៦ ១សយ ២៦:២០ ធ ១សយ ២០:១
**២៤:១២** ន លប ១៦:៥ ១សយ ២៥:៣៨ យប ៩:១៥ ប ជន ៣១:៣
**២៤:១៣** ផ មថ ៧:២០
**២៤:១៤** ព ១សយ ១៧:៤៣ ភ ១សយ ២៦:២០
**២៤:១៥** ម ខ.១២ យ លប ១៦:៥ រ ទដ ៣៥:១,២៣ អស ៤៩:២៥ ល ទដ ២៦:១ ៣៥:២៤ ៤៣:១ ៥០:៤ ៥៤:១ ១៣៥:១៤ វ ទដ ១១៩:១៣៤,១៥៤
**២៤:១៦** ស ១សយ ២៦:១៧
**២៤:១៧** ហ លប ៣៨:២៦ ឡ នក ៩:២៧ អ មថ ៥:៤៤
**២៤:១៨** ក ១សយ ២៦:២៣ **២៤:១៩** ខ នរ ២:១២ ២របា ១៥:៧ **២៤:២០** គ ១សយ ២០:៣១ ឃ ១សយ ១៣:១៤ **២៤:២១** ង លប ២១:២៣ ៤៧:៣១ ១សយ ១៨:៣ ២សយ ២១:១–៩ ច ១សយ ២០:១៤–១៥ **២៤:២២** ឆ ១សយ ២៣:២៩ **២៥:១** ក ១សយ ២៨:៣

**២៤:១១** *បពិត្រព្រះបិតាអើយ* ស្តេចសូលក៏បានមានបន្ទូលទៅកាន់ដាវីឌថា "ឱដាវីឌកូនអើយ"ដែរ (មើល ខ.១៦) ។ លោកដាវីឌក៏បានប្រើទម្រង់នៃការនិយាយបែបនេះដែរពីព្រោះ (១).លោកដាវីឌជាព្រះរាជ្យសន្ធរបស់ស្តេចសូល (សូមមើល ១៨:២៧) (២).ទំនាក់ទំនងដ៏វិសេសរវាងឪពុកនឹងកូននៅក្នុងពេលនេះធៀបដូចជាទំនាក់ទំនងដ៏ជិតស្និទ្ធ រវាងស្តេចនិងកូន (សូមមើលការពន្យល់ ២សយ ៧:១៤ ទដ ២:៧) ។

**២៤:១៤** *ឆ្កែស្លាប់* សូមមើលការពន្យល់ ២សយ ៩:៨ ។ *ចៃ* មើលការពន្យល់ ២៦:២០ ។

**២៤:១៦** *ទ្រង់ក៏ឡើងសំឡេងយំ* បទពិសោធន៍ទាំងឡាយដែលស្តេចសូលមានក្នុងលក្ខណៈបណ្តោះអាសន្ន បានធ្វើឲ្យទ្រង់មានការសោកស្តាយនូវរាល់ទង្វើដែលទ្រង់បានទាស់ប្រឆាំងនឹងលោកដាវីឌ (មើល ២៦:២១) ប៉ុន្តែមិនយូរប៉ុន្មានទ្រង់ក៏បានត្រឡប់ទៅជាចង់សម្លាប់ដាវីឌវិញ (មើល ២៦:២) ។

**២៤:២១** *ឯងនឹងមិនកាត់វង្ស របស់អញចេញឡើយ* មើល ២០:១៤–១៥ ។

**២៤:២២** *ទីពំនួន* ជាកន្លែងដែលពិបាកនឹងទៅដល់ (មើលការពន្យល់ ២២:៤) ។ តាំងពីមុនមកលោកដាវីឌមិនបានទុកចិត្តចំពោះការប្រែចិត្តរបស់ស្តេចសូលឡើយ ។

**២៥:១–៤៤** នៅក្នុងជំពូកនេះ និយាយអំពីទំនាក់ទំនងរបស់ដាវីឌជាមួយណាបាល (សូមមើលការពន្យល់ក្នុង ២៤:១–២៦:២៥) ។ ណាបាលជាមនុស្ស "កំណាច" (សូមមើល ខ.២៥) រស់នៅក្បែរកើមែល ជាកន្លែងដែលស្តេចសូលបានដំឡើងគោល ជាគ្រឿងចំណាំទុកនៅទីនោះ (សូមមើល ១៥:១២ និងការពន្យល់) ។ ណាបាលមានមុខងារដូចជាបំណងរបស់អ្នកនិពន្ធ (១).លក្ខណៈសម្បត្តិទូទៅរបស់ណាបាល ការមើលងាយចំពោះ

ជាតិអ៊ីស្រាអែលទាំងអស់ គេមូលគ្នា យំសោក[ខ]នឹងលោក
ហើយបញ្ចុះសពលោកក្នុងម៉ុងរបស់លោកនៅត្រង់រ៉ាម៉ា[គ]
ឯដាវីឌលោកចេញទៅឯទីរហោស្ថានប៉ារ៉ានវិញ ។
២ រីឯនៅម៉ាអូន[ឃ] មានម្នាក់ជាអ្នកមានស្តុកស្តម្ភ ដែល
ទ្រព្យសម្បត្តិ[ង]នៅឯកើមែល គាត់មានចៀម៣ពាន់ និង
ពពែ១ពាន់ នៅគ្រានោះគាត់កំពុងតែកាត់រោម[ច]ចៀម
នៅឯកើមែល ៣ អ្នកនោះឈ្មោះណាបាល ជាពូជពង្សនៃ
កាលែប ប្រពន្ធឈ្មោះអ័ប៊ីកែល[ឆ] ឯនាងជាស្ត្រីប្រកបដោយ
ប្រាជ្ញា ទាំងរូបក៏ស្រស់បស់ល្អ តែប្តីជាមនុស្សកាចអាក្រក់[ជ]
ក្នុងកិរិយាប្រព្រឹត្តវិញ ៤ ឯដាវីឌនៅទីរហោស្ថាន ក៏ឮថា
ណាបាលកំពុងតែកាត់រោមចៀម ៥ នោះក៏ចាត់កំឡោះ១០
នាក់ឱ្យទៅដោយបង្គាប់ថា ចូរឡើងទៅឯណាបាលនៅត្រង់
កើមែល ហើយជំរាបសួរគាត់ ដោយនូវឈ្មោះយើង ៦ ត្រូវ
ឱ្យនិយាយដូច្នេះថា ជំរាបសួរលោក សូមឱ្យលោកបាន
ប្រកបដោយសេចក្តីសុខ[ឈ] ព្រមទាំងពួកគ្រួលោក និងរបស់
ទ្រព្យលោកទាំងអស់ផង[ញ] ៧ ចំណែកខ្ញុំបានឮថា លោកបាន
ហៅជាងកាត់រោមចៀមមកហើយ ឯពួកអ្នកគង្វាលចៀម
របស់លោក គេបាននៅជាមួយនឹងយើងខ្ញុំ យើងខ្ញុំឥតមាន
ធ្វើអ្វី[ដ]ដល់គេទេ គេក៏គ្មានបាត់អ្វី១នៅវេលាដែលគេនៅ
ត្រង់កើមែលដែរ ៨ សូមឱ្យលោកសួរពួកលោកចុះ គេនឹង
ជំរាបលោកតាមពិត ដូច្នេះសូមលោកអាណិតមេត្តាដល់
ពួកកំឡោះរបស់យើងខ្ញុំផង ដ្បិតយើងខ្ញុំបានមកឯលោក
ត្រូវពេលដ៏ស្រួលហើយ សូមលោកមេត្តាចែករលែករបស់
ខ្លះ[ឋ] ដែលនៅដៃលោក ឱ្យដល់ពួកខ្ញុំជាអ្នកបំរើរបស់លោក

**២៤:១** ខ លវ ១០:៦ ចទ ៣៤:៨ គ ១សយ ៧:១៧
**២៥:២** ឃ យស ១៥:៥៥ ង ២សយ ១៩:៣២ ច លប ៣១:១៩
**២៥:៣** ឆ សភ ៣១:១០ ជ យស ១៤:១៣ ១៥:១៣
**២៥:៦** ឈ ទដ ១២២:៧ មថ ១០:១២ ញ ១របា ១២:១៨
**២៥:៧** ដ ខ.១៥
**២៥:៨** ឋ នហ ៨:១០

លោកដាវីឌ ទោះបីជាដាវីឌជាអ្នកគង្វាលលើហ្វូងសត្វរបស់គាត់ ហើយគាត់ក៏ត្រូវស្លាប់មួយរំពេចដោយសារព្រះហស្តនៃព្រះអម្ចាស់អ៊ីៗទាំងអស់ គឺដូចគ្នាទៅនឹងស្តេចសូល (ដាវីឌក៏ក្លាយជាអ្នកការពារលើ"ហ្វូងសត្វ"ទាំងនោះ) ដូច្នេះហើយ នេះគឺជាអ្វីដែលអ្នកនិពន្ធក៏បានលើកយកពីការកំណាចរបស់ស្តេចសូល ដោយមិនចាំយកមកនិយាយ (សូមមើល ១៣:១៣ ២៦:២១) និងជាស្រមោលនៃចុងបញ្ចប់របស់សូល ។ (២).គំនុំគុំគួនរបស់លោកដាវីឌចំពោះលោកណាបាល បានបង្ហាញពីនិន្នការធម្មជាតិរបស់គាត់ បានដៅចំណាំពីការអត់ធ្មត់របស់គាត់ចំពោះស្តេចស្តេចសូល ជាអ្នកដែលព្រះអម្ចាស់បានចាក់ប្រេងតាំង ។ (៣).សេចក្តីប្រុងប្រយ័ត្នរបស់នាងអ័ប៊ីកែលបានរារាំងដាវីឌពីការប្រើអំណាច ដើម្បីសងសឹកផ្ទាល់ខ្លួន (គ្រប់យ៉ាងទាំងអស់ស្តេចសូលបានធ្វើ) ។ នៅក្នុងព្រឹត្តិការណ៍នេះព្រះអម្ចាស់ (ជាអ្នកសងសឹកសម្រាប់រាស្ត្រទ្រង់) បានសម្អាតដាវរបស់ដាវីឌ ហើយការនេះក្លាយជាមេរៀនមួយ ដែលគាត់មិនអាចបំភ្លេចបាន ។ (៤).ការទទួលស្គាល់ដោយមានទំនុកចិត្តរបស់នាងអ័ប៊ីកែលចំពោះអានាគត់ លោកដាវីឌក្នុងការទទួលយករាជ្យបល្ល័ង្ក ជាស្រមោលថា ទោះបីជាស្ថិតនៅក្នុងស្ថានការណ៍ណាក៏ដោយការប្តេជ្ញាចិត្តរបស់ព្រះអម្ចាស់ គឺទ្រង់នឹងសង់ដំណាក់របស់លោកដាវីឌជា"វង្សាចុងក្រោយ" (មើល ខ.២៨ ធៀបនឹង ២សយ ៧:១១-១៦) ។ (៥).អាពាហ៍ពិពាហ៍របស់នាងអ័ប៊ីកែលជាមួយលោកដាវីឌ បានធ្វើឱ្យគាត់មានប្រពន្ធដែលឆ្លាត និងមានតម្លៃ ដើម្បីជាការប្រឆាំងតបរបស់ព្រះអម្ចាស់ចំពោះអ្វីដែលស្តេចសូលធ្វើដល់លោកដាវីឌ ដោយលើកមីកែលជាប្រពន្ធលោកដាវីឌឱ្យទៅអ្នកផ្សេង ។

**២៥:១** អ្នកនិពន្ធចាប់ផ្តើមលើកយកវគ្គរវាងលោកដាវីឌ និងលោកណាបាល ដោយលោកដាវីឌមិនបានបាត់បង់តំណែង ជាអ្នកគ្រប់គ្រងលើអ៊ីស្រាអែលឡើយ (សូមមើល ១៩:១៨-២៤) ហើយនៅចុងបញ្ចប់បានបង្ហាញថា លោកដាវីឌត្រូវបាត់បង់នាងមីកែលជាប្រពន្ធ ជាអ្នកដែលការពារវង្សានុវង្សរបស់នាង (មើល ១៩:១១-១៧) ។ នៅក្នុងគ្រានោះ គាត់ទទួលបានប្រពន្ធដែលមានប្រាជ្ញាដ៏លើសលប់ដូចជាលោកអ័ហ៊ីថូផែល (សូមមើល ២សយ ១៦:២៣) ។ នាងគឺជាប្រពន្ធម្នាក់ក្នុងចំណោមប្រពន្ធទាំង២ ដែលបានភ្ជាប់គាត់ជាមួយអភិជនយូដា ។ តំណើររឿងនេះបានបង្ហាញពីរបៀបដែលដាវីឌទទួលយកប្រពន្ធរបស់ណាបាលមក និងរបៀបដែលគាត់យកប្រពន្ធលោកអ៊ូរីជាសាសន៍ហេតមក (មើល ២សយ ១១) ។ ទាំងនេះគឺជាការប្រព្រឹត្តដោយការចំកួតរបស់លោកដាវីឌ ។ *នោះពួកជនជាតិអ៊ីស្រា-អែលទាំងអស់ . . . យំសោកនឹងលោក* ហោរាសាំយូអែលត្រូវបានគេទទួលស្គាល់ថា គាត់គឺជាអ្នកដឹកនាំប្រជាជាតិអ៊ីស្រាអែលទាំងមូលជាអ្នកដឹកនាំចម្បងនៅក្នុងរចនាសម្ព័ន្ធវង្សានុវង្ស (សូមមើល ជំពូក ៨-១២) ។ នៅពេលបាត់បង់អ្នកដឹកនាំរបស់គេធ្វើឱ្យពួកគេមានទុក្ខសោកយ៉ាងខ្លាំង ដូចជាកើតទុក្ខចំពោះអ្នកដឹកនាំនាសម័យកាលមុនៗដែរ ដូចជាលោកយ៉ាកុបជាដើម (សូមមើល លប ៥០:១០) លោកអើរ៉ុន (សូម មើល ជន ២០:២៩) និងលោកម៉ូសេ (មើល ចទ ៣៤:៨) ។ *រ៉ាម៉ា* សូមមើល ៧:១៧ និងការពន្យល់ ១:១ ។

**២៥:២** នៅសម័យបុរាណ ទ្រព្យសម្បត្តិ គឺទាក់ទងជាមួយនឹងហ្វូងសត្វ (សូមមើល លប ១២:១៦ ១៣:២) ។

**២៥:៣** *ជាស្ត្រីប្រកបដោយប្រាជ្ញា ទាំងរូបក៏ស្រស់បស់ល្អ . . . កាចអាក្រក់* ការខុសគ្នារវាងការកំណាចរបស់លោកណាបាល និងការប្រកបដោយប្រាជ្ញារបស់នាងអ័ប៊ីកែល គឺមាននិយាយពេញជំពូកតែម្តង ។ *ពូជពង្សនៃកាលែប* ជាកូនចៅរបស់លោកកាលែប (មើល ជន ១៤:២៤) ដែលបានតាំងលំនៅនៅក្នុងតំបន់ហេប្រុន (សូមមើល យស ១៤:១៣) បន្ទាប់ពីច្បាំងឈ្នះពួកកាណាន ។ ក្នុងអំឡុងពេលដែលឈ្មោះរបស់កាលែប អាចមានន័យថា "សត្វឆ្កែ" នោះលោកណាបាលដូចជាឆ្កែដែរ ព្រោះគាត់បានប្រព្រឹត្តដោយកំណាច ។ មិនយូរមិនឆាប់គាត់ក្លាយជាខ្មោចឆ្កែ (មើល ២សយ ៩:៨) នៅក្នុងគ្រា ដែលព្រះអម្ចាស់ទ្រង់សងសឹកចំពោះទង្វើដែលគាត់បានធ្វើមកលើលោកដាវីឌ ។

**២៥:៤** *កាត់រោមចៀម* គេតែងតែកាត់ក្នុងឱកាសដ៏សប្បាយមួយ (មើល ខ.៨ ២សយ ១៣:២៣-២៤) ។

**២៥:៨** *សូមលោកមេត្តារលែករបស់ខ្លះ ដែលនៅដៃលោក* លោកដាវីឌ និងមនុស្សរបស់គាត់សុំចំណែកខ្លះ ដើម្បីឱ្យពួកអ្នកដែលបានការពារពួកអ្នកគង្វាលរបស់លោកណាបាល និងហ្វូងសត្វមិនឱ្យមានចោរលួច (សូមមើល ខ.១៥-១៦,២១) ។

និងដាវីឌ ជាកូនលោកផង ។
៩រីឯកាលពួកកំឡោះរបស់ដាវីឌបានទៅនិយាយនឹង
ណាបាល តាមពាក្យទាំងនេះ ដោយនូវឈ្មោះដាវីឌរួច
ហើយ ១០នោះណាបាលឆ្លើយតបទៅថា ដាវីឌជាអ្វី[ឪ] តើកូន
អ៊ីសាយនេះជាអ្វី សព្វថ្ងៃនេះមានបាវជាច្រើន ដែលរត់
ចោលពីចៅហ្វាយរបស់ខ្លួនទៅ ១១ដូច្នេះ តើត្រូវឱ្យអញយក
នំបុ័ង[ឮ]របស់អញ ព្រមទាំងទឹក និងសាច់ដែលអញបាន
សំឡាប់ សំរាប់ពួកជាងកាត់រោមចៀម ទៅចែកដល់ពួក
មនុស្ស ដែលអញមិនដឹងជាមកពីណាផងឬអី ១២ដូច្នេះ ពួក
កំឡោះរបស់ដាវីឌក៏វិលត្រឡប់ទៅវិញ ជិរាបតាមសេចក្ដី
ទាំងនោះ ១៣រួចដាវីឌបង្គាប់ដល់គេថា[ណ] ចូរអ្នករាល់គ្នា
ក្រវាត់ដាវគ្រប់គ្នាឡើង នោះគេក៏ក្រវាត់ដាវរៀងខ្លួន
ហើយដាវីឌក៏ក្រវាត់ដាវរបស់លោកដែរ ខណនោះមាន
មនុស្សប្រហែលជា៤០០នាក់ ឡើង[ត]តាមដាវីឌទៅ ហើយ
មាន២០០នាក់ទៀតនៅថែរក្សាអីវ៉ាន់[ថ] ។
១៤មានពួកកំឡោះម្នាក់របស់ណាបាលបានទៅជិរាប
ដល់អ័ប៊ីកែល ជាប្រពន្ធណាបាលថា មើល ដាវីឌបានចាត់
មនុស្សពីទីរហោស្ថាន មកជិរាបសួរ[ទ]ចៅហ្វាយយើងខ្ញុំ តែ
លោកបានស្ដីកិនដល់គេវិញ ១៥ពួកអ្នកទាំងនោះបានប្រព្រឹត្ត
ល្អនឹងយើងខ្ញុំណាស់ គេមិនបានធ្វើអ្វី[ធ]ដល់យើងខ្ញុំទេ
ហើយកាលយើងខ្ញុំនៅជាមួយនឹងគេ ក្នុងគ្រាដែលយើងខ្ញុំ
កំពុងតែឃ្វាលហ្វូងចៀម នោះយើងខ្ញុំឥតមានបាត់អ្វីឡើយ[ន]
១៦គេជាកំផែង[ប]ដល់យើងខ្ញុំទាំងយប់ទាំងថ្ងៃ ក្នុងពេលដែល
យើងខ្ញុំនៅជាមួយនឹងគេ កំពុងឃ្វាលចៀមនោះ ១៧ដូច្នេះ
សូមជិរាបជូនលោកស្រីជ្រាប សូមពិចារណាចុះ តើត្រូវធ្វើ
ដូចម្ដេច ដ្បិតមុខជាគេបានសំរេចនឹងធ្វើអាក្រក់ដល់
ចៅហ្វាយយើងខ្ញុំ និងពួកគ្រួលោកទាំងអស់គ្នាហើយ ពី
ព្រោះលោកប្រុសជាមនុស្សកំណាចណាស់[ផ] ឥតមានអ្នក

**២៥:១០** ឪ ពច ៩:២៨
**២៥:១១** ឮ ពច ៨:៦
**២៥:១៣** ណ ១សយ ២២:២ ត ១សយ ២១:១០ ថ ជណ ៣១:២៧
**២៥:១៤** ទ ១សយ ១៣:១០
**២៥:១៥** ធ ខ.៧ ន ខ.២១
**២៥:១៦** ប នក ១៤:២២ យប ១:១០ ទដ ១៣៩:៥
**២៥:១៧** ផ ចទ ១៣:១៣ ១សយ ២០:៧
**២៥:១៨** ព លវ ២៣:១៤ ១សយ ១៧:១៧ ភ ១រប ១២:៤០ ម លប ៤២:២៦ ២សយ ១៦:១ អស ៣០:៦
**២៥:១៩** យ លប ៣២:២០ រ ខ.៣៦
**២៥:២១** ល ខ.១៥ វ ១សយ ១៩:៤ ស ទដ ១០៩:៥
**២៥:២២** ហ ១ពវ ១៤:១០ ២១:២១ ២ពវ ៩:៨ ឡ នរ ១:១៧
**២៥:២៣** អ លប ១៩:១ ១សយ ២០:៤១
**២៥:២៤** ក ២សយ ១៤:៩

ណានិយាយនឹងលោកបានទេ ។
១៨នោះនាងក៏ប្រញឹកប្រញាប់ ចាត់ចែងនំបុ័ង២០០ដុំ ថង់
ស្បែកពេញដោយស្រាទំពាំងបាយជូរ២ ចៀមរៀបជា
ស្រេច៥លាជ៥រង្វាល់[ព] ផ្លែទំពាំងបាយជូរក្រៀម១០០
ចង្កោម[ភ] និងផ្លែល្វាក្រៀម២០០ផែន ផ្ទុកលើសត្វលានាំ
ទៅ[ម] ១៩នាងក៏ប្រាប់ដល់ពួកបំរើរបស់នាងថា ចូរចេញទៅ
មុនអញចុះ[យ] អញនឹងទៅតាមក្រោយ តែនាងមិនបានប្រាប់[រ]
ដល់ណាបាល ជាប្ដីនាងឡើយ ២០កាលនាងកំពុងតែជិះលា
ចុះតាមផ្លូវច្រកភ្នំទៅ នោះគាប់ចួនជាដាវីឌនិងពួកលោក
ក៏ចុះដំរង់មកខាងមុខនាង ហើយនាងក៏ទៅជួបនឹងគេ ២១រី
ឯដាវីឌលោកបានគិតថា ដែលអញបានថែរក្សាទ្រព្យរបស់
ទាំងប៉ុន្មាននៃមនុស្សនោះ ឱ្យគង់វង់នៅទីរហោស្ថាន
ឥតមានបាត់អ្វីណាមួយឡើយ[ល] នោះពិតប្រាកដជាឥត
ប្រយោជន៍សោះ វាបានប្រព្រឹត្តការអាក្រក់[វ]ស្នង[ស]នឹងការ
ល្អដល់អញវិញ ២២ដូច្នេះ បើខ្ញុំទុកឱ្យសល់អ្នកណាក្នុងពួកវា
សូម្បីតែកូនប្រុស[ហ]១ក្ដី ឱ្យរស់នៅដរាបដល់ស្រាងឡើង
នោះសូមឱ្យព្រះធ្វើដូច្នោះដល់ដាវីឌខ្ញុំនេះចុះ ហើយលើស
ទៅទៀតផង[ឡ] ។
២៣កាលអ័ប៊ីកែលបានឃើញដាវីឌ នោះនាងក៏ចុះពីលើ
លាជាប្រញាប់ ទៅក្រាបផ្កាប់មុខចុះនឹងដី[អ] គោរពដល់
ដាវីឌ ២៤នាងទំលាក់ខ្លួននៅទៀបជើងលោក ជិរាបថា ឱ
លោកជាម្ចាស់ខ្ញុំអើយ សូមឱ្យទោស[ក]នោះធ្លាក់មកលើរូប
ខ្ញុំវិញចុះ សូមឱ្យខ្ញុំជាបាវស្រីរបស់លោក ជិរាបជូនលោក
ស្ដាប់បន្តិច ហើយសូមទទួលស្ដាប់ពាក្យរបស់បាវស្រីលោក
សិន ២៥កុំឱ្យលោកម្ចាស់តាំងចិត្តចំពោះណាបាលជាមនុស្ស
កំណាចនោះឡើយ ដ្បិតគាត់ដូចជាឈ្មោះរបស់គាត់ពិត
មែន គឺគាត់ឈ្មោះណាបាល ហើយក៏មានសេចក្ដីចំកួត[ខ]

**២៥:២៥** ខ សភ ១៧:១២

**២៥:១០** *កូនអ៊ីសាយ* សូមមើលការពន្យល់ ២០:២៧,៣០–៣១ ។
**២៥:១៧** *មនុស្សកំណាច* មើលការពន្យល់ ចទ ១៣:១៣ ។ *ឥតមានអ្នកណានិយាយនឹងលោកបានទេ* លោកណាបាល និងស្ដេចសូលមានចរិតដូចគ្នា (ធៀបនឹង ២០:២៧–៣៣) ។
**២៥:១៨** *នាងក៏ប្រញឹកប្រញាប់ចាត់ចែងនំបុ័ង . . . ស្រាទំពាំងបាយជូរ . . . ចៀម . . . លាជ . . . ផ្លែទំពាំងបាយជូរក្រៀម* ទាំងនោះគឺជាអាហារសម្រាប់ស្ដេច ។ សូមធៀបនឹងអ្វីដែលលោកណាបាលបាននិយាយនៅក្នុង ខ.១១ ។
**២៥:១៩** *នាងមិនបានប្រាប់ដល់ណាបាល ជាប្ដីនាងឡើយ* សូមធៀបជាមួយការគំរាមរបស់ស្ដេចសូលចំពោះនាងមីកាល (មើល ១៩:១១–១៧) ។
**២៥:២២** *សូមឱ្យព្រះធ្វើដូច្នោះដល់ដាវីឌខ្ញុំនេះចុះ ហើយលើសទៅទៀតផង* សូមមើលការពន្យល់ក្នុង ៣:១៧ ។ លោកដាវីឌបានអធិស្ឋានដាក់បណ្ដាសាខ្លួនឯងបើសិនជាគាត់បរាជ័យក្នុងការសម្លាប់ពួកមនុស្សប្រុសទាំងអស់ ដែលនៅផ្ទះលោកណាបាល និងចាប់បង្ខំគ្រួសារលោកណាបាល ។
**២៥:២៤** *សូមឱ្យទោសនោះធ្លាក់មកលើរូបខ្ញុំវិញចុះ* នាងអ័ប៊ីកែលចាប់ផ្ដើមសុំអង្វរដល់លោកដាវីឌ ដើម្បីឱ្យលើកទោសឱ្យ (នាងមិនបានយកទោសរបស់ណាបាលមកដាក់លើខ្លួននាងឡើយ) ដូចដែលនាងបានអង្វរលោកដាវីឌម្ដងទៀត (ខ.២៨) ។ ផ្ទុយពីណាបាលដែលប្រើអំណាចដើម្បីគំរាមដល់លោកដាវីឌ ។
**២៥:២៥** *មនុស្សកំណាច* សូមមើល ខ.១៧ និងការពន្យល់ ចទ ១៣:១៣ ។ *ដ្បិតគាត់ដូចជាឈ្មោះរបស់គាត់ពិតមែន* នៅក្នុងសម័យបុរាណឈ្មោះរបស់មនុស្សត្រូវបានគេជឿថា មានទាក់ទងជាមួយនឹងធម្មជាតិ និងចរិតលក្ខណៈរបស់អ្នកនោះ ។

នោះឯង[គ] ឯខ្ញុំជាបាវស្រីរបស់លោក ខ្ញុំឥតបានឃើញ
ពួកកំឡោះរបស់លោកម្ចាស់ ដែលបានចាត់ទៅនោះទេ
២៦ដូច្នេះ ឱលោកម្ចាស់ខ្ញុំអើយ ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា
ដ៏មានព្រះជន្មរស់នៅ ហើយដោយនូវព្រលឹងលោកដែរថា
ពួកខ្មាំងសត្រូវរបស់លោកម្ចាស់នៃខ្ញុំ ព្រមទាំងអស់អ្នក
ដែលរកធ្វើអាក្រក់ដល់លោក នឹងបានដូចជាណាបាល[ឃ]
នោះឯង ដោយព្រោះព្រះយេហូវ៉ាទ្រង់បានឃាត់លោក
មិនឱ្យកំចាយឈាម[ង] ហើយមិនឱ្យសងសឹក[ច]ដោយដៃលោក
ឡើយ ២៧រីឯជំនូននេះ[ឆ]ដែលខ្ញុំម្ចាស់ ជាអ្នកបំរើរបស់
លោក បាននាំយកមកជូន នោះសូមចែកឱ្យដល់ពួកកំឡោះ
ដែលតាមលោកម្ចាស់នៃខ្ញុំមកនោះចុះ ២៨សូមអត់ទោស[ជ]
សេចក្ដីរំលងនេះដល់បាវស្រីរបស់លោកផង ដ្បិតព្រះ
យេហូវ៉ាទ្រង់នឹងតាំងជំនួរវង្សរបស់លោកម្ចាស់នៃខ្ញុំ ឱ្យ
មាំមួនឡើង[ឈ]ជាពិតប្រាកដ ពីព្រោះលោកម្ចាស់នៃខ្ញុំ តែង
ធ្វើសង្គ្រាមនៃព្រះយេហូវ៉ា[ញ] ហើយនិងគ្មានឃើញសេចក្ដី
អាក្រក់ណា[ដ] នៅក្នុងលោកម្ចាស់ឡើយ គ្រប់១ជីវិតរបស់
លោក ២៩មួយទៀត ទោះបើមានមនុស្សលើកដេញ តាមរក
ប្រហារជីវិត[ឋ]របស់លោកក៏ដោយ គង់តែជីវិតលោកម្ចាស់
នៃខ្ញុំ និងបានចងជាប់ក្នុងបាច់នៃជីវិត ជាមួយនិព្រះ
យេហូវ៉ា ជាព្រះនៃលោកដែរ ឯជីវិតរបស់ពួកខ្មាំងសត្រូវ
នៃលោកនឹងត្រូវបាត់[ឌ]ទៅ ដូចជាបាញ់ចេញពីខ្សែដង្ហក់
វិញ[ឍ] ៣០រួចកាលណាព្រះយេហូវ៉ាបានប្រោសលោកម្ចាស់
នៃខ្ញុំ តាមគ្រប់ទាំងសេចក្ដីល្អ ដែលទ្រង់បានមានបន្ទូល
ពីដំណើរលោក ព្រមទាំងតាំងលោកឡើង ឱ្យគ្រប់គ្រង[ណ]
លើសាសន៍អ៊ីស្រាលអែលហើយ ៣១នោះដំណើរនេះមិន
បានជាហេតុឱ្យលោកតូចចិត្តស្តាយ ដោយលោកបាន
កំចាយឈាមគេឥតហេតុ ឬបានសងសឹកដល់គេដោយខ្លួន
លោកឡើយ ហើយកាលណាព្រះយេហូវ៉ាបានប្រោស
សេចក្ដីល្អដល់លោកម្ចាស់ នោះសូមទានឹកចាំ[ត]ពីខ្ញុំ ជាបាវ
ស្រី[ថ]របស់លោកផង ។

៣២ដាវីឌក៏ឆ្លើយនឹងនាងអ័ប៊ីកែលថា សូមក្រាបថ្វាយ
បង្គំ[ទ]ដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ដែល
ទ្រង់បានចាត់អ្នកឱ្យមកជួបនឹងខ្ញុំ នៅថ្ងៃនេះ ៣៣ហើយសូម
ពរដល់ប្រាជ្ញារបស់អ្នក និងដល់ខ្លួនអ្នកផង ដោយព្រោះ
អ្នកបានឃាត់មិនឱ្យខ្ញុំកំចាយឈាម[ធ] ហើយមិនឱ្យសងសឹក
ដល់គេដោយដៃខ្លួនខ្ញុំនៅថ្ងៃនេះ ៣៤ដ្បិតខ្ញុំស្បថដោយនូវ
ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលដែលទ្រង់មាន
ព្រះជន្មរស់នៅ ហើយបានឃាត់មិនឱ្យខ្ញុំធ្វើបាបដល់អ្នកថា
បើអ្នកមិនបានប្រញាប់មកជួបនឹងខ្ញុំទេ នោះប្រាកដជាដល់
ស្រាងឡើង នោះនឹងគ្មានសល់អ្វី ដល់ណាបាល[ន] សូម្បីតែ
កូនប្រុស១ផង ៣៥នោះដាវីឌក៏ទទួលយកជំនូនពីដៃនាង
ដែលនាងបាននាំយកមកជូននោះ ដោយពាក្យថា សូម
អញ្ជើញឡើងទៅឯផ្ទះអ្នកវិញ ដោយសុខសាន្តចុះ ខ្ញុំបាន
យល់ព្រមតាម[ប]ពាក្យអ្នកហើយ ក៏អរគុណដល់អ្នកដែរ ។

៣៦រីឯអ័ប៊ីកែល នាងក៏វិលទៅឯណាបាល ជាប្ដីវិញ
ឃើញគាត់កំពុងតែលៀងលោមភ្ញៀវនៅក្នុងផ្ទះ ដូចជាការ
លៀងលោមនៃស្ដេច ឯណាបាលក៏មានចិត្តសប្បាយឡើង[ផ]
ដោយព្រោះស្រវឹងជាខ្លាំង[ព] ដូច្នេះ នាងមិនបានប្រាប់[ភ]អ្វី
ដល់គាត់ឡើយ ទោះតិចឬច្រើនក្ដី រហូតដល់ព្រឹកឡើង

**២៥:២៥** គ សភ ១២:១៦ ១៤:១៦ ២០:៣ អស ៣២:៥
**២៥:២៦** ឃ ខ.៣៤ ២សយ ១៨:៣២ ង ខ.៣៣ ច ហព ១០:៣០
**២៥:២៧** ឆ លប ៣៣:១១
**២៥:២៨** ជ ខ.២៤ ២សយ ១៤:៩ ឈ ២សយ ៧:១១,២៦ ញ ១សយ ១៨:១៧ ដ ១សយ ២៤:១១
**២៥:២៩** ឋ ១សយ ២០:១ ឌ យរ ១០:១៨ ២២:២៦ ឍ ១សយ ១៧:៥០ ២សយ ៤:៨
**២៥:៣០** ណ ១សយ ១២:១២ ១៣:១៤
**២៥:១៣** ត លប ៤០:៤១ ថ ២សយ ៣:១០
**២៥:៣២** ទ លប ២៤:២៧
**២៥:៣៣** ធ ខ.២៦
**២៥:៣៤** ន ខ.២៦
**២៥:៣៥** ប លប ១៩:២១
**២៥:៣៦** ផ នរ ៣:៧ ព សភ ២០:១ សស ១០:១៧ អស ៥:១១, ២២ ២២:១៣ ២៨:៧ ៥៦:១២ ហស ៤:១១ ភ ខ.១៩

**២៥:២៦** *ដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់* មើលការពន្យល់ ១៤:៣៩, ៤៥ ។

**២៥:២៨** *ដ្បិតព្រះយេហូវ៉ាទ្រង់នឹងតាំងជំនួរវង្សរបស់លោកម្ចាស់នៃខ្ញុំ* ក្នុងខណៈពេលដែលមានគំនិតគិតថា លោកដាវីឌមានគោលបំណងចង់ធ្វើជាស្ដេចជំនួសស្ដេចសូល ប្រហែលជាត្រូវបានផ្សព្វផ្សាយទៅដល់ប្រជានុរាស្ត្រទូទៅ ។ ការប៉ាន់ប្រមាណរបស់នាងអ័ប៊ីកែលចំពោះចំពោះដាវីឌ គឺផ្ទុយគ្នាជាមួយនិងប្ដីរបស់នាង (មើល ខ.១០) ។ *ធ្វើសង្គ្រាមនៃព្រះយេហូវ៉ា* នាងអ័ប៊ីកែលអរសប្បាយចំពោះជ័យជម្នះរបស់លោកដាវីឌ លើពួកភីលីស្ទីន ព្រោះនាងបានគិតពីសិរីល្អរបស់ព្រះអម្ចាស់ ជាជាងគិតចំពោះខ្លួនឯង (មើល ១៧:២៦,៤៥–៤៧ ១៨:១៧) ។ *គ្មានឃើញសេចក្ដីអាក្រក់ណានៅក្នុងលោកម្ចាស់ឡើយ* មើល ខ.៣៩ ។ នាងអ័ប៊ីកែលបានបង្ហាញពីការខ្វល់ខ្វាយទុកសម្រាប់ជាការបង្ការពីសេចក្ដីសុចរិតរបស់លោកដាវីឌ នៅពេលគាត់ទទួលដំណែងនៅរយៈពេលក្រោយទៀត (មើល ខ.៣០–៣១) ។

**២៥:២៩** *បានចងជាប់ក្នុងបាច់នៃជីវិត* ការប្រើរូបភាពនៃការវេចខ្ចប់ទ្រព្យធនដែលមានតម្លៃដើម្បីឱ្យមានសុវត្ថិភាព នាងអ័ប៊ីកែលធានាអះអាងថា លោកដាវីឌនឹងបានរួចជីវិតពីចំណោមគ្រោះថ្នាក់ទាំងឡាយ ។ *ដូចជាបាញ់ចេញពីខ្សែដង្ហក់វិញ* ពាក្យនេះនឹងក្លាយជាការពិតដល់លោកណាបាល បន្ទាប់ពីគាត់ត្រឡប់ទៅជា"រឹងស្ទូក" (មើល ខ.៣៧) ។

**២៥:៣០** *ឱ្យគ្រប់គ្រង* សូមមើលការពន្យល់ ៩:១៦ ។

**២៥:៣១** *កំចាយឈាមគេឥតហេតុ* សូមមើលការពន្យល់ ខ.២៨ ។

**២៥:៣២–៣៤** ធៀបជាមួយពាក្យសម្ដីរបស់លោកដាវីឌក្នុង ខ.២១–២២ ។ ពាក្យដែលគាត់បាននិយាយនៅទីនោះ និងទីនេះបានផ្ដាច់រឿងដែលគាត់បានជួបប្រជុំជាមួយនាងអ័ប៊ីកែល ហើយបានបង្ហាញពីសម្រេចដោយការប្រើប្រាជ្ញាដ៏ឆ្លាតវ័យរបស់នាងអ័ប៊ីកែល ។

**២៥:៣២** *ដែលទ្រង់បានចាត់អ្នក ឱ្យមកជួបនឹងខ្ញុំ* លោកដាវីឌទទួលស្គាល់ថាព្រះអម្ចាស់ទ្រង់បានធ្វើឱ្យគាត់ និងនាងអ័ប៊ីកែលជួបគ្នា (មើល ខ.៣៩) ។

**២៥:៣៣** *អ្នកបានឃាត់មិនឱ្យខ្ញុំកំចាយឈាម* មើលការពន្យល់ ខ.៣ ។

**២៥:៣៦** *លៀងលោម* សូមមើល សភ ៣០:២១–២២ ។ *ដូចជាការលៀងលោមនៃស្ដេច* គឺជាតម្រុយផ្សេងៗទៀតដែលអ្នកនិពន្ធបានប្រើលោកណាបាល ដូចជាដើម្បីបង្ហាញពីស្ដេចសូល ។

៣៧លុះព្រឹកឡើង គ្រាដែលណាបាលស្វាងពីស្រាហើយ
នោះ ប្រពន្ធក៏ថ្លែងប្រាប់ពីសេចក្តីទាំងនោះ រួចគាត់ត្រូវ
គាំងបេះដូង ហើយត្រឡប់ជារឹងស្តូកទៅ[ម] ៣៨លុះក្រោយ
មកបានប្រហែលជា១០ថ្ងៃ នោះព្រះយេហូវ៉ាទ្រង់វាយ[យ]
ណាបាលឱ្យស្លាប់ទៅ ។
៣៩កាលដាវីឌបានឮថា ណាបាលស្លាប់ហើយ នោះ
លោកមានប្រសាសន៍ថា សូមក្រាបថ្វាយបង្គំដល់ព្រះ–
យេហូវ៉ា ដែលទ្រង់បានកាន់ក្តីខាងខ្ញុំ ពីដំណើរដែលណា
បាលបានដៀលត្មះដល់ខ្ញុំនោះ ព្រមទាំងឃាត់ខ្ញុំ ជាអ្នកបំរើ
ទ្រង់ មិនឱ្យប្រព្រឹត្តការអាក្រក់ តែកិរិយាអាក្រក់របស់
ណាបាល នោះទ្រង់បានទំលាក់ទៅលើក្បាលវាវិញ រួច
ដាវីឌចាត់គេឱ្យទៅស្នើការនឹងអ័ប៊ីកែល ដើម្បីនឹងយក
នាងធ្វើជាប្រពន្ធ ៤០កាលពួកបំរើរបស់ដាវីឌបានមកឯ
អ័ប៊ីកែលនៅកើមែលហើយ នោះក៏ជំរាបនាងថា ដាវីឌ
បានចាត់យើងខ្ញុំឱ្យមកអញ្ជើញអ្នកទៅធ្វើជាប្រពន្ធលោក
៤១នោះនាងក៏ក្រោកឡើង រួចក្រាបផ្កាប់មុខនឹងដីតបថា
ខ្ញុំនេះជាអ្នកបំរើសំរាប់នឹងលាងជើង ដល់ពួកអ្នកបំរើ
របស់លោកម្ចាស់ខ្ញុំ ៤២អ័ប៊ីកែល[រ]ក៏ប្រញាប់ប្រញាល់ឡើង
ជិះលាទៅ មានទាំងស្រីបំរើ៥នាក់តាមទៅដែរ នាងក៏តាម
ពួកអ្នកបំរើរបស់ដាវីឌ ទៅធ្វើជាប្រពន្ធលោកទៅ ។
៤៣ឯដាវីឌ លោកក៏យកអ័ហ៊ីណោម[ល] ជាអ្នកនៅស្រុក
យេសរាល ធ្វើជាប្រពន្ធដែរ នាងទាំង២នោះបានធ្វើជា
ប្រពន្ធរបស់លោក[វ] ៤៤ចំណែកនាងមីកាល ប្រពន្ធរបស់
ដាវីឌ នោះសូលជាបិតាទ្រង់ បានលើកឱ្យទៅប៉ាលធី[ស]
ជាកូនឡាអ៊ីស ដែលនៅកាលីមវិញ[ហ] ។

## លោកដាវីឌទុកជីវិតឱ្យស្តេចសូលម្តងទៀត

**២៦** ១គ្រានោះ ពួកស្រុកស៊ីភ[ក]គេមកឯសូល នៅត្រង់
គីបៀរទូលថា ដាវីឌកំពុងតែពួន[ខ]នៅក្នុងភ្នំហាគីឡា ដែល
នៅប្រទល់មុខនឹងទីរហោស្ថាន[គ] ២នោះសូលទ្រង់ក៏រៀប
ចំយាងចុះទៅឯទីរហោស្ថានស៊ីភ នាំទាំងមនុស្សជ្រើស
រើសក្នុងពួកអ៊ីស្រាអែល៣ពាន់នាក់ ដើម្បីនឹងរក[ឃ]ដាវីឌ
ក្នុងទីរហោស្ថាននោះ ៣ទ្រង់បោះទ័ពក្បែរផ្លូវ នៅលើភ្នំ
ហាគីឡា[ង]ដែលនៅប្រទល់មុខនឹងទីរហោស្ថាន ឯដាវីឌ
លោកអាស្រ័យនៅក្នុងទីរហោស្ថាននោះឯង ក៏ឮថា សូល
តាមលោកមកដូច្នោះ ៤នោះលោកចាត់គេឱ្យទៅឈ្លបលប
មើល ក៏ដឹងពិតថា សូលបានយាងមកហើយ ៥ដូច្នេះ ដាវីឌ
រៀបចំចេញទៅឯកន្លែង ដែលសូលបានបោះទ័ពនោះ
លោកក៏ឃើញកន្លែងដែលសូល និងអ័ប៊ីនើរ[ច] កូននើរ ជា
មេទ័ពទ្រង់បានដេកនៅ ឯសូលទ្រង់ផ្ទំនៅកណ្តាលវង់
ទីបោះទ័ព ហើយបណ្តាទ័ព គេដេកនៅព័ទ្ធជុំវិញ ។
៦នោះដាវីឌសួរទៅអ័ហ៊ីម៉ាលេក ជាសាសន៍ហេត[ឆ] និង
អ័ប៊ីសាយ[ជ]ប្អូនយ៉ូអាប់ ជាកូនសេរូយ៉ា[ឈ]ថា តើអ្នកណានឹង
ចុះទៅឯសូលក្នុងទីបោះទ័ពជាមួយនឹងខ្ញុំ អ័ប៊ីសាយឆ្លើយថា

**២៥:៣៧** ម នក ១៥:១៦
**២៥:៣៨** យ ចទ ៣២:៣៥ ១សយ ២៤:១២ ២៦:១០ ២សយ ៦:៧ ១២:១៥
**២៥:៤២** រ ២សយ ២:២ ៣:៣ ១រប ៣:១
**២៥:៤៣** ល ២សយ ៣:២ ១រប ៣:១ វ ១សយ ២៧:៣ ៣០:៥ ២សយ ២:២
**២៥:៤៤** ស ២សយ ៣:១៥ ហ អស ១០:៣០
**២៦:១** ក ១សយ ២៣:១៩ ខ ទដ ៥៤ គ ១សយ ២៣:២៤
**២៦:២** ឃ ១សយ ២៤:២
**២៦:៣** ង ១សយ ២៣:១៩
**២៦:៥** ច ១សយ ១៧:៥៥
**២៦:៦** ឆ លប ១០:១៥ ជ ២សយ ២:១៨ ១០:១០ ១៦:៩ ១៨:២ ១៩:២១ ២៣:១៨ ១រប ១១:២០ ១៩:១១ ឈ ១រប ២:១៦

**២៥:៣៧** *គ្រាដែលណាបាលស្វាងពីស្រាហើយ* តាមលក្ខណៈអក្សរសាស្ត្រគេនិយាយថា"ពេលដែលស្រាអស់អំណាចពីលោកណាបាលហើយ" គឺទាក់ទងទៅនឹងការលេងពាក្យចំពោះឈ្មោះរបស់លោកណាបាល ដែលដូចគ្នាបេះបិទទៅនឹងព្រះគម្ពីរភាសាហេព្រើរ "ថង់ស្បែក" (មើល ខ.១៨) ។ *ត្រឡប់ជារឹងស្តូក* ប្រហែលជាគាត់ដាច់សរសៃរឈាមក្នុងខួរក្បាល ធ្វើឱ្យគាត់លែងដឹងខ្លួនត្រឡប់រឹងស្តូក ។

**២៥:៤២** *នាងក៏តាម . . . ធ្វើជាប្រពន្ធលោកទៅ* នាងជាអ្នកដែលបានទទួលស្គាល់ថា ព្រះអម្ចាស់បានចាក់ប្រេងតាំងដល់នាង ដើម្បីឱ្យធ្វើជាអ្នកចែកចាយពីនគររបស់ទ្រង់ ក្នុងខណៈពេលដែលសេចក្តីកំណាចអាក្រក់របស់ប្តីនាងបានបញ្ចប់ដូចជាខ្មោចឆ្អែត ជាសាកសពដ៏កំណាច ជាថង់ស្បែកទទេជាគ្រាប់គ្រួសដែលបាញ់ចេញពីខ្សែដង្ហក់ ។ លោកណាបាលធ្វើជាគំរូដល់ស្តេចសូល ព្រមទាំងដល់មនុស្សឯទៀត ដែលមិនព្រមទទួលស្គាល់ការចាក់ប្រេងតាំងរបស់ព្រះអម្ចាស់ ។

**២៥:៤៣** *អ័ហ៊ីណោម* នាងបានបង្កើតកូនច្បងឱ្យលោកដាវីឌ ឈ្មោះថាអាំណូន (សូមមើល ២សយ ៣:២) ។ *ស្រុកយេសរាល* មានទីតាំងនៅក្បែរកើមែល (សូមមើល ខ.២ យស ១៥:៥៥–៥៦) ហើយសូមកុំឱ្យមានការច្រឡំជាមួយទីក្រុង១នៅភាគខាងជើងដែលមានឈ្មោះដូចគ្នានេះដែរ ជាកន្លែងដែលពួកកូនចៅអ៊ីស្រាអែលបោះជំរុំប្រឆាំងជាមួយពួកភីលីស្ទីន (សូមមើល ២៩:១,១១) ហើយក៏ជាកន្លែងដែលស្តេចអ័ហាប់មកស្នាក់នៅក្នុងសម័យកាលក្រោយមកទៀត(សូមមើល ១ពវ ១៨:៤៥–៤៦ ២១:១) ។

**២៥:៤៤** *មីកាល ប្រពន្ធរបស់ដាវីឌ* សូមមើល ១៨:២៧ ។

**២៦:១–២៥** លោកដាវីឌបានផ្តល់សេចក្តីមេត្តាករុណាដល់ស្តេចសូល ក្នុងខណៈពេលដែលទាហានរបស់ស្តេចសូលដេកជុំវិញទ្រង់ (មើលការពន្យល់ ២៤:១–២៦:២៥ ២៤:១–២២) ។

**២៦:១** *ពួកស្រុកស៊ីភ* មើល ២៣:១៩ និងការពន្យល់ ២៣:១៤ ។ *គីបៀរ* ជាកន្លែងដែលស្តេចសូលបានតាំងលំនៅនៅទីនោះ (សូមមើល ១០:២៦) ។

**២៦:២** *ទីរហោស្ថានស៊ីភ* សូមមើល ២៣:១៩ និងការពន្យល់ ២៣:១៤ ។ *៣ពាន់នាក់* ប្រហែលជាលំនឹងទាហានរបស់ស្តេចសូល (មើល ២៤:២) ។

**២៦:៥** *អ័ប៊ីនើរ* លោកគឺជាបងប្អូនជីដូនមួយជាមួយស្តេចសូល(សូមមើល ១៤:៥០) ។ *ដេកនៅ* លោកដាវីឌបានមកដល់ជំរុំរបស់សូលក្នុងពេលរាត្រីស្របពេលដែលមនុស្សទាំងឡាយកំពុងតែដេក ។

**២៦:៦** *អ័ហ៊ីម៉ាលេក ជាសាសន៍ហេត* ឃ្លាដែលនិយាយថាលោកអ័ហ៊ីម៉ាលេកជាសាសន៍ហេត មិនត្រូវបាននិយាយនៅកន្លែងផ្សេងទៀតឡើយ ។ ពួកសាសន៍ហេតបានតាំងលំនៅក្នុងប្រទេសកាណានជាយូរមកហើយ (មើលការពន្យល់ លប ១០:១៥ និងមើល លប ១៥:២០ ២៣:៣–២០ ចទ ៧:១ ២០:១៧) ។ អ្នកបម្រើរបស់លោកដាវីឌផ្សេងទៀតដែលជាពួកហេតនោះ

ខ្ញុំនេះនឹងចុះទៅ ៧ដូច្នេះ ដាវីឌ និងអ័ប៊ីសាយក៏ចូលទៅក្នុង
បណ្ដាទ័ពទាំងយប់ ឃើញសូលកំពុងផ្ទំលក់ នៅក្នុងវង់
ទីបោះទ័ព មានលំពែងរបស់ទ្រង់ដោតនៅដីត្រង់ក្បាល
ដំណេក ឯអ័ប៊ីនើរ និងបណ្ដាទ័ពទាំងប៉ុន្មាន គេដេកនៅ
ព័ទ្ធជុំវិញទ្រង់ ៨នោះអ័ប៊ីសាយជំរាបដាវីឌថា នៅថ្ងៃនេះ
ព្រះទ្រង់បានប្រគល់ខ្មាំងសត្រូវ មកក្នុងកណ្ដាប់ដៃលោក
ហើយ ដូច្នេះ សូមបើកឱ្យខ្ញុំចាក់នឹងលំពែងឱ្យធ្លុះដល់ដីតែ
១ដងទៅ ដើម្បីកុំឱ្យអំពល់ទៅមុខទៀត ៩តែដាវីឌឃាត់ថា
កុំឱ្យបំផ្លាញជីវិតទ្រង់ឡើយ ដ្បិតតើមានអ្នកឯណា អាចនឹង
លូកដៃទៅទាស់នឹងអ្នកដែលព្រះយេហូវ៉ាបានចាក់ប្រេង
តាំង[ញ]ឱ្យ ហើយឥតមានទោសបានឬទេ[ដ] ១០ដាវីឌក៏និយាយ
ទៀតថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់
នៅថា ព្រះយេហូវ៉ានឹងប្រហារ[ឋ]ជីវិតទ្រង់ ឬថ្ងៃ[ឌ]កំណត់
ដែលទ្រង់ត្រូវសុគតនឹងមកដល់[ឍ] ឬទ្រង់នឹងចេញទៅវិនាស
ក្នុងទីចំបាំងណាមួយជាមិនខាន ១១សូមឱ្យព្រះយេហូវ៉ាឃាត់
កុំឱ្យខ្ញុំលូកដៃទៅទាស់នឹងអ្នកដែលទ្រង់បានចាក់ប្រេងតាំង
ឱ្យឡើយ ដូច្នេះ ចូរយកតែលំពែងដែលនៅត្រង់ក្បាល
ដំណេកទ្រង់ និងក្អមទឹកប៉ុណ្ណោះ រួចយើងវិលទៅវិញចុះ
១២យ៉ាងនោះដាវីឌក៏យកលំពែង និងក្អមទឹកពីត្រង់ក្បាល
ដំណេករបស់សូលចេញបាត់ទៅ ឥតមានអ្នកណាឃើញឬ
ដឹងឡើយ ក៏គ្មានអ្នកណាភ្ញាក់ផង ដោយគ្រប់គ្នាកំពុងតែ
ដេកលក់ ពីព្រោះយេហូវ៉ាទ្រង់បានធ្វើឱ្យគេលក់ស៊ប់[ណ] ។
១៣ដាវីឌក៏ត្រឡប់ទៅឯខាងខ្លួនវិញ ហើយឈរលើកំពូល

**២៦:៩** ញ ខ.១៦ លប ២៦:១១ ១សយ ៩:១៦ ២សយ ១:១៤ ១៩:២១ បទ ៤:២០ ដ ១សយ ២៤:៥
**២៦:១០** ឋ លប ១៦:៥ ១សយ ២៥:៣៨ រម ១២:១៩ ឌ ចទ ៣១:១៤ ទជ ៣៧:១៣ ឍ ១សយ ៣១:៦ ២សយ ១:១
**២៦:១២** ណ ពច ៤:២១
**២៦:១៧** ត ១សយ ២៤:១៦
**២៦:១៨** ថ យប ១៣:២៣ យរ ៣៧:១៨
**២៦:១៩** ទ ១សយ ២៤:៩

ភ្នំពីចំងាយ មានប្រឡោះធំនៅជាកណ្ដាល ១៤រួចស្រែក
ដាស់ពួកបណ្ដាទ័ព និងអ័ប៊ីនើរ ជាកូននើរថា នែ អ័ប៊ីនើរ
មិនឆ្លើយទេឬ នោះអ័ប៊ីនើរឆ្លើយឡើងថា តើអ្នកណាដែល
ស្រែកហៅស្ដេចនោះ ១៥ដាវីឌឆ្លើយតបទៅអ័ប៊ីនើរថា តើ
ឯងមិនមែនជាមនុស្សទេឬអី តើមានអ្នកឯណា ក្នុងបណ្ដា
សាសន៍អ៊ីស្រាអែល ឱ្យដូចជាឯង ដូច្នេះ ហេតុអ្វីបានជាឯង
មិនបានរក្សាស្ដេច ជាចៅហ្វាយនៃឯង ដ្បិតមានមនុស្ស
ម្នាក់ បានចូលមកចង់បំផ្លាញស្ដេច ជាចៅហ្វាយនៃឯង
ចោល ១៦ឯងធ្វើយ៉ាងដូច្នេះមិនល្អទេ អញស្បថដោយនូវ
ព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅថា ឯងគួរស្លាប់ហើយ
ដោយព្រោះឯងរាល់គ្នាមិនបានរក្សាចៅហ្វាយរបស់ខ្លួន
ដែលព្រះយេហូវ៉ាបានចាក់ប្រេងតាំងឱ្យ ឥឡូវនេះ ចូរឯង
មើលលំពែងរបស់ស្ដេច និងក្អមទឹក ដែលបាននៅត្រង់
ក្បាលដំណេកទ្រង់ នោះតើនៅឯណា ។
១៧រីឯសូល ទ្រង់បានស្គាល់សំឡេងដាវីឌ ហើយក៏សួរថា
ឱដាវីឌកូនអើយ នេះជាសំឡេងឯងឬ នោះដាវីឌទូលឆ្លើយ
ថា បពិត្រព្រះករុណា ជាម្ចាស់នៃទូលបង្គំអើយ នេះជា
សំឡេងទូលបង្គំមែនហើយ[ត] ១៨រួចទូលសួរថា ហេតុអ្វី
បានជាព្រះករុណា ជាម្ចាស់នៃទូលបង្គំ ដេញតាមទូលបង្គំ
ជាបាវបំរើទ្រង់ដូច្នេះ តើទូលបង្គំបានធ្វើអ្វី ឬមានទោស[ថ]
យ៉ាងណា ១៩ដូច្នេះ សូមព្រះករុណា ជាម្ចាស់នៃទូលបង្គំ
ទ្រង់ព្រះសណ្ដាប់[ទ]ទូលបង្គំ ជាបាវបំរើទ្រង់បន្តិច បើសិន
ជាគឺព្រះយេហូវ៉ា ដែលញុះញង់ព្រះករុណាឱ្យទាស់នឹងទូល

គឺជាលោកអ៊ូរី (មើល ២សយ ១១:៦–៧ ២៣:៣៩) ។ *អ័ប៊ីសាយជាប្អូនយ៉ូអាប់ជាកូនសេរូយ៉ា* សេរូយ៉ា នាងគឺជាបងប្អូនស្រីរបស់លោកដាវីឌ (១រប ២:១៦) ដូច្នេះ លោកអ័ប៊ីសាយនិងលោកយ៉ូអាប់ (និងប្អូនប្រុសរបស់គេ អេសាអែល ២សយ ២:១៨) គឺជាក្មួយប្រុសរបស់លោកដាវីឌ ដែលជាអ្នកដឹកនាំគួរឱ្យទុកចិត្តបំផុតរបស់លោកដាវីឌ ។ លោកយ៉ូអាប់ធ្វើជាមេបញ្ជាការអស់រយៈពេលជាយូរ ។

**២៦:៨** *ទ្រង់បានប្រគល់ខ្មាំងសត្រូវ មកក្នុងកណ្ដាប់ដៃលោកហើយ* សូមមើល ២៤:៤ និងការពន្យល់ ។ *ខ្ញុំចាក់នឹងលំពែងឱ្យធ្លុះដល់ដីតែ១ដងទៅ* ដូចគ្នានឹងអ្វីដែលសូលព្យាយាមទំលុះលោកដាវីឌឱ្យជាប់នឹងជញ្ជាំង ដោយដែកពួយរបស់ទ្រង់ដែរ (សូមមើល ១៨:១១ ១៩:១០) ។

**២៦:៩,១១** សូមមើលការពន្យល់ ២៤:៦ ។

**២៦:១០,១៦** *ស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ* សូមមើលការពន្យល់ ១៤:៣៩,៤៥ ។

**២៦:១២** *ដាវីឌក៏យកលំពែង និងក្អមទឹក* នៅក្នុងមធ្យោបាយនេះ លោកដាវីឌធ្វើដើម្បីបង្ហាញដល់ស្ដេចសូលថា គាត់មិនបានស្វែងរកជីវិតរបស់ទ្រង់នោះឡើយ ។ ប៉ុន្តែគាត់ក៏បានបង្ហាញដល់ស្ដេចសូលថា ព្រះអម្ចាស់ទ្រង់បានប្រទានឱ្យគាត់មានអំណាច និងកម្លាំងដើម្បីចូលយកដែកពួយដែលស្ដេចសូលតែងតែព្យាយាមសម្លាប់គាត់ និងក្អមទឹកដែលជាសេចក្ដីសង្ឃឹមគ្រប់យ៉ាងរបស់ស្ដេចសូលនៅក្នុងទីរហោស្ថានស៊ីភ ដែលជាកន្លែងក្ដៅហើយហួតហែង ។

**២៦:១៩** *សូមឱ្យទ្រង់ទទួលដង្វាយ១ចុះ* លោកដាវីឌមិនបានដឹងថា តើមានហេតុផលអ្វីដែលបណ្ដាលឱ្យព្រះអម្ចាស់ទ្រង់ខ្ញាល់នឹងគាត់នោះឡើយ ប៉ុន្តែបើសិនជាមានហេតុផលខ្លះៗមែននោះ គឺព្រះអម្ចាស់ទ្រង់ជាអ្នកនៅពីខាងក្រោយស្ដេចសូលក្នុងការប៉ុនប៉ងសម្លាប់លោកដាវីឌ ដូច្នេះបានជាលោកដាវីឌអង្វរ និងលន់តួដល់ព្រះអម្ចាស់សូមឱ្យទ្រង់ទទួលយកដង្វាយនៃការរំសាយកំហឹង (សូមផ្ទៀប ១៦:៥) ។ *នោះសូមឱ្យគេត្រូវបណ្ដាសានៅចំពោះព្រះយេហូវ៉ាចុះ* លោកដាវីឌសុំឱ្យអស់ទាំងមនុស្សដែលញុះញង់ស្ដេចសូលត្រូវទទួលការជំនុំជម្រះមកពីព្រះអម្ចាស់ ។ *មរដកផងព្រះយេហូវ៉ា* មើលការពន្យល់ ១០:១ ។ លោកដាវីឌបានទូលអង្វរដល់ស្មារតីរបស់ស្ដេចសូលដោយគាត់បានពិពណ៌នាពីការបណ្ដេញវត្តមានគាត់ចេញពីទំនាក់ទំនងជាមួយព្រះអម្ចាស់ក្នុងនាមគាត់ជារាស្ត្រទ្រង់ និងការបណ្ដេញគាត់ចេញពីការរស់នៅប្រកបដោយសន្តិភាព ដែលមាននៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។ *ដោយថា ចូរទៅគោរពប្រតិបត្តិដល់ព្រះដទៃចុះ* នៅក្នុងទស្សនៈរបស់គេ ការបណ្ដេញចេញពីទឹកដីរបស់ព្រះអម្ចាស់ គឺត្រូវបានដាច់

បង្គំ នោះសូមឱ្យទ្រង់ទទួលដង្វាយ១ចុះ[ផ] តែបើគឺជាពួក
មនុស្សជាតិវិញ នោះសូមឱ្យគេត្រូវបណ្ដាសានៅចំពោះ
ព្រះយេហូវ៉ាចុះ ដ្បិតនៅថ្ងៃនេះ គេបានបណ្ដេញទូលបង្គំ
មិនឱ្យមានចំណែកក្នុងមរដកផងព្រះយេហូវ៉ាទេ[ទ] ដោយថា
ចូរទៅគោរពប្រតិបត្តិដល់ព្រះដទៃចុះ[ប]
២០ ដូច្នេះសូមកុំ
ឱ្យឈាម[ផ]ទូលបង្គំបានស្រក់ចុះទៅដី ឃ្លាតពីចំពោះព្រះ
យេហូវ៉ាឡើយ ដ្បិតស្ដេចនៃសាសន៍អ៊ីស្រាអែលបានចេញ
មក ដើម្បីរកតែចៃ[ព]ទេ ដូចជាកាលគេដេញតាមក្រួច
នៅលើភ្នំដែរ[ភ]។

២១ នោះសូលមានបន្ទូលថា អញបានធ្វើបាប[ម]ហើយ
ដាវីឌកូនអើយ ចូរមកវិញចុះ អញលែងធ្វើបាបឯងហើយ
ពីព្រោះនៅថ្ងៃនេះ ជីវិតអញបានថ្លៃវិសេស[យ] នៅភ្នែកឯង
មើល អញបានប្រព្រឹត្តដោយសេចក្ដីចំកួត ហើយធ្វើខុស
ជាខ្លាំងណាស់
២២ ដាវីឌទូលឆ្លើយថា មើលនែ នេះលំពែង
របស់ទ្រង់ សូមឱ្យពួកទ្រង់ម្នាក់មកយកទៅវិញចុះ
២៣ ព្រះ
យេហូវ៉ាទ្រង់នឹងសង[រ]ដល់មនុស្សតាមសេចក្ដីសុចរិត[ល] និង
សេចក្ដីស្មោះត្រង់របស់គេរៀងខ្លួន ពីព្រោះនៅថ្ងៃនេះ ព្រះ
យេហូវ៉ាទ្រង់បានប្រគល់[វ]ព្រះករុណា មកក្នុងកណ្ដាប់ដៃ
ទូលបង្គំហើយ តែទូលបង្គំមិនព្រមលូកដៃទាស់នឹងអ្នកដែល
ព្រះយេហូវ៉ាបានចាក់ប្រេងតាំងឱ្យទេ
២៤ ហើយដែលព្រះ
ជន្មនៃព្រះករុណាបានថ្លៃវិសេសនៅភ្នែកទូលបង្គំ នៅថ្ងៃ
នេះយ៉ាងណា នោះសូមឱ្យជីវិតទូលបង្គំបានថ្លៃវិសេសនៅ
ព្រះនេត្រនៃព្រះយេហូវ៉ាយ៉ាងនោះដែរ ហើយសូមទ្រង់
មេត្តាប្រោស[ស] ឱ្យទូលបង្គំរួចចាកពីគ្រប់ទាំងសេចក្ដីវេទនា
ផង
២៥ នោះសូលមានបន្ទូលថា ដាវីឌកូនអើយ សូមព្រះ
ទ្រង់ប្រទានពរ[ហ]ដល់ឯងចុះ ឯងនឹងបានធ្វើការយ៉ាងពូកែ
ហើយមានជ័យជំនះផង រួចដាវីឌក៏ចេញបាត់ទៅ ហើយ
សូលទ្រង់ត្រឡប់វិលទៅឯកន្លែងរបស់ទ្រង់វិញ ។

## ស្ដេចដាវីឌ នៅក្នុងចំណោមពួកភីលីស្ទីន

**២៧** ១ គ្រានោះដាវីឌនឹកក្នុងចិត្តថា មានថ្ងៃណាមួយ អញ
នឹងស្លាប់ដោយសារដៃសូលជាមិនខាន គ្មានផ្លូវណាជាជាង
ឱ្យអញរត់ទៅជ្រក នៅឯស្រុករបស់ពួកភីលីស្ទីនទេ នោះ
សូលនឹងអស់ចិត្តចង់រកអញនៅគ្រប់ក្នុងអស់ទាំងដែនស្រុក
អ៊ីស្រាអែលទៀត ដូច្នេះ ទើបអញនឹងរួចចេញពីព្រះហស្ត
ទ្រង់បាន
២ ស្រេចហើយ ដាវីឌក៏ក្រោកឡើងនាំទាំងពួក
៦០០នាក់[ក] ដែលនៅ[ខ]ជាមួយនឹងលោក ទៅឯស្រុករបស់
អ័គីស[គ] ជាបុត្រម៉ាអូក ដែលជាស្ដេចក្រុងកាថទៅ
៣ ក៏
អាស្រ័យនៅក្នុងក្រុងកាថ ជាស្រុករបស់អ័គីសនោះ ព្រម
ទាំងពួកលោកទាំងប៉ុន្មាន ដែលគ្រប់គ្នាមានពួកគ្រួរបស់
ខ្លួននៅជាមួយផង ឯដាវីឌ លោកបាននាំប្រពន្ធទាំង២មក
ដែរ[ឃ] គឺនាងអ័ហ៊ីណោម ជាអ្នកស្រុកយេសរាល និងអ័ប៊ី
កែលជាអ្នកស្រុកកើមែល ដែលជាប្រពន្ធរបស់ខ្មោចណា
បាលផង
៤ នោះមានគេទូលដល់សូលថា ដាវីឌបានរត់ទៅ
នៅឯក្រុងកាថហើយ ដូច្នេះ ទ្រង់ក៏ឈប់លែងរកទៀត ។

៥ ឯដាវីឌ លោកទូលនឹងអ័គីសថា បើទូលបង្គំបានប្រកប
ដោយព្រះគុណនៅចំពោះទ្រង់ឥឡូវ នោះសូមទ្រង់ឱ្យគេ
ចែកទីកន្លែងដល់ទូលបង្គំ នៅទីក្រុងណាមួយ ក្នុងអាណា

**២៦:១៩** ធ ២សយ ១៦:១១ ន ចទ ២០:១៦ ៣២:៩ ២សយ ១៤:១៦ ២០:១៩ ២១:៣ ប ចទ ៤:២៨ ១១:២៨
**២៦:២០** ផ ១សយ ២៤:១១ ព ១សយ ២៤:១៤ ភ យរ ៤:២៩ ១៦:១៦ អម ៩:៣
**២៦:២១** ម នក ៩:២៧ យ ទដ ៧២:១៤
**២៦:២៣** រ លប ១៦:៥ នរ ២:១២ ទដ ៦២:១២ ល ២សយ ២២:២១, ២៥ ទដ ៧:៨ ១៨:២០,២៤ វ ១សយ ២៤:១៨
**២៦:២៤** ស ទដ ៥៤:៧
**២៦:២៥** ហ នរ ២:១២
**២៧:២** ក ១សយ ៣០:៩ ២សយ ២:៣ ខ ១សយ ២១:១០ គ ១ពវ ២:៣៩
**២៧:៣** ឃ ១សយ ២៥:៤៣

ចេញពីទីបរិសុទ្ធរបស់ព្រះ (ជាទម្រង់នៃការសន្ទនាដើម ដែលមាននៅក្នុងព្រះគម្ពីរសញ្ញាចាស់) ។ ហើយត្រូវរស់នៅនិងបម្រើព្រះដទៃរបស់ទឹកដីនៃសាសន៍នោះ (មើល យស ២២:២៤–២៧ និងការពន្យល់ ១ពវ ៥:១៧) ។

**២៦:២០** *ដើម្បីរកតែចៃទេ* សូមមើល ២៤:១៤ ។ លោកដាវីឌបានលើកឡើងថា ស្ដេចសូលគឺកំពុងតែធ្វើឱ្យខ្លួនទ្រង់ត្រឡប់ជាសេចក្ដីចំកួត ដោយទ្រង់បានតាមចាប់មនុស្សដែលគ្មានកំហុស ។

**២៦:២១** *អញបានធ្វើបាបហើយ* សូមមើល ២៤:១៧ ។ *អញបានប្រព្រឹត្តដោយសេចក្ដីចំកួត* ស្ដេចសូលព្រមទទួលស្គាល់ថា ការប្រព្រឹត្តរបស់ទ្រង់មិនត្រឹមតែមិនឆ្លាតប៉ុណ្ណោះនោះទេ តែថែមទាំងកំណាច និងចំកួតទៀតផង (សូមមើលការពន្យល់ ១៣:១៣ ២៥:២–៤៤) ។

**២៦:២៣** *ទូលបង្គំមិនព្រមលូកដៃទាស់នឹងអ្នកដែលព្រះយេហូវ៉ាបានចាក់ប្រេងតាំងឱ្យទេ* សូមមើល ខ.៩ ២៤:៦ ។

**២៦:២៥** *ឯងនឹងបានធ្វើការយ៉ាងពូកែ ហើយមានជ័យជំនះផង* ស្ដេចសូលបានធ្វើការផ្ដន្ទាទោសចំពោះខ្លួនទ្រង់ ដោយមិនចាំថាលោកដាវីឌនឹងជំនួសកន្លែងរបស់ទ្រង់ដោយទទួលយកតំណែងជាស្ដេច (សូមមើល ២៤:២០) ។

**២៧:១** *មានថ្ងៃណាមួយអញនឹងស្លាប់ ដោយសារដៃសូលជាមិនខាន* ដោយសារគាត់មានការយល់ច្បាស់ជាមុនពីស្ដេចសូល នោះលោកដាវីឌមានអារម្មណ៍ថា ត្រូវតែបង្ខំចិត្តទៅរស់នៅកន្លែងផ្សេង ដើម្បីឱ្យបានសុវត្ថិភាពក្រៅពីព្រំប្រទល់ទឹកដីអ៊ីស្រាអែល ។ *ស្រុករបស់ពួកភីលីស្ទីន* ជាលើទី២ ហើយ ដែលលោកដាវីឌបានរត់ទៅជ្រកនៅស្រុកភីលីស្ទីន (សូមមើល ២១:១០–១៥) ។

**២៧:២** *អ័គីស . . . ជាស្ដេចក្រុងកាថ* មើល ២១:១០ និងការពន្យល់ ។ លើកនេះមានការខុសពីដំណើរការលើកដំបូងរបស់លោកដាវីឌ នៅស្រុកភីលីស្ទីន ស្ដេចអ័គីសបានត្រៀមលក្ខណៈទទួលលោកដាវីឌរួចជាស្រេច ពីព្រោះពេលនេះគាត់ជាបច្ចាមិត្ររបស់ស្ដេចសូល ។

**២៧:៣** *អ័ហ៊ីណោម* សូមមើលការពន្យល់ ២៥:៤៣ ។ *អ័ប៊ីកែល* មើល ២៥:៣៩–៤២ ។

**២៧:៤** *ទ្រង់ក៏ឈប់លែងរកទៀត* ស្ដេចសូលគ្មានកម្លាំងទ័ពគ្រប់គ្រាន់ដើម្បីលុកលុយលើទឹកដីភីលីស្ទីនឡើយ ហើយក៏គ្មាននរណាទៀតគំរាមគំហែងចំពោះរាជ្យបល្ល័ង្ករបស់ទ្រង់ទៀតដែរ ពីព្រោះលោកដាវីឌមិនបាននៅក្នុងស្រុកទៀតឡើយ ។

**២៧:៥** *ទីក្រុងណាមួយ ក្នុងអាណាខេត្រ* លោកដាវីឌមានបំណងប្រាថ្នាចង់

ខែត្ររបស់ទ្រង់ ឱ្យទូលបង្គំបានអាស្រ័យនៅផង ដ្បិតមិន
គួរឱ្យទូលបង្គំ ជាបាវទ្រង់ បាននៅក្នុងទីក្រុងធំរបស់ស្តេច
ជាមួយនឹងទ្រង់ទេ ៦នៅថ្ងៃនោះឯង អ័គីសក៏ប្រទានក្រុង
ស៊ីកឡាក់[ង]ឱ្យដល់ដាវីឌ ព្រោះហេតុនោះបានជាក្រុង
ស៊ីកឡាក់ ក៏នៅជារបស់ផងពួកស្តេចយូដា ដរាបដល់សព្វ
ថ្ងៃនេះ ៧ដាវីឌក៏អាស្រ័យនៅ[ច]ក្នុងស្រុកភីលីស្ទីនអស់១ឆ្នាំ
៤ខែ ។

៨នៅគ្រានោះដាវីឌ និងពួកលោក ក៏ចូលលុកក្នុងស្រុក
របស់ពួកកេស៊ូរី[ឆ] ពួកកេសើរ និងពួកអាម៉ាលេក[ជ] ដ្បិត
សាសន៍ទាំងនោះ ជាអ្នកស្រុក តាំងតែពីដើមរៀងមក គេ
នៅតាមផ្លូវ ដែលទៅឯស្រុកសើរ[ឈ] រហូតដល់ស្រុកអេស៊ីព្ទ
៩ដាវីឌវាយស្រុកគេ ឥតទុកឱ្យមានប្រុសឬស្រី នៅរស់
ឡើយ[ញ] ក៏ចាប់យកចៀម គោ លា អូដ្ឋ និងសំលៀកបំពាក់
របស់គេ រួចនាំគ្នាត្រឡប់មកឯអ័គីសវិញ ១០អ័គីសទ្រង់សួរ
ថា តើអ្នកបានលុកចូលវាយស្រុកណាខ្លះនៅថ្ងៃនេះ រួច
ដាវីឌទូលឆ្លើយថា បានទៅខាងត្បូងស្រុកយូដា និងខាង
ត្បូងពួកយេរ៉ាម្អែល ហើយខាងត្បូងពួកកែន ១១ដាវីឌមិន
ទុកគេ ទោះប្រុសទោះស្រីក្តីឱ្យនៅរស់ ដើម្បីនឹងនាំមកឯ
ក្រុងកាថទេ ដោយថាខ្លាចក្រែងគេផ្សាយដំណឹងថា ដាវីឌ
បានធ្វើដូច្នេះមួយៗ ក៏ធ្លាប់ធ្វើដូច្នោះចាប់តាំងពីវេលា
ដែលចូលមកនៅក្នុងស្រុកភីលីស្ទីននេះដែរ ១២អ័គីសក៏ជឿ
ដាវីឌ ដោយថា វាបានបណ្តាលឱ្យពួកអ៊ីស្រាអែល ជា
សាសន៍ខ្លួន ស្អប់ខ្ពើម[ដ] ដល់ខ្លួនហើយ ដូច្នេះវានឹងធ្វើជាអ្នក
បំរើរបស់អញជាដរាបតទៅ[ឋ] ។

## ស្តេចសូល និងស្ត្រីគ្រូខាបនៅក្រុងអេន–ដោរ

**២៨** ១នៅគ្រានោះ ពួកភីលីស្ទីន គេប្រមូល[ក]ពលទ័ពគេ
មក ដើម្បីច្បាំងនឹងសាសន៍អ៊ីស្រាអែល ហើយអ័គីសមាន
បន្ទូលទៅដាវីឌថា ចូរឱ្យអ្នកដឹងថា ត្រូវឱ្យអ្នក ព្រមទាំងពួក
ពលរបស់អ្នកផង ចេញទៅក្នុងកងទ័ពជាមួយនឹងយើង
២ដាវីឌទូលឆ្លើយថា បើដូច្នេះ ទ្រង់នឹងបានជ្រាបការដែល
ទូលបង្គំជាបាវទ្រង់នឹងធ្វើជាយ៉ាងណា នោះអ័គីស មាន
បន្ទូលតបថា បើដូច្នោះមែន យើងនឹងតាំងអ្នកឱ្យការពារ[ខ]
យើងជាដរាបតទៅ ។

៣រីឯសាំយូអែលលោកបានស្លាប់ហើយ[គ] ពួកអ៊ីស្រាអែល
ទាំងអស់ក៏កាន់ទុក្ខនឹងលោក ហើយបានបញ្ចុះសពលោក
នៅត្រង់រ៉ាម៉ា[ឃ] ក្នុងទីក្រុងរបស់លោករួចជាស្រេច ហើយ
សូលទ្រង់បានបណ្តេញ[ង]អស់ទាំងពួកគ្រូខាប និងពួកគ្រូ

**២៧:៦** ង យស ១៥:៣១ ១៩:៥ ១សយ ៣០:១ ១រប ១២:២០ នហ ១១:២៨
**២៧:៧** ច ១សយ ២៩:៣
**២៧:៨** ឆ យស ១២:៥ ជ នក ១៧:១៤ ១សយ ១៤:៤៨ ៣០:១ ២សយ ១:៨ ៨:១២ ឈ លប ១៦:៧
**២៧:៩** ញ ១សយ ១៥:៣
**២៧:១០** ដ ១សយ ៣០:២៩ ឋ ពច ១:១៦
**២៧:១២** ឌ លប ៣៤:៣០ ឍ ១សយ ២៩:៦
**២៨:១** ក ១សយ ២៩:១
**២៨:២** ខ ១សយ ២៩:២
**២៨:៣** គ ១សយ ២៥:១ ឃ ១សយ ៧:១៧ ង ខ.៩

បានសេរីភាព និងឯករាជ្យនៅក្នុងខ្លួនគាត់ ជាងរស់នៅក្រោមក្រសែភ្នែក និងការគ្រប់គ្រងរបស់ស្តេចនៃក្រុងកាថ ។ *មិនគួរឱ្យទូលបង្គំ ជាបាវទ្រង់ បាននៅក្នុងទីក្រុងធំរបស់ស្តេច ជាមួយនឹងទ្រង់ទេ* លោកដាវីឌបានប្រៀបធៀបថាគាត់មិនគួរនឹងទទួលបានកិត្តិយសនេះទេ ។

**២៧:៦** *ស៊ីកឡាក់* គ្មាននរណាម្នាក់បានដឹងពីទីន្លែងពិតប្រាកដនៃក្រុងនេះទេ ប៉ុន្តែ គេរាប់បញ្ចូលជាមួយនឹងបញ្ជីឈ្មោះទីក្រុងទាំងប៉ុន្មាននៅភាគខាងត្បូងនៃស្រុកយូដា (សូមមើល យស ១៥:៣១) ។ ទីក្រុងនេះ ត្រូវបានគេប្រគល់ឱ្យទៅអំបូរស៊ីម្មាន (មើល យស ១៩:១–៥) ។ *ជារបស់ផងពួកស្តេចយូដា* ជាអចលនទ្រព្យរបស់ស្តេច ។

**២៧:៧** *ដាវីឌក៏អាស្រ័យនៅក្នុងស្រុកភីលីស្ទីនអស់១ឆ្នាំ៤ខែ* លោកដាវីឌបានត្រឡប់ពីក្រុងស៊ីកឡាក់មកហេប្រុនវិញ ដោយមិនចាំបាច់រង់ចាំឱ្យស្តេចសូលសុគតហើយនោះឡើយ (សូមមើល ២សយ ១:១ ២:១–៣) ។

**២៧:៨** *ពួកកេស៊ូរី* គឺជាពួកមនុស្សដែលរស់នៅក្នុងតំបន់ខាងត្បូងនៃស្រុកភីលីស្ទីន ហើយជាពួកមនុស្សដែលមិនទទួលការឈ្លានពានពីសំណាក់ពួកអ៊ីស្រាអែលក្នុងអំឡុងដែលមានចម្បាំងដណ្តើមទឹកដីនោះឡើយ (សូមមើល យស ១៣:១–៣) ពួកគេមានឈ្មោះល្បីចាប់តាំងពីពួកកេស៊ូរី ដែលរស់នៅភាគខាងជើងក្បែរទន្លេយ័រដាន់លើ ក្នុងស្រុកអារ៉ាម (សូមមើល ២សយ ៣:៣ ១៣:៣៧–៣៨ ចទ ៣:១៤ យស ១២:៥) ។ *ពួកកេសើរ* ពួកមនុស្សនេះមិនត្រូវបាននិយាយ នៅក្នុងកន្លែងណាផ្សេងទៀតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ឡើយ ។ *ពួកអាម៉ាលេក* សូមមើលការពន្យល់ ១៥:២ ។ *ស្រុកសើរ* សូមមើលការពន្យល់ ១៥:៧ ។

**២៧:៩** *ឥតទុកឱ្យមានប្រុសឬស្រីនៅរស់ឡើយ* មូលហេតុដែលលោកដាវីឌធ្វើដូច្នេះ ត្រូវបាននិយាយនៅក្នុង ខ.១១ ។ គាត់ធ្វើបែបនេះគឺអនុលោមទៅតាមលោកយ៉ូស្វេ ក្នុងពេលមានចម្បាំងដណ្តើមទឹកដីជាមួយពួកកាណាន (សូមមើល យស ៦:២១ និងការពន្យល់ ៦:១៧) ។

**២៧:១០** *ខាងត្បូងស្រុកយូដា* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ "ខាងត្បូង" មានន័យថា "ស្ងួត" ដែលនិយាយអំពីឈ្មោះនៃតំបន់ដ៏ធំមួយចាប់តាំងពីបៀរសេបា រហូតដល់ឧបទ្វីបស៊ីណាយ ។ *ខាងត្បូងពួកយេរ៉ាម្អែល* ពូជពង្សរបស់ពួកយេរ៉ាម្អែល គឺហេស្រុនជាពួកយូដា (១រប ២:៩,២៥) ។ *ពួកកែន* មើលការពន្យល់ ១៥:៦ ។

**២៧:១២** *អ័គីសក៏ជឿដាវីឌ* លោកបានធ្វើឱ្យអ័គីសជឿជាក់ថា គាត់បានវាយលុកទឹកដីអ៊ីស្រាអែល ក្នុងពេលដែលគាត់បានវាយលុកពួកកេស៊ូរី ពួកកេសើរ និងពួកអាម៉ាលេក (សូមមើល ខ.៨) ។

**២៨:១** *ត្រូវឱ្យអ្នកនិងពួកពលរបស់អ្នកផង . . . ជាមួយយើង* នៅក្នុងមជ្ឈឹមបូព៌ាសម័យបុរាណ អ្នកភៀសខ្លួនទៅប្រទេសដទៃត្រូវធ្វើជាទាហានបម្រើប្រទេសនោះ (សូមមើលការពន្យល់ ២៧:២) ។

**២៨:២** *ទ្រង់នឹងបានជ្រាបការដែលទូលបង្គំ ជាបាវទ្រង់នឹងធ្វើជាយ៉ាងណា* ប្រហែលជាចម្លើយមួយដែលមានន័យមិនគ្រប់គ្រាន់ ។ *យើងនឹងតាំងអ្នកឱ្យការពារយើងជាដរាប* មើលទៅវាជាលក្ខខ័ណ្ឌមួយដើម្បីឱ្យលោកដាវីឌបង្ហាញភស្តុតាងពីនគរ និងពីប្រសិទ្ធិភាពក្នុងយុទ្ធនាការ ។ ក្រោយមកទៀតលោកដាវីឌមានអ្នកការពារផ្ទាល់ខ្លួនរបស់គាត់ជាច្រើននាក់(មើល ២សយ ១៥:១៨ និងការពន្យល់) ។

**២៨:៣** *រីឯសាំយូអែល លោកបានស្លាប់ហើយ* មើល ២៥:១ ។ ស្តេចសូលមិនអាចត្រឡប់មករជិនួយពីលោកសាំយូអែលវិញឡើយ ទោះបីជាទ្រង់អស់

អន្ទងខ្មោច[ច]ពីស្រុកចេញ ៤គ្រានោះពួកភីលីស្ទីន គេប្រមូល
គ្នាមកបោះទ័ពនៅត្រង់ស៊ូណែម[ឆ] ហើយសូលទ្រង់ក៏ប្រមូល
ពួកអ៊ីស្រាអែលទាំងអស់ ទៅបោះទ័ពនៅត្រង់គីលបោដែរ[ជ]
៥កាលសូលទ្រង់ទតឃើញពលទ័ពខាងពួកភីលីស្ទីន នោះ
ទ្រង់ក៏ភ័យ ហើយមានព្រះទ័យញាប់ញ័រ[ឈ]ជាខ្លាំង ៦តែកាល
សូលទូលសួរ[ញ]ដល់ព្រះយេហូវ៉ា នោះទ្រង់មិនឆ្លើយតប
មកឡើយ ទោះបើដោយការពន្យល់សប្តិ[ដ] ឬដោយសារ
យូរីម[ឋ] ឬដោយពួកហោរាក្តី[ឌ] ៧ដូច្នេះ សូលទ្រង់មានបន្ទូល
ប្រាប់ទៅពួកអ្នកបំរើទ្រង់ថា ចូរទៅរកស្រីដែលចេះខាប
ខ្មោចឱ្យអញចុះ[ឍ] ដើម្បីឱ្យអញបានទៅសួរទំនាយពីស្រីនោះ
ពួកអ្នកបំរើទ្រង់ក៏ទូលឆ្លើយថា មើលនៅឯអេន-ដោរ[ណ]
មានស្ត្រីម្នាក់ជាអ្នកចេះខាប ។
៨នោះសូលទ្រង់ក៏ក្លែងខ្លួន[ត] ហើយផ្លាស់សំលៀកបំពាក់
រួចចេញទៅ មានមនុស្ស២នាក់ទៅជាមួយផង ក៏បានដល់
ទៅស្រីនោះនៅពេលយប់ ហើយមានបន្ទូលថា សូមទាយ
ប្រាប់ខ្ញុំដោយនូវខ្មោចចុះ ហើយសូមខាបយក[ថ]អ្នក១ ដែល
ខ្ញុំនឹងប្រាប់អ្នកឱ្យមកឯខ្ញុំផង ៩ស្ត្រីនោះឆ្លើយឡើងថា លោក
ជ្រាបហើយ ពីការដែលស្តេចសូលបានធ្វើជាយ៉ាងណា គឺ
ទ្រង់បានបណ្តេញ[ទ]ពួកចេះខាប និងពួកអន្ទងខ្មោចពីស្រុក
ចេញ ចុះហេតុអ្វីបានជាលោកដាក់អន្ទាក់[ធ]ចាប់ជីវិតខ្ញុំឱ្យ
ត្រូវស្លាប់ដូច្នេះ ១០នោះសូលក៏ស្បថឱ្យស្ត្រីនោះ ដោយនូវ
ព្រះយេហូវ៉ាថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះ
ជន្មរស់នៅថា អ្នកមិនត្រូវមានទោសក្នុងការនេះឡើយ
១១រួចស្រីនោះសួរថា តើចង់ឱ្យខ្ញុំខាបយកអ្នកណាមកឱ្យ
លោក នោះទ្រង់មានបន្ទូលថា សូមខាបយកសាំយូអែលមក
ឱ្យខ្ញុំចុះ ១២កាលស្ត្រីនោះបានឃើញសាំយូអែល នោះក៏
ស្រែកឡើងជាខ្លាំងរួចទូលសូលថា ហេតុអ្វីបានជាបញ្ឆោត
ខ្ញុំម្ចាស់ដូច្នេះ[ន] ដ្បិតខ្លួនលោកនេះហើយ គឺជាសូល ១៣តែ
ទ្រង់មានបន្ទូលថា កុំឱ្យភ័យខ្លាចឡើយ តើអ្នកបានឃើញអ្វី
រួចស្ត្រីនោះទូលឆ្លើយថា ខ្ញុំម្ចាស់បានឃើញពួកព្រះឡើង
ពីដីមក[ប] ១៤ទ្រង់មានបន្ទូលទៀតថា តើមានភាពយ៉ាងដូម្តេច
គាត់ឆ្លើយថា មានភាពជាមនុស្សចាស់គ្រលុំដោយអាវ[ផ]
ដែលឡើងមក នោះសូលទ្រង់យល់ថា ជាសាំយូអែលហើយ
រួចទ្រង់ក្រាបព្រះភក្ត្រចុះដល់ដីដោយគោរព ។

**២៨:៣** ច នក ២២:១៨ **២៨:៤** ឆ យស ១៩:១៨ ជ ១សយ ៣១:១,៣ ២សយ ១:៦,២១ ២១:១២ **២៨:៥** ឈ នក ១៩:១៦ **២៨:៦** ញ ១សយ ៨:១៨ ១៤:៣៧ ដ ចទ ១៣:៣ ឋ នក ២៨:៣០ លវ ៨:៨ ឌ អគ ២០:៣ អម ៨:១១ មីក ៣:៧ **២៨:៧** ឍ ១រប ១០:១៣ កច ១៦:១៦ ណ យស ១៧:១១ ទដ ៨៣:១០ **២៨:៨** ត ១ពវ ២៣:៣០ ២រប ១៨:២៩ ៣៥:២២ ថ ២ពវ ១:៣ អស ៨:១៩

**២៨:៩** ទ ខ.៣ ធ យប ១៨:១០ ទដ **២៨:១២** ន លប ២៧:៣៦ ១ពវ ១៤:៦ **២៨:១៣** ប ខ.១៥ លវ ១៩:៣១ ២រប ៣៣:៦ **២៨:១៤** ផ ១សយ ១៥:២៧

សង្ស័យក៏ដោយ ។ *បណ្តេញ . . . ពីស្រុកចេញ* បើនិយាយឱ្យអាក្រក់ស្តាប់ទៅ គឺ"សម្លាប់ចោល"តាមច្បាប់ដែលបានចែងនៅក្នុងបញ្ញកណ្ឌ (សូមមើល ខ.៩,២១) ។

**២៨:៤** *ស៊ូណែម* ពួកភីលស្ទីនបានប្រជុំពីកិច្ចការចម្បាំងរបស់គេនៅឯនាយខាងជើង តាមបណ្តោយខ្ពង់រាបយេសរាលក្នុងទឹកដីពួកអ៊ីសាខារ (សូមមើល យស ១៩:១៨) ។ *គីលបោ* គឺជាជ្រលងភ្នំនៅភាគខាងកើតនៃខ្ពង់រាបយេសរាល ។

**២៨:៥** *មានព្រះទ័យញាប់ញ័រ* ពីព្រោះទ្រង់មានការអស្វារ្យមកពីព្រះអម្ចាស់ ហើយការនេះ មិនមែនជាទម្រង់ដើមដំបូងនៃតួនាទីរបស់ទ្រង់ដែលជាស្តេចដ៏ពិត (សូមមើលការពន្យល់ ១៧:១១)។

**២៨:៦** *ទូលសួរដល់ព្រះយេហូវ៉ា* ប្រហែលជាទូលសួរតាមរយៈភ្នាក់ងាររបស់សង្ឃ ។ ស្តេចសូលហាក់បីដូចជា មានអារម្មណ៍កើតទុក្ខលំបាក នៅក្នុងពេលមានចម្បាំង ហើយស្វែងរកជំនួយមកពីព្រះ ។ *ពន្យល់សប្តិ* គឺជាការបើកសម្តែងដោយចំៗផ្ទាល់ខ្លួន (សូមមើល ជន ១២:៦ និងការពន្យល់ ១២:៦-៨) ។ *យូរីម* សម្តេចសង្ឃប្រើយូរីម ដើម្បីឱ្យបានដឹងពីការបើកសម្តែងមកពីព្រះអម្ចាស់ (សូមមើលការពន្យល់ ២:២៨) ។ ក្នុងអំឡុងពេលដែលអេផូឌ និងយូរីមនៅជាមួយលោកអ័បៀរ ថើរជាអ្នកដែលបម្រើការងារជាមួយលោកដាវីឌ (មើល ២៣:២,៦,៩) ស្តេចសូលបានធ្វើអេផូឌមួយផ្សេងទៀតដើម្បីប្រើប្រាស់ ។ *ពួកហោរា* លោកដាវីឌមានហោរាម្នាក់លោកកាឌ់ (២២:៥) ប៉ុន្តែក្រោយដែលហោរាសាំយូអែល និងស្តេចសូលបែកបាក់គ្នាមក (មើល ១៥:៣៥) នោះគ្មានហោរាណាម្នាក់បម្រើស្តេចសូលទៀតឡើយ ។

**២៨:៧** *ចូរទៅរកស្រីដែលចេះខាបខ្មោច* នៅក្នុងស្ថានភាពនៃការអស់សង្ឃឹមបែបនេះ ធ្វើឱ្យស្តេចសូលគាត់ត្រឡប់ទៅជាអ្នកគោរពរូបព្រះ ដែលកាលពីដើមទ្រង់បានដាក់ការថ្វាយបង្គំរូបព្រះនៅក្រៅច្បាប់ (ខ.៣) ដោយយោងតាមច្បាប់លោកម៉ូសេ (មើល លវ ១៩:៣១) ។ *អេន-ដោរ* មានទីតាំងប្រមាណជា ៧គ.ម ភាគខាងជើងស៊ីគែម (មើល ខ.៤ យស ១៧:១១) ។

**២៨:៩** *ហេតុអ្វីបានជាលោកដាក់អន្ទាក់ចាប់ជីវិតខ្ញុំឱ្យត្រូវស្លាប់ដូច្នេះ* ស្ត្រីនេះមានការប្រយ័ត្នប្រយែងចំពោះមុខរបររបស់នាង ហើយដោយសារនាងគ្មានកម្លាំងអាចនឹងធ្វើការបានអាចជាស្តេចមូលហេតុធ្វើឱ្យសូលក្បត់គាត់ (មើលការពន្យល់ ខ.៣) ។

**២៨:១០** *ដោយនូវព្រះយេហូវ៉ា ដែលមានព្រះជន្មរស់នៅ* សូមមើល ១៤:៣៩,៤៥ ។

**២៨:១២** *កាលស្ត្រីនោះឃើញសាំយូអែល* វគ្គនេះ មានការយល់ដឹងផ្សេងៗគ្នាជាច្រើនដូចជា (១).ព្រះអម្ចាស់ទ្រង់ជាអ្នកអនុញ្ញាតឱ្យវិញ្ញាណរបស់ហោរាសាំយូអែលមកឯស្ត្រីនោះ (២). ស្តីនោះបានទាក់ទងជាមួយវិញ្ញាណអាក្រក់ក្នុងទម្រង់វិញ្ញាណរបស់ហោរាសាំយូអែល ដោយសារតែនាងទទួលការបោកបញ្ឆោត និងគ្រប់គ្រងមកពីវិញ្ញាណអាក្រក់នោះ (៣).តាមរយៈការប្រើចិត្តវិជ្ជា ធ្វើឱ្យស្ត្រីនោះមានលទ្ធភាពដឹងពីគំនិតស្តេចសូល ហើយនិងរូបភាពរបស់ហោរាសាំយូអែលក្នុងគំនិតរបស់គាត់ ។ ទោះបីជាយ៉ាងនេះក៏ដោយស្ត្រីនេះបានពន្យល់ពីការអាថ៌កំបាំងនៃរឿងនេះ ដោយប្រើប្រាស់មធ្យោបាយមួយចំនួនដើម្បីឱ្យស្តេចសូលបានដឹងថា ការជិទាស់ចំពោះចម្បាំងនិងបណ្តាលឱ្យស្លាប់ វានឹងរុញច្រានសេចក្តីសង្ឃឹមចេញពីតំណវង្ស ហើយវាអាចនឹងកាត់បន្ថយរាជ្យទ្រង់ចេញ ។

**២៨:១៤** *ភាពជាមនុស្សចាស់គ្រលុំដោយអាវ* ស្តេចសូលចងចាំថា ហោរាសាំយូអែលតែងតែស្លៀកសំលៀកបំពាក់បែបនេះ (សូមមើល ១៥:២៧) ។

១៥ឯសាំយូអែល លោកទូលសួរថា ហេតុអ្វីបានជាធ្វើឱ្យ
ទូលបង្គំរំខាន ដោយហៅឱ្យទូលបង្គំឡើងមកដូច្នេះ សូល
មានបន្ទូលឆ្លើយថា ខ្ញុំមានសេចក្ដីវេទនាជាខ្លាំង ពីព្រោះ
ពួកសាសន៍ភីលីស្ទីនគេមកច្បាំងនឹងខ្ញុំ ហើយព្រះទ្រង់បាន
ថយចេញ[ព]ពីខ្ញុំទៅ ទ្រង់ឥតមានបន្ទូលឆ្លើយ[ភ]មកខ្ញុំទៀត
ឡើយ ទោះបើដោយហោរា ឬដោយការពន្យល់សប្ដិក្ដី[ម]
ហេតុនោះបានជាខ្ញុំហៅលោកមក ដើម្បីឱ្យលោកបង្ហាញ
ការ ដែលខ្ញុំគួរធ្វើជាយ៉ាងណា ១៦នោះសាំយូអែលឆ្លើយថា
បើព្រះយេហូវ៉ាបានថយចេញពីទ្រង់ទៅ ហើយបានត្រឡប់
ជាទាស់ទទឹងនឹងទ្រង់ផង ចុះហេតុអ្វីបានជាទ្រង់សួរដល់
ទូលបង្គំវិញដូច្នេះ ១៧ព្រះយេហូវ៉ាបានសំរេចដល់ទ្រង់តាម
សេចក្ដីទំនាយ ដែលទាយដោយសារទូលបង្គំហើយគឺ បាន
ដក[យ]រាជ្យពីព្រះហស្តទ្រង់ចេញប្រគល់ឱ្យដល់អ្នកដទៃម្នាក់
គឺដាវីឌ ១៨ពីព្រោះទ្រង់មិនបានស្ដាប់តាម[រ]ព្រះបន្ទូលនៃព្រះ
យេហូវ៉ាឡើយ ក៏មិនបានធ្វើដល់សាសន៍អាម៉ាលេក[ល] តាម
សេចក្ដីក្រេវក្រោធ[វ]របស់ព្រះផង ហេតុនោះបានជានៅ
ថ្ងៃនេះ ព្រះយេហូវ៉ាបានប្រព្រឹត្តនឹងទ្រង់យ៉ាងដូច្នេះ ១៩មួយ
ទៀតព្រះយេហូវ៉ានឹងប្រគល់សាសន៍អ៊ីស្រាអែលជាមួយ
នឹងទ្រង់ ទៅក្នុងកណ្ដាប់ដៃនៃពួកភីលីស្ទីនដែរ ស្អែកនេះ
ទ្រង់ ព្រមទាំងពួកបុត្រា[ស]ទ្រង់ នឹងបាននៅជាមួយនឹងទូល
បង្គំហើយ ព្រះយេហូវ៉ាទ្រង់នឹងប្រគល់ពួកពលទ័ពរបស់
សាសន៍អ៊ីស្រាអែលទៅក្នុងកណ្ដាប់ដៃនៃពួកភីលីស្ទីនដែរ។
២០ខណនោះស្រាប់តែសូលទ្រង់ដួលស្រប៉ាបចុះនៅដី
មានសេចក្ដីភ័យជាខ្លាំង ដោយពាក្យដែលសាំយូអែលបាន
ប្រាប់នោះ ហើយគ្មានកំឡាំងនៅសល់ទៀតទេ ពីព្រោះមិន
បានសោយព្រះស្ងោយអស់ពេញ១ថ្ងៃ១យប់នោះហើយ
២១ដូច្នេះ ស្ត្រីនោះក៏មកឯសូលឃើញថា ទ្រង់តក់ស្លុតជាខ្លាំង
នោះក៏ទូលថា មើល ខ្ញុំម្ចាស់ជាបាវស្រីរបស់ទ្រង់ បានស្ដាប់
តាមទ្រង់ហើយ ក៏បានប្រថុយជីវិត[ហ]នឹងធ្វើតាមអស់ទាំង
សេចក្ដី ដែលទ្រង់បានមានបន្ទូលមកខ្ញុំម្ចាស់ផង ២២ដូច្នេះ
សូមឱ្យ ទ្រង់ស្ដាប់តាមពាក្យរបស់ខ្ញុំម្ចាស់ជាអ្នកបំរើទ្រង់
ឥឡូវចុះ សូមអនុញ្ញាតឱ្យខ្ញុំម្ចាស់រៀបនំបុ័ងបន្តិចថ្វាយទ្រង់
សោយ ដើម្បីឱ្យមានកំឡាំងក្នុងកាលដែលយាងតាមផ្លូវទៅ
២៣ទ្រង់ប្រកែក[ឡ]ថា ខ្ញុំមិនបរិភោគទេតែ ដោយពួកអ្នក
បំរើទ្រង់ ព្រមទាំងស្ត្រីនោះចេះតែទទូចអង្វរ បានជាទ្រង់
ក៏ស្ដាប់តាម រួចក្រោកពីដីឡើងទៅគង់នៅលើគ្រែ ២៤ស្រី
នោះមានកូនគោ១យ៉ាងធាត់[អ] នៅក្នុងផ្ទះ គាត់ក៏ប្រញឹក
ប្រញាប់នឹងសំឡាប់គោនោះ ហើយយកម្សៅមក ច្របាច់
ដុតធ្វើជានំបុ័ងឥតដំបែ ២៥រួចលើកយកមកដាក់នៅចំពោះ
សូល និងពួកបំរើរបស់ទ្រង់ គេក៏បរិភោគគ្រប់គ្នា រួចគេ
ក្រោកឡើងចេញទៅ ទាំងយប់នោះវិញ ។

## ស្ដេចអ័គីសនាំលោកដាវីឌទៅ

២៩ ១រីឯពួកភីលីស្ទីន គេប្រមូល[ក]ពួកពលទាំងអស់មក
នៅត្រង់អាផែក[ខ] ហើយពួកអ៊ីស្រាអែល គេបោះទ័ពនៅ
ត្រង់រន្ធទឹកយេសរាល[គ] ២ឯពួកមេនៃសាសន៍ភីលីស្ទីន ក៏
នាំពលទ័ពគេទាំងរយទាំងពាន់ទៅខាងមុខ ហើយដាវីឌ
និងពួកលោកក៏នាំគ្នាដើរតាមក្រោយ[ឃ]ទៅជាមួយនឹងអ័គីស
៣នោះពួកមេនៃសាសន៍ភីលីស្ទីនសួរថា ពួកសាសន៍ហេ-
ព្រើរទាំងនេះមកធ្វើអី រួចអ័គីសឆ្លើយតបថា នេះតើមិន
មែនដាវីឌ[ង] ជាអ្នកបំរើរបស់សូល ស្ដេចសាសន៍
អ៊ីស្រាអែល ដែលបាននៅជាមួយនឹងខ្ញុំ ជាយូរថ្ងៃ យូរឆ្នាំ[ច]
មកហើយទេឬអី ហើយខ្ញុំមិនឃើញជាមានទោសអ្វីនៅ
ក្នុងគាត់ចាប់តាំងពីវេលា ដែលគាត់មក ដរាបដល់ថ្ងៃនេះ
៤តែពួកមេភីលីស្ទីន គេខឹងនឹងទ្រង់ រួចទូលថា ចូរឱ្យ[ឆ]

**២៨:១៥** ព ពច ១៦:២០ ភ ១សយ ១៤:៣៧ ម ចទ ១៣:៣
**២៨:១៧** យ ១សយ ១៥:២៨
**២៨:១៨** រ ១សយ ១៥:២០ ល លប ១៤:៧ ១សយ ១៤:៤៨ វ ចទ ៩:៨ ១សយ ១៥:៣
**២៨:១៩** ស ១សយ ៣១:២ ១រប ៨:៣៣
**២៨:២១** ហ ពច ៩:១៧ ១២:៣
**២៨:២៣** ឡ ១ពវ ២១:៤
**២៨:២៤** អ លប ១៨:៧
**២៩:១** ក ១សយ ២៨:១ ខ ១សយ ៤:១ គ យស ១៧:១៦ ១ពវ ១៨:៤៥ ២១:១,២៣ ២ពវ ៩:៣០ យរ ៥០:៥ ហស ១:៤,៥,១១ ២:២២
**២៩:២** ឃ ១សយ ២៨:២
**២៩:៣** ង ១រប ១២:១៩ ច ១សយ ២៧:៧
**២៩:៤** ឆ ១រប ១២:១៩

**២៨:១៧** *ដករាជ្យពីព្រះហស្តទ្រង់ចេញ . . . ដាវីឌ* មើល ១៥:២៨ និងការពន្យល់ ។ នៅក្នុងកង្វល់ព្រួយនេះ ស្ដេចសូលបានទាញសំលៀកបំពាក់របស់ហោរាសាំយូអែលឱ្យរហែកជានិមិត្តរូបមួយបញ្ជាក់ថា ព្រះអម្ចាស់ទ្រង់នឹងដករាជ្យពីស្ដេចសូលចេញ (មើល ១៥:២៧–២៨) ។ លោកដាវីឌបានកាត់ជាយព្រះពស្ត្ររបស់ស្ដេចសូល ជានិមិត្តរូបនៃការដករាជ្យចេញ (សូមមើល ២៤:៤ និងការពន្យល់) ។

**២៨:១៨** សូមមើល ១៥:១៧–២៦ ។

**២៨:១៩** *ស្អែកនេះ ទ្រង់ ព្រមទាំងពួកបុត្រាទ្រង់ នឹងបាននៅជានឹងមួយទូលបង្គំហើយ* នៅក្នុងឋានឃុំព្រលឹងមនុស្សស្លាប់ សេចក្ដីហិនវិនាសរបស់ស្ដេចសូលត្រូវបានទាយទុកជាមុន (សូមមើល ៣១:៦) ។

**២៨:២១** *ស្ត្រីនោះក៏មកឯសូល* នៅក្នុងឃ្លានេះបង្ហាញថា ស្ត្រីនោះបានឃ្លាតចេញពីសូលក្នុងកំឡុងពេលដែលនាងបានទាយ និងខាបព្រលឹងសាំយូអែលមកនោះ ។

**២៩:១** *រីឯពួកភីលីស្ទីន គេប្រមូលពួកពលទាំងអស់* បន្តពីវគ្គថា ពីការបែកបាក់គ្នានៅក្នុង ២៨:២ ។ *អាផែក* ជាទីកន្លែងមួយស្ថិតនៅក្នុងបរិវេណសីគែម (សូមមើល ២៨:៤) ។ មានទីកន្លែងដែលឈ្មោះមួយទៀត ដែលមានឈ្មោះដូចគ្នាត្រូវបាននិយាយនៅក្នុង ៤:១ (សូមមើលការពន្យល់នៅទីនេះ ១ពវ ២០:២៦,៣០ ២ពវ ១៣:១៧) ។

**២៩:២** *ពួកមេនៃសាសន៍ភីលីស្ទីន* សូមមើលការពន្យល់ ៥:៨ ។

**២៩:៣** *ខ្ញុំមិនឃើញមានទោសអ្វីនៅក្នុងគាត់* ល្បិចយុទ្ធសាស្ត្ររបស់លោកដាវីឌបានពិពណ៌នាប្រាប់តាំងពីក្នុង ២៧:១០–១២ នោះឥឡូវនេះបានទទួលជ័យជម្នះយ៉ាងធំ ។

**២៩:៤** *កន្លែងដែលទ្រង់បានដំរូវឱ្យនៅនោះ* កន្លែងនោះគឺជាក្រុងសិកឡាក់ (សូមមើល ២៧:៦) ។ *ក្រែងលោកំពុងតែច្បាំង នោះវាត្រឡប់ជាទាស់នឹង*

មនុស្សនេះទៅវិញទៅ ដើម្បីឱ្យត្រឡប់ទៅឯកន្លែងដែល
ទ្រង់បានដំរូវឱ្យនៅនោះ កុំឱ្យចុះទៅឯចំបាំងជាមួយនឹង
យើងឡើយ ក្រែងលោកំពុងតែច្បាំង នោះវាត្រឡប់[ជ]ជា
ទាស់នឹងយើងវិញ ដ្បិតវានឹងបានជាមេត្រីនឹងចៅហ្វាយ
វាយ៉ាងណាបាន បើមិនមែនដោយសារយកក្បាលនៃ
មនុស្សទាំងនេះទេ ⁵តើនេះមិនមែនដាវីឌទេឬអី ជាអ្នក
ដែលគេបានច្រៀងឆ្លើយគ្នាពីដំណើរវា ក្នុងរបាំគេថា
សូលបានសំឡាប់ទាំងពាន់ តែដាវីឌទាំងម៉ឺន[ឈ] ។
៦នោះអ័គីស ទ្រង់ហៅដាវីឌមកមានបន្ទូលថា ខ្ញុំស្បថ
ដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅថា អ្នកជា
មនុស្សស្មោះត្រង់ ហើយដែលអ្នកចេញចូលក្នុងពលទ័ព
ជាមួយនឹងខ្ញុំ នោះក៏ជាទីពេញចិត្តខ្ញុំណាស់ ដោយខ្ញុំមិន
ឃើញជាមានទោសអ្វីនៅក្នុងអ្នកឡើយ ចាប់តាំងពីវេលា[ញ]
ដែលអ្នកមកឯខ្ញុំដរាបដល់ថ្ងៃនេះ ប៉ុន្តែពួកមេ[ដ]របស់យើង
គេមិនចូលចិត្តនឹងអ្នកទេ ៧ដូច្នេះ សូមអ្នកត្រឡប់វិលទៅវិញ
ដោយសុខសាន្តចុះ ក្រែងនាំឱ្យបង្អាក់ដល់ចិត្តនៃពួកមេ
សាសន៍ភីលីស្ទីនទាំងប៉ុន្មាន ។
៨នោះដាវីឌទូលសួរអ័គីសថា តើទូលបង្គំបានធ្វើខុស
អ្វីខ្លះ ចាប់តាំងពីទូលបង្គំមកនៅចំពោះទ្រង់ ដរាបដល់ថ្ងៃ
នេះ នោះតើទ្រង់បានឃើញទូលបង្គំមានទោសយ៉ាងណា
បានជាមិនឱ្យទូលបង្គំ ទៅច្បាំងនឹងពួកខ្មាំងសត្រូវរបស់
ស្តេច ជាចៅហ្វាយនៃទូលបង្គំដូច្នេះ ៩អ័គីសទ្រង់ឆ្លើយថា ខ្ញុំ
ដឹងហើយថា អ្នកជាមនុស្សល្អនៅចំពោះខ្ញុំប្រៀបដូចជា
ទេវតា[ឋ]នៃព្រះផង ប៉ុន្តែពួកមេ[ឌ]ភីលីស្ទីនគេបានសំរេចថា
មិនត្រូវឱ្យអ្នកឡើងទៅឯចំបាំងជាមួយនឹងយើងឡើយ

**២៩:៤** ជ ១សយ ១៤:២១
**២៩:៥** ឈ ១សយ ១៨:៧
**២៩:៦** ញ ១សយ ២៧:៨–១២ ដ ខ.៣
**២៩:៩** ឋ ២សយ ១៤:១៧,២០ ១៩:២៧ ឌ ខ.៤
**២៩:១០** ឍ ១រប ១២:១៩
**៣០:១** ក ១សយ ២៧:៦ ខ ១សយ ២៧:៨ គ ខ.១៤
**៣០:៣** ឃ លប ៣១:២៦
**៣០:៤** ង លប ៣១:២៦
**៣០:៥** ច ១សយ ២៥:៤៣
**៣០:៦** ឆ នក ១៧:៤ យហ ៨:៥៩ ជ នរ ១:១៣ ឈ ១សយ ២៣:១៦ រម ៤:២០

១០ហេតុនោះចូរឱ្យអ្នកក្រោកឡើងពីព្រលឹម ព្រមទាំងពួក
បំរើរបស់ចៅហ្វាយអ្នករាល់ដែលមកជាមួយគ្នា លុះបាន
ក្រោកឡើងពីព្រលឹមស្រាងដូច្នេះ ហើយមានពន្លឺល្មមនោះ
សូមចេញទៅ[ឍ]ចុះ ១១ដូច្នេះ ដាវីឌនិងពួកលោកក៏ក្រោក
ឡើងពីព្រលឹម ដើម្បីកាលណាភ្លឺស្រាងឡើង នោះឱ្យបាន
វិលត្រឡប់ទៅឯស្រុកភីលីស្ទីនវិញ តែឯពួកភីលីស្ទីនគេក៏នាំ
គ្នាឡើងទៅឯយេសរាលទៅ ។

### លោកដាវីឌវាយពួកអាម៉ាលេក

**៣០** ១លុះដល់ថ្ងៃទី៣ កាលដាវីឌ និងពួកលោកបានមក
ដល់ស៊ីកឡាក់[ក]នោះឃើញថា ពួកអាម៉ាលេក[ខ]បានលុកចូល
ស្រុកត្បូង ព្រមទាំងក្រុងស៊ីកឡាក់ផង គេបានទាំងវាយ
ក្រុងស៊ីកឡាក់ ហើយដុត[គ]ដោយភ្លើងទៅ ២ក៏ចាប់យកពួក
ស្រីៗទាំងតូចទាំងធំ ដែលនៅទីនោះ នាំទៅជាឈ្លើយ ឥត
មានសំឡាប់អ្នកណាឡើយ គ្រាន់តែដឹកនាំទៅប៉ុណ្ណោះ
៣ដូច្នេះ កាលដាវីឌនិងពួកលោកបានមកដល់ នោះក៏
ឃើញទីលំនៅបានឆេះអស់ហើយ ឯប្រពន្ធនិងកូនប្រុសកូន
ស្រី ក៏ត្រូវគេចាប់យកទៅជាឈ្លើយទាំងអស់ផង[ឃ] ៤នោះ
ដាវីឌនិងពួកមនុស្សដែលនៅជាមួយ ក៏ឡើងសំឡេងយំ[ង]
ជាខ្លាំង ដរាបដល់គ្មានកំឡាំងនឹងយំទៀត ៥ឯប្រពន្ធដាវីឌ
ទាំង២[ច] គឺអ័ហ៊ីណោម ជាអ្នកស្រុកយេសរាល និងអ័ប៊ីកែល
ជាប្រពន្ធរបស់ខ្មោចណាបាលដែលជាអ្នកស្រុកកើមែល
នោះគេក៏បាននាំទៅជាឈ្លើយដែរ ៦ចំណែកដាវីឌលោក
ច្របល់ក្នុងចិត្តជាខ្លាំង ដ្បិតបណ្តាពួកលោកគិតចោលនឹង
ថ្ម[ឆ] ពីព្រោះគ្រប់គ្នាមានសេចក្តីទំនាស់ចិត្តជាខ្លាំង[ជ] ដោយ
ព្រោះកូនប្រុសកូនស្រីរបស់គេ តែដាវីឌបានកំឡាចិត្ត[ឈ]ខ្លួន

*យើងវិញ* ពួកមេសាសន៍ភីលីស្ទីនគេមានបទពិសោធម្តងទៅហើយកាលពីគ្រាមុន (សូមមើល ១៤:២១) ។ *យកក្បាល* ការកាត់យកក្បាលបែបនេះ គឺដើម្បីទុកជាជ័យភ័ណ្ឌនៃជ័យជម្នះ (សូមមើល ១៧:៥១ ៥:៤ ៣១:៩) ។

**២៩:៥** សូមមើល ២១:១១ និងការពន្យល់ ១៨:៧ ។

**២៩:៦** *ស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ* សូមមើលការពន្យល់ ១៤:៣៩,៤៥ ។ ស្តេចអ័គីសបានស្បថដោយនូវព្រះនាមរបស់ព្រះនៃពួកសាសន៍អ៊ីស្រាអែល ដែលមើលទៅដូចជាមានន័យថា ទ្រង់ព្រមប្រគល់ភាពស្មោះត្រង់របស់ទ្រង់ទៅចំពោះលោកដាវីឌ ។

**២៩:៨** *តើទូលបង្គំបានធ្វើខុសអ្វី* លោកដាវីឌគាត់ធ្វើពុតជាមានការខកចិត្ត ដើម្បីកុំឱ្យខូចគម្រោងការណ៍បោកបញ្ឆោតរបស់គាត់ ។ នៅក្នុងស្ថានភាពជាក់ស្តែង ហេតុការណ៏នេះបានបង្វែលោកដាវីឌពីគ្រោះដ៏កំណាច ។ *បានជាមិនឱ្យទូលបង្គំ . . . ជាចៅហ្វាយនៃទូលបង្គំដូច្នេះ* លោកដាវីឌបានប្រើប្រាស់ពាក្យសម្តីមិនច្បាស់លាស់ម្តងទៀតហើយ (សូមមើល ២៨:២) ។ ចំពោះអ្នកដែលគាត់និយាយថា "ចៅហ្វាយនៃទូលបង្គំ" មិនដឹងថាតើជាស្តេចអ័គីស ជាស្តេចសូល ឬមួយជាព្រះអម្ចាស់នោះឡើយ ។

**២៩:៩** *ប្រៀបដូចជាទេវតានៃព្រះ* គឺជាពាក្យទំហៀបន័យជាសាមញ្ញមួយ (សូមមើល ២សយ ១៤:១៧ និងការពន្យល់) ។

**២៩:១១** *យេសរាល* ជាជំរុំរបស់ពួកអ៊ីស្រាអែល (២:១) ។

**៣០:១–៣១:១៣** នៅក្នុងខណៈដែលស្តេចសូលមករកសេចក្តីស្លាប់ក្រោមកណ្តាប់ដៃពួកភីលីស្ទីន លោកដាវីឌបែរជាបន្តការធ្វើសង្គ្រាមរបស់ព្រះជាមួយពួកសាសន៍អាម៉ាលេក(សូមមើល ១៥:២–៣ និងការពន្យល់) ។

**៣០:១** *ស៊ីឡាក់* សូមមើល ២៧:៦ ។ *ពួកអាម៉ាលេក* មើល ២៧:៨ និងមើលការពន្យល់ ១៥:២ ។ ការធ្វេសប្រហែសរបស់លោកដាវីឌ និងពួកលោកបានធ្វើឱ្យពួកអាម៉ាលេកមានឱកាសនឹងសងសឹក ។ *ស្រុកត្បូង* សូមមើលការពន្យល់ ២៧:១០ ។

**៣០:៥** *អ័ហ៊ីណោម* សូមមើលការពន្យល់ ២៥:៤៣ ។ *អ័ប៊ីកែល* សូមមើល ២៥:៤២។

**៣០:៦** *ដាវីឌបានកំឡាចិត្តខ្លួនឡើង ដោយនូវព្រះយេហូវ៉ា* ជានិច្ចកាលគាត់

ឡើង ដោយនូវព្រះយេហូវ៉ា ជាព្រះនៃលោកវិញ ។
៧គ្រានោះ ដាវីឌនិយាយទៅអ័បៀថើរ[ញ]ដ៏ជាសង្ឃ ជាកូន
អហ៊ីម៉ាលេកថា សូមយកអេផូឌ[ដ]មកឱ្យខ្ញុំឯណេះ នោះ
អ័បៀថើរក៏យកអេផូឌមក ៨រួចដាវីឌទូលសួរ[ឋ]ដល់ព្រះ
យេហូវ៉ាថា តើត្រូវឱ្យទូលបង្គំដេញតាមពួកនោះឬអី តើនឹង
បានទាន់គេឬទេ ទ្រង់មានបន្ទូលឆ្លើយថា ចូរដេញតាមចុះ
ដ្បិតនឹងបានទាន់គេជាពិតប្រាកដ ហើយនិងចាប់បាន[ឌ]មក
វិញទាំងអស់[ឍ]ជាមិនខានផង ៩ដូច្នេះ ដាវីឌព្រមទាំងពួក
៦០០នាក់[ណ]ដែលនៅជាមួយក៏លើកគ្នាចេញទៅ កាលទៅ
ដល់ជ្រោះបេសោរហើយ នោះក៏ទុកអ្នកខ្លះឱ្យនៅទីនោះ
១០ដ្បិតមាន២០០នាក់ឈប់នៅ ដោយគេល្វើយ[ត] និងឆ្លង
ជ្រោះបេសោរទៅមិនបាន តែឯដាវីឌនិង៤០០នាក់ឯទៀត
ចេះតែខំដេញតាមទៅទៀត ។
១១រីឯនៅវាល គេប្រទះឃើញសាសន៍អេស៊ីព្ទម្នាក់
ហើយក៏នាំវាមកឯដាវីឌ រួចឱ្យនំបុ័ងនិងទឹកបរិភោគ ១២ក៏ឱ្យ
ផ្លែល្វាក្រៀម១ផែន ហើយនិងផ្លែទំពាំងបាយជូរក្រៀម
២ចង្កោមដែរ កាលវាបានបរិភោគហើយ នោះក៏មាន
កំឡាំងឡើង[ថ] ពីព្រោះមិនបានបរិភោគ ទោះអាហារឬទឹក
អស់៣ថ្ងៃ៣យប់មកហើយ ១៣ដាវីឌសួរវាថា ឯងជាបាវ
របស់អ្នកណា ហើយមកពីណា វាឆ្លើយតបថា ខ្ញុំជាសាសន៍
អេស៊ីព្ទជាអ្នកបំរើរបស់សាសន៍អាម៉ាលេក[ទ]ម្នាក់ ចៅហ្វាយ
ខ្ញុំបានលះចោលខ្ញុំ៣ថ្ងៃមកហើយ ពីព្រោះខ្ញុំឈឺ ១៤យើងខ្ញុំ
បានលុកចូលស្រុកត្បូងរបស់ពួកកេរេធីម[ធ] និងស្រុករបស់
ពួកយូដា ហើយនិងស្រុកត្បូង ជាស្រុករបស់កាលែប[ន] ក៏
ដុត[ប]ក្រុងស៊ីកឡាក់ដោយភ្លើង ១៥នោះដាវីឌសួរថា ឯងចូល
ចិត្តនឹងនាំយើងចុះទៅឯពួកនោះឬទេ វាឆ្លើយថា សូមស្បថ
នឹងខ្ញុំដោយនូវព្រះចុះ ថាលោកមិនសំឡាប់ខ្ញុំឡើយ ក៏មិន
ប្រគល់ខ្ញុំទៅឱ្យចៅហ្វាយខ្ញុំវិញដែរ[ផ] នោះខ្ញុំនឹងនាំលោក
ចុះទៅឱ្យដល់គេ ។
១៦កាលវាបាននាំចុះទៅដល់ហើយ នោះឃើញគេនៅ
ពាសពេញលើដីកំពុងតែស៊ីផឹក ហើយលោតកព្លេង[ព] ដោយ
ព្រោះរបឹប[ភ]ជាច្រើន ដែលគេចាប់បាន នាំយកមកពីស្រុក
ភីលីស្ទីន និងស្រុកយូដានោះ ១៧ដាវីឌក៏ប្រហារ[ម]គេចាប់
តាំងពីពេលព្រលប់នោះ រហូតដល់ល្ងាចថ្ងៃក្រោយ ឥត
មានអ្នកណារត់រួចឡើយ លើកតែពួកកំឡោះ៤០០នាក់
ដែលជិះសត្វអូដ្ឋរត់ទៅប៉ុណ្ណោះ[យ] ១៨ដូច្នេះ ដាវីឌចាប់យក
បានរបស់ទាំងអស់[រ] ដែលសាសន៍អាម៉ាលេកបានប្លន់យក
ទៅនោះ ក៏បានប្រពន្ធទាំង២មកវិញដែរ ១៩ឯរបស់ទាំង
ប៉ុន្មានដែលគេប្លន់យកទៅនោះ គ្មានខ្វះអ្វីសោះ ទោះតូចឬ
ធំ កូនប្រុស កូនស្រី ឬរបឹបណាក្តី ដាវីឌបាននាំយកទាំងអស់
មកវិញ ២០លោកក៏ចាប់យកហ្វូងចៀម និងហ្វូងគោដែរ
ហើយពួកអ្នកគង្វាលដែលដេញសត្វទាំងនោះនៅមុខគេ
ក៏និយាយថា នេះជារបឹបនៃដាវីឌ ។
២១រួចដាវីឌត្រឡប់មកដល់ពួក២០០នាក់ ដែលឥតមាន
កំឡាំង[ល]នឹងតាមទៅ គឺជាពួកអ្នកដែលគេបានទុកនៅត្រង់
ជ្រោះបេសោរនោះ អ្នកទាំងនោះក៏ចេញទៅទទួលដាវីឌ
នឹងពួកអ្នកដែលទៅជាមួយ កាលដាវីឌចូលមកជិត នោះ
ក៏សួរគេពីសេចក្តីសុខទុក្ខ ២២ឯបណ្តាមនុស្ស កំណាច និង
មនុស្សចោលម្សៀត ក្នុងពួកអ្នកដែលបានទៅជាមួយនឹង
ដាវីឌ គេនិយាយឡើងថា យើងមិនព្រមចែករបឹបដែល
យើងបានចាប់យកមកវិញ ឱ្យដល់អ្នកទាំងនេះទេ លើកតែ
ប្រពន្ធកូនគេប៉ុណ្ណោះ នោះឱ្យគេនាំទៅចុះ ពីព្រោះគេមិន
បានទៅជាមួយនឹងយើងសោះ ២៣តែដាវីឌប្រកែកថា បង
ប្អូនអើយ កុំឱ្យធ្វើដូច្នេះចំពោះរបស់ដែលព្រះយេហូវ៉ា
បានប្រទានមកយើងឡើយ ដ្បិតទ្រង់បានការពារយើង
ហើយប្រគល់ពួកអ្នកដែលបានញាំញីយើង មកក្នុងកណ្តាប់
ដៃយើងហើយ ២៤តើអ្នកណានឹងស្តាប់តាមអ្នករាល់គ្នាក្នុង
ដំណើរនេះ ដ្បិតអ្នកដែលចុះទៅច្បាំងបានចំណែកប៉ុណ្ណា
នោះអ្នកដែលនៅចាំអីវ៉ាន់ ក៏ត្រូវបានចំណែកប៉ុណ្ណោះដែរ
គឺត្រូវចែកឱ្យស្មើៗគ្នា[វ] ២៥នោះក៏បានដូច្នោះ ចាប់តាំងពីថ្ងៃ
នោះតទៅ ដាវីឌក៏តាំងសេចក្តីនោះឡើង ទុកជាច្បាប់ជា
បញ្ញត្តិសំរាប់សាសន៍អ៊ីស្រាអែលដរាបដល់សព្វថ្ងៃនេះ ។

**៣០:៧** ញ ១សយ ២២:២០ ដ ១សយ ២:២៨
**៣០:៨** ឋ ១សយ ២៣:២ ឌ នក ២:១៧ ឍ លប ១៤:១៦
**៣០:៩** ណ ១សយ ២៧:២
**៣០:១០** ត ខ.២១
**៣០:១២** ថ ពច ១៥:១៩
**៣០:១៣** ទ ១សយ ១៤:៤៨
**៣០:១៤** ធ ២សយ ៨:១៨ ១៥:១៨ ២០:៧,២៣ ១ពវ ១:៣៨,៤៤ ១រប ១៨:១៧ អក ២៥:១៦ សផ ២:៥ ន យស ១៤:១៣ ១៥:១៣ ប ខ.១
**៣០:១៥** ផ ចទ ២៣:១៥
**៣០:១៦** ព លក ១២:១៩ ភ ខ.១៧ យស ២២:៨
**៣០:១៧** ម ខ.១៦ ១សយ ១១:១១ ២សយ ១:១
**៣០:១៧** យ ២សយ ១:៨
**៣០:១៨** រ លប ១៤:១៦
**៣០:២១** ល ខ.១០
**៣០:២៤** វ ជន ៣១:២៧ ពច ៥:៣០

តែងតែកំសាន្តចិត្តខ្លួនឯងដោយព្រះអម្ចាស់(មើលការពន្យល់ ១៧:៣៧) ។

**៣០:៧** *អ័បៀថើរដ៏ជាសង្ឃ* មើលការពន្យល់ ២២:២០ ។ *អេផូឌ* មើលការពន្យល់ ២:២៨ ។

**៣០:១៤** *ស្រុកត្បូង* មើលការពន្យល់ ២៧:១០ ។ *ពួកកេរេធីម* ពេលក្រោយមកទៀតពួកកេរេធីម និងពួកពេលេធីម ក្លាយជាថ្នឹកក្នុងចំបាំងពលទ័ពផ្ទាល់ខ្លួនរបស់លោកដាវីឌ (មើល ២សយ ៨:១៧ និងការពន្យល់, និងមើល ១៥:១៨ ២០:៧ ១ពវ ១:៣៨) ។ យោងទៅតាមឈ្មោះរបស់គេ នោះប្រហែលជាគេមានដើមកំណើតនៅលើកោះក្រេត (មើល យរ ៤៧:៤ និងការពន្យល់) ។ *ស្រុកត្បូងរបស់ពួកកេរីធីម* នៅខាងត្បូងហេប្រុន (សូមមើល យស ១៤:១៣) ។

**៣០:២២** *មនុស្សចោលម្សៀត* សូមមើលការពន្យល់ ចទ ១៣:១៣ ។

**៣០:២៣** *របស់ដែលព្រះយេហូវ៉ាបានប្រទានមកយើង* មើល ២៥:២៨ និងការពន្យល់ ។ លោកដាវីឌបានបដិសេធចំពោះគំនិតដែលថា ជ័យជម្នះរបស់ពួកគេ គឺកើតឡើងដោយអំណាចរបស់គេផ្ទាល់ ពីព្រោះព្រះអម្ចាស់ទ្រង់បានប្រទានឱ្យគេទទួលបានជ័យជម្នះ ។

**៣០:២៤** *ចែកឱ្យស្មើៗគ្នា* ធៀបជាមួយ នក ១៦:១៨ និងការពន្យល់ ។

២៦ លុះកាលដាវីឌបានត្រឡប់មកដល់ស៊ីកឡាក់វិញហើយ នោះក៏ផ្ញើរបឹបខ្លះទៅជូនដល់ពួកចាស់ទុំ នៅស្រុកយូដា ដែលជាមិត្រសំឡាញ់របស់លោក ដោយពាក្យថា នេះជាចំណែករបឹប[ស] ដែលចាប់ពីពួកខ្មាំងសត្រូវនៃព្រះយេហូវ៉ា ខ្ញុំផ្ញើមកជូនដល់លោករាល់គ្នា ២៧ គឺផ្ញើទៅដល់ពួកចាស់ទុំនៅបេត-អែល[ហ] រ៉ាម៉ូត[ឡ]ខាងត្បូង និងយ៉ាទារ[អ] ២៨ នៅអារ៉ូអើរ[ក] ស៊ីផម៉ូត[ខ] អែលធេម៉ូរ[គ] ២៩ រ៉ាកាល និងដល់ពួកដែលនៅអស់ទាំងទីក្រុងរបស់ពួកយេរ៉ាម្អែល[ឃ] ហើយនិងពួកដែលនៅអស់ទាំងទីក្រុងនៃពួកកែន[ង] ៣០ ពួកនៅហោម៉ា[ច] កោរ-អាសាន[ឆ] អាថាក ៣១ ហេប្រុន[ជ]ហើយនៅគ្រប់កន្លែងដែលដាវីឌ និងពួកលោកធ្លាប់ដើរទៅមកផង ។

## ស្តេចសូលធ្វើអត្តឃាត

*៣១:១-១៣ – ២សយ ១:៤-១២ ១រប ១០:១-១២*

**៣១** ១ រីឯពួកភីលីស្ទីន គេចូលតនឹងពួកអ៊ីស្រាអែល ពួកអ៊ីស្រាអែលក៏រត់ពីមុខពួកភីលីស្ទីនទៅ ហើយត្រូវគេសំឡាប់នៅលើភ្នំគីលបោ[ក] ២ ពួកភីលីស្ទីនដេញតាមសូល និងពួកបុត្រាទ្រង់យ៉ាងប្រកិត គេបានសំឡាប់យ៉ូណាថាន[គ] អ័ប៊ីណាដាប់ ហើយនិងម៉ាលគី-ស៊ូអា[ឃ] ជាបុត្រាសូលទៅ ៣ ចំបាំងនោះក៏ប្រែជាលំបាកណាស់ដល់សូល ពួកពលធ្នូក៏តាមទ្រង់ទាន់ ហើយទ្រង់មានព្រះទ័យតក់ស្លុត[ង]ជាខ្លាំង ៤ ទើបទ្រង់មានបន្ទូលទៅអ្នកដែលកាន់គ្រឿងទ្រង់ថា ចូរហូតដាវឯងមកចាក់ទំលុះអញទៅ[ច] ក្រែងពួកមិនកាត់ស្បែកនេះ[ឆ] គេមកកាប់ចាក់ ហើយមើលងាយដល់អញ តែអ្នកកាន់គ្រឿងរបស់ទ្រង់មិនហ៊ានទេ ដោយគាត់មានសេចក្តីភ័យជាខ្លាំង ដូច្នេះសូលទ្រង់ក៏ហូតយកដាវរបស់ទ្រង់ផ្តួលខ្លួនទៅលើ ៥ កាលអ្នកកាន់គ្រឿងរបស់ទ្រង់បានឃើញថា សូលបានសុគតហើយ នោះគាត់ក៏ផ្តួលខ្លួនទៅលើដាវស្លាប់ទៅជាមួយដែរ ៦ ដូច្នេះ សូលព្រមទាំងបុត្រាទ្រង់៣អង្គ និងអ្នកកាន់គ្រឿងរបស់ទ្រង់ ហើយនិងពួកពលទាំងប៉ុន្មានបានស្លាប់[ជ] ទាំងអស់គ្នានៅថ្ងៃនោះឯង ។

៧ កាលពួកសាសន៍អ៊ីស្រាអែល ដែលនៅច្រកភ្នំនោះម្ខាង និងពួកដែលនៅត្រើយខាងនាយទន្លេយ័រដាន់ បានឃើញថា ពួកទ័ពនៃសាសន៍អ៊ីស្រាអែលបានរត់ ហើយសូលនិងពួកបុត្រាទ្រង់បានសុគតអស់ហើយ នោះគេក៏រត់ចោលអស់ទាំងទីក្រុងទៅ ឯពួកភីលីស្ទីន ក៏មកតាំងទីលំនៅក្នុងទីក្រុងទាំងនោះ ៨ ដល់ថ្ងៃស្អែក កាលពួកភីលីស្ទីន[ឈ]បានចូលទៅ ដោះយករបស់ពីខ្មោចទាំងប៉ុន្មាន នោះគេប្រទះឃើញសពសូល និងបុត្រាទ្រង់ទាំង៣អង្គនៅលើភ្នំគីលបោ ៩ ដូច្នេះ គេក៏កាត់យកព្រះសិរទ្រង់ ព្រមទាំងដោះគ្រឿងសស្ត្រាវុធរបស់ទ្រង់ ផ្ញើទៅគ្រប់ក្នុងស្រុកភីលីស្ទីន ដើម្បីនឹងផ្សាយដំណឹងនោះ[ញ] ដល់អស់ទាំងវិហាររបស់ពួកព្រះនៃគេ ហើយដល់បណ្តាជនផង[ដ] ១០ គេដំកល់ទុកគ្រឿងសស្ត្រាវុធនោះ នៅក្នុងវិហារនៃរូបព្រះ[ឋ] ឯសពទ្រង់គេបោះភ្ជាប់នឹងកំផែងទីក្រុងបេត-សាន[ឌ] ១១ តែកាលពួកអ្នកនៅក្រុងយ៉ាបេស ក្នុងស្រុកកាឡាត[ឍ] បានឮនិយាយ ពីការ

**៣០:២៦** ស លប ៣៣:១១
**៣០:២៧** ហ យស ៧:២ ឡ យស ១០:៤០ អ យស ១៥:៤៨
**៣០:២៨** ក ជន ៣២:៣៤ យស ១៣:១៦ ខ ១រប ២៧:២៧ គ យស ១៥:៥០
**៣០:២៩** ឃ ១រប ២៧:១០ ង ១សយ ១៥:៦
**៣០:៣០** ច ជន ១៤:៤៥ ២១:៣ ឆ យស ១៥:៤២
**៣០:៣១** ជ ជន ១៣:២២ យស ១០:៣៦ ២សយ ២:១,៤
**៣១:១** ក ១សយ ២៨:៤
**៣១:២** ខ ១សយ ២៨:១៩ គ ១សយ ១៨:១ ឃ ១សយ ១៤:៤៩
**៣១:៣** ង ១សយ ២៨:៤
**៣១:៤** ច ពច ៩:៥៤ ឆ លប ៣៤:១៤
**៣១:៦** ជ ១សយ ២៦:១០ **៣១:៨** ឈ ២សយ ១:២០ **៣១:៩** ញ ២សយ ១:២០ ៤:៤ ដ ពច ១៦:២៤ **៣១:១០** ឋ ពច ២:១២-១៣ ១សយ ៧:៣ ឌ យស ១៧:១១ **៣១:១១** ឍ ពច ២១:៨ ១សយ ១១:១

**៣០:២៦** *ពួកចាស់ទុំនៅស្រុកយូដា ដែលជាមិត្រសំឡាញ់របស់លោក* លោកដាវីឌបានផ្ញើរបឹបទុកដូចជាការដឹងគុណ ចំពោះពួកអ្នកដែលបានតម្រូវដីឱ្យគាត់រស់នៅ ក្នុងអំឡុងពេលដែលគាត់រត់ចេញពីស្តេចសូល (មើល ខ.៣១) អ្នកទាំងនោះបានរៀបផ្លូវសម្រាប់គាត់ និងជិន្នូរវង្សគាត់ នៅក្នុងស្រុកយូដា (សូមមើល ២សយ ២:១-៤) ។

**៣០:២៩** *យេរ៉ាម្អែល* មើលការពន្យល់ ២៧:១០ ។ *ពួកកែន* សូមមើលការពន្យល់ ១៥:៦ ។

**៣០:៣១** *ហេប្រុន* គឺជាទីក្រុងដែលមានសារៈសំខាន់នៅក្នុងស្រុកយូដា ។

**៣១:១,៨** *ភ្នំគីលបោ* ជងភ្នំ (សូមមើល ២សយ ១:២១) ដែលស្ថិតនៅខាងត្បូងឆៀងខាងកើត រហូតដល់ទំនាបយេសរាល ហើយវាជាក្បាលជ្រោះដែលហូរទៅក្នុងបេត-សាន ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានតែនិយាយនៅក្នុងកន្លែងដែលស្តេចសូលសុគតប៉ុណ្ណោះ (សូមមើល ២សយ ១:៦,២១ ២១:១២) ។

**៣១:២** *យ៉ូណាថាន អ័ប៊ីណាដាប់ ហើយនិងម៉ាលគី-ស៊ូអា* សូមមើលការពន្យល់ ១៤:៤៩ ។ នៅពេលក្រោយអែស-បាល ឬអ៊ីសបូសែតជាបុត្រាដែលបានរួចជីវិត (១រប ៨:៣៣ ៩:៣៩) ត្រូវបានលោកអ័ប៊ីនើរ ជាមេទ័ពរបស់ស្តេចសូលតាំងឱ្យធ្វើជាស្តេច (សូមមើល ២សយ ២:៨-៩) ។

**៣១:៤** *ពួកមិនកាត់ស្បែកនេះ គេមកកាប់ចាក់* មើល ១៤:៦ និងការពន្យល់ ។ *មើលងាយដល់អញ* ទង្វើបែបនេះ គឺជារឿងមួយខុសប្លែកពីធម្មតា ។ កាលពីគ្រាមុនពួកភីលីស្ទីនបានកាត់យកអវៈយវៈ និងបន្ទាបបន្ថោកលោកសាំសុនបន្ទាប់ពីគ្រាដែលចាប់គាត់បាន (មើល ពច ១៦:២១-២៥) ។ *ហូតយកដាវរបស់ទ្រង់ផ្តួលខ្លួនទៅលើ* ជាវិធីបំផ្លាញខ្លួនដែលមានកំរិតខ្ពស់បំផុត ។

**៣១:៦** *ពួកពលទាំងប៉ុន្មាន* គឺជាពួកអ្នកដែលបម្រើទ្រង់ (មើលការពន្យល់ ខ.២) ។

**៣១:៩** *គេក៏កាត់យកព្រះសិរទ្រង់* លោកដាវីឌក៏បានធ្វើចំពោះកូលីយ៉ាតបែបដូច្នេះដែរ (សូមមើល ១៧:៥១) ។ *ដើម្បីនឹងផ្សាយដំណឹងនោះ ដល់អស់ទាំងវិហាររបស់ពួកព្រះនៃគេ* ប្រហែលជាការនាំយកសិររបស់ស្តេចសូល និងគ្រឿងសស្ត្រាវុធ គឺជាភស្តុតាង និងជាជ័យភ័ណ្ឌរបស់ពួកគេ (មើល ៥:៤ និងការពន្យល់) ។

**៣១:១០** *គេដំកល់ទុកគ្រឿងសស្ត្រាវុធនោះ នៅក្នុងព្រះវិហារនៃរូបព្រះ* ជានិមិត្តរូបដើម្បីបង្ហាញភស្តុតាងដល់រូបព្រះរបស់ពួកភីលីស្ទីន ។ *រូបព្រះ* សូមមើលការពន្យល់ ៧:៣ ។ *បេត-សាន* មើលការពន្យល់ យស ១៧:១១ ។

ដែលពួកភីលីស្ទីនធ្វើ ដល់សពរបស់សូល
១២នោះពួកអ្នកក្លាហានទាំងប៉ុន្មានរបស់គេ[ណ] ក៏លើកគ្នាទៅទាំងយប់នាំយកសពរបស់សូល និងសពនៃពួកបុត្រាទ្រង់ ពីកំផែងបេត–សាន ត្រឡប់ទៅឯក្រុងយាបេសបូជាភ្លើង[ត]ទៅ
១៣រួចគេរើសអដ្ឋិ[ថ] យកទៅបញ្ចុះ នៅក្រោមដើមឈើ១[ទ] នៅក្រុងយ៉ាបេស ហើយនាំគ្នាតមអាហារ[ធ]កាន់ទុក្ខអស់៧ថ្ងៃ[ន]។/

**៣១:១២** ណ ទដ ៧៦:៥ ១សយ ១៤:៦
**៣១:១២** ត លប ៣៨:២៤ អម ៦:១០
**៣១:១៣** ថ ២សយ ២១:១២–១៤ ទ លប ២១:៣៣ ធ ២សយ ៣:៣៥ ១២:១៩–២៣ ន លប ៥០:១០

**៣១:១១** *ក្រុងយ៉ាបេស ក្នុងស្រុកកាឡាត* សូមមើលការពន្យល់ ១១:១ ។
**៣១:១២** *នាំយកសពរបស់សូល និងសពនៃពួកបុត្រាទ្រង់* ពួកមនុស្សនៅក្រុងយ៉ាបេស–កាឡាតមិនដែលភ្លេចពីអ្វីដែលសូលបានការពារពួកគេ ក្នុងអំឡុងពេលដែលពួកគេទទួលការគំរាមកំហែង និងឈ្លានពានពីសំណាក់ពួកសាសន៍អាំម៉ូន (មើល ១១:១–១១) ។ *បូជាភ្លើង* ការបូជាសព មិនមែនជាវប្បធម៌របស់ពួកអ៊ីស្រាអែលនាសម័យបុរាណនោះឡើយ ហើយដែលធ្វើនៅទីនេះដើម្បីបង្ការ និងទប់ស្កាត់ចំពោះការធ្វើទុក្ខចំពោះសាកសពរបស់ស្ដេចសូល និងបុត្រារបស់ទ្រង់នៅពេលក្រោយៗទៀត ពីសំណាក់នៃពួកភីលីស្ទីន ។
**៣១:១៣** *រើសអដ្ឋិ យកទៅបញ្ចុះ* ក្រោយមកលោកដាវីឌបានយកអដ្ឋិរបស់អ្នកទាំងនោះចេញពីយ៉ាបេស ហើយបញ្ចុះស្ដេចសូល និងបុត្រារបស់ទ្រង់នៅត្រង់សេឡាក្នុងស្រុកបេនយ៉ាមីន(សូមមើល ២សយ ២១:១១–១៤) ។ *កាន់ទុក្ខស់៧ថ្ងៃ* ទុកដូចជាការចូលរួមការសោកស្ដាយចំពោះសូល (ផ្ទៀបនឹង ២សយ ១:១២ ៣:៣៥ ១២:១៦,២១–២៣) ។

# សាំយូអែលទី២

## សេចក្តីផ្តើម

### ចំណងជើង

ព្រះគម្ពីរសាំយូអែលទី១ និងទី២ គឺជាកណ្ឌគម្ពីរ ដើមដំបូង (សូមមើលសេចក្តីផ្តើម សាំយូអែលទី១: ត្រង់ចំណងជើង)។

### ផ្នែកអក្សរសាស្ត្រ ភាពជាអ្នកនិពន្ធ និងកាលបរិច្ឆេទ

សូមមើលសេចក្តីផ្តើមក្នុងសាំយូអែលទី១: លក្ខណៈអក្សរសាស្ត្រ អ្នកនិពន្ធ និងកាលបរិច្ឆេទ ។

### គម្រោងអត្ថបទ និងផ្នែករឿង : ភាពជាព្រះមហាក្សត្រ និងសេចក្តីសញ្ញា

សាំយូអែលទី២ ពណ៌នាពីលោកដាវីឌដែលជាដំណាងពិត (ទោះបើមានភាពចន្លោះ) នៃព្រះមហាក្សត្រដែលមានសណ្ឋាននិស្ស័យជាមហាក្សត្រក៏ដោយ ក៏លោកដាវីឌត្រូវបានប្រកាសឱ្យគ្រងរាជ្យ នៅក្រុងហេប្រុនដោយអំបូរយូដា (ជំពូក ១–៤) ក៏ទទួលស្គាល់ដោយអំបូរដទៃទៀត បន្ទាប់ពីអ៊ីសបូសែបជាបុត្រាសូលដែលត្រូវបានគេសម្លាប់ (៥:១–៥) ។ ភាពជាថ្នាក់ដឹកនាំរបស់ស្តេចដាវីឌ គឺមានលក្ខណៈមិនរុញរា និងមានប្រសិទ្ធិភាពបំផុត ទ្រង់បានចាប់យកក្រុងយេរូសាឡិមពីសាសន៍ប៊ូស ដើម្បីរៀបចំឡើងជាទីក្រុងនៃរាជវង្ស និងសម្រាប់ជាដំណាក់ទ្រង់ផ្ទាល់ (៥:៦–១៣) មួយរយៈពេលបន្ទាប់មកទៀតទ្រង់ (ស្តេចដាវីឌ) បាននាំហិបសញ្ញានៃព្រះយេហូវ៉ាពីដំណាក់របស់អ័ប៊ីនាដាប់ ទៅកាន់ក្រុងយេរូសាឡិម ។ ជាការទទួលស្គាល់ជាសាធារណៈនូវភាពជាព្រះមហាក្សត្រនៃព្រះយេហូវ៉ា គឺជាច្បាប់ដឹកនាំអង្គទ្រង់ផ្ទាល់ និងដល់រាស្ត្រអ៊ីស្រាអែលទាំងមូល (ជំពូក ៦ ទដ ១៣២:៣–៥) ។

ក្រោមការដឹកនាំរបស់ស្តេចដាវីឌ ព្រះយេហូវ៉ាក៏បានបណ្តាលឱ្យប្រជាជាតិទាំងមូល បានទទួលភាពសុខសាន្ត និងអាចកំចាត់សត្រូវរបស់ផងទ្រង់ ក្នុងការសម្រេចតាមព្រះបន្ទូលសន្យារបស់ទ្រង់ (មើល លប ១៥:១៨) គឺដើម្បីពង្រីកនូវព្រំដីស្រុកអេស៊ីព្ទ រហូតទល់ទន្លេអឺប្រាត (ជំពូក ៨) ហើយស្តេចដាវីឌចង់សាងសង់វិហារមួយសម្រាប់ព្រះយេហូវ៉ា គឺដូចជាដំណាក់ស្តេចរបស់ទ្រង់ដែរ (ហិបសញ្ញា) ក៏ដូចជាទីកន្លែងសម្រាប់អ៊ីស្រាអែល ដើម្បីថ្វាយបង្គំទ្រង់ ។ តែហោរាណាថាន់ប្រាប់ទៅស្តេចដាវីឌថា ទ្រង់មិនត្រូវសង់ឬសាងវិហារសម្រាប់ព្រះយេហូវ៉ាទេ តែទ្រង់ដែលត្រូវសាងសង់រាជវង្សឱ្យស្តេចដាវីឌវិញ ។ ក្នុងជំពូកទី៧ គឺក្នុងចំណោមព្រះបន្ទូលសន្យារបស់ព្រះទាំងអស់ថា រាជវង្សដាវីឌនឹងនៅស្ថិតស្ថេរជានិច្ច ។ ដូចជានៅផ្នែកខ្លះបានបកស្រាយពីការរៀបចំឡើងនៅសេចក្តីសញ្ញានៃរាជវង្សដាវីឌ (មើលការពន្យល់នៅ ៧:១–២៩,១១,១៦ ទដ ៨៩:៣០–៣៧) ។ ក្រោយមកទៀតពួកហោរាក៏បានបញ្ជាក់ទៀតថា ពូជរបស់ស្តេចដាវីឌដែលកំពុងសោយរាជ្យនេះនឹងបំពេញមុខងារដ៏ល្អឥតខ្ចោះ នូវតួនាទីជាស្តេច ដែលព្រះយេហូវ៉ាបានត្រាស់ហៅ និងកត់ក្នុងប្រវត្តិសាស្ត្រ ។ ស្តេចអង្គនេះនឹងបានសង្គ្រោះដល់រាស្ត្ររបស់ព្រះទាំងអស់ (មើល អស ៩:៦–៧ ១១:១–១៦ យរ ២៣:៥–៦ ៣០:៨–៩ ៣៣:១៤–១៦ អគ ៣៤:២៣–២៤ ៣៧:២៤–២៥) គឺព្រះយេហូវ៉ាបានជួយសម្រេចឱ្យមានជ័យជម្នះលើគ្រប់ទាំងអស់ ដោយមានទ្រង់ជាអ្នកជំនួយ (រម ១៦:២០) ។

បន្ទាប់ពីបានពណ៌នាពីស្តេចដាវីឌក្នុងសិរីល្អទ្រង់ និងជ័យជម្នះក៏មានក្នុងជំពូក ១០–២០ ពីភាពខ្មៅងងឹតខ្លះក្នុងរាជ្ជកាលរបស់ទ្រង់ និងពណ៌នាពីភាពខ្សោយរបស់ស្តេចដាវីឌ ហើយនិងការបរាជ័យខ្លះដែរ ។ តែខណៈនោះ ទោះបីស្តេចដាវីឌនៅជាស្តេចក៏ដោយ គឺព្រោះតែទ្រង់មានព្រះទ័យនឹងបើកចំហរចិត្តទទួលស្គាល់គ្រប់អំពើបាបរបស់គាត់ទាំងអស់ និងលន់តួគ្រប់ទាំងអស់ (១២:១៣) ចំពោះលទ្ធផលមួយនៃការមិនស្តាប់បង្គាប់ដល់ព្រះយេហូវ៉ា(១២:១០–១២) ។ ដូចជាអំពើបាបរបស់ទ្រង់និងនាងបាតសេបា (ជំពូក ១១–១២) ការអត់ទោសរបស់ទ្រង់ចំពោះការអាក្រក់របស់បុត្រាទ្រង់ (១៣:១២–១៩,២១ ១៤:១,៣៣ ១៩:៤–៦) និងលោកយ៉ូអាប់ (៣:២៨–៣៩ ២០:១០,២៣) ធ្វើឱ្យមានភាពឃោរឃៅកើតឡើង និងការបង្ហូរឈាមក្នុងរង្វង់រាជវង្សរបស់ទ្រង់ ចំពោះការមិនចុះចូលរបស់ជាតិពូជសាសន៍ ដែលជាហេតុនាំឱ្យគាត់ឃ្លាតឆ្ងាយពីក្រុងយេរូសាឡិម ក្នុងពេលនៃការបះបោររបស់ព្រះអង្គម្ចាស់អាប់សាឡុម ។ ទោះបីជាយ៉ាងណាព្រះយេហូវ៉ាទ្រង់បានផ្តល់ព្រះគុណដល់ស្តេចដាវីឌ ហើយក្នុងរាជ្យទ្រង់ ក៏ប្រែក្លាយជាខ្នាតគំរូមួយដ៏ល្អ រហូតដល់ស្តេចជំនាន់ក្រោយៗទៀត (មើល ២ពវ ១៨:៣ ២២:២) ។

កណ្ឌគម្ពីរនេះបានបញ្ជាក់ដោយការពោលពាក្យអធិស្ឋានរបស់ស្តេចដាវីឌផ្ទាល់ និងការសរសើរតម្កើងដល់ព្រះ ដែលព្រះជាអង្គមួយដែលបានជួយសង្គ្រោះស្តេចដាវីឌពីគ្រប់សត្រូវទាំងអស់(២២:៣១–៥១)និងពាក្យពេជន៍នៃសេចក្តីសង្ឃឹម ចំពោះការបំពេញសម្រេចនៃព្រះបន្ទូលសន្យាថា ស្តេចមួយអង្គចេញពីដំណាក់នៃស្តេចដាវីឌ និងដឹកនាំលើទាំងមនុស្សក្នុងភាពសុចរិត(២៣:៣–៥)បទ

ចម្រៀងទាំងនេះបានពូទ្បើងក្នុងផ្ទៃរឿងនៃបទចម្រៀងរបស់នាងហាណា (១សយ ២:១-១០) នូវគោលការណ៍វគ្គដ៏សំខាន់ ។

**កាលប្បវត្តិវិជ្ជា**

មើលសេចក្តីផ្តើមក្នុងព្រះគម្ពីរសាំយូអែលទី១ : ត្រង់ចំណុចពង្សាវតារក្សត្រ ។

**គម្រោងសង្ខេប**

ផ្នែកខាងក្រោមនេះគឺជាគម្រោងសង្ខេបចំពោះសាំយូអែលទី២ ។ ចំពោះគម្រោងសង្ខេបទាំងសាំយូអែលទី១និងសាំយូអែលទី២ និងមើលសេចក្តីផ្តើមសាំយូអែលទី១ ត្រង់ចំណុចគម្រោងសង្ខេប ។

៤. ការបង្រួបបង្រួមនៃស្តេចក្នុងប្រទេសអ៊ីស្រាអែល (២សយ ជំពូក ១-២០)

ក. ការទួញសោករបស់ស្តេចដាវីឌចំពោះលោកសូល និងលោកយ៉ូណាថាន (ជំពូក ១)

ខ. លោកដាវីឌប្រែក្លាយជាស្តេច លើពួកយូដា (ជំពូក ២,៤)

គ. លោកដាវីឌប្រែក្លាយជាស្តេច លើពួកអ៊ីស្រាអែលទាំងអស់ (៥:១-៥)

ឃ. ស្តេចដាវីឌគ្រប់គ្រងយេរូសាឡិម(៥:៦-២៥)

ង. ស្តេចដាវីឌនាំហឹបសញ្ញាទៅក្រុងយេរូសាឡិម(ជំពូក ៦)

ច. ព្រះអម្ចាស់សន្យានឹងស្តេចដាវីឌ ស្ថិតក្នុងវង្សប្តូរាជវង្សជារៀងរហូត (ជំពូក ៧)

ឆ. ការពង្រីកអាណាចក្ររបស់ស្តេចដាវីឌ(ជំពូក ៨)

ជ. ស្តេចដាវីឌមានការស្មោះត្រង់នឹងសេចក្តីសញ្ញារបស់ទ្រង់ និងចំពោះលោកយ៉ូណាថាន(ជំពូក ៩)

ឈ. ស្តេចដាវីឌបានប្រព្រឹត្តការកំផិត និងការសម្លាប់ធ្វើឃាត(ជំពូក ១០-១២)

ញ. ស្តេចដាវីឌបានបាតបង់កូនរបស់ទ្រង់(ជំពូក ១៣:១៤)

ដ. ស្តេចដាវីឌបានបាត់បង់បុត្រារបស់ទ្រង់គឺ ព្រះអង្គម្ចាស់អាប់សាឡុំម (ជំពូក ១៥-២០)

៥. ការឆ្លុះបញ្ចាំងចុងក្រោយស្តីអំពីរាជ្យបល្ល័ង្ករបស់ស្តេចដាវីឌ(២សយ ជំពូក ២១-២៤)

## លោកដាវីឌឮពីដំណឹងស្ដេចសូលសុគត

*១:៤-១២ – ១សយ ៣១:១-១៣ ១រប ១០:១-១២*

១ ១រីឯក្រោយដែលសូលបានសុគត[ក]ហើយ កាលដាវីឌ
បានត្រឡប់មកពីវាយ[ខ]ពួកអាម៉ាលេកវិញ[គ] ហើយបាននៅ
ក្រុងស៊ីកឡាក់អស់២ថ្ងៃ
២នោះដល់ថ្ងៃទី៣ មានមនុស្ស
ម្នាក់[ឃ]មកពីទីបោះទ័ពរបស់សូល ស្លៀកពាក់រហែករហោក
ហើយមានដីនៅលើក្បាល[ង] កាលមកដល់ដាវីឌ នោះក៏
ទំលាក់ខ្លួនក្រាបចុះ[ច]ដល់ដីដោយគោរព[ឆ]
៣ដាវីឌសួរថា
អ្នកមកពីណា គាត់ជំរាបថា ខ្ញុំបានរត់រួចមកពីកងទ័ព
អ៊ីស្រាអែល
៤ដាវីឌសួរថា ចុះយ៉ាងដូចម្ដេចទៅ សូមប្រាប់
ខ្ញុំផង គាត់ជំរាបថា ពួកបណ្ដាទ័ពបានរត់ពីចំបាំងចេញ
ហើយមានមនុស្សជាច្រើនបានដួលស្លាប់ដែរ ឯសូល និង
យ៉ូណាថាន ជាបុត្រាទ្រង់ក៏បានសុគតហើយ
៥រួចដាវីឌសួរ
អ្នកកំឡោះ ដែលនាំដំណឹងមកជំរាបនោះថា ដូចម្ដេចបាន
ជាអ្នកដឹងថា សូលនិងយ៉ូណាថានជាបុត្រាទ្រង់ បានសុគត
ហើយដូច្នោះ
៦មនុស្សកំឡោះនោះជំរាបថា គាប់ជួនជាខ្ញុំ
កំពុងនៅលើភ្នំគីលបោ[ជ] នោះឃើញសូលទ្រង់ច្រត់លើ
លំពែងរបស់ទ្រង់ ឯពលរទេះ និងពលសេះរបស់គេក៏តាម
ទ្រង់ជាប្រកិត
៧កាលទ្រង់បែរទតមកក្រោយឃើញខ្ញុំ នោះ
ទ្រង់ក៏ហៅខ្ញុំ ហើយខ្ញុំទូលថា ព្រះករុណាវិសេសព្រះអម្ចាស់
៨រួចទ្រង់មានបន្ទូលសួរថា ឯងជាអ្នកណា ខ្ញុំក៏ទូលឆ្លើយថា
ទូលបង្គំជាសាសន៍អាម៉ាលេក[ឈ]
៩នោះទ្រង់បង្គាប់មកខ្ញុំថា
ចូលមកជិតនេះ ហើយសំឡាប់យើង[ញ]ទៅដ្បិតដែលយើង
រស់នៅ នោះមានសេចក្ដីទុក្ខព្រួយសង្កត់ខ្លាំងណាស់
១០ដូច្នេះ
ខ្ញុំក៏ចូលទៅជិតធ្វើគុតទ្រង់ទៅ ដោយខ្ញុំដឹងពិតថា ដែលទ្រង់
ដួលដូច្នេះហើយ នោះនឹងគង់ព្រះជន្មនៅមិនបានឡើយ ឯ
មកុដ[ដ]ដែលនៅលើព្រះសិរ និងកងកន់ដែលនៅព្រះហស្ត
ទ្រង់ នោះខ្ញុំបាននាំយកមកជូនលោកជាម្ចាស់ខ្ញុំ ។
១១នោះដាវីឌក៏ចាប់ហែកសំលៀកបំពាក់របស់ខ្លួន ហើយ
ពួកអ្នកដែលនៅជាមួយក៏ធ្វើដូច្នោះ[ឋ]ដែរ
១២គេនាំគ្នាកាន់
ទុក្ខព្រមទាំងយំ ហើយតមអាហារ ដរាបដល់ល្ងាចដោយ
ព្រោះសូល និងយ៉ូណាថាន ជាបុត្រាទ្រង់ និងពួកទ័ពនៃ
ព្រះយេហូវ៉ា ហើយនិងពួកវង្សអ៊ីស្រាអែលទាំងប៉ុន្មាន
ពីព្រោះគេបានដួលស្លាប់ដោយដាវ
១៣រួចដាវីឌលោកសួរ
មនុស្សកំឡោះ ដែលនាំដំណឹងមកនោះថា អ្នកជាសាសន៍
ណា គាត់ជំរាបថា ខ្ញុំជាកូនរបស់សាសន៍ដទៃម្នាក់ គឺ
សាសន៍អាម៉ាលេក[ឌ]
១៤ដាវីឌសួរទៀតថា ម្ដេចក៏អ្នកមិនខ្លាច
នឹងលូកដៃ ទៅសំឡាប់អ្នកដែលព្រះយេហូវ៉ាបានចាក់ប្រេង
តាំងឱ្យដូច្នោះ[ឍ]
១៥នោះដាវីឌក៏ហៅពួកកំឡោះម្នាក់មក
ប្រាប់ថា ចូលទៅសំឡាប់អ្នកនោះចោលចុះ[ណ] គេក៏ប្រហារ
ឱ្យស្លាប់ទៅ[ត]
១៦រួចដាវីឌមានប្រសាសន៍ថា ចូរឱ្យឈាមអ្នក

**១:១** ក ១សយ ២៦:១០ ១រប ១០:១៣ ខ យស ២២:៨ ១សយ ៣០:១៧ គ លប ១៤:៧ ជន ១៣:២៩
**១:២** ឃ ២សយ ៤:១០ ង ១សយ ៤:១២ យប ២:១២ អក ២៧:៣០ ច ១សយ ២០:៤១ ឆ លប ៣៧:៧
**១:៦** ជ ខ.២១ ១សយ ២៨:៤
**១:៨** ឈ ខ.១៣ ១សយ ៥:២ ២៧:៨ ៣០:១៣,១៧
**១:៩** ញ ពច ៩:៥៤
**១:១០** ដ ២ពវ ១១:១២
**១:១១** ឋ លប ៣៧:២៩ ជន ១៤:៦
**១:១៣** ឌ ខ.៨ ១សយ ១៤:៤៨
**១:១៤** ឍ ១សយ ១២:៣ ២៦:៩
**១:១៥** ណ ២សយ ៤:១២ ត ២សយ ៤:១០

**១:១** *ក្រោយដែលសូលបានសុគត* មើល យស ១:១ ពច ១:១ ២ពវ ១:១ ។ គឺជាការពណ៌នានៃកណ្ឌគម្ពីរសាំយូអែលទី១ ហើយបន្តរហូតដល់គម្ពីរសាំយូអែលទី២ ដែលពីមុនព្រះគម្ពីរទាំងពីរគឺគម្ពីរកណ្ឌតែមួយ (មើល សេចក្ដីផ្ដើម១សយ និងចំណងជើង) ។ *ដាវីឌបានត្រឡប់មកពីវាយពួកអាម៉ាលេកវិញ* មើល ១សយ ៣០:២៦ ។ *ក្រុងស៊ីកឡាក់* មើលការពន្យល់ ១សយ ២៧:៦ ។

**១:២** *ស្លៀកពាក់រហែករហោក . . . ដីនៅលើក្បាល* មើលការពន្យល់ ១យស ៤:១២ និងមើល សយ ៧:៦ កច ១៤:១៤ និងការពន្យល់ ។

**១:៨** *សាសន៍អាម៉ាលេក* គឺមិនចាំបាច់បញ្ចូលក្នុង ខ.៣ គឺក្នុងខនោះសាសន៍អាម៉ាលេកនេះ គឺជាពលទ័ពរបស់ស្ដេចសូល ។ គាត់បានបញ្ជាក់ថា វាកើតឡើងនៅលើភ្នំគីលបោ (ខ.៦) ការនេះមិនមែនអត់ទោសកំហុសនោះទេ ។ កាលដែលគាត់នៅទីនោះ គឺអាចជាអ្នកតាមរកផលប្រយោជន៍ ឬអ្នកប្លន់ទាហានដែលបាក់ទ័ពយកនូវវត្ថុមានតម្លៃ ឬជាអាវុធ ។ វាក៏ជាការចំអកពីការសុគតរបស់ស្ដេចសូល ហើយក៏បានរាយការណ៍ដោយសាសន៍អាម៉ាលេក (មើល ១សយ ១៥) ។

**១:១០** *ខ្ញុំក៏ចូលទៅជិតធ្វើគុតទ្រង់ទៅ* រឿងរបស់សាសន៍អាម៉ាលេក ដែលជាជម្លោះគឺមានក្នុង ១សយ ៣១:៣-៦ ក៏ជាទីដែលស្ដេចសូលត្រូវបានពណ៌នាក្នុងខណៈដែលគេដកហូតជីវិតទ្រង់ទៅ ។ វាក៏បង្ហាញឱ្យឃើញដែរថា ពួកសាសន៍អាម៉ាលេកបានប្រឌិតក្នុងវគ្គនេះ គឺទាក់ទងទៅនឹងការសុគតរបស់ស្ដេចសូលដែលសង្ឃឹមថា ស្ដេចដាវីឌឱ្យរង្វាន់ដល់គាត់ (មើល ៤:១០) ការយល់ខុសពីការឆ្លើយតបរបស់ស្ដេចដាវីឌ គឺធ្វើឱ្យគាត់បាត់បង់ជីវិតវិញ (មើល ខ.១៥) ។

**១:១១** *ចាប់ហែកសំលៀកបំពាក់របស់ខ្លួន* មើលការពន្យល់ ខ.២ ។

**១:១២** *កាន់ទុក្ខព្រមទាំងយំ* ស្ដេចដាវីឌព្រមទាំងទាហានរបស់ទ្រង់បានបង្ហាញនូវសេចក្ដីសោកសៅរបស់ពួកគេក្នុងសម័យមជ្ឈិមបូព៌ា (មើល លប ២៣:២ ១ពវ ១៣:៣០ យរ ២២:១៨) ។ *តមអាហារ* មើលការពន្យល់ ១សយ ៣១:១៣ ។

**១:១៣** *សាសន៍អាម៉ាលេក* គឺជាបុរសម្នាក់ដែលពុំដឹងពីការជួបប្រទះ និងសត្រូវរបស់ស្ដេចដាវីឌពេលថ្មីៗនេះ គឺស្ដេចដាវីឌ និងពួកអាម៉ាលេក(មើល ខ.១ ១សយ ៣០ មើលការពន្យល់ ១សយ ១៥:២) ។

**១:១៤** ពួកអាម៉ាលេក គឺពុំយល់អ្វីទាំងអស់ពីលក្ខណៈដ៏ស៊ីជម្រៅ ដែលស្ដេចដាវីឌមានទំនាក់ទំនងចំពោះភាពឧត្តុង្គឧត្តមនៃរាជវង្ស ក្នុងស្រុកអ៊ីស្រាអែល (មើល ១សយ ២៤:៦ និងការពន្យល់) ។ *ព្រះយេហូវ៉ាបានចាក់ប្រេងតាំង* មើលការពន្យល់ ១សយ ៩:១៦ ។

**១:១៥** *សំឡាប់អ្នកនោះចោលចុះ* ស្ដេចដាវីឌសម្ដែងនូវភាពពុំពេញព្រះទ័យចំពោះការស្លាប់របស់ស្ដេចសូល និងត្រូវកាត់ទោសប្រហារជីវិតដល់អ្នកដែលទ្រង់យល់ដឹងថា ជាឃាតករសម្លាប់ស្ដេចសូលនោះ មើលការពន្យល់ ខ.១០ ក៏មើល ៤:១០ ដែរ) ។

ធ្លាក់ទៅលើក្បាលអ្នកវិញចុះ[ឋ] ដ្បិតមាត់អ្នកបានធ្វើបន្ទាល់
ទាស់នឹងខ្លួនអ្នកហើយថា អ្នកបានសំឡាប់មនុស្សដែលព្រះ
យេហូវ៉ាបានចាក់ប្រេងតាំងឱ្យ ។

## ទំនុកបទដាវីឌពីដំណើរសូល និងយ៉ូណាថាន

១៧ នេះជាបទទំនួញ[ទ] ដែលដាវីឌបានលើកនិពន្ធទុកពី
ដំណើរសូល និងយ៉ូណាថាន ជាបុត្រាទ្រង់[ធ] ១៨ លោកក៏
បង្គាប់ឱ្យគេបង្រៀនបទចំរៀងពីធ្នូនេះ ដល់ពួកកូនចៅ
យូដា ឯបទនេះសឹងមានកត់ទុក នៅក្នុងសៀវភៅរបស់
យ៉ាសើរ ថា[ន] ១៩ ឱសាសន៍អ៊ីស្រាអែលអើយ អ្នកដ៏ជាសិរីល្អ
នៃឯង បានត្រូវគេសំឡាប់នៅលើទីខ្ពស់របស់ឯង ឱះឱពួក
ខ្លាំងពូកែ[ប]បានដួលស្លាប់ហើយ[ផ] ២០ កុំឱ្យថ្លែងប្រាប់នៅក្រុង
កាថ[ព] ក៏កុំឱ្យប្រកាសប្រាប់ តាមផ្លូវនៅក្នុងក្រុងអាសកាឡូន
ឡើយ[ភ] ក្រែងពួកកូនស្រីនៃសាសន៍ភីលីស្ទីន[ម]គេរីករាយ
សប្បាយ ហើយក្រែងកូនស្រីនៃពួកមិនកាត់ស្បែកនោះ បាន
អរសាទរ[យ] ២១ ឱភ្នំគីលបោអើយ[រ] កុំឱ្យមានសន្សើម[ល] ឬ
ភ្លៀងធ្លាក់មកលើឯងឡើយ[វ] ក៏កុំឱ្យមានស្រែពេញដោយ
ដង្វាយ[ស]ទៀតដែរ ដ្បិតនៅទីនោះខែលនៃពួកខ្លាំងពូកែ
បានត្រូវបង្អាប់ គឺជាខែលរបស់សូល ទុកដូចជាមិនបាន
ចាក់ប្រេងតាំងទ្រង់ឡើងសោះ[ហ] ២២ ឯធ្នូ[ឡ]របស់យ៉ូណាថាន
នោះមិនបានថយចេញពីឈាម[អ]នៃមនុស្សរបួស ឬពីខ្លាញ់
របស់មនុស្សខ្លាំងពូកែឡើយ ដាវរបស់សូលក៏មិនបានមក
វិញទទេដែរ ២៣ សូលនិងយ៉ូណាថានជាទីគួរស្រឡាញ់ គួរ
រីករាយណាស់ពីកាលនៅរស់ ហើយកាលទ្រង់សុគត នោះ
ក៏មិនឃ្លាតពីគ្នាដែរ ទ្រង់រហ័សជាងសត្វឥន្ទ្រី[ក] ហើយខ្លាំង
ជាងសត្វសិង្ហ[ខ] ២៤ ឱពួកកូនស្រីនៃសាសន៍អ៊ីស្រាអែលអើយ
ចូរយំសោកនឹងសូល ដែលទ្រង់បានចាត់ចែង ឱ្យឯងស្លៀក
ពាក់ ដោយសំពត់ក្រហមយ៉ាងរុងរឿង ហើយតែងសំលៀក
បំពាក់ឱ្យឯងដោយគ្រឿងមាស[គ] ២៥ ឱះឱពួកខ្លាំងពូកែបាន
ដួលស្លាប់នៅកណ្តាលចំបាំងហើយ យ៉ូណាថានត្រូវគេ
សំឡាប់នៅលើទីខ្ពស់របស់ឯង ២៦ ឱយ៉ូណាថាន[ឃ] បងអើយ[ង]
ខ្ញុំមានសេចក្តីទុក្ខ[ច]ចំពោះបង ដោយព្រោះបងជាទីពេញ
ចិត្តដល់ខ្ញុំណាស់ ហើយដែលបងស្រឡាញ់ដល់ខ្ញុំ នោះជា
ទីអស្ចារ្យ[ឆ] ក៏លើសជាងសេចក្តីស្រឡាញ់របស់ស្រីៗផង
២៧ ឱះឱពួកខ្លាំងពូកែបានដួលស្លាប់ហើយ អស់ទាំងគ្រឿង
ចំបាំងក៏បានវិនាសអស់ទៅ[ជ] ។

**១:១៦** ឋ លវ ២០:៩ មថ ២៧:២៤–២៥ កច ១៨:៦
**១:១៧** ទ លប ៥០:១០ អគ ៣២:២ ធ ខ.២៦
**១:១៨** ន យស ១០:១៣
**១:១៩** ប ២សយ ២៣:៨ ទដ ២៩:១ ៤៥:៣ ផ ២សយ ៣:៣៨
**១:២០** ព មីក ១:១០ ភ យស ១៣:៣ ម ១សយ ៣១:៨ យ ១សយ ១៨:៦
**១:២១** រ ខ.៦ ល លប ២៧:២៨ អស ១៨:៤ វ ចទ ១១:១៧ ១ពវ ៨:៣៥ ១៧:១ ១៨:១ ២រប ៦:២៦ យប ៣៦:២៧ ៣៨:២៨ ទដ ៦៥:១០ ១៤៧:៨ អស ៥:៦ យរ ៥:២៤ ១៤:៤ អម ១:២ ស យរ ១២:៤ អគ ៣១:១៥ ហ អស ២១:៥ **១:២២** ឡ អស ៣៤:៣, ៧ ៤៩:២៦ អ ចទ ៣២:៤២ **១:២៣** ក ចទ ២៨:៤៩ ខ ពច ១៤:១៨ **១:២៤** គ ពច ៥:៣០ **១:២៦** ឃ ១សយ ២០:៤២ ង យរ ២២:១៨ ៣៤:៥ ច ខ.១៧ ឆ ១សយ ១៨:១ **១:២៧** ជ ១សយ ២:៤

**១:១៦** *ចូរឱ្យឈាមអ្នកធ្លាក់ទៅលើក្បាលអ្នកវិញចុះ* គឺជាបន្ទាល់ផ្ទាល់ខ្លួនរបស់សាសន៍អាម៉ាលេកដែលទទួលការកាត់ទោស (យស ២:១៩ ១ពវ ២:៣៧) ។

**១:១៧** *និពន្ធទុក* វាគឺជារឿងធម្មតាក្នុងការអនុវត្តនៅមជ្ឈឹមបុព៌ាក្នុងការនិពន្ធបទទំនុកចំពោះអ្នកដឹកនាំ ដែលធ្លាប់ចុះក្នុងភាពទន់ខ្សោយ ក៏ដូចជាវីរៈបុរស និងរាជធានី (មើល ២រប ៣៥:២៥ និងការពន្យល់ក្នុងគម្ពីរបរទេវ គឺពិសេសនៅត្រង់សេចក្តីផ្តើមខ្លឹមសា និងវិជ្ជាសិក្សាអំពីព្រះ) ។

**១:១៨** *បទចំរៀងពីធ្នូ* ប្រហែលជាលោកដាវីឌ បង្រៀនទាហានរបស់គាត់ឱ្យច្រៀងបទចម្រៀងពីធ្នូនោះ (គឺនៅពេលដែលគេរឹកហាត់បាញ់ធ្នូ) មើល ២២:៣៥ គឺជាយុទ្ធសាស្ត្រជំរុញលើកទឹកចិត្តឱ្យមានជំនាញយ៉ាងពិតប្រាកដក្នុងការប្រើគ្រឿងសឹក គឺដើម្បីកុំឱ្យពួកគេជួបប្រទះបទពិសោធន៍បរាជ័យតទៅទៀត (មើលការពន្យល់ អគ ២១:៩) ។ *សៀវភៅរបស់យាសើរ* មើលការពន្យល់ យស ១០:១៣ ។

**១:១៩** *សិរីល្អនៃឯង* គឺជាការពោលបញ្ជាក់ ចំពោះស្តេចសូល និងព្រះអង្គម្ចាស់យ៉ូណាថាន គឺជាអ្នកដឹកនាំដែលព្រះបានចាក់ប្រេងតាំងចំពោះសេចក្តីសញ្ញា គឺចំពោះអ្នកបានសម្រេចការជោគជ័យជាច្រើន ទៅលើខ្មាំងត្រូវរបស់ប្រជាជនអ៊ីស្រាអែល (មើល ១សយ ១៤:៤៧–៤៨ និងការពន្យល់) ។ *ឱះឱពួកខ្លាំងពូកែបានដួលស្លាប់ហើយ* គឺជាបទចម្រៀងរបស់ស្តេចដាវីឌ (មើល ខ.២៥,២៧) ពាក្យសម្តីរបស់ស្តេចដាវីឌពុំមានលើកឡើងពីភាពល្វីងជូរចតចំពោះស្តេចសូលទេ តែបានពោលជំនួសដោយពាក្យថា គុណសម្បត្តិនិងការសម្រេចបានរបស់ស្តេចសូល និងយ៉ូណាថាន ១សយ ២:១–១០ ដែលមានចម្រៀងស្តេចដាវីឌក្នុង ២សយ ២២ វិញ ។

**១:២០** *កុំឱ្យថ្លែងប្រាប់នៅក្រុងកាថ . . . ក្រុងអាសកាឡូន* គឺជាទីក្រុងសាសន៍ភីលីស្ទីន ដែលមានទីតាំងឆ្ងាយពីព្រំដីនៃស្រុកអ៊ីស្រាអែលក៏មានដែរ ។ ស្តេចដាវីឌមិនចង់ឱ្យសត្រូវនៃសេចក្តីសញ្ញារបស់ព្រះ សប្បាយរីករាយក្នុងពេលរាស្ត្រអ៊ីស្រាអែលត្រូវបានគេផ្តួលឡើយ (មើល ១សយ ៣១:៩–១០) ។ ដែលនាំមកនូវការរិះគន់ដល់ព្រះនាមទ្រង់ជាព្រះយេហូវ៉ា (មើល នក ៣២:១២ ជន ១៤:១៣–១៩ ចទ ៩:២៨ មើល យស ៧:៩ មីក ១:១០ និងការពន្យល់) ។ *មិនកាត់ស្បែកនោះ* មើលការពន្យល់ ១សយ ១៤:៦ ។

**១:២១** *ឱភ្នំគីលបោអើយ* ដូចជាបានបញ្ជាក់នៃអំណោយទានដ៏ពិសេស ហើយស្តេចដាវីឌបានប្រកាសពីបណ្តាសានៅទីកន្លែង ដែលរាស្ត្រអ៊ីស្រា–អែលត្រូវបានគេវាយផ្តួលស្តេចសូល និងលោកយ៉ូណាថាន គឺត្រូវបានគេសម្លាប់ (មើល យប ៣:៣–២៦ យរ ២០:១៤–១៨) ។

**១:២៣** *ហើយកាលទ្រង់សុគត នោះក៏មិនឃ្លាតពីគ្នាដែរ* ទោះបីជាព្រះអង្គម្ចាស់យ៉ូណាថានប្រឆាំងនឹងទង្វើអាក្រក់ ដែលស្តេចសូលប្រព្រឹត្តចំពោះលោកដាវីឌក៏ដោយ ក៏ទ្រង់នៅតែព្រមលះបង់ជីវិតជាមួយបិតាទ្រង់នៅក្នុងសង្គ្រាមការពារនគរអ៊ីស្រាអែល ឬជំនួសឪពុកគាត់ក្នុងការការពាររាស្ត្រអ៊ីស្រាអែល ។

**១:២៦** *ក៏លើសជាងសេចក្តីស្រឡាញ់របស់ស្រីៗ* លោកដាវីឌគិតថា សេចក្តីស្រឡាញ់ជាគ្រួសារ មិនអាចធ្វើឱ្យបាត់បង់សេចក្តីស្រឡាញ់ជាមិត្តភាពទេ ។ ដោយលោកដាវីឌបានដឹងច្បាស់ ពីទឹកចិត្តរបស់ព្រះអង្គម្ចាស់យ៉ូណាថានបានពុះពារជួយដល់គាត់ ហើយក៏ជាអ្នកដែលព្រះយេហូវ៉ាបានជ្រើសតាំងឱ្យធ្វើជាអ្នកសម្របសម្រួលផងដែរ (មើលការពន្យល់ ១សយ ២០:១៣–១៦) ។

**១:២៧** *គ្រឿងចំបាំង* គឺជាពាក្យប្រៀបធៀប ចំពោះស្តេចសូល និងលោក

## ការចាក់ប្រេងតាំងដាវីឌឱ្យធ្វើជាស្តេចនៃសាសន៍យូដា

**២** ១ក្រោយនោះមក ដាវីឌក៏ទូលសួរដល់[ក]ព្រះយេហូវ៉ាថា
តើត្រូវឱ្យទូលបង្គំឡើងទៅក្នុងទីក្រុង របស់ស្រុកយូដាណា
មួយឬអី ព្រះយេហូវ៉ាទ្រង់មានបន្ទូលឆ្លើយថា ចូរឡើងទៅ
ចុះ រួចដាវីឌទូលសួរថា តើឱ្យទូលបង្គំឡើងទៅឯណា ទ្រង់
មានបន្ទូលថា ចូរទៅឯហេប្រុនចុះ[ខ] ២ដូច្នេះដាវីឌក៏ឡើង
ទៅដល់ទីនោះ នាំប្រពន្ធខ្លួនទាំង២[គ]ទៅជាមួយផង គឺ
អ័ហ៊ីណោម ជាអ្នកស្រុកយេសរាល និងអ័ប៊ីកែល[ឃ] ជាអ្នក
ស្រុកកើមែល ដែលជាប្រពន្ធរបស់ខ្មោចណាបាល ៣ឯពួក
អ្នកដែលនៅជាមួយ[ង] នោះលោកក៏នាំគេ ព្រមទាំងពួកគ្រួ
គេរៀងខ្លួនឡើងទៅដែរ គេក៏តាំងទីលំនៅៗក្នុងអស់ទាំង
ដំបន់នៃក្រុងហេប្រុន[ច] រួចពួកយូដា គេមកចាក់ប្រេងតាំង[ឆ]
ដាវីឌឡើងឱ្យធ្វើជាស្តេចលើជនជាតិរបស់ខ្លួននៅទីនោះ[ជ] ។
៤មានគេទូលដល់ដាវីឌថា ពួកដែលបញ្ចុះអដ្ឋិរបស់សូល
នោះគឺជាពួកអ្នកនៅក្រុងយ៉ាបេស-កាឡាត[ឈ] ៥នោះដាវីឌ
ទ្រង់ចាត់សារ ឱ្យទៅឯពួកក្រុងយ៉ាបេស-កាឡាតប្រាប់ថា
សូមឱ្យព្រះយេហូវ៉ា ទ្រង់ប្រទានពរ[ញ]ដល់អ្នករាល់គ្នាចុះ
ពីព្រោះអ្នករាល់គ្នាបានសំដែងសេចក្តីសប្បុរសដល់សូល
ជាចៅហ្វាយនៃអ្នក ដោយបញ្ចុះអដ្ឋិទ្រង់ ៦ឥឡូវនេះ សូមឱ្យ
ព្រះយេហូវ៉ាទ្រង់សំដែងសេចក្តីសប្បុរស ហើយនិងសេចក្តី
ទៀងត្រង់ដល់អ្នករាល់គ្នាចុះ[ដ] ឯខ្ញុំក៏នឹងសងដល់អ្នករាល់គ្នា
ដោយព្រោះការសប្បុរសនោះដែរ ៧ដូច្នេះ សូមឱ្យអ្នក
រាល់គ្នាមានកំឡាំងដៃឡើង[ឋ] ហើយមានចិត្តក្លាហានចុះ
ដ្បិតសូល ជាចៅហ្វាយនៃអ្នករាល់គ្នា ទ្រង់អស់ព្រះជន្ម
ហើយ មួយទៀតពួកជនជាតិយូដា បានចាក់ប្រេងតាំងខ្ញុំឱ្យ
ធ្វើជាស្តេចលើគេវិញ ។

## សង្គ្រាមរវាងពួកខាងស្តេចដាវីឌ និងពួកខាងស្តេចសូល

*៣:២-៥ – ១រប ៣:១-៤*

៨រីឯអ័ប៊ីនេរ[ឌ] កូននេរ ជាមេទ័ពរបស់សូល លោកបាននាំ
យកអ៊ីស-បូសែត[ឍ]ជាបុត្រាសូល ទៅឯក្រុងម៉ាហាណែម[ណ]

**២:១** ក ១សយ ២៣:២,១១-១២ ខ លប ១៣:១៨ ២៣:១៩
**២:២** គ ១សយ ២៥:៤៣ ឃ ១សយ ២៥:៤២
**២:៣** ង ១សយ ២៧:២ ១រប ១២:២២ ច លប ១៣:១៨ ២៣:២ ៣៧:១៤
**២:៤** ឈ ពច ២១:៨ ១សយ ១១:១
**២:៥** ញ ពច ១៧:២ ១សយ ២៣:២១ ២ទត ១:១៦
**២:៦** ដ នក ៣៤:៦
**២:៧** ឋ យស ១:៦ ពច ៥:២១
**២:៨** ឌ ១សយ ១៤:៥០ ២សយ ៣:២៧ ឍ ២សយ ៤:៥ ១រប ៨:៣៣ ៩:៣៩ ណ លប ៣២:២

យ៉ូណាថាន ។

**២:១** *ក្រោយនោះមក* នៅឃ្លានេះបានបង្ហាញពីព្រឹត្តិការណ៍ក្នុងជីវិតរបស់ស្តេចដាវីឌ ការចាក់ប្រេងតាំងនៃទ្រង់គឺធ្វើជាស្តេចនៃពួកសាសន៍យូដា ដែលបង្ហាញពីភាពជោគជ័យ(៨:១)អំពើកំផិតក្បត់របស់ទ្រង់ គឺបានប្រព្រឹត្តការកំផិតក្បត់ជាមួយនាងបាតសេបា និងប្រព្រឹត្តអំពើកាប់សម្លាប់ដល់លោកអ៊ូរី (១០:១) ការសុគតរបស់បុត្រាច្បងរបស់ទ្រង់អាំណូន (១៣:១) និងការរួមគំនិតប្រព្រឹត្តអំពើទុច្ចរិតនៃបុត្រាទ្រង់ គឺព្រះអង្គម្ចាស់អាប់សាឡំម (១៥:១) ។ *ដាវីឌក៏ទូលសួរដល់ព្រះយេហូវ៉ា* គឺតាមរយៈសង្ឃ (មើលការពន្យល់ នក ២៨:៣០ ១សយ ២:២៨ ២៣:២) ។ *ទីក្រុងរបស់ស្រុកយូដា* ទោះជាក្នុងខណៈដែលស្តេចសូលបានស្លាប់ក៏ដោយ ហើយស្តេចដាវីឌមានសំឡាញ់ជាច្រើននិងទាក់ទងនិងមនុស្ស ឬប្រជាជននៅក្នុងពូជអំបូរផ្ទាល់ខ្លួនរបស់ផងទ្រង់(មើល ១សយ ៣០:២៦-៣១) ស្តេចដាវីឌពុំបានសន្មត់ថានឹងផ្លាស់ប្តូរព្រំដីរបស់ពួកភីលីស្ទីនទេ ដើម្បីធ្វើគម្រោងទុកជាមុនក្នុងភាពជាស្តេចដោយគ្មានការស្វែងរកព្រះហឫទ័យ និងការណែនាំពីព្រះយេហូវ៉ា ។ *ហេប្រុន* គឺជាទីក្រុងដ៏សំខាន់មួយនៅសម័យនោះ (មើលការពន្យល់ លប ១៣:១៨ ២៣:២ យស ១៥:១៣-១៤ មើលការ ពន្យល់ ១សយ ៣០:៣១) មានទីតាំងនៅចំកណ្តាលក្នុងស្រុកនៃអំបូរពួកសាសន៍យូដា ។

**២:២** *អ័ហ៊ីណោម ជាអ្នកស្រុកយេសរាល* សូមមើលការពន្យល់ ១សយ ២៥:៤៣ ។ *អ័ប៊ីកែល* មើល ១សយ ជំពូក ២៥ ។

**២:៣** *ឯពួកអ្នកដែលនៅជាមួយ* មើលការពន្យល់ ខ.១៣ ។

**២:៤** *គេទូលដល់ស្តេចដាវីឌថា* មើលការពន្យល់ ១សយ ២:១០ ៩:១៦ ។ ឯស្តេចដាវីឌក៏បានហោរាសាំយូអែលចាក់ប្រេងតាំងដោយផ្ទាល់ ក្នុងវត្តមាននៃក្រុមគ្រួសារទ្រង់ទាំងអស់គ្នា(មើលការពន្យល់ ១សយ ១៦:១៣) ។ តែពេលខ្លះពិធីចាក់ប្រេងតាំងក៏បានធ្វើឡើងវិញ ជាសាធារណៈដើម្បីឱ្យពូជអំបូររបស់ទ្រង់បានទទួលស្គាល់ជាទូទៅ គឺជាការត្រាស់ហៅពីព្រះដើម្បីគ្រងរាជ្យជាស្តេច ។ គឺជាស្តេចគ្រប់គ្រងលើពួកជនជាតិយូដាទាំងអស់ ។ ទំនងមានទាំងពូជអំបូរនៃពួកស៊ីម្មានក៏មាននៅក្នុងនោះដែរ (មើល យស ១៩:១ ពច ១:៣) ក៏ប៉ុន្តែពួក(ពូជអំបូរ)យូដាមានចំនួនច្រើនជាងក្នុងស្រុកទាំងមូល ។ *ពួកអ្នកនៅក្រុងយ៉ាបេស-កាឡាត* មើលការពន្យល់ ១សយ ១១:១ ៣:១២ ។ *បញ្ចុះអដ្ឋិរបស់សូល* មើលការពន្យល់ ១សយ ៣១:១៣ ។

**២:៧** *ចៅហ្វាយនៃអ្នករាល់គ្នា ទ្រង់អស់ព្រះជន្មហើយ មួយទៀតពួកជនជាតិយូដា បានចាក់ប្រេងតាំងខ្ញុំឱ្យធ្វើជាស្តេចលើគេវិញ* ដាវីឌបានបង្ហាញបញ្ជាក់ប្រាប់ដល់ប្រជាជនអ្នកស្រុកយូដានៅស្រុកយ៉ាបេស-កាឡាត គឺដើម្បីឱ្យពួកគេទទួលស្គាល់ទ្រង់ថាជាស្តេចរបស់ពួកគេ គឺធ្វើដូចជាក្នុងពូជអំបូរសាសន៍យូដាបានធ្វើហើយដូច្នេះដែរ ។ គឺដើម្បីជាការគាំទ្រពីពួកគេ តែត្រូវបានពួកគេធ្វើព្រងើយទៅវិញ ។

**២:៨** *រីឯអ័ប៊ីនេរ កូននេរ* មើល ១សយ ១៤:៥០ ។ *ជាមេទ័ពរបស់សូល* គឺជាមេទ័ពដែលមានជំនាញច្បាស់លាស់ សម្រាប់រាជ្យវាំងនិងក្រុមរាជវង្ស (មើល ១សយ ១៣:២,១៥ ១៤:២,២៥) ។ *អ៊ីស-បូសែត* ដែលមាននាមឈ្មោះដើម គឺអ៊ីស(ឬក៏អ៊ែស) (១រប ៨:៣៣) តែឈ្មោះត្រូវបានកែដោយអ្នកនិពន្ធសាំយូអែលគឺដូចជាឈ្មោះ អ៊ីស-បូសែតវិញ គឺមានន័យថា"មនុស្សដែលមានសណ្ឋានថោកទាប"(មើលការពន្យល់ ៤:៤ ពច ៦:៣២ យរ ២:២៦ ៣:២៤-២៥ ១១:១៣) ។ តាមការពិតពាក្យថាប៊ិល (គឺមានន័យថា "ព្រះយេហូវ៉ា"ឬ"ចៅហ្វាយ") រួចគេក៏ប្រើសំរាប់សំអាងលើឈ្មោះព្រះនាមព្រះយេហូវ៉ា ។ តែក្រោយមកទៀតឈ្មោះនេះក៏បានឈប់ប្រើទៅទៀត ព្រោះវាច្រឡំ និងឈ្មោះព្រះរបស់សាសន៍កាណានគឺព្រះ"បាល"(Baal) តែអ្នកនិពន្ធហោរាសាំយូអែលបានប្រាប់ថា ប្តូរដើម្បីសម្រួលឱ្យអាចយល់បាន មើលការពន្យល់ ១សយ ៣១:២ ។ *នាំយកអ៊ីស-បូសែត* កាលដែលស្តេចសូលបានសុគត ហើយអ័ប៊ីនេរបានផ្តើមគំនិតក្នុងភាពលោភលន់របស់គាត់ (មើល ៣:១១ និងការពន្យល់ ៤:១) គឺគ្មានភស្តុតាងណាបញ្ជាក់ថា

៩ហើយបានតាំងឡើងជាស្ដេចលើពួកកាឡាត[ត] ពួកអេស៊ើរ[ថ]
ពួកយេសរាល ពួកអេប្រាអិម និងពួកបេនយ៉ាមីន ហើយ
និងលើពួកអ៊ីស្រាអែលទាំងអស់[ទ] ១០ឯអ៊ីស-បូសែត ជា
បុត្រាសូលនេះ ទ្រង់មានព្រះជន្ម៤០ឆ្នាំហើយ ក្នុងកាល
ដែលចាប់សោយរាជ្យលើពួកអ៊ីស្រាអែល ទ្រង់ក៏សោយ
រាជ្យបាន២ឆ្នាំ តែពួកជនជាតិយូដា គេប្រតិបត្តិតាមដាវីឌ
វិញ ១១ហើយគ្រាដែលដាវីឌសោយរាជ្យលើជនជាតិយូដា
នៅក្រុងហេប្រុន នោះទាំងអស់បាន៧ឆ្នាំ៦ខែ[ធ]។
១២ឯអ័ប៊ីនើរ ជាកូននើរ និងពួកខាងអ៊ីស-បូសែតជាបុត្រា
សូល គេក៏ចេញពីម៉ាហាណែម ទៅឯគីបៀន[ន] ១៣ហើយ
យ៉ូអាប់[ប]ជាកូនសេរូយ៉ា និងពួកខាងដាវីឌ ក៏ចេញទៅប្រទះ
គ្នា នៅត្រង់ស្រះគីបៀន គេអង្គុយនៅទាំងសងខាងស្រះ គឺ
ម្ខាងពួក១ ម្ខាងពួក១ ១៤នោះអ័ប៊ីនើរ និយាយទៅយ៉ូអាប់ថា
ចូរឱ្យពួកកំឡោះៗ ក្រោកឡើងលេងគ្នានៅមុខយើងទៅ
យ៉ូអាប់ក៏ឆ្លើយថា ចូរឱ្យគេក្រោកឡើងចុះ ១៥នោះគេក៏
ក្រោកឡើងទៅតាមចំនួនដែលបានកំណត់ គឺមាន១២នាក់
ដំណាងខាងពួកបេនយ៉ាមីន និងអីស-បូសែតជាបុត្រាសូល
ហើយ១២នាក់ដំណាងខាងពួកដាវីឌ ១៦គ្រប់គ្នាក៏ចាប់ក្បាល
គូគេរៀងខ្លួន ហើយចាក់គ្នាត្រង់ចំហៀងដោយដាវ[ផ] ដួល
ស្លាប់ទាំងអស់គ្នាទៅ ដូច្នេះគេហៅទីនោះថា ហេលកាត-
ហាស៊ូរីម ទីនោះនៅត្រង់គីបៀន ១៧រួចនៅថ្ងៃនោះ ចំបាំង
ក៏សាហាវណាស់ ហើយអ័ប៊ីនើរ និងពួកខាងអ៊ីស្រាអែល
ត្រូវចាញ់ដៃ[ព]នៃពួកខាងដាវីឌ[ភ]។
១៨រីឯយ៉ូអាប់[ម] អ័ប៊ីសាយ[យ] និងអេសាអែល[រ] ទាំង៣នាក់
ដែលជាកូនសេរូយ៉ា[ល] ក៏នៅទីនោះ ឯអេសាអែលមានជើង
លឿនណាស់ ដូចជាប្រើសព្រៃ[វ] ១៩គាត់ក៏ដេញតាមអ័ប៊ីនើរ
ទៅ ឥតបង្អង់ដោយងាកបែរទៅខាងស្តាំឬខាងឆ្វេងឡើយ
២០នោះអ័ប៊ីនើរក៏ក្រឡេកមើលមកក្រោយសួរថា តើឯង
ឬអីអេសាអែលអើយ គាត់ឆ្លើយថា គឺអញនេះហើយ
២១ដូច្នេះ អ័ប៊ីនើរប្រាប់គាត់ថា ចូរឯងបែរទៅខាងស្តាំឬ
ខាងឆ្វេង ដើម្បីនឹងចាប់កំឡោះណាម្នាក់ ហើយយកគ្រឿង
សស្ត្រាវុធរបស់គេវិញ តែអេសាអែលចេះតែដេញតាម

**២:៩** ត ជន ៣២:២៦ ថ យស ១៩:២៤-៣១ ទ ១រប ១២:២៩
**២:១១** ធ ២សយ ៥:៥
**២:១២** ន យស ៩:៣
**២:១៣** ប ២សយ ៨:១៦ ១៩:១៣ ១ពវ ១:៧ ១រប ២:១៦ ១១:៦ ២៧:៣៤
**២:១៦** ផ ពច ៣:២១
**២:១១** ធ ២សយ ៥:៥
**២:១៧** ព ២សយ ៣:១ ភ ១សយ ១៧:៨
**២:១៨** ម ២សយ ៣:៣០ ១០:៧ ១១:១ ១៤:១ ១៨:១៤ ២០:៨ ២៤:៣ ១ពវ ១:៧

២:៥,៣៤ យ ១សយ ២៦:៦ រ ២សយ ២៣:២៤ ១រប ២:១៦ ១១:២៦ ២៧:៧ ល ២សយ ៣:៣៩ ១៦:១០ ១៩:២២ វ ១រប ១២:៨ សភ ៦:៥ ២:៩

ព្រះអង្គម្ចាស់អ៊ីស-បូសែតមានការគាំទ្រក្នុងរង្វង់រាស្ត្រអ៊ីស្រាអែល ។ *ក្រុងម៉ាហាណែម* គឺជាទីក្រុងកាឡាត ជាក្រុងនៅផ្នែកខាងកើតនៃទន្លេយ័រដាន នឹងមានទីតាំងនៅដាច់ដោយឡែកពីក្រុមចំណុះភីលីស្ទីន ដែលជាមហាក្សត្រនៃរាជធានីជនភៀសខ្លួន ។

**២:៩** *បានតាំងឡើងជាស្ដេចលើពួកកាឡាតពួកអេស៊ើរ* ដូចជាញាតិវង្សនិងស្ដេចសូល(មើល ១សយ ១៤:៥០) លោកអ័ប៊ីនើរមានទាំងក្រុមគ្រួសារ និងមានសមត្ថភាព អាចទទួលសោយរាជ្យស្នងនូវខ្សែរាជវង្ស ជំនួសដំណាក់រាជ្យវាំងរបស់ស្ដេចសូល ។ *លើពួកកាឡាត . . . និងលើពួកអ៊ីស្រាអែលទាំងអស់* នេះជាការពណ៌នាអំពីព្រះអង្គម្ចាស់អ៊ីស-បូសែត ដែលមានតួនាទីច្បាស់លាស់ក្នុងការកាន់កាប់ព្រំទឹកដី ទាំងខាងកើតនិងខាងលិចនៃទន្លេយ័រដាន ក៏ជាការកំណត់និងថា "គ្រប់រាស្ត្រអ៊ីស្រាអែល" ដែលបានអះអាងថា ការពិតស្ដេចដាវីឌគ្រប់គ្រងទាំងយូដា ឯសីម្មានពួកភីលីស្ទីនគឺត្រួតត្រាតំបន់យ៉ាងធំនៃពូជអំបូរភូមិភាគខាងត្បូង ។

**២:១១** *៧ឆ្នាំ៦ខែ* ប្រៀបធៀបនឹងការសោយរាជ្យរបស់អ៊ីស-បូសែតគឺ២ឆ្នាំក្នុងក្រុងម៉ាហាណែម (ខ.១០) ដោយសារមានកើតឡើងនូវស្ដេចដាវីឌដែលគ្រងលើរាស្ត្រអ៊ីស្រាអែល មួយរយៈក្រោយមកអ៊ីស-បូសែតបានសុគត (៥:១-៥) និងការប្ដូរផ្លាស់ទីក្រុងទៅឯស្រុកយេរូសាឡិមវិញ (៥:៦-១២) មិនយូរប៉ុន្មានមានដំណោះស្រាយរវាងទឹកដីស្ដេចដាវីឌ និងស្ដេចអ៊ីស-បូសែត ក៏មានភាពប្លែកគ្នាពីរាជ្យបល្ល័ង្ក ធ្វើឱ្យលំបាកក៏ត្រូវបានដោះស្រាយដោយភាពល្អប្រសើរដោយការគិតយោងទៅលើ ឆ្នាំនៃការគ្រងរាជ្យ និងការសម្រេចបានពីការគ្រងរាជ្យនោះ ។

**២:១២** អ័ប៊ីនើរ បានផ្ដើមសកម្មភាពដើម្បីការពារទប់និងស្ដេចដាវីឌ ដែលមានឥទ្ធិពលពង្រីកអាណាចក្រនោះទៅផ្នែកខាងត្បូង នៃស្រុកយ័រដាន់ ។ ភ្នំភីលបោក៏មានទីតាំងត្រង់តំបន់ពូជអំបូរ នៃពូជបេនយ៉ាមីន(មើល សយ ១៨:២១,២៥)ដែលមានលោកសូល និងក្រុមគ្រួសារគាត់ក៏ជាកម្មសិទ្ធិទ្រង់ និងពួកដែលភីលីស្ទីនពុំមានចំណែកទេ ។

**២:១៣** *យ៉ូអាប់ជា កូនសេរូយ៉ា* មើលការពន្យល់ ១សយ ២៦:៦ លោកយ៉ូអាប់ប្រែក្លាយជាអ្នកសំខាន់មួយ ក្នុងរជ្ជកាលស្ដេចដាវីឌ ដែលមានលក្ខណៈជាអ្នកមានសមត្ថភាពផ្នែកខាងដឹងនាំទ័ព(មើល ១០:៧-១៤ ១១:១ ១២:២៦ ១ពវ ១១:១៥-១៦)ខណៈនោះស្ដេចដាវីឌ ពុំមានលទ្ធភាពក្នុងការត្រួតត្រាគាត់(៣:៣៩ ១៨:៥,១៤ ១ពវ ២:៥-៦)និងដោយចៃដន្យគាត់ត្រូវបានធ្វើឃាតដោយព្រោះការរួមគំនិតនេះគឺចង់ឱ្យ "អ័ដូនីយ៉ា" (Adoniah) គ្រងរាជ្យលើបល្ល័ង្កស្ដេចដាវីឌជាងស្ដេចសាឡាម៉ូន(១ពវ ២:២៨-៣៤) ។ *ពួកខាងដាវីឌ* គឺយ៉ាងហោចណាស់ក្រុមពួកខាងដាវីឌ ក៏មានជំនាញច្បាស់លាស់ខាងផ្នែកយោធាដែលជួបជុំគ្នានៅជុំវិញគាត់ (មើល ១សយ ២២:២ ២៣:១៣ ២៧:២ ៣០:៣,៩) ។ *ស្រះគីបៀន* មើល យរ ៤១:១២ នៅក្នុងឆ្នាំ ១៩៥៦ ក្រុមអ្នកបូរាណវិទ្យា បានរកឃើញស្រះមួយដ៏ធំគឺស្រះ (គីបៀនបូរាណ) គឺប្រហែលរយៈពេលមួយឆ្នាំក្នុង ១៥-១៦ ។

**២:១៥** *បេនយ៉ាមីន* ក្នុងពេលនេះ អ៊ីស-បូសែត ត្រូវបានផ្ទុកផ្ដាក់យ៉ាងខ្លាំងឬតាមពូជអំបូររបស់ពួកគេ ។

**២:១៧** *ចំបាំងក៏សាហាវណាស់* ពីព្រោះតំណាងខាងការប្រយុទ្ធ(មើលការពន្យល់ ១សយ ១៧:១៤ ដោយពួកទ័ព ១២នាក់ដែលមកពីភាគីទាំងសងខាងមានលក្ខណៈមិនប្រាកដក្នុងចិត្ត ហើយទ័ពរបស់ស្ដេចដាវីឌបានឈ្នះ ។ ដោយមានសេចក្ដីប៉ងក្នុងការប្រើតំណាងភាគី ក្នុងការប្រយុទ្ធគ្នា ក្នុងគោលបំណងកុំឱ្យមានការសម្លាប់រង្គាលនៅពេលចាញ់សង្គ្រាម (មើល ៣:១) ។

**២:២១** *បែរទៅ* គឺលោកអ័ប៊ីនើរ ខំព្យាយាមតែពុំបានសម្រេចក្នុងការ

លោកទៅ មិនព្រមបែរចេញឡើយ ២២អ័ប៊ីនើរក៏ប្រាប់ទៅ
អេសាអែលម្ដងទៀតថា ចូរឯងបែរចេញលែងតាមអញ
ទៅ ត្រូវឱ្យអញវាយឯងឱ្យដួលដល់ដីធ្វើអី បើដូច្នោះធ្វើដូច
ម្ដេចឱ្យអញបានងើបមុខនៅចំពោះយ៉ូអាប់ ជាបងឯងបាន[ស]
២៣ប៉ុន្តែគាត់មិនព្រមបែរចេញសោះឡើយបានជាអ័ប៊ីនើរ
កាន់លំពែងបុះទៅក្រោយ ត្រូវត្រង់ពោះ[ហ]គាត់ដោយចុង
ដងលំពែង ធ្លុះចេញមកក្រោយ ហើយគាត់ដួលស្លាប់នៅ
ទីនោះឯង ឯអស់អ្នកដែលមកតាមក្រោយ ដល់កន្លែង
អេសាអែលដួលស្លាប់នោះ គេក៏ឈប់នៅ[ឡ]។
២៤យ៉ូអាប់ និងអ័ប៊ីសាយ គេចេះតែដេញតាមអ័ប៊ីនើរ
ទៅ កាលគេមកដល់ភ្នំអាំម៉ា ដែលនៅប្រទល់មុខនឹងគីយ៉ា
តាមផ្លូវកាត់ទីរហោស្ថានគីបៀន នោះថ្ងៃក៏លិច ២៥ចំណែក
ពួកខាងបេនយ៉ាមីន គេមូលផ្ដុំគ្នាជាពួក១នឹងអ័ប៊ីនើរ ក៏ឈរ
នៅលើកំពូលកូនភ្នំ១ ២៦នោះអ័ប៊ីនើរ ក៏ស្រែកហៅទៅ
យ៉ូអាប់ថា តើត្រូវឱ្យដាវស៊ីបំផ្លាញ[អ]ជារៀងរាបដរាបឬ តើ
មិនដឹងទេឬអី ថាដល់ចុងបំផុតនឹងមានសេចក្ដីជូរចត់ ដូច្នេះ
តើចាំដល់កាលណាទៀត ទើបប្រាប់ដល់ពួកពល ឱ្យត្រឡប់
វិលទៅវិញលែងដេញតាមបងប្អូនគេនោះ ២៧យ៉ូអាប់ឆ្លើយ
ថា ខ្ញុំស្បថដោយនូវព្រះដ៏មានព្រះជន្មរស់ថា បើឯងមិនបាន
និយាយទេ នោះដល់ព្រឹកឡើង គង់តែពួកពលទាំងប៉ុន្មាន
បានចេញទៅ លែងដេញតាមបងប្អូនគេរៀងខ្លួនហើយ
២៨ដូច្នេះយ៉ូអាប់[ក]ក៏ផ្លុំត្រែឡើង[ខ] ហើយពួកពលឈប់នឹងនៅ
គេលែងដេញតាមពួកអ៊ីស្រាអែលតទៅ ក៏មិនបានច្បាំង
គ្នាទៀតឡើយ ២៩ឯអ័ប៊ីនើរ ព្រមទាំងពួកពលទ័ពរបស់
លោក គេដើរកាត់ស្រុកវាល[គ] ចេញ១យប់នោះ រួចគេឆ្លង
ទន្លេយ័រដាន់ ហើយក៏ដើរកាត់ស្រុកប៊ីត្រោន ដល់ទៅ
ម៉ាហាណែមវិញ[ឃ]។
៣០យ៉ូអាប់ក៏វិលត្រឡប់មក ពីដេញតាមអ័ប៊ីនើរដែរ
ហើយកាលលោកបានប្រមូលពួកពលខាងដាវីឌទាំងអស់
មក នោះឃើញបាត់តែ១៩នាក់ ហើយនិងអេសាអែល
ប៉ុណ្ណោះ ៣១តែពួកពលរបស់ដាវីឌ បានវាយសំឡាប់ខាង
ពួកបេនយ៉ាមីន និងពួកអ័ប៊ីនើរអស់៣៦០នាក់ ៣២រួចគេនាំ
យកសពរបស់អេសាអែល ទៅបញ្ចុះក្នុងផ្នូរ[ង]របស់ឪពុក
គាត់ដែលនៅបេថ្លេហិមទៅ នោះយ៉ូអាប់ព្រមទាំងពួក
លោកក៏ដើរពេញ១យប់នោះ មកដល់ក្រុងហេប្រុននៅ
ពេលថ្ងៃទើបនឹងភ្លឺ ។

៣ ១នៅគ្រានោះ រាជវង្សសូល និងរាជវង្សដាវីឌ គេច្បាំង
គ្នាអស់កាលជាយូរ[ក] តែដាវីឌចេះតែមានកំឡាំងខ្លាំងឡើង[ខ]
ហើយរាជវង្សសូល ក៏កាន់តែខ្សោយទៅ[គ]។
២រីឯនៅក្រុងហេប្រុន ដាវីឌបង្កើតបានបុត្រាខ្លះ បុត្រ
ច្បងរបស់ទ្រង់ គឺអាំណូន[ឃ] ដែលកើតនឹងនាងអ័ហ៊ីណោម[ង]
ជាអ្នកស្រុកយេសរាល ៣បុត្របន្ទាប់ គឺគីលាប ដែលកើត
នឹងនាងអ័ប៊ីកែល[ច] ជាអ្នកស្រុកកើមែល ប្រពន្ធរបស់
ខ្មោចណាបាល បុត្រទី៣ គឺអាប់សាឡំម[ឆ] ជាបុត្រនាងម្អាកា
ដែលជាបុត្រីរបស់តាលម៉ាយ ស្ដេចស្រុកកេស៊ូរី[ជ] ៤បុត្រទី៤
គឺអ័ដូនីយ៉ា[ឈ] ជាបុត្ររបស់នាងហាគីត បុត្រទី៥ គឺសេផាធា
ជាបុត្រនាងអ័ប៊ីថាល ៥បុត្រទី៦ គឺយិតរាម ដែលកើតនឹង
នាងអេកឡាភរិយារបស់ដាវីឌ បុត្រទាំងនេះបានកើតឡើង

**២:២២** ស ២សយ ៣:២៧
**២:២៣** ហ ២សយ ៣:២៧ ៤:៦
ឡ ២សយ ២០:១២
**២:២៦** អ ចទ ៣២:៤២ យរ ៤៦:១០,១៤ ណហ ២:១៣ ៣:១៥
**២:២៨** ក ២សយ ១៨:១៦ ២០:២៣
ខ ពច ៣:២៧
**២:២៩** គ ចទ ៣:១៧
ឃ លប ៣២:២
**២:៣២** ង លប ៤៩:២៩
**៣:១** ក ១ពវ ១៤:៣០ ខ ២សយ ៥:១០ គ ២សយ ២:១៧ ២២:៤៤ នអ ៩:៤
**៣:២** ឃ ២សយ ១៣:១ ង ១សយ ២៥:៤៣
**៣:៣** ច ១សយ ២៥:៤២ ឆ ២សយ ១៣:១,២៨
ជ ២សយ ១៣:៣៧ ១៤:៣២ ១៥:៨
**៣:៤** ឈ ១ពវ ១:៥, ១១ ២:១៣,២២

---

បញ្ជាក់កុំឱ្យគេសម្លាប់អេសាអែល ។
**២:២២** *ដូចម្ដេចឱ្យអញបានងើបមុខនៅចំពោះយ៉ូអាប់ ជាបងឯងបាន* អ័ប៊ីនើរពុំចង់បានភាពជាសត្រូវរវាងខ្លួនគាត់និងយ៉ូអាប់ ទៅជាការអនុវត្តដោយការសងសឹកបង្ហូរឈាមនោះទេ (មើលការពន្យល់ ៣:២៧) ។
**២:២៣** ការឈឺចាប់ចំពោះសត្រូវនៅក្នុងខ្លួន ដែលមានទៅដោយកំហឹងកាត់ទៅវិញ ៣:២៣ ៤:៦ (ប្រៀបធៀប ពច ៣:២១) ។
**២:២៦** *តើត្រូវឱ្យដាវស៊ីបំផ្លាញជារៀងដរាបឬ* អ័ប៊ីនើរក៏ស្នើរសុំនូវបទឈប់ប្រហារគ្នា គឺជាមធ្យោបាយនៃការជៀសវាងមានឡើងនូវសង្គ្រាមស៊ីវិល ។
**២:២៨** *ក៏មិនបានច្បាំងគ្នាទៀតឡើយ* ក្នុងខណៈពេលបច្ចុប្បន្ន ក្នុងការបើកយុទ្ធនាការឈប់បាញ់គ្នា ប៉ុន្តែភាពជាសត្រូវនៅមានជានិច្ច (មើល ៣:១) ។
**៣:២–៥** គឺជាបញ្ជីឈ្មោះកូនទាំង៦ តាមរយៈស្ដេចដាវីឌ ក្នុងក្រុងហេប្រុន ដែលបង្ហាញពីភាពខ្លាំងនៃស្ដេចដាវីឌ ដែលផ្ទុយទៅនិងស្ដេចសូល (ខ.១) ហើយបុត្រាទាំង៦នោះ គឺកើតចេញពីម្ដាយទីទៃៗពីគ្នា ដោយព្រោះស្ដេចដាវីឌបានការជាមួយប្រពន្ធ៤បន្ថែមទៀត (មើល ២:២) គឺក្នុងរជ្ជកាលទ្រង់នៅក្នុងក្រុងហេប្រុន ។ *អាំណូន* ជាកូនច្បងនៅស្រុកហេប្រុន ក្រោយមកក៏រំលោភប្អូនស្រីរបស់តាលម៉ាយ និងត្រូវបានសម្លាប់បងប្រុសគាត់ឈ្មោះអាប់សាឡំម (មើល ជំពូក ១៣) ។ *នាមអ័ហ៊ីណោមជាអ្នកស្រុកយេសរាល* មើលការពន្យល់ ១សយ ២៥:៤៣ ។
**៣:៣** *គីលាប* ដែលហៅថាដានីយ៉ែល ក្នុង ១របា ៣:១ ។ *នាងអ័ប៊ីកែល* មើល ១សយ ២៥ ។ *អាប់សាឡំម* ក្រោយមកបានសងសឹកទៅលើបទរំលោភដោយការសម្លាប់អាំណូន ហើយក៏ប្រឆាំងនិងបិតាដែលជាស្ដេចដាវីឌ ក្នុងគោលបំណងលើកខ្លួនឯងធ្វើជាស្ដេច (មើល ជំពូក ១៣:១៨) ។ *ម្អាកាដែលជាបុត្រីរបស់តាលម៉ាយ* ការរៀបការនៃស្ដេចដាវីឌ និងម្អាកាដោយមិនគិតពីបញ្ហានយោបាយ ។ ដែលមានតាលម៉ាយបានចងសម្ព័ន្ធភាពនិងអ៊ីស–បូសែតជាបុត្រាសូលឯព្រំប្រទល់ខាងជើង ឯស្ដេចដាវីឌបានវាយយកនគរខាងជើង និងខាងត្បូង ។ *ស្រុកកេស៊ូរី* គឺជាទីក្រុងតូចមួយ (មើល ១៥:៨) គឺមានទីតាំង ផ្នែកខាងជើងនៃសមុទ្រកាលីឡេ (មើល យស ១២:៥ ១៣:១១–១៣) ។
**៣:៤** *អ័ដូនីយ៉ា* ត្រូវបានកាត់ទោសប្រហាជីវិត ក្នុងការប៉ុនប៉ងយករាជបល្ល័ង្គមុនស្ដេចសាឡូម៉ូន (មើល ១ពវ ១–២) ។

ដល់ដាវីឌនៅក្រុងហេប្រុន ។

## អ័ប៊ីនើរចុះចូលនឹងស្ដេចដាវីឌ

៦ នៅគ្រាដែលរាជវង្សសូល និងរាជវង្សដាវីឌកំពុងតែ
មានចំបាំងដល់គ្នា នោះអ័ប៊ីនើរ[ញ]ក៏ចំរើនកំឡាំងខ្លួនខាងឯ
រាជវង្សសូល ៧ រីឯសូលទ្រង់មានអ្នកម្នាងម្នាក់[ដ] ឈ្មោះរីស
ប៉ា[ឋ] ជាកូនអ័យ៉ា គ្រានោះ អ៊ីស-បូសែតមានបន្ទូលទៅ
អ័ប៊ីនើរថា ហេតុអ្វីបានជាអ្នកចូលទៅឯស្ត្រីអ្នកម្នាងរបស់
បិតាយើងដូច្នេះ ៨ នោះអ័ប៊ីនើរក៏មានសេចក្ដីកំហឹងឆួល
ឡើង ដោយព្រោះពាក្យរបស់អ៊ីស-បូសែត ហើយទូលថា
ទូលបង្គំជាក្បាលឆ្កែ[ឌ]របស់ផងពួកយូដាឬអី សព្វថ្ងៃនេះ
ទូលបង្គំកំពុងតែសំដែងគុណ ដល់រាជវង្សរបស់សូល ជា
បិតាទ្រង់ ព្រមទាំងវង្សានុវង្ស និងមិត្រសំឡាញ់ទ្រង់ផង
ដោយមិនបានប្រគល់ទ្រង់ ទៅក្នុងកណ្ដាប់ដៃដាវីឌឡើយ
តែនៅថ្ងៃនេះ ទ្រង់ហ៊ានបន្ទោសទូលបង្គំ ពីរឿងស្រីនោះឬ
៩ បើសិនជាទូលបង្គំមិនលើកដាវីឌឡើង តាមដូចជាព្រះ
យេហូវ៉ាបានស្បថនឹងទ្រង់ហើយ[ឍ] នោះសូមឱ្យព្រះធ្វើដល់
អ័ប៊ីនើរខ្ញុំនេះយ៉ាងដូច្នោះ ហើយលើសទៅទៀតផង ១០ គឺ
ទូលបង្គំនឹងផ្ទេររាជ្យ ពីរាជវង្សសូលទៅលើដាវីឌ ឱ្យ
សោយរាជ្យឡើង លើពួកអ៊ីស្រាអែល និងពួកយូដាវិញ
ចាប់តាំងពីក្រុងដាន់ រហូតដល់បៀរ-សេបា[ណ] ១១ នោះទ្រង់
រកឆ្លើយតបនឹងអ័ប៊ីនើរសូម្បីតែ១ម៉ាត់ក៏មិនបានផង ដោយ

៣:៦ ញ ១សយ ១៤:៥០
៣:៧ ដ លប ២២:២៤ ២សយ ១៦:២១-២២ ១ពវ ១:៣ ឋ ២សយ ២១:៨-១១
៣:៨ ឌ ១សយ ១៧:៤៣ ២សយ ៩:៨ ១៦:៩ ២ពវ ៨:១៣
៣:៩ ឍ ១សយ ១៥:២៨
៣:១០ ណ ពច ២០:១ ១សយ ២៥:២៨-៣១ ២សយ ២៤:២
៣:១៣ ត លប ៤៣:៥
៣:១៤ ថ ១សយ ១៨:២៧
៣:១៥ ទ ចទ ២៤:១-៤ ធ ១សយ ២៥:៤៤
៣:១៦ ន ២សយ ១៦:៥ ១៧:១៨
៣:១៧ ប ពច ១១:១១

ព្រោះខ្លាចលោក ។
១២ នោះអ័ប៊ីនើរចាត់សារឱ្យទៅឯដាវីឌ ដោយនូវឈ្មោះ
ខ្លួន ដើម្បីទូលថា តើអ្នកណាជាស្ដេចផែនដី សូមតាំងសញ្ញា
នឹងទូលបង្គំចុះ នោះទូលបង្គំនឹងចូលដៃខាងទ្រង់ ដើម្បីនឹង
នាំពួកអ៊ីស្រាអែលទាំងអស់ ឱ្យវិលមកខាងទ្រង់ ១៣ ដាវីឌក៏
តបថា អើ យើងនឹងចុះសញ្ញានឹងអ្នក ប៉ុន្តែតោងឱ្យអ្នកធ្វើ
ការនេះសិន គឺអ្នកមិនឃើញមុខយើងឡើយ ទាល់តែបាននាំ
មីកាល ជាបុត្រីសូលមក ក្នុងកាលដែលអ្នកមកសួរយើង[ត]
១៤ ដាវីឌក៏ចាត់សារឱ្យទៅឯអ៊ីស-បូសែត ជាបុត្រាសូល
ថា ចូរឱ្យមីកាល[ថ] ជាប្រពន្ធខ្ញុំ ដែលខ្ញុំបានដណ្ដឹង ដោយ
សាស្បែកចុងស្វាសនៃពួកភីលីស្ទីន១០០នាក់នោះមកខ្ញុំ
វិញ ១៥ នោះអ៊ីស-បូសែតក៏ចាត់គេឱ្យទៅនាំយកនាងពី
ប៉ាលធាល[ទ] ជាកូនឡាអ៊ីសប្ដីនាង[ធ]មក ១៦ ឯប្ដីនាង គាត់ដើរ
មកតាមនាងទាំងយំបណ្ដើរ រហូតដល់ភូមិបាហ៊ូរីម[ន]ទើប
អ័ប៊ីនើរបង្គាប់ទៅថា ចូរវិលទៅវិញចុះ នោះគាត់ក៏ត្រឡប់
ទៅវិញ ។
១៧ គ្រានោះ អ័ប៊ីនើរមានប្រសាសន៍នឹងពួកចាស់ទុំ[ប]នៃ
ពួកអ៊ីស្រាអែលថា កាលពីដើមអ្នករាល់គ្នាចង់បានដាវីឌឱ្យ
ធ្វើជាស្ដេចលើអ្នករាល់គ្នា ១៨ ឥឡូវនេះចូរតាំងឡើងចុះ
ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូលពីដាវីហើយថា អញ

៣:១៨ ផ ១សយ ៩:១៦ ព ២សយ ៨:៦

**៣:៧** *រីសប៉ា* មើល ២១:៨-១១ ។ *ហេតុអ្វីបានជាអ្នកចូលទៅឯស្ត្រីអ្នកម្នាងរបស់បិតាយើងដូច្នេះ* អ៊ីស-បូសែត សង្ស័យថាសកម្មភាពរបស់អ័ប៊ីនើរ គឺកំពុងរួមគំនិតធ្វើឃាដព្រះមហាក្សត្រ (ខ.៦) មើលការពន្យល់ ១២:៨ ១៦:២១ ១ពវ ២:២២ ។

**៣:៨** *ក្បាលឆ្កែ* ប្រៀបធៀប ការពន្យល់ ៩:៨ ។

**៣:៩** *សូមឱ្យព្រះធ្វើដល់អ័ប៊ីនើរខ្ញុំនេះយ៉ាងដូច្នេះ ហើយលើសទៅទៀតផង* (មើលការពន្យល់ ១សយ ៣:១៧) គឺជាផែនការព្រះយេហូវ៉ាបានសន្យានិងទ្រង់ ។ គឺជាចំណេះដឹងទាំងឡាយដែលស្ដេចដាវីឌបានទទួលពីព្រះបានទទួលជ័យជម្នះដល់ស្ដេចសូល ក៏បានពង្រីកយ៉ាងធំធេង(មើលការពន្យល់ ២:៤ ១សយ ១៦:១៣ ២៥:២៨) ។

**៣:១២** *តើអ្នកណាជាស្ដេច* គឺជាសំណួរដែលទាក់ទងនិងស្រុកជារបស់អ័ប៊ីនើរ និងស្ដេចដាវីឌ គឺដូចឃ្លាខាងក្រោមបញ្ជាក់ ។ *តើអ្នកណាជាស្ដេចផែនដី សូមតាំងសញ្ញានិងទូលបង្គំចុះ* អ័ប៊ីនើរចង់បានការវាយយកមកវិញដោយស្មោះត្រង់ សម្រាប់ពេលកន្លងមកដែលនៅក្នុងដំណាក់របស់សូល ។

**៣:១៣** *មីកាលជាបុត្រីសូស* ទោះជាលោកសូលបានថ្វាយបុត្រីមីកាលឱ្យទៅស្ដេសដាវីឌក៏ដោយ (១សយ ១៨:២៧) តែក្រោយមកទៀតលោកបានថ្វាយទៅបុរសផ្សេងមួយទៀត ក្នុងខណៈពេលដែលស្ដេចដាវីឌចេញពីទីជំនុំរបស់គាត់(១សយ ២៥:៤៤)ស្ដេចដាវីឌក៏មានអារម្មណ៍ ចំពោះចាស់ទុំនៅផ្នែកតំបន់ខាជើង ការផ្សះផ្សារបស់គាត់ជាមួយនាងមីកាល គឺជាការពង្រីកសេចក្ដីប្រកាស់របស់គាត់ចំពោះរាជបល័ង្គ ជាលក្ខណៈស្របតាមក្រឹត្យច្បាប់ដែលជាកូនប្រសារប្រុសនៃលោកសូល ។

**៣:១៤** *ដាវីឌក៏ចាត់សារឱ្យទៅឯអ៊ីស-បូសែត* ដាវីឌចង់ឱ្យនាងមីកាលវិលត្រឡប់មកវិញជាចំហរ ហើយតាមច្បាប់ត្រឹមត្រូវ ។ ស្ដេចដាវីឌដឹងថា អ៊ីស-បូសែតមិនហានបដិសេធដើម្បីប្រឆាំងនិងសេចក្ដីប៉ងប្រាថ្នា(មើល ខ.១១)។ *ពួកភីលីស្ទីន១០០នាក់នោះមកឯខ្ញុំវិញ* មើល ១សយ ១៨:២៥ ។ ស្ដេចសូលបានទាមទាពួកភីលីស្ទីន ១០០នាក់ ឯស្ដេចដាវីឌក៏បង្ហាញថាយកចំនួន ២០០ (១សយ ១៨:២៧) ។

**៣:១៦** *ភូមិបាហ៊ូរីម* គឺជិតភ្នំអូលីវ ។

**៣:១៧** *ពួកចាស់ទុំនៃពួកអ៊ីស្រាអែល* គឺជាការប្រមូលផ្ដុំអ្នកដឹកនាំ នៃពូជអំបូរ(មើលការពន្យល់ នក ៣:១៦ យអ ១:២ មើល ១សយ ៨:៤ ២សយ ៥:៣ ១ពវ ៨:១,៣ ២០:៧ ២ពវ ១០:១ ២៣:១) ។ *អ្នករាល់គ្នាចង់បានដាវីឌឱ្យធ្វើជាស្ដេចលើអ្នករាល់គ្នា* យើងឃើញថា អ៊ីស-បូសែត គឺមានប្រភពចេញពីអំបូរពួកបេនយ៉ាមីន(មើល ២:១៥ និងការពន្យល់) និងចេញពីពួកកាឡាត នៅផ្នែកខាងកើតនៃទន្លេយ័រដាន់(មើល ២:៨ ១សយ ១១:៩-១១ ៣១:១១-១៣)។

**៣:១៨** *ព្រះយេហូវ៉ាបានមានបន្ទូលពីដាវីឌហើយ* គឺខណៈពេលដែលសាំយូអែលបានចាក់ប្រេងតាំងឱ្យស្ដេចដាវីឌ ក៏មានចំណេះដឹងរួមមួយ ។ (មើល ៥:២) ឯលោកអ័ប៊ីនើរប្រហែលជាមានការចាប់អារម្មណ៍ ពីការចាក់ប្រេង

នឹងជួយសង្គ្រោះពួកអ៊ីស្រាអែល ជារាស្ត្រអញ ឱ្យរួចពី
កណ្ដាប់ដៃនៃពួកភីលីស្ទីន[ផ] ហើយពីកណ្ដាប់ដៃនៃពួកខ្មាំង
សត្រូវទាំងអស់ ដោយសារដៃដាវីឌ ជាអ្នកបំរើរបស់អញ[ព]
១៩ អ័ប៊ីនេរក៏មានប្រសាសន៍ដល់ពួកបេនយ៉ាមីនដែរ រួច
លោកទៅក្រាបទូលដាវីឌ នៅត្រង់ក្រុងហេប្រុន តាមគ្រប់
ទាំងសេចក្ដីដែលពេញចិត្តដល់ពួកអ៊ីស្រាអែល និងពួកគ្រួ
បេនយ៉ាមីន[ភ]ទាំងអស់ ២០ ដូច្នេះ អ័ប៊ីនេរបានមកឯដាវីឌនៅ
ក្រុងហេប្រុន មានទាំងមនុស្ស២០នាក់មកជាមួយផង ឯ
ដាវីឌ ទ្រង់រៀបជប់លៀង[ម]អ័ប៊ីនេរ និងពួកមនុស្សដែល
មកជាមួយដែរ ២១ នោះអ័ប៊ីនេរទូលទៅដាវីឌថា ទូលបង្គំ
នឹងឡើងចេញទៅប្រមូលពួកអ៊ីស្រាអែលទាំងអស់ ឱ្យមក
ឯព្រះករុណា ជាម្ចាស់នៃទូលបង្គំ ដើម្បីឱ្យគេចុះសញ្ញា[យ]
នឹងទ្រង់ ឱ្យទ្រង់បានសោយរាជ្យលើគ្រប់ទាំងអស់តាមព្រះ
ហឫទ័យ[រ] រួចដាវីឌទ្រង់ឱ្យអ័ប៊ីនេរទៅវិញ ហើយលោកក៏
ទៅដោយសុខសាន្ត ។

## យ៉ូអាប់សម្លាប់អ័ប៊ីនេរ

២២ ខណនោះ យ៉ូអាប់នឹងពួកពលរបស់ដាវីឌ ត្រឡប់មក
ពីលុកលុយស្រុកក្រៅវិញ ក៏នាំយករបឹបជាច្រើនមកជាមួយ
ដែរ តែចំណែកអ័ប៊ីនេរមិននៅជាមួយនឹងដាវីឌក្នុងក្រុង
ហេប្រុនទេ ដ្បិតទ្រង់បានឱ្យលោកទៅផុតហើយលោកក៏
បានទៅដោយសុខសាន្ត ២៣ កាលយ៉ូអាប់ និងពួកពលទាំង
ប៉ុន្មាន ដែលនៅជាមួយនឹងលោក បានមកដល់ហើយ នោះ
មានគេជំរាបយ៉ូអាប់ថា អ័ប៊ីនេរ ជាកូននេរបានឡើងមក
គាល់ស្ដេច ហើយទ្រង់បានឱ្យទៅវិញដោយសុខសាន្ត
២៤ នោះយ៉ូអាប់លោកចូលទៅឯស្ដេចទូលសួរថា តើទ្រង់
បានធ្វើអ្វីដូច្នេះ មើលអ័ប៊ីនេរបានមកគាល់ទ្រង់ តើហេតុ
អ្វីបានជាទ្រង់ឱ្យចេញទៅ ហើយវាទៅបាត់ដូច្នេះ ២៥ ទ្រង់
ស្គាល់អ័ប៊ីនេរ ជាកូននេរហើយ ថាវាបានមកដើម្បីតែនឹង
បញ្ឆោតទ្រង់ទេ ហើយឱ្យបានដឹងពីដំណើរទ្រង់យាងចេញ
ចូល និងគ្រប់ទាំងកិច្ចការដែលទ្រង់ធ្វើផង ២៦ រួចកាល
យ៉ូអាប់បានចេញពីចំពោះដាវីឌទៅ នោះក៏ចាត់គេឱ្យទៅ
តាមហៅអ័ប៊ីនេរមក គេនាំលោកពីត្រង់អណ្ដូងស៊ីរ៉ាមក
វិញ តែដាវីឌមិនជ្រាបទេ ។
២៧ កាលអ័ប៊ីនេរ[ល]បានមកដល់ក្រុងហេប្រុនវិញ នោះ
យ៉ូអាប់ក៏នាំលោក ទៅឯទីកណ្ដាលទ្វារកំផែងក្រុងដោយ
ឡែក ដើម្បីមានប្រសាសន៍នឹងលោកដោយសំងាត់ រួចក៏
ចាក់លោក[វ]ត្រង់ពោះនៅទីនោះឱ្យស្លាប់ទៅ[ស] ដើម្បីសង
សឹកចំពោះឈាមអេសាអែលជាប្អូនខ្លួន ២៨ កាលដាវីឌបាន
ជ្រាប នោះទ្រង់មានបន្ទូលថា ឯអញហើយនិងរាជ្យអញ
ឥតមានទោស[ហ]ខាងឯសាច់ឈាមអ័ប៊ីនេរ ជាកូននេរនេះ
នៅចំពោះព្រះយេហូវ៉ា ជាដរាបទៅ ២៩ សូមឱ្យទោស
នោះ[ឡ]ធ្លាក់ទៅលើក្បាលយ៉ូអាប់ និងវង្សាញាតិរបស់គេ
ទាំងអស់[អ]វិញចុះ សូមកុំឱ្យខានមានអ្នកណា ក្នុងពូជពង្ស
យ៉ូអាប់ដែលហូរខ្ទុះ[ក] ឬកើតឃ្លង់ ឬដែលត្រូវច្រត់លើឈើ
ច្រត់ ឬដែលដួលស្លាប់ដោយដាវ ឬដែលខ្វះអាហារនោះ
ឡើយ ៣០ គឺយ៉ាងនោះ ដែលយ៉ូអាប់ និងអ័ប៊ីសាយ ជាប្អូន
លោកបានសំឡាប់អ័ប៊ីនេរទៅ ដោយព្រោះសំឡាប់អេសា
អែលជាប្អូន នៅក្នុងចំបាំងត្រង់គីបៀន ។
៣១ គ្រានោះ ដាវីឌទ្រង់ត្រាស់បង្គាប់ដល់យ៉ូអាប់ និង
បណ្ដាទ័ពរាល់គ្នា ដែលនៅជាមួយនឹងលោកថា ចូរឯង
រាល់គ្នាហែកសំលៀកបំពាក់ខ្លួន ហើយស្លៀកសំពត់ធ្មៃ[ខ]រួច
យំសោក[គ]នៅចំពោះសពអ័ប៊ីនេរទៅ ឯដាវីឌទ្រង់ក៏យាង

**៣:១៩** ភ ១របា ១២:២,១៦,២៩
**៣:២០** ម ១របា ១២:៣៩
**៣:២១** យ ២សយ ៥:៣ រ ១ពវ ១១:៣៧
**៣:២៧** ល ២សយ ២:៨ ៤:១ ១ពវ ២:៥,៣២ វ នក ២១:១៤ ពច ៣:២១ ២សយ ២:២៣ ស ២សយ ២:២២
**៣:២៨** ហ ខ.៣៧ ចទ ២១:៩
**៣:២៩** ឡ លវ ២០:៩ អ ១ពវ ២:៣១–៣៣ ក លវ ១៥:២
**៣:៣១** ខ ទដ ៣០:១១ ៣៥:១៣ ៦៩:១១ អស ២០:២ គ លប ៣៧:៣៤

តាំងដូចជាព្រះបានសន្យារួមមក ។

**៣:១៩** *អ័ប៊ីនេរក៏មានប្រសាសន៍ដល់ពួកបេនយ៉ាមីន* ពីព្រោះស្ដេចសូលនិងក្រុមគ្រួសារគាត់ក៏ចេញពីពូជអំបូរបេនយ៉ាមីនដែរ ។ ឯអ័ប៊ីនេរបានទទួលព្រឹក្សាយ៉ាងប្រុងប្រយ័ត្ន គឺអ្វីៗដែលទាក់ទងនិងការផ្លាស់ប្ដូរស្ដេចឱ្យទៅជាអំបូរសាសន៍យូដា ។

**៣:២១** *ដើម្បីឱ្យចុះសញ្ញានឹងទ្រង់* មើល ៥:៣ និងការពន្យល់ ។

**៣:២៥** *មកដើម្បីតែបញ្ឆោតទ្រង់ទេ* យ៉ូអាបបានម៉ាកងាយប្រមាតដល់លោកអ័ប៊ីនេរចំពោះការសម្លាប់បងប្រុសរបស់គាត់(២:១៨,២៨ ៣:២៧)និងបានប្រមាថគាត់នៅខាងមុខស្ដេចដាវីឌ ។ ហើយគាត់ក៏ត្រូវបានគម្រាមកំហែងឱ្យចូលរួមជាមួយដាវីឌ គឺក្នុងពេលអ័ប៊ីនេរមានអំណាចយ៉ាងខ្លាំងក្លាក្នុងតំបន់ពូជអំបូរផ្នែកខាងជើង ។

**៣:២៧** *ទ្វារកំផែងក្រុង . . . ដោយឡែក* ទ្វារកំផែងក្រុងគឺមានទំហំតូចល្មមដែលមានតូបយាម *យ៉ូអាប់ក៏នាំ . . . រួចចាក់លោកត្រង់ពោះនៅទីនោះឱ្យស្លាប់ទៅ* ការធ្វើឃាដរបស់យ៉ូអាប់ចំពោះអ័ប៊ីនេរគឺមិនមែនដោយព្រោះសង្គ្រាមឬសងសឹកឈាមដោយឈាមទេ(ជន ៣៥:១២ ចទ ១៩:១១–១៣) ។ (មើល ខ.៣០ ក៏មើល ២:២១,២៣ និងការពន្យល់) ។

**៣:២៩** *សូមឱ្យទោសនោះធ្លាក់លើក្បាលយ៉ូអាប់ និងវង្សាញាតិរបស់គេទាំងអស់វិញចុះ* បន្ទាប់ពីការប្រកាសមិនគាំទ្រពីការចូលរួមក្នុងការរួមគំនិតលបធ្វើការអាក្រក់ ក្នុងការធ្វើឃាដលោកអ័ប៊ីនេរ (ខ.២៨) ស្ដេចដាវីឌបានដាក់បណ្ដាសាដល់យ៉ូអាប់ ហើយអំពាវនាវដល់ព្រះយេហូវ៉ាឱ្យកាត់ទោសដល់អំពើអាក្រក់របស់យ៉ូអាប់ ។ កាលស្ដេចដាវីឌមានទំនាក់ទំនងនិងក្រុមពូជអំបូរនៅតំបន់ខាងជើងគឺមានហេតុការអាក្រក់របស់យ៉ូអាប់(មើល ខ.៣៩) (១ពវ ២:៥–៦,២៩–៣៤) ។

**៣:៣១** *យ៉ូអាប់* គាត់ក៏ដូចគ្នាដែរគឺត្រូវបានគេបង្ខំឱ្យចូលរួមក្នុងការទទួលទុក្ខការចូលរួមរបស់យ៉ូអាប់ក៏គេពុំបានដឹងជាទូទៅទេ ហើយស្ដេចដាវីឌសង្ឃឹមនិងរក្សាបញ្ហានេះជាសម្ងាត់ក្នុងរយៈពេលនោះ ។

តាមក្តាមឈូសដែរ ៣២ គេបញ្ចុះសពអ័ប៊ីនេរ នៅត្រង់
ហេប្រុន ហើយស្តេចទ្រង់ព្រះកន្សែង[ឃ] នៅត្រង់ផ្នូរលោក ឯ
ពួករាស្ត្រទាំងប៉ុន្មានក៏យំសោកដែរ ៣៣ ទ្រង់ទួញទំនួញ[ង]នឹង
អ័ប៊ីនេរថា តើគួរឱ្យអ័ប៊ីនេរស្លាប់ ដូចជាមនុស្សលីលា
ដូច្នេះឬអី ៣៤ ដៃឯងឥតជាប់ចំណង ហើយជើងក៏ឥតជាប់
ច្រវាក់ដែរ[ច] ឯងបានដួលស្លាប់ ដូចជាមនុស្សដែលត្រូវដួល
ស្លាប់ ដោយសារពួកទុច្ចរិត រួចបណ្តាជនទាំងអស់គ្នា ក៏យំ
នឹងលោកម្តងទៀត ៣៥ នោះបណ្តាជនទាំងប៉ុន្មានក៏មូលមក
ដើម្បីនឹងតឿនឱ្យដាវីឌសោយព្រះស្ងោយ ក្នុងពេលដែល
នៅភ្លឺនៅឡើយ ប៉ុន្តែដាវីឌទ្រង់ស្បថា បើយើងគ្រាន់តែភ្លក់
អាហារ[ឆ] ឬអ្វីទៀតមុនដែលថ្ងៃលិច នោះសូមឱ្យព្រះទ្រង់
ធ្វើដល់យើងដូច្នេះ ហើយលើសទៅទៀតផងចុះ[ជ] ៣៦ ពួក
បណ្តាជនទាំងឡាយក៏ឃើញ ហើយការនោះបានពេញចិត្ត
ដល់គេ ដូចជាគ្រប់ការទាំងអស់ដែល ស្តេចធ្វើក៏ត្រូវចិត្តគេ
ដែរ ៣៧ ដូច្នេះនៅថ្ងៃនោះបណ្តាជននឹងពួកអ៊ីស្រាអែលទាំង
អស់ គេយល់ឃើញថា ដែលគេបានសំឡាប់អ័ប៊ីនេរ ជាកូន
នេរទៅ នោះមិនមែនមក[ឈ]អំពីស្តេចទេ ៣៨ ស្តេចទ្រង់ក៏
មានបន្ទូលទៅពួកមហាតលិកទ្រង់ថា តើមិនដឹងទេឬអីថា
នៅថ្ងៃនេះ មានមេជាអ្នកធំម្នាក់ ក្នុងពួកអ៊ីស្រាអែល បាន
ដួល[ញ]ស្លាប់ហើយ ៣៩ ហើយនៅថ្ងៃនេះ ទោះបើគេបានចាក់
ប្រេងតាំងយើង ឱ្យធ្វើជាស្តេចក៏ដោយ គង់តែយើងខ្សោយ
ដែរ ឯពួកកូនសេរូយ៉ា[ដ]ទាំងនេះ គេរឹងទទឹងនឹង[ឋ] យើង
ហួសពេក[ឌ] ដូច្នេះ សូមឱ្យព្រះយេហូវ៉ាសង[ឍ]ដល់អ្នកដែល
ប្រព្រឹត្តអាក្រក់នេះ តាមការអាក្រក់របស់ខ្លួនគេចុះ ។

## ការធ្វើឃាតអ៊ីស-បូសែត

៤ ១ កាលអ៊ីស-បូសែតជាបុត្រាសូល បានជ្រាបថាអ័ប៊ីនេរ[ក]
ស្លាប់នៅក្រុងហេប្រុនដូច្នោះ នោះព្រះហស្តទ្រង់ក៏អន់ថយ
កំឡាំងទៅ ហើយពួកអ៊ីស្រាអែលទាំងអស់គ្នាក៏មានសេចក្តី
វន្ទត់ ២ រីឯអ៊ីស-បូសែតទ្រង់មានមេទ័ព២នាក់ ១ឈ្មោះ
បាណា ហើយ១ទៀតឈ្មោះរេកាប ទាំង២នោះជាកូនរីម៉ូន
ដែលជាពួកបៀរ៉ុត[ខ] ក្នុងពូជអំបូរបេនយ៉ាមីនដ្បិតស្រុក
បៀរ៉ុត ក៏រាប់ទុកជារបស់ផងពួកបេនយ៉ាមីនដែរ ៣ ហើយ
ពួកបៀរ៉ុតនោះ បានរត់ទៅតាំងទីលំនៅ នៅឯគីថែម[គ]វិញ
ដរាបដល់សព្វថ្ងៃនេះ។
៤ ចំណែកយ៉ូណាថាន[ឃ] ជាបុត្រាសូលទ្រង់មានបុត្រា១
នាមជាមភីបូសែត[ង] ដែលមានជើងខ្វិន ដ្បិតកាលមាន
ព្រះជន្ម៥ឆ្នាំ ក្នុងខណដែលឮដំណឹង[ច]មកពីយេសរាលពី
ដំណើរសូលនិងយ៉ូណាថាន នោះភីលៀង ក៏ពររត់ទៅ
ហើយដោយព្រោះនាងរត់ទៅប្រញាប់ប្រញាល់ពេក បាន
ជាកុមារភ្លាត់ធ្លាក់ ហើយខ្វិនទៅ[ឆ] ។
៥ រីឯរេកាប និងបាណា ជាកូនរីម៉ូន ពួកបៀរ៉ុតនោះគេ
ក៏ទៅឯដំណាក់អ៊ីស-បូសែត[ជ] ក្នុងពេលប្រហែលជាថ្ងៃ
ពេញកំដៅ កំពុងដែលទ្រង់ផ្ទំនៅវេលាថ្ងៃត្រង់[ឈ] ៦ គេចូល
ទៅក្នុងដំណាក់ធ្វើដូចជាចូលទៅ យកស្រូវភោជ្ជសាលីក៏
ចាក់ទ្រង់ត្រង់ឧទរសំឡាប់ទៅ រួចនាំគ្នារត់ទៅបាត់ ៧ រីឯ
កាលគេបានចូលទៅក្នុងដំណាក់ កំពុងដែលទ្រង់ផ្ទំនៅលើ
ព្រះទែនក្នុងបន្ទប់សំរាប់ផ្ទំ នោះគេបានធ្វើគុត[ញ]ទ្រង់ទៅរួច

**៣:៣២** ឃ លប ៥០:១០ **៣:៣៤** ង យប ៣៦:៨ ទដ ២:៣ ១៤៩:៨ អស ៤៥:១៤ ណហ ៣:១០ **៣:៣៥** ច នរ ១:១៧ ឆ ១សយ ៣១:១៣ ២សយ ១២:១៧ យរ ១៦:៧ **៣:៣៧** ជ ខ.២៨ **៣:៣៨** ឈ ២សយ ១:១៩ **៣:៣៩** ញ ២សយ ២:១៨ ដ ២សយ ១៦:៩ ១៨:១១ ឋ ពច ១៨:២៦ ឌ ១ពវ ២:៣២ ទដ ៤១:១០ ១០១:៨ **៤:១** ក ២សយ ៣:២៧ **៤:២** ខ យស ៩:១៧ **៤:៣** គ នហ ១១:៣៣ **៤:៤** ឃ ១សយ ១៨:១ ង ២សយ ៩:៨,១២ ១៦:១-៤ ១៩:២៤ ២១:៧-៨ ១រប ៨:៣៤ ៩:៤០ ច លវ ២១:១៨ ឆ ១សយ ៣១:៩ **៤:៥** ជ ២សយ ២:៨ ឈ នរ ២:៧ **៤:៦** ញ ២សយ ២:២៣ **៤:៧** ដ ចទ ៣:១៧

**៣:៣២** *ហេប្រុន* គឺជាទីក្រុងរាជវាំងរបស់ស្តេចដាវីឌនៅពេលនោះ ។ *ស្តេចទ្រង់ព្រះកន្សែង នៅត្រង់ផ្នូរលោកឯពួករាស្ត្រទាំងប៉ុន្មានក៏យំសោកដែរ* ដោយព្រោះការធ្វើឃាដរបស់លោក អ័ប៊ីនេរគឺជាការបំផ្លាញសាសន៍ជាតិក្រោមការដឹកនាំរបស់ស្តេចដាវីឌ ។ ស្តេចដាវីឌបានប្រើលទ្ធភាពដើម្បីបង្ហាញបញ្ជាក់ពីភាពគ្មានកំហុសរបស់គាត់ចំពោះរាស្ត្រទ្រង់ ។ គឺក្នុងកាលៈទេសៈនេះហើយស្តេចដាវីឌបានជោគជ័យ (មើល ខ.៣៦-៣៧) ។

**៣:៣៣-៣៤** គឺជាការទួញសោកដោយច្រៀងដោយស្តេចដាវីឌ ចំពោះការដឹកនាំធ្លាក់ចុះ មើល ១:១៩-២៧ ។

**៣:៣៥** *តឿនឱ្យដាវីឌសោយព្រះស្ងោយ . . . ប៉ុន្តែដាវីឌ* មើល ១:១២ មើល ១សយ ៣១:១៣ និងការពន្យល់ ។ *សូមឱ្យព្រះទ្រង់ធ្វើដល់យើងដូច្នេះ* គឺជាសញ្ញានៃបណ្តាសា (មើល ១សយ ៣:១៧) ។

**៣:៣៩** *សូមឱ្យព្រះយេហូវ៉ាសងដល់អ្នកដែល ប្រព្រឹត្តអាក្រក់នេះតាមការអាក្រក់របស់ខ្លួនគេចុះ* មើលការពន្យល់ ខ.២៩ ។

**៤:១** *អន់ថយកំឡាំងចិត្ត* លោក អ៊ីស-បូសែតក៏មានការព្រួយព្រះទ័យក្នុងការដែលទ្រង់ពឹងផ្អែកលើអ័ប៊ីនេរ (មើលការពន្យល់ ២:៨) ។ *ពួកអ៊ីស្រាអែលទាំងអស់គ្នាក៏មានសេចក្តីវន្ទត់* ជាសេចក្តីតស៊ូរដ៏វេទនា ដែលត្រូវគម្រាមកំហែងនិងពូជអំបូរផ្នែកខាងជើង គឺពុំមានអ្នកដឹកនាំខ្លាំងពូកែទេ ។

**៤:២** *ស្រុកបៀរ៉ុត* គឺជាទីក្រុងមួយនៃទីក្រុងគីបៀន (យស ៩:១៧) គឺមានពួកបេនយ៉ាមីន (យស ១៨:២១,២៥) ។

**៤:៤** *យ៉ូណាថានជាបុត្រាសូលទ្រង់មានបុត្រា១* អ្នកនិពន្ធក៏បានបញ្ជាក់ពីការស្លាប់របស់ អ៊ីស-បូសែត (មើល ខ.៦) ក៏ពុំមានអ្នកទាមទារណាមួយអាចទៅរួចចំពោះបល្ល័ង្គនៃដំណាក់របស់ស្តេចសូល ។ *ពីដំណើរសូលនិងយ៉ូណាថាន* មើល ១:៤ ១សយ ៣១:២-៦ មភីបូសែត មើល ៩:១-១៣ ១៦:១-៤ ១៩:២៤-៣០ ២១:៧ ឈ្មោះដែលជាប្រភពដើម គឺមេរីបបាល (ក៏មានអត្ថន័យត្រូវនិងបាល មើល ១រប ៨:៣៤) ប្រហែលគេបញ្ចេញសំឡេងថា "បាល" (សេចក្តីស្រឡាញ់នៃព្រះបាល) តែត្រូវប្តូរដោយអ្នកនិពន្ធ សាំយូអែលទៅជាឈ្មោះថាមភីបូសែត (មានន័យថាចេញពីមាត់ដែលនាំឱ្យខូចកិត្តិយស) ។ មើលការពន្យល់ ២:៨ ។

**៤:៦** *ក៏ចាក់ទ្រង់ត្រង់ឧទរសំឡាប់ទៅ* មើល ២:២៣ និងការពន្យល់ ។

**៤:៧** *កាត់យកព្រះសិរចេញ* មើល ១សយ ៥:៤ និងការពន្យល់ ។ *ស្រុកវាល*

កាត់យកព្រះសិរចេញ ទៅតាមផ្លូវស្រុកវាលអស់១យប់
នោះ ៨គេនាំយកព្រះសិរ[ឋ]នៃអ៊ីស–បូសែត ទៅឯដាវីឌនៅ
ក្រុងហេប្រុន ទូលថា បពិត្រព្រះរាជា នេះព្រះសិររបស់
អ៊ីស–បូសែត បុត្រសូល[ឌ] ជាខ្មាំងសត្រូវ ដែលស្វែងរកជីវិត
ទ្រង់ នៅថ្ងៃនេះព្រះយេហូវ៉ាទ្រង់បានសងសឹក[ឍ]នឹងសូល
ព្រមទាំងវង្សារបស់ទ្រង់ ជិនួសព្រះករុណាដ៏ជាម្ចាស់នៃ
ទូលបង្គំហើយ ៩តែដាវីឌទ្រង់មានបន្ទូលឆ្លើយទៅរេកាប
និងបាណា ប្អូនគាត់ ជាកូនរីម៉ូន ពួកបៀរ៉ូតនោះថា យើង
ស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅ ដែល
ទ្រង់បានលោះ[ណ]ព្រលឹងយើង ចេញពីគ្រប់ទាំងសេចក្ដីវេទ
នាថា ១០កាលមានម្នាក់មកប្រាប់យើងពីសូលបានសុគត
ហើយ ដោយស្មានថា ខ្លួននាំដំណឹងល្អណាមួយមក ប្រាប់
ដល់យើង នោះយើងបានចាប់សំឡាប់វា នៅត្រង់ស៊ីកឡាក់
ទៅ[ត] ទុកជារង្វាន់ដល់វា ដោយព្រោះដំណឹងដែលនាំមក
នោះ ១១ដូច្នេះ ចំណង់បើមនុស្សអាក្រក់បានសំឡាប់មនុស្ស
សុចរិតនៅលើដំណេក ក្នុងលំនៅរបស់ខ្លួន នោះតើមិនត្រូវ
ឱ្យយើងសងសឹកជំនួសឈាម[ថ] អ្នកនោះដោយដកឯងចេញ
ពីផែនដីទៅ លើសជាងទៅទៀតទេឬអី ១២រួចដាវីឌបង្គាប់
ដល់ពួកកំឡោះរបស់ទ្រង់ ហើយគេក៏សំឡាប់អ្នកទាំង២
នោះទៅ[ទ] ព្រមទាំងកាត់ដៃកាត់ជើងយកទៅព្យួរនៅក្បែរ
ស្រះត្រង់ហេប្រុន តែគេនាំយកព្រះសិរនៃអ៊ី–បូសែត ទៅ
បញ្ចុះនៅក្នុងផ្នូររបស់អ័ប៊ីនើរ នៅក្រុងហេប្រុនទៅ ។

## ស្តេចដាវីឌគ្រងរាជ្យលើអ៊ីស្រាអែល

*៥:១–៣ – ១រប ១១:១–៣*

**៥** ១គ្រានោះ ពូជអំបូរនៃអ៊ីស្រាអែល[ក]ទាំងប៉ុន្មាន ក៏មកឯ
ដាវីឌ នៅក្រុងហេប្រុន ទូលថា ទូលបង្គំគ្រប់គ្នាជាសាច់
លោហិត[ខ]ជាមួយនឹងទ្រង់ដែរ ២កាលពីដើមដែលសូលធ្វើ
ជាស្តេចលើទូលបង្គំគ្រប់គ្នា[គ] នោះគឺទ្រង់ហើយ ដែលជាអ្នក
នាំមុខពួកអ៊ីស្រាអែលចេញចូល ១ទៀតព្រះយេហូវ៉ាទ្រង់
បានមានបន្ទូល[ឃ]នឹងទ្រង់ថា ត្រូវឱ្យឯងធ្វើជាអ្នកគង្វាល[ង]
ឃ្វាលអ៊ីស្រាអែល ជារាស្ត្រអញ គឺជាមេគ្រប់គ្រងលើពួក
សាសន៍អ៊ីស្រាអែលផង[ច] ៣គឺយ៉ាងនោះហើយ ដែលពួក
ចាស់ទុំទាំងប៉ុន្មាននៃសាសន៍អ៊ីស្រាអែល បានមកឯស្តេច
នៅក្រុងហេប្រុន រួចស្តេចដាវីឌក៏តាំងសញ្ញា[ឆ]នឹងគេ នៅ
ចំពោះព្រះយេហូវ៉ាត្រង់ហេប្រុន ហើយគេចាក់ប្រេងតាំង[ជ]

**៤:៨** ឋ ២សយ ២០:២១ ២ពវ ១០:៧ ឌ ១សយ ២៤:៤ ២៥:២៩ ឍ ជន ៣១:៣ **៤:៩** ណ លប ៤៨:១៦ ១ពវ ១:២៩ **៤:១០** ត ២សយ ១:២–១៦ **៤:១១** ថ លប ៤:១០ ៩:៥ ទដ ៩:១២ ៧២:១៤ **៤:១២** ទ ២សយ ១:១៥ **៥:១** ក ២សយ ១៩:៤៣ ខ លប ២៩:១៤ ៣៥:២៦ **៥:២** គ ១សយ ១៨:៥,១៣,១៦ ឃ ១សយ ១១:៦ ង លប ៤៨:១៥ ១សយ ១៦:១ ២សយ ៧:៧ មថ ២:៦ យហ ២១:១៦ ច ១សយ ១២:១២ ១៣:១៤ ២សយ ៦:២១ **៥:៣** ឆ ២សយ ៣:២១ ជ ចទ ១៧:១៥ ២សយ ២:៤

មើលការពន្យល់ ចទ ១:១ ។

**៤:៨** *នៅថ្ងៃនេះព្រះយេហូវ៉ាទ្រង់បានសងសឹកនឹងសូល* ព្រមទាំងវង្សារបស់ទ្រង់ គឺរេកាបនិងបាណាបានពណ៌នាពីការធ្វើឃាដរបស់គេ ចំពោះអ៊ីស–បូសែត ក្នុងចិត្តដែលស្រឡាញ់ហើយគោរព ដោយសង្ឃឹមថាដាវីឌបង្ហាញឱ្យពួកគេដឹងពីសកម្មភាពរបស់ពួកគេដែលមានការគិតខុសយ៉ាងខ្លាំង ។

**៤:៩** *ព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅ* ជាពាក្យមួយទៅកាន់ព្រះយេហូវ៉ាក្នុងការដែលពួកគេបានស្បថនឹងអ្នកណាម្នាក់ (មើលការពន្យល់ ១សយ ១៤:៣៩,៤៥) ។

**៤:១១** *ឱ្យយើងសងសឹក ជំនួសឈាមអ្នកនោះ* គឺជាការប្រកាសប្រាប់ពីការដាក់ទណ្ឌកម្មដល់ស្លាប់ចំពោះអ្នកដែលមានបាតដៃប្រឡាក់ឈាម(មើល លប ៩:៥–៦) ។ ស្តេចដាវីឌបានធ្វើអ្វីៗ ដែលទ្រង់ពុំមានលទ្ធភាពធ្វើជាមួយនិងយ៉ូអាប់(មើលការពន្យល់ ៣:២៩) ។

**៤:១២** *កាត់ដៃកាត់ជើង* គឺដៃដែលបានលបធ្វើឃាដដល់លោក អ៊ីស–បូសែត និងជើងដែលបានរត់(មើលការពន្យល់ ១សយ ៥:៤) ។

**៥:១–២៤:២៥** គឺមានការចាប់ផ្តើមដោយ ជំពូក៥គឺមានក្នុងផ្នែក ២សយ (មើល ៣:២–៥)និងមានអត្ថបទជាពាក្យប្រដៅនៅក្នុង ១រប(ដែលមានចុះសរសេរនៅផ្នែក ចំណងជើងគម្រោងសង្ខេប) ។ មានឧទាហរណ៍ខ្លះជាពាក្យប្រៀបប្រដូច ជាការបង្ហាញបញ្ជាក់ដល់ផ្នែកផ្សេងៗទៀត ។

**៥:១** *ពូជអំបូរអ៊ីស្រាអែលទាំងប៉ុន្មាន* គឺចង់ប្រាប់ពីការជាតំណាងឱ្យពូជអំបូរទាំងអស់ឬនិមួយៗក៏មានទាំងពួកចាស់ទុំ និងផ្នែកពលទ័ព(មើល ១រប ១២:២៣–៤០) ។ *ជាសាច់លោហិតជាមួយនឹងទ្រង់ដែរ* គឺតំណាងពូជអំបូរនិមួយៗ ដែលបានទទួលស្គាល់ស្តេចដាវីឌជាស្តេចលើពួកគេ ។ លក្ខណៈទី១គឺគេដឹងថាដាវីឌជាសាសន៍អ៊ីស្រាអែល ។ ទោះបីជាការរួបរួមជាតិសាសន៍បានបាក់បែកក្នុងពេលដែលស្តេចសូលសុគតក៏ដោយ(២:៨–៣:១)ក៏ភាពជាប់ជាសាច់លោហិតជាមួយគ្នាក៏មិនត្រូវបានបំភ្លេចដែរ ។

**៥:២** *ដែលជាអ្នកនាំមុខពួកអ៊ីស្រាអែលចេញចូល* លក្ខណៈទី២គឺ(មើលការពន្យល់ ខ.១) គឺជាការទទួលស្គាល់ថា ស្តេចដាវីឌជាស្តេច (មើល ១សយ ១៨:៥,១៣–១៤,១៦,៣០) ។ *ទ្រង់បានមានបន្ទូលនិងទ្រង់ថា* និងលក្ខណៈទី៣និងហេតុផលដ៏សំខាន់បំផុត (មើល ១សយ ១៣:១៣–១៤ ១៦:១,១៣ ២៣:១៧ ២៥:២៦–៣១) ។ *ជាអ្នកគង្វាល . . . ជាមេគ្រប់គ្រង* ពាក្យថា "អ្នកគង្វាល" ពាក្យនេះជារឿយៗត្រូវបានគេប្រើក្នុងការប្រៀបធៀបចំពោះការដឹកនាំខាងនយោបាយ ដូចក្នុងគ្រាសញ្ញាចាស់ (មើល ទដ ២៣:១,យរ ២:៨ អរ ៣៤:២ និងការពន្យល់) ក៏ប្រើក្នុងគ្រាផ្សេងៗទៅក្នុងជិតតំបន់បូព៌ាបុរាណ(មើលការពន្យល់ ១សយ ១២:២)("អ្នកដឹកនាំរបស់អ្នក")ប្រៀបធៀបការពន្យល់ ១សយ ៩:១៦ ("អ្នកដឹកនាំ") ។

**៥:៣** *ស្តេចដាវីឌក៏តាំងសញ្ញានិងគេ ចំពោះព្រះយេហូវ៉ា* ដាវីឌនិងរាស្ត្រអ៊ីស្រាអែល បានចូលទៅឯសេចក្តីសញ្ញាទាំងរាស្ត្រ គឺនៅចំពោះមុខព្រះយេហូវ៉ាដើម្បីទទួលកិច្ចការរបស់ពួកគេ(២ពវ ១១:១៧ និងការពន្យល់) ។ គឺជាតំណាក់ការដែលស្តេចដាវីឌ ធ្វើជាស្តេចលើសាសន៍យូដានិងក្រោយមកជាព្រះមហាក្សត្រលើស្រុកយេរូសាឡិម គឺដោយសារតែការច្បាំងដណ្តើមយក (ខ.៦–១០)ការដឹកនាំរបស់ទ្រង់លើពូជអំបូរខាងជើង គឺដោយទទួលសេចក្តីសញ្ញា ។ សិទ្ធសញ្ញានោះមិនបានយកមកធ្វើឱ្យថ្មីឡើងវិញទេ ក្នុងជំនាន់ចៅប្រុសស្តេចដាវីឌនោះ ដោយព្រោះទ្រង់នោះបដិសេធស្តេចទាំងនោះ ក្នុងគ្រាដែលស្តេចនោះគ្រងរាជ្យ (១ពវ ១២:១–១៦) ។ គេចាក់ប្រេងតាំងដាវីឌ

ដាវីឌឡើង ឱ្យធ្វើជាស្តេចលើពួកអ៊ីស្រាអែលដែរ ៤កាល
ដាវីឌបានទទួលគ្រងរាជ្យ នោះទ្រង់មានព្រះជន្ម៣០ឆ្នាំ[ឈ]
ទ្រង់ក៏សោយរាជ្យ[ញ]បាន៤០[ដ]ឆ្នាំ ៥[ឋ]គឺទ្រង់បានសោយរាជ្យ
លើពួកយូដា នៅហេប្រុនអស់៧ឆ្នាំ៦ខែ[ឋ] ឯនៅក្រុង
យេរូសាឡិម ទ្រង់ក៏សោយរាជ្យ លើពួកអ៊ីស្រាអែល និង
ពួកយូដាផង បាន៣៣ឆ្នាំ ។

## ស្តេចដាវីឌកាន់កាប់ទីក្រុងយេរូសាឡិម

*៥:៦–១០ – ១រប ១១:៤–៩*

*៥:១១–១៦ – ១រប ៣:៥–៩ ១៤:១–៧*

៦នៅគ្រានោះស្តេចហើយនិងពួកទ័ពទ្រង់ ក៏ទៅឯក្រុង
យេរូសាឡិម[ឌ] ច្បាំងនឹងសាសន៍យេប៊ូស[ឍ]ដែលនៅស្រុក
នោះ គេបានមើលងាយដល់ដាវីឌថា ឯងចូលមកក្នុងទីនេះ
មិនបានឡើយ សូម្បីតែពួកកង្វាក់ នឹងពួកកង្វិនក៏អាចនឹង
វាយកំចាត់ឯងបានដែរ ដោយស្មានថា ដាវីឌ ពុំអាចនឹង
ចូលបានទេ ៧ប៉ុន្តែដាវីឌទ្រង់ចាប់យកបានទីមាំមួនឈ្មោះ
ស៊ីយ៉ូន[ណ] (នេះហើយដែលហៅថា ទីក្រុងរបស់ដាវីឌ)[ត,ថ]
៨នៅថ្ងៃនោះ ដាវីឌបានមានបន្ទូលថា បើអ្នកណានឹងវាយ
ពួកយេប៊ូសបាន នោះត្រូវតែឡើងតាមផ្លូវបង្ហូរទឹក[ទ]ទៅ
ហើយវាយទាំងពួកកង្វាក់ និងពួកកង្វិន[ធ] នុ៎ះឯង ដែលចិត្ត
យើងខ្ពើមទាំងម្ល៉េះ ដោយព្រោះពួកកង្វាក់ ហើយពួកកង្វិន
បាននិយាយថា វាចូលមកមិនបានទេ ៩រួចទ្រង់ក៏គង់ នៅ
ក្នុងទីមាំមួននោះ ហើយបានហៅថាជាទីក្រុងដាវីឌទ្រង់សង់
ឡើង នៅទ័ព្ធជុំវិញ ចាប់តាំងពីមីឡូរ[ន] ចូលមកខាងក្នុង
១០ដាវីឌទ្រង់ក៏ចំរើនកាន់តែខ្លាំងឡើង[ប] ដោយព្រះយេហូវ៉ា
ជាព្រះនៃពួកពលបរិវារ[ផ]ទ្រង់គង់ជាមួយ[ព]។
១១ហ៊ីរ៉ាម[ភ] ជាស្តេចក្រុងទីរ៉ុសទ្រង់ចាត់សារឱ្យទៅ
ឯដាវីឌ ព្រមទាំងជាងឈើជាងថ្ម ហើយនិងឈើតាត្រៅ

**៥:៤** ឈ លប ៣៧:២ លក ៣:២៣ ញ ១ពវ ២:១១ ១រប ៣:៤ ដ ១រប ២៦:៣១ **៥:៥** ឋ ២សយ ២:១១ ១ពវ ២:១១ ១រប ៣:៤ **៥:៦** ឌ ពច ១:៨ ឍ យស ១៥:៨ **៥:៧** ណ ទដ ៧៦:២ ត យរ ២១:១៣ ថ ២សយ ៦:១២,១៦ ១ពវ ២:១០ ៨:១ អស ២៩:១ យរ ២៥:២៩

**៥:៨** ទ ២ពវ ២០:២០ ២រប ៣២:៣០ ធ មថ ២១:១៤ **៥:៩** ន ១ពវ ៩:១៥,២៤ ប ២សយ ៣:១ ផ ទដ ២៤:១០ ព ២សយ ៧:៩ **៥:១១** ភ ១ពវ ៥:១,១៨ ២រប ២:៣

ឡើយធ្វើជាស្តេចលើពួកអ៊ីស្រាអែលដែរ ។ *គឺជាលើកទី៣ដែលស្តេចដាវីឌបានចាត់ប្រេងតាំង* (មើលការពន្យល់ ២:៤) ។

**៥:៥** *នៅហេប្រុនអស់ . . . ៧ឆ្នាំ៦ខែ* មើល ២:១១ ពួកអ៊ីស្រាអែលនិងពួកយូដាទំនាក់ទំនងដ៏ជាក់លាក់នៃស្តេចដាវីឌ ចំពោះផ្នែកទាំងពីរ ក៏ស្ថិតនៅជាលក្ខណៈចំលែក(មើលការពន្យល់ ខ.៣) ។

**៥:៦** *ក្រុងយេរូសាឡិម* ជាទីក្រុងមួយក្នុងចំណោមទីក្រុងដែលសម្រេចបាននូវស្នាដៃល្អបំផុតរបស់រាជបល័ង្គដាវីឌ គឺបង្កើតបានជាក្រុងយេរូសាឡិមជារាជធានីរបស់ទ្រង់ និងរាជធានីជាតិ(មើលសេចក្តីផ្តើមនឹងគម្រោងអត្ថបទ) គឺក្នុងសហវត្សរ៍ទី៣ មុនគ.ស និងជារាជធានីនាសម័យលោកអ័ប្រាហាំ(មើលការពន្យល់ លប ១៤:១៨) វាមានទីតាំងនៅឯព្រំដីរវាងស្រុកយូដា និងស្រុកបេនយ៉ាមីន គឺផ្នែកខ្លះត្រួតត្រាដោយពូជអំបូរខ្លះដែរ ។ គឺក្នុងខណៈពេលនៃការវាយដណ្តើមយកទាំងយូដា និងស្រុកបេនយ៉ាមីនត្រូវបានប្រយុទ្ធគ្នាដល់ទីក្រុង (មើលការពន្យល់ ពច ១:៨,២១) ប៉ុន្តែគេក៏ប្រឆាំងនឹងពួកសាសន៍យេប៊ូសដែលមកនៅក្នុងក្រុងយេរូសាឡិមជាមួយគ្នា(យស ១៥:៦៣) (មើល ពច ១៩:១០ ១រប ១១:៤) ពីមុនទីក្រុងយេរូសឡិមមានឈ្មោះថា ទីក្រុងយេប៊ូស ។ ទីក្រុងដែលស្តេចដាវីឌគ្រប់គ្រងនេះគឺមានផ្ទៃដីជិត ១១ អេយឃើរ ដែល១ អេយឃើស្មើ ៤០៥០ម៉ែត្រក្រឡា ។ ដែលមានផ្ទះអ្នកស្រុកដើមជាង ៣៥០០ផ្ទះ ។ ស្តេចដាវីឌបានបង្រួបបង្រួមឯនគរនោះក្រោមការដឹកនាំរបស់គាត់ ក៏ទំនងជានៅក្រោមនៃការគ្រប់គ្រងក្នុងតំបន់មួយទៀតនៃទីក្រុងនោះ ។

**៥:៧** *ទីមាំមួន* គឺជាការបង្ហាញពីទីតាំងនៃក្រុងនោះផ្ទាល់ ដែលមានភាពរឹងមាំមួន ។ *ស៊ីយ៉ូន* ជាទីក្រុងដាវីឌដែលមានលេចឮឈ្មោះតាំងពីគ្រាសញ្ញាចាស់ ។ គឺមានប្រវត្តិចេញពីប្រភពដើមនៃកូនភ្នំ ផ្នែកភាគខាងត្បូងនៃទីក្រុងដែលជាទីតាំងមាំមួនមួយរបស់ក្រុងយេប៊ូស ។ ពេលនោះទីក្រុងក៏ពង្រីកទំហំតាំងពីសម័យស្តេចសាឡូម៉ូន ហើយមានឈ្មោះនេះតៗឮពេញទាំងទីក្រុងទាំងមូល (មើល ១សយ ១:៨ និងការពន្យល់ ២:៣)។*ទីក្រុងរបស់ដាវីឌ* ក្នុងនាមជាអ្នកគ្រប់គ្រងក្នុងស្រុកយេរូសាឡិមទាំងមូល ស្តេចដាវីឌជាឈ្មោះផ្ទាល់របស់ទ្រង់ដាវីឌ ។ គឺជាតំបន់ផ្នែកអាគ្នេយ៍ គឺទិសខាងកើតឈាងខាងត្បូងនៃក្រុងយេរូសាឡិម (គឺត្រង់អូផែល មើលការពន្យល់នៅ នហ ៣:២៦) ឈ្មោះនោះនៅមានរហូតដល់ពេលរជ្ជកាស្តេចដាវីឌមកដល់ (មើល អស ២២:១៩ ប្រៀបធៀប អស ២៩:១) ។

**៥:៨** *នៅថ្ងៃនោះដាវីឌមានបន្ទូលថា* ១រប ១១:៦ ន័យរួមរបស់ស្តេចដាវីឌបង្ហាញពីភាពទទួលខុសត្រូវ ។ គឺជាផ្នែកមួយនៃយ៉ូអាប់ក្នុងការវាយ ដណ្តើមទីក្រុងក៏បង្ហាញពីការប្រឆាំងនឹងអំណាចផ្នែកយោធារបស់ទ្រង់ ហើយក៏អះអាងសារជាថ្មីថាទ្រង់ជាអ្នកមេបញ្ជាការ របស់កាទ័រនៃស្តេចដាវីឌ ។ *ផ្លូវបង្ហូទឹកទៅ* ឈ្មោះនេះជាភាសាហេព្រើរ គឺមានភាពពិបាកយល់ឬច្រឡំបន្តិច (មើលក្នុងគម្ពីរសិក្សានេះតាមការពន្យល់) ដោយដឹងថាដាវីឌស្គាល់ផ្លូវរូងដ៏សម្ងាត់គឺហូរឬចាប់ពីទន្លេគីហុន ដែលខ្សែទឹកខាងក្រៅទីក្រុងចូលទៅទីប្រជុំផ្លូវទឹកដែលផ្តល់ជាច្រកចូលទៅទីក្រុង(មើល ២រប ៣២:៣០) ។ *ពួកកង្វាក់និងពួកកង្វិននុ៎ះឯង* គឺចង់សំអាងទៅលើ ឬនិយាយពីពូជសាសន៍យេប៊ូស(ប្រៀបធៀប ខ.៦ និងការពន្យល់) ។ *ពួកកង្វាក់ និងពួកកង្វិនវាចូលមកមិនបានទេ* ពាក្យសុភាសិតនេះមានន័យថាពួកសាសន៍យេប៊ូល ពុំអាចមានលទ្ធភាពចូលក្នុងព្រះរាជវាំងបានទេ ។ គឺគេនោះត្រូវបានអនុញ្ញាត្តិត្រឹមតែក្នុងទីក្រុង និងក្នុងបរិវេណជុំវិញរបស់ពួកគេ ។

**៥:៩** *ចាប់តាំពីមីឡូរ ចូលមកខាង* ជាទីតាំងតាមភ្នំដែលចោទ ហើយដែលមានទីកន្លែងសម្រាប់សាងសង់ទីតាំងនោះ(មើលការពន្យល់ ពច ៩:៦)។

**៥:១០** *ដោយព្រះយេហូវ៉ាជាព្រះនៃពួកពលបរិវារទ្រង់គង់ជាមួយ* មើលការពន្យល់ ១សយ ១៦:១៨ ។

**៥:១១** *ហ៊ីរ៉ាមជាស្តេចក្រុងទីរ៉ុស* ស្តេចអង្គនេះ គឺបានឯកភាពព្រមព្រៀងឱ្យមានស្តេចដាវីឌ ក៏ជាអ្នកទទួលស្គាល់លក្ខណៈអន្តរជាតិផងដែរ ។ ទ្រង់ក៏មានការទំនាក់ទំនងដ៏ល្អជាមួយស្តេចអ៊ីស្រាអែលផងដែរ គឺក្នុងខណៈដែលរាស្ត្រអ៊ីស្រាអែលបានគ្រប់ដណ្តប់លើពាណិជ្ជកម្មក្នុងប្រទេសរបស់សាសន៍ទីរ៉ុសនោះ ។ ហើយសាសន៍ទីរ៉ុសក៏បានពឹងផ្អែកលើវិស័យកសិកម្ម នៃរាស្ត្រ

ផង ពួកនោះក៏សង់ដំណាក់ថ្វាយដាវីឌ ១២ នោះដាវីឌក៏យល់
ឃើញថា ព្រះយេហូវ៉ាបានតាំងទ្រង់ឡើងជាស្តេចលើ
សាសន៍អ៊ីស្រាអែល ព្រមទាំងលើកដំកើងរាជ្យទ្រង់[ម] ដោយ
យល់ដល់សាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ព្រះអង្គ ។
១៣ គ្រាដែលបានមកពីហេប្រុនហើយ នោះដាវីឌយកស្រី
អ្នកម្នាង និងភរិយា[យ] ពីពួកក្រុងយេរូសាឡិមថែមទៀត
ហើយទ្រង់បង្កើតបានបុត្រាបុត្រីច្រើនឡើង ១៤ ឯបុត្រាទាំង
ប៉ុន្មាន ដែលទ្រង់បានបង្កើតនៅក្រុងយេរូសាឡិម[រ] មាន
នាមដូច្នេះ គឺសាំមួរ សូបាប់ ណាថាន់[ល] សាឡូម៉ូន
១៥ យីមហារ អេលីសួរ នេផេក យ៉ាភា ១៦ អេលីសាម៉ា
អេលាដា ហើយនិងអេលីផាលេក ។

## ស្តេចដាវីឌយកឈ្នះលើសាសន៍ភីលីស្ទីន

*៥:១៧–២៥ – ១របា ១៤:៨–១៧*

១៧ កាលសាសន៍ភីលីស្ទីនឮថា គេបានចាក់ប្រេងតាំង
ដាវីឌឡើង ជាស្តេចលើសាសន៍អ៊ីស្រាអែលហើយនោះគេ
លើកគ្នាទាំងអស់ ឡើងមករកដាវីឌ តែដាវីឌបានជ្រាប
រួចទ្រង់យាងចុះទៅឯទីពំនួន[វ] ១៨ ឯពួកភីលីស្ទីសគេក៏មក
ដល់ ហើយរាយគ្នាពេញក្នុងវាលច្រកភ្នំរេផែម[ស] ១៩ នោះ
ដាវីឌទូលសួរ[ហ] ដល់ព្រះយេហូវ៉ាថា តើត្រូវឱ្យទូលបង្គំឡើង
ទៅច្បាំងនឹងពួកភីលីស្ទីនឬទេ តើទ្រង់នឹងប្រគល់គេមកក្នុង
កណ្តាប់ដៃរបស់ទូលបង្គំឬអី ព្រះយេហូវ៉ាទ្រង់មានបន្ទូល
តបថា ចូរឡើងទៅចុះ ដ្បិតអញនឹងប្រគល់ពួកភីលីស្ទីនមក
ក្នុងដៃឯងជាពិតប្រាកដ ២០ នោះដាវីឌទ្រង់យាងទៅដល់
បាល–ពេរ៉ាស៊ីម ហើយក៏ប្រហារពួកគេនៅទីនោះ រួច
ទ្រង់មានបន្ទូលថា ព្រះយេហូវ៉ាទ្រង់បាន ទំលាយមកលើ
ពួកខ្មាំងសត្រូវរបស់យើង នៅចំពោះមុខដូចជាទឹក ធ្លាយ
ទំនប់ ហេតុនោះបានជាគេហៅទីនោះឈ្មោះថា បាល–
ពេរ៉ាស៊ីម[ឡ] ២១ គេក៏លះចោលអស់ទាំងរូបព្រះគេនៅទីនោះ
ហើយដាវីឌ និងពួកទ័ពទ្រង់នាំយកទាំងអស់ទៅ[អ] ។
២២ ក្រោយនោះពួកភីលីស្ទីសក៏ឡើងមករាយទ័ពរបស់
គេពេញ ក្នុងវាលច្រកភ្នំរេផែមម្តងទៀត ២៣ តែកាលដាវីឌ
បានទូលសួរដល់ព្រះយេហូវ៉ា នោះទ្រង់មានបន្ទូលហាមថា

**៥:១២** ម ជន ២៤:៧
**៥:១៣** យ ចទ ១៧:១៧
**៥:១៤** រ ១របា ៣:៥ ល លក ៣:៣១
**៥:១៧** វ ២សយ ២៣:១៤ ១របា ១១:១៦
**៥:១៨** ស យស ១៥:៨ ១៧:១៥
**៥:១៩** ហ ពច ១៨:៥ ១សយ ២៣:២
**៥:២០** ឡ លប ៣៨:២៩
**៥:២១** អ ចទ ៧:៥ អស ៤៦:២

អ៊ីស្រាអែលដែរ ដើម្បីឱ្យបានស្បៀងសម្រាប់ប្រទេសរបស់ពួកគេ(ក៏បង្ហាញការពិតផងដែរ គឺក្នុងសតវត្សរ៍ទី១ (មើល កច ១២:២០)។ មិត្តិភាពដ៏ជិតស្និតរវាងព្រះរាជាណាចក្រទាំងពីនេះ បានស្ថិតស្ថេររហូតដល់សាសន៍បាប៊ីឡូនបានលុកលុយដល់សាសន៍នេះ ។ *ទីរ៉ុស* ឬក្រុងទីរ៉ុសគឺជាតំបន់ផែរសមុទ្រស្រុកភេនីស ដ៏មានសារៈសំខាន់នៅឯឈូងសមុទ្រមេឌីទែរ៉ាណេនៅឯស្រុកអ៊ីស្រាអែលខាងជើង(មើល អគ ២៦–២៧) ឈើតាត្រៅ គឺជាប្រភេទឈើ ដែលប្រើបានយូរមាំរឹង គេប្រើសម្រាប់ការតុបតែងសាងសង់វិហារ ឬរាជវាំងដ៏មានអំណាច និងធនធានសំបូរបែបនៅមជ្ឈឹមបូពាំបុរាណ (មើល ១ពវ ៥:៦ ៦:៩,៥៥ ៨:៩ យរ ២២:១៤–១៥ ហក ១:៤ និងការពន្យល់) ។

**៥:១២** *ស្តេចដាវីឌក៏យល់ឃើញថា ព្រះយេហូវ៉ាបានតាំងទ្រង់ឡើង* គឺជាផ្នែកមនោគមន៍វិជ្ជារបស់ស្តេច នៃការគ្រងរាជវាំងនៅផ្នែកជិតបូពាំបូរាណក៏ជាការបញ្ជាក់ពីស្ថានភាពនិងមិត្តភាពរួមមួយ ។ *ដោយយល់ដល់សាសន៍អ៊ីស្រាអែល* ស្តេចដាវីឌបានទទួលស្គាល់ថាការលើកតាំងរបស់ទ្រង់ ដើម្បីឱ្យទ្រង់ធ្វើជាស្តេចលើរាស្ត្រអ៊ីស្រាអែល គឺជាព្រះរាជកិច្ចរបស់ព្រះយេហូវ៉ា ហើយក៏ជាការលោះបាបដល់រាស្ត្រអ៊ីស្រាអែលដែរ ។ ក៏ដូចជាការងាររបស់លោកម៉ូសេ លោកយ៉ូស្វេ ពួកចៅហ្វាយ និងសាំយូអែលបានធ្វើ ។

**៥:១៣** *ដាវីឌយកស្ត្រីអ្នកម្នាងនឹងភរិយា* មើលការពន្យល់ ៣:២–៥ លប ២៥:៦ ។

**៥:១៧** *កាលសាសន៍ភីលីស្ទីនឮថា គេបានចាក់ប្រេងតាំងដាវីឌឡើងជាស្តេច* តាមលក្ខណៈប្រវត្តិសាស្ត្រវាបង្ហាញថា ពួកភីលីស្ទីនក៏បានមកទំនាក់ទំនងនិងចុះចូលបន្ទាប់ពីហេតុការណ៍ក្នុង ខ.៣ ហើយមុនពេលចាប់យកក្រុងយេរូសាឡិម(ខ.៦–១០) (អ្នកនិពន្ធបានចងក្រងផ្នែកទេវកថា តាមសាច់រឿងមួយៗ ៧:១)ពួកប៉ាលីស្ទីនពុំទាន់បានអុកឡុកដោយរាជ្យស្តេចដាវីឌឡើយ ជាពិសេសលើពួកសាសន៍យូដា ។ ប៉ុន្តែពួកគេឥឡូវនេះកំពុងការពារនូវផលប្រយោជន៍របស់ពួកគេក្នុងទឹកដីខាងជើង លើសពីនេះទៅទៀតគេបានគ្រប់ដណ្តប់លើផ្ទៃដី បន្ទាប់ពីផ្តួលស្តេចសូល(១សយ ៣១) ។ *ទីពំនួន* គឺសំដៅលើតំបន់វាលខ្សាច់(វាលរហោស្ថាន) ក្នុងស្រុកយូដាខាងត្បូងដែលជាទីកន្លែងស្តេចដាវីឌបានលាក់ខ្លួនពីស្តេចសូល(មើលការពន្យល់ ១សយ ២២:៤ ២៣:១៤) គឺជាកាលស្តេចដាវីឌពុំទាន់បានយកស្រុកអ៊ីស្រាអែលនៅឡើយ ។

**៥:១៨,២២** *វាលច្រកភ្នំរេផែម* គឺជាទីដីព្រំប្រទល់បុរាណ នៃក្រុងយេរូសាឡិមនៅឯទិសខាងលិចនិងខាងត្បូងឈៀងខាងលិច (មើល យស ១៥:៨ ១៨:១៦ មើលការពន្យល់នៅ អស ១៧:៥) ។

**៥:១៩** *ដាវីឌទូលសួរដល់ព្រះយេហូវ៉ា* មើលការពន្យល់ ២:១ ១សយ ២:២៨ ២២:២០ ២៣:២ ។

**៥:២០** *ព្រះយេហូវ៉ាបានទំលាយ . . . បាល–ពេរ៉ាស៊ីម* គឺទ្រង់មានលក្ខណៈជាស្តេចទេវាធិបតេយ្យនៃសេចក្តីពិត ។ ស្តេចដាវីឌបានកំណត់ការទទួលជ័យជម្នះថ្វាយព្រះយេហូវ៉ា មិនមែនអង្គទ្រង់ផ្ទាល់ទេ(មើលការពន្យល់ ១សយ ១០:១៨,២៧ ១១:១៣ ១៤:២៣ ១៧:១១,៤៥–៤៧) ។

**៥:២១** *គេក៏លះចោលអស់ទាំងរូបព្រះគេនៅទីនោះ* ដូចជារាស្ត្រអ៊ីស្រាអែលបានយកហឹបទៅឯសមរភូមិផងដែរ(មើល ១សយ ៤:៣) ដូចជាពួកភីលីស្ទីន បានយករូបព្រះបដិមាកររបស់គេទៅឯសមរភូមិដូច្នោះដែរ ដែលសង្ឃឹមថា និងបានទទួលជោគជ័យ ។ *នាំយកទាំងអស់ទៅ* ក្នុងការសុខចិត្តធ្វើតាមការព្រមព្រៀងតាមសេចក្តីណែនាំ ចទ ៧:៥ គេក៏ដុតព្រះទាំងអស់នោះចោលទៅ (១របា ១៤:១២) ។

**៥:២៣** *ទ្រង់មានបន្ទូលហាម* (ដាវីឌ)ដូចជាមានសេចក្តីពិតក្នុងករណីដែលដណ្តើមយកស្រុកយូដា ។ ព្រះយេហូវ៉ាបានបញ្ជាក្នុងសមរភូមិហើយទ្រង់បានធ្វើធម្មយាត្រាប្រយុទ្ធនឹងសត្រូវដែលមានទ័ពពីស្ថានសួគ៌មកជាច្រើន ។

កុំឱ្យឡើងទៅឡើយ ត្រូវឱ្យវាងទៅពីខាងក្រោយ ហើយ
ចូលទៅឯគេពីខាងចំការមនវិញ [២៤]កាលណាឯងឮសូរ
សន្ធឹក[ក]នៅលើចុងដើមមន ដូចជាពួកពលដើរ នោះចូរឱ្យ
ឯងប្រញាប់ប្រញាល់ឡើង ដ្បិតគឺវេលានោះឯងហើយ
ដែលព្រះយេហូវ៉ានឹងចេញទៅចំពោះមុខ[ខ]ឯង ដើម្បី
ប្រហារពួកទ័ពភីលីស្ទីន [២៥]ដាវីឌទ្រង់ក៏ធ្វើយ៉ាងនោះ
ដូចជាព្រះយេហូវ៉ាទ្រង់បានបង្គាប់មក ហើយស្តេចទ្រង់
ប្រហារពួកភីលីស្ទីន[គ] ចាប់តាំងពីក្រុងកេបា[ឃ] រហូតទៅដល់
ក្រុងកេសើរ[ង]។

## ការបញ្ជូនហឹបសញ្ញាទៅក្រុងយេរូសាឡិម

*៦:១–១១ – ១រប ១៣:១–១៤*

*៦:១២–១៩ – ១រប ១៥:២៥– ១៦:៣*

**៦** [១]រួចមកដាវីឌទ្រង់ប្រមូលអស់ទាំងមនុស្សជ្រើសរើសក្នុង
សាសន៍ អ៊ីស្រាអែលម្តងទៀត បានចំនួន៣ម៉ឺននាក់ [២]រួច
ដាវីឌ ព្រមទាំងបណ្តាជនទាំងប៉ុន្មាន ក៏នាំគ្នាឡើងចេញពី
បាលេ[ក]–យូដា ដើម្បីនឹងនាំយកហឹបនៃព្រះឡើងមកជា
ហឹប[ខ]ដែលគេឱ្យឈ្មោះ[គ] តាមព្រះនាមរបស់ព្រះយេហូវ៉ា
នៃពួកពលបរិវារ ដែលទ្រង់គង់នៅ[ឃ]កណ្តាលចេរូប៊ីន[ង]
[៣]គេផ្ទុកហឹបនៃព្រះលើរទេះថ្មី[ច] ដឹកចេញពីផ្ទះអ័ប៊ីនាដាប់
ដែលនៅលើភ្នំ[ឆ]ទៅ មានឈ្មោះអ៊ុសា ហើយនិងអ័ហ៊ីយ៉ូរជា
កូនអ័ប៊ីនាដាប់ ជាអ្នកបររទេះថ្មីនោះ [៤]គេនាំយករទេះដែល
ផ្ទុកហឹបនៃព្រះ ចេញពីផ្ទះអ័ប៊ីនាដាប់ ដែលនៅលើភ្នំនោះ
ទៅមានអ័ហ៊ីយ៉ូរដើរខាងមុខហឹបផង [៥]ឯដាវីឌនឹងពួកផ្ទះ
អ៊ីស្រាអែលទាំងអស់ គេលេង[ជ]ប្រដាប់ភ្លេងគ្រប់មុខ ដែល
ធ្វើពីឈើកកោះ គឺស៊ុង ពិណ ក្រាប់ រុម្មនា ហើយនិងឈឹង
នៅចំពោះព្រះយេហូវ៉ា[ឈ]។
[៦]លុះគេបានទៅដល់លានស្រូវរបស់ណាកុនហើយ នោះ
អ៊ុសាគាត់លូកដៃទៅចាប់ទប់[ញ]ហឹបនៃព្រះ ពីព្រោះគោ
កញ្ជ្រោលឡើង [៧]ដូច្នេះ ព្រះយេហូវ៉ាទ្រង់ខ្ញាល់នឹងអ៊ុសាក៏
ប្រហារ[ដ]គាត់នៅទីនោះ ដោយព្រោះកំហុសរបស់គាត់[ឋ]
ហើយគាត់ស្លាប់នៅទីនោះ ជិតហឹបនៃព្រះទៅ [៨]ឯដាវីឌ
ទ្រង់មានព្រះទ័យទោមនស្ស ដោយព្រោះព្រះយេហូវ៉ា[ឌ]បាន
ប្រហារជីវិតអ៊ុសាបង់ រួចទ្រង់ហៅកន្លែងនោះឈ្មោះថា
ពេរេស–អ៊ុសា ដរាបដល់សព្វថ្ងៃនេះ[ឍ] [៩]នៅថ្ងៃនោះដាវីឌ
ក៏មានសេចក្តីកោត ខ្លាចដល់ព្រះយេហូវ៉ា ហើយមានបន្ទូល
ថា ធ្វើដូចម្តេច[ណ]ឱ្យហឹបនៃព្រះយេហូវ៉ាចូលមកឯអញបាន

**៥:២៤** ក នក ១៤:២៤ ខ ពច ៤:១៤
**៥:២៥** គ ២សយ ៨:១២ ២១:១៥ ឃ អស ២៨:២១ ង យស ១០:៣៣
**៦:២** ក យស ១៥:៩ ខ ១សយ ៤:៤ ៧:១ គ លវ ២៤:១៦ ចទ ២៨:១០ អស ៦៣:១៤ ឃ ទដ ៩៩:១ ១៣២:១៤ ង លប ៣:២៤ នក ២៥:២២
**៦:៣** ច ខ.៧ ជន ៧:៤–៩ ១សយ ៦:៧ ឆ ២សយ ៧:១
**៦:៥** ជ នក ១៥:២០ ឈ អរ ៣:១០ នហ ១២:២៧ ទដ ១៥០:៥
**៦:៦** ញ ជន ៤:១៥,១៩–២០
**៦:៧** ដ ១រប ១៥:១៣–១៥ ឋ នក ១៩:២២ ១សយ ៥:៦ ៦:១៩ ២៥:៣៨ **៦:៨** ឌ ទដ ៧:១១ ឍ លប ៣៨:២៩ **៦:៩** ណ ១សយ ៦:២០

(យស ៦:២–៥ ៨:១–២ ១០:៨,១៤ ១១:៦) ។ សង្គ្រាមដោយស្តេចដាវីឌនេះបានបន្ត ហើយបញ្ចប់សង្គ្រាមដែលប្រយុទ្ធដឹកនាំទ័ពដោយយ៉ូស្វេ ។

**៥:២៤** *ឮសូរសន្ធឹកនៅ* គឺជាទាហានស្ថានសួគ៌ចូលទៅឯសមរភូមិប្រយុទ្ធ ។

**៥:២៥** *ក្រុងកេបា* មើលការពន្យល់ ២:១២–១៣ យស ៩:៣ ។ *ក្រុងកេសើរ* ដែលមានប្រវែង១៥ម៉ៃ ពីតំបន់ខាងលិចនៃក្រុងកេបា ដែលមើលទៅស្រុកភីលីស្ទីនបានច្បាស់ (មើលការពន្យល់ យស ១០:៣៣) ។

**៦:២** *បាលេ–យូដា* មើលការពន្យល់ យស ១៥:៦០ ១៨:១៤ ១សយ ៧:១ ។ *ហឹបនៃព្រះ* មើលការពន្យល់ នក ២៥:១០–២២ ឬមើលការពន្យល់ ១សយ ៤:៣–៤,២១ ។ ហឹបនោះមាននៅឯការយ៉ាក្នុងរជ្ជកាលស្តេចសូល ។ *គេឱ្យឈ្មោះតាមព្រះនាម* ដែលប្រើគ្រប់ទីកន្លែងដើម្បីឱ្យដឹងភាពជាកម្មសិទ្ធ(មើល ១២:២៨ ចទ ២៨:១០ អស ៤:១ ៦៣:១៩) ។ *ព្រះនៃពួកពលបរិវារ* មើលការពន្យល់ ១សយ ១:៣ ។ *ទ្រង់គង់នៅកណ្តាលចេរូប៊ីន* មើលការពន្យល់ ១សយ ៤:៤ មើល ១រប ២៨:២ ផងដែរ ។ ស្តេចដាវីឌបានទទួលស្គាល់នូវសេចក្តីសញ្ញាដ៏អស្ចារ្យ នៃហឹបសញ្ញាដែលជាតំណាងព្រះនៃរាស្ត្រអ៊ីស្រាអែល ។ គឺជាព្រះនៃភាព ទេវាធិតេយ្យ ស្តេចដាវីឌទទួលស្គាល់នូវភាពជាស្តេចនៃព្រះយេហូវ៉ាដែលដឹកនាំទាំងលើអង្គទ្រង់ផ្ទាល់(ដាវីឌ) និងរាស្ត្រអ៊ីស្រាអែលទាំងមូលដោយតំឡើងហឹបនោះនៅទីដែលអាចឃើញដល់ជាតិទាំងមូល ។

**៦:៣** *រទេះថ្មី* ស្តេចដាវីឌធ្វើតាមគំរូនៃសាសភីលីស្ទីន(មើល ១សយ ៦:៧) ជាជាងតាមការណែនាំផ្សេងៗនៃគម្ពីរ នក ២៥:១២–១៥ ជន ៤:៥–៦,១៥ ដែលតម្រូវឱ្យហឹបនោះត្រូវសែងនៅលើស្មារបស់ពួកលេវី (មើល ១រប ១៥:១៣–១៥) ។ *ដឹកចេញពីផ្ទះអ័ប៊ីនាដាប់* មើល ១សយ ៧:១ ។ *ឈ្មោះអ៊ុសាហើយនិងអ័ហ៊ីយ៉ូរជាកូនអ័ប៊ីនាដាប់* ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យ "កូនប្រុស"អាចមានអត្ថន័យថា"ពូជ"ឬពូជអំបូរ ។

**៦:៥** *រុម្មនា* ឧបករណ៍ភ្លេងដែលគេលេងដោយយកដៃក្រឡុងក្រវី ឧបករណ៍នេះបង្ហាញពន្យល់នៅតែក្នុងអត្ថបទនេះទេក្នុងព្រះគម្ពីរទាំងមូល ។

**៦:៧** *កំហុសរបស់គាត់* គឺលោកអ៊ុសាពេលដែលបានខុសមិនព្រមស្តាប់បង្គាប់ព្រះយេហូវ៉ាទេ អ៊ុសាមាននាទីជាអ្នកថែរក្សាហឹបសេចក្តីសញ្ញានេះ (មើលការពន្យល់ ខ.៣ ១សយ ៦:១៩) ។ ភាពចាំបាច់ក្នុងការគោរពសេចក្តីទាំងនោះថ្មីៗនេះបានឱ្យរាស្ត្រអ៊ីស្រាអែល រក្សាច្បាប់នោះក្នុងជីវិតជាមួយព្រះយេហូវ៉ា ហើយទ្រង់បានផ្តល់ឱ្យស្តេចដាវីឌ ចងចាំជារៀងរហូតដោយប្រុងនឹកជាប់ រួមទាំងច្បាប់ទាំងឡាយឱ្យកាន់ខ្ជាប់ខ្ជួន (មើល លវ ១០:១–៣ យស ៧:២៤–២៥ ២៤:១៩–២០ កច ៥:១–១១) ។

**៦:៨** *ដាវីឌទ្រង់មានព្រះទ័យទោមនស្ស* ប្រវត្តិកម្មបំបូងរបស់ស្តេចដាវីឌគឺការថ្នាំថ្នាក់ចិត្តដែលគោលបំណងទ្រង់ បានគោរពដល់ព្រះយេហូវ៉ាលទ្ធផលបានឱ្យឃើញនូវការក្រោធរបស់ព្រះ ។ *ដរាបដល់សព្វថ្ងៃនេះ* គឺបានន័យថារហូតដល់ពេលឬក្នុងកំឡុងពេលការសរសេរគម្ពីរ សាំយូអែលទី២ *ពេរេស–អ៊ុសា* ពាក្យនេះជាទីកន្លែងដែលព្រះក្រោធដាក់ទណ្ឌកម្ម ដើម្បីឱ្យយើងមិនអាចភ្លេចបាន(មើល យស ៧:២៦ និងការពន្យល់)ដូចជាក្នុងការកាត់ទោសរបស់ផងទ្រង់ដើម្បីប្រឆាំងនឹងអ្នកមានបាប គឺទ្រង់សំដែងនូវភាពមិនពេញចិត្ត ដូចជាទ្រង់បានធ្វើនោះ (មើល ៥:២០ និងការពន្យល់) ។

**៦:៩** *ដាវីឌក៏មានសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា* សេចក្តីកំហឹងរបស់ស្តេចដាវីឌមានការកោតខ្លាច ហើយគោរពដល់ព្រះយេហូវ៉ា(មើល ១សយ ១២:២៤ សយ ២៤:១៤ មើលការពន្យល់ លប ២០:១១ សភ ១:៧) (លប

១០យ៉ាងនោះ ដាវីឌបែរជាមិនបាននាំយកហឹបនៃព្រះ
យេហូវ៉ា ចូលទៅឯទ្រង់ ក្នុងក្រុងរបស់ទ្រង់ទេ គឺទ្រង់នាំ
យកទៅដាក់ទុកនៅក្នុងផ្ទះរបស់អូបិឌ–អេដំម[ត] ជាអ្នកមក
ពីក្រុងកាថវិញ ១១ដូច្នេះ ហឹបនៃព្រះយេហូវ៉ាក៏នៅក្នុងផ្ទះ
របស់អូបិឌ–អេដំម ពីក្រុងកាថនោះអស់៣ខែ ហើយព្រះ
យេហូវ៉ាក៏ប្រទានពរដល់អូបិឌ–អេដំម ព្រមទាំងពួកគ្រួគាត់
ទាំងអស់គ្នា[ថ] ។
១២មានគេក្រាបទូលដល់ស្តេចដាវីឌ[ទ]ថា ព្រះយេហូវ៉ា
បានប្រទានពរដល់ពួកគ្រួអូបិឌ–អេដំម និងរបស់គាត់ទាំង
អស់ ដោយព្រោះហឹបនៃព្រះ ដូច្នេះ ដាវីឌទ្រង់ក៏យាងទៅ
នាំយកហឹបនៃព្រះ ពីផ្ទះអូបិឌ–អេដំម ចូលមកក្នុងក្រុង
របស់ទ្រង់វិញដោយអំណរ ១៣កាលពួកអ្នកដែលសែងហឹប
នៃព្រះយេហូវ៉ាដើរទៅបាន៦ជំហាន នោះទ្រង់ថ្វាយ[ធ] គោ
ឈ្មោល១ និងកូនគោ១យ៉ាងធាត់ ១៤ដាវីឌក៏លោតកញ្ឆ្វេង[ន]
អស់ ពីកំឡាំងទ្រង់នៅចំពោះព្រះយេហូវ៉ា ទ្រង់ពាក់អេផូឌ[ប]
ធ្វើពីសំពត់ខ្លូតទេស ១៥ដូច្នេះ ដាវីឌនឹងជំនួរវង្សនៃសាសន៍
អ៊ីស្រាអែលទាំងអស់ បាននាំហឹបនៃព្រះយេហូវ៉ាឡើងមក
ដោយសំឡេងហ៊ោឡើង[ផ]នឹងសូរផ្លុំត្រែផង[ព] ។
១៦ក្នុងវេលាដែលហឹបនៃព្រះយេហូវ៉ា កំពុងតែចូលមក
ក្នុងក្រុងដាវីឌ[ភ] នោះមីកាល[ម]ជាបុត្រីសូល ក៏ទតតាមបង្អួច
ទៅឃើញស្តេចដាវីឌ កំពុងតែហក់លោតកញ្ឆ្វេងនៅ
ចំពោះព្រះយេហូវ៉ា នាងក៏មានព្រះទ័យប្រមាថមើលងាយ
ដល់ទ្រង់ ១៧គេនាំយកហឹបនៃព្រះយេហូវ៉ាចូលមកដាក់នៅ
កន្លែងរៀបចំត្រង់កណ្តាលត្រសាល ដែលដាវីឌបានដំឡើង
សំរាប់ហឹបនោះ[យ] រួចទ្រង់ថ្វាយដង្វាយដុត[រ] និងដង្វាយ
មេត្រី នៅចំពោះព្រះយេហូវ៉ា ១៨លុះបានថ្វាយដង្វាយដុត

**៦:១០** ត ១រប ១៥:១៨ ២៦:៤–៥
**៦:១១** ថ លប ៣០:២៧ ៣៩:៥
**៦:១២** ទ ១ពវ ៨:១
**៦:១៣** ធ ១ពវ ៨:៥,៦២ អរ ៦:១៧
**៦:១៤** ន នក ១៥:២០ ប នក ១៩:៦ ១សយ ២:១៨
**៦:១៥** ផ យស ៦:៥ ព ទដ ៤៧:៥ ៩៨:៦
**៦:១៦** ភ ២សយ ៥:៧ ម ១សយ ១៨:២៧
**៦:១៧** យ ១ពវ ៨:៦ ១រប ១៥:១ ២រប ១:៤ រ លវ ១:១–១៧ ១ពវ ៨:៦២–៦៤
**៦:១៨** ល ១ពវ ៨:២២ វ នក ៣៩:៤៣
**៦:១៩** ស ហស ៣:១ ហ ចទ ២៦:១៣ នហ ៨:១០
**៦:២០** ឡ ១សយ ១៩:២៤
**៦:២១** អ ១សយ ១៣:១៤ ១៥:២៨ ក ២សយ ៥:២ ៧:៨ ១រប ៥:២ ១៧:៧ មីក ៥:២
**៧:១** ក ២សយ ៦:៣

និងដង្វាយមេត្រីរួចហើយ[ល] នោះទ្រង់ក៏ប្រទានពរ[វ]ដល់
ប្រជាជន ដោយនូវព្រះនាមព្រះយេហូវ៉ា នៃពួកពលបរិវារ
១៩រួចទ្រង់ចែកនំបុ័ង១ដុំ សាច់១ដុំ និងផ្លែទំពាំង បាយជូរ១
ផែន[ស] ដល់ប្រជាជនទាំងឡាយ គឺដល់ពួកសាសន៍អ៊ីស្រា–
អែលទាំងអស់គ្នា ទាំងប្រុសទាំងស្រីផង[ហ]ដូច្នេះប្រជាជនក៏
ត្រឡប់ទៅឯលំនៅរបស់គេរៀងខ្លួនវិញ ។
២០រួចហើយ ដាវីឌទ្រង់យាងត្រឡប់ទៅឯដំណាក់ដើម្បី
ឱ្យពរដល់ពួកដំណាក់ទ្រង់ នោះមីកាលជាបុត្រីសូលនាង
ចេញមកទទួលទ្រង់ទូលថា នៅថ្ងៃនេះ ស្តេចនៃសាសន៍
អ៊ីស្រាអែល មានសេចក្តីរុងរឿងឧត្តមអីម្ល៉េះទេ ដោយបាន
បើក ឱ្យអង្គទ្រង់អាក្រាត[ឡ]នៅមុខពួកស្រីបំរើរបស់ពួក
មហាតលិកទ្រង់នៅថ្ងៃនេះ បែបដូចជាមនុស្សចោលម្សៀត
ណាមួយដែលបើកឱ្យខ្លួនអាក្រាតដូច្នេះ ២១តែដាវីឌមាន
បន្ទូលតបថា នោះគឺនៅចំពោះព្រះយេហូវ៉ាទេ ជាព្រះ
ដែលបានរើសអញជាជាងបិតាឯង និងវង្សានុវង្សរបស់
ឯងទាំងអស់គ្នាដែរ ដើម្បីនឹងតាំង[អ]អញឡើងជាស្តេច[ក]លើ
សាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ព្រះយេហូវ៉ា ហេតុ
ដូច្នេះ បានជាអញនឹងលេងសប្បាយ នៅចំពោះព្រះ
យេហូវ៉ា ២២ហើយនឹងចេះតែប្រព្រឹត្តអាក្រក់ជាងនោះទៅ
ទៀត ព្រមទាំងបានទាបថោកដល់ភ្នែកខ្លួនអញផង តែ
ចំណែកពួកបាវស្រីដែលឯងបាននិយាយនោះ គេនឹងលើក
សរសើរដល់អញវិញ ២៣ដូច្នេះ មីកាលជាបុត្រីសូលនាង
ឥតមានបុត្រឡើយ រហូតដល់អស់ជីវិត ។

## ព្រះបន្ទូលសន្យាដល់ស្តេចដាវីឌ

*៧:១–១៧–១រប ១៧:១–១៥*

**៧** ១រួចមកកាលស្តេចទ្រង់គង់នៅក្នុងដំណាក់[ក] ហើយព្រះ

៣:១០,ចទ ៥:៥) ។

**៦:១០** *ក្រុងកាថ* (សូមមើលការពន្យល់ ១រប ១៣:១៣ ប្រៀបធៀប ១រប ១៥:១៨,២៤ ១៦:៤ ២៦:៥ ២៦:៤–៨,១៥,២រប ២៥:២៤) មានការខ្លះពេលខ្លះពាក្យថាក្រុងកាថ ដូចជាស៊ីគ្នានិងទីកន្លែងកំនើតរបស់គាត់នៅឯទីក្រុងភីលីស្ទីននៅក្រុងទ្វារកំផែង (មើល ១៥:១៨ និងការពន្យល់) ទោះជាយ៉ាណាពាក្យថាក្រុងកាថអាចនិយាយសំអាងទៅលើទីក្រុងកាថ–រីម៉ូន ក្នុងអំបូរម៉ាន៉ាសេ (យស ២១:២០–២៥) ។

**៦:១២** *ដាវីឌទ្រង់ក៏យាងទៅនាំយកហឹបនៃព្រះ* ព្រះអម្ចាស់បានប្រទានពរដល់ផ្ទះអូបិឌ–អេដំម ក៏បង្ហាញដាវីឌថាកំហឹងរបស់ព្រះ បានបង្ហាញឱ្យឃើញហើយ ។

**៦:១៣** *អ្នកដែលសែងហឹងនៃព្រះយេហូវ៉ា* ស្តេចដាវីឌក៏បានភ័យខ្លាច ពីកំហុសគាត់ពីមុនមក (១រប ១៥:១៣–១៥) ។

**៦:១៤** *ទ្រង់ពាក់អេផូឌ* មើលការពន្យល់ ១សយ ២:១៨ ។

**៦:១៦** *នាងក៏មានព្រះទ័យប្រមាថមើលងាយដល់ទ្រង់* គឺនាងមីកាលជាបុត្រីសូលមិនបានសរសើដល់ស្តេចដាវីឌទេ ដែលកំពុងសរសើតម្កើងដល់ព្រះយេហូវ៉ាទោះបីជាដាវីឌជាស្តេចក៏ដោយ (មើល ខ.២០–២៣) ។

**៦:១៧** *ដង្វាយដុត* មើល លវ ១ ។ *ដង្វាយមេត្រី* មើល ១សយ ១១:១៥ ។ មើលការពន្យល់ ១សយ ១១:១៥ ។

**៦:១៨** *ទ្រង់ក៏ប្រទានពរដល់ប្រជាជន* គឺដូចជាស្តេចសាឡូម៉ូនក្រោយមកបានធ្វើដាច់ដល់ព្រះនៅឯព្រះវិហារ (១ពវ ៨:៥៥–៦១) ។ *ព្រះយេហូវ៉ានៃពួកពលបរិវារ* មើលការពន្យល់ ១សយ ១:៣ ។

**៦:២១** *ជាបិតាឯង* មើលការពន្យល់ ១សយ ៩:១៦ នៅទីនេះពាក្យថាបិតាគឺមានន័យថា (អ្នកដឹកនាំ) ។

**៦:២៣** *មីកាល . . . នាងឥតមានបុត្រឡើយ* វាគឺជាការដាក់ទណ្ឌកម្មដល់មោទនៈភាពរបស់នាង ក្នុងគ្រានោះហើយក៏ជាការកាត់ទោស របស់ព្រះទៅលើដំណាក់របស់សូល ។

យេហូវ៉ាបានប្រោសប្រទាន ឱ្យទ្រង់មានសេចក្ដីសំរាករួច
ពីខ្មាំងសត្រូវ[ខ]នៅគ្រប់ទិស[គ] ២នោះទ្រង់មានបន្ទូលទៅ
ហោរ៉ាណាថាន់[ឃ]ថា មើលចុះ យើងនៅក្នុងដំណាក់[ង]ធ្វើពី
ឈើតាត្រៅ តែហឹបនៃព្រះមានតែសំពត់បាំងប៉ុណ្ណោះទេ[ច]
៣ណាថាន់ទូលឆ្លើយថា សូមព្រះករុណាទ្រង់ធ្វើតាមគ្រប់
ទាំងសេចក្ដីប្រាថ្នា ដែលនៅក្នុងព្រះទ័យចុះ[ឆ] ដ្បិតព្រះ
យេហូវ៉ាគង់ជាមួយនឹងទ្រង់ហើយ ៤តែនៅវេលាយប់នោះ
ឯង ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកណាថាន់ថា ៥ចូរទៅ
ប្រាប់ដាវីឌ ជាអ្នកបំរើអញថា ព្រះយេហូវ៉ាទ្រង់សួរដូច្នេះ
តើឯង[ជ]នឹងស្អាងវិហារឱ្យអញនៅឬ[ឈ] ៦អញមិនដែលនៅ
ក្នុងវិហារណាទេ ចាប់តាំងពីថ្ងៃដែលអញបាននាំពួកកូន
ចៅអ៊ីស្រាអែល ចេញពីស្រុកអេស៊ីព្ទមក ដរាបដល់សព្វ
ថ្ងៃនេះ[ញ] គឺអញបាននៅតែក្នុងត្រសាល[ដ] ហើយក្នុងរោង
ឧបោសថវិញ[ឋ] ៧នៅគ្រប់ទីកន្លែង ដែលអញបានដើរជា
មួយនឹងពួកកូនចៅអ៊ីស្រាអែលទាំងប៉ុន្មាន[ឌ] នោះតើអញ
ដែលនិយាយ១ម៉ាត់[ឍ] ទៅពូជអំបូរសាសន៍អ៊ីស្រាអែលណា
មួយ ដែលអញបានបង្គាប់ឱ្យឃ្វាលសាសន៍អ៊ីស្រាអែលជា
រាស្ត្រអញថា ហេតុអ្វីបានជាឯងរាល់គ្នាមិនបានស្អាង

**៧:១** ខ ខ.១១ គ ១រប ២២:១៨ **៧:២** ឃ ២សយ ១២:១ ១ពវ ១:៨,២២ ១រប ២៩:២៩ ២រប ៩:២៩ ង ២សយ ៥:១១ ១ពវ ៣:១ ៧:១,២។៧ ៩:១ ២រប ៨:១ យរ ២២:១៤ ហាក ១:៤ ច នក ២៦:១ ទដ ១៣២:៣ កច ៧:៤៥–៤៦ **៧:៣** ឆ ១សយ ១០:៧ ទដ ១៣២:១–៥ **៧:៥** ជ ១ពវ ៨:១៩ ១រប ២២:៨ ឈ ១ពវ ៥:៣–៥ ១រប ២៨:៣ **៧:៦** ញ កច ៧:៤៥ ដ នក ៤០:១៨,៣៤ យស ១៨:១ ឋ ១ពវ

វិហារ[ណ] ពីឈើតាត្រៅឱ្យអញឬទេ[ត] ៨ដូច្នេះ ចូរឯងប្រាប់
ដាវីឌជាអ្នកបំរើអញឥឡូវថា ព្រះយេហូវ៉ានៃពួកពល
បរិវារទ្រង់មានបន្ទូលយ៉ាងនេះ អញបានយកឯងពីក្រោល
ចៀមគឺពីការឃ្វាលហ្វូងសត្វ[ថ]មក ដើម្បីឱ្យឯងបានធ្វើជា
អ្នកនាំមុខ[ទ]សាសន៍អ៊ីស្រាអែល ជារាស្ត្រអញ[ធ] ៩អញបាន
នៅជាមួយនឹងឯង គ្រប់ទីកន្លែងណាដែលឯងបានទៅ[ន] ក៏
បានធ្វើឱ្យពួកខ្មាំងសត្រូវឯងទាំងប៉ុន្មាន វិនាសពីមុខឯង
ចេញ[ប] អញបានលើកឈ្មោះឯងឱ្យជាធំ ស្មើនឹងឈ្មោះនៃ
អស់អ្នកធំដែលនៅផែនដី[ផ] ១០អញបានដំរូវទីកន្លែង១ ឱ្យពួក
អ៊ីស្រាអែលជារាស្ត្រអញ ហើយបានដាំ[ព]គេ ឱ្យបាននៅជាប់
ក្នុងស្រុករបស់គេ ឥតរលើងទៅឯណាទៀតឡើយ ឯពួក
មនុស្សអាក្រក់[ភ]នឹងមិនធ្វើទុក្ខគេ[ម] ដូចកាលពីដើមទៀត[យ]
១១ឬដូចនៅគ្រាដែលអញបានតាំងពួកចៅហ្វាយ[រ] ឱ្យគ្រប់

៨:១៦ **៧:៧** ឌ ចទ ២៣:១៤ ឍ ២សយ ៥:២ ណ ១ពវ ៨:២៧ អស ៦៦:១ ត លវ ២៦:១១–១២ **៧:៨** ថ ១សយ ១៦:១១ ១រប ២១:១៧ ទដ ៧៨:១ អម ៧:១៥ ទ ១សយ ២:៧–៨ ៩:១៦ ១៦:១ ២សយ ៦:២១ ធ ទដ ៧៨:៧០–៧២ ២កថ ៦:១៨ **៧:៩** ន ១សយ ១៨:១៤ ២សយ ៥:១០ ប ទដ ១៨:៣៧–៤២ ផ នក ១១:៣ **៧:១០** ព នក ១៥:១៧ អស ៥:១–៧ ភ ទដ ៨៩:២២–២៣ ម ២ពវ ២១:៨ ២រប ៣៣:៨ យ ទដ ១៤៧:១៤ អស ៥៤:១៤ ៦០:១៨

**៧:១–២៩** ជាសន្យារបស់ព្រះចំពោះដាវីឌ(មើលសេចក្ដីផ្ដើម គម្រោងបទនិងផ្ទៃរឿង)ទោះវាមិនបានបង្ហាញ ឬបញ្ជាក់ថាជាសេចក្ដីសញ្ញាក៏ដោយ (២៣:៥ ទដ ៨៩:៣,២៨,៣៤,៣៩ ប្រៀបធៀប ទដ ១៣២:១១) ហើយស្ដេចដាវីឌឆ្លើយតប ជាសេចក្ដីសំណើរជាពាក្យវាចារ ដោយការទទួលស្គាល់ថាសេចក្ដីសញ្ញាក៏បានតាំងរួចហើយ(មើលការពន្យល់ ខ.១១,១៦,២០,២៨)។

**៧:១** *កាលស្ដេចទ្រង់គង់នៅក្នុងដំណាក់* មើល ៥:១១ មើលការពន្យល់ ៥:១២ ។ *ព្រះយេហូវ៉ាបានប្រោសប្រទាន ឱ្យទ្រង់មានសេចក្ដីសំរាករួចពីពួកខ្មាំងសត្រូវនៅគ្រប់ទិស* តាមប្រវត្តិដែលទទួលបានជោគជ័យ សូមមើលការពន្យល់ ក្នុង ៨:១–១៤ គឺជាព្រឹត្តការណ៍ក្នុងជំពូកនេះ ។ ការរៀបចំនូវសំភារៈគឺជាកិច្ចការមួយ(មើលការពន្យល់ ៥:១៧ ៨:១)ក្នុងជំពូកទី៦ គឺជាការកត់ត្រាពីការនាំហឹបនៃសេចក្ដីសញ្ញាទៅឯក្រុងយេរូសាឡិម គឺក្នុងផ្ទះនៃហឹប ។

**៧:២** *ហោរាណាថាន់* គឺជាអ្នកដែលយើងចង់បង្ហាញឱ្យឃើញពីហោរា ។ *ឈើតាត្រៅ* មើលការពន្យល់ ៥:១១ ។ *សំពត់បាំង* មើល ខ.៦ ៦:១៧ ឥឡូវអង្គទ្រង់នេះហើយ ដែលមានរាជវាំង(ជាសញ្ញាដែលថាទ្រង់បង្កើតអង្គទ្រង់ផ្ទាល់ជាស្ដេច)សំពត់បាំងនោះ មិនទំនងដល់ស្ដេចដាវីឌជាអ្នកដែលសាកសម និងទទួលរាជបល្ល័ង្កនោះឡើយ គឺជាព្រះមហាក្សត្រនៃរាស្ត្រអ៊ីស្រាអែល ។ (មើលការពន្យល់ ៦:២ ក៏មើល ទដ ១៣២:២–៥ កច ៧:៤៦)ទ្រង់ចង់ស្អាង នូវដំណាក់នៃស្ថានសួគ៌នៃរាស្ត្រអ៊ីស្រាអែលក្នុងរាជធានី នៃទីក្រុងនៃនគរផងទ្រង់ ។

**៧:៣** *ណាថាន់ទូលឆ្លើយថា* ក្នុងការព្រឹក្សានិងហោរាដាវីឌ បានស្វែងរកព្រះហឫទ័យទ្រង់ ប៉ុន្តែសេចក្ដីសម្រេចដ៏មោះមុតចេញជាសម្លេង នៃផែនការស្ដេចដាវីឌ ក្នុងព្រះនាមព្រះយេហូវ៉ាការបើកសម្ដែងពីព្រះអម្ចាស់ ។ *ដ្បិតព្រះយេហូវ៉ាគង់ជាមួយនឹងទ្រង់ហើយ* មើល ខ.៩ និងការពន្យល់ ១សយ ១៦:១៨ ។

**៧:៥–១៦** *សេចក្ដីសញ្ញាដល់ស្ដេចដាវីឌ* (មើលការពន្យល់ ខ.១១) ។

**៧:៥** *តើឯងនឹង . . . ?* សេចក្ដីប៉ងប្រាថ្នារបស់ស្ដេចដាវីឌ គឺមានលក្ខណៈសាមញ្ញ(១ពវ ៨:១៨–១៩) ប៉ុន្តែ អំណោយទានរបស់ទ្រង់ និងបេសកកម្ម គឺត្រូវប្រយុទ្ធក្នុងសមរភូមិរបស់ព្រះយេហូវ៉ា រហូតដល់រាស្ត្រអ៊ីស្រាអែលបានទទួលភាពសុខសាន្តនៅឯទឹកដីសន្យា(សូមមើល ខ.១០ ១ពវ ៥:៣ ១រប ២២:៨–៩ និងការពន្យល់) ។

**៧:៧** *នោះតើអញបាននិយាយ . . . ហេតុអ្វី . . . មិនបានស្អាងវិហារ . . . ?* ស្ដេចដាវីឌបានភ្លេច ឬមិនយល់ពីអទិភាពរបស់ព្រះយេហូវ៉ា ។ គឺគាត់បានមើលឃើញ ឬគិតពីសាសន៍ដទៃហើយសំគាល់ពីពួកគេ ដែលព្រះគេនោះត្រូវបានមនុស្សជាច្រើនចាប់អារម្មណ៍ ទៅលើអ្នកដែលបង្កើតរូបព្រះនោះ និងអ្នកដែលកាន់តាមចំពោះសាសន៍របស់ពួកគេ ។ ពួកគេបានយករូបព្រះជាធំដោយពុំបានគិតពីព្រះយេហូវ៉ា ដែលទ្រង់បានលើកតាំងអ្នកដឹកនាំក្នុងស្រុកអ៊ីស្រាអែល គឺដើម្បីឃ្វាលរាស្ត្ររបស់ផងទ្រង់ (ដោយហេតុនោះទ្រង់បានជ្រើសរើសដាវីឌពី"វាលស្មៅ"ខ.៨) ។

**៧:៩** *ធ្វើឱ្យពួកខ្មាំងសត្រូវឯងទាំងប៉ុន្មាន វិនាសពីមុខឯងចេញ* មើលការពន្យល់នៅ ខ.១ ។

**៧:១០** *អញបានតំរូវទីកន្លែង១ឱ្យពួកអ៊ីស្រាអែល* គឺជាហេតុផលនេះហើយ ដែលព្រះយេហូវ៉ាបានលើកដាវីឌជាស្ដេចហើយតាមរយៈ ស្ដេចដាវីឌជាអ្នករៀបចំ ។ *ដូចកាលពីដើម* ក្នុងប្រទេសអេស៊ីព្ទ ។

**៧:១១** *ពួកចៅហ្វាយ* គឺក្នុងកំឡុងពេលពួកចៅហ្វាយ។ *អញឱ្យឯងបានសំរាក*

គ្រងលើអ៊ីស្រាអែល ជារាស្ត្រអញនោះឡើយ អញបាន
ប្រោសឱ្យឯងបានសំរាក រួចពីពួក ខ្មាំងសត្រូវឯងទាំង
អស់[ល] ហើយ (យ៉ាងនោះព្រះយេហូវ៉ាទ្រង់មានបន្ទូល[វ]ឱ្យ
ព្រះរាជាជ្រាបថា ទ្រង់នឹងតាំង[ស] ព្រះវង្សា[ហ] ព្រះករុណា
ឡើង) [១២]កាលណាឯងបានរស់នៅគ្រប់កំណត់អាយុហើយ
រួចបានដេកលក់ទៅ[ឡ]ជាមួយនឹងពួកព្ធយុកោឯង នោះអញ
នឹងតាំងពូជពង្សដែលកើតពីឯងមក ឱ្យសោយរាជ្យឡើង
ជំនួសឯង[អ] ហើយអញនឹងតាំងរាជ្យវាឱ្យខ្ជាប់ខ្ជួនឡើង[ក]
[១៣]គឺវាដែលនឹងស្អាងវិហារ១[ខ]សំរាប់ឈ្មោះអញ[គ] ហើយ
អញនឹងតាំងបល្ល័ង្កនៃរាជ្យវា ឱ្យនៅស្ថិតស្ថេរជាដរាប
ទៅ[ឃ] [១៤]អញនឹងធ្វើជាឪពុកដល់វា ហើយវានឹងបានជាកូន
ដល់អញ[ង] បើកាលណាវាប្រព្រឹត្តការទុច្ចរិត នោះអញនឹង
ផ្ចាញ់ផ្ចាលវា[ច] ដោយដំបង[ឆ] របស់មនុស្ស ហើយនឹងស្នាម
រំពាត់នៃពួកមនុស្សជាតិ [១៥]ប៉ុន្តែសេចក្ដីសប្បុរសរបស់អញ
មិនដែលឃ្លាតចេញពីវា[ជ] ដូចជាអញបានដកចេញពីសូល[ឈ]
ដែលអញបានចោលពីមុខឯងចេញនោះឡើយ [១៦]នោះ
វង្សា និងរាជ្យរបស់ឯងនឹងបានតាំងជាប់នៅចំពោះឯង
ជាដរាបតទៅ បល្ល័ង្កឯង[ញ]នឹងបានខ្ជាប់ខ្ជួន[ដ]នៅជារៀង
រាបដរាបទៅ[ឋ] [១៧]ណាថាន់ក៏ទូលនឹងដាវីឌ តាមគ្រប់ទាំង
ព្រះបន្ទូល ហើយតាមការជាក់ស្តែងទាំងនេះគ្រប់ជំពូក ។

## សេចក្ដីអធិស្ឋានរបស់ស្តេចដាវីឌ

*៧:១៨–២៩ – ១របា ១៧:១៦–២៧*

[១៨]នោះស្តេចដាវីឌទ្រង់ក៏យាងចូលទៅ គង់នៅចំពោះ
ព្រះយេហូវ៉ាទូលថា ឱព្រះអម្ចាស់យេហូវ៉ាអើយទូលបង្គំ
ជាអ្វី[ឌ] ហើយពូជពង្សទូលបង្គំជាអ្វី បានជាទ្រង់ប្រោសឱ្យ
ទូលបង្គំបានដល់ត្រឹមនេះ [១៩]ប៉ុន្តែ ឱព្រះអម្ចាស់យេហូវ៉ា

**៧:១១** រ ៣ច ២:១៦ ១សយ ១២:៩–១១ ល ខ.១ វ ១ពវ ២:២៤ ស ១សយ ២៥:២៨ ទដ ៨៩ៗ៣៥–៣៧ មថ ១:១ លក ១:៣២–៣៣ កថ ១៣:២២–២៣ ២ធថ ២:៨ ហ នក ១:២១ អស ៧:២ **៧:១២** ឡ លប ១៥:១៥ ១ពវ ២:១ កថ ១៣:៣៦ អ ១ពវ ៨:២០ ទដ ១៣២:១១–១២ យរ ៣០:២១ ៣៣:១៥ ក ២របា ២៣:៣ **៧:១៣** ខ ចទ ១២:៥ ១ពវ ៦:១២ គ ចទ ១៦:១១ ១ពវ ៥:៥ ៨:១៩,២៩ ២ពវ ២១:៤,៧ឃ ខ.១៦ លប ៩:១៦ ២សយ ២២:៥១ ១ពវ ២:៤,៤៥ ១របា ២២:១០ ២៨:៦ ២របា ៦:១៦ ៧:១៨ ១៣:៥ ២១:៧ ទដ ៨៩:៣–៤,២៩,៣៥–៣៧ សផ ២៥:៥ អស ៩:៧ ១៦:៥ យរ ១៧:២៥ ៣៣:១៧,២១ ដយ ៧:២៧ **៧:១៤** ង ទដ ២:៧ ៨៩:២៦ យរ ៣:១៩ មថ ៣:១៧ យហ ១:៤៩ ២កថ ៦:១៨ ហព ១:៥ វវ ២១:៧ ច ចទ ៨:៥ ១ពវ ១១:៣៤ ១របា ២២:១០ ហព ១២:៧ ឆ ទដ ៨៩:៣០–៣៣ សភ ១៣:២៤ **៧:១៥** ជ ខ.២៥ ១ពវ ២:៤ ៦:១២ ៨:២៥ ៩:៥ ១១:១៣,៣២ ២ពវ ១៩:៣៤ ២របា ៦:១៦ ៧:១៨ ២១:៧ ទដ ៨៩:២៤,៣៣ យរ ៣៣:១៧ ឈ ១សយ ១៣:១៣ ១៥:២៨ ១៦:១៤ **៧:១៦** ញ ទដ ៨៩:៣៦–៣៧ លក ១:៣៣ ដ ទដ ៩:៧ ៩៣:២ ១០៣:១៩ ឋ ខ.១៣ **៧:១៨** ឌ នក ៣:១១ **៧:១៩** ឍ អស ៥៥:៨–៩

*រួចពីពួកខ្មាំងសត្រូវឯងទាំងអស់ហើយ* មើល ខ.១,៩ ស្តេចដាវីឌបានជ័យជម្នះលើការគម្រាមកំហែង គឺដែលមានជាសេចក្ដីអំណរ និងសម្រាកសម្រាប់ថ្ងៃអានាគតទ្រង់ជាព្រះក៏នឹងផ្ដល់នូវជំរកដ៏សុខសាន្តដល់រាស្ត្រទ្រង់ គឺយើងប្រៀបធៀបថាស្តេចដាវីឌ មិនបានសាងសង់ផ្ទះឬជាតំ ណាក់ផ្ទាល់ខ្លួនទេការសំខាន់ គឺស្តេចអង្គនេះដែលព្រះបានរើសតាំងឡើយ គឺដើម្បីស្អាងឬសាងផ្ទះ (ព្រះវិហារ) ដែលមានភាពអស់កល្បជានិច្ចវិញ (ខ.១៦) ព្រះទ្រង់បានស្អាង ឬលើកឡើងឱ្យមានអំណាចតាមរយៈលោកតាអ័ប្រាហាំឱ្យធ្វើជាបិតានៃមនុស្សលើពិភពលោក ។ ហើយឥឡូវនេះទ្រង់បានស្អាង ដំណាក់រាជវាំងនៃស្តេចដាវីឌ ដោយសន្យាឱ្យរាស្ត្រអ៊ីស្រាអែលបានសំរាកនៅឯទឹកដីសន្យាព្រះក៏មានបន្ទូលសន្យាដោយគ្មានលក្ខខណ្ឌ ជាមួយស្តេចដាវីឌដូចជាមួយលោកណូអេនិងលោកអ័ប្រាហាំ (មើលការពន្យល់ លប ៩:៩) ព្រះទ្រង់បានបញ្ជាក់ទៀតថា មានការសម្រេចមួយចុងក្រោយតាម រយៈព្រះគ្រីស្ទដែលជាអង្គមួយមកយកនិស្ស័យក្នុងពូជយូដាតាមរយៈពូជដាវីឌ (មើល ២៣:៥ ទដ ៨៩:៣–៤,៣០–៣៧ និងការពន្យល់ ១៣២:១១–១៨ អស ៩:១–៧ ៥៥:៣ មថ ១:១ លក ១:៣២–៣៣,៦៩ កថ ២:២៩–៣០:២៣ ។

**៧:១២** *អញនឹងតាំងពូជពង្សដែលកើតពីឯងមក ឱ្យសោយរាជ្យឡើងជំនួសឯង* គឺជាខ្សែរាជវង្សដាវីឌ ដែលមិនមែនជាស្តេចសូលដែលបន្តរលើការគ្រងរាជលើរាស្ត្រអ៊ីស្រាអែល គឺបន្ទាប់ពីស្តេចដាវីឌសុគត ។

**៧:១៣** *គឺវាដែលនឹងស្អាងវិហារ១សំរាប់ឈ្មោះអញ ហើយអញនឹងតាំងបល័ង្កនៃរាជ្យវា* គឺជាអទិភាពនៃព្រះរាជតំណាក់ផ្ទាល់ គឺជាបល័ង្កដែលទ្រង់អាចសម្រាកបាន (១របា ៦:៣១ ២៨:២) គឺក៏ដូចជាព្រះរាជបុត្រទ្រង់គឺជាស្តេចសាឡូម៉ូនផងដែរក្នុង ខ.៥ (មើលការពន្យល់ ១សយ ២៥:២៥) ។

**៧:១៤** *ធ្វើជាឪពុកដល់វា . . . ជាកូនដល់អញ* ភាសាដែលដឹងច្បាស់នេះបានបញ្ជាក់ភាពជាទំនាក់ទំនងពិសេស ដែលព្រះយេហូវ៉ាបានសន្យាថានិងរក្សាជាមួយនឹងពូជរបស់ស្តេចដាវីឌ ដែលនិងពង្រីកបល័ង្កស្តេចដាវីឌ ។ ដែលជាតំណាងរបស់ព្រះដែលបានជ្រើសរើស ឱ្យគ្រប់គ្រងលើរាស្ត្ររបស់ផងទ្រង់ (មើលការពន្យល់ ទដ ២:៧ ៤៥:៦ ៨០:២៧ មើល ៨៩:២៦) ផងដែរ ។ តាមរយៈព្រះគ្រីស្ទព្រះបន្ទូលសន្យានេះនិងបានបំពេញសម្រេចតាម (មើល ១:១១ ហព ១:៥ និងការពន្យល់) ។

**៧:១៥** *ប៉ុន្តែសេចក្ដីសប្បុរសរបស់អញ* គឺជាសេចក្ដីសប្បុរសដែលមិនចេះផុតហើយមានលក្ខណៈវិសេសវិសាល (មើលការពន្យល់ នៅ ទដ ៦:៤) ។

**៧:១៦** *បល្ល័ង្កឯងនឹងបានខ្ជាប់ខ្ជួននៅ* មើលការពន្យល់ ខ.១១ ក៏សូមមើលសេចក្ដីផ្ដើមគម្រោងអត្ថបទនិងសាច់រឿងទាំងមូល ។ ជាព្រះបន្ទូលសន្យាចំពោះនគរដែលស្ថិតស្ថេរអស់កល្ប សម្រាប់ដំណាក់ដាវីឌ ។

**៧:១៨–២៩** ស្តេចដាវីឌបានអធិស្ឋានចំពោះភាពអស្ចារ្យ ដែលព្រះអម្ចាស់មានព្រះទ័យប្ដូរផ្ដាច់ចំពោះទ្រង់ និងពូជដែលជាវង្សានុវង្សរបស់ទ្រង់ ។ ហើយស្តេចដាវីឌបានទទួលស្គាល់នូវអ្វីៗ ដែលព្រះបានសន្យាចំពោះទ្រង់គឺសម្រាប់ការសង្គ្រោះរាស្ត្រអ៊ីស្រាអែលទាំងអស់ ដែលជាគោលបំណងនៃព្រះហឫទ័យក្នុងការបំពេញនូវព្រះបន្ទូលសន្យាក្នុងសេចក្ដីសញ្ញា ក៏ជាសេចក្ដីតម្រូវឱ្យមនុស្សទូទាំងសកលលោកទាំងមូល បានសរសើដល់ទ្រង់ជាព្រះនៃពួកគេ ។

**៧:១៨** *យាងចូលទៅ* ជាការសន្មតបញ្ជាក់នៃសំពត់បាំង (៦:១៧) ដែលជាទីកន្លែងហឹបសញ្ញាបានរក្សានៅទីនោះ ។ *គង់នៅចំពោះព្រះយេហូវ៉ា* ហឹបនៃសេចក្ដីសញ្ញាជានិមិត្តនៃវត្តមានរបស់ព្រះអម្ចាស់ និងរាស្ត្ររបស់ផងទ្រង់ (មើល នក ២៥:២២ មើលការពន្យល់ ១សយ ៤:៣–៤,២១) ។

**៧:១៩** *យ៉ាងនោះតើត្រូវរបៀបរបស់មនុស្សឬ* អត្ថន័យនៃអនុប្រយោគនេះមិនមានលក្ខណៈច្បាស់លាស់ទេ (ប្រៀបធៀប ១របា ១៧:១៧) ។ ប្រយោគនេះក៏មាលក្ខណៈសង្កត់សម្លេង (នេះគឺជាច្បាប់សំរាប់បុរសៗ ឱព្រះអម្ចាស់

អើយ នេះជាការយ៉ាងតូចនៅព្រះនេត្រទ្រង់ទេ បានជាទ្រង់
មានបន្ទូលពីពូជពង្សនៃទូលបង្គំ ជាបាវបំរើទ្រង់ រហូតដល់
យូរអង្វែងទៅមុខទៀត ឱព្រះអម្ចាស់យេហូវ៉ាអើយ យ៉ាង
នោះតើត្រូវតាមរបៀបរបស់មនុស្សឬ[ឍ] [២០]តើដាវីឌទូលបង្គំ
នេះ នឹងទូលទ្រង់បានដូចម្តេចទៅទៀត[ណ] ដ្បិត ឱព្រះអម្ចាស់
យេហូវ៉ាអើយ ទ្រង់ស្គាល់[ត]ទូលបង្គំ ជាអ្នកបំរើទ្រង់ហើយ[ថ]
[២១]ទ្រង់បានធ្វើការយ៉ាងធំទាំងនេះ ឱ្យទូលបង្គំជាបាវបំរើ
ទ្រង់បានដឹង ដោយយល់ដល់ព្រះបន្ទូលនៃទ្រង់ទេ ហើយក៏
តាមព្រះហឫទ័យទ្រង់ផង [២២]ដូច្នេះ ឱព្រះយេហូវ៉ាដ៏ជាព្រះ
អើយ ទ្រង់ធំណាស់[ទ,ធ] គ្មានណាឱ្យស្មើទ្រង់ឡើយ[ន] ហើយ
តាមគ្រប់ទាំងសេចក្តី ដែលត្រចៀកទូលបង្គំរាល់គ្នាបានឮ[ប]
នោះក៏គ្មានព្រះឯណា[ផ]ក្រៅពីទ្រង់ដែរ [២៣]តើមានសាសន៍
ឯណាមួយនៅផែនដី ឱ្យដូចអ៊ីស្រាអែលជារាស្ត្ររបស់ផង
ទ្រង់[ព] ដែលព្រះបានយាង ទៅលោះចេញទុកជារាស្ត្ររបស់
ទ្រង់ ដើម្បីឱ្យបានល្បីព្រះនាម[ភ] ហើយនិងប្រោសការយ៉ាង
ធំ[ម]ដល់គេ ហើយការគួរស្ញែងខ្លាចសំរាប់ស្រុកគេ នៅមុខ
រាស្ត្ររបស់ផងទ្រង់ ដែលទ្រង់បានលោះ[យ]គេចេញពីស្រុក
អេស៊ីព្ទ គឺឱ្យរួចពីសាសន៍ដទៃហើយនឹងព្រះរបស់គេផង
[២៤]ទ្រង់ក៏បានតាំងពួកអ៊ីស្រាអែល ជារាស្ត្ររបស់ទ្រង់ ឱ្យ
បានធ្វើជារាស្ត្ររបស់ផងទ្រង់[រ] ជារៀងរាបដរាបទៅ
ហើយឯទ្រង់ ឱព្រះយេហូវ៉ាអើយ ទ្រង់បានត្រឡប់ជាព្រះ
ដល់គេដែរ[ល] [២៥]ឥឡូវនេះឱព្រះយេហូវ៉ាដ៏ជាព្រះអើយ
សូមបញ្ជាប់ព្រះបន្ទូល[វ] ដែលទ្រង់បានមានបន្ទូលមក ពី
ដំណើរទូលបង្គំ ជាបាវបំរើទ្រង់ហើយពីពូជពង្សរបស់
ទូលបង្គំ ឱ្យបានជាប់ជានិច្ចតទៅមុខសូមទ្រង់ធ្វើសំរេច ដូច
ជាទ្រង់បានមានបន្ទូលមកនោះចុះ [២៦]សូមឱ្យព្រះនាមទ្រង់[ស]
បានថ្កុំថ្កើងឡើងជានិច្ច ដោយគេថា ព្រះយេហូវ៉ានៃពួក
ពលបរិវារ ទ្រង់ជាព្រះនៃសាសន៍អ៊ីស្រាអែល ហើយសូម
ឱ្យពូជពង្សរបស់ដាវីឌ ជាបាវបំរើទ្រង់ បានស្ថិតស្ថេរ[ហ]
នៅចំពោះទ្រង់ [២៧]ពីព្រោះឱព្រះយេហូវ៉ា នៃពួកពល
បរិវារជាព្រះនៃសាសន៍អ៊ីស្រាអែលអើយ ទ្រង់បានសំដែង
ឱ្យទូលបង្គំ ជាបាវបំរើទ្រង់បានដឹងហើយ ដោយបន្ទូលថា
អញនឹងតាំងវង្សាឯងឡើងហេតុដូច្នោះ បានជាទូលបង្គំ
ជាបាវបំរើទ្រង់ មានចិត្តក្លាហាន និងហ៊ានអធិស្ឋានពាក្យ
ទាំងនេះ ទូលដល់ទ្រង់ [២៨]ឥឡូវនេះ ឱព្រះអម្ចាស់យេហូវ៉ា
អើយ ទ្រង់ជាព្រះពិត ហើយព្រះបន្ទូលទ្រង់សុទ្ធតែពិតត្រង់[ឡ]
ទ្រង់បានមានបន្ទូលពីព្រះគុណនេះមកទូលបង្គំ ជាបាវបំរើ
ទ្រង់ [២៩]ដូច្នេះ សូមទ្រង់សព្វព្រហឫទ័យ និងប្រទានពរ ដល់
ពូជពង្សរបស់ទូលបង្គំ ជាបាវបំរើទ្រង់ ដើម្បីឱ្យបានស្ថិត
ស្ថេរ នៅចំពោះទ្រង់ជាដរាប ដ្បិត ឱព្រះអម្ចាស់យេហូវ៉ា
អើយ ទ្រង់បានសន្យាហើយ ដូច្នេះ ដោយសារព្រះពរទ្រង់
នោះពូជពង្សរបស់ទូលបង្គំ ជាបាវបំរើទ្រង់ និងបានពរ[អ]
នៅអស់កល្បជានិច្ច ។

## ជ័យជំនះរបស់ស្តេចដាវីឌ

*៨:១–១៤–១របា ១៨:១–១៣*

**៨** [១]ក្រោយនោះមក ដាវីឌទ្រង់វាយបង្ក្រាបពួកភីលីស្ទីន[ក]
បានហើយ ទ្រង់ចាប់យក[ខ]អំណាចទីក្រុងហ្លួង ពីកណ្តាប់ដៃ
នៃពួកភីលីស្ទីន [២]ទ្រង់ក៏ប្រហារសាសន៍ម៉ូអាបដែរ[គ] ទ្រង់ឱ្យ

**៧:២០** ឍ អស ៣៨:១៥ ណ យហ ២១:១៧ ថ ១សយ ១៦:៧
**៧:២២** ទ ទដ ៤៨:១ ៧៧:១៣ ៨៦:១០ យរ ១០:៦ ធ ចទ ៣:២៤ ន នក ៩:១៤ ប នក ១០:២ ពច ៦:១៣ ទដ ៤៤:១ ផ នក ៨:១០ ២០:៤
**៧:២៣** ព ចទ ៤:៣២–៣៨ ៣៣:២៩ ១សយ ១២:២២ ភ ជន ៦:២៧ ម ចទ ១០:២១ យ ចទ ៧:៧–៨ ៩:២៦
**៧:២៤** រ ចទ ២៦:១៨ ល នក ៦:៦–៧ ទដ ៤៨:១៤
**៧:២៥** វ ខ.១៥ ជន ២៣:១៩ ២របា ១:៩
**៧:២៦** ស នក ៦:៣ នហ ៩:៥ ទដ ៧២:១៩ ៨៦:៨ មថ ៦:៩ ហ ១សយ ២៥:២៨
**៧:២៨** ឡ នក ៣៤:៦ យហ ១៧:១៧
**៧:២៩** អ ជន ៦:២៣–២៧ **៨:១** ក ទដ ៦០:៨ ៨៧:៤ ១០៨:៩ ខ ហព ១១:៣២–៣៣ **៨:២** គ លប ១៩:៣៧ ជន ២១:២៩

យេហូវ៉ាអើយ) ក៏ជាការសរុបនៃច្បាប់ពីព្រះអម្ចាស់ ដែលទំនាក់ទំនងនិងស្តេចដាវីឌនិងដំណាក់ទ្រង់ផងដែរ ។

**៧:២០** *ទ្រង់ស្គាល់* ឬទ្រង់ទទួលស្គាល់(មើល ហស ២:២០ ៦:៦)ឬ(មើល លប ១៨:១៩ អម ៣:២) ដាវីឌទទួលស្គាល់ព្រះបន្ទូលសន្យា គឺជាសេចក្តីសញ្ញា(២៣:៥)។

**៧:២១** *ព្រះបន្ទូល* ជាពាក្យបន្ទូលសេចក្តីសញ្ញារបស់ព្រះ ដែលសន្យាដល់រាស្ត្រទ្រង់ ។

**៧:២២** *គ្មាននណាឱ្យស្មើទ្រង់ឡើយ* មើល ២២:៣២ ១សយ ២:២ ។

**៧:២៣** *តើមានសាសន៍ណានៅផែនដី ឱ្យដូចអ៊ីស្រាអែល ជារាស្ត្ររបស់ផងទ្រង់* គឺជាផែនការនៃព្រះដល់រាស្ត្ររបស់ផងទ្រង់ ដែលរើសសម្រាប់នឹងថែរក្សាទុក(ចទ ៧:៦–៨ ៣៣:២៦–២៩) ។ *ដើម្បីឱ្យបានល្បីព្រះនាម* គឺព្រះទ្រង់មានមូលដ្ឋាន និងគោលការណ៍ច្បាស់លាស់ដែលបានជ្រើសរើសដោយសេចក្តីស្រឡាញ់ដោយបើកសម្តែង ហើយភ្ជាប់នឹងសាសន៍អ៊ីស្រាអែល (មើល ១សយ ១២:២២ ចទ ៧:៦–៨ ៩:៤–៦ នហ ៩:១០ អស ៦៣:១២ យរ ៣២:២០–២១) ។

**៧:២៤** តាមរយៈស្តេចដាវីឌគឺព្រះបានត្រាសហៅ ដោយភាពមានសារៈសំខាន់ចំពោះទំនាក់ទំនង(មើល យរ ៧:២៣ និងការពន្យល់) ។ *ហើយឯទ្រង់ឱព្រះយេហូវ៉ាអើយ ទ្រង់បានត្រឡប់ជាព្រះដល់គេដែរ* គឺអ្វីៗដែលព្រះអម្ចាស់បានសន្យានិងដាវីឌ នោះទ្រង់បានសន្យាក្នុងនាមជាព្រះនៃរាស្ត្រអ៊ីស្រាអែល ។

**៧:២៧** *ជាបាវបំរើទ្រង់ មានចិត្តក្លាហាន និងហ៊ានអធិស្ឋានពាក្យទាំងនេះទូលដល់ទ្រង់* គឺជាការរៀបចំការអធិស្ឋានរបស់ស្តេចដាវីឌ ប្រកាសសុំតាមការសន្យារបស់ព្រះ ។

**៨:១** *ក្រោយនោះមក* មើលការពន្យល់ ២:១ ។ មួយចំនួនធំគឺទាក់ទងនិងជំពូក៥ និងជំពូកទី៦ (មើល ៧:១ និងការពន្យល់) ។

**៨:២** *សាសន៍ម៉ូអាប់* គឺជាពូជលោកឡុត(លប ១៩:៣៦–៣៧)គឺបានកាន់កាប់តំបន់ខាងកើតនៃសមុទ្រស្លាប់ ឯស្តេចសូលក៏បានវាយលុកដល់សាសន៍ម៉ូអាប់ផងដែរ(១សយ ១៤:៤៧) និងស្តេចដាវីឌក៏បានលាក់ខ្លួននៅឯស្រុកម៉ូអាប់ គឺស្វែងរកការលាក់ខ្លួនដោយសូមដល់ស្តេចស្រុកនោះ នូវសិទ្ធិជ្រកកោនក្នុងពេលដែលបានចេញពីស្រុកអ៊ីស្រាអែលមក (១សយ ២២:៣–៤)

គេដេកដង្ហែគ្នានៅដីដោយជួរៗ រួចដំរូវឱ្យត្រូវសំឡាប់២
ជួរ ហើយទុកពេញ១ជួរឱ្យរស់នៅ ដូច្នេះ សាសន៍ម៉ូអាប់
បានត្រឡប់ជាបាវបំរើរបស់ដាវីឌ ហើយក៏នាំយកសួយ
អាករមកថ្វាយ[ឃ] ។
៣ ១ទៀត ដាវីឌក៏ប្រហារហាដារេសើរ[ង] បុត្រារេហុបជា
ស្តេចស្រុកសូបា[ច] ក្នុងកាលដែលស្តេចនោះ ទៅតាំង
អំណាចខ្លួន នៅក្បែរមាត់ទន្លេអើប្រាត[ឆ] ឡើងវិញ ៤ដាវីឌ
ទ្រង់ចាប់យកបានពលសេះ១ពាន់៧រយនាក់ និងពលថ្មើរ
ជើង២ម៉ឺននាក់ពីស្តេចនោះ ហើយក៏កាប់សរសៃកជើង
សេះ[ជ] ដែលទឹមរទេះទាំងអស់បានទុកឱ្យនៅល្មមតែនឹងទឹម
រទេះ១០០ប៉ុណ្ណោះ ៥កាលពួកសាសន៍ស៊ីរីពីក្រុងដាម៉ាស[ឈ]
បានមក ដើម្បីជួយហាដារេសើរ ជាស្តេចសូបានោះដាវីឌក៏
ប្រហារសំឡាប់ពួកស៊ីរីនោះ អស់២ម៉ឺន២ពាន់នាក់ ៦រួច
ទ្រង់តាំងឱ្យមានពួកទាហាន[ញ] ត្រួតត្រាមើលក្នុងស្រុកស៊ីរី
ប៉ែកខាងក្រុងដាម៉ាស ហើយពួកសាសន៍ស៊ីរី ក៏ចំណុះ[ដ]
ជាបាវបំរើរបស់ដាវីឌ ព្រមទាំងយកសួយអាករមកថ្វាយ
ដែរ ព្រះយេហូវ៉ាទ្រង់ចេះតែជួយការពារដាវីឌ នៅគ្រប់
ទីកន្លែងណាដែលទ្រង់យាងទៅ[ឋ] ៧ដាវីឌបានយកអស់ទាំង
ខែលមាស[ឌ] ដែលពួកបំរើរបស់ហាដារេសើរកាន់នាំមក
ទុកនៅក្រុងយេរូសាឡិម ៨ហើយពីក្រុងបេថាស និងពីក្រុង
បេរ៉ូថាយ[ឍ] ជាទីក្រុងរបស់ហាដារេសើរ នោះស្តេចទ្រង់
យកបានលង្ហិនយ៉ាងសន្ធឹកដែរ ។

**៨:២** ឃ ពច ៣:១៥ អស ៤៥:១៤
**៨:៣** ង ២សយ ១០:១៦,១៩ ១ពវ ១១:២៣ ច ១សយ ១៤:៤៧ ឆ លប ២:១៤ ជ លប ៤៩:៦ យស ១១:៩
**៨:៥** ឈ លប ១៤:១៥ ២សយ ១០:៦ ១ពវ ១១:២៤ ២ពវ ៨:៣ ១៤:២៨
**៨:៦** ញ ១ពវ ២០:៣៤ ដ ២សយ ១០:១៩ ឋ ២សយ ៣:១៨
**៨:៧** ឌ ១ពវ ១០:១៦ ១៤:២៦ ២ពវ ១១:១០
**៨:៨** ឍ អគ ៤៧:១៦
**៨:៩** ណ ១ពវ ៨:៦៥ ២ពវ ១៤:២៨ ២របា ៨:៤ ត លក ១៤:៣១–៣២
**៨:១១** ថ ខ.១២ ១ពវ ៧:៥១ ១៥:១៥ ១របា ២៦:២៦ ២របា ៥:១
**៨:១២** ទ ជន ២៤:១៨ ២ ខ.២ ធ ២សយ ១០:១៤ ប ២សយ ៥:២៥ ផ ជន ២៤:២០ ១សយ ២៧:៨ **៨:១៣** ព ២សយ ៧:៩ ភ ២ពវ ១៤:៧ ១របា ១៨:១២ ទដ ៦០ **៨:១៤** ម ជន ២៤:១៧–១៨ ទដ ១០៨:៩ អស ៣៤:៥ ៦៣:១ យរ ៤៩:៧ អគ ២៥:១២ យ លប ២៧:២៩,៣៧–៤០

៩កាលថូអ៊ី ជាស្តេចក្រុងហាម៉ាត[ណ] បានឮថា ដាវីឌវាយ
ពួកពលទ័ព របស់ហាដារេសើរ[ត] ទាំងអស់ហើយដូច្នោះ
១០នោះក៏ចាត់យ៉ូរ៉ាម ជាបុត្រា ឱ្យទៅឯស្តេចដាវីឌ ដើម្បី
នឹងទូលសួរពីសេចក្តីសុខទុក្ខ ហើយនិងឱ្យពរ ដោយព្រោះ
ទ្រង់បានច្បាំងឈ្នះហាដារេសើរ ដ្បិតហាដារេសើរចេះ
តែច្បាំងនឹងថូអ៊ីជានិច្ច យ៉ូរ៉ាមក៏នាំយកប្រដាប់មាសប្រាក់
និងលង្ហិនមកថ្វាយដែរ ១១ឯប្រដាប់ទាំងនោះស្តេចដាវីឌ
ក៏ថ្វាយ[ថ] ដល់ព្រះយេហូវ៉ា ព្រមទាំងមាស និងប្រាក់ទាំង
ប៉ុន្មាន ដែលបានចាប់យកពីអស់ទាំងសាសន៍ដែលទ្រង់បាន
បង្ក្រាបនោះ ១២គឺពីសាសន៍ស៊ីរី[ទ] សាសន៍ម៉ូអាប់[ធ] ពួកកូន
ចៅអាំម៉ូន[ន] សាសន៍ភីលីស្ទីន[ប] សាសន៍អាម៉ាលេក[ផ] ហើយ
និងរបឹបដែលបានយកពីហាដារេសើរជាកូនរេហុប ស្តេច
ក្រុងសូបាផង ។
១៣កាលដាវីឌត្រឡប់មក ពីប្រហារសាសន៍ស៊ីរីវិញនោះ
ទ្រង់បានល្បីនាម[ព] ឡើងទៀត ដោយបានវាយមនុស្សអស់១
ម៉ឺន៨ពាន់នាក់ នៅក្នុងវាលច្រកភ្នំអំបិល[ភ] ១៤ទ្រង់ក៏តាំងឱ្យ
មានពួកទាហានត្រួតត្រាមើល នៅស្រុកអេដំម[ម] គឺទ្រង់តាំង
ឱ្យគេត្រួតត្រាមើល នៅពេញក្នុងស្រុកអេដំមនោះ ហើយ
ពួកស្រុកអេដំមទាំងអស់ ក៏ចំណុះចំពោះដាវីឌ[យ] ព្រះ

នាងរស់ គឺជាជីដូនរបស់ស្តេចដាវីឌ (មើល នរ ១:៤ ៤:១៣,២១–២២) ។

**៨:៣** *ហាដារេសើរ* "អត្ថន័យហាដារនេះ គឺមានន័យថាជំនួយ(របស់ខ្ញុំ) ជាហាគឺជាអាទិទេព អារ៉ាមៀនដែលមានអំណាចស្មើរនឹងព្រះបាលរបស់សាសន៍កាណាន ។ ពីមុនស្តេចសូលក៏បានប្រឆាំងនិងស្តេចសូបា(១សយ ១៤:៤៧) គឺស្តេចអង្គនេះគ្រប់គ្រងទឹកដីដែលមានទីតាំងក្នុងតំបន់ព្រំដីផ្នែកខាងជើងនៃប្រទេសអ៊ីស្រាអែល ។ *តាំង* គឺការជោគជ័យដំបូងបង្អស់របស់ស្តេចសូលទៅលើស្តេចសូបា ហើយក៏ពង្រីកនៅការគ្រប់គ្រងនៃរាស្ត្រអ៊ីស្រាអែល និងតាំងអំណាចនៅក្បែរមាត់ទន្លេអើប្រាត ។ *ទ្លេអើប្រាត* គឺជាស្រុកដែលជាទឹកដីសន្យាដល់លោកអ័ប្រាហាំ ហើយមានទាំងព្រំដីពីស្រុកអេស៊ីព្ទ រហូតដល់ទន្លេអើប្រាត(មើល លប ១៥:១៨–២១ ចទ ១:៧ និងការពន្យល់ ១១:២៤ យស ១:៤ និងការពន្យល់)ក៏មានទីខេត្តខ្លះទៀតដែលទ្រង់និងឱ្យតាមព្រះបន្ទូលសន្យា(មើល ១ពវ ៤:២១,២៤ និងការពន្យល់ លប ១៧:៨ យស ១២:៤៣–៤៥) ។

**៨:៤** *ក៏កាប់សរសៃកជើងសេះដែលទឹមរទេះនោះទាំងអស់* មើល យស ១១:៦ និងការពន្យល់ ។ សកម្មភាពរបស់ស្តេចដាវីឌជារឿយៗ បានកំណត់ឬបង្ហាញតំរូវពីការមិនឱ្យតម្លៃទៅលើរទេះចំបាំងទាំងនោះ ដែលជាអាវុធផ្នែកខាងយោធា ។ ក៏ប៉ុន្តែដោយព្រោះស្តេចទ្រង់នេះបានប្រព្រឹត្តតាមសេចក្តីបញ្ញត្តពីបុរាណ មិនចាំបាច់ឱ្យមានចំនួនសេះច្រើនទេ (ចទ ១៧:១៦ ប្រៀបធៀប ១សយ ៨:១១ និងការពន្យល់) ។

**៨:៦,១៤** *ព្រះយេហូវ៉ាទ្រង់ចេះតែជួយការពារដាវីឌ នៅគ្រប់ទីកន្លែងដែលទ្រង់យាងទៅ* ប្រយោគនេះបានសង្ខេបពីភាពជោគជ័យនៃស្តេចដាវីឌ នៅត្រង់ចំណុចពីរ ។ (ខ.១–១៤) ហើយក៏រំលឹកដល់អ្នកអានថាព្រះ គឺមិនមែនជាដាវីឌទេដែលព្រះជាព្រះអង្គសង្គ្រោះ ដល់រាស្ត្ររបស់ទ្រង់ ។

**៨:៧** *ខែលមាស* គឺជាប្រភេទខែល ដែលគេតុបតែងកែលំអរដោយមាស ។ ឃ្លានេះគឺមានលក្ខណៈស្រដៀងនិងរទេះចំបាំងលោហៈម្យ៉ាង(មើល យស ១៧:១៦ និងការពន្យល់) ។

**៨:៨** *លង្ហិន* ក្រោយមកគឺបានប្រើដោយស្តេច សាឡូម៉ូន ក្នុងការសាងសង់ព្រះវិហារ (មើល ១របា ១៨:៨ និងការពន្យល់) ។

**៨:៩** *ក្រុងហាម៉ាក* គឺជានគរមួយនៅចំកណ្តាលនៃទន្លេអររុន នៅផ្នែកខាងជើងនៃសូបា(មើល ខ.៣ និងការពន្យល់) ។

**៨:១៣** *២ម៉ឺន៨ពាន់នាក់* ក្នុងនាមជាស្តេចដាវីឌ បានទទួលនូវកិត្តិយសក្នុងការវាយឈ្នះទ័ព១ម៉ឺន៨ពាន់នាក់ ។ ឯលោកអ័ប៊ីសាយគឺមេទ័ពម្នាក់ក្នុងចំណោមមេទ័ពដាវីឌទាំងអស់ក្នុងសមរភូមិ(១របា ១៨:១២ និងការពន្យល់) ដោយសាសន៍អេដំមមានចំនួន១២០០០នាក់ ក៏ត្រូវបានវាយឱ្យចុះចាញ់ ដោយសារភាពជាអ្នកដឹកនាំរបស់លោកយ៉ូអាប់ ក៏មើលយោងទៅលើ ចំណងជើងក្នុងគម្ពីរ ទដ ៦០ គឺនៅច្រកភ្នំ ។ *អំបិល* មើល ១ពវ ១៤:៧ និងការពន្យល់ ។

យេហូវ៉ាទ្រង់ជួយការពារដាវីឌ[វ] នៅគ្រប់ទីកន្លែងណា
ដែលទ្រង់យាងទៅ[ល] ។

## មន្ត្រីរបស់ស្តេចដាវីឌ

*៨:១៥–១៨ – ១របា ១៨:១៤–១៧*

[១៥]ដាវីឌទ្រង់សោយរាជ្យលើស្រុកអ៊ីស្រាអែលទាំងមូល
ហើយក៏ប្រព្រឹត្តនឹងបណ្តារាស្ត្ររបស់ទ្រង់ ដោយសុច្ចរិត
យុត្តិធម៌[វ] [១៦]មានយ៉ូអាប់[ស] កូនសេរូយ៉ា ធ្វើជាអ្នកត្រួតត្រា
លើពលទ័ព យេហូសាផាត[ហ] កូនអ័ហ៊ីលូឌ ធ្វើជាអ្នកកត់ទុក
នូវពង្សាគារ[ឡ] [១៧]សាដុក[អ]ជាកូនអ័ហ៊ីទូប និងអ័ហ៊ីម៉ាលេក
ជាកូនអ័បៀថើរ[ក] ធ្វើជាសង្ក្រាជ សេរ៉ាយ៉ាជាស្មៀនហ្លួង[ខ]
[១៨]បេណា[គ] កូនយេហូយ៉ាដា ធ្វើជាមេពួកកេរេធីម[ឃ]
និងពួកពេលេធីម ហើយបុត្រាទាំងប៉ុន្មានរបស់ដាវីឌ ធ្វើជា
សេនាបតី ។

**៨:១៤** វ ទដ ១៤៤:១០ ល ២សយ ២២:៤៤ ទដ ១៨:៤៤ **៨:១៥** វ លប ១៨:១៩ ១ពវ ១១:៣៨ ១៤:៨ ១៥:១១ ២២:៤៣ ២ពវ ១២:២ យប ២៩:១៤ ទដ ៥:១២ ១១៩:១២១ ហព ១១:៣៣ **៨:១៦** ស ២សយ ២:១៣ ហ ២សយ ២០:២៤ ១ពវ ៤:៣ ឡ អស ៣៦:៣,២២ **៨:១៧** អ ១សយ ២:៣៥ ២សយ

## ស្តេចដាវីឌ និងមភីបូសែត

**៩** [១]គ្រានោះ ដាវីឌមានបន្ទូលសួរថា តើមានពូជពង្សរបស់
សូលសល់នៅឬទេ ដើម្បីឱ្យយើងបានសំដែងសេចក្តីករុណា
ដល់អ្នកនោះ ដោយយល់ដល់យ៉ូណាថាន[ក] [២]រីឯនៅក្នុងពួក
ដំណាក់សូល មានអ្នកបំរើម្នាក់ឈ្មោះស៊ីបា[ខ] គេក៏ហៅអ្នក
នោះមកឯដាវីឌ រួចទ្រង់មានបន្ទូលសួរថា តើឯងឈ្មោះ
ស៊ីបាឬអី អ្នកនោះឆ្លើយថា ព្រះករុណាវិសេសគឺ ទូលបង្គំ
នេះហើយ [៣]នោះស្តេចទ្រង់មានបន្ទូលសួរថា តើមានពូជ

១៥:២៤,២៩ ២០:២៥ ១ពវ ១:៨ ៤:៤ ១របា ៦:៨,៥៣ ១៦:៣៩ ២៤:៣ ២៧:១៧ ២របា ៣១:១០ អគ ៤០:៤៦ ៤៣:១៩ ៤៤:១៥ ៤៨:១១ ក មក ២:២៦ ខ ១ពវ ៤:៣ ២ពវ ១២:១០ ១៩:២ ២២:៣ អស ៣៦:៣ យរ ៣៦:១២ **៨:១៨** គ ២សយ ២០:២៣ ២៣:២០ ១ពវ ១:៨,៣៨ ២:២៥,៣៥,៤៦ ៤:៤ ឃ ១សយ ៣០:១៤ **៩:១** ក ១សយ ២០:១៤–១៧,៤២ ២៣:១៨ **៩:២** ខ ២សយ ១៦:១–៤ ១៩:១៧, ២៦,២៩

**៨:១៥** *ដោយសុចរិតយុត្តិធម៌* គឺជាស្តេចដាវីឌ គឺជាស្តេចដែលសោយរាជ្យ ហើយប្រកបដោយទេវធិបតេយ្យនិងមានសេចក្តីពិត សុចរិតត្រឹមត្រូវដោយមានខ្នាតគំរូពីច្បាប់ក្រឹត្យវិន័យពីព្រះអម្ចាស់ដ៏ពិតប្រាកដណាស់ ។ (មើលការពន្យល់ ១សយ ៨:៣ ១២:៣ ទដ ១១៩:១២១) (មើល ១សយ ១០:២៥ ១ពវ ២:៣–៤ និងការពន្យល់) ។

**៨:១៦** *យ៉ូអាប់កូនសេរូយ៉ាធ្វើជាអ្នកត្រួតត្រាលើពលទ័ព* មើលការពន្យល់ ២:១៣ ៥:៨ ។ *អ្នកកត់ទុកនូវពង្សាវតារ* គឺជាតួនាទីដ៏សំខាន់នៅពេលកត់ត្រានូវហេតុការណ៍ផ្សេងៗ ហើយការកត់ត្រានេះគឺមានលក្ខណៈសម្រាប់ពេលកាត់ទោស ឬកាត់ក្តីរបស់តុលាការ ។ ហើយគេរក្សាទុករហូតតាំងពីរបបនោះមក(សូមមើល ២ពវ ១៨:១៨,៣៧ ២របា ៣៤:៨) ។ ទ្រង់ក៏ធ្លាប់បានធ្វើជាអធិការ ឬក៏កាន់រដ្ឋបាលនៃកិច្ចការរាជវាំង និងបន្ទុកនៃការទទួល ខុសត្រូវរាល់កិច្ចការផ្សេងៗសម្រាប់ការងារពង្សាគារ នៃព្រះមហាក្សត្រ និងតំណាក់ទ្រង់ ។

**៨:១៧** *សាដុកជាកូនអ័ហ៊ីទូប* គឺទើបបានបង្ហាញលើកទី១នៅក្នុងអត្ថបទគម្ពីរសាំយូអែលទី២នេះ សាដុកនេះគឺជាពូជរបស់អេលីស្បាជាកូនប្រុសរបស់អើរ៉ុន(មើល ១របា ៦:៤–៨,៥០–៥២ ២៤:១–៣) ឪពុករបស់គាត់ឈ្មោះអ័ហ៊ីទូប គឺគម្ពីរក៏ពុំបានបញ្ជាក់ច្បាស់ទេ(១សយ ១៤:៣) ។ សាដុកក៏នៅជាខ្សែរាជវង្សតាមរយៈស្តេចដាវីឌរាជបល័ង្ក (១៥:២៤–២៩ ១៧:១៥–១៦ ១៩:១១) ។ សាដុកនិងហោរាណាថាន់ ក៏ជាអ្នកចាក់ប្រេងតាំងឱ្យស្តេចសាឡូម៉ូន ដើម្បីជាការសោយរាជស្នងពីស្តេចដាវីឌ(១ពវ ១:៤៣–៤៥) ។ *អ័ហ៊ីលេកជាកូនអ័បៀថើរ* ក៏មានកំហុសក្នុងការកត់ចំលង ក៏មានលេចឱ្យឃើញក្នុងទីនេះដែរ(មើល ១របា ២៤:៦) គឺក្នុងនោះមានឈ្មោះពីរត្រូវបានប្តូរផ្លាស់ ។ អ័បៀថើគឺសំដៅទៅលើកូនប្រុសអ័ហ៊ីម៉ាលេកក្នុង ១សយ ២២:២០ ។ ដែលការពិតថាអ័បៀថើរក្នុង ១សយ ២២:២០ អាចមានកូនប្រុសឈ្មោះអ័ហ៊ីមាលេក (បន្ទាប់ពីជីតារបស់គេ) ក្នុងការរៀបរាប់ក៏មានឃើញនៅកន្លែងខ្លះៗដែរសាំយូអែល និងស្តេចដូចជាមានលក្ខណៈទំនាក់ទំនងគ្នានឹងសាដុកប៉ុន្តែអ័បៀថើរ គឺមិនប្រែប្រួលទេ (១៥:២៩,៣៥ ១៧:១៥ ១៩:១១ ២០:២៥ ១ពវ ១:៧–៨ ២:៣៥ ៤:៤) ។ *សេរ៉ាយ៉ា* គឺអាចជាមនុស្សតែមួយ ដែលគេហៅថាស៊ីវ៉ា(២០:២៥)ស៊ីសា(១ពវ ៤:៣) និងសាវសារជាស្មៀនហ្លួង ។ ភារៈកិច្ចកាត់ជាអ្នកទំនាក់ទំនងការងារក្រៅ និងក្នុងប្រទេសក៏រក្សាឯកសារពត៌មានពីព្រឹត្តិការណ៍នយោបាយ និងការងាររដ្ឋបាលគ្រប់គ្រង (២ពវ ១២:១០–១២) ។

**៨:១៨** *ពួកកេរេធីម* មើលការពន្យល់ ១សយ ៣០:១៤ ។ *ពេលេធីម* វាប្រហែលជាមានលក្ខណៈឆ្លាស់គ្នានៃពាក្យ"ភីលីស្ទីន"ដែលបកប្រែពីភាសាហេព្រើរការប្រើជាទូទៅរបស់ពាក្យនេះ គឺសម្រាប់ចង់និយាយចំពោះ "ពួកសង្ឃ"(មើលការពន្យល់ ២០:២៦) តែពេលនេះយើងឃើញន័យពាក្យនេះហើយ ។ ការបកប្រែមុនៗជាច្រើនបានប្រែពាក្យនេះមិនឱ្យចំៗថា ជាពួកសង្ឃទេ ។ តាមពង្សាវតារហៅពាក្យនេះថា មន្ត្រីជាន់ខ្ពស់របស់ព្រះមហាក្សត្រ (មើល ១របា ១៨:១៧ និងការពន្យល់)ដែលវាស៊ីនិងអត្ថន័យថា "សេនាបតី" ។

**៩:១–២០:២៦** ក្នុងជំពូកទាំងនេះរួមទៅមានដូចជា ១ពវ ១:១–២:៤៦ គឺជាផ្នែកគំរូទៅនិងការរៀបរាប់ ដែលមានក្នុងយុគ្គសម័យបុរាណ ។

**៩:១–១៣** ហេតុការណ៍ដែល ផ្នែកនៃវគ្គជំពូកនេះមានឱ្យឃើញឡើងប៉ុន្មានឆ្នាំ បន្ទាប់ពីស្តេចដាវីឌចាប់យកក្រុងយេរូសាឡិម ។ មភីបូសែត ឈ្មោះដើមគឺមេរីបបាល ក្នុងពេលនោះមានអាយុ៥ឆ្នាំ គឺក្នុងពេលដែលមាតារបស់ទ្រង់បានសុគត (មើល ៤:៤) ឥឡូវនេះគាត់មានកូនប្រុសផ្ទាល់ខ្លួន របស់គាត់ហើយ (ខ.១២) ។

**៩:១** *ដើម្បីឱ្យបានសម្តែងសេចក្តីករុណាដល់អ្នកនោះ ដោយយល់ដល់យ៉ូណាថាន* (ប្រៀបធៀប ១សយ ២០:១៤–១៧,៤២) ។

**៩:២** *ស៊ីបា* អ្នកដែលកាន់កាប់ទ្រព្យសម្បត្តិរបស់ស្តេចសូល ដែលបានទទួលដោយមភីបូសែត គឺកូនប្រុសរបស់យ៉ូណាថាន គឺជាកូនច្បងរបស់ស្តេចសូល (មើល ១៦:១–៤ ១៩:១៧)។

**៩:៣,១៣** *ខ្វិនជើងទាំងពីរ* គឺបង្ហាញពីលក្ខណៈពុំមានសមត្ថភាពក្នុងការតតាំង និងតំណែងស្តេចដាវីឌ(មើល ៤:៤ និងការពន្យល់) ។

**៩:៣** *ជាបុត្រនៃយ៉ូណាថាន* ស្តេចសូលក៏មានពូជមួយផ្សេងទៀត(មើល ២១:៨)ប៉ុន្តែ ស៊ីបាបង្ហាញតែអ្នកដែលគួរឱ្យចាប់អារម្មណ៍ទេ ។

ពង្សរបស់សូលណាមួយសល់នៅឬទេ ដើម្បីឱ្យយើងបាន
សំដែងសេចក្ដីករុណានៃព្រះដល់អ្នកនោះ សីបាទូលឆ្លើយ
ថា នៅមានម្នាក់ខ្វិនជើង[គ] ជាបុត្រនៃយ៉ូណាថាន[ឃ] ៤ស្ដេច
ទ្រង់មានបន្ទូលសួរថា តើនៅឯណា រួចសីបាទូលតបថា
លោកនៅឯផ្ទះម៉ាគារ ជាកូនអាំមាល ដែលនៅក្រុងឡូរ-
ដេបារ ៥នោះស្ដេចដាវីឌទ្រង់ក៏ចាត់គេ ឱ្យទៅនាំលោកពី
ផ្ទះម៉ាគារ[ង] ជាកូនអាំមាល ជាអ្នកដែលនៅក្រុងឡូរ-
ដេបារនោះមក ៦ដូច្នេះមភីបូសែត ជាបុត្រានៃយ៉ូណាថាន
ដែលជាបុត្រាសូល ក៏មកឯដាវីឌទំលាក់ខ្លួនក្រាបចុះផ្កាប់
មុខថ្វាយបង្គំ[ច] រួចដាវីឌទ្រង់មានបន្ទូលថា មភីបូសែតអើយ
លោកក៏ទូលឆ្លើយថា បតិត្រព្រះករុណាវិសេស ៧នោះ
ដាវីឌមានបន្ទូលថា កុំខ្លាចអ្វីឡើយ ដ្បិតយើងនឹងសំដែង
សេចក្ដីករុណាដល់អ្នក ដោយយល់ដល់យ៉ូណាថាន[ឆ]បិតា
អ្នក ហើយយើងនឹងប្រគល់អស់ទាំងស្រែចំការរបស់សូល
ជាជីតាដល់អ្នក តែឯខ្លួនអ្នកនឹងបរិភោគនៅតុជាមួយនឹង
យើងជានិច្ច[ជ] ៨នោះលោក[ឈ]ក៏ក្រាបថ្វាយបង្គំទូលថា តើ
បាវបំរើនៃទ្រង់នេះជាអ្វី បានជាទ្រង់ព្រមក្រឡេកមើលមក
ទូលបង្គំ ដែលទុកដូចជាឆ្កែស្លាប់[ញ]នេះ ។
៩ស្ដេចទ្រង់ក៏មានបន្ទូលហៅសីបា ជាបាវបំរើរបស់
សូលមកត្រាស់បង្គាប់ថា បណ្ដារបស់ទ្រព្យទាំងប៉ុន្មានដែល
ជារបស់សូល និងពូជពង្សទ្រង់ នោះអញប្រគល់ឱ្យដល់
បុត្រារបស់ចៅហ្វាយឯងនេះហើយ ១០ត្រូវឱ្យឯងភ្ជួររាស់
ស្រែចំការនោះឱ្យលោក ព្រមទាំងកូនចៅឯង ហើយពួក
បាវបំរើរបស់ឯងទាំងអស់គ្នាផង ត្រូវប្រមូលផលផ្លែយក
មក ជូនបុត្រា[ដ]របស់ចៅហ្វាយឯងបានអាហារបរិភោគ
ប៉ុន្តែ ឯមភីបូសែត ជាបុត្រាចៅហ្វាយឯង លោកនឹង

**៩:៣** គ លវ ២១:១៨ ឃ ១របា ៨:៣៤ ១សយ ២០:១៤
**៩:៤** ង ២សយ ១៧:២៧-២៩
**៩:៦** ច លប ៣៧:៧
**៩:៧** ឆ ១សយ ២០:១៤-១៥ ជ ខ.១៣ ២សយ ១៩:២៨ ២១:៧ ១ពវ ២:៧ ២ពវ ២៥:២៩ យរ ៥២:៣៣
**៩:៨** ឈ ២សយ ៤:៤ ញ ២សយ ៣:៨
**៩:១០** ដ ២សយ ១៦:៣
**៩:១១** ឋ យប ៣៦:៧ ទដ ១១៣:៨
**៩:១២** ឌ ២សយ ៤:៤
**១០:២** ក ១សយ ១១:១
**១០:៣** ខ ជន ២១:៣២
**១០:៤** គ លវ ១៩:២៧ អស ៧:២០ ១៥:២ ៥០:៦ ៥២:១៤ យរ ៤៨:៣៧ អគ ៥:១ ឃ អស ២០:៤

បរិភោគនៅតុជាមួយនឹងអញជានិច្ច រីឯសីបាមានកូនប្រុស
១៥នាក់ នឹងបាវ២០នាក់ ១១នោះសីបាទូលទៅស្ដេចថា ទូល
បង្គំ ជាបាវបំរើទ្រង់ នឹងធ្វើតាមគ្រប់ទាំងសេចក្ដីដែល ទ្រង់
ព្រះករុណា ជាអម្ចាស់នៃទូលបង្គំ បានមានបន្ទូលប្រាប់មក
តែចំណែកមភីបូសែតនោះ ទ្រង់មានបន្ទូលថា លោកត្រូវ
បរិភោគនៅតុយើង ទុកដូចជាបុត្រណាមួយរបស់ស្ដេច[ឋ]
១២ឯមភីបូសែត លោកមានកូនប្រុស១ឈ្មោះមីកា ហើយ
អស់ពួកអ្នកដែលនៅក្នុងផ្ទះសីបានោះ សុទ្ធតែជាបាវបំរើ
របស់មភីបូសែតទាំងអស់[ឌ] ១៣ដូច្នេះមភីបូសែតលោក ក៏នៅ
ក្រុងយេរូសាឡិមទៅ ដោយព្រោះលោកត្រូវបរិភោគនៅ
តុនៃស្ដេច ហើយលោកខ្វិនជើងទាំង២ ។

## ស្ដេចដាវីឌយកឈ្នះលើពួកសាសន៍អាំម៉ូន

*១០:១-១៩–១របា ១៩:១-១៩*

**១០** ១ក្រោយនោះមក ស្ដេចនៃពួកកូនចៅអាំម៉ូនទ្រង់អស់
ព្រះជន្មទៅ ហើយហានូនជាបុត្រាទ្រង់ក៏ឡើងសោយរាជ្យ
ជំនួស ២នោះដាវីឌទ្រង់ព្រះដំរិះថា អញនឹងសំដែងសេចក្ដី
សប្បុរស ដល់ហានូន កូនណាហាស[ក] ដូចជាបិតាលោកបាន
សំដែងដល់អញដែរ ដូច្នេះ ដាវីឌក៏ចាត់ពួករាជទូតឱ្យទៅ
ជួយកំសាន្តទុក្ខទ្រង់ពីដំណើរបិតាសុគតពួករាជទូតរបស់
ដាវីឌ ក៏ចូលទៅក្នុងស្រុកនៃពួកកូនចៅអាំម៉ូន ៣ប៉ុន្តែពួកមេ
របស់កូនចៅអាំម៉ូន ទូលដល់ហានូនជាម្ចាស់គេថា ទ្រង់ជឿ
ថា ដាវីឌចង់លើកមុខបិតាទ្រង់ដោយចាត់ពួកនេះមកជួយ
កំសាន្តទុក្ខទ្រង់ឬអី ឯគំនិតដាវីឌ ដែលចាត់ពួកទូតនេះ ឱ្យ
មកដូច្នេះ គឺដើម្បីតែនឹងឈ្លបលប[ខ] ហើយសង្កេតមើល
ទីក្រុង រួចរំលំចេញប៉ុណ្ណោះវិញទេតើ ៤ដូច្នេះ ហានូនក៏
ចាប់ពួកទូតរបស់ដាវីឌ កោរពុកចង្កាគេ១ចំហៀង[គ]ក៏កាត់

**៩:៤** *ម៉ាគារ* គេគឺជាអ្នកឧបត្ថម្ភដល់មភីបូសែត ក្រោយមកក៏មកជួយដល់ស្ដេចដាវីឌ (១៧:២៧) ។ *ក្រុងឡូរ-ដេបារ* គឺជាទីក្រុងមួយក្នុងព្រំដី ។

**៩:៦** *មភីបូសែត* មើល ៤:៤ និងការពន្យល់ ។

**៩:៧** *ប្រគល់អស់ទាំងស្រែចំការ* ទោះជាទ្រព្យសម្បត្តិស្ដេចសូលក៏ត្រូវប្រគល់ឱ្យទៅស្ដេចដាវីឌក៏ដោយ ។ ក៏ដូចជានាងសីបា ក៏ត្រូវទទួលទ្រព្យសម្បត្តិដែរ (មើល ១៦:១-៤ ១៩:២៦-៣០) ។ *តែឯខ្លួនអ្នកនឹងបរិភោគនៅតុជាមួយនឹងយើងជានិច្ច* គឺជាការគោរពមួយ នៅតែតាមដានមើលជានិច្ច (ប្រៀបធៀប ១សយ ២០:២៤-២៧ ២ពវ ២៥:២៩) ។

**៩:៨** *ដែលទូលបង្គំដែលទុកដូចជាឆ្កែស្លាប់* ជាសំនួនវោហាបង្ហាញពីការបន្ទោកខ្លួនឯង ។ អ្នកនិពន្ធប្រើពាក្យឆ្កែស្លាប់ គឺបញ្ជាក់ពីឥទ្ធិពលដ៏ខ្លាំងក្លា ។ ខណៈដំបូងកូលីយ៉ាត់ បានមើលងាយដល់អ្នកចំបាំងដាវីឌដ៏ក្មេងវ័យ រួចដាវីឌសួរថា "តើខ្ញុំជាឆ្កែឬ" (១សយ ១៧:៤៣) ដាវីឌក៏បានពណ៌នាពីខ្លួនគាត់ទៀតថា ប្រៀបធៀបដូចជាឆ្កែស្លាប់ (១សយ ២៤:១៤) ដោយសន្មតចំពោះស្ដេចសូលថា ស្ដេចនៃរាស្ត្រអ៊ីស្រាអែលកុំវាយតម្លៃអី ដែលតាមតែភ្នែកមើលឃើញដូច្នេះ (មើលការពន្យល់ ១សយ ២៥:៣) ។ នេះគឺជាចៅប្រុសរបស់ស្ដេចសូលហើយនៅក្នុង ១៦:៩ គឺជាសំដីដែលដូចស្ដេចសូលមើលងាយដល់ដាវីឌ (មើល ៧:១៨ ១សយ ១៨:១៨) ។

**៩:១២** *មានកូនប្រុសឈ្មោះមីកា* គេក៏មានពូជអំបូរតៗមកដែរ (១របា ៨:៣៥-៣៩) ។

**១០:១** *ក្រោយនោះមក* មើលការពន្យល់ ២:១ *ស្ដេច* ។ ណាហាស (មើល ខ.២ ១សយ ១១) *កូនចៅអាំម៉ូន* មើលការពន្យល់ ។

**១០:២** *សំដែងសេចក្ដីសប្បុរស* ពាក្យភាសាហេព្រើរចំពោះវោហាស័ព្ទនេះ គឺកំណត់ន័យថាវាជាការទំនាក់ទំនងរវាងសាសន៍អ៊ីស្រាអែល និងសាសន៍ឬកូនចៅអាំម៉ូន (ប្រៀបធៀប ១សយ ២០:៨) ។

**១០:៣,១៤** *ក្រុងរ៉ាបាត* គឺជារាជធានីមួយ (១១:១ ១២:២៥) មើលការពន្យល់ ចទ ៣:១១ ។

**១០:៤** *កោរពុកចង្កាគេ១ចំហៀង* ក្នុងពិភពលោកនេះចំពោះពាក្យនេះត្រូវបានគេដាក់ថា គឺជាពាក្យប្រមាថមាក់ងាយ ដល់ស្ដេចដ៏ធ្ងន់ធ្ងរបំផុត (ប្រៀប

អាវគេផ្តាច់ផ្នែកខាងក្រោមនៅត្រឹមគូថ[ឃ] រួចលែងឱ្យទៅ
វិញ ៥កាលដំណឹងនោះបានជ្រាបដល់ដាវីឌ នោះទ្រង់ក៏
ចាត់មនុស្សឱ្យទៅទទួល ដ្បិតគេមានសេចក្តីខ្មាសណាស់
ស្តេចទ្រង់បង្គាប់ថា ចូរស្នាក់នៅក្រុងយេរីខូរសិនចុះ ចាំ
ទំរាំពុកចង្កាដុះជាថ្មីឡើង រួចសឹមត្រឡប់មកវិញ ។
៦កាលពួកកូនចៅអាំម៉ូនឃើញថា ដាវីឌត្រឡប់ជាខ្ពើម[ង]
គេហើយ នោះគេក៏ចាត់ឱ្យទៅជួលពួកសាសន៍ស៊ីរី[ច]ពីក្រុង
បេត-រេហុប[ឆ] និងពីក្រុងសូបា[ជ] បានពលថ្មើរជើង២ម៉ឺននាក់
និងស្តេចស្រុកម្អាកា[ឈ] ព្រមទាំងពល១ពាន់នាក់ហើយពួក
ស្រុកថូប១ម៉ឺន២ពាន់នាក់ទៀត[ញ] ៧កាលដាវីឌបានជ្រាប
ហើយ នោះទ្រង់ចាត់យ៉ូអាប់[ដ] នឹងពួកពលខ្លាំងពូកែទាំង
អស់ឱ្យទៅ ៨ឯពួកកូនចៅអាំម៉ូន គេក៏ចេញមកត្រៀមពល
នៅត្រង់មាត់ទ្វារក្រុងដើម្បីច្បាំង ឯពួកសាសន៍ស៊ីរីពីក្រុង
សូបា និងក្រុងរេហុប ហើយពួកថូប និងពួកស្តេចម្អាកា គេ
នៅឯវាលដោយឡែក ។
៩រីឯយ៉ូអាប់ កាលឃើញថា គេចោមច្បាំងនឹងលោកពី
ខាងមុខខាងក្រោយដូច្នោះ នោះលោកក៏រើសយកពួក
ជ្រើសរើសក្នុងពួកអ៊ីស្រាអែល ចាត់ទៅឱ្យដំរៀបគ្នា តនឹង
ពួកស៊ីរី ១០ឯបណ្តាទ័ពដែលសល់នៅ នោះក៏ប្រគល់ទៅក្នុង
អំណាចអ័ប៊ីសាយ[ឋ]ជាប្អូន ហើយប្អូនក៏ដំរៀប ពលតនឹងពួក
កូនចៅអាំម៉ូន ១១លោកប្រាប់ថា បើសិនជាពួកស៊ីរីមាន
កំឡាំងហួសពេក អញឈ្នះគេមិនបាន នោះចូរឯងមកជួយ
អញផង បើពួកកូនចៅអាំម៉ូនមានកំឡាំងហួសពេកឯងឈ្នះ
គេមិនបាន នោះអញនឹងទៅជួយឯងវិញ ១២ចូរឱ្យយើង
រាល់គ្នាមានចិត្តក្លាហានឡើង ហើយមានកំឡាំងចុះ[ឌ] ដោយ
ព្រោះសាសន៍យើង និងទីក្រុងរបស់ព្រះនៃយើងផង សូមឱ្យ
ព្រះយេហូវ៉ាសំរេចសេចក្តី តាមព្រះហឫទ័យទ្រង់ចុះ[ឍ]
១៣ដូច្នេះ យ៉ូអាប់ និងពួកពល ដែលនៅជាមួយក៏ចូលទៅ
តស៊ូនឹងពួកស៊ីរី ហើយគេបាក់ទ័ពរត់ពីមុខលោកចេញទៅ
១៤កាលពួកកូនចៅអាំម៉ូន[ណ]បានឃើញថា ពួកស៊ីរីបាក់ទ័ព
ហើយ នោះគេក៏រត់ចេញពីមុខអ័ប៊ីសាយដែរ នាំគ្នាចូល
ទៅក្នុងទីក្រុងវិញ រួចយ៉ូអាប់ក៏ត្រឡប់ពីពួកកូនចៅអាម៉ូន
វិលទៅឯក្រុងយេរូសាឡិមវិញ ។
១៥កាលពួកស៊ីរីឃើញថា បានចាញ់ពួកអ៊ីស្រាអែល
ហើយ នោះគេក៏មូលគ្នា ១៦ហើយហាដារេស៊ើរចាត់ទូតឱ្យ
ទៅអង្វរបានពួកស៊ីរីដែលនៅខាងនាយទន្លេនាំចេញមក
ជួយ ក៏ទន្ទ្រានចូលស្រុកហេឡាម មានសូបាក ជាមេទ័ពធំ
របស់ហាដារេស៊ើរជាអ្នកនាំមុខ ១៧កាលដាវីឌទ្រង់ជ្រាប
នោះក៏ប្រមូលពួកទ័ពអ៊ីស្រាអែលទាំងអស់ ឆ្លងទន្លេយ័រដាន់
ទៅដល់ស្រុកហេឡាម ពួកស៊ីរីគេក៏ត្រៀមពលតនឹងដាវីឌ
១៨តែគេបាក់ទ័ពរត់ចេញពីមុខពួកអ៊ីស្រាអែលទៅ ហើយ
ដាវីឌបានសំឡាប់ពួកគេ ដែលនៅរទេះចំបាំងអស់៧០០
រទេះ និងពួកពលសេះ៤ម៉ឺននាក់ ក៏ប្រហារសូបាក ជា
មេទ័ពគេ ឱ្យស្លាប់នៅទីនោះដែរ ១៩កាលពួកស្តេចទាំង
ប៉ុន្មាន ដែលនៅក្រោមអំណាចហាដារេស៊ើរ ឃើញថា
ខ្លួនចាញ់ពួកអ៊ីស្រាអែលហើយ នោះក៏ចងជាស្ពានមេត្រី
និងពួកអ៊ីស្រាលអែល ហើយចំណុះ[ត]គេវិញ ដូច្នេះពួកស៊ីរី
មិនហ៊ានជួយពួកកូនចៅអាំម៉ូន[ថ]ទៀតឡើយ ។

## ស្តេចដាវីឌ និងនាងបាតសេបា

**១១** ១ដល់១ខួបក្រោយមក ក្នុងរដូវ[ក]ដែលល្មមឱ្យស្តេច
ទាំងប៉ុន្មាន ចេញទៅច្បាំងបាន នោះដាវីឌទ្រង់ចាត់យ៉ូអាប់[ខ]

**១០:៦** ង លប ៣៤:៣០ ច ២សយ ៨:៥ ឆ ជន ១៣:២១ ច ១សយ ១៤:៤៧ ឈ ចទ ៣:១៤ ញ ពច ១១:៣-៥
**១០:៧** ដ ២សយ ២:១៨
**១០:១០** ឋ ១សយ ២៦:៦
**១០:១២** ឌ ចទ ១:២១ ៣១:៦ អភ ៦:១០ ឍ ពច ១០:១៥ នហ ៤:១៤
**១០:១៤** ណ ២សយ ៨:១២
**១០:១៩** ត ២សយ ៨:៦ ថ ១ពវ ១១:២៥ ២២:៣១ ២ពវ ៥:១
**១១:១** ក ១ពវ ២០:២២,២៦
ខ ២សយ ៣:១៨ គ ១រប ២០:១ ឃ ចទ ៣:១១

ធៀបនឹង ៧:២០)។ *ក៏កាត់អាវគេផ្តាច់ផ្នែកខាងក្រោមនៅត្រឹមគូថ* គឺជាវិធីមួយ ដែលគេទំលាប់យកមកអនុវត្តន៍ ចំពោះអ្នកដែលឈ្លើយសឹក ឬសម្រាប់អ្នកទោសនយោបាយក្នុងសង្គ្រាម(ប្រៀបធៀប អស ២០:៤)។

**១០:៥** *ក្រុងយេរីខូរ* មើលការពន្យល់ យស ៦:១ ១ពវ ១៦:៣៤ ។ ក្រុងយេរីខូរបានខូចហើយក៏ពុំបានធ្វើ ឬជុសជុលឡើងវិញទេ ក្នុងកំឡុងពេលជាច្រើនសតវត្សមកហើយ ក្នុងចន្លោះពេលច្បាំងដណ្តើមយករបស់យ៉ូស្វេ និងជិនាន់លោកអ័ហាប់ផងដែរ ។

**១០:៦** *ខ្ពើម* មើលការពន្យល់ ១សយ ១៣:៤ ។ *ក្រុងបេតរេហុប* មើល ជន ១៣:២១ ពច ១៨:២៨ និងការពន្យល់ ។ *ក្រុងសូបា* មើលការពន្យល់ ៨:៣ ។ *ស្រុកម្អាកា* មើល ចទ ៣:១៤ និងការពន្យល់ សយ ១៣:៥ ១៣:១៣ ។ *ពួកថូប* មើល ចទ ១១:៣-៦ និងការពន្យល់ ១១:៣ ។

**១០:១០** *អ័ប៊ីសាយ* មើលការពន្យល់ ១សយ ២៦:៦ ។

**១០:១៦** *ហាដារេស៊ើរ* មើលការព្យល់ ៨:៣ ។

**១០:១៨** *អស់ ៧០០រទេះ* ប្រហែលមានការកត់ត្រាខុស មើលក្នុង ១រប ១៩:១៨ គឺទូរលេខគឺ ៧០០០ ។

**១០:១៩** *ចងជាស្ពានមេត្រីនឹងពួកអ៊ីស្រាអែល* ក៏គ្មានការបញ្ជាក់ច្បាស់ថាហាដារេស៊ើរអង្គទ្រង់ផ្ទាល់ បានផ្សះផ្សាសន្តិភាពជាមួយរាស្ត្រអ៊ីស្រាអែល ។ ហេតុការណ៍ទាំងនេះ ជាតំណាងឱ្យយុទ្ធនាការចុងក្រោយរបស់ដាវីឌប្រឆាំងនឹងអំណាចពួកក្រៅប្រទេស ។

**១១:១-២៧** អំពើបាបជាច្រើនដែលដាវីឌទទួលបានរាំងស្ទះដល់រឿងដែលដាវីឌទទួលយកប្រពន្ធលោកណាប៉ាល គឺនាងអាប៊ីហ្គែលមកធ្វើជាប្រពន្ធទ្រង់(១សយ ២៥) ព្រះយេហូវ៉ាបានយកប្តីនោះចេញពីព្រោះគាត់បានបែរចេញពីការចាត់តាំងពីរបស់ព្រះ ហើយមើលអ័ប៊ីហ្គែលមកឯដាវីឌសួរដល់ម្នាក់ ដែលទ្រង់បានការពាគាត់ពីការប្រើអំណាចជាស្តេចថ្មីៗ ដើម្បីបំណងផ្ទាល់ខ្លួនម្នាក់ ។ នៅត្រង់នេះស្តេចដាវីឌបានប្រើសិទ្ធជាស្តេច ដើម្បីយកប្រពន្ធ ។ គឺដាវីឌបានប្រព្រឹត្តបាបយ៉ាងសន្ធឹក គឺដើម្បីបំពេញបំណងផ្ទាល់ខ្លួន (មក ១០:៤៥) ។

**១១:១** *រដូវ* ជារដូវផ្ការីកមួយឆ្នាំមានម្តងក៏បានបែងចែកក្នុងជិពូកទី១០ ។

ព្រមទាំងពលទ័ពរបស់លោក និងពួកអ៊ីស្រាអែលទាំងអស់
គ្នាឱ្យទៅ[គ] គេក៏បំផ្លាញពួកកូនចៅអាំម៉ូន ហើយឡោមព័ទ្ធ
ច្បាំងនឹងក្រុងរ៉ាបាត[ឃ] តែឯដាវីឌទ្រង់គង់នៅក្នុងក្រុង
យេរូសាឡិមវិញ ។
២មានកាល១ថ្ងៃ ពេលជិតងងឹតហើយ នោះដាវីឌក្រោក
ពីព្រះទែនយាងទៅមក នៅលើដំបូល[ង]ដំណាក់ ក៏ទតព្រះ
នេត្រទៅឃើញ[ច]ស្ត្រីម្នាក់កំពុងតែងូតទឹក នាងនោះមាន
រូបឆោមស្រស់ល្អណាស់ ៣ដាវីឌក៏ចាត់គេឱ្យទៅស៊ើបសួរ
ពីនាង ហើយម្នាក់នោះទូលថា នាងឈ្មោះបាតសេបា[ឆ]ជា
កូនអេលាម[ជ]ប្រពន្ធអ៊ូរី[ឈ] សាសន៍ហេត ៤នោះដាវីឌចាត់គេ
ឱ្យទៅនាំនាងយកមក[ញ] រួចនាងក៏ចូលមកឯទ្រង់ ហើយទ្រង់
ផ្ទំ[ដ]ជាមួយនឹងនាងទៅ ដ្បិតនាងទើបនឹងបានស្អាតពីរដូវ
នាងហើយ[ឋ] រួចនាងត្រឡប់ទៅផ្ទះវិញ ៥នាងក៏មានគភ៌
ហើយចាត់គេឱ្យទៅទូលដាវីឌថា ខ្ញុំម្ចាស់មានគភ៌ហើយ ។
៦នោះដាវីឌចាត់គេឱ្យទៅឯយ៉ូអាប់ប្រាប់ថា ចូរចាត់អ៊ូរី
ជាសាសន៍ហេត ឱ្យមកឯយើង ដូច្នេះយ៉ូអាប់ក៏ឱ្យអ៊ូរី[ឌ]ទៅឯ
ដាវីឌ ៧កាលគាត់បានទៅដល់ហើយ នោះដាវីឌសាកសួរ
ដំណឹងពីយ៉ូអាប់ ហើយពីបណ្ដាទ័ព និងពីការសង្គ្រាមបាន
ជាយ៉ាងណា ៨រួចដាវីឌមានបន្ទូលទៅអ៊ូរីថា ចូរចុះទៅផ្ទះ
ហើយ លាងជើងឯងទៅ[ឍ] លុះគាត់ចេញពីដំណាក់ស្ដេច
ហើយ នោះក៏មានគេនាំយកម្ហូបម្ហាពីស្ដេចទៅជូនគាត់
៩ប៉ុន្តែអ៊ូរីគាត់ទៅដេកជាមួយនឹងពួកមហាតលិករបស់
ម្ចាស់ខ្លួន នៅត្រង់មុខមាត់ទ្វារដំណាក់វិញ ឥតបានចុះទៅ
ផ្ទះខ្លួនទេ ១០កាលគេទូលដាវីឌថា អ៊ូរីមិនបានចុះទៅឯផ្ទះ
គាត់ទេ នោះទ្រង់សួរអ៊ូរីថា តើឯងមិនបានមកពីឆ្ងាយទេឬ
អី ដូច្នេះ ម្ដេចក៏មិនចុះទៅឯផ្ទះ ១១នោះអ៊ូរីទូល ឆ្លើយថា
ហឹបនៃព្រះ[ណ] និងពួកអ៊ីស្រាអែល ហើយពួកយូដាសុទ្ធតែ
នៅក្នុងបង្ហារ ព្រមទាំងយ៉ូអាប់ជាចៅហ្វាយទូលបង្គំ និង
ពួកពលផងទ្រង់ ជាម្ចាស់នៃទូលបង្គំ ក៏សុទ្ធតែដេកនៅវាល
ដែរ ដូច្នេះ តើឱ្យទូលបង្គំចូលទៅឯផ្ទះនឹងទទួលទាន ហើយ
ដេក[ត]នៅជាមួយនឹងប្រពន្ធ ទូលបង្គំដូចម្ដេចកើត ទូលបង្គំ
ស្បថដោយនូវព្រះជន្មទ្រង់ និងព្រលឹង ទ្រង់ដ៏មានជីវិតរស់
នៅថា ទូលបង្គំមិនព្រមធ្វើដូច្នោះឡើយ ១២នោះ ដាវីឌមាន
បន្ទូលថា បើដូច្នេះចូរឯនៅឯណេះក្នុងថ្ងៃនេះទៀតចុះ
ស្អែកឡើងយើងនឹងឱ្យឯងទៅវិញ នោះអ៊ូរីក៏ស្នាក់នៅក្រុង

**១១:២** ង ចទ ២២:៨ យស ២:៨ ច មថ ៥:២៨
**១១:៣** ឆ ១របា ៣:៥ ជ ២សយ ២៣:៣៤ ឈ ២សយ ២៣:៣៩
**១១:៤** ញ លវ ២០:១០ ទដ ៥១ យក ១:១៤–១៥ ដ ចទ ២២:២២ ឋ លវ ១៥:២៥–៣០
**១១:៦** ឌ ១របា ១១:៤១
**១១:៨** ឍ លប ១៨:៤
**១១:១១** ណ ២សយ ៧:២ ត ១សយ ២១:៥

គឺជារដូវប្រពេល ។ *ដែលល្មមឱ្យស្ដេចទាំងប៉ុន្មានចេញទៅច្បាំងបាន* គឺពេលដែលភ្លៀងបានរាំងជារដូវប្រាំង ។ គឺពេលនោះហើយដែលផ្លូវទាំងឡាយក៏គោកហើយអាចដើរបាន ក៏ជារដូវច្រូតកាត់ក៏បានជាស្បៀងសំរាប់ឧបត្ថម្ភដល់កងទ័ព ។ *ក្រុងរ៉ាបា* សូមមើលការពន្យល់ ១០:៣,១៤ ។ សូម្បីតែឥឡូវនៅតែឯងក៏ដោយ (មើល ១០:១៩) ឯសាសន៍អាំម៉ូនក៏ពុំទាន់បានគ្រប់គ្រងនៅឡើយទេ ។

**១១:២** *យាងទៅមកនៅលើដំបូលដំណាក់* ជាទីដែលទ្រង់សប្បាយនឹងខ្យល់អាកាសនាពេលរសៀល (មើលការពន្យល់ ១សយ ៩:២៥) ។

**១១:៣** *អេលាម* ឈ្មោះនេះប្រហែលជាអេលាម ដែលជាពួកសមាជិកក្រុមអង្គរក្សរបស់គាត់ (មើល ១៥:១២ និងការពន្យល់) ។ *អ៊ូរី* ក៏ជាឈ្មោះក្រុមអ្នកយាមរាជវាំងនោះដែរ (២៣:៣៩) ។ គេជាមនុស្សដែលមកពីអំបូរសាសន៍ហេត ដែលបានទទួលសេចក្ដីជំនឿដូចសាសន៍អ៊ីស្រាអែលដែរ (ពាក្យថា អ៊ូរីមានន័យថា "ព្រះអម្ចាស់ជាពន្លឺរបស់ខ្ញុំ") ។ *សាសន៍ហេត* មើលការពន្យល់ ១សយ ២៦:៦ ។

**១១:៤** *ដាវីឌក៏ចាត់គេឱ្យទៅស៊ើបសួរពីនាង* ក្នុងគ្រានោះហើយដែលស្ដេចដាវីឌ បានបំពានរំលងបញ្ញត្តិទាំងទី៦ និងទី៧ក្នុងបញ្ញត្តិទាំង១០ប្រការ (នក ២០:១៣–១៤,១៧) ។ *រួចនាងក៏ចូលទៅឯទ្រង់ ហើយទ្រង់ផ្ទំជាមួយនាងទៅ* នាងបាតសេបាបង្ហាញឱ្យឃើញពីភាពមិនជិទាស់ នូវគោលបំណងស្ដេចដាវីឌក្នុងការប្រព្រឹត្តអំពើកំផិតក្បត់ ជាមួយស្ដេចដាវីឌ ។ *ដ្បិតនាងទើបនឹងបានស្អាត ពីរដូវនាងហើយ* លក្ខណៈសមស្របនេះហើយដែលអាចឱ្យនាងទទួលបានពីភាពទំនាក់ទំនងផ្លូវភេទជាមួយស្ដេចដាវីឌ ព្រោះនាងទើបបានស្អាតពីរដូវរបស់នាង (លវ ១៥:២៨–៣០) ដោយដឹងថានាងពុំទាន់មានផ្ទៃពោះនៅឡើយក្នុងការរួមរស់ជាមួយប្ដីរបស់នាង នោះក្នុងខណៈពេលបន្ទាប់មកដាវីឌបានរួមរក្សជាមួយនាង ។

**១១:៥** *ខ្ញុំម្ចាស់មានគភ៌ហើយ* តាមច្បាប់បានចែងនោះ គឺទាំងស្ដេចដាវីឌ និងនាងបាតសេបា គឺត្រូវកាត់ទោសប្រហាជីវិត (លវ ២០:១០) ប៉ុន្តែដោយសារតែពួកគេជាអ្នកមានឈ្មោះល្បីល្បាញ ។

**១១:៦** *ចូរចាត់អ៊ូរី* ការស៊ើបពីពត៌មានអំពីផ្នែកនៃសង្គ្រាមស្ដេចដាវីឌបានយកលោកអ៊ូរីទៅឯក្រុងយេរូសាឡិមវិញ ។

**១១:៨** *ចូរចុះទៅផ្ទះហើយលាងជើងឯងទៅ* គឺក្នុងភាពចាំបាច់ស្ដេចដាវីឌបានប្រាប់អ៊ូរីឱ្យទៅផ្ទះ ហើយសម្រាកចុះ ។ ដោយទ្រង់ពុំបានមានបន្ទូលចំៗ តែលោកអ៊ូរីបានយល់យ៉ាងច្បាស់ (ខ.១១) ។ *នោះក៏គេនាំយកម្ហូបម្ហាពីស្ដេចទៅជូនគាត់* ព្រះគម្ពីរភាសាហេព្រើរប្រើពាក្យថា "រង្វាន់"មានន័យថា "ម្ហូបម្ហា" មើលក្នុង លប ៤៣:៣៤ (ជាចំណែកខ្លះពីចំណែកដែលគេទុកថ្វាយស្ដេច) ។ ស្ដេចដាវីឌចង់ឱ្យលោកអ៊ូរីនិងបាតសេបា មានសេចក្ដីសប្បាយក្នុងរាត្រីរបស់ពួកគេ ។

**១១:១១** *ហឹប* លោកអ៊ូរីបានបញ្ជាក់ថា គឺហឹបនោះគួរតែនៅឯសមរភូមិប្រយុទ្ធជាមួយកងទ័ពជាជាងនៅឯត្រសាល ។ ដែលដាវីឌបានតំឡើងនៅឯយេរូសាឡិម (៦:១៧) ។ គឺវាសម្រាប់គោលបំណងធ្វើការថ្វាយបង្គំព្រះ និងសុំការបង្ហាញផ្លូវពីព្រះក្នុងការធ្វើសង្គ្រាម តែក្នុងខណៈនោះព្រះយេហូវ៉ាបានគង់សណ្ឋិតនៅឯទីប្រយុទ្ធជាមួយទ័ពរបស់ទ្រង់ គឺក្នុងពេលដែលដាវីឌបានគងនៅឯដំណាក់ទ្រង់ ។ *ដូច្នេះតើឱ្យទូលបង្គំចូលទៅឯផ្ទះនឹងទទួលទានហើយនៅ* មើលការពន្យល់ក្នុង ខ.៨ (រង្វាន់) ការលះបង់របស់លោកអ៊ូរីចំពោះភារៈកិច្ច ក្នុងការលាតត្រដាងពីភាពផ្ទុយគ្នាពីភាពនៅខ្ជិខាងឯគំនិតរបស់ស្ដេចដាវីឌ ដែលសំងំនៅឯរាជដំណាក់ គឺខណៈពេលកូនទាហានទាំងអស់កំពុងស្ថិតនៅសមរភូមិ មើលការពន្យល់ ១សយ ១៤:៣៩,៤៥ ។

យេរូសាឡិមក្នុងថ្ងៃនោះ ហើយថ្ងៃស្អែកទៀត ១៣កាលដាវីឌ
ទ្រង់ហៅគាត់មក នោះគាត់ក៏បរិភោគនៅចំពោះទ្រង់
ហើយទ្រង់បំផឹកឱ្យគាត់ស្រវឹង តែដល់ល្ងាចគាត់ចេញទៅ
ដេកនៅគ្រែ ជាមួយនឹងពួកមហាតលិករបស់ម្ចាស់ខ្លួនទៀត
ឥតមានចុះទៅឯផ្ទះឡើយ ។
១៤ដល់ព្រឹកឡើង ដាវីឌទ្រង់ធ្វើសំបុត្រ[ថ] ផ្ញើទៅយ៉ូអាប់
ដោយសារអ៊ូរី ១៥ក្នុងសំបុត្រនោះមានសេចក្ដីបង្គាប់ថា ចូរ
ឱ្យអ៊ូរីមានកន្លែងក្នុងពួកទ័ពខាងមុខ ត្រង់កន្លែងដែលកំពុង
ច្បាំងគ្នាជាខ្លាំង[ទ] រួចថយចោលវាទៅឱ្យគេបានវាសំឡាប់
ចេញ[ធ] ១៦ដូច្នេះយ៉ូអាប់ក៏សង្កេតមើលទីក្រុង រួចចាត់អ៊ូរី
ឱ្យទៅឯកន្លែង១ ដែលលោកដឹងថា មានមនុស្សក្លាហាន
នៅ ១៧ពួកទ័ពក្នុងក្រុងនោះក៏ចេញមកច្បាំងនឹងយ៉ូអាប់
ហើយមានពួកពលទ័ពរបស់ដាវីឌខ្លះបានដួលស្លាប់ ឯអ៊ូរី
ជាសាសន៍ហេតគាត់ក៏ស្លាប់ដែរ ១៨នោះយ៉ូអាប់ចាត់ម្នាក់
ឱ្យនាំដំណឹងទៅទូលដល់ដាវីឌ ពីរឿងចំបាំង ១៩លោក
បង្គាប់អ្នកនោះថា កាលណាឯងបានរាប់រៀបទូលពីរឿង
ច្បាំងដល់ស្ដេចរួចហើយ ២០នោះបើសិនជាស្ដេចទ្រង់
ក្រោធ ហើយបន្ទោសថា ហេតុអ្វីបានជាចូលទៅច្បាំង
ជិតទីក្រុងអីម្ល៉េះ តើឯងមិនដឹងជាគេនឹងបាញ់ ពីលើកំផែង
មកទេឬអី ២១តើអ្នកណាបានសំឡាប់អ័ប៊ីម៉ាលេក[ន] ជាកូន
យេរូបាល តើមិនមែនជាស្រីដែលទំលាក់ត្បាល់កិនពីលើ
កំផែងមកលើវា[ប] ឱ្យស្លាប់នៅត្រង់ថេបេសទេឬអី ហេតុអ្វី
បានជាចូលទៅជិតកំផែងយ៉ាងដូច្នេះ នោះត្រូវឱ្យឯងទូល
ឆ្លើយយ៉ាងនេះថា អ៊ូរី សាសន៍ហេត ជាបាវបំរើនៃទ្រង់
បានស្លាប់ដែរ ។
២២អ្នកនាំដំណឹងក៏ទៅទូលដល់ដាវីឌ តាមសេចក្ដីដែល
យ៉ូអាប់បានបង្គាប់គ្រប់ប្រការ ២៣គាត់ទូលថា ពួកពលគេ
មានកំឡាំងជាងពួកទូលបង្គំ គេចេញមកដល់ទូលបង្គំទាំង
ឡាយនៅឯវាល ហើយពួកទូលបង្គំក៏ដេញគេទៅវិញ រហូត
ដល់ទ្វារក្រុង ២៤នោះពួកពលធ្នូ គេបាញ់ពីកំផែងមកលើ
ពួកបាវបំរើនៃទ្រង់ ហើយមានពួកអ្នកបំរើខ្លះ របស់ព្រះ
ករុណាបានស្លាប់ ឯអ៊ូរី សាសន៍ហេត ជាអ្នកបំរើទ្រង់ ក៏
ស្លាប់ដែរ ២៥នោះដាវីឌមានបន្ទូលទៅអ្នកដែលនាំដំណឹង
មកថា ចូរឯងទៅប្រាប់យ៉ូអាប់វិញ ដូច្នេះថា កុំឱ្យតូចចិត្តពី
ការនោះឡើយ ពីព្រោះដាវតែងសំឡាប់អ្នក១ ដូចជាអ្នក១
ចូរខំប្រឹងច្បាំងនឹងក្រុងនោះ ឱ្យកាន់តែខ្លាំងឡើង ហើយ
ចាប់យកឱ្យបានចុះ ចូរឯងនិយាយកំឡាចិត្តលោកឡើង ។
២៦កាលប្រពន្ធអ៊ូរីបានឮថាប្ដីស្លាប់ហើយ នោះនាងក៏យំ
សោកនឹងប្ដី ២៧លុះវេលាកាន់ទុក្ខ[ផ]បានគ្រប់កំណត់ហើយ
នោះដាវីឌទ្រង់ ចាត់គេ ឱ្យទៅទទួលនាងមកនៅក្នុងដំណាក់
នាងក៏ធ្វើជាភរិយាទ្រង់ ហើយបង្កើតបានបុត្រា ១ថ្វាយទ្រង់
តែអំពើដែលដាវីឌបានប្រព្រឹត្ត នោះជាទីទាស់ដល់ព្រះ
ហឫទ័យ[ព]នៃព្រះយេហូវ៉ាណាស់ ។

**១១:១៤** ថ ១ពវ ២១:៨
**១១:១៥** ទ ខ.១៤–១៧ ២សយ ១២:៩ ធ ២សយ ១២:១២
**១១:២១** ន ពច ៨:៣១ ប ពច ៩:៥០–៥៤
**១១:២៧** ផ ចទ ៣៤:៨ ព ២សយ ១២:៩ ទដ ៥១:៤–៥

## លោកណាថាន់បន្ទោសដល់ស្ដេចដាវីឌ

*១១:១ ១២:២៩–៣១ – ១របា ២០:១–៣*

**១២** ១ព្រះយេហូវ៉ាទ្រង់ចាត់ណាថាន់[ក] ឱ្យទៅឯដាវីឌ[ខ]
លោកក៏ទៅគាល់ទ្រង់[គ]ទូលដូច្នេះថា នៅទីក្រុង១មានមនុស្ស

**១២:១** ក ២សយ ៧:២ ខ ទដ ៥១ គ ២សយ ១៤:៤

**១១:១៣** *ហើយទ្រង់បំផឹកគាត់ស្រវឹង* គឺក្នុងលក្ខខណ្ឌបែបនេះ ដែលទ្រង់អាចមានឱកាសទៅរកនាងបាសេតបាបាន ។

**១១:១៤** អ៊ូរី ដូចជាធ្វេសប្រហែសនឹងជីវិត ដែលត្រូវប្រឈរមុខនឹងសេចក្ដីស្លាប់ ។

**១១:១៥** *គេវាយសំឡាប់ចេញ* គឺថាបើអ៊ូរីនៅរស់នោះស្ដេចដាវីឌ ក៏គ្មានឱកាសល្អសម្រាប់ទ្រង់ទេ ។ ដូច្នេះ ដាវីឌមានផែនការសម្លាប់អ៊ូរី ដើម្បីទ្រង់អាចមានលទ្ធភាពរៀបការជាមួយនាងបាតសេបា ដោយអង្គទ្រង់ផ្ទាល់ ។

**១១:១៦** *ទីក្រុង* គឺជាទីក្រុងរ៉ាបាត(មើលការពន្យល់ ១០:៣–១៤) ។

**១១:១៧** *ឯអ៊ូរីជាសសន៍ហេតគាត់ក៏បានស្លាប់ដែរ* (សូមមើល ខ.២១,២៤,១៥,២៦) ។

**១១:២១** *យេរូ–បាល* គេក៏អាចសរសេរវាបានមួយបែបទៀតថា យេរូ–ប៊ូសែល (មើលការពន្យល់ ពច ៦:៣២) ។ កាលដែលមានឈ្មោះស្រដៀងគ្នានេះគឺតែងតែដូរគ្រប់ទីកន្លែងទៀត ។ ក្នុង ២សយ មើលការពន្យល់ ២:៨ ៤:៤ ។ *ត្បាល់កិន* មើល ពច ៩:៥៣ និងការពន្យល់ ។ *អ៊ូរី . . . បានសុគតដែរ* លោកយ៉ូអាប់ដឹងថាដំណឹងនេះហើយ ដែលស្ដេចដាវីឌអាចប្រើវាជាយុទ្ធសាស្ត្រក្នុងផែនការទ្រង់ ក៏ជាយុទ្ធសាស្ត្ររបស់ផងទ្រង់នៅក្នុងការធ្វើសង្គ្រាមដែរ ។

**១១:២៤** *អ្នកបំរើខ្លះរបស់ព្រះករុណាបានស្លាប់* គឺជាទាហានអង់អាចបានស្លាប់ជាមួយអ៊ូរីដែរ ជាការបង្ហាញពីភាពសាហាវរបស់ស្ដេចដាវីឌ ដែលជាអំពើបាបរបស់ទ្រង់ ។

**១១:២៥** *ដាវីឌមានបន្ទូលទៅអ្នកនាំដំណឹង* ស្ដេចដាវីឌបានលាក់ការពេញចិត្តដែលទាក់ទងនិងពត៌មាននេះ ក៏មានបន្ទូលដោយមានពុធថា សង្គ្រាមគឺជារឿងសង្គ្រាម គឺមិនត្រូវធ្លាក់ទឹកចិត្តដោយសាររឿងនេះទេ ។

**១១:២៧** *លុះវេលាកាន់ទុក្ខបានគ្រប់កំណត់ហើយ* តាមការស្មានបុណ្យនេះប្រហែលរយៈពេល ៧ថ្ងៃ(មើល ៣១:១៣ និងការពន្យល់ លប ៥០:១០) ។ *នាងក៏ធ្វើជាភរិយាទ្រង់* មើលការពន្យល់ ៥:១៤ ។ *តែអំពើដែលស្ដេចដាវីឌបានប្រព្រឹត្តនោះជាទីទាស់ដល់ព្រះហឫទ័យនៃព្រះយេហូវ៉ា* មិនត្រឹមតែទ្រង់ខុសនឹងបញ្ញត្តិទ្រង់ប៉ុណ្ណោះទេ ក៏ថែមទាំងធ្វើឱ្យមានភាពអាប់ឱនកិត្តយស់ដល់អំណាចរាជវង្សរបស់ទ្រង់ផងដែរ ។ គឺអំណាចដែលព្រះយេហូវ៉ាបានទុកចិត្តដល់ទ្រង់ (មើល ៥:២ ៧:៧ និងការពន្យល់) ។

**១២:១** *ព្រះយេហូវ៉ាទ្រង់ចាត់* គឺជាហោរា គឺជាអ្នកនាំសារពីព្រះយេហូវ៉ា ។ ស្ដេចអធិរាជ្យបានបញ្ជូនបេសកជនទ្រង់ទៅ ដើម្បីថ្កោលទោស និងប្រកាស

មនុស្ស២នាក់ ម្នាក់ជាអ្នកមាន ម្នាក់ក្រីក្រ ២ អ្នកដែលមាន
នោះ មានចៀមហើយនឹងគោយ៉ាងសន្ធឹក ៣ តែអ្នកដែលក្រ
គ្មានអ្វីសោះ មានតែកូនចៀម១ ដែលបានទិញមកចិញ្ចឹម
ប៉ុណ្ណោះ កូនចៀមនោះក៏ចំរើនធំឡើងនៅជាមួយនឹងគាត់
ហើយនឹងកូនគាត់ វាតែងស៊ីអាហារ ហើយផឹកពីពែងរបស់
គាត់ ក៏ដេកនៅនាដើមទ្រូងគាត់ដែរ គាត់ទុកវាដូចជាកូន
ស្រីរបស់ខ្លួន ៤ គ្រានោះមានអ្នកដំណើរម្នាក់មកឯមនុស្ស
អ្នកមាននោះ តែអ្នកមានមិនព្រមយកសត្វណាមួយពីហ្វូង
ចៀមហ្វូងគោរបស់ខ្លួន ដើម្បីនឹងចាត់ចែងរៀបចំទទួល
អ្នកដំណើរ ដែលមកឯខ្លួននោះទេ គឺបានចាប់យកកូនចៀម
របស់អ្នកក្រីក្រនោះ ទៅចាត់ចែងទទួលអ្នកដែលមកនោះ
វិញ ៥ ដូច្នេះដាវីឌ[យ]ទ្រង់មានសេចក្តីខ្ញាល់[ង]ក្តៅឡើងចំពោះ
អ្នកនោះ[ច]ជាខ្លាំង ក៏មានបន្ទូលទៅណាថាន់ថា យើងស្បថ
ដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅថា[ឆ] មនុស្ស
ណាដែលប្រព្រឹត្តដូច្នោះគួរស្លាប់ហើយ ៦ ត្រូវឱ្យវាសង១ជា
៤ជំនួសចៀមនោះ[ជ] ដោយព្រោះបានប្រព្រឹត្តឥតប្រណី
ដូច្នោះ ។
៧ នោះណាថាន់ទូលសបថា ឯមនុស្សនោះ គឺជាអង្គទ្រង់
នេះហើយ[ឈ] ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលដូច្នេះថា អញបានចាក់ប្រេងតាំង[ញ]ឯង[ដ]
ឡើងជាស្តេចនៃសាសន៍អ៊ីស្រាអែល ក៏បានជួយឯងឱ្យរួចពី
កណ្តាប់ដៃរបស់សូល ៨ ហើយបានប្រគល់ដំណាក់[ឋ] និង
ប្រពន្ធទាំងប៉ុន្មានរបស់ចៅហ្វាយឯង មកឱ្យឯងឱបនៅនា
ទ្រូង ព្រមទាំងឱ្យពូជពង្សអ៊ីស្រាអែល និងយូដាមកក្នុង
អំណាចឯងដែរ បើនៅមិនល្មមគ្រាន់ នោះអញនឹងបន្ថែម
យ៉ាងនេះមួយៗឱ្យថែមទៀត ៩ ហេតុអ្វីបានជាឯងមើល
ងាយ[ឌ]ឆ្លោះព្រះបន្ទូលនៃព្រះយេហូវ៉ា ដោយប្រព្រឹត្តការ
អាក្រក់ នៅព្រះនេត្រទ្រង់ដូច្នេះ ឯងបានសំឡាប់[ឍ]អ៊ូរី[ណ] ជា
សាសន៍ហេតដោយដាវ ក៏ក្បត់យកប្រពន្ធគាត់មក ធ្វើជា
ប្រពន្ធឯង ហើយសំឡាប់[ត]គាត់ដោយដាវរបស់ពួកកូនចៅ
អាំម៉ូន ១០ ដូច្នេះ ដាវ[ថ]មិនដែលឃ្លាតពីគ្រួឯងឡើយ ដ្បិតឯង
បានមើលងាយដល់អញ ហើយបានយកប្រពន្ធរបស់អ៊ូរីជា
សាសន៍ហេតមកធ្វើជាប្រពន្ធរបស់ឯង ១១ ព្រះយេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា ចាំមើលអញនឹងបណ្តាលឱ្យមានការ
អាក្រក់កើតឡើងពីក្នុងគ្រួឯង[ទ] ឱ្យទាស់នឹងឯង[ធ]ក៏នឹងយក
ពួកប្រពន្ធទាំងប៉ុន្មានរបស់ឯង ប្រគល់ឱ្យដល់អ្នកជិតនិត
ឯងនៅមុខឯងផង អ្នកនោះនឹងរួចដំណេកនឹងប្រពន្ធឯង
ទាំងនោះនៅទីពន្លឺថ្ងៃ[ន] ១២ ដ្បិតឯងបានធ្វើការនោះដោយ
សំងាត់[ប] តែអញនឹងធ្វើការនេះនៅទីពន្លឺវិញ[ផ] ឱ្យពួក
អ៊ីស្រាអែលទាំងអស់គ្នាបានឃើញ ១៣ រួចដាវីឌមានបន្ទូល
ទៅណាថាន់ថា យើងបានធ្វើបាប[ព]នឹងព្រះយេហូវ៉ាហើយ

**១២:៥** យ ១ពវ ២០:៤០ ង លប ៣៤:៧ ច រម ២:១ ឆ ១សយ ១៤:៣៩
**១២:៦** ជ នក ២២:១
**១២:៧** ឈ ២សយ ១៤:១៣ ដយ ៤:២២ ញ ១សយ ២:៣៥ ដ ១ពវ ២០:៤២
**១២:៨** ឋ ២សយ ៩:៧
**១២:៩** ឌ ជន ១៥:៣១ ១សយ ១៣:១៤ ឍ ២សយ ១១:១៥ ណ ១ពវ ១៥:៥ ត ទដ ២៦:៩ ៥១:១៤
**១២:១០** ថ ២សយ ១៣:២៨ ១៨:១៤–១៥ ១ពវ ២:២៥
**១២:១១** ទ ២សយ ១៦:១១ ធ ចទ ២៨:៣០ ២សយ ១៦:២១–២២ ន ចទ ១៧:១៧
**១២:១២** ប ២សយ ១១:៤–១៥ ផ ២សយ ១៦:២២
**១២:១៣** ព លប ១៣:១៣ ២០:៦ ជន ២២:៣៤

កាត់ទោសដល់ស្តេចដែលទ្រង់បានលើកឱ្យត្រួតលើរាស្ត្រទ្រង់ ។ *ណាថាន* មើលការពន្យល់ ៧:២ ។

**១២:៥** មើលការពន្យល់ ១សយ ១៤:៣៩,៤៥ ។

**១២:៦** *១ជា៤ជំនួស* គឺតម្រូវតាមកិច្ចព្រមព្រៀងនៅ គម្ពីរ នក ២២:១ ។

**១២:៧** *ឯមនុស្សនោះ* លោកណាថានបានបញ្ជាក់បង្ហាញពីស្តេចដាវីឌ ដែលធៀបទៅនិងមនុស្សអ្នកមានក្នុងពាក្យប្រស្នាក្នុង ខ.១–៤ ។ គឺជាប្រយោគរបស់ស្តេចដាវីឌ នៃការដាក់ទោសមួយជាបួន(ខ.៦)មានជាសេចក្តីពិតក្នុងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ ។ គឺជាលទ្ធផលនៃការស្លាប់របស់លោកអ៊ូរី គឺស្តេចដាវីឌបានបាត់បង់កូន៤អង្គ(មើល ខ.១០ និងការពន្យល់ ខ.១៨) វាជាអំពើបាបដែលប្រឆាំង និងអ៊ូរី (មើល ១ពវ ១៥:៥)។

**១២:៨** *ប្រពន្ធទាំងប៉ុន្មានរបស់ចៅហ្វាយឯង* តាមការរៀបរាប់ដំបូងគឺសង្កត់ទៅលើប្រពន្ធតែមួយនៃសូល(អ័ហ៊ីណោម ១សយ ១៤:៤០ ២សយ ៣:៧ ២១:៨–១១)។ ស្តេចដាវីឌបានបញ្ជាក់ថា មានផ្សេងៗទៀតដូចជាតាមទំនៀមស្តេចមុនៗ(មើលការពន្យល់ ៣:៧) វាក៏អាចជាលោកណាថានដែលប្រើភាសាដែលជាការទំលាប់ ក្នុងការបញ្ជាក់ថាព្រះយេហូវ៉ាបានរៀបចំស្តេចដាវីឌលើបល្ល័ង្កស្តេចសូល ។ *ហើយបានប្រគល់ដំណាក់ . . . ពង្សអ៊ីស្រាអែលនិងយូដា* មើល ២:១,៤,៥:២–៣ ។

**១២:៩** *ហេតុអ្វីបានជាឯងមើលងាយ ឆ្លោះព្រះបន្ទូលនៃព្រះយេហូវ៉ា* មើលការពន្យល់ ១១:៤,២៧ ។ *ហើយសម្លាប់គាត់* ស្តេចដាវីឌត្រូវធានារាប់រងផ្ទាល់ពីការស្លាប់របស់លោកអ៊ូរី ទោះក្នុងសមរភូមិក្តី(មើល ១១:១៥ និងការពន្យល់) ។

**១២:១០** *ដាវមិនដែលឃ្លាតពីគ្រួឯងឡើយ* កូនប្រុសដាវីឌទាំងបីបានស្លាប់ដោយអំពើឃោរឃៅ(១៣:២៨–២៩) អាំណូន,អាប់សាឡុំម(១៨:១៤–១៥) និងអ័ដូនីយ៉ា(១ពវ ២:១៥) ។

**១២:១១** ស្តេចដាវីឌបានចេញពីក្រុងយេរូសាឡិមដោយព្រោះអំពើអាក្រក់របស់អាប់សាឡុំម ដែលចង់ដណ្តើមយកអំណាចជាស្តេចពីព្រះបិតាទ្រង់(១៥:១–១៧) ។ *អ្នកនេះនឹងរួមដំណេកនឹងប្រពន្ធឯងទាំងនោះនៅទីពន្លឺថ្ងៃ* ទំនាយនេះក៏បានពីអាប់សាឡុំម (មើលការពន្យល់ ១៦:២២) ។

**១២:១៣** *យើងបានធ្វើបាបនឹងព្រះយេហូវ៉ា* ស្តេចដាវីឌបានទទួលស្គាល់អំពើអាក្រក់របស់គាត់ ហើយក៏លន់តួបាបក្នុងការឆ្លើយតបនឹងការបន្ទោសដល់យ៉ូណាថាន(មើល ទដ ៥១:៤ និងការពន្យល់)ក៏មានភាពផ្ទុយគ្នាដាច់ស្រឡះរវាងការលន់តួរបស់ស្តេចដាវីឌ និងការលន់តួបាបរបស់ស្តេចសូល(មើលការពន្យល់ ១សយ ១៥:២៤) ។ *ព្រះយេហូវ៉ាក៏បានប្រោសលើកទោសទ្រង់ចោល* ស្តេចដាវីឌកាលបានទទួលការអស្ចារ្យ ដែលទ្រង់ជាព្រះយេហូវ៉ាបានលើកលែងទោសដល់ទ្រង់(មើល ទដ ៣១:១,៥ ប្រៀបធៀប ទដ ៥១:៨,១២) ។ *ទ្រង់មិនត្រូវសុគត* គឺព្រះយេហូវ៉ា ដែលនៅក្នុងព្រះគុណទ្រង់បានលោះស្តេចដាវីឌ ពីការដាក់ទណ្ឌកម្មដល់ស្លាប់ ពីការក្បត់ប្រពៃណីយ៍ក្នុងការប្រព្រឹត្តអំពើកំផឹតក្បត់និងឃាដកម្ម(លវ ២០:១០ ២៤:១៧,២១) ។

ណាថាន់ក៏ទូលតបថា ព្រះយេហូវ៉ាក៏បានប្រោសលើក[ភ]
ទោស[ម]ទ្រង់ចោលដែរ ទ្រង់មិនត្រូវសុគតទេ[យ] ១៤ប៉ុន្តែ
ដោយប្រព្រឹត្តអំពើយ៉ាងនេះ ទ្រង់បានឱ្យពួកខ្មាំងសត្រូវនៃ
ព្រះយេហូវ៉ា មានឱកាសនឹងត្មះតិះដៀលជាខ្លាំង[រ] បានជា
បុត្រដែលត្រូវប្រសូតមកនោះ នឹងសុគតទៅជាពិតប្រាកដ
រួចណាថាន់ក៏វិលទៅផ្ទះលោកវិញទៅ ។
១៥ព្រះយេហូវ៉ាទ្រង់ក៏ប្រហារ[ល]បុត្រ ដែលប្រពន្ធអ៊ូរីបាន
បង្កើតឱ្យដាវីឌ ឱ្យមានជំងឺឈឺជាខ្លាំង ១៦ដូច្នេះដាវីឌក៏សូម
អង្វរដល់ព្រះ ពីដំណើរបុត្រទ្រង់ ក៏តមព្រះស្ងោយ ព្រម
ទាំងចូលទៅផ្ទំ[វ]នៅដីពេញ១យប់នោះ ១៧ពួកចាស់ទុំនៅ
ដំណាក់ទ្រង់ក៏ក្រោកឡើងទៅឯទ្រង់ ចង់លើកឱ្យតើនពីដី
ឡើង តែទ្រង់មិនព្រមទេ[ស] ក៏មិនព្រមសោយជាមួយនឹងគេ
ដែរ[ហ] ១៨លុះដល់ថ្ងៃទី៧ បុត្រនោះក៏សុគតទៅ ហើយពួក
អ្នកបំរើរបស់ដាវីឌ គេខ្លាចមិនហ៊ានទូលទ្រង់ឱ្យជ្រាបថា
បុត្រនោះសុគតទេ ដោយគិតគ្នាថា មើលកាលបុត្រមានព្រះ
ជន្មរស់នៅឡើយ នោះយើងបានទូលអង្វរដល់ទ្រង់ តែទ្រង់
មិនព្រមស្តាប់តាមយើងទៅហើយ ចំណង់បើយើងទូល
ទ្រង់ឱ្យជ្រាបពីបុត្រសុគតទៅ នោះតើនឹងធ្វើទុក្ខដល់អង្គ
ទ្រង់យ៉ាងណាទៅទៀត ១៩ប៉ុន្តែកាលដាវីឌឃើញថា ពួកអ្នក
បំរើកំពុងតែខ្សឹបគ្នាដូច្នោះ នោះទ្រង់យល់ឃើញថា ប្រាកដ
ជាបុត្របានសុគតហើយឬអី គេទូលឆ្លើយថា សុគតហើយ
២០នោះដាវីឌក៏តើនពីដីឡើង ទៅស្រង់ទឹក[ឡ] ព្រមទាំងប្រោះ
ទឹកអប់ ហើយផ្លាស់សំលៀកបំពាក់[អ] រួចចូលទៅថ្វាយបង្គំ
នៅក្នុងដំណាក់នៃព្រះយេហូវ៉ាក្រោយមក កាលទ្រង់បាន
ត្រឡប់ចូលមកក្នុងដំណាក់វិញ នោះទ្រង់បង្គាប់ដល់ពួក
អ្នកបំរើ ហើយគេក៏លើកព្រះស្ងោយមកថ្វាយទ្រង់សោយ

២១ដូច្នេះ ពួកមហាតលិកទូលសួរថា យ៉ាងដូចម្តេចហ្ន៎ ដែល
ទ្រង់ប្រព្រឹត្តដូច្នេះនេះ ដ្បិតកាលបុត្រមានព្រះជន្មនៅឡើយ
នោះទ្រង់បានតមព្រះស្ងោយ ហើយសោយសោកនឹងបុត្រ[ក]
តែកាលបុត្រសុគតហើយ នោះបែរជាទ្រង់តើនឡើង
សោយព្រះស្ងោយវិញ ២២ដាវីឌមានបន្ទូលតបថា កាលបុត្រ
មានព្រះជន្មនៅឡើយ យើងបានតមហើយយំ ដោយគិតថា
ប្រហែលជាព្រះយេហូវ៉ា ទ្រង់នឹងប្រោសមេត្តាដល់យើង
ឱ្យបុត្រមានព្រះជន្មតទៅ[ខ]ទេដឹង[គ] ២៣តែឥឡូវនេះបុត្រសុគត
ទៅហើយ ដូច្នេះ តើយើងនៅតមអត់ធ្វើអ្វីទៀត តើយើង
អាចនឹងនាំបុត្រឱ្យត្រឡប់មកវិញបានដែរឬ យើងនឹងទៅឯ
វា[ឃ] តែវាមិនដែលត្រឡប់មកឯយើងវិញឡើយ[ង]។
២៤ដាវីឌក៏ជួយកំសាន្តទុក្ខនាងបាតសេបា[ច] ជាភរិយាទ្រង់
ដែរ រួចចូលទៅរួមបន្ទំជាមួយនឹងនាង ហើយនាងប្រសូត
បានបុត្រា១ទ្រង់ប្រទានព្រះនាមថា សាឡូម៉ូន[ឆ]ព្រះយេហូវ៉ា
ទ្រង់មានព្រះហឫទ័យស្រឡាញ់បុត្រនោះ ២៥ក៏ចាត់ហោរា
ណាថាន់ឱ្យទៅតាំងនាមថា យេឌីឌីយ៉ាដោយព្រោះជាទី
ស្រឡាញ់ដល់ព្រះយេហូវ៉ា[ជ]។
២៦ឯយ៉ូអាប់លោកកំពុងតែច្បាំងនឹងក្រុងរ៉ាបាត[ឈ]របស់
ពួកកូនចៅអាំម៉ូន ក៏វាយចាប់យកក្រុងហ្លួងបាន ២៧រួច
លោកចាត់គេឱ្យទៅទូលដាវីឌថា ទូលបង្គំបានចូលទៅវាយ
ក្រុងរ៉ាបាត ហើយចាប់យកបាន ប៉ែកដែលនៅខាងមាត់
ទឹកហើយ ២៨ដូច្នេះ សូមទ្រង់ប្រមូលពួកពលទ័ព ដែលនៅ
សល់មកបោះទ័ព ចាប់យកទីក្រុងនោះចុះ ក្រែងទូលបង្គំ
វាយយកបាន ហើយគេតាំងឈ្មោះក្រុងនោះតាមឈ្មោះ

**១២:១៣** ភ ទដ ៣២:១–៥ ៥១:១,៩ ១០៣:១២ អស ៤៣:២៥ ៤៤:២២ សក ៣:៤,៩ ម សភ ២៨:១៣ យរ ២:៣៥ មីក ៧:១៨–១៩ យ លវ ២០:១០ ២៤:១៧ **១២:១៤** រ អស ៥២:៥ រម ២:២៤ **១២:១៥** ល ១សយ ២៥:៣៨ **១២:១៦** វ ទដ ៥:៧ ៩៥:៦ **១២:១៧** ស លប ៣៧:៣៥ ១សយ ១:៧ ហ ២សយ ៣:៣៥ ដយ ៦:១៨ **១២:២០** ឡ មថ ៦:១៧ អ លប ៤១:១៤ **១២:២១** ក ពច ២០:២៦ **១២:២២** ខ យហ ៣:៩ គ អស ៣៨:១–៥ **១២:២៣** ឃ លប ៣៧:៣៥ ង ១សយ ៣១:១៣ ២សយ ១៣:៣៩ យប ៧:១០ ១០:២១ **១២:២៤** ច ១ពវ ១:១១ ឆ ១ពវ ១:១០ ១រប ២២:៩ ២៨:៥ មថ ១:៦ **១២:២៥** ជ នហ ១៣:២៦ **១២:២៦** ឈ ចទ ៣:១១

**១២:១៤** *ទ្រង់បានឱ្យពួកខ្មាំងសត្រូវនៃព្រះយេហូវ៉ា មានឱកាសនឹងត្មះតិះដៀលជាខ្លាំង* គឺជាការតម្រូវពីព្រះឱ្យស្តេចដាវីឌទទួលការឈឺចាប់ ដែលស្តែងចេញពីលទ្ធផលនៃអំពើបាបរបស់គាត់ ។

**១២:១៦** *សូមអង្វរដល់ព្រះ . . . តមព្រះស្ងោយ* សូមមើលការពន្យល់ អគ ៨:២៣ ។

**១២:១៨** *ថ្ងៃទី៧* គឺនិយាយពីអាយុក្មេង ដែលជីវិតទ្រង់មានលក្ខណៈខ្លីណាស់ (មើល លក ១:៥៩ ២:២១ ប្រៀបធៀប លប ២១:៣–៤) ។

**១២:២០** *ព្រមទាំងប្រោសទឹកអប់* គឺជាការអនុវត្តទៅតាមទម្លាប់ ដែលទាក់ទងទៅនឹងថ្វាយនៃការកាន់ទុក្ខ (មើល ១៤:២) ។ *ផ្លាស់សំលៀកបំពាក់* ក៏ដោះអាវកាន់ទុក្ខចេញ ដោយដាក់អាវធម្មតា ។ *រួចចូលទៅថ្វាយបង្គំក្នុងដំណាក់នៃព្រះយេហូវ៉ា* ក្នុងសណ្ឋានរបៀបបែបនេះ គឺបង្ហាញពីភាពបន្ទាបខ្លួនក្នុងការដែរទ្រង់បានប្រព្រឹត្តបាប (មើលការពន្យល់ ខ.១៣) ប្រៀបធៀបភាពខុសគ្នារវាងដាវីឌ និងស្តេចសូល (មើលការពន្យល់ ១សយ ១៥:២៥) ។

**១២:២៣** *យើងនឹងទៅឯវា* គឺឱ្យដូចជាកូននោះដែរ ស្តេចដាវីឌមានបន្ទូលថា ខ្ញុំនឹងស្លាប់ហើយទៅរួមនឹងវា ឯស្ថានឃុំព្រលឹងមនុស្សស្លាប់ជាមួយកូនទ្រង់ដែរ (លប ៣៧:៣៥) ។ *តែវាមិនដែលត្រឡប់កងយើងវិញសោះ* មើល យប ៧:៩ និងការពន្យល់ ។

**១២:២៤** *សាឡូម៉ូន* មើល ១រប ២២:៩ និងការពន្យល់ ។

**១២:២៥** *យេឌីឌីយ៉ា* មើលការពន្យល់ ។ ការដាក់ឈ្មោះគឺជាព្រះហឫទ័យរបស់ទ្រង់តាមការបើកសម្តែង ទៅលើស្តេចសាឡូម៉ូន ហើយឈ្មោះក៏បានឮសុសសាយរហូតដល់ឈ្មោះស្តេចដាវីឌ គឺបង្ហាញពីសេចក្តីស្រឡាញ់ពីព្រះមកលើរូបលោក និងរក្សារាជវង្សដល់ស្តេចដាវីឌ ។

**១២:២៦** *ឯយ៉ូអាប់លោកកំពុងតែច្បាំងនឹងក្រុងរ៉ាបាត* គឺអ្នកនិពន្ធបានបង្វែទៅសរសេរពីការច្បាំង និងសាសន៍អាំមូន (១១:១,២៥) ដែលបង្ហាញពីប្រវត្តិនូវរឿងរ៉ាវរបស់ស្តេចដាវីឌ និងនាងបាតសេបា ។ ទោះព្រះយេហូវ៉ាមិនសព្វព្រះហឫទ័យនឹងស្តេចដាវីឌ (១១:២៧) តែទ្រង់បានឱ្យរាស្ត្រអ៊ីស្រាអែលមានជ័យជម្នះលើពួកដែលរំលោភលើពួកគេ ។

ទូលបង្គំវិញ ២៩នោះដាវីឌក៏ប្រមូលពួកពលទ័ពទាំងអស់
ទៅវាយយកក្រុងរ៉ាបាតបាន ៣០ទ្រង់ក៏យកមកុដ[ញ]ពីព្រះសិរ
របស់ស្តេចគេ មកបំពាក់លើព្រះសិរនៃទ្រង់វិញ ឯមកុដ
នោះ មានទំងន់ជា១ហាបមាស ក៏ដាំដោយត្បូងមានដំឡៃ
ផ្សេងៗ រួចទ្រង់នាំយករបឹបយ៉ាងសន្ធឹកពីទីក្រុងនោះមក
៣១ក៏នាំមនុស្សទាំងអស់ដែលនៅក្រុងនោះចេញមក ប្រើគេ
ធ្វើការកាប់រំលំហើយអារឈើ ព្រមទាំងភ្ជួររាស់ ហើយ
ធ្វើការក្នុងឡឥដ្ឋ ទ្រង់ក៏ធ្វើដូច្នោះដល់អស់ទាំងក្រុងរបស់
ពួកកូនចៅអាំម៉ូន[ដ] រួចទ្រង់នាំបណ្តាទ័ពទាំងប៉ុន្មានត្រឡប់
ទៅឯក្រុងយេរូសាឡិមវិញ ។

### អាំណូន និងតាម៉ារ

**១៣** ១ក្រោយនោះមក កើតមានរឿងដូច្នេះ គឺអាប់សា–
ឡុំម[ក] បុត្រាដាវីឌមានកនិដ្ឋា១ មានរូបស្រស់បស់ល្អនាម
នាងតាម៉ារ[ខ] ហើយអាំណូន[គ]ជាបុត្រាដាវីឌ មានព្រះទ័យ
ប្រតិព័ទ្ធស្រឡាញ់ ២អាំណូនមានសេចក្តីរំជួលស្រឡាញ់នាង
តាម៉ារជាកនិដ្ឋាដល់ម្ល៉េះ បានជាទ្រង់ទៅជាប្រឈួនទ្រង់
នឹកឃើញថា ពិបាកនឹងធ្វើអ្វីដល់នាងណាស់ ដោយព្រោះ
នាងនៅបរិសុទ្ធ ៣តែអាំណូនមានពួកម៉ាកម្នាក់ឈ្មោះ
យ៉ូណាដាប ជាបុត្រាសាំម៉ា[ឃ] ជេដ្ឋារបស់ដាវីឌ ជាមនុស្ស
ឆ្លៀវឆ្លាតណាស់ ៤អ្នកនោះសួរថា ហេតុអ្វីបានជាឯង
ដែលជាកូនស្តេច នៅតែស្គាំងស្គមរាល់តែថ្ងៃដូច្នេះ សូម
ប្រាប់ឱ្យអញដឹងផង នោះអាំណូនប្រាប់ថា អញមានចិត្ត
ស្រឡាញ់ដល់នាងតាម៉ារ ជាប្អូនអាប់សាឡុំម បងអញ
ណាស់ ៥រួចយ៉ូណាដាបប្រាប់ថា ដូច្នេះចូរឯងដេកនៅលើ
គ្រែក្លែងធ្វើជាឈឺទៅ បើកាលណាបិតាឯងមកសួរនោះ
ចូរទូលថា សូមបិតាអនុញ្ញាតឱ្យនាងតាម៉ារ ជាកនិដ្ឋាទូល
បង្គំ មករៀបអាហារនៅមុខ ទូលបង្គំ ឱ្យទូលបង្គំបាន
ឃើញ ហើយបានទទួលពីដៃនាងមកបរិភោគបន្តិច ៦ដូច្នេះ
អាំណូនក៏ដេកទៅ ហើយក្លែងធ្វើជាប្រឈួន លុះកាលស្តេច
បានយាងមកសួរ នោះអាំណូនទូលថា សូមបិតាអនុញ្ញាត
ឱ្យនាងតាម៉ារ ជាកនិដ្ឋាទូលបង្គំ មកធ្វើនំ២នៅមុខទូលបង្គំ
ដើម្បីឱ្យទូលបង្គំបានទទួលពីដៃនាងមកបរិភោគ ។
៧នោះដាវីឌក៏ចាត់គេឱ្យទៅឯដំណាក់ ប្រាប់នាងតាម៉ារ
ថា ចូរឯងទៅឯដំណាក់អាំណូនជេដ្ឋាឯង ហើយធ្វើនំឱ្យវា
ចុះ ៨ដូច្នេះនាងតាម៉ារក៏ទៅដល់ដំណាក់អាំណូនជាជេដ្ឋា
ខ្លួន កំពុងដែលទ្រង់ផ្ទំ នាងក៏យកម្សៅមកច្របាច់ធ្វើនំ
ហើយដុតនៅចំពោះទ្រង់ ៩រួចលើកខ្ទះចាក់នំនោះនៅ
ចំពោះទ្រង់ តែទ្រង់មិនព្រមបរិភោគទេ ហើយបង្គាប់ថា[ង]
ចូរឱ្យមនុស្សទាំងអស់ចេញពីអញទៅ គេក៏ចេញទាំងអស់គ្នា
១០រួចអាំណូនប្រាប់ទៅនាងតាម៉ារថា សូមនាំយកនំមកក្នុង
បន្ទប់ឯណេះ ដើម្បីអញនឹងបរិភោគពីដៃឯង នាងក៏នាំយក
នំដែលធ្វើនោះ ទៅឯអាំណូន ជាជេដ្ឋា នៅក្នុងបន្ទប់
១១កាលនាងទៅជិត ដើម្បីថ្វាយនំទៅឱ្យសោយនោះទ្រង់ក៏
ចាប់[ច]នាងដោយពាក្យថា ប្អូនអើយ ចូរមកដេកនឹងអញ
ចុះ[ឆ] ១២តែនាងប្រកែកថា ទេ បងអើយ សូមកុំបន្ទាបខ្ញុំ
ឡើយ ព្រោះធ្វើដូច្នេះ ខុសនឹងបវេណីក្នុងពួកអ៊ីស្រាអែល[ជ]
ណាស់ សូមកុំធ្វើការអាក្រក់នេះឱ្យសោះ[ឈ] ១៣ឯខ្ញុំម្ចាស់[ញ]
តើនឹងយកសេចក្តីខ្មាសទៅទុកឯណា ហើយចំណែកឯបង
នោះគេនឹងរាប់បង ទុកជាមនុស្សងងឹតល្ងើក្នុងសាសន៍
អ៊ីស្រាអែលដែរ ដូច្នេះ សូមទូលដល់ស្តេចចុះ ដ្បិត ទ្រង់មិន
ប្រកែក នឹងឱ្យខ្ញុំម្ចាស់ដល់បងទេ ១៤ប៉ុន្តែអាំណូនមិនព្រម
ស្តាប់នាងឡើយ គឺបានចាប់បង្ខំដេកនឹងនាងទៅ ដោយទ្រង់
មានកំឡាំងច្រើនជាង[ដ] ។

**១២:៣០** ញ នអ ៨:១៥ ទដ ២១:៣ ១៣២:១៨
**១២:៣១** ដ ១សយ ១៤:៤៧
**១៣:១** ក ២សយ ៣:៣ ខ ២សយ ១៤:២៧ ១រប ៣:៩ គ ២សយ ៣:២
**១៣:៣** ឃ ១សយ ១៦:៩
**១៣:៩** ង លប ៤៥:១
**១៣:១១** ច លប ៣៩:១២ ឆ លប ៣៨:១៦
**១៣:១២** ជ លវ ២០:១៧ ឈ លប ៣៤:៧
**១៣:១៣** ញ លវ ១៨:៩ ចទ ២២:២១, ២៣–២៤
**១៣:១៤** ដ លប ៣៤:២ អគ ២២:១១

**១២:៣០** *មកុដពីព្រះសិររបស់ស្តេចគេមកបំពាក់លើព្រះសិរនៃទ្រង់*(ដាវីឌ) ជាភាពដ៏មានតម្លៃនៃឱកាសពិសេសនេះ គឺអាចមានការបំពាក់មួយដងក្នុងការតំណាងជានិមិត្ត នៃការផ្ទេរភាពជាស្តេចឱ្យដាវីឌគ្រប់គ្រងលើអាំណូនវិញ ។

**១២:៣១** *ប្រើគេឱ្យធ្វើការកាប់រំលំហើយអារឈើ* ព្រះមហាក្សត្រដែលមានជ័យជម្នះជារឿយៗប្រើឈ្លើយសឹកឱ្យធ្វើការ ឬសាងសង់(មើល ១ពវ ៩:២០–២១ ប្រៀបធៀប នក ១១:១១) ។

**១៣:១–៣៩** បញ្ហាក្នុងរង្វង់គ្រួសារនៃរាជវង្សស្តេចដាវីឌចាប់ផ្តើម (មើល ១២:១០) ។

**១៣:១** *ក្រោយនោះមក* មើលការពន្យល់ ៣:១ ។ *អាំណូន* ជាកូនច្បងប្រុសរបស់ស្តេចដាវីឌ (៣:២) ។ *នាងតាម៉ារ* ជាកូនស្រីដាវីឌជាមួយនាងម្អាកា (ប្រៀបធៀប ៣:៣) និងប្អូនស្រីបង្កើតរបស់អាប់សាឡុំម ។

**១៣:៣** *សាំម៉ា* មើល ១សយ ១៦:៩ ។

**១៣:៦** *កាលស្តេចបានយាងមកសួរ* អាំណូនបានប្រើឈ្មោះឪពុករបស់គាត់ គឺដាវីឌដើម្បីទទួលគោលបំណងខុសច្បាប់របស់គាត់(មើល ១១:១៤–១៧) ។

**១៣:១២** *ការអាក្រក់* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ដូចជាពាក្យដែលជាឈ្មោះថា ណាបាល ជាឈ្មោះមនុស្សតែអាចមានន័យថាការអាក្រក់(មើល ១សយ ២៥:២៥) ។

**១៣:១៣** *ហើយចំណែកឯបង* គឺជាសកម្មភាពឱ្យមានគ្រោះថ្នាក់ដល់មុខតំណែងរបស់អាំណូន ដែលដូចជាស្តេច មកុដ និងមរដកក្នុងរាជបល្ល័ង្ក ។ *គេនឹងរាប់បងទុកជាមនុស្សងងឹតល្ងើ* គឺជាដូចជាណាបាល(មើលការពន្យល់ ខ.១២ ឬ មើល សភ ១:៧) ។ ភាពងងឹតល្ងើ របស់ស្តេចដាវីឌក្នុងការទំនាក់ទំនងជាមួយនឹងបាតសេបា គឺទទួលបានផលផ្លែដ៏ជូរចត់ គឺកូនប្រុសច្បងរបស់ទ្រង់ដោយសកម្មភាពរបស់គេ ក៏ប្រែក្លាយជាលោកណាបាលម្នាក់ទៀត ។

១៥ រួចមកអាំណូនមានព្រះទ័យណាយ ស្អប់ដល់នាងជា
ខ្លាំងក្រៃលែង ដល់ម្ល៉េះបានជាសេចក្ដីស្អប់ខ្ពើម ដែលទ្រង់
មានដល់នាង នោះខ្លាំងលើសជាងសេចក្ដីស្រឡាញ់ដែល
ទ្រង់បានមានដល់នាងទៅទៀត ហើយទ្រង់បណ្ដេញនាងថា
ចូរក្រោកឡើងទៅឱ្យបាត់ទៅ ១៦ នោះនាងឆ្លើយថា កុំឡើយ
ដ្បិតការកំហុសដែលបណ្ដេញខ្ញុំម្ចាស់នេះ នោះអាក្រក់ជាង
ការ ដែលបានធ្វើហើយ ដល់ខ្ញុំម្ចាស់ទៅទៀត តែទ្រង់មិន
ព្រមស្ដាប់តាមនាងឡើយ ១៧ ក៏ហៅអ្នកដែលតែងបំរើទ្រង់
មកប្រាប់ថា ចូរយកស្រីនេះចេញទៅរួចបិទទ្វារដាក់រនុក
ផង ១៨ ដូច្នេះ អ្នកបំរើក៏នាំនាងទៅក្រៅ រួចបិទទ្វារឯនាង
តាម៉ារ ទ្រង់ព្រះភូសាពណ៌ផ្សេងៗ[ឋ] ដ្បិតពួកបុត្រីស្ដេច
ដែលនៅក្រមុំធ្លាប់តែងអង្គយ៉ាងនោះ ១៩ រួចនាងយកផេះ[ឌ]
មកដាក់លើព្រះសិរ ក៏ហែកព្រះភូសាហើយ យកព្រះហស្ត
ដាក់លើព្រះសិរ យាងទៅទាំងទ្រង់ព្រះកន្សែងជាខ្លាំង។
២០ អាប់សាឡុមជាជេដ្ឋាក៏សួរថា តើអាំណូនបងឯងបាន
នៅជាមួយនឹងឯងឬអី ប្អូនអើយ ចូរនៅស្ងៀមសិនចុះ ដ្បិត
ជាបងឯងទេ កុំឱ្យមានចិត្តព្រួយនឹងការនេះពេកឡើយ
នោះនាងក៏នៅតែឯងក្នុងដំណាក់អាប់សាឡុម ជាជេដ្ឋា
២១ កាលស្ដេចដាវីឌបានឮនិយាយពីរឿងទាំងនោះ ទ្រង់
មានសេចក្ដីពិរោធជាខ្លាំង[ឍ] ២២ តែអាប់សាឡុមមិន បាន
មានបន្ទូលអ្វីនឹងអាំណូន ទោះល្អឬអាក្រក់ក្ដី[ណ] ដ្បិតទ្រង់ស្អប់[ត]
អាំណូន ដោយព្រោះបានបង្ខូចនាងតាម៉ារជាកនិដ្ឋាទ្រង់។

## អាប់សាឡុមសម្លាប់អាំណូន

២៣ ក្រោយ២ឆ្នាំមក មានពួកជាងមកកាត់រោមចៀម[ថ]
របស់អាប់សាឡុម នៅត្រង់បាល-ហាសោរ ដែលនៅជិត
ដែនអេប្រាអិម ហើយអាប់សាឡុមក៏អញ្ជើញពួកបុត្រាស្ដេច
ទាំងអស់មក ២៤ ទ្រង់ចូលទៅគាល់ស្ដេចទូលថា បពិត្រ
ព្រះករុណា ទូលបង្គំជាអ្នកបំរើនៃទ្រង់ មានពួកជាងមក
កាត់រោមចៀម ដូច្នេះសូមព្រះករុណា ព្រមទាំងពួកអ្នក
បំរើទ្រង់ឯទៀត យាងទៅទទួលជប់លៀងជាមួយនឹងទូល
បង្គំ ២៥ តែស្ដេចទ្រង់មានបន្ទូលតបទៅអាប់សាឡុមថា ទេ
កូនអើយ មិនត្រូវឱ្យយើងទៅទាំងអស់គ្នាទេក្រែងជាបន្ទុក
ធ្ងន់ដល់ឯងពេក អាប់សាឡុមក៏ទូលបង្ខំទ្រង់ តែទ្រង់មិន
ព្រមទៅទេ គឺបែរជាប្រទានពរឱ្យវិញ ២៦ នោះអាប់សាឡុម
ទូលថា បើទ្រង់មិនយាងទៅទេ នោះសូមឱ្យតែអាំណូនជា
ជេដ្ឋាទូលបង្គំទៅជាមួយចុះ តែស្ដេចមានបន្ទូលសួរថា
ចង់ឱ្យវា ទៅជាមួយនឹងឯងធ្វើអី ២៧ ប៉ុន្តែដោយអាប់សាឡុម
ចេះតែបង្ខំទ្រង់ បានជាទ្រង់ក៏អនុញ្ញាតឱ្យអាំណូន ហើយនិង
ពួកបុត្រាទ្រង់ទាំងអស់ទៅជាមួយ ២៨ [ទ]រីឯអាប់សាឡុម[ធ]បាន
បង្គាប់ដល់ពួកអ្នកបំរើទ្រង់ថា ចូរឯងឃ្លាំមើលកាលណា
អាំណូនផឹកស្រាទំពាំងបាយជូរ បានសប្បាយចិត្ត[ន] ហើយ

**១៣:១៨** ឋ លប ៣៧:២៣
**១៣:១៩** ឌ យស ៧:៦ នអ ៤:១ ដយ ៩:៣
**១៣:២១** ឍ លប ៣៤:៧
**១៣:២២** ណ លប ៣១:២៤ ត លប ១៩:១៧-១៨ ១យហ ២:៩-១១
**១៣:២៣** ថ ១សយ ២៥:៧
**១៣:២៨** ទ ២សយ ៣:៣ ធ នរ ៣:៧ ន ២សយ ១២:១០

**១៣:១៥** *អាំណូនមានព្រះទ័យណាយ* ភាពត្រឡប់មកវិញ ដែលមានក្នុងអារម្មណ៍របស់អាំណូនចំពោះនាងតាម៉ាបានបង្ហាញថា "ការស្រឡាញ់របស់គាត់ពីមុន (ខ.១) គឺអត់បានការអ្វីទាំងអស់តែគ្រាន់តែដើម្បីបំពេញសេចក្ដីប៉ងប្រាថ្នាខាងកាមគុណតែប៉ុណ្ណោះ ។

**១៣:១៦** *ដ្បិតការកំហុសដែលបណ្ដេញខ្ញុំម្ចាស់នេះ នោះអាក្រក់ជាងការដែលបានធ្វើហើយ* គឺមានន័យថានាងពុំមានភាពបរិសុទ្ធទៀត ហើយឪពុករបស់នាងក៏ពុំអាចលើកនាងឱ្យទៅបុរសណាដែលមានឥទ្ធិពលដែរ (មើល ខ.២១ និងការពន្យល់) ។

**១៣:១៩** *រួចនាងយកផេះមកដាក់លើព្រះសិរ . . . ក៏ហែកព្រះភូសាហើយយកព្រះហស្តដាក់លើព្រះសិរ* គឺជាសញ្ញាបង្ហាញពីភាពទន្ទិចផ្លូវចិត្ត ហើយបង្ហាញឱ្យដឹងថា ភាពបរិសុទ្ធរបស់នាងគឺត្រូវបានគេរំលោភបំពានអស់ហើយ ។

**១៣:២០** *ប្អូនអើយចូរនៅស្ងៀមសិនចុះ . . . កុំមានចិត្តព្រួយនឹងការនេះពេកឡើយ* អាប់សាឡុមអង្វរបង្ខំប្អូនស្រីគាត់ កុំឱ្យធ្វើរឿងនេះក្លាយជារឿងអាស្រូវឱ្យគេដឹងឮឡើយ ។ គឺមានន័យថាគាត់ត្រូវរៀបចំការសម្ងាត់របស់គាត់ដើម្បីសងសឹកវិញ (មើល ខ.២២,២៨,៣២) ។

**១៣:២១** *ទ្រង់មានសេចក្ដីពិរោធជាខ្លាំង* ទោះជាស្ដេចដាវីឌបានមានព្រះទ័យពិរោធខ្លាំង ដោយព្រោះអំពើររំលោភ សេពសន្ថវៈរបស់អាំណូនទៅលើតាម៉ារយ៉ាងណាក៏គ្មានអ្វីជាសំគាល់ថា ទ្រង់នោះបានប្រឆាំងឡើយ ។ ទ្រង់ (ដាវីឌ) បាននឹកឃើញអំពើបាបរបស់ទ្រង់ ជាមួយបាតសេបាក៏ជាឥទ្ធិពលមួយដល់ការដោះស្រាយបញ្ហានេះ គឺការធានាខុសត្រូវចំពោះដាវីឌជាស្ដេចផង ក៏ជាព្រះបិតាផង ក្នុងការដាក់វិន័យទៅលើកូន របស់ព្រះអង្គផ្ទាល់ (មើលការពន្យល់ ១៤:៣៣ ១ពវ ១:៦) ក៏អាចប្រហាជីវិតដល់អាំណូន និងការបះបោរប្រឆាំងរបស់អាប់សាឡុម និងអ័ដូនីយ៉ា ។

**១៣:២២** *អាប់សាឡុមមិនបានមានបន្ទូលអ្វីនឹងអាំណូន . . . ទ្រង់ស្អប់អាំណូន* ទ្រង់ពិតជារងចាំឱកាសរបស់ទ្រង់ ។

**១៣:២៣** *ក្រោយ២ឆ្នាំមក* គឺជារយៈពេលចំពោះអាប់សាឡុម ហើយក៏ពេលដែលស្ដេចដាវីឌពុំបានធ្វើអ្វីដល់អាំណូនឡើយ គឺក្នុងរឿងអាំណូនបានរំលោបសេបសតវៈ និងនាងតាម៉ារ ។ *ហើយអាប់សាឡុមក៏អញ្ជើញពួកបុត្រាស្ដេចទាំងអស់មក* គឺជាពេល ឬជាឱកាសមួយសម្រាប់ទទួលយោបល់ពីគ្នាទៅវិញទៅមក (មើល ១សយ ២៥:៤,៨) ។

**១៣:២៦** *នោះសូមឱ្យតែអាំណូនជាជេដ្ឋាទូលបង្គំទៅជាមួយចុះ* ដោយយោងទៅតាមសេចក្ដីបដិសេធរបស់ស្ដេចដាវីឌពីការអញ្ជើញនេះ ។ អាប់សាឡុមបានស្នើរជាផ្លូវការថាអាំណូន គឺជាបុត្រាដែលបានអភិសេកនឹងបុត្រាច្បងដែលជាតំណាង ។ *ចង់ឱ្យទៅជាមួយនឹងឯងធ្វើអ្វី* សំនួររបស់ស្ដេចដាវីឌខ្លះៗក៏មិនទាន់ស៊ីគ្នាស្របគ្នា ដោយព្រោះមានឈាមជ័រខុសគ្នារវាបងប្អូនពីរអ្នកដែលមានម្ដាយទីទៃពីគ្នា (មើល ខ.២២) ។

**១៣:២៨** *ត្រូវសំឡាប់វា* អាប់សាឡុមបានរៀបចំផែនការសម្លាប់បងប្រុស

អញប្រាប់ថា ចូរវាយអាំណូនចុះ នោះត្រូវសំឡាប់វាទៅ កុំ
ក្រែងខ្លាចអ្វីឡើយ គឺអញហើយដែលបានបង្គាប់ការនេះ
ចូរតាំងចិត្តឱ្យមាំ ឱ្យបានក្លាហានចុះ[ន] ២៩ពួកអ្នកបំរើរបស់
អាប់សាឡំម ក៏ធ្វើដល់អាំណូនតាមបង្គាប់របស់ចៅហ្វាយ
ខ្លួន រួចពួកបុត្រាស្តេចគ្រប់អង្គក៏ក្រោកឡើង ជិះលាកាត់
រៀងអង្គរត់ទៅ ។
៣០កាលបុត្រាស្តេចទាំងនោះ កំពុងតែយាងមកតាមផ្លូវ
នោះដំណឹងក៏ឮទៅដល់ដាវីឌថា អាប់សាឡំមបានសំឡាប់
បុត្រទ្រង់ព្រះករុណាទាំងអស់ហើយ គ្មានសល់១ឡើយ
៣១នោះស្តេចទ្រង់ក៏ក្រោកឡើងហែក[ប]ព្រះពស្ត្រ រួចផ្ទំនៅ
ដី ឯពួកមហាតលិកទ្រង់ទាំងប៉ុន្មាន ក៏ឈរនៅជិតទាំងមាន
អាវរហែកដែរ ៣២តែយ៉ូណាដាប ជាបុត្រាស៊ីម៉ា ជេដ្ឋា
ដាវីឌ ទូលឡើងថា បពិត្រព្រះករុណា សូមទ្រង់កុំមានព្រះ
ទ័យស្មានថា គេបានធ្វើគុតពួកព្រះរាជបុត្រទាំងអស់នៃ
ព្រះករុណាឡើយ សុគតតែអាំណូនប៉ុណ្ណោះទេ ដ្បិតការ
នោះបានគិតជាស្រេច តាមបង្គាប់នៃអាប់សាឡំមតាំងពីថ្ងៃ
ដែលអាំណូនបានបង្ខូចនាងតាម៉ារ ជាកនិដ្ឋាមក ៣៣ដូច្នេះ
សូមកុំឱ្យទ្រង់ព្រះករុណា ជាម្ចាស់នៃទូលបង្គំមានព្រះ
ទ័យព្រួយពេក ដោយស្មានថា ពួកព្រះរាជបុត្រាបានសុគត
ទាំងអស់នោះឡើយ ដ្បិតសុគតតែអាំណូនប៉ុណ្ណោះទេ ឯ
អាប់សាឡំមទ្រង់រត់បាត់ទៅ ។
៣៤រីឯទាហានដែលចាំយាម គេបានងើបភ្នែកឡើង
មើលទៅ ឃើញមានមនុស្សជាច្រើន មកតាមផ្លូវចង្កេះភ្នំ
ខាងក្រោយខ្លួន ៣៥នោះយ៉ូណាដាបទូលទៅស្តេចថា នុ៎ះន៍
ពួកបុត្រានៃព្រះករុណាមកហើយ ដូចជាទូលបង្គំជាអ្នកបំរើ
ទ្រង់បានទូលទុក ៣៦កាលទូលដូច្នោះរួចជាស្រេចនោះពួក
បុត្រាស្តេចក៏មកដល់ ហើយឡើងសំឡេងទ្រង់ព្រះកន្សែង
ឯស្តេចទ្រង់ព្រះកន្សែងដែរ ព្រមទាំងពួកមហាតលិក ក៏យំ
ទាំងអស់គ្នាយ៉ាងខ្លាំងក្រៃលែង ។
៣៧តែអាប់សាឡំមទ្រង់រត់ទៅឯតាម៉ាយ ជាបុត្រា
អាំមិហ៊ូត[ផ] ស្តេចស្រុកកេស៊ូរី ឯដាវីឌទ្រង់សោយសោកនឹង
បុត្រជារាល់ថ្ងៃ ៣៨អាប់សាឡំមកបានរត់ទៅនៅឯស្រុក
កេស៊ូរី នោះអស់៣ឆ្នាំ ៣៩ហើយស្តេចដាវីឌទ្រង់មាន
ព្រះទ័យឮកចង់ទៅឯអាប់សាឡំម[ព] ដោយព្រោះបានក្សាន្ត
ព្រះទ័យ[ភ] ពីដំណើរអាំណូន ដែលសុគតនោះហើយ ។

## អាប់សាឡំមត្រឡប់មកក្រុងយេរូសាឡិមវិញ

**១៤** ១រីឯយ៉ូអាប់[ក] ជាកូនសេរូយ៉ា លោកយល់ឃើញថា
ស្តេចមានព្រះទ័យនឹករឮកដល់អាប់សាឡំម ២នោះក៏ចាត់
គេទៅឯក្រុងត្កូអា[ខ] នាំស្រីប្រាជ្ញម្នាក់[គ]មកពីទីនោះហើយ
បញ្ចេះថា សូមឱ្យអ្នកក្លែងខ្លួន ធ្វើជាអ្នកកាន់ទុក្ខដោយ
ស្លៀកពាក់បែបកាន់ទុក្ខ ឥតលាយប្រេងឡើយ[ឃ] គឺឱ្យធ្វើដូច
ស្ត្រីដែលបានកាន់ទុក្ខខ្មោចស្លាប់ជាយូរមកហើយ ៣រួចចូល
ទៅគាល់ស្តេចទូលយ៉ាងដូច្នេះ នោះយ៉ូអាប់[ង]ក៏បង្គាប់ពាក្យ
ឱ្យនិយាយ ។
៤កាលស្ត្រីពីក្រុងត្កូអានោះ បានចូលទៅចំពោះស្តេចក៏
ទំលាក់ខ្លួន ក្រាបចុះផ្កាប់មុខដល់ដី ថ្វាយបង្គំទូលថា បពិត្រ
ព្រះករុណា សូមទ្រង់ជួយខ្ញុំម្ចាស់ផង ៥នោះស្តេចទ្រង់សួរ

**១៣:៣១** ប ជន ១៤:៦
**១៣:៣៧** ផ ២សយ ៣:៣
**១៣:៣៩** ព ២សយ ១៤:១៣ ភ ២សយ ១២:១៩–២៣
**១៤:១** ក ២សយ ២:១៨
**១៤:២** ខ នហ ៣:៥ យរ ៦:១ អម ១:១ គ ២សយ ២០:១៦ ឃ នរ ៣:៣ អស ១:៦ **១៤:៣** ង ខ.១៩

ដែលជាម្តាយទីទៃ ហើយធ្វើខុសនឹងសីលធម៌ក្រម ។ ការអាក្រក់របស់អាំណូនចំពោះអាប់សាឡំម គឺជាបុត្រាច្បងរបស់ស្តេចដាវីឌ ដោយព្រោះគេប្រព្រឹត្តនូវអំពើអាក្រក់ក្នុងការរួមរក្សអសីលធម៌ និងអំពើឃាដកម្មដូចជាបិតារបស់ពួកគេដែរ គឺការដែលស្តេចដាវីឌបានធ្វើកាលពីមុននោះ ។ ក្នុងរឿងឃាដកម្មរបស់អាំណូន និងអាប់សាឡំម គឺមិនមែនគ្រាន់តែជាការសងសឹកក្នុងករណីរំលោភដល់ប្អូនស្រីរបស់ទ្រង់ប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ជាពិធីសាស្ត្រដើម្បីការពារតួនាទីមុខដំណែងដែលជាអ្នកស្នងរាជ្យ(មើល ៣:៣ ១៥:១–៦) ។ គីលាបគឺជាបុត្រាទី២របស់ដាវីឌ (៣:៣) ក៏បានសុគតតាំងពីកុមារភាព ។

**១៣:២៩** *លាកាត់* គឺនៅឯទីភ្នំសំរាប់អាណាចក្ររបស់ដាវីឌ (មើល ១៨:៩ ១ពវ ១:៣៣,៣៨,៤៤ មើលការពន្យល់ ១ពវ ១:៣៣) ។

**១៣:៣១** *ហែកព្រះពស្ត្ររួចផ្ទំនៅដី* គឺជាវិធីសាស្ត្រទូទៅមួយ ដែលបង្ហាញពីការទុក្ខសោកសៅ(មើល ខ.១៩ យស ៧:៦ ១ពវ ២១:២៧ នអ ៤:១,៣,យប ១:២០ ២:៨) ។

**១៣:៣៤** *តាមផ្លូវចង្កេះភ្នំ* ជាកន្លែងក្រុងពួកលេវីនៅផ្នែកខាងលើ និងខាងក្រោមក្នុងស្រុក ឬភូមិអេប្រាអិម(មើល យល ២១:២០,២២ ១រប ៧:២៤) មានចម្ងាយ ១៦ គ.ម ពីភូមិភាគខាងជើងយេរូសាឡិម (មើលការពន្យល់ នហ ២:១០) ។

**១៣:៣៧** *ឯតាលម៉ាលជាបុត្រាអាំមិហ៊ូតស្តេចស្រុកកេស៊ូរី* គឺជាជីតារបស់អាប់សាឡំម (មើល ៣:៣ និងការពន្យល់) ។

**១៣:៣៩** *ព្រះទ័យរឮកចង់ទៅឯអាប់សាឡំម* ដោយសារអាប់សាឡំមគឺជាជនភៀសខ្លួន ស្តេចដាវីឌបានបាត់បង់បុត្រាពីរអង្គ ។ ស្តេចដាវីឌដូចជាពុំអាចធ្វើអ្វីបាន ហើយគិតអ្វីក៏ពុំចេញ ព្រោះទ្រង់ធ្លាប់មានបាតដៃប្រលាក់ឈាម និងអាំណូន ។

**១៤:១** *រីឯយ៉ូអាប់ជាកូនសេរ៉ូយ៉ា* មើលការពន្យល់ ២:១៣ ១សយ ២៦:៦ ។ *ស្តេចមានព្រះទ័យនឹករឮកដល់អាប់សាឡំម* ការញែករវាងកំហឹង និងសេចក្តីស្រឡាញ់(ប្រហែលត្រឡប់ក្រោយវិញ)ដាវីឌចង់ធ្វើដំណើរទៅទីផ្សេងៗ។

**១៤:២** *នោះយ៉ូអាប់ក៏បង្គាប់* នោះយ៉ូអាប់ត្រូវបានគេលើកទឹកចិត្ត ដោយបានទាក់ទងនឹងរឿងនយោបាយក្នុងការមិនបានដោះស្រាយ ជម្លោះរវៀងដាវីឌ និងបុត្រាដែលទាក់ទងនឹងរាជបល្ល័ង្ក ។ ដោយព្យាយាមបួរដាវីឌយកលេសបង្កើតជារឿងរ៉ាវដើម្បីធ្វើឱ្យស្តេចដាវីឌបរាជ័យ (១២:១–៧ មើល ១ពវ ២០:៣៨–៤៣) ។

ថា តើវាថ្វី នាងទូលឆ្លើយថា ឱហ្ន៎ព្រះអង្គអើយខ្ញុំម្ចាស់នេះ
ជាស្រីមេម៉ាយប្ដីបានស្លាប់ចោលទៅហើយ ៦ហើយខ្ញុំម្ចាស់
ជាអ្នកបំរើទ្រង់ មានកូនប្រុស២ វាឈ្លោះគ្នានៅឯចំការ
ឥតមានអ្នកណានឹងញែកចេញពីគ្នាឡើយ ហើយ១បាន
វាយ១ស្លាប់ទៅ ៧ឥឡូវនេះ ញាតិសន្តានទាំងអស់បានលើក
គ្នាមកទាស់នឹងខ្ញុំម្ចាស់ ជាអ្នកបំរើទ្រង់ដោយថា ចូរប្រគល់
អា១ដែលសំឡាប់បងខ្លួនមកឱ្យយើងសំឡាប់ចោល[ច] ឱ្យធួន
នឹងជីវិតរបស់បង ដែលវាបានសំឡាប់នោះចុះ យើងនឹង
សំឡាប់ ទាំងអ្នកដែលត្រូវស៊ីមរដកនេះទៅផង[ឆ] ដូច្នេះគេ
នឹងពន្លត់រងើកភ្លើងរបស់ខ្ញុំម្ចាស់ ដែលនៅសល់នេះ[ជ] ឥត
ទុកឱ្យប្ដីខ្ញុំម្ចាស់មានឈ្មោះមានពូជពង្សសល់ នៅលើផែនដី
ឡើយ ។
៨ស្ដេចទ្រង់មានបន្ទូលទៅស្ត្រីនោះថា ចូរទៅផ្ទះចុះ[ឈ]
យើងនឹងបង្គាប់ពីដំណើរនាង ៩នោះស្ត្រីពីក្រុងត្កូអា នាង
ទូលថា ឱទ្រង់ព្រះករុណា ជាព្រះអម្ចាស់នៃខ្ញុំម្ចាស់អើយ
សូមឱ្យសេចក្ដីទុច្ចរិតនេះ[ញ] នៅលើខ្ញុំម្ចាស់ និងពូជពង្សនៃ
ឪពុករបស់ខ្ញុំម្ចាស់ចុះ[ដ] ហើយសូមឱ្យព្រះករុណា និងរាជ្យ
ទ្រង់បានឥតទោសឡើយ[ឋ] ១០ស្ដេចទ្រង់មានបន្ទូលថា បើអ្នក
ណានិយាយអ្វីនឹងនាង នោះចូរនាំគេ មកឯយើងយ៉ាងនោះ
គេនឹងមិនហ៊ានពាល់នាងទៀតទេ ១១រួចនាងទូលថា សូម
ទ្រង់ព្រះករុណានឹកចាំពីព្រះយេហូវ៉ា ជាព្រះនៃទ្រង់ដើម្បីកុំ
ឱ្យអ្នកដែលសងសឹក[ឌ]នឹងឈាម មកបំផ្លាញទៀតឡើង ក្រែង
គេសំឡាប់កូនរបស់ខ្ញុំម្ចាស់ នោះទ្រង់មានបន្ទូលថា យើង
ស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅថា នឹង
គ្មានសក់១សរសៃ[ឍ]ជ្រុះពីក្បាលរបស់កូននាងចុះដល់ដី
ឡើយ[ណ] ។
១២ស្ត្រីនោះក៏ទូលថា សូមទ្រង់ព្រះករុណាអនុញ្ញាឱ្យខ្ញុំ
ម្ចាស់ ជាអ្នកបំរើទ្រង់ បានទូល១ម៉ាត់សិន រួចទ្រង់មាន
បន្ទូលថា ចូរនិយាយចុះ ១៣ដូច្នេះស្ត្រីនោះក៏ទូលសួរថា បើ
យ៉ាងនោះ ហេតុអ្វីបានជាទ្រង់ បង្កើតការយ៉ាងនេះទាស់
នឹងរាស្ត្ររបស់ព្រះវិញ ដ្បិតដែលទ្រង់មានបន្ទូលដូច្នេះ
នោះទ្រង់ក៏ដូចជាអ្នកមានទោសដែរ[ត] ដោយព្រោះទ្រង់
មិននាំអ្នកដែលទ្រង់បានទិរទេសទៅឱ្យមកវិញ[ថ] ១៤ឯយើង
រាល់គ្នាត្រូវតែស្លាប់ជាមិនខាន[ទ] ហើយយើងរាល់គ្នាក៏ដូច
ជាទឹក[ធ]ដែលកំពប់ខ្ចាយទៅលើដី នឹងប្រមូលមកវិញមិនបាន
ឡើយ ឯព្រះទ្រង់មិនកាត់ជីវិតចេញទេ គឺទ្រង់បង្កើតផ្លូវណា
មួយ ដើម្បីឱ្យអ្នកដែលត្រូវនិរទេស[ន] មិនត្រូវកាត់ចេញពី
ទ្រង់ នៅជាងរាបវិញ ១៥ឥឡូវនេះ ដែលខ្ញុំម្ចាស់មកក្រាប
ទូលពាក្យទាំងនេះ ដល់ព្រះករុណា ជាព្រះអម្ចាស់ នោះគឺពី
ព្រោះបណ្ដាជនបានធ្វើឱ្យខ្ញុំម្ចាស់ភិតភ័យ ដូច្នេះ ខ្ញុំម្ចាស់
ជាអ្នកបំរើទ្រង់ បានសំរេចនឹងមកទូលដល់ព្រះករុណា
ដោយស្មានថា ប្រាកដជាទ្រង់នឹងធ្វើសំរេចតាមពាក្យសំណូម

**១៤:៧** ច ជន ៣៥:១៩ ឆ មថ ២១:៣៨ ជ ចទ ១៩:១០–១៣
**១៤:៨** ឈ ១សយ ២៥:៣៥
**១៤:៩** ញ ១សយ ២៥:២៤ ដ មថ ២៧:២៥ ឋ ១សយ ២៥:២៨
**១៤:១១** ឌ ជន ៣៥:១២,២១ ឍ មថ ១០:៣០ ណ ១សយ
**១៤:១៣** ត ២សយ ១២:៧ ១ពវ ២០:៤០ ថ ២សយ ១៣:៣៨–៣៩
**១៤:១៤** ទ យប ១០:៨ ១៧:១៣ ៣០:២៣ ទដ ២២:១៥ ហព ៩:២៧ ធ យប ១៤:១១ ទដ ៥៨:៧ អស ១៩:៥ ន ជន ៣៥:១៥,២៥–២៨

**១៤:៧** *ញាតិសន្តានទាំងអស់បានលើកគ្នា មកទាស់នឹងខ្ញុំម្ចាស់ ជាអ្នកបំរើទ្រង់* វាគឺជាទំនៀមទម្លាប់ក្នុងស្រុកអ៊ីស្រាអែល ចំពោះជនរងគ្រោះដោយឃាដកម្ម គឺត្រូវយកឃាដករនោះមកសម្លាប់ ដោយឈាមសងដោយឈាម ។ មើលការពន្យល់ ៣:២៧ មើល ៣៥:១២ ចទ ១៩:១១–១៣) ។ ក្នុងករណីរដែលបានបង្ហាញថា តើត្រូវសងសឹកឈាមដោយឈាម គឺដោយសម្លាប់មួយពូជទាំងគ្រួសារជួនកាលច្បាប់រាស្ត្រអ៊ីស្រាអែល និងប្រពៃណីដែលគេព្យាយាមបំភ្លេចជៀសវាងគ្រប់ការទាំងអស់ មើលការពន្យល់ ចទ ២៥:៥–៦ នរ ២:២០ ។ *យើងនឹងសំឡាប់ទាំងអ្នកដែលត្រូវស៊ីមរដកនេះទៅផង* ស្ត្រីសន្មតថាការជំរុញឱ្យមានការសងសឹកដោយឈាម គឺជាការសម្រេចចិត្តដ៏អាក្រក់មួយដើម្បីទទួលមរដកគ្រួសារ ប្រសើរជាងចង់បានភាពយុត្តិធម៌(មើល ជន ២៧:១១) ។ *ឥតទុកឱ្យប្ដីខ្ញុំម្ចាស់មានឈ្មោះមានពូជពង្សសល់* ភាពទាក់ទងទាំងនេះគឺអំពើបទល្មើស ដើម្បីបញ្ជាក់ត្រកូលគ្រួសាររបស់ស្ត្រី ។

**១៤:៨** *យើងនឹងបង្គាប់ពីដំណើរនាង* សកម្មភាពដ៏ពិនិត្យពិចៃរបស់ស្ដេចដាវីឌ អាចឱ្យទ្រង់បានទទួលសម្រាក់នៅស្រុកដ៏ល្អ ដែលអ្នកធ្វើការអាក្រក់នោះមិនបានដឹងជាមុនឡើយ (មើល ចទ ១៩:៤–៦) ។

**១៤:១១** *សូមទ្រង់ព្រះករុណានឹកចាំពីព្រះយេហូវ៉ាជាព្រះនៃទ្រង់* ស្ត្រីចង់ឱ្យស្ដេចដាវីឌប្រកាស់នូវព្រះបន្ទូលសន្យាផងទ្រង់ ដោយការស្បថក្នុងព្រះនាមព្រះយេហូវ៉ា ។ *ដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ* គឺជាវិធីប្រើពាក្យស្បថស្បែរ (មើលការពន្យល់ លប ៤២:១៥ ១សយ ១៤:៣៩,៤៥) ដែលភ្ជាប់នឹងភាពប្តូរផ្តាច់របស់ដាវីឌ ។

**១៤:១៣** *ទាស់និងរាស្ត្ររបស់ព្រះវិញ្ញាណ* សេចក្ដីស្នើររបស់ស្ត្រី គឺមើលដាវីឌបានធ្វើការនេះចំពោះរាស្ត្រអ៊ីស្រាអែល ដូចជាគ្រួសារនាងបានធ្វើចំពោះរូបនាង ។ សាសន៍អ៊ីស្រាអែលចង់ឱ្យស្ដេចគ្រងរាជរបស់គេឱ្យត្រឡប់មកដោយសុវត្ថិភាពមកដល់ពួកគេ ។ *នោះទ្រង់ក៏ដូចជាអ្នកមានទោសដែរ* ការមានជម្លោះពេលស្ដេចដាវីឌបានរួចផុតពីអ្នកសងសឹកដែលពុំពិត ដោយឈាមសងដោយឈាម គឺទ្រង់ក្នុងលំដាប់អ្នកសងសឹកដ៏មានឥទ្ធិពលគឺភាពឃោរឃៅរបស់ទ្រង់ដោយមិនធ្វើដដែលៗ ដូចជាក្នុងករណីអាប់សាឡំម ។ គឺមានភាពខ្លះស្ដេចដាវីឌស្ថិតក្នុងមុនងារជាអ្នកសងសឹកដោយឈាម ។

**១៤:១៤** *ក៏ដូចជាទឹកដែលកំពប់ខ្ចាយទៅលើដី* ការសងសឹកឈាមដោយឈាម មិនមែនបានន័យថាអ្នករងគ្រោះនោះដល់ស្លាប់ទេ ។ កាលដែលថាទឹកដែលកំពប់ខ្ចាយទៅលើដី នោះក៏ពុំអាចឱ្យទឹកនោះវិលត្រឡប់មកវិញបានដែរ ។ *ឯព្រះទ្រង់មិនកាត់ជីវិតចេញទេ* ក្នុងសេចក្ដីសន្និដ្ឋាននេះ ជាការសងសឹកឈាមដោយឈាម គឺមិនមែនផ្លូវរបស់ព្រះដែលធ្វើមកលើរាស្ត្រទ្រង់នោះទេ ស្ត្រីបានបំផ្លាញសេចក្ដីបង្រៀនព្រះបន្ទូលរបស់ព្រះ (មើលការពន្យល់ លប ៩:៦)។ ប៉ុន្តែនាងបានស្ថិតនៅក្នុងសេចក្ដីមេត្តាករុណានៃព្រះជាអម្ចាស់ ។ (មើល អរ ១៨:៣២ ២៣:១១ និងការពន្យល់) ។

**១៤:១៥** *បណ្ដាជនបានធ្វើឱ្យខ្ញុំម្ចាស់ភិតភ័យ* ស្ត្រីបានត្រឡប់ជារឿងប្រឌិតផ្ទាល់ខ្លួនរបស់នាង"បណ្ដាជន"ដែលជាបន្ទាល់នឹងភ្នែក គឺក្នុងគ្រួសារនាង

របស់ខ្ញុំម្ចាស់ ជាអ្នកបំរើទ្រង់ជាមិនខាន ១៦ដ្បិតមុខជាទ្រង់
នឹងស្តាប់តាម ដើម្បីនឹងប្រោសឱ្យអ្នកបំរើទ្រង់ រួច
ពីកណ្តាប់ដៃនៃមនុស្ស ដែលចង់បំផ្លាញទាំងខ្ញុំម្ចាស់ និង
កូនខ្ញុំម្ចាស់ឱ្យបាត់ពីមរដក[ប]នៃព្រះទៅផង ១៧នោះខ្ញុំម្ចាស់
ជាអ្នកបំរើទ្រង់បាននឹកថា ព្រះបន្ទូលនៃព្រះករុណាជា
ព្រះអម្ចាស់នឹងបានស្រួល ពីព្រោះទ្រង់ព្រះករុណាជា
ព្រះអម្ចាស់ ទ្រង់ដូចជាទេវតា[ផ]នៃព្រះហើយ ដើម្បីនឹង
ពិចារណា[ព] ឱ្យជ្រាបខុសត្រូវ ហើយព្រះយេហូវ៉ា ជាព្រះនៃ
ទ្រង់ ក៏គង់ជាមួយនឹងទ្រង់ដែរ ។
១៨នោះស្តេចទ្រង់មានបន្ទូលនឹងស្ត្រីនោះថា កុំឱ្យលាក់អ្វី
ចំពោះសេចក្តីនេះដែលយើងសួរនាងឡើយ នាងទូលតប
ថា សូមទ្រង់ព្រះករុណា ជាព្រះអម្ចាស់ មានបន្ទូលឥឡូវ
នេះចុះ ១៩នោះស្តេច មានបន្ទូលសួរថា ឯសេចក្តីទាំងនេះ
តើមិនមែនយ៉ូអាប់[ភ] ដែលរួមគំនិតជាមួយនឹងនាងទេឬអី
ស្ត្រីនោះទូលឆ្លើយថា ខ្ញុំម្ចាស់ស្បថដោយ នូវព្រះជន្មនៃទ្រង់
ព្រះករុណាជាព្រះអម្ចាស់ថា គ្មានអ្នកណាអាចនឹងគេចទៅ
ខាងឆ្វេង ឬទៅខាងស្តាំ ចេញពីគ្រប់ទាំងសេចក្តីដែលទ្រង់
ព្រះករុណា ជាព្រះអម្ចាស់ បានមានបន្ទូលនោះឡើយ គឺ
យ៉ូអាប់ជាអ្នកបំរើនៃទ្រង់ហើយ ដែលបានបង្គាប់មកខ្ញុំម្ចាស់
ព្រមទាំងបញ្ចេះពាក្យទាំងអស់នេះដល់ខ្ញុំម្ចាស់ ជាអ្នកបំរើ
ទ្រង់ផង ២០យ៉ូអាប់ជាអ្នកបំរើទ្រង់ បានធ្វើដូច្នេះ ដើម្បីនឹង
បំផ្លាស់ភាពនៃដំណើរនេះទៅ ហើយព្រះអម្ចាស់ទ្រង់មាន
បញ្ញា[ម] ដូចជាទេវតានៃព្រះ អាចនឹងជ្រាបគ្រប់ទាំងអស់
ដែលនៅផែនដីបាន[យ]។
២១រួចពីនោះមក ស្តេចទ្រង់មានបន្ទូលនឹងយ៉ូអាប់ថា
មើលការនេះ យើងបានអនុញ្ញាហើយ ដូច្នេះចូរទៅនាំ
អាប់សាឡំម ជាកូនប្រុសយើងមកវិញចុះ ២២នោះយ៉ូអាប់ក៏
ទំលាក់ខ្លួនក្រាបផ្កាប់មុខដល់ដីថ្វាយបង្គំ ព្រមទាំងសូមពរ
ថ្វាយដល់ស្តេច[រ] ហើយទូលថា បពិត្រព្រះករុណាជា ព្រះ
អម្ចាស់នៃទូលបង្គំអើយ នៅថ្ងៃនេះ ទូលបង្គំដឹងថា ទូលបង្គំ
ជាបាវបំរើទ្រង់ បានប្រកបដោយព្រះគុណនៃទ្រង់ហើយ
ដោយទ្រង់បានធ្វើតាមសេចក្តីសំណូមរបស់ទូលបង្គំ ជា
បាវបំរើទ្រង់ ២៣ដូច្នេះ យ៉ូអាប់ក៏រៀបចំឡើងទៅឯស្រុក
កេស៊ូរី នាំអាប់សាឡំមមកឯក្រុងយេរូសាឡិមវិញ ២៤តែ
ស្តេចមានបន្ទូលប្រាប់ថា ចូរឱ្យវាត្រឡប់ទៅ ឯលំនៅវាទៅ
កុំឱ្យមកឃើញមុខអញឡើយ ដូច្នេះ អាប់សាឡំមក៏វិលទៅឯ
ដំណាក់ទ្រង់វិញទៅ ឥតបានឃើញព្រះភ័ក្ត្រស្តេចទេ ។
២៥រីឯនៅក្នុងពួកអ៊ីស្រាអែលទាំងអស់គ្នា គ្មានអ្នកណា
ដែលគួរសរសើរ ឱ្យស្មើនឹងអាប់សាឡំម ពីដំណើរទ្រង់
មានរូបល្អនោះទេ ដ្បិតចាប់តាំងពីផ្ទៃព្រះបាទ រហូតដល់
កំពូលព្រះសិរទ្រង់ នោះឥតមានខ្ចោះត្រង់ណាសោះ ២៦រីឯ
ព្រះកេសា លុះដល់ចុងឆ្នាំទ្រង់ក៏កាត់ចេញ[ល] ពីព្រោះធ្ងន់
ណាស់ដល់ទ្រង់ ហេតុនេះបានជារាល់តែឆ្នាំ ទ្រង់តែងកាត់
ចេញ ហើយតាមដំឡឹងហ្លួង ឃើញមានទំងន់២០០ដំឡឹង
២៧អាប់សាឡំមបង្កើតបានបុត្រា[វ]៣អង្គ និងបុត្រី១អង្គ នាម
នាងតាម៉ារ[ស] នាងនោះជាស្ត្រីមានរូបល្អស្រស់ ។
២៨អាប់សាឡំម ទ្រង់គង់នៅក្រុងយេរូសាឡិម ពេញ២ឆ្នាំ
ឥត ដែលឃើញព្រះភ័ក្ត្រស្តេចឡើយ ២៩រួចមកទ្រង់ចាត់គេ
ឱ្យទៅហៅយ៉ូអាប់មក ដើម្បីឱ្យលោកទៅគាល់ស្តេច តែ
លោកមិនព្រមមកទេ ទ្រង់ក៏ចាត់គេទៅម្តងទៀតតែលោក
មិនព្រមមកសោះឡើយ ៣០ហេតុនោះបានជាអាប់សាឡំម
បង្គាប់ដល់ពួកបាវបំរើទ្រង់ថា មើលន៍ ស្រែរបស់យ៉ូអាប់
នៅជាប់នឹងស្រែយើង មានទាំងស្រូវឱក[ហ]ផងចូរដុតចោល
ទៅ ពួកបាវបំរើរបស់ទ្រង់ក៏ទៅដុតស្រែនោះ ៣១ដូច្នេះ
យ៉ូអាប់ក៏ក្រោកឡើង ចូលទៅឯអាប់សាឡំម នៅក្នុងលំនៅ
ទ្រង់សួរថា ហេតុអ្វីបានជាបាវរបស់ទ្រង់បានដុតស្រែរបស់

**១៤:១៦** ប នក ៣៤:៩ ១សយ ២៦:១៩
**១៤:១៧** ផ ១សយ ២៩:៩ ព ១ពវ ៣:៩ ដយ ២:២១
**១៤:១៩** ភ ខ.៣
**១៤:២០** ម ១ពវ ៣:១២,២៨ ១០:២៣–២៤ អស ២៨:៦ យ ២សយ ១៨:១៣
**១៤:២២** រ លប ៤៧:៧
**១៤:២៦** ល ២សយ ១៨:៩
**១៤:២៧** វ ២សយ ១៨:១៨ ស ២សយ ១៣:១
**១៤:៣០** ហ នក ៩:៣១

នោះកំពុងរកវិធីសងសឹក ។
**១៤:១៧** *ទ្រង់ដូចជាទេវតានៃព្រះហើយ* ដើម្បីនឹងពិចារណាឱ្យជ្រាបខុសត្រូវ (មើល ខ. ២០ ១៩:២៧) ។
**១២:២១** *យ៉ូអាប់* ជាអ្នកដែលមានវត្តមានគ្រប់ពេល គឺពីដើមដល់ចប់ ។
**១៤:២៣** *យ៉ូអាប់ក៏រៀបចំឡើងទៅឯស្រុកកេស៊ូរី* មើល ១៣:៣៧ ។
**១៤:២៤** *កុំឱ្យមកឃើញមុខអញឡើយ* ស្តេចដាវីឌនៅតែប្រែប្រួលចិត្តយោបល់ (មើលការពន្យល់ ខ.១) ជារឿយៗទ្រង់មិនបានអត់ទោសឱ្យអ្នកណាទេហើយក៏គ្មានការផ្សះផ្សាដែរ ។
**១៤:២៥** *គ្មានអ្នកណាដែលគួរសរសើរ* ភាពសង្ហារបស់អាប់សាឡំម បាននាំឱ្យមានភាពចាប់អារម្មណ៍ និងប្រជាប្រិយភាព ហើយមិនយូរប៉ុន្មាន ។
**១៤:២៦** *ទ្រង់តែងកាត់ចេញ* ប្រជាជនក្នុងពេលនោះសក់ គឺជាសញ្ញាពីភាពរឹងមាំ ។ ព្រះមហាក្សត្រ និងវិរៈបុរសមួយចំនួន ជារឿយៗមានសណ្ឋានដូចជាភាពគំនួរ ដែលមានថ្នាក់សក់ជាច្រើន ខណៈពេលដែលទំពែកគឺហាក់ដូចជាធ្វើឱ្យអាប់យស់(មើល ២ពវ ២:២៣ និងការពន្យល់) ។ ក្នុងផ្នែកនេះក៏ដូច្នេះដែរគឺស្តេចអាប់សាឡំម ដែលជាបុត្រាហាក់ដូចជាមានទិសដៅឆ្ពោះទៅរកគ្រងរាជ្យ ។ *ហើយតាមដំឡឹងហ្លួង* គឺជាប្រាក់កាក់រាជវង្សដែលមានទម្ងន់ធ្ងន់ជាងប្រាក់កាក់បរិសុទ្ធ(មើល នក ៣០:១៣) ។
**១៤:២៧** *បុត្រា៣អង្គ* ពុំមានព្រះឱ្យបានស្គាល់ទេ យើងសន្មតថាទ្រង់ទាំង៣អង្គនេះបានសុគតតាំងពីកុមារភាព ១៨:១៨ ។ *តាម៉ារ* អាប់សាឡំមបានដាក់ព្រះនាមបុត្រីរបស់ផងទ្រង់បន្ទាប់ពីប្អូនស្រីទ្រង់ (១៣:១) ។ *នាងម្អាកា* (មើល ១ពវ ១៥:២ និងការពន្យល់) គឺជាបងប្អូនស្រីៗរបស់តាម៉ារ និងគឺជាយាយរបស់អាប់សាឡំម (មើលការពន្យល់ ១រប ១១:២០) ។

ទូលបង្គំដូច្នេះ[ឬ] ៣២ អាប់សាឡំមទ្រង់ឆ្លើយថា មើល យើង
បានចាត់គេឱ្យទៅហៅអ្នកមក ដើម្បីឱ្យអ្នកទៅទូលសួរ
ស្ដេចថា ដែលទូលបង្គំមកពីស្រុកកេស៊ូរី[អ] នោះតើមាន
ប្រយោជន៍អ្វី ស៊ូឱ្យទូលបង្គំបាននៅទីនោះល្អជាង ដូច្នេះ ឱ្យ
យើងទៅគាល់ស្ដេចឥឡូវ បើយើងមានទោសខុសអ្វី នោះ
សូមឱ្យទ្រង់សំឡាប់យើងចុះ[ក] ៣៣ យ៉ូអាប់ក៏ចូលទៅទូលដល់
ស្ដេច រួចកាលលោកបានហៅអាប់សាឡំមមក នោះទ្រង់ក៏
ចូលទៅគាល់ស្ដេច ឱនព្រះអង្គក្រាបព្រះភ័ក្ត្រចុះដល់ដី នៅ
ចំពោះទ្រង់ រួចស្ដេចទ្រង់ក៏ថើប[ខ]អាប់សាឡំម ។

## គម្រោងការក្បត់របស់អាប់សាឡំម

**១៥** ១ រួចអំពីនោះមក[ក] អាប់សាឡំមទ្រង់ចាត់ចែងរទេះ[ខ]
នឹងសេះ ហើយមនុស្ស៥០នាក់ សំរាប់រត់ខាងមុខទ្រង់
២ ទ្រង់ក៏តែងតើនឡើងពីព្រលឹម យាងទៅឈរនៅមាត់ថ្នល់
ដែលចូលតាមទ្វារក្រុង[គ] បើកាលណាមានអ្នកណាមានក្ដី
ដែលត្រូវបញ្ជូនទៅថ្វាយស្ដេចឱ្យជំនុំជំរះ នោះអាប់សាឡំម
ទ្រង់ហៅអ្នកនោះមកសួរថា អ្នកមកពីស្រុកណា គេទូល
ឆ្លើយថា ទូលបង្គំជាអ្នកបំរើនៃទ្រង់ មកពីពូជអំបូរណាមួយ
ក្នុងសាសន៍អ៊ីស្រាអែល ៣ ទើបអាប់សាឡំមមានបន្ទូលថា
មើល ដំណើររឿងរបស់អ្នកជាល្អត្រឹមត្រូវហើយ តែស្ដេច
មិនបានតាំងអ្នកណា ឱ្យស្ដាប់រឿងអ្នកទេ[ឃ] ៤ អាប់សាឡំមក៏
មានបន្ទូលថែមទៀតថា ឱបើយើងបានធ្វើជាចៅហ្វាយ
នៅក្នុងនគរនេះទៅអេះ នោះអស់អ្នក[ង]ណាដែលមានរឿង
មានក្ដីនឹងបានមកឯយើង ហើយយើងនឹងជំនុំជំរះ ឱ្យគេ
តាមយុត្តិធម៌ ៥ នៅគ្រានោះ បើមានអ្នកណាមកថ្វាយបង្គំ
ដល់ទ្រង់ នោះទ្រង់ក៏លូកព្រះហស្តទៅចាប់ទាញមកថើប
អ្នកនោះ ៦ អាប់សាឡំមទ្រង់តែងប្រព្រឹត្តយ៉ាងនេះ ដល់ពួក
អ៊ីស្រាអែលទាំងអស់គ្នា ដែលនាំរឿងមកថ្វាយស្ដេចឱ្យជំនុំ
ជំរះ ដូច្នេះ ទ្រង់បានទាក់ចិត្ត[ច]ពួកជនជាតិអ៊ីស្រាអែលទាំង
ឡាយ ។

៧ គ្រាកន្លងដល់ចុងឆ្នាំទី៤០ នោះអាប់សាឡំមទូលស្ដេច
ថា សូមទ្រង់អនុញ្ញាតឱ្យទូលបង្គំទៅឯស្រុកហេប្រុនដើម្បី
នឹងលាបំណន់ ដែលទូលបង្គំបានបន់ដល់ព្រះយេហូវ៉ា ៨ ដ្បិត
កាលទូលបង្គំ ជាអ្នកបំរើទ្រង់ នៅស្រុកកេស៊ូរី[ឆ]អើរ៉ាម
នៅឡើយ នោះទូលបង្គំបានបន់ទុកថា[ជ] បើកាលណា
ព្រះយេហូវ៉ានាំទូលបង្គំ ត្រឡប់មកឯក្រុងយេរូសាឡិមវិញ
នោះទូលបង្គំនឹងប្រតិបត្តិដល់ព្រះយេហូវ៉ា ៩ ដូច្នេះស្ដេចទ្រង់
មានបន្ទូលថា ចូរទៅដោយសុខសាន្តចុះ នោះទ្រង់ក៏ក្រោក
ឡើងទៅឯក្រុងហេប្រុន ១០ រួចចាត់មនុស្សឱ្យទៅពេញក្នុង
ពូជអំបូរអ៊ីស្រាអែលទាំងប៉ុន្មាន ប្រាប់ដោយសំងាត់ថា
កាលណាឮសូរផ្លុំត្រែ[ឈ] នោះត្រូវស្រែកប្រកាស ឡើងថា
អាប់សាឡំម ទ្រង់បានសោយរាជ្យ នៅក្រុងហេប្រុនហើយ
១១ មានមនុស្ស២០០នាក់ចេញពីក្រុងយេរូសាឡិម ទៅជា
មួយនឹងអាប់សាឡំម ទ្រង់បានអញ្ជើញគេទៅ គេក៏ទៅ
ដោយចិត្តត្រង់ ឥតដឹងការអ្វីឡើយ ១២ ហើយកំពុងដែល

**១៤:៣១** ឡ ពច ១៥:៥
**១៤:៣២** អ ២សយ ៣:៣ ក ១សយ ២០:៨
**១៤:៣៣** ខ លក ១៥:២០
**១៥:១** ក ២សយ ១២:១១ ខ ១សយ ៨:១១
**១៥:២** គ លប ២៣:១០ ២សយ ១៩:៨
**១៥:៣** ឃ សភ ១២:២
**១៥:៤** ង ពច ៩:២៩
**១៥:៦** ច រម ១៦:១៨
**១៥:៨** ឆ ២សយ ៣:៣ ជ លប ២៨:២០
**១៥:១០** ឈ ១ពវ ១:៣៤,៣៩ ២ពវ ៩:១៣

**១៤:៣២** *បើយើងមានទោសខុសអ្វីនោះសូមឱ្យទ្រង់សំឡាប់យើងចុះ* អាប់សាឡំមទោះជាស្លាប់ឬរស់ក៏ទ្រង់នៅតែពោលពាក្យ គោរពសុំទោសនិងការលន់តួបាប ។

**១៤:៣៣** *រួចស្ដេចដាវីឌទ្រង់ក៏ថើបអាប់សាឡំម* គឺជាសញ្ញានៃការអត់ទោសបាបឱ្យនិងការផ្សះផ្សាឡើងវិញរវាងអាប់សាឡំម និងក្រុមគ្រួសារាជវង្ស ។ ដូចជាស្ដេចដាវីឌបានជៀសវាងការទាំងអស់នោះ គឺស្របតាមបទទំនាយនៃហោរានាថាន់ (មើល ១២:១០–១១ និងការពន្យល់) ។

**១៥:១** *រួចអំពីនោះមក* មើលការពន្យល់ ២:១ ។ *រទេះនឹងសេះ* តាមតែការដែលដឹងមក អាប់សាឡំមគឺជាអ្នកដឹកនាំរាស្ត្រអ៊ីស្រាអែលដំបូងបង្អស់ ដោយមានរទេះ និងសេះ (ប្រៀបធៀប ចទ ១៧:១៦) ។ *មនុស្ស៥០នាក់* គេមាននាទីដូចជាអង្គរក្ស និងផ្ដល់ជាអទិភាពដ៏មហាសាល ។ អាប់សាឡំម គឺជាបងប្រុសរបស់អ័ដូនីយ៉ា (មើល ១ពវ ១:៥ និងការពន្យល់) ។

**១៥:២** ផ្លូវក្លោងទ្វារចូលទៅទីក្រុង គឺជាផ្នែកឯកសិទ្ធិដែលគេរៀបចំឡើង (លប ១៩:១ នរ ៤:១) ។

**១៥:៣** *មើលដំណើររឿងរបស់អ្នកជាល្អត្រឹមត្រូវហើយ* អាប់សាឡំម ក៏រកការគាំទ្រដល់ខ្លួនពីប្រជាជន គឺការគាំទ្រនូវសេចក្ដីទុក្ខព្រួយរបស់ពួកគេ ។

**១៥:៤** *ឱបើយើងបានធ្វើជាចៅហ្វាយនៅក្នុងនគរនេះទៅអេះ* អាប់សាឡំមបានបង្ហាញខ្លួនឯងដូចជាដំណោះស្រាយ ចំពោះការទុក្ខសោកមួយរបស់ប្រជាជន ។ ក្នុងករណីដែលអាំណូនគាត់បាននាំបញ្ហាចូលទៅទឹកដីផ្ទាល់ខ្លួនរបស់គាត់ គឺដោយព្រោះតែការប្រព្រឹត្តខុសរបស់មាតារបស់គាត់ គាត់បានយល់ហើយក៏ឃើញភាពខ្សោយរបស់ឪពុករបស់គាត់ក្នុងការគ្រងរាជ្យ ។

**១៥:៧** *ឆ្នាំទី៤០* បន្ទាប់ពីអាប់សាឡំមត្រឡប់ទៅថែចង់ (១៤:៣៣) បើគិតទៅគាត់បានអាយុ៣០ឆ្នាំហើយ ។ ដូច្នេះការប្រឆាំងបះបោររបស់គាត់ត្រូវតែកំណត់នៅមុនទសវត្សរ៍ចុងក្រោយ នៃរជ្ជកាលគ្រងរាជរបស់ស្ដេចដាវីឌ ។ *ក្រុងហេប្រុន* គឺជាទីដែលស្ដេចដាវីឌបានគេប្រកាសឱ្យធ្វើជាស្ដេច (មើលការពន្យល់ ២:១,៤ ៥:៣,៥) ជាទីកន្លែងអាប់សាឡំមបានកើត (៣:២–៣) ។ អាប់សាឡំមអាចមានហេតុផលដើម្បីជឿថា គាត់អាចនិងពឹងលើភាពថ្នាំងថ្នាក់ពីខាងក្នុងខ្លះពីរឿងការផ្លាស់ប្ដូរស្ដេចដាវីឌ នៃរដ្ឋធានីទៅក្នុងយេរូសាឡិមក្រុងហេប្រុន ក៏ជាផ្នែកមួយនៃទីកន្លែងបរិសុទ្ធដ៏សំខាន់ ។ *ដើម្បីលាបំណន់ដែលទូលបង្គំបានបន់ដល់ព្រះយេហូវ៉ា* អាប់សាឡំមបានកុហកដល់បិតារបស់ខ្លួនដើម្បីឱ្យបិតាទ្រង់មានការចាប់អារម្មណ៍ ពីការពិតរបស់គាត់ : ប្រៀបធៀបការចាប់អារម្មណ៍របស់ស្ដេចដាវីឌ ក្នុងរឿងរ៉ាវរបស់អ៊ូរី (១១:៧–១៥) ។

**១៥:៨** *ស្រុកកេស៊ូរី* មើល ១៣:៣៧ ។

**១៥:១២** *អ័ហ៊ីថូផែល* គឺជាជីតារបស់នាងបាតសេបា (មើល ១១:៣,២៣:៣៤ និងការពន្យល់) ហើយគាត់ជាអ្នកមានចំណេះដឹងគួឱ្យគោរព (១៦:២៣) ។

អាប់សាឡំុមថ្វាយយញ្ញបូជានោះទ្រង់ ក៏ចាត់គេ ឱ្យទៅហៅ
អ័ហ៊ីថូផែល[ញ] ជាអ្នកស្រុកគីឡោ ដែលជាបុរោហិតរបស់
ដាវីឌ[ដ] ឱ្យមកពីគីឡោ[ឋ] ជាក្រុងរបស់ខ្លួនដែរ ការក្បត់នេះ
ក៏បានកើតកាន់តែខ្លាំងឡើង ដ្បិតមានប្រជាជនចុះចូលខាង
អាប់សាឡំុម រឹតតែច្រើនឡើង[ឌ]។

### ស្តេចដាវីឌភាសខ្លួន

១៣គ្រានោះមានម្នាក់នាំដំណឹងមកក្រាបទូលដាវីឌថា
ពួកជនជាតិអ៊ីស្រាអែលទាំងអស់គ្នា មានចិត្តនិយមទៅតាម
អាប់សាឡំុមហើយ ១៤ដូច្នេះ ដាវីឌទ្រង់មានបន្ទូលទៅពួក
មហាតលិកទ្រង់ទាំងប៉ុន្មាន ដែលនៅក្រុងយេរូសាឡិម ជា
មួយនឹងទ្រង់ថា ចូរយើងនាំគ្នារត់ចេញទៅ[ឍ] ពុំនោះ នឹង
គ្មានពួកយើងណាមួយ បានរួចពីអាប់សាឡំុមឡើយ[ណ] ចូរ
ប្រញាប់ប្រញាល់ចេញទៅចុះ ក្រែងលោវាមកទាន់ ធ្វើ
អាក្រក់ដល់យើងរាល់គ្នា ហើយប្រហារពួកក្រុងដោយ
មុខដាវ ១៥ពួកមហាតលិករបស់ស្តេចទូលថា បពិត្រ ព្រះ
ករុណា ទូលបង្គំរាល់គ្នាប្រុងប្រៀប នឹងធ្វើតាមតែព្រះ
ហឫទ័យព្រះអម្ចាស់នៃទូលបង្គំហើយ ១៦នោះស្តេចទ្រង់ក៏
យាងចេញទៅ ព្រមទាំងពួកវង្សានុវង្សទាំងអស់ផង បាន
ទុកនៅតែស្រីអ្នកម្នាង១០នាក់[ត] ឱ្យរក្សាដំណាក់ប៉ុណ្ណោះ
១៧ស្តេចទ្រង់យាងចេញទៅមានទាំងពួកទ្រង់ទាំងអស់
ដើរទៅតាម ឯទ្រង់ក៏ឈប់នៅត្រង់ផ្ទះដែលនៅទីបំផុត
១៨ហើយពួកមហាតលិក ទ្រង់ទាំងប៉ុន្មានគេដើរមកឈរអម
ទ្រង់ រួចពួកកេរេធីម[ថ] និងពួកពេលេធីមទាំងប៉ុន្មាន ព្រម
ទាំងពួកកាថ ចំនួន៦០០នាក់ ដែលបានមក តាមទ្រង់ពីក្រុង
កាថ គេក៏ដើរកាត់នៅចំពោះទ្រង់ទៅ ។
១៩ស្តេចទ្រង់មានបន្ទូលសួរអ៊ីតតាយ[ទ] ជាពួកក្រុងកាថថា
ហេតុអ្វីបានជាអ្នកមកជាមួយនឹងពួកយើងដូច្នេះ ចូរត្រឡប់
ទៅនៅជាមួយនឹងស្តេចចុះ ដ្បិតអ្នកជាសាសន៍ដទៃ[ធ] បាន
ត្រូវនិរទេសចោលស្រុករបស់ខ្លួនមក ដូច្នេះ ចូរវិលទៅ
វិញចុះ ២០ដែលអ្នកទើបនឹងមកពីម្សិលមិញ តើថ្ងៃនេះគួរឱ្យ
យើងនាំអ្នកមកដើរសាតព្រាត់[ន] ទៅជាមួយនឹងយើង ដែល
យើងក៏មិនដឹងជាទៅឯណាផងឬអី ចូរត្រឡប់ទៅវិញ
ហើយនាំបងប្អូនអ្នកទៅផង សូមឱ្យអ្នកបានប្រកបដោយ
សេចក្តីមេត្តាករុណា និងសេចក្តីពិតត្រង់[ប]ចុះ ២១តែអ៊ីតតាយ
ទូលតបថា ទូលបង្គំស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះ
ជន្មរស់នៅ នឹងទ្រង់ព្រះករុណា ជាព្រះអម្ចាស់នៃទូលបង្គំដ៏
មានព្រះជន្មាយុថា នៅកន្លែងណាដែលទ្រង់ ព្រះករុណាជា
ព្រះអម្ចាស់នៃទូលបង្គំគង់នៅ ទោះបើស្លាប់ ឬរស់ក្តី នោះ
ទូលបង្គំ ជាបាវបំរើទ្រង់ នឹងនៅទីនោះដែរ[ផ] ២២ដូច្នេះ
ដាវីឌមានបន្ទូលប្រាប់ថា ចូរឆ្លងទៅចុះ នោះអ៊ីតតាយ ជា
អ្នកក្រុងកាថ ព្រមទាំងពួកលោក និងកូនចៅទាំងប៉ុន្មាន
ដែលនៅជាមួយ ក៏នាំគ្នាឆ្លងទៅ ២៣ពួកអ្នកទាំងប៉ុន្មាននៅ
ស្រុកនោះ គេនាំគ្នាយំដោយសំឡេងជាខ្លាំង[ព] ហើយបណ្តា
ជនទាំងឡាយក៏ឆ្លងទៅ ឯស្តេចទ្រង់យាងឆ្លងជ្រោះកេដ្រុន
ដែរ[ភ,ម] គ្រប់គ្នាឆ្លងទៅ តាមផ្លូវដែលនាំទៅទីរហោស្ថាន។
២៤រីឯសាដុក[យ] លោកក៏មកដែរ ព្រមទាំងពួកលេវីទាំង
អស់ ដែលសែងហឹបនៃសេចក្តីសញ្ញា[រ]របស់ព្រះផង គេក៏
ដាក់ហឹបនៃព្រះចុះ ហើយអ័របៀថើរ[ល]លោកឡើងទៅ
ដរាបដល់ពួកបណ្តាជនបានចាក ចេញផុតពីទីក្រុងទាំងអស់

**១៥:១២** ញ ឧ.៣១,៣៤ ២សយ ១៦:១៥,២៣ ១៧:១៤ ២៣:៣៤ ១រប ២៧:៣៣ ដ យប ១៩:១៤ ទដ ៤១:៩ ៥៥:១៣ យរ ៩:៤ ឋ យស ១៥:៥១ ឌ ទដ ៣:១ **១៥:១៤** ឍ ១ពវ ២:២៦ ទដ ១៣២:១ ទដ ៣ ណ ២សយ ១៩:៩ **១៥:១៦** ត ២សយ ១៦:២១–២២ ២០:៣ **១៥:១៨** ថ ១សយ ៣០:១៤ ២សយ ២០:៧,២៣ ១ពវ ១:៣៨,៤៤ ១រប ១៨:១៧ **១៥:១៩** ទ ២សយ ១៨:២ ធ លប ៣១:១៥ **១៥:២០** ន ១សយ ២២:២ ប ២សយ ២:៦ **១៥:២១** ផ នរ ១:១៦–១៧ សភ ១៧:១៧ **១៥:២៣** ព ១សយ ១១:៤ យប ២:១២ ភ ១ពវ ២:៣៧ ពវ ២៣:១២ ២រប ១៥:១៦ ២៩:១៦ ៣០:១៤ យរ ៣១:៤០ ម យហ ១៨:១ **១៥:២៤** យ ២សយ ៨:១៧ ១៩:១១ រ ជន ៤:១៥ ១០:៣៣ ១ពវ ២:២៦ ល ១សយ ២២:២០

ក៏យល់ដឹងដោយខ្លួនឯងពីភាពបះបោររបស់អាប់សាឡំុម ក្នុងពេលកំពុងមានផែនការប្រឆាំងនឹងដាវីឌ ចំពោះទង្វើរបស់ទ្រង់ចំពោះនាងបាតសេបា និងអ៊ូរី ។ អំពើក្បត់ចិត្តដោយមិត្តដ៏ពិតអាចមានការឮដំណឹងដល់ស្តេចដាវីឌបាន ទដ ៤១:៩ ៥៥:១២–១៤ ។ *គីឡោ* ស្ថិតនៅក្បែរហេប្រុន (មើល យស ១៥:៥១,៥៤) ។

**១៥:១៤** *នឹងគ្មានពួកយើងណាមួយបានរួចពីអាប់សាឡំុម* គឺជាភាពមិនពិតប្រាកដនៃការគាំទ្ររបស់អាប់សាឡំុម (មើល ឧ.១៣) ការកោតខ្លាចរបស់ស្តេចដាវីឌបានជាប់គាំងនៅក្នុងយេរូសាឡិម ។

**១៥:១៦** *បានទុកនៅតែស្រីអ្នកម្នាង១០នាក់ឱ្យរក្សាដំណាក់ប៉ុណ្ណោះ* មើល ៥:១៣ មើល ៣:២ ។ ស្តេចដាវីឌក៏ពុំបានដឹងពីការរៀបចំសម្រេចតាមបទទំនាយតាមរយៈហោរាណាថាន់ (មើលការពន្យល់ ១២:១១ ១៦:២២ មើល ២០:៣) ។

**១៥:១៨** *ពួកកេរេធីមនឹងពួកពេលេធីម* សូមមើលការពន្យល់ ៨:១៨ យរ ៤៧:៤ ។ *ពួកកាថចំនួន៦០០* នាក់គឺជាពួកទាហាន ដែលចូលរួមការងារកងទ័ពរបស់ស្តេចដាវីឌ ហើយមេទ័ពរបស់ពួកគេគឺអ៊ីតតាយ (ឧ.១៩ ១៨:២) ។

**១៥:១៩** *ត្រឡប់ទៅនៅជាមួយនឹងស្តេចចុះ* ស្តេចដាវីឌបានដោះលែងឱ្យសាសន៍ភីលីស្ទីនឱ្យរួចពីការជាប់កាតព្វកិច្ចបម្រើដល់ទ្រង់ ។

**១៥:២១** *ដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់* ការសន្មត់នៃភាពស្មោះត្រង់ ដែលធ្វើឡើងដោយមានព្រះអម្ចាស់របស់អ៊ីស្រាអែល (មើលការពន្យល់ ១សយ ១៤:៣៩,៤៥)។ *ព្រះករុណាជាព្រះអម្ចាស់ . . . ជាបាវបំរើទ្រង់* គឺជាឃ្លាដែលស្រដៀងនឹងការប្រកាសនៃការប្តូរផ្តាច់ ។

**១៥:២៣** *ជ្រោះកេដ្រុន* គឺនៅផ្នែកខាងកើតទីក្រុងយេរូសាឡិម (មើលការពន្យល់ អស ២២:៧)។ *ទីរហោស្ថាន* នៅផ្នែកខាងជើងនៃទីរហោស្ថានយូដាដែលលាតសន្ធឹងពីយេរូសាឡិមទៅដល់សមុទ្រស្លាប់ ។

**១៥:២៤** *សាដុក* មើលការពន្យល់ ៨:១៧ ។ *អ័បៀថើរ* មើលការពន្យល់ ៨:១៧ ១សយ ២២:២០–២៣ និងការពន្យល់ ២២:២០ ។

ទៅ ២៥រួចស្ដេចមានបន្ទូលទៅសាដុកថា ចូរនាំយកហឹបនៃ
ព្រះត្រឡប់ទៅឯទីក្រុងវិញទៅ បើសិនជាយើងនឹងបាន
ប្រកបដោយព្រះគុណនៃព្រះយេហូវ៉ា នោះមុខជាទ្រង់នឹង
នាំ យើងមកវិញ ឱ្យបានឃើញទាំងហឹបនេះ និងទីលំនៅ[វ]
របស់ទ្រង់ផង ២៦តែបើទ្រង់មានបន្ទូលមកដូច្នេះថា អញមិន
សព្វព្រះហឫទ័យនឹងឯងទេ នោះមើល យើងនេះហើយ
សូមទ្រង់ប្រព្រឹត្តនឹងយើង តាមព្រះហឫទ័យចុះ[ស] ២៧ស្ដេច
ទ្រង់ក៏មានបន្ទូលទៅសាដុកដ៏ជាសង្ឃទៀតថា លោកជាអ្នក
មើលឆុត[ហ] ដូច្នេះ ចូរត្រឡប់ទៅក្នុងទីក្រុងវិញ ដោយសុខ
សាន្តចុះ នាំទាំងអ័ហ៊ីម៉ាស កូនលោក និងយ៉ូណាថាន[ឡ]
ជាកូនអ័បៀថើរទៅជាមួយផង ២៨ឯយើងៗនឹងចាំនៅត្រង់
វាល[អ]នៃទីរហោស្ថាន ដរាបដល់មានដំណឹងមកបញ្ជាក់
ដល់យើង ២៩ដូច្នេះ សាដុក និងអ័បៀថើរ ក៏សែងហឹបនៃ
ព្រះទៅក្នុងក្រុងយេរូសាឡិមវិញ ហើយក៏នៅទីនោះ ។
៣០ឯដាវីឌ ទ្រង់យាងឡើងទៅតាមផ្លូវភ្នំដើមអូលីវទាំង
ទ្រង់ព្រះកន្សែង[ក]បណ្ដើរ ទ្រង់ទទូរព្រះសិរ[ខ] ហើយយាង
ទៅដោយព្រះបាទទទេ ឯពួកអ្នកដែលនៅជាមួយនឹងទ្រង់
ក៏ឡើងទៅទាំងទទូរក្បាល ហើយយំបណ្ដើរដែរ ៣១មាន
ម្នាក់ទូលដាវីឌថា អ័ហ៊ីថូផែល[គ]ក៏នៅក្នុងពួកក្បត់នោះ
ជាមួយនឹងអាប់សាឡុំមដែរ នោះដាវីឌអធិស្ឋានទូលថា
ឱព្រះយេហូវ៉ាអើយ សូមទ្រង់បំផ្លាស់បំប្រែសេចក្ដីទូន្មាន
របស់អ័ហ៊ីថូផែល ឱ្យទៅជាផ្ដេសផ្ដាសវិញទៅ ៣២កាល
ដាវីឌបានយាងដល់លើកំពូលភ្នំ ជាកន្លែងដែលទ្រង់ធ្លាប់
ថ្វាយបង្គំព្រះ នោះឃើញហ៊ូសាយ[ឃ] ជាពួកអើគី[ង]ចូលមក

**១៥:២៥** វ នក ១៥:១៣ លវ ១៥:៣១ ទដ ៤៣:៣ ៤៦:៤ ៨៤:១ ១៣២:៧
**១៥:២៦** ស ពច ១០:១៥ ២សយ ២២:២០
**១៥:២៧** ហ ១សយ ៩:៩ ឡ ខ.៣៦
**១៥:២៨** អ ២សយ ១៧:១៦
**១៥:៣០** ក ជន ២៥:៦ ទដ ៣០:៥ ខ នអ ៦:១២
**១៥:៣១** គ ខ.១២
**១៥:៣២** ឃ ខ.៣៧ ២សយ ១៦:១៦ ១៧:៥ ១ពវ ៤:១៦ ង យស ១៦:២ ច យស ៧:៦
**១៥:៣៣** ឆ ២សយ ១៩:៣៥
**១៥:៣៤** ជ ២សយ ១៦:១៩ ឈ ២សយ ១៧:១៤ សភ ១១:១៤
**១៥:៣៥** ញ ២សយ ១៧:១៥–១៦
**១៥:៣៦** ដ ២សយ

នៅចំពោះទ្រង់ ទាំងមានអាវរហែក និងដី[ច]នៅលើក្បាល
៣៣ដាវីឌមានបន្ទូលទៅលោកថា បើអ្នកទៅជាមួយនឹង
យើង នោះអ្នកនឹងបានជាបន្ទុក[ឆ]ដល់យើងទេ ៣៤តែ
បើសិនជាអ្នកត្រឡប់ទៅឯទីក្រុងវិញ ហើយទូលដល់អាប់
សាឡុំមថា បពិត្រព្រះករុណា ទូលបង្គំសូមថ្វាយខ្លួនធ្វើជាខ្ញុំ
បំរើរបស់ទ្រង់ ដូចជាបានធ្វើជាខ្ញុំបំរើ[ជ]ដល់ព្រះបិតាទ្រង់
កាលពីដើមដែរ បើធ្វើដូច្នេះ នោះអ្នកនឹងអាចឈ្នះ[ឈ] សេច
ក្ដីទូន្មានរបស់អ័ហ៊ីថូផែលឱ្យយើងបាន ៣៥នៅទីនោះអ្នកក៏
មានសាដុក និងអបៀថើរដ៏ជាសង្ឃនៅជាមួយដែរ យ៉ាង
នោះ ការអ្វីដែលអ្នកឮពីក្នុងដំណាក់ស្ដេចមក នោះចូរសា
សព្ទ ប្រាប់ដល់សាដុក និងអ័បៀថើរដ៏ជាសង្ឃ[ញ] ៣៦លោក
ទាំង២នោះមាន កូន២នាក់នៅជាមួយគឺអ័ហ៊ីម៉ាស[ដ]ជាកូន
សាដុក និងយ៉ូណាថាន[ឋ]ជាកូន អ័បៀថើរត្រូវឱ្យអ្នកចាត់មក
ឱ្យយើងដឹងពីគ្រប់សេចក្ដី ដែលអ្នកឮ ៣៧ដូច្នេះ ហ៊ូសាយ[ឌ]
ជាសំឡាញ់របស់ដាវីឌ ក៏ត្រឡប់ទៅក្នុងទីក្រុងវិញ ឯ
អាប់សាឡុំម[ឍ]ទ្រង់ក៏យាងចូលមក ដល់ក្រុងយេរូសាឡិម
ដែរ ។

## ស្ដេចដាវីឌនិងស៊ីបា

**១៦** ១កាលដាវីឌបានយាងហួសពីកំពូលភ្នំបន្តិចទៅ នោះ
ឃើញស៊ីបា[ក] ជាអ្នកបំរើរបស់មភីបូសែត មកជួបនឹងទ្រង់
នាំទាំងសត្វលា២ ចងកែបជាស្រេច ផ្ទុកដោយនំបុ័ង២០០ដុំ
ទំពាំងបាយជូរក្រៀម១០០ ចង្កោម ហើយផ្លែរដូវក្ដៅ១០០

១៨:១៩ ឋ ខ.២៧ ២សយ ១៧:១៧ ១ពវ ១:៤២ **១៥:៣៧** ឌ ១រប ២៧:៣៣ ឍ ២សយ ១៦:១៥ **១៦:១** ក ២សយ ៩:១–១៣ ខ ១សយ ២៥:១៨

**១៥:២៥** *សែងហឹបនៃសេចក្ដីសញ្ញារបស់ព្រះ* ការបើកសម្ដែងដល់ដាវីឌនូវការយល់យ៉ាងច្បាស់នៃភាពទំនាក់ទំនងររៀងសេចក្ដីសញ្ញា និងវត្តមានព្រះអម្ចាស់នៃរាស្ត្ររបស់ទ្រង់ ។ ទ្រង់ដឹងថាការទទួលនៃហឹបសេចក្ដីសញ្ញាមិនបានកំណត់នូវព្រះពរទេ (មើលការពន្យល់ ១សយ ៤:៣,២១) ។ ទ្រង់ទទួលស្គាល់ថាហឹបនោះ គឺជារបស់ទីក្រុងរាជធានីដូចជានិមិត្តច្បាប់របស់ព្រះយេហូវ៉ា លើគ្រប់ជាតិសាស្ត្រទាំងមូល(មើលការពន្យល់ ៦:២) គឺពុំគិតថាអ្នកណាជាស្ដេចដែលសោយរាជ្យឡើយ ។

**១៥:២៦** *សូមទ្រង់ប្រព្រឹត្តនឹងយើងតាមព្រះហឫទ័យចុះ* ស្ដេចដាវីឌបានលន់តួថា ទ្រង់ពុំអាចអះអាងជាឯកសិទ្ធិ រាជបល្ល័ង្កនឹងជារបស់ទ្រង់ទេស្ដេចដែលមកពីព្រះរបស់រាស្ត្រអ៊ីស្រាអែលនោះត្រូវមានឯកសិទ្ធិទទួល ទោះស្ដេចអង្គណាក៏ដោយ ឱ្យតែព្រះជើសរើស ។

**១៥:២៧** *លោកជាអ្នកមើលឆុត* គឺប្រហែលជាការនិយាយបញ្ឈៀងចំពោះការព្យាបាលរបស់សម្ដេចសង្ឃ ដែលជាអត្ថន័យការទំនាក់ទំនងពីព្រះ (មើលការពន្យល់ នក ២៨:៣០ ២សយ ២:២៨ ១សយ ៩:៩) ។

**១៥:២៨** *ចាំនៅត្រង់វាលនៃ* កន្លែងឆ្លងកាត់ស្រុកយ័រដាន់ដំបន់ភ្នំគីលបោ ។

**១៥:៣០** *ទ្រង់ទទូរព្រះសិរ* គឺជាការបង្ហាញភាពទុក្ខសោកសៅ (មើល នអ ៦:១២ យរ ១៤:៤ ប្រៀបធៀប ២សយ ១៩:៤ និងការពន្យល់) ។ *ដោយព្រះបាទទទេ* គឺជាសញ្ញានៃការកាន់ទុក្ខ (មើល អរ ២៤:១៧ មថ ១:៨) ។

**១៥:៣១** *អ័ហ៊ីថូផែល* មើលការពន្យល់ ខ.១២ ។

**១៥:៣២** *ហ៊ូសាយជាពួកអើគី* ឯពួកអើគីគឺក្រុមបក្សសម្ព័ន្ធមួយក្រុម(អ្នកខ្លះគិតថា ពួកគេមិនមែនអំបូរអ៊ីស្រាអែលទេ) ដែលមានទឹកដីផ្នែកខាងលិចឈាងខាងត្បូងនៃស្រុកបេតថែល (សយ ១៦:២)ចាប់តាំងពីហ៊ូសាយគឺជាសមាជិកដ៏ពិតប្រាកដរបស់ក្រុមស្ដេចដាវីឌ (មើលការពន្យល់ ខ.៣៧) គេក៏បានបង្ហាញឱ្យឃើញពីការចាប់ផ្ដើមរបស់ពួកគេ ដែលឆ្លើយទៅនឹងការអធិស្ឋាន និងការងាររបស់ស្ដេចដាវីឌ (ខ.៣១) ។

**១៥:៣៧** *ហ៊ូសាយជាសំឡាញ់របស់ដាវីឌ* ១រប ២៧:៣៣ ដែលគេហៅគាត់ថាអ្នកសំឡាញ់ព្រះមហាក្សត្រ ក៏មានលក្ខណៈត្រូវគ្នានឹងទីព្រឹក្សាផ្សេងៗទៀត (១ពវ ៤:៥)។ ក្នុងព្រះគម្ពីរភាសាហេព្រើរ ចំពោះពាក្យ "អ្នកសំឡាញ់ព្រះមហាក្សត្រ" គឺមានន័យថាទីព្រឹក្សាផ្ទាល់នៃព្រះមហាក្សត្រ ។

**១៦:១** *ស៊ីបា* មើលជំពូក៩ មភីបូសែត មើលការពន្យល់ ៤:៤ ។

ព្រមទាំងថង់ស្បែកពេញដោយស្រាទំពាំងបាយជូរផង[ខ]
២ស្តេចទ្រង់មានបន្ទូលសួរស៊ីបាថា ឯងយករបស់ទាំងនេះ
មកធ្វើអី ស៊ីបាទូលថា សត្វលាសំរាប់ជាជំនិះដល់ពួកព្រះ
រាជវង្សនៃទ្រង់ ឯនំបុ័ង និងផ្លែរដូវក្តៅសំរាប់ឱ្យពួក
កំឡោះៗបរិភោគ ហើយស្រាទំពាំងបាយជូរសំរាប់[គ]អ្នក
ណា ដែលហេវនៅទីរហោស្ថាន ៣ស្តេចទ្រង់សួរថា តើ
រាជបុត្ររបស់ចៅហ្វាយឯងនៅឯណា[ឃ] ស៊ីបា[ង] ទូលថា
លោកនៅឯក្រុងយេរូសាឡិម ដ្បិតលោកគិតថានៅថ្ងៃនេះ
ពួកវង្សានុវង្សសាសន៍អ៊ីស្រាអែល គេនឹងប្រគល់រាជ្យរបស់
បិតាមកអញវិញ ៤នោះស្តេចមានបន្ទូលទៅស៊ីបាថា នែ
របស់ទ្រព្យទាំងប៉ុន្មាននៃមភីបូសែត[ច]ជារបស់ផងឯងវិញ
ស៊ីបាទូលថា បពិត្រព្រះករុណាជាព្រះអម្ចាស់នៃទូលបង្គំ
អើយ ទូលបង្គំក្រាបថ្វាយបង្គំដល់ទ្រង់ សូមឱ្យទូលបង្គំបាន
ប្រកបដោយព្រះគុណនៃទ្រង់ផង ។

## ស៊ីម៉ាយជេរស្តេចដាវីឌ

៥រួចមក កាលស្តេចដាវីឌទ្រង់បានយាងទៅដល់ភូមិ
បាហ៊ូរីម[ឆ] នោះឃើញមានមនុស្សម្នាក់ជាញាតិវង្សរបស់
សូល ឈ្មោះស៊ីម៉ាយ[ជ]ជាកូនកេរ៉ា អ្នកនោះចេញមក
ទាំងជេរ[ឈ]បណ្តើរ ៦ក៏យកថ្មចោលដាវីឌ ហើយនិងពួក
មហាតលិកទាំងប៉ុន្មាន ឯពួកបណ្តាលជននិងពួកមនុស្សខ្លាំង
ពូកែទាំងប៉ុន្មាន គេដើរអមទ្រង់ ទាំងខាងស្តាំ និងខាង
ឆ្វេង ៧ស៊ីម៉ាយវាជេរដូច្នេះថា អាខ្ចាយឈាម អាមនុស្ស
ពាលចូរទៅៗ ៨ព្រះយេហូវ៉ាបានទំលាក់លោហិតទាំង
ប៉ុន្មាននៃវង្សរបស់សូលមកលើឯង ដែលឯងបានជែង
យករាជ្យរបស់ទ្រង់នោះ[ញ] ហើយព្រះយេហូវ៉ាបានប្រគល់
រាជ្យ ទុកក្នុងអំណាចអាប់សាឡំម ជាកូនឯងវិញ មើល
ឥឡូវនេះ ឯងជាប់ក្នុងការអាក្រក់របស់ខ្លួនហើយ ពីព្រោះ
ឯងជាមនុស្សខ្ចាយឈាម[ដ] ។
៩នោះអ័ប៊ីសាយ[ឋ]ជាកូនសេរូយ៉ាទូលទៅស្តេចថា តើ
មានហេតុអ្វីឱ្យអាឆ្កែងាប់នេះ[ឌ] បានជេរប្រមាថដល់ទ្រង់
ព្រះករុណា ជាព្រះអម្ចាស់នៃទូលបង្គំយ៉ាងនេះ សូម
អនុញ្ញាតឱ្យទូលបង្គំទៅកាត់ក្បាលវាចេញ[ឍ] ១០ស្តេចមាន
បន្ទូលថា នែ កូនសេរូយ៉ាអើយ [ណ]តើយើងនឹងអ្នកមាន
ប្រកបអ្វីនឹងគ្នា ដែលវាជេរប្រមាថដូច្នេះ នោះគឺដោយ
ព្រោះព្រះយេហូវ៉ា ទ្រង់បានប្រាប់ឱ្យវាជេរប្រមាថដល់
ដាវីឌទេតើ បើយ៉ាងនោះតើអ្នកណានឹងហ៊ានសួរថា ហេតុ
អ្វីបានជាធ្វើដូច្នេះ[ត] ១១រួចដាវីឌមានបន្ទូលទៅអ័ប៊ីសាយ
និងពួកមហាតលិកទ្រង់ទាំងប៉ុន្មានថា មើល អំបាលតែកូន[ថ]
ដែលខ្លួនយើងបង្កើត ម៉េចវារកជីវិតយើងទៅហើយ
ចំណង់បើពូជពួកបេនយ៉ាមីននេះ តើនឹងលើសជាងអំបាល
ម៉ានទៅទៀត កុំធ្វើវា ឱ្យវាជេរចុះ ដ្បិតព្រះយេហូវ៉ាទ្រង់
បានបង្គាប់វាមកហើយ[ទ] ១២ប្រហែលជាព្រះយេហូវ៉ា ទ្រង់
នឹងទតមើលសេចក្តីវេទនារបស់យើងទេដឹង[ធ] រួចទ្រង់នឹង
ប្រោសសេចក្តីល្អមកយើង[ន] ជំនួសសេចក្តីដែលវាជេរ
ប្រមាថនៅថ្ងៃនេះវិញ[ប] ១៣នោះដាវីឌក៏យាងតាមផ្លូវទៅ
ព្រមទាំងពួកទ្រង់ផង ឯស៊ីម៉ាយវាដើរតាមចង្កេះភ្នំទន្ទឹម
នឹងទ្រង់ដែរ ទាំងជេរបណ្តើរ ព្រមទាំងចោលថ្មទៅលើ
ទ្រង់ ហើយបាចសាចធូលីដីផង ១៤យ៉ាងនោះស្តេច និងពួក
បណ្តាជនទាំងប៉ុន្មាន ដែលនៅជាមួយ ក៏ទៅដល់ទីឈប់
ទាំងអស់កំឡាំង[ផ] ហើយគេសំរាកនៅទីនោះ ។

## យោបល់របស់អ័ហ៊ីថូផែល និងហ៊ូសាយ

១៥រីឯអាប់សាឡំម[ព] និងជនជាតិអ៊ីស្រាអែលទាំងអស់គ្នា
គេក៏មកដល់ក្រុងយេរូសាឡិម មានទាំងអ័ហ៊ីថូផែល[ភ]មក
ជាមួយដែរ ១៦ហើយកាលហ៊ូសាយ[ម] ជាពួកអើគី ជា
សំឡាញ់ដាវីឌ បានមកដល់អាប់សាឡំម នោះលោកទូល
ទៅអាប់សាឡំមថា សូមឱ្យព្រះករុណាមានព្រះជន្មជាយូរ
អង្វែងទៅ សូមឱ្យព្រះករុណាប្រកបដោយសេចក្តីចំរើន

**១៦:១** ១រប ១២:៤០
**១៦:២** គ ២សយ ១៧:២២,២៩
**១៦:៣** ឃ ២សយ ៩:៩–១០ ង ២សយ ៩:២
**១៦:៤** ច ២សយ ៤:៤
**១៦:៥** ឆ ២សយ ៣:១៦ ជ ២សយ ១៩:១៦–២៣ ១ពវ ២:៨–៩,៣៦,៤៤ ឈ នក ២២:២៨
**១៦:៨** ញ ២សយ ១៩:២៨ ២១:៩ ដ ២សយ ១៩:១៩ ទដ ៥៥:៣
**១៦:៩** ឋ ១សយ ២៦:៦ ឌ ២សយ ៣:៨ ឍ ២សយ ៣:៣៩ លក ៩:៥៤
**១៦:១០** ណ ២សយ ២:១៨ ១៩:២២ ត រម ៩:២០
**១៦:១១** ថ ២សយ ១២:១១ ទ លប ៤៥:៥ ១សយ ២៦:១៩
**១៦:១២** ធ ទដ ៤:១ ២៥:១៨ ន ចទ ២៣:៥ រម ៨:២៨ ប ទដ ១០៩:២៨
**១៦:១៤** ផ ២សយ ១៧:២
**១៦:១៥** ព ២សយ ១៥:៣៧ ភ ២សយ ១៥:១២ **១៦:១៦** ម ២សយ ១៥:៣២

**១៦:២** *ស៊ីបាថា* (៩:៧–១០) ។
**១៦:៣** *រាជបុត្ររបស់ចៅហ្វាយឯង* មភីបូសែត (មើល ៩:២–៣,៩) ។
**១៦:៤** *របស់ទ្រព្យទាំងប៉ុន្មាននៃមភីបូសែតជារបស់ផងឯងវិញ* ដោយព្រោះការប្រឆាំងបះបោរមានលក្ខណៈធំទូលាយ ។
**១៦:៥** *បាហ៊ូរីម* ជាភូមិនៅជិតភ្នំដើមអូលីវ ។ មនុស្សម្នាក់ជាញាត្តិវង្សរបស់សូល គឺជាពួកគ្រួម៉ាទី(មើល ១សយ ១០:២១) ។ *កេរ៉ា* មើលការពន្យល់ ១ពវ ២:៨ ។
**១៦:៦** *ឯពួកបណ្តាជននិងពួកមនុស្សខ្លាំងពូកែ* (មើល ១៥:១៨ និងការពន្យល់) ។
**១៦:៧** *អាមនុស្សពាល* មើល ចទ ១៥:១៣ ។
**១៦:៨** *ទំលាក់លោហិតទាំងប៉ុន្មាននៃវង្សរបស់សូលមកលើឯង* គឺសម្អាងទៅលើរបាយការណ៍អំពីអ្នក ដែលត្រូវសម្លាប់ក្នុង ២១:១–១៤ តែពេលនោះហេតុការណ៍អ្វីៗក៏មិនប្រាកដ(មើលការពន្យល់ ២១:១) ។
**១៦:៩** *អ័ប៊ីសាយ* មើលការពន្យល់ ១សយ ២៦:៦ ។ *អាឆ្កែងាប់នេះ* គឺការបញ្ជាក់នូវភាពមើលងាយ ហើយមិនពេញចិត្ត(មើលការពន្យល់ ៩:៨)។
**១៦:១០** *កូនសេរូយ៉ាអើយ* ជាការមានបំណងដើម្បីបន្ទាបបន្ថោក (ប្រៀបធៀប ការពន្យល់ ១សយ ២០:២៧,៣០–៣១)១ពវ ២:៨–៩ ។
**១៦:១៥** *អ័ហ៊ីថូថែល* មើលការពន្យល់ ១៥:១២ ។
**១៦:១៦** *ហ៊ូសាយជាពួកអេគី . . . ជាសំឡាញ់ដាវីឌ* មើលការពន្យល់ ១៥:៣២,៣៧ ព្រះជន្មជាយូរអង្វែងទៅ មើលការពន្យល់ ទដ ៦២:៤ ។

[១៧]អាប់សាឡំមមានបន្ទូលទៅហ៊ូសាយថា អ្នកសងគុណដល់
សំឡាញ់អ្នកយ៉ាងហ្នឹងឬ ហេតុអ្វីបានជាអ្នកមិនបានទៅតាម
សំឡាញ់ទៅ[យ] [១៨]នោះហ៊ូសាយទូលឆ្លើយថា ទេ តែអ្នកណា
ដែលព្រះយេហូវ៉ា និងបណ្ដាជនទាំងនេះ ហើយពួក
អ៊ីស្រាអែលទាំងអស់គ្នាបានរើស នោះទូលបង្គំនឹងនៅជា
មួយនឹងអ្នកនោះវិញ [១៩]មួយសោតទៀត តើគួរឱ្យទូលបង្គំ
បានបំរើចំពោះអ្នកណា តើមិនគួរឱ្យបំរើនៅចំពោះព្រះ
រាជបុត្រាទេឬអី ដូច្នេះ ទូលបង្គំនឹងបំរើនៅចំពោះព្រះ
ករុណា ដូចជាបានបំរើនៅចំពោះព្រះវរបិតាដែរ[រ] ។

[២០]នោះអាប់សាឡំមមានបន្ទូល ទៅអ័ហ៊ីថូផែលថា ចូរ
បង្ហាញគំនិតរបស់អ្នក ឱ្យយើងដឹងជាធ្វើយ៉ាងណាផង
[២១]អ័ហ៊ីថូផែលក៏ឆ្លើថា ដូច្នេះ សូមទ្រង់ចូលទៅឯពួកអ្នក
ម្នាងរបស់ព្រះបិតាទ្រង់ ដែលបានទុកឱ្យរក្សាដំណាក់ចុះ
នោះពួកអ៊ីស្រាអែលទាំងអស់នឹងដឹងថា ព្រះបិតាទ្រង់បាន
ស្អប់ខ្ពើមដល់ទ្រង់ហើយ នោះពួកអ្នកទាំងប៉ុន្មានដែលនៅ
ជាមួយនឹងទ្រង់ គេនឹងបានចំរើនកំឡាំងដៃឡើង [២២]ដូច្នេះ
គេក៏ដំឡើងត្រសាលនៅលើដំបូលដំណាក់ថ្វាយអាប់សាឡំម
រួចទ្រង់ក៏ចូលទៅឯពួកអ្នកម្នាងរបស់បិតាទ្រង់ ឱ្យពួក
អ៊ីស្រាអែលទាំងអស់គ្នាឃើញច្បាស់[ល] [២៣]ឯគំនិត[វ]របស់
អ័ហ៊ីផែល ដែលសំដែងមកនៅគ្រានោះ ក៏ដូចជាអ្នកណា
បានទូលសួរចំពោះព្រះហើយ ឯការដែលលោកជួយគំនិត
ដល់ទាំងដាវីឌ[ស]និងអាប់សាឡំមផង ក៏យ៉ាងនោះទាំងអស់។

**១៧** [១]មួយទៀតអ័ហ៊ីថូផែល លោកមានបន្ទូលទៅអាប់–
សាឡំមថា សូមឱ្យទូលបង្គំទៅរើសទាហាន១ម៉ឺន២ពាន់
នាក់ នាំចេញទៅដេញតាមដាវីឌនៅយប់នេះឯង [២]ទូលបង្គំ
នឹងបានទាន់ក្នុងកាលដែលកំពុងតែអស់កំឡាំងហើយមាន
ដៃខ្សោយ[ក] រួចនឹងធ្វើឱ្យភ័យ យ៉ាងនោះបណ្ដាទ័ពទាំងអស់
ដែលនៅជាមួយ នឹងរត់ចេញទៅ ទូលបង្គំ នឹងវាយតែ
ស្ដេចប៉ុណ្ណោះ[ខ] [៣]ហើយនិងនាំបណ្ដាជនទាំងអស់មកវិញ
ថ្វាយដល់ទ្រង់ ដ្បិតបើចាប់បានម្នាក់ដែលទ្រង់ត្រូវរកនោះ
ទុកដូចជាបានមនុស្សទាំងអស់មកវិញដែរ យ៉ាងនោះ
បណ្ដាជនទាំងអស់គ្នានឹងបានសេចក្ដីសុខហើយ [៤]ពាក្យនោះ
ក៏គាប់ព្រះទ័យដល់អាប់សាឡំម និងពួកចាស់ទុំនៃសាសន៍
អ៊ីស្រាអែលទាំងអស់គ្នា ។

[៥]តែអាប់សាឡំមមានបន្ទូលថា ចូរហៅហ៊ូសាយ[គ] ជាពួក
អើគីមក ដើម្បីយើងបានស្ដាប់សេចក្ដីដែលគាត់ថា ជាយ៉ាង
ណាដែរ [៦]កាលហ៊ូសាយបានមកដល់អាប់សាឡំមហើយ
នោះទ្រង់មានបន្ទូលថា អ័ហ៊ីថូផែលបាននិយាយដូច្នេះ តើ
គួរឱ្យយើងធ្វើតាមឬអី បើមិនគួរទេ សូមឆ្លើយប្រាប់មក
ចុះ [៧]ដូច្នេះហ៊ូសាយក៏ទូលឆ្លើយថា សេចក្ដីប្រឹក្សាដែល
អ័ហ៊ីថូផែលបានទូលម្ដងនេះ មិនល្អទេ [៨]ដ្បិតទ្រង់ជ្រាបថា
ព្រះបិតា និងពួកអ្នកដែលនៅជាមួយ សុទ្ធតែជាមនុស្សខ្លាំង
ពូកែ ហើយមានចិត្តក្ដៅក្រហាយ ដូចជាខ្លាឃ្មុំញីនៅវាល
ដែលត្រូវព្រាត់ពីកូន[ឃ] មួយទៀតព្រះបិតាទ្រង់ជាមនុស្សថ្នឹក
ចំបាំងផង[ង] ទ្រង់មិនផ្ទំនៅជាមួយនឹងពួកពលទេ [៩]ពេលថ្មើរ
នេះ មុខជាទ្រង់ពួននៅក្នុងរណ្ដៅណាមួយ ឬនៅកន្លែងណា
ទៀតមិនខាន[ច] ដូច្នេះ កាលណាចាប់តាំងច្បាំងគ្នា ហើយ
មានពួកយើងខ្លះដួលស្លាប់នោះអ្នកណាដែលឮ គេនឹង
ផ្សាយប្រាប់ថា មានពួកខាងអាប់សាឡំមស្លាប់សន្ធឹកហើយ
[១០]យ៉ាងនោះ ទោះទាំងមនុស្សក្លាហាន ដែលមានចិត្ត
ដូចជាសិង្ហ[ឆ] គេនឹងក្រាកចិត្តដែរ[ជ] ដ្បិតពួកអ៊ីស្រាអែលទាំង
អស់គ្នាដឹងថា ព្រះបិតាទ្រង់ និងពួកដែលនៅជាមួយសុទ្ធតែ
ជាមនុស្សក្លាហានណាស់[ឈ] [១១]ឯទូលបង្គំ សូមថ្វាយសេចក្ដី
ដូច្នេះថា គួរឱ្យប្រមូលពួកសាសន៍អ៊ីស្រាអែលទាំងអស់មក
ឯទ្រង់ ចាប់តាំងពីក្រុងដាន់ រហូតទៅដល់បៀរ–សេបា[ញ]

**១៦:១៧** យ ២សយ ១៩:២៥
**១៦:១៩** រ ២សយ ១៥:៣៤
**១៦:២២** ល ២សយ ៣:៧ ១២:១១–១២ ១៥:១៦
**១៦:២៣** វ ២សយ ១៧:១៤,២៣ ស ២សយ ១៥:១២
**១៧:២** ក ២សយ ១៦:១៤ ខ ១ពវ ២២:៣១ សក ១៣:៧
**១៧:៥** គ ២សយ ១៥:៣២
**១៧:៨** ឃ ហស ១៣:៨ ង ១សយ ១៦:១៨
**១៧:៩** ច យរ ៤១:៩
**១៧:១០** ឆ ១របា ១២:៨ ជ យស ២:៩,១១ អគ ២១:១៥ ឈ ២សយ ២៣:៨ ១រប ១១:១១
**១៧:១១** ញ ពច ២០:១ ដ លប ១២:២ យស ១១:៤

**១៦:១៨** ពាក្យសំដីរបស់ហ៊ូសាយ គឺធ្វើឱ្យមានចម្ងល់ឯអាប់សាឡំម បានបង្ហាញពីអ្នកដែលព្រះ"បានហៅ"ឯទ្រង់ដាវីឌក៏សាក់សមជាអ្នក ដែលព្រះបានត្រាស់ហៅ (មើល ៦:២១,១សយ ១៦:៨–១៣,១ពវ ៨:១៦,១១:៣៤,១រប ២៨:៤,ទដ ៧៨:៧០) ។

**១៦:២១** *ចូលទៅឯអ្នកម្នាងរបស់ព្រះបិតាទ្រង់* មានន័យថាអាប់សាឡំម គឺស្មានថារាជអំណាចមិនអាចបង្វិលវិញបាន ដូច្នេះហើយក៏ធ្វើឱ្យមានការបាក់បែកគ្នារវាងឪពុក និងកូន (មើលការពន្យល់ ៣:៧ ១២:៨ ១រប ២:២២) ។ *ស្អប់ខ្ពើម* មើលការពន្យល់ ១សយ ១៣:៤ ។

**១៦:២២** *ទ្រង់ក៏ចូលទៅឯពួកអ្នកម្នាងរបស់បិតាទ្រង់* គឺបានសម្រេចតាមទំនាយរបស់ហោរាណាថាន់(១២:១១–១២) ។ សម្រាប់បូកបន្ថែមនូវសេចក្ដីសំខាន់ៗ មើលការពន្យល់ ខ.២១ ។

**១៧:១–៣** អ័ហ៊ីថូផែលបានណែនាំអាប់សាឡំមថា នៅក្នុងតំបន់ជុំវិញនេះងាយស្រួលនឹងយកជ័យជម្នះណាស់ បើសិនជាយើងមិនចាកចេញពីទឹកដីនេះដែលនាំឱ្យទន់ខ្សោយនេះ ។

**១៧:៤** *ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលទាំងអស់* មើលការពន្យល់ ១៥:៣២, ៣៧ ។ ការបះបោររបស់អាប់សាឡំមត្រូវមានការគាំទ្រយ៉ាងខ្លាំង ពីមេពូជអំបូរមួយចំនួន ។

**១៧:៥** *ហ៊ូសាយជាពួកអើគីមក* មើល ១៦:១៦–១៩ ១៥:៣២,៣៧ ។

**១៧:៧–១៣** ការឱ្យជាយោបល់របស់ហ៊ូសាយ បានបង្ហាញពីភាពមិនទៀងទាត់ជាក់លាក់របស់អាប់សាឡំមដូចជាការភ័យព្រួយ និងការគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ។

**១៧:១១** *តាំងពីក្រុងដាន់រហូតទៅដល់បៀរសេបា* មើលការពន្យល់ ១សយ

ដូចជាខ្សាច់[ដ]នៅមាត់សមុទ្រ រួចយាងទៅច្បាំងដោយព្រះ
អង្គទ្រង់វិញ ១២យ៉ាងនោះ យើងខ្ញុំរាល់គ្នានឹងទៅទាន់ព្រះ
បិតាទ្រង់ នៅកន្លែងណាដែលរកឃើញ ហើយនឹងស្ទុះទៅ
លើ ដូចជាទឹកសន្សើមធ្លាក់មកលើដីតែម្តង ឥតទុកឱ្យអ្នក
ណាមួយនៅសល់ឡើយ ទោះទាំងព្រះបិតានិងពួកដែល
នៅជាមួយផង ១៣ឬបើបានចូលទៅជ្រកក្នុងទីក្រុងណា
នោះពួកអ៊ីស្រាអែលទាំងអស់នឹងយកពួរ ទៅទាញអូស
ទីក្រុងនោះទំលាក់ចុះក្នុងទន្លេ[ឋ] ដរាបដល់រកថ្ម១យ៉ាងតូច
នៅទីនោះមិនឃើញផង ១៤នោះអាប់សាឡុម និងពួក
អ៊ីស្រាអែលក៏ឆ្លើយឡើងថា គំនិត[ឌ]របស់ហ៊ូសាយ ជាពួក
អើគីនេះ ល្អជាងគំនិតរបស់អ័ហ៊ីថូផែល[ឍ] (ព្រះយេហូវ៉ា
ទ្រង់បានដំរូវឱ្យបំបាត់[ណ]គំនិតរបស់អ័ហ៊ីថូផែលចេញ ដើម្បី
នឹងនាំសេចក្តីអាក្រក់[ត]មកលើអាប់សាឡុមវិញ[ថ]) ។
១៥គ្រានោះហ៊ូសាយរ៉ាយរឿងប្រាប់សាដុក ហើយនិង
អ័បៀថើរដ៏ជាសង្ឃថា អ័ហ៊ីថូផែលបានទូលប្រាប់ដល់
អាប់សាឡុម និងពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលថា គួរ
ធ្វើដូច្នេះ១៧ តែខ្ញុំបានទូលយ៉ាងនេះវិញ ១៦ដូច្នេះ សូមចាត់
គេជាប្រញាប់ ឱ្យទៅទូលដល់ព្រះករុណាថា នៅយប់នេះ
សូមទ្រង់កុំផ្អឹនៅទីរហោស្ថានឡើយ[ទ] សូមយាងឆ្លងទៅ ខាង
មុខទៀតទៅក្រែងព្រះករុណា និងពួកអ្នកដែលនៅជាមួយ
ត្រូវវិនាសបាត់[ធ] ។
១៧រីឯយ៉ូណាថាន[ន] និងអ័ហ៊ីម៉ាស គេនៅត្រង់អេនរ៉ូកែល[ប]
ដ្បិតគេមិនហ៊ានចូល ក្នុងទីក្រុងឱ្យអ្នកណាឃើញទេ ហើយ
មានបាវស្រីម្នាក់ទៅប្រាប់ រួចគេក៏ទៅក្រាបទូលដល់ស្តេច
ដាវីឌ ១៨ប៉ុន្តែមានក្មេងម្នាក់បានឃើញ ក៏ទៅក្រាបទូលដល់
អាប់សាឡុម តែអ្នកទាំង២នាំគ្នាចេញទៅជាប្រញាប់ បាន
ទៅដល់ផ្ទះរបស់មនុស្សម្នាក់ នៅត្រង់បាហ៊ូរីម[ផ] ដែលមាន
អណ្តូងនៅទីធ្លាផ្ទះ អ្នកទាំង២ក៏ចុះទៅពួនក្នុងអណ្តូងនោះ
១៩ឯស្ត្រីជាម្ចាស់ផ្ទះ ក៏យកសំពត់គ្របមាត់អណ្តូង ហើយ
រាយហាលអង្ករពីលើ ឥតមានអ្នកណាសង្ស័យឡើយ[ព]
២០ចំណែកពួកអ្នកដែលអាប់សាឡុមចាត់ប្រើ ក៏មកដល់ស្រី
នោះ[ភ] នៅក្នុងផ្ទះសួរថា តើអ័ហ៊ីម៉ាស និងយ៉ូណាថាននៅឯ
ណា តែស្រីនោះឆ្លើយថា គេបានឆ្លងស្ទឹងទៅបាត់ហើយ
កាលគេស្វែងរកមិនឃើញសោះនោះក៏នាំគ្នា ត្រឡប់ទៅ
ឯក្រុងយេរូសាឡិមវិញ ។
២១លុះកាលគេចេញទៅបាត់ហើយ នោះអ្នកទាំង២ក៏នាំ
គ្នាឡើងចេញពីអណ្តូងមក ទៅក្រាបទូលដល់ស្តេចដាវីឌ
ដោយពាក្យថា សូមទ្រង់តើនឡើងយាងឆ្លងទឹកនេះជា
ប្រញាប់ទៅ ដ្បិតអ័ហ៊ីថូផែលបានបញ្ចេញគំនិតទាស់នឹង
ទ្រង់យ៉ាងនេះហើយ ២២ដូច្នេះ ដាវីឌនឹងពួកអ្នកដែលនៅជា
មួយ ក៏ក្រោកឡើងឆ្លងទន្លេយ័រដាន់ទៅ លុះថ្ងៃភ្លឺឡើង
នោះគ្រប់គ្នាបានឆ្លងទន្លេយ័រដាន់ទាំងអស់ផុតឥតសល់ដល់
ម្នាក់ឡើយ ។
២៣កាលអ័ហ៊ីថូផែលឃើញថា គេមិនបានតាមគំនិត[ម]
ខ្លួនដូច្នោះ នោះលោកក៏ចងកែបលា ជិះត្រឡប់ទៅដល់ផ្ទះ
នៅទីក្រុងរបស់លោកវិញ ចាត់ចែងការក្នុងផ្ទះស្រេច
ហើយ[យ] រួចចងកស្លាប់ទៅ គេបញ្ចុះសពលោកនៅក្នុងផ្ទះ
របស់ឪពុកលោក ។
២៤រួចមកដាវីឌយាងទៅដល់ក្រុងម៉ាហាណៃម[រ] ឯអាប់–
សាឡុម និងពួកពលទ័ពអ៊ីស្រាអែលទាំងប៉ុន្មាន ដែលនៅ
ជាមួយ ក៏ឆ្លងទន្លេយ័រដាន់ទៅ ២៥អាប់សាឡុមបាន
តាំងអ័ម៉ាសា[ល]ឡើង ឱ្យធ្វើជាមេទ័ពជំនួសយ៉ូអាប់ រីឯម៉ាសា

**១៧:១៣** ឋ មីក ១:៦
**១៧:១៤** ឌ ២សយ ១៦:២៣ ឋ ២សយ ១៥:១២ ណ ២សយ ១៥:៣៤ នហ ៤:១៥ ត ទដ ៩:១៦ ថ ២របា ១០:៨
**១៧:១៦** ទ ២សយ ១៥:២៨ ធ ២សយ ១៥:៣៥
**១៧:១៧** ន ២សយ ១៥:២៧,៣៦ ប យស ១៥:៧ ១៨:១៦ ១ពរ ១:៩
**១៧:១៨** ផ ២សយ ៣:១៦
**១៧:១៩** ព យស ២:៦
**១៧:២០** ភ នក ១:១៩
**១៧:២៣** ម ២សយ ១៦:២៣ យ ២ពរ ២០:១
**១៧:២៤** រ លប ៣២:២
**១៧:២៥** ល ២សយ ១៩:១៣ ២០:៤,៩–១២ ១ពរ ២:៥,៣២ ១របា ១២:១៨ វ ១របា ២:១៣–១៧

៣:២០ ។
**១៧:១២–១៣** *យើង . . . យើង . . . យើង* ហ៊ូសាយក៏ប្រុងប្រយ័ត្នខ្លួនដែលមានពាក់ព័ន្ធក្នុងការបះបោរនេះ ។
**១៧:១៤** *ព្រះយេហូវ៉ាទ្រង់បានដំរូវឱ្យបំបាត់គំនិតរបស់អ័ហ៊ីថូផែល* គឺជាចម្លើយការឆ្លើយតបនឹងការអធិស្ឋានរបស់ស្តេចដាវីឌ(មើល ១៥:៣១ ប្រៀបធៀប ទដ ៣៣:១០ សភ ២១:៣០) ។
**១៧:១៥** *សាដុកហើយនិងអ័បៀថើរ* សូមមើលការពន្យល់ ១៥:២៤–២៩, ៣៥–៣៦ ។
**១៧:១៦** *សូមទ្រង់កុំផ្អឹនៅទីរហោស្ថានឡើយ* មើលការពន្យល់ ១៥:២៨ ។ *សូមយាងទ្រង់ឆ្លងទៅខាងមុខទៀតទៅ* គឺលោកហ៊ូសាយបានផ្តល់ការប្រឹក្សាដល់ស្តេចដាវីឌកុំឱ្យនៅស្ងៀមលើទីរហោស្ថាន ដោយដឹងថាអាប់សាឡុមនិងបានប្តូរចិត្តហើយអាចមករកទ្រង់ ។
**១៧:១៧** *យ៉ូណាថាននឹងអ័ហ៊ីម៉ាស* មើល ១៥:៣៦ ។ *អេរ៉ូកែល* គឺជាដីដែលប្រេះចែកជាពីរក្នុងជ្រលងកេដរ៉ុន គឺនៅខាក្រៅកំផែងក្រុងយេរូសាឡិម ។ *បាវស្រីម្នាក់* ដែលបានទៅឯជ្រលងដើម្បីដងទឹក ។
**១៧:១៨** *បាហ៊ូរីម* មើលការពន្យល់ ១៦:៥ ។
**១៧:២៣** *នៅទីក្រុងរបស់លោក* គឺគីឡូ(មើល ១៥:១២ និងការពន្យល់) ។ *រួចចងកស្លាប់ទៅ* អ័ហ៊ីថូផែលដឹងថាការបះបោរនោះ មិនបានសម្រេចទេ ហើយគាត់ក៏ត្រូវបានជាប់ជាអ្នកចូលរួមក្នុងអំពើក្បត់ជាតិ ។
**១៧:២៤** *ក្រុងម៉ាហាណៃម* គឺជាទីកន្លែងតែមួយក្នុងពេល អ៊ីស–បូសែតជាបុត្រាសូលរកទីជំរំលាក់ខ្លួននៅទីនោះបន្ទាប់ពីសូលស្លាប់(មើល ២:៨ និងការពន្យល់) ។
**១៧:២៥** *អ័ម៉ាសា* គឺជាក្មួយប្រុសរបស់ស្តេចដាវីឌ ជាបងប្អូនជីដូនមួយអាប់សាឡុម និងយ៉ូអាប់ ជាកូនប្រុសរបស់ អ័ប៊ីកែល គឺជាកូនរបស់ណាហាស និងជាប្អូនស្រីសេរូយ៉ា សេរូយ៉ាគឺជាប្អូនស្រីដាវីឌ(សូមមើល ១របា ២:១៦) តាំងពីឪពុករបស់អ័ប៊ីកែលនិងសេរូយ៉ាគឺណាហាស មិនមែនអ៊ីសាយទេ ។ ម្តាយ ដែលឥតបញ្ចេញឈ្មោះអាចរៀបការនឹងអ៊ីសាយ បន្ទាប់ពីណាថានសុគត ។

នេះ លោកជាកូនរបស់សាសន៍អ៊ីស្រាអែលម្នាក់ឈ្មោះ
យីត្រា[ខ] ដែលបានចូលទៅឯនាងអ័ប៊ីកែល ជាកូនណា
ហាស ដែលជាប្អូនស្រីរបស់សេរូយ៉ា ម្តាយយ៉ូអាប់
[26]ចំណែកពួកអ៊ីស្រាអែល និងអាប់សាឡុម គេបោះទ័ព
នៅស្រុកកាឡាត ។
[27]កាលដាវីឌបានទៅដល់ម៉ាហាណែមហើយ នោះសូប៊ី
ជាកូនណាហាស[គ] ដែលនៅត្រង់រ៉ាបា[ឃ] ស្រុករបស់ពួកកូន
ចៅអាំម៉ូន ហើយម៉ាការ[ង]ជាកូនអាំមាលនៅឡូរ-ដេបារ
និងបារស៊ីឡាយ[ច]ជាពួកកាឡាត[ឆ]ដែលនៅរ៉ូគីលីម [28]គេ
យកគ្រែ ចាន ឆ្នាំងផ្សេងៗ ព្រមទាំងស្រូវភោជ្ជសាលី ស្រូវ
ឱក ម្សៅ លាជ ពពាយ សណ្តែកបាយ និងសណ្តែក
លីង [29]ទឹកឃ្មុំ ខ្លាញ់ទឹកដោះ សត្វចៀម ទឹកដោះគោខះ
មកសំរាប់ដាវីឌ និងពួកបណ្តាជនដែលនៅជាមួយបាន
បរិភោគ[ជ] ដោយថា ពួកបណ្តាជនគេស្រេកឃ្លាន ហើយ
ល្វើយនៅទីរហោស្ថាន[ឈ]។

## ការស្លាប់របស់អាប់សាឡុម

**១៨** [1]គ្រានោះ ដាវីឌទ្រង់ត្រួតត្រាមើលពួកពលទ័ពដែល
នៅជាមួយនឹងទ្រង់ ក៏តាំងឱ្យមានមេលើ១ពាន់នាក់ ហើយ
មេលើ១រយនាក់ [2]រួចទ្រង់ចែកគេ[ក]ជា៣កង ចាត់ឱ្យចេញ
ទៅ១កងនៅក្រោមអំណាចយ៉ូអាប់ មួយទៀតនៅក្រោម
អំណាចអ័ប៊ីសាយ[ខ] ជាប្អូនយ៉ូអាប់ កូនសេរូយ៉ា ហើយមួយ
ទៀត នៅក្រោមអំណាចអ៊ីតតាយ[គ] ជាពួកកាថ ស្តេចទ្រង់
មានបន្ទូលទៅគេថា យើងនឹងចេញទៅជាមួយនឹងឯងរាល់
គ្នាដែរ [3]តែបណ្តាទ័ពទូលឆ្លើយថា មិនត្រូវឱ្យទ្រង់យាងទៅ
ឡើយ ដ្បិតបើយើងខ្ញុំរាល់គ្នារត់ទៅ នោះគេមិនសូវរវល់
នឹងយើងខ្ញុំប៉ុន្មានទេ បើកាលណាពួកយើងខ្ញុំស្លាប់អស់ពាក់

**១៧:២៧** ស ១សយ ១១:១ ហ ចទ ៣:១១
ឡ ២សយ ៩:៤
អ ២សយ ១៩:៣១-៣៩ ១ពវ ២:៧
ក ២សយ ១៩:៣១
អគ ២:៦១
**១៧:២៩** ខ ១រប ១២:៤០ គ ២សយ ១៦:២ រម ១២:១៣
**១៨:២** ក ពច ៧:១៦ ១សយ ១១:១១
ខ ១សយ ២៦:៦
គ ២សយ ១៥:១៩
**១៨:៣** ឃ ១សយ ១៨:៧ ង ២សយ ២១:១៧
**១៨:៦** ច យស ១៧:១៥
**១៨:៩** ឆ ២សយ ១៤:២៦

កណ្តាល ក៏គេឥតរវល់ដែរ តែឯទ្រង់វិញនោះមានដំឡៃ
ស្មើនឹងពួកយើងខ្ញុំ១ម៉ឺននាក់[ឃ] ដូច្នេះស៊ូឱ្យទ្រង់ប្រុងប្រៀប
នឹងជួយយើងខ្ញុំរាល់គ្នា ពីទីក្រុងនេះវិញជាជាង[ង] [4]នោះ
ស្តេចទ្រង់មានបន្ទូលថា យើងនឹងធ្វើតាមដែលឯងរាល់គ្នា
គិតឃើញថាត្រូវ ដូច្នេះស្តេចទ្រង់ក៏ឈរនៅមាត់ទ្វារទីក្រុង
ហើយពួកបណ្តាទ័ពទាំងប៉ុន្មាន គេចេញទៅដោយពួករយ
ពួកពាន់ [5]ស្តេចទ្រង់ក៏បង្គាប់ដល់យ៉ូអាប់ អ័ប៊ីសាយ និង
អ៊ីតតាយថា ចូរមេត្តា ដល់អាប់សាឡុម ជាកូនប្រុសយើង
ផង ដោយយល់ដល់យើងបណ្តាទ័ពក៏បានឮ ក្នុងកាលដែល
ស្តេចបានផ្តាំ ពីដំណើរអាប់សាឡុម ដល់ពួកមេទាំងប៉ុន្មាន
ដែរ ។
[6]ដូច្នេះពួកបណ្តាទ័ព ក៏ចេញទៅទាស់នឹងពួកអ៊ីស្រា-
អែល ហើយតយុទ្ធគ្នានៅក្នុងព្រៃ[ច]អេប្រាអិម [7]បណ្តាពួក
ទ័ពនៃសាសន៍អ៊ីស្រាអែល គេចាញ់ពួកពលខាងដាវីឌនៅ
ទីនោះ ហើយនៅថ្ងៃនោះ មានមនុស្សស្លាប់យ៉ាងសន្ធឹក
ណាស់ អស់ចំនួន២ម៉ឺននាក់ [8]ដ្បិតការសង្គ្រាមបានលុកលុយ
ពេញក្នុងស្រុកនោះ ហើយនៅថ្ងៃនោះ ព្រៃក៏ធ្វើឱ្យបណ្តា
មនុស្សវិនាសទៅច្រើនជាងវិនាសដោយមុខដាវទៅទៀត ។
[9]រីឯអាប់សាឡុម ទ្រង់ប្រទះនឹងពួកពលទ័ពខាងដាវីឌ
គ្រានោះ ទ្រង់កំពុងគង់លើលាកាត់ សត្វជំនិះក៏ទៅក្រោម
មែកដើមម៉ៃសាក់ដែលសាងញាំង នោះព្រះសិរ[ឆ]ក៏ទាក់
ជាប់នៅនឹងមែកឈើ ព្យួរផុតពីដីឡើង ឯលាកាត់ដែលទ្រង់
គង់ក៏ដើរបង្ហួសទៅ [10]ខណនោះ មានមនុស្សម្នាក់បាន
ឃើញ ក៏ទៅជំរាបដល់យ៉ូអាប់ថា នែ៎ ខ្ញុំបានឃើញអាប់សា
ឡុមព្យួរនៅលើដើមម៉ៃសាក់មួយ [11]ឯយ៉ូអាប់ក៏បន្ទោស
ដល់អ្នកដែលប្រាប់ដំណឹងនោះថា បើឯងបានឃើញហើយ

**១៧:២៧** *សូប៊ីជាកូនណាហាស* តាមការមើលឃើញគឺជាបងប្រុសហានូន (មើល ១០:២-៤)គឺជាអ្នកដែលស្តេចដាវីឌវាយផ្តួលបំបាក់គឺក្នុងរជ្ជកាលស្តេចដាវីឌ(១១:១ ១២:២៦-៣១) ។ *ត្រង់រ៉ាបាស្រុករបស់ពួកកូនចៅអាំម៉ូន* មើលការពន្យល់ ១០:៣ ។ *ម៉ាការ* មើលការពន្យល់ ៩:៤ ។ *បារស៊ីឡាយ* គឺជាឧបការី (អ្នកឧបត្ថម្ភ)ដល់ដាវីឌក្នុងពេលកាត់ភៀសខ្លួនទៅឯស្រុកម៉ាហាណែម(មើល ១៩:៣២ ១ពវ ២:៧) ។

**១៨:២** *អ៊ីតតាយ ជាពួកកាថ* មើល ១៥:១៨-២២ ។

**១៨:៣** *មិនត្រូវឱ្យទ្រង់យាងទៅឡើយ* ក្នុងហេតុផលនោះដោយស្តេចដាវីឌចាស់ផង ក៏លែងជាអ្នកចំបាំងទៀតហើយ ។

**១៨:៥** *ចូរមេត្តាដល់អាប់សាឡុមជាកូនប្រុសយើង* គឺស្តេចដាវីឌមានព្រះទ័យស្រឡាញ់ដល់រាជបុត្រារបស់ផងទ្រង់ (មើល ១៩:៥-៧ និងការពន្យល់ ១៩:៥) ។

**១៨:៦** *អ៊ីស្រាអែល* ដូចជាកងទ័ពរបស់អាប់សាឡុម(មើល ១៥:១៣ ១៦:១៥ ១៧:៤,១១,២៤-២៦) ។ *ក្នុងព្រៃអេប្រាអិម* សង្គ្រាមបានកើតឡើងក្នុងស្រុកកាឡាតដែលស្ថិតនៅខាងកើតទន្លេយ័រដាន់ (មើល ១៧:២៤,២៤,២៦ ពច ១២:១-៤) ។

**១៨:៨** *សង្គ្រាមបានលុកលុយពេញក្នុងស្រុកនោះ* ហើយកងទ័ពជាច្រើនក៏បានរប៉ាត់រប៉ាយ មានទាហានជាច្រើនបានស្លាប់ក្នុងព្រៃរកពុំឃើញ ។

**១៨:៩** *លាកាត់* មើលការពន្យល់ ១៣:២៩ នោះព្រះសិរ (របស់អាប់សាឡុម) ក៏ទាក់ជាប់នៅនឹងមែកដើមម៉ៃសាក់ ។ *ព្យួរផុតពីដីឡើង* គឺដោយសាទ្រង់មានមែកដើមម៉ៃសាក់ដ៏ច្រើនសន្ធឹក ហើយព្រះកេសា(សក់) នោះក៏មានភាពស្រស់ស្អាតទៀត (មើល ១៤:២៥-២៦) ។

**១៨:១១** *នោះអញនឹងបានឱ្យប្រាក់* លោកយ៉ូអាប់មានបំណងឱ្យទៅអោយអ្នកណាដែលបានសម្លាប់អាប់សាឡុម នោះគឺជារង្វាន់និងប្រាក់ដួង ។ សកម្មភាពរបស់យ៉ូអាប់នឹងផលប្រយោជន៍ គឺមិនស៊ីគ្នា ឬត្រូវគ្នានឹងបំណងព្រះទ័យស្តេចដាវីឌ (មើលការពន្យល់ ២:១៣) ។

ម្តេចក៏មិនបានវាយសំឡាប់[ជ]នៅទីនោះភ្លាមទៅ នោះអញ
នឹងបានឱ្យប្រាក់១០ដួង និងខ្សែក្រវាត់១ដល់ឯង[ឈ]
១២តែអ្នក
នោះឆ្លើយតបថា បើទុកជាបានប្រាក់១ពាន់មកដៃខ្ញុំ គង់តែ
ខ្ញុំក៏មិនព្រមលូកដៃទៅទាស់នឹងព្រះរាជបុត្រានៃស្តេចដែរ
ដ្បិតយើងខ្ញុំបានឮព្រះបន្ទូលដែលទ្រង់បានផ្តាំដល់លោក
និងអ័ប៊ីសាយ ហើយអ៊ីតតាយថា ចូរប្រយ័ត្ន កុំឱ្យអ្នកណា
ពាល់អាប់សាឡំម ជាកូនមានវ័យក្មេងនោះឡើយ
១៣បើ
សិនជាខ្ញុំបានក្បត់ចំពោះព្រះជន្មព្រះរាជបុត្រានោះវិញ
គ្មានអ្វីលាក់កំបាំងនឹងស្តេចឡើយ[ញ] សូម្បីតែលោកក៏នឹង
លើកទាស់នឹងខ្ញុំដែរ
១៤យ៉ូអាប់[ដ]ឆ្លើយថា មិនគួរឱ្យអញនៅ
បង្ខាតពេលជាមួយនឹងឯងដូច្នេះទេ រួចលោកចាប់យក
ដែកពួយ៣កាន់នៅដៃ ទៅពួយទំលុះត្រង់បេះដូងអាប់សា–
ឡំម ក្នុងកាលដែលកំពុងនៅរស់ ជាប់នៅនឹងដើមម៉ៃសាក់
នៅឡើយ
១៥ឯមនុស្សកំឡោះ១០នាក់ ដែលកាន់គ្រឿង
របស់យ៉ូអាប់ ក៏ចោមរោមវាយសំឡាប់អាប់សាឡំមទៅ[ឋ] ។
១៦រួចហើយយ៉ូអាប់[ឌ]ផ្លុំត្រែឡើង នោះពួកទ័ពក៏វិល
ត្រឡប់ពីដេញតាមពួកអ៊ីស្រាអែលមកវិញ ដ្បិតលោកប្រណី
ដល់គេ
១៧គេយកសពរបស់អាប់សាឡំម ទៅបោះចោល
ក្នុងរណ្តៅធំនៅកណ្តាលព្រៃ រួចបង្គរ[ឍ]ថ្ម[ណ]ពីលើជាគំនរ
យ៉ាងធំ ឯពួកអ៊ីស្រាអែលទាំងអស់ គេរត់ទៅឯទីលំនៅ
របស់គេរៀងខ្លួនទៅ
១៨រីឯនៅគ្រាដែលអាប់សាឡំមគង់
ព្រះជន្មនៅឡើយ នោះទ្រង់ធ្វើបង្គោលថ្ម១ ទុកនៅច្រកភ្នំ
នៃហ្លួង[ត]សំរាប់ជាទីរំឭក[ថ] ដោយនឹកថាអញគ្មានកូនប្រុស[ទ]
ដើម្បីនឹងបន្តឈ្មោះអញទេ ទ្រង់ក៏ដាក់ឈ្មោះថ្មនោះតាម
នាមរបស់ទ្រង់ គេក៏ហៅថ្មនោះថា "ថ្មអាប់សាឡំម"
ដរាបដល់សព្វថ្ងៃនេះ ។

## ស្តេចដាវីឌសោយសោក

១៩គ្រានោះអ័ហ៊ីម៉ាស[ធ] កូនសាដុក មានវាចាថា សូម
អនុញ្ញាតឱ្យខ្ញុំនាំដំណឹង រត់ទៅទូលស្តេច ពីដំណើរដែល
ព្រះយេហូវ៉ាបានសងសឹកនឹងខ្មាំងសត្រូវទ្រង់ហើយ[ន]
២០តែ
យ៉ូអាប់ឆ្លើយថា ថ្ងៃនេះឯងមិនត្រូវនាំយកដំណឹងទៅទេចាំ
ដល់ថ្ងៃក្រោយវិញ តែថ្ងៃនេះមិនត្រូវនាំយកដំណឹងទៅ
ឡើយ ពីព្រោះព្រះរាជបុត្រនៃស្តេចសុគតហើយ
២១រួច
មកយ៉ូអាប់ប្រាប់ទៅគូស៊ីថា ចូរឯងទៅទូលស្តេចពីការ
ដែលឯងបានឃើញចុះ គូស៊ីក៏ក្រាបសំពះយ៉ូអាប់ ហើយរត់
ទៅ
២២នោះអ័ហ៊ីម៉ាស ជាកូនសាដុក គាត់សូមយ៉ូអាប់ម្តង
ទៀតថា ទោះបីជាយ៉ាងណាក៏ដោយ សូមឱ្យខ្ញុំរត់ទៅតាម
គូស៊ីផង យ៉ូអាប់តបថា កូនអើយ ឯងចង់រត់ទៅធ្វើអី
ដំណឹងយ៉ាងនេះមិនមែនជាគុណដល់ឯងទេ
២៣តែគាត់ថា
ទោះបើយ៉ាងណាក៏ដោយចុះ គង់តែខ្ញុំនឹងរត់ទៅដែរ ដូច្នេះ
យ៉ូអាប់ក៏បណ្តោយថា ចូររត់ទៅចុះ អ័ហ៊ីម៉ាសក៏រត់ទៅ
តាមផ្លូវវាលដល់មុខគូស៊ី ។
២៤ឯដាវីឌទ្រង់គង់នៅត្រង់រវាងទ្វារទាំង២ អ្នកចាំយាម[ប]
ក៏ឡើងទៅលើខ្លោងទ្វារកំផែង រួចងើបភ្នែកឡើងមើល
ទៅ ឃើញមនុស្សម្នាក់កំពុងតែរត់មក
២៥អ្នកចាំយាមក៏
ស្រែកទូលដល់ស្តេច ទ្រង់មានបន្ទូលថា បើវាមកតែឯង
នោះគឺវានាំដំណឹងមកហើយ អ្នកនោះមកកាន់តែជិតដល់
២៦រួចអ្នកចាំយាមឃើញម្នាក់ទៀតកំពុងតែរត់មក ក៏ស្រែក
ប្រាប់ទៅអ្នកឆ្មាំទ្វារថា មើលន៏ មានម្នាក់ទៀតរត់មកដែរ
ស្តេចទ្រង់មានបន្ទូលថា នោះក៏នាំដំណឹង[ផ]មកដែរ
២៧អ្នក
ចាំយាមទូលថា ទូលបង្គំស្មានថា អ្នកដែលរត់មកមុន នោះ
មានភាពរត់ដូច[ព]ជាអ័ហ៊ីម៉ាស កូនសាដុក ស្តេចមានបន្ទូល
តបថា អ្នកនោះជាមនុស្សក៏នាំដំណឹងល្អមក ។
២៨គ្រានោះ អ័ហ៊ីម៉ាសស្រែកទូលមកស្តេចថា មានសុខ
ហើយ រួចគាត់ក្រាបផ្កាប់មុខដល់ដី នៅចំពោះស្តេចទូលថា
សូមក្រាបថ្វាយបង្គំដល់ព្រះយេហូវ៉ា ជាព្រះនៃព្រះករុណា
ដោយទ្រង់បានប្រគល់ពួកអ្នក ដែលលើកដៃទាស់នឹងព្រះ

**១៨:១១** ជ ២សយ ៣:៣៩ ឈ ១សយ ១៨:៤
**១៨:១៣** ញ ២សយ ១៤:១៩–២០
**១៨:១៤** ដ ២សយ ២:១៨
**១៨:១៥** ឋ ២សយ ១២:១០
**១៨:១៦** ឌ ២សយ ២:២៨
**១៨:១៧** ឍ យស ៦:២៦ ណ យស ៨:២៩
**១៨:១៨** ត លប ១៤:១៧ ថ លប ៥០:៥ ជន ៣២:៤២ ទ ២សយ ១៤:២៧
**១៨:១៩** ធ ២សយ ១៥:៣៦ ន ពច ១១:៣៦
**១៨:២៤** ប ១សយ ១៤:១៦ យរ ៥១:១២
**១៨:២៦** ផ ១ពវ ១:៤២ អស ៥២:៧ ៦១:១
**១៨:២៧** ព ២ពវ ៩:២០

**១៨:១៥** *វាយសំឡាប់* (អាប់សាឡំម)ក៏ជាយុទ្ធសាស្ត្រដ៏ងាយ ក្នុងការបញ្ជាក់ការបះបោរ ក៏ប៉ុន្តែការសម្លាប់ដ៏កាចសាហាវនេះក៏ជាការបង្ហាញពីគំនិតសងសឹងដោយទាហានរបស់ស្តេចដាវីឌ ចំពោះអាប់សាឡំម ។

**១៨:១៧** *បង្គរថ្មពីលើជាគំនរយ៉ាងធំ* គឺជាគំនរថ្មជាច្រើន ដាក់ពីលើព្រះសពរបស់អាប់សាឡំមបានជាវិមានមួយដែលឈរឡើង(ខ.១៨) ។ *រីឯពួកអ៊ីស្រាអែលទាំងអស់គេរត់ទៅឯទីលំនៅរបស់គេរៀងខ្លួនទៅ* មើលការពន្យល់ ខ.៦ ។

**១៨:១៨** *ធ្វើបង្គោលថ្ម១ទុកនៅច្រកភ្នំនៃហ្លួង សំរាប់ជាទីរំឭក* គឺដូចជាលោកប៉ុលបានធ្វើដូច្នេះដែរ (មើល ១សយ ១៥:១២ និងការពន្យល់) ។ *ច្រកភ្នំនៃហ្លួង* គឺស្ថិតនៅក្បែរក្រុងយេរូសាឡិម(មើល លប ១៤:១៧) ។ *អញគ្មានកូនប្រុស* មើល ១៤:២៧ និងការពន្យល់ ។ *ថ្មអាប់សាឡំម* គឺដើម្បីកុំឱ្យច្រឡំដល់ថ្មបង្គោលជាច្រើនទៀតដែលមាននៅ ហើយអាចមើលឃើញក្នុងច្រកភ្នំតំបន់ខាងកើត នៃក្រុងយេរូសាឡិម គឺមានសព្វថ្ងៃនេះ ។

**១៨:១៩** *អ័ហ៊ីម៉ាសកូនសាដុក* មើល ១៥:២៧ ១៧:១៧–២១ ។

**១៨:២០** *ថ្ងៃនេះឯងមិនត្រូវនាំយកដំណឹងទៅទេ* ការជ្រើសរើសអ្នកនាំសារគឺស្របទៅតាមអត្ថបទដែលមាន (មើល ខ.២៧ និងការពន្យល់) ។

**១៨:២១** *គូស៊ី* (មើលការពន្យល់ ជន ១២:១) ។

**១៨:២៧** *ក៏នាំដំណឹងល្អមក* ដាវីឌក៏សន្មតថាលោកយ៉ូអាប់ក៏មិនបញ្ជូនអ្នកណាម្នាក់មកមានលក្ខណៈដូចជាអ័ហ៊ីម៉ាល ដើម្បីកាន់យកដំណឹងអាក្រក់ទេ(មើល ខ.២០ និងការពន្យល់) ។

ករុណា ជាព្រះអម្ចាស់នៃទូលបង្គំមកហើយ ២៩ស្ដេចទ្រង់
មានបន្ទូលសួរថា តើអាប់សាឡំម ជាកូនប្រុស យើងសុខ
សប្បាយទេឬ អ័ហ៊ីម៉ាសទូលឆ្លើយថា កាលយ៉ូអាប់បាន
ចាត់ទូលបង្គំ ជាអ្នកបំរើនៃព្រះករុណាមកនោះទូលបង្គំ
ឃើញថា មានជ្រួលជ្រើមជាខ្លាំង តែមិនដឹងជាមានហេតុអ្វី
ទេ ៣០ដូច្នេះស្ដេចប្រាប់ថា ចូរឯងបែរទៅ ឈរខាងនោះ
សិន គាត់ក៏បែរទៅឈរស្ងៀមនៅទីនោះ ។

៣១លំដាប់នោះ គូស៊ីក៏មកដល់ទូលថា ទូលបង្គំមាន
ដំណឹងមកថ្វាយព្រះករុណា ជាព្រះអម្ចាស់នៃទូលបង្គំ ដ្បិត
នៅថ្ងៃនេះ ព្រះយេហូវ៉ាបានសងសឹកនឹងពួកក្បត់ ដែលបាន
លើកដៃទាស់នឹងព្រះករុណាហើយ ៣២ស្ដេចទ្រង់មានបន្ទូល
សួរគូស៊ីថា តើអាប់សាឡំមកូនប្រុសយើងសុខសប្បាយទេឬ
គូស៊ីទូលឆ្លើយថា សូមឱ្យពួកខ្មាំងសត្រូវនៃព្រះករុណា
ជាព្រះអម្ចាស់នៃទូលបង្គំ និងអស់អ្នកដែលលើកគ្នា ក្បត់
ចំពោះទ្រង់ បានដូចជាបុត្រាទ្រង់ចុះ[ភ] ៣៣នោះស្ដេចទ្រង់
មានសេចក្ដីរំជួលក្នុងព្រះទ័យជាខ្លាំង ក៏យាងឡើងទៅក្នុង
បន្ទប់ខាងលើខ្លោងទ្វារ ហើយទ្រង់ព្រះកន្សែងកំពុងដែល
ទ្រង់យាងទៅ ទ្រង់ក៏មានបន្ទូលដូច្នេះថា ឱអាប់សាឡំម
កូនអញ កូនអញអើយ ឱអាប់សាឡំម កូនអញអើយ ស៊ូឱ្យ
អញបានស្លាប់[ម]ជំនួសឯង ឱអាប់សាឡំម កូនអញ កូនអញ
អើយ[យ] ។

**១៩** ១មានគេទៅជំរាបដល់យ៉ូអាប់ថា ស្ដេចទ្រង់ព្រះ
កន្សែងសោកទោមនស្សនឹងអាប់សាឡំម ២ថ្ងៃនោះឯង ការ
ជ័យជំនះក៏ត្រឡប់ទៅ ជាសេចក្ដីទុក្ខសោក ដល់ពួកជនទាំង
ឡាយវិញ ពីព្រោះនៅថ្ងៃនោះ គេឮដំណឹងថា ស្ដេចទ្រង់
សោកទោមនស្សនឹងព្រះរាជបុត្រា ៣ដូច្នេះ នៅថ្ងៃនោះ
ប្រជាជនចូលមកក្នុងទីក្រុងដោយលួចលាក់ ដូចជាពួក
មនុស្ស ដែលលបចេញពីទីចំបាំងទៅ ដោយខ្មាស ៤ឯស្ដេច
ទ្រង់បិទព្រះភ័ក្ត្រ ស្រែកឡើងជាខ្លាំងថា ឱអាប់សឡំម កូន
អញអើយ ឱអាប់សាឡំម កូនអញ ជាកូនអញអើយ ៥គ្រា
នោះ យ៉ូអាប់មកឯស្ដេច នៅក្នុងព្រះរាជមន្ទីរទូលថា នៅ
ថ្ងៃនេះ ព្រះករុណាបានធ្វើឱ្យពួកប្រជាជនទាំងឡាយ ដែល
ជាពួកអ្នកបំរើទ្រង់មានសេចក្ដីខ្មាស គឺជាពួកអ្នកដែលបាន
ជួយសង្គ្រោះដល់ព្រះជន្មនៃព្រះករុណា នឹងព្រះរាជបុត្រា
បុត្រី ពួកភរិយា ហើយនិងពួកអ្នកម្នាង របស់ព្រះករុណា
នៅថ្ងៃនេះផង ៦ដោយស្រឡាញ់ដល់ពួកអ្នកដែលស្អប់ទ្រង់
ហើយក៏ស្អប់ដល់ពួកអ្នកដែលស្រឡាញ់ទ្រង់វិញ ដ្បិតនៅថ្ងៃ
នេះព្រះករុណាបានសំដែងថា ទ្រង់មិនរាប់អាន ដល់ទាំង
ពួកអ្នកធំតូចផង ហើយនៅថ្ងៃនេះទូលបង្គំក៏យល់ឃើញថា
បើអាប់សាឡំមនៅរស់នៅឡើយ ហើយយើងខ្ញុំទាំងអស់គ្នា
បានស្លាប់ទៅ នោះនឹងបានជាទីពេញដល់ព្រះហឫទ័យទ្រង់
ណាស់ ៧ដូច្នេះ សូមព្រះករុណាក្រោកឡើង យាងចេញ
ទៅមានបន្ទូលឱ្យពួកអ្នកបំរើទ្រង់ក្សាន្តចិត្តឥឡូវចុះ ដ្បិត
ទូលបង្គំស្បថដោយនូវព្រះយេហូវ៉ាថា បើសិនជាទ្រង់មិន
ធ្វើដូច្នោះទេ នោះនឹងគ្មានអ្នកណាមួយ នៅជាមួយនឹង
ទ្រង់នៅយប់នេះឡើយ យ៉ាងនោះនឹងបានអាក្រក់ដល់ព្រះ
ករុណាលើសជាងអស់ទាំងការអាក្រក់ដែលកើតដល់ទ្រង់
តាំងពីកុមារ ដរាបដល់សព្វថ្ងៃនេះទៅទៀត[ក] ៨ដូច្នេះ ស្ដេច
ទ្រង់ក៏ក្រោកឡើង យាងចេញទៅគង់នៅមាត់ទ្វារក្រុង
ហើយមានគេទៅប្រកាសដល់បណ្ដាជនទាំងឡាយថា មើល
ស្ដេចទ្រង់កំពុងតែគង់នៅមាត់ទ្វារ[ខ] នោះពួកបណ្ដាជន
ទាំងឡាយ ក៏មកគាល់នៅចំពោះស្ដេច ។

### ស្ដេចដាវីឌត្រឡប់ទៅយេរូសាឡិមវិញ

៩រីឯពួកអ៊ីស្រាអែល គេបានរត់ទៅឯទីលំនៅរបស់
គេរៀបខ្លួន ហើយបណ្ដាជនទាំងឡាយក៏កើតវិវាទគ្នា នៅ

**១៨:៣២** ភ ពច ៥:៣១ ១សយ ២៥:២៦
**១៨:៣៣** ម នក ៣២:៣២ យ លប ៤៣:១៤ ២សយ ១៩:៤
**១៩:៧** ក សភ ១៤:២៨
**១៩:៨** ខ ២សយ ១៥:២

**១៨:២៩** អ័ហ៊ីម៉ាសជៀសវាងនូវការឆ្លើយត្រង់ៗ ចំពោះសំនួររបស់ស្ដេចដាវីឌដោយគេដឹងថាអាប់សាឡំមបានសុគតហើយ ។

**១៨:៣៣** *ឱអាប់សាឡំមកូនអញអើយ* ស្ដេចដាវីឌបានពោលគ្រប់ទាំងសូរស័ព្ទអំពីភាពសោកស្ដាយចំពោះការសុគតនៃបុត្រារបស់ទ្រង់ ។ *ស៊ូឱ្យអញបានស្លាប់ជំនួសឯង* គឺជាហេតុការណ៍របស់ស្ដេចដាវីឌ ដែលទ្រង់ជាអ្នកទទួលខុសត្រូវគ្រប់ទាំងអស់ក៏ដូចជាការសុគតរបស់បុត្រាទ្រង់ ។ សកម្មភាពរបស់អង្គទ្រង់ផ្ទាល់បានផ្ដល់ឱ្យមានឧទាហរណ៍ អវិជ្ជមានដោយព្រោះបុត្រានៃអង្គទ្រង់បានធ្វើសកម្មភាពសងតបមកវិញឱ្យដូចទ្រង់បានធ្វើដែរ ។ គឺដោយគ្មានសមត្ថភាពក្នុងភាពជាស្ដេច ដែលនាំឱ្យអាប់សាឡំមធ្វើការបះបោរ ។ ក្នុងការដែលអាប់សាឡំមបានសុគតក្នុងកណ្ដាប់ដៃលោកយ៉ូអាប់ ។ អំពើរបសស្ដេចដាវីឌបានបន្ទាបបន្ថោកដល់អំណាចរបស់រាជវង្ស ហើយទទួលបានលទ្ធផលចុងក្រោយគឺផលផ្លែដ៏អាក្រក់បំផុត ។

**១៩:៤** *ឯស្ដេចទ្រង់បិទព្រះភ័ក្ត្រ* ប្រៀបធៀបការពន្យល់ ១៥:៣០ ។

**១៩:៥** *គ្រានោះយ៉ូអាប់មកឯស្ដេច* គឺភ្លាមនោះទ្រង់យល់ថា ឬពុំបានគិតថាលោកយ៉ូអាប់មានចំណែកក្នុងរឿងសុគតរបស់បុត្រាទ្រង់អាប់សាឡំមទេ ។ ដាវីឌក៏ពុំនឹកស្មានថាទ្រង់ទទួលការងារនេះដែរ (មើល ១ពវ ២:៥) ។ *ព្រះករុណាបានធ្វើឱ្យពួកប្រជាជនទាំងឡាយមាន ដែលជាពួកអ្នកបំរើទ្រង់មានស្ដេចក្ដីខ្មាស* យ៉ូអាប់ក៏បន្ទោសដល់ស្ដេចដាវីឌដែលការសោកស្ដាយរបស់ទ្រង់ បង្ហាញពីការមិនឱ្យតម្លៃដល់អ្នកដែលការពារបល្ល័ង្កទ្រង់ បានធ្វើឱ្យមាន មហន្តរាយដល់ជីវិតទ្រង់ ។

**១៩:៩** *ស្ដេចទ្រង់បានជួយឱ្យយើងរួច* ក្នុងរឿងសុគតរបស់អាប់សាឡំមនោះគឺពួជអំបូរផ្នែកភូមិភាគខាងជើងចងចាំថា គឺជាកិច្ចការរបស់ស្ដេចដាវីឌបាន

ពេញក្នុងពូជអំបូរសាសន៍អ៊ីស្រាអែលទាំងអស់ថា ស្ដេច
ទ្រង់បានជួយឱ្យយើងរួចពីកណ្ដាប់ដៃរបស់ពួកខ្មាំងសត្រូវ
យើងក៏បានជួយសង្គ្រោះឱ្យរួចពីកណ្ដាប់ដៃពួកភីលីស្ទីន
ដែរ[គ] ឥឡូវនេះ ទ្រង់បានរត់ពីមុខអាប់សាឡុម ចេញពីនគរ
ទៅ[ឃ] ១០ឯអាប់សាឡុម ដែលយើងបានចាក់ប្រេងតាំងឱ្យ
សោយរាជ្យលើយើង នោះបានសុគតក្នុងសង្គ្រាមហើយ
ដូច្នេះហេតុអ្វីបានជានៅស្ងៀម មិនទៅនាំស្ដេចត្រឡប់មក
វិញ ។

១១ចំណែកស្ដេចដាវីឌ ទ្រង់ចាត់គេទៅឯសាដុក[ង] និង
អ័បៀថើរដ៏ជាសង្ឃ ដោយបន្ទូលថា ចូរសួរដល់ពួកចាស់ទុំ
នៃពួកយូដាថា ហេតុអ្វីបានជាអ្នករាល់គ្នាយឺតយូរជាងគេ
ក្នុងការអញ្ជើញស្ដេចមកក្នុង ដំណាក់វិញដូច្នេះដ្បិតសួរ
សព្ទ ដែលពួកអ៊ីស្រាអែលកំពុងតែនិយាយ គ្នានោះបានឮ
ទៅដល់ស្ដេចនៅឯព្រះរាជមន្ទីរហើយ ១២អ្នករាល់គ្នាជា
ពួកញាតិ ហើយជាសាច់ឈាមនឹងយើងផង ហេតុអ្វីបាន
ជានៅយឺតយូរជាងគេ ក្នុងការអញ្ជើញស្ដេចមកវិញដូច្នេះ
១៣មួយទៀតត្រូវប្រាប់ដល់អ័ម៉ាសាថា[ច] តើអ្នកមិនមែនជា
សាច់ឈាមនឹងយើងទេឬអី[ឆ] បើយើងមិនបានលើកអ្នកឡើង
ឱ្យធ្វើជាមេទ័ពជំនួសយ៉ូអាប់[ជ] នៅមុខ យើងជាដរាបទៅទេ
នោះសូមឱ្យព្រះធ្វើទោសដល់យើង ហើយលើសទៅទៀត
ផង[ឈ] ១៤យ៉ាងនោះទ្រង់បានបំពត់ចិត្តរបស់ពួកយូដាទាំង
អស់ ឱ្យព្រមព្រៀងគ្នាដូចជាមនុស្សតែម្នាក់វិញ ដល់ម្ល៉េះ
បានជាគេចាត់ទៅស្ដេចទូលថា សូមព្រះករុណាទ្រង់យាង
ត្រឡប់មក ព្រមទាំងពួកទ្រង់ផង ១៥ដូច្នេះ ស្ដេចក៏យាង
ត្រឡប់ទៅវិញ បានដល់ត្រឹមទន្លេយ័រដាន់ ឯពួកយូដាគេទៅ
ដល់ក្រុងគីលកាល[ញ] ដើម្បីនឹងទៅទទួលស្ដេច ហើយចំឡង
ទ្រង់ពីទន្លេយ័រដាន់មក ។

១៦រីឯស៊ីម៉ាយ[ដ] ជាកូនកេរ៉ា ក្នុងពូជអំបូរបេនយ៉ាមីន
ដែលនៅភូមិបាហ៊ូរីម ក៏ប្រញាប់ចុះមកទទួលស្ដេចដាវីឌ
ជាមួយនឹងពួកយូដាដែរ ១៧មានទាំងពួកបេនយ៉ាមីន១ពាន់
នាក់ ហើយស៊ីបា[ឋ]ជាអ្នកបំរើរបស់ព្រះវង្សនៃសូល[ឌ]និងកូន
ទាំង១៥នាក់ ព្រមទាំងបាវបំរើគាត់ទាំង២០នាក់មកជា
មួយផង គេនាំគ្នាឆ្លងទន្លេយ័រដាន់ទៅ នៅចំពោះស្ដេច
១៨ក៏មានទូក១ឆ្លងទៅ សំរាប់នឹងទទួលចំឡងពួករាជវង្ស
ស្ដេចមក ហើយនឹងធ្វើតាមព្រះទ័យទ្រង់ នៅគ្រាដែលស្ដេច
រៀបឆ្លងទន្លេយ័រដាន់មក នោះស៊ីម៉ាយ ជាកូនកេរ៉ាក៏ផ្តួល
ខ្លួនក្រាបចុះ នៅចំពោះទ្រង់ទូលថា ១៩បពិត្រព្រះអម្ចាស់
សូមកុំប្រកាន់ទោសទូលបង្គំឡើយ សូមកុំរឭកដល់សេចក្ដី
អាក្រក់ ដែលទូលបង្គំជាបាវបំរើទ្រង់បានប្រព្រឹត្ត ដោយ
ល្មើស នៅថ្ងៃដែលទ្រង់ព្រះករុណា ជាព្រះអម្ចាស់នៃទូល
បង្គំបានយាងចេញពីក្រុងយេរូសាឡិមទៅនោះ[ឍ] ឬយកព្រះ
ទ័យទុកដាក់ឱ្យសោះ ២០ដ្បិតទូលបង្គំជាបាវបំរើនៃទ្រង់
យល់ឃើញថា បានធ្វើអាក្រក់ហើយ ហេតុនោះបានជាទូល
បង្គំមកដល់នៅថ្ងៃនេះមុន ជាងបណ្ដាវង្សានុវង្សនៃយ៉ូសែប
ទៅទៀត ដើម្បីនឹងចុះមកទទួលព្រះករុណា ជាព្រះអម្ចាស់
នៃទូលបង្គំ ២១តែអ័ប៊ីសាយ[ណ] ជាកូនសេរូយ៉ា ចាប់ពាក្យ
ទូលថា តើមិនត្រូវសំឡាប់ស៊ីម៉ាយដោយព្រោះបានជេរ
ប្រមាថ[ត]ដល់ អ្នកដែលព្រះយេហូវ៉ា បានចាក់ប្រេងតាំងឱ្យ
ទេឬអី[ថ] ២២ប៉ុន្តែដាវីឌមានបន្ទូលថា ឱកូនសេរូយ៉ា[ទ]រាល់
គ្នាអើយ តើយើងត្រូវការអ្វីនឹងឯង បានជាឯងមកធ្វើជាអ្នក
ទាស់ទទឹងនឹងយើងនៅថ្ងៃនេះដូច្នេះ តើត្រូវសំឡាប់មនុស្ស
ក្នុងពួកអ៊ីស្រាអែលនៅថ្ងៃនេះឬអី[ធ] ដ្បិតតើយើងមិនដឹងទេ

**១៩:៩** គ ២សយ ៨:១–១៤ ឃ ២សយ ១៥:១៤
**១៩:១១** ង ២សយ ១៥:២៤
**១៩:១៣** ច ២សយ ១៧:២៥ ឆ លប ២៩:១៤ ជ ២សយ ២:១៣ ឈ នរ ១:១៧
**១៩:១៥** ញ ១សយ ១១:១៥
**១៩:១៦** ដ ២សយ ១៦:៥–១៣
**១៩:១៧** ឋ ២សយ ៩:២ ឌ លប ៤៣:១៦
**១៩:១៩** ឍ ២សយ ១៦:៦–៨
**១៩:២១** ណ ១សយ ២៦:៦ ត នក ២២:២៨ ថ ១សយ ១២:៣ ២៦:៩
**១៩:២២** ទ ២សយ ២:១៨ ១៦:១០ ធ ១សយ ១១:១៣

ធ្វើចំពោះពួកគេទៅវិញ (មើល ៣:១៧–១៨,៥:២) ។

**១៩:១១** *ចូរសួរដល់ពួកចាស់ទុំនៃពួកយូដា* ទោះជាការបះបោរបានកើតឡើងនៅឯហេប្រុនស្រុកយូដាក៏ដោយ(មើល ១៥:៩–១២) ស្ដេចដាវីឌបានធ្វើការទំនាក់ទំនងនឹងពួកចាស់ទុំ ក្នុងពូជអំបូររបស់គាត់ផ្ទាល់ ដើម្បីការងាររៀបចំរាជបល្ល័ង្កឡើងវិញ ក្នុងក្រុងយេរូសាឡិម (មើល ២:៤ ១សយ ៣០:២៦ និងការពន្យល់) ។ ការងារនេះបានជាលទ្ធផលតាមសេចក្ដីប្រាថ្នាក៏នាំឱ្យមានភាពច្រណែនគ្នាក្នុងពូជអំបូរនិមួយៗ(មើល ខ.៤១–៤៣) ។

**១៩:១៣** *អ័ម៉ាសាថា តើមិនមែនជាសាច់ឈាមនឹងយើងទេឬអី* មើល ១៧:២៥ និងការពន្យល់ ។ ស្ដេចដាវីឌបានចាត់ឱ្យអ័ម៉ាសាថា ធ្វើជាមេទ័ពក្នុងទីកន្លែងរបស់យ៉ូអាប់ដោយសង្ឃឹមថា អ័ម៉ាសាថាអាចដឹកនាំពួកយ៉ូដា និងកេណ្ឌពួកយូដាឱ្យមកចូលរួមគ្នា(មើល ២០:៤ និងការពន្យល់) ។ *នោះសូមឱ្យព្រះធ្វើទោសដល់យើងហើយលើសទៅទៀតផង* គឺជាបណ្ដាសាមួយ (មើល ១សយ ៣:១៧) ។

**១៩:១៥** *ក្រុងគីលកាល* មើលការពន្យល់ យស ៤:១៩ ។

**១៩:១៧** *ពួកបេនយ៉ាមីន១ពាន់នាក់* គឺពុំបាច់ឆ្ងល់ឡើយគេបានភ័យដោយពួកគេស្ថិតក្នុងការសង្ស័យពីស្ដេចដែលទាក់ទង និងស៊ីម៉ាយ ។

**១៩:១៩** *បាវបំរើទ្រង់បានប្រព្រឹត្តបទល្មើស* មើល ១៦:៥–១៣ ។

**១៩:២០** *ដ្បិតទូលបង្គំជាបាវបំរើនៃទ្រង់យល់ឃើញថា បានធ្វើអាក្រក់ហើយ* គឺជាអំពើអាក្រក់របស់ស៊ីម៉ាយ តម្រូវឱ្យគាត់សុំនូវការអត់ទោសបាប ។ *វង្សានុវង្សនៃយ៉ូសែប* មើលស យស ១៨:៥ ពច ១:២២ ពវ ១១:២៨ អម ៥:៦ ។

**១៩:២១** *អ័ប៊ីសាយ* មើលការពន្យល់ ១សយ ២៦:៦ គឺព្រះបានចាត់ប្រេងតាំង មើលការពន្យល់ ១សយ ៩:១៦ មើល ១សយ ២៤:៦ ២៦:១១ នក ២២:២៨ ១ពវ ២១:១០ ។

**១៩:២២** *ឱកូនសេរូយ៉ារាល់គ្នាអើយ* មើលការពន្យល់ ១៦:១០ ។ *តើត្រូវសំឡាប់មនុស្សក្នុងពួកអ៊ីស្រាអែលនៅថ្ងៃនេះឬអី* ដោយថ្ងៃនេះជាទូទៅវាជាថ្ងៃដែលត្រូវលើកលែងទោស(មើល ១សយ ១១:១៣) ។

ឬអីថា នៅថ្ងៃនេះ យើងជាស្តេចលើសាសន៍អ៊ីស្រាអែល
វិញហើយ ២៣រួចស្តេចទ្រង់មានបន្ទូលស្បថនឹងស៊ីម៉ាយថា
ឯងមិនត្រូវស្លាប់ទេ[ន] ។
២៤ចំណែកមភីបូសែត[ប] ជាព្រះវង្សសូល លោកក៏ចុះទៅ
ទទួលស្តេចដែរ លោកមិនបានមើលជំងឺជើង ឬកាត់ពុក
ចង្កា ឬគក់បោកខោអាវឡើយ តាំងតែពីថ្ងៃដែលស្តេចទ្រង់
ចាកចេញទៅ ដរាបដល់ថ្ងៃដែលទ្រង់យាងមកវិញដោយ
សុខសាន្ត ២៥រីឯកាលលោកបានទៅដល់ក្រុងយេរូសាឡិម
ដើម្បីនឹងគាល់ស្តេច នោះទ្រង់មានបន្ទូលសួរថា មភីបូ-
សែតអើយ ហេតុអ្វីបានជាអ្នកមិនបានទៅជាមួយនឹងយើង[ផ]
២៦លោកក្រាបទូលថា បពិត្រព្រះករុណាជាព្រះអម្ចាស់នៃ
ទូលបង្គំអើយ បាវ[ព]ទូលបង្គំបានបញ្ឆោតទូលបង្គំ ដ្បិតទូល
បង្គំ ជាបាវបំរើនៃទ្រង់បានសំរេចថា នឹងចងកែបលាជិះ
ទៅជាមួយនឹងព្រះករុណាដែរ ពីព្រោះទូលបង្គំជាមនុស្ស
ខ្វិនជើង[ភ] ២៧តែវាបានទូលបង្កាច់ទូលបង្គំ ជាបាវបំរើនៅ
ចំពោះទ្រង់វិញ ឯព្រះករុណា ជាព្រះអម្ចាស់នៃទូលបង្គំ
ទ្រង់ដូចជាទេវតា[ម]នៃព្រះហើយ ដូច្នេះ សូមទ្រង់សំរេច
តាមតែព្រះហឫទ័យចុះ ២៨ដ្បិតព្រះវង្សនៃបិតាទូលបង្គំ
បានដូចជាមនុស្សស្លាប់ហើយ[យ] នៅចំពោះព្រះករុណាជា
ព្រះអម្ចាស់នៃទូលបង្គំ ប៉ុន្តែ ទ្រង់បានប្រោសដំរូវឱ្យទូល
បង្គំ ជាបាវបំរើនៃទ្រង់ បាននៅក្នុងពួកនាក់ដែលបរិភោគ
នៅតុរបស់ទ្រង់[រ] ដូច្នេះតើទូលបង្គំនៅមានច្បាប់អ្វីនឹង
ស្រែករកព្រះករុណាទៀត ២៩ស្តេចទ្រង់មានបន្ទូលតបថា
អ្នកនៅនិយាយពីរឿងអ្នកទៀតធ្វើអី យើងសំរេចថា ចូរ
ឱ្យអ្នកនឹងស៊ីបាបែងចែកស្រែចំការគ្នាទៅ ៣០មភីបូសែត
ទូលឆ្លើយថា ឱ្យគេយកទាំងអស់ទៅចុះ ពីព្រោះព្រះករុណា
ជាព្រះអម្ចាស់ បានវិលមកឯដំណាក់ ដោយសុខសាន្ត
ហើយ។
៣១ឯបារស៊ីឡាយ[ល]ជាពួកកាឡាត លោកចុះពីក្រុងរ៉ូគីលីម
មក ឆ្លងទន្លេយ័រដាន់ ដើម្បីនឹងជូនស្តេចទៅត្រើយម្ខាងដែរ
៣២លោកជាមនុស្សមានវ័យកន្លងហើយ មានអាយុ៨០ឆ្នាំ
គត់ លោកបានផ្គត់ផ្គង់ស្បៀងអាហារថ្វាយស្តេច ក្នុងកាល
ដែលទ្រង់គង់នៅស្រុកម៉ាហាណែម ដ្បិតលោកជាអ្នកមាន
ស្តុក[វ] ៣៣ស្តេចទ្រង់មានបន្ទូលទៅលោកថា សូមអញ្ជើញ
ទៅជាមួយនឹងខ្ញុំ នោះខ្ញុំនិងបីបាច់រក្សាលោក នៅឯក្រុង
យេរូសាឡិម ៣៤តែបារស៊ីឡាយទូលឆ្លើយថា តើទូលបង្គំ
នឹងនៅរស់បានប៉ុន្មានទៅទៀត ដែលនឹងគួរតាមព្រះ
ករុណាឡើងទៅឯក្រុងយេរូសាឡិមនោះ ៣៥ថ្ងៃនេះទូល
បង្គំមានអាយុ៨០[ស]ឆ្នាំហើយ តើនឹងអាចសង្កេតរបស់ល្អ
ពីរបស់អាក្រក់បានឬអី តើទូលបង្គំជាបាវបំរើទ្រង់ អាចនឹង
ភ្លក់រសនៃរបស់ដែលទទួលទាន ឬអាចស្តាប់សំឡេងរបស់
ពួកចំរៀងប្រុសស្រីទៀតបានឬទេ[ហ] ដូច្នេះ តើគួរអ្វីឱ្យទូល
បង្គំបាននៅផ្ទុក[ឡ]លើព្រះករុណា ជាព្រះអម្ចាស់នៃទូលបង្គំ
ទៀត ៣៦ទូលបង្គំជាបាវបំរើទ្រង់ ចង់គ្រាន់តែឆ្លងជូនព្រះ
ករុណា ទៅត្រឹមត្រើយទន្លេយ័រដាន់ម្ខាងប៉ុណ្ណោះទេ ហេតុ
អ្វីបានជាចង់សងទូលបង្គំដោយរង្វាន់ជាធំម្ល៉េះធ្វើអី ៣៧សូម
អនុញ្ញាតឱ្យទូលបង្គំ ជាបាវបំរើទ្រង់ត្រឡប់ទៅវិញចុះ
ដើម្បីឱ្យបានស្លាប់នៅឯស្រុករបស់ទូលបង្គំជិតផ្នូរនៃមាតា
បិតា[អ]វិញ តែមើល នេះគឹមហាំ ជាអ្នកបំរើទ្រង់[ក] សូមឱ្យវា
ឆ្លងទៅជាមួយនឹងព្រះករុណា ជាព្រះអម្ចាស់នៃទូលបង្គំចុះ
ហើយសូមប្រោសដល់វា តាមព្រះទ័យផង ៣៨ស្តេចទ្រង់
មានបន្ទូលតបថា គឹមហាំនឹងឆ្លងទៅជាមួយនឹងខ្ញុំពិត ខ្ញុំ
នឹងធ្វើគុណដល់គាត់ តាមបំណងចិត្តលោក ហើយបើ
លោកត្រូវការអ្វីៗ នោះខ្ញុំនឹងជួយទាំងអស់ដែរ ៣៩ដូច្នេះ
បណ្តាជនទាំងឡាយបានឆ្លងទន្លេយ័រដាន់ផុតទៅ រួចស្តេច
ទ្រង់ក៏ឆ្លងទៅដែរ ទ្រង់ថើបបារស៊ីឡាយ ហើយប្រទានពរ
ដល់លោក[ខ] រួចលោកក៏ត្រឡប់ទៅឯទីលំនៅវិញ ។

**១៩:២៣** ន ១ពវ ២:៨,៤២
**១៩:២៤** ប ២សយ ៤:៤
**១៩:២៥** ផ ២សយ ១៦:១៧
**១៩:២៦** ព ២សយ ៩:២ ភ លវ ២១:១៨
**១៩:២៧** ម ១សយ ២៩:៩
**១៩:២៨** យ ២សយ ១៦:៨ រ ២សយ ៩:៧,១៣
**១៩:៣១** ល ២សយ ១៧:២៧–២៩ ១ពវ ២:៧
**១៩:៣២** វ ១សយ ២៥:២
**១៩:៣៥** ស ទដ ៩០:១០ ហ ២រប ៣៥:២៥ អរ ២:៦៥ សស ២:៨ ១២:១ ឡ ២សយ ១៥:៣៣
**១៩:៣៧** អ លប ៤៩:២៩ ក យរ ៤១:១៧ **១៩:៣៩** ខ លប ៤៧:៧

**១៩:២៣** *ឯងមិនត្រូវស្លាប់ទេ* ស្តេចដាវីឌបានគោរពពាក្យព្រះបន្ទូលសន្យាគឺមិនសងសឹកដល់អ្នកដែលប្រឆាំងនឹងទ្រង់ឡើយ (មើលការពន្យល់ ១សយ ២៥:១–៤៤) ។ ប៉ុន្តែនៅពេលទ្រង់សុគតទ្រង់បានផ្តាំផ្ញើស្តេចសាឡូម៉ូនជារាជបុត្រារបស់ទ្រង់ឱ្យកាន់កាប់ករណីក្តីក្តាំង រឿងរ៉ាវរបស់ស៊ីម៉ាយនៅនឹងដៃឱ្យជាប់(មើល ១ពវ ២:៨–៩,៣៦–៤៦) ។
**១៩:២៤** *មភីបូសែត* មើល ៩:៦–១៣ ។
**១៩:២៥** *ហេតុអ្វីបានជាអ្នកមិនបានទៅជាមួយនឹងយើង* គឺស្តេចដាវីឌបានចងចាំពីពាក្យសំដីថ្លែងរបស់ស៊ីបាពីមុនមក (មើល ១៦:៣) ។
**១៩:២៦** *ខ្វិនជើង* មើល ៤:៤ ៩:៣ ។
**១៩:២៧** *វាបានទូលបង្កាច់ទូលបង្គំជាបាវបំរើ* មើល ១៦:៣ ។ *ទ្រង់ដូចជាទេវតានៃព្រះ* មើល ១៤:១៧ និងការពន្យល់ ។ *សំរេចតាមតែព្រះហឫទ័យចុះ* (មើល ១៦:៤) ។
**១៩:២៩** *បែងចែកចំការគ្នា* បន្ទាប់ពីជំលោះដែលពុំបង្ហាញឱ្យច្បាស់ ការវិនិច្ឆ័យទូទៅរបស់ស្តេចដាវីឌ តាមលំដាប់ពីការបែងចែកទ្រព្យសម្បត្តិរបស់សូល(ប្រៀបធៀប ១ពវ ៣:២៥ និងការពន្យល់) ។
**១៩:៣១** *បារស៊ីឡាយ* មើលការពន្យល់ ១៧:២៧ ។
**១៩:៣៥** ប្រៀបធៀប សស ១២:២–៥ និងការពន្យល់ ។ *តើនឹងអាចសង្កេតរបស់ល្អអាក្រក់បានឬទេ* តាមអាយុរបស់គាត់ គាត់នឹងមិនអើពើពីគ្រប់ទាំងទីកន្លែងដែលសប្បាយទៀតហើយ ។
**១៩:៣៧** *គឹមហាំ* ឈ្មោះនេះដូចជាកូនបារស៊ីឡាយ (មើល ១ពវ ២:៧) ។

៤០ រីឯស្ដេចទ្រង់យាងទៅដល់ក្រុងគីលកាល ហើយ
គីមហាំក៏តាមទៅដែរ ចំណែកបណ្ដាពួកយូដា និងពួក
អ៊ីស្រាអែល១ចំហៀង គេក៏ដង្ហែស្ដេចទៅ
៤១ នោះពួក
អ៊ីស្រាអែលទាំងអស់ គេមកគាល់ស្ដេច ទូលថា ហេតុអ្វីបាន
ជាពួកយូដា ជាបងប្អូនយើងខ្ញុំ បានទាក់ព្រះទ័យព្រះករុណា
ដោយចំឡងទ្រង់ ព្រមទាំងព្រះរាជវង្សាទាំងប៉ុន្មាននឹង
បណ្ដាពួកទ័ពទ្រង់ ឆ្លងទន្លេយ័រដាន់មកដូច្នេះ[គ]
៤២ ពួកយូដា
ទាំងប៉ុន្មាន គេឆ្លើយទៅពួកអ៊ីស្រាអែលថា គឺពីព្រោះស្ដេច
ជាញាតិវង្សជិតដិតនឹងយើងទេតើ ដូច្នេះ ហេតុអ្វីបានជា
អាក់អន់ចិត្តដោយព្រោះការនេះ តើយើងបានបរិភោគអ្វី
ដែលត្រូវឱ្យស្ដេចបង់ខាត ឬទ្រង់បានប្រទាន រង្វាន់អ្វីមក
យើងខ្លះ
៤៣ តែពួកអ៊ីស្រាអែល[ឃ]គេឆ្លើយតបទៅពួកយូដា
វិញថា យើងមានចំណែក១០ភាគខាងស្ដេចដែរ ហើយខាង
ដាវីឌនេះ យើងមានច្បាប់លើសជាងអ្នករាល់គ្នាទៅទៀត
ដូច្នេះ ហេតុអ្វីបានជាអ្នករាល់គ្នាមើលងាយយើង ដោយ
មិនបានពិគ្រោះនឹងយើងជាមុន ពីដំណើរនាំស្ដេចមក ប៉ុន្តែ
ពាក្យសំដីរបស់ពួកយូដា បានម៉ឺងម៉ាត់ ជាងពាក្យរបស់ពួក
អ៊ីស្រាអែលវិញ ។

## សេបាបះបោរប្រឆាំងនិងស្ដេចដាវីឌ

**២០** ១ រីឯនៅទីនោះ មានមនុស្សចោលម្សៀតម្នាក់ឈ្មោះ
សេបា ជាកូនប៊ីគ្រី ពូជបេនយ៉ាមីន វាក៏ផ្លុំត្រែឡើងពោលថា
យើងរាល់គ្នាគ្មាន ចំណែក[ក]ខាងដាវីឌ[ខ] ក៏គ្មានមរដកខាង
កូនអ៊ីសាយទេ[គ] ឱអ៊ីស្រាអែលអើយ ចូរយើងត្រឡប់ទៅឯ
ទីលំនៅយើងគ្រប់គ្នាទៅ
២ ដូច្នេះ ពួកអ៊ីស្រាអែលទាំងអស់
ក៏លះបង់ចោលដាវីឌ ទៅតាមសេបាជា កូនប៊ីគ្រីវិញ តែ
ពួកយូដាគេតាមស្ដេចគេជាប់ទៅ ចាប់តាំងពីទន្លេយ័រដាន់
រហូតដល់ក្រុងយេរូសាឡិម ។
៣ ដាវីឌក៏យាងមកដល់ដំណាក់ទ្រង់ នៅក្រុងយេរូសាឡិម
នោះទ្រង់យកពួកអ្នកម្នាងទាំង១០នាក់[ឃ] ដែលបានទុកឱ្យ
នៅចាំដំណាក់ទៅបង្ខាំងទុក ហើយចិញ្ចឹមរក្សាដោយ
ស្បៀងអាហារ តែមិនបានយាងចូលទៅឯនាងណាមួយ
ទៀតទេ ដូច្នេះ នាងទាំងនោះត្រូវបង្ខាំងទុក ឱ្យនៅជា
មេម៉ាយរហូតដល់ថ្ងៃស្លាប់ ។
៤ រួចមក ស្ដេចទ្រង់មានបន្ទូលបង្គាប់ នៅអ័ម៉ាសាថា[ង]
ចូរកេណ្ឌ ពួកយូដា ឱ្យមកឯយើងក្នុង៣ថ្ងៃ ហើយត្រូវឱ្យអ្នក
នៅទីនេះដែរ
៥ ដូច្នេះ អ័ម៉ាសាក៏ចេញទៅកេណ្ឌពួកយូដា
តែលោកបង្អង់នៅហួសវេលាកំណត់ដែលស្ដេចបានបង្គាប់
៦ នោះដាវីឌមានបន្ទូលទៅអ័ប៊ីសាយ[ច]ថា ឥឡូវនេះ សេបា
ជាកូនប៊ីគ្រី នឹងប្រទូសរ៉ាយដល់យើង លើសជាងអាប់–
សាឡុំមទៅទៀត ដូច្នេះ ចូរអ្នកនាំយកពួកពលរបស់
ចៅហ្វាយនៃអ្នក ទៅដេញតាមវា ក្រែងវាបានទីក្រុងមាន
កំផែងណាមួយ ហើយបាត់ពីយើងទៅ
៧ ដូច្នេះ កងទ័ព
របស់យ៉ូអាប់ព្រមទាំងពួកកេរេធីម[ឆ] នឹងពួកពេលេធីម
ហើយពួកខ្លាំងពូកែទាំងអស់ ក៏ចេញទៅជាមួយនឹងលោក
គេចេញពីក្រុងយេរូសាឡិម ទៅដេញតាមសេបា ជាកូន
ប៊ីគ្រី
៨ កាលបានទៅដល់ថ្មធំនៅស្រុកគីបៀនហើយ[ជ] នោះ
អ័ម៉ាសាក៏មកប្រទះនឹងគេ ឯយ៉ូអាប់[ឈ]លោកបានពាក់អាវ
គ្រោះ ហើយនៅចង្កេះមានកាំបិតនៃបនៅខ្សែក្រវាត់
កំពុងដែលលោកដើរទៅមុខ នោះកាំបិតក៏របូតចេញ
៩ រួច
លោកសួរទៅអ័ម៉ាសាថា បងអើយ សុខសប្បាយជាទេឬ
យ៉ូអាប់ក៏លូកដៃស្ដាំទៅចាប់ពុកចង្កាអ័ម៉ាសា ដើម្បីនឹងថើប
១០ ឯអ័ម៉ាសាមិនបានជារវាំងនឹងកាំបិត[ញ] ដែលនៅដៃ

**១៩:៤១** គ ពច ៨:១ ១២:១
**១៩:៤៣** ឃ ២សយ ៥:១
**២០:១** ក លប ៣១:១៤ ខ លប ២៩:១៤ ១ពរ ១២:១៦ គ ១សយ ២២:៧–៨
**២០:៣** ឃ ២សយ ១៥:១៦
**២០:៤** ង ២សយ ១៧:២៥
**២០:៦** ច ២សយ ២១:១៧
**២០:៧** ឆ ១សយ ៣០:១៤ ២សយ ១៥:១៨
**២០:៨** ជ យស ៩:៣ ឈ ២សយ ២:១៨
**២០:១០** ញ ពច ៣:២១

**១៩:៤០** *ក្រុងគីលកាល* មើល ខ.១៥ និងការពន្យល់ ។
**១៩:៤៣** *ចំណែក១០ភាគ* គឺមានអំបូរទាំងអស់១០តែមិនបញ្ចូលយូដា និង ស៊ីម្មូនទេ (មើល ២:៤) ។ *ខាងស្ដេចហើយខាងដាវីឌនេះ យើងមានច្បាប់លើសជាងអ្នករាល់គ្នាទៅទៀត* ដោយហេតុនេះហើយគឺជាព្រះទ័យនៃព្រះយេហូវ៉ាបានរើសតាំងដាវីឌជាស្ដេច សោយរាជ្យនៅកន្លែងតំណែងរបស់ស្ដេចសូស(មើល ៣:១៧–១៨ ៥:២)។
**២០:១** *មនុស្សចោលម្សៀតម្នាក់* មើលការពន្យល់ ចទ ១៣:១៣ ។ ពូជបេនយ៉ាមីន គឺជាពូជអំបូរមួយដែលតែងតែមានភាពច្រណែនឈ្នានីស ពីការផ្លាស់ប្ដូរពីខ្សែរាជវង្សបេនយ៉ាមីន ទៅឱ្យពូជអំបូរយូដាវិញ ។ ក្នុងក្រុងគីលកាល(១៩:៤០) ។ *យើងគ្មានចំណែកខាងដាវីឌ* (មើល ១ពរ ១២:១៦) ។ មើលការពន្យល់ ១សយ ២០:២៧,៣០–៣១ ។
**២០:២** *ពួកអ៊ីស្រាអែលទាំងអស់* គឺយោងទៅតាមនៅក្នុង ១៩:៤១–៤៣ ។
**២០:៣** *អ្នកម្នាងទាំង១០នាក់* មើលការពន្យល់ ១៥:១៦ ១៦:២២ ។
**២០:៤** *អ័ម៉ាសា* មើលការពន្យល់ ១៧:២៥ ១៩:១៣ ស្ដេចដាវីឌបានរំលងយ៉ូអាប់ ។
**២០:៦** *អ័ប៊ីសាយ* ស្ដេចដាវីឌបានរំលងពីយ៉ូអាប់ជាលើកទីពីរ (ខ.៧) ។
**២០:៧** *កងទ័ពរបស់យ៉ូអាប់* មើល ១៨:២ ។ វាបង្ហាញឱ្យច្បាស់ថា យ៉ូអាប់បានទៅរួមដំណើរជាមួយកងទ័ពដែលមិនមែន បញ្ជាដោយស្ដេចទេគេរៀបទ័ពឡើងដោយពលទាហានទាំងអស់(មើល ខ.៧,១១,១៥) ។ ពួកកេរេធីម និងពួកពេរេធីម មើលការពន្យល់ ៨:១៨ ។ *ពួកខ្លាំងពូកែទាំងអស់* មើល ២៣:៨–៣៩ ។ គឺមានពេលមួយទៀត ដែលស្ដេចដាវីឌជួបប្រទះវិបត្តិហើយក៏បែរទៅពឹងផ្អែកកងទ័ពដ៏តូចមួយក្រុម ដែលជាទ័ពមានជំនាញច្បាស់លាស់ខាងចម្បាំង(កងទ័ពភាគច្រើន គឺមិនមែនជារាស្ត្រអ៊ីស្រាអែលទៀត) គឺជាទ្រង់ដែលរៀបចំទ័ពនោះជាលក្ខណៈផ្ទាល់ខ្លួន (ទាហានផ្ទាល់ខ្លួន) ។
**២០:៨** *ស្រុកគីបៀន* មើលការពន្យល់ ២:១២ ។ *អ័ម៉ាសាក៏មក* (មើល ខ.១១ និងការពន្យល់) ។

យ៉ូអាប់[ដ] ទេ ដូច្នេះ យ៉ូអាប់ក៏ចាប់វះពោះលោកឱ្យធ្លាយពោះ
វៀនចេញទ្រេលដល់ដី ឥតមានចាក់ម្តងទៀតទេ ហើយ
លោកក៏ស្លាប់ទៅ រួចយ៉ូអាប់ និងអ័ប៊ីសាយ ជាប្អូនក៏ដេញ–
តាមសេបា ជាកូនប៊ីគ្រីទៅ ១១មានម្នាក់ក្នុងពួកយ៉ូអាប់ឈរ
ជិតលោកប្រកាសថា អ្នកណាដែលស្ម័គ្រចិត្តខាងយ៉ូអាប់
ហើយនៅខាងដាវីឌ ចូរមកតាមយ៉ូអាប់ចុះ ១២ឯអ័ម៉ាសា
លោកននៀលនៅក្នុងឈាម នាកណ្តាលផ្លូវ កាលអ្នកនោះ
ឃើញថា បណ្តាទ័ពទាំងប៉ុន្មានឈប់ឈរនៅ[ឋ] នោះគាត់យក
អ័ម៉ាសាចេញពីផ្លូវទៅដាក់នៅវាលវិញ ហើយយកអាវ១
គ្រប់ ព្រោះឃើញថាគ្រប់គ្នាដែលមកដល់ទីនោះចេះតែ
ឈប់នៅ ១៣កាលបានយកលោកចេញពីផ្លូវហើយ នោះ
បណ្តាទ័ពដើរតាមយ៉ូអាប់ទៅដើម្បី និងដេញតាមសេបាជា
កូនប៊ីគ្រី ។
១៤អ្នកនោះដើរកាត់គ្រប់ទាំងខែត្រនៃពូជអំបូរអ៊ីស្រាអែល
ទៅដល់ត្រឹមក្រុងអេបិល–បេត–ម្អាកា ហើយពួកបេរី[ឌ] ក៏
មូលគ្នាទាំងអស់ ទៅតាមវាដែរ ១៥ពួកខាងយ៉ូអាប់ក៏មក
ឡោមព័ទ្ធវា នៅក្រុងអេបិល–បេត–ម្អាកា[ឍ] គេលើកដី
បង្គរឡើង[ណ] ធ្វើជាផ្លូវទៅដល់កំផែងហើយ ពួកទ័ពក៏បុក
កំផែង ដើម្បីនឹងរំលំចេញ ១៦នៅគ្រានោះមានស្រីប្រាជ្ញ
ម្នាក់[ត] ស្រែកមកពីក្នុងទីក្រុងថា សូមស្តាប់ៗសូមជំរាបឱ្យ
យ៉ូអាប់អញ្ជើញមកជិតនេះសិន ដើម្បីឱ្យខ្ញុំបាននិយាយនឹង
លោក ១៧លោកក៏ចូលទៅជិតនាង រួចនាងសួរថា តើ
លោកឈ្មោះយ៉ូអាប់ឬអី លោកឆ្លើយថា គឺខ្ញុំនេះហើយរួច
នាងពោលថា សូមស្តាប់ពាក្យរបស់ខ្ញុំជាបាវលោកសិន
លោកឆ្លើយថា ខ្ញុំកំពុងស្តាប់ ១៨នោះនាងនិយាយថា កាល
ដើមដំបូងគេធ្លាប់ពោលថា ពិតប្រាកដជាគេនឹងសួររក
ដំបូន្មាននៃពួកក្រុងអេបិល គឺយ៉ាងនោះដែលគេបានសំរេច
ការនីមួយៗ ១៩ចំណែកខ្ញុំ ជាម្នាក់ក្នុងពួកដែលចង់បាន
សេចក្តីសុខ[ថ] ហើយក៏ស្មោះត្រង់នៅស្រុកអ៊ីស្រាអែល ឯ
លោកវិញ លោករកបំផ្លាញទីក្រុង១ ដែលទុកដូចជាម្តាយ
ក្នុងស្រុកអ៊ីស្រាអែល ហេតុអ្វីបានជាលោកចង់លេបបំបាត់
មរដកនៃព្រះយេហូវ៉ាធ្វើអី[ទ] ២០នោះយ៉ូអាប់ឆ្លើយតបថា
សូមឱ្យបំណងចង់លេបបំបាត់ ហើយបំផ្លាញ បាននៅឆ្ងាយ
ពីខ្ញុំ គឺឱ្យបាននៅឆ្ងាយពីខ្ញុំទៅពិត ២១មិនមែនដូច្នោះទេ គឺ
មានមនុស្សម្នាក់ដែលមកពីស្រុកភ្នំអេប្រាអិម ឈ្មោះសេបា
ជាកូនប៊ីគ្រី វាបានលើកដៃក្បត់ចំពោះស្តេចដាវីឌវិញ
ចូរប្រគល់តែខ្លួនវា១មកប៉ុណ្ណោះនោះយើងនឹងថយចេញពី
ទីក្រុងនេះទៅហើយ ស្រីនោះឆ្លើយមកយ៉ូអាប់ថា ចាំមើល
គេនឹងបោះក្បាលវា[ធ]រំលងកំផែងមកជូនលោក ២២នោះ
នាងក៏ទៅបញ្ចុះបញ្ចូលមនុស្សទាំងឡាយ ដោយប្រាជ្ញា
របស់នាង[ន] ហើយគេកាត់ក្បាលសេបា ជាកូនប៊ីគ្រី បោះទៅ
ជូនយ៉ូអាប់ រួចលោកផ្លុំត្រែឡើង ហើយគេក៏ថយចេញពី
ទីក្រុងនោះ ត្រឡប់ទៅឯទីលំនៅរបស់គេគ្រប់ៗគ្នាទៅ
ចំណែកយ៉ូអាប់ លោកក៏វិលត្រឡប់ទៅឯក្រុងយេរូសាឡិម
វិញ រួចចូលទៅគាល់ស្តេច ។
២៣ចំណែកឯយ៉ូអាប់[ប] លោកជាអ្នកត្រួតលើពួកពល
ទ័ពនៃសាសន៍អ៊ីស្រាអែលទាំងអស់ បេណាយ៉ា ជាកូនយេ–
ហូយ៉ាដា លោកជាមេលើពួកកេរេធីម និងពួកពេលេធីម

**២០:១០** ដ ១ពវ ២:៥
**២០:១២** ឋ ២សយ ២:២៣
**២០:១៤** ឌ ជន ២១:១៦
**២០:១៥** ឍ ១ពវ ១៥:២០ ២ពវ ១៥:២៩ ណ អស ៣៧:៣៣ យរ ៦:៦ ៣២:២៤
**២០:១៦** ត ២សយ ១៤:២
**២០:១៩** ថ ចទ ២:២៦ ទ ១សយ ២៦:១៩
**២០:២១** ធ ២សយ ៤:៨
**២០:២២** ន សស ៩:១៣
**២០:២៣** ប ២សយ ២:២៨ ៨:១៦–១៨ ២៤:២
**២០:២៤** ផ ១ពវ ៤:៦ ៥:១៤ ១២:១៨ ២របា ១០:១៨

**២០:១០** *ចាក់វះពោះលោក* មើល ២:២៣,៣:២៧ ។ គឺជាលើកទីពីរហើយ ដែលយ៉ូអាប់បានសម្លាប់ធ្វើឃាដ ដើម្បីធានាភាពស្ថិតស្ថេរនៃដំណែងរបស់គាត់គឺក្នុងនាមជាមេទ័ពរបស់ស្តេចដាវីឌ (មើល ១ពវ ២:៥–៦) ។ *យ៉ូអាប់និងអ័ប៊ីសាយជាប្អូន* គឺជាអ្នកដែលរឹងទទឹងជម្នះមិនព្រមស្តាប់ការបញ្ជារបស់ស្តេចដាវីឌ (មើល ខ.២៣) ។

**២០:១១** *អ្នកណាដែលស្ម័គ្រចិត្តខាងយ៉ូអាប់ហើយនៅខាងដាវីឌ* គឺជាការបំបាត់នៅគំនិតដែលយ៉ូអាប់ត្រូវបានគេរៀបចំជាស្រេច ក្នុងការរួមគំនិតធ្វើអំពើទុច្ចរិត ហើយទំនងជាបង្កើតក្រុមទ័ពអ័ម៉ាសា ដើម្បីគាំទ្រដល់យ៉ូអាប់បើពួកគេពិតជាមានភាពស្មោះនឹងដាវីឌ ។

**២០:១៤** *ក្រុងអេបិល–បេត–ម្អាកា* គឺមានទីតាំងនៅភូមិភាគខាងជើងនៃស្រុកដាន់ (មើល ១ពវ ១៥:២០ ១របា ១៦:៤ និងការពន្យល់) ។ ហើយយុទ្ធសាស្ត្ររបស់សេបាគឺត្រូវកេណ្ឌពួកអ្នកស្ម័គ្រ ដើម្បីប្រឆាំងបះបោរតែគាត់មានការភិតភ័យយ៉ាខ្លាំង ក្នុងការរួមកម្លាំង ។

**២០:១៩** *ដូចជាម្តាយក្នុងស្រុកអ៊ីស្រាអែល* គឺជាទីក្រុងដែលបង្កើតរាស្ត្រអ៊ីស្រាអែល ដែលមានភាពស្មោះត្រង់ ក៏ជាទីក្រុងដែលបញ្ជាក់ពីស្ត្រីម្នាក់ (មើល ៥០:១២ កទ ៥:២៦) ។ គឺជាមរដកពីព្រះយេហូវ៉ា មើលការពន្យល់ ១យស ១០:១ ។

**២០:២១** *ពីស្រុកភ្នំអេប្រាអិម* គឺឈ្មោះសេបាផងដែរ (មើល ខ.១) ដែលមានមនុស្សរស់នៅក្នុងបែបតាមតំបន់ព្រំប្រទល់អំបូររបស់ពួកគេនៃអេប្រាអិមជាទីដែលពួកគេបានកំណត់ចំពោះភូមិសាស្ត្រនៃអំបូរបានល្អប្រសើរ ។

**២០:២២** *ចំណែកយ៉ូអាប់លោកក៏វិលត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ រួចចូលទៅគាល់ស្តេច* មើលការពន្យល់ ខ.៧,១០ ។

**២០:២៣–២៦** មន្ត្រីរាជវាំងទាំងនេះបានមានមុខបម្រើការនៅរាជវាំងដល់ស្តេចដាវីឌ គឺក្នុងរាជបល័ង្កស្តេចដាវីឌ (មើល ៨:១៥–១៨) ។

**២០:២៣** *ចំណែកឯយ៉ូអាប់លោកជាអ្នកត្រួតលើពួកពលទ័ព នៃសាសន៍អ៊ីស្រាអែលទាំងអស់* តែមានពេលខ្លះគាត់បានធ្វើទាស់ព្រះហឫទ័យស្តេច ក្នុងការចូលរួមធ្វើអំពើអាក្រក់ ជាមួយអ័ដូនីយ៉ាជាបុត្រនៃនាងហាគីត (១ពវ ១:៧ ២:២៨–៣៥) ។ *កេរេធីមនិងពួកពេលេធីម* មើលការពន្យល់ ៨:១៨ ។

**២០:២៤** *អ័ដូរ៉ាមលោកជាមេកំណែន* ដែលបានតែងតាំងជាមេកំណែនតាំងពីឆ្នាំដំបូងនៃរាជកាលស្តេចដាវីឌមកម្លេះ (មើល ៨:១៥–១៦) ។ ការតែងតាំងនេះក្រោយមកក៏បានបម្រើការងារក្រោមការគ្រប់គ្រងដោយបុត្រាសាឡូម៉ូន (១ពវ ៤:៦ ៥:១៤) ក៏ត្រូវបានស្លាប់ដោយគេសម្លាប់ក្នុងថ្ងៃដំបូងនៃរជ្ជ

២៤ អ័ដូរ៉ាម[ឍ] លោកជាមេកំណែន ឯយ៉ូសាផាត[ព] ជាកូនអ័ហ៊ី–
លូឌ លោកជាអ្នកកត់ត្រាពង្សាវតារ ២៥ សេរ៉ាយ៉ាជាស្មៀន
ហ្លួងសាដុក[ភ] និងអ័បៀថើរជាសង្ក្រាជ ២៦ ហើយអ៊ីរ៉ា ជាពូជ
យ៉ាអ៊ារ លោកជាចាងហ្វាងលើពួកសេនាបតីរបស់ដាវីឌ ។

## ការសងសឹករបស់គីបៀន

**២១** ១ នៅគ្រាស្តេចដាវីឌ នោះមានអំណត់អត់[ក]អស់ចេញ
៣ឆ្នាំ ហើយដាវីឌទ្រង់រក[ខ] ព្រះយេហូវ៉ា ដើម្បីទូលសួរហេតុ
រួចព្រះយេហូវ៉ាទ្រង់ឆ្លើយថា គឺដោយព្រោះសូល និងវង្ស
ញាតិទ្រង់ ដែលកំចាយឈាម ដ្បិតទ្រង់បានសំឡាប់ពួក
គីបៀន ២ ដូច្នេះស្តេចដាវីឌទ្រង់ហៅ ពួកគីបៀន[គ] មកសួរគេ
(រីឯពួកគីបៀនគេមិនមែនជាពូជកូនចៅអ៊ីស្រាអែលទេ គឺ
ជាសំណល់នៃពូជអាម៉ូរីវិញ ហើយពួកកូនចៅអ៊ីស្រាអែល
បានស្បថនឹងគេ តែសូលទ្រង់រកសំឡាប់គេដោយមានសេច
ក្តីខ្នះខ្នែង ដល់ពួកកូនចៅអ៊ីស្រាអែលនិងពួកយូដាវិញ)
៣ ដាវីឌទ្រង់សួរពួកគីបៀនថា តើចង់ឱ្យយើងសងអ្នករាល់
គ្នាយ៉ាងណាខ្លះ តើត្រូវឱ្យយើងធ្វើអ្វីឱ្យធួននឹងការនោះ
ដើម្បីឱ្យអ្នករាល់គ្នាបានឱ្យពរដល់ មរដកនៃព្រះយេហូវ៉ា
ផង[ឃ] ៤ ពួកគីបៀនទូលឆ្លើយថា ឯរឿងរបស់យើងខ្ញុំ និង
សូល ព្រមទាំងរាជវង្សរបស់ទ្រង់នោះមិនមែនចំពោះមាស
ឬប្រាក់ទេ ក៏មិនស្រេចឱ្យយើងខ្ញុំសំឡាប់អ្នកណាមួយក្នុងពួក
អ៊ីស្រាអែលដែរ[ង] ទ្រង់មានបន្ទូលតបថា ការអ្វីដែលអ្នក
រាល់គ្នាថា នោះយើងនឹងសំរេចឱ្យ ៥ គេទូលឆ្លើយទៅស្តេច
ថា ឯមនុស្សនោះដែលបានពង្រើងយើងខ្ញុំរាល់គ្នា ហើយ
បានបង្កើតហេតុនឹងបំផ្លាញយើងខ្ញុំ មិនឱ្យមាន នៅក្នុងព្រំ
ដែនស្រុកអ៊ីស្រាអែលណាឡើយ ៦ នោះសូមប្រគល់កូនចៅ
របស់អ្នកនោះ៧នាក់មកយើងខ្ញុំ ដើម្បីឱ្យយើងខ្ញុំបានចង
កគេ នៅចំពោះ[ច] ព្រះយេហូវ៉ាត្រង់គីបៀរ ជាទីក្រុងរបស់
សូល ជាអ្នកដែលព្រះយេហូវ៉ាបានរើសតាំង[ឆ] ឯស្តេចទ្រង់

**២០:២៤** ព ២សយ ៨:១៦
**២០:២៥** ភ ១សយ ២:៣៥ ២សយ ៨:១៧
**២១:១** ក លប ១២:១០ ចទ ៣២:២៤ ខ នក ៣២:១១
**២១:២** គ យស ៩:១៥
**២១:៣** ឃ ១សយ ២៦:១៩
**២១:៤** ង ជន ៣៥:៣៣–៣៤
**២១:៦** ច ជន ២៥:៤ ឆ ១សយ ១០:២៤

កាលស្តេចរេហូបោម(១ពវ ១២:១៨) ។ មេកំណែន គឺជាកំលាំងបានមកពីភិរុតជនសង្គ្រាម ដែលយកចេញពីជាតិសាសន៍មួយចំនួនដែលបានចាញ់ក្នុងសង្គ្រាម (មើល ១២:៣១ និងការពន្យល់ ១ពវ ៩:១៥,២០–២១) ។ *អ្នកកត់ត្រា* មើលការពន្យល់ ៨:១៦ ។

**២០:២៥** *សេរ៉ាយ៉ា* មើលការពន្យល់ ៨:១៧ (សេរ៉ាយ៉ា)ជាស្មៀនហ្លួង ។ មើលការពន្យល់ ៨:១៧ ។ *សាដុកនឹងអ័បៀថើរ* មើលការពន្យល់ ៨:១៧ ។

**២០:២៦** *ពូជយ៉ាអ៊ារ* គឺសំដៅលើពូជនៃអំបូរម៉ាន៉ាសេ គឺជាអ្នកស្រុកមួយដែលបានបោះជំរុំនៅស្រុកមួយ គឺជាស្រុក ហារ៉ុ–យ៉ាអ៊ារ (ជន ៣២:៤១) (១ពវ ៤:១៣) ។ *សង្គ្រាម* មើលការពន្យល់ ៨:១៨ ។

**២១:១–២៤:២៥** ផ្នែកវគ្គបញ្ចប់នេះបង្កើតបានជាទម្រង់សង្ខេបសាច់រឿងមួយពី ១,២ សយ និងបន្ថែមរឿងរ៉ាវដែលទាក់ទងនឹងរជ្ជកាលហ្លួងដាវីឌ ។ ដែលរៀបចំជាលំដាប់អក្សរនៃការតែងនិពន្ធ គឺដូចពីលំដាប់អក្សរ ក,ខ,គ/គ,ខ,ក ឧទាហរណ៍ ទដ ២៥ និងសេចក្តីផ្តើមរបស់វា ៤៥(ប្រៀបធៀប អស ៦:១០ និងការពន្យល់) ។ ដូចជាផ្នែកដំបូងនឹងផ្នែកចុងក្រោយ(២១:១–១៤ ២៤:១–២៥)គឺការរៀបរាប់នៃព្រឹត្តការណ៍ពីការកើតឡើង ដែលស្តេចដាវីឌមានទំនាក់ទំនងនឹងព្រះ ។ ការក្រោធរបស់ព្រះប្រឆាំងនឹងរាស្ត្រអ៊ី–ស្រាអែល(ការងារស្តេចសូលដំបូងក្រោយមកជាលើកទីពីរ ជាព្រឹត្តការណ៍ទី២ និងទី៥ នៅផ្នែក(២១:១៥–២២ ២៣:៨–៣៩)បង្ហាញពីដាវីឌជាអ្នកចំបាំង មានផ្នែកទីពីរទៀត គឺវែងជាងផ្នែកទី១ ។ នៅផ្នែកសាច់រឿងកណ្តាល គឺមានឃើញពីរឿងបទរបស់ដាវីឌចំរៀងទី១វែងជាងទី២ មួយផ្នែកនោះ បង្ហាញពីការប្រារព្ធពីបុណ្យជ័យជំនះរបស់ស្តេចដាវីឌ ដែលជាស្តេចអ្នកសង្គ្រាម ផ្នែកមួយទៀតហោរាទ្រង់ជាអ្នកតែងនិពន្ធបទទំនុកចំរៀងសរសើរ មើលការពន្យល់ ១សយ ១៦:១៤–១៧:៥៨ ។ ក៏បង្ហាញពីចម្រៀងកាលស្ត្រីបានទៅជួបស្តេចសូល និងដាវីឌបន្ទាប់ពីគេបានទទួលជ័យជន្នះលើពួកភីលីស្ទីន ដោយសូលបានសម្លាប់សត្រូវ១ពាន់ និងដាវីឌបានសម្លាប់១ម៉ឺន ១សយ ១៨:៧ ។ គេក៏សន្មតថា"អ្វីដែលស្ត្រីបាននិយាយ គឺជាដាវីឌនិងសូល" ស្ថិតក្នុងភាពជោគជ័យពីលើសត្រូវបរទេស តែសព្វថ្ងៃនេះអំពើកាប់សម្លាប់នេះ គឺធ្លាក់មកលើរាស្ត្រអ៊ីស្រាអែលជាអ្នកទទួល ។

**២១:១–១៤** ព្រឹត្តិការណ៍បង្ហាញឱ្យឃើញភាពអត់ធម៌មេត្តា របស់ស្តេចដាវីឌក៏បានរីកដុះដាលរហូតដល់មភីបូសែត គឺមុនពេលអាប់សាឡំមបះបោរ (១៦:៧–៨ ១៨:២៨ និងការពន្យល់ ១៦:៨) ។

**២១:១** *ដ្បិតទ្រង់បានសំឡាប់ពួកគីបៀន* សកម្មភាពសូលដែលប្រឆាំងនិងគីបៀន គឺមិនទាក់ទងនិងទីកន្លែងផ្សេងៗទេតែវាមានតាំងពីការគ្រងរាជដំបូងរបស់ទ្រង់ ។ ក៏មានការចូលរួមចាប់តាំងពីពួកគីបៀនបានគ្រប់គ្រងផ្នែកព្រំដីខ្លះក្នុងស្រុកពួកបេនយ៉ាមីន ។ ជីតាទួតរបស់សូលគឺគេស្គាល់ថាជាបិតារបស់កេបា (១របា ៨:២៩,៩:៣៥) ។

**២១:២** *ពូជអាម៉ូរី* តាមការយល់ដឹងបើជាឈ្មោះត្រូវបានគេប្រើ កំណត់ឱ្យគ្រប់អស់អ្នកស្រុកអ៊ីស្រាអែលទាំងអស់ តាំងពីមុនមកម្ល៉េះដែលមានទឹកដីក្នុងស្រុកកាណាន(លប ១៥:១៦ យស ២៤:១៨ ពច ៦:១០ អម ២:១០) (យស ៩:៧ ១១:១៩) ។ *ពួកកូនចៅអ៊ីស្រាអែលបានស្បថនឹងគេ* គឺជាការស្បថស្បែក្នុងព្រះនាមព្រះយេស៊ូគ្រីស្ទ(សយ ៩:១៥,១៨–២១) ។ *មានចិត្តខ្នះខ្នែងដល់ពួកកូនចៅអ៊ីស្រាអែល* ហេតុផលដែលលោកសូល ពុំបានជោគជ័យដោយលោកពុំបានស្គាល់ច្បាប់ ។

**២១:៣** *ឱ្យពរដល់* តាំងពីគេបានស្បថសច្ចាក្នុងព្រះនាមព្រះយេហូវ៉ា គេក៏បានបំពានព្រះនាមព្រះយេហូវ៉ា គេពុំអាចឃាត់បញ្ឈប់បណ្តាសាដែលមាននៅលើទឹកដីស្រុករបស់គេ ។ *មរដកនៃព្រះយេហូវ៉ា* មើលការពន្យល់ ១សយ ១០:១ ។

**២១:៥** *ឯមនុស្សនោះ* លោកសូល *មិនឱ្យមាននៅក្នុងព្រំដែនស្រុកអ៊ីស្រាអែល* គឺអ្នកដែលគេចចេញពីការធ្វើទុករបស់សូល ក៏បានចេញពីទីក្រុងរបស់គេ និងចេញពីស្រុករបស់គេ(មើល ៤:២–៣) ។

**២១:៦** *៧នាក់* គឺជាតំណាងតួរលេខទាំងអស់ (៧តំណាងជិន្នសភាពទាំងអស់) នៃពួកគីបៀនដែលបានសម្លាប់យ៉ាងសាហាវនោះ ។ ត្រង់គីបៀន គឺជាទីកន្លែងរបស់ស្រុកលោកប៉ុល ទីលំនៅលោកប៉ុល (សូមមើល ១សយ ១០:២៦) ។

មានបន្ទូលថា យើងនឹងប្រគល់ឱ្យ។
៧ស្តេចទ្រង់ប្រណីដល់មភីបូសែត[ជ] ជាកូនយ៉ូណាថាន
ដែលជាបុត្រសូល ដោយព្រោះដាវីឌ និងយ៉ូណាថាន ជា
បុត្រាសូលបានស្បថគ្នា[ឈ]នៅចំពោះព្រះយេហូវ៉ា ៨តែទ្រង់
យកកូនប្រុសទាំង២របស់រីសបា[ញ]ជាកូនអ័យ៉ា ដែលនាង
បានបង្កើតថ្វាយសូល គឺអើម៉ូនី១ មភីបូសែត១ ព្រមទាំងកូន
ប្រុស៥នាក់របស់នាងមីកាល ជាបុត្រីសូល ដែលនាង បាន
បង្កើតឱ្យអ័ទ្រីអែល ជាកូនបារស៊ីឡាយ នៅមហូឡាដែរ[ដ]
៩ទ្រង់ក៏ប្រគល់អ្នកទាំងនោះ ទៅក្នុងកណ្តាប់ដៃរបស់ពួក
គីបៀន ហើយគេចងកនៅលើភ្នំ នៅចំពោះព្រះយេហូវ៉ា
ទៅ អ្នកទាំង៧នោះក៏ស្លាប់ជាមួយគ្នាគេសំឡាប់អ្នកទាំង
នោះ[ឋ] នៅថ្ងៃដំបូងក្នុងរដូវចំរូត កាលទើបនឹងចាប់តាំង
ច្រូតស្រូវឱក[ឌ]។
១០ឯរីសបា ជាកូនអ័យ៉ា នាងក៏យកសំពត់ធ្មៃក្រាល
សំរាប់ខ្លួននៅ លើថ្មដានោះ ចាប់តាំងពីដើមរដូវចំរូត
រហូតដល់មានភ្លៀងធ្លាក់ពីលើមេឃមកលើសពទាំងនោះ
នាងមិនឱ្យសត្វហើរមកទំលើសពនៅវេលាថ្ងៃ ឬសត្វព្រៃ
នៅ វេលាយប់ឡើយ[ឍ] ១១មានគេមកទូលដាវីឌ ពីការដែល
រីសប៉ា កូនអ័យ៉ា ជាអ្នកម្នាងរបស់សូលធ្វើនោះ ។
១២លំដាប់នោះ ដាវីឌក៏ទៅយកអដ្ឋិរបស់សូល[ណ] និង
យ៉ូណាថាន ជាបុត្រទ្រង់ ពីពួកយ៉ាបេស–កាឡាត[ត] ដែលគេ
បានលួចយកពីទីធ្លាក្រុងបេត–សាន[ថ] ជាកន្លែងដែលពួក
ភីលីស្ទីនបានព្យួរ[ទ] នៅថ្ងៃដែលគេសំឡាប់ទ្រង់ នៅភ្នំគីល
បោ[ធ] ១៣ទ្រង់ក៏នាំយកអដ្ឋិរបស់សូល និងយ៉ូណាថានជាបុត្រា
ទ្រង់ ពីទីនោះមក រួចគេប្រមូលអដ្ឋិនៃពួកបុត្រដែលត្រូវ
ចងកនោះដែរ ១៤គេបញ្ចុះអដ្ឋិរបស់សូល និងយ៉ូណាថាន
ជាបុត្រាទ្រង់ នៅក្នុងផ្នូររបស់គីស ជាបិតាទ្រង់ត្រង់សេឡា[ន]
ក្នុងស្រុកបេនយ៉ាមីន គេក៏ធ្វើសំរេចតាមគ្រប់ទាំងការដែល
ស្តេចទ្រង់បង្គាប់មក គ្រាក្រោយនោះមក[ប]ព្រះទ្រង់ប្រោស
សណ្តាប់ស្តាប់សេចក្តីទូលអង្វរ[ផ] របស់ស្រុកនោះវិញ[ព]។

## ការច្បាំងនឹងពួកភីលីស្ទីន

*២១:១៥–២២ – ១របា ២០:៤–៨*

១៥នៅគ្រានោះ ពួកភីលីស្ទីនបានច្បាំងនឹងពួកអ៊ីស្រាអែល
១លើកទៀត ឯដាវីឌទ្រង់ក៏ចុះទៅជាមួយនឹងពួកពលទ័ព
ទ្រង់ ដើម្បីតស៊ូនឹងពួកភីលីស្ទីនដែរ[ភ] ទ្រង់ក៏ទន់កំឡាំងជា
ខ្លាំង ១៦ហើយយីសប៊ី–បេណូប ជាកូនរបស់ពួកអ្នកដែល
មានមាឌធំសំបើម លំពែងរបស់វាមានទំងន់ជាលង្ហិន៣០០
ដំឡឹងហើយវាក្រវាត់ដាវថ្មីក៏គិតចង់សំឡាប់ដាវីឌ ១៧តែ
អ័ប៊ីសាយ[ម] ជាកូនសេរូយ៉ា បានមកការពារជិន្ទួសទ្រង់
ក៏កាប់សំឡាប់សាសន៍ភីលីស្ទីននោះទៅ ដូច្នេះពួកទ័ពរបស់
ដាវីឌបានស្បថនឹងទ្រង់ថា ទ្រង់មិនត្រូវចេញទៅជាមួយនឹង
យើងខ្ញុំរាល់គ្នា ក្នុងទីចំបាំងទៀតឡើយ ក្រែងរលត់ពន្លឺ[យ]

**២១:៧** ជ ២សយ ៤:៤ ឈ ១សយ ១៨:៣ ២សយ ៩:៧ **២១:៨** ញ ២សយ ៣:៧ **២១:៩** ដ ២សយ ១៦:៨ ឋ នរ ១:២២ **២១:១០** ឌ លប ៤០:១៩ ១សយ ១៧:៤៤ **២១:១២** ឍ ១សយ ៣១:១១–១៣ ណ ពច ២១:៨ ១សយ ១១:១ ត យស ១៧:១១ ថ ១សយ ៣១:១០ ទ ១សយ ២៨:៤ **២១:១៤** ធ យស ១៨:២៨ ន យស ៧:២៦ ប ២សយ ២៤:២៥ ផ ១របា ៨:៣៤ **២១:១៥** ព ២សយ ៥:២៥ **២១:១៧** ភ ២សយ ២០:៦ ម ១ពរ ១១:៣៦ ១៥:៤ ២ពរ ៨:១៩ ២របា ២១:៧ ទដ ១៣២:១៧ **២១:១៧** យ ២សយ ១៨:៣

**២១:៧** *ដោយព្រោះដាវីឌ និងយ៉ូណាថានជាបុត្រសូល បានស្បថនៅចំពោះព្រះយេហូវ៉ា* មើល ៩:១–១៣ ១សយ ១៨:៣ ២០:១៥ និងការពន្យល់ ។

**២១:៨** *រីសប៉ា* មើល ៣:៧ ។ *នាងមីកាល* មើល ១សយ ១៨:១៩ ។ *បារស៊ីឡាយនៅមហូឡា* កុំច្រឡំនឹងក្រុងដាឡាត (១៧:២៧ ១៩:៣១) ។

**២១:៩** *អ្នកទាំង៧នោះក៏ស្លាប់ជាមួយគ្នា* គឺស្ទើរតែគ្មានសល់ផ្ទះរបស់លោកសូល គឺព្រះបានបដិសេធ(មើល ១សយ ១៣:១៣–៤ ១៥:២៣–២៦)។ ក្នុង ១របា ៨:២៩–៣៩ ៩:៣៥–៤៤ គឺពុំមានពូជរបស់លោកសូលដែលបានចុះក្នុងបញ្ជីទេលើកលែងតែពូជដំណររបស់លោកយ៉ូណាថាន់ ។

**២១:១០** *សំពត់ធ្មៃក្រាល* មើលការពន្យល់ លប ៣៧:៣៤ ភ្លៀងធ្លាក់ពីលើមេឃមក ជាការបញ្ជាក់ពីការអត់អាហារបានកើតឡើងដោយសារភាពហួតហែង និងជាសាក្សីពីការកាត់ទោសរាស្ត្រអ៊ីស្រាអែល ដោយសារការល្មើសពាក្យសម្បថ ចំពោះពួកគីបៀន(មើល ខ.១)តែឥឡូវនេះវាផុតហើយ ។

**២១:១២–១៤** *យកអដ្ឋិរបស់សូលនិងយ៉ូណាថានជាបុត្រាទ្រង់* មើល ១សយ ៣១:១១–១៣ សកម្មភាពចុងក្រោយរបស់ដាវីឌចំពោះសូស និងយ៉ូណាថាន គឺជាការគោរពយ៉ាងជ្រៀលជ្រៅ ចំពោះស្តេចដែលបានគោរពដល់មិត្តភ័ក្ត្រដែលទ្រង់បានស្រឡាញ់ ។

**២១:១៤** *គ្រាក្រោយនោះមកព្រះទ្រង់សណ្តាប់ស្តាប់ សេចក្តីទូលបង្វររបស់ស្រុកនោះវិញ* ផ្នែកជំពូកដំបូងតាមលេខលំដាប់ ក,ខ,គ នៃអក្សរសាស្ត្របង្ហាញពីលក្ខណ:ជំពូក៤ចុងក្រោយនៃគម្ពីរ១សាំយូអែលដូចជាមានលក្ខណ:ឆ្លងឆ្លើយទៅនឹងជំពូក ២៤:២៥ មាននៅក្នុងផ្នែកចុងក្រោយ (មើលការពន្យល់ ២១:១–២៤:២៥) ។

**២១:១៥–២១** ព្រឹត្តិការណ៍ក្នុងជីវិតនៃពួកភីលីស្ទីនទាំង៤ (មើល ១៥–១៧ ១៨,១៩,២០–២១)មិនអាចជាលក្ខណ:យកជាប្រវត្តិសាស្ត្រទេ (មើលការពន្យល់ ២១:១–២៤:២៥)ក៏មានការសម្រេចបានពីភាពជាវីរ:បុរសតាមរយ:មនុស្សដ៏អស្ចារ្យគឺស្តេចដាវីឌ ។ ក៏នាំមកជាលទ្ធផលបណ្តាលឱ្យពូជរបស់រ៉ាផា (មើល ខ.២២) ។

**២១:១៦,១៨,២០,២២** *រេផាយ៉ា* គឺជាជីដូនជីតា(បុព្វជន)នៃពូជមួយ នៃក្រុមរេផាយ៉ា(១របា ២០:៤,៨)ដោយគេបានហៅថា ពួកអ្នកចម្បាំងដែលជាសត្រូវនឹងគួរឱ្យភ័យខ្លាចដូចជាក្នុងន័យថា"រេផាយ៉ា"ក្នុងខ.២២ តាមន័យក្នុងវគ្គនេះគឺសំដៅទៅលើមនុស្សធំដូចយក្ស (មើល ខ.២០ ចទ ២:១០–១១,២០–២១) ។ វាមានទំនាក់ទំនងទៅនិងពួកសាសន៍អ័ណាក់(មើល ជន ១៣:២៨,៣២–៣៣ យស ១១:២១–២២)។ គឺបញ្ជីឈ្មោះមនុស្សទាំង១០នៃពួកកាណានក្នុង លប ១៥:១៩–២១ ក៏បង្ហាញថាពួករេផាយ៉ា ប៉ុន្តែមិនមែនសាសន៍អ័ណាក់ ។

**២១:១៧** *អ័ប៊ីសាយ* មើលការពន្យល់ ១សយ ២៦:៦ ។ *ក្រែងរលត់ពន្លឺនៃសាសន៍អ៊ីស្រាអែលទៅ* គឺតាមការប្រៀបធៀបន័យគឺរាស្ត្រអ៊ីស្រាអែលទាំងមូលត្រូវពឹងផ្អែកស្តេចដាវីឌ គឺដើម្បីសន្តិសុខហើយបន្តឱ្យមានជីវិតជាជាតិមួយ គឺជាសេចក្តីសង្ឃឹមដល់ជាតិសាសន៍របស់ខ្លួន(មើល ២២:២៩ ២៣:៣–

នៃសាសន៍អ៊ីស្រាអែលទៅ[រ] ។
១៨ក្រោយនោះមក កើតមានចំបាំងនឹងពួកភីលីស្ទីនម្តង
ទៀត នៅត្រង់កូប នៅវេលានោះស៊ីបាកាយ[ល] ជាពូជហ៊ូ
សាយ គាត់បានសំឡាប់សាភ ជាកូននៃអ្នកមានមាឌធំនោះ
ទៅ ១៩ក៏មានចំបាំងនឹងពួកភីលីស្ទីន នៅត្រង់កូបម្តងទៀត
ហើយអែលហាណាន ជាកូនយ្អារេ-អូរគីមពីបេថ្លេហិម
គាត់បានសំឡាប់កូលីយ៉ាត ក្នុងពួកកាថ[វ]ទៅឯដងលំពែង
របស់អ្នកនោះមានទំហំប៉ុនផ្សិដំបាញ[ស] ២០នៅត្រង់ក្រុងកាថ
ក៏មានចំបាំងទៀតដែរ នៅទីនោះមានមនុស្សម្នាក់មាន
មាឌធំសំបើម មានម្រាមដៃ៦ទាំងសងខាង ឯជើងទាំងសង
ខាង ក៏មានម្រាម៦ដែរ រួមទាំងអស់២៤ អ្នកនោះក៏កើតពី
ពូជអ្នកដែលមានមាឌធំនោះ ២១កាលវាប្រកួត[ហ]នឹងសាសន៍
អ៊ីស្រាអែល នោះយ៉ូណាថានជាកូនសាំម៉ា[ឡ] ជេដ្ឋានៃដាវីឌ
បានសំឡាប់វាទៅ ២២អ្នកទាំង៤នេះជាពូជនៃអ្នកមានមាឌ
ធំសំបើម ដែលនៅក្រុងកាថហើយក៏ស្លាប់ទៅ ដោយដៃ
ដាវីឌ និងពួកទ័ពទ្រង់ ។

## ទំនុកដំកើងនៃស្តេចដាវីឌ

*២២:១-៥១ – ទដ ១៨:១-៥០*

**២២** ១រីឯនៅថ្ងៃ ដែលព្រះយេហូវ៉ាបានជួយសង្គ្រោះ
ដាវីឌ ឱ្យរួចពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវទ្រង់ទាំងប៉ុន្មាន
ហើយពីកណ្តាប់ដៃនៃសូល នោះទ្រង់ក៏ពោលទំនុក[ក]នេះ
ទូលព្រះយេហូវ៉ាថា ២ព្រះយេហូវ៉ាទ្រង់ជាថ្មដា[ខ] ហើយជា
បន្ទាយ[គ]នៃទូលបង្គំ ទ្រង់ជាអ្នកជួយទូលបង្គំឱ្យរួច[ឃ] ៣ព្រះ
ទ្រង់ជាថ្មដានៃទូលបង្គំៗនឹងយកទ្រង់ជាទីពឹង[ង] ទ្រង់ក៏ជា
ខែល[ច] ជាស្នែង[ឆ] នៃសេចក្តីសង្គ្រោះរបស់ទូលបង្គំ ជាប៉ម
យ៉ាងខ្ពស់ហើយជាទីជ្រកកោន[ជ]នៃទូលបង្គំ ទ្រង់ជាអ្នកជួយ
សង្គ្រោះ ដែលសង្គ្រោះទូលបង្គំឱ្យរួចពីអំណាចអាក្រក់
៤ទូលបង្គំនឹងអំពាវនាវដល់ព្រះយេហូវ៉ា ដែលទ្រង់គាប់
គួរ[ឈ]សរសើរ យ៉ាងនោះទូលបង្គំនឹងបានសង្គ្រោះ ឱ្យរួចពី
ពួកខ្មាំងសត្រូវហើយ ៥ដ្បិតរលក[ញ]នៃសេចក្តីស្លាប់បាន
ព័ទ្ធជុំវិញទូលបង្គំ សេចក្តីទុច្ចរិតបានហូរជន់ឡើង បំភ័យ
ទូលបង្គំ ។
៦ខ្សែនៃស្ថានឃុំព្រលឹងមនុស្សស្លាប់[ដ]បានរុំរួបជុំវិញ
ទូលបង្គំ ខ្សែរូតនៃសេចក្តីស្លាប់បានស្ទះផ្លូវទូលបង្គំហើយ
៧នៅគ្រាមានសេចក្តីវេទនា[ឋ] នោះទូលបង្គំបានអំពាវនាវ

**២១:១៨** រ ១រប ១១:២៩ ២៧:១១ **២១:១៩** ល ១សយ ១៧:៤ វ ១សយ ១៧:៧ **២១:២១** ស ១សយ ១៧:១០ ហ ១សយ ១៦:៩ **២២:១** ក នក ១៥:១ **២២:២** ខ ១សយ ២:២ គ ទដ ៣១:៣ ៩១:២ ឃ ទដ ១៤៤:២ **២២:៣** ង ចទ ២៣:១៥ ៣២:៣៧ ទដ ១៤:៦ ៣១:២ ៥៩:១៦ ៧១:៧ ៩១:២ ៩៤:២២ សភ ១០:២៩ អស ២៥:៤ យរ ១៦:១៩ យអ ៣:១៦ ច លប ១៥:១ ឆ ចទ ៣៣:១៧ លក ១:៦៩ ជ ទដ ៩:៩ ៥២:៧ **២២:៤** ឈ ទដ ៤៨:១ ៩៦:៤ ១៤៥:៣ **២២:៥** ញ ទដ ៦៩:១៤-១៥ យហ ២:៣ **២២:៦** ដ ទដ ១១៦:៣ កច ២:២៤ **២២:៧** ឋ លប ៣៥:៣ ពច ២:១៥ ២រប ១៥:៤ ទដ ៤:១ ៧៧:២ ១២០:១ អស ២៦:១៦

៤ ១ពវ ១១:៣៦ និងការពន្យល់ ធៀប ២សយ ២២:២៩ ២៣:៣-៤) ។

**២១:១៨-១៩** *កូប* គឺបានបង្ហាញតែទីនេះទេចំពោះពាក្យថាកូបជាតំបន់មួយ ដែលមានទីតាំងជិតខាងក្បែរទីក្រុងកេស៊ើន ដែលជាទីកន្លែងធ្វើចំបាំងជាមួយមនុស្សមាឌធំ ១រប ២០:៤ បើជាភាសាហេព្រើរអានថា"នោប"ក៏ជាទីក្រុងនៅផ្នែកភូមិភាគខាងជើង ឈាងខាងកើតក្រុងយេរូសាឡិម (មើល ១សយ ២១:១ និងការពន្យល់) ។ ក្នុងរឿងនេះបើតាមឈ្មោះ ពិតគឺគេហៅថា យីសប៊ី-បេណូប (ខ.១៦) ដែលមានន័យថាអ្នកប្រុស"នោប" ។

**២១:១៩** *អែលហាណាន . . . គាត់បានសំឡាប់កូលីយ៉ាត* មើល ១សយ ១៧ គឺស្តេចដាវីឌសម្លាប់កូលីយ៉ាត ។ អ្នកគត់ត្រាចំលងអាចមានការភ័ណ្ឌច្រឡំខ្លះៗ(មើល ១រប ២០:៥)ដូចជាពាក្យ"អ្នកស្រុកបេថ្លេហិម" ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យ"បានសម្លាប់"គេបានសរសេរនៅដើមអនុប្រយោគ ។

**២១:២១** *ប្រកួតនឹង* គឺដូចជាកូលីយ៉ាតបានធ្វើអញ្ចឹងដែរ (មើល ១សយ ១៧:១០,២៥) ។ *សាំម៉ា* (១សយ ១៦:៩ ១៧:១៣) ។

**២២:១-៥១** *ភាពទំនាក់ទំនងនៃបទទំនុកចម្រៀងនេះ* ប្រៀបនឹងចម្រៀងបទទំនុករបស់លោកហាណានក្នុងគ្រប់នៃឃ្លាឃ្លោងក្នុងគម្ពីរ សាំយូអែលទី១ និងទី២ មើលការពន្យល់ ១សយ ២:១-១០ ជាពិសេសនៅ ២:១ បទទំនុកស្តេចដាវីឌក៏មានក្នុង ទដ ១៨ (មើលការពន្យល់ក្នុងជំពូក ១៨ នោះ) ។ ក្រៅពីសេចក្តីផ្តើមនិង(ខ.២-៤) និងការបញ្ជាក់(ខ.៤៧-៥១) បទទំនុកនោះក៏មានទៅដោយផ្នែកសំខាន់ៗបី : បទទំនុកដំបូងទីមួយពណ៌នាពីការរំដោះស្តេចដាវីឌឱ្យចេញពីគ្រោះថ្នាក់ ដែលអាចបណ្តាលឱ្យស្លាប់បានគឺក្នុងកណ្តាប់ដៃនៃពួកសត្រូវ(ខ.៥-២០) ។ បទទំនុកទីពីរបង្ហាញពីព្រះទ័យជួយសង្គ្រោះ (ខ.២១-៣០) ផ្នែកបទទំនុកទីបីបានរៀបរាប់អំពីជំនួយពីព្រះអម្ចាស់បានផ្តល់មកឱ្យទ្រង់ជាស្តេចដាវីឌ (ខ.៣១-៤៦) បទទំនុកចម្រៀងទាំងអស់នោះបានជ័យជម្នះពីសត្រូវបរទេស(សាសន៍ដទៃ) (៨:១-១៤) និងមុនពេលដែលទ្រង់មានអំពើបាបជាមួយនាងបាតសេបា និងអ៊ូរី (១១:២-៤,១៤-១៧) ប្រៀបធៀប ខ. ២១-២៥ ជាមួយនឹង ១ពវ ១៥:៥) ។

**២២:១** *ឱ្យរួចពីកណ្តាប់ដៃនៃ . . . ពួកខ្មាំងសត្រូវ . . . និងពីស្តេចសូល . . .* មើល ១សយ ១៨-២៧ ។

**២២:២** *ជាថ្មដា* គឺបង្ហាញនូវភាពរឹមាំមួយក្នុងបទពិសោធន៍របស់ស្តេចដាវីឌ (មើល ខ.៣,៣២,៤៧ ២៣:៣ ធៀបនឹង ចទ ៣២:៤,១៥,១៨,៣១,ទដ ២៨:១ ៣១:២ ៧៨:៣៥ ៨៩:១៦ ៩៥:១)។ ទ្រង់ជាស្តេចដាវីឌបានពឹងទីជំរកនៅឯថ្មដានៅវាលរហោស្ថាន(១សយ ២៣:២៥,២៤:២) តែទ្រង់ជាដាវីឌបានដឹងពីអាថ៌កំបាំងនៃភាពសុខសាន្តដ៏ពិតប្រាកដ គឺអាចប្រទះឃើញបានពូទទួលបានតែនៅក្នុងព្រះយេហូវ៉ាប៉ុណ្ណោះ ។ *បន្ទាយ* ពាក្យជាភាសាហេព្រើរចំពោះពាក្យនេះគឺមានក្នុងគម្ពីរ (សូមមើល ៥:១៧ ២៣:១៤ ១សយ ២២:៤-៥ ២៤:២២) គឺជាការសំអាងទៅលើទីដ៏រឹងមាំដែលស្តេចដាវីឌស្វែងរកដើម្បីលាក់ខ្លួន ។

**២២:៣** *ជាខែល* មើល ខ.៣១ លប ១៥:១ និងការពន្យល់ ចទ ៣៣:១៧,យរ ៤៨:២៥ ។

**២២:៥** *រលកនៃសេចក្តីស្លាប់* ក្នុង ខ.៥-៦ គឺជាពាក្យបទទំនុកចម្រៀងដែលស្តេចដាវីឌបានពណ៌នានិងគ្រោះថ្នាក់ដល់ជីវិត ។

**២២:៦** *ស្ថានឃុំព្រលឹង* មើលការពន្យល់ យហ ២:២ ។

ដល់[ឌ] ព្រះយេហូវ៉ា គឺបានស្រែករកព្រះនៃទូលបង្គំ ទ្រង់ក៏
ឮសំឡេងនៃទូលបង្គំពីក្នុងព្រះវិហារទ្រង់ សំរែករបស់
ទូលបង្គំបានឮនៅព្រះកាណ៌ទ្រង់ ៨នោះផែនដី[ឍ]បានញ័រ
កក្រើក[ណ] ឫស[ត]ផ្ទៃមេឃក៏រំពើក ហើយត្រូវរញ្ជួយ ដោយ
ព្រោះទ្រង់មានសេចក្តីក្រោធ ៩មានផ្សែងហុយចេញពីព្រះ
នាសាទ្រង់ ភ្លើង[ថ]ដែលចេញពីព្រះឱស្ឋទ្រង់មក ក៏ឆេះ
បន្សុសហើយផុសចេញជាព្រាក[ទ]ផ្លេកៗ ១០ទ្រង់បានបន្ទាប
ផ្ទៃមេឃយាងចុះមក មានងងឹតយ៉ាងក្រាស់[ធ]នៅក្រោមព្រះ
បាទទ្រង់ ១១ទ្រង់គង់លើចេរូប៊ីន[ន]ហោះមកឃើញទ្រង់គង់
លើស្លាបនៃខ្យល់[ប] ១២ទ្រង់បានយកសេចក្តីងងឹត[ផ]ធ្វើជាព្រះ
ពន្លាបាំងជុំវិញទ្រង់ គឺជាទឹកប្រមូលផ្តុំគ្នា ហើយនឹងពពកយ៉ាង
ក្រាស់នៅលើមេឃ ១៣មានព្រាកផ្លេកៗ[ព]បានកាត់ឡើង
ដោយសាររស្មីនៅចំពោះទ្រង់ ១៤ព្រះយេហូវ៉ាទ្រង់
បញ្ចេញជាផ្គរ[ភ]ពីលើមេឃ ព្រះដ៏ខ្ពស់បំផុតទ្រង់បន្លឺព្រះ
សូរសៀង ១៥ក៏បាញ់ព្រួញ[ម]នៃទ្រង់ទៅកំចាត់កំចាយគេ និង
រន្ទះទៅបំបាក់គេដែរ ១៦នោះបាតសមុទ្រក៏លេចឡើង
ហើយឫសនៃលោកីយបានបើកឱ្យឃើញច្បាស់ ដោយព្រះ
យេហូវ៉ាទ្រង់បន្ទោស[យ] គឺកាលឮសូរខ្យល់គំហុក[រ]ចេញពី
ព្រះនាសាទ្រង់ ។
១៧ទ្រង់ចាត់ពីលើស្ថានដ៏ខ្ពស់[ល] ឱ្យមកចាប់[វ]ទូលបង្គំស្រង់
ចេញពីទឹកធំ ១៨ទ្រង់បានដោះ[ស]ឱ្យទូលបង្គំរួចពីខ្មាំងសត្រូវ
យ៉ាងខ្លាំងរបស់ទូលបង្គំ គឺពីពួកអ្នកដែលស្អប់ទូលបង្គំ ដ្បិត
គេមានកំឡាំងច្រើនជាងទូលបង្គំ ១៩នៅថ្ងៃដែលទូលបង្គំ
កើតមានសេចក្តីអន្តរាយ នោះគេបានមកស្ទាក់ផ្លូវទូលបង្គំ
តែព្រះយេហូវ៉ាទ្រង់ជាជន្ទល់នៃទូលបង្គំ[ហ] ២០ទ្រង់ក៏បាននាំ
ទូលបង្គំចេញទៅនៅទីធំទូលាយ[ឡ] ទ្រង់បានដោះ[អ]ទូលបង្គំ

**២២:៧** ឌ ទដ ៣៤:៦,១៥ ១១៦:៤ **២២:៨** ឍ ពច ៥:៤ ទដ ៩៧:៤ ណ នក ១៩:១៨ ពច ៥:៤ ទដ ៦៨:៨ ៧៧:១៨ យរ ១០:១០ ត យប ៩:៦ ២៦:១១ ទដ ៧៥:៣ **២២:៩** ថ ទដ ៥០:៣ ៩៧:៣ ហព ១២:២៩ វវ ១១:៥ ទ អស ៦:៦ អគ ១:១៣ ១០:២ **២២:១០** ធ នក ១៩:៩ លវ ១៦:២ ចទ ៣៣:២៦ ១ពវ ៨:១២ យប ២៦:៩ ទដ ១០៤:៤ អស ១៩:១ យរ ៤:១៣ ណហ ១:៣ **២២:១១** ន លប ៣:២៤ នក ២៥:២២ ប ទដ ១០៤:៣ **២២:១២** ផ នក ១៩:៩ **២២:១៣** ព យប ៣៧:៣ ទដ ៧៧:១៨ **២២:១៤** ភ ១សយ ២:១០ **២២:១៥** ម ចទ ៣២:២៣ **២២:១៦** យ ទដ ៦:១ ៥០:៨,២១

ឱ្យរួច ដោយព្រោះទ្រង់ស្រឡាញ់[ក]ដល់ទូលបង្គំ[ខ] ២១ព្រះ
យេហូវ៉ាទ្រង់បានប្រទានរង្វាន់ តាមសេចក្តីសុច្ចរិតរបស់
ទូលបង្គំ[គ] ទ្រង់បានសងទូលបង្គំ តាមសេចក្តីបរិសុទ្ធ[ឃ]នៃដៃ[ង]
ទូលបង្គំ ២២ដ្បិតទូលបង្គំបានកាន់តាម[ច]អស់ទាំងផ្លូវនៃព្រះ
យេហូវ៉ា ហើយមិនដែលថយចេញពីព្រះនៃទូលបង្គំ ដោយ
ប្រព្រឹត្តសេចក្តីអាក្រក់ឡើយ ២៣ពីព្រោះគ្រប់ទាំងបញ្ញត្តិ
របស់ទ្រង់ បាននៅចំពោះមុខទូលបង្គំ[ឆ] ហើយទូលបង្គំមិន
បានងាកចេញ[ជ] ពីក្រិត្យរបស់ទ្រង់ណាមួយសោះ ២៤ទូល
បង្គំបានគ្រប់លក្ខណ៍[ឈ]នៅចំពោះទ្រង់ ហើយបានរក្សាខ្លួន
ឱ្យរួចពីសេចក្តីអាក្រក់របស់ទូលបង្គំ ២៥ហេតុនោះបានជា
ព្រះយេហូវ៉ាទ្រង់ប្រទានរង្វាន់មក តាមសេចក្តីទៀងត្រង់
របស់ទូលបង្គំ[ញ] គឺតាមសេចក្តីបរិសុទ្ធរបស់ទូលបង្គំ នៅ
ចំពោះព្រះនេត្រទ្រង់ ។
២៦ទ្រង់សំដែងសេចក្តីមេត្តា ចំពោះអ្នកណា ដែលមាន
ចិត្តមេត្តា ក៏សំដែងសេចក្តីគ្រប់លក្ខណ៍ ចំពោះអ្នកណា
ដែលគ្រប់លក្ខណ៍ ២៧ទ្រង់សំដែងសេចក្តីបរិសុទ្ធ[ដ]ចំពោះ
អ្នកណាដែលបរិសុទ្ធ តែទ្រង់តយុទ្ធនឹងមនុស្សក្រវិចក្រវៀន
វិញ[ឋ] ២៨ទ្រង់តែងសង្គ្រោះដល់មនុស្ស ដែលត្រូវគេសង្កត់
សង្កិន[ឌ] តែព្រះនេត្រទ្រង់ទតឃើញពួកឆ្មើងឆ្មៃ[ឍ]ដើម្បីបន្ទាប

១០៦:៩ ណហ ១:៤ រ នក ១៤:២១ អស ៣០:៣៣ ៤០:២៤ **២២:១៧** ល ទដ ១៤៤:៧ វ នក ២:១០ **២២:១៨** ស លក ១:៧១ **២២:១៩** ហ ទដ ២៣:៤ **២២:២០** ឡ យប ៣៦:១៦ ទដ ៣១:៨ អ ទដ ១១៨:៥ ក ទដ ២២:៨ អស ៤២:១ មថ ១២:១៨ ខ ២សយ ១៥:២៦ **២២:២១** គ ១សយ ២៦:២៣ ឃ ទដ ២៦:៦ ង យប ១៧:៩ ២២:៣០ ៤២:៧–៨ ទដ ២៤:៤ **២២:២២** ច លប ១៨:១៩ ទដ ១២៨:១ សភ ៨:៣២ **២២:២៣** ឆ ចទ ៦:៤–៩ ទដ ១១៩:៣០–៣២ ជ ទដ ១១៩:១០២ **២២:២៤** ឈ លប ៦:៩ អភ ១:៤ **២២:២៥** ញ ១សយ ២៦:២៣ **២២:២៧** ដ មថ ៥:៨ ឋ លវ ២៦:២៣–២៤ **២២:២៨** ឌ នក ៣:៨ ១សយ ២:៨–៩ ទដ ៧២:១២–១៣ ឍ ទដ ១៣១:១ សភ ៣០:១៣ ដយ ៤:៣១

**២២:៧** *ព្រះវិហារទ្រង់* គឺជាស្ថានសួគ៌ ដែលជាទីកន្លែងរបស់ព្រះយេហូវ៉ាគង់សណ្ឋិតនៅ ធ្វើដូចជាស្តេច(ព្រះមហាក្សត្រ) ។ មើលការពន្យល់ ទដ ១១:៤ អស ៦:១ និងការពន្យល់ (ក៏មើល យហ ២:៧) ។

**២២:៩** *មានផ្សែងហុយចេញពីព្រះនេសាទ្រង់* សូមមើលការពន្យល់ ទដ ១៨:៨ ។

**២២:១១** *ចេរូប៊ីនហោះមកឃើញ* មើលការពន្យល់ ១យស ៤:៤ លប ៣:២៤ ទដ ១៨:១០ អគ ១:៥ ។

**២២:១៤** *ព្រះយេហូវ៉ាទ្រង់បញ្ចេញជាផ្គរលាន់* ក៏ជាការសំអាងទៅលើសំឡេងរបស់ព្រះ(មើលក្នុងគម្ពីរសញ្ញាចាស់ ទដ ២៩ យប ៣៧:២–៥) ។ ផ្គរក៏បញ្ជាក់ពីអំណាចព្រះចេស្តានិងព្រះតេជះនៃទ្រង់បានសម្តែងឱ្យឃើញ ។

**២២:១៧** *ទ្រង់ចាក់ពីលើទីខ្ពស់* ក្នុង ខ.១៧–២០ ស្តេចដាវីឌបានពណ៌នាពីការដែលទ្រង់បានរួចពីគ្រោះថ្នាក់(ខ.១៧ ប្រៀបធៀប ខ.៥) ដែលប្រើពាក្យបែបអក្សរសាស្ត្រទំនើប(ខ.១៨–២០) ។

**២២:២០** *ទីធំទូលាយ* មើលការពន្យល់ ទដ ១៨:១៩ ។ *ទ្រង់ស្រឡាញ់* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យវោហារស័ព្ទនេះគឺប្រើក្នុងជំពូក ១៥:២៦ គឺស្មើនឹង "ពេញចិត្តនិងអ្វីមួយ" ។ បទគម្ពីរ ទដ ២២:៨(ប្រៀបធៀប ៣:១៧ "រីករាយយ៉ាងខ្លាំងនិង") ជាការបង្ហាញពីគំនិតនិងចិត្តនៃភាពជាមហាក្សត្រដែលពេញចិត្តអ្នកដែលព្រះអង្គបានចាក់ប្រេងតាំងឱ្យ(ខ.៥១) ។

**២២:២១–២៥** *តាមសេចក្តីសុចរិតរបស់ទូលបង្គំ* មើល ១ពវ ១៥:៥ ក្នុង ខ.២១–២៥ ស្តេចដាវីឌបានបញ្ជាក់ពីការសង្គ្រោះរបស់ព្រះយេហូវ៉ា គឺមានលក្ខណៈដូចជារង្វាន់ចំពោះភាពសុចរិតផ្ទាល់របស់ផងទ្រង់ ។ (១)សេចក្តីប៉ងប្រាថ្នារបស់ស្តេចដាវីឌគឺដើម្បីបំពេញព្រះហឫទ័យក្នុងការដែលទ្រង់បានបម្រើក្នុងនាមជាអ្នកដែលព្រះបានចាក់ប្រេងតាំង(មើលការពន្យល់ ខ.៥១) (២)ទ្រង់ដាវីឌទទួលស្គាល់ថា ព្រះយេហូវ៉ាឱ្យរង្វាន់អ្នកណាដែលស្មោះត្រង់ក្នុងការស្វែងរកការបម្រើទ្រង់ ។

**២២:២៦–៣០** មើលការពន្យល់ ទដ ១៨:២៥–២៩ ។

គេចុះ[ណ] ២៩ដ្បិត ឱព្រះយេហូវ៉ាអើយ ទ្រង់ជាចង្កៀងនៃទូល
បង្គំ[ត] ព្រះយេហូវ៉ាទ្រង់បំភ្លឺក្នុងទីងងឹតនៃទូលបង្គំ ៣០ពីព្រោះ
ដោយពឹងដល់ទ្រង់ នោះទូលបង្គំរត់ចូលទៅតនឹងកងទ័ព
ដោយសារព្រះនៃទូលបង្គំ នោះទូលបង្គំលោតរំលងកំផែង
បាន ៣១ឯផ្លូវរបស់ព្រះ នោះគ្រប់លក្ខណ៍[ថ] ហើយព្រះបន្ទូល
នៃព្រះយេហូវ៉ាបានសាកមើលដែរ[ទ] ទ្រង់ជាខែល[ធ]ដល់អស់
អ្នកដែលជ្រកក្នុងទ្រង់ ។
៣២តើអ្នកណាជាព្រះ លើកតែព្រះយេហូវ៉ាប៉ុណ្ណោះ ហើយ
តើអ្នកជាថ្មដា[ន] លើកតែព្រះនៃយើងខ្ញុំតែមួយ[ប] ៣៣ព្រះទ្រង់
ជាបន្ទាយមាំមួននៃទូលបង្គំ ទ្រង់នាំទូលបង្គំតាមផ្លូវគ្រប់
លក្ខណ៍ ៣៤ទ្រង់ធ្វើឱ្យជើងទូលបង្គំ បានដូចជាជើងក្តាន់[ផ]
ហើយក៏ដាក់ឱ្យទូលបង្គំឈរលើទីខ្ពស់របស់ទូលបង្គំ[ព]
៣៥ទ្រង់បង្ហាត់ដៃ[ភ]ទូលបង្គំឱ្យជំនាញក្នុងការចំបាំង រហូត
ដល់ដើមដៃទូលបង្គំ មានកំឡាំងនឹងដំឡើងធ្នូ[ម]លង្ហិនបាន
៣៦ទ្រង់បានប្រទានខែល[យ] នៃសេចក្តីសង្គ្រោះរបស់ទ្រង់
មកទូលបង្គំ ហើយព្រះហឫទ័យស្រទន់របស់ទ្រង់បានលើក
ទូលបង្គំឡើងជាធំ ៣៧ទ្រង់បានធ្វើឱ្យជំហាន[រ]ទូលបង្គំ
ទូលាយចេញទៅ ហើយជើងទូលបង្គំមិនបានរអិលភ្លាត់
ឡើយ ៣៨ទូលបង្គំបានដេញតាមពួកខ្មាំងសត្រូវហើយ
បំផ្លាញគេបង់ ទូលបង្គំក៏មិនបានវិលមកវិញ ទាល់តែគេ
ត្រូវវិនាសអស់រលីង ៣៩ទូលបង្គំបានធ្វើឱ្យ[ល]គេវិនាសអស់
រលីង បានទាំងចាក់ទំលុះគេ ឱ្យគេក្រោកឡើងវិញមិនរួច
គេបានដួលនៅក្រោមជើងទូលបង្គំ ៤០ដ្បិតទ្រង់បានក្រវាត់
ទូលបង្គំ ដោយកំឡាំងសំរាប់ធ្វើចំបាំង ឯពួកអ្នកដែល
លើកគ្នាឡើងទាស់នឹងទូលបង្គំ នោះទ្រង់បានបន្ទន់គេ នៅ
ក្រោមទូលបង្គំវិញ[វ] ៤១ទ្រង់បានធ្វើឱ្យពួកខ្មាំងសត្រូវបែរ
ខ្នង[ស]នៅមុខទូលបង្គំ ដើម្បីឱ្យទូលបង្គំបានកាត់ពួកអ្នកដែល
ស្អប់ទូលបង្គំចេញ ៤២គេបានមើលជុំវិញ[ហ] តែគ្មានអ្នកណា
មួយ សំរាប់នឹងជួយសង្គ្រោះគេឡើយ[ឡ] ក៏សង្ឃឹមដល់ព្រះ
យេហូវ៉ា តែទ្រង់មិនបានឆ្លើយមកសោះ[អ] ៤៣នោះទូលបង្គំ
បានវាយគេឱ្យខ្ទេចខ្ទី ដូចធូលីដី[ក]ក៏បានជាន់ឈ្លី[ខ]គេ ដូចជា
ភក់[គ] នៅក្នុងផ្លូវ ហើយកំចាត់កំចាយអស់ទៅ ។
៤៤ទ្រង់បានជួយទូលបង្គំឱ្យរួច[ឃ]ពីការទាស់ទែងគ្នាក្នុង
ពួករាស្ត្រទូលបង្គំ ទ្រង់បានរក្សា[ង]ទូលបង្គំទុក ឱ្យធ្វើជាមេ
លើអស់ទាំងនគរ សាសន៍១[ច]ដែលទូលបង្គំមិនបានស្គាល់គេ
នឹងមកចំណុះទូលបង្គំ ៤៥ពួកសាសន៍ដទៃនឹងចុះចូលស្តាប់
បង្គាប់[ឆ]ទូលបង្គំ កាលគេឮពាក្យបង្គាប់ជាមុនដំបូង នោះគេ
នឹងស្តាប់តាមទូលបង្គំភ្លាម[ជ] ៤៦ពួកសាសន៍ដទៃនឹងត្រូវ
ស្រពោនបាត់ទៅ[ឈ] ហើយនិងចេញពីទីពួនរបស់គេមក
ដោយញាប់ញ័រ ។
៤៧ព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់នៅ សូមក្រាបថ្វាយ
បង្គំដល់ថ្មដានៃទូលបង្គំ ហើយសូមឱ្យព្រះដ៏ជាថ្មដានៃសេច
ក្តីសង្គ្រោះទូលបង្គំ[ញ] បានលើកជាខ្ពស់ឡើង[ដ] ៤៨គឺជាព្រះ
ដែលសំរេចសេចក្តីសងសឹក[ឋ]ជំនួសទូលបង្គំ[ឌ] ហើយបង្ក្រាប
សាសន៍ផ្សេងៗនៅក្រោមអំណាចទូលបង្គំ ៤៩ព្រមទាំងនាំ
ទូលបង្គំចេញឱ្យរួចពីពួកខ្មាំងសត្រូវ[ឍ] ហើយលើក[ណ]ទូល
បង្គំឡើងជាខ្ពស់ ជាងអស់អ្នកដែលលើកខ្លួនទាស់នឹងទូល
បង្គំ ក៏ដោះទូលបង្គំ ឱ្យរួចពីមនុស្សច្រឡោតផង ៥០ហេតុ
ដូច្នេះ ឱព្រះយេហូវ៉ាអើយ ទូលបង្គំនឹងអរព្រះគុណដល់
ទ្រង់ នៅកណ្តាលអស់ទាំងសាសន៍ ហើយនិងច្រៀងទំនុក
សរសើរ[ត]ថ្វាយដល់ព្រះនាមទ្រង់[ថ] ។
៥១ទ្រង់បានប្រោសសេចក្តីសង្គ្រោះយ៉ាងធំដល់ស្តេចនៃ
ទ្រង់[ទ] ហើយក៏សំដែងសេចក្តីសប្បុរសដល់អ្នកដែលទ្រង់
បានចាក់ប្រេងតាំងឱ្យ[ធ] គឺដល់ដាវីឌ[ន]និងព្រះរាជវង្ស ជា
រៀងរាបដរាបទៅ[ប] ។

**២២:២៨** សផ ៣:១១ ណ អស ២:១២,១៧ ៥:១៥ លក ១:៥១ **២២:២៩** ត ទដ ២៧:១ អស ២:៥ មីក ៧:៨ វវ ២១:២៣ ២២:៥ **២២:៣១** ថ ចទ ៣២:៤ មថ ៥:៤៨ ទ ទដ ១២:៦ ១១៩:១៤០ សភ ៣០:៥–៦ ធ លប ១៥:១ **២២:៣២** ន ១សយ ២:២ ប ២សយ ៧:២២ **២២:៣៤** ផ អស ៣៥:៦ ហប ៣:១៩ ព ចទ ៣២:១៣ **២២:៣៥** ភ ទដ ១៤៤:១ ម ទដ ៧:១២ ១១:២ សក ៩:១៣ **២២:៣៦** យ អភ ៦:១៦ **២២:៣៧** រ សភ ៤:១១ **២២:៣៩** ល ទដ ៤៤:៥ ១១០:៦ មឡ ៤:៣ **២២:៤០** វ យស ១០:២៤ ១ពវ ៥:៣ **២២:៤១** ស នក ២៣:២៧ **២២:៤២** ហ អស ១:១៥ ឡ ទដ ៥០:២២ អ ១សយ ១៤:៣៧ **២២:៤៣** ក ១ពវ ២០:១០

២ពវ ១៣:៧ អស ៤១:២ អម ១:៣ ខ ទដ ៧:៥ អស ៤១:២៥ មីក ៧:១០ សក ១០:៥ គ អស ៥:២៥ ១០:៦ ២២:៥ មីក ៧:១០ **២២:៤៤** ឃ នក ១១:៣ ២សយ ៣:១ ង ចទ ២៨:១៣ ច ២សយ ៨:១–១៤ អស ៥៥:៣–៥ **២២:៤៥** ឆ ទដ ៦៦:៣ ៨១:១៥ ជ ចទ ៣៣:២៩ **២២:៤៦** ឈ មីក ៧:១៧ **២២:៤៧** ញ ចទ ៣២:១៥ ទដ ១៨:៣១ ៨៩:២៦ ៩៥:១ ដ នក ១៥:២ **២២:៤៨** ឋ ជន ៣១:៣ ឌ ទដ ១៤៤:២ **២២:៤៩** ឍ ទដ ១៤០:១,៤ ណ ទដ ២៧:៦ **២២:៥០** ត ទដ ៩:១១ ៤៧:៦ ៦៨:៤ ថ រម ១៥:៩ **២២:៥១** ទ ទដ ២១:១ ១៤៤:៩–១០ ធ ១សយ ១៦:១៣ ទដ ៨៩:២០ កច ១៣:២៣ ន ២សយ ៧:១៣ ប ទដ ៨៩:២៤,២៩

**២២:២៩** *ទ្រង់ជាចង្កៀងនៃទូលបង្គំ* ព្រះយេហូវ៉ាបានធ្វើឱ្យជីវិតស្តេចដាវីឌទទួលបាននូវភាពចម្រើនរុងរឿងទៅមុខជានិច្ច (មើលការពន្យល់ យប ១៨:៥–៦ ២១:១៧ មើលការពន្យល់ ទដ ២៧:១) ។

**២២:៣១** *ឯផ្លូវរបស់ព្រះ នោះគ្រប់លក្ខណ៍* គឺជាប្រភេទបទទំនុកដែលស្តេចដាវីឌសរសើរតម្កើងដល់ព្រះអម្ចាស់(ខ.៣១–៥១) ក្នុងការដែលទ្រង់បានទទួលការសង្គ្រោះពីព្រះ ។

**២២:៣២–៤៧** *ជាថ្មដា* មើលការពន្យល់ ខ.២ ។

**២២:៣៤** មើល ហប ៣:១៩ និងការពន្យល់ ។

**២២:៤៧** *ព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់* មើលការពន្យល់ ទដ ១៨:៤៦ ។

**២២:៥០** *ឱព្រះយេហូវ៉ាអើយ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ នៅកណ្តាលអស់ទាំងសាសន៍* គឺទាក់ទងនឹងការសំអាងទៅលើលោកប៉ុល ចំពោះការសច្ចានេះ មើល រម ១៥:៩ ។

**២២:៥១** *ដល់ស្តេចនៃទ្រង់ . . . ដែលទ្រង់បានចាក់ប្រេងតាំងឱ្យ* មើលការពន្យល់ ១សយ ២:១០ ១០:២៥ ១២:១៤–១៥ ។ ដាវីឌបានបង្ហាញខ្លួនជាបុរសទី៣ ក្នុងការទទួលស្គាល់ចរិតលក្ខណៈនៃសេចក្តីសញ្ញា ក្នុងភាពជាស្តេចនៃអង្គទ្រង់ គឺជាស្តេចដាវីឌ ។ ក៏ជាសមត្តិភាពដល់ទ្រង់ដែលព្រះយេ

## បន្ទូលចុងក្រោយរបស់ស្តេចដាវីឌ

**២៣** ១រីឯព្រះបន្ទូលក្រោយបង្អស់របស់ដាវីឌ នោះគឺថា
ដាវីឌជា បុត្រអ៊ីសាយ ទ្រង់មានបន្ទូល គឺជាមនុស្សដែលបាន
ដំកើងឡើងជាខ្ពស់[ក] ជាអ្នកដែលព្រះនៃយ៉ាកុបបានចាក់
ប្រេងតាំងឱ្យ[ខ] ជាអ្នកតែងទំនុកយ៉ាងពីរោះ ក្នុងសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលថា ២ព្រះវិញ្ញាណ[គ]នៃព្រះ
យេហូវ៉ាបានមានបន្ទូលដោយសារខ្ញុំ ព្រះបន្ទូលនៃទ្រង់នៅ
លើអណ្តាតខ្ញុំ ៣ព្រះនៃសាសន៍អ៊ីស្រាអែលទ្រង់បានមាន
បន្ទូល គឺថ្មដា[ឃ]នៃសាសន៍អ៊ីស្រាអែលបានមានបន្ទូលមកខ្ញុំ
ថា អ្នកណាដែលសោយរាជ្យលើប្រជាជន នោះត្រូវតែបាន
សុច្ចរិត[ង] ហើយត្រូវសោយរាជ្យ ដោយសេចក្តីកោតខ្លាច[ច]
ដល់ព្រះ[ឆ] ៤អ្នកនោះនឹងបានដូចជាពន្លឺ[ជ]នៅពេលព្រលឹម
ស្រាង[ឈ] កាលថ្ងៃកំពុងតែរះ[ញ] ជាពេលព្រឹកមេឃស្រឡះ
ដែលមានស្មៅពន្លកពីដីឡើង ដោយពន្លឺភ្លឺមកក្រោយពេល
ភ្លៀងធ្លាក់[ដ] ៥តើវង្សខ្ញុំមិនមែនដូច្នោះ នៅចំពោះព្រះទេឬអី
ដ្បិតទ្រង់បានតាំងសេចក្តីសញ្ញានឹងខ្ញុំឱ្យនៅជាប់អស់កល្ប
ជានិច្ច[ឋ] ជាសេចក្តីសញ្ញាដែលមានរបៀបរៀបរយ ហើយ
ក៏ពិតប្រាកដ ឯសេចក្តីសង្គ្រោះនឹងសេចក្តីប៉ងប្រាថ្នាគ្រប់
ជំពូករបស់ខ្ញុំ បានកើតអំពីនោះមកទោះបើទ្រង់មិនទាន់ឱ្យ
ដុះដាល់ឡើងក៏ដោយ ៦តែបណ្តាពួកមនុស្សអាក្រក់សុទ្ធតែ
ដូចបន្លា[ឌ]ដែលគេចោល ពីព្រោះនឹងចាប់កាន់ដោយដៃមិន
បាន ៧មនុស្សណាដែលពាល់វា ត្រូវតែមានដែក ហើយដង
លំពែងផង គេនឹងដុតវាឱ្យសុសនៅទីនោះឯង ។

## ពួកខ្លាំងពូកែរបស់ស្តេចដាវីឌ

*២៣:៨–៣៩ – ១រប ១១:១០–៤១*

៨នេះជាឈ្មោះពួកខ្លាំងពូកែ[ឍ]របស់ដាវីឌ គឺយ៉ូសែប–
បាសេបែត[ណ] ជាពូជតាកម៉ូនី លោកជាមេលើពួកមេទ័ព
លោកបានលើកលំពែងតស៊ូ សំឡាប់មនុស្ស៨០០ក្នុងគ្រា
តែ១ ៩បន្ទាប់ពីលោកមក មានអេលាសារ ជាកូនដូដូរ[ត]
ពូជអ័ហូអា[ថ] លោកជាម្នាក់ក្នុងពួកខ្លាំងពូកែទាំង៣នាក់
ដែលនៅជាមួយនឹងដាវីឌ ក្នុងកាលដែលប្រកួតនឹងពួក
ភីលីស្ទីនដែលមូលគ្នាមកច្បាំង នៅវេលាដែលពួកអ៊ីស្រា
អែលឡើងទៅបាត់ហើយ ១០លោកនេះក៏ក្រោកឡើងកាប់
ចាក់ពួកភីលីស្ទីន ទាល់តែរោយដៃ ហើយដៃជាប់នៅ
នឹងដងដាវ នៅថ្ងៃនោះព្រះយេហូវ៉ាទ្រង់ប្រោសឱ្យ មាន
ជ័យជំនះយ៉ាងធំ រួចបណ្តាទ័ពក៏ត្រឡប់មកឯលោកឱ្យទាន់
តែនឹងប្រមូលរបឹបទេ ១១បន្ទាប់ពីលោកនោះមកមាន
សាំម៉ាជាកូនអ័កេ ពួកហារ៉ារី គ្រានោះពួកភីលីស្ទីនបាន
មូលគ្នា១កង នៅទីដែលមានចំការសណ្តែកបាយហើយ
ពួកពលទ័ពរត់ចេញពីមុខពួកភីលីស្ទីនទៅ ១២តែលោក
ឈរនៅកណ្តាលចំការនោះ រាំងរាហើយសំឡាប់ពួក
ភីលីស្ទីន ព្រះយេហូវ៉ាទ្រង់ក៏ប្រោសឱ្យមានជ័យជំនះយ៉ាងធំ
១៣មាន៣នាក់ ក្នុងពួកជាប្រធានទាំង៣០ បានចុះទៅឯ

**២៣:១** ក នក ១១:៣ ទដ ៧៨:៧០–៧១ ៨៩:២៧ ខ ១សយ ២:១០,៣៥ ទដ ១៨:៥០ ២០:៦ ៨៤:៩ អស ៤៥:១ ហព ៣:១៣ **២៣:២** គ មថ ២២:៤៣ មក ១២:៣៦ ២ពត ១:២១ **២៣:៣** ឃ ចទ ៣២:៤ ១សយ ២:២ ទដ ១៨:៣១ ង ទដ ៧២:២ ច លប ៤២:១៨ ឆ អស ១១:១–៥ **២៣:៤** ជ យហ ១:៥ ឈ ទដ ១១៩:១៤៧ ១៣០:៦ សភ ៤:១៨ ញ ពច ៥:៣១ មថ ១៣:៤៣ ដ ចទ ៣២:២ **២៣:៥** ឋ លប ៩:១៦ ទដ ៨៩:២៩ **២៣:៦** ឌ អស ៥:៦ ៩:១៨ ១០:១៧ ២៧:៤ ៣៣:១២ មីក ៧:៤ ណាហ ១:១០
មថ ១៣:៤០–៤១ **២៣:៨** ឍ ២សយ ១៧:១០ ណ ១រប ២៧:២ **២៣:៩** ត ១រប ២៧:៤ ថ ១រប ៨:៤

ហូវ៉ាប្រទានឱ្យតាមរយៈការចាក់ប្រេងតាំង ក៏បង្ហាញតាមរយៈបទទំនុកទាំងមូលដែលបានអាន ។ *គឺដល់ដាវីឌនឹងព្រះរាជវង្ស ជារៀងដរាបទៅ* ដាវីឌមានបន្ទូលពីព្រះបន្ទូលសន្យាជាមួយព្រះនៃទ្រង់ តាមរយៈហោរាណាថាន់ (មើល ៧:១២–១៦) ។

**២៣:១** *ព្រះបន្ទូលក្រោយបង្អស់របស់ដាវីឌ* យើងដឹងថាគឺជាបទទំនុកជាទីបន្ទាល់បង្ហាញឱ្យឃើញពីព្រះបន្ទូលរៀបរាប់ផ្នែកចុងក្រោយបង្អស់(នៅក្នុងផ្នែកដែលជាទំនុករបស់ផងទ្រង់) គឺប្រហែលជាទ្រង់បាននិពន្ធក្នុងគ្រាដែលទ្រង់ណែនាំនឹងរំលឹកចំពោះស្តេចសាឡូម៉ូន ជាបុត្រារបស់ផងទ្រង់នៅគ្រាចុងក្រោយ(មើល ១ពវ ២:១–១០) ។

**២៣:២** មើលការពន្យល់ ២ធថ ៣:១៦ ២ពត ១:២០ ។

**២៣:៣** *ថ្មដា* មើលការពន្យល់ ២២:២ មើល ១សយ ២:២ និងការពន្យល់ ចទ ៣២:៤,១៥,១៨,៣០–៣១ ។ *អ្នកដែលសោយរាជ្យលើប្រជាជន* គឺជាលក្ខណៈសង្ខេបនឹងភាពប៉ះពាល់ដាវីឌដែលពណ៌នា ពីភាពជាស្តេចដែលពឹងផ្អែកយ៉ាងពេញទំហឹងទៅលើច្បាប់អធិរាជ្យដាវីឌ មើល ៧:១២–១៦ ។

**២៣:៤** *ដូចជាពន្លឺនៅពេលព្រលឹមស្រាង* សូមមើលការពន្យល់ ទដ ២៧:១ ៣៦:៩ ។

**២៣:៥** *តើវង្សខ្ញុំមិនមែនដូច្នោះ នៅចំពោះព្រះទេឬអី* គឺជាសំនួរពីការត្រាស់ហៅសារជាថ្មីពីសេចក្តីសញ្ញារបស់ព្រះជាមួយដាវីឌ និងខ្សែរាជវង្សរបស់ផងទ្រង់(មើល ៧:១២–១៦) ។ *សេចក្តីតាំងសញ្ញានឹងខ្ញុំនៅជាប់អស់កល្បជានិច្ច* ដាវីឌបានបញ្ជាក់ថាព្រះបន្ទូលសន្យាចំពោះទ្រង់ គឺសេចក្តីសញ្ញាដែលមិនអាចច្រានចោលបាន(មើលការពន្យល់ ៧:២០,២៨ អស ៥៥:៣ មើល ទដ ៨៩:៣–៤,២៨–២៩,៣៤–៣៧ ១៣២:១១–១២) ។ *មិនទាន់ឱ្យដុះដាលឡើងក៏ដោយ* ដាវីឌបានសន្យា និងពួកអំបូរជាពូជរបស់ទ្រង់ ។

**២៣:៦** *ពួកមនុស្សអាក្រក់ . . . ដូចបន្លាដែលគេចោល* ពួកមនុស្សដែលគ្មានព្រះគឺជាមនុស្សដែលមិនមានការចាប់អារម្មណ៍ នូវព្រះមហាក្សត្រដ៏សុចរិតក៏ពួកគេត្រូវវិនាសបាត់ទៅ (មើល ទដ ២:៨–៩ ១១០:៥–៦) ។

**២៣:៨–៣៩** មើលការពន្យល់ ២១:១–២៤:២៥ ។ តាមបញ្ជីនៃជំពូក ៣៧ (មើល ខ.៣៩) គឺបង្ហាញពីភាពជាអ្នកចំបាំងដ៏ក្លាហានបំផុត របស់ស្តេចដាវីឌនឹងពណ៌នាពីភាពក្លាហានរបស់ពួកគេ គឺត្រូវលើកឡើងក្នុងពេលស្របគ្នា មើល ១រប ១១:១១–៤១ ។ ក៏មានបញ្ជីឈ្មោះរហូតដល់ ១៦រូប (មើល រប ១១:៤១–៤៧) ។

**២៣:៨** *៣នាក់* នៅក្រុមពីរនៃអ្នកចំបាំងទាំងបី(ខ.៨–១២ ហើយ ១៣:២៣) និងមួយក្រុមក្នុងចំណោម៣០នាក់ចំបាំង(ខ.២៤–៣៩)គឺក៏បានបង្ហាញ(មើល ៣៩ គឺជាចំនួនសរុបទាំងអស់) ។

**២៣:១៣** *ក្នុងរដូវចំរូត* មើល ១១:១ និងការពន្យល់ ។ គឺជាស្ថានភាពថា និងកើតឡើងបន្ទាប់ពីដាវីឌបានភៀសខ្លួនចេញពីលោកសូល (សូមមើល ១សយ

ដាវីឌនៅក្នុងរអាងអាឌូឡាម[ទ] ក្នុងរដូវចំរូត ឯកងពួក
ភីលីស្ទីន គេបានបោះទ័ពនៅក្នុងវាលច្រកភ្នំរេផែម[ធ]
១៤ នៅគ្រានោះដាវីឌគង់នៅទីពំនួន[ន] ហើយមានពួកទ័ព
ភីលីស្ទីននៅត្រង់បេថ្លេហិម[ប] ១៥ ដាវីឌទ្រង់នឹកកន្លែងក្នុង
ព្រះទ័យហើយមានបន្ទូលថា ឱបើសិនជាមានអ្នកណា យក
ទឹកពីអណ្តូងនៅមាត់ទ្វារក្រុងបេថ្លេហិម មកឱ្យអញផឹក
ទៅអេះ ១៦ ចំណែកពួកអ្នកខ្លាំងពូកែទាំង៣នាក់នោះ ក៏
បំបែកពួកទ័ពភីលីស្ទីន កាត់ចូលទៅដងទឹកអណ្តូង នៅមាត់
ទ្វារបេថ្លេហិមយកមកថ្វាយដាវីឌ តែទ្រង់មិនព្រមសោយ
ទេ គឺទ្រង់ចាក់ច្រួច[ផ]ថ្វាយដល់ព្រះយេហូវ៉ាវិញ ១៧ រួចទូល
ថា ឱព្រះយេហូវ៉ាអើយ សូមឱ្យការយ៉ាងនេះនៅឆ្ងាយពី
ទូលបង្គំទៅ កុំឱ្យទូលបង្គំធ្វើឡើយ តើគួរឱ្យទូលបង្គំផឹក
ឈាម[ព]របស់មនុស្ស ដែលទៅទាំងប្រថុយជីវិតដូច្នេះឬអី
គឺដោយហេតុនោះ បានជាទ្រង់មិនព្រមសោយទឹកនោះទេ
អ្នកខ្លាំងពូកែទាំង៣នេះ បានប្រព្រឹត្តយ៉ាងដូច្នោះ ។
១៨ ឯអ័ប៊ីសាយ[ភ] ជាប្អូនយ៉ូអាប់កូនសេរូយ៉ា លោកជាមេ
លើអ្នកទាំង៣នោះ លោកបានលើកលំពែងសំឡាប់៣០០
នាក់ ហើយក៏ល្បីឈ្មោះក្នុង៣នាក់នោះ ១៩ ក្នុងបណ្តា៣នាក់
នោះ គេរាប់អានលោកជាងគេ បានជាលើកលោកធ្វើជា
មេ ប៉ុន្តែលោកមិនស្មើនឹងពួក៣នាក់មុននោះទេ ។
២០ រីឯបេណាយ៉ា[ម] ជាកូនយេហូយ៉ាដា ជាកូនរបស់អ្នក
ខ្លាំងពូកែម្នាក់នៅកាបសៀល[យ] ជាអ្នកដែលបានធ្វើការ
មានថ្វីដៃច្រើន លោកបានសំឡាប់កូនទាំង២របស់អ័រាល–
សាសន៍ម៉ូអាប់ទៅ ហើយក៏ចុះទៅក្នុងរណ្តៅសំឡាប់សត្វ
សិង្ហ១នៅថ្ងៃមានហិមៈ ២១ ហើយលោកសំឡាប់សាសន៍
អេស៊ីព្ទម្នាក់ដែលគួរស្ញែងខ្លាច វាកាន់លំពែងនៅដៃ តែ
លោកមានតែដំបងកាន់ចុះទៅឯវាប៉ុណ្ណោះ ក៏កន្ត្រាក់យក
លំពែងពីដៃនៃសាសន៍អេស៊ីព្ទនោះបាន រួចចាក់សំឡាប់
នឹងលំពែងរបស់ខ្លួនវានោះឯង ២២ គឺការយ៉ាងនោះដែល
បេណាយ៉ា ជាកូនយេហូយ៉ាដាបានធ្វើ ហើយក៏មានល្បី
ឈ្មោះក្នុងពួកខ្លាំងពូកែទាំង៣នាក់នោះ ២៣ គេរាប់អាន
លោក ជាជាងមនុស្ស៣០នាក់ តែលោកមិនស្មើនឹងពួក
៣នាក់មុននោះទេ ដាវីឌទ្រង់តាំងលោកឱ្យត្រួតលើពួក
ទាហានរក្សាអង្គ ។
២៤ ឯអេសាអែល[រ] ជាប្អូនយ៉ូអាប់ លោកជាម្នាក់ក្នុងពួក
៣០នាក់នោះដែរ អែលហាណាន ជាកូនដូដូរ ពីក្រុងបេ–
ថ្លេហិម ២៥ សាំម៉ា ជាពួកហារ៉ូឌ[ល] អេលីកា ជាពួកហារ៉ូឌ
២៦ ហេលែស[វ] ជាពួកប៉ាលធី អ៊ីរ៉ា[ស] ជាកូនអ៉ីកកែស ពីក្រុង
ត្កូអា ២៧ អ័បៀសើរ[ហ] ពីអានាថោត[ឡ] មប៊ូណាយ ជាពួក
ហ៊ូសាយ ២៨ សាលម៉ូន ជាពួកអ័ហូអា ម៉ាហារ៉ាយ[អ]
ពីនថូផា[ក] ២៩ ហេលែប[ខ] ជាកូនប្អាណាពីនថូផា អ៉ីតតាយ
ជាកូនរីបាយ ពីគីបៀរ[គ] ក្នុងពូជកូនចៅបេនយ៉ាមីន
៣០ បេណាយ៉ា ពីពីរ៉ាថូន[ឃ] ហ៊ីដាយ ពីណាហាលេ–កាអាស[ង]
៣១ អ័ប៊ីអាលបូន ពីអើរ៉ាបា អាសម៉ាវែត ពីបាហ៊ូរីម[ច]
៣២ អេលីយ៉ាបា ពីស្អាឡាប៊ីន ពួកកូនយ៉ាសេន យ៉ូណាថាន
៣៣ សាំម៉ា ពីស្រុកហារ៉ារី អ័ហ៊ីយ៉ាម ជាកូនសារើរ ពីស្រុក
ហារ៉ារី ៣៤ អេលីផាលេត ជាកូនអ័ហាសបាយ កូនរបស់
ម្នាក់ក្នុងពួកម៉ាកាធី[ឆ] អេលាម[ជ] ជាកូនអ័ហ៊ីថូផែល[ឈ] ពួក
គីឡោ ៣៥ ហេស្រាយ ជាពួកកើមែល[ញ] ប្អារ៉ាយ ជាអ្នកមក
ពីអារ៉ាប ៣៦ យីកាល ជាកូនណាថាន់ ពីសូបា[ដ] បានី ជាកូន
កាឌ់ ៣៧ សេលេក ជាសាសន៍អាំម៉ូន ណាហារ៉ាយ ពីបៀរ៉ុត[ឋ]
ជាអ្នកដែលកាន់គ្រឿងសស្ត្រាវុធរបស់យ៉ូអាប់ ជាកូនសេរូ–
យ៉ា ៣៨ អ៉ីរ៉ា ជាពួកយេធើ[ឌ] គារេប ជាពួកយេធើ ៣៩ ហើយ

**២៣:១៣** ទ លប ៣៨:១ យស ១២:១៥ ធ យស ១៧:១៥
**២៣:១៤** ន ១សយ ២២:៤–៥ ២សយ ៥:១៧ ប នរ ១:១៩
**២៣:១៦** ផ លប ៣៥:១៤
**២៣:១៧** ព លវ ១៧:១០–១២
**២៣:១៨** ភ ១សយ ២៦:៦
**២៣:២០** ម ២សយ ៨:១៨ ១របា ២៧:៥ យ យស ១៥:២១
**២៣:២៤** រ ២សយ ២:១៨
**២៣:២៥** ល ពច ៧:១
**២៣:២៦** វ ១របា ២៧:១០ ស ១របា ២៧:៩
**២៣:២៧** ហ ១របា ២៧:១២ ឡ យស ២១:១៨
**២៣:២៨** អ ១របា ២៧:១៣ ក ២ពរ ២៥:២៣ អគ ២:២២ នហ ៧:២៦ យរ ៤០:៨
**២៣:២៩** ខ ១របា ២៧:១៥ គ យស ១៥:៥៧
**២៣:៣០** ឃ ពច ១២:១៣ ង យស ២៤:៣០
**២៣:៣១** ច ២សយ ៣:១៦ **២៣:៣៤** ឆ ចទ ៣:១៤ ជ ២សយ ១១:៣ ឈ ២សយ ១៥:១២ **២៣:៣៥** ញ យស ១២:២២ **២៣:៣៦** ដ ១សយ ១៤:៤៧ **២៣:៣៧** ឋ យស ៩:១៧ **២៣:៣៨** ឌ ១របា ២:៥៣

២២:១–៤) មិនយូរប៉ុន្មាន បន្ទាប់ពីគាត់ដណ្តើមច្បាំងយកទីក្រុងយេរូសាឡិមបានមក (មើល ២សយ ៥:១៧–១៨) ។ *៣នាក់* ពាក្យនេះគឺមិនមែនដូចចំនួនដែលនិយាយថាអ្នកខ្លាំងពូកែ ៣នាក់នោះទេក្នុង ខ.៩ ។ *មនុស្ស៣០នាក់* មើល ខ.២៣–២៤,៣៩ ។ *ក្នុងរអាងអាឌូឡាម* មើល ១សយ ២២:១ ។ *ភ្នំរេផែម* មើល ៥:១៨ ។

**២៣:១៤** *ទីពំនួន* មើលការពន្យល់ ១សយ ២២:៤ ។

**២៣:១៥–១៧** មើលការពន្យល់ ១របា ១១:១៥–១៩ ។

**២៣:១៥** បេថ្លេហិម ជាទីក្រុងស្រុកកំនើតរបស់ដាវីឌ (១សយ ១៧:៥៨) ។

**២៣:២០** *បេណាយ៉ាជាកូនយេហូយ៉ាដា* គឺជាមេទ័ពនៃពួកកេរេធីមនិងពួកពេលេធីម (មើល ៨:១៨ និងការពន្យល់) គឺជាមេទី៣ជាមេធំលើពួកទ័ពនៅខែជេស្ឋ គឺបេណាយ៉ាជាកូនយេហូយ៉ាដាដ៏ជាសង្ឃ ហើយនៅវេននេះមាន ២ម៉ឺន៤ពាន់នាក់ ។

**២៣:២៤** *ពួក៣០នាក់* គឺថាយ៉ាងតិចណាស់ក៏មានឈ្មោះ៣០នាក់បានចុះក្នុងបញ្ជី ខ.២៤–៣៩ ។ (មើល ខ.១៣) អ្នកចំបាំងមានចំនួនសរុបទាំងអស់គឺបានបង្ហាញយ៉ាងតិចបំផុតក៏មាន៣៣នាក់ ។ ១របា ១១:៤១–៤៧ ក៏មានបញ្ជីបន្ថែមទៀតគឺ១៦នាក់ចំពោះក្រុមនេះនឹងតាមការជាក់ស្តែង មានទាំងឈ្មោះទាហានដែលត្រូវយកមកជំនួស នៅពេលអ្នកចំបាំងនោះត្រូវគេដកចេញ ឬត្រូវស្លាប់បាត់បង់ក្នុងសមរភូមិ ។ *អេសាអែល* មើល ២:១៨–២៣ ។

**២៣:៣៤** *អេលាម* គឺជាឪពុកនាងបាតសេបា (មើល ១១:៣ និងការពន្យល់) ក៏ជាកូនប្រុសទីប្រឹក្សារបស់ស្តេចដាវីឌ ។ *គឺជាលោកអ័ហ៊ីថូផែល* ដែលបានចូលរួមគំនិតក្នុងការបះបោរជាមួយអាប់សាឡំម (មើល ១៥:១២ និងការពន្យល់ ១៦:២០–២៣ ១៧:១–២៣) ។

និងអ៊ូរី[ឈ] ជាសាសន៍ហេត រួមទាំងអស់មាន៣៧នាក់ ។

## ស្តេចដាវីឌរាប់ចំនួនទ័ព

*២៤:១-១៧ – ១របា ២១:១-១៧*

**២៤** ១មានមួយគ្រាទៀត[ក] ដែលព្រះយេហូវ៉ាទ្រង់មាន
សេចក្តីខ្ញាល់ឆួលឡើងចំពោះពួកអ៊ីស្រាអែល[ខ] ហើយទ្រង់
បណ្តាលដាវីឌឱ្យប្រព្រឹត្តទាស់នឹងគេ ដោយបន្ទូលថា ចូរទៅ
រាប់ចំនួន[គ]ពួកអ៊ីស្រាអែល និងពួកយូដាចុះ ២ដូច្នេះ ស្តេច
ទ្រង់មានបន្ទូលទៅយ៉ូអាប់[ឃ] ជាមេទ័ពដែលនៅចំពោះទ្រង់
ថា ចូរឱ្យដើរទៅមកគ្រប់ក្នុងអស់ទាំងពូជអំបូរសាសន៍
អ៊ីស្រាអែលទាំងប៉ុន្មាន ចាប់តាំងពីក្រុងដាន់ រហូតដល់
បៀរ-សេបា[ង] ហើយរាប់[ច]បណ្តាជនទាំងឡាយ ដើម្បីឱ្យ
យើងបានដឹងចំនួន ៣យ៉ូអាប់[ឆ]ទូលទាស់ថា សូមឱ្យព្រះ
យេហូវ៉ា ជាព្រះនៃទ្រង់ បន្ថែមពួកជនឱ្យមានចំនួន១០០ដង
លើសទៅទៀត[ជ] ហើយសូមឱ្យព្រះនេត្រព្រះករុណា ជាព្រះ
អម្ចាស់នៃទូលបង្គំ បានឃើញផង តែហេតុអ្វីបានជាព្រះ
ករុណា ជាព្រះអម្ចាស់នៃទូលបង្គំ សព្វព្រះហឫទ័យក្នុងការ
នេះ ៤ប៉ុន្តែព្រះបន្ទូលនៃស្តេចបានឈ្នះយ៉ូអាប់ ហើយនិង
ពួកមេទ័ព រួចយ៉ូអាប់នឹងពួកមេទ័ព ក៏ចេញពីចំពោះស្តេច
ទៅ ដើម្បីរាប់ចំនួនពួកសាសន៍អ៊ីស្រាអែល ៥គេឆ្លងទន្លេ
យ័រដាន់ ទៅដំឡើងត្រសាលនៅត្រង់អារ៉ូអេរ[ឈ] ជាខាងស្តាំ
ទីក្រុងដែលនៅកណ្តាលច្រកភ្នំខាងស្រុកកាឌ់ជិតយ៉ាសេរ[ញ]
៦រួចគេទៅដល់ស្រុកកាឡាតនឹងស្រុកថាសធីម-ហ៊ុតសីពី
នោះក៏ទៅដល់ដាន់-យ្អាន ហើយវាងរហូតដល់ស៊ីដូន[ដ] ៧គេ
ទៅដល់បន្ទាយក្រុងទីរ៉ុស[ឋ] ហើយអស់ទាំងទីក្រុងរបស់
សាសន៍ហេវី[ឌ] និងសាសន៍កាណាន រួចគេបែរទៅខាង
ត្បូង[ឍ]ស្រុកយូដាត្រង់បៀរ-សេបា[ណ] ៨ដូច្នេះកាលគេបាន
ដើរចុះឡើងពេញក្នុងស្រុកទាំងអស់រួចហើយ ដល់ផុត៩ខែ
២០ថ្ងៃ នោះគេវិលមកដល់ក្រុងយេរូសាឡិមវិញ ៩យ៉ូអាប់
ក៏ប្រគល់បញ្ជីពួកជនទាំងឡាយដល់ស្តេច ឃើញមានមនុស្ស
ខ្លាំងពូកែ ដែលចេះកាន់ដាវ ក្នុងពួកអ៊ីស្រាអែលចំនួន៨
សែននាក់ ហើយក្នុងពួកយូដាមាន៥សែននាក់[ត] ។
១០ក្រោយដែលរាប់ចំនួនបណ្តាជនហើយ នោះដាវីឌ
មានព្រះទ័យឈឺសាយជាខ្លាំង[ថ] រួចទ្រង់ទូលទៅព្រះយេហូវ៉ា
ថា ទូលបង្គំបានធ្វើបាបយ៉ាងធ្ងន់ក្នុងការដែលទូលបង្គំធ្វើ
នោះ[ទ] តែឥឡូវនេះ ឱព្រះយេហូវ៉ាអើយ សូមលើកចោល
ទោសនៃការអាក្រក់របស់ទូលបង្គំ ជាបាវបំរើទ្រង់ ដ្បិត
ទូលបង្គំបានប្រព្រឹត្តដោយខ្លៅល្ងង់[ធ] ១១ព្រឹកឡើង កាល
ដាវីឌបានតើនហើយ នោះព្រះយេហូវ៉ាទ្រង់ បង្គាប់ដល់
ហោរាកាឌ់[ន] ជាអ្នកមើលឆុតរបស់ដាវីឌ[ប] ១២ឱ្យទៅទូល
ដាវីឌថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អញដាក់
សេចក្តីទាំង៣នេះឱ្យឯង ចូររើសយក១ចុះ ឱ្យអញបាន

**២៣:៣៩** ឈ ២សយ ១១:៣
**២៤:១** ក យស ៩:១៥ ខ យប ១:៦ សក ៣:១ គ នក ៣០:១២ ១រប ២៧:២៣
**២៤:២** ឃ ២សយ ២០:២៣ ង ២សយ ៣:១០ ច ២រប ២:១៧ ១៧:១៤ ២៥:៥
**២៤:៣** ឆ ២សយ ២:១៨ ជ ចទ ១:១១
**២៤:៥** ឈ យស ១៣:៩ ញ ជន ២១:៣២
**២៤:៦** ដ លប ១០:១៩ ៣ច ១:៣១
**២៤:៧** ឋ យស ១៩:២៩ ឌ នក ៣:៨ ឍ ចទ ១:៧ ណ លប ២១:៣១
**២៤:៩** ត ជន ១:៤៤-៤៦
**២៤:១០** ថ ១សយ ២៤:៥ ទ ជន ២២:៤ ធ ជន ១២:១១
**២៤:១១** ន ១សយ ២២:៥ ប ១សយ ៩:៩

**២៣:៣៩** *អ៊ូរី* គឺជាប្តីរបស់នាងបាតសេបា (មើល ១១:៣-២៧ មើលការពន្យល់ ១១:១៧ ១២:៧) ។

**២៤:១** *ខ្ញាល់ឆួលឡើងចំពោះ* ដូចជាពេលពីមុនដែលគេទទួលភាពអត់ឃ្លាន ២១:១ ។ *ដែលព្រះយេហូវ៉ាទ្រង់មានសេចក្តីខ្ញាល់ឆួលឡើង ចំពោះពួកអ៊ីស្រាអែល* ហេតុផលពិសេសដែលព្រះយេហូវ៉ាពុំសព្វព្រះហឫទ័យ គឺមិនបានបង្ហាញឱ្យឃើញទេ ។ ព្រោះសេចក្តីខ្ញាល់ឆួលឡើងគឺនៅចំពោះរាស្ត្រអ៊ីស្រាអែលច្រើនតែទៅលើស្តេចដាវីឌ ។ ក៏នាំឱ្យមានការរីកដុះដាលពីព្រោះការបះបោររបស់អាប់សាឡុម (មើល ១៥:១២ ១៧:១១,២៤-២៦ ១៨:៧ ២០:១-២) ព្រះយេហូវ៉ាបានជ្រើសឱ្យមានស្តេច មើលជំពូក ១៥-២៥ ។ *ទ្រង់បណ្តាលដាវីឌឱ្យប្រព្រឹត្តទាស់នឹងគេ* មើល ១រប ២១:១ ។ ទោះជាបទគម្ពីរពុំបានបញ្ជាក់ថា ព្រះអម្ចាស់ពុំបានធ្វើឱ្យអ្នកណាមួយប្រព្រឹត្តបាបនោះឡើយ (យក ១:១៣-១៤) ។ ដោយអំណាចអាក្រក់ពីសាតាំងបានបង្ហាញឱ្យឃើញតាមរយៈមនុស្ស និងសាតាំងស្ថិតនៅក្រោមអំណាចនៃភាពជាព្រះមហាក្សត្ររបស់ព្រះម្ចាស់ (មើល នក ៤:២១ ៧:៣ ៩:១២ ១០:១ ២០:២៧ ១១:១០ ១៤:៤,៨ ១ពវ ២២:២២-២៣ សយ ១:១២ ២:៦ ។ *ចូររាប់ចំនួនពួកអ៊ីស្រាអែល និងពួកយូដាចុះ* ការជំរឿនទ័ពរបស់ស្តេចដាវីឌ (មើល ខ.២-៣) ដោយពុំមានលក្ខណៈងាយស្រួល គឺដោយព្រោះការគំរាមកំហែងពីប្រភពខាងក្រៅ គឺពេលដែលទ្រង់ចង់ដឹង (ខ.២) វាបង្ហាញឱ្យឃើញថាសកម្មភាពរបស់អង្គទ្រង់ បានផ្តើមចេញតាមរយៈមោទនៈភាពក្នុងអំណាចជាស្តេច ឬក៏ដោយការទុកចិត្តដល់អំណាចមកពីមនុស្សការធ្វើបែបនេះគឺជាអំពើបាបមួយដ៏ពិតប្រាកដ (មើល ជន ១:២-៣ ២៦:២-៤) ។ ការដែលទ្រង់ធ្វើដូច្នេះ គឺជាការពឹងផ្អែកលើអំណាចរបស់មនុស្សមិនមែនពឹងអំណាចមកពីព្រះទេមិនខុសប៉ុន្មាន ពីរាស្ត្រអ៊ីស្រាអែលដែលស្រែកអំពាវនាវឱ្យមានស្តេចរបស់ពួកគេ មើល ១សយ ៨-១២) ។ (មើល ២២:២-៤,៤៧-៥១ ១សយ ១៧:២៦,៣៧,៤៥ -៤៧) ។

**២៤:២,១៥** *ពីក្រុងដាន់រហូតដល់បៀរ-សេបា* មើលការពន្យល់ ១សយ ៣:២០ ។

**២៤:៣** *ហេតុអ្វី* សេចក្តីបង្គាប់របស់ស្តេចដាវីឌមិនបានឱ្យមានការលើកទឹកចិត្តឡើយ ។ តាមការពិតស្តេចដាវីឌពុំបានឆ្លើយ នូវសេចក្តីស្នើដែលទ្រង់ដឹងនូវហេតុរបស់ទ្រង់ដែលគួឱ្យដឹងណាស់ ។ ក្នុងពេលខ្លះការជំរុញរបស់លោកយ៉ូអាប់បានធ្វើឱ្យដាវីឌតបត្រឡប់មកវិញ តាមបែបឃោរឃៅ ។

**២៤:៥-៨** ការរាប់ចំនួនកងទ័ពគឺចាប់ផ្តើមក្នុងផ្នែកតំបន់ បន្ទាប់មកផ្នែកខាងលិចឆ្លងទន្លេយ័រដាន់ពីខាងជើងទៅខាងត្បូង ។

**២៤:៩** *៨សែននាក់ . . . ៥សែននាក់* តួរលេខនេះគឺផ្ទុយពីតួរលេខក្នុង ១រប ២១:៥ (មើលការពន្យល់ ១រប ២១:៥-៦) ។

**២៤:១០** *ទូលបង្គំបានធ្វើបាបយ៉ាងធ្ងន់* មើលការពន្យល់ ខ.១០ ។

**២៤:១១** *ហោរាកាឌ់ជាអ្នកមើលឆុតរបស់ដាវីឌ* មើលការពន្យល់ ១សយ ៩:៩,២២:៥ ។

ធ្វើយ៉ាងនោះដល់ឯង ១៣ដូច្នេះកាឌ់ក៏ទៅឯដាវីឌទូលថា
តើព្រះករុណាសព្វព្រះហឫទ័យយ៉ាងណា ចង់ឱ្យមាន
អំណត់[ផ]៧ឆ្នាំនៅក្នុងនគរ ឬចង់រត់ពីមុខពួកខ្មាំងសត្រូវក្នុង
រវាង៣ខែ កំពុងដែលគេដេញតាម ឬឱ្យមានជំងឺអាសន្ន
រោគ[ព]អស់៣ថ្ងៃនៅក្នុងនគរវិញ សូមពិចារណាឥឡូវចុះ
ហើយមានបន្ទូលមក ឱ្យទូលបង្គំបានឆ្លើយដល់ព្រះ ដែល
ទ្រង់ចាត់ឱ្យទូលបង្គំមក ១៤ដាវីឌមានបន្ទូលតបថា យើង
មានសេចក្តីចង្អៀតចិត្តជាខ្លាំង សូមឱ្យយើងរាល់គ្នាធ្លាក់
ទៅក្នុងកណ្តាប់ព្រះហស្តនៃព្រះយេហូវ៉ាវិញចុះ ដ្បិតសេច
ក្តីមេត្តាករុណា[ភ]របស់ទ្រង់ធំណាស់ សូមកុំឱ្យយើងធ្លាក់
ទៅក្នុងកណ្តាប់ដៃនៃមនុស្សឡើយ ។
១៥ដូច្នេះព្រះយេហូវ៉ាទ្រង់បណ្តាលឱ្យមានជំងឺអាសន្ន
រោគកើតឡើងក្នុងសាសន៍អ៊ីស្រាអែល ចាប់តាំងពីព្រឹក
រហូតដល់ពេលកំណត់នោះ ហើយមានមនុស្សស្លាប់តាំង
តែពីក្រុងដាន់ រហូតដល់បៀរ–សេបា អស់ចំនួន៧ម៉ឺន
នាក់[ម] ១៦តែកាលទេវតាលើកដៃទៅ ដើម្បីនឹងបំផ្លាញក្រុង
យេរូសាឡិម នោះព្រះយេហូវ៉ាទ្រង់មានព្រះហឫទ័យ
រំជួល[យ]ថយចេញពីការអាក្រក់នោះ ក៏មានបន្ទូលទៅ
ទេវតាដែលកំពុង តែបំផ្លាញបណ្តាជនថា ល្មមហើយ ចូរ
បញ្ឈប់ដៃឥឡូវចុះ ខណនោះ ទេវតានៃព្រះយេហូវ៉ា[រ]
កំពុងតែនៅជិតលានស្រូវរបស់អ័រ៉ោណា សាសន៍យេប៊ូស
១៧ឯដាវីឌ កាលទ្រង់ទតឃើញទេវតា ដែលបានប្រហារ
ពួកជន នោះក៏ទូលដល់ព្រះយេហូវ៉ាថា មើល ទូលបង្គំបាន
ធ្វើបាប គឺទូលបង្គំដែលត្រូវមានទោស តែឯតួចៀមទាំង
នេះ[ល] តើបានធ្វើអ្វី សូមឱ្យព្រះហស្តនៃទ្រង់ បានទាស់នឹង
ទូលបង្គំ ហើយនិងពួកវង្សបិតារបស់ទូលបង្គំវិញចុះ[ស]។

## ស្តេចដាវីឌសាងអាសនាមួយ

*២៤:១៨–២៥ – ១រប ២១:១៨–២៦*

១៨នៅថ្ងៃនោះឯង កាឌ់ក៏ចូលមកគាល់ដាវីឌ ទូលថា
សូមព្រះករុណាឡើងទៅស្អាងអាសនា១ ថ្វាយព្រះយេហូវ៉ា
នៅត្រង់លានស្រូវ របស់អ័រ៉ោណា[ហ] ជាសាសន៍យេប៊ូសទៅ
១៩ដូច្នេះ ដាវីឌក៏ឡើងទៅតាមពាក្យរបស់កាឌ់ ដូចជាព្រះ
យេហូវ៉ាទ្រង់បានបង្គាប់មក ២០ឯអ័រ៉ោណា គាត់ក្រឡេក
មើលទៅឃើញស្តេច និងពួកមហាតលិក កំពុងតែមក
ឯគាត់ នោះគាត់ក៏ចេញទៅក្រាបផ្កាប់មុខដល់ដីថ្វាយបង្គំ
នៅចំពោះស្តេច ទូលថា ២១បពិត្រព្រះករុណា ជាព្រះ
អម្ចាស់នៃទូលបង្គំ តើទ្រង់យាងមកឯទូលបង្គំមានការអ្វី
ដាវីឌឆ្លើយថា មកទិញលានស្រូវរបស់ឯង ដើម្បីនឹងស្អាង
អាសនា ១ថ្វាយព្រះយេហូវ៉ា ប្រយោជន៍ឱ្យសេចក្តីវេទនា
នេះបានថយចេញពីពួកជនទៅ[ឡ] ២២អ័រ៉ោណាទូលទ្រង់ថា
បពិត្រព្រះអម្ចាស់នៃទូលបង្គំ សូមឱ្យព្រះករុណាយកចុះ
ហើយថ្វាយអ្វីតាមបំណងព្រះទ័យ មើល មានគោនេះ[អ]
សំរាប់ដង្វាយដុត ហើយប្រដាប់បែនស្រូវ និងនឹមគោ ទុក
ជាឧសស្រាប់ ២៣អ័រ៉ោណាក៏ថ្វាយ[ក]ទាំងអស់នោះ ដល់ស្តេច
ដោយពាក្យថា សូមឱ្យព្រះយេហូវ៉ា ជាព្រះនៃទ្រង់ទទួល
ទ្រង់ផង ២៤តែស្តេចមានបន្ទូលទៅអ័រ៉ោណាថា កុំឡើយ
គឺយើងចង់ទិញពីឯងតាមដំឡៃវិញ យើងមិនព្រមយករបស់

**២៤:១៣** ផ ចទ ២៨:៣៨–៤២,៤៨ ៣២:២៤ អគ ១៤:២១ ព នក ៥:៣ ៣០:១២ លវ ២៦:២៥ ចទ ២៨:២១–២២,២៧–២៨,៣៥ **២៤:១៤** ភ នហ ៩:២៨ ទដ ៤:១ ៥១:១ ៨៦:៥ ១០៣:៨,១៣ ១១៩:១៣២ ១៣០:៤ អស ៥៤:៧ ៥៥:៧ យរ ៣៣:៨ ៤២:១២ ដយ ៩:៩ **២៤:១៥** ម ១រប ២៧:២៤ **២៤:១៦** យ លប ៦:៦ រ លប ១៦:៧ ១៩:១៣ នក ១២:២៣ កច ១២:២៣ **២៤:១៧** ល ទដ ៧៤:១ ១០០:៣ យរ ៤៩:២០ វ លប ១៨:២៣ ស យហ ១:១២ **២៤:១៨** ហ លប ២២:២ ២រប ៣:១ **២៤:២១** ឡ ជន ១៦:៤៤–៥០ **២៤:២២** អ ១សយ ៦:១៤ **២៤:២៣** ក លប ២៣:១១

**២៤:១២** *ឱ្យទៅប្រាប់ដាវីឌថា* មើល ១២:១ និងការពន្យល់ ។ សេចក្តីទាំងនេះ ។ គឺជាការកាត់ទោសបីផ្នែកផ្សេងៗពីគ្នា(ខ.១៣) នេះគឺជាទំនាយដែលនិងត្រូវធ្លាក់មកលើរាស្ត្ររបស់ផងទ្រង់ ក៏ជាសេចក្តីរបស់លោកម៉ូសេបើកសម្តែងផងដែរ ។ គឺដោយព្រោះគេពុំបានដើរតាមអ្វីដែលជាកាតព្វកិច្ចរបស់ពួកគេទៅតាមសេចក្តីសញ្ញារបស់ព្រះ(មើល ចទ ២៨:១៥–២៥) ។

**២៤:១៤** *សូមកុំឱ្យយើងធ្លាក់ទៅក្នុងកណ្តាប់ដៃនៃមនុស្សឡើយ* ស្តេចដាវីឌទ្រង់ដឹងគ្រប់ការទាំងអស់ ពីព្រះហឫទ័យ និងពីការធ្វើសង្គ្រាមក៏យល់ដឹងពីព្រឹត្តការណ៍ដែលព្រះអម្ចាស់បានមានសេចក្តីក្រោធ ហើយព្រះអម្ចាស់ក៏មានព្រះទ័យមេត្តាករុណាជាមនុស្សលោក ដ្បិតសេចក្តីនោះនៅអស់មួយជីវិតវិញ (មើល ទដ ៣០:៥) ។

**២៤:១៦** *ទេវតា* ទេវតាបានលេចឱ្យឃើញគ្រប់ទីកន្លែង ក្នុងអត្ថបទគឺមានលក្ខណៈដូចជាឧទាហរណ៍នៃការកាត់ទោសរបស់ព្រះ(មើល នក ៣៣:២, ២ពវ ១៩:៣៥ ទដ ៣៥:៥–៦ ៧៨:៤៩ មថ ១៣:៤១ កច ១២:២៣) ។ *ព្រះយេហូវ៉ាមានព្រះហឫទ័យរំជួលថយ* មើលការពន្យល់ ១សយ ១៥:២៩ ។ *ជិតលានស្រូវរបស់អ័រ៉ោណា* គឺមានទីតាំងនៅលើភ្នំ ។ *ម៉ូរីយ៉ា* គឺនៅជាប់ក្រុងដាវីឌក្រោយមកទៅជាវាលនៃបរវេនព្រះវិហារ (មើល ១រប ២១:២៨–២២:១ ២រប ៣:១) ។ *សាសន៍យេប៊ូស* មើពន្យល់ ៥:៦ ។

**២៤:១៧** *សូមឱ្យព្រះហស្តនៃទ្រង់បានទាស់នឹងទូលបង្គំ ហើយនិងពួកវង្សបិតារបស់ទូលបង្គំវិញចុះ* គឺទោះបីជារាស្ត្រអ៊ីស្រាអែលបានធ្វើទាស់ខុសក៏ដោយ (មើល ខ.១) តែស្តេចដាវីឌក៏បន្ទោសយ៉ាងខ្លាំងចំពោះការប្រព្រឹត្តរបស់គេផ្ទាល់និងស្គាល់នៃការទទួលខុសត្រូវនានា ក្នុងនាមជាស្តេចដែលត្រូវគ្រងរាជ្យឱ្យល្អដល់ព្រះអម្ចាស់(មើល ៥:២ ៧:៧–៨) ។

**២៤:១៩** *ដូចជាព្រះយេហូវ៉ាបានបង្គាប់មក* ព្រះយេហូវ៉ាដែលជាព្រះ ទ្រង់បានដាក់ឱ្យមានការបូជាលុបលាងកំហុសដោយអង្គទ្រង់ផ្ទាល់ ឱ្យចម្រើនក្នុងការអធិស្ឋានរបស់ស្តេចដាវីឌ ។

**២៤:២១** *មកទិញលានស្រូវរបស់ឯង* ស្តេចដាវីឌមិនបានអនុវត្តន៍សិទ្ធិដកហូតយកស្របច្បាប់ សម្រាប់ទិសដៅរាជវង្សរបស់ផងទ្រង់ (សូមមើល ១សយ ៨:១៤) ។

**២៤:២២** *ហើយប្រដាប់បែនស្រូវ* សូមមើល អម ១:៣ (និងការពន្យល់ នរ ១:២២) ។

ដែលយើងមិនបានចេញថ្លៃទិញ ទៅថ្វាយដល់ព្រះយេហូវ៉ា
ជា ព្រះនៃយើងឡើយ[ខ] ដូច្នេះ ដាវីឌក៏ទិញលានស្រូវ និង
គោទាំងនោះ ដំឡៃជាប្រាក់៥០រៀល[គ] ២៥រួចទ្រង់ស្អាង
អាសនា១[ឃ] ថ្វាយព្រះយេហូវ៉ានៅទីនោះ ក៏ថ្វាយដង្វាយដុត
និងដង្វាយមេត្រីទៅ នោះព្រះយេហូវ៉ាទ្រង់ព្រះសណ្ដាប់
សេចក្ដីទូលអង្វរ[ង]ឱ្យស្រុកនោះ ហើយសេចក្ដីវេទនានោះ
ក៏ថយចេញពីពួកអ៊ីស្រាអែលទៅ ។/

**២៤:២៤** ខ មឡ ១:១៣–១៤ គ លប ២៣:១៦

**២៤:២៥** ឃ ១សយ ៧:១៧ ង ២សយ ២១:១៤

**២៤:២៤** *ដង្វាយដុត* មើល លវ ១:១–១៧ ។ *ដូច្នេះដាវីឌបានទិញលានស្រូវ* គឺជាកន្លែងព្រះវិហារក្រោយមកទៀត(មើលការពន្យល់ ឧ.១៦)គឺជាសម្បត្តិរាជទ្រព្យនៃវង្សហ្លួងដាវីឌនិងសត្វគោជាច្រើន ។ ភាពរួសរាន់របស់ស្តេចដាវីឌក៏ពុំអាចចាំសត្វគោដែលត្រូវទិញ ពីស្រុកឆ្ងាយទេ ។ *ដំឡៃជាប្រាក់ ៥០ រៀល* មើលការពន្យល់ ១រប ២១:២៥ ។

**២៤:២៥** *ដង្វាយមេត្រី* មើលការពន្យល់ ១សយ ១១:១៥ គឺជាការផ្សះផ្សាឡើងវិញនិងឱ្យមានការបង្កើតឱ្យមានឡើងវិញ នូវសម្ព័ន្ធមេត្រីនៃសេចក្ដីសញ្ញាឡើងវិញ តាមរយៈកាតទូលអង្វរលន់តួបាបរបស់ព្រះមហាក្សត្រនឹងដង្វាយយញ្ញបូជា ។ *ព្រះយេហូវ៉ាទ្រង់ ព្រះសណ្ដាប់សេចក្ដីទូលអង្វរឱ្យស្រុកនោះ* មើលការពន្យល់ ២១:១៤ ។

# ពង្សាវតារក្សត្រទី១

## សេចក្តីផ្តើម

### ចំណងជើង

កណ្ឌគម្ពីរ ១ពង្សាវតារ និង២ពង្សាវតារទី២ (មានលក្ខណៈដូចគ្នានឹងកណ្ឌគម្ពីរ ១,២សាំយូអែល និង១,២របាក្សត្រ) គឺមានលក្ខណៈអក្សរសាស្រ្តឯកភាពគ្នាតែមួយ ក្នុងភាសាហេព្រើរបញ្ជាក់ថា "ពួកស្តេច" ។ ការចែកកណ្ឌគម្ពីរនេះជាពីរផ្នែកត្រូវបានធ្វើឡើងដោយពួកអ្នកបកប្រែកណ្ឌគម្ពីរសញ្ញាចាស់ដំបូងគេ (ជាភាសាក្រិក) ហើយជាបន្តបន្ទាប់មកទៀត ត្រូវបានបកប្រែជាភាសាឡាតាំងដំបូងនៅឆ្នាំ៤០០ នៃ គ.ស ដែលមានលក្ខណៈទាន់សម័យបំផុត ។ នៅក្នុងឆ្នាំ១៤៤៨ នៃ គ.ស ការបែងចែកកណ្ឌគម្ពីរនេះជាពីរផ្នែក ក៏បានលេចឡើងជាភាសាព្រើរ ហើយនៅស្ថិតស្ថេរជាភាសាហេព្រើរនេះ ក្នុងការបោះពុម្ពក្រោយៗមកទៀត ។ ទាំងការបកប្រែជាភាសាក្រិក និងការបកប្រែឆ្នាំ៤០០ នៃ គ.ស សុទ្ធតែបានបង្កើតទំនាក់ទំនងរវាងកណ្ឌគម្ពីរសាំយូអែល និងពង្សាវតារក្សត្រផងដែរ ។ កណ្ឌគម្ពីរសាំយូអែល និងពង្សាវតារក្សត្រ គឺមានជាប់ទាក់ទងទាំងស្រុងទៅនឹងប្រវត្តិនៃស្តេចនិមួយៗ ដែលបានលេចឡើងក្រោមការដឹកនាំរបស់សាំយូអែល ហើយស្តេចទាំងនោះត្រូវដួលចុះក្រោមកណ្តាប់ដៃពួកបាប៊ីឡូនទៅវិញ ។

ការបែងចែករាជ្យនៅក្នុងកណ្ឌគម្ពីរ១និង២ពង្សាវតារក្សត្រនៅមានការរំលោភបំពានខ្លះៗ ហើយនៅមិនទាន់មានលក្ខណៈសមស្របនៅត្រង់កន្លែងមួយចំនួន ។ សរុបយ៉ាងខ្លីមកការនេះកើតមានក្រោយពីការសុគតរបស់ស្តេចអ័ហាប់នៃពួកអ៊ីស្រាអែល(២២:៣៧) និងយេហូសាផាតនៃទឹកដីយូដា (២២:៥០) ។ ការប្រឈមមុខនឹងការបែងចែកទឹកដីនៅត្រង់ចំណុចនេះក្នុងរាជ្យស្តេចអ័ហាស៊ីយ៉ា នៃពួកអ៊ីស្រាអែល បានបន្តគ្រប់គ្រងរបស់ខ្លួនចាប់តាំងពីការបញ្ចប់កណ្ឌគម្ពីរ១ពវ(២២:៥១–៥៣) និងការចាប់ផ្តើម (ជំពូកទី១) នៃកណ្ឌគម្ពីរ២ពវ ។ ហោរាអេលីយ៉ា បានរៀបរាប់ពីហេតុការណ៍ដូចគ្នានេះដែរនៅក្នុង១ពវ(ជំពូក១៧–១៩) ។ ទោះបីជាសកម្មភាពចុងក្រោយនៃការជំនុំជម្រះ និងការប្រគល់អាវទៅឱ្យលោកអេលីសេនៅខណៈដែលគាត់ត្រូវបានលើកឡើងទៅឯស្ថានសួគ៌ដោយខ្យល់កួចនោះក៏ដោយ គឺហេតុការណ៍ទាំងអស់នោះបានបញ្ចូលទៅក្នុង ២ពវ (១:១–២:១៧) ។

### អ្នកនិពន្ធ ប្រភព និងកាលបរិច្ឆេទ

កណ្ឌគម្ពីរ១ និង២ពង្សាវតារក្សត្រនេះ មានភស្តុតាងតិចតួចណាស់ក្នុងការបញ្ជាក់ពីអ្នកនិពន្ធ ។ ទោះបីប្រពៃណី វប្បធម៌ពួកយូដាទទួលស្គាល់លោកយេរេមាក៏ដោយ តែបច្ចុប្បន្ននេះមានតិចតួចណាស់ដែលទទួលស្គាល់ ថានរណាជាអ្នកនិពន្ធនោះ គឺវាបានបញ្ជាក់យ៉ាងច្បាស់ថា នៃកណ្ឌគម្ពីរនេះត្រូវគ្នានិងកណ្ឌគម្ពីចោទិយកថា ដែលមានហោរាអ៊ីស្រាអែលជាច្រើន ។ កណ្ឌគម្ពីរនេះ បានបញ្ជាក់យ៉ាងច្បាស់ថា អ្នកនិពន្ធបានប្រើប្រភពជាច្រើនក្នុងការចងក្រងជាបញ្ជីពង្សាវតារក្សត្រនេះឡើង ។ ប្រភពបីផ្សេងគ្នា នោះគឺៈ "សៀវភៅជាពង្សាវតារស្តេចសាឡូម៉ូន(១១:៤១)" "សៀវភៅជាពង្សាវតារពួកស្តេចអ៊ីស្រាអែល (១៤:១៩)" ហើយនិង "សៀវភៅជាពង្សាវតារ ពួកស្តេចយូដា (១៤:២៩)" ។ ហើយលើសពីនេះទៀត ក៏មានបន្ថែមពីប្រភពឯកសារ ផ្សេងៗទៀតផងដែរ (ដូចដែលបានលើកឡើង នៅក្នុងកណ្ឌគម្ពីររបាក្សត្រ) ។

ទោះបីមានអ្នកប្រាជ្ញខ្លះ បានសន្និដ្ឋានថាប្រភពទាំងបីខាងលើមានអំណះអំណាងគ្រប់គ្រាន់ក្នុងការបញ្ជាក់ពីកណ្ឌគម្ពីរ១,២ពវ ថាបានមានលកណ្ខៈជាសៀវភៅបញ្ជីពង្សាវតារក្សត្រនៅក្រុងយេរូសាឡិម និងក្រុងសាម៉ារីមែន គឺមិនអាចបដិសេធបានឡើយ ។ សៀវភៅពង្សាវតារទាំងអស់នោះ យ៉ាងហោចណាស់ក៏អាចចោទជាសំនួនមួយបានថាតើ សៀវភៅបញ្ជីពង្សាវតារក្សត្រ មាននិយាយពីការក្បត់របស់ស្តេចមួយចំនួន ដូចដែលបានលើកឡើងនៅក្នុង ១៦:២០ ២ពវ ១៥:១៥ ។ ប្រភពទាំងបីនេះ យ៉ាងហោចណាស់ក៏អាច ធ្វើឱ្យមានភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ ដូចដែលអ្នកនិពន្ធបានចងក្រងឡើងនេះផងដែរ ។ ការពិចារណាមួយដែលពួកអ្នកប្រាជ្ញ បានទាញការសន្និដ្ឋានថា ប្រភពទាំងអម្បាលម្មានខាងលើនេះពិតជាកំណត់ត្រានៃរាជ្យរបស់ស្តេចនិមួយៗរបស់ពួកអ៊ីស្រាអែល និងពួកយូដាដែលបានចងក្រងឡើងដោយពួកហោរាអ៊ីស្រាអែលពីជំនាន់មួយទៅជំនាន់មួយទៀតនោះ ។ កណ្ឌគម្ពីរ ១,២សាំយូអែល បានទាញការសន្និដ្ឋានពីចំនួននៃការសរសេរ"កំណត់ត្រាសាំយូអែល ណាថាន់ កាឌ់ ជាហោរា (១របា ២៩:២៩)" និង"ហោរាអ័ហ៊ីយ៉ាជាអ្នកក្រុងស៊ីឡូហើយនិងទស្សនៈហោរាអ៊ីដោ(២របា ៩:២៩)" "កំណត់ត្រាសេម៉ាយ៉ាជាហោរា (២របា ១២:២៥)" ហើយនិងបញ្ជីនៃការតែងតាំងពួកស្តេច (២របា ២៤:២៧) ហើយនិង"ព្រឹត្តិការណ៍នៃរាជ្យស្តេច អូសៀស...ដែលបានកត់ត្រាដោយ អេសាយជាកូនអ័ម៉ូស (២របា ២៦:២២ និងមើលបន្ថែម ២របា ៣២:៣២)" ហើយក៏មានការបញ្ចូលឯកសារដទៃទៀតដែរ ។ ការសន្និដ្ឋានខាងលើនេះ វាទំនងជាឧទាហរណ៍

ដាក់ស្តែងក្នុងការប្រៀបធៀបបេសកកម្មលោកអេលីយ៉ា លោកអេលីសេ ជាមួយនិងលោកម៉ូសេ លោកយ៉ូស្វេ ដោយសំអាងលើប្រភពពីពួកហោរាផ្សេងៗផងនោះ ។

មានពួកអ្នកប្រាជ្ញ បានដាក់កាលបរិច្ឆេទនៃការនិពន្ធកណ្ឌគម្ពីរ១,២ពវ នៅក្នុងពេលបន្ទបន្ទាប់មកទៀត គឺក្នុងកំឡុងពេលដែលគេបានដោះលែងយេហូគីមពីពន្ធធនាគារ (ឆ្នាំ ៥៦២ មុន គ.ស ២ពវ ២៥:២៧–៣០) និងមុនពេលបញ្ចប់ការនិរទេសពួកបាប៊ីឡូនឆ្នាំ៥៣៨ មុន គ.ស ។ ការអះអាងមួយទៀតដែលឈរលើមូលដ្ឋានកណ្ឌគម្ពីរ ១,២ពវ ថាកណ្ឌគម្ពីរនេះបាននិយាយដល់ការពិតមួយ មុនពេលការនិរទេសខ្លួន ពួកគេត្រូវបន្តមកដល់សព្វថ្ងៃ "ថ្ងៃនោះ" (សូមមើលឧទាហរណ៍ ៨:៨ បញ្ជាក់ពីស្នែង ដែលគេប្រើក្នុងការសែងហឹបសញ្ញា ៩:២០–២១ កេណ្ឌកម្លាំងពលកម្ម ១២:១៩ ពួកអ៊ីស្រាអែលបះបោរប្រឆាំងនិងពួកជិនួរស្តេចដាវីឌ ២ពវ ៨:២២ និងពួកអេដំមបះបោរប្រឆាំងនឹងពួកយូដា) ។ តាមរយៈការអះអាងខាងលើនេះបញ្ជាក់ថា អ្នកនិពន្ធត្រូវតែជាមនុស្សដែលបានរស់នៅក្នុងទឹកដីយូដា នៅអំឡុងពេលមុនការនិរទេសខ្លួន គឺមិនមែនក្រោយពេលនៃការនិរទេសខ្លួនរបស់ពួកបាប៊ីឡូន ។ ប្រសិនបើជម្លោះនេះត្រូវបានគេទទួលយក នោះអ្នកនិពន្ធបានធ្វើការសន្និដ្ឋានថា អត្ថបទដើមត្រូវបាននិពន្ធឡើងនៅអំឡុងពេលនៃការសុគតរបស់ស្តេចយូសៀស ហើយនិងសម្ភារៈដែលមានការជាប់ទាក់ទងទៅនឹងរជ្ជកាលរបស់ទ្រង់ ត្រូវបានគេបន្ថែមឆ្នាំក្នុងអំឡុងពេលនិរទេស ឆ្នាំ៥៥០មុនគ.ស ។ ទស្សនៈខាងក្រោយនេះ អាចទទួលយកបាន ដោយយល់ដល់ពាក្យ"ថ្ងៃនោះ" ។

## ខ្លឹមសារៈ រាជ្យស្តេច និង សេចក្តីសញ្ញា

កណ្ឌគម្ពីរ ១,២ពង្សាវតារក្សត្រ មិនបានបញ្ជាក់ពីខ្លឹមសារសំខាន់ច្បាស់លាស់ឡើយ ។ ទោះបី យើងសញ្ជឹងគិតមើលទៅបរិបទនៃកណ្ឌគម្ពីរនេះ ឃើញថាអ្នកនិពន្ធបានជ្រើសរើស ហើយរៀបចំសម្ភារៈរបស់គាត់ក្នុងគោលបំណងតភ្ជាប់ប្រវត្តិសាស្ត្រដែលបានរកឃើញនៅក្នុង ១,២ សាំយូអែល គឺប្រវត្តិនៃស្តេចនិមួយៗឱ្យមានរបៀបរៀបរយដោយសារសេចក្តីសញ្ញា ។ ជាទូទៅនៅក្នុង ១,២នៃកណ្ឌគម្ពីរពង្សាវតារក្សត្រ បានរៀបរាប់អំពីពួកស្តេចអ៊ីស្រាអែល និង ស្តេចពួកយូដានៅក្នុងពន្លឺនៃសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា ។ ការបង្ហាញ–តាមរយៈស្នាដៃនេះ គឺបានបង្ហាញពីសង្គ្រាមរបស់ពួកអ៊ីស្រាអែល និងស្តេចរបស់ពួកគេ បានអាស្រ័យលើការចុះចូលរបស់ពួកគេ ចំពោះសេចក្តីសញ្ញារបស់ព្រះយេហូវ៉ាដែលបានប្រទានមកពួកគេនោះ ពោលគឺពួកគេបានប្រព្រឹត្តតាមសេចក្តីសញ្ញានៅភ្នំស៊ីណាយ និងសេចក្តីជំនឿដែលពួកគេមានដល់ពួកហោរារបស់ព្រះ ។

នៅត្រង់នេះ បញ្ជាក់យ៉ាងច្បាស់ពីគោលបំណងរបស់អ្នកនិពន្ធថា គេមិនមានបំណងចង់បង្ហាញពី សង្គម នយោបាយ និងប្រវត្តិសាស្ត្រសេដ្ឋកិចនៃពួកស្តេចអ៊ីស្រាអែល ដើម្បីឱ្យស៊ីជាមួយនឹងប្រវត្តិសាស្ត្រសម័យទំនើបនោះឡើយ ។ អ្នកនិពន្ធកណ្ឌគម្ពីរនេះ បានលើកឡើងដដែលៗ សំដៅដល់ប្រភពឯកសារដទៃៗទៀតសម្រាប់ពត៌មានលំអិតបន្ថែមអំពីស្តេចផ្សេងៗទៀតនោះផងដែរ (សូមមើល ឧទាហរណ៍ ១១:៤១ ១៤:១៩,២៩ ១៥:៧,៣១ ១៦:៥,១៤,២៧) ហើយគាត់ផ្តល់នូវក្រឹត្យច្បាប់លើសជាងសង្គមនយោបាយ និងទ្រព្យសម្បត្តិរបស់ទ្រង់ទៅទៀត ។ ចេញពីទស្សនៈប្រវត្តិខាងនយោបាយ នោះអំរីត្រូវបានគេពិចារណាក្នុងចំណោមអ្នកដឹកនាំសំខាន់ៗជាច្រើនរបស់ពួកអ៊ីស្រាអែល ។ គាត់បានកសាងសន្តតិវង្សមួយដ៏មានអំណាច និងទីក្រុងសាម៉ារីដ៏រឹងមាំផងដែរ ។ ដោយយោលទៅលើផ្ទាំងចារឹកស្រុកម៉ូអាប់ អំរីជាអ្នកគ្រប់គ្រងដែលនៅក្រោមអំណាចពួកសាសន៍ម៉ូអាប់ ។ ក្រោយពីការស្លាប់ដ៏យូររបស់អំរី ពួកអាសសើរ បានលើកយេហ៊ូវ ជា"កូនអំរី"ឱ្យធ្វើជាអ្នកដឹកនាំ ។ ទោះជាអំរី ជាមនុស្សសំខាន់នៅក្នុងឆាកនយោបាយ តែនៅក្នុងរាជ្យរបស់ទ្រង់ត្រូវបានគេទម្លាក់ចុះនៅក្នុង ខ.៦(១៦:២៣–២៨) ដែលបញ្ជាក់ថា ទ្រង់បាន"ប្រព្រឹត្តអំពើលាមកនៅក្នុងព្រះភក្ររបស់ព្រះយេហូវ៉ា លើសជាង ស្តេចដទៃទៀត ដែលបានប្រព្រឹត្តមុនទ្រង់នោះ (១៦:២៥)" ។ ស្រដៀងគ្នានេះ រាជ្យស្តេចយេរូបោមទី២ បានគ្រប់គ្រងលើពួកអ៊ីស្រាអែលដែលអំណាចនយោបាយ និងសេដ្ឋកិច្ចរបស់ទ្រង់មានលក្ខណៈខ្លាំងខ្លា ហើយព្រះអង្គក៏បានប្រព្រឹត្តអំពើដ៏លាមកនៅចំពោះព្រះយេហូវ៉ាខ្លះៗផងដែរ (២ពវ ១៤:២៣–២៩) ។

ឧទាហរណ៍ផ្សេងទៀតនៃសេចក្តីសញ្ញា បានបញ្ជាក់ពីភាពខុសគ្នាយ៉ាងច្បាស់ក្នុងវិស័យនយោបាយ និងចំណាប់អារម្មណ៍សេដ្ឋកិច្ចដែលមានរៀបរាប់នៅក្នុងរាជ្យស្តេចយ៉ូសៀសនៃពួកយូដា ។ ហើយនៅត្រង់នេះ មិនបានបញ្ជាក់ពីឆ្នាំនៃរាជ្យដំបូងរបស់ទ្រង់ ប៉ុន្តែបានរៀបរាប់យ៉ាងក្បោះក្បាយអំពីកំណែទម្រង់ និងការបំផ្លាស់បំប្រែនៃសេចក្តីសញ្ញាដែលទ្រង់បានប្រកាសឡើងនៅក្នុងឆ្នាំទី១៨នៃរាជ្យរបស់ទ្រង់ជាស្តេចនោះ (២ពវ ២២:៣–២៣:២៨) ។ នៅត្រង់នេះ មិនមានអ្វីផ្សេងទៀតដែលនិយាអំពីការជំរុញឱ្យស្តេចយ៉ូសៀសប្រឆាំងនឹងស្តេចផារោ–នេកោនៃពួកអេស៊ីព្ទត្រង់មេគីដោ ហើយក៏មិនមានបញ្ជាក់ពីការផ្លាស់ប្តូរសំខាន់ៗណាមួយអំពីនយោបាយក្រៅ

ប្រទេសនោះដែរ ពីពួកអាសស៊ើរ និងពួកបាប៊ីឡូនដែលបានភ្ជាប់ទំនាក់ទំនងគ្នាដោយគ្មានការព្រៀងទុក (សូមមើលការពន្យល់ ២ពវ ២៣:២០–៣០) ។

ការនេះគឺពិត ព្រោះថាពួកស្តេចដែលមានរៀបរាប់ច្រើនបំផុតនៅក្នុង ១,២ពង្សាវតារក្សត្រ គឺសំដៅដល់ពួកស្តេចទាំងឡាយណាដែលក្នុងរាជ្យរបស់ទ្រង់មានទាំងការងាកចេញពីសេចក្តីសញ្ញារបស់ទ្រង់ និងចុះចូលជាមួយនឹងសេចក្តីសញ្ញារបស់ទ្រង់ (បង្ហាញអំពីពួកស្តេច និងពួកហោរារបស់ព្រះ សូមមើលទៅខាងក្រោយនេះ) ។ ស្តេចអ័ហាប់ជាបុត្ររបស់អំរី ជាគំរូឧទាហរណ៍ពីដើម ក្នុង (១៦:២៩–២២:៣៩) ។ ក្នុងរាជ្យរបស់ទ្រង់ ទ្រង់បានប្រព្រឹត្តយ៉ាងខ្លាំងក្លាលើសជាងស្តេចណាៗទាំងអស់ ហើយរហូតប្រព្រឹត្តជិទាស់នឹងសេចក្តីសញ្ញានៃភាពស្មោះត្រង់ ហើយនិងបន្តរហូតដល់ទឹកដីនៃភាគខាងជើងរបស់ពួកអ៊ីស្រាអែលទៀតផង ។ នៅទីបញ្ចាប់ពួកសាសន៍ដទៃបានទទួលរងនូវឥទ្ធិពលរបស់យេសិបិលភរិយារបស់អ័ហាប់ តាមរយៈអ័ថាលាជាបុត្រីអ័ហាប់នេះឯង(មិនច្បាស់ថា ព្រះនាងជាបុត្រីរបស់យេសិបិលទេ) ហើយស្ទើរតែនាំឱ្យបំផ្លិចបំផ្លាញពួកជិនូវវង្សស្តេចដាវីឌទាំងអស់ផងដែរ(មើល ២ពវ ១១:១–៣) ។

ស្តេចម៉ាន៉ាសេ(២ពវ ២១:១–១៨) គឺជាគម្រូមួយដែលស្រដៀងគ្នានេះដែរ ។ ត្រង់នេះ បានបង្ហាញពីការងាកចេញពីសេចក្តីសញ្ញារបស់ព្រះ ដែលរៀបរាប់អំពីរាជ្យរបស់ព្រះអង្គ គឺមិនមែនបរិយាយពីលក្ខណៈនយោបាយនោះឡើយ ដូចជាការចូលរួមក្នុងសកម្មភាពជិទាស់ប្រឆាំងជាមួយនឹងពួកអាសស៊ើរ(កត់ត្រាទុកក្នុងកំណត់ត្រាពួកអាសស៊ើរ តែមិនមាននៅក្នុង ២ពវទេ) ។ ចរិតលក្ខណៈនៃការមិនជឿព្រះរបស់ស្តេចម៉ាន៉ាសេនៅក្នុងរាជ្យរបស់ព្រះអង្គ នោះទ្រង់បាននិរទេសពួកយូដាចេញពីទឹកដីកំណើតរបស់ខ្លួនដោយ មិនអាចប្រកែកបាន (២ពវ ២១:១០–១៥ ២៣:២៦–២៧) ។

នៅក្នុងន័យវិជ្ជមាន ស្តេចហេសេគា(២ពវ ១៨:១–២០:២១) និងស្តេចយ៉ូសៀស(២ពវ ២២:១–២៣:២៩) ព្រះយេហូវ៉ាបានប្រទានសិទ្ធិឱ្យដល់ពួកគេក្នុងការបំផ្លាស់បំប្រែសេចក្តីសញ្ញា ។ ស្តេចទាំងពីរអង្គនេះ នៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការបញ្ជាក់ពីភាពស្មោះត្រង់របស់ទ្រង់ចំពោះព្រះយេហូវ៉ា ដែលអ្នកនិពន្ធចង់បង្ហាញនោះឡើយ(មើល ២ពវ ១៨:៣ ២២:២) ។ នេះជាតម្លៃនៃកំណត់ត្រាដែលបញ្ជាក់ថា គ្រប់ស្តេចទាំងអស់របស់ពួកអ៊ីស្រាអែលសុទ្ធតែបានប្រព្រឹត្តបាបនៅចំពោះព្រះនេត្រនៃព្រះយេហូវ៉ា ហើយបានដើរតាមគន្លងរបស់ស្តេចយេរ៉ូបោម ដែលធ្វើឱ្យអ៊ីស្រាអែលធ្លាក់ចូលក្នុងបាប (សូមមើល ឧទាហរណ៍ ១៦:២៦,៣១,២២:៥២ ២ពវ ៣:៣ ១០:២៩) ។ ស្តេចយេរ៉ូបោមនេះហើយ ដែលបានសង់រូបព្រះគោដើម្បីថ្វាយបង្គំនៅបេត–អែល និងដាន់យ៉ាងឆាប់បំផុត បន្ទាប់ពីការបែងចែកទឹកដី(សូមមើល ១២:២៦–៣៣ ១៣:១–៦) ។

ក្នុងខណៈដែលអ្នកនិពន្ធ រៀបរាប់អំពី ការស្តាប់បង្គាប់ និង មិនស្តាប់បង្គាប់របស់ពួកអ៊ីស្រាអែស ចំពោះសេចក្តីសញ្ញាភ្នំស៊ីណាយ ថាជាជោគវាសនាដ៏ជាក់លាក់មួយនោះអ្នកនិពន្ធបានទទួលស្គាល់ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃសេចក្តីសញ្ញាដែលបានប្រទានមកស្តេចដាវីឌមកនោះ ថាពួកជិនូវវង្សរបស់ព្រះអង្គត្រូវបានគ្រងរាជ្យជារៀងរហូត ។ នេះជាការកំណត់ត្រាដែលអាចយកជាការបានមួយដែលសំដៅដល់"ចង្កៀង"ដែលព្រះយេហូវ៉ាបានសន្យាដល់ស្តេចដាវីឌ(សូមមើល ១១:៣៦ និងការពន្យល់ ១៥:៤ ២ពវ ៨:១៩ និងមើល បន្ថែមការពន្យល់ ២សយ ២១:១៧) ។ ហើយសេចក្តីទាំងប៉ុន្មានខាងលើនេះ ត្រូវបានបញ្ជាក់បន្ថែមទៀតនៅក្នុង (៨:២០,២៥) និងលទ្ធផលយ៉ាងជាក់ស្តែង សម្រាប់ប្រវត្តិសាស្ត្រពិត ក្នុងការអភិវឌ្ឍន៍ប្រវត្តសាស្ត្ររបស់ពួកយូដា (១១:១២–១៣,៣២ ២ពវ ១៩:៣៤ ២០:៦) ។ លើសពីនេះទៀត អ្នកនិពន្ធបានប្រើជីវិត និងរាជ្យស្តេចដាវីឌជាស្តង់ដាក្នុងការរៀបរាប់ពីជីវិតស្តេចក្រោយៗមកទៀត (មើល ១៥:៣,៥,១១ ២ពវ ១៦:២ ១៨:៣ ២២:២) ។

លក្ខណៈសន្យានៃការពិពណ៌នាកណ្ឌគម្ពីរ ១,២ពង្សាវតារ គឺបញ្ជាក់ពីទំនាក់ទំនងរវាងពួកហោរា និងការអភិវឌ្ឍន៍នៃសន្តតិវង្សរបស់ពួកស្តេចនិមួយៗ ។ យ៉ាងហោចណាស់ មាន១១ករណីដែលការទស្សទាយរបស់ពួកហោរាបានកត់ត្រាទុកហើយក្រោយមកហេតុការណ៍ដែលបានទាយទុកនោះបានកើតឡើងពិតប្រាកដមែន(មើល ឧទារណ៍ ២សយ ៧:១៣ និង ១ពវ ៨:២០ ១ពវ ៨:២០ ១ពវ ១១:២៩:៣៩ និង ១ពវ ១២:១៥ ១ពវ ១៣ ហើយនិង ២ពវ ២៣:១៦–១៨) ។ លទ្ធផលទាំងអស់នេះ គឺបញ្ជាក់ពីប្រវត្តិទឹកដី គឺមិនមែនបង្ហាញពីព្រឹត្តិការណ៍ទាំងឡាយដែលកើតឡើងបន្តបន្ទាប់គ្នានោះទេ ឬជាសកម្មភាពរបស់មនុស្សដែលមានប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកនោះដែរ តែជាការលាតត្រដាងនៃជោគវាសនារបស់ប្រវត្តិសាស្ត្រអ៊ីស្រាអែល ក្រោមការដឹកនាំដែលប្រកបដោយសព្វញ្ញុភាពរបស់ព្រះយេហូវ៉ា គឺសេចក្តីសញ្ញារបស់ព្រះយេហូវ៉ាប្រទានមកពួកអ៊ីស្រាអែល ដែលទ្រង់បានដឹកនាំពួកឆ្លងកាត់គ្រប់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ គឺព្រះទ្រង់បានសោយរាជ្យលើពួកគេក្នុងការសម្រេចគោលបំណងផ្សេងៗ (សូមមើល ៨:៦៥ ២ពវ ១០:១០) ។

អ្នកនិពន្ធក៏បានបញ្ជាក់បន្ថែមពីសារៈសំខាន់ នៃពួកហោរាដែលពួកគេម្នាក់បានដើរតួរជាអ្នកការទូតច្បាប់នៃសេចក្តីសញ្ញារបស់ព្រះ

របស់ពួកអ៊ីស្រាអែល ហើយសេចក្តីសញ្ញានោះបានប្រទានមកឱ្យពួកស្តេចខ្លាំងពូកែ ដែលពួកស្តេចទាំងនោះត្រូវសម្រេចការនោះតាមរយៈសេចក្តីសញ្ញាដែលបានប្រទានតាមរយៈហោរានេះ ។ ទន្ទឹមនឹងនេះ ព្រះអម្ចាស់ បានបញ្ជូនអ្នកស្នងរាជ្យដូចជាពួកហោរានេះដើម្បីហៅពួកស្តេច និងប្រជារាស្ត្រឱ្យត្រឡប់មកកាន់តាមបញ្ញត្តដ៏ស្មោះត្រង់របស់ព្រះយេហូវ៉ាវិញ (មើល ១៧:១៣) ។ ចំពោះការព្រមាន និង ការដាស់តឿនពួកគេ នោះព្រះយេហូវ៉ាបានធ្វើឱ្យពួកគេធ្លាក់ចូលក្នុងភាពថ្លង់ផងដែរ ។ ត្រង់ចំណុចនេះ ពួកហោរាទាំងអស់នោះមានលើកឡើងនៅក្នុង ១,២ពវ (មើល ឧទាហរណ៍ លោកអេលីយ៉ា ១១:២៩–៤០ ១៤:៥–១៨ លោកសេផានា ១២:២២–២៤ លោកមីកា ២២:៨–២៨ លោកយ៉ូណាស ២ពវ ១៤:២៥ ២ពង្សាវតារក្សត្រ ១៤:២៤ លោកអេសាយ ២ពវ ១៩:១–៧ ២០–៣៤ លោកហ៊ីលគីយ៉ា ២ពវ ២២:១៤–២០) ប៉ុន្តែ បេសកកម្មដែលគួរយកចិត្តទុកដាក់ជាងគេ គឺលោកហោរាអេលីយ៉ា និងហោរាអេលីសេ (១ពវ ១៧–១៩ ២ពវ ១–១៣) ។

ត្រឡប់មកជាថ្មីម្តងទៀត លក្ខណៈនៃកណ្ឌគម្ពីរ ១,២ពង្សាវតារក្សត្រនេះ គឺសរសេរឡើងក្នុងគោលបំណងពន្យល់ដល់ពួកមនុស្សនៅដែលត្រូវនិរទេសខ្លួន ហើយបានធ្លាក់ក្នុងភាពអាម៉ាស ដោយព្រោះតែពួកគេម្នាក់មានចិត្តមានះ ប្រព្រឹត្តរំលងនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ។ ពួកគេ បានធ្លាក់ចូលក្នុងការនិរទេសខ្លួន ក្រោយពីព្រះយេហូវ៉ាឈប់អត់ទ្រាំនឹងពួកគេ ដូចដែលព្រះទ្រង់បានប្រកាសនៅក្នុងការព្រមានរបស់ទ្រង់តាំងពីដើមដំបូងមកម្លេះ (សូមមើល លវ ២៦:២៧–៤៥ ចទ ២៨:៦៤–៦៨) ។ ការនេះ ព្រះយេហូវ៉ាធ្វើឡើងឱ្យឃើញយ៉ាងច្បាស់ពីការគោរពមួយក្នុងការជាប់ជាឈ្លើយរបស់ពួកអ៊ីស្រាអែល នៅក្នុង ២ពវ ១៧:៧–២៣ ១៨:៩–១២ និងពួកយូដា ២ពវ ២១:១២–១៥ ។ ការធ្វើកំណែទម្រង់របស់ស្តេចយ៉ូសៀសនៃពួកយូដា គឺមានតិចតួច ហើយហាក់បីដូចជាយឺតពេល (សូមមើល ២ពវ ២៣:២៦–២៧ ២៤:៣) ។

កណ្ឌគម្ពីរនេះ បានផ្តល់ឱ្យយើងដឹងពីការវិភាគមួយអំពីប្រវត្តិសាស្ត្រអ៊ីស្រាអែល ដោយបានពន្យល់ពីហេតុផលពីរយ៉ាងគឺៈ ការបំផ្លាញស្រុកសាម៉ារី និងក្រុងយេរូសាឡិម ហើយក៏បានរៀបរាប់ពីអាណាចក្ររបស់ពួកគេនិមួយៗ ហើយនិងការប្រឈមមុខនឹងការនិរទេសខ្លួន តែទោះជាយ៉ាងក៏ដោយ ទាំងអស់នេះមិនមែនមានន័យថា ពួកគេបានធ្លាក់ចូលក្នុងភាពទ័លច្រកក្នុងអនាគតនោះដែរ គឺអ្នកនិពន្ធបានបញ្ជាក់យ៉ាងច្បាស់ អំពីការរក្សានូវសេចក្តីសន្យាដែលព្រះយេហូវ៉ាបានធ្វើដល់ស្តេចដាវីឌថា ពួករាស្ត្រអ៊ីស្រាអែលត្រូវមានសង្ឃឹមនៅក្នុងអនាគតក្នុងការស្នងរាជ្យ គឺមិនត្រូវបានធ្លាក់ក្នុងភាពអស់សង្ឃឹមឡើយ ។ ការតភ្ជាប់ការនេះនៅក្នុងខទាំង៤នៃកណ្ឌគម្ពីរនេះបានបង្ហាញពីការភាពមានទោសរបស់ស្តេចយេហូគីមត្រូវបានដោះលែងពីពន្ធនាគាក្នុងចក្រភពបាប៊ីឡូន ហើយទ្រង់ត្រូវបានគ្រងរាជ្យជាស្តេច(សូមមើល ២ពវ ២៥:២៧–៣០) ។

គម្ពីរនេះ មានសារៈសំខាន់ក្នុងការកត់ចំណាំ ថាអ្នកនិពន្ធគ្មានការសង្ស័យលើការនិរទេសខ្លួនរបស់ពួកយូដា និងពួកអ៊ីស្រាអែលដែលពួកគេបានរស់នៅបែកខ្ញែកគ្នាអស់រយៈពេលមួយសត្សវត្សរ៍កន្លះ ហើយរយៈពេលនោះអ្នកនិពន្ធផ្ទាល់បានផ្តោតលើពួកអ៊ីស្រាអែលទាំងមូល ពោលគឺសេចក្តីសញ្ញាដែលព្រះយេហូវ៉ាបានប្រទានមកពួកគេ ។ មិនមែនអ្នកនិពន្ធ និងពួកហោរាទេដែលបានបង្ហាញពីការបែងចែកទឹកដីនៃអាណាចក្រអ៊ីស្រាអែល ថាជាការបដិសេធរបស់ពូជអំបូរទាំង១០ (សូមមើល អស ១០:២០–២១ ១១:១១–១៣ យរ ៣១ អគ ៤៨:១–២៩ ហស ១១:៨–១១ អម ៩:១១–១៥ សក ៩:១០–១៣) គឺពួកគេថែមទាំងបានមើលឃើញពីការនិរទេសខ្លួនដំបូងរបស់ពួកអ៊ីស្រាអែលដែលពួកគេត្រូវដកចេញពីសាសន៍របស់ខ្លួននៅក្នុងអនាគតផងដែរ ។ បញ្ហាពិតនៅក្នុងរឿងនេះ គឺមានពួកអ៊ីស្រាអែលជាច្រើនបានជម្លៀសទៅឯទឹកដីយូដាក្នុងអំឡុងពេលឈ្លានពានរបស់ពួកអាសស៊ើរ ដូច្នេះសំណល់សំខាន់នៃពូជអំបូរអ៊ីស្រាអែលដែលបានរស់នៅក្នុងទឹកដីយូដា បានចែករំលែកនិងបន្តប្រវត្តិសាស្ត្រនេះទៅទៀត ។

## ផ្នែកប្រវត្តិសាស្ត្រ

គម្ពីរ១,២ពង្សាវតារក្សត្រ បានបង្ហាញដល់អ្នកអាន នូវប្រវត្តិសាស្ត្រដ៏សំបូរបែប គឺវាមិនគ្រាន់តែបានផ្តល់នូវរយៈពេល នៃរជ្ជកាលរបស់ស្តេចនិមួយៗ និងរយៈពេលនៃការបែងចែកទឹកដីអ៊ីស្រាអែល ហើយនិងការគ្រងរាជ្យរបស់ស្តេចនិមួយៗ ។ ហើយលើសពីនេះទៀត វាបានផ្តល់នូវទិន្នន័យបន្ថែមទៀត ដូចជាអាយុកាលនៃអ្នកស្នងរាជ្យ ក៏បានផ្តល់ផងដែរ ។

ការរួមបញ្ចូលគ្នារវាងទិន្នន័យដែលមាននៅក្នុងព្រះគម្ពីរជាមួយនឹងកំណត់ត្រាប្រវត្តិសាស្ត្រពួកអាសស៊ើរ ដូច្នេះឆ្នាំទី ៨៥៣ មុន គ.ស អាចធ្វើការសន្និដ្ឋានថា ឆ្នាំនេះស្តេចអ័ហាប់បានសុគត ហើយឆ្នាំ៨៤១ ជាឆ្នាំដែលស្តេចយេហ៊ូវឡើងគ្រងរាជ្យ ។ ឆ្នាំដែលស្តេចអ័ហាប់ និងស្តេចយេហ៊ូវ បានធ្វើការទាក់ទងជាមួយនឹងស្តេចសាលម៉ានទី៣របស់ពួកអាសស៊ើក៏ត្រូវបានកត់ត្រាយ៉ាងច្បាស់លាស់ផងដែរ (កំណត់ត្រានេះផ្អែកលើការគណនា តាមរយៈសូគ្រាសរបស់ពួកអាសស៊ើរ) ។ ជាមួយនឹងហេតុការណ៍ខាងលើនេះ ដែលសំដៅ

លើសន្តតិវង្ស ជាន់មុន និងក្រោយរបស់អ៊ីស្រាអែល និងយូដាបានផ្តល់ការបរិច្ឆេទនូវគ្រប់រាជ្យស្តេចនិមួយៗ ។ ទន្ទឹមនឹងនេះ វាក៏ជាការការបញ្ជាក់យ៉ាងច្បាស់ថា ហេតុការណ៍នោះជាការបែងចែកទឹកដីនៅក្នុងឆ្នាំ ៩៣០មុនគ.ស ដែលស្រុកសាម៉ារីធ្លាក់ក្នុងកណ្តាប់ដៃពួកអាសសើរនៅក្នុងឆ្នាំ ៧២២-៧២១មុនគ.ស ហើយក្រុងយេរូសាឡិមក៏ធ្លាក់ក្នុងពួកបាប៊ីឡូនឆ្នាំ ៥៨៦មុនគ.ស ។

ទិន្នន័យដែលដូចគ្នា និងជាប់ទាក់ទងទៅនឹងរាជស្តេចនិមួយៗរបស់ពួកអ៊ីស្រាអែល និងយូដា បានបង្ហាញពីភាពជិពាក់វាក់វ័ន្តគ្នា ដែលបញ្ហាទាំងនោះឈានទៅរកមិនអាចដោះស្រាយបាន ។ ហើយក្រោមមកទៀត បញ្ហាទាំងអស់នោះត្រូវបានដោះស្រាយក្នុងមធ្យោបាយដោយសមស្រប តាមរយៈការគ្រងរាជ្យបល្ល័ង្កត្រួតគ្នា ជាការសោយរាជ្យជាមួយគ្នារវាងព្រះរាជ្យបុត្រានិង ព្រះបិតារបស់ពួកគេ ។

**បរិបទព្រះគម្ពីរ**

កណ្ឌគម្ពីរទាំងពីរនេះ បានរៀបរាប់ពីប្រវត្តិសាស្ត្រអ៊ីស្រាអែល នៅក្នុងអំឡុងពេលនៃការបញ្ចប់រាជ្យរបស់ស្តេចដាវីឌ រហូតដល់សម័យដែលពួកបាប៊ីឡូនបាននិរទេសខ្លួនពួកគេ ។ ក្រោយពីការរៀបរាប់ដ៏សែនវែងរបស់រាជ្យស្តេចសាឡូម៉ូន ក៏បន្តរៀបរាប់ពីការបែងចែកទឹកដី និងការអភិវឌ្ឍរវាងទឹកដីទាំងពីរនេះផងដែរ ។ ការនិយាយខាងលើនេះ គឺបានផ្តោតលើបេសកម្មរបស់លោកអេលីយ៉ា និងលោកអេលីសេនៅក្នុងទឹកដីភាគខាងជើងរបស់ពួកអ៊ីស្រាអែល (រាជ្យស្តេចសាឡូម៉ូន) ដែលព្រះយេហូវ៉ាទ្រង់មានព្រះទ័យទុកដាក់ចំពោះពួកគេ តាមរយៈពួកហោរា ដើម្បីឱ្យពួករាស្ត្រទាំងនោះលះចោលការមិនគោរពព្រះ ហើយវិលបែរមករកក្រឹត្យវិន័យរបស់ព្រះអង្គវិញ (សូមមើល ការពន្យល់ ១ពវ ១២:២៥-២ពវ ១៧:៤១) ។

រាជ្យបល្ល័ង្កនៅក្នុងភាគខាងជើង(ទឹកដីអ៊ីស្រាអែល) ត្រូវបានរុកគួន និងគ្មានសុវត្ថិភាព ហើយនិងការរំលោភបំពាន ។ ពួកអ្នកដឹកនាំទាំង២០នាក់ បានបង្ហាញពីភាពផ្សេងគ្នានៃសន្តតិវង្ស៩អង្គ នៅប្រមាណជាង២១០ឆ្នាំនៃការបែងចែកទឹកដីចាប់ពីឆ្នាំ៩១០មុន គ.ស មកដល់ការដួលរលំស្រុកសាម៉ារីឆ្នាំ ៧២២-៧២១ ។ នៅភាគខាងត្បូង(ពួកយូដា) មានអ្នកដឹកនាំ២០នាក់ ប៉ុន្តែពួកទាំងនោះមកពីជិន្នូវង្សរបស់ដាវីឌតែមួយប៉ុណ្ណោះ(លើកលែងតែ អ័ថាលាជាស្តេចជ្រែករាជ្យ) ហើយបន្តរហូតអស់រយៈពេល៣៤៥ ឆ្នាំមុន គ.សក្នុងការបែងចែកទឹកដីរហូតដល់ការដួលចុះរបស់ក្រុងយេរូសាឡិមឆ្នាំ ៥៨៦ មុន គ.ស ។

**គ្រោងសង្ខេប**

កណ្ឌគម្ពីរ១,២ពង្សាវតារ បានផ្តល់ជាទម្រង់មួយដ៏ធំទូលាយ ដែលជាប់ទាក់ទងទៅនឹងរយៈពេលនៃប្រវត្តិសាស្ត្រសំខាន់ៗ ក្នុងការពិពណ៌នាអំពីបេសកកម្មរបស់ហោរាអេលីសេ និងលោកអេលីយ៉ា ។

**I. រជ្ជកាលក្នុងរាជ្យស្តេចសាឡូម៉ូន (១:១-១២:២៤)**

ក.ការស្នងរាជ្យរបស់ស្តេចសាឡូម៉ូន(១:១-២:១២)

ខ.ការកសាងអាណាចក្ររបស់ស្តេចសាឡូម៉ូន(២:១៣-៤៦)

គ.ប្រាជ្ញារបស់ស្តេចសាឡូម៉ូន(ជំពូក ៣)

ឃ.លក្ខណៈនៃការគ្រងរាជ្យរបស់ស្តេចសាឡូម៉ូន(ជំពូក ៤)

ង.គម្រោងនៃការសង់វិហាររបស់ស្តេចសាឡូម៉ូន(៥:១-៩:៩)

១. ការរៀបចំសំណង់អាគារសម្រាប់វិហារ (ជំពូក ៥)

២.សំណង់អាគារវិហារ (ជំពូក៦)

៣.សំណង់ព្រះរាជ្យដំណាក់(៧:១-១២)

៤.ការបរិចាកសម្ភារៈផ្សេងៗដល់វិហារ (៧:១៣-៥១)

៥.ការស្អាងព្រះវិហារឡើង(ជំពូក៨)

៦.ការឆ្លើយតប និងការព្រមានរបស់ព្រះយេហូវ៉ាចំពោះស្តេចសាឡូម៉ូន(៩:១-៩)

ច.លក្ខណៈនៃការគ្រងរាជ្យរបស់ស្តេចសាឡូម៉ូន(៩:១០-១០:២៩)

ឆ.ភាពល្ងីល្ងើរបស់ស្តេចសាឡូម៉ូន(១១:១-១៣)

ជ.ការគម្រាមកំហែងមកដល់បល្ល័ង្កសាឡូម៉ូន(១១:១៤-៤៣)

ឃ.ការស្នងរាជ្យរបស់ស្តេចរេហូបោម(១២:១-២៤)

**II. ពួកអ៊ីស្រាអែល និង ពួកយូដាតាមរយៈស្តេចយេរ៉ូបោម១ ហើយនិង រេហូបោម ទៅដល់អ័ហាប់និងអេសា(១២:២៥-១៦:៣៤)**

ក.ស្តេចយេរ៉ូបោម១របស់ពួកអ៊ីស្រាអែល (១២:២៥-១៤:២០)

ខ.រេហូបោម ស្តេចរបស់ពួកយូដា (១៤:២១-៣១)

គ.អ័ប៊ីយ៉ារបស់ពួកយូដា (១៥:១-៨)

ឃ.អេសា ស្តេចពួកយូដា (១៥:២៥-៣២)

ង.ណាដាប ស្តេចពួកអ៊ីស្រាអែល (១៥:២៥-៣២)

ច.អេឡា ស្តេចពួកអ៊ីស្រាអែល (១៦:៨-១៤)

ឆ.ស៊ីមរី ស្តេចពួកអ៊ីស្រាអែល (១៦:១៥-២០)

ជ.អំរី ស្តេចពួកអ៊ីស្រាអែល (១៦:២១-២៨)

ឃ.អ័ហាប់ ស្តេចពួកអ៊ីស្រាអែល (១៦:២៩-៣៤)

**III. បេសកកម្មរបស់លោកហោរាអេលីសេ និង ហោរាផ្សេងទៀត តាមរយៈស្តេចអ័ហាប់ អេសា រហូតដល់អ័ហាស៊ីយ៉ា យេហូសាផាត (ជំពូក ១៧-២២)**

ក.ហោរាអេលីយ៉ា (ហោរាផ្សេងទៀត) ក្នុងរាជ្យអ័ហាប់ (១៧:១-២២:៤០)

១.ហោរាអេលីយ៉ា និងភាពរាំងស្ងួត (ជំពូក ១៧)

២.ហោរាអេលីយ៉ា នៅលើភ្នំកើមែល (ជំពូក ១៨)

៣.ការវាយប្រហាររបស់លោកអេលីយ៉ា នៅភ្នំហូរែប (ជំពូក ១៩)

៤.ហោរាម្នាក់ផ្តន្ទាទោសដល់ស្តេចអ័ហាប់ក្នុងកាលដែលទ្រង់បានទុកជីវិតដល់ស្តេចបេន-ហាដាឌ់ (ជំពូក ២០)

៥.ហោរាអេលីយ៉ា ផ្តន្ទាទោសដល់ស្តេចអ័ហាប់ក្នុងកាលដែលទ្រង់បានចាប់ខ្លួនស្តេចណាបាតម្ចាស់ចំការទំពាំងបាយជូរ (២២:១-៤០)

៦.ហោរាមីកា បានទាយពីការសុគតរបស់ស្តេចអ័ហាប់ ហើយបានសម្រេចបទទំនាយ (២២:១-៤០)

ខ.ស្តេចយ៉ូសាផាត របស់ពួកយូដា (២២:៥១-៥៣)

គ.ស្តេចអ័ហាស៊ីយ៉ា របស់ពួកអ៊ីស្រាអែល

**IV- បេសកកម្មរបស់ហោរាអេលីយ៉ា និង អេលីសេ នៅក្នុងរជ្ជកាលស្តេចអ័ហាស៊ីយ៉ា និង យ៉ូរ៉ាម (២ពវ ១:១-៨:១៥)**

ក.ហោរាអេលីយ៉ា នៅក្នុងរជ្ជកាលស្តេចអ័ហាស៊ីយ៉ា (ជំពូក ១)

ខ.ការកាត់ស្រាយរបស់ហោរាអេលីយ៉ា និង ការកាន់តំណែងជាហោរាដំបូងរបស់លោកអេលីសេ (២:១-១៨)

គ.ហោរាអេលីសេ ក្នុងរជ្ជកាលរបស់ស្តេចយ៉ូរ៉ាម (២:១៩-៨:១៥)

១.ទីសំគាល់ការអស្ចារ្យដំបូងរបស់ហោរាអេលីសេ (២:១៩-២៥)

២.ហោរាអេលីសេ នៅក្នុងយុទ្ធនាការប្រឆាំងនឹងស្រុកម៉ូអាប់ (ជំពូក៣)

៣.បេសកកម្មរបស់ហោរាអេលីសេ នៅក្នុងភាពក្រខ្សត់របស់ពួកអ៊ីស្រាអែល (ជំពូក ៤)

៤.ហោរាអេលីសេ ព្យាបាលមេទ័ពណាម៉ាន់ (ជំពូក ៥)

៥.សេចក្តីសង្គ្រោះរបស់ហោរាអេលីសេ ក្នុងចំណោមហោរាផ្សេងៗទៀត (៦:១-៧)

៦.ការសង្គ្រោះរបស់ហោរាអេលីសេ ដល់យ៉ូរ៉ាមក្នុងពេលពួកអាសស៊ើរវាយលុក (៦:៨-២៣)

៧.ការទាយរបស់ហោរាអេលីសេ ចំពោះការឡោមព័ទ្ធរបស់ពួកអាសស៊ើរមកលើស្រុកសាម៉ារី (៦:២៤-៧:២០)

៨.ការស្តាឡើងវិញនៃទឹកដីស៊ូណែម (៨:១-៦)

៩.ហោរាអេលីសេ បានទស្សទាយពីការគៀបសង្កត់របស់ហាសែលមកលើពួកអ៊ីស្រាអែល (៨:៧-១៥)

**V. ពួកយូដា និងអ៊ីស្រាអែល ត្រូវនិរទេសខ្លួនដោយយ៉ូរ៉ាម (៨:១៦-១៧:៤១)**

ក.យ៉ូរ៉ាម ស្តេចពួកយូដា (៨:១៦-២៤)

ខ.អ័ហាស៊ីយ៉ា ស្តេចពួកយូដា (៨:២៥-២៩)

គ.ការបះបោររបស់យេហ៊ូវ និងរាជ្យរបស់ព្រះអង្គ (ជំពូក ៩-១០)

១.ហោរាអេលីសេ ចាក់ប្រេងតាំងលើយេហ៊ូវ (៩:១–១៣)
២.យេហ៊ូវ ធ្វើគតដល់ស្តេចយ៉ូរ៉ាម និង អ័ហាស៊ីយ៉ា (៩:១៤–២៩)
៣.យេហ៊ូវ ធ្វើគតដល់យេសិបិល (៩:៣០–៣៧)
៤.យេហ៊ូវ ធ្វើគតបុត្រស្តេចអ័ហាប់ (១០:១–១៧)
៥.យេហ៊ូវ បំបាត់ការថ្វាយបង្គំរូបព្រះបាល (១០:១៨–៣៦)
ឃ.អ័ថាលា និង យ៉ូអាស ស្តេចពួកយូដា ជួសជុលព្រះវិហារឡើងវិញ (ជំពូក ១១–១២)
ង.យ៉ូអាហាស ស្តេចពួកអ៊ីស្រាអែល (១៣:១–៩)
ច.យ៉ូអាហាស ស្តេចពួកអ៊ីស្រាអែល និងហោរាអេលីសេចុងក្រោយបំផុត (១៣:១០–២៥)
ឆ.អ័ម៉ាស៊ីយ៉ា ស្តេចពួកយូដា (១៤:១–២២)
ជ.យេរ៉ូបោមទី២ ស្តេចពួកអ៊ីស្រាអែល (១៤:២៣–២៩)
ឈ.អ័សារា ស្តេចពួកយូដា (១៥:១–៧)
ញ.សាការី ស្តេចពួកអ៊ីស្រាអែល (១៥:៨–១២)
ដ.សាលូម ស្តេចពួកអ៊ីស្រាអែល (១៥:១៣–១៥)
ឋ.មហាណិម ស្តេចពួកអ៊ីស្រាអែល (១៥:១៧–២២)
ទ.ពេកាហ៊ា ស្តេចពួកអ៊ីស្រាអែល (១៥:២៣–២៦)
ធ.ពេកា ស្តេចពួកអ៊ីស្រាអែល (១៥:២៧–៣១)
ន.យ៉ូថាម ស្តេចពួកយូដា (១៥:៣២–៣៨)
ប.អ័ហាស ស្តេចពួកយូដា (ជំពូក ១៦)
ព.ហូសៀ ស្តេចពួកយូដា (១៧:១–៦)
ម.ការនិរទេសខ្លួនរបស់ពួកអ៊ីស្រាអែល និង ការតាំងលំនៅថ្មី (១៧:៧–៤១)

**VI. ពួកយូដាចាកចេញពីស្តេចហេសេគា ដោយសាការនិរទេសខ្លួនរបស់ពួកបាប៊ីឡូន (ជំពូក ១៨–២៥)**

ក.ស្តេចហេសេគា (ជំពូក ១៨–២០)
១.ការគ្រប់គ្រងល្អរបស់ស្តេចហេសេគា (១៨:១–៨)
២.ការគាបសង្កត់របស់ពួកអាសស៊ើរ និងការរួចផុតពីសេចក្តីវេទនា (១៨:៩–១៩:៣៧)
៣.ហេសេគាទ្រង់មានជម្ងឺ និង ការចងសម្ព័ន្ធជាមួយចក្រភពបាប៊ីឡូន (ជំពូក ២០)
ខ.ស្តេចម៉ាន៉ាសេ (២១:១–១៨)
គ.ស្តេចអាំម៉ូន (២១:១៩–២៦)
ឃ.ស្តេចយ៉ូសៀស (២២:១–២៣:៣០)
១.ការជួសជុលព្រះវិហារ និង ការរកឃើញគម្ពីរក្រឹត្យវិន័យថ្មី (ជំពូក ២២)
២.សេចក្តីសញ្ញាថ្មី និង ការបញ្ចប់រាជ្យស្តេចយ៉ូសៀស (២៣:៣៦–២៤:៧)
ង.ស្តេចយ៉ូអាហាស ត្រូវបាននិរទេសខ្លួនទៅអេស៊ីព្ទ (២៣:៣១–៣៥)
ច.យេហូយ៉ាគីមៈ និរទេសខ្លួនលើកទី១ទៅបាប៊ីឡូន (២៣:៣៦–២៤:៧)
ឆ.យេហូយ៉ាគីមៈ និរទេសខ្លួនលើកទី២ទៅបាប៊ីឡូន (២៤:១៨–២៥:២១)
ជ.សេដេគាៈ និរទេសខ្លួនលើកទី៣ទៅបាប៊ីឡូន (២៤:១៨–២៥:២១)
ឈ.ពួកអ្នកនៅសល់ ចូលទៅក្នុងទឹកដីអេស៊ីព្ទ (២៥:២២–២៦)
ញ.ការលើកយ៉ូយ៉ាគីនធ្វើជាស្តេចនៅបាប៊ីឡូន (២៥:២៧–៣០)

## អ័ដូនីយ៉ាតាំងខ្លួនឯងជាស្ដេច

**១** [១]គ្រានោះ ស្ដេចដាវីឌ ទ្រង់មានព្រះជន្មាយុកន្លងបង់
ហើយ គេដណ្ដប់សំពត់ថ្វាយទ្រង់ជាច្រើន តែទ្រង់មិនកក់
ក្ដៅទេ [២]ហេតុនោះបានជាពួកមហាតលិកទ្រង់ទូលថា សូម
ឱ្យគេទៅរកស្រីក្រមុំ១មកថ្វាយព្រះករុណា ជាព្រះអម្ចាស់នៃ
ទូលបង្គំ ឱ្យនាងបានឈរនៅចំពោះទ្រង់ ដើម្បីនឹងថែទាំ
ទ្រង់ ហើយឱ្យនាងបានដេកឱបទ្រង់ ប្រយោជន៍ឱ្យព្រះ
ករុណា ជាព្រះអម្ចាស់ បានកក់ក្ដៅ [៣]ដូច្នេះគេក៏ចេញទៅ
ស្វែងរកស្រីក្រមុំយ៉ាងល្អ នៅគ្រប់ក្នុងស្រុកអ៊ីស្រាអែល
បានប្រទះនឹងនាងអ័ប៊ីសាក [ក]ជាអ្នកស្រុកស៊ូណែម[ខ]ហើយ
នាំនាងមកថ្វាយស្ដេច [៤]នាងនោះមានរូបរាងស្រស់ល្អ
ណាស់ ហើយក៏ថែទាំងបំរើស្ដេច តែទ្រង់មិនបានរួមរស់
នឹងនាងសោះ ។
[៥]ខណនោះ អ័ដូនីយ៉ា[គ] ជាបុត្រនៃនាងហាគីត ក៏លើកខ្លួន
ឡើង ដោយពាក្យថា យើងនឹងធ្វើជាស្ដេច ដូច្នេះទ្រង់ក៏
ត្រៀមរទេះចំបាំង[ឃ] និងពួកពលសេះ ព្រមទាំងមនុស្ស៥០
នាក់ ឱ្យរត់នាំមុខទ្រង់ [៦]ឯព្រះបិតារបស់ទ្រង់មិនដែលធ្វើឱ្យ
ទាស់ចិត្តម្ដង[ង] ដោយពាក្យថា ហេតុអ្វីបានជាធ្វើដូច្នេះ
នោះឡើយ ១ទៀតទ្រង់ជាមនុស្សមានរូបរាងល្អណាស់
ទ្រង់បានប្រសូតមកក្រោយអាប់សាឡំម [៧]ទ្រង់ពិគ្រោះនឹង
យ៉ូអាប់[ច] ជាកូនសេរូយ៉ា ហើយនិងអ័បៀថើរ[ឆ] ដ៏ជាសង្ឃ
គេទាំង២ក៏តាមជួយ [៨]តែសាដុក[ជ]ដ៏ជាសង្ឃ បេណាយ៉ា[ឈ]
ជាកូនយេហូយ៉ាដា ហោរាណាថាន់[ញ] ស៊ីម៉ាយ[ដ] ហើយរេអ៊ី
ព្រមទាំងពួកអ្នកខ្លាំងពូកែ[ឋ]របស់ដាវីឌ គេមិនបានចូលដៃ
ជួយអ័ដូនីយ៉ាទេ [៩]ទ្រង់ក៏សំឡាប់ចៀមគោ និងសត្វយ៉ាងធាត់
នៅត្រង់ថ្មសូហេលែត ដែលនៅជិតអេន-រ៉ូកែល[ឌ] ទ្រង់
អញ្ជើញពួកបងប្អូនទាំងអស់ ជាបុត្រាស្ដេច[ឍ]និងពួកជនជាតិ
យូដាទាំងប៉ុន្មាន ដែលជាអ្នកថែរក្សាហ្លួងដែរ [១០]តែមិន
បានអញ្ជើញ[ណ]ហោរាណាថាន់ បេណាយ៉ា និងពួកមនុស្ស

**១:៣** ក ខ.១៥ ២សយ ៣:៧ ១ពវ ២:១៧,២២ ខ យស ១៩:១៨ **១:៥** គ ២សយ ៣:៤ ឃ ១សយ ៨:១១ **១:៦** ង ១សយ ៣:១៣ **១:៧** ច ២សយ ២:១៣,១៨ ឆ ១សយ ២២:២០ **១:៨** ជ ១សយ ២:៣៥ ២សយ ៨:១៧ ឈ ២សយ ៨:១៨ ញ ២សយ ៧:២ ដ ១ពវ ៤:១៨ ឋ ២សយ ២៣:៨ **១:៩** ឌ ២សយ ១៧:១៧ ឍ ១រប ២៩:២៤ **១:១០** ណ ខ.២៦

**១:១-១២:២៤** ការរៀបរាប់ពីរជ្ជកាលរបស់ស្ដេចសាឡូនម៉ូន គឺជាគំរូនៃភាពល្អឆើតក្នុងកំណាព្យរបស់គាត់ ហើយការលើកឡើងនេះ មានរហូតដល់ទៅចំនួន៩ផ្នែកឯណោះ ។ ផ្នែកទី១ និងផ្នែកបញ្ចប់មានលក្ខណៈស្របគ្នាជាមួយនឹងផ្នែកទី២ ហើយនិងផ្នែកទី៨ក៏ស៊ីគ្នាដែរ វាជាចំណែកមួយភាគប្រាំជាមួយនឹងតួនាទីនៃការរចនាសម្ព័ន្ធ ដែលមានរយៈពេលវែងនៃផ្នែកទី៩ ហើយជាកម្មវិធីសាងសងមួយក្រោមការស្ដាប់បង្គាប់ពីស្ដេចសាឡូម៉ូន ។

**១:១** *ជន្មាយុកន្លងបង់* ២សយ បានប្រាប់ថាស្ដេចដាវីឌប្រហែលជា សុគតនៅក្នុងជន្មាយុ៧០ព្រះវស្សា(ធៀប ១ពវ ២:១១) ។

**១:២** *កក់ក្ដៅ* ពាក្យនេះមានការពន្យល់ពីយ៉ាង (១).លោកយ៉ូសែបហ្វី (Josephus) សតវត្សទី១ (២).លោកកាឡែន (Galen) ជាវេជ្ជបណ្ឌិតក្រិកនៅសតវត្សទី២ ។ ចំណុចទាំងពីរនេះ សំដៅលើការប្រើប្រាស់ថ្នាំសង្កូវដើម្បីឱ្យខ្លួនបានកក់ក្ដៅនៅពេល កំពុងមានជម្ងឺ ។

**១:៣** *ស៊ូណែម* ស្ដ្រីរូបនេះមកពីស្រុកស៊ូណែម ដែលស្ថិតនៅជិតវាលរាបយេសរាលក្នុងដែនដីនៃពួកសាសន៍អ៊ីសាខា (២ពវ ៤:៨ ហស ១៩:១៨ ១សយ ២៨:៤) ។

**១:៤** *មិនបានរួមរស់នឹងនាងសោះ* នេះជាសេចក្ដីសំខាន់ក្នុងទំនាក់ទំនងរបស់អ័ដូនីយ៉ាថាឱ្យនាងអ័ប៊ីសាក ជាមហេសីរបស់ទ្រង់ក្រោយពីទ្រង់សុគតទៅ(ការពន្យល់ ២:១៧,២២) ។

**១:៥** *អ័ដូនីយ៉ា* ជាបុត្រទីបួនរបស់ស្ដេចដាវីឌ ដែលមានព្រះជន្មប្រហែលជា ៣៥ វស្សា(មើល ២សយ ៣:៤) ។ អ័ដូនីយ៉ានេះ ពិតជាមានព្រះជន្មច្រើនជាងគេមែន ក្នុងចំណោមបុត្ររបស់ស្ដេចដាវីឌដែលមានព្រះជន្មរស់នៅ (សូមមើល ២សយ ១៣:២៨ ២សយ ១៨:១៤) ។ *លើកខ្លួនឡើង* នេះបញ្ជាក់ថាគាត់នៅក្នុងភាពឯកតោភាគីក្នុងបំណងជ្រែករាជ ដោយមិនគោរពច្បាប់ក្នុងការគ្រងរាជដែលបានជ្រើសតាំង អ្នកស្នងរាជរួចហើយនោះក៏ដោយគាត់បានដឹងច្បាស់ថា បិតារបស់គាត់បានយល់ព្រមលើករាជសម្បត្តិនេះឱ្យដល់សាឡូម៉ូនរួចហើយ (មើល ខ.១០) ។ នៅក្នុងចំណុចនេះដែរ ប្រសិនបើគាត់ធ្វើបានសម្រេច នោះនឹងធ្វើឱ្យខកបំណងព្រះហឫទ័យព្រះ និងជម្រើសរបស់ស្ដេចដាវីឌដែលជ្រើសសាឡូម៉ូន ជាអ្នកគ្រងរាជបន្តពីទ្រង់ (សូមមើល ខ.១៣ ១៧ ៣០ ១រប ២២:៩-១០ និងការពន្យល់ ២សយ ១២:២៥) ។ *៥០នាក់ឱ្យរត់មុខទ្រង់* នៅត្រង់នេះគាត់ធ្វើពីតាមគំរូអាប់សាឡំម (មើល ការពន្យល់ ២សយ ១៥:១) ។

**១:៦** *មិនដែលធ្វើឱ្យទាស់ចិត្ត* នៅត្រង់នេះស្ដេចដាវីឌ ទ្រង់មិនទទួលខុសត្រូវចំពោះទង្វើរបស់បុត្រទ្រង់នេះទៀតទេ (មើលការពន្យល់ ២សយ ១៣:២១ ១៤:៣៣) ។ *រូបរាងល្អណាស់* រូបសម្រស់របស់គាត់គឺស័ក្តសមនឹងឡើងគ្រងរាជលើបល្ល័ង្ក(មើល ១សយ ៩:២ ១៦:១២ ២សយ ១៤:២៥) ។

**១:៧** *យ៉ូអាប់ ជាកូនសេរូយ៉ា* មើលការពន្យល់ ១សយ ២៦:៦ ២សយ ២:១៣ ១៩:១៣ ២០:១០ ២៣ ។ ការសហការរបស់យ៉ូអាប់ ជាមួយនឹងអ័ដូនីយ៉ា និងជម្រុញឱ្យឈានដល់ការវាយប្រហាជាមួយបេណាយ៉ា(មើល ខ.៨ ២សយ ៨:១៨ ២០:២៣ ២៣:២០-២៣) ។ លោកយ៉ូអាប់ទុកចិត្តលើអំណាចទាហានជាងការពឹងអាងលើស្ដេចដាវីឌ (មើល ២:៥-៦) ។ *អ័បៀថើរដ៏ជាសង្ឃ* មើលការពន្យល់ ២សយ ៨:១៧ ។

**១:៨** *សាដុក ដ៏ជាសង្ឃ* មើលការពន្យល់ ២សយ ៨:១៧ ។ *បេណាយ៉ា ជាកូនយេហូយ៉ាដា* មើលការពន្យល់ ២សយ ២៣:២០ ។ *ហោរាណាថាន់* សូមមើល ២សយ ១២:១-២៥ ។ *ស៊ីម៉ាយ* មិនមែនស៊ីម៉ាយនៅក្នុង មើល ២:៨, ៤៦ ២សយ ១៦:៥-៨ ប្រហែលជាឈ្មោះនេះដូចគ្នានឹងកូនរបស់លោកអេឡា (៤:១៨) ។

**១:៩** នៅត្រង់នេះបានបង្ហាញពីការដែលលោកសូលត្រូវគេលើកតាំងឱ្យធ្វើជាស្ដេច នោះទ្រង់បានថ្វាយដង្វាយមេត្រីដល់សេចក្ដីសញ្ញារបស់ព្រះដែលប្រទានឱ្យដល់ពួកគេនៅភ្នំស៊ីណាយ ។ ដូច្នេះនៅត្រង់នេះ ប្រហែលអ័ដូនីយ៉ាមានបំណងចង់ថ្វាយនូវដង្វាយដល់ព្រះអម្ចាស់ ក្នុងគោលបំណងឱ្យស្របទៅតាមច្បាប់រាជវង្ស ។ ប៉ុន្ដែ អ័ដូនីយ៉ារូបនេះ មិនមែនជាមនុស្សដែលព្រះជ្រើសរើសក្នុងការផ្ដួលស្ដេចដាវីឌឡើយ ។

ខ្លាំងពូកែ ឬសាឡូម៉ូន ជាអនុជទ្រង់ទេ[ត]។
11 ដូច្នេះណាថាន់ក្រាបទូលដល់បាតសេបា[ថ] ជាមាតា
សាឡូម៉ូនថា តើព្រះនាងមិនបានជ្រាបថា អ័ដូនីយ៉ា[ទ] ជាកូន
ហាគីតបានឡើងសោយរាជ្យ ឥតជ្រាបដល់ដាវីឌ ជាព្រះ
អម្ចាស់នៃយើងរាល់គ្នាផងទេឬអី 12 ដូច្នេះ សូមព្រះនាង
មក ឱ្យទូលបង្គំបានជួយគំនិតខ្លះ[ធ] ប្រយោជន៍ឱ្យបានរួចជីវិត
របស់ព្រះនាង និងជីវិតរបស់សាឡូម៉ូនជាបុត្រផងដែរ
13 សូមចូលទៅគាល់ស្តេចដាវីឌទូលថា បពិត្រព្រះករុណា
ជាព្រះអម្ចាស់ តើទ្រង់មិនបានស្បថ[ន]នឹងខ្ញុំម្ចាស់ ជាបាវបំរើ
ទ្រង់ថា ត្រូវឱ្យសាឡូម៉ូន ជាកូនឯង សោយរាជ្យក្រោយអញ
ជាពិត ក៏ត្រូវអង្គុយលើបល្ល័ង្កអញនោះទេឬអី ដូច្នេះ ហេតុ
អ្វីបានជាអ័ដូនីយ៉ាសោយរាជ្យវិញ 14 មើលកំពុងដែលព្រះ
នាងនៅទូលនឹងស្តេច ក្នុងទីនោះនៅឡើយ នោះទូលបង្គំ
នឹងចូលទៅតាមក្រោយ ហើយនឹងបញ្ជាក់ពាក្យរបស់ព្រះ
នាងដែរ ។
15 បាតសេបាក៏ចូលទៅគាល់ស្តេច នៅក្នុងបន្ទប់ក្រឡា
ព្រះបន្ទំ រីឯស្តេចទ្រង់ជរាណាស់ហើយ ក៏មាននាង
អ័ប៊ីសាក[ប] ពីស៊ូណែម នាងកំពុងតែបំរើទ្រង់ 16 បាតសេបា
ក៏ឱនខ្លួនគោរពនៅចំពោះស្តេច រួចស្តេចទ្រង់មានបន្ទូល
សួរថា តើមកមានប្រាថ្នាអ្វី 17 ព្រះនាងទូលឆ្លើយថា បពិត្រ
ព្រះអម្ចាស់អើយ ទ្រង់បានស្បថ[ផ]នឹងខ្ញុំម្ចាស់ ជាបាវបំរើ
ទ្រង់ ដោយនូវព្រះយេហូវ៉ា ជាព្រះនៃទ្រង់ថា សាឡូម៉ូនជា
កូនឯង នឹងឡើងសោយរាជ្យក្រោយអញជាពិត ហើយ
នឹងអង្គុយលើបល្ល័ង្កអញមិនមែនឬ 18 តែមើល ឥឡូវនេះ
អ័ដូនីយ៉ាបានឡើងសោយរាជ្យហើយ ទ្រង់ព្រះករុណាជា
ព្រះអម្ចាស់ឥតបានជ្រាបទេ 19 វាបានសំឡាប់[ព]គោនិងចៀម
ហើយសត្វយ៉ាងធាត់ៗជាច្រើន ក៏បានអញ្ជើញ ពួកបុត្រា
ទាំងអស់នៃព្រះករុណា ព្រមទាំងអ័បៀថើរដ៏ជាសង្ឃនឹង
យ៉ូអាប់ ជាមេទ័ពដែរ តែឯសាឡូម៉ូន ជាបាវបំរើទ្រង់នោះ
គេមិនបានហៅទៅទេ 20 ដូច្នេះ ឱព្រះករុណាជាព្រះអម្ចាស់
អើយ ភ្នែកនៃពួកអ៊ីស្រាអែលទាំងអស់ គេគន់មើលមកទ្រង់
ចាំតែទ្រង់ប្រាប់ឱ្យគេដឹង ជាអ្នកណាដែលត្រូវគង់លើបល្ល័ង្ក
រាជ្យរបស់ព្រះករុណា ជាព្រះអម្ចាស់ទ្រង់ទៅ 21 បើពុំនោះ
ដល់កាលណាព្រះករុណា ជាព្រះអម្ចាស់ទ្រង់ផ្ទំលក់[ភ]ទៅជា
មួយនឹងពួកព្ធយុកោទ្រង់ នោះខ្ញុំម្ចាស់ នឹងសាឡូម៉ូន ជាកូន
របស់ខ្ញុំម្ចាស់ និងត្រូវរាប់ទុកជាមនុស្សប្រទាំងការហើយ ។
22 លុះកាលព្រះនាងកំពុងតែក្រាប ទូលនឹងស្តេចនៅ
ឡើយ នោះហោរាណាថាន់ក៏ចូលមកដល់ 23 គេទូលស្តេច
ថា បពិត្រព្រះរាជា ហោរាណាថាន់មកគាល់ហើយរួច
កាលលោកបានចូលមកដល់ចំពោះស្តេចហើយ នោះក៏
ក្រាបផ្កាប់មុខដល់ដីនៅចំពោះទ្រង់ទូលថា 24 បពិត្រព្រះ
ករុណា ជាព្រះអម្ចាស់នៃទូលបង្គំអើយ តើទ្រង់បានមាន
បន្ទូលថា អ័ដូនីយ៉ាត្រូវឡើងសោយរាជ្យតពីទ្រង់ ហើយគង់
លើបល្ល័ង្ករាជ្យឬអី 25 ដ្បិតនៅថ្ងៃនេះ លោកបានចុះទៅ
សំឡាប់គោនិងចៀម ហើយសត្វយ៉ាងធាត់ៗជាច្រើនក៏បាន
អញ្ជើញពួកបុត្រាទាំងប៉ុន្មាន នៃព្រះករុណា ព្រមទាំងពួក
មេទ័ព និងអ័បៀថើរដ៏ជាសង្ឃផង មើល គេកំពុងតែ
លៀងលោមគ្នា នៅចំពោះមុខលោក ដោយបន្លឺវាចាថា

**១:១០** ត ២សយ ១២:២៤
**១:១១** ថ ២សយ ១២:២៤ ទ ២សយ ៣:៤
**១:១២** ធ សភ ១៥:២
**១:១៣** ន ខ.១៧,៣០
**១:១៥** ប ខ.៣
**១:១៧** ផ ខ.១៣
**១:១៩** ព ខ.៩
**១:២១** ភ លប ១៥:១៥ ១ពវ ២:១០

**១:១១** *បាតសេបា ជាមាតាសាឡូម៉ូន* នៅត្រង់នេះបញ្ជាក់ថា ម្ចាស់ស្ត្រីមានតួនាទី និងមានឥទ្ធិពលខ្លាំងនៅក្នុងរាជតុលាការ (មើល ២:១៩ ១៥:១៣ ២ពវ ១០:១៣ ២របា ១៥:១៦) ។ *បានឡើងសោយរាជ្យ* ទោះបីការរៀបរាប់ពីខាងដើម មិនឃើញមាននិយាយពីការប្រកាសជាក់ស្តែង ពីភាពជាស្តេចរបស់អ័ដូនីយ៉ាក៏ដោយ ក៏អាចសន្និដ្ឋានបាននៅក្នុង (មើល ខ.២៥ ២:១៥ ធៀប ២សយ ១៥:១០) ។

**១:១២** *ឱ្យបានរួចជីវិតរបស់នាង និងជីវិតរបស់សាឡូម៉ូន* ឃ្លានេះត្រូវបានគេលើកឡើងនៅក្នុងសម័យបុរាណសម្រាប់អ្នកដែលគេជ្រែករាជ្យឱ្យរក្សាជីវិតក្នុងគោលបំណងដណ្តើមយកអំណាចនោះមកវិញ (មើល ១៥:២៩ ២ពវ ១០:១១ ១១:១) ។

**១:១៣** *តើទ្រង់មិនបានស្បថនឹងខ្ញុំម្ចាស់* ទោះបីជានៅក្នុងកណ្ឌគម្ពីរពង្សាវតាក្សត្រទី២មិនបានកត់ត្រាពីពាក្យសម្បថរបស់ស្តេចដាវីឌ ចំពោះការផ្តល់រាជ្យសម្បតិដល់ស្តេចសាឡូម៉ូនក៏ដោយ ក៏នៅតែបញ្ជាក់ថាស្តេចសាឡូម៉ូននេះ គឺជាបុត្ររបស់ទ្រង់ ដែលព្រះយេហូវ៉ាទ្រង់បានសន្យាចំពោះស្តេចដាវីឌថា សាឡូម៉ូននេះជាសន្តតិវង្សរបស់គាត់ជារៀងតទៅ (សូមមើលពន្យល់ ខ.៥) ។

**១:១៥** *ស៊ូណែម* មើលការពន្យល់ ខ.៣ ។

**១:១៧** *ទ្រង់បានស្បថនឹងខ្ញុំម្ចាស់ . . . ដោយនូវព្រះយេហូវ៉ា* ឃ្លានេះបញ្ជាក់ថាពាក្យសម្បថដែលធ្វើនៅចំពោះព្រះយេហូវ៉ា គឺមិនអាចប្រែក្រឡាស់បានឡើយ (មើល នក ២០:៧ លវ ១៩:១២ យស ៩:១៥,១៨,២០ ពច ១១:៣០, ៣៥ សស ៥:៤-៧) ។

**១:២១** *ទ្រង់ផ្ទំលក់ទៅនឹងពួកព្ធយុកោទ្រង់* ឃ្លានេះប្រាប់ពីការសុគតរបស់ទ្រង់ (មើល លប ៤៧:៣០ ចទ ៣១:១៦) ។

**១:២៤** នៅចំណុចនេះ ហោរាណាថាន់ បានចូលទៅជិតស្តេចដាវីឌក្នុងនាមជាមុខការីជន ដោយលើកជាសំណួរដែលពិបាកក្នុងការសម្រេចចិត្ត ។ ស្តេចដាវីឌ បានសន្យាជាសម្ងាត់ចំពោះការឡើងគ្រងរាជ្យរបស់អ័ដូនីយ៉ា និងពាក្យសន្យាចំពោះនាងបាតសេបា និងសាឡូម៉ូន (ខ.២៧) ក្នុងការឡើងគ្រងរាជសម្បត្តិនេះដែរ ។ ដូច្នេះសរុបមក ស្តេចដាវីឌទ្រង់បានក្បត់សន្យាចំពោះអ័ដូនីយ៉ា បាតសេបា និងសាឡូម៉ូនផងដែរ ។

**១:២៥** *សូមឱ្យស្តេចអ័ដូនីយ៉ាប្រកបដោយសេចក្តីចំរើន* នេះបង្ហាញពីការទទួលស្គាល់ និងការសារទរចំពោះព្រះមហាក្សត្រថ្មី (មើល ១សយ ១០:២៤ ២សយ ១៦:១៦ ២ពវ ១១:១២) ។

សូមឱ្យស្តេចអ័ដូនីយ៉ាប្រកបដោយសេចក្តីចំរើនចុះ [២៦]តែឯ
ទូលបង្គំ ជាបាវបំរើទ្រង់ ហើយសាដុកដ៏ជាសង្ឃ បេណាយ៉ា
ជាកូនយេហូយ៉ាដា និងសាឡូម៉ូន ជាអ្នកបំរើទ្រង់ នោះ
លោកមិនបានអញ្ជើញទៅទេ[ម] [២៧]តើព្រះករុណា ជាព្រះ
អម្ចាស់នៃទូលបង្គំ បានបង្គាប់ការនេះឥតប្រាប់ឱ្យទូលបង្គំ
ដឹងជាអ្នកណា ដែលត្រូវអង្គុយលើបល្ល័ង្កនៃព្រះករុណាតពី
ទ្រង់ឬអី។

## ស្តេចដាវីឌតែងតាំងសាឡូម៉ូនជាស្តេច

*១:២៨-៥៣ – ១រប ២៩:២១-២៥*

[២៨]ខណនោះ ស្តេចដាវីឌទ្រង់មានបន្ទូលថា ចូរហៅ
បាតសេបាមកនេះ ព្រះនាងក៏ចូលមកឈរគាល់នៅចំពោះ
ស្តេច [២៩]រួចស្តេចទ្រង់មានបន្ទូលថា យើងស្បថដោយនូវ
ព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ ដែលទ្រង់បានលោះ
ព្រលឹងយើង ឱ្យរួចពីគ្រប់ទាំងសេចក្តីវេទនាថា[យ] [៣០]នៅថ្ងៃ
នេះ យើងនឹងសំរេចតាមសេចក្តីដែលយើងបានស្បថ[រ]នឹង
ឯង ដោយនូវព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលថា
សាឡូម៉ូនជាកូនឯង ត្រូវឡើងសោយរាជ្យតពីយើងជាពិត
ហើយនឹងអង្គុយលើបល្ល័ង្កជំនួសយើង [៣១]ដូច្នេះបាតសេបា
ក៏ក្រាបផ្កាប់មុខដល់ដី គោរពចំពោះស្តេចទូលថា បពិត្រ
ព្រះករុណា សូមឱ្យព្រះអម្ចាស់នៃខ្ញុំម្ចាស់ បានប្រកបដោយ
សេចក្តីចំរើនជានិច្ចតទៅ ។
[៣២]រួចមក ស្តេចដាវីឌទ្រង់មានបន្ទូលថា ចូរហៅសាដុក[ល]
ដ៏ជាសង្ឃ ហោរាណាថាន់ និងបេណាយ៉ា ជាកូនយេហូ–
យ៉ាដាមកនេះ លោកទាំងនោះក៏ចូលមកគាល់នៅចំពោះ
ស្តេច [៣៣]ទ្រង់មានបន្ទូលបង្គាប់ថា ចូរអ្នករាល់គ្នានាំយក
ពួកពលទ័ព របស់ចៅហ្វាយអ្នក ទៅបញ្ជិះសាឡូម៉ូនជាបុត្រ
យើង ឱ្យជិះលើលាកាត់របស់យើង[វ] នាំចុះទៅឯគីហុនទៅ[ស]
[៣៤]ហើយត្រូវឱ្យសាដុកដ៏ជាសង្ឃ និងហោរាណាថាន់ ចាក់
ប្រេងតាំង[ហ]ឡើងជាស្តេចលើសាសន៍អ៊ីស្រាអែលនៅទី
នោះ រួចឱ្យផ្លុំត្រែ[ឡ]ឡើង ហើយស្រែកថា សូមឱ្យស្តេច
សាឡូម៉ូនប្រកបដោយសេចក្តីចំរើនចុះ [៣៥]ក្រោយមកត្រូវ
ឱ្យអ្នករាល់គ្នាដង្ហែឡើងមក ឱ្យអង្គុយលើបល្ល័ង្ករាជ្យរបស់
យើង ដ្បិតវាត្រូវសោយរាជ្យជំនួសយើង គឺយើងនេះហើយ
បានដំរូវឱ្យវាធ្វើជាអ្នកនាំមុខពួកអ៊ីស្រាអែល និងពួកយូដា
[៣៦]បេណាយ៉ា ជាកូន យេហូយ៉ាដា ក៏ទូលឆ្លើយថា អាម៉ែន
សូមឱ្យព្រះយេហូវ៉ា ជាព្រះនៃព្រះករុណា ដ៏ជាម្ចាស់នៃ
ទូលបង្គំ បានព្រមដូច្នេះដែរ [៣៧]សូមឱ្យព្រះយេហូវ៉ាទ្រង់
សណ្ឋិត[អ]នៅជាមួយនឹងព្រះករុណាជាម្ចាស់នៃទូលបង្គំ
ហើយប្រោសឱ្យរាជ្យទ្រង់បានវិសេសជាង[ក]រាជ្យរបស់ព្រះ
ករុណា ជាម្ចាស់នៃទូលបង្គំទៅទៀតផង ។
[៣៨]ដូច្នេះ សាដុក[ខ] ដ៏ជាសង្ឃ ណាថាន់ ជាហោរា
បេណាយ៉ា ជាកូនយេហូយ៉ាដា ហើយពួកកេរេធីម[គ] និងពួក
កេរេធីម គេក៏បញ្ជិះសាឡូម៉ូននៅលើលាកាត់របស់ស្តេច
ដាវីឌ នាំចុះទៅដល់គីហុន[ឃ] [៣៩]ឯសាដុក ដ៏ជាសង្ឃលោក
យកស្នែងដែលដាក់ប្រេង[ង] ចេញពីត្រសាលជុំនុំ[ច] ទៅចាក់
ថ្វាយសាឡូម៉ូន រួចគេផ្លុំត្រែ[ឆ]ឡើង ហើយបណ្តាជនទាំង
ឡាយ គេបន្លឺវាចា[ជ]ថា សូមឱ្យស្តេចសាឡូម៉ូនបានប្រកប
ដោយសេចក្តីចំរើនចុះ [៤០]ស្រេចហើយ បណ្តាជនទាំងអស់

**១:២៦** ម ខ.១០
**១:២៩** យ ២សយ ៤:៩
**១:៣០** រ ខ.១៣ ១រប ២៣:១
**១:៣២** ល ១សយ ២:៣៥
**១:៣៣** វ ពច ១០:៤ សក ៩:៩ ស ខ.៣៨ ២រប ៣២:៣០ ៣៣:១៤
**១:៣៤** ហ ១សយ ២:៣៥ ១០:១ ឡ ២សយ ១៥:១០
**១:៣៧** អ យស ១:៥,១៧ ក ខ.៤៧
**១:៣៨** ខ ខ.៨ គ ១សយ ៣០:១៤ ២សយ ១៥:១៨ ឃ ខ.៣៣
**១:៣៩** ង នក ២៩:៧ ១សយ ១០:១ ២ពវ ១១:១២ ទដ ៨៩:២០ ច នក ២៦:១ ២៧:២១ ឆ ២សយ ១៥:១០ ២ពវ ១១:១៤ ជ ខ.៣៤ ជន ២៣:២១ ទដ ៤៧:៥ សក ៩:៩

**១:៣១** *សូមឱ្យព្រះអម្ចាស់ . . . ចំរើនជានិច្ច* នេះជាការអរព្រះគុណរបស់នាងបាតសេបានៅទីលានកាត់ក្តី (សូមមើល នហ ២:៣ ដយ ២:៤ ៣:៩ ៥:១០ ៦:២១) ។

**១:៣៣** នៅវគ្គនេះយើងសង្ស័យថា ស្តេចដាវីឌទ្រង់បានបញ្ជូនសេះចម្បាំងដ៏អស្ចារ្យ និងលឿនដើម្បីនាំយកសាឡូម៉ូនទៅអភិសេកឡើងគ្រងរាជ្យផ្ទុយមកវិញសាឡូម៉ូនជិះសេះស្តេចដាវីឌវិញ ។ សេះរទេះរបស់ស្តេចដាវីឌនៅសម័យនោះមានតម្លៃថ្លៃណាស់ ដែលអាចជិះបានក្នុងតំម្លៃថ្លៃ និងពោពេញទៅដោយអំណាច ។ តែក្នុងពេលដែលព្រះយេស៊ូយាងចូលក្នុងក្រុងយេរូសាឡឹមទ្រង់មិនជិះសេះទេទ្រង់បែជាជិះសត្វលាវិញ (សក ៩:៩ មថ ២១:១៧) ។

**១:៣៤** *ចាក់ប្រេងតាំង* មើលការពន្យល់ ១សយ ២:១០ ៩:៦ ។ *ផ្លុំត្រែ* មើល ២ពវ ៩:១៣ ២សយ ១៥:១០ ២០:១ ។ *សូមឱ្យស្តេចសាឡូម៉ូនប្រកបដោយសេចក្តីចំរើនចុះ* មើលការពន្យល់ ខ.២៥ ។

**១:៣៥** *ពួកអ៊ីស្រាអែល និងពួកយូដា* នេះជាភាពខុសគ្នារវាងពួកអ៊ីស្រាអែល និងពួកយូដា គឺជាឫសគល់នៃការបែកបាក់គ្នា នៅក្នុងពេលដែលស្តេចដាវីឌបានគ្រប់គ្រងលើពូជអំបូរទាំងពីរនេះ (មើល ២សយ ២:៤ ៥:៣) ។

**១:៣៦** *អាម៉ែន សូមឱ្យព្រះយេហូវ៉ា* សូមមើល យរ ២៨:៦ ។

**១:៣៧** *បានវិសេសជាង* ពាក្យនេះមិនមែនមានន័យថា និយាយក្នុងគោលបំណងមើលងាយរាជ្យស្តេចដាវីឌទេ តែជាការសរសើរដោយស្មោះត្រង់ចំពោះស្តេចដាវីឌ និងស្តេចសាឡូម៉ូនវិញ ។ លោកបេណាយ៉ា បានផ្តល់យោបល់ឱ្យដល់ស្តេចក្នុងការជ្រើសរើសអ្នកបន្តរាជបល្ល័ង្ក (ខ.៤៧–៤៨) ។

**១:៣៩** *សាដុក . . . ថ្វាយសាឡូម៉ូន* ព្រះមហាក្សត្រដែលជ្រើសតាំងដោយព្រះអម្ចាស់ ដើម្បីដឹកនាំរាស្ត្ររបស់ទ្រង់ដែលមិនជាប់សន្តតិវង្ស គឺត្រូវតែងតាំងឡើងដោយពួកហោរ៉ា (ស្តេចសូល ១សយ ៩:១៦ ដាវីឌ ១សយ ១៦:១២ យេហ៊ូវ ២សយ ៩) ។ កណ្ឌគម្ពីរ ពង្សាវតារក្សត្រនេះ អ្នកណាដែលគេបានសន្មតថា ជាសន្តតិវង្សដើម្បីគ្រងរាជ្យបន្ត នោះត្រូវបានរៀបអភិសេកដោយពួកសង្ឃ (ស្តេចសាឡូម៉ូន យ៉ូអា ២ពវ ១១:១២) ។ ការគូសបញ្ជាក់ខាងលើនេះ ហាក់ដូចជាពួកសង្ឃបានធ្វើការជាមួយនិងការបង្កើតការគ្រប់គ្រង ក្នុងខណៈដែលពួកហោរ៉ាបានទាយពីព្រះដើមដំបូង។ *ស្នែងដែលចាក់ប្រេង* នេះប្រហែលជា ចាក់ប្រេងចូលក្នុងស្នែងនោះផងដែរ (នក ៣០:២២–២៣)។ *ត្រសាលជំនុំ* ត្រសាលរបស់ស្តេចដាវីឌនេះ សង់ឡើងនៅក្នុងក្រុងយេរូសាឡឹម (មើល ២សយ ៦:១៧) ដែលវាមានលក្ខណៈល្អប្រសើរជាងរោងឧបោសថនៅឯគីបៀន (មើល ៣:៤ និងការពន្យល់ ២រប ១:៣) ។

ក៏ដង្ហែអង្គឡើងមកដោយផ្លុំខ្លុយ[ឈ] ហើយមានសេចក្តីត្រេក
អររីករាយជាខ្លាំង ដល់ម្ល៉េះបានជាផែនដីក៏ខ្ទរ ដោយសូរ
សព្ទអឺងកងរបស់គេ ។
៤១ ឯអ័ដូនីយ៉ា និងពួកភ្ញៀវដែលនៅជាមួយ គេក៏ឮក្នុង
កាលដែលគេស៊ីលៀងរួច កាលយ៉ូអាប់បានឮសូរផ្លុំត្រែ
នោះលោកសួរថា ហេតុអ្វីបានជាមានសូរអឺងកងនៅក្នុង
ទីក្រុងដូច្នេះ[ញ] ៤២ កាលលោកកំពុងតែ និយាយនៅឡើយ
នោះយ៉ូណាថាន[ដ] ជាកូនអ័បៀថើរដ៏ជាសង្ឃក៏ចូលមក ដល់
អ័ដូនីយ៉ាមានបន្ទូលទៅគាត់ថា ចូរចូលមកចុះ ដ្បិតឯងជា
មនុស្សក្លាហានពិត ក៏នាំដំណឹងល្អមក[ឋ] ៤៣ នោះយ៉ូណាថាន
ក៏ទូលតបទៅអ័ដូនីយ៉ាថា ស្តេចដាវីឌជាព្រះអម្ចាស់នៃ
យើងរាល់គ្នា ទ្រង់បានតាំងសាឡូម៉ូនឱ្យសោយរាជ្យឡើង
ជាពិតហើយ ៤៤ ទ្រង់បានចាត់សាដុកដ៏ជាសង្ឃ ហេរាណា
ថាន់ បេណាយ៉ា ជាកូនយេហូយ៉ាដាព្រមទាំងពួកកេរេធីម
និងពួកពេលេធីមផង ឱ្យទៅបញ្ជិះសាឡូម៉ូនលើលាកាត់
របស់ស្តេច ៤៥ ហើយសាដុកដ៏ជាសង្ឃ នឹងហោរាណាថាន់
បានចាក់ប្រេងតាំងឡើងជាស្តេចនៅត្រង់គីហុនរួចគេឡើង
ពីនោះមកដោយរីករាយសាទរ ដល់ម្ល៉េះបានជាឮសូរអឺង
កងនៅទីក្រុង[ឌ] គឺសូរនោះហើយ ដែលអស់លោកអ្នកបានឮ
៤៦ ឯសាឡូម៉ូនទ្រង់គង់[ឍ] លើបល្ល័ង្ករាជហើយ ៤៧ មួយទៀត
ពួកលោកជាជិនិតស្តេច បានមកចំរើនពរដល់ស្តេចដាវីឌ
ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដោយពាក្យថា សូមឱ្យព្រះនៃ
ទ្រង់ដំកើងព្រះនាម សាឡូម៉ូន ឱ្យវិសេសជាងព្រះនាមនៃ
ទ្រង់ហើយតាំងរាជ្យសាឡូម៉ូន ឱ្យធំលើសជាង[ណ] រាជ្យរបស់
ទ្រង់ទៅទៀត ឯស្តេចទ្រង់ក៏ឱនកាយនៅលើព្រះបន្ទំ
៤៨ ហើយមានបន្ទូលថា សូមក្រាបថ្វាយបង្គំដល់ព្រះយេហូ
វ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ដែលទ្រង់បានប្រទានឱ្យ
មានម្នាក់[ត] អង្គុយលើបល្ល័ង្ក នៃទូលបង្គំនៅថ្ងៃនេះ ឱ្យភ្នែក
ទូលបង្គំបានឃើញផង ។
៤៩ ឯពួកភ្ញៀវរបស់អ័ដូនីយ៉ា គេមានសេចក្តីតក់ស្លុតទាំង
អស់គ្នា ក៏ក្រោកឡើងចេញទៅតាមផ្លូវគេរៀងខ្លួនទៅ
៥០ អ័ដូនីយ៉ាក៏ភ័យខ្លាច ដោយព្រោះសាឡូម៉ូនដែរ ទ្រង់
ក្រោកឡើងទៅចាប់កាន់ស្នែង[ថ] អាសនា ៥១ មានគេទៅទូល
សាឡូម៉ូនថា មើល អ័ដូនីយ៉ាខ្លាចដល់ទ្រង់ក៏បាន ទៅចាប់
កាន់ស្នែងអាសនា ដោយពាក្យថា សូមឱ្យស្តេចសាឡូម៉ូន
ស្បថនឹងទូលបង្គំនៅថៃនេះថា ទ្រង់មិនសំឡាប់ទូលបង្គំជា
ខ្ញុំដោយដាវឡើយ ៥២ នោះសាឡូម៉ូនមានបន្ទូលថា បើវានឹង
សំដែងខ្លួនថាជាមនុស្ស គួរគប្បី នោះសូម្បីសក់ក្បាល១
សរសៃ[ទ] របស់វា ក៏មិនត្រូវធ្លាក់ចុះដល់ដីផង តែបើសិនជា
ប្រទះឃើញមានសេចក្តីទុច្ចរិតអ្វី នោះនឹងត្រូវស្លាប់វិញ
៥៣ ដូច្នេះ ស្តេចសាឡូម៉ូនក៏ចាត់គេឱ្យទៅនាំចុះពីអាសនាមក
នោះ អ័ដូនីយ៉ាក៏មកក្រាបថ្វាយបង្គំដល់ស្តេចសាឡូម៉ូន រួច
ទ្រង់មានបន្ទូលថា ចូរទៅផ្ទះទៅ ។

## ស្តេចដាវីឌផ្តាំសាឡូម៉ូន

*២:១០–១២ – ១រប ២៩:២៦–២៨*

**២** ១ រីឯពេលកំណត់ ដែលដាវីឌត្រូវសុគត[ក] បានជិតដល់
ទ្រង់ក៏ផ្តាំសាឡូម៉ូន ជាព្រះរាជបុត្រាទ្រង់ថា ២ អញរៀបនឹង
ទៅតាមផ្លូវរបស់មនុស្សលោកទាំងឡាយហើយ[ខ] ដូច្នេះ
ចូរឯងខំប្រឹងឡើង[គ] ហើយសំដែងខ្លួន ឱ្យបានពេញជាប្រុស
ចុះ ៣ ចូររក្សា[ឃ] បញ្ញើរបស់ព្រះយេហូវ៉ា ជាព្រះនៃឯង
ដើម្បីប្រព្រឹត្តតាមអស់ទាំងផ្លូវរបស់ទ្រង់ ព្រមទាំងកាន់តាម
សេចក្តីបង្គាប់នឹងក្រិត្យក្រម ហើយនឹងសេចក្តីបន្ទាល់របស់

**១:៤០** ឈ ១សយ ១០:៥
**១:៤១** ញ ២រប ២៣:១២–១៣
**១:៤២** ដ ២សយ ១៥:២៧,៣៦ ឋ ២សយ ១៨:២៦
**១:៤៥** ឌ ខ.៤០
**១:៤៦** ឍ ចទ ១៧:១៨
**១:៤៧** ណ ខ.៣៧
**១:៤៨** ត ១ពវ ៣:៦
**១:៥០** ថ នក ២៧:២
**១:៥២** ទ ១សយ ១៤:៤៥
**២:១** ក លប ២៧:២ ជន ២៧:១៣
**២:២** គ យស ២៣:១៤ ឃ យស ១:៦

**១:៤១** *គេក៏ឮ* ទោះបីតំបន់គីហុននេះ ពួកគេមើលមិនឃើញពីអេន–រ៉ូកេល ក៏ដោយ តែចម្ងាយមិនឆ្ងាយពីទីនេះប៉ុន្មានទេ ហើយសម្លេងបានឮដល់ជ្រោះកេដ្រុន ។

**១:៤២** *យ៉ូណាថាន ជាកូនអ័បៀថើរ* មើល ២សយ ១៧:១៧–២១ ។

**១:៤៧** *វិសេសជាងព្រះនាម* មើលការពន្យល់ ខ.៣៧ ។

**១:៤៨** *អង្គុយលើបល្ល័ង្ក* សូមមើល ២សយ ៧:១២, ១៦ ។

**១:៤៩** *ក្រោកឡើងចេញទៅតាមផ្លូវគេ* នៅត្រង់ចំណុចនេះ គ្មាននរណាទៅតាមអ័ដូនីយ៉ាដែលការធ្វើរដ្ឋប្រហាររបស់គាត់មិនបានសម្រេច រហូតធ្លាក់ក្នុងការបរាជ័យ ។

**១:៥០** *ចាប់កាន់ស្នែងអាសនា* ស្នែងនៃអាសនានេះលយចេញត្រង់គ្រប់មុំនៃជ្រុងនីមួយៗ ។ គំនិងនៃការស្វែងរកសិទ្ធជ្រកកោននៅទីអាសនា មានកត់ចុះនៅក្នុងកណ្ឌគម្ពីរបញ្ញកណ្ឌ (មើល នក ២១:១៣–១៤) ។ ពួកសង្ឃបានលាបឈាមនៃយញ្ញបូជាលើស្នែងអាសនានៅពេលធ្វើពិធីថ្វាយយញ្ញបូជា (មើល នក ២៩:១២ លវ ៤:៧,១៧,២៥,៣០,៣៤) ។ ដូច្នេះ អ័ដូនីយ៉ាស្វែងរកជោគវាសនារបស់ខ្លួន ក្រោមការការពាររបស់ព្រះ ។

**១:៥២** *មនុស្សគួរគប្បី* នៅត្រង់នេះបញ្ជាក់ថា នរណាដែលស្គាល់ហើយចុះចូល ចំពោះរាជ្យស្តេចសាឡូម៉ូន និងអំណាចរបស់ទ្រង់នោះចាត់ទុកថាជាមនុស្សប្រពៃ ។ *បើសិនជាប្រទះឃើញ មានសេចក្តីទុច្ចរិត* ពាក្យនេះបញ្ជាក់ថា គេនៅតែបន្តការស្វែងរកឱ្យឃើញ ថាតើពួកគេនៅតែបន្តការប្រឆាំងចំពោះស្តេចសាឡូម៉ូន។

**២:១** *ទ្រង់ក៏ផ្តាំ* សូមមើលពីគំរូលោកម៉ូសេ (ចទ ៣១:១–៨) លោកយ៉ូស្វេ (យស ៣:៣១–១៦) និងសាំយ៉ូអែល (១សយ ១២:១–២៥) ជាអ្នកតំណាងរបស់ព្រះអម្ចាស់ក្នុងការដឹកនាំ ដែលពួកគេម្នាក់ៗទទួលបានការបង្រៀន និងការណែនាំពីព្រះអម្ចាស់ មុនពេលពួកគេស្លាប់ ។

**២:២** *តាមផ្លូវរបស់មនុស្សលោកទាំងឡាយ* ឃ្លានេះសំគាល់ពីផ្នូ (មើល យស ២៣:១៤) ។ *ខំប្រឹងឡើង* មើល ចទ ៣១:៧,២៣ យស ១:៦–៧,៩,១៨ ។

**២:៣** *ចូររក្សាបញ្ញើរបស់ព្រះយេហូវ៉ា* សូមមើល លប ២៦:៥ លវ ១៨:៣០ ចទ ១១:១ ។ *តាមអស់ទាំងផ្លូវរបស់ទ្រង់* ឃ្លានេះជាការបញ្ជាក់ពី ការគោ

ត្រង់តាមសេចក្ដី ដែលបានកត់ទុកហើយ ក្នុងក្រិត្យវិន័យ
របស់លោកម៉ូសេ ប្រយោជន៍ឱ្យឯងបានប្រព្រឹត្តដោយ
ប្រាជ្ញា[ង]ក្នុងគ្រប់ទាំងការដែលឯងធ្វើ ហើយនៅកន្លែងណា
ដែលឯងទៅ 4 ដើម្បីឱ្យព្រះយេហូវ៉ាបានសំរេចតាមព្រះ
បន្ទូល[ច]ដែលទ្រង់បានមានបន្ទូលនឹងអញថា បើកូនចៅឯង
រក្សាផ្លូវរបស់គេ ឱ្យបានដើរនៅចំពោះមុខអញ ដោយ
ស្មោះត្រង់[ឆ] អស់ពីចិត្ត អស់ពីព្រលឹងគេ នោះនឹងមិនដែល
ខានមានពូជឯង អង្គុយលើបល្ល័ង្ករាជ្យនៃសាសន៍អ៊ីស្រា-
អែលឡើយ ។
5 មួយទៀតឯងដឹងការដែលយ៉ូអាប់[ជ]ជាកូនសេរូយ៉ាបាន
ប្រព្រឹត្តនឹងអញ ជាការដែលវាបានធ្វើ ដល់មេទ័ពសាសន៍
អ៊ីស្រាអែល២នាក់នោះ គឺអ័ប៊ីនើរ[ឈ] ជាកូននើរ ហើយនិង
អ័ម៉ាសា[ញ]ជាកូនយេធើ ដែលវាបានសំឡាប់បង់ ទាំងកំ
ចាយឈាមចំបាំង នៅវេលាសុខសាន្តត្រាណ ក៏បាន
ប្រឡាក់សំពត់ក្រវាត់ ដែលនៅចង្កេះខ្លួន និងស្បែកជើង
ដែលវាពាក់ដោយឈាមចំបាំង 6 ដូច្នេះ ចូរឯងប្រព្រឹត្ត
ដោយប្រាជ្ញារបស់ឯង[ដ] កុំឱ្យសក់ស្កូវរបស់វាចុះទៅដល់
ស្ថានឃុំព្រលឹងមនុស្សស្លាប់ ដោយសុខសាន្តឡើយ 7 តែចូរ
សំដែងសេចក្ដីសប្បុរស[ឋ] ដល់ពួកកូនបារស៊ីឡាយ[ឌ] ជាពួក
ស្រុកកាឡាតវិញ ហើយឱ្យគេនៅក្នុងពួកអ្នកដែលបរិភោគ
នៅតុឯង[ឍ] ដ្បិតគេបានមកទទួលអញ នៅគ្រាដែលអញបាន
រត់ពីអាប់សាឡំម ជាបងឯងទៅ 8 មួយទៀតមានស៊ីម៉ាយ[ណ]
ជាកូនកេរ៉ា ក្នុងពូជអំបូរបេនយ៉ាមីន ជាអ្នកស្រុកបាហ៊ូរីម
នៅជាមួយនឹងឯងដែរ វាបានជេរប្រមាថដល់អញ ដោយ
ពាក្យជេរយ៉ាងធ្ងន់ នៅថ្ងៃដែលអញបានទៅឯស្រុកម៉ាហា
ណែម[ត] ប៉ុន្តែវាបានចុះមកក្រាបទទួលអញនៅទន្លេយ័រដាន់
វិញ ហើយអញបានស្បថ[ថ]នឹងវាដោយនូវព្រះយេហូវ៉ាថា
អញមិនសំឡាប់វា ដោយដាវទេ 9 ដូច្នេះ កុំទុកឱ្យវានៅជាឥត
ទោសឡើយ ដ្បិតឯងជាអ្នកប្រាជ្ញ[ទ]ឯងដឹងជាត្រូវប្រព្រឹត្ត
យ៉ាងណាដល់វា ត្រូវឱ្យសក់ស្កូវវាចុះទៅដល់ស្ថានឃុំព្រលឹង
មនុស្សស្លាប់ដោយឈាម ។
10 ស្រេចហើយ ដាវីឌក៏ផ្ទឹលក់ទៅ ជាមួយនឹងពួកព្ធយុកោ
ទ្រង់ទៅ ហើយគេបញ្ចុះសពទ្រង់[ធ] នៅក្នុងទីក្រុងដាវីឌ[ន]
11 ឯពេលវេលាដែលស្តេចដាវីឌសោយរាជ្យ[ប]លើសាសន៍
អ៊ីស្រាអែលទាំងអស់បាន៤០ឆ្នាំ គឺសោយរាជ្យនៅក្រុង
ហេប្រុនបាន៧ឆ្នាំ ហើយនៅក្រុងយេរូសាឡិមបាន ៣៣ឆ្នាំ
12 រួចសាឡូម៉ូនក៏ឡើងគង់លើបល្ល័ង្ក[ផ]របស់ដាវីឌ ជាព្រះ
បិតាទ្រង់ ហើយរាជ្យទ្រង់ក៏បានខ្ជាប់ខ្ជួនមាំមួនឡើង[ព]។

## សាឡូម៉ូនឡើងគ្រងរាជ្យបល្ល័ង្ក

13 គ្រា១អ័ដូនីយ៉ា[ភ] ជាបុត្រនាងហាគីត ចូលមកគាល់
បាតសេបា ជាមាតាសឡូម៉ូន ព្រះនាងសួរថា ឯងមកនេះ
ដោយមេត្រីឬអី[ម] ទ្រង់ទូលឆ្លើយថា ដោយមេត្រីទេ 14 រួច
ទ្រង់ទូលទៀតថា ទូលបង្គំមានការចង់ទូលនឹងព្រះនាង
បន្តិច ព្រះនាងក៏ប្រាប់ថា ចូរនិយាយមកចុះ 15 នោះទ្រង់

**២:៣** ង ចទ ៤:៦ ១០:១២ ១៧:១៤–២០ យស ១:៧ ១រប ២២:១៣
**២:៤** ច ២សយ ៧:១៣,២៥ ២រប ២៣:៣ ឆ ២ពវ ១៨:៣–៦ ២០:៣ ទដ ២៦:១–៣ ១៣២:១២
**២:៥** ជ ២សយ ២:១៨ ឈ ១សយ ១៤:៥០ ២សយ ៣:២៧ ញ ២សយ ១៧:២៥
**២:៦** ដ ខ.៩
**២:៧** ឋ លប ៤០:១៤ ឌ ២សយ ១៧:២៧ ១៩:៣១–៣៩ ឍ ២សយ ៩:៧
**២:៨** ណ ខ.៣៦–៤៦ ២សយ ១៦:៥–១៣ ត លប ៣២:២ ថ ២សយ ១៩:១៨–២៣
**២:៩** ទ ខ.៦
**២:១០** ធ កច ២:២៩ ន ២សយ ៥:៧
**២:១១** ប សយ ៤,៥ **២:១២** ផ ១រប ១៧:១៤ ២៩:២៣ ២រប ៩:៨ ព ខ.៤៦ ២រប ១:១ ១២:១៣ ១៧:១ ២១:៤ **២:១៣** ភ ២សយ ៣:៤ ម ១សយ ១៦:៤

រពចំពោះសេចក្ដីសញ្ញារបស់ព្រះ (ចទ ៥:៣៣ ៨:៦ ១០:១២ ១១:២២ ១៩:៩ ២៦:១៧ ២៨:៩ ៣០:១៦) ។ *កាន់តាមសេចក្ដីបង្គាប់ . . . ក្នុងក្រិត្យវិន័យ* ឃ្លានេះប្រាប់ពីលក្ខណៈបួនយ៉ាងនៃពាក្យខាងលើនេះ ក្នុងកាតព្វកិច្ចនៃការគោរពនូវសេចក្ដីសញ្ញារបស់ព្រះ (មើល ៦:១២ ៨:៥៨ ២ពវ ១៧:៣៧ ចទ ៨:១១ ១១:១ ២៦:១៧ ២៨:១៥,៤៥ ៣០:១០,១៦) ។ *គ្រប់ការដែលឯងធ្វើ* មើល ចទ ២៩:៩ ។

**២:៤** *ទ្រង់បានមានបន្ទូលនឹងអញថា* នៅត្រង់នេះជាការនិយាយដោយបញ្ជិតបញ្ចៀងរបស់ស្តេចដាវីឌចំពោះការសន្យារបស់ព្រះអម្ចាស់ ដែលប្រទានមកឱ្យ សន្តតិវង្សរបស់គាត់ តាមរយៈហោរាណាថាន់ (មើលពន្យល់ ២សយ ៧:១១–១៦) ។ ទោះបីសេចក្ដីសន្យានេះ បានផ្ដល់ឱ្យស្តេចដាវីឌដោយគ្មានលក្ខ័ណ និងជាបុគ្គលក៏ដោយ តែវាជាលក្ខ័ណចំពោះសេចក្ដីសញ្ញានៅភ្នំស៊ីណាយដែរ (មើល រប ៧:១៧–២២) ។ *អស់ពីចិត្ត ពីព្រលឹង* មើល ចទ ៤:៤៩ ៦:៥ ១០:១២ ៣០:៦ ។

**២:៥** *យ៉ូអាប់ជាកូនសេរូយ៉ា* មើលការពន្យល់ ១:៧ ។ *អ័ប៊ីនើរ ជាកូននើរ* មើលការពន្យល់ ២សយ ៣:២៥–៣២ ។ *អ័ម៉ាសា ជាកូនយេធើ* មើល ២សយ ២០:១០ ។ *កំចាយឈាមចំបាំង នៅវេលាសុខសាន្តត្រាន* សកម្មភាពរបស់លោកយ៉ូអាប់នេះ គឺជាការបំពានច្បាប់ដ៏ខ្លាំង (មើល ចទ ១៩:១–១៣ ២១:១–៩) ហើយសម្មភាពគាត់គ្រាន់តែជាកបម្រើឱ្យ ប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ។ លើសជាងនេះទៀត គាត់បានសម្លាប់ អាប់សាឡំមជាបុត្រស្តេចដាវីឌ (២សយ ១៨:១៤–១៥) និងបានចូលរួមជាមួយអ័ដូនីយ៉ាក្នុងដំណើរជ្រែករាជ្យបល្ល័ង្កផងដែរ (មើល ១:៧,១៩) ។

**២:៧** *ពួកកូនចៅបារស៊ីឡាយ* មើលការពន្យល់ ២សយ ១៧:២៧ ។ *បរិភោគនៅតុឯង* នេះបញ្ជាក់ថា មុខតំណែងធំ នឹងនាំឱ្យពួកគេនូវផលប្រយោជន៍ផ្សេងៗ (មើល ១៨:១៩ ២ពវ ២៥:២៩ ២សយ ៩:៧ ១៩:២៨) ។

**២:៩** *កុំទុកឱ្យវានៅជាឥតទោសឡើយ* នេះជាបម្រាមក្រឹត្យវិន័យរបស់លោកម៉ូសេ ចំពោះបណ្ដាសា (២១:១០ នក ២២:២៨) ។

**២:១០** *ដាវីឌក៏ផ្ទឹលក់ទៅ ជាមួយនឹងពួកព្ធយុកោទ្រង់* មើលការពន្យល់ ១:២១ ។ *ទីក្រុងដាវីឌ* មើលការពន្យល់ ២សយ ៥:៧ និងការពន្យល់ ។ លោកពេត្រុស បានបញ្ជាក់ថា ផ្នូររបស់ស្តេចដាវីឌនៅតែមានគេស្គាល់នៅឡើយក្នុងសម័យរបស់គាត់ (កច ២:២៩) ។

**២:១១** *៤០ឆ្នាំ* មើល ២សយ ៥:៤–៥ ។ ស្តេចដាវីឌបានដឹកនាំនៅឆ្នាំ ១០១០–៩៧០ មុន គស (មើលសេចក្ដីផ្ដើម ១សយ) ។

**២:១៣** *អ័ដូនីយ៉ា ជាបុត្រនាងហាគីត* មើលការពន្យល់ ១:៥ ។ *ឯងមកនេះដោយមេត្រី ឫអី* នេះជាឃ្លាសំណួរ (មើល ១សយ ១៦:៤ ២ពវ ៩:២២) ដែលព្រះនាងបាតសេបា សួរដល់អ័ដូនីយ៉ាពីគោលបំណងរបស់គាត់ (សូមមើល ១:៥) ។

ទូលថា ព្រះនាងជ្រាបហើយ ថារាជ្យនេះជារបស់ផងទូល
បង្គំ ហើយថា សាសន៍អ៊ីស្រាអែលទាំងអស់បានមើលចំទូល
បង្គំ ដោយសង្ឃឹមនឹងគ្រងរាជ្យឡើង ប៉ុន្តែរាជ្យបានត្រឡប់
វិលទៅជារបស់ផងប្អូនទូលបង្គំវិញ ដ្បិតគឺព្រះយេហូវ៉ា
ដែលទ្រង់ប្រទានទៅឱ្យ ១៦ឥឡូវនេះ ទូលបង្គំសូមតែសេច
ក្តី១ចំពោះព្រះនាងប៉ុណ្ណោះ សូមកុំប្រកែកឡើយ ព្រះនាង
ឆ្លើយតបថា ចូរពោលឱ្យអស់សេចក្តីទៅចុះ ១៧ដូច្នេះ ទ្រង់
ទូលថា ទូលបង្គំសូមព្រះនាងទូលដល់ស្តេចសាឡូម៉ូន ដ្បិត
ទ្រង់នឹងមិនប្រកែកចំពោះព្រះនាងទេ គឺសូមឱ្យទ្រង់ប្រទាន
នាងអ័ប៊ីសាក[យ] ជាអ្នកស្រុកស៊ូណែមមកឱ្យធ្វើជាប្រពន្ធ
របស់ទូលបង្គំ ១៨បាតសេបាទូលថា អើ អញនឹងទូលដល់
ស្តេចឱ្យឯង ។
១៩ដូច្នេះ បាតសេបាក៏ចូលទៅគាល់ស្តេចសាឡូម៉ូន ដើម្បី
ទូលទ្រង់ឱ្យអ័ដូនីយ៉ា ឯស្តេចទ្រង់ក្រោកឡើងទទួលក៏ឱន
ព្រះអង្គគោរពរួចគង់លើបល្ល័ង្កទ្រង់វិញ ហើយបង្គាប់ឱ្យគេ
យកបល្ល័ង្ក១មកដាក់ថ្វាយមាតាទ្រង់[រ] ព្រះនាងក៏គង់ខាង
ស្តាំទ្រង់[ល]ទូលថា ២០មាតាចង់សូមការតូច១ ពីបុត្រសូមកុំ
ប្រកែកឡើយ ស្តេចទ្រង់មានបន្ទូលតបថា សូមព្រះមាតា
មានព្រះសវនីយ៍មកចុះ ដ្បិតទូលបង្គំមិនប្រកែកទេ ២១ដូច្នេះ
ព្រះនាងទូលថា សូមប្រទាននាងអ័ប៊ីសាក[វ] ជាអ្នកស្រុក
ស៊ូណែមឱ្យទៅធ្វើជាប្រពន្ធអ័ដូនីយ៉ាជាដេវ្ឋាទៅ ២២ស្តេច
សាឡូម៉ូនទ្រង់ឆ្លើយតបទៅមាតាថា ហេតុអ្វីបានជាព្រះ
មាតាសូមនាងអ័ប៊ីសាក[ស] ជាអ្នកស្រុកស៊ូណែមឱ្យអ័ដូនីយ៉ា
ដូច្នេះ ត្រូវសូមទាំងរាជសម្បត្តិឱ្យវាផង ដ្បិតវាជាបងរបស់
ទូលបង្គំស្រាប់[ហ] គឺសូមឱ្យវានឹងអ័បៀថើរ[ឡ]ដ៏ជាសង្ឃ ហើយ
នឹងយ៉ូអាប់ ជាកូនសេរូយ៉ាដែរ ២៣នោះស្តេចសាឡូម៉ូន
ក៏ស្បថដោយនូវព្រះយេហូវ៉ាថា បើអ័ដូនីយ៉ាមិនត្រូវស្លាប់
ដោយព្រោះពោលពាក្យនេះទេ នោះសូមឱ្យព្រះទ្រង់
ប្រព្រឹត្តនឹងទូលបង្គំយ៉ាងនេះ ហើយលើសទៅទៀតផង[អ]
២៤ដូច្នេះ ទូលបង្គំស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្ម
រស់នៅ ដែលទ្រង់បានតាំងទូលបង្គំឡើងឱ្យអង្គុយលើ
បល្ល័ង្កនៃដាវីឌ ជាព្រះវរបិតា ហើយបានឱ្យទូលបង្គំមាន
ជំនួរវង្ស ដូចជាទ្រង់បានសន្យាទុក[ក] គឺស្បថថា នៅថ្ងៃនេះ
អ័ដូនីយ៉ាត្រូវស្លាប់ជាពិត ២៥ស្តេចក៏ចាត់បេណាយ៉ា ជាកូន
យេហូយ៉ាដា[ខ] ឱ្យទៅប្រហារជីវិតអ័ដូនីយ៉ា ហើយទ្រង់ក៏
សុគតទៅ[គ] ។
២៦ខណៈនោះ ស្តេចក៏មានបន្ទូលទៅអ័បៀថើរ[ឃ]ដ៏ជា
សង្ឃថា ចូរឯងត្រឡប់ទៅឯស្រែចំការរបស់ឯង ដែលនៅ
ស្រុកអាន៉ាថោតវិញទៅ[ង] ដ្បិតឯងគួរនឹងស្លាប់ហើយ ប៉ុន្តែ
យើងមិនសំឡាប់នៅវេលានេះទេ ព្រោះឯងជាអ្នកសែង
ហឹប[ច]នៃព្រះអម្ចាស់យេហូវ៉ា នៅចំពោះដាវីឌ ជាព្រះវរ
បិតាយើង ហើយដោយព្រោះឯងបានរងទុក្ខ ក្នុងគ្រប់ទាំង
សេចក្តីលំបាករបស់ព្រះវរបិតាយើងដែរ[ឆ] ២៧ដូច្នេះ
សាឡូម៉ូនបានបណ្តេញអ័បៀថើរ ចេញពីដំណែងងារជា

**២:១៧** យ ១ពវ ១:៣
**២:១៩** រ ១ពវ ១៥:១៣ ២ពវ ១០:១៣ ២៤:១៥ ២រប ១៥:១៦ យរ ១៣:១៨ ២២:២៦ ២៩:២ ល ទដ ៤៥:៩
**២:២១** វ ១ពវ ១:៣
**២:២២** ស លប ២២:២៤ ១ពវ ១:៣ ហ ១រប ៣:២ ឡ ១សយ ២២:២០
**២:២៣** អ នរ ១:១៧
**២:២៤** ក ២សយ ៧:១១
**២:២៥** ខ ២សយ ៨:១៨ គ ២សយ ១២:១០
**២:២៦** ឃ ១សយ ២២:២០ ង យស ២១:១៨ ច ២សយ ១៥:២៤ ឆ ២សយ ១៥:១៤

**២:១៥** *រាជ្យនេះ ជារបស់ផងទូលបង្គំ* មើល ១:១១ ។ *អ៊ីស្រាអែលទាំងអស់បានមើលចំទូលបង្គំ ដោយក្តីសង្ឃឹម* ឃ្លានេះបានប្រាប់ពីការបំផ្លើសដ៏ធំធេងរបស់គាត់(មើល ១:៧–៨) ។ *ជារបស់ផងប្អូន . . . ដ្បិតគឺព្រះយេហូវ៉ាដែលទ្រង់ជាអ្នកប្រទានឱ្យ* នៅត្រង់នេះអ័ដូនីយ៉ាបានទទួលស្គាល់ ស្តេចសាឡូម៉ូនថាជាព្រះរាជបំណងរបស់ព្រះអម្ចាស់ ហើយលែងប៉ុនប៉ងធ្វើជាស្តេចទៀតហើយ ។

**២:១៧** *ប្រទាននាងអ័ប៊ីសាក . . . មកឱ្យធ្វើជាប្រពន្ធរបស់ទូលបង្គំ* ការស្នើរសុំរបស់អ័ដូនីយ៉ានេះ មើលទៅហាក់ដូចជាគ្មានទោសអ្វីទេ (ប៉ុន្តែសូមមើលការពន្យល់ ខ.២២) ក្នុងកាលដែលនាងអ័ប៊ីសាកនៅតែជាស្ត្រីក្រមុំ ទោះនាងទៅបម្រើស្តេចដាវីឌក៏ដោយ (មើល ១:១–៤ ចទ ២២:៣០) ។

**២:១៩** *គង់ខាងស្តាំ* នេះជាការផ្តល់នូវការគោរពដ៏ខ្ពង់ខ្ពស់(មើល ទដ ១១០:១ មថ ២០:២១) ។

**២:២០** *សូមការតូច១* នៅចំណុចនេះនាងបាតសេបា មើលទៅហាក់ដូចជាមិនបានប្រឹងប្រែងជួយដល់សំណើររបស់អ័ដូនីយ៉ាទេ ។

**២:២២** *សូមទាំងរាជសម្បត្តិឱ្យវាផង* ភ្លាមៗនោះ ស្តេចសាឡូម៉ូនបានយល់ពីសំណូមរបស់អ័ដូនីយ៉ា ដូចគ្នានឹងការប៉ុនប៉ងដណ្តើមរាជបល្ល័ង្ក ។ ភាពជាម្ចាស់រាជបល្ល័ង្ករបស់ស្រីក្រមុំ ត្រូវបានគេចាត់ទុកថា នាងមានសិទ្ធិលើរាជបល្ល័ង្ក (មើលការពន្យល់ ២សយ ៣:៧ ១២:៨ ១៦:២១) ។ ទោះបីនាងអ័ប៊ីសាក ជាស្រីក្រមុំ តែនាងត្រូវបានពួកមនុស្សទទួលស្គាល់ថា ជាមហេសីរបស់ស្តេចដាវីឌ ។ ដូច្នេះ ចំពោះបំណងរបស់ អ័ដូនីយ៉ាក្នុងការរៀបអភិសេកជាមួយនាងអ័ប៊ីយ៉ា នឹងនាំឱ្យអ័ដូនីយ៉ា ប្រកាសខ្លួនថាជាម្ចាស់រាជ្យបល្ល័ង្ក ។ *អ័បៀថើរ ដ៏ជាសង្ឃ និងយ៉ូអាប់ជាកូនសេរូយ៉ា* មើលការពន្យល់ ១:៧ ។ ស្តេចសាឡូម៉ូន បានសន្មតថា អ័បៀថើរ និងយ៉ូអាប់ នៅតែបន្តគម្រោងការណ៍ក្បត់ជាមួយនឹងអ័ដូនីយ៉ាដដែល ។

**២:២៣** *ស្បថដោយនូវព្រះយេហូវ៉ា* សូមមើល ការពន្យល់ ១សយ ៣:១៧ ។

**២:២៤** *ទូលបង្គំមានជំនួរវង្ស* នេះបញ្ជាក់ពីជំនួរវង្ស និងអ្នកស្នងរាជ្យរបស់ស្តេចសាឡូម៉ូន ។ រេហូបោម បានប្រសូតមកយ៉ាងឆាប់ មុនពេលស្តេចសាឡូម៉ូនឡើងគ្រងរាជ្យជាស្តេច(ធៀប ១១:៤២ ១៤:២១) ។ *ស្បថថា* មើល ១រប ២២:៩–១០ ។

**២:២៥** *បេណាយ៉ា ជាកូនយេហូយ៉ាដា* មើលការពន្យល់ ១:៧ ២សយ ២៣:២០ ។

**២:២៦** *ជាអ្នកសែងហឹប* សូមមើល ២សយ ១៥:២៤–២៥,២៩ ១រប ១៥:១១–១២ ។ *រងទុក្ខ ក្នុងគ្រប់ទាំងសេចក្តីលំបាករបស់ព្រះវរបិតាយើង* មើល ១សយ ២២:២០–២៣ ២៣:៦–៩ ៣០:៧ ២សយ ១៧:១៥ ១៩:១១ ។

**២:២៧** *សំរេចព្រះបន្ទូល . . . ដំណើរវង្សាអេលី* មើលការពន្យល់ ១សយ ២:៣០–៣៥ ។

សង្ឃនៃព្រះយេហូវ៉ាទៅ ដើម្បីឱ្យបានសំរេច[ជ] ព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ដែលទ្រង់បានមានបន្ទូលពីដំណើរវង្សាអេលី
នៅត្រង់ស៊ីឡូរ ។
២៨ ដំណឹងនោះក៏ឮទៅដល់យ៉ូអាប់ ហើយលោកក៏រត់ទៅ
ឯត្រសាលនៃព្រះយេហូវ៉ា ចាប់កាន់ស្នែង[ឈ]អាសនា ដ្បិត
ទោះបើលោកមិនបានទៅតាមអាប់សាឡំមក៏ពិត ប៉ុន្តែបាន
និយមតាមអ័ដូនីយ៉ាដែរ ២៩ មានគេមកក្រាបទូលស្តេច
សាឡូម៉ូនថា យ៉ូអាប់បានរត់ទៅឯត្រសាលនៃព្រះយេហូវ៉ា
ហើយ ក៏នៅជិតអាសនា[ញ] នោះសាឡូម៉ូនបាត់បេណាយ៉ា[ដ]
ជាកូនយេហូយ៉ាដា ឱ្យទៅដោយបន្ទូលថា ចូរទៅប្រហារ
ជីវិតវាទៅ ៣០ បេណាយ៉ាក៏ទៅឯត្រសាល[ឋ]នៃព្រះយេហូវ៉ា
ប្រាប់យ៉ូអាប់ថា ស្តេចទ្រង់បង្គាប់ឱ្យចេញមក[ឌ] តែលោក
ប្រកែកថា ទេ ខ្ញុំនឹងស្លាប់នៅទីនេះវិញ ដូច្នេះបេណាយ៉ាក៏
ទៅក្រាបទូលដល់ស្តេចថា យ៉ូអាប់បានឆ្លើយ មកទូលបង្គំ
យ៉ាងនោះ ៣១ ស្តេចមានបន្ទូលតបថា ចូរធ្វើតាមពាក្យវាចុះ
ចូរសំឡាប់វា ហើយកប់វាទៅ ដើម្បីនឹងលុបឈាម[ឍ] ដែល
យ៉ូអាប់បានកំចាយ ដោយឥតហេតុចេញពីយើង ហើយពី
ជិនូរវង្សនៃព្រះវរបិតាយើងទៅ ៣២ ព្រះយេហូវ៉ាទ្រង់នឹង
ទំលាក់[ណ]ឈាម[ត]វា ទៅលើក្បាលខ្លួនវាវិញ ពីព្រោះវាបាន
ប្រហារជីវិតមនុស្ស២នាក់ដែលសុច្ចរិត ហើយល្អជាងវា[ថ]
ដោយកាប់នឹងដាវ តែដាវីឌជាព្រះវរបិតាយើងទ្រង់មិន
បានជ្រាបសោះគឺអ័ប៊ីនេរ កូននេរ ជាមេទ័ពពួកអ៊ីស្រាអែល
និងអ័ម៉ាសា[ទ] កូនយេធើ ជាមេទ័ពពួកយូដា ៣៣ ឈាមរបស់
គេនឹងធ្លាក់មកលើក្បាលយ៉ូអាប់ ហើយនឹងពូជពង្សវាជា
ដរាបទៅ តែចំណែកឯដាវីឌនឹងពូជពង្សទ្រង់ ព្រមទាំង
ជិនូរវង្សទ្រង់ ហើយរាជ្យរបស់ទ្រង់នោះនឹងបានសេចក្តី
សុខសាន្ត មកអំពីព្រះយេហូវ៉ាជានិច្ចតទៅវិញ ៣៤ ដូច្នេះ
បេណាយ៉ា[ធ] ជាកូនយេហូយ៉ាដា ក៏ឡើងទៅប្រហារសំឡាប់
យូអាប់[ន]បង់ រួចគេបញ្ចុះក្នុងម៉ុងរបស់លោកនៅទីរហោ
ស្ថាន ៣៥ ស្តេចទ្រង់ក៏តាំង បេណាយ៉ា[ប]ជាកូនយេហូយ៉ាដា
ឱ្យធ្វើជាមេទ័ពជំនួសលោក ហើយតាំងសាដុក[ផ]ដ៏ជាសង្ឃ
ជំនួសអ័បៀថើរដែរ ។
៣៦ រួចមក ស្តេចទ្រង់ចាត់គេទៅ ឱ្យហៅស៊ីម៉ាយ[ព]មក
បង្គាប់ថា ចូរឯងសង់ផ្ទះ១នៅក្រុងយេរូសាឡិមទៅ ហើយ
អាស្រ័យនៅទីនោះចុះ កុំឱ្យចេញទៅឯណាទៀតឡើយ
៣៧ ដ្បិតនៅថ្ងៃណា ដែលឯងចេញទៅ ឆ្លងជ្រោះកេដ្រុន
នោះ[ភ] ចូរឯងដឹងខ្លួនថា ឯងនឹងត្រូវស្លាប់ជាមិនខាន ឈាម
ឯងនឹងធ្លាក់លើក្បាលឯងវិញ[ម] ៣៨ ស៊ីម៉ាយទូលឆ្លើយថា ព្រះ
បន្ទូលទ្រង់ល្អណាស់ទូលបង្គំជាបាវបំរើទ្រង់ និងធ្វើដូចជា
ព្រះករុណាជាព្រះអម្ចាស់នៃទូលបង្គំ បានមានបន្ទូលហើយ
ស៊ីម៉ាយក៏នៅក្នុងក្រុងយេរូសាឡិមជាយូរ ។
៣៩ លុះកន្លងទៅ៣ឆ្នាំហើយ នោះបាវរបស់ស៊ីម៉ាយ២
នាក់រត់ទៅឯអ័គីស[យ] ជាស្តេចក្រុងកាថ ជាបុត្រនៃម្អាកា
រួចមានគេប្រាប់ដល់ស៊ីម៉ាយថា មើល បាវរបស់អ្នកនៅ
ឯក្រុងកាថ ៤០ ដូច្នេះ ស៊ីម៉ាយក៏ចាត់ចែង ចងកែបលាចេញ
ទៅឯអ័គីសនៅក្រុងកាថ ដើម្បីរកបាវរបស់ខ្លួន ក៏ទៅនាំ
យកបាវពីក្រុងកាថមកវិញ ៤១ មានគេក្រាបទូលដល់
សាឡូម៉ូនថា ស៊ីម៉ាយបានចេញពីក្រុងយេរូសាឡិមទៅដល់
ក្រុងកាថឥឡូវមកវិញហើយ ៤២ ស្តេចទ្រង់ក៏ចាត់គេឱ្យទៅ
ហៅស៊ីម៉ាយមក មានបន្ទូលសួរថា តើយើងមិនបានឱ្យឯង
ស្បថដោយនូវព្រះយេហូវ៉ាទេឬអី តើមិនបានប្រាប់បញ្ជាក់[រ]
ដល់ឯងឱ្យដឹងជាប្រាកដថា នៅថ្ងៃណា ដែលឯងនឹងចេញ
ដំណើរ ទៅឯស្រុកដ៏ទៃណាមួយ នោះឯងនឹងត្រូវស្លាប់ជា
មិនខានទេឬអី ហើយឯងបានទទួលព្រមថា ព្រះបន្ទូលនៃ
ទ្រង់ ដែលទូលបង្គំបានឮនេះល្អណាស់ដែរ ៤៣ ដូច្នេះ ហេតុ
អ្វីបានជាឯងមិនបាន កាន់តាមសំបថនៃព្រះយេហូវ៉ានឹង

**២:២៧** ជ ១សយ ២:២៧–៣៦
**២:២៨** ឈ នក ២៧:២
**២:២៩** ញ នក ២១:១៤ ដ ខ.២៥
**២:៣០** ឋ ២ពវ ១១:១៥ ឌ នក ២១:១៤
**២:៣១** ឍ ចទ ១៩:១៣
**២:៣២** ណ ពច ៩:៥៧ ត លប ៤:១៤ ពច ៩:២៤ ថ ២សយ ១៧:២៥ ទ ២របា ២១:១៣
**២:៣៤** ធ ខ.២៥ ន ២សយ ២:១៨
**២:៣៥** ប ២សយ ៨:១៨ ផ ១សយ ២:៣៥
**២:៣៦** ព ២សយ ១៦:៥
**២:៣៧** ភ ២សយ ១៥:២៣ យហ ១៨:១ ម លប ២០:៩
**២:៣៩** យ ១សយ ២៧:២
**២:៤២** រ ២សយ ១៩:២៣

**២:២៨** *ដំណឹង* នេះនិយាយពីការស្លាប់របស់ អ័ដូនីយ៉ា និងការនិរទេសខ្លួនរបស់អ័បៀថើរ ។ *និយមតាមអ័ដូនីយ៉ា* មើល ១:៧ ។ *ត្រសាលនៃព្រះយេហូវ៉ា* មើលការពន្យល់ ១:៣៩ ។ *កាន់ស្នែងអាសនា* សូមមើលការពន្យល់ ១:៥០ ។

**២:២៩** *ប្រហារជីវិតវាទៅ* ឃ្លានេះបញ្ជាក់ពីសិទ្ធិជ្រកកោន ដែលពន្យាពេលទៅលើតែមនុស្សណា ដែលអាចបង្កឱ្យនរណាម្នាក់ស្លាប់ដោយអចេតនាប៉ុណ្ណោះ (មើល នក ២១:១៤) ។ ស្តេចសាឡូម៉ូន បានបំពេញសេចក្តីយុត្តិធម៌ ក្នុងការបដិសេធសិទ្ធិនេះទៅដល់យ៉ូអាប់ ដែលគាត់មិនគ្រាន់តែបានចូលរួមគំនិតជាមួយអ័ដូនីយ៉ាក្នុងការផ្តួលស្តេចសាឡូម៉ូនប៉ុណ្ណោះទេ ថែមទាំងសម្លាប់អ័ប៊ីនេរ និងអ័ម៉ាសាផងដែរ (មើល ខ.៣១–៣៣) ។ រឿងរ៉ាវនេះ ស្តេចសាឡូម៉ូន បានស្វែងរកឱកាសសមរម្យមួយក្នុងការបំពេញសេចក្តីណែនាំរបស់បិតាទ្រង់ (មើល ខ.៥–៦) ។

**២:៣២** *ប្រហារជីវិតមនុស្សពីរនាក់* សូមមើល ២សយ ៣:២៧ ២០:៩–១០ ។ *មេទ័ពពួកអ៊ីស្រាអែល* សូមមើល ២សយ ២:៨–៩ ។ *មេទ័ពពួកយូដា* សូមមើល ២សយ ២០:៤ ។

**២:៣៥** *បេយ៉ាណា ជាកូនយេហូយ៉ាដា* សូមមើលការពន្យល់ ២សយ ២៣:២០ ។ *សាដុកដ៏ជាសង្ឃ* សូមមើលការពន្យល់ ១សយ ២:៣៥ ២សយ ៨:១៧ ។

**២:៣៦** *កុំឱ្យចេញទៅឯណាទៀតឡើយ* ចំពោះការដាប់ទោសរបស់លោកស៊ីម៉ាយនៅឯក្រុងយេរ៉ូសាឡិមគឺជាការកាត់បន្ថយដ៏សំខាន់មួយ (មើល ខ.៨) នៃការរួមគំនិតក្បត់ ដែលសល់នៅពីជំនាន់ស្តេចសូល ដើម្បីប្រឆាំងនឹងស្តេចសាឡូម៉ូន ។

**២:៣៩** *អ័គីស ជាបុត្រក្រុងកាថ ជាបុត្រនៃម្អាកា* ក្រុងកាថ នេះជាក្រុងសំខាន់នៃទីក្រុងប៉ាលេស្ទីន (មើល យស ១៣:៣ ១សយ ៦:១៦–១៧) ។

សេចក្ដីដែលយើងបានបង្គាប់នោះ ៤៤ស្ដេចក៏មានបន្ទូលនឹង
ស៊ីម៉ាយទៀតថា ឯងស្គាល់ការងារអាក្រក់ទាំងប៉ុន្មាន ដែល
លាក់ក្នុងចិត្តឯង គឺជាការ[ល]ដែលឯងបានប្រព្រឹត្តដល់ដាវីឌ
ជាព្រះបិតាយើងហើយ ដូច្នេះ ព្រះយេហូវ៉ានឹងទំលាក់ការ
អាក្រក់របស់ឯងនោះ មកលើក្បាលឯងវិញ ៤៥តែស្ដេច
សាឡូម៉ូននឹងបានពរ ហើយរាជ្យរបស់ដាវីឌ និងបានតាំង
នៅ[វ]ចំពោះព្រះយេហូវ៉ាជាដរាបទៅ ៤៦នោះស្ដេចទ្រង់
បង្គាប់ទៅបេណាយ៉ា[ស]ជាកូនយេហូយ៉ាដា ហើយលោកក៏
ចេញទៅប្រហារជីវិតឱ្យវា[ហ]ស្លាប់ទៅ ឯរាជ្យនោះបាន
តាំង[ឡ]ជាមាំមួន ក្នុងអំណាចសាឡូម៉ូនហើយ។

## ស្ដេចសាឡូម៉ូនទូលសូមប្រាជ្ញា

*៣:៤–១៥ – ២រប ១:២–១៣*

**៣** ១ឯសាឡូម៉ូន ទ្រង់ចងញាតិពន្ធនឹងផារ៉ោន ជាស្ដេច
ស្រុកអេស៊ីព្ទ ដោយយក[ក]បុត្រី[ខ]ផារ៉ោនធ្វើជាភរិយា ហើយ
នាំនាងមកក្នុងក្រុងដាវីឌ[គ] ទាល់តែទ្រង់បានសង់ដំណាក់[ឃ]
របស់ទ្រង់ និងព្រះវិហារនៃព្រះយេហូវ៉ា ព្រមទាំងកំផែង
ជុំវិញក្រុងយេរូសាឡិមរួចជាស្រេច ២នៅគ្រានោះបណ្ដាជន
គេថ្វាយយញ្ញបូជា នៅតែលើទីខ្ពស់ទាំងប៉ុន្មាន[ង] ពីព្រោះមិន
ទាន់បានស្អាងព្រះវិហារណា ថ្វាយដល់ព្រះនាម[ច]ព្រះយេហូ
វ៉ានៅឡើយ ៣រីឯសាឡូម៉ូន ទ្រង់ស្រឡាញ់[ឆ]ដល់ព្រះយេហូវ៉ា
ហើយបានកាន់[ជ]តាមបញ្ញត្តិទាំងប៉ុន្មាន[ឈ] របស់ដាវីឌជាព្រះ
វរបិតាទ្រង់វៀរតែការដែលថ្វាយយញ្ញបូជា និងដុត
កំញាន នៅលើអស់ទាំងទីខ្ពស់ប៉ុណ្ណោះ[ញ]។
៤ស្ដេចសាឡូម៉ូន ទ្រង់ក៏យាងទៅឯគីបៀន[ដ] ដើម្បីថ្វាយ
យញ្ញបូជានៅទីនោះ ពីព្រោះពីខ្ពស់នោះ ជាទីយ៉ាងប្រសើរ
វិសេសជាងគេ ទ្រង់បានថ្វាយដង្វាយដុតអស់១ពាន់ នៅ
លើអាសនានៅទីនោះ ៥ហើយនៅត្រង់គីបៀននោះ ព្រះ
យេហូវ៉ាទ្រង់ក៏លេចមក[ឋ] ឱ្យសាឡូម៉ូនឃើញក្នុងសុបិន
និមិត្ត[ឌ]នៅវេលាយប់ ដោយបន្ទូលថា ចូរសូម[ឍ]អ្វីដែលចង់
ឱ្យអញប្រទានដល់ឯងចុះ ៦នោះសាឡូម៉ូនទ្រង់ទូលឆ្លើយថា
ព្រះអង្គបានសំដែងសេចក្ដីសប្បុរសដ៏ធំដល់បាវបំរើទ្រង់ គឺ
ដាវីឌ ជាព្រះបិតានៃទូលបង្គំ តាមដែលលោកបានប្រព្រឹត្ត
នៅចំពោះទ្រង់ ដោយសេចក្ដីពិត និងសេចក្ដីសុច្ចរិត
ហើយដោយមានចិត្តទៀងត្រង់[ណ]ដល់ទ្រង់ព្រះអង្គក៏បាន
បំរុងទុកសេចក្ដីសប្បុរសដ៏ធំនេះ ឱ្យលោកទៀត គឺបាន
ប្រទានឱ្យលោកមានកូន[ត] សំរាប់អង្គុយលើបល្ល័ង្ករបស់
លោក ដូចជា មានសព្វថ្ងៃនេះ ៧ឥឡូវនេះ ឱព្រះយេហូវ៉ា
ជាព្រះនៃទូលបង្គំអើយ ទ្រង់បានតាំងទូលបង្គំជាបាវបំរើ
ទ្រង់ឡើង ធ្វើជាស្ដេចជំនួសដាវីឌ ព្រះបិតាទូលបង្គំ
តែទូលបង្គំដូចជាក្មេងតូច[ថ] ឥតដឹងជាត្រូវចេញចូលយ៉ាង

**២:៤៤** ល ២សយ ១៦:៥–១៣ **២:៤៥** វ ២សយ ៧:១៣ **២:៤៦** ស ២សយ ៨:១៨ ហ ខ.៨ ឡ ខ.១២ **៣:១** ក ១ពវ ៧:៨ ១១:១–១៣ ខ ១ពវ ៩:២៤ ២រប ៨:១១ គ ២សយ ៥:៧ ១ពវ ២:១០ ឃ ២សយ ៧:២ ១ពវ ៩:១០ **៣:២** ង លវ ១៧:៣–៥ ២៦:៣០ ចទ ១២:១៤ ១ពវ ១៥:១៤ ២២:៤៣ ច ចទ ១៤:២៣ **៣:៣** ឆ ចទ ៦:៥ ទដ ៣១:២៣ ១៤៥:២០ ជ ចទ ១០:១២ យស ១:៧ ឈ ចទ ១៧:១៩ ១ពវ ១៤:៨ ញ ខ.២ លវ ១៧:៣–៥ ២ពវ ១២:៣ ១៥:៤,៣៥ ១៦:៤ ២១:៣ **៣:៤** ដ យស ៩:៣ **៣:៥** ឋ ១ពវ ៩:២ ១១:៩ ឌ មថ ២៧:១៩ ឍ មថ ៧:៧ **៣:៦** ណ លប ១៧:១ ត ១ពវ ១:៤៨ **៣:៧** ថ ជន ២៧:១៧ ១រប ២២:៥ ២៩:១ យរ ១:៦

**២:៤៣** សូមមើល ខ.៣៦ និងការពន្យល់ ។

**២:៤៦** នៅវគ្គនេះស្ដេចសាឡូម៉ូន បានបញ្ជាឱ្យគេសម្លាប់អ័ដូនីយ៉ា យ៉ូអាប់ និង ស៊ីម៉ាយ ហើយអ័បៀថើត្រូវបានគេបណ្ដេញចេញពីតំណែងជាសង្ឃ ហើយ តែងតាំងអ្នកថ្មីជំនួសតំណែងនេះ ។

**៣:១** នៅវគ្គនេះនិយាយពីការរៀបអភិសេធនៅក្នុងរាជ្យវង្សស្ដេច នៅក្នុង បជ្ឈឹមបូព៌ា ពីព្រោះការធ្វើយ៉ាងដូច្នេះនាំឱ្យកើតមានសន្តិភាព ។ ទោះបីការ រៀបអភិសេធរបស់ស្ដេចសាឡូម៉ូនដើម្បីបង្កើតចំណងមិត្តភាពជាមួយនឹង ជាតិសាសន៍ដែលនៅជុំវិញក៏ដោយ ក៏ពួកគេចាប់ផ្ដើមធ្លាក់ចុះដែរ ។ ទំនាក់ ទំនងនេះ បានចូលលុកលុយដោយគំនិតពួកសាសន៍ដទៃ ។ មហេសីបរទេស របស់ស្ដេចសាឡូម៉ូន បាននាំយករូបព្រះចូលក្នុងក្រុងយេរូសាឡិម ហើយ បាននាំឱ្យស្ដេចសាឡូម៉ូនធ្លាក់ក្នុងសេចក្ដីកំផឹត (១១:១–៦) ។

**៣:២,៣** នៅត្រង់នេះបញ្ជាក់ថា ក្រឹត្យវិន័យរបស់ព្រះបានប្រាប់ដល់ពួកគេ ឱ្យថ្វាយដង្វាយរបស់ព្រះនៅទីណា ដែលព្រះបានកំណត់ប៉ុណ្ណោះ (ចទ ១២:១៣,១៤ ) ។ ការនេះ គឺដើម្បីឱ្យពួកគេគេចចេញពីការ បង្កើតនូវវិធី របស់ពួកគេក្នុងការថ្វាយបង្គំ ។ ប៉ុន្តែសាសន៍អ៊ីស្រាអែលជាច្រើន ដែលរួម បញ្ចូលទាំងស្ដេចសាឡូម៉ូន បានថ្វាយដង្វាយដល់ព្រះដែលនៅជុំវិញជើងភ្នំ។ ស្ដេចសាឡូម៉ូនទ្រង់ស្រឡាញ់ព្រះ ប៉ុន្តែទង្វើរបស់ទ្រង់ ធ្វើឱ្យខ្លួនគាត់ធ្លាក់ចូល ក្នុងអំពើបាប ។

**៣:៤** *គីបៀន* ពួកគីបៀននេះ បានបញ្ឆោតឱ្យយ៉ូស្វេ និងពួកអ៊ីស្រាអែល ឱ្យធ្លាក់ចូលក្នុងសេចក្ដីសញ្ញាសន្តិភាព នៅក្នុងរយៈពេលសង្គ្រាមនៅទឹកដី កាណាន (យស ៩:៣–២៧) ។ ទីក្រុងជាបន្តបន្ទាប់ ត្រូវបានផ្ដល់ទៅឱ្យពួក កូនចៅ បេនយ៉ាមីន និងញែកទឹកដីសម្រាប់ពួកលេវី (យស ១៨:២៥ ២១:១៧) ។ ស្ដេចដាវីឌ បានសងសឹកស្ដេចសូលចំពោះការរំលោភដល់ ពួកគីបៀនដោយការចងកពួកកូនចៅរបស់ស្ដេចសូល៧នាក់ (មើល ២សយ ២១:១–៩) ។

**៣:៥** *សុបិននិមិត្ត* ការបើកសំដែងឱ្យឃើញតាមរយៈសុបិន គឺឃើញមាននៅ ក្នុងកន្លែងផ្សេងៗទៀតនៅក្នុងសញ្ញាចាស់(មើល លប ២៨:១២ ៣១:១១ ៤៦:២ ជន ១២:៦ ពច ៧:១៣ ដយ ២:៤ ៧:១) ហើយមាននៅក្នុងសញ្ញាថ្មី (មថ ១:២០ ២:១២,២២) ។

**៣:៦** *សេចក្ដីសប្បុរស* ភាសាហេព្រើរពាក្យនេះសំដៅលើ សេចក្ដីសញ្ញា អនុគ្រោះរបស់ព្រះ (មើលការពន្យល់ ២សយ ៧:១៥ ទដ ៦:៤) ។ ស្ដេច សាឡូម៉ូនបានសរសើរដល់ព្រះអម្ចាស់សម្រាប់ការសម្រេច នូវសេចក្ដីសន្យា របស់ទ្រង់ចំពោះស្ដេចដាវីឌ (៧:៨–១៦) ។

**៣:៧** *ទូលបង្គំដូចជាក្មេងតូច* ការប្រសូតរបស់ស្ដេចសាឡូម៉ូន ប្រហែលជា នៅក្នុងរជ្ជកាលនៃការសោយរាជ្យរបស់ស្ដេចដាវីឌដែលទ្រង់មានព្រះជន្ម ៤០វស្សានៅឡើយ ដូច្នេះមានន័យថា ស្ដេចសាឡូម៉ូននេះ មានព្រះជន្ម២០ វស្សានៃការចាប់ផ្ដើមគ្រងរាជរបស់ទ្រង់ (មើល ២:១១–១២) ហើយទ្រង់ ពុំទាន់មានបទពិសោធន៍នៅក្នុងការងាររបស់ទ្រង់នៅឡើយ(ធៀប ១:៦) ។

ណាឡើយ ៨ទូលបង្គំ ជាបាវបំរើទ្រង់ នៅកណ្តាលប្រជាជន
ដែលទ្រង់បានជ្រើសរើស[ទ] ជាសាសន៍១ធំ មានគ្នាច្រើន
ហួសកំណត់នឹងរាប់បាន[ធ] ៩ដូច្នេះ សូមទ្រង់ប្រទានឱ្យទូល
បង្គំ ជាបាវបំរើទ្រង់ មានចិត្តប្រកបដោយប្រាជ្ញា[ន] ដើម្បី
នឹងគ្រប់គ្រងលើរាស្ត្រទ្រង់ ប្រយោជន៍ឱ្យទូលបង្គំបាន
ពិចារណា[ប]ដឹងខុសត្រូវ ដ្បិតតើមានអ្នកណាអាច[ផ]នឹងគ្រប់
គ្រងលើរាស្ត្រទ្រង់ ដែលមានគ្នាច្រើនទាំងនេះបាន ។
១០ព្រះអម្ចាស់ ទ្រង់ក៏សព្វព្រះហឫទ័យចំពោះសេចក្តី
ដែលសាឡូម៉ូនបានសូមនោះ ១១ហើយទ្រង់មានបន្ទូលតប
ថា ដោយព្រោះឯងបានសូម[ព]សេចក្តីនេះ គឺមិនបានសូមឱ្យ
បានអាយុវែង ឬឱ្យបានទ្រព្យសម្បត្តិ ឬឱ្យបានយកជីវិតនៃ
ពួកខ្មាំងសត្រូវឯង គឺបានសូមឱ្យមានយោបល់[ភ] សំរាប់នឹង
យល់សេចក្តីយុត្តិធម៌វិញ ១២ដូច្នេះ អញបានធ្វើតាមពាក្យ
ឯងហើយ[ម] មើល អញបានឱ្យឯងមានចិត្តប្រកបដោយ
ប្រាជ្ញា[យ] និងយោបល់ ដល់ម្ល៉េះបានជាមុនឯងឥតមានអ្នក
ណាមួយកើតឡើងឱ្យដូចឯងដែរ ១៣អញក៏បានឱ្យសេចក្តី
ដែលឯងមិនបានសូមផង[រ] គឺទាំងទ្រព្យសម្បត្តិនឹងកេរ្តិ៍
ឈ្មោះ[ល] ដល់ម្ល៉េះបានជាក្នុងពួកស្តេចទាំងប៉ុន្មាន និងគ្មាន
អ្នកណាមួយដូច[វ]ឯង ដរាបដល់គ្រប់១ជីវិតឯងឡើយ ១៤បើ
សិនជាឯងប្រព្រឹត្ត[ស] តាមអស់ទាំងផ្លូវរបស់អញដើម្បីនឹង
កាន់តាមបញ្ញត្តិ និងក្រិត្យក្រមអញទាំងប៉ុន្មាន ដូចជាដាវីឌ
ជាឪពុកឯងបានប្រព្រឹត្ត នោះអញនឹងចំរើនអាយុឯង
ឱ្យបានវែងថែមទៀតដែរ[ហ] ១៥រួចសាឡូម៉ូនក៏តើនឡើង[ឡ]
ហើយមើល នោះជាសុបិននិមិត្តទេ[អ] ដូច្នេះទ្រង់យាង
ត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ ក៏ឈរនៅចំពោះហឹប
នៃសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា ហើយថ្វាយដង្វាយដុត[ក]
និងដង្វាយមេត្រី[ខ] រួចក៏ជប់លៀង[គ]បណ្តាពួកអ្នករាជការ
របស់ទ្រង់គ្រប់គ្នា ។

**ការដឹកនាំប្រកបដោយគតិបណ្ឌិត**

១៦ក្រោយតមក មានស្រីសំផឹង២នាក់បានមកឈរនៅ
ចំពោះស្តេច ១៧នាង១ទូលថា បពិត្រព្រះអម្ចាស់អើយ ខ្ញុំ
ម្ចាស់នឹងស្ត្រីនេះនៅផ្ទះជាមួយគ្នា យើងខ្ញុំទាំង២បាន
សំរាលកូននៅផ្ទះនោះ ១៨កាលខ្ញុំម្ចាស់ សំរាលកូនមកបាន
៣ថ្ងៃ នោះស្ត្រីនេះក៏សំរាលមកដែរ យើងខ្ញុំទាំង២នៅជា
មួយគ្នា ឥតមានអ្នកដទៃណានៅក្នុងផ្ទះនោះឡើយ មានតែ
យើងខ្ញុំ២នាក់ប៉ុណ្ណោះ ១៩ចួនជានៅវេលាយប់១កូនរបស់
នាងនេះបានស្លាប់ទៅ ដោយម្តាយបានដេកសង្កិនលើ
២០ដល់ពាក់កណ្តាលអធ្រាត្រ កាលខ្ញុំម្ចាស់ ជាបាវបំរើទ្រង់
កំពុងតែទទួលទានដំណេកលក់ នោះនាងក្រោកឡើងយក
កូនខ្ញុំម្ចាស់ពីខាងខ្ញុំម្ចាស់ទៅបី ហើយដាក់កូនស្លាប់របស់
នាងនែបនៅទ្រូងខ្ញុំម្ចាស់វិញ ២១លុះព្រឹកឡើង កាលខ្ញុំម្ចាស់
ក្រោកឡើងនឹងបំបៅកូន នោះមើល វាបានស្លាប់ហើយ
ប៉ុន្តែដល់ភ្លឺឡើង នោះខ្ញុំម្ចាស់បានពិនិត្យមើលទៅឃើញ ថា
មិនមែនជាកូនដែលខ្ញុំម្ចាស់បង្កើតទេ ២២ស្ត្រី១ទៀតនោះក៏
ឆ្លើយកាត់ទៅថា ទេមិនមែនដូច្នោះទេ គឺកូនដែលរស់នៅ
នោះជាកូនរបស់អញ ហើយកូនដែលស្លាប់ទៅជាកូនរបស់
ឯងវិញ តែស្រីនេះប្រកែកថា មិនមែនឡើង គឺកូនដែល
ស្លាប់ជាកូនរបស់ឯង ហើយកូនដែលរស់នៅនេះ ជាកូន
របស់អញវិញ ស្ត្រីទាំង២ដបានជជែកគ្នាយ៉ាងនោះ នៅ
ចំពោះស្តេច ។
២៣ឯស្តេចទ្រង់មានបន្ទូលថា នាង១ថា កូនរស់នេះ ជា

**៣:៨** ទ ចទ ៧:៦ ធ លប ១២:២ ១៥:៥ ១រប ២៧:២៣
**៣:៩** ន ២សយ ១៤:១៧ យក ១:៥ ប ចទ ១:១៦ ផ ២កថ ២:១៦
**៣:១១** ព យក ៤:៣ ភ ១រប ២២:១២
**៣:១២** ម ១យហ ៥:១៤–១៥ យ ២សយ ១៤:២០ ១ពវ ៤:២៩,៣០,៣១ ៥:១២ ១០:២៣ សស ១:១៦
**៣:១៣** រ មថ ៦:៣៣ អភ ៣:២០ ល សភ ៣:១–២,១៦ ៨:១៨ វ ១ពវ ១០:២៣ ២រប ៩:២២ នហ ១៣:២៦
**៣:១៤** ស ១ពវ ៩:៤ ទដ ២៥:១៣ ១០១:២ ១២៨:១ សភ ៣:១–២,១៦ ហ ទដ ៦១:៦
**៣:១៥** ឡ លប ២៨:១៦ អ ខ.៥ ក លវ ៦:៨–១៣ ខ លវ ៧:១១–២១
គ នអ ១:៣,៩ ២:១៨ ៥:៨ ៦:១៤ ៩:១៧ ដយ ៥:១

**៣:៨** *គ្នាច្រើនហួសកំណត់នឹងរាប់បាន* ចំនួននេះចាប់ផ្តើមឡើងដោយតិចតួច តែគ្រួសារមួយរស់នៅក្នុងប្រទេសអេស៊ីព្ទ(មើល លប ៤៦:២៦–២៧ ចទ ៧:៧) ពួកអ៊ីស្រាអែល បានកើនឡើងយ៉ាងឆាប់រហ័ស (លប ១៣:១៦ ២២:១៧–១៨) និងកូនចៅយ៉ាកុប(លប ៣២:១២) និងមើលបន្ថែម ៤:២០ និងការពន្យល់ ។

**៣:៩** *ពិចារណាដឹងខុសត្រូវ* ឃ្លានេះបញ្ជាក់ថាមានសមត្ថភាពស្តាប់ដោយអត់ធ្មត់គ្រប់បញ្ហា ដើម្បីទទួលបានសេចក្តីពិត និងប្រាជ្ញាក្នុងការសម្រេចចិត្តជាស្តេចល្អ (ធៀប ១សយ ១១:២–៥) ។

**៣:១១** *អាយុវែង . . . ទ្រព្យសម្បត្តិ . . . ជីវិតនៃពួកខ្មាំងសត្រូវ* ជាតួយ៉ាងចំពោះសេចក្តីប៉ងប្រាថ្នានេះ គឺសម្រាប់ព្រះមហាក្សត្រនៅសម័យបុរាណដែលនៅជិតអេសស្ទើន ។

**៣:១២** *ឥតមានអ្នកណាឱ្យដូចឯង* សូមមើល ២:២៩–៣៤ ១០:១–១៣ ។

**៣:១៣** *អញក៏បានឱ្យសេចក្តីដែលឯងមិនបានសូមផង* សូមធៀបនឹង សេចក្តីសន្យារបស់ព្រះយេស៊ូវមាន លក ១២:៣១ ។

**៣:១៤** *បើសិនជាឯងប្រព្រឹត្តតាមអស់ទាំងផ្លូវរបស់អញ . . . អញនឹងចំរើនអាយុ* នេះជាពាក្យបន្ទុដែលមាននៅក្នុង ចទ ៦:២ ១៧:២០ ២២:៧ ។ ជាអកុសលស្តេចសាឡូម៉ូន មិនបានធ្វើតាមសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា ដូចស្តេចដាវីឌជាបិតានោះឡើយ (១១:៦) ហើយស្តេចអង្គនេះមិនមានព្រះជន្មគង់នៅលើល៦០វស្សាឡើយ (ការពន្យល់ ខ.៧ ធៀប ១១:៤២) ។

**៣:១៥** *ហឹបនៃសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា* មើលការពន្យល់ ៦:១៩ ២សយ ៦:២ ។ *ដង្វាយមេត្រី* មើលការពន្យល់ ១សយ ១១:១៥ ។

**៣:១៦** *ស្រីសំផឹង២នាក់បានមកឈរនៅចំពោះស្តេច* ការនេះពួកអ៊ីស្រាអែល អាចធ្វើរំលងចំពោះមន្ត្រីដែលគ្មានភាពយុត្តធម៌ ហើយពួកគេអំពាវនាវដល់ព្រះមហាក្សត្រផ្ទាល់ (មើល ២ពវ ៨:៣ ២សយ ១៥:២) ។

**៣:១៧** *នៅផ្ទះជាមួយគ្នា* ផ្ទះស្រីសំផឹងនេះ ត្រូវបានគេលើកឡើងនៅមជ្ឈឹមបូព៌ាបូរាណ ។

កូនរបស់អញ ហើយកូនស្លាប់ ជាកូនរបស់ឯង ហើយ១ទៀត
ថា មិនមែនដូច្នោះទេ គឺកូនស្លាប់ជារបស់ឯង ហើយកូនរស់
ជារបស់អញវិញ [២៤]រួចស្តេចទ្រង់បង្គាប់ថា ចូរយកដាវ១
មកណេះ នោះគេក៏យកដាវ១មក នៅចំពោះស្តេច [២៥]ទ្រង់
មានបន្ទូលថា ចូរកាប់កូនដែលនៅរស់នោះ ជា២ភាគទៅ
ចែក១ចំហៀងឱ្យដល់ស្ត្រីនេះ ហើយ១ចំហៀងទៀតដល់
ដល់ស្ត្រីនោះ [២៦]ដូច្នេះ ស្ត្រីដែលជាម្តាយនៃកូនដែលរស់ក៏
ទូលដល់ស្តេច ដោយមានចិត្តអាណិតអាល័យ[ឃ]ដល់កូនខ្លួន
ថា ឱព្រះអម្ចាស់នៃខ្ញុំ ម្ចាស់អើយ សូមប្រទានកូនរស់ទៅគេ
ចុះ សូមកុំឱ្យតែសំឡាប់ឡើយ តែស្ត្រី១នោះថា កូននេះមិន
ត្រូវបានជារបស់ឯងឬរបស់អញឡើយ ត្រូវពុះជា២ទៅ
[២៧]ដូច្នេះ ស្តេចទ្រង់ក៏មានបន្ទូលឆ្លើយឡើងថា ចូរឱ្យកូន
រស់នោះទៅនាងដើមចុះ កុំសំឡាប់វាឡើយ ដ្បិតនាងនោះ
ជាម្តាយពិត [២៨]ឯជនជាតិអ៊ីស្រាអែលទាំងអស់គ្នា ក៏ឮពីបែប
ដែលស្តេចវិនិច្ឆ័យរឿងនោះ ហើយគេមានចិត្តកោតខ្លាច
ដល់ទ្រង់ដោយយល់ឃើញថា ប្រាជ្ញា[ង]នៃព្រះបានសណ្ឋិត
នៅក្នុងទ្រង់ សំរាប់នឹងសំរេចសេចក្តីយុត្តិ ធម៌។

## ពួកមន្ត្រី និងពួកអភិបាលរបស់ស្តេចសាឡូម៉ូន

**៤** [១]រីឯសាឡូម៉ូន ទ្រង់ជាស្តេចលើសាសន៍អ៊ីស្រាអែលទាំង
អស់គ្នា [២]ហើយទ្រង់មានពួកអ្នកដែលជាប្រធាន[ក] ដូចកត់
ទុកនេះ គឺអ័សារា[ខ] កូនសាដុក លោកជាសំដេចសង្ឃ
[៣]អេលីហូរែប នឹងអ័ហ៊ីយ៉ា កូនស៊ីសា ជាស្មៀនហ្លួង[គ]
យេហូសាផាត[ឃ] កូនអ័ហ៊ីលូឌ ជាអ្នកតែងពង្សាវតារ
[៤]បេណាយ៉ា[ង] កូនយេហូយ៉ាដា ជាមេទ័ព សាដុក[ច] និង
អ័បៀថើរ ជាសង្ឃ [៥]អ័សារា កូនណាថាន់ ជាចាងហ្វាងលើ
ពួកសេនាបតី សាប៊ុត កូនណាថាន់ ជារដ្ឋនាយក ហើយជា
មិត្រសំឡាញ់នឹងស្តេច [៦]អ័ហ៊ីសា ជាឧកញ៉ាវាំង[ឆ] អ័ដូនីរ៉ាម[ជ]
កូនអាប់ដា ជាមេកំណែន[ឈ]។
[៧]សាឡូម៉ូនទ្រង់ក៏មាននាយក១២នាក់[ញ] ត្រួតលើពួក
អ៊ីស្រាអែលទាំងអស់ ជាអ្នកសំរាប់ផ្គត់ផ្គង់ស្បៀងអាហារ
ថ្វាយស្តេច និងពួកដំណាក់ទ្រង់ ម្នាក់ៗត្រូវផ្គត់ផ្គង់ស្បៀង
អាហារអស់១ខែក្នុង១ឆ្នាំ [៨]ឯឈ្មោះនៃលោកទាំងនោះ
ដូចមាននៅខាងក្រោមនេះ គឺបេន-ហើរ នៅស្រុកភ្នំ[ដ]
អេប្រាអិម១ [៩]បេន-ដេកើរ នៅស្រុកម៉ាកាស ស្រុកស្អាល
ប៊ីម[ឋ] ស្រុកបេត-សេមែស[ឌ] និងស្រុកហេឡូន-បេត-
ហាណាន១ [១០]បេន-ហេសេឌ នៅស្រុកអារូបូត១ ឯស្រុក
សូកូរ[ឍ] និងស្រុកអេភើរ[ណ]ទាំងមូល ក៏នៅក្រោមអំណាច

**៣:២៦** ឃ ទដ ១០២:១៣ អស ៤៩:១៥ ៦៣:១៥ យរ ៣:១២ ៣១:២០ ហស ១១:៨
**៣:២៨** ង ២សយ ១៤:២០ កល ២:៣
**៤:២** ក ១ពវ ១២:៦ យប ១២:១២ ខ ១រប ៦:១០ ២រប ២៦:១៧
**៤:៣** គ ២សយ ៨:១៧ ឃ ២សយ ៨:១៦
**៤:៤** ង ២សយ ៨:១៨ ច ២សយ ៨:១៧
**៤:៦** ឆ លប ៤១:៤០ ជ ២សយ ២០:២៤ ឈ លប ៤៩:១៥
**៤:៧** ញ ខ.២៧
**៤:៨** ដ យស ២៤:៣៣
**៤:៩** ឋ ពច ១:៣៥ ស ១៥:១០
**៤:១០** ឍ យស ១៥:៣៥ ណ យស ១២:១៧

**៣:២៥** *កាប់កូនដែលនៅរស់នោះជាពីរភាគ* ព្រះរាជបញ្ហានេះស្តេចសាឡូម៉ូន នោះទ្រង់បានដោះស្រាយវិវាតនេះដោយការដោះប្រស្នា និងការផ្សះផ្សាទំនាស់របស់ពួកគេ ។ អ្នកនិពន្ធបានរៀបរាប់ពីភាពល្ញីល្ញើរបស់ស្តេចសាឡូម៉ូននៅក្រោយមកទៀត ដែលទ្រង់បានកាត់ទឹកដីជាពីរភាគ ដែលមួយផ្នែកឱ្យដល់កូនចៅស្តេចសាឡូម៉ូន និងមួយផ្នែកទៀត ឱ្យដល់យេរ៉ូបោម (មើល ១១:៩-១៣) ។ តាមទំនាយអក្សសាស្ត្រអាណាចក្រទាំងពីរនេះត្រូវបានគេធៀបនឹងស្រីសំផឹង (មើល ខ.១៦ មើលបន្ថែម យរ ៣:៦-១២ អគ ១៦:១៥-៤៦ ២៣:៣-៥ ហស ១:២ និងការពន្យល់) ។

**៣:២៨** *យល់ឃើញថា ប្រាជ្ញានៃព្រះបានសណ្ឋិតនៅក្នុងទ្រង់* ឃ្លានេះបានប្រាប់ពីការបង្ហាញដ៏ងាយៗ ថាព្រះអម្ចាស់បានឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ស្តេចសាឡូម៉ូនចំពោះការយល់ដឹងរបស់ទ្រង់ (សូមមើល ខ.៩,១២) ។

**៤:១** *លើសាសន៍អ៊ីស្រាអែលទាំងអស់គ្នា* នៅត្រង់នេះបញ្ជាក់ថា ស្តេចសាឡូម៉ូនទ្រង់បានដឹកនាំពួកដែលមិនទាន់បានបែងចែកទឹកដី ដូចដែលព្រះបិតាទ្រង់បានធ្វើមកដែរ (មើល ២ សយ ៨:១៥) ។

**៤:២** *កូន* នៅត្រង់នេះដោយយោលទៅលើការពន្យល់ ១៥:២៧,៣៦ និង ១រប ៦:៨-៩ អ័សារា ជាកូនរបស់អ័ហ៊ីម៉ាស ហើយត្រូវជាចៅរបស់សាដុក (មើលការពន្យល់ ២:៨) ។ ប៉ុន្តែជាការពិត អ័ហ៊ីម៉ាសកូនសាដុកបានស្លាប់រួចទៅហើយ ដូច្នេះ កូនរបស់សាដុកជាប់តមកគឺអ័សារា ។ *សាដុក* មើលការពន្យល់ ២:២៧,៣៥ ។

**៤:៣** *ស៊ីសា* មើលការពន្យល់ ២សយ ៨:១៧ ។ *ស្មៀន* មើលការពន្យល់ ២សយ ៨:១៧ ។ *ហេហូសាផាត កូនអ័ហ៊ីលូឌ* ម្នាក់នេះដូចនឹងអ្នកដែលធ្វើការនៅសាជីនុំរបស់ស្តេចដាវីឌ (២សយ ៨:១៦) ។ *អ្នកតែងពង្សាវតា* មើល ការពន្យល់ ២សយ ៨:១៦ ។

**៤:៤** *បេណាយ៉ា* ម្នាក់នេះបានជំនួសមុខនាទីរបស់លោកយ៉ូអាប់ដែលជាមេបញ្ជាការកងទ័ព(មើល ២:៣៥ ២សយ ៨:១៨) ។ *សាដុក និងអ័បៀថើរ* លោកអ័បៀថើរនេះ ត្រូវបានគេនិរទេសខ្លួនចេញពីប្រទេស នៅចាប់តាំងពីការចាប់ផ្តើមរាជ្យរបស់ស្តេចសាឡូម៉ូន(២:២៧,៣៥) ហើយគាត់មានកូនឈ្មោះអ័សារាជាអ្នកបន្តវេនរបស់លោក (ខ.២) ។

**៤:៥** *ណាថាន់* នេះសំដៅលើហោរានៅក្នុង (១:១១) និងបុត្រស្តេចដាវីឌ (២សយ ៥:១៤) ។

**៤:៦** *ឧកញ៉ាវាំង* ពាក្យនេះញឹកញាប់ឃើញ មាននៅក្នុង ១ និង២ នៃព្រះគម្ពីរពង្សាវតាក្សត្រ(១ពវ ១៦:៩ ១៨:៣ ២ពវ ១៨:១៨,៣៧ ១៩:២) ។ ពាក្យនេះទំនងជាសំគាល់ពីមន្ត្រីដែលគ្រប់គ្រងទ្រព្យសម្បត្តិរបស់ស្តេច ។ *អ័ដូនីរ៉ាម* ម្នាក់នេះ មិនគ្រាន់តែជាអ្នកបម្រើនៅក្រោមបង្គាប់របស់ស្តេចសាឡូម៉ូន តែក៏ជាអ្នកបម្រើរបស់ស្តេចដាវីឌផងដែរ (២០:២៤) ហើយរេហោបោមជាអ្នកបម្រើក្រោយពីអ័ដូនីរ៉ាមនេះ (១ពវ ១២:១៨) ។ *មេកំណែន* មើលការពន្យល់ ៩:១៥ ២សយ ២០:២៤ ។

**៤:៧** *សាឡូម៉ូន . . . មាននាយក១២នាក់* នៅត្រង់នេះបញ្ជាក់ថា ទឹកដីទាំង ១២ស្រុករបស់ពូជអំបូរ មិនមានលក្ខណៈដូគ្នាទេ ពីព្រោះតែពួកកុលសម្ព័ន្ធទាំងនោះបានផលិតនូវកសិផលផ្សេងៗគ្នា ។

**៤:៨** *បេន-ហើរ* ភាសាហេព្រើរមានន័យថា"កូននរណាម្នាក់" ។

លោកដែរ) ១១បេន-អ័ប៊ីណាដាប់ នៅស្រុកដោរ[ត]ទាំង
មូល១ (លោកនោះបានយកនាងថាផាត ជាបុត្រី សាឡូម៉ូន
ធ្វើជាប្រពន្ធ) ១២បាណា ជាកូនអ័ហ៊ីលូឌ១ លោកនោះត្រួត
លើស្រុកតាណាក ស្រុកមេគីដោ ហើយគ្រប់ស្រុកបេត-
សៀន[ថ] ដែលនៅជិតសារថាន[ទ] ខាងក្រោមក្រុងយេសរាល
ចាប់តាំងពីបេត-សៀន រហូតដល់អេបិល-មហូឡា[ធ] ខាង
នាយយ៉ុកមាម[ន] ១៣បេន-កេប៊ើរនៅ រ៉ាម៉ូត-កាឡាត១
លោកនោះត្រួតលើអស់ទាំងភូមិរបស់យ៉ាអ៊ារ[ប] ជាកូន
ម៉ាន៉ាសេ ដែលនៅស្រុកកាឡាត[ផ] ហើយលើស្រុកនៅ
ជុំវិញអើកុប ដែលនៅស្រុកបាសាន ទាំងអស់មានទីក្រុង
យ៉ាងធំ៦០[ព] ដែលមានកំផែង ហើយនិងរនុកលង្ហិន)
១៤អ័ហ៊ីណាដាប់ ជាកូនអ៊ីដោ នៅស្រុកម៉ាហាណែម១[ភ]
១៥អ័ហ៊ីម៉ាស[ម] នៅខែត្រណែបថាលី១ (លោកនោះបានយក
នាងបាសម៉ាត ជាបុត្រីសាឡូម៉ូនធ្វើជាប្រពន្ធ) ១៦បាណា
ជាកូនហ៊ូសាយ[យ] នៅខែត្រអេសើរ និងស្រុកអាឡូត១
១៧យេហូសាផាត ជាកូនផារូអា នៅខែត្រអ៊ីសាខារ១
១៨ស៊ីម៉ាយ[រ] ជាកូនអេឡា នៅខែត្រ បេនយ៉ាមីន១ ១៩កេប៊ើរ
ជាកូនអ៊ូរី១ ដែលនៅស្រុកកាឡាត ជាស្រុក របស់ស៊ីហុន[ល]
ស្តេចសាសន៍អាម៉ូរី និងស្រុករបស់អុក[វ] ជាស្តេចបាសាន
លោកនោះជានាយកតែ១នៅក្នុងស្រុកនោះ ។

## ស្បៀងអាហារដែលចាត់ចែងសំរាប់ព្រះរាជវាំង ស្តេចសាឡូម៉ូនប្រចាំថ្ងៃ

២០ឯពួកយូដា និងពួកអ៊ីស្រាអែល គេមានគ្នាសន្ធឹកដូចជា
ខ្សាច់[ស] ដែលនៅមាត់សមុទ្រ ក៏តែងតែបរិភោគហើយ
លេងសប្បាយ[ហ] ២១ចំណែកសាឡូម៉ូនទ្រង់សោយរាជ្យ[ឡ]លើ
អស់ទាំងនគរ ចាប់តាំងពីទន្លេអ៊ើប្រាត[អ] រហូតដល់ស្រុក
ភីលីស្ទីន ហើយទៅដល់ព្រំស្រុកអេស៊ីព្ទទៀត[ក] នគរទាំង
នោះ ក៏នាំយកសួយអាករ[ខ]មកថ្វាយសាឡូម៉ូន ព្រមទាំង
គោរពដល់ទ្រង់រហូតដល់អស់ព្រះជន្ម ២២ឯស្បៀងអាហារ
ដែលចាត់ចែងសំរាប់ព្រះរាជវាំងក្នុង១ថ្ងៃ[គ] នោះគឺជាម្សៅ
យ៉ាងម៉ដ្ត៣០រង្វាល់ម្សៅធម្មតា៦០រង្វាល់ ២៣គោយ៉ាងធាត់
១០គោដែលរកស៊ីនៅវាល២០ ចៀម១០០ ព្រមទាំងប្រើស
ឈ្លូស ក្តាន់ និងសត្វស្លាបធាត់ៗផង[ឃ] ២៤ដ្បិតទ្រង់មាន
អំណាចលើគ្រប់ទាំងអស់ នៅខាងអាយទន្លេចាប់តាំងពី
ក្រុងធីពសា[ង] រហូតដល់ក្រុងកាសា ហើយលើអស់ទាំងស្តេច
នៅខាងអាយទន្លេដែរ ក៏មានសេចក្តីសុខ[ច]នៅគ្រប់ទិស
ជុំវិញ ២៥ពួកយូដា និងពួកអ៊ីស្រាអែលគេនៅដោយសុខ
សាន្តត្រាណ[ឆ] គ្រប់គ្នានៅក្រោម ទ្រើងទំពាំងបាយជូរ
ហើយក្រោមដើមល្វារបស់ខ្លួន[ជ] ចាប់តាំងពីក្រុងដាន់រហូត
ដល់បៀរ-សេបា[ឈ] ដរាបដល់អស់ព្រះជន្មនៃសាឡូម៉ូន
២៦ទ្រង់ក៏មានរោងសំរាប់សេះ៤ម៉ឺន[ញ] ដែលទឹមរទេះចំបាំង
ហើយមានពលសេះ ១ម៉ឺន២ពាន់នាក់ ២៧ឯពួកនាយកទាំង
នោះ[ដ] គេផ្គត់ផ្គង់ស្បៀងអាហារ សំរាប់ស្តេចសាឡូម៉ូន និង
អស់ពួកអ្នកដែលចូលមកបរិភោគ នៅតុរបស់ទ្រង់គ្រប់
គ្នាបានផ្គត់ផ្គង់តាមកំណត់ខែរបស់ខ្លួនឥតមានខ្វះអ្វីឡើយ
២៨បណ្តាមនុស្សទាំងប៉ុន្មាន ក៏ដឹកស្រូវឱក និងចំបើងសំរាប់
សេះ និងសត្វជិនិះផ្សេងៗ មកដល់កន្លែងដែលពួកនាយក

**៤:១១** ត យស ១១:២ **៤:១២** ថ យស ១៧:១១ ទ យស ៣:១៦ ធ ពច ៧:២២ ន ១របា ៦:៦៨ **៤:១៣** ប ជន ៣២:៤១ ផ ជន ៣២:៤០ ព ចទ ៣:៤ **៤:១៤** ភ យស ១៣:២៦ **៤:១៥** ម ២សយ ១៥:២៧ **៤:១៦** យ ២សយ ១៥:៣២ **៤:១៨** រ ១ពវ ១:៨ **៤:១៩** ល យស ១២:២ វ ចទ ៣:៨-១០ យស ១២:៤ **៤:២០** ស លប ១២:២ ៣២:១២ ហ ១របា ២២:៩ **៤:២១** ឡ ២របា ៩:២៦ អរ ៤:២០ ទដ ៧២:១១ បទ ១:១ អ លប ២:១៤ ទដ ៧២:៨ ក នក ២៣:៣១ ខ ពច ៣:១៥ អគ ១៦:១៣ **៤:២២** គ ១ពវ១០:៥ **៤:២៣** ឃ នហ ៥:១៨

**៤:២៤** ង ២ពវ ១៥:១៦ ច យក ១៤:១៥ **៤:២៥** ឆ ចទ ៨:៨ ២ពវ ១៨:៣១ ទដ ១០៥:៣៣ អស ៣៦:១៦ យរ ៥:១៧ យអ ២:២២ មីក ៤:៤ សក ៣:១០ ជ ១របា ២២:៩ យរ ២៣:៦ អគ ២៨:២៦ ឈ ពច ២០:១ **៤:២៦** ញ ចទ ១៧:១៦ **៤:២៧** ដ ខ.៧

**៤:១១** *បេន-អ័ប៊ីណាដាប់* ម្នាក់នេះ ជាកូនរបស់បងស្តេចដាវីឌ (សូមមើល ១សយ ១៦:៨ ១៧:១៣) ដូច្នេះគាត់ត្រូវជាបងប្អូនជីដូន១នឹងស្តេចសាឡូម៉ូន (ហើយគាត់ជា កូនប្រសារបស់ស្តេចសាឡូម៉ូនផងដែរ ) ។

**៤:១២** *បាណា ជាកូនអ័ហ៊ីណាដាប់* ម្នាក់នេះជាកូនយេហូសាផាត ដូចមាននៅកត់ត្រានៅក្នុង(ខ.៣) ។

**៤:១៦** *បាណា ជាកូនហ៊ូសាយ* ម្នាក់នេះប្រហែលជាអ្នកទីប្រឹក្សារបស់បុត្រស្តេចដាវីឌ(មើល ២សយ ១៥:៣២,៣៧) ។

**៤:១៨** *ស៊ីម៉ាយ ជាកូនអេឡា* ស៊ីម៉ាយនេះប្រហែលជាបានលើកឡើងនៅក្នុង ១:៨ ។

**៤:២០** *មានគ្នាសន្ធឹក ដូចជាខ្សាច់នៅមាត់សមុទ្រ* មើល ៣:៨ និងការពន្យល់មើលបន្ថែម ខ.២៩ លប ២២:១៧ ២សយ ១៧:១១ ១សយ ១០:២២ យរ ៣៣:២២ ហស ១:១០ ធៀប លប ៤១:៤៩ យស ១១:៤ ពច ៧:១២ ទដ ៧៨:២៧ ។ *តែងតែបរិភោគ លេងសប្បាយ* ការនេះសំដៅលើលោកយូដា និងពួកអ៊ីស្រាអែលទទួលបានជោគជ័យគ្រប់ការ (៥:៤) ។

**៤:២១** *ទន្លេអ៊ើប្រាត រហូតដល់ស្រុកភីលីស្ទីន ទៅដល់ព្រំប្រទល់ស្រុកអេស៊ីព្ទ* ទោះបីការរំលោភបំពាន បានធ្វើឱ្យអ្នកស្រុកអេដំម(១១:១៤-២១) និងស្រុកដាម៉ាស(១១:២៣-២៥)មានការភ័យខ្លាចក៏ដោយ ក៏បានប្រាប់ពីព្រំប្រទល់របស់ចក្រភពសាឡូម៉ូន បានពង្រីកទៅដល់ទឹកដីដើមកំណើតលោកអ័ប្រាហាំ (មើល ២សយ ៨:៣) ។ *នាំយកសួយអាករ* ចាប់តាំងពីការចាប់ផ្តើមរាជ្យរបស់ស្តេចសាឡូម៉ូន ទ្រង់មានព្រះទ័យរីករាយ ចំពោះការចុះចូលរបស់រាស្ត្រនៃស្តេចដាវីឌ(ធៀបការពន្យល់ ទដ ២:១-៣) ។

**៤:២២** *ស្បៀងអាហារ* នេះសំដៅលើព្រះរាជទ្រព្យរបស់ទ្រង់ បានផ្គត់ផ្គង់ដល់គ្រប់មន្ត្រីជាន់ថ្នាក់ និងដល់ក្រុមគ្រួសារនៃពួកគេនីមួយៗផងដែរ ។

**៤:២៤** *ក្រុងធីពសា* ក្រុងនេះស្ថិតនៅខាងលិចនៃទន្លេអ៊ើប្រាត ។ *ក្រុងកាសា* ក្រុងនេះស្ថិតនៅភាគខាងលិចបំផុត នៃក្រុងភីលីស្ទី សមុទ្រមេឌីទែរ៉ាណេ ។

**៤:២៥** *ចាប់តាំងពីក្រុងដាន់ រហូតដល់បៀរ-សេបា* សូមមើលការពន្យល់ ១សយ ៣:២០ ។

**៤:២៧** *ពួកនាយក* មើល ខ.៧ ។

ទាំងនោះ តាំងនៅតាមដែលលោកបង្គាប់រៀងខ្លួន ។

## ប្រាជ្ញានៃស្តេចសាឡូម៉ូន

២៩ ព្រះទ្រង់បានប្រទានឱ្យសាឡូម៉ូនមានប្រាជ្ញា[ឋ] និង
យោបល់ច្រើនក្រៃលែង ព្រមទាំងព្រះហឫទ័យធំទូលាយ
ដូចជាបណ្តាខ្សាច់[ឌ]ដែលនៅមាត់សមុទ្រ ៣០ ប្រាជ្ញារបស់
សាឡូម៉ូនក៏លើសហួសជាងប្រាជ្ញារបស់ អស់ទាំងពួកស្រុក
ខាងកើត[ឍ] ហើយនិងអស់ទាំងប្រាជ្ញារបស់ស្រុកអេស៊ីព្ទ
ផង[ណ] ៣១ ដ្បិតទ្រង់មានប្រាជ្ញា លើសជាង[ត]មនុស្សទាំងអស់ គឺ
លើសជាងអេថាន ជាពូជសេរ៉ាគីត ហើយលើសជាង
ហេម៉ាន កាល់កូល និងដារដា ជាកូនទាំង៣របស់ម៉ាហូល
ទៅទៀត កិត្តិនាមរបស់ទ្រង់ ក៏ឮសុសសាយទូទៅក្នុងគ្រប់
ទាំងនគរនៅជុំវិញ ៣២ ទ្រង់បាននិពន្ធពាក្យសុភាសិត[ថ]៣
ពាន់ខ ហើយក៏លើកទំនុកចំរៀង[ទ]១ពាន់៥បទ ៣៣ ទ្រង់មាន
បន្ទូលពីដើមឈើទាំងពួង ចាប់តាំងពីដើមតាត្រៅ ដែល
នៅលើភ្នំល្បាណូន រហូតដល់ដើមហ៊ីសុប[ធ]ដែលដុះលើ
កំផែង ក៏មានបន្ទូលពីសត្វផ្សេងៗ សត្វស្លាប សត្វលូនវារ
ហើយនិងត្រីផង ៣៤ មានមនុស្សមូល មកពីគ្រប់ទាំងសាសន៍
ដើម្បីស្តាប់ប្រាជ្ញារបស់សាឡូម៉ូន គឺមកពីអស់ទាំងស្តេច[ន]
នៅផែនដី ជាកន្លែងដែលគេបានឮថ្លែងប្រាប់ពីប្រាជ្ញាទ្រង់

## ការរៀបចំសាងសង់ព្រះវិហារ

*៥:១-១៦ - ២របា ២:១-១៨*

**៥** ១ រីឯហ៊ីរ៉ាម[ក] ជាស្តេចស្រុកទីរ៉ុស ទ្រង់ចាត់ពួកមហាត
លិកឱ្យមកគាល់សាឡូម៉ូន ដោយឮថា គេបានចាក់ប្រេងតាំង
សាឡូម៉ូនឡើង ជាស្តេចជំនួសបិតាទ្រង់ ពីព្រោះហ៊ីរ៉ាមទ្រង់
បានស្រឡាញ់ដាវីឌ តាំងតែពីដើមមក ២ ចំណែកសាឡូម៉ូន
ទ្រង់ចាត់គេឱ្យទៅឯហ៊ីរ៉ាមទូលថា ៣ ទ្រង់ជ្រាបហើយថា
ដាវីឌ ជាបិតានៃទូលបង្គំ រកស្អាង[ខ]ព្រះវិហារថ្វាយព្រះ
នាមព្រះយេហូវ៉ា ជាព្រះនៃលោកមិនបាន ដោយព្រោះ
ចេះតែមានចំបាំង[គ]នៅគ្រប់ទិសជុំវិញ ដរាបដល់ព្រះ
យេហូវ៉ាបានបង្ក្រាបគេនៅក្រោមបាទាលោក[ឃ] ៤ តែឥឡូវ
នេះ ព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំ ទ្រង់បានប្រោស
ប្រទាន ឱ្យទូលបង្គំបានឈប់សំរាក[ង] នៅគ្រប់ទិសឥតមាន
សត្រូវ[ច] ឬហេតុអាក្រក់ណាកើតឡើងឡើយ ៥ ដូច្នេះ មើល
ទូលបង្គំ បានគិតសំរេចនឹងស្អាងព្រះវិហារ[ឆ]១ថ្វាយព្រះ
នាមព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំ តាមដែលព្រះយេហូវ៉ា
បានមានបន្ទូលនឹងដាវីឌ ជាបិតាទូលបង្គំថា កូនឯងដែល
អញនឹងតាំងឱ្យសោយរាជ្យជំនួសឯង នោះនឹងស្អាងវិហារ
១ សំរាប់ឈ្មោះអញ[ជ] ៦ ហេតុនេះ សូមព្រះរាជាបង្គាប់ឱ្យគេ
កាប់ដើមតាត្រៅ[ឈ] នៅលើភ្នំល្បាណូនឱ្យទូលបង្គំឯពួកបាវ
ទូលបង្គំ គេនឹងធ្វើការជាមួយនឹងពួកបាវរបស់ទ្រង់ ហើយ
ទូលបង្គំនឹងចេញឈ្នួលថ្វាយទ្រង់សំរាប់ ពួកបាវទ្រង់តាម

**៤:២៩** ឋ ១ពវ ៣:១២ ឌ លប ៣២:១២ **៤:៣០** ឍ លប ២៥:៦ ពច ៦:៣ ដយ ១:២០ មថ ២:១ ណ អស ១៩:១១ កច ៣:២២ **៤:៣១** ត ១ពវ ៣:១២ **៤:៣២** ថ សភ ១:១ ១០:១ ២៥:១ សស ១២:៩ ទ ទដ ៧៨:៦៣ ១:១ អគ ៣៣:៣២ **៤:៣៣** ធ លវ ១៤:៤៩ **៤:៣៤** ន ២របា ៩:២៣ **៥:១** ក ២សយ ៥:១១ **៥:៣** ខ ២សយ ៧:៥ គ ១របា ២២:៨ ២៨:៣ ឃ ២សយ ២២:៤០ ទដ ៨:៦ ១១០:១ មថ ២២:៤៤ ១កថ ១៥:២៥ **៥:៤** ង យស ១៤:១៥ ១របា ២២:៩ លក ២:១៤ ច ១ពវ ១១:១៤, ២៣ **៥:៥** ឆ ចទ ១២:៥ ១របា ១៧:១២ ១កថ ៣:១៦ វវ ២១:២២ ជ ចទ ១២:៥ ២សយ ៧:១៣ **៥:៦** ឈ ១របា ១៤:១ ២២:៤

**៤:២៩** *ព្រះទ័យទូលាយ ដូចជាបណ្តាខ្សាច់ដែលនៅមាត់សមុទ្រ* មើលការពន្យល់ ខ.២០ ។

**៤:៣០** *ពួកស្រុកខាងកើត* នេះសំដៅដល់ពួកអ្នកស្រុក មេសូប៉ូតាមា (Mesopotamia) (លប ២៩:១) និងពួកអារ៉ាប់បៀ (Arabia) (មើល យរ ៤៩:២៨ អគ ២៥:៤,១០) ។ *ប្រាជ្ញារបស់ស្រុកអេស៊ីព្ទ* មើល លប ៤១:៨ នក ៧:១១ កច ៧:២២ ។

**៤:៣១** *ទ្រង់មានប្រាជ្ញា លើសជាងមនុស្ស* ឃ្លានេះមានប្រើរហូតដល់ព្រះយេស៊ូវទ្រង់បានយាងមកផែនដី (មើល លក ១១:៣១) ។ *អេថានជាពូជសេរ៉ាគីត* សូមមើលចំណងជើងគម្ពីរទំនុកដំកើង ។ *ហេម៉ាន កាល់កូល និងដារដា* សូមមើល ការពន្យល់ ១របា ២:៦ ។ *កិត្តិនាមរបស់ទ្រង់ ក៏ឮសុស-សាយ* មើល ១០:១ ។

**៤:៣២** *ទ្រង់បាននិពន្ធកាព្យ សុភាសិត៣ពាន់ខ* កំណាព្យទាំងនោះ បានរក្សាទុកនៅក្នុងកណ្ឌគម្ពីរសុភាសិត ។

**៤:៣៣** *សត្វស្លាប សត្វលូនវារ ហើយនិងត្រីផង* នេះជាឧទាហរណ៍នេះចំណេះដឹងរបស់ស្តេចដាវីឌ ដែលរកឃើញនៅក្នុង ទដ ៦:៦-៨ ២៦:២-៣,១១ ២៧:៨,១៥ ។

**៤:៣៤** *គ្រប់ទាំងសាសន៍ . . . បានឮថ្លែងប្រាប់ពីប្រាជ្ញាទ្រង់* នេះជាការលើកឡើងជាទូទៅ សំដៅមជ្ឈឹមបូពា៌ (ធៀប ៤១:៥៧) ។

**៥:១** *ហ៊ីរ៉ាម ជាស្តេចស្រុកទីរ៉ុស* ស្តេចនេះបានគ្រប់គ្រងលើស្រុកទីរ៉ុស ចាប់តាំងពិ ៩៧៨-៩៤៤ មុន គ.ស ។

**៥:៣** *ដាវីឌ . . . រកស្អាង . . . មិនបាន* នៅត្រង់នេះ ទោះបីស្តេចដាវីឌមិនបានស្អាងព្រះវិហារថ្វាយព្រះយេហូវ៉ា តែទ្រង់បានរៀបគម្រោងសម្រាប់ការសាងសង់ព្រះវិហារ ដើម្បីថ្វាយទ្រង់ដែរ (មើល ១របា ២២:២-៥ ២៨:២ សូមធៀប ទដ ជំពូក ៣០) ។

**៥:៤** *ឈប់សម្រាក* នេះមានន័យថា"គ្មានសត្រូវ ឬគ្មានការបំផ្លាញ" ហើយជាព្រះហឫទ័យនៃការសន្យារបស់ព្រះ ចំពោះរាស្ត្ររបស់ទ្រង់ (សូមមើល នក ៣៣:១៤ ចទ ២៥:១៩ យស ១:១៣,១៥) និងស្តេចដាវីឌ (សូមមើល ២សយ ៧:១១) ហើយនិងការសម្រេចនូវបន្ទូលសន្យានេះ (សូមមើល ៨:៥៦ និងពន្យល់) ដូច្នេះ ពួកអ៊ីស្រាអែល បានសម្រាកដើម្បីប្រមូលផ្តុំកម្លាំង និងធនធានដើម្បីសាងសង់ព្រះវិហារសម្រាប់ព្រះអម្ចាស់ (សូមមើលការពន្យល់ ២សយ ៧:១១) ។

**៥:៥** *ព្រះនាមព្រះយេហូវ៉ា* មើល ៣:២ និងការពន្យល់ ។ *តាមដែលព្រះយេហូវ៉ាបានមានបន្ទូលនិងស្តេចដាវីឌ* មើល ២សយ ៧:១២-១៣ ១របា ២២:៨-១០ ។

**៥:៦** *សូមព្រះរាជាបង្គាប់* ការរៀបរាប់ពិស្តាអំពីសំណូមរបស់ស្តេចសាឡូម៉ូន គឺមាននៅក្នុង ២របា ២:៣-១០ ។ *ដើមតាត្រៅនៅភ្នំល្បាណូន* ឈើប្រភេទនេះ មានប្រើច្រើននៅក្នុងមជ្ឈឹមបូពា៌ ក្នុងការសាងសង់ព្រះរាជវាំង និងសំណង់ព្រះវិហារ ។

តែទ្រង់មានបន្ទូល ដ្បិតទ្រង់ជ្រាបហើយថា នៅក្នុងពួក
សាសន៍នៃទូលបង្គំ គ្មានអ្នកណាចេះកាប់ ឈើដូចជាពួក
ស៊ីដូនទេ ។
[៧]កាលហ៊ីរ៉ាមបានឮព្រះបន្ទូលរបស់សាឡូម៉ូន នោះទ្រង់
មានសេចក្ដី អំណរជាខ្លាំង ក៏មានបន្ទូលថា នៅថ្ងៃនេះ សូម
ក្រាបថ្វាយបង្គំដល់ព្រះយេហូវ៉ា[ញ] ដែលទ្រង់បានប្រទានឱ្យ
ដាវីឌមានបុត្រ១ ដែលមានប្រាជ្ញា ឱ្យត្រួតលើសាសន៍ដ៏ធំ
ម្ល៉េះនេះ [៨]ហ៊ីរ៉ាមក៏ចាត់គេឱ្យទៅទូលសាឡូម៉ូនថា ទូល
បង្គំបានឮសេចក្ដីដែលទ្រង់ផ្ញើទៅទូលបង្គំ ហើយទូលបង្គំ
ទទួលធ្វើឈើតាត្រៅនឹងឈើកកោះ តាមបំណងព្រះទ័យ
ទ្រង់គ្រប់ចំពូក [៩]ពួកបាវរបស់ទូលបង្គំនឹងយកដុលឈើចុះ
ពីភ្នំល្បាណូនដល់សមុទ្រ[ដ] ចងជាក្បូនបណ្តែតទៅតាម
សមុទ្ររហូតដល់កន្លែងណាដែលទ្រង់កំណត់ទុក រួចទូល
បង្គំនឹងឱ្យគេស្រាយថ្វាយដល់ទ្រង់នៅទីនោះ បើទ្រង់ចង់ធ្វើ
សំរេចតាមបំណងចិត្តទូលបង្គំវិញ នោះត្រូវឱ្យផ្គត់ផ្គង់
ស្បៀងអាហារ[ឋ] សំរាប់ពួកនៅដំណាក់ទូលបង្គំផង [១០]ដូច្នេះ
ហ៊ីរ៉ាមក៏ថ្វាយឈើតាត្រៅ និងឈើកកោះដល់សាឡូម៉ូន
តាមបំណងព្រះទ័យទ្រង់គ្រប់ចំពូក [១១]ហើយសាឡូម៉ូនក៏
ថ្វាយភោជ្ជសាលី២ម៉ឺនរង្វាល់ ដល់ហ៊ីរ៉ាមទុកជាស្បៀង
អាហារ[ឌ] នៃពួកដំណាក់ទ្រង់ និងប្រេងសំរាំង២០រង្វាល់ គឺ
យ៉ាងនោះដែលសាឡូម៉ូនបញ្ជូនទៅហ៊ីរ៉ាម រាល់ៗតែឆ្នាំ

**៥:៧** ញ ១ពវ ១០:៩ អស ៦០:៦
**៥:៩** ដ អរ ៣:៧ ឋ ខ.១១ អក ២៧:១៧ កច ១២:២០
**៥:១១** ឌ ខ.៩
**៥:១២** ឍ ១ពវ ៣:១២ ណ យស ៩:៧ ១ពវ ១៥:១៩ អម ១:៩
**៥:១៣** ត លប ៤៩:១៥ លវ ២៥:៣៩ ១ពវ ៩:១៥
**៥:១៤** ថ ២សយ ២០:២៤ ១ពវ ៤:៦ ២របា ១០:៨១
**៥:១៦** ទ ១ពវ ៩:២៣
**៥:១៧** ធ ១ពវ ៦:៧ ន ១របា ២២:២
**៥:១៨** ប ២សយ ៥:១១ ផ យស ១៣:៥

[១២]ព្រះយេហូវ៉ាទ្រង់ក៏ប្រទានឱ្យសាឡូម៉ូនមានប្រាជ្ញា[ឍ] ដូច
ជាទ្រង់បានសន្យា ហើយហ៊ីរ៉ាម នឹងសាឡូម៉ូនក៏មានមេត្រី
នឹងគ្នា ព្រមទាំងចុះសញ្ញានឹងគ្នាទៅវិញទៅមកផង[ណ] ។
[១៣]ស្ដេចសាឡូម៉ូនទ្រង់ក៏កេណ្ឌមនុស្ស[ត] ពីគ្រប់ក្នុងពួក
អ៊ីស្រាអែលបានចំនួន៣ម៉ឺននាក់ [១៤]រួចទ្រង់ចាត់គេឱ្យទៅឯ
ភ្នំល្បាណូន ដោយវេន ក្នុង១ខែ១ម៉ឺននាក់ គឺគេនៅឯភ្នំ
ល្បាណូន១ខែ ហើយនៅឯផ្ទះ២ខែ មានអ័ដូនីរ៉ាម[ថ]ជាអ្នក
ត្រួតលើពួកមនុស្ស ដែលត្រូវកេណ្ឌមកធ្វើការនោះ [១៥]ទ្រង់
ក៏មានមនុស្ស៧ម៉ឺននាក់ សំរាប់លីសែង ហើយ៨ម៉ឺននាក់
សំរាប់ដាប់ថ្មនៅឯភ្នំ [១៦]ហើយក្រៅពីពួកនោះ មានពួក
នាយ[ទ]របស់សាឡូម៉ូន សំរាប់ត្រួតត្រាការចំនួន៣នាក់៣រយ
នាក់ទៀត គឺជាពួកអ្នកបង្គាប់ការដែលបណ្ដាពួកជាងធ្វើ
នោះ [១៧]ស្ដេចទ្រង់ក៏ចេញបង្គាប់ ហើយគេដាប់យកថ្មយ៉ាង
ធំៗមក[ធ] ជាថ្មមានដំឡៃ[ន] សំរាប់ដាក់ធ្វើជាឫស ជញ្ជាំងនៃ
ព្រះវិហារ [១៨]ឯពួកជាងរបស់សាឡូម៉ូន នឹងពួកជាងរបស់
ហ៊ីរ៉ាម[ប] ហើយពួកជាងដាប់ក្រឡាថ្មនោះ[ផ] គេក៏ត្រៀមឈើ
និងថ្មី ទុកសំរាប់ស្អាងព្រះវិហារ ។

## ស្ដេចសាឡូម៉ូនសង់ព្រះវិហារ

*៦:១–២៩ – ២របា ៣:១–១៤*

**៦** [១]គ្រាក្រោយ ដែលពួកកូនចៅអ៊ីស្រាអែល បានចេញពី
ស្រុកអេស៊ីព្ទមក បាន៤៨០ឆ្នាំហើយ គឺនៅឆ្នាំទី៤ ដែល

**៥:៧** *សូមក្រាបថ្វាយបង្គំដល់ព្រះយេហូវ៉ា* នៅក្នុងវប្បធម៌ពទេវចម្រុះ ពាក្យនេះត្រូវបានគេប្រើ សម្រាប់ជាតិសាសន៍មួយក្នុងការបែងចែកទេវតាថែរក្សាជាតិដ៏ទៃផ្សេងទៀត (មើល ១០:៩ ១១:១៥) ហើយសេចក្ដីនេះជាការផ្ដល់អំណាចឱ្យដល់ពួកគេដែរ (មើល ២ពវ ២របា ២:១២) ។

**៥:៩** *កន្លែងណាដែលទ្រង់កំណត់* កន្លែងនេះជាក្រុងយ៉ុបប៉េ(មើល ២របា ២:១៦ និងការពន្យល់ ១ពវ ៣:១) ។ *ផ្គត់ផ្គង់ស្បៀងអាហារ សំរាប់ពួកនៅដំណាក់ទូលបង្គំ* ការផ្គត់ផ្គង់ម្ហូបអាហារសម្រាប់បុគ្គលិកមន្ត្រីតុលាការរបស់ហ៊ីរ៉ាមដោយគ្រាន់តែតម្លៃឈើប៉ុណ្ណោះ ។ លើសពីនេះទៀត ស្ដេចសាឡូម៉ូន បានផ្គត់ផ្គង់ប្រាក់ខែដល់កម្មករនៅស្រុកភេនីសទៀតផង (ខ.៦) ។ ការប្រៀបធៀបរវាង ខ.១១ ជាមួយនឹង ២របា ២:១០ បានបង្ហាញថា ក្រៅពីស្រូវសាឡី និងប្រេងអូលីវសម្រាប់មន្ត្រីតុលាការរបស់ហ៊ីរ៉ាម ហើយស្ដេចសាឡូម៉ូនក៏ថែមទាំងបានផ្ញើរស្រូវបាឡេ និងស្រាដ៏មានតម្លៃដល់ពួកកម្មករនៅទីនោះផងដែរ ។ ហើយហ៊ីរ៉ាមនេះ បានលក់របស់ទាំងនេះ ដើម្បីផ្គត់ផ្គង់ការចំណាយលើកម្មករ (សូមមើល ការពន្យល់ ៩:១១) ។

**៥:១១** *ស្រូវភោជ្ជសាលី២ម៉ឺនរង្វាល់* តាមរយៈភស្តុតាងផ្សេងៗ និងការប្រៀបធៀប បានបញ្ជាក់ថាស្ដេចសាឡូម៉ូនបានទទួលស្រូវភោជ្ជសាលីនេះចំនួន១០៩៥០រង្វាល់ និង ២១៩០០សម្រាប់ម្ហូបអាហារប្រចាំឆ្នាំ (មើល ៤:២២) ។ គ្រាប់ធុញ្ញជាតិជាស្រូវ របស់ស្ដេចសាឡូម៉ូនទាំងអស់ដែលប្រគល់ទៅដល់ស្ដេចហ៊ីរ៉ាមមានចំនួន ២០០០០ រង្វាល់ និងស្រូវភោជ្ជសាលីចំនួន២០០០០រង្វាល់ (២របា ២:១០) ។

**៥:១៣** *កេណ្ឌមនុស្ស* សូមមើលការពន្យល់ ៩:១៥ ២សយ ២០:២៤ ។ ការមិនពេញចិត្តនៅក្នុងចំណោមប្រជាជនទាំងអស់នោះ បានជម្រុញឱ្យមានការបះបោរ និងបែងចែកអាណាចក្រក្រោយពីស្ដេចសាឡូម៉ូនបាសុគតទៅ (១២:១–១៨) ។

**៥:១៥** *៧ម៉ឺននាក់ សំរាប់លីសែង ហើយ៨ម៉ឺននាក់ សំរាប់ដាប់ថ្មនៅឯភ្នំ* ពួកអ្នកទាំងនេះ ត្រូវបានគេកេណ្ឌយកមកពីពួកដែលមិនមែនប្រជាជនអ៊ីស្រាអែល ដែលស្ដេចដាវីឌបានបង្ក្រាប ហើយបានធ្វើការបង្រួបបង្រួមនៅក្នុងអណាចក្ររបស់ទ្រង់ (មើល ២របា ២:១៧–១៨) ។ *ភ្នំ* នេះជាភ្នំដែលគេយកកំបោរ ដែលនៅត្រង់នេះជាទីដែលគេយកថ្ម ។

**៥:១៦** *៣ពាន់ ៣រយនាក់* ចំពោះ ១ពវ ៩:២៣ សំដៅលើពួកមេត្រួតទាំង៥៥០នាក់ ។ ប្រសិនបើ ចំនួនទាំងពីរនេះខុសគ្នា អញ្ចឹងចំនួនសរុបមានរហូតដល់ទៅ ៣៨៥០ នាក់ ។ រីឯនៅក្នុង ២របា ២:២ សំដៅដល់ចំនួន ៣៦០០នាក់ ហើយ ២របា ៨:១០ និយាយសំដៅលើពួកមេត្រួត ២៥០នាក់ ។

**៥:១៧** *ដាប់យកថ្មយ៉ាងធំ* ចំពោះទំហំថ្មនៅក្នុងចំណុចនេះ មើល ៧:១០ ។

**៦:១** *៤៨០ឆ្នាំ* នេះជាចំនួនឆ្នាំដែលពួកអ៊ីស្រាអែលបានចេញពីស្រុកអេស៊ីព្ទហើយ ត្រូវនឹងឆ្នាំទី៤របស់ស្ដេចសាឡូម៉ូនដែលសោយរាជ្យ គឺនៅឆ្នាំ ៩៦៦ មុន គ.ស(មើលសេចក្ដីផ្ដើម) ។ ប្រសិនបើ ពួកអ៊ីស្រាអែលបានចាកចេញពីស្រុកអេស៊ីព្ទមានរយៈពេល៤៨០ឆ្នាំដែលត្រូវនឹងឆ្នាំ ៩៦៦ មុន គ.ស នោះ

សាឡូម៉ូនសោយរាជ្យលើសាសន៍អ៊ីស្រាអែល ក្នុងខែពិសាខ
ជាខែទី២[ក] នោះសាឡូម៉ូនបានចាប់ តាំងស្អាងព្រះវិហារ
នៃព្រះយេហូវ៉ា[ខ] ២ ឯព្រះវិហារ[គ]ដែលស្តេចសាឡូម៉ូន បាន
ស្អាងថ្វាយព្រះយេហូវ៉ា នោះមានបណ្តោយ៦០ហត្ថ ទទឹង
២០ហត្ថ ហើយកំពស់៣០ហត្ថ ៣ មានបាំងសាច់[ឃ]ខាង
មុខទីបរិសុទ្ធរបស់ព្រះវិហារ បណ្តោយ២០ហត្ថឱ្យត្រូវទទឹង
ព្រះវិហារ ហើយទទឹង១០ហត្ថ ចេញពីមុខព្រះវិហារទៅ
៤ ទ្រង់ក៏ធ្វើឱ្យមានបង្អួច[ង]ក្នុងព្រះវិហារ មានចំរឹងខ្មាស់គ្នា
៥ ឯជាប់នឹងជញ្ជាំងព្រះវិហារ និងទីបរិសុទ្ធបំផុតនោះក៏
ធ្វើបន្ទប់យ៉ភ្ជាប់នឹងជញ្ជាំងជាខណ្ឌៗនៅជុំវិញ[ច] ៦ ឯថ្នាក់
ក្រោម នោះទទឹង៥ហត្ថ ថ្នាក់កណ្តាល ទទឹង៦ហត្ថ ហើយ
ថ្នាក់ទី៣ ទទឹង៧ហត្ថ ពីព្រោះខាងក្រៅជញ្ជាំងនៃព្រះ
វិហារ ទ្រង់ធ្វើឱ្យរៀវទៅជាថ្នាក់ៗនៅជុំវិញ ដើម្បីកុំឱ្យរត់
ចូលទៅក្នុងជញ្ជាំងនោះ ៧ មួយទៀតកាលដែល គេស្អាង
ព្រះវិហារ នោះគេប្រើតែថ្មដាប់ស្រាប់[ឆ]មុនដែលដឹកមក
គ្មានឮសូរញញួរ ឬពូថៅឬគ្រឿងដែក[ជ]ណាមួយ នៅក្នុងព្រះ
វិហារកំពុង ដែលគេស្អាងឡើងនោះឡើយ ៨ ឯទ្វារនៃបន្ទប់
ខាងៗថ្នាក់កណ្តាល នោះនៅខាងស្តាំព្រះវិហារ គេឡើង
ទៅដល់ថ្នាក់កណ្តាលនោះ ហើយពីថ្នាក់កណ្តាល ទៅឯថ្នាក់
ទី៣ដោយសារជណ្តើរវង់[ឈ] ៩ ដូច្នេះ ទ្រង់បានស្អាងព្រះ
វិហារនោះហើយជាស្រេច រួចទ្រង់ធ្វើគ្រោងដំបូល ហើយ
ប្រក់ដោយឈើតាត្រៅ ១០ ក៏ធ្វើបន្ទប់ខាងក្រៅដែលភ្ជាប់
នឹងព្រះវិហារជុំវិញ មានកំពស់៥ហត្ថរាល់តែថ្នាក់ បន្ទប់
ទាំងនោះមានធ្នឹម ឈើតាត្រៅថ្កល់លើជញ្ជាំងព្រះវិហារ ។
១១ គ្រានោះ ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មក[ញ]ដល់សាឡូ
ម៉ូនថា ១២ ឯព្រះវិហារដែលឯងកំពុងតែស្អាងនេះ បើឯង
នឹងប្រព្រឹត្តតាមបញ្ញត្តរបស់អញ ហើយសំរេចតាមសេចក្តី
យុត្តិធម៌ ព្រមទាំងរក្សាសេចក្តីបង្គាប់[ដ]របស់អញទាំង ប៉ុន្មាន
ដើម្បីនឹងប្រព្រឹត្តតាម នោះអញនឹងសំរេចដល់ឯង តាម
ពាក្យដែលអញបានសន្យា[ឋ]នឹងដាវីឌ ជាឪពុកឯង ១៣ ហើយ
អញនឹងស្ថិតនៅកណ្តាលពួកកូនចៅអ៊ីស្រាអែល ឥតបោះ
បង់ចោល[ឌ]រាស្ត្ររបស់អញឡើយ ។
១៤ ដូច្នេះ សាឡូម៉ូន[ឍ] ទ្រង់បានស្អាងព្រះវិហារនោះរួច
ជាស្រេច[ណ] ១៥ គឺទ្រង់ធ្វើជញ្ជាំងខាងក្នុងពីឈើតាត្រៅ ចាប់
តាំងពីដីរហូតដល់ពិតាន[ត] ខាងក្នុងទាំងអស់សុទ្ធតែស្រោប
ដោយឈើ ក៏ក្រាលព្រះវិហារដោយក្តារកកោះដែរ[ថ] ១៦ ឯ
ទីខាងចុងនៃព្រះវិហារ មានបណ្តោយ២០ហត្ថ នោះទ្រង់
ក៏ស្រោបដោយឈើតាត្រៅដូចគ្នា ចាប់តាំងពីដីរហូតដល់
ពិតាន ហើយខណ្ឌទុកជាទីបរិសុទ្ធបំផុត សំរាប់ជាទីទទួល
ព្រះបន្ទូល[ទ] ១៧ ផ្នែកខាងមុខនៃព្រះវិហារ នោះមាន
បណ្តោយ៤០ហត្ថ ១៨ ហើយឈើតាត្រៅ[ធ]ដែលស្រោបខាង
ក្នុងព្រះវិហារ នោះក៏ឆ្លាក់ជាផ្កាក្រពុំ និងផ្ការីកគ្រប់ទាំង
អស់បានបិទ ដោយឈើតាត្រៅ ឥតឃើញថ្មឡើយ ១៩ ទ្រង់
រៀបចំទីបរិសុទ្ធបំផុត[ន]ក្នុងព្រះវិហារ សំរាប់ដាក់ហឹបនៃ
សេចក្តីសញ្ញា[ប]ផងព្រះយេហូវ៉ា ២០ ឯខាងក្នុងទីបរិសុទ្ធ

**៦:១** ក អរ ៣:៨ ខ អរ ៥:១១ **៦:២** គ នក ២៦:១ **៦:៣** ឃ អគ ៤០:៤៩ **៦:៤** ង អគ ៤១:១៦ **៦:៥** ច យរ ៣៥:២ អគ ៤១:៥–៦ **៦:៧** ឆ នក ២០:២៥ ជ ចទ ២៧:៥ **៦:៩** ឈ បស ១:១៧ **៦:១១** ញ ១ពវ ១២:២២ ១៣:២០ ១៦:១,៧ ១៧:២ ២១:១៧ យរ ៤០:១ **៦:១២** ដ ១ពវ ១១:១០ ឋ ២សយ ៧:១២–១៦ ១ពវ ៩:៥ **៦:១៣** ឌ លវ ២៦:១១ ចទ ៣១:៦ យហ ១៤:១៨ ហព ១៣:៥ **៦:១៤** ឍ កច ៧:៤៧ ណ ១របា ២៨:២០ ២របា ៥:១ **៦:១៥** ត ១ពវ ៧:៧ ថ អគ ៤១:១៥–១៦ **៦:១៦** ទ នក ២៦:៣៣ **៦:១៨** ធ ខ.២៩ ទដ ៧៤:៦ អគ ៤១:១៨ **៦:១៩** ន ១ពវ ៨:៦ ប នក ២៥:១០ ១សយ ៣:៣

ពួកគេប្រហែលជាចាកចេញមកតាំពីឆ្នាំ ១៤៤៦ មុន គ.ស ។

**៦:២** *ព្រះវិហារដែលស្តេចសាឡូម៉ូនបានស្អាង* ព្រះវិហារនេះត្រូវបានគេរៀបចំឡើងជាថ្នាក់ៗ បន្ទាប់ពីរោងឧបោសថ គឺទីបរិសុទ្ធបំផុត ទីបរិសុទ្ធ និងទីធ្លាខាងក្រៅ ។

**៦:៦** *រៀវទៅជាថ្នាក់ៗ* នេះជារចនាបថមួយនៃការសាងសង់ ដើម្បីកុំឱ្យមានប្រហោងនៅក្នុងជញ្ជាំង និងសង់ឡើងជាថ្នាក់ៗ ដែលថ្នាក់និមួយៗមានបីជាន់សម្រាប់បន្ទប់សម្រាក ។ ត្រង់នេះជាការរៀបរាប់ពីទទឹងរបស់ជាន់និមួយៗដែលមានភាពខុសគ្នា ។

**៦:១១** *ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់សាឡូម៉ូន* នៅត្រង់នេះប្រហែលជាព្រះវិហារចូលមកដល់ទីបញ្ចប់នៃការសាងសង់ ហើយដែលព្រះអម្ចាស់មានបន្ទូលដល់សាឡូម៉ូន តាមរយៈហោរាដែលមិនស្គាល់ឈ្មោះ (ប៉ុន្តែសូមមើល ៣:៥,១១–១៤ ៩:២–៩) ។

**៦:១២** *បើឯងនឹងប្រព្រឹត្តតាមបញ្ញត្តរបស់អញ . . . អញនឹងសំរេចដល់ឯង* បន្ទូលនេះគឺស្រដៀងគ្នា នឹងអ្វីដែលស្តេចដាវីឌបានលើកឡើង (មើល ២:១–៤ និងការពន្យល់) និងព្រះអម្ចាស់បានអះអាងចំពោះស្តេចសាឡូម៉ូន ក្នុងការបន្តតំណវង្សរបស់ព្រះអង្គទៀត (មើល ២សយ ៧:១២–១៦) តែស្តេចសាឡូម៉ូនត្រូវតែស្មោះត្រង់ចំពោះសេចក្តីសញ្ញានៅភ្នំស៊ីណាយ ប្រសិនបើស្តេចសាឡូម៉ូនទទួលយកនូវសេចក្តីសន្យារបស់ស្តេចដាវីឌ ។

**៦:១៣** *ស្ថិតនៅកណ្តាលពួកអ៊ីស្រាអែល* ចំណុចនេះបានប្រាប់ពីការដែលព្រះវិហារកំពុងតែត្រូវបានសាងសង់នៅឡើយ (មើល ៩:៣) ។ ដើម្បីកុំឱ្យពួកគេមានសេចក្តីព្រួយបារម្ភចំពោះវត្តមានរបស់ទ្រង់ (ធៀប ទដ ៧៨:៦០ យរ ២៦:៦,៩ មើលការពន្យល់ ១សយ ៧:១) នោះព្រះអម្ចាស់បានប្រទានឱ្យពួកគេនូវការធានាថា ទ្រង់នឹងសណ្ឋិតក្នុងពួកគេ (មើល ៨:១០–១៣ លវ ២៦:១១) ។

**៦:១៦** *ទីបរិសុទ្ធបំផុត* បច្ចេកពាក្យដូចគ្នាដដែលនេះ ត្រូវបានគេប្រើនៅក្នុងដំណាក់បរិសុទ្ធអាសនានៃរោងឧបោសថ (មើល នក ២៦:៣៣–៣៤ លវ ១៦:២,១៦–១៧,២០,២៣) ។

**៦:១៩** *ហឹបនៃសេចក្តីសញ្ញាផងព្រះយេហូវ៉ា* នេះជាក្រឹត្យវិន័យទាំង១០ប្រការដែលត្រូវបានគេហៅថា"ក្រឹត្យច្បាប់"មានចែងក្នុង នក ៣៤:២៨ ។ បន្ទះថ្មក្រឹត្យវិន័យ ទាំង១០ប្រការនេះ ត្រូវបានចារឹកហើយហៅថា "បន្ទះក្រឹត្យវិន័យ" នៅក្នុង ចទ ៩:៩ ។ ហឹបសញ្ញាដែលគេរក្សាទុក (មើល នក ២៥:១៦,២១ ៤០:២០ ចទ ១០:១–៥) ដូច្នេះពេលខ្លះត្រូវបានគេហៅថា "ហឹបសញ្ញានៃព្រះអម្ចាស់" (មើល ចទ ១០:៨ ៣១:៩,២៥ យស ៣:១១) ។

**៦:២០** *មាសសុទ្ធ* មាសទាំងអស់នេះ មានចំនួនច្រើនហើយដែលភ្ជីចិញ្ចាំងជា

បំផុត[ផ] នោះមានបណ្តោយ២០ហត្ថ និងទទឹង២០ហត្ថ
ហើយកំពស់២០ហត្ថដែរ ទ្រង់ស្រោបទីនោះដោយមាស
សុទ្ធ ហើយអាសនាដែលធ្វើពីឈើតាត្រៅ[ព] ក៏ស្រោប
ដូច្នោះដែរ ២១ ដូច្នេះ សាឡូម៉ូនបានស្រោបប៉ែកខាងក្នុង
នៃព្រះវិហារ ដោយមាសសុទ្ធ ហើយទ្រង់សន្ធឹងច្រវាក់
មាសតាំងពីមុខទីបរិសុទ្ធបំផុត ដែលបានស្រោបមាសដែរ
២២ ដូច្នេះ ព្រះវិហារទាំងមូល សុទ្ធតែស្រោបដោយមាស
ទាល់តែបាន រួចជាស្រេចទាំងអស់ ទោះទាំងអាសនាទាំង
មូលរបស់ផង ទីបរិសុទ្ធបំផុត ក៏ស្រោបដោយមាសដែរ ។
២៣ នៅខាងក្នុងទីបរិសុទ្ធបំផុត នោះទ្រង់បានធ្វើរូប
ចេរូប៊ីន[ភ]២ ដោយឈើអូលីវ មានកំពស់១០ហត្ថទាំងគូ
២៤ ស្លាបម្ខាងៗរបស់ចេរូប៊ីន១ មានប្រវែង៥ហត្ថ គឺពី
ចុងស្លាបម្ខាងទៅដល់ចុងស្លាបម្ខាងត្រូវជា១០ហត្ថ ២៥ ឯ
ចេរូប៊ីន ១ទៀតនោះ ក៏មាន១០ហត្ថដែរ ចេរូប៊ីនទាំង២
មានរាងមានទំហំប៉ុនគ្នា ២៦ ចេរូប៊ីន១មានកំពស់១០ហត្ថ
ហើយ១ទៀតក៏យ៉ាងនោះដែរ ២៧ ទ្រង់ដាក់ចេរូប៊ីន[ម]ទាំង២
នៅកណ្តាល ប៉ែកខាងក្នុងនៃព្រះវិហារ ឯស្លាបនៃចេរូប៊ីន
ទាំង២ក៏ត្រដាងទៅ ទាល់តែចុងស្លាបចេរូប៊ីន១ ទល់នឹង
ជញ្ជាំងម្ខាង នឹងចុងស្លាបចេរូប៊ីន១ទៀត ក៏ទល់នឹងជញ្ជាំង
ម្ខាងដូចគ្នា ហើយចុងស្លាបចេរូប៊ីនទាំង២នៅប្រទល់គ្នា
ត្រង់កណ្តាលព្រះវិហារ ២៨ ទ្រង់ក៏ស្រោបចេរូប៊ីនទាំង២
ដោយមាសដែរ ។
២៩ ទ្រង់ឆ្លាក់ជារូបចេរូប៊ីន[យ] ជាដើមលម៉ើ ហើយជា
ផ្ការីកនៅនាជញ្ជាំង[រ]ព្រះវិហារជុំវិញ ទាំងខាងក្នុងខាង
ក្រៅ ៣០ ហើយក្តារក្រាលព្រះវិហារ ទាំងខាងក្នុងខាងក្រៅ
ទ្រង់ក៏ស្រោបដោយមាសដែរ ៣១ ត្រង់កន្លែងចូលទៅក្នុង
ទីបរិសុទ្ធបំផុត នោះទ្រង់ធ្វើទ្វារពីឈើអូលីវ ឯក្របទ្វារ
នោះ មានកំពស់១ភាគក្នុង៥នៃជញ្ជាំង ៣២ ទ្វារទាំង២នោះ
ធ្វើពីឈើអូលីវ[ល] ហើយទ្រង់ក៏ឆ្លាក់ជារូបចេរូប៊ីន ជាដើម
លម៉ើ ហើយនឹងផ្ការីកដែរ រួចស្រោបដោយមាសទាំងអស់
គឺស្រោបមាសទាំងចេរូប៊ីន និងដើមលម៉ើផង ៣៣ នៅត្រង់
ផ្លូវចូលទៅក្នុងព្រះវិហារ នោះទ្រង់ធ្វើក្របទ្វារ ពីឈើ
អូលីវបែបដូច្នោះដែរ ឯក្របទ្វារនោះមាន កំពស់១ភាគ
ក្នុង៥នៃជញ្ជាំង ៣៤ ហើយផ្ទាំងទ្វារទាំង២ នោះធ្វើពីឈើ
កកោះឱ្យបត់បានគ្រប់សន្លឹកទាំងសងខាង ៣៥ ទ្រង់ក៏ឆ្លាក់ជា
រូបចេរូប៊ីន ជាដើមលម៉ើនិងផ្ការីក ហើយស្រោបមាសទ្វារ
ទាំងនោះ ព្រមទាំងចំឡាក់ផង ៣៦ ទ្រង់ធ្វើទីលានខាងក្នុង[វ]
ដោយថ្មដាក់៣ជាន់[ស] និងឈើតាត្រៅ១ជាន់។
៣៧ នៅឆ្នាំ៤ ខែពិសាខ នោះគេបានដាក់ចុះជើងជញ្ជាំង
ព្រះវិហារ នៃព្រះយេហូវ៉ា ៣៨ រួចដល់ឆ្នាំ១១ ខែកត្តិក គឺជា
ខែទី៨ គេបានស្អាងព្រះវិហាររួចជាស្រេចសព្វគ្រប់[ហ] តាម
ផែនទីគ្រប់ចំពូក[ឡ] ដូច្នេះ ទ្រង់ស្អាងព្រះវិហារនោះអស់៧ឆ្នាំ
ទើបបានហើយ ។

## សាឡូម៉ូនសង់ដំណាក់របស់ទ្រង់

**៧** ១ សាឡូម៉ូនទ្រង់ក៏សង់ដំណាក់របស់ទ្រង់ ក្នុងរវាងអស់
១៣ឆ្នាំ ទើបបានស្រេចទាំងអស់[ក] ២ ទ្រង់បានសង់មន្ទីរ[ខ]នៃ
ព្រៃល្បាណូន[គ] មានបណ្តោយ១០០ហត្ថ ទទឹង៥០ហត្ថ និង
កំពស់៣០ហត្ថ មានសសរតាត្រៅ៤ជួរ ដាក់ធ្នឹមតាត្រៅ
នៅលើសសរទាំងនោះ ៣ ក៏ប្រកប់ដោយឈើតាត្រៅ នៅ

**៦:២០** ផ អគ ៤១:៣–៤ ព នក ៣០:១
**៦:២៣** ភ នក ៣៧:១–៩
**៦:២៧** ម លប ៣:២៤ នក ២៥:១៨
**៦:២៩** យ ខ.៣២,៣៥ អគ ៤១:១៨,២៥ រ ខ.១៨
**៦:៣២** ល អគ ៤១:២៣
**៦:៣៦** វ ២រប ៤:៩ ស ១ពវ ៧:១២ អរ ៦:៤
**៦:៣៨** ហ ១រប ២៨:១៩ ឡ នក ២៥:៩ ហព ៨:៥
**៧:១** ក ២សយ ៧:២
**៧:២** ខ ២សយ ៧:២ គ ១ពវ ១០:១៧ ២រប ៩:១៦ អស ២២:៨ ៣៧:២៤ យរ ២២:៦,២៣

និមិត្តសញ្ញាពីសិរីល្អរបស់ព្រះ និងអាណាចក្ររបស់ទ្រង់ (សូមធៀប *វវ* ២១:១០–១១,១៨,២១) ។

**៦:២១** *ច្រវ៉ាក់មាស* វាំងនននេះ បានបាំងចំពោះច្រកចូលព្រះវិហារក្នុងទីបរិសុទ្ធបំផុត ដែលវាំងនននេះព្យួរលើច្រវ៉ាក់មាសនេះ (មើល ២រប ៣:១៤ មថ ២៧:៥១ ហព ៦:១៩) ។

**៦:២២** *អាសនាទាំងមូលរបស់ផងទីបរិសុទ្ធ* នេះជាទីសម្រាប់ដាក់គ្រឿងក្រអូប(មើល ៧:៧៨ នក ៣០:១,៦ ៣៧:២៥–២៨ ហព ៩:៣–៤ និងការពន្យល់ ៩:៤) ។

**៦:២៣** *ចេរូប៊ីន* មើលពន្យល់ នក ២៥:១៨ ។ រូបនេះ ឈយាមផ្នែកទាំងពីនៃអាសនា(៨:៦–៧ រប ៣:១០–១៣) ។

**៦:២៩** *ឆ្លាក់ជារូបចេរូប៊ីន* ការឆ្លាក់នេះមិនមែនបំពាន ទៅដល់សេចក្តីបង្គាប់ទីពីរ ដែលបានហាមមិនឱ្យធ្វើអ្វីតំណាងរូបព្រះ ហើយថ្វាយបង្គំនោះទេ(មើលការពន្យល់ នក ២០:៤) ។ *ដើមលម៉ើ ហើយជាផ្ការីក* នេះជាការពិពណ៌នាពីរូបចេរូប៊ីន ដើមឈើ និងផ្កាដ៏ស្រស់ស្អាត គឺរំលឹកដល់សួនអេដែន ពីអ្វីដែលលោកអ័ដាម និងនាងអេវ៉ា បានប្រព្រឹត្តបាបទាស់នឹងព្រះអម្ចាស់(លប ៣:២៤) ។ និមិត្តរូប នៃស្ថានសួគ៌របស់ព្រះអម្ចាស់ គឺត្រូវបានធ្វើនៅមធ្យោបាយប្រោសលោះសម្រាប់អំពើរបាបនៅកន្លែងបរិសុទ្ធ (មើលការពន្យល់ នក ២៦:១ "រោងឧបោសថ") ។

**៦:៣៦** *ទីលានខាងក្នុង* នេះបញ្ជាក់ថា ជាទីធ្លាខាងក្រៅព្រះវិហារ(មើល ៨:៦៤) ។ ព្រះគម្ពីរ ២រប សំដៅលើទីលានខាងក្នុងរបស់ពួកសង្ឃ (ខាងក្នុង) និងទីលានធំ(ខាងក្រៅ) ។ ទីធ្លាខាងក្នុងក៏ត្រូវបានគេហៅថា "ធ្លាខាងលើ"(យរ ៣៦:១០) ដោយសាតែវា មានទីតាំងនៅទីខ្ពស់ ។

**៦:៣៧** *ឆ្នាំទី៣៤* នេះបញ្ជាក់ពីឆ្នាំដែលស្តេចសាឡូម៉ូនឡើងគ្រងរាជ្យ (មើល ខ.១ និងការពន្យល់) ។

**៧:១** *១៣ឆ្នាំ* ស្តេចសាឡូម៉ូន ចំណាចពេលស្មើរតែពីរដងនៃចំនួននេះ ក្នុងការសាងសង់វាំងរបស់ទ្រង់ជាងការសង់ព្រះវិហារថ្វាយព្រះអម្ចាស់ (មើល ៦:៣៨ មើលបន្ថែម ហក ១:២–៤) ។

**៧:២** *មន្ទីរនៃល្បាណូន* មន្ទីរនេះសង់ឡើងមានសសរសស្តម្ភ៤ជួរ ជាទីដែលធ្វើឱ្យមាកការទាក់ចិត្តយ៉ាងខ្លាំង ។

**៧:៣** *៥០ហត្ថ និងកំពស់៣០ហត្ថ* សំណង់អាគានេះ មានបីជាន់ហើយក៏ជា

លើផ្ទឹមទាំង៤៥ ដែលដាក់លើសសរទាំងនោះ ឯផ្ទឹមទាំង
នោះ ក្នុង១ជួរមាន១៥ ៤ឯបង្អួច៣ជាន់ នៅប្រទល់គ្នាទាំង
សងខាងគ្រប់ទាំង៣ជាន់ ៥អស់ទាំងទ្វារ និងក្រប ក៏ធ្វើពី
ឈើ៤ជ្រុង ព្រមទាំងបង្អួច៣ជាន់ប្រទល់គ្នានោះដែរ ៦ទ្រង់
ក៏ធ្វើបាំងសាចដោយមានសសរ បាំងសាចនោះមាន
បណ្តោយ៥០ហត្ថ នឹងទទឹង៣០ហត្ថ ក៏មានរានហាលពីមុខ
នោះ ដែលមានសសរនឹងផ្ទឹមពីលើនៅជុំវិញ ៧ទ្រង់ក៏ធ្វើ
មន្ទីរបាំងសាចសំរាប់បល្ល័ង្ក ជាកន្លែងដែលទ្រង់ស្តីការ
គឺជាព្រះទីនាំងវិនិច្ឆ័យ[ឃ] ហើយក៏បិទដោយក្តាតាត្រៅ ចាប់
តាំងពី ក្រោមរហូតដល់ពិតាន[ង] ៨ឯដំណាក់ដែលទ្រង់គង់
នៅ នោះបានធ្វើ បែបដូចគ្នា ហើយមានទីធ្លា១ទៀត ក៏នៅ
ខាងអាយមន្ទីរមុននោះ រួចមកទ្រង់ធ្វើដំណាក់១ បែបដូច
ជាមន្ទីរមុននោះ សំរាប់បុត្រីផារ៉ោន ដែលទ្រង់បានយកជា
ភរិយា[ច]។

៩ឯរបស់ទាំងអស់នេះបានធ្វើ ដោយថ្មមានដំឡៃ ជាថ្ម
ដាប់តាមទំហំ ហើយអារដំរីម ដោយរណារទាំងក្នុងទាំង
ក្រៅ ចាប់តាំងពីឫសជញ្ជាំងទៅដល់សំយ៉ាប ហើយខាង
ក្រៅរហូតដល់ទីធ្លាធំដែរ ១០ឯឫសជញ្ជាំង នោះសុទ្ធតែធ្វើ
ពីថ្មមានដំឡៃទាំងអស់ គឺថ្មយ៉ាងធំៗ ខ្លះ១០ហត្ថ ខ្លះ៨ហត្ថ
១១ហើយពីនោះទៅលើក៏មានថ្មដែលមានដំឡៃ ដាប់តាម
ទំហំ នឹងឈើតាត្រៅផង ១២ឯទីធ្លាធំ នោះមានថ្មដាប់៣
ជាន់[ឆ] និងឈើតាត្រៅ១ជាន់នៅជុំវិញ ដូចជាទីលានខាង
ក្នុងនៃព្រះវិហារព្រះយេហូវ៉ា ហើយដូចជាបាំងសាចនៃ
ព្រះវិហារដែរ ។

## ការបំពាក់គ្រឿងប្រដាប់នៅក្នុងព្រះវិហារ

*៧:២៣–២៦ – ២របា ៤:២–៥*

**៧:៧** ឃ ១សយ ៧:១៥ ទដ ១២២:៥ សភ ២០:៨ ង ១ពវ ៦:១៥
**៧:៨** ច ១ពវ ៣:១
**៧:១២** ឆ ១ពវ ៦:៣៦
**៧:១៣** ជ ខ.៤៥ ២របា ២:១៣ ៤:១៦
**៧:១៤** ឈ នក ៣១:២–៥ ៣៥:៣១ ញ ២របា ៤:១១,១៦
**៧:១៥** ដ ២ពវ ១១:១៤ ២៣:៣ ២៥:១៧ ២របា ៣:១៥ ២៣:១៣ ៣៤:១៣ យរ ២៧:១៩ ៥២:១៧, ២១ អគ ៤០:៤៩
**៧:១៦** ឋ ខ.២០,៤២ ២ពវ ២៥:១៧ យរ ៥២:២២
**៧:២០** ឌ ខ.១៨ ២របា ៣:១៦ ៤:១៣
**៧:២១** ឍ ២របា ៣:១៧
**៧:២២** ណ ២ពវ ២៥:១៧
**៧:២៣** ត ខ.៤៧ ២ពវ ២៥:១៣ ១របា ១៨:៨ ២របា ៤:១៨ យរ ៥២:១៧ វវ ៤:៦

*៧:៣៨–៥១ – ២របា ៤:៦,១០–៥:១*

១៣ស្តេចសាឡូម៉ូន ទ្រង់ចាត់គេ ឱ្យទៅរកហ៊ីរ៉ាមនៅក្រុង
ទីរ៉ុសនាំមក[ជ] ១៤អ្នកនោះជាកូនរបស់ស្រីមេម៉ាយម្នាក់ក្នុង
ពូជអំបូរណែបថាលី តែឪពុកជាជាងលង្ហិន នៅស្រុកទីរ៉ុស
អ្នកនោះជាអ្នកមានប្រាជ្ញាវាងវៃ[ឈ] ហើយមានថ្វីដៃចេះធ្វើ
គ្រប់ទាំងរបស់លង្ហិន គាត់ក៏មកឯស្តេចសាឡូម៉ូន ដើម្បីនឹង
ធ្វើការទាំងអស់[ញ]នេះថ្វាយទ្រង់ ១៥គាត់សិតធ្វើសសរ២
ដោយលង្ហិន[ដ] ទាំង២មានកំពស់១៨ហត្ថដូចគ្នា ហើយបើ
វាស់ជុំវិញ នោះត្រូវជា១២ហត្ថក្នុងសសរមួយៗ ១៦គាត់សិត
ធ្វើក្បាច់លង្ហិន២ដុំ ដាក់លើក្បាលសសរទាំង២[ឋ] មួយៗមាន
កំពស់៣ហត្ថដូចគ្នា ១៧មានក្បាច់តារាង ដូចជាក្រឡាអួន
ហើយមានវង់កំរងច្រវាក់៧នៅក្បាលសសរមួយៗ ក្នុងទាំង
២នោះ ១៨គឺយ៉ាងនោះដែលគាត់ធ្វើសសរទាំង២ ហើយ
មានផ្លែទទឹម២ជួរព័ទ្ធជុំវិញ ជាប់នឹងក្បាច់ក្រឡាអួន នោះ
សំរាប់នឹងបាំងទីភ្ជាប់ក្បាលសសរដូចគ្នាទាំង២ ១៩ឯក្បាល
សសរនៃបាំងសាចមានកំពស់៤ហត្ថ ក៏មានក្បាច់ជាផ្កា
ច័ន្ទរ ២០មានក្បាលនៅលើសសរទាំង២នោះដែរ ជាប់ពី
គែមត្រង់ក្បាច់ក្រឡាអួន ហើយមានផ្លែទទឹម២០០ រៀង[ឌ]
ជា២ជួរនៅព័ទ្ធជុំវិញសសរទាំង២នោះដូចគ្នា ២១គាត់ក៏
លើកសសរទាំង២នោះបញ្ឈរឡើង នៅត្រង់បាំងសាច
នៃព្រះវិហារ កាលគាត់បានលើកសសរខាងស្តាំឡើង
នោះក៏ឱ្យឈ្មោះថា យ៉ាគិន រួចកាលគាត់លើកសសរខាង
ឆ្វេងឡើង នោះក៏ឱ្យឈ្មោះថាបូអូស[ឍ] ២២នៅខាងលើ
សសរមានក្បាច់ផ្កាច័ន្ទរ ដូច្នេះ ការធ្វើសសរ[ណ] នោះបាន
រួចជាស្រេច ។

២៣គាត់ក៏សិតធ្វើជាសមុទ្រ[ត] មានរាងមូលទំហំ១០ហត្ថ

កន្លែងសម្រាប់ដាក់អាវុធផងដែរ (មើល ១០:១៦–១៧) ។

**៧:៦** *សសរ* សសរនេះយើងអាចឃើញយ៉ាងច្បាស់ នៅច្រកចូលនៃមន្ទីរព្រៃល្បាណូន ។

**៧:៧** *បល្ល័ង្ក* នេះមិនច្បាស់ថា ជាសំណង់របស់ស្តេច(កន្លែងកាត់សេចក្តី) ដំណាក់របស់ស្តេចសាឡូម៉ូនរស់នៅ និងដំណាក់របស់បុត្រីផារ៉ោន ដែលត្រូវបានគេបែងចែក ឬជាមន្ទីរនៃព្រៃល្បាណូន ។

**៧:៨** *អារដំរីម ដោយរណា* ថ្មពណ៌ស៊ីជម្ពូរ គឺមានភាពងាយស្រួលក្នុងការកាត់ ឬដាប់នៅកន្លែងយកថ្មនោះតែម្តង ហើយក្រោយបន្ទាប់មកវាឡើងរឹង ហើយចាប់ផ្តើមមានពន្លឺ ។

**៧:១២** *ទីធ្លាធំ* ទីធ្លានេះត្រូវបានគេសង់ឡើងនៅក្នុងមធ្យោបាយដូចគ្នា និងទីធ្លាខាងក្នុងព្រះវិហារដែរ (៦:៣៦) ។

**៧:១៣** *ស្តេចសាឡូម៉ូន ទ្រង់ចាត់គេ* ការនេះស្តេចសាឡូម៉ូនបានធ្វើមុនពេលការបញ្ចប់នៃការសាងសង់ព្រះវិហារ និងការសាងសង់ព្រះរាជវាំងរបស់ស្តេចសាឡូម៉ូន (មើល ២របា ២:៧,១៣–១៤) ។

**៧:១៤** *ពូជអំបូរណែបថាលី* គម្ពីរ ២របា បញ្ជាក់ថា ជាកូនស្រីរបស់អ្នកស្រុកដាន់ ។ ស្ត្រីម្នាក់នេះ ពិតជាបានកើតនៅក្រុងដាន់ នៃអ៊ីស្រាអែលខាងជើង ជាប់សាច់ញាតិជាមួយនឹងសាសន៍ណែបថានី ដោយព្រោះប្តីទី១របស់នាង ។ ក្រោយពីប្តីរូបនេះ បានស្លាប់ទៅ នាងបានរៀបការជាមួយនឹងបុរសម្នាក់មកពីស្រុកទីរ៉ុស ។ *ថ្វីដៃចេះគ្រប់ទាំងរបស់លង្ហិន* ឃ្លានេះបញ្ជាក់ថា ស្ត្រីម្នាក់នេះ ជំនាញច្រើនផងដែរ (២របា ២:៧,១៤) ។

**៧:១៥** *សសរ២ដោយលង្ហិន* សសរនេះ មានទីតាំងស្ថិតនៅជាយច្រកចូលដ៏សំខាន់នៃព្រះវិហារ (ខ.២១) ដែលរចនាតាមក្បាច់ដ៏ស្រស់ស្អាត ហើយប្រហែលជាបានតំណាងជានិមិត្តសញ្ញាណាមួយ ដែលយើងទាំងអស់គ្នាមិនអាចយល់បាន ។ ហើយអ្នកខ្លះទៀតយល់ថា សសរដែលឈរយ៉ាងត្រង់ដូចនេះ ត្រូវបានគេរកឃើញ នៅក្នុងកំណាយមជ្ឈឹមបូព៌ា ។ ហើយតាមប្រភពផ្សេងទៀត បញ្ជាក់ថា សសរនេះសម្រាប់ទ្រដំបូលព្រះវិហារ ។

**៧:១៦** *កំពស់៥ហត្ថ* មើល ២ពវ និងការពន្យល់ ។

**៧:២១** *សសរខាងស្តាំ* មើល អគ ៨:១៦ ។

គឺពីមាត់ម្ខាង ទៅដល់ម្ខាង ហើយកំពស់៥ហត្ថ បើយកខ្សែ[ថ]
វាស់ជុំវិញ នោះត្រូវជា៣០ហត្ថ [២៤]នៅក្រោមគែមជុំវិញ
មានក្បាច់ផ្កាក្រពុំ១០ក្នុង១ហត្ថ នៅព័ទ្ធជុំវិញ ផ្កាក្រពុំទាំង
នោះបានសិតជា២ជួរ ក្នុងកាលដែលគេសិត សមុទ្រនោះ
តែម្តង [២៥]ក៏ដាក់លើរូបគោ១២[ទ] ដែលមាន៣បែរទៅខាង
ជើង ៣បែរទៅខាងលិច ៣បែរទៅខាងត្បូង ហើយ៣បែរ
ទៅខាងកើត សមុទ្រនោះបានដាក់ដំកល់លើខ្នងគោ ហើយ
គូថរបស់គោទាំងនោះ បែរទៅខាងក្នុងទាំងអស់ [២៦]តួ
សមុទ្រនោះមានកំរាស់១ទះ មានគែមដូចជាមាត់ពែង
ហើយរាងដូចផ្កាច័ន្ទរក៏មានចំណុះបានទឹក២ពាន់អម្រែក។
[២៧]គាត់ក៏ធ្វើគ្រោង[ធ]លង្ហិន១០ បណ្តោយ៤ហត្ថ ទទឹង៤
ហត្ថ ហើយកំពស់៣ហត្ថ [២៨]គ្រោងទាំងនោះបានធ្វើយ៉ាង
ដូច្នេះ គឺមានបន្ទះ ដែលមានក្របជុំវិញ ហើយមានក្រប
ខណ្ឌកណ្តាលទៀត [២៩]ឯបន្ទះទាំងប៉ុន្មានដែលនៅកណ្តាល
ក្របនោះមានឆ្លាក់ជារូបសិង្ហ គោ ហើយនិងចេរូប៊ីន ឯនៅ
ខាងលើក្របនោះ មានជើងកំណល់ ហើយក្រោម រូបសិង្ហ
និងគោនោះមានក្បាច់វិយោល [៣០]គ្រោងមួយៗ[ន] នោះមាន
កង់លង្ហិន៤ និងភ្លៅលង្ហិនដែរ ឯជើងកំណល់របស់គ្រោង
ទាំងនោះ មានប្រដាប់ទ្រដែលសិតភ្ជាប់ទាំង៤ជ្រុង ពីក្រោម
ចានក្លាំមានទាំងក្បាច់កំរងខាងៗទាំងអស់ [៣១]ខាងក្នុង
គ្រោងនោះ មានកំណល់បែប ដូចជាជើងតាំងកំពស់១ហត្ថ
រាងមូល១ហត្ថកន្លះ មានក្បាច់ចំឡាក់ផង តែបន្ទះទាំង
ប៉ុន្មាន ត្រូវជា៤ជ្រុងវិញ មិនមែនមូលទេ [៣២]ឯខាង ក្រោម
បន្ទះ នោះមានកង់៤ភ្លៅកង់ទាំងនោះនៅ ជាប់នឹងតួគ្រោង
កង់១កំពស់១ហត្ថកន្លះ [៣៣]ឯរបៀបធ្វើកង់ទាំងនោះ ក៏ដូច
ជាធ្វើកង់រទេះចំបាំង គឺមានទាំងភ្លៅ ទាំងខ្នងកង់ទាំងកាំ
នឹងដុំផង គ្រឿងទាំង នោះបានសិត ដោយលង្ហិនទាំងអស់
[៣៤]នៅត្រង់ជ្រុងទាំង៤របស់គ្រោងទាំងនោះ មានកំណល់
ដែលសិតជាប់ជាមួយនឹងតួគ្រោងនោះឯង [៣៥]ហើយពីខាង
លើជញ្ជាំងគ្រោងនោះ មានបន្ទះចេញជារាងមូល កំពស់
កន្លះហត្ថឯខាងលើបន្ទះនោះ និងជើងកំណល់បានភ្ជាប់
ជាមួយគ្នា [៣៦]គាត់ក៏ឆ្លាក់ជារូបចេរូប៊ីន សិង្ហ និងដើមលម៉ើ
នៅនឹងបន្ទះ ដែលជាប់នឹងជើងកំណល់ ហើយនឹងបន្ទះ
ដែលជាប់ក្នុងក្របទាំងនោះ តាមកន្លែងដែលឆ្លាក់បាន
ហើយមានក្បាច់វិយោលជុំវិញដែរ [៣៧]គឺយ៉ាងនោះដែល
គាត់ធ្វើគ្រោងទាំង១០នោះ ទាំងអស់សិតពីពុម្ពតែ១ មាន
ទំហំមានរាងដូចគ្នា ។
[៣៨]គាត់ក៏ធ្វើចានក្លាំលង្ហិន[ប]១០ ចានមួយៗចំណុះទឹក៤០
អម្រែក មានទំហំ៤ហត្ថ ហើយគ្រប់គ្រោងទាំង១០នោះមាន
ចានក្លាំមួយៗ [៣៩]រួចគាត់ដាក់គ្រោង៥នៅខាងស្តាំព្រះ
វិហារ ហើយ៥នៅខាងឆ្វេង រួចក៏ដាក់សមុទ្រនោះ ត្រង់
ខាងស្តាំព្រះវិហារ ទិសខាងកើតឆៀងខាងត្បូង ។
[៤០]ហ៊ីរ៉ាមក៏ធ្វើចានក្លាំ ចបចូក និងខ្ទះទាំងប៉ុន្មាន[ផ] ដូច្នេះ
ហ៊ីរ៉ាម គាត់ធ្វើប្រដាប់ទាំងអស់ជាស្រេច ថ្វាយស្តេច
សាឡូម៉ូន សំរាប់ព្រះវិហារនៃព្រះយេហូវ៉ា [៤១]គឺសសរទាំង
២តួ ក្បាលសសរទាំង២ ដែលនៅលើកំពូលសសរនឹង
ក្បាច់ក្រឡាអួន សំរាប់បិទតួក្បាលសសរ ដែលនៅលើ
កំពូលសសរនោះជុំវិញ [៤២]ហើយផ្លែទទឹមទាំង៤០០ សំរាប់
ក្បាច់ក្រឡាអួននោះ គឺផ្លែទទឹម២ជួរសំរាប់ក្បាច់ក្រឡាអួន
មួយៗ[ព] ដើម្បីនឹងបាំងទីភ្ជាប់តួក្បាលសសរទាំង២នោះ
[៤៣]ព្រមទាំងគ្រោង១០ និងចានក្លាំ១០ ដែលនៅលើគ្រោង
ទាំងនោះ[៤៤]នឹងសមុទ្រ១ ហើយគោទាំង១២ ដែលទ្រពីខាង
ក្រោម [៤៥]ហើយទាំងឆ្នាំង ចបចូក និងខ្ទះទាំងប៉ុន្មាន[ភ] គឺ
ប្រដាប់ទាំងនោះឯង ដែលហ៊ីរ៉ាម[ម]បានធ្វើថ្វាយស្តេច
សាឡូម៉ូន សំរាប់ព្រះវិហារនៃព្រះយេហូវ៉ា នោះសុទ្ធតែ
ធ្វើពីលង្ហិន ហើយខាត់រំលីងផង [៤៦]ស្តេចទ្រង់ឲ្យគេសិត
ប្រដាប់ទាំងនោះ ក្នុងពុម្ពដីឥដ្ឋ ដែលនៅវាល[យ]ទន្លេយ័រដាន់
ត្រង់កណ្តាលភូមិស៊ិកូត[រ] និងសាថាន[ល] [៤៧]សាឡូម៉ូនទ្រង់មិន

**៧:២៣** ថ យរ ៣១:៣៩ សក ២:១
**៧:២៥** ទ យរ ៥២:២០
**៧:២៧** ធ ២ពវ ១៦:១៧
**៧:៣០** ន ២ពវ ១៦:១៧
**៧:៣៨** ប នក ៣០:១៨
**៧:៤០** ផ នក ២៧:៣ យរ ៥២:១៨
**៧:៤២** ព ខ.១៦
**៧:៤៥** ភ នក ២៧:៣ យរ ៥២:១៨ ម ខ.១៣
**៧:៤៦** យ លប ១៣:១០ រ លប ៣៣:១៧ ល យស ៣:១៦

**៧:២៣** *សិតធ្វើជាសមុទ្រមានរាងមូល* នេះជាទឹកដែលគេស្តុកទុក ដែលស្រដៀងគ្នានឹងចានក្លាំ ដែលគេដាក់នៅរោងឧបោសថ (នក ៣០:១៧–២១ ៣៨:៨) ។ ទឹកដែលគេដាក់នៅក្នុង ចាននេះត្រូវបានប្រើដោយពួកសង្ឃនៅក្នុងពិធីលាងសំអាត (២រប ៤:៦) ។

**៧:២៦** *២ពាន់អម្រែក* មើល ២រប ៤:៥ និងការពន្យល់ ។

**៧:២៧–៣៩** នៅត្រង់នេះបង្ហាញ ពីចានក្លាំ១០ដែលអាចលើកទៅលើកមកបាន សម្រាប់ការលាងសំអាតសត្វផ្សេងៗដើម្បីបូជា ។

**៧:៤០** *ចានក្លាំ* ចាននេះប្រហែលប្រើក្នុងការចំអិនសាច់ដើម្បីបរិភោគ ក្នុងការភ្ជាប់ទំនាក់ទំនងនឹងការថ្វាយដង្វាយមេត្រី (សូមមើល លវ ៧:១១–១៧ ២២:២១–២៣) ។ *ចបចូក* ប្រើសម្រាប់ជ្រោយផេះ នៅលើអាសនា ។

**៧:៤១** *សសរទាំង២* មើល ខ.១៧ ។

**៧:៤២** *ផ្លែទទឹមទាំង៤០០* មើល ខ.១៨,២០ ។

**៧:៤៣** *គ្រោង១០ និងចានក្លាំ១០* មើល ខ.២៧–៣៧ ។ ចានក្លាំនេះអាចលើកបានគ្រប់ទីកន្លែងដែលជាតម្រូវការ ។

**៧:៤៤** *សមុទ្រ១ គោទាំង១២* មើល ខ.២៣–២៦ ។

**៧:៤៥** *ឆ្នាំង ចបចូក និងខ្ទះទាំងប៉ុន្មាន* មើល ខ.៤០ ។

**៧:៤៦** *ភូមិស៊ិកូត* ភូមិនេះមានទីតាំងនៅខាងកើតទន្លេយ័រដាន់ (លប ៣៣:១៧ យស ១៣:២៧ ពច ៨:៤–៥) ភាគខាងជើងនៃស្ទឹងយ៉ាបុក ។ តាមកំណាព្យបុរាណវិទ្យា នៅតំបន់នេះបានបញ្ជាក់ថា តំបន់នេះជាមជ្ឈមណ្ឌលសិក្សានៅអំឡុង របបរាជានិយម ។ *សារថាន* ភូមិនេះស្ថិតនៅក្នុងក្រុងអាដាំ (សូមមើល យស ៣:១៦) និងក្រុងអេបិល–មហូឡា (សូមមើល ៤:១២) ។

បានថ្លឹង[វ] របស់ទាំងនោះទេ ពីព្រោះមានច្រើនក្រៃលែង[ស]
ហើយ ដែលលង្ហិន[ហ]ទាំងនោះទំងន់ប៉ុណ្ណា នោះក៏គ្មានអ្នក
ណារកដឹងបានឡើយ ។
៤៨ រួចមក សាឡូម៉ូនក៏ធ្វើក្រប់អស់[ឡ]ទាំងគ្រឿងប្រដាប់
ដែលនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា គឺជាអាសនាមាស
តុ[អ]មាសសំរាប់ដាក់នំបុ័ងតាំងទុក[ក] ៤៩ ជើងចង្កៀង[ខ]មាស
សុទ្ធទាំងប៉ុន្មាន ៥ខាងស្តាំ ៥ខាងឆ្វេង នៅមុខទីបរិសុទ្ធ
បំផុត ព្រមទាំងផ្កាចង្កៀង និងឃ្នាបប្រឆេះធ្វើពីមាស
៥០ ហើយទាំងឆ្នាំង ដង្កៀប ចានគោម កូនចាន[គ] និងពានធ្វើ
ពីមាស[ឃ]សុទ្ធទាំងអស់ ក៏ធ្វើត្រចៀកទ្វារមាសសំរាប់ទ្វារនៃ
ព្រះវិហារខាងក្នុង គឺជាទ្វារនៃទីបរិសុទ្ធបំផុត ហើយសំរាប់
ទ្វារព្រះវិហារខាងក្រៅដែរ ។
៥១ ដូច្នេះ អស់ទាំងប្រដាប់ទាំងប៉ុន្មាន ដែលស្តេច
សាឡូម៉ូនបានធ្វើ សំរាប់ព្រះវិហារនៃព្រះយេហូវ៉ា នោះ
បានធ្វើរួចជាស្រេចហើយ[ង] ទ្រង់ក៏នាំយករបស់ទាំងប៉ុន្មាន
ដែលដាវីឌ ជាបិតាទ្រង់ បានថ្វាយចូលមកដែរ គឺប្រាក់
មាស និងគ្រឿងប្រដាប់ទាំងអស់[ច] ក៏ដាក់ទុកនៅក្នុងឃ្លាំង
នៃព្រះវិហារព្រះយេហូវ៉ា ។

## ការនាំយកហឹបនៃសេចក្តីសញ្ញាទៅកាន់ព្រះវិហារ

*៨:១–២១ – ២របា ៥:២–៦:១១*

៨ ១ រួចមក សាឡូម៉ូនទ្រង់ប្រមូលពួកចាស់ទុំនៃសាសន៍
អ៊ីស្រាអែល និងពួកអ្នកដែលជាប្រធាន[ក]លើពូជអំបូរទាំង
ប៉ុន្មាន ហើយពួកអ្នកដែលជាកំពូលលើវង្សានុវង្សនៃពួក
កូនចៅអ៊ីស្រាអែលទាំងអស់ ឲ្យមកឯទ្រង់ នៅក្រុងយេរូ–
សាឡិម ដើម្បីនឹងនាំយកហឹបនៃសេចក្តីសញ្ញា[ខ]ផងព្រះ
យេហូវ៉ាពីក្រុងដាវីឌ គឺជាក្រុងស៊ីយ៉ូនឡើងមក[គ]
២ ដូច្នេះ
ពួកបណ្តាជន សាសន៍អ៊ីស្រាលអែលទាំងអស់ក៏មក ក៏ប្រជុំ
គ្នាឯស្តេចសាឡូម៉ូន នៅវេលាបុណ្យ[ឃ] ក្នុងខែអស្សុជ គឺជា
ខែទី៧[ង]
៣ ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលទាំងអស់ក៏មក
ហើយពួកសង្ឃ[ច]ក៏លើកហឹបសែងទៅ
៤ គេនាំយកហឹបនៃ
ព្រះយេហូវ៉ា ព្រមទាំងត្រសាលជំនុំ[ឆ] និងគ្រឿងប្រដាប់
បរិសុទ្ធទាំងប៉ុន្មាន ដែលនៅក្នុងត្រសាលឡើងមកផង គឺ
ពួកសង្ឃ និងពួកលេវី[ជ]ដែលសែងឡើងមក
៥ រួចស្តេច
សាឡូម៉ូន និងពួកជំនុំសាសន៍អ៊ីស្រាអែលទាំងអស់ ដែល
បានប្រជុំគ្នាមកឯទ្រង់ គេនៅជាមួយនឹងទ្រង់ នៅត្រង់មុខ
ហឹប កំពុងតែបូជាថ្វាយ[ឈ]ចៀម និងគោយ៉ាងសន្ធឹក ដែល
នឹងរាប់ចំនួនមិនអស់ឡើយ
៦ រួចពួកសង្ឃក៏សែងយកហឹបនៃ
សេចក្តីសញ្ញា[ញ]ផងព្រះយេហូវ៉ាចូលទៅ ដំកល់ទុកនៅ
កន្លែងដែលបំរុងទុកឲ្យ គឺនៅទីទទួលព្រះបន្ទូល ជាទី
បរិសុទ្ធបំផុត[ដ]ត្រង់ក្រោមស្លាបនៃចេរូប៊ីន[ឋ] ក្នុងព្រះវិហារ
៧ ដ្បិតចេរូប៊ីនទាំង២ត្រដាងស្លាប ពីលើកន្លែងដែលដំកល់
ទុកហឹបនោះ ចេរូប៊ីនក៏គ្រប់នៅ[ឌ]ពីលើហឹប និងឈើស្នែង
របស់ហឹបផង
៨ គេបានធ្វើឈើស្នែងនោះឲ្យវែង ដល់ម្ល៉េះ
បានជាមើលឃើញពីត្រង់ទីបរិសុទ្ធ ជាទីដែលនៅមុខទី

**៧:៤៧** វ ១របា ២២:៣ យរ ៥២:២០ ស នក ៣៦:៥–៧ ហ ខ.២៣ **៧:៤៨** ឡ នក ៣៩:៣២–៤៣ អ នក ២៥:២៣ ក នក ២៥:៣០ **៧:៤៩** ខ នក ២៥:៣១–៣៨ **៧:៥០** គ ជន ៧:១៤ ឃ ២ពវ ២៥:១៣ យរ ៥២:១៩ **៧:៥១** ង ២សយ ៨:១១ ច ២ពវ ១២:១៣ ២៤:១៣ យរ ២៧:១៩ **៨:១** ក ជន ៧:២ ខ ១សយ ៣:៣ វវ ១១:១៩ គ ២សយ ៥:៧ **៨:២** ឃ ខ.៦៥ លវ ២៣:៣៦ នហ ៨:១៧ ង លវ ២៣:៣៤ ជន ២៩:១២ **៨:៣** ច យស ៣:៣ **៨:៤** ឆ លវ ១៧:៤ ជ ១របា ១៥:១៣ **៨:៥** ឈ ២សយ ៦:១៣ ២របា ១៥:១៣ **៨:៦** ញ នក ២៦:៣៣ ២សយ ៦:១៧ វវ ១១:១៩ ដ នក ២៦:៣៣ ឋ លប ៣:២៤ នក ២៥:១៨ **៨:៧** ឌ នក ២៥:២០ **៨:៨** ឍ នក ២៥:១៣–១៥

**៧:៤៨** *អាសនាមាស* មើល ៦:២២ ។ *តុមាស* តុនេះសម្រាប់ដាក់នំបុ័ងតាំងទុក(មើល នក ២៥:២៣–៣០ ១របា ៩:៣២ ២របា ១៣:១១ ២៩:១៨) ។ តុមាសនេះ មាននិយាយចំនួន១០ដងនៅក្នុង ១របា ២៨:១៦ និង ២របា ៤:៨,១៩ ។

**៧:៤៩** *ជើងចង្កៀងមាសសុទ្ធ* ជើងចង្កៀងមាសនេះមានតែមួយគត់ដែលមានដៃប្រាំពីរដែលបញ្ឈរនៅក្នុងរោងឧបោសថ ដែលទុលមុខនឹងតុនំបុ័ងតាំងទុក (នក ២៥:៣១–៤០ ២៦:៣៥) ។ ជើងចង្កៀងនេះមានចំនួន១០ដែលតម្កល់នៅក្នុងវិហារ ហើយចំនួនប្រាំដាក់នៅទិសខាងជើង ហើយនិងប្រាំទៀតដាក់នៅទិសខាងត្បូង ដែលបង្កើតបានជាពន្លឺនៅទីបរិសុទ្ធ ។ *ផ្កាចង្កៀង* មើល នក ២៥:៣៣ ។ *ចង្កៀង* មើល នក ២៥:៣៧ ។ *ឃ្នាប* មើល ២របា ៤:២១ អស ៦:៦ ។

**៧:៥០** *ពាន* មើល ២ពវ ២៥:១៥ ២របា ៤:២២ យរ ៥២:១៨–១៩ ។

**៧:៥១** *របស់ទាំងប៉ុន្មានដែលដាវីឌ ជាបិតាទ្រង់បានថ្វាយ* នៅត្រង់នេះបានប្រាប់ពីវត្ថុមានតម្លៃមួយចំនួនដូចជា មាស ប្រាក់ ដែលស្តេចដាវីឌរឹបអូសពីសង្គ្រាម និងទទួលបានមកពីស្តេចដទៃនោះ ទ្រង់បានប្រមូលរបស់ទាំងអស់នេះមកទុកក្នុងឃ្លាំងនៃព្រះយេហូវ៉ា(មើល ២សយ ៨:៩–១២ ១របា ១៨:៧–១១ ២របា ៥:១) ។ *គ្រឿងប្រដាប់ទាំងអស់ . . . ឃ្លាំងនៃព្រះយេហូវ៉ា* មើល ១៥:១៨ ២ពវ ១២:១៨ ១របា ៩:២៦ ២៦:២០–២៦ ២៨:១២ ។

**៨:១** *នាំយកហឹបនៃសេចក្តីសញ្ញាផងព្រះយេហូវ៉ា* កាលពីមុនសម័យស្តេចដាវីឌ បាននាំហឹបសញ្ញាពីផ្ទះលោក អូបិឌ–អេដំម ទៅក្នុងយេរូសាឡឹម (សូមមើល ២សយ ៦) ។ *ក្រុងដាវីឌ គឺជាក្រុងស៊ីយ៉ូន* មើលការពន្យល់ ២សយ ៥:៧ ។

**៨:២** *វេលាបុណ្យ* នៅត្រង់នេះបានបញ្ជាក់យ៉ាងច្បាស់ថា ស្តេចសាឡូម៉ូនបានរង់ចាំអស់រយៈពេល១១ខែ ដើម្បីថ្វាយព្រះវិហារដល់ព្រះយេហូវ៉ានៅថ្ងៃបុណ្យបារាំ (មើល ៦:៣៨) ដែលត្រូវនឹងខែទីប្រាំពីរនៃឆ្នាំដែលមានចំនួនខែដប់ពីរ(លវ ២៣:៣៤ ចទ ១៦:១៣–១៥) ។ *ខែទី៧* ខែនេះជាការសន្មតយ៉ាងច្បាស់មួយថា ជាឆ្នាំទី១២នៃការឡើងគ្រងរាជ្យរបស់ស្តេចសាឡូម៉ូន ។

**៨:៤** *ត្រសាលជំនុំ* នេះជារោងឧបោសថ ដែលគេរក្សានៅឯគីបៀន(មើលពន្យល់ ៣:៤ ១សយ ៧:១ មើលបន្ថែម ២របា ៥:៤–៥) ។

**៨:៦** *ក្រោមស្លាបនៃចេរូប៊ីន* មើល ៦:២៣–២៨ ។

**៨:៨** *បានជាមើលឃើញ* មើល នក ២៥:១៥ ។ *នៅទីនោះដល់សព្វថ្ងៃ* ឃ្លាទាំងប៉ុន្មាននៃចំណុចនេះជាគំនិតរបស់អ្នកនិពន្ធដើម ដែលរៀបរាប់ពីការថ្វាយព្រះវិហារដល់ព្រះយេហូវ៉ា ប្រសើរជាងការចងក្រងនៅទីបញ្ចប់

ទូលព្រះបន្ទូលបាន តែមិនបានឃើញពីខាងក្រៅទេ ហើយក៏
នៅទីនោះ ៩ឯនៅក្នុងហឹប នោះមានតែបន្ទះថ្ម២ផ្ទាំង[ណ]
ប៉ុណ្ណោះ ដែលលោកម៉ូសេបានដាក់ ពីកាលនៅត្រង់ភ្នំ
ហោរែប នៅគ្រាដែលព្រះយេហូវ៉ាបានតាំងសញ្ញា និងពួក
កូនចៅអ៊ីស្រាអែល ក្រោយដែលគេចេញពីស្រុកអេស៊ីព្ទមក
១០លុះពួកសង្ឃបានចេញពីទីបរិសុទ្ធមកវិញ នោះពពក[ត]ក៏
មកពេញក្នុងព្រះវិហារនៃព្រះយេហូវ៉ា ១១ដល់ម្ល៉េះបានជា
ពួកសង្ឃឈរធ្វើការងារពុំបាន[ថ] ដោយព្រោះពពកនោះ
ដ្បិតសិរីល្អ[ទ] នៃព្រះយេហូវ៉ាបាននៅពេញ ក្នុងព្រះវិហារ
នៃព្រះអង្គហើយ ។
១២គ្រានោះ សាឡូម៉ូនទ្រង់ពោលថា ព្រះយេហូវ៉ាបាន
មានបន្ទូលថា ទ្រង់នឹងគង់នៅក្នុងទីងងឹតយ៉ាងក្រាស់[ធ]
១៣ដូច្នេះ ទូលបង្គំបានស្អាង ព្រះវិហារនេះថ្វាយទ្រង់គង់ទុក
ជាទីលំនៅ[ន]ឱ្យទ្រង់គង់នៅអស់កល្បជានិច្ច ១៤រួចស្តេចទ្រង់
បែរ ព្រះភក្ត្រមក ប្រទានពរ[ប]ដល់ពួកជំនុំសាសន៍អ៊ីស្រា–
អែលទាំងអស់ ដែលគេកំពុងតែឈរនៅ ១៥ទ្រង់មានបន្ទូល
ថា សូមឱ្យព្រះយេហូវ៉ា[ផ] ជាព្រះនៃសាសន៍អ៊ីស្រាអែលបាន
ប្រកបដោយព្រះពរ ជាព្រះដែលទ្រង់មានបន្ទូលនឹងដាវីឌ
ជាបិតានៃយើង ដោយព្រះឱស្ឋទ្រង់ ហើយបានសំរេចព្រះ
បន្ទូលនោះ ដោយសារព្រះហស្តទ្រង់ថា ១៦ចាប់តាំងពីថ្ងៃ
ដែលអញបាននាំអ៊ីស្រាអែល ជារាស្ត្រអញចេញពីស្រុក
អេស៊ីព្ទមក[ព] នោះអញមិនបានរើសទីក្រុងណាមួយក្នុងពូជ
អំបូរ សាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន ដើម្បីនឹងស្អាងវិហារ
ឱ្យឈ្មោះ[ភ]អញបាន នៅទីនោះឡើយ តែងអញបានរើស[ម]
ដាវីឌ[យ]តាំងឡើង ឱ្យគ្រប់គ្រងលើសាសន៍អ៊ីស្រាអែលជា
រាស្ត្រអញ ១៧រីឯបំណងព្រះទ័យ[រ]នៃដាវីឌជា បិតាយើង
នោះទ្រង់ចង់ស្អាងព្រះវិហារ[ល]ថ្វាយព្រះនាមព្រះយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែលទៅហើយ ១៨តែព្រះយេហូវ៉ា

**៨:៩** ណ នក ១៦:៣៤ ២៥:១៦ ហព ៩:៤
**៨:១០** ត នក ១៦:១០ លវ ១៦:២ វវ ១៥:៨
**៨:១១** ថ ២រប ៧:២ វវ ១៥:៨ ទ នក ១៦:៧ ២៩:៤៣
**៨:១២** ធ នក ៤០:៣៤ ២សយ ២២:១០
**៨:១៣** ន នក ១៥:១៧ ទដ ១៣២:១៣ ១៣៥:២១ មថ ២៣:២១
**៨:១៤** ប នក ៣៩:៤៣
**៨:១៥** ផ ១រប ១៥:៣៦ លក ១:៦៨
**៨:១៦** ព នក ៣:១០ ភ ចទ ១២:៥ ម ១សយ ៩:១៦ ១៦:១ យ ទដ ៨៩:៣–៤
**៨:១៧** រ ១សយ ១០:៧ កច ៧:៤៦ ល ២សយ ៧:២៧ ១រប ២២:៧ ទដ ២៦:៨ ១៣២:៥
**៨:១៩** វ ២សយ ៧:៥ ស ២សយ ៧:១៣
**៨:២០** ហ ២សយ ៧:១២ ឡ ១រប ២៨:៦

ទ្រង់មានបន្ទូលនឹងដាវីឌ ជាបិតាយើងថា ដែលឯងមានចិត្ត
ចង់ស្អាងវិហារសំរាប់ឈ្មោះអញ នោះបានល្អហើយ
ដោយអញមានបំណងចិត្តដូច្នោះ ១៩ប៉ុន្តែមិនត្រូវឱ្យឯង[វ]
ស្អាងវិហារនោះទេ គឺជាកូនដែលឯងនឹងបង្កើតមក កូន
នោះនឹងស្អាងសំរាប់ឈ្មោះអញវិញ[ស] ២០ដូច្នេះព្រះយេហូវ៉ា
ទ្រង់បានសំរេចតាមព្រះបន្ទូលនោះហើយ ដ្បិតយើងនេះ
បានកើតឡើង ជំនួស[ហ]ដាវីឌ ជាបិតាយើង ក៏អង្គុយលើ
បល្ល័ង្ករាជ្យនៃសាសន៍អ៊ីស្រាអែល ដូចជាព្រះយេហូវ៉ាបាន
សន្យា ហើយយើងបានស្អាង[ឡ]ព្រះវិហារនេះ ថ្វាយព្រះនាម
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ២១ក៏បានតាំង
កន្លែងនៅទីនេះ ទុកសំរាប់ហឹប ដែលមានសេចក្ដីសញ្ញានៃ
ព្រះយេហូវ៉ា ជាសេចក្តីដែលទ្រង់បានតាំងនឹងពួកឰយុកោ
យើង ពីកាលទ្រង់នាំគេចេញពីស្រុកអេស៊ីព្ទមក ។

## ការអធិស្ឋានរបស់ស្តេចសាឡូម៉ូន

*៨:២២–៥៣ – ២រប ៦:១២–៤០*

២២រួចមក សាឡូម៉ូនទ្រង់ឈរនៅមុខអាសនានៃព្រះ
យេហូវ៉ា ចំពោះមុខពួកជំនុំអ៊ីស្រាអែលទាំងអស់គ្នា ក៏លើក
ព្រះហស្ត[អ]ប្រទូលទៅលើមេឃថា ២៣ឱព្រះយេហូវ៉ាជា
ព្រះនៃសាសន៍អ៊ីស្រាអែលអើយ គ្មានព្រះឯណាឱ្យដូច[ក]ទ្រង់
ឡើយ ទោះនៅផ្ទៃមេឃខាងលើឬនៅផែនដី ខាងក្រោមក្តី
ទ្រង់កាន់តាមសេចក្តីសញ្ញា និងសេចក្តីសប្បុរស[ខ]ដល់ពួក
បាវបំរើទ្រង់ ដែលខំដើរនៅចំពោះទ្រង់អស់ពីចិត្ត ២៤ទ្រង់
បានកាន់តាមសេចក្តីសន្យា ដែលទ្រង់មានបន្ទូលនឹងដាវីឌ
អ្នកបំរើទ្រង់ ជាបិតាទូលបង្គំ គឺទ្រង់បានមានបន្ទូលដោយ
ព្រះឱស្ឋ ហើយបានសំរេចតាម ដោយសារព្រះហស្តទ្រង់
ដូចជាមានសព្វថ្ងៃនេះ ២៥ដូច្នេះ ឱព្រះយេហូវ៉ា ជាព្រះនៃ

**៨:២២** អ នក ៩:២៩ **៨:២៣** ក នក ៩:១៤ ខ ចទ ៧:៩,១២ នហ ១:៥ ៩:៣២ ដយ ៩:៤

នៃគម្ពីរពង្សាវតាក្សត្រ (មើលសេចក្តីផ្តើម ចំណុចអ្នកនិពន្ធ ប្រភពនិងកាល បរិច្ឆេទ មើលបន្ថែម ២រប ៥:៩) ។

**៨:១០** *ពពកក៏មកពេញ ក្នុងព្រះវិហារ* នៅត្រង់នេះពួកគេអាចមើលឃើញពីវត្តមានរបស់ព្រះយេហូវ៉ា ដែលបានយាងចុះមកនៅទីឧបោសថនៅភ្នំស៊ីណាយដូច្នេះពេលនេះព្រះអម្ចាស់បានចុះមកហើយសណ្ឋិតនៅក្នុងព្រះវិហារនេះតែម្តង (មើល នក ៤០:៣៣–៣៥ អគ ១០:៣–៥,១៨–១៨ ៤៣:៤–៥) ។

**៨:១២** *ទ្រង់នឹងគង់នៅទីងងឹតយ៉ាងក្រាស់* មើល នក ១៩:៩ ២៤:១៥,១៨ ៣៣:៩–១០ ៣៤:៥ លវ ១៦:២ ចទ ៤:១១ ៥:២២ ទដ ១៨:១០–១១ ។

**៨:១៥** *ព្រះដែលទ្រង់មានបន្ទូល* មើល ២សយ ៧:៥–១៦ ។

**៨:១៦** *មិនបានរើសទីក្រុងណាមួយ* មើល ចទ ១២:៥ និងការពន្យល់ ។ *ឱ្យឈ្មោះអញ* សូមមើល ៣:២ និងការពន្យល់ ។

**៨:២១** *សេចក្តីសញ្ញានៃព្រះយេហូវ៉ា* នេះជាបន្ទះក្រឹត្យវិន័យពីរ ដែលមាននិយាយពីរក្រឹត្យវិន័យទាំង១០ប្រការ (មើល នក ២៥:១៦ និងការពន្យល់ ហព ៩:៤) ។

**៨:២២** *លើកព្រះហស្តប្រទូលទៅលើមេឃថា* នេះជាការអធិស្ឋាន(មើល នក ៩:២៩ និងការពន្យល់) ។

**៨:២៣** *គ្មានព្រះឯណាឱ្យដូចទ្រង់ឡើយ* នេះបញ្ជាក់ថា គ្មានព្រះឯណាទៀតបានដើរតួនៅក្នុងប្រវត្តិសាស្ត្រដូចព្រះរបស់ពួកអ៊ីស្រាអែល ដែលព្រះទ្រង់បានសំដែងការអស្ចារ្យ និងហេតុការណ៍ផ្សេងៗ ដូច្នេះ សេចក្តីសញ្ញារបស់ទ្រង់បានសម្រេចនៅ អនាគតយ៉ាងជាក់ច្បាស់ (មើល នក ១៥:១១ ចទ ៤:៣៩ ៧:៩ ទដ ៨៦:៨–១០) ។

**៨:២៤** *កាន់តាមសេចក្តីសន្យា* មើល ខ.១៥ ២សយ ៧:៥–១៦ ។

សាសន៍អ៊ីស្រាអែលអើយ សូមទ្រង់រក្សាសេចក្ដីនេះទៀត
ជាសេចក្ដីដែលទ្រង់បានសន្យា[ក] នឹងបិតាទូលបង្គំ គឺនឹង
ដាវីឌ ជាអ្នកបំរើទ្រង់ថា នឹងមិនដែលខានមានពូជឯង
អង្គុយលើបល្ល័ង្ករាជ្យ របស់សាសន៍អ៊ីស្រាអែល នៅមុខ
អញឡើយ ឱ្យតែកូនចៅឯងបានប្រុងប្រយ័ត្ននឹងដើរតាមផ្លូវ
នៅមុខអញ ដូចជាឯងបានដើរនោះដែរ ២៦ដូច្នេះ ឱព្រះនៃ
សាសន៍អ៊ីស្រាអែលអើយ ឥឡូវនេះ សូមទ្រង់បញ្ជាក់ព្រះ
បន្ទូលនៃទ្រង់ ដែលទ្រង់បានមានបន្ទូល[ឃ]នឹងបិតាទូលបង្គំ
គឺដាវីឌជាអ្នកបំរើទ្រង់ចុះ ២៧យីអើ តើព្រះនឹងគង់[ង]លើផែន
ដីជាប្រាកដឬ មើល ផ្ទៃមេឃនឹងអស់ទាំងជាន់នៃផ្ទៃមេឃ[ច]
នោះមិនល្មម[ឆ]ឱ្យទ្រង់គង់ចុះទៅហើយ ចំណង់បើព្រះវិហារ
ដែលទូលបង្គំបានស្អាងនេះ តើនឹងចង្អៀតអំបាលម៉ានទៅ
ទៀត ២៨ប៉ុន្តែឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ សូម
ទ្រង់ប្រោសមេត្តាទទួលពាក្យដែលទូលបង្គំ ជាបាវបំរើ
ទ្រង់អធិស្ឋាន ហើយទូលអង្វរ ដើម្បីនឹងស្តាប់តាមសំរែក
នឹងសេចក្ដីអធិស្ឋាន ដែលទូលបង្គំទូលសូមចំពោះទ្រង់នៅ
ថ្ងៃនេះ ២៩ប្រយោជន៍ឱ្យព្រះនេត្រទ្រង់ បានបើក[ជ]ទតមក[ឈ]ឯ
ព្រះវិហារនេះទាំងយប់ទាំងថ្ងៃ គឺទតមើលមកទីកន្លែង
ដែលទ្រង់បានមានបន្ទូលហើយថា ព្រះនាមទ្រង់[ញ]នឹងនៅ
ទីនេះ ដើម្បីនឹងស្តាប់សេចក្ដីអធិស្ឋាន ដែលទូលបង្គំជាបាវ
បំរើទ្រង់បានមានបន្ទូលហើយថា ព្រះនាមទ្រង់នឹងនៅទីនេះ
ដើម្បីនឹងស្តាប់សេចក្ដីអធិស្ឋាន ដែលទូលបង្គំ ជាបាវបំរើ
ទ្រង់នឹងទូលដំរង់មកឯទីនេះ ៣០ហើយកាលណាទូលបង្គំជា
បាវបំរើទ្រង់ និងពួកអ៊ីស្រាអែល ជារាស្ត្ររបស់ទ្រង់ និង
អធិស្ឋាន[ដ]ដំរង់មកឯទីនេះ នោះសូមទ្រង់ស្តាប់សេចក្ដីទូល

**៨:២៥** គ ២សយ ៧:១៥ ១រប ១៧:២៣ ២រប ១:៩ **៨:២៦** ឃ ២សយ ៧:២៥ **៨:២៧** ង កច ៧:៤៨ ១៧:២៤ ច ចទ ១០:១៤ ឆ ២រប ២:៦ ទដ ១៣៩:៧–១៦ អស ៦៦:១ យរ ២៣:២៤ **៨:២៩** ជ ខ.៥២ ២ពវ ១៩:១៦ ២រប ៧:១៥ នហ ១:៦ ទដ ៥:១ ៣១:២ ១០២:១៧ ១៣០:២ អស ៣៧:១៧ ឈ ទដ ២៨:២ ១៣៨:២ ដយ ៦:១០ ញ ចទ ១១:១២ ១២:១១ ២សយ ៧:១៣ **៨:៣០** ដ ខ.៤៧ លវ ២៦:៤០ នហ ១:៦ យរ ២៩:១២ ដយ ៩:៤ ឋ ខ.៣៩ ទដ ៣៤:៦ ឌ នក ៣៤:៧,៩ លវ ២៦:៤០–៤២ ទដ ៨៥:២ **៨:៣១** ឍ នក ២២:១១ **៨:៣២** ណ ចទ

អង្វរ របស់យើងខ្ញុំផង គឺសូមទ្រង់ស្តាប់[ឋ]ពី លើស្ថានសួគ៌
ជាទីលំនៅរបស់ទ្រង់ លុះកាលណាទ្រង់ព្រះសណ្ដាប់ហើយ
នោះសូមអត់ទោសឱ្យផង[ឌ] ។
៣១បើសិនជាអ្នកណាធ្វើបាប ចំពោះអ្នកជិតខាងខ្លួន
ហើយគេឱ្យអ្នកនោះស្បថ រួចអ្នកនោះក៏មកស្បថ[ឍ]នៅមុខ
អាសនានៃទ្រង់ ក្នុងព្រះវិហារនេះ ៣២នោះសូមទ្រង់ប្រោស
ស្តាប់ពីលើស្ថានសួគ៌ ហើយសំរេចការ ដោយជំនុំជំរះពួក
បាវបំរើទ្រង់ ទាំងដាក់ទោសដល់មនុស្សអាក្រក់ ដើម្បីនឹង
ទំលាក់អំពើអាក្រក់របស់គេ ទៅលើក្បាលគេវិញ ហើយ
សំរេចដល់មនុស្សសុច្ចរិតទុកជាសុច្ចរិត ដើម្បីនឹងសងដល់
គេ តាមសេចក្ដីសុច្ចរិតរបស់ខ្លួនគេទៅ[ណ] ។
៣៣បើកាលណាសាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ទ្រង់
ត្រូវចាញ់[ត]នៅមុខពួកខ្មាំងសត្រូវ ដោយព្រោះគេបានធ្វើ
បាប[ថ]នឹងទ្រង់ នោះបើគេត្រឡប់មកឯទ្រង់វិញ ព្រមទាំង
គោរពដល់ព្រះនាមទ្រង់ ហើយអធិស្ឋានទូលអង្វរដល់
ទ្រង់ក្នុងព្រះវិហារនេះ[ទ] ៣៤នោះសូមទ្រង់ប្រោសស្តាប់ពី
លើស្ថានសួគ៌ ហើយអត់ទោសចំពោះអំពើបាបរបស់ពួក
អ៊ីស្រាអែល ជារាស្ត្រទ្រង់ផង រួចសូមនាំគេត្រឡប់មកនៅ
ក្នុងស្រុក ដែលទ្រង់បានប្រទានមកពួកឰយុកោគេវិញ ។
៣៥បើកាលណាមេឃរាំងភ្លៀង[ធ] ដោយព្រោះគេបាន
ធ្វើបាបនឹងទ្រង់ នោះបើគេអធិស្ឋានមកឯទីនេះ ព្រមទាំង
គោរពដល់ព្រះនាមទ្រង់ ហើយលះបង់ចោលអំពើបាប[ន]
របស់គេចេញ ដោយព្រោះទ្រង់បានផ្ចាញ់ផ្ចាលគេ ៣៦នោះ

២៥:១ អគ ១៨:២០ **៨:៣៣** ត លវ ២៦:១៧ ថ លវ ២៦:៣៩ ទ អស ៣៧:១,១៤,៣៨ **៨:៣៥** ធ ចទ ២៨:២៤ ២សយ ១:២១ **៨:៣៥** ន យរ ៥:២៥

**៨:២៥** សូមមើល ៩:៤–៩ ២រប ៧:១៧–២២ មើលបន្ថែម ១ពវ ២:៤ ។

**៨:២៧** នៅត្រង់នេះស្ដេចសាឡូម៉ូនទ្រង់បានអធិស្ឋាន ទោះស្ថានសួគ៌ដ៏ខ្ពស់ក៏មិនល្មមនឹងទ្រង់គង់នៅដែរ គឺទ្រង់គង់នៅជាមួយនឹងអស់អ្នកណាដែលជឿលើទ្រង់ ។

**៨:២៩** *ព្រះនាមទ្រង់* មើលការពន្យល់ ៣:២ ។

**៨:៣០** *អធិស្ឋានដំរង់មកឯទីនេះ* នៅត្រង់នេះបញ្ជាក់ថា នៅពេលពួកអ៊ីស្រាអែលមិនអាចអធិស្ឋាននៅក្នុងព្រះវិហារ នោះស្ដេចសាឡូម៉ូនទ្រង់នឹងយាងមកទីនេះ ដែលជាទីដែលព្រះវត្តមានរបស់ព្រះទ្រង់បានសន្យាថានឹងយាងមកគង់នៅក្នុងចំណោមពួកគេ(សូមមើល ដយ ៦:១០ និងការពន្យល់ ខ.២៧) ។

**៨:៣១** *ឱ្យអ្នកនោះស្បថ* នៅត្រង់នេះបញ្ជាក់ថា នៅពេលគ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីឡើងទៅដល់ការតវ៉ាជាលក្ខណៈច្បាប់ នោះពួកគេតម្រូវឱ្យចូលមកស្បថនៅក្នុងទីបរិសុទ្ធដើម្បីបញ្ជាក់ពីភាពស្អាតស្អំរបស់ពួកគេ ។ ដូចនៅក្នុងករណីអ្នកណាដែលធ្វើហុសចំពោះអ្នកជិតខាង(នក ២២: ១០–១២) ឬពោលពាក្យអាសអាភាស(ជន ៥:១១–៣១) នោះត្រូវចូលមកទីនេះដើម្បីបញ្ជាក់ពីភាពស្អាតស្អំរបស់ខ្លួនផងដែរ ។

**៨:៣២** *ស្តាប់ពីស្ថានសួគ៌* នៅត្រង់នេះស្ដេចសាឡូម៉ូនបាន និយាយប្រាប់ពីការសម្បថរបស់ទ្រង់ ជាការអំពាវនាវទៅដល់ព្រះអម្ចាស់ ដែលព្រះអម្ចាស់នឹងធ្វើការអស្ចារ្យណាមួយដល់ទ្រង់ជាមិនខាន ។

**៨:៣៣** *ត្រូវចាញ់នៅមុខពួកខ្មាំងសត្រូវ ដោយព្រោះគេបានធ្វើបាបនឹងទ្រង់* ឃ្លានេះបានប្រាប់ថា ពួកគេបានចាញ់ក្រោមដៃសត្រូវ ដូចដែលបានកត់ចុះនៅក្នុង ចទ ២៨:២៥ ថាជាផ្នែកមួយនៃបណ្ដាសាដែលពួកអ៊ីស្រាអែលនឹងត្រូវប្រឈមមុខនឹងការនេះប្រសិនបើពួកគេមិនគោរពនូវសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ ។ សេចក្ដីអធិស្ឋានរបស់ស្ដេចសាឡូម៉ូនបានបង្ហាញពីការស្គាល់សេចក្ដីសញ្ញារបស់ព្រះដែលបានប្រទានមកដល់រាស្ត្ររបស់ទ្រង់ និងលទ្ធផលនៃចំណេះដឹងទាំងឡាយណាដែលឈានដល់ការបដិសេធព្រះ ។

**៨:៣៤** *រាំងភ្លៀង* ការរាំងស្ងួតជាបណ្ដាសាផ្សេងទៀតនៃសេចក្ដីសញ្ញាដែលមានកត់ចុះក្នុង ចទ ២៨:២២–៣៤ ។

**៨:៣៥** *ផ្លូវល្អណាដែលត្រូវដើរ* ឃ្លានេះបញ្ជាក់ពី សេចក្ដីសញ្ញាដែលត្រូវប្រព្រឹត្ត (មើល ចទ ៦:១៨ ១២:២៥ ១៣:១៨ ១សយ ១២:២៣) ។

សូមទ្រង់ប្រោសស្តាប់ពីលើស្ថានសួគ៌ ហើយអត់ទោស
ចំពោះអំពើបាបរបស់ពួកបាវបំរើទ្រង់ គឺពួកអ៊ីស្រាអែល
ជារាស្ត្រទ្រង់ ដោយបង្រៀន[ប]ឱ្យដឹងផ្លូវល្អណាដែលត្រូវ
ដើរ[ផ] រួចសូមបង្អុរភ្លៀងឱ្យ[ព]ធ្លាក់មកលើស្រុករបស់ទ្រង់
ដែលបានប្រទានមករាស្ត្រទ្រង់ ទុកជាមរដកផង ។
៣៧ បើកាលណាកើតមានអំណត់[ភ]នៅក្នុងស្រុក ឬបើមាន
អន្តរាយ[ម] ស្កកស្រូវ[យ] ក្រាចាប់ កណ្តូបឬដង្កូវស៊ី[រ] បើពួកខ្មាំង
សត្រូវលុកលុយក្នុងស្រុកឡោមព័ទ្ធទីក្រុង ឬកើតមានសេច
ក្តីវេទនាណា ឬជំងឺណាក៏ដោយ ៣៨ នោះទោះបើមនុស្សណា
មួយ ឬបណ្តាពួកអ៊ីស្រាអែល ជារាស្ត្រទ្រង់ដែលស្គាល់
សេចក្តីវេទនានៅក្នុងចិត្តខ្លួន គេលើកដៃ[ល]ដំរង់មកឯព្រះ
វិហារនេះ ហើយអធិស្ឋាន ឬទូលសូមអ្វីក៏ដោយ ៣៩ នោះ
សូមទ្រង់ប្រោសស្តាប់[វ]ពីលើស្ថានសួគ៌ ជាទីលំនៅរបស់ទ្រង់
ហើយអត់ទោស[ស] ព្រមទាំងសំរេចការ ដោយសងដល់គ្រប់
គ្នា តាមផ្លូវគេប្រព្រឹត្ត តាមតែទ្រង់ជ្រាប[ហ]ចិត្តគេ (ដ្បិតគឺ
ទ្រង់តែ១ ដែលជ្រាបចិត្តនៃពួកមនុស្សលោកទាំងអស់)
៤០ ដើម្បីឱ្យគេបានកោតខ្លាច[ឡ]ដល់ទ្រង់នៅគ្រប់១ជីវិត ដែល
គេរស់នៅក្នុងស្រុក[អ] ដែលទ្រង់បានប្រទានមកពួកព្ធយុកោ
យើងខ្ញុំទាំងឡាយ ។
៤១ មួយទៀត ត្រង់ឯពួកសាសន៍ដទៃ[ក] ដែលមិនមែនជា
ពូជពង្សអ៊ីស្រាអែល ជារាស្ត្រទ្រង់ទេ បើកាលណាគេចាក
ចេញពីស្រុកឆ្ងាយមក ដោយយល់ដល់ព្រះនាមទ្រង់
៤២ (ដ្បិតគេនឹងឮ[ខ]និយាយ ពីព្រះនាមដ៏ជាធំឧត្តមរបស់ទ្រង់
នឹងពីព្រះហស្តដ៏ខ្លាំងពូកែ[គ] ហើយពីព្រះពាហុដែលលើក
សំរេចដែរ) ហើយគេមកអធិស្ឋានដំរង់ចំពោះព្រះវិហារ
នេះ ៤៣ នោះសូមទ្រង់ប្រោសស្តាប់ពីលើស្ថានសួគ៌ ជាទី
លំនៅរបស់ទ្រង់ ហើយសំរេចសព្វគ្រប់ តាមសេចក្តីដែល
សាសន៍ដទៃនោះនឹងសូមដល់ទ្រង់ ដើម្បីឱ្យគ្រប់ទាំងសាសន៍
នៅផែនដីបានស្គាល់[ឃ]ព្រះនាមទ្រង់ ប្រយោជន៍ឱ្យគេបាន
កោតខ្លាច[ង]ដល់ទ្រង់ ដូចជាសាសន៍អ៊ីស្រាអែល ជារាស្ត្រ
ទ្រង់ដែរ ហើយឱ្យគេបានដឹងថា ព្រះវិហារដែលទូលបង្គំ
បានស្អាងនេះ បានហៅតាមព្រះនាមទ្រង់[ច] ។
៤៤ បើកាលណារាស្ត្ររបស់ទ្រង់ចេញទៅច្បាំងនឹងខ្មាំង
សត្រូវ តាមផ្លូវណាក៏ដោយ ដែលទ្រង់នឹងចាត់គេឱ្យទៅ
ហើយគេអធិស្ឋាន[ឆ]ដល់ព្រះយេហូវ៉ាទាំងបែរមកឯទីក្រុង
នេះ ដែលទ្រង់បានរើស និងព្រះវិហារនេះ ដែលទូលបង្គំ
បានស្អាងថ្វាយដល់ព្រះនាមទ្រង់ ៤៥ នោះសូមទ្រង់ប្រោស
ស្តាប់ពីលើស្ថានសួគ៌ ចំពោះពាក្យដែលគេអធិស្ឋាន ហើយ
ទូលអង្វរ ព្រមទាំងសំរេចតាមសេចក្តីយុត្តិធម៌ឱ្យគេផង[ជ] ។

**៨:៣៦** ប ចទ ៨:៣ ១សយ ១២:២៣ ផ ទដ ៥:៨ ២៧:១១ ១០៧:៧ សក ១១:៥ អស ៤៥:១៣ យរ ៦:១៦ ៧:២៣ ៣១:២១ ព ខ.៣៥ ១ពវ ១៧:១ ១៨:១,៤៥ យរ ៥:២៤ ១០:៣ ១៤:២២ សក ១០:១ **៨:៣៧** ភ លវ ២៦:២៦ ម នក ៣០:១២ លវ ២៦:២៥ យ ចទ ២៨:២២ រ នក ១០:១៣ ទដ ១០៥:៣៤ **៨:៣៨** ល នក ៩:២៩ **៨:៣៩** វ ខ.៣០ ស ទដ ១៣០:៤ ហ យស ២២:២២ ទដ ៤៤:២១ យហ ២:២៤ វវ ២:២៣ **៨:៤០** ឡ ខ.៣៩–៤០ ចទ ៦:១៣ ទដ ១០៣:១១ ១៣០:៤ អ ចទ ១២:១ **៨:៤១** ក លប ៣១:១៥ អស ៥៦:៣,៦ ៦១:១៥ **៨:៤២** ខ ១ពវ ១០:១ អស ៦០:៣ កច ៨:២៧ គ ចទ ៣:២៤ **៨:៤៣** ឃ យស ៤:២៤ ១សយ ១៧:៤៦ ង ទដ ១០២:១៥ ច ចទ ២៨:១០ **៨:៤៤** ឆ ១របា ៥:២០ ២របា ១៤:១១ **៨:៤៥** ជ ទដ ៩:៤ ១៤០:១២

**៨:៣៧** *អំណត់* មើល ចទ ៣២:២៤ ។ *ក្រាចាប់* មើល ចទ ២៨:២១–២២ ៣២:២៤ ។ *កណ្តូប ឬដង្កូវស៊ី* មើល ចទ ២៨:៣៨,៤២ ។ *ខ្មាំងសត្រូវលុកលុយក្នុងស្រុកឡោមព័ទ្ធទីក្រុង* មើល ចទ ២៨:៥២ ។ *សេចក្តីវេទនា* មើល ៣១:២៩ ៣២:២៣–២៥ ។

**៨:៣៨** *ស្គាល់សេចក្តីវេទនានៅក្នុងចិត្តខ្លួន* ឃ្លានេះស្តេចសាឡូម៉ូន បានទូលដល់ព្រះយេហូវ៉ាជំនួសឱ្យសាសន៍អ៊ីស្រាអែលណា ដែលស្គាល់ពីទោសកំហុសរបស់ខ្លួន ក្នុងបំណងចង់ឱ្យព្រះអម្ចាស់បានអត់ទោសឱ្យគេ (មើល ២របា ២៨:៦១ ទដ ៣៨:១៧–១៨ យរ ១៧:៩ ។

**៨:៣៩** *ទ្រង់តែ១ ដែលជ្រាបចិត្តនៃពួកមនុស្សលោក* នៅត្រង់នេះមិនបានបង្ហាញឱ្យឃើញថា វាជារង្វាន់ចំពោះការប្រព្រឹត្តខុសនោះទេ (ការអត់ទោស និងរង្វាន់ គឺមិនអាចកើតឡើងក្នុងពេលតែ១) ប៉ុន្តែជាការកែតម្រូវ និងការបង្រៀនរាស្ត្ររបស់ទ្រង់តាមសេចក្តីសញ្ញារបស់ព្រះអម្ចាស់ (មើល ខ.៤០ សក ៣:១១ ហព ១២:៥–១៥) ប៉ុណ្ណោះ ។

**៨:៤០** *កោតខ្លាច* សូមមើល ការពន្យល់ លប ២០:១១ សភ ១:៧ មើលបន្ថែម ចទ ៥:២៩ ៦:១–២ ៨:៦ ៣១:១៣ ២របា ៦:៣១ ទដ ១៣០:៤ ។

**៨:៤១** *ពួកសាសន៍ដទៃ ដែលមិនមែនជាពូជពង្សអ៊ីស្រាអែល* ជាពួកដែលមកពីប្រទេសដទៃដើម្បីអធិស្ឋាននៅចំពោះព្រះរបស់ពួកអ៊ីស្រាអែល នៅក្នុងព្រះវិហារ និងការទទួលបានជោគជ័យដោយទទួលបានសិទ្ធជាម្ចាស់ស្រុក ។

**៨:៤១–៤៣** នៅវគ្គនេះព្រះអម្ចាស់បានជ្រើសពួកអ៊ីស្រាអែលឱ្យធ្វើជាព្រះពរដែលបង្ហូរនៅគ្រប់ទីកន្លែង (លប ១២:១–៣) ។ ព្រះពរនេះ បង្ហូរមកតាមរយៈអង្គព្រះយេស៊ូវគ្រីស្ទ គឺពួកកូនចៅលោកអ័ប្រាហាំ និងស្តេចដាវីឌ (លប ៣:៨,៩) ជាអ្នកទទួលមរដកនេះ ។ ព្រះយេស៊ូវ បានក្លាយជាព្រះមែស៊ីសម្រាប់គ្រប់មនុស្ស ទាំងសាសន៍យូដា និងមិនមែនសាសន៍យូដា ។ ពេលពួកអ៊ីស្រាអែលបានចូលមកក្នុងទឹកដីសន្យាដំបូង ពួកគេត្រូវបានបញ្ជាឱ្យធ្វើជាអ្នកដឹកនាំ កំចាត់ពួកសាសន៍ខ្សោយៗ ដូច្នេះយើងឃើញថា នៅក្នុងសម័យសញ្ញាចាស់មានការធ្វើសង្គ្រាមជាច្រើន ប៉ុន្តែយើង ពុំគម្បីសន្និដ្ឋានថា សង្គ្រាមជាកាតព្វកិច្ចទី១របស់ពួកអ៊ីស្រាអែលដែរ ។ ក្រោយពីពង្រាបពួកមនុស្សមានបាបមក នោះពួកអ៊ីស្រាអែលក្លាយជាចង្កៀងបំភ្លឺសាសន៍ដែលនៅជុំវិញពួកគេ ។ ប៉ុន្តែ គួរឱ្យស្តាយអំពើរបាប និងការខ្វាក់ខាងឯវិញ្ញាណរបស់ពួកអ៊ីស្រាអែល បានធ្វើឱ្យពួកគេមិនអាចចូលទៅក្នុងពិភពនៃសេចក្តីស្រឡាញ់របស់ព្រះផងដែរ ។ ការរកឱ្យឃើញ ពិភពនៃសេចក្តីស្រឡាញ់របស់ព្រះជាបេសកកម្មរបស់រាស្ត្ររបស់ព្រះនៅសម័យនេះ ពោលគឺ គ្រីស្ទបរិស័ទគ្រប់រូប ត្រូវឆក់គ្រប់ឱកាសដើម្បីពង្រីកសេចក្តីស្រឡាញ់របស់ព្រះផងដែរ ។

**៨:៤៤** *ច្បាំងនឹងខ្មាំងសត្រូវ តាមផ្លូវណាក៏ដោយ* នេះជាកាផ្តួចផ្តើមផ្នែកកងទ័ព ដែលស្ថិតក្រោមការគ្រប់គ្រងព្រះដ៏សុចរិតបរិសុទ្ធ (មើល លវ ២៦:៧ ចទ ២០ ២១:១០ ១សយ ១៥:៣ ២៣:២,៤ ៣០:៨ ២សយ ៥:១៩,២៤) ។ *មកឯទីក្រុងនេះ ដែលទ្រង់បានរើស* មើលការពន្យល់ ខ.៣០ ។

៤៦ បើកាលណាគេធ្វើបាបនឹងទ្រង់ (ដ្បិតគ្មានមនុស្សណា
មួយដែលមិនធ្វើបាបឡើយ[ឈ]) ហើយទ្រង់កើតមានសេចក្តី
ក្រោធនឹងគេ ព្រមទាំងប្រគល់គេ ដល់ពួកខ្មាំងសត្រូវឱ្យ
បានដឹកនាំទៅជាឈ្លើយ[ញ] នៅស្រុករបស់សត្រូវនោះ ទោះ
នៅឆ្ងាយឬជិតក្តី ៤៧ នោះបើគេនឹកចាំនៅក្នុងស្រុក ដែល
បានដឹកនាំទៅជាឈ្លើយនោះ ហើយបែរត្រឡប់ចិត្តមកវិញ
ព្រមទាំងទូលអង្វរ[ដ]ដល់ទ្រង់ នៅក្នុងស្រុករបស់ពួកសាសន៍
ដែលដឹកនាំគេ ទៅជាឈ្លើយនោះដោយពាក្យថា យើងខ្ញុំ
បានធ្វើបាបហើយ ក៏បានប្រព្រឹត្តក្រវិចក្រវៀន ហើយធ្វើ
ការអាក្រក់ផង[ឋ] ៤៨ បើសិនជាគេវិលត្រឡប់[ឌ]មកឯទ្រង់
ដោយអស់ពីចិត្ត[ឍ]អស់ពីព្រលឹង នៅក្នុងស្រុករបស់ខ្មាំង
សត្រូវ ដែលបាននាំគេទៅជាឈ្លើយនោះ ហើយក៏
អធិស្ឋាន[ណ]ដល់ទ្រង់ ទាំងបែរមកឯស្រុកនេះ ដែលទ្រង់បាន
ប្រទានឱ្យពួកឰយុកោគេ គឺជាទីក្រុង ដែលទ្រង់បានរើស
តាំង និងព្រះវិហារ[ត]ដែលទូលបង្គំបាន ស្អាងថ្វាយព្រះនាម
ទ្រង់[ថ] ៤៩ នោះសូមទ្រង់ប្រោសស្តាប់ពីលើស្ថានសួគ៌ ជាទីលំ
នៅទ្រង់ ចំពោះពាក្យដែលគេអធិស្ឋាន ហើយទូលអង្វរ
នោះ ព្រមទាំងសំរេចសេចក្តីត្រឹមត្រូវឱ្យគេផង ៥០ សូមអត់
ទោសដល់រាស្ត្រទ្រង់ ដែលបានធ្វើបាបនឹងទ្រង់ដូច្នេះ
ហើយអស់ទាំងការរំលងច្បាប់ ដែលគេបានប្រព្រឹត្តទាស់
នឹងទ្រង់ដែរ សូមបណ្តាលឱ្យពួកអ្នកដែលនាំគេទៅជា
ឈ្លើយនោះ បានអាណិតមេត្តាដល់គេវិញ[ទ] ៥១ (ដ្បិតគេជា
រាស្ត្ររបស់ផងទ្រង់ និងជាមរដក[ធ]របស់ទ្រង់ ដែលទ្រង់
បាននាំចេញពីស្រុកអេស៊ីព្ទមក គឺពីកណ្តាលគុករំលាយ
ដែកនោះ)[ន] ៥២ ដើម្បីឱ្យព្រះនេត្រទ្រង់បានបើក[ប] សំរាប់
ទតក្នុងវេលាណា ដែលទូលបង្គំជាបាវបំរើទ្រង់ និងសាសន៍
អ៊ីស្រាអែល ជារាស្ត្រទ្រង់ ទូលអង្វរហើយនឹងស្តាប់ តាម
សេចក្តី ដែលគេទូលសូមដល់ទ្រង់[ផ] ៥៣ ដ្បិត ឱព្រះអម្ចាស់
យេហូវ៉ាអើយ ទ្រង់បានញែកគេចេញពីអស់ទាំងសាសន៍
នៅផែនដី ទុកសំរាប់ជាមរដក[ព]របស់ទ្រង់ហើយដូចជាទ្រង់
បានមានបន្ទូលដោយសារលោកម៉ូសេ ជាបាវបំរើនៃទ្រង់
ពីកាលទ្រង់បាននាំពួកឰយុកោយើងខ្ញុំ ចេញពីស្រុកអេស៊ីព្ទ
មក ។

៥៤ កាលសាឡូម៉ូនបានអធិស្ឋាន ហើយទូលអង្វរដល់ព្រះ
យេហូវ៉ា តាមគ្រប់សេចក្តីទាំងនោះរួចហើយ នោះទ្រង់ក៏
ក្រោកពីមុខអាសនានៃព្រះយេហូវ៉ា គឺពីកន្លែងដែលទ្រង់
បានលុតព្រះជង្ឃ លើកព្រះហស្តដំរង់ទៅឯមេឃនោះ
ឡើង ៥៥ ទ្រង់ក៏ឈរឡើង ប្រទានពរ[ភ]ដល់ពួកជំនុំនៃ
សាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន ដោយព្រះសៀងដ៏ខ្លាំងថា
៥៦ សូមឱ្យព្រះយេហូវ៉ាបានប្រកបដោយព្រះពរ ដែលទ្រង់
បានប្រទានសេចក្តីសំរាក[ម] ដល់ពួកអ៊ីស្រាអែល ជារាស្ត្រ
របស់ទ្រង់ តាមគ្រប់ទាំងសេចក្តី ដែលទ្រង់បានសន្យា[យ]
ឥតមានខ្វះព្រះបន្ទូលណាមួយ ក្នុងគ្រប់សេចក្តីល្អ ដែលទ្រង់
បានសន្យា ដោយសារលោកម៉ូសេ ជាអ្នកបំរើទ្រង់នោះ
ឡើយ ៥៧ សូមឱ្យព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា បាន
គង់ជាមួយនឹងយើង ដូចជាទ្រង់បានគង់ជាមួយនឹងពួក
ឰយុកោយើងដែរ សូមកុំឱ្យទ្រង់លះបង់[រ]ឬទុកយើងរាល់គ្នា
ចោលឡើយ ៥៨ ដើម្បីឱ្យទ្រង់បានបង្វែរចិត្តយើង[ល]ទៅឯ
ទ្រង់ ឱ្យយើងបានដើរតាមគ្រប់ទាំងផ្លូវរបស់ទ្រង់ព្រមទាំង
កាន់តាមសេចក្តីបង្គាប់នឹងក្រិត្យក្រម ហើយនិងបញ្ញត្តទាំង
ប៉ុន្មានរបស់ទ្រង់ ដែលទ្រង់បានបង្គាប់ដល់ពួកឰយុកោ
យើងរាល់គ្នា ៥៩ សូមឱ្យពាក្យទាំងនេះ ដែលយើងបានទូល

**៨:៤៦** ឈ ទដ ១៣០:៣ ១៤៣:២ សភ ២០:៩ រម ៣:៩ វ ២៦:៣៣–៣៩ ចទ ៤:២៧ ២១:១០ ២៨:៦៤ ២ពវ ២៥:២១ **៨:៤៧** ដ ខ.៣០ លវ ៥:៥ អរ ៩:១៥ នហ ១:៦ យរ ១៤:២០ ឋ អរ ៩:៧ ទដ ១០៦:៦ យរ ៣:២៥ **៨:៤៨** ឌ ចទ ៤:៣០ ឍ ចទ ៤:២៩ ណ ១យហ ១:៨–១០ ត ទដ ៥:៧ ១១:៤ យហ ២:៤ ថ ចទ ១២:១១–១៤ នហ ១:៩ យរ ២៣:៣ ៣១:៨ **៨:៥០** ទ ២ពវ ២៥:២៨ ២រប ៣០:៩ ទដ ១០៦:៤៦ ដយ ១:៩ **៨:៥១** ធ នក ៣៤:៩ ចទ ៩:២៩ ន នក ១:១៣ អស ៤៨:១០ យរ ១១:៤ **៨:៥២** ប ខ.២៩ ផ យប ៣០:២០ ទដ ៣:៤ ២២:២ ៧៧:១ ១៤២:១ **៨:៥៣** ព នក ១៩:៥ ៣៤:៩ **៨:៥៥** ភ នក ៣៩:៤៣ ជន ៦:២៣ **៨:៥៦** ម នក ៣៣:១៤ ចទ ១២:១០ ហព ៤:៨ យ យស ២៣:១៥ យរ ២៩:១០ **៨:៥៧** រ ចទ ៤:៣១ ៣១:៦ មថ ២៨:២០ ហព ១៣:៥ **៨:៥៨** ល យស ២៤:២៣

**៤:៤៦** *ដ្បិតគ្មានមនុស្សណាមួយដែលមិនធ្វើបាបឡើយ* នេះជាការទទួលស្គាល់ថា អំពើបាបគឺមានទូទៅ (មើល ទដ ១៤:១ និងការពន្យល់មើលបន្ថែម លប ៦:៥ ៨:២១ រម ៣:១០–២៣) ។ *ប្រគល់គេ ដល់ពួកខ្មាំង សត្រូវឱ្យបានដឹកនាំទៅជាឈ្លើយ* សេចក្តីនេះមាននៅក្នុង លវ ២៦:៣៣–៤៥ ចទ ២៨:៦៤–៦៨ ។ នៅក្នុង ៣០:១–៥ បានដឹងអំពីការដែលក្បាលរឹង មិន–ស្តាប់បង្គាប់ព្រះ និងឈានទៅដល់ការនិរទេសចេញពីទឹកដីសន្យា ។

**៨:៥១** *គុករំលាយដែក* មើល ចទ ៤:២០ និងការពន្យល់ ។

**៨:៥៣** *ទ្រង់បានញែក . . . ជាមរដករបស់ទ្រង់ហើយ* ពាក្យនេះស្តេចសាឡូម៉ូនបានចាប់ផ្តើមអធិស្ឋាន ដោយអំពាវនាវទៅដល់ជំនួវង្សដាវីឌ (ខ.២៣–៣០) និងទៅដល់សេចក្តីសញ្ញានៅភ្នំស៊ីណាយ (មើល នក ១៩:៥ លវ ២០:២៤,២៦ ចទ ៧:៦ ៣២:៣៩) ។

**៨:៥៤** *ទ្រង់បានលុតព្រះជង្ឃ* សូមធៀប ខ.២២ មើល ២រប ៦:១៣ មើលបន្ថែម ២សយ ៧:១៨ លក ២២:៤១ អភ ៣:១៤ ។

**៨:៥៦** *សូមឱ្យព្រះយេហូវ៉ាបានប្រកបដោយព្រះពរ* នៅត្រង់នេះស្តេចសាឡូម៉ូនយល់ពីថ្ងៃសំខាន់ក្នុងការធ្វើបន្ទាល់ចំពោះសេចក្តីសញ្ញារបស់ព្រះដែលបានសម្រេចបទទំនាយរបស់ទ្រង់ ។ *សេចក្តីឈប់សំរាក* ទោះបីនៅទីនោះមានដីជាច្រើនដើម្បីចាប់ យកធ្វើជាកម្មសិទ្ធ (មើល យស ១៣:១ ពច ១) តែក្រោយពីពួកគេ បានឈ្នះសង្គ្រាមនៅកាណាន ក្រោមការដឹកនាំរបស់លោកយ៉ូស្វេ ព្រះអម្ចាស់បានផ្តល់ឱ្យពួកគេនូវពេលឈប់សម្រាក (យស ១១:២៣ ២១:៤៤ ២២:៤) ។

**៨:៥៨** *បង្វែរចិត្តយើងទៅឯទ្រង់* ត្រង់នេះស្តេចសាឡូម៉ូនបានសូមដល់ព្រះគុណរបស់អម្ចាស់ និងរាស្ត្ររបស់ទ្រង់ បានសម្រេចនូវសេចក្តីសញ្ញារបស់ទ្រង់ (មើល ចទ ៣០:៦ ទដ ៥១:១០ សភ ២:១៣) ។

**៨:៥៩** *បាវបំរើ* ត្រង់សំដៅលើស្តេច ដែលជាមនុស្សដែលព្រះបានរើសតាំង

អង្វរ បាននៅចំពោះព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា
ទាំងយប់ទាំងថ្ងៃ ដើម្បីឱ្យទ្រង់បានសំរេចតាមសេចក្ដីត្រឹម
ត្រូវចំពោះយើង ជាបាវបំរើទ្រង់ និងពួកអ៊ីស្រាអែល ជា
រាស្ត្ររបស់ទ្រង់ផង តាមត្រូវការរាល់តែថ្ងៃ ៦០ប្រយោជន៍
ឱ្យអស់ទាំងសាសន៍[វ] នៅផែនដី បានដឹងថា ព្រះយេហូវ៉ា
ទ្រង់ជាព្រះ ឥតមានព្រះឯណាទៀតសោះឡើយ[ស] ៦១ដូច្នេះ
សូមឱ្យចិត្ត[ហ] ឯងរាល់គ្នាបានគ្រប់ក្ខណ៍[ឡ]ចំពោះព្រះយេហូវ៉ា
ជាព្រះនៃយើងរាល់គ្នា ដើម្បីឱ្យបានប្រព្រឹត្តតាមបញ្ញត្ត
ហើយកាន់តាមក្រិត្យទ្រង់ទាំងប៉ុន្មាន ដូចជាមានសព្វថ្ងៃនេះ

## ការធ្វើបុណ្យឆ្លងព្រះវិហារ

*៨:៦២–៦៦ – ២របា ៧:១–១០*

៦២រួចមក ស្ដេចនឹងពួកអ៊ីស្រាអែលទាំងអស់ ក៏ថ្វាយ
យញ្ញបូជា[អ] នៅចំពោះព្រះយេហូវ៉ា ៦៣ឯយញ្ញបូជា ដែល
សាឡូម៉ូនបានថ្វាយដល់ព្រះយេហូវ៉ា ទុកជាដង្វាយមេត្រី
នោះគឺគោ២ម៉ឺន២ពាន់ និងចៀម១សែន២ម៉ឺន គឺយ៉ាងនោះ
ហើយ ដែលស្ដេចនឹងពួកកូនចៅអ៊ីស្រាអែលទាំងអស់គ្នា
បានធ្វើបុណ្យឆ្លង[ក] ព្រះវិហារនៃព្រះយេហូវ៉ា ៦៤នៅថ្ងៃនោះ
ឯង ស្ដេចទ្រង់បានញែកទីលានកណ្ដាល ដែលនៅមុខព្រះ
វិហារនៃព្រះយេហូវ៉ា ចេញជាបរិសុទ្ធ ដ្បិតនៅទីនោះ
ទ្រង់បានថ្វាយទាំងដង្វាយដុត និងដង្វាយម្សៅ ហើយខ្លាញ់[ខ]
នៃដង្វាយមេត្រី គឺដោយព្រោះអាសនា លង្ហិន[គ] ដែលនៅ
ចំពោះព្រះយេហូវ៉ានោះតូចពេក មិនល្មមនឹងដុតអស់ទាំង
ដង្វាយដុត និងដង្វាយម្សៅ ហើយខ្លាញ់របស់ដង្វាយមេត្រី
ផងបានទេ[ឃ] ៦៥នៅវេលានោះ[ង] សាឡូម៉ូន និងពួកអ៊ីស្រា–
អែលទាំងអស់គ្នា គឺជាជំនុំយ៉ាងធំ ដែលមូលមក ចាប់តាំង
ពីទ្វារស្រុកហាម៉ាត[ច] រហូតដល់ជ្រោះទឹកនៃស្រុកអេស៊ីព្ទ[ឆ]
គេបានធ្វើបុណ្យនោះនៅចំពោះយេហូវ៉ាជា ព្រះនៃយើង

**៨:៦០** វ យស ៤:២៤
**៨:៦០** ស ចទ ៤:៣៥
**៨:៦១** ហ ចទ ៦:៥
ឡ ១ពវ ៩:៤ ១១:៤
១៥:៣,១៤ ២២:៤៣
២ពវ ២០:៣ ១របា
២៨:៩ ២៩:១៩
២របា ១៦:៩ ១៧:៦
២៥:២ ទដ ១១៩:៨០
អស ៣៨:៣
**៨:៦២** អ ២សយ
៦:១៣ ១របា
២៩:២១ អគ
៤៥:១៧
**៨:៦៣** ក អរ ៦:១៦
**៨:៦៤** ខ នក
២៩:១៣ គ នក
២៧:១ ២ពវ
១៦:១៤ ២របា ៤:១
៨:១២ ១៥:៨ អគ
៤៣:១៣–១៧
ឃ ២សយ ៦:១៧
**៨:៦៥** ង ខ.២
ច ជន ១៣:២១
ឆ លប ១៥:១៨
**៨:៦៦** ជ នក ១៨:៩
**៩:១** ក ២សយ ៧:២
**៩:២** ខ ១ពវ ៣:៥
**៩:៣** គ ១សយ ៩:១៦
២ពវ ១៩:២០ ២០:៥
ទដ ១០:១៧ ៣៤:១៧
ឃ នក ២០:២៤
ចទ ១២:៥
ង ចទ ១១:១២
**៩:៤** ច ចទ

រាល់គ្នាអស់៧ថ្ងៃ រួចរាល់៧ថ្ងៃទៀត រួមទាំងអស់ជា១៤
ថ្ងៃ ៦៦ដល់ថ្ងៃទី៨ នោះទ្រង់ឱ្យពួករាស្ត្រត្រឡប់ទៅវិញ គេ
ក៏ថ្វាយពរដល់ស្ដេច រួចវិលទៅឯទីលំនៅរបស់គេវិញ
ដោយមានចិត្តសប្បាយ ហើយត្រេកអរចំពោះអស់ទាំង
សេចក្ដីសប្បុរស[ជ] ដែលព្រះយេហូវ៉ាបាន ប្រោសដល់ដាវីឌ
ជាអ្នកបំរើទ្រង់ ហើយដល់ពួកអ៊ីស្រាអែល ជារាស្ត្ររបស់
ទ្រង់ដែរ ។

## ព្រះអម្ចាស់បង្ហាញអង្គទ្រង់ដល់ស្ដេចសាឡូម៉ូន

*៩:១–៩ – ២របា ៧:១១–២២*

**៩** ១គ្រាក្រោយ ដែលសាឡូម៉ូនបានស្អាងព្រះវិហារ នៃព្រះ
យេហូវ៉ា និងព្រះរាជវាំងស្រេចហើយ[ក] ព្រមទាំងរបស់ទាំង
ប៉ុន្មាន ដែលទ្រង់សព្វព្រះទ័យចង់ធ្វើ ២នោះព្រះយេហូវ៉ា
ក៏លេច[ខ] មកឱ្យទ្រង់ឃើញម្ដងទៀត ដូចជាបានលេចមកឱ្យ
ឃើញ នៅត្រង់គីបៀនដែរ ៣ព្រះហេូវ៉ាមានបន្ទូលថា អញ
បានឮ[គ] សេចក្ដី ដែលឯងបានអធិស្ឋាន ហើយទូលអង្វរនៅ
ចំពោះអញនោះ អញក៏បានញែកព្រះវិហារនេះ ដែលឯង
បានស្អាង ចេញជាបរិសុទ្ធ ទុកសំរាប់នឹងតាំងឈ្មោះអញ[ឃ]
នៅអស់កល្បជានិច្ច ហើយភ្នែក[ង]នឹងចិត្តអញនឹងស្ថិតនៅ
ទីនោះ ជាដរាបតទៅ ៤ឯឯង បើសិនជាឯងនឹងដើរនៅ
ចំពោះអញ ដូចជាដាវីឌ[ច]ជាឪពុកឯង ដោយចិត្តស្មោះ[ឆ]
ហើយទៀតត្រង់ ដើម្បីនឹងប្រព្រឹត្ត តាមគ្រប់ទាំងសេចក្ដី
ដែលអញបានបង្គាប់ដល់ឯង ព្រមទាំងកាន់តាមបញ្ញត្ត និង
សេចក្ដីយុត្តិធម៌របស់អញទាំងប៉ុន្មាន[ជ] ៥នោះអញនឹងតាំង[ឈ]
រាជ្យឯងលើសាសន៍អ៊ីស្រាអែល ឱ្យនៅជាប់ជារៀងរាប
តទៅ តាមដែលអញបានសន្យានឹងដាវីឌ ជាឪពុកឯងថា

១៧:២០ ១ពវ ១៤:៨ ១៥:៥ ឆ លប ១៧:១ ជ ១ពវ ៣:១៤ ១របា ២៨:៩ សក
៤:៤ **៩:៥** ឈ ១របា ២២:១០ ញ ២សយ ៧:១៥

ហើយជាអ្នកតំណាងនៃការដឹកនាំរបស់ព្រះលើរាស្ត្ររបស់ទ្រង់ (មើលការ
ពន្យល់ ទដ ២:២,៧) ។

**៨:៦០** *ប្រយោជន៍អស់ទាំង . . . បានដឹង* មើលការពន្យល់ ទដ ៤៦:១០ ។

**៨:៦៣** *ដង្វាយមេត្រី* ពាក្យនេះសំគាល់ពីការដែលពួកគេប្រកបអាហារជា
មួយគ្នា (មើលពន្យល់ ១សយ ១១:១៥) ។ *គោ២ម៉ឺន២ពាន់ នឹងចៀម១សែន
២ម៉ឺន* ទោះបីសត្វទាំងអស់នេះមើលទៅហាក់មានចំនួនច្រើនក៏ដោយ ប៉ុន្តែ
ចំនួនមនុស្សក៏ច្រើនដែរ ដែលបានមកចូលរួមក្នុងពិធីថ្វាយដង្វាយនេះ ដែល
មានរយៈពេលរហូតទៅដល់១៤ថ្ងៃឯណោះ (មើល ខ.១–២ ខ.៦៥) ។

**៨:៦៥** *ស្រុកហាម៉ាត* មើលពន្យល់ អគ ៤៧:១៥ ។ *ស្រុកអេស៊ីព្ទ* មើលពន្យល់
(លប ១៥:១៨) ។ នេះបញ្ជាក់ថាពួកមនុស្ស បានមកឯក្រុងយេរូសាឡឹម
ដើម្បីចុះចូលនឹងអាណាចក្ររបស់ស្ដេចសាឡូម៉ូនគ្រប់គ្រង (មើលពន្យល់
៤:២១) ។ *៧ថ្ងៃ រួចរាប់៧ថ្ងៃទៀត រួមទាំងអស់១៤ថ្ងៃ* ចំណុចនេះបញ្ជាក់
ពីចំនួនថ្ងៃដែលពួកគេត្រូវចូលក្នុងព្រះវិហារមាន៧ថ្ងៃ និង៧ថ្ងៃទៀត
សម្រាប់ការប្រារព្ធពិធីបុណ្យបារាំ (ការពន្យល់ ខ.២) ដែលបុណ្យបារាំនេះ
ចាប់ផ្ដើមនៅថ្ងៃទី ១៥ រហូតដល់ទី២១ក្នុងខែទី៧ ។

**៩:១** *សាឡូម៉ូនបានស្អាងព្រះវិហារ . . . ស្រេចហើយ* នេះជារយៈពេលដំបូង
បំផុត គឺត្រូវនឹងឆ្នាំទី២៤ (៤+៧+១៣=២៤) នៃរាជ្យស្ដេចសាឡូម៉ូននៃឆ្នាំ
៩៤៦ គ.ស (មើល ៦:១,៣៧–៣៨ ៧:១ ៩:១០) ។

**៩:២** *លេចមកឱ្យឃើញ . . . នៅត្រង់គីបៀន* មើលពន្យល់ ៣:៤–១៥ ។

**៩:៣** *ទុកសំរាប់នឹងតាំងឈ្មោះអញ នៅអស់កល្បជានិច្ច* មើលពន្យល់ ៣:២
៨:១៦ ។ *ភ្នែកនឹងចិត្តអញ នឹងស្ថិតនៅទីនោះ ជាដរាបតទៅ* មើល ៨:២៩ ។

**៩:៤–៥** *បើសិនជាឯងនឹងដើរនៅចំពោះអញ . . . ឱ្យនៅជាប់ជារៀងដរាប*
សូមមើលការពន្យល់ ៨:២៥ និង ២:៤ ។ ត្រង់នេះព្រះអម្ចាស់បានបញ្ជាក់
ម្ដងទៀត ទៅដល់សាឡូម៉ូនអំពីសារសំខាន់នៃការប្រព្រឹត្តតាមក្រឹត្យវិន័យ

នឹងមិនដែលខានមានពូជឯងអង្គុយលើបល្ល័ង្ក រាជ្យនៃសា
សន៍អ៊ីស្រាអែលឡើយ ៦តែបើកាលណាឯង[ញ]បែរចេញ[ដ]
លែងប្រព្រឹត្តតាមអញ ទោះទាំងឯង ឬកូនចៅឯងផង
ហើយមិនកាន់តាមបញ្ញត្ត និងក្រិត្យរបស់អញទាំងប៉ុន្មាន
ដែលអញបានដាក់នៅមុខឯងទេ គឺនឹងទៅគោរពប្រតិបត្តិ
ហើយថ្វាយបង្គំដល់ព្រះដទៃ[ឋ] ៧នោះអញនឹងកាត់សាសន៍
អ៊ីស្រាអែលចេញពីស្រុក[ឌ] ដែលអញបានឱ្យដល់គេ ហើយ
ព្រះវិហារនេះ ដែលអញបានញែកចេញជាបរិសុទ្ធ សំរាប់
ឈ្មោះអញ[ឍ] នោះអញនឹងបោះបង់ចោលពីមុខអញចេញ
វិញ ដូច្នេះ សាសន៍អ៊ីស្រាអែលនឹងត្រឡប់ជាសេចក្តីប្រៀន
ផ្ចឹម[ណ] ហើយជាទីដំនៀល[ត] នៅក្នុងពួកសាសន៍ទាំងអស់
៨ឯព្រះវិហារនេះ ទោះបើខ្ពស់ដល់ម្ល៉េះ គង់តែអស់អ្នកណា
ដែលដើរទៅមក គេនឹងមានសេចក្តីអស្ចារ្យក្នុងចិត្ត[ថ] ហើយ
និងចំអកឡកឡឺយឱ្យ ដោយពាក្យថា ហេតុអ្វីបានជាព្រះ
យេហូវ៉ាឱ្យទ្រង់ធ្វើដូច្នេះ ដល់ស្រុកនឹងវិហារនេះ[ទ] ៩នោះ
គេនឹងឆ្លើយ[ធ]ឡើងថា គឺពីព្រោះគេបានបោះបង់ចោល[ន]
ព្រះយេហូវ៉ា ជាព្រះនៃគេ ដែលទ្រង់បាននាំពួកឰយុកោគេ
ចេញពីស្រុកអេស៊ីព្ទមក ហើយគេបានទៅភ្ជាប់ខ្លួននឹងព្រះ
ដទៃ ព្រមទាំងថ្វាយបង្គំ ហើយគោរពប្រតិបត្តិតាម គឺហេតុ
នោះ បានជាព្រះយេហូវ៉ា ទ្រង់បាននាំគ្រប់ទាំងសេចក្តី
អាក្រក់នេះ[ប]មកលើគេ ។

## ការងារដទៃទៀតរបស់ស្តេចសាឡូម៉ូន

*៩:១០–២៨ – ២រប ៨:១–១៨*

១០លុះផុត២០ឆ្នាំដែលសាឡូម៉ូនស្អាងទាំងព្រះវិហារនៃ
ព្រះយេហូវ៉ា និងព្រះរាជវាំងទាំង២រួចជាស្រេចហើយ
១១រីឯហីរ៉ាមជាស្តេចក្រុងទីរ៉ុស ទ្រង់បានផ្គត់ផ្គង់ឈើតា
ត្រៅ និងឈើកកោះ ហើយមាស[ផ]ថ្វាយ សាឡូម៉ូនតាមព្រះ
ហឫទ័យទ្រង់គ្រប់ជិពូក) នោះស្តេចទ្រង់ក៏ប្រទាន ទីក្រុង
២០ក្នុងស្រុកកាលីឡេ ឱ្យដល់ហីរ៉ាម ១២រួចហីរ៉ាមចេញពី
ក្រុងទីរ៉ុស ទៅមើលទីក្រុងទាំងប៉ុន្មាន ដែលសាឡូម៉ូនបាន
ប្រទាននោះ តែទ្រង់មិនសព្វព្រះទ័យនឹងក្រុងទាំងនោះទេ
១៣ក៏មានបន្ទូលថា ប្អូនអើយ តើទីក្រុងយ៉ាងណាដែលបាន
ឱ្យមកខ្ញុំនេះ រួចទ្រង់ហៅទីក្រុងទាំងនោះថា ស្រុកកាបួល[ព]
ដរាបដល់សព្វថ្ងៃនេះ ១៤ឯហីរ៉ាមទ្រង់ក៏ ផ្ញើមាស១២០
ហាប[ភ]មក ថ្វាយដល់សាឡូម៉ូន ។
១៥ឯហេតុដែលស្តេចសាឡូម៉ូនបានកេណ្ឌកំណែននោះគឺ
ដើម្បីនឹង[ម]ស្អាងព្រះវិហារនៃព្រះយេហូវ៉ា នឹងព្រះរាជវាំង
ព្រមទាំងប៉មមីឡូរ[យ] កំផែងក្រុងយេរូសាឡិម ហើយក្រុង
ហាសោរ[រ] ក្រុងមេគីដោ និងក្រុងកេសើរ[ល] ១៦ដ្បិតពីមុន
ផារ៉ោន ជាស្តេចស្រុកអេស៊ីព្ទ ទ្រង់បានឡើង មកចាប់យក
ក្រុងកេសើរនោះ ព្រមទាំងដុតនឹងភ្លើង ហើយសំឡាប់ ពួក
សាសន៍កាណាន ដែលនៅស្រុកនោះដែរ រួចបានប្រទាន
ទីក្រុងនោះទៅព្រះរាជបុត្រីទ្រង់[វ] ដែលជាភរិយាសាឡូម៉ូន
ទុកជាចំណងដៃ ១៧ដូច្នេះសាឡូម៉ូនក៏សង់ក្រុងកេសើរនោះ
ឡើង និងក្រុងបេត–ហូរ៉ូន នៅខាងក្រោម[ស] ១៨ព្រមទាំង

**៩:៦** ដ ចទ ២៨:១៥ ២សយ ៧:១៤ ២ពវ ១៨:១២ យរ ១៧:២៧ ២៦:៤ ៣២:២៣ ៤៤:២៣ ឋ ១ពវ ១១:១០ **៩:៧** ឌ លវ ១៨:២៤–២៨ ចទ ៤:២៦ យស ២៣:១៣ ២ពវ ១៧:២៣ យរ ២៤:១០ ឍ ចទ?១២:៥ យរ ៧:១៤ ណ យប ១៧:៦ ទដ ៤៤:១៤ យរ ២៤:៩ យអ ២:១៧ ត ចទ ២៨:៣៧ អគ ៥:១៥ **៩:៨** ថ លវ ២៦:៣២ ទ ចទ ២៩:២៤ យរ ៧:៤–១៥ មថ ២៣:៣៨ **៩:៩** ធ ចទ ២៩:២៥ ២ពវ ២២:១៧ យរ ៥:១៩ ១៣:២២ ១៦:១១,១៣ ២២:៩ ន ជន ២៥:៣ យរ ៤០:៣ ៤៤:២៣ បទ ប ចទ ៣១:២៩ **៩:១១** ផ ខ.១៤ **៩:១៣** ព យស ១៩:២៧ **៩:១៤** ភ ខ.១១ **៩:១៥** ម ១ពវ ៥:១៣ យ ២សយ ៥:៩ រ យស ១១:១០–១១ ល យស ១០:៣៣ **៩:១៦** វ ១ពវ ៣:១ ទដ ៤៥:១២ ៦៨:២៩ ៧២:១០ **៩:១៧** ស យស ១០:១០

ដើម្បីឱ្យទទួលបាននូវព្រះពរជាជាងបណ្តាសា ។

**៩:៦** *គោរពប្រតិបត្តិ ហើយថ្វាយបង្គំដល់ព្រះដទៃ* សូមមើល ១១:៤–៨ ។

**៩:៧** *អញនឹងកាត់សាសន៍អ៊ីស្រាអែលចេញពីស្រុក* សូមមើលអំពីការដាក់បណ្តាសារបស់ព្រះមាននៅក្នុង ចទ ២២:៨–៣០ ។

**៩:១១** *ទ្រង់ក៏ប្រទាន ទីក្រុង២០ ក្នុងស្រុកកាលីឡេ ឱ្យដល់ហីរ៉ាម* នៅត្រង់នេះជាការប្រៀបធៀបរវាង ខ.១០–១៤ ជាមួយនឹង ៥:១–១២ បានបញ្ជាក់ថា នៅអំឡុងរយៈពេល២០ឆ្នាំនៃការសាងសង់ ហើយទ្រង់បានក្លាយជាអ្នកជំពាក់បំណុលដល់ហីរ៉ាម ជាងអ្វីដែលបានស្មានទុកលើកិច្ចព្រមព្រៀង (មើលពន្យល់ ៥:៩) ដែលទ្រង់បានសន្យាថា និងផ្តល់ឱ្យនូវពួកកម្មករ (៥:៦) និងឈើ (៥:១០–១១) ។ នៅក្នុង ខ.១១,១៤ បានបញ្ជាក់ថា ស្តេចសាឡូម៉ូនបានទទួលសួយសាអាករជាច្រើនពី ហីរ៉ាម ។ ហើយនៅចំណុចនេះ បានបញ្ជាក់ថា ស្តេចសាឡូម៉ូនបានប្រគល់ខេត្តចំនួន២០ជាថ្នូរ ពីការដែលហីរ៉ាមបានប្រគល់មាសដល់ទ្រង់ ។ នៅក្នុង ២រប ៨:១–២ បានបញ្ជាក់ពីកាលបរិច្ឆេទក្រោយពេលដែលមាសរបស់ស្តេចសាឡូម៉ូនរក្សាទុកនោះបានកើនឡើង នោះប្រហែលជាមាសប្រាក់ទាំងអស់នោះជាការផ្ញើទុកនៅក្រុងអូភារ (១ពវ ២៦–២៨ ១០:១១) ឬជាការយាងមករបស់មហាក្សត្រីស្រុកសេបា ក្នុងការល្បងប្រាជ្ញាដល់ស្តេចសាឡូម៉ូន ហើយទីបញ្ចប់បានដោះស្រាយបញ្ហាបំណុលរវាងសាឡូម៉ូន និងហីរ៉ាមដោយការកាត់ក្រុង២០នេះ ។

**៩:១៣** *ប្អូនអើយ* ពាក្យនេះប្រើនៅក្នុងភាពជាការគួរសមជាទូទៅ ដែលបង្ហាញ ទំនាក់ទំនងយ៉ាងស្អិតរមួត (មើល ២០:៣២)។

**៩:១៥** *កេណ្ឌកំណែន* នេះមិនសំដៅលើពួកអ៊ីស្រាអែល ។ *ក្រុងហាសោរ* ក្រុងនេះជាប៉មយ៉ាងសំខាន់នៅភាគខាងជើងទន្លេកាលីឡេ ជាច្រកពាណិជ្ជកម្មពីទន្លេអ៊ើប្រាតទៅស្រុកអេស៊ីព្ទ ។ *មេគីដោ* នេះជាប៉ម ផ្សេងមួយទៀតដែលស្ថិតនៅតាមច្រកពាពិជ្ជកម្ម ដែលនៅតាមបណ្តោយស្រុក កើមែលលាតសន្ធឹងទៅតាមវាលទំនាបយេសរាល ទៅដល់ឆ្នេរនៃស្រុកសារ៉ុន ។ *ក្រុងកេសើរ* មើលការពន្យល់ ៣:១ ។

**៩:១៦** *ផារ៉ោន* មើលការពន្យល់ ៣:១ ។ *សំឡាប់ពួកសាសន៍កាណាន* ទោះបីលោកយ៉ូស្វេបានសម្លាប់ស្តេចក្រុងកេសើរនៅក្នុងអំឡុងពេលសង្គ្រាមក៏ដោយ(យស ១០:៣៣ ១២:១២) និងពួកសាសន៍អេប្រាអិមមិនត្រូវបានបណ្តេញចេញពីភាពជាម្ចាស់ស្រុកឡើយ(សយ ១៦:១០ ពច ១:២៩) ។

**៩:១៧** *ក្រុងបេត–ហូរ៉ូន* ក្រុងស្ថិតនៅក្នុងចម្ងាយ ១០,៤០០ គីឡូម៉ែត្រភាគពាយព្ទនៃក្រុងយេរូសាឡឹម ។

ក្រុងប្អាឡាត[ហ] ហើយក្រុងថាត់ម៉ោរ ដែលនៅទីរហោស្ថាន
ក្នុងស្រុកនោះ ១៩និងអស់ទាំងទីក្រុងសំរាប់ជាឃ្លាំង[ឡ] របស់
សាឡូម៉ូន និងទីក្រុងសំរាប់ទុករទេះចំបាំង[អ] ហើយសំរាប់
ពួកពលសេះទ្រង់ ក៏ធ្វើរបស់ទាំងអស់ ដែលសាឡូម៉ូន
សព្វព្រះទ័យចង់ធ្វើ នៅក្រុងយេរូសាឡិម នៅភ្នំល្បាណូន
ហើយក្នុងគ្រប់ទាំងស្រុក ដែលនៅក្រោមអំណាចទ្រង់ផង
២០ចំណែកពួកសាសន៍អាម៉ូរី សាសន៍ហេត[ក] សាសន៍
ពេរេសីតសាសន៍ហេវី និងសាសន៍យេប៊ូស[ខ]ដែលនៅសល់
ជាមនុស្សដែលមិនមែនជាពួកកូនចៅអ៊ីស្រាអែល ២១គឺជា
កូនចៅ[គ]របស់សាសន៍ទាំងប៉ុន្មាន ដែលនៅសល់ក្នុងស្រុក
ជាអ្នកដែលពួកកូនចៅ អ៊ីស្រាអែលមិនបានបំផ្លាញអស់
រលីងទេ[ឃ] នោះសាឡូម៉ូនបានកេណ្ឌគេ មកធ្វើជាពួកអ្នក
បំរើ[ង]ដរាបដល់សព្វថ្ងៃនេះ ២២តែឯពួកកូនចៅអ៊ីស្រា
អែលវិញ នោះសាឡូម៉ូនមិនបានយកគេធ្វើជាបាវបំរើទេ[ច]
គឺគេជាពួក ទាហាន ពួកមហាតលិក ជាចៅហ្វាយ ជាមេទ័ព
ហើយជានាយរទេះចំបាំង និងពួកទ័ពសេះទ្រង់វិញ ២៣ឯ
ពួកមេដែលត្រួតមើលការ[ឆ]របស់សាឡូម៉ូនទាំងប៉ុន្មាន មាន
ចំនួន៥៥០នាក់ជានាយបង្គាប់ដល់ពួកអ្នកធ្វើការទាំងនោះ។
២៤ចំណែកព្រះរាជបុត្រីផារ៉ោន[ជ] ព្រះនាងក៏យាងចេញ
ពីក្រុងដាវីឌឡើងមកឯដំណាក់ ជាទីដែលទ្រង់បានសង់ឱ្យ
រួចមកទ្រង់ក៏សង់ប៉មមីឡូរ[ឈ]។

**៩:១៨** ហ យស ១៩:៤៤
**៩:១៩** ឡ នក ១:១១ អ ចទ ១៧:១៦ ១ពវ ៤:២៦ ២របា ១:១៤ ៩:២៥
**៩:២០** ក ជន ១៣:២៩ ខ យស ១១:៣
**៩:២១** គ លប ៩:២៥-២៦ ឃ យស ១៥:៦៣ ង លប ៤៩:១៥ នក ១:១១ ចទ ២០:១១
**៩:២២** ច លប ២៥:៣៩
**៩:២៣** ឆ ១ពវ ៥:១៦
**៩:២៤** ជ ១ពវ ៣:១ ឈ ២សយ ៥:៩ ១ពវ ១១:២៧
**៩:២៥** ញ នក ២៣:១៤
**៩:២៦** ដ ១ពវ

២៥មាន៣[ញ]ដងក្នុង១ឆ្នាំ ដែលសាឡូម៉ូនទ្រង់ថ្វាយដង្វាយ
ដុត និងដង្វាយមេត្រី នៅលើអាសនា ដែលទ្រង់បានស្អាង
ថ្វាយព្រះយេហូវ៉ា ព្រមទាំងដុតកំញានថ្វាយនៅលើអាសនា
ដែលនៅចំពោះព្រះយេហូវ៉ាផង គឺយ៉ាងនោះដែលទ្រង់
បានស្អាងព្រះវិហាររួចជាស្រេច ។
២៦ស្តេចសាឡូម៉ូនក៏ធ្វើនាវា១[ដ]ក្រុមនៅត្រង់អេស៊ានគេ
បើ[ឋ] ជាទីនៅមាត់សមុទ្រក្រហម ជិតអេឡាត[ឌ] ក្នុងស្រុក
អេដំម ២៧ឯហ៊ីរ៉ាមទ្រង់ក៏ចាត់ពួកបាវបំរើទ្រង់ខ្លះ ដែលជា
ពួកជំនាញខាងដើងទឹក[ឍ] គឺជាអ្នកមានចំណេះខាងផ្លូវ
សមុទ្រ ឱ្យទៅក្នុងនាវាទាំងនោះ ជាមួយនឹងពួកបំរើរបស់
សាឡូម៉ូន ២៨គេក៏ទៅដល់ស្រុកអូភារ[ណ] យកមាសពីស្រុក
នោះមក បាន៤២០ហាប[ត]នាំមកថ្វាយស្តេចសាឡូម៉ូន ។

## មហាក្សត្រីស្រុកសេបាមកល្បងសាឡូម៉ូន

*១០:១-១៣ – ២របា ៩:១-១២*

**១០** ១កាលមហាក្សត្រីស្រុកសេបា[ក]បានឮពីកិត្តិនាម[ខ]របស់
សាឡូម៉ូន ខាងឯព្រះនាមព្រះយេហូវ៉ា នោះព្រះនាងក៏យក
មកល្បងសួរទ្រង់ ដោយប្រស្នាដ៏ជ្រៅ[គ] ២ព្រះនាងយាងមក

១០:២២ ២២:៤៨ ២របា ២០:៣៧ អស ២:១៦ ឋ ជន ៣៣:៣៥ ឌ ២ពវ ១៤:២២ ១៦:៦ **៩:២៧** ឍ អគ ២៧:៨ **៩:២៨** ណ លប ១០:២៩ ត ខ.១៤ ១ពវ ១០:១០,១១, ១៤,២១ ២របា ១:១៥ សស ២:៨ **១០:១** ក លប ១០:៧,២៨ ២៥:៣ មថ ១២:៤២ លក ១១:៣១ ខ ១៦:១៤ គ ជន ១២:៨ ពច ១៤:១២

**៩:១៨** *ប្អាឡាត* សូមមើល ១៥:២៤ ។

**៩:១៩** *ទីក្រុងសម្រាប់ទុករទេះចំបាំង . . . ពលសេះទ្រង់* ក្រុងនេះមិនបានបញ្ជាក់ពីឈ្មោះ តែវាជាទីតាំងយុទ្ធសាស្ត្រក្នុងការធ្វើសង្គ្រាម ។ ទោះបីស្តេចសាឡូម៉ូនជាបុរសន្តិភាព ប៉ុន្តែទ្រង់ជាមនុស្សពោពេញដោយការរៀបចំនូវយុទ្ធសាស្ត្រសង្គ្រាម(ធៀប ១៧:១៦-១៧ និងការពន្យល់) ។

**៩:២០** *សាសន៍អាម៉ូរី . . . សាសន៍យេប៊ូស* មើលការពន្យល់ ចទ ៧:១ ២០:១៧ បន្ថែម លប ១០:១៥-១៨ ១៣:៧ ១៥:១៦ ២៣:៩ យស ៥:១ ពច ៣:៣ ៦:១០ ២សយ ២១:១២ ។

**៩:២២** *សាឡូម៉ូនមិនបានយកគេធ្វើជាបាវបំរើ* មើលពន្យល់ ខ.១៥ ។

**៩:២៣** *៥៥០នាក់ជានាយបង្គាប់* មើលការពន្យល់ ៥:១៦ ។

**៩:២៥** *៣ដងក្នុង១ឆ្នាំ* នេះជាឱកាសសំខាន់ៗសម្រាប់ប្រចាំឆ្នាំ គឺបុណ្យនំប៉័ងឥតដំបែបុណ្យចម្រូត និងបុណ្យបារាំ (សូមមើល នក ២៣:១៤-១៧ ២របា ៨:១) ។

**៩:២៦** *នាវា* គេប្រើវាសម្រាប់ការធ្វើជំនួញហើយនាវានេះបានដឹកជញ្ជូនរបស់មានតម្លៃទៅជូនដល់ស្តេចសាឡូម៉ូនផងដែរ (មើល ខ.២៨ ១០:១១) ។ *សមុទ្រក្រហម* ពាក្យនេះសំដៅលើផ្ទៃទឹកដែលពួកអ៊ីស្រាអែលឆ្លងកាត់នៅអំឡុងពេលនិរទេសខ្លួនចេញមកពីប្រទេសអេស៊ីព្ទ(មើលពន្យល់ នក ១៣:១៨ ១៤:២) ។

**៩:២៨** *ស្រុកអូភារ* ស្រុកនេះជាប្រភពធនធានរ៉ែមាស (មើល ២របា ៨:១៨ យក ២៨:១៦ ទដ ៤៥:៩ អស ១៣:១២) ឈើនិងថ្មមានតម្លៃ (១០:១១) ប្រាក់ ភ្លុក ស្វាឪ ស្វាបាបូន(១០:២២) ។ ស្រុកនេះត្រូវបានគេយកមកជជែកចំពោះទីតាំងភូមិសាស្ត្ររបស់វាដោយការពន្យល់ផ្សេងគ្នាៗថា ស្ថិតនៅផ្នែកនិរតី អាគ្នេយ៍ នៃប្រទេសអារ៉ាប់ប៊ី និងផ្នែកឥសាននៃឆ្នេរអាហ្វ្រិក ដែលប្រទេសឥណ្ឌា និងប្រទេសស៊ីមបាវី (zimbabwe) បានលើកឡើងពីបញ្ហានេះ ។ ប្រសិនបើស្រុកអូភារស្ថិតនៅក្នុងទឹកដីនៃប្រទេសអារ៉ាប់នោះវាជាតំបន់ពាណិជ្ជកម្មក្នុងការនាំទំនិញពីភាគខាងលិចទៅភាគខាងកើតនៃទ្វីបអាហ្វ្រិកផងដែរ ប៉ុន្តែរយៈពេលបីឆ្នាំនៃការធ្វើដំណើរតាមសមុទ្ររបស់នាវាជំនួញស្តេចសាឡូម៉ូន(១០:២២)បានបញ្ជាក់ស្រុកនេះមាន ទីតាំងនៅឆ្ងាយពីឆ្នេរសមុទ្រនៃប្រទេសអារ៉ាប់ទៅទៀត ។

**១០:១** *ស្រុកសេបា* ភស្តុតាងខាងផ្នែកបុរាណវិទ្យាបញ្ជាក់ថាស្រុកនេះត្រូវបានគេដាក់ឈ្មោះឱ្យថាជាតំបន់ពាណិជ្ជកម្ម ដែលល្បីរន្ទឺនៅភាគនិរតីនៃប្រទេសអារ៉ាប់ នៅអំឡុងឆ្នាំ ៩០០-៤៥០ មុន គ.ស (មើលការពន្យល់ លប ១០:២៨ យអ ៣:៨) ។ ស្រុកនេះទទួលបានផលចំណេញ ពីការធ្វើពាណិជ្ជកម្មតាមសមុទ្រនៃប្រទេសឥណ្ឌា និងភាគខាងកើតនៃប្រទេសអាហ្វ្រិក ដោយការដឹកជញ្ជូនវត្ថុមានតម្លៃនៅភាគខាងជើង ទៅក្រុងដាម៉ាស និងក្រុងកាសា ដោយឆ្លងកាត់វាលខ្សាច់អារ៉ាប់ប៊ី ។ នៅត្រង់នេះវាក៏អាចទៅរួចផងដែរថា ក្រុមនាវារបស់ស្តេចសាឡូម៉ូនបានបន្តការគ្រប់គ្រងលើផ្នែកពាណិជ្ជកម្មនៅក្នុងតំបន់នេះ ។ *កិត្តនាមរបស់សាឡូម៉ូន* មើល ៤:៣១ ។ *ខាងឯព្រះនាមព្រះយេហូវ៉ា* នៅត្រង់នេះម្ចាស់ក្សត្រីស្រុកសេបា បានរៀបចំការល្បងលចំពោះប្រាជ្ញារបស់ស្តេចសាឡូម៉ូន និងព្រះដែលទ្រង់បម្រើ ។

ដល់ក្រុងយេរូសាឡិម មានមនុស្សដង្ហែមកយ៉ាងសន្ធឹក[ឃ] ក៏
មានសត្វអូដ្ឋជាច្រើនផ្ទុកដោយគ្រឿងក្រអូប និងមាសជា
ច្រើនណាស់ ហើយត្បូងមានដំឡៃផង លុះកាល ព្រះនាង
បានចូលមកគាល់សាឡូម៉ូនហើយ នោះក៏មានសវនីយ៍
សន្ទនានឹងទ្រង់ ពីគ្រប់ទាំងសេចក្តីដែលមាននៅក្នុងព្រះទ័យ
[៣]ឯសាឡូម៉ូន ទ្រង់ក៏ឆ្លើយស្រាយន័យគ្រប់ទាំងសេចក្តីដែល
ព្រះនាងសួរ ឥតមានអ្វីលាក់កំបាំងដល់ស្តេច ដែលទ្រង់មិន
បានស្រាយន័យថ្វាយព្រះនាងនោះទេ [៤]កាលមហាក្សត្រី
ស្រុកសេបា បានឃើញប្រាជ្ញារបស់សាឡូម៉ូនទាំងប៉ុន្មាន
នឹង ដំណាក់ដែលទ្រង់ធ្វើ [៥]ព្រមទាំងព្រះស្ងោយនៅលើតុ[ង]
ទ្រង់ ទីលំនៅរបស់ពួកបំរើទ្រង់សណ្ឋានពួកបរិវាររបស់
ទ្រង់ និងគ្រឿងតែងកាយរបស់គេ ហើយពួកបំរើថ្វាយពែង
របស់ទ្រង់ និងដង្វាយដុត ដែលទ្រង់ថ្វាយ ក្នុងព្រះវិហារនៃ
ព្រះយេហូវ៉ា នោះព្រះនាងក៏ភាំងស្មារតី [៦]ហើយមាន
សវនីយ៍ទៅស្តេចថា ពាក្យដែលខ្ញុំម្ចាស់បានឮផ្សាយទៅដល់
ស្រុកខ្ញុំម្ចាស់ ពីព្រះរាជកិច្ចនឹងប្រាជ្ញារបស់ទ្រង់ នោះក៏ពិត
ប្រាកដមែន [៧]ប៉ុន្តែខ្ញុំម្ចាស់មិនបានជឿទេ[ច] លុះត្រាតែបាន
មកឃើញនឹងភ្នែកខ្លួនឯង ហើយមើល ដំណឹងដែលខ្ញុំម្ចាស់
បានឮនោះ មិនទាំងដល់ត្រឹមពាក់កណ្តាលផង គឺប្រាជ្ញា
នឹងសេចក្តីចំរើន[ឆ]របស់ទ្រង់ នោះហួសលើសពីកិត្តិសព្ទ
ដែលខ្ញុំម្ចាស់បានឮទៅទៀត [៨]មានពរហើយ ពួកទ្រង់នឹង
ពួកអ្នកបំរើនេះ ដែលឈរចំពោះទ្រង់ជានិច្ច ទាំងស្តាប់[ជ]
ប្រាជ្ញារបស់ទ្រង់ [៩]សូមឱ្យព្រះយេហូវ៉ាជាព្រះនៃទ្រង់បាន
ប្រកបដោយព្រះពរ[ឈ] ជាព្រះដែលសព្វព្រះហឫទ័យនឹង
ទ្រង់ ដើម្បីនឹងតាំងឡើងលើបល្ល័ង្ករាជ្យ នៃសាសន៍អ៊ីស្រា
អែល គឺដោយព្រោះព្រះយេហូវ៉ា ទ្រង់ស្រឡាញ់សាសន៍
អ៊ីស្រាអែលអស់កល្បជានិច្ច[ញ] បានជាតាំងទ្រង់ឡើងឱ្យធ្វើ

**១០:២** ឃ លប ២៤:១០
**១០:៥** ង ១ពវ ៤:២២
**១០:៧** ច លប ៤៥:២៦ ឆ ១រប ២៩:២៥
**១០:៨** ជ សភ ៨:៣៤
**១០:៩** ឈ ១ពវ ៥:៧ អស ៤២:១០ ញ ចទ ៧:៨ ដ ទដ ១១:៧ ៣៣:៥ ៧២:២ ៩៩:៤ ១០៣:៦
**១០:១០** ឋ ១ពវ ៩:២៨ អស ៦០:៦
**១០:១១** ឌ លប ១០:២៩
**១០:១៤** ឍ ១ពវ ៩:២៨
**១០:១៦** ណ ២សយ ៨:៧

ជាស្តេចលើគេ ប្រយោជន៍ឱ្យបានសំរេចសេចក្តីយុត្តិធម៌[ដ]
និងសេចក្តីសុច្ចរិត [១០]រួចព្រះនាងទ្រង់ថ្វាយមាស១២០
ហាប[ឋ] និងគ្រឿងក្រអូបយ៉ាងសន្ធឹក ព្រមទាំងត្បូងមានដំឡៃ
ដល់ស្តេច ក្រោយនោះមកមិនដែលមានគ្រឿងក្រអូបជា
បរិបូរដល់ម្ល៉េះបានចូលមក ឱ្យដូចជាគ្រឿងក្រអូប ដែល
មហាក្សត្រីស្រុកសេបាបានថ្វាយដល់ស្តេចសាឡូម៉ូន នោះ
ទៀតឡើយ ។
[១១]ឯក្រុមនាវារបស់ហ៊ីរ៉ាម ដែលដឹកយកមាសមកពី
ស្រុកអូភារ[ឌ] នោះក៏ដឹកយកឈើចាន់ជាបរិបូរ នឹងត្បូងមាន
ដំឡៃមកពីស្រុកនោះដែរ [១២]ស្តេចទ្រង់យកឈើចាន់នោះ
ធ្វើជាភ្នាក់ដៃ នៅក្នុងព្រះវិហារ នៃព្រះយេហូវ៉ា និងក្នុង
ដំណាក់របស់ស្តេច ព្រមទាំងស៊ុង និងពិណ សំរាប់ពួក
ចំរៀងផង មិនដែលមានឈើចាន់យ៉ាងនោះមកទៀត ក៏
មិនដែលឃើញសោះឡើយ ដរាបដល់សព្វថ្ងៃនេះ ។
[១៣]ស្តេចសាឡូម៉ូនទ្រង់ក៏ប្រទានដល់មហាក្សត្រីស្រុក
សេបា តាមបំណងព្រះទ័យរបស់ព្រះនាង គឺរបស់អ្វីដែល
ព្រះនាងសូម លើសអំពីព្រះរាជទ្រព្យហ្លួងទាំងប៉ុន្មានដែល
សាឡូម៉ូនបានប្រទានឱ្យផង ដូច្នេះព្រះនាង ព្រមទាំងពួក
បរិវារ ក៏វិលត្រឡប់ទៅឯស្រុករបស់ខ្លួនវិញ ។

## ភាពរុងរឿងរបស់សាឡូម៉ូន

*១០:១៤–២៩ – ២រប ១:១៤–១៧ ៩:១៣–២៨*

[១៤]រីឯមាស[ឍ]ដែលមកដល់សាឡូម៉ូនក្នុង១ឆ្នាំ នោះមាន
ទំនងជា៦៦៦ហាប [១៥]ក្រៅពីនោះ មានមាសដែលមក
ដោយសារពួកអ្នកលក់ដូរនឹងការជំនួញ ហើយពីអស់ទាំង
ស្តេចស្រុកអារ៉ាប់និងពួកចៅហ្វាយស្រុកទាំងប៉ុន្មានថែម
ទៀត [១៦]ស្តេចសាឡូម៉ូនទ្រង់ផែមាសធ្វើខែលធំ[ណ] ២០០គឺ
យកមាស៦០០ដំឡឹង ដើម្បីធ្វើខែលមួយៗ [១៧]ទ្រង់ក៏ផែមាស

**១០:៩** *សូមឱ្យព្រះយេហូវ៉ាជាព្រះនៃទ្រង់បានប្រកបដោយព្រះពរ* នេះជាព្រះសវនីយ៍ របស់ម្ចាស់ក្សត្រីស្រុកសេបា ដែលបានសារភាពចេញពីចិត្តដ៏ជ្រៅក្នុងការដែលថា ពួកអ៊ីស្រាអែលបានប្រកាន់ភ្ជាប់នូវសេចក្តីសញ្ញារបស់ព្រះអម្ចាស់យ៉ាងខ្ជាប់ខ្ជួនបំផុតនោះ ។ ទោះបីជាយ៉ាងនេះក៏ដោយក៏មិនមានអ្វីបញ្ជាក់ឱ្យលើសពីនេះ ចំពោះការទទួលស្គាល់ព្រះពួកអ៊ីស្រាអែលរបស់ព្រះនាងគឺនៅដដែលដូចដែលពួកសាសន៍ដទៃអញ្ជឹងដែរ (មើលការពន្យល់ ៥:៧ បន្ថែម ២រប ២:១២ ដយ ៣:២៨–២៩) ។ គ្មានការសារភាព ថាព្រះរបស់ស្តេចសាឡូម៉ូន បានត្រឡប់មកជាព្រះរបស់ពួកមនុស្សទាំងអស់នោះដែរ ។

**១០:១០** *មាស១២០ហាប* មើលការពន្យល់ ៩:១១,២៨ ។

**១០:១១** *នាវារបស់ហ៊ីរ៉ាម* មើល ៩:២៦–២៨ ។ ស្តេចហ៊ីរ៉ាម បានផ្គត់ផ្គង់ដល់ពួកអ៊ីស្រាអែលមានដូចជា ឈើ កម្មករនាវា និងពួកអ្នកជំនាញក្នុងការសាងសង់ ដែលពួកអ៊ីស្រាអែលពុំមាន ។ *ឈើចាន់* មើល ២រប ៩:១០–១១ ហើយឈើនេះប្រហែលជាយកមកពីភ្នំល្បាណូន ដូចនៅក្នុង ២រប ២:៨ ។

**១០:១៣** *តាមបំណងព្រះហឫទ័យរបស់ព្រះនាង គឺរបស់អ្វីដែលព្រះនាងសូម* ឃ្លានេះប្រាប់ពីការដោះដូរអំណោយរវាងស្តេចសាឡូម៉ូន និងព្រះនាងស្រុកសេបា ដែលជានិមិត្តរូបនៃការយល់ព្រមលើកិច្ចព្រមព្រៀងផ្នែកពាណិជ្ជកម្ម (មើលការពន្យល់ ខ.១) ។

**១០:១៥** *មកដោយសា . . . ស្តេចស្រុកអារ៉ាប់* សួយសារអាការនេះសម្រាប់ការឆ្លងកាត់របស់ពួកគេក្នុងការឆ្លងកាត់ទឹកដីរបស់ពួកអ៊ីស្រាអែល ។ *ចៅហ្វាយស្រុក* ប្រហែលជាសំដៅលើពួកអ្នកនៅក្នុង ៤:៧–១៩ ។

**១០:១៦** *ខែល* ខែលនេះមានរាងជាចតុកោណកែង ដែលផ្តល់នូវរបាំងការពារយ៉ាងសុវត្ថិភាពបំផុត ។ ខែលមាសដែលរៀបរាប់នៅក្នុងខនេះគឺមិនសំដៅលើការយករបស់នេះទៅប្រើនៅក្នុងសង្គ្រាមនោះទេ តែជាការប្រើក្នុងការប្រារព្ធពិធីផ្សេងៗ ហើយវាជានិមិត្តសញ្ញាពីតម្លៃ និងសិរីល្អរបស់ពួកអ៊ីស្រាអែលវិញ ។ ខែលនេះធ្វើអំពីឈើ ស្រោបពីលើមាស ។

ធ្វើខែលតូច៣០០ ក្នុងខែលមួយៗ មានមាស៦នាលិ
ហើយទ្រង់ដឹកលទុកទាំងអស់ក្នុងដំណាក់នៃព្រៃល្បាណូន[ត]
[១៨]មួយទៀតស្តេចទ្រង់ធ្វើបល្ល័ង្ក១ធំ ដោយភ្លុក ហើយ
ស្រោបមាសសុទ្ធលេខ១ [១៩]មានជណ្តើរ៦ថ្នាក់ឡើងទៅដល់
បល្ល័ង្កនោះ ឯបង្អែកបល្ល័ង្កនោះរាងមូល ហើយមាន
កំណល់ដៃ នៅទាំងសងខាងទីអង្គុយ មានរូបសិង្ហ២ឈរ
នៅខាងកំណល់ដៃ [២០]ហើយមានសិង្ហ១២ឈរនៅថ្នាក់
ជណ្តើរ៦ម្ខាង គ្មានបល្ល័ង្កណានៅក្នុងនគរណា ដែលនឹង
ផ្ទឹមស្មើបានឡើយ [២១]ឯអស់ទាំងប្រដាប់សំរាប់សាឡូម៉ូន
សោយគ្រឿងទឹក នោះសុទ្ធតែធ្វើពីមាសទាំងអស់[ថ] ហើយ
អស់ទាំងគ្រឿងប្រដាប់ នៅក្នុងដំណាក់នៃព្រៃល្បាណូន ក៏
ធ្វើពីមាសសុទ្ធដែរ គ្មានណាមួយធ្វើពីប្រាក់ទេ នៅក្នុងរាជ្យ
សាឡូម៉ូន នោះគេមិនសូវរាប់អានប្រាក់ប៉ុន្មានទេ [២២]ដ្បិត
ស្តេចទ្រង់មានក្រុមនាវា[ទ]តើស៊ីស ដើរផ្លូវសមុទ្រ ជាមួយនឹង
នាវារបស់ហ៊ីរ៉ាម ក្រុមនាវា[ធ]តើស៊ីសនោះ ក៏ដឹកយកមាស
ប្រាក់ ភ្លុក ទោច និងក្ងោកមកក្នុង៣ឆ្នាំ១ដង ។
[២៣]ដូច្នេះ ស្តេចសាឡូម៉ូនទ្រង់មានទ្រព្យសម្បត្តិ[ន] និង
ប្រាជ្ញា[ប]លើសជាងអស់ទាំងស្តេចនៅផែនដី [២៤]ហើយប្រ
ជាជនក្នុងលោកទាំងមូល គេរកចង់ចូលទៅគាល់ស្តេច
សាឡូម៉ូន ដើម្បីនឹងស្តាប់ប្រាជ្ញា[ផ]ទ្រង់ ដែលព្រះបានដាក់
នៅក្នុងព្រះទ័យ [២៥]គ្រប់គ្នាក៏នាំយកដង្វាយមកថ្វាយ[ព] គឺជា
គ្រឿងមាស ប្រាក់សំលៀកបំពាក់ គ្រឿងសស្ត្រាវុធ គ្រឿង
ក្រអូប សេះ និងលាកាត់តាមកំណត់រាល់តែឆ្នាំ [២៦]សាឡូ
ម៉ូនក៏ប្រមូលចំរើន រទេះចំបាំង និងពលសេះ[ភ] ទ្រង់មាន
រទេះចំបាំង១ពាន់៤០០ ហើយពលសេះ១ម៉ឺន២ពាន់នាក់
ដែលទ្រង់ដាក់ឱ្យនៅក្នុងទីក្រុង សំរាប់រទេះចំបាំងទាំង
ប៉ុន្មាន ហើយនៅជាមួយនឹងស្តេច នៅក្នុងក្រុងយេរូសាឡិម
ដែរ [២៧]ទ្រង់បានធ្វើឱ្យមានប្រាក់សម្បូរ[ម] ដូចជាថ្ម[យ]នៅក្នុង
ក្រុងយេរូសាឡិម ហើយឱ្យមានដើមតាត្រៅសម្បូរដូចជា
ដើមឧទុម្ពរ[រ] ដែលដុះនៅដីទំនាប [២៨]ឯអស់ទាំងសេះរបស់
សាឡូម៉ូន នោះបានយកមកពីស្រុកអេស៊ីព្ទ ពួកជំនួញរបស់
ស្តេចគេទិញមកទាំងហ្វូង តាមដំឡៃ១ហ្វូងៗ [២៩]គេក៏នាំ
រទេះចំបាំងពីស្រុកអេស៊ីព្ទមក ១ថ្លៃ៦០០រៀល ហើយសេះ
១ថ្លៃ១៥០ គេក៏ទិញដឹកនាំមក សំរាប់ឱ្យអស់ទាំងស្តេចនៃ
សាសន៍ហេត[ល] និងពួកស្តេចស្រុកស៊ីរីយ៉ាងដូច្នោះដែរ ។

## ប្រពន្ធស្តេចសាឡូម៉ូន

**១១** [១]រីឯស្តេចសាឡូម៉ូន ទ្រង់បានស្រឡាញ់ពួកស្រីៗ
សាសន៍ដទៃជាច្រើន[ក] ក្រៅពីព្រះរាជបុត្រីផារ៉ោននោះគឺជា
ស្ត្រីសាសន៍ម៉ូអាប់ សាសន៍អាំម៉ូន[ខ] សាសន៍អេដំម សាសន៍
ស៊ីដូន និងសាសន៍ហេត [២]ជាស្ត្រីនៃសាសន៍ផ្សេងៗដែល
ព្រះយេហូវ៉ាបានហាមដល់ពួកកូនចៅអ៊ីស្រាអែលថា មិន
ត្រូវឱ្យឯងរាល់គ្នាចូលទៅ[គ]ឯគេ ឬឱ្យគេចូលមកឯឯង
រាល់គ្នាឡើយ ដ្បិតគេនឹងបង្វែរចិត្តឯងរាល់គ្នាឱ្យទៅ
តាមព្រះគេជាមិនខាន តែសាឡូម៉ូនបានចងពន្ធនឹងគេ
ដោយសេចក្តីស្រឡាញ់វិញ [៣]ទ្រង់មានភរិយាអស់៧០០ សុទ្ធ
តែជាកូនស្តេចទាំងអស់ ហើយមានស្រីអ្នកម្នាង៣០០[ឃ]

**១០:១៧** ត ១ពវ ៧:២
**១០:២១** ថ អស ៦០:១៧
**១០:២២** ទ ១ពវ ៩:២៦ ធ ១ពវ ៩:២៧ ទដ ៤៨:៧ អស ២:១៦ ២៣:១,១៤ ៦០:៦,៩
**១០:២៣** ន ១ពវ ៣:១៣ មថ ៦:២៩ ប ១ពវ ៣:១២ មថ ១២:៤២
**១០:២៤** ផ ២សយ ១៤:២០
**១០:២៥** ព ១សយ ១០:២៧
**១០:២៦** ភ ចទ ១៧:១៦
**១០:២៧** ម ចទ ១៧:១៧ យ យប ២៧:១៦ អស ៦០:១៧ រ ១រប ២៧:២៨ អម ៧:១៤
**១០:២៩** ល ជន ១៣:២៩
**១១:១** ក ខ.៣ នក ៣៤:១៦ ខ ១ពវ ១៤:២១,៣១
**១១:២** គ នក ៣៤:១៦ ១ពវ ១៦:៣១ **១១:៣** ឃ លប ២២:២៤ នអ ២:១៤ ង ខ.១ ចទ ១៧:១៧ នហ ១៣:២៦ សភ ៣១:៣

**១០:១៧** *ដំណាក់នៃព្រៃល្បាណូន* មើល ៧:២ និងការពន្យល់ ។ *ក្រុមនាវា* នាវាដដែលនេះគឺសំដៅលើនាវាក្នុងខ.១១,៩:២៦–២៨។ (Ships of Tarshish) នាវានេះគឺមិនមានភាពចាំបាច់ និងសារសំខាន់ ដែលបើកទៅ (Tarshish) (មើលការពន្យល់ យហ ១:៣) ប៉ុន្តែការបង្ហាញ នាវាធំ សម្រាប់ដឹកទំនិញ ។

**១០:២៦** *រទេះចំបាំង និងពលសេះ* មើលការពន្យល់ ៤:២៦ ។ ការបង្កើនពលសេះ ត្រូវបានហាមប្រាមនៅក្នុងក្រឹត្យវិន័យលោម៉ូសេ(ចទ ១៧:១៦) ។

**១០:២៧** *ដើមឧទុម្ពរ* មើលការពន្យល់ អម ៧:១៤ ។

**១០:២៩** *ទិញនាំមក* តាមរយៈខ.២៨នេះយើងឃើញថា ស្តេចសាឡូម៉ូនជាឈ្មួញកណ្តាល ហើយចំណេញបានច្រើននៅក្នុងអាជីវកម្មនេះផងដែរ ។ *សាសន៍ហេត* មើលការពន្យល់ លប ១០:១៥ ។

**១១:១–១៣** នៅវគ្គនេះ ជាភាពឆ្គួតលីលារបស់ស្តេចសាឡូម៉ូន ដែលកើតមាននៅក្នុងប្រាជ្ញារបស់ទ្រង់(សូមមើល ជំពូក ៣ និងការពន្យល់ ១:១–១២:២៤) ។

**១១:១** *ទ្រង់បានស្រឡាញ់ ពួកស្រីៗសាសន៍ដទៃជាច្រើន* ការរៀបអភិសេករបស់ស្តេចសាឡូម៉ូនជាច្រើនលើកច្រើនសា នោះគឺគ្មានការសង្ស័យនោះទេ គឺធ្វើឡើងក្នុងគោលបំណងការទូត ពោលគឺភ្ជាប់ទំនាក់ទំនងរវាងអាណាចក្រផ្សេងៗ គឺធំនិងតូចត្រូវបានគេអនុវត្តនៅមជ្ឈឹមបូព៌ាបុរាណ ។ ប៉ុន្តែការនេះមិនគ្រាន់តែបានបំពាននូវអ្វីដែលបាបចែង នៅក្នុង ចទ ១៧:១៧ ដែលនិយាយ អំពីការរៀបអាពាហ៍ពិពាហ៍ច្រើននោះទេ តែថែមទាំងការហាមប្រាមចំពោះអាពាហ៍ពិពាហ៍ក្នុងចំណោមពួកសាសន៍ដទៃផងដែរ ដែលពួកគេបានមករស់នៅក្នុងចំណោមពួកអ៊ីស្រាអែល(មើល នក ៣៤:១៦ ចទ ៧:១–៣ យស ២៣:១២–១៣ អគ ៩:២ ១០:២–៣ នហ ១៣:២៣–២៧) ។ *សាសន៍ម៉ូអាប់* មើលការពន្យល់ លប ១៩:៣៦–៣៨ ។ *សាសន៍អាំម៉ូន* មើលការពន្យល់ លប ១៩:៣៦–៣៨ បន្ថែម ១៤:២១ ចទ ២៣:៣ ។ *សាសន៍អេដំម* មើលការពន្យល់ លប ២៥:២៦ ៣៦:១ អម ១:១១ បន្ថែម ចទ ៣៧:៧–៨ ។ *សាសន៍ស៊ីដូន* មើល ១៦:១៣ ។

**១១:២** *ដ្បិតគេនឹងបង្វែរចិត្តឯងរាល់គ្នា ឱ្យទៅតាមព្រះគេជាមិនខាន* ការនេះបានសម្រេចក្នុងខ.៤ ជាឧទាហរណ៍ពីប្រវត្តិសាស្ត្រដំបូង មាននៅក្នុង ជន ២៥:១–១៥ ។

**១១:៣** *ភរិយាអស់៧០០ . . . អ្នកម្នាង៣០០* សូមធៀប បស ៦:៨ ប៉ុន្តែមើលការពន្យល់ត្រង់នោះផងដែរ ។ *អ្នកម្នាង* មើល លប ២៥:៦ ។

ឯភរិយាទាំងនោះ ក៏នាំបង្វែរព្រះទ័យទ្រង់ចេញ[ង] ៤ដ្បិត
កាលសាឡូម៉ូនទ្រង់ចាស់ហើយ នោះភរិយាទ្រង់បានបង្វែរ
ព្រះទ័យទ្រង់ឱ្យទៅតាមព្រះដទៃវិញ[ច] ហើយព្រះទ័យទ្រង់
មិនបានស្មោះត្រង់[ឆ] នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃទ្រង់
ដូចជាព្រះទ័យរបស់ដាវីឌ ជាបិតាទ្រង់ទេ ៥ពីព្រោះ
សាឡូម៉ូនទ្រង់ប្រតិបត្តិតាមព្រះអាសថារ៉ូត[ជ] ជាព្រះនៃពួក
ស៊ីដូន ហើយតាមព្រះមីលកូម[ឈ] ជាសេចក្តីគួរខ្ពើមរបស់
ពួកអាំម៉ូនដែរ ៦សាឡូម៉ូនក៏ប្រព្រឹត្តការដែលអាក្រក់[ញ]
នៅព្រះនេត្រនៃព្រះយេហូវ៉ា ហើយមិនបានតាមព្រះ
យេហូវ៉ា ដោយពេញខ្នាត ដូចជាដាវីឌ ជាព្រះបិតាទ្រង់ទេ
៧នៅគ្រានោះសាឡូម៉ូនទ្រង់ក៏ធ្វើកន្លែង សំរាប់ថ្វាយបង្គំ
ដល់ព្រះកេម៉ូស[ដ] ជាសេចក្តីគួរខ្ពើមរបស់ពួកម៉ូអាប់[ឋ] នៅ
លើទីខ្ពស់១ ដែលជាភ្នំនៅទល់មុខ[ឌ]នឹងក្រុងយេរូសាឡិម
និងសំរាប់ព្រះម៉ូឡុក ជាសេចក្តីគួរខ្ពើមរបស់ពួកកូនចៅ
អាំម៉ូនដែរ ៨ទ្រង់ក៏ធ្វើយ៉ាងនោះសំរាប់ដល់គ្រប់ទាំង
ភរិយារបស់ទ្រង់ ជាសាសន៍ដទៃទាំងនោះ ហើយនាងទាំង
នោះក៏ដុតកំញាន ព្រមទាំងថ្វាយយញ្ញបូជា ដល់ព្រះ
របស់គេ ។

៩ដូច្នេះ ព្រះយេហូវ៉ាទ្រង់កើតមានសេចក្តីខ្ញាល់ចំពោះ
សាឡូម៉ូន ដោយព្រោះព្រះទ័យទ្រង់បានបែរចេញពីព្រះ
យេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រាអែល ដែលបានលេច
មក[ឍ] ឱ្យទ្រង់ឃើញ២ដងហើយ ១០ក៏បានបង្គាប់ដល់ទ្រង់
ពីដំណើរនេះដែរថា មិនត្រូវឱ្យទ្រង់ប្រតិបត្តិតាមព្រះដទៃ
ឡើយ[ណ] តែទ្រង់មិនបានរក្សាសេចក្តីដែលព្រះយេហូវ៉ា
បានបង្គាប់មកនោះទេ[ត] ១១ហេតុដូច្នោះ ព្រះយេហូវ៉ាទ្រង់
មានបន្ទូលនឹងសាឡូម៉ូនថា ដោយព្រោះឯងបានធ្វើយ៉ាង
នេះ ហើយមិនបានរក្សាសេចក្តីសញ្ញារបស់អញ និងបញ្ញត្ត[ថ]
ដែលអញបានបង្គាប់ដល់ឯង នោះបានជាអញនឹងកន្ត្រាក់[ទ]
យករាជ្យ ពីឯងវិញជាពិត ហើយឱ្យទៅអ្នកបំរើរបស់ឯង
វិញ ១២ប៉ុន្តែ អញមិនធ្វើក្នុងគ្រានៃជីវិតឯងទេ ដោយយល់
ដល់ដាវីឌ[ធ]ជាឪពុកឯង គឺអញនឹងកន្ត្រាក់យកពីដៃកូនឯង
វិញ ១៣អញក៏មិនយកនគរទាំងមូលពីវាដែរ គឺនឹងឱ្យពូជ
អំបូរ១[ន]ដល់កូនឯង ដោយយល់[ប]ដល់ដាវីឌ ជាអ្នកបំរើអញ
ហើយយល់ដល់ក្រុងយេរូសាឡិម ដែលអញបានរើស
ហើយផង[ផ] ។

### អ្នកតតាំងនឹងស្តេចសាឡូម៉ូន

១៤ព្រះយេហូវ៉ាទ្រង់ក៏បណ្តាល ឱ្យមានអ្នកតតាំង[ព]នឹង
សាឡូម៉ូនម្នាក់ គឺហាដាឌ់ ជាសាសន៍អេដំម ដែលជាវង្សានៃ
ស្តេចស្រុកនោះ ១៥ពីព្រោះកាលដាវីឌបានទៅស្រុកអេដំម
ហើយយ៉ូអាប់ ជាមេទ័ពបានឡើង ទៅកប់ខ្មោចនៃពួកអ្នក
ដែលស្លាប់ក្នុងចំបាំង គឺក្នុងពេលក្រោយដែល បានសំឡាប់
ពួកប្រុសៗទាំងអស់នៅសាសន៍អេដំម[ភ] ១៦(ដ្បិតយ៉ូអាប់ និង
ពួកអ៊ីស្រាអែលទាំងអស់ បាននៅស្រុកនោះអស់៦ខែ ទាល់
តែបានសំឡាប់ពួកប្រុសៗ នៃសាសន៍អេដំមនោះអស់រលីង
ទៅ) ១៧គ្រានោះ ហាដាឌ់បានរត់រួចព្រមទាំងសាសន៍អេដំម

**១១:៤** ច នក ៣៤:១៦ ឆ ១ពវ ៨:៦១ ១រប ២៩:១៩ **១១:៥** ជ ពច ២:១៣ ឈ ខ.៧ លវ១៨:២១ អស ៥៧:៩ សផ១:៥ **១១:៦** ញ ចទ ៤:២៥ **១១:៧** ដ ជន ២១:២៩ ឋ លប ១៨:២១ ២០:២–៥ កច ៧:៤៣ ឌ ២ពវ ២៣:១៣ **១១:៩** ឍ ១ពវ ៣:៥ **១១:១០** ណ ១ពវ ៩:៦ ត ១ពវ ៦:១២ **១១:១១** ថ លវ ១៨:៤ ទ ខ.៣១ ១សយ ១៥:២៧ ២ពវ ១៧:២១ មថ ២១:៤៣ **១១:១២** ធ ទដ ៨៩:៣៣ **១១:១៣** ន ១ពវ ១២:២០ ប ២សយ ៧:១៥ ផ ចទ ១២:១១ **១១:១៤** ព ១ពវ ៥:៤ **១១:១៥** ភ ១រប ១៨:១២

**១១:៤** *ភរិយាទ្រង់បានបង្វែរទ្រង់ឱ្យទៅតាមព្រះដទៃវិញ* នៅត្រង់ដូចទៅនឹងអ្វីដែលព្រះអម្ចាស់បានព្រមាននៅក្នុងខ.២ ។ *ព្រះទ័យទ្រង់មិនបានស្មោះត្រង់* មើល ៨:៦១ ។ បរិយាកាស ពួកសាសន៍ដ៏ទៃ និង សេចក្តីកំផិតបានធ្វើឱ្យស្តេចសាឡូម៉ូនធ្លាក់ទៅក្នុងភរិយាសាសន៍ដទៃហើយបន្តិចក្រោយមកស្តេច សាឡូម៉ូនធ្លាក់ខ្លួនទៅការគោរពនូវជំនឿខុសឆ្គងទាំងនេះ ។

**១១:៥** *ព្រះអាសថារ៉ូត* មើល ខ.៣៣ ១៤:១៥ ២ពវ ២៣:១៣ មើលបន្ថែម ពច ២:១៣ ១សយ ៧:៣ ។

**១១:៦** *ដូចជាដាវីឌ ជាព្រះបិតាទ្រង់ទេ* ទោះបីស្តេចដាវីឌបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ ប៉ុន្តែទ្រង់ក៏មានការសោកស្តាយចំពោះអំពើនេះផងដែរ ហើយទ្រង់ក៏មិនដែលនឹងជាប់ទាក់ទងនឹងភាពកំផិត ។

**១១:៧** *លើទីខ្ពស់* មើលពន្យល់ ៣:២ ។ *កេម៉ូស* មើលពន្យល់ ២ពវ ៣:២៧។

**១១:៩** *បានលេចមកឱ្យទ្រង់ឃើញ២ដង* សូមមើល ៣:៤–៥ ៩:១–៩ ។

**១១:១១** *មិនបានរក្សាសេចក្តីសញ្ញារបស់អញ* ស្តេចសាឡូម៉ូនបានប្រព្រឹត្តខុសចំពោះការទាមទាររបស់ក្រឹត្យវិន័យ(មើល នក ២០:២–៥) និងធ្វើឱ្យរាស្ត្ររបស់ព្រះអង្គបាត់ទំនាក់ទំនងជាមួយនឹងទ្រង់ ។

**១១:១២** *ដោយយល់ដល់ដាវីឌ ជាឪពុកឯង* ឃ្លានេះបានប្រាប់ពីពីការយោគយល់របស់ព្រះអម្ចាស់ចំពោះការ ដែលស្តេចដាវីឌបានធ្វើតាមគ្រប់បញ្ញត្តិរបស់ព្រះវរបិតា និងសេចក្តីសញ្ញារបស់ទ្រង់(មើល ២សយ ៧:១១–១៦)។

**១១:១៣** *អំបូរ១* សំដៅលើអំបូយូដា(មើលការពន្យល់ ខ.៣១–៣២ បន្ថែម ១២:២០) ។ *យល់ដល់ក្រុងយេរូសាឡិម ដែលអញបានរើស* ត្រង់ចំណុចនេះក្រុងយេរូសាឡឹមបានបន្ថែមនូវព្រះវិហារមួយទៀត ដែលសង់ឡើងដោយព្រះរាជបុត្ររបស់ស្តេចដាវីឌ ដូចមានចែងនៅក្នុង ២សយ ៧:១៣ និងជោគវាសនាក្រុងយេរូសាឡឹម តំណវង្សរបស់ស្តេចដាវីឌ គឺមានចែងនៅក្នុង (មើល ២ពវ ១៩:៣៤ ២១:៧–៨ ទដ ១៣២) ។ ព្រះវិហារតំណាងឱ្យព្រះរាជវាំងដ៏ខ្ពង់ខ្ពស់របស់ព្រះនៅផែនដី ដែលកំពុងឈរយ៉ាងស្ថិតស្ថេរ ហើយព្រះវិហារនេះក៏ជា អ្វីដែលព្រះទ្រង់បានសន្យាថានឹងប្រទានទីនេះ ដល់ពួកស្តេចអ៊ីស្រាអែលជាអំណោយផងដែរ (៩:៣) ។

**១១:១៤** *ហាដាឌ់* នេះជាឈ្មោះអទិទេពផ្នែកផ្គរ រន្ទះ(មើលពន្យល់ ពច ២:១៣ អគ ១២:១១) ដែលអទិទេពរូបនេះត្រូវបានពួកអ្នកស្រុកស៊ីរីគោរពបូជា(មើល ១៥:១៨ ២០:១ និងការពន្យល់) និងពួកស្តេចនៅស្រុកអេដំម (មើល លប ៣៦:៣៥,៣៩) ជានាមដ៏ប្រសើររបស់ពួកគេ ។

**១១:១៥** *ដាវីឌបានទៅស្រុកអេដំម* មើល ២សយ ៨:១៣–១៤ ។

**១១:១៦** *ពួកអ៊ីស្រាអែលទាំងអស់ . . . ប្រុសៗនៃសាសន៍អេដំម* ឃ្លានេះបានប្រាប់ពីការដែលពួកគេរស់នៅក្នុងទីកន្លែងតែមួយជាមួយគ្នា ។

ខ្លះដែលជាអ្នកបំរើរបស់ឪពុកលោកដែរ ក៏រត់ទៅអាស្រ័យ
នៅស្រុកអេស៊ីព្ទ ក្នុងកាលដែលហាដាឌ់នៅជាកុមារតូច
នៅឡើយ ១៨គេនាំគ្នាចេញពីស្រុកម៉ាឌានទៅ ដល់ស្រុក
ប៉ារ៉ាន[ម] ក៏នាំយកមនុស្សខ្លះពីប៉ារ៉ាន ទៅជាមួយនឹងគេ ចូល
ទៅក្នុងស្រុកអេស៊ីព្ទ គាល់ផារ៉ោន ជាស្តេចស្រុកនោះ
ហើយទ្រង់ក៏ប្រទានផ្ទះ១ឱ្យលោកនៅ នឹងស្រែចំការដែរ
ព្រមទាំងផ្គត់ផ្គង់ស្បៀងអាហារផង ១៩ឯហាដាឌ់ បានប្រកប
ដោយគុណរបស់ផារ៉ោនយ៉ាងធំ ដល់ម៉្លេះបានជាទ្រង់
ប្រទានប្អូនរបស់ភរិយាទ្រង់ គឺជាប្អូននាងថាផ្នេស ដែលជា
អគ្គមហេសី ឱ្យធ្វើជាប្រពន្ធលោក ២០ប្អូនរបស់នាងថាផ្នេស
ក៏បង្កើតកូនប្រុស១ឱ្យលោកឈ្មោះថា គេនូបាត ហើយនាង
ថាផ្នេស ក៏ផ្តាច់ដោះ នៅក្នុងដំណាក់ផារ៉ោន រួចគេនូបាត
បាននៅក្នុងដំណាក់ផារ៉ោន ជាមួយនឹងព្រះរាជបុត្រនៃ
ស្តេច ២១ក្រោយមកកាលហាដាឌ់ បានឮនៅស្រុកអេស៊ីព្ទថា
ដាវីឌបានផ្ទំលក់ជាមួយនឹងពួកព្ធយុកោទ្រង់ហើយ ព្រមទាំង
យ៉ូអាប់ជាមេទ័ពដែរ នោះហាដាឌ់ទូលផារ៉ោនថា សូមឱ្យ
ទូលបង្គំត្រឡប់ទៅឯស្រុកទូលបង្គំវិញ ២២តែផារ៉ោនមាន
បន្ទូលសួរថា នៅជាមួយនឹងយើងនេះ តើឯងមានខ្វះខាត
អ្វីបានជាចង់ត្រឡប់ទៅស្រុកវិញដូច្នេះ លោកទូលឆ្លើយថា
គ្មានខ្វះអ្វីទេ ប៉ុន្តែសូមឱ្យតែទូលបង្គំបានទៅចុះ ។
២៣ព្រះក៏បណ្តាលឱ្យមានអ្នកតតាំងនឹងទ្រង់ម្នាក់ទៀត[យ]
គឺឈ្មោះរេសោន ជាកូនអេលីយ៉ាដា ជាអ្នកដែលបានរត់
ពីហាដា-រេស៊ើរ[រ] ជាស្តេចសូបា ចៅហ្វាយរបស់ខ្លួន ២៤អ្នក
នោះក៏ប្រមូលមនុស្សមកតាមខ្លួន ហើយបានធ្វើជាមេទ័ព
លើពួកនោះ ក្នុងគ្រាដែលដាវីឌបានសំឡាប់ពួកសូបា រួច
គេទៅអាស្រ័យនៅក្រុងដាម៉ាស[ល] ហើយបានគ្រប់គ្រងនៅ
ទីនោះ ២៥អ្នកនោះក៏ទាស់ទទឹងនឹងសាសន៍អ៊ីស្រាអែល
រហូតដល់អស់ព្រះជន្មនៃសាឡូម៉ូន នេះជាការប្រទូសរ៉ាយ
ក្រៅពីការដែលហាដាឌ់បានធ្វើ ឯរេសោនបានស្អប់ខ្ពើម
ដល់សាសន៍អ៊ីស្រាអែល ក៏សោយរាជ្យលើស្រុកស៊ីរី[វ] ។

## យេរ៉ូបោមទាស់ប្រឆាំងនឹងស្តេចសាឡូម៉ូន

២៦ឯយេរ៉ូបោម កូននេបាត ជាពួកអេប្រាអិម ពីស្រុក
សេរេដា ជាអ្នកបំរើសាឡូម៉ូន ដែលម្តាយជាស្រីមេម៉ាយ
ឈ្មោះសេរូអា នោះក៏បានលើកដៃឡើងទាស់[ស]នឹងស្តេច
ដែរ ២៧ហើយហេតុដែលលើកដៃទាស់នឹងស្តេច នោះគឺ
ពីព្រោះសាឡូម៉ូនទ្រង់បានសង់ប៉មមីឡូរ ព្រមទាំងជួសជុល
ទីបាក់បែកនៃកំផែងទីក្រុងរបស់ដាវីឌ ជាព្រះបិតាទ្រង់
២៨យេរ៉ូបោមនេះ ជាអ្នកក្លាហានស្ទាត់ជំនាញ[ហ] សាឡូម៉ូន
ទ្រង់ឃើញថា អ្នកកំឡោះនេះមានចិត្តឧស្សាហ៍[ឡ]ធ្វើការបាន
ជាទ្រង់តាំងឱ្យត្រួតលើការទាំងអស់ របស់ពូជពង្សយ៉ូសែប
២៩នៅគ្រានោះ មានកាល១ថ្ងៃយេរ៉ូបោមចេញពីក្រុង
យេរូសាឡិមទៅ ហើយហោរាអ័ហ៊ីយ៉ា[អ]ជាពួកក្រុងស៊ីឡូរ
ក៏ប្រទះនឹងលោកនៅកណ្តាលផ្លូវ មានតែគ្នា២នាក់នៅ
កណ្តាលវាលនោះ ៣០ឯអ័ហ៊ីយ៉ា លោកបានពាក់អាវថ្មីក៏
ចាប់អាវថ្មីនោះ ហែក[ក]ជា១២ផ្នែកទៅ ៣១រួចប្រាប់ដល់
យេរ៉ូបោមថា ចូរអ្នកយក១០ផ្នែកទៅ ដ្បិតព្រះយេហូវ៉ាជា
ព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់បានមានបន្ទូល ដូច្នេះថា
មើល អញនឹងកន្ត្រាក់[ខ]យករាជ្យពីដៃសាឡូម៉ូន ហើយនឹងឱ្យ

**១១:១៨** ម ជន ១០:១២
**១១:២៣** យ ១ពវ ៥:៤ រ ២សយ ៨:៣
**១១:២៤** ល ២សយ ៨:៥
**១១:២៥** វ លប ១០:២២ ២សយ ១០:១៩
**១១:២៦** ស ២របា ១៣:៦
**១១:២៧** ហ ១ពវ ៩:២៤
**១១:២៨** ឡ នរ ២:១ អ លប ៣៩:៤ សភ ២២:២៩
**១១:៣០** ក ១សយ ១៥:២៧
**១១:៣១** ខ ឌ.១១ ១សយ ១៥:២៧

**១១:១៨** *ស្រុកម៉ាឌាន* ស្រុកនេះមានទីតាំងនៅភាគខាងលិច ជាប់និងស្រុកម៉ូអាប់ និងស្រុកអេដំម ។ *ប៉ារ៉ាន* នេះជាតំបន់វាលខ្សាច់ នៅភាគខាងត្បូងត្រង់កាដេស(មើល ជន ១០:១២ ១២:១៦ ១៣:៣) ។ *ស្រុកអេស៊ីព្ទ គាល់ផារ៉ោន ជាស្តេចស្រុកនោះ* មើលពន្យល់ ៣:១ ។

**១១:២១** *សូមឱ្យទូលបង្គំត្រឡប់ទៅ* គឺវាបានលេចឡើងនៅពេលដែលហាដាឌ់បានត្រឡប់ទៅអេដំមវិញមុនថ្ងៃកំណត់ នៃរាជ្យស្តេចសាឡូម៉ូន ។

**១១:២២** *តើឯងមានខ្វះខាតអ្វី* ឃ្លានេះបានប្រាប់ពីទំនាក់ទំនងល្អរបស់ស្រុកអេស៊ីព្ទ ជាមួយនឹងពួកអ៊ីស្រាអែល(មើលពន្យល់ ៣:១) ហើយស្តេចផារ៉ោនមានសេចក្តីមន្ទិលសង្ស័យចំពោះការដែល ហាដាឌ់បានវិលទៅស្រុកអេដំមដើម្បីបង្ករបញ្ហាជាមួយនឹងស្តេចសាឡូម៉ូន ។

**១១:២៣** *ស្តេចសូបា* មើលពន្យល់ ២សយ ៨:៣ ។

**១១:២៤** *ធ្វើជាមេទ័ព* នេះជាបទពិសោធន៍របស់ស្តេចដាវីឌ (១សយ ២២:១-២) និងយែបថា មុនទ្រង់ទៅទៀត(ពច ១១:៣) ។ *អាស្រ័យនៅក្រុងដាម៉ាស ហើយបានគ្រប់គ្រងនៅទីនោះ* ត្រង់នេះយើងអាចសន្មត់ថា គឺនៅក្នុងពេលនៃការចាប់ផ្តើមឡើងគ្រងរាជ្យរបស់ស្តេចដាវីឌ(មើល ២សយ ៨:៦ សម្រាប់ស្ថានភាពក្រុងដាម៉ាសនៅក្នុងរជ្ជកាលរបស់ស្តេចដាវីឌ) ។

**១១:២៦** *ទាស់នឹងស្តេច* មើលការពន្យល់ ឌ.៤០ ។

**១១:២៧** *ជួសជុលទីបាក់បែក* មើល ៩:១៥ និងការពន្យល់ ។

**១១:២៨** *ឧស្សាហ៍ធ្វើការ . . . របស់ពូជពង្សយ៉ូសែប* មើល ៥:១៣-១៨ ។

**១១:៣១-៣២** *ពូជអំបូរ១០ . . . ពូជអំបូរ១* បើតាមទំនៀមទម្លាប់នៃពូជអំបូរខាងជើង និងដូចជាមាត្រាដែលមកពីពូជអំបូរខាងត្បូង (យូដា និងស៊ីមាន ដែលមិនបានទទួលកេរ្តិ៍មរដកនៃទឹកដីនោះ មើល យស ២១) ដែលជាសម័យកាលនៃការកាត់ក្តី (មើល ពច ៥:១៣-១៨) ។ ការបែងចែកនៃនយោបាយទៅតាមផ្នែកមុនពេលកំណត់នៃរាជ្យស្តេចដាវីឌ គឺវាមានភាពខុសគ្នាទៅនឹងការត្រៀមទុកដែលនឹងផ្តល់ឱ្យជាចំណែក ទៅទិសខាងជើង ហើយនិងទិសខាងត្បូងដែលនៅក្រោមការត្រួតត្រារបស់ស្តេចដាវីឌ (មើល ២សយ ២:៤ ៥:៣) ក្នុងការពង្រឹងនៃការបែងចែក ។ ជាមួយនឹងជ័យជម្នះ នៃក្រុងយេរូសាឡិមដែលបានដោយសាស្តេចដាវីឌ (២សយ ៥:៦-៧) ហើយព្រះចៅហ្វារ៉ោនបានផ្តលអំណោយជាស្រុកកេស៊ើរទៅបុត្រីរបស់ទ្រង់ ដែលជាភិយារបស់ស្តេចសាឡូម៉ូន (៩:១៦-១៧) នេះហើយដែលពួកកូនចៅអ៊ីស្រាអែលត្រូវបានបន្ថែមទឹកដី ។ យោងទៅតាមការបែងចែកនៅកន្លែងនេះ"ពូជអំបូរ១"ត្រូវបានគ្រប់គ្រងដោយយូដា (ប៉ុន្តែត្រូវបាន

ពូជអំបូរ១០ដល់ឯងវិញ ៣២ (តែសាឡូម៉ូននឹងបានពូជ
អំបូរ១ ដោយអញយល់[គ]ដល់ដាវីឌ ជាអ្នកបំរើអញ ហើយ
យល់ដល់ក្រុមយេរូសាឡិម ដែលអញបានរើសចេញពីអស់
ទាំងពូជអំបូរសាសន៍អ៊ីស្រាអែលផង) ៣៣ពីព្រោះគេបាន
បោះបង់ចោលអញ ហើយបានក្រាបថ្វាយបង្គំ[ឃ]ដល់ព្រះ
អាសថារ៉ូត ជាព្រះនៃសាសន៍ស៊ីដូន និងកេម៉ូស ជាព្រះនៃ
សាសន៍ម៉ូអាប់ ហើយមីលកូម ជាព្រះនៃពួកកូនចៅអាំម៉ូន
វិញ គេមិនបានដើរ[ង]តាមផ្លូវអញ ដើម្បីនឹងប្រព្រឹត្តសេចក្តី
ដែលទៀងត្រង់នៅភ្នែកអញ ហើយកាន់តាមបញ្ញត្តិ[ច]នឹង
សេចក្តីយុត្តិធម៌របស់អញ ដូចជាដាវីឌ ជាបិតាទ្រង់ទេ
៣៤ប៉ុន្តែអញមិនយករាជ្យទាំងមូលពីដៃទ្រង់ទេ គឺនឹងឱ្យ
ទ្រង់ធ្វើជាស្តេច រហូតដល់អស់ព្រះជន្ម ដោយព្រោះយល់
ដល់ដាវីឌ ជាអ្នកបំរើអញដែលអញបានរើស ជាអ្នកដែល
កាន់តាមបញ្ញត្តិ និងក្រិត្យក្រមទាំងប៉ុន្មានរបស់អញ ៣៥អញ
នឹងយករាជ្យពីដៃរបស់បុត្រទ្រង់វិញ ហើយនឹងឱ្យពូជ
អំបូរ១០មកឯង ៣៦ឯបុត្ររបស់ ទ្រង់អញនឹងឱ្យពូជអំបូរ១[ឆ]
ដើម្បីឱ្យដាវីឌ ជាអ្នកបំរើអញ បានចង្កៀង[ជ]១ភ្លឺជាដរាប
នៅចំពោះអញ ក្នុងក្រុងយេរូសាឡិម ជាទីក្រុងដែលអញ
បានរើសសំរាប់តាំងឈ្មោះអញ ៣៧អញនឹងយកឯងតាំង
ឡើង ហើយឯងនឹងគ្រប់គ្រង[ឈ]តាមបំណងចិត្ត[ញ] ព្រមទាំង
សោយរាជ្យលើពួកអ៊ីស្រាអែល ៣៨ដូច្នេះ បើឯងនឹងស្តាប់
តាមគ្រប់ទាំងសេចក្តីដែលអញបង្គាប់[ដ] ហើយដើរតាមអស់
ទាំងផ្លូវរបស់អញ ព្រមទាំងប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ

**១១:៣២** គ ២សយ ៧:១៥
**១១:៣៣** ឃ ពច ២:១៣ ង ២ពវ ២១:២២ ច ១ពវ ៣:៣
**១១:៣៦** ឆ ១ពវ ១២:១៧ ជ ២សយ ២១:១៧
**១១:៣៧** ឈ ១ពវ ១៤:៧ ញ ២សយ ៣:២១
**១១:៣៨** ដ ចទ ១២:២៥ ២សយ ៨:១៥
ឋ ចទ ១៧:១៩ ឌ នក ១:២១
**១១:៤០** ឍ ១ពវ ១២:២ ២របា ១០:២ ណ ២របា ១២:២
**១១:៤៣** ត មថ ១:៧
**១២:១** ក ខ.២៥ លប ១២:៦ យស ២៤:៣២

នៅភ្នែកអញ ដោយកាន់តាមបញ្ញត្តិ និងក្រិត្យក្រមរបស់
អញ ដូចជាដាវីឌ ជាអ្នកបំរើអញដែរ នោះអញនឹងនៅជា
មួយនឹងឯង ហើយនិងតាំងជិន្ទូរវង្សឯងឡើង[ឋ]ឱ្យខ្ជាប់ខ្ជួន
ដូចជាអញបានតាំងឱ្យដាវីឌដែរ អញនឹងប្រគល់ពួកអ៊ីស្រា
អែលឱ្យដល់ឯង ៣៩អញនឹងផ្ចាញ់ផ្ចាលវង្សាដាវីឌដោយ
សារការនោះ តែមិនមែនជាដរាបទេ ៤០ដូច្នេះ សាឡូម៉ូន
ទ្រង់រកសំឡាប់យេរ៉ូបោម តែយេរ៉ូបោមរត់ទៅ[ឌ]ឯ
ស៊ីសាក[ឍ] ជាស្តេចស្រុកអេស៊ីព្ទ ក៏នៅស្រុកនោះដរាបដល់
សាឡូម៉ូនអស់ព្រះជន្មទៅ ។

## ការសុគតរបស់ស្តេចសាឡូម៉ូន

១១:៤១–៤៣ – ២របា ៩:២៩–៣១

៤១រីឯដំណើរឯទៀតពីសាឡូម៉ូន និងការដែលទ្រង់បាន
ធ្វើទាំងប៉ុន្មាន ហើយប្រាជ្ញារបស់ទ្រង់ នោះសុទ្ធតែកត់ទុក
ក្នុងសៀវភៅ ពីកិច្ចការរបស់សាឡូម៉ូនហើយ ៤២សាឡូម៉ូន
ទ្រង់សោយរាជ្យលើសាសន៍អ៊ីស្រាអែលទាំងមូល នៅក្រុង
យេរូសាឡិមបាន៤០ឆ្នាំ ៤៣ទ្រង់ក៏ផ្ទំលក់ទៅជាមួយនឹងពួក
ព្ធយុកោទ្រង់ទៅ គេបញ្ចុះសពនៅក្នុងក្រុងរបស់ដាវីឌ
ជាបិតាទ្រង់ រួចរេហូបោម[ណ] ជាបុត្រាក៏សោយរាជ្យឡើង
ជំនួសបិតា ។

## សាសន៍អ៊ីស្រាអែលប្រឆាំងនឹងស្តេចរេហូបោម

*១២:១–២៤ – ២របា ១០:១–១១:៤*

**១២** ១ឯរេហូបោម ទ្រង់យាងទៅឯស៊ីគែម[ក] ដ្បិតសាសន៍
អ៊ីស្រាអែលទាំងអស់បានមូលមកឯស៊ីគែម ដើម្បីនឹងតាំង

រាប់បញ្ចូលទាំងពូជអំបូរស៊ីម្មាន មើល យស ១៩:១–៩) ហើយ"ពូជអំបូរ ១០" ផ្សេងទៀត ដែលសំដៅទៅលើភូមិភាគដែលមកជ្រកកោនស្តេចដាវីឌ (មើលការពន្យល់ យស ១៤:៤) ។ សម្រាប់ទៅអនាគតចំពោះការសម្អាតនៃព្រំដែនថ្មីនោះ សូមមើលការពន្យល់ ១២:២១ ។

**១១:៣៣** *បោះបង់ចោលអញ* សូមមើល ខ.៥–៧ ។

**១១:៣៤** *ឱ្យទ្រង់ធ្វើជាស្តេច រហូតដល់អស់ព្រះជន្ម* មើល ខ.១២–១៣ ។

**១១:៣៦** *ចង្កៀង១ភ្លឺជាដរាប នៅចំពោះអញ ក្នុងក្រុងយេរូសាឡិម* នេះជានិមិត្តរូបនៃការបន្តសន្តតិវង្សស្តេចដាវីឌនៅក្រុងនេះដដែល ជាទីដែលព្រះបានរើសក្នុងបុព្វហេតុឱ្យព្រះនាមរបស់ទ្រង់បានគង់នៅទីនោះ (មើល ខ.១៣) ។ នៅក្នុងអត្ថបទមួយចំនួន បានបញ្ជាក់ថា ការដុត និងការពន្លត់ចង្កៀង ជាសញ្ញាណនៃការរីកចម្រើន និងការផុតរលត់នៃជីវិតរបស់នរណាម្នាក់ (យប ១៨:១៦ ២១:១៧ សភ ១៣:៩ ២០:២០ ២៤:២០) ។

**១១:៣៧** *ពួកអ៊ីស្រាអែល* សំដៅលើពួកសាសន៍ទាំង១០នៅភាគខាងជើង ។

**១១:៣៨** *បើឯងនឹងស្តាប់តាម....អញនឹងនៅជាមួយនឹងឯង* ត្រង់នេះសំដៅលើយេរ៉ូបោម ដែលត្រូវជំនួសស្តេចដាវីឌ សាឡូម៉ូន ក្នុងមុខនាទីដូចគ្នា (មើល ២:៣–៤ ៣:១៤ ) ។

**១១:៣៩** *ផ្ចាញ់ផ្ចាល់វង្សាដាវីឌ* នៅត្រង់នេះព្រះអម្ចាស់បានដកសិទ្ធ និងអំណាចចេញពីហ្លួវដាវីឌ ។ *មិនមែនជាដរាបទេ* ឃ្លានេះអាចសន្និដ្ឋានបានថាជាការផ្សះផ្សាឡើវិញ (សូមមើល ទំនាយរបស់ព្រះមែស៊ី យរ ៣០:៩ អគ ៣៤:២៣ ៣៧:១៥–២៨ ហស ៣:៥ អម ៩:១១–១២) ក្រោមការដឹកនាំរបស់ហ្លួងដាវីឌ ។

**១១:៤០** *សាឡូម៉ូទ្រង់រកសំឡាប់យេរ៉ូបោម* យេរ៉ូបោមត្រង់នេះប្រហែលជាបានលើកឡើងដោយលោក អ័ហ៊ីយ៉ា (ខ.៣៤–៣៥) ដែលគម្រោងការផ្តួលរំលំស្តេចសាឡូម៉ូនរបស់គាត់ មិនបានជោគជ័យ ក្នុងការគ្រប់គ្រងអាណាចក្ររបស់ទ្រង់(មើល ខ.២៦) ។ *ស៊ីសាក ជាស្តេចស្រុកអេស៊ីព្ទ* មើល ១៤:២៥–២៦ ។ ស្តេចអង្គនេះ ជាផារ៉ោនទី១ ដែលបានលើកឡើងនៅក្នុងគម្ពីរសញ្ញាចាស់ ហើយជាស្ថាបនិកនៃតំណវង្សទី២២នៃពួក លីបយ៉ាន់ Libyan (៩៤៥–៩២៤ មុន គ.ស) ។

**១១:៤១** *ក្នុងសៀវភៅ ពីកិច្ចការរបស់សាឡូម៉ូន* នេះជាប្រភពឯកសារមួយដែលនិយាយពីជីវិត និងការគ្រប់គ្រងរបស់ស្តេចសាឡូម៉ូន ដែលបានរៀ–បរាប់ នៅក្នុងកណ្ឌគម្ពីរ១,២ ពង្សាវតារ (មើលសេចក្តីផ្តើម ១៥:៧,២៣)។

**១១:៤៣** *ផ្ទំលក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់ទៅ* មើលការពន្យល់ ១:២១។

**១២:១** *ស៊ីគែម* ក្រុងនេះល្បីល្បាញនៅក្នុងប្រវត្តិសាស្ត្រ ដែលស្ថិតនៅជើងភ្នំភាគខាងជើងនៃក្រុងអេប្រាអិម (មើល លប ១២:៦ ៣៣:១៨–២០ យស

ទ្រង់ឡើងជាស្តេច ២កាល យេរ៉ូបោម ជាកូននេបាតបាន
ឮក្នុងកាលដែលលោកកំពុងនៅ ស្រុកអេស៊ីព្ទជាកន្លែង
ដែលលោកបានរត់[ខ]ទៅអាស្រ័យនៅ ដើម្បីឱ្យរួចពីស្តេច
សាឡូម៉ូន ៣ហើយមានគេចាត់មនុស្សឱ្យទៅហៅលោកមក
នោះយេរ៉ូបោម និងពួកជំនុំអ៊ីស្រាអែលទាំងអស់ក៏មកគាល់
រេហូបោមទូលថា ៤ព្រះបិតា[គ]ទ្រង់បានធ្វើឱ្យនឹមយើងខ្ញុំធ្ងន់
ពន់ពេក ដូច្នេះ សូមទ្រង់មេត្តាប្រោសឱ្យការតឹងរ៉ឹងរបស់
ព្រះវរបិតាទ្រង់ និងនឹមយ៉ាងធ្ងន់ដែលទ្រង់ បានដាក់លើ
យើងខ្ញុំរាល់គ្នា បានស្រាលចេញ នោះយើង ខ្ញុំរាល់គ្នានឹង
ប្រតិបត្តិតាមទ្រង់ ៥ដូច្នេះ ទ្រង់មានបន្ទូលឆ្លើយថា ចូរទៅ
សិនចុះ ចាំបីថ្ងៃទៀតសូមត្រឡប់មកវិញ បណ្តាជនទាំង
ឡាយក៏បង្គំលាទៅ ។
៦ស្តេចរេហូបោមក៏ប្រឹក្សានឹងពួកចាស់ៗ[ឃ]ជាពួកជំនិតនៃ
សាឡូម៉ូន បិតាទ្រង់ ពីកាលទ្រង់គង់ព្រះជន្មនៅឡើយថា
តាមគំនិតរបស់លោករាល់គ្នា នោះតើត្រូវយើងឆ្លើយ
នឹងពួករាស្ត្រនេះយ៉ាងដូចម្តេច ៧លោកទាំងនោះទូលឆ្លើយ
ថា នៅថ្ងៃនេះ បើទ្រង់សព្វព្រះទ័យនឹងធ្វើតាមចិត្ត ប្រជា
ជនទាំងឡាយ ហើយយកចិត្តគេ ដោយឆ្លើយនឹងគេជាពាក្យ
ផ្អែមពីរោះ[ង] នោះគេនឹងនៅជាបាវបំរើរបស់ទ្រង់ដរាប
ទៅ ៨ប៉ុន្តែទ្រង់ មិនព្រម[ច]តាមគំនិតនៃពួកចាស់ៗទាំងនោះ
ទេ គឺទ្រង់ទៅប្រឹក្សានឹងពួកមនុស្សស្រករ និងទ្រង់ជាពួក
ជំនិតទ្រង់វិញ ៩ដោយបន្ទូលថា តើអ្នករាល់គ្នាគិតយ៉ាងណា
តើត្រូវឱ្យយើងឆ្លើយនឹងពួករាស្ត្រនេះដូចម្តេច ដែលគេ
បានមកសូមយើងថា សូមមេត្តាប្រោសឱ្យនឹមដែលព្រះបិតា
ទ្រង់បានដាក់លើយើងរាល់គ្នាបានស្រាលទៅ ១០រួចពួក
ដែលស្រករនឹងទ្រង់ គេទូលឆ្លើយថា ឯពួករាស្ត្រនេះ ដែល
មកទូលសូមទ្រង់ថា ព្រះបិតាទ្រង់បានធ្វើឱ្យនឹមយើងខ្ញុំរាល់
គ្នាធ្ងន់ពន់ពេក សូមទ្រង់មេត្តា ប្រោសឱ្យបានស្រាលដល់
យើងខ្ញុំវិញដូច្នេះ នោះត្រូវឱ្យទ្រង់មាន បន្ទូលឆ្លើយនឹងគេ
យ៉ាងនេះថា កូនដៃយើងនឹងបានធំជាងភ្លៅរបស់ព្រះបិតា
យើង ១១ឯព្រះបិតាយើង ទ្រង់បានដាក់នឹមយ៉ាងធ្ងន់លើឯង
រាល់គ្នា តែឥឡូវនេះ យើងនឹងបន្ថែមឱ្យនឹមឯងរាល់គ្នា
បានធ្ងន់ជាងទៅទៀត ព្រះបិតាយើង បានវាយផ្ចាលឯង
រាល់គ្នាដោយរំពាត់ តែយើងនឹងវាយផ្ចាលឯងរាល់គ្នា
ដោយខ្យាដំរីវិញ ។
១២លុះដល់ថ្ងៃទី៣ យេរូបោម នឹងបណ្តាជនទាំងឡាយ
ក៏មូលមកគាល់រេហូបោម ដូចជាស្តេចបានបង្គាប់ដោយ
បន្ទូលថា ដល់ថ្ងៃទី៣ ចូរឯងរាល់គ្នាមកឯយើងវិញ
១៣នោះស្តេចទ្រង់មានបន្ទូលឆ្លើយដល់គេជាពាក្យគំរោះ
គំរើយ ឥតតាមគំនិតរបស់ពួកចាស់ៗឡើយ ១៤គឺទ្រង់មាន
បន្ទូលទៅគេ តាមគំនិតរបស់ពួកមនុស្សស្រករគ្នាវិញថា
ព្រះបិតាយើងបានធ្វើឱ្យនឹមឯងរាល់គ្នាមានទំងន់តែយើង
នឹងបន្ថែមឱ្យ នឹមឯងរាល់គ្នា បានធ្ងន់ជាងទៅទៀត
ព្រះបិតាបានវាយផ្ចាលឯងរាល់គ្នាដោយរំពាត់[ឆ] តែយើង
នឹងវាយផ្ចាលឯងរាល់គ្នាដោយខ្យាដំរីវិញ ១៥ស្តេចទ្រង់មិន
ព្រមស្តាប់តាមបណ្តាជនទេ ដ្បិតការនេះកើតមកអំពីព្រះ

**១២:២** ខ ១ពវ ១១:៤០
**១២:៤** គ ១សយ ៨:១១–១៨ ១ពវ ៤:២០–២៨
**១២:៦** ឃ ១ពវ ៤:២
**១២:៧** ង សភ ១៥:១
**១២:៨** ច លវ ១៩:៣២
**១២:១៤** ឆ នក ១:១៤

៨:៣០–៣៥ និងការពន្យល់ ៨:៣០ បន្ថែម យស ២០:៧ ២១:២១ ២៤:១–៣៣) ។ *អ៊ីស្រាអែលទាំងអស់* ពួកនេះតំណាងឱ្យពួកសាសន៍ដែលនៅភាគខាងជើង(ខ.១៦) ។ ជាការពិត ស្តេចដាវីឌបានក្លាយជាស្តេចលើពួកសាសន៍ដែលនៅភាគខាងជើងដោយឈរលើសេចក្តីសញ្ញាដែលមានចែងនៅក្នុង(មើល ២សយ ៥:៣) ដែលបានលើកឡើងថា សកម្មភាពនៃការចុះចូលរបស់ពួកគេ គឺជាការបន្តនៃការចរចារគ្រប់ស្តេចនីមួយៗ ។

**១២:២** *បានឮ* នេះជាដំណឹងពីការសុគតរបស់ស្តេចសាឡូម៉ូន(១១:៤៣) ។ *ស្រុកអេស៊ីព្ទ* មើល ២របា ១០:២ ។

**១២:៤** *នឹមយ៉ាងធ្ងន់ដែលទ្រង់បានដាក់លើយើងខ្ញុំ* ឃ្លានេះបានប្រាប់ពីការមិនពេញចិត្តរបស់ពួកគេចំពោះស្តេចសាឡូម៉ូន ជាមួយនឹងការយកពន្ធដ៏ធ្ងន់ធ្ងរ ការកេណ្ឌពួកគេឱ្យធ្វើការងារ និងការមិនពេញចិត្តចំពោះការកេណ្ឌពួកគេឱ្យធ្វើទ័ព (មើល ៤:៧,២២–២៣,២៧–២៨ ៥:១៣–១៤ ៩:២២ មើលការពន្យល់ ៩:១៥ ១១:២៨) ។ នៅក្នុលក្ខណៈនេះ បានបន្តឱ្យស្តេចសាឡូម៉ូនធ្វើ នូវកំហុសជាច្រើននៅក្នុងរជ្ជកាលនៃការដឹកនាំរបស់ទ្រង់ (មើល ៤:២០) ។

**១២:៦** *ពួកចាស់ៗ ជាពួកជំនិតនៃសាឡូម៉ូន បិតាទ្រង់* នេះសំដៅដល់មន្ត្រីដែលនៅក្រោមបង្គាប់ស្តេចសាឡូម៉ូនមានដូចជា អ័ដូនីរ៉ាម(៤:៦) និងពួកចៅហ្វាយស្រុក(៤:៧–១៩) ។

**១២:៧** នៅក្នុងចំណុចនេះសំដៅលើការការបម្រើចំពោះអណាចក្ររបស់ព្រះមិនមែនសម្រាប់អំណាចបុគ្គលឡើយ ។

**១២:៨** *មនុស្សស្រករនឹងទ្រង់* សំដៅលើមនុស្សដែលមានវ័យស្មើរនឹង មនុស្សដែលនៅបម្រើស្តេចសាឡូម៉ូន(១៤:២១) ។ រេហូបោម មានអាយុ៤១ឆ្នាំនៅពេលគាត់បានឡើងគ្រងរាជ្យជាស្តេច(១៤:២១) ។

**១២:១០** *កូនដៃយើង នឹងបានធំជាងភ្លៅរបស់ព្រះវបិតាយើង* នេះជាសុភាសិតដែលបង្ហាញពីភាពកម្សោយរបស់រេហូបោម តែបែជានិយាយថាខ្លាំងជាងព្រះបិតាទ្រង់វិញ ។

**១២:១១** *ខ្យាដំរី* នេះជាខ្សែតីដែលខាងចុងខ្សែ មានរាងកោងដូចជាកន្ទុយសត្វខ្យាដំរី ។ នៅត្រង់នេះមិនមែនគ្រាន់តែជាការបង្ខិតបង្ខំមនុស្សប៉ុណ្ណោះទេ តែថែមដាក់ទោសដល់ពួកទាំងឡាយណាដែលមិន ចុះចូលជាមួយនឹងអ្នកដឹកនាំដោយអំណរផងដែរ ។

**១២:១៤** *តាមគំនិតមនុស្សស្រករគ្នាវិញ* នៅត្រង់នេះរេហូបោមបានឆ្លើយផ្ទុយទៅពួកគេវិញយ៉ាងដាច់ខាត ចំពោះការជិទាស់ទៅនឹងការព្រមព្រៀងរួចហើយ នៃរាជ្យអ៊ីស្រាអែល (មើល ចទ ១៧:១៤–២០ និងការពន្យល់ ១សយ ១០:២៥) ។

យេហូវ៉ា[ង] ដើម្បីនឹងសំរេចតាមសេចក្តី ដែលទ្រង់បានមាន
បន្ទូលនឹងយេរូបោម ជាកូននេបាត ដោយសារអ័ហ៊ីយ៉ា[ឈ]
ជាពួកក្រុងស៊ីឡូរ ។
១៦កាលពួកអ៊ីស្រាអែលទាំងប៉ុន្មានឃើញថា ស្តេចមិន
ព្រមស្តាប់តាមគេដូច្នោះ នោះគេទូលឆ្លើយថា តើយើង
រាល់គ្នាមានចំណែកអ្វី[ញ] ខាងដាវីឌ យើងក៏គ្មានមរដក
ជាមួយនឹងកូនចៅអ៊ីសាយដែរ ឱពួកអ៊ីស្រាអែលអើយ[ដ]
ចូរយើងវិលទៅផ្ទះវិញទៅ ឥឡូវនេះដាវីឌ ចូរមើលព្រះ
វង្សរបស់ខ្លួនឯងចុះ ដូច្នេះ ពួកអ៊ីស្រាអែលក៏ត្រឡប់ទៅឯទី
លំនៅគេវិញទៅ[ឋ] ១៧ឯត្រង់ពួកកូនចៅអ៊ីស្រាអែល ដែល
នៅក្នុងអស់ទាំងទីក្រុងរបស់ពួកយូដា[ឌ] នោះរេហូបោម
បានគ្រងរាជ្យលើគេវិញ ១៨រួចមកស្តេចរេហូបោមទ្រង់
ចាត់អ័ដូរ៉ាម[ឍ] ដែលត្រួតលើពួកកំណែនឱ្យទៅ តែពួក
អ៊ីស្រាអែលទាំងអស់គ្នាគេចោលលោកនឹងថ្មឱ្យស្លាប់ទៅ[ណ]
ដូច្នេះស្តេចរេហូបោមក៏ប្រញាប់ប្រញាល់ នឹងឡើងព្រះរាជ
រថរត់ទៅឯក្រុងយេរូសាឡិម ១៩គឺយ៉ាងនោះ ដែលពួក
អ៊ីស្រាអែលបានបះបោរនឹងរាជវង្សរបស់ដាវីឌ[ត] ដរាប
ដល់សព្វថ្ងៃនេះ ២០គ្រានោះ កាលពួកអ៊ីស្រាអែលទាំងអស់
គ្នាបានឮថា យេរ៉ូបោមបានត្រឡប់មកវិញហើយ នោះក៏
ចាត់គ្នាឱ្យទៅអញ្ជើញលោកមកក្នុងជំនុំគេ រួចគេតាំង
លោកឡើង ឱ្យធ្វើជាស្តេចលើពួកអ៊ីស្រាអែលទាំងអស់
គ្មានអ្នកណាបានតាមព្រះរាជវង្សរបស់ដាវីឌឡើយ[ថ] មាន
តែពូជអំបូរយូដា១ប៉ុណ្ណោះ ។
២១លុះកាលរេហូបោមបានមកដល់ក្រុងយេរូសាឡិម
នោះទ្រង់ក៏ប្រមូលពូជពង្សយូដាទាំងអស់ នឹងពូជអំបូរបេន
យ៉ាមីន រួមទាំងអស់បានប្រុស១១សែន៨ម៉ឺននាក់សុទ្ធតែ
ជាអ្នកជ្រើសរើសហើយថ្នឹកចំបាំង ដើម្បីលើកទៅច្បាំង[ទ]
នឹងពួកពូជពង្សអ៊ីស្រាអែល ដោយប្រាថ្នាចង់បង្វិលរាជ្យ
មកឱ្យរេហូបោម ជាកូនសាឡូម៉ូនវិញ ២២ប៉ុន្តែព្រះបន្ទូលនៃ
ព្រះបានមកដល់សេម៉ាយ៉ា[ធ] ជាអ្នកសំណប់របស់ព្រះថា[ន]
២៣ចូរប្រាប់ដល់រេហូបោម ជាកូនសាឡូម៉ូន ស្តេចស្រុក
យូដា ព្រមទាំងពូជពង្សយូដា និងបេនយ៉ាមីន ហើយនឹងពួក
ជនឯទៀតថា ២៤ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ គឺកុំឱ្យ
ឡើងទៅច្បាំងនឹងពួកកូនចៅអ៊ីស្រាអែល ជាបងប្អូនរបស់
ឯងរាល់គ្នាឡើយ ចូរវិលទៅឯផ្ទះរបស់ឯងរៀងខ្លួនទៅ
ដ្បិតការនេះ គឺអញបានបង្កើតឡើងទេ ដូច្នេះ គេក៏ស្តាល់
តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ហើយវិលត្រឡប់ទៅតាម
ផ្លូវគេវិញតាមព្រះបន្ទូលនៃព្រះយេហូវ៉ាទៅ ។

**១២:១៥** ង ចទ ២:៣០ ២រប ២៥:២០ ឈ ១ពវ ១១:២៩
**១២:១៦** ញ លប ៣១:១៤ ដ ២សយ ២០:១ ត អស ៧:១៧
**១២:១៧** ឌ ១ពវ ១១:១៣,៣៦
**១២:១៨** ឍ ២សយ ២០:២៤ ណ យស ៧:២៥
**១២:១៩** ត ២ពវ ១៧:២១
**១២:២០** ថ ១ពវ ១១:១៣,៣២ អគ ៣៧:១៦
**១២:២១** ទ ១ពវ ១៤:៣០ ១៥:៦,១៦ ២រប ១១:១
**១២:២២** ធ ២រប ១២:៥–៧ ន ចទ ៣៣:១ ២ពវ ៤:៧

**១២:១៥** *ដ្បិតការនេះកើតមក អំពីព្រះយេហូវ៉ា* នៅវគ្គនេះអ្នកនិពន្ធបានដាក់ទោសដល់អំពើឆ្គួតលីលារបស់រេហូបោម និងការប្តូសេចក្តីជំនឿរបស់ពួកសាសន៍នៅភាគខាងជើង ប៉ុន្តែក៏ជាការរំលឹកដល់អ្នកអានថា គ្រប់អ្វីៗដែលបានកើតឡើង ចំពោះការនាំចូលនូវការគោរពព្រះផ្សេងៗ នោះជាការកាត់ទោសដល់ហ្លួងដាវីឌទាំងមូល សម្រាប់សេចក្តីកំផិតរបស់ស្តេចសាឡូម៉ូន និងការមិនប្រព្រឹត្តតាមក្រិត្យវិន័យ (១១:៩–១៣) ។ សម្រាប់ទំនាក់ទំនងរវាងភាពជាព្រះដែលសោយរាជ្យលើគ្រប់របស់ និងការទទួលខុសត្រូវសម្រាប់អំពើរបាបទាំងឡាយ សូមមើល ២សយ ២៤:១ ។ *ទ្រង់បានមានបន្ទូលនឹងយេរ៉ូបោម . . . ដោយសារអ័ហ៊ីយ៉ា* មើល ១១:២៩–៣៩ ។
**១២:១៦** *ពួកអ៊ីស្រាអែលទាំងប៉ុន្មាន* នេះសំដៅលើពួកអ៊ីស្រាអែលទាំងអស់ដែលនៅភាគខាងជើង(ខ.១) ។ *ដាវីឌ* ពាក្យនេះសំគាល់ថា ជាសន្តតិវង្សនៃហ្លួងដាវីឌ (មើល ២សយ ២០:១) ។
**១២:១៧** *កូនចៅអ៊ីស្រាអែល ដែលនៅក្នុងអស់ទាំងទីក្រុងពួកយូដា* ពួកនេះជាម្ចាស់ស្រុកដែលរស់នៅភាគខាងជើង ហើយមានទីជម្រកនៅក្នុងស្រុកយូដា ហើយក្រោយមកត្រូវបានគេបញ្ចូលទៅក្នុងពួកដែលនៅភាគខាងជើងដទៃទៀត ដែលពួកគេចង់បម្រើព្រះ និងថ្វាយបង្គំព្រះនៅក្នុងព្រះវិហារ (មើល ២រប ១១:១៦–១៧) ។
**១២:១៨** *អ័ដូរ៉ាម ដែលត្រួតលើពួកកំណែន* អ័ដូរ៉ាមនេះ គាត់ជាអ្នកបម្រើក្នុងសមាសភាពតែមួយក្នុងរាជ្យស្តេដាវីឌ(២សយ ២០:២៤) និងស្តេចសាឡូម៉ូន (១ពវ ៤:៦ ៥:១៤) ។
**១២:១៥–១៩** នៅវគ្គនេះរៀបរាប់ពីការដែល យេរ៉ូបោម និងរេហូបោម បានធ្វើការល្អសម្រាប់តែខ្លួនពួកគេប៉ុណ្ណោះ ។ រេហូបោម បានប្រព្រឹត្តការអាក្រក់យង់ឃ្នង ហើយមិនស្តាប់ចំពោះការទាមទាររបស់ប្រជាជន ។ រីឯយេរ៉ូបោម បានកសាងទីកន្លែងថ្មីមួយសម្រាប់ថ្វាយបង្គំ ក្នុងគោលបំណងទប់ស្កាត់មិនឱ្យមនុស្សចូលទៅក្នុងក្រុងយេរូសាឡឹមដែលទីក្រុងនោះមានឈ្មោះថា"ក្រុងយេរ៉ូបោម"។ រេហូបោម បានបែងចែក ជាតិសាសន៍ ហើយ យេរ៉ូបោម បានអូសទាញពួកមនុស្សចេញពីការគោរពព្រះ ។ សកម្មភាពរបស់អ្នកទាំងពីរនេះ គឺជាទង្វើទាស់ ប្រឆាំងមួយជាមួយព្រះផងដែរ។
**១២:២១** *អំបូរបេនយ៉ាមីន* ទោះបីអំបូរនេះបេនយ៉ាមីននេះ រស់នៅលាយឡំជាមួយពួកសាសន៍អ៊ីស្រាអែល(មើលពន្យល់ ១១:៣១–៣២)ហើយតំបន់នេះស្ថិតនៅក្រវល់ក្រុងយេរូសាឡឹមក្រោមការត្រួតត្រារបស់រេហូបោម ។ ព្រំប្រទល់ខាងជើងរបស់ពួកយូដា បានលាតសន្ធឹងស្ទើរតែដល់ក្រុងបេត–អែល ។ *ប្រុស១១សែន៨ម៉ឺននាក់* ចំនួននេះប្រហែលជារួមបញ្ចូលពួកមនុស្សដែលចូលរួមក្នុងការធ្វើសង្គ្រាម ។
**១២:២២** *សេម៉ាយ៉ា* មនុស្សនេះជាអ្នកសរសរប្រវត្តិនៃការគ្រងរាជ្យរបស់ស្តេចរេហូបោម(២រប ១២:១៥) ។ ចំពោះការកត់ត្រាផ្សេងៗ របស់ពួកហោរាមាននៅក្នុង ២រប ១២:៥–៨ ។ *អ្នកសំណប់របស់ព្រះ* ឃ្លានេះសំដៅដល់ពួកហោរា (មើលឧទាហរណ៍ ១៣:១ ចទ ១៨:១៨ ៣៣:១ ១សយ ២:២៧ ៩:៩–១០) ។
**១២:២៤** *ចូរវិលទៅឯផ្ទះរបស់ឯងរៀងខ្លួន* នេះបញ្ជាក់ថាទោះបីសង្គ្រាមដ៏ធំធេងត្រូវបានគេការពារមិនឱ្យកើតមាន ប៉ុន្តែក៏នៅតែមានសង្គ្រាមតូចតាចកើតមាននៅក្នុងសមរភូមិ រវាងពួកអ៊ីស្រាអែល និងពួកយូដា

## រូបកូនគោមាសនៅក្រុងបេតអែល និងក្រុងដាន់

២៥ក្រោយនោះមក យេរ៉ូបោមទ្រង់សង់ក្រុងស៊ីគែម[ប]នៅ
ស្រុកភ្នំអេប្រាអិម រួចទ្រង់គង់នៅទីនោះ ហើយចេញពីទី
នោះទៅសង់ក្រុងពេនួលទៀត[ផ] ២៦យេរ៉ូបោមទ្រង់ព្រះ
ដំរិះក្នុងព្រះទ័យថា រាជ្យនេះនឹងត្រឡប់ទៅឯរាជវង្សដាវីឌ
វិញ ២៧បើសិនជាបណ្ដាជនទាំងនេះ ចេះតែឡើងទៅ
ថ្វាយយញ្ញបូជា ក្នុងព្រះវិហារនៃព្រះយេហូវ៉ា នៅក្រុង
យេរូសាឡិម[ព] នោះចិត្តគេនឹងវិលត្រឡប់ ទៅឯចៅហ្វាយ
គេវិញ គឺឯរេហូបោម ជាស្ដេចស្រុកយូដា គេនឹងសំឡាប់
អញបង់ ហើយត្រឡប់ទៅគោរពតាមរេហូបោម ជាស្ដេច
ស្រុកយូដា ២៨ដូច្នេះ ស្ដេចទ្រង់ក៏ជិនុំការ រួចធ្វើរូបកូនគោ
មាស២[ភ] ហើយមានបន្ទូលថា ឱអ៊ីស្រាអែលអើយ ឯងរាល់
គ្នាបានឡើងទៅឯក្រុងយេរូសាឡិម ជាយូរណាស់ហើយ
ឥឡូវនេះ មើល នេះនែ ព្រះរបស់ឯង ដែលបាននាំឯង
រាល់គ្នា ឡើងចេញពីស្រុកអេស៊ីព្ទមក[ម] ២៩ទ្រង់ក៏ដំកល់ទុក
១នៅក្រុងបេត-អែល[យ] ហើយ១ទៀតនៅក្រុងដាន់[រ]
៣០ដំណើរនោះក៏ត្រឡប់ជាហេតុឱ្យមានបាបឡើង [ល]ពី
ព្រោះពួកជនទាំងឡាយ គេខំទៅថ្វាយបង្គំ នៅចំពោះរូប
១នោះ ដែលនៅក្រុងដាន់ ៣១ទ្រង់ក៏ស្អាងវិហារ[វ]នៅលើ
ទីខ្ពស់ទាំងប៉ុន្មាន ហើយបានយកមនុស្សពីបណ្ដាជនទាំង
ឡាយ ដែលមិនមែនជាពូជលេវី តាំងឡើងឱ្យធ្វើជាសង្ឃ[ស]
៣២រួចទ្រង់ដំរូវឱ្យមានបុណ្យនៅថ្ងៃ១៥ខែកត្ដិក[ហ] ឱ្យដូចជា
បុណ្យដែលគេធ្វើនៅស្រុកយូដាដែរ ហើយទ្រង់ថ្វាយយញ្ញ
បូជានៅលើអាសនា ទ្រង់ក៏ធ្វើដូច្នោះនៅក្រុងបេត-អែល[ឡ]
ទៀត ព្រមទាំងថ្វាយយញ្ញបូជាដល់រូបគោដែលទ្រង់បាន
ធ្វើផង ទ្រង់ដាក់ពួកសង្ឃដែលបានតាំងឡើង សំរាប់ទីខ្ពស់
ទាំងប៉ុន្មានឱ្យនៅក្រុងបេត-អែល ៣៣ដល់ថ្ងៃ១៥ ខែកត្ដិក
ជាវេលាដែលទ្រង់បានគិតសំរេចក្នុងព្រះទ័យហើយនោះ
ទ្រង់ក៏ថ្វាយយញ្ញបូជានៅលើអាសនានោះ ដែលទ្រង់បាន
ស្អាង នៅក្រុងបេត-អែល[អ] ហើយទ្រង់ក៏តាំងថ្ងៃនោះ ទុក
ជាថ្ងៃបុណ្យ ដល់ពួកកូនចៅអ៊ីស្រាអែល រួចទ្រង់ឡើងទៅ
ដុតកំញានថ្វាយ នៅលើអាសនាផង ។

**១២:២៥** ប ខ.១ ផ ពច ៨:៨,១៧
**១២:២៧** ព ចទ ១២:៥-៦
**១២:២៨** ភ នក ៣២:៤ ២របា ១១:១៥ ម នក ៣២:៨
**១២:២៩** យ លប ១២:៨ យស ៧:២ រ ពច ១៨:២៧-៣១ អម ៨:១៤
**១២:៣០** ល ១ពវ ១៣:៣៤ ១៤:១៦ ១៥:២៦,៣០ ១៦:២ ២ពវ ៣:៣ ១០:២៩ ១៣:២ ១៧:២១

គឺនៅក្នុងរជ្ជកាលរបស់ រេហូបោម អ័ប៊ីយ៉ា និងអេសា ។ ការនេះនៅតែបន្តរហូតធ្វើឱ្យអ៊ីស្រាអែលគ្មានស្ថេរភាពនយោបាយ ក្រោយពីការការស្លាប់របស់ប្អាសា ដែលចុងក្រោយជម្លោះបានឈានដល់ការបញ្ចប់ ។ យេហូសូផាត ជាបុត្ររបស់អេសា បានចងមេត្រីជាមួយ អ័ហាប់ និងបានភ្ជាប់ទំនាក់ទំនងនេះដោយការ ការអភិសេកបុត្រារបស់ទ្រង់ដែលមាននាមថា យូរ៉ាម ជាមួយនឹងបុត្រីរបស់ស្ដេចអ័ហាប់ដែលមាននាមថា អ័ថាលា (មើល ១៤:៣០ ១៥:៦,១៦ ២២:២,៤៤ ២ពវ ៨:១៨) ។

**១២:២៥-២ពវ ១៧:៤១** នេះជារយៈពេលរបស់ស្ដេចពីរអង្គ ។

**១២:២៥** *ក្រុងពេនួល* ក្រុងនេះគឺនៅក្នុងការ ធ្វើដំណើរនៅក្រុងយ័រដាន់ (មើល លប ៣២:៣១ ពច ៨:៩,១៧) ដែលជាយុទ្ធសាស្ត្រក្នុងការការពារប្រឆាំងនឹងពួកស៊ើរីនៃក្រុងដាម៉ាស (១១:២៣-២៥)និងពួកកូនចៅអាំម៉ូន ។

**១២:២៦** *ត្រឡប់ទៅឯរាជ្យវង្សដាវីឌវិញ* ចំណុចនេះយេរ៉ូបោមមិនមានទំនុកចិត្តនៅក្នុងការបែងចែកសេចក្ដីសន្យារបស់ព្រះ ដែលនឹងផ្ដល់មកឱ្យទ្រង់តាមរយៈលោកអ័ហ៊ីយ៉ា(មើល ១១:៣៨) ហើយដូច្នេះសម្មភាពនេះ គឺជាការបាត់បង់សិទ្ធិអំណាចភាពជាស្ដេច ។

**១២:២៨** *រូបកូនគោមាស២* ព្រះដទៃរបស់ពួកស៊ីរី និងពួកកាណានជានិច្ចកាលគោញី ឬកូនគោ ត្រូវបានគេបញ្ឈរបង្ហាញពីភាពរឹងមាំ និងភាពសម្បូរសប្បាយ (មើលការពន្យល់ ពច ២:១៣) ។ *នេះនែ ព្រះរបស់ឯង ដែលបាននាំឯងរាល់គ្នា ឡើងចេញ ពីស្រុកអេស៊ីពមក* ដូចលោកអើរ៉ុន (នក ៣២:៤-៥) យេរ៉ូបោម មានសេចក្ដីប្រាថ្នាចង់បញ្ចូលរូបព្រះគោរបស់សាសន៍ដទៃហើយថ្វាយបង្គំដល់ព្រះអម្ចាស់ ។ ទោះបីការប៉ុនប៉ងរបស់គាត់យ៉ាងដូច្នេះក៏ដោយ ក៏នៅតែមិនមានរូបព្រះអម្ចាស់ឈរនៅពីក្រោយរូបគោនោះដដែល ។

**១២:២៩** *ក្រុងបេត-អែល* ក្រុងនេះមានប្រវែង ១៩,២០០ គ.ម ភាគខាងជើងនៃក្រុងយេរូសាឡិមជាប់នឹងព្រំប្រទល់ពួកអេប្រាអិម ប៉ុន្តែស្ថិតនៅក្នុងទឹកដីនៃពួកបេនយ៉ាមីន(យស ១៨:១១-១៣,២២) ។ ក្រុងបេតអែលនេះបានលេចឡើងក្នុងប្រវត្តិសាស្ត្រនៃការថ្វាយបង្គំព្រះអម្ចាស់របស់ពួកអ៊ីស្រាអែល(មើល លប ១២:៨ ២៨:១១-១៩ ៣៥:៦-៧ ពច ២០:២៦-២៨ ១សយ ៧:១៦) ។ *ក្រុងដាន់* ក្រុងនេះលាតសន្ធឹងទៅភាគខាងជើងដ៏ឆ្ងាយជិតដល់ភ្នំហ៊ើម៉ូន ។

**១២:៣០** *ដំណើរនោះក៏ត្រឡប់ ជាហេតុឱ្យមានបាប* នៅត្រង់នេះរាជរបស់យេរ៉ូបោមបានប្រព្រឹត្តរំលង ចំពោះក្រឹត្យវិន័យជាលើកទី២ម្ដងទៀត(នក ២០:៤-៦) ។ ការរនេះ គឺមិនអាចជៀសផុតចំពោះការបំពានក្រឹត្យវិន័យជាលើកទី១ផងដែរ(នក ២០:៣) និងបានបើកទ្វាសម្រាប់ការហូរចូលនូវការគោរពព្រះដទៃនៅក្នុងពួកអ៊ីស្រាអែល (ពិសេសនៅក្នុងរជ្ជកាលរបស់ស្ដេចអ័ហាប់ មើល ១៦:២៩-៣៤) ។ សេចក្ដីឆ្កួតលីលា របស់យេរូបោម បានបង្ខំឱ្យពួកគេឈប់ថ្វាយបង្គំព្រះ ហើយតម្រូវឱ្យពួកគេធ្វើតាមសេចក្ដីទំនាយរបស់ហោរាអ័ហ៊ីយ៉ា(មើល ១១:៣៨) ។

**១២:៣១** *ទ្រង់ក៏ស្អាងវិហារនៅលើទីខ្ពស់* មើលការពន្យល់ ៣:២ ។ *មិនមែនពូជលេវី* សង្ឃជាច្រើន និងពួកលេវីដែលនៅភាគខាងជើងបានធ្វើចំណាកស្រុកចូលក្នុងទឹកដីយូដា ពីព្រោះយេរូបោមបានបោះបង់ចោលពួកគេនៅពេលដែលគេចាក់ប្រេងតាំងពួកដទៃឱ្យធ្វើជាសង្ឃជំនួសពួកគេវិញ (មើល ២របា ១១:១៣-១៦) ។

**១២:៣២** *បុណ្យដែលគេធ្វើនៅស្រុកយូដា* នេះមិនច្បាស់ជាបុណ្យបារាំហើយបុណ្យនេះគេធ្វើនៅថ្ងៃទី១៥ ទៅដល់ថ្ងៃទី២១នៃខែទី៧(មើល ៨:២ លវ ២៣:៣៤) ។ *ថ្វាយយញ្ញបូជានៅលើអាសនា* នេះជាការកំណត់នូវសិទ្ធិជាស្ដេចដែលមិនអាចទទួលយកបាន ហើយបានសន្មតការនេះ ថាជាតួនាទីរបស់ពួកសង្ឃ(មើល ២របា ២៦:១៦-២១) ។

## អ្នកសំណប់របស់ព្រះម្នាក់ពីស្រុកយូដា

**១៣** ១ខណនោះ មានអ្នកសំណប់របស់ព្រះ[ក]ម្នាក់ចេញពី
ស្រុកយូដា មកដល់បេត-អែល[ខ] តាមបង្គាប់នៃព្រះយេហូវ៉ា
ឯយេរ៉ូបោម ទ្រង់កំពុងតែឈរ នៅមុខអាសនាដើម្បីដុត
កំញាន ២អ្នកនោះស្រែកឡើង ទាស់នឹងអាសនាដោយព្រះ
បន្ទូលនៃព្រះយេហូវ៉ាថា ម្នាលអាសនាៗអើយ ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ មើល នឹងមានបុត្រា១កើតមកក្នុង
ព្រះវង្សរបស់ដាវីឌ ព្រះនាមយ៉ូសៀស[គ] ទ្រង់នឹងថ្វាយពួក
សង្ឃនៃអស់ទាំងទីខ្ពស់[ឃ] ដែលដុតកំញាននៅលើឯង ទុកជា
យញ្ញបូជានៅលើឯង ព្រមទាំងដុតឆ្អឹងមនុស្សនៅលើឯង
ដែរ ៣អ្នកនោះក៏ប្រាប់ទីសំគាល់ ១នៅថ្ងៃនោះដែរ ដោយ
ពាក្យថា នេះជាទីសំគាល់[ង]ដែលព្រះយេហូវ៉ា បានមាន
បន្ទូលហើយ មើល អាសនានេះនឹងបាក់បែកទៅ ហើយផេះ
នៅលើ និងត្រូវខ្ចាយចេញ ៤កាលស្តេចយេរ៉ូបោមទ្រង់
ឮពាក្យ ដែលអ្នកសំណប់របស់ព្រះបានស្រែកទាស់នឹង
អាសនា នៅក្រុងបេត-អែល ដូច្នោះ នោះទ្រង់ក៏ដកព្រះ
ហស្តពីអាសនាចង្អុលទៅថា ចូរចាប់វាទៅ ឯព្រះហស្ត
ដែលទ្រង់បានចង្អុលទៅគាត់នោះ ក៏ស្វិតទៅកន្ត្រាក់មកវិញ
មិនបាន ៥អាសនានោះក៏បាក់បែក ហើយផេះក៏ខ្ចាត់ខ្ចាយពី
លើទៅ តាមទីសំគាល់ដែលអ្នកសំណប់របស់ព្រះបានប្រាប់
ដោយព្រះបន្ទូលនៃព្រះយេហូវ៉ា ៦នោះស្តេចទ្រង់មាន
បន្ទូលទៅអ្នកសំណប់របស់ព្រះថា សូមទូលអង្វរ[ច]ដល់ព្រះ
យេហូវ៉ា ជាព្រះនៃអ្នក ហើយអធិស្ឋានឱ្យខ្ញុំផង ដើម្បីឱ្យដៃខ្ញុំ
បានជាឡើងវិញ អ្នកសំណប់របស់ព្រះក៏ទូលអង្វរដល់ព្រះ
យេហូវ៉ា រួចព្រះហស្តស្តេចបានជាឡើងដូចកាលដើមវិញ
៧ដូច្នេះ ស្តេចទ្រង់មានបន្ទូលទៅអ្នកសំណប់របស់ព្រះថា
អញ្ជើញទៅផ្ទះខ្ញុំលំហើយខ្លួនបន្តិចសិន ខ្ញុំនឹងឱ្យរង្វាន់ដល់
អ្នក[ឆ] ៨តែអ្នកសំណប់របស់ព្រះ ទូលឆ្លើយថា បើទុកជាទ្រង់
ប្រទានដំណាក់ទ្រង់១ចំហៀងមកទូលបង្គំ[ជ] ក៏ទូលបង្គំមិនទៅ
ជាមួយនឹងទ្រង់ដែរ ទូលបង្គំមិនព្រមទទួលនំបុ័ង[ឈ] ឬទឹកនៅ
ទីនេះឡើយ ៩ដ្បិតព្រះយេហូវ៉ាទ្រង់បានហាមទូលបង្គំថា
កុំឱ្យឯងបរិភោគអាហារ ឬទឹក ហើយកុំឱ្យវិលមកវិញតាម
ផ្លូវ ដែលឯងទៅនោះឡើយ ១០ដូច្នេះ គាត់ក៏ចេញទៅតាម
ផ្លូវ១ទៀត ឥតវិលទៅតាមផ្លូវដែលមកដល់ក្រុងបេត
អែលនោះទេ ។
១១រីឯនៅក្រុងបេត-អែល មានហោរាចាស់ម្នាក់ ឯកូន
គាត់ម្នាក់ក៏មកប្រាប់ឪពុក ពីគ្រប់ទាំងការ ដែលអ្នកសំណប់
របស់ព្រះបានធ្វើ នៅក្រុងបេត-អែល នាថ្ងៃនោះព្រមទាំង
ពាក្យទាំងប៉ុន្មាន ដែលគាត់បានទូលដល់ស្តេចដែរ ១២ឯផ្លូវ
ដែលអ្នកសំណប់របស់ព្រះ មកពីស្រុកយូដា បានទៅវិញ
នោះកូនគាត់ក៏បានឃើញ ដូច្នេះគាត់សួរកូនថា តើអ្នកនោះ
បានចេញទៅតាមផ្លូវណា ១៣រួចគាត់ប្រាប់កូនថា ចូរចង
កែបលាឱ្យអញ កូនក៏ចងកែបលាហើយគាត់ឡើងជិះទៅ
១៤គាត់ទៅតាមអ្នកសំណប់របស់ព្រះ បានទាន់ឃើញកំពុង

**១៣:១** ក ចទ ៣៣:១ ពច ១៣:៦ ខ អម ៧:១៣
**១៣:២** គ ២ពវ ២៣:១៥-១៦ ២របា ៣៤:៥ ឃ លវ ២៦:៣០
**១៣:៣** ង លប ២៤:១៤ នក ៤:៨ យហ ២:១១
**១៣:៦** ច លប ២០:៧ ជន ១១:២ យរ ៣៧:៣ កច ៨:២៤
**១៣:៧** ឆ ១សយ ៩:៧
**១៣:៨** ជ ជន ២២:១៨ ឈ ខ.១៦

**១៣:១** *អ្នកសំណប់របស់ព្រះ* មើលពន្យល់ ១២:២២ ។ *ចេញពីស្រុកយូដាមកដល់បេត-អែល* នៅត្រង់នេះបញ្ជាក់ថា ព្រះអម្ចាស់ទ្រង់បានបញ្ជូនហោរាម្នាក់ពីខាងត្បូង ទៅក្រុងបេត-អែលខាងជើងនៃអណាចក្រនេះ ។ នៅត្រង់នេះ ការតែងតាំងភាពជាព្រះ (១១:១១,២៩-១៨ ១២:១៥,២៤) គឺមិនមែនក្នុងគោលបំណង ប្រឆាំងនឹងសាសនាដែលមាននៅក្នុងអាណាចក្រទាំងពីរនេះ ។ នៅពីរសតវត្សរ៍ក្រោយមកទៀត ហោរាអេម៉ុសដែលមកពីក្រុងត្កូអាក្នុងពួកយូដា បានទៅក្រុងបេត-អែលខាងជើងដេម្បីប្រកាសពីការកាត់ទោសយេរ៉ូបោម (អម ៧:១០-១៧) ។

**១៣:២** *យ៉ូសៀស* នេះការថ្លែងទំនាយអំពីការដឹកនាំរបស់ស្តេចយ៉ូសៀស ដែលទ្រង់បានសោយរាជ្យ នៅស្រុកយូដាអស់រយៈពេលជិត៣០០រយឆ្នាំ ក្រោយពីការបែងចែកអាណាចក្រ ។ *ថ្វាយពួកសង្ឃនៃអស់ទាំងទីខ្ពស់* ការនេះបានសម្រេចនៅក្នុង ២ពវ ២៣:១៥-២០ ។

**១៣:៣** *ទីសំគាល់* នេះជាទីសំគាល់ដំបូងដែលមានរយៈពេលខ្លី ដែលឈានចូលទៅរកការពិតនៃការថ្លែងទំនាយដែលមានរយៈពេលដ៏វែង (មើល ចទ ១៨:២១-២២ និងការពន្យល់) ។

**១៣:៥** *ផេះក៏ខ្ចាត់ខ្ចាយ* នេះជាការបើសម្តែងឱ្យឃើញ ពីអំណាចរបស់ព្រះ ដើម្បីឱ្យសម្រេចតាមទំនាយដែលហោរាបានទាយមក (មើលពន្យល់ ខ.៣) និងជាសញ្ញាយ៉ាងច្បាស់ថាដង្វាយរបស់យេរ៉ូបោមមិនបានសព្វព្រះទ័យចំពោះព្រះជាអម្ចាស់នៃយើង (មើល លវ ៦:១០-១១) ។

**១៣:៦** *ព្រះនៃអ្នក* ព្រះអម្ចាស់នៃយើងនៅត្រង់នេះមិនត្រូវបានទុកថាជាព្រះទៀតទេ ដូចដែលស្តេចយេរ៉ូបោមឈប់ទទួលស្គាល់ព្រះអម្ចាស់ថាជាព្រះអម្ចាស់ របស់ខ្លួនទៀតនោះ (ធៀប ២:៣ លប ២៧:២០) ប៉ុន្តែ ទ្រង់ទទួលស្គាល់ថាហោរា បានទទួលសិទ្ធិយ៉ាងពិសេសក្នុងការចូលទៅចំពោះព្រះ ។ *ដៃខ្ញុំបានជាឡើងវិញ* សេចក្តីសប្បុរសរបស់ព្រះ បានឆ្លើយតបចំពោះការស្នើរសូមរបស់ស្តេចយេរ៉ូបោម ដូចមានបង្ហាយបន្ថែមនៅក្នុង (ខ.៣) ដែលបានផ្តល់មកដើម្បីពីពិភពហោរា ហើយបំផ្លាស់យេរ៉ូបោមឱ្យមានការសោកស្តាយចំពោះទង្វើរបស់ខ្លួន ។

**១៣:៧** *អញ្ជើញទៅផ្ទះខ្ញុំ* ស្តេចយេរ៉ូបោម បានប៉ុនប៉ងការបន្តនូវកិត្តិមានរបស់ខ្លួនចំពោះក្រសែភ្នែកចំពោះមុខរាស្ត្រ ដោយការបង្កើតនូវចំណាប់អារម្មណ៍ថា គ្មានការបែកបាក់រវាងទ្រង់ និងសេចក្តីបញ្ជារបស់ពួកហោរា (មើល ១សយ ១៥:២០ សម្រាប់សេចក្តីស្រដៀងគ្នានេះ) ។

**១៣:៩** *ទ្រង់បានហាម* នេះជាការបដិសេធរបស់ពួកហោរា ចំពោះការអញ្ជើញរបស់ស្តេចយេរ៉ូបោមដើម្បីឱ្យពួកគេគាំទ្រចំពោះការដែលទ្រង់ មិនគោរពបទបញ្ញត្តិរបស់ព្រះដែលប្រទានមក ។ ចំណុចនេះព្រះអម្ចាស់មានសេចក្តីក្រោធយ៉ាងខ្លាំង ជាមួយនឹងការដែលពួកគេឈប់ថ្វាយបង្គំព្រះនៅបេត-អែល ។

អង្គុយនៅក្រោមដើមម៉ៃសាក់ក៏សួរថា តើអ្នកជាអ្នកសំណប់
របស់ព្រះ ដែលមកពីស្រុកយូដាឬអី អ្នកនោះឆ្លើយថា គឺខ្ញុំ
នេះហើយ ១៥រួចគាត់និយាយថា សូមអញ្ជើញទៅពិសា
អាហារ នៅឯផ្ទះជាមួយនឹងខ្ញុំសិន ១៦តែអ្នកនោះឆ្លើយតបថា
ខ្ញុំគ្មានច្បាប់នឹងត្រឡប់ទៅជាមួយនឹងអ្នក ឬចូលទៅក្នុងផ្ទះ
អ្នកឡើយ ក៏មិនព្រមទទួលទានអាហារ[ញ] ឬទឹក ជាមួយនឹង
អ្នកនៅស្រុកនេះដែរ ១៧ពីព្រោះព្រះយេហូវ៉ាទ្រង់បាន
ហាមថា មិនត្រូវបរិភោគអាហារ ឬទឹកនៅ ស្រុកនេះឡើយ
ក៏មិនត្រូវវិលទៅវិញ តាមផ្លូវដែលឯងបានចូលមក នោះ
ដែរ ១៨តែគាត់និយាយថា ខ្ញុំក៏ជាហោរាដូចអ្នកដែរ ហើយ
មានទេវតាប្រាប់ខ្ញុំ ដោយព្រះបន្ទូលនៃព្រះយេហូវ៉ា[ដ]ថា
ចូរទៅនាំអ្នកនោះ មកឯផ្ទះជាមួយនឹងឯងវិញ ដើម្បីឱ្យបាន
បរិភោគភោជន៍ គឺគាត់កុហក[ឋ]ដល់អ្នកនោះទេ ១៩ដូច្នេះ
អ្នកនោះក៏ត្រឡប់ទៅជាមួយ ព្រមទាំងបរិភោគនៅក្នុងផ្ទះ
គាត់ផង ។

២០កាលអ្នកទាំង២កំពុងតែអង្គុយនៅតុ នោះព្រះបន្ទូល
នៃព្រះយេហូវ៉ាក៏មកដល់ហោរា ដែលបាននាំគាត់ត្រឡប់
មកវិញ ២១ហើយអ្នកនោះបន្លឺវាចាឡើងដល់អ្នកសំណប់
របស់ព្រះ ដែលមកពីស្រុកយូដាថា ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ ដោយព្រោះឯងមិនបានស្តាប់[ឌ] តាមព្រះបន្ទូល
នៃព្រះយេហូវ៉ា ហើយមិនបានកាន់តាមបញ្ញត្តដែលព្រះ
យេហូវ៉ាជាព្រះនៃឯងបានហាមប្រាម ២២គឺបានវិលមកវិញ
ព្រមទាំង បរិភោគនៅក្នុងស្រុក ដែលអញបានហាមឯងថា
កុំឱ្យបរិភោគភោជន៍ឡើយ នោះខ្មោចរបស់ឯងនឹងមិន

**១៣:១៦** ញ ខ.៨
**១៣:១៨** ដ ១ពវ ២២:៦,១២ ២រប ៣៥:២១ អស ៣៦:១០ ឋ លប ១៩:១៤ ចទ ១៣:៣
**១៣:២១** ឌ ខ.២៦ ១សយ ១៣:១៤ ១ពវ ២០:៣៥
**១៣:២៤** ឍ ១ពវ ២០:៣៦
**១៣:២៦** ណ ខ.២១
**១៣:៣០** ត ២ពវ ២៣:១៧ ថ យរ ២២:១៨
**១៣:៣១** ទ ២ពវ ២៣:១៨

បានបញ្ចុះក្នុងផ្នូរនៃពួកឰយុកោឯងឡើយ ២៣ក្រោយដែល
បានបរិភោគរួចហើយ នោះគាត់ក៏ចង់កែបលាឱ្យហោរា
ដែលបាននាំមកវិញបានចេញទៅ ២៤លុះកាលអ្នកនោះ បា
ចេញទៅ ហើយក៏ប្រទះនឹងសិង្ហ១[ឍ]តាមផ្លូវ សិង្ហក៏សំឡាប់
គាត់ទៅ ហើយសពរបស់គាត់ដេកនៅកណ្តាលផ្លូវ សត្វលា
ឈរនៅជិត ឯសិង្ហក៏ឈរនៅក្បែរសពដែរ ២៥ហើយមើល
មានមនុស្សដើរទៅមកតាម នោះបានឃើញសពដេកនៅ
កណ្តាលផ្លូវ នឹងសិង្ហឈរនៅជិត ដូច្នោះ គេក៏ទៅប្រាប់ដល់
ក្នុងទីក្រុងជាទីលំនៅនៃហោរាចាស់នោះ ។

២៦កាលដំណឹងបានឮទៅដល់ហោរា ដែលនាំគាត់ពីផ្លូវ
មកវិញ គាត់ ក៏និយាយថា នេះគឺជាអ្នកសំណប់របស់ព្រះ
ដែលមិនបានស្តាប់តាម[ណ] ព្រះបន្ទូលនៃព្រះយេហូវ៉ាហើយ
បានជាព្រះយេហូវ៉ា ទ្រង់បានប្រគល់ទៅឱ្យសត្វសិង្ហហែក
សំឡាប់បង់ តាមសេចក្តីដែលទ្រង់មានបន្ទូលប្រាប់នោះ
២៧រួចគាត់បង្គាប់ទៅកូនថា ចូរចងកែបលាឱ្យអញ កូនក៏
ចងឱ្យ ២៨នោះគាត់ក៏ចេញទៅឃើញសពដេកនៅកណ្តាល
ផ្លូវ និងសត្វលា ហើយសិង្ហកំពុងតែឈរនៅជិត សិង្ហនោះ
មិនបានស៊ីសពឬហែកលាឡើយ ២៩ដូច្នេះ ហោរាចាស់ក៏
លើកដាក់លើលា នាំត្រឡប់ទៅឯទីក្រុងរបស់ខ្លួន ដើម្បីនឹង
កាន់ទុក្ខ ហើយបញ្ចុះសពនៃអ្នកសំណប់របស់ព្រះ ៣០គាត់ក៏
បញ្ចុះនៅក្នុងផ្នូររបស់ខ្លួន[ត] ហើយនាំគ្នាកាន់ទុក្ខ ដោយ
ពាក្យថា ស្តាយណាស់ប្អូនអើយ[ថ] ៣១កាលក្រោយដែលបាន
បញ្ចុះរួចហើយ នោះគាត់ផ្តាំកូនថា កាលណាអញស្លាប់ទៅ
ត្រូវឱ្យបញ្ចុះសពអញ[ទ]នៅក្នុងផ្នូរ ដែលបានបញ្ចុះអ្នក

**១៣:១៨** *ខ្ញុំជាហោរាដូចអ្នកដែរ* ត្រង់នេះពិតប្រហែលជាពាក់កណ្តាល ។ វាទំនងជាដូចពួកហោរាចាស់ៗនៅក្រុងបេត-អែល បានប្រកាសយ៉ាងមុតមាំពីព្រះបន្ទូលរបស់ព្រះតាំងពីយូរលង់មកហើយ ប៉ុន្តែការទាំងនោះបានកន្លងផុតបាត់ទៅហើយ ។

**១៣:១៩** *អ្នកនោះក៏ត្រឡប់ទៅជាមួយ* នៅត្រង់នេះបញ្ជាក់ថា មិនមានទាំងហោរាក្លែងក្លាយចាស់ៗ និងតម្រូវការដែលមិនស្តាប់បង្គាប់ដល់ព្រះ ។ តាមរយៈកាយវិការរបស់គាត់ បានធ្វើឱ្យពួកគេចុះខ្សោយក្នុងការទទួលស្គាល់ពីអំណាចរបស់ព្រះ ក្នុងខណៈដែកគាត់បានថ្លែងនៅក្រុងបេត-អែល ។

**១៣:២០** *ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ហោរា* ឃ្លានេះជាបានប្រាប់ពីលក្ខណៈពីរយ៉ាងរវាងពួកហោរាត្រឹមត្រូវ និងពួកហោរាក្លែងក្លាយដែលបានលេចមកក្នុងពេលតែមួយ ។ ចំពោះពួកហោរាក្លែងក្លាយ បានលេចមកពីការស្រមើស្រមៃផ្ទាល់ខ្លួន (យរ ២៣:១៦ អគ ១៣:២,៧) ក្នុងខណៈដែលពួកហោរាត្រឹមត្រូវមកអំពីព្រះ (នក ៤:១៦ ចទ ១៨:១៨ យរ ១:៩ ២ពត ១:២១) ។

**១៣:២២** *ខ្មោចរបស់ឯង នឹងមិនបានបញ្ចុះក្នុងផ្នូរនៃពួកឰយុកោ* ឃ្លានេះបានប្រាប់ថា សាកសពរបស់ពួកយូដាដែលជារាស្ត្ររបស់ព្រះ ពួកគេនឹងស្លាប់នៅក្រៅទឹកដីកំណើតរបស់ខ្លួន ។

**១៣:២៤** *សំឡាប់គាត់ទៅ* នេះជាសេចក្តីព្រមានដ៏ខ្លាំងមួយដល់ស្តេចយេរ៉ូបោម ដោយព្រះបានប្រើនូវអត្ថន័យនៃឃ្លាខាងលើនេះ ។ *សត្វលាឈរនៅជិត ឯសិង្ហឈរនៅក្បែរសពដែរ* នៅត្រង់នេះ ការមួយដែលអស្ចារ្យ គឺសត្វលាមិនបានរត់ ហើយសត្វសិង្ហក៏មិនស៊ីសត្វលា ឬហែកសាកសពរបស់មនុស្សដែរ (ខ.២៨) ដែលជាការបង្ហាញពីការនេះថា ជាការជំនុំជម្រះរបស់ព្រះវិញ ។ នេះជាការអស្ចារ្យបន្ថែមទៀត ដែលត្រូវបានកត់ត្រានៅក្នុងក្រុងបេត-អែល ហើយនៅមិនទាន់បានផ្តល់នូវសញ្ញាណផ្សេងបន្ថែមទៀតថា មនុស្សរបស់ព្រះដែលចេញមកពីពួកយូដា បានទទួលអាសនារបស់ស្តេចយេរ៉ូបោម ប៉ុន្តែផ្ទុយទៅវិញ ស្តេចយេរ៉ូបោមនៅមិនបែរចេញពីការអាក្រក់ (ខ.៣៣) ។

**១៣:៣០** *គាត់ក៏បញ្ចុះនៅក្នុងផ្នូររបស់ខ្លួន* មើល ខ.២២ ។ ហោរាចាស់ៗធ្វើតែអ្វីដែលបាត់បង់សម្រាប់អ្នកសំណប់ព្រះ ដើម្បីកែប្រែការគិតទុកមុនរបស់គាត់ និងការបំភាន់ពីដោកវាសនា ។

**១៣:៣១** *បញ្ចុះសពអញ នៅក្នុងផ្នូរ ដែលបានបញ្ចុះអ្នកសំណប់ព្រះ* ពួកហោរាចាស់ៗ បានជ្រើសរើសមធ្យោបាយនេះ ក្នុងការបញ្ជាក់ពីខ្លួនគេ ជាអ្នក

សំណាប់របស់ព្រះនេះដែរ ចូរដាក់ឆ្អឹងអញនៅទន្ទឹមគ្នា
៣២ពីព្រោះពាក្យដែលគាត់បានស្រែក ដោយនូវព្រះបន្ទូល
នៃព្រះយេហូវ៉ា ទាស់នឹងអាសនានៅក្រុងបេត–អែល
ហើយទាស់នឹងអស់ទាំងវិហារនៅទីខ្ពស់[ធ] ដែលនៅក្នុងក្រុង
ស្រុក សាម៉ារី[ន]ទាំងប៉ុន្មាននោះ នឹងកើតមកជាពិត[ប] ។
៣៣ក្រោយការនោះមក យេរ៉ូបោមក៏នៅតែមិនព្រមបែរ
ចេញ ពីផ្លូវអាក្រក់របស់ទ្រង់ឡើយ[ផ] គឺទ្រង់ចេះតែយក
មនុស្ស[ព]ពីបណ្តាជនទាំងឡាយ តាំងឡើងឱ្យធ្វើជាសង្ឃនៃ
អស់ទាំងទីខ្ពស់ទៀត ឯអ្នកណាដែលចង់ធ្វើជាសង្ឃ នោះ
ទ្រង់ក៏ប្រោសតាំង ឱ្យអ្នកនោះធ្វើជាសង្ឃនៃអស់ ទាំងទី
ខ្ពស់ទៅ ៣៤ដំណើរនោះក៏ត្រឡប់ជាបាប[ភ] ដល់ព្រះវង្សា
យេរ៉ូបោម រហូតដល់ត្រូវកាត់កាល់[ម] ហើយលាញចេញពី
ផែនដីទៅ ។

## អ័ហ៊ីយ៉ាថ្លែងទំនាងទាស់នឹងស្តេចយេរ៉ូបោម

**១៤** ១នៅគ្រានោះ អ័ប៊ីយ៉ា ជាបុត្រយេរ៉ូបោម ទ្រង់ចាប់
ប្រឈួន ២ហើយយេរ៉ូបោមមានបន្ទូលនឹងភរិយាថា ចូរឱ្យ
ឯងក្រោកឡើងក្លែងខ្លួន ដើម្បីកុំឱ្យគេស្គាល់ឯងថាជាប្រពន្ធ
អញឡើយ រួចទៅឯក្រុងស៊ីឡូរទៅ នៅទីនោះមានហោរា
អ័ហ៊ីយ៉ា[ក]ដែលបានទាយពីដំណើរ ដែលអញ និងសោយ
រាជ្យលើបណ្តាជននេះ ៣ចូរនាំយកនំបុ័ង១០ដុំ[ខ] និងនំផ្អែម
ខ្លះ ហើយពួច១ពេញដោយទឹកឃ្មុំ ទៅឯលោក លោកនឹង
ប្រាប់ឯង ឱ្យដឹងជាកូននេះនឹងទៅជាយ៉ាងណា ៤ភរិយា
របស់យេរ៉ូបោមក៏ធ្វើដូច្នោះ នាងក្រោកឡើងទៅឯផ្ទះ
អ័ហ៊ីយ៉ានៅក្រុងស៊ីឡូរ រីឯអ័ហ៊ីយ៉ា លោកមើលមិនឃើញ
ទេពីព្រោះភ្នែកងងឹតដោយចាស់ណាស់ហើយ ៥តែព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដល់អ័ហ៊ីយ៉ាថា មើលភរិយារបស់
យេរ៉ូ–បោមមកសួរឯង ពីដំណើរកូនដែលឈឺត្រូវឱ្យឯង
ប្រាប់នាង ដូច្នេះមួយៗ ដ្បិតកាលណានាងចូលមក នោះ
នាងនឹងធ្វើភាពជាស្ត្រីផ្សេងទៀត ។
៦ដូច្នេះ កាលអ័ហ៊ីយ៉ា បានឮសូរជើងនាង កំពុងតែចូល
មកតាមទ្វារនោះ ក៏ពោលថា ភរិយារបស់យេរ៉ូបោមអើយ
សូមអញ្ជើញចូលមកចុះ ព្រះនាងធ្វើភាពជាមនុស្សផ្សេង
ទៀតធ្វើអី[គ] ទូលបង្គំបានទទួលបង្គាប់ ដើម្បីមកថ្វាយដំណឹង
ដ៏ធន់នេះដល់ព្រះនាង ៧សូមទៅទូលយេរ៉ូបោមថា ព្រះ
យេហូវ៉ា ជាព្រះនៃពួកអ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ
ថា[ឃ] ដោយព្រោះអញបានលើកឯង ពីកណ្តាលពួកប្រជាជន
តាំងឡើងឱ្យធ្វើជាស្តេច[ង]លើអ៊ីស្រាអែល ជារាស្ត្រអញ
៨ព្រមទាំងកន្ត្រាក់[ច]យករាជ្យ ពីព្រះវង្សាដាវីឌមកឱ្យឯងវិញ
តែឯងមិនបានដូចដាវីឌជាអ្នកបំរើអញ ដែលបានកាន់តាម
បញ្ញត្តិអញ ហើយដើរតាមអញ ដោយអស់ពីចិត្ត ដើម្បីនឹង
ប្រព្រឹត្តតែសេចក្តីដែលទៀតត្រង់[ឆ] នៅភ្នែកអញទេ ៩គឺឯង
បានប្រព្រឹត្តនៅចំពោះអញ ដោយអាក្រក់[ជ]លើសជាងអស់

**១៣:៣២** ធ លវ ២៦:៣០ ១ពវ ១២:៣១ ន ១ពវ ១៦:២៤,២៨ ២០:១ ២ពវ ១០:១ ១៥:១៣ ប ២ពវ ២៣:១៦ **១៣:៣៣** ផ ១ពវ ១៥:២៦ ព ១ពវ ១២:៣១ **១៣:៣៤** ភ ១ពវ ១២:៣០ ម ១ពវ ១៤:១០ ១៥:២៩ ២ពវ ៩:៩ យរ ៣៥:១៧ អម ៧:៩ **១៤:២** ក ១ពវ ១១:២៩ **១៤:៣** ខ ១សយ ៩:៧ **១៤:៦** គ ១សយ ២៨:១២ **១៤:៧** ឃ ១ពវ ១៥:២៩ ង ១ពវ ១១:៣៧ **១៤:៨** ច ១សយ ១៥:២៧ ឆ ២សយ ៨:១៥ ១ពវ ៣:៣ ១៥:៥ ២ពវ ១៤:៣ ១៥:៣,៣៤ ១៦:២ ១៨:៣ ២០:៣ ២២:២ **១៤:៩** ជ ១ពវ ១៦:៣០,៣៣ ២១:២៥ ២ពវ ២១:៩,១១ ២៤:៣

នាំនូវព្រះរាជសាររបស់ព្រះ ថាអ្នកសំណាប់ព្រះម្នាក់ដែលបានចេញពីស្រុកយូដាបានដល់ក្រុងបេត–អែល ។

**១៣:៣២** *ស្រុកសាម៉ារី* តំបន់នៅភាគខាងជើងនៃអាណាចក្រកាណាន (បច្ចុប្បន្ន) (មើលពន្យល់ ១៦:២៤) ។ ទោះជាយ៉ាងណាក៏ដោយ ស្រុកនេះមិនត្រូវបានហៅយ៉ាងដូច្នេះរហូតដល់៥០ឆ្នាំក្រោយពីព្រឹត្តិការណ៍ (១៦:២៣–២៤) ។ ការប្រើឈ្មោះនេះ គឺដើម្បីរំលឹកដល់អ្នកនិពន្ធកណ្ឌគម្ពីរនេះ (មើលការពន្យល់ លប ១៤:១៤) ។

**១៣:៣៣** *ឱ្យអស់អ្នកនោះ ធ្វើជាសង្ឃនៃអស់ទាំងទីខ្ពស់* មើល ១២:៣១ និងការពន្យល់ ។

**១៣:៣៤** *បាប* អំពើបាបដែលមាននៅក្នុង ១២:៣០ បានបង្កើតឡើងដោយពួកគេបានថ្វាយបង្គំរូបព្រះដទៃ ។ នេះជាសេចក្តីមានះនៅក្នុងការថ្វាយបង្គំជាមួយនឹងអំពើរបាប ។

**១៤:១** *នៅគ្រានោះ* ពាក្យនេះប្រាប់ពី រយៈពេលមិនយូរពីព្រឹត្តិការណ៍ ដែលបានរៀបរាប់នៅក្នុងជំពូក ១៣ ។ *អ័ប៊ីយ៉ា* ពាក្យនេះមានន័យថា "ព្រះវបិតារជាព្រះ" ហើយបានបញ្ជាក់ថាស្តេចយេរ៉ូបោម ក៏មានចំណុចខ្លះដែលទ្រង់បានថ្វាយបង្គំដល់ព្រះយេហូវ៉ាដែរ ។

**១៤:២** *ក្លែងខ្លួន* នៅត្រង់នេះប្រាប់ពីការប៉ុនប៉ងរបស់យេរ៉ូបោម ដើម្បីឱ្យហោរាអ័ហ៊ីយ៉ាយល់ខុស ចំពោះការដែលបុត្រនេះមានជម្ងឺថា (១).ការដឹងពីទោសកំហុសរបស់ខ្លួន (២).ជំនឿលើមន្តអាគមរបស់ពួកហោរា និង (៣).ការបដិសេធរបស់គាត់ ប៉ុន្តែជាការគោរពដល់អំណាចរបស់ពួកហោរារបស់ព្រះ ។ *ស៊ីឡូរ* មើលការពន្យល់ ១សយ ១:៣ ។ *ទាយពីដំណើរដែលអញ នឹងសោយរាជ្យលើបណ្តាជននេះ* មើល ១១:២៩–៣៩ ។

**១៤:៥** *ព្រះយេហូវ៉ាទ្រង់មានបន្ទូលដល់អ័ហ៊ីយ៉ា* មើល ១សយ ៩:១៥–១៧ ២ពវ ៦:៣២ សម្រាប់ការបើកសម្តែងរបស់ព្រះឱ្យឃើញពីគ្រោះមហន្តរាយដែលនឹងមកដល់ក្នុងពេលខាងមុខឆាប់ៗ ។

**១៤:៦** *ភរិយារបស់យេរ៉ូបោមអើយ សូមអញ្ជើញចូលមក* នេះជាការទទួលស្គាល់របស់ហោរាចំពោះស្ត្រីដែលជាប្រពន្ធរបស់យេរ៉ូបោម និងចំណេះដឹងរបស់នាងដែលចូលមកទីនេះក្នុងការបម្រើ ដើម្បីបញ្ជាក់ពីព្រះបន្ទូលដ៏ពិតរបស់ព្រះអម្ចាស់ ។

**១៤:៧–៨** *បានលើកឯង . . . ជាស្តេចលើអ៊ីស្រាអែល* សូមមើល (១១:២៦ ៣០–៣៨) ។

**១៤:៨** *តែឯងមិនបានដូចជាដាវីឌ* កាយវិការរបស់យេរ៉ូបោមមិនបានឆ្លើយតបយ៉ាងសមសួនចំពោះព្រះអម្ចាស់ ហើយមិនបានបំពេញចំពោះតម្រូវការដែលហោរាអ័ហ៊ីយ៉ាបានផ្តល់ឱ្យគាត់នៅពេលគាត់បានឡើងគ្រងរាជ្យជាស្តេច (មើល ១១:៣៨) ។

**១៤:៩** *អ្នកដែលនៅមុនឯង* ភាពកម្សោយរបស់ស្តេចយេរ៉ូបោម គឺមាន

អ្នកដែលនៅមុខឯងវិញ[ឈ] ព្រមទាំងធ្វើព្រះដទៃ[ញ] និងរូប
សិតផង ជាការដែលបណ្ដាលឱ្យអញខឹង[ដ] ហើយឯងបាន
បោះបង់ចោលអញ ទៅខាងក្រោយខ្នងឯង[ឋ] [១០]នោះបាន
ជាអញនឹងនាំសេចក្ដីអាក្រក់[ឪ] មកលើពូជពង្សយេរ៉ូបោម
ហើយនឹងកាត់គ្រប់ទាំងកូនប្រុសៗ ពីវង្សារបស់យេរ៉ូបោម
ចេញ ទោះទាំងអ្នកដែលបិទបាំងទុក ឬជាអ្នកឥតមាន
ចំណង[ឍ] ក្នុងពួកអ៊ីស្រាអែលក្ដី ហើយអញនឹងបោសពួកវង្ស
របស់យេរ៉ូបោមទៅ ដូចជាគេបោសអាចម៍សត្វចោល
ទាល់តែអស់រលីង[ណ] [១១]អ្នកណាក្នុងវង្សយេរ៉ូបោម ដែល
ស្លាប់នៅក្នុងទីក្រុង នោះឆ្កែ[ត]នឹងទំពាស៊ីខ្មោច ហើយអ្នក
ណាដែល ស្លាប់នៅទីវាល នោះសត្វហើរលើអាកាស[ថ]នឹង
ចឹកស៊ីខ្មោចអ្នកនោះ ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូល
ហើយ [១២]ដូច្នេះ សូមព្រះនាងក្រោកឡើង យាងទៅឯ
ដំណាក់ទៅ កាលណាព្រះបាទបានឈានចូល ទៅក្នុងទី
ក្រុងហើយ នោះបុត្រនឹងសុគតទៅ [១៣]ពួកអ៊ីស្រាអែលទាំង
អស់គ្នានឹងកាន់ទុក្ខ ហើយបញ្ចុះសពទ្រង់ ដ្បិតក្នុងវង្សារបស់
យេរ៉ូបោម នោះមានតែបុត្រនេះ១ប៉ុណ្ណោះ ដែលនឹងបាន
បញ្ចុះក្នុងផ្នូរ ពីព្រោះក្នុងវង្សាយេរ៉ូបោមមានតែបុត្រមួយ
នេះទេ ដែលឃើញមានសេចក្ដីល្អខ្លះចំពោះព្រះយេហូវ៉ា
ជាព្រះនៃពួកអ៊ីស្រាអែល[ទ] [១៤]មួយទៀត ព្រះយេហូវ៉ាទ្រង់
នឹងតាំង ឱ្យមានស្ដេច១ផ្សេងសោយរាជ្យលើពួកអ៊ីស្រា–

**១៤:៩** ឈ ១ពវ ១៦:២ ញ នក ២០:៤ ៣២:៤ ២របា ១១:១៥ ដ ចទ ៣២:១៦ ១ពវ ១៦:២ ទដ ៧៨:៥៨ យរ ៧:១៨ ៨:១៩ ៣២:៣២ ៤៤:៣ អគ ៨:១៧ ១៦:២៦ ឋ នហ ៩:២៦ ទដ ៥០:១៧ យរ ២:២៧ ៣២:៣៣ អគ ២៣:៣៥ **១៤:១០** ឪ យស ២៣:២៥ ១ពវ ១៣:៣៤ ឍ ចទ ៣២:៣៦ ២ពវ ៩:៨–៩ ណ ១សយ ១២:២៥ ១៥:២៦ ១ពវ ១៥:២៩ ហស ១៣:១១ **១៤:១១** ត ១ពវ ១៦:៤ ២១:២៤ ថ លប ៤០:២៩ ចទ ២៨:២៦ **១៤:១៣** ទ ២របា ១២:១២ ១៩:៣ **១៤:១៥** ធ ចទ ២៩:២៨ ២របា ៧:២០ ន ចទ ១២:៣ប ចទ ៤៤:៣ **១៤:១៦** ផ ១ពវ ១២:៣០ ១៥:២៦ **១៤:១៧** ព យស ១២:២៤ ១ពវ ១៥:៣៣

អែល ជាអ្នកដែលនឹងធ្វើឱ្យវង្សារបស់យេរ៉ូបោមសាបសូន្យ
ទៅក្នុងថ្ងៃនោះ តើកាលណាទៅ គឺឥឡូវនេះហើយ [១៥]ដ្បិត
ព្រះយេហូវ៉ាទ្រង់នឹងវាយពួកអ៊ីស្រាអែល ដូចជាដើមបបុស
ដែលញ័រនៅក្នុងទឹក ហើយទ្រង់នឹងរំលីង[ធ]ពួកអ៊ីស្រាអែល
ចេញពីដីល្អនេះដែលទ្រង់បានប្រទានដល់ពួកឰយុកោគេ
ក៏នឹងកំចាត់កំចាយគេទៅខាងនាយទន្លេ ដោយព្រោះគេ
បានធ្វើអស់ទាំងរូបព្រះសំរាប់ខ្លួន[ន] ដែលបណ្ដាល[ប]ឱ្យព្រះ
យេហូវ៉ាមានសេចក្ដីក្រោធ [១៦]ទ្រង់នឹងបោះបង់ពួកអ៊ីស្រា
អែលចោល ដោយព្រោះអំពើបាប[ផ]របស់យេរ៉ូបោម
ជាការដែលស្ដេចបានធ្វើហើយ ព្រមទាំងនាំឱ្យពួកអ៊ីស្រា
អែលធ្វើបាបផង ដោយសារការនោះឯង ។
[១៧]ដូច្នេះភរិយារបស់យេរ៉ូបោមក៏ក្រោឡើង យាងចេញ
ទៅឯក្រុងធើសា[ព] កាលព្រះនាងបានដល់មាត់ទ្វារដំណាក់
ហើយបុត្រនោះក៏សុគតទៅ [១៨]រួចពួកអ៊ីស្រាអែលទាំងអស់
គ្នាក៏បញ្ចុះសពទ្រង់ ហើយកាន់ទុក្ខតាមសេចក្ដីដែលព្រះ
យេហូវ៉ាបានមានបន្ទូល ដោយសារហោរាអ័ហ៊ីយ៉ាជាអ្នក
បំរើទ្រង់ ។
[១៩]រឿងដំណើរឯទៀតពីយេរ៉ូបោម គឺពីទ្រង់ធ្វើចំបាំង
យ៉ាងណា ហើយសោយរាជ្យយ៉ាងណា នោះសុទ្ធតែបាន

ច្រើនជាងស្ដេចសូលទៅទៀត ។ ស្ដេចដាវីឌ និងសាឡូម៉ូន នៅត្រង់នេះ បាន បង្រួបបង្រួមដល់អាណាប្រជារាស្ត្រ ដែលនៅភាគខាងជើងចំពោះប្រព័ន្ធថ្វាយបង្គំព្រះទាំងមូល ។ *ព្រះដទៃ* មើលការពន្យល់ ១២:២៨,៣០ ។

**១៤:១០,១១** នៅត្រង់នេះជាគ្រោះមហន្តរាយដែលពួកអ៊ីស្រាអែល បានជួបប្រទះនៅក្នុងសេចក្ដីបង្រៀនយ៉ាងពិតប្រាកដនៅក្នុង ចទ (មើល ចទ ២៨:១៥–១៩ ៣៦:១៥–២០) ។ លោអ័ហ៊ីយ៉ា បានទោះទាយពីការធ្លាក់ចុះរបស់ពួកអ៊ីស្រាអែលក្នុងការដែលពួកគេបានរំលងចំពោះក្រឹត្យវិន័យ ។

**១៤:១២** *បុត្រ* ពាក្យនេះភាសាហេព្រើរមានន័យថា"វ័យជិទង់"(បច្ចេកពាក្យដដែលនេះ ប្រើសម្រាប់ទីប្រឹក្សាវ័យក្មេង យេរ៉ូបោម មើល ១២:៨ និងការពន្យល់) ។ *និងសុគត* ទោះបីមរណៈភាពរបស់លោកអ័ប៊ីយ៉ា បានធ្វើឱ្យយេរ៉ូបោមនិងប្រពន្ធរបស់គាត់មាកការខកចិត្តយ៉ាងខ្លាំង តែវាការសណ្ដោស ការទុកជីវិត របស់ព្រះដែលមានដល់ម្ចាស់ក្សត្រី ដែលគ្រាន់តែទទួលរងនូវភាពអាម៉ាស និងការឈឺចាប់ប៉ុណ្ណោះ(អស ៥៧:១–២) ។

**១៤:១៣** *ពួកអ៊ីស្រាអែលទាំងអស់គ្នានឹងកាន់ទុក្ខ ហើយបញ្ចុះសពទ្រង់* នៅត្រង់នេះប្រហែលជាបញ្ជាក់ថា លោកអ័ប៊ីយ៉ាទទួលបានមុដដ៏ខ្លង់ខ្លស់ល្បីល្បាញ និងទទួលបាននូវសេចក្ដីស្រឡាញ់ពីពួកបណ្ដាជន ។ *បញ្ចុះក្នុងផ្នូរ* គាត់តែម្នាក់គត់ដែលទទួលបាននូវកិត្តិយសពីសំណាក់កូនចៅយេរ៉ូបោមនៅពេលគាត់ត្រូវបញ្ចុះក្នុងផ្នូរនោះ ។

**១៤:១៤** *ស្ដេច១ . . . ធ្វើឱ្យវង្សារបស់យេរ៉ូបោមសាបសូន្យ* នៅត្រង់នេះហោរាអ័ហ៊ីយ៉ាបានប្រាប់ទៅពេលក្រោយរាជស្ដេចណាដាប បុត្ររបស់យេរ៉ូបោម (១៥:២៥–២៦) និងការបះបោររបស់ស្ដេចបា្អសា(១៥:២៧–១៦:២៧) ។

**១៤:១៥** *ដូចជាដើមបបុស ដែលញ័រនៅក្នុងទឹក* នៅត្រង់នេះជាការរៀបរាប់ប្រាប់ពីភាពគ្មានស្ថេរភាពនៃអាណាចក្រខាងជើង ដែលត្រូវបាននឹងកំពុងតែជួបនឹងការកាប់សំឡាប់ និងការបះបោរ(មើល ១៥:២៧–២៨ ១៦:១៦ ២ពវ ៩:២៤ ១៥:១០,១៤,១៥,៣០) ។ *ទ្រង់នឹងរំលីងពួកអ៊ីស្រាអែល* មើល ២ពវ ១៧:២២–២៣ ចំពោះទំនាយបានសម្រេចរបស់ពួកហោរា និងមើលបន្ថែមចំពោះបណ្ដាសាដែលប្រព្រឹត្តិរំលងក្រឹត្យវិន័យដែលមានចែងនៅក្នុង ចទ ២៨:៦៣–៦៤ ២៩:២៥–២៨ ។

**១៤:១៦** *អំពើរបាបរបស់យេរ៉ូបោម ជាការដែលស្ដេចបានធ្វើ* មើល ១២:២៦–៣៣ ១៣:៣៣–៣៤ ។ *នាំឱ្យពួកអ៊ីស្រាអែលធ្វើបាប* ឃ្លានេះជានិច្ចកាលនិយាយម្ដងហើយ ម្ដងទៀតនៅក្នុង ១,២ ពវ (មើល ឧទាហរណ៍ ១៥:២៦ ១៦:២,១៣,១៩,២៦) ។

**១៤:១៧** *ក្រុងធើសា* ក្រុងនេះជារាជធានីរបស់ស្ដេចនៃពួកអ៊ីស្រាអែលរហូតដល់ស្ដេចអំរីបានទិញក្រុងសាម៉ារី ហើយប្ដូរក្រុងនេះមកជារាជធានីវិញ(១៦:២៤) ។ ក្រុងនេះ ប្រហែលជាមានឈ្មោះថា ធែល–អេផារាស (tell-el-Farah) នៅសម័យទំនើប ដែលមានប្រវែង ៩.២០០ គ.ម នៅភាគខាង ជើងក្រុងសីគែម(មើល ពន្យល់ ៦:៤) ។

កត់ទុកក្នុងសៀវភៅ ជាពង្សាវតារនៃពួកស្តេចអ៊ីស្រាអែល
ហើយ ២០យេរ៉ូបោមបានសោយរាជ្យអស់២២ឆ្នាំ រួចក៏ផ្ទំ
លក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់ទៅ ហើយណាដាប
ព្រះរាជបុត្រាទ្រង់ ក៏សោយរាជ្យឡើងជំនួសបិតា ។

## រេហូបោមឡើងជាស្តេចអ៊ីស្រាអែល

*១៤:២១,២៥–៣១ – ២រប ១២:៩–១៦*

២១ឯរេហូបោមជាព្រះរាជបុត្រា នៃសាឡូម៉ូន ទ្រង់បាន
សោយរាជ្យនៅស្រុកយូដា កាលរេហូបោមបានចាប់តាំង
សោយរាជ្យឡើង នោះទ្រង់បានព្រះជន្ម៤១ឆ្នាំហើយ ក៏
សោយរាជ្យបាន១៧ឆ្នាំ នៅក្រុងយេរូសាឡិម ជាទីក្រុង
ដែលព្រះយេហូវ៉ា ទ្រង់បានរើសចេញ ពីពូជអំបូរសាសន៍
អ៊ីស្រាអែលទាំងអំបាលម៉ាន សំរាប់ជាទីតាំងព្រះនាមទ្រង់
ឯមាតារេហូបោម ព្រះនាងនាមជាន៉ាអាម៉ា ជាសាសន៍
អាំម៉ូន[ភ] ២២ពួកយូដា[ម]ក៏ប្រព្រឹត្តអាក្រក់លាមកនៅចំពោះ
ព្រះនេត្រព្រះយេហូវ៉ា ហើយគេបណ្តាលឱ្យទ្រង់មានសេច
ក្តីប្រចណ្ឌ[យ] ដោយសារអំពើបាប ដែលគេប្រព្រឹត្តលើស
ជាងពួកព្ធយុកោរបស់គេទៅទៀត ២៣ដ្បិតគេបានធ្វើទីខ្ពស់
បង្គោលសំរាប់គោរព[រ] និងរូបព្រះ[ល]សំរាប់ខ្លួនគេនៅលើ
គ្រប់ទាំងកំពូលភ្នំ ហើយនៅក្រោមគ្រប់ទាំងដើមឈើខ្ចីៗ[វ]
២៤ក៏តាំងឱ្យមានកូនជីង[ស]នៅក្នុងស្រុកដែរ គេប្រព្រឹត្តតាម
អស់ទាំងអំពើគួរស្អប់ខ្ពើម[ហ]របស់ពួកសាសន៍ដទៃ ដែលព្រះ
យេហូវ៉ាទ្រង់បានបណ្តេញ ពីមុខពួកកូនចៅអ៊ីស្រាអែល
ចេញ ។
២៥លុះឆ្នាំទី៥ ក្នុងរាជ្យស្តេចរេហូបោម នោះស៊ីសាកជា
ស្តេចស្រុកអេស៊ីព្ទ បានឡើងមកច្បាំង[ឡ]នឹងក្រុងយេរូសា
ឡិម ២៦ក៏យកអស់ទាំងទ្រព្យសម្បត្តិ នៃព្រះវិហារ[អ]ព្រះយេ
ហូវ៉ា និងទ្រព្យសម្បត្តិក្នុងដំណាក់ ស្តេចទាំងអស់ទៅហើយ
យកទាំងខែលមាស[ក] ដែលសាឡូម៉ូនបានធ្វើផងដែរ
២៧រួចមកស្តេចរេហូបោមទ្រង់ធ្វើខែលលង្ហិនជំនួសខែល
ទាំងនោះ ក៏ប្រគល់ទៅក្នុងអំណាចនៃមេទ័ព ដែលរក្សា
មាត់ទ្វារដំណាក់ស្តេច[ខ] ២៨ដូច្នេះ កាលស្តេចទ្រង់យាងចូល
ទៅក្នុងព្រះវិហារព្រះយេហូវ៉ាវេលាណា នោះពួករក្សាអង្គ
ក៏កាន់ខែលទាំងនោះ រួចយកទៅទុកក្នុងបន្ទប់របស់ពួក
រក្សាអង្គវិញ ។

**១៤:២១** ភ ១ពវ ១១:១
**១៤:២២** ម ២ពវ ១៧:១៩ ២រប ១២:១ យ ចទ ៣២:២១ ទដ ៧៨:៥៨ យរ ៤៤:៣ ១កថ ១០:២២
**១៤:២៣** រ នក ២៣:២៤ ចទ ១៦:២២ ហស ១០:១ ល ចទ ១២:៣ វ ចទ ១២:២ អគ ៦:១៣
**១៤:២៤** ស ចទ ២៣:១៧ ហ ១ពវ ១១:៥–៧ ២ពវ ២១:២ អរ ៩:១១ សភ ២១:២៧ អស ១:១៣ យរ ១៦:១៨ ៣២:៣៥ ៤៤:៤
**១៤:២៥** ឡ ២រប ១២:២ **១៤:២៦** អ ១ពវ ១៥:១៥,១៨ ក ២ សយ ៨:៧
**១៤:២៧** ខ ២ពវ ១១:៥

**១៤:១៩** *ទ្រង់ធ្វើចំបាំង* មើល ខ.៣០ ១៥:១៦ ២រប ១៣:២–២០ ។ *កត់ទុកក្នុងសៀវភៅ ជាពង្សាវតារនៃពួកស្តេចអ៊ីស្រាអែល* នេះជាកំណត់ត្រានៃតំណវង្សស្តេចនៅភាគខាងជើងដែលអ្នកនិពន្ធកណ្ឌគម្ពីរ១,២ពវ បានកត់ត្រាទុក និងធ្វើឱ្យមានភាពងាយស្រួលដល់អស់អ្នកណាដែលចាប់អារម្មណ៍ចំពោះប្រវត្តិសាស្ត្រពិស្តារនៃតំណវង្សរាជ្យស្តេចអ៊ីស្រាអែល ។ ចំណុចត្រង់នេះ ក៏មិនមានភាពខុសគ្នាខ្លាំងនៅក្នុងបញ្ញត្តិនៃកណ្ឌគម្ពីរ១,២ រប ដែលមានការបរិច្ឆេទក្រោយកណ្ឌគម្ពីរ១,២ ពវ មានបញ្ចូលពីប្រវត្តិសាស្ត្រស្តេចសាសនិយូដា តែប៉ុណ្ណោះ(មើលសេចក្តីផ្តើម អ្នកនិពន្ធ ប្រភព និងការបរិច្ឆេទ) ។

**១៤:២០** *សោយរាជ្យអស់២២ឆ្នាំ* នេះនៅក្នុងឆ្នាំ ៩៣០–៩០៩ មុន គ.ស ។ *ផ្ទំលក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់ទៅ* មើលការពន្យល់ ១:២១ ។ *ណាដាប* សូមមើល ១៥:២៥–៣២ ។

**១៤:២១** *១៧ឆ្នាំ* នេះគឺនៅក្នុងឆ្នាំ ៩៣០–៩១៣មុន គ.ស ។ *ទីក្រុងដែលព្រះយេហូវ៉ា ទ្រង់បានរើសចេញ* មើល ៩:៣ ទដ ១៣២:១៣ ។

**១៤:២២** *ពួកយូដាក៏ប្រព្រឹត្តអាក្រក់ . . . ព្រះនេត្រព្រះយេហូវ៉ា* រាជ្យស្តេចរេហូបោម មានពិពណ៌នាយ៉ាងពិស្តារនៅក្នុង ២រប ១១–១២ ។ ពួកសង្ឃ និងពួកលេវី បានធ្វើចំណាកស្រុកចូលទៅក្នុងស្រុកយូដា ដើម្បីដឹកនាំពួកគេឱ្យដើតាម ស្តេចដាវីឌ និងសាឡូម៉ូននៅឆ្នាំដំបូងនៃរយៈពេលបីឆ្នាំនៃរាជ្យស្តេចរេហូបោម (មើល ១២:២៤ ២រប ១១:១៧) ។ នៅឆ្នាំចុងក្រោយរបស់ស្តេចយេហូបោម និងពួកយូដា បានត្រឡប់បែចេញពីព្រះអម្ចាស់ (២រប ១២:១) ។

**១៤:២៣** *ទីខ្ពស់* មើលការពន្យល់ ៣:២ ។ *បង្គោលសំរាប់គោរព* នេះជាសរសរថ្ម តំណាងឱ្យផលផ្លែផ្សេងៗ នៅក្នុងពិធីអភិសេក សាសនាដែលដាក់នៅជិតអាសនា ។ សរសរស្តម្ភថ្មនេះ បានលើកឡើងនៅក្នុងចំណោមពួកកាណាន ហើយបានហាមជាដាច់ខាតចំពោះពួកអ៊ីស្រាអែលនៅក្រឹត្យវិន័យលោកម៉ូសេ(នក ២៣:២៤ លវ ២៦:១ ចទ ១៦:២១–២២) ។ ការបង្ហាយនេះ ក្នុងគោលបំណងបង្ហាញពីភាពជាព្រះដែលមានចែងនៅក្នុង ២ពវ (៣:២) ។ ចំពោះក្រឹត្យច្បាប់ ក្នុងការប្រើសរសរថ្មនេះ មានចែងនៅក្នុង លប ២៨:១៨ ៣១:៤៥ នក ២៤:៤ ។

**១៤:២៤** *កូនជីងនៅក្នុងស្រុក* ត្រង់នេះបញ្ជាក់ថា ពួកស្រីសំផឹងតាមបែបសាសនា គឺមានភាពសំខាន់ដល់សាសនាខុសឆ្គងរបស់ពួកកាណាន ។ ពួកអ៊ីស្រាអែល ត្រូវបានព្រមានដោយលោកម៉ូសេ ដោយមិនឱ្យពួកគេជាប់ទាក់ទិនក្នុងពិធីដ៏គួរឱ្យស្អប់ខ្ពើមនេះ(មើល ចទ ២៣:១៧–១៨ មើលបន្ថែម ១ពវ ១៥:១២ ២ពវ ២៣:៧ ហស ៤:១៤) ។

**១៤:២៥** *ឆ្នាំទី៥ ក្នុងរាជ្យស្តេចរេហូបោម* ឆ្នាំនេះស្ថិតនៅក្នុង ៩២៦ មុន គ.ស ។ *ស៊ីសាក* មើលការពន្យល់ ៣:១ ១១:៤០ ។ *ច្បាំងនឹងក្រុងយេរូសាឡិម* នេះជាការឈ្លានពានរបស់ស៊ីសាកដែលមានរៀបរាប់យ៉ាងពិស្តារនៅក្នុង ២រប ១២:២–៤ និងការបញ្ជាក់បន្ថែមពីជ័យជម្នះដែលបានចារនៅតាមជញ្ជាំងវិហារ អាមុន (Amun) នៅក្នុងតំបន់ តែប៊ី (Thebes) ។ តំបន់នេះ មានទីក្រុងចំនួន១៥ ដែលស៊ីសាកបានប្លន់ពីពួកយូដា និងពួកអ៊ីស្រាអែល ហើយដែលមានកត់ចុះ មើល ២រប ១៥:៥–៨ ដែលបញ្ជាក់ថាសេចក្តីភ័យខ្លាចបានគម្រាមដល់ពួកយូដា ក្នុងការកែទម្រង់ក្នុងរយៈពេលមួយដ៏ខ្លី ។

**១៤:២៦** *ហើយយកទាំងខែលមាស* មើលការពន្យល់ ១០:១៦ ។

**១៤:២៧** *ខែលលង្ហិន* នេះជាការកាត់បន្ថយចំនួនខែល ដែលមិនអាចប្រៀបឱ្យស្មើនឹងចំនួនដ៏ច្រើននិងមានតម្លៃរបស់ស្តេចសាឡូម៉ូនដែលមានពាសពេញនៅក្នុងក្រុងយេរ៉ូសាឡិម (មើល ១០:២១,២៣,២៧) ។

[២៩]រីឯដំណើរឯទៀត ពីរេហូបោម និងការទាំងប៉ុន្មាន
ដែលទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជា
ពង្សាវតាររបស់ពួកស្តេចយូដាហើយ [៣០]ឯរេហូបោមនិង
យេរ៉ូបោមទ្រង់ចេះតែច្បាំងគ្នាជានិច្ច[ក] [៣១]រេហូបោមក៏ផ្ទំ
លក់ជាមួយនឹងពួកឰយុកោទ្រង់ទៅ គេបញ្ចុះទ្រង់នៅជា
មួយនឹងពួកឰយុកោទ្រង់ ក្នុងទីក្រុងរបស់ដាវីឌ ឯមាតាទ្រង់
នោះ មានព្រះនាមជាន៉ាអាម៉ា សាសន៍អាំម៉ូន[ឃ] លំដាប់
នោះ អ័ប៊ីយ៉ា ជាព្រះរាជបុត្រាទ្រង់ ក៏សោយរាជ្យឡើង
ជំនួសបិតា ។

**អ័ប៊ីយ៉ាសោយរាជនៅស្រុកយូដា**

*១៥:១-២,៦-៨-២រប ១៣:១-២,២២-១៤:១*

**១៥** [១]លុះដល់ឆ្នាំទី១៨ ក្នុងរាជ្យយេរ៉ូបោម ជាបុត្រនេបាត
នោះ អ័ប៊ីយ៉ាក៏ចាប់តាំងសោយរាជ្យឡើងនៅស្រុកយូដា
[២]ទ្រង់គ្រងរាជ្យបាន៣ឆ្នាំនៅក្រុងយេរូសាឡិម ឯមាតា
ព្រះនាមជាម្អាកា[ក] បុត្រីអ័ប៊ីសាឡុម [៣]ទ្រង់ក៏ប្រព្រឹត្តតាមអស់
ទាំងអំពើបាប ដែលព្រះបិតាបានប្រព្រឹត្តពីមុនមកដែរ
ព្រះទ័យទ្រង់មិនបានស្មោះត្រង់[ខ] ដល់ព្រះយេហូវ៉ា ជាព្រះ
នៃទ្រង់ ដូចជាព្រះទ័យដាវីឌ ជាឰយុកោទ្រង់ទេ [៤]ប៉ុន្តែ
ដោយព្រោះយល់ដល់ដាវីឌ បានជាព្រះយេហូវ៉ា ជាព្រះនៃ
ទ្រង់ បានប្រទានឱ្យមានចង្កៀង១ភ្លឺ[គ] នៅក្រុងយេរូសាឡិមគឺ
បានតាំងព្រះរាជបុត្រាទ្រង់ឱ្យសោយរាជ្យឡើងជំនួសបិតា
ដើម្បីនឹងប្រោសឱ្យក្រុងយេរូសាឡិមនៅជាប់តទៅ [៥]ពី
ព្រោះដាវីឌបានប្រព្រឹត្តសេចក្តីដែលទៀតត្រង់នៅព្រះ
នេត្រព្រះយេហូវ៉ា ដោយឥតបែរចេញ[ឃ] ពីសេចក្តីបង្គាប់
ណាមួយរបស់ទ្រង់ ដរាបដល់អស់ព្រះជន្ម លើកតែក្នុងរឿង
ពីអ៊ូរី[ង]ជាសាសន៍ហេតប៉ុណ្ណោះ [៦]ឯរេហូបោម និងយេរ៉ូ
បោមទ្រង់ចេះតែច្បាំងគ្នា[ច]ដរាបដល់អស់ព្រះជន្ម ។
[៧]រីឯដំណើរឯទៀតពីអ័ប៊ីយ៉ា នឹងការទាំងប៉ុន្មានដែល
ទ្រង់ធ្វើ នោះសុទ្ធតែកត់ទុកក្នុងសៀវភៅ ជាពង្សាវតារនៃ
ពួកស្តេចយូដាហើយ អ័ប៊ីយ៉ា និងយេរ៉ូបោម ក៏តែងតែ
ច្បាំងគ្នា [៨]អ័ប៊ីយ៉ាទ្រង់ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោ
ទ្រង់ទៅ គេបញ្ចុះទ្រង់នៅក្នុងទីក្រុងរបស់ដាវីឌ រួចអេសា
ជាព្រះរាជបុត្រា ក៏សោយរាជ្យឡើងជំនួសបិតា ។

**អេសាស្តេចនៃស្រុកយូដា**

*១៥:៩-២២ – ២រប ១៤:២-៣ ១៥:១៦-១៦:៦*

*១៥:២៣-២៤ – ២រប ១៦:១១-១៧:១*

[៩]លុះដល់ឆ្នាំទី២០ ក្នុងរាជ្យយេរ៉ូបោម ជាស្តេចពួក
អ៊ីស្រាអែល នោះអេសាចាប់តាំងសោយរាជ្យឡើង នៅ
ស្រុកយូដា [១០]ទ្រង់សោយរាជ្យ នៅក្រុងយេរូសាឡិមបាន
៤១ឆ្នាំ ឯមាតាទ្រង់ ព្រះនាមជាម្អាកា[ឆ] បុត្រីអ័ប៊ីសាឡុម
[១១]អេសានេះទ្រង់បានប្រព្រឹត្តទៀងត្រង់ នៅព្រះនេត្រព្រះ
យេហូវ៉ា ដូចជាដាវីឌ[ជ] ជាឰយុកោទ្រង់ដែរ [១២]ទ្រង់កំចាត់
ពួកកូន[ឈ]ជឹងពីនគរចេញ ក៏បំបាត់អស់ទាំងរូបព្រះ[ញ]ដែល

**១៤:៣០** ក ២សយ ៣:១ ១ពវ ១២:២១ **១៤:៣១** ឃ ១ពវ ១១:១ **១៥:២** ក ខ.១០,១៣ ២រប ១១:២០ **១៥:៣** ខ ១ពវ ៨:៦១ **១៥:៤** គ ២សយ ២១:១៧ **១៥:៥** ឃ ចទ ៥:៣២ ១ពវ ៩:៤ ង ២សយ ១១:២-២៧ ១២:៩ **១៥:៦** ច ខ.១៦,៣២ ១ពវ ១២:២១ ២រប ១៦:៩ **១៥:១០** ឆ ខ.២ **១៥:១១** ជ ១ពវ ៩:៤ **១៥:១២** ឈ ១ពវ ១៤:២៤ ញ ២រប ១៥:៨

**១៤:២៩** *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* កំណត់ត្រានៃពង្សាវតាពួកយូដា គឺមានភាពស្រដៀងគ្នាទៅនឹងស្តេចនៃអណាចក្រខាងជើងដែរ (មើលពន្យល់ ខ.១៩ និងសេចក្តីផ្តើមត្រង់ចំណុច អ្នកនិពន្ធ ប្រភព និងកាលបរិច្ឆេទ) ។

**១៤:៣០** *យេរ៉ូបោម ទ្រង់ចេះតែច្បាំងគ្នា* មើលពន្យល់ ខ.១៩ ១២:២៤ ។

**១៤:៣១** *ផ្ទំលក់ជាមួយនឹងពួកឰយុកោទ្រង់* មើលពន្យល់ ១:២១ ។

**១៥:១** *ឆ្នាំទី១៨ ក្នុងរាជ្យយេរ៉ូបោម* ឆ្នាំនេះមានលើកឡើងច្រើនហើយកើតឡើងក្នុងពេលដំណាលគ្នាចំពោះគម្ពីរ១,២ពវ រវាងពង្សាវតារស្តេចនៅភាគខាងជើង និងពង្សាវតារពួកយូដា (មើល ខ.៩,២៥,៣៣ ១៦:៨,១៥) ។ *អ័ប៊ីយ៉ា* មើលការពន្យល់ ១៤:១ ។ នៅត្រង់នេះទាំងរេហូបោម និងយេរ៉ូបោម មានបុត្រឈ្មោះនេះទាំងអស់គ្នា ។

**១៥:២** *៣ឆ្នាំ* នេះសំគាល់ពីការឡើងគ្រងរាជ្យរបស់ស្តេចអ័ប៊ីយ៉ាគឺ នៅក្នុងឆ្នាំ ៩:១៣–៩១០ មុន គ.ស ។ *ម្អាកា បុត្រីអ័ប៊ីសាឡុម* មាតារបស់អ័ប៊ីយ៉ា គឺជាកូនអ៊ូរាលអ្នកក្រុងគីបៀរ ២រប ១៣:២ ។ ត្រង់នេះ ប្រហែលជាម្អាកាជាចៅរបស់អ័ប៊ីសាឡុមហើយត្រូវជាកូនរវាងអាហ៏ពាហ៏ពិពាហ៏ នាងតាម៉ារ និងអ៊ូរាល (មើល ២សយ ១៤:២៧) ។

**១៥:៣** *អំពើបាប ដែលព្រះបិតាបានប្រព្រឹត្ត* សូមមើល ១៤:២២–២៤ ។ *ព្រះទ័យទ្រង់ . . . ដូចជាព្រះទ័យដាវីឌជាឰយុកោទ្រង់* ឃ្លានេះប្រាប់ថា ទោះបីស្តេចដាវីឌបានប្រព្រឹត្តនូវអំពើបាបដ៏ធ្ងន់ធ្ងរក៏ដោយ ប៉ុន្តែចិត្តរបស់ទ្រង់មិនដែលងាកចង់ទៅបម្រើព្រះរបស់ពួកកាណានដែរ ។

**១៥:៤** *ចង្កៀង១ភ្លឺ នៅក្រុងយេរូសាឡិម* មើលការពន្យល់ ១១:៣៦ ។

**១៥:៥** *អ៊ូរី ជាសាសន៍ហេត* សូមមើល ២សយ ១១ ។

**១៥:៦** *រេហូបោម* សូមមើល ១២:២៤ ។

**១៥:៧** *អ័ប៊ីយ៉ា និងការទាំងប៉ុន្មានដែលទ្រង់ធ្វើ* សូមមើល ២រប ១៣ ។ *សៀវភៅ ជាពង្សាវតារនៃពួកស្តេចយូដា* មើលពន្យល់ ១៤:២៩ ។ *អ័ប៊ីយ៉ានឹងយេរ៉ូបោមក៏តែងតែច្បាំងគ្នា* ចំពោះឃ្លានេះ សូមធៀប ខ.៦ ១៤:៣០ ។ ឃ្លានេះចាប់ពី ២រប បានបញ្ជាក់យ៉ាងច្បាស់ថា វាជាសង្គ្រាមយ៉ាងរ៉ាំរ៉ៃដែលមានតាំងពីមុនមក នោះបានធ្លាក់ចូលក្នុងជម្លោះមួយយ៉ាងធ្ងន់ធ្ងរដែលអ័ប៊ីយ៉ា បានវាយយេរូបោមនឹងរឹបអូសយកបានទីក្រុងមួយចំនួនដែលរួមទាំងក្រុងបេត–អែលផងដែរ (២រប ១៣:១៩) ។

**១៥:៨** *ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ* ត្រង់នេះនៅក្នុងឆ្នាំ ៩១០ មុន គ.ស (មើលការពន្យល់ ១៤:២០) ។

**១៥:១០** *៤១ឆ្នាំ* នេះស្ថិតនៅចន្លោះ នៃឆ្នាំ ៩១០–៨៦៩ គ.ស ។ *ម្អាកា បុត្រីអ័ប៊ីសាឡុម* មើលការពន្យល់ ខ.២ ។

**១៥:១២** *ទ្រង់កំចាត់ពួកកូនជឹងពីនគរចេញ* មើលការពន្យល់ ១៤:២៤ ។ *បំបាត់អស់ទាំងរូបព្រះ ដែលវង្សានុវង្សបានធ្វើ* មើល ១៤:២៣ ។ *រូបព្រះ*

វង្សានុវង្សទ្រង់បានធ្វើបង់ ១៣ទ្រង់ដកម្អាកា[ដ] ជាមាតា[ឋ] ពី
ដំណែងជាមាតាហ្លួង ដោយព្រោះព្រះនាងបានធ្វើរូប១
ដែលគួរស្អប់ខ្ពើម ទុកសំរាប់ជាព្រះ ហើយអេសាក៏កាប់រូប
នោះ[ឌ] យកទៅដុតនៅត្រង់ជ្រោះកេដ្រុន ១៤តែឯទីខ្ពស់ទាំង
ប៉ុន្មាន នោះមិនបានបំបាត់[ឍ]ចេញទេ ប៉ុន្តែទ្រង់មានព្រះ
ទ័យស្មោះត្រង់[ណ] ដល់ព្រះយេហូវ៉ារហូតដល់អស់ព្រះជន្ម
១៥ហើយគ្រឿងប្រដាប់ទាំងប៉ុន្មាន ដែលព្រះបិតាបានថ្វាយ
នឹងរបស់ដែលអង្គទ្រង់បានថ្វាយ គឺជាប្រាក់ មាស និង
គ្រឿងប្រដាប់ផ្សេងៗ នោះទ្រង់ក៏យកទៅដាក់ក្នុងព្រះ
វិហារនៃព្រះយេហូវ៉ា[ត]។
១៦អេសានេះ និងបាសា ជាស្តេចស្រុកអ៊ីស្រាអែលទ្រង់
ច្បាំងគ្នា[ថ]រហូតដល់អស់ព្រះជន្ម ១៧ឯបាសា ជាស្តេចស្រុក
អ៊ីស្រាអែល ទ្រង់ឡើងទៅឡើងទៅទាស់នឹងពួកយូដា ក៏
សង់ក្រុងរ៉ាម៉ាឡើង[ទ] ដើម្បីកុំឱ្យមាន អ្នកណាចេញចូលទៅ
ខាងអេសា ជាស្តេចស្រុកយូដាបានឡើយ ១៨ដូច្នេះ អេសា
ទ្រង់យកអស់ទាំងប្រាក់មាស ដែលនៅសល់ក្នុងឃ្លាំង នៃ
ព្រះវិហារ[ធ]ព្រះយេហូវ៉ា និងទ្រព្យសម្បត្តិទាំងប៉ុន្មាន ដែល
នៅក្នុងដំណាក់ស្តេច ប្រគល់ទៅក្នុងដៃនៃពួកមហាតលិក
ទ្រង់ចាត់[ន]គេទៅឯបេន-ហាដាឌ់[ប] ជាបុត្រថាបរីម៉ូន ដែល
ជាបុត្រហេសយ៉ូន ស្តេចស្រុកស៊ីរី ដែលនៅក្រុងដាម៉ាស
ដោយពាក្យថា ១៩ទ្រង់ ហើយនិងទូលបង្គំមានសេចក្តីសញ្ញា[ផ]
នឹងគ្នាមកហើយ ព្រមទាំងព្រះបិតាទូលបង្គំ និងព្រះបិតា
របស់ទ្រង់ផង នេះនែ ទូលបង្គំផ្ញើដង្វាយជាប្រាក់មាសមក
ថ្វាយដល់ទ្រង់ សូមឱ្យទ្រង់ទៅផ្តាច់សេចក្តីសញ្ញា ដែល
ទ្រង់មានចំពោះបាសា ជាស្តេចស្រុកអ៊ីស្រាអែលទៅ ដើម្បី
ឱ្យគេថយពីទូលបង្គំចេញ ២០បេន-ហាដាឌ់ក៏ស្តាប់តាមស្តេច
អេសាទ្រង់ចាត់ពួកពលទ័ព ទៅច្បាំងនឹងអស់ទាំងទីក្រុង
នៅស្រុកអ៊ីស្រាអែល គេក៏វាយ[ព]ក្រុង អ៊ីយ៉ូន ក្រុងដាន់ និង
ក្រុងអេបិល-បេត-ម្អាកា ព្រមទាំងស្រុកគីនេ រ៉ែតទាំង

**១៥:១៣** ដ ខ.២ ឋ ១ពវ ២:១៩ ឌ នក ៣៤:១៣ **១៥:១៤** ឍ ២របា ១៤:៥ ១៧:៦ ណ ១ពវ ៨:៦១ **១៥:១៥** ត ២សយ ៨:១១ **១៥:១៦** ថ ខ.៦ ១ពវ ១២:២១ **១៥:១៧** ទ យស ១៨:២៥ **១៥:១៨** ធ ១ពវ ១៤:២៦ ន ២ពវ ១២:១៨ ១៦:៨ ១៨:១៤-១៦,១៥ យអ ៣:៥ ប ខ.១៨-២០ ១ពវ ២០:១ ២ពវ ៦:២៤ ១៣:៣ យរ ៤៩:២៧

**១៥:១៩** ផ នក ២៣:៣២ ១ពវ ៥:១២ **១៥:២០** ព ១ពវ ២០:៣៤

មើលការពន្យល់ លវ ២៦:៣០ ។

**១៥:១៣** *ទ្រង់ដកម្អាកា ជាមាតា* បទគម្ពីរ ២របា ១៤:១-១៥:១៦ បានបង្ហាញអំពីការធ្វើកំណែទម្រង់បន្តិចម្តងៗរបស់ស្តេចអេសា ក្នុងអំឡុងពេលជាច្រើនឆ្នាំ ។ ទ្រង់បានកំទេចរូបព្រះ និងអាសនារបស់សាសន៍ដទៃ នៅដើមនៃរជ្ជកាលទ្រង់(២របា ១៤:២-៣) ប៉ុន្តែទាល់តែនៅក្រោយពេលទទួលជ័យជំនះលើស្តេចសេរ៉ាស នៃនគរអេធីយ៉ូពី(២របា ១៤:៨-១៥) ទើបទ្រង់ប្រមូលពួកបណ្តាជន ឱ្យមូលគ្នានៅក្រុងយេរូសាឡិម ដើម្បីតាំងសញ្ញាជាថ្មីនៅក្នុង ឆ្នាំទី១៥ នៃរជ្ជកាលរបស់ទ្រង់ ដែលជាការឆ្លើយតបនឹងពាក្យរបស់ហោរាអ័សារា(២របា ១៥:១០)។ បន្ទាប់ពីតាំងសញ្ញា នោះហើយទ្រង់ទម្លាក់ព្រះឰយុការទ្រង់ គឺព្រះនាងម្អាកា ដែលជាអ្នកថ្វាយបង្គំរូបព្រះ(២របា ១៥:១៦)។ *ធ្វើរូប១ដែលគួរស្អប់ខ្ពើម* មើល ការពន្យល់ ១៤:១៥ ។

**១៥:១៤** *តែឯទីខ្ពស់ ទាំងប៉ុន្មាន នោះមិនបានបំបាត់ចេញទេ* ឃ្លានេះនិយាយសំដៅដល់ ២របា ១៥:១៧ ហើយទីខ្ពស់ទាំងនោះដែលព្រះអម្ចាស់ទ្រង់បានថ្វាយបង្គំ(មើលការពន្យល់ ៣:២) ។ នៅក្នុង ២របា ១៤:១៣ បានបញ្ជាក់ថាស្តេចអេសាបានបំបាត់ទីខ្ពស់ ដែលជាកន្លែងដែលពួកសាសន៍ដទៃ(សាសន៍កាណាន)ថ្វាយបង្គំព្រះរបស់ពួកគេ(មើល ២របា ១៧:៦ ២០:៣៣ សម្រាប់រយៈចម្ងាយដូចគ្នា) ។ សេចក្តីសម្រេចដូចគ្នា ដែលបានធ្វើឡើងដោយស្តេចអេសា ក្នុងការបង្កើតឱ្យមានស្តេចប្រាំអង្គនៅស្រុកយូដាមុនរាជ្យស្តេចអេសេគា(យ៉ូសាផាត ២២:៤៤ យ៉ូអាស ២ពវ ១២:៣ អ័ម៉ាស៊ា ២ពវ ១៤:៤ សេរ៉ាស ២ពវ ១៥:៤ យ៉ូថាម ២ពវ ១៥:៣៥) ។ *ទ្រង់មានព្រះទ័យស្មោះត្រង់ ដល់ព្រះយេហូវ៉ា រហូតអស់ព្រះជន្ម* សូមមើល ខ.៣ ។

**១៥:១៥** *ប្រាក់ មាស និងគ្រឿងប្រដាប់ផ្សេងៗ* របស់ទាំងអស់នេះ បានមកពីការរឹបអូសក្រោយពីសង្គ្រាម ដែលអ័ប៊ីយ៉ាប្រមូលមកពីក្រុងយេរ៉ូសាឡិម (របា ១៣) និងស្តេចអេសា បានទទួលពី សេរ៉ាស និងគូស៊ី(១៤:៨-១៥) ។

**១៥:១៦** *អេសា . . . បាសា . . . ច្បាំងគ្នា* សង្គ្រាមរវាងពួកគេទាំងពីរនៅត្រង់នេះបានបន្តយ៉ាងយូរ រហូតដល់មានការបែងចែកអាណាចក្រផងដែរ (មើលពន្យល់ ខ.៧ ១២:២៤ មើលបន្ថែម ២របា ១៥:១៩) ។

**១៥:១៧** *សង់ក្រុងរ៉ាម៉ា* ដោយព្រោះតែក្រុងរ៉ាម៉ា មានទីតាំងនៅជាប់ភាគខាងត្បូងនៃក្រុងបេត-អែលហើយមានចម្ងាយប្រហែល ៨ គីឡូម៉ែត្រ ពីក្រុងយេរ៉ូសាឡិម នោះបាសាបានរឹបអូសទឹកដីនេះជាថ្មីម្តងទៀត ដែលទឹកដីនេះគេយកពីយេរ៉ូបោមដោយអ័ប៊ីយ៉ា (មើល ខ.៧ បន្ថែម ២របា ១៣:១៩) ។ *កុំឱ្យមានអ្នកណា ចេញចូលទៅខាងអេសា* សូមមើល ២របា ១៥:៩-១០ ។

**១៥:១៨** *អស់ទាំងមាសប្រាក់ដែលនៅសល់* របស់ទាំងអស់នេះ នៅសល់ក្រោយពីការឆក់ប្លន់របស់ស៊ីសាកជាស្តេចស្រុកអេស៊ីព្ទ (មើល ១៤:២៥) ។ *ហេសយ៉ូន* នៅត្រង់នេះ មិនបានបញ្ជាក់ថា គាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងរេសោនអ្នកក្រុងដាម៉ាស(មើល ១១:២៣-២៥) ឬជាអ្នកបង្កើតសន្តិវង្សជំនាន់ថ្មីនោះឡើយ ។

**១៥:១៩** *សេចក្តីសញ្ញា . . . ព្រះបិតា* នៅត្រង់នេះនិយាយសំដៅដល់ការដែលមិនបានលើកឡើងពីសេចក្តីសញ្ញារបស់ស្តេចអ័ប៊ីយ៉ា និងថាបរីម៉ូនជាកូនរបស់អើរ៉ាម គឺនៅពេលដែលថាបរីម៉ូនស្លាប់ទៅ នោះបាសាបានទទួលជោគជ័យ នៅក្នុងការបង្កើតសេចក្តីសញ្ញាជាមួយនឹងអ្នកស្នងរាជ្យរបស់ខ្លួនគឺ បេន-ហាដាឌ់ ។ អេសា គ្មានសង្ឃឹមយកជ័យជម្នះលើបាសាដោយគ្មានជំនួយពីសេចក្តីសញ្ញារបស់លោកអើរ៉ាម ។ ទោះបីគម្រោងការណ៍គាត់ ហាក់ដូចជាជោគជ័យ ប៉ុន្តែការនេះ ត្រូវបានកាត់ទោសដោយហាណានី ដែលជាហោរាល្បីល្បើដែលបដិសេធ និងដកសេចក្តីទុចិត្តចេញពីព្រះ(មើល ២របា ១៦:៧-១០)។ ស្តេចដែលទទួលការដឹកនាំពីព្រះមិនត្រូវមានការភ័យខ្លាចចំពោះសត្រូវរបស់ខ្លួនទេ ប៉ុន្តែត្រូវទុកចិត្តលើសុវត្ថិភាព និងការការពាររបស់ទ្រង់(ការពន្យល់ ១សយ ១៧:១១)។ អ័ហាសក្រោយមកទៀត បានដើរតាមគម្រូអាក្រក់របស់អេសា(២ពវ ១៦:៥-៩ អស ៧) ។

**១៥:២០** *ណែបថាលី* នៅត្រង់នេះបញ្ជាក់ថា គ្រប់ទីក្រុងដែលបេន-ហាដាឌ់បានឈ្លានពាន និងលុកលុយផ្នែកសំខាន់នៅទីនេះ ពីព្រោះវាជាមធ្យោបាយពាណិជ្ជកម្មផ្លូវទឹក ដោយចាប់ពីក្រុងដាម៉ាសភាគខាងលិចស្រុកទីរ៉េ ភាគ

មូល ហើយស្រុកណែបថាលីទាំងអស់ ២១កាលបាសាបាន
ជ្រាប នោះទ្រង់ក៏លែងសង់ក្រុងរ៉ាម៉ា[ក] ទៅអាស្រ័យនៅឯ
ក្រុងធើសាវិញ[ខ] ២២គ្រានោះស្តេចអេសាទ្រង់ចេញព្រះ
រាជឱង្ការ ប្រកាសដល់ពួកយូដាទាំងអស់គ្នា ឥតប្រោសទុក
អ្នកណាមួយឡើយ ហើយគេក៏ទៅយកទាំងថ្មនឹងឈើ ដែល
បាសាបានប្រើ ដើម្បីនឹងសង់ក្រុងរ៉ាម៉ាមក[គ] រួចស្តេច
អេសាក៏យកទៅសង់ក្រុងកេបា[ឃ]នៅខែត្របេនយ៉ាមីន ព្រម
ទាំងក្រុងមីសប៉ាវិញ ។
២៣រីឯដំណើរឯទៀត ពីអេសា និងអំណាចរបស់ទ្រង់
ហើយការ ដែលទ្រង់ធ្វើទាំងប៉ុន្មាន ព្រមទាំងទីក្រុងទាំង
អស់ដែលទ្រង់បានសង់ នោះសុទ្ធតែបានកត់ទុកក្នុងសៀវ
ភៅជាពង្សាវតាររបស់ពួកស្តេចយូដាហើយ តែកាលស្តេច
ទ្រង់ព្រះជរាហើយ នោះក៏កើតព្រះរោគឡើងត្រង់ ព្រះ
បាទ ២៤អេសាទ្រង់ក៏ផ្ទំលក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់
ទៅគេបញ្ចុះទ្រង់នៅជាមួយនឹងពួកព្ធយុកោទ្រង់ ក្នុងទីក្រុង
របស់ដាវីឌ ជាព្ធយុកោ រួចយ៉ូសាផាត[ង]ជាព្រះរាជបុត្រា
ក៏សោយរាជ្យឡើងជំនួសបិតា ។

## ណាដាបស្តេចស្រុកអ៊ីស្រាអែល

២៥លុះដល់ឆ្នាំទី២ ក្នុងរាជ្យអេសា ជាស្តេចស្រុកយូដា
នោះណាដាប ជាព្រះរាជបុត្រាយេរ៉ូបោម ទ្រង់ចាប់តាំង
សោយរាជ្យ នៅស្រុកអ៊ីស្រាអែល ទ្រង់គ្រងរាជ្យនៅស្រុក

**១៥:២១** ក យស ១៨:២៥ ម ១ពវ ១៦:១៥-១៧
**១៥:២២** យ ខ.១៧ រ ខ.៩-២៤ យរ ៤១:៩ ល យស ១៨:២៤ ២ពវ ២៣:៨ វ យស ១១:៣
**១៥:២៤** ស មថ ១:៩
**១៥:២៦** ហ ចទ ៤:២៥ ឡ ១ពវ ១២:៣០
**១៥:២៧** អ ១ពវ ១៤:១៤ ក យស ១៩:៤៤
**១៥:២៩** ខ ១ពវ ១៣:៣៤
**១៥:៣០** គ ១ពវ ១២:៣០ យ ១ពវ ១៦:២៦ ២ពវ ៣:៣ ១៤:២៤ ១៥:២៨ ២១:១៦

អ៊ីស្រាអែលបាន២ឆ្នាំ ២៦ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ក]
នៅព្រះនេត្រព្រះយេហូវ៉ា ហើយប្រតិបត្តិតាមផ្លូវ និងតាម
អំពើបាបរបស់ព្រះបិតា[ឡ]ជាការដែលនាំឱ្យពួកអ៊ីស្រាអែល
ធ្វើបាបដែរ ២៧រួចបាសា ជាកូនអ័ហ៊ីយ៉ា ក្នុងពូជអំបូរ
អ៊ីសាខារ ក៏ក្បត់ទ្រង់ ហើយប្រហារសំឡាប់ទ្រង់[អ]នៅត្រង់
គីបថោន[ក] ជាទីក្រុងរបស់ពួកភីលីស្ទីនទៅ ដ្បិតនៅគ្រានោះ
ណាដាប និងពួកអ៊ីស្រាអែលទាំងអស់ គេកំពុងឡោមព័ទ្ធ
ច្បាំងនឹងក្រុងគីបថោន ២៨គឺនៅឆ្នាំទី៣ ក្នុងរាជ្យអេសាជា
ស្តេចស្រុកយូដា ដែលបាសាបានធ្វើគុតណាដាប រួចក៏
សោយរាជ្យឡើងជំនួសទ្រង់ ២៩លុះបានតាំងឡើងជាស្តេច
ហើយ នោះទ្រង់ក៏ប្រហារជីវិតនៃពួកវង្សរបស់យេរ៉ូបោម
ទាំងអស់បង់ ឥតមានទុកឱ្យពូជពង្សយេរ៉ូបោមណាមួយ
មានដង្ហើមនៅរស់ទៀតឡើយ រហូតដល់បានធ្វើឱ្យវិនាស
អស់រលីងទៅ តាមសេចក្តីដែលព្រះយេហូវ៉ាបានមាន
បន្ទូល ដោយសារអ័ហ៊ីយ៉ាជាអ្នកបំរើទ្រង់ ដែលនៅក្រុង
ស៊ីឡូរ ៣០ដោយព្រោះអំពើបាប[គ]ដែលយេរ៉ូបោមបានធ្វើ
ព្រមទាំងនាំឱ្យពួកអ៊ីស្រាអែលប្រព្រឹត្តតាមដែរ ជាអំពើ
ដែលបណ្តាល[ឃ]ឱ្យព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រា
អែលមានសេចក្តីក្រោធ ។
៣១រីឯដំណើរឯទៀតពីណាដាប និងការទាំងប៉ុន្មាន
ដែលទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជា

និរតី ដោយកាត់តាមវាលរាបនៃស្រុកយេសរាល រហូតដល់ឆ្នេរនៃស្រុកអេស៊ីព្ទនៃតំបន់នេះ ។ ទឹកដីនេះ ក្រោយមកត្រូវបានរឹបអូសដោយស្តេចស្រុកអាសស៊ើរ (២ពវ ១៥:២៩) ។

**១៥:២១** *ក្រុងធើសា* មើលការពន្យល់ ១៤:១៧ ។

**១៥:២២** *ប្រកាសដល់ពួកយូដាទាំងអស់គ្នា* នេះជា ព្រះរាជឱង្ការរបស់ស្តេចអេសា គឺជាការបង្ខិតបង្ខំក្នុងការកេណ្ឌកម្លាំងពលកម្មដែលបានធ្វើឡើងដោយស្តេចសាឡូម៉ូន (មើល ៥:១៣-១៤ ១១:២៨) ។ *ក្រុងកេបា... ក្រុងមីសប៉ាវិញ* នៅត្រង់នេះបញ្ជាក់ថា ស្តេចអេសាបានបង្កើតប៉មព្រំដែនពីរក្នុងគោលបំណងត្រួតពិនិត្យដល់ស្តេចបាសាក្នុងការពង្រីកទឹកដីរបស់គាត់ទៅភាគខាងត្បូងបន្តទៀត ។ ក្រុងកេបា នៅភាគខាងកើតនៃក្រុងរ៉ាម៉ា រីឯក្រុងមីសប៉ាស្ថិតនៅភាគខាងកើតនៃក្រុងរ៉ាម៉ា ។

**១៥:២៣** *ដំណើរឯទៀត ពីអេសា* សូមមើល ២របា ១៤:២-១៦:១៤ ។ *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* មើលការពន្យល់ ១៤:២៩ ។ *ព្រះរោគឡើងត្រង់ព្រះបាទ* សូមមើល ២របា ១៦:១២ ។

**១៤:២៤** *ផ្ទំលក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់* សូមមើល ១:២១ ។ *យ៉ូសាផាត ជាព្រះរាជបុត្រា ក៏សោយរាជ្យ* សម្រាប់រាជ្យស្តេចយ៉ូសាផាត សូមមើល ២២:៤១-៥០ ២របា ១៧:១-២១:១ ។

**១៥:២៥** *ឆ្នាំទី២ ក្នុងរាជ្យអេសា* មើលការពន្យល់ ខ.១ ។ ឆ្នាំទី២ ក្នុងរាជ្យស្តេចអេសានៃពួកយូដានេះ គឺត្រូវនឹងឆ្នាំទី២២ ហើយក៏ជាឆ្នាំចុងក្រោយនៃរាជ្យស្តេចយេរ៉ូបោមរបស់ពួកអ៊ីស្រាអែល (មើល ខ.៩ ១៤:២០) ។ *២ឆ្នាំ* ឆ្នាំនេះស្ថិតនៅក្នុង ៩០៩-៩០៨ មុន គ.ស ។

**១៥:២៦** *អំពើរបាប... នាំឱ្យពួកអ៊ីស្រាអែលធ្វើបាប* នៅត្រង់នេះ បញ្ជាក់ពីអំពើរបាបរបស់ស្តេចយេរ៉ូបោម (មើលការពន្យល់ ១៤:១៦) ។ ទោះបីលោកអ័ហ៊ីយ៉ា បានរស់នៅក្នុងក្រុងបេត-អែល នារជ្ជកាលស្តេច យេរ៉ូបោម (មើលការពន្យល់ ខ.៧) តែក៏ជាការពិតផងដែរថា ចំពោះការថ្វាយបង្គំព្រះដទៃដែលស្តេចយេរ៉ូបោមបានបង្កើតឡើងជាលើកទី១ ដែលបន្តរហូតពេញក្រុងបេត-អែល ហើយដែលនៅទីបញ្ចប់ត្រូវបានត្រួតត្រាដោយស្តេចបាសា ។

**១៥:២៧** *គីបថោន* ក្រុងនេះ មានទីតាំងស្ថិតនៅចន្លោះក្រុងយេរូសាឡិម និងក្រុងយ៉ុបប៉េ ដែលស្ថិតនៅក្នុងទឹកដីកំណើត របស់ពួកកូនចៅដាន់ (យស ១៩:៤៣-៤៥) ។

**១៥:២៨** *ឆ្នាំទី៣* នេះគឺជាឆ្នាំទី ៩០៨ មុន គ.ស (សូមមើល ខ.១០) ។

**១៥:២៩** *តាមសេចក្តីដែលព្រះយេហូវ៉ាបានមានបន្ទូល ដោយសារអ័ហ៊ីយ៉ា* ចំពោះអត្ថន័យនៅក្នុងឃ្លានេះ សូមមើលក្នុង ១៤:១០-១១ ។ ចំពោះបទទំនាយរបស់ហោរាអ័ហ៊ីយ៉ាដែលនិយាយពីហេតុការណ៍នេះ សូមមើល ១ពវ ១៤:១២-១៤ ។

**១៥:៣០** *អំពើបាបដែលយេរ៉ូបោម... ពួកអ៊ីស្រាអែលព្រព្រឹត្តតាមដែរ* សូមមើលការពន្យល់ ១៤:១៦ ។

ពង្សាវតា[ង] របស់ពួកស្ដេចអ៊ីស្រាអែលហើយ ៣២ អេសា
និងបាសា ជាស្ដេចអ៊ីស្រាអែល ក៏ច្បាំងគ្នា[ច] ដរាបដល់អស់
ព្រះជន្ម ។

## បាសាស្ដេចលើស្រុកអ៊ីស្រាអែល

៣៣ លុះដល់ឆ្នាំទី៣ ក្នុងរាជ្យអេសា ជាស្ដេចយូដានោះ
បាសា ជាកូនអ័ហ៊ីយ៉ា ចាប់តាំងសោយរាជ្យលើស្រុក
អ៊ីស្រាអែលទាំងមូលនៅក្រុងធើសា[ឆ] ទ្រង់បានសោយ
រាជ្យអស់២៤ឆ្នាំ
៣៤ ទ្រង់ក៏ប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ជ]
នៅព្រះនេត្រព្រះយេហូវ៉ា ហើយបានប្រតិបត្តិតាមផ្លូវ និង
អំពើបាប ដែលយេរ៉ូបោមបានធ្វើ ជាការដែលនាំឱ្យពួក
អ៊ីស្រាអែលធ្វើបាបដែរ ។

**១៦** ១ នៅគ្រានោះព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់
យេហ៊ូវ[ក] ជាកូនហាណានី[ខ] ទាស់នឹងបាសាថា
២ ដោយព្រោះ
អញបានលើកឯងពីធូលីដីឡើង[គ] តាំងឱ្យធ្វើជាស្ដេច[ឃ] លើ
អ៊ីស្រាអែលជារាស្ត្រអញ តែឯងបានដើរតាមផ្លូវរបស់
យេរ៉ូបោមវិញ ព្រមទាំងបណ្ដាល[ង] ឱ្យអ៊ីស្រាអែល ជារាស្ត្រ
អញធ្វើបាបដែរ ជាការដែលនាំឱ្យអញខឹង ដោយសារ
អំពើបាបរបស់គេ
៣ នេះនែ អញនឹងបោសឯង[ច] នឹងពូជពង្ស
ឯងចេញអស់រលីង[ឆ] ឱ្យបានដូចជាពូជពង្សរបស់យេរ៉ូបោម
ជាកូននេបាតដែរ
៤ អ្នកណាក្នុងវង្សបាសាដែលស្លាប់នៅ
ក្នុងទីក្រុង នោះឆ្កែ[ជ] នឹងទំពាស៊ី ហើយអ្នកណាដែលស្លាប់នៅ
ទីវាល នោះសត្វហើរលើអាកាស[ឈ] នឹងចឹកស៊ីទៅ ។
៥ រីឯដំណើរឯទៀតពីបាសា ហើយការដែលទ្រង់ធ្វើ
នឹងពីអំណាចទ្រង់ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ
ជាពង្សាវតារ[ញ] របស់ពួកស្ដេចអ៊ីស្រាអែលហើយ
៦ បាសាក៏
ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ គេបញ្ចុះទ្រង់នៅ
ក្រុងធើសា[ដ] រួចអេឡាជាព្រះរាជបុត្រា ក៏សោយរាជ្យឡើង
ជំនួសបិតា
៧ ឯព្រះបន្ទូលនៃព្រះយេហូវ៉ា នោះបានសំដែង
មក[ឋ] ទាស់នឹងបាសា ហើយនិងព្រះរាជវង្សទ្រង់ដោយសារ
ហោរាយេហ៊ូវ[ឌ] ជាកូនហាណានី គឺដោយព្រោះការដ៏លា
មកអាក្រក់ទាំងប៉ុន្មាន ដែលទ្រង់បានប្រព្រឹត្តនៅព្រះនេត្រ
ព្រះយេហូវ៉ា ជាការដែលបណ្ដាលឱ្យទ្រង់ក្រោធដោយ
សារអំពើដែលបានធ្វើ ដោយប្រព្រឹត្តដូចជាព្រះវង្សា
យេរ៉ូបោមនោះ ហើយដោយព្រោះទ្រង់បានប្រហារជីវិត
គេថែមទៀត ។

## អេឡាស្ដេចស្រុកអ៊ីស្រាអែល

៨ លុះដល់ឆ្នាំទី២៦ ក្នុងរាជ្យអេសា ជាស្ដេចយូដានោះ
អេឡា ជាកូនបាសា ចាប់តាំងសោយរាជ្យឡើង លើស្រុក
អ៊ីស្រាអែលនៅក្រុងធើសា ក៏សោយរាជ្យបាន២ឆ្នាំ
៩ រួច

**១៥:៣១** ង ១ពវ ១១:៤១
**១៥:៣២** ច ខ.៦
**១៥:៣៣** ឆ ១ពវ ១៤:១៧ ១៦:៦,២៣ ២ពវ ១៥:១៤ ៦:៤
**១៥:៣៤** ជ ខ.២៦
**១៦:១** ក ខ.៧ ២រប ១៩:២ ២០:៣៤ ខ ២រប ១៦:៧
**១៦:២** គ ១សយ ២:៨ ឃ ១ពវ ១៤:៧–៩ ង ១ពវ ១២:៣០
**១៦:៣** ច ២ពវ ៩:៩ ឆ ខ.១១ ១ពវ ២១:២២
**១៦:៤** ជ ១ពវ ១៤:១១ ឈ លប ៤០:១៩
**១៦:៥** ញ ១ពវ ១៥:៣១
**១៦:៦** ដ ១ពវ ១៥:៣៣
**១៦:៧** ឋ ១ពវ ៦:១១ ឌ ខ.១

**១៥:៣១** *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្ដេចអ៊ីស្រាអែល* សូមមើលការពន្យល់ ១៤:១៩ ។

**១៥:៣២** *ច្បាំង . . . អស់ព្រះជន្ម* សូមមើល ខ.១៦ ។ ចម្បាំងនេះ បានបន្តរហូតដល់ទីបញ្ចប់នៃរាជ្យស្ដេចយេរ៉ូបោម ដែលនៅតែមិនអាចផ្សះផ្សាទំនាក់ទំនងចំពោះអាណាចក្រទាំងពីរនេះបានដដែល ។

**១៥:៣៣** *ឆ្នាំទី៣ក្នុងរាជ្យអេសា* នេះស្ថិតនៅក្នុងឆ្នាំទី ៩០៨ មុន គ.ស (មើលការពន្យល់ ខ.១០) ។ *ក្រុងធើសា* សូមមើលការពន្យល់ ១៤:១៧ ។ *២៤ឆ្នាំ* ឆ្នាំនេះស្ថិតនៅចន្លោះពី ៩០៨–៨៨៦ មុនគ.ស ។ ឆ្នាំដែលទ្រង់បានឡើងគ្រងរាជ្យត្រូវបានគេរាប់ថាមានចំនួន២៤ឆ្នាំ ប៉ុន្តែចំនួនពិតប្រាកដមានតែ២៣ ប៉ុណ្ណោះ (សូមមើល ១៦:៨ និងសេចក្ដីផ្ដើម) ។

**១៥:៣៤** *អំពើបាបដែលយេរូបោម . . . នាំឱ្យពួកអ៊ីស្រាអែលធ្វើបាប* ត្រង់នេះ សូមមើល ១៤:១៦ ។

**១៦:១** *យេហ៊ូវ* ស្ដេចអង្គនេះ មានលក្ខណៈដូចជាបិតារបស់ទ្រង់ (សូមមើល ២រប ១៦:៧–១០) ។ យេហ៊ូវ បាននាំនូវព្រះបន្ទូលរបស់ព្រះដើម្បីកាត់ទោសដល់ពួកស្ដេច ដូចក្នុងករណីអ្នកសំណប់ព្រះដែលមកពីស្រុកយូដា (មើលការពន្យល់ ១៣:១) និងក្រោយមកហោរាអេម៉ុសត្រូវបានបញ្ជូនចេញពីពីភាគខាងត្បូងទៅភាគខាងជើង ។ បេសកកម្ម របស់គាត់បានបន្តប្រហែលជា ៥០ឆ្នាំ គឺរហូតដល់រាជ្យស្ដេចយ៉ូសាផាតជាស្ដេចយូដា (មើល ២រប ១៩:២ ២០:៣៤) ។

**១៦:២** *អញបានលើកឯងពីធូលីដីឡើង* សូមធៀប ១៤:៧ ។ *ដើរតាមផ្លូវរបស់យេរ៉ូបោម* សូមមើលការពន្យល់ ១៤:១៦ ។

**១៦:៣** *អញនឹងបោសឯង នឹងពូជពង្សឯងចេញអស់រលីង* សូមធៀប ១៤:១០ (ពូជរបស់យេរ៉ូបោម) និង ២១:២១ (ពូជរបស់អ័ំរី និងអ័ហាប់) ។

**១៦:៤** នៅក្នុងខនេះគឺដូចគ្នាទាំងស្រុង ចំពោះការដែលពួកហោរា ប្រឆាំងជាមួយនឹងសន្តតិវង្សយេរ៉ូបោមដូចមាន ១៤:១១ ។

**១៦:៥** *ការដែលទ្រង់ធ្វើ* ចំពោះគោលបំណងរបស់អ្នកនិពន្ធកណ្ឌគម្ពីរនេះ សូមមើលសេចក្ដីផ្ដើម ត្រង់ចំណុចគោលរឿង ដែលការទាំងអស់នោះវាមិនមានសារៈសំខាន់ដែលបាសាបានធ្វើ ។ ស្ដេចអង្គនេះ បានទទួលជោគជ័យខ្លាំងក្នុងការដឹកនាំផ្នែកទស្សនៈយោធានយោបាយ ។ *សៀវភៅជាពង្សាវតាររបស់ពួកស្ដេចអ៊ីស្រាអែល* សូមមើលការពន្យល់ ១៤:១៩។

**១៦:៦** *ផ្ទំលក់ ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ* មើលការពន្យល់ ១:២១ ។

**១៦:៧** *ការដ៏លាមក . . . ព្រះវង្សាយេរ៉ូបោម* សូមមើល ខ.២ ១៥:៣៤ ។ *ទ្រង់បានប្រហារជីវិតគេ* ទោះបីបាសា បានបំពេញនូវគោលបំណងហាបូទ័យព្រះ (១៤:១០,១៤) ក្នុងការបំផ្លាញវង្សារបស់ស្ដេចយេរ៉ូបោម តែទ្រង់នៅតែរំលោភបំពានក្រឹត្យវិន័យរបស់ព្រះ (សូមធៀប លប ៥០:២០ អស ១០:៥–៧,១២) ។

**១៦:៨** *ឆ្នាំទី២៦ ក្នុងរាជ្យស្ដេចអេសា* ឆ្នាំនេះស្ថិតនៅក្នុង ៨៨៦ មុន គ.ស (សូមមើលការពន្យល់ ១៥:១០ និងសេចក្ដីផ្ដើម) ។ *២ឆ្នាំ* នេះនៅក្នុង ៨៨៦–៨៨៥ មុន គ.ស ។

**១៦:៩** *សោយស្រាស្រវឹង* នេះជាការពិតដែលថា លោកអេឡា បានស្រវឹង

សុីមរី ជាមេទ័ពរបស់ទ្រង់ ដែលត្រួតលើរទេះចំបាំងទ្រង់
ពាក់កណ្ដាល លោកបានក្បត់ទ្រង់ រីឯកាលទ្រង់គង់នៅ
ក្រុងធើសា កំពុងតែសោយស្រាស្រវឹង[ល] ក្នុងផ្ទះរបស់
អើសា ជាឧកញ៉ា[ណ]វាំងនៅក្រុងធើសា ១០នោះសុីមរីក៏ចូល
ទៅធ្វើគុកទ្រង់ ក្នុងឆ្នាំទី២៧នៃរាជ្យអេសា ជាស្តេចយូដា
រួចសោយរាជ្យឡើងជំនួសទ្រង់[ត] ។
១១លុះបានគង់លើបល្ល័ង្កសោយរាជ្យឡើងហើយ នោះក៏
ប្រហារជីវិតនៃវង្សានុវង្សរបស់បាសាទាំងអស់ទៅ[ថ] ឥតទុក
ពួកប្រុស១ ណាមួយខាងបាសា ទោះទាំងវង្សា ឬជាមិត្រ
សំឡាញ់របស់ទ្រង់ ឱ្យនៅសល់ឡើយ ១២គឺយ៉ាងនោះដែល
សុីមរីបានរំលាយពួកវង្សរបស់បាសាទាំងអស់ទៅ តាម
សេចក្តីដែលព្រះយេហូវ៉ាទ្រង់មានបន្ទូលទាស់នឹងបាសា
ដោយសាហោរាយេហ៊ូវ ១៣ដោយព្រោះអំពើបាបរបស់
បាសា និងអំពើបាបរបស់អេឡា ជាបុត្រទ្រង់ ដែលទ្រង់
បានប្រព្រឹត្ត ព្រមទាំងបណ្តាលឱ្យពួកអុីស្រាអែលធ្វើបាប
ដែរ ជាការដែលនាំឱ្យព្រះយេហូវ៉ា ជាព្រះនៃពួកអុីស្រា
អែល មានសេចក្តីក្រោធដោយសាររបស់ជាអាសាឥតការ
របស់គេ[ទ] ១៤រីឯដំណើរឯទៀតពីអេឡា និងការទាំងប៉ុន្មាន
ដែលទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជា
ពង្សាវតាររបស់ពួកស្តេចអុីស្រាអែលហើយ ។

## សុីមរី ស្តេចស្រុកអុីស្រាអែល

១៥លុះដល់ឆ្នាំទី២៧ ក្នុងរាជ្យអេសា ជាស្តេចយូដានោះ
សុីមរីបានសោយរាជ្យអស់៧ថ្ងៃ នៅក្រុងធើសា រីឯពួកពល
ទ័ព គេកំពុងតែច្បាំងនឹងគីបថោន[ធ] ជាទីក្រុងរបស់ពួក
ភីលីស្ទីន ១៦ហើយពួកទាំងនោះក៏ឮថា សុីមរីបានក្បត់ស្តេច
ហើយធ្វើគុតទ្រង់ផង ដូច្នេះ ពួកអុីស្រាអែល ទាំងអស់គ្នា
ក៏លើកអំរី ជាមេទ័ពធំតាំងឡើងជាស្តេចលើពួកអុីស្រា–
អែល នៅឯទីបោះទ័ពក្នុងថ្ងៃនោះឯង ១៧ដូច្នេះ អំរី និងពួក
អុីស្រាអែលទាំងអស់គ្នា ក៏ចេញពីក្រុងគីបថោនឡើង ទៅ
ឡោមព័ទ្ធក្រុងធើសាវិញ ១៨កាលសុីមរីបានឃើញថា គេ
ចាប់បានទីក្រុងហើយ នោះក៏ចូលទៅក្នុងដំណាក់ស្តេច ក្នុង
រាជវាំង រួចដុតដំណាក់ ហើយខ្លួនក៏ស្លាប់ក្នុងភ្លើងនោះទៅ
១៩ដោយព្រោះអំពើបាបដែលបានធ្វើ ដោយប្រព្រឹត្តលា
មកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ាព្រមទាំងដើរតាម
ផ្លូវនឹងអំពើបាប ដែលយេរ៉ូបោមបានធ្វើជាការដែលនាំឱ្យ
ពួកអុីស្រាអែលធ្វើបាបតាមដែរ ២០រីឯដំណើរឯទៀតពី
សុីមរី និងការដែលលោកក្បត់នោះសុទ្ធតែបានកត់ទុក
ក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអុីស្រាអែល
ហើយ ។

## អំរី ស្តេចស្រុកអុីស្រាអែល

២១គ្រានោះ ប្រជាជនទាំងឡាយ ជាសាសន៍អុីស្រាអែល
គេបែក គ្នាជា២ពួក ពួក១កាន់ខាងធីបនី ជាកូនគីណាត
ប្រាថ្នានឹងលើកឡើងជាស្តេច ហើយពួក១ទៀតកាន់ខាង
អំរី ២២តែបណ្តាជនដែលចូលដៃខាងអំរី គេឈ្នះពួកខាង
ធីបនីជាកូនគីណាត ដូច្នេះធីបនីក៏ស្លាប់ទៅ ហើយអំរី
សោយរាជ្យឡើង ២៣គឺនៅឆ្នាំទី៣១ ក្នុងរាជ្យអេសាជា

**១៦:៩** ល ១ពវ ២០:១២,១៦ សភ ៣១:៤–៥ ណ ១ពវ ១៨:៣
**១៦:១០** ត ២ពវ ៩:៣១
**១៦:១១** ថ ខ.៣
**១៦:១៣** ទ ចទ ៣២:២១
**១៦:១៥** ធ យស ១៩:៤៤

ស្រានៅក្រុងធើសា (Tirzah) ក្នុងខណៈដែលកងទ័ពកំពុងឡោមព័ទ្ធនៅគីបថោន (ខ.១៥) ដែលបញ្ជាក់ថាគាត់បានប្រាចាកពីភាពទទួលខុសត្រូវជាស្តេច ។

**១៦:១០** *ឆ្នាំទី២៧នៃរាជ្យអេសា* ឆ្នាំនៅក្នុង ៨៨៥ មុន គ.ស ។

**១៦:១១** *ប្រហារជីវិតនៃវង្សរបស់បាសាទាំងអស់ទៅ* សូមមើល ១៥:២៩ ២ពវ ១០:១–៧ ១១:១ ។ *មិត្រសំឡាញ់* នេះជាទីប្រឹក្សារបស់ស្តេច (សូមមើលការពន្យល់ ២សយ ១៥:៣៧) ។

**១៦:១២** *សេចក្តីដែលព្រះយេហូវ៉ា . . . ដោយសារហោរាយេហ៊ូវ* មើល ខ.១–៤ ។ នៅត្រង់នេះ សុីមរីបានសម្រេចចិត្តដោយមិនដឹងខ្លួន ដើម្បីឱ្យបទទំនាយរបស់ហោរាយេហ៊ូវបានសម្រេច ប៉ុន្តែការធ្វើដោយឥតមានចិត្តប៉ងនេះ បានធ្វើឱ្យការនេះសម្រេចតាមអ្វីដែលមាន(ក្នុងខ.៧) គឺនៅពេលដែលគាត់បានក្បត់នឹងអេឡា និងបំផ្លាញវង្សារបស់បាសា ។

**១៦:១៣** *បាបរបស់បាសា និងអំពើបាបអេឡា* សូមមើល ១៥:៣៤ ។ *របស់ជាអសារឥតការ* ការនេះនិយាយយោងទៅដល់ ការដែលពួកអុីស្រាអែលបានគោរពនូវសាសនាដទៃ ដែលរួមមានការថ្វាយបង្គំរូបគោមាស(សូមមើល ១២:២៨ ១៤:៩) ។

**១៦:១៤** *សៀវភៅ ជាពង្សាវតាររបស់ស្តេចពួកអុីស្រាអែល* សូមមើលការពន្យល់ ១៤:១៩ ។

**១៦:១៥** *ឆ្នាំទី២៧ ក្នុងរាជ្យអេសា* នេះសំដៅឆ្នាំ ៨៨៥ មុន គ.ស (សូមមើលការពន្យល់ ១៥:១,១០)។ *គីបថោន* សូមមើលការពន្យល់ ខ.៩ ១៥:២៧ ។

**១៦:១៦** *ក្បត់ស្តេច ហើយធ្វើគុតទ្រង់* សូមមើល ខ.៩–១២ ។ *អំរី ជាមេទ័ពធំ* នេះបញ្ជាក់ថា គាត់មានឋានៈធំជាងសុីមរី (សូមមើល ខ.៩) ។

**១៦:១៧** *ក្រុងធើសា* ក្រុងនេះជារាជាណាចក្រ(សូមមើល ខ.៨–១០ និងការពន្យល់បន្ថែម ១៤:៧) ។

**១៦:១៩** *ដើរតាមផ្លូវ និងអំពើបាបដែលយេរ៉ូបោមបានធ្វើ* សូមមើលការពន្យល់ ១៤:១៦ ។

**១៦:២០** *សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអុីស្រាអែល* សូមមើលការពន្យល់ ១៤:១៩ ។

**១៦:២២** *ធីបនីក៏ស្លាប់* ត្រង់នេះមិនបានបញ្ជាក់ច្បាស់ ថាមរណៈភាពធីបនីថាតើគាត់ស្លាប់ដោយលក្ខណៈធម្មជាតិ ឬជាលទ្ធផលនៃការតស៊ូក្នុងភាពជាទាហានដើម្បីការពារទឹកដី ។

**១៦:២៣** *ឆ្នាំទី៣១ ក្នុងរាជ្យអេសា* ឆ្នាំនេះត្រូវនឹង ៨៨០មុន គ.ស (សូមមើលការពន្យល់ ១៥:១០ និងមើលសេចក្តីផ្តើម) ។ *តាំងសោយរាជ្យ* គឺជាស្តេចតែមួយអង្គគត់ ។ ការតស៊ូដើម្បីការពារទឹកដីភាគខាងជើងរវាង អំរីនិង

ស្តេចយូដា ដែលអំរីចាប់តាំងសោយរាជ្យឡើងលើស្រុក
អ៊ីស្រាអែល ក៏សោយរាជ្យបាន១២ឆ្នាំ ទ្រង់សោយរាជ្យនៅ
ក្រុងធើសាបាន៦ឆ្នាំ[ន] ២៤រួចទ្រង់ទិញភ្នំសាម៉ារីពីសេមើរ
ដំឡៃ២ហាបប្រាក់ ទ្រង់ក៏សង់ទីក្រុង នៅលើភ្នំនោះឱ្យ
ឈ្មោះថា សាម៉ារី[ប] តាមឈ្មោះសេមើរជាម្ចាស់ភ្នំ ២៥ឯអំរី
ទ្រង់ប្រព្រឹត្តដ៏លាមកអាក្រក់[ប] នៅព្រះនេត្រព្រះយេហូវ៉ា
ក៏ធ្វើ អាក្រក់លើសជាងអស់អ្នកណាដែលនៅមុនទ្រង់ទៅ
ទៀត ២៦ដ្បិតទ្រង់បានប្រតិបត្តិតាមអស់ទាំងផ្លូវ នឹងអំពើបាប
របស់យេរ៉ូបោម ជាកូននេបាតជាអ្នកដែលបណ្តាលឱ្យ
ពួកអ៊ីស្រាអែលធ្វើបាបតាមដែរ គឺជាការដែលនាំឱ្យ[ផ] ព្រះ
យេហូវ៉ា ជាព្រះនៃពួកអ៊ីស្រាអែលមានសេចក្តីក្រោធ
ដោយសាររបស់ជាអសារឥតការរបស់គេ[ព] ២៧រីឯដំណើរ
ឯទៀត ដែលអំរីធ្វើនឹងអំណាចទ្រង់នោះសុទ្ធតែបានកត់ទុក
ក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែល

**១៦:២៣** ន យស ១២:២៤ ១ពវ ១៥:៣៣
**១៦:២៤** ប ១ពវ ១៣:៣២ មថ ១០:៥
**១៦:២៦** ផ ១ពវ ១៥:៣០ ព ចទ ៣២:២១
**១៦:២៨** ភ ១ពវ ១៣:៣២
**១៦:៣០** ម ១ពវ ១៤:៩
**១៦:៣១** យ ១ពវ ១១:២ រ ពច ៣:៦ ២ពវ ៩:៣៤ ល ពច ២:១១

ហើយ ២៨អំរីផ្ទំលក់ទៅជាមួយនឹងពួកព្ទយុកោទ្រង់ទៅ
ហើយគេបញ្ចុះទ្រង់នៅក្នុងក្រុងសាម៉ារី[ភ] រួចអ័ហាប់ជាព្រះ
រាជបុត្រាបានសោយរាជ្យឡើងជំនួសបិតា ។

## អ័ហាប់ឡើងជាស្តេចស្រុកអ៊ីស្រាអែល

២៩លុះដល់ឆ្នាំទី៣៨ ក្នុងរាជ្យអេសា ជាស្តេចយូដានោះ
អ័ហាប់ជាបុត្រអំរី ចាប់តាំងសោយរាជ្យឡើងលើស្រុក
អ៊ីស្រាអែល ទ្រង់គ្រងរាជ្យលើពួកអ៊ីស្រាអែល នៅក្រុង
សាម៉ារីបាន២២ឆ្នាំ ៣០អ័ហាប់ ជាបុត្រអំរី ទ្រង់ប្រព្រឹត្ត
លាមកអាក្រក់នៅព្រះនេត្រព្រះយេហូវ៉ា លើសជាង[ម]អស់
អ្នកណាដែលនៅមុខទ្រង់ទៅទៀត ៣១ទ្រង់ក៏យក[យ]នាងយេសិ
បិលជាបុត្រីអេតបាល[រ] ស្តេចពួកស៊ីដូន ធ្វើជាភរិយាព្រម
ទាំងទៅគោរពប្រតិបត្តិថ្វាយបង្គំដល់ព្រះបាលផង ទុកដូច
ជាការ ដែលទ្រង់ប្រព្រឹត្ត តាមអំពើបាបរបស់យេរ៉ូបោម[ល]
ជាបុត្រនេបាតនោះ ជាការយ៉ាងស្រាលវិញ ៣២ទ្រង់ក៏ស្អាង

ធីបនី បានបន្តរអស់រយៈពេល៤ឆ្នាំ (សូមផ្ទៀប ខ.នេះ ជាមួយនឹង ខ.១៥) ។ *១២ឆ្នាំ* នេះស្ថិតនៅក្នុងឆ្នាំ ៨៨៥–៨៧៤ មុន គ.ស ។ ឆ្នាំទាំង១២ នៃរាជ្យអំរី គឺរួមបញ្ចូលនូវរយៈពេល៤ឆ្នាំនៃការតស៊ូរវាងអំរី និងធីបនី (ផ្ទៀប ខ.១៥,២៩) ។ *ក្រុងធើសា* មើលការពន្យល់ ១៤:១៧ ។

**១៦:២៤** *សាម៉ារី* នៅត្រង់នេះ ជាទីក្រុងអំរីថ្មី ហើយក្រុងនេះបានផ្តល់នូវភាពសំខាន់ខ្លះៗក្នុងផ្នែកនយោបាយ ។ ហើយក្រុងនេះ ជាកម្មសិទ្ធផ្ទាល់របស់គាត់ ដូច្នេះតំបន់នេះត្រូវបានគាត់គ្រប់គ្រងទាំងមូល ។ ក្រុងនេះ ជាបញ្ជាការលើកំពូលភ្នំ ដែលមានភាពងាយស្រួលក្នុងការការពារ នៅពេលមានសត្រូវឡោមព័ទ្ធ ។ *អំរី* បានស្លាប់មុនពេលបញ្ចប់ការកសាងទីតាំងនេះ ដូច្នេះហើយ អ័ហាប់ដែលជាកូនជាអ្នកបញ្ចប់កិច្ចការនេះ ។ អ្វីដែលគាត់ បានសាងសង់នៅទីនេះ គឺមិនគ្រាន់តែជាដំណាក់ភ្លុកប៉ុណ្ណោះទេ តែក៏ជាវិហាររបស់ព្រះបាល (មើល ១ពវ ២២:៣៩ អម ៣:១៥) ។

**១៦:២៥** *ធ្វើអាក្រក់លើសជាងអស់អ្នកណា* នៅក្នុងចំណុចនេះបង្ហាញពីសម្ព័ន្ធមិត្រដែលអំរីមានជាមួយនឹងអេតបាល ក្រុងទីរ៉ុស និងស៊ីដូន ដែលឈានទៅរកការពង្រីកនូវប្រព័ន្ធថ្វាយបង្គំរូបព្រះនៅភាគខាងជើង (មើល ខ.៣១–៣៣) ហើយជាចុងក្រោយឈានដល់ការបញ្ចប់សន្តតិវង្សស្តេចដាវីឌនៅភាគខាងត្បូងនៃអាណាចក្រនេះ (មើល ២ពវ ១១ បន្ថែមការពន្យល់ ២ពវ ៨:១៨) ។ សម្ព័ន្ធនៃការរៀបអភិសេកដើម្បីភ្ជាប់ពីទំនាក់ទំនងគ្នាត្រូវបានបង្កើតឡើងនៅក្នុងរាជ្យស្តេចអំរី (មើលពន្យល់ ខ.២៣) ហើយប្រហែលជាការពង្រឹងអំណាចរបស់ខ្លួនដើម្បីតតាំងនឹងពួកធីបនី (ខ.២១–២២) ។

**១៦:២៦** *អំពើបាប . . . អ៊ីស្រាអែលធ្វើបាប* សូមមើលការពន្យល់ ១៤:១៦ ។ *ជាអសារឥតការ* សូមមើល ខ.១៣ ។

**១៦:២៧** *ដំណើរឯទៀត ដែលអំរីធ្វើ* នៅក្នុងចំណុចនេះ បានប្រាប់ថាទាហានរបស់អំរី និងការសម្រេចខាងផ្នែកនយោបាយរបស់គាត់ គឺមិនមានសារៈសំខាន់ចំពោះអ្នកនិពន្ធនៃកណ្ឌគម្ពីរនេះទេ (មើល សេចក្តីផ្តើម និងខ្លឹមសារ) ។ ផ្នែកមួយនៃការស្ថាបនាក្រុងសាម៉ារីដែលជាក្រុងនៅភាគខាងជើងនៃអាណាចក្ររបស់គាត់ ហើយគ្រប់ការទាំងអស់នេះ ដែលបានរៀ-បរាប់នៅក្នុងព្រះគម្ពីរហើយ ទើបធ្វើឱ្យគាត់ត្រូវបានស្គាល់ ថាជាអ្នករៀបចំនូវរចនាសម្ព័ន្ធគ្រប់គ្រងនៅភាគខាងជើង ដែលជាទីដែលអ័ហាប់ជាកូនរបស់គាត់បានដឹកនាំ (មើល ២០:១៤–១៥) ។

**១៦:២៨** *ផ្ទំលក់ទៅ ជាមួយបិតានឹងពួកព្ទយុកោទ្រង់* មើល ១:២១ ។

**១៦:២៩** *ឆ្នាំទី៣៨ ក្នុងរាជ្យអេសា* ឆ្នាំនេះស្ថិតនៅក្នុង ៨៧៤ មុន គ.ស (មើលការពន្យល់ ១៥:៩–១០) ។ **២២ឆ្នាំ** ស្ថិតនៅក្នុង ៨៧៤–៨៥៣ មុន គ.ស ។

**១៦:៣០** *លាមកអាក្រក់ . . . លើសជាង . . . អ្នកណាដែលនៅមុនទ្រង់ទៀត* នេះបញ្ជាក់ថា អំរីបានប្រព្រឹត្តអំពើបាបលើសជាងអ្នកពីមុនៗមក (សូមមើល ខ.២៥) និងអ័ហាប់បានធ្វើបាបលើសជាងបិតាទ្រង់ទៅទៀត ។ អំពើបាបបានឆ្លងរីករាលដាលយ៉ាងអាក្រក់នៅក្នុងអាណាចក្រភាគខាងជើងនេះ ។ ស្ទើតែមួយភាគបីនៃការពិពណ៌នានៅក្នុង ១,២ពវ បញ្ជាក់រយៈពេល៣៤ឆ្នាំនៃរាជ្យស្តេច អ័ហាប់ និងបុត្រារបស់ទ្រង់ពីរអង្គទៀត នោះគឺអ័ហាស៊ីយ៉ា និងយ៉ូរ៉ាម ។ នៅក្នុងអំឡុងពេលនេះ វាជាការតស៊ូរវាង អាណាចក្ររបស់ព្រះ និងអាចក្ររបស់អារក្សសាតាំងយ៉ាងខ្លាំងក្លាបំផុត ។

**១៦:៣១** *យេសិបិល ជាបុត្រីអេតបាល ស្តេចពួកស៊ីដូន ធ្វើជាភរិយា* នៅសតវត្សរ៍ទី១នៃប្រវត្តិសាស្ត្រពួកយូដាតាមរយៈសៀវភៅលោក យ៉ូសែប (Josephus) សំដៅលើអេតបាលបានឡើងគ្រងរាជ្យធ្វើជាស្តេចបានដឹកនាំនៅក្រុង ទីរ៉ុស និងស្រុកស៊ីដូនអស់រយៈពេល៣២ឆ្នាំ ។ អ័ហាប់ បានរៀបអភិសេកជាមួយនឹងព្រះនាងយេសិបិល នៅក្នុងរាជ្យនៃបិតារបស់ទ្រង់ (មើល ខ.២៥) ។ *ព្រះបាល* រូបព្រះនេះប្រហែលជាគេបានគោរពនៅក្នុងក្រុងទីរ៉ុស ដែលការថ្វាយបង្គំរូបព្រះនេះ បានហូរចូលទៅដល់ពួកអ៊ីស្រាអែលដោយសារតែព្រះនាងយេសិបិលនេះឯង ។ រូបព្រះនេះ ប្រហែលជាទ្រង់ធ្លាប់បានចូលរួមថ្វាយបង្គំ នៅក្នុងពេលដែលរៀបអភិសេក ។ ចំពោះបុត្រទាំងពីររបស់ស្តេចអ័ហាប់គឺ អ័ហាស៊ីយ៉ា មានន័យថា "អំណោយរបស់ព្រះអម្ចាស់" និងយ៉ូរ៉ាមថា "ព្រះអម្ចាស់លើក ឡើង" ដែលត្រង់នេះបញ្ជាក់ថាស្តេចអ័ហាប់មិនមានគោលបំណងផ្លាស់ប្តូរការថ្វាយបង្គំព្រះអម្ចាស់នៃយើងទៅ ថ្វាយបង្គំរូបព្រះបាលនោះទេ ប៉ុន្តែជាការបញ្ចូលគ្នាឱ្យទៅជាតែមួយ ។

អាសនាមួយ[រ] ថ្វាយព្រះបាលនៅក្នុងវិហារ[ស] ព្រះបាលដែល
ទ្រង់បានស្អាងនៅក្នុងសាម៉ារី ៣៣ អ័ហាប់ទ្រង់ធ្វើរូបព្រះ[ហ]
ហើយប្រព្រឹត្តអំពើអាក្រក់ លើសជាង[ឡ]អស់ទាំងស្ដេច ដែល
នៅមុនទ្រង់ទៅទៀត ជាការដែលបណ្ដាលឱ្យព្រះយេហូវ៉ា
ជាព្រះនៃពួកអ៊ីស្រាអែលមានសេចក្ដីក្រោធ ៣៤ នៅក្នុងរាជ្យ
ទ្រង់ នោះហ៊ីអែល ជាអ្នកក្រុងបេត-អែល ក៏សង់ក្រុង
យេរីខូរឡើងវិញ កាលគាត់ដាក់ជើងកំផែងចុះ នោះអ័ប៊ី
រ៉ាម ជាកូនច្បងក៏ស្លាប់ទៅ ហើយការរៀបចំទ្វារក្រុង
ឡើង នោះសេគូបជាកូនពៅក៏ស្លាប់ទៅ តាមសេចក្ដីដែល
ព្រះយេហូវ៉ាបានមានបន្ទូល ដោយសារយ៉ូស្វេជាកូននុន[អ] ។

## លោកអេលីយ៉ារស់ដោយសត្វក្អែកចិញ្ចឹម

**១៧** ១ គ្រានោះ អេលីយ៉ា[ក] ជាអ្នកស្រុកធេសប៊ី ដែលនៅជា
មួយនឹងពួកស្រុកកាឡាត[ខ] លោកទូលនឹងអ័ហាប់ថា ទូលបង្គំ
ស្បថ ដោយនូវព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
ដ៏មានព្រះជន្មរស់ ដែលទូលបង្គំឈរនៅចំពោះទ្រង់នេះថា
ក្នុងប៉ុន្មានឆ្នាំទៅមុខនេះនឹងគ្មានភ្លៀង[គ] គ្មានសន្សើមឡើយ
វៀរតែដោយសារពាក្យទូលបង្គំប៉ុណ្ណោះ ២ រួចព្រះបន្ទូល
នៃព្រះយេហូវ៉ាក៏មកបង្គាប់លោកថា ៣ ចូរចេញពីទីនេះ
បែរទៅខាងកើត ហើយពួន[ឃ]ខ្លួននៅឯជ្រោះកេរីត ដែល
នៅប្រទល់មុខនឹងទន្លេយ័រដាន់ទៅ ៤ ឯងនឹងផឹកទឹកពីជ្រោះ
នោះ ហើយអញបានបង្គាប់ឱ្យក្អែក[ង]ចិញ្ចឹមឯងនៅទីនោះ
ដែរ ៥ ដូច្នេះ លោកក៏ធ្វើតាមព្រះបន្ទូលនៃ ព្រះយេហូវ៉ាគឺ
ទៅអាស្រ័យនៅក្បែរជ្រោះកេរីត ដែលនៅប្រទល់មុខ
ទន្លេយ័រដាន់ ៦ ហើយរាល់ព្រឹក[ច]រាល់ល្ងាច ក្អែកតែងពាំ
នំបុ័ងនឹងសាច់មកជូនលោក លោកក៏ផឹកទឹកពីជ្រោះនោះ ។

## ស្ត្រីមេម៉ាយនៅសារិបតា

៧ លុះកន្លងយូរបន្តិចមក ទឹកជ្រោះក៏រីងទៅពីព្រោះមិន
មានភ្លៀងធ្លាក់នៅស្រុកនោះសោះ ។
៨ នោះព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកបង្គាប់លោកថា

**១៦:៣២** រ ពច ៦:២៨ ស ២ពវ ១០:២១,២៧ ១១:១៨ យរ ៤៣:១២ **១៦:៣៣** ហ ពច ៣:៧ ២ពវ ១៣:៦ ឡ ១ពវ ១៤:៩ ២១:២៥ **១៦:៣៤** អ យស ៦:២៦ **១៧:១** ក មឡ ៤:៥ មថ ១១:១៤ ១៧:៣ ខ ពច ១២:៤ គ ចទ ១១:១៧ ២៨:២៤ ២សយ ១:២១ ១ពវ ៨:៣៦ យប ១២:១៥ លក ៤:២៥ **១៧:៣** ឃ ១ពវ ១៨:៤,១០ យរ ៣៦:១៩,២៦ **១៧:៤** ង លប ៨:៧ **១៧:៦** ច នក ១៦:៨

**១៦:៣២** *ស្អាងអាសនាមួយថ្វាយព្រះបាល . . . នៅក្រុងសាម៉ារី* នៅត្រង់នេះបង្ហាញថា ស្ដេចអ័ហាប់បាននាំរូបព្រះបាលរបស់យេសិបិលដែលជាអគ្គមហេសីរបស់ខ្លួនចូលក្នុងទឹកដីភាគខាងជើង ហើយបានស្អាងព្រះវិហារនៅក្នុងក្រុងសាម៉ារី គឺដូចដែលស្ដេចសាឡូម៉ូនបានស្អាងវិហារនៅយេរូសាឡិមដើម្បីថ្វាយព្រះអម្ចាស់នៃយើងដែរ ។ ព្រះវិហារដែលស្ដេចអ័ហាប់ បានសង់ថ្វាយព្រះបាលនេះក្រោយមកត្រូវយេហ៊ូវបំផ្លាញ (២ពវ ១០:២១-២៧) ។

**១៦:៣៣** *លើសអស់ជាងស្ដេច* សូមមើលការពន្យល់ ខ.៣០ ។ ស្ដេចអ័ហាប់បានទទួលយកការថ្វាយបង្គំរូបព្រះបាលនេះ នៅភាគខាងជើងជាផ្លូវការនៅក្នុងរជ្ជកាលនៃ ការចាប់ផ្ដើមរបស់ទ្រង់ ។

**១៦:៣៤** *សង់ក្រុងយេរីខូឡើងវិញ* នៅត្រង់នេះមិនមានន័យថា ក្រុងយេរីខូនៅតែមិនមានមនុស្សរស់នៅ នៅអំឡុងពេលដែលលោកយ៉ូស្វេបានបំផ្លាញ (សូមមើល ១៨:២១ ពច ១:១៦ ៣:១៣ ២សយ ១០:៥) ប៉ុន្តែវាជា ក្រុងឬភូមិដែលគ្មានជញ្ជាំងប៉ុណ្ណោះ ។ នៅក្នុងរជ្ជកាលរបស់ស្ដេចអ័ហាប់ កំផែងក្រុងជញ្ជាំងក្រុង និងរបងត្រូវបានសាងសង់ជាថ្មីឡើងវិញម្ដងទៀត (មើល យស ៩:១៧ សម្រាប់សេចក្ដីស្រដៀងគ្នានៃការសាងសង់នេះផងដែរ) ។ ការទាស់ប្រឆាំងនឹងបំណងរបស់ព្រះដែលបំផ្លាញក្រុងយេរីខូរ គឺជាការរំលឹកអំពីការចងចាំជារៀងរហូត ដែលពួកអ៊ីស្រាអែលបានទទួលទឹកដីកាណានពីព្រះហស្តរបស់ព្រះទុកជាព្រះគុណ ។ ហេតុដូច្នេះហើយកំផែងនេះ បានទទួលរងនូវបណ្ដាសាដែលលោកយ៉ូស្វេបានប្រកាសនៅក្នុង (យស ៦:២៦) ។

**១៧:១–២ពវ ៨:១៥** វគ្គនេះរៀបរាប់អំពីភារកិច្ចរបស់ អេលីយ៉ា និងអេលីសេ ហើយនិងពួកហោរាផ្សេងៗទៀតដែលមកពីរាជ្យស្ដេចអ័ហាប់ស្ដេចអេសា យ៉ូរ៉ាម យេហូសាផាត ។

**១៧:១** *អេលីយ៉ា* ឈ្មោះរបស់លោកអេលីយ៉ាមានន័យថា"ព្រះអម្ចាស់គឺជាព្រះរបស់ទូលបង្គំ" ។ ហោរាម្នាក់នេះ គឺជាមនុស្សដែលមានសារៈសំខាន់ដែលព្រះអម្ចាស់បានបញ្ជូនគាត់ទៅស្រុកអ៊ីស្រាអែល និងយូដា ។ ទឹកដីអ៊ីស្រាអែលភាគខាងជើង មិនមានស្ដេចដែលមានភាពស្មោះត្រង់ ហើយស្ដេចទាំងនោះមានភាពកម្សោយ រហូតដល់បានដឹកនាំពួករាស្ត្រទាំងអស់នោះឱ្យថ្វាយបង្គំរូបព្រះ ។

**១៧:៣** *ចេញពីទីនេះ* ពាក្យនេះបង្ហាញថា ព្រះអម្ចាស់បានដកហោរានិងរាស្ត្ររបស់ទ្រង់ឱ្យចេញពីទឹកដីនេះដោយទុកឱ្យពួកគេនៅឯកកោ គឺព្រះអម្ចាស់បានដកយកពីការទាំងអស់នេះ តាមរយៈបន្ទូលនិងព្រះពរដែលព្រះទ្រង់ធ្លាប់បានប្រទានឱ្យពួកគេ ។ លើសពីនេះទៀត អវត្តមានរបស់ពួកហោរានៅត្រង់នេះ បញ្ជាក់អំពីការជំនុំជម្រះមួយដល់ពួកគេ ។

**១៧:៤** *ក្អែកចិញ្ចឹមឯងនៅទីនោះ* ត្រង់នេះហោរាអេលីយ៉ាដែលជាអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះ ដែលគាត់ត្រូវបានព្រះយេហូវ៉ាគាំទ្រ និងថែរក្សាគាត់នៅពេលគាត់មានវត្តមាននៅតាមដងទន្លេយ័រដាន់ (ដូចពួកអ៊ីស្រាអែលនៅក្នុងទីរហោស្ថានដែលលោកម៉ូសេជាអ្នកដឹកនាំពួកគេ) ដែលក្នុងអំឡុងពេលដែលពួកអ៊ីស្រាអែលចូលទៅក្នុងទឹកដីសន្យា ហើយកំពុងស្រេកឃ្លាន ។ ចំណុចនេះក៏អាចនិយាយថា ពួកអ៊ីស្រាអែលពេលនោះ គឺមានការទាស់ប្រឆាំងនិងរូបព្រះបាល ។ *ក្អែក* សត្វនេះរស់នៅដោយសារស៊ីបក្សីនិងសត្វផ្សេងៗទៀតដែលងាប់ដែលគេឃើញមាននៅតាមវាល និងទីសត្តឃាត ។ ពីព្រោះតែ សត្វនេះស៊ីសត្វដែលងាប់នៅទីនោះ ហើយគេអាចរកឃើញវាហើរក្រវិលសាកសពសត្វអត្តឃាតទាំងអស់នោះ ដូច្នេះទីនេះហើយដែលលោកអេលីយ៉ាអាចលាក់ខ្លួនដោយមានសុវត្ថភាព ។ សត្វនេះជាទម្លាប់គឺពាំចំណីរនៅទីខ្ពស់ៗ ។

**១៧:៦** *សាច់* នៅត្រង់នេះបញ្ជាក់ថា សាច់របស់វាមិនត្រូវបានគេបរិភោគ (លវ ១១:១៥ ចទ ១៤:១៤) ហើយក្នុងការបរិភោគសត្វនេះត្រូវហាមឃាត់ជាដាច់ខាត(លវ ៧:២៤ ចទ ១៤:២១ អគ ៤:១៤) ។ *រាល់ព្រឹករាល់ល្ងាច* នេះបញ្ជាក់ថា គាត់បានទទួលទានអាហារដែលសត្វក្អែកពាំមកឱ្យគាត់មួយថ្ងៃពីរដងដោយគាត់មិនបាន និយាយឬធ្វើអ្វីសោះ ដូច្នេះអាហារនេះវាមិនមែនសម្រាប់មនុស្សសាមញ្ញនោះទេ ។

៩ចូរក្រោកឡើង ទៅឯសារិបតា[ឆ] ជាទីក្រុងរបស់ពួកស៊ីដូន
អាស្រ័យនៅទីនោះវិញចុះ អញបានបង្គាប់ស្រីមេម៉ាយម្នាក់[ជ]
នៅទីនោះឱ្យចិញ្ចឹមឯង ១០ដូច្នេះ លោកក៏ក្រោកឡើងទៅ
ឯក្រុងសារិបតា កាលបានទៅដល់មាត់ទ្វារក្រុងហើយ
នោះឃើញមានស្រីមេម៉ាយម្នាក់ កំពុងតែរើសរំកាច់ឈើ
លោកក៏ហៅនាងថា សូមយកទឹកក្នុងផ្តិលមកឱ្យខ្ញុំផឹកបន្តិច[ឈ]
១១កាលនាងកំពុងតែទៅយកទឹក នោះលោកស្រែកផ្តាំថា
សូមយកនំបុ័ងបន្តិចមកឱ្យខ្ញុំផង ១២តែនាងឆ្លើយថា ខ្ញុំស្បថ
ដោយនូវព្រះយេហូវ៉ា ជាព្រះនៃអ្នកដ៏មានព្រះជន្មរស់នៅ
ថា ខ្ញុំគ្មាន១ដុំឡើយ មានតែម្សៅ១ក្តាប់ នៅក្នុងខាប់ និង
ប្រេង[ញ]បន្តិចបន្តួចនៅដបប៉ុណ្ណោះមើលនែ ខ្ញុំកំពុងតែរើស
រំកាច់ឈើ២នេះ ដើម្បីចូលទៅចំអិនសំរាប់ខ្ញុំនឹងកូន យើង
នឹងបរិភោគតែប៉ុណ្ណោះ រួចស្លាប់ទៅ ១៣តែអេលីយ៉ាប្រាប់
នាងថា កុំឱ្យខ្លាចឡើយ សូមទៅធ្វើដូចជាអ្នកបានថាចុះ តែ
សូមធ្វើនំ១យ៉ាងតូច មកឱ្យខ្ញុំជាមុនសិន រួចសឹមធ្វើសំរាប់
អ្នកនឹងកូនអ្នកចុះ ១៤ដ្បិតព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា ម្សៅក្នុងខាប់នោះនឹង
មិនដែលផុតទៅ ហើយប្រេងក្នុងដបក៏មិនដែលរលោះ
ឡើយ ដរាបដល់ថ្ងៃដែលព្រះយេហូវ៉ានឹងបង្អុរភ្លៀង[ដ]មក
លើផែនដី ១៥ដូច្នេះ នាងក៏ទៅធ្វើតាមបង្គាប់របស់អេលីយ៉ា
រួចទាំងនាង និងលោក ព្រមទាំងកូននាងគ្រប់គ្នាបាន
បរិភោគតមកជាយូរថ្ងៃ ១៦ឯម្សៅក្នុងខាប់នោះ មិនដែល
អស់ទៅ ហើយប្រេងក្នុងដបក៏មិនចេះរលោះឡើយ ដូច
ជាសេចក្តីដែលព្រះយេហូវ៉ាបានមានបន្ទូល ដោយសារ
អេលីយ៉ា ។

១៧ក្រោយនោះមក មានកាល១ថ្ងៃ កូនរបស់នាងម្ចាស់ផ្ទះ
នោះចាប់ជំងឺឈឺ ជំងឺនោះមានទំងន់ណាស់ ដល់ម្ល៉េះបាន
ជាគ្មានដង្ហើមក្នុងខ្លួនទៀតឡើយ ១៨ដូច្នេះ នាងនិយាយទៅ
អេលីយ៉ាថា ឱអ្នកសំណប់របស់ព្រះអើយ តើខ្ញុំនឹងលោក
មានការណ៍អ្វីនឹងគ្នា លោកបានមកឯណេះ ដើម្បីរំឭកពី

**១៧:៩** ឆ អប ១:២០ ជ លក ៤:២៦
**១៧:១០** ឈ លប ២៤:១៧ យហ ៤:៧
**១៧:១២** ញ ២ពវ ៤:២
**១៧:១៤** ដ ខ.១

**១៧:៩** *សារិបតា ជាទីក្រុងរបស់ពួកស៊ីដូន* ក្រុងនេះ នៅជាប់ទីរ៉ុស និងក្រុងស៊ីដូន ដែលគ្រប់គ្រងដោយព្រះនាងយេសិបិល (១៦:៣១) ។ នៅគ្រានេះ លោកអេលីយ៉ា ត្រូវបានបញ្ជូនចេញឱ្យទៅរស់នៅជាមួយនឹងពួកដែលថ្វាយបង្គំរូបព្រះបាល ហើយដែលពេលនោះព្រះបាលកំពុងតែត្រូវគេបានលើកតម្កើងនៅក្នុងចំណោមពួកអ៊ីស្រាអែល ។ *អញបានបង្គាប់ស្រីមេម៉ាយ ម្នាក់នៅទីនោះ ឱ្យចិញ្ចឹមឯង* ដូចដែលយើងធ្លាប់ដឹងថា គាត់ជាអ្នកនាំសាររបស់ព្រះ អញ្ចឹងហើយបណ្តាជនគេបានផ្គត់ផ្គង់គាត់គ្រប់យ៉ាង ប៉ុន្តែពួកគេក៏កំពុងប្រឈមមុខនឹងគ្រោះអត់ឃ្លានដែរ (ខ.១២) ។ រីឯស្ត្រីមេម៉ាយ ម្នាក់នេះវិញ គាត់មិនមែននៅក្នុងវង្សជារាស្ត្ររបស់ព្រះ (ធៀប លក ៤:២៥-២៦) ហើយក៏មិនដើរ តាមគោលជំនឿរបស់ព្រះ ហើយថែមទាំងប្រឆាំងនឹងរាស្ត្ររបស់ព្រះផងដែរ ។

**១៧:១០** *លោកក៏ក្រោកឡើង* ការរស់នៅពឹងលើព្រះអម្ចាស់របស់លោកអេលីយ៉ា បានបង្ហាញពីសេចក្តីជំនឿរបស់គាត់ ថាពួកអ៊ីស្រាអែលត្រូវតែរស់នៅដោយពឹងអាងដល់ព្រះយ៉ាងដូចគាត់ដែរ ។

**១៧:១២** *ជាព្រះនៃអ្នកដ៏មានព្រះជន្មរស់នៅ* ឃ្លានេះបានប្រាប់អំពីពាក្យសម្បថ របស់ស្ត្រីនេះ នៅក្នុងព្រះយេហូវ៉ា ចំពោះទីស្នាក់អាស្រ័យដែលគាត់ផ្តល់ជូនលោកអេលីយ៉ា ដែលនាងចាត់ទុកគាត់ថាជាពួកអ៊ីស្រាអែល (មើលការពន្យល់ ៥:៧ ១០:៩) ហើយនាងក៏បានបូជានូវចំណេះដឹង និងប្តេជ្ញាដើរតាមព្រះរបស់ពួកអ៊ីស្រាអែលដែរ ។

**១៧:១៣** *ធ្វើនំ១យ៉ាងតូច . . . សំរាប់អ្នក និងកូនអ្នកចុះ* នៅក្នុងខ.នេះ គ្រប់ពាក្យរបស់លោកអេលីយ៉ា ជាសេចក្តីបង្គាប់របស់ព្រះជាអម្ចាស់ ។ ស្ត្រីមេម៉ាយ បានបរិច្ចាកនូវអ្វីៗដែលគាត់មាន ដល់អ្នកនាំសាររបស់ព្រះ នោះមានសារៈសំខាន់ ចំពោះសេចក្តីសញ្ញារបស់ព្រះដែលពួកអ៊ីស្រាអែល បានបំភ្លេចចោលនោះផងដែរ ។

**១៧:១៤** *ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូល* ត្រង់នេះ ការដែលលោកអេលីយ៉ាប្រាប់ស្ត្រីមេម៉ាយថា "កុំឱ្យខ្លាយឡើយ" នោះពីព្រោះតែការបង្គាប់សេចក្តីសញ្ញានោះ មិនត្រូវបានផ្តល់ឱ្យដោយគ្មានការសន្យានោះទេ ពោលគឺព្រះអម្ចាស់ទ្រង់មិនសុំ ច្រើនជាងការសន្យាថាទ្រង់នឹងប្រទានពរឱ្យយើងនោះទេ ។

**១៧:១៥** *នាងក៏ទៅធ្វើតាមបង្គាប់របស់អេលីយ៉ា* នេះជាការប្រព្រឹត្តតាមសេចក្តីជំនឿរបស់ស្ត្រី នោះនាងក៏ទទួលបានព្រះពរសន្យាមកអំពីទ្រង់ ។ ព្រះអម្ចាស់ទ្រង់មិនសុំអ្វីច្រើនជាងអ្វីដែលទ្រង់ប្រទានឱ្យតាមរយៈការសន្យារបស់ទ្រង់នោះទេ ។

**១៧:១៥** *នាងក៏ទៅធ្វើតាមបង្គាប់របស់អេលីយ៉ា* ដោយសេចក្តីជំនឿដែលនាងបានធ្វើ នោះនាងក៏ទទួលបានព្រះពរសន្យា ។ ពួកអ៊ីស្រាអែល បានលះចោលសេចក្តីសន្យារបស់ព្រះដោយវិលបែរទៅគោរពព្រះបាលវិញក្នុងន័យដែលគេគិតថាខ្ពង់ខ្ពស់និងប្រសើរ ។ មកដល់ត្រង់នេះ ជាងពាក់កណ្តាលនៃអាណាចក្រពួកប្រឆាំងដែលជាស្ត្រីមេម៉ាយ បានដឹងថា ការគោរព និងប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះគឺជាមធ្យោបាយមួយសម្រាប់ដឹកនាំជីវិតពួកគេឱ្យបានល្អប្រសើរ ។

**១៧:១៦** *ម្សៅក្នុងខាប់នោះ មិនដែលអស់ទៅ* នៅត្រង់នេះ ព្រះអម្ចាស់ទ្រង់បានធ្វើការអស្ចារ្យដោយផ្តល់ម្សៅឱ្យពួកដែលមិនមែនជាអ៊ីស្រាអែល ដោយសារការប្រព្រឹត្តតាមនូវព្រះបន្ទូលរបស់ពួកគេ ។ ព្រះអម្ចាស់បានប្រទានដល់ពួកគេនូវនំម៉ាន៉ាពីស្ថានសួគ៌មក ក្នុងខណៈដែលទ្រង់បានបង្អត់ពួកអ្នកដែលគ្មានសេចក្តីជំនឿក្នុងទឹកដីសន្យានោះផងដែរ ។ ចំពោះសេចក្តីព្រមាននៅក្នុង ចទ ៣២:២១ ត្រូវបានសម្រេច (ធៀប រម ១០:១៩ ១១:១១,១៤) ។

**១៧:១៨** *បានមកឯណេះ ដើម្បីរំឭកពីអំពើបាបរបស់ខ្ញុំ ហើយនឹងសំឡាប់កូនខ្ញុំឬ* ឃ្លានេះស្ត្រីមេម៉ាយបានសន្និដ្ឋានថា វត្តមានរបស់លោកអេលីយ៉ាដែលចូលមកក្នុងផ្ទះនាង នោះជាការយកព្រះទ័យទុកដាក់របស់ព្រះចំពោះអំពើបាបរបស់នាង និងការស្លាប់របស់កូនប្រុសរបស់នាងដែលនាងសន្មតថាជាការដាក់ទោសរបស់គាត់ចំពោះអំពើបាបរបស់កូននោះ ។ ទោះបី ទោស

អំពើបាប[ឋ]របស់ខ្ញុំ ហើយនឹងសំឡាប់កូនខ្ញុំឬ ១៩ តែលោក
ឆ្លើយតបថា សូមឱ្យកូនអ្នកមកខ្ញុំចុះ រួចលោកក៏ទទួលកូនពី
ទ្រូងនាងបីឡើងចូលទៅក្នុងបន្ទប់ដែលលោកអាស្រ័យនៅ
ហើយផ្តេកនៅលើដំណេករបស់លោក ២០ រួចអំពាវនាវ[ឌ]
ដល់ព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ាជាព្រះនៃទូលបង្គំអើយ
តើទ្រង់បាននាំសេចក្តីអាក្រក់មកលើស្រីមេម៉ាយនេះ ដែល
ទូលបង្គំអាស្រ័យនៅជាមួយដោយសំឡាប់កូននាងដែរឬ
២១ លោកក៏ទ្រោប[ឍ]លើកូននោះ៣ដង ទាំងអំពាវនាវដល់
ព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ
សូមឱ្យព្រលឹងរបស់កូននេះ ត្រឡប់ចូលមកក្នុងខ្លួនវាវិញចុះ
២២ ព្រះយេហូវ៉ាទ្រង់ស្តាប់តាមអេលីយ៉ា ហើយព្រលឹងរបស់
កូននោះ ក៏ត្រឡប់ចូលមកក្នុងខ្លួនវា ឱ្យរស់ឡើងវិញ ២៣ នោះ
អេលីយ៉ាក៏បីកូននោះចុះពីបន្ទប់មក ចូលទៅក្នុងផ្ទះប្រគល់
ដល់ម្តាយ[ណ]វិញ ដោយពាក្យថា មើល កូនអ្នកមានជីវិតរស់
២៤ នាងនិយាយឡើងថា ឥឡូវនេះខ្ញុំដឹង[ត]ហើយថា លោកជា
អ្នកសំណប់របស់ព្រះពិត[ថ] ហើយថា ព្រះបន្ទូលនៃព្រះ
យេហូវ៉ា ដែលនៅមាត់លោក នោះជាសេចក្តីពិតមែន[ទ] ។

## លោកអេលីយ៉ា និងលោកអូបាឌា

**១៨** ១ កាលកន្លងមកជាយូរហើយ គឺដល់ឆ្នាំទី៣[ក]នោះព្រះ
បន្ទូលនៃព្រះយេហូវ៉ាបានមកដល់អេលីយ៉ាថា ចូរទៅ
បង្ហាញខ្លួន[ខ]ឱ្យអ័ហាប់ឃើញ នោះអញនឹងបង្អុរឱ្យភ្លៀង[គ]
ធ្លាក់ចុះមកលើផែនដី ២ ដូច្នេះ អេលីយ៉ាក៏ទៅ ដើម្បីបង្ហាញ
ខ្លួនដល់អ័ហាប់ រីឯនៅស្រុកសាម៉ារី មានអំណត់អត់ជាខ្លាំង
ណាស់[ឃ] ៣ ចំណែកអ័ហាប់ទ្រង់ហៅអូបាឌា ជាឧកញ៉ា[ង]វាំង
មក (រីឯអូបាឌានេះ លោកកោតខ្លាចដល់ព្រះយេហូវ៉ា
ណាស់[ច] ៤ ដ្បិត កាលយេសិបិល[ឆ]បានសំឡាប់ពួកហោរានៃ
ព្រះយេហូវ៉ា នោះលោកក៏នាំយកពួកហោរានោះ១០០នាក់
ទៅបំពួន[ជ]នៅក្នុងរអាង ក្នុង១ពួក៥០នាក់ ហើយបាន
ចិញ្ចឹម[ឈ]ដោយនំបុ័ងនឹងទឹក) ៥ អ័ហាប់មានបន្ទូលទៅ
អូបាឌាថា ចូរឯងទៅឯអស់ទាំងរន្ធទឹក[ញ] នឹងជ្រោះទឹកទាំង
អស់ ដែលនៅក្នុងស្រុក ប្រហែលជាយើងនឹងរកបានស្មៅ
ល្មមនឹងចិញ្ចឹមសេះ ហើយនិងលាកាត់ឱ្យរស់នៅបាន ដើម្បី
កុំឱ្យហ្វូងសត្វស្លាប់ទៅទាំងអស់ឡើយ[ដ] ៦ ដូច្នេះ គេក៏ចែក
ស្រុកគ្នា ដើម្បីនឹងដើរទៅមក គឺអ័ហាប់បានដើរផ្លូវ១តែឯង
ទៅ ហើយអូបាឌាក៏ទៅតាមផ្លូវ១ទៀតតែឯងដែរ ។

**១៧:១៨** ឋ លក ៥:៨
**១៧:២០** ឌ ២ពវ ៤:៣៣
**១៧:២១** ឍ ២ពវ ៤:៣៤ កច ២០:១០
**១៧:២៣** ណ ហព ១១:៣៥
**១៧:២៤** ត យហ ១៦:៣០ ថ ខ.១៨ ទ ១ពវ ២២:១៦ ទដ ១១៩:៤៣ យហ ១៧:១៧
**១៨:១** ក ១ពវ ១៧:១ លក ៤:២៥ ខ ខ.១៥ គ ចទ ២៨:១២
**១៨:២** ឃ លវ ២៦:២៦
**១៨:៣** ង ១ពវ ១៦:៩ ច នហ ៧:២
**១៨:៤** ឆ ១ពវ ២១:២៣ ២ពវ ៩:៧ ជ ១ពវ ១៧:៣ អស ១៦:៣ ២៥:៤ ៣២:២ អប ១:១៤ ឈ យរ ២៦:២៤ **១៨:៥** ញ យរ ១៤:៣ ដ លប ៤៧:៤

កំហុសរបស់នាង បានទទួលឥទ្ធិពលមកពីគំនិតពួកសាសន៍ដទៃ ប៉ុន្តែទាំងគាត់ និងលោកអេលីយ៉ាគឺស្ថិតក្នុងស្ថានភាពសំណួរមួយដែលចោទថា តើការសន្យាថានឹងប្រទានជីវិតឱ្យនោះនៅឯណា? ហើយហេតុអ្វីបានជាទ្រង់ដកជីវិតគេទៅវិញយ៉ាងដូច្នេះ?

**១៧:២១** *ទ្រោបលើកូននោះ៣ដង* ទង្វើនេះធ្វើឡើងក្នុងគោលបំណង ឱ្យរាងមានការប្រែប្រួលត្រឡប់ទៅជាមានភាពកក់ក្តៅ និងជាការកែប្រែស្ថានភាពក្មេងនេះឱ្យបានរស់ឡើងវិញរបស់ហោរា ។ ទោះបីសេចក្តីអធិស្ឋានរបស់ហោរាអេលីយ៉ា បានបង្ហាញពីការជឿជាក់ថាកូននេះនឹងបានរស់ឡើងវិញក៏ដោយ ក៏គាត់នៅមិនបោះបង់ចោលការធ្វើចលនាលើរាង្គកាយក្មេងនោះដែរ ។ *សូមឱ្យព្រលឹងរបស់កូននេះ ត្រឡប់ចូលមកក្នុងខ្លួនវាវិញ* នេះជាការហៅព្រលឹងរបស់គាត់ដោយសេចក្តីជំនឿ ដូចដែលលោកអ័ប្រាហាំបានធ្វើនៅក្នុង (រម ៤:១៧ ហព ១១:១៩) ។ លោកអេលីយ៉ា បានអធិស្ឋានសុំឱ្យក្មេងនេះមានជីវិតឡើងវិញនោះ ដូច្នេះការនេះបញ្ជាក់ថា ការពោលនូវពាក្យពិត និងទុកចិត្តដល់ព្រះ នោះការអស្ចារ្យរបស់ព្រះនឹងបើកសម្តែងឱ្យឃើញដូចអ្វីដែលបានសូម ។

**១៧:២២** *ព្រលឹងរបស់ក្មេងនោះ ក៏ត្រឡប់ចូលក្នុងខ្លួនវា* គម្រូនៃសេចក្តីស្លាប់បានកត់ត្រានៅក្នុងបទគម្ពីរ ។ ស្ត្រីមេម៉ាយដែលមិនមែនជាសាសន៍អ៊ីស្រាអែល បានទទួលនូវព្រះពរដ៏ធំមហិមា គឺអំណោយជីវិតដែលរួចផុតពីអំណាចនៃសេចក្តីស្លាប់ ក្នុងខណៈដែលកូនប្រុសរបស់គាត់បានរស់ឡើងវិញ ហើយនេះជាសេចក្តីសង្ឃឹមតែមួយគត់ សម្រាប់ស្ត្រីមេម៉ាយនៅបុរាណកាលនោះផងដែរ (២ពវ ៤:១៤ នរ ១:១១-១២ ៤:១៥-១៧ លក ៧:១២) ។

**៧:២៤** *លោកជាអ្នកសំណប់របស់ព្រះ* ការពន្យល់ ១សយ ២:២៧ ។ ស្ត្រីមេម៉ាយបានហៅគាត់ថាជាអ្នកសំណប់ព្រះតាំងតែពីនៅក្នុង (ខ.១៨) ប៉ុន្តែត្រង់នេះស្ត្រីនេះគាត់បានដឹងបន្ថែមទៀតថា លោកអេលីយ៉ាជាហោរារបស់ព្រះដ៏ពិត (មើលការពន្យល់ ១២:២២) ។ *ព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលនៅមាត់លោក នោះជាសេចក្តីពិតមែន* ព្រះអម្ចាស់ទ្រង់ បានប្រើការនេះដើម្បីឱ្យពួកស្ត្រីមេម៉ាយដែលមិនមែនជារាស្ត្រអ៊ីស្រាអែល ដែលការនេះពិតជាអាចជឿបាន ។ ម្យ៉ាងទៀត ការលន់តួបាបរបស់នាង គឺជាអ្វីដែលរាស្ត្ររបស់ព្រះនៅអ៊ីស្រាអែល បានលះចោល ។

**១៨:១** *ឆ្នាំទី៣* រយៈកាលនេះជាឆ្នាំរាំងស្ងួត ។ ក្រោយមកប្រពៃណីពួកយូដាបានកំណត់ឆ្នាំរាំស្ងួតថា មានរយៈពេលបីឆ្នាំកន្លះ (ធៀប លក ៤:២៥ យក ៥:១៧) ប៉ុន្តែឆ្នាំនេះ តំណាងឱ្យភាពអំណត់វិញ (ជាងប្រាំពីរឆ្នាំ មើល ៤១:២៧ ២ពវ ៨:១) ។ *ទៅបង្ហាញខ្លួនឱ្យអ័ហាប់ឃើញ នោះអញនឹងបង្អុរភ្លៀងធ្លាក់ចុះមកលើផែនដី* លោកអេលីយ៉ាមានការស្តាយក្រោយដោយមិនទៅឯអ៊ីស្រាអែលវិញ ប៉ុន្តែលោកស្តាប់បង្គាប់ដលព្រះអម្ចាស់ថា តើនរណាមួយក្នុងចំណោមព្រះមហាក្សត្រដែលមានភាពច្បាស់លាស់ក្នុងការបរិហារខ្លួនឯងជាថ្មីចំពោះបណ្តាលជន ។

**១៨:៣** *អូបាឌា* ឈ្មោះនេះមាននិយាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយមានន័យថា "អ្នកបម្រើព្រះអម្ចាស់" ។ *ឧកញ៉ាវាំង* មើលការពន្យល់ ៤:៦ ។

**១៨:៥** ការប្រឈរមុខចំពោះការអត់អាហារនេះមិនបានធ្វើឱ្យអ័ហាបមានការស្តាយក្រោយក្នុងការផ្លាស់ប្តូរទីកន្លែងនោះឡើយ (អ័ហាប់បានទទួលចម្លើយផ្ទុយគ្នាពីស្តេចដាវីឌចំពោះការអត់អាហារនេះ ២សយ ២១:១) ។ ប៉ុន្តែ នៅពេលដែលការច្បាំងរបស់គាត់ធ្វើឱ្យអន្តរាយនោះ គាត់បានធ្វើឱ្យដីបង្កើតផលផ្លែ ជាម្ហូបអាហារ និងទឹក (មើល ១០:២៦) ។

[៧]កាលអូបាឌាកំពុងតែដើរទៅ នោះអេលីយ៉ាមកប្រទះ
ហើយ លោកក៏ស្គាល់[ឋ]អេលីយ៉ា រួចក្រាបផ្កាប់មុខចុះសួរថា
នេះគឺលោកអេលីយ៉ា ជាម្ចាស់ខ្ញុំឬអី [៨]លោកឆ្លើយតបថា គឺ
ខ្ញុំនេះហើយ សូមទៅទូលចៅហ្វាយអ្នកថា មើល អេលីយ៉ា
មកហើយ [៩]តែអូបាឌាប្រកែកថា តើខ្ញុំបានធ្វើបាបអ្វីបានជា
លោកចង់ប្រគល់ខ្ញុំប្របាទទៅក្នុងកណ្ដាប់ដៃនៃអ័ហាប់ ឱ្យ
សំឡាប់ខ្ញុំដូច្នេះ [១០]ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ជាព្រះនៃ
លោកដ៏មានព្រះជន្មរស់នៅថា គ្មានសាសន៍ណា ឬនគរណា
មួយដែលចៅហ្វាយខ្ញុំមិនបានចាត់គេឱ្យទៅរក[ឌ]លោកនោះ
ឡើយ ហើយកាលណាគេថា លោកមិននៅទីនេះទេ នោះ
ទ្រង់ក៏ឱ្យពួកសាសន៍នោះ ឬនគរនោះស្បថថា គេមិនបាន
ឃើញលោកមែន [១១]ឥឡូវនេះលោកមានប្រសាសន៍ថាសូម
ទៅទូលចៅហ្វាយរបស់អ្នកថា មើល អេលីយ៉ាមកហើយ
[១២]រួចកាលណាខ្ញុំចេញពីលោកទៅ នោះព្រះវិញ្ញាណ[ឍ]នៃ
ព្រះយេហូវ៉ានឹងយកលោកទៅកន្លែងណាក៏មិនដឹង ដូច្នេះ
កាលខ្ញុំទៅទូលដល់អ័ហាប់ ហើយទ្រង់រកលោកមិនឃើញ
នោះទ្រង់នឹងសំឡាប់ខ្ញុំចោល ប៉ុន្តែខ្ញុំប្របាទនេះបានកោត
ខ្លាចដល់ព្រះយេហូវ៉ា តាំងតែពីក្មេងមក [១៣]តើគេមិនបាន
ជំរាបដល់លោកជាម្ចាស់ខ្ញុំទេឬអី ពីការដែលខ្ញុំបានធ្វើ ក្នុង
កាលដែលយេសិបិលសំឡាប់ពួកហោរានៃព្រះយេហូវ៉ាថា
ខ្ញុំបានបំពួនពួកហោរានៃព្រះយេហូវ៉ា ចំនួន១០០នាក់នៅ
ក្នុងរអាងភ្នំក្នុង១ពួក១៥០នាក់ ព្រមទាំងចិញ្ចឹមគេ ដោយ
នំបុ័ងហើយនឹងទឹកផង [១៤]ឥឡូវនេះលោកមានប្រសាសន៍
ឱ្យខ្ញុំទៅទូលថ្វាយថា មើលអេលីយ៉ាមកហើយ ដូច្នេះ ទ្រង់
នឹងសំឡាប់ខ្ញុំជាមិនខាន [១៥]តែអេលីយ៉ាតបថា ខ្ញុំស្បថដោយ
នូវព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារដ៏មានព្រះជន្ម
រស់នៅដែលខ្ញុំឈរ[ណ]នៅចំពោះទ្រង់ដែរថា នៅថ្ងៃនេះ ខ្ញុំ
នឹងបង្ហាញខ្លួន ឱ្យស្ដេចឃើញជាពិតប្រាកដ ។

**លោកអេលីយ៉ានៅលើភ្នំកើមែល**

[១៦]ដូច្នេះ អូបាឌាក៏ទៅជួបនឹងអ័ហាប់ ទូលឱ្យទ្រង់ជ្រាប
រួចអ័ហាប់ ទ្រង់យាងទៅជួបនឹងអេលីយ៉ា [១៧]កាលអ័ហាប់
ឃើញអេលីយ៉ាហើយ នោះទ្រង់មានបន្ទូលសួរថា ឱអ្នក
ដែលធ្វើឱ្យមានសេចក្ដីវេទនា[ត] ដល់ពួកអ៊ីស្រាអែលអើយ
តើឯងឬអី [១៨]តែលោកឆ្លើយថា ទូលបង្គំមិន បានធ្វើឱ្យពួក
អ៊ីស្រាអែលមានសេចក្ដីវេទនាទេ គឺទ្រង់[ថ]និងវង្សានុវង្សនៃ
ព្រះបិតាទ្រង់វិញទេតើ ពីព្រោះទ្រង់បានបោះបង់ចោល[ទ]
អស់ទាំងបញ្ញត្តនៃព្រះយេហូវ៉ា ព្រមទាំងប្រតិបត្តិតាមព្រះ
បាលវិញ [១៩]ដូច្នេះ ឥឡូវនេះសូមចាត់គេទៅប្រមូល[ធ]ពួក
អ៊ីស្រាអែលទាំងអស់គ្នាមកឯទូលបង្គំ នៅត្រង់ភ្នំកើមែល[ន]
ព្រមទាំងពួកហោរានៃព្រះបាលទាំង៤៥០នាក់ និងពួក
ហោរានៃរូបព្រះទាំង៤០០នាក់ ដែលបរិភោគនៅតុរបស់
ព្រះនាងយេសិបិលមកផង[ប] ។
[២០]អ័ហាប់ក៏ចាត់គេឱ្យទៅឯពួកកូនចៅអ៊ីស្រាអែលទាំង
អស់បានប្រមូលទាំងពួកហោរាមកឯភ្នំកើមែលដែរ[ផ] [២១]រួច
អេលីយ៉ាក៏ចូលទៅជិត ពួកជនសួរថា តើអ្នករាល់គ្នា នៅតែ

**១៨:៧** ឋ ២ពវ ១:៨ សក ១៣:៤ **១៨:១០** ឌ ១ពវ ១៧:៣ **១៨:១២** ឍ ២ពវ ២:១៦ អគ ៣:១៤ កច ៨:៣៩ **១៨:១៥** ណ ឧ.១ **១៨:១៧** ត យស ៧:២៥ ១សយ ១៤:២៩ ១ពវ ២១:២០ យរ ៣៨:៤ **១៨:១៨** ថ ១ពវ ១៦:៣១,៣៣ ២១:២៥ ទ ចទ ៣១:១៦ **១៨:១៩** ធ ២ពវ ១០:១៩ ន យស ១៩:២៦ ប ២ពវ ៩:២២ **១៨:២០** ផ ២ពវ ២:២៥ ៤:២៥

**១៨:៨** *ទៅទូលចៅហ្វាយអ្នកថា មើល អេលីយ៉ាមកហើយ* សកម្មភាពនេះបង្ហាញថា លោកអូបាឌា និងហោរាអេលីយ៉ាមានភាពជិតស្និទ្ធនឹងគ្នា ដែលផ្ទុយស្រឡះពីកាលដែលលោកអូបាឌាបានធ្វើការងារសំងាត់ឱ្យហោរាយេសិបិលពីមុនមកនោះវិញ (មើល ខ.៤,១៣) ។

**១៨:១២** *ព្រះវិញ្ញាណនៃព្រះយេហូវ៉ា នឹងយកលោកទៅកន្លែងណាក៏មិនដឹង* ឃ្លានេះបានប្រាប់ថា ភាពបាត់ខ្លួនអេលីយ៉ាយ៉ាងឆាប់រហ័ស ហើយបានលេចមកវិញ នោះបញ្ជាក់ថាលោកអូបាឌាសដែលព្រះវិញ្ញាណរបស់ព្រះបានលើកគាត់ឡើង(សូមមើល ២:១៦) ។

**១៨:១៣** *យេសិបិលសំឡាប់ ពួកហោរានៃព្រះយេហូវ៉ា* ត្រង់នេះបញ្ជាក់ថាទង្វើរបស់គាត់ដើម្បីផ្គាប់ចិត្តដល់ព្រះបាល ដើម្បីឱ្យបានភ្លៀងធ្លាក់មក ។ *ពួកហោរានៃព្រះយេហូវ៉ា* សូមមើលការពន្យល់ ២០:៣៥ ។

**១៨:១៧** *ឱអ្នកដែលធ្វើឱ្យមានសេចក្ដីវេទនា ដល់ពួកអ៊ីស្រាអែលទេឬអើយ* នៅត្រង់នេះអ័ហាប់ បានស្ដីបន្ទោសដល់អេលីយ៉ាដែលបណ្ដាឱ្យមានគ្រោះរាំងស្ងួត ហើយគាត់បានចោទប្រកាន់លោកអេលីយ៉ាថា បានប្រព្រឹត្តបទឧក្រិដ្ឋ ចំពោះប្រទេសជាតិ ដែលសមនឹងកាត់ទោសប្រហារជីវិត (មើល យស ៧:២៥)

**១៨:១៨** *ទ្រង់បានបោះបង់ចោលអស់ទាំងបញ្ញត្តនៃព្រះយេហូវ៉ា ព្រមទាំងប្រតិបត្តិតាមព្រះបាលវិញ* ឃ្លានេះបញ្ជាក់ពីបុព្វហេតុនៃទុក្ខវេទនារបស់ពួកអ៊ីស្រាអែលថា មិនមែនមកពីលោកអេលីយ៉ា ឬភាពរាំងស្ងួតទេ គឺមកអំពីភាពមិនស្មោះត្រង់របស់លោកអ័ហាប់នៅចំពោះព្រះយេហូវ៉ាវិញ ។

**១៨:១៩** *ភ្នំកើមែល* កំពូលភ្នំនេះជាប់នឹងមហាសមុទ្រមេឌីទែរ៉ានេ ហើយជាទីដែលទទួលរងនូវភាពរាំងស្ងួតតិចតួចបំផុត(មើល អម ១:២) ហើយក៏ជាកន្លែងដែលឥទ្ធិពលនៃព្រះបាលមានឥទ្ធិពលលើជីវិតរបស់មនុស្សយ៉ាខ្លាំងបំផុត ។ *ពួកហោរានៃព្រះបាល . . . ពួកហោរានៃរូបព្រះ* មើល ខ.២៩ និងការពន្យល់ ។ *តុរបស់ព្រះនាងយេសិបិល* មើលការពន្យល់ ២:៧ ។

**១៨:២១** នៅក្នុងវគ្គនេះ លោកអេលីយ៉ាបានប្រើគ្រប់មធ្យោបាយដើម្បីឱ្យពួកគេក្រោកឈរ ហើយដើរតាមព្រះពិតវិញ ។ សំណួរសួរថា តើហេតុអ្វីបានជាមនុស្សមួយចំនួនមានការស្ទាក់ស្ទើរ ហើយជ្រើសរើសយកផ្លូវពីរ? ពីព្រោះមានអ្នកខ្លះ គេមិនប្រាកដច្បាស់ពីអ្វីដែលគេដឹង ឬស្គាល់នោះ ។ នៅក្នុងចំណុចនេះ ក៏មានអ្នកខ្លះបានដឹងថា ព្រះអម្ចាស់ជាព្រះដ៏ពិតក៏ដោយ ក៏គេនៅតែរីករាយជាមួយនឹងអំពើរបាប និងផលប្រយោជន៍ដែលគេបានមកពីការដើរតាមលោកអ័ហាប់ដែលគាត់ជាអ្នកភាពកំផិតក្នុងការថ្វាយបង្គំរូបព្រះនោះ ។ ចំណុចដែលមានរៀបរាប់មកខាងលើនេះ គឺចង់បញ្ជាក់ថាគឺវាមានសារៈសំខាន់ណាស់ចំពោះព្រះអម្ចាស់ ហើយប្រសិនបើយើងភ្លាត់

ស្ទាក់ស្ទើរ[ព]នាកណ្ដាលផ្លូវ២នេះ ដល់កាលណាទៀត បើ
ព្រះយេហូវ៉ា[ភ]ទ្រង់ជាព្រះ នោះចូរដើរតាមទ្រង់ទៅ តែបើ
ព្រះបាលជាព្រះវិញ នោះចូរប្រតិបត្តិតាមចុះ តែពួក
បណ្ដាជនមិនបានឆ្លើយ សូម្បី១ម៉ាត់ឡើយ ២២ នោះអេលីយ៉ា
មានប្រសាសន៍ទៅបណ្ដាជនថា ក្នុងពួកហោរានៃព្រះ
យេហូវ៉ា នោះសល់នៅតែខ្ញុំម្នាក់ឯងទេ[ម]ឯហោរារបស់ព្រះ
បាលវិញ មានចំនួន៤៥០នាក់[យ] ២៣ ដូច្នេះ សូមយកគោ
ឈ្មោល២មកឱ្យយើង ឱ្យគេរើសយក១សំរាប់ពួកគេ ហើយ
កាប់ជាដុំៗដាក់លើឱសទៅ តែកុំឱ្យដាក់ភ្លើងឡើយ រួចខ្ញុំ
នឹងរៀបគោ១ទៀតដាក់លើឱសឥតដាក់ភ្លើងដែរ ២៤ ហើយ
ចូរឱ្យអ្នករាល់គ្នាអំពាវនាវ[រ]ដល់ព្រះនាមព្រះយេហូវ៉ាវិញ[ល]
បើព្រះណាឆ្លើយមកដោយសារភ្លើង[វ] នោះចូរឱ្យរាប់ព្រះ
នោះទុកជាព្រះពិតចុះ ពួកបណ្ដាជនទាំងឡាយក៏ឆ្លើយឡើង
ថា ស្រួលហើយ ។
២៥ [ឝ]ដូច្នេះ អេលីយ៉ាក៏ប្រាប់ដល់ពួកហោរារបស់ព្រះបាល
ថា ចូររើសគោ១សំរាប់អ្នករាល់គ្នាចុះ ហើយរៀបដាក់ជា
មុនទៅ ដ្បិតខាងអ្នករាល់គ្នាច្រើន រួចចូរអំពាវនាវដល់
ព្រះនាមនៃព្រះរបស់អ្នករាល់គ្នាចុះ តែកុំឱ្យដាក់ភ្លើងឡើយ
២៦ គេក៏ទទួលយកគោ១ ដែលបានឱ្យដល់គេ រួចគេរៀបចំ
ហើយអំពាវនាវ[ស]ដល់ព្រះនាមនៃព្រះបាល ចាប់តាំងពីព្រឹក
រហូតដល់ថ្ងៃត្រង់ថា ឱព្រះបាលអើយ សូមឆ្លើយមកយើងខ្ញុំ
រាល់គ្នាផង ប៉ុន្តែគ្មានឮសំឡេង ឬចំឡើយណាឆ្លើយមក

**១៨:២១** ព យស ២៤:១៥ ២ពវ ១៧:៤១ ទដ ១១៩:១១៣ មថ ៦:២៤ ភ ខ.៣៩ ទដ ១០០:៣ ១១៨:២៧ **១៨:២២** ម ១ពវ ១៩:១០ យ យរ ២:៨ ២៣:១៣ **១៨:២៤** រ ១សយ ៧:៨ ល លប ៤:២៦ វ ខ.៣៨ នក ១៩:១៨ លវ ៩:២៤ **១៨:២៦** ស អស ៤៤:១៧ ៤៥:២០ ហ ទដ ១១៥:៤-៥ ១៣៥:១៦ អស ៤១:២៦,២៨ ៤៦:៧ យរ ១០:៥ ១កថ ៨:៤ ១២:២ **១៨:២៧** ឡ ហព ២:១៩ **១៨:២៨** អ លប ១៩:២៨ **១៨:២៩** ក នក ២៩:៤១ ខ ២ពវ ១៩:១២ អស ១៦:១២ យរ ១០:៥

សោះ[ហ] គេក៏លោតព័ទ្ធជុំវិញអាសនា ដែលគេបានធ្វើនោះ
២៧ គ្រាដល់ពេលថ្ងៃត្រង់ហើយ នោះអេលីយ៉ាពោលចំអក
ថា ចូរស្រែកឱ្យខ្លាំងឡើង ដ្បិតលោកជាព្រះ ប្រហែល
ជាកំពុងរំពឹងគិតឬបានថយចេញ១ភ្លែត ឬធ្វើដំណើរ ឬ
ប្រហែលជាដេកលក់ទេដឹង ត្រូវដាស់លោកឡើង[ឡ] ២៨ គេក៏
ស្រែកខ្លាំងឡើង ព្រមទាំងយកកាំបិតឆូតសាច់[អ]តាមទំលាប់
របស់គេទាល់តែឈាមហូរប្រឡាក់កាយ ២៩ លុះកាលហួស
ថ្ងៃត្រង់ហើយ នោះគេក៏ថ្វាយបង្គំ រហូតដល់ពេលថ្វាយ
ដង្វាយល្ងាច[ក] តែគ្មានឮសំឡេង ឬចំឡើយណាឆ្លើយមក
សោះ ក៏គ្មានអ្នកណាស្ដាប់ផង[ខ] ។
៣០ បន្ទាប់នោះ អេលីយ៉ាមានប្រសាសន៍ទៅបណ្ដាជនថា
សូមចូលមកជិតខ្ញុំវិញ ជនទាំងឡាយក៏អែបចូលមកជិត
លោក រួចលោកជួសជុលអាសនា[គ]នៃព្រះយេហូវ៉ាដែល
បានរំលំហើយ ៣១ អេលីយ៉ាលោកយកថ្ម១២តាមចំនួនពូជ
អំបូរពួកកូនចៅយ៉ាកុប ដែលព្រះបន្ទូលនៃព្រះយេហូវ៉ា
បានមកដល់លោកនោះថា ឈ្មោះឯងត្រូវហៅថា អ៊ីស្រា–
អែលវិញ[ឃ] ៣២ លោកក៏យកថ្មទាំងនោះ ស្អាងអាសនា១ថ្វាយ
ព្រះនាម[ង]ព្រះយេហូវ៉ា ក៏ជីកប្រឡាយព័ទ្ធជុំវិញ មានទំហំ
ល្មមដាក់ពូជស្រូវ២រង្វាល់ ៣៣ រួចលោកដាក់[ច]ឱសជាលំដាប់
ក៏កាប់គោនោះជាដុំៗ ដាក់ពីលើ ហើយប្រាប់ថា ចូរដងទឹក

**១៨:៣០** គ ១ពវ ១៩:១០ **១៨:៣១** ឃ លប ១៧:៥ ២ពវ ១៧:៣៤ **១៨:៣២** ង ចទ ១៨:៧ កល ៣:១៧ **១៨:៣៣** ច លប ២២:៩

ដួលដើរតាមព្រះដែលយើងគិតថាអាចធ្វើឱ្យយើងរីករាយ ឬងាយស្រួល នោះថ្ងៃមួយយើងនឹងបែរទៅជាថ្វាយបង្គំព្រះខុសឆ្គងវិញ ។

**១៨:២២** *សល់នៅតែខ្ញុំម្នាក់ឯងទេ* ឃ្លានេះ បានប្រាប់ថា យ៉ាងហោចណាស់ក៏មានម្នាក់ដែលហ៊ានឈរតតាំងនឹងពួកស្ដេច និងហោរារបស់ពួកព្រះបាល (ប៉ុន្តែ សូមមើល ខ.៤ ១៩:១០,១៤ ២០:១៣,២៨,៣៥ ២២:៦,៨ ធៀប ១៩:១៨ និងការពន្យល់ រម ១១:៤) ។

**១៨:២៤** *អំពាវនាវ* សូមមើលការពន្យល់ ទដ ១១៨:៥ ។ *ព្រះណាឆ្លើយដោយសារភ្លើង–នោះចូររាប់ព្រះនោះទុកជាព្រះពិត* នៅត្រង់ចំណុចនេះ បញ្ជាក់ថា ទាំងព្រះអម្ចាស់ និង ព្រះបាល សុទ្ធតែបានយកពពកធ្វើជារថ (សូមមើល ទដ ១០៤:៣ និងការពន្យល់) ពពកជាសម្លេង(មើល ទដ ២៩:៣–៩ និងការពន្យល់) ផ្លេកបន្ទោលជាភ្លើង និងអាវុធ (មើល ទដ ១៨:១៤ និងការពន្យល់) ។ ចំពោះការប្រកួតប្រជែង របស់លោកអេលីយ៉ានោះ សូមធៀប លវ ៩:២៤ ។

**១៨:២៦** *លោតពទ្ធ័ជុំវិញអាសនា* នៅត្រង់នេះបញ្ជាក់ថា គេបានធ្វើតាមប្រពៃណីពួកគេគឺលោតរាំ ក្នុងគោលបំណងផ្គាប់ចិត្តព្រះរបស់ពួកគេ ។

**១៨:២៧** *រំពឹងគិត... ឬប្រហែលជាដេក* នៅត្រង់នេះ លោកអេលីយ៉ាបានសើចចំអកដល់ព្រះបាល ។ លោកអេលីយ៉ា ធ្វើយ៉ាងដូច្នេះ គឺគាត់ចង់ឱ្យព្រះបាលបញ្ចេញពីរិទ្ធបារមី ។

**១៨:២៨** *ទាល់តែឈាមហូរប្រឡាក់កាយ* នេះបញ្ជាក់ថា ពួកគេបានធ្វើឱ្យរាង្គកាយរបស់ខ្លួនឈឺចាប់ដោយការឆូតសាច់ខ្លួនឯង ហើយត្រង់នេះផងដែរពួកគេបូជាខ្លួនដល់ព្រះដែលគេដើរតាម ។ ការធ្វើឱ្យរាង្គកាយ មានការឈឺចាប់ គឺត្រូវបានហាមជាដាច់ខាតនៅក្នុងក្រឹត្យវិន័យលោកម៉ូសេ(លវ ១៩:២៨ ចទ ១៤:១) ។

**១៨:២៩** នៅក្នុងចំណុចនេះបញ្ជាក់ថា ពួកហោរារបស់ព្រះបាលបានស្រែកពេញមួយថ្ងៃរសៀលដើម្បីឱ្យបានចម្លើយពីព្រះនេះ ប៉ុន្តែផ្ទុយទៅវិញពួកគេមិនឮសំឡេងណាឡើយ ។

**១៨:៣០** *ជួសជុលអាសនានៃព្រះយេហូវ៉ា ដែលបានរំលំហើយ* អាសនានៅត្រង់នេះ គឺត្រូវបានស្អាងឡើងដោយពូជអំបូរទាំង១០នៅភាគខាងជើងក្រោយពីការបែងចែកអាណាចក្រ (ការពន្យល់ ៣:២) ហើយអាសនានេះក៏ត្រូវបានបំផ្លាយដោយពួកយេសិបិល (មើល ខ.៤,១៣ ១៩:១០,១៤) ។

**១៨:៣១** *ថ្ម១២តាមចំនួនពូជអំបូរ* ត្រង់នេះ លោកអេលីយ៉ាបាន ប្រើនូវមធ្យោបាយបង្រួបបង្រួមនៃសេចក្ដីសញ្ញារបស់ព្រះ ដើម្បីឱ្យពួកគេបានត្រឡប់ទៅជារាស្ត្ររបស់ព្រះ ដូចនឹងអ៊ីស្រាអែល ថ្វីបើពួកគេមានបែងចែកនយោបាយផ្សេងគ្នាក៏ដោយ ។ ការនេះ គឺត្រូវតែកើតមាននៅចំពោះជាតិសាសន៍ទាំមូល គឺមិនមែនក្នុងមួយផ្នែកណាទេ ។

**១៨:៣៣** *ទឹក* ការស្រោចទឹកនេះបង្ហាញថា គាត់មិនបានប្រើល្បិចអ្វីទេ ។

ពេញ៤ក្អម យកមកចាក់លើដង្វាយនឹងឱសនេះ ៣៤រួច
លោកប្រាប់ថា ចូរចាក់ម្តងទៀត នោះគេក៏ចាក់ម្តងទៀត
រួចលោកប្រាប់ថា ចូរចាក់ម្តងទៀត គេក៏ចាក់ជាគំរប់៣ដង
៣៥ទឹកនោះបានហូរព័ទ្ធជុំវិញអាសនា គេក៏ចាក់ទឹករហូត
ដល់ពេញប្រឡាយដែរ ៣៦លុះដល់ពេល[ឆ]ថ្វាយដង្វាយល្ងាច
នោះហោរាអេលីយ៉ាក៏ចូលមកជិតទូលថា ឱព្រះយេហូវ៉ា
ជាព្រះនៃអ័ប្រាហាំ[ជ] នៃអ៊ីសាក ហើយនៃអ៊ីស្រាអែលអើយ
សូមឱ្យមនុស្សបានដឹង[ឈ]នៅថ្ងៃនេះថា ទ្រង់ជាព្រះនៃពួក
អ៊ីស្រាអែល ហើយថា ទូលបង្គំជាអ្នកបំរើទ្រង់ ព្រមទាំងថា
ទូលបង្គំបានធ្វើការទាំងនេះ ដោយស្តាប់តាមព្រះបន្ទូល
ទ្រង់ផង[ញ] ៣៧សូមស្តាប់ទូលបង្គំ ឱព្រះយេហូវ៉ាអើយ
សូមស្តាប់ទូលបង្គំ ដើម្បីឱ្យប្រជាជននេះបានដឹង[ដ]ថា គឺទ្រង់
ឱព្រះយេហូវ៉ាអើយ ដែលជាព្រះ ហើយថា គឺទ្រង់ដែលនាំ
ចិត្តគេត្រឡប់មកវិញ ៣៨ខណនោះ ភ្លើង[ឋ]នៃព្រះយេហូវ៉ា
ក៏ធ្លាក់ចុះមកបញ្ឆេះដង្វាយ ព្រមទាំងឧស ថ្ម និងធូលីដី
ហើយក៏លិទ្ធទឹកដែលនៅក្នុងប្រឡាយអស់ទៅដែរ ៣៩កាល
ពួកជនទាំងឡាយបានឃើញ នោះគេក៏ក្រាបផ្កាប់មុខ[ឌ]
ពោលថា ព្រះយេហូវ៉ាទ្រង់ជាព្រះ ព្រះយេហូវ៉ា ទ្រង់ជា
ព្រះពិតហើយ[ឍ] ៤០រួចអេលីយ៉ាប្រាប់គេថា ចូរចាប់ពួក
ហោរារបស់ព្រះបាលទៅ កុំឱ្យអ្នកណាមួយរួចឡើយ គេក៏
ចាប់ ហើយអេលីយ៉ាលោកនាំចុះទៅឯជ្រោះគីសុន[ណ]
សំឡាប់ចោល[ត]ទាំងអស់នៅទីនោះទៅ ។

**១៨:៣៦** ឆ នក ២៩:៣៩,៤១ ជ លប ២៤:១២ នក ៤:៥ មថ ២២:៣២ ឈ យស ៤:២៤ ១សយ ១៧:៤៦ ទដ ៤៦:១០ ញ ជន ១៦:២៨ **១៨:៣៧** ដ យស ៤:២៤ **១៨:៣៨** ឋ ខ.២៤ នក ១៩:១៨ លវ ៩:២៤ ២ពវ ១:១០ ២របា ២១:២៦ ២របា ៧:១ យប ១:១៦ **១៨:៣៩** ឌ លវ ៩:២៤ ឍ ខ.២៤ ទដ ៤៦:១០ **១៨:៤០** ណ ពច ៤:៧ ត នក ២២:២០ ចទ ១៧:១២ ២ពវ ១១:១៨ **១៨:៤២** ថ ១សយ ១២:១៧ យក ៥:១៨ **១៨:៤៤** ទ យស ៦:១៥ ធ លក ១២:៥៤ **១៨:៤៥** ន ១ពវ ៨:៣៦ យប ៣៧:១៣ ប ១សយ ២៩:១

៤១រួចមកអេលីយ៉ាទូលដល់អ័ហាប់ថា សូមស្តេចឡើង
ទៅសោយព្រះស្ងោយចុះ ដ្បិតមានសូរសទ្ទឹកភ្លៀងជាធំមក
ហើយ ៤២ដូច្នេះ អ័ហាប់ក៏ឡើងទៅសោយ ឯអេលីយ៉ាលោក
ឡើងទៅលើកំពូលភ្នំកើមែលវិញ ក៏ក្រាបខ្លួនចុះដល់ដី
ដាក់មុខនៅកណ្តាលក្បាលជង្គង់[ថ] ៤៣រួចប្រាប់អ្នកបំរើថា
ចូរឡើងទៅមើលខាងសមុទ្រឥឡូវ អ្នកបំរើក៏ឡើងទៅ
មើល រួចជំរាបថា គ្មានអ្វីឡើយ លោកប្រាប់ថា ចូរទៅឱ្យ
អស់វារៈ៧ដងទៀត ៤៤លុះដល់គំរប់៧ដង[ទ] នោះក៏ជំរាបថា
ឃើញមានពពក[ធ]តូចប៉ុនបាតដៃមនុស្ស ឡើងពីសមុទ្រមក
នោះលោកបង្គាប់ថា ចូរឡើងទៅទូលអ័ហាប់ថា សូមទឹម
រទេះ ហើយចុះទៅចុះ ដើម្បី កុំឱ្យអាក់ដំណើរដោយសារ
ភ្លៀង ៤៥បន្ទាប់នោះបន្តិចមក មេឃត្រឡប់ជាខ្មៅ ដោយ
ពពកនឹងខ្យល់ ក៏ធ្លាក់ភ្លៀងជាខ្លាំង[ន] ឯអ័ហាប់ទ្រង់ជិះរទេះ
ទៅឯយេសរាល[ប] ៤៦ហើយព្រះហស្ត[ផ]នៃព្រះយេហូវ៉ាបាន
សណ្ឋិតនៅលេអេលីយ៉ាលោកក៏ក្រវាត់ចង្កេះ[ព] រត់ទៅខាង
មុខអ័ហាប់ទៅ រហូតដល់មាត់ទ្វារក្រុងយេសរាល ។

## លោកអេលីយ៉ាភាសខ្លួនទៅភ្នំហោរែប

**១៩** ១អ័ហាប់ទ្រង់ប្រាប់ដល់យេសិបិល[ក]ពីគ្រប់ទាំងការ
ដែលអេលីយ៉ាបានធ្វើ ហើយពីការដែលលោកបានសំ–
ឡាប់[ខ]ហោរាទាំងប៉ុន្មានដោយដាវ ២ដូច្នេះ យេសិបិលព្រះ

ហស ១:៤ **១៨:៤៦** ផ ពច ៣:១០ ១សយ ១១:៦ លក ១:៣៥ ៤:១៤ ព ២ពវ ៤:២៩ ៩:១ **១៩:១** ក ១ពវ ១៦:៣១ ខ នក ២២:២០

**១៨:៣៦–៣៨** នៅត្រង់នេះព្រះអម្ចាស់ទ្រង់បាន ទំលាក់ភ្លើងពីស្ថានសួគ៌ឱ្យមក លោកអេលីយ៉ា ។ ព្រះទ្រង់នឹងជួយយើងឱ្យសម្រេចនូវកិច្ចការដែលព្រះអម្ចាស់ទ្រង់បង្គាប់ដល់យើង ។ ភ្លើងនេះ នឹងមិនបំផ្លាញ ជីវិតរបស់យើង គឺដូចជាលោកអេលីយ៉ាដែរ តែភ្លើងនេះជាធនធានដ៏សំខាន់សម្រាប់ជីវិតយើងក្នុងការសម្រេចនូវគោលបំណង ។ ព្រះទ្រង់នឹង ប្រទានឱ្យយើងនូវប្រាជ្ញា ដើម្បីលើកស្ទួយគ្រួសារ និងការលើកទឹកចិត្តដើម្បីឱ្យយើងឈរលើសេចក្តីពិត ហើយនិងផ្តល់នូវជំនួយសម្រាប់នរណារម្នាក់ដែលត្រូវការវា ។ ដូចមាន គម្រូរបស់លោកអេលីយ៉ាខាងលើនេះ យើងត្រូវតែមានភាពស្មោះត្រង់ គ្រប់ការដែលព្រះបង្គាប់ដល់យើង នោះទ្រង់នឹងប្រទាន ដល់យើងគ្រប់តម្រូវការ ដែលយើងចង់បាន ។

**១៨:៤០** *ជ្រោះគីសុន* ទឹកជ្រោះនេះ ហូរធ្លាក់ទៅតាមទន្លេកើមែល ។ *សំឡាប់ចោល ទាំងអស់នៅទីនោះ* នៅត្រង់នេះលោកអេលីយ៉ា បានដើរតួរយ៉ាងសំខាន់ក្នុងការ ប្រើសិទ្ធអំណាចរបស់ព្រះដើម្បីកាត់ទោសដល់ពួកដែលប្រឆាំងនឹងក្រឹត្យវិន័យរបស់ លោកម៉ូសេ (សូមមើល ចទ ១៣:១៣–១៨ ១៧:២–៥) ។

**១៨:៤១** *សូរសទ្ទឹកភ្លៀងជាធំ* សូរភ្លៀងនេះជាការវាយផ្ចាលក្នុងការថ្វាយបង្គំព្រះបាល ពោលគឺការនេះជាភ្លៀងនៃសេចក្តីសន្យា (មើល ១៧:១) ។

**១៨:៤២** *អេលីយ៉ា . . . ក៏ក្រាប . . . ដាក់មុខនៅកណ្តាលក្បាលជង្គង់* មកដល់ត្រង់នេះពួកមនុស្សគេបានលន់តួរ និងសារភាពថាមានតែព្រះមួយគត់ ហើយលោកអេលីយ៉ា បានអធិស្ឋានសូមឱ្យព្រះបានដាក់បណ្តាសាពួកគេ (មើល ១៧:១) ដោយភ្លៀង (សូមមើល ៨:៣៥ ២របា ៧:១៣–១៤) ។

**១៨:៤៣** *វារៈ៧ដង* នេះជានិមិត្តរូបនៃសេចក្តីសម្រេច ។

**១៨:៤៤** *ឡើងពីសមុទ្រមក* ឃ្លានេះ បញ្ជាក់ថាពពកលេចឡើងនៅភាគខាងលិចនៃឆ្នេរសមុទ្រមេឌីទែរ៉ាណេ ។

**១៨:៤៦** *រត់ទៅខាងមុខអ័ហាប់ទៅ រហូតដល់មាត់ទ្វាក្រុងយេសរាល* ឃ្លានេះបញ្ជាក់ថា លោកអេលីយ៉ាបានរត់នៅពីមុខរទេះចម្បាំងឆ្ពោះទៅក្រុងយេសរាល(២៥,៦០០ គីឡូម៉ែត្រ) ដែលព្រះយេហូវ៉ាជាអ្នកជម្រុញ កម្លាំងឱ្យគាត់ ។ មហាវិនាសកម្មនេះ ជាមួយនឹងពួកហោររបស់ព្រះអម្ចាស់ដែលបានរត់នៅពីមុខស្តេច និងព្រះអម្ចាស់ទ្រង់បានរត់ពីក្រោយពួកគេដោយអមដោយសម្លេងផ្គរ និងរទេះចម្បាំង(មើលការពន្យល់ ខ.២៤) សម្រាប់ជាជំនួយដល់ស្តេចអ័ហាប់ដើម្បីវាយបំបាក់ព្រះបាលតាមរយៈអ្នកបម្រើនៃព្រះយេហូវ៉ា ។

**១៩:១** *យេសិបិល* សូមមើល ពន្យល់(១៦:២៥,៣១–៣២) ។

**១៩:២** នៅត្រង់នេះ យេសិបិលមានការក្តៅចិត្តយ៉ាងខ្លាំងចំពោះការស្លាប់របស់ពួកហោរារបស់ព្រះនាង ពីព្រោះពួកនេះប្រាប់គ្រប់រឿងដល់នាងជាពិសេសចំពោះអំណាចនៅពេលអនាគត និង សិរីល្អរបស់នាង ។

នាងចាត់គេឱ្យនាំពាក្យទៅប្រាប់អេលីយ៉ាថា ដល់ស្អែកនេះ
ពេលថ្មើរនេះ បើយើងមិនបានធ្វើឱ្យជីវិតឯងបានដូចជា
ជីវិតនៃអ្នកទាំងនោះទេ[គ] នោះសូមឱ្យអស់ទាំងព្រះធ្វើដល់
យើង ដូច្នោះវិញ ហើយលើសទៅទៀតផង[ឃ] ៣កាលលោក
បានជ្រាបដូច្នោះហើយ នោះក៏ក្រោកឡើងរត់[ង]ទៅឱ្យរួច
ជីវិត[ច] បានដល់ទៅបៀរ-សេបា[ឆ] ជាស្រុករបស់ពួកយូដា
លោកក៏ទុកអ្នកបំរើនៅទីនោះ ៤តែខ្លួនលោក ដើរពេល១
ថ្ងៃ ចូលក្នុងទីរហោស្ថាន ទៅអង្គុយនៅក្រោមដើមដង្កោ[ជ]
រួចទូលសូមឱ្យខ្លួនស្លាប់ទៅ ដោយពាក្យថា ល្មមហើយ
ឱព្រះយេហូវ៉ា អើយ សូមយកព្រលឹងទូលបង្គំទៅឥឡូវ
ចុះ[ឈ] ដ្បិតទូលបង្គំមិនវិសេស ជាងពួកព្ធយុកោទូលបង្គំទេ
៥លោកក៏ប្រះខ្លួនដេកលក់[ញ]នៅក្រោម ដើមដង្កោនោះទៅ
នោះមានទេវតា[ដ]មកដាស់លោកប្រាប់ថា ចូរក្រោកឡើង
បរិភោគសិន ៦លោកក្រឡេកមើលទៅឃើញនៅក្បាល
ដំណេក មាននំដុតឆ្អិននៅលើថ្មដុតភ្លើង ហើយមានទឹក១ក្អម
ផង នោះលោកក៏បរិភោគនំនឹងទឹកនោះរួចដេកទៅវិញ
៧ទេវតានៃព្រះយេហូវ៉ាក៏មកដាស់ម្តងទៀតប្រាប់ថា ចូរ
ក្រោកឡើងបរិភោគទៅ ដ្បិតផ្លូវដែលត្រូវដើរ នោះហួស
កំឡាំងឯងណាស់ ៨លោកក៏ក្រោកឡើងបរិភោគទៅ ហើយ
ដោយសារកំឡាំង ដែលបានពីអាហារនោះ លោកក៏
ដើរទៅអស់៤០ថ្ងៃ[ឋ]៤០យប់ បានដល់ទៅភ្នំហោរែប[ឌ]ជាភ្នំ
នៃព្រះ ។
៩កាលលោកបានទៅដល់ហើយ នោះក៏ចូលទៅអាស្រ័យ
ក្នុងរអាង[ឍ] ១នៅទីនោះ ។

**ព្រះអម្ចាស់លេចមកលោកអេលីយ៉ា**

គ្រានោះឮព្រះបន្ទូលនៃព្រះយេហូវ៉ាមកសួរថា អេលីយ៉ា
អើយ តើធ្វើអីនៅទីនេះ[ណ] ១០លោកទូលថា ទូលបង្គំបាន
មានចិត្តឈឺឆ្អាល[ត]នឹងព្រះយេហូវ៉ា ជាព្រះនៃពួកពល
បរិវារជាខ្លាំង ដ្បិតពួកកូនចៅអ៊ីស្រាអែលគេបានបោះបង់
ចោលសេចក្តីសញ្ញាទ្រង់[ថ] គេបានរំលំអស់ទាំងអាសនា
របស់ទ្រង់[ទ] ហើយបានសំឡាប់ពួកហោរាទ្រង់ដោយដាវផង
នៅសល់តែទូលបង្គំម្នាក់ឯងប៉ុណ្ណោះ[ធ] ហើយគេរកជីវិត
ទូលបង្គំថែមទៀត ១១ទ្រង់មានបន្ទូលទៅថា ចូរឯងចេញ
ទៅឈរលើភ្នំ[ន]នៅចំពោះព្រះយេហូវ៉ាចុះ នោះមើល ព្រះ
យេហូវ៉ាទ្រង់យាងទៅតាមទីនោះ[ប] ហើយកើតមានខ្យល់
ព្យុះគំហុកជាខ្លាំង[ផ] បក់មកប៉ះបំបាក់[ព]ភ្នំបែកថ្មខ្ទេចខ្ទីនៅ
ចំពោះព្រះយេហូវ៉ា តែព្រះយេហូវ៉ាទ្រង់មិន មែនគង់នៅ
ក្នុងខ្យល់នោះទេ ក្រោយខ្យល់នោះមក ក៏មានកក្រើកដី តែ

**១៩:២** គ នរ ១:១៧ ឃ ទដ ១៣:៤ យរ ២០:១០ ២៦:២១ ៣៦:២៦ **១៩:៣** ង លប ៣១:២១ ច លប ១៩:១៧ ឆ យស ១៩:២ **១៩:៤** ជ យប ៣០:៤ ឈ ជន ១១:១៥ យប ៦:៩ ៧:១៦ ១០:១ ទដ ៦៩:១៩ យរ ២០:១៨ យហ ៤:៨ **១៩:៥** ញ លប ២៨:១១ ដ លប ១៦:៧ **១៩:៨** ឋ នក ២៤:១៨ មថ ៤:២ ឌ នក ៣:១ **១៩:៩** ឍ នក ៣៣:២២ ណ លប ៣:៩ **១៩:១០** ត ជន ២៥:១៣ កច ២២:៣ កទ ៤:១៨ ថ ចទ ៣១:១៦ ទ ១ពវ ១៨:៣០ ធ ១ពវ ១៨:៤,២២ យរ ៥:១១ ៩:២ រម ១១:៣ **១៩:១១** ន នក ៣៤:២ មថ ១៧:១-៣ប នក ៣៣:១៩ផ នក ១៤:២១ ២ពវ ២:១ព ណហ ១:៦

កិច្ចការរបស់ពួកហោនេះ គឺជួយលើកសរសើរដល់ព្រះមហាក្សត្រ និងម្ចាស់ក្សត្រីឱ្យគ្រងរាជ្យស្ថិតស្ថេរលើអាណាចក្រនេះ ។ សេចក្តីក្រោធរបស់យេសិបិល នេះបណ្តាមកពីអ្នកគាំទ្ររបស់ព្រះនាងទាំងប៉ុន្មាន ត្រូវបានគេវាយផ្ចាល ដូច្នេះអំណាច និងសេចក្តីអំណួតរបស់នាងត្រូវបានដួលរលំទៅយ៉ាងដូច្នេះឯង ។

**១៩:៣** នៅក្នុងខ.នេះបញ្ជាក់ថា លោកអេលីយ៉ាធ្លាប់បានមុជចូលជ្រៅក្នុងការងារលំបាក និងបាក់ទឹកចិត្តបន្ទាប់ពីគាត់ទទួលបានជ័យជម្នះខាងឯវិញ្ញាណពីរដង: ទី១ គឺការវាយប្រហារលើពួកហោរារបស់ព្រះបាលឱ្យដួលចុះ និង ទី២ គឺព្រះបានឆ្លើយតបចំពោះពាក្យអធិស្ឋានសូមភ្លៀងរបស់គាត់ ។

**១៩:៤** *សូមយកព្រលឹងទូលបង្គំទៅឥឡូវចុះ* ធៀប យហ ៤:៣,៨ ។ លោកអេលីយ៉ា បានបញ្ជាក់ថា កិច្ចការដែលលោកបានបំពេញហាក់បីដូចជាគ្មានប្រយោជន៍ រហូតគាត់គិតថាគាត់មិនសមនឹងរស់នៅបន្តទៀត ។ មកដល់ត្រង់នេះ គាត់បាត់បង់ទំនុកចិត្តក្នុងការយកជ័យជម្នះនៅក្នុងអាណាចក្ររបស់ព្រះ ហើយគាត់កំពុងតែដកថយពីសមរភូមិនេះផងដែរ ។

**១៩:៧** *ទេវតានៃព្រះយេហូវ៉ា* មើលការពន្យល់ លប ១៦:៧ ។ សេចក្តីមេត្តាករុណារបស់ព្រះ បានផ្តល់អាហារ និងការសម្រាកដល់អ្នកបម្រើទ្រង់ដែលកំពុងធ្លាក់ទឹកចិត្ត ។ *ដ្បិតផ្លូវដែលត្រូវដើរ នោះហួសកំឡាំងឯងណាស់* ឃ្លានេះបានប្រាប់យ៉ាងច្បាស់ថា ផ្លូវដែលលោកអេលីយ៉ាត្រូវទៅនោះគឺភ្នំហោរែប ជាទីដែលព្រះបានប្រទានក្រឹត្យវិន័យសម្រាប់រាស្ត្ររបស់ទ្រង់ ។ នៅត្រង់នេះ គ្មានសញ្ញាណាដែលបញ្ជាក់ថា ព្រះបានដៅគាត់ឱ្យធ្វើការនេះ ដូចក្នុងករណីគាត់លាក់ខ្លួននៅកេរីត(១៧:២-៣) និងនៅឯសារិបតា (១៧:៨-៩) មកនោះទេ ។ ហើយនិងការបង្ហាញខ្លួនឱ្យអ័ហាប់ឃើញ (១៨:១) ។

**១៩:៨** *៤០ថ្ងៃ៤០យប់* នេះជារយៈពេលដែលលោកអេលីយ៉ាទ្រាំទ្រក្នុងដំណើរដែលព្រះអម្ចាស់ជាអ្នកជួយ ហើយរយៈចម្ងាយនេះគឺដូចក្នុងករណីលោកម៉ូសេនៅឯភ្នំស៊ីណាយ (នក ២៤:១៨ ៣៤:២៨) និងក្នុងកាលដែលព្រះយេស៊ូវជួបសេចក្តីល្បួងនៅទីរហោស្ថាន(មថ ៤:២,១១) ។ *ភ្នំហោរែបជាភ្នំនៃព្រះ* ត្រង់នេះក៏អាចជាភ្នំស៊ីណាយ (មើល នក ៣:១ ១៩:១-៣) ដែលស្ថិតនៅវាលរហោស្ថានភាគខាងត្បូង បៀរ-សេបា ។

**១៩:៩** *តើធ្វើអីនៅទីនេះ?* សំណួរនេះបញ្ជាក់ថា លោកអេលីយ៉ាមកភ្នំស៊ីណាយនេះ គឺគាត់បានយល់ខុស ហើយការនេះព្រះអម្ចាស់មិនបានបញ្ជូនគាត់ឱ្យមកកាន់ទីនេះទេ ។

**១៩:១០** នៅត្រង់នេះលោកអេលីយ៉ា មិនបានឆ្លើយតបចំពោះសំណួររបស់ព្រះអម្ចាស់ដោយផ្ទាល់នោះទេ តែគាត់បានបញ្ជាក់ថាគាត់មានចិត្តបម្រើការងាររបស់ព្រះ ដែលព្រះអម្ចាស់ទ្រង់បានប្រទានសេចក្តីសញ្ញានៅភ្នំស៊ីណាយ ហើយឥឡូវបែរជាគ្មានអ្វីទាំងអស់ទៅវិញ ។ ទោះជាលោកម៉ូសេបានសូមឱ្យមានការអត់ទោសឱ្យពួកអ៊ីស្រាអែល ចំពោះការដែលគេបានប្រព្រឹត្តបាបដោយទៅគោរពរូបព្រះគោ (នក ៣២:១១-១៣) ក៏ដោយ ក៏លោកអេលីយ៉ានៅតែកាត់ទោសពួកគេសម្រាប់ការប្រព្រឹត្តរំលងក្រឹត្យវិន័យ និងការដែលខ្លួនគាត់បានប្រព្រឹត្តតាមបែបគ្មានផលផ្លែនេះផងដែរ ។ *សល់តែទូលបង្គំម្នាក់ឯង* សូមមើលការពន្យល់ ១៨:២២ ។

ព្រះយេហូវ៉ាទ្រង់មិនមែនគង់នៅក្នុងការ កក្រើកដីនោះទេ
១២ បន្ទាប់ពីការកក្រើកដីនោះមក នោះមានភ្លើងឆេះ[ភ] តែ
ព្រះយេហូវ៉ាទ្រង់មិនមែនគង់នៅក្នុងភ្លើងនោះទេ ក្រោយ
ពីភ្លើងនោះមក មានឮសំឡេងតូចរហៀងៗ[ម] ១៣ កាល
អេលីយ៉ាបានឮហើយ នោះលោកក៏យកក្រមាគ្រលុំមុខ[យ]
ចេញមកឈរនៅមាត់រអាង នោះមានឮសំឡេងមកដល់
លោកថា អេលីយ៉ាអើយ តើឯងធ្វើអ្វីនៅទីនេះ ១៤ លោក
ទូលឆ្លើយថា ទូលបង្គំបានមានចិត្តឈឺឆ្អាលនឹងព្រះយេ
ហូវ៉ា ជាព្រះនៃពួកពលបរិវារជាខ្លាំង ដ្បិតពួកកូនចៅ
អ៊ីស្រាអែល គេបានបោះបង់ចោលសេចក្ដីសញ្ញាទ្រង់
គេបានរំលំអស់ទាំងអាសនាទ្រង់ ហើយបានសំឡាប់ពួក
ហោរាទ្រង់ ដោយដាវផង នៅសល់តែទូលបង្គំម្នាក់ឯង
ប៉ុណ្ណោះ[រ] ហើយគេស្វែងរកជីវិតទូលបង្គំថែមទៀត ។
១៥ ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅលោកថា ចូរឯង
ត្រឡប់ទៅតាមផ្លូវ ដែលកាត់ទីរហោស្ថាន ទៅឯក្រុង
ដាម៉ាសទៅ កាលណាបានដល់ហើយ នោះចូរចាក់ប្រេង
តាំងហាសែលឡើង[ល] ឱ្យធ្វើជាស្តេចស្រុកស៊ីរីចុះ ១៦ ហើយ
ត្រូវចាក់ប្រេងតាំង[វ] យេហ៊ូវ ជាកូននីមស៊ីឡើង ឱ្យធ្វើជា
ស្តេចសោយរាជ្យលើស្រុកអ៊ីស្រាអែលដែរ ឯអេលីសេ[ស]
ជាកូនសាផាត ដែលនៅអេបិល-មហូឡា[ហ] នោះត្រូវចាក់
ប្រេងតាំងឱ្យធ្វើជាហោរាជំនួសឯង ១៧ ដូច្នេះអ្នកណាដែល
រួចពីដាវរបស់ហាសែល[ឡ] នោះយេហ៊ូវ នឹងសំឡាប់គេវិញ
ហើយអ្នកណាដែលរួចពីដាវរបស់យេហ៊ូវ[អ] នោះអេលីសេ
នឹងសំឡាប់បង់ ១៨ ប៉ុន្តែ អញនឹងទុកឱ្យមាន[ក] មនុស្ស៧ពាន់
នាក់សល់នៅ ក្នុងពួកអ៊ីស្រាអែល ជាពួកអ្នកដែលមិនបាន
លុតជង្គង់ក្រាប នៅចំពោះព្រះបាល ឬថើប[ខ] វាឡើយ ។

## ការត្រាស់ហៅលោកអេលីសេ

១៩ ដូច្នេះ លោកក៏ចេញពីទីនោះ ទៅរកអេលីសេជាកូន
សាផាត ឃើញកំពុងតែភ្ជួរ មានគោ១២នឹមភ្ជួរនៅខាងមុខ
គាត់ គឺគាត់ដែលភ្ជួរដោយនឹមក្រោមបង្អស់នៅខណនោះ
អេលីយ៉ាក៏ដើរដំរង់ទៅឯគាត់ ហើយបោះក្រមា[គ] ខ្លួនទៅ
លើ ២០ គាត់ក៏លះបង់គោចោលរត់ទៅតាម អេលីយ៉ា
ដោយពាក្យថា សូមអនុញ្ញាតឱ្យខ្ញុំទៅថើបលា[ឃ] ឪពុកម្តាយខ្ញុំ

**១៩:១២** ភ នក ៣:២ ម ខ.១១ ១សយ ១៤:៦ យប ៤:១៦ សក ៤:៦ ២កថ ១២:៩ **១៩:១៣** យ នក :៦ **១៩:១៤** រ ១ពវ ១៨:២២ រម ១១:៣ **១៩:១៥** ល ២ពវ ៨:៧-១៥ **១៩:១៦** វ ២ពវ ៩:១-៣,៦ ស ខ.២១ ២ពវ ២:១ ៣:១១ ហ ពច ៧:២២ **១៩:១៧** ឡ ២ពវ ៨:១២,២៩ ១០:៣២ ១២:១៧ ១៣:៣,៧, ២២ អម ១:៤ អ យរ ៤៨:៤៤ **១៩:១៨** ក រម ១១:៤ ខ ហស ១៣:២

**១៩:១៩** គ លប ៤១:៤២ ២ពវ ២:៨,១៤ **១៩:២០** ឃ ១សយ ៦:១៤

**១៩:១២** *ឮសំឡេងតូចរហៀងៗ* អត្ថសញ្ញាណនេះមានរៀបរាប់នៅក្នុង (ខ.១១-១២) ដែលព្រះអម្ចាស់បានលេចមកដើម្បីប្រាប់លោកអេលីយ៉ាថា ទោះបីគេកាត់ទោសរាស្ត្ររបស់ទ្រង់ក៏ដោយ អំពាវនាវដល់ព្រះ សូមឱ្យមានព្យុះភ្លៀង រញ្ជួយដីក៏ដោយ ក៏ការវាមិនមែនជាបំណងហឫទ័យរបស់ព្រះ ។

**១៩:១៣** *អេលីយ៉ាអើយ តើឯងធ្វើអ្វីនៅទីនេះ* ក្រោយពីការបង្ហាញពីព្រះវត្តមានរបស់ទ្រង់នៅក្នុងភាពស្ងៀមស្ងាត់ ដែលមានលក្ខណៈប្រសើរជាងការបង្ករឱ្យមានខ្យល់ រញ្ជួយផែនដី និងភ្លើង នោះព្រះអម្ចាស់បានប្រទានឱកាសឱ្យលោកអេលីយ៉ាផ្លាស់ប្តូរចម្លើយដែលទ្រង់បានប្រទានឱ្យគាត់នៅក្នុង(ខ.៩-១០) ។

**១៩:១៤** នៅក្នុងខ.នេះបញ្ជាក់ថា លោកអេលីយ៉ាមិនបានផ្លាស់ប្តូរចំពោះចម្លើយរបស់គាត់ដែលថា គាត់មិនបានយល់ពីបំណងព្រះហឫទ័យទ្រង់ដែលគាត់បានយល់នៅពេលនេះ ។

**១៩:១៥,១៦** នៅវគ្គនេះព្រះអម្ចាស់ទ្រង់បានបង្គាប់ដល់លោកអេលីយ៉ា ឱ្យចាក់ប្រេងតាំងលើមនុស្សបីរូបដើម្បីធ្វើការវាយបំបាក់ពួកមិនជឿ ។ ជាបឋមលោកតែងតាំងហាសែ ឱ្យធ្វើជាស្តេចជំនួសអើរ៉ាមនៅស្រុកស៊ីរី។ អេលីយ៉ា បានតែងតាំង អើរ៉ាមដែលជាសត្រូវរបស់គាត់ពីមុនឱ្យធ្វើជាអ្នកកាត់ទោសដល់អំពើរបាបរបស់ពួកអ៊ីស្រាអែល ដូច្នេះការងាររបស់គាត់គឺនាំពួកអ៊ីស្រាអែលដែលធ្វើបាបនៅខាងក្រៅមកកាត់ទោស ។ រីឯអំពើរបាបដែលនៅខាងក្នុងខ្លួនរបស់ពួកអ៊ីស្រាអែលគឺយេហ៊ូវជាអ្នកកាត់ទោស ។ យេហ៊ូវម្នាក់នេះ ជាអ្នកបំផ្លាញដល់ពួកអ៊ីស្រាអែលណាដែលបានថ្វាយបង្គំរូបព្រះខុសឆ្គង (ព្រះបាល ២ពវ ៩,១០) ។ ចំពោះមនុស្សទី៣ លោកអេលីយ៉ា បានតែងតាំងលោកអេលីសេ ដែលជាហោរាឱ្យធ្វើការនៅក្នុងបណ្តាលពួកអ៊ីស្រាអែល ដើម្បីឱ្យពួកគេបានវិលបែរមករកព្រះដើមវិញ ។

**១៩:១៦** *ចាក់ប្រេងតាំងយេហ៊ូវ* ម្នាក់នេះជាមេបញ្ជាការកងទ័ពស្ថិតនៅក្រោមស្តេចអ័ហាប់ និង យ៉ូរ៉ាម ហើយគាត់ជាបុត្ររបស់អ័ហាប់(មើល ៩:៥-៦) ។ យេហ៊ូវ ត្រូវបានតែងតាំងធ្វើជាស្តេចគ្រប់គ្រងលើពួកអ៊ីស្រាអែល ដោយសាហោរាអេលីសេជាអ្នកបង្ហាត់បង្រៀនដើម្បីផ្តួលរំលំរាជ្យស្តេចអ័ហាប់ ។ *អេលីសេ* ឈ្មោះនេះមានន័យដូចនឹង អេលីយ៉ា(មើល ១៧:១) ។ អេលីសេមានន័យថា"ព្រះ គឺជាសេចក្ដីសង្គ្រោះ"ឬ"ព្រះសង្គ្រោះ" ដែលអត្ថន័យនេះ មានសារៈសំខាន់ណាស់ចំពោះបេសកកម្មរបស់គាត់ ។ ឈ្មោះរបស់គាត់នេះ ក៏បានដាស់សតិឱ្យយើងនឹកចាំដល់ឈ្មោះរបស់លោកយ៉ូស្វេដែលមានន័យថា"ព្រះសង្គ្រោះ"ដែរ ។ ចំពោះឈ្មោះអេលីយ៉ាវិញ ត្រូវដាក់ឱ្យចំពោះអស់អ្នកណាដែលបានបញ្ចប់បេសកកម្មរបស់ទ្រង់ដូចក្នុង ករណីលោកម៉ូសេបានធ្វើកន្លងមក ។ យ៉ាងណាមិញឈ្មោះអេលីសេនេះសម្រាប់ តែបុគ្គលណាដែលអាចនាំព្រះពរ និងសេចក្ដីជំនឿដូចដែលលោកយ៉ូស្វេបាននាំរាស្ត្រអ៊ីស្រាអែលចូលក្នុងទឹកដីសន្យា (មើល ២ពវ ២:១៩-៨:១៥ ៩:១-៣ ១៣:១៤-២០) ។

**១៩:១៧** *អ្នកណាដែលរួចពីដាវរបស់ហាសែល* សូមមើល ២ពវ ៩:២៤ ។ *អ្នកណាដែលរួចពីពីដាវរបស់យេហ៊ូវ នោះអេលីសេនឹងសំឡាប់បង់* សូមមើល ២ពវ ២:២៤ ៨:១ និងបន្ថែម ហស ៦:៥ ។

**១៩:១៨** *៧ពាន់នាក់* នៅត្រង់នេះ ជាការបញ្ជាក់ពីចំនួនមនុស្សដែលព្រះអម្ចាស់បម្រុងទុក ដើម្បីឱ្យបានសម្រេចតាមបទទំនាយ (រម ១១:២-៤) ។ ករណីខ្លះលោកអេលីយ៉ា បានសន្និដ្ឋានខុសដោយគាត់បានគិតថា មានតែគាត់មួយប៉ុណ្ណោះដែលស្មោះត្រង់ (មើល ខ.១០,១៤ ១៨:២២ និងការពន្យល់)។ *មិនបានលុតជង្គង់ក្រាប នៅចំពោះព្រះបាល ឬថើបវាឡើយ* មើល ហស ១៣:២ ។

**១៩:១៩** *បោះក្រមាខ្លួនទៅលើ* ឃ្លានេះបញ្ជាក់ថា លោកអេលីសេជាមនុស្សធ្វើជាអ្នកស្នងងារនេះអំពីគាត់ (មើល ខ.១៦) ។

សិន នោះខ្ញុំនឹងមកតាមលោក តែអេលីយ៉ាឆ្លើយតបថា
ចូរទៅវិញទៅ តើអញបានធ្វើអ្វីដល់ឯង[ង] ២១ដូច្នេះ គាត់ក៏
ត្រឡប់ទៅវិញ យកគោ១នឹមសំឡាប់ទៅ ហើយស្ងោរ
ដោយគ្រឿងប្រដាប់ទឹមគោ រួចចែកគ្នាបរិភោគទៅ រួច
ហើយគាត់ក្រោកឡើងទៅតាមអេលីយ៉ាដើម្បីបំរើលោក[ច] ។

## ស្តេចបេន-ហាដាឌ់វាយប្រហារក្រុងសាម៉ារី

**២០** ១គ្រានោះ បេន-ហាដាឌ់[ក]ជាស្តេចស្រុកស៊ីរីទ្រង់ប្រជុំ
ពួកពលទ័ពរបស់ទ្រង់មក មានស្តេចរង៣២អង្គនៅជាមួយ
នឹងទ្រង់ ព្រមទាំងសេះ និងរទេះចំបាំងផង ទ្រង់ឡើងទៅ
ឡោមព័ទ្ធច្បាំងនឹងក្រុងសាម៉ារី[ខ] ២ក៏ចាត់រាជទូតទៅក្នុង
ទីក្រុង ទូលដល់អ័ហាប់ ជាស្តេចអ៊ីស្រាអែលថា បេន-
ហាដាឌ់ទ្រង់មានបន្ទូលដូច្នេះថា ៣មាសប្រាក់របស់ឯងជា
របស់ផងអញវិញ ហើយប្រពន្ធកូនទាំងប៉ុន្មានរបស់ឯង
ដែលមានរូបល្អបំផុត នោះសុទ្ធតែរបស់ផងអញដែរ
៤ស្តេចអ៊ីស្រាអែលក៏តបទៅថា បពិត្រស្តេចជាម្ចាស់អើយ
តាមព្រះបន្ទូលទ្រង់ នោះខ្លួនទូលបង្គំ ព្រមទាំងសព្វសារពើ
ដែលទូលបង្គំមាន ក៏ជារបស់ផងទ្រង់ដែរ ៥រួចពួករាជទូត
ក៏មកម្តងទៀតទូលថា បេន-ហាដាឌ់ទ្រង់មានបន្ទូលម្តង
ហើយថា អញបានចាត់ទូតឱ្យមកឯឯងប្រាប់ថា ត្រូវឱ្យឯង
ប្រគល់មាស ប្រាក់ និងប្រពន្ធកូនឯងមកអញ ៦តែដល់ថ្ងៃ
ស្អែកពេលថ្មើរនេះ នោះអញនឹងចាត់ពួកអញឱ្យមកឯឯង
គេនឹងឆែកមើលក្នុងដំណាក់ឯង ហើយក្នុងផ្ទះពួកបំរើឯង
ឯរបស់ណា ដែលជាទីគាប់ភ្នែកឯង នោះគេនឹងចាប់កាន់
នៅដៃយកទៅ ។

៧ដូច្នេះ ស្តេចអ៊ីស្រាអែលក៏ហៅពួកចាស់ទុំ[គ]ក្នុងស្រុកមក
មានបន្ទូលថា សូមអ្នករាល់គ្នាពិចារណាមើល ដែលមនុស្ស
នេះរករឿងហេតុ[ឃ]នឹងយើងជាយ៉ាងណា ដ្បិតវាបានចាត់
ទូតឱ្យមកទារយកប្រពន្ធកូន នឹងមាសប្រាក់របស់យើងទៅ
យើងក៏ឥតមានប្រកែកឡើយ ៨នោះពួក ចាស់ទុំនឹងប្រជាជន
ទាំងឡាយទូលឆ្លើយឡើងថា សូមទ្រង់កុំស្តាប់ ឬព្រមតាម
គេឡើយ ៩ហេតុដូច្នេះទ្រង់ឆ្លើយប្រាប់ទៅពួករាជទូតរបស់
បេន-ហាដាឌ់ថា ចូរទៅទូលស្តេចជាម្ចាស់យើងថា គ្រប់
ទាំងសេចក្តី ដែលទ្រង់បានចាត់មកបង្គាប់ឱ្យខ្ញុំធ្វើជាមុន
នោះខ្ញុំសុខចិត្តធ្វើហើយ តែស្តេចក្រោយនេះខ្ញុំមិនអាចនឹង
ធ្វើបានទេ ពួករាជទូតក៏នាំពាក្យនោះ ទៅទូលដល់បេន-
ហាដាឌ់វិញ ១០ដូច្នេះ ទ្រង់ចាត់គេឱ្យមកទូលថា បើមាន
ធូលី[ង]ក្នុងក្រុងសាម៉ារីល្មម១កំបង់ដៃ ដល់ពួកអ្នកដែលតាម
អញមកគ្រប់គ្នា នោះសូមឱ្យអស់ទាំងព្រះធ្វើដល់អញយ៉ាង
ដូច្នេះ ហើយលើសទៅទៀតផង ១១រួចសេចក្តីអ៊ីស្រាអែល
មានបន្ទូលឆ្លើយថា ចូរទៅប្រាប់បេន-ហាដាឌ់វិញថា កុំបី
ឱ្យអ្នកដែលកំពុងតែពាក់គ្រឿង ក្រោះអួតអាងខ្លួន[ច] ដូចជា
អ្នកដែលដោះគ្រឿងចេញនោះឡើយ ១២បេន-ហាដាឌ់បាន
ឮពាក្យនោះក្នុងវេលាកំពុងដែលសោយស្រា[ឆ] នៅក្នុងពន្លា
ជាមួយនឹងពួកស្តេចរងនោះទ្រង់ប្រាប់ដល់ពួកពលទ័ពទ្រង់

**១៩:២០** ង ខ.១៦
**១៩:២១** ច ១សយ ៦:១៤ ឆ ខ.១៦
**២០:១** ក ១ពវ ១៥:១៨ ខ ១ពវ ១៣:៣២
**២០:៧** គ ១សយ ១១:៣ ឃ ២ពវ ៥:៧
**២០:១០** ង ២សយ ២២:៤៣
**២០:១១** ច សភ ២៧:១ យរ ៩:២៣ អម ២:១៤
**២០:១២** ឆ ១ពវ ១៦:៩

**១៩:២១** នៅក្នុងខនេះ បានប្រាប់ថាការសម្លាប់គោដើម្បីបរិភោគ នោះធ្វើឱ្យអេលីសេកាន់តែមានការប្តេជ្ញាចិត្តក្នុងការដើរតាមលោអេលីយ៉ា ។ ប្រសិនបើគ្មានគោទាំងនេះទេ នោះគាត់មិនអាចក្លាយជាកសិករស្តុកស្តម្ភបានឡើយ ហើយការបរិភោគបែបនេះ បង្ហាញថាគាត់ជាអ្នកមានជាងគេក្នុងចំណោមកសិករទាំងពួង ។ សរុមមកការបរិភោគនៅត្រង់នេះជាការថ្លែងអំណរគុណដល់ព្រះអម្ចាស់ ដែលបានរើសលោកអេលីសេ ធ្វើជាហោរារបស់ទ្រង់ ។

**២០:១** *បេន-ហាដាឌ់ជាស្តេចស្រុកស៊ីរី* នៅត្រង់នេះ តាមរយៈជិនួរវង្សបញ្ជាក់ថាជា បេន-ហាដាឌ់ទី II គឺទាំងកូន និងចៅរបស់បេន-ហាដាឌ់ទីI បានគ្រប់គ្រងស្រុកស៊ីរីចាប់តាំងពីដើមសតវត្សរ៍ទី៩០០-៨៩៥ មុន គ.ស (មើលការពន្យល់ ១៥:៩-១០,១៨-២០,៣៣) ។ ព្រឹត្តិការណ៍នៅក្នុងជិពូកនេះបានកើតឡើងពីរដង (សូមមើល ខ.២២-២៦) ដែលបន្តរហូតដល់បីឆ្នាំដែលជាឆ្នាំសន្តិភាពរវាងពីអ៊ីស្រាអែល និងពួកស៊ីរី (មើល ២២:១) ។ ស្តេចអ័ហាប់បានសុគតនៅក្នុងឆ្នាំទីបី នៅពេលមានសន្តិសុខនៅក្នុងសមរភូមិចម្បាំងក្នុងក្រុងសាម៉ារីនៃឆ្នាំ៨៣៥ មុន គ.ស (២២:៣៧) ។ គ្រប់ហេតុការណ៍ដែលបានកើតមានមកខាងលើនេះ អាចនិយាយបានថា គឺគេបានកត់ត្រានៅក្នុងឆ្នាំទី ៨៥៧ មុន គ.ស ។ *៣២អង្គ* ពួកគេជាស្តេចដែលស្ថិតនៅក្រោមការត្រួតត្រារបស់បេន-ហាដាឌ់ ។ *ក្រុងសាម៉ារី* សូមមើលការពន្យល់ ១៦:២៤ ។

**២០:៤** *សព្វសារពើដែលទូលបង្គំមាន ក៏ជារបស់ផងទ្រង់ដែរ* ឃ្លានេះបានប្រាប់ពីការចុះចូលរបស់អ័ហាប់ ចំពោះសំណើររបស់ហាដាឌ់ នោះបញ្ជាក់ថាពួកអ៊ីស្រាអែលបានមើលឃើញពីក្តីសង្ឃឹមពីជ័យជម្នះរបស់អ៊ីស្រាអែលលើកងទ័ពពួកស៊ីរី ។ ដំណោះស្រាយនៃកិច្ចចរចារនេះ គឺសម្រេចថា ឈប់ឡោមពទ្ធ័ពួកស៊ីរី ហើយទុកជីវិតឱ្យអ័ហាប់ និងជៀសវាងអំពើឆក់ប្លន់នៅក្នុងទីក្រុងទៀត ។

**២០:៦** *អញនឹងចាត់ពួកអញ ឱ្យមកឯឯង គេនឹងឆែកមើលក្នុងដំណាក់ឯង ហើយក្នុងផ្ទះពួកបំរើឯង* នេះជាការបង្គាប់របស់ស្តេច បេន-ហាដាឌ់ ដែលតម្រូវឱ្យពួកគេប្រគល់អ្វីៗទាំងអស់តាមការបង្ខំរបស់ទ្រង់ ។

**២០:៩** *ខ្ញុំមិនអាចធ្វើបានទេ* នៅត្រង់នេះអ័ហាប់បានឆ្លើយតបតាមរបៀបចុះចូលចំពោះស្តេច បេន-ហាដាឌ់ ប៉ុន្តែធាតុពិតនៃឃ្លានេះ គឺគាត់បដិសេធចំពោះការនេះទៅវិញ ។

**២០:១០** *សូមឱ្យអស់ទាំងព្រះធ្វើដល់អញយ៉ាងដូច្នេះ ហើយលើសទៅទៀតផង* នេះគឺជាពាក្យបណ្តាសា (មើល ពន្យល់ ១សយ ៣:១៧) ។

**២០:១១** *គ្រឿងក្រោះអួតអាងខ្លួន ដូចជាអ្នកដែលដោះគ្រឿងចេញនោះឡើយ* ការនិយាយរបៀបនេះ គឺស្រដៀងនឹងការយល់មួយបែបទៀតថា "កុំរាប់កូនមាន់មុនពេលវាមិនទាន់ញាស់មក" ។

ថា ចូរ រៀបចំឡើង គេក៏ដំរៀបគ្នារៀបច្បាំងនឹងទីក្រុង ។

## ស្ដេចអ័ហាប់យកឈ្នះលើស្ដេចបេន–ហាដាឌ់

១៣ខណនោះ មានហោរាម្នាក់[ជ]ចូលទៅគាល់អ័ហាប់
ជាស្ដេចអ៊ីស្រាអែល ទូលថា ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះថា តើឃើញហ្វូងទ័ពធំនេះឬទេ មើលនៅថ្ងៃនេះ អញ
នឹងប្រគល់គេមកក្នុងកណ្ដាប់ដៃឯងហើយ នោះឯងនឹងដឹង[ឈ]
ថាអញនេះជាព្រះយេហូវ៉ាពិត ១៤អ័ហាប់មាន បន្ទូលសួរថា
តើដោយសារអ្នកណា រួចគាត់ទូលឆ្លើយថា ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ គឺដោយសារពួកទ័ពរបស់ចៅហ្វាយ
ខែត្រទាំងប៉ុន្មាន ស្ដេចក៏សួរទៀតថា តើអ្នកណាត្រូវនាំ[ញ]
ទៅបះនឹងគេជាមុន គាត់ទូលឆ្លើយថា គឺជាទ្រង់ព្រះករុណា
១៥ដូច្នេះ ស្ដេចក៏ចេញទៅត្រួតមើលពួកទ័ពរបស់ចៅហ្វាយ
ខែត្រទាំងប៉ុន្មាន ឃើញមានគ្នា១៣២នាក់ បន្ទាប់មក ស្ដេច
ក៏ត្រូវមើលបណ្ដាជន ជាពួកកូនចៅអ៊ីស្រាអែលទាំងអស់
ឃើញមាន៧ពាន់នាក់ ។

១៦គេក៏ចេញទៅនៅពេលថ្ងៃត្រង់ ឯបេន–ហាដាឌ់នឹង
ពួកស្ដេចរងទាំង៣២អង្គ ដែលមកជួយទ្រង់ គេកំពុង
តែសោយស្រាស្រវឹង នៅក្នុងពន្លា[ដ] ១៧ហើយពួកពលទ័ព
របស់ចៅហ្វាយខែត្រទាំងប៉ុន្មានក៏នាំ មុខចេញទៅ បេន–
ហាដាឌ់ក៏ចាត់ម្នាក់ឱ្យទៅក្រៅមើល អ្នកនោះមក ទូលដល់
ទ្រង់វិញថា មានពួកមនុស្សចេញពីក្រុងសាម៉ារីមកហើយ
១៨នោះទ្រង់បង្គាប់ថា ទោះបើគេចេញមកដោយមេត្រី ឬ
ដោយចង់ធ្វើសង្គ្រាមក៏ដោយ គង់តែត្រូវចាប់គេមកទាំង
រស់ដែរ ១៩យ៉ាងនោះ ពួកទ័ពរបស់ចៅហ្វាយខែត្រទាំង

**២០:១៣** ជ ពច ៦:៨ ឈ នក ៦:៧
**២០:១៤** ញ ១:១
**២០:១៦** ដ ១ពវ ១៦:៩
**២០:២២** ឋ ពច ៦:៨ ឌ ២សយ ១១:១
**២០:២៣** ឍ ខ.២៨ អស ៣៦:២០ រម ១:២១–២៣
**២០:២៦** ណ ២សយ ១១:១ ត ខ.៣០ ១សយ ៤:១ ២ពវ ១៣:១៧

ប៉ុន្មាន និងកងទ័ពដែលទៅតាម ក្រោយក៏ចេញពីទីក្រុងទៅ
២០គ្រប់គ្នាក៏សំឡាប់ខ្មាំងសត្រូវដែលតនឹងខ្លួន ដូច្នេះ ពួក
ស៊ីរីគេបែកខ្ញែករត់ទៅ ហើយពួកអ៊ីស្រាអែលក៏ដេញតាម
ឯបេន–ហាដាឌ់ ជាស្ដេចស្រុកស៊ីរី ទ្រង់ជិះសេះរត់រួចជា
មួយនឹងពួកទ័ពសេះ ២១នេះគឺស្ដេចអ៊ីស្រាអែល ទ្រង់ចេញ
ទៅវាយទាំងពួកទ័ពសេះ និងរទេះចំបាំង ប្រហារជីវិតពួក
ស៊ីរីយ៉ាសន្ធឹក ។

២២រួចមក ហោរានោះ[ឋ]ក៏ចូលទៅឯស្ដេចអ៊ីស្រាអែល
ទូលថា សូមទ្រង់ទៅចំរើនកំឡាំងឡើង ហើយខំប្រឹងមើល
ការដែលទ្រង់ធ្វើ ដ្បិតដល់ចូលឆ្នាំថ្មី[ឌ] ស្ដេចស៊ីរីនឹងឡើង
មកច្បាំងនឹងទ្រង់ទៀត ២៣ឯពួកជំនិតខាងស្ដេចស៊ីរី គេទូល
ស្ដេចរបស់ខ្លួនថា ព្រះរបស់គេជាព្រះ[ឍ]នៃភ្នំ បានជាម្ដងនេះ
គេពូកែជាងយើងរាល់គ្នា ដូច្នេះសូមយើងរាល់គ្នាតនឹង
គេនៅស្រុកវាលចុះ នោះប្រាកដជាយើងនឹងបានពូកែជាង
គេវិញ ២៤ហើយត្រូវធ្វើដូច្នេះ គឺត្រូវដកពួកស្ដេចទាំងប៉ុន្មាន
ពីដំណែងរបស់ទ្រង់ចេញ ហើយតាំងឱ្យមានមេទ័ពឡើង
ជំនួសវិញ ២៥រួចសូមលើកពលទ័ព ឱ្យស្មើនឹងពលទ័ពដែល
ទើបនឹងបាត់នោះ គឺចំនួនសេះស្មើគ្នា នឹងចំនួនរទេះក៏ស្មើ
គ្នា នោះយើងរាល់គ្នានឹងច្បាំងនឹងគេនៅស្រុកវាល ប្រាកដ
ជាយើងនឹងមានកំឡាំងជាងគេទ្រង់ក៏យល់ព្រមតាមពាក្យគេ
ហើយបានធ្វើដូច្នោះ ។

២៦លុះដល់ចូលឆ្នាំថ្មី[ណ] បេន–ហាដាឌ់ក៏ត្រួតមើលពួកទ័ព
ស៊ីរី ហើយឡើងទៅដល់ក្រុងអាផែក[ត] ដើម្បីច្បាំងនឹងពួក
អ៊ីស្រាអែល ២៧ពួកកូនចៅអ៊ីស្រាអែលក៏មានគេត្រួតត្រា

**២០:១៣** នៅវគ្គនេះបានប្រាប់ថា ព្រះអម្ចាស់បានវាយផ្ចាល់ពួកស៊ីរីជួយដល់អ័ហាប់ ដូច្នេះអ័ហាប់នឹងស្គាល់ថាព្រះតែមួយអង្គ គឺជាព្រះពិត ។ ទោះជ័យជម្នះដ៏មហិមានេះ បានបន្តរហូតដល់តំបន់វាលរាបទៀត (២០:២៨,២៩) តែអ័ហាប់នៅតែបន្តការរស់នៅដោយគ្មានព្រះទៀត ។ ការនេះបញ្ជាក់ថាជ័យជម្នះរបស់ព្រះគឺនៅជុំវិញយើង តែក្នុងករណីលោកអ័ហាប់យើងពុំគួរធ្វើតាមឡើយ ។ តែប្រសិនបើយើងប្រព្រឹត្តបាប ដូចពួកស្ដេចអ៊ីស្រាអែល នោះយើងនឹងជួបនូវគ្រោះមហន្តរាយ ។ ដូច្នេះ ចូរបើកភ្នែកអ្នកឡើង ហើយក្រឡេកមើលពីជ័យជម្នះរបស់ព្រះដែលមានក្នុងជីវិតរបស់អ្នក ហើយថ្វាយខ្លួនអ្នកទៅព្រះជាថ្មីម្ដងទៀត ។

**២០:១៤** *ចៅហ្វាយខែត្រទាំងប៉ុន្មាន* មើលការពន្យល់ ១៦:២៧ ។

**២០:១៥** *២៣២នាក់... ៧ពាន់នាក់* ចំនួននេះមិនមែនជាកងពលធំដែលមានទាហានច្រើន ប៉ុន្តែវាបង្ហាញថា ជ័យជម្នះគឺបានមកអំពីព្រះ មិនមែនមកពីទ័ពពួកអ៊ីស្រាអែលនោះទេ (ធៀប ពច ៧:២) ។

**២០:២០** *គ្រប់គ្នាក៏សំឡាប់ខ្មាំងសត្រូវដែលតនឹងខ្លួន* នៅត្រង់នេះមើលទៅដូចជាពួកគេកំពុងប្រឈមមុខនិងការគម្រាមកំហែង (មើល ២សយ ២:១៥–១៦) ។ *ទ្រង់ជិះសេះរត់រួចជាមួយនឹងពួកទ័ពសេះ* ពីព្រោះការវាយប្រហារគ្នានៅលើខ្នងសេះមិនបានបន្តរហូតមកដល់ក្រោយទៀត នោះការនេះបញ្ជាក់ថា វាជារទេះចម្បាំង និងអ្នកបររថ ។ ក្រោយពីការវាយប្រហារនោះមក ពួកស៊ីរីហាក់ដូចជាបានដកថយត្រឡប់ទៅឯក្រុងដាម៉ាសវិញ ។

**២០:២២** *ស្ដេចស៊ីរី នឹងឡើងមកច្បាំងនឹងទ្រង់ទៀត* ឃ្លានេះមានន័យថា ជាសេចក្ដីអាថ៌កំបាំងរបស់ពួកហោរា (មើល ខ.១៣) បានព្រមានចំពោះអ័ហាប់ ឱ្យមានការប្រយ័ត្នចំពោះសត្រូវរបស់ខ្លួនដែលនឹងវាយបកវិញ ។ ការប្រកាសរបស់ពួកហោរាអំពីកាលដែលស្ដេច បេន–ដាឌ់ ធ្វើមកលើអ័ហាប់ជាថ្មីម្ដងទៀត នោះគឺគាត់ចង់ឱ្យអ័ហាប់មានសេចក្ដីទំនុកចិត្តដល់ព្រះដែលទ្រង់បានបើសម្ដែងនៅភ្នំកើមែល និងជ័យជម្នះរបស់ពួកពលបរិវា ។

**២០:២៣** នៅក្នុងសម័យលោកយូស្វេ ទាហានរបស់ពួកអ៊ីស្រាអែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាអធិរាជចម្បាំងនៅតាមជើងភ្នំ ប៉ុន្តែមិនពូកែនៅក្នុងការប្រយុទ្ធនៅវាលរាប និងតាមដងទន្លេ ពីព្រោះពួកគេមិនប្រើរទេះចម្បាំងនៅក្នុងសមរភូមិ ។

**២០:២៦** *ក្រុងអាផែក* ក្រុងនេះស្ថិតនៅភាគខាងកើតនៃសមុទ្រកាលីឡេ ។

មើល ហើយចែកស្បៀងអាហារឱ្យដែរ រួចគេចេញទៅ
ទាស់នឹងពួកស៊ីរី ឯពួកកូនចៅអ៊ីស្រាអែល គេបោះទ័ពទល់
មុខនឹងពួកស៊ីរី ដូចជាកូនពពែ២ហ្វូងយ៉ាងតូចតែពួកស៊ីរី
គេ នៅពេញពាសក្នុងស្រុកនោះ[ថ] ២៨ គ្រានោះមានអ្នក
សំណប់របស់ព្រះម្នាក់ បានចូលមកទូលដល់ស្តេចអ៊ីស្រា–
អែលថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ដោយព្រោះ
ពួកស៊ីរី បាននិយាយថា ព្រះយេហូវ៉ាទ្រង់ជាព្រះនៃភ្នំ មិន
មែនជាព្រះ[ទ]នៃស្រុកវាលទេ បានជាអញនឹងប្រគល់ហ្វូងទ័ព
ធំទាំងនេះ មកក្នុងកណ្តាប់ដៃឯង ហើយឯងនឹងដឹង[ធ]ថា
អញនេះជាព្រះយេហូវ៉ាពិត ២៩ គេក៏បោះទ័ពប្រទល់មុខគ្នា
អស់៧ថ្ងៃ ដល់ថ្ងៃទី៧ នោះគេចូលតយុទ្ធគ្នា ក្នុង១ថ្ងៃនោះ
ឯង ពួកកូនចៅអ៊ីស្រាអែលក៏សំឡាប់ពួកពលថ្មើរជើង
របស់សាសន៍ស៊ីរីអស់១សែននាក់ ៣០ ឯសំណល់ដែលសល់
នៅ គេបានរត់ចូលទៅក្នុងក្រុងអាផែក[ន] ហើយកំផែងក្រុង
នោះក៏រលំ[ប]មក សង្កត់ស្លាប់អស់២ម៉ឺន៧ពាន់នាក់ទៀត
ឯបេន–ហាដាឌ់ទ្រង់រត់ចូលទៅក្នុង[ផ]ទីក្រុង ពួននៅក្នុង
បន្ទប់ខាងក្នុង ។
៣១ ពួកជំនិតទ្រង់ទូលថា យើងខ្ញុំបានឮថា អស់ទាំង
ស្តេចនៃពួកអ៊ីស្រាអែល សុទ្ធតែជាស្តេចមានសេចក្តីមេត្តា
ករុណា[ព] ដូច្នេះ សូមយើងរាល់គ្នាស្លៀកសំពត់ធ្មៃ[ភ] ហើយ
ដាក់ខ្សែរូតនៅកចេញទៅគាល់ ស្តេចអ៊ីស្រាអែលប្រហែល
ទ្រង់នឹងទុកជីវិតដល់ព្រះករុណាទេដឹង ៣២ ដូច្នេះគេក៏ស្លៀក

**២០:២៧** ថ ពច ៦:៦ ១សយ ១៣:៦
**២០:២៨** ទ ខ.២៣ ធ នក ៦:៧ យរ ១៦:១៩–២១
**២០:៣០** ន ខ.២៦ ប ទដ ៦២:៤ អស ២៦:២១ ៣០:១៣ ផ ១ពវ ២២:២៥
**២០:៣១** ព យប ៤១:៣ ភ លប ៣៧:៣៤
**២០:៣៤** ម លប ១០:២២ យ ១ពវ ១៥:២០ រ ២សយ ៨:៦ ល លប ១៤:១៥ យរ ៤៩:២៣–២៧ វ នក ២៣:៣២
**២០:៣៥** ស ១សយ ១០:៥ អម ៧:១៤ ហ ១ពវ ១៣:២១
**២០:៣៦** ឡ ១ពវ ១៣:២៤

សំពត់ធ្មៃ ព្រមទាំងដាក់ខ្សែរូតនៅកចេញទៅ គាល់ស្តេច
អ៊ីស្រាអែលទូលថា បេន–ហាដាឌ់ ជាអ្នកបំរើទ្រង់ទូលថា
សូមទុកជីវិតឱ្យទូលបង្គំនៅរស់ផង ស្តេចអ៊ីស្រាអែលទ្រង់
សួរថា ដូច្នេះ តើលោកនៅរស់នៅឡើយឬ លោកជាបង
ប្អូននឹងយើងដែរ ៣៣ អ្នកទាំងនោះបានយកពាក្យនេះទុកជា
ផ្លូវល្អ ក៏ទូលតបភ្លាមថា ហ្នឹងហើយ បងប្អូនទ្រង់ រួចទ្រង់
ប្រាប់គេថា ចូរទៅនាំលោកមក ដូច្នេះបេន–ហាដាឌ់ក៏
ចេញមកគាល់ទ្រង់ ហើយទ្រង់ឱ្យឡើងជិះលើរាជរថជា
មួយនឹងទ្រង់ ៣៤ នោះបេន–ហាដាឌ់ទូល[ម]ទ្រង់ថា អស់ទាំង
ទីក្រុង[យ]ដែលព្រះបិតាទូលបង្គំបានរឹបយកពីព្រះបិតាទ្រង់
នោះទូលបង្គំ នឹងប្រគល់ថ្វាយទាំងអស់វិញ ហើយទ្រង់នឹង
ធ្វើថ្នល់[រ]សំរាប់ទ្រង់នៅក្រុងដាម៉ាសបាន[ល] ដូចជាព្រះបិតា
ទូលបង្គំបានធ្វើនៅក្រុងសាម៉ារីដែរ អ័ហាប់មានបន្ទូល
ឆ្លើយថា ឯខ្ញុំៗនឹងឱ្យលោកទៅវិញ ដោយសេចក្តីសញ្ញា
នេះ[វ] ដូច្នេះ ទ្រង់ក៏តាំងសេចក្តីសញ្ញានឹងគ្នារួចលែងឱ្យទៅ
វិញ។

## ពួកហោរាម្នាក់ថ្កោលទោសស្តេចអ័ហាប់

៣៥ បន្ទាប់មក មានម្នាក់ជាសិស្សពួកហោរា[ស] គាត់និយាយ
ទៅគូកន ដោយព្រះបន្ទូលព្រះយេហូវ៉ាថា សូមឱ្យវាយខ្ញុំចុះ
តែអ្នកនោះមិនព្រមវាយទេ[ហ] ៣៦ គាត់ក៏ប្រាប់ថា ដោយព្រោះ
អ្នកមិនបានស្តាប់តាមព្រះបន្ទូល នៃព្រះយេហូវ៉ា នោះមើល
កាលណាអ្នកចេញពីខ្ញុំទៅ នឹងមានសិង្ហ[ឡ]មកសំឡាប់អ្នក

**២០:២៨** *អ្នកសំណប់របស់ព្រះ* នៅត្រង់នេះមើលទៅដូចជាហោរាដែលលើកឡើងនៅក្នុងខ.១២,១៣ ។ *ឯងនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត* មើលការពន្យល់ ខ.១៣ ។ ព្រះអម្ចាស់នឹងបើកសម្តែងឱ្យឃើញម្តងទៀតថា ទ្រង់សោយរាជ្យលើ ធម្មជាតិ ប្រវត្តិសាស្ត្រ និងពួកសាសន៍ដទៃ ។

**២០:២៩** *១សែននាក់* នៅត្រង់នេះ ចំពោះការរៀបរាប់អំពីចំនួនមនុស្សនៅក្នុងព្រះគម្ពីរ សូមមើល សេចក្តីផ្តើម ។

**២០:៣០** *កំផែងក្រុងនោះក៏រលំ* ឃ្លានេះប្រាប់ថា ព្រះរបស់ពួកអ៊ីស្រាអែលមិនត្រឹមតែផ្តល់ឱ្យពួកគេមានជ័យជម្នះក្នុងសមរភូមិប្រយុទ្ធប៉ុណ្ណោះទេ តែថែមទាំងបង្ករឱ្យពួកស៊ីរីមានគ្រោះមហន្តរាយដោយជញ្ជាំងក្រុងរលំលើទៀតផង ។ *២ម៉ឺន ៧ពាន់នាក់* មើលការពន្យល់ ខ.២៩ ។

**២០:៣១** *ស្តេចនៃពួកអ៊ីស្រាអែល សុទ្ធតែជាស្តេចមានសេចក្តីមេត្តាករុណា* ឃ្លានេះបានប្រាប់ថា ពួកសាសន៍ស៊ីរីបានទទួលស្គាល់ថាស្តេចរបស់ពួកគេខុសពីស្តេចពួកអ៊ីស្រាអែល ដែលស្តេចទាំងនោះមិនមានសេចក្តីមេត្តាករុណា ។ *សំពត់ធ្មៃ . . . ខ្សែរូត* ឃ្លានេះប្រហែលជា និមិត្តសញ្ញានៃការបន្ទាបខ្លួន និងការចុះចូល ។

**២០:៣២** *អ្នកបំរើទ្រង់* ន័យនៅត្រង់នេះជាការនិយាយបែបលើកសរសើរដែលស្តេចបេន–ហាដាឌ់បានទទួលស្គាល់ថា ខ្លួនជាមនុស្សបន្ទាប់បន្សំក្នុងគោលបំណងចុះចូលធ្វើជាអ្នកបម្រើរបស់ស្តេចអ័ហាប់ (មើល ខ.៩) ។ *បងប្អូន* ស្តេចអ័ហាប់ មិនបានយកព្រះទ័យទុកដាក់ចំពោះការធ្វើសម្បទានរបស់ស្តេចបេន–ហាដាឌ់ ហើយអ័ហាប់បានឱ្យពួកអ្នកគ្រប់គ្រងឆ្លើយជំនួសទ្រង់ដែលពួកនោះមានថានៈស្មើរនឹងស្តេចបេន–ហាដាឌ់ (មើល ៩:១៣ និងការពន្យល់) ។ ដោយការធ្វើរបៀបនេះ ស្តេចអ័ហាប់បានផ្តល់ឱ្យអ្វីៗជាច្រើនដល់ស្តេចបេន–ហាដាឌ់លើសជាងទ្រង់រំពឹងទុកទៀត ។

**២០:៣៣** *ចេញមកគាល់ទ្រង់ ហើយទ្រង់ឱ្យឡើងជិះលើរាជ្យរថ* ទង្វើនេះមិនមែនជារឿងធម្មតា តែជាផ្លូវសត្រូវក្នុងសមរភូមិវិញ ។

**២០:៣៤** *ទីក្រុងដែលព្រះបិតាទូលបង្គំបានរឹបយកពីបិតាទ្រង់* ក្រុងរ៉ាម៉ូត–កាឡាត (មើល ២២:៣) នេះប្រហែល ជារបស់ស្តេចបេន–ហាដាឌ់១ ដែលទ្រង់បានរឹបអូស ពីបួាសា (១៥:២០) ។ *តាំងសេចក្តីសញ្ញានឹងគ្នា រួចលែងឱ្យទៅវិញ* នេះជាសេចក្តីសញ្ញាស្តីអំពីភាពស្មើគ្នា (សេចក្តីសញ្ញាសន្តិភាពរវាងភាពស្មើគ្នា) ដែលរួមបញ្ចូលទាំងផ្នែកនយោបាយ ពាណិជ្ជកម្ម ដែលស្នើរឡើងដោយស្តេចបេន–ហាដាឌ់ ។

**២០:៣៥** *ម្នាក់ជាសិស្សរបស់ហោរា* នេះបញ្ជាក់ថា ម្នាក់នេះត្រូវបានរើសទុកជាមុនដើម្បីធ្វើជាគូកនរបស់ពួកហោរា (មើល ២ពវ ២:៣,៥,១៥ ៤:១,៣៨ ៥:២២ ៦:១ ៩:១) ។

**២០:៣៦** *ចេញពីខ្ញុំទៅ នឹងមានសិង្ហមកសំឡាប់អ្នក* នេះជាការរំលឹកឡើងវិញពីការកាត់ទោសលើអ្នកសំណប់ព្រះ មកពីស្រុកយូដា (១៣:២៣–២៤) ។

ដូច្នេះ កាលអ្នកនោះបានចេញពីគាត់ទៅ ក៏មានសិង្ហ១
មកប្រទះ ហើយសំឡាប់ទៅ [៣៧]រួចគាត់ជួបនឹងម្នាក់ទៀត
ប្រាប់ថា សូមឱ្យអ្នកវាយខ្ញុំចុះ អ្នកនោះក៏វាយគាត់ឱ្យមាន
របួស [៣៨]នោះហោរាក៏ក្លែងខ្លួន ដោយយកសំពត់ឈ្នួតមក
បិទភ្នែក រួចទៅនៅចាំស្តេចយាងមកតាមផ្លូវ [៣៩]កាលស្តេច
ទ្រង់យាងមកតាមផ្លូវ នោះគាត់ស្រែកឡើងទូលថា ទូលបង្គំ
បានចេញទៅឯកណ្តាលទីចំបាំងហើយមើល មានម្នាក់ទៀត
បែរមក នាំមនុស្សម្នាក់មកឯទូលបង្គំ ដោយបង្គាប់ថា ចូរ
រក្សាមនុស្សនេះទុក បើវាបាត់ទៅដោយហេតុណា នោះ
ត្រូវយកជីវិតឯងជំនួសវាវិញ[អ] ឬត្រូវឱ្យឯងសងអញជាប្រាក់
១ហាប [៤០]តែកាលទូលបង្គំ កំពុងតែរវល់នេះផងនោះផង
អ្នកនោះក៏បាត់ទៅឯស្តេចអ៊ីស្រាអែល មានបន្ទូលតបថា
ទោសឯងត្រូវដូច្នោះហើយ[ក] គឺខ្លួនឯងបានកាត់សេចក្តី
នោះស្រាប់ [៤១]គាត់ក៏ប្រញាប់នឹងបកសំពត់ពីភ្នែកចេញ
រួចស្តេចអ៊ីស្រាអែលទ្រង់ស្គាល់ថា ជាពួកហោរា [៤២]គាត់ក៏
ទូលដល់ស្តេចថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះហើយ
ថា ដោយព្រោះឯង[ខ]បានលែងមនុស្ស ឱ្យរួចពីដៃឯង ដែល
អញបានកាត់ទោសថា ត្រូវវិនាស[គ] នោះត្រូវយកជីវិតឯង
ជំនួសវាវិញ[ឃ] ហើយរាស្ត្រឯងជំនួសរាស្ត្រវា [៤៣]ដូច្នេះ
ស្តេចអ៊ីស្រាអែល ក៏យាងត្រឡប់ទៅឯដំណាក់នៅក្រុង
សាម៉ារីវិញ ដោយអន់អាក់ថ្នាំងថ្នាក់ព្រះទ័យ[ង] ។

## ចំការទំពាំងបាយជូររបស់ណាបោត

**២១** [១]រីឯណាបោត[ក] ជាអ្នកស្រុកយេសរាល គាត់មាន
ចំការទំពាំងបាយជូរ នៅស្រុកយេសរាល[ខ] ជិតបង្អើយ
និងដំណាក់អ័ហាប់ ជាស្តេចនៃក្រុងសាម៉ារី [២]ហើយក្រោយ
ការទាំងនោះមក អ័ហាប់ក៏មានបន្ទូលនឹងណាបោតថា ចូរ
ឱ្យចំការទំពាំងបាយជូររបស់ឯងមកយើងចុះ ដើម្បីឱ្យយើង
បានធ្វើជាច្បារបន្លែ ដ្បិតនៅជិតដំណាក់របស់យើង យើង
នឹងឱ្យចំការ១ល្អជាងដល់ឯង ឬបើឯងចូលចិត្តនឹងប្រាក់
នោះយើង និងឱ្យតាមដំឡៃចំការនោះវិញ [៣]តែណាបោត
ទូលតបថា សូមព្រះយេហូវ៉ាទ្រង់ឃាត់កុំឱ្យទូលបង្គំថ្វាយ
មរដក[គ]របស់ពួកព្ធយុកោទូលបង្គំ ដល់ព្រះករុណាឡើយ
[៤]អ័ហាប់ក៏ត្រឡប់ទៅឯដំណាក់ទ្រង់វិញ មានព្រះទ័យអន់
អាក់ថ្នាំងថ្នាក់[ឃ] ដោយព្រោះពាក្យដែលណាបោតជា អ្នក
ស្រុកយេសរាលបានទូលដល់ទ្រង់ថា ទូលបង្គំមិនថ្វាយ
មរដករបស់ពួកព្ធយុកោទូលបង្គំ ដល់ព្រះករុណាទេ ហើយ
ទ្រង់ក៏ប្រះផ្ទំ លើព្រះទែនបន្ទំ បែរព្រះភក្ត្រចេញមិនព្រម[ង]
សោយព្រះស្ងោយឡើយ ។
[៥]ឯយេសិបិល ជាភរិយាទ្រង់ ក៏មកទូលសួរថា ហេតុអ្វី
បានជាព្រួយព្រះទ័យ មិនសោយព្រះស្ងោយដូច្នេះ [៦]ទ្រង់
មានបន្ទូលតបថា គឺពីព្រោះអញបាននិយាយនឹងណាបោត
ជាអ្នកស្រុកយេសរាលថា ចូរលក់ ចំការទំពាំងបាយជូរឯង
មកឱ្យយើង ឬបើឯងចូលចិត្ត នោះយើងនឹងឱ្យចំការ១ផ្សេង
ទៀតប្តូរនឹងចំការនេះ តែវាឆ្លើយមកថា ទូលបង្គំមិនថ្វាយ
ចំការទូលបង្គំដល់ទ្រង់ទេ [៧]នោះយេសិបិន ជាភរិយាក៏ទូល
ថា ឥឡូវនេះទ្រង់សោយរាជ្យនៅនគរអ៊ីស្រាអែលមិនមែន
ឬ សូមតើនឡើង សោយព្រះស្ងោយទៅ ឱ្យព្រះទ័យបានរីក
រាយសប្បាយចុះ ខ្ញុំម្ចាស់នឹងថ្វាយចំការទំពាំងបាយជូរ[ច]

**២០:៣៩** អ យស ២:១៤
**២០:៤០** ក ២សយ ១២:៥ ១៤:១៣
**២០:៤២** ខ ២សយ ១២:៧ គ យរ ៤៨:១០ ឃ យស ២:១៤
**២០:៤៣** ង ១ពវ ២១:៤
**២១:១** ក ២ពវ ៩:២១ ខ ១សយ ២៩:១ ២ពវ ១០:១
**២១:៣** គ លវ ២៥:២៣
**២១:៤** ឃ ១ពវ ២០:៤៣ ង ១សយ ២៨:២៣
**២១:៧** ច ១សយ ៨:១៤

**២០:៣៩** *ប្រាក់១ហាប* ពីព្រោះតែ ពួកទាហានសុទ្ធតែអាចចំណាយប្រាក់ជាច្រើនបានដូច្នេះ នោះស្តេចអាហាបបានដាក់កំហិតនេះរហូតដល់ជីវិតរបស់ពួកគេ ។

**២០:៤០** *ទោសឯងត្រូវដូច្នោះហើយ* នេះបញ្ជាក់ថា ស្តេចអ័ហាប់បដិសេធការអត់ទោស ។ គាត់ដឹងថា ខ្លួនគាត់កំពុងប្រកាសកាត់ទោសប្រហាជីវិតរបស់ខ្លួនផងដែរ (ធៀបនឹង ២សយ ១២:១–១២) ។

**២០:៤១,៤២** នៅវគ្គនេះ គឺពិបាកក្នុងការពន្យល់ថា តើហេតុអ្វី បានជាស្តេចអ័ហាប់ អនុញ្ញាតឱ្យស្តេចបេន–ហាដាឌ់រួចខ្លួន ក្រោយពីបញ្ចប់បញ្ហាផ្សេងនៅក្រុងស៊ីរីដែលបង្ករដោយស្តេចអង្គនេះនោះ ។ ព្រះអម្ចាស់ទ្រង់បានជួយដល់អ័ហាប់ក្នុងការវាយផ្ទាល់ពួកកងទ័ពស៊ីរីដើម្បីលើកអ័ហាប់ និងអេរ៉ាមឡើង ដែលទ្រង់តែមួយគត់ដែលជាព្រះពិត ។ ប៉ុន្តែផ្ទុយទៅវិញ អ័ហាប់បានបរាជ័យនៅក្នុងសង្គ្រាមក្នុងការវាយផ្ទាលពួកស្តេចទាំងអស់នោះជាមួយនឹងពួកទាហានដែលមានចំនួនដ៏មហិមា ។ រីឯស្តេចបេន–ហាដាឌ់ត្រូវប្រឈរមុខក្នុងការកាត់ទោសរបស់ព្រះរហូតអស់ជីវិត ហើយអ័ហាប់គ្មានឯកសិទ្ធណាមួយដើម្បីឱ្យស្តេចអង្គនេះបានរួចជីវិតបានឡើយ ។ សម្រាប់ការទាំងអស់នេះ ព្រះអម្ចាស់បានមានបន្ទូលមកកាន់ អ័ហាប់ថា គាត់ត្រូវតែស្លាប់ជំនួសការនេះ ហើយ បានសម្រេចតាមរយៈការបើកសម្តែងតាមរយៈពួកហោរា នៅពេលដែលអ័ហាប់ត្រូវបានសម្លាប់នៅក្នុងសមរភូមិ

**២១:១** *ជិតបង្អើយ នឹងដំណាក់អ័ហាប់* ឃ្លានេះបានប្រាប់ថា ស្តេចអ័ហាប់នៅតែស្នាក់នៅក្នុងស្រុយេសរាល ទោះជាមានដំណាក់នៅក្នុងក្រុងសាម៉ារី (មើល ១៨:៤៥ ២ពវ ៩:៣០) ។ *សាម៉ារី* មើលការពន្យល់ ១៦:២៤ ។

**២១:២** *ចូឱ្យចំការទំពាំងបាយជូររបស់ឯងមកយើងចុះ* ឃ្លានេះ បានប្រាប់ថា អំណាចរបស់ពួកស្តេចនៅអ៊ីស្រាអែល ត្រូវបានកំណត់តាមសេចក្តីសញ្ញារបស់ព្រះ (មើល ចទ ១៤–២០ ១សយ ១០:២៥) ដូច្នេះ ស្តេចអ័ហាប់មិនអាចរឹបអូសទ្រព្យសម្បត្តិនៅលើទឹកដីនេះទេ គឺដូចនឹងស្តេចពួកសាសន៍កាណានដែរ (មើលពន្យល់ ខ.៧ បន្ថែម ១សយ ៨:៩–១៧) ។

**២១:៣** ការបដិសេធរបស់ណាបោត ចំពោះការលះបង់ដីដែលស្ថិតក្រោមការកាត់ក្តី ដែលដីនេះជាកម្មសិទ្ធរបស់ព្រះ ។
(មើល ២២:៣៥) ។

**២១:៧** *ទ្រង់សោយរាជ្យនៅអ៊ីស្រាអែមិនមែនឬ* ពាក្យនេះជាការនិយាយចំអកបែបមិនពិត ដែលពួកគេស៊ាំក្នុងការចំអកឡកឡើយ ទៅដល់ពួកអ្នកដែលរស់នៅតាមឆ្នេរសមុទ្រមេឌីទែរ៉ាណេ និងពួកស្តេចកាណាន ។

របស់ណាបោត ជាអ្នកស្រុកយេសរាលដល់ទ្រង់ ៨នោះព្រះ
នាងក៏ធ្វើសំបុត្រ[ឆ] ដោយនូវព្រះនាមអ័ហាប់ ហើយប្រថាប់
ត្រាផែនដី[ជ] រួចផ្ញើទៅពួកចាស់ទុំ នឹងពួកអ្នកមានត្រកូល
ខ្ពស់ ដែលនៅក្នុងទីក្រុងជាមួយនឹងណាបោត ៩ក្នុងសំបុត្រ
នោះ ព្រះនាងបង្គាប់ថា ចូរប្រកាសប្រាប់ឱ្យមានបុណ្យ
ត្រណម ហើយតាំងណាបោត ឱ្យអង្គុយនៅទីដ៏ប្រសើរ
កណ្ដាលពួកជន ១០រួចនាំមនុស្សខូចអាក្រក់[ឈ]២នាក់មកឱ្យ
ឈរនៅមុខវា ដើម្បីធ្វើបន្ទាស់ទាស់នឹងវាថា វាបាន
ប្រមាថ[ញ]ដល់ព្រះ ហើយដល់ស្ដេចផង ស្រេចហើយ ចូរនាំ
វាចេញទៅក្រៅ ចោលនឹងថ្មសំឡាប់ទៅ ។
១១ពួកមនុស្សនៅក្រុងរបស់គាត់ គឺជាពួកចាស់ទុំ និងពួក
អ្នកមាន ត្រកូលខ្ពស់ដែលនៅទីក្រុងជាមួយនឹងគាត់ គេក៏ធ្វើ
តាមសេចក្ដីដែលយេសិបិលបានបង្គាប់ ដូចជាសេចក្ដីដែល
ព្រះនាងបានសរសេរចុះក្នុងសំបុត្រ ផ្ញើទៅគេ ១២គេក៏
ប្រកាសប្រាប់ឱ្យមានបុណ្យត្រណម[ដ] ហើយដាក់ណាបោត
ឱ្យអង្គុយនៅទីដ៏ប្រសើរកណ្ដាលពួកជន ១៣រួចមានមនុស្ស
ខូចអាក្រក់២នាក់ ចូលមកអង្គុយខាងមុខណាបោត ធ្វើ
បន្ទាល់ទាស់នឹងគាត់នៅមុខបណ្ដាជនថា ណាបោតនេះបាន
ប្រមាថដល់ព្រះ ហើយដល់ស្ដេចផង ដូច្នេះ គេនាំយកគាត់
ចេញទៅឯក្រៅទីក្រុង ហើយចោលសំឡាប់នឹងថ្មទៅ[ឋ]
១៤រួចហើយគេចាត់មនុស្សឱ្យទៅទូល យេសិបិនឱ្យជ្រាបថា
បានចោលសំឡាប់ណាបោតនឹងថ្មហើយ ១៥កាលយេសិបិល
បានឮថា គេបានចោលសំឡាប់ណាបោតនឹងថ្មហើយ
ដូច្នោះ នោះព្រះនាងក៏ទូលអ័ហាប់ថា សូមតើនឡើងទទួល
យកចំការ[ឌ] របស់ណាបោត ជាអ្នកស្រុកយេសរាល ដែល
វាមិនព្រមលក់ថ្វាយ នោះមកទុកជារបស់ផងទ្រង់វិញចុះ
ពីព្រោះណាបោតមិននៅរស់ទៀតទេ គឺវាស្លាប់ហើយ
១៦ដូច្នេះ កាលអ័ហាប់បានជ្រាបថាណាបោតបានស្លាប់
នោះទ្រង់ក៏តើនឡើង ដើម្បីចុះទៅឯចំការរបស់ណាបោត
ជាអ្នកស្រុកយេសរាល ប្រយោជន៍នឹងយកធ្វើជារបស់ផង
ទ្រង់ទៅ ។
១៧ខណនោះ ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់
អេលីយ៉ាជាអ្នកស្រុកធេសបីថា ១៨ចូរក្រោកឡើងចុះទៅ
ជួបនឹងអ័ហាប់ ជាស្ដេចអ៊ីស្រាអែល ដែលគង់នៅក្រុង
សាម៉ារីទៅ មើលទ្រង់នៅក្នុងចំការរបស់ណាបោតទ្រង់
បានចុះទៅទទួលយកចំការនោះ ទុកជារបស់ផងទ្រង់
១៩ដូច្នេះ ឯងត្រូវទទូលថា ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះ តើឯងបានសំឡាប់ ហើយបានទាំងរឹបជាន់យករបស់
ទ្រព្យផងមែនឬ[ឍ] ក៏ត្រូវទូលដូច្នេះទៀត ព្រះយេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា នៅកន្លែងដែលឆ្កែ[ណ]បានលិទ្ធឈាម[ត]
របស់ណាបោតនោះនឹងលិទ្ធឈាមរបស់ឯងដែរ ២០អ័ហាប់
មានបន្ទូលតបថា ឱខ្មាំងសត្រូវយើងអើយ[ថ] តើឯងមកតាម
យើងទាន់ហើយឬ លោកទូលឆ្លើយថា ទាន់ហើយពីព្រោះ
ព្រះករុណាបានលក់[ទ]ព្រះអង្គទ្រង់ ឱ្យធ្វើអំពើដ៏លាមក
អាក្រក់នៅព្រះនេត្រព្រះយេហូវ៉ា ២១មើល អញនឹងនាំ
សេចក្ដីវេទនាមកលើឯង អញនឹងបោសឯងចេញអស់
រលីង ហើយនឹងកាត់អស់ទាំងកូនប្រុសៗ[ធ]ពីអ័ហាប់ចេញ
ព្រមទាំងអ្នកបិទបាំងទុក និងអ្នកដែលឥតមានចំណង[ន]ក្នុង
ពួកអ៊ីស្រាអែលផង ២២អញនឹងធ្វើឱ្យជិន្នូរវង្សរបស់ឯង[ប]

**២១:៨** ឆ ២សយ ១១:១៤ ជ លប ៣៩:១៨
**២១:១០** ឈ ចទ ១៣:១៣ កច ៦:១១ ញ នក ២២:២៨ លវ ២៤:១៥–១៦
**២១:១២** ដ អស ៥៨:៤
**២១:១៣** ឋ លវ ២៤:១៦
**២១:១៥** ឌ ១សយ ៨:១៤
**២១:១៩** ឍ យប ២៤:៦ ៣១:៣៩ ណ ២ពវ ៩:២៦ ទដ ៩:១២ អស ១៤:២០ ត ១ពវ ២២:៣៨ ទដ ៦៨:២៣ យរ ១៥:៣
**២១:២០** ថ ១ពវ ១៨:១៧ ទ ២ពវ ១៧:១៧ រម ៧:១៤
**២១:២១** ធ ពច ៩:៥ ២ពវ ១០:៧ ន ចទ ៣២:៣៦

**២១:៩** *ប្រកាសឱ្យមានបុណ្យត្រណម* នៅត្រង់នេះ យេសិបិលមានបំណង បង្កើតចំណាប់អារម្មណ៏ដល់ពួកមនុស្សទាំងនោះថា គ្រោះមហន្តរាយនឹងកើតមានហើយគម្រាគំហែងពួកគេ ក្នុងន័យឱ្យពួកគេត្រូវតែរៀបចំខ្លួន ដើម្បីជៀសពីការនេះ ដូច្នេះពួកគេត្រូវតែបន្ទាបខ្លួន មុនពេលព្រះអម្ចាស់កាត់ទោសបាបរបស់ពួកគេ (ធៀប ពច ២០:២៦ ១សយ ៧:៥–៦ ពរប ២០:២–៤) ។
**២១:១០** *២នាក់* នៅត្រង់នេះសំដៅក្រឹត្យវិន័យលោកម៉ូសេ ដែលតម្រូវឱ្យមានពីរនាក់ធ្វើជាបន្ទាល់ក្នុងការកាត់ទោសប្រហារជីវិត (ជន ៣៥:៣០ ចទ ១៧:៦ ១៩:១៥) ។ *មនុស្សខូចអាក្រក់* មើលការពន្យល់ ចទ ១៣:១៣ ។ *ធ្វើបន្ទាល់ទាស់នឹងវាថា* សូមមើល នក ២០:១៦ ២៣:៧ លវ ១៩:១៦ ។ *ប្រមាថដល់ព្រះ ហើយស្ដេចផង* ទោសកំហុសនៅត្រង់នេះ ក្រឹត្យវិន័យរបស់លោកម៉ូសេតម្រូវឱ្យចោលនឹងថ្មសម្លាប់ (លវ ២៤:១៥–១៦) ។
**២១:១៣** *ចេញទៅឯក្រៅទីក្រុង* ទង្វើនេះគឺធ្វើតាមអ្វីដែលមានចែងនៅក្នុងក្រឹត្យវិន័យលោកម៉ូសេ (លវ ២៤:១៤ ជន ១៥:៣៥–៣៦) ។ ណាបោត ត្រូវបានចោលសម្លាប់នឹងថ្មនៅក្នុងដីរបស់ខ្លួន (ធៀប ខ.១៩ និង ២ពវ ៩:២១,២៦) និងកូនប្រុសរបស់គាត់ក៏ត្រូវគេចោលនឹងថ្មសម្លាប់ជាមួយនឹងគាត់ពេលនោះដែរ (មើល ២ពវ ៩:២៦ ធៀប ជាមួយលោកអេកាន យស ៧:២៤–២៥) ដូច្នេះទ្រព្យសម្បត្តិដែលគាត់មានទាំងប៉ុន្មានត្រូវធ្លាក់ទៅលើកូនចៅជិនាន់ក្រោយមកទៀត ។
**២១:១៩** *តើឯងសំឡាប់ ហើយបានទាំងរឹបជាន់យករបស់ទ្រព្យ ផងមែនឬ* នៅត្រង់នេះ បញ្ជាក់ថា ស្ដេចអ័ហាប់បានចូលរួមជាមួយនឹងគម្រោងការណ៏អាក្រក់របស់យេសិបិល ដែលធ្វើឱ្យខ្លួនគាត់ក្លាយជាមានទោសពីបទ សម្លាប់ និងលួច ។ *កន្លែងដែលឆ្កែ . . . នោះនឹងលិទ្ធឈាមរបស់ឯង* លទ្ធផលរបស់ស្ដេចអ័ហាប់គឺទ្រង់បានបន្ទាបខ្លួន (ខ.២៩) ហើយទោសកំហុសរបស់ទ្រង់ត្រូវបានអត់ឱ្យនឱ្យ ហើយសេចក្ដីវេទនាទាំងប៉ុន្មានត្រូវធ្លាក់មកលើបុត្ររបស់ទ្រង់វិញ (សូមមើល ២ពវ ៩:២៥–២៦) ។ ស្ដេចអ័ហាប់បានសុគតនៅក្នុងសមរភូមិនៃក្រុងរ៉ាម៉ូត–កាឡាត (២២:២៩–៣៧) ហើយសាកសពរបស់ព្រះអង្គត្រូវបានបញ្ជូនទៅស្រុកសាម៉ារីជាទីដែលសត្វឆ្កែបានលិទ្ធឈាមគាត់ និងគេលាងរទេះរបស់ទ្រង់ (២២:៣៨) ។
**២១:២១** *បិទបាំងទុកនឹងអ្នកដែលឥតមានចំណង* មើលការពន្យល់ ១៤:១០។

បានដូចជាជិន្នូរវង្សរបស់យេរ៉ូបោម ជាកូននេបាត ហើយ
ដូចជាជិន្នូរវង្សរបស់បា្អសា ជាកូនអ័ហ៊ីយ៉ាដោយព្រោះ
ការប្រទាំង ដែលឯងបានធ្វើឱ្យអញបានក្នាញ់ក្នុងព្រះទ័យ
ហើយបានបណ្តាលឱ្យពួកអ៊ីស្រាអែលធ្វើបាបដែរ[ផ] ២៣ព្រះ
យេហូវ៉ាក៏មានបន្ទូលពីដំណើរយេសិបិលដែរថា ឆ្កែ[ព]នឹង
ទំពាស៊ីយេសិបិល នៅជិតកំផែងក្រុងយេសរាល ២៤អ្នកណា
ក្នុងពូជពង្សអ័ហាប់ ដែលស្លាប់នៅក្នុងទីក្រុង នោះឆ្កែ[ភ]នឹង
ទំពាស៊ី ហើយអ្នកណាដែលស្លាប់នៅទីវាល នោះសត្វហើរ
លើអាកាស[ម]នឹងចឹកស៊ីវិញ ២៥ពីឯអ័ហាប់គ្មាន[យ] អ្នកណាមួយ
ឱ្យដូចទ្រង់ ដែលបានលក់ខ្លួនឱ្យធ្វើអំពើដ៏លាមកអាក្រក់
នៅព្រះនេត្រព្រះយេហូវ៉ា ដែលយេសិបិលជាភរិយាបាន
ញុះញង់នោះទេ ២៦ទ្រង់បានប្រព្រឹត្តបែបគួរស្អប់ខ្ពើម
ណាស់ ដោយគោរពប្រតិបត្តិតាមអស់ទាំងរូបព្រះតាមគ្រប់
ទាំងទំនៀមរបស់សាសន៍អាម៉ូរី[រ] ដែលព្រះយេហូវ៉ាទ្រង់
បានបណ្តេញ ពីមុខពួកកូនចៅអ៊ីស្រាអែលចេញ ។
២៧កាលអ័ហាប់បានឮពាក្យទាំងនោះហើយ នោះទ្រង់ក៏
ហែកព្រះពស្ត្រទ្រង់ រួចស្លៀកសំពត់ធ្មៃវិញ[ល] ហើយតម
ព្រះស្ងោយ ទ្រង់ផ្ទំទាំងសំពត់ធ្មៃនោះ ហើយក៏យាងមួយៗ[វ]
២៨នោះព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់អេលីយ៉ា ជា
អ្នកស្រុកធេសប៊ីថា ២៩ឯងបានឃើញឬទេ អ័ហាប់បន្ទាប
ខ្លួន[ស] នៅមុខអញហើយ ដូច្នេះ ដោយព្រោះបានបន្ទាបខ្លួន
នៅមុខអញ នោះអញមិននាំសេចក្តីវេទនានោះ មកក្នុងគ្រា
ព្រះជន្មទ្រង់ទេ[ហ] គឺអញនឹងនាំសេចក្តីវេទនានោះ មកលើ
ជិន្នូរវង្សទ្រង់ក្នុងគ្រា នៃបុត្រទ្រង់វិញ[ឡ]។

## មីកាយ៉ាថ្លែងទំនាយទាស់នឹងស្តេចអ័ហាប់

*២២:១–២៨ – ២របា ១៨:១–២៧*

**២២** ១ក្នុងរវាង៣ឆ្នាំនោះ សាសន៍ស៊ីរី និងសាសន៍
អ៊ីស្រាអែល ឥតមានចំបាំងនឹងគ្នាឡើយ ២តែដល់ឆ្នាំទី៣
នោះយ៉ូសាផាត ជាស្តេចយូដា ទ្រង់យាងចុះមកគាល់ស្តេច
អ៊ីស្រាអែល ៣ហើយស្តេចអ៊ីស្រាអែលទ្រង់ មានបន្ទូលនឹង
ពួកជំនិតទ្រង់ថា អ្នករាល់គ្នាដឹងហើយថា ក្រុងរ៉ាម៉ូត–
កាឡាត[ក]ជារបស់ផងយើង ចុះហេតុអ្វីបានជាយើងនៅតែ
ស្ងៀមឥតទៅ ចាប់យកពីកណ្តាប់ដៃស្តេចស៊ីរីមកវិញដូច្នេះ
៤រួចទ្រង់ទូលសួរយ៉ូសាផាតថា តើទ្រង់នឹងទៅច្បាំង[ខ]នឹង
ក្រុងរ៉ាម៉ូត–កាឡាត ជាមួយនឹងទូលបង្គំឬទេ យ៉ូសាផាត
ទូលឆ្លើយថា ទូលបង្គំក៏ដូចជាទ្រង់ រាស្ត្ររបស់ទូលបង្គំ
ក៏ដូចជារាស្ត្ររបស់ទ្រង់ ហើយសេះរបស់ទូលបង្គំទាំង
ប៉ុន្មាន ក៏ដូចជាសេះរបស់ទ្រង់ដែរ ។
៥តែយ៉ូសាផាតទូលដល់ស្តេចអ៊ីស្រាអែលថា សូមទ្រង់

**២១:២២** ប ១ពវ ១៦:៣ ផ ១ពវ ១២:៣០ **២១:២៣** ព ២ពវ ៩:១០,៣៤–៣៦ **២១:២៤** ភ ១ពវ ១៤:១១ ម លប ៤០:១៩ ចទ ២៨:២៦ **២១:២៥** យ ១ពវ ១៤:៩ ១៦:៣៣ **២១:២៦** រ លប ១៥:១៦ **២១:២៧** ល លប ៣៧:៣៤ យរ ៤:៨ វ អស ៣៨:១៥ **២១:២៩** ស នក ១០:៣ ហ នក ៣២:១៤ ២ពវ ២២:២០ ឡ នក ២០:៥ ២ពវ ៩:២៦ ១០:៦–១០ **២២:៣** ក ចទ ៤:៤៣ **២២:៤** ខ ២ពវ ៣:៧

**២១:២២** *ដូចជាជិន្នូរវង្សរបស់យេរ៉ូបោម* សូមមើល ការពន្យល់ ១៤:១០ ១៥:២៨–៣០ ។ *ដូចជាជិន្នូរវង្សរបស់បា្អសា* សូមមើលការពន្យល់ ១៤:១១, ១១–១៣ ។

**២១:២៤** សូមមើលការពន្យល់ ១៤:១១ ១៦:៤ ។

**២១:២៥** *អំពើដ៏លាមកអាក្រក់នៅ ព្រះនេតព្រះយេហូវ៉ា ដែលយេសិបិល* សូមមើល ១៦:៣១ ១៨:៤ ១៩:១–២ ២១:៧ ។

**២១:២៦** *រូបព្រះ* មើលការពន្យល់ លវ ២៦:៣០ ។ *សាសន៍អាម៉ូរី* សាសន៍នេះបានមករស់នៅមុនពួកអ៊ីស្រាអែលនៅលើទឹកដីកាណាន (មើល លប ១៥:១៦ ចទ ១:៧) ។

**២១:២៧** *សំពត់ធ្មៃ* សូមមើលការពន្យល់ លប ៣៧:៣៤ ។

**២១:២៩** *ដោយព្រោះ . . .នោះអញមិននាំសេចក្តីវេទនា* សូមមើល យហ ៣:១០ ។ *គ្រានៃបុត្រទ្រង់វិញ* នៅត្រង់នេះបង្ហាញពីការកាត់ទោស ត្រូវបានលើកពេលមកក្រោយមកទៀត ប៉ុន្តែមិនត្រូវលើកលែងឡើយ (មើលការពន្យល់ ឧ.១៩) ។

**២២:១** *៣ឆ្នាំ* មើលការពន្យល់ ២០:១ ។ *ឥតមានចំបាំងនឹងគ្នាឡើយ* កំណត់ត្រាប្រវត្តិសាស្ត្ររបស់ពួកស៊ីរីនៃស្តេចសាលម៉ានទី៣ (៨៥៩–៨២៤មុនគ.ស) ដែលបានកត់ត្រាឈ្មោះអ្នកចូលរួម "ស្តេចអ័ហាប់របស់ពួកអ៊ីស្រាអែល" និង "បេន–ហាដាឌ់ស្តេចក្រុងដាម៉ាស" ដែលចងជាសម្ព័ន្ធទាំង១២ ដែលវាយប្រហារលើពួកកងទ័ពស៊ីរីនៅក្នុងតំបន់កាកា (qarqar) នៅតាមដងទន្លេ (Orontes) នៅក្នុងឆ្នាំទី៨៥៣មុនគ.ស ។ យោងលើកំណត់ត្រារបស់ពួកស៊ីរីបានបញ្ជាក់ថា ស្តេចអ័ហាប់បានផ្តល់កងទ័ពសេះចំនួន ២០០០ពាន់ និងទ័ពជើងគោកចំនួន ១០.០០០នាក់ដល់សម្ព័ន្ធមិត្រនេះផងដែរ ។ ពួកស៊ីរីបានប្រកាសជ័យជម្នះ តាំងពីពួកគេ បានដកថយចេញ និងឈប់ ទន្ទ្រានចូលទៅភាគខាងលិចម្តងទៀត ក្នុងរយៈពេលពី៤ទៅ៥ឆ្នាំមក ។

**២២:២** *យ៉ូសាផាត ជាស្តេចយូដា ទ្រង់យាងចុះមកគាល់ស្តេចអ៊ីស្រាអែល* នៅត្រង់នេះប្រហែលជាស្តេចយ៉ូសាផាតទ្រង់មានបំណងចង់អបអរសាទរដល់ស្តេចស្រុកអ៊ីស្រាអែលក្នុងការយកលើជ័យជម្នះលើពួកស៊ីរី (សូមមើលពន្យល់ ឧ.១ ២របា ១៨:២) ។

**២២:៣** *ក្រុងរ៉ាម៉ូត–កាឡាត* ក្រុងនេះស្ថិតនៅជិតដងទន្លេស្រុកស៊ីរី ជាក្រុងរបស់ពួកអ៊ីស្រាអែលក្នុងសម័យលោកម៉ូសេ (សូមមើល ៤:១៣ ចទ ៤:៤៣ យស ២០:៨) ។ *ជារបស់ផងយើង* ឃ្លានេះបញ្ជាក់ថា ពួកគេគួរតែទទួលបានក្រុងរ៉ាម៉ូត–កាឡាតនេះ តាមសេចក្តីសញ្ញារបស់បេន–ហាដាឌ់តាំងពីពីរបីឆ្នាំមុនដំបូងម្លេះ (មើល ២០:៣៤) ។

**២២:៤** *ទ្រង់ទូលសួរយ៉ូសាផាតថា* មកដក់ត្រង់នេះស្តេចអ័ហាប់មិនចង់ឱ្យស្តេចយ៉ូសាផាតចូលរួមក្នុងសមរភូមិប្រយុទ្ធជាមួយនឹងទ្រង់ទេ ។ *ទូលបង្គំក៏ដូចជាទ្រង់ រាស្ត្ររបស់ទូលបង្គំក៏ដូចជារបស់ទ្រង់ ហើយសេះរបស់ទូលបង្គំទាំងប៉ុន្មានក៏ដូចជាសេះរបស់ទ្រង់ដែរ* សម្ព័ន្ធមិត្រនេះ យ៉ូសាផាតបានប្រព្រឹត្តដូចនឹងអេសាបិតារបស់ព្រះអង្គ ដែលទ្រង់បានសហការជាមួយពួកសាសន៍ស៊ីរីដើម្បីប្រឆាំងនឹងបា្អសា (មើល ១៥:១៧–២៣) ។

**២២:៥** *សូមទូលសួរព្រះបន្ទូលនៃព្រះយេហូវ៉ា* នៅត្រង់នេះ យ៉ូសាផាត មាន

ទូលសួរព្រះបន្ទូល[គ]នៃព្រះយេហូវ៉ាជាមុនសិន 6ដូច្នេះស្តេច
អ៊ីស្រាអែលក៏ប្រមូលពួកហោរាប្រហែលជា៤០០នាក់មក
សួរថា តើត្រូវឱ្យយើងចេញ[ឃ]ទៅច្បាំង និងរ៉ាម៉ូត–កាឡាត
ឬឈប់ខាន គេទូលឆ្លើយថា សូមយាងឡើងទៅចុះ ដ្បិតព្រះ
អម្ចាស់ទ្រង់នឹងប្រគល់គេ មកក្នុងកណ្តាប់ព្រះហស្តនៃព្រះ
ករុណាហើយ[ង] 7តែយ៉ូសាផាតសួរថានៅទីនេះ តើគ្មាន
ហោរា[ច]ណាម្នាក់របស់ព្រះយេហូវ៉ា ល្មមឱ្យយើងសួរ[ឆ]គាត់
ដែរទេឬ 8ស្តេចអ៊ីស្រាអែលទូលឆ្លើយថា មានម្នាក់ទៀត
ដែលល្មមឱ្យយើងទូលសួរដល់ព្រះយេហូវ៉ាបាន គឺឈ្មោះ
មីកាយ៉ា ជាកូនយីមឡា តែទូលបង្គំស្អប់[ជ]វា ដ្បិតវាមិន
ដែលទាយល្អ[ឈ] ពីទូលបង្គំសោះ គឺចេះតែទាយអាក្រក់វិញ
យ៉ូសាផាតទូលថាសូមទ្រង់កុំមានបន្ទូលដូច្នោះឡើយ 9នោះ
ស្តេចអ៊ីស្រាអែល ទ្រង់ហៅមហាតលិកម្នាក់មកបង្គាប់ថា
ចូរទៅនាំមីកាយ៉ាជា កូនយីមឡាមកនេះជាឆាប់ៗ 10ឯ
ស្តេចអ៊ីស្រាអែល និងយ៉ូសាផាត ជាស្តេចស្រុកយូដា ទ្រង់
ព្រះពស្ត្ររាជ្យគង់លើបល្ល័ង្ករៀងអង្គត្រង់ទីធ្លា[ញ] នៅទ្វារ
ក្រុងសាម៉ារី ហើយពួកហោរាក៏ឈរទាយ នៅចំពោះទ្រង់
11ឯសេដេគា[ដ] ជាកូនក្នាណា គាត់បានធ្វើស្នែងដែក ហើយ
ក៏ទូលថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ព្រះករុណា
នឹងជល់ពួកស៊ីរីដោយស្នែងនេះ[ឋ] ដរាបដល់វិនាសសូន្យទៅ
12ហើយពួកហោរាទាំងអស់ ក៏ទាយដូច្នោះដែរថា សូម
យាងឡើងទៅឯរ៉ាម៉ូត–កាឡាត ហើយមានជ័យជំនះចុះ
ដ្បិតព្រះយេហូវ៉ាទ្រង់នឹងប្រគល់ក្រុងនោះ មកក្នុងកណ្តាប់
ព្រះហស្តនៃព្រះករុណាហើយ ។
13រីឯអ្នកដែលទៅហៅមីកាយ៉ាមក ក៏ប្រាប់គាត់ថាមើល
ពួកហោរាទាំងអស់ សុទ្ធតែទាយល្អដល់ស្តេចព្រមគ្នា ដូច្នេះ
សូមឱ្យពាក្យលោក បានដូចជាពាក្យរបស់ហោរាទាំងនោះ
ដែរ ដោយពោលតែសេចក្តីល្អចុះ[ឍ] 14តែមីកាយ៉ាឆ្លើយថា
ខ្ញុំស្បថដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់ថា សេចក្តី
ណាដែលព្រះយេហូវ៉ាមានបន្ទូលមកខ្ញុំ នោះខ្ញុំនឹងបញ្ចេញ
តាមសេចក្តីនោះ[ឍ] 15រួចកាលបានចូលទៅគាល់ស្តេច
ហើយ នោះទ្រង់មានបន្ទូលសួរថា មីកាយ៉ាអើយ តើត្រូវឱ្យ
យើងទៅច្បាំងនឹងរ៉ាម៉ូត–កាឡាត ឬឈប់ខានគាត់ទូលឡក
ថា សូមយាងទៅ ហើយមានជ័យជំនះចុះ ដ្បិតព្រះយេហូវ៉ា
ទ្រង់នឹងប្រគល់គេមក ក្នុងកណ្តាប់ព្រះហស្តនៃព្រះករុណា
ហើយ 16ដូច្នេះ ស្តេចទ្រង់មានបន្ទូលថា អញបានស្តីឯង
ប៉ុន្មានដងហើយ ឱ្យនិយាយតែសេចក្តីពិតប៉ុណ្ណោះ ដោយនូវ
ព្រះនាមព្រះយេហូវ៉ា 17គាត់ទូលឆ្លើយថា ទូលបង្គំបាន
ឃើញពួកអ៊ីស្រាអែលត្រូវខ្ចាត់ខ្ចាយ[ណ]នៅលើភ្នំ ប្រៀបដូច

**២២:៥** គ នក ៣៣:៧ ២ពវ ៣:១១ យប ៣៨:២ ទដ ៣២:៨ ៧៣:២៤ ១០៧:១១
**២២:៦** ឃ ពច ១៨:៦ ង ១ពវ ១៣:១៨
**២២:៧** ច ចទ ១៨:១៥ ២ពវ ៣:១១ ៥:៨ ឆ ជន ២៧:២១ ២ពវ ៣:១១
**២២:៨** ជ អម ៥:១០ ឈ ខ.១៣ អស ៥:២០ ៣០:១០ យរ ២៣:១៧
**២២:១០** ញ ពច ៦:៣៧
**២២:១១** ដ ខ.២៤ ឋ ចទ ៣៣:១៧ យរ ២៧:២ ២៨:១០ សក ១:១៨–២១
**២២:១៣** ឍ ខ.៨
**២២:១៤** ឍ ជន ២២:១៨ ១សយ ៣:១៧ **២២:១៧** ណ លប ១១:៤ ណាហ ៣:១៨

សេចក្តីស្ទាក់ស្ទើក្នុងការបន្តគម្រោងការណ៍របស់ខ្លួនដោយមិនបានគិតដល់ពីសេចក្តីសង្គ្រោះរបស់ព្រះ (មើល ១សយ ២៣:១–៤ ២សយ ២:១) ។

**២២:៦** *ពួកហោរា* នេះគឺមិនមានការពាក់ពន្ធ័នឹងការថ្វាយបង្គំព្រះដទៃនៅក្រុងបេត–អែលទេ(មើលការពន្យល់ ១២:២៨–២៩) ពួកគេបានប្រកាសជាផ្លូវការថា ពួកគេធ្វើរបៀបយ៉ាងដូច្នេះដើម្បីឱ្យស្តេចមានការសប្បាយព្រះទ័យ (សូមមើល ៧:១០–១៣) ។

**២២:៧** *នៅទីនេះ តើគ្មានហោរាណាម្នាក់របស់ព្រះយេហូវ៉ា* នេះបញ្ជាក់ថា យ៉ូសាផាត ទទួលស្គាល់ថាហោរាទាំង៤០០រយនាក់នេះ មិនត្រូវបានគាត់ពឹងពាក់អាស្រ័យឡើយ(សូមមើល អគ ១៣:២–៣) ហើយគាត់នៅតែទទូចសូមហោរាដ៏ពិតមកអំពីព្រះយេហូវ៉ាទៀត ។

**២២:៨** *វាមិនដែលទាយល្អពីទូលបង្គំសោះ* ពាក្យនេះជាការសន្និដ្ឋានរបស់ស្តេចអ័ហាប់ដោយពឹងផ្អែកលើខ្លួន ព្រះអង្គផ្ទាល់ (សូមមើល ១៨:១៧ ២១:២០) ។

**២២:១០** ការផ្អាកសកម្មភាព នៃការពិពណ៌នាជារូបភាពនៅលើផែនដី (រាជ្យបាល្ល័ង្គនៃស្តេច និងភាពរុងរឿងរបស់ទ្រង់ត្រូវបានឡោមព័ទ្ធដោយអ័ហាប់ដែលជាអ្នកជំនិត និងដោយផែនការបញ្ចុះបញ្ចូលដោយសម្ងាត់ដើម្បីដណ្តើមជ័យជម្នះ) រូពភាពខ្លីៗបែបនេះនឹងត្រូវបានពិណ៌នារបស់ស្ថានសួគ៌ (អ៊ីស្រាអែលគឺជារាជ្យបល្ល័ង្គដ៏ធំមួយនៃការឡោមព័ទ្ធដោយស្ថានសួគ៌ ដើម្បីបញ្ចុះបញ្ចូលក្នុងការប្រឆាំងនឹងស្តេចអ័ហាប់ ខ.១៩–២៣) ។ តាមអ្នករាយការណ៍របស់ស្តេចអ័ហាប់ និងស្តេចយ៉ូសាថាតដែលត្រូវអង្គុងក្នុងទីលានបោកស្រូវ (មីក ៤:១២) ហើយគ្រាប់ពូជនឹងត្រូវខ្ចាត់ខ្ចាយ (យរ ១៥:៧) ។

**២២:១១** *សេដេគា* ម្នាក់ជាអ្នកនាំពាក្យជំនួសឱ្យហោរាទាំង៤០០រយនាក់ ។ *ស្នែងដែក* នេះតំណាងឱ្យអំណាច(មើល ចទ ៣៣:១៧) ។

**២២:១៣** *សូមឱ្យពាក្យលោកបានដូចជាពាក្យរបស់ហោរាទាំងនោះដែរ* នេះជាការដាស់តឿនដ៏តូចមួយប៉ុណ្ណោះសម្រាប់ពួកហោរាទាំងអស់នោះដើម្បីឱ្យពួកគេមានភាពម្ចាស់ការលើខ្លួនរៀងៗខ្លួន ។

**២២:១៥,១៦** តើហេតុអ្វីបានជា មីកាយ៉ាប្រាប់ដល់ស្តេចអ័ហាប់ឱ្យច្បាំងក្នុងខណៈដែលពេលមុននេះបន្តិចគាត់បានស្បថដោយនូវព្រះយេហូវ៉ាថា គាត់និយាយតែសេចក្តីណា ដែលព្រះយេហូវ៉ាមានបន្ទូល មកកាន់គាត់ប៉ុណ្ណោះ? ចំណុចនេះប្រហែលជាគាត់និយាយចំអកឱ្យស្តេចអ័ហាប់ ដោយលេងសើជាមួយនឹងពួកហោរាខុសឆ្គងទាំងអស់នោះ ដោយគាត់ដឹងថាពួកគេគ្រាន់តែចង់ដឹងនូវអ្វីដែលគេចង់បានប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ ការនិយាយរបស់មីកាយ៉ា បានធ្វើឱ្យអ្នកទាំងអស់គ្នា ដឹងថាជាការនិយាយចំអកឱ្យពួកហោរាសាសន៏ដទៃនោះដែរ ។ គាត់ បានទាយថា ស្តេចអង្គនេះនឹងសុគត នៅក្នុងសង្គ្រាម ។ ទោះបី ស្តេចអ័ហាប់មានការសោក–ស្តាយក្នុងរយះពេលខ្លី (២១:២៧) គាត់នៅតែប្រព្រឹត្តតាមប្រព័ន្ធរបស់ពួកហោរាក្លែងក្លាយ ។ ពួកទាយរបស់ពួកគេ នឹងឈានទៅរកការបំផ្លិចបំផ្លាញខ្លួនគាត់ផ្ទាល់ ។

**២២:១៧** *ប្រៀបដូចជាហ្វូងចៀមដែលគ្មានអ្នកគង្វាល . . . ពួកទាំងនេះគ្មានចៅហ្វាយ* ពាក្យទាំងនេះ ប្រាប់អំពីការប្រើប្រាស់រូបសំណាកអ្នកគង្វាល និង

ជាហ្វូងចៀមដែលគ្មានអ្នកគង្វាល[ត] ហើយព្រះយេហូវ៉ាបាន
មានបន្ទូលថា ពួកទាំងនេះគ្មានចៅហ្វាយទេ ចូរឱ្យគេ
ត្រឡប់ទៅផ្ទះរៀងខ្លួនវិញ ដោយសេចក្តីសុខចុះ ១៨ដូច្នេះ
ស្តេចអ៊ីស្រាអែលទ្រង់ទូលទៅយ៉ូសាផាតថា តើទូលបង្គំមិន
បានទូលទ្រង់ទេឬអី ថាវាមិនដែលទាយល្អពីទូលបង្គំទេ
គឺទាយតែអាក្រក់ប៉ុណ្ណោះ ១៩នោះមីកាយ៉ាទូលថា ដូច្នេះ
សូមស្តាប់ព្រះបន្ទូល នៃព្រះយេហូវ៉ាសិន ទូលបង្គំបានឃើញ
ព្រះយេហូវ៉ា ទ្រង់គង់លើបល្ល័ង្ក[ថ] មានទាំងពួកពលបរិវារ
នៃស្ថានសួគ៌ទាំងអស់[ទ]ឈរអមអង្គ ទាំងខាងស្តាំ និងខាង
ឆ្វេង ២០ហើយព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា តើអ្នកណា
នឹងទៅបបួលអ័ហាប់ ឱ្យឡើងទៅច្បាំង ហើយដួលស្លាប់
នៅត្រង់រ៉ាម៉ូត-កាឡាត ម្នាក់ក៏ថា យ៉ាងនោះ ២១រួចមាន
វិញ្ញាណ១ចេញមកឈរនៅចំពោះព្រះយេហូវ៉ា ទូលថា
ទូលបង្គំចង់ទៅ ២២ដូច្នេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរ
ថា និងធ្វើយ៉ាងណាទៅ វិញ្ញាណនោះទូលថា ទូលបង្គំនឹង
ចេញទៅធ្វើជាវិញ្ញាណភូតកុហក[ធ] នៅក្នុងមាត់នៃពួក
ហោរាទាំងប៉ុន្មានរបស់ស្តេច ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ថា ចូរចេញទៅធ្វើដូច្នោះចុះ ឯងនឹងបបួលវាឱ្យសំរេច
បាន ២៣ដូច្នេះ មើល ឥឡូវនេះព្រះយេហូវ៉ាទ្រង់ដាក់
វិញ្ញាណភូតកុហក[ន]នៅក្នុងមាត់នៃពួកហោរា[ប]របស់ព្រះ
ករុណាទាំងនេះ ហើយព្រះយេហូវ៉ាបានមានបន្ទូលពីសេច
ក្តីអន្តរាយ[ផ] ដែលនឹងកើតដល់ព្រះករុណាវិញ ។
២៤លំដាប់នោះសេដេគា[ព]ជាកូនក្នាណា ក៏ចូលទៅទះ
កំផ្លៀង[ភ]មីកាយ៉ាសួរថា ព្រះវិញ្ញាណនៃព្រះយេហូវ៉ាបាន
ចេញពីអញ ទៅមានបន្ទូល[ម] នឹងឯងតាមណា ២៥មីកាយ៉ា
ឆ្លើយថា ចាំមើលនៅថ្ងៃនោះឯងនឹងបានឃើញ ក្នុង
កាលដែលឯងរត់ទៅពួន[យ]នៅក្នុងបន្ទប់ខាងក្នុង ២៦ស្តេច
អ៊ីស្រាអែល ទ្រង់បង្គាប់ថា ចូរនាំយកមីកាហ៉ាត្រឡប់ទៅឯ
អាំម៉ូន ជាចៅហ្វាយទីក្រុង នឹងយ៉ូអាស ជាព្រះរាជបុត្រទៅ
២៧ហើយបង្គាប់ថា ស្តេចទ្រង់មានបន្ទូលដូច្នេះ គឺឱ្យដាក់
មនុស្សនេះក្នុងគុក[រ]ចិញ្ចឹមដោយនំបុ័ងនឹងទឹកដ៏វេទនាដរាប
ដល់អញមកវិញដោយសុខសាន្ត ២៨នោះ មីកាយ៉ាទូលថា
បើសិនជាទ្រង់ដែលយាងមកវិញ ដោយសុខសាន្តនោះ គឺ
ព្រះយេហូវ៉ាមិនបានមានបន្ទូល[ល]ដោយសារទូលបង្គំទេ រួច
គាត់ ថែមពាក្យនេះថា ឱជនទាំងឡាយអើយ ចូរស្តាប់ចុះ ។

## ស្តេចអ័ហាប់ត្រូវស្លាប់នៅក្រុងរ៉ាម៉ូត-កាឡាត

*២២:២៩-៣៦ - ២របា ១៨:២៨-៣៤*

២៩ដូច្នេះ ស្តេចអ៊ីស្រាអែលនឹងយ៉ូសាផាត ជាស្តេចយូដា
ក៏ឡើងទៅឯក្រុងរ៉ាម៉ូត-កាឡាត ៣០ស្តេចអ៊ីស្រាអែលទ្រង់

**២២:១៧** ត ជន ២៧:១៧ អស ១៣:១៤ មថ ៩:៣៦
**២២:១៩** ថ ទដ ៤៧:៨ អស ៦:១ ៦៣:១៥ អគ ១:២៦ ដយ ៧:៩ ទ យប ១:៦ ១៥:៨ ៣៨:៧ ទដ ១០៣:២០-២១ ១៤៨:២ យរ ២៣:១៨,២២ លក ២:១៣
**២២:២២** ធ ពច ៩:២៣ ២ថន ២:១១
**២២:២៣** ន ចទ ១៣:៣ ប អគ ១៤:៩ ផ ចទ ៣១:២៩
**២២:២៤** ព ខ.១១ ភ កច ២៣:២ ម យប ២៦:៤
**២២:២៥** យ ១ពវ ២០:៣០
**២២:២៧** រ ២របា ១៦:១០ យរ ២០:២ ២៦:២១ ៣៧:១៥ ហព ១១:៣៦
**២២:២៨** ល ចទ ១៨:២២

ចៀម (មើល ជន ២៧:១៦-១៧ អគ ១៣:៧ មថ ៩:៣៦ ២៦:៣១) ដែលមីកាយ៉ា បានរៀបរាប់ពីការស្លាប់របស់អ័ហាប់នឹងមកដក់ក្នុងពេលខាងមុខនៅក្នុងសមរភូមិ ។

**២២:១៩-២២** នៅវគ្គនេះ ហោរាមីកាយ៉ា បានបង្ហាញឱ្យឃើញពី រូបភាពនៃនគរស្ថានសួគ៌ និង ពាក្យប្រៀបធៀបនៃអ្វីៗដែលបានកើតមាននៅផែនដីដែលជាឥទ្ធិពលរបស់ពួកហោរាក្លែងក្លាយ ដែលការនេះឈានដល់ការជំនុំជម្រះរបស់ព្រះឆ្លងតាមស្តេចអ័ហាប់នេះឯង(២២:២៣) ។ ទោះជាព្រះអម្ចាស់ បានបញ្ជូនពួកទេវតាក្លែងក្លាយ ឬមិនបញ្ជូនក៏ដោយ តែគាត់នៅតែប្រើបធ្យោបាយតាមបែបពួកហោរាក្លែងក្លាយក្នុងការដាក់ ឱ្យស្តេចអ័ហាប់ឱ្យធ្លាក់ក្នុងអន្ទាក់ក្នុងអំពើរបាបរបស់គាត់ ។ វិញ្ញាណបោកបញ្ឆោតបានបង្ហាញពីមធ្យោបាយរបស់ពួកហោរាទាំងនោះ ដែលបានប្រាប់ដល់ស្តេចនោះនូវអ្វីដែលទ្រង់ចង់បាន (មើល ២២:២២) ។

**២២:២៣** *ព្រះយេហូវ៉ាទ្រង់ដាក់វិញ្ញាណភូតកុហកនៅក្នុងមាត់នៃពួកហោរា* នៅត្រង់នេះ មានមតិខ្លះបានបញ្ជាក់ថា វិញ្ញាណភូតកុហកជាអារក្សឬជាភ្នាក់ងាររបស់វាមួយ ។ រីឯមតិផ្សេងទៀតបានលើកឡើងថា ព្រះវិញ្ញាណរបស់ព្រះ បានសណ្ឋិតលើពួកគេហើយទ្រង់ប្រើមធ្យោបាយនេះ (ប៉ុន្តែ សូមមើល ១សយ ១៥:២៩) ។ ទោះជាមតិទាំងពីរខាងលើ បានអះអាងយ៉ាងដូច្នេះក្តី ក៏នៅតែមានការយល់ថា វិញ្ញាណភូតកុហក ជាអំណាច នៃសេចក្តីកំភូត ដូចដែលព្រះអម្ចាស់បានប្រទានឱ្យពួកហោរា ទាំង៤០០ រយនាក់ក្លែងនូវសេចក្តីទំនាយ ដោយព្រោះពួកគេទាំងនោះ មិនស្រឡាញ់ សេចក្តីពិតហើយក៏និយាយពីអ្វីចេញពីចិត្តខ្លួនឯងមក(មើល យរ ១៤:១៤ ២៣:១៦,២៦ អគ ១៣:២-៣,១៧ បន្ថែមការពន្យល់ ២សយ ២៤:១ ធៀប ២ថន ២:៩-១២ និងការពន្យល់ ២:១១) ។ ស្តេចអ័ហាប់ បានរស់ក្នុងភាព ភូតកុហកហើយស្អប់ចំពោះហោរាទាំងឡាយណាដែលថ្លែងទំនាយពិតនោះ បានធ្លាក់ចូលក្នុងការកាត់ទោសរបស់ព្រះ តាមរយៈការដែលព្រះអង្គចូលចិត្តសេចក្តីភូតភដែលព្រះអង្គបានជឿតាម(មើល ជន ១១:១៨-២០ ទដ ១៨:២៥-២៦ អគ ១៤:៩ និងការពន្យល់) ។

**២២:២៤** *ព្រះវិញ្ញាណនៃព្រះយេហូវ៉ា បានចេញពីអញទៅមានបន្ទូលនឹងឯងតាមណា* ការចំអកឡកឡើយរបៀបយ៉ាងដូច្នេះ សេដេគាបានលើកឡើងថាមានហោរាម្នាក់កំពុងតែនិយាយកុហកដល់អ្នកផ្សេងទៀត ។

**២២:២៥** *ពួននៅក្នុងបន្ទប់ខាងក្នុង* នេះជាទីដែលសេដេគារកទីជម្រក(ធៀប ២០:៣០) ។ នៅត្រង់នេះ គឺបញ្ជាក់អំពីភាពគ្មានទោសរបស់ហោរាមីកាយ៉ា ។

**២២:២៦** *ព្រះរាជបុត្រា* ពាក្យនេះសំដៅលើ មន្ត្រីនៅក្នុងក្រុមរាជវង្ស(មើលការពន្យល់ យរ ៣៦:២៦) ។

**២២:២៧** *ស្តេចទ្រង់មានបន្ទូលដូច្នេះ* នេះជាពាក្យរបស់អ័ហាប់និយាយជាភាសាស្តេច ក្នុងន័យទាស់ប្រឆាំងនឹងពួកហោរារបស់ព្រះយេហូវ៉ា ពីព្រោះទ្រង់មានការជឿជាក់លើពួកហោរាខុសឆ្គងដែលទ្រង់បានចំណាយឱ្យពួកគេនូវលាភសក្ការៈយ៉ាងពេញទំហឹង(មើល ខ.១១) ។

**២២:៣០** *ស្តេចអ៊ីស្រាអែលទ្រង់មានបន្ទូល* នៅត្រង់នេះអ័ហាប់នៅតែគិតថា

ទូលទៅយ៉ូសាផាតថា ទូលបង្គំនឹងក្លែងខ្លួនចូលទៅច្បាំង[វ]
តែព្រះអង្គ សូមឱ្យទ្រង់គ្រឿងព្រះពស្ត្ររាជ្យរបស់ទ្រង់វិញ
ស្តេចអ៊ីស្រាអែលក៏ក្លែងខ្លួនចូលទៅច្បាំងនឹងគេ ៣១ រីឯខាង
ស្តេចស៊ីរី[ស] បានបង្គាប់ដល់ពួកមេទ័ពរទេះចំបាំងទ្រង់ ទាំង
៣២នាក់ថា កុំឱ្យតនឹងអ្នកណា ទោះតូចឬធំក្តីចូរតតែនឹង
ស្តេច[ហ]អ៊ីស្រាអែល១ប៉ុណ្ណោះ ៣២ ដូច្នេះ កាលពួកមេទ័ព
ទាំងនោះបានឃើញយ៉ូសាផាត គេក៏បែរទៅបំរុងនឹងទ្រង់
ដោយស្មានថា នេះប្រាកដជាស្តេចអ៊ីស្រាអែលហើយ តែ
យ៉ូសាផាតទ្រង់ស្រែកឡើង ៣៣ កាលពួកមេទ័ពឃើញថាមិន
មែនជាស្តេចអ៊ីស្រាអែលទេ នោះក៏លែងតាមតទៅ ៣៤ តែ
មានមនុស្សម្នាក់យឹតធ្នូ[ឡ]បាញ់ព្រាវទៅត្រូវស្តេចអ៊ីស្រាអែល
ត្រង់ប្រឡោះអាវក្រោះទ្រង់ ដូច្នេះ ទ្រង់មានបន្ទូលបង្គាប់
ដល់អ្នកបរព្រះរាជរថទ្រង់ថា ចូរញាក់បង្វៀរត្រឡប់រថ
នាំយើងចេញពីពលទ័ពទៅ ដ្បិតយើងមានរបួសជាទំងន់
៣៥ នៅថ្ងៃនោះ ចំបាំងក៏កាន់តែខ្លាំងឡើង តែគេគ្រាហ៍គាំ
ស្តេចនៅក្នុងព្រះរាជរថ ដើម្បីតស៊ូនឹងពួកស៊ីរី លុះដល់
ពេលល្ងាចទ្រង់សុគតទៅ ហើយឈាមពីរបួសនោះក៏ហូរ
ទៅក្នុងបាតព្រះរាជរថ ៣៦ រួចដល់ពេលថ្ងៃលិច នោះក៏មាន
ឮសំរែក នៅពេញក្នុងពួកទ័ពថា ចូរគ្រប់គ្នាត្រឡប់ទៅឯ
ទីក្រុង នឹងស្រុករបស់ខ្លួនវិញទៅ[អ] ។
៣៧ គឺយ៉ាងនោះដែលស្តេចទ្រង់សុគត ហើយគេក៏នាំសព
ទ្រង់មកវិញ បញ្ចុះនៅក្នុងក្រុងសាម៉ារី ៣៨ គេលាងព្រះរាជ
រថនៅត្រង់ស្រះទឹកនៃក្រុងសាម៉ារី ហើយមានឆ្កែ[ក]លិទ្ធ
ឈាម រីឯនៅទីនោះពួកស្រីសំផឹងតែងងូតទឹក) តាមសេច
ក្តីដែលព្រះយេហូវ៉ាបានមានបន្ទូលទុក ៣៩ ឯដំណើរឯទៀត
ពីអ័ហាប់ និងការទាំងប៉ុន្មានដែលទ្រង់ធ្វើ ព្រមទាំងដំណាក់
ភ្លុក[ខ]ដែលទ្រង់បានធ្វើ និងអស់ទាំងទីក្រុងដែលទ្រង់បាន
សង់ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅជាពង្សាវតារ
របស់ពួកស្តេចអ៊ីស្រាអែលហើយ ៤០ គឺយ៉ាងនោះ ដែល
អ័ហាប់បានផ្ទំលក់ទៅជាមួយ នឹងពួកឰយុកោទ្រង់ រួចអ័ហា
ស៊ីយ៉ាជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា ។

**២២:៣០** វ ១សយ ២៨:៨
**២២:៣១** ស លប ១០:២២ ២សយ ១០:១៩ ហ ២សយ ១៧:២
**២២:៣៤** ឡ ២ពវ ៩:២៤ ២រប ៣៥:២៣
**២២:៣៦** អ ២ពវ ១៤:១២
**២២:៣៨** ក ១ពវ ២១:១៩
**២២:៣៩** ខ ២រប ៩:១៧ ទដ ៤៥:៨ អម ៣:១៥
**២២:៤៣** គ ១ពវ ៨:៦១ ២រប ១៧:៣ ឃ ១ពវ ៣:២

## យ៉ូសាផាតឡើងជាស្តេចស្រុកយូដា

*២២:៤១-៥០ – ២រប ២០:៣១-២១:១*

៤១ រីឯនៅឆ្នាំទី៤ ក្នុងរាជ្យអ័ហាប់ ស្តេចអ៊ីស្រាអែល
នោះយ៉ូសាផាត ជាកូនអេសា ក៏ចាប់តាំងសោយរាជ្យឡើង
លើស្រុកយូដា ៤២ កាលយ៉ូសាផាតចាប់តាំងសោយរាជ្យ
នោះទ្រង់មានព្រះជន្ម៣៥ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន២៥ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជា អ័ស៊ូបា
បុត្រីស៊ីលហ៊ី ៤៣ ទ្រង់ក៏ដើរតាមគ្រប់ទាំងផ្លូវរបស់អេសា[គ]
ជាព្រះបិតាត្រង់ ឥតងាកបែរចេញឡើយ គឺបានប្រព្រឹត្ត
សេចក្តីដែលត្រឹមត្រូវ នៅព្រះនេត្រព្រះយេហូវ៉ា ប៉ុន្តែមិន
បានបំបាត់អស់ទាំងទីខ្ពស់ចេញទេ [ឃ]ពួកបណ្តាជនគេនៅ
តែថ្វាយយញ្ញបូជា ហើយដុតកំញាននៅលើទីខ្ពស់ ទាំងនោះ
នៅឡើយ ៤៤ យ៉ូសាផាតទ្រង់ក៏បានចងស្ពានមេត្រីនឹងស្តេច

ខ្លួនជាអ្នកគ្រប់គ្រងដដែល ។ *ក្លែងខ្លួន* ការធ្វើរបៀបជាយ៉ាងដូច្នេះ អ័ហាប់អាចចូលទៅដោយផ្ទាល់ និងគ្រោះថ្នាក់តិចបំផុត ក្នុងការធ្វើឱ្យសម្រេចតាមការទាយរបស់ហោរាមីកាយ៉ា ។ ស្តេចដែលស្រឡាញ់ការភូតកុហកនោះទ្រង់នឹងអាចរត់គេចពីសេចក្តីពិតដោយការរស់នៅក្នុងភាពកុហក ។

**២២:៣១** *ចូរតតែនឹងស្តេចអ៊ីស្រាអែល* ប្រសិនបើ អ្នកដឹកនាំស្លាប់ ចាប់ខ្លួននោះពួកទាហាននៅសម័យបុរាណ ជាទូទៅគឺរត់បែកខ្ញែកគ្នា(ធៀប ៣៥-៣៦) ។

**២២:៣៤** *យឹតធ្នូ* នៅត្រង់នេះ ស្តេចស្មានសួគ៌ បានប្រកាសពីព្រួញ ។ *ព្រះរាជរថទ្រង់* រទេះចំបាំងនេះអាចផ្ទុកមនុស្សបានពីរនាក់ គឺអ្នកប្រយុទ្ធ និងអ្នកបររទេះ ។ ពេលខ្លះ មានចំនួនបីនាក់ តែអ្នកទីបីប្រហែលជាមេបញ្ជាការរបស់អ្នកបររទេះ(មើល ៩:២២ ២ពវ ៩:២៥ នក ១៤:៧ ១៥:៤ ) ។

**២២:៣៥** *ពេលល្ងាចទ្រង់សុគតទៅ* នៅត្រង់នេះ គឺសម្រេចតាមបទទំនាយរបស់ហោរា មីកាយ៉ា (ខ.១៧,២៨) ។

**២២:៣៨** *តាមសេចក្តីដែលព្រះយេហូវ៉ាមានបន្ទូលទុក* សេចក្តីនៅត្រង់នេះបញ្ជាក់អំពីការមិនទាន់បានសម្រេចតាមបទទំនាយរបស់ហោរាអេលីយ៉ាដែលបានទាយអំពីការសុគតរបស់ស្តេចអ័ហាប់(មើល ពន្យល់ ២១:១៩) ។

**២២:៣៩** *ព្រមទាំងដំណាក់ភ្លុកដែលទ្រង់បានធ្វើ និងអស់ទីក្រុងដែលទ្រង់បានធ្វើ* ពួកអ្នកកំណាយផ្នែកវត្ថុបុរាណវិទ្យានៅស្រុកសាម៉ារី បានរកឃើញរូបភ្លុកឆ្លាក់នៅក្នុងការបំផ្លាញនៃសំណង់ទីក្រុងនៅក្នុងប្រវត្តិសាស្ត្ររបស់នៃពួកអ៊ីស្រាអែល ។ ស្តេចអ័ហាប់ បានប្រើសម្ភារៈផ្សេងៗធ្វើអំពីភ្លុក ដើម្បីបញ្ជាក់អំពីភាពរុងរឿងក្នុងរជ្ជកាលរបស់ទ្រង់ ។ *ទីក្រុងដែលទ្រង់បានធ្វើ* តាមរយៈកំណាយនៅក្នុងតំបន់នោះ បានរកឃើញពីភស្តុតាងមួយចំនួនដែលបញ្ជាក់អំពីភាពរឹងមាំនៃការកសាងក្រុងមេគីដោ និងក្រុងហាសោរ ។ *កត់ទុកក្នុងសៀវភៅជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែល* សូមមើលការពន្យល់ ១៤:១៩ ។

**២២:៤០** *ផ្ទំលក់ទៅ ជាមួយនឹងពួកឰយុកោទ្រង់* សូមមើលពន្យល់ ១:២១ ។ *អ័ហាស៊ីយ៉ា ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា* សម្រាប់រាជរបស់អ័ហាស៊ីយ៉ា សូមមើលការពន្យល់ ខ.៥១-៥៣ ២ពវ ១ ។

**២២:៤១** *យ៉ូសាផាត . . . ក៏ចាប់តាំសោយរាជ្យឡើងលើស្រុកយូដា* សូមមើលការពន្យល់ ខ.៤២ ១៦:២៩ មើលបន្ថែម សេចក្តីផ្តើម ។

**២២:៤២** *៣៥ឆ្នាំ* នេះស្ថិតនៅឆ្នាំ ៨៧២-៨៤៨ មុន គ.ស ។

**២២:៤៣** *មិនបានបំបាត់អស់ទាំងទីខ្ពស់ចេញទៅ* មើលការពន្យល់ ៣:២ ១៥:១៤ ។

**២២:៤៤** *ស្តេច* ប្រហែលជាទ្រង់យល់ពីការរួបរួមគ្នាខាងវិញ្ញាណ និងការរាប់បញ្ចូលទាំង អ័ហាប់ អ័ហាស៊ីយ៉ា និងយ៉ូរាម ព្រមទាំងអ្នកកាន់ច្បាប់ក្នុងភាគខាងជើងនៅក្នុងរជ្ជកាល ស្តេចយ៉ូសាផាតនៅទិសខាងត្បូង (មើលការ

អ៊ីស្រាអែលដែរ ។
៤៥ រីឯដំណើរឯទៀតពីយ៉ូសាផាតនឹងអំណាចដែលទ្រង់
បានសំដែង ហើយពីការសង្គ្រាមរបស់ទ្រង់ នោះសុទ្ធតែ
បានកត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា
ហើយ ៤៦ ឯសំណល់ពួកកូនជីង[ង] ដែលនៅសល់ពីក្នុងរាជ្យ
អេសាជាព្រះបិតា នោះទ្រង់ក៏បណ្តេញគេចេញពីស្រុកទៅ
៤៧ គ្រានោះនៅស្រុកអេដំមគ្មានស្តេចទេ[ច] មានតែអ្នកដំណាង
រាជការ ដែលកាន់កាប់ត្រួតត្រាប៉ុណ្ណោះ ៤៨ យ៉ូសាផាតក៏
បានធ្វើក្រុមនាវាតើស៊ីស[ឆ] ដើម្បីនឹងទៅយកញមាសពីស្រុក
អូភារមក តែនាវាទាំងនោះមិនបានចេញទៅទេ ពីព្រោះ
ត្រូវបាក់បែកទាំងអស់ នៅត្រង់ក្រុងអេស៊ាន-គេបើរវិញ[ជ]
៤៩ គ្រានោះ អ័ហាស៊ីយ៉ាជាបុត្រអ័ហាប់ក៏ទូលដល់យ៉ូសាផាត
ថា សូមឱ្យពួកបំរើទូលបង្គំបានចុះនាវា ទៅជាមួយនឹង
ពួកបំរើទ្រង់ផង តែយ៉ូសាផាតទ្រង់មិនព្រមទេ ៥០ រួចមក
យ៉ូសាផាតក៏ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ គេ
បញ្ចុះទ្រង់នៅជាមួយនឹងពួកឰយុកោទ្រង់ ក្នុងក្រុងរបស់
ដាវីឌ ជាឰយុកោ រួចយ៉ូរ៉ាម ជាព្រះរាជបុត្រា ក៏ឡើង
សោយរាជ្យជំនួសបិតា ។
៥១ ឯអ័ហាស៊ីយ៉ាជាបុត្រអ័ហាប់ ទ្រង់ចាប់តាំងសោ
យរាជ្យនៅក្រុងសាម៉ារី លើពួកអ៊ីស្រាអែល ក្នុងឆ្នាំទី១៧
នៃរាជ្យយ៉ូសាផាត ជាស្តេចយូដា ក៏សោយរាជ្យលើពួក
អ៊ីស្រាអែលបាន២ឆ្នាំ ៥២ ទ្រង់បានប្រព្រឹត្តអំពើដ៏លាមក
អាក្រក់[ឈ] នៅព្រះនេត្រព្រះយេហូវ៉ា ក៏ដើរតាមផ្លូវរបស់
ព្រះបិតា នឹងព្រះមាតាទ្រង់ ហើយតាមផ្លូវរបស់យេរ៉ូបោម
ជាកូននេបាត ដែលបានបណ្តាលឱ្យពួកអ៊ីស្រាអែលធ្វើ
បាបនោះដែរ ៥៣ ទ្រង់បានគោរពប្រតិបត្តិ ហើយថ្វាយបង្គំ
ដល់ព្រះបាល [ញ] ជាការដែលនាំឱ្យព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែល មានសេចក្តីក្រោធ ដូចជាព្រះបិតា[ដ]
បានធ្វើដែរ ។/

**២២:៤៦** ង ចទ ២៣:១៧
**២២:៤៧** ច ១ពវ ១១:១៤-១៨ ២ពវ ៣:៩ ៨:២០
**២២:៤៨** ឆ ១ពវ ៩:២៦ ជ ជន ៣៣:៣៥
**២២:៥២** ឈ ១ពវ ១៥:២៦
**២២:៥៣** ញ ពច ២:១១ ដ ១ពវ ២១:២៥

ពន្យល់ ខ.៤) ។
**២២:៤៥** *អំណាចដែលទ្រង់បានសំដែង* មើល ២ពវ ៣ ២ពវ ១៧:១១,២០ ។ *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* មើលការពន្យល់ ១៤:២៩ ។
**២២:៤៦** *ពួកកូនជីង ដែលនៅសល់* មើលការពន្យល់ ១៤:២៤ ។
**២២:៤៧** *ស្រុកអេដំមគ្មានស្តេចទេ* នេះបញ្ជាក់ថា ស្រុកអេដំមជាសេចក្តីចម្បងក្នុងស្រុយូដា (មើល ២សយ ៨:១៤ ២ពវ ៨:២០) ។
**២២:៤៨** *ស្រុកអូភារ* សូមមើលការពន្យល់ ៩:២៨ ។ *ត្រូវបាក់បែកទាំងអស់ នៅត្រង់អេស៊ាន-គេបើរវិញ* នេះជាការបំផ្លិចបំផ្លាញ នៃកប៉ាល់ពាណិជ្ជកម្ម ជាការកាត់សេចក្តីរបស់ព្រះ ។
**២២:៥០** *ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់* មើលការពន្យល់ ១:២១ ។ *យ៉ូរ៉ាម ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា* សម្រាប់រាជរបស់យ៉ូរ៉ាម សូមមើល ២ពវ ៨:១៦-២៤ រប ២១ ។
**២២:៥១** *ក្នុងឆ្នាំទី១៧ នៃរាជ្យយ៉ូសាផាត* ស្ថិតនៅឆ្នាំ ៨៥៣ មុន គ.ស (មើលពន្យល់ ខ.៤១-៤២) ។ *២ឆ្នាំ* នេះស្ថិតនៅក្នុងឆ្នាំ ៨៥៣-៨៥២ មុន គ.ស (មើលការពន្យល់ ២ពវ ១:១៧) ។
**២២:៥២** *ដើរតាមផ្លូវរបស់ព្រះបិតា និងព្រះមាតាទ្រង់* សូមមើល ១៦:៣០-៣៣ ។ *ផ្លូវរបស់យេរ៉ូបោម* សូមមើល ១២:២៨-៣៣ ។

# ពង្សាវតារក្សត្រទី២

## សេចក្តីផ្តើម

ចំពោះសេចក្តីផ្តើមកណ្ឌគម្ពីរនេះ សូមមើល កណ្ឌគម្ពីរ១ពង្សាវតារទី១ ។

### គម្រោងសង្ខេប

**IV- បេសកកម្មរបស់ហោរាអេលីយ៉ា និង អេលីសេ នៅក្នុងរជ្ជកាលស្តេចអ័ហាស៊ីយ៉ា និង យ៉ូរ៉ាម (២ពវ ១:១–៨:១៥)**

ក. ហោរាអេលីយ៉ា នៅក្នុងរជ្ជកាលស្តេចអ័ហាស៊ីយ៉ា (ជំពូក ១)

ខ. ការកាត់ស្រាយរបស់ហោរាអេលីយ៉ា និង ការកាន់តំណែងជាហោរាដំបូងរបស់លោកអេលីសេ (២:១–១៨)

គ. ហោរាអេលីសេ ក្នុងរជ្ជកាលរបស់ស្តេចយ៉ូរ៉ាម (២:១៩–៨:១៥)

១. ទីសំគាល់ការអស្ចារ្យដំបូងរបស់ហោរាអេលីសេ (២:១៩–២៥)

២. ហោរាអេលីសេ នៅក្នុងយុទ្ធនាការប្រឆាំងនឹងស្រុកម៉ូអាប់ (ជំពូក ៣)

៣. បេសកកម្មរបស់ហោរាអេលីសេ នៅក្នុងភាពក្រខ្សត់របស់ពួកអ៊ីស្រាអែល (ជំពូក ៤)

៤. ហោរាអេលីសេ ព្យាបាលមេទ័ពណាម៉ាន់ (ជំពូក ៥)

៥. សេចក្តីសង្គ្រោះរបស់ហោរាអេលីសេ ក្នុងចំណោមហោរាផ្សេងៗទៀត (៦:១–៧)

៦. ការសង្គ្រោះរបស់ហោរាអេលីសេ ដល់យ៉ូរ៉ាមក្នុងពេលពួកអាសស៊ើរវាយលុក (៦:៨–២៣)

៧. ការទាយរបស់ហោរាអេលីសេ ចំពោះការឡោមព័ទ្ធរបស់ពួកអាសស៊ើរមកលើស្រុកសាម៉ារី (៦:២៤–៧:២០)

៨. ការស្តាឡើងវិញនៃទឹកដីស៊ូណែម (៨:១–៦)

៩. ហោរាអេលីសេ បានទស្សទាយពីការគៀបសង្កត់របស់ហាសែលមកលើពួកអ៊ីស្រាអែល (៨:៧–១៥)

**V. ពួកយូដា និងអ៊ីស្រាអែល ត្រូវនិរទេសខ្លួនដោយយ៉ូរ៉ាម (៨:១៦–១៧:៤១)**

ក. យ៉ូរ៉ាម ស្តេចពួកយូដា (៨:១៦–២៤)

ខ. អ័ហាស៊ីយ៉ា ស្តេចពួកយូដា (៨:២៥–២៩)

គ. ការបះបោររបស់យេហ៊ូវ និងរាជ្យរបស់ព្រះអង្គ (ជំពូក ៩–១០)

១. ហោរាអេលីសេ ចាក់ប្រេងតាំងលើយេហ៊ូវ (៩:១–១៣)

២. យេហ៊ូវ ធ្វើគតដល់ស្តេចយ៉ូរ៉ាម និង អ័ហាស៊ីយ៉ា (៩:១៤–២៩)

៣. យេហ៊ូវ ធ្វើគតដល់យេសិបិល (៩:៣០–៣៧)

៤. យេហ៊ូវ ធ្វើគតបុត្រស្តេចអ័ហាប់ (១០:១–១៧)

៥. យេហ៊ូវ បំបាត់ការថ្វាយបង្គំរូបព្រះបាល (១០:១៨–៣៦)

ឃ. អ័ថាលា និង យ៉ូអាស ស្តេចពួកយូដា ជួសជុលព្រះវិហារឡើងវិញ (ជំពូក ១១–១២)

ង. យ៉ូអាហាស ស្តេចពួកអ៊ីស្រាអែល (១៣:១–៩)

ច. យ៉ូអាហាស ស្តេចពួកអ៊ីស្រាអែល និងហោរាអេលីសេចុងក្រោយបំផុត (១៣:១០–២៥)

ឆ. អ័ម៉ាស៊ីយ៉ា ស្តេចពួកយូដា (១៤:១–២២)

ជ. យេរ៉ូបោមទី២ ស្តេចពួកអ៊ីស្រាអែល (១៤:២៣–២៩)

ឈ. អ័សារា ស្តេចពួកយូដា (១៥:១–៧)

ញ. សាការី ស្តេចពួកអ៊ីស្រាអែល (១៥:៨–១២)

ដ. សាលូម ស្តេចពួកអ៊ីស្រាអែល (១៥:១៣–១៥)

ឋ. មហាណិម ស្តេចពួកអ៊ីស្រាអែល (១៥:១៧–២២)

ទ.ពេកាហ៊ា ស្តេចពួកអ៊ីស្រាអែល (១៥:២៣–២៦)
ធ.ពេកា ស្តេចពួកអ៊ីស្រាអែល (១៥:២៧–៣១)
ន.យ៉ូថាម ស្តេចពួកយូដា (១៥:៣២–៣៨)
ប.អ័ហាស ស្តេចពួកយូដា (ជំពូក ១៦)
ព.ហូសៀ ស្តេចពួកយូដា (១៧:១–៦)
ម.ការនិរទេសខ្លួនរបស់ពួកអ៊ីស្រាអែល និង ការតាំងលំនៅថ្មី (១៧:៧–៤១)

**VI.** ពួកយូដាចាកចេញពីស្តេចហេសេគា ដោយសាការនិរទេសខ្លួនរបស់ពួកបាប៊ីឡូន (ជំពូក ១៨–២៥)
ក.ស្តេចហេសេគា (ជំពូក ១៨–២០)
១.ការគ្រប់គ្រងល្អរបស់ស្តេចហេសេគា (១៨:១–៨)
២.ការគាបសង្កត់របស់ពួកអាសស៊ើ និងការរួចផុតពីសេចក្តីវេទនា (១៨:៩–១៩:៣៧)
៣.ហេសេគាទ្រង់មានជម្ងឺ និងការចងសម្ព័ន្ធជាមួយចក្រភពបាប៊ីឡូន (ជំពូក ២០)
ខ.ស្តេចម៉ាន៉ាសេ (២១:១–១៨)
គ.ស្តេចអាំម៉ូន (២១:១៩–២៦)
ឃ.ស្តេចយ៉ូសៀស (២២:១–២៣:៣០)
១.ការជួសជុលព្រះវិហារ និង ការរកឃើញគម្ពីរក្រឹត្យវិន័យថ្មី (ជំពូក ២២)
២.សេចក្តីសញ្ញាថ្មី និង ការបញ្ចប់រាជ្យស្តេចយ៉ូសៀស (២៣:៣៦–២៤:៧)
ង.ស្តេចយ៉ូអាហាស ត្រូវបាននិរទេសខ្លួនទៅអេស៊ីព្ទ (២៣:៣១–៣៥)
ច.យេហូយ៉ាគីម: និរទេសខ្លួនលើកទី១ទៅបាប៊ីឡូន (២៣:៣៦–២៤:៧)
ឆ.យេហូយ៉ាគីម: និរទេសខ្លួនលើកទី២ទៅបាប៊ីឡូន (២៤:១៨–២៥:២១)
ជ.សេដេគា: និរទេសខ្លួនលើកទី៣ទៅបាប៊ីឡូន (២៤:១៨–២៥:២១)
ឈ.ពួកអ្នកនៅសល់ ចូលទៅក្នុងទឹកដីអេស៊ីព្ទ (២៥:២២–២៦)
ញ.ការលើកយ៉ូយ៉ាគីនធ្វើជាស្តេចនៅបាប៊ីឡូន (២៥:២៧–៣០)

## ព្រះអម្ចាស់កាត់ទោសស្តេចអ័ហាប់ស៊ីយ៉ា

**១** ១ ក្រោយដែលអ័ហាប់សុគតហើយ នោះសាសន៍ម៉ូអាប់[ក]
គេបះបោរនឹងពួកអ៊ីស្រាអែល ២ នៅខណនោះអ័ហាប់–
ស៊ីយ៉ាទ្រង់ធ្លាក់ ពីភ្នាក់ដៃរានជាន់លើ នៃដំណាក់នៅក្រុង
សាម៉ារី ហើយក៏ទ្រង់ប្រឈួន នោះទ្រង់ប្រើគេឱ្យទៅ[ខ]
ដោយបង្គាប់ថា ចូរទៅសួរដល់ព្រះបាល–សេប៊ូប[គ] ជាព្រះ
នៃពួកអេក្រុន[ឃ] តើអញនឹងបានជា[ង]ពីការឈឺនេះឬទេ ៣ តែ
ទេវតា[ច] នៃព្រះយេហូវ៉ាក៏មកប្រាប់អេលីយ៉ា[ឆ]ជាអ្នកស្រុក
ធេសប៊ីថា ចូរក្រោកឡើងទៅជួបនឹងពួកអ្នកដែលស្តេច
ក្រុងសាម៉ារីចាត់ប្រើទៅនោះ សួរគេថា តើដោយហេតុ
តែគ្មានព្រះនៅស្រុកអ៊ីស្រាអែលឬអី[ជ] បានជាឯងរាល់គ្នា
ទៅសួរដល់ព្រះបាល–សេប៊ូប ជាព្រះនៃពួកអេក្រុនវិញ
៤ ហេតុនោះ ឥឡូវនេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
ឯងនឹងមិនចុះ[ឈ]ពីដំណេក ដែលឯងបានឡើងទៅនោះបាន
ឡើយ គឺនឹងត្រូវស្លាប់ជាពិត រួចអេលីយ៉ាក៏ចេញបាត់ទៅ ។
៥ ឯពួកអ្នកដែលស្តេចចាត់ប្រើនោះ គេក៏វិលត្រឡប់មក
ឯទ្រង់វិញ ហើយទ្រង់មានបន្ទូលសួរថា ហេតុអ្វីបានជាឯង
រាល់គ្នាវិលមកវិញដូច្នេះ ៦ គេក៏ទូលឆ្លើយថា មានមនុស្ស
ម្នាក់ឡើងមកជួបនឹងយើងខ្ញុំប្រាប់ថា ចូរវិលទៅឯស្តេច
ដែលចាត់ប្រើឯងរាល់គ្នាមក ហើយទូលទ្រង់ថា ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ តើដោយហេតុតែគ្មានព្រះ
នៅស្រុកអ៊ីស្រាអែលឬអី បានជាព្រះករុណាចាត់គេឱ្យទៅ
សួរដល់ព្រះបាល–សេប៊ូប ជាព្រះនៃពួកអេក្រុនវិញ ហេតុ
នេះទ្រង់នឹងមិនចុះ[ញ]ពីដំណេក ដែលបានឡើងទៅនោះបាន
ឡើយ គឺត្រូវសុគតជាពិតវិញ ៧ ទ្រង់មានបន្ទូល សួរគេថា
មនុស្សដែលឡើងមកជួបនឹងឯងរាល់គ្នា ពោលសេចក្តីទាំង
នេះ តើបែបយ៉ាងណា ៨ គេទូលតបថា មនុស្សនោះពាក់អាវ
ធ្វើពីរោម[ដ] ហើយមានខ្សែក្រវាត់ស្បែកនៅចង្កេះ ទ្រង់មាន
បន្ទូលថា នោះគឺជាអេលីយ៉ា ជាអ្នកស្រុកធេសប៊ីហើយ ។
៩ នោះទ្រង់ចាត់[ឋ] មេទ័ពម្នាក់[ឌ] នឹងពួកទាហាន៥០នាក់
របស់គាត់ ឱ្យទៅរកអេលីយ៉ា គេក៏ឡើងទៅឯលោកដែល
កំពុងអង្គុយនៅលើកំពូលភ្នំ មេទ័ពនោះនិយាយនឹងលោក
ថា ឱអ្នកសំណប់របស់ព្រះអើយ ស្តេចទ្រង់បង្គាប់ឱ្យអ្នកចុះ
មក ១០ អេលីយ៉ាឆ្លើយទៅមេទ័ពនោះថា បើខ្ញុំជាអ្នកសំណប់

**១:១** ក លប ១៩:៣៧
២ពវ ៣:៥
**១:២** ខ ខ.១៦
គ មក ៣:២២
ឃ ១សយ ៦:២
អស ២:៦ ១៤:២៩
ង ពច ១៨:៥
**១:៣** ច ខ.១៥
ឆ ១ពវ ១៧:១
ជ ១សយ ២៨:៨
**១:៤** ឈ ខ.៦,១៦
ទដ ៤១:៨
**១:៦** ញ ខ.៤
**១:៨** ដ ១ពវ ១៨:៧
មថ ៣:៤ មក ១:៦
**១:៩** ឋ ២ពវ ៦:១៤
ឌ នក ១៨:២៥ អស
៣:៣

**១:១** *ក្រោយដែល អ័ហាប់សុគត* សូមមើល យស ១:១ ពច ១:១ ២សយ ១:១ ។ *សាសន៍ម៉ូអាប់ គេបះបោរ* ស្រុកម៉ូអាប់ បានធ្លាក់នៅក្នុងការគ្រប់គ្រងរបស់ស្តេចដាវីឌ (មើល ២សយ ៨:២) ។ ពីព្រោះនៅក្នុង១និង២នៃព្រះគម្ពីរពង្សាវតាក្សត្រនេះ ជាព្រះគម្ពីរតែមួយ ។ នៅក្នុង ២ពវ បានបន្តពីតំណវង្សរបស់ស្តេច ១ពវ ដែលសាសន៍អ៊ីស្រាអែល បានបែងចែកជាពីផ្នែក ដោយសារពួកគេបានបំភ្លេចព្រះ ។ កណ្ឌនេះ បានចាប់ផ្តើមជាមួយលោកអេលីយ៉ា ដែលជាហោរារបស់ព្រះ ដែលនៅទីបញ្ចប់គាត់ត្រូវបានព្រះលើកឡើងទៅឯស្ថានសួគ៌ ។ រឿងរ៉ាវដែលកើតមាននៅទីនេះ ត្រូវបានបញ្ចប់ជាមួយនឹងរាស្ត្រអ៊ីស្រាអែល និងយូដា ត្រូវចាប់ខ្លួន ។ នៅក្នុង ១ពវ ព្រះវិហារស្អាតៗ ត្រូវបានកសាងឡើង រីឯ ២ពវ វិញ ព្រះវិហារមិនត្រូវកសាងបន្ថែមទៀតទេ តែថែមទាំងបំផ្លាញវិញ ។

**១:២** *ព្រះបាល–សេប៊ូប* មើលការពន្យល់ ពច ១០:៦ ។ *ពួកអេក្រុន* ក្រុងនេះនៅភាគខាងជើងដែលមានសារៈសំខាន់បំផុតនៃក្រុងទាំងប្រាំរបស់ ភីលីស្ទីន (មើល យស ១៣:៣ ១សយ ៥:១០ និងការពន្យល់) ។ *តើអញនឹងបានជាពីការឈឺនេះឬទេ* នៅត្រង់នេះ អ័ហាស៊ីយ៉ា លេចមកក្នុងភាពភ័យខ្លាច ក្នុងសេចក្តីគ្រោះថ្នាក់ ។ គាត់បានត្រឡប់ទៅគោរពព្រះរបស់សាសន៍ដទៃ ដែលបួលនូវទំនាយខុសឆ្គង មិនមែនជាការប្រោះជម្ងឺ ។

**១:៣** *ទេវតានៃព្រះយេហូវ៉ា* សូមមើល ១ពវ ១៩:៧ និងមើលបន្ថែម លប ១៦:៧ ។ ព្រះអម្ចាស់ ជានិច្ចកាលតែងតែមានបន្ទូលទៅកាន់ពួកហោរាដោយផ្ទាល់(សូមមើល ១ពវ ១៧:២,៨ ១៨:១ ១៩:៩ ២១:១៧) ។ ត្រង់នេះប្រហែលជា ការបើកសំដែងពីអំពើរឃោរឃៅរបស់ពួកទេវតា ដែលមានភាពផ្ទុយគ្នារវាងអ្នកនាំសារហោរាអ័ហាស៊ីយ៉ា (ខ.២–៣,៥) និងទេវតា (អ្នកនាំសារ)នៃព្រះអម្ចាស់ ។ *អេលីយ៉ា ជាអ្នកស្រុកធេសប៊ីថា* សូមមើលការពន្យល់ ១ពវ ១៧:១ ។ *ស្តេចក្រុងសាម៉ារី* សូមមើលការពន្យល់ ១ពវ ២១:១ ។

**១:៤** *គឺនឹងត្រូវស្លាប់ជាពិត* ត្រង់នេះអ័ហាស៊ីយ៉ាទ្រង់គិតថា វាគ្រាន់តែជាការបួលធម្មតាទេ ប៉ុន្តែវាមកពីព្រះយេហូវ៉ាដោយឆ្លងកាត់តាមហោរាអេលីយ៉ា មិនមែនមកអំពីបាល–សេប៊ូប ។

**១:៥** *ហេតុអ្វីបានជាឯងវិលមកវិញដូច្នេះ* នៅត្រង់នេះ អ័ស៊ីយ៉ាបានឱ្យដឹងថា អ្នកនាំសារមិនអាចនឹងធ្វើដំណើរយ៉ាងលឿនទៅក្រុងអេក្រុន និងដំណើរត្រឡប់មកវិញ ។

**១:៨** *អាវធ្វើពីរោម* នេះជាអាវរបស់លោកអេលីយ៉ាដែលគាត់ដណ្តប់(១ពវ ១៩:១៩) ដែលអាវនេះធ្វើអំពីរោមចៀម និងអូដ្ឋ ដែលចងក្រវ៉ាត់ដោយខ្សែស្បែក(ធៀប មថ ៣:៤) ។ សំលៀកបំពាក់នេះ មានលក្ខណៈខុសពីសំពត់ទេសឯកដែលមានលក្ខណៈល្អប្រណិត (មើល យរ ១៣:១) ដែលសំលៀកបំពាក់នេះសម្រាប់ពួកអ្នកមានទ្រព្យសម្បត្តិ និងឋានៈខ្ពង់ខ្ពស់ ដូចជាវណ្ណៈស្តេចជាដើម(ធៀប មថ ១១:៧–៨ លក ៧:២៤–២៥) ។ *នោះគឺជាអេលីយ៉ាជាអ្នកស្រុកធេសប៊ី* ឃ្លានេះបានប្រាប់ថា អ័ស៊ីយ៉ា បានស្គាល់អេលីយ៉ាពីព្រោះមានហោរាជាច្រើនបានជួបអ័ហាប់ដែលជាបិតារបស់ទ្រង់ ។

**១:៩** *ទ្រង់ចាត់មេទ័ពម្នាក់ នឹងពួកទាហាន៥០នាក់* ពួកសាសន៍ដទៃនៅសម័យនោះបានគិតថា អំណាចនៃមន្តអាគមក្នុងបណ្តាសា គឺអាចសាបសូន្យទៅទាំងដោយការបង្ខិតបង្ខំឱ្យអ្នកដែលថ្លែងពាក្យទាំងនោះ ដកបណ្តាសានោះចេញ និងសម្លាប់អ្នកនោះចោល ដូច្នេះអ្នកទាំងនោះនឹងធ្លាក់ចូលនៅក្នុងការកាត់ទោសក្រោយពីគេស្លាប់ទៅ ។ *អ្នកសំណប់របស់ព្រះអើយ ស្តេចទ្រង់បង្គាប់ឱ្យអ្នកចុះមក* អ័ស៊ីយ៉ាបានប៉ុនប៉ងទៅកន្លែងរបស់ពួកហោរា ក្រោមសិទ្ធិអំណាចរបស់ស្តេច ។

**១:១០** *សូមឱ្យភ្លើងធ្លាក់ពីលើមេឃមកបញ្ឆេះឯង* សូមមើល ១ពវ ១៨:២៨ ។ ហើយបេសកកម្មផ្សេងៗទៀត របស់លោកអេលីយ៉ា និងលោកម៉ូសេ (សូម

របស់ព្រះពិត នោះសូមឱ្យភ្លើងធ្លាក់ពីលើមេឃមកបញ្ឆេះ
ឯង និងពួក៥០នាក់របស់ឯងទៅ នោះក៏មានភ្លើង[ឃ]ធ្លាក់ពី
លើមេឃមក បញ្ឆេះមេទ័ពនោះ នឹងពួក៥០នាក់របស់គាត់
មែន ១១ទ្រង់ក៏ចាតមេទ័ពម្នាក់ នឹងពួក៥០នាក់របស់គាត់ឱ្យ
ទៅរកលោកទៀត មេទ័ពនោះ និយាយនឹងលោកថា ឱអ្នក
សំណប់របស់ព្រះអើយ ស្តេចទ្រង់មានបន្ទូលដូច្នេះថា ចូរ
ចុះមកជាឆាប់ ១២អេលីយ៉ាក៏ឆ្លើយទៅគេថា បើខ្ញុំជាអ្នក
សំណប់របស់ព្រះពិត នោះសូមឱ្យភ្លើងធ្លាក់ពីលើមេឃមក
បញ្ឆេះឯង និងពួក៥០នាក់របស់ឯងទៅ នោះក៏មានភ្លើងនៃ
ព្រះធ្លាក់ពីលើមេឃ មកបញ្ឆេះមេទ័ពនោះនឹងពួក៥០នាក់
របស់គាត់ដែរ ១៣រួចទ្រង់ក៏ចាត់មេទ័ពទី៣ និងពួក៥០នាក់
របស់គាត់ ឱ្យទៅថែមទៀត មេទ័ពទី៣នោះក៏ឡើងទៅលុត
ជង្គង់ក្រាបនៅមុខអេលីយ៉ាអង្វរថា ឱអ្នកសំណប់របស់ព្រះ
អើយ សូមអាណិតមេត្តាឱ្យជីវិត[ណ]របស់ខ្ញុំប្របាទ នឹងជីវិត
របស់៥០នាក់នេះ បានមានដំឡៃនៅភ្នែកលោកចុះ ១៤មើល
មានភ្លើងធ្លាក់ ចុះពីលើមេឃមកបញ្ឆេះមេទ័ពទាំង២នាក់
នឹងពួក៥០នាក់របស់គេ ដែលមកនោះទៅហើយ តែឥឡូវ
នេះសូមឱ្យជីវិតខ្ញុំប្របាទ មានដំឡៃ នៅភ្នែកលោកវិញ
១៥នោះទេវតា[ត]នៃព្រះយេហូវ៉ា ក៏ប្រាប់អេលីយ៉ាថា ចូរចុះ
ទៅជាមួយនឹងគេចុះកុំឱ្យខ្លាច[ថ]ឡើយដូច្នេះ លោកក៏ក្រោក
ឡើងចុះទៅជាមួយនឹងគេ ចូលទៅគាល់ស្តេច ១៦លោក
ទូលស្តេចថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះឯងចាត់

**១:១០** ឃ ១ពវ ១៨:៣៨ វវ ១១:៥ ១៣:១៣
**១:១៣** ណ ទដ ៧២:១៤
**១:១៥** ត ខ.៣ ថ អស ៥១:១២ ៥៧:១១ យរ ១:១៧ អគ ២:៦
**១:១៦** ទ ខ.២ ធ ខ.៤
**១:១៧** ន ២ពវ ៨:១៥ យរ ២០:៦ ២៨:១៧ ប ២ពវ ៣:១ ៨:១៦
**២:១** ក លប ៥:២៤ ខ ខ.១១ ១ពវ ១៩:១១ អស ៥:២៨ ៦៦:១៥ យរ ៤:១៣ ណហ ១:៣ គ ១ពវ ១៩:១៦,២១ ឃ ចទ ១១:៣០ ២ពវ ៤:៣៨
**២:២** ង ខ.៦ ច នរ ១:១៦
**២:៣** ឆ ១សយ ១០:៥

ប្រើគេ[ទ]ឱ្យទៅសួរដល់ព្រះបាល–សេប៊ូប ជាព្រះនៃពួក
អេក្រុន នោះតើមិនមែនដោយព្រោះគ្មានព្រះ នៅស្រុក
អ៊ីស្រាអែល ដែលល្មមសួរព្រះបន្ទូលទ្រង់បានឬអី ហេតុ
នេះឯងនឹងមិនបានចុះ[ធ]ពីដំណេក ដែលបានឡើងទៅនោះ
ឡើយ គឺនឹងត្រូវស្លាប់វិញជាពិត ។
១៧ទ្រង់ក៏សុគតទៅ[ន] តាមព្រះបន្ទូលនៃព្រះយេហូវ៉ាដែល
អេលីយ៉ាបានពោលហើយ រួចយ៉ូរ៉ាម[ប]ក៏ឡើងសោយរាជ្យ
ជំនួសទ្រង់ គឺក្នុងឆ្នាំទី២នៃរាជ្យយ៉ូរ៉ាម ជាបុត្រនៃយ៉ូសាផាត
ស្តេចយូដា ដ្បិតអ័ហាស៊ីយ៉ាគ្មានព្រះរាជបុត្រាទេ ១៨រីឯ
ដំណើរឯទៀត ពីអ័ហាស៊ីយ៉ា ដែលទ្រង់បានធ្វើ នោះសុទ្ធតែ
បានកត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេច
អ៊ីស្រាអែលហើយ ។

## លោកអេលីយ៉ាត្រូវលើកឡើងស្ថានសួគ៌

២ ១ក្រោយមក ក្នុងគ្រាដែលព្រះយេហូវ៉ា ទ្រង់សព្វព្រះ
ហឫទ័យនឹងលើក[ក]អេលីយ៉ា ឡើងទៅស្ថានសួគ៌ ដោយខ្យល់
កួច[ខ] នោះអេលីយ៉ា និងអេលីសេ[គ]ក៏ចេញពីក្រុងគីលកាល[ឃ]
ទៅជាមួយគ្នា ២ឯអេលីយ៉ាលោកប្រាប់ដល់អេលីសេថា ចូរ
ឯងរង់នៅទីនេះសិន[ង] ដ្បិតព្រះយេហូវ៉ាទ្រង់បានចាត់អញ
ឱ្យទៅឯក្រុងបេត–អែល តែអេលីសេប្រកែកថា ខ្ញុំស្បថ
ដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ ហើយដោយ
ព្រលឹងលោកដ៏រស់នៅដែរថា ខ្ញុំមិនព្រមឃ្លាតពីលោកទេ[ច]
ដូច្នេះអ្នកទាំង២ក៏ចុះទៅឯបេត–អែល ៣រីឯពួកសិស្ស[ឆ]

មើល លវ ១០:២ ជន ១៦:៣៥) ។ នៅក្នុងចំណុចនេះ បានចោទឡើងថា តើនរណាឡើងសោយរាជ្យនៅក្នុងដំណាក់កាលនេះ? តើអ័ស៊ីយ៉ាទទួលស្គាល់ថា ស្តេចនៅអ៊ីស្រាអែលជាអ្នកដែលសម្រេចរាជកិច្ចបន្ទាប់ពីព្រះអង្គ ឬពួកគេប្រើអំណាចផ្តាច់ការដូចជាស្តេចនៃពួកសាសន៍ដទៃ (សូមមើលការពន្យល់ ១សយ ១២:១៤–១៥) នៅភ្នំកើមែល ព្រះយេហូវ៉ាបានបើកសម្តែងអង្គទ្រង់តាមរយៈពួកហោរារបស់ទ្រង់ ដោយទម្លាក់ភ្លើងចុះពីស្ថានសួគ៌មក (មើល ១ពវ ១៨:៣៨–៣៩) ។ ហើយមកដល់ត្រង់នេះ ការបើកសម្តែងនេះ ធ្លាក់មកលើអ័ស៊ីយ៉ាវិញ ។

**១:១១** *ទ្រង់ក៏ចាត់មេទ័ព* នៅត្រង់នេះអ័ស៊ីយ៉ា បានបដិសេធបន្ទូលរបស់ព្រះយេហូវ៉ាដោយមិនស្គាល់ពីអំណាចរបស់ព្រះ ។

**១:១៣** *លុតជង្គង់ក្រាបនៅមុខអេលីយ៉ា* ម្នាក់នេះជាមេទ័ពទីបី ដែលបានទទួលស្គាល់ថា លោកអេលីយ៉ាជាអ្នកនាំសាររបស់ព្រះ ហើយនៅពេលនេះគាត់មានសេចក្តីភ័យខ្លាចចំពោះអាយុជីវិតរបស់គាត់ ដូច្នេះគាត់ក៏លុតជង្គង់នៅចំពោះលោកអេលីយ៉ាដោយការបន្ទាបខ្លួនយ៉ាងដូចនេះ ។

**១:១៥** *ទេវតានៃព្រះយេហូវ៉ា ក៏ប្រាប់អេលីយ៉ាថា* មើលការពន្យល់ ខ.៣ ។

**១:១៧** *ទ្រង់ក៏សុគតទៅ តាមព្រះបន្ទូលនៃព្រះយេហូវ៉ា* នេះប្រាប់អំពីទីអវសាន្តរបស់អ័ស៊ីយ៉ាត្រូវបានកាត់ទោសក្នុងការដែលបានរត់គេចចេញពីព្រះរបស់ពួកអ៊ីស្រាអែល ហើយត្រឡប់ទៅគោរពព្រះរបស់ពួកសាសន៍ដទៃ ហើយព្រះបន្ទូលរបស់ព្រះនៅត្រង់នេះ អាចបញ្ជាក់ទាំងពីករណីថាគួរឱ្យជឿ និងអំណាចរបស់ស្តេចគឺជាអសាឥតការ ។ *យ៉ូរ៉ាម* ម្នាក់នេះជាប្អូនប្រុសរបស់អ័ស៊ីយ៉ា (សូមមើល ៣:១ ១ពវ ២២:៥១) ។ *ឆ្នាំទី២នៃរាជ្យយ៉ូរ៉ាម ជាបុត្រនៃយ៉ូសាផាត* រាជ្យស្តេចអង្គនេះគឺត្រួតលើរាជ្យស្តេចយ៉ូសាផាតជាបិតារបស់ខ្លួនពីឆ្នាំ ៨៥៣–៨៤៨ មុន គ.ស (មើលការពន្យល់ ៨:១៦) ។

**១:១៨** *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែល* សូមមើលការពន្យល់ ១ពវ ១៤:១៩ ។

**២:១** *ក្រុងគីលកាល* ទីក្រុងនេះមិនមានល្បីល្បាញនៅក្នុងតំបន់ទន្លេយ័រដាន់ ដោយព្រោះតែពួកគេបានធ្វើដំណើរចុះទៅក្រុងបេត–អែល (ខ.២ និងមើល ៤:៣៨) ហើយក្រុងនេះ មានចំងាយប្រហែល ៩៨០០ម៉ែត្រពីក្រុងបេត–អែល ។

**២:២** *ខ្ញុំមិនព្រមឃ្លាតពីលោកទេ* ឃ្លានេះបានប្រាប់លោកអេលីសេ បានដឹងថាបេសកកម្មរបស់លោកអេលីយ៉ា ស្ទើរតែបានបញ្ចប់ ហើយដំណើរការចាប់ផ្តើមក៏ជិតមកដល់ (ខ.៥) ។ លោកអេលីសេ នៅតែបញ្ជាក់ថាខ្លួនគាត់ថាគាត់នឹងនៅជាមួយហោរាអេលីយ៉ារហូតព្រះបានលើកគាត់ឡើង ។ ការប្តេជ្ញាចិត្តរបស់គាត់ចំពោះបេសកកម្មហោរាអេលីយ៉ា នៅតែមិនប្រែប្រួល (មើល ខ.៩ ១ពវ ១៩:២១) ។

របស់ពួកហោរា ដែលនៅក្រុងបេត–អែល គេចេញ
មកសួរអេលីសេថា តើលោកជ្រាបថា នៅថ្ងៃនេះ ព្រះ
យេហូវ៉ានឹងលើកគ្រូលោក ពីមុខលោកចេញឬទេ គាត់
ឆ្លើយថា អើ ខ្ញុំដឹងហើយ ចូរអ្នករាល់គ្នានៅសៀមទៅ
៤ អេលីយ៉ាក៏ប្រាប់គាត់ថា អេលីសេអើយ សូមរង់ចាំនៅ
ទីនេះសិន ដ្បិតព្រះយេហូវ៉ាបានចាត់ខ្ញុំឱ្យទៅក្រុងយេរីខូរ[ជ]
តែគាត់ប្រកែកថា ខ្ញុំស្បថ ដោយនូវព្រះយេហូវ៉ាដ៏មានព្រះ
ជន្មរស់នៅ ហើយដោយព្រលឹងលោកដ៏នៅរស់ដែរថា ខ្ញុំ
មិនព្រមឃ្លាតពីលោកទេ ដូច្នេះអ្នកទាំង២ក៏ទៅដល់
យេរីខូរ ៥ រីឯពួកសិស្ស[ឈ] របស់ពួកហោរា ដែលនៅក្រុង
យេរីខូរ គេមកសួរអេលីសេថា តើលោកជ្រាបថា នៅថ្ងៃ
នេះ ព្រះយេហូវ៉ានឹងលើកគ្រូលោកពីមុខលោកទៅឬទេ
គាត់ឆ្លើយថា អើ ខ្ញុំដឹងហើយ ចូរអ្នករាល់គ្នានៅសៀមទៅ
៦ រួចអេលីយ៉ាប្រាប់គាត់ថា សូមឱ្យឯងរង់ចាំនៅទីនេះ
សិន[ញ] ដ្បិតព្រះយេហូវ៉ាបានចាត់ខ្ញុំឱ្យទៅឯទន្លេយ័រដាន់[ដ] តែ
គាត់ប្រកែកថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្ម
រស់នៅ ហើយដោយព្រលឹងលោកដ៏នៅរស់ដែរថា ខ្ញុំមិន
ព្រមឃ្លាតពីលោកទេ[ឋ] ដូច្នេះអ្នកទាំង២ដ៏ដើរទៅ ៧ មានពួក
សិស្ស៥០នាក់នៃពួកហោរា ក៏តាមទៅឈរមើលពីចំងាយ

តែអ្នកទាំង២ក៏ឈរនៅមាត់ទន្លេយ័រដាន់ ៨ ឯអេលីយ៉ា
លោកយកក្រមា[ឌ] របស់លោកបត់វាយ[ឍ] ទឹក នោះទឹកក៏ញែក
ចេញ[ណ] ពីគ្នា ឱ្យលោកទាំង២បានដើរឆ្លងទៅនៅដីគោក[ត]
៩ កាលបានឆ្លងទៅផុតហើយ នោះអេលីយ៉ាប្រាប់អេលីសេ
ថា ចូរឱ្យឯងសូមអ្វីៗ ដែលចង់ឱ្យអញធ្វើសំរាប់ឯង ក្នុង
ពេលមុខដែលព្រះបានលើកអញឡើងពីឯងទៅ អេលីសេ
ឆ្លើយថា សូមឱ្យវិញ្ញាណរបស់លោកបាន សណ្ឋិតលើខ្ញុំ
ដល់ទៅ២[ថ] ភាគផង[ទ] ១០ លោកមានប្រសាសន៍ថា ឯងបាន
សូមសេចក្តីយ៉ាងពិបាក ប៉ុន្តែបើឯងឃើញអញ ក្នុងកាល
ដែលព្រះលើកអញឡើងពីឯងទៅ នោះនឹងបានដូចប្រាថ្នា
បើមិនបានឃើញវិញ នោះមិនបានទេ ១១ រួចកំពុងដែលអ្នក
ទាំង២ដើរទៅ ហើយនិយាយគ្នាទៀត នោះស្រាប់តែឃើញ
រថជាភ្លើង[ធ] និងសេះជាភ្លើង មកញែកលោកចេញពីគ្នា
ហើយអេលីយ៉ាក៏ឡើងទៅឯស្ថានសួគ៌[ន] ដោយខ្យល់កួច[ប]
១២ អេលីសេក៏បានឃើញ ហើយស្រែកឡើងថា ឱលោក
ឪពុក លោកឪពុកខ្ញុំអើយ នុ៎ះន៍ ព្រះរាជរថ[ផ] និងទ័ពសេះ
របស់ពួកអ៊ីស្រាអែលហើយ រួចលោកមិនបានឃើញ
អេលីយ៉ាទៀតឡើយ នោះលោកចាប់អាវខ្លួនហែក[ព] ចេញ
ជា២ផ្នែក ១៣ ក៏រើសយកក្រមារបស់អេលីយ៉ា ដែលជ្រុះចុះ

**២:៤** ជ យស ៣:១៦
**២:៥** ឈ ខ.៣
**២:៦** ញ ខ.២
ដ យស ៣:១៥
ឋ នរ ១:១៦
**២:៨** ឌ ១ពវ ១៩:១៩ ឍ ខ.១៤
ណ នក ១៤:២១
ត នក ១៤:២២,២៩
**២:៩** ថ ចទ ២១:១៧
ទ ជន ១១:១៧
**២:១១** ធ ២ពវ ៦:១៧ ទដ ៦៨:១៧ ១០៤:៣,៤ អស ៦៦:១៥ ហប ៣:៨ សក ៦:១ ន លប ៥:២៤ ប ខ.១
**២:១២** ផ ២ពវ ៦:១៧ ១៣:១៤ ព លប ៣៧:២៩

**២:៣** *ពួកសិស្សរបស់ពួកហោរា* តាមន័យអក្សរសិល្ប៍មានន័យថា"ពួកកូន" (មើលការពន្យល់ ១ពវ ២០:៣៥) ។ នៅអំឡុងពេលរបស់លោក អេលីយ៉ា និងអេលីសេ ហើយសិស្សរបស់ពួកហោរា គឺកំពុងស្ថិតនៅក្រុងបេត–អែល ក្រុងយេរីខូរ (ខ.៥) និងគីលកាល (៤:៣៨) ។ ចំណុចបញ្ជាក់ថា វគ្គមានរបស់លោកអេលីយ៉ាដែលបានធ្វើដំណើរមកដល់តំបន់ទាំងអស់នេះ គឺស្ថិតក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់គីលកាល (ខ.១) បេត–អែល (ខ.២) និងក្រុងយេរីខូរ (ខ.៤) ហើយនិងការជួបជុំពួកសិស្សជាលើកចុងក្រោយ ។

**២:៧** *សិស្ស៥០នាក់* នៅត្រង់នេះ ស្តេចស្ថានសួគ៌របស់ពួកអ៊ីស្រាអែល បានប្រមូលផ្តុំពួកហោរាទាំង៥០នាក់(មើល ១:៩,១១,១៣ ២:១៦–១៧ ១ពវ ១៨:៤) ។ ពួកហោរាទាំង៥០នាក់នោះ គឺជាបន្ទាល់នៃការអស្ចារ្យដែលលោកអេលីយ៉ា និងលោកអេលីសេបានឆ្លងកាត់ទន្លេនោះ ។

**២:៨** *អេលីយ៉ាលោកយកក្រមារបស់លោកបត់វាយទឹក* នៅត្រង់នេះ លោកអេលីយ៉ាបានយកក្រមារបស់គាត់វាយទឹក គឺដូចនឹងលោកម៉ូសេបានយកដំបងវាយទឹកបើកផ្លូវក្នុងការនាំពួកអ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម(មើល នក ១៤:១៦,២១,២៦) ។

**២:៩** *សូមឱ្យវិញ្ញាណរបស់លោកបាន សណ្ឋិតលើខ្ញុំ ដល់ទៅ២ភាគ* នេះលោកអេលីសេមិនបានបញ្ជាក់ពីសេចក្តីសំណូមរបស់គាត់ ចំពោះព្រះឱ្យបានដូចលោកអេលីយ៉ា ប៉ុន្តែពាក្យដែលគាត់ប្រើនៅទីនេះគឺបានមកពីមរដកក្រឹត្យវិន័យដើម្បីបញ្ជាក់ពីការធ្វើឱ្យបានសម្រេចបេសកកម្មរបស់លោកអេលីយ៉ា ។ ច្បាប់ទទួលកេរ្តិ៍មរដក បានតម្រូវឱ្យផ្តល់ដល់កូនច្បងលើសជាងពីរភាគ(មើល ចទ ២១:១៧ និងការពន្យល់) ។

**២:១០** *សេចក្តីយ៉ាងពិបាក* ទោះបីលោកអេលីយ៉ា បានបង្ហាញប្រាប់នឹងតែងតាំងលោកអេលីសេជាអ្នកបន្តវេនពីគាត់ (១ពវ ១៩:១៦,១៩–២១) តែលោកអេលីយ៉ាបានបញ្ជាក់យ៉ាងច្បាស់គាត់នឹងលែងដឹងឮ ហើយគាត់នឹងសោយរាជ្យនៅជាមួយព្រះ ។ *បើឯងឃើញអញ ... នោះនឹងបានដូចប្រាថ្នា ... នោះមិនបានទេ* ឃ្លានេះបញ្ជាក់ថា លោកអេលីយ៉ា បានបន្សល់ទុកនូវចម្លើយរបស់លោកអេលីសេនៅក្នុងព្រះហស្តរបស់ព្រះយេហូវ៉ា ។

**២:១១** *រថភ្លើង និងសេះជាភ្លើង* ការទទួលភ្ញៀវរបស់ព្រះនៃស្ថានសួគ៌ បានលើកតម្លៃ និងគាំទ្រដល់បេសកកម្មរបស់លោកអេលីយ៉ា(ដូចការងាររបស់លោកម៉ូសេ មើល នក ១៥:១–១០) ហើយឥឡូវនេះគាត់បានចាកចោលលោកអេលីសេ (ធៀប ៦:១៧) ។ *អេលីយ៉ាក៏ឡើងទៅឯស្ថានសួគ៌ ដោយខ្យល់កួច* លោកអេលីយ៉ា ដូចនឹងលោកហេណុកសម័យមុនគាត់(លប ៥:២៤) ដែលគាត់ត្រូវបានព្រះលើកឡើងទៅស្ថានសួគ៌ដោយមិនទាន់ស្លាប់នៅឡើយ ។ ចំពោះលោកម៉ូសេ(ចទ ៣៤:៤–៦) ដែលការស្លាប់របស់គាត់នៅក្រៅទឹកដីសន្យា ។

**២:១២** *ព្រះរាជរថនឹងទ័ពសេះរបស់ពួកអ៊ីស្រាអែល* នេះជាការពិពណ៌នារបស់លោកអេលីសេ ចំពោះលោកអេលីយ៉ាជាអ្នកតំណាងដ៏រឹងមាំសម្រាប់រាស្ត្រអ៊ីស្រាអែល ។ គាត់បានលះចោលពួកស្តេច ហើយធ្វើជាអ្នកតំណាងព្រះយេហូវ៉ា ។ ការពិពណ៌នាដូចគ្នានេះ ក្រោយមកបានរៀបរាប់អំពីលោកអេលីសេវិញម្តង(សូមមើល ១៣:១៤ និងការពន្យល់) ។ *ចាប់អាវខ្លួនហែក* សូមមើល លប ៤៤:១៣ និងការពន្យល់ ។

**២:១៣** *រើសយកក្រមារបស់អេលីយ៉ា* សូមមើលការពន្យល់ ខ.៨ ។ ក្រមានេះជាកម្មសិទ្ធរបស់លោកអេលីយ៉ា ហើយការរើសនេះជានិមិត្តរូបនៃការទទួកបន្ទុកការងារបន្តពីលោកអេលីសេ (មើល ១ពវ ១៩:១៩) ។

មក វិលត្រឡប់ទៅវិញ ឈរនៅមាត់ទន្លេយ័រដាន់ ១៤ហើយ
ក៏យកក្រមា[ភ]របស់អេលីយ៉ា ដែលជ្រុះមកពីលោកនោះ
ទៅវាយ[ម]ទឹក ដោយពាក្យថា តើព្រះយេហូវ៉ា ជាព្រះនៃ
អេលីយ៉ា ទ្រង់គង់នៅឯណា កាលបានវាយទឹកហើយនោះ
ទឹកក៏ញែកចេញពីគ្នា ហើយអេលីសេឆ្លងផុតទៅ ។
១៥លុះកាលពួកសិស្ស[យ]របស់ពួកហោរា ពីក្រុងយេរីខូរ
ដែលឈរ មើលពីត្រើយម្ខាង បានឃើញហើយ នោះក៏ថា
វិញ្ញាណ[រ]របស់អេលីយ៉ា បានសណ្ឋិតលើអេលីសេហើយ
រួចគេមកទទួលលោក ក៏ក្រាបចុះដល់ ដីនៅចំពោះលោក
១៦គេជំរាបលោកថា មើល មានមនុស្សខ្លាំងពូកែ ៥០នាក់
នៅជាមួយនឹងយើងខ្ញុំប្របាទនេះ ដូច្នេះ សូមឱ្យគេទៅរកគ្រូ
របស់លោកចុះ ក្រែងព្រះវិញ្ញាណ[ល]នៃព្រះយេហូវ៉ាបាន
លើក[វ]លោកឡើង ទៅបោះចោលនៅលើភ្នំណា ឬក្នុងច្រក
ណា១ តែលោកប្រកែកថា កុំឱ្យប្រើគេទៅឡើយ ១៧តែ
ដោយគេចេះតែទទូចសូម ទាល់តែលោកបានខ្មាស[ស] បាន
ជាលោកបណ្តោយទៅថា ចូរឱ្យគេទៅចុះ ដូច្នេះ គេក៏ប្រើ
៥០នាក់នោះឱ្យទៅ ហើយគេរកលោកអស់៣ថ្ងៃឥតឃើញ
សោះ ១៨រួចគេវិលត្រឡប់មកឯអេលីសេវិញ ដែលលោក

**២:១៤** ភ ១ពវ ១៩:១៩ ម ខ.៨
**២:១៥** យ ១សយ ១០:៥ រ ជន ១១:១៧
**២:១៦** ល ១ពវ ១៨:១២ វ កច ៨:៣៩
**២:១៧** ស ពច ៣:២៥
**២:២១** ហ នក ១៥:២៥ ២ពវ ៤:៤១ ៦:៦
**២:២២** ឡ នក ១៥:២៥
**២:២៣** អ នក ២២:២៨ ២រប ៣០:១០ ៣៦:១៦ យប ១៩:១៨ ទដ ៣១:១៨

រង់ចាំនៅក្រុងយេរីខូរ ហើយលោកមានប្រសាសន៍ថា តើ
ខ្ញុំមិនបានប្រាប់ថា កុំឱ្យទៅឡើយទេឬអី ។
១៩រួចមក ពួកមនុស្សនៅទីក្រុងនោះ ក៏និយាយនឹង
អេលីសេថា សូមទានលោកមើល កន្លែងសង់ទីក្រុងនេះ
សប្បាយ ដូចជាលោក ម្ចាស់ឃើញហើយ ប៉ុន្តែទឹកមិនល្អទេ
ហើយដីក៏មិនកើតផលផង ២០ដូច្នេះ លោកប្រាប់ថា
ចូរយកក្អមថ្មី១មកឱ្យខ្ញុំ ហើយដាក់អំបិលផង គេក៏យកមក
២១រួចលោកចេញទៅចាក់[ហ]អំបិលនោះ ទៅក្នុងរន្ធទឹក
ដោយពាក្យថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អញបាន
កែទឹកនេះ ឱ្យបានល្អឡើងវិញហើយ ពីនេះទៅមុខនឹងគ្មាន
អ្វីស្លាប់ឬឥតផល ដោយព្រោះទឹកនេះទៀតឡើយ ២២ដូច្នេះ
ទឹកនោះក៏បានប្រែជាល្អ[ឡ] ដរាបដល់សព្វថ្ងៃនេះ ដូចជា
ពាក្យដែលអេលីសេបានពោល ។

## លោកអេលីសេត្រូវប្រមាថ

២៣លោកក៏ចេញពីទីនោះឡើងទៅឯក្រុងបេត–អែល
កាលលោក កំពុងតែឡើងតាមផ្លូវទៅ នោះមានពួកក្មេង
ជំទង់ប្រុសៗចេញពីទីក្រុងមក ពោលមើលងាយ[អ]ដល់
លោកថា អាទំពែកអើយ ចូរឡើងទៅចុះ អាទំពែកអើយ

**២:១៤** *ទៅវាយទឹក . . . ទឹកក៏ញែកចេញពីគ្នា* សូមមើល ខ.៨ ។ នៅត្រង់នេះ ព្រះអម្ចាស់បញ្ជាក់យ៉ាងច្បាស់ អំពីការស្នងការងាររបស់លោកអេលីសេ ចំពោះបេសកកម្មរបស់ហោរាអេលីយ៉ា និងបង្ហាញថាអំណាចដូចគ្នាបានធ្វើការនៅក្នុងហោរាអេលីសេ ។ លោកយ៉ូស្វេ បានឆ្លងកាត់ទន្លេយ័រដាន់ មុនលោកអេលីសេ គឺគាត់ដើរតួធ្វើជាលោកអេលីយ៉ា"យ៉ូស្វេ" (អេលីសេ និង អេលីយ៉ា គឺឈ្មោះនេះមានភាពស្រដៀងគ្នា) ។ អេលីសេមានន័យថា "ព្រះសង្គ្រោះ" និងយ៉ូស្វេមានន័យថា"ព្រះយេហូវ៉ាថែរក្សា" ។

**២:១៥** *ក្រាបចុះដល់ដីនៅចំពោះលោក* ត្រង់នេះពួកមនុស្សបានមកទទួលស្គាល់លោកអេលីសេ ក្នុងឋានៈលោកជាអ្នកស្នងការងាររបស់លោកអេលីយ៉ា ។ លោកអេលីសេ មកដល់ត្រង់នេះជាមន្ត្រីរបស់ព្រះនៅអំឡុងពេលពួកមនុស្សបោះបង់ព្រះយេហូវ៉ា ។

**២:១៦** *ក្រែងព្រះវិញ្ញាណនៃព្រះយេហូវ៉ា បានលើកលោកឡើង ទៅបោះចោល* នៅត្រង់នេះ អូបាឌាបានបញ្ជាក់ពីគំនិតដូចគ្នានេះ(សូមមើល ១ពវ ១៨:១២) ។ *កុំឱ្យប្រើគេទៅឡើយ* នៅត្រង់នេះលោកអេលីសេ បានដឹងអំពីការរុករករបស់ពួកគេថាជាការឥតប្រយោជន៍ ។

**២:១៧** *ទាល់តែលោកបានខ្មាស* ន័យសេចក្តីដូចគ្នានេះ គឺមានប្រើនៅក្នុងភាសាហេព្រើរ ពច ៣:២៥ ។ ក្រោមសំពាធខាងលើ បានធ្វើឱ្យហោរាអេលីសេបញ្ជូនពួកហោរាដើរស្វែងរក លោកអេលីយ៉ា ដូច្នេះលោកអេលីសេមិនអាចបដិសេធការនេះបានឡើយ ។ *គេក៏ប្រើ* នៅពេលដែលពួកហោរាបានបដិសេធជាមួយនឹងចម្លើយរបស់លោកអេលីសេ ដូច្នេះគាត់អនុញ្ញាតឱ្យពួកគេចេញទៅ ដូច្នេះសិទ្ធអំណាច និងសេចក្តីពិត ចេញអំពីគាត់បាននៅជាមួយនឹងពួកគេ ។

**២:១៩** *ទីក្រុង* គឺសំដៅលើក្រុងយេរីខូរ (មើល ខ.១៨) ។ *ទឹកមិនល្អទេ ហើយដីក៏មិនកើតផលផង* ត្រង់នេះបញ្ជាក់ថា ពួកអ្នកស្រុកនៅក្នុងតំបន់នេះធ្លាប់ទទួលបណ្តាសា(ភាពផ្ទុយគ្នា ចទ ២៨:១៥–១៨ និង នក ២៣:២៥–២៦ លវ ២៦:៩ ចទ ២៨:១–៤) និង ១ពវ ១៦:៣៤ យស ៦:២៦ ។

**២:២០** *ក្អមថ្មី* ក្អមនេះត្រូវបានយកមកប្រើក្នុងការងារបម្រើព្រះអម្ចាស់ ដើម្បីលាងជម្រះរបស់ដែលមិនស្អាតឱ្យបានបរិសុទ្ធ(មើល ១:៣,១០ ជន ១៩:២ ចទ ២១:៣ ១សយ ៦:៧) ។ *ដាក់អំបិល* អំបិលលោកអេលីសេប្រើ ពីព្រោះវាតំណាងឱ្យគុណភាព ប៉ុន្តែប្រហែលជាគាត់ប្រើអំបិលនេះ ក្នុងគោលបំណង បញ្ជាក់ពីការស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា (មើលពន្យល់ ជន ១៨:១៩ មើលបន្ថែម ២រប ១៣:៥) ។

**២:២១** *អញបានកែទឹកនេះ ឱ្យបានល្អ* នេះជាការអស្ចារ្យដែលភាពបរិសុទ្ធនៃអំបិល គឺត្រូវបានបញ្ជាក់យ៉ាងច្បាស់ថាទឹកនៅត្រង់នេះ ត្រូវបានព្រះអម្ចាស់ធ្វើឱ្យបរិសុទ្ធស្អាតឡើង ។ នៅក្នុងមធ្យោបាយនេះ លោកអេលីសេបានដើរតួយ៉ាងសំខាន់ក្នុងការបំពេញមហាបេសកកម្មរបស់ទ្រង់លើកទី១នេះ ដល់ពួកអ្នកដែលមិនគោរពដល់ទ្រង់ តែទ្រង់នៅតែមានសេចក្តីមេត្តាករុណាដល់ពួកគេដដែល(មើល ១៣:២៣) ។

**២:២៣** *ចូរឡើងទៅ* ដោយសារតែក្រុងបេត–អែល ជាមជ្ឈមណ្ឌលសាសនា(មើល ១ពវ ១២:២៩ អម ៧:១៣) ហើយលោកអេលីយ៉ា និងលោកអេលីសេដែលជាញយៗត្រូវបានគេស្គាល់ថា ជាអ្នកស្រុកសាម៉ារី (មើលការពន្យល់ ៥:៣) ដូច្នេះចំពោះពួកក្មេងៗនៅក្រុងបេត–អែលនេះ ពុំមានការសង្ស័យ ចំពោះកាលដែលគាត់ឡើងទៅស្រុកសាម៉ារីទេដើម្បីធ្វើការវាយផ្ចាលពួកអ្នកគោរពសាសនានៅទីនោះ ។ *អាទំពែកអើយ* ឃ្លានេះបានប្រាប់ថា ភាពជាមនុស្សទំពែកមិនត្រូវបានគេលើកយកមកនិយាយទេនៅក្នុងសង្គមពួកយូដាសម័យដើមរីឯភាពមានសក់ល្អស្អាតបញ្ជាក់ពីភាពមាន

ចូរ ឡើងទៅចុះ ២៤លោកក៏បែរ មើលមក ក្រោយឃើញ
ហើយដាក់បណ្តាសា[ក]ដល់វា ដោយនូវព្រះនាម[ខ]ព្រះ
យេហូវ៉ាស្រាប់តែមានខ្លាឃ្មុំញី២ ចេញពីព្រៃមកហែកក្មេង
ទាំងនោះ អស់៤២នាក់ទៅ ២៥លោកក៏ចេញពីទីនោះ
ទៅឯភ្នំកើមែល[គ]ហើយពីនោះ លោកវិលត្រឡប់ទៅឯក្រុង
សាម៉ារីវិញ ។

## សាសន៍ម៉ូអាប់បះបោរ

៣ ១រីឯយ៉ូរ៉ាម[ក] ជាបុត្រអ័ហាប់ ទ្រង់ចាប់តាំងសោយរាជ្យ
លើពួកអ៊ីស្រាអែលនៅក្រុងសាម៉ារី ក្នុងឆ្នាំទី១២នៃរាជ្យ
យ៉ូសាផាត ជាស្តេចយូដា ក៏សោយរាជ្យបាន១២ឆ្នាំ ២ទ្រង់
ប្រព្រឹត្តដ៏លាមកអាក្រក់[ខ]នៅព្រះ នេត្រព្រះយេហូវ៉ាតែមិន
ដល់ព្រះបិតា[គ] និងព្រះមាតាទ្រង់ទេ ដ្បិតទ្រង់ បានបំបាត់
រូប[ឃ]ព្រះបាល ដែលព្រះបិតាទ្រង់បានធ្វើចេញ ៣ប៉ុន្តែទ្រង់
នៅតែកាន់តាមអំពើបាប[ង]របស់យេរ៉ូបោម ជាកូននេបាត
ដែលបាននាំឱ្យពួកអ៊ីស្រាអែលធ្វើតាមផងនៅឡើយ ទ្រង់
មិនបានលះបង់អំពើបាបនោះទេ។
៤រីឯមេសា ជាស្តេចសាសន៍ម៉ូអាប់[ច] ទ្រង់ជាអ្នកមានហ្វូង
ចៀមច្រើន ហើយទ្រង់ក៏ឡើងសួយ ជារោមរបស់កូនចៀម
១សែន[ឆ]នឹងរោមរបស់ចៀមឈ្មោល១សែន មកថ្វាយ
ស្តេចអ៊ីស្រាអែល ៥តែកាលអ័ហាប់ទ្រង់សុគតទៅនោះស្តេច
ម៉ូអាប់បានបះបោរ[ជ]នឹងស្តេចអ៊ីស្រាអែល ៦គ្រានោះ ស្តេច
យ៉ូរ៉ាមក៏ចេញពីក្រុងសាម៉ារី ទៅត្រួតមើលពួកអ៊ីស្រាអែល
ទាំងអស់ ហើយយាងនាំមុខគេទៅ ៧ទ្រង់ក៏ចាត់សារ ទៅឯ
យ៉ូសាផាត ជាស្តេចយូដាថា ស្តេចម៉ូអាប់បានបះបោរនឹង
ទូលបង្គំហើយ តើទ្រង់សព្វព្រះទ័យចង់ទៅច្បាំងនឹង[ឈ]
សាសន៍ម៉ូអាប់ជាមួយនឹងទូលបង្គំឬទេ ទ្រង់មានបន្ទូលឆ្លើយ
ថា ទូលបង្គំចង់ទៅដែរ ទូលបង្គំក៏ដូចជាទ្រង់ រាស្ត្រទូល
បង្គំក៏ដូចជារាស្ត្ររបស់ទ្រង់ ហើយសេះទូលបង្គំក៏ដូចជា
សេះរបស់ទ្រង់ដែរ ៨ទ្រង់ក៏សួរថា តើត្រូវឱ្យយើងឡើងទៅ
តាមផ្លូវណា ស្តេចអ៊ីស្រាអែលឆ្លើយថា តាមផ្លូវកាត់ទី
រហោស្ថានស្រុកអេដុំម ៩ដូច្នេះ ស្តេចអ៊ីស្រាអែល ព្រមទាំង
ស្តេចយូដា និងស្តេចអេដុំម[ញ]ក៏នាំគ្នាចេញទៅ គេដើរផ្លូវ
វាងអស់៧ថ្ងៃ ឥតមានទឹកសំរាប់ពលទ័ពនឹងហ្វូងសត្វ ដែល
តាមគាត់ទៅនោះសោះ ១០ដូច្នេះស្តេចអ៊ីស្រាអែលទ្រង់មាន
បន្ទូលថា ស្តាយណាស់ ព្រះយេហូវ៉ាទ្រង់បានហៅយើងខ្ញុំ
ជាស្តេចទាំង ៣អង្គនេះមកដើម្បីនឹងប្រគល់ទៅក្នុងកណ្តាប់
ដៃនៃសាសន៍ម៉ូអាប់ហើយ ១១តែយ៉ូសាផាតមានបន្ទូលសួរ ថា
នៅទីនេះ តើគ្មានហោរាម្នាក់របស់ព្រះយេហូវ៉ា ឱ្យយើង

**២:២៤** ក លប ៤:១១ ខ ចទ ១៨:១៩
**២:២៥** គ ១ពវ ១៨:២០
**៣:១** ក ២ពវ ១:១៧
**៣:២** ខ ១ពវ ១៥:២៦ គ ១ពវ ១៦:៣០-៣២ ឃ នក ២៣:២៤
**៣:៣** ង ១ពវ ១២:២៨-៣២
**៣:៤** ច លប ១៩:៣៧ ២ពវ ១:១ ឆ អរ ៧:១៧ អស ១៦:១
**៣:៥** ជ ២ពវ ១:១
**៣:៧** ឈ ១ពវ ២២:៤
**៣:៩** ញ ១ពវ ២២:៤៧

កម្លាំងនិងភាពខ្លាំងក្លា (មើលការពន្យល់ ២សយ ១៤:២៦) ។ ដោយការហៅលោកអេលីសេថា អាទំពែកនេះដល់អ្នកតំណាងរបស់ព្រះនោះពួកក្មេងៗ នៅក្រុងនេះគិតថាក្រុងនេះនឹងគ្មានអំណាចសោះឡើយ ។

**២:២៤** *ដាក់បណ្តាសាដល់វា ដោយនូវព្រះនាមព្រះយេហូវ៉ា* នៅត្រង់នេះលោកអេលីសេ បានប្រកាសដាក់បណ្តាសា ដែលស្រដៀងនឹងបណ្តាសានៅក្នុង លវ ២៦:២១-២២ ។ បណ្តាសានេះជាលទ្ធផលនៃការដែលពួកគេនៅតែមានៈមិនគោរពដល់ព្រះយេហូវ៉ា តែគោរពព្រះដទៃឯណោះវិញ (មើល ២រប ៣៦:១៦) ។ ដូច្នេះ សកម្មភាពជាដំបូងរបស់លោកអេលីសេដែលត្រូវធ្វើនោះគឺ: លោកបានប្រាប់ដល់ពួកគេថា ព្រះពររបស់ព្រះយេហូវ៉ានឹងធ្លាក់មកដល់អស់អ្នកដែលគោរពទ្រង់ (មើល ខ.១៩-២២) តែបណ្តាសានឹងធ្លាក់ដល់អស់អ្នកណាដែលងាកចេញពីព្រះយេហូវ៉ា (ធៀប ១ពវ ១៩:១៧ និងការពន្យល់) ។

**៣:១** *រីឯយ៉ូរ៉ាម ជាបុត្រអ័ហាប់ . . . រាជ្យយ៉ូសាផាត* សូមមើលការពន្យល់ ១:១៧ ។ *ក្នុងឆ្នាំទី១២* ឆ្នាំនេះស្ថិតនៅចន្លោះ ៨៥២-៨៤១ មុន គ.ស ។

**៣:២** *តែមិនដល់ព្រះបិតា និងព្រះមាតាទ្រង់ទេ* នេះបញ្ជាក់ថាអំពើបាបរបស់ទ្រង់មិនស្មើនឹងព្រះមាតានិងបិតាទ្រង់ទេ (មើលការពន្យល់ ១ពវ ១៦:៣០-៣៤) និងយេសិបិល (មើល ១ពវ ១៨:៤ ១៩:១-២ ២១:៧-១៥) *ទ្រង់បានបំបាត់រូបព្រះបាល ដែលព្រះបិតាទ្រង់បានធ្វើ* នៅត្រង់នេះបញ្ជាក់ថាលោកបានលុបបំបាត់ចោលរូបព្រះផ្សេងៗ (សូមមើលការពន្យល់ ១ពវ ១៤:២៣) ដែលអ័ហាប់ជាបិតាបានគោរព និងសង់វិហារជាច្រើននៅស្រុកសាម៉ារី (មើល ១ពវ ១៦:៣២-៣៣) ។ ចាប់ពី ១០:២៧ និយាយអំពីរូបព្រះនេះត្រូវបានគេគោរពឡើងវិញ ហើយប្រហែលជាយេសិបិល ។

**៣:៣** *អំពើបាបរបស់យេរ៉ូបោម . . . នាំឱ្យពួកអ៊ីស្រាអែលធ្វើតាមផង* មើលការពន្យល់ ១ពវ ១៤:១៦ ។

**៣:៤** *មេសា ជាស្តេចសាសន៍ម៉ូអាប់* មើលការពន្យល់ ១:១ ។ *ទ្រង់មានហ្វូងចៀម . . . និងរោមចៀមឈ្មោល១សែន* ត្រង់នេះបញ្ជាក់ពីចំនួនដ៏មហិមាដែលស្តេចអ៊ីស្រាអែលបានតម្រូវឱ្យស្តេចស្រុកម៉ូអាប់យកមកថ្វាយ ដែលទ្រង់មានដូចជាពួកអ្នកបម្រើ និងសួយសាអាករជាដើម (មើល សយ ១៦:១) ។

**៣:៥** *ស្តេចម៉ូអាប់បានបះបោរ* មើលការពន្យល់ ១:១ ។

**៣:៧** *តើទ្រង់សព្វព្រះទ័យចង់ទៅច្បាំង នឹងសាសន៍ម៉ូអាប់ជាមួយនឹងទូលបង្គំឬទេ* នៅត្រង់នេះស្តេចយ៉ូរ៉ាមមានបំណងចង់ទៅវាយផ្តួលស្តេចស្រុកម៉ូអាប់ ប៉ុន្តែពួកកងទ័ពត្រូវឆ្លងកាត់ទឹកដីពួកយូដា (ខ.៨) ។ *ទូលបង្គំក៏ដូចជាទ្រង់ រាស្ត្រទូលបង្គំក៏ដូចជារាស្ត្ររបស់ទ្រង់ដែរ* សូមមើល ១ពវ ២២:៤ ។

**៣:៨** *តាមផ្លូវកាត់ទីរហោស្ថានស្រុកអេដុំម* តាមច្រកនេះពួកទាហានអ៊ីស្រាអែល និងយូដាដែលនៅភាគខាងត្បូងសមុទ្រស្លាប់ នោះធ្វើឱ្យពួកគេអាចធ្វើដំណើរវាងពីបន្ទាយរបស់ពួកម៉ូអាប់ និងគេចពីការវាយប្រហាររបស់ពួកអើរ៉ាម និងពួកដាម៉ាស ។ ពួកអេដុំម គឺត្រូវបានពួកយូដាកាន់កាប់ ដូច្នេះពួកគេមិនបានតតាំងចំពោះពួកទាហានអ៊ីស្រាអែលដែលឆ្លងកាត់ទីនេះទេ ។

**៣:៩** *ស្តេចអេដុំម* ទោះបីស្តេចអង្គនេះត្រូវបានគេជ្រើសរើសទុកជាមុនហើយក៏ដោយ គឺទ្រង់នៅតែស្ថិតក្រោមការតែងតាំងរបស់ស្តេចយ៉ូសាផាតដដែល (មើល ៨:២០ ១ពវ ២២:៤៧) ។

**៣:១១** *នៅទីនេះ តើគ្មានហោរាម្នាក់របស់ព្រះយេហូវ៉ា* មើលការពន្យល់ ១ពវ ២២:៧ ។ ចំណុចនេះ មានតែហោរាបីនាក់គត់ដែលស្វែងរកជំនួយពីព្រះយេហូវ៉ា (ខ.១២) ។ *អេលីសេ ជាកូនសាផាត* ដោយលោកអេលីយ៉ា

បានសួរ[ដ]ដល់ព្រះអង្គដោយសារអ្នកនោះទេឬអី នោះអ្នក
ជិនិតម្នាក់របស់ស្ដេចអ៊ីស្រាអែលក៏ទូលឆ្លើយឡើងថា អេ-
លីសេ[ឋ] ជាកូនសាផាតដែលបានចាក់ទឹកលាងដៃអេលីយ៉ា
លោកនៅទីនេះដែរ[ឌ] ១២យ៉ូសាផាតក៏មានបន្ទូលថា ព្រះ
បន្ទូល[ឍ]នៃព្រះយេហូវ៉ាក៏សណ្ឋិតនៅនឹងលោក ដូច្នេះ ស្ដេច
អ៊ីស្រាអែល និងយ៉ូសាផាត ហើយស្ដេចអេដំម ទាំង៣អង្គក៏
យាងចុះទៅឯលោក ។
១៣ឯអេលីសេ ក៏ទូលដល់ស្ដេចអ៊ីស្រាអែលថា តើទ្រង់នឹង
ទូលបង្គំត្រូវការអ្វីនឹងគ្នា ចូរទៅឯពួកហោរ៉ារបស់ព្រះបិតា
នឹងព្រះមាតាទ្រង់ចុះ តែស្ដេចអ៊ីស្រាអែលមានបន្ទូលតបថា
ទេ ដ្បិតព្រះយេហូវ៉ាបានហៅស្ដេចទាំង៣អង្គនេះមក ដើម្បី
នឹងប្រគល់ទៅក្នុងកណ្ដាប់ដៃនៃពួកម៉ូអាប់ហើយ ១៤រួច
អេលីសេទូលថា ទូលបង្គំស្បថដោយនូវព្រះយេហូវ៉ា នៃពួក
ពលបរិវារ ដ៏មានព្រះជន្មរស់នៅ ដែលទូលបង្គំឈរ នៅ
ចំពោះទ្រង់នេះថា បើទូលបង្គំមិនបានយល់ដល់យ៉ូសាផាត
ជាស្ដេចយូដា នោះប្រាកដជាទូលបង្គំមិនព្រមទាំងក្រឡេក
មើលទៅទ្រង់ ឬឃើញទ្រង់ទេ ១៥តែឥឡូវនេះ សូមនាំអ្នក
ភ្លេងម្នាក់[ណ]មកឯទូលបង្គំ រួចកាលអ្នកនោះកំពុងតែលេង
ភ្លេង នោះព្រះហស្ត[ត]នៃព្រះយេហូវ៉ាក៏មកលើអេលីសេ
១៦ហើយលោកទាយថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ
ចូរជីកប្រឡាយឱ្យពេញក្នុងច្រកភ្នំនេះទៅ ១៧ដ្បិតព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា ឯងរាល់គ្នានឹងមិនឃើញខ្យល់
បក់ ឬភ្លៀងធ្លាក់ឡើយ តែច្រកភ្នំនេះនឹងមានទឹកពេញ[ថ]

**៣:១១** ដ លប ២៥:២២ ១ពវ ២២:៥ ឋ លប ២០:៧ ឌ ១ពវ ១៩:១៦
**៣:១២** ឍ ជន ១១:១៧
**៣:១៥** ណ ១សយ ១០:៥ ត យរ ១៥:១៧ អគ ១:៣
**៣:១៧** ថ ទដ ១០៧:៣៥ អស ១២:៣ ៣២:២ ៣៥:៦ ៤១:១៨ ៦៥
**៣:១៨** ទ លប ១៨:១៤ ២ពវ ២០:១០ អស ៤៩:៦ យរ ៣២:១៧,២៧ មក ១០:២៧
**៣:២០** ធ នក ២៩:៤១ ន នក ១៧:៦ ប អស ១៥:១ ១៦:៧ យរ ៤៨:៣១,៣៦

នោះឯងរាល់គ្នានឹងបានទឹកផឹក ព្រមទាំងហ្វូងសត្វ នឹងសត្វ
ជំនិះរបស់ឯងរាល់គ្នាផង ១៨ឯការនេះក៏ជាការយ៉ាងតូច[ទ]
នៅព្រះនេត្រព្រះយេហូវ៉ាទេ គឺព្រះទ្រង់នឹងប្រគល់សាសន៍
ម៉ូអាប់មកក្នុងកណ្ដាប់ព្រះហស្តនៃទ្រង់ទៀត ១៩ត្រូវឱ្យវាយ
អស់ទាំងទីក្រុងមានកំផែង នឹងគ្រប់ទាំងទីក្រុងយ៉ាងវិសេស
ព្រមទាំងកាប់អស់ទាំងឈើល្អ នឹងខ្ទប់អស់ទាំងរន្ធទឹក ហើយ
យកដុំថ្មទៅរាយបង្ខូចអស់ទាំងស្រែចំការល្អៗ ២០លុះព្រឹក
ឡើង នៅពេល[ធ]ថ្វាយដង្វាយ ក៏មានទឹកហូរមកពីខាងស្រុក
អេដំម ទោះច្រកភ្នំក៏មានទឹកពេញ[ន] ។
២១រីឯពួកសាសន៍ម៉ូអាប់ កាលគេបានឮថា ស្ដេចទាំង
នោះបានឡើងមក ដើម្បីច្បាំងនឹងខ្លួន នោះក៏ប្រមូលគ្នា គឺ
អស់អ្នកណាដែលមានអាយុល្មម នឹងកាន់គ្រឿងសស្ត្រាវុធ
បានរហូតឡើងទៅលើ រួចទៅដំរៀបគ្នានៅត្រង់ព្រំប្រទល់
២២ព្រឹកព្រហាមថ្ងៃនោះ ពួកម៉ូអាប់ក្រោកឡើងឃើញពន្លឺ
ថ្ងៃចាំងមកពីលើទឹក ដែលនៅមុខគេនោះ មើលទៅក្រហម
ដូចជាឈាម ២៣គេក៏និយាយគ្នាថា នោះគឺជាឈាមហើយ
ពួកស្ដេចនោះបានប្រហារជីវិតគ្នា ប្រាកដជាបានសំឡាប់
គ្នានឹងគ្នា វិនាសអស់ហើយ ដូច្នេះ ឱពួកម៉ូអាប់អើយ ចូរ
យើងទៅរឹបជាន់ចាប់យករបឹបរបស់គេចុះ ២៤ដូច្នេះ ក៏នាំ
គ្នាទៅដល់ទីបោះទ័ពនៃពួកអ៊ីស្រាអែល តែពួកអ៊ីស្រាអែល
ក្រោកឡើង ប្រហារពួកម៉ូអាប់ឱ្យគេរត់ ទៅនៅមុខខ្លួនពួក
អ៊ីស្រាអែលក៏ចេះតែដេញតាមវាយពួកម៉ូអាប់ទៅ រហូត
ដល់ក្នុងស្រុកគេ ២៥ក៏វាយរំលំអស់ទាំងទីក្រុង ហើយយកថ្ម

បានបញ្ជូនសារមួយដល់យ៉ូសាផាតដែលបុត្ររបស់យ៉ូរ៉ាមក្រោយពីការសុគត របស់បិតាទ្រង់ (មើល រប ២១:១២–១៥) ដែលហាក់ដូចជាអេលីសេ និងពួកកងទ័ពបានឈរនៅក្នុងយុទ្ធនាការ នៃការធ្វើជាអ្នកបន្តវេនរបស់លោកអេលីយ៉ា ។ ហេតុការណ៍ដែលរៀបរាប់នៅទីនេះ គឺជាការរៀបរាប់ពីសេចក្ដីបង្រៀនរបស់លោកអេលីសេ ដែលដើរតួជាអ្នកបន្តវេនពីលោកអេលីយ៉ា ហើយហេតុការណ៍ពីរទៀតគឺ រៀបរាប់ពីកិច្ចការដែលខ្លួនគាត់ធ្វើផ្ទាល់ ។

**៣:១៣** *ចូរទៅឯពួកហោរ៉ារបស់ព្រះបិតា និង . . . ព្រះមាតាទ្រង់ចុះ* សូមមើល ១ពវ ២២:៦ ។

**៣:១៤** *បើទូលបង្គំមិនបានយល់ដល់...យ៉ូសាផាត ... មិនព្រមទាំងក្រឡេកមើលទៅទ្រង់* ។ យ៉ូរាមនិងចែកចាយព្រះពរ ដែលជាព្រះបន្ទូលរបស់ព្រះដោយលោកបានរួមចំណែកជាមួយនិងយ៉ូសាផាត ។

**៣:១៥** *សូមនាំអ្នកភ្លេងម្នាក់* ការនាំអ្នកភ្លេងមកនេះ ក្នុងគោលបំណងនាំឱ្យពួកគេទទួលនូវបន្ទូលរបស់ព្រះយេហូវ៉ា ។ *ព្រះហស្តនៃព្រះយេហូវ៉ា* មើលការពន្យល់ អគ ១:៣ ។

**៣:១៦** *ច្រកភ្នំ* ច្រកនេះជាទីដែលពួកទាហានអ៊ីស្រាអែល បានតាំងជាបន្ទាយនៅក្នុងជ្រលងនេះ គឺចន្លោះតំបន់ខ្ពង់រាបនៃស្រុកម៉ូអាប់ក្នុងភាគខាងកើតដែលត្រូវនឹងភាគខាងលិចនៃស្រុកយូដា ហើយសរុបមកគឺស្ថិតនៅភាគខាងត្បូងនៃសមុទ្រស្លាប់ ។

**៣:១៧** *នឹងមានទឹកពេញ* ព្រះបន្ទូលនៃព្រះយេហូវ៉ាជាសេចក្ដីសន្យា ហើយក៏ជាការបង្គាប់ដោយផ្ទាល់ដែរ ។ ព្រះយេហូវ៉ា នឹងប្រទានឱ្យពួកគេយ៉ាងសមសួនដល់រាស្ត្ររបស់ទ្រង់ ប៉ុន្តែពួកគេត្រូវតែឈរឱ្យបានមាំមួននៅក្នុងសេចក្ដីជំនឿ និងភាពស្មោះត្រង់ដល់ទ្រង់ (ឧ.១៦) ។

**៣:១៩** នៅក្នុងចំណុចនេះ ទាហានពីរនាក់បានវាយកំទេច ហើយនិងមានការបះបោរ ។

**៣:២០** *ពេលថ្វាយដង្វាយ* សូមមើលការពន្យល់ នក ២៩:៣៨–៣៩ ជន ២៨:៣–៤ ។ *ទឹកហូរមកពីខាងស្រុកអេដំម* ទឹកដែលហូរមកពីស្រុកអេដំមធ្លាក់ចុះទៅតំបន់ទំនាបខាងក្រោមដោយឆ្លងកាត់ប្រទេសផ្សេងៗ រហូតដល់សមុទ្រស្លាប់ (មើលការពន្យល់ ឧ.១៦) ។

**៣:២៣** *ពួកស្ដេចនោះបានប្រហារជីវិតគ្នា* នៅត្រង់នេះបញ្ជាក់ថាស្ដេចសាសន៍ម៉ូអាប់មានហេតុផលល្អគ្រប់គ្រាន់ ក្នុងការទទួលយកផលប្រយោជន៍ក្នុងកាលដែលគូរភាគីមានទំនាស់ផ្ទៃក្នុងដែលជាសម្ព័ន្ធមិត្តចាស់នោះ ។

**៣:២៥** *ក្រុងគារ–ហារ៉ាសែត* នេះជាទីក្រុងរបស់ពួកម៉ូអាប់ (មើល អស ១៦:៧,១១ យរ ៤៨:៣១,៣៦) ។

គ្រប់ៗគ្នា បោះទៅពេញក្នុងអស់ទាំងស្រែចំការល្អ ក៏ខ្ទប់រន្ធ
ទឹកទាំងប៉ុន្មាន ហើយកាប់អស់ទាំងដើមឈើដែលល្អដែរ
មានតែក្រុងគារ–ហារ៉ាសែត[ប] ប៉ុណ្ណោះទេ ដែលគេបានទុក
ថ្មឱ្យនៅវិញ ប៉ុន្តែពួកបាញ់ក្រួស គេបានឡោមព័ទ្ធវាយ
ទីក្រុងនោះ ២៦កាលស្តេចម៉ូអាប់ឃើញថា ចំបាំងជាខ្លាំង
ទប់មិនបាន នោះទ្រង់រើសយកទាហាន៧០០នាក់ ដែលកាន់
ដាវនាំទៅដោយប្រាថ្នានឹងទំលាយចូលទៅដល់ស្តេចអេដុំម
តែធ្វើមិនកើតទេ ២៧រួចមកទ្រង់យកបុត្រាច្បង[ផ] ដែលត្រូវ
សោយរាជ្យជំនួសទ្រង់ ទៅថ្វាយជាដង្វាយដុត នៅលើ
កំផែងក្រុងនោះក៏កើត មានសេចក្តីក្រេវក្រោធចំពោះពួក
អ៊ីស្រាអែលជាខ្លាំង ហើយគ្រប់គ្នាថយចេញត្រឡប់ទៅ
ស្រុកគេរៀងខ្លួនវិញ ។

## ប្រេងរបស់ស្ត្រីមេម៉ាយ

**៤** ១រីឯមានស្ត្រីម្នាក់ ជាប្រពន្ធនៃពួកសិស្ស[ក] របស់ពួកហោ–
រាម្នាក់ នាងបានស្រែកដល់អេលីសេថា ប្តីខ្ញុំជាអ្នកបំរើ
លោកបានស្លាប់ហើយ លោកក៏ជ្រាបថា អ្នកបំរើរបស់
លោកបានកោតខ្លាចដល់ព្រះយេហូវ៉ាដែរ ឥឡូវនេះម្ចាស់
បំណុល[ខ] បានមកចង់យកកូនខ្ញុំទាំង២ទៅធ្វើការជាបាវបំរើ
២អេលីសេសួរនាងថា តើចង់ឱ្យខ្ញុំធ្វើអ្វីឱ្យអ្នក សូមប្រាប់ខ្ញុំ
ចុះ តើអ្នកមានអ្វីនៅផ្ទះ នាងឆ្លើយតបថា នាងខ្ញុំគ្មានអ្វីនៅ
ផ្ទះទេ មានតែដបប្រេង១ប៉ុណ្ណោះ[គ] ៣ដូច្នេះលោកប្រាប់ថា
ចូរអ្នកចេញទៅខ្ចីភាជនៈ ពីពួកអ្នកជិតខាងទាំងប៉ុន្មានគឺជា
ភាជនៈ ដែលនៅទទេ ហើយកុំឱ្យខ្ចីតិចឡើយ ៤រួចឱ្យអ្នក
នាំកូនចូលទៅក្នុងផ្ទះ បិទទ្វារទៅ ហើយចាក់ប្រេងទៅ
ក្នុងភាសជនៈទាំងនោះ កាលណាមាន១ណាពេញ នោះចូរ
ដាក់ទុកទៅខាងម្ខាង ៥ដូច្នេះ នាងក៏ចេញពីលោកទៅនាំ
កូនចូលទៅក្នុងផ្ទះបិទទ្វារ កូនទាំង២ក៏ហុចភាជនៈមកឱ្យ
ម្តាយ ហើយម្តាយក៏ចាក់ប្រេងដាក់ ៦លុះភាជនៈទាំងនោះ
បានពេញហើយ នោះនាងបង្គាប់កូនថា ចូរហុច១ទៀត
មកឱ្យអញ តែកូនឆ្លើយតបថា មានតែប៉ុណ្ណឹងទេ នោះប្រេង
ក៏ឈប់ហូរទៅ ៧នាងក៏ទៅជំរាបដល់អ្នកសំណប់របស់
ព្រះ[ឃ] ហើយលោកប្រាប់ថា ចូរយកប្រេងនោះទៅលក់សង
បំណុលគេទៅ ឯចំណែកដែលសល់នៅ នោះចូរទុកចិញ្ចឹម
ខ្លួននឹងកូនចុះ ។

## កូនរបស់ស្ត្រីនៅក្រុងស៊ូណែមត្រូវប្រោសឱ្យរស់វិញ

៨មានកាល១ថ្ងៃទៀត អេលីសេបានដើរទៅឯក្រុង
ស៊ូណែម[ង] រីឯនៅទីនោះមានស្ត្រីអ្នកធំម្នាក់ នាងបានឃាត់
លោកឱ្យនៅពិសាបាយ រួចមកវេលាណាដែលលោកទៅ
តាមទីនោះ លោកតែងតែចូលទៅពិសាបាយនៅផ្ទះនាង
៩នាងក៏និយាយនឹងប្តីថា មើល ខ្ញុំយល់ឃើញថា មនុស្សដែល
តែងធ្លាប់មកផ្ទះយើង ជាញយៗនេះ លោកជាអ្នកបរិសុទ្ធ
របស់ព្រះ ១០សូមឱ្យយើងធ្វើបន្ទប់១តូចនៅលើជញ្ជាំងព្រម
ទាំងដាក់គ្រែ តុ កៅអី និងជើងទៀន សំរាប់លោកផង[ច]
ដូច្នេះ កាលណាលោកមកផ្ទះយើង នោះនឹងនៅក្នុងបន្ទប់
នោះ ១១ក្រោយមក មានកាល១ថ្ងៃ លោកក៏មកដល់ហើយ
ចូលទៅសំរាន្តក្នុងបន្ទប់នោះ ១២លោកប្រាប់កេហាស៊ី ជា
អ្នកបំរើលោកថា ចូរហៅស្ត្រីដែលនៅក្រុងស៊ូណែមនេះ
មក[ឆ] កាលបានហៅមកដល់ហើយ នោះនាងឈរនៅ

**៣:២៧** ផ ចទ ១២:៣១ ២ពវ ១៦:៣ ២១:៦ ២របា ២៨:៣ ទដ ១០៦:៣៨ យរ ១៩:៤–៥ មីក ៦:៧
**៤:១** ក ១សយ ១០:៥ ខ នក ២២:២៦ លវ ២៥:៣៩–៤៣ នហ ៥:៣–៥ យប ២២:៦ ២៤:៩
**៤:២** គ ១ពវ ១៧:១២
**៤:៧** ឃ ១ពវ ១២:២២
**៤:៨** ង យស ១៩:១៨
**៤:១០** ច មថ ១០:៤១ រម ១២:១៣
**៤:១២** ឆ ២ពវ ៨:១

**៣:២៦** *ទំលាយចូលទៅដល់ស្តេចអេដុំម* នៅត្រង់នេះស្តេចក្រុងម៉ូអាប់បាន បង្ខំឱ្យពួកអេដុំមប្រឆាំងនឹងពួកអ៊ីស្រាអែល និងពួកយូដា ។

**៣:២៧** *ថ្វាយជាដង្វាយដុត នៅលើកំផែងក្រុង* នៅត្រង់នេះ មេសាជាស្តេចសាសន៍ម៉ូអាប់ បានថ្វាយបុត្រច្បងរបស់ទ្រង់ជាដង្វាយដុត (មើល ១៦:៣ យរ ៧:៣១) នៅចំពោះព្រះរបស់ពួកម៉ូអាប់ (មើល ១ពវ ១១:៧ ជន ២១:២៩ យរ ៤៨:៤៦) ។

**៤:១** *ស្ត្រីម្នាក់ ជាប្រពន្ធនៃពួកសិស្ស របស់ពួកហោរាម្នាក់* សូមមើល ២:៣ ១ពវ ២០:៣៥ ។ *យកកូនខ្ញុំទាំងពីរទៅធ្វើជាបាវបំរើ* ពាក្យថាបាវបម្រើ ក្នុងនេះមានន័យថា ជាប់ជំពាក់ព័ន្ធនូវកម្លាំងពលកម្មរបស់គេ ដូចមានចែងនៅក្នុងក្រឹត្យវិន័យ (នក ២១:១–២ លវ ២៥:៣៩–៤១ ចទ ១៥:១–១១) ។ តែទោះជាយ៉ាងនេះក្តី ក៏ការអនុវត្តនៅតែមានការរំលោភបំពាន (មើល នហ ៥:៥,៨ អម ២:៦ ៨:៦) ដែលពួកអ្នកទាំងនោះតម្រូវឱ្យធ្វើជាទាសករ ដូចជាពួកស៊ីឈ្នួលអញ្ចឹងដែរ ។

**៤:៤** *របស់ពួកហោរា* សូមមើលការពន្យល់ ២:៣ ១ពវ ២០:៣៥ ។ *យកកូនខ្ញុំទាំងពីរទៅធ្វើជាបាវបំរើ* ឃ្លានេះបញ្ជាក់ពីការជំពាក់បំណុល ហើយកូនទាំងពីរនេះជាអ្នកសងនូវអ្វីដែលគាត់បានជំពាក់ ដូចដែលមានចែងនៅក្នុងក្រឹត្យវិន័យលោកម៉ូសេ (នក ២១:១–២ លវ ២៥:៣៩–៤១ ចទ ១៥:១–១១)

**៤:៤** *នាំកូនចូលទៅក្នុងផ្ទះ បិទទ្វារទៅ* ការគំរាមគំហែងនេះ មិនបានធ្វើឡើងជាបុគ្គលខ្លួនគាត់ផ្ទាល់ទេ តែជាការសម្តែងពីសេចក្តីមេត្តាករុណា និងព្រះគុណរបស់ព្រះតាមរយៈបង្អួចនេះ (សូមធៀប ទដ ៦៨:៥) ។ ចំពោះស្ត្រីនេះនាងគ្មានសេចក្តីសង្ស័យចំពោះការណែនាំតាមរយៈអ្នកតំណាងដែលជាហោរារបស់ព្រះ ពោលគឺនាងមានសេចក្តីជំនឿ និងកោតខ្លាចដល់ព្រះ ។

**៤:៨** *ក្រុងស៊ូណែម* សូមមើលការពន្យល់ ១ពវ ១:៣ ។

**៤:៩** *អ្នកបរិសុទ្ធរបស់ព្រះ* ស្ត្រីម្នាក់នេះ ទទួលស្គាល់លោកអេលីសេថាជាមនុស្សដែលព្រះបានញែកគេចេញ ជាបរិសុទ្ធសម្រាប់ការងារផ្សេងៗរបស់ព្រះ (មើលការពន្យល់ នក ៣:៥) ។ ចំពោះពាក្យថា អ្នកបរិសុទ្ធរបស់ព្រះដែលជាហោរា គឺមាននិយាយតែត្រង់នេះទេ ។

**៤:១០** *ដូច្នេះ កាលណាលោកមកផ្ទះយើង នោះនឹងនៅក្នុងបន្ទប់នោះ* ដោយការទទួលរាក់ទាក់របស់ស្ត្រីនេះ នោះលោកអេលីសេអាចប្រកាសពីព្រះនាមរបស់ព្រះបានដោយងាយ ។

**៤:១២** *កេហាស៊ី* ម្នាក់នេះទើបតែបានលេចមកជាលើកទី១ ក្នុងនាមជាអ្នកបម្រើលោកអេលីសេ គឺដូចក្នុងកាលដែលលោកអេលីសេជាអ្នកបម្រើលោក

ចំពោះលោក ១៣រួចលោកប្រាប់អ្នកបំរើថា ចូរនិយាយនឹង
នាងថា មើល នាងបានចាត់ចែងគោរពដល់យើងជាច្រើន
ដល់ម៉្លេះឥឡូវនេះ តើត្រូវឱ្យយើងសងគុណដល់នាងយ៉ាង
ណាខ្លះ តើចង់ឱ្យខ្ញុំទូលដល់ស្តេច ឬជិរាបមេទ័ពធំឱ្យនាង
ឬទេ តែនាងឆ្លើយតបថា នាងខ្ញុំចូលចិត្តនៅតែកណ្តាល
ពួកសាសន៍នាងខ្ញុំនេះទេ ១៤លោកសួរទៀតថា បើដូច្នេះ
តើត្រូវសងគុណដល់នាងយ៉ាងណា កេហាស៊ីឆ្លើយឡើងថា
មើលគាត់គ្មានកូនទេ ហើយប្តីក៏ចាស់ផង ១៥លោកប្រាប់ថា
ចូរហៅនាងមកនេះ កាលបានហៅមកដល់ហើយ នោះ
នាងឈរនៅត្រង់មាត់ទ្វារ ១៦ហើយលោកប្រាប់ថា ដល់
កំណត់ ឆ្នាំក្រោយ[ជ] នោះនាងនឹងបានបីកូនប្រុស១ តែនាង
ឆ្លើយថា ទេ លោកម្ចាស់ ជាអ្នកសំណប់របស់ព្រះអើយ
សូមកុំកុហកដល់នាងខ្ញុំឡើយ ។
១៧ស្ត្រីនោះក៏មានទំងន់ ហើយដល់កំណត់ឆ្នាំក្រោយនាង
សំរាលបានកូនប្រុស១ ដូចពាក្យដែលអេលីសេបានប្រាប់
១៨កាលកូននោះ បានធំឡើងហើយ នោះមានកាល១ថ្ងៃវា
ចេញទៅឯឪពុក ដែលនៅជាមួយនឹងពួកអ្នកច្រូត[ឈ] ១៩នោះ
វាត្អូញប្រាប់ឪពុកថា ខ្ញុំឈឺក្បាល ខ្ញុំឈឺ ក្បាលណាស់ ឪពុក
បង្គាប់ទៅអ្នកបំរើថា ចូរបីវាយកទៅឱ្យម្តាយវាទៅ ២០អ្នក
នោះក៏បីយកទៅឱ្យម្តាយ ហើយវាអង្គុយលើភ្លៅម្តាយ
រហូតដល់ថ្ងៃត្រង់រួចស្លាប់ទៅ ២១ម្តាយក៏ឡើងទៅ ដាក់

**៤:១៦** ជ លវ ១៨:១០
**៤:១៨** ឈ រម ២:៣
**៤:២១** ញ ខ.៣២
**៤:២៣** ដ ជន ១០:១០ ១រប ២៣:៣១ ទដ ៨១:៣
**៤:២៥** ឋ ១ពវ ១៨:២០
**៤:២៧** ឌ ១សយ ១:១៥

វាផ្តេកនៅលើដំណេក[ញ]នៃអ្នកសំណប់របស់ព្រះ ហើយបិទ
ទ្វារចេញទៅ ២២រួចនាងស្រែកទៅប្តីថា សូមចាត់បំរើម្នាក់
នឹងលា១មកសិន ដើម្បីឱ្យខ្ញុំរត់ទៅ ឯអ្នកសំណប់របស់ព្រះ
រួចវិលមកវិញ ២៣ប្តីតបថា ឯងចង់ទៅរកលោកនៅថ្ងៃ
នេះធ្វើអី នេះមិនមែនជាថ្ងៃចូលខែ[ដ] ឬថ្ងៃឈប់សំរាកទេ
តែនាងឆ្លើយថា មិនអីទេ ២៤នាងក៏ចងកែបលា រួចបង្គាប់
អ្នកបំរើថា ចូរវាយជិះរត់ទៅ កុំបង្អង់ឡើយ លើកតែអញ
បង្គាប់ គឺយ៉ាងនោះដែល នាងធ្វើដំណើរទៅឯអ្នកសំណប់
របស់ព្រះ នៅត្រង់ភ្នំកើមែល[ឋ] ។
២៥កាលអ្នកសំណប់របស់ព្រះបានឃើញនាងមកពី
ចំងាយ នោះលោកបង្គាប់ទៅកេហាស៊ី ជាអ្នកបំរើថា នុ៎ះន៏
ស្ត្រីស្រុកស៊ូណែម ២៦ចូររត់ទៅទទួល ហើយសួរថា តើអ្នក
សុខសប្បាយជាទេឬ តើប្តី អ្នកជាទេឬ ហើយកូនអ្នកជាទេឬ
តែនាងឆ្លើយថាជាទេ ២៧កាលបានមកដល់អ្នកសំណប់
របស់ព្រះ នៅលើភ្នំហើយ នោះនាងក៏ចាប់ជើងលោក
កេហាស៊ីក៏ចូលទៅ ដើម្បីច្រាននាងចេញ តែអ្នកសំណប់
របស់ព្រះឃាត់ថា បណ្តោយតាមនាងចុះ ពីព្រោះនាងមាន
សេចក្តីជូរចត់ក្នុងចិត្ត[ឌ] ហើយព្រះយេហូវ៉ាទ្រង់បានលាក់
នឹងអញ ឥតសំដែងឱ្យអញដឹងសោះ ២៨នោះនាងនិយាយ
ឡើងថា តើនាងខ្ញុំបានសូមកូន ពីលោកម្ចាស់ឬទេ តើនាងខ្ញុំ
មិនបានសូមថា កុំបញ្ឆោតនាងខ្ញុំទេឬអី ២៩នោះលោក

អេលីយ៉ាដែរ ។ ទោះជាអ្នកទាំងពីរនេះ ធ្លាប់ធ្វើជាអ្នកបម្រើដូចគ្នាក៏ដោយ ក៏ពួកគេមិនអាចដូចគ្នាបានឡើយ (មើល ៥:១៩–២៧ ៦:១៥) ។

**៤:១៣** *នាងខ្ញុំចូលចិត្តនៅតែកណ្តាលពួកសាសន៍នាងខ្ញុំ* ឃ្លានេះបានប្រាប់ថា ស្ត្រីស្រុកស៊ូណែម ក្រុមគ្រួសារ និងពួកសាសន៍របស់នាង កំពុងស្ថិតក្នុងភាពមានសុវត្ថភាព ដូច្នេះហើយនាងមិនត្រូវការសេចក្តីអនុគ្រោះពីពួកអ្នកដឹកនាំដែលជាមន្ត្រីធំៗនោះទេ ។

**៤:១៤** *គាត់គ្មានកូនទេ ហើយប្តីក៏ចាស់ផង* ការខកចិត្តដ៏ធំរបស់គាត់ដោយព្រោះវាជាសេចក្តីអាក្រក់ ដែលឈ្មោះនៃគ្រួសាររបស់គាត់ត្រូវញប់ត្រឹមនេះហើយដីរបស់គាត់ត្រូវផ្តល់សិទ្ធឱ្យអ្នកដទៃកាន់កាប់ទៅវិញ ។ (មើល ៨:១–៦ និងការពន្យល់ ១ពវ ១៧:១២) ។

**៤:១៦** *ដល់កំណត់ ឆ្នាំក្រោយ* សូមមើល លក ១៧:២១ ១៨:១៤ ។ *លោកម្ចាស់ ជាអ្នកសំណប់របស់ព្រះអើយ* នៅត្រង់នេះ នាងបានបង្ហាញពីការមិនទុកចិត្ត ចំពោះដែលលោកហោរាអេលីសេ បានទាយពីការដែលនាងនឹងបាបកូនប្រុស១ ។

**៤:១៧** *ដូចពាក្យ ដែលអេលីសេបានប្រាប់* ការនេះបានសម្រេចតាមការទាយទុករបស់លោកអេលីសេ ហើយកូនប្រុសនោះបានកើតមក ដើម្បីបង្ហាញពីលទ្ធផលដ៏សមសួនរបស់ព្រះដែលមាននៅក្នុងស្ត្រីនេះ ។

**៤:២០** *ស្លាប់ទៅ* នេះបញ្ជាក់ថាកូនដែលទើបតែនឹងកើតមកបានស្លាប់ទៅវិញ ដែលជាព្រះគុណរបស់ព្រះ ដែលការនេះព្រះអម្ចាស់បានធ្វើការល្បងលលើសេចក្តីជំនឿរបស់នាង ។ ហើយជាលទ្ធផលនៅត្រង់នេះ នាងបានបង្ហាញពីសេចក្តីជំនឿដ៏រឹងមាំរបស់នាងនៅក្នុងស្ថានភាពដ៏លំបាក ។

**៤:២១** *ផ្តេកនៅលើដំណេកនៃអ្នកសំណប់របស់ព្រះ* នៅក្នុងមធ្យោបាយនេះ នាងបានលាក់កំបាំងពីសេចក្តីស្លាប់របស់កូននេះ ក្នុងខណៈដែលនាងបានស្វែងរកហោរាដើម្បីជួយកូននាងបានរស់ជាថ្មីម្តងទៀត ។

**៤:២៣** *ឯងចង់ទៅរកលោកនៅថ្ងៃនេះធ្វើអី* ការនេះនៅតែជាចំណុចចោទសួរដដែលថា វាមិនមែនជារឿងធម្មតានោះទេ ចំពោះកាលដែលស្ត្រីនេះបានទៅឯលោកហោរាអេលីសេ ហើយការមួយដែលចំឡែកទៅទៀតនោះគឺ នាងបានរៀបចំនូវពេលវេលាយ៉ាងសមប្រពៃដើម្បីទៅជួបហោរា ។

**៤:២៦** *ជាទេ* ស្ត្រីរូបនេះមិនបានប្រាប់អំពីសេចក្តីព្រួយលំបាកទាំងនេះដល់អ្នកណាក្រៅពីហោរាដែលបានសន្យាថា និងផ្តល់ឱ្យកូនគាត់បានរស់ឡើងវិញឡើយ ។

**៤:២៨** *តើនាងខ្ញុំ មិនបានសូមថា កុំបញ្ឆោតនាងខ្ញុំទេឬអី* ពាក្យទាំងអស់នេះនាងនៅតែទទូចសួរដល់ព្រះអម្ចាស់ ក្នុងកាលដែលព្រះអម្ចាស់បានដកយកនូវអ្វីដែលទ្រង់បានប្រទានមកឱ្យនាង ។

**៤:២៩** *ចូរ ទៅដាក់ដំបងអញនៅលើមុខកូននោះចុះ* ត្រង់នេះហោរាអេលីសេដឹងយ៉ាងច្បាស់ថា ព្រះយេហូវ៉ានឹងប្រោសកូននេះឱ្យបានរស់ឡើងវិញ នៅពេលដែលគាត់ដាក់ដំបងនៅលើមុខក្មេងនេះ ។ ការប្រោសតាមមធ្យោបាយនេះ ពុំមានន័យថាលោកអេលីយ៉ាសម្តែងការអស្ចារ្យនៅក្នុងដំបងនេះទេ តែគាត់បានសម្តែងឱ្យឃើញពីអំណាចរបស់ព្រះវិញ (សូមមើលការពន្យល់ ២:៨ ធៀប នក ១៤:១៦ កច ១៩:១២) ។

បង្គាប់កេហាស៊ីថា ចូរក្រវាត់ចង្កេះ[ឍ]កាន់ដំបងរបស់អញ[ណ]
ចេញទៅ បើចួបនឹងអ្នកណាតាមផ្លូវ កុំឱ្យគំនាប់គេឡើយ
បើអ្នកណាគំនាប់ដល់ឯង ក៏កុំឱ្យគំនាប់តបវិញដែល ចូរទៅ
ដាក់ដំបងអញនៅលើមុខកូននោះទៅ ៣០តែម្តាយរបស់កូន
នោះនិយាយថា នាងខ្ញុំស្បថ ដោយនូវព្រះយេហូវ៉ាដ៏មាន
ព្រះជន្មរស់នៅ ហើយដោយនូវព្រលឹង លោកដ៏នៅរស់
ដែរថា នាងខ្ញុំមិនព្រមឃ្លាតចេញពីលោកទេ ដូច្នេះ លោក
ក៏ក្រោកឡើងទៅតាមនាងទៅ ៣១ឯកេហាស៊ីគាត់ក៏ទៅមុន
ហើយដាក់ដំបងនៅលើមុខកូនតែគ្មានឮសំឡេងកូនក៏គ្មាន
ស្តាប់អ្វីដែរ ដូច្នេះ គាត់វិលទៅចួបនឹងអេលីសេវិញជំរាប
ថា កូនមិនបានភ្ញាក់ទេ។

៣២កាលអេលីសេបានចូលទៅក្នុងផ្ទះ ក៏ឃើញកូននោះ
ស្លាប់នៅលើដំណេករបស់លោក[ត] ៣៣ដូច្នេះ លោកចូល
ទៅបិទទ្វារមានតែគ្នា២នាក់ ហើយក៏អធិស្ឋាន[ថ]ដល់ព្រះ
យេហូវ៉ា ៣៤រួចលោកឡើងទៅពោបលើកូននោះ ដាក់មាត់
លោកទល់នឹងមាត់វា ភ្នែកទល់នឹងភ្នែក ហើយដៃនៅលើ
ដៃដែរ ក៏សន្ធឹង[ទ]ខ្លួនលើវា រួចសាច់កូននោះក៏ក្តៅឧណ្ហ
ឡើង ៣៥នោះលោកក្រោកចេញទៅ ដើរចុះឡើងនៅក្នុង
ផ្ទះ រួចឡើងទៅសន្ធឹងខ្លួនលើវាទៀត ហើយវាកណ្តាស់
៧ដង[ធ] រួចបើកភ្នែកឡើង[ន] ៣៦ដូច្នេះ លោកហៅកេហាស៊ី
មកបង្គាប់ថា ចូរទៅហៅស្ត្រីដែលនៅក្រុងស៊ូណែមនេះមក
គាត់ក៏ហៅ កាលនាងបានចូលមកដល់ហើយ នោះលោក
ប្រាប់ថា ចូរលើកបីកូននាងឡើង[ប] ៣៧នាងក៏ចូលទៅផ្តួលខ្លួន
ក្រាបចុះដល់ដី នៅទៀបជើងលោក រួចលើកកូនបីចេញ
ទៅ ។

## សេចក្តីស្លាប់នៅក្នុងឆ្នាំង

៣៨ឯអេលីសេ លោកត្រឡប់ទៅឯក្រុងគីលកាល[ផ]វិញ
ទៀត ហើយមានអំណត់[ព]នៅក្នុងស្រុកនោះ ឯពួកសិស្ស
របស់ពួកហោរា គេអង្គុយចំពោះមុខលោក ហើយលោក
បង្គាប់អ្នកបំរើថា ចូរដាក់ឆ្នាំងធ្វើបបរ ឱ្យពួកសិស្សហោរា
ទាំងនោះទៅ ៣៩មានម្នាក់ចេញទៅរកបន្លែឯទីវាល ក៏
ឃើញវល្លិព្រៃ ហើយបេះផ្លែពេញថ្នក់អាវ វិលមកកាប់ជា
កង់ៗដាក់ ចុះទៅក្នុងឆ្នាំង ដ្បិតគេមិនបានស្គាល់ផ្លែនោះទេ
៤០រួចគេដួសបបរនោះឱ្យគ្រប់គ្នាបរិភោគ តែកាលគេកំពុង
តែបរិភោគ នោះក៏ស្រែកឡើងថា ឱអ្នកសំណប់របស់ព្រះ
អើយ បបរនេះពុលទេ ហើយគេបរិភោគពំបាន ៤១តែ
លោកប្រាប់ថា ដូច្នេះ ចូរយកម្សៅមកចុះ រួចលោកក៏ចាក់
ទៅក្នុងឆ្នាំង ហើយប្រាប់ថា ចូរដួសចែកឱ្យគេបរិភោគទៅ
នោះក៏គ្មានជាតិពុលនៅក្នុងបបរទៀតឡើយ[ភ] ។

## ការផ្តល់អាហារដល់មនុស្សមួយរយនាក់

៤២នៅគ្រានោះ មានមនុស្សម្នាក់ មកពីស្រុកបាល–
សាលីសា[ម] គាត់យកនំបុ័ងម្សៅឱក២០ដុំ[យ] ធ្វើពីផលដំបូងនឹង
គួរស្រូវស្រស់[រ] មកជូនដល់ អ្នកសំណប់របស់ព្រះនោះលោក

**៤:២៩** ឍ ១ពវ ១៨:៤៦ ណ នក ៤:២
**៤:៣២** ត ខ.២១
**៤:៣៣** ថ ១ពវ ១៧:២០ មថ ៦:៦
**៤:៣៤** ទ ១ពវ ១៧:២១ កច ២០:១០
**៤:៣៥** ធ យស ៦:១៥ ន ២ពវ ៨:៥
**៤:៣៦** ប ហព ១១:៣៥
**៤:៣៨** ផ ២ពវ ២:១ ព លវ ២៦:២៦ ២ពវ ៨:១
**៤:៤១** ភ នក ១៥:២៥ ២ពវ ២:២១
**៤:៤២** ម ១សយ ៩:៤ យ មថ ១៤:១៧ ១៥:៣៦ រ ១សយ ៩:៧

**៤:៣០** *នាងខ្ញុំមិនព្រមឃ្លាតចេញពីលោកទេ* ស្ត្រីរូបនេះ ពុំបានដឹងច្បាស់ថា បេសកកម្មរបស់កេហាស៊ី នឹងឈានទៅរកភាពជោគជ័យ ហើយលោកអេលីសេ មានបំណងចូលទៅឯក្រុងស៊ូណែមជាមួយនាងផងដែរ ។

**៤:៣៣** *ចូលទៅបិទទ្វារ មានតែគ្នា២នាក់ ហើយក៏អធិស្ឋាន* ការធ្វើរបៀបនេះគឺដូចនឹងលោកអេលីយ៉ាបានធ្វើកន្លងមក(មើល ១ពវ ១៧:២០–២២) ។ ការអធិស្ឋានរបស់លោកអេលីសេជាដំបូងនេះ គឺគាត់ទទួលបានលទ្ធផលល្អបំផុតមកពីព្រះយេហូវ៉ា ដែលធ្វើឱ្យកូនតូចនេះរស់ពីស្លាប់ឡើងវិញ ។ ការអធិស្ឋាននេះជាភស្តុតាង មួយដែលបញ្ជាក់ពីលទ្ធផលនៃបេសកកម្មរបស់គាត់ដែលធ្វើឱ្យក្មេងនេះបានរស់ឡើងវិញ ដោយមិនមែនជាការសម្តែងវេទមន្តបន្លំភ្នែកមនុស្សឡើយ ។

**៤:៣៤** *ឡើងទៅពោបលើកូននោះ* សូមមើលការពន្យល់ ១ពវ ១៧:២១ ។ ចំណុចនេះប្រហែលជាលោកអេលីសេ បានដឹងពីការដែលលោកអេលីយ៉ាបានធ្វើពីមុនមកដែរ ។

**៤:៣៧** *ផ្តួលខ្លួន ក្រាបចុះដល់ដី* ស្ត្រីរូបនេះគាត់មានសេចក្តីដឹងគុណ ចំពោះសេចក្តីសង្គ្រោះដែលព្រះយេហូវ៉ាប្រទានឱ្យនាងតាមរយៈលោកអេលីសេ (សូមមើល ១ពវ ១៧:២៤) ។

**៤:៣៨** *ក្រុងគីលកាល* មើលការពន្យល់ ២:១ ។ *មានអំណត់នៅក្នុងស្រុកនោះ* សេចក្តីអំណត់ស្រដៀងគ្នានេះ មាននិយាយនៅក្នុង ៨:១ ។ សេចក្តីអត់ឃ្លាននេះជាបណ្តាសារបស់ព្រះ(មើល លវ ២៦:១៩–២០,២៦ ចទ ២៨:១៨, ២៣–២៤ ១ពវ ៨:៣៦–៣៧) ហើយជាសេចក្តីក្រោធរបស់ព្រះ ដល់ពួកអ្នកដែលមិនស្តាប់តាមសេចក្តីបង្គាប់របស់ទ្រង់ ។ *ពួកសិស្សហោរាទាំងនេះ* សូមមើលការពន្យល់ ២:៣ ។

**៤:៣៩** *វល្លិព្រៃ . . . ឆ្នាំង* ក្នុងប្រយោគនេះ មិនបានរៀបរាប់ពីប្រភេទរុក្ខជាតិឱ្យបានជាក់លាក់ឡើយ ។

**៤:៤១** *ម្សៅ* ម្សៅនេះមិនត្រូវបានគេចំអិន (មើល ២:២១ និងពន្យល់) ។ ម្សៅនេះព្រះអម្ចាស់ប្រទានដល់អស់អ្នកណាដែលជឿលើទ្រង់ តែអស់អ្នកណាដែលមិនជឿនោះព្រះយេហូវ៉ានឹងប្រទានឱ្យគេនូវបណ្តាសាវិញ ។

**៤:៤២** *ម្សៅឱក២០ដុំ* ការជ្រើសរើសយកម្សៅនេះ ក្នុងគោលបំណងដើម្បីជំនួសដល់រដូវចម្រូតថ្មី (មើល លវ:១៤ ២៣:១៥–១៧ ចទ ១៨:៣–៥) ហើយពួកសង្ឃដែលមិនជឿព្រះនៅបេត–អែល និងដាន់(មើល ១ពវ ១២:២៨–៣១) ហើយនិងពួកអ្នកស្រឡាញ់ព្រះ និងពួកអ្នកដែលទៅជាមួយគាត់បានថ្វាយដង្វាយរបស់ពួកគេ ដើម្បីផ្គត់ផ្គង់ ដល់លោកអេលីសេ(មើលការពន្យល់ ខ.២៣) ។ ដូច្នេះ ពួកគេផ្គត់ផ្គង់លោកអេលីសេ លើសជាងអ្នកតំណាងដែលបានលះចោលសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា ។

ប្រាប់ថា ចូរចែកឱ្យបណ្ដាជនបរិភោគទៅ ៤៣អ្នកបម្រើ
លោកសួរថា តើធ្វើដូចម្ដេចឱ្យខ្ញុំដាក់តែប៉ុណ្ណោះ ឱ្យមនុស្ស
១០០នាក់បរិភោគបាន តែលោកបង្គាប់ថា ចូរចែកឱ្យគេ
បរិភោគទៅ[ល] ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
គេនឹងបរិភោគឆ្អែត ហើយនឹងនៅមានសល់ផង[វ] ៤៤ដូច្នេះ
គាត់ក៏ដាក់ឱ្យគេបរិភោគ ហើយគេបានឆ្អែត រួចនៅមាន
សល់ដូចជាព្រះយេហូវ៉ាបានមានបន្ទូលហើយ ។

## លោកណាម៉ាន់បានជាពីជំងឺឃ្លង់

**៥** ១[ក]រីឯណាម៉ាន់ជាមេទ័ពរបស់ស្ដេចស៊ីរី[ក] លោកជាអ្នកធំ
នៅចំពោះចៅហ្វាយខ្លួន ក៏មានយសខ្ពស់ ដោយព្រោះ
ព្រះយេហូវ៉ាបានប្រោស ឱ្យពួកស៊ីរីមានជ័យជំនះ ដោយ
សារលោក លោកក៏ជាមនុស្សខ្លាំងពូកែដែរ តែកើតរោគ
ឃ្លង់[ខ] ២គ្រានោះ ពួកទ័ព[គ]ស៊ីរីបានចេញ ទៅដោយកងៗគេ
ចាប់ក្មេងស្រីម្នាក់ នាំមកពីស្រុកអ៊ីស្រាអែល នាងនោះក៏
បំរើប្រពន្ធណាម៉ាន់ ៣នាងនិយាយនឹងចៅហ្វាយស្រីរបស់
ខ្លួនថា ឱបើជាលោកប្រុសជាចៅហ្វាយនាងខ្ញុំ បាននៅជា
មួយនឹងហោរា[ឃ]ដែលនៅក្រុងសាម៉ារីទៅអេះ នោះលោក
នឹងមើលរោគឃ្លង់នេះឱ្យជាទៅ ៤នោះមានម្នាក់ចូលទៅ
ជំរាប់ចៅហ្វាយខ្លួនថា ក្មេងស្រីដែលមកពីស្រុកអ៊ីស្រាអែល
វានិយាយយ៉ាងនេះមួយៗ ៥ដូច្នេះ ស្ដេចស៊ីរីមានបន្ទូលថា
ចូរទៅចុះ អញនឹងធ្វើសំបុត្រ១ផ្ញើទៅស្ដេចអ៊ីស្រាអែលដែរ
នោះលោក ក៏ចេញទៅ នាំយកទាំងប្រាក់១០ហាប និង
មាស៦ពាន់ ហើយសំលៀកបំពាក់១០បន្លាស់[ង] ៦លោកក៏នាំ
យកសំបុត្រនោះទៅថ្វាយស្ដេចអ៊ីស្រាអែល មានសេចក្ដីថា
កាលណាទ្រង់ទទួលសំបុត្រនេះ នោះមើល ទូលបង្គំបាន
ចាត់ណាម៉ាន់ ជាអ្នកជំនិតរបស់ទូលបង្គំមកហើយ ដើម្បីឱ្យ
ទ្រង់បានប្រោសឱ្យគាត់រួចពីរោគឃ្លង់ ៧កាលស្ដេចអ៊ីស្រា–
អែលទ្រង់ បានទតសំបុត្រនោះរួចហើយ[ច] នោះក៏ហែកព្រះ
ពស្ត្រទ្រង់ដោយបន្ទូលថា តើយើងជាព្រះ[ឆ]ដែលអាចនឹង
ធ្វើឱ្យស្លាប់ ឬឱ្យរស់បានឬ[ជ]បានជាគេឱ្យមនុស្សឃ្លង់នេះមក
ចង់ឱ្យយើងមើលរោគឱ្យជាដូច្នេះ ចូរពិចារណាមើល ជា
យ៉ាងណា ដែលគេរករឿង[ឈ]នឹងយើងនេះ ។
៨កាលអេលីសេ ជាអ្នកសំណប់របស់ព្រះបានឮថាស្ដេច
អ៊ីស្រាអែលបានហែកព្រះពស្ត្រទ្រង់ដូច្នោះ នោះក៏ចាត់គេ
ឱ្យទៅទូលសួរស្ដេចថា ហេតុអ្វីបានជាទ្រង់ហែកព្រះពស្ត្រ
ដូច្នេះ សូមឱ្យលោកនោះមកឯទូលបង្គំសិនចុះ នោះលោក
នឹងបានជ្រាបថា មានហោរា១[ញ]នៅ ពួកអ៊ីស្រាអែលមែន
៩ដូច្នេះ ណាម៉ាន់ក៏មកឈរនៅមាត់ទ្វារផ្ទះរបស់ អេលីសេ

**៤:៤៣** ល លក ៩:១៣ វ មថ ១៤:២០ យហ ៦:១២
**៥:១** ក លប ១០:២២ ២សយ ១០:១៩ ខ នក ៤:៦ ជន ១២:១០ លក ៤:២៧
**៥:២** គ ២ពវ ៦:២៣ ១៣:២០ ២៤:២
**៥:៣** ឃ លប ២០:៧
**៥:៥** ង ខ.២២ លប ២៤:៥៣ ពច ១៤:១២ ១សយ ៩:៧
**៥:៧** ច ២ពវ ១៩:១៤ ឆ លប ៣០:២ ជ ចទ ៣២:៣៩ ឈ ១ពវ ២០:៧
**៥:៨** ញ ១ពវ ២២:៧

**៤:៤៣** *ព្រះយេហូវ៉ាទ្រង់មានបន្ទូល* នៅត្រង់នេះបញ្ជាក់ថា ពួកគេបានបរិភោគយ៉ាងឆ្អែត ដោយព្រោះមាននំបុ័ងយ៉ាងច្រើនសន្ធឹកដោយសារព្រះយេហូវ៉ាប្រទានដល់ពួកគេ(ផ្ទុយគ្នា ខ.៤១ ២:២០ ធៀប មក ៦:៣៥–៤៣) ។
**៥:១** *ស្ដេចស៊ីរី* សំដៅលើស្ដេច បេន–ហាដាឌ់ទី២(មើលការពន្យល់ ៨:៧ ១៣:៣ ១ពវ ២០:១) ។ *ព្រះយេហូវ៉ាបានប្រោស ឱ្យពួកស៊ីរីមានជ័យជំនះ* សូមមើលការពន្យល់ ១ពវ ២២:១ ។ នៅក្នុងការពិពណ៌នា តាមគោលនៃសេចក្ដីជំនឿវិញ បានបញ្ជាក់ថាជ័យជម្នះនេះគឺបានមកដោយសាព្រះអម្ចាស់ទ្រង់បានសោយរាជ្យក្នុងពួកអ៊ីស្រាអែល (មើល អគ ៣០:២៤ អម ២:១–៣ ៩:៧) ។ នៅវគ្គនេះ បានប្រាប់អំពីជម្ងឺឃ្លង់ ដូចនឹងជម្ងឺអេដស៍សព្វថ្ងៃ ដែលមនុស្សកំពុងមានសេចក្ដីភ័យបារម្ភ ពីព្រោះវាមិនអាចនឹងមានវិធីព្យាបាល ។ មនុស្សកើតឃ្លង់នៅសម័យនោះ គឺរង់ចាំតែសេចក្ដីស្លាប់ប៉ុណ្ណោះ ហើយពួកគេ ត្រូវគេនិរទេសចេញពីភូមិកំណើតទៀតផង ។
**៥:២** *ពួកទ័ពបានចេញ ទៅដោយកងៗ* ទោះបីពួកអ៊ីស្រាអែល និងពួកស៊ីរីបានចុះកិច្ចព្រមព្រៀងគ្នារវាងសន្ធិសញ្ញាសន្តិភាពនៅក្នុងរជ្ជកាលស្ដេចអ័ហាប់(មើល ១ពវ ២០:៣៤) ប៉ុន្តែនៅមានដែនដីមួយភាគតូចកំពុងប្រឈមមុខដាក់គ្នានៅឡើយ ដែលជាបានធ្វើឱ្យស្ដេចអ័ហាប់បានសុគតទៅ (មើលការពន្យល់ ១ពវ ២២:៤ បន្ថែម ១ពវ ២២:៣៥) ។ *ក្មេងស្រីម្នាក់នាំមកពីស្រុកអ៊ីស្រាអែល* ស្ត្រីនេះត្រូវបានគេចាប់ខ្លួនក្នុងគោលបំណងទាស់ប្រឆាំងនឹងស្ដេចពួកអ៊ីស្រាអែល ។
**៥:៣** *ហោរាដែលនៅក្រុងសាម៉ារី* គឺលោកអេលីសេនេះតែម្ដង ដែលត្រូវរស់នៅក្នុងក្រុងនេះ ដើម្បីថែរក្សាការពារពួកគេ (សូមមើល ខ.៩ ២:២៥ ៦:១៩) ។
**៥:៥** *អញនឹងធ្វើសំបុត្រ១ផ្ញើទៅស្ដេចអ៊ីស្រាអែល* នៅត្រង់នេះការបញ្ចប់សង្គ្រាមចាំបាច់ត្រូវការសន្ធិសញ្ញាសន្តិភាពរួមមួយដែលជាតិសាសន៍ទាំងពីរត្រូវបង្កើតរួមគ្នាជាចាំបាច់ ។ ស្ដេចរបស់ពួកអ៊ីស្រាអែលពេលនោះ គឺមាននាមថាយ៉ូរ៉ាម (មើល ១:១៧ ៣:១ ៩:២៤) ។
**៥:៦** *ដើម្បីឱ្យទ្រង់បានប្រោសឱ្យគាត់រួចពីរោគឃ្លង់* ស្ដេចបេន–ហាដាឌ់បានសន្មត់ថា អ្វីដែលហោរាបានពិពណ៌នាអំពីបាវបម្រើស្រីរបស់ជនជាតិអ៊ីស្រាអែល គឺបានអនុញ្ញាតឱ្យស្ដេច ហើយអ្នកបម្រើអាចទិញដោយដង្វាយដ៏ធំ ។ តាមគំនិតរបស់គាត់ គឺចង់បានន័យថាអាចទិញអ្វីៗក្នុងលោកិយនេះដោយសារទ្រព្យសម្បត្តិតែមួយគត់ ប៉ុន្តែមនុស្សម្នាក់អាចទទួលការសង្គ្រោះបានគឺដោយសារព្រះប្រទានពរក្នុងចំមោមនុស្ស ។
**៥:៧** *ចូរ ពិចារណាមើល ជាយ៉ាងណា ដែលគេរករឿងនឹងយើងនេះ* ស្ដេចយ៉ូរ៉ាម បានសន្និដ្ឋានថានេះជាល្បិចកលរបស់ស្ដេចបេន–ហាដាឌ់ ដើម្បីបង្កសង្គ្រាម ។
**៥:៨** *ហេតុអ្វី បានជាទ្រង់ហែកព្រះពស្ត្រដូច្នេះ* ហោរាអេលីសេ បាននិយាយដោយគំហកដាក់ស្ដេចយ៉ូរ៉ាម (មើលការពន្យល់ ១សយ ១៧:១១) និងកាលដែលគាត់មិនបានពិគ្រោះយោបលជាមួយហោរារបស់ព្រះ (សូមមើល ៣:១៣–១៤ ) ។
**៥:៩** *មានទាំងសេះ និងរទេះ* នៅត្រង់នេះ ណាម៉ាន់ដែលជាអ្នកមានអំណួតបានស្រែកសំឡុតឱ្យហោរាអេលីសេព្យាបាលជម្ងឺគាត់ដោយព្រះវត្តមានរបស់ព្រះយេហូវ៉ា ។

មានទាំងសេះនឹងរទេះផង ¹⁰ឯអេលីសេលោកចាត់អ្នកបំរើ
ម្នាក់ឱ្យទៅជំរាបថា សូមឱ្យលោកទៅមុជទឹក[ដ]ក្នុងទន្លេ
យ័រដាន់៧ដង[ឋ]ទៅ នោះសាច់របស់លោកនឹងបានជា ហើយ
លោកនឹងបានស្អាតឡើងវិញ ¹¹តែណាម៉ាន់មានសេចក្ដី
កំហឹង ហើយក៏ចេញទៅដោយពោលថា មើលអញស្មាន
ថាប្រាកដជាលោកនឹងចេញមកឯអញ ឈរអំពាវនាវដល់
ព្រះនាមព្រះយេហូវ៉ា ជាព្រះនៃលោក ហើយរាដៃ[ឌ]ពីលើ
ដំបៅ ឱ្យរោគឃ្លង់បានជា ¹²ឯទន្លេអាបាណា និងទន្លេផើ
ផើរ ជាទន្លេស្រុកដាម៉ាស តើមិនល្អជាងទឹកទាំងឡាយ[ឍ]
នៅស្រុកអ៊ីស្រាអែលទេឬអី បើអញមុជទឹកទន្លេនោះ តើមិន
បានស្អាតទេឬអី ដូច្នេះលោកក៏ត្រឡប់ ចេញពីទីនោះទៅ
ដោយសេចក្ដីឃោរឃៅជាខ្លាំង[ណ] ¹³តែពួកអ្នកបំរើលោក
ក៏អែបចូលជិតជំរាបថា លោកឪពុកអើយ[ត] បើសិនជា
ហោរានោះបានប្រាប់ឱ្យលោកធ្វើការអ្វីយ៉ាងធំ នោះតើ
លោកមិនធ្វើតាមទេឬអី ចំណង់បើលោកគ្រាន់តែឱ្យទៅ
មុជទឹកប៉ុណ្ណោះ ដើម្បីឱ្យបានស្អាត តើនឹងគួរធ្វើតាមជាជាង
អំបាលម៉ានទៅទៀត ¹⁴ដូច្នេះ លោកក៏ចុះ ទៅមុជទឹកក្នុង
ទន្លេយ័រដាន់អស់៧ដង[ថ]តាមពាក្យនៃអ្នកសំណប់របស់ព្រះ
នោះសាច់របស់លោកក៏ដុះឡើងជាថ្មី[ទ] ដូចជាសាច់របស់
ក្មេងៗ[ធ] ហើយលោកបានស្អាត ។
¹⁵រួចលោក ព្រមទាំងពួកលោក ក៏វិលទៅឯអ្នកសំណប់
របស់ព្រះវិញ[ន] ឈរនៅចំពោះមុខជំរាបថា មើលឥឡូវ
នេះខ្ញុំដឹងថា[ប] នៅផែនដីទាំងមូល គ្មានព្រះឯណាសោះ
វៀរតែព្រះនៃសាសន៍អ៊ីស្រាអែល១ប៉ុណ្ណោះ ដូច្នេះ សូម
លោកទទួលរង្វាន់[ផ]ពីខ្ញុំប្របាទចុះ ¹⁶តែលោក ឆ្លើយតបថា
ខ្ញុំស្បថ ដោយនូវព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ ដែលខ្ញុំ
ឈរនៅចំពោះទ្រង់ថា ខ្ញុំមិនទទួលយកអ្វីសោះឡើយ
ណាម៉ាន់ក៏អង្វរឱ្យទទួល តែលោកប្រកែកមិនព្រមទេ[ព]
¹⁷ណាម៉ាន់និយាយថា បើដូច្នេះ សូមតែឱ្យដី[ភ]ល្មមផ្ទុកលើ
លាកាត់២មកខ្ញុំប្របាទចុះ ដ្បិតពីនេះទៅមុខខ្ញុំប្របាទនឹង
មិនថ្វាយដង្វាយដុតឬយញ្ញបូជាដល់ព្រះឯណាទៀត ក្រៅពី
ព្រះយេហូវ៉ាឡើយ ¹⁸តែក្នុងការនេះ សូមព្រះយេហូវ៉ាអត់
ទោសដល់ខ្ញុំប្របាទផង គឺកាលចៅហ្វាយខ្ញុំប្របាទព្រយុង
ខ្លួនមកលើដៃខ្ញុំ ចូលទៅថ្វាយបង្គំក្នុងវិហារព្រះរីម៉ូនវេលា
ណា ហើយខ្ញុំប្របាទក៏ឱនខ្លួននៅក្នុងវិហារព្រះរីម៉ូន នោះ
សូមព្រះយេហូវ៉ាអត់ទោសដល់ខ្ញុំប្របាទ ពីការដែលឱន

**៥:១០** ដ យហ ៩:៧ ឋ លប ៣៣:៣ លវ ១៤:៧
**៥:១១** ឌ នក ៧:១៩
**៥:១២** ឍ អស ៨:៦ ណ សភ ១៤:១៧, ២៩ ១៩:១១ ២៩:១១
**៥:១៣** ត ២ពវ ៦:២១ ១៣:១៤
**៥:១៤** ថ លប ៣៣:៣ លវ ១៤:៧ យស ៦:១៥ ទ នក ៤:៧ ធ យប ៣៣:២៥
**៥:១៥** ន យស ២:១១ ប យស ៤:២៤ ១សយ ១៧:៤៦ ផ ១សយ ៩:៧
**៥:១៦** ព ខ.២០,២៦ លប ១៤:២៣ ដយ ៥:១៧
**៥:១៧** ភ នក ២០:២៤

**៥:១០** *មុជទឹកក្នុងទន្លេយ័រដាន់៧ដងទៅ* នេះជាការផ្ដល់នូវដំបូន្មានដល់ណាម៉ាន់ក្នុងការព្យាបាលជម្ងឺរបស់គាត់តាមរយៈព្រះរបស់ពួកអ៊ីស្រាអែល ប៉ុន្តែការនេះសម្រេចទៅបាន តែអស់អ្នកណាដែលគោរពតាមហោរារបស់ព្រះប៉ុណ្ណោះ ពោលគឺហោរាខ្លួនគាត់ផ្ទាល់មិនមែនជាអ្នកព្យាបាលនោះទេ ។ ពិធីលាងសំអាតនេះ បានប្រារព្ធឡើងនៅក្នុងចំណោមពួកអ្នកកាន់សាសនានៅភាគខាងកើត ដែលពិធីនេះតំណាងឱ្យភាពបរិសុទ្ធ ហើយចំនួន៧តំណាងឱ្យភាពបរិបូរ លោកណាម៉ាន់ បានលាងសំអាតខ្លួននៅក្នុងទឹកទន្លេយ័រដាន់ ដើម្បីបញ្ជាក់ពីភាពគ្មានជាប់ទាក់ទងរវាងការលាងសំអាតកាយ និងចំណង់នៃការព្យាបាល ។ ចំណុចនេះ ប្រហែលជាចង់បញ្ជាក់ថាការព្យាបាលតាមវិធីនេះតម្រូវឱ្យឆ្លងតាមទន្លេយ័រដាន់ ដូចដែលពួកអ៊ីស្រាអែលបានធ្វើកន្លងមកដើម្បីឱ្យព្រះយេហូវ៉ាព្យាបាលពួកគេអញ្ចឹងដែរ (មើលការពន្យល់ យស ៣:១–៤:២៤ ៣:១០) ។

**៥:១១** *រាដៃពីលើដំបៅឱ្យរោគឃ្លង់បានជា* នៅត្រង់នេះលោកណាម៉ាន់គិតថា គាត់ទទួលបាននូវការព្យាបាលតាមវេទមន្តរបស់ពួកហោរា មិនមែនជាការដែលគាត់ត្រូវដាក់សេចក្ដីជំនឿលើព្រះយេហូវ៉ានោះទេ ។

**៥:១២** *ទន្លេអាបាណា និងទន្លេផើផើរ* ទន្លេអាបាណាត្រូវបានហៅដោយពួកក្រិកថាជាទន្លេមាស ។ ទន្លេអាបាណានេះ គឺមានកាជាប់ទាក់ទងជាមួយនិងទន្លេស្រុកដាម៉ាស ពោលគឺហូកាត់ស្រុកដាម៉ាស ។

**៥:១៤** *សាច់របស់លោកក៏ដុះឡើងជាថ្មី ដូចជាសាច់របស់ក្មេង* ឃ្លានេះបញ្ជាក់ថា រាងកាយរបស់គាត់ត្រូវបានកើតជាថ្មីម្ដងទៀត (មើល ខ.១៥ និងការពន្យល់) ។ ដោយណាម៉ាន់បានគោរពដល់ព្រះ នោះគាត់ត្រូវទទួលបានអំណោយដែលជាព្រះគុណរបស់ព្រះយេហូវ៉ា ។ នៅពេលណាដែលរាស្ត្ររបស់ព្រះបានវិលបែរឈប់ជឿដល់ទ្រង់ នោះព្រះយេហូវ៉ានិងលើកទោសដល់ពួកសាសន៍ដទៃដែលបានជឿដល់ព្រះនាមទ្រង់វិញ (មើលការពន្យល់ ១ពវ ១៧:៩–២៤ មើលបន្ថែម មថ ៨:១០ លក ៤:២៧) ។

**៥:១៥** *នៅផែនដីទាំងមូល គ្មានព្រះឯណាសោះ វៀរតែព្រះនៃសាសន៍អ៊ីស្រាអែល១ប៉ុណ្ណោះ* ឃ្លានេះបញ្ជាក់ថា សេចក្ដីលន់តួរបស់លោកណាម៉ាន់ បានធ្វើឱ្យពួកអ៊ីស្រាអែលធ្លាក់ក្នុងសេចក្ដីអាម៉ាស ដែលពួកអ៊ីស្រាអែលនៅតែបន្តភាពមិនច្បាស់លាស់ក្នុងការគោរពព្រះបាល ឬព្រះយេហូវ៉ា (មើលការពន្យល់ ១ពវ ១៨:២១) ។

**៥:១៦** *ខ្ញុំមិនទទួលយកអ្វីសោះឡើយ* លោកហោរាអេលីសេ មិនបានស្វែងរកប្រាក់ក្នុងការប្រកាសពីបន្ទូលរបស់ព្រះយេហូវ៉ាឡើយ (សូមមើល មថ ១០:៨) ។ លោកណាម៉ាន់ បានប្រោសឱ្យជា ដោយសាតែព្រះគុណរបស់ព្រះប៉ុណ្ណោះ គឺមិនមែនអំណាចរបស់លោកអេលីសេឡើយ ។

**៥:១៧** នៅក្នុងវគ្គនេះបញ្ជាក់ថា នៅសម័យបុរាណពួកបានគិតថា ការថ្វាយបង្គំព្រះគឺត្រូវធ្វើឡើងនៅលើផែនដីទាំងមូល (មើល ខ.១៥) ។ សម្រាប់ហេតុផលនេះ លោកណាម៉ាន់ចង់បានដីរបស់ពួកអ៊ីស្រាអែលដែលនៅក្នុងស្រុកដាម៉ាសធ្វើជាកន្លែងសម្រាប់ថ្វាយបង្គំដល់ព្រះយេហូវ៉ា ។

**៥:១៨** *ចៅហ្វាយខ្ញុំប្របាទ* នេះសំដៅដល់ស្ដេចបេន–ហាដាឌ់ ជាស្ដេចនៃស្រុកស៊ីរី ។ *ព្រះរីម៉ូន* ចំពោះព្រះនេះត្រូវបានគេស្គាល់ថា ជាព្រះរបស់ពួកហាដាឌ់ (នៅក្នុងទឹកដីកាណាន គឺជាព្រះបាល) ព្រះរបស់ពួស៊ីរី គឺជាអទិទេពរន្ទះ ("រីម៉ូន" មានន័យថាផ្គរ) និងសង្គ្រាម ។ ឈ្មោះទាំងពីរនេះពេលខ្លះត្រូវបានគេបញ្ចូលជាឈ្មោះតែមួយ (សូមមើលការពន្យល់ សក ១២:១១) ។

ខ្លួន[ម]នៅក្នុងវិហារព្រះរីម៉ូននោះផង ១៩អេលីសេក៏និយាយ
ថា អញ្ជើញទៅដោយសុខសាន្តចុះ[យ] ដូច្នេះណាម៉ាន់ក៏ចេញ
ពីលោកទៅតាមផ្លូវបន្តិច ។
២០ឯកេហាស៊ី ជាអ្នកបំរើរបស់អេលីសេ ជាអ្នកសំណប់
របស់ព្រះ គាត់នឹកថា មើល ចៅហ្វាយអញបានយល់ដល់
ណាម៉ាន់ជាសាសន៍ស៊ីរីនោះ ដោយមិនបានទទួលរបស់ស្នង
ពីដៃលោក ដែលនាំមកជូននោះសោះ អញស្បថ ដោយនូវ
ព្រះយេហូវ៉ា[រ]ដ៏មានព្រះជន្មរស់នៅថា អញនឹងរត់ទៅតាម
ហើយទទួលយករបស់ខ្លះពីលោកវិញ ២១ដូច្នោះ កេហាស៊ីក៏
ទៅតាមណាម៉ាន់ កាលណាម៉ាន់ឃើញម្នាក់កំពុងរត់មក
តាមនោះលោកក៏ចុះពីរទេះទៅទទួល ហើយសួរថា សុខ
សប្បាយទាំងអស់គ្នាទេឬ ២២គាត់ឆ្លើយថា សុខសប្បាយជា
ទេ តែចៅហ្វាយខ្ញុំបានចាត់ខ្ញុំឱ្យមកជំរាបលោកថា មើល
មានមនុស្សកំឡោះ២នាក់ជាសិស្សនៃពួកហោរា ទើបនឹង
មកដល់ពីស្រុកភ្នំអេប្រាអិម ដូច្នេះ សូមលោកមេត្តាឱ្យ
ប្រាក់១ហាប និងសំលៀកបំពាក់២បន្លាស់មកសំរាប់គេ[ល]
២៣ណាម៉ាន់ឆ្លើយតបថា សូមឱ្យអ្នកបានសុខចិត្តយកដល់
ទៅ២ហាបចុះ លោកក៏បង្ខំ រួចដាក់ប្រាក់២ហាបចុះក្នុង
ការុង២ ព្រមទាំងឱ្យអាវ ២បន្លាស់ដាក់ឱ្យអ្នកបំរើរបស់
លោក២នាក់បានលីទៅខាងមុខកេហាស៊ី ២៤លុះដល់ទៅ
ភ្នំហើយ នោះគាត់យកពីដៃគេទៅដាក់ទុកក្នុងផ្ទះ រួចឱ្យគេ
ទៅវិញ គេក៏ចេញទៅ ២៥លំដាប់នោះគាត់ចូលទៅឈរ
នៅមុខអេលីសេជាចៅហ្វាយខ្លួន ហើយលោកសួរថា
កេហាស៊ីអើយ ឯងមកពីណា គាត់ឆ្លើយថា ខ្ញុំប្របាទមិនបាន
ទៅឯណាទេ ២៦តែលោកមានប្រសាសន៍ថា តើវិញ្ញាណ
អញមិនបានទៅតាមឯង ក្នុងកាលដែលលោកនោះចុះពី
រទេះមកទទួលឯងទេឬអី នេះតើជាឱកាស[ស]គួរនឹង ទទួល
ប្រាក់ និងសំលៀកបំពាក់ ព្រមទាំងចំការអូលីវចំការ
ទំពាំងបាយជូរ និងចៀមគោ ហើយបាវប្រុសបាវស្រីឬអី[ស]
២៧ហេតុនេះ រោគឃ្លង់[ហ] របស់ណាម៉ាន់នឹងនៅជាប់នឹង
ឯងវិញព្រមទាំង កូនចៅឯងជារៀងរាបដរាបទៅ ដូច្នេះ
គាត់[ឡ]ក៏ចេញពីមុខលោកទៅ កើតមានរោគឃ្លង់សដូច
ហិមៈតែម្តង[អ] ។

## ផ្លែពូថៅអណ្តែត

**៦** ១គ្រានោះ ពួកសិស្ស[ក]របស់ពួកហោរា គេជំរាបដល់
អេលីសេថា សូមមើល ទីកន្លែងដែលយើងខ្ញុំនៅជាមួយនឹង
លោកនេះ ចង្អៀតដល់យើងខ្ញុំពេកណាស់ ២សូមបើកឱ្យ
យើងខ្ញុំទៅឯទន្លេយ័រដាន់ កាប់យកឈើមួយដើមម្នាក់ ធ្វើ
ជាទីអាស្រ័យនៅទីនោះ លោកឆ្លើយថា ចូរទៅចុះ ៣មាន
ម្នាក់និយាយថា សូមលោកអញ្ជើញទៅជាមួយនឹងយើងខ្ញុំ
ប្របាទផង លោកតបថា អញនឹងទៅដែរ ៤ដូច្នេះ លោកក៏
ទៅជាមួយ លុះគេបានទៅដល់ទន្លេយ័រដាន់ហើយ នោះក៏
កាប់ឈើ ៥តែកាលម្នាក់កំពុងតែកាប់ នោះផ្លែពូថៅបាន
របូតធ្លាក់ទៅក្នុងទឹក រួចអ្នកនោះស្រែកឡើងថា វរហើយ
លោកម្ចាស់ខ្ញុំអើយ ដ្បិតពូថៅនេះខ្ញុំបានខ្ចីមកពីគេ ៦អ្នក

**៥:១៨** ម ២ពវ ៧:២
**៥:១៩** យ ១សយ ១:១៧ កច ១៥:៣៣
**៥:២០** រ នក ២០:៧
**៥:២២** ល ខ.៥ លប ៤៥:២២
**៥:២៦** ស យរ ៤៥:៥
**៥:២៧** ហ ជន ១២:១០ ឡ កល ៣:៥ អ នក ៤:៦
**៦:១** ក ១សយ ១០:៥

**៥:១៩** *អញ្ជើញ ទៅដោយសុខសាន្តចុះ* លោកអេលីសេ មិនបាននិយាយសំដៅដល់លោកណាម៉ាន់ដោយផ្ទាល់អំពីបញ្ហារបស់គាត់នោះទេ (ខ.១៨) តែលោក បានសរសើរពីការដឹកនាំដ៏ល្អមកពីព្រះ ហើយបានឱ្យគាត់ត្រឡប់ទៅឯផាកានវិញដែលបញ្ជាក់ពីការទទួលខុសត្រូវជាផ្លូវការ ។

**៥:២០** *អញស្បថ ដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់នៅ* នេះជាពាក្យសម្បថដែលគេធ្វើឡើង(មើលការពន្យល់ ១សយ ១៤:៣៩,៤៥) ។

**៥:២២** *ពួកហោរា* សូមមើលការពន្យល់ ២:៣ ។ *សូមលោកមេត្តាឱ្យប្រាក់១ហាប និងសំលៀកបំពាក់២បន្លាស់* នៅត្រង់នេះ កេហាស៊ីបានធ្វើការបោកបញ្ឆោតណាម៉ាន់អោយផ្តល់នូវរបស់ទាំងនេះ ក្នុងគោលបំណងឱ្យគាត់បានសប្បាយចិត្ត ។ ភាពកខ្វក់នៃសេចក្តីកំភូតរបស់កេហាស៊ី បានធ្វើឱ្យបាំងភាពស្អាតស្អំរបស់ព្រះដែលមាននៅក្នុងណាម៉ាន់ ដែលធ្វើឱ្យគាត់មិនអាចមើលដឹងថាមួយណាជាហោរារបស់ព្រះ ហើយនិង ពួកហោរាខុសឆ្គង និងពួកគ្រូទាយមួយនោះទេ ។

**៥:២៤** *ផ្ទះ* សំដៅលើផ្ទះលោកអេលីសេ (មើល ខ.៩) ។

**៥:២៦** *តើនេះជាឱកាសគួរនឹងទទួលប្រាក់ . . .* ត្រង់នេះកេហាស៊ីបានគិតអំពីការប្រើប្រាស់នូវព្រះគុណរបស់ព្រះដែលជាប្រាក់នោះ ផ្តល់ទៅឱ្យអ្នកដទៃទៀតដើម្បីឱ្យខ្លួនបានចំណេញ ។ ចំណុចត្រង់នេះ គឺស្មើនឹងកាលដែលគេធ្វើជំនួញលើព្រះគុណរបស់ព្រះ(មើលការពន្យល់ ២កថ ២:១៧) ។ ពាក្យថា "ប្រាក់" នៅទីនេះ និងកន្លែងផ្សេងៗទៀតនៅក្នុង ២ពវ គឺសំដៅលើ មាស និងប្រាក់ នៅក្នុងទម្ងន់ផ្សេងៗគ្នា គឺមិនមែនជាកាក់ដែលគេបង្កើតក្រោយមកនោះឡើយ ។ *សំលៀកបំពាក់ . . .បាវប្រុសបាវស្រី* នេះសំដៅដល់ការដែលកេហាស៊ីបានសង្ឃឹមថាខ្លួននឹងអាចទិញ ដូរ នូវរបស់ផ្សេងៗ ។

**៥:២៧** *នៅជាប់នឹងឯងវិញ ព្រមទាំងកូនចៅឯងជារៀងទៅ* នេះជាការកាត់ទោស ដល់ពួកកូនចៅជំនាន់ក្រោយបន្តទៀត ក្នុងកាលដែលគេប្រព្រឹត្តរំលងចំពោះក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា(មើល នក ២០:៥ និងការពន្យល់បន្ថែម យស ៧:២៤) ។ *សដូចហិមៈ* សូមមើល នក ៤:៦ ។

**៦:១** *ពួកសិស្សរបស់ពួកហោរា* មើលការពន្យល់ ២:៣ ។

**៦:២** *ធ្វើជាទីអាស្រ័យនៅទីនោះ* នៅត្រង់នេះ បញ្ជាក់ថាសិស្សរបស់ពួកហោរាបានរស់នៅក្នុងសហគមន៍តែមួយ ។ ឃ្លានេះ ភាសាហេព្រើរប្រែថា "សាលប្រជុំ" វិញ ។ ចាប់ពី ៤:១-៧ និយាយពីការរស់នៅរបស់ពួកសិស្សហោរា(មើលការពន្យល់ ១សយ ១៩:១៨) ។

**៦:៥** *ពូថៅនេះ ខ្ញុំម្ចាស់ខ្ចីមកពីគេ* នៅសម័យនោះពូថៅដែក មានតម្លៃថ្លៃហួសពីសមត្ថភាពដែលសិស្សរបស់ពួកហោរាអាចទិញបាន ដូច្នេះក្នុងករណីដែលបាត់បង់វា នោះអ្នកខ្ចីប្រឈមមុខនឹងការលះបង់ការងារ ឬទៅធ្វើជា

សំណាប់របស់ព្រះសួរថា តើធ្លាក់ត្រង់ណា អ្នកនោះក៏
បង្ហាញកន្លែង រួចលោកកាប់មែកឈើ១កំណាត់ បោះ[ខ]ទៅ
ក្នុងទឹក ហើយផ្លែពូថៅក៏អណ្តែតឡើងមក ៧នោះលោក
បង្គាប់ថា ចូរចាប់យកចុះ អ្នកនោះក៏លូកដៃចាប់យកមក ។

## លោកអេលីសេធ្វើឱ្យពួកស៊ីរីថ្លឹនភ្នែក

៨រីឯស្តេចស្រុកស៊ីរី ទ្រង់កំពុងតែច្បាំងនឹងសាសន៍
អ៊ីស្រាអែល ក៏ហៅពួកអ្នកជិនិតទ្រង់មកពិគ្រោះគ្នា រួច
បង្គាប់ថា យើងនឹងបោះទ័ពនៅទីណាមួយនោះ ៩ដូច្នេះ
អ្នកសំណាប់របស់ព្រះលោកចាត់គេឱ្យទៅ ទូលដល់ស្តេច[គ]
អ៊ីស្រាអែលថា សូមទ្រង់ប្រយ័ត្ន កុំយាងទៅតាមទី១នោះ
ឡើយ ដ្បិតពួកស៊ីរីគេចុះមកតាមផ្លូវនោះហើយ ១០ស្តេច
អ៊ីស្រាអែលក៏ចាត់គេ ឱ្យទៅឯកន្លែងណាដែលអ្នកសំណាប់
របស់ព្រះបានប្រាប់ឱ្យប្រយ័ត្ន[ឃ]នោះទ្រង់ក៏បានរួចពីសេចក្តី
អន្តរាយនៅទីទាំងនោះ មិនមែនតែម្តង ឬពីរដងប៉ុណ្ណោះ
ទេ ១១ឯស្តេចស្រុកស៊ីរី ទ្រង់មានព្រះទ័យវល់អំពីដំណើរ
នោះ ក៏ហៅពួកអ្នកជិនិតមកសួរថា តើអ្នករាល់គ្នាមិន
ព្រមប្រាប់ឱ្យយើងដឹងជាអ្នកណាក្នុងពួកយើង ដែលកាន់
ខាងស្តេចអ៊ីស្រាអែលទេឬ ១២នោះអ្នកជិនិតទ្រង់ម្នាក់ទូល
តបថា បពិត្រព្រះករុណា[ង] ជាព្រះអម្ចាស់នៃទូលបង្គំអើយ
ឥតមានអ្នកណាឡើយ គឺជាអេលីសេ ជាហោរាដែលនៅ
ស្រុកអ៊ីស្រាអែលវិញ គាត់នាំយកអស់ទាំងព្រះបន្ទូល ដែល
ទ្រង់មានបន្ទូល នៅក្នុងក្រឡាព្រះបន្ទំរបស់ទ្រង់ ទៅប្រាប់

**៦:៦** ខ នក ១៥:២៥ ២ពវ ២:២១
**៦:៩** គ ខ.១២
**៦:១០** ឃ យរ ១១:១៨
**៦:១២** ង ខ.៩
**៦:១៣** ច លប ៣៧:១៧
**៦:១៤** ឆ ២ពវ ១:៩
**៦:១៦** ជ លប ១៥:១ ឈ ២រប ៣២១:៧ ទដ ៥៥:១៨ រម ៨:៣១ ១យហ ៤:៤
**៦:១៧** ញ ២ពវ ២:១១,១២
**៦:១៨** ដ លប ១៩:១១

ដល់ស្តេចអ៊ីស្រាអែល ១៣រួចទ្រង់បង្គាប់ថា ចូរទៅសង្កេត
មើល កន្លែងណាដែលវានៅ ដើម្បីឱ្យអញបានចាត់គេឱ្យ
ទៅចាប់នាំមក នោះមានគេទូលទ្រង់ថា មើល គាត់នៅឯ
ក្រុងដូថាន់[ច] ។
១៤ដូច្នេះ ទ្រង់ក៏ចាត់[ឆ]ពលសេះ រទេះចំបាំង នឹងពួកទ័ព
សន្ធឹកឱ្យចេញទៅ គេក៏ទៅឡោមព័ទ្ធទីក្រុងនោះទាំងយប់
១៥ឯអ្នកបំរើនៃអ្នកសំណាប់របស់ព្រះ កាលបានក្រោកពី
ព្រលឹមចេញទៅក្រៅ នោះឃើញ មានពលទ័ពដែលមាន
ទាំងសេះ និងរទេះចំបាំង នៅព័ទ្ធជុំវិញទីក្រុង រួចអ្នកបំរើ
ជំរាបលោកថា វរហើយ ចៅហ្វាយខ្ញុំអើយ តើយើងនឹងធ្វើ
ដូចម្តេច ១៦លោកឆ្លើយតបថា កុំខ្លាចអ្វីឡើយ[ជ] ដ្បិតពួក
ដែលនៅខាងយើង មានគ្នាច្រើនជាង[ឈ]ពួកដែលនៅខាង
គេទៅទៀត ១៧នោះអេលីសេក៏អធិស្ឋានថា ឱព្រះយេហូវ៉ា
អើយ សូមទ្រង់ប្រោសឱ្យភ្នែកវាបាន មើលឃើញ ព្រះ
យេហូវ៉ាទ្រង់ក៏ប្រោសភ្នែកបំរើនោះ ហើយវាក៏មើលទៅ
ឃើញភ្នំនោះ មានពេញដោយពលសេះ និងរទេះចំបាំង[ញ]
ដែលសុទ្ធតែជាភ្លើង នៅព័ទ្ធជុំវិញអេលីសេ ១៨កាលបាន
ចុះមកដល់អេលីសេហើយ នោះលោកអធិស្ឋានដល់ព្រះ
យេហូវ៉ាថា សូមព្រះអង្គវាយពួកស៊ីរីនេះឱ្យភ្នែកគេត្រូវថ្លឹន
ទៅ[ដ] ដូច្នេះ ទ្រង់ក៏ធ្វើឱ្យភ្នែកគេត្រូវថ្លឹន តាមពាក្យអេលីសេ
១៩ហើយអេលីសេប្រាប់គេថា មិនមែនផ្លូវនេះ ហើយមិន
មែនទីក្រុងនេះដែរ សូមមកតាមខ្ញុំចុះ ខ្ញុំនឹងនាំអ្នករាល់គ្នា

---

អ្នកបម្រើគេវិញ ។
**៦:៦** *លោកកាប់មែកឈើ១កំណាត់ បោះទៅក្នុងទឹក ហើយផ្លែពូថៅក៏អណ្តែតឡើង* នៅត្រង់នេះព្រះអម្ចាស់ បានបង្ហាញពីសេចក្តីជំនឿដែលគាត់មានចំពោះព្រះយេហូវ៉ា នោះបានសង្គ្រោះខ្លួនគាត់ ។
**៦:៨** *ស្តេចស្រុកស៊ីរី* នេះជាស្តេច បេន–ហាដាឌ់ទី២ (មើលការពន្យល់ ៥:១) ។ *ច្បាំងនឹងសាសន៍អ៊ីស្រាអែល* សូមមើល ខ.២៣ និងបន្ថែមការពន្យល់ ៥:២) ។
**៦:៩** *អ្នកសំណាប់របស់ព្រះ* គឺលោកអេលីសេ(សូមមើល ខ.១០) ។ *ស្តេចអ៊ីស្រាអែល* គឺស្តេចយ៉ូរ៉ាម(មើល ១:១៧ ៣:១ ៩:២៤) ។
**៦:១១** *អ្នកណាក្នុងពួកយើង ដែលកាន់ខាងស្តេចអ៊ីស្រាអែលទេឬ* នេះជាភស្តុតាងរលឹកឡើងវិញ ដែលពួកអ៊ីស្រាអែលបានធ្វើជាម្ចាស់លើការដឹកនាំពួកកងទ័ពរបស់ពួកស៊ីរី ។
**៦:១២** *ស្តេចអ៊ីស្រាអែល* នេះជាស្តេចយ៉ូរ៉ាម(មើល ៣:១) ។
**៦:១៣** *ចាប់នាំមក* ការនេះស្តេចស្រុកស៊ីរី បានរិះរកមធ្យោបាយដើម្បីបំផ្លិចបំផ្លាញឥទ្ធិពលលោកអេលីយ៉ាដោយការបដិសេធមិនឱ្យលោកមានទំនាក់ទំនងជាមួយពួកស្តេចអ៊ីស្រាអែល ។ *ក្រុងដូថាន់* ក្រុងនេះមានព្រំប្រទល់ពាក់កណ្តាលជាប់នឹងក្រុងយេសរា និងស្រុកសាម៉ារី ដែលទីនេះជាកន្លែងសំខាន់សម្រាប់ពួកអ្នករស់នៅទីនោះ(សូមមើល ១:២ ៣:១ ៨:២៩ ៩:១៥ ១០:១ ១ពវ ២១:១) ។
**៦:១៦** *ពួកដែលនៅខាងយើង មានគ្នាច្រើនជាងពួកដែលនៅខាងគេឯទៀត* លោកអេលីសេ បានដឹងថាពួកពលបរិវាររបស់ព្រះមានចំនួនច្រើនជាងពួកកងទ័ពស៊ីរី (មើល ២រប ៣២:៧–៨ ទដ ៣៤:៧ ១យហ ៤:៤) ។
**៦:១៧** *មានពេញ ដោយពលសេះ និងរទេះចំបាំង* នេះជាសេចក្តីឆ្លើយតបចំពោះការអធិស្ឋានរបស់លោកអេលីសេ នោះអ្នកបម្រើរបស់គាត់បានមើលឃើញ ពីការការពាររបស់ពួកពលបរិវារដែលជាទាហានរបស់ព្រះបានការពារលោកអេលីសេ(មើល លប ៣២:១–២ ទដ ៣៤:៧ ៩១:១១–១២ មថ ១៨:១០ ២៦:៥៣ មើលបន្ថែមការពន្យល់ ២ពវ ២:១១) ។
**៦:១៨** *វាយពួកស៊ីរី ឱ្យភ្នែកគេត្រូវថ្លឹនទៅ* នៅត្រង់នេះ លោអេលីសេបានអធិស្ឋានឱ្យភ្នែករបស់អ្នកបម្រើរបស់គាត់បានបើកឡើងដែលពួកគេមិនអាចមើលឃើញពីពួកពលបរិវាររបស់ព្រះយេហូវ៉ា គឺឥឡូវនេះពួកលោកបានអធិស្ឋានទូលសូមដល់ព្រះយេហូវ៉ាឱ្យពួកកងទ័ពស៊ីរីបានខ្វាក់ភ្នែកទៅវិញ (មើល លប ១៩:១១) ។
**៦:១៩** *មិនមែនផ្លូវនេះ ហើយមិនមែនទីក្រុងនេះដែរ* ការប្រកាសរបស់លោកអេលីយ៉ាយ៉ាងដូច្នេះ បានធ្វើឱ្យទាហានរបស់ពួកស៊ីរីជឿថាពួកគេកំពុងចូលទៅក្នុងទីក្រុង ដែលហោរាអេលីសេកំពុងតែស្វែងរកនោះ ។ មធ្យោបាយដែលលោកប្រើនៅទីនេះ មិនមែនជាការភូតកុហកនោះទេ

ទៅ ឯមនុស្ស ដែលត្រូវរកនោះ តែលោកនាំគេទៅឯក្រុង
សាម៉ារីវិញ ។
២០ លុះគេបានចូលទៅក្នុងក្រុងសាម៉ារីហើយ នោះអេ–
លីសេអធិស្ឋានថា ឱព្រះយេហូវ៉ាអើយ សូមទ្រង់ធ្វើឱ្យភ្នែក
មនុស្សទាំងនេះបានភ្លឺឡើង ដើម្បីឱ្យមើលឃើញវិញ ព្រះ
យេហូវ៉ាទ្រង់ក៏ប្រោសប្រទានឱ្យភ្នែកគេបានភ្លឺឡើងវិញ ឱ្យ
គេបានមើលឃើញ នោះក៏ឃើញថា គេនៅកណ្ដាលក្រុង
សាម៉ារីហើយ
២១ កាលស្ដេចអ៊ីស្រាអែលបានឃើញគេ
នោះទ្រង់មានបន្ទូលសួរអេលីសេថា លោកឪពុកអើយ[ឋ]
តើត្រូវឱ្យប្រហារជីវិតគេ តើត្រូវសំឡាប់គេឬអី
២២ លោក
ទូលឆ្លើយថា មិនត្រូវប្រហារគេទេ តើនឹងវាយសំឡាប់ពួក
ឈ្លើយ ដែលចាប់[ឌ]ក្នុងការសង្គ្រាមឬអី សូមដាក់នំបុ័ងនឹង
ទឹកមក នៅមុខគេឱ្យបរិភោគវិញ រួចឱ្យត្រឡប់ទៅឯចៅ
ហ្វាយគេទៅ
២៣ ដូច្នេះ ស្ដេចក៏ចាត់ចែងភោជនាហារយ៉ាង
ច្រើន ឱ្យគេកាលគេបានបរិភោគរួចហើយ នោះទ្រង់លែង
ឱ្យទៅវិញ ហើយគេវិលត្រឡប់ទៅឯចៅហ្វាយខ្លួនទៅ ឯ
សាសន៍[ឍ]ស៊ីរីក៏លែង ទន្ទ្រានចូលក្នុងស្រុកអ៊ីស្រាអែលដោយ
ពួកៗទៀត ។

## អំណត់មកពីការឡោមព័ទ្ធក្រុងសាម៉ារី

២៤ ក្រោនោះមក បេន–ហាដាឌ់[ណ] ជាស្ដេចស្រុកស៊ីរីទ្រង់
ក៏ប្រមូលកងទ័ពទាំងអស់ លើកឡើងទៅឡោមព័ទ្ធ[ត]ច្បាំង
នឹងក្រុងសាម៉ារី
២៥ ដូច្នេះ នៅក្រុងសាម៉ារីមានអំណត់អត់[ថ]
ជាខ្លាំង ពួកស៊ីរីឡោមព័ទ្ធច្បាំងនឹងទីក្រុងនោះទាល់តែ
ក្បាលលា១លក់ថ្លៃ៨០រៀល ហើយអាចម៍ព្រាប១កំប៉ុង[ទ]
លក់ថ្លៃ៥រៀល
២៦ គ្រានោះ កាលស្ដេចអ៊ីស្រាអែលទ្រង់
កំពុងតែយាងនៅលើកំផែងក្រុង នោះមានស្ត្រីម្នាក់ស្រែក
ទូលទ្រង់ថា បពិត្រព្រះករុណា ជាព្រះអម្ចាស់អើយ សូម
ជួយខ្ញុំម្ចាស់ផង
២៧ តែទ្រង់មានបន្ទូលតបថា បើព្រះយេហូវ៉ា
មិនជួយអ្នកទេ នោះធ្វើដូចម្ដេចឱ្យយើងជួយបាន តើនឹងជួយ
ដោយស្រូវពីទីលាន ឬដោយស្រាទំពាំងបាជូរពីធុងឃ្នាប
ឬអី
២៨ ស្ដេចក៏សួរស្ត្រីនោះថា តើអ្នកកើតមានអ្វី ស្ត្រីនោះ
ទូលឆ្លើយថា នាងនេះបាននិយាយមកខ្ញុំម្ចាស់ថា ចូរឱ្យកូន
ឯងមកឱ្យយើងបរិភោគនៅថ្ងៃនេះ ហើយថ្ងៃស្អែកឡើង
នោះយើងនឹងបរិភោគកូនអញវិញ
២៩ ដូច្នេះ ខ្ញុំម្ចាស់បាន
ស្ងោរកូនខ្ញុំម្ចាស់ រួចយើងខ្ញុំបានបរិភោគ[ធ]ទៅ លុះដល់ថ្ងៃ
ក្រោយ ខ្ញុំម្ចាស់បាននិយាយទៅនាងថា ចូរយកកូនឯងមកឱ្យ
យើងបរិភោគទៀត តែគេបានយកកូនទៅលាក់ទុកវិញ
៣០ កាលស្ដេចបានឮពាក្យរបស់ស្ត្រីនោះហើយ នោះទ្រង់
ហែក[ន]ព្រះពស្ត្រទ្រង់ ហើយកំពុងដែលទ្រង់យាងនៅលើ
កំផែងហួសទៅ នោះពួករាស្ត្រគេក្រឡេកមើលទៅឃើញ
ថា ទ្រង់ស្លៀកសំពត់ធ្មៃ[ប]ខាង ក្នុងជាប់នឹងអង្គទ្រង់
៣១ នោះ
ទ្រង់មានបន្ទូលស្បថថា បើក្បាលអេលីសេកូនសាផាត នៅ

**៦:២១** ឋ ២ពវ ៥:១៣
**៦:២២** ឌ ចទ ២០:១១ ២របា ២៨:៨–១៥
**៦:២៣** ឍ ២ពវ ៥:២
**៦:២៤** ណ ១ពវ ១៥:១៨ ២ពវ ៨:៧ ត ចទ ២៨:៥២
**៦:២៥** ថ លវ ២៦:២៦ នរ ១:១ ទ អស ៣៦:១២
**៦:២៩** ធ លវ ២៦:២៩ ចទ ២៨:៥៣–៥៥
**៦:៣០** ន ២ពវ ១៨:៣៧ អស ២២:១៥ ប លប ៣៧:៣៤

ក្នុងកាលដែលគាត់នាំពួកគេចូលទៅក្នុងក្រុងសាម៉ារី ប៉ុន្តែក៏មានន័យថាជាការបោកបញ្ឆោតដល់ពួកទាហានស៊ីរី ឱ្យធ្លាក់ទៅក្នុងអន្ទាក់របស់ស្រុកសាម៉ារី (មើល នក ១:១៩–២០ យស ២:៦ ១សយ ១៦:១–២) ។

**៦:២០** *គេនៅកណ្ដាលក្រុងសាម៉ារី* ឃ្លានេះបានប្រាប់ថា អំណាចរបស់ព្រះយេហូវ៉ាដែលធ្វើការនៅក្នុងលោកអេលីយ៉ា បានធ្វើឱ្យពួកអ្នកចាប់ខ្លួនគេបានក្លាយជាអ្នកទោសវិញ ។

**៦:២១** *ស្ដេចអ៊ីស្រាអែល* មើលការពន្យល់ ខ.៩) ។

**៦:២២** *តើត្រូវឱ្យប្រហាជីវិតគេ តើត្រូវសំឡាប់គេឬអី* ការពិតដាក់ស្ដែងទាហានរបស់ពួកស៊ីរីត្រូវបានចាប់ជាឈ្លើយ ដោយអំណាចរបស់ព្រះយេហូវ៉ា គឺមិនមែនភាពអង់អាចនៃទាហាររបស់ស្ដេចយ៉ូរ៉ាមនោះទេ ។ ព្រះហឫទ័យរបស់ព្រះ បានបើកសម្ដែងឱ្យពួកគេ និងពួកស្ដេចអ៊ីស្រាអែលថា សុវត្ថភាពរបស់សាសន៍អ៊ីស្រាអែល ដែលបន្តដល់ពេលចុងក្រោយ នោះគឺដោយសារតែពួកគេបាននៅជាប់ជាមួយនឹងព្រះយេហូវ៉ារហូត គឺមិនមែនមកពីកងទ័ព ឬពួកគេចេះប្រើនូវយុទ្ធសាស្ត្រផ្សេងៗក្នុងការបញ្ជាកងទ័ពនោះឡើយ ។

**៦:២៣** *សាសន៍ស៊ីរីក៏លែងទន្ទ្រានចូលក្នុងស្រុកអ៊ីស្រាអែល* សូមមើលការពន្យល់ ខ.៨ ៥:២ ។ នៅត្រង់នេះ ពួកសាសន៍ស៊ីរី បានទទួលស្គាល់ការនេះដោយឈប់ប៉ុនប៉ងការទន្ទ្រាន ដោយជិទាស់នឹងព្រះរាជបំណងរបស់ព្រះយេហូវ៉ា ។

**៦:២៤** *បេន–ហាដាឌ់* ស្ដេចអង្គនេះហើយដែលបានឡោមព័ទ្ធស្រុកសាម៉ារីនៅគ្រាមុននោះ (មើលការពន្យល់ ១៣:៣ ១ពវ ២០:១) ។ ការឡោមព័ទ្ធនោះស្ថិតនៅក្នុងឆ្នាំទី ៨៥០ មុន គ.ស ។

**៦:២៥** *ក្បាលលា* ដោយយោលទៅលើគម្ពីរទាំងប្រាំកណ្ឌដំបូង (បច្ចកណ្ឌ) បានចែងថា សត្វលាដែលមិនស្អាត គឺមិនត្រូវឱ្យបរិភោគឡើយ (មើល លវ ១១:២–៧ ចទ ១៤:៤–៨) ។ ភាពអត់ឃ្លានបានធ្វើឱ្យពួកគេប្រព្រឹត្តរំលងចំពោះក្រឹត្យវិន័យនេះ និងបែរទៅបរិភោគសត្វលាដែលមិនស្អាតនេះវិញ ។

**៦:២៧** *បើព្រះយេហូវ៉ាមិនជួយអ្នកទេ នោះធ្វើដូចម្ដេចឱ្យយើងជួយបាន* ឃ្លានេះស្ដេចយ៉ូរ៉ាមទ្រង់បានទទួលស្គាល់ថា ខ្លួនគ្មានសមត្ថភាពដើម្បីនឹងជួយស្ត្រីនេះទេ ប្រសិនបើព្រះយេហូវ៉ាមិនមានវត្តមាននៅក្នុងពួកអ៊ីស្រាអែលនោះ ។

**៦:២៨** *ថ្ងៃស្អែកឡើង នោះយើងនឹងបរិភោគកូនអញវិញ* អំពើបាបរបស់ស្ដេច និងរាស្ត្ររបស់ទ្រង់បានរីកដុះដាល លវ ២៦:២៩ និង ចទ ២៨:៥៣, ៥៧ បានកាត់ទោសដល់អស់អ្នកដែលប្រព្រឹត្ត (ធៀប បទ ៤:១០) ។

**៦:៣០** *ទ្រង់ហែកព្រះពស្ត្រទ្រង់* សកម្មភាពនៃការខឹងដែលស្ដែងតាមរយៈលោកអេលីសេ និងព្រះយេហូវ៉ា (មើល ខ.៣១) ច្រើនជាងការសោកស្ដាយ និងទុក្ខព្រួយរបស់ទ្រង់ ចំពោះអំពើបាបដែលពួកគេបានប្រព្រឹត្ត រហូតធ្វើឱ្យទ្រង់ប្រទាននូវក្រឹត្យវិន័យបណ្ដាសាដល់ពួកគេ ។ *សំពត់ធ្មៃ* សំលៀកបំពាក់នេះ ជាទូទៅគេស្លៀកនៅក្នុងពិធីកាន់ទុក្ខ (មើលការពន្យល់ លប ៣៧:៣៤ វវ ១១:៣) ។

ជាប់លើខ្លួនវានៅថ្ងៃនេះ នោះសូមឱ្យព្រះទ្រង់ ប្រព្រឹត្តនឹង
យើងយ៉ាងនោះវិញ ហើយលើសទៅទៀតផង ។
៣២ឯអេលីសេ លោកកំពុងតែអង្គុយនៅក្នុងផ្ទះ មានពួក
ចាស់ទុំ[ប]នៅជាមួយ ហើយស្តេចទ្រង់ចាត់មនុស្សម្នាក់ពី
ចំពោះទ្រង់ឱ្យទៅរកលោក តែមុនដែលអ្នកនោះមកដល់
នោះលោកមានប្រសាសន៍ទៅពួកចាស់ទុំថា សូមមើល
បែបយ៉ាងណា ដែលកូនរបស់អ្នកសំឡាប់គេនេះ[ផ] បាន
ចាត់មនុស្សមកយកក្បាលខ្ញុំទៅ[ព] សូមចាំមើល កាលណា
អ្នកនោះមកដល់ ឱ្យបិទទ្វារឱ្យជាប់ កុំឱ្យគេចូលឡើយ តើមិន
ឮសូរជើងរបស់ចៅហ្វាយគេ មកតាមក្រោយទេឬ ៣៣កាល
លោកកំពុងមានប្រសាសន៍ និងអ្នកទាំងនោះនៅឡើយ អ្នក
នោះក៏ចុះមកដល់និយាយថា មើល សេចក្តីវេទនានេះ មក
ពីព្រះយេហូវ៉ា តើត្រូវឱ្យយើងនៅចាំ[ភ]ព្រះយេហូវ៉ាធ្វើអី
ទៀត ។

**៧** ១តែអេលីសេ លោកមានប្រសាសន៍ថា សូមស្តាប់ព្រះ
បន្ទូលនៃព្រះយេហូវ៉ាសិន ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះថា ដល់ថ្ងៃស្អែក វេលាថ្មើរណេះ នោះម្សៅយ៉ាងម៉ដ្ត
១រង្វាល់នឹងលក់ថ្លៃតែ១រៀល និងម្សៅឱក២រង្វាល់ថ្លៃតែ១
រៀលទេ[ក] នៅត្រង់មាត់ទ្វារក្រុងសាម៉ារី ២ដូច្នេះ មេទ័ព
ដែលស្តេចទ្រង់ព្រយុងអង្គលើ[ខ]ដៃលោក ក៏ឆ្លើយទៅអ្នក
សំណប់របស់ព្រះថា បើទោះជាព្រះយេហូវ៉ាទ្រង់ធ្វើទាំង
ទ្វា[គ]នៅលើមេឃផង នោះតើការយ៉ាងនោះនឹងកើតមក
ដូចម្តេចបាន អេលីសេឆ្លើយតបថា ចាំមើល ភ្នែកលោកនឹង
ឃើញច្បាស់ តែមិនបានបរិភោគ[ឃ]ទេ ។

**៦:៣២** ផ អគ ៨:១ ១៤:១ ២០:១ ព ១ពវ ១៨:៤ ភ ខ.៣១
**៦:៣៣** ម លវ ២៤:១១ យប ២:៩ ១៤:១៤ អស ៤០:៣១
**៧:១** ក ខ.១៦
**៧:២** ខ ២ពវ ៥:១៨ គ ខ.១៩ លប ៧:១១ ទដ ៧៨:២៣ មឡ ៣:១០ ឃ ខ.១៧
**៧:៣** ង លវ ១៣:៤៥–៤៦ ជន ៥:១–៤
**៧:៦** ច នក ១៤:២៤ អគ ១:២៤ ឆ ២សយ ១០:៦ យរ ៤៦:២១ ជ ជន ១៣:២៩
**៧:៧** ឈ ពច ៧:២១ ទដ ៤៨:៤–៦ សភ ២៨:១ អស ៣០:១៧
**៧:៨** ញ អស ១៣:២៣ ៣៥:៦

## ការឡោមព័ទ្ធត្រូវបរាជ័យ

៣រីឯនៅមាត់ទ្វារទីក្រុង នោះមានមនុស្សឃ្លង់[ង]៤នាក់
គេនិយាយគ្នាទៅវិញទៅមកថា យើងអង្គុយនៅទីនេះទាល់
តែស្លាប់ធ្វើអី ៤បើសិនជាយើងសំរេចថា នឹងចូលទៅក្នុង
ទីក្រុង នោះទីក្រុងក៏មានអំណត់ហើយ យើងនឹងស្លាប់នៅ
ទីនោះ បើយើងអង្គុយសៀមនៅទីនេះវិញ នោះគង់តែនឹង
ស្លាប់ដូចគ្នា ដូច្នេះ ចូរយើងចូលទៅខាងឯពួកទ័ពស៊ីរីវិញ
បើគេទុកជីវិតដល់យើង នោះយើងនឹងបានរស់នៅតែបែគេ
សំឡាប់ នោះយើងនឹងគ្រាន់តែស្លាប់ទៅដូចគ្នា ៥ដូច្នេះ
គេក៏ក្រោកឡើងនៅពេលព្រលប់ទៅឯទីបោះទ័ពរបស់ពួក
ស៊ីរី តែកាលគេទៅដល់ជើងទីបោះទ័ពហើយ នោះមិន
ឃើញមានអ្នកណាសោះ ៦ពីព្រោះព្រះអម្ចាស់ ទ្រង់បានធ្វើ
ឱ្យពួកទ័ពស៊ីរីបានឮសូរសន្ធឹក[ច]រទេះចំបាំង និងសន្ធឹកពល
សេះ គឺជាសូរសព្ទនៃកងទ័ពយ៉ាងធំនៅក្នុងទីបោះទ័ពរបស់
គេក៏និយាយគ្នាថា មើលស្តេចអ៊ីស្រាអែលបានជួល[ឆ] ពួក
ស្តេចនៃសាសន៍ហេត[ជ] និងស្តេចអេស៊ីព្ទឱ្យមកច្បាំងនឹង
យើងហើយ ៧ហេតុនោះគេក៏ក្រោកឡើង រត់ទៅ[ឈ]នៅ
ពេលព្រលប់នោះ លះចោលទាំងត្រសាលនឹងសេះ ហើយ
លារបស់គេ ទុកទីបោះទ័ពឱ្យនៅដូចដែល ក៏រត់យកតែជីវិត
ឱ្យរួចទៅប៉ុណ្ណោះ ៨ដូច្នេះកាលពួកគំលង់នោះ[ញ]បានទៅ
ដល់ជើងទីបោះទ័ព នោះក៏ចូលទៅក្នុងត្រសាលមួយ នាំគ្នា
ស៊ីផឹកទៅ រួចគេយកមាសប្រាក់ សំពត់អាវ ទៅលាក់ ទុកក៏
ត្រឡប់ទៅចូលក្នុងត្រសាល១ទៀត យករបស់ពីនោះទៅ
លាក់ទុកដែរ ។
៩នោះគេនិយាយគ្នាថា យើងប្រព្រឹត្តដូច្នេះមិនល្អទេដ្បិត

**៦:៣១** *សូមឱ្យព្រះទ្រង់ប្រព្រឹត្តនឹងយើងយ៉ាងនោះវិញ ហើយលើសទៅទៀតផង* ពាក្យទាំងនេះ គឺជាបណ្តាសា (សូមមើលការពន្យល់ ១សយ ៣:១៧) ។

**៦:៣២** *ពួកចាស់ទុំ* សំដៅលើពួកអ្នកដឹកនាំនៅក្នុងទីក្រុង (មើលការពន្យល់ នក ៣:១៦ ២សយ ៣:១៧) ។

**៦:៣៣** *តើត្រូវឱ្យយើង នៅចាំព្រះយេហូវ៉ាធ្វើអីទៀត* នៅត្រង់នេះស្តេចយ៉ូរ៉ាម គឺទ្រង់មានអារម្មណ៍ថាខ្លួនទ្រង់ចាញ់ល្បិចលោកអេលីសេ ហើយព្រះយេហូវ៉ាបានបោះបង់គាត់ចោលទៀតនោះ ដែលព្រះយេហូវ៉ាបានដាក់ទោសដល់ទីក្រុងឱ្យធ្លាក់ទៅក្នុងភាពរឹកររដ៏ខ្លាំង ។

**៧:១,២** នៅវគ្គនេះ លោកហោរាអេលីសេបានថ្លែងទំនាយពីសេចក្តីប្រោសលោះរបស់ព្រះ តែលោកមហាតលិកពោលថា ការនោះមិនអាចកើតមានឡើងបានឡើយ ។ សេចក្តីជំនឿ និងសេចក្តីសង្ឃឹមរបស់លោកមហាតលិកបានផុតរលត់អស់ទៅហើយ ប៉ុន្តែបន្ទូលសន្យាដ៏ពិតរបស់ព្រះយេហូវ៉ាត្រូវតែកើតឡើងគ្រប់បធ្យោបាយ (មើល ៧:១៤–១៦) ។ ពេលខ្លះ យើងមានអារម្មណ៍ខ្វល់ខ្វាយនឹងបញ្ហាដែលកើតមាននោះ ។ ជំនួសឱ្យការគិតបែបអវិជ្ជមាន យើងគួរផ្លាស់ប្តូការគិតបែបនេះឱ្យទៅជាលក្ខណៈវិជ្ជមានវិញ ។ យើងត្រូវគិតថា ព្រះមិនអាចសង្គ្រោះនរណាម្នាក់ ឬស្រោចស្រង់ស្ថានការណ៍មួយបាននោះ គឺបណ្តាមកពីពួកអ្នកទាំងអស់នោះគ្មានជំនឿលើព្រះយេហូវ៉ា ។

**៧:២** *ទ្រង់ធ្វើទាំងទ្វារនៅលើមេឃផង* មើល ខ.១៩ លប ៨:២ ១សយ ២៤:១៨ ។

**៧:៣** *មាត់ទ្វាទីក្រុង* ត្រង់នេះចំពោះកណ្ឌគម្ពីរទាំងប្រាំដំបូង (បញ្ញកណ្ឌ) មិនបានរាប់បញ្ចូលពួកអ្នកដែលមានជម្ងឺសើរស្បែក ហើយថែមទាំងដេញចេញពីភូមិស្រុកទៀតផង (សូមមើល លវ ១៣:៤៦ ជន ៥:២–៣) ។

**៧:៦** *ពីព្រោះព្រះអម្ចាស់ ទ្រង់បានធ្វើឱ្យពួកទ័ពស៊ីរី បានឮសូរសន្ធឹក* សូមមើល ២សយ ៥:២៤ និងការពន្យល់ ។ *សាសន៍ហេត...ស្តេច* ឃ្លានេះបានប្រាប់អំពីស្តេចនៃអាណាចក្រតូចៗ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សន្តតិវង្សនៃស្តេចសាសន៍ហេត ។

**៧:៩** ដោយព្រោះពួកគេ មានសេចក្តីភ័យខ្លាចចំពោះការកាត់ទោស នោះធ្វើឱ្យពួកគេផ្លាស់ប្តូរនូវឥរិយាបថប្រព្រឹត្ត ។

ថ្ងៃនេះជា ថ្ងៃមានដំណឹងល្អ តែយើងនៅតែស្ងៀមវិញ បើ
យើងនៅចាំរហូតដល់ព្រឹកឡើង នោះមុខជានឹងមានទោស
មកទាន់ជាមិនខាន ដូច្នេះ ចូរយើងទៅប្រាប់ដល់ពួកដំណាក់
ស្តេចឥឡូវចុះ ១០គេក៏ទៅហៅអ្នកឆ្មាំទ្វារទីក្រុងប្រាប់ថា
ពួកយើងខ្ញុំបានទៅដល់ទីបោះទ័ពរបស់ពួកស៊ីរី តែមើល
គ្មានអ្នកណាមួយសោះ ក៏គ្មានឮសំឡេងមនុស្សណាឡើយ
មានតែសេះនឹងលាដែលគេបានចងទុកហើយទាំងត្រសាល
គេក៏នៅដូចដែល ១១អ្នកឆ្មាំទ្វារក៏ហៅពួកអ្នកយាម ឱ្យ
គេបន្តដំណឹងនោះដល់ទៅខាងក្នុងព្រះរាជវាំង ១២ឯ
ស្តេចទ្រង់តើនឡើងទាំងយប់ មានបន្ទូល នឹងពួកជំនិតទ្រង់
ថា យើងនឹងសំដែងឱ្យអ្នករាល់គ្នាដឹងពីឧបាយរបស់ពួកស៊ីរី
ដែលគេគិតធ្វើដល់យើង គឺគេដឹងថា យើងរាល់គ្នាអត់ឃ្លាន
បានជាគេថយចេញពីទីបោះទ័ព ទៅពួន[ដ]នៅឯទីវាល
ដោយនឹកថា កាលណាយើងចេញពីទីក្រុងទៅ នោះគេនឹង
ចាប់យើងទាំងរស់ ហើយនឹងចូលមកក្នុងទីក្រុងបាន ១៣តែ
ពួកជំនិតម្នាក់ទូលថា សូមឱ្យគេយកសេះ៥ដែលនៅសល់
ដែលបានទុកក្នុងទីក្រុង (មើល សេះទាំងនោះក៏ដូចជា
សាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន ដែលនៅក្នុងទីក្រុងនៅ
ឡើយ គឺដូចជាពួកអ៊ីស្រាអែល ដែលកំពុងតែរោយរៀវ
ទៅហើយនេះ) សូមចាត់គេទៅមើលចុះ ១៤ដូច្នេះ គេក៏យក
រទេះចំបាំង២ទឹម ដោយសេះ ហើយស្តេចទ្រង់ចាត់គេឱ្យ
ទៅតាមពលទ័ពស៊ីរី ដោយបន្ទូលថា ចូរទៅមើលចុះ
១៥អ្នកទាំងនោះក៏ទៅតាមរហូតដល់ទន្លេយ័រដាន់ ឃើញ
មានសុទ្ធតែរអាវនឹងភាជនៈផ្សេងៗ ដែលពួកស៊ីរីបាន
បោះចោលរាយរហូតតាមផ្លូវទៅ ដោយខំរត់ជាប្រញាប់[ឋ]
រួចពួកអ្នក ដែលស្តេចចាត់ឱ្យទៅ ក៏វិលមកទូលទ្រង់វិញ ។
១៦ឯពួកប្រជាជនទាំងឡាយ ក៏ចេញទៅចាប់យករបឹប[ឌ]
នៅទីបោះទ័ពនៃពួកស៊ីរី ដូច្នេះ ម្សៅយ៉ាងម៉ដ្ឋ១រង្វាល់ក៏

**៧:១២** ដ យស ៨:៤
**៧:១៥** ឋ យប ២៧:២២
**៧:១៦** ឌ អស ៣៣:៤,២៣ ឍ ខ.១
**៧:១៧** ណ ខ.២
**៧:១៩** ត ខ.២
**៨:១** ក ២ពវ ៤:៨–៣៧ ខ លវ ២៦:២៦ ចទ ២៨:២២ នរ ១:១ គ លប ១២:១០

បានលក់ថ្លៃ១រៀល នឹងម្សៅឱក២រង្វាល់បានលក់ថ្លៃ១
រៀលដែរ[ឍ] តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ១៧ហើយស្តេច
ទ្រង់ដំរូវមេទ័ពម្នាក់ ដែលទ្រង់បានព្រយុងលើដៃលោក
ឱ្យចេញទៅត្រួតត្រាមើលការនៅត្រង់មាត់ទ្វារក្រុងតែ
បណ្តាជន គេជាន់លោកស្លាប់[ណ] នៅត្រង់ទ្វារទីក្រុងទៅ ដូច
ជាអ្នកសំណាប់របស់ព្រះបានទាយទុក ក្នុងកាលដែលស្តេច
យាងចុះទៅឯលោកនោះ ១៨ហើយក៏កើតមាន ដូចជាអ្នក
សំណាប់របស់ព្រះ បានទូលដល់ស្តេចថា លុះថ្ងៃស្អែកពេល
ថ្មើរណេះ នោះម្សៅឱក២រង្វាល់នឹងលក់ថ្លៃ១រៀល ហើយ
ម្សៅយ៉ាងម៉ដ្ឋ១រង្វាល់នឹងលក់ថ្លៃ១រៀលដែរ នៅត្រង់ទ្វារ
ក្រុងសាម៉ារី ១៩ឯមេទ័ពដែល បានឆ្លើយតបនឹងអ្នកសំណាប់
របស់ព្រះថា បើទោះជាព្រះ យេហូវ៉ាទ្រង់ធ្វើទាំងទ្វារ[ត]នៅ
លើមេឃផង នោះតើការយ៉ាងនោះនឹងកើតមកដូចម្តេច
បាន ហើយអេលីសេបានឆ្លើយថា មើលភ្នែកលោកនឹង
ឃើញច្បាស់ តែមិនបានបរិភោគទេ ២០នោះក៏កើតដល់
មេទ័ពនោះ ដូច្នោះមែន ដ្បិតបណ្តាជនទាំងឡាយ គេបាន
ជាន់លោកស្លាប់ នៅត្រង់ទ្វារទីក្រុងទៅ ។

## ការប្រគល់ដីធ្លីឱ្យទៅស្ត្រីនៅក្រុងស៊ូណែមវិញ

**៨** ១នៅគ្រានោះ អេលីសេបានមានប្រសាសន៍ដល់ស្ត្រី[ក]
ដែលលោកបានធ្វើឱ្យកូនរស់ឡើងវិញនោះថា ចូរអ្នកនឹង
គ្រួរបស់អ្នកទាំងប៉ុន្មាន រៀបចំឡើង ចេញទៅអាស្រ័យនៅ
ទីណា ដែលអាចនឹងអាស្រ័យនៅបានចុះ ដ្បិតព្រះយេហូវ៉ា
ទ្រង់បានបង្គាប់ឱ្យមានគ្រាអំណត់ អំណត់នោះ[ខ]នឹងមាននៅ
ក្នុងស្រុកគ្រប់៧ឆ្នាំ[គ] ២ដូច្នេះ ស្ត្រីនោះក៏រៀបចំឡើងធ្វើតាម
ពាក្យនៃអ្នកសំណាប់របស់ព្រះ នាងនាំយកគ្រួរបស់នាង ទៅ
នៅឯក្រុងភីលីស្ទីនអស់៧ឆ្នាំ ៣កាលគ្រប់៧ឆ្នាំហើយ នោះ
នាងបានត្រឡប់ពីស្រុកភីលីស្ទីនមកវិញ ក៏ទៅថ្លែងទុក្ខដល់
ស្តេច ដើម្បីឱ្យបានផ្ទះសំបែង និងស្រែចំការរបស់នាងមក

**៧:១២** *អ្នករាល់គ្នា ដឹងពីឧបាយរបស់ពួកស៊ីរី ដែលគេគិតធ្វើដល់យើង* នេះបញ្ជាក់ថា ភាពគ្មានជំនឿរបស់ស្តេចយ៉ូរ៉ាម បានធ្វើឱ្យខ្លួនព្រះអង្គសន្និដ្ឋានថា ពួកអ្នកកើតរោគឃ្លង់ទាំង៤នាក់នោះ ជាផ្នែកមួយនៃកលល្បិចសង្គ្រាមរបស់ពួកស៊ីរី មិនមែនការនេះសម្រេចតាមទំនាយហោរាអេលីយ៉ានោះទេ (សូមមើល ខ.១) ។

**៧:១៦–២០** នៅក្នុងវគ្គនេះ ជាការបញ្ជាក់ពីតម្លៃដ៏ពិតរបស់លោកហោរាអេលីសេបានថ្លែងទុកមកនោះ ។ ការសម្រេចតាមបទទំនាយទាំងប៉ុន្មានខាងលើនេះ គឺជាការរំលឹងថាការសង្គ្រោះដែលបានមកពីពួកខ្មាំងនោះ គឺជាអំណោយនៃព្រះគុណរបស់ព្រះ និងការបដិសេធព្រះបន្ទូលរបស់ព្រះនោះនឹងធ្លាក់ទៅក្នុងសេចក្តីក្រោធ ហើយនិងជំនុំជម្រះទៀតផង ។

**៨:១** *បង្គាប់ឱ្យមានគ្រាអំណត់* សេចក្តីអត់ឃ្លាន និងមានដល់ពួកគេដោយសារតែអំពើបាបដែលធ្វើឱ្យពួកគេធ្លាក់ទៅក្នុងសេចក្តីបណ្តាសា (មើលការពន្យល់ ៤:៣៨) ។ *៧ឆ្នាំ* នៅត្រង់នេះមិនបានកំណត់ច្បាស់ថា គ្រាអំណត់កើតមាននៅមុនពេល ឬក្រោយពេលនៃការព័ទ្ធចាប់ខ្លួនពួកស៊ីរីនៅស្រុកសាម៉ារី (មើល ៤:៣៨ ៦:២៤–៧:២០) ។

**៨:២** *នាងនាំយកគ្រួរបស់នាង* សេចក្តីណែនាំរបស់លោកអេលីសេ បានធ្វើឱ្យស្ត្រីដែលស្រឡាញ់ព្រះ និងពួកគ្រួសាររបស់នាង គេចផុតពីគ្រោះអត់ឃ្លានដែលកើតមាននៅពេលនោះបានដោយងាយ ។

**៨:៣** *ទៅថ្លែងទុក្ខដល់ស្តេច* មើលការពន្យល់ ១ពវ ៣:១៦ ។ *ដើម្បីឱ្យបានផ្ទះសំបែង និងស្រែចំការរបស់នាងវិញ* នៅចំណុចនេះ ពួកគេមានសិទ្ធគ្រប់គ្រងលើសម្បត្តិខុសច្បាប់របស់ស្ត្រី និងទ្រព្យសម្បត្តិនេះធ្លាក់ទៅក្នុងកម្មសិទ្ធិរបស់ស្តេច ដោយសារស្ត្រីនេះបានបោះបង់ចោល ។

វិញ ៤រីឯនៅគ្រានោះ ស្តេចទ្រង់ក៏កំពុងតែមានបន្ទូលនឹង
កេហាស៊ី ជាអ្នកបំរើនៃអ្នកសំណប់របស់ព្រះថា ចូរប្រាប់
យើងពីការយ៉ាងធំទាំងពួង ដែលអេលីសេបានធ្វើ ៥កាល
គាត់កំពុងតែថ្លែងទូលស្តេចពីរឿង ដែលលោកបានធ្វើឱ្យ
កូន ដែលស្លាប់បានរស់ឡើងវិញ នោះមើល ស្ត្រីនោះឯង
បានធ្វើឱ្យកូននាងរស់ឡើងវិញ[ឃ] ក៏មកថ្លែងទុក្ខដល់ស្តេច
ដើម្បីឱ្យបានផ្ទះសំបែង និងស្រែចំការរបស់នាងមកវិញ
កេហាស៊ីក៏ទូលថា បពិត្រព្រះករុណា ជាព្រះអម្ចាស់នៃទូល
បង្គំអើយ គឺស្ត្រីនេះឯងហើយនេះគឺកូននាង ដែលអេលី
សេបានធ្វើឱ្យរស់ឡើងវិញនោះ ៦កាលស្តេចបានសួរដល់
ស្ត្រីនោះ នាងក៏ទូលបញ្ជាក់ដល់ទ្រង់ ដូច្នេះ ស្តេចទ្រង់ដំរូវ
ពួករាជការម្នាក់សំរាប់ជួយនាង ដោយបង្គាប់ថា ចូរ
ប្រគល់របស់ទ្រព្យទាំងប៉ុន្មានរបស់នាងទៅនាងវិញ ព្រម
ទាំងផលដែល កើតពីស្រែចំការរបស់នាង ចាប់តាំងពី
ថ្ងៃដែលនាងចេញពីស្រុក ដរាបដល់សព្វថ្ងៃនេះផង ។

## ហាសែលធ្វើគត់ស្តេចបេន-ហាដាឌ់

៧ឯអេលីសេ លោកបានទៅឯស្រុកដាម៉ាស[ង] នៅគ្រា
នោះបេន-ហាដាឌ់[ច] ជាស្តេចស្រុកស៊ីរី ទ្រង់ប្រឈួន មាន
គេទូលប្រាប់ថា មើល អ្នកសំណប់របស់ព្រះបានមកទីនេះ
ហើយ ៨ដូច្នេះ ស្តេចទ្រង់បង្គាប់ដល់ហាសែលថា[ឆ] សូមនាំ
យកជំនូន[ជ]នៅដៃ ចេញទៅជួប[ឈ]នឹងអ្នកសំណប់របស់ព្រះ
ហើយសួរដល់ព្រះយេហូវ៉ា ដោយសារលោកថា តើយើង
នឹងបានជាពីជំងឺនេះឬទេ ៩ដូច្នេះ ហាសែលក៏យកជំនូនជា
របស់ប្រសើរនៅក្រុងដាម៉ាសគ្រប់មុខ ល្មមផ្ទុកលើសត្វអូដ្ឋ
៤០ចេញទៅ ដើម្បីជួបនឹងលោក ក៏ទៅឈរនៅមុខលោក
ជំរាបថា បេន-ហាដាឌ់ ជាកូនលោក ដែលជាស្តេចស្រុក
ស៊ីរី ទ្រង់បានចាត់ឱ្យខ្ញុំមកសួរលោកថា តើទ្រង់នឹងបានជា
ពីជំងឺនោះឬទេ ១០អេលីសេក៏តបថា ចូរទៅទូលទ្រង់វិញថា
នឹងបានជាៗពិត[ញ] ប៉ុន្តែព្រះយេហូវ៉ាបានសំដែងឱ្យខ្ញុំដឹង
ជាក់ថា ទ្រង់ត្រូវស្លាប់ជាប្រាកដវិញ ១១នោះអ្នកសំណប់
របស់ព្រះក៏ផ្តោតភ្នែកសំឡឹងមើលមុខហាសែល ទាល់
តែខ្មាស[ដ] រួចលោកក៏យំ[ឋ] ១២នោះហាសែលសួរលោកថា
ហេតុអ្វីបានជាលោកម្ចាស់យំ ដូច្នេះ លោកឆ្លើយថា
ពីព្រោះខ្ញុំដឹងពីការអាក្រក់ទាំងប៉ុន្មាន[ឌ] ដែលអ្នកនឹងធ្វើ
ដល់ពួកកូនចៅអ៊ីស្រាអែល គឺទីមាំមួនរបស់គេ នោះអ្នក
នឹងដុតចោល ពួកកំឡោះៗរបស់គេ អ្នកនឹងសំឡាប់ដោយ
ដាវអស់ទាំងកូនតូចៗ[ឍ]របស់គេ អ្នកនឹងបោកសំឡាប់
ចោល[ណ] ហើយពួកស្រីៗមានទំងន់ នោះ អ្នកនឹងវះ[ត]ពោះគេ
១៣នោះហាសែលឆ្លើយតបថា ខ្ញុំប្របាទ ដែលទុកដូចជា
ឆ្កែ[ថ] តើជាអ្វីដែលនឹងធ្វើការយ៉ាងធំនេះបាន តែអេលីសេ

**៨:៥** ឃ ២ពវ ៤:៣៥
**៨:៧** ង ២សយ ៨:៥
ច ២ពវ ៦:២៤
**៨:៨** ឆ ១ពវ ១៩:១៥
ជ លប ៣២:២០
១សយ ៩:៧ ឈ ពច ១៨:៥
**៨:១០** ញ ៣៨:១
**៨:១១** ដ ពច ៣:២៥
ឋ លក ១៩:៤១
**៨:១២** ឌ ១ពវ ១៩:១៧ ឍ លប ៣៤:២៩ ណ ទដ ១៣៧:៩ អស ១៣:១៦ ហស ១៣:១៦ ណហ ៣:១០ លក ១៩:៤៤
ត ២ពវ ១៥:១៦ អម ១:១៣
**៨:១៣** ថ ១សយ ១៧:៤៣ ២សយ ៣:៨

**៨:៤** *ចូរ ប្រាប់យើងពីការយ៉ាងធំទាំងពួង ដែលអេលីសេបានធ្វើ* នៅត្រង់នេះបញ្ជាក់ថា ស្តេចយេហ៊ូរមិនដឹងអំពីកិច្ចការរបស់ហោរាអេលីសេទេ ពីព្រោះទ្រង់ឡើងសោយរាជ្យដោយចៃដន្យ គឺជំនួសស្តេចយ៉ូរ៉ាម (មើល ៣:១៣-១៤ ៥:៧-១០ ៦:១០-២៣ ៦:២៤-៧:២០) ប៉ុន្តែសូមមើលការពន្យល់ ៥:៧ ។

**៨:៦** *ចូរ ប្រគល់របស់ទ្រព្យទាំងប៉ុន្មានរបស់នាងទៅនាងវិញ* ស្ត្រីនេះបានរស់នៅក្នុងភាពជាស្ត្រីមេម៉ាយ ហើយរស់តាមអ្វីដែលព្រះបានប្រទានមកឱ្យនាង ដែលនាងបានធ្វើតាមព្រះតាមរយៈហោរារបស់ព្រះនេះឯង ។

**៨:៧** *អេលីសេ លោកបានទៅឯក្រុងដាម៉ាស* នេះជាវេលាដែលហោរាអេលីសេត្រូវធ្វើឱ្យបានសម្រេច១នៅក្នុងចំណោមកិច្ចការ៣ ដែលព្រះយេហូវ៉ាបានប្រទានមកឱ្យគាត់នៅភ្នំហោរែប (មើលការពន្យល់ ១ពវ ១៩:១៥-១៦) ។

**៨:៨** *សួរដល់ព្រះយេហូវ៉ា* សម្រាប់ស្ថានភាពផ្លាស់ប្រែ សូមមើលក្នុង ១:១-៤ ។ ស្តេចសាសន៍ដទៃ ស្វែងរកការទស្សទាយពីព្រះរបស់ពួកអ៊ីស្រាអែល ។ *តើយើងនឹងបានជាពីជំងឺនេះឬទេ* សំណួរនេះដូចគ្នាចំពោះស្តេចអ័ហាស៊ីយ៉ានៅក្នុង ១:២ ។

**៨:៩** *របស់ប្រសើរនៅក្រុងដាមាស់គ្រប់មុខ ល្មមផ្ទុកលើសត្វអូដ្ឋ៤០ចេញទៅ* ក្រុងដាម៉ាស់គឺជាចំណុចកណ្តាលនៃជំនួញរវាងប្រទេសអេស៊ីព្ទ ហើយនិងតំបន់មេសូប៉ូតាម៉ា ។ ជាការជាក់ស្តែងតាមគំនិតរបស់បេន-ហាដាឌ់ គឺជូនជាអំណោយដោយបញ្ជាក់ពីសេចក្តីអាណិតអាសូរពីលោកអេលីសេ ដែលជាអ្នកព្យាករ (អំណោយក្នុង ៥:៥) ។ *នេ-ហាដាឌ់ ជាកូនលោក* គឺជាបច្ចេកទេសនៃការប្រើឈ្មោះឪពុក ក្នុងការទទួលស្គាល់ដោយស្វាត់ៗរបស់បេន-ហាដាឌ់ដោយលោកអេលីសេដែលវិសេសបំផុត (មើល ៦:២១ ១សយ ២៥:៨) ។

**៨:១០** *នឹងបានជាៗពិត* នៅត្រង់នេះជាការប្រកាសថា ជម្ងឺរបស់ស្តេចបេន-ហាដាឌ់មិនអាចជាបានឡើយ ។ *ដឹងជាក់* ការនេះស្ថិតនៅក្នុងកណ្តាប់ដៃហាសែល (មើល ខ.១៤-១៥) ។

**៨:១២** *អ្នកនឹងធ្វើដល់ពួកកូនចៅអ៊ីស្រាអែល* ព្រះអម្ចាស់ទ្រង់បានប្រទានឱ្យហោរាអេលីសេឃើញច្បាស់អំពីការកាត់ទោសពួកអ៊ីស្រាអែល ស្ថិតក្រោមកណ្តាប់ដៃហាសែល (មើល ៩:១៤-១៦ ១០:៣២ ១២:១៧-១៨ ១៣:៣, ២២) ។ *ពួកស្រីៗមានទំងន់ នោះអ្នកនឹងវះពោះ* នេះជាសកម្មភាពឃោរឃៅមួយដែលជានិច្ចកាលអំពើរនេះពួកទាហានដែលមានជ័យជម្នះបានអនុវត្តនៅសម័យនោះ (មើល ១៥:១៦ ហស ១៣:១៦ អម ១:១៣) ។ ភាពឃោរឃៅនេះ ធ្វើឡើងក្នុងគោលបំណងឱ្យប្រាកដច្បាស់ថា ក្រោយពីសង្គ្រាមចប់ ក្មេងប្រុសនឹងលែងមាននៅលើទឹកដីនេះទៀត ។ ពាក្យទំនាយរបស់ហោរាអេលីសេ មិនមែនជាក្រឹត្យច្បាប់ តែជាការពិពណ៌នាពីអនាគតនៃការវាយប្រហាររបស់ស្តេចហាសែលលើពួកអ៊ីស្រាអែល ។

**៨:១៣** *ខ្ញុំប្របាទ ដែលទុកដូចជាឆ្កែ តើជាអ្វីដែលនឹងធ្វើការយ៉ាងនេះបាន* សូមមើល ២សយ ៩:៨ និងការពន្យល់ ។ *អ្នកនឹងបានធ្វើជាស្តេចលើស្រុកស៊ីរី* នេះជាការបញ្ជាក់របស់ហោរាអេលីសេថា ហាសែលមិនមែនជាសន្ត

ឆ្លើយថា ព្រះយេហូវ៉ាទ្រង់បានសម្តែងឱ្យខ្ញុំដឹងថា អ្នក
នឹងបានធ្វើជាស្តេច[ទ]លើស្រុកស៊ីរី [១៤]លោកក៏ចេញពី
អេលីសេ ត្រឡប់ទៅឯចៅហ្វាយវិញ ដល់ហើយទ្រង់សួរ
ថា តើអេលីសេបានប្រាប់អ្នកយ៉ាងដូចម្តេច រួចលោកទូល
ទ្រង់ថា លោកបានប្រាប់ទូលបង្គំថា ទ្រង់នឹងបានជាៗពិត
[១៥]ដល់ថ្ងៃស្អែកឡើងហាសែលបានយកភួយមួយជ្រលក់ទឹក
ទៅខ្ទប់ព្រះភក្ត្រ នៃស្តេចឱ្យទ្រង់សុគតទៅ[ធ] រួចហាសែប
បានសោយរាជ្យឡើងជំនួសទ្រង់ ។

## យ៉ូរ៉ាមឡើងជាស្តេចស្រុកយូដា

*៨:១៦-២៤ - ២រប ២១:៥-១០,២០*

[១៦]នៅឆ្នាំទី៥ក្នុងរាជ្យយ៉ូរ៉ាម[ន] ជាបុត្រអ័ហាប់ ស្តេចស្រុក
អ៊ីស្រាអែល កំពុងដែលយ៉ូសាផាតសោយរាជ្យលើស្រុក
យូដា នោះយ៉ូរ៉ាម[ប] ជាបុត្រយ៉ូសាផាតក៏ចាប់តាំងសោយ
រាជ្យឡើង [១៧]កាលទ្រង់ចាប់តាំងសោយ រាជ្យឡើងនោះ
ទ្រង់មានព្រះជន្ម៣២ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន៨ឆ្នាំ [១៨]ទ្រង់បានដើរតាមផ្លូវនៃពួក
ស្តេចអ៊ីស្រាអែល ដូចជាជំនួរវង្សអ័ហាប់ដែរ ពីព្រោះ
ទ្រង់បានយកបុត្រី[ផ]របស់អ័ហាប់ ធ្វើជាភរិយា ក៏ប្រព្រឹត្ត

**៨:១៣** ទ ១ពវ ១៩:១៥
**៨:១៥** ធ ២ពវ ១:១៧
**៨:១៦** ន ២ពវ ១:១៧ ប ២រប ២១:១-៤
**៨:១៨** ផ ខ.២៦ ២ពវ ១១:
**៨:១៩** ព លប ៦:១៣ ភ ២សយ ២១:១៧ វវ ២១:២៣
**៨:២០** ម ១ពវ ២២:៤៧
**៨:២២** យ លប ២៧:៤០ រ ជន ៣៣:២០ យស ២១:១៣ ២ពវ ១៩:៨

អំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា [១៩]ប៉ុន្តែ
ព្រះយេហូវ៉ា ទ្រង់មិនសព្វព្រះហឫទ័យ និងបំផ្លាញ[ព]ពួក
យូដាទេ ដោយយល់ដល់ដាវីឌ ជាអ្នកបំរើទ្រង់ ដូចជាបាន
សន្យាដល់ទ្រង់ថា និងប្រោសប្រទានឱ្យទ្រង់មានចង្កៀង១[ភ]
ភ្លឺសំរាប់ពួកជំនួរវង្សរបស់ទ្រង់តទៅ ។
[២០]នៅក្នុងរាជ្យយ៉ូរ៉ាម នោះសាសន៍អេដំមបានបះបោរ
ដោះខ្លួន ពីក្នុងកណ្តាប់ដៃនៃសាសន៍យូដា ហើយក៏តាំង
ស្តេច១អង្គ ឱ្យសោយរាជ្យលើខ្លួនគេ[ម] [២១]គ្រានោះយ៉ូរ៉ាម
ទ្រង់យាងទៅឯក្រុងសាអ៊ារ នាំទាំងរទេះចំបាំងទាំងអស់
ទៅជាមួយផង ក៏លើកគ្នាទាំងយប់ទៅវាយពួកអេដំម ដែល
ឡោមព័ទ្ធទ្រង់ ព្រមទាំងពួកមេទ័ពរបស់រទេះចំបាំងផង
ហើយបណ្តាទ័ពទាំងឡាយ ក៏រត់ទៅទីលំនៅរបស់គេវិញ
[២២]ប៉ុន្តែ សាសន៍អេដំមគេបះបោរ[យ] ដោះខ្លួនពីអំណាច
នៃពួកយូដា ដរាបដល់សព្វថ្ងៃនេះ នៅគ្រានោះឯង ក្រុង
លិបណា[រ]ក៏បះបោរដែរ [២៣]រីឯដំណើរ ឯទៀតពីយ៉ូរ៉ាម
នឹងការទាំងប៉ុន្មានដែលទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុក
ក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដាហើយ
[២៤]យ៉ូរ៉ាមក៏ផ្ទំលក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់ ហើយគេ

តិវង្សរបស់ស្តេចបេន-ហាដាឌ់ស្របច្បាប់នោះទេ ។ សិលាចារឹករបស់ពួកស៊ីរីមួយបានប្រាប់ថា ហាសែលនេះជាមនុស្សដែលបានជ្រើសទុកជាមុន "កូនអនាថា" មនុស្សដណ្តើមរាជ្យ ។

**៨:១៥** *សុគត* លោកអេលីសេបានទាយអំពីរាជ្យរបស់ហាសែល គឺជាឃាតកម្មមួយដែលមិនបានត្រឹមត្រូវតាមច្បាប់ ។ អំពើឃាតកម្មរបស់ហាសែលចំពោះស្តេចបេន-ហាដាឌ់នេះ គឺវានឹងមានចំពោះជនជាតិអ៊ីស្រាអែលនៅថ្ងៃអនាគតដោយសារមានអំពើបាបកម្មនៅក្នុងចិត្តរបស់ពួកគេ (មើល អស ១០:៥-៩) ។ បេន-ហាដាឌ់គឺធ្វើតាមលោកហាសែល (មើល ១៣:២៤) ។

**៨:១៦** *ឆ្នាំទី៥ ក្នុងរាជ្យយ៉ូរ៉ាម* ស្ថិតនៅក្នុងឆ្នាំទី ៨៤៨ មុន គ.ស និង សូមមើលការពន្យល់ ១:១៧ ។

**៨:១៧** *សោយរាជ្យនៅក្រុងយេរូសាឡិមបាន៨ឆ្នាំ* នេះជារាជ្យស្តេចយ៉ូរ៉ាមដែលព្រះអង្គបានគ្រងរាជ្យចាប់ពីឆ្នាំ ៨៤៨-៨៤១ មុន គ.ស ។

**៨:១៨** *ដើរតាមផ្លូវនៃពួកស្តេចអ៊ីស្រាអែល ដូចជាជំនួរវង្សអ័ហាប់* នៅត្រង់នេះ បញ្ជាក់ថាស្តេចយ៉ូរ៉ាមបាននាំពួកយូដាឱ្យគោរពព្រះបាល ដូចដែលស្តេចអ័ហាប់បាននាំពួកយូដានៅភាគខាងជើងដែរ (មើល ១១:១៨) ។ មកដល់ពេលនេះ ការថ្វាយបង្គំព្រះបាល បានពង្រីកមកដល់អាណាចក្រខាងត្បូងទៀត ដែលនៅក្នុងខណៈនេះអាណាចក្រនៅភាគខាងជើងមានការរីតបណ្តឹងយ៉ាងខ្លាំងដោយបុត្រារបស់ស្តេចអ័ហាប់គឺស្តេចយ៉ូរ៉ាមនេះឯង (មើល ៣:១-២) ។ *យកបុត្រីរបស់អ័ហាប់ ធ្វើជាភរិយា* ភរិយារបស់ស្តេចយ៉ូរ៉ាម គឺអ័ថាលាដែលជាបុត្រីរបស់ស្តេចអ័ហាប់ គឺមិនមែនយេសិបិលនោះទេ(មើល ខ.២៦ ២រប ១៨:១) ។ ឥទ្ធិពលរបស់អ័ថាលាដែលមានទៅលើស្តេចយ៉ូរ៉ាម គឺមានការជាប់ទាក់ទងទៅនឹងឥទ្ធិពលរបស់យេសិបិលលើស្តេចអ័ហាប់(មើល ១ពវ ១៦:៣១ ១៨:៤ ១៩:១-២ ២ពវ ២១:៦) ។

**៨:១៩** *ចង្កៀង១ភ្លឺ សំរាប់ពួកជំនួរវង្សរបស់ទ្រង់តទៅ* មើលការពន្យល់ ១ពវ ១១:៣៦ មើលបន្ថែម ទដ ១៣២:១៧ ។ ព្រះអម្ចាស់ទ្រង់ មិនបានលះចោលពួកយូដា និងកាត់ទោសជំនួរវង្សនេះ ដោយព្រោះព្រះទ្រង់បានសន្យា ជាមួយនឹងស្តេចដាវីឌយ៉ាងច្បាស់(មើល ២សយ ៧:១៦,២៩ ២រប ២១:៧) ។

**៨:២០** *តាំងស្តេច១អង្គ ឱ្យសោយរាជ្យលើខ្លួនគេ* ក្នុងវគ្គខាងដើមបានបញ្ជាក់ថា ស្រុកអេដំមនេះជារឿងរ៉ាវមួយដែលទាក់ទងនៅនឹងពួកយូដា ហើយត្រូវបានដឹកនាំដោយអ្នកតំណាងរាជ្យការ (មើលការពន្យល់ ៣:៩ មើលបន្ថែម ២២:៤៧) ។

**៨:២២** *ដរាបដល់សព្វថ្ងៃនេះ* ឃ្លានេះនៅតែមានប្រើរហូតមកដល់រាជ្យស្តេចយ៉ូរ៉ាមដោយអ្នកនិពន្ធកណ្ឌគម្ពីរ ១,២ពវ(មើលសេចក្តីផ្តើម ១ពវ : អ្នកនិពន្ធ ប្រភពនិងកាលបរិច្ឆេទ ហើយនិងមើលបន្ថែមការពន្យល់ ១ពវ ៨:៨) ។ ក្រោយមកទៀត អ័ម៉ាស៊ីយ៉ាដែលជាពួកយូដា បានប្រហារពួកអ្នកស្រុកអេដំមអស់យ៉ាងច្រើន (មើល ១៤:៧) និងអ័សារាដែលជាកូនចៅបានត្រួតត្រាលើផ្លូវពាណិជ្ជកម្មនៅក្រុងអេឡាត នៅពេញទឹកដីស្រុកអេដំម (មើល ១៤:២២ ២រប ២៦:២) ។ *នៅគ្រានោះឯង ក្រុងលិបណាក៏បះបោរ* ក្រុងនេះនៅពេលនោះ ជាប់ទៅនឹងក្រុងភីលីស្ទីន ជិតក្រុងឡាគីសេ (មើល ១៩:៨) ។ ការបោះនៅក្រុងលិបណានេះ គឺជាប់ទាក់ទងទៅនឹងការបះបោរនៅភីលីស្ទីន និងក្រុងអារ៉ាបដែលបានពិពណ៌នានៅក្នុង ២រប ២១:១៦-១៧ ។

**៨:២៣** *ដំណើរឯទៀតពីយ៉ូរ៉ាម* សូមមើល ២រប ២១:៤-២០ ។ *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

បញ្ចុះទ្រង់ នៅក្នុងក្រុងដាវីឌ ជាមួយនឹងពួកព្ធយុកោទ្រង់
ទៅ រួចអ័ហាប់ស៊ីយ៉ា ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យ
ជំនួសបិតា ។

## អ័ហាស៊ីយ៉ាឡើងជាស្តេចស្រុកយូដា

*៨:២៥–២៩ – ២របា ២២:១–៦*

២៥នៅឆ្នាំទី១២[ល]ក្នុងរាជ្យយ៉ូរ៉ាប ជាបុត្រអ័ហាប់ស្តេច
អ៊ីស្រាអែល នោះអ័ហាស៊ីយ៉ា ជាបុត្រយ៉ូរ៉ាមស្តេចយូដា
ក៏ចាប់តាំងសោយរាជ្យឡើង ២៦កាលអ័ហាស៊ីយ៉ាចាប់តាំង
សោយរាជ្យ នោះមានព្រះជន្ម២២ឆ្នាំហើយ ក៏សោយរាជ្យ
នៅក្រុងយេរូសាឡិមបាន១ឆ្នាំ មាតាទ្រង់ព្រះនាមជាអ័ថា
ណា[វ]ជាបុត្រីអំរី[ស] ដែលបានធ្វើជាស្តេចអ៊ីស្រាអែល ២៧ទ្រង់
បានដើរតាមផ្លូវនៃជំនួរវង្សរបស់អ័ហាប់[ហ] ក៏ប្រព្រឹត្តអំពើ
ដ៏លាមកអាក្រក់[ឡ] នៅព្រះនេត្រព្រះយេហូវ៉ាដូចជាជំនួរ
វង្សអ័ហាប់ដែរ ដ្បិតទ្រង់បានចងព័ន្ធនឹងជំនួរវង្សអ័ហាប់
២៨ទ្រង់ក៏បានយាងទៅច្បាំងនឹងហាសែល ជាស្តេចស្រុក
ស៊ីរី នៅក្រុងរ៉ាម៉ូត–កាឡាត[អ] ជាមួយនឹងយ៉ូរ៉ាម ជាបុត្រ
អ័ហាប់ ហើយពួកស៊ីរីបានធ្វើឱ្យយ៉ូរ៉ាមមានរបួស ២៩រួច
ស្តេចយ៉ូរ៉ាមទ្រង់ត្រឡប់ទៅឯក្រុងយេសរាល[ក] ដើម្បីនឹង
រក្សារបួស ដែលពួកស៊ីរីបានធ្វើដល់ទ្រង់ នៅត្រង់រ៉ាម៉ា
ក្នុងកាលដែលទ្រង់ច្បាំងនឹងហាសែល[ខ] ជាស្តេចស្រុកស៊ីរី
ឯអ័ហា–ស៊ីយ៉ា[គ] ជាបុត្រយ៉ូរ៉ាមស្តេចស្រុកយូដា ទ្រង់ក៏យាង
ចុះទៅឯក្រុងយេសរាល ដើម្បីនឹងសួរយ៉ូរ៉ាមជាបុត្រ
អ័ហាប់ ពីព្រោះទ្រង់ប្រឈួន ។

## យេហ៊ូវទទួលការចាក់ប្រេងតាំងជាស្តេចអ៊ីស្រាអែល

**៩** ១គ្រានោះ ហោរាអេលីសេ លោកហៅម្នាក់ក្នុងពួក
សិស្ស[ក]នៃពួកហោរាមកប្រាប់ថា ចូរក្រវាត់ចង្កេះ[ខ] យក

**៨:២៥** ល ២ពវ ៩:២៩
**៨:២៦** វ ខ.១៨ ស ១ពវ ១៦:២៣
**៨:២៧** ហ ១ពវ ១៦:៣០ ឡ ១ពវ ១៥:២៦
**៨:២៨** អ ចទ ៤:៤៣ ២ពវ ៩:១,១៤
**៨:២៩** ក ១ពវ ២១:២៩ ២ពវ ៩:២១ ខ ១ពវ ១៩:១៥,១៧ គ ២ពវ ១០:១៣
**៩:១** ក ១សយ ១០:៥ ខ ១ពវ ១៨:៤៦
គ ១សយ ១០:១ ឃ ២ពវ ៨:២៨
**៩:៣** ង ១ពវ ១៩:១៦
**៩:៦** ច ១ពវ ១៩:១៦
**៩:៧** ឆ លប ៤:២៤ វវ ៦:១០ ជ ចទ ៣២:៤៣ ឈ ១ពវ ១៨:៤
**៩:៨** ញ ២ពវ ១០:១៧ ដ ១សយ ២៥:២២

ខួចប្រេង[គ]នេះកាន់នៅដៃ ទៅឯក្រុងរ៉ាម៉ូត–កាឡាតចុះ[ឃ]
២កាលណាទៅដល់ហើយ ចូររកយេហ៊ូវ ជាកូនយេហូសា
ផាតដែលជាកូននឹមស៊ី ហើយចូលទៅហៅលោក ឱ្យក្រោក
ពីកណ្តាលពួកបងប្អូនលោក នាំទៅឯបន្ទប់ខាងក្នុង ៣រួច
យកខួបប្រេង[ង]នេះចាក់លើក្បាលលោក ដោយជំរាបថា
ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អញបានចាក់ប្រេងតាំង
ឯងឡើងជាស្តេច ឱ្យសោយរាជ្យលើស្រុកអ៊ីស្រាអែល រួច
ហើយចូរឯងបើកទ្វាររត់ទៅ កុំឱ្យបង្អង់ឡើយ ៤ដូច្នេះ
មនុស្សកំឡោះ ជាអ្នកបំរើពួកហោរានោះ ក៏ទៅឯរ៉ាម៉ូត–
កាឡាតទៅ ៥កាលគាត់ទៅដល់ហើយ នោះឃើញពួក
មេទ័ពកំពុងអង្គុយនៅជាមួយគ្នា គាត់ក៏ជំរាបថា លោក
មេទ័ពអើយ ខ្ញុំមានការ១ចំពោះលោក រួចយេហ៊ូវសួរថា
តើចំពោះអ្នកណាក្នុងពួកយើងនេះ គាត់ឆ្លើយថា លោក
មេទ័ពអើយ គឺចំពោះលោកនេះឯង ៦ដូច្នេះ យេហ៊ូវក៏
ក្រោកឡើង ចូលទៅក្នុងផ្ទះ រួចអ្នកនោះចាក់ប្រេង[ច]លើ
ក្បាល លោកជំរាបថា ព្រះយេហូវ៉ាជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ អញបានចាក់ប្រេងតាំង
ឯងឡើង ជាស្តេចលើសាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់
អញ ៧ត្រូវឱ្យប្រហារជំនួរវង្សរបស់អ័ហាប់ ជាចៅហ្វាយ
ឯងទៅ ប្រយោជន៍ឱ្យអញបានសងសឹក[ឆ]នឹងយេសិបិល
ដោយព្រោះឈាមនៃពួកហោរា ជាអ្នកបំរើអញ[ជ] នឹង
ឈាមនៃពួកអ្នកបំរើរបស់អញទាំងអស់ដែរ[ឈ] ៨ដ្បិតជំនួរ
វង្ស[ញ]របស់អ័ហាប់ ត្រូវវិនាសទៅអស់រលីង ហើយអញនឹង
កាត់កាល់អស់ទាំងកូនប្រុសៗ[ដ]ពីអ័ហាប់ចេញ ទោះទាំងអ្នក
ដែលបិទបាំងទុកនឹងពួកអ្នកឥតចំណងក្នុងសាសន៍អ៊ីស្រា–
អែលផង ៩អញនឹងធ្វើឱ្យជំនួរវង្សអ័ហាប់បានដូចជាជំនួរ

**៨:២៤** *ផ្ទុំលក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់* មើលការពន្យល់ ១ពវ ១:២១ ២របា ២១:២០ ។

**៨:២៥** *១២ឆ្នាំក្នុងរាជ្យយ៉ូរ៉ាម* នេះគឺឆ្នាំទី ៨៤១ នៃ គ.ស ។ នៅក្នុង ៩:២៩ ជាឆ្នាំទី១នៃរាជ្យរបស់ស្តេចយ៉ូរ៉ាម ត្រូវបានគេរាប់ថា ជាឆ្នាំនៃការឡើងគ្រងរាជ្យ ហើយឆ្នាំទី២ត្រូវបានគេចាត់ទុកថាជាឆ្នាំទី១នៃការឡើងគ្រងរាជ្យដំបូង តែនៅទីនេះ ឆ្នាំនៃការឡើងគ្រងរាជ្យដំបូងត្រូវបានគេរាប់ជាឆ្នាំទី១នៃរាជ្យរបស់គាត់(មើលសេចក្តីផ្តើម ១ពវ) ។

**៨:២៦** *ព្រះជន្ម២២ឆ្នាំហើយ ក៏សោយរាជ្យ* មើលការពន្យល់ ២របា ២២:២ *អ័ថាលា* មើលការពន្យល់ ខ.១៨ ។

**៨:២៧** *ផ្លូវនៃជំនួរវង្សរបស់អ័ហាប់* មើលការពន្យល់ ២របា ២២:៣–៥ ។

**៨:២៨** នៅវគ្គនេះ យេហូសាផាតបានពួតដៃជាមួយស្តេចអ័ហាប់ ធ្វើសង្គ្រាមប្រឆាំងជាមួយនឹងស្តេចស្រុកស៊ីរីនៅក្រុងរ៉ាម៉ូត–កាឡាត(មើល ១ពវ ២២) ដូច្នេះ មកដល់ត្រង់នេះ អ័ហាស៊ីយ៉ាក៏បានពួតដៃជាមួយនឹងពូរបស់ខ្លួនដើម្បីផ្សងព្រេងនឹងសឹកសង្គ្រាមនេះដែរ ។ នៅក្នុងសមរភូមិនេះ ស្តេចយ៉ូរ៉ាមទទួលរងរបួសយ៉ាងធ្ងន់ធ្ង ហើយបានសះស្បើឡើងវិញនៅក្រុងយេសរាល (មើល ការពន្យល់ ១ពវ ២១:១) ។ អ្នកទាំងពីរនាក់នេះ ត្រូវយេហ៊ូវសម្លាប់ (សូមមើល ៩:១៤–២៨) ។

**៩:១** *សិស្សនៃពួកហោរា* មើលការពន្យល់ ២:៣ ។

**៩:៣** *អញ បានចាក់ប្រេងតាំងឯងឡើងជាស្តេច* មើលការពន្យល់ ១សយ ២:១០ ៩:១៦ ១ពវ ១៩:១៦ ។

**៩:៧** *ប្រហារជំនួរវង្សរបស់អ័ហាប់* នៅត្រង់នេះយេហ៊ូវ បានរៀនអំពីការដែលគាត់ជាអ្នកដែលព្រះបានចាក់ប្រេងតាំង ដើម្បីធ្វើឱ្យបានសម្រេចតាមបទទំនាយរបស់ហោរាអេលីយ៉ា ដែលបានប្រកាសពីឆ្នាំកន្លងមក ឱ្យគាត់ធ្វើជាអ្នកប្រឆាំងជាមួយនឹងជំនួរវង្សនៃស្តេចអ័ហាប់(មើល ខ.២៥–២៦ ១ពវ ២១:២១–២៤) ។ *សងសឹកនឹងយេសិបិល ដោយព្រោះឈាមនៃពួកហោរាជាអ្នកបំរើអញ* សូមមើល ១ពវ ១៨:៤ ២១:១៣ ។

**៩:៩** *ដូចជាជំនួរវង្សរបស់យេរ៉ូបោម* មើល ១ពវ ១៤:៧–១១ ១៥:២៧–៣០ *ដូចជាជំនួរវង្សនៃបាអាសា* សូមមើល ១ពវ ១៦:១–៤,៨–១២ ។ ខ្លឹមសារនៅ

វង្សរបស់យេរ៉ូបោម[ឋ] ជាកូននេបាត ហើយដូចជាជិន្ធូរវង្ស
នៃប្អាសា[ឌ] ជាកូនអ័ហ៊ីយ៉ាដែរ ១០ឆ្កែ[ឍ]នឹងទំពាស៊ីយេសិបិល
នៅដីបន់១ ក្នុងក្រុងយេសរាល ឥតមាន អ្នកណាកប់នាង
ឡើយ រួចហើយគាត់ក៏បើកទ្វាររត់ចេញទៅ ។
១១បន្ទាប់នោះ យេហ៊ូវក៏ចេញមកឯពួកមេទ័ពរបស់ចៅ
ហ្វាយលោកមានម្នាក់សួរថា តើស្រួលបួលទេ ឬមនុស្ស
ចំកួតនេះ[ណ]មករកលោកធ្វើអី លោកឆ្លើយថា លោករាល់
គ្នាស្គាល់មនុស្សនោះនឹងរឿងគេហើយ ១២តែពួកនោះ
ឆ្លើយឡើងថា នេះភរទេ សូមប្រាប់យើងឱ្យត្រង់មក លោក
ក៏ប្រាប់ថា អ្នកនោះបាននិយាយប្រាប់ខ្ញុំយ៉ាងនេះមួយៗ
ដោយពាក្យថា ព្រះយេហូវ៉ាមានបន្ទូលដូច្នេះ អញបានចាក់
ប្រេងតាំងឯងឡើង ជាស្តេចលើស្រុកអ៊ីស្រាអែលហើយ
១៣ដូច្នេះ គេក៏ប្រញាប់ ប្រញាល់នឹងយកអាវរបស់គេរៀង
ខ្លួន ដាក់[ត]ឱ្យលោកអង្គុយនៅត្រង់ក្បាលជណ្តើរ រួចផ្លុំ
ត្រែ[ថ]ឡើងថា យេហ៊ូវជាស្តេចហើយ ។

## យេហ៊ូវសម្លាប់យ៉ូរ៉ាម និងអ័ហាស៊ីយ៉ា

*៩:២១–២៩ – ២រប ២២:៧–៩*

១៤ដូច្នេះ យេហ៊ូវ ជាកូនយេហូសាផាត ដែលជាកូននីមស៊ី
លោក ក៏គិតក្បត់នឹងយ៉ូរ៉ាម (រីឯយ៉ូរ៉ាម នឹងពួកទ័ពអ៊ីស្រា–
អែលទាំងប៉ុន្មាន គេកំពុងតែការពាររក្សាក្រុងរ៉ាម៉ូត–
កាឡាត [ទ]ដោយព្រោះហាសែល ជាស្តេចស្រុកស៊ីរី ១៥តែ
ស្តេចយ៉ូរ៉ាមទ្រង់បានវិលទៅឯយេសរាល ដើម្បីរក្សា
របួស[ធ] ដែលពួកស៊ីរីបានធ្វើ ក្នុងកាលដែលទ្រង់ច្បាំងនឹង
ហាសែល ជាស្តេចស៊ីរីនោះ) នោះយេហ៊ូវពោលថា បើអ្នក
រាល់គ្នាពេញចិត្តដូច្នេះហើយ នោះកុំឱ្យអ្នកណាចេញរួច
ពីទីក្រុងនេះ នាំដំណឹងទៅប្រាប់ក្នុងក្រុងយេសរាលឡើយ
១៦យេហ៊ូវក៏ឡើងជិះរថទៅឯយេសរាល ដ្បិត យ៉ូរ៉ាមទ្រង់ផ្ទុំ
ប្រឈួននៅទីនោះ ហើយអ័ហាស៊ីយ៉ា[ន] ជាស្តេចយូដាបាន
យាងចុះមកសួរ ។
១៧មានអ្នកចាំយាម[ប]ឈរលើប៉មយេសរាល ក៏ឃើញពួក
យេហ៊ូវដែលកំពុងតែមក ហើយគាត់ប្រាប់ថា ខ្ញុំឃើញ
មនុស្ស១ពួកមក យ៉ូរ៉ាមក៏បង្គាប់ថា ចូរដំរូវទ័ពសេះម្នាក់
ចាត់ឱ្យទៅចួបនឹងគេសួរថា តើមកដោយមេត្រីឬ[ផ] ១៨ដូច្នេះ
ទ័ពសេះម្នាក់នោះ ក៏ចេញទៅចួបនឹងគេ ប្រាប់ថា ស្តេច
ទ្រង់មានបន្ទូលសួរដូច្នេះ តើមកដោយមេត្រីឬ តែយេហ៊ូវ
តបថា តើឯងត្រូវការអ្វីនឹងសេចក្តីមេត្រីនោះ ចូរថយទៅ
ខាងក្រោយយើងទៅ អ្នកចាំយាមក៏ប្រាប់ថា អ្នកដែលចាត់
ទៅនោះ បានទៅដល់គេហើយ តែមិនមកវិញសោះ ១៩នោះ
ទ្រង់ក៏ចាត់ម្នាក់ទៀតឱ្យជិះសេះទៅ អ្នកនោះបានទៅដល់
គេប្រាប់ថា ស្តេចទ្រង់មានបន្ទូលសួរដូច្នេះថា តើមកដោយ
មេត្រីឬ តែយេហ៊ូវឆ្លើយតបថា តើឯងត្រូវការអ្វីនឹងសេចក្តី
មេត្រីនោះ ចូរថយទៅខាងក្រោយយើងទៅ ២០ដូច្នេះ អ្នក
ចាំយាមប្រាប់ថា អ្នកនោះបានទៅដល់គេហើយ តែមិន
មកវិញសោះ ឯភាពដែលបររថ នោះមើលទៅដូចជា[ព]
យេហ៊ូវ ជាកូននីមស៊ី ដ្បិតគេបរមកយ៉ាងលឿនអាក្រក់
ណាស់ ។
២១នោះយ៉ូរ៉ាមបង្គាប់ថា ចូររៀបចំឡើង គេក៏ទឹមព្រះ
រាជរថថ្វាយទ្រង់ រួចយ៉ូរ៉ាម ជាស្តេចអ៊ីស្រាអែល និង
អ័ហាស៊ីយ៉ា ជាស្តេចយូដា ទ្រង់គង់នៅរថ១រៀងអង្គចេញ
ទៅចួបនឹងយេហ៊ូវ បានប្រទះគ្នានៅត្រង់ដីបន់របស់ ណា
បោត[ភ] ជាអ្នកស្រុកយេសរាល ២២កាលយ៉ូរ៉ាមទ្រង់
ឃើញយេហ៊ូវ នោះទ្រង់មានបន្ទូលសួរថា យេហ៊ូវអើយ តើ
អ្នកមកដោយមេត្រីឬ លោកឆ្លើយតបថា កំពុងដែលមាន
សេចក្តីកំផិត និងមន្តអាគមរបស់យេសិបិល[ម] ជាមាតាទ្រង់
ជាច្រើនម្ល៉េះ នោះតើនឹងមានសេចក្តីមេត្រីឯណាបាន
២៣ដូច្នេះ យ៉ូរាមក៏ញាក់បង្វៀររត់ទៅ ដោយបន្ទូលនឹង
អ័ហាស៊ីថា អ័ហាស៊ីយ៉ាអើយ នេះជាការក្បត់ទេ[យ] ២៤យេ
ហ៊ូវក៏យឹតធ្នូ[រ]ពេញកំឡាំង បាញ់ទៅត្រូវទីកណ្តាលខ្នង
យ៉ូរ៉ាម ព្រួញក៏ត្រូវត្រង់បេះដូងទ្រង់ ចេញមកខាងក្រៅ
ហើយទ្រង់ស្រុតចុះ នៅក្នុងព្រះរាជរថ ២៥នោះយេហ៊ូវ
បង្គាប់ទៅប៊ីឌកការ ជាមេទ័ពលោកថា ចូរលើកវាបោះ
ចោលទៅក្នុងដីបន់ របស់ចំការណាបោត ជាអ្នកស្រុក
យេសរាលទៅ ដ្បិតត្រូវឱ្យនឹកចាំពីកាលដែលខ្ញុំ និងអ្នកបាន
ជិះសេះទៅតាមអ័ហាប់ជាបិតាវា នោះព្រះយេហូវ៉ាបាន

**៩:៩** ឋ ១ពវ ១៣:៣៤ ១៤:១០ ឌ ១ពវ ១៦:៣
**៩:១០** ឍ ១ពវ ២១:២៣
**៩:១១** ណ ១សយ ១០:១១ យហ ១០:២០
**៩:១៣** ត មថ ២១:៨ លក ១៩:៣៦ ថ ២សយ ១៥:១០
**៩:១៤** ទ ចទ ៤:៤៣ ២ពវ ៨:២៨
**៩:១៥** ធ ២ពវ ៨:២៩
**៩:១៦** ន ២រប ២២:៧
**៩:១៧** ប ១សយ ១៤:១៦ អស ២១:៦
ផ ១សយ ១៦:៤
**៩:២០** ព ២សយ ១៨:២៧
**៩:២១** ភ ១ពវ ២១:១–៧,១៥–១៩
**៩:២២** ម ១ពវ ១៨:១៩ វវ ២:២០
**៩:២៣** យ ២ពវ ១១:១៤
**៩:២៤** រ ១ពវ ២២:៣៤

ត្រង់នេះ ហោរាអេលីសេបានលើកឡើងពីស្តេចអ័ហាប់ថា ជាឆ្នាំកន្លង
មកហើយ (មើល ១ពវ ២១:២១–២៤) ។

**៩:១១** *មនុស្សចំកួត* ពាក្យនេះ ជាវោហាសព្ទដែលបញ្ជាក់អំពីអាកប្បកិរិយា
មើលងាយមើលថោកពួកទាហាននៅភាគខាងជើងរបស់ពួកយូដា ដែលពួក
សិស្សរបស់ហោរាបានហៅពួកគេថាជាយ៉ាងដូច្នេះ សូមប្រៀបធៀប ១សយ
២១:១៣–១៥ ។

**៩:១៥** *ក្រុងយេសរាល* ក្រុងនេះមានចម្ងាយប្រហែល ៧២ គ.ម ពីក្រុង
រ៉ាម៉ូត–កាឡាត ។ ទីនេះហើយដែលស្តេចយ៉ូរ៉ាម បានសម្រាកលំហែកាយ
(សូមមើល ១ពវ ២១:១ និងការពន្យល់) ។

**៩:១៦** *អ័ហាស៊ីយ៉ា . . .បានយាងចុះមកសួរ* សូមមើល ៨:២៩ ។

**៩:២២** *តំបន់របស់ណាបោត ជាអ្នកស្រុកយេសរាល* សូមមើលការពន្យល់
១ពវ ២១:២–៣,១៣,១៩ ។

**៩:២២** *សេចក្តីកំផិត និងមន្តអាគម* សេចក្តីទាំងពីនេះគឺឈានទៅដល់ការ
កាត់ទោសឱ្យធ្លាក់ក្នុងសេចក្តីស្លាប់ (មើល ចទ ១៣,១៨:១០–១២) ។

មានបន្ទូលសេចក្ដីនេះ[ល]ចំលើរូបវាថា [២៦]"ប្រាកដមែន
ម្សិលមិញ អញបានឃើញឈាមរបស់ណាបោត[វ] នឹង
ឈាមរបស់កូនប្រុសវា ដូច្នេះ អញនឹងសងឯងនៅក្នុង
ចំការនេះឯង នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា" ដូច្នេះ
ចូរលើកវាបោះចោលទៅក្នុងចំការនេះ តាមព្រះបន្ទូល
នៃព្រះយេហូវ៉ាចុះ[ស] ។
[២៧]កាលអ័ហាស៊ីយ៉ាជាស្ដេចយូដាបានឃើញការ ដូច្នោះ
នោះទ្រង់ក៏រត់ទៅតាមច្បារ តែយេហ៊ូវដេញតាមដោយ
បង្គាប់គេថា ចូរវាយសំឡាប់វានៅលើរទេះតែម្ដងទៅ
ដូច្នេះ គេក៏វាយទ្រង់ត្រង់ផ្លូវឡើងទៅឯគើរជិតក្រុងយីប
លាម[ហ] តែទ្រង់រត់ទៅដល់ក្រុងមេគីដោ[ឡ] ហើយសុគត
នៅទីនោះ [២៨]ពួកអ្នកបំរើទ្រង់ ក៏ដឹកនាំ[អ]សពទៅឯក្រុង
យេរូសាឡិម បញ្ចុះក្នុងផ្នូររបស់ទ្រង់ នៅជាមួយនឹងពួក
ព្វយុកោទ្រង់ក្នុងក្រុងដាវីឌទៅ ។
[២៩]ឯអ័ហាស៊ីយ៉ាបានចាប់តាំងសោយរាជ្យលើស្រុកយូដា
ក្នុងឆ្នាំទី១១[ក]នៃរាជ្យយ៉ូរ៉ាម ជាបុត្រអ័ហាប់ ។

## យេសិបិលត្រូវសម្លាប់

[៣០]កាលយេហ៊ូវបានទៅដល់យេសរាលហើយ នោះ
យេសិបិលក៏ឮ ហើយព្រះនាងក៏ផាត់[ខ]វង្វង់ភ្នែក នឹងតែង
ព្រះកេសា រួចទតមើលតាមបង្អួចមក [៣១]កាលយេហ៊ូវកំពុង
តែចូលតាមទ្វារបង នោះយេសិបិល ស្រែកសួរថា តើមាន
សេចក្ដីសុខឬអី ស៊ីមរី[គ]ជាអ្នកសំឡាប់ចៅហ្វាយ ខ្លួនអើយ
[៣២]នោះលោកក៏ងើបមើលទៅឯបង្អួចសួរថា តើអ្នកណា
កាន់ខាងអញ តើមានអ្នកណាឬទេ ខណនោះមានមនុស្ស
កំរៀវពីរបីនាក់បានអើតមុខមក [៣៣]ដូច្នេះលោកបង្គាប់គេ

**៩:២៥** ល ១ពវ ២១:១៩–២២, ២៤–២៩
**៩:២៦** វ ១ពវ ២១:១៩ ស ១ពវ ១២:២៩
**៩:២៧** ហ ពច ១:២៧ ឡ ២ពវ ២៣:២៩
**៩:២៨** អ ២ពវ ១៤:២០ ២៣:៣០
**៩:២៩** ក ២ពវ ៨:២៥
**៩:៣០** ខ យរ ៤:៣០ អគ ២៣:៤០
**៩:៣១** គ ១ពវ ១៦:៩–១០
**៩:៣៣** ឃ ទដ ៧:៥
**៩:៣៤** ង ១ពវ ១៦:៣១
**៩:៣៦** ច ទដ ៦៨:២៣ យរ ១៥:៣ ឆ ១ពវ ២១:២៣
**៩:៣៧** ជ ទដ ៨៣:១០ អស ៥:២៥ យរ ៨:២ ៩:២២ ១៦:៤ ២៥:៣៣ សផ ១:១៧
**១០:១** ក ១ពវ ១៣:៣២ ខ ពច ៨:៣០ គ ១ពវ ២១:១ ឃ ខ.៥

ថា ចូរបោះវាចុះមក នោះគេក៏បោះទំលាក់យេសិបិលចុះ
មក ហើយឈាមខ្លះក៏ខ្ទាតទៅប្រឡាក់នឹងជញ្ជាំង និងសេះ
រួចលោកឱ្យសេះជាន់ឈ្លី[ឃ] [៣៤]កាលលោកបានចូលទៅ
បរិភោគភោជនាហាររួចហើយ នោះក៏បង្គាប់ថា ចូរទៅ
មើលស្ត្រីដែលត្រូវបណ្ដាសានោះ ហើយកប់វាទៅ ដ្បិតវា
ជាបុត្រស្ដេចដែរ[ង] [៣៥]គេក៏ទៅដើម្បីនឹងកប់សព តែរកបាន
តែរលាក្បាល ប្រអប់ជើង និងបាតដៃប៉ុណ្ណោះ [៣៦]ដូច្នេះ
គេត្រឡប់មកវិញ ជំរាបដល់លោកហើយលោកមាន
ប្រសាសន៍ថា នេះហើយជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែល
ទ្រង់មានបន្ទូល ដោយសារអេលីយ៉ាជាអ្នកស្រុកធេសប៊ី
ជាអ្នកបំរើទ្រង់ថា ឆ្កែ[ច]នឹងទំពាស៊ីសាច់យេសិបិល នៅដំបន់
យេសរាល[ឆ] [៣៧]ហើយសពរបស់យេសិបិលនឹងបានជា
លាមក[ជ]នៅលើដី ក្នុងទីដំបន់នៃស្រុកយេសរាល បានជាមិន
ដែលមានអ្នកណាថា នេះជាសពយេសិបិលនោះឡើយ ។

## ជិនួរវង្សរបស់អ័ហាប់ត្រូវបំផ្លាញ

**១០** [១]ឯអ័ហាប់ទ្រង់មានព្រះរាជបុត្រា៧០អង្គ[ក] នៅក្រុងសា
ម៉ារី[ខ] ហើយយេហ៊ូវក៏ធ្វើសំបុត្រផ្ញើទៅឯពួកអ្នកដែលជា
កំពូល នៅយេសរាល[គ] ក្នុងក្រុងសាម៉ារី គឺជាពួកចាស់ទុំ
និងពួកអ្នកបីបាច់រក្សា[ឃ]អស់ទាំងបុត្រានៃអ័ហាប់ថា [២]ឥឡូវ
នេះ ដែលអ្នករាល់គ្នាមានបុត្រាទាំងប៉ុន្មាន នៃចៅហ្វាយ
របស់អ្នករាល់គ្នានៅជាមួយនោះ ក៏មានរទេះចំបាំង និង
សេះ ហើយទាំងទីក្រុងដែលមានកំផែង និងគ្រឿងសស្ត្រា
វុធផង ដូច្នេះ កាលណាសំបុត្រនេះបានមកដល់អ្នករាល់គ្នា
ហើយ[៣]នោះចូររើសយកអ្នកណាមួយដែលល្អ ហើយសំណំ
ជាងគេក្នុងពួកបុត្រានៃចៅហ្វាយរបស់អ្នករាល់គ្នា តាំង

**៩:២៦** *តាមព្រះបន្ទូលនៃព្រះយេហូវ៉ា* នៅត្រង់នេះ យេហ៊ូវបានមើលឃើញពីកាលដែលខ្លួនកំពុងតែធ្វើឱ្យសម្រេចតាមបទទំនាយរបស់ហោរាអេលីយ៉ាដែលបានថ្លែងកាលពីឆ្នាំកន្លងទៅនោះ (មើល ១ពវ ២១:១៨–២៤) ។ ទោះបី ឈាមរបស់ស្ដេចអ័ហាប់ មិនបានខ្ចាយនៅក្នុងចំការរបស់ណាបោត (មើល ១ពវ ២១:៩ និងការពន្យល់) ។ ប៉ុន្តែ យេហ៊ូវបានមើលឃើញពីការស្លាប់របស់ស្ដេចយេរ៉ូបោម ដែលសម្រេចតាមបទទំនាយរបស់ហោរាអេលីសេ (មើលការពន្យល់ ១ពវ ២១:១៩) ។

**៩:២៧** *ទ្រង់រត់ទៅដល់ក្រុងមេគីដោ ហើយសុគតនៅទីនោះ* ត្រង់នេះនៅតែជាសំណួរមួយថា តើយេហ៊ូវបានដេញតាមប្រកៀកស្ដេចអ័ហាស៊ីយ៉ាដល់ដំណាក់អ័ហាប់(ហស ១:៤) ឬ ពួកកូនចៅស្ដេចដាវីឌដោយកាត់តាមបុត្រីរបស់ស្ដេចអ័ហាប់ គឺនាងអ័ថាលា (មើល ៨:១៨,២៦) ។

**៩:៣១** *ស៊ីមរីជាអ្នកសំឡាប់ចៅហ្វាយខ្លួន* ឃ្លានេះយេសិបិលបានចំអកឡកឡើយដល់យេហ៊ូវដោយហៅឈ្មោះគាត់ថា ស៊ីមរី ។ អស់រយៈពេលប្រហែលជា ៤៥ឆ្នាំ ស៊ីមរីបានធ្វើការបះបោរផ្ដួលរំលំរាជបល្ល័ង្កពីស្ដេចអេឡាដោយធ្វើគត់ទ្រង់ចោល និងប្រហារពួកជិនួរវង្សប្អាសា ។ ទោះជាយ៉ាងណាក៏ដោយ ស៊ីមរីឡើងគ្រងរាជ្យបានតែប្រាំពីរថ្ងៃគត់ (មើល ១ពវ ១៦:៨–២០) ប៉ុណ្ណោះ ។

**៩:៣៦** *ព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលទ្រង់មានបន្ទូល ដោសាអេលីយ៉ា* ការស្លាប់របស់យេសិបិលព្រះបន្ទូលព្រះបានបញ្ជាក់យ៉ាងច្បាស់ គឺមានបន្ទូលនេះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងខណៈដែលព្រះនាងកំពុងមានព្រះជន្ម (សូមមើល ១ពវ ២១:២៣) ។

**១០:១** *បុត្រា៧០អង្គ* ចំនួននេះរួមបញ្ចូលទាំងបុត្រា និង ចៅ ។ *ក្រុងសាម៉ារី* នៅត្រង់នេះ យេហ៊ូវមានសេចក្ដីភ័យបារម្ភចំពោះការធ្វើរដ្ឋប្រហាររបស់គាត់ ក្នុងការវាយយកអាណាចក្រភាគខាងជើង(មើលការពន្យល់ ១ពវ ១៦:២៤) និងក្រោយបន្តិចទៀតមកបានបំផ្លាញជិនួរវង្សអ័ហាប់ ។ *ពួកចាស់ទុំ* នេះសំដៅដល់ពួកអ្នកដឹកនាំប្រចាំតំបន់នីមួយៗ (មើលការពន្យល់ នក ៣:១៦ ២សយ ៣:១៧) ។

**១០:៣** *តស៊ូការពារដំណាក់នៃចៅហ្វាយអ្នករាល់គ្នាទៅ* នៅត្រង់នេះហេហ៊ូវ

ឡើងឱ្យសោយរាជ្យជំនួសបិតាចុះ រួចឱ្យតស៊ូការពារ
ដំណាក់នៃចៅហ្វាយអ្នករាល់គ្នាទៅ ៤តែអ្នកទាំងនោះមាន
សេចក្តីភ័យខ្លាចជាខ្លាំង ក៏និយាយថា មើល ស្តេច២អង្គ
នោះពុំអាចនឹងឈរ នៅមុខលោកបានទៅហើយ ចំណង់
បើយើងធ្វើ ដូចម្តេចឱ្យយើងឈរនៅបាន ៥ដូច្នេះ ឧកញ៉ា
វាំង និងចៅហ្វាយទីក្រុង ព្រមទាំងពួកចាស់ទុំ និងពួកអ្នក
ដែលបានបីបាច់រក្សាពួកបុត្រា ក៏ចាត់គេឱ្យទៅជិរាប
យេហ៊ូវថា យើងខ្ញុំរាល់គ្នា ជាអ្នកបំរើ[ង]របស់លោក និងធ្វើ
តាមតែលោកបង្គាប់គ្រប់ជំពូក យើងខ្ញុំមិនព្រមតាំងអ្នក
ណាឱ្យធ្វើជាស្តេចទេ សូមលោកធ្វើតាមតែសេចក្តីដែល
លោកគិតឃើញថាល្អចុះ ៦រួចលោកក៏ធ្វើសំបុត្រទី២ផ្ញើទៅ
គេថា បើអ្នករាល់គ្នាកាន់ខាងខ្ញុំ ហើយចង់ស្តាប់តាម
បង្គាប់ខ្ញុំមែន នោះចូរកាត់ក្បាលពួកបុត្រានៃចៅហ្វាយ
របស់អ្នករាល់គ្នាចុះ រួចដល់ថ្ងៃស្អែកពេលថ្មើរណេះ ត្រូវ
ឱ្យអ្នករាល់គ្នា ទៅឯខ្ញុំនៅត្រង់យេសរាល រីឯពួកបុត្រានៃ
ស្តេចទាំង៧០អង្គ នោះសុទ្ធតែនៅជាមួយនឹងពួកអ្នកធំ
ក្នុងទីក្រុងដែលបានបីបាច់រក្សា ៧ដូច្នេះ កាលសំបុត្រនោះ
បានទៅដល់ហើយ គេក៏ចាប់ពួកបុត្រាស្តេចទាំង៧០[ច]អង្គ
សំឡាប់ទៅ ដាក់ព្រះសិរ[ឆ]គ្រប់អង្គទៅក្នុងកញ្ជេផ្ញើទៅឯ
លោក នៅត្រង់យេសរាល ៨នោះមានម្នាក់នាំដំណឹងមក
ជិរាបលោកថា គេយកព្រះសិរនៃពួកបុត្រាស្តេចមកហើយ

**១០:៥** ង យស ៩:៨
**១០:៧** ច ១ពវ ២១:២១ ឆ ២សយ ៤:៨
**១០:១០** ជ ២ពវ ៩:៧–១០ ឈ ១ពវ ២១:២៩
**១០:១១** ញ ហស ១:៤ ដ ខ.១៤ យប ១៨:១៩ មឡ ៤:១
**១០:១៣** ឋ ២ពវ ៨:២៤,២៩ ២បរ ២២:៨ ឌ ១ពវ ២:១៩

លោកបង្គាប់ថា ចូរដាក់ជា២គំនរ នៅត្រង់មាត់ទ្វារកំផែង
រហូតដល់ព្រឹកទៅ ៩លុះដល់ព្រឹកឡើងលោកក៏ចេញទៅ
ឈរ មានប្រសាសន៍នឹងបណ្តាជនទាំងឡាយថា អ្នករាល់គ្នា
សុចរិតទេ មើល គឺខ្ញុំហើយដែលបានបះបោរនឹងចៅហ្វាយ
របស់ខ្ញុំ ព្រមទាំងសំឡាប់ផង តែអ្នកណាបានសំឡាប់អ្នក
ទាំងនេះ ១០ដូច្នេះ សូមឱ្យដឹងថា ក្នុងព្រះបន្ទូលនៃព្រះ
យេហូវ៉ា ដែលបានទាយទាស់នឹងជំនួរវង្សអ័ហាប់ នោះនឹង
គ្មានណា១ធ្លាក់ដល់ដីឡើយ ដ្បិតព្រះយេហូវ៉ាទ្រង់បានធ្វើ
តាមសេចក្តី ដែលទ្រង់បានមានបន្ទូល[ជ] ដោយសារ
អេលីយ៉ា ជាអ្នកបំរើទ្រង់ហើយ[ឈ] ១១ដូច្នេះ យេហ៊ូវ[ញ]បាន
ប្រហារជីវិតនៃអស់អ្នកណាដែលសល់នៅ ក្នុងជំនួរវង្ស
របស់អ័ហាប់ នៅត្រង់យេសរាល ព្រមទាំងពួកអ្នកធំ និង
ពួកមិត្រសំឡាញ់ស្និទ្ធស្នាល ហើយពួកសង្ឃរបស់ទ្រង់ផង
ឥតទុកឱ្យមានអ្នកណា មួយសល់នៅខាងទ្រង់ឡើយ[ដ]។
១២ក្រោយមក យេហ៊ូវក៏ក្រោកឡើងចេញទៅឯក្រុង
សាម៉ារី កាលបានទៅដល់សាលា ដែលនៅតាមផ្លូវនោះ
ជាទីដែលពួកគង្វាលចៀមធ្លាប់ប្រជុំគ្នា ១៣នោះក៏ប្រទះនឹង
ពួកបងប្អូនរបស់អ័ហាស៊ីយ៉ា[ឋ] ជាស្តេចយូដា ហើយលោក
សួរថា អ្នករាល់គ្នាតើជាអ្នកណា គេឆ្លើយតបថា យើងរាល់
គ្នាជាបងប្អូននៃអ័ហាស៊ីយ៉ា យើងចុះទៅជិរាបសួរដល់ពួក
បុត្រនៃក្សត្រាក្សត្រី[ឌ]។

---

បានប្រើយុទ្ធសាស្ត្ររបស់ខ្លួន ក្នុងការដឹកនាំពួកអ្នកដឹកនាំនៅស្រុកសាម៉ារីឱ្យចុះចូលខ្លួន ដោយការគម្រាមកំហែងផ្នែកយោធា ។

**១០:៤** *សេចក្តីភ័យខ្លាច* នៅត្រង់នេះ ពួកអ្នកដឹកនាំនៅស្រុកសាម៉ារីកំពុងតែត្រូវបានយេហ៊ូវបំភ័យទាំងអស់គ្នា ។ *ស្តេច២អង្គ* គឺស្តេចយ៉ូរ៉ាម និងអ័ហាស៊ីយ៉ា (មើល ៩:២៤,២៧) ។

**១០:៥** *ឧកញ៉ាវាំង* មើលការពន្យល់ ១ពវ ៤:៦ ។ *ចៅហ្វាយទីក្រុង* នេះជាមន្ត្រីដែលបានតែងតាំងដោយស្តេច ឱ្យធ្វើជាមេនៃពួកឈ្លបទីក្រុង ។ *ពួកចាស់ទុំ និង ពួកអ្នកដែលបានបីបាច់រក្សា* សូមមើល ខ.១ ។

**១០:៦** *ចូរ កាត់ក្បាលពួកបុត្រានៃចៅហ្វាយរបស់អ្នករាល់គ្នាចុះ* សេចក្តីបង្គាប់នេះ យេហ៊ូវមិនបានបញ្ជាក់ច្បាស់នោះទេ ។ "ក្បាលពួកបុត្រានៃចៅហ្វាយរបស់អ្នករាល់គ្នា" គឺសំដៅដល់ពួកកូនចៅអ័ហាប់ ដែលពួកគេម្នាក់ៗសុទ្ធតែនៅជាមួយនឹងពួកអ្នកធំ ។ ម្យ៉ាងវិញទៀត ការលើកឡើងនេះ ប្រាកដជាសំដៅលើពួកទាំង ៧០នាក់នេះ ។

**១០:៧** *ទាំង៧០អង្គសំឡាប់ទៅ* ពួកអ្នកដឹកនាំនៃក្រុងនេះ បានធ្វើការរាយការណ៍បំផ្លើសការពិត ថាពួកគេបានកាត់ក្បាលពួកស្តេចទាំងនោះថ្វាយយេហ៊ូវរួចហើយ ។ *ព្រះសិរគ្រប់អង្គទៅក្នុងកញ្ជេរ ផ្ញើទៅឯលោក* ពួកអ្នកដឹកនាំនៅស្រុកសាម៉ារី មិនបានកាត់ក្បាលពួកស្តេចទាំងនោះផ្ញើទៅយេសរាលដូចដែលយេហ៊ូវបានបង្គាប់មកនោះទេ (មើល ខ.៦) ។ ពួកអ្នកដឹកនាំទាំងនេះ មើលទៅហាក់បីដូចជាមានការព្រួយបារម្ភក្នុងការរស់នៅក្នុង ជីវិតរបស់ពួកគេម្នាក់ៗ ។

**១០:៨** *ចូរ ដាក់ជាពីរគំនរ នៅត្រង់មាត់ទ្វារ* មធ្យោបាយដ៏កខ្វក់នេះ គឺអនុវត្តតាមស្តេចពួកស៊ីរី ដែលពួកគេបានអនុវត្តនូវវិធីនេះ ក្នុងរជ្ជកាលដែលពួកគេគ្រងរាជ្យ ។

**១០:៩** *គឺខ្ញុំហើយដែល . . . សំឡាប់អ្នកទាំងនេះ* ឃ្លានេះបានប្រាប់ពីការសារភាពរបស់យេហ៊ូវដែលបានផ្តួលរំលំរាជ្យវង្សរបស់យ៉ូរ៉ាម ។

**១០:១០** *ទ្រង់បានមានបន្ទូល ដោយសាអេលីយ៉ា ជាអ្នកបំរើទ្រង់* សូមមើល ២១:២០–២៤,២៩ ។ នៅត្រង់នេះ យេហ៊ូវមិនគ្រាន់តែបញ្ជាក់ពីការកាត់ទោសដែលព្រះអម្ចាស់បានធ្វើកន្លងមកនោះទេ តែថែមទាំងបំបាត់ពួកវង្សអ័ហាប់ និងគ្នីគ្នាផ្សេងទៀត ។

**១០:១១** *ពួកអ្នកធំ និង ពួកមិត្រសំឡាញ់ ស្និទ្ធស្នាលហើយពួកសង្ឃរបស់ទ្រង់ផង* ចំណុចនេះបញ្ជាក់ថា យេហ៊ូវមិនបាទទួលខុសត្រូវចំពោះអ្វីដែលព្រះយេហូវ៉ាបានបង្គាប់មកនោះទេ (សូមមើល ៩:៧ ហស ១:៤) និងការបម្រើឱ្យនយោបាយខ្លួនឯង ។ យេហ៊ូវខ្លួនគាត់ផ្ទាល់ ធ្វើអ្វីៗគ្រប់យ៉ាងបម្រើឱ្យស្តេចអ័ហាប់ (មើល ៩:២៥) ។

**១០:១៣** *ពួកបងប្អូនរបស់អ័ស៊ីយ៉ា* សូមមើល ២របា ២១:១៧ ។ *ពួកបុត្រនៃក្សត្រាក្សត្រី* នៅត្រង់ចំណុចនេះសំដៅដល់ក្រុមរាជ្យវង្ស របស់ពួកសាសន៍យូដា ដែលមិនទាន់បានឮពីការសុគតរបស់ស្តេចយ៉ូរ៉ាម និងយេសិបិលនៅឡើយ ។

១៤នោះលោកបង្គាប់ថា ចូរចាប់គេទាំងរស់ទៅ ពួក
លោកក៏ចាប់ អ្នកទាំងនោះទាំងរស់ នាំទៅសំឡាប់ទាំង៤២
នាក់ នៅត្រង់អណ្តូងរបស់សាលានោះ ឥតទុកឱ្យសល់ដល់
ម្នាក់ឡើយ[ឍ] ។
១៥កាលយេហ៊ូវបានចេញពីទីនោះទៅ នោះក៏ប្រទះនឹង
យ៉ូណាដាប[ណ]ជាកូនរេកាប[ត] ដែលដើរមកពីខាងមុខលោក
ក៏គំនាប់គាត់សួរថា តើចិត្តអ្នកស្មោះត្រង់ ដូចជាខ្ញុំដែល
ស្មោះត្រង់ពិត លោកក៏ថា បើដូច្នេះ ចូរហុចដៃមក[ថ]អ្នកនោះ
ក៏ហុចដៃទៅ ហើយលោកចាប់ទទួលឱ្យឡើងជិះលើរថជា
មួយគ្នា ១៦រួចលោកប្រាប់ថា សូមអ្នកទៅជាមួយនឹងខ្ញុំចុះ
ដើម្បី មើលសេចក្តីឧស្សាហ៍[ទ]របស់ខ្ញុំចំពោះព្រះយេហូវ៉ា
ដូច្នេះ គេក៏ឱ្យគាត់ឡើងជិះក្នុងរថរបស់យេហ៊ូវ ១៧កាល
បានដល់ក្រុងសាម៉ារីហើយ នោះលោកក៏វាយសំឡាប់
អស់អ្នក ដែលសល់នៅក្នុងជិនួរវង្សអ័ហាប់[ធ] ក្នុងក្រុង
សាម៉ារី ដរាបដល់បានបំផ្លាញជិនួរវង្សនៃទ្រង់អស់រលីង
ទៅ តាមព្រះបន្ទូលដែលព្រះយេហូវ៉ាបានមានបន្ទូលនឹង
អេលីយ៉ា ។

## ពួកសង្ឃរបស់ព្រះបាលត្រូវសម្លាប់

១៨នៅគ្រានោះ យេហ៊ូវក៏ប្រមូលពួកបណ្តាជនទាំងអស់
មកប្រាប់ថា អ័ហាប់បានគោរព[ន]ដល់ព្រះបាលតែបន្តិចទេ
តែយេហ៊ូវនឹងគោរពដល់ ទ្រង់ជាច្រើនវិញ ១៩ដូច្នេះ ចូរ
ហៅ[ប]ពួកហោរារបស់ព្រះបាលទាំងអស់ មកឯយើងឥឡូវ
ព្រមទាំងពួកអ្នកដែលថ្វាយបង្គំដល់ទ្រង់ និងអស់ពួកសង្ឃ
របស់ទ្រង់ផង កុំឱ្យមានខ្វះអ្នកណាមួយឡើយ ដ្បិតយើងត្រូវ
ថ្វាយយញ្ញបូជាយ៉ាងធំដល់ព្រះបាល បើអ្នកណាខានមក
នោះនឹងត្រូវស្លាប់ តែយេហ៊ូវលោកប្រព្រឹត្តដោយឧបាយទេ
ប្រយោជន៍ដើម្បីនឹងបំផ្លាញពួកអ្នក ដែលថ្វាយបង្គំដល់ព្រះ
បាលទាំងអស់ចេញ ២០យេហ៊ូវបង្គាប់ឱ្យគេញែកថ្ងៃ១[ផ]ទុក
ជាថ្ងៃបុណ្យមុតមាំថ្វាយព្រះបាល គេក៏ប្រកាសប្រាប់ទួទៅ
២១យេហ៊ូវចាត់គេឱ្យទៅគ្រប់ក្នុងស្រុកអ៊ីស្រាអែល ដូច្នេះ
ពួកអ្នកដែលថ្វាយបង្គំព្រះបាលក៏មកទាំងអស់គ្នា ឥតមាន

**១០:១៤** ឍ ឧ.១១
**១០:១៥** ណ យរ ៣៥:៦,១៤–១៩
ត ១រប ២:៥៥ យរ ៣៥:២ ថ អរ ១០:១៩ អគ ១៧:១៨
**១០:១៦** ទ ជន ២៥:១៣
**១០:១៧** ធ ២ពវ ៩:៨
**១០:១៨** ន ពច ២:១១
**១០:១៩** ប ១ពវ ១៨:១៩
**១០:២០** ផ នក ៣២:៥
**១០:២៤** ព យស ២:១៤
**១០:២៥** ភ នក ២២:២០ ២ពវ ១១:១៨ ម ១ពវ ១៨:៤០
**១០:២៦** យ នក ២៣:២៤
**១០:២៧** រ ១ពវ ១៦:៣២
**១០:២៨** ល ១ពវ ១៩:១៧
**១០:២៩** វ ១ពវ ១២:៣០ ស នក ៣២:៤ ហ ១ពវ ១២:៣២

សល់ដល់ម្នាក់ឡើយ គេចូលទៅក្នុងវិហារនៃព្រះបាល
ទាល់តែវិហារនោះ បានពេញណែនតាំងតែពីចុងម្ខាង
រហូតដល់ចុងម្ខាង ២២នោះលោកបង្គាប់ដល់អ្នករក្សាអាវ
ដែលសំរាប់ពាក់ថ្វាយបង្គំថា ចូរយកអាវមកចែកឱ្យពួក
អ្នកដែលថ្វាយបង្គំដល់ព្រះបាលទាំងអស់គ្នាទៅ អ្នកនោះក៏
ចែកឱ្យគ្រប់គ្នា ២៣រួចយេហ៊ូវនឹងយ៉ូណាដាប ជាកូនរេកាប
ក៏ចូលទៅក្នុងវិហារព្រះបាលប្រាប់ដល់ពួកអ្នកដែលថ្វាយ
បង្គំថា ចូររកមើល កុំឱ្យមានអ្នកណាដែលថ្វាយបង្គំដល់
ព្រះយេហូវ៉ា នៅជាមួយនៅទីនេះឡើយ ឱ្យមានសុទ្ធតែពួក
ថ្វាយបង្គំព្រះបាលប៉ុណ្ណោះ ២៤កាលយេហ៊ូវបានចូរទៅ
ដើម្បីនឹងថ្វាយយញ្ញបូជានឹងដង្វាយដុត នោះលោកបានដំរូវ
ឱ្យមនុស្ស៨០នាក់នៅជាខាងក្រៅ ដោយបង្គាប់ថា បើអ្នក
ណាក្នុងពួកអ្នកដែលខ្ញុំប្រគល់មកក្នុងកណ្តាប់ដៃអ្នករាល់គ្នា
បានរត់រួច នោះអ្នកដែលឱ្យគេរួចទៅ និងត្រូវស្លាប់ជំនួស
អ្នកនោះវិញ[ព] ។
២៥កាលលោកបានថ្វាយដង្វាយដុតរួចហើយ នោះក៏
បង្គាប់ដល់ពួកចាំយាម នឹងពួកមេទ័ពថា ចូរឱ្យចូលទៅ
សំឡាប់[ភ]គេចុះ កុំឱ្យអ្នកណា មួយចេញរួចឡើយ[ម] ដូច្នេះ
គេក៏ប្រហារជីវិតអ្នកទាំងនោះដោយមុខដាវ ឯពួកចាំយាម
នឹងពួកមេទ័ព ក៏បោះខ្មោចចេញទៅក្រៅ រួចគេទៅក្នុង
ទីក្រុងនៃវិហារព្រះបាលនោះ ២៦ក៏យកអស់ទាំងរូបព្រះ
ចេញ[យ]ពីវិហារព្រះបាលមកដុតចោល ២៧ហើយវាយបំបាក់
រូបព្រះព្រមទាំងបំផ្លាញវិហារ[រ]ព្រះបាល ធ្វើឱ្យទៅជា
កន្លែងបន្ទោលាមក ដរាបដល់សព្វថ្ងៃនេះ ២៨គឺយ៉ាងនោះ
ដែលយេហ៊ូវ[ល]បានបំបាត់ព្រះបាលពីពួកអ៊ីស្រាអែលចេ ។
២៩ប៉ុន្តែត្រង់ឯអំពើបាប[វ]របស់យេរ៉ូបោមជាកូននេបាត
ដែលបាននាំ ឱ្យពួកអ៊ីស្រាអែលធ្វើបាបតាមនោះដែរ គឺជា
កូនគោមាស[ស]នៅក្រុងបេត–អែល[ហ] និងនៅក្រុងដាន់ នោះ
យេហ៊ូវមិនបានលែងប្រព្រឹត្តតាមទេ ៣០រួចព្រះយេហូវ៉ា
ទ្រង់មានបន្ទូលមកយេហ៊ូវថា ដោយព្រោះឯងបាន ប្រព្រឹត្ត
ល្អដោយសំរេចសេចក្តីដែលត្រឹមត្រូវនៅភ្នែកអញ ហើយ

ពួកអ្នកដើរតាមគាត់ បានអនុវត្តនូវគោលការណ៍នេះអស់រយៈកាលជាង ២០០រយឆ្នាំ (មើល យរ ៣៥:៦–១០) ។

**១០:១៦** *គាត់ឡើងជិះក្នុងរថរបស់យេហ៊ូវ* ការធ្វើយ៉ាងដូច្នេះ បានធ្វើឱ្យយេហ៊ូវទទួលបាននូវការគាំទ្រពីសំណាក់អាណាប្រជារាស្ត្រ ថាទ្រង់ជាអ្នកដែលដើរតាមឱវាទរបស់ព្រះយេហូវ៉ា ។

**១០:១៨** *អ័ហាប់បានគោរពដល់ព្រះបាលតែបន្តិចទេ តែយេហ៊ូវនឹងគោរពដល់ទ្រង់ជាច្រើនវិញ* ឃ្លានេះបានប្រាប់ថា ក្រោយពីទ្រង់បានដោះស្រាយបញ្ហានៅស្រុកសាម៉ារី នោះយេហ៊ូវបានបង្ហាញឱ្យឃើញពីការបើកសំដែងពីព្រះបន្ទូលរបស់ព្រះយេហូវ៉ា ក្នុងន័យជាកលល្បិចនយោបាយ ។

**១០:២៦** *ដុតចោល* មើលការពន្យល់ ១ពវ ១៤:១៥ ១៦ ១៦:៣២–៣៣ ។

**១០:២៧** *វិហារព្រះបាល* មើលការពន្យល់ ១ពវ ១៤:២៣ ។

**១០:២៩** *អំពើបាបរបស់យេរ៉ូបោម . . . ប្រព្រឹត្តិតាម* សូមមើល ១ពវ ១២:២៦–៣២ ១៣:៣៣–៣៤ ១៤:១៦ ។

**១០:៣០** *ដោយព្រោះឯងបានប្រព្រឹត្ត . . . ជិនួរវង្សរបស់អ័ហាប់ តាមគ្រប់ទាំងគំនិតដែលគិតនៅក្នុងចិត្ត* ត្រង់នេះបញ្ជាក់ថា យេហ៊ូវជាឧបរណ៍របស់ព្រះយេហូវ៉ា ដើម្បីនាំពួកជិនួរវង្សរបស់ស្តេចអ័ហាប់មកកាត់ទោស ។ ប៉ុន្តែ

បានធ្វើដល់ជិន្នូរវង្សរបស់អ័ហាប់ តាមគ្រប់ទាំងគំនិត
ដែលនៅក្នុងចិត្តអញ នោះពួកកូនចៅឯងនឹងបានសោយ
រាជ្យលើសាសន៍អ៊ីស្រាអែលរហូតដល់អស់៤ដំណ[ឡ] ៣១តែ
យេហ៊ូវមិនបានប្រុងប្រយ័ត្ន[អ] នឹងដើរតាមក្រិត្យវិន័យរបស់
ព្រះយេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រាអែល ឱ្យអស់ពីចិត្ត
ទេគឺលោកមិនបានលែងប្រព្រឹត្ត តាមអំពើបាប[ក]របស់
យេរ៉ូបោម ដែលបាននាំឱ្យពួកអ៊ីស្រាអែល ធ្វើបាបតាម
នោះទេ ។
៣៣នៅគ្រានោះ ព្រះយេហូវ៉ាទ្រង់ចាប់តាំងកាត់ដែន[ខ]
ស្រុកចេញពីនគរអ៊ីស្រាអែល គឺហាសែល[គ]ទ្រង់មកវាយ
សាសន៍អ៊ីស្រាអែល នៅអស់ទាំងព្រំដែនស្រុករបស់គេ
៣៣ចាប់តាំងពីទន្លេយ័រដាន់ទៅខាងកើត គឺស្រុកកាឡាត
ទាំងអស់ ជាស្រុករបស់ពួកកាឌ់ ពួករូបេន និងពួកម៉ា
ន៉ាសេ ចាប់តាំងពីក្រុងអារ៉ូមអើរ[ឃ] ដែលនៅមាត់ស្ទឹង
អើណូន[ង] ជាស្រុកកាឡាត និងស្រុកបាសានទាំងមូល ៣៤រីឯ
ដំណើរឯទៀតពីយេហ៊ូវ និងការទាំងប៉ុន្មានដែលលោកធ្វើ
ហើយពីអំណាចរបស់លោកទាំងអស់ នោះសុទ្ធតែបានកត់
ទុកក្នុងសៀវភៅ ជាពង្សាវតារ[ច]របស់ពួកស្តេចអ៊ីស្រាអែល
ហើយ ៣៥យេហ៊ូវក៏ដេកលក់ទៅជាមួយនឹងពួកឰយុកោ
ហើយគេបញ្ចុះលោកនៅក្រុងសាម៉ារី រួចយ៉ូអាហាស ជា
បុត្រា ក៏សោយរាជ្យឡើងជំនួសលោក ៣៦យេហ៊ូវបាន
សោយរាជ្យលើស្រុកអ៊ីស្រាអែល នៅក្នុងក្រុងសាម៉ារីអស់
២៨ឆ្នាំ ។

## អ័ថាលានិងយ៉ូអាស

*១១:១–២១ – ២រប ២២:១០–២៣:២១*

**១១**១រីឯអ័ថាលា[ក] ព្រះមាតានៃអ័ហាស៊ីយ៉ា កាលបាន
ឃើញថា ព្រះរាជបុត្រាសុគតហើយដូច្នោះ នោះព្រះនាង
ក៏ចាត់ចែងបំផ្លាញជិន្នូរវង្ស នៃស្តេចទាំងប៉ុន្មានទៅ ២តែ
យ៉ូសេបា ជាបុត្រីស្តេចយ៉ូរ៉ាម ហើយជាកនិដ្ឋារបស់អ័ហា–
ស៊ីយ៉ា នាងបានលួចយកយ៉ូអាស[ខ] ជាបុត្រារបស់អ័ហា–
ស៊ីយ៉ា ចេញពីពួកបុត្រារបស់ស្តេច ដែលត្រូវស្លាប់នោះ
ព្រមទាំងមេនំផង ទៅលាក់ទុកក្នុងបន្ទប់ដេក ឱ្យរួចពី
អ័ថាលា មិនឱ្យត្រូវស្លាប់[គ] ៣បុត្រនោះក៏នៅជាមួយនឹងនាង
លាក់ទុកក្នុងព្រះវិហារនៃព្រះយេហូវ៉ាអស់៦ឆ្នាំ ឯព្រះនាង
អ័ថាលា បានសោយរាជ្យលើនគរ ។
៤លុះដល់ឆ្នាំទី៧ នោះយេហូយ៉ាដាក៏ដាក់គេឱ្យទៅនាំ
ពួកមេទ័ព ពួកនាយ[ឃ] និងពួកថ្មើរជើង មកឯលោកនៅក្នុង
ព្រះវិហារនៃព្រះយេហូវ៉ា លោកក៏តាំងសញ្ញានឹងគេ ហើយ

**១០:៣០** ឡ ២ពវ ១៥:១២ **១០:២៦** យ នក ២៣:២៤ **១០:២៧** រ ១ពវ ១៦:៣២ **១០:២៨** ល ១ពវ ១៩:១៧ **១០:២៩** វ ១ពវ ១២:៣០ ស នក ៣២:៤ ហ ១ពវ ១២:៣២ **១០:៣០** ឡ ២ពវ ១៥:១២ **១០:៣១** អ ចទ ៤:៩ សភ ៤:២៣ ក ១ពវ ១២:៣០ **១០:៣២** ខ ២ពវ ១៣:២៥ ទដ ១០៧:៣៩ គ ១ពវ ១៩:១៧ **១០:៣៣** ឃ ជន ៣២:៣៤ ចទ ២:៣៦ ពច ១១:២៦ អស ១៧:២ ង ជន ២១:១៣

**១០:៣៤** ច ១ពវ ១៥:៣១ **១១:១** ក ២ពវ ៨:១៨ **១១:២** ខ ២ពវ ១២:១ គ ពច ៩:៥ **១១:៤** ឃ ខ.១៩

ក្រោយមកទៀត យេហ៊ូវត្រូវបានកាត់ទោសដោយហោរាហូសេសម្រាប់កាលដែលគាត់បានសម្លាប់ជិន្នូរវង្សស្តេចអ័ហាប់ (ហស ១:៤) ។ *៤តំណ* នេះបញ្ជាក់ថា ជាព្រះពររបស់ព្រះយេហូវ៉ាដែលពួកកូនចៅរបស់យេហ៊ូវបានគ្រប់គ្រងលើរាស្ត្រអ៊ីស្រាអែលមានចំនួន៤តំណតរៀងមកទៀត (មើលការពន្យល់ ១៥:១២) ។

**១០:៣១** *មិនបានប្រុងប្រយ័ត្ន . . . ឱ្យអស់ពីចិត្តទេ* ឃ្លានេះមើលទៅហាក់បីដូចយេហ៊ូវធ្វើអ្វីៗដើម្បីបម្រើផលប្រយោជន៍ខាងនយោបាយផ្ទាល់ខ្លួនដើម្បីឱ្យជៀសផុតពីការដួលចុះពីរាជ្យបល្ល័ង្ក ជាជាងការធ្វើតាមសេចក្តីបង្គាប់របស់ព្រះយេហូវ៉ា ។ នៅក្នុងករណីនេះ យេហ៊ូវមានសេចក្តីអៀនខ្មាសក្នុងការដែលយកការកាត់ទោសរបស់ព្រះមកដាក់លើជិន្នូរវង្សស្តេចអ័ហាប់ដើម្បីបម្រើឱ្យផលប្រយោជន៍ខ្លួនឯង ។

**១០:៣២** *ព្រះយេហូវ៉ាទ្រង់ចាប់តាំងកាត់ដែនស្រុកចេញពីនគរអ៊ីស្រាអែល* នៅត្រង់នេះបញ្ជាក់ពីសេចក្តីក្រោធរបស់ព្រះយេហូវ៉ាបានឡើងដល់កំពូល ហើយបានប្រទាននូវស្តេចក្តីសញ្ញាបណ្តាសា ដូចមានរៀបរាប់នៅក្នុង លវ ២៦ និង ចទ ២៨ ដែលជាការបណ្តេញពួកអ៊ីស្រាអែលចេញពីទឹកដីកាណាន ។ នៅក្នុងអំឡុងពេលនៃការដឹកនាំរបស់ស្តេចយេហ៊ូវ បានធ្វើឱ្យកើតមានការចាប់ផ្តើមនៃបណ្តាសានេះទៀត (មើល ១៧:៧–១៨) ។

**១០:៣៤** *ពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែល* សូមមើលការពន្យល់ ១ពវ ១៤:១៩ ។

**១០:៣៥** *ដេកលក់ទៅជាមួយនឹងពួកឰយុកោលោក* មើលការពន្យល់ ១ពវ ១:២១ ។ *យ៉ូអាហាស ជាបុត្រា ក៏សោយរាជ្យឡើងជំនួសលោក* សម្រាប់រាជ្យយ៉ូអាហាស សូមមើល ១៣:១–៩ ។

**១០:៣៦** *២៨ឆ្នាំ* នេះស្ថិតនៅឆ្នាំ ៨៤១–៨១៤ មុន គ.ស ។

**១១:១** *អ័ថាលា* មើលការពន្យល់ ៨:១៨ ។ *ព្រះរាជបុត្រាសុគត* មើលការពន្យល់ ៩:២៧ ។ *បំផ្លាញជិន្នូរវង្សនៃស្តេចទាំងប៉ុន្មាន* ការធ្វើបែបនេះគឺក្នុងគោលបំណងឱ្យបានរួចផុតពីការគ្រោះថ្នាក់រាជបល្ល័ង្ករបស់ព្រះនាង ។ នៅអំឡុងពេលនោះ ជិន្នូរវង្សនៃពួកយូដាត្រូវបានបង្ក្រាបឱ្យដួលចុះ ក្នុងករណីដែលពួកគេនៅមានជីវិត ។ ស្តេចយ៉ូរ៉ាម ជាស្វាមីចុងក្រោយរបស់ព្រះនាងអ័ថាលា ហើយជាបិតានាងអ័ហាស៊ីយ៉ា ព្រះអង្គបានធ្វើគតដល់ពួកប្អូនៗរបស់ទ្រង់ទាំងអស់ចោល ក្រោយពីព្រះអង្គឡើងគ្រងរាជ្យជំនួសព្រះបិតារបស់ព្រះអង្គដែលមាននាមថា យេហូសាផាត(សូមមើល ២រប ២១:៤) ។

**១១:២** *បុត្រីស្តេចយ៉ូរ៉ាម ហើយជាកនិដ្ឋារបស់អ័ហាស៊ីយ៉ា* នេះបញ្ជាក់ថា យ៉ូសេបា ជាបុត្រីរបស់ស្តេចយ៉ូរ៉ាមជាមួយមហាសីដទៃទៀត គឺមិនមែនជាមួយព្រះនាងអ័ថាលាទេ ដូច្នេះព្រះនាងយ៉ូសេបានេះ ជាបងប្អូនពាក់កណ្តាលរបស់អ័ហាស៊ីយ៉ា ។ យ៉ូសេបា បានរៀបអភិសេកជាមួយនឹងយេហូយ៉ាដាដែលជាសម្តេចសង្ឃ(សូមមើល ២រប ២២:១១) ។ *បុត្រារបស់អ័ហាស៊ីយ៉ា ចេញពីពួកបុត្រារបស់ស្តេច ដែលត្រូវស្លាប់នោះ ព្រមទាំងមេនំផង* នៅត្រង់នេះបញ្ជាក់ថា បុត្រតូចនេះមានព្រះជន្មមិនលើសពីមួយវស្សា គឺមិនទាន់ផ្តាច់ដោះនៅឡើយ(សូមមើល ខ.៣,២១) ។

**១១:៤** *ឆ្នាំទី៧* នេះជាឆ្នាំនៃការគ្រប់គ្រងរបស់អ័ថាលា ។ *ពួកមេទ័ពពួកនាយ*

ឱ្យគេស្បថ នៅក្នុងព្រះវិហារ នៃព្រះយេហូវ៉ារួចបង្ហាញឱ្យ
គេឃើញបុត្រានៃស្តេចនោះ ៥លោកបង្គាប់គេថា ត្រូវឱ្យ
អ្នករាល់គ្នាធ្វើយ៉ាងនេះ គឺពួកអ្នករាល់គ្នា១ភាគ ក្នុង៣
ដែលចូលវេននៅថ្ងៃឈប់សំរាក[ង] នោះត្រូវត្រួតលើការ
ចាំយាមរក្សានៅមន្ទីររបស់ស្តេច[ច] ៦ត្រូវឱ្យ១ភាគក្នុង៣
ទៀត នៅត្រង់មាត់ទ្វារស៊ើរ ហើយ១ភាគក្នុង៣ទៀត នៅ
ត្រង់ទ្វារខាងក្រោយទីនៃពួកចាំយាម អ្នករាល់គ្នាត្រូវចាំ
យាមរក្សាព្រះវិហារយ៉ាងនោះ កុំឱ្យអ្នកណាចូលឡើយ
៧ឯអ្នករាល់គ្នាទាំង២កង ដែលចេញវេននៅថ្ងៃឈប់សំរាក
នោះត្រូវចាំយាមរក្សាព្រះវិហារនៃព្រះយេហូវ៉ានៅព័ទ្ធជុំវិ
ញស្តេច ៨ត្រូវឱ្យអ្នករាល់គ្នាកាន់គ្រឿងសស្ត្រាវុធនៅដៃ
រៀងខ្លួនចោមព័ទ្ធស្តេច បើមានអ្នកណាចូលហួសថែវ
អ្នករាល់គ្នាមក នោះត្រូវសំឡាប់ចេញ ហើយត្រូវឱ្យអ្នក
រាល់គ្នានៅជាមួយនឹងស្តេច ក្នុងកាលដែលទ្រង់យាងចេញ
ទៅនឹងចូលមកផង ។
៩ពួកមេទ័ព គេធ្វើតាមបង្គាប់យេហូយ៉ាដាដ៏ជាសង្ឃគ្រប់
ជិពូក គេនាំយកពួកកងគេរៀងខ្លួន ជាពួកដែលចូលវេន
នៅថ្ងៃឈប់សំរាក នឹងពួកដែលចេញវេននៅថ្ងៃឈប់
សំរាកដែរ មកឯយេហូយ៉ាដាដ៏ជាសង្ឃ ១០លោកក៏ចែក
លំពែង និងខែល[ឆ]របស់ស្តេចដាវីឌ ដែលនៅក្នុងព្រះ
វិហារនៃព្រះយេហូវ៉ាដល់ពួកមេទ័ព ១១ដូច្នេះ ពួកចាំយាម
គេក៏កាន់គ្រឿងសស្ត្រាវុធនៅដៃរៀងខ្លួន ឈរនៅព័ទ្ធជុំ
វិញស្តេច ចាប់តាំងពីខាងស្តាំព្រះវិហារ រហូតដល់ខាង
ឆ្វេងតាមក្បែរអាសនាព្រះវិហារ ១២នោះលោកកនាំព្រះរា

**១១:៥** ង ១របា ៩:២៥ ច ១ពវ ១៤:២៧
**១១:១០** ឆ ២សយ ៨:៧
**១១:១២** ជ នក ២៥:១៦ ២ពវ ២៣:៣ ឈ ១សយ ៩:១៦ ១ពវ ១:៣៩ ញ ទដ ៤៧:១ ៩៨:៨ អស ៥៥:១២ ដ ១សយ ១០:២៤
**១១:១៤** ឋ ១ពវ ៧:១៥ ឌ ១ពវ ១:៣៩ ឍ លប ៣៧:២៩ ណ ២ពវ ៩:២៣
**១១:១៥** ត ១ពវ ២:៣០
**១១:១៦** ថ នហ ៣:២៨ យរ ៣១:៤០ ទ លប ៤:១៤
**១១:១៧** ធ នក ២៤:៨ ២សយ ៥:៣ ២របា ១៥:១២ ២៣:៣ ២៩:១០ ៣៤:៣១ អរ ១០:៣ ន ២ពវ ២៣:៣ យរ ៣៤:៨

ជ បុត្រានៃស្តេចចេញមក ហើយបំពាក់មកុដរាជ្យថ្វាយទ្រង់
ព្រមទាំងប្រគល់សេចក្តីបន្ទាល់[ជ]ដល់ទ្រង់ តាំងឡើងជា
ស្តេច ហើយចាក់ប្រេង[ឈ]ថ្វាយ នោះគេក៏ទះដៃ[ញ]បន្លឺឡើង
ថា សូមឱ្យព្រះករុណាប្រកបដោយសេចក្តីចំរើន[ដ]។
១៣កាលព្រះនាងអ័ថាលា បានឮសូរអឺងកងនៃពួកចាំ
យាម និងបណ្តាជនទាំងប៉ុន្មាន នោះព្រះនាងយាងចូលទៅ
ឯគេ នៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា ១៤ក៏ទតមើលទៅ
ឃើញស្តេចទ្រង់ប្រថាប់នៅលើទីថ្កល់[ឋ] តាមទំនៀមមាន
ទាំងពួកមេទ័ព និងពួកផ្លុំត្រែ ឈរនៅជិតផងពួកបណ្តាជន
ជាអ្នកស្រុកនោះទាំងអស់ ក៏រីករាយសប្បាយឡើង ទាំងផ្លុំ
ត្រែផង[ឌ] ដូច្នេះ ព្រះនាងអ័ថាលាទ្រង់ហែក[ឍ]ព្រះពស្ត្រ
ស្រែកឡើងថា នេះជាការក្បត់ ជាការក្បត់ហើយ[ណ] ១៥តែ
យេហូយ៉ាដាដ៏ជាសង្ឃ លោកបង្គាប់ដល់ពួកមេទ័ព ដែល
ត្រួតលើពលទ័ពថា ចូរនាំព្រះនាងចេញទៅក្រៅទៅ ហើយ
បើអ្នកណាតាមព្រះនាង នោះត្រូវសំឡាប់គេដោយដាវ
នោះគឺពីព្រោះសង្ឃបានប្រាប់ថា កុំឱ្យសំឡាប់ព្រះនាង
នៅក្នុងព្រះវិហារ[ត]នៃព្រះយេហូវ៉ាឡើយ ១៦ដូច្នេះ គេក៏
ចៀសបើកផ្លូវឱ្យព្រះនាងយាងចេញ ហើយព្រះនាងយាង
ចេញទៅតាមផ្លូវសេះ[ថ] ដែលចូលទៅឯដំណាក់ស្តេច រួចគេ
ធ្វើគុតនៅទីនោះទៅ[ទ] ។
១៧រួចមកយេហូយ៉ាដា លោកឱ្យស្តេច និងពួកជនចុះ
សញ្ញា[ធ]នឹងព្រះយេហូវ៉ាថា គេនឹងធ្វើជារាស្ត្ររបស់ផងព្រះ
យេហូវ៉ា ហើយឱ្យស្តេច និងពួករាស្ត្រចុះសញ្ញាគ្នាដែរ[ន]
១៨ក្រោយនោះពួកបណ្តាជនទាំងឡាយ ដែលនៅក្នុងស្រុក

*ថ្ងៃដើង* មើល ២របា ២៣:១ បានបញ្ជាក់ពីតារាងឈ្មោះមេទ័ពប្រាំនាក់ដែលពួកទាំងអស់នោះជាសាសន៍អ៊ីស្រាអែល ។ *មកឯលោកនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា* មើល ២របា ២៣:២ រួមបញ្ចូលពួកលេវី និងពួកអ្នកដឹកនាំដែលក្បត់របស់ពួកយូដា ។

**១១:១០** *លំពែង និងខែលរបស់ស្តេចដាវីឌ ដែលនៅក្នុងព្រះវិហារ* ស្តេចដាវីឌបានរឹបអូសយកខែលមាស និងពួកអ្នកបម្រើរបស់ហាដារេស៊ើរ ហើយ បន្ទាប់មកព្រះអង្គបានថ្វាយរបស់ទាំងអស់នេះទៅដល់ព្រះយេហូវ៉ា (សូមមើល ២សយ ៨:៧–១១) ។ ស្តេចស៊ីសាកជាស្តេចស្រុកអេស៊ីព្ទបានប្លន់របស់ទ្រព្យព្រះវិហារ និង ព្រះរាជវាំងនៅក្នុងរាជ្យស្តេចយេរ៉ូបោម (មើល ១ពវ ១៤:២៦) ។

**១១:១២** *សេចក្តីបន្ទាល់របស់ទ្រង់* សេចក្តីបន្ទាល់ទាំងនេះគឺ(១).ក្រឹត្យវិន័យទាំង១០ប្រការ (២).សេចក្តីសញ្ញាភ្នំស៊ីណាយនិង(៣).ច្បាប់ផ្សេងៗរបស់ពួកស្តេច(មើល ចទ ១៧:១៤–២០ និងមើលការពន្យល់បន្ថែម ១សយ ១០:២៥) ។ ជម្រើសទី៣ ខាងក្រោយនេះ ហាក់មានភាពត្រឹមត្រូវជាងគេ ។ *តាំងឡើងជាស្តេច* មើលការពន្យល់ ១សយ ២:១០ ៩:១៦ ១ពវ ១:៣៩ ។ *សូមឱ្យព្រះករុណាប្រកបដោយសេចក្តីចំរើន* មើលការពន្យល់ ទដ ៦២:៤ ។

**១១:១៤** *ទីថ្កល់* នេះសំដៅលើសរសរស្តម្ភសំខាន់ទាំងពីរដែលនៅច្រកចូលក្នុងព្រះវិហារ(មើល ២៣:៣ ១ពវ ៧:១៥–២២ ២របា ២៣:១៣) ។ *អ្នកស្រុកនោះទាំងអស់* ជាការពិតណាស់ យេហូយ៉ាដាបានវាយយកទីកន្លែងនៅក្នុងថ្ងៃឈប់សម្រាកក្នុងខណៈដែលពួកគេកំពុងប្រារព្ធពិធីសាសនាដែលពួកមនុស្សទាំងអស់គេមានភាពស្មោះត្រង់ចំពោះព្រះយេហូវ៉ា ដែលកំពុងមានវត្តមាននៅក្រុងយេរ៉ូសាឡិម ។

**១១:១៥** *កុំឱ្យសំឡាប់ព្រះនាងនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ាឡើយ* ពាក្យនេះបានប្រាប់ឱ្យពួកគេកុំឱ្យប្រព្រឹត្តអំពើកខ្វក់ផ្សេងៗ នៅក្នុងវិហារនៃព្រះយេហូវ៉ាដែលជាកន្លែងបរិសុទ្ធ(មើល នក ២១:១៤ និងការពន្យល់) ។

**១១:១៧** នៅក្នុងវគ្គនេះព្រះយេហូវ៉ាបានប្រទានដល់ពួកអ៊ីស្រាអែល នូវសេចក្តីសញ្ញាថ្មីមួយទៀតនៅភ្នំស៊ីណាយសម្រាប់ឱ្យពួកគេធ្វើជារាស្ត្ររបស់ព្រះអង្គ(មើលការពន្យល់ នក ១៩:៥–៦ ចទ ៤:២០) ។ *ស្តេច និងពួករាស្ត្រចុះសញ្ញាគ្នា* សំគាល់អំពីការទទួលខុសត្រូវរបស់ស្តេច និងការតព្វកិច្ចរបស់រាស្ត្រដែលត្រូវធ្វើការរួមគ្នាដើម្បីឱ្យពួកគេម្នាក់ៗមានទំនាក់ទំនងជាមួយព្រះយេហូវ៉ា(មើលការពន្យល់ ១សយ ១០:២៥ ២សយ ៥:៣) ។

**១១:១៨** *រូបព្រះ* មើលការពន្យល់ ១:១៤:២៣ និង ១ពវ ១៤:១៥ ។

គេចូលទៅបំផ្លាញវិហារ[ប]ព្រះបាលបំបាក់បំបែក[ផ]អស់ទាំង
អាសនា ព្រមទាំងរូបព្រះអស់រលីង ក៏សំឡាប់ម៉ាត់ថាន
ជាសង្ឃ[ព]នៃព្រះបាល នៅត្រង់មុខអាសនា រួចយេហូយ៉ាដា
ដ៏ជាសង្ឃលោកតាំងឱ្យមានពួកអ្នកត្រួតត្រា ក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា ១៩លោកក៏នាំយកពួកមេទ័ព ពួកនាយ[ភ] និង
ពួកថ្មើរជើង ព្រមទាំងពួកបណ្តាជនទាំង ប៉ុន្មាននៅក្នុង
ស្រុកទៅដង្ហែស្តេច ចុះពីព្រះវិហារនៃព្រះយេហូវ៉ា ចូល
ទៅក្នុងដំណាក់ហ្លួង តាមផ្លូវទារកំផែង ជាទីរបស់ពួក
ចាំយាម ហើយទ្រង់ក៏ឡើងគង់លើបល្ល័ង្ករាជ្យ ២០ដូច្នេះ
ពួកបណ្តាជនទាំងឡាយនៅក្នុងស្រុក គេរីករាយសប្បាយ
ឡើងទាំងអស់គ្នា[ម] ហើយទីក្រុងក៏មានសេចក្តីសុខសាន្ត
ត្រាណ ឯអ័ថាលា គេបានធ្វើគត់ព្រះនាងដោយដាវ នៅ
ត្រង់ដំណាក់ស្តេចទៅ ។

## ស្តេចយ៉ូអាសជួសជុលព្រះវិហារ

*១២:១-២១ – ២រប ២៤:១-១៤ ២៤:២៣-២៧*

២១កាលយ៉ូអាសចាប់តាំងសោយរាជ្យឡើង នោះទ្រង់
**១២** មានព្រះជន្ម៧ឆ្នាំហើយ ១គឺនៅឆ្នាំទី៧ក្នុងរាជ្យយេ
ហ៊ូវ ដែលយ៉ូអាស[ក]ចាប់តាំង សោយរាជ្យឡើងក៏សោយ
រាជ្យនៅក្រុងយេរូសាឡិមបាន៤០ឆ្នាំ ព្រះមាតាទ្រង់ព្រះ
នាមជាស៊ីបយ៉ា ជាអ្នកស្រុកបៀរ-សេបា ២រីឯយ៉ូអាសទ្រង់
ប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ[ខ] នៅព្រះនេត្រព្រះយេហូវ៉ា
រហូតដល់អស់វេលា ដែលយេហូយ៉ាដាដ៏ជាសង្ឃបង្រៀន
ទ្រង់ ៣ប៉ុន្តែមិនបានបំបាត់អស់ទាំងទីខ្ពស់ចេញទេ[គ] ហើយ
ពួកបណ្តាជន គេនៅតែថ្វាយយញ្ញបូជាព្រមទាំងដុតកំញាន
នៅលើទីខ្ពស់ ទាំងនោះនៅឡើយ ។
៤យ៉ូអាស ទ្រង់មានបន្ទូលទៅពួកសង្ឃថា ឯអស់ទាំង
ប្រាក់[ឃ] ជាដង្វាយទាំងប៉ុន្មាន[ង] ដែលគេយកមកថ្វាយ
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា និងប្រាក់របស់មនុស្ស
និមួយៗដែលកត់ទុកក្នុងបញ្ជី[ច] គឺជាដង្វាយនៃគ្រប់គ្នាតាម
ច្បាប់ ហើយអស់ទាំងប្រាក់ ដែលអ្នកណាកើតមានចិត្តចង់[ឆ]
យកមកថ្វាយ ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ៥នោះត្រូវឱ្យ
ពួកសង្ឃទទួលប្រាក់នោះ គឺត្រូវឱ្យគ្រប់គ្នាទទួលយកពីពួក
អ្នកដែលខ្លួនស្គាល់ ដើម្បីជួសជុល[ជ]ត្រង់កន្លែងបាក់បែកក្នុង
ព្រះវិហារ ទោះបើឃើញមានបាក់បែកនៅត្រង់ណាក៏
ដោយ ៦ប៉ុន្តែដល់ឆ្នាំទី២៣ ក្នុងរាជ្យស្តេចយ៉ូអាស នោះពួក
សង្ឃមិនទាន់បានជួសជុលកន្លែងបាក់បែក ក្នុងព្រះវិហារ
នៅឡើយ ៧ដូច្នេះ ស្តេចយ៉ូអាស ទ្រង់ហៅយេហូយ៉ាដាដ៏ជា
សង្ឃ និងពួកសង្ឃឯទៀតមកសួរថា ហេតុអ្វីបានជាមិន
បានជួសជុលកន្លែងបាក់បែកក្នុងព្រះវិហារដូច្នេះ ឥឡូវនេះ
មិនត្រូវ ឱ្យយកប្រាក់ពីពួកអ្នកដែលស្គាល់ទៀតទេ គឺត្រូវ
ប្រគល់ប្រាក់នោះទៅ សំរាប់ជួសជុលកន្លែងបាក់បែកក្នុង
ព្រះវិហារវិញ ៨ពួកសង្ឃក៏យល់ព្រមថា មិនត្រូវទទួលប្រាក់

**១១:១៨** ប ១ពវ ១៦:៣២ ផ ចទ ១២:៣ ព ១ពវ ១៨:៤០ ២ពវ ១០:២៥ ២៣:២០
**១១:១៩** ភ ខ.៤
**១១:២០** ម សភ ១១:១០ ២៨:១២ ២៩:២
**១២:១** ក ២ពវ ១១:២
**១២:២** ខ ចទ ១២:២៥ ២សយ ៨:១៥
**១២:៣** គ ១ពវ ៣:៣ ២ពវ ១៨:៤
**១២:៤** ឃ ២ពវ ២២:៤ ង ជន ១៨:១៩ ច នក ៣០:១២ ឆ នក ២៥:២ ៣៥:២៩
**១២:៥** ជ ២ពវ ២២:៥

**១១:១៩** *ពួកមេទ័ព ពួកនាយ ពួកថ្មើរជើង* មើលការពន្យល់ ខ.៤ ។

**១១:២១** នៅត្រង់ចំណុចនេះសូមមើលក្នុង ខ.៣ ក្នុងកាលដែលព្រះយេហូវ៉ាបានបម្រុងទុកចៀមមួយដល់ស្តេចដាវីឌនៅក្រុងយេរូសាឡិម (មើល ១ពវ ១១:៣៦) ។

**១២:១** *ឆ្នាំទី៧ក្នុងរាជ្យយេហ៊ូវ* មកដល់រាជ្យត្រង់នេះស្ថិតនៅក្នុងឆ្នាំទី ៨៣៥ មុន គ.ស(មើលការពន្យល់ ១០:៣៦) ។ *៤០ឆ្នាំ* ឆ្នាំនេះស្ថិតនៅក្នុងចន្លោះនៃឆ្នាំ ៨៣៥-៧៩៥ មុន គ.ស ។

**១២:២** *វេលាដែលយេហូយ៉ាដាដ៏ជាសង្ឃបង្រៀនទ្រង់* នៅត្រង់នេះក្រោយពីយេហូយ៉ាដាសុគតទៅ យ៉ូអាសបានត្រឡប់ទៅជាចាកចោលព្រះយេហូវ៉ា (មើល ២រប ២៤:១៧-២៧) ។

**១២:៣** *មិនបានបំបាត់អស់ទាំងទីខ្ពស់* នៅត្រង់នេះបញ្ជាក់ពីទីដែលគេថ្វាយបង្គំព្រះយេហូវ៉ា លើសជាងការថ្វាយបង្គំរូបព្រះដទៃ (មើលការពន្យល់ ១ពវ ១៥:១៤) ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ពួកអ្នកដែលថ្វាយបង្គំព្រះក្លែងក្លាយមានប្រភពសក្តានុពលគ្រប់គ្រាន់ ក្នុងការនាំអ៊ីស្រាអែលធ្លាក់ចូលក្នុងការថ្វាយបង្គំព្រះដទៃ (មើលការពន្យល់ ១ពវ ៣:២) ។

**១២:៤** *ប្រាក់ . . . គេយកមកថ្វាយក្នុងព្រះវិហារ* ប្រាក់ទាំងអស់នេះមានប្រភពមកពីកន្លែងផ្សេងៗ ។ (១). ប្រាក់ដែលបានមកពីការប្រមូលពីប្រជាជនដែលមានអាយុ២០ឆ្នាំ យុវជនអ៊ីស្រាអែលត្រូវបានតម្រូវឱ្យចុះឈ្មោះចូលធ្វើជាទាហាន និងថ្វាយសាច់ប្រាក់អ៊ីស្រាអែលពាក់កណ្តាល (មើលការពន្យល់ ៥:២៦) សម្រាប់ប្រើប្រាស់ក្នុងការងារវិហារ (មើលការពន្យល់ នក ៣០:១១-១៦ ៣៨:២៥-២៦) ។ (២). ប្រាក់ទាំងអស់នោះ បានមកពីពួកអ្នកដែលបានធ្វើការសន្យាស្បថស្បែរ ដូចដែលមានរៀបរាប់នៅក្នុងកណ្ឌគម្ពីរ លវ ២៧:១-២៥ ។ (៣).ប្រាក់ទាំងអស់នោះ បានមកពីការថ្វាយដោយស្ម័គ្រអំពីចិត្តដល់ព្រះវិហារ ដូចមានក្នុង លវ ២២:១៨-២៣ ចទ ១៦:១០ ។

**១២:៥** *ប្រាក់* ការងារសាងសង់វិហារដ៏លំបាក ដែលពួកគេម្នាក់ៗត្រូវការថវិការ ដើម្បីដោះស្រាយបញ្ហាខ្វះខាតនេះ ។ *កន្លែងបាក់បែកក្នុងវិហារ* ដំណើរនៃការសាងសង់វិហារត្រូវបានសងសព្វគ្រប់ក្នុងរយៈពេល ១២៩ ឆ្នាំ មុនការចាប់ផ្តើមរាជ្យស្តេចយ៉ូអាស(មើលការពន្យល់ ខ.១ ១ពវ ៦:៣៨) ។ បន្ថែមពីនេះទៀត ការខូចបង់នូវវិហារទាំងអស់នោះ គឺបណ្តាមកពីអាយុកាលរបស់ច្រើននិងទ្រុឌទ្រោមដែលទាមទាឱ្យមានការជួសជុលឡើងវិញ ហើយនិងការរំលោភក្នុងរជ្ជកាលស្តេចអ័ថាលា(មើល ២រប ២៤:២៧) ។

**១២:៦** *ឆ្នាំទី៣២ ក្នុងរាជ្យស្តេចយ៉ូអាស* មកដល់ឆ្នាំនេះស្តេចយ៉ូអាសបានស្ថាបនាគម្រោងនៃការជួសជុលវិហារឡើងវិញ ក្នុងរយៈពេលពីរបីឆ្នាំ មុនរាជ្យទី២៣របស់ទ្រង់ ។ មកដល់រាជ្យទី៣០ ទ្រង់បានធ្វើការការពាររាជ្យបល្ល័ង្ករបស់ទ្រង់ដោយការជួសជុលវិហារទាំងអស់នោះឡើងវិញ ។

**១២:៧** *ដូច្នេះ មិនត្រូវយកប្រាក់ពីពួកអ្នកដែលស្គាល់ទៀតទេ* នេះប្រាប់ថាប្រភពចំណូលដូចដែលបានលើកឡើងនៅក្នុងខ.៤ គឺត្រូវឈប់បរិច្ចាកឱ្យដល់ពួកសង្ឃទៀតហើយ ។

ពីពួកបណ្ដាជនទៀត ក៏មិនត្រូវជួសជុលកន្លែងបាក់បែក
ក្នុងព្រះវិហារដែរ ។
[៩]ឯយេហូយ៉ាដាដ៏ជាសង្ឃ លោកយកហឹប១មកចោះ
ប្រហោងត្រង់គ្រប រួចដាក់ហឹបនៅខាងស្ដាំអាសនាតាម
ផ្លូវចូល[ឈ]ទៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា នោះពួកសង្ឃ
ដែលរក្សាត្រង់មាត់ទ្វារ ក៏យកអស់ទាំងប្រាក់[ញ] ដែលគេយក
មកថ្វាយក្នុងព្រះវិហារនៃព្រះយេហូវ៉ា ទៅដាក់ក្នុងហឹប
នោះ [១០]រួចមកកាលឃើញថា មានប្រាក់ច្រើននៅក្នុងហឹប
ហើយ នោះស្មៀនហ្លួង[ដ] និងសំដេចសង្ឃ ក៏ឡើងទៅរាប់
ប្រាក់ ដែលនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា ហើយច្រក
ក្នុងបាវទុក [១១]ឯប្រាក់ដែលបានថ្លឹងប្រគល់មកក្នុងអំណាច
សំដេចសង្ឃ នោះលោកក៏ចំណាយដល់ពួកជាងដែល
ធ្វើការ គឺជាពួកអ្នកដែលត្រួតត្រាការ នៅក្នុងព្រះវិហារនៃ
ព្រះយេហូវ៉ា ហើយអ្នកទាំងនោះក៏ចេញឱ្យ ដល់ពួកជាង
ឈើ នឹងពួកជាងផ្សេងៗ ដែលជួសជុលព្រះវិហារនៃព្រះ
យេហូវ៉ា [១២]ហើយដល់ពួកជាងរៀបថ្ម និងពួកជាងដាប់ថ្ម[ឋ]
ហើយសំរាប់ទិញឈើ និងថ្មដាប់ស្រាប់ សំរាប់នឹងជួសជុល
ត្រង់កន្លែងបាក់បែក ក្នុងព្រះវិហារនៃព្រះយេហូវ៉ាក៏
សំរាប់អស់ទាំងការចំណាយ ដែលត្រូវចាយ ដើម្បីជួសជុល
ព្រះវិហារឡើង [១៣]ប៉ុន្តែមិនបានយកប្រាប់ ដែលគេយកមក
ថ្វាយក្នុងព្រះវិហារនៃព្រះយេហូវ៉ា ទៅធ្វើជាគ្រឿងមាស[ឌ]
គ្រឿងប្រាក់ ដូចជាពែង គ្របប្រឆេះ ចានក្លាំ ឬត្រែឡើយ
[១៤]ដ្បិតគេបានឱ្យដល់ពួកជាង ដែលធ្វើការវិញសំរាប់នឹង
ប្រើការជួសជុលព្រះវិហារព្រះយេហូវ៉ា [១៥]មួយទៀត គេ
មិនបានគិតនឹងពួកអ្នក ដែលគេប្រគល់ប្រាក់នោះទៅឱ្យ
សំរាប់ចំណាយដល់ពួកជាងដែលធ្វើការនោះទេ ពីព្រោះ
អ្នកទាំងនោះបានប្រព្រឹត្តដោយចិត្តស្មោះត្រង់[ឍ] [១៦]ឯប្រាក់
ជាដំឡៃនៃដង្វាយដោយព្រោះការរំលង[ណ] និងប្រាក់ជា
ដំឡៃនៃដង្វាយលោះបាប[ត]នោះ មិនបានយកទៅទុកក្នុង
ព្រះវិហារនៃព្រះយេហូវ៉ាទេ ប្រាក់នោះទុកជាចំណែក[ថ]
ដល់ពួកសង្ឃវិញ ។
[១៧]នៅគ្រានោះ ហាសែល[ទ]ជាស្ដេចស្រុកស៊ីរី ក៏ឡើងទៅ
ច្បាំងនឹងក្រុងកាថ ហើយចាប់យកបាន រួចហាសែលដំរង់
ព្រះភក្ត្រឆ្ពោះទៅឯក្រុងយេរូសាឡិមទៀត [១៨]នោះយ៉ូអាស
ជាស្ដេចយូដា ទ្រង់យកអស់ទាំងរបស់បរិសុទ្ធដែលពួក
ស្ដេចយូដា គឺយ៉ូសាផាត យ៉ូរ៉ាម និងអ័ហាស៊ីយ៉ាជាពួក
ឰយុកោទ្រង់បានថ្វាយ និងរបស់ទាំងប៉ុន្មានដែលអង្គទ្រង់
បានថ្វាយ ព្រមទាំងមាសទាំងអស់ ដែលនៅក្នុងឃ្លាំងព្រះ
វិហារនៃព្រះយេហូវ៉ា ហើយក្នុងដំណាក់ស្ដេចផង ផ្ញើ[ធ]ទៅ
ថ្វាយហាសែលជាស្ដេចស៊ីរី ដូច្នេះ ហាសែលក៏ថយ[ន]ចេញ

**១២:៩** ឈ ២ពវ ២៥:១៨ យរ ៣៥:៤ ៥២:២៤ ញ មក ១២:៤១ លក ២១:១
**១២:១០** ដ ២សយ ៨:១៧
**១២:១២** ឋ ២ពវ ២២:៥-៦
**១២:១៣** ឌ ១ពវ ៧:៤៨-៥១
**១២:១៥** ឍ ២ពវ ២២:៧ ១កថ ៤:២
**១២:១៦** ណ លវ ៥:១៤-១៩ ត លវ ៤:១-៣៥ ថ លវ ៧:៧
**១២:១៧** ទ ២ពវ ៨:១២
**១២:១៨** ធ ១ពវ ១៥:១៨ ២របា ២១:១៦-១៧ ន ១ពវ ១៥:២១ ២ពវ ១៥:២០ ១៩:៣៦

**១២:៨** *ពួកសង្ឃក៏យល់ព្រម* ពួកសង្ឃបានសន្យាថា ពួកគេលែងយកប្រាក់ពីពួកបណ្ដាជនទៀតហើយ តែប្រាក់ដែលគេទទួលបានពីមុនមកនោះពួកគេត្រូវយកទៅជួសជុលវិហារតាមការសន្យា ដែលពួកគេបានធ្វើជាមួយបណ្ដាជនទាំងអស់ផងដែរ ។

**១២:៩** *ពួកសង្ឃដែលរក្សាត្រង់មាត់ទ្វារ* ពួកសង្ឃនៅត្រង់នេះ គឺមានចំនួនបីរូប ដែលមាននាទីការពារវិហារចំពោះអស់អ្នកណាដើរចូលក្នុងវិហារដោយគ្មានការអនុញ្ញាត្ត (មើល ២៥:១៨ យរ ៥២:២៤) ។ *ក៏យកអស់ទាំងប្រាក់ . . . ទៅដាក់ក្នុងហឹប* នៅពេលពួកបណ្ដាជនបានដឹងច្បាស់ថា ប្រាក់របស់ពួកគេទាំងអស់ត្រូវបានយកទៅប្រើសម្រាប់ការសង់វិហារ នោះពួកគេម្នាក់មានចិត្តអំណរសាទរចំពោះការនេះយ៉ាងខ្លាំងក្រៃលែង ។ សូមមើល ២២:៣-៧ សម្រាប់ការបន្តការងារសាងសង់ព្រះវិហារនៅក្នុងរាជ្យ ស្ដេចយ៉ូសៀស ។

**១២:១០** *ស្មៀនហ្លួង* មើលការពន្យល់ ២សយ ៨:១៧ ។

**១២:១១** *ពួកអ្នកដែលត្រួតត្រាការ* ពួកទាំងនេះស្ថិតក្រោមការដឹកនាំរបស់ពួកសង្ឃ ។

**១២:១៣** *ព្រះវិហារនៃព្រះយេហូវ៉ា ទៅធ្វើជាគ្រឿងមាស គ្រឿងប្រាក់* ឃ្លានេះបញ្ជាក់ថា មាសប្រាក់ទាំងអស់នេះត្រូវបានសម្រិតសម្រាំងទុកក្នុងការសាងសង់វិហារឡើងវិញ ។ នៅពេលដែលដំណើរការនៃការសាងសង់បានចប់សព្វគ្រប់ មាសប្រាក់បន្ថែមដែលពួកគេទទួលបាននោះសម្រាប់យកមកប្រើក្នុងវិហារ (មើល ២របា ២៤:១៤) ។

**១២:១៦** *ប្រាក់ជាដំឡៃនៃដង្វាយលោះបាប* សូមមើល លវ ៥:១៦ ៦:៥ និង ជន ៥:៧-១០ ។

**១២:១៧** *គ្រានោះ* ពាក្យនេះសំដៅដល់ព្រឹត្តការណ៍ដែលបានកើតឡើងនៅចុងបញ្ចប់នៃរាជ្យស្ដេចយ៉ូអាស ។ ចាប់ពី ២របា ២៤:១៧-២៤ បានបញ្ជាក់ច្បាស់ថា ការវាយប្រហាររបស់ពួកស៊ីរី គឺបណ្ដាមកពីយ៉ូអាសបានវិលបែរចេញពីព្រះយេហូវ៉ា ក្រោយពីយេហូយ៉ាដាសុគតទៅនោះ ។ ការវិលបែរចេញពីព្រះរបស់យ៉ូអាសបានឈានដល់កម្រិតកំពូល រហូតប្រព្រឹត្តខ្លួនជាអ្នកសម្លាប់សាការីដែលជាកូនយេហូយ៉ាដា (មើល ២របា ២៤:២២) ។ *ហាសែល* មើល ៨:៧-១៥ ១០:៣២-៣៣ ១៣:៣,២២ ។ *ក្រុងកាថ* នេះជាក្រុងសំខាន់មួយនៃអាណាចក្រភីលីស្ទីន (មើល ១៨:១) ហើយក្រុងនេះនៅតែជាផ្នែកសំខាន់មួយរបស់ពួកយូដានៅក្នុងរជ្ជកាលរបស់ស្ដេចយេហូបោម (មើល ២របា ១១:៨) ។ នៅឆ្នាំក្រោយៗមកទៀតក្នុងរាជ្យស្ដេចយ៉ូអាសរបស់ពួកយូដា (៨៣៥-៧៩៦ មុន គ.ស) និងអំឡុងរាជ្យស្ដេចយ៉ូអាហាសរបស់ពួកអ៊ីស្រាអែល (៨១៤-៧៩៨ មើល ១៣:៣,៧) ហើយនិងពួកស៊ីរីបានលុកលុយអាណាចក្រខាងជើងបានជោគជ័យ ក្នុងការប្រឆាំងនឹងពួកភីលីស្ទីនក្នុងទឹកដីនៃសាសន៍យូដា ។ *ដំរង់ព្រះភក្ត្រឆ្ពោះទៅឯក្រុងយេរូសាឡិមទៀត* សូមមើល ២របា ២៤:២៣-២៤ ។

**១២:១៨** *អស់ទាំងរបស់បរិសុទ្ធ . . . មាស . . . ទៅថ្វាយហាសែល* នេះជាឆ្នាំដំបូង ដែលអេសា បានថ្វាយដល់ស្ដេចស្រុកស៊ីរីជាមួយនឹងអំណោយដ៏សាមញ្ញ ក្នុងបំណងឱ្យបានសុវត្ថិភាព (មើល ១ពវ ១៥:១៨) ។

ពីក្រុងយេរូសាឡិមទៅ ។
១៩ រីឯដំណើរឯទៀតពីយ៉ូអាស និងការទាំងប៉ុន្មានដែល
ទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅជាពង្សាវតារ
របស់ពួកស្តេចយូដាហើយ ២០ ពួកអ្នកបំរើ[ប] របស់យ៉ូអាសក៏
លើកគ្នាក្បត់ទ្រង់ ហើយប្រហារសំឡាប់[ផ]នៅត្រង់ប៉មមីឡូរ[ព]
តាមផ្លូវដែលចុះទៅឯដំបន់ស៊ីឡា ២១ គឺយ៉ូសាការ ជាកូន
ស៊ីមាត និងយ៉ូសាបាឌ ជាកូនសូមើរជាអ្នកបំរើ ដែលវាយ
ទ្រង់ហើយទ្រង់ក៏សុគតទៅ រួចគេបញ្ចុះទ្រង់នៅក្នុងក្រុង
ដាវីឌ ជាមួយនឹងពួកព្ឋយុកោទ្រង់នោះអ័ម៉ាស៊ីយ៉ា ជាព្រះ
រាជបុត្រាទ្រង់ ក៏ឡើងសោយរាជ្យជំនួសបិតា ។

## យ៉ូអាហាសឡើងជាស្តេចអ៊ីស្រាអែល

**១៣** ១ នៅឆ្នាំទី២៣ក្នុងរាជ្យនៃយ៉ូអាសជាបុត្រអ័ហាស៊ីយ៉ា
ស្តេចយូដា នោះយ៉ូអាហាស ជាបុត្រយេហ៊ូវក៏ចាប់តាំង
សោយរាជ្យ លើស្រុកអ៊ីស្រាអែល នៅក្រុងសាម៉ារី ហើយ
បានសោយរាជ្យអស់១៧ឆ្នាំ ២ ទ្រង់ប្រព្រឹត្តអំពើដ៏លាមក
អាក្រក់[ក] នៅព្រះនេត្រព្រះយេហូវ៉ា ព្រមទាំងប្រព្រឹត្តតាម
អំពើបាបរបស់យេរ៉ូបោមជាកូននេបាត ដែលបាននាំឱ្យពួក
អ៊ីស្រាអែលធ្វើបាបតាមនោះដែរ ទ្រង់មិនវៀរបង់លែង
ធ្វើឡើយ ៣ នោះសេចក្តីក្រោធ[ខ]នៃព្រះយេហូវ៉ាក៏កាត់ឡើង
ទាស់នឹងពួកអ៊ីស្រាអែល ហើយទ្រង់ប្រគល់គេទៅក្នុង
កណ្តាប់ដៃ[គ]ហាសែល ជាស្តេចស៊ីរី នឹងក្នុងកណ្តាប់ដៃនៃ
បេន-ហាដាឌ់[ឃ] ជាបុត្រហាសែលតទៅ ៤ តែយ៉ូអាហាស
ទ្រង់អំពាវនាវ[ង]ដល់ព្រះយេហូវ៉ា ហើយព្រះយេហូវ៉ាទ្រង់
ក៏ស្តាប់តាម ដ្បិតទ្រង់បានទតឃើញ[ច]ការ ដែលស្តេចស៊ីរី
សង្កត់សង្កិន[ឆ]ដល់ពួកអ៊ីស្រាអែល ៥ (រីឯព្រះយេហូវ៉ាទ្រង់
ប្រោសប្រទាន ឱ្យពួកអ៊ីស្រាអែលមានអ្នកជួយសង្គ្រោះ
ម្នាក់[ជ] ឱ្យគេបានរួចពីអំណាចសាសន៍ស៊ីរី រួចពួកកូនចៅ
អ៊ីស្រាអែល គេក៏នៅក្នុងផ្ទះរបស់ខ្លួនដូចដើមវិញ ៦ ប៉ុន្តែ
គេមិនលែងធ្វើតាមអំពើបាប[ឈ] របស់ជិនួរវង្សយេរ៉ូបោម
ដែលនាំឱ្យពួកអ៊ីស្រាអែលធ្វើបាបនោះទេ គឺគេចេះតែ
ប្រព្រឹត្តតាមអំពើទាំងនោះវិញ ហើយនៅក្នុងក្រុងសាម៉ារី
ក៏នៅមានអស់ទាំងរូបព្រះ[ញ]នៅឡើយដែរ) ៧ ដ្បិតស្តេចស៊ីរី
បានទុកឱ្យ[ដ]យ៉ូអាហាស មានពលទ័ពតែប៉ុណ្ណោះ គឺឱ្យមាន
ពលសេះ៥០នាក់រ ទេះចំបាំង១០ និងពលថ្មើរជើង១ម៉ឺន
នាក់ ពីព្រោះស្តេចស៊ីរី បានរំលាងបំផ្លាញគេអស់ទៅ
ហើយ ទាំងធ្វើឱ្យគេដូចជាលំអងធូលី[ឋ] ដែលនៅទីលាន

**១២:២០** ប ២ពវ ១៤:៥ ផ ២ពវ ១៤:១៩ ១៥:១០,១៤,២៥,៣០ ២១:២៣ ២៥:២៥ ព ពច ៩:៦
**១៣:២** ក ១ពវ ១២:២៦-៣៣
**១៣:៣** ខ ចទ ៣១:១៧ គ ១ពវ ១៩:១៧ ឃ ខ.២៤
**១៣:៤** ង ចទ ៤:២៩ ច ចទ ២៦:៧ ឆ ជន ១០:៩ ២សយ ៧:១០
**១៣:៥** ជ លប ៤៥:៧ ចទ ២៨:២៩ ពច ២:១៨
**១៣:៦** ឈ ១ពវ ១២:៣០ ញ ១ពវ ១៦:៣៣
**១៣:៧** ដ ២ពវ ១០:៣២-៣៣ ឋ ២សយ ២២:៤៣

**១២:១៩** *ក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

**១២:២០** *លើកគ្នាក្បត់ទ្រង់* អំពើក្បត់ដ៏ធំនេះ ធ្វើឡើងក្នុងគោលបំណងសងសឹកដល់យ៉ូអាសដែលបានធ្វើឃាតចំពោះសាការី ដែលជាបុត្ររបស់យេហូយ៉ាដា (មើល ២របា ២៤:២៥) ។ *ប៉មមីឡូរ* នៅត្រង់នេះពាក្យថា ប៉ម មានន័យថា "ផ្ទះ" ហើយសម្រាប់អត្ថន័យនៃពាក្យថា មីឡូរ នោះសូមមើលការពន្យល់ ពច ៩:៦ ។

**១២:២១** *គេបញ្ចុះសពទ្រង់នៅក្នុងក្រុងដាវីឌ* មើល ២របា ២៤:២៥ ។ *អ័ម៉ាស៊ីយ៉ា ជាព្រះរាជបុត្រាទ្រង់ ក៏ឡើងសោយរាជ្យជំនួសបិតា* សម្រាប់រាជ្យរបស់អ័ម៉ាស៊ីយ៉ា សូមមើល ១៤:១-២២ ។

**១៣:១***ឆ្នាំទី២៣ ក្នុងរាជ្យនៃយ៉ូអាស* មកដល់ត្រង់នេះគឺក្នុងឆ្នាំទី ៨១៤ មុន គ.ស (មើលការពន្យល់ ១២:១ និងសេចក្តីផ្តើម ១ពវ ) ។ *១៧ឆ្នាំ* នេះស្ថិតនៅក្នុងឆ្នាំទី ៨១៤-៧៩៨ មុន គ.ស ។

**១៣:២** *អំពើរបាបរបស់យេរ៉ូបោម* សូមមើល ១ពវ ១២:២៦-៣២ ១៣:៣៣-៣៤ ១៤:១៦ ។

**១៣:៣** *ហាសែល* សូមមើលការពន្យល់ ៨:១២,១៣,១៥ ១០:៣៣ ។ *បេន-ហាដាឌ់* មើល ខ.២៤ បានបញ្ជាក់ពីការឡើងគ្រងរាជ្យរបស់ទ្រង់ទាំងពីរ គឺស្ថិតនៅក្នុងឆ្នាំទី ៨០៦ និង ៧៩៦ មុន គ.ស ។

**១៣:៤** *ព្រះយេហូវ៉ាទ្រង់ក៏ស្តាប់តាម* ទោះបីការសង្គ្រោះរបស់ព្រះយេហូវ៉ាមិនបានជួយដល់យ៉ូអាហាសក្នុងគ្រាដែលទ្រង់កំពុងមានព្រះជន្មរស់នៅ (ខ.២២) ប៉ុន្តែ ព្រះទ្រង់មានសេចក្តីករុណាមេត្តាដល់រាស្ត្ររបស់ព្រះអង្គ ទោះបីពួកគេជាប់មានបាបក៏ដោយ ដោយព្រោះសេចក្តីសញ្ញា ដែលទ្រង់តាំងនឹងអ័ប្រាហាំ អ៊ីសាក និង យ៉ាកុប (ខ.២៣) ។

**១៣:៥** *ឱ្យពួកអ៊ីស្រាអែលមានអ្នកជួយ* ពួកនេះគឺ (១). ជាស្តេចនៃពួកស៊ីរីគ្រងរាជ្យនៅក្នុងឆ្នាំ(៨១០-៧៨៣ មុន គ.ស) ដែលបានវាយប្រហារលើពួកស៊ីរីនៅក្នុងស្រុកដាម៉ាសនៅក្នុងឆ្នាំ ៨០៦-៨០៤ ដើម្បីបណ្តេញពួកអីស្រាអែលចេញពីទឹកដីស៊ីរី ក្នុងការគ្រប់គ្រងទឹកដីអ៊ីស្រាអែល(មើល ខ.២៥ ១៤:២៥) (២). គឺយ៉ូអាស ជាបុត្រនៃយ៉ូអាហាស(មើល ខ.១៧,១៩,២៥) និង (៣).យេរ៉ូបោមទី២ ដែលជាអ្នកពង្រីកទឹកដីអ៊ីស្រាអែលរហូតដល់ភាគខាងជើង(មើល ១៤:២៥,២៧) ក្រោយពីពួកស៊ីរីបានបាក់ទ័ពនៅក្នុងទឹកដីស៊ីរីផ្ទាល់ ។

**១៣:៦** *ក្រុងសាម៉ារីក៏នៅមានអស់ទាំងរូបព្រះនៅឡើយដែរ* រូបព្រះទាំងអស់នៅត្រង់នេះ បានបង្កើតឡើងដោយស្តេចអ័ហាប់(មើល ១ពវ ១៦:៣៣) ហើយរូបព្រះទាំងអស់នោះគេចផុតពីការបំផ្លាញរបស់យេហ៊ូវ នៅពេលដែលស្តេចអង្គនេះ បានលុបបំបាត់រូបព្រះបាលចេញពីស្រុកសាម៉ារី (មើល ១០:២៧-២៨) ហើយនិងរូបព្រះទាំងអស់នេះត្រូវបានគេគោរពឡើងវិញនៅក្នុងរាជ្យស្តេចយ៉ូអាហាស ។

**១៣:៧** *រទេះចំបាំង១០* នេះជាកងកម្លាំងមួយតូច តែមានប្រសិទ្ធភាពខ្ពស់បំផុត បើធៀបជាមួយនឹង រទេះចំបាំង ២០០០ ដែលស្តេចអ័ហាប់ បានវាយពួកស៊ីរីនៅក្នុងសមរភូមិប្រយុទ្ធនៅក្នុងឆ្នាំ ៨៥៣ មុន គ.ស (មើលការពន្យល់ ១ពវ ២២:១) ។ *ពលថ្មើរជើង១ម៉ឺននាក់* នៅក្នុងសមរភូមិប្រយុទ្ធស្តេចអ័ហាប់ បានផ្តល់ទាហានថ្មើរជើង ចំនួន ១០០០នាក់ទៅដល់សម្ព័ន្ធមិត្តក្នុងការប្រយុទ្ធជាមួយនឹងពួកស៊ីរី ។ ក្នុងខណៈពេលនេះពួកទ័ពអ៊ីស្រាអែលត្រូវមានអ្នកតំណាងមួយ ក្នុងចំណោមអ្នកដំណាងទាំងអស់នៃទ័ពស្មើជើង ។

បញ្ជាន់ស្រូវ ៨រឺឯដំណើរឯទៀត ពីយ៉ូអាហាស ហើយការ
ទាំងប៉ុន្មានដែលទ្រង់ធ្វើ និងអំណាចរបស់ទ្រង់ នោះសុទ្ធតែ
បានកត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេច
អ៊ីស្រាអែលហើយ ៩ចំណែកយ៉ូអាហាស ក៏ផ្ទំលក់ទៅជា
មួយនឹងពួកឰយុកោទ្រង់ គេបញ្ចុះទ្រង់នៅក្នុងក្រុងសាម៉ារី
រួចយ៉ូអាស ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួស
បិតា ។

## យ៉ូអាហាសឡើងជាស្តេចស្រុកអ៊ីស្រាអែល

១០នៅឆ្នាំទី៣៧ក្នុងរាជ្យយ៉ូអាសជាស្តេចយូដា នោះ
យ៉ូអាស ជាបុត្រយ៉ូអាហាស ក៏ចាប់តាំងសោយរាជ្យឡើង
លើស្រុកអ៊ីស្រាអែលនៅក្រុងសាម៉ារី ក៏សោយរាជ្យបាន
១៦ឆ្នាំ ១១ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រ
ព្រះយេហូវ៉ាទ្រង់មិនបានវៀរបង់លែងប្រព្រឹត្ត តាមអស់
ទាំងអំពើបាបរបស់យេរ៉ូបោម ជាកូននេបាត ដែលបាននាំ
ឱ្យពួកអ៊ីស្រាអែលធ្វើបាបតាមនោះទេ គឺទ្រង់បានប្រព្រឹត្ត
តាមអំពើទាំងនោះវិញ ១២រីឯដំណើរឯទៀតពីយ៉ូអាសនឹង
ការទាំងប៉ុន្មានដែលទ្រង់ធ្វើ និងអំណាចទ្រង់ដែលបានប្រើ
ដើម្បីច្បាំងនឹងអ័ម៉ាសីយ៉ា[ឌ] ស្តេចយូដានោះសុទ្ធតែបានកត់
ទុកក្នុងសៀវភៅ ជាពង្សាវតារ[ឍ]របស់ពួកស្តេចអ៊ីស្រា
អែលហើយ ១៣យ៉ូអាសក៏ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោ
ទ្រង់ទៅ រួចយេរ៉ូបោម[ណ]បានសោយរាជ្យឡើងជំនួសទ្រង់
ហើយគេបញ្ចុះសពយ៉ូអាសនៅក្រុងសាម៉ារី ជាមួយនឹងពួក
ស្តេចអ៊ីស្រាអែល ។

១៤នៅគ្រានោះ អេលីសេលោកចាប់ឈឺ ដោយជំងឺដែល
នាំឱ្យលោកស្លាប់ ហើយយ៉ូអាសជាស្តេចអ៊ីស្រាអែល ទ្រង់
យាងចុះទៅសួរលោក ក៏ឈ្ងោកយំនឹងលោកដោយបន្ទូល
ថា ឱលោកឪពុក លោកឪពុកខ្ញុំអើយ នេះគឺជាព្រះរាជរថ[ត]
និងទ័ពសេះរបស់ពួកអ៊ីស្រាអែលហើយ ១៥អេលីសេទូល
តបថា សូមយកធ្នូនឹងព្រួញមក[ថ] ទ្រង់ក៏យកធ្នូ និងព្រួញមក
ឯលោក ១៦រួចទូលថា សូមទ្រង់ដំឡើងធ្នូទៅ នោះទ្រង់ក៏
ដំឡើង ហើយអេលីសេដាក់ដៃលើព្រះហស្តស្តេច ១៧រួច
លោកទូលថា សូមបើកបង្អួចខាងកើតទៅ ទ្រង់ក៏បើក
អេលីសេទូលថា សូមបាញ់ទៅ ហើយទ្រង់ក៏បាញ់[ទ] លោក
ទូលថា នេះហើយជាព្រួញជ័យនៃព្រះយេហូវ៉ាគឺជាព្រួញ
ជ័យជំនះដែលឈ្នះពួកសាសន៍ស៊ីរី ដ្បិតទ្រង់នឹងប្រហារពួក
ស៊ីរីនៅត្រង់អាផែក ទាល់តែគេវិនាសសាបសូន្យទៅ[ធ]
១៨រួចលោកទូលថា សូមចាប់យកព្រួញទាំងនោះទៅ ទ្រង់ក៏
ចាប់យក លោកក៏ទូលទៀតថា សូមបាញ់ទៅដីទៅ ទ្រង់ក៏
បាញ់អស់គំរប់៣ដង រួចឈប់ ១៩នោះអ្នកសំណប់របស់ព្រះ
ក៏ខឹងនឹងស្តេចហើយទូលថា គួរតែទ្រង់បានបាញ់ដល់ទៅ
៥ឬ៦ដងចុះ នោះទ្រង់នឹងបានវាយពួកស៊ីរី ទាល់តែបាន
បំផ្លាញគេ ឱ្យសូន្យបាត់ទៅ តែឥឡូវនេះទ្រង់នឹងវាយគេ

**១៣:១២** ឌ ២ពវ ១៤:១៥ ឍ ១ពវ ១៥:១៣
**១៣:១៣** ណ ២ពវ ១៤:២៣ ហស ១:១
**១៣:១៤** ត ២ពវ ២:១២
**១៣:១៥** ថ ១សយ ២០:២០
**១៣:១៧** ទ យស ៨:១៨ ធ ១ពវ ២០:២៦

ក្នុងឆ្នាំ ៨៥៧ ស្តេចអ័ហាប់ បានដាក់ទោសចំពោះទ័ពដែលត្រូវរបួស និង ស្លាប់ចំនួន ១០ម៉ឺននាក់នៅក្នុងថ្ងៃនោះ (មើល ១ពវ ២០:២៩) ។

**១៣:៨** *សៀវភៅ ជាពង្សាវតាររបស់ទ្រង់* មើលការពន្យល់ ១ពវ ១៤:១៩ ។

**១៣:៩** *ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់* មើលការពន្យល់ ១ពវ ១:២១។

**១៣:១០** *ឆ្នាំទី៣៧ក្នុងរាជ្យយ៉ូអាស* ស្ថិតនៅក្នុងឆ្នាំ ៧៩៨ មុន គ.ស (មើលការពន្យល់ ១២:១) ។ *១៦ឆ្នាំ* ស្ថិតនៅក្នុងឆ្នាំ ៧៩៨–៧៨២ មុន គ.ស ។

**១៣:១១** *អំពើបាបរបស់យេរ៉ូបោម* សូមមើល ១ពវ ១២:២៦–៣២ ១៣:៣៣–៣៤ ១៤:១៦ ។

**១៣:១២** *ច្បាំងនឹងអ័ម៉ាស៊ីយ៉ា* មើល ១៤:៨–១៤ ២របា ២៥:១៧–២៤ ។ *សៀវភៅ ជាពង្សាវតារពួកស្តេចអ៊ីស្រាអែល* មើលការពន្យល់ ១៤:១៩ ។

**១៣:១៣** *ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ* សូមមើលការពន្យល់ ១ពវ ១:២១ ។ *យេរ៉ូបោមបានសោយរាជ្យឡើងជំនួសទ្រង់* សម្រាប់រាជ្យរបស់ស្តេចយេរ៉ូបោមទី២ សូមមើល ១៤:២៣–២៩ ។

**១៣:១៤** *អេលីសេលោកចាប់ឈឺ* នៅក្នុងជំពូក៩ បានលើករៀបរាប់ពីលោកអេលីសេ ។ ដោយសារយេហ៊ូវ ត្រូវបានតែងតាំងនៅក្នុងឆ្នាំ ៨៤១ មុន គ.ស (មើលការពន្យល់ ១០:៣៦) ហើយយ៉ូអាសចាប់ផ្តើមគ្រងរាជ្យនៅក្នុង ឆ្នាំ ៧៩៨ មុន គ.ស (មើលការពន្យល់ ៦.១០) ។ ដូច្នេះ យ៉ាងហោចណាស់អស់រយៈពេលជាង ៤៣ឆ្នាំ ដែលមិនមានរៀបរាប់អំពីសកម្មភាពរបស់ហោរាអេលីសេ ។ ដោយយោងទៅលើ ទំនាក់ទំនងរវាងហោរាអេលីសេ និងហោរាអេលីយ៉ា នោះយើងអាចដឹងថា ហោរាអេលីសេបានកើតមុនឆ្នាំ ៨៨០ មុន គ.ស ហើយគាត់មានអាយុលើសពី៨០ឆ្នាំឡើងទៅ ។ *ព្រះរាជរថ និងទ័ពសេះរបស់ពួកអ៊ីស្រាអែល* ឃ្លានេះបានប្រាប់អំពីការទទួលស្គាល់របស់យ៉ូអាសថា ហោរាអេលីសេជាមនុស្សដ៏សំខាន់ក្នុងភាពជោគជ័យក្នុងកងទ័ពពួកអ៊ីស្រាអែល ជាងកងទ័ពរបស់ពួកអ៊ីស្រាអែលដែលបានចែងនៅក្នុង (ការពន្យល់ ២:១២ ៦:១៣,១៦–២៣) ។

**១៣:១៦** *ដាក់ដៃលើព្រហស្តស្តេច* សកម្មភាពនេះលោកអេលីសេ បានបញ្ជាក់ថា យ៉ូអាសបានជាប់ទាក់ទងជាមួយនឹងពួកស៊ីរីនៅក្នុងសមរភូមិជាមួយនឹងព្រះពររបស់ព្រះយេហូវ៉ា ។

**១៣:១៧** *បង្អួចខាងកើត* បង្អួចនេះទល់មុខនឹងទន្លេយ័រដាន់ ដែលតំបន់នេះត្រូវបានត្រួតត្រាដោយពួកស៊ីរី (មើល ១០:៣២–៣៣) ។ *អាផែក* ប្រហែលជា៦០ឆ្នាំដំបូង ស្តេចអ័ហាប់បានទទួលជ័យជម្នះទាំងស្រុងនៅក្នុងស្រុកអាផែកលើពួកស៊ីរី និង ស្តេចបេន–ហាដាឌ់ទី២ (មើល ១ពវ ២០:២៦–៣០ និង ការពន្យល់ ២០:២៦) ។

**១៣:១៨** *បាញ់អស់គំរប់៣ដង រួចឈប់* ឃ្លានេះបានប្រាប់អំពីការធ្វើតាមហោរាអេលីសេ បានបង្ហាញឱ្យដឹងពីភាពមិនគ្រប់គ្រាន់ក្នុងការសម្រេចការងារនេះ ។

**១៣:១៩** *វាយគេ បានត្រឹមតែ៣ដង* ឃ្លានេះបានប្រាប់យ៉ូអាសមិនមានសេចក្តីត្រេកអរខ្លាំងណាស់ណាទេ នៅក្នុងការវាយប្រហារដោយគ្រាប់ព្រួញដែល

បានត្រឹមតែ៣ដងប៉ុណ្ណោះ[ន] ។
២០ឯអេលីសេ លោកក៏ស្លាប់ទៅ ហើយគេបញ្ចុះសព
លោក រួចដល់ចូលឆ្នាំថ្មី នោះពួកកងនៃសាសន៍ម៉ូអាប់ ក៏
ទន្ទ្រាន[ប]ចូលមកក្នុងស្រុក ២១ហើយកាលមនុស្សកំពុងតែកប់
ខ្មោចរបស់មនុស្សម្នាក់ នោះក៏ឃើញពួកកង១រួចគេបោះ
ខ្មោះនោះ ទៅក្នុងផ្នូររបស់អេលីសេ កាលខ្មោចនោះបាន
ប៉ះនឹងឆ្អឹងអេលីសេហើយ ស្រាប់តែរស់ឡើងវិញ[ផ] រួច
ក្រោកឈរឡើង ។
២២ឯហាសែល ជាស្តេចស្រុកស៊ីរី ទ្រង់ចេះតែសង្កត់
សង្កិន[ព]ពួកអ៊ីស្រាអែល ដរាបដល់អស់ព្រះជន្មយ៉ូអាហាស
២៣ប៉ុន្តែព្រះយេហូវ៉ាទ្រង់មានព្រះហឫទ័យសប្បុរសដល់គេ
ក៏មានសេចក្តីមេត្តាករុណា ហើយយល់ដល់គេ ដោយព្រោះ
សេចក្តីសញ្ញា[ភ] ដែលទ្រង់តាំងនឹងអ័ប្រាហាំ អ៊ីសាក និង
យ៉ាកុប ទ្រង់មិនសព្វព្រហឫទ័យ និងបំផ្លាញ[ម]គេទេ ហើយ
លុះដល់វេលានោះ ទ្រង់ក៏មិនទាន់បោះបង់ចោលគេចេញ
ពីចំពោះទ្រង់នៅឡើយដែរ[យ] ២៤រួចមកហាសែលជាស្តេច
ស៊ីរីក៏សុគតទៅ នោះបេន-ហាដាឌ់[រ] ជាព្រះរាជបុត្រាក៏
សោយរាជ្យឡើងជំនួសបិតា ២៥រួចយ៉ូអាស ជាបុត្រនៃ
យ៉ូអាហាស ក៏ចាប់យកអស់ទាំងទីក្រុង ដែលហាសែលបាន
ច្បាំងចាប់យក ពីកណ្តាប់ព្រះហស្តនៃព្រះបិតា ចេញពី
កណ្តាប់ដៃនៃបេន-ហាដាឌ់ ជាបុត្រហាសែល មកវិញ
យ៉ូអាសទ្រង់វាយគេអស់៣ដង[ល] ហើយក៏បាន[វ]ទីក្រុងទាំង
ប៉ុន្មាន នៃពួកអ៊ីស្រាអែលមកវិញ ។

## អ័ម៉ាស៊ីយ៉ាឡើងជាស្តេចស្រុកយូដា

*១៤:១-៧ – ២រប ២៥:១-៤,១១-១២*

**១៣:១៩** ន ខ.២៥
**១៣:២០** ប ២ពវ ៥:២
**១៣:២១** ផ មថ ២៧:៥២
**១៣:២២** ព ១ពវ ១៩:១៧
**១៣:២៣** ភ នក ២:២៤ ម ចទ ២៩:២០ យ នក ៣៣:១៥ ២ពវ ១៧:១៨ ២៤:៣,២០
**១៣:២៤** រ ខ.៣
**១៣:២៥** ល ខ.១៨, ១៩ វ ២ពវ ១០:៣២
**១៤:៤** ក ២ពវ ១២:៣
**១៤:៥** ខ ២ពវ ២១:២៤ គ ១ពវ ១២:២០
**១៤:៦** ឃ ចទ ២៨:៦១ ង ជន ២៦:១១ យប ២១:២០ យរ ៣១:៣០ ៤៤:៣ អគ ១៨:៤,២០
**១៤:៧** ច ២សយ ៨:១៣ ឆ ពច ១:៣៦

*១៤:៨-២២ – ២រប ២៥:១៧-២៦:២*

**១៤** ១នៅឆ្នាំទី២ ក្នុងរាជ្យនៃយ៉ូអាស ជាបុត្រយ៉ូអាហាស
ស្តេចអ៊ីស្រាអែល នោះអ័ម៉ាស៊ីយ៉ា ជាបុត្រយ៉ូអាស ស្តេច
យូដា ក៏ចាប់តាំងសោយរាជនោះអ័ម៉ាស៊ីយ៉ា ជាបុត្រ
យ៉ូអាស ស្តេចយូដា ក៏ចាប់តាំងសោយរាជ្យឡើង ២កាល
ទ្រង់បានចាប់តាំងសោយរាជ្យឡើង នោះទ្រង់មានព្រះជន្ម
២៥ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុងយេរូសាឡិមបាន២៩
ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមថា យ៉ូអាដាន ជាអ្នកក្រុង
យេរូសាឡិម ៣ទ្រង់បានប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវនៅ
ព្រះនេត្រព្រះយេហូវ៉ា តែមិនដល់ដាវីឌជាឰយុកោទ្រង់ទេ
ទ្រង់បានប្រព្រឹត្តតាមគ្រប់ទាំងការ ដែលយ៉ូអាស ជាព្រះ
បិតាបានធ្វើ ៤ប៉ុន្តែមិនបានបំបាត់អស់ទាំងទីខ្ពស់ចោល
ចេញទេ[ក]ពួកបណ្តាជននៅតែថ្វាយយញ្ញបូជា ហើយដុត
កំញានៅលើទីខ្ពស់ទាំងនោះនៅឡើយ ៥កាលរាជ្យបាន
ជាប់នៅក្នុងអំណាចទ្រង់ហើយ នោះទ្រង់ក៏សំឡាប់[ខ]ពួក
បំរើ[គ] ដែលបានធ្វើគុតស្តេច ជាព្រះបិតាទ្រង់ទៅ ៦តែឯ
កូនចៅនៃពួកអ្នកដែលធ្វើគុតស្តេចនោះ ទ្រង់មិនបាន
សំឡាប់គេទេ តាមសេចក្តីដែលចែងទុកមក ក្នុងគម្ពីរ
ក្រិត្យវិន័យ[ឃ]របស់លោកម៉ូសេ ដូចជាព្រះយេហូវ៉ាបាន
បង្គាប់មកថា "ឪពុកមិនត្រូវទោសដល់ស្លាប់ ដោយព្រោះកូន
ហើយកូនក៏មិនត្រូវទោសដល់ស្លាប់ ដោយព្រោះឪពុកដែរ
គឺគ្រប់មនុស្សត្រូវស្លាប់ ដោយព្រោះតែអំពើ បាបរៀងៗខ្លួន
វិញ"[ង] ។
៧ទ្រង់ក៏ប្រហារពួកសាសន៍អេដំមអស់១ម៉ឺននាក់ នៅត្រង់
ច្រកភ្នំអំបិល[ច] ក៏ច្បាំងចាប់យកក្រុងសេឡា[ឆ] រួចដាក់ឈ្មោះ

ជ័យជម្នះនេះសមល្មមធ្វើឱ្យគាត់ទាស់ប្រឆាំងនឹងពួកស៊ីរី ។ វាបានបន្សល់ទុកយេរ៉ូបោមទី២ ជាបុត្ររបស់យ៉ូអាស ក្នុងការយកជ័យជម្នះលើពួកគេ (មើល ១៤:២៥,២៨) ។

**១៣:២១** *កាលខ្មោចនោះបានប៉ះនឹងឆ្អឹងអេលីសេហើយ ស្រាប់តែរស់ឡើងវិញ* អំណាចដែលធ្វើឱ្យជីវិតរស់ឡើងវិញនៅត្រង់នេះ គឺបានមកពីព្រះរបស់ហោរាអេលីសេ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់នៅទីចុងបំផុតក្នុងសញ្ញាចាស់ដែលនិយាយដល់លោកអេលីសេ (ការលើកឡើងពីអំណាចអតីតរបស់ហោរាអេលីសេ មើល ៤:៣២-៣៧ និង ១ពវ ១៧:១៧-២៤ និងការដែលព្រះបានលើកលោកអេលីយ៉ា (មើល ២:១១-១២) ។

**១៣:២៤** *បេន-ហាដាឌ់* មើលការពន្យល់ ខ.៣ ។

**១៣:២៥** *ទីក្រុងដែលហាសែល បានច្បាំងចាប់យក* ក្រុងនេះនៅខាងលិចទន្លេយ័រដាន់ ដោយព្រោះតំបន់ខាងកើតទន្លេយ័រដាន់ត្រូវបានបាត់បង់នៅក្នុងរជ្ជកាលព្រះបាទយេហ៊ូវ (មើល ១០:៣២-៣៣) ។ នៅក្នុងពេលនេះ វាមិនមែនជារាជ្យរបស់យេរ៉ូបោមទី២ ដែលទឹកដីខាងកើតទន្លេយ័រដាន់មានពេញដោយរាស្ត្រអ៊ីស្រាអែល (មើល ១៤:២៥) ។ *៣ដង* ពាក្យនេះសំគាល់ការសម្រេចតាមបទទំនាយរបស់ហោរាអេលីសេ (មើល ខ.៩) ។

**១៤:១** *ឆ្នាំទី២ ក្នុងរាជ្យនៃយ៉ូអាស* គឺស្ថិតនៅក្នុងឆ្នាំទី ៧៩៦ មុន គ.ស (មើលការពន្យល់ ១៣:១០) ។

**១៤:២** *២៩ឆ្នាំ* គឺស្ថិតនៅក្នុងឆ្នាំ ៧៩៦-៧៦៧ មុន គ.ស ។

**១៤:៣** *តែមិនដល់ដាវីឌជាឰយុកោទ្រង់* អ័ម៉ាស៊ីយ៉ា មិនបានលះចោលការថ្វាយបង្គំរូបព្រះរបស់ពួកសាសន៍ដទៃ (សូមមើល ២រប ២៥:១៤-១៦) ។ ភាពស្មោះត្រង់របស់ទ្រង់ចំពោះព្រះយេហូវ៉ា មានរយៈពេលខ្លីជាងស្តេចអេសា និងយេហូសាផាត ដែលបានប្រព្រឹត្តចំពោះព្រះយេហូវ៉ាពីមុនទ្រង់នោះទៅទៀត (សូមមើល ១ពវ ១៥:១១,១៤ ២២:៤៣ និងមើលប ១ពវ ៩:៤ ១១:៤) ។

**១៤:៤** *មិនបានបំបាត់អស់ទាំងទីខ្ពស់ចោលចេញ* មើលការពន្យល់ ១ពវ ១៥:១៤ ។

**១៤:៧** *ប្រហារពួកសាសន៍អេដំមអស់១ម៉ឺននាក់* នៅត្រង់នេះបញ្ជាក់ថា អ័ម៉ាស៊ីយ៉ា បានយកមកវិញនូវអ្វីដែលពួកយូដាបានគ្រប់គ្រងនៅស្រុកអេដំម ដែលទឹកដីនោះបានបាត់បង់នៅក្នុងរាជ្យព្រះបាទយេរ៉ូបោម (៨:២០-២២)

ទីក្រុងនោះថា យ៉ុកធាល ដរាបដល់សព្វថ្ងៃនេះ ៨ក្រោយ
នោះមក អ័ម៉ាស៊ីយ៉ាទ្រង់ចាត់សារ ទៅឯយ៉ូអាស ជាបុត្រ
យ៉ូអាហាស ដែលជាបុត្រយេហ៊ូវ ស្តេចអ៊ីស្រាអែល ទូលថា
ចូរចេញមក យើងល្បងលគ្នាមើល ៩តែយ៉ូអាស ជាស្តេច
អ៊ីស្រាអែល ទ្រង់ចាត់សារឱ្យទៅឯអ័ម៉ាស៊ីយ៉ា ជាស្តេចយូដា
វិញ ទូលថា ដើមបន្លា[ជ]ដែលដុះនៅលើភ្នំល្បាណូន បាន
ចាត់សារទៅឯដើមតាត្រៅនៅលើភ្នំល្បាណូនថា ចូរលើក
កូនស្រីឯងមកឱ្យធ្វើជាប្រពន្ធរបស់កូនប្រុសអញ ក៏មានសត្វ
ព្រៃសាហាវ ដែលនៅភ្នំល្បាណូនមកតាមនោះ ជាន់ឈ្លី
ដើមបន្លានោះទៅ ១០ឯទ្រង់ បានវាយឈ្នះពួកសាសន៍អេដំម
ពិតមែនហើយ ព្រះទ័យទ្រង់បានដំកើងទ្រង់ឡើង[ឈ] ចូរអួត
ពីដំណើរនោះចុះ ហើយនៅឯដំណាក់ទ្រង់ទៅ តើចង់រក
រឿង ដែលនឹងនាំឱ្យមានអន្តរាយ ឱ្យទ្រង់ត្រូវដួល ព្រមទាំង
ពួកយូដាផងធ្វើអី ។
១១ប៉ុន្តែអ័ម៉ាស៊ីយ៉ា ទ្រង់មិនព្រមស្តាប់តាមទេ ដូច្នេះ
យ៉ូអាស ជាស្តេចអ៊ីស្រាអែល ទ្រង់ក៏យាងឡើងទៅ រួចទ្រង់
នឹងអ័ម៉ាស៊ីយ៉ា ជាស្តេចយូដា ក៏ល្បងលគ្នានៅត្រង់ក្រុង
បេត-សេមែស[ញ] ជាទីក្រុងរបស់ពួកយូដា ១២ពួកយូដាក៏
ចាញ់ពួកអ៊ីស្រាអែល ហើយរត់ទៅឯទីលំនៅគេរៀងខ្លួន

**១៤:៩** ជ ពច ៩:៨-១៥
**១៤:១០** ឈ ២របា ២៦:១៦ ៣២:២៥
**១៤:១១** ញ យស ១៥:១០
**១៤:១២** ដ ១ពវ ២២:៣៦
**១៤:១៣** ឋ ១ពវ ៣:១ ២របា ៣៣:១៤ ៣៦:១៩ យរ ៣៩:២ ឌ នហ ៨:១៦ ១២:៣៩ ឍ ២របា ២៦:៩ យរ ៣១:៣៨ សក ១៤:១០
**១៤:១៥** ណ ២ពវ ១៣:១២

វិញ[ដ] ១៣ឯយ៉ូអាស ជាស្តេចអ៊ីស្រាអែល ទ្រង់ចាប់អ័ម៉ាស៊ីយ៉ា
ស្តេចយូដា ជាបុត្រយ៉ូអាស ដែលជាបុត្រអ័ហាស៊ីយ៉ា នៅ
ត្រង់បេត-សេមែស រួចទ្រង់យាងទៅដល់ក្រុងយេរូសាឡិម
រំលំកំផែងទីក្រុងបង់[ឋ] ចាប់តាំងពីទ្វារ[ឌ]អេប្រាអិម រហូត
ដល់ទ្វារជ្រុងកំផែង[ឍ] អស់៤០០ហត្ថ ១៤ទ្រង់ក៏យកមាសប្រាក់
ទាំងអស់ និងគ្រប់គ្រឿងប្រដាប់ទាំងប៉ុន្មាន ដែលឃើញមាន
នៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា ហើយនៅក្នុងព្រះរាជ
ទ្រព្យទាំងប៉ុន្មាន ព្រមទាំងចាប់មនុស្សបញ្ចាំទុក រួចនាំទាំង
អស់ត្រឡប់ទៅឯក្រុងសាម៉ារីវិញ ។
១៥រីឯដំណើរឯទៀតពីយ៉ូអាស ដែលទ្រង់បានធ្វើនឹង
អំណាចរបស់ទ្រង់ ហើយពីទ្រង់ច្បាំង[ណ]នឹងអ័ម៉ាស៊ីយ៉ា ជា
ស្តេចស្រុកយូដាយ៉ាងណា នោះសុទ្ធតែបានកត់ទុកក្នុង
សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែលហើយ
១៦យ៉ូអាសក៏ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់ ហើយគេ
បញ្ចុះទ្រង់ នៅក្រុងសាម៉ារី ជាមួយនឹងពួកស្តេចអ៊ីស្រា
អែលទៅ រួចយេរ៉ូបោម ជាព្រះរាជបុត្រា ក៏ឡើងសោយ
រាជ្យជំនួសបិតា ។
១៧ក្រោយដែលយ៉ូអាស ជាបុត្រយ៉ូអាហាស ស្តេច
អ៊ីស្រាអែល បានសុគតទៅ នោះអ័ម៉ាស៊ីយ៉ា ជាបុត្រយ៉ូអាស

*ច្រកភ្នំអំបិល* នេះជាសមរភូមិតែមួយដែលស្តេចដាវីឌ បានវាយប្រហាលើស្រុកអេដំម (មើល ២សយ ៨:១៣ ១របា ១៨:១២ ទដ ៦០ ចំណងជើង) ហើយតំបន់នេះស្ថិតនៅភាគខាងត្បូងនៃសមុទ្រស្លាប់ ។ *សព្វថ្ងៃនេះ* ពាក្យនេះអ្នកនិពន្ធចង់បញ្ជាក់ពីរាជ្យរបស់អ័ម៉ាស៊ីយ៉ា (សូមមើលការពន្យល់ ១ពវ ៨:៨ និងសេចក្តីផ្តើម ប្រភព និងការបរិច្ឆេទ) ។

**១៤:៨** *ចូរចេញមក យើងល្បងគ្នាមើល* នេះជាការល្បងលគ្នា ក្នុងការប្រកាសសង្គ្រាម ។ នេះប្រហែលជាបង្កឡើងដោយពួកទាហានស៊ីឈ្នួលដែលចេញមកពីភាគខាងជើង ក្រោយពីការបណ្តេញពួកទាហាយូដា(មើល ២របា ២៥:១០,១៣) ហើយនិងការបដិសេធរបស់យ៉ូអាស ក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ជាមួយនឹងអ័ម៉ាស៊ីយ៉ា(ខ.៩) ។

**១៤:៩** *យ៉ូអាស . . . ទូលថា* សម្រាប់ការឆ្លើយតបទៅវិញ យ៉ូអាសបានប្រើរឿងព្រេងមួយនៅក្នុង (មើល ពច ៩:៨-១៥) ដែលទ្រង់បានបញ្ជាក់ខ្លួនទ្រង់ថា ជាដើមតាត្រៅ ហើយអ័ម៉ាស៊ីយ៉ាជាគុម្ពបន្លាដែលមិនមានសារៈសំខាន់ដែលងាយនឹងបំផ្លាញ ។

**១៤:១១** *ទ្រង់មិនព្រមស្តាប់តាម* មើល ២របា ២៥:២០ ។ *ក្រុងបេត-សេមែស* ក្រុងនេះមានចំងាយប្រហែលជា ២៤ គីឡូម៉ែត្រពីក្រុងយេរ៉ូសាឡិម (សូមមើល យស ១៥:១០ ១សយ ៦:៩ និងការពន្យល់) ។

**១៤:១៣** *យ៉ូអាស . . . ទ្រង់ចាប់អ័ម៉ាស៊ីយ៉ា* ចំណុចនេះបញ្ជាក់ថា អ័ម៉ាស៊ីយ៉ាប្រហែលជាត្រូវបានបញ្ជូនទៅអាណាចក្រខាងជើង ក្នុងនាមជាអ្នកទោស ហើយគេបានដោះលែងគាត់និងបញ្ជូនគាត់ទៅឯស្រុកយូដាវិញ ក្រោយពីការសុគតរបស់យ៉ូអាស (មើល ខ.១៥-១៦ និងមើលបន្ថែមការពន្យល់ ខ.២១) ។ *ទ្វារអេប្រាអិម រហូតដល់ទ្វារជ្រុងកំផែង* សម្រាប់ទ្វារកំផែងនេះគឺស្ថិតនៅទិសពាយព្យនៃជញ្ជាំងក្រុងយេរ៉ូសាឡិម (មើល យរ ៣១:៣៨ សក ១៤:១០) ។ ទ្វារអេប្រាអិមនេះ ស្ថិតនៅភាគខាងជើងក្រុងយេរ៉ូសាឡិម (មើល នហ ១២:៣៩) ហើយមានចំងាយ ១៨០ម៉ែត្រពីទ្វារកំផែងក្រុង ។ ភាគពាយព្យនៃកំផែងក្រុងយេរ៉ូសាឡិម ជាចំណុចគ្រោះថ្នាក់បំផុតក្នុងការវាយប្រហារ ។

**១៤:១៤** *មាសប្រាក់ទាំងអស់ នឹងគ្រប់គ្រឿងប្រដាប់ទាំងប៉ុន្មាន . . . នៅក្នុងព្រះរាជ្យទ្រព្យ* នៅត្រង់នេះបញ្ជាក់ថា វត្ថុមានតម្លៃ និង ប្រដាប់ប្រដាផ្សេងៗដែលបានមកពីការប្លន់នោះមិនមានចំនួនច្រើនណាស់ណាទេ ពីព្រោះយ៉ូអាស មានការយល់ច្រឡំដោយបរិច្ចាកវាទៅដល់ព្រះវិហារ និងឃ្លាំងព្រះរាជ្យទ្រព្យទៅដល់ស្តេចហាសែលនៃស្រុកដាម៉ាស (មើល ១២:១៧-១៨) ។ *ចាប់មនុស្សបញ្ចាំទុក* មនុស្សដែលត្រូវបានគេបង្ខាំងទុកនេះ គឺក្នុងគោលបំណង ឱ្យបានរួចផុតពីការឆក់ប្លន់របស់ទ្រព្យផ្សេងៗនៅក្នុសមរភូមិប្រយុទ្ធ ។

**១៤:១៥** *សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែល* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

**១៤:១៦** *ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់* មើល ១៣:១២-១៣ និងមើលការពន្យល់ ១ពវ ១:២១ ។

**១៤:១៧** *មានព្រះជន្មរស់នៅបាន១៥ឆ្នាំទៀត* ស្តេចយ៉ូអាសបានសុគតដោយស្ថិតនៅក្នុងឆ្នាំ ៧៨២ មុន គ.ស និងអ័ម៉ាស៊ីយ៉ាសុគតនៅក្នុងឆ្នាំ ៧៦៧ មុន គ.ស ។

ស្តេចយូដា ទ្រង់មានព្រះជន្មរស់នៅបាន១៥ឆ្នាំទៀត ¹⁸រីឯ
ដំណើរឯទៀតពីអ័ម៉ាស៊ីយ៉ា នោះសុទ្ធតែបានកត់ទុក ក្នុង
សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដាហើយ ¹⁹មាន
គេគិតក្បត់[ត]នឹងទ្រង់ នៅក្រុងយេរូសាឡិម ហើយទ្រង់រត់
ទៅឯក្រុងឡាគីស[ថ] តែគេចាត់មនុស្សឱ្យទៅឯក្រុងឡាគីស
តាមទ្រង់ ក៏ធ្វើគុតនៅទីនោះ ²⁰គេដាក់សពទ្រង់លើសេះ[ទ]
នាំយកបញ្ចុះនៅក្រុងដាវីឌ ជាមួយនឹងពួកឰយុកោទ្រង់វិញ
គឺនៅក្រុងយេរូសាឡិម ²¹នោះពួកបណ្តាជនទាំងឡាយ គេ
ក៏លើកអ័សារា[ធ] ដែលទ្រង់មានព្រះជន្ម១៦ឆ្នាំ តាំងឡើង
ឱ្យធ្វើជាស្តេច ជំនួសអ័ម៉ាស៊ីយ៉ាបិតាទ្រង់ ²²គឺស្តេចនេះ
ហើយ ដែលសង់ក្រុងអេឡាតឡើង[ន] ហើយបានបង្វិលមក
ខាងយូដាវិញ ក្រោយមកស្តេចក៏ផ្ទឹលក់ទៅជាមួយនឹងពួក
ឰយុកោទ្រង់ទៅ ។

## យេរ៉ូបោមឡើងជាស្តេចស្រុកអ៊ីស្រាអែល

²³នៅឆ្នាំទី១៥ក្នុងរាជ្យអ័ម៉ាស៊ីយ៉ា ជាបុត្រយ៉ូអាស ស្តេច
យូដា នោះយេរ៉ូបោម[ប] ជាបុត្រយ៉ូអាស ស្តេចអ៊ីស្រាអែល
ក៏ចាប់តាំងសោយរាជ្យឡើង នៅក្រុងសាម៉ារី ក៏សោយ
រាជ្យបាន៤១ឆ្នាំ ²⁴ទ្រង់បានប្រព្រឹត្តអំពើដ៏លាមកអាក្រក់
នៅព្រះនេត្រព្រះយេហូវ៉ា ទ្រង់មិនបានលាកបង់លែង
ប្រព្រឹត្តតាមអស់ទាំងអំពើបាបរបស់យេរ៉ូបោម ជាកូននេ
បាត ដែលបាននាំឱ្យពួកអ៊ីស្រាអែលធ្វើបាបតាមនោះទេ[ផ]
²⁵តែទ្រង់បានតាំងព្រំស្រុកអ៊ីស្រាអែលឡើងវិញ ចាប់តាំង
ពីទ្វារចូលស្រុកហាម៉ាត[ព] រហូតដល់សមុទ្រនៅស្រុកវាល[ភ]
តាមព្រះបន្ទូលដែលព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រា–
អែល បានមានបន្ទូលដោយសារហោរាយ៉ូណាស[ម]ជាកូន
អ័មីថាយ ជាអ្នកបំរើទ្រង់ ដែលនៅកាថ–ហេភើរ ²⁶ដ្បិត
ព្រះយេហូវ៉ាទ្រង់ទតឃើញសេចក្តីវេទនា[យ]របស់អ៊ីស្រា–
អែល ថាជាជូរចត់ណាស់ ដ្បិតគ្មានអ្នកណាបិតបាំងទុក[រ] ឬ
អ្នកណាដែលឥតចំណងឡើយ[ល] ក៏គ្មានអ្នកណា សំរាប់ជួយ
សង្គ្រោះ ដល់ពួកសាសន៍អ៊ីស្រាអែលដែរ ²⁷ឯព្រះ
យេហូវ៉ាទ្រង់មិនបានថា ទ្រង់និងលុប[វ]ឈ្មោះពួកអ៊ីស្រា–
អែលចេញ ពីក្រោមមេឃនោះទេ បានជាទ្រង់ជួយ
សង្គ្រោះ[ស]គេ ដោយសាព្រះហស្តយេរ៉ូបោម ជាបុត្រ
យូអាសវិញ ។

**១៤:១៩** ត ២ពវ ១២:២០ ថ យស ១០:៣
**១៤:២០** ទ ២ពវ ៩:២៨
**១៤:២១** ធ ២ពវ ១៥:១ ២របា ២៦:២៣ អស ១:១ ហស ១:១ អម ១:១
**១៤:២២** ន ១ពវ ៩:២៦
**១៤:២៣** ប ២ពវ ១៣:១៣ ១របា ៥:១៧ អម ១:១ ៧:១០
**១៤:២៤** ផ ១ពវ ១៥:៣០
**១៤:២៥** ព ជន ១៣:២១ ភ ចទ ៣:១៧ ម យហ ១:១ មថ ១២:៣៩
**១៤:២៦** យ ២ពវ ១៣:៤ រ ចទ ៣២:៣៦ ល ទដ ១៨:៤១ ២២:១១ ៧២:១២ ១០៧:១២ អស ៦៣:៥ បទ ១:៧
**១៤:២៧** វ ចទ ២៩:២០ ស ពច ៦:១៤

**១៤:១៨** *សៀវភៅ ជាពង្សាវតាររបស់ស្តេចយូដា* មើលការពន្យល់ ១ពវ ១៤:២៩ ។

**១៤:១៩** *ក្បត់នឹងទ្រង់* នៅក្នុង ២របា ២៥:២៧ ជាប់ទាក់ទងនឹងការក្បត់របស់អ័ម៉ាស៊ីយ៉ាដែលបានលះចោលព្រះយេហូវ៉ា ។ ចំណុចត្រង់នេះ វាមិនបានបម្រើឱ្យគោលបំណងរបស់អ្នកនិពន្ធកណ្ឌគម្ពីរពង្សាវតារក្សត្រនេះទេ ។ *ក្រុងឡាគីស* ក្រុងនេះជាប៉មមួយដែលស្ថិតនៅភាគខាងជើងស្រុកយូដាដែលមានចំងាយ២៤គីឡូម៉ែត្រពីភាគខាងលិចក្រុងហេប្រុន ដែលបច្ចុប្បន្នត្រូវបានគេហៅថា ថេលអេត "ឌូវៀ" (Tell ed-Duweir) មើល ១៨:១៤ ២របា ១១:៩) ។

**១៤:២១** *ពួកបណ្តាជនទាំងឡាយ គេក៏លើកអ័សារា . . . តាំងឡើង* នេះគឺមិនមែនពួកបណ្តាជនទាំងអស់នៅស្រុកយូដាគាំទ្រក្នុងការលើកអ័សារាឱ្យធ្វើជាស្តេចនោះទេ ។

**១៤:២២** *សង់ក្រុងអេឡាតឡើង ហើយបានបង្វិលមកខាងយូដាវិញ* អ័សារាបានពង្រីកការគ្រប់គ្រងនៅស្រុកអេដំម ដោយចាប់ផ្តើមឡើងតាំងពីបិតារបស់ទ្រង់(ខ.៧) ហើយបានធ្វើឱ្យពួកអ៊ីស្រាអែលគ្រប់គ្រងលើកំពង់ផែសំខាន់នៅស្រុកអេដំមនេះ(មើល ១ពវ ៩:២៦) ។ ស្នាមត្រារបស់ព្រះរាជាដែលជារបស់យ៉ូថាម(មើល ១៥:៣២) ត្រូវបានគេរកឃើញនៅជិតក្រុងអេឡាតបុរាណដែលបញ្ជាក់ពីវត្តមានរបស់ពួកសាសន៍យូដារស់នៅក្រុងអេឡាត ក្នុងពេលនោះ ។

**១៤:២៣** *ឆ្នាំទី១៥ក្នុងរាជ្យអ័ម៉ាស៊ីយ៉ា* ក្នុងរាជ្យនេះស្ថិតនៅក្នុងឆ្នាំទី ៧៨២ មុន គ.ស (មើលការពន្យល់ ខ.២) ។ នៅក្នុងឆ្នាំនេះ ជាការចាប់ផ្តើមនៃរាជ្យស្តេចយេរ៉ូបោម ។ *៤១ឆ្នាំ* ឆ្នាំនេះស្ថិតនៅក្នុងឆ្នាំ ៧៩៣–៧៥៣ មុន គ.ស ។

**១៤:២៤** *អំពើបាបរបស់យេរ៉ូបោម* សូមមើល ១ពវ ១២:២៦–៣២ ១៣:៣៣–៣៤ ១៤:១៦ អម ៣:១៣–១៤ ៤:៤–៥ ៥:៤–៦ ៧:១០–១៧ ។

**១៤:២៥** *ស្រុកហាម៉ាត* ស្តេចយេរ៉ូបោម គឺអាចធ្វើឱ្យទឹកដីអ៊ីស្រាអែលបានរួចចេញពីការសង្កត់សង្កិន ពីកណ្តាប់ដៃស្តេចហាសែល និង បេន–ហាដាឌ់ (មើល ១០:៣២ ១២:១៧ ១៣:៣,២២,២៥) ។ ស្តេចយ៉ូអាស ថែមទាំងបានពង្រីកនូវគោលនយោបាយអ៊ីស្រាអែលត្រួតត្រាលើពួកស៊ីរីនៅក្នុងស្រុកដាម៉ាស ដែលទ្រង់បានចាប់ផ្តើមធ្វើការងារនេះជាមួយនឹងបិតារបស់ទ្រង់ដែលមាននាមថាយ៉ូអាហាស (មើល ១៣:២៥) ។ *សមុទ្រនៅស្រុកវាល* ដោយយោងលើ អម ៦:១៤ ដែលអាណាចក្រខាងត្បូងនៃព្រំប្រទលស្រុករបស់ស្តេចយេរ៉ូបោមក្នុងការឆ្លងកាត់គឺ "ច្រកនៃសមុទ្រស្លាប់" ប្រហែលជាត្រូវតភ្ជាប់ទៅនឹងច្រកភ្នំអំបិល (មើលការពន្យល់ ខ.៧) ។ ប្រសិនបើដូច្នេះ ស្តេចយេរ៉ូបោម និងត្រូវស្អប់សាសន៍ម៉ូអាប់ហើយនិងសាសន៍អាំម៉ូន ។ ព្រះបន្ទូលដែល *ព្រះយេហូវ៉ា . . .បានមានបន្ទូលដោយសារហោរាយ៉ូណាស់* មិនបានបង្ហាញ ឱ្យឃើញនៅក្នុងព្រះគម្ពីរយូណាស់ទេ ។ យ៉ាងណាក៏ដោយ ទីសម្គាល់ទីនេះ អាចជួយក្នុងការបរិច្ឆេទនៃរបស់អ្នកតំណាង ។ *កាថ–ហេបភើរ* គឺបានរកឃើញពូជអំបូរតាំងលំនៅខាងជើងឈាងខាងកើតណាសារ៉ែត (មើល យស ១៩:១៣) ។

**១៤:២៧** *ព្រះយេហូវ៉ាទ្រង់មិនបានថា* ឃ្លានេះបានប្រាប់ថាអំពើបាបរបស់ពួកអ៊ីស្រាអែលនៅមិនទាន់ពេញហូហៀ ហើយសេចក្តីមេត្តាករុណារបស់ព្រះយេហូវ៉ាបានបង្ហូរទៅដល់ជាតិសាសន៍នេះ ជាការផ្តល់ឱកាសបន្ថែមទៀតដល់ពួកគេដើម្បីឱ្យបានសង្គ្រោះ (មើលការពន្យល់ ១៣:៣៣) ។ ទោះ

២៨រីឯដំណើរឯទៀតពីយេរ៉ូបោម នឹងការដែលទ្រង់ធ្វើ
ទាំងប៉ុន្មាន ហើយពីអំណាចទ្រង់ ដែលទ្រង់បានច្បាំងព្រម
ទាំងការដែលចាប់យកក្រុងដាម៉ាស[ហ]និងក្រុងហាម៉ាត់[ឡ]
ជាទីក្រុងនៃពួកយូដា មកខាងពួកអ៊ីស្រាអែលវិញជាយ៉ាង
ណា នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជាពង្សាវតារ[អ]
របស់ពួកស្តេចអ៊ីស្រាអែលហើយ ២៩យេរ៉ូបោមក៏ផុតលក់
ទៅជាមួយនឹងពួកឰយុកោ គឺជាពួកស្តេចអ៊ីស្រាអែលទាំង
ប៉ុន្មានទៅ រួចសាការី ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យ
ជំនួសបិតា ។

## អ័សារាឡើងជាស្តេចស្រុកអ៊ុស្រាអែល

*១៥:១-៧-២របា ២៦:៣-៤,២១-២៣*

**១៥** ១នៅឆ្នាំទី២៧ ក្នុងរាជយេរ៉ូបោម ស្តេចអ៊ីស្រាអែល
នោះអ័សារា[ក] ជាបុត្រអ័ម៉ាស៊ីយ៉ា ស្តេចយូដា ក៏ចាប់តាំង
សោយរាជ្យឡើង ២កាលទ្រង់ចាប់តាំងសោយរាជ្យឡើង
នោះទ្រង់មានព្រះជន្ម១៦ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន៥២ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជាយេកូលា
ជាអ្នកក្រុងយេរូសាឡិម ៣ទ្រង់បានប្រព្រឹត្តអំពើដ៏ត្រឹមត្រូវ[ខ]
នៅព្រះនេត្រព្រះយេហូវ៉ា តាមគ្រប់ទាំងសេចក្តីដែលអ័ម៉ា
ស៊ីយ៉ា ជាបិតាទ្រង់ បានធ្វើដែរ ៤ប៉ុន្តែ មិនបានបំបាត់អស់
ទាំងទីខ្ពស់ចោលចេញទេ ពួកបណ្តាជននៅតែថ្វាយយញ្ញ
បូជា ហើយដុតកំញាននៅលើទីខ្ពស់ទាំងនោះនៅឡើយ
៥ព្រះយេហូវ៉ាទ្រង់បានធ្វើ ឱ្យ[គ]ស្តេចកើតរោគឃ្លង់ ដរាប
ដល់អស់ព្រះជន្ម ហើយទ្រង់ត្រូវគង់នៅតំណាក់១ ដោយ
ខ្លួន[ឃ] ឯយ៉ូថាម[ង] ជាព្រះរាជបុត្រា ក៏ត្រួតត្រាការទាំងអស់
ក្នុងព្រះរាជវាំង[ច] ព្រមទាំងគ្រប់គ្រងលើបណ្តាជននៅស្រុក
នោះផង ៦រីឯដំណើរឯទៀតពីអ័សារា និងការទាំងប៉ុន្មាន
ដែលទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជា
ពង្សាវតារនៃពួកស្តេចយូដាហើយ ៧អ័សារាក៏ផុតលក់[ឆ]ទៅ
ជាមួយនឹងពួកឰយុកោទ្រង់ ហើយគេបញ្ចុះទ្រង់នៅក្រុង
ដាវីឌជា មួយនឹងពួកឰយុកោទ្រង់ រួចយ៉ូថាម[ជ] ជាព្រះរាជ
បុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា ។

## សាការីឡើងជាស្តេចអ៊ុស្រាអែល

៨នៅឆ្នាំទី៣៨ ក្នុងរាជអ័សារា ជាស្តេចយូដា នោះ
សាការី ជាបុត្រយេរ៉ូបោម ចាប់តាំងសោយរាជ្យឡើយ
លើស្រុកអ៊ីស្រាអែលនៅក្រុងសាម៉ារី ក៏ឡើងសោយបាន
៦ខែ ៩ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ឈ] នៅព្រះនេត្រ

**១៤:២៨** ហ ២សយ ៨:៥ ឡ ២សយ ៨:៩ អ ១ពវ ១៥:៣១
**១៥:១** ក ខ.៣២ ២ពវ ១៤:២១
**១៥:៣** ខ ១ពវ ១៤:៨
**១៥:៥** គ លប ១២:១៧ ឃ លវ ១៣:៤៦ ង ខ.៧,៣២ មីក ១:១ ច លប ៤១:៤០
**១៥:៧** ឆ អស ៦:១ ១៤:២៨ ជ ខ.៥
**១៥:៩** ឈ ១ពវ ១៥:២៦

ជាយ៉ាងណាក៏ដោយ ភាពមានះនៅក្នុងចំណោមពួកមិនជឿ បាននាំពួកគេឱ្យធ្លាក់ចូលក្នុងការជំនុំជម្រះរបស់ព្រះ (សូមមើល អម ៤:២-៣ ៦:១៤) ។ *ជួយសង្គ្រោះគេ ដោយសារព្រះហស្តយេរ៉ូបោម* មើលការពន្យល់ ១៣:៥ ។

**១៤:២៨** *ការដែលទ្រង់ធ្វើ* ក្នុងអំឡុងនៃរាជ្យស្តេចយេរ៉ូបោម ទឹកដីអ៊ុស្រាអែលមានភាពសម្បូរសម្បាយ ជាងរាជ្យស្តេចដាវីឌ និងសាឡូម៉ូន ។ តែជាអកុសល វាជាសម័យកាលសាសនា និងការបោះបង់សាសនា ហើយនិងអយុត្តិធម៌សង្គម (មើល អម និង ហស ដែលបញ្ជាក់ពីការទោះទាយក្នុងរាជ្យស្តេចយេរ៉ូបោម) ។ *ក្រុងដាម៉ាស និងក្រុងហាម៉ាត* មើលការពន្យល់ ខ.២៥ ។ *សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ុស្រាអែល* សូមមើលការពន្យល់ ១ពវ ១៤:១៩ ។

**១៤:២៩** *ផុតលក់ទៅជាមួយនឹងពួកឰយុកោ* មើលការពន្យល់ ១ពវ ១:២១ ។ *សាការី ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា* សម្រាប់រាជ្យរបស់ស្តេចសាការី សូមមើល ១៥:៨-១២ ។

**១៥:១** *ឆ្នាំទី២៧ក្នុងរាជ្យយេរ៉ូបោម* នេះជាឆ្នាំ៧៦៧ មុន គ.ស ដោយយោលលើការបរិច្ឆេទដំបូងការចាប់ផ្តើមនៃរាជ្យរបស់យេរ៉ូបោម ជាមួយនឹងរាជ្យរបស់យ៉ូអាសនៅក្នុងឆ្នាំ ៧៩៣ (សូមមើលការពន្យល់ ១៤:២៣) ។ *អ័សារា . . . ក៏ចាប់តាំងសោយរាជ្យឡើង* គឺគាត់ចាប់ផ្តើមឡើងគ្រងរាជ្យបន្ទាប់ពីអាយុ២៤ឆ្នាំ............ជាមួយនិងបិតរបស់ទ្រង់អ័ម៉ាស៊ីយ៉ា (មើលការពន្យល់ ខ.២ ១៤:២,២១) (ឆ្នាំដែលពិតប្រាកដនោះ គឺតិចជាងឆ្នាំដែលពិសេសដែរ) ។

**១៥:២** *៥២ឆ្នាំ* ឆ្នាំនេះស្ថិតនៅក្នុងឆ្នាំ ៧៩២-៧៤០ មុន គ.ស (ប៉ុន្តែលោកបានធ្វើតាមដែលបិតាទ្រង់អ័ហាស៊ីយ៉ាធ្លាប់ធ្វើ ៧៩២-៧៦៧) មើលការពន្យល់ ខ.១ ។

**១៥:៣** *សេចក្តីដែលអ័ម៉ាស៊ីយ៉ា ជាបិតាទ្រង់ បានធ្វើដែរ* សូមមើលការពន្យល់ ១៤:៣ ។

**១៥:៤** *ប៉ុន្តែ មិនបានបំបាត់អស់ទាំងទីខ្ពស់ចោលចេញទេ* សូមមើល ១៤:៣ និងមើលបន្ថែមការពន្យល់ ១ពវ ១៥:១៤ ។

**១៥:៥** *ព្រះយេហូវ៉ាទ្រង់បានធ្វើ ឱ្យស្តេចកើតរោគឃ្លង់* ឃ្លានេះបានប្រាប់ពីការកាត់ទោស ចំពោះការដណ្តើមការងាររបស់ពួកសម្តេចសង្ឃ ដែលព្រះអង្គទ្រង់បានចូលទៅដុតគ្រឿងក្រអូបនៅទីអាសនាក្នុងព្រះវិហារ (មើល ២៦:១៦-២១ ធៀប លវ ១៣:៤៦) ។ *ត្រួតត្រាការទាំងអស់ក្នុងព្រះរាជវាំង ព្រមទាំងគ្រប់គ្រងលើបណ្តាជននៅស្រុកនោះ* នេះបញ្ជាក់ថា ស្តេចយ៉ូថាមបានគ្រប់គ្រងលើទឹកដីនេះ ក្នុងខណៈដែលព្រះបិតារបស់ខ្លួនកំពុងមានព្រះជន្មនៅឡើយ (មើល ៧៥០-៧៤០ មុន គ.ស និង ការពន្យល់ ខ.៣៣) ។

**១៥:៦** *ការទាំងប៉ុន្មានដែលទ្រង់ធ្វើ* សម្រាប់សេចក្តីលំអិតបន្ថែមពីសម្មិទ្ធិផលរបស់ស្តេចអ័សារានោះត្រូវបានគេរកឃើញនៅក្នុង ២របា ២៦:១-១៥ ។ *សៀវភៅ ជាពង្សាវតារនៃពួកស្តេចយូដា* សូមមើលការពន្យល់ ១ពវ ១៤:១៩ ។

**១៥:៧** *ផុតលក់ទៅជាមួយនឹងពួកឰយុកោទ្រង់* សូមមើលការពន្យល់ ១ពវ ១:២១ ។ *យ៉ូថាម ជាព្រះរាជបុត្រា ក៏ឡើងសោយរាជជំនួសបិតា* សម្រាប់រាជរបស់ព្រះបាទយ៉ូថាម សូមមើល ការពន្យល់ ខ.៣២-៣៨ ។

**១៥:៨** *នៅឆ្នាំទី៣៨ ក្នុងរាជ្យអ័សារា* នេះគឺនៅក្នុងឆ្នាំ ៧៥៣ មុន គ.ស និង ការពន្យល់ ខ.២ ។

**១៥:៩** *អំពើបាបរបស់យេរ៉ូបោម* សូមមើល ១ពវ ១២:២៦-៣២ ១៣:៣៣-៣៤ ១៤:១៦ ។

ព្រះយេហូវ៉ា ដូចជាពួកឰយុកោទ្រង់បានធ្វើដែរ ទ្រង់មិន
បានលាកបង់លែងតាមអំពើបាបរបស់យេរ៉ូបោម ជាកូន
របស់នេបាត ដែលបាននាំពួកអ៊ីស្រាអែលធ្វើបាប តាម
នោះទេ ១០គ្រានោះសាលូម ជាកូនយាបេស បានក្បត់
ហើយធ្វើគុត[ញ]ទ្រង់នៅចំពោះប្រជាជនទាំងឡាយ រួចឡើង
សោយរាជ្យជំនួសទ្រង់ ១១រីឯដំណើរឯទៀតពីសាការី នោះ
សុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជាពង្សាវតារ[ដ]របស់ពួក
ស្តេចអ៊ីស្រាអែលហើយ ១២នេះហើយជាសេចក្តីដែលព្រះ
យេហូវ៉ាទ្រង់បានមានបន្ទូលនឹងយេហ៊ូវថា[ឋ] គឺពួកកូនចៅ
ឯងនឹងបានសោយរាជ្យលើពួកអ៊ីស្រាអែល ដរាបដល់៤
ដំណ ការនោះក៏កើតមានដូច្នោះមែន ។

## សាលូមឡើងជាស្តេចអ៊ីស្រាអែល

១៣ឯសាលូម ជាកូនយ៉ាបេស ទ្រង់ចាប់តាំងសោយរាជ្យ
នៅឆ្នាំទី៣៩ក្នុងរាជ្យអ័សារា ជាស្តេចយូដា ក៏សោយរាជ្យ
នៅក្រុងសាម៉ារី[ឍ]បាន១ខែ ១៤រួចមណាហិមជាកូនកាឌីក៏
ចេញពីក្រុងធើសា[ឈ] ឡើងទៅឯក្រុង សាម៉ារីសំឡាប់[ណ]
សាលូម ជាកូនយ៉ាបេសបង់ នៅក្រុងសាម៉ារីទៅហើយ
ឡើងសោយរាជ្យជំនួសទ្រង់ ១៥រីឯដំណើរឯទៀតពីសាលូម
និងការក្បត់ដែលទ្រង់បង្កើត នោះសុទ្ធតែបានកត់ទុកក្នុង

**១៥:១០** ញ ២ពវ ១២:២០
**១៥:១១** ដ ១ពវ ១៥:៣១
**១៥:១២** ឋ ២ពវ ១០:៣០
**១៥:១៣** ឌ ១ពវ ១៣:៣២
**១៥:១៤** ឍ ១ពវ ១៥:៣៣ ណ ២ពវ ១២:២០
**១៥:១៥** ត ១ពវ ១៥:៣១
**១៥:១៦** ថ ១ពវ ៤:២៤ ទ ២ពវ ៨:១២ ហស ១៣:១៦
**១៥:១៨** ធ ១ពវ ១៥:២៦
**១៥:១៩** ន ១រប ៥:៦,២៦

សៀវភៅ ជាពង្សាវតារ[ត]របស់ពួកស្តេចអ៊ីស្រាអែលហើយ
១៦គ្រានោះមណាហិមទ្រង់វាយ ក្រុងពីពសានឹងមនុស្សទាំង
អស់ដែលនៅក្នុងក្រុងនោះ ព្រមទាំងស្រុកនៅជុំវិញ ចាប់
តាំងពីធើសា[ថ]ទៅ ពីព្រោះគេមិនបានបើក[ទ]ទ្វារក្រុងទទួល
ទ្រង់ទេ បានជាទ្រង់ប្រហារជីវិតគេ ហើយវះពោះពួកស្រីៗ
ដែលមានទំងន់ទាំងប៉ុន្មានផង ។

## មណាហិមឡើងជាស្តេចលើពួកអ៊ីស្រាអែល

១៧នៅឆ្នាំទី៣៩ ក្នុងរាជ្យអ័សារា ជាស្តេចយូដា នោះ
មណាហិម ជាកូនកាឌី ចាប់តាំងសោយរាជ្យលើពួក
អ៊ីស្រាអែល ក៏សោយរាជ្យនៅក្រុងសាម៉ារីបាន១០ឆ្នាំ
១៨ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ធ] នៅព្រះនេត្រព្រះ
យេហូវ៉ា គឺដរាបដល់អស់ព្រះជន្មទ្រង់ នោះទ្រង់មិនបាន
វៀរបង់លែងតាមអំពើបាបដែលយេរ៉ូបោម ជាកូននេបាត
បានធ្វើ ទាំងនាំឱ្យពួកអ៊ីស្រាអែលធ្វើតាមនោះឡើយ ១៩នៅ
គ្រានោះពូល[ន] ជាស្តេចស្រុកអាសសើរ ក៏ទន្ទ្រានចូល ក្នុង
ស្រុក ហើយមណាហិម ទ្រង់ថ្វាយប្រាក់១ពាន់ហាប ដល់
ពូលឱ្យបានពួតដៃជួយឱ្យរាជ្យបានខ្ជាប់ខ្ជួន នៅក្នុងអំណាច
ខ្លួន ២០ឯមណាហិម ទ្រង់ទារប្រាក់នោះ ពីពួកជនជាតិ
អ៊ីស្រាអែលវិញ គឺពីពួកអ្នកមាន ក្នុងម្នាក់ៗ៥០រៀលសំរាប់

**១៥:១១** *សៀវភៅជាពង្សាវតារ របស់ពួកអ៊ីស្រាអែល* សូមមើលការពន្យល់ ១ពវ ១៤:១៩ ។

**១៥:១២** *ព្រះយេហូវ៉ាទ្រង់បានមានបន្ទូល . . . ការនោះក៏កើតមកដូច្នោះមែន* ការបែកបាក់នៅក្នុងសន្តតិវង្សយេហ៊ូវ ទឹកដីអ៊ីស្រាអែលបានធ្លាក់ចូលក្នុងភាពអស្ថេរភាពនយោបាយ(សូមមើល ហស ១:៤) ។ ស្តេចទាំងប្រាំអង្គដែលកំពុងមានព្រះជន្មរស់នៅក៏ត្រូវបានធ្វើគតដោយស្តេចមណាហិម ដែលទ្រង់បានឡើងគ្រងរាជ្យអស់រយៈពេល១០ឆ្នាំ ហើយហូសេក្នុងពេលនេះកំពុងស្ថិតក្នុងគុកដោយពួកស៊ីរីបានចាប់គាត់ ។ ចំពោះភាពខ្លាំង និង ភាពសម្បូររុងរឿងក្នុងរាជ្យរបស់ស្តេចយេរ៉ូបោមទី២ តែពួកអ៊ីស្រាអែលបានធ្លាក់ចូលក្នុងការធ្លាក់ចុះយ៉ាងខ្លាំងក្លាបំផុត ។

**១៥:១៣** *ឆ្នាំទី៣៩ ក្នុងរាជ្យអ័សារា* រាជ្យនេះស្ថិតនៅក្នុងឆ្នាំទី ៧៥២មុន គ.ស (សូមមើលការពន្យល់ ខ.២) ។

**១៥:១៤** *មណាហិម . . . ចេញពីក្រុងធើសា ឡើងទៅក្រុងសាម៉ារី* ឃ្លានេះបានប្រាប់ថា មណាហិមទំនងជាអគ្គយោធភូមិភាគក្រុងធើសា ដែលជាអតីតៈទីក្រុងរបស់ពួកអ៊ីស្រាអែល(មើល ១៤:១៧ ១៥:២១,៣៣) ។ *សោយរាជ្យជំនួសទ្រង់* សម្រាប់រាជ្យរបស់មណាហិម សូមមើល ខ.១៧–២២ ។

**១៥:១៥** *សៀវភៅជាពង្សាវតាររបស់ពួកអ៊ីស្រាអែល* សូមមើលការពន្យល់ ១ពវ ១៤:១៩ ។

**១៥:១៦** *ក្រុងធីពសា* ក្រុងនេះបានលាតសន្ធឹងរហូតទៅដល់ទ្វាស្រុកហាម៉ាត (មើល ១៤:២៥) តាមបណ្តោយទន្លេអឺប្រាត(មើល ១ពវ ៤:២៤) ។ *វះពោះពួកស្រីៗដែលមានទំងន់* សូមមើល ៨:១២ និងការពន្យល់ ។

**១៥:១៧** *ឆ្នាំទី៣៩ ក្នុងរាជ្យអ័សារា* នេះគឺឆ្នាំទី ៧៥២ មុន គ.ស (សូមមើលការពន្យល់ ខ.២) ។ *១០ឆ្នាំ* នេះស្ថិតនៅចន្លោះឆ្នាំ ៧៥២–៧៤២មុន គ.ស ។

**១៥:១៩** *ពូល* នេះជាឈ្មោះរបស់ពួកបាប៊ីឡូន(មើល ១រប ៥:២៥) ដែលពួកស៊ីរីបានគ្រប់គ្រងលើ ទីឡាត់–ពីលឡេសសីទី៣ (Tilath-Pillser III) (ឆ្នាំ ៧៤៥–៧២៧ មុន គ.ស) ។ *ទន្ទ្រានចូល ក្នុងស្រុក* កំណត់ត្រាពួកស៊ីរីអំពីទីឡាត់–ពីលឡេសសីទី៣ (Tilath-Pillser III) បានបញ្ជាក់ថា ស្តេចពូលនេះ បានពង្រីកទឹកដីរបស់ខ្លួនទៅភាគខាងលិចនៅក្នុងឆ្នាំទី ៧៤៣ មុន គ.ស ហើយបានបង្ខំឱ្យគេថ្វាយសួយសារអាករក្នុងចំណោមពួកគេដែលរស់នៅក្នុងស្រុកសាម៉ារី ។ *ប្រាក់១ពាន់ហាប* ទាំងនេះគឺជាចំនួនប្រាក់ដ៏ច្រើនបំផុត សម្រាប់ទេពកោសលដែលទាក់ទងទៅនឹងតម្លៃប្រាក់ មើលការពន្យល់ ៥:៦ ។ *ឱ្យបានពួតដៃជួយឱ្យរាជ្យបានខ្ជាប់ខ្ជួន* មណាហិមមានរម្មណ៍ស្វាត់ស្ងៀមចំពោះការបង្ហាញពីអ្នកដណ្តើមរាជ ដែលនឹងការធ្វើឱ្យរាជបល្ល័ង្គគ្មានសន្តិភាព ។ ចំពោះការប្រឆាំងនឹងច្បាប់នេះ គឺបណ្តាលមកពីជឿតាមអ្នកដឹកនាំ"ពីខេស"(Pekah) តើអ្នកណាដែលយល់ព្រមក្នុងការភ្ជាប់ទំនាក់ទំនងនឹងអ័រ៉ាមជាស្តេចដាម៉ាស នៅក្នុងការរៀបចំតទល់នឹងការគំរាមរបស់ស្តេចអាសសើរ (មើលការពន្យល់ ខ.២៧) ។ ស្តេចហូសេបានប្រកាស់មិនយល់ព្រមយ៉ាងឱឡារិកថា ការស្វែងរកជំនួយពីនយោបាយនោះធ្វើឱ្យមានការធ្លាក់ចុះព្យាករ (ហស ៥:១៣–១៥) ។

**១៥:២០** *៥០រៀល* ការគណនាដ៏សមញ្ញមួយ បានបង្ហាញឱ្យឃើញថា មនុស្សកំណាញ់ប្រហែលជា ៦មុឺននាក់ បានបរិច្ចាកប្រាក់ ១០០០ហាប ។ ការនេះបានបញ្ជាក់ពីភាពរុងរឿងរបស់អាណាចក្រអ៊ីស្រាអែល ក្នុងរជ្ជកាលស្តេច

នឹងថ្វាយដល់ស្ដេចស្រុកអាសស៊ើរ ដូច្នេះស្ដេចអាសស៊ើរ
ទ្រង់ក៏ថយចេញទៅវិញ[ប] មិនបាននៅជាប់ក្នុងស្រុកនោះទេ
[២១]រីឯដំណើរឯទៀតពីមណាហិម និងការទាំងប៉ុន្មានដែល
ទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅជាពង្សាវតារ
របស់ពួកស្ដេចអ៊ីស្រាអែលហើយ [២២]មណាហិមក៏ផ្ទំលក់ទៅ
ជាមួយនឹងពួកព្ធយុកោទ្រង់ទៅ រួចពេកាហ៊ា ជាព្រះរាជ
បុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា ។

**ពេកាហ៊ាឡើងជាស្ដេចស្រុកអ៊ីស្រាអែល**

[២៣]នៅឆ្នាំទី៥០ ក្នុងរាជ្យអ័សារា ស្ដេចយូដា នោះ
ពេកាហ៊ា ជាបុត្រមណាហិម ក៏ចាប់តាំងសោយរាជ្យឡើង
លើស្រុកអ៊ីស្រាអែលនៅក្រុងសាម៉ារី ក៏សោយរាជ្យបាន២
ឆ្នាំ [២៤]ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ផ] នៅព្រះនេត្រព្រះ
យេហូវ៉ាទ្រង់មិនបានវៀរបង់លែង តាមអំពើបាបរបស់
យេរ៉ូបោម ជាកូននេបាត ដែលបាននាំឱ្យពួកអ៊ីស្រាអែល
ធ្វើបាបតាមនោះទេ [២៥]ឯពេកា[ព] កូនរេម៉ាលា ជាមេទ័ព
របស់ទ្រង់ និងអើកុប ហើយអើរីយេ ក៏ក្បត់ធ្វើគុតទ្រង់នៅ
ឯដំណាក់ក្នុង ព្រះរាជវាំង នៅក្រុងសាម៉ារីទៅ ក៏មានពួក
កាឡាត៥០នាក់ នៅជាមួយនឹងលោកដែរ លោកបាន
ប្រហារ[ភ]ជីវិតស្ដេច ហើយឡើងសោយរាជ្យជំនួសទ្រង់
[២៦]រីឯដំណើរឯទៀតពីពេកាហ៊ា និងការទាំងប៉ុន្មានដែល
ទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជាពង្សាវ
តាររបស់ពួកស្ដេចអ៊ីស្រាអែលហើយ ។

**ពេកាឡើងជាស្ដេចស្រុកអ៊ីស្រាអែល**

[២៧]នៅឆ្នាំទី៥២ ក្នុងរាជ្យអ័សារា ស្ដេចយូដា នោះពេកា
[ម]ជាកូនរេម៉ាលា[យ]ក៏ចាប់តាំងសោយរាជ្យលើពួកអ៊ីស្រាអែ
លនៅក្រុងសាម៉ារី ហើយទ្រង់សោយរាជ្យបាន២០ឆ្នាំ
[២៨]ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេ
ហូវ៉ា ទ្រង់មិនបានវៀរបង់លែង តាមអំពើបាបរបស់យេរ៉ូ
បោម ជាកូននេបាត ដែលនាំឱ្យពួកអ៊ីស្រាអែលធ្វើបាប
តាមនោះទេ។
[២៩]នៅក្នុងរាជ្យពេកា ជាស្ដេចអ៊ីស្រាអែល នោះទីកឡាត
–ពីលេស៊ើរ[រ] ជាស្ដេចស្រុកអាសស៊ើរ ក៏មកចាប់យកក្រុង
អ៊ីយ៉ូន[ល] ក្រុងអេបិល–បេត–ម្អាកា ក្រុងយ៉ាណូហា ក្រុង
កេដេស ក្រុងហាសោរ និងស្រុកកាឡាត ហើយស្រុក
កាលីឡេ ព្រមទាំងស្រុកណែបថាលីទាំងមូល[វ] ក៏ដឹកនាំពួក
អ្នកស្រុកទាំងនោះ ទៅជាឈ្លើយ[ស] ដល់ស្រុកអាសស៊ើរ
[៣០]នោះហូសា៊[ហ] ជាកូនអេឡា បង្កើតការកម្បត់នឹងពេកា

**១៥:២០** ប ២ពវ ១២:១៨
**១៥:២៤** ផ ១ពវ ១៥:២៦
**១៥:២៥** ព ២រប ២៨:៦ អស ៧:១ ភ ២ពវ ១២:២០
**១៥:២៧** ម ២រប ២៨:៦ អស ៧:១ យ អស ៧:៤
**១៥:២៩** រ ២ពវ ១៦:៧ ១៧:៦ ១រប ៥:២៦ ២រប ២៨:២០ យរ ៥០:១៧ ល ១ពវ ១៥:២០ វ ២ពវ ១៦:៩ ១៧:២៤ ២រប ១៦:៤ អស ៧:៩ ៩:១ ១០:៩,១០ ២៨:១ ៣៦:១៩ ៣៧:១៨ ស ២រប ២៤:១៤–១៦ ១រប ៥:២២ អស ១៤:៦,១៧ ៣៦:១៧ ៤៥:១៣
**១៥:៣០** ហ ២ពវ ១៧:១

យេរ៉ូបោមទី២ ។

**១៥:២១** *សៀវភៅ ជាពង្សាវតាររបស់ពួកស្ដេចអ៊ីស្រាអែល* សូមមើលការពន្យល់ ១ពវ ១៤:១៩ ។

**១៥:២៤** *អំពើបាបរបស់យេរ៉ូបោម* សូមមើល ១ពវ ១២:២៦–៣២ ១៣:៣៣–៣៤ ១៤:៣១៦ ។

**១៥:២៥** *មេទ័ពរបស់ទ្រង់* នេះសំដៅដល់ពេកាជាមេទ័ពនៅទឹកដីទន្លេយ័រដាន់ ប៉ុន្តែភាពស្មោះត្រង់របស់ទ្រង់ចំពោះមណាហិម និងពេកាហ៊ាមើលទៅហាក់បីដូចជាលើសពីការពិតទៅទៀត (សូមមើល ខ.២៧) ។ *ក៏ក្បត់* នេះគឺមានភាពផ្សេងគ្នាលើគោលនយោបាយអន្តរជាតិ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កចលាចល ក្នុងការធ្វើបដិវត្តន៍របស់ពេកាហ៊ា ស្ដេចពេកាហ៊ា បានអនុវត្តការនេះតាមបិតារបស់ទ្រង់ដោយគ្មានការសង្ស័យក្នុងការបង្កើតទំនាក់ទំនងជាមិត្តភាពជាមួយពួកស៊ីរី (មើល ខ.២០) ។ ពេកាបានតស៊ូមតិយ៉ាងខ្លាំងក្លា ជាមួយនឹងពួកស៊ីរីក្នុងស្រុកដាម៉ាស ដើម្បីតទល់នឹងការរំលោភបំពានរបស់ពួកស៊ីរី (មើល ១៦:១–៩ សយ ៧:១–២,៤–៦) ។

**១៥:២៦** *សៀវភៅ ជាពង្សាវតាររបស់ពួកស្ដេចអ៊ីស្រាអែល* សូមមើលការពន្យល់ ១ពវ ១៤:១៩ ។

**១៥:២៧** *ឆ្នាំទី៥២ ក្នុងរាជ្យអ័សារា* មកដល់ត្រង់នេះគឺស្ថិតនៅក្នុងឆ្នាំទី ៧៤០ មុន គ.ស (សូមមើលការពន្យល់ ខ.២) ។ *២០ឆ្នាំ* គឺនៅរវាងឆ្នាំ ៧៥២–៧៣២ មុន គ.ស ដោយយោងទៅលើការពិតដែលថា ពេកាបានសាងសង់អាណាចក្រមួយនៅក្នុងស្រុកយ័រដាន់ដែលអាណាចក្រនេះជាការប្រកួតប្រជែងទៅនឹងអាចក្ររបស់ស្ដេចមណាហិម ក្នុងខណៈដែលស្ដេចមណាហិមបានធ្វើគតស្ដេចសាលូម(មើល ពន្យល់ ខ.១៧,១៩,២៥) ហើយនិងរជ្ជកាលដែលបានលើកមកនេះ គឺរួមបញ្ចូលទាំងរយៈពេលនៃប្រលងប្រជែងគ្នាក្នុងការដឹកនាំ ។

**១៥:២៨** *អំពើបាបរបស់យេរ៉ូបោម* សូមមើល ១ពវ ១២:២៦–៣២ ១៣:៣៣–៣៤ ១៤:១៦ ។

**១៥:២៩** *ទីកឡាត–ពីលេស៊ើរ ជាស្ដេចស្រុកអាសស៊ើរក៏មក* មើលការពន្យល់ ខ.៩ ។ ចំពោះប្រវត្តិសាស្ត្រនៃការវាយប្រហារនេះ ត្រូវបានរកឃើញនៅក្នុង ១៦:៥–៩ ២រប ២៨:១៦–២១ អស ៧:១–១៧ ។ *ក្រុងអ៊ីយ៉ូន . . . ស្រុកណែបថាលី* ឃ្លានេះបញ្ជាក់ពី អស់រយៈពេលជាង១៥០ឆ្នាំដំបូងក្នុងរជ្ជកាលបេន–ហាដាឌ់ទី១នៃស្រុកដាម៉ាស ត្រូវបានរឹបអូសដូចទឹកដីអ៊ីស្រាអែលដើម្បីឆ្លើយតបទៅនឹងការអំពាវនាវពួកស្ដេចយូដា (មើលការពន្យល់ ១ពវ ១៥:១៩–២០) ។ *នាំពួកអ្នកស្រុកទាំងនោះ ទៅជាឈ្លើយ ដល់ស្រុកអាសស៊ើរ* សូមមើល ១រប ៥:៥៦ ។ នៅត្រង់នេះ ពួកអ៊ីស្រាអែលត្រូវបាននិរទេសចេញពីទឹកដីរបស់ពួកគេ ដែលសម្រេចតាមបទទំនាយនៃសេចក្ដីសញ្ញាបណ្ដាសារបស់ព្រះយេហូវ៉ា (មើលការពន្យល់ ១០:៣២) ។

**១៥:៣០** *ហូសា៊ . . . បង្កើតការកម្បត់និងពេកា* មកដល់ត្រង់នេះហូសា៊ពិតជាបានបញ្ជាក់ថាខ្លួនមានទំនាក់ទំនងជាមួយពួកអ៊ីស្រាអែល ដែលការសង្គ្រោះបានធ្លាក់ដល់ពួកអាសស៊ើលើសជាងការតស៊ូគ្នា នឹងគ្នា ។ កំណត់ត្រាទីកឡាត–ពីលេស៊ើរទី៣របស់គាត់ បានអះអាងថា ហូសា៊បានគ្រងរាជ្យលើទឹកដីអ៊ីស្រាអែល ហើយបានរឹបអូសយកមាស និងប្រាក់ចំនួន១០០០ហាប ។ *ឆ្នាំទី២០នៃរាជ្យយ៉ូថាម* ស្ថិតក្នុងឆ្នាំ ៧៣២ មុន គ.ស (សូមមើលការពន្យល់

ជាកូនរេម៉ាលា ក៏ធ្វើគុត[ឬ]ទ្រង់ទៅ ហើយឡើងសោយរាជ្យ
ជំនួស ក្នុងឆ្នាំទី២០នៃរាជ្យយ៉ូថាម ជាបុត្រអ័សារា ៣១រីឯ
ដំណើរឯទៀតពីពេកា នឹងការទាំងប៉ុន្មានដែលទ្រង់ធ្វើ
នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅជាពង្សាវតារ[អ]របស់
ពួកស្តេចអ៊ីស្រាអែលហើយ ។

## យ៉ូថាមឡើងជាស្តេចស្រុកអ៊ីស្រាអែល

*១៥:៣៣–៣៨ – ២របា ២៧:១–៤,៧–៩*

៣២នៅឆ្នាំទី២ ក្នុងរាជ្យពេកា ជាកូនរេម៉ាលា ស្តេច
អ៊ីស្រាអែល នោះយ៉ូថាម[ក] ជាបុត្រអ័សារា ស្តេចយូដាក៏
ចាប់តាំងសោយរាជ្យឡើង ៣៣កាលទ្រង់ឡើងសោយរាជ្យ
នោះទ្រង់មានព្រះជន្ម២៥ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន១៦ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជា យេរូសា
បុត្រីសាដុក ៣៤ទ្រង់ប្រព្រឹត្តអំពើដ៏ត្រឹមត្រូវ[ខ]នៅព្រះនេត្រ
ព្រះយេហូវ៉ា គឺទ្រង់ប្រព្រឹត្តតាមគ្រប់អស់ទាំងសេចក្តី ដែល
អ័សារា ជាបិតាទ្រង់បានធ្វើ ៣៥ប៉ុន្តែមិនបានបំបាត់អស់ទាំង
ទីខ្ពស់ចោលចេញទេ[គ] ពួកបណ្តាជនគេនៅតែថ្វាយយញ្ញ
បូជា ហើយដុតកំញាន នៅលើទីខ្ពស់ទាំងនោះនៅឡើយ គឺ

**១៥:៣០** ឡ ២ពវ ១២:២០
**១៥:៣១** អ ១ពវ ១៥:៣១
**១៥:៣២** ក ខ.១,៥ ១របា ៥:១៧ អស ១:១ ហស ១:១
**១៥:៣៤** ខ ១ពវ ១៤:៨
**១៥:៣៥** គ ២ពវ ១២:៣
ឃ លបា ២៣:១០ ២របា ២៣:២០
**១៥:៣៧** ង ២ពវ ១៦:៥ អស ៧:១ ៨:៦ ៩:១១
**១៦:១** ក អស ១:១ ៧:១ ១៤:២៨ ហស ១:១ មីក ១:១
**១៦:២** ខ ១ពវ ១៤:៨

ស្តេចនេះហើយ ដែលធ្វើទ្វារកំផែងខាងលើ[ឃ] របស់ព្រះ
វិហារនៃព្រះយេហូវ៉ា ៣៦រីឯដំណើរឯទៀតពីយ៉ូថាម និង
ការទាំងប៉ុន្មានដែលទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុង
សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដាហើយ ។
៣៧នៅគ្រានោះ ព្រះយេហូវ៉ាទ្រង់ចាប់តាំងចាត់រេស៊ីន[ង]
ជាស្តេចស៊ីរី និងពេកា ជាកូនរេម៉ាលា ឱ្យទៅទាស់នឹងពួក
យូដា ៣៨យូថាមក៏ផ្ទំលក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់ទៅ
ហើយគេបញ្ចុះទ្រង់ជាមួយ និងពួកព្ធយុកោ នៅក្នុងក្រុង
ដាវីឌ ជាព្ធយុកោ រួចអ័ហាស ជាព្រះរាជបុត្រា ក៏សោយ
រាជ្យឡើងជំនួសបិតា ។

## អ័ហាសឡើងជាស្តេចស្រុកយូដា

*១៦:១–២០ – ២របា ២៨:១–២៧*

**១៦** ១នៅឆ្នាំទី១៧ ក្នុងរាជ្យពេកា ជាកូនរេម៉ាលានោះ
អ័ហាស[ក]ជាបុត្រយ៉ូថាម ស្តេចយូដា ក៏ចាប់តាំងសោយរាជ្យ
ឡើង ២កាលអ័ហាសសោយរាជ្យឡើង នោះទ្រង់មានព្រះ
ជន្ម២០ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុងយេរូសាឡិម១៦
ឆ្នាំ ទ្រង់មិនបានប្រព្រឹត្តអំពើដ៏ត្រឹមត្រូវ[ខ] នៅព្រះនេត្រព្រះ

ខ.៣២–៣៣) ។ ការលើកឡើងពីឆ្នាំទី២០របស់ទ្រង់ជាឆ្នាំផ្លូវការ តែតាពិត គឺមានចំនួនតែ១៩ឆ្នាំប៉ុណ្ណោះ ។

**១៥:៣១** *សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចអ៊ីស្រាអែល* មើលការពន្យល់ ១ពវ ១៤:១៩ ។

**១៥:៣២** *ឆ្នាំទី២ ក្នុងរាជ្យពេកា* គឺឆ្នាំទី ៧៥០ គ.ស (មើលការពន្យល់ ខ.២៧) ។

**១៥:៣៣** *១៦ឆ្នាំ* គឺនៅក្នុងរវាងឆ្នាំ ៧៥០–៧៣៥ មុន គ.ស ។ យ៉ូថាមជាស្តេចដែលគ្រងរាជ្យបន្ទាប់ពីព្រះបិតារបស់ទ្រង់ក្នុងឆ្នាំ ៧៥០–៧៤០ មុន គ.ស (មើលការពន្យល់ ខ.៥) ។ រាជរបស់យ៉ូថាមបានចូលមកដល់ទីបញ្ចប់ក្នុងឆ្នាំ ៧៣៥ ហើយអ័ហាសបុត្ររបស់ទ្រង់ ជាអ្នកបន្តរាជ្យពីទ្រង់ ។ តែទោះយ៉ាងណាក៏ដោយ ស្តេចយ៉ូថាមបានបន្តការរស់នៅរហូតដល់ ឆ្នាំ៧៣២ មុន គ.ស (មើលការពន្យល់ ខ.៣០,៣៧) ។

**១៥:៣៤** *អ័សារា ជាបិតាទ្រង់បានធ្វើ* សូមមើលការពន្យល់ ខ.៣ និងមើលការពន្យល់បន្ថែម ២របា ២៧:២ ។

**១៥:៣៥** *ប៉ុន្តែ មិនបានបំបាត់អស់ទាំងទីខ្ពស់ចោលចេញ* សូមមើល ខ.៤ និងមើលបន្ថែមការពន្យល់ ១ពវ ១៥:១៤ ។ *ទ្វារកំផែតខាងលើ* សូមមើល ២របា ២៣:២០ យរ ២០:២ អគ ៩:២ ។ ចំពោះពត៌មានបន្ថែមអំពីសកម្មភាពនៃការសាងសង់ព្រះវិហាររបស់ស្តេចយ៉ូថាម ត្រូវបានកត់ត្រានៅក្នុង ២របា ២៧:៣–៤) ។

**១៥:៣៦** *ដំណើរឯទៀតពីយ៉ូថាម* សូមមើល ២របា ២៧:១–៦ ។ *សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

**១៥:៣៧** នៅវគ្គនេះ ជាការបញ្ជាក់បន្ថែមអំពីរាជ្យរបស់យ៉ូថាមដែលគាំទ្រដល់គំនិតដែលលើកឡើងថា រជ្ជកាលរបស់ស្តេចអង្គនេះ គឺស្ថិតនៅក្នុងឆ្នាំជាមួយនឹងរាជ្យស្តេចអ័ហាស (សូមមើលការពន្យល់ ខ.៣៣) ដោយព្រោះនៅក្នុង ១៦:៥–១២ ២របា ២៨:៥–២១ និង អស ៧:១–១៧ បានកត់ត្រាថាគ្រប់ទីកន្លែងដូចបានចែងខាងលើនេះ ជាកិច្ចប្រឹងប្រែងរបស់ រេស៊ីន និង ពេកា នៅក្នុងរជ្ជកាលរបស់អ័ហាស់ ។

**១៦:១** *ឆ្នាំទី១៧ ក្នុងរាជ្យពេកា* គឺឆ្នាំទី ៧៣៥ នៃគ.ស (សូមមើលការពន្យល់ ១៥:២៧) ។ រជ្ជកាលរបស់ស្តេច អ័ហាស គឺស្ថិតក្នុងឆ្នាំតែមួយជាមួយនឹងស្តេចយ៉ូរាម ដែលអ័ហាសជាដៃគូការងារជាន់ខ្ពស់ដោយចាប់ផ្តើមពីឆ្នាំ ៧៣៥ (មើលការពន្យល់ ១៥:៣៣,៣៧ និងការពន្យល់បន្ថែម ខ.២ ១៧:១ ។ *អ័ហាស ជាបុត្រយ៉ូថាម ស្តេចយូដា* នៅត្រង់នេះ គេបានផ្តិតត្រាដែលធ្វើពីដីឥដ្ឋចំនួន ១៩៩៦ ដែលបញ្ជាក់អំពីអ័ហាស ថាជាបុត្ររបស់ស្តេចយ៉ូរ៉ាម ជាស្តេចនៃពួកសាសន៍យូដា ត្រូវបានលាតត្រដាងនៅពេលនោះផងដែរ ។ កំណត់ត្រាសិលាចារឹកបុរាណជាភាសាហេព្រើរបានបញ្ជាក់ថា ត្រានេះត្រូវបានគេប្រើនៅក្នុងការបែងចែករបបរាជាធិបតេយ្យ ដែលដំបូងឡើយត្រាចារឹកនេះត្រូវបានកំណត់ដោយស្តេចយូដា ។

**១៦:២** *សោយរាជ្យឡើងនោះ ទ្រង់មានព្រះជន្ម២០ឆ្នាំ* ត្រង់នេះប្រហែលអ័ហាសនៅធ្វើជាមន្ត្រីជាន់ខ្ពស់ជាមួយនឹងព្រះរាជាដែលជាបិតារបស់ខ្លួននៅឡើយ ៧៣៥ មុន គ.ស (មើលការពន្យល់ ខ.១) ។ ម៉្យាងវិញទៀត បើយោងទៅតាមអាយុ និងកាលបរិច្ឆេទដែលបានផ្តល់មក នោះស្តេចអ័ហាសនៅក្នុងអំឡុងពេលនោះមានព្រះជន្មពី១១ ឬ ១២វស្សា ជំនួសឱ្យព្រះជន្ម ១៤ ឬ ១៥ វស្សាដែលអំឡុងពេលនេះហេសេគាបុត្រារបស់ទ្រង់បានប្រសូតមក (ធៀប ១៨:១–២) *១៦ឆ្នាំ* នេះគឺជារយៈពេលតែមួយដែលស្តេចអ័ហាសហេសេគាធ្វើជាស្តេចនៅយូដា ហើយនិង ពេកា និងហូស៊ា ជាស្តេចលើពួកអ៊ុស្រាអែល ដែលបង្ហាញឱ្យឃើញច្បាស់ពីទំនាស់រាជ្យបល្ល័ង្កក្នុងពេលតែមួយ (មើលការពន្យល់ ខ.១ ១៧:១ ១៨:១,៩–១០) ។ វាជាការមួយល្អបំផុតក្នុងការដាក់ចំនួន១៦ឆ្នាំនៅទីនេះថាជា ចំនួនឆ្នាំនៃរាជ្យរបស់ស្តេច អ័ហាស ក្រោយ

យេហូវ៉ាជាព្រះនៃទ្រង់ ដូចជាដាវីឌ ជាព្ធយុកោទ្រង់ទេ
៣ គឺទ្រង់ប្រព្រឹត្តតាមផ្លូវរបស់ពួកស្តេចអ៊ីស្រាអែលវិញ[គ] ព្រម
ទាំងធ្វើឱ្យព្រះរាជបុត្រាទ្រង់[ឃ] ឆ្លងកាត់ភ្លើងផង តាមទំលាប់
គួរស្អប់ខ្ពើម[ង] របស់សាសន៍ដទៃ ដែលព្រះយេហូវ៉ាទ្រង់បាន
បណ្តេញពីមុខពួកកូនចៅអ៊ីស្រាអែលចេញ ៤ ទ្រង់ក៏ថ្វាយ
យញ្ញបូជា ហើយដុតកំញាន[ច] នៅលើអស់ទាំងទីខ្ពស់ ហើយ
នៅលើភ្នំ និងនៅក្រោមដើមឈើខ្ចីទាំងប៉ុន្មានដែរ[ឆ] ៥ នៅ
គ្រានោះ រេស៊ីន[ជ] ជាស្តេចស៊ីរី និងពេកា ជាកូនរេម៉ាលា
ស្តេចអ៊ីស្រាអែល បានឡើងមកច្បាំងនឹងអ័ហាស ក៏ឡោម
ព័ទ្ធក្រុងយេរូសាឡិម តែពុំអាចនឹងឈ្នះទ្រង់បានទេ ៦ នៅ
វេលានោះរេស៊ីន[ឈ] ជាស្តេចស៊ីរីទ្រង់ចាប់យកក្រុងអេឡាត
[ញ] បង្វិលឱ្យទៅខាងពួកស៊ីរីវិញ ហើយបណ្តេញពួកសាសន៍
យូដាពីក្រុងអេឡាតចេញ រួចពួកសាសន៍ស៊ីរី គេមកតាំង
ទីលំនៅៗ ក្រុងនោះដរាបដល់សព្វថ្ងៃនេះ ។

៧ ដូច្នេះ អ័ហាសទ្រង់ចាត់សារ ឱ្យទៅឯទីកឡាត–
ពីលេសើរ[ដ] ជាស្តេចស្រុកអាសស៊ើរថា ទូលបង្គំនេះជាអ្នក
បំរើ ហើយជាបុត្ររបស់ទ្រង់ ហេតុនេះសូមទ្រង់ឡើងមក
ជួយ[ឋ] ទូលបង្គំ ឱ្យរួចពីកណ្តាប់ដៃនៃស្តេចស៊ីរី និងស្តេច
អ៊ីស្រាអែល ដែលគេបានលើកគ្នាមកទាស់នឹងទូលបង្គំផង
៨ អ័ហាសក៏យកមាសនឹងប្រាក់ ដែលឃើញមាននៅក្នុងព្រះ
វិហារនៃព្រះយេហូវ៉ា ហើយនៅក្នុងឃ្លាំងព្រះរាជទ្រព្យផ្ញើ
ទៅថ្វាយជាដង្វាយ[ឍ] ដល់ស្តេចស្រុកអាសស៊ើរ ៩ ឯស្តេច
អាសស៊ើរក៏ស្តាប់តាម រួចទ្រង់ឡើងទៅទាស់នឹងក្រុង
ដាម៉ាស[ល] ទ្រង់ច្បាំងចាប់យកបាន ហើយដឹកនាំពួកអ្នកក្រុង
នោះ ទៅជាឈ្លើយដល់ស្រុកគារ[ណ] ព្រមទាំងធ្វើគុតរេស៊ីន
ផង ។

**១៦:៣** គ ២ពវ ១៧:១៩ ឃ លវ ១៨:២១ ២ពវ ៣:២៧ ង លវ ១៨:៣ ចទ ៩:៤ **១៦:៤** ច ២ពវ ២២:១៧ ២៣:៥ ឆ ចទ ១២:២ អគ ៦:១៣ **១៦:៥** ជ ២ពវ ១៥:៣៧ **១៦:៦** ឈ អស ៩:១២ ញ ១ពវ ៩:២៦ **១៦:៧** ដ ២ពវ ១៥:២៩ ឋ អស ២:៦ ១០:២០ យរ ២:១៨ ៣:១ អគ ១៦:២៨ ២៣:៥ ហស ១០:៦ **១៦:៨** ឍ ១ពវ ១៥:១៨ ២ពវ ១២:១៨ **១៦:៩** ល លប ១៤:១៥ ២ពវ ១៥:២៩ ណ អស២២:៦ អម ១:៥ ៩:៧

ពីការសុគតរបស់យ៉ូរាម ដូច្នេះគឺត្រូវនឹងឆ្នាំ ៧៣២–៧១៥ មុន គ.ស (សូមមើលការពន្យល់ ១៥:៣០,៣៣) ។ *ដូចជាដាវីឌ ជាព្ធយុកោទ្រង់ទេ* នៅត្រង់នេះបញ្ជាក់ថា អ័ហាសមិនត្រឹមតែមិនបានទទួលបាននូវការយល់ព្រមពីអ័ម៉ាស៊ីយ៉ា (១៤:៣) អ័សារា (១៥:៣) និងយ៉ូរាម ។

**១៦:៣** *ផ្លូវរបស់ពួកស្តេចអ៊ីស្រាអែល* នៅត្រង់នេះ មិនទំនងគួឱ្យជឿថា អ័ហាសបានបូជាកូនគោ ដែលទីនោះជាកន្លែងដែលស្តេចយេរ៉ូបោមបានសង់ឡើងដើម្បីឱ្យពួកអ៊ីស្រាអែលថ្វាយបង្គំនៅត្រង់ក្រុងបេត–អែល និងក្រុងដាន់ (សូមមើល ១ពវ ១២:២៦–៣២ ១៣:៣៣–៣៤ ១៤:១៦) ។ ការលើកឡើងនៅត្រង់នេះគឺសំដៅដល់ការថ្វាយបង្គំព្រះបាល ក្នុងវិញ្ញាណរបស់ស្តេចអ័ហាប់ (មើលការពន្យល់ ១ពវ ១៦:៣១–៣៣ និងបន្ថែម ២របា ២៨:២) ។ *ព្រះរាជបុត្រាទ្រង់ឆ្លងកាត់ភ្លើង* លោកម៉ូសេ បានព្រមានដល់ពួកអ៊ីស្រាអែលមិនឱ្យពួកគេថ្វាយបង្គំព្រះដទៃ (មើល លវ ១៨:២១ ចទ ១៨:១០) ។ ចំពោះពួកកូនប្រុសច្បងអ៊ីស្រាអែលវិញ ពួកគេម្នាក់ៗត្រូវបានថ្វាយទៅដល់ព្រះយេហូវ៉ា និងលោះមកវិញ ដោយការបរិច្ចាកប្រាក់ដល់ពួកសម្តេចសង្ឃ (សូមមើល នក ១៣:១,១១–១៣ ជន ១៨:១៦) និងមើលបន្ថែម ៣:២៧ ១៧:១៧ ២១:១៦ ២៣:១០ ២របា ២៨:៣ យរ ៧:៣១ ៣២:៣៥ ។

**១៦:៤** *ទីខ្ពស់* សូមមើល ១៥:៤,៣៥ និងមើលបន្ថែមការពន្យល់ ១ពវ ១៥:១៤ ។ ទីខ្ពស់នៅត្រង់នេះ បង្ហាញអំពីការប្រៀបធៀបមួយពីការថ្វាយបង្គំព្រះបាល ហើយរូបព្រះបាលនេះត្រូវបានគេប្រើប្រាស់ក្នុងខណៈដែលពួកគេថ្វាយបង្គំព្រះយេហូវ៉ា ។ *នៅក្រោមដើមឈើខ្ចីទាំងប៉ុន្មាន* ឃ្លានេះបានប្រាប់ថាដើមឈើធំៗ ត្រូវបានគេបង្ហាញឱ្យឃើញថា ជានិមិត្តរូបនៃភាពសម្បូសប្បាយនៃពួកអ៊ីស្រាអែលដើមក្នុងទឹកដីកាណាន ។ ភាពស្មោគគ្រោកនៃព្រះដទៃបានបង្ហាញឱ្យឃើញពីរូបស្លូបផ្សេងៗនៅក្រោមដើមឈើជាច្រើន ។ ផ្ទុយទៅនឹងបម្រាមនៃក្រឹត្យវិន័យរបស់លោកម៉ូសេ នោះពួកអ៊ីស្រាអែលបានទទួលយកប្រពៃណីពួកសាសន៍ដទៃនេះ (មើល ១៧:១០ ១ពវ ១៤:២៣ ចទ ១២:២ យរ ២:២០ ៣:៦ អគ ៦:១៣ ២០:២៨ ហស ៤:១៣–១៤) ។

**១៦:៥** *រេស៊ីន . . . ពេកា . . . ក៏ឡោមព័ទ្ធក្រុងយេរូសាឡិម* សូមមើលការពន្យល់ ១៥:២៥,៣៧ ។ *ពុំអាចនឹងឈ្នះទ្រង់បានទេ* សូមមើល សយ ៧:១–១៧ ២របា ២៨:៥–២១ ។ រេស៊ីន និងពេកា មានបំណងចង់ផ្លាស់ប្តូរអ័ហាសពីបល្ល័ង្កនៃទឹកដីយូដាជាមួយនិងបុត្រារបស់ទ្រង់គឺថា បេល ដើម្បីឱ្យអ្នកដទៃចូលជាសម្ព័ន្ធរបស់ពួកគេក្នុងការប្រឆាំង នឹងគោលនយោបាយរបស់ពួកអាស៊ើរ (មើលការពន្យល់ ១៥:១៩,២៥) ។ ព្រះយេហូវ៉ាបានសង្គ្រោះដល់ពួក យូដា និងអ័ហាសពីការគម្រាមគំហែងទោះបីពួកគេម្នាក់មានភាពកម្សោយក៏ដោយ តែព្រះយេហូវ៉ាទ្រង់នៅតែសង្គ្រោះដល់ពួកគេ ដោយព្រោះព្រះអម្ចាស់បានសន្យាជាមួយនឹងស្តេចដាវីឌនោះ (មើល ១ពវ ១១:៣៦ ២សយ ៧:១៣ អស ៧:៣–៧,១៤) ។

**១៦:៦** *រេស៊ីន ជាស្តេចស៊ីរី ទ្រង់ចាប់យកក្រុងអេឡាត* សូមមើលការពន្យល់ ១៤:២២ ។ ពួកភីលីស្ទីន បានឆក់យកឱកាសនេះសងសឹកចំពោះកាលដែលពួកគេបានព្យាបាទចំពោះខ្លួន (សូមប្រៀបធៀប ២របា ២៦:៥–៧ ជាមួយនឹង ២របា ២៨:១៨) ។ *សព្វថ្ងៃនេះ* សូមមើលការពន្យល់ ១ពវ ៨:៨ ។

**១៦:៧** *ទីឡាត–ពីលេស៊ើរ* សូមមើលការពន្យល់ ១៥:១៩,២៩ ។ *ទូលបង្គំនេះជាអ្នកបំរើ* ស្តេចអ័ហាស បានយកចិត្តទុកដាក់ចំពោះសន្តិសុខរបស់ពួកយូដាដោយការប្រព្រឹត្តសេចក្តីព្យាបាទដល់ពួកអាស៊ើរ មិនមែនជាការស្តាប់បង្គាប់ និងជឿទុកចិត្តដល់សេចក្តីសន្យាព្រះយេហូវ៉ា (មើល នក ២៣:២២ អស ៧:១០–១៦) ។

**១៦:៨** *មាស និង ប្រាក់ ដែលឃើញមាននៅក្នុងព្រះវិហារ* សម្ភារៈដែលមាននៅទីនេះ ត្រូវបានជួសជុលឡើងវិញខ្លះៗដោយស្តេចយ៉ូថាម (សូមមើល ១២:១៨ ១៤:១៤) ។

**១៦:៩** *ទាស់នឹងក្រុងដាម៉ាស ទ្រង់ច្បាំងចាប់យកបាន* នេះចង់បញ្ជាក់ពីចម្បាំងនៅក្នុងឆ្នាំទី ៧៣២ មុន គ.ស ដែលស្តេចទីឡាត–ពីលេស៊ើរបានកំទេចក្រុងដាម៉ាស (មើល អស ៧:១៦ អម ១:៣–៥) ។ *ដឹកនាំពួកអ្នកក្រុងនោះទៅជាឈ្លើយដល់ស្រុកគារ* សំដៅដល់ពួកអាស៊ើរដែលត្រូវបញ្ជូនទៅទីកន្លែងដើម ដែលពួកគេរស់នៅវិញ ដើម្បីសម្រេចតាមបទទំនាយរបស់ហោរាអេម៉ុស (អម ៩:៧) ។ ទីតាំងស្រុកគារ មិនត្រូវបានដឹងថានៅទីណាមួយ ទោះបីពួកនេះមានជាប់ទាក់ទងជាមួយនឹងពួកអេឡាំនៅក្នុងកណ្ឌគម្ពីរអេសាយ ២២:៦ ។

១០រួចមក ស្តេចអ័ហាសទ្រង់យាងទៅឯក្រុងដាម៉ាស
ដើម្បីជួបនឹងទីកឡាត–ពីលេសើរ ជាស្តេចស្រុកអាស–
សើរ អ័ហាសទ្រង់ឃើញអាសនា១ ដែលនៅក្រុងដាម៉ាស
នោះ រួចទ្រង់ផ្ញើគំរូ និងទ្រង់ទ្រាយ នៃអាសនានោះ តាម
របៀបរចនាគ្រប់យ៉ាងទៅអ៊ូរីយ៉ា[គ]ដ៏ជាសង្ឃ ១១រួចអ៊ូរីយ៉ាដ៏
ជាសង្ឃក៏ស្អាងអាសនា១ តាមគំរូដែលស្តេចអ័ហាស បាន
ផ្ញើមកពីក្រុងដាម៉ាសនោះគ្រប់ជំពូក អ៊ូរីយ៉ាក៏ធ្វើឱ្យទាន់
ស្តេចអ័ហាសយាងត្រឡប់មកពីក្រុងដាម៉ាសវិញ ១២កាល
ស្តេចបានយាងមកពីក្រុងដាម៉ាសវិញហើយ ទ្រង់ក៏ឃើញ
ហើយទ្រង់យាងទៅឯអាសនានោះ ដើម្បីនឹងថ្វាយដង្វាយ[ថ]
១៣ទ្រង់ក៏ដុតដង្វាយដុត[ទ] និងដង្វាយម្សៅ[ធ] នៅលើអាសនា
នោះ ព្រមទាំងច្រួចដង្វាយច្រួច[ន] ហើយប្រោះឈាមនៃ
ដង្វាយមេត្រីផង[ប] ១៤ឯអាសនាលង្ហិន[ផ]ដែលនៅចំពោះព្រះ
យេហូវ៉ា នោះទ្រង់ក៏យកចេញពីល្វែងមុខនៃព្រះវិហារ គឺ
ពីកណ្តាលអាសនាទ្រង់ ហើយនឹងទីបរិសុទ្ធបំផុត ទៅដាក់
នៅទិសខាងជើងនៃអាសនារបស់ទ្រង់វិញ ១៥ស្តេចអ័ហាស
ក៏បង្គាប់ដល់អ៊ូរីយ៉ាដ៏ជាសង្ឃថា ត្រូវដុតដង្វាយដុតពេល
ព្រឹក[ព] និងដង្វាយម្សៅពេលល្ងាច ព្រមទាំងដង្វាយដុតរបស់
ស្តេច និងដង្វាយម្សៅទ្រង់ ហើយទាំងដង្វាយដុត ដង្វាយ
ម្សៅ និងដង្វាយច្រួចរបស់ពួកជនទាំងឡាយ នៅលើ
អាសនាធំនោះ ក៏ត្រូវប្រោះឈាមដង្វាយដុត នឹងឈាមនៃ
យញ្ញបូជានៅលើនោះដែរ តែអាសនាលង្ហិននោះ ត្រូវទុក
សំរាប់ឱ្យយើងទូលសួរដល់ព្រះ[ភ] ១៦អ៊ូរីយ៉ាជាសង្ឃក៏ធ្វើ
ដូច្នោះ តាមគ្រប់ទាំងបង្គាប់របស់ស្តេចអ័ហាស ។
១៧ស្តេចអ័ហាបទ្រង់កាត់បន្ទះលង្ហិន ចេញពីគ្រោងជើង
នៃចានក្លាំ ក៏យកចានក្លាំពីលើជើងទាំងនោះចេញ ហើយ
យកសមុទ្រពីលើរូបគោលង្ហិន ដែលទ្រពីក្រោម ទៅដាក់
លើកំរាលថ្មវិញ[ម] ១៨ឯបាំងសាចដែលគេបានធ្វើនៅឯ
ព្រះវិហារ សំរាប់ថ្ងៃឈប់សំរាក និងទ្វារនៃស្តេច ខាង
ក្រៅ នោះទ្រង់ក៏រើចេញ ដោយព្រោះស្តេចស្រុកអាស
សើរ[យ] ១៩ឯដំណើរឯទៀតពីអ័ហាស ជាការដែលទ្រង់
បានធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជាពង្សាវ
តាររបស់ពួកស្តេចយូដាហើយ ២០អ័ហាសក៏ផ្ទំលក់ទៅ[រ]ជា
មួយនឹងពួកឰយុកោទ្រង់ទៅ ហើយគេបញ្ចុះទ្រង់នៅក្នុង
ក្រុងដាវីឌ ជាមួយនឹងពួកឰយុកោ រួចហេសេគាជាព្រះ
រាជបុត្រា ក៏ឡើងសោយរាជ្យជំនួសបិតា ។

## ហូសៀឡើងជាស្តេចចុងក្រោយនៃស្រុកអ៊ីស្រាអែល

*១៧:៣–៧ – ២ពវ ១៨:៩–១២*

**១៧** ១នៅឆ្នាំទី១២ ក្នុងរាជ្យស្តេចអ័ហាល ជាស្តេចយូដា
នោះហូសៀ[ក] ជាកូនអេឡា ក៏ចាប់តាំងសោយរាជ្យឡើង

**១៦:១០** គ ខ.១១, ១៥,១៦ អស ៨:២
**១៦:១២** ថ ២របា ២៦:១៦
**១៦:១៣** ទ លវ ៦:៨–១៣ ធ លវ ៦:១៤–២៣ ន នក ២៩:៤០ ប លវ ៧:១១–២១
**១៦:១៤** ផ នក ២០:២៤ ៤០:៦ ១ពវ ៨:៦៤
**១៦:១៥** ព នក ២៩:៣៨–៤១
ភ ១សយ ៩:៩
**១៦:១៧** ម ១ពវ ៧:២៧
**១៦:១៨** យ អគ ១៦:២៨
**១៦:២០** រ អស ១៤:២៨
**១៧:១** ក ២ពវ ១៥:៣០

**១៦:១០** *ស្តេចអ័ហាសទ្រង់យាងទៅឯក្រុងដាម៉ាសដើម្បីជួបនឹងទីកឡាត–ពីឡេសើរ* ឃ្លានេះបានប្រាប់ថា ក្នុងនាមជាស្តេចបម្រើមួយអង្គ ព្រះអង្គចង់បញ្ជាក់ពីការដឹងគុណ និងភាពស្មោះត្រង់ចំពោះមេដឹកនាំពួកអាសើរចំពោះជ័យជម្នះដែលទទួលបានមកនេះ ។ *អាសនា១ ដែលនៅក្រុងដាម៉ាស* នេះប្រហែលជាសំដៅលើព្រះរីម៉ូន (សូមមើល ៥:១៨ ២របា ២៨:២៣) ប៉ុន្តែទំនងជាអាសនារបស់ស្តេចទីកឡាត–ពីឡេសើរជាង ។ គ្រប់សម្ភារៈផ្សេងៗដូចជាអាសនារបស់ស្តេចអ័ហាសនេះ គឺជាភស្តុងតាងមួយដែលបញ្ជាក់ពីការចុះចូលជាមួយនឹងពួកអាសើរ ។

**១៦:១៣** *ដុតដង្វាយដុត . . . ដង្វាយច្រួច . . . ដង្វាយមេត្រី* ចំពោះដង្វាយច្រួចគឺមានលក្ខណៈលើកលែង ហើយដង្វាយដូចគ្នាដដែលនេះត្រូវបានគេថ្វាយនៅក្នុងព្រះវិហារ (មើល ១ពវ ៨:៦៤) ។

**១៦:១៤** *ទិសខាងជើង នៃអាសនារបស់ទ្រង់* ស្តេចអ័ហាសបានប្តូរអាសនាលង្ហិនចេញពីទីខ្ពស់នៅពីមុខវិហារ ទៅដាក់នៅជិតអាសនាថ្មីធ្វើអំពីថ្ម ។

**១៦:១៥** *អាសនាធំ* ទោះបីភ្លើងឋានសួគ៌ បានចាប់ផ្តើម និង ការទទួលយល់ព្រមឱ្យប្រើប្រាស់អាសនាលង្ហិននេះក្នុងការថ្វាយបង្គំព្រះយេហូវ៉ា (មើល ២របា ៧:១) តែស្តេចអ័ហាសមកដល់ត្រង់នេះបានផ្លាស់ប្តូរអាសនានេះ ហើយកសាងតាមបែបអាសនាសាសន៍ដទៃពីស្រុកដាម៉ាស ។ ទោះបីអាសនា លង្ហិននេះមានទំហំធំល្មម (២របា ៤:១) តែអាសនាថ្មីមួយនេះមានទំហំធំជាង ។ *ដុតដង្វាយដុតពេលព្រឹក* សូមមើល ការពន្យល់ ៣:២០ នក ២៩:៣៨–៣៩ ជន ២៨:៣–៤ ។ *ដង្វាយម្សៅពេលល្ងាច* សូមមើលការពន្យល់ ១ពវ ១៨:២៩ ។ *ដង្វាយដុតរបស់ស្តេច នឹង ដង្វាយម្សៅទ្រង់* នេះបញ្ជាក់ថា មិនមានដង្វាយពិសេសឯណាទៀតរបស់ស្តេចឡើយចំពោះសម័យសញ្ញាចាស់ ហើយការពិពណ៌នារបស់លោកអេសេគាល ចំពោះដង្វាយរបស់ព្រះមហាក្សត្រនាពេលអនាគត ជាករណីលើកលែងវិញទេ (អគ ៤៦:១២) ។

**១៦:១៧** *បន្ទះលង្ហិន . . . ចេញពីគ្រោងចានក្លាំ* សូមមើលការពន្យល់ ១ពវ ៧:២៧–៣៩ ។ *យកសមុទ្រពីលើរូបគោលង្ហិន* សូមមើល ១ពវ ៧:២៧–៣៩ ហើយប្រហែលរូបគោលង្ហិននេះ ត្រូវបានគេតម្រូវឱ្យថ្វាយទៅដល់ស្តេចទីឡាត–ពីឡេសើរទី៣ ។

**១៦:១៨** *ទ្រង់ក៏រើចេញ ដោយព្រោះស្តេចស្រុកអាសសើរ* នៅត្រង់នេះបញ្ជាក់ថា ភាពនៅក្រោចំណុះរបស់ស្តេចទីឡាត–ពីឡេសើរ អ័ហាសត្រូវបានបង្ខំឱ្យបោះបង់អំណាចរបស់ព្រះអង្គចោល ។

**១៦:១៩** *ដំណើរឯទៀតពីអ័ហាស* សូមមើល ២របា ជំពូក ២៨ ហើយត្រង់នេះក៏ចាប់ពីការផ្សេងៗទៀត ហើយក៏បានប្រាប់ផងដែរថា ស្តេចអ័ហាសបានចាកចេញទៅឆ្ងាយ ដោយបិទទ្វារព្រះវិហារចោល (មើល ២របា ២៨:២៤) ។ *សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

**១៦:២០** *ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់ទៅ* សូមមើលការពន្យល់ ១ពវ ១:២១ និងមើលបន្ថែម ២របា ២៨:២៧ ។ *ហេសេគា ជាព្រះរាជបុត្រា ក៏ឡើងទៅសោយរាជ្យជំនួសបិតា* សម្រាប់រាជ្យរបស់ហេសេគា សូមមើល ១៨:១–២០:២១ ។

លើស្រុកអ៊ីស្រាអែល នៅក្រុងសាម៉ារី ក៏សោយរាជ្យបាន
៩ឆ្នាំ ២ ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ខ] នៅព្រះនេត្រ
ព្រះយេហូវ៉ា តែមិនបានដល់ពួកស្តេចអ៊ីស្រាអែលដែលនៅ
មុនទ្រង់នោះទេ ៣ សាលម៉ានេស៊ើរ[គ]ជាស្តេច ស្រុកអាស
ស៊ើរ បានឡើងមកទាស់នឹងហូសៀនេះ ហើយទ្រង់ក៏
ចុះចូល ព្រមទាំងបង់សួយអាករថ្វាយផង[ឃ] ៤ តែស្តេច
អាសស៊ើរទ្រង់បានជ្រាបថា ហូសៀគិតក្បត់ហើយ ដ្បិត
ហូសៀបានចាត់សារទៅឯសូរ ជាស្តេចស្រុកអេស៊ីព្ទ[ង] ហើយ
លែងបង់សួយអាករថ្វាយទ្រង់ ដូចជារាល់ឆ្នាំទៀត ហេតុ
នោះបានជាស្តេចអាសស៊ើរ ក៏ចាប់ចងទ្រង់ឃុំទុកក្នុងគុក[ច]
៥ រួចមកស្តេចអាសស៊ើរ ទ្រង់យាងមកសព្វគ្រប់ក្នុងស្រុក ក៏
ឡើងទៅឡោមព័ទ្ធ[ឆ]ច្បាំងនឹងក្រុងសាម៉ារីអស់៣ឆ្នាំ ៦ នៅ
ឆ្នាំទី៩ក្នុងរាជ្យហូសៀ នោះស្តេចអាសស៊ើរក៏[ជ]វាយយក
ក្រុងសាម៉ារីបាន[ឈ] ហើយទ្រង់ដឹកនាំ[ញ]ពួកអ៊ីស្រាអែលទៅ
ឯស្រុកអាសស៊ើរ ដាក់ឱ្យនៅត្រង់ក្រុងហាឡានៅមាត់
ទន្លេហាបោ ជាទន្លេរបស់ស្រុកកូសាន[ដ] ហើយនៅក្នុងទីក្រុង
របស់សាសន៍មេឌីទាំងប៉ុន្មានដែរ ។

**១៧:២** ខ ចទ ៤:២៥ **១៧:៣** គ ហស ១០:១៤ ឃ ពច ៣:១៥ **១៧:៤** ង ទដ ១៤៦:៣ អស ៣០:១,៧ ៣៦:៦ យរ ២:៣៦ ហស ១២:១ ច ហស ១៣:១០ **១៧:៥** ឆ ហស ១៣:១៦ **១៧:៦** ជ ខ.២០ ២ពវ ១៥:២៩ អស ៤២:២៤ ឈ អស ១០:៩ ញ ចទ ៤:២៧ ២៤:១ ២ពវ ១៥:២៩ អម ៧:១៧ ដ ១របា ៥:២៦ **១៧:៧** ឋ យស ៧:១១ ឌ នក ១៤:១៥–៣១ **១៧:៨** ឍ នក

## ពួកកូនចៅអ៊ីស្រាអែលត្រូវនិរទេសដោយសារធ្វើបាប

៧ ការនោះកើតមក ដោយព្រោះតែពួកកូនចៅអ៊ីស្រាអែល
បានធ្វើបាប[ឋ]នឹងព្រះយេហូវ៉ាជាព្រះនៃគេ ដែលទ្រង់បាន
នាំគេឡើងចេញពីស្រុកអេស៊ីព្ទ[ឌ] ឱ្យរួចពីកណ្តាប់ដៃនៃ
ផារ៉ោន ជាស្តេចស្រុកអេស៊ីព្ទមក ហើយដោយព្រោះគេ
បានកោតខ្លាចដល់ព្រះដទៃ ៨ ព្រមទាំងប្រព្រឹត្តតាមអស់ទាំង
ទំនៀមទំលាប់នៃពួកសាសន៍ដទៃ[ឍ] ដែលព្រះយេហូវ៉ាបាន
បណ្តេញពីមុខពួកកូនចៅអ៊ីស្រាអែលចេញ នឹងតាមច្បាប់
ដែលពួកស្តេចអ៊ីស្រាអែលបានតាំងដែរ ៩ ពួកកូនចៅអ៊ីស្រា
អែលបានប្រព្រឹត្តអំពើដែលមិនត្រឹមត្រូវ ដោយលួចលាក់
ទាស់នឹងព្រះយេហូវ៉ា ជាព្រះនៃគេក៏ធ្វើទីខ្ពស់សំរាប់ខ្លួន
នៅគ្រប់ទាំងទីក្រុង ចាប់តាំងពីភូមិ ដែលមានតែប៉ម
ចាំយាម រហូតដល់ទីក្រុងមានកំផែង[ណ] ១០ គេបានធ្វើ
បង្គោលសំរាប់គោរព[ត] និងរូបព្រះ[ថ] នៅលើអស់ទាំងទីភ្នំ
ហើយនៅក្រោមដើមឈើខ្ចីទាំងប៉ុន្មានផង[ទ] ១១ ឯនៅលើ

៣៤:១៥ លវ ១៨:៣ ចទ ៩:៤ **១៧:៩** ណ ២ពវ ១៨:៨ **១៧:១០** ត នក ២៣:២៤ ថ នក ៣៤:១៣ អស

**១៧:១** *ឆ្នាំទី១២ ក្នុងរាជ្យស្តេចអ័ហាស* នេះគឺស្ថិតនៅក្នុងឆ្នាំទី ៧៣២ មុន គ.ស (មើលការពន្យល់ ១៥:៣០) ហើយនៅត្រង់នេះក៏អាចសន្មតថា ស្តេចអ័ហាសចាប់ផ្តើមគ្រងរាជជាមួយនឹងស្តេចអ័ហាស៊ីយ៉ានៅក្នុងឆ្នាំ៧៤៤ ឬ ៧៤៣ មុន គ.ស (សូមមើល ពន្យល់ ១៦:១–២) ។ *៩ឆ្នាំ* គឺនៅចន្លោះឆ្នាំទី ៧៣២–៧២២ (មើលសេចក្តីផ្តើម ១ពវ : ត្រង់កាលប្រវត្តិ) ។

**១៧:៣** *សាលម៉ានេស៊ើរ* នៅត្រង់នេះបានប្រាប់ថា ស្តេចហូសៀបានចុះចូលជាមួយនឹងស្តេចស្រុកអាសស៊ើរស្ថិតក្រោមការដឹកនាំរបស់ស្តេច ទីឡាត–ពីឡេស៊ើរ (សូមមើលការពន្យល់ ១៥:៣០) តែក្រោយមករាជ្យបល្ល័ង្កនេះបានគ្រងរាជ្យដោយសាលម៉ានេស៊ើរ ស្ថិតក្នុងឆ្នាំ ៧២៧–៧២២ មុន គ.ស ។

**១៧:៥** *៣ឆ្នាំ* ស្ថិតនៅក្នុងឆ្នាំទី ៧២៥–៧២២ មុន គ.ស ដែលស្រុកសាម៉ារីមានសភាពខ្លាំងក្លា ហើយពិបាកក្នុងការបង្ក្រាប (មើលការពន្យល់ ១ពវ ១៦:២៤) ។

**១៧:៦** *ឆ្នាំទី៩ក្នុងរាជ្យហូសៀ* គឺឆ្នាំទី ៧២២ មុន គ.ស (មើលការពន្យល់ ខ.១) ។ *ស្តេចស្រុកអាសស៊ើរ ក៏វាយយកក្រុងសាម៉ារី* ការនេះបានសម្រេចនៅក្នុងរដូវរងារ (ក្នុងខែធ្នូ)ក្នុងឆ្នាំ ៧២២–៧២១ ស្តេចសាលម៉ានេស៊ើរបានចូលទីវង្គត(ដោយការធ្វើគត) ហើយរាជបល្ល័ង្ករបស់ពួកអាសស៊ើត្រូវបានសើកុនទី២គ្រងរាជ្យ(ឆ្នាំ ៧២២–៧២១) ។ នៅក្នុងកំណត់ត្រារបស់ស្តេចអង្គនេះ បានអះអាងថាទ្រង់បានព្យាយាមធ្វើការចាប់ខ្លួន និងបោសសំអាតពួកសាម៉ារី ។ *ដឹកនាំពួកអ៊ីស្រាអែល* ពីព្រោះតែពួកអ៊ីស្រាអែលមិនបានស្តាប់បង្គាប់ដល់ព្រះយេហូវ៉ា នោះព្រះទ្រង់បាននាំពួកគេទៅកាត់ទោស ដូចដែលអ័ហ៊ីយ៉ាបានប្រកាសនៅក្នុងរាជ្យស្តេចរបស់ពួកអ៊ីស្រាអែលដំបូង គឺស្តេចយេរ៉ូបោមទី១ (សូមមើលការពន្យល់ ១ពវ ១៤:១៥) ។ ក្នុងរាជ្យសើកុនទី២ បានអះអាងថាទ្រង់បានបញ្ជូនពួកអ៊ីស្រាអែលចំនួន ២៧២៩០នាក់ ។ ហើយបន្ទាប់មកទ្រង់បានជម្លាសប្រជាជនដទៃទៀតចេញ ពីទីក្រុងនៃពួកអ៊ីស្រាអែល (សូមមើល ខ.២៤) ។

**១៧:៧–២៣** សាប់រឿងបរិបទគម្ពីរនៅត្រង់នេះ បានប្រាប់អំពីការដួលចុះរបស់ពួកអ៊ីស្រាអែល ដែលពួកគេត្រូវព្រះយេហូវ៉ាបោះបង់ ចោលម្តងទៀត ។ ពួកគេបានលះចោលសិរីល្អព្រះយេហូវ៉ា ការយកចិត្តទុកដាក់របស់ពួកហោរា (មើល ខ.១៣–១៤,២៣) ហើយពួកគេបានប្រព្រឹត្តប្រាកចាកពីកាតព្វកិច្ចរបស់ខ្លួន (មើល ខ.១៥) ។ នៅទីបំផុតពួកគេម្នាក់ៗបានធ្លាក់ចូលក្នុងសេចក្តីបណ្តាសាយ៉ាងជាក់ច្បាស់ ដូចដែលលោកម៉ូសេបានបង្គាប់ដល់ពួកគេមុនពួកគេចូលក្នុងទឹកដីសន្យាកាណាន (សូមមើល ចទ ២៨:៤៩–៦៨ ៣២:១–៤៧) ។

**១៧:៧** *ទ្រង់បាននាំគេឡើងចេញពីស្រុកអេស៊ីព្ទ* ការសង្គ្រោះពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទជាមូលដ្ឋានគ្រឹះនៃការរំដោះពួកគេនៅក្នុងប្រវត្តិសាស្ត្ររបស់ពួកអ៊ីស្រាអែល ។ ពួកគេ ជាម្ចាស់កម្មសិទ្ធនៃសញ្ញាតិមួយ ចំពោះភាពសមស្ងួន និងព្រះចេស្តានៃព្រះយេហូវ៉ា (សូមមើល នក ២០:២ ចទ ៥:១៥ ២៦:៨ យស ២៤:៥–៧,១៧ ពច ១០:១១ ១សយ ១២:៦ នហ ៩:៩–១៣ មីក ៦:៤) ។ *កោតខ្លាចដល់ព្រះដទៃ* នេះជាការប្រព្រឹត្តរំលងចំពោះព្រះយេហូវ៉ារបស់ពួកអ៊ីស្រាអែល (សូមមើល ខ.៣៥ ចទ ៥:៧ ៦:១៤ យស ២៤:១៤–១៦,២០ យរ ១:១៦ ២:៥–៦ ២៥:៦ ៣៥:១៥) ។

**១៧:៨** *ប្រព្រឹត្តតាមអស់ទាំងទំនៀមទំលាប់នៃពួកសាសន៍ដទៃ* សូមមើល ចទ ១៨:៩ ពច ២:១២–១៣ ។

**១៧:៩** *ធ្វើទីខ្ពស់សំរាប់ខ្លួន នៅគ្រប់ទាំងទីក្រុង* សូមមើល ១៤:៤ ១៥:៤,៣៥ និងមើលបន្ថែមការពន្យល់ ១៦:៤ ១ពវ ៣:២ ១៥:១៤ ។

**១៧:១០** *បង្គោលសំរាប់គោរព* មើលការពន្យល់ ១ពវ ១៤:២៣ ។ *នៅក្រោមដើមឈើខ្ចីទាំងប៉ុន្មានផង* មើល ១៦:៤ ១ពវ ៣:២ យរ ២:២០ ៣:៦,១៣ ១៧:២ ។

អស់ទាំងទីខ្ពស់នោះ គេក៏ដុតកំញានដូចជាសាសន៍ដទៃ
ដែលព្រះយេហូវ៉ាបានបណ្តេញពីមុខគេចេញ គេប្រព្រឹត្ត
អំពើដ៏លាមកអាក្រក់ ជាការដែលនាំឱ្យព្រះយេហូវ៉ាទ្រង់
មានសេចក្តីក្រោធ ១២ គេគោរពប្រតិបត្តិតាមរូបព្រះ[ធ]ដែល
ព្រះយេហូវ៉ាទ្រង់ហាមថា ឯងរាល់គ្នាមិនត្រូវធ្វើយ៉ាងនោះ
ឡើយ ១៣ ប៉ុន្តែព្រះយេហូវ៉ាទ្រង់បានធ្វើបន្ទាល់[ន] ដល់ពួក
អ៊ីស្រាអែល និងពួកយូដា ដោយសារគ្រប់ទាំងពួកហោរា
នឹងអ្នកមើលឆុតថា[ប] ចូរឱ្យឯងរាល់គ្នាបែរចេញ ពីផ្លូវ
អាក្រក់របស់ឯងទៅ[ផ] ហើយកាន់តាមក្រឹត្យក្រម និងបញ្ញត្ត
អញទាំងប៉ុន្មាន តាមច្បាប់ទាំងអស់ដែលអញបានបង្គាប់
ដល់ពួកឰយុកោឯង ហើយដែលអញបានផ្ញើមកឯងរាល់គ្នា
ដោយសារពួកហោរា ជាពួកអ្នកបំរើរបស់អញ[ព] ១៤ ប៉ុន្តែ
គេមិនព្រមស្តាប់ទេ គឺបានតាំងចិត្តរឹង[ភ]វិញ ដូចជាពួក
ឰយុកោគេ ដែលមិនបានជឿដល់ព្រះយេហូវ៉ា ជាព្រះនៃគេ
ដែរ ១៥ គេបោះបង់ចោលបញ្ញត្តរបស់ទ្រង់ និងសេចក្តី
សញ្ញា[ម] ដែលទ្រង់បានតាំងនឹងពួកឰយុកោគេចេញព្រម
ទាំងសេចក្តីបន្ទាល់ ដែលទ្រង់បានមានបន្ទូលនឹងគេផង
គេដើរតាមតែសេចក្តីជាអសារឥតការវិញ[យ] ហើយខ្លួនគេក៏
ត្រឡប់ជាអសារឥតការដែរ[រ] គេប្រព្រឹត្តតាមពួក សាសន៍
ដទៃនៅជុំវិញ[ល] ដែលព្រះយេហូវ៉ាហាមថា កុំឱ្យត្រាប់តាម
អ្នកទាំងនោះឡើយ ១៦ គេបោះបង់ចោលអស់ទាំងក្រឹត្យក្រម
របស់ព្រះយេហូវ៉ា ជាព្រះនៃខ្លួនក៏សិតធ្វើរូប គឺជារូបកូន
គោ២[វ] ហើយធ្វើរូបព្រះ[ស] ព្រមទាំងថ្វាយបង្គំដល់អស់ទាំង
ពលបរិវារ[ហ]នៅលើមេឃ ហើយគោរពប្រតិបត្តិដល់ព្រះ
បាលផង[ឡ] ១៧ គេធ្វើឱ្យកូនប្រុសកូនស្រីគេឆ្លងកាត់ភ្លើង[អ]
ហើយប្រើរបៀនផ្សេងៗ នឹងការមន្តអាគម[ក]ព្រមទាំងលក់[ខ]
ខ្លួនគេទៅឱ្យបានប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រ
ព្រះយេហូវ៉ា ជាការដែលនាំឱ្យទ្រង់មានសេចក្តីក្រោធ
១៨ ដោយហេតុនេះ បានជាព្រះយេហូវ៉ាទ្រង់មានសេចក្តី
ក្រេវក្រោធជាខ្លាំង ចំពោះពួកអ៊ីស្រាអែល ក៏រើគេចេញពី
ចំពោះព្រះនេត្រ[គ]ទ្រង់ទៅ សល់នៅតែពូជអំបូរយូដាតែ១
ប៉ុណ្ណោះ ។

១៩ ឯពួកយូដា គេក៏មិនបានកាន់តាមក្រឹត្យក្រមរបស់ព្រះ
យេហូវ៉ាជាព្រះនៃគេដែរ គឺគេដើរតាមតែទំនៀម ដែល

១៧:៨ មីក ៥:១៤ ទ ចទ ១២:២ **១៧:១២** ធ នក ២០:៤ **១៧:១៣** ន ពច ៦:៨ ២រប ៧:១៤ យប ៣៤:៣៣ អគ ៣:១៧–១៩ ប ១សយ ៩:៩ ផ យរ ៤:១ ១៨:១១ ២៣:២២ ២៥:៥ ៣៥:១៥ ៣៦:៣ សក ១:៤ ព មថ ២៣:៣៤ **១៧:១៤** ភ នក ៣២:៩ កច ៧:៥១ **១៧:១៥** ម លវ ២៦:១១ ចទ ២៩:២៥ ពច ២:២០ ១ពវ ១១:១១ ២ពវ ១៨:១២ ទដ ៧៨:១០ អគ ៥:៦ មឡ ២:១០ យ ចទ ៣២:២១ ហស ១១:២ រម ១:២១–២៣ រ យរ ២:៥ ល ចទ ១២:៤

**១៧:១៦** វ នក ៣២:៤ ស ចទ ១៦:២១ ហ លប ២:១ អស ៤០:២៦ យរ ១៩:១៣ ឡ ពច ២:១១ **១៧:១៧** អ ចទ ១២:៣១ ១៨:១០–១២ ២ពវ ១៦:៣ អគ ១៦:២១ ក លវ ១៩:២០ ខ ១ពវ ២១:២០ រម ៧:១៤ **១៧:១៨** គ លប ៤:១៤ នក ៣៣:១៥ ២ពវ ១២:២៣ ២ថន ១:៩

**១៧:១១** *ប្រព្រឹត្តអំពើដ៏លាមកអាក្រក់* ឃ្លានេះប្រហែលជាចង់សំដៅលើសេចក្តីកំផិត (មើលការពន្យល់ ១ពវ ១៤:២៤ និងមើលបន្ថែម ហស ៤:១៣–១៤ ) ។

**១៧:១២** *រូបព្រះ* មើលការពន្យល់ លវ ២៦:៣០ ។ *ព្រះយេហូវ៉ាទ្រង់ហាមថា ឯងរាល់គ្នាមិនត្រូវធ្វើយ៉ាងនោះឡើយ* សូមមើល នក ២៣:១៣ លវ ២៦:១ ចទ ៥:៦–១០ ។

**១៧:១៣** *ធ្វើបន្ទាល់ដល់ពួកអ៊ីស្រាអែល និងពួកយូដា ដោយសារគ្រប់ទាំងពួកហោរា* នៅត្រង់នេះបញ្ជាក់ថា ពួកអ៊ីស្រាអែលមិនគ្រាន់តែរំលោភដល់ក្រឹត្យវិន័យភ្នំស៊ីណាយប៉ុណ្ណោះទេ តែពួកគេក៏បានច្រានចោលសេចក្តីទំនាយរបស់ពួកហោរា ដែលព្រះយេហូវ៉ាបានបញ្ជូនពួកគេឱ្យមកនាំរាស្ត្ររបស់ព្រះអង្គតាមសេចក្តីសញ្ញារបស់ព្រះ (សូមមើល ឧទាហរណ៍ ១ពវ ១៣:១–៣ ១៤:៦–១៦ ពច ៦:៨–១០ ១សយ ៣:១៩–២១ គឺដូចនឹងបេសកកម្មរបស់លោកអេលីយ៉ា អេលីសេ អេម៉ុស និងហូសេ) ។ *មើលឆុត* សូមមើលការពន្យល់ ១សយ ៩:៩ ។

**១៧:១៤** *បានតាំងចិត្តរឹងវិញ* នៅត្រង់នេះចង់បង្ហាញថា ពួកគេមានចិត្តរឹងហើយតតាំងដូចសត្វគោ ដែលមិនព្រមចុះសម្រុងនឹងនឹមរបស់វាអញ្ចឹងដែរ (មើល ចទ ១០:១៦ យរ ២:២០ ៧:២៦ ១៧:២៣ ១៩:១៥ ហស ៤:១៦) ។

**១៧:១៥** *ដើរតាមសេចក្តីជាអសារឥតការវិញ* សូមមើល ចទ ៣២:២១ យរ ២:៥ ៨:១៩ ១០:៨ ១៤:២២ ៥១:១៨ ។

**១៧:១៦** *ក៏សិតធ្វើរូប គឺជារូបកូនគោ២ ហើយធ្វើរូបព្រះ* នេះគឺចង់សំដៅដល់រូបព្រះគោនៅឯបេតអែល និងក្រុងដាន់ (សូមមើល ១ពវ ១២:២៨–៣០) ។ *អស់ទាំងពលបរិវារនៅលើមេឃ* នេះបញ្ជាក់ថា ពួកអ៊ីស្រាអែលមិនត្រូវបានអនុញ្ញាតឱ្យគោរពផ្កាយនៅលើមេឃ ដូចនឹងពួកសាសន៍ដទៃដែលជាពួកអ្នកជិតខាងខ្លួននោះឡើយ (សូមមើល ចទ ៤:១៩ ១៧:៣) ។ ទោះបីទម្រង់នៃសេចក្តីកំផិតមិនត្រូវបាននិយាយនៅក្នុងព្រះគម្ពីរមុនៗ ដូចជា ១ពវ និង ២ពវ នេះក៏ដោយ ក៏លោកហោរាអេម៉ុសបាននិយាយបញ្ជិតបញ្ជៀងចំៗដល់ពួកអ៊ីស្រាអែលដែលបានប្រព្រឹត្តការនេះ នៅក្នុងរាជរបស់ស្តេចយេរ៉ូបោមទី២ (មើលការពន្យល់ អម ៥:២៦) ។ អំពើរនេះក្រោយមកបានហូរចូលទៅក្នុងពួកយូដានៅក្នុងរាជ្យស្តេចម៉ាន៉ាសេ (សូមមើល ២១:៣,៥) ហើយសេចក្តីទាំងអស់នេះត្រូវបានលុបបំបាត់ចោលនៅអំឡុងពេលកំណែទម្រង់របស់ស្តេចយ៉ូសៀស (សូមមើល ២៣:៤–៥,១២ និងមើលបន្ថែម អគ ៨:១៦) ទៅវិញ ។

**១៧:១៧** *កូនប្រុស កូនស្រីគេ* សូមមើលការពន្យល់ ១៦:៣ ។ *របៀនផ្សេងៗ និងមន្តអាគម* ទង្វើនេះត្រូវបានហាមប្រាមនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ (សូមមើលការពន្យល់ ១៦:១៥ លវ ១៩:២៦ ចទ ១៨:១០) ។

**១៧:១៨** *ក៏រើគេចេញ ពីចំពោះព្រះនេត្រទ្រង់* ព្រះយេហូវ៉ាទ្រង់បាននិរទេសពួកអ៊ីស្រាអែលចេញពីទឹកដីរបស់ពួកគេ (ខ.៦ ២៣:២៧) ។ *សល់នៅតែពូជអំបូរយូដាតែ១ប៉ុណ្ណោះ* នេះបញ្ជាក់ថានៅក្នុងពួកយូដាក៏មានរួមបញ្ចូលអំបូសំខាន់ៗមួយចំនួនផងដែរ ដូចជា ស៊ីម្មាន បេនយ៉ាមីន ប៉ុន្តែពួកយូដាជាសាសន៍តែមួយគត់ដែលនៅភាគខាងត្បូងដើម្បីទប់ស្កាប់នូវអំពើសុចរិតរបស់ពួកគេ (មើលការពន្យល់ ១ពវ ១១:៣១–៣២ និងមើលបន្ថែមការពន្យល់ ២ពវ ១៩:៤) ។

ពួកអ៊ីស្រាអែលធ្លាប់ប្រព្រឹត្តមកវិញ[ឃ] ២០ហេតុនោះបានជា
ព្រះយេហូវ៉ា ទ្រង់បោះបង់ចោលពូជអ៊ីស្រាអែលទាំងអស់
ក៏ធ្វើទុក្ខគេ ហើយប្រគល់គេទៅក្នុងកណ្ដាប់ដៃរបស់ពួកអ្នក
ដែលបំផ្លាញគេ[ង]ដរាបដល់ទ្រង់បានបោះគេចោលពីពោះ
ព្រះភក្ត្រទ្រង់ចេញ[ច] ២១ទ្រង់បានហែក[ឆ]ពួកអ៊ីស្រាអែល
ផ្ដាច់ចេញ ពីជិនួរវង្សដាវីឌ ក៏លើកយេរ៉ូបោម ជាកូន
នេបាត តាំងឡើងឱ្យធ្វើជាស្ដេចវិញ[ជ] ឯយេរ៉ូបោមក៏បាន
ញាក់ទាញពួកអ៊ីស្រាអែលចេញពីព្រះយេហូវ៉ា ព្រមទាំង
បណ្ដាលឱ្យគេធ្វើបាបជាទំងន់[ឈ] ២២ពួកកូនចៅអ៊ីស្រាអែល
ក៏បានដើរតាមអស់ទាំងអំពើបាប ដែលយេរ៉ូបោមបាន
ប្រព្រឹត្តទាំងនោះ គេមិនបានវៀរបង់លែងប្រព្រឹត្តតាម
អំពើទាំងនោះឡើយ ២៣ដរាបដល់ព្រះយេហូវ៉ាទ្រង់
បណ្ដេញគេ ពីចំពោះព្រះភ័ក្ត្រទ្រង់ចេញ[ញ]ដូចជាទ្រង់បាន
មានបន្ទូល[ដ] ដោយសារអស់ទាំងហោរាជាអ្នកបំរើទ្រង់
ដូច្នេះ អ៊ីស្រាអែលក៏ត្រូវគេដឹកនាំចេញពីស្រុករបស់ខ្លួន[ឋ]
ទៅនៅឯស្រុកអាសស៊ើរ ដរាបដល់សព្វថ្ងៃនេះ ។

## ការអាស្រ័យនៅស្រុកសាម៉ារីឡើងវិញ

២៤រួចមកស្ដេចអាសស៊ើរ[ឌ] ទ្រង់នាំយកមនុស្សពីក្រុង
បាប៊ីឡូន ក្រុងគូថា ក្រុងអាវ៉ា ក្រុងហាម៉ាត និងក្រុង
សេផារវែម[ឍ] ទៅដាក់ឱ្យនៅក្នុងអស់ទាំងទីក្រុងស្រុកសាម៉ារី
ជំនួសពួកកូនចៅអ៊ីស្រាអែលវិញ អ្នកទាំងនោះបានស្រុក
សាម៉ារីជារបស់ផងគេ ហើយក៏អាស្រ័យនៅក្នុងអស់ទាំង
ទីក្រុងស្រុកនោះ ២៥កាលគេចាប់តាំងនៅក្នុងស្រុក គេមិន
បានកោតខ្លាចដល់ព្រះយេហូវ៉ាទេ ហេតុនោះព្រះយេហូវ៉ា
ទ្រង់ប្រើសត្វសិង្ហ[ណ]ឱ្យទៅនៅកណ្ដាលគេ សិង្ហទាំងនោះ
បានសំឡាប់អ្នកខ្លះបង់ ២៦ដូច្នេះ គេទូលដល់ស្ដេចអាសស៊ើរ
ថា ពួកសាសន៍ទាំងប៉ុន្មាន ដែលទ្រង់បាននាំយកទៅ ទុកឱ្យ
នៅក្នុងអស់ទាំងទីក្រុងស្រុកសាម៉ារី គេមិនស្គាល់ច្បាប់នៃ
ព្រះរបស់ស្រុកនោះទេ បានជាព្រះទ្រង់ឱ្យសត្វសិង្ហ ទៅនៅ
កណ្ដាលគេ ហើយមើល សត្វទាំងនោះកំពុងតែសំឡាប់គេ
ទៅ ដោយព្រោះគេមិនស្គាល់ច្បាប់ នៃព្រះរបស់ស្រុក
នោះ ។

២៧នោះស្ដេចអាសស៊ើរទ្រង់បង្គាប់ថា ចូរនាំយកពួក
សង្ឃម្នាក់ ដែលបានដឹកនាំចេញមកពីស្រុកនោះ ឱ្យទៅនៅ
ឯណោះវិញចុះ ដើម្បីនឹងបង្រៀនគេពីច្បាប់នៃព្រះរបស់

**១៧:១៩** ឃ ២ពវ ១៦:៣ យរ ៣:៦-១០ អគ ២៣:១៣
**១៧:២០** ង ខ.៦ ច យរ ៧:១៥ ១៥:១
**១៧:២១** ឆ ១សយ ១៥:២៧ ១ពវ ១១:១១ ជ ១ពវ ១២:២០ ឈ ១ពវ ២:៣០
**១៧:២៣** ញ អគ ៣៩:២៣-២៤ ដ ពច ៦:៨ ឋ ១ពវ ៩:៧
**១៧:២៤** ឌ ២ពវ ១៩:៣៧ អរ ៤:២,១០ អស ៣៧:៣៨ ឍ ខ.៣១ ២ពវ ១៥:២៩ ១៨:៣៤ អស ៣៦:១៩ ៣៧:១៣ អម ៦:២
**១៧:២៥** ណ លប ៣៧:២០ អស ៥:២៩ ១៥:៩ យរ ៥០:១៧

**១៧:២០** *ធ្វើទុក្ខគេ ហើយប្រគល់គេទៅក្នុងកណ្ដាប់ដៃរបស់ពួកអ្នកដែលបំផ្លាញ* មើល ១០:៣២-៣៣ ១៣:៣,២០ ២៤:២ ២របា ២១:១៦ ២៨:១៨ អម ១:១៣ ។

**១៧:២១** *ហែកពួកអ៊ីស្រាអែលផ្ដាច់ចេញពីជិនួរវង្សដាវីឌ* សូមមើល ១ពវ ១១:១១,១៣ ១២:២៤ ។ ការបែងចែកអាណាចក្រនៅត្រង់នេះ គឺជាព្រះយេហូវ៉ា តែវាបានក្លាយទៅជាការកាត់ទោសនៃអំពើបាបរបស់ពួកគេ ។ *យេរ៉ូបោម...បណ្ដាលឱ្យគេធ្វើបាបជាទំងន់* សូមមើល ១ពវ ១២:២៦-៣២ ១៣:៣៣-៣៤ និងមើលបន្ថែមការពន្យល់ លប ២០:៩ ។

**១៧:២៣** *ដោយសារអស់ទាំងហោរា ជាអ្នកបំរើទ្រង់* នេះជាសេចក្ដីព្រមានដល់ពួកគេ ដែលព្រះយេហូវ៉ាមានបន្ទូលមកកាន់ពួកហោរាដោយផ្ទាល់ (សូមមើល ១ពវ ១៤:១៥-១៦ ហស ១០:១-៧ ១១:៥ អម ៥:២៧) ។

**១៧:២៤** *ស្ដេចអាសស៊ើរ* ស្ដេចសាកន់ ទី២ (Sargon II, ឆ្នាំ ៧២១-៧០៥ មុនគ.ស) ជាស្ដេចទីមួយដែលនាំឱ្យពួកសាសន៍ដទៃ ចូលមករស់នៅក្នុងទីក្រុងសាម៉ារី (អរ ៤:២,៩-១០) ហើយក្រោយមកស្ដេចនៃចក្រភពអាសស៊ើរផ្សេងទៀត បានបន្តធ្វើការនេះទៀត ។ ស្ដេចទាំងនោះមានដូចជា អេសាហាដ់ដុំម (Esarhaddon, ឆ្នាំ ៦៨១-៦៦៩) អាសស៊ើបានីប៉ា (Ashurbanipal, ឆ្នាំ ៦៦៩-៦២៧) ។ *បាប៊ីឡូន ក្រុងគូថា* ក្រុងបាប៊ីឡូន និងក្រុងគូថា (ត្រូវបានរកឃើញដែលមានចម្ងាយប្រហែល ៨,៦០៨ គ.ម ពីបាប៊ីឡូន) គឺត្រូវបានគេបង្ខំឱ្យធ្វើជាចំណុះនឹងស្រុកអាសស៊ើរដោយ ស្ដេចសាកន់ទី២ ក្នុងឆ្នាំ ៧០៩ មុនគ.ស ។ *ក្រុងអាវ៉ា* គឺប្រហែលដូចគ្នាទៅនឹងក្រុងអីវ៉ា (មើល ១៨:៣៤ ១៩:១៣) ។ វាជាការចូលរួមជាមួយក្រុងហាម៉ាត និងក្រុងអើផាឌ ដែលបានរកឃើញនៅកន្លែងណាមួយក្នុងក្រុងអ័រាម (សេរី) ។ *ក្រុងហាម៉ាត* បានរកឃើញតាមដងទន្លេ (Orontes) (មើល ១៤:២៥ ១៨:៣៤ និងមើលការពន្យល់ អគ ៤៧:១៥) ។ ស្រុកសាម៉ារី ត្រង់កន្លែងនេះគឺត្រូវបានជ្រើសរើសទុកជាមុនសម្រាប់រាជាណាចក្រខាងជើង (មើលការពន្យល់ ១ពវ ១៣:៣២) ។

**១៧:២៥** *មិនកោតខ្លាចដល់ព្រះយេហូវ៉ា* ពួកគេបានថ្វាយបង្គំព្រះរបស់ពួកគេ គឺមិនបានថ្វាយបង្គំដល់ព្រះយេហូវាឡើយ ។ *ព្រះយេហូវ៉ាទ្រង់ប្រើសត្វសិង្ហឱ្យនៅកណ្ដាលគេ* ចំពោះសត្វសិង្ហជានិច្ចកាលមានវត្តមាននៅក្នុងទឹកដីកាណាន (សូមមើល ១ពវ ១៣:២៤ ២០:៣៦ ពច ១៤:៥ ១អស ១៧:៣៤ អម ៣:១២) ។ លទ្ធផលនៃការវិនាន និង ការធ្វើឱ្យប្រជាជនពាយ ដែលបណ្ដាមកពីជម្លោះជាមួយពួកអាសស៊ើរ នោះចំនួនសត្វសិង្ហបានកើនឡើង (សូមមើល នក ២៣:៩) ។ ហេតុការណ៍នេះ ពួកអ្នកស្រុក និងអ្នកនិពន្ធកណ្ឌគម្ពីរនេះបានសន្និដ្ឋានថា វាជាការកាត់ទោសរបស់ព្រះយេហូវ៉ា (មើល លវ ២៦:២១-២២) ។

**១៧:២៦** *ស្ដេចអាសស៊ើរ* ស្ដេចនេះគឺសើកុនទី២ ។

**១៧:២៧** *ពួកសង្ឃម្នាក់* គឺសំដៅលើសង្ឃម្នាក់ដែលស្ដេចយេរ៉ូបោម បានតាំងឡើងនៅក្នុងពួកអ៊ីស្រាអែល (មើល ១ពវ ១២:៣១ និងការពន្យល់) ។

**១៧:២៧-២៩** នៅវគ្គនេះ ចង់បង្ហាញថាពួកអ្នកបោះទីលំនៅថ្មីនៅក្នុងទឹកដីអ៊ីស្រាអែលបានថ្វាយបង្គំព្រះ ដោយគ្មានការលះចោលការថ្វាយបង្គំព្រះដទៃរបស់ពួកគេឡើយ ។ ការថ្វាយបង្គំព្រះរបស់ពួកគេ គឺមិនមែនក្នុងគោលបំណងធ្វើឱ្យព្រះសព្វព្រះហឫទ័យទេ គឺគេចាត់ទុកព្រះយេហូវ៉ាជាអ្នកនាំព្រេងសំណាង ឬគ្រាន់តែជារូបព្រះមួយបែបដែលពួកគេត្រូវជ្រើសរើសប៉ុណ្ណោះ ។ ភាពស្រដៀងគ្នានេះ គឺដូចនឹងអ្វីដែលមនុស្សបច្ចុប្បន្នបាន និង

ស្រុកនោះ ២៨ដូច្នេះ ពួកសង្ឃម្នាក់ដែលគេបានដឹកនាំចេញពី
ស្រុកសាម៉ារីមក ក៏វិលទៅនៅឯក្រុងបេត–អែលបង្ហាត់
បង្រៀនគេ ពីបែបដែលត្រូវកោតខ្លាចដល់ព្រះយេហូវ៉ា
២៩ប៉ុន្តែគ្រប់ទាំងសាសន៍នោះបានធ្វើព្រះសំរាប់គេរៀង
ខ្លួន ដាក់ទុកនៅក្នុងអស់ទាំងវិហារ[ត]នៅទីខ្ពស់[ថ] ដែលពួក
សាម៉ារីបានធ្វើ គឺគ្រប់ទាំងសាសន៍នោះ តាមទីក្រុងដែល
គេអាស្រ័យនៅ[ទ] ៣០ពួកដែលមកពីក្រុងបាប៊ីឡូន គេធ្វើព្រះ
សិកូត–បេណូត ពួកក្រុងគូថា គេធ្វើព្រះនើ កាលពួកក្រុង
ហាម៉ាតគេធ្វើព្រះអ័ស៊ីម៉ា ៣១ពួកក្រុងអាវ៉ា គេធ្វើព្រះនីប
ហាសនិងព្រះថើថាក ហើយពួកសេផាវែមគេដុតកូនរបស់
គេក្នុងភ្លើងថ្វាយព្រះអ័ឌ្រាម៉ាលេក និងព្រះអ័ណាម៉ាលេក[ធ]
ជាព្រះរបស់ពួកសេផាវែមនោះ[ន] ៣២យ៉ាងនោះ គេបាន
កោតខ្លាចដល់ព្រះយេហូវ៉ា ព្រមទាំងតាំងពួកគេខ្លះ[ប]ឡើង
ឱ្យធ្វើជាសង្ឃនៃអស់ទាំងទីខ្ពស់ សំរាប់ខ្លួនគេផង ពួកសង្ឃ
នោះក៏ថ្វាយយញ្ញបូជារបស់គេ នៅក្នុងអស់ទាំងវិហារនៃ
ទីខ្ពស់ទាំងនោះ ៣៣គេបានកោតខ្លាចដល់ព្រះយេហូវ៉ាផង
ហើយគោរពប្រតិបត្តិតាមព្រះរបស់ខ្លួនផង តាមទំលាប់
របស់សាសន៍ទាំងប៉ុន្មាន នៅស្រុកកំណើតគេរៀងខ្លួន ៣៤គេ
នៅតែប្រព្រឹត្តតាមបែបនោះដរាបដល់សព្វថ្ងៃនេះ គេមិន
មែនកោតខ្លាចដល់ព្រះយេហូវ៉ាជាពិតទេ ហើយមិនមែន
ប្រព្រឹត្តតាមបញ្ញត្តតាមវិន័យរបស់ខ្លួនគេដែរ ឬតាមច្បាប់
និងក្រិត្យក្រម ដែលព្រះយេហូវ៉ាបានបង្គាប់ ដល់ពួកកូន
ចៅយ៉ាកុប ជាអ្នកដែលទ្រង់ឱ្យឈ្មោះថា អ៊ីស្រាអែលនោះ
ផង[ផ] ៣៥ព្រះយេហូវ៉ាទ្រង់បានតាំងសេចក្តីសញ្ញានឹងពួកកូន
ចៅយ៉ាកុបនោះ ហើយហាមថា ឯងរាល់គ្នាមិនត្រូវកោត
ខ្លាច[ព]ដល់ព្រះដទៃឡើយក៏មិនត្រូវ ក្រាបគោរពដល់ព្រះ

**១៧:២៩** ត លវ ២៦:៣០ ១ពវ ១២:៣១ ថ មីក ៤:៥ ទ យរ ២:២៨ ១១:១៣
**១៧:៣១** ធ ២ពវ ១៩:៣៧ ន ខ.២៤
**១៧:៣២** ប ១ពវ ១២:៣១
**១៧:៣៤** ផ លប ១៧:៥ ១ពវ ១៨:៣១
**១៧:៣៥** ព នក ២០:៥ ភ នក ២០:៣
**១៧:៣៦** ម នក ៣:២០ ទដ ១៣៦:១២
**១៧:៣៧** យ ចទ ៥:៣២ រ លវ ១៩:៣៧
**១៧:៣៨** ល ចទ ៦:១២
**១៧:៤១** វ ១ពវ ១៨:២១ អរ ៤:២ មថ ៦:២៤
**១៨:១** ក អស ១:១ ហាស ១:១ មីក ១:១

ទាំងនោះ ឬប្រតិបត្តិតាម ឬថ្វាយយញ្ញបូជាដល់វាដែរ[ភ]
៣៦គឺត្រូវកោតខ្លាចដល់ព្រះយេហូវ៉ាតែ១ប៉ុណ្ណោះ ដែល
ទ្រង់បាននាំឯងរាល់គ្នា ឡើងចេញពីស្រុកអេស៊ីព្ទមក
ដោយព្រះចេស្តាដ៏ធំ និងព្រះហស្តលើកសំរេច[ម] ហើយត្រូវ
ក្រាបគោរពដល់ទ្រង់ ព្រមទាំងថ្វាយយញ្ញបូជារបស់ឯង
ដល់ទ្រង់តែ១ព្រះអង្គប៉ុណ្ណោះ ៣៧ឯអស់ទាំងបញ្ញត្តនឹងវិន័យ
ហើយច្បាប់ និងក្រិត្យក្រម[យ]ទាំងប៉ុន្មាន ដែលទ្រង់បានកត់
ទុកឱ្យឯងរាល់គ្នា នោះត្រូវរក្សាទុក[រ] ហើយប្រព្រឹត្តតាមជា
ដរាបតទៅ ឥតកោតខ្លាចដល់ព្រះដទៃឡើយ ៣៨ក៏មិនត្រូវ
ភ្លេច[ល] សេចក្តីសញ្ញា ដែលអញបានតាំងនឹងឯងរាល់គ្នា
ដែរ គឺមិនត្រូវឱ្យកោតខ្លាចដល់ព្រះដទៃណាឱ្យសោះ ៣៩ត្រូវ
ឱ្យកោតខ្លាចដល់ព្រះយេហូវ៉ា ជាព្រះនៃឯងវិញ នោះទ្រង់
នឹងជួយឱ្យឯងរាល់គ្នារួចពីកណ្តាប់ដៃ នៃពួកអ្នកខ្មាំងសត្រូវ
ទាំងអស់ ៤០ប៉ុន្តែគេមិនបានស្តាប់តាមសោះ គឺបានប្រព្រឹត្ត
តាមតែបែបដើមនោះវិញ ៤១យ៉ាងនោះហើយដែលសាសន៍
ទាំងនោះបានក្រោតខ្លាច ដល់ព្រះយេហូវ៉ាផង[វ] ហើយ
គោរពប្រតិបត្តិ តាមព្រះឆ្លាក់របស់ខ្លួនគេផង ឯកូនចៅ
របស់គេ នោះក៏ប្រព្រឹត្តដូចជា ឪពុករៀងតមក ដរាបដល់
សព្វថ្ងៃនេះដែរ ។

## ហេសេគាឡើងជាស្តេចយូដា

*១៨:២–៤ – ២របា ២៩:១–២ ៣១:១*
*១៨:៥–៧ – ២របា ៣១:២០–២១*
*១៨:៩–១២ – ២ពវ ១៧:៣–៧*

**១៨** ១នៅឆ្នាំទី៣ ក្នុងរាជ្យហូសេ៊ា ជាបុត្រអេឡា ស្តេច
អ៊ីស្រាអែល នោះហេសេគា[ក] ជាបុត្រអ័ហាស ស្តេចយូដា
ក៏ចាប់តាំងសោយរាជ្យឡើង ២កាលទ្រង់សោយរាជ្យឡើង

កំពុងនឹងប្រព្រឹត្ត ។
**១៧:៣២** *តាំងពួកគេខ្លះឡើង ឱ្យធ្វើជាសង្ឃនៃអស់ទាំងទីខ្ពស់* សូមមើលការពន្យល់ ១ពវ ១២:៣១ ។
**១៧:៣៣** *គេបានកោតខ្លាចដល់ព្រះយេហូវ៉ាផង ហើយគោរពប្រតិបត្តិតាមព្រះរបស់ខ្លួនផង* ត្រង់នេះចង់បញ្ជាក់ប្រាប់ពីការរួមបញ្ចូលចម្រុះសាសនា ។
**១៧:៣៤** *ដរាបដល់សព្វថ្ងៃនេះ* ពាក្យនេះនៅតែមានប្រើបន្តរហូតដល់ក្នុង ១,២ពវ ។ *កោតខ្លាចដល់ព្រះយេហូវ៉ា* ឃ្លានេះសង្កត់ធ្ងន់ទៅលើការថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិត ។ ចំពោះនៅក្នុង ខ.៣២–៣៣ ពាក្យថា "កោតខ្លាចដល់ព្រះយេហូវ៉ា"សំដៅលើការថ្វាយបង្គំព្រះដទៃឯណេះវិញ ។
**១៧:៣៥** *ឯងរាល់គ្នាមិនត្រូវកោតខ្លាចដល់ព្រះដទៃឡើយ* នៅត្រង់នេះសំដៅលើក្រឹត្យវិន័យរបស់លោកម៉ូសេ បានទាឱ្យមនុស្សគ្រប់រូបមិនត្រូវថ្វាយបង្គំរូបព្រះដទៃក្រៅពីព្រះយេហូវាតែមួយគត់(នក ២០:៥ ចទ ៥:៩) ។ នេះជាបញ្ញត្តិទី១ហើយសំខាន់ (មថ ២២:៣៨) ហើយវាជាលក្ខណ:សំគាល់មួយដល់ពួកអ៊ីស្រាអែលគ្រប់ៗរូប ។
**១៧:៣៦** *ព្រះយេហូវ៉ា . . . ចេញពីស្រុកអេស៊ីព្ទ* ឃ្លាដដែលនេះ នៅក្នុង ខ.៧ បានបញ្ជាក់ពីសេចក្តីសង្គ្រោះពួកអ៊ីស្រាអែលចេញពីទឹកដីអេស៊ីព្ទថាជាព្រះគុណដ៏ថ្លៃថ្លារបស់ព្រះយេហូវ៉ា ។
**១៧:៣៩** *ទ្រង់នឹងជួយឱ្យឯងរាល់គ្នា . . . រួចពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ* សូមមើល ចទ ២០:១–៤ ២៣:១៤ ។
**១៧:៤១** *ដរាបដល់សព្វថ្ងៃនេះដែរ* សូមមើលការពន្យល់ ខ.៣៤ ។
**១៨:១** *ឆ្នាំទី៣ ក្នុងរាជ្យហូសេ៊ា . . . ហេសេគា . . . ចាប់តាំងសោយរាជ្យឡើង* នេះចង់បញ្ជាក់ពីព្រឹត្តិការណ៍នៅឆ្នាំទី ៧២៩ មុន គ.ស(សូមមើល ១៧:១) ហេសេគា បានឡើងសោយរាជ្យជាមួយនឹងបិតារបស់ទ្រង់គឺស្តេចអ័ហាស ចាប់តាំងពីឆ្នាំ ៧២៩ ដល់ ៧១៥ មុន គ.ស (មើលការពន្យល់ ១៦:២ អស ៣៦:១) ។ *ហេសេគា ជាបុត្រអ័ហាស ស្តេចយូដា* នៅក្នុងឆ្នាំទី១ ៩៩៨ មុន គ.ស ត្រាដែលធ្វើអំពីដីឥដ្ឋរបស់ស្តេចបានក្លាយជាពន្លឺមួយក្នុងការបញ្ជាក់ថា ហេសេគា ជាបុត្ររបស់ស្តេចអ័ហាសនៃស្រុកយូដា ។ ហើយនេះ ជាត្រាមួយក្នុងចំណោមត្រាពីររបស់ស្តេចយូដា (សូមមើលការពន្យល់ ១៤:២២) ។

នោះទ្រង់មានព្រះជន្ម២៥ឆ្នាំហើយ កំសោយរាជ្យនៅក្រុង
យេរូសាឡិមបាន២៩ឆ្នាំ[ខ] ព្រះមាតាទ្រង់ព្រះ នាមជាអ័ប៊ីយ៉ា
បុត្រីសាការី ៣ទ្រង់ប្រព្រឹត្តអំពើដ៏ត្រឹមត្រូវ[គ]នៅព្រះនេត្រ
ព្រះយេហូវ៉ា តាមគ្រប់ទាំងសេចក្ដីដែលដាវីឌ[ឃ] ជាឰយុកោ
ទ្រង់បានធ្វើដែរ ៤ទ្រង់បំបាត់[ង]អស់ទាំងទីខ្ពស់[ច]ចេញ ក៏បំបាក់
បំបែកបង្គោល[ឆ]ដែលសំរាប់គោរព រំលំរូបព្រះទាំងប៉ុន្មាន
ចោល ហើយបំបែកកំទេចពស់លង្ហិន[ជ]ដែលលោកម៉ូសេ
បានធ្វើផង ពីព្រោះពួកកូនចៅអ៊ីស្រាអែលបានដុតកំញាន
ថ្វាយដល់រូបពស់នោះ ដរាបដល់គ្រានោះ ក៏ឱ្យឈ្មោះថា
នេហ៊ូសថាន់ ៥ទ្រង់ទុកចិត្ត[ឈ]ដល់ព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែល ដល់ម្ល៉េះបានជាក្នុងពួកស្តេចយូដា
ក្រោយមក នោះគ្មានស្តេចណាឱ្យដូចទ្រង់ឡើយ ហើយមុន
ទ្រង់ក៏គ្មានដែរ ៦ដ្បិតទ្រង់កាន់ខ្ជាប់[ញ]តាមព្រះយេហូវ៉ា ឥត
លាកបង់លែងតាមទ្រង់ឡើយ គឺបានកាន់តាមអស់ទាំង
ក្រិត្យក្រម ដែលព្រះយេហូវ៉ាបានបង្គាប់ដល់លោកម៉ូសេ
៧ព្រះយេហូវ៉ាក៏គង់ជាមួយនឹងទ្រង់ដែរ ហើយកន្លែងណា
ដែលទ្រង់យាងទៅ នោះក៏បានកើតការ[ដ] ទ្រង់បះបោរ[ឋ]
លែងចុះចូលនឹងស្តេចស្រុកអាសស៊ើរ ៨ទ្រង់វាយពួក
ភីលីស្ទីន រហូតដល់ក្រុងកាសានិងខែត្រដែននៅជុំវិញ ចាប់
តាំងពីភូមិដែលមានតែប៉មចាំយាម រហូតដល់ទីក្រុងមាន
កំផែង[ឌ]។

៩នៅឆ្នាំទី៤[ឍ] ក្នុងរាជ្យស្តេចហេសេគា ត្រូវនឹងឆ្នាំទី៧
នៃរាជ្យហូសេ៊ា ជាបុត្រអេឡា ស្តេចអ៊ីស្រាអែល នោះ
សាលម៉ានេស៊ើរ ជាស្តេចស្រុកអាសស៊ើរ ទ្រង់ឡើងមក
ឡោមព័ទ្ធច្បាំងនឹងក្រុងសាម៉ារី ១០លុះច្បាំងគ្រប់៣ឆ្នាំ
ហើយ ទើបចាប់យកក្រុងនោះបាន គឺក្នុងឆ្នាំទី៦នៃរាជ្យ
ហេសេគា ដែលត្រូវនឹងឆ្នាំទី៩នៃរាជ្យហូសេ៊ា ស្តេចអ៊ីស្រា
អែល នោះគេចាប់យកក្រុងសាម៉ារីបាន ១១ស្តេច[ណ]ស្រុក
អាសស៊ើរ ទ្រង់ក៏ដឹកនាំពួកអ៊ីស្រាអែល ទៅឯស្រុកអាស
ស៊ើរ ដាក់ឱ្យនៅត្រង់ក្រុងហាឡា ដែលនៅមាត់ទន្លេហា
បោរ ជាទន្លេរបស់ស្រុកកូសាន ហើយនៅទីក្រុងរបស់
សាសន៍មេឌីទាំងប៉ុន្មានដែរ[ត] ១២ដោយព្រោះគេមិនព្រម
ស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ាជាព្រះនៃគេ គឺបាន
រំលងសេចក្ដីសញ្ញា[ថ]នៃទ្រង់ ជាសេចក្ដីទាំងប៉ុន្មានដែល

**១៨:២** ខ ឌ.១៣ អស ៣៨:៥ **១៨:៣** គ ១ពវ ១៤:៨ ឃ អស ៣៨:៥ **១៨:៤** ង ២របា ៣១:១ អស ៣៦:៧ ច ២ពវ ១២:៣ ២១:៣ ឆ នក ២៣:២៤ ជ ជន ២១:៩ **១៨:៥** ឈ ឌ.១៩ ១សយ ៧:៣ ២ពវ ១៩:១០ ទដ ២១:៧ ១២៥:១ សភ ៣:២៦ **១៨:៦** ញ ចទ ១០:២០ ចទ ៦:១៨ **១៨:៧** ដ លប ៣៩:៣ យប ២២:២៥ ឋ ២ពវ ២៤:១ អរ ៤:១៩ អស ៣៦:៥ **១៨:៨** ឌ ២ពវ ១៧:៩

**១៨:៩** ឍ អស ១:១ ៣៦:១ **១៨:១១** ណ អស ៣៧:១២ ត អគ ១៦:៣៩ ២៣:៩ **១៨:១២** ថ ២ពវ ១៧:១៥

**១៨:២** *ទ្រង់សោយរាជ្យឡើង* នេះបញ្ជាក់ថា ទ្រង់បានក្លាយជា ស្តេចពួកយូដា ។ *ព្រះជន្ម២៥ឆ្នាំ* គឺស្ថិតនៅក្នុងឆ្នាំ ៧១៥–៦៨៦ មុន គ.ស និងមើលបន្ថែម ២របា ជំពូក ២៩–៣០ និង អស ៣៦–៣៩ សម្រាប់ការពិពណ៌នាអំពីព្រឹត្តិការណ៍នៃរាជ្យស្តេចនេះ ដែលរួមបញ្ចូលនៃការរៀបរាប់លំអិតនៃការទទួលខុសត្រូវក្នុងការដឹកនាំរបស់ទ្រង់ (២របា ជំពូក ២៩–៣១) ។ សាច់រឿងនៅត្រង់វគ្គនេះ ជាសកម្មភាពដំបូង នៅក្នុងការកសាងវិហារសារជាថ្មីម្តងទៀត ដែលព្រះវិហារទាំងអស់នោះត្រូវបានបិទដោយស្តេចអ័ហាសជាបិតារបស់ទ្រង់ (សូមមើលការពន្យល់ ១៦:១៩ និងមើលបន្ថែម ២របា ២៩:៣) ។

**១៨:៣** *អំពើដ៏ត្រឹមត្រូវ . . . គ្រប់ទាំងសេចក្ដីដែលដាវីឌជាឰយុកោ* នៅត្រង់នេះបញ្ជាក់ថា ហេសេគាជាស្តេចមួយអង្គក្នុងចំណោមពីរបីអង្គទៀត ដែលត្រូវបានសង្គ្រោះតាមរយៈស្តេចដាវីឌ ។

**១៨:៤** *បំបាត់អស់ទាំងទីខ្ពស់* ហេសេគាមិនមែនជាស្តេចទី១ដែលបំបាត់ទីខ្ពស់ (សូមមើល ការពន្យល់ ១ពវ ៣:២ ១៥:៤) ប៉ុន្តែទ្រង់ជាស្តេចដែលបានលុបបំបាត់ដល់ការថ្វាយបង្គំដល់ព្រះយេហូវ៉ា (សូមមើល ១២:៣ ១៤:៤ ១៥:៤, ៣៥ ១៧:៩ ១ពវ ២២:៤៣) ។ *បង្គោលដែលសំរាប់គោរព* សូមមើល ១៣:៦ ១៧:១០–២៧ ១៧:១០ សូមមើលការពន្យល់ ១ពវ ១៤:២៣ ។ *ពួកកូនចៅអ៊ីស្រាអែលបានដុតកំញាន* ចំណុចនេះ ប្រហែលជាមិនមែនពស់លង្ហិនទេដែលពួកអ៊ីស្រាអែលថ្វាយបង្គំអស់រាប់សតវត្សមក ។ ប្រហែលជាពួកគេបានគោរពនូវសំណាកផ្សេងៗ នៅក្នុងរជ្ជកាលព្រះបាទអ័ហាសជាបិតាហេសេគា (មើល ជំពូក ១៦) ។ ការថ្វាយបង្គំរូបពស់ គឺមាននៅក្នុងទឹកដីមជ្ឈិមបូព៌ាបូរាណ (សូមមើល ការពន្យល់ ជន ២១:៨–៩) ។

**១៨:៥** *គ្មានស្តេចណាឱ្យដូចទ្រង់ឡើយ ហើយមុនទ្រង់ក៏គ្មានដែរ* ការលើកឡើងផ្ទុយពីសេចក្ដីដែលបានលើកឡើងនៅត្រង់នេះ នៅពេលដែលយើងធ្វើការប្រៀបធៀបវានៅក្នុង ២៣:២៥ ។ ភាពមានតែមួយរបស់ហេសេគា ត្រូវបានគេដឹងថា ទ្រង់ជាក្សត្រដែលទុកចិត្តលើព្រះយេហូវ៉ា ក្នុងកាលដែលភាពតែមួយរបស់ស្តេចយ៉ូសៀស ត្រូវបានគេរកឃើញថា ទ្រង់ជាស្តេចដែលយកចិត្តទុកដាក់លើក្រឹត្យវិន័យលោកម៉ូសេ ។

**១៨:៧** *បះបោរ លែងចុះចូលនឹងស្តេចស្រុកអាសស៊ើរ* ប្រទេសយូដាបានក្លាយជាប្រទេសចំណុះរបស់ពួកអាសស៊ើរ ក្រោមការគ្រប់គ្រងរបស់ស្តេចអ័ហាស(មើល ១៦:១៧) ដែលតម្រូវឱ្យពួកគេថ្វាយព្រះរបស់ពួកអាសស៊ើរ ។ ស្តេចហេសេគា បានផ្លាស់ប្តូរគោលនយោបាយរបស់បិតាខ្លួន និង ទាមទាឯករាជ្យពីពួកអាសស៊ើរមកវិញ ។

**១៨:៨** *វាយពួកភីលីស្ទីន* នៅក្នុងការផ្លាស់ប្តូរបបនយោបាយនៅក្នុងរជ្ជកាលស្តេចអ័ហាស ពួកភីលីស្ទីនបានវាយដណ្តើមយកក្រុងយូដាទៅតាមបណ្តោយជើងភ្នំ និងតំបន់ត្រីកោណ(សូមមើល ២របា ២៨:១៨) ហើយហេសេគាបានបង្ក្រាបពួកភីលីស្ទីនម្តង ។

**១៨:៩** *ឆ្នាំទី៤ ក្នុងរាជ្យស្តេចហេសេគា* រាជ្យនេះស្ថិតនៅក្នុងឆ្នាំទី ៧២៥ មុន គ.ស ហើយជាឆ្នាំដែលស្តេចហេសេគា និង អ័ហាសជាបិតាគ្រងរាជ្យជាមួយគ្នា (សូមមើល ការពន្យល់ ឌ.១ ១៧:១) ។ *សាលម៉ានេស៊ើរ* សូមមើលការពន្យល់ ១៧:៣ ។

**១៨:១០** *៣ឆ្នាំ* សូមមើលការពន្យល់ ១៧:៥ ។ *ឆ្នាំទី៩នៃរាជ្យហូសេ៊ា* សូមមើលការពន្យល់ ១៧:៦ ។

**១៨:១១** *ស្តេចស្រុកអាសស៊ើរ ទ្រង់ក៏ដឹកនាំពួកអ៊ីស្រាអែល* សូមមើលការពន្យល់ ១៧:៦ ។

**១៨:១២** *រំលងសេចក្ដីសញ្ញានៃទ្រង់* សូមមើល ១៧:៧–២៣ ។

លោកម៉ូសេ ជាអ្នកបំរើព្រះយេហូវ៉ា បានបង្គាប់មក[ទ]
គេមិនព្រមស្តាប់[ធ] ឬធ្វើតាមសញ្ញានោះឡើយ ។
១៣ដល់ឆ្នាំទី១៤[ន] ក្នុងរាជ្យសេចហេសេគា នោះសាន
ហេរីប ជាស្តេចស្រុកអាសសើរ ក៏ឡើងមកច្បាំងយកបាន
អស់ទាំងទីក្រុងមានកំផែងនៅស្រុកយូដា[ប] ១៤ឯហេសេគា
ជាស្តេចយូដា ទ្រង់ចាត់សារឱ្យទៅឯស្តេច ស្រុកអាសសើរ
នៅត្រង់ក្រុងឡាគីសថា[ផ] ទូលបង្គំបានធ្វើ ខុសហើយ[ព]
សូមទ្រង់ថយចេញពីទូលបង្គំទៅ ទូលបង្គំនឹង ទទួលរ៉ាប់រង
តាមបង្គាប់ទ្រង់ទាំងអស់ ដូច្នេះ ស្តេចអាសសើរក៏បង្គាប់
ឱ្យហេសេគា ជាស្តេចស្រុកយូដាបង់ ប្រាក់៣០០ហាប និង
មាស៣០ហាប ១៥ហេសេគា[ភ]ក៏យកប្រាក់ទាំងអស់ ដែល
ឃើញមានក្នុងព្រះវិហារនៃព្រះយេហូវ៉ា និងក្នុងឃ្លាំងព្រះ
រាជទ្រព្យទាំងប៉ុន្មាន ទៅថ្វាយដល់ទ្រង់ ១៦វេលានោះ
ហេសេគាក៏កាត់យកមាសពីទ្វារ[ម]ព្រះវិហារនៃព្រះយេហូវ៉ា
និងពីសសរដែលទ្រង់បានស្រោប ទៅថ្វាយដល់ស្តេចអាស
សើរដែរ ។

## ការគម្រាមកំហែងទីក្រុងយេរូសាឡឹម

*១៨:១៣,១៧ –៣៧ – អស ៣៦:១–២២*

*១៨:១៧–៣៥ – ២រប ៣២:៩–១៩*

១៧ឯស្តេចអាសសើរទ្រង់ចាត់[យ]ថើថាន និងរ៉ាប–សារី
ហើយរ៉ាបសាកេ ពីក្រុងឡាគីស នាំទាំងពលទ័ពជាច្រើន
ឱ្យទៅឯហេសេគា នៅក្រុងយេរូសាឡិម គេក៏ឡើងទៅ
កាលគេមកដល់ក្រុងយេរូសាឡិមហើយ នោះគេឈរក្បែរ
ប្រឡាយនៃស្រះខាងលើ[រ] ដែលនៅតាមផ្លូវវាលនៃជាងប្រ
មោក ១៨កាលបានហៅរកស្តេច នោះអេលាគីម[ល] កូន
ហ៊ីលគីយ៉ា ជាឧកញ៉ាវាំង និងសេបណា[វ] ជាស្មៀនហ្លួង
ហើយយ៉ូអា កូនអេសាភ ជាអ្នកតែងពង្សាវតារក៏ចេញទៅ
ឯគេ ។
១៩រ៉ាសាកេប្រាប់គេថា ចូរទៅប្រាប់ដល់ហេសេគាថា
ស្តេចដ៏ជាធំ គឺជាស្តេចស្រុកអាសសើរ ទ្រង់មានបន្ទូល
ដូច្នេះ តើទីពឹងណាដែល ឯងទុកចិត្ត[ស]នេះ ២០ឯងនិយាយថា
យើងមានគំនិត មានកំឡាំង ដើម្បីនឹងច្បាំងបាន (តែពាក្យ
ឯងជាឥតអំពើសោះ) ចុះតើឯងពឹងដល់អ្នកណា បានជា
ឯងបះបោរនឹងអញដូច្នេះ ២១មើល ឯងពឹងដល់ស្រុក
អេស៊ីព្ទ[ហ] ជាដើមត្រែងកំបាក់នោះទុកជាឈើច្រត់[ឡ] ដែល
បើកាលណាផ្អែកទៅលើ នោះនឹងចាក់ទំលុះដៃវិញ គឺ
ផារោន ជាស្តេចស្រុកអេស៊ីព្ទ គេបែបយ៉ាងនោះដល់
អស់អ្នកណាដែលពឹងដល់គេ ២២តែបើឯងរាល់គ្នានិយាយ
មកអញថា យើងរាល់គ្នាទុកចិត្តដល់ព្រះយេហូវ៉ាជាព្រះនៃ
យើងវិញ នោះតើមិនមែនជាព្រះនោះឯង ដែលហេសេគា
បានបំបាត់ អស់ទាំងទីខ្ពស់ និងអាសនានៃទ្រង់ចេញទេឬអី
ដោយប្រាប់ដល់ពួកសាសន៍យូដា និងពួកក្រុងយេរូសាឡិម
ថា ត្រូវឱ្យឯងរាល់គ្នាថ្វាយបង្គំ នៅមុខអាសនា១នេះ នៅ
ក្រុងយេរូសាឡិមវិញ ២៣ដូច្នេះ ចូរឯងចុះសន្យានឹងស្តេច
អាសសើរ ជាចៅហ្វាយអញឥឡូវចុះ នោះអញនឹងឱ្យសេះ

**១៨:១២** ទ ២ពវ ២១:៨ ដយ ៩:៦,១០ ធ ១ពវ ៩:៦
**១៨:១៣** ន ខ.២ ប អស ១:៧ មីក ១:៩
**១៨:១៤** ផ ២ពវ ១៩:៨ ព អស ២៤:៥ ៣៣:៨
**១៨:១៥** ភ ១ពវ ១៥:១៨ អស ៣៩:២
**១៨:១៦** ម ២រប ២៩:៣
**១៨:១៧** យ អស ២០:១
រ ២ពវ ២០:២០ ២រប ៣២:៤,៣០ នហ ២:១៤ អស ២២:៩
**១៨:១៨** ល ២ពវ ១៩:២ អស ២២:២០ ៣៦:៣,១១,២២ ៣៧:២ វ ខ.២៦,៣៧ អស ២២:១៥
**១៨:១៩** ស ខ.៥ យប ៤:៦
**១៨:២១** ហ អស ២០:៥ ៣១:១ អគ ២៩:៦ ឡ ២បវ ២៤:៧ អស ២០:៦
៣០:៥,៧ យរ ២៦:១៩ ៣៧:៧ ៤៦:២

**១៨:១៣** *ឆ្នាំទី១៤* នេះជាចំនួននៃការគ្រងរាជ្យរបស់ស្តេចហេសេគា គឺមកដល់ឆ្នាំទី ៧០១មុនគ.ស (មើលការពន្យល់ ខ.២) ។ *យកបាន* នៅក្នុងកំណត់ត្រា របស់ស្តេចសានហេរីប បានបញ្ជាក់ថាទ្រង់ បានវាយយកក្រុងរបស់ហេសេគាបាន៤៦ក្រុង ស្រុកដែលនៅចំណុះក្រុង និងចាប់បានមនុស្ស ២០០១៥០នាក់ជាចំណាប់ខ្មាំង ។ លើសពីនេះទៀត ស្តេចសានហេរីប បានអះអាងដោយផ្ទាល់ថា "ទ្រង់បានចាប់ស្តេចហេសេគាដាក់គុកនៅក្នុងក្រុងយេរូសាឡិម ដូចជាសត្វសារិការជាប់ក្នុងទ្រុងអញ្ចឹងដែរ" ប៉ុន្តែទ្រង់មិនបានមានបន្ទូលថា ទ្រង់វាយយកបានក្រុងយេរូសាឡិមបានទេ។
**១៨:១៤** *ក្រុងឡាគីស* សូមមើលការពន្យល់ ១៤:១៩ អស ៣៦:២ ។
**១៨:១៥** *ប្រាក់ . . . ក្នុងព្រះវិហារ . . . និងក្នុងឃ្លាំងព្រះរាជទ្រព្យ* សូមមើល ១២:១០,១៨ ១៤:១៤ ១៦:១៨ ១ពវ ៧:៥១ ១៤:២៦ ១៥:១៨ ។
**១៨:១៧–១៩:៣៧** សូមមើល អស ៣៦–៣៧ និងធៀប ២រប ជំពូក ៣២ ។
**១៨:១៧** *ប្រឡាយនៃស្រះ . . . វាល* សូមមើលការពន្យល់ អស ៧:៣ ។ វាជាសេចក្តីចំអកមួយ ដែលមន្ត្រីរបស់ពួកអាសសើរបានទាមទាឱ្យពួកយូដាចុះចាញ់ នៅគ្រប់ទីកន្លែងដែលហោរាអេសាយបានព្រមានដល់ស្តេចអ័ហាសឱ្យមានជំនឿលើព្រះយេហូវ៉ា ជាជាងលើការចងសម្ព័ន្ធជាមួយពួក អាសសើរ សម្រាប់ការសង្គ្រោះខ្លួនឱ្យចេញពីការគម្រាមកំហែងពីពួកស៊ីរី និងពួកអ៊ីស្រាអែល (សូមមើល ១៦:៥–១០ អស ៧:១–១៧) ។
**១៨:១៨** *ឧកញ៉ាវាំង* សូមមើលការពន្យល់ ១ពវ ៤:៦ ។ *ស្មៀនហ្លួង* មើលការពន្យល់ ២សយ ៨:១៧ ។ *អ្នកតែង* មើលការពន្យល់ ២សយ ៨:១៦ ។
**១៨:១៩** *ស្តេចដ៏ជាធំ* ជាញឹកញយ ឋានៈរនាមនេះត្រូវបានគេដាក់នាមពួកអ្នកដឹកនាំអាសសើរ ហើយជាពិសេសជាងនោះទៀតនោះគឺ សំដៅដល់ព្រះយេហូវ៉ា (សូមមើល ទដ ៤៧:២ ៤៨:២ ៩៥:៣ មឡ ១:១៤ មថ ៥:៣៥) ។ *បន្ទូល* នេះបញ្ជាក់ថា ពាក្យសំដីរខាងក្រោយមកទៀតនេះ ជាការប៉ិនប្រសិនក្នុងការលៃលកនៃការគម្រាមគំហែង និងសង្គ្រាមចិត្តសាស្ត្រ បានបង្កើតឡើងដើម្បីបំផ្លាញ សីលធម៌ពួកអ្នកស្រុកយេរូសាឡិម (សូមមើល ខ.២៦–២៧ និងធៀប ការពន្យល់ យស ៦:៥) ។
**១៨:២១** *ពឹងដល់ស្រុកអេស៊ីព្ទ* សូមមើល ១៩:៩ អស ៣០:១–៥ ៣១:១–៣ ។
**១៨:២២** *ហេសេគាបានបំបាត់អស់ទាំងទីខ្ពស់ និងអាសនានៃទ្រង់ចេញទេឬអី* មកដល់ត្រង់នេះ ពួកអាសសើរបានព្យាយាមនិងប៉ិនប៉ងធ្វើឱ្យទំនាក់ទំនងហេសេគា និងរាស្ត្ររបស់ទ្រង់ចុះខ្សោយ ។ ពួកគេ បានព្យាយាមព្យាបាទឱ្យពួកគេមានការតូចចិត្តនៅក្នុងចំណោមពួកអ្នកដែលប្រឆាំង និងកំណែទម្រង់ និងការបំផ្លាញទីខ្ពស់របស់ស្តេចហេសេគា (សូមមើល ខ.៤) ។
**១៨:២៣** *បើឯងរកអ្នកជិះបាន* ឃ្លានេះជាការចំអកឡកឡឺយមួយ ដែលពួក

២ពាន់ដល់ឯង បើឯងរកអ្នកជិះបាន ២៤បើដូច្នេះ ធ្វើដូច
ម្តេចឱ្យឯងឈ្នះមេទ័ព១យ៉ាងតូច[អ] ក្នុងពួកអ្នកបំរើរបស់
ចៅហ្វាយអញបាន ហើយទុកចិត្តនឹងស្រុកអេស៊ីព្ទ ឱ្យបាន
រទេះចំបាំង និងទ័ពសេះទៀត ២៥តើអញបានឡើងមក
ដើម្បីច្បាំងបំផ្លាញទីនេះ ដោយឥតព្រះយេហូវ៉ាឬអី[ក] គឺព្រះ
យេហូវ៉ាទេតើ ដែលទ្រង់បានមានបន្ទូលបង្គាប់អញថា ចូរ
ឡើងទៅច្បាំងបំផ្លាញស្រុកនេះចុះ ។
២៦ឯអេលាគីម ជាកូនហ៊ីសគីយ៉ា នឹងសេបណា ហើយ
យ៉ូអា ក៏ឆ្លើយតបទៅរ៉ាបសាកេថា សូមលោកមាន
ប្រសាសន៍ជាភាសាអារ៉ាម[ខ] មកយើងខ្ញុំប្របាទវិញ ដ្បិត
យើងខ្ញុំស្តាប់បាន សូមកុំមានប្រសាសន៍ ជាភាសារបស់
ពួកយូដា ឱ្យពួកបណ្តាជនដែលនៅលើកំផែងស្តាប់ផង
នោះឡើយ ២៧តែរ៉ាបសាកេតបថា ចុះតើចៅហ្វាយអញបាន
ចាត់អញ ឱ្យមកនិយាយសេចក្តីទាំងនេះ ចំពោះតែនឹង
ចៅហ្វាយឯង ហើយនឹងខ្លួនឯងប៉ុណ្ណោះឬអី គឺបានចាត់អញ
ឱ្យមកនិយាយនឹងមនុស្ស ដែលអង្គុយនៅលើកំផែងវិញទេ
តើ ដើម្បីឱ្យគេបានស៊ីលាមក ហើយផឹកទឹកនោមរបស់ខ្លួន
ជាមួយនឹងឯងដែរ ២៨នោះរ៉ាបសាកេក៏ឈរ បន្លឺឡើង ជា
ភាសារបស់ពួកសាសន៍យូដា ប្រាប់ថា ចូរស្តាប់ព្រះបន្ទូល
នៃស្តេចដ៏ជាធំឧត្តម គឺស្តេចអាសស៊ើរចុះ ២៩ទ្រង់មាន
បន្ទូលដូច្នេះថា កុំបណ្តោយឱ្យហេសេគាបញ្ឆោត[គ]ឯងរាល់
គ្នាឡើយ ដ្បិតវាពុំអាចនឹងជួយឯងរាល់គ្នា ឱ្យរួចពីកណ្តាប់
ដៃអញបានទេ ៣០ក៏កុំឱ្យហេសេគា នាំឱ្យឯងរាល់គ្នា ទុកចិត្ត
ដល់ព្រះយេហូវ៉ាដែរ ដោយថាព្រះយេហូវ៉ា ទ្រង់នឹងជួយឱ្យ
យើងរាល់គ្នា រួចជាមិនខាន ហើយទីក្រុងនេះនឹងមិន ត្រូវ
ប្រគល់ទៅ ក្នុងកណ្តាប់ដៃនៃស្តេចអាសស៊ើរនោះឡើយ
៣១កុំឱ្យស្តាប់តាមហេសេគាឱ្យសោះ ដ្បិតស្តេចអាសស៊ើរ
មានបន្ទូលដូច្នេះថា ចូរចងជាស្ពានមេត្រីនឹងអញ ហើយ
ចេញមកឯអញចុះ នោះគ្រប់គ្នា និងបានស៊ីផលចំការទំពាំង
បាយជូរ និងផលដើមល្វា[ឃ] ហើយផឹកទឹក អណ្តូងរបស់ខ្លួន
គ្រប់គ្នា[ង] ៣២ដរាបដល់អញមកនាំយកឯងរាល់គ្នា ទៅនៅឯ
ស្រុក១ ដូចជាស្រុករបស់ឯងនេះ ជាស្រុកមានស្រូវ និងទឹក
ទំពាំងបាយជូរ ហើយនំបុ័ង ព្រមទាំងចំការទំពាំងបាយជូរ
ចំការអូលីវ ហើយនិងទឹកឃ្មុំផង ដើម្បីឱ្យឯងរាល់គ្នាបាន
រស់នៅ[ច]ឥតស្លាប់ កុំឱ្យឯងរាល់គ្នាស្តាប់តាមហេសេគា
ដែលវាបញ្ចុះបញ្ចូលឯងរាល់គ្នាថា ព្រះយេហូវ៉ាទ្រង់នឹង
ជួយឱ្យរួចនោះឡើយ ៣៣តើមានព្រះ[ឆ]របស់សាសន៍ដទៃ
ណា ដែលជួយស្រុកគេ ឱ្យរួចពីកណ្តាប់ដៃនៃស្តេចអាស–
ស៊ើរបាន ៣៤តើព្រះនៃពួកក្រុងហាម៉ាត[ជ] និងក្រុងអើផាឌ[ឈ]
នៅឯណា ហើយព្រះរបស់ពួកក្រុងសេផាវែម ពួកក្រុង
ហេណា និងពួកក្រុងអ៊ីវ៉ា នោះតើព្រះទាំងនោះនៅឯណា
តើបានជួយឱ្យស្រុកសាម៉ារីរួចពីកណ្តាប់ដៃអញបានឬទេ
៣៥ក្នុងបណ្តាព្រះរបស់ស្រុកទាំងប៉ុន្មាននោះ តើមានព្រះ
ណាដែលជួយឱ្យស្រុកគេរួចពីកណ្តាប់ដៃអញបាន បានជា

**១៨:២៤** អ អស ១០:៨
**១៨:២៥** ក ២ពវ ១៩:៦,២២ ២៤:៣ ២រប ៣៥:២១
**១៨:២៦** ខ អរ ៤:៧
**១៨:២៩** គ ២ពវ ១៩:១០
**១៨:៣១** ឃ ជន ១៣:២៣ ១ពវ ៤:២៥ ង យរ ១៤:៣ បទ ៤:៤
**១៨:៣២** ច ចទ ៣០:១៩
**១៨:៣៣** ឆ ២ពវ ១៩:១២
**១៨:៣៤** ជ ២ពវ ១៧:២៤ យរ ៤៩:២៣ ឈ អស ១០:៩

អាសស៊ើរមិនមានការស្ទាក់ស្ទើរថា ពួកទាហានយូដាមានភាពខ្សោយដែលពួកគេម្នាក់លែងមានប្រយោជន៍តទៅទៀតហើយ ។ តែផ្ទុយមកវិញទាហានថ្មើជើងពួកយូដានាពេលនោះមានចំនួនកើនឡើងយ៉ាងច្រើន ។ ក្រុងដែលស្ថិតក្រោមការឡោមពទ្ធ័ដែលមានរទេះចំបាំងពីរបី គឺមិនត្រូវបានគេដឹងថារទេះនេះជាពួកអ៊ីស្រាអែលដែលគេជួលមកដើម្បីតយុទ្ធនិងពួកគេ ។

**១៨:២៦** *ភាសាអារ៉ាម* ភាសានេះបានក្លាយជាភាសាអន្តរជាតិនៅបង្ហើមបូព៌ា ហើយវាត្រូវបានគេប្រើនៅក្នុងផ្លូវការទូត និងពាណិជ្ជកម្ម ។ ភាពភ្ញាក់ផ្អើលមួយបានកើតឡើង គឺពួកអាសស៊ើរអាចនិយាយភាសាហេព្រើរជាភាសារបស់ពួកយូដាបាន (សូមមើល ២របា ៣២:១៨) ។

**១៨:២៧** *មនុស្សដែលអង្គុយនៅលើកំផែង* នេះជាយុទ្ធសាស្ត្ររបស់ពួកអាសស៊ើរក្នុងការចចារ ដើម្បីធ្វើឱ្យពួកគេលែងមានការទុកចិត្តដល់ហេសេគា ដើម្បីឱ្យបានពួកមនុស្សក្រោឈរទាស់នឹងស្តេចហេសេគា ។ *ដើម្បីឱ្យគេបានស៊ីលាមក ហើយផឹកទឹកនោមរបស់ខ្លួន* នេះសំដៅលើរូបគំនូរដ៏ឆើតឆាយដែលគេបានគូនៅលើជញ្ជាំង បង្ហាញអំពីសេចក្តីវេទនាក្នុងពេលដែលត្រូវគេឡោមពទ្ធ័ ។

**១៨:២៨** *ទ្រង់មានបន្ទូល* នេះបញ្ជាក់ថាស្តេចអាសស៊ើរ មានបន្ទូលមកកាន់អណាប្រជារាស្ត្រ គឺមិនមែនស្តេចហេសេគាទេ ដូចមាននៅក្នុង ខ.១៩–២៧ *កុំបណ្តោយឱ្យហេសេគាបញ្ឆោតឯងរាល់គ្នា* សេចក្តីនេះមាននៅក្នុង ខ.៣០–៣១ ដែលពួកមនុស្សត្រូវបានបង្ខំឱ្យទាស់នឹងហេសេគា ។

**១៨:៣០** *ទីក្រុងនេះនឹងមិនត្រូវប្រគល់ទៅ ក្នុងកណ្តាប់ដៃនៃស្តេចអាសស៊ើ* ស្តេចហេសេគា អាចនិយាយយ៉ាងដូច្នេះបាន ដោយសំអាងដល់សេចក្តីសន្យារបស់ព្រះយេហូវ៉ា (មើល ២០:៦ និងមើលបន្ថែមការពន្យល់ អស ៣៨:៦) ។

**១៨:៣១** *ស៊ីផលចំការទំពាំងបាយជូរ និងផលដើមល្វា ហើយផឹកទឹកអណ្តូង* ឃ្លានេះជាការពិពណ៌នាពីសន្តិភាព និងភាពសម្បូណ៌រុងរឿង (សូមមើល ១ពវ ៤:២៥ មីក ៤:៤ អគ ៣:១០ ) ។

**១៨:៣២** *ដរាបដល់អញមកនាំយកឯងរាល់គ្នាទៅនៅឯស្រុក១* នេះមានន័យថា ការចុះចាញ់គឺត្រូវនិរទេសចេញពីទឹកដី ប៉ុន្តែសានហេរីបបានពិពណ៌នាថាវាជាអ្វីមួយដែលគួរឱ្យយើងចង់បាន ។ *បានរស់នៅឥតស្លាប់* ការពិពណ៌នាផ្សេងទៀតដែលជំនួសឱ្យរូបនេះ បញ្ជាក់ថាមនុស្សទាំងនោះគឺ (១).កាទុកចិត្តដល់ព្រះយេហូវ៉ា ហើយទុកចិត្តដល់ហេសេគាហើយនិងបានធ្វើឱ្យពួកគេស្លាប់ (២). ការទុកចិត្តដល់ពួកអាសស៊ើរ គឺជាភាពរុងរឿងហើយនិងសុខសន្តិភាព ។ ពាក្យទាំងអស់ខាងលើនេះ គឺមានលក្ខណៈផ្ទុយស្រឡះដែលលោកម៉ូសេបាននិយាយមកកាន់ ពួកអ៊ីស្រាអែលនៅក្នុង ចទ ៣០:១៥–២០ ។

**១៨:៣៣–៣៥** នៅក្នុងវគ្គនេះ បញ្ជាក់ថា ហេតុផលខុសឆ្គងរបស់ពួកអាសស៊ើរ បានធ្វើឱ្យព្រះពិត និងព្រះរស់តែមួយ ដូចទៅនឹងព្រះរបស់ពួក

ព្រះយេហូវ៉ានឹងជួយសង្គ្រោះក្រុងយេរូសាឡិម ឱ្យរួចពី
កណ្ដាប់ដៃអញបានដែរ[ឈ] ។
៣៦ប៉ុន្តែពួកបណ្ដាជន គេនៅតែស្ងៀម ឥតឆ្លើយអ្វីសោះ
ដ្បិតស្ដេចទ្រង់បានហាមថា កុំឱ្យឆ្លើយទៅគេឡើយ ៣៧នោះ
អេលាគីម[ញ] កូនហ៊ីលគីយ៉ា ជាឧកញ៉ាវាំង និងសេបណា
ជាស្មៀនហ្លួង ហើយយ៉ូអា កូនអេសាភ ជាអ្នកតែងពង្សាវតារ
គេវិលមកគាល់ហេសេគាវិញ ទាំងអាវរហែក[ដ] ក៏ទូលទ្រង់
តាមពាក្យរបស់រ៉ាបសាកេទាំងអស់ ។

## ការថ្លែងទំនាយពីការរំដោះក្រុងយេរូសាឡិម

*១៩:១-១៣ – អស ៣៧:១-១៣*

**១៩** ១លុះកាលស្ដេចហេសេគាបានស្ដាប់ពាក្យទាំងនោះ
ហើយ នោះទ្រង់ក៏ហែក[ក]ព្រះពស្ត្រ ហើយស្លៀកពាក់សំពត់
ធ្មៃវិញ ចូលទៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា ២រួចទ្រង់
ចាត់អេលាគីម[ខ] ជាឧកញ៉ាវាំង និងសេបណាជាស្មៀនហ្លួង
ហើយពួកចាស់ទុំក្នុងពួកសង្ឃ[គ] ឱ្យស្លៀកពាក់សំពត់ធ្មៃ[ឃ]
ទៅឯហោរាអេសាយ[ង] ជាកូនអ័ម៉ូស ៣គេក៏ជំរាបដល់
លោកថា ហេសេគាទ្រង់មានបន្ទូលដូច្នេះ ថ្ងៃនេះជាថ្ងៃមាន
សេចក្ដីវេទនា សេចក្ដីផ្ចាញ់ផ្ចាល នឹងសេចក្ដីដំនៀលប្រៀប
ដូចជាកូនគ្រប់ខែហើយ[ច] តែគ្មានកំឡាំងនឹងសំរាលមក
សោះ ៤ប្រហែលជាព្រះយេហូវ៉ា ជាព្រះនៃលោកទ្រង់
នឹងឮអស់ពាក្យទាំងប៉ុន្មានរបស់រ៉ាបសាកេនេះ ដែលស្ដេច
អាសសើរ ជាចៅហ្វាយគេ បានចាត់ឱ្យមកប្រកួត[ឆ]នឹងព្រះដ៏
មានព្រះជន្មរស់នៅ ហើយនឹងបន្ទោស[ជ]ដល់គេ ដោយ
ព្រោះពាក្យទាំងនេះ ដែលព្រះយេហូវ៉ា ជាព្រះនៃលោក
បានឮហើយទេដឹង ដូច្នេះ សូមអធិស្ឋានឱ្យសំណល់[ឈ]ដែល
នៅសល់ចុះ ៥នោះពួកជំនិតស្ដេចហេសេគាក៏មកឯអេសាយ
៦ហើយអេសាយលោកមានប្រសាសន៍ថា ត្រូវឱ្យអ្នករាល់
គ្នាទូលដល់ចៅហ្វាយរបស់អ្នកថា ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ កុំឱ្យខ្លាច[ញ]ចំពោះពាក្យសំដី ដែលឯងបានឮ
ជាពាក្យដែលពួកបំរើរបស់ស្ដេចអាសសើរ បានប្រមាថ[ដ]
ដល់អញនោះឡើយ ៧មើល អញនឹងបណ្ដាលគំនិតវាឱ្យ
សំរេចនឹងត្រឡប់ទៅស្រុកវាវិញ ដោយបានឮដំណឹងមួយ[ឋ]
រួចអញនឹងឱ្យវាដួលស្លាប់ដោយដាវ នៅក្នុងស្រុករបស់វា
ទៅ[ឌ] ។
៨ឯរ៉ាបសាកេក៏ត្រឡប់ទៅរកស្ដេចអាសសើរ ឃើញ
កំពុងតែច្បាំង និងក្រុងលិបណាវិញ[ឍ] ដ្បិតលោកឮថា ទ្រង់
បានថយពីក្រុងឡាគីស[ណ]ទៅហើយ ៩រួចកាលមានដំណឹងឮ
មកដល់ទ្រង់ថា ទារហាកា ជាស្ដេចស្រុកអេធីយ៉ូពី បាន
ចេញមកច្បាំងនឹងទ្រង់ហើយ នោះទ្រង់ក៏ចាត់សារឱ្យទៅ
ឯហេសេគា ដោយពាក្យថា ១០ចូរឯងរាល់គ្នាប្រាប់ដល់
ហេសេគា ជាស្ដេចយូដាដូច្នេះថា កុំឱ្យព្រះរបស់ផងឯង

**១៨:៣៥** ញ ទដ ២:១-២
**១៨:៣៧** ដ ខ.១៨ អស ៣៣:៧ ៣៦:៣,២២ ឋ ២ពវ ៦:៣០
**១៩:១** ក លប ៣៧:៣៤ ជន ១៤:៦
**១៩:២** ខ ២ពវ ១៨:១៨ គ យរ ១៩:១ ឃ លប ៣៧:៣៤ ង អស ១:១
**១៩:៣** ច ហស ១៣:១៣
**១៩:៤** ឆ ១សយ ១៧:២៦ ជ ២សយ ១៦:១២ ឈ លប ៤៥:៧ យរ ៣៧:៣
**១៩:៦** ញ ចទ ៣:២ យស ១:៩ ដ ២ពវ ១៨:២៥
**១៩:៧** ឋ នក ១៤:២៤ យរ ៥១:៤៦ ឌ ខ.៣៧ ២រប ៣២:២១ អស ១០:១២
**១៩:៨** ឍ ជន ៣៣:២០ ២ពវ ៨:២២ ណ ២ពវ ១៨:១៤

សាសន៍ដទៃរបស់ពួកអាសសើរ (មើល ចទ ២:២១) ដែលពួកគេត្រូវបាន វាលផ្ចាល (សូមមើល ១៩:៤,៦ ២រប ៣២:១៣-១៩ អស ១០:៩-១១) ។

**១៨:៣៧** *អាវរហែក* ពាក្យនេះសម្ដែងពីអារម្មណ៍របស់ពួកគេ (មើល ៦:៣០ ១ពវ ២១:២៧) ។ ការនេះប្រហែលជាពួកអាសសើរ មានបំណងប្រមាថដល់ព្រះពិតតែមួយអង្គគត់នោះ (សូមមើល ១៩:៤,៦ មថ ២៦:៦៥ មក ១៤:៦៣-៦៤) ។

**១៩:១** *សំពត់ធ្មៃ* សូមមើលការពន្យល់ ៦:៣០ ។

**១៩:២** *ឧកញ៉ាវាំង* សូមមើលការពន្យល់ ១ពវ ៤:៦ ។ *ស្មៀនហ្លួង* សូមមើលការពន្យល់ ២សយ ៨:១៧ ។ *ចាស់ទុំក្នុងពួកសង្ឃ* ពួកសង្ឃនៅត្រង់នេះសំដៅលើពួកចាស់ទុំដែលមកពីពួកគ្រួផ្សេងៗជាច្រើន (មើល យរ ១៩:១) ។ វិបត្តមិនមែនកើតមាននៅតែក្រុងយេរូសាឡិមទេ ប៉ុន្តែនៅក្នុងព្រះវិហារផងដែរ ។ *ហោរាអេសាយ* ហោរាម្នាក់នេះ គឺបានលើកឡើងដំបូងគេនៅក្នុងកណ្ឌគម្ពីរពង្សាវតារក្សត្រ ទោះបីហោរានេះគាត់មានសកម្មភាពផ្សេងៗនៅក្នុងរាជ្យស្ដេចអ៊ូសៀស យ៉ូថាម និងអេហាស (មើល អស ១:១) ។

**១៩:៣** *កូនគ្រប់ខែហើយ តែគ្មានកំឡាំងនឹងសំរាលមកសោះ* អត្ថន័យនេះជាការលើកឡើងក្នុងការរិះគន់ដល់ការគម្រាមកំហែងដែលកំពុងកើតមាននៅក្នុងក្រុងនេះតែម្ដង ។

**១៩:៤** *ព្រះដ៏មានព្រះជន្មរស់នៅ* សំដៅលើព្រះយេហូវ៉ា ដែលមានលក្ខណៈខុសស្រឡះពីព្រះផ្សេងៗដែលបានលើកឡើងនៅក្នុង ១៨:៣៣-៣៥ ។ សូមមើល ១សយ ១៧:២៦,៣៦,៤៥ សម្រាប់ការចំអកដល់ព្រះដ៏មានព្រះជន្មរស់នោះ ។ *អធិស្ឋាន* ការធ្វើយ៉ាងដូច្នេះ វាមានសារៈសំខាន់ណាស់សម្រាប់កិច្ចការរបស់ពួកហោរាក្នុងការទូលសូមដល់ព្រះនូវអ្វី១នោះ (ឧទាហរណ៍ លោកម៉ូសេ និងលោកសាំយូអែល បានអធិស្ឋានលន់តួចំពោះកំហុសឆ្គងដែលខ្លួនបានធ្វើខុសដល់ព្រះយេហូវ៉ានោះ គឺមាននៅក្នុង នក ៣២:៣១-៣២ ៣៣:១២-១៧ ជន ១៤:១៣-១៩ ១សយ ៧:៨-៩ ១២:១៩,២៣ ទដ ៩៩:៦ យរ ១៥:១) ។ *សំណល់* សំដៅដល់ពួកអ្នកនៅសេសសល់ក្នុងទឹកដីយូដាក្រោយពីការវាយយកក្រុង និងប្រជាជនមួយចំនួនរបស់ស្ដេចសានហេរីបនោះ (សូមមើល អស ១០:២៨-៣២) ។ ភស្តុតាងខាងបុរាណវិទ្យាបានបង្ហាញឱ្យឃើញច្បាស់ថា ពួកអ៊ីស្រាអែលជាច្រើនបានភៀសខ្លួនទៅរស់នៅភាគខាងជើង ក្នុងអំពើរឃាតកម្មរបស់ពួកអាសសើរ ហើយពួកគេបានបោះជំរុំរស់នៅក្នុងទឹកដីយូដា ដូច្នេះពួកយូដាក៏បានក្លាយជាពួកសេសសល់នៅលើទឹកដីខ្លួនឯង ដោយព្រោះតែពួកអ៊ីស្រាអែល មានចំនួនច្រើនជាង ។

**១៩:៧** *គំនិត* នេះបញ្ជាក់ពីភាពគ្មានសន្តិសុខ និង ភាពភ័យខ្លាយទៅវិញទេ ។ *ស្លាប់ដោយមុខដាវ* សូមមើល ខ.៣៧ ។ នៅត្រង់នេះ បញ្ជាក់ថាអំពើមនុស្សឃាតរបស់ស្ដេចសានហេរីបជាចុងក្រោយ គឺបានធ្វើឱ្យមានការប្រមាថដល់ព្រះដ៏មានព្រះជន្មរស់នៅផងដែរ ។

**១៩:៨** *ក្រុងលិបណា* សូមមើលការពន្យល់ ៨:៣២ ។

**១៩:៩** *ទារហាកា* សូមមើលការពន្យល់ អស ៣៧:៩ ។

ដែលឯងទុកចិត្តនោះ[ត] បញ្ឆោត[ថ]ឯងដោយថា ក្រុងយេរូ
សាឡិមនឹងមិនត្រូវប្រគល់ទៅ ក្នុងកណ្ដាប់ដៃនៃស្ដេច
អាសស៊ើរនោះឡើយ ១១មើល ឯងបានឮនិយាយពីការ
ដែលស្ដេចអាសស៊ើរបានធ្វើ ដល់ស្រុកទាំងប៉ុន្មានហើយ
គឺដែលទ្រង់បានបំផ្លាញគេអស់រលីងទៅ ដូច្នេះ តើឯងនឹង
បានរួចឬ ១២ឯសាសន៍ដទៃទាំងប៉ុន្មាន ដែលពួកឰយុកោ
អញបានបំផ្លាញ គឺពួកក្រុងកូសាន[ទ] ក្រុងខារ៉ាន[ធ] ក្រុងរេ
សែភ និងពួកកូនចៅអេដែន ដែលនៅក្នុងស្រុកធេឡាសើរ
តើព្រះរបស់គេបានជួយឱ្យគេរួច[ន]ឬទេ ១៣តើស្ដេចក្រុង
ហាម៉ាត ស្ដេចក្រុងអើផាឌ និងស្ដេចនៃក្រុងសេផាវ៉ែម
ក្រុងហេណា និងក្រុងអ៊ីវ៉ានៅឯណា[ន] ។

## សេចក្ដីអធិស្ឋានរបស់ស្ដេចហេសេគា

*១៩:១៤–១៩ – អស ៣៧:១៤–២០*

១៤ហេសេគាក៏ទទួលសំបុត្រនោះ[ប] ពីដៃរបស់ពួកទូតទៅ
អានមើល រួចទ្រង់យាងឡើងទៅក្នុងព្រះវិហារនៃព្រះ
យេហូវ៉ា លាសំបុត្រនោះនៅចំពោះព្រះអង្គ ១៥ហើយទ្រង់
អធិស្ឋាន នៅចំពោះព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ាជាព្រះ
នៃសាសន៍អ៊ីស្រាអែល ដែលទ្រង់គង់ពីលើចេរូប៊ីន[ផ] អើយ គឺ
ទ្រង់តែ១ព្រះអង្គទ្រង់[ព] ដែលជាព្រះនៃអស់ទាំងសាសន៍នៅ
ផែនដីនេះ ទ្រង់បានបង្កើតផ្ទៃមេឃនឹងផែនដី ១៦ឱព្រះ
យេហូវ៉ាអើយ សូមទ្រង់ផ្ទៀងព្រះកាណ៌[ភ]ស្ដាប់[ម] ឱព្រះ
យេហូវ៉ាអើយ សូមបើកព្រះនេត្រ[យ]ទត សូមស្ដាប់អស់ទាំង
ពាក្យរបស់សានហេរីប ដែលបានផ្ញើមកប្រកួតដល់ទ្រង់ ជា
ព្រះដ៏មានព្រះជន្មរស់ចុះ ១៧ឱព្រះយេហូវ៉ាអើយ ស្ដេច
អាសស៊ើរបានបំផ្លាញអស់ទាំងសាសន៍ និងស្រុកគេជា

**១៩:១០** ត ២ពវ ១៨:៥ ថ ២ពវ ១៨:២៩ **១៩:១២** ទ ២ពវ ១៧:៦ ធ លប ១១:៣១ ន ២ពវ ១៨:៣៣ ២របា ៣២:១៧ **១៩:១៣** ប អស ១០:៩–១១ យរ ៤៩:២៣ **១៩:១៤** ផ ២ពវ ៥:៧ **១៩:១៥** ព លប ៣:២៤ នក ២៥:២២ ភ លប ១:១ យស ២:១១ **១៩:១៦** ម ទដ ៣១:២ ៧១:២ ៨៨:២ ១០២:២ យ ១ពវ ៨:២៩ យ នក ៣:១៦ **១៩:១៨** រ អស ៤៤:៩–១១ យរ ១០:៣–១០ ល ចទ ៤:២៨ ទដ ១១៥:៤ កច ១៧:២៩ **១៩:១៩** វ ១សយ ១២:១០ យប ៦:២៣ ទដ ៣:៧ ៧១:៤ ស ១ពវ ៨:៤៣ ១រប ១៦:៨ ហ យស ៤:២៤ ១សយ

ប្រាដកមែន ១៨ក៏បានបោះចោលព្រះរបស់គេ ទៅក្នុងភ្លើង
ដែរ ដ្បិតមិនមែនជាព្រះទេ[រ] គឺជាស្នាដៃដែលមនុស្សធ្វើមក
ពីឈើពីថ្មវិញ ហេតុនោះបានជាគេបំផ្លាញទៅបាន[ល]
១៩ដូច្នេះ ឱព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំអើយ សូមទ្រង់
ជួយសង្គ្រោះ[វ]យើងខ្ញុំ ឱ្យរួចពីកណ្ដាប់ដៃគេផង ដើម្បីឱ្យ
គ្រប់ទាំងសាសន៍[ស]នៅផែនដីបានដឹងថា[ហ] គឺទ្រង់ជាព្រះយេ
ហូវ៉ា ដែលជាព្រះតែ១ព្រះអង្គទេ ។

## លោកអេសាយថ្លែងទំនាយពីការធ្លាក់ចុះនៃស្ដេចសានហេរីប

*១៩:២០–៣៧ – អស ៣៧:២១–៣៨*
*១៩:៣៥–៣៧ – ២របា ៣២:២០–២១*

២០គ្រានោះ អេសាយ ជាកូនអ័ម៉ូស ក៏ចាត់គេឱ្យទៅឯ
ហេសេគាទូលថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រា
អែល ទ្រង់មានបន្ទូលដូច្នេះ សេចក្ដីដែលឯងបានអធិស្ឋាន
ដល់អញ ពីដំណើរសានហេរីប ជាស្ដេចអាសស៊ើរ នោះ
អញបានយល់ព្រម[ឡ]ហើយ ២១នេះជាព្រះបន្ទូល ដែលព្រះ
យេហូវ៉ាទ្រង់មានបន្ទូលពី[អ]ដំណើរស្ដេចនោះ គឺថា នាង
ក្រមុំ[ក]នៃក្រុងស៊ីយ៉ូនបានស្អប់ខ្ពើម[ខ]ដល់ឯង ហើយបានមើល
ងាយ[គ]ដល់ឯង កូនស្រីនៃក្រុងយេរូសាឡិមបានគ្រវីក្បាល[ឃ]
ដល់ឯង ២២តើឯងបានប្រកួត ហើយប្រមាថ[ង]ដល់អ្នកណា
តើទាស់នឹងអ្នកណាដែលឯងបានដំឡើងសំឡេង ហើយ

១៧:៤៦ **១៩:២០** ឡ ១ពវ ៩:៣ **១៩:២១** អ អស ១០:៥ ៣៣:១ ក អស ៤៧:១ យរ ១៤:១៧ ១៨:១៣ ៣១:៤ ៤៦:១១ បទ ២:១៣ អម ៥:២ ខ ទដ ៥៣:៥ គ សភ ១:២៦ ៣:៣៤ ឃ យប ១៦:៤ ទដ ៤៤:១៤ ៦៤:៨ ១០៩:២៥ យរ ១៨:១៦ **១៩:២២** ង ២ពវ ១៨:២៥

**១៩:១២** *ក្រុងកូសាន* សូមមើល ការពន្យល់ ១៧:៦ ។ *ក្រុងខារ៉ាន* សូមមើល ការពន្យល់ លប ១១:៣១ ។ ក្រុងនេះ មិនត្រូវបានគេស្គាល់ទេ នៅមុនពេលការរឹបយករបស់ពួកអាសស៊ើរ ។ *ក្រុងរេសែភ* ក្រុងនេះមានទីតាំងនៅភាគខាងត្បូងទន្លេអឺប្រាត និងភាគឥសាននៃស្រុកហាម៉ាត ។ *អេដែន* ស្រុកនេះនៅតាមបណ្ដោយទន្លេអឺប្រាត ស្ថិតក្នុងភាគខាងត្បូងនៃក្រុងខារ៉ាន (សូមមើល អគ ២៧:២៣ អម ១:៥) ហើយវាជាសួនអេដែនផងដែរ ។ ហើយតំបន់នេះ គឺមានកិច្ចសហប្រតិបត្តការល្អជាមួយនឹងចក្រភពអាសស៊ើ ក្នុងរជ្ជកាលស្ដេចសាលម៉ាន៉ាសេទី៣ ក្នុងឆ្នាំទី ៨៥៥ មុន គ.ស ។

**១៩:១៣** *ក្រុងហាម៉ាត . . . ក្រុងអ៊ីវ៉ា* សូមមើលការពន្យល់ ១៧:២៤ ។

**១៩:១៤** *សំបុត្រ* សូមមើល ២របា ៣២:១៧ ។

**១៩:១៥** *គង់ពីលើចេរូប៊ីន* សូមមើលការពន្យល់ នក ២៥:១៨ ១សយ ៤:៤ ។ *ទ្រង់តែ១ព្រះអង្គទ្រង់ ដែលជាព្រះ* សូមមើល ខ.១៩ ចទ ៤:៣៥,២៩ និងមើលបន្ថែម ២ពវ ១៨:៣៣–៣៥ អស ៤៣:១១ និងការពន្យល់ ។

**១៩:១៨** *ស្នាដៃដែលមនុស្សធ្វើមក* ស្នាដៃដ៏ល្វីល្វើ និងសេចក្ដីកំផិតសាវ៉ា សូមមើល ទដ ១១៥:៣–៨ ១៣៥:១៥–១៨ អស ២:២០ ៤០:១៩–២០ ៤១:៧ ៤៤:៩–២០ ។

**១៩:២០** *គ្រប់ទាំងសាសន៍នៅផែនដីបានដឹងថា គឺទ្រង់ជាព្រះយេហូវ៉ា* ហេសេគា បានទទួលស្គាល់ថា កិត្តិនាមរបស់ព្រះបានបោះជាប់នៅក្នុងសុខមាលនៃសេចក្ដីសញ្ញារបស់រាស្ត្ររបស់ព្រះអង្គ (មើល ១សយ ១២:២២ និងមើលបន្ថែម យស ៧:៩ ២សយ ៧:២៣ ទដ ២៣:៣ អគ ៥:១៣ និងការពន្យល់) ។

**១៩:២១–២៨** សេចក្ដីអំនួតរបស់ពួកអាសស៊ើរ ធ្វើឱ្យពួកគេសើចចំអកដល់ពួកអ៊ីស្រាអែល និងព្រះយេហូវ៉ា នោះពួកគេបានព្យាយាមធ្វើការកាត់ទោសដល់ពួកអ៊ីស្រាអែល (ធៀប ទដ ជំពូក ២) ដោយភាពអំនួតយល់ខុសរបស់ពួកគេ (មើល អស ១០:៥–៣៤) ។

**១៩:២១** *នាងក្រមុំនៃក្រុងស៊ីយ៉ូន . . . កូនស្រីនៃក្រុងយេរូសាឡិម* កំណាព្យភាសាហេព្រើរសំដៅលើរាជធានី សញ្ជាតិឬមនុស្ស ដែលទាំងអស់នេះមានទ្រង់ទ្រាយជាស្រី ដែលជានិច្ចកាលទាំងអស់នេះត្រូវបានគេរកឃើញនៅក្នុងក្រាំងទំនាយ ។

**១៩:២២** *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* នេះបញ្ជាក់ថា ព្រះនៃសាសន៍

ងើបភ្នែកឡើងជាខ្ពស់ដូច្នេះ គឺទាស់នឹងព្រះដ៏បរិសុទ្ធ[ច]នៃ
សាសន៍អ៊ីស្រាអែលទេតើ ២៣ឯងប្រកួតនឹងព្រះអម្ចាស់ដោយ
ពួកអ្នកដែលចាត់មកនោះដោយថា[ឆ] អញបានឡើងទៅឯ
កំពូលភ្នំទាំងប៉ុន្មាន ដោយសាររទេះចំបាំង[ជ]អញ ក៏ដល់
ទីជ្រៅបំផុតនៃព្រៃល្បាណូនផង អញនឹងកាប់[ឈ]អស់ទាំង
ដើមតាត្រៅដែលខ្ពស់ និងដើមកកោះ ដែលល្អជាងគេនៅ
ទីនោះ អញនឹងចូលទៅដល់ទីលំនៅផុតស្រុករបស់គេ គឺ
ដល់ចំការរបស់គេ ដែលដុះដាលដូចជាព្រៃ ២៤អញបានជីក
ហើយបានផឹកទឹកនៅស្រុកដទៃ ហើយអញនឹងធ្វើ ឱ្យអស់
ទាំងទន្លេស្រុកអេស៊ីព្ទ រីងស្ងួតទៅ ដោយបាតជើងអញ ។
២៥តើឯងមិនបានឮថា[ញ] អញបានគិតជាស្រេច[ដ] នឹងធ្វើ
ការទាំងប៉ុន្មាននេះ តាំងពីយូរមកហើយ ព្រមទាំងចាត់ចែង
តាំងពីចាស់បុរាណទេឬអី ឥឡូវនេះ អញបានសំរេចការ
នេះ គឺបានឱ្យឯងបំផ្លាញទីក្រុងមានកំផែង ឱ្យទៅជាគំនរ
បំណែក[ឋ] ២៦ហេតុនោះបានជាពួកអ្នកក្រុងទាំងនោះ ខ្សោយ
កំឡាំង[ឌ] គេបានស្រយុតចិត្ត[ឍ] ហើយទ្រឹងនៅគេក៏ដូចជាជា
ស្មៅនៅវាល និងពន្លកខ្ចី[ណ] ហើយដូចជាស្មៅដែលដុតនៅ
លើដំបូលផ្ទះ និងស្រូវដែលស្វិតក្រៀម[ត] មុនដែលដុះពេញ
កំឡាំង ២៧អញដឹង[ថ]កន្លែងដែលឯងអង្គុយនឹងវេលាណា
ដែលឯងចេញចូល ក៏ស្គាល់សេចក្តីដែលឯងខឹងក្តៅនឹង
អញដែរ ២៨ដោយព្រោះឯងខឹងនឹងអញដូច្នេះ ហើយដោយ
ព្រោះសេចក្តីព្រហើនរបស់ឯង បានឮមកដល់ត្រចៀកអញ
នោះអញនឹងដាក់កន្លុះ[ទ]របស់អញនៅច្រមុះឯង និងដែក
បង្ហៀ[ធ]របស់អញនៅមាត់ឯង ហើយអញនឹងញាក់ឯង ឱ្យ
វិល[ន]ទៅតាមផ្លូវ ដែលឯងបានមកនោះវិញ ។
២៩ការនេះនឹងបានជាទីសំគាល់[ប]ដល់ឯងរាល់គ្នា គឺនៅ
ឆ្នាំនេះ ឯងរាល់គ្នានឹងបរិភោគផលដែលដុះឯង[ផ] ដល់ឆ្នាំទី
២ នោះនឹងបរិភោគផល ដែលកើតពីនោះទៀត តែដល់ឆ្នាំ
ទី៣ត្រូវឱ្យឯងរាល់គ្នាសាបព្រោះ ច្រូតកាត់ ហើយដាំចំការ
ទំពាំងបាយជូរ[ព] រួចបរិភោគពីផលទាំងនោះទៅ ៣០ឯ
សំណល់[ភ]នៃពួកកូនចៅយូដា ដែលរួចជីវិត គេនឹងចាក់ឫស
[ម]ទៅក្រោម ហើយនិងបង្កើតផលទៅលើ ៣១ដ្បិតនឹងមាន
សំណល់[យ] ចេញពីក្រុងយេរូសាឡិមទៅ ព្រមទាំងពួកអ្នក
ដែលរួចជីវិត[រ] ចេញពីក្រុងស៊ីយ៉ូនដែរ សេចក្តីឧស្សាហ៍[ល]
របស់ព្រះយេហូវ៉ា នៃពួកពលបរិវារនឹងធ្វើការនោះ
៣២ហេតុនោះបានជាព្រះយេហូវ៉ា ទ្រង់មានបន្ទូលពីដំណើរ
ស្តេចអាសស៊ើរដូច្នេះថា គេនឹងមិនចូលមកក្នុងក្រុងនេះ
ឡើយ ក៏មិនបាញ់ព្រួញ ឬកាន់ខែលនៅមុខទីក្រុងនេះ ឬជីក
ស្នាមភ្លោះច្បាំងនឹងទីនេះដែរ ៣៣គឺគេនឹងវិលទៅវិញ[វ]

**១៩:២២** ច លវ ១៩:២ ១សយ ២:២ យប ៦:១០ ទដ ១៦:១០ ២២:៣ ៧១:២២ ៧៨:៤១ ៨៩:១៨ អស ១:៤ ៦:៣ ៥៧:១៥ ហស ១១:៩
**១៩:២៣** ឆ អស ១០:១៨ យរ ២១:១៤ អក ២០:៤៧ ជ ទដ ២០:៧ យរ ៥០:៣៧ ឈ អស ១០:៣៤ ១៤:៨ ៣៣:៩ អគ ៣១:៣ **១៩:២៥** ញ អស ៤០:២១,២៨ ដ អស ២២:១១ ឋ មីក ១:៦
**១៩:២៦** ឌ អស ១៣:៧ អក ៧:១៧ សផ ៣:១៦ ឍ ទដ ៦:១០ ៧១:២៤ ៨៣:១៧ អស ៤១:២៣ យរ ៨:៩ ណ អស ៤:២ ១១:១ ៥៣:២ យរ ២៣:៥ ត យប ៨:១២ ទដ ៣៧:២ ១២៩:៦

**១៩:២៧** ថ ទដ ១៣៩:១–៤ **១៩:២៨** ទ ២រប ៣៣:១១ អគ ១៩:៩ ២៩:៤ ៣៨:៤ អម ៤:២ ធ អស ៣០:២៨ ន ខ.៣៣ **១៩:២៩** ប នក ៧:៩ ចទ ១៣:២ លក ២:១២ ផ លវ ២៥:៥ ព ទដ ១០៧:៣៧ អស ៦៥:២១ អម ៩:១៤ **១៩:៣០** ភ លប ៤៥:៧ ម អស ៥:២៤ ១១:១ ២៧:៦ អគ ១៧:២២ អម ២:៩ **១៩:៣១** យ លប ៤៥:៧ រ អស ៦៦:១៩ សផ ២:៩ សក ១៤:១៦ ល អស ៩:៧ **១៩:៣៣** វ ខ.២៨

អ៊ីស្រាអែល បានជ្រើសរើសចរិតលក្ខណៈលោកហោរាអេសាយទុកជាមុន (សូមមើល លវ ១១:៤៤ អស ១:៤ និងការពន្យល់) ។

**១៩:២៣** *ព្រៃល្បាណូន . . .* សូមមើលការពន្យល់ ១ពវ ៥:៦ ។

**១៩:២៤** *ទន្លេស្រុកអេស៊ីព្ទរីងស្ងួតទៅ* ការច្បាំងដណ្តើមស្រុកអេស៊ីព្ទ ពុំមានអ្នកណាម្នាក់និយាយអួតអាងនោះឡើយ ។

**១៩:២៥** *អញបានគិតជាស្រេច . . . ឥឡូវនេះ អញបានសំរេចការនេះ* ព្រះនៃអ៊ីស្រាអែល គឺជាអ្នកគ្រប់គ្រងលើគ្រប់ជាតិសាសន៍នៃប្រវត្តិសាស្ត្រទាំងមូល ។ ស្រុកអាសស៊ើរត្រូវបានកំណត់ឱ្យជ័យជម្នះរបស់ពួកគេ ទៅម្ចាស់នៃចំបាំងមានឧត្តមភាព ។ យ៉ាងណាក៏ដោយកូនចៅអ៊ីស្រាអែលបានអំពាវនាវទៅរកព្រះតែមួយ ដើម្បីសុំឱ្យការនេះបានទទួលជ័យជន្នះ (មើល អស ១០:៥–៩ អគ ៣០:២៣–២៦) ។

**១៩:២៨** នៅវគ្គនេះ ពួកអាសស៊ើរបានចាប់ខ្លួនពួកគេយ៉ាងព្រៃផ្សៃបំផុត ។ ពួកអាសស៊ើរបានធ្វើទារុណកម្មពួកអ្នកទោសធ្វើជាការកំសាន្ត ដោយការបិទមុខ អាសាច់ ដោះសំលៀកបំពាក់ គឺប្រព្រឹត្តរហូតពួកគេស្លាប់ ។ ហើយប្រសិនបើ ពួកអាសស៊ើរមានបំណងចាប់ពួកគេធ្វើជាទាសករ នោះគេនឹងដាក់ពួកទាំងអស់នោះនឹងកន្លុះនៅត្រង់ច្រមុះ ។ ព្រះយេហូវ៉ា បានមានបន្ទូលទៅកាន់ពួកអាសស៊ើរថា ពួកគេនឹងទទួលការទាំងអម្បាលម្ទានដែលគេ បានប្រព្រឹត្តចំពោះអ្នកដទៃអញ្ចឹងដែរ ។

**១៩:២៩** *នៅឆ្នាំនេះ ឯងរាល់គ្នានឹងបរិភោគផលដែលដុះឯង* សានហេរីប ពិតជាបានបំផ្លាយ និងរឹបអូសភោគផលដែលគេបានដាំដុះតាំងពីមុនពេលនេះផងដែរ ។ ប្រជាជនបានស្នើសុំការមួយ ដោយព្រោះការលួតលាស់លើកទី២នេះមានការយឺតមកពីគ្រាប់ពូជដែលយើងប្រមូលផលបាន គឺតូចៗ (មើល លវ ២៥:៥) ។ *ដល់ឆ្នាំទី២ នោះត្រូវឱ្យរិភោគផលដែលកើតពីនោះទៀត* សានហេរីបចំណេញក្នុងការធ្វើដំណើរនៅក្នុង (ខែតុលា) ផែនការសម្រាប់ដំណាំដែលត្រូវមកឆាប់ក្នុងឆ្នាំនេះ ។ នៅក្នុងទឹកដីបរិសុទ្ធការព្រោះពូជធម្មតាក្នុងខែកញ្ញា និងខែតុលា ។ *ដល់ឆ្នាំទី៣ត្រូវឱ្យឯងរាល់គ្នាសាបព្រោះ* បើតាមទម្លាប់ដដែលៗនៅពេលដែលច្រូតកាត់ គឺអាចទៅតាមឆ្នាំនិមួយៗ ។

**១៩:៣០–៣១** *សំណល់* សូមមើលការពន្យល់ ខ.៤ ។ ការប្រើពាក្យថា "សំណល់"នេះជាការជ្រើសទុកជាមុន សម្រាប់អស់អ្នកណាដែលចូលរួមការលាតត្រដាងពីការដោះលែងរបស់ព្រះ មើល អស ១១:១១,២៦ ២៨:៥ មីក ៤:៧ រម ១១:៥ ។

**១៩:៣២** *មិនចូលមកក្នុងក្រុងនេះ* ត្រង់នេះបញ្ជាក់ថា សានហេរីប កំពុងតែស្ថិតនៅក្នុងក្រុងលិបណា (មើល ខ.៨ និងបន្ថែម ការពន្យល់ ៨:២២) ហើយមិនអាចតតាំងនឹងការគម្រាមគំហែងរបស់ក្រុងយេរ៉ូសាឡិម (មើល ការពន្យល់ ១៨:១៣) ។

តាមផ្លូវដដែល ដែលគេបានមកនោះ ឥតចូលមកក្នុងទីក្រុង
នេះឡើយ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ៣៤ដ្បិតអញ
នឹងការពារ[ស]ក្រុងនេះ រក្សាទុកសំរាប់ខ្លួនអញ គឺដោយ
យល់ដល់ដាវីឌ[ហ] ជាអ្នកបំរើអញផង ។
៣៥ដូច្នេះ នៅពេលយប់នោះ ទេវតានៃព្រះយេហូវ៉ា[ឡ]ក៏
ចេញទៅ ប្រហារទីបោះទ័ពរបស់ពួកសាសន៍អាសស៊ើរ
សំឡាប់មនុស្សអស់១សែន៨ម៉ឺន៥ពាន់នាក់ បានជាកាលគេ
ក្រោកពីព្រឹកឡើង នោះឃើញមនុស្សទាំងនោះសុទ្ធតែ
ខ្មោចស្លាប់ទាំងអស់[អ] ៣៦ហេតុនោះសានហេរីប ជាស្តេច
អាសស៊ើរ ក៏ត្រឡប់ទៅ[ក]អាស្រ័យនៅឯងក្រុងនីនីវេ[ខ]វិញ
៣៧រួចកាលទ្រង់កំពុងតែថ្វាយបង្គំ នៅក្នុងវិហាររបស់ព្រះ
នីសរូក ជាព្រះនៃទ្រង់នោះអ័ឌ្រ៉ាម៉ាលេក[គ] នឹងសារេស៊ើរ
ជាបុត្រទ្រង់បានធ្វើគុតទ្រង់ដោយដាវ[ឃ] ហើយរត់រួចទៅឯ
ស្រុកអារ៉ារ៉ាតទៅ[ង] នោះអេសារ–ហាដោន[ច] ជាព្រះរាជ
បុត្រាក៏ឡើងសោយរាជ្យជំនួសបិតា ។

## ជម្ងឺរបស់ស្តេចហេសេគា

*២០:១-១១ – ២រប ៣២:២៤-២៦ អស ៣៨:១-៨*

**២០** ១នៅគ្រានោះ ហេសេគាទ្រង់ប្រឈួនហៀបនឹងសុគត
ហើយ ហោរាអេសាយ ជាកូនអ័ម៉ូសក៏មកគាល់ទ្រង់ទូលថា
ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរផ្តាំដល់វង្សារបស់ឯង
ចុះ ដ្បិតឯងត្រូវស្លាប់ហើយ មិនរស់ទេ ២នោះទ្រង់ក៏បែរ
ព្រះភក្ត្រទៅឯជញ្ជាំងអធិស្ឋានដល់ព្រះយេហូវ៉ាថា ៣ឱព្រះ
យេហូវ៉ាអើយ សូមទ្រង់នឹកចាំ[ក]ពីទូលបង្គំ ដែលបានដើរ[ខ]
នៅចំពោះទ្រង់ ដោយពិតត្រង់ ហើយដោយចិត្តស្មោះ
ចំពោះ[គ] ព្រមទាំងប្រព្រឹត្តអំពើដ៏ល្អ នៅព្រះនេត្រទ្រង់ជា
យ៉ាងណា រួចហេសេគាទ្រង់ព្រះកន្សែងជាខ្លាំង ៤ឯអេសាយ
លោកបានចេញទៅមិនទាន់ដល់ទីធ្លាកណ្តាលនៅឡើយ
នោះព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់លោកថា ៥ចូរ
ត្រឡប់ទៅទូលដល់ហេសេគា ជាមេលើរាស្ត្រអញថា ព្រះ
យេហូវ៉ាជាព្រះនៃដាវីឌឰយុកោឯង ទ្រង់មានបន្ទូល ដូច្នេះ
អញបានឮពាក្យអធិស្ឋានរបស់ឯង[ឃ] ក៏បានឃើញទឹកភ្នែក
ឯងហើយ[ង] មើល អញនឹងប្រោសឱ្យឯងបានជារួចដល់ថ្ងៃទី
៣ឯងនឹងឡើងទៅក្នុងព្រះវិហារ នៃព្រះយេហូវ៉ាបាន ៦អញ
នឹងចំរើនអាយុឯងឡើង១៥ឆ្នាំទៀត ហើយនឹងដោះឯង
នឹងទីក្រុងនេះ ឱ្យរួចពីកណ្តាប់ដៃនៃស្តេចអាសស៊ើរ ព្រម
ទាំងការពារ[ច]ទីក្រុងនេះ រក្សាទុកសំរាប់ខ្លួនអញ គឺដោយ
យល់ដល់ដាវីឌ ជាអ្នកបំរើអញផង ៧អេសាយក៏ទូលថា សូម

**១៩:៣៤** ស ២ពវ ២០:៦ ហ ២សយ៧:១៥
**១៩:៣៥** ឡ លប ១៩:១៣ នក ១២:២៣ អ យប ២៤:២៤ អស ១៧:១៤ ៤១:១២ ណាហ ៣:៣
**១៩:៣៦** ក ២ពវ ១២:១៨ ខ លប ១០:១១
**១៩:៣៧** គ ២ពវ ១៧:៣១ ឃ ខ.៧ ង លប ៨:៤ ច ២ពវ ១៧:២៤
**២០:៣** ក លប ៨:១ នហ ១:៨ ៥:១៩ ១៣:១៤ ខ លប ៥:២២ គ ១ពវ ២:៤ ២រប ៣១:២០
**២០:៥** ឃ ១ពវ ៩:៣ ង ទដ ៦:៦,៨ ៣៩:១២ ៥៦:៨
**២០:៦** ច ២ពវ ១៩:៣៤ ១រប ១៧:១៩

**១៩:៣៤** *ដោយយល់ដល់ដាវីឌ ជាអ្នកបំរើអញផង* សូមមើលការពន្យល់ ១ពវ ១១:១៣ ។

**១៩:៣៥** *ទេវតានៃព្រះយេហូវ៉ា* សូមមើលការពន្យល់ លប ១៦:៧ ។ *១សែន៨ម៉ឺន៥ពាន់នាក់* មើល អស ៣៧:៣៦ និងការពន្យល់ ។

**១៩:៣៦** *នីនីវេ* នេះជាក្រុងនៃចក្រភពអាសស៊ើរ ។

**១៩:៣៧** *អ័ឌ្រ៉ាម៉ាលេក និងសារេស៊ើរ* កំណត់ត្រាដែលបានបន្សល់ទុកពីបុរាណកាលមកនោះ បានបញ្ជាក់ពីការធ្វើឃាតមកលើស្តេចសានហេរីបនៅក្នុងរាជ្យទី២៣របស់ទ្រង់ដោយបុត្រាមួយអង្គដែលមិនស្គាល់ព្រះនាម ។ *ស្រុកអារ៉ារ៉ាត* សូមមើលការពន្យល់ លប ៨:៤ ។ *អេសារ–ហាដោនជាព្រះរាជបុត្រាក៏ឡើងសោយរាជ្យជំនួសបិតា* ស្តេចអង្គនេះ បានឡើងគ្រងរាជ្យជំនួសបិតាទ្រង់នៅក្នុងឆ្នាំនេះ ៦៨១–៦៦៩ មុន គ.ស ។ សិលាចារឹកអាសស៊ើរបាននិយាយពីការតស៊ូរ ប្រឆាំងចំពោះបុត្ររបស់ស្តេចសានហេរីបសម្រាប់សិទ្ធនៃការឡើងកាន់កាប់រាជ្យបល្ល័ង្ករបស់ពួកអាសស៊ើរ ។

**២០:១** *នៅគ្រានោះ* នេះជាពេលដែលស្តេចហេសេគាទ្រង់ប្រឈួន (មើល ខ.១–១១) ដែលទ្រង់បានបញ្ចប់បេសកកម្មនៅក្រុងបាប៊ីឡូន (ខ.១២–១៩) ហើយហេតុការណ៍នេះត្រូវតែបានបញ្ចប់នៅមុនឆ្នាំ ៧០១ មុន គ.ស (មើលបន្ថែម ខ.៦ និងការពន្យល់ ខ.១២–១៣) ។ កំណត់ត្រារបស់ពួកបាប៊ីឡូនបានបញ្ជាក់ថាប្រដាក់–បាឡាដាន (ខ.១២) បានសុគតនៅក្នុងក្រុង អេឡាំក្រោយពីគេបាននិរទេសខ្លួនចេញពីក្រុងបាបីឡូនឆ្នាំ ៧០៣ មុន គ.ស ។ *ចូរផ្តាំដល់វង្សារបស់ឯងចុះ* នេះបញ្ជាក់ពីការរៀបចំ មរតករាជ្យ បល្ល័ង្កជាពិសេសគឺសំដៅដល់អ្នកដែលគ្រងរាជ្យបន្ត ។ *ត្បិតឯងត្រូវស្លាប់* ឃ្លានេះបានបញ្ជាក់យ៉ាងច្បាស់ថា ហេសេគាមានព្រះជន្ម២៥វស្សានៅក្នុង ឆ្នាំ៧១៥ មុន គ.ស ដែលទ្រង់បានឡើងគ្រងរាជ្យ (មើល ១៨:២) ហើយទ្រង់ចាប់ផ្តើមប្រឈួនតិចៗអស់រយៈពេល១៥ឆ្នាំមុនកាលដែលទ្រង់សុគត (មើល ខ.៦) ដែលមកដល់ឆ្នាំដែលទ្រង់សុគតនោះទ្រង់មានព្រះជន្មប្រហែលជា ៣៧ ឬ ៣៨ វស្សានៅអំឡុងពេលនោះ ។

**២០:៣** *ដើរនៅចំពោះទ្រង់ . . . ប្រព្រឹត្តអំពើរល្អ* ការអធិស្ឋានរបស់ហេសេគា មិនគ្រាន់តែអំពាវនាវដល់សេចក្តីសង្គ្រោះរបស់ព្រះប៉ុណ្ណោះទេ តែវាបានបញ្ជាក់ពីការបើកសំដែងឱ្យដឹងថា ព្រះគុណរបស់ព្រះបានផ្តល់ដល់អស់អ្នកណាដែលបានបម្រើទ្រង់(មើលការពន្យល់ ២សយ ២២:២១) ។

**២០:៥** *អញនឹងប្រោសឱ្យឯងបានជា* ព្រះអម្ចាស់គឺតែមួយ ដែលបានសោយរាជ្យលើរបស់ទាំងអស់តាំងពីអតីតរហូតដល់បច្ចុប្បន្ន (ទដ ១៣៩:៦ អភ ១:១១) ។ លិខិតរបស់ស្តេចហេសេគា និងការឆ្លើយតបរបស់ព្រះយេហូវ៉ាបានបង្ហាញថា (១).អំណាចគ្រប់គ្រងរបស់ព្រះ មិនបានធ្វើឱ្យអ្នកអធិស្ឋាននោះមិនគួរសម ប៉ុន្តែផ្ទុយមកវិញ ព្រះទ្រង់ជាអ្នកបង្កើតការនោះវិញទេ (២).ទាំងការអធិស្ឋាន និង ការឆ្លើយតបអំណាចរបស់ព្រះ គឺត្រូវបានរួមបញ្ចូលនូវគោលបំណងតែមួយនៃអំណាចរបស់ព្រះ (សូមមើល ១ពវ ២១:២៩ អគ ៣៣:១៣–១៦) ។

**២០:៦** *ចំរើនអាយុឯងឡើង១៥ឆ្នាំទៀត* មកដល់ត្រង់នេះស្តេចហេសេគាបានសុគតនៅក្នុងឆ្នាំ ៦៨៦ មុន គ.ស ។ ការចាប់ផ្តើមនៃការពន្យាព្រះជន្មារបស់ព្រះអង្គ ត្រូវបានគេកំណត់មិនឱ្យលើសពីឆ្នាំទី ៧០២ មុន គ.ស ។ *រក្សាទុកសំរាប់ខ្លួនអញ គឺដោយយល់ដល់ដាវីឌ ជាអ្នកបំរើអញ* សូមមើល ១៩:៣៤ និងមើលបន្ថែម ការពន្យល់ ១ពវ ១១:១៣ ។

**២០:៧** *ផ្លែល្វា* នៅត្រង់នេះព្រះយេហូវ៉ា បានព្យាបាលដល់ហេសេគា(មើល

យកផ្លែល្វា១ផែនមក នោះគេក៏យកមកបិទលើបូសនោះ[ឆ]
រួចទ្រង់បានជាឡើង ។
៨ហេសេគាទ្រង់មានបន្ទូលសួរអេសាយថា តើមានទី
សំគាល់ណា ឱ្យខ្ញុំដឹងថា ព្រះយេហូវ៉ានឹងប្រោសឱ្យខ្ញុំបានជា
ហើយដែលខ្ញុំនឹងឡើងទៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា
នៅថ្ងៃទី៣ដូច្នេះ ៩អេសាយទូលតបថា នេះជាទីសំគាល់[ជ]ពី
ព្រះយេហូវ៉ា ឱ្យទ្រង់បានជ្រាបថា ព្រះយេហូវ៉ាទ្រង់នឹង
សំរេចតាមសេចក្តីដែលមានបន្ទូលហើយ តើទ្រង់សព្វព្រះ
ទ័យ ឱ្យស្រមោលធ្លាក់ទៅមុខ១០ចុច ឬថយក្រោយ១០ចុច
វិញ ១០នោះហេសេគាមានបន្ទូលឆ្លើយថា ដែលស្រមោល
ជ្រេទៅ១០ចុច នោះស្រណុកទេ[ឈ] សូមឱ្យបានថយមកវិញ
១០ចុចចុះ ១១ដូច្នេះហោរាអេសាយ លោកអំពាវនាវដល់
ព្រះយេហូវ៉ា ហើយទ្រង់ក៏ធ្វើឱ្យស្រមោលដែលបានជ្រេទៅ
នៅនាឡិកាថ្ងៃរបស់ស្តេចអ័ហាស បានថយមកក្រោយ[ញ]
វិញ១០ចុច។

**២០:៧** ឆ នក ៩:៩
**២០:៩** ជ ចទ ១៣:២ យរ ៤៤:២៩
**២០:១០** ឈ ២ពវ ៣:១៨
**២០:១១** ញ យស ១០:១៣ ២របា ៣២:៣១ ដ ២ពវ ២៤:១៣ ២របា ៣៦:១០ យរ ២០:៥ ២៧:២២ ៥២:១៧–២៣

## បេសកជនពីស្រុកបាប៊ីឡូន

*២០:១២–១៩ – អស ៣៩:១–៨*
*២០:២០–២១ – ២របា ៣២:៣២–៣៣*

១២គ្រានោះ ម្រដាក់–បាឡាដាន ជាបុត្របាឡាដានស្តេច
ស្រុកបាប៊ីឡូន ក៏ផ្ញើសំបុត្រ និងជង្វាយ មកថ្វាយហេសេគា
ដោយព្រោះទ្រង់ឮថា ហេសេគាបានប្រឈួន ១៣ហេសេគា
ក៏ស្តាប់តាមគេ គឺទ្រង់បង្ហាញឃ្លាំងនៃព្រះរាជទ្រព្យទាំង
ប៉ុន្មាន គឺជាមាស ប្រាក់ គ្រឿងក្រអូប និងប្រេងវិសេស
ហើយឃ្លាំងគ្រឿងសស្ត្រាវុធរបស់ទ្រង់ទាំងអស់នឹងគ្រប់
ទាំងអស់ដែលឃើញមានក្នុងឃ្លាំងទ្រង់ផង គ្មានអ្វីនៅ
ក្នុងព្រះរាជវាំង ឬនៅក្រោមអំណាចទ្រង់ទាំងអស់ដែល
ហេសេគាមិនបានបង្ហាញដល់គេនោះឡើយ ១៤នោះហោរា
អេសាយ លោកមកគាល់ស្តេចហេសេគា ទូលសួរថា អ្នក
ទាំងនោះបាននិយាយអ្វីខ្លះ ហើយមកពីណា ដែលមកគាល់
ទ្រង់ដូច្នេះ ហេសេគាទ្រង់តបថា គេមកពីប្រទេសឆ្ងាយ
ណាស់ គឺពីស្រុកបាប៊ីឡូន ១៥រួចលោកទូលសួរទៀតថា គេ
បានឃើញអ្វីខ្លះ នៅក្នុងព្រះរាជវាំង ហេសេគាឆ្លើយថា គេ
បានឃើញរបស់ទាំងអស់ ដែលនៅក្នុងដំណាក់យើង ហើយ
ក្នុងព្រះរាជទ្រព្យយើងទាំងអំបាលម៉ាន គ្មានអ្វីដែលយើង
មិនបានបង្ហាញដល់គេនោះឡើយ ។
១៦ដូច្នេះអេសាយលោកទូលដល់ហេសេគាថា សូមស្តាប់
ព្រះបន្ទូលនៃព្រះយេហូវ៉ាសិន ១៧មើល នឹងមានគ្រាមកដល់
ដែលគេនឹងមកយកអស់ទាំងរបស់ទ្រព្យ ដែលនៅក្នុងព្រះ
រាជវាំងនឹងរបស់ទាំងប៉ុន្មាន ដែលពួកឰយុកោទ្រង់បាន
សន្សំទុករហូតដល់សព្វថ្ងៃនេះ នាំទៅឯក្រុងបាប៊ីឡូន[ដ] ឥត
ទុកឱ្យមានអ្វីសល់នៅឡើយ នេះឯងជាព្រះបន្ទូល នៃព្រះ
យេហូវ៉ា ១៨ឯពួកបុត្រាទាំងប៉ុន្មាន[ឋ] ដែលនឹងកើតពីទ្រង់មក
នោះនឹងត្រូវដឹកនាំទៅ ឱ្យធ្វើជាមនុស្សកំរៀវនៅក្នុង

**២០:១៧** ដ ២ពវ ២៤:១៣ ២ របា ៣៦:១០ យរ ២០:៥ ២៧:២២ ៥២:១៧–២៣
**២០:១៨** ឋ ២ពវ ៤:១៥ ដយ ១:៣

ខ.៥) ប៉ុន្តែការព្យាបាលនេះមិនចាំបាច់ប្រើឱសថសម្រាប់កែរោគឡើយ ។
**២០:៩** *ចុច* មើលខ.១១ (សូមមើលបន្ថែម អស ៣៨:៨) ។
**២០:១១** *នាឡិកាថ្ងៃរបស់ស្តេចអ័ហាស* នេះសំដៅលើរជ្ជកាលនៃការដឹកនាំរបស់ស្តេចអ័ហាស ឬជាឧបករណ៍សម្រាប់វាស់ពេលវេលា ។
**២០:១២** *ម្រដាក់–បាឡាដាន* មានន័យថា "ព្រះ"ដែលពួកបាប៊ីឡូនបានរាប់ខ្ញុំថាជាបុត្រា ។ គាត់បាន ដឹកនាំពួកបាប៊ីឡូនចាប់តាំងពីឆ្នាំ ៧២១–៧១០ មុន គ.ស មុនពេលទ្រង់ត្រូវបានបង្ខំឱ្យចុះចូលក្រោមអំណាចរបស់ស្តេចសើកុនទី២នៃពួកអាសស៊ើរ ។ ក្រោយពី ការសុគតរបស់ស្តេចសើកុនក្នុងឆ្នាំ ៧០៥ មុន គ.ស ម្រដាក់–បាឡាដាន បានកសាងអាចក្របាប៊ីឡូនឡើងវិញ ឱ្យបានឯករាជ្យ និងបានគ្រប់គ្រងអាណាចក្រនេះរហូតដល់រាជ្យស្តេចសានហេរីបបង្ខំឱ្យចុះចាញ់នៅក្នុងឆ្នាំ ៧០៣ មុន គ.ស (សូមមើលការពន្យល់ ខ.១) ។ *ផ្ញើសំបុត្រ នឹងជង្វាយ មកថ្វាយហេសេគា* នេះទំនងជាស្តេចម្រដាក់–បាឡាដាន មានបំណងចងសម្ព័ន្ធមិត្តជាមួយស្តេចហេសេគា ដើម្បីវាយផ្ចាលស្តេចពួកអាស៊ើរ ។ ទោះបី ហេសេគា បានបដិសេធ ចំពោះគោលនយោបាយរបស់ស្តេចអ័ហាប់ជាបិតារបស់ទ្រង់ និង បះបោរប្រឆាំងជាមួយនឹងពួកអាសស៊ើរ (ខ.១៨:៧) តែទ្រង់បាយល់ខុសចំពោះការស្វែងរកការពង្រឹងសន្តិភាពសន្តិសុខពួកអ៊ីស្រាអែលដោយចងមិត្តភាពជាមួយពួកបាប៊ីឡូន និងអេស៊ីព្ទ (មើល ២របា ៣២:៣១ អស ៣០–៣១ និងមើលបន្ថែម ១សយ ១៧:១១ ១ពវ ១៥:១៩) ។
**២០:១៣** *ស្តាប់តាមគេ គឺទ្រង់បង្ហាញឃ្លាំងនៃព្រះរាជទ្រព្យ* នេះជាការយកព្រះទ័យទុកដាក់ចំពោះអ្នកតំណាងមកពីប្រទេសបាប៊ីឡូន យ៉ាងកក់ក្តៅបំផុត ប្រហែលជាទ្រង់ មានបំណងចូលរួមជាមួយសកម្មភាពរបស់ពួកយូដាដោយការទាញចំណាប់អារម្មណ៍ ឱ្យពួកបាប៊ីឡូនចាប់អារម្មណ៍ជាមួយនិងទ្រព្យសម្បត្តិនិងអំណាចនៃអាណាចក្រនេះ ជាគ្រឹះក្នុងការធ្វើកិច្ចសហប្រតិបត្តការប្រឆាំងនិងពួកអាសស៊ើរ ។
**២០:១៤** *អ្នកទាំងនោះបាននិយាយអ្វីខ្លះ* នៅត្រង់នេះ ស្តេចហេសេគាមិនបានផ្តល់ការឆ្លើយតបចំពោះសំណួរតាមបែបការទូត ក្នុងនាមអ្នកតំណាងរបស់ប្រទេសបាប៊ីឡូនរបស់លោកហោរាអេសាយនោះទេ ។
**២០:១៧** *នាំទៅឯក្រុងបាប៊ីឡូន* មកដល់ត្រង់នេះ ការទទួលស្វាគមន៍ដល់ពួកបាប៊ីឡូននឹងធ្វើឱ្យស្តេចហេសេគាខកបំណង និងការរំពឹងទុករបស់ទ្រង់ ។ ការទោះទាយទុកមុន របស់ហោរាអេសាយអំពីការនិរទេស ពួកបាប៊ីឡូនកាលពី១១៥ឆ្នាំមុននោះវាបានកើតឡើងមែន កាលដែលគាត់ថ្លែងក្នុងពេលនោះ គឺគាត់បានផ្តោតលើពួកអាសស៊ើរជាងបាប៊ីឡូន ដែលពួកអាសស៊ើរនេះមានអំណាចលើពិភពលោកទាំមូលធ្វើឱ្យពួកយូដាមានសេចក្តីភ័យខ្លាចបំផុតនោះ ។
**២០:១៨** នៅវគ្គនេះបញ្ជាក់ថា បុត្រារបស់ស្តេចហេសេគាគឺម៉ាន៉ាសេ ត្រូវបានចាប់ខ្លួនដោយពួកអាសស៊ើរ និងបានក្លាយខ្លួនជាអ្នកទោសនៅក្រុងបាប៊ីឡូន (សូមមើល ២របា ៣៣:១១) ហើយក្រោយមក មានពួកកូនចៅនៃ

ដំណាក់នៃស្តេចស្រុកបាប៊ីឡូន[ឳ] ១៩ហេសេគាទ្រង់មានបន្ទូល
ទៅអេសាយថា ព្រះបន្ទូលនៃព្រះយេហូវ៉ាដែលបានថា
នោះជាល្អហើយ រួចមានបន្ទូលទៀថា បើមានសេចក្តីសុខ
សាន្ត និងសេចក្តីពិតនៅក្នុងគ្រាយើងនេះ តើមិនមែនជា
ការល្អទេឬ ២០រីឯដំណើរឯទៀតពីហេសេគានឹងពីអំណាច
ទ្រង់ទាំងប៉ុន្មាន ហើយដែលទ្រង់បានធ្វើស្រះទឹក[ឍ] និង
ប្រឡាយបង្ហូរទឹកចូលមក[ណ] ក្នុងទីក្រុងជាយ៉ាងណានោះ
សុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួក
ស្តេចយូដាហើយ ២១ហេសេគាក៏ផ្ទំលក់ទៅជាមួយនឹងពួក
ព្ធយុកោទ្រង់ទៅ រួចម៉ានាសេ ជាព្រះរាជបុត្រា ក៏ឡើង
សោយរាជ្យជំនួសបិតា ។

## ម៉ានាសេឡើងជាស្តេចស្រុកយូដា

*២១:១–១០ – ២របា ៣៣:១–១០*

*២១:១៧–១៨ – ២របា ៣៣:១៨–២០*

**២១** ១លុះកាលម៉ានាសេ ចាប់តាំងសោយរាជ្យឡើង
នោះទ្រង់មានព្រះជន្ម១២ឆ្នាំហើយ ទ្រង់ក៏សោយរាជ្យ
នៅក្រុងយេរូសាឡិមបាន៥៥ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជា
ហែបស៊ីបា[ក] ២ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ខ] នៅព្រះ
នេត្រព្រះយេហូវ៉ា តាមអស់ទាំងអំពើគួរស្អប់ខ្ពើម[គ]របស់
ពួកសាសន៍ដទៃ ដែលព្រះយេហូវ៉ាបានបណ្តេញពីមុខពួក
កូនចៅអ៊ីស្រាអែលចេញ ៣ដ្បិតទ្រង់បានស្អាងអស់ទាំងទី

**២០:១៨** ឳ មីក ៤:១០
**២០:២០** ឍ ២ពាវ ១៨:១៧ ណ ២សយ ៥:៨
**២១:១** ក អស ៦២:៤
**២១:២** ខ ខ.១៦ ចទ ៣:២៥ យរ ១៥:៤ គ ចទ ៩:៤ ១៨:៩ ១ពាវ ១៤:២៤ ២ពាវ ១៦:៣
**២១:៣** ឃ ១ពាវ ៣:៣ ២ពាវ ១៨:៤ ង ពច ៦:២៨ ច ចទ ១៦:២១ ឆ លប ២:១ ចទ ១៧:៣ យរ ១៩:១៣
**២១:៤** ជ អស ៦៦:៤ យរ ៤:១ ៧:៣០ ២៣:១១ ៣២:៣៤ អគ ២៣:៣៩ ឈ នក ២០:២៤ ២សយ ៧:១៣
**២១:៥** ញ ១ពាវ ៧:១២ ២ពាវ ២៣:១២

ខ្ពស់[ឃ] ដែលហេសេគា ជាព្រះបិតាទ្រង់បានបំផ្លាញចេញ
នោះឡើងវិញ ក៏ដំឡើងអាសនាថ្វាយព្រះបាល[ង] ហើយធ្វើ
រូបព្រះ[ច]ដូចជាអ័ហាប់ ជាស្តេចអ៊ីស្រាអែលបានធ្វើដែរ
ព្រមទាំងថ្វាយបង្គំ ហើយគោរពប្រតិបត្តិតាមអស់ទាំងពួក
ពលបរិវារ[ឆ] នៅលើមេឃផង ៤ទ្រង់ក៏ស្អាងអាសនា[ជ]នៅ
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ដែលព្រះយេហូវ៉ាទ្រង់បាន
មានបន្ទូលថា អញនឹងតាំងឈ្មោះអញ នៅក្រុងយេរូសាឡិម
នោះ[ឈ] ៥ទ្រង់ធ្វើសាសនាសំរាប់អស់ទាំងពួកពលបរិវារ
ដែលនៅលើមេឃ នៅក្នុងទីលានទាំង២[ញ]របស់ព្រះវិហារ
នៃព្រះយេហូវ៉ា ៦ទ្រង់ធ្វើឱ្យបុត្រាទ្រង់[ដ]ឆ្លងកាត់ភ្លើងក៏កាន់
នក្ខត្តឫក្ស[ឋ] ហើយអង្គុយធមិ៍ ព្រមទាំងប្រកបនឹងគ្រូខាប
ហើយគ្រូគាថាផង[ឌ] ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់យ៉ាង
ច្រើន នៅព្រះនេត្រព្រះយេហូវ៉ា ជាអំពើដែលនាំឱ្យ[ឍ]ព្រះ
នាមសេចក្តីក្រោធ ៧ទ្រង់ក៏យករូបព្រះឆ្លាក់[ណ] ដែលទ្រង់
បានធ្វើទៅតាំងនៅក្នុងព្រះវិហារ[ត] ដែលព្រះយេហូវ៉ាបាន
មានបន្ទូលនឹងដាវីឌ ហើយនឹងសាឡូម៉ូន ជាបុត្រទ្រង់ថា
អញនឹងតាំងឈ្មោះអញ[ថ] ឱ្យនៅក្នុងព្រះវិហារនេះ ហើយ
នៅក្នុងក្រុងយេរូសាឡិម ដែលអញបានរើសពីគ្រប់ទាំង

**២១:៦** ដ លវ ១៨:២១ ចទ ១៨:១០ ២ពាវ ៣:២៧ ឋ ចទ ១៨:១៤ ឌ លវ ១៩:៣១ **២១:៧** ណ ចទ ១៦:២១ ២ពាវ ២៣:៤ ត លវ ១៥:៣១ ថ នក ២០:២៤ ឍ នក ២០:២៤ ២សយ ៧:១៣ ២សយ ៧:១៣

ជំនួរវង្សស្តេចដាវីឌបានជាប់ទោសនៅទីនេះផងដែរ (សូមមើល ២៤:១៥ ២៥:៧ ដយ ១:៣) ។

**២០:១៩** *បន្ទូល . . . ល្អហើយ* ទោះបីស្តេចហេសេគា មានបន្ទូលយ៉ាងដូច្នេះក៏ដោយ គឺវាជាភាពអាត្មានិយមទៅវិញទេ ពីព្រោះខ្លួនព្រះអង្គមិនដែលអនុគ្រោះដល់អ្នកណាឡើយ ។ វាមើលទៅហាក់បីដូចជាប្រសើរឡើងចំពោះការទទួលយកនូវភាពបន្ទាបខ្លួន នៃការកាត់ទោសរបស់ព្រះយេហូវ៉ា (មើល ២របា ៣២:២៦) និងការដឹងគុណសម្រាប់ការធ្វើឱ្យមានសន្តិភាព ដែលព្រះយេហូវ៉ាមានសេចក្តីមេត្តាករុណា ហើយសេចក្តីនោះបានបង្ហូរដល់រាស្ត្ររបស់ព្រះអង្គ ។

**២០:២០** *ស្រះទឹកនិងប្រឡាយបង្ហូរទឹក* នេះជាស្នាព្រះហស្តរបស់ស្តេចហេសេគា ចាប់ពីគីហុន (សូមមើល ១ពាវ ១:៣៣,៣៨) និងលូបង្ហូរទឹកតាមជញ្ជាំងក្រុង ។ *សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* សូមមើលការពន្យល់ ១ពាវ ១៤:២៩ ។

**២០:២១** *ផ្ទំលក់ទៅជាមួយនឹងពួកព្ធយុកោទ្រង់* សូមមើលការពន្យល់ ១ពាវ ១:២១ ។

**២១:១** *១២ឆ្នាំ* ស្តេចម៉ានាសេ បានប្រសូតមកក្រោយពីស្តេចហេសេគា ទ្រង់មានប្រឈួនខ្លាំង (សូមមើល ២០:៦) ។ *៥៥ឆ្នាំ* ស្ថិតនៅក្នុងចន្លោះឆ្នាំ ៦៩៧–៦៤២ មុន គ.ស រួមបញ្ចូលទាំងរយៈពេល១០ឆ្នាំនៃការគ្រងរាជ្យ (៦៩៧–៦៨៦) ជាមួយនឹងបិតាទ្រង់គឺហេសេគា ស្តេចអង្គនេះហើយដែលបានគ្រងរាជ្យយូរជាងគេ ក្នុងចំណោមស្តេចនៃពួកអ៊ីស្រាអែល និងពួកយូដា ។

**២១:២** *ប្រព្រឹត្តអំពើដ៏លាមកអាក្រក់* នៅត្រង់នេះ ស្តេចម៉ានាសេបានប្តូរគោលជំនឿរបស់ហេសេគាជាបិតាទ្រង់ (មើល ១៨:៣–៥) ទៅគោរពតាមអ្វីដែលស្តេចអ័ហាសបានគោរព (មើល ១៦:៣) ។

**២១:៣** *ទីខ្ពស់ . . . ហេសេគាជាបិតាទ្រង់បានបំផ្លាញ* សូមមើលការពន្យល់ ១៨:៤ មើលបន្ថែម ២របា ៣១:១ ។ *ធ្វើរូបព្រះ* សូមមើល ១ពាវ ១៤:១៥,២៣ ១៥:១៣ ១៦:៣៣ ។ *ដូចអ័ហាប់* សំដៅដល់អំពើររបស់ស្តេចម៉ានាសេប្រព្រឹត្តដូចស្តេចអ័ហាប់នៃស្រុកយូដា (មើល ១ពាវ ១៦:៣០–៣៣) ។ *គោរពប្រតិបត្តិតាមអស់ទាំងពួកពលបរិវារនៅលើមេឃ* សូមមើលការពន្យល់ ១៧:១៦ ។

**២១:៤** *អញនឹងតាំងឈ្មោះអញ នៅក្រុងយេរូសាឡិម* សូមមើល ១ពាវ ៨:១៦ ៩:៣ និងការពន្យល់ ។

**២១:៦** *ទ្រង់ធ្វើឱ្យបុត្រាទ្រង់* សូមមើលការពន្យល់ ១៦:៣ និងមើលបន្ថែម ១៧:១៧ ធៀប ៣:២៧ និងការពន្យល់ ។ *កាន់នក្ខត្តឫក្ស ហើយអង្គុយធមិ៍* សូមមើលការពន្យល់ ១៦:១៥ ១៧:១៧ ។ *ប្រកបនឹងគ្រូខាប ហើយគ្រូគាថា* សូមមើល លវ ១៩:៣១ ចទ ១៨:១១ ១សយ ២៨:៣,៧–៩ និងការពន្យល់ ។

**២១:៧** *រូបព្រះឆ្លាក់* សូមមើលការពន្យល់ ១ពាវ ១៤:១៥ ។ *ដាវីឌ* សូមមើល ២សយ ៧:១៣ ។ *សាឡូម៉ូន* សូមមើល ១ពាវ ៩:៣ ។ *រើសពីគ្រប់ទាំងពូជអំបូរ* សូមមើល ១ពាវ ១១:១៣ ៣១:៣ ។

ពូជអំបូរសាសន៍អ៊ីស្រាអែល ឱ្យនៅជាដរាបតទៅ ៨ហើយ
នឹងមិនដែលឱ្យជើងសាសន៍អ៊ីស្រាអែល ដើរសាត់ព្រាត់
ចេញពីស្រុក ដែលអញបានឱ្យដល់ពួកព្ធយុកោគេទៀត
ឡើយ[ទ] ឱ្យតែគេបានប្រយ័ត្ននឹងកាន់តាមគ្រប់ទាំងសេចក្តី
ដែលអញបានបង្គាប់ដល់គេ ហើយតាមក្រឹត្យវិន័យទាំងអស់
ដែលម៉ូសេ[ធ] ជាអ្នកបំរើអញ បានបង្គាប់ដល់គេផង ៩តែគេ
មិនបានស្តាប់តាមសោះ ហើយម៉ានាសេក៏ល្បួងគេ ឱ្យ
ប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ន] លើសជាងសាសន៍ទាំង
ប៉ុន្មាន[ប] ដែលព្រះយេហូវ៉ាបានបំផ្លាញពីមុខពួកកូនចៅ
អ៊ីស្រាអែលចេញទៅទៀត ។
១០ព្រះយេហូវ៉ាទ្រង់បានមានបន្ទូល ដោយសារពួក
ហោរា ជាពួកអ្នកបំរើទ្រង់ថា ១១ដោយព្រោះម៉ានាសេជា
ស្តេចយូដា បានធ្វើការដែលគួរស្អប់ខ្ពើមទាំងអស់នេះ
ហើយបានប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ផ] លើសជាងគ្រប់
ទាំងអំពើរបស់សាសន៍អាម៉ូរី[ព] ដែលនៅមុខគេ ព្រមទាំង
បណ្តាលឱ្យពួកយូដាធ្វើបាបតាមរូបព្រះខ្លួនផង[ភ] ១២នោះ
បានជាព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់
មានបន្ទូលដូច្នេះថា មើល អញនឹងបណ្តាលឱ្យកើតមាន
សេចក្តីអាក្រក់[ម] នៅក្រុងយេរូសាឡិម ហើយនៅស្រុកយូដា
ដល់ម្ល៉េះបានជាអ្នកណាដែលឮនិយាយ នោះត្រចៀកគេ
ទាំងសងខាងនឹងខ្ទរខ្ទ័រ[យ] ១៣អញនឹងវាស់ក្រុងយេរូសាឡិម
ដោយខ្សែសិន[រ] របស់ក្រុងសាម៉ារី ហើយដោយកូនតឹងនៃ
ជិន្ធុវង្សអ័ហាប់ អញនឹងជូត[ល]ក្រុងយេរូសាឡិម ដូចជា
គេជូតចាន គឺទាំងជូត ហើយដាក់ផ្កាប់ផង ១៤អញនឹងបោះ

**២១:៨** ទ ២សយ ៧:១០ ធ ២ពវ ១៨:១២
**២១:៩** ន ១ពវ ១៤:៩ អគ ៥:៧ ប ចទ ៩:៤
**២១:១១** ផ ១ពវ ១៤:៩ ព លប ១៥:១៦ ភ អគ ១៨:១២
**២១:១២** ម ២ពវ ២៣:២៦ ២៤:៣ យរ ១៥:៤ អគ ៧:៥ យ ១សយ ៣:១១
**២១:១៣** រ អស ២៨:១៧ ៣៤:១១ បទ ២:៨ អម ៧:៧–៩ ល ២ពវ ២៣:២៧
**២១:១៤** វ ទដ ៧៨:៥៨–៦០ យរ ១២:៧ ២៣:៣៣ ស ២ពវ ១៩:៤ អរ ៩:៨
**២១:១៥** ហ នក ៣២:២២ ឡ យរ ២៥:៧

បង់ចោល[វ]សំណល់[ស]នៃមរដករបស់អញទៅ ព្រមទាំង
ប្រគល់គេទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ ហើយគេនឹង
ត្រឡប់ជារំពា និងរបឹប ដល់អស់ទាំងពួកខ្មាំងសត្រូវគេ ១៥គឺ
ដោយព្រោះគេបានប្រព្រឹត្តអំពើដ៏លាមកអាក្រក់[ហ] នៅ
ភ្នែកអញ ព្រមទាំងបណ្តាលឱ្យ[ឡ]អញមានសេចក្តីក្រោធ
ចាប់តាំងពីថ្ងៃដែលពួកព្ធយុកោគេ បានចេញពីស្រុក
អេស៊ីព្ទមកដរាបដល់សព្វថ្ងៃនេះ ។
១៦មួយទៀត ម៉ានាសេទ្រង់បានកំចាយឈាម ដែលឥត
ទោសជាច្រើន ទាល់តែបានធ្វើឱ្យក្រុងយេរូសាឡិមពេញ
ដោយឈាម[អ]នោះ ចាប់តាំងពីម្ខាងទៅដល់ម្ខាង នេះ
ក្រៅពីអំពើបាបដែលទ្រង់បានធ្វើ ដែលនាំឱ្យពួកយូដា[ក]ធ្វើ
តាមដោយប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះ
យេហូវ៉ា ១៧រីឯដំណើរឯទៀតពីម៉ានាសេ និងការទាំង
ប៉ុន្មានដែលទ្រង់ធ្វើ ហើយអំពើបាបដែលទ្រង់ប្រព្រឹត្តនោះ
សុទ្ធតែបានកត់ទុក ក្នុងសៀវភៅ ជាពង្សាវតាររបស់
ពួកស្តេចយូដាហើយ ១៨ម៉ានាសេក៏ផ្ទំលក់ទៅ ជាមួយនឹង
ពួកព្ធយុកោទ្រង់ទៅ ហើយគេបញ្ចុះទ្រង់ នៅក្នុងច្បារនៃ
ដំណាក់ទ្រង់[ខ] គឺក្នុងច្បាររបស់អ៊ូសា រួចអាំម៉ូន ជាព្រះរាជ
បុត្រាក៏ឡើងសោយរាជ្យជំនួសបិតា ។

**២១:១៦** អ ២ពវ ២៤:៤ យប ២២:១៤ ទដ ១០:១១ ៩៤:៧ ១០៦:៣៨ អស ២៩:១៥ ៤៧:១០ ៥៩:៣,៧ យរ ២:៣៤ ៧:៦ ១៩:៤ ២២:១៧ បទ ៤:១៣ អគ ៧:២៣ ៨:១២ ៩:៩ ២២:៣–៤ ហស ៤:២ សផ ១:១២ ក ខ.២,១១ **២១:១៨** ខ ខ.២៦ នរ ១:៥ ៧:៧

**២១:៩** *សាសន៍ទាំងប៉ុន្មាន ដែលព្រះយេហូវ៉ាបានបំផ្លាញ* សូមមើល ១ពវ ១៤:២៤ ចទ ១២:២៩–៣១ ៣១:៣ ។

**២១:១០** *ពួកហោរា ជាពួកអ្នកបំរើទ្រង់* សូមមើល ២របា ៣៣:១០,១៨ ។

**២១:១១** *លើសជាងគ្រប់ទាំងអំពើរបស់សាសន៍អាម៉ូរី* សូមមើលការពន្យល់ ១ពវ ២១:២៦ ។ *រូបព្រះ* សូមមើលការពន្យល់ លវ ២៦:៣០ ។

**២១:១២** *កើតមានសេចក្តីអាក្រក់នៅក្រុងយេរូសាឡិម* សេចក្តីនេះនៅទីបញ្ចប់បានធ្វើដោយពួកបាប៊ីឡូននៅក្នុងឆ្នាំ ៥៨៦ មុន គ.ស ក្នុងការ បំផ្លាញទីក្រុង (មើល ជិពូក ២៥) ។ *អ្នកណាដែលបានឮ . . . ខ្ទរ* សូមមើល យរ ១៩:៣ និងការពន្យល់ ។

**២១:១៣** *វាស់ . . . ខ្សែ* នៅវគ្គនេះបញ្ជាក់ថា ឧបករណ៍ទាំងពីរនេះត្រូវបានគេប្រើប្រាស់ក្នុងការសាងសង់ និងបំផ្លាញផងដែរ (សូមមើល អស ៣៤:១១ អម ៧:៧–៩,១៧) ។

**២១:១៤** *អញ នឹងបោះបង់ចោល* នេះជាការកាត់ទោសដល់ពួកគេ (សូមមើល យរ ១២:៧) គឺមិនមែនជាការលះចោលសេចក្តីសញ្ញាទេ (មើល ១សយ ១២:២២ អស ៤៣:១–៧) ។ *សំណល់នៃមរដកអញ* ស្ថិតក្នុងស្ថានភាពនៃការបំផ្លាញនៃអាណាចក្រភាគខាងជើង ពួកយូដាបានក្លាយជាពួកសំណល់នៃមរដករបស់ព្រះយេហូវ៉ា (សូមមើល ១ពវ ៨:៥១ ចទ ៤:២០ ១សយ ១០:១ ទដ ២៨:៩ និងមើលបន្ថែមការពន្យល់ ២ពវ ១៩:៤) ។

**២១:១៥** ប្រវត្តិសាស្ត្រអ៊ីស្រាអែល គឺជាប្រវត្តិនៃការរំលងនូវសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា ។ នៅក្នុងរាជ្យរបស់ស្តេចម៉ានាសេ ពែងនៃសេចក្តីក្រោធបានពោរពេញ ហើយបានជំនុំជម្រះដោយការនិរទេសពួកគេចេញពីទឹកដីសន្យា (មើលការពន្យល់ ១៧:៧–២៣) នោះមិនអាចគេចរួចបានឡើយ (មើល ២៤:១–៤) ។

**២១:១៦** *កំចាយឈាម ដែលឥតទោស* ការនេះសំដៅដល់ពួកអ្នកដែលគោរពព្រះ ហើយប្រហែលជាពួកហោរាដែលបានរងទុក្ខទោសចំពោះអំពើរំលងរបស់ស្តេចម៉ានាសេ (សូមមើល ខ.១០–១១) ។

**២១:១៧** *ដំណើរឯទៀតពីម៉ានាសេ* សូមមើល ២របា ៣៣:១២–១៩ ។ *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកយូដា* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

**២១:១៨** *ផ្ទំលក់ទៅជាមួយ និងពួកព្ធយុកោទ្រង់ទៅ* សូមមើលការពន្យល់ ១ពវ ១:២១ ។ *អ៊ូសា* សូមមើល ១៤:២១ និងបន្ថែម ២របា ២៦:១ និងការពន្យល់) ។

## អាំម៉ូនឡើងជាស្តេចស្រុកយូដា

*២១:១៩-២៤ – ២របា ៣៣:២១-២៥*

១៩កាលអាំម៉ូនចាប់តាំងសោយរាជ្យឡើង នោះទ្រង់មាន
ព្រះជន្ម២២ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុងយេរូសាឡិម
បាន២ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជា មស៊ូលេមេតបុត្រី
របស់ហារូស ជាអ្នកស្រុកយ៉ុតបា ២០ទ្រង់ប្រព្រឹត្តអំពើដ៏
លាមកអាក្រក់[គ]នៅព្រះនេត្រព្រះយេហូវ៉ាដូចជា ម៉ាន៉ាសេ
ជាព្រះបិតាទ្រង់ដែរ ២១ទ្រង់បានដើរតាមអស់ទាំងផ្លូវរបស់
ព្រះបិតា ព្រមទាំងគោរពប្រតិបត្តិ ហើយថ្វាយបង្គំ ដល់អស់
ទាំងរូបព្រះរបស់ព្រះបិតា ២២ទ្រង់បោះបង់ចោល[ឃ]ព្រះ
យេហូវ៉ាជាព្រះនៃពួកឰយុកោទ្រង់ ឥតដើរ[ង]តាមផ្លូវរបស់
ព្រះយេហូវ៉ាឡើយ ២៣ពួកអ្នកបំរើរបស់អាំម៉ូនគេគិតក្បត់
ហើយក៏ធ្វើគុត[ច]ទ្រង់ នៅក្នុងព្រះរាជដំណាក់ទៅ ២៤តែ
បណ្តាជននៅស្រុកនោះ គេសំឡាប់[ឆ]អស់អ្នកដែលបានក្បត់
នឹងស្តេចអាំម៉ូនវិញ រួចគេលើកយ៉ូសៀស[ជ]ជាព្រះរាជបុត្រា
ទ្រង់ តាំងឡើងឱ្យធ្វើជាស្តេចជំនួសព្រះបិតា ២៥រីឯដំណើរ
ឯទៀតពីអាំម៉ូន ដែលទ្រង់បានធ្វើ នោះសុទ្ធតែបានកត់ទុក
ក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដាហើយ
២៦គេបញ្ចុះសពក្នុងផ្នូររបស់ទ្រង់ នៅច្បារ[ឈ]របស់អ៊ូសា
រួចយ៉ូសៀស ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួស
បិតា ។

**២១:២០** ក ១ពវ ១៥:២៦
**២១:២២** ឃ ១សយ៨:៨ ង ១ពវ ១១:៣៣
**២១:២៣** ច ២ពវ ១២:២០
**២១:២៤** ឆ ២ពវ ១៤:៥ ជ ២របា ៣៣:២១ សផ ១:១
**២១:២៦** ឈ ខ.១៨

## គម្ពីរក្រឹត្យវិន័យត្រូវបានរកឃើញ

*២២:១-២០– ២របា ៣៤:១-២,៨-២៨*

**២២** ១រីឯកាលយ៉ូសៀស[ក]ចាប់តាំងសោយរាជ្យឡើង
នោះទ្រង់មានព្រះជន្ម៨ឆ្នាំ ព្រះមាតាព្រះនាមជា យេឌីដា
បុត្រីរបស់អ័ដាយ៉ា ជាអ្នកស្រុកបូសកាត់[ខ] ២ទ្រង់ប្រព្រឹត្ត
អំពើដ៏ត្រឹមត្រូវ[គ] នៅព្រះនេត្រព្រះយេហូវ៉ាហើយក៏ដើរ
តាមគ្រប់ទាំងផ្លូវរបស់ដាវីឌ ជាឰយុកោទ្រង់ ឥតបែរចេញ
ទៅខាងស្តាំ[ឃ] ឬខាងឆ្វេងឡើង ។
៣នៅឆ្នាំទី១៨ក្នុងរាជ្យស្តេចយ៉ូសៀស នោះទ្រង់ចាត់
សាផាន[ង]ដ៏ជាស្មៀន ជាកូនអ័សាលា ដែលជាកូនមស៊ូឡាម
ឱ្យទៅឯព្រះវិហារនៃព្រះយេហូវ៉ាដោយថា ៤ចូរឡើងទៅ
ឯហ៊ីលគីយ៉ា[ច] ជាសំដេចសង្ឃឱ្យលោកយក[ឆ]ប្រាក់ដែល គេ
បាននាំយកមកថ្វាយ ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ជាប្រាក់
ដែលពួកអ្នកឆ្មាំទ្វារបានទទួលពីពួកបណ្តាជន ៥ហើយ
ប្រគល់ទៅក្នុងអំណាច នៃពួកអ្នកដែលត្រួតមើលការក្នុង
ព្រះវិហារ នៃព្រះយេហូវ៉ាដើម្បីឱ្យគេបានចំណាយដល់
ពួកជាង ដែលធ្វើការជួសជុល[ជ]កន្លែងបាក់បែក ក្នុងព្រះ
វិហារនៃព្រះយេហូវ៉ាចុះ ៦គឺដល់ពួកជាងឈើ ពួកជាង
រៀបថ្មនឹងពួកជាងផ្សេងៗ សំរាប់នឹងទិញឈើ និងថ្មដាប់

**២២:១** ក យរ ១:២ ២៥:៣ ខ យស ១៥:៣៩
**២២:២** គ ចទ ១៧:១៩ ១ពវ ១៤:៨ ឃ ចទ ៥:៣២
**២២:៣** ង ២របា ៣៤:២០ យរ ៣៩:១៤
**២២:៤** ច អរ ៧:១ ឆ ២ពវ ១២:៤-៥
**២២:៥** ជ ២ពវ ១២:៥,១១-១៤

---

**២១:១៩** *២ឆ្នាំ* នេះស្ថិតនៅក្នុងឆ្នាំ ៦៤២-៦៤០ មុន គ.ស ។ *ស្រុកយ៉ុតបា* ស្រុកនេះអ្នកខ្លះគិតថាជាស្រុកដែលបានរៀបរាប់នៅក្នុង ជន ៣៣:៣៣-៣៤ និង ចទ ១០:៧ ។

**២១:២០** *ប្រព្រឹត្តអំពើដ៏លាមក* នៅត្រង់នេះបញ្ជាក់ថា ស្តេចអាំម៉ូនជាបុត្រារបស់ស្តេចម៉ាន៉ាសេ មិនបានផ្លាស់ប្តូការប្រព្រឹត្តអំពើលាមកដូចដែលបិតាទ្រង់ម៉ាន៉ាសេបានធ្វើរហូតដល់ទីអវសាននៃព្រះជន្មរបស់ទ្រង់នោះទេ (សូមមើល ២របា ៣៣:១២-១៩) ។ ទ្រង់បាន ស្តាឡើងវិញ នូវការគោរពរូបព្រះផ្សេងៗ ដែលម៉ាន៉ាសេបានលុបបំបាត់ ពីព្រោះរូបព្រះទាំងនោះបានលេចឡើងនៅក្នុងរជ្ជកាលស្តេចយ៉ូសៀស (មើល ២៣:៥-៧) ។

**២១:២៣** *ក្បត់ហើយធ្វើគុតទ្រង់* ការបះបោរ នៅត្រង់នេះមិនប្រាកដថាជាការជំរុញមកពីពួកអ្នកកាន់សាសនា ឬខាងនយោបាយឡើយ ។

**២១:២៤** *បណ្តាជននៅស្រុកនោះ* សំដៅលើប្រជាពលរដ្ឋទូទៅ (សូមមើល ១១:១៤,១៨ ១៤:២១ ២៣:៣០) ។

**២១:២៥** *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

**២១:២៦** *អ៊ូសា* សូមមើលការពន្យល់ ខ.១៨ ។

**២២:១** *៣១ឆ្នាំ* ស្ថិតនៅរវាងឆ្នាំទី ៦៤០-៦០៩ មុន គ.ស (មើល ការពន្យល់ ២១:៩) ។ *ស្រុកបូកាត់* ស្រុកនេះស្ថិតនៅក្នុងទឹកដីយូដា ក្បែរនឹងក្រុងឡាគីស (មើល យស ១៥:៣៩) ។

**២២:២** *ផ្លូវរបស់ដាវីឌ ជាឰយុកោទ្រង់* សូមមើលការពន្យល់ ១៨:៣ ។ យ៉ូសៀស គឺជាស្តេចតែមួយអង្គគត់ដែលគោរពដល់ព្រះយេហូវ៉ានៃសន្តតិវង្សដាវីឌ ។ ហោរាយេរេមា បានថ្លែងអំពីស្តេចអង្គនេះនៅក្នុងរជ្ជកាលរបស់ទ្រង់ (មើល យរ ១:២) ដែលគាត់បានលើកសរសើរដល់ស្តេចយ៉ូសៀសនេះផងដែរ (យរ ២២:១៥-១៦) ។ ហោរាសេផានា ក៏បានថ្លែងអំពីទ្រង់នាដើមរាជ្យរបស់ទ្រង់ផងដែរ (សផ ១:១) ។

**២២:៣** *ឆ្នាំទី១៨* គឺស្ថិតនៅក្នុងឆ្នាំទី ៦២២ មុន គ.ស ។ ស្តេចយ៉ូសៀសនៅពេលនោះមានព្រះជន្ម២៦វស្សា (មើល ខ.១) ។ ស្តេចអង្គនេះ ចាប់ផ្តើមបម្រើព្រះប្រកបដោយសេចក្តីជំនឿយ៉ាងមុតមាំនៅក្នុងព្រះជន្ម១៦វស្សា (ឆ្នាំទី៨ នៃរាជ្យរបស់ព្រះអង្គ មើល ២របា ៣៤:៣) ទ្រង់បានចាប់ផ្តើមបោសសំអាតទឹកដី ដែលមានការគោរពរូបព្រះនោះផងដែរ ។ *សាផានដ៏ជាស្មៀន* សូមមើលការពន្យល់ ២សយ ៨:១៧ ។ មនុស្សពីរនាក់បន្ថែមទៀតត្រូវបានគេលើកឡើងនៅក្នុង ២របា ៣៤:៨ ។

**២២:៤** *ហ៊ីលគីយ៉ា* គាត់ជាឪពុករបស់អ័សារា ហើយជាជីតារបស់សេរ៉ាយ៉ា ពួកសម្តេចសង្ឃ បានកាត់ទោសបំផ្លាញទីក្រុងយេរូសាឡិមដោយពួកបាប៊ីឡូន (មើល ២៥:១៨-២១) ។ ហ៊ីលគីយ៉ា គាត់ជាបិតារបស់ហោរាយេរេមា (មើល ១:១) ។ *ប្រាក់ . . . ពួកអ្នកឆ្មាំទ្វារបានទទួល* នៅក្នុងចំណុចនេះ យ៉ូសៀសបានប្រើវិធីសាស្ត្រ ដែលយ៉ូអាសបានបង្កើតឡើងក្នុងការប្រមូលប្រាក់មកជួលជុលព្រះវិហារឡើងវិញ (មើល ១២:១-១៦ ២របា ៣៤:៩) ។

**២២:៥** *ប្រគល់ទៅក្នុងអំណាច នៃពួកអ្នកដែលត្រួតមើលការ* សូមមើល ២របា ៣៤:១២-១៣ ។

ស្រាប់មកជួសជុលព្រះវិហារ[ញ] ៧ប៉ុន្តែគេមិនបានគិតប្រាក់
ដែលបានប្រគល់ទៅ ក្នុងអំណាចនៃអ្នកទាំងនោះទេ ដ្បិត
គេធ្វើការដោយស្មោះត្រង់[ដ] ។
៨ឯហ៊ីលគីយ៉ា ជាសំដេចសង្ឃ លោកប្រាប់ដល់សាផាន
ជាស្មៀនថា ខ្ញុំបានប្រទះឃើញគម្ពីរក្រិត្យវិន័យ[ឋ] នៅក្នុង
ព្រះវិហារនៃព្រះយេហូវ៉ា ហ៊ីលគីយ៉ាក៏ប្រគល់គម្ពីរនោះ
ទៅសាផាន ហើយសាផានបានអានមើល ៩រួចនាំដំណឹងវិល
ទៅវិញ ទូលស្តេចថា ពួកលោកជាអ្នកបំរើទ្រង់បានចាក់
ប្រាក់ដែលឃើញមានក្នុងព្រះវិហារ ចេញពីហឹបប្រគល់
ទៅក្នុងអំណាចនៃពួកអ្នក ដែលត្រួតមើលការក្នុងព្រះ
វិហារនៃព្រះយេហូវ៉ាហើយ ១០រួចសាផានដ៏ជាស្មៀនក៏
ទូលស្តេចថា ហ៊ីលគីយ៉ា ជាសំដេចសង្ឃបានឱ្យគម្ពីរនេះមក
ទូលបង្គំ ដូច្នេះ សាផានក៏អានមើលថ្វាយស្តេច[ឌ] ១១កាល
ស្តេចទ្រង់បានឮអស់ទាំងព្រះបន្ទូល ក្នុងគម្ពីរក្រិត្យវិន័យ
នោះ[ឍ] នោះទ្រង់ក៏ហែកព្រះពស្ត្រ ១២រួចបង្គាប់ដល់
ហ៊ីលគីយ៉ា ជាសំដេចសង្ឃ អ័ហ៊ីកាម[ណ] ជាកូនសាផាន
អ័កបោរ ជាកូនមីកាយ៉ា និងសាផាន ដ៏ជាស្មៀន ហើយ
អ័សាយ៉ា ជាអ្នកជិតស្តេចថា[ត] ១៣ចូរឱ្យអ្នករាល់គ្នាទៅទូល
សួរ[ថ]ដល់ព្រះយេហូវ៉ា ពីដំណើរព្រះបន្ទូលដែលមានក្នុង
គម្ពីរ ដែលគេបានប្រទះឃើញនេះ ឱ្យយើងនឹងពួកបណ្តា
ជនជាពួកយូដាទាំងអស់គ្នាផង ដ្បិតសេចក្តីក្រេវក្រោធ[ទ]
របស់ព្រះយេហូវ៉ា ដែលកើតឡើងទាស់នឹងយើងរាល់គ្នា
នោះខ្លាំងក្រៃលែង ពីព្រោះពួកឰយុកោយើងរាល់គ្នា មិន
បានស្តាប់តាមព្រះបន្ទូលក្នុងគម្ពីរនេះ ដើម្បីនឹងប្រព្រឹត្តតាម
គ្រប់ទាំងសេចក្តី ដែលបានបង្គាប់មកយើងរាល់គ្នាទេ ។
១៤ដូច្នេះ ហ៊ីលគីយ៉ា ជាសំដេចសង្ឃ និងអ័ហ៊ីកាមអ័កបោរ
សាផាន ហើយអ័សាយ៉ា គេក៏ទៅឯហោរាស្រី[ធ] ឈ្មោះ
ហ៊ុលដា ជាប្រពន្ធរបស់សាលូម ជាកូនធីកវ៉ា ដែលជាកូន
ហារហាស អ្នករក្សាព្រះពស្ត្រស្តេច (ហោរាស្រីនោះនៅ
ឃុំលេខ២ក្នុងក្រុងយេរូសាឡិម) ហើយគេស្នើការនឹង
នាង ១៥នាងប្រាប់គេថា ព្រះយេហូវ៉ាជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ ចូរទៅប្រាប់ដល់មនុស្ស
ដែលចាត់អ្នករាល់គ្នាមកឯខ្ញុំថា ១៦ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះថា មើល អញនឹងនាំសេចក្តីអាក្រក់[ប]មកលើ
ទីនេះ ហើយលើបណ្តាជនដែលនៅក្រុងនេះដែរ គឺគ្រប់
ទាំងសេចក្តីក្នុងគម្ពីរ[ផ] ដែលស្តេចយូដាបានទតនោះ ១៧ពី
ព្រោះគេបានបោះបង់ចោល[ព]អញ ហើយបានដុតកំញាន
ថ្វាយដល់ព្រះដទៃ ជាការដែលនាំឱ្យអញមានសេចក្តីក្រោធ
ដោយសារការទាំងប៉ុន្មានដែលដៃគេធ្វើ ដោយហេតុនោះ
បានជាសេចក្តីក្រោធរបស់អញ និងឆេះឆួលឡើងទាស់
នឹងទីនេះ ហើយនិងពន្លត់មិនបានផង ១៨តែត្រូវឱ្យអ្នក
រាល់គ្នាទូលដល់ស្តេចយូដា ដែលចាត់អ្នករាល់គ្នាឱ្យ ទៅ
ទូលសួរ[ភ]ព្រះយេហូវ៉ាថា ព្រះយេហូវ៉ាជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ ត្រង់ឯពាក្យដែលឯង
បានឮ ១៩នោះដោយព្រោះឯងមានចិត្តទន់ ហើយបាន
បន្ទាប[ម]ខ្លួននៅចំពោះព្រះយេហូវ៉ា ក្នុងកាលដែលឯងបាន
ឮសេចក្តីដែលអញបានទាយទាស់នឹងទីនេះ ហើយទាស់នឹង
បណ្តាជនដែលនៅក្រុងនេះថា គេនឹងត្រូវសាបសូន្យ[យ]
ហើយត្រឡប់ជាសេចក្តីបណ្តាសា[រ] ហើយដោយព្រោះឯង
បានហែកសំលៀកបំពាក់ ព្រមទាំងយំនៅមុខអញដូច្នេះ
នោះព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា អញក៏បានឮហើយ
២០ហេតុនេះបាន ជាអញនឹងឱ្យឯងទៅជួបជុំនឹងពួកឰយុកោ
ឯង ហើយគេនឹងបញ្ចុះឯង នៅក្នុងផ្នូរដោយសុខសាន្ត[ល]

**២២:៦** ញ ២ពវ ១២:១១–១២ **២២:៧** ដ ២ពវ ១២:១៥ **២២:៨** ឋ ចទ ២៨:៦១ ៣១:២៤ កទ ៣:១០ **២២:១០** ឌ យរ ៣៦:២១ **២២:១១** ឍ ខ.៨ **២២:១២** ណ ២ពវ ២៥:២២ យរ២៦:២៤ ៣៩:១៤ ត ១សយ ៨:១៤ **២២:១៣** ថ លប ២៥:២២ ១សយ ៩:៩ ទ ចទ ២៩:២៤–២៨ ៣១:១៧ អស ៥:២៥ ៤២:២៥ អម ២:៤ **២២:១៤** ធ នក ១៥:២០ **២២:១៦** ប ចទ ៣១:២៩ យស ២៣:១៥ យរ ៦:១៩ ១១:១១ ១៨:១១ ៣៥:១៧ ផ ដយ ៩:១១ **២២:១៧** ព ១ពវ ៩:៩ **២២:១៨** ភ យរ ២១:២ ៣៧:៣,៧ **២២:១៩** ម នក ១០:៣ អស ៥៧:១៥ ៦១:១ មីក ៦:៨ យលវ ២៦:៣១រ យរ ២៤:៩ ២៥:១៨ ២៦:៦ **២២:២០** ល អស ៤៧:១១ ៥៧:១ យរ ១៨:១១

**២២:៨** *គម្ពីរក្រិត្យវិន័យ* ការបកប្រែខ្លះ បញ្ជាក់ថាឃ្លានេះសំដៅគម្ពីរទាំងប្រាំកណ្ឌដំបូងទៅវិញ (មើល ចទ ៣១:២៤,២៦ ២របា ៣៤:១៤) ។
**២២:១១** *ហែកព្រះពស្ត្រ* សូមមើលការពន្យល់ ១៨:៣៧ យស ៧:៦ ហើយចំពោះប្រតិកម្មតបតរបស់ស្តេចយ៉ូសៀស ជាមួយនឹងយេហូគីម ត្រូវបានចានៅក្នុងក្រាំងដោយហោរាយេរេមា(សូមមើល យរ ២៥:២២) ។ ហើយវាប្រហែល ជាសេចក្តីសញ្ញាបណ្តាសានៅក្នុង លវ ២៦ និង ចទ ២៨ ដែលជាការគម្រាមកំហែងនៃការនិរទេសដ៏ខ្លាំងខ្លាមួយ ដែលបានលើកឡើងពីការដាក់គំនាប និងវិខានដល់ស្តេចយ៉ូសៀស ។
**២២:១២** *អ័ហ៊ីកាម* ម្នាក់នេះជាបិតារបស់កេដាលា ដែលក្រោយមកត្រូវបានតែតាំងឱ្យធ្វើជាអ្នកដឹកនៅស្រុកយូដា ដោយស្តេចប៊ូក្នេសា (សូមមើល ២៥:២២ យរ ៣៩:១៤) ។ អ័ហ៊ីកាម គាត់ថែមទាំងបានការពារហោរាយេរេមា ក្នុងខណៈពេលដែលជីវិតរបស់គាត់កំពុងស្ថិតក្រោមការគំរាមកំហែងរបស់យេហូគីម (មើល យរ ២៦:២៤) ។ *អ័កបោរ* មានលើកឡើងនៅក្នុង ២៤:៨ យរ ២៦:២២ ៣៦:១២ ។ *សាផាន* មើលការពន្យល់ ខ.៣ ។
**២២:១៤** *ហោរាស្រី ឈ្មោះហ៊ុលដា* សម្រាប់ពួកហោរាស្រីនៅក្នុងសញ្ញាចាស់ សូមមើលការពន្យល់ នក ១៥:២០ ពច ៤:៤ ។ *សាលូម . . . រក្សាព្រះពស្ត្រស្តេច* ម្នាក់នេះប្រហែជាសាលូម ដែលជាឱពុកមារបស់ហោរាយេរមា (សូមមើល យរ ៣២:៧) ។
**២២:១៦** *ទីនេះ* សំដៅលើក្រុងយេរូសាឡិម ។
**២២:១៩** *ឯងមានចិត្តទន់ ហើយបានបន្ទាបខ្លួន* សូមមើលខ.១១ ។
**២២:២០** *អញនឹងឱ្យឯងទៅជួបជុំនឹងពួកឰយុកោឯង* សូមមើល ការពន្យល់ ១ពវ ១:២១ ។ *គេនឹងបញ្ចុះឯង នៅក្នុងផ្នូរដោយសុខសាន្ត* ការទោះទាយនេះ សំដៅលើការសុគតមុនពេលការជំនុំជម្រះរបស់ព្រះ នៅក្នុងក្រុងយេរូសាឡិម តាមរយៈស្តេចប៊ូក្នេសានេះឯង(សូមមើល ២៣:២៩–៣០) ។

ភ្នែកឯង នឹងមិនឃើញអស់ទាំងសេចក្តីអាក្រក់ដែលអញនឹង
នាំមកលើទីនេះទេ ដូច្នេះ គេក៏នាំយកពាក្យទាំងនោះ ទៅ
ទូលដល់ស្តេចវិញ ។

## យ៉ូសៀសតាំងសញ្ញាជាថ្មី

*២៣:១-៣ – ២របា ៣៤:២៩-៣២*
*២៣:៤-២០ – ២របា ៣៤:៣-៧,៣៣*
*២៣:២១-២៣ – ២របា ៣៥:១,១៨-១៩*
*២៣:២៨-៣០ – ២របា ៣៥:២០-៣៦:១*

**២៣** 1 ស្តេចទ្រង់ក៏ចាត់គេ ឱ្យទៅប្រមូលពួកចាស់ទុំទាំង
ប៉ុន្មាននៃស្រុកយូដា និងក្រុងយេរូសាឡិមមកប្រជុំគ្នា 2 រួច
ស្តេចទ្រង់យាងឡើង ទៅឯព្រះវិហារនៃព្រះយេហូវ៉ា
ព្រមទាំងពួកស្រុកយូដាទាំងអស់ ហើយពួកអ្នកនៅក្រុង
យេរូសាឡិមទាំងប៉ុន្មាន និងពួកសង្ឃពួកហោរា ហើយនិង
អស់ទាំងបណ្តាជនទាំងតូចទាំងធំផង នោះទ្រង់ក៏អាន[ក]
មើលអស់ទាំងព្រះបន្ទូល នៅក្នុងគម្ពីរជាសេចក្តីសញ្ញា[ខ]
ដែលបានប្រទះឃើញ ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ឱ្យគេ
ស្តាប់ 3 ស្តេចទ្រង់ឈរនៅលើទីថ្កល់[គ] ចុះសញ្ញា[ឃ] និងព្រះ
យេហូវ៉ា ឱ្យបានដើរតាមព្រះយេហូវ៉ា ហើយកាន់តាម[ង]
ក្រឹត្យក្រម និងសេចក្តីបន្ទាល់ ហើយនិងបញ្ញត្តរបស់ទ្រង់
ទាំងប៉ុន្មានអស់អំពីចិត្ត ហើយអស់អំពីព្រលឹងទ្រង់ ដើម្បីនឹង
សំរេចតាមអស់ទាំងពាក្យនៃសញ្ញា ដែលកត់ទុកនៅក្នុង
គម្ពីរនេះ ហើយបណ្តាជនទាំងឡាយគេក៏ យល់ព្រមតាម
ដែរ ។
4 ស្តេចទ្រង់បង្គាប់ដល់ហ៊ីលគីយ៉ា ជាសំដេចសង្ឃនឹងពួក
សង្ឃជាបន្ទាប់ ព្រមទាំងពួកអ្នកឆ្មាំទ្វារ[ច] ឱ្យយក[ឆ]អស់ទាំង
ប្រដាប់ប្រដា ដែលបានធ្វើសំរាប់ព្រះបាល និងសំរាប់រូប
ព្រះ ហើយសំរាប់ពួកពលនៅលើមេឃ ចេញពីព្រះវិហារ
នៃព្រះយេហូវ៉ាទៅ រួចទ្រង់ដុតចោលទាំងអស់ នៅខាង
ក្រៅក្រុងយេរូសាឡិម ត្រង់វាលក្បែរជ្រោះកេដ្រុន ហើយ
ក៏យកផេះទៅឯក្រុងបេត-អែល 5 ទ្រង់បំបាត់ពួកសង្ឃនៃ
រូបព្រះ ដែលពួកស្តេចយូដាបានតាំង ឱ្យដុតកំញាន[ជ]នៅលើ
ទីខ្ពស់ទាំងប៉ុន្មាន នៅទីក្រុងនៃស្រុកយូដា ហើយនៅទីជុំវិញ
ក្រុងយេរូសាឡិមទាំងអស់ ព្រមទាំងពួកសង្ឃដែលដុត
កំញានថ្វាយដល់ព្រះបាល ព្រះអាទិត្យ ព្រះចន្ទ ចក្ររាសី
និងពួកពលបរិវ៉ារនៅលើមេឃទាំងប៉ុន្មានផង[ឈ,ញ] 6 ទ្រង់ក៏
យករូបព្រះចេញពីព្រះវិហារនៃព្រះយេហូវ៉ា ទៅដល់
ជ្រោះកេដ្រុន[ដ] ខាងក្រៅក្រុងយេរូសាឡិមដុតនៅ ទីនោះ
រួចវាយកំទេចជាផង់ធូលី[ឋ] ហើយបាចទៅលើផ្នូរ[ឌ] របស់
ពួកអ្នកស្រុក[ឍ] 7 ទ្រង់បានបំផ្លាញអស់ទាំងផ្ទះរបស់ពួក
កូនជឹង ដែលនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ាជាកន្លែង
ដែលពួកស្រីៗ[ណ]ត្បាញពិតាន សំរាប់រូបព្រះទាំងប៉ុន្មាន
ចេញ 8 រួចទ្រង់នាំពួកសង្ឃចេញ ពីទីក្រុងស្រុកយូដាទាំង
អស់ទៅធ្វើបង្អាប់ដល់អស់ទាំងទីខ្ពស់ ដែលពួកសង្ឃបានដុត

**២២:២០** វ ១ពាវ ២១:២៩
**២៣:២** ក ចទ ៣១:១១ ខ នក ២៤:៧
**២៣:៣** គ ១ពាវ ៧:១៥ ឃ ២ពាវ ១១:១២ ង ចទ ១៣:៤
**២៣:៤** ច ២ពាវ ២៥:១៨ យរ ៣៥:៤ ឆ ២ពាវ ២១:៧
**២៣:៥** ជ ២ពាវ ១៦:៤ ឈ យរ ៨:២ ញ យរ ៤៣:១៣
**២៣:៦** ដ យរ ៣១:៤០ ឋ នក ៣២:២០ ឌ ជន ១៩:១៦ ឍ យរ ២៦:២៣
**២៣:៧** ណ លប ៣៨:២១ ១ពាវ ១៤:២៤ អក ១៦:១៦

ស្តេចយ៉ូសៀស បានបញ្ជាក់យ៉ាងច្បាស់ថា ការជំនុំជម្រះចុងក្រោយនៅស្រុកយូដា និងក្រុងយេរូសាឡិម គឺមិនមែននៅក្នុងរាជ្យរបស់ព្រះអង្គឡើយ ។

**២៣:១** *ពួកចាស់ទុំ* សូមមើលការពន្យល់ ១០:១ ។

**២៣:២** *គម្ពីរជាសេចក្តីសញ្ញា* ទោះបីសេចក្តីសញ្ញានេះ ត្រូវបានលើកឡើងនៅក្នុង នក ២៤:៧ និងសេចក្តីយោងបន្ថែមទៀតនៅក្នុង នក ២០-២៣ តែវាមានលក្ខណៈត្រូវគ្នានឹងគម្ពីរចោទិយកថា និងក្រឹត្យវិន័យរបស់លោកម៉ូសេ ។ ហើយក៏មានសម្ភារៈផ្សេងៗទៀត ដែលបានលើកឡើងពីសេចក្តីនេះដូចជា ក្រាំងបានបញ្ជាក់យ៉ាងច្បាស់ពីសេចក្តីសញ្ញាបណ្តាសានៃគម្ពីរ លវជំពូក ២៦ និង ចទ ២៨ និង (ការពន្យល់ ខ.២១ ២២:៨,១១) ។

**២៣:៣** *ទីថ្កល់* សូមមើលការពន្យល់ ១១:១៤ ។ *ចុះសញ្ញា* ពាក្យនេះបញ្ជាក់ថាយ៉ូសៀស ធ្វើការផ្សះផ្សា សូមធៀប ពីដំណើរលោកម៉ូសេ (នក ២៤:៣-៨ និង ចទ) យ៉ូស្វេ (យស ២៤) សាំយ៉ូអែល (១សយ ១១:១៤-១២:២៥) និងយេហូដា (២ពាវ ១១:១៧) ។ *ដើរតាមព្រះយេហូវ៉ា* សូមមើលការពន្យល់ ១សយ ១២:១៤,២០ ។

**២៣:៤** *អស់អំពីចិត្ត ហើយអស់អំពីព្រលឹងទ្រង់ ដើម្បីនឹងសំរេច* នៅត្រង់នេះឃ្លានេះទំនងជាការអះអាងដែលបានធ្វើឡើងមានលក្ខណជាការប្តេជ្ញាដែលពួក គេម្នាក់ៗបានចូលរួមក្នុងការស្បថ ដើម្បីបង្ហាញពីភាពស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់ព្រះ ។ ការនេះ ប្រហែលជាធ្វើឡើងដោយការបង្ហាញពីអ្វី១ (យរ ៣៤:១៨) ឬ លាយលាក់អក្សរ (សូមមើល ចទ ២៧:១១-២៦) គឺមិនច្បាស់ឡើយ ។

**២៣:៥** *ឆ្មាំទ្វារ* សូមមើល ១២:៩ ។ *ព្រះបាល នឹងសំរាប់រូបព្រះ* សូមមើលការពន្យល់ អស ២២:៧ និងមើលបន្ថែម ការពន្យល់ ១៧:១៦ ។ *ជ្រោះកេដ្រុន* សូមមើលការពន្យល់ ២២:៧ និងមើលបន្ថែម ១ពាវ ១៥:១៣ និងការពន្យល់ ។ *យកផេះទៅឯក្រុងបេត-អែល* សូមមើល ខ.១៥-១៦ ។ ក្រុងបេត-អែលនេះមានទីតាំងនៅតាមព្រំប្រទល់យូដា និងទឹកដីអ៊ីស្រាអែល ដែលស្ថិតក្រោមការដឹកនាំរបស់ពួកអាសស៊ើរ ។ ជាមួយនឹងអំណាចចុះខ្សោយរបស់ពួកអាសស៊ើរ នោះយ៉ូសៀស អាចទទួលបានការពង្រីងពីឥទ្ធិពលរបស់ខ្លួននៅក្នុងអាណាចក្រភាគខាងជើង ។

**២៣:៦** *រូបព្រះ* នៅត្រង់នេះរូបព្រះជាច្រើនត្រូវបានបំផ្លាញដោយស្តេចហេសេគា (១៨:៤) ហើយកសាងឡើងវិញ ដោយស្តេចម៉ាន៉ាសេ (២១:៧) នៅពេលម៉ាន៉ាសេ បានត្រឡប់ទៅឯព្រះ នោះទំនងជាស្តេចអង្គនេះបានលះចោលរូបព្រះទាំងអស់នោះ (សូមមើល ២របា ៣៣:១៥) ហើយរូបព្រះទាំងអស់នោះត្រូវបានកសាងឡើងវិញ ជាថ្មីម្តងទៀតដោយអាំម៉ូន (មើល ២ពាវ ២១:២១ ២របា ៣៣:២២) ។ *វាយកំទេច ហើយបាចទៅលើផ្នូររបស់ពួកអ្នកស្រុក* សូមមើល យរ ២៦:២៣ ។

**២៣:៧** *ពួកកូនជឹង* សូមមើលការពន្យល់ ១ពាវ ២៤:២៤ ។

**២៣:៨** *ធ្វើបង្អាប់អស់ទាំងទីខ្ពស់* សូមមើលការពន្យល់ ១៨:៤ ។ *ក្រុងកេបា-រហូតដល់បៀរ-សេបា* ចំពោះក្រុងកេបា គឺមានទីតាំងនៅភាគខាងជើង នៃ

កំញាន ចាប់តាំងពីក្រុងកេបា[ត] រហូតដល់បៀរ–សេបា ទ្រង់
ក៏បំផ្លាញទីខ្ពស់នៃទ្វារក្រុង ដែលនៅខាងឆ្វេងដៃនៃខ្លោង
ទ្វាររបស់យ៉ូស្វេ ជាចៅហ្វាយក្រុង ៩ឯអស់ទាំងសង្ឃនៃទី
ខ្ពស់ទាំងនោះ គេមិនបានឡើងទៅឯ[ថ]អាសនាព្រះយេហូវ៉ា
នៅក្រុងយេរូសាឡិមទេ តែគេបរិភោគនំបុ័ងឥតដំបែ នៅ
ជាមួយនឹងពួកបងប្អូនគេដែរ ១០ទ្រង់ក៏ធ្វើបង្អាប់ដល់ដំបន
តូផែត[ទ] ដែលនៅក្នុងច្រកភ្នំ របស់ពួកកូនចៅហ៊ីនណំម[ធ]
ដើម្បីមិនឱ្យមានអ្នកណាធ្វើឱ្យកូនប្រុស ឬកូនស្រី[ន] ឆ្លងកាត់
ភ្លើងថ្វាយព្រះម៉ូឡុកទៀតឡើយ ១១ទ្រង់បំបាត់សេះទាំង
ប៉ុន្មាន ដែលពួកស្តេចយូដា[ប] បានថ្វាយដល់ព្រះអាទិត្យដែល
នៅមាត់ទ្វារព្រះវិហារនៃព្រះយេហូវ៉ា ក្បែរបន្ទប់របស់
នេថាន–មេលេក ជាមេដែលនៅដំបន់ក្រៅ ហើយក៏ដុតរថ
នៃព្រះអាទិត្យចោល[ផ] ១២ឯអាសនាដែលពួកស្តេចយូដាបាន
ធ្វើនៅលើដំបូល[ព]បន្ទប់ខាងលើរបស់អ័ហាស និងអាសនា
ដែលម៉ាន៉ាសេ បានធ្វើនៅក្នុងទីលានទាំង២[ភ]របស់ព្រះ
វិហារនៃព្រះយេហូវ៉ានោះ ស្តេចក៏បំបែកបំបាក់[ម]យកចេញ
ពីនោះ បោះចោលផង់កំទេចទៅក្នុងជ្រោះកេដ្រុនទៅ[យ]
១៣ហើយទីខ្ពស់ទាំងប៉ុន្មាន នៅមុខក្រុងយេរូសាឡិម គឺនៅ
ខាងស្តាំភ្នំអសោចិ៍ ដែលសាឡូនម៉ូន[រ]ជាស្តេចសាសន៍អ៊ីស្រា
អែល បានធ្វើថ្វាយដល់ព្រះអាសថារ៉ូត ជាព្រះគួរស្អប់ខ្ពើម
របស់សាសន៍ស៊ីដូន និងថ្វាយដល់ព្រះកេម៉ូស ជាព្រះគួរ
ស្អប់ខ្ពើម[ល] របស់សាសន៍ម៉ូអាប់ ហើយថ្វាយដល់ព្រះមីលកូម
ជាព្រះគួរស្អប់ខ្ពើមរបស់សាសន៍អាំម៉ូន នោះ[វ]ស្តេចទ្រង់ក៏
ធ្វើបង្អាប់ទាំងអស់ដែរ ១៤ក៏បំបាក់បំបែក[ស]អស់ទាំងបង្គោល
ដែលសំរាប់គោរព ហើយរំលំរូបព្រះ រួចយកឆ្អឹងមនុស្ស
មករាយពេញកន្លែងនោះ[ហ]។
១៥ឯអាសនា[ឡ]ដែលនៅត្រង់ក្រុងបេត–អែល និងទីខ្ពស់
ដែលយេរ៉ូបោម[អ] កូននេបាត ជាអ្នកដែលនាំឱ្យពួក
អ៊ីស្រាអែលធ្វើបាប បានធ្វើ ទ្រង់ក៏បំបែកបំបាក់អាសនា
និងទីខ្ពស់ ព្រមទាំងដុតទីខ្ពស់នោះ វាយកំទេចជាផង់ធូលី
ហើយដុតរូបព្រះផង ១៦កាលយ៉ូសៀស[ក]បែរទតទៅនោះ
ក៏ឃើញផ្នូរខ្មោចនៅភ្នំ រួចទ្រង់ចាត់គេឱ្យទៅយកឆ្អឹងពីផ្នូរ
ទាំងនោះ មកដុតលើអាសនា ធ្វើបង្អាប់ដល់អាសនានោះ
តាម[ខ]ព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលអ្នកសំណប់របស់
ព្រះបានប្រកាសទុក គឺជាអ្នកដែលបានទាយប្រាប់ពីការ
ទាំងនោះ ១៧រួចទ្រង់មានបន្ទូលសួរថា តើម៉ុងអីដែលអញ
ឃើញឯណោះ ពួកអ្នកក្រុងនោះគេទូលឆ្លើយថា នោះគឺជា
ម៉ុងនៃអ្នកសំណប់របស់ព្រះ ដែលមកពីស្រុកយូដាហើយ
បានទាយពីការទាំងប៉ុន្មាន ដែលទ្រង់បានធ្វើសិរេចដល់
អាសនាបេត–អែលនេះ ១៨ទ្រង់មានបន្ទូលថា ទុកចុះកុំឱ្យ
អ្នកណាទៅរើឆ្អឹងគាត់ឡើយ[គ] ដូច្នេះ គេក៏ទុកឆ្អឹងគាត់នៅ
ព្រមទាំងឆ្អឹងនៃហោរា[ឃ] ដែលមកពីសាម៉ារីនោះដែរ

**២៣:៨** ត យស ១៨:២៤ ១ពវ ១៥:២២ **២៣:៩** ថ អក ៤៤:១១–១៤ **២៣:១០** ទ អស ៣០:៣៣ យរ ៧:៣១,៣២ ១៩:៦ ធ យស ១៥:៨ ន លវ ១៨:២១ ចទ ១៨:១០ **២៣:១១** ប ខ.៥,១៩ នហ ៩:៣៤ យរ ៤៤:៩ ផ ចទ ៤:១៩ **២៣:១២** ព យរ ១៩:១៣ សផ ១:៥ ភ ២ពវ ២១:៥ ម ២រប ៣៣:១៥ យ ២សយ ១៥:២៣ **២៣:១៣** រ ១ពវ ១១:៧ ល ចទ ២៧:១៥ វ យរ ១១:១៣ **២៣:១៤** ស នក ២៣:២៤ ហ ជន ១៩:១៦ ទដ ៥៣:៥ **២៣:១៥** ឡ យស ៧:២ ១ពវ ១៣:១–៣ អ ១ពវ ១២:៣៣ **២៣:១៦** ក ១ពវ ១៣:២ ខ ១ពវ ១៣:៣២ **២៣:១៨** គ ១ពវ ១៣:៣១ ឃ ១ពវ ១៣:២៩

អាណាចក្រនេះ(សូមមើល ១ពវ ១៥:២២) ហើយក្រុងបៀរ–សេបាត្បូងនៃព្រំប្រទល់ខេត្តនេះ(សូមមើលការពន្យល់ ១សយ ៣:២០) ។

**២៣:៩** *បរិភោគនំបុ័ងឥតដំបែ នៅជាមួយនឹងពួកបងប្អូនគេដែរ* ទោះបីពួកគេមិនបានឡើងទៅឯអាសនាព្រះយេហូវ៉ា គឺដោយព្រោះពួកគេមានការគាំទ្រពីសំណាក់ពួកសង្ឃផ្សេងទៀតបានផ្តល់យោបលផងដែរ (មើល លវ ២:១០ ៦:១៦–១៨) និង (មើល លវ ២១:១៦–២៣)។

**២៣:១០** *តូផែត . . . ព្រះម៉ូឡុក* សូមមើលការពន្យល់ ១ពវ ១១:៥ ។ តូផែតនេះជាតំបន់មួយនៅតាមច្រកភ្នំហ៊ីណំមជាទីដែលអាសនា បានប្រើសម្រាប់ការបូជាក្មេងៗនៅទីនេះតែម្តង(មើល អស ៣០:៣៣ យរ ៧:៣១ ១៩:៥–៦ និងការពន្យល់) ។ *កូនប្រុស ឬ កូនស្រី* សូមមើល ១៧:១៧ ២១:៦ និងមើលការពន្យល់បន្ថែម ១៦:៣ ។

**២៣:១១** *សេះ . . . ថ្វាយដល់ព្រះអាទិត្យ* នៅត្រង់នេះបញ្ជាក់ថា ប្រសិនបើសេះទាំងនេះនៅរស់ នោះពួកគេត្រូវបានគេប្រើសម្រាប់ការអូសទាញរទេះដើម្បីថ្វាយដល់ព្រះអាទិត្យ ។ គំនូរសេះតូចៗ ដែលគេរកឃើញថ្មីៗនេះបង្ហាញថា ជាទីដែលពួកសាសន៍ដទៃថ្វាយបង្គំ ដែលទីនេះនៅក្រៅពីកំផែងក្រុងយេរូសាឡិមមួយទៀត ។ *នេថាន–មេលេក* ម្នាក់នេះប្រហែលជាមន្ត្រីទទួលបន្ទុកផ្នែករទេះចម្បាំង ។

**២៣:១២** *អាសនា . . . លើដំបូល* អាសនាទាំនេះគឺថ្វាយដល់ពួកពលបរិវារដែលនៅស្ថានសួគ៌(មើល យរ ១៩:១៣ សផ ១:៥) ដែលសង់ឡើងដោយស្តេចអ័ហាស (២ពវ ១៦:៣–៤ ១០–១៦) ម៉ាន៉ាសេ(២១:១៣) និង អាំម៉ូន (២១:២១) ។

**២៣:១៣** *ទីខ្ពស់ . . . សាឡូម៉ូន . . . បានធ្វើ* មើលការពន្យល់ ១ពវ ១១:៥ ។

**២៣:១៤** *យកឆ្អឹងមនុស្សមករាយពេញ កន្លែងនោះ* ការធ្វើដូច្នេះ គឺដើម្បីឱ្យទីកន្លែងនោះមានពេញដោយឆ្អឹងខ្មោច និងកខ្វក់ឡើង កុំឱ្យពួកសាសន៍ដទៃអាចបន្តការរស់នៅក្នុងពេលអនាគត (មើល ជន ១៩:១៦) ។

**២៣:១៥** *អាសនាដែលនៅត្រង់ក្រុងបេត–អែល* សូមមើល ១ពវ ១២:៣២–៣៣ ។ នៅត្រង់នេះ មិនមានអ្វីផ្សេងទៀតក្រៅពីរូបគោមាស ដែលគេបានបញ្ជូនទៅឱ្យពួកអាសស៊ើរជាសួយសាអាករ ក្នុងកំឡុងពេលដែលគេចាប់ខ្លួននិងរឹបអូសទឹកដីពួកអ៊ីស្រាអែល(សូមមើល ហស ១០:៥–៦) ។

**២៣:១៦** *ផ្នូរខ្មោច* ទីនេះជាផ្នូររបស់ពួកសង្ឃនៅក្រុងបេត–អែល(មើល ១ពវ ១៣:២) ។ *ដុតលើអាសនា ធ្វើបង្អាប់ដល់អាសនានោះ* សូមមើលការពន្យល់ ខ.៦,១៤ ។ *អ្នកសំណប់របស់ព្រះ បានប្រកាសទុក* សូមមើល ១ពវ ១៣:១–២,៣២ ។

**២៣:១៨** *ហោរា ដែលមកពីសាម៉ារី* សូមមើល ១ពវ ១៣:៣១–៣២ ។ ក្រុងសាម៉ារីនៅទីនេះ មិនត្រូវបានគេស្គាល់ថាឈ្មោះនេះនៅឡើយទេ នៅអំឡុងពេលដែលពួកហោរា បានវិលចូលមកឯក្រុងបេត–អែលនោះ (សូមមើល

១៩ ហើយអស់ទាំងវិហារនៃទីខ្ពស់ ក្នុងទីក្រុងនៃស្រុកសាម៉ារី
ទាំងប៉ុន្មាន ដែលពួកស្តេចអ៊ីស្រាអែលបានធ្វើ ជាការដែល
នាំឱ្យព្រះយេហូវ៉ាមានសេចក្តីក្រោធ នោះស្តេចយ៉ូសៀស
ក៏បំបាត់ចេញ ព្រមទាំងធ្វើដល់ទីទាំងនោះតាមគ្រប់ទាំង
សេចក្តី ដែលទ្រង់បានធ្វើនៅត្រង់បេត–អែលដែរ ២០ ទ្រង់
សំឡាប់[ង]ពួកសង្ឃទាំងអស់នៃទីខ្ពស់ ដែលនៅក្នុងស្រុកនោះ
នៅលើអាសនា ព្រមទាំងដុតឆ្អឹងខ្មោច[ច] នៅលើអាសនា
នោះផង រួចទ្រង់វិលត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ ។
២១ ស្តេចទ្រង់បង្គាប់ដល់ដណ្តាជនទាំងឡាយថា ចូរធ្វើ
បុណ្យរំលង[ឆ]ថ្វាយព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ដូច
ជាបានចែងទុកមកក្នុងគម្ពីរសញ្ញានេះចុះ[ជ] ២២ ពិតប្រាកដជា
មិនដែលមានបុណ្យរំលងយ៉ាងនេះឡើយ ចាប់តាំងពីគ្រា
ពួកចៅហ្វាយ ជាអ្នកដែលគ្រប់គ្រងលើពួកអ៊ីស្រាអែល
រហូតមកដល់គ្រាពួកស្តេចអ៊ីស្រាអែល និងពួកស្តេចយូដា
ទាំងប៉ុន្មានផង ២៣ គឺឆ្នាំទី១៨នៃរាជ្យស្តេចយ៉ូសៀសដែល
គេធ្វើបុណ្យរំលងនោះ ថ្វាយព្រះយេហូវ៉ានៅត្រង់ក្រុង
យេរូសាឡិម[ឈ] ។
២៤ មួយទៀត យ៉ូសៀសក៏បំបាត់ពួកគ្រូទាប គ្រូគាថា[ញ]
ព្រមទាំងរូបឆ្លាក់ និងព្រះទាំងប៉ុន្មាន[ដ] ហើយគ្រប់ទាំងសេច
ក្តីគួរស្អប់ខ្ពើម[ឋ] ដែលឃើញមាននៅស្រុកយូដា និងនៅ
ក្រុងយេរូសាឡិមទាំងអស់ចេញ ដើម្បីឱ្យបានសំរេចតាម
ពាក្យនៃក្រិត្យវិន័យកត់ទុកក្នុងគម្ពីរ ដែលហ៊ីលគីយ៉ា ជា
សំដេចសង្ឃ បានប្រទះឃើញក្នុងព្រះវិហារនៃព្រះយេហូវ៉ា
២៥ នៅមុនទ្រង់នោះគ្មានស្តេចណាឱ្យដូចទ្រង់ ដែលបាន
ត្រឡប់[ឌ] មកឯព្រះយេហូវ៉ា ឱ្យអស់ពីចិត្ត អស់ពីព្រលឹង
ហើយអស់ពីកំឡាំង តាមគ្រប់ទាំងក្រិត្យវិន័យរបស់លោក
ម៉ូសេឡើយ ហើយកាលក្រោយទ្រង់មក ក៏មិនដែលកើត
មានដែរ[ឍ] ។
២៦ ប៉ុន្តែព្រះយេហូវ៉ា ទ្រង់មិនបានអន់ថយពីសេចក្តី
ក្រោធដ៏ជាខ្លាំង[ណ] ដែលទ្រង់កើតមានដល់ពួកយូដា ដោយ
ព្រោះអស់ទាំងសេចក្តីចាក់រុក ដែលម៉ានាសេ[ត]បានប្រព្រឹត្ត
នឹងទ្រង់នោះឡើយ ២៧ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញ
នឹងដក[ថ]ពួកយូដាពីមុខ[ទ]អញចេញ ដូចជាអញបានដកពួក
អ៊ីស្រាអែលចេញដែរ ហើយអញនឹងបោះបង់ចោល[ធ]ក្រុង
យេរូសាឡិមនេះ ដែលអញបានរើស និងព្រះវិហារដែល
អញបានថា ឈ្មោះអញនឹងនៅទីនេះនោះផង ។
២៨ រីឯដំណើរឯទៀតពីយ៉ូសៀស និងការទាំងប៉ុន្មាន
ដែលទ្រង់ធ្វើនោះ សុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជា
ពង្សាវតាររបស់ពួកស្តេចយូដាហើយ ២៩ នៅក្នុងរាជ្យទ្រង់
នោះផារ៉ោន–នេកោ[ន]ជាស្តេចស្រុកអេស៊ីព្ទ ក៏ឡើងទៅ
ច្បាំងនឹងស្តេចស្រុកអាសស៊ើរ ត្រង់ទន្លេអ៊ើប្រាត ឯស្តេច

**២៣:២០** ង នក ២២:២០ ២ពវ ១១:១៨ ច ១ពវ ១៣:២ **២៣:២១** ឆ នក ១២:១១ ចទ ១៦:១–៨ ជ នក ២៤:៧ **២៣:២៣** ឈ នក ១២:១១ ជណ ២៨:១៦ **២៣:២៤** ញ លវ ១៩:៣១ ចទ ១៨:១១ ដ លប ៣១:១៩ ឋ ចទ ៧:២៦ ២ពវ ១៦:៣ **២៣:២៥** ឌ ១សយ ៧:៣ ឍ យរ ២២:១៥ **២៣:២៦** ណ ២ពវ ២១:៦ យរ ២៣:២០ ៣០:២៤ ត ២ពវ ២១:១២ **២៣:២៧** ថ ២ពវ ២១:១៣ ទ នក ៣៣:១៥ ២ពវ ២៤:៣ ធ យរ ២៧:១០ ៣២:៣១ **២៣:២៩** ន ខ.៣៣–៣៥ យរ ៤៦:២

១ពវ ១៣:១១) ហើយក្រុងសាម៉ារីនេះក៏ពុំទាន់មាននៅឡើយដែរ (មើល ១ពវ ១៦:២៤) ។ ហើយលើសពីនេះទៀតនោះ តំបន់នេះត្រូវបានជ្រើសទុកជាមុននៃការចូលមករស់នៅរបស់ពួកអ៊ីស្រាអែល (មើលការពន្យល់ ១៧:២៤,២៩ ១ពវ ១៣:៣២) ។

**២៣:២០** *ទ្រង់សំឡាប់ពួកសង្ឃទាំងអស់នៃទីខ្ពស់* ពួកសង្ឃទាំងនេះ មិនមែនជាពួកលេវី ដែលពួកគេបានជិទាស់ចំពោះការថ្វាយបង្គំព្រះរបស់ពួកអ៊ីស្រាអែល (សូមមើលការពន្យល់ ១៧:២៧–២៨ ៣៣–៣៤) ។ ពួកគេត្រូវបានគេប្រព្រឹត្តមកលើដូចពួកសាសន៍ដទៃក្នុងទឹកដីយូដា (មើល ខ.៥) នោះដែរ គឺផ្ទុយទៅនឹង ការប្រព្រឹត្តរបស់ស្តេចយ៉ូសៀសលើពួកសង្ឃនៅទីខ្ពស់ក្នុងទឹកដីយូដានោះវិញ (សូមមើល ខ.៨–៩) ។ ទង្វើរបស់ស្តេចយ៉ូសៀសគឺឆ្លើយតបចំពោះសេចក្តីតម្រូវដូចមានចែងនៅក្នុង ចទ ១៣,១៧:២–៧ ។

**២៣:២១** *ចូរធ្វើបុណ្យរំលង* ការរៀបរាប់ ពីការធ្វើតាមក្រឹត្យវិន័យត្រូវបានគេរកឃើញនៅក្នុង ២របា ៣៥:១–១៩ ។ *ចែងទុកមកក្នុងគម្ពីរសញ្ញានេះ* សូមមើលការពន្យល់ ខ.២ ។ ឃ្លានេះ សំដៅដល់សេចក្តីដែលមានចែងនៅក្នុង ចទ ១៦:១–៨ ដែលនិយាយអំពីបុណ្យរំលងដែលប្រារព្ធធ្វើរួមគ្នានៅឯទីបរិសុទ្ធនោះ (មើល នក ៣៥:១៥–១៧ ៣៤:២៣–២៤ លវ ២៣:៤–១៤) លើសជាងការប្រារព្ធធ្វើឡើងក្នុងរង្វង់គ្រួសារ នក ១២:១–១៤,៤៣–៤៩ ។

**២៣:២២** នៅវគ្គនេះ មើលទៅហាក់បីដូចជាការចាប់ផ្តើមដំបូងនៃបុណ្យរំលងរបស់ស្តេចយ៉ូសៀស ដែលកូនចៀមត្រូវបានសម្លាប់ដោយដៃពួកលេវីប៉ុណ្ណោះ (សូមមើល ២របា ៣៥:១–១៩ ផ្ទៀប ២របា ៣០:២–៣,១៧–២០ នៃការធ្វើបុណ្យរំលងរបស់ស្តេចហេសេគា) ។

**២៣:២៣** *ឆ្នាំទី១៨* សូមមើលការពន្យល់ ២២:៣ ។

**២៣:២៤** *រូបឆ្លាក់* សូមមើលការពន្យ់ លប ៣១:១៩ ។

**២៣:២៥** *គ្មានស្តេចណាឱ្យដូចទ្រង់* សូមមើលការពន្យល់ ១៨:៥ ។ *អស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំង* សូមមើល ចទ ៦:៥ ។

**២៣:២៦** *ទ្រង់មិនបានអន់ថយ ពីសេចក្តីក្រោធដ៏ជាខ្លាំង* ការជំនុំជម្រះដល់ពួកយូដា និង ក្រុងយេរូសាឡិម បានពន្យាពេល ប៉ុន្តែគឺមិនបានលើកលែងដោយព្រោះតែកំណែទម្រង់របស់យ៉ូសៀសនោះដែរ (សូមមើលការពន្យល់ ២១:១៥ ២២:២០) ។

**២៣:២៧** *ដូចជាអញបានដកពួកអ៊ីស្រាអែល* សូមមើល ១៧:១៨–២៣ ។ *ក្រុងយេរូសាឡិម នេះដែលអញបានរើស* សូមមើល ២១:៤,៧,១៣ ។ *ព្រះវិហារ ដែលអញបានថា ឈ្មោះអញនឹងបាននៅទីនោះ* សូមមើលការពន្យល់ ១ពវ ៨:១៦ ។

**២៣:២៨** *កត់ទុកក្នុងសៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដា* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

**២៣:២៩** *ផារ៉ោន–នេកោ ជាស្តេចស្រុកអេស៊ីព្ទ* ស្តេចអង្គនេះបានគ្រប់គ្រងនៅក្នុងឆ្នាំទី ៦១០–៥៩៥ មុន គ.ស ។

យ៉ូសៀសទ្រង់ក៏ចេញទៅស្ទាក់ផ្លូវ តែកាលផារ៉ោន–នេកោ
បានឃើញ នោះក៏សំឡាប់ទ្រង់នៅត្រង់មេគីដោទៅ[ប] ៣០ពួក
អ្នកបំរើទ្រង់ ក៏ដឹកសពទ្រង់ក្នុងរទេះ[ផ]ពីមេគីដោ ទៅដល់
ក្រុងយេរូសាឡិមវិញ បញ្ចុះនៅក្នុងផ្នូររបស់ទ្រង់ រួចពួក
អ្នកស្រុក គេលើកយ៉ូអាហាស ជាព្រះរាជបុត្រារបស់
យ៉ូសៀសចាក់ប្រេងតាំងឡើយជាស្តេចជំនួសបិតា ។

## យ៉ូអាហាសឡើងជាស្តេចស្រុកយូដា

*២៣:៣១–៣៤ – ២រប ៣៦:២–៤*

៣១លុះកាលយ៉ូអាហាស[ព]ចាប់តាំងសោយរាជ្យឡើយ
នោះទ្រង់មានព្រះជន្ម២៣ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន៣ខែ ព្រះមាតាព្រះនាមជាហាមូថាល[ភ]
បុត្រីយេរេមី ជាអ្នកស្រុកលីបណា ៣២ទ្រង់ប្រព្រឹត្តអំពើដ៏
លាមកអាក្រក់[ម] នៅព្រះនេត្រព្រះយេហូវ៉ាតាមគ្រប់ទាំង
អំពើ ដែលពួកព្ធយុកោទ្រង់បានប្រព្រឹត្តដែរ ៣៣ឯផារ៉ោន–
នេកោក៏ចាប់ចងទ្រង់ នៅត្រង់ក្រុងរីបឡា[យ] ក្នុងស្រុក
ហាម៉ាត[រ] ដើម្បីមិនឱ្យទ្រង់សោយរាជ្យនៅក្រុងយេរូសាឡិម
ទៀត ក៏ដំរូវឱ្យស្រុកនោះត្រូវបង់សួយជាប្រាក់១០០ហាប
និងមាស១ហាប ៣៤រួចផារ៉ោន–នេកោ ទ្រង់លើក
អេលាគីម[ល] ជាបុត្រយ៉ូសៀស តាំងឡើងជាស្តេចជំនួសយ៉ូ
សៀស តាំងឡើងជាស្តេចជំនួសយ៉ូសៀស ជាព្រះបិតា
ហើយផ្លាស់ព្រះនាមទ្រង់ទៅជា យេហូយ៉ាគីម វិញទ្រង់ក៏នាំ
យកយ៉ូអាហាស ទៅនៅស្រុកអេស៊ីព្ទ ហើយយ៉ូអាហាស
សុគតនៅស្រុកនោះ[វ] ៣៥ឯយេហូយ៉ាគីមទ្រង់ក៏ថ្វាយប្រាក់
និងមាស នោះដល់ផារ៉ោន តែទ្រង់ទារពន្ធអាករពីពួកអ្នក
ស្រុក ដើម្បីឱ្យបានប្រាក់នោះថ្វាយ តាមបង្គាប់ផារ៉ោន
ទ្រង់បានទារ មាសប្រាក់នោះពីពួកអ្នកស្រុកគ្រប់គ្នាតាមពន្ធ
រៀងខ្លួន ដើម្បីនឹងថ្វាយដល់ផារ៉ោន–នេកោ[ស]។

## យេហូយ៉ាគីមឡើងជាស្តេចស្រុកយូដា

*២៣:៣៦–២៤:៦ – ២រប ៣៦:៥–៨*

៣៦លុះកាលយេហូយ៉ាគីម[ហ]ចាប់តាំងសោយរាជ្យឡើង
នោះទ្រង់ មានព្រះជន្ម២៥ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន១១ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជាសេប៊ីដា
បុត្រីពេដាយ៉ា ជាអ្នកស្រុករូម៉ា ៣៧ទ្រង់ប្រព្រឹត្តអំពើដ៏លាមក
អាក្រក់[ឡ] នៅព្រះនេត្រព្រះយេហូវ៉ា តាមគ្រប់ទាំងអំពើ
ដែលពួកព្ធយុកោទ្រង់បានប្រព្រឹត្តដែរ ។

**២៣:២៩** ប ២ពវ ៩:២៧
**២៣:៣០** ផ ២ពវ ៩:២៨
**២៣:៣១** ព ១រប ៣:១៥ យរ ២២:១១ ភ ២ពវ ២៤:១៨
**២៣:៣២** ម ១ពវ ១៥:២៦
**២៣:៣៣** យ ជន ៣៤:១១ រ ១ពវ ៨:៦៥
**២៣:៣៤** ល ២ពវ ២៤:៦ ១រប ៣:១៥ ២រប ៣៦:៥–៨ យរ ១:៣ វ យរ ២២:១២
**២៣:៣៥** ស យរ ២:១៦ **២៣:៣៦** ហ យរ ២៦:១ **២៣:៣៧** ឡ ១ពវ ១៥:២៦

---

**២៣:៣០** *បញ្ចុះនៅក្នុងផ្នូររបស់ទ្រង់* សូមមើល ២រប ៣៥:២៤–២៥ ។ *ពួកអ្នកស្រុក* សូមមើល ការពន្យល់ ២១:២៤ ។ *យ៉ូអាហាស ជាព្រះរាជបុត្រារបស់យ៉ូសៀស* ព្រះនាមពិតរបស់ស្តេចអង្គនេះ គឺសាឡូម (សូមមើល ៣:១៥ យរ ២២:១១) ដែលព្រះនាមនេះបានប្តូរទៅជា អ័ហាស៊ីយ៉ានៅក្នុងរាជ្យរបស់ព្រះអង្គ ។

**២៣:៣១** *៣ខែ* ស្ថិតនៅឆ្នាំទី៦០៩ មុន គ.ស ។ *យេរេមី* ម្នាក់នេះមិនមែនជាហោរាទេ (សូមមើល យរ ១:១) ។ *ស្រុកលីបណា* សូមមើលការពន្យល់ ៨:២២ ។

**២៣:៣២** *ទ្រង់ប្រព្រឹត្តអំពើដ៏លាមក* សូមមើល ១៦:៣ ២១:២,២១ អគ ១៩:៣ និងការពន្យល់ ។

**២៣:៣៣** *ក្រុងរីបឡា* នេះបញ្ជាក់ថាញ ទាំងការឆបោក និងការបើកឱ្យឃើញពីការគម្រាមគំហែងរបស់ពួកអេស៊ីព្ទ គឺអាចចាប់ខ្លួនយ៉ូអាហាស និងថ្វាយសួយសាអាករដល់ពួកយូដា (សូមមើល ២រប ៣៦:៣) ។ យ៉ូអាហាសបានជាប់គុកនៅក្នុងទីបញ្ជាការដ្ឋាននេកោ ដែលបានបង្កើតឡើងនៅក្នុងក្រុងរីបឡានៃទន្លេអូរុន ។ ក្រោយមកទៀត ស្តេចនេប៊ូក្នេសា បានកសាងទីបញ្ជា ដ្ឋាននៅត្រង់តំបន់នេះផងដែរ (សូមមើល ២៥:៦,២០) ។

**២៣:៣៤** *អេលាគីមជាបុត្រយ៉ូសៀស* អេលាគីម គឺជាបងច្បងរបស់យ៉ូអាហាស (សូមមើល ១រប ៣:១៥) ។ នៅត្រង់នេះ ប្រហែលជាអេលាគីមនេះបានបដិសេធអ្នកស្នងរាជ្យបន្តពីយ៉ូសៀស ដោយព្រោះតែទំនោនយោបាយរបស់ពួកអេស៊ីព្ទ ។ *ផ្លាស់ប្តូព្រះនាមទ្រង់ទៅជា យេហូគីម* នេះបញ្ជាក់ថា នាមទាំងពីរនេះគឺស្រដៀងគ្នា (អេលាគីម មានន័យថា" ព្រះអទិករ" ហើយយេហូយ៉ាគីមមានន័យថា "ព្រះយេហូវ៉ា ទ្រង់ជាព្រះអទិករ") ។ ម្យ៉ាងវិញទៀត ការផ្លាស់ប្តូរនាមឈ្មោះនេះគឺក្នុង បំណងចង់បញ្ជាក់អំពីទង្វើរបស់យេហូគីមនេះជាហប្ញទ័យរបស់ព្រះយេហូវ៉ា ជាព្រះនៃពួកយូដា (សូមមើល ១៨:២៥ ២រប ៣៥:២១) ។ ក្នុងករណីផ្សេងទៀត គឺយេហូគីមនេះជាបុគ្គលសំខាន់នៅក្នុងចក្រភពឯកោផងដែរ ។ *យ៉ូអាហាសទៅនៅស្រុកអេស៊ីព្ទ ហើយយ៉ូអាហាសសុគតនៅស្រុកនោះ* សូមមើល ២រប ៣៦:៤ យរ ២២:១០–១២ ។

**២៣:៣៥** *ទ្រង់ទារពន្ធអាករពីពួកអ្នកស្រុក* សួយសាអាករសម្រាប់នេកោត្រូវបានប្រមូលដោយស្មើៗគ្នាទៅលើគ្រប់មនុស្ស ដែលបានគាំទ្រដោយរាជ្យស្តេចយ៉ូហាអា (មើល ខ.៣០ និងការពន្យល់ ២១:២៤) ។ មណាហិម ទ្រង់បានប្រើវិធីសាស្ត្រនេះក្នុងការទាប្រាក់ពីពួកបណ្តាជននោះផងដែរ (សូមមើល ១៥:២០) ។

**២៣:៣៦** *១១ឆ្នាំ* នេះគឺស្ថិតនៅចន្លោះឆ្នាំទី ៦០៩–៥៩៨ មុន គ.ស ។

**២៣:៣៧** *ប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា* នៅត្រង់នេះយេហូគីមមាននាទីជាអ្នកទទួលខុសត្រូវលើការសំឡាប់ហោរាអ៊ូរីយ៉ា ដែលនៅក្រុងគារយ៉ាត់–យារីម (សូមមើល យរ ២៦:២០–២៤) និងការដឹកនាំរបស់គាត់ត្រូវបានជម្រុញឱ្យមានភាពមិនស្មោះត្រង់ ការគាបសង្កត់ និងភាពគ្មានយុត្តិធម៌ (សូមមើល យរ ២២:១៣–១៩) ។ គាត់បានត្រឡប់មកថ្វាយព្រះវិញ តាមរយៈហោរាយេរេមា ក្នុងកាលដែលលោកបានបដិសេធព្រះ (សូមមើល យរ ជំពូក៣៦) ។ *ពួកព្ធយុកោទ្រង់* នេះគឺម៉ាន៉ាសេ (មើល ២១:១–១៨) និង អាំម៉ូន (២១:១៩–២៦) ។

**២៤** ១នៅរាជ្យទ្រង់ នោះនេប៊ូក្នេសា[ក] ជាស្តេចស្រុក
បាប៊ីឡូនក៏ឡើងមក ហើយយេហូយ៉ាគីមក៏ចុះចូលជាអ្នក
បំរើទ្រង់អស់៣ឆ្នាំ ក្រោយមកបែរជាបះបោរ[ខ]នឹងទ្រង់វិញ
២គ្រានោះព្រះយេហូវ៉ាទ្រង់ចាត់ប្រើពួកកងសាសន៍ ខាល់
ដេ[ឃ] សាសន៍ស៊ីរី[ង] សាសន៍ម៉ូអាប់ និងពួកកូនចៅអាំម៉ូន[ច]
ឱ្យមកទាស់នឹងទ្រង់ ដើម្បីនឹងបំផ្លាញ[ឆ]ស្រុកយូដា ទៅតាម
សេចក្តីដែលព្រះយេហូវ៉ាបានមានបន្ទូល ដោយសារពួក
ហោរា ជាអ្នកបំរើទ្រង់[ជ] ៣ពិតប្រាកដជាសេចក្តីទាំងនោះ
កើតមកដល់ស្រុកយូដា ដោយបង្គាប់នៃព្រះយេហូវ៉ា[ឈ]
ដើម្បីនឹងដកគេ ពីចំពោះ[ញ]ទ្រង់ចេញ ដោយព្រោះអំពើ
បាបរបស់ម៉ាន៉ាសេ[ដ] ដែលទ្រង់បានប្រព្រឹត្តទាំងប៉ុន្មាន
៤ហើយដោយព្រោះឈាម[ឋ]ឥតទោស ដែលទ្រង់កំចាយផង
ដ្បិតទ្រង់បានធ្វើឱ្យក្រុងយេរូសាឡិម ពេញដោយឈាម
ដែលឥតទោសនោះ ហើយព្រះយេហូវ៉ាទ្រង់មិនព្រមអត់
ទោសឱ្យទេ[ឌ] ៥រីឯដំណើរឯទៀតពីយេហ៊ូយ៉ាគិម[ឍ] និងការ
ទាំងប៉ុន្មានដែលទ្រង់បានធ្វើ នោះសុទ្ធតែបានកត់ទុកក្នុង
សៀវភៅ ជាពង្សាវតាររបស់ពួកស្តេចយូដាស្រេចហើយ
៦យេហ៊ូយ៉ាគីមក៏ផ្ទំលក់ទៅ[ណ] ជាមួយនឹងពួកឰយុកោទ្រង់
រួចយ៉ូយ៉ាគីន[ត] ជាព្រះរាជ្យបុត្រា ក៏ឡើងសោយរាជ្យជំនួស
ព្រះបិតា ៧ឯស្តេចស្រុកអេស៊ីព្ទ[ថ] ទ្រង់មិនបានចេញពីស្រុក
ទ្រង់មកទៀតទេ ដ្បិតស្តេចស្រុកបាប៊ីឡូន[ទ] ទ្រង់បានវាយ
យកស្រុករបស់ស្តេចអេស៊ីព្ទទាំងប៉ុន្មាន ចាប់តាំងពីជ្រោះ
ស្រុកអេស៊ីព្ទ រហូតដល់ទន្លេអ៊ើប្រាតហើយ ។

## យ៉ូយ៉ាគីនឡើងជាស្តេចស្រុកយូដា

*២៤:៨–១៧ – ២រប ៣៦:៩–១០*

៨កាលយ៉ូយ៉ាគីន[ធ]ចាប់តាំងសោយរាជ្យឡើង នោះទ្រង់
មានព្រះជន្ម១៨ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុងយេរូ–
សាឡិមបាន៣ខែ ព្រះមាតាទ្រង់ព្រះនាមជានេហ៊ូសថា[ន]

**២៤:១** ក ខ.១០ ២ពវ ២៥:១១ អរ ៥:១២ យរ ៤:៧ ២៥:១,៩ ៣៩:១ ៤០:១ ៥០:១៧ ៥២:១៥ អគ ៣២:២ ដយ ១:១ ៧:៤ ខ យរ ៣៥:១១ គ ២ពវ ១៨:៧ **២៤:២** ឃ យរ ៥:១៥ ហព ១:៦ ង យរ ៣៥:១១ ច ២ពវ ៥:២ ឆ អស ២៨:១៨–១៩ ជ យរ ១២:៧–៩ ២៥:១ ២៦:១ ៣៦:១ អគ ២៣:២៣ ដយ ១:២ **២៤:៣** ឈ ២ពវ ១៨:២៥ ញ ២ពវ ១២:២៣ ដ ១ពវ ១៤:៩ ២ពវ ២១:១២ យរ ១៥:៤ **២៤:៤** ឋ ២ពវ ២១:១៦ យរ ២២:៣ ឌ នក ២៣:២១ បទ ៣:៤២ **២៤:៥** ឍ យរ ២២:១៨–១៩ **២៤:៦** ណ យរ ២២:១៩ ៣៦:៣០ ត ១រប ៣:១៦ យរ ២២:២៤,២៨ អគ ១៩:១ **២៤:៧** ថ លប ១៥:១៨ ២ពវ ១៨:២១ យរ ៤៦:២៥ ទ យរ ១:១៤ ២៥:៩ ៤៦:២៤ **២៤:៨** ធ ១រប ៣:១៦ យរ ២២:២៤ ៣៧:១ ន ខ.១៥ យរ ១៣:១៨ ២២:២៦ ២៩:២

**២៤:១** *នេប៊ូក្នេសា* ពាក្យថា (នេប៊ូមានន័យថា "ព្រះ" ថែរក្សាការពារកូនចៅ និងដែនដី) នេប៊ូក្នេសានេះជាបុត្ររបស់ណាបូប៉ូឡាសា (Nabopolassar) ជាស្តេចដែលមានអំណាចខ្លាំងខ្លាបំផុតនៅក្នុងចក្រភព បាប៊ីឡូន (៦១២–៥៣៩ មុន គ.ស) ដែលព្រះអង្គបានគ្រងរាជ្យចាប់តាំងពីឆ្នាំ ៦០៥–៥៦២ មុន គ.ស (មើល ដយ ជំពូក ១–៤) ។ *បះបោរ* ក្នុងឆ្នាំ ៦០៥ នៃរាជ្យរបស់ស្តេចប៊ូក្នេសា ដែលព្រះអង្គកំពុងមានអំណាច ហើយជាមេបញ្ជាការនៃកងទ័ពបាប៊ីឡូន ព្រះអង្គបានវាយកំទេចស្តេចផារោន–នេកោ និងពួកអេស៊ីព្ទនៅឯសមរភូមិនៃទឹកដីក្រុងកើកេមីស ហើយម្តងទៀតនៅឯស្រុកហាម៉ាត (សូមមើល ២៣:២៩ យរ ២៦:២) ។ ជ័យជម្នះដ៏ធំធេងនេះជាប់ទាក់ទិនទៅនឹងសម្ព័ន្ធភាពនយោបាយនៃប្រទេសនៅភាគខាងលិចឆ្នេរសមុទ្រមេឌីទែរ៉ាណេ ។ ដោយយោលទៅលើកំណត់ត្រារបស់ពួកបាប៊ីឡូន បានបញ្ជាក់ថាស្តេចប៊ូក្នេសាបានចុះទៅវាយទន្ទ្រាននៅគ្រប់សមរភូមិនៃទឹកដីសាសន៍ហេតសាសន៍យូដា ដែលក្នុងនោះលោកដានីយ៉ែលក៏ស្ថិតនៅក្នុងចំណោមពួកយូដាដែលត្រូវបានចាប់ខ្លួនជាឈ្លើយនៅក្នុងពេលនោះផងដែរ (សូមមើល ដយ ១:១) ។ ប្រហែលជានៅដើមខែកញ្ញា ឆ្នាំ៦០៥ មុន គ.ស ស្តេចប៊ូក្នេសាបានឡើងកាន់អំណាចនៅក្នុងអាណាចក្របាប៊ីឡូនដែលបិតា របស់ទ្រង់បានសុគតទៅនោះ ។ *៣ឆ្នាំ* រយៈពេលនេះស្ថិតនៅក្នុងចន្លោះឆ្នាំទី ៦០៤–៦០២ មុន គ.ស ។ នៅក្នុងឆ្នាំទី៦០៤ ស្តេចប៊ូក្នេសា បានវិលចូលទៅ ភាគខាងលិចដោយនាំមកជាមួយនូវសួយសាអាករ ចេញពីទឹកដីនៃសាសន៍ហេត ហើយក្នុងនោះស្តេចយេហូគីមពិតជា នៅក្នុងចំណោមនោះផងដែរ ។ នៅក្នុងឆ្នាំទី ៦០១ ស្តេចប៊ូក្នេសាបានដឹកនាំទ័ពវាយចូលក្នុងទឹកដីអេស៊ីព្ទម្តងទៀត តែត្រូវបានពួកអេស៊ីព្ទតទល់យ៉ាងមុតមាំមិនបានឱ្យផែនការនេះ សម្រេចឡើយ ។ ការនេះបានធ្វើឱ្យស្តេចយេហូគីម មានកម្លាំងចិត្តយ៉ាងខ្លាំងក្នុងការរំលោភបំពាន តែលោកយេរេមាបានព្រមានដល់ទ្រង់ពីការទាំងអស់នេះមិនឱ្យប្រព្រឹត្តតទៅទៀត (សូមមើល យរ ២៧:៩–១១) ។

**២៤:២** នៅក្នុងវគ្គនេះបង្ហាញពីសកម្មភាពដែលពួកស្តេចទាំអម្បាម្ហាន មានសកម្មភាពតទល់នឹងការរំលោភបំពានរបស់ស្តេចយេហូគីម ។ ពួកគេបានបញ្ជូនកងទ័ពបាប៊ីឡូនឱ្យនៅប្រចាំនៃទឹកដីស៊ីរី និងពួកកងទ័ពដែលស្មោះត្រង់ផ្សេងទៀត ឱ្យចុះទៅយាមល្បាតដើម្បីតទល់នឹងការបះបោរពួកយូដា ។

**២៤:៣** *អំពើបាបរបស់ម៉ាន៉ាសេ* សូមមើល ២១:១១–១២ ២៣:២៦–២៧ យរ ១៥:៣–៤ ។

**២៤:៤** *ឈាមឥតទោស* សូមមើលការពន្យល់ ២១:១៦ ។ *មិនព្រមអត់ទោសឱ្យ* សូមមើល ការពន្យល់ ១ពវ ១៤:២៩ ។

**២៤:៥** *កត់ទុកក្នុងសៀវភៅ ជាពង្សវតាររបស់ពួកយូដា* សូមមើលការពន្យល់ ១ពវ ១៤:២៩ ។

**២៤:៦** *ផ្ទំលក់ទៅ ជាមួយនឹងពួកឰយុកោទ្រង់* សូមមើលការពន្យល់ ១ពវ ១:២១ ។ ស្តេចយេហូគីម បានសុគតភ្លាមៗ មុនពេលដែលក្រុងយេរូសាឡិមបានធ្លាក់នៅក្នុងកណ្តាប់ដៃរបស់ពួកបាប៊ីឡូន (សូមមើល ខ.៨–១២) ។ នៅត្រង់នេះ មិនដឹងថាតើការសុគតរបស់ទ្រង់នោះ បណ្តាមកពីគ្រោះធម្មជាតិ ឬជាឆាកនយោបាយឡើយ ពីព្រោះគ្មានការបញ្ជាក់ពីហេតុការនេះទេ ។

**២៤:៧** *ស្តេចស្រុកអេស៊ីព ទ្រង់មិនបានចេញពីស្រុកទ្រង់ទៀត* នេះបញ្ជាក់ថាដោយព្រោះតែស្តេចស្រុកអេស៊ីព្ទបានវាយផ្តួលយកស្រុកកើកេមីស (សូមមើល យរ ៤៦:២) នៅក្នុងឆ្នាំ ៦០៥ មុន គ.ស ហើយ វាបានពន្យល់ថាហេតុអ្វីបានជា ស្តេចយេហូគីមមិនបានទទួលជំនួយអ្វីសោះពីពួកអេស៊ីព្ទ នៅក្នុងការបោះប្រឆាំងនឹងពួកបាប៊ីឡូននោះ ។

**២៤:៨** *៣ខែ* នៅត្រង់នេះ ដោយយោងទៅលើកំណត់ត្រារបស់ពួកបាប៊ីឡូន បានបញ្ជាក់ពីការវាយយកបានក្រុងយេរូសាឡិម ដោយស្តេចប៊ូក្នេសានៅក្នុងខែមីនាឆ្នាំ ៥៩៧ មុន គ.ស ។ នេះមានន័យថា រយៈពេល៣ខែ និង១០ ថ្ងៃនៃការគ្រងរាជ្យរបស់ស្តេចយ៉ូយ៉ាគីន ចាប់ផ្តើមនៅក្នុងខែធ្នូរឆ្នាំ ៥៩៨ មុន គ.ស ។

បុត្រីអែលណាថាន ជាអ្នកក្រុងយេរូសាឡិម ៩ទ្រង់ប្រព្រឹត្ត
អំពើក៏លាមកអាក្រក់[ប] នៅព្រះនេត្រព្រះយេហូវ៉ាតាមគ្រប់
ទាំងអំពើ ដែលព្រះបិតាទ្រង់បានប្រព្រឹត្តដែរ ។
១០នៅគ្រានោះ ពួកពលទ័ពរបស់នេប៊ូក្នេសា[ផ] ជា
ស្ដេចស្រុកបាប៊ីឡូន ក៏ឡើងមកឡោមព័ទ្ធច្បាំងនឹងក្រុង
យេរូសាឡិម ១១ឯនេប៊ូក្នេសា ជាស្ដេចបាប៊ីឡូនទ្រង់ក៏ឡើង
មកដល់ទីក្រុង កំពុងដែលពួកពលទ័ពទ្រង់ឡោមព័ទ្ធនោះ
១២ហើយយ៉ូយ៉ាគីន ជាស្ដេចយូដា ព្រមទាំងព្រះមាតា ពួក
ជំនិត ពួកអ្នកធំ និងពួកមេទ័ពរបស់ទ្រង់ផងក៏ចេញទៅ[ព]
គាល់ស្ដេចបាប៊ីឡូន គឺនៅឆ្នាំទី៨ក្នុងរាជ្យទ្រង់នោះឯង
ដែលស្ដេចបាប៊ីឡូនចាប់យកបាន ១៣នេប៊ូក្នេសាកំនាំយក
អស់ទាំងទ្រព្យវិសេស[ភ] ពីព្រះវិហារនៃព្រះយេហូវ៉ា ហើយ
ពីព្រះរាជវាំងចេញមក ក៏យកអស់ទាំងគ្រឿងប្រដាប់
មាស[ម] ដែលសាឡូម៉ូន[យ] ជាស្ដេចអ៊ីស្រាអែលបានធ្វើនៅក្នុង
ព្រះវិហារនៃព្រះយេហូវ៉ាកាត់ជាដុំៗ ដូចជាព្រះយេហូវ៉ា
បានមានបន្ទូល[រ] ១៤ទ្រង់ក៏ដឹកនាំពួកក្រុងយេរូសាឡិមទាំង
អស់ទៅ[ល] ព្រមទាំងពួកអ្នកធំ[វ] និងពួកខ្លាំពូកែ ដែលមាន
ចិត្តក្លាហានទៅផង ឯពួកឈ្លើយទាំងអស់មានចំនួន១ម៉ឺន
នាក់ រួមទាំងពួករចនា និងពួកជាងទាំងអស់ដែរសល់
នៅតែមនុស្សទាល់ក្របំផុត[ស] នៅក្នុងស្រុកប៉ុណ្ណោះ ១៥ទ្រង់
ក៏ដឹកនាំយ៉ូយ៉ាគីន[ហ] ព្រមទាំងព្រះមាតា[ឡ] និងភរិយា ហើយ
ពួកមេទ័ព និងពួកអ្នកធំ[អ]ក្នុងស្រុកនោះផង ទៅឯស្រុក
បាប៊ីឡូន គឺទ្រង់នាំគេចេញពីក្រុងយេរូសាឡិម ទៅជា
ឈ្លើយដល់ស្រុកបាប៊ីឡូននោះ ១៦ឯអស់ទាំងមនុស្សខ្លាំង
ពូកែ ចំនួនជា៧ពាន់នាក់ និងពួករចនា ហើយពួកជាង
ចំនួនជា១ពាន់នាក់ ដែលសុទ្ធតែជាមនុស្ស ពេញកំឡាំល្មម
ច្បាំងបាន នោះស្ដេចបាប៊ីឡូនបាននាំទៅជាឈ្លើយ ដល់
ស្រុកបាប៊ីឡូនទាំងអស់[ក] ១៧រួចស្ដេចបាប៊ីឡូនទ្រង់លើក
ម៉ាថានា ជាមារបស់យ៉ូយ៉ាគីន តាំងឡើងឱ្យបានសោយ
រាជ្យជំនួស ក៏ផ្លាស់ព្រះនាមទៅជាសេដេគា[ខ] ។

## សេដេគាឡើងជាស្ដេចស្រុកយូដា

*២៤:១៨–២០ – ២របា ៣៦:១១–១៦ យរ ៥២:១–៣*

១៨កាលសេដេគា[គ]ចាប់តាំងសោយរាជ្យឡើង នោះ
ទ្រង់មានព្រះជន្ម២១ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន១១ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជាហាមូ–
ថាល[ឃ] បុត្រីយេរេមី ជាអ្នកស្រុកលិបណា ១៩ទ្រង់ប្រព្រឹត្ត
អំពើក៏លាមកអាក្រក់[ង] នៅព្រះនេត្រព្រះយេហូវ៉ា តាមគ្រប់
ទាំងអំពើដែលយេហូយ៉ាគីមបានប្រព្រឹត្តដែរ ២០គឺយ៉ាង
នោះដែលសេចក្ដីក្រោធនៃព្រះយេហូវ៉ា បានកើតឡើង
ទាស់នឹងក្រុងយេរូសាឡិម ហើយនិងស្រុកយូដា ដរាបដល់

**២៤:៩** ប ១ពវ ១៥:២៦ **២៤:១០** ផ ខ.១ **២៤:១២** ព ២ពវ ២៥:២៧ យរ ១៣:១៨ ២២:២៤–៣០ ២៤:១ ២៩:២ **២៤:១៣** ភ ២ពវ ២៥:១៥ អស ៣៩:៦ ៤២:២២ ម ២ពវ ២៥:១៤ អរ ១:៧ អស ៣៩:៦ យរ ១៥:១៣ ១៧:៣ ២០:៥ ២៧:១៦ ២៨:៣ អគ ៧:២១ ដយ ១:២ ៥:២,២៣ សផ ១:១៣ យ ១ពវ ៧:៥១ រ ២ពវ ២០:១៧ **២៤:១៤** ល ចទ ២៨:៣៦ ២របា ៣៦:២០ មថ ១:១១ វ អស ៣:១–៣ ស ចទ ១៥:១១ ២ពវ ២៥:១២ យប ៥:១៦ ទដ ៩:១៨ យរ ៤០:៧ ៥២:១៦ **២៤:១៥** ហ ២ពវ ២០:១៨ អគ ១៩:៩ ឡ ខ.៨ ១ពវ ២:១៩ អ នអ ២:៦ អស ៣៩:៧ បទ ២:៩ អគ ១:២ ១៧:១២–១៤ ដយ ១:៣ **២៤:១៦** ក អរ ២:១ យរ ២៤:១ **២៤:១៧** ខ ១របា ៣:១៥ ២របា ៣៦:១១ យរ ១:៣ ៣៧:១ ៥២:១ អគ ១៧:១៣ **២៤:១៨** គ ១របា ៣:១៦ យរ ៣៩:១ ឃ ២ពវ ២៣:៣១ **២៤:១៩** ង ១ពវ ១៥:២៦ យរ ៣៧:២

**២៤:៩** *តាមគ្រប់ទាំងអំពើ ដែលព្រះបិតាទ្រង់បានប្រព្រឹត្តដែរ* សូមមើល ២៣:៣៧ យរ ២២:២០–៣០ ។

**២៤:១២** *ឆ្នាំទី៨* មកដល់ត្រង់នេះគឺស្ថិតនៅក្នុងខែមេសាឆ្នាំ៥៩៧មុនគ.ស (សូមមើល ២របា ៣៦:១០ និងការពន្យល់ យរ ៥២:២៨ ដែលបានបញ្ជាក់ប្រព័ន្ធខុសគ្នាក្នុងការកំណត់ថ្ងៃខែឆ្នាំនៅត្រង់នេះ) ។

**២៤:១៣** *ដូចជាព្រះយេហូវ៉ាមានបន្ទូល* សូមមើល ២០:១៣,១៧ ។

**២៤:១៤** *១ម៉ឺននាក់* ចំនួនតួរលេខនៅត្រង់នេះ គឺរួមបញ្ចូលពួកទ័ពទាំង ៧000នាក់ និងពួកជាងរចនាចំនួន១ពាន់នាក់ដែលបានលើកឡើងនៅក្នុង ខ.១៦ (សូមមើល ការពន្យល់ យរ ៥២:២៨ ដែលបញ្ជាក់ពីចំនួននៃការចាប់ខ្លួននេះខុសគ្នា) ។

**២៤:១៥** *យ៉ូយ៉ាគីន . . . ទៅក្រុងបាប៊ីឡូ* នៅត្រង់នេះគឺសម្រេចតាមបទទំនាយរបស់ហោរាយេរេមា (សូមមើល យរ ២២:២៤–២៧ មើល ២របា ២៥:២៧–៣០) ។

**២៤:១៧** *ម៉ាថានា ជាមារបស់យ៉ូយ៉ាគីន* ម៉ាថានា ជាបុត្ររបស់យ៉ូសៀស (សូមមើល ១របា ៣:១៥ យរ ១:៣) ហើយត្រូវជាបងច្បងបិតាយ៉ូយ៉ាគីន និងយេហូគីម ។ *ផ្លាស់ព្រះនាមទៅជាសេដេគា* ឈ្មោះម៉ាថានាមានន័យថា "អំណោយរបស់ព្រះយេហូវ៉ា" ដែលបានផ្លាស់ទៅជា សេដេគា មានន័យថា "សេចក្ដីសុចរិតរបស់ព្រះយេហូវ៉ា" ហើយនៅត្រង់នេះប្រហែលជា ស្ដេចនេប៊ូក្នេសា ចង់បញ្ជាក់ថា ទង្វើរបស់ទ្រង់ដែលបះបោរនឹងក្រុងយេរូសាឡិម ហើយយេហូគីនជាមនុស្សត្រឹមត្រូវយុត្តិធម៌ ។ ក្នុងករណីផ្សេងទៀត ការប្ដូរឈ្មោះនេះ គឺចង់ធ្វើឱ្យស្ដេចនេប៊ូក្នេសាស្ថិតក្រោមអំណាចរបស់ទ្រង់ វិញម្ដង (សូមមើល ការពន្យល់ ២៣:៣៤) ។

**២៤:១៨** *១១ឆ្នាំ* ស្ថិតនៅក្នុងឆ្នាំទី ៥៩៧–៥៨៦មុនគ.ស ។ *យេរេមី* សូមមើល ការពន្យល់ ២៣:៣១ ។ *លិបណា* សូមមើលការពន្យល់ ៨:២២ ។

**២៤:១៩** *ប្រព្រឹត្តអំពើលាមកអាក្រក់...យេហូយ៉ាគីម* សូមមើលការពន្យល់ ២៣:៣៧ ។ នៅក្នុងអំឡុងរាជ្យរបស់សេដេគា ការគោរពរូបព្រះបានបន្តកាន់តែច្រើនឡើងទៀតនៅក្នុងក្រុងយេរូសាឡិម (សូមមើល ២របា ៣៦:១៤ អគ ៨–១១) ។ ព្រះអង្គជាស្ដេចទន់ខ្សោយ ហើយមានព្រះទ័យអល់អែកនៅក្នុងការដឹកនាំ (សូមមើល យរ ៣៨:៥,១៩) ហើយនិងបានបដិសេធចំពោះបន្ទូលរបស់ព្រះយេហូវ៉ា ដែលសំដែងតាមរយៈហោរាយេរេមា (សូមមើល ២របា ៣៦:១២) ។

**២៤:២០** នៅក្នុងវគ្គនេះ មានអ្នកបកប្រែជាច្រើន បានភ្ជាប់សាច់រឿងនៃការបះបោររបស់សេដេគា ទៅជាមួយនឹងអ្នកបន្តវេននៃអ្នកស្នងរាជ្យពួកអេស៊ីព្ទក្នុងឆ្នាំ៥៨៩មុនគ.សនៃមហិចតារបស់ស្ដេចផារោន–អូប្រា (Pharoh Hophra) (សូមមើល យរ ៤៤:៣០ និងការពន្យល់) ។ សេដេគា បានធ្វើការស្បថស្បែជាមួយនឹងស្ដេចនេប៊ូក្នេសា (មើល អគ ១៧:៣) ហើយទ្រង់បាន

ទ្រង់បានបោះ[ច]គេចោលពីចំពោះទ្រង់ចេញ[ឆ] ។

## ការរលំនៃក្រុងយេរូសាឡិម

*២៥:១-១២ - យរ ៣៩:១-១០*

*២៥:១-២១ - ២របា ៣៦:១៧-២០ យរ ៥២:៤-២៧*

*២៥:២២-២៦ - យរ ៤០:៧-៩ ៤១:១-៣,១៦-១៨*

**២៥** ១រួចមក សេដេគាទ្រង់បះបោរនឹងស្តេចស្រុក
បាប៊ីឡូន ហើយដល់ឆ្នាំទី៩[ក]ក្នុងរាជ្យទ្រង់ នៅថ្ងៃ១០ ខែ
បុស្ស នោះនេប៊ូក្នេសា[ខ] ជាស្តេចស្រុកបាប៊ីឡូនក៏មក នាំទាំង
ពួកពលទ័ពរបស់ទ្រង់ទាំងប៉ុន្មាន មកបោះទ័ពច្បាំងនឹងក្រុង
យេរូសាឡិមក៏លើកបន្ទាយនៅព័ទ្ធ[គ]ជុំវិញ ២ដូច្នេះទីក្រុង
ក៏មានគេឡោមព័ទ្ធច្បាំង រហូតដល់ឆ្នាំទី១១ក្នុងរាជ្យ ស្តេច
សេដេគា ៣ហើយដល់ថ្ងៃ៩ ខែអាសាធ នោះអំណត់អត់បាន
ខ្លាំង[ឃ]ណាស់ នៅក្នុងទីក្រុងដល់ម្លេះបានជាគ្មាននំបុ័ងសំរាប់
ពួកជនបរិភោគឡើយ ៤វេលានោះពួកខ្មាំងក៏បំបាក់
ទំលាយកំផែងក្រុង១ជុំ[ង] រួចពួកទាហានទាំងអស់រត់ចេញ
ទាំងយប់ តាមផ្លូវទ្វារដែលនៅកណ្តាល កំផែងទាំង២
ជិតច្បារស្តេចទៅតាមផ្លូវស្រុកវាល ឯពួកខាល់ដេគេ
ឡោមព័ទ្ធ[ច]ទីក្រុង ៥ហើយពួកទ័ពខាល់ដេដេញតាមស្តេច
ខាន់នៅត្រង់វាលក្រុងយេរីខូរ ហើយពួកពលរបស់ទ្រង់
ទាំងប៉ុន្មាន ក៏បែកខ្ញាយពីទ្រង់អស់រលីង[ឆ] ៦គេចាប់[ជ]ស្តេច
នាំឡើងទៅឯស្តេចបាប៊ីឡូន នៅត្រង់រិបឡា[ឈ] រួចគេកាត់
ទោសទ្រង់ ៧ក៏សំឡាប់ពួកបុត្រារបស់សេដេគានៅ ចំពោះ
ទ្រង់ រួចចាក់បង្ខូចព្រះនេត្រទ្រង់ ហើយដាក់ច្រវាក់លង្ហិន
ដឹកនាំទ្រង់ទៅឯក្រុងបាប៊ីឡូនទៅ[ញ] ។
៨ដល់ថ្ងៃ៧ ខែស្រាពណ៍ គឺនៅឆ្នាំទី១៩ ក្នុងរាជ្យស្តេច
នេប៊ូក្នេសា ជាស្តេចបាប៊ីឡូន នោះនេប៊ូសារ៉ាដានជាមេទ័ព
ធំរបស់ស្តេចបាប៊ីឡូន បានទៅឯក្រុងយេរូសាឡិម ៩ក៏ដុត[ដ]
ព្រះវិហារនៃព្រះយេហូវ៉ា និងព្រះរាជវាំង ហើយផ្ទះទាំង
អស់នៅក្រុងយេរូសាឡិមទៅ លោកដុតចោលអស់ទាំងផ្ទះ
ធំៗ[ឋ] ១០រួចពួកទ័ពខាលដេទាំងអស់ ដែលនៅជាមួយនឹង
មេទ័ពធំក៏រំលំកំផែង[ឌ]ក្រុងយេរូសាឡិមគ្រប់ជុំវិញ ១១ហើយ
សំណល់ជនដែលនៅសល់ក្នុងទីក្រុង និងពួកអ្នកដែលបាន
រត់ទៅពឹងស្តេចបាប៊ីឡូន[ឍ] នឹងមនុស្សឯទៀតដែលនៅៗ
ឡើយ នោះនេប៊ូសារ៉ាដាន ក៏ដឹកនាំទៅជាឈ្លើយទាំង
អស់[ណ] ១២តែបានទុកពួកទាល់ក្រនៅក្នុងស្រុក[ត] ឱ្យគេរក្សា
ចំការទំពាំងបាយជូរ ហើយធ្វើស្រែចំការវិញ ។
១៣រីឯសសរលង្ហិន និងជើងកំណល់ ហើយសមុទ្រលង្ហិន
ដែលនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា នោះពួកខាលដេ
ក៏បំបែក[ថ]ជាដុំៗ ដឹកយកលង្ហិនទាំងនោះទៅដល់ស្រុក
បាប៊ីឡូន ១៤ហើយឆ្នាំង ចបចូក ដង្កៀប កូនចាន[ទ] និង
គ្រឿងប្រដាប់លង្ហិនទាំងប៉ុន្មាន[ធ] ដែលសំរាប់ការងារនោះ
គេក៏យកទៅដែរ ១៥ឯជើងក្រាន និងចានក្លាំ គឺរបស់ដែល
ធ្វើពីមាស និងរបស់ដែលធ្វើពីប្រាក់ផង នោះមេទ័ពធំ
លោកក៏យកទាំងអស់ទៅ[ន] ១៦ចំណែកសសរទាំង២ និង

**២៤:២០** ច ចទ ៤:២៦ ២៩:២៧ ឆ នក ២៣:១៥ ២ពវ ១៣:២៣ **២៥:១** ក យរ ៣២:១ ខ យរ ២១:២ ៣៤:១-៧ គ អស ២៣:១៣ ២៩:៣ យរ ៤:១៦-១៧ ៣២:២ ៣៣:៤ អគ ២១:២២ ២៤:២ **២៥:៣** ឃ លវ ២៦:២៦ អស ២២:២ យរ ១៤:១៨ ៣៧:២១ បទ ២:២០ ៤:៩ **២៥:៤** ង យប ៣០:១៤ ទដ ១៤៤:១៤ យរ ៥០:១៥ ៥១:៤៤,៥៨ អគ ៣៣:២១ ច យរ ៤:១៧ ៦:៣ **២៥:៥** ឆ លវ ២៦:៣៦ អគ ១២:១៤ ១៧:២១ **២៥:៦** ជ អស ២២:៣ យរ ៣៨:២៣ ឈ ជណ ៣៤:១១ **២៥:៧** ញ ចទ ២៨:៣៦ យរ ២១:៧ ៣២:៤-៥ ៣៤:៣, ២១ អគ ១២:១១ ១៩:៩ ៤០:១ **២៥:៩** ដ អស ៦០:៧ ៦៣:១៥,១៨ ៦៤:១១ ឋ ចទ ១៣:១៦ នហ ១:៣ ទដ ៧៤:៣-៨ ៧៩:១ យរ ២:១៥ ១៧:២៧ ២១:១០ ២៦:៦,១៨ បទ ៤:១១ អម ២:៥ មីក ៣:១២ **២៥:១០** ឌ នហ ១:៣ យរ ៥០:១៥ **២៥:១១** ឍ ចទ ២៨:៣៦ ២ពវ ២៤:១ ណ លវ ២៦:៤៤ ២ពវ ២៤:១៤ **២៥:១២** ត ២ពវ ២៤:១៤ **២៥:១៣** ថ ១ពវ ៧:៥០ **២៥:១៤** ទ ជណ ៧:១៤ ធ ២ពវ ២៤:១៣ អរ ១:៧ **២៥:១៥** ន ២ពវ ២៤:១៣ យរ ១៥:១៣ ២០:៥ ២៧:១៦-២២

បញ្ជូនអ្នកការទូតទៅប្រទេសបាប៊ីឡូន (សូមមើល យរ ២៩:៣) ហើយនិងទ្រង់បានចេញទៅបំពេញទស្សនៈកិច្ចនៅទីនោះផ្ទាល់តែម្តង (សូមមើល យរ ៥១:៥៩) ។ ទោះបី ជាទ្រង់មើលទៅហាក់បីដូចជាយល់ព្រមចំពោះការលួងលោមឃោសនានៃពួកប្រឆាំងបាប៊ីឡូន និងអ្នកគាំទ្រពួកអេស៊ីព្ទនៅក្រុងយេរូសាឡិម (សូមមើល យរ ៣៧:៥ អគ ១៧:១៥-១៦) មធ្យោបាយនោះគឺព្រះអង្គគិតខុសក្នុងការដណ្តើមសន្តិភាពពីបាប៊ីឡូនទៅវិញ ។

**២៥:១** *ឆ្នាំទី៩ . . . ថ្ងៃទី១០ . . . ខែបុស្ស* ថ្ងៃខែឆ្នាំនៅត្រង់នេះគឺសំដៅដល់ខែមករា ទី១៥ ឆ្នាំ ៥៨៨ មុន គ.ស (សូមមើល យរ ៣៩:១ ៥២:២៤ អគ ២៤:១-២) ។ *នេប៊ូក្នេសា . . . បោះទ័ពច្បាំងនឹងក្រុងយេរូសាឡិម* ដំបូងឡើយស្តេចនេប៊ូក្នេសា បានវាយបង្ក្រាបគ្រប់ទាំងកំផែងក្រុងនៅក្នុងទឹកដីយូដា គឺលើកលែងតែក្រុងឡាគីស និង អាសេកា (សូមមើល យរ ៣៤:៧) ។

**២៥:២-៣** *ឆ្នាំទី១១ . . . ថ្ងៃ៩ . . . ខែអាសាធ* ត្រង់ចំណុចនេះស្ថិតនៅក្នុងខែកក្កដាឆ្នាំទី ៥៨៦ មុន គ.ស (សូមមើល យរ ៣៩:២ ៥២:៥-៧) ។ នៅត្រង់ចំណុចដដែលនេះផងដែរ មានពួកអ្នកប្រាជ្ញខ្លះបានកំណត់កាលបរិច្ឆេទតាមប្រព័ន្ធផ្សេងៗគ្នា ហើយបញ្ជាក់ថាការដួលចុះក្រុងយេរូសាឡឹមគឺនៅក្នុងរដូវក្តៅ នៃឆ្នាំ ៥៨៧ មុន គ.ស ។

**២៥:៣** *អំណត់អត់បានខ្លាំងណាស់ នៅក្នុងទីក្រុងដល់ម្លេះ* សូមមើល យរ ៣៨:២-៩ ។

**២៥:៦** *ស្តេចបាប៊ីឡូន នៅត្រង់រិបឡា* សូមមើលការពន្យល់ ២៣:៣៣ និងមើលបន្ថែម យរ ៣៩:៥ ៥២:៩ ។

**២៥:៧** *សំឡាប់ពួកបុត្រារបស់សេដេគា . . . បង្ខូចព្រះនេត្រទ្រង់ . . . ដឹកនាំទ្រង់ទៅឯក្រុងបាប៊ីឡូន* ចំពោះឃ្លានេះសូមមើល យរ ៣២:៤-៥ ៣៤:២-៣ ៣៨:១៨ ៣៩:៦-៧ ៥២:១០-១១ ។

**២៥:៨** *ថ្ងៃ៧ . . .ខែស្រាពណ៍ . . . ឆ្នាំទី១៩* ថ្ងៃខែនៅត្រង់នេះ គឺស្ថិតនៅខែទី១៤ខែសីហាឆ្នាំ ៥៨៦ មុន គ.ស (សូមមើល យរ ៥២:១២ និងការពន្យល់) ។

**២៥:៩** *ដុតព្រះវិហារ* សូមមើល ២របា ៣៦:១៩ យរ ៣៩:៨ ៥២:១៣ ។

**២៥:១៣** *សសរលង្ហិន* សូមមើល ១ពវ ៧:១៥-២២ ។ *ជើងកំណល់* សូមមើល ១ពវ ៧:២៧-៣៩ ។ *សមុទ្រលង្ហិន* សូមមើល ១ពវ ៧:២៣-២៦ ។

**២៥:១៤** *គ្រឿងប្រដាប់លង្ហិន ទាំងប៉ុន្មាន* សូមមើល ១ពវ ៧:៤០,៤៥ ។

សមុទ្រសិទ្ធ ហើយជើងកំណល់ទាំងប៉ុន្មាន ដែលសាឡូម៉ូន
ធ្វើសំរាប់ព្រះវិហារនៃព្រះយេហូវ៉ានោះ បានធ្វើពីលង្ហិន
មានទំងន់ថ្លឹងមិនបានឡើយ ១៧សសរ១[ប] កំពស់១៨ហត្ថ
ហើយក្បាលសសរលង្ហិននៅពីលើនោះក៏កំពស់៣ហត្ថទៀត
មានទាំងក្បាច់ក្រឡាអួន និងផ្លែទទឹមនៅជុំវិញ ធ្វើសុទ្ធតែ
ពីលង្ហិនផង ឯសសរទី២ ក៏ដូចគ្នា មានទាំងក្បាច់ក្រឡាអួន
ដែរ ។

១៨ឯមេទ័ពធំ លោកចាប់យកសេរ៉ាយ៉ា[ផ] ជាសំដេចសង្ឃ
និងសេផានា[ព] ជាសង្ឃបន្ទាប់ ហើយពួកឆ្មាំទ្វារទាំង៣នាក់[ភ]
១៩ក៏ចាប់យកមេទ័ពម្នាក់ពីទីក្រុង ជាអ្នកត្រួតលើពលទ័ព
និងមនុស្ស៥នាក់ ជាអ្នកធ្លាប់ឃើញព្រះភក្ត្រស្តេច ដែល
ឃើញមាននៅក្នុងក្រុង ហើយស្មៀនរបស់មេទ័ព ជាអ្នកធ្វើ
បញ្ជីកត់ពួកអ្នកស្រុក ព្រមទាំងពួកអ្នកស្រុក៦០នាក់ ដែល
ឃើញមានក្នុងក្រុងដែរ ២០លោកនាំទៅឯស្តេចបាប៊ីឡូន
នៅត្រង់រីបឡា ២១ស្តេចបាប៊ីឡូនក៏សំឡាប់អ្នកទាំងនោះ[ម]
នៅត្រង់រីបឡា[យ] ក្នុងស្រុកហាម៉ាតទៅ ដូច្នេះពួកយូដា
ត្រូវដឹកនាំទៅជាឈ្លើយ[រ] ក្រៅពីស្រុករបស់ខ្លួន[ល] ។

២២ឯពួកជនដែលនេប៊ូក្នេសា ជាស្តេចបាប៊ីឡូនបានទុក
ឱ្យសល់នៅ ក្នុងស្រុកយូដា នោះទ្រង់ក៏តាំងកេដាលា[វ] ជាកូន
អ័ហ៊ីកាម[ស] ដែលជាកូន សាផាន ឱ្យធ្វើជាចៅហ្វាយលើគេ
២៣រីឯពួកមេទ័ពទាំងប៉ុន្មាន និងពួកទាហានរបស់គេ កាល
បានឮថា ស្តេចបាប៊ីឡូនបានតាំងកេដាលា ឱ្យធ្វើជាចៅ
ហ្វាយដូច្នោះ នោះគេក៏មកឯកេដាលា នៅក្រុងមីសប៉ា គឺ
អ៊ីសម៉ាអែល ជាកូននេថានា១ យ៉ូហាណានជាកូនការា១
សេរ៉ាយ៉ា ជាកូនថានហ៊ូមែត ជាអ្នកស្រុកនថូផា១ និង
យ្អាសានា ជាកូនរបស់អ្នកស្រុកម៉ាកាធីម្នាក់១ ព្រមទាំងពួក
ទាហានរបស់គេផង ២៤កេដាលាក៏ស្បថនឹងគេ ហើយនឹង
ពួកគេទាំងប៉ុន្មាន ដោយពាក្យថា កុំឱ្យខ្លាច ដោយព្រោះ
ពួកអ្នកដែលចុះចូលខាងពួកខាល់ដេឡើយ ចូរនៅក្នុង
ស្រុក ហើយចុះចូលចំពោះស្តេចបាប៊ីឡូនចុះ នោះអ្នក
រាល់គ្នានឹងបានសេចក្តីសុខ ២៥ប៉ុន្តែដល់ខែអស្សុជនោះ
អ៊ីសម៉ាអែល កូននេថានា ដែលជាកូនអេលីសាម៉ា ជាពូជ
ស្តេច បាននាំមនុស្ស១០នាក់មកជាមួយប្រហារជីវិត[ហ]
កេដាលាទៅ ព្រមទាំងពួកយូដា និងពួកខាល់ដេ ដែល
នៅជាមួយនឹងលោក នៅក្នុងមីសប៉ាផង[ឡ] ២៦នោះពួកបណ្តា
ជនទាំងឡាយ ទាំងតូច ទាំងធំ និងពួកមេទ័ព ក៏នាំគ្នាទៅ
ឯស្រុកអេស៊ីព្ទ[អ] ទៅ ពីព្រោះគេខ្លាចពួកខាលដេ ។

### យ៉ូយ៉ាគីនត្រូវបានដោះលែង

*២៥:២៧–៣០ – យរ ៥២:៣១–៣៤*

២៧រីឯនៅឆ្នាំទី៣៧ ដែលយ៉ូយ៉ាគីន ជាស្តេចយូដា នៅ
ជាប់ជាឈ្លើយនៅឡើយ ក្នុងថ្ងៃ២៧ ខែផគ្គុណ នោះ
អេវីល–មេរ៉ូដាក ជាស្តេចស្រុកបាប៊ីឡូន ទ្រង់ចាប់តាំង

**២៥:១៧** ប ១ពវ ៧:១៥–២២
**២៥:១៨** ផ ខ.១៨–២១ ១របា ៦:១៤ អរ ៧:១ នហ ១១:១១ ព យរ ២១:១ ២៩:២៥ ៣៧:៣ ភ ២ពវ ១២:៩ ២៣:៤
**២៥:២១** ម យរ ៣៤:២១ យ ជន ៣៤:១១ រ ១ពវ ៨:៤៦ ល លវ ១២:៧ យស ២៣:១៣
**២៥:២២** វ យរ ៣៩:១៤ ៤០:៥,៧ ៤១:១៨ ស ២ពវ ២២:១២
**២៥:២៥** ហ ២ពវ ១២:២០ ឡ សផ ៧:៥
**២៥:២៦** អ អស ៣០:២ យរ ៤៣:៧

**២៥:១៨** *សេរ៉ាយ៉ា ជាសំដេចសង្ឃ* សេរ៉ាយ៉ា ជាចៅរបស់ហ៊ីលគីយ៉ា (សូមមើល ការពន្យល់ ២២:៤ និងការពន្យល់បន្ថែម ២២:៨ ១របា) ។ ចៅរបស់គាត់យេហូដាត្រូវបានឃុំខ្លួននៅក្នុងចក្រភពបាប៊ីឡូន ។

**២៥:១៩** *ពួកអ្នកស្រុក* សូមមើលការពន្យល់ ២១:២៤ ។

**២៥:២០** *នាំទៅឯស្តេចបាប៊ីឡូន នៅត្រង់រីបឡា* សូមមើល ខ.៦ និងការពន្យល់ ។

**២៥:២១** *ពួកយូដាត្រូវដឹកនាំទៅជាឈ្លើយ ក្រៅពីស្រុករបស់ខ្លួន* ការនិរទេសខ្លួនរបស់ពួកយូដាចេញពីទឹកដីកាណានត្រូវសម្រេចតាមទំនាយនៃការកាត់ទោស ដែលបានទាយមកក្នុរជ្ជកាលរបស់ស្តេចម៉ានាសេ (សូមមើល ២៣:២៧) ។ ការនិរទេសខ្លួន នេះបណ្តាសាមួយដ៏ធ្ងន់ធ្ងនៅក្នុងសេចក្តីសញ្ញារបស់ទ្រង់ (សូមមើល លវ ២៦:៣៣ ពច ២៨:៣៦ និងមើល យរ ២៥:៨–១១) ។

**២៥:២២** *កេដាលា* សូមមើលការពន្យល់ ២២:១២ ។ នៅត្រង់នេះ កេដាលា និងយេរេមា បានយកជ័យជម្នះលើចក្រភពបាប៊ីឡូនទាំងមូល (សូមមើល ខ.២៤) ហើយបានគ្រប់គ្រងលើទឹកដីយូដាទាំងមូល (សូមមើល ៤១:១០) ។

**២៥:២៣** *ក្រុងមីសប៉ា* ក្រុងនេះជាផ្នែកសំខាន់ក្នុងវិស័យនយោបាយនៅសម័យកាលនោះ មុនពេលការបង្កើតរបបរាជានិយម (សូមមើលការពន្យល់ ១សយ ៧:៥) ។ លោកយេរេមា បានរកលោកកេដាលាឃើញនៅទីនោះ (សូមមិល យរ ៤០:១–៦) ។ *អ៊ីសម៉ាអែល ជាកូននេថានា* នៅក្នុង ខ.២៥ ខាងមុខនេះ បានបញ្ជាក់យ៉ាងច្បាស់ពីពង្សាវតារនៃអ្នកស្នងរាជ្យយ៉ាងច្បាស់លាស់ ។ អេលីសាម៉ា ដែលជាចៅរបស់អ៊ីសម៉ាអែល គឺជាស្មៀនដែលស្ថិតក្រោមការត្រួតត្រារបស់យេហូគីម (យរ ៣៦:១២) ។

**២៥:២៤** លោកកេដាលា បានបង្ខំចិត្តចុះចូលជាមួយនឹងចក្រភពបាប៊ីឡូន ថាជាការកាត់ទោសរបស់ព្រះយេហូវ៉ា ។ លោកបានព្យាយាមតស៊ូមតិយ៉ាងខ្លាំងក្លាដើម្បីឱ្យមានសន្តិភាពក្នុងសង្គមនាពេលនោះ (សូមមើល យរ ២៧) ។ សេចក្តីស្រដៀងគ្នានេះ បានផ្ញើមកដល់ពួកអ្នកដែលកំពុងជាប់ជាឈ្លើយនៅក្រុងបាប៊ីឡូនដោយលោកយេរេមា នៅក្នុងឆ្នាំ ៥៩៧មុនគ.ស (យរ ២៩:៤–៧) ។

**២៥:២៥** *ខែអស្សុជ* ខែនេះស្ថិតនៅក្នុងខែតុលា ឆ្នាំ ៥៨៦ មុន គ.ស ។ *ប្រហារជីវិតកេដាលា* ការរៀបរាប់ពីការសម្លាប់កេដាលា ត្រូវបានលាតត្រដាងនៅក្នុង យរ ៤០:១៣–៤១:១៥ ។

**២៥:២៦** *ទៅឯស្រុអេស៊ីព្ទ* ស្រុងនេះស្ថិតក្រោមការដឹកនាំរបស់ស្តេផារោននៅអេស៊ីព្ទ (សូមមើលការពន្យល់ ២៤:២០) ។

**២៥:២៧** *ឆ្នាំទី៣៧ . . . ថ្ងៃ២៧ខែផគ្គុណ . . .* មកដល់ត្រង់នេះគឺស្ថិតនៅក្នុងខែមីនាទី២២ ឆ្នាំ ៥៦១ មុន គ.ស ។ *អេវីល–មេរ៉ូដាក ជាស្តេចស្រុកបាប៊ីឡូន* នៅឆ្នាំ ៥៦១ មុន គ.ស ពួកអ្នកប្រាជ្ញខ្លះយល់ថា អេវីល–មេរ៉ូដាក នេះជាម្ចាស់រាជ្យបល្ល័ង្កនៅក្នុង ខែតុលា ឆ្នាំ១៥៦២ (សូមមើលការពន្យល់ ២៤:១) ។ នាមនេះមានន័យថា "អ្នកសំណប់ព្រះម៉ាដាក់" ។

សោយរាជ្យឡើង ហើយក៏ប្រោសមេត្តា ដល់យ៉ូយ៉ាគីន[ក]ជា
ស្តេចយូដា ដោះចេញពីគុក នៅឆ្នាំនោះឯង ២៨ក៏មាន
បន្ទូលនឹងទ្រង់ ដោយផ្អែមពីរោះ[ខ] ព្រមទាំងតាំងបល្ល័ង្ក
ទ្រង់[គ]ឱ្យខ្ពស់ជាងពួកស្តេច ដែលនៅជាមួយ នៅក្រុង
បាប៊ីឡូនផង ២៩ហើយបំផ្លាស់សំលៀកបំពាក់គុក ពីទ្រង់
ចេញ ដូច្នេះ យ៉ូយ៉ាគីនក៏សោយព្រះស្ងោយនៅចំពោះទ្រង់
ជានិច្ចដរាបដល់អស់ព្រះជន្ម[ឃ] ៣០ស្តេចបាប៊ីឡូនក៏ផ្គត់ផ្គង់
ថ្វាយរាល់តែថ្ងៃជានិច្ច ដរាបដល់អស់ព្រះជន្មទ្រង់[ង] ។/

**២៥:២៧** ក ២ពវ ២៤:១២ **២៥:២៨** ខ ១ពវ ៨:៥០ គ អរ ៥:៥ ៧:៦,២៨ ៩:៩ នហ ២:១ ដយ ២:៤៨ **២៥:២៩** ឃ ២សយ ៩:៧ **២៥:៣០** ង លប ៤៣:៣៤ នអ ២:៩ ៩:២២ យរ ២៨:៤

**២៥:២៨** *មានបន្ទូលនឹងទ្រង់ ដោយផ្អែមពីរោះ ព្រមទាំងតាំងបល្ល័ង្កទ្រង់* កណ្ឌគម្ពីរ ពង្សាវតារនេះ បានបញ្ចប់ដោយកំណត់ត្រាក្នុងផ្លូវនៃក្តីសង្ឃឹម ។ ការនិរទេសនៃការជំនុំជម្រះ មិនត្រូវបានបំផ្លាញប្រជាជនអ៊ីស្រាអែលឬជំនួរវង្សរបស់ស្តេចដាវីឌ ។ សេចក្តីសន្យារបស់ព្រះយេហូវ៉ា បានផ្តល់ជំនួរវង្សនៃស្តេចដាវីឌទាំងអស់ (សូមមើល អស ២សយ ៧:១៤–១៦) ។

# ព្រះគម្ពីរបាក្សត្រទី១

## សេចក្ដីផ្ដើម

### ចំណងជើង

នៅក្នុងចំណងជើងជាភាសាហេព្រើរ "ឌីប្រេ ហាយយ៉ាមីម" (dibre hayyamim) អាចមានន័យថា "ព្រឹត្តិការណ៍ ឬកំណត់ត្រាប្រវត្តិសាស្ត្រប្រចាំថ្ងៃឬប្រចាំឆ្នាំ ។ ការលេចឡើងនូវឃ្លាដូចគ្នានេះគឺដើម្បីឆ្លើយតបទៅនឹងប្រភពដែលអ្នកនិពន្ធ ឬអ្នកចងក្រងនៃព្រះគម្ពីរពង្សាវតារក្សត្រ(បកប្រែថា កត់ត្រាទុកក្នុងសៀវភៅ ឧ.១ពវ ១៤:១៩,២៩ ១៥:៧,២៣,៣១ ១៦:៥,១៤,២០,២៧ ២២:៤៥) ។ សិបធូជីន (ការបកប្រែសញ្ញាចាស់របស់គ្រីស្ទបរិស័ទក្រិកជំនាន់មុន) ដែលយកតាមកំណត់ត្រាក្នុងសៀវភៅដែលបាន "លុបចោល" បានបញ្ជាក់ថា ក្រុមអ្នកបកប្រែព្រះគម្ពីរនេះបានយល់ឃើញថា គម្ពីរនេះគឺជាគម្ពីរមួយដែលបំពេញន័យឬបង្គ្រប់លក្ខណៈដល់ព្រះគម្ពីរសាំយូអែលនិងគម្ពីរពង្សាវតារក្សត្រ ។ យេរ៉ូម(គ.ស ៣៤៧-៤២០)ជាអ្នកបកប្រែព្រះគម្ពីរកាត់ស្រាយភាសារឡាតាំងបានបង្ហាញថា ចំណងជើងក្នុងព្រះគម្ពីរនេះអាចមានន័យថា "ពង្សាវតារនៃប្រវត្តិសាស្ត្រដ៏អាថ៌កំបាំង" ។ លោកម៉ាធីនលូធើបានយល់ស្របចំពោះអំណះអំណាងនោះហើយបានយកវាមកធ្វើជាអំណះអំណាងក្នុងគម្ពីរអាល្លឺមង់កំណែថ្មីរួមទាំងអ្នកដើរតាមគាត់ផ្សេងៗទៀត ។ ព្រះគម្ពីរបាក្សត្រគឺជាការបែងចែកលើកដំបូង ជា២ផ្នែកដោយក្រុមសិបធូជីន ។

### អ្នកនិពន្ធ កាលបរិច្ឆេទ និងប្រភព

យោងទៅតាមវប្បធម៌ និងទំនៀមទម្លាប់របស់ពួកយូដាសម័យបុរាណបាននិយាយថា លោកអែសរ៉ាជាអ្នកសរសេរព្រះគម្ពីរបាក្សត្រ អែសរ៉ា និងនេហេមាឡើង(សូមមើលសេចក្ដីផ្ដើម គម្ពីរអែសរ៉ា: ទម្រង់លក្ខណៈអក្សរសាស្ត្រ និងអ្នកនិពន្ធ) ប៉ុន្តែការនេះពុំអាចយកជាការពិតទាំងស្រុងបានឡើយ ។ មានមតិទូរទៅជាច្រើនបានយល់ស្របចំពោះកាលបរិច្ឆេទនៃការសរសេរព្រះគម្ពីរបាក្សត្រថាស្ថិតនៅពាក់កណ្ដាលសតវត្សរ៍ទី១៥ មុន គ.ស គឺដូចគ្នានឹងសម័យកាលដែលលោកអែសរ៉ាបានរស់នៅដែរ ។ បើដូច្នេះមែននោះលោកអែសរ៉ា គឺជាអ្នកនិពន្ធព្រះម្ពីរបាក្សត្រនេះឡើង ហើយបើសិនជាមិនមែនលោកអែសរ៉ាទេ យ៉ាងហោចណាស់ក៏បាននិយាយពីមូលដ្ឋានគ្រឹះជាច្រើនដែលបានទាក់ទងជាមួយការរៀបចំឱ្យមានសង្ឃឡើងវិញ ថ្វីដ្បិតតែព្រះគម្ពីរបាក្សត្រមិនសូវនិយាយអំពី "ពូជសង្ឃ" ក៏ដោយ។

អ្នកខ្លះទៀតជឿថា អត្ថបទនេះបានភ្ជាប់ជាមួយភស្តុតាងដែលមាននៅទីនេះស្រាប់ ហើយក្រោយមកទៀតក៏ចាប់ផ្ដើមតាក់តែងឡើងបន្ទាប់ពីកិច្ចការគ្រឹះបាននិពន្ធចប់ ។ ក្នុងខណៈពេលដែលគេធ្វើការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញឃើញថា វាមិនគួរឱ្យជឿ និងយកជាការបានឡើយ ។

នៅពេលដែលអ្នកនិពន្ធបានរ៉ាយរ៉ាប់ឡើងវិញ អំពីប្រវត្តិសាស្ត្រដែលបានកន្លងផុតទៅជាយូរមកហើយ អ្នកកត់ត្រាពង្សាវតារបានជឿទុកចិត្តលើឯកសារជាច្រើនដែលបានសរសេរ ប្រហែលជាពាក់កណ្ដាលនៃកិច្ចការរបស់គាត់គឺបានយកចេញពីគម្ពីរសាំយូអែលនិងពង្សាវតារក្សត្រ ។ ជាមួយគ្នានោះដែរ គាត់ក៏បានដកស្រង់ចេញពី កណ្ឌគម្ពីរបញ្ចកណ្ឌ ពួកចៅហ្វាយ នាងរស់ ទំនុកដំកើង អេសាយ យេរេមា បរិទេវ និងសាការី ។ ជារឿយៗក៏នៅមានអំណះអំណាងលើប្រភពឯកសារផ្សេងៗទៀតដែរ "បញ្ជីរបស់ស្ដេចសាសន៍អ៊ីស្រាអែល" (សូមមើល ៩:១ ២របា ២០:៣០ ធៀបជាមួយ ២របា ៣៣:១៨) "បញ្ជីពង្សាវតារនៃស្ដេចដាវីឌ" (២៧:២៤) "សៀវភៅដែលថ្លែងពីពួកយូដា និងអ៊ីស្រាអែល" (២របា ១៦:១១ ២៥:២៦ ២៧:៧ ២៨:២៦ ៣២:៣២ ៣៥:២៧ ៣៦:៨) "សៀវភៅបរិយាយពីពួកស្ដេច" (២របា ២៤:២៧) ។ វានៅតែមិនច្បាស់ ទោះបីជាការនិយាយទាំងនោះសំដៅលើប្រភពតែមួយ ឬផ្សេងពីគ្នាក៏ដោយ ហើយអ្វីដែលជាការទំនាក់ទំនងរបស់គេនោះ គឺជាការទាក់ទងជាមួយគម្ពីរសាំយូអែល និងពង្សាវតារក្សត្រ ឬក៏កំណត់ត្រាប្រវត្តិស្ដេចដែលបាននិយាយនៅក្នុងគម្ពីរពង្សាវតារក្សត្រ ។ អ្នកនិពន្ធក៏បានទាញយកហេតុផលពីពួកហោរាដែរ អ្នកទាំងនោះគឺជា: "សាំយូអែល ជាអ្នកមើលឆុត" (២៩:២៩) "សៀវភៅរបស់ហោរាណាថាន់" (២៩:២៩ ២របា៩:២៩) "សៀវភៅរបស់កាឌ់ ជាអ្នកមើលឆុត" (២៩:២៩) "ទំនាយនៃអ័ហ៊ីយ៉ា ជាអ្នកស្រុកស៊ីឡូ" (២របា ៩:២៩) "អ៊ីដោ ជាអ្នកមើលឆុត" (២របា ៩:២៩ ១២:១៥ ១៣:២២) "ហោរាសេម៉ាយ៉ា" (២របា ១២:១៥) "ហោរា អេសាយ" (២របា ២៦:២២) "ពួកអ្នកមើលឆុត" (២របា ៣៣:១៩) ។ គ្រប់ទាំងអស់នៃពួកហោរាដែលគាត់បានលើកមកនិយាយជានិច្ចកាល គឺមានការផ្លាស់ប្ដូរ ព្រោះដើម្បីបង្ហាញប្រាប់ពីរឿងផ្ទាល់ខ្លួនរបស់គាត់ កាលពីអតីតកាល ។

## គោលបំណង និងផ្ទៃរឿង

អ្វីដែលអ្នកនិពន្ធព្រះគម្ពីរពង្សាវតារក្សត្របានទទួលស្គាល់ និងកាត់ស្រាយអំពីទិន្ន័យ អំពីប្រវត្តិសាស្ត្រអ៊ីស្រាអែល គឺដើម្បីសម្ដែងសេចក្ដីត្រូវការរបស់សហគមន៍ដែលនិរទេស ដូច្នេះហើយអ្នកកត់ត្រាពង្សាវតារបានសរសេរព្រះគម្ពីរនេះឡើងដើម្បីឲ្យគេបានស្ថាបនាសហគមន៍របស់គេឡើងវិញ ។ ដំណើររឿងដ៏ក្ដៅគគុកនេះ បានក្លាយជាសំណួរស្ដីពីនិរន្តភាពនៃប្រទេសជាតិដែលបានកន្លងផុតទៅហើយថា :តើព្រះអម្ចាស់ទ្រង់នៅតែសព្វព្រះទ័យនឹងយើងដែរឬទេ? តើសេចក្ដីសញ្ញារបស់ទ្រង់នៅតែមានអនុភាពដែរឬទេ? ឥឡូវនេះយើងដឹងថាគ្មានរាជ្យរបស់ដាវីឌទៀតទេ ហើយយើងនឹងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកពើស៊ី តើសេចក្ដីសញ្ញារបស់ព្រះអម្ចាស់នៅមានន័យសម្រាប់យើងទៀតដែរឬទេ? បន្ទាប់ពីជិនុំជម្រះ(ទម្លាក់រាជ្យកូនចៅរបស់ដាវីឌ ការបំផ្លាញប្រជាជាតិ ការបំផ្លាញក្រុងយេរូសាឡិម និងព្រះវិហារ ព្រមទាំងការនិរទេសទៅក្រុងបាប៊ីឡូន)តើអ្វីជាទំនាក់ទំនងរបស់ពួកយើងចំពោះពួកអ៊ីស្រាអែល? បញ្ហាទាំងអស់នេះត្រូវបានអ្នកកត់ត្រាពង្សាវតារដោះស្រាយដូចតទៅ:

១. ព្រះវិហារក្រុងយេរូសាឡិម ដែលត្រូវស្ថាបនាឡើងវិញដោយអំណាចចេស្ដារបស់ព្រះអម្ចាស់ ដែលទ្រង់បានបង្ក្រាប់មកអធិរាជ្យពើស៊ី(២របា ៣៦:២២-២៣) នោះគឺជាអត្តសញ្ញាណមួយដែលបញ្ជាក់ពីនិរន្តភាពនាពេលអតីតកាល ។ សម្រាប់កូនចៅជំនាន់ក្រោយ ដែលមានគោលនយោបាយឯករាជ និងគ្មានរាជ្យរបស់ដាវីឌ អ្នកនិពន្ធបានធ្វើការពណ៌នាយ៉ាងល្អិតល្អន់ ដើម្បីបង្ហាញថាព្រះវិហារនៃព្រះអម្ចាស់ និងការងារបម្រើរ(រាប់បញ្ចូលទាំងគម្ពីរទំនុកនៃសេចក្ដីអធិស្ឋាន និងសរសើរ ដែលមាននៅក្នុងគម្ពីរទំនុកដំកើង ដែលបានបោះពុម្ព កាលពីលើកមុន) គឺជាអំណោយទានដ៏វិសេសរបស់ព្រះអម្ចាស់ ដែលទ្រង់បានប្រទានដល់ពួកអ៊ីស្រាអែលតាមរយៈជិនួរវង្សស្ដេចដាវីឌ ។ ហេតុផលរបស់គាត់ ចំពោះដំណើររឿងដែលស្ថិតនៅក្នុងរាជ្យស្ដេចដាវីឌ និងសាឡូម៉ូន ភាគច្រើនគឺជាការរៀបចំរបស់ស្ដេចដាវីឌ សម្រាប់សាឡូម៉ូនសាងសង់ព្រះវិហារនៃព្រះអម្ចាស់ និងការទូន្មានរបស់ដាវីឌពីរបៀបដែលត្រូវបម្រើក្នុងព្រះវិហារ(រួមទាំងកាឌ់ដែលជាអ្នកមើលឆុតរបស់ទ្រង់ និងហោរាណាថាន់ ២របា ២៩:២៥ និងពួកលេវីដែលមានដូចជា អេសាភ ហេមាន និងយេឌូថិន ២របា ៣៥:១៥) ។ ជាមួយគ្នានោះដែរ សូមមើលកំណត់ត្រារបស់អ្នកកត់ត្រាពង្សាវតារស្ដីពីរាជ្យរបស់អេសា យេហូសាផាត យ៉ូអាស ហេសេគា និងយ៉ូសៀស ។ ព្រះវិហារនៃព្រះអម្ចាស់ដែលស្ថិតក្នុងទីក្រុងបរិសុទ្ធកាលពីសម័យបុរាណនិងកិច្ចការងារទាំងឡាយ(រួមទាំងគម្ពីរទំនុកដំកើង)គឺជាកេរ្តិ៍ដំណែលមួយស្ដីពីការអនុញ្ញាត្តិឲ្យស្ថាបនាសហគមន៍របស់គេឡើងវិញ ពីដំណរពូជពង្សដាវីឌ ។

២. គុណតម្លៃនៃកេរ្តិ៍ដំណែលនេះមានតម្លៃធំធេងណាស់ ដោយព្រោះអ្នកនិពន្ធបានផ្ដោតលើព្រះគុណរបស់ព្រះអម្ចាស់ចំពោះពួកអ៊ីស្រាអែលតាមរយៈវិធីបោះឆ្នោត (ទី១)អំបូរលេវីត្រូវបម្រើរដោយការសែងហឹបនៃសេចក្ដីសញ្ញា( ១៥:២ ២៣:២៤-៣២) ដាវីឌជាស្ដេចគ្រប់គ្រងលើពួកអ៊ីស្រាអែល(២៨:៤ ២របា ៦:៦)(ទី៣) សាឡូម៉ូនជាកូនដាវីឌត្រូវធ្វើជាស្ដេច និងអ្នកកសាងព្រះវិហារថ្វាយព្រះអម្ចាស់(២៨:៥-៦,១០ ២៩:១) (ទី៤)ទីក្រុងយេរូសាឡិម(២របា ៦:៦,៣៤,៣៨ ១២:១៣ ៣៣:៧) និងព្រះវិហារ(២របា ៧:១២,១៦ ៣៣:៧)ជាកន្លែងដែលអនុញ្ញាតឲ្យព្រះនាមរបស់ទ្រង់គង់នៅទីនោះក្នុងចំណោមរាស្ត្ររបស់ទ្រង់ ។

៣. បន្ថែមនៅក្នុងព្រះវិហារ ពួកអ៊ីស្រាអែលមានក្រឹត្យវិន័យ និងពួកហោរា ដែលជាចៅហ្វាយផ្ដោតលើសេចក្ដីសញ្ញារបស់ពួកគេ ក្រោមការដឹកនាំពីសំណាក់ពូជពង្សរបស់ដាវីឌ ។ មិនមែនដោយពូជពង្សរបស់ស្ដេចដាវីឌ ហើយក៏មិនមែនដោយសារព្រះវិហារនោះជាអ្នកធានាពីសុវត្ថភាពសេចក្ដីសុខ និងព្រះពរសម្រាប់ពួកកូនចៅអ៊ីស្រាអែលឡើយ ។ គ្រប់ទាំងអស់ដែលមានគឺសុទ្ធតែជាលក្ខខ័ណ្ឌទៅលើការស្មោះត្រង់របស់ពួកអ៊ីស្រាអែល និងព្រះមហាក្សត្រចំពោះក្រឹត្យវិន័យដែលទ្រង់បានប្រទានដល់ពួកគេ(សូមមើល ២៨:៧ ២របា ៦:១៦ ៧:១៧ ១២:១ ៣៣:៨) ។ នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នកកត់ត្រាពង្សាវតារ គឺបាននិយាយពណ៌នាគ្រប់ទាំងរឿងរាវសំខាន់ៗរបស់ស្ដេចដាវីឌ និងពូជពង្សរបស់គាត់ស្មោះត្រង់ចំពោះព្រះនិងប្រព្រឹត្តតាមក្រឹត្យវិន័យ: ស្ដេចដាវីឌ (៦:៤៩ ១៥:១៣,១៥ ១៦:៤០ ២២:១១-១៣ ២៩:១៩) យ៉ូសាផាត(២របា ១៧:៣-៩ ១៩:៨-១០) យ៉ូអាស (២របា ២៤:៦,៩)ហេសេគា(របា ២៩:១០,៣១ ៣០:១៥-១៦ ៣១:៣-៤,២១) យ៉ូសៀស(២របា ៣៤:១៩-២១,២៩-៣៣ ៣៥:៦,១២,២៦) ។ ស្ដេចដែលមានសេចក្ដីស្មោះត្រង់ចំពោះអម្ចាស់ដូចជាដាវីឌ អាសា យ៉ូសាផាត ហេសេគា និងយ៉ូសៀស រួមទាំងយេហូបោម (២របា ១១:៤ ១២:៦) និងអ័ម៉ាស៊ីយ៉ា (២របា ២៥:៧-១០) គឺសុទ្ធតែមានកិត្តិយសដ៏ធំឧត្តម្ភ ។ ស្ដេចទាំងឡាយណាដែលមិនស្មោះត្រង់ចំពោះព្រះអម្ចាស់ នោះព្រះអម្ចាស់ទ្រង់បណ្ដោយទៅតាមសេចក្ដីហិនវិនាសរបស់ពួកគេ (យ៉ូរ៉ាម ២របា ២១:១២-១៩ យ៉ូអាស ២របា ២៤:១៩-២៥ អ័ម៉ាស៊ីយ៉ា ២របា ២៥:១៥-១៦,២០ ម៉ាន៉ាសេ ២របា ៣៣:១០-១១ សូមមើល ៣៦:១៥-១៦) ។ ព្រះគម្ពីរបាក្សត្រ បាននិយាយច្រើនលើកិច្ចការរបស់ពួកហោរាជាងព្រះគម្ពីរសាំយូអែលនិងពង្សាវតារ ។ ព្រះរាជឱការរបស់យ៉ូសាផាតទៅកាន់ពួកអ៊ីស្រាអែលសម្ដែងពីទស្សនៈដ៏ខ្លី ហើយច្បាស់លាស់របស់អ្នក

កត់ត្រាពង្សាវតារ "ចូរឱ្យមានសេចក្ដីជំនឿជឿដល់ព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នាទើបអ្នករាល់គ្នានឹងបានខ្ជាប់ខ្ជួនចូរជឿតាមពួកហោរារបស់ទ្រង់ ទើបអ្នករាល់គ្នានឹងប្រកបដោយចម្រើន "(២របា ២០:២០) ។ នៅក្នុងសៀវភៅកំណត់ត្រារបស់អ្នកកត់ត្រាពង្សាវតារដែលស្ដីពីគ្រាដែលពួកអ៊ីស្រាអែលស្ថិតក្រោមការដឹកនាំរបស់ស្ដេចទាំងឡាយ នោះជាការទទួលខុសត្រូវរបស់គាត់ចំពោះក្រឹត្យវិន័យនិងពួកហោរា គឺមានលក្ខណៈម៉ឹងម៉ាត់ទៅលើវាសនារបស់គាត់ ជាងសម័យកាលរបស់ស្ដេចទាំងនោះ ។

ដូច្នេះហើយក្រឹត្យវិន័យ និងពួកហោរាទាំងអស់នោះ ប្រៀបបានទៅនឹងព្រះវិហារនៃព្រះអម្ចាស់ដែលមានសារៈសំខាន់ជាងវត្តមាន ឬក៏អវត្តមានរបស់ស្ដេចទៅទៀត សម្រាប់ពួកអ៊ីស្រាអែលក្នុងការអាស្រ័យទាក់ទងជាមួយព្រះអម្ចាស់ ។ ពូជពង្សរបស់ដាវីឌផ្ទាស់បានចាប់ផ្ដើមបង្ហាញពីទីបន្ទាល់ដ៏ល្អនេះ ។

៤. អ្នកកត់ត្រាពង្សាវតារបានគូសបញ្ជាក់ពីសារៈសំខាន់ក្នុងការស្ដាប់បង្គាប់ចំពោះក្រឹត្យវិន័យ និងពួកហោរា ដោយបានលើកយកផ្ទៃរឿងនៃការដាក់ទណ្ឌកម្មរបស់ព្រះអម្ចាស់មកពន្យល់បង្ហាញ ។ សូមមើលសេចក្ដីពន្យល់លើសេចក្ដីថ្លែងការណ៍របស់ដាវីឌ (សូមមើល ២៨:៩)ពីព្រះអម្ចាស់(២របា ៧:១៤) និងពួកហោរា(២របា ១២:៥ ១៥:២,៧ ១៦:៧,៩ ១៩:២–៣ ២១:១៤–១៥ ២៥:១៥–១៦ ២៨:៩ ៣៤:២៤–២៨) ។

៥. អ្នកនិពន្ធព្រះគម្ពីរបាក្យត្រមានបំណងប្រាថ្នាជួយគាំទ្រ និងទ្រទ្រង់ចំពោះសេចក្ដីសង្ឃឹមរបស់ប្រជាជនអ៊ីស្រាអែលនូវអ្វីដែលព្រះម៉ែស៊ីបានសន្យា ដោយយោងទៅតាមសេចក្ដីសញ្ញាដែលបានតាំងជាមួយពូជពង្សដាវីឌ(២សយ ជំពូក ៧) និងការធានាអះអាងរបស់ពួកហោរានៃទ្រង់ និងអ្នកជំនិតរបស់ព្រះអម្ចាស់ថែមទៀត(ហាកាយ សាការី និងម៉ាឡាគី) ។ គាត់មានការប្រុងប្រយ័ត្នក្នុងការអំពាវនាវដល់ព្រះអម្ចាស់ម្ដងទៀតសម្រាប់ដាវីឌ(សូមមើល ជំពូក១៧)និងអ្នកឯទៀៗ(ជាពិសេសក្នុងរាជ្យសាឡូម៉ូន និងក្នុង ២របា ១៣:៥ ២១:៧ ២៣:៣) ។ ប៉ុន្តែ ប្រហែលជាការចង្អុលបង្ហាញជាច្រើន ជាគំនិតរបស់គាត់ដែលពណ៌នាពីដាវីឌ សាឡូម៉ូន អាសា យ៉ូសាផាត ហេសេគា និងយ៉ូសៀស ។ នៅពេលដែលមិនបានធ្វើការពណ៌នា វាមិនមែនជាកំហុសនោះឡើយ ព្រោះពូជពង្សរបស់ដាវីឌទាំងនោះជាគំរូឧទាហរណ៍ចម្បងអំពីឧត្ដមគតិពូជពង្សរបស់ម៉ាន៉ាសេ ជាឧទាហរណ៍ ពូជពង្សដែលបានបម្រើដល់ព្រះអម្ចាស់ដែលសម័យកាលរបស់ពួកគេត្រូវបានរាប់ថា ជាអ្នកដែលស្រឡាញ់ និងស្មោះត្រង់ចំពោះសេចក្ដីសញ្ញាក្នុងប្រទេសអ៊ីស្រាអែល ។ ពួកគេត្រូវបានព្រះអម្ចាស់ទ្រង់សព្វព្រះទ័យ ហើយបំពាក់មកុដឱ្យក្លាយជារាស្ត្ររបស់ទ្រង់ ដែលទទួលជ័យជម្នះ ការរំដោះនិងសេចក្ដីសុខសាន្ត ។ មួយវិញទៀតពួកគេបានគង់នៅលើ "បល្ល័ង្កនៃព្រះយេហូវ៉ា"(២៩:២៣ ២៨:៥ ២របា ៩:៨) និងជាអ្នកដែលគ្រប់គ្រងលើនគររបស់ទ្រង់ ហើយរាជ្យអ្នកនោះនឹងជាប់នៅ (សូមមើល ១៧:១៤ ២របា ១៣:៨) ។ ដូច្នេះ ពួកគេគឺជាស្រមោលនៃ"ស្ដេចដាវីឌ"ដែលបានសម្រេចតាមទំនាយដែលពួកហោរាបានទាយនិងដាស់តឿននៃការបង្រៀនរបស់ពួកគេឱ្យមានសេចក្ដីសង្ឃឹមក្នុងពេលមានការធ្លាក់ទឹកចិត្ត (មាននិយាយនៅក្នុងគម្ពីរ ម៉ាឡាគី) ។ សូមមើលពីការពណ៌នា អំពីស្ដេចដាវីឌ និងសាឡូម៉ូន នៅផ្នែកបន្ទាប់ទៀត ។

៦. ផ្ទៃរឿងសំខាន់ៗឯទៀតនៃប្រវត្តិសាស្ត្ររបស់អ្នកកត់ត្រាពង្សាវតារ គឺទំនាក់ទំនងរបស់គាត់ជាមួយ "សាសន៍អ៊ីស្រាអែលទាំងអស់"(សូមមើល ៩:១ ១១:១–៤ ១២:៣៨–៤០ ១៦:១–៣ ១៨:១៤ ២១:១–៥ ២៨:១–៨ ២៩:២១–២៦ ២របា ១:១–៣ ៧:៨–១០ ៩:៣០ ១០:១–៣,១៦ ១២:១ ១៨:១៦ ២៨:២៣ ២៩:២៤ ៣០:១–១៣,២៣–២៧ ៣៤:៦–៩,៣៣) ។ តាមការពិតគាត់បានបង្ហាញពីការស្ថាបនានិរន្តភាពសំណល់ពួកអ៊ីស្រាអែលឡើងវិញ គឺទាំងនគរខាងត្បូង និងនគរខាងជើង(៩:២–៣) ។ បញ្ហាទាំងអស់នេះ គឺមាននិយាយច្រើនជាងលក្ខណៈវិជ្ជាព្រះ ។ និទានកថារបស់គាត់តែងតែកត់ចំណាំការផ្លាស់ប្ដូរលំនៅ និងព្រះរបស់ពួកអ្នកដែលស្រឡាញ់ព្រះពីស្រុកអ៊ីស្រាអែលមករស់ក្នុងស្រុកយូដា ដោយសារហេតុផលនៃសាសនារបស់ពួកគេ ។ អ្នកដែលផ្លាស់ប្ដូរទីលំនៅមុនគេ គឺពួកលេវី ក្នុងសម័យកាលរាជ្យស្ដេចរេហូបោម (២របា ១១:១៤) ។ នៅក្នុងរាជ្យស្ដេចអេសា មានអ្នកខ្លះបានចេញពីពួកអេប្រាអិម និងពួកម៉ាន៉ាសេ(២របា ១៥:៩) ។ ក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពួកអាសើរីបំផ្លាញអាណាចក្រខាងជើងមក ភាគច្រើននៃពួកអ្នកដែលរស់ក្នុងទឹកដីនោះបានមករស់នៅក្នុងស្រុកយូដា ដោយការកោះអញ្ជើញពីសំណាក់ស្ដេចហេសេគា(២របា ជំពូក ៣០) ។ តាមការសន្មត់បាននិយាយថា អាណាចក្រយូដាមិនមែនមានតែពួកអ្នកដែលមកដើម្បីចូលរួមក្នុងពិធីបុណ្យរំលងដែលស្ដេចហេសេគាបានធ្វើឡើយ ប៉ុន្តែអ្នកបុរាណវិជ្ជាបានបង្ហាញការកើនឡើងចំនួនប្រជាជនជាច្រើននៅតំបន់ជុំវិញក្រុងយេរូសាឡិម ក្នុងសម័យកាលនោះ ហើយអ្នកកត់ត្រាពង្សាវតារបាននិយាយពិសេសលើ "ពួកកូនចៅអ៊ីស្រាអែល . . . ដែលនៅអស់ទាំងទីក្រុងស្រុកយូដា"(សូមមើល ២របា ៣១:៦) ។ គាត់ក៏បាននិយាយទៀតថា "ពួកម៉ាន៉ាសេ អេប្រាអិម និងសំណល់អ៊ីស្រាអែលទាំងអស់"ដែលបានចូលរួម" ជាមួយពួកយូដា និងបេនយ៉ាមីន ព្រមទាំងអ្នកក្រុងយេរូសាឡិម" ក្នុងសម័យកាលស្ថាបនាព្រះវិហារឡើងវិញ ក្នុងសម័យកាលស្ដេចយ៉ូសៀស(២របា ៣៤:៩) ។ ដូច្នេះពួកអ្នកទាំងនោះក៏មាននិយាយក្នុងពេល

បុណ្យរំលងដែលយ៉ូសៀសបានរៀបចំដែរ (២របា ៣៥:១៧–១៨) ។ ដូច្នេះហើយស្រុកយូដាមានមនុស្សជាច្រើនបានមករស់នៅចាប់តាំងពីអាណាចក្រខាងជើង ហើយអ្នកកត់ត្រាពង្សាវតារបានបង្ហាញថា គឺជាសំណល់នៃពួកអ៊ីស្រាអែលទាំងអស់ ចាប់តាំងពីពួកសាម៉ារីដួលរលំ ។

៧. ជិនួរវង្សនេះក៏បានបង្ហាញពីនិរន្តភាព កាលពីអតីតកាលដែរ ។ ជាការឆ្លើយតបទៅនឹងសំណួរដែលបានចោទសួរថា "តើព្រះអម្ចាស់ទ្រង់នៅសព្វព្រះទ័យលើយើងដែរឬទេ?"អ្នកកត់ត្រាពង្សាវតារបានឆ្លើយនូវសំណួរនេះថា "ទ្រង់នៅតែសព្វព្រះទ័យនឹងយើងជានិច្ច"។ ព្រះគុណនិងសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ក្នុងការស្ថាបនាប្រទេស និងសហគមន៍នេះឡើងវិញ មិនមែនចាប់ផ្តើមឡើងដោយដាវីឌ ឬការច្បាំងដណ្តើមទឹកដី ឬក៏ការចាកចេញនោះឡើយ ប៉ុន្តែគឺតាមរយៈការបង្កើត(១:១) ។

៨. ជាញឹកញាប់អ្នកកត់ត្រាពង្សាវតារគាត់បានធ្វើការណែនាំបង្ហាញនូវអ្វីគ្មាននិយាយនៅក្នុងគម្ពីរសាំយូអែលនិងពង្សាវតារក្សត្រ ដោយគាត់បានប្រើប្រាស់ពាក្យសំខាន់ៗមួយចំនួនដើម្បីភ្ជាប់ឃ្លា ។ នៅក្នុងគម្ពីរបាក្សត្រមាននិយាយពីការប្រែប្រួលពេលវេលាចំនួន ១៦៥ ដង ហើយមានតែ៩៥ដងប៉ុណ្ណោះដែលស្របទៅនឹងគម្ពីរសាំយូអែល និងពង្សាវតារក្សត្រ ឧ.សុន្ទរកថារបស់ស្តេចអ័បៀយ៉ា(២របា ១៣:៤–១២) អាសា(២របា ១៤:១១) និងយ៉ូសាផាត(២របា ២០:៥–១២)។

## ជីវពណ៌នាអំពីដាវីឌ និងសាឡូម៉ូន

ប្រវត្តិសាស្ត្ររបស់អ្នកកត់ត្រាពង្សាវតារ គឺបង្ហាញពីភក្តីភាពក្នុងរាជ្យរបស់ដាវីឌ(ជិពូក ១១–២៩)និងសាឡូម៉ូន(២របា ១–៩)។ ការពិពណ៌នារបស់គាត់ចំពោះស្តេច២អង្គនេះ គឺមានលក្ខណៈច្បាស់លាស់ និងបង្ហាញពីទំនាក់ទំនងគ្រឹះរបស់គាត់:

១. អ្នកកត់ត្រាពង្សាវតារបានផ្តោតលើចំនុចវិជ្ជមានរបស់ដាវីឌ និងសាឡូម៉ូន ។ នៅក្នុងឯកសារផ្សេងៗទៀតរបស់គាត់ (គម្ពីរសាំយូអែល និងពង្សាវតារ)ដែលអាចនឹងឱ្យមានការស្រពិចស្រពិលលើរូបភាពនៃផ្ទៃរឿងដែលបានលុបចេញ ឬបាត់ ។ គាត់មិនបាននិយាយអំណះអំណាងសង្គ្រាមរវាងពួកផ្ទះសូល និងដាវីឌ ការចរចារជាមួយអ័ប៊ីនើរ ឬក៏ឃាតកម្មចំពោះអ័ប៊ីនើរ និងអ៊ីសបូសែតឡើយ (សូមមើល ២សយ ១–៤) ។ អ្នកកត់ត្រាពង្សាវតារបានបង្ហាញថា ដាវីឌគឺជាស្តេចដែលទទួលការចាក់ប្រេងតាំងឱ្យគ្រប់គ្រងលើស្រុកអ៊ីស្រាអែលបន្ទាប់ពីការស្លាប់របស់ស្តេចសូល(ជិពូក ១១) និងការចូលរួមគាំទ្រពីសំណាក់ប្រជារាស្ត្រ(១០:១០–១២:៤០ សូមមើលការពន្យល់ក្នុង ៣:១–៩) ។ សេចក្តីទុក្ខលំបាករបស់ស្តេចដាវីឌនៅគ្រាបន្តបន្ទាប់ទៀត មិនបាននិយាយឡើងវិញឡើយ ។ អ្វីដែលមិនបាននិយាយឡើងវិញនោះគឺ អំពើបាបរបស់ដាវីឌជាមួយនាងបេត–សេបា បទឧក្រិដ្ឋ និងការស្លាប់របស់អាប់ណូន ការក្បត់របស់អាប់សាឡំម និងគម្រោងការណ៍ក្បត់លើបិតារបស់គាត់ ការចាកចេញពីទីក្រុងយេរ៉ូសាឡិមរបស់ស្តេចដាវីឌ ការបះបោរប្រឆាំងរបស់សេបា និងស៊ីម៉ាយនិងហេតុការណ៍ផ្សេងៗទៀត ដែលអាចនឹងបន្ទាបបន្ថោកដល់កិត្តិយសរាជ្យរបស់ដាវីឌ(២សយ ១១–២០) ។ ដាវីឌគាត់គឺជាម្នាក់ដែលរាប់ថាគ្រប់លក្ខណ៍ មិនចាប់ទោសបាន ។

អ្នកកត់ត្រាពង្សាវតារក៏បានលើកយកសាឡូម៉ូនមកនិយាយក្នុងភាពប្រហាក់ប្រហែលគ្នានេះដែរ ។ សាឡូម៉ូនគឺជាឈ្មោះដ៏ពិសេសមួយ ដែលព្រះអម្ចាស់បានថ្លែងទំនាយថា នឹងក្លាយជាអ្នកស្នងរាជ្យពីដាវីឌ(២២:៧–១០ ២៨:៦) ។ សាឡូម៉ូនត្រូវបានដាវីឌ ជាបិតាប្រកាសជាផ្លូវការ និងទទួលបានការគាំទ្រពីសំណាក់ប្រជាជនទាំងអស់ នៅពេលដែលគាត់ឡើងគ្រងរាជ្យ(ជិពូក ២៨–២៩) ។ ការប្រហារជីវិតរបស់សាឡូម៉ូនចំពោះអ្នកដែលធ្វើខុសនឹងដាវីឌ (១ពវ ជិពូក ២) ក៏មិនបាននិយាយដែរ ។ ការស្នងរាជ្យរបស់សាឡូម៉ូន គឺធ្វើឡើងដោយគ្មានការប្រកួតប្រជែង ឬដោយយថាហេតុណាមួយឡើយ ។ ស្ទើរតែទាំងអស់នៃរឿងរាវក្នុងយុគសម័យកាលរបស់គាត់ គឺជាការពណ៌នាពីភក្តីភាពក្នុងការសាងសង់ព្រះវិហារថ្វាយព្រះយេហូវ៉ា (២របា ២–៨) ។ អ្វីដែលមិនបាននិយាយនោះគឺការកំផិតរបស់គាត់ ប្រពន្ធដែលជាសាសន៍ដទៃ ឬការបះបោរប្រឆាំងពីសំណាក់អ្នកដ៏ទៃក្នុងពេលដែលគាត់គ្រប់គ្រងលើស្រុកអ៊ីស្រាអែល(១ពវ ជិពូក ១១) ។ យេរ៉ូបោមគាត់ទទួលរងទណ្ឌកម្មជិនួសសាឡូម៉ូនពីបទមានការបែកខ្ញែកគ្នា (១ពវ ១១:២៦–៤០ ១២:១–៤) ។ រូបភាពរបស់សាឡូម៉ូនក្នុងគម្ពីរបាក្សត្រគឺគាត់អាចប្រៀបធៀបជាមួយដាវីឌជាបិតារបស់គាត់បាន (២របា ១១:១៧) ។

នៅក្នុងគំនិតរបស់អ្នកកត់ត្រាពង្សាវតារដាវីឌ និងសាឡូម៉ូនមិនគ្រាន់តែជាដាវីឌ និងសាឡូម៉ូនដែលមនុស្សទូរទៅមើលឃើញប៉ុណ្ណោះនោះទេ តែពួកគេតំណាងឱ្យព្រះម៉ែស៊ីទៀតផង ។

២. នៅទីនេះ មិនគ្រាន់តែបង្ហាញពីគំនិតរបស់ដាវីឌ និងសាឡូម៉ូនប៉ុណ្ណោះនោះទេ ប៉ុន្តែក៏បាននិយាយពីអ្នកនិពន្ធ ដែលគាត់មានស្មារតី បានលើកយករឿងការបន្តវង្ស ពីម៉ូសេ មកយ៉ូស្វេ សម្រាប់ជាគំរូដល់ការបន្តរាជ្យរបស់ដាវីឌ និងសាឡូម៉ូន:

ក. ទាំងដាវីឌ ទាំងម៉ូសេ គឺសុទ្ធតែជាអ្នកដែលបរាជ័យក្នុងទិសដៅរបស់ពួកគេ ម្នាក់បរាជ័យក្នុងការសាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់ ហើយម្នាក់ទៀតបរាជ័យដោយមិនបានចូលក្នុងទឹកដីសន្យា ។ ក្នុងរឿងទាំង២នេះហេតុផលដែលព្រះអម្ចាស់ទ្រង់បដិសេធ

ចំពោះពួកគេគឺមានទំនាក់ទំនងទៅនឹងការរៀបចំបន្តរាជ្យ (២២: ៥–១៣ ២៨:២–៨ ចទ ១:៣៧–៣៨ ៣១:២–៨) ។

ខ. ទាំងសាឡូម៉ូន និងលោកយ៉ូស្វេ គឺពួកគេម្នាក់សុទ្ធតែបានធ្វើឱ្យរាស្ត្រនៃព្រះបានទទួលនូវសេចក្ដីសម្រាកពេញលេញ (សូម ២២:៨ –៩ យស ១១:២៣ ២១:៤៤) ។

គ. មានដំណើររឿងជាច្រើននៅក្នុងជីវិតសាឡូម៉ូន ដែលមានភាពប្រហាក់ប្រហែលគ្នានឹងលោកយ៉ូស្វេ (សូមប្រៀបធៀប ២២:១១–១៣,១៦ ២៨:៧–១០,២០ ២រប ១:១ ជាមួយ ចទ ៣១:៥–៨,២៣ យស ១:៥,៧–៩) ។

ឃ. ទាំងលោកយ៉ូស្វេ និងសាឡូម៉ូនសុទ្ធតែទទួលការចាក់ប្រេងតាំងជាលក្ខណៈបុគ្គល និងប្រកាសជាសាធារណៈនៅពេលបន្តតំណែង (២២:៦ ចទ ៣១:២៣) នៅក្នុងចំណោមប្រជាជនអ៊ីស្រាអែល (២៨:៨ ចទ ៣១:៧) ។

ង. ទាំងសាឡូម៉ូន និងលោកយ៉ូស្វេ គឺសុទ្ធតែបានទទួលការគាំទ្រពីសំណាក់ប្រជាជនអ៊ីស្រាអែល (២៩:២៣–២៤ ចទ ៣៤:៩ យស ១:១៦–១៨) ។

ច. មានចំនួន២ដងដែលបាននិយាយថាព្រះអម្ចាស់ទ្រង់ "លើកតម្កើង" ឬ "យ៉ាងក្រៃលែង" (២៩:២៥ ២រប ១:១ យស ៣:៧ ៤:១៤) ។

អ្នកកត់ត្រាពង្សាវតារក៏បានលើកយករឿងផ្សេងៗទៀតដែលមាននិយាយនៅក្នុងកណ្ឌគម្ពីរបញ្ចកណ្ឌមកពណ៌នានៅក្នុងជីវប្រវត្តិរបស់ដាវីឌ និងសាឡូម៉ូន ។ លោកម៉ូសេនិងដាវីឌ បានទទួលគម្រោងការនិងប្លង់មកពីព្រះអម្ចាស់ដើម្បីសាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់ (២៨:១១–១៩ នក ២៥:៩) ហើយបានអំពាវនាវសុំដង្វាយស្ម័គ្រចិត្តពីប្រជាជន ដើម្បីយកដង្វាយទាំងនោះមកសាងសង់ព្រះវិហារ (២៩:១–៩ នក ២៥:១–៧) ។ ទំនាក់ទំនងរបស់សាឡូម៉ូន ជាមួយហ៊ីរ៉ាម ដែលជាជាងជំនាញការមកពីទីក្រុងទីរ៉ុស (២រប ២:១៣–១៤) បានបង្ហាញពីការគ្រប់គ្រងរបស់បេតសាលាល និងអូហូលីអាប់ក្នុងការសាងសង់រោងឧបោសថ (នក ៣៥:៣០–៣៦:៧) ។ សូមមើលការពន្យល់ក្នុង ២រប ១:៥ ។

## ជិនូរវង្ស

តាមរយៈការវិភាគលើជិនូរវង្សទាំងក្រៅ និងក្នុងព្រះគម្ពីរបានបង្ហាញថា ពួកគេមានតួរនាទីផ្សេងគ្នាក្នុងកិច្ចការបម្រើ ។

ពួកគេមានតួរនាទី៣ក្នុងកិច្ចការបម្រើ : ក្រុមគ្រួសារ មានមុខងារក្នុងគោលនយោបាយ និងសាសនា ។ នៅក្នុងគ្រួសារ កិត្តិយសក្នុងសង្គមឯកសិទ្ធនិងការកាតព្វកិច្ចប្រហែលជាបានឆ្លុះបញ្ចាំងពីជិនូរវង្សរបស់គាត់ (សូមមើល ៧:១៤–១៩) សិទ្ធិរបស់កូនច្បង និងសិទ្ធកូនប្រពន្ធចុង គឺបានបង្ហាញនៅទីនេះដោយយកចេញពីព្រះគម្ពីរ ។ គោលនយោបាយដែលមាននៅក្នុងតំណវង្សបង្ហាញពីភស្តុតាងបន្តវេនកិច្ចការបម្រើរ ឬការផ្សះផ្សាការប្រកួតប្រជែងតំណែងគ្នា នៅពេលដែលមន្ត្រីណាមួយឈ្លោះគ្នាពីរឿងនេះ ។ ទឹកដី និងព្រំប្រទល់របស់សហគមន៍នៃបក្សសម្ព័ន្ធប្រហែលជាបានរឹងមាំដោយសារការរាប់បញ្ជីរជិនូរវង្សរបស់គេ ឧ.ការបែងចែកទឹកដីក្នុងចំណោមអំបូរទាំង១២ ។ កិច្ចការបម្រើរបស់ពង្សាវតារ នៅលើផ្នែកសាសនាគឺ

ការប្រៀបធៀបបញ្ជីពង្សាវតារដែលមានអំបូរដូចគ្នា ឬជាមួយក្រុមគ្រួសាររបស់គេ ជាញឹកញាប់គេឃើញមានការខុសគ្នាគួរឱ្យភ្ញាក់ផ្អើល ។ ការបំរែបម្រួលនៃពង្សាវតារទាំងនេះ ប្រហែលជាការសញ្ជឹងគិតលើកិច្ចការបម្រើរដែលមានតួរនាទីផ្សេងៗគ្នា ។ ប៉ុន្តែពេលខ្លះតួរនាទីទាំងនោះមានការប្រែប្រួល ឬក៏មានទំនាក់ទំនងទៅនឹងរចនាសម្ព័ន្ធនៅក្នុងសង្គម ដោយសារមានការផ្លាស់ប្តូរឈ្មោះនៅក្នុងពង្សាវតាររបស់ពួកគេ (សូមមើលការពន្យល់ក្នុង ១:៣៥–៤២ ៦:២២,២៧) ឬក៏ដោយសារតែមានបញ្ចូលបន្ថែមឈ្មោះមួយចំនួនទៀតនៅក្នុងពង្សាវតាររបស់គេ (សូមមើលការពន្យល់ ៥:១១–២២ ៦:២៧ ៧:៦–១២) ។

## គម្រោងអត្ថបទ

**I. ជិនូរវង្ស: ការបង្កើត រហូតដល់គ្រាស្ដាបនាឡើងវិញ (១រប ១–៩)**

ក. ពួកព្ធយុកោ (ជំពូក ១)

ខ. កូនទាំង១២របស់យ៉ាកុប/អ៊ីស្រាអែល (២:១–២)

គ. ក្រុមគ្រួសាររបស់យូដា (២:៣–៤:២៣)

ឃ. កូនរបស់ស៊ីម្មាន (៤:២៤–៤៣)

ង. រូបេន កាដ់ និងអំបូម៉ាន៉ាសេមួយចំហៀង (ជំពូក៥)

ច. ពួកលេវី និងក្រុមគ្រួសាររបស់គេ (ជំពូក៦)

ឆ. អ៊ីសាខារ បេនយ៉ាមីន ណែបថាលី ម៉ាន៉ាសេ អេប្រាអិម និងអ៊ីសាខារ (ជំពូក ៧-៩)

**II. រជ្ជកាលស្ដេចដាវីឌ (១របា ១០-១២)**

ក. ការស្លាប់របស់ស្ដេចសូល (ជំពូក ១០)

ខ. ការចាប់បានក្រុងយេរូសាឡិម អំណាចរបស់ស្ដេចដាវីឌ (ជំពូក ១១-១២)

គ. ការនាំហឹបនៃសេចក្ដីសញ្ញាមកវិញ និងការស្ថាបនានគររបស់ដាវីឌ (ជំពូក១៣-១៦)

ឃ. សេចក្ដីសន្យា (ជំពូក ១៧)

ង. ចម្បាំងដណ្ដើមទឹកដីរបស់ស្ដេចដាវីឌ (ជំពូក១៨-២០)

ច. ការធ្វើជំរឿន (ជំពូក២១)

ឆ. ការរៀបចំកសាងព្រះវិហារ (ជំពូក២២)

ជ. ការរៀបចំកិច្ចការបម្រើក្នុងព្រះវិហារ (ជំពូក ២៣-២៦)

ឈ. រចនាសម្ព័ន្ធប្រព័ន្ធរដ្ឋបាលក្នុងអាណាចក្រ (ជំពូក២៧)

ញ. ការរៀបចំចុងក្រោយសម្រាប់ការស្នងរាជ្យ និងកសាងព្រះវិហាររបស់ស្ដេចដាវីឌ (២៨:១-២៩:២០)

ដ. ការស្នងរាជ្យរបស់សាឡូម៉ូន និងការស្លាប់របស់ដាវីឌ (២៩:១-៣០)

**III. រជ្ជកាលស្ដេចសាឡូម៉ូន (២របា ១-៩)**

ក. អំណោយទាននៃប្រាជ្ញា (ជំពូក ១)

ខ. ការសាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់ (២:១-៥:១)

គ. ការឧទ្ទិសថ្វាយព្រះវិហារទៅចំពោះព្រះអម្ចាស់ (៥:២-៧:២២)

ឃ. សកម្មភាពផ្សេងៗទៀតរបស់ស្ដេចសាឡូម៉ូន (ជំពូក ៨)

ង. ប្រាជ្ញារបស់សាឡូម៉ូន ភាពរុងរឿង និងការសុគតរបស់ទ្រង់ (ជំពូក ៩)

**IV. ការបាក់បែកគ្នា និងប្រវត្តិសាស្ត្ររបស់ស្ដេចស្រុកយូដា (២របា ១០-៣៦)**

ក. រេហូបោម (ជំពូក ១០-១២)

ខ. អ័ប៊ីយ៉ា (១៣:១-១៤:១)

គ. អាសា (១៤:២-១៦:១៤)

ឃ. យេសូផាត (១៧:១-២១:៣)

ង. យ៉ូរ៉ាម និងអ័ហាស៊ីយ៉ា (២១:៤-២២:៩)

ច. យ៉ូអាស (២២:១០-២៤:២៧)

ឆ. អ័ម៉ាស៊ីយ៉ា (ជំពូក ២៥)

ជ. អូសៀស (ជំពូក ២៦)

ឈ. យ៉ូថាម (ជំពូក ២៧)

ញ. អ័ហាប់ (ជំពូក ២៨)

ដ. ហេសេគា (ជំពូក ២៩-៣២)

ឋ.ម៉ាន៉ាសេ (៣៣:១-២០)

ឌ. អាំម៉ូន (៣៣:២១-២៥)

ឍ. យ៉ូសៀស (៣៤:១-៣៦:១)

ណ. អ្នកស្នងរាជ្យបន្ទាប់ពីយ៉ូសៀស (៣៦:២-១៤)

ត. ការនិរទេស និងការស្ថាបនាប្រទេសជាតិឡើងវិញ (៣៦:១៥-២៣)

## កំណត់ត្រាប្រវត្តិសាស្ត្រពីលោកអ័ដាម ដល់លោកអ័ប្រាហាំ

### ចាប់ពីកូនរបស់លោកណូអេ

**១** ១អ័ដាម[ក] សេត អេណុស ២កៃណាន[ខ] ម៉ាលេលាល[គ]
យ៉ារេឌ[ឃ] ៣ហេណុក[ង] មធូសាឡា[ច] ឡាមេក[ឆ] ៤ណូអេ[ជ,ឈ]
សិម ហាំ និងយ៉ាផែត[ញ]។

### ពូជរបស់យ៉ាផែត

*១:៥-៧ – លប ១០:២-៥*

៥កូនរបស់យ៉ាផែត គឺកូមើរ ម៉ាកុក ម៉ាដាយ យ៉ាវ៉ាន
ទូបាល មែសេក និងទីរ៉ាស ៦កូនរបស់កូមើរគឺអាសក្នាស
រីផាត និងតូកាម៉ា ៧កូនរបស់យ៉ាវ៉ាន គឺអេលីសា តើស៊ីស
គីទីម និងដូដានីម ។

### ពូជរបស់ហាំ

*១:៨-១៦ – លប ១-:៦-២០*

៨កូនរបស់ហាំ គឺគូស មីសរ៉ែម ពូត និងកាណាន
៩កូនរបស់គូស គឺសេបា ហាវីឡា សាបតារ៉ាម៉ា និង
សាប់តិកា កូនរបស់រ៉ាម៉ា គឺសេបា និងដេដាន់ ១០ឯគូសក៏
បង្កើតនីមរ៉ូឌ នេះជាអ្នកដែលចាប់តាំងមានអំណាចនៅ
ផែនដី ១១មីសរ៉ែមបង្កើតពួកលូឌីម ពួកអ័ណាមីម ពួក
លេហាប៊ីម ពួកណាបធូហ៊ីម ១២ពួកប៉ាទ្រូស៊ីម និងពួក
កាសលូហ៊ីម(សាសន៍នោះបង្កើតពួកភីលីស្ទីន) ហើយនិង
ពួកកាប់ថោរីម ១៣កាណានបង្កើតស៊ីដូន ជាកូនច្បង និង
ហេត ១៤ហើយទាំងពួកយេប៊ូស ពួកអាម៉ូរី ពួកគើកាស៊ី
១៥ពួកហេវី ពួកអើគី ពួកស៊ីនីត ១៦ពួកអើ វ៉ាឌីត ពួក
សេម៉ារីត និងពួកហាម៉ាធីត ។

### ពូជរបស់សិម

*១:១៧-២៣ – លប ១-:២១-៣១ ១១:១០-២៧*

១៧កូនរបស់សិម គឺអេឡាំ អាសស៊ើរ អើប៉ាក់សាឌ លូឌ
អើរ៉ាម អ៊ូស ហ៊ុល កេធើរ និងមែសេក ១៨អើប៉ាក់សាឌ
បង្កើតសេឡា។បង្កើតហេប៊ើរ ១៩ឯហេប៊ើរ គាត់បង្កើត
បានកូនប្រុស២ មួយឈ្មោះផាលេក ពីព្រោះនៅជំនាន់អ្នក
នោះ ផែនដីបានបែកពីគ្នា ហើយប្អូនគាត់ឈ្មោះ យ៉ុកថាន
២០យ៉ុកថាបង្កើតអាល់ម៉ូដាឌ សេលែប ហាសាម៉ាវែត
យេរ៉ា ២១ហាដូរ៉ាម អ៊ូសាលឌីកឡា ២២អេបាល អ័ប៊ីម៉ែល
សេបា ២៣អូភារ ហាវីឡានឹងយ៉ូបាប់ អ្នកទាំងនោះសុទ្ធតែ
ជាកូនយ៉ុកថាន ។

**១:១** ក លប ៥:១-៣២ លក ៣:៣៦-៣៨
**១:២** ខ លប ៥:៩ គ លប ៥:១២ ឃ លប ៥:១៥
**១:៣** ង លប ៥:១៨ ពច ១:១៤ ច លប ៥:២១ ឆ លប ៥:២៥
**១:៤** ជ លប ៥:២៩ ឈ លប ៦:១០ ១០:១ ញ លប ៥:៣២

**១:១-៩:៤៤** បញ្ជីពង្សាវតារក្សត្រដ៏ខ្លីនេះ បានបង្ហាញពីការស្ដាបនា និរន្តភាពសហគមន៍ឡើងវិញ ដែលបាក់បែកគ្នាកាលពីអតីតកាល ។ ទង្វើរល្អរបស់ព្រះអម្ចាស់ ដែលទ្រង់បានធ្វើចំពោះពួកអ៊ីស្រាអែល ក្នុងអំឡុងពេលដែលព្រះអង្គលើកស្ដេចដាវីឌឡើង បានកន្លងផុតទៅហើយ ប៉ុន្តែបញ្ជីពង្សាវតារដែលជាគ្រោងឆ្អឹងនៃប្រវត្តិសាស្ត្រ បានបង្ហាញថា ការស្ដាបនាឡើងវិញនៃប្រជាជនអ៊ីស្រាអែល គឺជាគោលបំណងរបស់ព្រះអម្ចាស់ តាំងពីដើមរៀងមក (ចាប់តាំងពីអ័ដាម ខ.១) ។ គេបានផ្ដល់គម្រោងតាមរយៈជាតិពន្ធ និងភាពត្រឹមត្រូវនៃសាសនារបស់មនុស្ស ដែលអាចក្លាយជាអំណះអំណាងមួយសម្រាប់ពួកគេ ។ ពួកគេក៏បានស្ដាបនានិរន្តភាពជិនួរវង្សនៃអ្នកស្នងរាជ្យនិងភាពត្រឹមត្រូវរបស់សង្ឃ សម្រាប់បម្រើកិច្ចការងារក្នុងព្រះវិហារបន្តទៀតដែរ ។ សូមមើល សេចក្ដីផ្ដើម: បញ្ជីពង្សាវតារ ។

**១:១-២:១** នៅទីនេះអ្នកកត់ត្រាពង្សាវតារ បានលាតត្រដាងចាប់តាំងសម័យកាលលោកអ័ដាមរហូតដល់លោកយ៉ាកុប ហើយភាគច្រើននៃធនធានឯកសារទាំងនេះគឺយកចេញពីព្រះគម្ពីរលោកុប្បត្តិ ។ ជិនួរវង្សតូចៗទាំងនោះត្រូវបានលើកមកនិយាយមុនគេ: យ៉ាផែត និងហាំ(ខ.៥១៧) អ្នកទាំងនោះត្រូវបានលើកមកនិយាយមុនសិម (សូមមើល ខ.១៧-២៧) ។ កូនចៅរបស់សិមមានចំនួនច្រើនជាងគេទាំងអស់ក្នុងចំណោមពូជពង្សរបស់លោកអ័ប្រាហាំ (មើល ខ.១៧-២៣) ។ នៅមុនជិនួរវង្សនេះ (ខ.២៤-២៧) គឺពិពណ៌នាពីកូនរបស់ប្រពន្ធចុងលោកអ័ប្រាហាំ (ខ.២៨-៣៣) នៅមុនជិនួរវង្សអ៊ីសាក(ខ.៣៤) គឺជាព្ធយុកោរបស់អេសាវ និងពួកអេដំម (ខ.៣៥-៥៤) ដែលបាននិយាយមុនកូនរបស់អ៊ីស្រាអែល(២:១) ។

លក្ខណៈពិសេសជាច្រើននៅក្នុងពង្សាវតារទាំងនេះ ធ្វើឱ្យយើងមានអារម្មណ៍អណ្ដែតអណ្ដូង នៅពេលដែលយើងប្រៀបធៀបជាមួយឯកសារក្រៅព្រះគម្ពីរ ។ ចំនួរវង្សនេះបានចាប់ផ្ដើមនិយាយដោយគ្មានសេចក្ដីផ្ដើមឡើយ ។ មានជិនួរវង្ស២ដែលគ្មានសាច់ញ្ញាត្តិ ដែលមានតែឈ្មោះរបស់ពួកគេប៉ុណ្ណោះ ។ ១៣គ្រួដំបូង (ខ.១-៤ សូមមើលការពន្យល់ ខ.៤) និង ខ.២៤-២៧ និង ខ.៥-១៦(ខ.២៧) គឺមានសាច់ញ្ញាត្តិរបស់ពួកគេ ។ រចនាសម្ព័ន្ធដែលមានលក្ខណៈដូចគ្នាបេះបិទ គឺមាននៅក្នុងឯកសារថតចម្លងរបស់ស្ដេចអាស៊ើ ។ វាគ្មានសេចក្ដីផ្ដើម ឬក៏ការណែនាំឡើយ ហើយអ្នកនិពន្ធបានដកស្រង់ជិនួរវង្សនេះ មកធ្វើការបែងចែកជា៤ផ្នែក ដែលមាន២ជិនួរវង្សមានតែឈ្មោះគ្មានសាច់ញ្ញាត្តិឡើយ ហើយ២ជិនួរវង្សទៀតដែលមានសាច់ញ្ញាត្តិត្រឹមត្រូវ និងក្បោះក្បាយ ។

**១:១-៤** នៅក្នុងខ.ទាំងនេះគឺបានពណ៌នាតាំងពីការបង្កើត រហូតដល់គ្រាទឹកជំនន់ ។ បញ្ជីឈ្មោះរបស់អ្នកទាំងនេះ គឺដកស្រង់ចេញពីព្រះគម្ពីរ លប ៥:១-៣២ (សូមមើល ការពន្យល់នៅទីនេះ) ។ ការលុបចោល កាអ៊ីន និងអេបិល បានបង្ហាញពីចំណាប់អារម្មណ៍របស់អ្នកកាលប្រវត្តិ ក្នុងការជ្រើសរើស (សូមមើល លប ៤:១៧-២៥) ។

**១:៥-២៣** ពង្សាវតារនេះ គឺបានដកស្រង់ចេញពីប្រជាជាតិ ទាំងប៉ុន្មានដែលបាននិយាយនៅក្នុង លប ១០:២-២៩ (សូមមើល ការពន្យល់នៅទីនេះ) ។ ដោយសារការលុបចេញពួកភីលីស្ទីន(ខ.១២)ដែលបាននិយាយនៅក្នុងវង់ក្រចកនោះ ចំនួនប្រជាជាតិសរុបទាំងអស់មានចំនួន៧0គឺ: យ៉ាផែត មាន១៤ ហាំ ៣0 សិមមាន ២៦ (សូមមើល លប ១0:២) ជាឧទាហរណ៍អំពីពង្សាវតារដែលបានរួមបញ្ចូលគ្នា ដើម្បីឱ្យបានចំនួនមនុស្សកើតឡើងរបស់ជិនួរវង្សទាំង៧ (សូមមើលសេចក្ដីផ្ដើម: ពង្សាវតារ) ។

២៤សិម[ដ] អើប៉ាក់សាឌ សេឡា ២៥ហេប៊ើរ ផាលេក
រេហ៊ូវ ២៦សេរូក ណាឃរ ថេរ៉ា ២៧និងអាប់រ៉ាម គឺជា
អ័ប្រាហាំ ។

## គ្រួសាររបស់លោកអ័ប្រាហាំ

២៨ឯកូនអ័ប្រាហាំ គឺអ៊ីសាក និងអ៊ីសម៉ាអែល

## កូនចៅរបស់ហាកា

*១:២៩–៣១ – លប ២៥:១២–១៦*

២៩នេះជាកូនចៅគេ តរៀងទៅ គឺនេបាយ៉ូតជាកូនច្បង
របស់អ៊ីសម៉ាអែល រួចកេដារ អ័ឌុ ប៊ែ្ឌល មីបសាម
៣០មីសម៉ា ឌូម៉ា ម៉ាសា ហាដាឌ់ ថេម៉ា ៣១យេធើរ ណាភីស
នឹងកេតម៉ា នោះសុទ្ធតែជាកូនចៅរបស់អ៊ីសម៉ាអែល ។

## កូនចៅរបស់កិទូរ៉ា

*១:៣២–៣៣ – លប ២៥:១–៤*

៣២ឯកូនរបស់កិទូរ៉ា ជាប្រពន្ធចុងរបស់អ័ប្រាហាំ[ឋ] នាង
បង្កើតបាន ស៊ីមរ៉ាន យ៉ុកសាន មីដាន ម៉ាឌានអ៊ីសបាក់ និង
ស៊ូអា ឯកូនរបស់ យ៉ុកសាន គឺសេបានឹងដេដាន់[ឌ] ៣៣ឯកូន
របស់ម៉ាឌាន គឺអេផា អេភើរ ហេណុក អ័ប៊ីដា និងអែលដ្អា
នោះសុទ្ធតែជាកូនចៅរបស់កិទូរ៉ា ។

## កូនចៅរបស់សារ៉ា

*១:៣៥–៣៧ – លប ៣៦:១០–១៤*

៣៤អ័ប្រាហាំ[ឍ]បង្កើតអ៊ីសាក ឯកូនអ៊ីសាក[ណ] គឺអេសាវ
និងអ៊ីស្រាអែល[ត]

## កូនប្រុសរបស់អេសាវ

៣៥ឯកូនរបស់អេសាវ[ថ] គឺអេលីផាស រេហួល[ទ] យេអ៊ូស
យ៉ាឡាម និងកូរេ ៣៦កូនរបស់អេលីផាស គឺថេម៉ាន អូម៉ារ
សេផូរ កាថាម កេណាស ធីមណា និងអាម៉ាលេក[ធ]
៣៧កូនរបស់រេហួល[ន] គឺណាហាត់ សេរ៉ាស សាំម៉ា និង
មីសសា ។

## កូនចៅរបស់សៀរនៅអេដុំម

*១:៣៨–៤២ – លប ៣៦:២០–២៨*

៣៨កូនរបស់សៀរ គឺឡូថាន សូបាល ស៊ីបៀន អ័ន៉ា
ឌីសុន អេសើរ និងឌីសសាន ៣៩ឯកូនរបស់ឡូថាន គឺហូរី
និងហោម៉ាម ឯធីមណានាងជាប្អូនរបស់ឡូថាន ៤០ឯកូន
របស់សូបាល គឺអាលវ៉ាន ម៉ាន៉ាហាត់ អេបាល សេផូរ
និងអូណាម ឯកូនរបស់ស៊ីបៀន គឺអៃយ៉ា និងអ័ន៉ា[ប] ៤១ឯ
កូនអ័ន៉ា គឺឌីសុន កូនឌីសុន គឺហិបដាន់ អែសបាន់
យីតរ៉ាន និងកេរ៉ាន ៤២ឯកូនរបស់អេសើរ គឺប៊ីលហាន
សាវ៉ាន និងយ៉ាកាន ហើយកូនរបស់ឌីសសាន គឺអ៊ូស និង
អ័រ៉ាន ។

## ស្តេចរបស់ស្រុកអេដុំម

*១:៤៣–៥៤ – លប ៣៦:៣១–៤៣*

៤៣រីឯស្តេចទាំងប៉ុន្មាន ដែលបានសោយរាជ្យ នៅស្រុក
អេដុំម មុនដែលមានស្តេចណាសោយរាជ្យលើពួកកូនចៅ
អ៊ីស្រាអែលនៅឡើយ នោះគឺបេឡា ជាបុត្រាបេអ័រ ហើយ
ទីក្រុងរបស់ទ្រង់នោះ ឈ្មោះឌីនហាបា ៤៤បេឡានក៏សុគត
ទៅ រួចយ៉ូបាប់ ជាបុត្រាសេរ៉ាស ពីក្រុងបុសរ៉ា បានឡើង
សោយរាជ្យជំនួសទ្រង់ ៤៥យ៉ូបាប់ក៏សុគតទៅ រួចហ៊ូសាម
ពីស្រុកសាសន៍ថេម៉ាន[ផ] បានឡើងសោយរាជ្យជំនួសទ្រង់
៤៦ហ៊ូសាមក៏សុគតទៅ រួចហាដាឌ់ ជាបុត្រា បេដាឌ់
បានឡើងសោយរាជ្យជំនួសទ្រង់ ទីក្រុងរបស់ទ្រង់ឈ្មោះ
អាវីតគឺស្តេចនេះហើយដែល វាយសាសន៍ម៉ាឌាននៅវាល
ស្រុកម៉ូអាប់ ៤៧ហេដាឌ់ក៏សុគតទៅ រួចសាំឡាជាអ្នកស្រុក

**១:២៤** ដ លប ១០:២១–២៥ លក ៣:៣៤–៣៦
**១:៣២** ឋ លប ២២:២៤ ឌ លប ១០:៧
**១:៣៤** ឍ លក ៣:៣៤ ណ មថ ១:២ កច ៧:៨ ត លប ១៧:៥
**១:៣៥** ថ លប ៣៦:១៩ ទ លប ៣៦:៤
**១:៣៦** ធ នក ១៧:១៤
**១:៣៧** ន លប ៣៦:១៧
**១:៤០** ប លប ៣៦:២
**១:៤៥** ផ លប ៣៦:១១

**១:២៤–២៧** សូមមើល ១:១–២:១ និង លប ១១:១០–២៦ ។

**១:២៨–៣៤** សូមមើល លប ២៥:១–១៨ ។

**១:៣៥–៤២** សូមមើល លប ៣៦:១០–២៨ ។

**១:៣៦** *កូនរបស់អេលីផាស* កូនរបស់អេលីផាសទាំងនោះ មានទំនាក់ទំនងជាមួយ លប ៣៦:១១–១២ ប៉ុន្តែមានបញ្ហាពិបាកមួយគឺ: អត្ថបទគម្ពីរហេព្រើរក្នុងគម្ពីររបាក្សត្រ (សូមមើលវគ្គទី២នៅក្នុងអត្ថបទគម្ពីរនេះ) បាននិយាយថា ធីមណាគឺជាកូនរបស់អេលីផាស ដែលនៅក្នុងលោកុប្បត្តិ ៣៦:១២ បាននិយាយថា ធីមណាគឺជាប្រពន្ធចុងរបស់អេលីផាសហើយជាម្តាយរបស់អាម៉ាលេកវិញ ។ សិបធ្យូជីន (ការបកប្រែសញ្ញាចាស់របស់គ្រីស្ទបរិស័ទក្រិចជំនាន់មុន) យល់ថា ធីមណាជាម្តាយរបស់អាម៉ាលេកមិនមែនជាកូនរបស់អេលីផាសឡើយ ។ យោងទៅតាមដំណោះស្រាយដែលអាចយកជាការណ៍បាន អត្ថបទគម្ពីរហេព្រើរដែលប្រើនៅទីនេះ គឺមានកំហុសឬមួយអ្នកកត់ត្រាពង្សាវតារបានលុបចេញញ្ញាត្តិសណ្តាន ដែលមានលក្ខណៈប្រជុំសព្ទ (សូមមើល ១:១–២:១ និងខ.៤) ។ អ្នកខ្លះទៀតយល់ថានេះគឺជាឧទាហរណ៍នៃការបំរែបម្រួលពង្សាវតារប៉ុណ្ណោះ (សូមមើលសេចក្តីផ្តើម : ពង្សាវតារ) ។ ក្នុងអំឡុងពេលដែលធីមណាក្លាយជាមេសាសន៍អេដុំម (ខ.៥១ លប ៣៦:៤០) នោះមិនយូរប៉ុន្មានធីមណាបានទៅរស់នៅជាមួយពង្សាវតារនៃសាសន៍អេដុំម ហើយបានក្លាយជាកូនរបស់អេលីផាស និងជាបងប្រុសរបស់អាម៉ាលេក ។

**១:៤៣–៥៤** សូមមើល លប ៣៦:៣១–៤៣ ។ អ្នកកត់ត្រាពង្សាវតារនៅតែបន្តនិយាយអំពីទឹកដីដ៏ធំរបស់ស្រុកអេដុំម ។ សារៈសំខាន់នេះមានការផ្ទុយគ្នានិងអ្វីដែលគាត់បានលុបចេញពីជំនួរវង្សរបស់កាអ៊ីននិងការគំរាមកំហែងក្នុងរយៈពេលខ្លីរបស់អំបូរអ៊ីស្មាអែល ។ ប្រហែលជាអ្នកកត់ត្រាពង្សាវតារចង់និយាយសំដៅលើកត្តាពិតដែលថា ពួកសាសន៍អេដុំមមានសារៈសំខាន់ណាស់ក្នុងសម័យកាលដែលគាត់រស់នៅ (សូមមើល ១៨:១–១៣ ២របា ៨:១៧ ២១:៨ ២៥:២០ ២៨:១៧) ។

ម៉ាសរេកា បានឡើងសោយរាជ្យជំនួសទ្រង់ ៤៨សាំឡាក៏
សុគតទៅ រួចសូល ជាអ្នកស្រុករេហូបូត ដែលនៅមាត់ទន្លេ
នោះបានឡើងសោយរាជ្យជំនួសទ្រង់ ៤៩សូលក៏សុគតទៅ
រួចបាល-ហាន៉ាន់ ជាបុត្រាអ័កបោរ បានឡើងសោយរាជ្យ
ជំនួសទ្រង់ ៥០បាល-ហាន៉ាន់ក៏សុគតទៅ រួចហាដាឌ់បាន
ឡើងសោយរាជ្យជំនួសទ្រង់ទីក្រុង របស់ទ្រង់ឈ្មោះប៉ារ
ហើយព្រះទេពីទ្រង់ព្រះនាមជាមហេថាបែល ជាបុត្រី
ម៉ាតរេឌ ដែលជាកូនមេសាហាប់ ៥១រួចហាដាឌ់ក៏សុគត
ទៅដែរ ។

ឯពួកមេសាសន៍អេដំម នោះគឺធីមណា១ អាលវ៉ា១
យេថេត១ ៥២អ័ហូលីបាម៉ា១ អេឡា១ ពីណូន១
៥៣កេណាស១ ថេម៉ាន១ មីបសារ១ ៥៤ម៉ាកឌាល១និង
អ៊ីរ៉ាម១ នោះសុទ្ធតែជាពួកមេនៃសាសន៍អេដំម ។

## កូនរបស់អ៊ីស្រាអែល

*២:១-២ - លប ៣៥:២៣-២៦*

**២** ១នេះជាកូនរបស់អ៊ីស្រាអែល គឺរូបេន ស៊ីម្មាន
លេវីយូដា អ៊ីសាខារ សាប់យូល៉ូន ២ដាន់ យ៉ូសែប
បេនយ៉ាម៉ីន ណែបថាលី កាឌ់ និងអេស៊ើរ ។

## យូដា

*២:៥-១៥ - នរ ៤:១៨-២២ មថ ១:៣-៦*

## កូនប្រុសរបស់ស្រុន

៣ឯកូនរបស់យូដា[ក] គឺអ៊ើរ អូណាន់ និងសេឡា[ខ]ជាកូន
ទាំង៣ ដែលកូនស្រីរបស់ស៊ូអា[គ] គាត់ជាមនុស្សអាក្រក់ នៅ
ព្រះនេត្រព្រះយេហូវ៉ា ហើយទ្រង់ក៏សំឡាប់ចោលទៅ[ឃ]
៤តាម៉ារ[ង]ជាកូនប្រសាស្រី[ច]យូដា ក៏បង្កើតពេរេស[ឆ] និង
សេរ៉ាសឱ្យគាត់ដែរ ដូច្នេះ កូនរបស់យូដាទាំងអស់មាន
៥នាក់ ។

៥ឯកូនរបស់ពេរេស[ជ] គឺហេស្រុន[ឈ] និងហាមុល ៦កូន
របស់សេរ៉ាស គឺស៊ីមរី អេថាន ហេម៉ាន កាលកូល និង
ដារ៉ាទាំងអស់មាន៥នាក់ ៧កូនរបស់កើមី គឺអេកាន[ញ] ជាអ្នក
ដែលនាំឱ្យមានសេចក្តីវេទនានៅក្នុងពួកអ៊ីស្រាអែលដោយ
បានរំលងច្បាប់ ខាងឯរបស់ដែលត្រូវបំផ្លាញអស់រលីង[ដ]
៨ឯកូនអេថាន គឺអ័សារា ។

៩ឯកូនរបស់ហេស្រុន[ឋ] នោះគឺយេរ៉ាម្អែល រ៉ាម និង
កាលែប ។

## ចាប់ពីរ៉ាមកូនប្រុសរបស់ហេស្រុន

១០រ៉ាម[ឌ] ក៏បង្កើតអ័មីនាដាប់[ឍ] ហើយអ័មីនាដាប់
គាត់បង្កើតណាសូន[ណ] ដែលជាកំពូលលើពួកកូនចៅយូដា

**២:៣** ក លប ២៩:៣៥ ៣៨:២-១០ ខ លប ៣៨:៥ គ លប ៣៨:២ ឃ ជន ២៦:១៩
**២:៤** ង លប ៣៨:១១-៣០ ច លប ១១:៣១ ឆ លប ៣៨:២៩
**២:៥** ជ លប ៤៦:១២ ឈ ជន ២៦:២១
**២:៧** ញ យស ៧:១ ដ យស ៦:១៨
**២:៩** ឋ ជន ២៦:២១
**២:១០** ឌ លក ៣:៣២-៣៣ ឍ នក ៦:២៣ ណ ជន ១:៧

**២:១-២** ទោះបីជាមានចំនួនមនុស្សជាច្រើននៅក្នុងសញ្ញាចាស់ បានកើតចេញពីអំបូរទាំង១២ក៏ដោយមានតែ៤ប៉ុណ្ណោះ ដែលរាប់បញ្ចូលក្នុងទម្រង់នៃពង្សាវតារគឺៈ (ទី១) នៅក្នុងគម្ពីរ លប ២៩:៣១-៣០:២៤ ៣៥:១៦-២០ (ទី២) នៅក្នុងគម្ពីរ លប ៣៥:២២-២៦ (ទី៣) លប ៤៦:៨-២៧ (ទី៤) គឺនៅទីនេះតែម្តង ។ បញ្ជីរឈ្មោះផ្សេងៗទៀតនៃពូជអំបូរទាំង ១២នេះមាននិយាយនៅក្នុង ១២:២៤-៣៧ ២៧:១៦-២២ នក ១:២-៥ ចទ ២៧:១២-១៣ អរ ៤៨:៣១-៣៤ ។ បញ្ជីរឈ្មោះខ្លះៗទៀតរបស់អំបូរលេវីត្រូវបានគេលុបចេញ ហើយចំនួនអំបូរទាំង១២នៅគ្រប់លក្ខណៈ គឺដោយការបែងចែកពូជពង្សយ៉ូសែប ដាក់បញ្ចូលក្នុងអំបូរអេប្រាអិម និងម៉ាន៉ាសេ (សូមមើល ជន ១:៥-១៥ ១:២០-៤៣ ២:៣-៣១ ៧:១២-៨៣ ១០:១៤-២៨ ១៣:៤-១៥ ២៦:៥-៥១) ។ នៅក្នុងអត្ថបទនេះអ្នកកត់ត្រាពង្សវតារបានដកស្រង់ចេញពីគម្ពីរលោកុប្បត្តិ លើកលែងតែតួរនាទីរបស់អំបូរដាន់ប៉ុណ្ណោះដែលស្ថិតក្នុងជំនួរវង្សទី៧ ជំនួសទី៩ ។

**២:៣-៩** វង្សត្រកូលរបស់យូដា គឺបានបន្លាយរហូតដល់កូនប្រុសទាំងអស់របស់ហេស្រុន (មើល ខ.៩) ដែលពួកព្ធយុកោរបស់គេបាននិយាយនៅក្នុង ២:១០-៣:២៤ ។ នៅក្នុងចំណោមកូនទាំង៥របស់យូដាមានកូនច្បង២នាក់ (អ៊ើរនិងអូណាន់) បានស្លាប់ដោយព្រោះអំពើបាបរបស់ពួកគេ ដូចដែលបានកត់ចុះក្នុងគម្ពីរ លក ជំពូក៣៨ ។ សេឡាជាកូនទី៣ត្រូវបានគេលើកតាំងនៅក្នុង ៤:២១ ។ នៅក្នុងផ្នែកនេះ គឺបានផ្តោតទៅលើសំណល់តែ២នាក់ (សូមមើល លប ៤៦:១២ ជន ២៦:១៩-២២) ។

**២:៦** *អេថាន ហេម៉ាន កាលកូល និងដារ៉ា* ពួកគេមិនមែនជាព្ធយុកោរបស់សេរ៉ាក្នុងពេលឥឡូវនេះទេ ទំនងជានៅក្នុងយុគសម័យកាលក្រោយៗមកទៀតក្នុងរាជ្យស្តេចសាឡូម៉ូនវិញ (សូមមើល ១ពវ ៤:៣១) ។ ហេម៉ាន និងអេថាន ពួកគេគឺជាអ្នកលេងភ្លេងរបស់ស្តេចដាវីឌ (សូមមើល ១៥:១៩ ទដ ៨៨-៨៩) ប៉ុន្តែទោះបីជាបែបនេះក៏ដោយក៏មិនប្រាកដថា ពួកគេនោះគឺជាមនុស្សតែមួយនោះឡើយ ។ បើសិនជាគេជាមនុស្សតែមួយមែន នោះអ្វីដែលបាននិយាយនៅក្នុង ៦:៣៣-៤២ និង ១៥:១៩ ដែលថា ហេម៉ូន និងអេថានជាអ្នកដែលបានតម្រូវទុកសម្រាប់អំបូរលេវី នោះប្រហែលជាឧទាហរណ៍ផ្សេងទៀតអំពីពង្សាវតារ ដែលពួកអ្នកជំនាញខាងដូរតន្ត្រីទាំងនោះត្រូវបានគេនាំមកដាក់បញ្ចូលជាមួយពូជពង្សរបស់លេវី ។ ម្យ៉ាងទៀត ការនិយាយស្ទួនបែបនេះអាចកើតឡើងដោយសារពួកលេវីមានទំនាក់ទំនងជាមួយពួកយូដានោះពួកគេត្រូវបានរាប់បញ្ចូលក្នុងវង្សត្រកូលនេះតែម្តង ។

**២:៧** *អេកាន* ការប្តូរឈ្មោះពីអេកា មកអេកានមានន័យថា "នាំសេចក្តីវេទនា" គឺប្រហែលជាការលេងពាក្យដែលសំដៅទៅលើការនាំសេចក្តីវេទនានៅក្នុងពួកអ៊ីស្រាអែល (យូស្វេជំពូក ៧) ។

**២:១០-៣:២៤** នៅក្នុងខ.ទាំងនោះគឺជាការពណ៌នាពីទំនាក់ទំនងគ្រឹះរបស់អ្នកកត់ត្រាពង្សាវតារជាមួយវង្សាវតារយូដាដែលជាជំនួរវង្សរបស់ដាវីឌ ដែលឃើញមាននៅក្នុង ផ្នែកនេះគឺៈ

ពួកកូនចៅរបស់រ៉ាម (ព្ធយុកោរបស់ស្តេចដាវីឌ) ២:១០-១៧
ពួកកូនចៅរបស់កាលែប ២:១៨-២៤
ពួកកូនចៅរបស់យេរ៉ាម្អែល ២:២៥-៣៣
ពួកកូនចៅផ្សេងៗទៀតរបស់យេរ៉ាម្អែល ២:៣៤-៤១

១១ណាសូនក៏បង្កើតសាលម៉ូនៗបង្កើតបូអូស ១២បូអូស[ត]
បង្កើតអូបិឌៗបង្កើតអ៊ីសាយ[ថ] ១៣អ៊ីសាយ[ទ]បង្កើតអេលាប[ធ]
ដែលជាកូនច្បងរបស់អ័ប៊ីនាដាប់ ជាកូនទី២ សាំម៉ាទី៣
១៤នេថានេលទី៤ រ៉ាដាយទី៥ ១៥អូសែមទី៦ នឹងដាវីឌជាទី៧
១៦ឯបងប្អូនស្រីរបស់អ្នកទាំងនោះ គឺសេរូយ៉ា[ន] និងអ័ប៊ីកែល
ឯកូននាងសេរូយ៉ា[ប] គឺអ័ប៊ីសាយ យ៉ូអាប់[ផ] និងអេសាអែល
ទាំងអស់មាន៣នាក់ ១៧ឯនាងអ័ប៊ីកែលក៏បង្កើតអ័ម៉ាសា[ព]
ឪពុកអ័ម៉ាសាឈ្មោះយេធើ ជាសាសន៍អ៊ីសម៉ាអែល ។

## កាលែបជាកូនហេស្រុន

១៨កាលែប ជាកូនហេស្រុន ក៏បង្កើតកុននឹងអ័ស៊ូបា
ប្រពន្ធគាត់ ហើយនិងយេរីអូតដែរ កូនរបស់នាងអ័ស៊ូបា
គឺយេសើរ សុបាប់ និងអើដូន ១៩រួចអ័ស៊ូបានាងស្លាប់ទៅ
ហើយកាលែប[ភ]គាត់យកនាងអេប្រាតាធ្វើជាប្រពន្ធ នាង
នោះបង្កើតហើរឱ្យគាត់ ២០ហើយហើរបង្កើតយូរីៗបង្កើត
បេតសាលាល[ម] ។

២១ក្រោយនោះមក ហេស្រុនក៏ចូលទៅយកកូនស្រីម្នាក់
របស់ម៉ាគារ ជាឪពុកកាឡាត[យ] ធ្វើជាប្រពន្ធ ក្នុងកាល
ដែលគាត់បានអាយុ៦០ឆ្នាំហើយ នាងនោះបង្កើតសេគូប
អោយគាត់ ២២សេគូបបង្កើតយ៉ាអ៊ារ ជាអ្នកដែល មាន
ទីក្រុង២៣នៅស្រុកកាឡាត ២៣ទីក្រុងយ៉ាអ៊ារទាំងនោះ[រ]
និងក្រុងកេណាត[ល] ហើយនិងភូមិនៅជុំវិញផង គឺយក
បានទីក្រុង ពីគេទាំងអស់៦០ ទីក្រុងទាំងនោះជារបស់ផង
ម៉ាគារឪពុកកាឡាត ២៤ក្រោយដែល ហេស្រុនបានស្លាប់
នៅត្រង់ក្រុងកាលែប–អេប្រាតា ហើយនោះអ័ប៊ីយ៉ា ជា
ប្រពន្ធគាត់ ក៏សំរាលកូនអោយគាត់ ឈ្មោះអាសហើរ[វ]
ដែលជាឪពុកត្កូអា ។

## យេរ៉ាម្អែល

២៥ឯកូនរបស់យេរ៉ាម្អែល ជាកូនច្បងហេស្រុន នោះ
គឺរ៉ាមជាកូនច្បង រួចប៊ូណា អូរេន អូសែម និងអ័ហ៊ីយ៉ា
២៦យេរ៉ាម្អែលក៏មានប្រពន្ធ១ទៀតឈ្មោះអ័ថារ៉ា នាងនោះ
ជាម្ដាយអូណាម ២៧ឯកូនរបស់រ៉ាមជា កូនច្បងយេរ៉ាម្អែល
នោះគឺម៉ាអាស យ៉ាមីន និងអេគើរ ២៨កូនរបស់ អូណាម
គឺសាម៉ាយ និងយ៉ាដា ឯកូនរបស់សាម៉ាយ គឺណាដាប
និងអ័ប៊ីស៊ើរ ២៩រីឯប្រពន្ធអ័ប៊ីស៊ើរ នោះឈ្មោះអ័ប៊ីហែល
នាងនោះ បង្កើតអ័បាន់ និងម៉ូលីឌឱ្យគាត់ ៣០ឯកូនរបស់
ណាដាប គឺសេលេឌ និងអ័ផែម តែសេលេឌនេះគាត់
ស្លាប់ទៅឥតមានកូន ៣១កូនរបស់ អ័ផែម គឺអ៊ីស៊ី ហើយកូន
របស់អ៊ីស៊ី គឺសេសាន ឯកូនសេសាន គឺអ័ឡាយ ៣២ឯកូន
របស់យ៉ាដា ជាប្អូនសាម៉ាយ គឺយេធើ និងយ៉ូណាថាន តែ
យេធើគាត់ស្លាប់ទៅឥតមានកូន ៣៣ឯកូនរបស់យូណាថាន
គឺពេលេត និងសាសា នោះសុទ្ធតែជាកូនចៅនៃយេរ៉ាម្អែល
៣៤រីឯសេសានគាត់គ្មានកូនប្រុសទេ មានសុទ្ធតែកូនស្រីវិញ
ក៏មានអ្នកបំរើសាសន៍អេស៊ីព្ទម្នាក់ឈ្មោះយ៉ារហា ៣៥ហើយ
សេសានគាត់អោយកូនស្រីគាត់ ទៅធ្វើជាប្រពន្ធរបស់
យ៉ារហា ជាអ្នកបំរើនោះ នាងបង្កើត អ័ថាយឱ្យអោយ
គាត់ ៣៦ហើយអ័ថាយបង្កើតណាថាន់ៗបង្កើតសាបាឌ[ស]

**២:១២** ត នរ ២:១ ថ នរ ៤:១៧
**២:១៣** ទ នរ ៤:១៧ ធ ១សយ ១៦:៦
**២:១៦** ន ១សយ ២៦:៦ ប ២សយ ២:១៨ ផ ២សយ ២:១៣
**២:១៧** ព ២សយ ១៧:២៥
**២:១៩** ភ ខ.៤២,៥០
**២:២០** ម នក ៣១:២
**២:២១** យ ជន ២៧:១
**២:២៣** រ ជន ៣២:៤១ ចទ ៣:១៤ ល ជន ៣២:៤២
**២:២៤** វ ១របា ៤:៥
**២:៣៦** ស ១របា ១១:៤១

ពួកកូនចៅផ្សេងៗទៀតរបស់កាលែប ២:៤២–៥៥ពួកកូនចៅផ្សេងៗទៀតរបស់រ៉ាម (ព្ធយុកោរបស់ដាវីឌ)ជិពូក៣ អ្នកកត់ត្រាពង្សាវតារបានធ្វើការណែនាំពីចំណែកដ៏សំខាន់របស់ពង្សាវតារយូដានេះ ដើម្បីបង្ហាញពីពូជពង្ស និងពួកព្ធយុកោរបស់ដាវីឌដែលបាននិយាយនៅក្នុងផ្នែកនេះ និងតួនាទីរបស់ដាវីឌ ដែលជាជិន្នូរវង្សមួយដែលមានការចាប់អារម្មណ៍នៅក្នុងប្រវត្តិសាស្ត្រ (សូមមើល ៤:១–២៣) ។

**២:១០–១៧** នៅក្នុងខ.១០–១២ គឺនិយាយពីពង្សាវតារដែលចេញពីរ៉ាមរហូតដល់អ៊ីសាយ ហើយដែលពូជពង្សរបស់អ៊ីសាយ គឺបាននិយាយនៅក្នុង ១សយ ១៦:១–១៣ ។ ភាគច្រើននៃធនធានឯកសារទាំងនោះ គឺបានយកចេញពីគម្ពីរ នរ ៤:១៩–២២ ។ សូមមើល ១សយ ១៦:១០–១៣ ដាវីឌគាត់គឺជាកូនទី៨របស់អ៊ីសាយដែលបានមកឯសាំយូអែលនៅក្នុងអត្ថបទនេះ មានតែ៧នាក់ទេដែលមានឈ្មោះ ។ ដោយសារសមត្ថភាពដ៏ពេញបរិបូរទើបធ្វើឱ្យដាវីឌជិន្នូសកន្លែងបងៗទាំង៧របស់គាត់ (ខ.១៥ សូមមើលសេចក្ដីផ្ដើមៈ ពង្សាវតារ) ។ ដាវីឌគឺជាពូបង្កើតរបស់អ័ប៊ីសាយ យូអាប់ អេសាអែល និងអ័ម៉ាសា ដែលអ្នកទាំងនោះសុទ្ធតែជាអ្នកល្បីខាងធ្វើចម្បាំង ។

**២:១៨–២៤** មនុស្សសំខាន់សម្រាប់អ្នកកត់ត្រាពង្សាវតារ នៅក្នុងពង្សាវតាររបស់កាលែប គឺបេតសាលាល (ខ.២០) គាត់គឺជាអ្នកដែលមានជំនាញផ្នែកសិល្បៈ ហើយជាអ្នកដែលគ្រប់គ្រងរោងឧបោសថ (នក ៣១:១–៥) ។ គាត់បាននិយាយតែនៅក្នុងគម្ពីរនិក្ខមនំនិងរបាក្សត្រប៉ុណ្ណោះ ។ អ្នកកត់ត្រាពង្សាវតារ បានលើកយកឈ្មោះបេតសាលាល និងអូហូលីអាប់ (នក ៣១:៦) គឺសម្រាប់ធ្វើជាគំរូដល់សាឡូម៉ូននិងហើរ៉ាមក្នុងការសាងសង់ព្រះវិហារថ្វាយព្រះយេហូវ៉ា (សូមមើល ២របា ១:៥) ។

**២:២៥–៣៣** នៅក្នុងផ្នែកនេះ គឺនិយាយពីការបំបែកអង្គភាពចេញពីពួកកូនចៅផ្សេងៗទៀតតាមរយៈការចាប់បើកនិងបិទមកវិញនៃរូបមន្ត ដែលបាននិយាយថា "ឯកូនរបស់យេរ៉ាម្អែល"(ខ.២៥)"នោះសុទ្ធតែជាកូនចៅរបស់យេរ៉ាម្អែល"(ខ.៣៣) ។ ខ.២៥–៤១ គឺជាពង្សាវតាររបស់យេរ៉ាម្អែល ។ នៅក្នុង ១សយ ២៧:១០ និង ៣០:២៧–២៩ ពួកគេរស់នៅឯស្រុកត្បូង ។

**២:៣៤–៤១** ចំនួនមនុស្សបន្ថែមលើវង្សត្រកូលសេសាន (ខ.៣១) ពួកគេគឺជាជិន្នូរវង្សទី១៣ ។ បើសិនជាគ្មានអ្វីដែលបង្ហាញច្បាស់លាស់ពីវង្សត្រកូលនេះទេ នោះជិន្នូរវង្សរបស់អេលីសាម៉ាអាចជាជិន្នូរវង្សទី២៣ដោយរាប់ពីយូដាមក ។ បើសិនជាគ្មានឈ្មោះណាមួយ ត្រូវបានដកចេញនោះទេ នោះអេលីសាម៉ា គឺអាចជាមនុស្សដែលរស់នៅជិនាន់ស្ដេចដាវីឌ ទោះបីជាយើងមិនបានដឹងអ្វីអំពីគាត់សោះក៏ដោយ ។

៣៧សាបាឌបង្កើតអែបឡាល អែបឡាលបង្កើតអូបិឌ
៣៨អូបិឌបង្កើតយេហ៊ូវ។បង្កើតអ័សារា ៣៩អ័សារាបង្កើត
ហាលេស។បង្កើតអេឡាសា ៤០អេឡាសាបង្កើតស៊ីសម៉ាយ។
បង្កើតសាលូម ៤១ឯសាលូម គាត់បង្កើតយេកាមា ហើយ
យេកាមាបង្កើតអេលីសាម៉ា ។

## **កូនរបស់កាលែប**

៤២ឯកូនរបស់កាលែប[ហ] ជាប្អូនយេរ៉ាម្អែល នោះគឺ
មេសាជាកូនច្បងដែលជាឪពុកស៊ីភហើយកូន១ទៀតឈ្មោះ
ម៉ារីសា ដែលជាឪពុកហេប្រុន ៤៣កូនរបស់ហេប្រុន គឺកូរេ
ថាពួរ រេគេម និងសាម៉ា ៤៤សេម៉ាបង្កើតរ៉ាហាំ ជាឪពុក
យ៉ូរគាម ហើយរេគេមបង្កើតសាម៉ាយ ៤៥កូនរបស់
សាម៉ាយ គឺម៉ាអូន[ឡ] ហើយម៉ាអូន ជាឪពុកបេត-ស៊ើរ[អ]
៤៦ឯអេផាជាប្រពន្ធចុងរបស់កាលែប នាងបង្កើតបាន
ហារ៉ាន ម៉ូសា និងកាសេស ហើយហារ៉ានបង្កើតកាសេស
៤៧កូនរបស់យ៉ាដាយ គឺរេគេម យ៉ូថាម កេសាន ពេលេត
អេផា និងសាអាប់ ៤៨ឯម្អាកា ជាប្រពន្ធចុងរបស់ កាលែប
នាងបង្កើតសេប៊ើរ និងទាហាណា ៤៩នាងនោះក៏បង្កើត
សាអាប ជាអ្នកតាំងក្រុងម៉ាត់ម៉ាណា[ក] ស៊ីវ៉ា ជាអ្នកតាំងក្រុង
ម៉ាកបេណា ហើយនឹងក្រុងគីបៀរដែរ ឯកូនស្រីកាលែប
នាងឈ្មោះអាកសា[ខ] ។

៥០នេះជាកូនចៅរបស់កាលែប ជាកូនហ៊ើរ[គ] ដែល
ជាកូនច្បងនៃនាងអេប្រាតា គឺសូបាល ជាអ្នកតាំងក្រុង
គារយ៉ាត់-យារីម[ឃ] ៥១សាលម៉ា ជាអ្នកតាំងក្រុងបេថ្លេហិម
ហារេប ជាអ្នកតាំង ក្រុងបេត-កាឌើរ ៥២ហើយសូបាល
ជាអ្នកតាំងក្រុងគារយ៉ាត់-យារីម គាត់ក៏មាន កូនប្រុសដែរ
គឺហារ៉ូអេ និងពួកហាស៊ី-ហាមេនូហូត ៥៣ឯពួកគ្រូនៅក្រុង
គារយ៉ាត់-យារីម គឺពួកយេធើ[ង] ពួកពូធី ពួកស៊ូម៉ាធី
និងពួកមីសរ៉ា ពួកនោះក៏បង្កើតពួកសូរ៉ាត និងអែសថោល
៥៤ឯកូនរបស់ សាលម៉ា គេបង្កើតពួកបេថ្លេហិម ពួកនថូផា[ច]
ពួកអាត្រូត-បេត-យ៉ូអាប់ និងពួកហាស៊ី-ហាម៉ាន៉ាធី
គឺជាពួកសោរីត ៥៥ព្រមទាំងគ្រូពួកស្មៀនទាំងប៉ុន្មាន ដែល
នៅក្រុងយ៉ាបេស គឺពួកធីរ៉ាត ពួកស៊ីម៉ាត និងពួកស៊ូកាត
នេះសុទ្ធតែជាពួកកែន[ឆ]ដែលកើតពីហាម៉ាត[ជ] ជាឪពុកនៃ
ដំនួរវង្សរបស់រេកាប[ឈ] ។

## **កូនរបស់ដាវីឌ**

*៣:១-៤- ២សយ ៣:២-៥*

*៣:៥-៨-២សយ ៥:១៤-១៦ ១រប ១៤:៤-៧*

**៣** ១នេះជាពួកបុត្រារបស់ដាវីឌ[ក] ដែលស្តេចទ្រង់បង្កើត
នៅក្រុងហេប្រុន គឺអាំណូន ជាបុត្រច្បង ដែលកើតពីនាង
អ័ហ៊ីណោម[ខ] ជាអ្នកស្រុកយេសរាល[គ] បុត្រទី២ គឺដានីយ៉ែល
ដែលកើតពីនាងអ័ប៊ីកែល[ឃ] ជាអ្នកស្រុកកើមែល ២ទី៣ គឺ
អាប់សាឡុំម ជាបុត្រនាងម្អាកា ដែលជាបុត្រីតាលម៉ាយ
ស្តេចស្រុកកេស៊ូរី ទី៤ គឺអ័ដូនីយ៉ា[ង] ជាបុត្រនាង ហាគីត ៣ទី៥
គឺសេផាធា ជាបុត្រនាងអ័ប៊ីថាល ទី៦ គឺយីតរាម ដែល
កើតពីនាងអេកឡាជាទេពីទ្រង់ ៤ទ្រង់បង្កើតបុត្រទាំង៦នេះ
នៅក្រុងហេប្រុន[ច] ហើយទ្រង់ក៏សោយរាជ្យនៅក្រុងនោះ
អស់៧ឆ្នាំ៦ខែ[ឆ] រួចសោយរាជ្យនៅក្រុងយេរូសាឡិមអស់
៣៣ឆ្នាំទៀត ៥នៅក្រុងយេរូសាឡិម ទ្រង់ក៏បង្កើតកូនទាំង
នេះ គឺសាំម៉ា សូបាប់ ណាថាន់ និងសាឡូម៉ូន ទាំងអស់មាន
៤អង្គកើតពីនាងបាតសេបា[ជ] ជាបុត្រីរបស់អាំមាល ៦ហើយ

**២:៤២** ហ ខ.១៩
**២:៤៥** ឡ យស ១៥:៥៥ អ យស ១៥:៥៨
**២:៤៩** ក យស ១៥:៣១ ខ យស ១៥:១៦
**២:៥០** គ ១រប ៤:៤ ឃ ខ.១៩
**២:៥៣** ង ២សយ ២៣:៣៨
**២:៥៤** ច អរ ២:២២ នហ ៧:២៦ ១២:២៨
**២:៥៥** ឆ លប ១៥:១៩ ពច ៤:១១ ជ យស ១៩:៣៥ ឈ ២ពវ ១០:១៥,២៣ យរ ៣៥:២-១៩
**៣:១** ក ១រប ១៤:៣ ២៨:៥ ខ ១សយ ២៥:៤៣ គ យស ១៥:៥៦ ឃ ១សយ ២៥:៤២
**៣:២** ង ១ពវ ២:២២
**៣:៤** ច ២សយ ៥:៤ ១រប ២៩:២៧ ឆ ២សយ ៥:៥
**៣:៥** ជ ២សយ ១១:៣

**២:៤២-៥៥** នៅក្នុង ខ.៤២,៥០ក វាគឺជាទម្រង់នៃរូបមន្តបើកនិងបិទដែលមានលក្ខណៈដូចគ្នានិង ខ.២៥,៣៣ ដែលបាននិយាយថា "ឯកូនរបស់កាលែប" (ខ.៤២) "នេះជាកូនចៅរបស់កាលែប" (ខ.៥០ក) ។ ឈ្មោះមនុស្សទាំងនេះគឺជាការល្បាយចូលគ្នានៃបណ្តាមនុស្ស និងទីកន្លែង ។ ឃ្លាដែលនិយាយថា "បង្កើត" ជាញឹកញាប់គួរតែនិយាយថា "ជាអ្នកតាំងក្រុង" វិញ (សូមមើល ១:១០ ៤:៤) ។

**២:៥០-៥៥** នៅក្នុងខ.ទាំងនេះ គឺការបន្តនិយាយពីពង្សាវតាររបស់ហ៊ើរ (ខ.២០) ។ នៅក្នុងផ្នែកនេះក៏មានទម្រង់នៃរូបមន្តដូចគ្នានៅក្នុង ខ.២៥,៣៣ និង ៤២,៥០ក ដែលគេឃើញប្រើនៅក្នុង ខ.៥០ខ និង ៤:៤ ។ "ជាកូនហ៊ើរ . . . សុទ្ធតែជាកូនចៅរបស់ហ៊ើរ" ។ វត្តមានទម្រង់រូបមន្តទាំងនេះបង្ហាញថាផ្នែកនេះនិង ៤:៤ គឺបានបញ្ចូលគ្នាតែមួយ ។ អ្នកកត់ត្រាពង្សាវតារបានកត់ចុះបញ្ជីកូនចៅរបស់ដាវីឌ (ជំពូក៣) ទៅក្នុងសៀវភៅរបស់គាត់ (សូមមើល ២:១០-៣:២៤ ៤:១-២៣) ។ មួយទៀតមូលហេតុនៃការមិននិយាយពីពង្សាវតាររបស់ហ៊ើរ ប្រហែលជាបានកត់ចុះនៅក្នុងសៀវភៅរបស់អ្នកកត់ត្រាពង្សាវតាររួចទៅហើយ ។

**២:៥៥** *ពួកធីរ៉ាត ពួកស៊ីមាត និងពួកសូកាត* ប្រហែលជាចង់និយាយសំដៅទៅលើក្រុមគ្រួសារ៣ ដែលបាននិយាយនៅទីនេះស្រាប់ ឬក៏ពួកអ្នកនិពន្ធ៣នាក់ផ្សេងៗគ្នាដែលអ្នកទាំងនោះអាចជា (ទី១) ជាអ្នកអាន (ទី២) ជាអ្នកថតចម្លង (ទី៣) ជាអ្នកពិនិត្យកិច្ចការ ។ *ពួកកែន* គឺជាជនជាតិដើមដែលពួកគេជាច្រើនបានចូលរួមជាមួយពួកយូដា (សូមមើល ជន ១០:២៩-៣២ ពច ១:១៦ ៤:១១) ។

**៣:១-២៤** សូមមើលការពន្យល់ក្នុង ២:១០-៣:២៤ ។

**៣:១-៩** បញ្ជីឈ្មោះកូនចៅរបស់ដាវីឌនៅទីនេះ គឺភាគច្រើនបានយកចេញពី ២សយ ៣:២-៥ ៥:១៣-១៦ ១៣:១ (សូមមើលការពន្យល់នៅទីនោះ) ។ កូនទាំងប៉ុន្មានរបស់ដាវីឌដែលបានកើតនៅក្រុងយេរូសាឡិម គឺនឹងនិយាយឡើងវិញនៅក្នុង ១រប ១៤:៣-៧ ។ ឈ្មោះរបស់អេលីផាលេត បានលេចឡើង២ដង (ខ.៦,៨) នៅក្នុង ១៤:៥,៧ គឺបាននិយាយអំពីការសរសេរ២យ៉ាងដែលខុសគ្នា (ឈ្មោះតែមួយនៃមនុស្សនេះ គឺនិយាយនៅក្នុង ២សយ

និងយីបហារ អេលីសាម៉ា អេលីផាលេត ៧ណូកា នេផេក
យ៉ាកា ៨អេលីសាម៉ា អេលីយ៉ាដា និងអេលីផាលេត ទាំង
អស់ទ្រង់ក៏មានបុត្រកើតនឹងពួកអ្នកម្នាងថែមទៀត ហើយ
មាននាងតាម៉ារ[ឈ] ជាកនិដ្ឋានៃបុត្រទាំងនោះដែរ[ញ]។

## ពួកស្តេចនៃស្រុកយូដា

១០ឯបុត្ររបស់សាឡូម៉ូន គឺរេហូបោម[ដ] ហើយរេហូបោម
ក៏មានបុត្រ ព្រះនាមជាអ័ប៊ីយ៉ា[ឋ] ៗ មានបុត្រ ព្រះនាមជា
អេសា[ឌ] ៗ មានបុត្រ ព្រះនាមជាយ៉ូសាផាត[ឍ] ១១យ៉ូសាផាត
មានបុត្រ ព្រះនាមជាយ៉ូរាម[ណ] ៗ មានបុត្រ ព្រះនាមជា
អ័ហាស៊ីយ៉ា[ត] ៗ មានបុត្រ ព្រះនាមជា យ៉ូអាស[ថ] ១២យ៉ូអាស
មានបុត្រ ព្រះនាមជា អ័ម៉ាស៊ា[ទ]ៗ មានបុត្រ ព្រះនាមជា
អ័សារា[ធ]ៗ មានបុត្រព្រះនាមជាយ៉ូថាម[ន] ១៣យ៉ូថាមមានបុត្រ
ព្រះនាមជា អ័ហាស[ប] ៗ មានបុត្រ ព្រះនាមជា ហេសេគា[ផ] ៗ
មានបុត្រ ព្រះនាមជា ម៉ាន៉ាសេ[ព] ១៤ម៉ាន៉ាសេ មានបុត្រ
ព្រះនាមជា អាំម៉ូន[ភ]ៗ មានបុត្រព្រះនាមជា យ៉ូសៀស[ម]។

១៥យ៉ូសៀសក៏មានបុត្រ ឯបុត្រច្បង ព្រះនាមជា
យ៉ូហាណាន បុត្រទី២ ព្រះនាមជាយេហូយ៉ាគីម[យ] ទី៣
សេដេគា[រ] ទី៤សាលូម[ល] ១៦ឯបុត្ររបស់យេហូយ៉ាគីម[វ] គឺ
យេកូនាស ៗមានបុត្រ ព្រះនាមជាសេដេគា[ស]។

## ខ្សែរាជ្យត្រនៅក្រោយពេលនិរទេស

១៧ឯបុត្ររបស់យេកូនាស ដែលជាប់ជាឈ្លើយ គឺ
សាលធាល[ហ] ១៨នឹងម៉ាលគីរ៉ាម ពេដាយ៉ា សេណាសារ[ឡ]
យេកាមា ហូសាម៉ា និងនេដាបយ៉ា[អ] ១៩ឯបុត្ររបស់ពេដាយ៉ា
គឺសូរ៉ូបាបិល[ក] និងស៊ីម៉ាយ បុត្រ សូរ៉ូបាបិល គឺមស៊ូឡាម

**៣:៩** ឈ ២សយ ១៣:១ ញ ១រប ១៤:៤ **៣:១០** ដ ១ពវ ១៤:២១–៣១ ២រប ១២:១៦ ឋ ១ពវ ១៥:១–៨ ២រប ១៣:១ ឌ ១ពវ ១៥:៩–២៤ ឍ ២រប ១៧:១–២១:៣ **៣:១១** ណ ២ពវ ៨:១៦–២៤ ២រប ២១:១ ត ២ពវ ៨:២៥–១០:១៤ ២រប ២២:១–១០ ថ ២ពវ ១:១–១២:២១ ២រប ធ ២ពវ ១៥:១–៧ ២រប ២៦:១–២៣
ន ២ពវ ១៥:៣២–៣៨ ២រប ២៧:១ អស ១:១ ហស ១:១ មីក ១:១ ២២:១១–២៤:២៧ **៣:១២** ទ ២ពវ ១៤:១–២២ ២រប ២៥:១–២៨ **៣:១៣** ប ២ពវ ១៦:១–២០ ២រប ២៨:១ អស ៧:១៨ ២ពវ ១៨:១–២០:២១ ២រប ២៩:១ អស ១:១ យរ ២៦:១៩ ហស ១:១ មីក ១:១ ព ២ពវ ២១:១–១៨ ២រប ៣៣:១**៣:១៤** ភ ២ពវ ២១:១៩–២៦ ២រប ៣៣:២១ សផ ១:១ ម ២ពវ ២២:១ ២រប ៣៤:១ យរ ១:២ ៣:៦ ២៥:៣ **៣:១៥** យ ២ពវ ២៣:៣៤ រ យរ ៣៧:១ ល ២ពវ ២៣:៣១ **៣:១៦** វ ២ពវ ២៤:៦,៨ ស ២ពវ ២៤:១៨ **៣:១៧** ហ អរ ៣:២ **៣:១៨** ឡ អរ ១:៨ ៥:១៤ អ យរ ២២:៣០ **៣:១៩** ក អរ ២:២

៥:១៤–១៦) ។ ការនិយាយសំដៅថា ដាវីឌគ្រប់គ្រងនៅហេប្រុនអស់៧ឆ្នាំ និងលើកយកមកនិយាយម្តងទៀតនៅក្នុង ២៩:២៧ ទោះបីជាអ្នកកាលប្បវត្តិ មិនបាននិយាយឱ្យលំអិតពីពេលវេលានោះក្នុងនិទានកថាក៏ដោយ ។ អំណះអំណាងថា អាប់សាឡុំម តាម៉ារ អ័ដូនីយ៉ា អាំម៉ូន និងបេតសេបា ដែលពួកគេទាំងអស់ មិនបានសប្បាយចិត្តម្តងទៀត ចំពោះឧប្បត្តហេតុដែលកើតឡើងចំពោះជីវិតដាវីឌនោះអ្នកកត់ត្រាពង្សាវតារបានលុបចេញពីនិទានកថារបស់គាត់ហើយ (សូមមើល ២សយ ១១–១៥,១៧–១៨ ១ពវ ជំពូក១) ។

**៣:១០** *រេហូបោម* សូមមើល ២រប ១០–១២ និង ១១:១–២៣ ។ *អ័ប៊ីយ៉ា* សូមមើល ២រប ១៣:១–១៤ ។ *អេសា* សូមមើល ២រប ១៤:២–១៦:១៤ ។ *យ៉ូសាផាត* សូមមើល ២រប ១៧:១–២១:៣ ។

**៣:១១** *យ៉ូរ៉ាម* សូមមើល ២រប ២១ ។ *អ័ហាស៊ីយ៉ា* មើល ២រប ២២:១–៩ *យ៉ូអាស* សូមមើល ២រប ២៣:១–២៤:២៧ ។

**៣:១២** *អ័ម៉ាស៊ា* សូមមើល ២រប ២៥:១–២៨ ។ *អ័សារ៉ា* ឈ្មោះនេះគេហៅម្យ៉ាងទៀតថា អ័សារា (សូមមើល ២រប ២៦:១–២៣) ។ *យ៉ូថាម* សូមមើល ២រប ២៧ និង២ពវ ១៥:២៣–២៨ ។

**៣:១៣** *អ័ហាស* សូមមើល ២រប ២៨:១–២៧ ។ *ហេសេគា* សូមមើល ២រប ២៩:១–៣១:១៣ ។ *ម៉ាន៉ាសេ* សូមមើល ២រប ៣៣:១–២០ ។

**៣:១៤** *អាំម៉ូន* សូមមើល ២រប ៣៣:២១–២៥ ។ *យ៉ូសៀស* សូមមើល ២រប ៣៤:១–៣៦:១ ។

**៣:១៥** *ឯបុត្រច្បង នោះព្រះនាមជាយ៉ូហាណាន* ឈ្មោះនេះមិនត្រូវបាននិយាយនៅកន្លែងណាផ្សេងឡើយ ហើយប្រហែលជាគាត់ស្លាប់មុនយ៉ូសៀសទៅទៀត ។ ពូជពង្សាវតារមួយចំណែកដ៏តូចក្នុងចំនុចនេះ គឺបានរាប់បញ្ចូលជាមួយជិនួរវង្សនៅក្នុងខ.១០–១៤ ។ ក្នុងអំឡុងពេលដែលកូន៣នាក់ផ្សេងទៀតរបស់យ៉ូសៀស ដែលអាចនឹងទទួលស្នងដំណែង នោះការស្នងត្រកូលមិនមែនជាការផ្លាស់ប្តូររាជ្យត្រឹមត្រូវ ពីបិតាទៅបុត្រនោះឡើយ ។ សាឡូមយ៉ូអាហាស(២រប ៣៦:២–៤ ២ពវ ២៣:៣០–៣៥)ត្រូវបានយេហូយ៉ាគីមជាអ្នកជំនួសកន្លែងគាត់វិញ(មើល ២រប ៣៦:៥–៨ ២ពវ ២៣:៣៤–២៤:៦) ហើយក្រោយមកទៀតយ៉ូយ៉ាគីនជាបុត្ររបស់គាត់ (យេហូយ៉ាគីម) បានឡើងស្នងរាជ្យបន្តរទៀត (២រប ៣៦:៩–១០ ២ពវ ២៤:៨–១៦) ។ បន្ទាប់ពីនេប៊ូក្នេសាចាប់យកយ៉ូយ៉ាគីនទៅក្រុងបាប៊ីឡូនមកនោះ សេដេគាជាកូនយ៉ូសៀសគាត់ក្លាយជាស្តេចចុងក្រោយនៅក្នុងស្រុកយូដា (សូមមើល ២រប ៣៦:១១–១៤ ២ពវ ២៤:១៧–២៥:៧) ។

**៣:១៧–២០** មានកូនប្រុស៧នាក់សម្រាប់ស្នងរាជ្យពីយេហូយ៉ាគីន ប៉ុន្តែបែជាគ្មាននរណាម្នាក់ស្នងរាជ្យពីគាត់បានឡើយ (មើល ខ.១៥ យរ ២២:៣០) សិលាចារិកមួយនៅក្នុងប្រទេសបាប៊ីឡូន ដែលមានកំណើតនៅក្នុងឆ្នាំទី១០ ដល់ទី៣៥ ក្នុងរាជ្យស្តេចនេប៊ូក្នេសា (៥៩៩–៥៧០ មុន គ.ស) និងចំនួនឈ្មោះអ្នកដែលបានរំដោះ បាននិយាយផ្តោតលើយ៉ូយ៉ាគីន និងកូនប្រុសរបស់គាត់៥នាក់និងពួកជនជាតិយូដាឯទៀតៗគឺបានដោះលែងនៅឆ្នាំនោះឯង ។ យ៉ូយ៉ាគីនគាត់បានទទួលការប្រោសប្រណីពីអេវីល–មេរ៉ូដាក ដែលជាអ្នកបន្តរាជ្យពីនេប៊ូក្នេសា (៥៦២–៥៦០ មុន គ.ស សូមមើល ២សយ ២៥:២៧–៣០) ។

**៣:១៨** *សេណាសារ* ប្រហែលជាសរសេរម្យ៉ាងទៀតនៃឈ្មោះសេសបាសារ បើសិនគេជាមនុស្សតែមួយមែន នោះគាត់គឺជាអ្នកបញ្ជូនទ្រព្យសម្បត្តិរបស់ព្រះវិហារមកស្រុកយូដាវិញ (អរ ១:១១) ។ គាត់ក៏បានបម្រើការងារជាចៅហ្វាយខេត្តក្នុងរយៈពេលដ៏ខ្លីមួយ ហើយគាត់ជាអ្នកសាងសង់ជើងជញ្ជាំងព្រះវិហារឡើងវិញ (អរ ៥:១៤–១៦) ។ មានព័ត៌មានតិចតួចពីគាត់ថា គាត់បានបាត់ខ្លួនចេញពីរឿងនេះ ហើយជំនួសមកវិញដោយក្មួយប្រុសរបស់គាត់ឈ្មោះសេរ៉ូបាបិល ដែលគាត់ជាតួរអង្គដ៏សំខាន់នៅក្នុងគម្ពីរ អែសរ៉ាហាកាយ និងសាការី ។ ប៉ុន្តែសូមមើល ការពន្យល់ក្នុង អរ ១:៨ ។

**៣:១៩** *ពេដាយ៉ា* នៅកន្លែងនេះបាននិយាយថា ពេដាយ៉ា ជាឪពុករបស់សូរ៉ូបាបិល តែនៅក្នុងអត្ថបទខ្លះទៀត បាននិយាយថា ឈ្មោះសាលធាស (មើល ខ.១៧) គឺជាឪពុករបស់សូរ៉ូបាបិលវិញ(សូមមើល អរ ៣:២,៨ នហ ១២:១

នឹងហាណានា ហើយសឡូមិត នាងជាកនិដ្ឋាន របស់បុត្រ
ទាំង២នោះ [២០]ព្រមទាំង ហាស៊ូបា អូហែល បេរេគា ហា
សាឌា និងយ៉ាសាប-ហេសេឌ ទាំងអស់មាន៥អង្គ [២១]ឯបុត្រ
របស់ហាណានា គឺពេឡាធា និងអេសាយ រួចមានបុត្រទាំង
ប៉ុន្មានរបស់រេផាយ៉ា អើណាន អបាឌា និងសេកានា
[២២]ឯបុត្ររបស់សេកានា គឺសេម៉ាយ៉ា ហើយបុត្ររបស់
សេម៉ាយ៉ា គឺហាធូស[ខ] យីកាល បារីយ៉ា នារីយ៉ា និង
សាផាត ទាំងអស់មាន៦អង្គ [២៣]ឯបុត្ររបស់នារីយ៉ា គឺ
អេលីយ៉ូន៉ាយ ហេសេគា នឹងអាសរីកាមទាំងអស់មាន៣អង្គ
[២៤]ឯបុត្ររបស់អេលីយ៉ូន៉ាយ គឺហូដាវា អេលាសីប
ពេឡាយ៉ា អ័កកាប យ៉ូហាណាន ដេឡាយ៉ា និងអ័ណានី
ទាំងអស់មាន៧អង្គ ។

## កូនដទៃទៀតរបស់យូដា

**៤** [១]ឯកូនរបស់យូដា[ក] គឺពេរេស ហេស្រុន[ខ]កើមីហើរ
និងសូបាល [២]ឯរីអាយ៉ា ជាកូនសូបាល គាត់បង្កើតយ៉ាហាត
ហើយយ៉ាហាតបង្កើតអ័ហ៊ូម៉ាយ និងឡាហាឌនេះហើយ
ជាគ្រួនៃពួកសូរ៉ាត [៣]ឯពួកអ្នកដែលកើតពីឪពុករបស់
អេថាម គឺយេសរាល យីសម៉ា និងយីឌបាស ហើយប្អូនស្រី
របស់គេ នាងឈ្មោះហាសលែល-ពូនី [៤]ឯពេនួលជាអ្នក
តាំងក្រុងកេដោរ ហើយអេសើរជាអ្នកតាំងក្រុងហ៊ូសា[គ]
នោះសុទ្ធតែជាកូនចៅរបស់ហើរ ជាកូនច្បងនៃនាង
អេប្រាតា ហើយជាអ្នកតាំងក្រុងបេថ្លេហិម[ឃ] ។
[៥]ឯអាសហើ[ង] ជាអ្នកតាំងក្រុងត្កូអា គាត់មានប្រពន្ធ២
មួយឈ្មោះហេឡា ហើយមួយឈ្មោះណាអារ៉ា [៦]នាង
ណាអារ៉ាបង្កើតបានអ័ហ៊ូ សាម ហេភើរ ថេម៉ានី និង
អ័ហាសថារីឱ្យគាត់ នោះសុទ្ធតែជាកូនរបស់ នាងណាអារ៉ា
ទាំងប៉ុន្មាន [៧]ឯកូនរបស់ហេឡា គឺសេរ៉ែត សូហារ និង
អេតណាន [៨]ឯកោស គាត់បង្កើតអ័នូប និងសូបេបា ហើយ
និងគ្រួ អ័ខាអែល ជាកូនហារូម ។
[៩]ឯយ៉ាបេស គាត់ជាមនុស្សដែលគេរាប់អាន លើសជាង
ពួកបង ប្អូនគាត់ ម្តាយបានឱ្យឈ្មោះថា យ៉ាបេសដោយថា
ពីព្រោះខ្ញុំបានបង្កើតវាមក ដោយមានចិត្តព្រួយ [១០]យ៉ាបេស

៣:២ ៥:២ នហ ៧:៧ ១២:១ ហក ១:១ ២:២ សក ៤:៦
**៣:២២** ខ អរ ៨:២-៣
**៤:១** ក លប ២៩:៣៥ ១រប ២:៣ ខ ជន ២៦:២១
**៤:៤** គ ១រប ២:៥០ ឃ នរ ១:១៩
**៤:៥** ង ១រប ២:២៤

ហក ១:១,១២,១៤ ២:២,២៣) ។ ការឆ្លើយតបចំពោះបញ្ហាដ៏ពិបាកនេះគឺ: (ទី១) សាលធាសប្រហែលជាគាត់បានស្លាប់កាលពីគ្រាមុន ហើយពេដាយ៉ាក្លាយជាមេគ្រួសារ (ទី២) ប្រហែលជាពេដាយ៉ាគាត់បានរៀបការជាមួយប្រពន្ធរបស់សាលធាសជាស្ត្រីមេម៉ាយគ្មានកូន ហើយដោយយោងទៅតាមច្បាប់រៀបការជាមួយប្អូនថ្លៃ នោះសូរ៉ូបាបិលត្រូវមានឈ្មោះថាជាកូនរបស់សាលធាស(សូមមើល ចទ ២៥:៥-៦ ។ នៅក្នុង លក ៣:២ នេរីជិន្ទួសឱ្យយេហូយ៉ាគីន(១រប ៣:១៧)ដោយនិយាយថា នេរីជាឪពុករបស់សាលធាសមានការគួរឱ្យកត់សំគាល់ដូច្នេះថា ជិន្នូរវង្សរបស់ព្រះយេស៊ូវនៅក្នុង មថ ជំពូក១ និងលក ជំពូក៣ គឺបានកើតចេញពីសូរ៉ូបាបិល ប៉ុន្តែគ្មាននរណាម្នាក់ស្នងត្រកូលពីសូរ៉ូបាបិលឡើយ (មើល ខ.១៩-២៤) ។

**៣:២០** *ទាំងអស់មាន៥អង្គ* ពួកគេទាំងនោះប្រហែលជាកូនសូរ៉ូបាបិល ប៉ុន្តែពួកគេគ្មានសាច់ញ្ញាត្តិឡើយ ។ នៅពេលដែលកូនរបស់ហាណានា (ខ.១៩) បាននិយាយយ៉ាងច្បាស់នៅក្នុង ខ.២១ ពួកគេក៏អាចជាកូនរបស់មស៊ូឡាម (ខ.១៩) ។

**៣:២១** *រេផាយ៉ា . . . សេកានា* ពួកគេប្រហែលជាកូនចៅនៃក្រុមគ្រួសាររបស់ដាវីឌផ្សេងទៀតដែលរស់ក្នុងអំឡុងគ្រាសូរ៉ូបាបិល(ខ.១៩)ឬពេឡាធា និងយ៉ូសៀស ។ បើសិនជាពួកគេរស់នៅក្នុងជំនាន់ជាមួយសូរ៉ូបាបិល នោះជិន្នូរវង្សរបស់គាត់គឺអាចមានឈ្មោះតែ២ដំណរប៉ុណ្ណោះ(កូនរបស់គាត់ និងចៅរបស់គាត់) នោះសម័យកាលនៃការសរសេរគម្ពីររបាក្សត្រគឺក្នុងឆ្នាំ ៤៥០ មុន គ.ស គឺពិតជាត្រឹមត្រូវ (សូមមើលសេចក្តីផ្តើម: អ្នកនិពន្ធកាលបរិច្ឆេទនិងប្រភព) ។

**៣:២២** *ទាំងអស់មាន៦អង្គ* សេម៉ាយ៉ាគាត់មានកូនសរុបចំនួន៦នាក់ ប៉ុន្តែមាននិយាយតែ៥នាក់ប៉ុណ្ណោះ ។ មានម្នាក់ក្នុងចំណោមទាំង៦បានបាត់ខ្លួន ឬមួយសេម៉ាយ៉ារាប់ខ្លួនឯងថា ជាបងប្រុសរបស់អ្នកទាំង៥នោះ ។

**៤:១-២៣** គ្មាននរណាម្នាក់នៃជិន្នូរវង្សរបស់យូដានៅក្នុងផ្នែកនេះឬបានឃើញនៅកន្លែងណាផ្សេងទៀតនៅក្នុងបទគម្ពីរឡើយ ។ ទោះបីជានៅក្នុងផ្នែកនេះអាចធ្វើឱ្យមានការកត់សំគាល់ខ្លះៗ ។ ទ្រង់ទ្រាយនៃពង្សាវតារនេះ គឺបានផ្តល់ជាពន្លឺលើសលប់ ពីរចនាសម្ពន្ធ័របស់ពង្សាវតារវិលច្រាសរបស់យូដាដូចតទៅ :

| | |
|---|---|
| ២:៣ | សេឡា |
| ២:៤-៨ | ពេរេស |
| ២:៩-៣:២៤ | ហេស្រុន |
| ៤:១-២០ | ពេរេស |

៤:២១-២៣ សេឡាតុល្យភាពនៃការវិលច្រាសនេះ គឺដើម្បីបង្ហាញពីសេចក្តីពិតក្នុងពង្សាវតាររបស់ហេស្រុន ហើយនិងតំណាក់ដាវីឌ ។ មួយវិញទៀត គឺដើម្បីឱ្យគេបានធ្វើការអង្កេតមើលយុគសម័យកាលហេស្រុន (សូមមើល ២:១០-៣:២៤) ។ ការកត់ចុះពីសេឡាជាកូនប្រុសច្បងរបស់យូដាបានបង្ហាញពីពង្សាវតាររបស់យូដាទាំងមូល ។ មានការបែកជិន្នូរវង្សជា១៥ ចំណែកនៅក្នុងផ្នែកនេះដែលមានពី ២-៦ នាក់ក្នុងមួយជិន្នូរវង្ស ។

**៤:១-២** ពួកឰយុកោរបស់យូដានៅទីនេះ គឺមិនមែនជាបងប្អូននឹងគ្នាឡើយ ប៉ុន្តែបែបដូចជាជិន្នូរវង្សវិញ ។

**៤:១** *កើមើ* ប្រហែលជាអ្នកនិពន្ធច្រឡំ ឬមានការប្តូរឈ្មោះរបស់កាលែប (សូមមើល ២:៩) ការច្រឡំនេះប្រហែលតាំងពី ២:៧ មកម្ល៉េះ ។

**៤:២** *រីអាយ៉ា* ប្តូរពីឈ្មោះហារ៉ូអេ (សូមមើល ២:៥២) ។

**៤:៥-៨** ព័ត៌មានបន្ថែមលើ ២:២៤ ។

**៤:៩-១០** ការបញ្ចូលប្រវត្តិសាស្ត្រខ្លីមួយទៅក្នុងពង្សាវតារ គឺដើម្បីបញ្ជាក់ពង្សាវតារក្រៅព្រះគម្ពីរ នៅមជ្ឈិមបូព៌ា រួមទាំងពង្សាវតារដែលមាននៅក្នុងព្រះម្ពីរផងដែរ (មើល លប ៤:១៩-២៤ ១០:៨-១២) ។

នេះ គាត់បានអំពាវនាវ ដល់ព្រះនៃសាសន៍អ៊ីស្រាអែលថា
ឱបើទ្រង់នឹងប្រទានពរមកទូលបង្គំទៅអេះ ព្រមទាំងវាត
ព្រំដែនរបស់ទូលបង្គំ ឱ្យទូលាយឡើង ហើយឱ្យព្រះហស្ត
ទ្រង់បាននៅជាមួយនឹងទូលបង្គំ ដើម្បីនឹងរក្សាទូលបង្គំ មិន
ឱ្យប្រព្រឹត្តអាក្រក់ឡើយ ប្រយោជន៍មិនឱ្យទូលបង្គំកើតចិត្ត
ព្រួយ ព្រះទ្រង់ក៏ប្រោសប្រទានដល់គាត់ដូចជាបានសូម
១១ ឯកេលូបជាប្អូនស៊ូហា គាត់បង្កើតមហ៊ារ ដែលជាឪពុក
អែសថូន ១២ អែសថូនបង្កើតបេតរ៉ាផា ផាសហា និង
ថេហ៊ីណា ដែលជាអ្នកតាំងក្រុងណាហាស នោះសុទ្ធតែជា
ពួកអ្នកនៅត្រង់រេកា ១៣ ឯកូនរបស់កេណាស គឺអូធ្នាល[ច]
និងសេរ៉ាយ៉ា កូនរបស់អូធ្នាល គឺហាផាត ១៤ ឯមេវណូថាយ
គាត់បង្កើតអូប្រាសេរ៉ា យ៉ាបង្កើតយ៉ូអាប់ ជាអ្នកតាំងដំបន់
នៃពួកនៅច្រកភ្នំហារ៉ាស៊ីម ពីព្រោះ គេសុទ្ធតែជាពួកជាង
រចនា ១៥ ឯកូនរបស់កាលែប ជាកូនយេភូនេ គឺអ៊ីរូវ អេឡា
និងណាអាម ឯកូនរបស់អេឡា គឺកេណាស ១៦ ឯកូនរបស់
យេហាលែល គឺស៊ីភ ស៊ីផា ធារីយ៉ា និងអ័សើរ៉ែល ១៧ ឯ
កូនរបស់ អែសរ៉ា គឺយេធើ ម៉ារេឌ អេភើរ និងយ៉ាឡូន
ហើយប្រពន្ធរបស់ ម៉ារេឌបង្កើតបានម៉ារាម[ឆ] សាម៉ាយ
និងយីសបា ដែលជាអ្នកតាំងក្រុងអែសធេម៉ូរ ១៨ ឯប្រពន្ធ
គាត់ ដែលជាសាសន៍យូដា នាងបង្កើតយេរេឌ ជាអ្នកតាំង
ក្រុងកេដោរ និងហេប៊ើរ ជាអ្នកតាំងក្រុងសូគរ ហើយ
យេគូធាល ជាអ្នកតាំងក្រុងសាណូអា[ជ] នេះសុទ្ធតែជាកូន
របស់ប៊ីធា បុត្រីផារ៉ោន ដែលយេរេឌបានយកធ្វើជាប្រពន្ធ
១៩ ឯកូនរបស់ប្រពន្ធហូឌា ដែលជាប្អូនស្រីណាហាំនោះជា
ពួកអ្នកតាំងក្រុងកៃឡា[ឈ] ជាស្រុករបស់ ពួកកាមីត និងក្រុង
អែសធេម៉ូរ ជាស្រុករបស់ពួកម៉ាកាធី[ញ] ២០ ឯកូនរបស់ស៊ីម៉ូន
គឺអាំណូន រីនណា បេន-ហាណាន់ និងធីឡូន ឯកូនរបស់
អ៊ីស៊ី គឺសូហេត និងបេន-សូហេត ។
២១ ឯកូនរបស់សេឡា[ដ] ដែលជាកូនយូដា គឺអេ៊ើរ ជាអ្នក
តាំងក្រុងលេកា ហើយឡាអាដា ជាអ្នកតាំងក្រុងម៉ារីសា
ហើយជាមេអស់ទាំងគ្រួនៃពួកអ្នក ដែលត្បាញសំពត់ខ្លូត
ទេសយ៉ាងម៉ដ្ត ក្នុងវង្សរបស់អាស បេអា ២២ ព្រមទាំងពួក
យ៉ូគីម ជាពួកអ្នកដែលនៅកូសេបា ហើយយ៉ូអាស និង
សារ៉ាប ជាអ្នកដែលមានអំណាចនៅស្រុកម៉ូអាប់ ហើយ
យ៉ាស៊ូប៊ី-លេហែម ឯបញ្ជីនេះតមកពីចាស់បុរាណ ២៣ ពួក
អ្នកទាំងនេះជាពួកជាងស្មូន ហើយក៏នៅកណ្ដាលដំណាំ និង
សួនច្បារ គេអាស្រ័យនៅទីនោះជិតស្ដេច ដើម្បីធ្វើការ
ថ្វាយទ្រង់ ។

## ស៊ីម្មាន

*៤:២៨-៣៣ - យស ១៩:២-១០*

២៤ ឯកូនរបស់ស៊ីម្មាន[ឋ] គឺនេមួយ យ៉ាមីន យ៉ាគិន[ឌ]
សេរ៉ាស និងសូល ២៥ សូលមានកូនឈ្មោះសាលូម។មានកូន
ឈ្មោះមីបសាម។ មានកូនឈ្មោះមីសម៉ា ២៦ មីសម៉ាមានកូន
ឈ្មោះហាមូអែល។មានកូន ឈ្មោះសាគើរ។មានកូនឈ្មោះ
ស៊ីម៉ាយ ២៧ ឯស៊ីម៉ាយ គាត់មានកូន ប្រុស១៦នាក់ ហើយ
និងកូនស្រី៦តែបងប្អូនគាត់មិនសូវមានកូនច្រើនទេ ពូជពង្ស
របស់ស៊ីម្មានមិនបានចំរើន ដូចជាពួកកូនចៅយូដាទេ
២៨ អ្នកទាំងនោះនៅត្រង់ក្រុងបៀរ-សេបា[ឍ] ម៉ូឡាដា[ណ]
ហាសា-ស៊ូអាល ២៩ ប៊ីលហា អេសែម[ត] ថូឡាឌ ៣០ បេធូល
ហោម៉ា[ថ] ស៊ីកឡាក់[ទ] ៣១ បេត-ម៉ារកាបូតហាសា-ស៊ូសា

**៤:១៣** ច យស ១៥:១៧
**៤:១៧** ឆ នក ១៥:២០
**៤:១៨** ជ យស ១៥:៣៤
**៤:១៩** ឈ យស ១៥:៤៤ ញ ចទ ៣:១៤
**៤:២១** ដ លប ៣៨:៥
**៤:២៤** ឋ លប ២៩:៣៣ ឌ ជន ២៦:១២
**៤:២៨** ឍ លប ២១:១៤ ណ យស ១៥:២៦
**៤:២៩** ត យស ១៥:២៩
**៤:៣០** ថ ជន ១៤:៤៥ ទ យស ១៥:៣១
**៤:៣១** ធ យស ១៥:៣៦

**៤:១៣** *អូធ្នាស* គាត់គឺជាចៅហ្វាយដំបូងរបស់ពួកអ៊ីស្រាអែល (មើល យស ១៥:១៧ ពច ១:១៣ ៣:៩-១១) ។

**៤:១៦-២០** ចំណែកមរដករបស់ពង្សាវតារនេះ គឺមានតាំងពីពេលមុនមកម្ល៉េះ ។ ទីកន្លែង ៣ឬ៤ មិនបានរាប់បញ្ចូលនៅក្នុងខេត្តរបស់យូដាក្នុងអំឡុងពេលដែលស្ថាបនាប្រទេសឡើងវិញឡើយ (ឧ.ក្រុងស៊ីភនិងក្រុងអែលធេម៉ូរជាដើម) ។

**៤:១៧** *ប្រពន្ធរបស់ម៉ារេឌ* នាងជាបុត្រីរបស់ផារ៉ោន (ខ.១៨) ។ ម៉ារេឌមិនត្រូវបានគេស្គាល់ឡើយ ។ សេចក្ដីពិតមួយគឺបានបញ្ជាក់យ៉ាងច្បាស់ថាគាត់បានរៀបការជាមួយបុត្រីផារ៉ោន ។ ព្រឹត្តិការណ៍នេះប្រហែលជាកើតឡើងក្នុងគ្រាដែលពួកកូនចៅអ៊ីស្រាអែលទៅរស់នៅក្នុងប្រទេសអេស៊ីព្ទក្រោមការត្រួតត្រារបស់លោកយ៉ូសែប ។

**៤:២១,២៣** នៅក្នុងផ្នែកនេះ គឺបានផ្ដោតលើរូបភាពនៃសង្គមមួយនៅក្បែរមជ្ឈិមបូព៌ា ។ ជាញឹកញាប់ពូជអំបូរនីមួយៗមិនគ្រាន់តែមានទំនាក់ទំនងជាមួយពូជអំបូរដែលនៅក្នុងតំបន់របស់គេឡើយ ប៉ុន្តែពួកគេមានទំនាក់ទំនងជាមួយពួកអាជីវកម្មពិសេសៗផ្សេងទៀតដែរ ដូចជាពួកជិន្ទូញ (ខ.២១) ជាងស្មូន (ខ.២៣) និងអ្នកធ្វើការថ្វាយស្ដេច (ខ.២៣) ។

**៤:២៤-៤៣** ពង្សាវតាររបស់ស៊ីម្មានក៏មាននិយាយនៅក្នុងគម្ពីរ លប ៤៦:១០ នក ៦:១៥ ជន ២៦:១២-១៣ ។ អំបូរស៊ីម្មានបានតាំងលំនៅក្នុងតំបន់មួយចំនួនក្នុងស្រុកយូដា ហើយឈ្មោះទីក្រុងទាំងនោះ គួរតែធ្វើការប្រៀបធៀបជាមួយ យស ១៥:២៦-៣២,៤២ ១៩:២-៧ ។ ក្នុងអំឡុងពេលដែលគេបានតាំងលំនៅដ្ឋាន នៅជាមួយពួកយូដា នោះគោលនយោបាយនៃអំបូរនេះបានផ្សារភ្ជាប់ជាមួយអំបូរយូដា ហើយយើងក៏ឃើញទៀតថា មានទីក្រុងជាច្រើនដែលជាទីក្រុងរបស់អំបូរនេះដែលបាននិយាយនៅក្នុងប្រវត្តិសាស្ត្រ (សូមមើល លប ៣៤:២៤-៣១ ៤៩:៥-៧ និង លប ៣៤:២៥ ៤៩:៧) ។ ទីតាំងភូមិសាស្ត្រនិងប្រវត្តិសាស្ត្របាន គឺសុទ្ធតែដាក់បញ្ចូលក្នុងពង្សាវតារនេះ (សូមមើល ខ.៩-១០) ។ មើលទៅហាក់បីដូចជាមានអំបូរពីរដែលបានរាប់បញ្ចូលនៅទីនេះ ខ.២៤-៣៣ ដែលនៅចុងបញ្ចប់បាននិយាយថា "និងតំណគេតមក" ហើយ ខ.២៤-៤៣ ។ ចំនួនប្រជាជនដ៏ច្រើន (មើល ខ.៣៨) ជាមូលហេតុ ដែលធ្វើឱ្យពួកគេពង្រីកទឹកដីរហូតដល់ស្រុកកេដោរ ហើយនៅភាគខាងកើតរហូតដល់ស្រុកអេដំម ក្នុងរាជ្យស្ដេចហេសេគា (មើល

បេត-បិរៃ ហើយនៅស្អារ៉ែម[ង] នេះហើយ ជាទីក្រុងរបស់
គេ ដរាបដល់រាជ្យដាវីឌ ៣២ ហើយភូមិរបស់គេទាំងអស់
មាន៥ គឺអេថាម អាយិន[ន] រីម៉ូន ថូកែន និងអេសាន[ប]
៣៣ ព្រមទាំងភូមិដែលនៅជុំវិញទីក្រុងទាំងនោះ រហូតដល់
ក្រុងបាលផង នេះជាទីលំនៅរបស់គេនឹងដំណគេតមក ៣៤ ឯ
មសូបាប់ យ៉ាមលេក និងយ៉ូសាជាកូនអ័ម៉ាស៊ា ៣៥ ហើយ
យ៉ូអែល និងយេហ៊ូវ ជាកូនយ៉ូស៊ីបយ៉ា ដែលជាកូន
សេរ៉ាយ៉ា ជាកូនអ័ស៊ីអែល ៣៦ ហើយអេលី យ៉ូន៉ាយ យ្អាកូបា
យេសូហាយ៉ា អ័សាយ៉ា អ័ឌីអែល យេស៊ីមាល បេណាយ៉ា
៣៧ នឹងស៊ីសា ជាកូនស៊ីភី ដែលជាកូនអ័ឡូន ជាកូនយេដា
យ៉ាជាកូន ស៊ីមរី ដែលជាកូនសេម៉ាយ៉ា ៣៨ អ្នកទាំងនោះ
ដែលមាន ឈ្មោះកត់ទុកហើយ សុទ្ធតែជាអ្នកប្រធានក្នុង
គ្រួគេ ហើយពួកវង្សនៃពួយុកោគេ ក៏ចំរើនជាច្រើនឡើង។
៣៩ ពួកនោះបានទៅឯទ្វារចូលស្រុកកេដោរ[ផ] គឺខាងកើត
ច្រកភ្នំ ដើម្បីស្វែងរកស្មៅសំរាប់ចិញ្ចឹមហ្វូងសត្វ ៤០ នៅ
ទីនោះ គេឃើញមាន ស្មៅបរិបូរល្អ ស្រុកនោះក៏ធំទូលាយ
ហើយសុខស្រួលផង[ព] ដ្បិតពួកសាសន៍ហាំបាននៅឯនោះ
ពីដើម ៤១ ហើយពួកអ្នកដែលមានឈ្មោះកត់ ទុកទាំងនេះ
បានមក នៅគ្រាហេសេគា ជាស្តេចយូដាបំផ្លាញត្រសាល
គេ និងផ្ទះទាំងប៉ុន្មាន[ភ]ដែលឃើញមាននៅស្រុកនោះ រួច
តាំងទីលំនៅនៅស្រុករបស់គេ ដោយព្រោះទីនោះមានស្មៅ
សំរាប់ហ្វូងសត្វ ៤២ ហើយពួកកូនចៅស៊ីម្មាន៥០០នាក់ ក៏ទៅ
ឯស្រុកសៀរ មានពេឡា ធានារីយ៉ា រេផាយ៉ា និងអ៊ូស៊ាល
ជាកូនអ៊ីស៊ី ធ្វើជាមេគេ[ម] ៤៣ ហើយគេប្រហារសំណល់ពួក

**៤:៣២** ន ជន ៣៤:១១ ប យស ១៥:៤២
**៤:៣៩** ផ យស ១៥:៥៨
**៤:៤០** ព ពច ១៨:៧-១០
**៤:៤១** ភ ២រប ២០:១ ២៦:៧
**៤:៤២** ម លប ១៤:៦
**៤:៤៣** យ លប ១៤:៧
**៥:១** ក លប ២៩:៣២ ខ លប ៣៥:២២ ៤៩:៤ គ លប ៤៨:១៦,២២ ៤៩:២៦ ឃ លប ៤៨:៥ ង ១រប ២៦:១០
**៥:២** ច លប ៤៩:១០,១២ ឆ ១សយ ៩:១៦ ១២:១២ ២សយ ៦:២១ ១រប ១១:២ ២រប ៧:១៨ មថ ២:៦ ជ លប ២៥:៣១
**៥:៣** ឈ លប ២៩:៣២ ៤៦:៩

អាម៉ាលេក[យ] ដែលបានរួចជីវិតនៅ រួចក៏តាំងទីលំនៅគេ
នៅស្រុកនោះ រហូតដល់សព្វថ្ងៃនេះ ។

## រូបេន

**៥** ១ ឯកូនរបស់រូបេន[ក] ជាកូនច្បងអ៊ីស្រាអែល (រូបេននេះ
ជាកូនច្បងមែន តែដោយព្រោះគាត់ធ្វើបង្អាប់ដល់ដំណេក
ឪពុក[ខ] បានជាអំណាច របស់បងច្បងបានឱ្យទៅកូនយ៉ូសែប[គ]
ដែលជាកូនអ៊ីស្រាអែលវិញ[ឃ] ហើយពង្សាវតារមិនត្រូវ
រាប់តាមច្បាប់បងច្បងពិតនោះទេ[ង] ២ ដ្បិតយូដា[ច]គាត់មាន
អំណាចជាងបងប្អូនគាត់ទាំងអស់ ហើយអ្នកដែលជា
ប្រធាន[ឆ] ក៏កើតពីគាត់មក តែអំណាចនៃបងច្បង[ជ] ជា
របស់យ៉ូសែបវិញ) ៣ ដូច្នេះ កូនរបស់រូបេន[ឈ]ជាកូនច្បង
អ៊ីស្រាអែល គឺហេណូក ប៉ាលូវ[ញ] ហេស្រុន[ដ] កើមី ៤ ឯកូន
របស់យ៉ូអែល គឺសេម៉ាយ៉ា១មានកូនឈ្មោះកុក១មានកូន
ឈ្មោះស៊ីម៉ាយ ៥ ស៊ីម៉ាយមានកូនឈ្មោះមីកា១មានកូនឈ្មោះ
រីអាយ៉ា១ មានកូនឈ្មោះបាល ៦ បាលមានកូនមួយឈ្មោះ
បេអ៊ូរ៉ា ជាអ្នកដែលទីកឡាត-ពីលេសើរ[ឋ] ស្តេចស្រុក
អាសស៊ើរបានដឹកនាំទៅជាឈ្លើយ អ្នកនោះជាកំពូលលើ
ពួករូបេន ៧ ឯពួកបងប្អូនគាត់តាមគ្រួគេ[ឌ] ក្នុងកាល ដែលធ្វើ
បញ្ជីពង្សាវតារ តាមអស់ទាំងដំណគេ នោះបានរាប់ជាមេ
គឺយីអែល និងសាការី ៨ ហើយបេឡា ជាកូនអ័សាសដែល
ជាកូនសេម៉ា ជាកូនយ៉ូអែល ដែលនៅស្រុកអារ៉ូអ៊ើរ[ឍ]រហូត

នក ៦:១៤ ជណ ២៦:៥-១១ ញ ជន ២៦:៥ ដ ជន ២៦:៦ **៥:៦** ឋ ខ.២៦ ២ពវ ១៥:១៩ ១៦:១០ ២រប ២៨:២០ **៥:៧** ឌ យស ១៣:១៥-២៣ **៥:៨** ឍ ជន ៣២:៣៤ ពច ១១:២៦ ណ ជន ៣២:៣ ត យស ១៣:១៧

ខ.៣៩-៤៣) ។ សត្រូវតាំងពីយូរលង់រវាងអ៊ីស្រាអែលនិងអាម៉ាលេកនិងកើតឡើងម្តងទៀត (មើល ខ.៣៤ ធៀប នក ១៧:៨-១៦ ចទ ២៥:១៧-១៩ ១សយ ១៥ និងសេចក្តីផ្តើមនាងអែសធើរៈ គោលបំណងផ្ទៃរឿងនិងលក្ខណៈអក្សរសាស្ត្រ) ។

**៥:១-២៦** នៅក្នុងផ្នែកនេះ និយាយពីការកត់ចុះអំបូរដែលនៅភាគខាងកើតនៃទន្លេយ័រដាន់ ដែលមានដូចជា រូបេន កាឌ់ និងអំបូរម៉ាន៉ាសេមួយចំហៀង (សូមមើល ជន ៣២:៣៣-៣៤) ។ កង្វល់ព្រួយរបស់អ្នកកត់ត្រាពង្សាវតារចំពោះ"ពួកអ៊ីស្រាអែលទាំងអស់"គឺទាំងការដែលគេបានភ្ជាប់ពង្សាវតារជាមួយគ្នា ជាហេតុធ្វើឱ្យគេគ្មានសារៈសំខាន់នៅក្នុងអង្គភាពនៃជីវិតរស់នៅក្នុងការកសាងប្រទេសជាតិឡើងវិញ នៅក្នុងអំឡុងពេលនោះឡើយ គឺដោយព្រោះតែពួកគេបានត្រូវបណ្តេញចេញដោយសារពួកអាស៊ើរ ។

**៥:១-១០** ការចាំបាច់ដើម្បីពន្យល់ពីមូលហេតុថា ហេតុអ្វីបានជាសិទ្ធជាកូនច្បងមិនបានឱ្យទៅរូបេន (សូមមើល លប ៣៥:២២ ៤៩:៤ ដែលនិយាយពីអំពើបាបរបស់រូបេន) គឺបានកាត់ផ្តាច់ប្រយោគនេះ តាំងពីដំបូងមកម្ល៉េះ (ខ.១) ហើយក៏នឹងមាននិយាយម្តងទៀតដែរ (ខ.៣) ។ ឯកសារបន្ទាប់បន្សំ (ខ.១-៣) បានបង្ហាញពីភាពលំអៀងរបស់អ្នកនិពន្ធចំពោះយូដា ទោះបីជាលោកយ៉ូសែបគាត់ទទួលបានចំណែកទ្វេរ (អេប្រាអិម និងម៉ាន៉ាសេ) នៃសិទ្ធជាកូនច្បងនេះក៏ដោយ ។ នៅក្នុងបរិបទនៃភាសាក្រិកបាននិយាយថា "អ្នកនាំមុខ"(មើល ខ.២) គឺបានប្រើសម្រាប់ដាវីឌដែលនិងនិយាយនៅក្នុង ១១:២ ១៧:៧ ២សយ ៥:២ ៦:២១ ៧:៨) ។ ការនិយាយអំពីតួរនាទីរបស់នាយទាហាន និងអ្នកចម្បាំង (ខ.១០) បានបង្ហាញដូច្នេះថា ពង្សាវតារនេះប្រហែលជាមានមុខងារនៅក្នុងជួរកងទ័ព (មើលក្នុងសេចក្តីផ្តើមៈ ពង្សាវតារ) ។ ប្រភពឯកសារខ្លះៗទៀតដែលស្តីពីរូបបេន គឺមាននៅក្នុង ជន ២៦:៥១១ ។ អ្នកកត់ត្រាពង្សាវតារបានលុបចេញនូវឈ្មោះរបស់អេលាប និងកូនទាំងបីរបស់គាត់ ដែលបានស្លាប់ក្នុងការបះបោរជាមួយព្រះយេហូវ៉ា ជាមួយពួកកូរេ (មើល ជន ២៦:៨-១០) ដូច្នេះហើយបានជាឈ្មោះនេះមិនជាប់ទាក់ទងជាមួយអ្នកនិពន្ធ ។

**៥:៦** *ទីកឡាត-ពីលេសើរ* គេគឺជាស្តេចស្រុកអាសស៊ើរ (៧៤៥-៧២៧ មុន គ.ស) បានវាយពួកអ៊ីស្រាអែល (សូមមើល ខ.២៦ ២ពវ ១៥:២៩) ហើយជាអ្នកបាននាំសេចក្តីលំបាកដល់អ័ហាសជាស្តេចស្រុកយូដា (សូមមើល ២រប ២៨:១៩-២០ ២ពវ ១៦:៧-១០) ។

ដល់នេបូរ[ណ] និងបាល–មេ យ៉ូន[ត] [៩]ក៏នៅលយទៅខាងកើត
ចាប់តាំងពីទន្លេអ៊ើប្រាត[ថ] រហូតដល់ មាត់ទីរហោស្ថាន
ពីព្រោះហ្វូងសត្វគេបានចំរើនជាច្រើនឡើងនៅស្រុក
កាឡាត[ទ] [១០]ហើយនៅក្នុងរាជ្យសូល នោះគេបានច្បាំងនឹង
ពួកហាការេន[ធ] ពួកនោះក៏ចាញ់គេ រួចគេនៅក្នុងទីលំនៅ
របស់ពួកនោះនៅពេញក្នុងស្រុកកាឡាតប៉ែកខាងកើត ។

### កាឌ់

[១១]ពួកកូនចៅកាឌ់[ន]ក៏នៅក្នុងស្រុកបាសានជាប់នឹងគេ
រហូតដល់ ដល់សាលកា[ប] [១២]មានយ៉ូអែលជាមេ សាផាមជា
បន្ទាប់ រួចយ៉ាណាយ និងសាផាត នៅស្រុកបាសាននោះ
[១៣]រីឯពួកបងប្អូនគេ ដែលកើតក្នុងវង្សរបស់ឪពុកគេ នោះ
គឺមីកែល មស៊ូឡាម សេបា យ៉ូរ៉ាយ យ៉ាកាន ស៊ីអា និង
ហេប៊ើរ ទាំងអស់មាន៧នាក់ [១៤]នេះសុទ្ធតែជាកូនចៅ
អ័ប៊ីហែល ជាកូនហ៊ូរី ដែលជាកូនយ៉ារ៉ូអា។ជាកូនកាឡាត។
ជាកូន មីកែល។ជាកូនយេស៊ីសាយ។ជាកូនយ៉ាដោ ដែលជា
កូនប៊ូស [១៥]ឯអ័ហ៊ី ជាកូនអ័ឌាល ដែលជាកូនគូនី គាត់ជាមេ
លើវង្សឪពុកគេ [១៦]ពួកនោះគេនៅស្រុកកាឡាត ក្នុងស្រុក
បាសាន ហើយក្នុងទីក្រុងតូចទាំង ប៉ុន្មាននៅស្រុកនោះ
នឹងក្នុងភូមិដែលនៅជុំវិញក្រុងសារ៉ុនរហូតដល់ ព្រំស្រុកគេ
[១៧]ពួកអ្នកទាំងនោះបានកត់ក្នុងបញ្ជីតាមពង្សាវតាររបស់
គេ នៅក្នុងរាជ្យយ៉ូថាម[ផ] ជាស្តេចយូដា ហើយនៅក្នុងរាជ្យ
យេរ៉ូបោម[ព] ជាស្តេចអ៊ីស្រាអែល ។
[១៨]ឯកូនរបស់រូបេន ព្រមទាំងពួកកាឌ់ នឹងពួកម៉ាន៉ាសេ១
ចំហៀង គេមានមនុស្សក្លាហាន ដែលអាចនឹងកាន់ខែល
និងដាវ បាញ់ធ្នូ ហើយក៏ថ្នឹកនឹងចំបាំង គឺចំនួនជា៤ម៉ឺន៤ពាន់
៧៦០នាក់ ដែលអាចនឹងចេញទៅច្បាំងបាន[ភ] [១៩]គេលើកគ្នា
ទៅច្បាំងនឹងពួកហាការេន ពួកយេធើរ[ម] ពួកណាភីស និង
ពួកណូដាប់ [២០]គេក៏មានសេចក្តីជំនួយ[យ]ជួយ ទាស់នឹងពួក
ទាំងនោះ ហើយពួកហាការេន ព្រមទាំងអស់អ្នកដែល
នៅជាមួយ ក៏ត្រូវប្រគល់មកក្នុងកណ្តាប់ដៃគេ ពីព្រោះគេ
បានអំពាវនាវ[រ]ដល់ព្រះនៅវេលាចំបាំង ទ្រង់ក៏ទទួលព្រម
តាម ដោយព្រោះគេបានទីពឹង[ល]ដល់ទ្រង់ [២១]គេចាប់យកហ្វូង
សត្វរបស់ពួកនោះ គឺអូដ្ឋ៥ម៉ឺន ចៀម២សែន ៥ម៉ឺននិងលា២
ពាន់ព្រមទាំងមនុស្ស១សែននាក់ [២២]មានមនុស្សដួលស្លាប់
សន្ធឹកណាស់ ដ្បិតចំបាំងនោះ[វ]កើតពីព្រះ គេក៏អាស្រ័យនៅ
ក្នុងទីលំនៅរបស់អ្នកទាំងនោះ ដរាបដល់វេលាដែលគេ
ត្រូវជាប់ជាឈ្លើយវិញ[ស]។

### អំបូរម៉ាន៉ាសេពាក់កណ្តាល

[២៣]ឯពួកកូនចៅរបស់ពូជអំបូរម៉ាន៉ាសេ១ចំហៀង ដែល
នៅក្នុងស្រុកនោះ គេក៏ចំរើនឡើង ចាប់តាំងពីស្រុក
បាសាន[ហ] រហូតដល់ស្រុកបាល–ហើម៉ូន និងសេនារ ហើយ
ភ្នំហើម៉ូន[ឡ] [២៤]ឯពួកដែលជាកំពូល លើវង្សរបស់ឪពុកគេ
គឺអេភើរ អ៊ីស៊ី អេលាល អាសរាល យេរេមី ហូដាវា
និងយ៉ាឌាល នោះសុទ្ធតែជាអ្នកខ្លាំងពូកែ ដែលមានចិត្តក្លា
ហាន ជាមនុស្សមានល្បីឈ្មោះ ហើយជាកំពូលលើវង្ស
របស់ឪពុកគេ។

**៥:៩** ថ លប ២:១៤ ទ ជន ៣២:២៦
**៥:១០** ធ ខ.២២ ១រប ២៧:៣១
**៥:១១** ន លប ៣០:១១ ជន ១:២៥ យស ១៣:២៤–២៨ ប ចទ ៣:១០
**៥:១៧** ផ ២ពវ ១៥:៣២ ព ២ពវ ១៤:២៣
**៥:១៨** ភ ជន ១:៣
**៥:១៩** ម លប ២៥:១៥
**៥:២០** យ ទដ ៣៧:៤០ ៤៦:៥ ៥៤:៤ រ ១ពវ ៨:៤៤ ២រប ៦:៣៤ ១៣:១៤ ១៤:១១ ទដ ២០:៧–៩ ២២:៥ ១០៧:៦ ល ទដ ២៦:១ អស ២៦:៣ ដយ ៦:២៣
**៥:២២** វ ចទ ២០:៤ ២រប ៣២:៨ ស ខ.១០ ២ពវ ១៥:២៩
**៥:២៣** ហ ១រប ៧:១៤ ឡ ចទ ៣:៨,៩ ៤:៨

**៥:១០** *ពួកហាការេន* សូមមើល ខ.១៩–២២ ។ គេគឺជាម្នាក់ក្នុងចំណោមសត្រូវទាំងឡាយរបស់ពួកអ៊ីស្រាអែល (សូមមើល ទដ ៨៣:៦) ។ អំបូរនេះប្រហែលជាប់ទាក់ទងជាមួយនាងហាកា ដែលជាម្តាយរបស់អ៊ីសម៉ាអែល (មើល លប ១៦) ប៉ុន្តែសូមមើល ទដ ៨៣:៦ ។

**៥:១១–២២** បញ្ជីឈ្មោះទាំងប៉ុន្មានរបស់អំបូរកាឌ់ គឺមិនស្របគ្នាឡើយនៅក្នុងព្រះគម្ពីរ ។ ពង្សាវតាររបស់កាឌ់ខ្លះបាននិយាយថាមានកូន៧ (សូមមើល លប ៤៦:១៦ ជន ២៦:១៥–១៨) នៅទីនេះមានឈ្មោះ៤នាក់ដែលមិនបានឃើញនៅកន្លែងណាផ្សេងទៀតក្នុងព្រះគម្ពីរឡើយ ។ តាមសម្តីរបស់អ្នកកត់ត្រាពង្សាវតារ (ខ.១៧) បាននិយាយថា ការកំណត់ត្រានៃពង្សាវតារនោះ គឺនៅក្នុងរាជ្យស្តេចយ៉ូថាមជាស្តេចយូដា (៧៥០–៧៣២ មុន គ.ស) និងក្នុងរាជ្យស្តេចយេរូបោមជាស្តេចស្រុកអ៊ីស្រាអែល (៧៩៣–៧៥៣ មុន គ.ស) ។ កេមរដករបស់អំបូរកាឌ់ គឺនិយាយនៅក្នុង ចទ ៣:១២ ។

**៥:១៨–២២** គឺជាឧទាហរណ៍ដំបូងរបស់អ្នកកត់ត្រាពង្សាវតារដែលស្តីពីផ្ទៃរឿងនៃការដាក់ទណ្ឌកម្មមកពីព្រះ (សូមមើលសេចក្តីផ្តើមៈ គោលបំណងនិងផ្ទៃរឿង) ។ ជ័យជម្នះដ៏ធំក្នុងចម្បាំងនេះ គឺអាស្រ័យដោយគេបានពឹងពាក់និងមានសេចក្តីជំនួយមកពីព្រះអម្ចាស់ (សូមមើល ខ.២០ ធៀប ២រប ៦:២៤–២៥,៣៤–៣៩ ១២:៧–១២ ១៣:១៣–១៦ ១៤:៩–១៥ ១៨:៣១ ២០:១–២៣) ។

**៥:២៣–២៦** ពូជអំបូរម៉ាន៉ាសេ គឺបានរីកចម្រើនក្នុង ៧:១៤–១៩ ។ អំបូរម៉ាន៉ាសេមួយចំហៀងដែលបានតាំងលំនៅដ្ឋាននៅភាគខាងកើតនៃទន្លេយ័រដាន់ បាននិយាយនៅទីនេះ ក្នុងអំឡុងពេលដែលគេមានគ្រោះកម្មដូចគ្នានឹងរូបេនហើយនិងកាឌ់ដែរ ។ មួយវិញទៀតអ្នកកត់ត្រាពង្សាវតារបានទុកចំនួនអំបូរទាំង១២នេះ សម្រាប់ជាអំបូរនៃពង្សាវតាររបស់គាត់ (សូមមើល ២:១–២) ។ ជាថ្មីម្តងទៀត ទណ្ឌកម្មនឹងកើតឡើងៈ គ្រាន់តែទុកចិត្តព្រះអម្ចាស់នោះនិងមានជ័យជម្នះ (សូមមើល ខ.១៨–២២) ជាមួយគ្នានោះផងដែរ ពួកអ្នកដែលមានជ័យជម្នះទាំងនោះក៏ក្លាយជាអ្នកដែលមិនស្មោះត្រង់ទៅវិញ (សូមមើល ខ.២៥–២៦) ។ ការលើកឡើងពីការដាក់ទណ្ឌកម្មនៅក្នុងរឿងនេះបានធ្វើឱ្យមានជម្លោះ ក្នុងចំណោមពង្សាវតារជាមួយនិងប្រវត្តិសាស្ត្រនៃពង្សាវតារ ។ បញ្ជីឈ្មោះដែលមាននៅទីនេះប្រហែលជាមិនមែនបញ្ជីពង្សាវតារនោះឡើយ ប៉ុន្តែប្រហែលជាបញ្ជីឈ្មោះនៃពូជអំបូរវិញ ។ នៅពេលដែលគេពិពណ៌នាថា ជាអ្នកខ្លាំងពូកែក្នុងចម្បាំង (សូមមើល ខ.២៤–២៦) ។

២៥ ប៉ុន្តែគេបានរំលងទាស់[អ]នឹងព្រះនៃពួកព្ធយុកោគេ
ព្រមទាំងផិត[ក] តាមអស់ទាំងព្រះរបស់ពួកជន នៅស្រុក
ដែលព្រះបានបំផ្លាញចេញពីមុខគេ ២៦ ដូច្នេះ ព្រះនៃ
សាសន៍អ៊ីស្រាអែល ទ្រង់បានបណ្តាលព្រះទ័យ[ខ]នៃពូល[គ]
ជាស្តេចស្រុកអាសសើរ និងទីកឡាត–ពីលេសើរ[ឃ] ជា
ស្តេចស្រុកអាសសើរ ឱ្យដឹកនាំគេទៅ គឺពួករូបេនពួកកាឌ់
និងពូជអំបូរម៉ាន៉ាសេ១ចំហៀងនោះ ស្តេចទាំង២នោះ
ក៏ដឹកនាំគេទៅនៅឯហាឡា[ង] ហាបោរ ហារ៉ា ហើយដល់
ទន្លេស្រុកកូសាន ដរាបដល់សព្វថ្ងៃនេះ ។

## លេវី

**៦** ១ ឯកូនរបស់លេវី[ក] គឺគើសុន កេហាត់ និងម្រ៉ារី ២ កូន
របស់កេហាត់ គឺអាំរ៉ាម យីតសារ ហេប្រុន និងអ៊ូស៊ាល[ខ]
៣ កូនអាំរ៉ាម គឺអើរ៉ុន ម៉ូសេ និងម៉ារាម[គ] ឯកូនចៅរបស់
អើរ៉ុន គឺណាដាប អ័ប៊ីហ៊ូវ[ឃ] អេលាសារ[ង] និងអ៊ីថាម៉ារ[ច]
៤ អេលាសារបង្កើតបានភីនេហាស[ឆ]ៗបង្កើតអ័ប៊ីសួរ ៥ ឯ
អ័ប៊ីសួរបង្កើតប៊ូកគីៗបង្កើតអ៊ូស៊ី ៦ អ៊ូស៊ីបង្កើតសេរ៉ាហ៊ា
ៗបង្កើតមេរ៉ាយ៉ូត ៧ មេរ៉ាយ៉ូតបង្កើតអ័ម៉ារា អ័ម៉ារាបង្កើត
អ័ហ៊ីទូប ៨ ឯអ័ហ៊ីទូបក៏បង្កើតសាដុក[ជ]ៗបង្កើតអ័ហ៊ីម៉ាស
៩ អ័ហ៊ីម៉ាសបង្កើតអ័សារាៗបង្កើតយ៉ូហាណាន ១០ យ៉ូហា
ណានបង្កើតអ័សារា[ឈ] (គឺលោកនោះឯងដែលធ្វើការងារ
ជាសង្ឃ នៅក្នុងព្រះវិហារ ដែលសាឡូម៉ូនបានស្អាង នៅ
ក្រុងយេរូសាឡិម) ១១ ឯអ័សារាក៏បង្កើតអ័ម៉ារា អ័ម៉ារា
បង្កើតអ័ហ៊ីទូប ១២ អ័ហ៊ីទូបបង្កើតសាដុកៗបង្កើតសាលូម
១៣ សាលូមបង្កើតហ៊ីលគីយ៉ា[ញ] ៗបង្កើតអ័សារា ១៤ អ័សារា
បង្កើតសេរ៉ាយ៉ា[ដ]ៗបង្កើតយេហូសាដាក ១៥ យេហូសាដាក[ឋ]
ក៏ទៅជាឈ្លើយ ក្នុងកាលដែលព្រះយេហូវ៉ាបានដឹកនាំពួក
យូដា និងពួកក្រុងយេរូសាឡិមទៅ ដោយព្រះហស្តនៃ
នេប៊ូក្នេសា ។
១៦ កូនរបស់លេវី[ឌ] គឺគើសុន កេហាត់ និងម្រ៉ារី[ឍ]

**៥:២៥** អ ចទ ៣២:១៥–១៨ ១របា ៩:១ ១០:១៣ ២របា ១២:២ ២៦:១៦ ២៨:១៩ ២៩:៦ ៣០:៧ ៣៦:១៤ ក នក ៣៤:១៥ លវ ១៨:៣
**៥:២៦** ខ អស ៣៧:៧ គ ២ពវ ១៥:១៩ ឃ ខ.៦ ២ពវ ១៥:២៩ ង ២ពវ ១៧:៦
**៦:១** ក លប ២៩:៣៤ ជន ៣:១៧
**៦:២** ខ នក ៦:១៨
**៦:៣** គ នក ១៥:២០ ឃ លវ ១០:១ ១០:១–២០:២ ង លវ ១០:៦ ច នក ៦:២៣ **៦:៤** ឆ អរ ៧:៥ **៦:៨** ជ ២សយ ៨:១៧ ១របា ១២:២៨ អរ ៧:២
**៦:១០** ឈ ១ពវ ៤:២ **៦:១៣** ញ ២ពវ ២២:១–២០ ២របា ៣៤:៩ ៣៥:៨
**៦:១៤** ដ ២ពវ ២៥:១៨ អរ ២:២ **៦:១៥** ឋ ជន ១២:១ ហក ១:១,១៤ ២:២,៤ សក ៦:១១ **៦:១៦** ឌ លប ២៩:៣៤ ជន ៣:១៧–២០ ឍ ជន

**៥:២៥** *ប៉ុន្តែគេបានរំលង . . . ព្រះបំផ្លាញគេចេញពីមុខ* សូមមើល នក ៣៤:១៥ ។

**៥:២៦** *ពូល* ជាឈ្មោះបល្ល័ង្ករបស់ទីកឡាត–ពីលេសើរ នៅបាប៊ីឡូន ។

**៦:១–៨១** នៅក្នុងជំពូកនេះបានរំឭកពីលំដាប់នៃបញ្ជីពង្សាវតារទាំងឡាយដែលជាប់ទាក់ទងជាមួយអំបូរលេវី ។ នៅក្នុងផ្នែកដំបូង (មើល ខ.១–១៥) បានកត់ចុះពីជំនួរវង្សរបស់សម្តេចសង្ឃរហូតដល់ពេលនិរទេស ។ ទាំងនេះគឺជាពូជអំបូររបស់លេវី (សូមមើល ខ.១៦–៣០) ។ ដាវីឌបានជ្រើសរើសអ្នកលេងភ្លេងក្នុងព្រះវិហារ ចេញពីពូជអំបូរលេវី៣ គឺៈគើសុន កេហាត់ និងម្រ៉ារី (មើល ខ.៣៣–៤៧) ។ ពង្សាវតារអើរ៉ុន និងអ័ហ៊ីហាស គឺបានបំបែកចេញពីគ្នា (មើល ខ.៤៩–៥៣) ដើម្បីឱ្យដឹងពីការងាររបស់សង្ឃ និងពួកលេវី (មើល នក ៣២:៦) ។ បញ្ជីកត់ចុះទ្រព្យសម្បត្តិរបស់លេវី ក្នុងចំណោមពូជអំបូរ គឺមាននៅក្នុងជំពូកនេះ (មើល ខ.៥៤–៨១) ។

**៦:១–៣** បំណែងចែកពង្សាវតារ ជាចំណែកតូចៗនៃពួកព្ធយុកោរបស់អំបូរលេវី ទៅក្នុងវង្សត្រកូលអេលាសារ ដែលជាពង្សាវតារសម្តេចសង្ឃ និងបាននិយាយនៅក្នុង (ខ.៤១៥) ។ កូនប្រុសលេវីទាំងនោះ (ខ.១) ជានិច្ចកាលតែងតែលេចឡើងនៅក្នុងរឿងនេះ ដោយយោងតាមអាយុកាល (សូមមើល ខ.១៦ លប ៤៦:១១ នក ៦:១៦ ជន ៣:១៧ ២៦:៥៧) ។ ដោយសារនៅក្នុងចំណោមកូនទាំង៤របស់អើរ៉ុន (ខ.៣) មានកូនច្បងទាំង២បានស្លាប់ដោយព្រោះបានប្រមាថទីបរិសុទ្ធក្នុងកាលដែលយកភ្លើងមកថ្វាយ (សូមមើល លវ ១០:១–២ ជន ២៦:៦១) នោះអ្នកបន្តតំណែងជាសង្ឃអាចជា អេលាសារ ឬ អ័ថាម៉ា ។

**៦:៤–១៥** បញ្ជីឈ្មោះរបស់សម្តេចសង្ឃទាំងនេះ គឺរាប់ចាប់តាំងពីគ្រាអេលាសាររហូតដល់គ្រានិរទេស ។ សម្តេចសង្ឃទាំងនេះដែលគេបានស្គាល់តាំងពីសញ្ញាចាស់មកមិនបាននិយាយទៀតឡើយៈ យេហូយ៉ាដា (២ពវ ១២:២) អ៊ូរីយ៉ា (២ពវ ១៦:១០–១៦) និងសង្ឃផ្សេងៗទៀត គឺអ័សារា (មើលក្នុង ២របា ២៦:១៧,២០ ៣១:១០–១៣) អេលី (១សយ ១:៩ ១៤:៣) និងអ័ប៊ីថើរ (២សយ ៨:១៧) ។ បញ្ជីឈ្មោះទាំងនោះនឹងលើកយកមកនិយាយម្តងទៀតនៅក្នុង អរ ៧:១–៥ ។

**៦:៨** *ឯអ័ហ៊ីទូបក៏បង្កើតសាដុក* សាដុកគាត់គឺជាសង្ឃម្នាក់ក្នុងចំណោមសង្ឃទាំង២របស់ដាវីឌ (សូមមើល ១៨:១៦ ២សយ ៨:១៧) ។ នៅពេលដែលអ័បៀរថើរជាសង្ឃផ្សេងទៀតរបស់ដាវីឌ (មើល ខ.៤–១៤) បានគាំទ្រចំពោះការបះបោររបស់អ័ដូនីយ៉ា នោះសាដុកបានគាំទ្រចំពោះសាឡូម៉ូន (មើល ១ពវ១) ។ បន្ទាប់ពីអ័បៀរថើរត្រូវបានបណ្តេញចេញពីការងារមក (មើល ១ពវ ២:២៦–២៧) នោះគឺមានតែសាដុកម្នាក់ទេ (មើល ១បរ ២៩:២២) ដែលបម្រើការងារជាសង្ឃនៅក្នុងជំនួរវង្សរបស់គាត់ (មើល ១ពវ ៤:២) ។ ការផ្តោតលើអ័ហ៊ីទូបទីនេះ សូមកុំឱ្យមានយល់ច្រឡំជាមួយនឹងសង្ឃម្នាក់ដែលជាចៅរបស់របស់អេលី (១សយ ១៤:៣) និងជាជីតារបស់អ័បៀរថើរ (១សយ ២២:២០) ឱ្យសោះព្រោះជំនួរវង្សរបស់សាដុកគឺជាអ្នកបន្តពីជំនួរវង្សរបស់អេលី (១សយ ២:២៧–៣៦ ១ពវ ២:២៦–២៧) ។ សម្រាប់សារៈសំខាន់នៃជំនួរវង្សសាដុក សូមមើល អគ ៤០:៤៦ ៤៣:១៩ ៤៤:១៥ ៤៨:១១ ។ លោកអែសរ៉ាក៏មានទំនាក់ទំនងជាមួយសាដុកដែរ (សូម អរ ៧:១–៥) ។

**៦:១៣** *ហ៊ីលគីយ៉ា* អាចរកឃើញនៅក្នុងសៀវភៅក្រឹត្យវិន័យ នៅក្នុងព្រះវិហារក្នុងអំឡុងពេលស្តេចយូសៀស (មើល ២ពវ ២២ ២របា ៣៤) ។

**៦:១៤** *សេរ៉ាយ៉ា* គាត់ត្រូវបានពួកបាប៊ីឡូនប្រហាជីវិត បន្ទាប់ពីមានការចម្បាំងដណ្តើមក្រុងយេរ៉ូសាឡិមនៅក្នុងឆ្នាំ៥៨៦ មុន គ.ស (២ពវ ២៥:១៨–២១) ។ *យេហូសាដាក* លោកជាឪពុករបស់លោកយ៉ូស្វេ (សូមមើល អរ ២:២) គាត់ជាសម្តេចសង្ឃក្នុងជំនាន់ទី១ក្នុងអំឡុងពេលស្ថាបនាប្រទេសជាតិឡើងវិញ (មើល ហក ១:១ ២:២ អគ ៣:១ ៦:១១) ឈ្មោះរបស់គាត់គេអាចហៅម្យ៉ាងទៀតថា យូសាដាក (មើលក្នុង អរ ៣:២ ៥:២ ១០:១៨) ។

១៧ ហើយឈ្មោះ ពួកកូនគើសុន គឺលិបនី និងស៊ីម៉ាយ[ណ]
១៨ ឯកូនរបស់កេហាត់ គឺអាំរ៉ាម យីតសារ ហេប្រុននិង
អ៊ូស៊ាល[ត] ១៩ កូនរបស់ម្រ៉ារី[ថ] គឺម៉ាស់លើ និងមូស៊ី[ទ] នេះជាគ្រួ
ទាំងប៉ុន្មានរបស់ពួកលេវី តាមជំនួរវង្សនៃឰយុកោគេ
២០ ខាងឯគើសុន នោះបង្កើតបានលិបនីៗបង្កើតយ៉ាហាតៗ
បង្កើតស៊ីម្មា ២១ ស៊ីម្មាបង្កើតយ៉ូអាៗបង្កើតអ៊ីដោៗបង្កើត
សេរ៉ាសៗបង្កើតយាតរ៉ាយ ២២ ឯកូនចៅរបស់កេហាត់
គឺលោកបង្កើតអ័មីនាដាប់ៗបង្កើតកូរេ[ធ] កូរេបង្កើត
អាស់ស៊ា ២៣ អាស់ស៊ាបង្កើតអែលកាណា អែលកាណា
បង្កើតអាស់ស៊ាៗបង្កើតអេបៀសាប់ៗបង្កើតអាស់ស៊ា
២៤ អាស់ស៊ាបង្កើតថា ហាតៗបង្កើតអ៊ូរាល[ន] អ៊ូរាលបង្កើត
អ៊ូស៊ីយ៉ាៗបង្កើតសូល ២៥ ឯកូនអែល កាណាគឺអ័ម៉ាសាយ
និងអ័ហ៊ីម៉ូត ២៦ ឯអែលកាណានេះ គាត់មានកូនគាត់បង្កើត
បានសូផាយៗបង្កើតណាហាត់ ២៧ ណាហាត់បង្កើតអេលាប
ៗបង្កើតយេរ៉ូហាំៗបង្កើតអែលកាណា[ប] ២៨ ឯកូនរបស់
សាំយូអែល[ផ] គឺវ៉ាសនី[ព] ជាកូនច្បង រួចអ័ប៊ីយ៉ា ២៩ ឯកូនចៅ
ម្រ៉ារី គឺម៉ាសលីៗបង្កើតលិបនីៗបង្កើតស៊ីម៉ាយៗបង្កើត
អ៊ូសា ៣០ អ៊ូសាបង្កើតសំម៉ាៗបង្កើតហាគីយ៉ាៗបង្កើត
អ័សាយ៉ា ។

២៦:៥៧
**៦:១៧** ណ នក ៦:១៧
**៦:១៨** ត នក ៦:១៨
**៦:១៩** ថ លប ៤៦:១១ ១រប ២៣:២១ ២៤:២៦ ទ នក ៦:១៩
**៦:២២** ធ នក ៦:២៤
**៦:២៤** ន ១រប ១៥:៥
**៦:២៧** ប ១សយ ១:១
**៦:២៨** ផ ១សយ ១:២០ ព ខ.៣៣ ១សយ ៨:២
**៦:៣១** ភ ១រប ២៥:១ ២រប ២៩:២៥–២៦ នហ ១២:៤៥ ម ១រប ៩:៣៣ ១៥:១៩ អរ ៣:១០ ទដ ៦៨:២៥
**៦:៣៣** យ ១ពវ ៤:៣១ ១រប ១៥:១៧ ២៥:១ រ ខ.២៨

## ការងារចំរៀងក្នុងព្រះវិហារ

*៦:៥៤–៨០ – យស ២១:៤–៣៩*

៣១ កាលហឹបនៃព្រះបានសេចក្ដីសំរាកហើយ នោះស្ដេច
ដាវីឌទ្រង់តាំងឱ្យមានពួកអ្នក[ភ] ត្រួតលើការងារចំរៀង[ម]
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ៣២ គេបានប្រតិបត្តិក្នុងការ
ចំរៀងនៅមុខរវាងឱបោសថផងត្រសាលជំនុំ ដរាបដល់
សាឡូម៉ូនបានស្អាងព្រះវិហារនៃព្រះយេហូវ៉ា នៅក្រុង
យេរូសាឡិម គេក៏ចូលធ្វើការងារគេ តាមវេនរៀងខ្លួន
៣៣ ឯពួកអ្នកដែលធ្វើការងារនោះ និងកូនចៅគេ គឺក្នុងពួក
កូនចៅកេហាត់មានហេម៉ាន[យ] ជាអ្នកចំរៀង គាត់ជាកូន
របស់យ៉ូអែល[រ] ដែលជាកូនសាំយូអែល ៣៤ សាំយូអែលជា
កូនអែលកាណា[ល] ៗជាកូនយេរ៉ូហាំៗជាកូនអេលាបៗ ជាកូន
ណាហាត់ ៣៥ ណាហាត់ជាកូនស៊ូភៗជាកូនអែលកាណា
អែលកាណាជាកូនម៉ាហាតៗជាកូនអ័ម៉ាសាយ ៣៦ អ័ម៉ាសាយ
ជាកូនអែលកាណាៗជាកូនយ៉ូអែលៗជាកូនអ័សារាៗជា
កូនសេផានា ៣៧ សេផានាជាកូនថាហាត ថាហាត ជាកូន
អាស់ស៊ាៗជាកូនអេបៀសាប់ៗជាកូនកូរេ ៣៨ កូរេជាកូនយីត
សារ[ស] ៗជាកូនកេហាត់ៗជាកូនលេវីៗជាកូនអ៊ីស្រាអែល

**៦:៣៤** ល ១សយ ១:១ **៦:៣៧** វ នក ៦:២៤ **៦:៣៨** ស នក ៦:២១

**៦:១៦–១៩ក** គឺបានដកស្រង់ចេញពី នក ៦:១៦–១៩ ជន ៣:១៧–២០ ២៦:៥៧–៦១ ។

**៦:២២–២៣** *អាស់ស៊ា . . . អែលកាណា . . . អេបៀសាប់* នៅក្នុង នក ៦:២៤ បានប្រាប់ថា អ្នកទាំងនោះគឺជាកូនចៅរបស់ពួកកូរេ ប៉ុន្ដែ នៅទីនេះ និយាយថា ពួកគេគឺជាប្រភេទមនុស្សធម្មតា ដែលស្នងត្រកូលពីគ្រួសារមួយទៅគ្រួសារមួយ ពីមួយជំនាន់ទៅមួយជំនាន់វិញ (សូមមើល ខ.២០–២១ ២៥–២៦,២៩–៣០) ។ នេះគឺជាឧទាហរណ៍ផ្សេងទៀតអំពីការបំរែបម្រួលនៃតំណរវង្ស និងដើម្បីឱ្យយល់នូវឃ្លាដែលថា "បង្កើត"គឺនិយាយសំដៅលើពួកអំបូរកេហាត់ មិនមែនលើពួកកូរេជំនាន់មុននោះឡើយ ។

**៦:២២** *អ័មីនាដាប់* ស្ទើតែទាំងអស់នៃតំណរវង្សជំនាន់ក្រោយនៅក្នុងជំពូកនេះ គឺសុទ្ធតែមានឈ្មោះប្រហាក់ប្រហែលគ្នា ដែលបាននិយាយអំពីយីតសារនៅក្នុងពួកអ័ប៊ីនាដាប់ នោះគ្មានកន្លែងណាទៀតដែលនិយាយថាគាត់ជាកូនរបស់កេហាត់នោះឡើយ នៅក្នុងខណៈពេលដែលកន្លែងខ្លះទៀតក៏បាននិយាយអំពីយីតសារ (ខ.២,៣៧–៣៨ នក ៦:១៨,២១) ។ អ័ប៊ីនាដាប់ គឺជាមនុស្សម្នាក់ផ្សេងទៀតដែលមិនបានបញ្ជាក់ច្បាស់លាស់ក្នុងអំបូរយីសារ ឬក៏មិនដឹងតែម្ដង ថាគាត់ជានរណានោះឡើយ ។ ឬមួយនេះគ្រាន់តែជាឧទាហរណ៍ ពីការប្រែប្រួលនៃពង្សាវតាររបស់ពួកលេវី ដែលជាប់ទាក់ទងជាមួយពួកយូដា និងរាជ្យរបស់ដាវីឌ (សូមមើល នរ ៤:១៨–២២ មថ ១:៤ លក ៣:៣៣) នៅពេលដែលអើរ៉ុនរៀបការជាមួយកូនស្រីរបស់អ័ប៊ីនាដាប់ជាពួកស្រុកយូដា (មើល នក ៦:២៣ ១រប ២:១០) ។

**៦:២៤** *អាល់ស៊ា* ប្រហែលជាម្នាក់ដែលជាអ្នកដឹកនាំពួកកេហាត់ក្នុងអំឡុងរាជ្យដាវីឌ (សូមមើល ១៥:៥) ។

**៦:២៦–២៧** *សូផាយ . . . ណាហាត់ . . . អេលាប* ប្រហែលជាប្ដូរទៅជា ស៊ូភ អេលាប ណាហាត់ (សូមមើល ខ.៣៤–៣៥) ។

**៦:២៧** *សាំយូអែល* តំណរវង្សរបស់គាត់ក៏មាននិយាយនៅក្នុង ១សយ ១:១ នៅកន្លែងដែលនិយាយអំពីគ្រួសាររបស់គាត់ ថាពួកអេប្រាអិម (សូមមើលទីនោះ) ។ នេះក៏ជាឧទាហរណ៍អំពីការប្រែប្រួលនៃតំណរវង្សដែលនិយាយអំពីទំនាក់ទំនងរបស់សាំយូអែលនៅក្នុងរោងឧបោសថ (សូមមើល ១សយ ជំពូក៣) និងកិច្ចការរបស់ពួកសង្ឃ (មើល ៩:២២ ១សយ ២:១៨ ៣:១) ដែលជាលទ្ធផលនៅក្នុងការចូលរួមរបស់គាត់ជាមួយពួកលេវី ។

**៦:៣១–៤៨** ពួកគេម្នាក់ៗក្នុងចំណោមពូជអំបូរទាំងបីនៃអំបូរលេវី គឺសុទ្ធតែជាអ្នកលេងភ្លេងក្នុងព្រះវិហារ ។ នៅក្នុងពួកកូនចៅកេហាត់មានហាម៉ាន ពួកកូនចៅគើសុន មានអេសាភ និងកូនចៅរបស់ម្រ៉ារី មានអេថាន ។ អ្នកកាលប្រវត្តិ តែងតែនិយាយជាច្រើនដងអំពីក្រុមភ្លេងរបស់ដាវីឌ (មើល ១៥:១៦,២៧ ២៥:១–៣១ ២រប ២៩:២៥–២៦ និង នហ ១២:៤៥–៤៧) ។ ការនិយាយម្ដងហើយម្ដងទៀតអំពីតួរនាទីរបស់ពួកលេវី ធ្វើឱ្យមានការប៉ាន់ស្មានថា អ្នកនិពន្ធព្រះគម្ពីរនេះ ក៏ជាអ្នកលេងភ្លេងផងដែរ ។ អក្សរសាស្ត្រមួយក្រៅព្រះគម្ពីរក៏បានបញ្ជាក់ថា នៅក្នុងព្រះវិហារពួកកាណាន ក៏មានពួកអ្នកចម្រៀង និងក្រុមភ្លេងផងដែរ ។ ពូជពង្សាវតារនេះបានទទួលស្គាល់ពីតួរនាទីរបស់ពួកលេវី ក្នុងអំឡុងពេលដែលគេស្ថាបនាប្រទេសជាតិឡើងវិញ (មើល អរ ២:៤០–៤១ នហ ៧:៤៣–៤៤ ១០:៩–១៣,២៨–២៩ ១១:១៥–១៨ ១២:២៤–៤៧) ។

៣៩ ហើយមានអេសាភ[ហ] ជាប្អូនឈរនៅខាងស្តាំ គឺអេសាភ
ជាកូនបេរេគា ដែលបេរេគា ជាកូនសាំម៉ា[ឡ] ៤០ សាំម៉ា
ជាកូនមីកែល។ ជាកូនបាសេយ៉ា។ជាកូនម៉ាលគា ៤១ ម៉ាលគា
ជាកូនអែតនី។ជាកូនសេរ៉ាស សេរ៉ាស ជាកូនអ័ដាយ៉ា
៤២ អ័ដាយ៉ា ជាកូនអេថាន។ជាកូនស៊ីម៉្មា។ ជាកូនស៊ីម៉ាយ
៤៣ ស៊ីម៉ាយ ជាកូនយ៉ាហាត យ៉ាហាត ជាកូនគើ សុន។ជាកូន
លេវី ៤៤ ហើយនៅខាងឆ្វេង មានពួកកូនចៅម្រ៉ារី[អ] ជាបង
ប្អូនគេ គឺអេថាន ជាកូនគីសី ដែលជាកូនអាប់ឌី។ជាកូន
ម៉ាលូក ៤៥ ម៉ាលូកជាកូនហាសាបយ៉ា។ជាកូនអ័ម៉ាស៊ា។
ជាកូនហ៊ីលគីយ៉ា ៤៦ ហ៊ីលគីយ៉ា ជាកូនអាំស៊ី។ជាកូនបានី។ជា
កូនសេមើរ ៤៧ សេមើរជាកូនម៉ាសលី។ជាកូនមូស៊ី។ជាកូន
ម្រ៉ារី។ជាកូនលេវី ៤៨ ហើយគឺពួកលេវី[ក] ជាបងប្អូនគេដែល
បានដំរូវឱ្យធ្វើការងារទាំងអស់ នៅក្នុងរោងឧបោសថ
ផងព្រះវិហារនៃព្រះ ។

៤៩ ឯអើរ៉ុន និងពួកកូនលោក គេថ្វាយដង្វាយនៅលើ
អាសនានៃដង្វាយដុត និងអាសនា[ខ] គ្រឿងក្រអូបក៏ធ្វើសំរេច
ការងារទាំងអស់ នៅក្នុងទីបរិសុទ្ធបំផុត និងការថ្វាយ
ដង្វាយឱ្យធួន[គ] និងបាប នៃពួកអ៊ីស្រាអែលផង តាមគ្រប់ទាំង
បង្គាប់របស់ម៉ូសេជាអ្នកបំរើនៃព្រះ ៥០ នេះកូនចៅអើរ៉ុន
គឺលោកបង្កើតអេលាសារ។បង្កើតភីនេហាស។បង្កើត
អ័ប៊ីសួរ ៥១ ឯអ័ប៊ីសួរក៏បង្កើតប៊ូកគី។បង្កើតអ៊ូស៊ី។បង្កើត
សេរ៉ាហ៊ា ៥២ សេរ៉ាហ៊ាបង្កើតមេរ៉ាយ៉ូត។បង្កើតអ័ម៉ារា។
បង្កើតអ័ហ៊ីទូប ៥៣ អ័ហ៊ីទូបបង្កើតសាដុក[ឃ]។បង្កើតអ័ហ៊ីម៉ាស

៥៤ ឯទីលំនៅ[ង] របស់ពួកកូនចៅអើរ៉ុន តាមទីក្រុង តាម
ព្រំដែននោះ ខាងឯពួកគ្រួកេហាត់ (ដ្បិតពួកគេបានឆ្នោត
ទី១) ៥៥ បានឱ្យគេមានក្រុងហេប្រុន នៅស្រុកយូដា និង
ដំបន់នៅជាប់ជុំវិញ ៥៦ តែស្រែចំការនៃទីក្រុង និងភូមិនៅ
ជាប់ជុំវិញ នោះបានឱ្យដល់កាលែប ជាកូនយេភូនេវិញ[ច]
៥៧ ហើយបានឱ្យទីក្រុងពំនាក់ទាំងប៉ុន្មាន ដល់ពួកកូនចៅ
អើរ៉ុនដែរគឺក្រុងហេប្រុន ក្រុងលិបណា[ឆ] និងដំបន់នៅជុំវិញ
ក្រុងយ៉ាទារ[ជ] ក្រុងអែសថេម៉ូរ និងដំបន់នៅជុំវិញ ៥៨ ក្រុង
ហូឡូន និងដំបន់នៅជុំវិញ ក្រុងដេបៀរ[ឈ] និងដំបន់នៅជុំវិញ
៥៩ ក្រុងអាសាន[ញ] និងតំបន់នៅជុំវិញ ក្រុងបេត-សេមែស
និងដំបន់នៅជុំវិញ ៦០ ហើយពីពូជអំបូរ បេនយ៉ាមីន នោះក៏
ឱ្យក្រុងកេបា និងតំបន់នៅជុំវិញ ក្រុងអាលេមែត និងដំបន់
នៅជុំវិញ ហើយក្រុងអាន៉ាថោត[ដ] និងដំបន់នៅជុំវិញ ទីក្រុង
សំរាប់ពួកគ្រួកេហាត់ទាំងអស់មាន១៣ ។

៦១ ឯពួកកូនចៅកេហាត់ ដែលសល់ក្នុងពួកគ្រួទាំងប៉ុន្មាន
របស់ពូជអំបូរនោះ នោះតាមឆ្នោតបានឱ្យទីក្រុង១០ពីពូជ
អំបូរម៉ាន៉ាសេ១ចំហៀងដល់គេ ៦២ ឯពួកកូនចៅគើសុនតាម
គ្រួគេ នោះបានឱ្យទីក្រុង១៣ ពីពូជអំបូរអ៊ីសាខារ អេសើរ
ណែបថាលី ហើយពីពូជអំបូរម៉ាន៉ាសេ ដែលនៅស្រុក
បាសាន ៦៣ ចំណែកឯពួកកូនចៅម្រ៉ារីតាមគ្រួគេ នោះតាម
ឆ្នោតបានឱ្យទីក្រុង១២ ពីពូជអំបូររូបេនកាឌ់ និងសាប់
យូលូន ៦៤ ពួកកូនចៅសាសន៍អ៊ីស្រាអែលបានឱ្យទីក្រុងទាំង
នោះ[ឋ] ព្រមទាំងដំបន់នៅជុំវិញទៅពួកលេវី ៦៥ គេបានចែក
ទីក្រុងទាំងប៉ុន្មាន ដែលមានឈ្មោះកត់ទុកនេះដល់គេ ពីពូជ
អំបូរនៃកូនចៅយូដា កូនចៅស៊ីម្មាន និងកូនចៅបេនយ៉ាមីន
ដោយចាប់ឆ្នោត ។

៦៦ មានពួកគ្រួនៃកូនចៅកេហាត់ខ្លះ គេបានទីក្រុងរបស់
ព្រំដែនខ្លួន ពីក្នុងពូជអំបូរអេប្រាអិមវិញ ៦៧ ទីក្រុងទំនាក់
ទាំងប៉ុន្មាន ក៏បានឱ្យដល់ពួកកេហាត់ដែរ គឺក្រុងស៊ីគែម
ដែលនៅស្រុកភ្នំអេប្រាអិម ព្រមទាំងដំបន់នៅជុំវិញ ក្រុង
កេស៊ើ[ឌ] និងដំបន់នៅជុំវិញ ៦៨ ក្រុងយ៉ុកមាម[ឍ] និងដំបន់នៅ
ជុំវិញ ក្រុងបេត-ហូរ៉ុន[ណ] និងដំបន់នៅជុំវិញ ៦៩ ក្រុង
អាយ៉ាឡូន[ត] និងដំបន់នៅជុំវិញ[ថ] ៧០ ហើយពីពូជអំបូរ
ម៉ាន៉ាសេ១ចំហៀង នោះក៏ឱ្យក្រុងអាន់នើរ និងដំបន់នៅ
ជុំវិញក្រុងប៊ីលាម និងដំបន់នៅជុំវិញ សំរាប់ពួកគ្រួកូនចៅ
កេហាត់ដែលសល់ដែរ ។

៧១ ឯពួកកូនចៅគើសុន[ទ] នោះបានចែកឱ្យមានទីក្រុង
របស់ពូជអំបូរម៉ាន៉ាសេ១ចំហៀង គឺក្រុងកូឡាននៅស្រុក
បាសាន[ធ] និងដំបន់នៅជុំវិញ ហើយក្រុងហាសថារ៉ូត និង
ដំបន់នៅជុំវិញ ៧២ ហើយពីពូជអំបូរអ៊ីសាខារ ក៏ឱ្យក្រុង
កេដេសនិងដំបន់នៅជុំវិញ ក្រុងដាប្រាត និងដំបន់នៅ
ជុំវិញ[ន] ៧៣ ក្រុងរ៉ាម៉ូត និងដំបន់នៅជុំវិញ ហើយក្រុងអានេម
និងដំបន់នៅជុំវិញ ៧៤ ពីពូជអំបូរអេសើរ ក៏ឱ្យក្រុងម៉ាសាល
និងដំបន់នៅជុំវិញ ក្រុងអាប់ដូន[ប] និងដំបន់នៅជុំវិញ ៧៥ ក្រុង
ហ៊ូកូក[ផ] និងដំបន់នៅជុំវិញ ក្រុងរេហុប[ព] និងដំបន់នៅជុំវិញ

**៦:៣៩** ហ ១រប ២៥:១,៩ ២រប ២៩:១៣ នហ ១១:១៧ ឡ ១រប ១៥:១៧
**៦:៤៤** អ ១រប ១៥:១៧
**៦:៤៨** ក ១រប ២៣:៣២
**៦:៤៩** ខ នក ២៧:១–៨ គ នក ៣០:១–៧,១០ ២រប ២៦:១៨
**៦:៥៣** ឃ ២សយ ៨:១៧
**៦:៥៤** ង ជន ៣១:១០
**៦:៥៦** ច យស ១៤:១៣ ១៥:១៣
**៦:៥៧** ឆ ជន ៣៣:២០ ជ យស ១៥:៤៨
**៦:៥៨** ឈ យស ១០:៣
**៦:៥៩** ញ យស ១៥:៤២
**៦:៦០** ដ យរ ១:១
**៦:៦៤** ឋ ជន ៣៥:១–៨
**៦:៦៧** ឌ យស ១០:៣៣
**៦:៦៨** ឍ ១ពវ ៤:១២ ណ យស ១០:១០
**៦:៦៩** ត យស ១០:១២ ថ យស ១៩:៤៥
**៦:៧១** ទ ១រប ២៣:៧ ធ យស ២០:៨
**៦:៧២** ន យស ១៩:១២
**៦:៧៤** ប យស ១៩:២៨

**៦:៤៩–៥៣** នៅក្នុងខ.ទាំងនេះ គឺជាការនិយាយឡើងវិញពី ខ.៤–៨ ប៉ុន្តែពួកគេទាំងនោះមានតួនាទីផ្សេងៗពីគ្នាគឺៈ ដើម្បីបំពេញច្បាប់ជាជិនួរវង្សរបស់សាដុក ដែលបន្តរហូតដល់គ្រាស្តេចសាឡូម៉ូនគឺមានតែពួកលេវីប៉ុណ្ណោះ ដែលត្រូវបានគេផ្តល់សិទ្ធឱ្យ ដើម្បីធ្វើការថ្វាយយញ្ញបូជាទៅចំពោះព្រះអម្ចាស់បាន ។

**៦:៥៤–៨១** ទ្រព្យសម្បត្តិរបស់ពួកលេវីទាំងនេះ គឺដកស្រង់ចេញពី យស ២១ ដែលគ្រាន់តែមានការខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ (សូមមើលការពន្យល់នៅទីនោះ) ។

៧៦ពីពូជអំបូរណៃមថាលី ក៏ឱ្យក្រុងកេដេស នៅស្រុក
កាលីឡេ និងដំបន់នៅជុំវិញក្រុងហាំម៉ូន[ភ] និងដំបន់នៅ
ជុំវិញ ហើយក្រុងគារយ៉ាថែម[ម] និងដំបន់នៅជុំវិញ ។
៧៧ឯពួកលេវីដែលសល់ គឺជាពួកម្រ៉ារី នោះបានចែក
ឱ្យគេ ពីពូជអំបូរសាប់យូល៉ូន គឺក្រុងរីម៉ូនរ និងដំបន់នៅ
ជុំវិញ ក្រុងតាបោរ និងដំបន់នៅជុំវិញ ៧៨នឹងខាងនាយទន្លេ
យ័រដាន់ ត្រង់ក្រុងយេរីខូរ គឺខាងកើតទន្លេនោះពីពូជអំបូរ
រូបេនក៏ឱ្យក្រុងបេសើរ[យ] ដែលនៅទីរហោស្ថាន និងដំបន់
នៅជុំវិញ ក្រុងយ៉ាឃាស និងដំបន់នៅជុំវិញ ៧៩ក្រុងក្ដេម៉ូត[រ]
និងដំបន់នៅជុំវិញ ហើយក្រុងមេផ្អាត និងដំបន់នៅជុំវិញ
៨០ពីពូជអំបូរកាឌ់ បានឱ្យក្រុងរ៉ាម៉ូតនៅស្រុកកាឡាត[ល] និង
ដំបន់នៅជុំវិញ ក្រុងម៉ាហាណែម[វ] និងដំបន់នៅជុំវិញ
៨១ក្រុងហែសបូន និងដំបន់នៅជុំវិញ ហើយក្រុងយ៉ាសើរ[ស]
និងដំបន់នៅជុំវិញ[ហ] ។

## អ៊ីសាខារ

**៧** ១ឯកូនរបស់អ៊ីសាខារ[ក] គឺថូឡា ពូវ៉ា[ខ] យ៉ាសុប និង
ស៊ីមរ៉ុន ទាំងអស់មាន៤នាក់ ២ឯកូនថូឡា គឺអ៊ូស៊ីរេផាយ៉ា
យេរីអែល យ៉ាម៉ាយ យីបសាម និងសាំយូអែលនោះសុទ្ធ
តែជាកំពូលលើពួកវង្សរបស់ឪពុកគេ គឺថូឡានោះឯង
ពួកនោះជាមនុស្សខ្លាំងពូកែ ដែលមានចិត្តក្លាហាន តាម
ដំណគេរៀងខ្លួន ហើយនៅក្នុងរាជ្យដាវីឌនោះ គេមាន
ចំនួន២ម៉ឺន២ពាន់៦០០នាក់ ៣ឯកូនរបស់អ៊ូស៊ី គឺយីសរ៉ាហ៊ា
ហើយកូនរបស់ យីសរ៉ាហ៊ា គឺមីកែលអូបាឌា យ៉ូអែល
និងយីសយ៉ា ទាំងអស់មាន៥នាក់ដែលសុទ្ធតែជាមេ ៤ហើយ
នៅជាមួយនឹងគេ មានពួកទាហានសំរាប់ចំបាំង ចំនួន៣ម៉ឺន
៦ពាន់នាក់ តាមដំណតាមវង្សានុវង្សរបស់ពួកឰយុកោគេ
ពីព្រោះគេមានប្រពន្ធមានកូនច្រើន ៥រួមពួកបងប្អូនគេនៅ
ក្នុងពួកគ្រួអ៊ីសាខារទាំងប៉ុន្មាន ជាមនុស្សខ្លាំងពូកែ មានចិត្ត
ក្លាហាន ដែលរាប់តាមពង្សាវតារគេ នោះមានចំនួន
៨ម៉ឺន៧ពាន់នាក់ ។

## បេនយ៉ាមីន

៦ឯកូនរបស់បេនយ៉ាមីន[គ] គឺបេឡា បេគើរ និងយេឌីអែល
ទាំងអស់មាន៣នាក់ ៧ឯកូនរបស់បេឡាគឺអេសបូន អ៊ូស៊ី
អ៊ូស៊ាល យេរី ម៉ូត និងអ៊ីរីទាំងអស់មាន៥នាក់ ដែលសុទ្ធតែ
ជាកំពូលលើវង្សរបស់ ឪពុកគេ ហើយជាមនុស្សខ្លាំងពូកែ
មានចិត្តក្លាហាន តាមពង្សាវតាររបស់គេ នោះបានរាប់
ចំនួនជា២ម៉ឺន២ពាន់៣៤នាក់ ៨ឯកូនរបស់បេគើរ គឺ
សេមីរ៉ា យ៉ូអាស អេលាសើរ អូលីយ៉ូនាយ អំរី យេរេម៉ូត
អ័ប៊ីយ៉ា អ័ណាថូត និងអ័ឡាមែត នេះសុទ្ធតែជាកូនរបស់
បេគើរ ៩ក៏បានរាប់គេតាមពង្សាវតារ តាមដំណគេ សុទ្ធ
តែជាកំពូលលើវង្សរបស់ឪពុកគេ ជាមនុស្សខ្លាំងពូកែ
មានចិត្តក្លាហានឃើញមានចំនួន២ម៉ឺន២០០នាក់ ១០ឯកូន
របស់យេឌីអែល គឺប៊ីលហាន ហើយកូនរបស់ប៊ីលហាន
គឺយេអ៊ូសបេនយ៉ាមីន អេហ៊ុឌ ក្នាអាណា សេថាន តើស៊ីស
និងអ័ហ៊ីសាហារ ១១នោះសុទ្ធតែជាកូនរបស់យេឌីអែល
តាមពួកអ្នក ដែលជាកំពូលលើវង្សរបស់ឪពុកគេ ជាមនុស្ស
ខ្លាំងពូកែ មានចិត្តក្លាហាន ដែលអាចនឹងចេញទៅច្បាំង
ក្នុងពួកពលទ័ពបាន មានចំនួន១ម៉ឺន៧ពាន់២០០នាក់ ១២ក៏
មានស៊ូភីម នឹងហ៊ូភីម ជាកូនអ៊ា ហើយហ៊ូស៊ីមជាកូន
អ័ហេើរដែរ ។

## ណែបថាលី

១៣ឯកូនរបស់ណែបថាលី[ឃ] គឺយ៉ាស៊ាល គូនី យេសើរ
នឹងស៊ីលិម សុទ្ធតែជាកូនរបស់នាងប៊ីលហា ។

## ម៉ាន៉ាសេ

១៤ឯកូនរបស់ម៉ាន៉ាសេ[ង] គឺអាសរាល ដែលប្រពន្ធចុង
របស់គាត់ ជាស្រីសាសន៍អើរ៉ាមបានបង្កើត នាងក៏បង្កើត
ម៉ាគារជាឪពុកកាឡាត[ច] ១៥ហើយម៉ាគារបានយកប្រពន្ធ

**៦:៧៥** ផ យស ១៩:៣៤ ព ជន ១៣:២១
**៦:៧៦** ភ យស ១៩:២៨ ម ជន ៣២:៣៧
**៦:៧៨** យ យស ២០:៨
**៦:៧៩** រ ចទ ២:២៦
**៦:៨០** ល យស ២០:៨ វ លប ៣២:២
**៦:៨១** ស ជន ២១:៣២ ហ ២រប ១១:១៤
**៧:១** ក លប ៣០:១៨ ខ លប ៤៦:១៣
**៧:៦** គ ជន ២៦:៣៨
**៧:១៣** ឃ លប ៣០:៨
**៧:១៤** ង លប ៤១:៥១ យស ១៧:១ ១រប ៥:២៣ ច ជន ២៦:៣០
**៧:១៥** ឆ ជន ២៦:៣៣ ៣៦:១–១២

**៧:១–៥** ពង្សាវតារទាំងអស់នៃអំបូរអើសាខា គឺបានដកស្រង់ចេញពីព្រះគម្ពីរ លប ៤៦:១៣ ជន ១:២៨ ២៦:២៣–២៥ ទោះបីជាភាគច្រើននៃមនុស្សមិនបានបញ្ជាក់ក៏ដោយ ។ បញ្ជីឈ្មោះពូជអំបូរទាំងនេះគឺសុទ្ធតែជាទាហាន (មើល ខ.២,៤–៥) ដែលបានបម្រើការងារក្នុងគ្រាដាវីឌ (សូមមើល ខ.២) ហើយប្រហែលជាស្រង់ចំនួនប្រជាជន ដែលមាននៅក្នុងជំពូក ២១ និង ២សយ ២៤ ។

**៧:៦–១២** នេះគឺជាសារៈសំខាន់នៃការប្រែប្រួលនៃឈ្មោះកូនចៅ បេនយ៉ាមីន ។ បញ្ជីឈ្មោះកូនចៅបេនយ៉ាមីននៅកន្លែងនេះមាន៣នាក់ តែនៅក្នុង លប ៤៦:២១ វិញបានកត់ចុះកូនចៅរបស់បេនយ៉ាមីន១០នាក់ ។ នៅក្នុង ជន ២៦:៣៨–៣៩ និង ១រប ៨:១–២ គឺមានចំនួន៥វិញ(មានតែម្នាក់ប៉ុណ្ណោះដែលឃើញមាននៅគ្រប់បទគម្ពីរទាំងនោះ គឺបេឡាដែលគាត់ជាកូនច្បង) ។ ការបំរែបម្រួលនេះ បានផ្ដោតទៅលើយុគសម័យកាលផ្សេងៗគ្នា និងតួរនាទីរបស់ពង្សាវតារទាំងនោះ ។ បញ្ជីឈ្មោះទាំងប៉ុន្មាននេះ គឺសុទ្ធតែមានតួរនាទីក្នុងជួរកងទ័ព (មើល ខ.៧,៩,១១) ។

**៧:១៣** ដកស្រង់ចេញពី លប ៤៦:២៤ ជន ២៦:៤៨–៥០ ។ *ជាកូនរបស់នាងប៊ីលហា* ដាន់និងណែបថាលី គឺពិតជា"កូន"របស់នាងប៊ីលហាជាប្រពន្ធចុងលោកយ៉ាកុប (សូមមើល លប ៣០:៣–៨) ដូច្នេះហើយបានជាកូនរបស់ណែបថាលី គឺជាកូនចៅរបស់នាងប៊ីលហា ។

**៧:១៤–១៩** សូមមើលការពន្យល់ក្នុង ៥:២៣–២៦ ។ ប្រភពនៃពង្សាវតារនៃជំនួរវង្សនេះ គឺនៅក្នុង ជន ២៦:២៩–៣៤ យស ១៧: ១–១៨ ។ កូនស្រី

ឈ្មោះម្អាកា ជាប្អូនស្រីរបស់ពួកហ៊ូភីម នឹងស៊ូភីមហើយកូន
ទី២របស់ម៉ាន៉ាសេ គឺស្លូផិហាត[ឆ] រីឯស្លូផិហាតគាត់មានសុទ្ធ
តែកូនស្រី 16ឯនាងម្អាកាជាប្រពន្ធម៉ាគារនាងបង្កើតបាន
កូនប្រុស១ ឱ្យឈ្មោះថា ពេរែស ប្អូនគាត់ឈ្មោះសេរែស
ហើយកូនរបស់អ្នកនោះ គឺអ៊ូឡាមនឹងរ៉ាគែម 17ឯកូនរបស់
អ៊ូឡាម គឺបេដាននេះ សុទ្ធតែជាកូនចៅរបស់កាឡាត[ជ]
ដែលជាកូនម៉ាគារ ជាកូនម៉ាន៉ាសេ 18ហើយហាម៉ូលេកេត
ជាប្អូនស្រីគាត់ ក៏បង្កើតអ៊ីសហូឌ អ័បៀស៊ើរ[ឈ] និងម៉ាឡា
19ហើយកូនរបស់សេមីដា[ញ] គឺអ័សយ៉ាន ស៊ីគែម លីកហ៊ី
អ័នីយ៉ាម ។

## អេប្រាអិម

20ឯកូនរបស់អេប្រាអិម[ដ] គឺស៊ុថេឡាៗបង្កើតថាហាត
21ថាហាត គាត់បង្កើតសាបាឌៗបង្កើតស៊ុថេឡាៗបង្កើត
អេស៊ើរ និងអេលាឌ ដែលពួកអ្នកកើតនៅស្រុកកាថបាន
សំឡាប់ ដោយព្រោះអ្នកទាំង២នោះបាន ចុះទៅចង់យក
ហ្វូងសត្វរបស់គេ 22ឯអេប្រាអិមជាឪពុក ក៏កាន់ទុក្ខជាយូរ
ថ្ងៃ ហើយពួកបងប្អូនក៏មកជួយរំដោះទុក្ខ 23រួចគាត់ចូល
ទៅឯប្រពន្ធ ហើយនាងមានទំងន់ បង្កើតបានកូនប្រុស១
គាត់ឱ្យឈ្មោះថា បេរា ដោយព្រោះកើតមានសេចក្ដីអាក្រក់
ដល់គ្រួគាត់ 24កូនស្រីរបស់គាត់ គឺសេអេរ៉ា ជាអ្នកសង់
ក្រុងបេត-ហូរ៉ុន[ឋ]ខាងក្រោម ហើយខាងលើផង និងក្រុង
អ៊ូសេន-សេអេរ៉ាដែរ 25បេរាបង្កើតរេផា និងរេសែប
រេផាបង្កើតថេឡាៗបង្កើតថាហាន 26ថាហានបង្កើតឡាអា
ដានៗបង្កើតអាំមិហ៊ូតៗបង្កើតអេលីសាម៉ា 27អេលីសាម៉ា
បង្កើតនុនៗ បង្កើតយ៉ូស្វេ។
28ឯកេរ្តិ៍អាករ និងទីលំនៅរបស់គេ នោះគឺនៅក្រុង
បេត-អែល និងភូមិនៅជុំវិញ ហើយទៅខាងកើតដល់ក្រុង
ណាអារ៉ាន និងខាងលិចដល់ក្រុងកេស៊ើរ[ឌ] និងភូមិជុំវិញ

**៧:១៧** ជ ជន ២៦:៣០
**៧:១៨** ឈ យស ១៧:២
**៧:១៩** ញ យស ១៧:២
**៧:២០** ដ លប ៤១:៥២ ជន ១:៣៣
**៧:២៤** ឋ យស ១០:១០
**៧:២៨** ឌ យស ១០:៣៣
**៧:២៩** ឍ យស ១៧:១១ ណ យស ១១:២

ព្រមទាំងក្រុងស៊ីគែម និងភូមិនៅជុំវិញ រហូតដល់ក្រុង
កាសា និងភូមិនៅជុំវិញ រហូតដល់ក្រុងកាសា និងភូមិនៅ
ជុំវិញទាំងប៉ុន្មាន 29ហើយតាមព្រំដែននៃពួកកូនចៅ
ម៉ាន៉ាសេ នោះមានក្រុងបេត-សៀន[ឍ] និងភូមិនៅជុំវិញ
ក្រុងតាណាក និងភូមិនៅជុំវិញ ក្រុងមេគីដោ និងភូមិនៅ
ជុំវិញក្រុងដោរ[ណ] និងភូមិនៅ ជុំវិញទាំងប៉ុន្មាន ពួកកូនចៅ
យ៉ូសែប ជាកូនអ៊ីស្រាអែល គេនៅក្នុងទីក្រុងទាំងនោះ ។

## អេស៊ើរ

30ឯកូនរបស់អេស៊ើរ[ត] គឺយីមន៉ា យីសវ៉ា យីសវីបេរា
នឹងសេរ៉ា ជាប្អូនស្រីគេ 31ឯកូនបេរា គឺហេបើរ និង
ម៉ាលគាល ជាឪពុកប៊ីសាវីត 32ហើយហេបើរបង្កើត
យ៉ាផ្លេត សូមើរ ហូថាម និងស៊ូអា ដែលជាប្អូនស្រីគេ 33ឯ
កូនរបស់យ៉ាផ្លេត គឺផាសាក់ ប៊ីមហាល និងអ័សវ៉ាត នេះ
សុទ្ធតែជាកូនយ៉ាផ្លេត 34ឯកូនរបស់សូមើរ គឺអ័ហ៊ី រ៉ូកា
ហ៊ូបបា និងអើរ៉ាម 35កូនរបស់ហេលេមជាប្អូនគាត់ គឺសូផា
យីមន៉ា សេលេស និងអាំម៉ាល 36ឯកូនរបស់សូផា គឺស៊ូអា
ហានេភើរ ស៊ូ អាល បេរីយីមរ៉ា 37បេស៊ើរ ហូឌ សាំម៉ា
ស៊ីលសា យីតរ៉ាន និងបេអ៊េរ៉ា 38ឯកូនរបស់យេធើ គឺយេភូនេ
ពីសផា និងអើរ៉ា 39កូន របស់អ៊ូឡា គឺអើរ៉ាស ហានាស
និងរីសយ៉ា 40នោះសុទ្ធតែជាកូនចៅរបស់អេស៊ើរ ជា
កំពូលលើវង្សរបស់ឪពុកគេ ជាមនុស្សជ្រើសរើស ហើយ
ខ្លាំងពូកែ មានចិត្តក្លាហាន ជាមេលើពួកចៅហ្វាយ ដែល
បានរាប់តាមពង្សាវតារ សំរាប់ក្រសួងខាងចំបាំង មាន
ចំនួនជា២ម៉ឺន៦ពាន់នាក់ ។

## ពង្សាវតាររបស់

៨ 1ឯបេនយ៉ាមីន[ក] គាត់បង្កើតបេឡាជាកូនច្បង រួច
អ័សបេល ជាកូនទី២ អ័ហ៊ីរ៉ាមទី៣ 2ណូហាទី៤រ៉ាផាទី៥ 3ឯ

**៧:៣០** ត ជន ១:៤០ **៨:១** ក លប ៤៦:២១

---

របស់ស្លូផិហាត (ខ.១៥) មានសិទ្ធទទួលយកកេរ្តិ៍មរដកតាមច្បាប់របស់ស្ត្រី (សូមមើល ជន ២៦:២៩–៣៤ ២៧:១–១១ ៣៦:១–១២ យស ១៧:៣–៤) ។

**៧:២០–២៩** ប្រភពឯកសារនៃពង្សាវតាររបស់ពួកអេប្រាអិម គឺមាននិយាយនៅក្នុង ជន ២៦:៣៥ ។ បើសិនរេផា (មើល ខ.២៥) ជាចៅរបស់អេប្រាអិម នោះមានកូនចៅជំនាន់ទៀត ដែលត្រូវបានកត់ចុះក្នុងសៀវភៅចាប់តាំងពីគ្រាអេប្រាអិម រហូតដល់គ្រាលោកយ៉ូស្វេ ដែលមានរយៈពល ៤០០ឆ្នាំ ចន្លោះពេលដែលពួកអ៊ីស្រាអែលរស់នៅក្នុងប្រទេសអេស៊ីព្ទ ។ សូមមើល ជន ១៣:៨ ក៏បាននិយាយថា ពួកព្ធយុកោរបស់យ៉ូស្វេ គឺជាពួកអេប្រាអិម (កន្លែងដែលនិយាយថា "ហូសេ" សូមមើល ជន ១៣:១៦) ។ ការវាយលុកប្រឆាំងពួកអ្នកស្រុកកាថ (មើល ខ.២១–២២) គឺប្រហែលជាមុនពេលដែលពួកគេច្បាំងដណ្ដើមទឹកដីជាមួយពួកកាណាន គឺតាំងពីពួកគេស្ថិតក្នុងស្រុកអេស៊ីព្ទមកម្ល៉េះ ។ ទីលំនៅរបស់ពួកគេ (មើល ខ.២៨–២៩) គឺសង្ខេបចេញពីគម្ពីរ (យស ១៦–១៧) ។

**៧:៣០–៤០** ពួកកូនចៅដំបូង៣ នៃពង្សាវតាររបស់អាសស៊ើរ គឺកើតចេញពី លប ៤៦:១៧ ហើយក៏មានការប្រហាក់ប្រហែលគ្នានៅក្នុង ជន ២៦:៤៤–៤៦ លើកលែងតែឈ្មោះរបស់យីសវ៉ា (មើល ខ.៣០) មិនបានឃើញនៅទីនោះឡើយ ។ ពង្សាវតារនេះ ក៏មានតួរនាទីក្នុងជួរកងទ័ពដែរ (សូមមើល ខ.៤០) ។

**៨:១–៤០** ការសនិដ្ឋានលើកទី២ ចំពោះពង្សាវតាបេនយ៉ាមីន (សូមមើល ៧:៦–១២) គឺដោយសារតែពង្សាវតារនេះមានសារៈសំខាន់ និងដោយសាចំណាប់អារម្មណ៍របស់អ្នកកត់ត្រាពង្សាវតាក្នុងជំនាន់រាជ្យស្តេចសូល ។ យូដា ស៊ីម្មាន និងពួកបេនយ៉ាមីនមួយចំនួន បានបង្កើតអាណាចក្រខាងត្បូង

បេឡាក៏មានកូន គឺអ័តដើរ[ខ] កេរ៉ា អ័ប៊ីហ៊ូឌ ៤អ័ប៊ីស្វួរ
ណាម៉ាន អ័ហូអា[គ] ៥កេរ៉ា សេភូផាន និងហ៊ូរ៉ាម ៦ឯកូន
របស់អេហ៊ុឌ[ឃ] ជាកូនអ្នកដែលជាកំពូលលើវង្សរបស់ឪពុក
គេ ក្នុងពួកអ្នកស្រុកកេបា ដែលត្រូវផ្លាស់ទៅនៅក្រុង
ម៉ាន៉ាហាត់វិញ ៧គឺណាម៉ាន អ័ហ៊ីយ៉ានឹងកេរ៉ា គឺកេរ៉ានេះ
ដែលនាំគេផ្លាស់ទៅនោះ ហើយគាត់ក៏បង្កើតអ៊ូសា និង
អ័ហ៊ីហ៊ូឌ ៨ឯសាហារេម គាត់បង្កើតកូននៅស្រុកម៉ូអាប់
ក្រោយដែលបានឱ្យគេទៅ ឯប្រពន្ធគាត់ គឺហ៊ូស៊ីម និងប្អារ៉ា
៩ហើយគាត់បង្កើតកូននឹងហូដេស ជាប្រពន្ធគាត់ គឺយ៉ូបាប់
ស៊ីបយ៉ា មេសា ម៉ាលកាម ១០យេអ៊ូស សុកយ៉ា នឹងមារម៉ា
នោះសុទ្ធតែជាកូនគាត់ ជាកំពូលលើវង្សរបស់ឪពុកគេ
១១គាត់ក៏បង្កើតកូននិងហ៊ូស៊ីមដែរ គឺអ័ប៊ីធូប និងអែលផ្អាល
១២ឯកូនរបស់អែលផ្អាល គឺហេប៊ើរ មីសាម សេមើរ ជា
អ្នកដែលសង់ក្រុងអូណូរ[ង] និងក្រុងឡូឌ ព្រមទាំងភូមិនៅ
ជុំវិញទាំងប៉ុន្មានផង ១៣ហើយបេរា និងសេម៉ា ដែលជា
កំពូលលើវង្សរបស់ឪពុកគេ ជាពួកអ្នកស្រុកអាយ៉ាឡូន[ច]គេ
បានឈ្នះធ្វើឱ្យពួកអ្នកស្រុកកាថរត់ចេញ[ឆ] ១៤ហើយអ័ហ៊ីយ៉ូរ
សាសាក់ យេរេម៉ូត ១៥សេបាឌា អើរ៉ាត អេឌើរ ១៦មីកែល
យីសប៉ា និងយ៉ូហា នោះសុទ្ធតែជាកូនរបស់បេរា ១៧ឯ
សេបាឌា មស៊ូឡាម ហ៊ីសគីហេប៊ើរ ១៨យីសមេរ៉ាយ
យីសលា និងយ៉ូបាប់ នោះសុទ្ធតែជាកូនរបស់អែលផ្អាល
១៩ឯយ៉ាគីម ស៊ីកគ្រីសាប់ឌី ២០អេលីយេណាយ ស៊ីលថាយ
អេលាល ២១អ័ដាយ៉ា បេរ៉ាយ៉ា និងស៊ីមរ៉ាត សុទ្ធតែ
ជាកូនរបស់ស៊ីម៉ាយ ២២ឯយីសផាន ហេប៊ើរ អេលាល
២៣អាបដូនស៊ីកគ្រី ហាណាន ២៤ហាណានា អេឡាំ
អាន់ថូធីយ៉ា ២៥យីបដេយ៉ា និងពេនួល សុទ្ធតែជាកូនរបស់
សាសាក់ ២៦ឯសាំសេរ៉ាយ សេហារា អ័ថាលា
២៧យ៉ារេសយ៉ា អេលីយ៉ា និងស៊ីកគ្រី នោះសុទ្ធតែជាកូន
របស់យេរ៉ូហាំ ២៨នេះសុទ្ធតែជាពួកអ្នក ដែលជាកំពូលលើ
វង្សរបស់ឪពុកគេ តាមដំណគេរៀងខ្លួន ជាពួកមេទាំងអស់
ហើយជាអ្នកនៅក្រុងយេរូសាឡិម ។
២៩ឯអ្នកដែលតាំងក្រុងគីបៀន[ជ] ក៏នៅក្រុងនោះឯង
ប្រពន្ធគាត់ ឈ្មោះម្អាកា ៣០ឯកូនច្បង គឺអាបដូន រួចស៊ើរ
គីស បាល ណាដាប ៣១កេដោរ អ័ហ៊ីយ៉ូរ និងសាការី
៣២ឯមីកឡូត ក៏បង្កើតសាំម៉ា អ្នកទាំងនោះក៏នៅក្រុង
យេរូសាឡិម ជាមួយនឹងបងប្អូនគេដែរ ។
៣៣ឯនើរ[ឈ]ក៏បង្កើតគីស[ញ]ហើយគីសបង្កើតសូល ឯសូល[ដ]
ក៏បង្កើត យ៉ូណាថាន ម៉ាលគី-ស៊ូអា អ័ប៊ីន៉ាដាប់ នឹងអែស-
បាល[ឋ] ៣៤ឯកូនរបស់យ៉ូណាថាន[ឌ] គឺមេរីប-បាល ហើយ
មេរីប-បាលនោះ[ឍ] ក៏បង្កើតមីកា ៣៥ឯកូនរបស់មីកា គឺ
ពីថូន មែលេក ថាក់រា និងអ័ហាស ៣៦ឯអ័ហាសបង្កើត
យេហូអាដា។បង្កើអ័លេមេត អាសម៉ាវែតនឹងស៊ីមរី ឯស៊ីម
បង្កើតម៉ូសា ៣៧ម៉ូសាបង្កើតប៊ីនា ប៊ីនាមានកូន ឈ្មោះរេផា
យ៉ា។មានកូន ឈ្មោះអេលាសា អេលាសាមានកូនឈ្មោះ
អ័សេល ៣៨ឯអ័សេលគាត់មានកូនប្រុស៦នាក់ឈ្មោះ
អាសរីកាម បូករូវ អ៊ីសម៉ាអែល ស្អារា អូបាឌា និង
ហាណាន នោះសុទ្ធតែជាកូនរបស់អ័សេល ៣៩ឯកូនរបស់
អេសែក ជាប្អូនគាត់ គឺអ៊ូឡាមជាកូនច្បង រួចយេអ៊ូសជា
កូនទី២ អេលីផាលេតទី៣ ៤០ឯកូនរបស់អ៊ូឡាម សុទ្ធតែ
ជាអ្នកខ្លាំងពូកែ មានចិត្តក្លាហានស្ទាត់ក្នុងការបាញ់ធ្នូ
ហើយគេមានកូនមានចៅជាច្រើន រួមទាំងអស់មាន១៥០
នាក់ នេះសុទ្ធតែជាកូនចៅរបស់បេនយ៉ាមីន[ណ]។

**៩** ១គឺយ៉ាងនោះ ដែលបានរាប់សាសន៍អ៊ីស្រាអែលទាំង
អស់[ក] តាមពង្សាវតាររបស់គេ ហើយបានកត់ទុកក្នុងបញ្ជី
របស់ពួកស្តេចសាសន៍អ៊ីស្រាអែល ។

## ប្រជាជននៅក្នុងក្រុងយេរូសាឡិម

*៩:១-១៧ - នហ ១១:៣-១៩*

រួចមកពួកយូដាត្រូវដឹកនាំទៅជាឈ្លើយដល់ស្រុកបាប៊ីឡូន
ដោយព្រោះអំពើរំលងរបស់គេ[គ]។

**៨:៣** ខ លប ៤៦:២១
**៨:៤** គ ២សយ ២៣:៩
**៨:៦** ឃ ពច ៣:១២-៣០
**៨:១២** ង អរ ២:៣៣ នហ ៦:២ ៧:៣៧ ១១:៣៥
**៨:១៣** ច យស ១០:១២ ឆ យស ១១:២២
**៨:២៩** ជ យស ៩:៣
**៨:៣៣** ឈ ១សយ ២៨:១៩ ញ ១សយ ៩:១ ដ ១សយ ១៤:៤៩ ឋ ២សយ ២:៨
**៨:៣៤** ឌ ២សយ ៩:១២ ឍ ២សយ ៤:៤ ២១:៧-១៤
**៨:៤០** ណ ជន ២៦:៣៨
**៩:១** ក ១របា ១១:១,១០ ១២:៣៨ ១៤:៨ ១៥:៣,២៨ ១៨:១៤ ១៩:១៧ ២១:៥ ២៨:៤,៨ ២៩:២១,២៣ ២របា ១:២ ៥:៣ ៧:៨ ១០:៣,១៦ ១២:១ ១៣:៤,១៥ ១៨:១៦ ២៤:៥ ២៨:២៣ ២៩:២៤ ៣០:១ ខ ចទ ២១:១០ គ ១របា ៥:២៥

(មើល ១ពរ ១២:១-២១) ។ ពង្សាវតារនៃបេនយ៉ាមីនគឺមានចំនួនច្រើនជាងពូជអំបូរផ្សេងៗទៀតលើកលែងតែពួកយូដានិងពួកលេវី ។ អ្នកកត់ត្រាប្រវត្តិសាស្ត្រក៏មានទំនាក់ទំនងជាមួយពង្សាវតាររបស់សូលដែរ (មើល ៩.២៩-៣៨) ។

**៨:១-៥** សូមប្រៀបធៀបជាមួយ ៧:៦-១២ លប ៤៦:២១-២២ ជន ២៦:៣៨-៤១ ។

**៨:៦-២៧** មានឃើញតែម្តងគត់ក្នុងរបាក្សត្រ ។

**៨:២៩-៣៨** មានសារៈសំខាន់ដូចគ្នានឹងឈ្មោះក្នុង ៩:៣៥-៤៤ ។

**៨:៣៣** សម្រាប់កូនរបស់សូល មើល ១សយ ១៤:៤៩ ៣១:២ ។ *យ៉ូណាថាន* ជាកូនច្បងរបស់ស្តេចសូល ។ លោកយ៉ូណាថាន គាត់ជានាយទាហាន និងជាមិត្តសម្លាញ់របស់ដាវីឌ (មើល ១សយ ១៣-១៤ ១៨:១-៤ ១៩:១-៧ ២០:១-៤២ ២៣:១៦-១៨ ២សយ ២១: ១៣-១៤) ។ *អែល-បាល* សូមមើល ២សយ ២:៨ ។

**៨:៣៤** *មេរីប-បាល* សូមមើល ២សយ ៤:៤ ។

**៩:១** *អ៊ីស្រាអែលទាំងអស់* ទំនាក់ទំនងរបស់អ្នកកត់ត្រាពង្សាវតារ ជាមួយពួកអ៊ីស្រាអែលទាំងអស់គឺជាគន្លឹះមួយដែលប្រាប់ថា ហេតុអ្វីបានជាគាត់រាប់បញ្ចូលពង្សាវតារទាំងអស់ដូច្នេះ (មើលសេចក្តីផ្តើមៈគោលបំណង និងផ្ទៃរឿង) ។ *បញ្ជីរបស់ពួកស្តេចសាសន៍អ៊ីស្រាអែល* (សូមមើលសេចក្តីផ្តើមៈ

២[ឃ]រីឯពួកដែលបាននៅក្នុងទីក្រុងទាំងប៉ុន្មាន[ឃ] ដែលជា
កេរ្តិ៍អាកររបស់គេមុនបង្អស់ នោះគឺពួកអ៊ីស្រាអែល ពួក
សង្ឃពួកលេវី និងពួកនេធីនិម[ង] ៣ឯពួកកូនចៅយូដា ពួកកូន
ចៅបេនយ៉ាមីន ពួកកូនចៅអេប្រាអិម នឹងម៉ាន៉ាសេគេសុទ្ធ
តែនៅក្រុងយេរូសាឡិម ៤ក្នុងពួកកូនរបស់ពេរេសជាកូន
យូដា[ច] នោះមានអ៊ូថាយ ជាកូនអាំមិហ៊ូត ដែលជាកូនអំរី។
ជាកូនអ៊ីមរី។ជាកូនបានី ៥ហើយក្នុងពួកស៊ីឡូរ នោះមាន
អ័សាយ៉ា ជាកូនច្បង និងកូនចៅគាត់ទាំងអស់ ៦ក្នុងពួកកូន
សេរ៉ាស នោះមានយេអួល និងពួកបងប្អូនគាត់ រួមទាំងអស់
មាន៦៩០នាក់ ៧ក្នុងពួកកូនចៅបេនយ៉ាមីន នោះមានសាលូវ
ជាកូនមស៊ូឡាមជាកូនហូដាវ៉ា ជាកូនហាសេនួរ ៨ព្រមទាំង
យីបនេយ៉ា ជាកូនយេរ៉ូហាំ និងអេឡា ជាកូនអ៊ូស៊ី ដែលជា
កូនមីករី។ ជាកូនមស៊ូឡាម។ ជាកូនសេផាធា។ ជាកូន
រេហួល។ ជាកូនយីបនីយ៉ា ៩នឹងពួកបងប្អូនគេតាមពូជដំណ
គេរៀងខ្លួនទាំងអស់មាន៩៥៧នាក់ អ្នកទាំងនោះសុទ្ធតែជា
កំពូលលើវង្សរបស់ឪពុកគេ តាមជំនួរវង្សឪពុកគេរៀងខ្លួន
១០ក្នុងពួកសង្ឃ នោះមានយេដាយ៉ា យេហូយ៉ារីប
យ៉ាគិន ១១អ័សារា ជាកូនហ៊ីលគីយ៉ា ដែលជាកូនរបស់
មស៊ូឡាម។ ជាកូនសាដុក។ ជាកូនមេរ៉ាយ៉ូត។ ជាកូនអ័ហ៊ីទូប
ដែលជាអ្នកត្រួតត្រាក្នុងព្រះវិហារនៃព្រះ ១២ព្រមទាំង
អ័ដាយ៉ា ជាកូនយេរ៉ូហាំ ដែលជាកូនផាសហើរ[ឆ]។ ជាកូន
ម៉ាលគា ហើយមានម្អាសាយ ជាកូនអ័ឌីអែល ដែលជាកូន
យ៉ាសេរ៉ា។ជាកូនមស៊ូឡាម។ជាកូនមស៊ីលេមីត។ជាកូន
អ៊ីមមើរ ១៣ហើយនិងបងប្អូនគេ ដែលសុទ្ធតែជាកំពូលលើ
វង្សរបស់ឪពុកគេទាំងអស់ មាន១៧៦០នាក់ ជាពួកមនុស្ស
ស្ទាត់ណាស់ក្នុងការងារខាងព្រះវិហារនៃព្រះ ។
១៤ក្នុងពួកលេវី នោះមានសេម៉ាយ៉ា ជាកូនហាស៊ូបដែល
ជាកូនអាសរីកាម។ ជាកូនហាសាបយ៉ា ក្នុងពួកកូនចៅម្រ៉ារី
១៥ព្រមទាំងបាក បាការ ហេរេស កាឡាល នឹងម៉ាថានា[ជ]
ជាកូនមីកា ដែលជាកូនស៊ីក គ្រី។ ជាកូនអេសារា ១៦ហើយ
អូបាឌា ជាកូនសេម៉ាយ៉ា ដែលជាកូនកាឡាល។ ជាកូន
យេឌូថិន ហើយមានបេរេគា ជាកូនអេសា ដែលជាកូន
អែលកាណា នៅភូមិទាំងប៉ុន្មាននៃពួកនថូផា[ឈ]។
១៧ក្នុងពួកអ្នកឆ្មាំទ្វារ[ញ] នោះមានសាលូម អ័រគូបថាលម៉ូន
អ័ហ៊ីម៉ាន និងបងប្អូនគេ ឯសាលូមនេះ គាត់ជាមេគេ ១៨ពី
ដើមរៀងមក អ្នកទាំងនោះតែងតែចាំទ្វារស្តេច[ដ] ជាទ្វារ
ទិសខាងកើត ពួកអ្នកទាំងនោះសុទ្ធតែជាពួកឆ្មាំទ្វារ ក្នុង
ពួកកូនចៅលេវី ១៩ឯសាលូម[ឋ] ជាកូនកូរ៉ា ដែលជាកូន
អេបៀសាប់។ ជាកូនកូរេ និងពួកបងប្អូនដែលជាជំនួរវង្ស
ឪពុកគាត់ គឺជាពួកកូរេ គេត្រួតត្រាលើការងាររបស់ពួក
ឆ្មាំទ្វារនៃត្រសាល ឯពួកឰយុកោគេក៏បានត្រួតត្រាលើ
ត្រសាលនៃព្រះយេហូវ៉ា គឺជាពួកឆ្មាំទ្វារដែរ ២០ហើយពី
ដើមភីនេហាស[ឌ] ជាកូនអេលាសារ គាត់ជាអ្នកត្រួតត្រាលើ
គេ ព្រះយេហូវ៉ាទ្រង់បានគង់ជាមួយនឹងគាត់ ២១ឯសាការី[ឍ]

**៩:២** ឃ យស ៩:២៧ អរ ២:៧០ ង អរ ២:៤៣,៥៨ ៨:២០ នហ ៧:៦០
**៩:៤** ច លប ៣៨:២៩ ៤៦:១២
**៩:១២** ឆ អរ ២:៣៨ ១០:២២ នហ ១០:៣ យរ ២១:១ ៣៨:១
**៩:១៥** ជ ២របា ២០:១៤ នហ ១១:២២
**៩:១៦** ឈ នហ ១២:២៨
**៩:១៧** ញ ខ.២២ ១រប ២៦:១ ២រប ៨:១៤ ៣១:១៤ អរ ២:៤២ នហ ៧:៤៥
**៩:១៨** ដ ១រប ២៦:១៤ អគ ៤៣:១ ៤៦:១
**៩:១៩** ឋ យរ ៣៥:៤
**៩:២០** ឌ ជន ២៥:៧–១៣

អ្នកនិពន្ធ កាលបរិច្ឆេទ និងប្រភព) ។

**៩:២–៣៤** បញ្ជីឈ្មោះរបស់មុនស្សដែលបានស្ថាបនាសហគមន៍ឡើងនៅទីនេះ គឺបានបង្ហាញពីទំនាក់ទំនងរបស់អ្នកកត់ត្រាពង្សាវតារជាមួយនឹងការបង្កើតច្បាប់ក្នុងសម័យកាលដែលគាត់រស់នៅជាពិសេសគឺភាពត្រឹមត្រូវរបស់អ្នកដែលទទួលតំណែង ។ គាត់បានកត់ចុះប្រជាជនទាំងអស់ (ពួកអ៊ីស្រាអែល ខ.២) នៅក្នុង ខ.៣–៩ ពួកសង្ឃក្នុង ខ.១០–១៣ ហើយពួកលេវីនៅក្នុង ខ.១៤–៣៤ ។ គាត់បានផ្តោតលើក្រុមមនុស្សទី៤ ដើម្បីឱ្យបម្រើកិច្ចការក្នុងព្រះវិហារ (មើល ខ.២) ប៉ុន្តែគាត់មិនបានបែងចែងឱ្យពួកគេរស់នៅដាច់ពីគ្នានោះឡើយ ។ ពួកគេប្រហែលជាក្រុមមនុស្សដើម ដែលបានចូលរួមជាមួយពួកលេវី (មើល យស ៩:២៣ អរ ៨:២០) ដូច្នេះហើយបានជាគេមិនបែកចេញពីពូជអំបូរនោះ ។ មនុស្សទាំងអស់ដែលមាននៅទីនេះគឺមានទំនាក់ទំនងទៅនិង នហ ជំពូក១១ ប៉ុន្តែភាគតិចណាស់ដែលពួកគេទាំងនោះមានឈ្មោះដូចគ្នា ។

**៩:៣** *អេប្រាអិមនិងម៉ាន៉ាសេ* ជាថ្មីម្តងទៀតអ្នកកត់ត្រាពង្សាវតារកំពុងតែបង្ហាញពីទំនាក់ទំនងរបស់គាត់ជាមួយ "ពួកអ៊ីស្រាអែលទាំងអស់" ដើម្បីបង្ហាញថា អ្នកបានវិលត្រឡប់មកវិញមិនមែនមានតែពួកយូដា ឬក៏បេនយ៉ាមីនឡើយ ប៉ុន្តែគឺទាំងពូជអំបូរដែលនៅភាគខាងជើងដែរ ។

**៩:៤–៦** សូមមើល ២:៣–៦ ៤:២១ ។ ពួកយូដាដែលវិលត្រឡប់មកវិញនោះគឺមានទាំងពេរេស សេឡា និងសេឡា ដែលសុទ្ធតែជាកូនយូដា (សូមមើល ជន ២៦:២០) ។

**៩:១០–១៣** ឈ្មោះសង្ឃទាំងនេះ គឺមានសារៈសំខាន់ចាំបាច់ដូចគ្នានឹង នហ ១១:១០–១៤ ដែរ ។ ដោយព្រោះតែមាននិយាយឈ្មោះរបស់សង្ឃតាំងពីដើមដំបូងក្នុងពង្សាវតារមកនិងជំនួរវង្សមក (មើល ៦:១–១៥,៥០–៥៥) នោះនិរន្តភាពអចិន្ត្រៃយ៍របស់អ៊ីស្រាអែលតាំងពីអតីតកាល គឺត្រូវបានបង្ហាញ ។

**៩:១៥–១៦** *អេសារា . . . យេឌូថិន* ពួកគេគឺជាអ្នកដឹកនាំក្រុមភ្លេង (មើល ៦:៣៩ ១៦:៤១) ។ ក្រោយមកទៀតអ្នកកត់ត្រាពង្សាវតាក៏បានកត់ចុះពួកអ្នកលេងភ្លេង (មើល ជំពូក ២៥) មុនអ្នកឆ្មាំទ្វារ (ជំពូក២៦) ។

**៩:១៦** *ពួកនថូផា* សូមមើលការពន្យល់ក្នុង ហន ១២:២៨ ។

**៩:១៧–២១** អ្នកកាលប្រវិត្តបានលើកឈ្មោះអ្នកឆ្មាំទ្វារ៤នាក់មកនិយាយក្នុងខណៈពេលដែលនៅក្នុង នហ ១១:១៩ មាននិយាយតែ២ប៉ុណ្ណោះ ។ ព្រះចៅក្រុង (ស្តេច) បានផ្តល់កិត្តិយស និងការទទួលខុសត្រូវពិសេសដល់ចៅហ្វាយនៃឆ្មាំទ្វារ (សូមមើល អគ ៤៦:១–២) ។ ពួកអ្នកឆ្មាំទ្វារក៏បាននិយាយនៅក្នុង ជំពូក ២៦ និង អរ ២:៤២ ផងដែរ ។ ពួកអ្នកត្រួតត្រាទាំងនោះ គឺមានដើមកំណើតចេញមកពីភីនេហាស (សូមមើល ខ.២០ ៦:៤ ជន ៣:៣២ ២៥:៦–១៣) ។

ជាកូនមសេលេមា គាត់ជាអ្នកឆ្មាំទ្វារនៃត្រសាលជំនុំ
22 អស់ពួកអ្នកទាំងនេះ ដែលបានរើស ឱ្យធ្វើជាអ្នកឆ្មាំ
ទ្វារ[ណ] ទាំងអស់មាន២១២នាក់ បានរាប់គេតាមពង្សាវតារ
នៅក្នុងភូមិគេទាំងប៉ុន្មាន ជាពួកអ្នកដែលដាវីឌ និង
សាំយូអែល ជាអ្នកមើលធុត បានតាំងឡើងឱ្យធ្វើការងារ
នោះ[ត] 23 ដូច្នេះ គេនឹងពួកកូនចៅគេ មានអំណាចត្រួតត្រា
លើទ្វារព្រះវិហារនៃព្រះយេហូវ៉ា គឺជាត្រសាលនៃរោង
ឧបោសថតាមលំដាប់វេន 24 មានពួកឆ្មាំទ្វារ នៅគ្រប់ទាំង
៤ទិស គឺខាងកើត ខាងលិច ខាងជើង និងខាងត្បូង
25 ឯពួកបងប្អូនគេ ដែលនៅឯភូមិគេរៀងខ្លួន ក៏ត្រូវចូល
មកនៅជាមួយម្តងៗអស់៧ថ្ងៃ[ថ] 26 ដ្បិតពួកលេវីទាំង៤នាក់
ដែលជាមេពួកឆ្មាំទ្វារ គេជាប់ធ្វើការងារគេ ហើយក៏ត្រួត
លើបន្ទប់នឹងលើរបស់ថ្លៃវិសេស[ទ] ក្នុងព្រះវិហារនៃព្រះ
27 គេមានទីអាស្រ័យនៅជុំវិញព្រះវិហារនៃព្រះ[ធ] ដ្បិតការ
ងារបើកទ្វារ[ន] រាល់ព្រឹក នោះស្រេចនៅលើគេ។
28 មានពួកគេខ្លះ ជាអ្នកដែលរក្សាភាជនៈ ដែលសិរាប់
ការងារ ដ្បិតកាលណាយកគ្រឿងទាំងនោះសិរាប់ចេញ
ចូល នោះក៏ត្រូវរាប់គ្រប់វេលា 29 មានខ្លះទៀតបានតាំង
ឡើងឱ្យត្រួតមើលគ្រឿងប្រដាប់ទាំងប៉ុន្មាន នឹងភាជនៈ
របស់ទីបរិសុទ្ធ[ប] ព្រមទាំងម្សៅយ៉ាងម៉ដ្ត ស្រាទំពាំងបាយ
ជូរ និងប្រេងកំញាន ហើយនិងគ្រឿងក្រអូបផង 30 មាន
អ្នកខ្លះ[ផ]ជាកូនរបស់ពួកសង្ឃ ធ្វើជាអ្នកផ្សំគ្រឿងក្រអូប
31 ឯម៉ាធិធា ជាពួកលេវីម្នាក់ ដែលជាកូនច្បងរបស់
សាលូម ក្នុងពួកកូរេ គាត់មានការងារត្រួតមើលនំទាំង
ប៉ុន្មាន ដែលចំអិនក្នុងដើក្រាន 32 ហើយបងប្អូនគេខ្លះ
ដែលជាពួកគេ ហាត់ដូចគ្នា ក៏ត្រួតមើលការធ្វើនំបុ័ងតាំង
ទុករាល់តែថ្ងៃឈប់សំរាក[ព]។
33 ឯពួកអ្នកចំរៀង[ភ] ដែលសុទ្ធតែជាកំពូលលើវង្សរបស់
ពួកឪពុក ក្នុងពួកលេវី គេអាស្រ័យនៅក្នុងបន្ទប់ទាំងប៉ុន្មាន
ហើយក៏ទំនេរពីការឯទៀត ដ្បិតគេធ្វើការងាររបស់គេ

**៩:២១** ឈ ១របា ២៦:២,១៤
**៩:២២** ណ ខ.១៧ ត ១សយ ៩:៩
**៩:២៥** ថ ២ពវ ១១:៥
**៩:២៦** ទ ១របា ២៦:២២
**៩:២៧** ធ ជនា ៣:៣៨ ន អស ២២:២២
**៩:២៩** ប ជនា ៣:២៨ ១របា ២៣:២៩
**៩:៣០** ផ នក ៣០:២៣–២៥
**៩:៣២** ព លប ២៤:៥–៨ ១របា ២៣:២៩ ២របា ១៣:១១
**៩:៣៣** ភ ១របា ៦:៣១ ២៥:១–៣១ ២របា ៥:១២ ម ទដ ១៣៤:១
**៩:៣៥** យ ១របា ៨:២៩
**៩:៣៩** រ ១របា ៨:៣៣ ល ១សយ ៩:១ វ ១សយ ១៣:២២ ស ២សយ ២:៨
**៩:៤០** ហ ២សយ ៤:៤

ទាំងយប់ទាំងថ្ងៃ[ម] 34 នេះជាពួកអ្នកដែលជាកំពូលលើវង្ស
នៃពួកឪពុកក្នុងពួកលេវី តាមពង្សាវតារគេ គឺជាមេទាំង
អស់ ហើយគេអាស្រ័យនៅក្នុងក្រុងយេរូសាឡិម ។

## ដំណវង្សរបស់សូល

*៩:៣៤–៤៤ – ១របា ៨:២៨–៣៨*

35 ឯយេហ៊ីអែល[យ] ជាអ្នកតាំងក្រុងគីបៀនក៏នៅក្នុងទីក្រុង
នោះឯង ប្រពន្ធគាត់ឈ្មោះម្អាកា 36 ឯកូនច្បង គឺអាបដូន
រួចស៊ើរ គីស បាល នេរ ណាដាប 37 កេដោរ អ័ហ៊ីយ៉ូរ
សាការី និងមីកឡូត 38 ឯមីកឡូត ក៏បង្កើតសាំម៉ា ពួកអ្នក
ទាំងនោះក៏អាស្រ័យនៅជាមួយនឹងបងប្អូនគេ នៅក្នុងក្រុង
យេរូសាឡិមដែរ 39 ឯនេរ[រ]គាត់បង្កើតគីស[ល] គីសបង្កើត
សូលៗបង្កើតយ៉ូណាថាន[វ] ហើយម៉ាលគី–ស៊ូអា អ័ប៊ីនាដាប់
និងអែស–បាល[ស] 40 កូនរបស់យ៉ូណាថាន គឺមេរីប–
បាល[ហ]ៗ បង្កើតមីកា 41 ឯកូន របស់មីកា គឺពីថូន មែលេក
ថាក់រា និងអ័ហាស 42 ឯអ័ហាសគាត់ បង្កើតយ៉ារ៉ាៗបង្កើត
អ័លេមេត អាសម៉ាវែត និងស៊ីមរីៗបង្កើតម៉ូសា 43 ម៉ូសា
បង្កើតប៊ីនា រួចប៊ីនាមានកូនឈ្មោះរេផាយ៉ា រេផាយ៉ាមាន
កូនឈ្មោះអេលាសារ ហើយអេលាសារមានកូនឈ្មោះ
អ័សេល 44 ឯអ័សេលមានកូនប្រុស៦ ឈ្មោះរបស់គេ គឺ
អាសរីកាម បូករូវ អ៊ីសម៉ាអែល ស្អារា អូបាឌា និង
ហាណាន នោះសុទ្ធតែជាកូនចៅរបស់អ័សេល ។

## សូលសម្លាប់ខ្លួន

*១០:១–១២–១សយ ៣១:១–១៣ ២សយ ១:៤–១២*

**១០** 1 រីឯពួកភីលីស្ទីន គេច្បាំងនឹងពួកអ៊ីស្រាអែល ហើយ
ពួកខាងអ៊ីស្រាអែល ក៏បាក់ទ័ពរត់ពីមុខពួកភីលីស្ទីនចេញ
គេដួលស្លាប់នៅលើភ្នំគីលបោ 2 ពួកភីលីស្ទីនក៏ដេញតាម
សូល នឹងពួកបុត្រាទ្រង់យ៉ាងប្រកិត បានធ្វើគុតយ៉ូណាថាន
អ័ប៊ីណាដាប់ និងម៉ាលគី–ស៊ូអា ជាបុត្រាសូលទៅ 3 ចំបាំង
នោះបានប្រែជាសាហាវណាស់ដល់សូល ពួកពលធ្នូក៏
តាមទ្រង់ទាន់ ហើយទ្រង់មានសេចក្តីវេទនាដោយព្រោះគេ

**៩:២២–២៧** ប៉ុស្តិ៍ចាំយាមទាំង២៤ មានអ្នកយាម៣វេន ដោយយាម២៤ ម៉ោងលើ២៤ម៉ោង ។ រាល់សប្តាហ៍នីមួយៗត្រូវការមនុស្សចំនួន៧២នាក់ ក្នុងចំណោមមនុស្សទាំងអស់ ២១២ នាក់ ។ ក្រុមនីមួយៗអាចធ្វើការងារ៣ សប្តាហ៍ (មើល ២៦:១២–១៨) ។

**៩:២៨–៣៤** ពួកលេវីមិនគ្រាន់តែមានទំនួលខុសត្រូវតែក្នុងបរិវេណព្រះវិហារ និងបើកទ្វារនៅពេលព្រឹកនោះឡើយ ប៉ុន្តែពួកគេក៏មានតួនាទីទទួលខុសត្រូវលើបន្ទប់និងឃ្លាំង (មើល ២៣:២៨ ២៦:២០–២៩) ថែមទាំងប្រដាប់ប្រដារ និងផ្គត់ផ្គង់គ្រឿងសង្ហារឹមផ្សេងៗទៀត (មើល ២៨:១៣–១៨ អរ ១:៩–១១) ។

**៩:៣៥–៤៤** ពង្សាវតាររបស់សូលចម្បងគឺបានចេញនៅទីនេះ (សូមមើល ៨:២៩–៣៨) ដូចគ្នានឹងអ្វីដែលអ្នកកត់ត្រាពង្សាវតារបាននិយាយយ៉ាងខ្លីអំពីរាជ្យ របស់គាត់កាលពីដំបូង (មើល ជំពូក ១០) ។

**១០:១–១៤** ការសង្ខេបដ៏ខ្លីឡើងវិញពីសេចក្តីស្លាប់របស់សូល បានបង្ហាញពីរាជ្យរបស់ដាវីឌដែលដាវីឌនេះឯងគឺជាម្នាក់ដែលអ្នកកត់ត្រាពង្សាវតារដែលមានចំណាប់អារម្មណ៍បំផុត (សូមមើលសេចក្តីផ្តើមៈគោលបំណងនិងផ្ទៃរឿង) ។

**១០:២** យុទ្ធសាស្ត្រដេញតាមរបស់ស្តេចក្នុងសង្គ្រាម សូមមើលក្នុង ១ពវ ២២:៣១ ។

៤ដូច្នេះ សូលមានបន្ទូលទៅអ្នកដែលកាន់គ្រឿងសស្ត្រាវុធ
ទ្រង់ថា ចូរហូតដាវឯងមកចាក់ទំលុះអញទៅ ក្រែងពួកមិន
កាត់ស្បែកនេះ គេមកមើលងាយអញ តែអ្នកនោះមិនហ៊ាន
ទេ ដ្បិតគាត់ភ័យខ្លាចជាខ្លាំង ដូច្នេះ សូលក៏ហូតយកដាវ
របស់ទ្រង់ ផ្ទួលអង្គទៅលើ ៥រួចកាលអ្នកកាន់គ្រឿង
សស្ត្រាវុធទ្រង់ បានឃើញថាសូលសុគតហើយដូច្នោះ នោះ
គាត់ក៏ផ្ទួលខ្លួនទៅលើដាវរបស់ខ្លួនស្លាប់ទៅដែរ ៦គឺយ៉ាង
នោះ ដែលសូល និងបុត្រាទ្រង់ទាំង៣ ព្រមទាំងពួកវង្សទ្រង់
ទាំងអស់បានស្លាប់ទៅជាមួយគ្នា ។

៧កាលពួលសាសន៍អ៊ីស្រាអែល ដែលនៅច្រកភ្នំបាន
ឃើញថា ពួកពលបែករត់ទៅ ហើយថា សូល និងពួកបុត្រា
ទ្រង់បានសុគតហើយ នោះគេលះចោលទីក្រុងរបស់គេរត់
ទៅដែរ រួចពួកភីលីស្ទីនបានមកអាស្រ័យនៅក្នុងទីក្រុង
ទាំងនោះ ៨ដល់ថ្ងៃស្អែកកាល ពួកភីលីស្ទីនបានទៅដោះ
អស់ទាំងអស់ ពីខ្មោចទាំងនោះ ក៏ឃើញសពសូល និងបុត្រា
ទ្រង់ទាំង៣ ដែលបានដួលសុគត នៅលើភ្នំគីលបោ ៩រួច
គេដោះគ្រឿងពីទ្រង់ ព្រមទាំងកាត់យកព្រះសិរ និងគ្រឿង
សស្ត្រាវុធទ្រង់ ចាត់គេឱ្យនាំដំណឹងទៅឯស្រុកភីលីស្ទីន
ប្រាប់ដល់ទាំងរូបព្រះគេ និងពួកបណ្ដាជនផង ១០គេដាក់
គ្រឿងសស្ត្រាវុធរបស់ទ្រង់ នៅក្នុងវិហាររបស់គេ ហើយ
បោះព្រះសិរទ្រង់ភ្ជាប់ក្នុងព្រះវិហារនៃព្រះដាកុន[ក] ១១កាល
ពួកក្រុងយ៉ាបេស-កាឡាត[ខ]បានឮពីគ្រប់ទាំងការ ដែលពួក
ភីលីស្ទីនបានធ្វើដល់សូល ១២នោះពួកមនុស្សក្លាហានទាំង
ប៉ុន្មាន ក៏ក្រោកឡើងទៅយកព្រះសពរបស់សូល និងពួក
បុត្រាទ្រង់នាំត្រឡប់ទៅក្រុងយ៉ាបេសវិញ រួចបញ្ចុះអដ្ឋិទ្រង់
ក្រោមដើមម៉ៃសាក់ នៅត្រង់ក្រុងយ៉ាបេស ហើយនាំគ្នាតម
អស់៧ថ្ងៃ ។

**១០:១០** ក ពច ១៦:២៣
**១០:១១** ខ ពច ២១:៨
**១០:១៣** គ ២សយ ១:១ ឃ ១របូ ៥:២៥ ង ១សយ ១៣:១៣ ច លវ ១៩:៣១ ២០:៦ ចទ ១៨:៩-១៤
**១០:១៤** ឆ ១រប ១២:២៣ ជ ១សយ
**១១:១** ក ១រប ៩:១ ខ លប ១៣:១៨ ២៣:១៩
**១១:២** គ ១សយ ១៨:៥,១៦ ឃ ទដ ៧៨:៧១ មថ ២:៦ ង ១រប ៥:២
**១១:៣** ច ១សយ ១៦:១-១៣
**១១:៤** ឆ លប ១០:១៦ ១៥:១៨-២១

១៣ដូច្នេះ សូលបានសុគត[គ] ដោយគ្រោះអំពើដែលទ្រង់
បានប្រព្រឹត្តរំលងទាស់[ឃ]នឹងព្រះយេហូវ៉ាដោយមិនបានកាន់
តាម[ង]ព្រះបន្ទូលនៃព្រះយេហូវ៉ា ហើយដោយព្រោះទ្រង់
បានសួរទំនាយនឹងស្រី ជាគ្រូខាប[ច] ១៤ឥតទូលសួរដល់ព្រះ
យេហូវ៉ា ហេតុនោះបានជាព្រះធ្វើឱ្យទ្រង់សុគត ព្រមទាំង
បង្វែរ[ឆ]រាជ្យ[ជ]ទៅឱ្យដាវីឌ ជាបុត្រអ៊ីសាយវិញ ។

## ដាវីឌឡើងជាស្តេចស្រុកអ៊ីស្រាអែល

*១១:១-៣-២សយ ៥:១-៣*

**១១** ១គ្រានោះ សាសន៍អ៊ីស្រាអែល[ក]ទាំងអស់គ្នា ក៏ប្រមូល
គ្នាមកឯដាវីឌ នៅក្រុងហេប្រុន[ខ] ទូលថា មើលយើងខ្ញុំរាល់
គ្នាជាសាច់ឈាមជាមួយនឹងលោក ២កាលពីដើមដែលសូល
ធ្វើជាស្តេចនៅឡើយ នោះគឺលោកហើយដែលនាំពួក
អ៊ីស្រាអែលចេញចូល[គ] ហើយព្រះយេហូវ៉ាជាព្រះនៃលោក
ទ្រង់បានមានបន្ទូលដល់លោកថា គឺឯងហើយដែលត្រូវ
ឃ្វាល[ឃ]សាសន៍អ៊ីស្រាអែល ព្រមទាំងធ្វើជាអ្នកនាំមុខនៃ
រាស្ត្រអញផង[ង] ៣គឺយ៉ាងនោះ ដែលពួកចាស់ទុំនៃសាសន៍
អ៊ីស្រាអែល បានមកឯស្តេច នៅក្រុងហេប្រុន ហើយដាវីឌ
ក៏តាំងសញ្ញានឹងគេ នៅចំពោះព្រះយេហូវ៉ា ត្រង់ក្រុង
ហេប្រុន រួចគេចាក់ប្រេងតាំង[ច]ដាវីឌឡើង ឱ្យធ្វើជាស្តេច
លើពួកអ៊ីស្រាអែល តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ដោយ
សារសាំយូអែល ។

## ស្តេចដាវីឌកាន់កាប់ក្រុងយេរូសាឡិម

*១១:៤-៩ - ២សយ ៥:៦-១០*

៤លំដាប់នោះ ដាវីឌនិងពួកអ៊ីស្រាអែលទាំងអស់ក៏ទៅឯ
ក្រុងយេរូសាឡិម (គឺជាក្រុងយេប៊ូស) ឯពួកសាសន៍
យេប៊ូស[ឆ] ជាពួកអ្នករបស់ស្រុកនោះ ក៏នៅទីក្រុងនោះនៅ
ឡើយ ៥ហើយពួកអ្នកក្រុងយេប៊ូស គេស្តីដល់ដាវីឌថាឯង

**១០:៦** *បុត្រាទ្រង់ទាំង៣* សូមមើល ខ.២ (អ៊ីសបូសែតនៅរស់ សូមមើល ១សយ ៣១:២) ។ *ព្រមទាំងពូជពង្សទ្រង់ទាំងអស់* គឺមានតែកូនគាត់និងមន្ត្រីទាំងអស់ប៉ុណ្ណោះ មិនមែនទាំងកូនចៅរបស់គាត់នោះឡើយ (សូមមើល ៨:៣៣-៣៤ ១សយ ៣១:៦) ។

**១០:១៣-១៤** ខ.គម្ពីរទាំងនេះមិនស្របគ្នាជាមួយរឿងដែលមាននៅក្នុងគម្ពីរសាំយូអែលទេ ។ ការស្វែងរកគ្រូខាប គ្រូអន្ទងព្រលឹងគឺត្រូវបានហាមឃាត់ (សូមមើល ចទ ១៨:៩-១៤) ដែលទង្វើបែបនេះ បាននាំសេចក្តីស្លាប់មកដល់សូល ។ អ្នកកត់ត្រាពង្សាវតារបានសរសេរពីការជាក់ស្តែងដល់អ្នកស្តាប់អ្នកមើល អ្នកអានរួចមកហើយអំពីក្រុមគ្រួសារសាំយូអែល និងស្តេចផ្សេងៗទៀតហើយជាញឹកញាប់គាត់តែងតែក្លែងពីចំនេះដឹងនោះ ។ ការសុំពិគ្រោះយោបល់ជាមួយគ្រូខាបនៅត្រង់អោន-ដោរ គឺជាការនិយាយបញ្ឆិតបញ្ឆៀង (សូមមើល ១សយ ជំពូក២៨) ប៉ុន្តែអ្នកកត់ត្រាពង្សាវតារមិនបានរ៉ាយរ៉ាប់រឿងនោះឡើយ ។

**១១:១-២រប ៩:៣១** សូមមើលសេចក្តីផ្តើម: អំពីការពិពណ៌នានៃដំណើររឿងរបស់ស្តេចដាវីឌ និងសាឡូម៉ូន ។

**១១:១-៣** រឿងរ៉ាវនៅទីនេះ គឺប្រហាក់ប្រហែលគ្នាជាមួយនឹង ២សយ ៥:១-៣ ប៉ុន្តែអ្នកកត់ត្រាពង្សាវតារគាត់បាននិទានឡើងវិញដោយយោងតាមការគាំទ្រចំពោះដាវីឌពីសំណាក់ "សាសន៍អ៊ីស្រាអែលទាំងអស់" (មើល ខ.១) នៅពេលដែលអ្នកកត់ត្រាពង្សាវតារ គាត់បាននិយាយ២ឬ៣ដងអំពីការគ្រប់គ្រង៧ឆ្នាំរបស់ដាវីឌនៅឯក្រុងហេប្រុន មុនពេលការស្លាប់របស់អ៊ីសបូសែតនិងសេចក្តីសញ្ញាជាមួយអំបូរខាងជើង (៣:៤ ២៩:២៧) រឿងរ៉ាវទាំងនោះហាក់បីដូចជាឃ្លាតឆ្ងាយពីនិទានកថា ។ ភាគច្រើននៃការបាត់នូវព័ត៌មាននៅក្នុងចំនុចនេះ គឺមាននិយាយនៅក្នុង ២សយ ៥:៤-៥ ។

**១១:៤-៩** សូមមើល ២សយ ៥:៦-១០ ។ "សាសន៍អ៊ីស្រាអែលទាំងអស់" គឺជាផ្ទៃរឿងដែលបានលេចឡើងក្នុង ខ.៤ ជំនួសឱ្យពាក្យ "ស្តេចហើយនិងពួកទ័ពទ្រង់" (មើល ២សយ ៥:៦) ។

នឹងចូលមកក្នុងទីនេះមិនបានឡើយ ប៉ុន្តែ ដាវីឌវាយចាប់
យកទីមាំមួនស៊ីយ៉ូនបាន នោះគឺជាក្រុងរបស់ដាវីឌ ៦រួចទ្រង់
មានបន្ទូលថា អ្នកណាដែលវាយពួកយេប៊ូសមុនគេ អ្នក
នោះនឹងបានធ្វើជាអ្នកមុខ ហើយជាមេទ័ពធំ ដូច្នេះយ៉ូអាប់[ជ]
ជាកូនសេរូយ៉ា ក៏ឡើងទៅជាមុនគេ ហើយបានតាំងឡើង
ឱ្យធ្វើជាមេទ័ព ៧ឯដាវីឌទ្រង់គង់នៅក្នុងទីមាំមួន ហេតុនោះ
បានជាគេហៅទីនោះថា ក្រុងដាវីឌ ៨ទ្រង់ក៏សង់ទីក្រុងនោះ
ឡើងនៅជុំវិញចាប់តាំងពីប៉មមីឡូរ[ឈ]ព័ទ្ធជុំវិញ ហើយ
យ៉ូអាប់លោកក៏ជួសជុលទីក្រុងត្រង់កន្លែងឯទៀត ៩ចំណែក
ដាវីឌបានកាន់តែថ្កុំថ្កើនឡើង[ញ] ហើយព្រះយេហូវ៉ានៃពួក
ពលបរិវារទ្រង់ក៏គង់ជាមួយ ។

## ពួកខ្លាំងពូកែរបស់ស្តេចដាវីឌ

*១១:១០–៤១ – ២សយ ២៣:៨–៣៩*

១០[ក]រីឯពួកប្រធានក្នុងពួកខ្លាំងពូកែរបស់ដាវីឌ ដែលកាន់
ខ្ជាប់ខាងទ្រង់ ជាមួយនឹងពួកអ៊ីស្រាអែលទាំងអស់[ដ] ដើម្បីនឹង
តាំងនគរឡើង តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ពីដំណើរ
សាសន៍អ៊ីស្រាអែល[ឋ] ១១ឯពួកអ្នកខ្លាំងពូកែរបស់ដាវីឌ[ឌ]
នោះបានរាប់ដូចជាមានឈ្មោះខាងក្រោមនេះស្រាប់ គឺ
យ៉ាសុបៀម ជាកូនរបស់ពួកហាក់ម៉ូនីម្នាក់ លោកជាមេលើ
ពួក៣០នាក់ ហើយបានពួកលំពែង សំឡាប់មនុស្ស៣០០នាក់
តែ១គ្រា ១២បន្ទាប់នោះ មានកូនដូដូរ ឈ្មោះអេលាសារ
ជាពួកអ័ហូអា ដែលជាម្នាក់ក្នុងពួកមនុស្សខ្លាំងពូកែទាំង
៣នាក់ ១៣លោកបាននៅជាមួយ នឹងដាវីឌនៅត្រង់ផាស់–
ដាំមីមក្នុងកាលដែលពួកភីលីស្ទីនបានមូលគ្នា មកច្បាំង
នៅកន្លែងដែលមានស្រែស្រូវឱកហើយពួកទ័ពបានរត់
ពីមុខពួកភីលីស្ទីនទៅ ១៤តែពួកនោះ គេឈរនៅកណ្តាល
ស្រែនោះ ហើយបានការពារព្រមទាំងសំឡាប់ពួកភីលីស្ទីន
បង់ ព្រះយេហូវ៉ាទ្រង់បានជួយសង្គ្រោះគេ ដោយជ័យជំនះ
យ៉ាងធំ[ឍ] ១៥ក៏មាន៣នាក់ក្នុងពួកប្រធានទាំង៣០នាក់នោះ
គេបានចុះទៅ ឯដាវីឌត្រង់ថ្មដា ក្នុងអាងអាឌូឡាម នៅគ្រា
នោះពួកភីលីស្ទីនបានបោះទ័ពនៅច្រកភ្នំ[ណ]រេផែម ១៦ហើយ
ដាវីឌទ្រង់គង់នៅក្នុងទីមាំមួន[ត] ឯពួកភីលីស្ទីន គេមានទ័ព១
កងរក្សាស្រុក នៅឯក្រុងបេថ្លេហិម ១៧ចំណែកដាវីឌ ទ្រង់
នឹងកន្លែងក្នុងព្រះទ័យ ហើយមានបន្ទូលថា ឱបើសិនជាមាន
អ្នកណាយកទឹកពីអណ្តូង ដែលនៅមាត់ទ្វារក្រុងបេថ្លេហិម
មក ឱ្យអញផឹកទៅអេះ ១៨រួចអ្នកទាំង៣នោះក៏បំបែកពួកទ័ព
ភីលីស្ទីន កាន់ចូលទៅដងទឹកពីអណ្តូងនៅមាត់ទ្វារក្រុង
បេថ្លេហិមនោះ នាំយកមកថ្វាយដល់ដាវីឌ តែទ្រង់មិនព្រម
សោយទេ[ថ] គឺទ្រង់ចាក់ច្រួចថ្វាយព្រះយេហូវ៉ាវិញ ១៩ដោយ
បន្ទូលថា សូមឱ្យព្រះនៃទូលបង្គំឃាត់មិនឱ្យទូលបង្គំធ្វើ
ដូច្នោះឡើយ តើទូលបង្គំនឹងផឹកឈាមរបស់មនុស្សទាំងនេះ
ដែលបាន ប្រថុយជីវិតយ៉ាងនេះឬអីដ្បិតគេបានយកទឹកនេះ
មក ដោយប្រថុយជីវិតរបស់គេពិត ហេតុនោះបានជាទ្រង់
មិនព្រមសោយឡើយ គឺការយ៉ាងនោះឯង ដែលមនុស្សខ្លាំង
ពូកែទាំង៣នាក់នោះបានធ្វើ ២០ឯអ័ប៊ីសាយ[ទ] ប្អូនយ៉ូអាប់ជា
កូនសេរូយ៉ា លោកជាមេលើអ្នកទាំង៣នាក់នោះ ពីព្រោះ
លោកបានពួយលំពែងសំឡាប់មនុស្ស៣០០នាក់ ហើយមាន
ល្បីឈ្មោះក្នុងពួក៣នាក់នោះ ២១ក្នុងពួក៣នាក់នោះ គេរាប់
អាន លោកជាជាង២នាក់ទៀត ហើយក៏តាំងឡើងធ្វើជាមេ
លើគេ ប៉ុន្តែលោកមិនដល់ពួក៣នាក់ខាងដើមនោះទេ ។

២២ឯបេណាយ៉ា ជាកូនយេហូយ៉ាដា ដែលជាកូនរបស់
អ្នកខ្លាំងពូកែម្នាក់ នៅក្រុងកាបសៀល[ធ] លោកជាអ្នកដែល
បានធ្វើការយ៉ាងពូកែ លោកបានសំឡាប់កូនទាំង២របស់
អ័រាល ជាសាសន៍ម៉ូអាប់ ហើយក៏ចុះទៅក្នុងរណ្តៅសំឡាប់
សត្វសិង្ហ១[ន] នៅថ្ងៃមានហិមៈ ២៣ក៏សំឡាប់សាសន៍អេស៊ីព្ទ
ម្នាក់ ជាមនុស្សធំសំបើមកំពស់៥ហត្ថ សាសន៍អេស៊ីព្ទ នោះ
កាន់លំពែង១ប៉ុនផ្សំដំបាញ តែលោកចុះទៅឯវា កាន់តែ
ដំបង[ប]ទេ ក៏កន្ត្រាក់យកលំពែងពីដៃរបស់មនុស្សសាសន៍
អេស៊ីព្ទនោះ រួចចាក់សំឡាប់ដោយលំពែងរបស់វាទៅ
២៤គឺការយ៉ាងនោះដែលបេណាយ៉ា ជាកូនយេហូយ៉ាដាបាន
ធ្វើ ហើយមានល្បីឈ្មោះនៅក្នុងពួកខ្លាំងពូកែទាំង៣នាក់
នោះ ២៥គេបានរាប់អានលោកជាជាងពួក៣០នាក់នោះ តែ
លោកមិនដល់ពួក៣នាក់ខាងដើមទេ ដាវីឌទ្រង់ក៏តាំង
លោកឱ្យត្រួតលើពួកទាហានរក្សាអង្គ ។

**១១:៦** ជ ២សយ ២:១៣
**១១:៨** ឈ ២សយ ៥:៩ ២របា ៣២:៥
**១១:៩** ញ នអ ៩:៤
**១១:១០** ដ ខ.១ ឋ ខ.៣ ១របា ១២:២៣
**១១:១១** ឌ ២សយ ១៧:១០
**១១:១៤** ឍ នក ១៤:៣០ ១សយ ១១:១៣
**១១:១៥** ណ ១របា ១៤:៩ អស ១៧:៥
**១១:១៦** ត ២សយ ៥:១៧
**១១:១៨** ថ ចទ ១២:១៦
**១១:២០** ទ ១សយ ២៦:៦
**១១:២២** ធ យស ១៥:២១ ន អស ១៧:៣៦
**១១:២៣** ប ១សយ ១៧:៧

**១១:១០–៤១ក** សូមមើល ២សយ ២៣:៨–៣៩ ។ នៅក្នុងគម្ពីរសាំយូអែល ពួកទាហានដ៏ខ្លាំងពូកែរបស់ដាវីឌ គឺបាននិយាយនៅជិតចុងបញ្ចប់រាជ្យរបស់ទ្រង់ ។ អ្នកកត់ត្រាពង្សាវតារបានប្តូរនូវយុទ្ធសាស្ត្រនេះដោយបានលើកយកពួកទាហានដ៏ខ្លាំងពូកែរបស់ដាវីឌ មកនិយាយនៅដើមដំបូងនៃរាជ្យរបស់គាត់វិញហើយបានពង្រីកយ៉ាងល្អ (សូមមើល ១១:៤១ ១២:៤០) នោះជាផ្នែកដ៏សំខាន់១ ដែលគាត់បានផ្តោតអារម្មណ៍ទៅលើប្រធានក្នុង "ពួកខ្លាំងពូកែ"សម្រាប់អ្វីៗដែលមាននៅក្នុងនគររបស់ស្តេចដាវីឌ (សូមមើល ខ.១០) ។

**១១:១១** *៣០០នាក់* តាមពិតចំនួនទាំងអស់មាន៨០០នាក់ (សូមមើល ២សយ ២៣:៨) ។ នៅទីនេះនិយាយត្រឹម៣០០នាក់ ប្រហែលជាកំហុសរបស់អ្នកសរសេរចម្លងហើយនៅក្នុង ខ.២០ ក៏បានប្រើចំនួនបែបនេះដែរ ។

**១១:១៥–១៩** តាមពិតដាវីឌគាត់ទទួលស្គាល់ថា គាត់មិនគួរនិងថ្វាយដង្វាយច្រួចទៅចំពោះព្រះអម្ចាស់ឡើយ (សូមមើល លប ៣៥:១៤ ២ពាវ ១៦:១៣ យរ ៧:១៨ ហស ៩:៤) ។

២៦ឯមនុស្សខ្លាំងពូកែ ក្នុងពួកពលទ័ពទាំងប៉ុន្មាន គឺ
អេសាអែល[ផ] ជាប្អូនយ៉ូអាប់ អែលហាណាន ជាកូនដូដូរ
ដែលនៅក្រុងបេថ្លេហិម ២៧សាំម៉ូត[ព] ជាអ្នកស្រុកហារ៉ូ
ហេលែស ជាអ្នកស្រុកពេទ្បូន ២៨អ៊ីរ៉ា ជាកូនអ៊ីកកែស
ជាអ្នកក្រុងត្កូអា អ័បៀស៊ើរ[ភ] ជាអ្នកនៅក្រុងអាន៉ាថោត
២៩ស៊ីបាកាយ[ម] ជាអ្នកស្រុកហ៊ូសាយ អ៊ីឡាយ ជាអ្នកស្រុក
អ័ហូអា ៣០ម៉ាហារ៉ាយ ជាអ្នកក្រុងនថូផា ហេលែប កូន
ប្អាណា ជាអ្នកក្រុងនថូផា ៣១អ៊ីតតាយ កូនរីបាយ ជាអ្នក
ក្រុងគីបៀន ក្នុងពួកកូនចៅបេនយ៉ាមីន បេណាយ៉ា[យ]ជាអ្នក
ស្រុកពីរ៉ាថូន[រ] ៣២ហ៊ូរ៉ាយ ជាអ្នកស្រុកណាហាលេ-កាអាស
អ័បៀល ជាអ្នកស្រុកអីរ៉ាបា ៣៣អាសម៉ាវែតជាអ្នកស្រុក
បាហ៊ូរីម អេលីយ៉ាបា ជាអ្នកស្រុកស្អាឡាប៊ីន ៣៤នឹង
ពួកកូនហាសេម ជាអ្នកស្រុកគិសូន យ៉ូណាថានកូនសាកេ
ជាអ្នកស្រុកហារ៉ារី ៣៥អ័ហ៊ីយ៉ាម កូនសាកើរ ជាអ្នកស្រុក
ហារ៉ារី អេលីផាល ជាកូនអ៊ើរ ៣៦ហេភើរ ជាអ្នកស្រុក
មេកេរ៉ា អ័ហ៊ីយ៉ា ជាអ្នកស្រុកពេទ្បូន ៣៧ហេស្រូ ជាអ្នកស្រុក
កើមែល ណ្ហារ៉ាយ ជាកូនអែសបាយ ៣៨យ៉ូអែល ជាប្អូន
ណាថាន់ មីបហា ជាកូនហាគ្រី ៣៩សេលេក ជាសាសន៍
អាំម៉ូន ណាហារ៉ាយ ជាអ្នកស្រុកបេរ៉ូត ដែលកាន់គ្រឿង
សស្ត្រាវុធឱ្យយ៉ូអាប់ ជាកូនសេរូយ៉ា ៤០អ៊ីរី ជាអ្នកស្រុក
យេធើ ការេប ជាអ្នកស្រុកយេធើ ៤១អ៊ូរី[ល] ជាសាសន៍ហេត
សាបាឌ[វ] ជាកូនអ័ឡាយ ៤២អ័ឌីណា ជាកូនស៊ីសា ក្នុងពួក
រូបេន ជាអ្នកប្រធានក្នុងពួករូបេន ព្រមទាំង៣០នាក់នៅ
ជាមួយផង ៤៣ហាណាន ជាកូនម្អាកា យេហូសាផាត
ជាអ្នកស្រុក មីតនី ៤៤អ៊ូស៊ីយ៉ា ជាអ្នកស្រុកអាសថារ៉ូត[ស]
សាម៉ា និងយេហ៊ីអែល កូនហូថាម ជាអ្នកស្រុកអារ៉ូអ៊ើរ
៤៥យេឌីអែល ជាកូនស៊ីមរី និងយូហា ជាប្អូនគាត់ ជាអ្នក
ស្រុកធីសា ៤៦អេលាល ជាអ្នកស្រុក ម៉ាហាវីម យេរីបាយ
និងយ៉ូសាវា ជាកូនអែលណ្អាម យីតម៉ា ជាសាសន៍
ម៉ូអាប់ ៤៧អេលាល អូបិឌ និងយ្អាសៀល ជាពួកអ្នកស្រុក
មេសូបាយ៉ា ។

## ពួកអ្នកខ្លាំងពូកែចុះចូលស្តេចដាវីឌ

**១២** ១រីឯពួកអ្នក ដែលបានមកឯដាវីឌ នៅត្រង់ក្រុង
ស៊ីកឡាក់[ក] ក្នុងគ្រាដែលទ្រង់កំពុងតែពួននឹងសូល ជាបុត្រ
គីសនៅឡើយ ជាពួកអ្នកខ្លាំងពូកែ ដែលបានជួយទ្រង់ក្នុង
ចំបាំង ២សុទ្ធតែមានធ្នូ ហើយក៏ស្ទាត់បាញ់គ្រួសនិងព្រួញ
ដោយដៃឆ្វេងដៃស្តាំបានផង[ខ] ជាដំនួរវង្សរបស់ បងប្អូន
សូល[គ] ក្នុងពូជអំបូរបេនយ៉ាមីន ៣នោះអ្នកដែលជាមេលើ
គេ គឺអ័ហ៊ីយេស៊ើរ បន្ទាប់មកមានយ៉ូអាស ជាកូនសេម៉ាអា
ជាអ្នកក្រុង គីបៀរ យេស៊ាល និងពេលេត ជាកូន
អាសម៉ាវែត បេរ៉ាកា យេហ៊ូ ជាអ្នកក្រុងអាន៉ាថោត
៤យីសម៉ាយ៉ា ជាអ្នកក្រុងគីបៀន ដែលជាមនុស្ស ខ្លាំងពូកែ
ក្នុងពួក៣០នាក់នោះ ហើយជាមេលើគេ និងយេរេមីយ៉ាហា
សៀល យ៉ូហាណាន យ៉ូសាបាឌ ជាអ្នកស្រុកកេដេរ៉ា[ឃ]
៥អេលូសាយ យេរេម៉ូត ប្អាលា សេម៉ារីយ៉ា សេផាធា ជា
អ្នកស្រុកហារ៉ូប ៦អែលកាណា យីសយ៉ា អ័សារាល
យ៉ូអេស៊ើរ យ៉ាសុបៀម ជាពួកកូរេ ៧ហើយយ៉ូអេឡា និង
សេបាឌា ជាកូនយេរ៉ូហាំ ជាអ្នកស្រុកកេដោរ[ង]។
៨ក៏មានមនុស្សក្នុងពួកកាឌ់[ច] បានញែកខ្លួនទៅខាងដាវីឌ
ក្នុងទីពំនួន នៅទីរហោស្ថាន គេសុទ្ធតែជាមនុស្សខ្លាំងពូកែ
មានចិត្តក្លាហាន ហើយស្ទាត់ក្នុងចំបាំង ក៏ចេះប្រើទាំងខែល
និងលំពែង គេមានមុខដូចជាមុខសិង្ហ[ឆ] ហើយក៏រហ័ស
ដូចជាឈ្លូស[ជ]នៅលើភ្នំ ៩នោះគឺអេស៊ើរជាមេ អូបាឌា
ជាទី២ អេលាប ជាទី៣ ១០មីសម៉ាណាជាទី៤ យេរេមី ជាទី៥
១១អ័ថាយ ជាទី៦ អេលាល ជាទី៧ ១២យ៉ូហាណាន ជាទី៨
អែលសាបាឌ ជាទី៩ ១៣យេរេមី ជាទី១០ ម៉ាបាណាយ
ជាទី១១ ១៤ពួកកូនចៅកាឌ់ទាំងនោះ សុទ្ធតែជាមេលើពល
ទ័ព ឯអ្នកដែលខ្សោយជាងគេ នោះក៏ស្មើនឹង១០០នាក់[ឈ]
ហើយអ្នកដែលខ្លាំងជាងក៏ស្មើនឹង១ពាន់នាក់[ញ] ១៥នេះជាពួក
អ្នក ដែលបានឆ្លងទន្លេយ័រដាន់នៅខែចេត្រ ក្នុងវេលាដែល
ទន្លេបានឡើងលិចច្រាំងទាំងអស់[ដ] រួចគេច្បាំងនឹងពួក
មនុស្សនៅច្រកភ្នំទាំងអស់ នៅខាងកើត និងខាងលិចផង
ក៏បំបាត់ទ័ពឱ្យគេរត់ទៅ ។

**១១:២៦** ផ ២សយ ២:១៨
**១១:២៧** ព ១របា ២៧:៨
**១១:២៨** ភ ១របា ២៧:១២
**១១:២៩** ម ២សយ ២១:១៨
**១១:៣១** យ ១របា ២៧:១៤ រ ពច ១២:១៣
**១១:៤១** ល ២សយ ១១:៦ វ ១របា ២:៣៦
**១១:៤៤** ស ចទ ១:៤
**១២:១** ក យស ១៥:៣១
**១២:២** ខ ពច ៣:១៥ គ ២សយ ៣:១៩
**១២:៤** ឃ យស ១៥:៣៦
**១២:៧** ង យស ១៥:៥៨
**១២:៨** ច លប ៣០:១១ ឆ ២សយ ១៧:១០ ជ ២សយ ២:១៨
**១២:១៤** ឈ លវ ២៦:៨ ញ ចទ ៣២:៣០
**១២:១៥** ដ យស ៣:១៥

**១១:៤១ខ–១២:៤០** សូមមើល ឧ.១០–៤១ក ។ នៅក្នុង ២សយ ជំពូក ២៣ បញ្ចប់ដោយមានឈ្មោះអ៊ូរីជាសាសន៍ហេត (២សយ ជំពូក១១) ។ នៅពេលបានឃើញឈ្មោះមនុស្សក្រៅពីនេះ គេមិនបានដឹងថាមកពីណាឡើយ ។ ការគាំទ្រដែលសំខាន់ គឺគេនៅតែនិយាយចំពោះ "ពួកអ៊ីស្រាអែលទាំងអស់" ទោះបីជាញាត្តិសណ្តានរបស់សូលផ្ទាល់ ក៏បានទទួលស្គាល់នគររបស់ដាវីឌនៅមុនពេលដែលសូលស្លាប់ដែរ (មើល ១២:១–៧,១៦–១៨,២៣,២៩) ។

**១២:១** អ្នកកត់ត្រាពង្សាវតារ បានធ្វើការប៉ាន់ស្មានពីការប្រៀនប្រដៅរបស់អ្នកអានអំពីហេតុការណ៍ដែលបានកើតឡើងនៅក្រុងស៊ីកឡាក់ (១សយ ២៧) មើល ឧ.១៩–២០ ។

**១២:៨–១៥** មនុស្សក្នុងពួកកាឌ់គេបានឆ្លងទន្លេយ័រដាន់ ។ ការរំលាយទឹកនៅភាគខាងជើង អាចធ្វើឱ្យមានទឹកជំនន់នៅទន្លេយ័រដាន់នៅខែទី១ (មីនា–មេសា) នៅក្នុងអំឡុងពេលដែលពួកគេឆ្លងទន្លេ (ខ.១៥) ។ ពេលវេលានេះបានកើតឡើងក្នុងអំឡុងពេលការត្រេចចររបស់ដាវីឌ នៅក្នុងតំបន់សមុទ្រស្លាប់ (១សយ ២៣:១៤ ២៤:១ ២៥:១ ២៦:១) ។

១៦ក៏មានពួកកូនចៅបេនយ៉ាមីន[ឋ] និងយូដា មកឯដាវីឌ
នៅទីពំនួននោះដែរ ១៧ឯដាវីឌទ្រង់ចេញទៅទទួលគេ
ដោយបន្ទូលថា បើអ្នករាល់គ្នាបានមកដោយមេត្រីដើម្បី
នឹងជួយខ្ញុំពិត នោះចិត្តខ្ញុំនឹងមូលជាប់នឹងអ្នករាល់គ្នា តែបើ
សិនជាមក ដើម្បីក្បត់បញ្ជូនខ្ញុំដល់ពួកខ្មាំងសត្រូវ ដែលខ្ញុំ
គ្មានធ្វើខុសអ្វីឡើយ នោះសូមឱ្យព្រះនៃពួកឰយុកោ យើង
រាល់គ្នាទតមើលផង ហើយកាត់សំរេចចុះ ១៨ព្រះវិញ្ញាណ[ឌ]
ក៏មកសណ្ឋិតនៅលើអ័ម៉ាសាយ[ឍ] ជាមេលើពួក៣០នាក់
ហើយលោកទូលថា ឱដាវីឌអើយ យើងខ្ញុំរាល់គ្នាជារបស់
ផងលោក ឱកូនអ៊ីសាយអើយ យើងខ្ញុំកាន់ខាងលោកហើយ
សូមឱ្យលោកបានប្រកបដោយសេចក្ដីសុខចំរើន[ណ] ព្រម
ទាំងពួកអ្នកដែលជួយខាងលោកផង ដ្បិតព្រះនៃលោក
ទ្រង់ជួយដល់លោក ដូច្នេះដាវីឌក៏ទទួលគេ ហើយតាំងគេ
ឡើងឱ្យធ្វើជាមេលើកងទាហាន ។
១៩ក្នុងពួកម៉ាន៉ាសេ ក៏មានអ្នកខ្លះរវាតមក ចូលខាង
ដាវីឌដែរ គឺក្នុងវេលាដែលទ្រង់ចេញទៅ ដើម្បីច្បាំងនឹង
សូលជាមួយនឹងពួកភីលីស្ទីន តែមិនបានជួយគេទេ ពីព្រោះ
ពួកមេរបស់សាសន៍ភីលីស្ទីន គេបានពិគ្រោះគ្នា រួចបង្គាប់
ឱ្យទ្រង់ទៅវិញ ដោយថា ក្រែងវារវាតចេញទៅខាងសូល
ជាចៅហ្វាយវា ហើយនាំឱ្យអន្តរាយដល់ក្បាលយើងវិញ[ត]
២០ដូច្នេះកំពុងដែលទ្រង់វិលទៅឯក្រុងស៊ីកឡាក់វិញ[ថ] នោះ
មានពួកម៉ាន៉ាសេខ្លះចូលខាងទ្រង់ គឺអ័ឌណា យ៉ូសាបាឌ
យេឌីអែល មីកែល យ៉ូសាបាឌ អេលីហ៊ូវ និងស៊ីលថាយ
ដែលសុទ្ធតែជាមេលើទ័ពនៃពួកម៉ាន៉ាសេ១ពាន់នាក់ ២១អ្នក
ទាំងនោះក៏ជួយដាវីឌទាស់នឹងពួកចោរ ដ្បិតសុទ្ធតែជា
មនុស្សខ្លាំងពូកែ មានចិត្តក្លាហាន ហើយជាមេទ័ពផង
២២ហើយសឹងតែរាល់ថ្ងៃ ក៏មានមនុស្សមកឯដាវីឌ ដើម្បី
ជួយទ្រង់ ដរាបដល់មានពួកទ័ពយ៉ាងសន្ធឹក គឺដូចជាពួក
ពលនៃព្រះ ។

## អ្នកដទៃទៀតចុះចូលនឹងស្ដេចដាវីឌនៅក្រុងហេប្រុន

២៣ឯពួកមេទាំងប៉ុន្មាន ជាអ្នកកាន់គ្រឿងសស្ត្រាវុធដែល
មកឯដាវីឌ នៅក្រុងហេប្រុន[ទ] ដើម្បីនឹងបង្វែរ[ធ]រាជ្យរបស់
សូលមកឯដាវីឌវិញ តាមព្រះបន្ទូលនៃព្រះយេហូវ៉ា នោះ
មានចំនួនដូចកត់ទុកខាងក្រោមនេះ[ន] ២៤គឺពួកកូនចៅយូដា
ដែលកាន់ខែលនឹងលំពែងប្រុងនឹងទៅច្បាំង ហើយនោះ
មាន៦ពាន់៨រយនាក់ ២៥ខាងពួកកូនចៅស៊ីម្មានោះ មាន
ពួកមនុស្សខ្លាំងពូកែ សំរាប់ចេញទៅច្បាំង៧ពាន់១រយនាក់
២៦ខាងពួកកូនចៅលេវីមាន៤ពាន់៦រយនាក់ ២៧ហើយ
យេហូយ៉ាដា ជាមេពួកវង្សអើរ៉ុន ក៏មាន៣ពាន់៧រយនាក់
មកជាមួយនឹងលោកដែរ ២៨ហើយមានសាដុក[ប]ជាមនុស្ស
កំឡោះខ្លាំងពូកែ មានចិត្តក្លាហាន ព្រមទាំងមេទ័ព២២នាក់
មកពីជំនួរវង្សរបស់ឪពុកលោកផង ២៩ខាងឯពួកកូនចៅ
បេនយ៉ាមីន[ផ]ជាបងប្អូនសូល នោះមាន៣ពាន់នាក់ ដ្បិតដរាប
ដល់គ្រានោះ ចំណែកពួកបេនយ៉ាមីនជាច្រើនគ្នា[ព] គេបាន
នៅតែស្មោះត្រង់នឹងពួកវង្សរបស់សូល ៣០ខាងពួកកូនចៅ
អេប្រាអិម មាន២ម៉ឺន ៨រយនាក់ សុទ្ធតែជាមនុស្សខ្លាំងពូកែ
មានចិត្តក្លាហាន ដែលមានល្បីឈ្មោះ នៅក្នុងជំនួរវង្ស
របស់ឪពុកគេ ៣១ខាងពូជអំបូរម៉ាន៉ាសេ១ ចំហៀងនោះ
មាន១ម៉ឺន៨ពាន់នាក់ ដែលបានដំរូវដោយឈ្មោះ ឱ្យមក
តាំងដាវីឌឡើងជាស្ដេច ៣២ខាងពួកកូនចៅអ៊ីសាខារ នោះ
មានមនុស្ស ដែលស្គាល់សម័យអាចនឹងដឹងជាសាសន៍

**១២:១៦** ឋ ២សយ ៣:១៩
**១២:១៨** ឌ ពច ៣:១០ ១រប ២៨:១២ ២រប ១៥:១ ២០:១៤ ២៤:២០ ឍ ២សយ ១៧:២៥ ណ ១សយ ២៥:៥-៦
**១២:១៩** ត ១សយ ២៩:២-១១
**១២:២០** ថ ១សយ ២៧:៦
**១២:២៣** ទ ២សយ ២:៣-៤ ធ ១រប ១០:១៤ ន ១សយ ១៦:១ ១រប ១១:១០
**១២:២៨** ប ១រប ៦:៨ ១៥:១១ ១៦:៣៩ ២៧:១៧
**១២:២៩** ផ ២សយ ៣:១៩ ព ២សយ ២:៨-៩
**១២:៣២** ភ នអ ១:១៣

**១២:១៨** តើព្រះវិញ្ញាណបរិសុទ្ធធ្វើការយ៉ាងដូចម្ដេចក្នុងគ្រាសញ្ញាចាស់? នៅពេលមានកិច្ចការងារសំខាន់ដែលត្រូវធ្វើ ព្រះអម្ចាស់ទ្រង់បានជ្រើសរើសមនុស្សដើម្បីឱ្យធ្វើកិច្ចការនោះ ហើយព្រះវិញ្ញាណទ្រង់បានផ្ដល់ឱ្យមនុស្សនោះមានកម្លាំង និងសមត្ថភាព ។ ព្រះវិញ្ញាណបានប្រទានឱ្យបេតសាលាសមានសម្ថភាពខាងសិល្បៈប្រកបដោយភាពប៉ិនប្រសព (នក ៣១:១-៥) បានប្រទានឱ្យយ៉ែបថាមានកម្លាំង (ពច ១១:២៩) ឱ្យដាវីឌមានកម្លាំងក្នុងការគ្រប់គ្រងដឹកនាំ (១សយ ១៦:១៣) ហើយប្រទានឱ្យសាការីមានអំណាចក្នុងការថ្លែងទំនាយ (២សយ ២៤:២០) ។ នៅទីនេះព្រះវិញ្ញាណបរិសុទ្ធបានគង់នៅជាមួយអ័ម៉ាសាយជាអ្នកចម្បាំងម្នាក់ក្នុងចំណោមអ្នកចម្បាំងឯទៀតរបស់ដាវីឌ ។ ព្រះវិញ្ញាណទ្រង់បានគង់នៅជាលក្ខណៈបុគ្គលបែបនេះដើម្បីបំពេញគោលបំណងដ៏ជាក់លាក់ណាមួយ ។ ព្រះវិញ្ញាណបរិសុទ្ធក៏បានគង់នៅជាមួយអ្នកជឿគ្រប់រូបផងដែរ មិនគ្រាន់តែប្រទានមកក្នុងពេលដែលគេបម្រើកិច្ចការតាមបំណងព្រះទ័យរបស់ទ្រង់ប៉ុណ្ណោះនោះឡើយ ប៉ុន្តែគឺគង់នៅជាមួយគេរាល់ថ្ងៃ (កច ២:១៤-២១) ។ បើសិនជាអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ នោះព្រះវិញ្ញាណបរិសុទ្ធទ្រង់នឹងធ្វើការនៅក្នុងជីវិតរបស់អ្នក ។

**១២:២២** ដាវីឌគាត់មាន "ទាហានយ៉ាងសន្ធឹកគឺដូចជាពួកពលនៃព្រះ" ។ ទាហានទាំងនោះបានមកជួយដាវីឌ ក្នុងនាមជាអ្នកចម្បាំងរបស់ព្រះធ្វើឱ្យពួកគេមានជ័យជម្នះនិងបំណងប្រាថ្នា ដែលគេចង់ឃើញពីបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់មកលើស្ដេចដាវីឌ ។

**១២:៣២** ពួកអ៊ីសាខារដែលជាប្រធាន២០០នាក់ជា "អ្នកស្គាល់សម័យ" ជាលទ្ធផល ដោយសារចំណេះនិងការវិនិច្ឆ័យរបស់ពួកគេ គេក្លាយជាអ្នកផ្ដល់ជំនួយក្នុងសេចក្ដីតម្រូវការ និងជាអ្នកធ្វើការសម្រេចចិត្តសម្រាប់ប្រជាជាតិទាំងមូលរបស់គេ ។ ជាការល្អហើយសំខាន់បំផុតសម្រាប់អ្នកដឹកនាំបច្ចុប្បន្ននេះក្នុងការដឹងថា មានហេតុការអ្វីកើតឡើងនៅក្នុងសង្គម ដើម្បីឱ្យយើងចេះរៀបចំផែនការ ដែលល្អសម្រាប់ក្រុមជំនុំ ។ ការយល់ដឹងពីហេតុការណ៍

អ៊ីស្រាអែលត្រូវធ្វើយ៉ាងណា[ភ] ឯអ្នកដែលជាប្រធានក្នុងពួក
គេ នោះមាន២០០នាក់ ហើយពួកបងប្អូនគេក៏ទទួលតាម
បង្គាប់គេទាំងអស់ ៣៣ខាងពួកសាប់យូល៉ូន មាន៥ម៉ឺននាក់
ដែលអាចនឹងចេញទៅច្បាំង សុទ្ធតែមានគ្រឿងសស្ត្រាវុធ
គ្រប់មុខ ហើយគេប្រុងប្រៀបទៅច្បាំងដោយចិត្តស្មោះ
៣៤ខាងពួកណែបថាលី មានមេទ័ព១ពាន់នាក់ ហើយមាន៣
ម៉ឺន៧ពាន់នាក់ដែលកាន់ខែល នឹងលំពែងមកជាមួយនឹង
គេដែរ ៣៥ខាងពួកដាន់ មាន២ម៉ឺន៨ពាន់៦០០នាក់ដែលថ្នឹក
ច្បាំងហើយ ៣៦ខាងពួកអេស៊ើរ នោះមាន៤ម៉ឺននាក់ ដែល
អាចនឹងចេញទៅជាមួយនឹងពលទ័ព ជាមនុស្សថ្នឹកច្បាំង
ដែរ ៣៧ឯខាងនាយទន្លេយ័រដាន់ ក្នុងពួករូបេន ពួកកាឌ់
នឹងពូជអំបូរម៉ាន៉ាសេ១ចំហៀង នោះមានចំនួន១សែន២
ម៉ឺននាក់ ដែលមានគ្រឿងចំបាំងគ្រប់មុខ ។

៣៨ពួកអ្នកទាំងនោះ ដែលសុទ្ធតែជាមនុស្សថ្នឹកច្បាំងក៏
មកឯដាវីឌនៅត្រង់ក្រុងហេប្រុន ដោយចិត្តស្មោះត្រង់ដើម្បី
នឹងតាំងទ្រង់ឡើង ឱ្យធ្វើជាស្តេចលើសាសន៍អ៊ីស្រាអែល
ទាំងមូល[ម] ហើយពួកអ៊ីស្រាអែលឯទៀតទាំងប៉ុន្មានក៏ស្រុះ
ចិត្តគ្នានឹងតាំងដាវីឌឡើងជាស្តេចដែរ ៣៩គេនៅទីនោះ
ជាមួយនឹងដាវីឌ ដោយការលៀងលោម[យ]គ្នាអស់៣ថ្ងៃ
ដ្បិតពួកបងប្អូនគេបានរៀបចំឱ្យ ៤០មួយទៀត ពួកណាដែល
នៅជិតល្មមត្រឹមពួកអ៊ីសាខារ ពួកសាប់យូល៉ូន និងពួក
ណែបថាលី គេក៏យកស្បៀងអាហារផ្ទុកលើសត្វលា អូដ្ឋ
លាកាត់ និងគោមកដែរ គឺជានំបុ័ង ផែនល្វាក្រៀម ចង្កោម
ទំពាំងបាយជូរ[រ] ស្រាទំពាំងបាយជូរ ប្រេង គោ ហើយនិង
ចៀមយ៉ាងសន្ធឹក[ល] ដ្បិតមានសេចក្តីអំណរអរ[វ]នៅក្នុងពួក
អ៊ីស្រាអែល ។

**១២:៣៨** ម ១របៈ៩:១
**១២:៣៩** យ ២សយ ៣:២០ អស ២៥:៦–៨
**១២:៤០** រ ១សយ ២៥:១៨ ល ២សយ ១៦:១ ១៧:២៩ វ ១រប ២៩:២២
**១៣:៣** ក ១សយ ៧:១–២ ខ ២រប ១:៥
**១៣:៥** គ ១រប ១១:១ ១៥:៣ ឃ យស ១៣:៣ ង ជន ១៣:២១ ច ១សយ ៧:២
**១៣:៦** ឆ យស ១៥:៩ ជ នក ២៥:២២ ២ពរ ១៩:១៥

## ការយកហឹបសញ្ញាត្រឡប់មកវិញ

*១៣:១–១៤ – ២សយ ៦:១–១១*

**១៣** ១ដាវីឌទ្រង់បានពិគ្រោះជាមួយនឹងពួកមេទ័ពធំតូច
គឺជាអ្នកនាំមុខទាំងអស់ ២ហើយទ្រង់មានបន្ទូលនឹងពួកជំនុំ
អ៊ីស្រាអែលទាំងអស់ថា បើការនេះពេញចិត្តដល់អ្នករាល់
គ្នា ហើយក៏កើតអំពីព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា
ដែរ នោះចូរយើងចាត់គេឱ្យទៅពេញក្នុងស្រុក ដល់ពួក
បងប្អូនយើង ដែលនៅសល់ក្នុងពួកអ៊ីស្រាអែល ហើយដល់
ពួកសង្ឃ និងពួកលេវី ដែលនៅអស់ទាំងទីក្រុង និងភូមិ
គេទាំងប៉ុន្មាន ដើម្បីឱ្យគេមូលគ្នា មកឯយើងផងចុះ ៣ហើយ
ចូរយើងនាំហឹបរបស់ព្រះនៃយើង មកឯយើង[ក]ដែរ ដ្បិត
យើងរាល់គ្នាមិនបាននឹក[ខ]ដល់ហឹបនោះ ក្នុងគ្រាសូលឡើយ
៤ពួកជំនុំទាំងអស់គ្នា ក៏យល់ព្រមនឹងធ្វើដូច្នោះ ដ្បិតការ
នោះជាទីពេញចិត្តដល់ពួកជនទាំងឡាយ ៥ដូច្នេះ ដាវីឌក៏
ប្រមូលពួកអ៊ីស្រាអែលទាំងអស់[គ]មក ចាប់តាំងពីស្ទឹង
ស៊ីហោ[ឃ]របស់ស្រុកអេស៊ីព្ទ រហូតដល់ទ្វារចូលស្រុក
ហាម៉ាត[ង] ដើម្បីនឹងយកហឹបនៃព្រះពីក្រុងគារយ៉ាត់–យារីម
មក[ច] ៦ដាវីឌនឹងពួកអ៊ីស្រាអែលទាំងអស់ ក៏ឡើងទៅឯ
ក្រុងបាឡា[ឆ] គឺជាគារយ៉ាត់–យារីមរបស់ពួកយូដា ដើម្បី
នឹងយកហឹបនៃព្រះយេហូវ៉ាដ៏ជាព្រះមក ដែលទ្រង់គង់នៅ

នាពេលបច្ចុប្បន្ននេះ និន្នាការជាកត្តាដែលជួយឱ្យយើងយល់ពីគំនិតគិត និងអាកប្បកិរិយារបស់មនុស្ស ។ កត្តាទាំងនោះជួយឱ្យអ្នកដឹកនាំចេះធ្វើការសម្រេចចិត្តប្រកបដោយប្រាជ្ញា សម្រាប់ក្រុមជំនុំ និងព្រះបន្ទូលព្រះទៅដល់មនុស្ស ។

**១២:៤០** ពួកសាសន៍អ៊ីស្រាអែលទាំងអស់បានប្រុងប្រៀបខ្លួនជាស្រេចក្នុងការផ្លាស់ប្តូរអ្នកដឹកនាំ ។ បណ្តាជនទាំងនោះបានរងទុក្ខលំបាកជាយូរមក ហើយក្រោមការដឹកនាំរបស់សូល ពីព្រោះសូលគាត់មិនបានស្តាប់បង្គាប់ព្រះអម្ចាស់(សូមមើល ១០:១៣) ។ ពួកគេគ្រប់គ្នាមានអំណរអសប្បាយក្នុង ពិធីអភិសេកតែងតាំងដាវីឌឱ្យធ្វើជាស្តេច ។

**១៣:១–១៤** សូមមើល ២សយ ៦:១–១១ ។ អ្នកនិពន្ធគាត់បានបំភ្លេចចោលពីដំបូន្មានរបស់ពង្សាវតារដែលបាននិយាយនៅក្នុង ២សយ ជំពូក៥–៦ ដោយគិតពីរឿងនាំយកហិបនៃសេក្តីសញ្ញាជាមុន ហើយបានពន្យាពេលក្នុងការសាងសង់ព្រះវិហារ និងធ្វើសង្គ្រាមជាមួយពួកភីលីស្ទីនរហូតដល់ពេលក្រោយ (មើល ជំពូក ១៤) ។

**១៣:១–៤** ខ.គម្ពីរទាំងនោះ មិនបាននិយាយនៅក្នុងគម្ពីរសាំយូអែលនោះឡើយហើយបានផ្តោតលើទំនាក់ទំនងរបស់អ្នកកត់ត្រាពង្សាវតារជាមួយ "សាសន៍អ៊ីស្រាអែលទាំងអស់" ។ នៅក្នុង ២សយ ៦:១ ពួកទាហានពាក់កណ្តាលជាអ្នកដែលមានបេសកម្មទទួលយកហិបនៃសេចក្តីសញ្ញាមកវិញ ហើយនៅទីនេះ គឺបាននិយាយថាគ្រប់ទាំងអស់នៃសាសន៍អ៊ីស្រាអែល "ពួកជំនុំអ៊ីស្រាអែលទាំងអស់" (មើល ខ.២) គឺរាប់ចាប់តាំងពីសង្ឃនិងពួកលេវី ហើយមានតែម្នាក់ប៉ុណ្ណោះ ដែលមានសិទ្ធក្នុងការសែងហិបនៃសេចក្តីសញ្ញា (មើល ១៥:២,១៣ ២៣:២៥–២៧ ចទ ១០:៨) ។

**១៣:៣** *ដ្បិតយើងរាល់គ្នាមិនបាននឹកដល់ហឹបនោះ ក្នុងគ្រាសូលឡើយ* នៅក្នុង ១សយ ១៤:១៨ ផ្ទុយពីទីនេះ ។

**១៣:៥–៦** នៅតែបន្តនិយាយពីការរួបរួមរបស់ "សាសន៍អ៊ីស្រាអែលទាំងអស់" ។ ពួកអ៊ីស្រាអែលទាំងអស់បានមកចូលរួមចំណែកនេះចាប់តាំងពីស្រុកហាមាត់ ដែលស្ថិតនៅភាគខាងជើងនៃស្ទឹងស៊ីហោរ នៃដំបន់ភាគខាងត្បូង ។

**១៣:៥** *ស៊ីហោរ* នៅក្នុងវាយស័ព្ទរបស់ពួកអេស៊ីព្ទមានន័យថា"អណ្តូងរបស់ហូរើស" ជាផ្នែកមួយរបស់ទន្លេនីល (សូមមើល យស ១៣:៣ អស ២៣:៣ យរ ២:១៨) ។

**១៣:៦** *ក្រុងបាឡា* គឺជាឈ្មោះដែលពួកជនជាតិកាណានបានដាក់ឱ្យ គារយ៉ាត់–យ៉ារីម ហើយគេក៏អាចហៅថា គារយ៉ាត់–បាល (សូមមើល យស ១៨:១៤) ។

កណ្តាលចេរូប៊ីនទាំង២[ជ] ដែលហឹបនោះបានហៅតាមព្រះ
នាមទ្រង់ ៧គេក៏យកហឹបនៃព្រះដាក់លើរទេះថ្មី នាំចេញ
ពីផ្ទះអ័ប៊ីនាដាប់មក[ឈ] មានអ៊ុសា នឹងអ័ហ៉ីយ៉ូរជាអ្នកបរ
៨ឯដាវីឌនឹងពួកអ៊ីស្រាអែលទាំងអស់គ្នា គេក៏ប្រគំភ្លេងនៅ
ចំពោះព្រះអស់ពីកំឡាំង ព្រមទាំងច្រៀងចំរៀងផង ដោយ
ស៊ុយ ពិណ ក្រាប់ ឈឹង និងត្រែ[ញ] ។
៩តែកាលគេទៅដល់លានស្រូវរបស់គីដូន នោះអ៊ុសា
លូកដៃទៅចាប់ទប់ហឹប ពីព្រោះគោកព្រៀលឡើង
១០ដូច្នេះ ព្រះយេហូវ៉ាទ្រង់ មានសេចក្តីក្រោធ[ដ]នឹងអ៊ុសា
ក៏ប្រហារគាត់បង់[ឋ] ដោយព្រោះគាត់បាន លូកដៃទៅពាល់
ហឹប គាត់ក៏ស្លាប់នៅទីនោះចំពោះព្រះទៅ ១១ឯដាវីឌទ្រង់
មានព្រះទ័យទោមនស្ស ដោយព្រោះព្រះយេហូវ៉ាទ្រង់បាន
ប្រហារជីវិតអ៊ុសា រួចទ្រង់ហៅកន្លែងនោះ ឈ្មោះថា ពេ
រេស-អ៊ុសា[ឌ] ដរាបដល់សព្វថ្ងៃនេះ ១២នៅថ្ងៃនោះដាវីឌ
ក៏មានសេចក្តីកោតខ្លាចដល់ព្រះ ហើយមានបន្ទូលថា ធ្វើ
ដូចម្តេចឱ្យយើងនាំយកហឹបនៃព្រះមកឯយើងបាន ១៣ដូច្នេះ
ដាវីឌទ្រង់មិនបាននាំយកហឹបមកឯទ្រង់ក្នុងក្រុងរបស់ទ្រង់
ទេ គឺបានយកទៅដាក់ក្នុងផ្ទះអូបិឌ-អេដំម[ឍ] ជាអ្នកក្រុងកាថ
វិញ ១៤ហើយហឹបនៃព្រះ ក៏នៅជាមួយនឹងគ្រួអូបិឌ-អេដំម
ក្នុងផ្ទះ គាត់អស់៣ខែ ព្រះយេហូវ៉ាទ្រង់ក៏ប្រទានពរដល់
គ្រួ[ណ]របស់អូបិឌ-អេដំម ព្រមទាំងបណ្តារបស់ទ្រព្យគាត់
ទាំងអស់ផង ។

## ដំណាក់ និងរាជវង្សានុវង្សនៃស្តេចដាវីឌ

*១៤:១-៧-២សយ ៥:១១-១៦ ១រប ៣:៥-៨*

១៤ ១ហ៊ីរ៉ាម ជាស្តេចក្រុងទីរ៉ុស ទ្រង់ចាត់សារមកឯ
ដាវីឌ ព្រមទាំងផ្ញើឈើតាមត្រៅ[ក] និងជាងរៀបថ្ម ហើយ
ជាងឈើ ដើម្បីនឹងសង់ដំណាក់ថ្វាយទ្រង់ ២ដាវីឌក៏យល់
ឃើញថា ព្រះយេហូវ៉ាបានតាំងទ្រង់ឡើងជាស្តេចលើ
សាសន៍អ៊ីស្រាអែលពិត ពីព្រោះរាជ្យទ្រង់បានថ្កុំថ្កើងឡើង
យ៉ាងខ្ពស់[ខ] ដោយព្រះអង្គយល់ដល់អ៊ីស្រាអែលជារាស្ត្រ
របស់ទ្រង់ ។
៣នៅក្រុងយេរូសាឡិម ដាវីឌទ្រង់បានយកភរិយាថែម
ហើយក៏បង្កើតបានបុត្រា[គ]បុត្រីទៀត ៤នេះជានាមនៃបុត្រ
ទាំងប៉ុន្មាន ដែលទ្រង់បង្កើតនៅក្រុងយេរូសាឡិម[ឃ] គឺ
សាំមួរ សូបាប់ ណាថាន់ សាឡូម៉ូន ៥យីបហារ អេលីសួរ
អែលផាលេត ៦ណូកា នេផេក យ៉ាភា ៧អេលីសាម៉ា
បេ្អលីយ៉ាដា នឹងអេលីផាលេត ។

## ស្តេចដាវីឌយកឈ្នះលើពួកភីលីស្ទីន

*១៤:៨-១៧ - ២សយ ៥:១៧-២៥*

៨កាលពួកភីលីស្ទីនឮថា គេបានចាក់ប្រេងតាំងដាវីឌ
ឡើង ឱ្យធ្វើជាស្តេច លើសាសន៍អ៊ីស្រាអែលទាំងមូល
ហើយ[ង] នោះពួកភីលីស្ទីន ទាំងអស់ក៏លើកគ្នាឡើងទៅរក

**១៣:៧** ឈ ១សយ ៧:១
**១៣:៨** ញ ១រប ១៥:១៦,១៩,២៤ ២រប ៥:១២ ទដ ៩២:៣
**១៣:១០** ដ ១រប ១៥:១៣,១៥ ឋ លវ ១០:២
**១៣:១១** ឌ ១រប ១៥:១៣ ទដ ៧:១១
**១៣:១៣** ឍ ១រប ១៥:១៨,២៤ ១៦:៣៨ ២៦:៤-៥,១៥
**១៣:១៤** ណ ២សយ ៦:១១
**១៤:១** ក ១ពវ ៥:៦ ១រប ១៧:៦ ២២:៤ ២រប ២:៣ អរ ៣:៧ ហក ១:៨
**១៤:២** ខ ជន ២៤:៧ ចទ?២៦:១៩
**១៤:៣** គ ១រប ៣:១
**១៤:៤** ឃ ១រប ៣:២៩
**១៤:៨** ង ១រប ១១:១

**១៣:៧** *អ៊ុសា និងអ័ហ៉ីយូរ* ជាកូន ឬជាកូនចៅរបស់អ័ប៊ីនាដាប់ (សូមមើល ២សយ ៦:៣) ។

**១៣:១០** *ដោយព្រោះគាត់បានលូកដៃទៅពាល់ហឹប* មានតែពួកលេវីទេដែលអាចសែងហឹបនៃសេចក្តីសញ្ញារបស់ព្រះបាន ។ ពួកគេត្រូវសែងហឹបនោះដោយយកឈើស្នែងមកដាក់នៅនឹងកងហឹប (មើល នក ២៥:១២-១៥) ។ គ្មានអ្វីមួយដែលជាវត្ថុបរិសុទ្ធ អាចប៉ះពាល់បានឡើយ លទ្ធផលនៃការរំលងបញ្ញត្តិ គឺជាសេចក្តីស្លាប់(សូមមើល ជន ៤:១៥) ។ នៅក្នុងការផ្លាស់ប្តូរហឹបនៃសេចក្តីសញ្ញានេះទៅក្រុងយេរ៉ូសាឡិម ត្រូវតែធ្វើឡើងដោយការប្រុងប្រយ័ត្ននិងម៉ត់ចត់បំផុត សូម្បីតែអ៊ុសារនិងអ័ហ៉ីយូរ ដែលទោះបីជាពួកគេជាពួកលេវីក៏មិនត្រូវដឹងដែរ ។ មួយវិញទៀតហឹបនៃសេចក្តីសញ្ញាមិនអាចដាក់នឹងរទេះ (ដូចជាក្នុងករណីដែលពួកភីលីស្ទីនបានធ្វើ ១សយជំពូក ៦) ឬក៏ប៉ះពាល់បានឡើយ ។

**១៣:១៣** *អូបិឌ-អេដំម* ប្រហែលជាមនុស្សតែមួយ ជាមួយនឹងឈ្មោះម្នាក់ដែលបាននិយាយនៅក្នុង ១៥:១៨,២១,២៤ ។ ព្រះពររបស់ព្រះអម្ចាស់មកលើអូបិឌ-អេដំម គឺទាំងការដែលលោកមានកូនច្រើន ។ អំណះអំណាងនេះក៏បានបង្ហាញទៀតថា អូបិឌ-អេដំម គឺជាពួកលេវីហើយប្រហែលគាត់ជាអ្នកថែរក្សាហឹបនៃសេចក្តីសញ្ញានោះយ៉ាងគួរសមបំផុត ។

**១៤:១-៧** អ្នកកត់ត្រាពង្សាវតារ បានលើកយកសាច់រឿងនៅក្នុង ២សយជំពូក៥ បន្តរហូតដល់ចំនុចនេះ (សូមមើលការពន្យល់ ១៣:១១៤) ។ ក្នុងអំឡុងពេល៣ខែដែលហឹបនៃសេចក្តីសញ្ញានៅក្នុងផ្ទះរបស់អូបិឌ-អេដំម (សូមមើល ១៣:១៤) គឺជាគ្រាមួយដែលព្រះអម្ចាស់ទ្រង់ប្រទានព្រះពរមកលើស្តេចដាវីឌឱ្យបានសម្រេចពេញលេញៈ ដើម្បីសង់ដំណាក់ថ្វាយទ្រង់ (សូមមើល ខ.១-២) ក្រុមគ្រួសារដ៏ធំរបស់ទ្រង់ (សូមមើល ខ.៣-៧) និងជ័យជម្នះក្នុងចម្បាំងរបស់ទ្រង់ (សូមមើល ខ.៨-១៦) គ្រប់ការទាំងអស់នេះគឺដោយសារតែព្រះអម្ចាស់ទ្រង់បានប្រទានព្រះពរមកដល់គាត់ (សូមមើល ខ.២,១៧) ។

**១៤:១-២** សូមមើល ២សយ ៥:១១-១២ ។

**១៤:១** *ហ៊ីរ៉ាម* ក្រោយមកទៀតគាត់ក៏ផ្ញើសម្ភារៈ និងពួកកម្មករដើម្បីកសាងព្រះវិហារថ្វាយព្រះអម្ចាស់(សូមមើល ២រប ២) ។ ការនិយាយអំពីគាត់នៅកន្លែងនេះ គឺក្នុងន័យជាលក្ខណៈបញ្ជៀងពីការទទួលស្គាល់ជាអន្តរជាតិថាដាវីឌគឺជាស្តេចលើពួកអ៊ីស្រាអែល និងការតាំងស្ពានមេត្រីរវាងដាវីឌ និងហ៊ីរ៉ាម ។

**១៤:៣-៧** សូមមើល ៣:១-៩ និងការពន្យល់ក្នុង ២សយ ៥:១៣-១៦ ។ កូនប្រុសទាំងប៉ុន្មានរបស់ដាវីឌដែលបានកើតនៅក្រុងហេប្រុន ត្រូវបានបាត់ឈ្មោះ (សូមមើល ៣:១-៤ ២សយ ៣:២-៥ និងការពន្យល់ ១១:១-៣) ។

**១៤:៧** *បេ្អលីយ៉ាដា* គឺជាឈ្មោះតែមួយនឹងឈ្មោះអេលីយ៉ាដាដែលបាននិយាយនៅក្នុង ៣:៨ ២សយ ៥:១៦ ។

**១៤:៨-១២** សូមមើល ២សយ ៥:១៧-២១ ។

ដាវីឌ ដាវីឌទ្រង់ក៏ជ្រាប រួចទ្រង់ចេញទៅទាស់នឹងគេ ៩ឯ
គេបានទន្ទ្រានចូលមកក្នុងច្រកភ្នំ[ច]រេផែមហើយ ១០ដូច្នេះ
ដាវីឌទ្រង់ទូលសួរដល់ព្រះថា តើត្រូវឱ្យទូលបង្គំឡើងទៅ
ច្បាំងនឹងពួកភីលីស្ទីននេះឬទេ តើទ្រង់នឹងប្រគល់គេមក
ក្នុងកណ្តាប់ដៃទូលបង្គំឬ ព្រះយេហូវ៉ាទ្រង់ឆ្លើយថា ចូរ
ឡើងទៅចុះ ដ្បិតអញនឹងប្រគល់គេមកក្នុងកណ្តាប់ដៃឯង
ពិត ១១គេក៏ឡើងមកដល់បាល-ពេរ៉ាស៊ីម[ឆ] ហើយដាវីឌទ្រង់
ប្រហារគេនៅទីនោះ រួចទ្រង់មានបន្ទូលថា ព្រះទ្រង់បាន
ទំលាយមកលើពួកខ្មាំងសត្រូវរបស់យើង ដោយសារដៃ
យើងដូច ជាទឹកធ្លាយទំនប់ ហេតុនោះបានជាគេហៅទីនោះ
ឈ្មោះថា បាល-ពេរ៉ាស៊ីម ១២គេក៏លះចោលអស់ទាំងរូប
ព្រះរបស់គេនៅទីនោះ រួចដាវីឌចេញបង្គាប់ឱ្យដុត[ជ]រូបព្រះ
ទាំងនោះចោល [ឈ]។

១៣ពួកភីលីស្ទីនក៏ទន្ទ្រានចូលមក ក្នុងច្រកភ្នំនោះម្តង
ទៀត[ញ] ១៤ហើយដាវីឌទ្រង់ទូលសួរដល់ព្រះដូចមុន តែព្រះ
ទ្រង់មានបន្ទូលថា កុំឱ្យឡើងទៅតាមគេឡើយ គឺត្រូវបែរ
ចេញពីគេ ឡើងទៅទាស់នឹងគេ ទល់មុខ និងចំការមនវិញ
១៥រួចកាលណាឯងឮសូរសន្ធឹកនៅលើចុងដើមមន ដូច
ជាពួកពលដើរ នោះត្រូវឱ្យឯងចេញទៅច្បាំងចុះ ដ្បិត
ព្រះទ្រង់នឹងចេញទៅនៅមុខឯង ដើម្បីនឹងវាយពួកពល
ភីលីស្ទីនហើយ ១៦ដាវីឌទ្រង់ក៏ធ្វើដូចជាព្រះបានបង្គាប់
ហើយប្រហារពួកពលទ័ពភីលីស្ទីន ចាប់តាំងពីក្រុងគីបៀន[ដ]
រហូតដល់ក្រុងកេស៊ើរ[ឋ] ១៧ដូច្នេះកិត្តិនាម[ឌ]របស់ដាវីឌ
ក៏ល្បីសុសសាយទូទៅគ្រប់ស្រុក ហើយព្រះយេហូវ៉ាទ្រង់

**១៤:៩** ច ខ.១៣ យស ១៥:៨ ១រប ១១:១៥ **១៤:១១** ឆ ទដ ៩៤:១៦ អស ២៨:២១ **១៤:១២** ជ នក ៣២:២០ ឈ យស ៧:១៥ **១៤:១៣** ញ ខ.៩ **១៤:១៦** ដ យស ៩:៣ ឋ យស ១០:៣៣ **១៤:១៧** ឌ យស ៦:២៧ ឍ នក ១៥:១៤-១៦ ចទ ២:២៥ ទដ ២:១-១២

**១៥:១** ក ទដ ១៣២:១-១៨ ខ ២សយ ៦:១៧ ១រប ១៦:១ ១៧:១ **១៥:២** គ ជន ៣:៦ ៤:១៥ ចទ ១០:៨ ៣១:២៥ ២រប ៥:៥ ឃ ចទ ៣១:៩ ង ១រប ១៦:៤ ២៣:១៣ ២រប ២៩:១១ ៣១:២ ទដ ១៣៤:១ ១៣៥:២ **១៥:៣** ច ១រប

បណ្តាល ឱ្យគ្រប់ទាំងសាសន៍ខ្លាច[ឍ]ដល់ទ្រង់ ។

## ហឹបសញ្ញាត្រូវបញ្ជូនដល់ក្រុងយេរូសាឡិម

*១៥:២៥-១៦:៣ - ២សយ ៦:១២-១៩*

**១៥** ១ដាវីឌទ្រង់ក៏សង់ដំណាក់ សំរាប់ទ្រង់នៅក្នុងក្រុង
ដាវីឌ ហើយក៏រៀបចំ[ក]កន្លែង សំរាប់ហឹបនៃព្រះ គឺបាន
ដំឡើង[ខ]ត្រសាលសំរាប់ហឹបនោះ ២រួចដាវីឌទ្រង់មាន
បន្ទូលថា មិនត្រូវឱ្យអ្នកណាសែងហឹបនៃព្រះឡើយ លើក
តែពួកលេវី[គ]ប៉ុណ្ណោះ ដ្បិតព្រះយេហូវ៉ាទ្រង់បានរើសគេ
ទុកជាអ្នកសែង[ឃ]ហឹបនៃព្រះ ហើយឱ្យធ្វើការងារ[ង] ថ្វាយ
ទ្រង់ជាដរាប ៣ដូច្នេះ ដាវីឌទ្រង់ប្រមូលពួកអ៊ីស្រាអែល
ទាំងអស់[ច]មកឯក្រុងយេរូសាឡិម ដើម្បីនឹងនាំយកហឹបនៃ
ព្រះយេហូវ៉ា មកឯកន្លែងដែលទ្រង់បានរៀបសំរាប់ ៤ទ្រង់
ក៏ប្រមូលពួកកូនចៅអើរ៉ុន និងពួកលេវី[ឆ] ៥គឺក្នុងពួកកូនចៅ
កេហាត់ មានអ៊ូរាល[ជ]ជាមេ នឹងបងប្អូនលោក១២០នាក់
៦ក្នុងពួកកូនចៅម្រ៉ារី មានអ័សាយ៉ាជាមេ និងបងប្អូនលោក
២២០នាក់ ៧ក្នុងពួកកូនចៅគើសុន មានយ៉ូអែលជាមេ និង
បងប្អូនលោក១៣០នាក់ ៨ក្នុងពួកកូនចៅអេលីសាផាន[ឈ]
ថានសេម៉ាយ៉ាជាមេ និងបងប្អូនលោក២០០នាក់ ៩ក្នុងពួក
កូនចៅហេប្រុន[ញ] មានអេលាលជាមេ នឹងបងប្អូនលោក៨០
នាក់ ១០ក្នុងពួកកូនចៅអ៊ូស៊ាលមមានអ័មីន៉ាដាប់ជាមេ និង
បងប្អូនលោក១១២នាក់ ១១ដាវីឌទ្រង់ក៏ហៅសាដុក[ដ] និង
អ័បៀថើរ[ឋ] ដ៏ជាសង្ឃមក ព្រមទាំងពួកលេវី គឺអ៊ូរាល

១៣:៥ **១៥:៤** ឆ ជន ៣:១៧-២០ **១៥:៥** ជ ១រប ៦:២៤ **១៥:៨** ឈ នក ៦:២២ **១៥:៩** ញ នក ៦:១៨ **១៥:១១** ដ ១រប ១២:២៨ ឋ ១សយ

**១៤:១១** *ទំលាយ . . . ហៅកន្លែងនោះថា បាល-ពេរ៉ាស៊ីម* នៅក្នុងភាសាព្រើរ ទីកន្លែងដែលព្រះអម្ចាស់ទ្រង់បានទំលាយពួកភីលីស្ទីននៅទីនេះក៏ដូចគ្នា នឹងទីកន្លែងដែលព្រះអម្ចាស់ទ្រង់បានទំលាយអ៊ុសា (សូមមើល ១៣:១១) ។

**១៤:១២** *ចេញបង្គាប់ឱ្យដុតរូបព្រះទាំងនោះចោល* នៅក្នុង ២សយ ៥:២១ មិនបាននិយាយពីការដុតរូបព្រះចោលនោះឡើយ ប៉ុន្តែបាននិយាយថា ដាវីឌ និងពួកទាហានរបស់គាត់បាននាំយករូបព្រះទាំងអស់នោះទៅ ។ អ្វីដែលបានឃើញនៅទីនេះ គឺជាបំលាស់ប្តូររបស់អ្នកកត់ត្រាពង្សាវតារ ដើម្បីបង្ហាញពីសកម្មភាពដ៏តឹងតែងរបស់ដាវីឌដោយអនុលោមទៅតាមច្បាប់ដែលបានតម្រូវឱ្យដុតរូបព្រះទាំងនោះចោល (សូមមើល ចទ ៧:៥, ២៥) ។ ទោះបីជាយ៉ាងណាក៏ដោយក៏មានសិបធ្យូជីនខ្លះ (ការបកប្រែរបស់គ្រីស្ទបរិសទ័ក្រិចជិនាន់មុននៅក្នុងសញ្ញាចាស់) ដែលមាននៅក្នុងសៀវភៅរបស់សាំយូអែល បានយល់ស្របជាមួយគម្ពីរពង្សាវតារនេះថាដាវីឌបានដុតរូបព្រះទាំងនោះចោល ។

**១៤:១៣-១៦** សូមមើល ២សយ ៥:២២-២៥។

**១៤:១៧** *ព្រះយេហូវ៉ាទ្រង់បណ្តាល ឱ្យគ្រប់ទាំងសាសន៍ខ្លាចដល់ទ្រង់* នៅទីនេះនិងកន្លែងផ្សេងៗទៀតអ្នកកត់ត្រាពង្សាវតារបានប្រើនូវប្រយោគដែលសំដៅទៅលើអសម្ថភាពដែលអ្នកឯទៀតមិនអាចធ្វើបានហើយមានការភ័យខ្លាចចំពោះអំណាចរបស់ព្រះ ដែលបានគង់នៅជាមួយរាស្ត្រទ្រង់(សូមមើល នក ១៥:១៦) ។ ប្រជាជាតិទាំងអស់បានឃើញថាដាវីឌគឺជាអ្នកតំណាងរបស់ព្រះអម្ចាស់ (ដូចគ្នានិងអេសា ២រប ១៤:១៤ យេហូសាផាត ២រប ១៧:១០ ២០:២៩) ។

**១៥:១-១៦:៣** ការយកហឹបនៃសេចក្តីសញ្ញាទៅក្រុងយេរ៉ូសាឡិម ប្រកបដោយជោយជ័យ គឺហាក់បីដូចជាត្រូវការធនធានច្រើនជាងអ្វីដែលបាននិយាយនៅក្នុង ២សយទៅទៀត ។ មានតែនៅក្នុង ១៥:២៥-១៦:៣ ប៉ុណ្ណោះដែលមានដំណើររឿងស្របគ្នា(២សយ ៦:១២-១៩) ។

**១៥:១** *សង់ដំណាក់សំរាប់ទ្រង់* សូមមើល ១៤:១-២ និងការពន្យល់ក្នុង ១៣:១-១៤ ។

**១៥:២-៣** សូមមើលការពន្យល់ក្នុង ១៣:១០ ។

**១៥:៤-១០** នៅកន្លែងនេះបាននិយាយអំពីពូជអំបូរទាំង៣របស់អំបូរលេវី (ពួកកេហាត់ ពួកម្រ៉ារី និងពួកគើសុន) រួមទាំងក្រុមផ្សេងៗចំនួន៣ទៀត (អេលីសាផាន ហេប្រុន និងអ៊ូសាល) ដែលទាំងអស់មាន៨៦២នាក់ ។

អ័សាយ៉ា យ៉ូអែល សេម៉ាយ៉ា អេលាល នឹងអ័មីនាដាប់ផង
១២ទ្រង់មានបន្ទូលទៅគេថា អ្នករាល់គ្នាជាប្រធានលើ
វង្សានុវង្សរបស់ឪពុកនៃពួកលេវីទាំងប៉ុន្មាន ដូច្នេះ ចូរ
ញែកខ្លួនចេញជាបរិសុទ្ធចុះ[ឌ] ព្រមទាំងបងប្អូនអ្នករាល់គ្នា
ផង ដើម្បីនឹងយកហឹបនៃព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល មកឯកន្លែងដែលយើងបានរៀបចំ ១៣ដ្បិត
ដោយព្រោះកាលពីដាន់មុនអ្នករាល់គ្នា[ឍ]មិនបានសែងទេ
បានជាព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា ទ្រង់បាន
ប្រហារពួកយើងទៅ[ណ] គឺពីព្រោះយើងរាល់គ្នាមិនបានរក
ទ្រង់ ឱ្យត្រូវតាមច្បាប់[ត] ១៤ដូច្នេះពួកសង្ឃនឹងពួកលេវី ក៏
ញែកខ្លួនជាបរិសុទ្ធ ដើម្បីនឹងនាំយកហឹបនៃព្រះយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែលឡើងមក ១៥ពួកកូនចៅលេវី
បានសែងហឹបនៃព្រះទៅដោយឈើស្នែង ដូចជាលោក
ម៉ូសេបានបង្គាប់មក[ថ] តាមព្រះបន្ទូលនៃព្រះយេហូវ៉ា[ទ] ។
១៦ដាវីឌ[ធ]ក៏ប្រាប់ ឱ្យមេពួកលេវី[ន]ដំរូវ ឱ្យពួកចំរៀង[ប] ជា
បងប្អូនគេ កាន់ប្រដាប់ភ្លេង គឺពិណ ស៊ុង និងឈឹង[ផ] លេង
ឱ្យឮសូរក្រលួច ហើយឡើងសំឡេងច្រៀងដោយអំណរ
១៧ពួកលេវីក៏ដំរូវឱ្យមានពួកអ្នកនេះ គឺហេម៉ាន[ព] ជាកូន
យ៉ូអែល ហើយក្នុងពួកបងប្អូនរបស់លោក គឺអេសាភ[ភ] ជា
កូនបេរេគា ឯក្នុងពួកម្រ៉ារី[ម] ជាបងប្អូនលោក គឺអេថាន ជា
កូនគូសាយ៉ា ១៨ហើយពួកបងប្អូនគេ ដែលជាថ្នាក់ទី២ឱ្យបាន
នៅជាមួយដែរ គឺសាការី បេន យ្អាស៊ាល សេមីរ៉ាម៉ូត
យេហ៊ីអែល អ៊ូនី អេលាប បេណាយ៉ា ម្អាសេយ៉ា ម៉ាធិធា
អេលីផាលេ មីកនេយ៉ា អូបិឌ-អេដំម[យ] និងយីអែល
ដែលសុទ្ធតែជាម្ចាក់អ្នកឆ្មាំទ្វារ ១៩ដូច្នេះពួកអ្នកចំរៀង គឺ
ហេម៉ាន[រ] អេសាភ និងអេថាន ក៏កាន់ឈឹងលង្ហិន សំរាប់
វាយឱ្យឮរងំ ២០ហើយសាការី យ្អាស៊ាល សេមីរ៉ាម៉ូត
យីអែល អ៊ូនី អេលាប ម្អាសេយ៉ា និងបេណាយ៉ា ក៏កាន់

២២:២០
**១៥:១២** ឌ នក ២៩:១ ៣០:១៩-២១,៣០ ៤០:៣១-៣២ លវ ១១:៤៤
**១៥:១៣** ឍ ១ពវ ៨:៤ ណ ១រប ១៣:៧-១០ ត លវ ៥:១០
**១៥:១៥** ថ នក ២៥:១៤ ទ ២សយ ៦:៧
**១៥:១៦** ធ ១រប ៦:៣១ ន ២រប ៧:៦ ប អរ ២:៤១ នហ ១១:២៣ ទដ ៦៨:២៥ ផ ១រប ១៣:៨ ២៣:៥ ២រប ២៩:២៦ នហ ១២:២៧,៣៦ យប ២១:១២ ទដ ១៥០:៥ អម ៦:៥
**១៥:១៧** ព ១រប ៦:៣៣ ភ ១រប ៦:៣៩ ម ១រប ៦:៤៤
**១៥:១៨** យ ២សយ ៦:១០ ១រប ២៦:៤-៥
**១៥:១៩** រ ១រប ១៦:៤១ ២៥:៦
**១៥:២៤** ល ២រប ៥:១២ ៧:៦ ២៩:២៦
**១៥:២៥** វ ២រប ១:៤ ៥:២ យរ ៣:១៦

ពិណ សំរាប់ដេញ តាមសំឡេងស្រួច ២១ហើយម៉ាធិធា
អេលីផាលេ មីកនេយ៉ា អូបិឌ-អេដំម យីអែល នឹងអ័សាស៊ា
ក៏កាន់ស៊ុងខ្សែ៨ សំរាប់នឹងចាប់នាំមុខពួកចំរៀង ២២ហើយ
កេណានា ជាមេពួកលេវី លោកត្រួតលើការចំរៀង គឺ
លោកដែលបង្ហាត់ការនោះពីព្រោះលោកជាអ្នកប្រសប់
២៣ឯបេរេគានឹងអែលកាណាគេជាអ្នកឆ្មាំទ្វារ ២៤សេបានា
យេហូសា ផាត នេថានេល អ័ម៉ាសាយ សាការី បេណាយ៉ា
អេលាស៊ើរ ដ៏ជាពួកសង្ឃ គេក៏ផ្លុំត្រែ[ល] នៅចំពោះហឹបនៃ
ព្រះ ឯអូបិឌ-អេដំម នឹងយេ ហ៊ីយ៉ា គេជាអ្នកឆ្មាំទ្វារ
សំរាប់បើកឱ្យហឹបចេញ ។
២៥ដូច្នេះ ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែល និងពួក
មេទ័ព ក៏ទៅនាំយកហឹបនៃសេចក្តីសញ្ញាផងព្រះយេហូវ៉ា[វ]
ពីផ្ទះអូបិឌ-អេដំមមកដោយអរសប្បាយ ២៦រួចដោយព្រោះ
ព្រះទ្រង់ប្រោសមេត្តាដល់ពួកលេវី ដែលសែងហឹបនៃ
សេចក្តីសញ្ញាផងព្រះយេហូវ៉ា បានជាគេថ្វាយកូនគោ៧
និងពពែ៧[ស] ទុកជាយញ្ញបូជា ២៧ឯដាវីឌទ្រង់ព្រះពស្ត្រសំពត់
ខ្លូតទេសយ៉ាងម៉ដ្ត ព្រមទាំងពួកលេវីដែលសែងហឹប ពួក
ចំរៀង និងកេណានា ជាមេលើពួកចំរៀងផង ហើយ
ដាវីឌក៏ពាក់អេផូឌ ធ្វើពីសំពត់ខ្លូតទេសដែរ[ហ] ២៨គឺយ៉ាង
នោះ ដែលពួកអ៊ីស្រាអែលទាំងអស់[ឡ] បាននាំយកហឹបនៃ
សេចក្តីសញ្ញាផងព្រះយេហូវ៉ាឡើងមក ដោយសំរែក
អរសប្បាយ[អ] នឹងសូរស្នែង[ក] ត្រែ ហើយនិងឈឹង ព្រមទាំង
ដេញពិណ ហើយចាប់ស៊ុងផង ។
២៩កាលហឹបនៃសេចក្តីសញ្ញាផងព្រះយេហូវ៉ា បានចូល
មកក្នុងទីក្រុងដាវីឌហើយ នោះមីកាល ជាបុត្រីសូល នាង
ទតទៅតាមបង្អួច ឃើញស្តេចដាវីឌកំពុងតែលោតកញ្ឆេង

**១៥:២៦** ស ជន ២៣:១-៤,២៩ **១៥:២៧** ហ ១សយ២:១៨ **១៥:២៨** ឡ ១រប ៩:១ អ ១បរ ១:៣៩ សក ៤:៧ ក នក ១៩:១៣

**១៥:១២** *ញែកខ្លួនចេញជាបរិសុទ្ធ* សម្អាតតាមក្បួនច្បាប់ និងធ្វើពិធីសម្អាត (មើល នក ២៩:១-៣៧ ៣០:១៩-២១ ៤០:៣១-៣២ លវ ៨:៥-៣៥) ។

**១៥:១៣-១៥** អ្នកកត់ត្រាប្រវត្តិសាស្ត្របានធ្វើការពន្យល់ពីមូលហេតុដែលបណ្តាលឱ្យមានការបរាជ័យ ក្នុងការនាំយកហឹបសញ្ញាទៅក្នុងក្រុងយេរូសាឡិមកាលពីគ្រាដំបូងដែលការពន្យល់នេះមិនបាននិយាយនៅក្នុង គម្ពីរសាំយូអែលឡើយ (សូមមើល ១៣:១០) ។

**១៥:១៨,២១,២៤** *អូបិឌ-អេដំម* សូមមើល ១៣:១៣ ។

**១៥:២៤** *ដ៏ជាសង្ឃ គេក៏ផ្លុំត្រែ* សូមមើល ១៦:៦ ជន ១០:១-១០ ។

**១៥:២៧** ទាំងក្នុងគម្ពីរ ២សយ ៦:១៤ និងអ្នកកត់ត្រាពង្សាវតារគឺសុទ្ធតែបាននិយាយថាដាវីឌបានពាក់អេផូឌដែលជាសំលៀកបំពាក់របស់សង្ឃ (១សយ ២:១៨ ២២:១៨) ។ អ្នកកត់ត្រាពង្សាវតារក៏បានបន្ថែមទៀតថាដាវីឌគាត់បានស្លៀកពាក់សំពត់ខ្លូតទេសយ៉ាងម៉ត់ដែលប្រៀបបានទៅនឹងសង្ឃ ។ មើលទៅអ្នកកាលប្រវត្តិចង់បង្ហាញថាដាវីឌជាសង្ឃ ជាស្តេចដែលតំណាងឱ្យព្រះមែស៊ី (សូមមើល ទដ ១១០ សក ៦:៩-១៥) ។

**១៥:២៩** នៅក្នុងខ.នេះ មានការប្រហាក់ប្រហែលគ្នាទៅនឹង ២សយ ៦:១៦ ប៉ុន្តែអ្នកកត់ត្រាពង្សាវតារគាត់បានលុបបំបាត់សំណល់រឿងដែលបានកត់ចុះនៅទីនោះ (សូមមើល ២សយ ៦:២០-២៣) ។ អ្នកកាត់ស្រាយមួយចំនួនគាត់មានអារម្មណ៍សោយស្តាយចំពោះការលុបបំបាត់សាច់រឿងនៅទីនោះ ដែលវាជាផ្នែកបតិដ្ឋានមួយរបស់អ្នកកត់ត្រាពង្សាវតារ ក្នុងការបង្ហាញប្រាប់អំពីដាវីឌ ដូច្នេះហើយ ដោយសារតែរឿងដែលមិនសមរម្យបែបនេះ បានជាគេលុបបំបាត់នូវរឿងនោះចោល ។ រឿងដែលគួរឱ្យយកជាការម៉្យាងទៀតនោះ គឺនៅទីនេះអ្នកកត់ត្រាពង្សាវតារបានធ្វើការប៉ាន់ស្មានយ៉ាងសាមញ្ញអំពីចំណេះដឹងរបស់អ្នកអានសម្រាប់រឿងក្រោយៗទៀត (សូមមើល ១០:១៣-១៤ ១១:១-៣ ១២:១-៣ ១២:១ ១៣:៦) ។

ហើយលេងភ្លេង រួចនាងមានព្រះទ័យប្រមាថមើលងាយ
ដល់ទ្រង់ ។

**១៦** ១គេនាំយកហឹបនៃព្រះមក ដាក់នៅកណ្ដាលត្រសាល
ដែលដាវីឌបានដំឡើងទុក[ក]សំរាប់ រួចក៏ថ្វាយដង្វាយដុត
និងដង្វាយមេត្រី នៅចំពោះព្រះ ២កាលដាវីឌ បានថ្វាយ
ដង្វាយដុត និងដង្វាយមេត្រីទាំងនោះរួចហើយនោះទ្រង់
ក៏ប្រទានពរ[ខ]ដល់ពួកជន ដោយនូវព្រះនាមព្រះយេហូវ៉ា
៣រួចទ្រង់ចែកនំបុ័ង១ដុំ សាច់១ដុំ និងផ្លែទំពាំងបាយជូរ១
ផែន[គ] ឱ្យដល់សាសន៍អ៊ីស្រាអែលគ្រប់ៗគ្នា ទាំងប្រុសទាំង
ស្រី ។
៤ទ្រង់ក៏ដំរូវពួកលេវីខ្លះ ឱ្យធ្វើការងារ[ឃ]នៅចំពោះហឹប
នៃព្រះយេហូវ៉ា ដើម្បីនឹងរំឭក អរព្រះគុណ ហើយនឹង
សរសើរដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
៥គឺអេសាភជាមេ ហើយបន្ទាប់មកមាន សាការី យីអែល
សេមីរ៉ាម៉ូត យេហ៊ីអែល ម៉ាធិធា អេលាប បេណាយ៉ា
អូបិឌ–អេដំម និងយីអែល សុទ្ធតែកាន់ពិណ និងស៊ុង ហើយ
អេសាភ ជាអ្នកវាយឈឹងឱ្យឮរងំ ៦ឯបេណាយ៉ា និង
យ៉ាហាសៀល ជាពួកសង្ឃ ក៏ផ្លុំត្រែជានិច្ច នៅចំពោះហឹប
នៃសេចក្ដីសញ្ញាផងព្រះ ។

### ទំនុងអរព្រះគុណរបស់ស្ដេចដាវីឌ

*១៦:៨–២២ – ទដ ១០៥:១–១៥*
*១៦:២៣–៣៣ – ទដ ៩៦:១–១៣*
*១៦:៣៤–៣៦ – ទដ ១០៦:១,៤៧–៤៨*

៧នៅថ្ងៃនោះឯង ដាវីឌបានបង្គាប់មុនដំបូង ឱ្យមានការ
អរព្រះគុណ[ង] ដល់ព្រះយេហូវ៉ា ដោយសារអេសាភ និងពួក
បងប្អូនលោកថា ៨ចូលអរព្រះគុណ[ច]ដល់ព្រះយេហូវ៉ា ចូរ
អំពាវនាវដល់ព្រះនាមទ្រង់ចុះ ចូរសំដែងពីអស់ទាំងការ
នៃទ្រង់នៅកណ្ដាលគ្រប់ទាំងសាសន៍[ឆ] ៩ចូរច្រៀងថ្វាយ
ទ្រង់ ចូរច្រៀងសរសើរ[ជ]ដល់ទ្រង់ចុះ ចូរនឹងថ្លែងពីអស់
ទាំងការអស្ចារ្យរបស់ទ្រង់ ១០ចូលមានចិត្តរីករាយ ដោយ
នូវព្រះនាមបរិសុទ្ធរបស់ទ្រង់[ឈ] ចូរឱ្យអស់អ្នក ដែលស្វែង
រកព្រះយេហូវ៉ា មានចិត្តអរសប្បាយឡើង ១១ចូលសង្កិនរក
ព្រះយេហូវ៉ា និងឥទ្ធានុភាពរបស់ទ្រង់ ចូររក[ញ]ព្រះភ័ក្ត្រ
ទ្រង់ជានិច្ច ១២ចូរនឹងចាំ[ដ]ពីអស់ទាំងការអស្ចារ្យ[ឋ]ដែល
ទ្រង់បានធ្វើ គឺពីការចំឡែក[ឌ]របស់ទ្រង់ និងពីសេចក្ដី
យុត្តិធម៌ដែលចេញពីព្រះឱស្ឋទ្រង់មក ១៣ឱអ្នករាល់គ្នា
ជាពូជពង្សអ៊ីស្រាអែល ជាពួកបំរើទ្រង់ គឺពួកកូនចៅ
យ៉ាកុប ជាពួកអ្នកជ្រើសរើសរបស់ទ្រង់អើយ ១៤ទ្រង់ជាព្រះ
យេហូវ៉ា ជាព្រះនៃយើងរាល់គ្នា សេចក្ដីបញ្ញត្ត[ឍ]ទាំងប៉ុន្មាន
នៃទ្រង់ នៅពេញលើផែនដី ១៥ចូរនឹកចាំ[ណ]ពីសេចក្ដីសញ្ញា
របស់ទ្រង់ជាដរាប គឺជាព្រះបន្ទូល ដែលទ្រង់បានបង្គាប់
ដល់មនុស្សទាំងពាន់ដំណ ១៦ជាសេចក្ដីសញ្ញា[ត] ដែលទ្រង់
បានតាំងនឹងអ័ប្រាហាំ ហើយជាសេចក្ដីសំបថ ដែលទ្រង់
បានស្បថនឹងអ៊ីសាក ១៧ព្រមទាំងបញ្ជាក់ សេចក្ដីនោះឯង
ទុកជាច្បាប់ដល់យ៉ាកុប[ថ] ហើយដល់អ៊ីស្រាអែល សំរាប់ជា
សញ្ញាដ៏នៅអស់កល្បជានិច្ច ១៨ដោយបន្ទូលថា អញនឹងឱ្យ
ស្រុកកាណាន[ទ]ដល់ឯង ទុកជាចំណែកមរដករបស់ឯង
១៩ក្នុងកាលដែលអ្នករាល់គ្នានៅគ្នាតិចនៅឡើយ[ធ] គឺមាន
គ្នាតិចណាស់ ក៏គ្រាន់តែស្នាក់នៅស្រុកនេះប៉ុណ្ណោះផង
២០គេចេញដំណើរពីនគរ១ទៅនគរ១[ន] ហើយពីសាសន៍១
ដល់សាសន៍១ទៀត ២១ទ្រង់មិនបើកឱ្យមនុស្សណាសង្កត់
សង្កិនគេឡើយ ទ្រង់បានបន្ទោសដល់ទាំងពួកស្ដេចដោយ
ព្រះគេផង[ប] ២២ដោយបន្ទូលថា កុំពាល់ពួកដែលអញបាន
ចាក់ប្រេងឱ្យឡើយ ក៏កុំឱ្យធ្វើបាបដល់ពួកហោរា[ផ]របស់អញ
ដែរ ២៣ឱលោកីយទាំងមូលអើយ ចូលច្រៀងថ្វាយព្រះយេ
ហូវ៉ាចុះ ហើយសំដែងពីសេចក្ដីសង្គ្រោះរបស់ទ្រង់រាល់ៗ

**១៦:១** ក ១របា ១៥:១
**១៦:២** ខ នក ៣៩:៤៣ ជន ៦:២៣–២៧
**១៦:៣** គ អស ១៦:៧
**១៦:៤** ឃ ១របា ១៥:២
**១៦:៧** ង ទដ ៤៧:៧
**១៦:៨** ច ខ.៣៤ ទដ ១០៧:១ ១១៨:១ ១៣៦:១ ឆ ២ពវ ១៩:១៩
**១៦:៩** ជ នក ១៥:១ ទដ ៧:១៧
**១៦:១០** ឈ ទដ ៨:១ ២៩:១ ៦៦:២
**១៦:១១** ញ ខ.១០ ១របា ២៨:៩ ២របា ៧:១៤ ១៤:៤ ១៥:២,១២ ១៦:១២ ១៨:៤ ២០:៤ ៣៤:៣ ទដ ២៤:៦ ២៧:៨ ១០៥:៤ ១១៩:២,៥៨ សភ ៨:១៧
**១៦:១២** ដ ទដ ៧៧:១១ ឋ ចទ ៤:៣៤ ឌ ទដ ៧៨:៤៣
**១៦:១៤** ឍ អស ៤:៤ ២៦:៩
**១៦:១៥** ណ លប ៨:១ ទដ ៩៨:៣ ១១១:៥ ១១៥:១២ ១៣៦:២៣
**១៦:១៦** ត លប ១២:៧ ១៥:១៨ ២២:១៦–១៨
**១៦:១៧** ថ លប ៣៥:៩–១២ **១៦:១៨** ទ លប ១៣:១៤–១៧ **១៦:១៩** ធ ចទ ៧:៧ **១៦:២០** ន លប ២០:១៣ **១៦:២១** ប លប ១២:១៧ ២០:៣ នក ៧:១៥–១៨ ទដ ៩:៥ **១៦:២២** ផ លប ២០:៧

**១៦:១–៣** ដាវីឌគាត់ប្រៀបបានទៅនឹងសង្ឃ ដោយសារកិច្ចការងារគ្រប់គ្រងដង្វាយ និងការហ្វឹកហាត់ការងារជាសង្ឃរបស់គាត់ ក្នុងកាលដែលគាត់ប្រទានពរដល់បណ្ដាមនុស្ស (សូមមើល ជន ៦:២២–២៧ និង ១៥:២៧) ។ ការដុតដង្វាយដែលដាវីឌបានថ្វាយនោះ គឺទុកដូចជាដង្វាយមេត្រីដែលនៅចំពោះព្រះអម្ចាស់ (សូមមើល លវ ៣:១–១៧ ៧:១១–២១, ២៨–៣៦) ។

**១៦:៤** *ដើម្បីរំឭកអរព្រះគុណ ហើយនិងសរសើរព្រះយេហូវ៉ា* គឺជាបទនៃប្រភេទទំនុកដំកើង៣សំខាន់ៗដែលមាន (ទី១) ទំនុកនៃការទំនួញសោក ឬរំឭក (ទី២) ទំនុកនៃការអរព្រះគុណ (ទី៣) ទំនុកនៃការសរសើរ (សូមមើល សេចក្ដីផ្ដើមគម្ពីរទំនុកដំកើងៈប្រភេទនៃទំនុកដំកើងនិង កល ៣:១៦) ។

**១៦:៨–៣៦** នៅក្នុងខ.ទាំងនេះគឺមានការប្រហាក់ប្រហែលគ្នាខ្លះៗទៅនឹងកណ្ឌគម្ពីរទំនុកដំកើង (ខ.៨–២២ សូមមើល ទដ ១០៥:១–៥ ខ.២៣–៣៣ មើល ទដ ៩៦ ខ.៣៤–៣៦ មើល ទដ ១០៦:១,៤៧–៤៨) ។ ទំនុកនេះមិនបាននិយាយនៅក្នុងគម្ពីរសាំយូអែលឡើយ ។ ការយកផ្នែកខ្លះនៃគម្ពីរ ដទ ១០៥ គឺចង់បង្ហាញថាសេចក្ដីសន្យាដែលព្រះអម្ចាស់ទ្រង់បានសន្យាជាមួយលោកអ័ប្រាហាំ អាចនឹងមានទំនាក់ទំនងទៅនឹងអ្នកអានរបស់អ្នកកត់ត្រាពង្សាវតារសម្រាប់អ្នកដែលមានសេចក្ដីស្មោះត្រង់ចំពោះព្រះអម្ចាស់ គេបានត្រឡប់ជាបរិសុទ្ធរួចទៅហើយ ក្នុងដំណើរវិលត្រឡប់របស់គេ ។ គុណកថាចាប់ពី ទដ ១០៦ ក៏មានទំនាក់ទំនងទៅនឹងអ្នកអានរបស់អ្នកកត់ត្រាពង្សាវតារដែរ គឺជាពួកអ្នកដែលបានប្រមូលបំប្រួម និងប្រោសលោះ (មើល ខ.៣៥) ។

ថ្ងៃ ២៤ចូរថ្លែងប្រាប់ពីសិរីល្អ[ត]នៃទ្រង់ នៅក្នុងគ្រប់ទាំងនគរ
ហើយពីការអស្ចារ្យរបស់ទ្រង់នៅកណ្ដាលអស់ទាំងសាសន៍
២៥ដ្បិតព្រះយេហូវ៉ាទ្រង់ជាធំក៏គួរសរសើរណាស់[ភ] ហើយ
គួរស្ញែងខ្លាច[ម]លើសជាងអស់ទាំងព្រះ[យ] ២៦ពីព្រោះអស់
ទាំងព្រះនៃសាសន៍ដទៃ សុទ្ធតែជារូបទទេ តែឯព្រះ
យេហូវ៉ាវិញ ទ្រង់បានបង្កើតផ្ទៃមេឃ[រ] ២៧ឯសេចក្ដីរឿង
ហើយសិរីលំអ នោះនៅចំពោះទ្រង់ឥទ្ធានុភាពនឹងសេចក្ដី
អំណរ ក៏នៅទីកន្លែងរបស់ទ្រង់ ២៨ឱអស់ទាំងសាសន៍អើយ
ចូរទទួលថ្លែងពីព្រះយេហូវ៉ា ចូលទទួលថ្លែងប្រាប់ថា ព្រះ
យេហូវ៉ាទ្រង់មានសិរីល្អ និងព្រះចេស្ដា[ល] ២៩ចូរទទួលថ្លែង
ប្រាប់ពីសិរីល្អនៃព្រះយេហូវ៉ា ឱ្យសំណាំនឹងព្រះនាមទ្រង់[វ]
ចូរនាំយកដង្វាយ១មកនៅចំពោះព្រះយេហូវ៉ាចុះ ហើយ
ថ្វាយបង្គំដល់ទ្រង់ ដោយសិរីលំអនៃសេចក្ដីបរិសុទ្ធ[ស]
៣០គ្រប់ផែនដីអើយ ចូរភ័យញ័រ[ហ]នៅចំពោះទ្រង់ចុះ ឯ
លោកីយ នោះក៏បានតាំងជាមាំមួនហើយ និងកក្រើករញ្ជួយ
មិនបានឡើយ[ឡ] ៣១ចូរឱ្យផ្ទៃមេឃមានសេចក្ដីអំណរ[អ]
ហើយឱ្យផែនដីបានត្រេកអរឡើង ឱ្យបានថ្លែងនៅគ្រប់
ទាំងសាសន៍ថា ព្រះយេហូវ៉ាទ្រង់សោយរាជ្យ[ក] ៣២ចូរឱ្យ
សមុទ្រ និងបណ្ដាលដែលនៅក្នុងនោះទាំងប៉ុន្មាន[ខ] បានឮ
កងរំពងឡើង ចូរឱ្យស្រែចំការ និងរបស់ដែលមាននៅ
ទីនោះទាំងប៉ុន្មាន មានសេចក្ដីរីករាយអរសប្បាយផង
៣៣ចូរឱ្យដើមឈើ[គ]នៅព្រៃបញ្ចេញសូរយ៉ាង សប្បាយ
នៅចំពោះព្រះយេហូវ៉ា ដ្បិតទ្រង់យាងមក ដើម្បីជំនុំជំរះ[ឃ]
ផែនដី ៣៤ចូរអរព្រះគុណ[ង]ដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ[ច]
ពីព្រោះសេចក្ដីសប្បុរសនៃទ្រង់នៅអស់កល្បជានិច្ច[ឆ] ៣៥ចូរ
ទូលថា ឱព្រះនៃសេចក្ដីសង្គ្រោះនៃយើងខ្ញុំអើយ[ជ] សូមជួយ
សង្គ្រោះយើងខ្ញុំផង សូមប្រមូលបំប្រួមយើងខ្ញុំ ហើយ
ប្រោសយើងខ្ញុំ ឱ្យរួចពីពួកសាសន៍ដទៃប្រយោជន៍ឱ្យបាន
ពោលពាក្យអរព្រះគុណដល់ព្រះនាមបរិសុទ្ធនៃទ្រង់ ហើយ
មានសេចក្ដីរីករាយ ក្នុងសេចក្ដីសរសើរដំកើងដល់ទ្រង់
៣៦សូមក្រាបថ្វាយបង្គំដល់ព្រះយេហូវ៉ា[ឈ] ជាព្រះនៃសាសន៍
អ៊ីស្រាអែល ចាប់តាំងពីអស់កល្ប ដរាបដល់អស់កល្ប
ជានិច្ច ។
ស្រេចហើយ បណ្ដាជនទាំងអស់គ្នាក៏ទទួលឡើងថា
អាម៉ែន ហើយក៏សរសើរដំកើងដល់ព្រះយេហូវ៉ាដែរ ។
៣៧ដូច្នេះ ដាវីឌទ្រង់ទុកឱ្យអេសាភ នឹងបងប្អូនលោកនៅ
ចំពោះហឹបនៃសេចក្ដីសញ្ញាផងព្រះយេហូវ៉ា ឱ្យបានធ្វើ
ការងារនៅទីនោះតាមដែលត្រូវការ រាល់តែថ្ងៃជានិច្ច[ញ]
៣៨ឯអូបិឌ-អេដំម[ដ] ជាកូនយេឌូថិន និងហូសា[ឋ] ព្រមទាំង
បងប្អូនលោកចំនួន៦៨នាក់ បានតាំងឡើងឱ្យធ្វើជាអ្នកឆ្មាំ
ទ្វារ ៣៩ចំណែកសាដុក[ឌ]ដ៏ជាសង្ឃ នឹងបងប្អូនលោកជាពួក
សង្ឃ បានតាំងឱ្យនៅមុខរោងឧបោសថនៃព្រះយេហូវ៉ា
ដែលនៅលើ ទីខ្ពស់ត្រង់គីបៀន[ឍ] ៤០ដើម្បីនឹងថ្វាយដង្វាយ
ដល់ព្រះយេហូវ៉ា នៅលើអាសនា ដែលសំរាប់ដង្វាយដុត
រាល់ព្រឹករាល់ល្ងាចជានិច្ច តាមគ្រប់ទាំងសេចក្ដី ដែលបាន
ចែងទុកមកក្នុងក្រិត្យវិន័យ[ណ]ព្រះយេហូវ៉ា ដែលទ្រង់បាន
បង្គាប់ដល់ពួកអ៊ីស្រាអែល ៤១មានទាំងហេម៉ាន[ត] និងយេឌូ
ថិននៅជាមួយដែរ ព្រមទាំងពួកអ្នកឯទៀត ដែលបានដំរូវ
ដោយឈ្មោះផង ដើម្បីនឹងអរព្រះគុណដល់ព្រះយេហូវ៉ា
ដោយព្រោះសេចក្ដីសប្បុរសទ្រង់ នៅអស់កល្បជានិច្ច
៤២ហេម៉ាននឹងយេឌូថិននេះ គេមានត្រែ នឹងឈឹងសំរាប់
ពួកអ្នកភ្លេង នឹងប្រដាប់ឯទៀតសំរាប់ប្រកបភ្លេងថ្វាយព្រះ[ថ]
ហើយពួកកូនចៅយេឌូថិន[ទ] គេនៅត្រង់មាត់ទ្វារ ៤៣រួច
បណ្ដាជនក៏វិលទៅផ្ទះកេរៀងខ្លួនទៅ ហើយដាវីឌទ្រង់ក៏
ត្រឡប់ទៅ ដើម្បី ឱ្យពរដល់ពួកវង្សាញាតិរបស់ទ្រង់ ។

## ព្រះមានបន្ទូលសន្យាដល់ស្ដេចដាវីឌ

*១៧:១-១៥ – ២សយ ៧:១-១៧*

**១៧** ១លុះកាលដាវីឌបានគង់នៅក្នុងដំណាក់ទ្រង់ហើយ
នោះទ្រង់ មានបន្ទូលទៅហោរាណាថាន់ថា មើលខ្ញុំនៅក្នុង

**១៦:១៩** ធ ចទ ៧:៧ **១៦:២០** ន លប ២០:១៣ **១៦:២១** ប លប ១២:១៧ ២០:៣ នក ៧:១៥-១៨ ទដ ៩:៥ **១៦:២២** ផ លប ២០:៧ **១៦:២៤** ព អស ៤២:១២ ៦៦:១៩ **១៦:២៥** ភ ទដ ១៨:៣ ៤៨:១ ម ទដ ៧៦:៧ ៨៩:៧ យ នក ១៨:១១ ចទ ៣២:៣៩ ២របា ២:៥ ទដ ១៣៥:៥ អស ៤០:២៥ **១៦:២៦** រ ទដ ៨:៣ ១០២:២៥ **១៦:២៨** ល ទដ ២៩:១-២ **១៦:២៩** វ ទដ ៨:១ ស ២រប ២០:២១ ទដ ២៩:១-២ **១៦:៣០** ហ ទដ ២:១១ ៣៣:៨ ៧៦:៨ ៩៩:១ ១១៤:៧ ឡ ទដ ៩៣:១ **១៦:៣១** អ អស ៤៤:២៣ ៤៩:១៣ ក ទដ ៩:៧ ៤៧:៨ ៩៣:១ ៩៧:១ ៩៩:១ ១៤៦:១០ អស ៥២:៧ បទ ៥:១៩ **១៦:៣២** ខ នក ២០:១១ អស ៤២:១០ **១៦:៣៣** គ អស ១៤:៨ ៥៥:១២ ឃ ១សយ ២:១០ ទដ ៧:៨ ៩៦:១០ ៩៨:៩ ១១០:៦ អស ២:៤

**១៦:៣៤** ង ខ.៨ ទដ ១០៥:១ អស ១២:៤ ច ទដ ២៥:៧ ៣៤:៨ ១០០:៥ ១៣៥:៣ ១៤៥:៩ ណាហ ១:៧ ឆ ២របា ៥:១៣ ៧:៣ អរ ៣:១១ ទដ ១៣៦:១-២៦ យរ ៣៣:១១ **១៦:៣៥** ជ ចទ ៣២:១៥ ទដ ១៨:៤៦ ៣៨:២២ មីក ៧:៧ **១៦:៣៦** ឈ ១ពរ ៨:១៥ ទដ ៧២:១៨-១៩ **១៦:៣៧** ញ ២របា ៨:១៤ **១៦:៣៨** ដ ១របា ១៣:១៣,២៦:៤-៥ ១របា ២៦:១០ **១៦:៣៩** ឋ ១សយ ២:៣៥ ឌ ៨:១៧ ១របា ១២:២៨ យស ៩:៣ ២របា ១:៣ **១៧:១** ក ១របា ១៥:១

**១៦:២៩** *ដោយសិរីលំអនៃសេចក្ដីបរិសុទ្ធ* មើល ២របា ២០:២១ ទដ ២៩:២ ៩៦:៩ ១១០:៣ ។

**១៦:៣៩** *រោងឧបោសថ . . . ត្រង់គីបៀន* រោងឧបោសថបានតម្កល់នៅត្រង់គីបៀនរហូតដល់គ្រាដែលស្ដេចសាឡូម៉ូនបានសាងសង់ព្រះវិហារនៅក្រុងយេរូសាឡិម (មើល ២របា ១:១៣ ៥:៥) ពេលនោះគេបានយករោងឧបោសថទុកក្នុងព្រះវិហារ ។ ការស្ថិតនៅជាអចិន្ត្រៃយ៍នៃទីកន្លែងសសក្ការៈទាំង២នេះ នោះរោងឧបោសថ និងត្រសាលសម្រាប់ដាក់ហឹបនៃសេក្ដីសញ្ញានៅក្នុងក្រុងយេរូសាឡិម (មើល ខ.១)គឺទុកសម្រាប់ពួកសម្ដេចសង្ឃ២នាក់: សាដុកបម្រើនៅត្រង់គីបៀន អ័បៀថើរបម្រើនៅយេរូសាឡិម (១៨:១៦ ២៧:៣៤ ៦:៨) ។

**១៦:៤២** *គេមានត្រែនិងឈឹង* សូមមើល ជន ១០:១-១០ ។

**១៧:១-២៧** សូមមើល ២សយ ៧ ។

**១៧:១,១០** នៅក្នុងខ.ទាំងនេះអ្នកកត់ត្រាពង្សាវតាបានលុបចោលពាក្យដែលបាននិយាយថា ព្រះយេហូវ៉ាទ្រង់បានប្រទានឱ្យដាវីឌមានសេចក្ដីសម្រាករួច

ដំណាក់ធ្វើពីឈើតាត្រៅ តែឯហឹបនៃសេចក្តីសញ្ញាផង
ព្រះយេហូវ៉ា មានតែសំពត់បាំងប៉ុណ្ណោះ[ក] ២ដូច្នេះណាថាន់
ទូលថា សូមទ្រង់ធ្វើតាមគ្រប់ទាំងសេចក្តីប្រាថ្នាដែលនៅ
ក្នុងព្រះទ័យចុះ[ខ] ដ្បិតព្រះទ្រង់គង់ជាមួយនឹងទ្រង់ហើយ ៣តែ
នៅវេលាយប់នោះឯង ព្រះបន្ទូលនៃព្រះបានមកដល់
ណាថាន់ថា ៤ចូរទៅប្រាប់ដល់ដាវីឌ ជាអ្នកបំរើអញថា
ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ មិនត្រូវឱ្យឯង[គ]ស្អាង
ព្រះវិហារឱ្យអញបាននៅនោះឡើយ ៥ដ្បិតតាំងពីអញនាំ
សាសន៍អ៊ីស្រាអែលឡើងមក ដរាបដល់សព្វថ្ងៃនេះ នោះ
អញមិនបាននៅក្នុងព្រះវិហារណាទេ គឺបានទៅពីត្រសាល
១ដល់ត្រសាល១ ហើយពីរោងឧបោសថ១ដល់រោង
ឧបោសថ១ទៀត ៦នៅគ្រប់ទីកន្លែង ដែលអញដើរជាមួយ
នឹងពួកអ៊ីស្រាអែល នោះតើអញដែលនិយាយ១ម៉ាត់នឹងពួក
ចៅហ្វាយនៃសាសន៍អ៊ីស្រាអែលណាមួយ ដែលអញបាន
បង្គាប់ឱ្យឃ្វាលរាស្ត្រអញថា ហេតុអ្វីបានជាឯងមិនបាន
ស្អាងព្រះវិហារ ពីឈើតាត្រៅឱ្យអញឬទេ[ឃ] ៧ដូច្នេះ
ត្រូវឱ្យឯងនិយាយ នឹងដាវីឌ ជាអ្នកបំរើអញថាព្រះយេហូវ៉ា
នៃពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះ អញបានយកឯង
ពីក្រោលសត្វ គឺពីការឃ្វាលហ្វូងចៀមមក ឱ្យធ្វើជាអ្នកនាំ
មុខ[ង]សាសន៍អ៊ីស្រាអែលជារាស្ត្រអញ ៨អញបាននៅជា
មួយនឹងឯង នៅគ្រប់ទីកន្លែងណា ដែលឯងបានទៅដែរ
ក៏បានដកពួកខ្មាំងសត្រូវទាំងអស់ពីមុខឯងចេញ ហើយ
បានលើកឈ្មោះឯងជាធំ ដូចជាឈ្មោះនៃអស់អ្នកធំ ដែល
នៅផែនដី ៩អញបានដំរូវ ឱ្យពួកអ៊ីស្រាអែល ជារាស្ត្រអញ
មានទីលំនៅ ដើម្បីឱ្យគេបាននៅជាប់ក្នុង ស្រុករបស់ផង
គេ ឥតដែលត្រូវរើទៅឯណាទៀតពួកខូចអាក្រក់នឹងមិន
ពង្រេចពង្រើលគេ ដូចកាលពីមុន ១០គឺដូចជាគ្រាកាលចាប់
តាំងពីថ្ងៃ ដែលអញបានតាំងពួកចៅហ្វាយ ឱ្យគ្រប់គ្រងលើ
អ៊ីស្រាអែល ជារាស្ត្រអញនោះឡើយ អញបានបង្ក្រាប់អស់
ទាំងខ្មាំងសត្រូវឯងហើយ (មួយទៀតទូលបង្គំក្រាបទូលថា
ព្រះយេហូវ៉ាទ្រង់នឹងតាំងព្រះវង្សាទ្រង់ឡើង) ១១កាលណា
ឯងបានរស់នៅគ្រប់កំណត់អាយុហើយ នៅខណៈដែលឯង
ត្រូវទៅជួបជុំនឹងពួកឰយុកោឯង នោះអញនឹងតាំងពូជពង្ស
ឯងឡើង គឺជាម្នាក់ក្នុងពួកកូនឯង ហើយនឹងតាំងរាជ្យរបស់
អ្នកនោះ ឱ្យខ្ជាប់ខ្ជួនឡើង ១២អ្នកនោះនឹងស្អាងព្រះវិហារ១
ឱ្យអញ ហើយអញនឹងប្រោសឱ្យរាជ្យអ្នកនោះបានស្ថិតស្ថេរ
នៅ ជារៀងរាបដរាបទៅ ១៣អញនឹងធ្វើជាឪពុកដល់អ្នក
នោះ ហើយអ្នកនោះនឹងធ្វើជាកូនរបស់អញ អញមិនដែល
ដកសេចក្តីសប្បុរសរបស់អញ ចេញពីអ្នកនោះ ដូចជាបាន
ដកចេញពីអ្នក ដែលនៅមុខឯងនោះឡើយ ១៤គឺនឹងតាំងអ្នក
នោះ នៅក្នុងព្រះវិហារ ហើយក្នុងនគររបស់អញ ឱ្យនៅជា
ដរាប ហើយរាជ្យអ្នកនោះនឹងបាននៅជាប់ ជារៀងរាប
ដរាបទៅ ១៥ណាថាន់ក៏ទូលដល់ដាវីឌ តាមគ្រប់ទាំងព្រះ
បន្ទូលនេះ ហើយតាម ការជាក់ស្តែងនេះគ្រប់ជំពូក ។
១៦ដូច្នេះ ស្តេចដាវីឌទ្រង់ចូលទៅគង់នៅចំពោះព្រះ

**១៧:២** ខ ១រប ២២:១៧,២៨:២ ២រប ៦:៧
**១៧:៤** គ ១រប ២២:១០,២៨:៣
**១៧:៦** ឃ ១រប ១៤:១
**១៧:៧** ញ ២សយ ៦:១២
**១៧:១០** ពច ២:១៦
**១៧:១២** ១សយ ៥:៥ ១រប ២២:១០ ២រប ៧:១៨ ១៣:៥
**១៧:១៣** ២កថ ៦:១៨ ១រប ២៨:៦ លក ១:៣២ ពហ ១:៥
**១៧:១៤** ១សយ ២:១២ ១រប ២៨:៥ ២៩:២៣ ២ថប ៩:៨ ទដ ១៣២:១១ យរ៣៣:១៧

ពីខ្មាំងសត្រូវគ្រប់ទិសទី (សូមមើល ២សយ ៧:១,១១) ។ មានកត្តាជាច្រើនដែលបណ្តាលឱ្យមានការលុបចោលនូវពាក្យទាំងនោះ (១)ដោយសារតែពេលវេលារបស់ដាវីឌដែលត្រូវដម្កើងឡើងបានមកដល់(ជំពូក១៨–២០)។ ជំនួរពង្សាវតាររបស់គេ ត្រូវតែកើតចេញពីការធ្វើសង្គ្រាមរបស់ដាវីឌ (ខ.៨)ប៉ុន្តែអ្នកនិពន្ធ គាត់បានជំនួសវានៅកន្លែងនេះគឺដើម្បីបន្តរពីទំនាក់ទំនងរបស់គាត់ជាមួយហឹបនៃសេចក្តីសញ្ញានិងការកសាងព្រះវិហារ (មើល ខ.៤–៦,១២) ។ (២)អ្នកកត់ត្រាពង្សាវតារក៏បានបង្ហាញថា ស្ទើរតែ១ជីវិតរបស់ដាវីឌគាត់គឺជាអ្នកធ្វើសង្គ្រាម(សូមមើល ២២:៦៨) ដែលផ្ទុយពីសាឡូម៉ូនដែលគាត់ជាមនុស្សនៃ"សន្តិភាពនិងសម្រាក"(មើល ២២:៩) មិនតែប៉ុណ្ណោះសោធសាឡូម៉ូនគឺជាម្នាក់ដែលនឹងត្រូវកសាងព្រះវិហារថ្វាយព្រះយេហូវ៉ា(មើល ២២:១០) ។ សម្រាប់អ្នកកត់ត្រាពង្សាវតារវិញគិតថាដាវីឌគាត់បានសម្រាកពីខ្មាំងសត្រូវនៅពេលដែលគាត់មានវ័យចំណាស់ទៅហើយ (មើល ២២:១៨) ។ (៣)តាមរយៈទំនាក់ទំនងខ្លះៗរបស់គាត់ដែលដូចគ្នានឹងដាវីឌ សាឡូម៉ូនជាមួយម៉ូសេ និងយ៉ូស្វេនោះសាឡូម៉ូន (ដូចជាលោកយ៉ូស្វេ) គាត់ជាអ្នកនាំឱ្យបណ្តាជនបានសម្រាកពីខ្មាំងសត្រូវគ្រប់ទិសទី (សូមមើលសេចក្តីផ្តើម ការពិពណ៌នាអំពី ដាវីឌ និងសាឡូម៉ូន) ។

**១៧:១២–១៤** ទោះបីជាបរិបទនៅកន្លែងនេះនិយាយសំដៅលើសាឡូម៉ូនក៏ដោយ ប៉ុន្តែនៅក្នុងសញ្ញាថ្មីវិញគឺសំដៅលើព្រះយេស៊ូវគ្រីស្ទ(សូមមើល មក ១:១១ លក ១:៣២–៣៣ ហប ១:៥) ។

**១៧:១៣** អ្នកកត់ត្រាពង្សាវតារបានលុបចោលនូវពាក្យនៃការព្រមានរបស់គាត់ដែលបាននិយាយថា "វាយនឹងដំបង" និង "ស្នាមរំពាត់" ដែលជាវិន័យសម្រាប់សាឡូម៉ូន ។ ការលុបបំបាត់នេះបានបង្ហាញពីគំនិតដែលគាត់បានគិតចំពោះសាឡូម៉ូនថា ជាពូជពង្សនៃព្រះមែស៊ីដែលមិនសមនឹងទទួលនូវការព្រមានឡើយ(សូមមើលសេចក្តីផ្តើមៈការពិពណ៌នា ដាវីឌ និងសាឡូម៉ូន) ។

**១៧:១៤** អ្នកកត់ត្រាពង្សាវតាបានណែនាំពីទំនាក់ទំនងផ្ទាល់ខ្លួនរបស់គាត់តាមរយៈប្តូរនូវរបៀបនៃការនិយាយរបស់គាត់ (មើល ២សយ ៧:១៦) ដោយជំនួសពាក្យ"ពង្សានិងរាជ្យរបស់ឯង"មកពាក្យ"នៅក្នុងវិហារហើយក្នុងនគររបស់អញ" ។ គេក៏អាចរកឃើញនូវរបប់រាជាធិបតេយ្យ (ការគ្រប់គ្រងរបស់ព្រះ) ជាច្រើនទៀតនៅក្នុងអត្ថបទផ្សេងៗទៀតដែរ ដែលមាននៅក្នុងគម្ពីរ របាក្សត្រនេះ (សូមមើល ២៨:៥–៦ ២៩:២៣ ២រប ១:១១ ៩:៨ ១៣:៤–៨) ។

**១៧:១៦** *គង់* មានការនិយាយប្រហាក់ប្រហែលគ្នាមួយកន្លែងទៀត គឺបាននិយាយក្នុង ២សយ ៧:១៨ ។ អំណះអំណាងតែ១គតនៅក្នុងសញ្ញាចាស់ដែលនិយាយពីការអង្គុយឬគង់គឺនៅក្នុង ១ពវ ១៩:៤ ។

យេហូវ៉ាទូលថា ឱព្រះយេហូវ៉ាដ៏ជាព្រះអើយ តើទូលបង្គំ
ជាអ្វី តើកូនចៅទូលបង្គំជាអ្វី បានជាទ្រង់ប្រោសឱ្យទូលបង្គំ
បានដល់ត្រឹមនេះ ១៧ប៉ុន្តែ ឱព្រះអង្គអើយ នេះជាការយ៉ាង
តូច នៅព្រះនេត្រទ្រង់ទេ បានជាទ្រង់ មានបន្ទូលពីពូជពង្ស
នៃទូលបង្គំ រហូតដល់យូរអង្វែងទៅមុខទៀត ឱព្រះយេហូ
វ៉ាដ៏ជាព្រះអើយ ទ្រង់បានទតមកទូលបង្គំ តាមសណ្ឋាន
មនុស្សជាន់ខ្ពស់ ១៨តើដាវីឌទូលបង្គំនឹងទូលដល់ទ្រង់យ៉ាង
ដូចម្តេច ទៀត ពីកិត្តិយសដែលទ្រង់បានប្រទានមកទូលបង្គំ
ដ្បិតទ្រង់ស្គាល់ទូលបង្គំហើយ ១៩ឱព្រះយេហូវ៉ាអើយ ទ្រង់
បានធ្វើការធំទាំងនេះ ដោយយល់ដល់ទូលបង្គំ ហើយតាម
បំណងព្រះហឫទ័យទ្រង់ ដើម្បីនឹងសំដែង ឱ្យស្គាល់អស់
ទាំងការដ៏ធំទាំងនេះ ២០ឱព្រះយេហូវ៉ាអើយ គ្មានព្រះឯណា
ឱ្យដូចទ្រង់ឡើយ ហើយតាមគ្រប់ទាំងសេចក្តី ដែល
ត្រចៀកទូលបង្គំរាល់គ្នាបានឮនោះក៏គ្មានព្រះឯណាក្រៅពី
ទ្រង់ដែរ ២១តើមានសាសន៍ឯណាមួយ នៅផែនដី ឱ្យដូច
អ៊ីស្រាអែល ជារាស្ត្ររបស់ផងទ្រង់នេះ ដែលព្រះបានយាង
ទៅប្រោសលោះ ទុកជារាស្ត្ររបស់ទ្រង់ ដើម្បីឱ្យបានល្បី
ព្រះនាម ដោយការយ៉ាងធំហើយគួរស្ញែងខ្លាច ដោយ
បណ្តេញសាសន៍ដទៃ ពីមុខរាស្ត្រទ្រង់ចេញ ជារាស្ត្រ ដែល
ទ្រង់បានលោះពីស្រុកអេស៊ីព្ទមកដូច្នេះ ២២ដ្បិតទ្រង់បាន
យកអ៊ីស្រាអែល ជារាស្ត្រទ្រង់ ធ្វើជារបស់ផងទ្រង់ នៅជា
រៀងរាបដរាបទៅហើយ ឱព្រះយេហូវ៉ាអើយ ទ្រង់ក៏បាន
ត្រឡប់ជាព្រះដល់គេដែរ ២៣ឥឡូវនេះ ឱព្រះយេហូវ៉ាអើយ
សូមឱ្យសេចក្តីដែលទ្រង់បានមានបន្ទូល ពីដំណើរទូលបង្គំ
នឹងពីពូជពង្សរបស់ទូលបង្គំ បានជាប់នៅជាដរាបតទៅ
ហើយសូមទ្រង់សំរេច ដូចជាទ្រង់បានមានបន្ទូលនោះ
២៤សូមឱ្យសេចក្តីនោះបានតាំងឡើង ដើម្បីឱ្យព្រះនាមទ្រង់
បានដំកើងឡើងជាដរាប ដោយពាក្យថា ព្រះយេហូវ៉ានៃ
ពួកពលបរិវារ ទ្រង់ជាព្រះនៃសាសន៍អ៊ីស្រាអែល គឺជាព្រះ
ដល់ពួកអ៊ីស្រាអែល ហើយពូជពង្សរបស់ដាវីឌ ក៏បានខ្ជាប់
ខ្ជួននៅចំពោះទ្រង់ដែរ ២៥ដ្បិតឱព្រះនៃទូលបង្គំអើយ ទ្រង់
បានសំដែងឱ្យទូលបង្គំដឹងថា ទ្រង់នឹងតាំងវង្សទូលបង្គំឡើង
ហេតុនោះបានជាទូលបង្គំបាននឹកក្នុងចិត្តចង់អធិស្ឋាននៅ
ចំពោះទ្រង់ ២៦ឥឡូវនេះ ឱព្រះយេហូវ៉ាអើយ ទ្រង់ជាព្រះ
ហើយទ្រង់បានមានបន្ទូលសេចក្តីល្អនេះ ដល់ទូលបង្គំ
២៧ឥឡូវនេះ ទ្រង់បានសព្វព្រះហឫទ័យ នឹងប្រទានពរដល់
វង្សរបស់ទូលបង្គំ ឱ្យបាននៅជាប់ចំពោះទ្រង់ជាដរាបទៅ
ដ្បិតឱព្រះយេហូវ៉ាអើយ ទ្រង់បានប្រទានពរហើយ ដូច្នេះ
វង្សទូលបង្គំនឹងបានពរពិតជាដរាបទៅ ។

**១៨** ១ក្រោយនោះមក ដាវីឌទ្រង់វាយបង្ក្រាបពួកភីលីស្ទីន
ហើយក៏ ចាប់យកក្រុងកាថនឹងស្រុកនៅជុំវិញពីកណ្តាប់ដៃ
នៃពួកភីលីស្ទីននោះ ២ទ្រង់ក៏វាយស្រុកម៉ូអាប់ ហើយ
សាសន៍ម៉ូអាប់ គេចំណុះដល់ដាវីឌ ព្រមទាំងបង់សួយអាករ
ផង ។
៣ដាវីឌក៏វាយហាដារេស៊ើរ ជាស្តេចសូបា រហូតដល់
ក្រុងហាម៉ាត ក្នុងគ្រាដែលលោកកំពុងទៅ ដើម្បីតាំង
អំណាចនៅទន្លេអ៊ើប្រាត ៤ដាវីឌទ្រង់ចាប់បានរទេះចំបាំង
១ពាន់ នឹងទ័ពសេះ៧ពាន់នាក់ ហើយពលថ្មើរជើង២ម៉ឺន
នាក់របស់ស្តេចនោះ ទ្រង់ក៏កាប់សរសៃកជើង សេះដែល
សំរាប់រទេះចំបាំងទាំងអស់ បានទុកឱ្យល្មមតែទឹមរទេះ
១០០ប៉ុណ្ណោះ ។
៥កាលពួកសាសន៍ស៊ីរី ពីក្រុងដាម៉ាស បានមកជួយហា
ដារេស៊ើរ ជាស្តេចសូបា នោះដាវីឌក៏ប្រហារពួកស៊ីរីនោះ

**១៧:១៩** ២សយ ៧:១៦-១៧ ២រប ២០:៦ អស ៩:៧ ៣៧:៣៥ ៥៥:៣ ២សយ ៧:២៥
**១៧:២០** នក ៨:១០ ៩:១៤ ១៥:១១ អស ៤៤:៦ ៤៦:៩
**១៧:២១** នក ៦:៦
**១៧:២២** នក ១៩:៥-៦
**១៧:២៣** ១សយ ៨:២៥
**១៧:២៧** ទដ ១៦:១១ ២១:៦
**១៨:២** ជន ២១:២៩
**១៨:៣** ១ពវ ១៩:៦
**១៨:៥** ២រប ១៦:៩

**១៧:២១-២២** ការនិយាយទៅដល់គ្រាចាកចេញពីអេស៊ីព្ទ អាចនឹងរំឭកដល់ពួកអ្នកអានរបស់អ្នកកត់ត្រាពង្សាវតារអំពីការចាកចេញដ៏អស្ចារ្យលើកទី២ គឺជាការដោះលែងឱ្យមានសេរីភាពចេញពីពួកបាប៊ីឡូន ។

**១៨:១-២០:៨** សង្គ្រាមរបស់ដាវីឌបានបង្ហាញពីព្រះពររបស់ព្រះអម្ចាស់មកលើរាជ្យរបស់ដាវីឌ ។ ព្រះអម្ចាស់ទ្រង់បាននឹកចាំពីសេចក្តីសន្យារបស់ទ្រង់ក្នុងការបង្ក្រាបពួកខ្មាំងសត្រូវរបស់ស្តេចដាវីឌ (សូមមើល ១៧:១០) ។ ដំណើររឿងនេះក៏មានទំនាក់ទំនងទៅនឹងការអភិវឌ្ឍន៍របស់ហោរាដែលបានជាប់ជាឈ្លើយនៅប្រទេសភីលីស្ទីន ។ ប្រាក់ និងមាសទាំងប៉ុន្មានរបស់ប្រជាជាតិប្រទេសនោះនឹងនាំយកមកក្រុងយេរូសាឡិម ដែលធនធានរបស់ពួកខ្មាំងសត្រូវទាំងនោះគឺដើម្បីកសាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់ (សូមមើល ១៨:៧-៨,១១ ២២:២-៥,១៤-១៥ ធៀបជាមួយ ហាក ២:១-៩,២០-២៣ សក ២:៧-១៣ ៦:៩-១៥ ១៤:១២-១៤) ។ នៅពេលដែលព្រះរាជសារនៅក្នុងគម្ពីររបាក្សត្រនេះ ដែលបានពណ៌នាពីព្រះពររបស់ព្រះអម្ចាស់មកលើដាវីឌ វាបានពន្យល់ដំណាលគ្នាទៅនឹងសេចក្តីរាយការរបស់អ្នកកាលប្រវត្តិពេលក្រោយទៀត (មើល ២២:៦-៨ ២៨:៣) ដែលថាដាវីឌគាត់មិនអាចសាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់បានឡើយ ពីព្រោះគាត់គឺជាអ្នកចម្បាំង ។

**១៨:១-១៣** សូមមើល ២សយ ៨:១-១៤ ។

**១៨:២** អ្នកកត់ត្រាពង្សាវតារបានលុបចោលការគំរាមកំហែងដ៏យង់ឃ្នងរបស់ពួកម៉ូអាប់ដែលបានកត់ចុះក្នុង ២សយ ៨:២ ។ ប្រហែលជាភាពយង់ឃ្នងបែបនេះអាចធ្វើឱ្យរាជ្យដាវីឌប្រែក្លាយទៅជាស្រអាប់ ។

**១៨:៥** *ពួកសាន៍ស៊ីរី* ពួកគេក៏ជាខ្មាំងសត្រូវរបស់សូលដែរ (១សយ ១៤:៤៧ "ស្រុកសូបា" ។ នៅគ្រានៃស្តេចដាវីឌ ពួកគេបានមករួមរួមគ្នានៅភាគខាងជើង (ស្រុកសូបា) និងភាគខាងត្បូង (ក្រុងបេត-រេហុប ២សយ ១០:៦) ។ ដោយស្ថិតនៅក្រោមការគ្រប់គ្រងពីសំណាក់ហាដារេស៊ើរ ។ ពួកគេប្រឆាំងក្នុងនាមជាបច្ចាមិត្ត របស់អ៊ីស្រាអែលអស់រយៈ២សតវត្សរ៍ រហូតដល់គ្រា

អស់២ម៉ឺន២ពាន់នាក់ ៦រួចទ្រង់តាំងឱ្យមានពួកទាហាន
រក្សាស្រុក នៅស្រុកស៊ីរី ប៉ែកខាងក្រុងដាម៉ាស ហើយពួក
ស៊ីរីក៏ចំណុះដាវីឌ ព្រមទាំងសួយអាករមកថ្វាយផង ព្រះយេ
ហូវ៉ាទ្រង់ប្រោស ឱ្យដាវីឌមានជ័យជំនះនៅគ្រប់ទីកន្លែង
ណាដែលទ្រង់យាងទៅ ៧ដាវីឌក៏យកអស់ទាំងខែលមាស
របស់ពួកទាហាន នៃហាដារេស៊ើរនាំមកឯក្រុងយេរូសា
ឡិម ៨ហើយពីក្រុងបេថាស នឹងក្រុងគូន ជាទីក្រុងរបស់ហា
ដារេស៊ើរ នោះដាវីឌក៏យកលង្ហិនសន្ធឹកដែរ ដែលសាឡូ
ម៉ូនបានប្រើធ្វើសមុទ្រលង្ហិន សសរ នឹងគ្រឿងប្រដាប់
លង្ហិនទាំងប៉ុន្មាន ។
៩កាលថូអ៊ី ជាស្តេចក្រុងហាម៉ាតបានឮថា ដាវីឌបាន
ប្រហារពួកទ័ពរបស់ហាដារេស៊ើរ ជាស្តេចសូបាទាំងអស់
ហើយ ១០នោះលោកក៏ចាត់យ៉ូរ៉ាម ជាបុត្រទ្រង់ ឱ្យទៅគាល់
ស្តេចដាវីឌ ដើម្បីនឹងគំនាប់ ហើយចំរើនពរថ្វាយ ដោយ
ព្រោះទ្រង់បានច្បាំងឈ្នះហាដារេស៊ើរ ដ្បិតហាដារេស៊ើរ
ចេះតែច្បាំងនឹងថូអ៊ីជានិច្ច យ៉ូរ៉ាមក៏នាំយកប្រដាប់មាស
ប្រាក់ នឹងលង្ហិនគ្រប់មុខ ទៅថ្វាយដែរ ១១ស្តេចដាវីឌទ្រង់ក៏
ថ្វាយរបស់ទាំងនោះ ដល់ព្រះយេហូវ៉ាជាមួយនឹងប្រាក់
ហើយមាសទាំងប៉ុន្មាន ដែលទ្រង់បាននាំយកមកពីអស់ទាំង
សាសន៍ដទៃ គឺពីសាសន៍អេដំមសាសន៍ម៉ូអាប់ ពួកកូនចៅ
អាំម៉ូន សាសន៍ភីលីស្ទីន និងសាសន៍អាម៉ាលេក ។
១២ឯអ័ប៊ីសាយ ជាកូនសេរូយ៉ា ក៏ប្រហារពួកសាសន៍
អេដំមអស់១ម៉ឺន៨ពាន់នាក់ នៅត្រង់ច្រកភ្នំអំបិល ១៣ក៏ដាក់
កងទ័ពឱ្យរក្សានៅស្រុកអេដំម ដូច្នេះ ពួកអេដំមទាំងអស់
បានចំណុះដាវីឌ ព្រះយេហូវ៉ាទ្រង់ក៏ប្រោសឱ្យដាវីឌ មាន
ជ័យជំនះ នៅគ្រប់ទីកន្លែងណា ដែលទ្រង់ យាងទៅ ។
១៤ឯដាវីឌ ទ្រង់បានសោយរាជ្យ លើសាសន៍អ៊ីស្រាអែល
ទាំងមូល ហើយក៏សំរេចការទាំងអស់ដល់បណ្តាជនដោយ
យុត្តិធម៌ នឹងសេចក្តីសុចរិត ១៥មានយ៉ូអាប់ ជាកូនសេរូយ៉ា
ធ្វើជាមេត្រួតត្រាលើបណ្តាពលទ័ពទាំងអស់ នឹងយេហូ
សាផាត ជាកូនអ័ហ៊ីលូឌ ធ្វើជាអ្នកកត់ទុកនូវពង្សាវតារ
១៦សាដុក ជាកូនអ័ហ៊ីទូប នឹងអ័ហ៊ីម៉ាលេក ជាកូនអ័
បៀរថើរ ធ្វើជាសង្ឃ សេរ៉ាយ៉ា ជាស្មៀនហ្លួង ១៧បេណា
យ៉ា កូនយេហូយ៉ាដា ធ្វើជាមេលើពួកកេរេធីម ហើយនឹង
ពួកពេលេធីម ហើយបុត្រាទាំងប៉ុន្មានរបស់ដាវីឌ ក៏ធ្វើជា
សេនាបតី ។

## សង្គ្រាមជាមួយពួកអាំម៉ូន

*១៩:១-១៩ – ២សយ ១:១-១៩*

**១៩** ១ក្រោយនោះមក ណាហាស ជាស្តេចពួកកូនចៅ
អាំម៉ូន[ក] ទ្រង់សុគតទៅ ហើយបុត្រាទ្រង់ក៏ឡើងសោយរាជ្យ

**១៨:៨** ១ពវ ៧:២៣ ២របា ៤:២-៥
**១៨:១១** ជន ២៤:១៨ ជន ២៤:២០
**១៨:១២** ១ពវ ១១:១៥
**១៨:១៤** ១ពវ ២៩:២៦ ១ពវ ១១:១
**១៨:១៥** ២សយ ៥:៦-៨
**១៨:១៦** ១ពវ ៦:៨ ១ពវ ២៤:៦
**១៨:១៧** ១សយ ៣០:១៤ ២សយ ១៥:១៨
**១៩:១** ក លប ១៩:៣៨ ពច ១០:១៧-១១:៣៣ ២របា ២០:១-២ សផ ២:៨-១១

ដែលគេបានផ្តួលរំលំពួកអាសស៊ើរក្នុងរយៈពេលដ៏ខ្លីមុនអាណាចក្រខាងជើងដែលត្រូវដួលរលំដែរ (សូមមើល ២ពវ ១៦:៧-៩ ចទ ២៦:៥) ។

**១៨:៨** *ដែលសាឡូម៉ូនបានប្រើធ្វើសមុទ្រលង្ហិន សសរនិងគ្រឿងប្រដាប់លង្ហិនទាំងប៉ុន្មាន* សូមមើល ២របា ៤:២-៥,១៨ ។

**១៨:១២** *អ័ប៊ីសាយ* នៅក្នុង ២សយ ៨:១៣ បាននិយាយថា មានតែដាវីឌប៉ុណ្ណោះ (សូមមើល ១ពវ ១១:១៥-១៦ ទដ ៦០) ។

**១៨:១៥-១៧** មុខងារ និងតួនាទីទាំងប៉ុន្មានរបស់ពួកអ្នកដែលធ្វើការនៅក្នុងដំណាក់ដាវីឌ គឺបានយកគំរូតាមពួកអ្នកដែលបម្រើក្នុងដំណាក់ផារ៉ោន ។

**១៨:១៥** សម្រាប់របៀបដែលយ៉ូអាប់គាត់បានទទួលនូវតួនាទីនៃការត្រួតត្រាលើបណ្តាទ័ព សូមមើល ១១:៤-៦ ២សយ ៥:៦-៨ ។

**១៨:១៦** *សាដុក . . . អ័ប៊ីម៉ាលេកជាកូនអ័បៀរថើរ* សូមមើលការពន្យល់ក្នុង ៦:៨ ១៦:៣៩ ២សយ ៨:១៧ ។

**១៨:១៧** *ពួកកេរីធីមហើយនិងពួកពេលេធីម* គឺជាពួកបរទេសមួយក្រុមដែលធ្វើការស៊ីឈ្នួល ហើយបានទទួលការតែងតាំងឱ្យធ្វើជាអង្គរក្សដ៏ស្មោះត្រង់ (សូមមើល ២សយ ៨:១៨ ២០:២៣ និង ១សយ ៣០:១៤) ។ ពួកគេបានក្លាយជាអ្នកស្មោះត្រង់ចំពោះដាវីឌ នៅក្នុងអំឡុងពេលនៃការបះបោររបស់អាប់សាឡំម (២សយ ១៥:១៨)និងសេបា(សូមមើល ២សយ ២០:៧) ហើយគួកគេក៏ជាអ្នក ដែលបានគាំទ្រចំពោះសាឡូម៉ូនក្នុងការទាស់ប្រឆាំងជាមួយអ័ដូនីយ៉ាដែលជាគូប្រជែងរាជ្យបល្ល័ង្ក (សូមមើល ១ពវ ១:៣៨,៤៤) *សេនាបតី* នៅក្នុងនិទានកថាដើមដំបូងក្នុងចំនុចនេះ គេបានប្រើពាក្យដ៏សាមញ្ញរបស់ភាសាហេព្រើរមួយដែលហៅថា "សង្ឃ" (មានតែក្នុងគម្ពីរអង់គ្លេសប៉ុណ្ណោះឯគម្ពីរខ្មែរបកប្រែចាស់ គឺប្រើពាក្យ"សេនាបតី"សូមមើល ២សយ ៨:១៨) ។ អ្នកកត់ត្រាពង្សាវតារបានប្រើជាពាក្យគួរសមសម្រាប់អ្នកបម្រើសាមញ្ញចំនួសឱ្យពាក្យដែលគេប្រើសម្រាប់សង្ឃ ។ មានហេតុផលសមស្រប២ ដែលបណ្តាលឱ្យអត្ថបទកន្លែងនេះប្រើជាទំរង់ពាក្យសាមញ្ញ (ទី១) មានអ្នកកាត់ស្រាយមួយចំនួនបានយល់ឃើញថានៅទីនេះពួកអ្នកកាលប្បវត្តិបានព្យាយាមថែរក្សាទុកពួកសង្ឃ ដែលជាផ្នែកនៃការទំនាក់ទំនងដ៏ធំរបស់គាត់ជាមួយនិងធម្មរូបសាសនា ក្នុងស្ថាប័នក្នុងគ្រារបស់គាត់ផ្ទាល់ (ទី២) មានការជជែកវែញកញែកផ្សេងទៀតថា ការប្រើប្រាស់ភាសាហេព្រើរក្នុង ២សយ ៨:១៨ គឺអាចមានន័យទូលំទូលាយជាង "សង្ឃ" ហើយអាចប្រើសម្រាប់មន្ត្រីផ្សេងៗទៀត(សូមធៀប ២សយ ២០:២៦ ១ពវ ៤:៥) ។ អ្នកកត់ត្រាពង្សាវតារប្រើពាក្យដែលសមូលគ្នានេះ ពីព្រោះក្នុងសម័យកាលរបស់គាត់ពាក្យជាភាសាហេព្រើរសម្រាប់"សង្ឃ"ត្រូវបានគេប្រើសម្រាប់តែពួកសង្ឃប៉ុណ្ណោះ ។

**១៩:១-២០:៣** អ្នកកត់ត្រាពង្សាវតា បានដកស្រង់ចេញពី ២សយ ១០-១២ (សូមមើលការពន្យល់នៅទីនោះ)ជាផ្នែកមួយដែលអ្នកកត់ត្រាពង្សាវតារបានបំពេញលើការលុបបំបាត់ផ្ទៃរឿងនៃអំពើបាបរបស់ដាវីឌជាមួយនាងបេតសេបា(មើល ១១:២ ១២:៣) ។ ពួកសាសន៍អាំម៉ូនគឺជាសត្រូវសួរពូជរបស់អ៊ីស្រាអែល (សូមមើល ២របា ២០:១-២,២៣ ២៧:៥ ពច ៣:១៣ យរ ៤៩:១-៦ សផ ២:៨-១១) ។ ក្នុងអំឡុងពេលអ៊ីស្រាអែលជាប់ជាឈ្លើយនៅ

ជិន្នួស [២]នោះដាវីឌទ្រង់ព្រះដំរិះថា អញនឹងសំដែងសេចក្តី
សប្បុរសដល់ហានូនជាកូនណាហាស ដ្បិតឪពុកបានសំដែង
សេចក្តីសប្បុរសដល់អញដែរ ដូច្នេះដាវីឌក៏ចាត់ពួករាជទូត
ឱ្យទៅជួយកំសាន្តទុកទ្រង់ ពីដំណើរបិតាសុគត ពួករាជទូត
របស់ដាវីឌ ក៏ចូលទៅក្នុងស្រុករបស់ពួកកូនចៅអាំម៉ូន ដល់
ហានូន ដើម្បីជួយកំសាន្តទុកទ្រង់ [៣]ប៉ុន្តែពួកមេរបស់កូន
ចៅអាំម៉ូនទូលដល់ហានូនថា ទ្រង់ជឿថា ដាវីឌចង់លើកមុខ
បិតាទ្រង់ ដោយចាត់ពួកនេះមកជួយកំសាន្តទុក្ខទ្រង់ឬអី
ដែលពួកទូតនេះបានមកឯទ្រង់ដូច្នេះ គឺដើម្បីតែនឹងឈ្លប
លប ហើយសង្កេតមើល[ខ]ស្រុកប៉ុណ្ណោះ រួចបំផ្លាញវិញទេ
តើ [៤]ដូច្នេះ ហានូនក៏ចាប់ពួកទូតរបស់ដាវីឌមកកោរ ហើយ
កាត់អាវគេផ្តាច់ផ្នែកខាងក្រោម នៅត្រឹមគូថ រួចលែងឱ្យ
ទៅវិញ [៥]មានមនុស្សមកទូលដល់ដាវីឌ ពីការដែលគេ
ប្រព្រឹត្តនឹងពួកទូតទាំងនោះ ដូច្នេះ ទ្រង់ចាត់មនុស្សឱ្យទៅ
ទទួល ដ្បិតគេមានសេចក្តីខ្មាសណាស់ ហើយស្តេចទ្រង់មាន
បន្ទូលថា ចូរស្នាក់នៅក្រុងយេរីខូរសិនចុះ ចាំទំរាំពុកចង្កា
បានដុះជាថ្មីឡើង រួចសឹមត្រឡប់មកវិញ ។

[៦]លុះកាលពួកកូនចៅអាំម៉ូនឃើញថា គេបាននាំឱ្យដាវីឌ
ខ្ពើម[គ]ដល់ខ្លួនហើយ នោះហានូន នឹងពួកកូនចៅអាំម៉ូន ក៏
ផ្ញើប្រាក់១ពាន់ហាប ទៅជួលរទេះចំបាំង នឹងទ័ពសេះ
ពីស្រុកមេសូប៉ូតាមា ស្រុកស៊ីរី–ម្អាកា និងពីស្រុកសូបាមក
ជួយ[ឃ] [៧]យ៉ាងនោះ គេជួលបានរទេះ៣ម៉ឺន២ពាន់ ព្រមទាំង
ស្តេចស្រុកម្អាកា និងបណ្តារាស្ត្ររបស់ទ្រង់ផង ពួកទាំង
នោះក៏មកបោះទ័ព នៅមុខក្រុងមេឌីបា[ង] ឯពួកកូនចៅអាំម៉ូន
ក៏ចេញពីទីក្រុងខ្លួនទាំងប៉ុន្មាន មូលមកច្បាំង [៨]កាលដាវីឌ
បានជ្រាប នោះទ្រង់ចាត់យ៉ូអាប់ និងពួកពលទ័ពខ្លាំងពូកែ
ទាំងអស់ឱ្យចេញទៅ [៩]ពួកកូនចៅ អាំម៉ូនក៏ចេញមកត្រៀម
ពល នៅត្រង់មាត់ទ្វារក្រុងដើម្បីច្បាំង ហើយពួកស្តេច
ដែលមកជួយគេ ក៏នៅឯវាលដោយខ្លួន ។

[១០]រីឯយ៉ូអាប់ កាលឃើញថា គេឡោមច្បាំងនឹងលោក
ពីខាងមុខខាងក្រោយដូច្នេះ នោះលោកក៏យកពួកជ្រើស
រើស ក្នុងពួកអ៊ីស្រាអែល ដាក់ឱ្យដំរៀបគ្នាតនឹងពួកស៊ីរី

**១៩:៣** ខ ជន ២១:៣២
**១៩:៦** គ លប ៣៤:៣០ ឃ ១រប ១៨:៣
**១៩:៧** ឃ ជន ២១:៣០
**១៩:១១** ង ១សយ ២៦:៦
**១៩:១៧** ច ១រប ៩:១

[១១]ឯបណ្តាទ័ពដែលសល់ នោះក៏ប្រគល់ទៅក្នុងអំណាច
អ័ប៊ីសាយ[ច]ជាប្អូន ហើយគេក៏ដំរៀបគ្នាតនឹងពួកកូនចៅ
អាំម៉ូន [១២]លោកប្រាប់ថា បើសិនជាពួកស៊ីរីមានកំឡាំង
ហួសពេក អញឈ្នះគេមិនបាន នោះចូរឯងមកជួយអញផង
បើពួកកូនចៅអាំម៉ូនមានកំឡាំងហួសពេក ឯងឈ្នះគេមិន
បាន នោះអញនឹងទៅជួយឯងវិញ [១៣]ចូរយើងមានចិត្តក្លា
ហានឡើង ហើយមានកំឡាំងចុះ ដោយព្រោះសាសន៍យើង
នឹងទីក្រុងរបស់ព្រះនៃយើងផង សូមព្រះយេហូវ៉ាទ្រង់
សំរេចសេចក្តីតាមព្រះហឫទ័យទ្រង់ចុះ [១៤]ដូច្នេះ យ៉ូអាប់
នឹងពួកពលដែលនៅជាមួយ ក៏ចូលទៅតស៊ូនឹងពួកស៊ីរី
ហើយគេបាក់ទ័ពរត់ពីមុខលោកចេញទៅ [១៥]កាលពួកកូន
ចៅអាំម៉ូនឃើញថា ពួកស៊ីរីបានបាក់ទ័ពហើយ នោះគេក៏
រត់ពីមុខអ័ប៊ីសាយ ជាប្អូនយ៉ូអាប់ដែរ នាំគ្នាចូលទៅក្នុង
ទីក្រុង រួចយ៉ូអាប់ក៏ត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ ។

[១៦]កាលពួកស៊ីរីឃើញថា បានចាញ់ពួកអ៊ីស្រាអែល
ហើយ នោះក៏ចាត់ទូត ឱ្យទៅអង្វរបានពួកស៊ីរី ដែលនៅ
ខាងនាយទន្លេ នាំចេញមកជួយ មានសូបាក ជាមេទ័ពរបស់
ហាដារេស៊ើរ [១៧]កាលដាវីឌទ្រង់បានជ្រាប នោះទ្រង់
ប្រមូលពួកទ័ពអ៊ីស្រាអែល[ឆ]ទាំងអស់ឆ្លងទន្លេយ័រដាន់ទៅ
ប្រទះនឹងគេ ហើយក៏ដំរៀបគ្នាច្បាំងកាលដាវីឌបានដំរៀប
ទ័ព ច្បាំងនឹងពួកស៊ីរីដូច្នេះ នោះគេក៏តនឹងទ្រង់ [១៨]តែពួក
ស៊ីរីគេបាក់ទ័ព រត់ពីពួកអ៊ីស្រាអែលចេញទៅ ហើយដាវីឌ
បានសំឡាប់ពួកទ័ពស៊ីរី ដែលនៅរទេះចំបាំងអស់៧នាក់
នឹងពលថ្មើរជើង៤ម៉ឺននាក់ ក៏សំឡាប់សូបាក ជាមេទ័ពដែរ
[១៩]កាលពួកពលទ័ពរបស់ហាដារេស៊ើរ បានឃើញថា គេ
ចាញ់ពួកអ៊ីស្រាអែលហើយ នោះក៏តាំងមេត្រីនឹងដាវីឌ
ហើយចំណុះទ្រង់ ដូច្នេះ ពួកស៊ីរីមិនព្រមជួយពួកកូនចៅ
អាំម៉ូនទៀតឡើយ ។

## ការកាន់កាប់ក្រុងរ៉ាបា

*២០:១–៣–២សយ ១១:១ ១២:២៩–៣១*

**២០** [១]ដល់១ខួបក្រោយមក ក្នុងរដូវដែលល្មមឱ្យស្តេច

**២០:១** ក ចទ ៣:១១ខ អម ១:១៣–១៥

ក្រុងបាប៊ីឡូនជាពេលដែលថូប៊ីយាជាសាសន៍អាំម៉ូនបង្ករបញ្ហាដល់ក្រុង
យេរូសាឡិម(សូមមើល នហ ២:១៩ ៤:៣ ៧ ៦:១,១២,១៤ ១៣២:៤–៩) ។

**១៩:១** *ណាហាស* ដូចគ្នានឹងសត្រូវសួរពូជរបស់សូលដែរ (សូមមើល ១សយ
១១:១)ឬអាចជាកូនចៅរបស់គេតែម្តង ។

**១៩:៦** *ស្រុកមេសូប៉ូតាមា ស្រុកស៊ីរី–ម្អាកានិងពីស្រុកសូបា* សូមមើល ២សយ
១០:៦ នៅកន្លែងនោះក៏មាននិយាយពីស្រុកបេត–រេហុប និងស្រុកថូបថែម
ពីលើនេះទៀត ។ ស្រុកទាំងនោះស្ថិតនៅខាងជើងប្រទេសអ៊ីស្រាអែល ។

**១៩:៧** *ក្រុងមេឌីបា* ជាក្រុងដែលស្ថិតនៅស្រុកម៉ូអាប់ ហើយប្រហែលស្ថិតនៅ
ក្រោមការគ្រប់គ្រងរបស់ពួកអាំម៉ូន ។

**១៩:៩** *ក្រុង* ស្ថិតនៅកណ្តាលទីក្រុង ដែលមានឈ្មោះថា រ៉ាបាតដែលលោក
យ៉ូអាប់បានឡោមព័ទនៅឆ្នាំបន្ទាប់ទៀត (មើល ២០:១–៣) ។

**១៩:១៨** *៧ពាន់* នៅក្នុង ២សយ ១០:១៨ បានថាមានត្រឹមតែ៧រយនាក់
ប៉ុណ្ណោះ ដូច្នេះនៅទីនេះប្រហែលជាកំហុសឆ្គងរបស់អ្នកកត់ត្រា ។

**២០:១** *ក្នុងរដូវដែលល្មមឱ្យស្តេចទាំងប៉ុន្មាន ចេញទៅច្បាំងបាន* គឺនៅក្នុង

ទាំងប៉ុន្មាន ចេញទៅច្បាំងបាន នោះយ៉ូអាប់លោកនាំ
ពលទ័ព ចេញទៅបំផ្លាញស្រុករបស់ពួកកូនចៅអាំម៉ូន
ក៏ឡោមព័ទ្ធច្បាំងនឹងក្រុងរ៉ាបាត[ក] តែដាវីឌទ្រង់គង់នៅ
ឯក្រុងយេរូសាឡិមវិញ យ៉ូអាប់ក៏ច្បាំងឈ្នះក្រុងរ៉ាបាត
នោះ[ខ] ២ឯដាវីឌ ទ្រង់យកមកុដ ពីព្រះសិរស្តេចរបស់គេ
មកថ្លឹងមើល ឃើញមានទំងន់ជាមាស១ហាប ក៏មានដាំត្បូង
មានដំឡៃផង ហើយគេបំពាក់ថ្វាយទ្រង់វិញ ទ្រង់ក៏យក
របឹបពីទីក្រុងនោះមកយ៉ាងសន្ធឹកដែរ ៣រួចនាំពួកដែលនៅ
ក្រុងនោះ ចេញមកដាក់ឱ្យកាប់រំលំ ហើយអារឈើព្រម
ទាំងភ្ជួររាស់ផង[គ] ទ្រង់ក៏ធ្វើយ៉ាងនោះដល់អស់ទាំងទីក្រុង
របស់ពួកកូនចៅអាំម៉ូនដែរ រួចទ្រង់នឹងពួកទ័ពទាំងប៉ុន្មាន
ក៏ត្រឡប់ ទៅឯក្រុងយេរូសាឡិមវិញ ។

## សង្គ្រាមជាមួយពួកភីលីស្ទីន

*២០:៤–៨ – ២សយ ២១:១៥–២២*

៤ក្រោយនោះមក ក៏កើតមានចំបាំងនឹងពួកភីលីស្ទីននៅ
ត្រង់ក្រុងកេសើរ[ឃ] នៅគ្រានោះ ស៊ីបាកាយ ជាពូជហ៊ូសាយ
គាត់បានសំឡាប់ស៊ីផាយ ជាកូននៃម្នាក់នោះ[ង] ដែលមាន
មាឌធំបង់ ហើយគេត្រូវចុះចូល ៥ក៏កើតមានចំបាំងនឹង
ពួកភីលីស្ទីនម្តងទៀត នោះអែលហាណាន ជាកូនយ៉ាអ៊ារ
គាត់សំឡាប់ឡាមី ជាប្អូនកូលីយ៉ាត ជាអ្នកក្រុងកាថទៅ ឯ
ដងលំពែងរបស់អ្នកនោះ មានទំហំប៉ុនផ្សឹដំបាញ[ច] ៦ហើយ
កើតមានចំបាំង នៅក្រុងកាថទៀត នៅទីនោះមានមនុស្ស
មានមាឌធំណាស់ មានម្រាម២៤ គឺម្រាមដៃ៦ទាំងសងខាង
នឹងម្រាមជើង៦ទាំងសងខាងដែរ ជាអ្នកកើពីពូជមនុស្ស
មានមានឌធំ ៧កាលវាបានប្រកួតនឹងសាសន៍អ៊ីស្រាអែល
នោះយ៉ូណាថាន ជាកូនសាំម៉ា ជេដ្ឋាដាវីឌ ក៏សំឡាប់វា បង់
៨អ្នកទាំងនោះសុទ្ធតែជាពូជមនុស្សមានមាឌធំ ដែលនៅ
ក្រុងកាថ ហើយក៏ស្លាប់ដោយព្រះហស្តដាវីឌ និងដៃនៃពួក
ទ័ពទ្រង់ទៅ ។

## ស្តេចដាវីឌរាប់ចំនួនពួកចម្បាំង

*២១:១–២៦ – ២សយ ២៤:១–២៥*

**២១** ១គ្រានោះ សាតាំង[ក]ក៏ឈរឡើង ទាស់នឹងពួកអ៊ីស្រា–
អែល បណ្តាលឱ្យដាវីឌរាប់ចំនួន[ខ]បណ្តារាស្ត្រទាំងឡាយ
២ដាវីឌទ្រង់មានបន្ទូលទៅយ៉ូអាប់ នឹងពួកជាប្រធានលើ
បណ្តាជនថា ចូរទៅរាប់[គ]ចំនួនសាសន៍អ៊ីស្រាអែល ចាប់
តាំងពីក្រុងបៀរ–សេបា រហូតដល់ក្រុងដាន់ ទៅរួចមក
ប្រាប់យើង ឱ្យបានដឹងចំនួនផង ៣យ៉ូអាប់តបថា សូមឱ្យព្រះ
យេហូវ៉ាចំរើនពួកជនរបស់ទ្រង់ ឱ្យបាន១ជា១០០ភាគ
ឡើង[ឃ] តែបពិត្រព្រះករុណាជាព្រះអម្ចាស់នៃទូលបង្គំ តើ
គេមិនមែនសុទ្ធតែជា អ្នកបំរើរបស់ទ្រង់ព្រះករុណាទេឬអី
ចុះហេតុអ្វីបានជា ទ្រង់ព្រះករុណាបង្គាប់ឱ្យធ្វើការនេះ
ទ្រង់ចង់បណ្តាលឱ្យអ៊ីស្រាអែល មានទោសធ្វើអី ៤ប៉ុន្តែព្រះ
បន្ទូលនៃស្តេចបានឈ្នះវិញ បានជាយ៉ូអាប់លោកបង្គំលា
ចេញទៅ ដើរគ្រប់ក្នុងស្រុកអ៊ីស្រាអែល រួចត្រឡប់មកឯ
ក្រុងយេរូសាឡិមវិញ ៥នោះយ៉ូអាប់ក៏បង្ហាញចំនួននៃជន
ទាំងឡាយដែលបានរាប់នោះថ្វាយដាវីឌ គឺពួកអ៊ីស្រាអែល
ទាំងអស់[ង] ដែលចេះ កាន់ដាវ នោះមាន១លាន១សែននាក់

**២០:៣** គ ចទ ២៩:១១
**២០:៤** ឃ យស ១០:៣៣ ង លប ១៤:៥
**២០:៥** ច ១សយ ១៧:៧
**២១:១** ក ២រប ១៨:២១ ទដ ១០៩:៦ ខ ២រប ១៤:៨ ២៥:៥
**២១:២** គ ១រប ២៧:២៣–២៤
**២១:៣** ឃ ចទ ១:១១ **២១:៥** ង ១រប ៩:១

រដូវចម្រូតដែលប្រជាជនខ្លះបានសម្រាក់ពីការងារកសិកម្ម និងប្រមូលផល
របស់ពួកគេ ។ *រ៉ាបាត* សូមមើលការពន្យល់ក្នុង ១៩:៩ ។

**២០:២–៣** អ្នកកត់ត្រាពង្សាវតាបានធ្វើការប៉ាន់ស្មានថាអ្នកអានទាំងនោះគឺ
មានភាពស្និទ្ធស្នាលជាមួយ ២សយ ១២:២៦–២៩ មិនបានពន្យល់ពីដាវីឌ
ជាអ្នកគង់នៅក្រុងយេរូសាឡិម (ខ.១) មកឯក្រុងរេប៉ាតបានយ៉ាងដូចម្តេច
ឡើយ ។

**២០:៤** *ស៊ីបាកាយ* សូមមើល ១១:២៩ ២៧:១១ ។

**២០:៥** សូមមើល ២សយ ២១:១៩ ។ *មានទំហំប៉ុនផ្សឹដំបាញ* សូមមើល
១១:២៣ ១សយ ១៧:៧ ។

**២០:៦** *មាឌធំ* សូមមើល ២សយ ២១:១៦ ។

**២១:១–២២:១** សូមមើល ២សយ ២៤ ។ ស្ទើរតែទាំងអស់នៃការធ្វើជំរឿន
របស់ដាវីឌគឺមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងនិទានកថានៃព្រះគម្ពីរ
ទាំង២(សាំយូអែល និងរបាក្សត្រ) ។ ផ្នែករឿងនៅក្នុងគម្ពីរសាំយូអែល គឺ
បានចាប់ផ្តើមនិងបញ្ចប់ដោយលើកយករឿងរាវ នៃសេចក្តីក្រោធរបស់
ព្រះអម្ចាស់ទាស់ប្រឆាំងជាមួយពួកអ៊ីស្រាអែលក្នុងអំឡុងគ្រារាជ្យស្តេចដាវីឌ
ដោយសារតែទង្វើរនៃស្តេចរបស់គេ(នៅក្នុងជំពូក ២១ ដោយសារស្តេច
សូល ក្នុងជំពូក ២៤ ទង្វើររបស់ស្តេចដាវីឌ) ។ សូមមើលការពន្យល់ក្នុង
២សយ ២១:១–២៤:២៥ ។

**២១:១** សូមមើល ២សយ ២៤:១ ។ *សាតាំង* សូមមើលអត្ថបទគម្ពីរ យប
១:៦ សក ៣:១ មថ ១៦:២៣ ២កថ ៤:៤ ១ថន ៣:៥ ១យហ ៣:៨ ។

**២១:៤** អ្នកកត់ត្រាពង្សាវតារ បានសង្ខេបបំព្រួញរឿងត្រាចចររបស់យ៉ូអាប់
ដែលមាននៅក្នុង ២សយ ២៤:៤–៨ ។ គាត់មិនបាននិយាយថា ការធ្វើ
ជំរឿននេះមិនចំណាយពេល៩ខែ និង២០ថ្ងៃនោះឡើយ (សូមមើល ២សយ
២៤:៨) ។

**២១:៥** *ពួកអ៊ីស្រាអែលទាំងអស់ . . . ១លាន១សែន ហើយយូដាដែលចេះ
កាន់ដាវនោះមាន៤សែន៧ម៉ឺននាក់* នៅក្នុង ២សយ ២៤:៩ បាននិយាយថា
ពួកអ៊ីស្រាអែលមានចំនួន ៨សែននាក់ ហើយពួកយូដាមាន ៥សែននាក់(អាច
មានត្រឹមតែ៤សែន៧ម៉ឺននាក់) ។ មូលហេតុនៃការនិយាយខុសគ្នានេះមិន
អាចដឹងច្បាស់ឡើយ ប្រហែលវាជាការធ្វើជំរឿននោះមិនមែនស្ថិតនៅក្នុង
ផ្លូវការ ឬមិនទាន់បញ្ចប់ ដែលជាមូលហេតុមួយធ្វើឱ្យមានការពិបាករាប់
ចំនួនពិតប្រាកដ (សូមមើល ខ.៦) ។ ម្យ៉ាងទៀតអាចបណ្តាលមកពីកំហុស
របស់អ្នកដែលចម្លង ។

ហើយពួកយូដាដែល ចេះកាន់ដាវនោះ មាន៤សែន៧ម៉ឺន
នាក់ ៦តែពួកលេវីនឹងពួកបេនយ៉ាមីន លោកមិនបានរាប់ក្នុង
ពួកគេទេ ដ្បិត ព្រះបន្ទូលនៃស្តេចជាទីទំនាស់ចិត្តដល់
យ៉ូអាប់ ៧ហើយព្រះក៏មិនសព្វព្រះហឫទ័យនឹងការនោះ
ដែរ ហេតុដូច្នោះទ្រង់ក៏ប្រហារសាសន៍អ៊ីស្រាអែល ៨ឯ
ដាវីឌទ្រង់ទូលដល់ព្រះថា ទូលបង្គំបានធ្វើបាបមានទំងន់
ណាស់ ដោយធ្វើការនេះ តែឥឡូវនេះ សូមទ្រង់អត់ទោស
ចំពោះការអាក្រក់របស់ទូលបង្គំផង ដ្បិតទូលបង្គំបាន
ប្រព្រឹត្ត ដោយបែបចំកួតណាស់ ។

៩ខណនោះ ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់កាឌ់[ច] ជាអ្នក
មើលឆុត[ឆ]របស់ដាវីឌ ១០ឱ្យចូលទៅប្រាប់ដាវីឌថា ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អញដាក់សេចក្តីទាំង៣នេះ
ឱ្យឯង ចូររើសយក១ចុះ ឱ្យអញបានធ្វើយ៉ាងនោះដល់ឯង
១១កាឌ់ក៏ចូលទៅទូលនឹងដាវីឌថា ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ ចូររើសយក១ចុះ ១២ទោះបើជាសេចក្តីអំណត់
អស់៣ឆ្នាំ[ជ]ឬឱ្យពួកខ្មាំងសត្រូវបំផ្លាញ ក្នុងរវាង៣ខែ កំពុង
ដែលដាវរបស់ពួកខ្មាំងតាមឯងទាន់ ឬជាដាវ[ឈ]នៃព្រះ
យេហូវ៉ា[ញ] នៅរវាង៣ថ្ងៃវិញ គឺជាជំងឺអាសន្នរោគ កើត
ឡើងក្នុងស្រុក និងទេវតានៃព្រះយេហូវ៉ា បំផ្លាញទូទៅអស់
ទាំងដែនស្រុកអ៊ីស្រាអែល ដូច្នេះ សូមពិចារណាឥឡូវ
នេះចុះ តើចង់ឱ្យទូលបង្គំឆ្លើយដល់ព្រះដែលចាត់ ឱ្យទូល
បង្គំមកជាយ៉ាងណា ១៣ដាវីឌទ្រង់មានបន្ទូលទៅកាឌ់ថា
យើងមានសេចក្តីចង្អៀតចិត្តជាខ្លាំង សូមឱ្យយើងធ្លាក់ទៅ
ក្នុងព្រះហស្ត នៃព្រះយេហូវ៉ាវិញចុះ ដ្បិតសេចក្តីមេត្តា
ករុណា[ដ]របស់ទ្រង់ធំណាស់ កុំឱ្យយើងធ្លាក់ទៅក្នុងកណ្តាប់
ដៃនៃមនុស្សឡើយ ១៤ដូច្នេះ ព្រះយេហូវ៉ាទ្រង់ បណ្តាលឱ្យ
មានជំងឺអាសន្នរោគកើតឡើង ក្នុងពួកអ៊ីស្រាអែល ហើយ
ពួកអ៊ីស្រាអែលក៏ដួលស្លាប់អស់៧ម៉ឺននាក់[ឋ] ១៥ព្រះទ្រង់ក៏
ចាត់ទេវតា១[ឌ] ទៅបំផ្លាញក្រុងយេរូសាឡិម[ឍ] តែកាល
ទេវតា នោះហៀបនឹងបំផ្លាញទៅ នោះព្រះយេហូវ៉ាទ្រង់
ទតឃើញ ក៏មានព្រះហឫទ័យរំជួល[ណ]ថយចេញពីការ
អាក្រក់នោះ ហើយមានបន្ទូលទៅទេវតាដែលបំផ្លាញ[ត]ថា

**២១:៩** ច ១សយ ២២:៥ ឆ ១សយ ៩:៩
**២១:១២** ជ ចទ ៣២:២៤ ឈ អគ ៣០:២៥ ញ លប ១៩:១៣
**២១:១៣** ដ ទដ ៦:៤ ៨៦:១៥ ១៣០:៤,៧
**២១:១៤** ឋ ១របា ២៧:២៤
**២១:១៥** ឌ លប ៣២:១ ឍ ទដ ១២៥:២ ណ លប ៦:៦ នក ៣២:១៤ ត លប ១៩:១៣
**២១:១៦** ថ ជណ ១៤:៥ យស ៧:៦
**២១:១៧** ទ ២សយ ៧:៨ ធ យហ ១:១២
**២១:១៨** ន ២របា ៣:១
**២១:២០** ប ពច ៦:១១

ល្មមហើយ ចូរបញ្ឈប់ដៃឥឡូវចុះ ខណនោះ ទេវតានៃព្រះ
យេហូវ៉ាកំពុងតែឈរ នៅជិតលានស្រូវរបស់អ័រ៉ោណា
ជាសាសន៍យេប៊ូស ១៦ដាវីឌទ្រង់ងើបព្រះនេត្រឡើង ឃើញ
ទេវតានៃព្រះយេហូវ៉ាកំពុងឈរ នៅកណ្តាលមេឃ និង
ផែនដី មានដាវហូតជាស្រេចនៅដៃលូកទៅលើក្រុង
យេរូសាឡិម នោះដាវីឌ និងពួកចាស់ទុំដែលស្លៀកសំពត់
ធ្មៃក៏ផ្តួលខ្លួនក្រាបចុះផ្កាប់មុខ[ថ] ១៧ហើយ ដាវីឌទ្រង់ទូលដល់
ព្រះថា គឺទូលបង្គំទេតើ ដែលបង្គាប់ឱ្យរាប់ចំនួនជនទាំង
ឡាយ គឺទូលបង្គំដែលបានធ្វើបាបហើយប្រព្រឹត្តដោយការ
ល្មើស តែពួកចៀមទាំងនេះវិញ[ទ] តើគេបានធ្វើខុសអ្វី ឱព្រះ
យេហូវ៉ា ជាព្រះនៃទូលបង្គំអើយ សូមឱ្យព្រះហស្តទ្រង់បាន
ទាស់នឹងទូលបង្គំ ហើយនឹងពួកវង្សរបស់ទូលបង្គំចុះ[ធ] សូម
កុំឱ្យទាស់នឹងរាស្ត្ររបស់ទ្រង់ ឱ្យគេត្រូវវេទនាឡើយ ។

១៨នោះទេវតានៃព្រះយេហូវ៉ាបង្គាប់ដល់កាឌ់ ឱ្យទៅ
ទូលដាវីឌ ឱ្យទ្រង់ឡើងទៅស្អាងអាសនា១ថ្វាយព្រះយេហូ
វ៉ា ត្រង់លានស្រូវ[ន]របស់អ័រ៉ោណា ជាសាសន៍យេប៊ូស
១៩ដូច្នេះ ដាវីឌក៏ឡើងទៅតា មពាក្យដែលកាឌ់បានទូល
ដោយនូវព្រះនាមព្រះយេហូវ៉ា ២០កាលអ័រ៉ោណាកំពុង
តែបញ្ជាន់ស្រូវ[ប] នោះស្រាប់តែបែរមកឃើញទេវតា ឯកូន
គាត់ទាំង៤នាក់ ដែលនៅជាមួយ ក៏ពួនខ្លួន ២១ហើយកំពុង
ដែលដាវីឌយាងមកឯអ័រ៉ោណា នោះគាត់ក៏ក្រឡេកទៅ
ឃើញ រួចចេញពីទីលានមក ក្រាបផ្កាប់មុខចុះដល់ដីនៅ
ចំពោះដាវីឌ ២២ឯដាវីឌ ទ្រង់មានបន្ទូលនឹងគាត់ថា សូមឱ្យ
ដីទីលាននេះមកយើងចុះ ដើម្បីនឹងស្អាងអាសនា១ថ្វាយ
ព្រះយេហូវ៉ា ចូរលក់ឱ្យយើងពេញថ្លៃចុះ ប្រយោជន៍ ដើម្បី
ឱ្យសេចក្តីវេទនានេះ បានបាត់ចេញពីបណ្តាជនទេ ២៣អ័រ៉ោ
ណាគាត់ទូលតបថា បពិត្រព្រះករុណា សូមទ្រង់ទទួលយក
ចុះ ហើយសូមឱ្យព្រះអម្ចាស់ទ្រង់ធ្វើតាមតែបំណងព្រះទ័យ
ទ្រង់ចុះ មើល ទូលបង្គំក៏ថ្វាយគោ សំរាប់ដង្វាយដុត
ប្រដាប់បញ្ជាន់ស្រូវ សំរាប់ជាឧស នឹងស្រវនេះ សំរាប់
ជាដង្វាយម្សៅផង ទូលបង្គំថ្វាយទាំងអស់ ២៤តែស្តេចដាវីឌ
ទ្រង់មានបន្ទូលនឹងអ័រ៉ោណាថា កុំឡើយគឺយើងចង់ ទិញ

**២១:៦** អ្នកកត់ត្រាពង្សាវតារបានបន្ថែមនូវសេចក្តីពន្យល់ដែលថា យ៉ូអាប់បានលើកលែងដោយមិនធ្វើជំរឿនលើពួកលេវីនិងពួកបេនយ៉ាមីន ។ ការបន្ថែមសេចក្តីពន្យល់នេះ បានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរបស់អ្នកកត់ត្រាពង្សាវតារជាមួយនឹងពួកលេវី ហើយនិងព្រះដែលពួកអ៊ីស្រាអែលថ្វាយបង្គំ រោងឧបោសថដែលស្ថិតនៅត្រង់គីបៀន និងហឹបនៃសេចក្តីសញ្ញាដែលស្ថិតនៅក្រុងយេរ៉ូសាឡិម គឺសុទ្ធតែស្ថិតនៅក្នុងព្រំប្រទល់របស់ពួកកូនចៅបេនយ៉ាមីន ។

**២១:៩** *កាឌ់* គាត់ជាមិត្តសម្លាញ់របស់ដាវីឌជាយូរមកហើយ ។ កាឌ់បាននៅជាមួយដាវីឌក្នុងអំឡុងពេលដែលគាត់បានរត់គេចពីការតាមសម្លាប់របស់ស្តេចសូល (សូមមើល ១សយ ២២:៣–៥ ធៀប ១របា ២៩:២៩ ២របា ២៩:២៥) ។

**២១:១២** *អំណត់អស់៣ឆ្នាំ* សូមមើលការពន្យល់ក្នុង ២សយ ២៤:១៣ ។

**២១:២០–២១** អ្នកកត់ត្រាពង្សាវតារបានធ្វើសេចក្តីរាយការណ៍ដូច្នេះថា អ័រ៉ោណាកំពុងបញ្ជាន់ស្រូវ មើល ២សយ ២៤:២០ មិនបាននិយាយឡើយ ។

ដោយពេញថ្លៃវិញ យើងមិនព្រមយករបស់ឯង ទៅថ្វាយ
ដល់ព្រះយេហូវ៉ា ២៥ដូច្នេះ ដាវីឌក៏ថ្លឹងមាសដ៏ថ្លៃ៦០០រៀល
ឱ្យដល់អ័រ៉ោណា ប្តូរនឹងទីលាន ២៦រួចទ្រង់ស្អាងអាសនា១
ថ្វាយព្រះយេហូវ៉ានៅទីនោះ ក៏ថ្វាយដង្វាយដុតនឹងដង្វាយ
មេត្រី ហើយអំពាវនាវដល់ព្រះយេហូវ៉ា ព្រះទ្រង់ក៏តបពី
ស្ថានសួគ៌មក ដោយភ្លើង[ប]នៅលើអាសនាដង្វាយដុត ២៧ព្រះ
យេហូវ៉ាទ្រង់បង្គាប់ទៅ ហើយទេវតាក៏ស៊កដាវទៅក្នុង
ស្រោមវិញ ។
២៨នៅវេលានោះ កាលដាវីឌឃើញថា ព្រះយេហូវ៉ា
បានមានបន្ទូលតបមកទ្រង់ នៅត្រង់ទីលានរបស់អ័រ៉ោណា
ជាសាសន៍យេប៊ូស ដូច្នេះ នោះទ្រង់ក៏ថ្វាយយញ្ញបូជា នៅ
ទីនោះ ២៩ដ្បិតរោងឧបោសថ នៃព្រះយេហូវ៉ាដែលលោក
ម៉ូសេបានធ្វើនៅទីរហោស្ថាន ហើយអាសនាដង្វាយដុត
នោះនៅលើទីខ្ពស់ត្រង់ក្រុងគីបៀនវិញ[ផ] ៣០ដាវីឌយាង ទៅ
ឯមុខអាសនានោះ ដើម្បីទូលសួរដល់ព្រះមិនបាន ដោយ
ភ័យខ្លាច ដល់ដាវរបស់ទេវតានៃព្រះយេហូវ៉ា ។

**២២** ១ដាវីឌក៏មានបន្ទូលថា នេះគឺជាព្រះវិហារនៃព្រះ
យេហូវ៉ាដ៏ជាព្រះ[ក] ហើយនេះជាអាសនានៃដង្វាយដុត
សំរាប់ពួកអ៊ីស្រាអែលហើយ ។

**២១:២៦** ផ នក ១៩:១៨ ពច ៦:២១
**២១:២៩** ព យស ៩:៣
**២២:១** ក លប ២៨:១៧
**២២:២** ខ នក ១:១១ ចទ ២០:១១ ២របា ៨:១០ អស ៥៦:៦ គ ១ពវ ៥:១៧-១៨ អរ ៣:៧
**២២:៣** ឃ ១ពវ ៧:៤៧ ១របា ២៩:២-៥
**២២:៤** ង ១ពវ ៥:៦
**២២:៥** ច ១ពវ ៣:៧ ១របា ២៩:១ ឆ ២របា ២:៥
**២២:៦** ជ កច ៧:៤៧
**២២:៧** ឈ ១របា ១៧:២ ញ ១ពវ ៨:១៧ ដ ចទ ១២:៥,១១
**២២:៨** ឋ ១ពវ ៥:៣ ឌ ១របា ២៨:៣

## ការរៀបចំសម្រាប់ព្រះវិហារ

២គ្រានោះ ទ្រង់បង្គាប់ ឱ្យប្រមូលពួកសាសន៍ដទៃ[ខ]ទាំង
អំបាលម៉ាន ដែលអាស្រ័យនៅក្នុងស្រុកអ៊ីស្រាអែល ហើយ
ចាត់ជាងឱ្យទៅដាប់ថ្ម[គ] សំរាប់ស្អាងព្រះវិហារនៃព្រះ ៣ទ្រង់
ក៏រៀបចំដែកយ៉ាងសន្ធឹក ដើម្បីធ្វើដែកគោលសំរាប់សន្លឹក
និងក្របទ្វារ ហើយសំរាប់ត្រចៀកទ្វារផង និងលង្ហិនយ៉ាង
សន្ធឹក ដែលថ្លឹងមិនបានដែរ[ឃ] ៤ព្រមទាំងឈើតាត្រៅ[ង]ឥត
គណនា ដ្បិតពួកសាសន៍ស៊ីដូន និងពួកអ្នកក្រុងទីរ៉ុសគេនាំ
ឈើតាត្រៅយ៉ាងសន្ធឹក មកថ្វាយដាវីឌ ៥ហើយទ្រង់មាន
បន្ទូលថា សាឡូម៉ូន បុត្រយើងនៅក្មេងខ្ចី[ច]ពេកណាស់ ហើយ
ព្រះវិហារដែលត្រូវស្អាងថ្វាយ ព្រះយេហូវ៉ានោះត្រូវតែ
បានរុងរឿងយ៉ាងក្រៃលែង ព្រមទាំងមានសិរីល្អ[ឆ] និង
ល្បីឮទួទៅ នៅគ្រប់ទាំងនគរផង ដូច្នេះ យើងនឹងរៀបចំឱ្យ
យ៉ាងនោះដាវីឌក៏ត្រៀមប្រដាប់ទុកជាបរិបូរមុនដែលទ្រង់
អស់ព្រះជន្មទៅ ។
៦រួចមកទ្រង់ហៅសាឡូម៉ូន ជាព្រះរាជបុត្រា មកផ្តាំឱ្យ
ស្អាង[ជ]ព្រះវិហារ ថ្វាយព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ៧ដាវីឌក៏មានបន្ទូលនឹងសាឡូម៉ូនថា កូនអើយ
ក្នុងចិត្តអញមានគំនិត[ឈ]ចង់ស្អាង[ញ]ព្រះវិហារ ថ្វាយដល់ព្រះ
នាម[ដ]ព្រះយេហូវ៉ា ជាព្រះនៃអញហើយ ៨តែព្រះបន្ទូលនៃ

**២១:២៥** *ក៏ថ្លឹងមាសដ៏ថ្លៃ៦០០រៀល* នៅក្នុង ២សយ ២៤: ២៤ បាននិយាយថា ដាវីឌគាត់បានទិញលានស្រូវ និងគោទាំងនោះតម្លៃជាប្រាក់៥០រៀល ។ មានការពន្យល់មូលហេតុនៃការខុសគ្នានេះខ្លះៗថាអ្នកកត់ត្រាប្រវត្តិសាស្ត្រគាត់ចង់លើកតម្កើងកិត្តិយសរបស់ស្តេចដាវីឌនិងព្រះវិហារដោយបំប៉ោងពីតម្លៃនេះ ។ ទោះបីជាយ៉ាងនេះក៏ដោយការនិយាយខុសគ្នាពីតម្លៃនេះគឺវាមានការដូចគ្នាជាច្រើនទៅនឹងពាក្យសម្តីរបស់អ្នកកត់ត្រាពង្សាវតារដែលបាននិយាយថា តម្លៃនេះគឺសម្រាប់"ទីកន្លែង"ឱ.ទីកន្លែងដែលមានទំហំធំជាងទីលានស្រូវនេះ ។

**២១:២៦** *ព្រះទ្រង់ក៏តបពីស្ថានសួគ៌មក ដោយភ្លើងនៅលើអាសានា* គឺជាការគូសបញ្ជាក់ចំពោះព្រះអម្ចាស់ដែលព្រមទទួលយកដង្វាយ និងទីបរិសុទ្ធនេះ (សូមមើល ២របា ៧:១ លវ ៩:២៤ ១ពវ ១៨:៣៧-៣៨) ។

**២១:២៨-២២:១** អ្វីដែលបាននិយាយនៅត្រង់កន្លែងនេះ មិនបាននិយាយនៅក្នុង ២សយ ជំពូក ២៤ ទេ ។ ចំនុចនេះវាបានបង្ហាញពីទំនាក់ទំនងចម្បងរបស់អ្នកកត់ត្រាប្រវត្តិសាស្ត្រក្នុងការធ្វើសេចក្តីរាយការណ៍អំពីនិទានកថានេះ (សូម មើល ២១:១-២២:១) ។

**២១:៣០** *អាសនានោះ* គឺជារោងឧបោសថ ។

**២២:១** ដាវីឌគាត់បានឧទ្ទិសថ្វាយអចលនទ្រព្យនេះ(មើល ២១:១៨-៣០) ទុកសម្រាប់សាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់(មើល ឱ.២-៦ ទដ ៣០) ។

**២២:២-៩** ការតាំងសាឡូម៉ូនទុកជាមុនដើម្បីឱ្យស្នងរាជ្យបន្តពីដាវីឌ គឺមាន ២ដំណាក់កាលៈ(ទី១) គឺធ្វើឡើងជាលក្ខណៈឯកជន ដោយគ្រាន់តែមានដាវីឌ និងពួកចាស់ទុំខ្លះៗប៉ុណ្ណោះដែលបានចូលរួម (សូមមើល ១៧-១៩) (ទី២) ប្រកាសជាសាធារណៈចំពោះបណ្តាជន (មើលជំពូក ២៨)ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងសម័យកាលលោកយ៉ូស្វេបន្តតំណែងពីលោកម៉ូសេដែរ(សូមមើលសេចក្តីផ្តើមៈ ការពិពណ៌នា ពីដាវីឌ និងសាឡូម៉ូន) ។

**២២:២** *សាសន៍ដទៃ . . . ឱ្យទៅដាប់ថ្ម* នៅក្នុង ២សយ ២០:២៤ បានបញ្ជាក់ថាដាវីឌបានបង្ខំពួកជាងឱ្យធ្វើកិច្ចការទាំងនោះ ប៉ុន្តែមិនបានបញ្ជាក់ច្បាស់ថា ពួកជាងទាំងនោះជាសាសន៍ដទៃឡើយ ហើយមិនមែនជាពួកអ៊ីស្រាអែលឡើយ ។ សាឡូម៉ូនគាត់បានកែនពីគ្រប់មនុស្សក្នុងពួកអ៊ីស្រាអែល (សូមមើល ១ពវ ៥:១៣-១៨ ៩:១៥-២៣) ប៉ុន្តែអ្នកកត់ត្រាប្រវត្តិសាស្ត្របែជានិយាយថាជាងទាំងនោះ គឺជាសាសន៍ដទៃ (មើល ២របា ៨:៧-១០) ។ ទោះបីជាពួកគេមានសេរីភាពផ្ទាល់ខ្លួនក៏ដោយ ពួកសាសន៍ដទៃគេគ្មានសិទ្ធធ្វើនយោបាយហើយពួកគេងាយនឹងអបុព្វកិច្ចណាស់ ។ នៅក្នុងសញ្ញាចាស់តែងតែរំឭកថា ពួកគេមិនត្រូវបាននរណាម្នាក់ជិះជាន់ឡើយ(សូមមើល នក ២២:២១ ២៣:៩ លវ ១៩:៣៣ ចទ ២៥:១៤ យរ ៧:៦ សក ៧:១០) ។

**២២:៣** *លង្ហិន* សូមមើល ១៨:៨ ។

**២២:៥** *ក្មេងខ្ចី* អាយុកាលពិតប្រាកដរបស់សាឡូម៉ូនក្នុងសម័យកាលនោះមិនដឹងពិតប្រាកដឡើយ ។ គាត់គ្រងរាជ្យក្នុងឆ្នាំ ៩៧០ មុន គ.ស ដែលមើលទៅហាក់បីដូចជាកើតនៅក្នុងអំឡុងឆ្នាំ៩៩១ មុន គ.ស ។

**២២:៧** *ថ្វាយដល់ព្រះនាមព្រះយេហូវ៉ា* សូមមើល ១ពវ ៣:២ ។

ព្រះយេហូវ៉ាបានមកដល់អញថា ឯងបានកំចាយឈាមជា
ច្រើន ហើយបានច្បាំងចំបាំងយ៉ាងធំ[ឋ] មិនត្រូវឱ្យឯងស្អាង
ព្រះវិហារសំរាប់ឈ្មោះអញទេ[ឌ] ពីព្រោះបានកំចាយឈាម
ជាច្រើន នៅលើផែនដី នៅចំពោះអញ ៩មើល នឹងមានកូន
ប្រុស១កើតដល់ឯង កូននោះនឹងបានជាមនុស្សទំនេរនៅ[ឍ]
ហើយអញនឹងឱ្យវាមានសេចក្តីសំរាក[ណ] ពីពួកខ្មាំងសត្រូវ
នៅជុំវិញ ដ្បិតនឹងមានឈ្មោះថា សាឡូម៉ូន[ត] ហើយ
នៅជំនាន់វា អញនឹងឱ្យពួកអ៊ីស្រាអែលបានសេចក្តីសុខ
សាន្ត[ថ] និងសេចក្តីស្រាកស្រាន្ត
១០កូននោះនឹងស្អាងព្រះ
វិហារសំរាប់ឈ្មោះអញ[ទ]វិញ វានឹងធ្វើជាកូនរបស់អញ[ធ]
អញក៏នឹងធ្វើជាឪពុកដល់វាហើយនឹងតាំងរាជ្យវា លើនគរ
អ៊ីស្រាអែលជាដរាបទៅ
១១ដូច្នេះ កូនអើយ សូមឱ្យព្រះ
យេហូវ៉ាគង់ជាមួយ[ន]នឹងឯង ហើយសូមឱ្យឯងបានចំរើន
ឡើង ដើម្បីស្អាងព្រះវិហារនៃព្រះយេហូវ៉ា ជាព្រះនៃឯង
ដូចជាទ្រង់បានមានបន្ទូលពី ដំណើរឯងហើយ
១២សូមតែ
ឱ្យព្រះយេហូវ៉ា ទ្រង់ប្រទានប្រាជ្ញា នឹងយោបល់ ដល់ឯង[ប]
ហើយបង្គាប់បញ្ជាឯងពីដំណើរសាសន៍អ៊ីស្រាអែល ដើម្បី
ឱ្យឯងបានកាន់តាមក្រិត្យវិន័យរបស់ព្រះយេហូវ៉ា ជាព្រះនៃ
ឯង
១៣យ៉ាងនោះ ឯងនឹងបានចំរើនឡើង[ផ] គឺបើឯងរក្សា
ហើយប្រព្រឹត្តតាមច្បាប់[ព] និងបញ្ញត្តទាំងប៉ុន្មាន ដែលព្រះ
យេហូវ៉ាទ្រង់បានបង្គាប់ដល់លោកម៉ូសេ ពីដំណើរពួក
អ៊ីស្រាអែលជាពិត ចូរឱ្យឯងមានកំឡាំងចុះ ហើយឱ្យចិត្ត
ក្លាហាន[ភ]ដែរ កុំឱ្យខ្លាច ឬរសាយចិត្តឡើយ
១៤ឥឡូវនេះ
មើលក្នុងអស់ទាំងសេចក្តីទុក្ខលំបាករបស់អញ នោះអញ
បានចាត់ចែងទុក ជាមាស១សែនហាប និងប្រាក់១លាន
ហាប ព្រមទាំងលង្ហិន និងដែកដែលថ្លឹងមិនបានផង ដ្បិត
ច្រើនហួសកំណត់ណាស់ ក៏បានចាត់ចែងឈើ និងថ្មដែរ
ហើយឯងនឹងចង់បន្ថែមទៀតក៏បាន[ម]
១៥មួយទៀត មានពួក
ជាងនៅជាមួយនឹងឯងជាបរិបូរដែរ គឺមានជាងដាប់ថ្មជាង
អារឈើ[យ] ហើយគ្រប់ទាំងមនុស្ស ដែលជំនាញ ក្នុងការ
គ្រប់មុខ
១៦ខាងឯមាសប្រាក់ លង្ហិន និងដែក[រ] នោះមាន
ជាច្រើនឥតគណនា ដូច្នេះ ចូរឯងរៀបចំឡើង ចាប់ធ្វើចុះ
សូមឱ្យព្រះយេហូវ៉ាគង់នៅជាមួយនឹងឯងផង ។

១៧ដាវីឌក៏បង្គាប់[ល]ដល់ពួកអ្នក ដែលជាកំពូលរបស់
សាសន៍អ៊ីស្រាអែលដែរ ឱ្យគេត្រូវជួយសាឡូម៉ូន ជាព្រះ
រាជបុត្រាទ្រង់
១៨ដោយបន្ទូលថា តើព្រះយេហូវ៉ា ជាព្រះនៃ
អ្នករាល់គ្នា មិនគង់នៅជាមួយទេឬអី តើទ្រង់មិនបានឱ្យអ្នក
រាល់គ្នាឈប់សំរាក[វ] នៅគ្រប់ទិសដែរទេឬ[ស] ដ្បិតទ្រង់បាន
ប្រគល់ពួកអ្នកស្រុកនេះមកក្នុងកណ្តាប់ដៃយើងហើយ ស្រុក
នេះបានចុះចូលនៅចំពោះព្រះយេហូវ៉ា នឹងពួករាស្ត្ររបស់
ទ្រង់
១៩ដូច្នេះ ចូរអ្នករាល់គ្នាតាំងចិត្ត តាំងព្រលឹង ដើម្បីរក
តាមព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នាចុះ ចូរខំប្រឹងឡើង
ស្អាងទីបរិសុទ្ធផងព្រះយេហូវ៉ាដ៏ជាព្រះ[ហ] ដើម្បីនឹងនាំហឹប
នៃសេចក្តីសញ្ញាផងព្រះយេហូវ៉ា ព្រមទាំងគ្រឿងប្រដាប់
បរិសុទ្ធរបស់ទ្រង់ មកក្នុងព្រះវិហារ ដែលនឹងត្រូវស្អាង
សំរាប់ព្រះនាមទ្រង់ ។

## ពួកលេវី

**២៣** ១រីឯដាវីឌ កាលទ្រង់មានវ័យកន្លង បានស្កប់ស្កល់
នឹងព្រះជន្មទ្រង់ហើយ នោះទ្រង់តាំងសាឡូម៉ូន[ក] ជាព្រះ
រាជបុត្រាឡើង ជាស្តេចលើពួកអ៊ីស្រាអែល[ខ]
២ទ្រង់បាន
ប្រមូលពួកអ្នកដែលជាកំពូលលើសាសន៍ អ៊ីស្រាអែល
ទាំងប៉ុន្មាន ព្រមទាំងពួកសង្ឃ នឹងពួកលេវីមក
៣ឯពួកលេវី
នោះបានរាប់ចាប់តាំងពីអាយុ៣០ឆ្នាំឡើងទៅលើ[គ] ហើយ

**២២:៩** ឋ យស ១៤:១៥ ១បវ ៥:៤ ឌ ខ.១៨ ១រប ២៣:២៥ ២រប ១៤:៦,៧ ១៥:១៥ ២០:៣០ ៣៦:២១ ត ២សយ ១២:២៤ ១រប ២៣:១ ថ ១ពវ ៤:២០ **២២:១០** ទ ១រប ១៧:១២ ធ ២សយ ៧:១៣ ន ១ពវ ៩:៥ ប ២សយ ៧:១៤ ១រប ១៧:៤ ២រប ៦:១៥ **២២:១១** ផ ១សយ ១៦:១៨ ១៨:១២ **២២:១២** ព ១ពវ ៣:៩–១២ **២២:១៣** ភ ១ពវ ២:៣ ម ១រប ២៨:៧ យ ចទ ៣១:៦ **២២:១៤** រ ១រប ២៩:២–៥,១៩ **២២:១៥** ល អរ ៣:៧ **២២:១៦** វ ២រប ២:៧ **២២:១៧** ស ១រប ២៨:១–៦ **២២:១៨** ហ ខ.៩ ឡ ២សយ ៧:១ **២២:១៩** អ ២រប ៧:១៤ **២៣:១** ក ១រប ២២:៩ ២៨:៥ ២រប ១:៨ ខ ១ពវ ១:៣០ ១រប ២៩:២៨ **២៣:៣** គ ជន

**២២:៨–៩** សូមមើលការពន្យល់ក្នុង ១៧:១ ។ នៅក្នុង ១ពវ ៥:៣ សាឡូម៉ូនគាត់បានពន្យល់ថា ដាវីឌជាបិតាទ្រង់មិនអាចនឹងសាងព្រះវិហារថ្វាយព្រះយេហូវ៉ាបានឡើយ ពីព្រោះគាត់មានការរវល់ក្នុងសង្គ្រាម ។ ភាពលាយលំគ្នារបស់អ្នកកត់ត្រាពង្សាវតារគឺមានការខុសគ្នាបន្តិចបន្តួច ។ ដាវីឌគាត់មិនគ្រាន់តែមានការរវល់ក្នុងការធ្វើសង្គ្រាមនោះឡើយ ប៉ុន្តែដាវីឌបានធ្វើឱ្យខ្លួនគាត់ត្រឡប់ជាស្មោគគ្រោកថែមទៀត គឺព្រោះគាត់បានកំចាយឈាម ។

**២២:១០** សូមមើល ១៧:១២–១៤ ។

**២២:១២–១៣** សូមមើលសេក្តីផ្តើមៈ ការពិពណ៌នាដាវីឌ និងសាឡូម៉ូន ។

**២២:១៩** *នាំយកហឹបនៃសេចក្តីសញ្ញា . . . មកក្នុងព្រះវិហារ* សូមមើល ២រប ៥:២–៧ ។

**២៣:១–២៧:៣៤** ការរៀបចំកសាងព្រះវិហាររបស់ដាវីឌ មិនបានដាក់ព្រំដែនដើម្បីប្រមូលធនធានសម្រាប់កសាងព្រះវិហារឡើយ គាត់ក៏បានត្រៀមទុកសម្រាប់កិច្ចការរដ្ឋបាល និងថ្វាយបង្គំព្រះថែមទៀត ។ យោងតាមគម្ពីររបាក្សត្រ (សូមមើល ២២:១–២៩:៣០) ការពិពណ៌នាលំអិតពីកិច្ចការងាររដ្ឋបាលនៃទេវាធិបតេយ្យ(នគរព្រះ)គឺមានទំនាក់ទំនងទៅនឹងជំនាន់របស់អ្នកកត់ត្រាពង្សាវតារ ។

**២៣:១** *តាំងសាឡូម៉ូន ជាព្រះបុត្រាឡើង* ការគ្រងរាជ្យរបស់សាឡូម៉ូននឹងបន្តនិយាយនៅក្នុងជំពូក ២៨–២៩ ។ អ្នកកត់ត្រាពង្សាវតារបានលុបចេញនូវរឿងរាវជម្លោះដណ្តើមរាជបល្ល័ង្គ និងការបង្រួបបង្រួមឡើងវិញដែលបានកត់ចុះក្នុង ១ពវ ជំពូក ១–២ (សូមមើល ២៨:១–២៩:៣០) ។

**២៣:២–៥** ពីព្រោះការមិនធ្វើជំរឿនលើពួកលេវីជាមូលហេតុដែលធ្វើឱ្យព្រះអម្ចាស់ទ្រង់មានសេចក្តីខ្ញាល់និងវាយប្រហារពួកអ៊ីស្រាអែល (សូមមើល ២១:៦–៧) ។

**២៣:៣** *ឯពួកលេវី នោះគេបានរាប់ចាប់តាំងពីអាយុ៣០ឆ្នាំឡើងទៅលើ*

ដែលរាប់[ឃ]ម្នាក់ៗគ្រប់គ្នា នោះមានចំនួន៣ម៉ឺន៨ពាន់នាក់[ង]
៤ក្នុងពួកនោះ មាន២ម៉ឺន៤ពាន់នាក់ដែលត្រូវត្រួតត្រា[ច]ការ[ឆ]
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ហើយមាន៦ពាន់នាក់
ដែលជាចៅក្រម និងសុភា[ជ] ៥មាន៤ពាន់ នាក់ជាអ្នកឆ្មាំទ្វារ
៤ពាន់នាក់ទៀត ជាអ្នកច្រៀងសរសើរដល់ព្រះយេហូវ៉ា
ដោយប្រដាប់ភ្លេង[ឈ] ដែលដាវីឌបានធ្វើសំរាប់ការច្រៀង
សរសើរ[ញ] ៦រួចដាវីឌទ្រង់ញែក[ដ]គេចេញជាវេនតាមពួក
វង្សរបស់លេវី[ឋ] គឺគើសុន កេហាត់ ហើយនឹងម្រ៉ារី ។

## គើសុន

៧ក្នុងពួកកូនរបស់គើសុន[ឌ] មានឡាអាដាន នឹងស៊ីម៉ាយ
៨ឯកូន របស់ឡាអាដាន គឺយេហ៊ីអែល ជាមេរួចសេថាម
នឹងយ៉ូអែល ទាំងអស់៣នាក់ ៩ឯកូនរបស់ស៊ីម៉ាយ គឺសឡូមិត
ហាស៊ាល និងហារ៉ាន ទាំងអស់៣នាក់ នេះហើយជាមេ ក្នុង
ពួកវង្សខាងឡាអាដាន ១០ឯកូន ស៊ីម៉ាយ គឺយ៉ាហាត ស៊ីណា
យេអ៊ូស នឹងបេរាអ្នកទាំង៤នេះ ជាកូនស៊ីម៉ាយ ១១ហើយ
យ៉ាហាត ជាមេស៊ីណា ជាអ្នកបន្ទាប់ តែយេអ៊ូស គេមិនសូវ
មានកូនច្រើនទេ បានជាគេរាប់ទុកជាវង្សាតែ១វិញ ។

## កេហាត់

១២ឯកូនរបស់កេហាត់[ឍ] គឺអាំរ៉ាម យីតសារ ហេប្រុន
និងអ៊ូស៊ាល ទាំងអស់៤នាក់នេះ ១៣ឯកូនរបស់អាំរ៉ាម[ណ] គឺ
អើរ៉ុន និងម៉ូសេ ហើយអើរ៉ុននិងកូនលោកទាំងប៉ុន្មាន
បានត្រូវញែកចេញ[ត] ទុកជាបរិសុទ្ធបំផុតជាដរាបទៅ
ដើម្បីនឹងដុតគ្រឿងក្រអូប នៅចំពោះព្រះយេហូវ៉ាព្រមទាំង
ធ្វើការងារ[ថ]ថ្វាយទ្រង់ ហើយសរសើរដំកើង[ទ]ដល់ព្រះនាម
ទ្រង់ជាដរាបទៅ ១៤តែឯកូនរបស់ម៉ូសេ ជាអ្នកសំណប់[ធ]
របស់ព្រះ នោះបានរាប់បញ្ចូល ក្នុងពូជអំបូរលេវី ១៥ឯកូន
របស់ម៉ូសេ គឺគើសុន នឹងអេលាស៊ើរ[ន] ១៦ឯកូនរបស់
គើសុន[ប] គឺសេប៊ួលជាមេ ១៧កូនរបស់អេលាស៊ើរ
គឺរេហាបយ៉ា[ផ]ជាមេ ហើយអេលាស៊ើរគ្មានកូនប្រុសណា
ទៀតទេ តែរេហាបយ៉ាមានកូនច្រើនណាស់ ១៨ឯកូនរបស់
យីតសារ គឺសឡូមិត[ព]ជាមេ ១៩កូនរបស់ហេប្រុន[ភ]គឺយេរីយ៉ា
ជាមេ អ័ម៉ារា ជាអ្នកទី២ យ៉ាហាសៀលទី៣ និងយេកាមាម
ទី៤ ២០ឯកូនរបស់អ៊ូស៊ាល គឺមីកា ជាមេ និងយីសយ៉ា ជាទី២

## ម្រ៉ារី

២១ឯកូនរបស់ម្រ៉ារី[ម] គឺម៉ាស់លី និងមូស៊ី[យ] កូនរបស់
ម៉ាស់លី គឺអេលាសារ និងគីស ២២ឯអេលាសារគាត់ស្លាប់
ទៅ ឥតមានកូនប្រុសទេ មានតែកូនស្រីៗ ហើយកូនចៅគីស
ជាបងប្អូនគេក៏យកនាងទាំងនោះធ្វើជាប្រពន្ធ[រ] ២៣ឯកូន
របស់មូស៊ីគឺម៉ាស់លី អេឌើរ និងយេរេម៉ូត ទាំងអស់៣នាក់
២៤ពួកនោះសុទ្ធតែជាកូនចៅរបស់លេវី តាមវង្សនៃ
ឪពុកគេ គឺជាមេលើវង្សនៃឪពុកគេ ក្នុងពួកអ្នកដែលបាន
រាប់តាមឈ្មោះគេរៀងរាល់ខ្លួន ជាពួកអ្នកដែលធ្វើការ
ងារក្នុងព្រះវិហារនៃព្រះយេហូវ៉ា ចាប់តាំងពីអាយុ២០ឆ្នាំ
ឡើងទៅលើ[ល] ២៥ដ្បិតដាវីឌទ្រង់បានមានបន្ទូលថា ព្រះ
យេហូវ៉ាជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់បានប្រោស
ប្រទាន ឱ្យរាស្ត្រទ្រង់បានសេចក្តីស្រាកស្រាន្ត[វ] ហើយទ្រង់
នឹងគង់នៅក្រុងយេរូសាឡិម ជារៀងរាបដរាបទៅ ២៦ឯ
ពួកលេវី គេមិនត្រូវការសែងរោងឧបោសថ នឹងគ្រឿង
ប្រដាប់សំរាប់ការងារនៃរោងនោះទៀតឡើយ[ស] ២៧ដ្បិត
តាមពាក្យបង្គាប់ក្រោយបង្អស់របស់ដាវីឌ នោះគេបានរាប់
ចំនួនពួកកូនចៅលេវី ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ
២៨ពីព្រោះ ការងាររបស់គេ គឺឱ្យបំរើពួកកូនចៅអើរ៉ុន
សំរាប់ការងារក្នុងព្រះវិហារ នៃព្រះយេហូវ៉ា ព្រមទាំង
នៅទីលាន ហើយក្នុងបន្ទប់ទាំងប៉ុន្មាន និងការសំអាត
របស់បរិសុទ្ធ[ហ]ទាំងអស់ គឺជាការងាររបស់ព្រះវិហារនៃ
ព្រះ ២៩ហើយគឺជាអ្នកធ្វើនំបុ័ងតាំងទុក[ឡ] ម្សៅយ៉ាងម៉ដ្ត
សំរាប់ដង្វាយម្សៅ[អ] ទោះបើធ្វើនំក្រៀបឥតដំបែ ឬនំដែល
ចំអិនក្នុងពុម្ព ឬដែលចៀនក្តី ហើយនឹងការវាល់វាស់ទាំង
ប៉ុន្មានផង[ក] ៣០គេត្រូវឈររាល់តែព្រឹក ដើម្បីនឹងអរព្រះ

៨:២៤ ឃ ១រប ២១:៧ ង ជន ៤:៣-៤៩ **២៣:៤** ច អរ ៣:៨ ឆ ២រប ៣៤:១៣ នហ ៤:១០ ជ ១រប ២៦:២៩ ២រប ១៩:៨ អគ ៤៤:២៤ **២៣:៥** ឈ ១រប ១៥:១៦ ទដ ៩២:៣ ញ នហ ១២:៤៥ **២៣:៦** ដ ២រប ៨:១៤ ២៣:១៨ ២៩:២៥ ឋ ជន ៣:១៧ ១រប ២៤:២០ **២៣:៧** ឌ ១រប ៦:៧១ **២៣:១២** ឍ លប ៤៦:១១ នក ៦:១៨ **២៣:១៣** ណ នក ៦:២០ ត នក ៣០:៧-១០ ថ ១រប ១៥:២ ទ ជន ៦:២៣ **២៣:១៤** ធ ចទ ៣៣:១ **២៣:១៥** ន នក ១៨:៤ **២៣:១៦** ប ១រប ២៦:២៤-២៨ **២៣:១៧** ផ ១រប ២៤:២១ **២៣:១៨** ព ១រប ២៦:២៥ **២៣:១៩** ភ ១រប ២៤:២៣ ២៦:៣១ **២៣:២១** ម ១រប ៦:១៩ យ នក ៦:១៩ **២៣:២២** រ ជន ២៦:៨

**២៣:២៤** ល ជន ៤:៣ **២៣:២៥** វ ១រប ២២:៩ **២៣:២៦** ស ជន ៤:៥, ១៥ ៧:៩ ចទ ១០:៨ **២៣:២៨** ហ ២រប ២៩:១៥ នហ ១៣:៩ មឡ ៣:៣ **២៣:២៩** ឡ នក ២៥:៣០ អ លវ ២:៤-៧ ៦:២០-២៣ ក លវ ១៩:៣៥-៣៦ ១រប ៩:២៩,៣២ **២៣:៣០** ខ ១រប ៩:៣៣ ទដ ១៣៤:១

ដោយយោងទៅតាមបញ្ញត្តិរបស់ម៉ូសេ នោះពួកលេវីត្រូវតែធ្វើជិរឿនមុន គេបង្អស់(សូមមើល ជន ៤:១-៣) ។ បន្ទាប់ពីការរាប់ចំនួននេះមក ដាវីឌបានណែនាំថា ពួកកូនចៅលេវីដែលមានអាយុច្រើនជាង២០ឆ្នាំ (ខ.២៤, ២៧) ដែលមានការប្រហាក់ប្រហែលជាមួយនឹងពួកអ្នកដែលធ្វើការក្នុងក្រសួងដែលមានអាយុចាប់ពី២៥ឡើងទៅ ពួកគេត្រូវធ្វើជិរឿនតាមច្បាប់របស់លោកម៉ូសេ(សូមមើល ជន ៨:២៣-២៤ ប៉ុន្តែសូមមើល ៨:២៤) ។ **២៣:៦** *គើសុន គេហាត់ ហើយនិងម្រ៉ារី* ពួកកូនចៅលេវីត្រូវបានរៀបចំស្ថាបនាឡើងដោយពូជអំបូរទាំង៣របស់ពួកគេ(ជិពូក ៦ នក ៦:១៦-១៩ ជនជិពូក ៣) ។ ឈ្មោះទាំងនេះ គឺស្របគ្នានឹង ៦:១៦-៣០ ២៤:២០-៣០ ។ **២៣:២៤,២៧** *ចាប់តាំងពីអាយុ២០ឆ្នាំឡើងទៅលើ* សូមមើល ខ.៣ ។ **២៣:២៨-៣២** សូមមើល ៩:២៨-៣៤ ។ តួនាទីរបស់ពួកលេវី គឺជួយដល់ពួកសង្ឃ ។ អ្នកកត់ត្រាពង្សាវតារបាននិយាយយ៉ាងលំអិតពីកិច្ចការងាររបស់ពួកលេវី គឺពួកគេជាអ្នកថែរក្សារោងឧបោសថ ដុតនំ លេងភ្លេងថ្វាយព្រះអម្ចាស់ (សូមមើល ៩:២២-៣៤) ។

គុណ ហើយសរសើរដល់ព្រះយេហូវ៉ា ព្រមទាំងពេលល្ងាច
ផង[ខ] [៣១]ក៏ត្រូវថ្វាយគ្រប់ទាំងដង្វាយដុត ដល់ព្រះយេហូវ៉ា
នៅរាល់តែថ្ងៃឈប់សំរាកថ្ងៃចូលខែ[គ] និងថ្ងៃបុណ្យ[ឃ] នៅ
ចំពោះព្រះយេហូវ៉ាជានិច្ចតាមចំនួន តាមរបៀបនៃពេល
ទាំងនោះ [៣២]ព្រមទាំងរក្សាបញ្ញើជាត្រសាលជំនុំ[ង] និង
ទីបរិសុទ្ធ ហើយបញ្ញើរបស់ពួកកូនចៅអើរ៉ុន ជាបងប្អូនគេ
ដែលសំរាប់ការងាររបស់ព្រះវិហារនៃព្រះយេហូវ៉ាផង[ច]។

## ផ្នែកពួកសង្ឃ

**២៤** [១]ឯផ្នែក[ក]របស់ពួកកូនចៅអើរ៉ុន គឺយ៉ាងនេះក្នុងពួក
កូនរបស់អើរ៉ុននោះ[ខ] មានណាដាប អ័ប៊ីហ៊ូវ អេលាសារ
និងអ៊ីថាម៉ារ[គ] [២]តែណាដាប និងអ័ប៊ីហ៊ូវ គេស្លាប់មុនឪពុក
ទៅ[ឃ] ឥតមានកូនទេ ដូច្នេះ អេលាសារ នឹងអ៊ីថាម៉ារបាន
ធ្វើការងារជាសង្ឃវិញ [៣]ឯដាវីឌ និងសាដុក[ង] ជាវង្ស
អេលាសារ ហើយអ័ហ៊ីម៉ាលេក ជាវង្សអ៊ីថាម៉ារ ក៏ញែក
គេចេញ ជាពួកតាមវេនការងារគេ [៤]រីឯខាងពួកវង្ស
អេលាសារ នោះមានមេច្រើនជាងខាងពួកវង្សអ៊ីថាម៉ារ
ហើយគេត្រូវចែកជាពួកៗយ៉ាងនេះ គឺក្នុងពួកវង្សរបស់
អេលាសារ មានមេលើវង្សរបស់ឪពុកគេ១៦នាក់ ហើយ
ក្នុងវង្សរបស់អ៊ីថាម៉ារ មាន៨នាក់តាមវង្សារបស់ឪពុកគេ
[៥]រួចបានញែកគេចេញជាពួកៗ ស្មើគ្នារៀងរាល់ពួក[ច] ដ្បិត
មានពួកមេលើទីបរិសុទ្ធ និងពួកមេសំរាប់ការងារនៃព្រះ
នៅពួកទាំងសងខាង គឺខាងពួកវង្សអេលាសារ និងខាងពួក
វង្សអ៊ីថាម៉ារផង [៦]ឯសេម៉ាយ៉ា កូននេថានេល ដ៏ជា
ស្មៀនជាអ្នកក្នុងពួកលេវី លោកបានកត់ឈ្មោះគេ នៅ
ចំពោះស្តេច និងពួកមេ ព្រមទាំងសាដុកដ៏ជាសង្ឃ និង
អ័ហ៊ីម៉ាលេក[ឆ] ជាកូនអ័បៀថើរ ហើយពួកអ្នក ជាកំពូលលើ
វង្សរបស់ឪពុកគេ ក្នុងពួកសង្ឃ និងពួកលេវីផង គេបាន
រើសយកពួកវង្ស១ សំរាប់អេលាសារ ហើយ១សំរាប់
អ៊ីថាម៉ារ ។
[៧]ឆ្នោតទី១ត្រូវលើឈ្មោះយេហូយ៉ារីប ទី២ត្រូវលើ
យេដាយ៉ា[ជ] [៨]ទី៣ត្រូវហារីម[ឈ] ទី៤ត្រូវសេអូរីម [៩]ទី៥ត្រូវ
ម៉ាលគា ទី៦ត្រូវមីយ៉ាមីន [១០]ទី៧ត្រូវហាកូស ទី៨ត្រូវ
អ័ប៊ីយ៉ា[ញ] [១១]ទី៩ត្រូវយេសួរ ទី១០ត្រូវសេកានា [១២]ទី១១ត្រូវ
អេលីយ៉ាស៊ីប ទី១២ត្រូវយ៉ាគីម [១៣]ទី១៣ត្រូវ ហ៊ូផា ទី១៤
ត្រូវយេសេបៀប [១៤]ទី១៥ត្រូវប៊ីលកា ទី១៦ត្រូវអ៊ីមមើរ[ដ]
[១៥]ទី១៧ត្រូវហេស៊ារ[ឋ] ទី១៨ត្រូវហាភីសេស [១៦]ទី១៩
ត្រូវពេថាហ៊ីយ៉ា ទី២០ត្រូវយេហេសិគាល [១៧]ទី២១ត្រូវ
លើយ៉ាគិន ទី២២ត្រូវលើកាមូល [១៨]ឯទី២៣ នោះត្រូវលើ
ដេឡាយ៉ា ហើយទី២៤ត្រូវម្អាស៊ា [១៩]នេះហើយជារបៀប
វេនរបស់គេ តាមការងាររៀងខ្លួនដើម្បីឱ្យបានចូលទៅ
ក្នុងវិហារនៃព្រះយេហូវ៉ា តាមកំណត់ដែលអើរ៉ុន ជា
ឰយុកោគេ បានចែកឱ្យ ដូចជាព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែលបានបង្គាប់ដល់លោក ។

## ពួកកូនចៅលេវីដែលនៅសល់

[២០]ឯពួកកូនចៅលេវីដែលសល់នៅ[ឌ] គឺក្នុងពួកកូនរបស់
អាំរ៉ាម មានសេប៊ូល ក្នុងពួកកូនរបស់សេប៊ូល ក្នុងពួកកូន
របស់សេប៊ូល មានយេដាយ៉ា [២១]ខាងឯរេហាបយ៉ា[ឍ] គឺកូន
គាត់ឈ្មោះយីសយ៉ាជាមេ [២២]ខាងឯពួកយីតសារ នោះមាន
សឡូមិតកូនរបស់សឡូមិត គឺយ៉ាហាត [២៣]ឯពួកកូនរបស់
ហេប្រុន[ណ] គឺយេរីយ៉ា ជាទី១ អ័ម៉ារា ជាទី២ យ៉ាហាសៀល
ជាទី៣យេកាមាមជាទី៤ [២៤]ឯកូនរបស់អ៊ូស៊ាល គឺមីកា កូន
របស់មីកា គឺសាមារ [២៥]ឯប្អូនរបស់មីកា គឺយីសយ៉ា ហើយ

**២៣:៣១** ក ២ពវ ៤:២៣ ឃ ជន ២៨:៩–២៩:៣៩ អស ១:១៣–១៤ កល ២:១៦
**២៣:៣២** ង ជន ៣:៦–៨,៣៨ ច ២រប ២៣:១៨ ៣១:២ អគ ៤៤:១៤
**២៤:១** ក ១រប ២៣:៦ ២៨:១៣ ២រប ៥:១១ ៨:១៤ ២៣:៨ ៣១:២ ៣៥:៤,៥ អរ ៦:១៨ ខ ជន ៣:២–៤ គ នក ៦:២៣
**២៤:២** ឃ លវ ១០:១–២
**២៤:៣** ង ២សយ ៨:១៧
**២៤:៥** ច ខ.៣១ ១រប ២៥:៨ ២៦:១៣
**២៤:៦** ឆ ១រប ១៨:១៦
**២៤:៧** ជ អរ ២:៣៦ នហ ១២:៦
**២៤:៨** ឈ អរ ២:៣៩ ១០:២១ នហ ១០:៥
**២៤:១០** ញ នហ ១២:៤,១៧ លក ១:៥
**២៤:១៤** ដ អរ ២:៣៧ ១០:២០ យរ ២០:១
**២៤:១៥** ឋ នហ ១០:២០ **២៤:២០** ឌ ១រប ២៣:៦ **២៤:២១** ឍ ១រប ២៣:១៧
**២៤:២៣** ណ ១រប ២៣:១៩

**២៣:៣០** *រាល់តែព្រឹក . . .ពេលល្ងាចផង* សូមមើល នក ២៩:៣៨–៤១ ជន ២៨:៣–៨ ។

**២៤:១–១៩** នៅក្នុងខ.គម្ពីរទាំងនេះ មានឈ្មោះសង្ឃមួយចំនួនដែលបានរួចចេញពីភាពជាឈ្លើយរបស់ពួកបាប៊ីឡូន (សូមមើល ៦:៣–១៥ ៩:១០–១៣ អរ២:៣៦–៣៩ នហ ១០:១–៨ ១១:១០–១២ ១២:១–៧,១២–២១) ។

**២៤:២** *តែណាដាប និងអ័ប៊ីហ៊ូវ គេបានស្លាប់មុនឪពុកទៅ* អ្នកកត់ត្រាពង្សាវតារបានបង្ហាញរំឭកពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុង លវ ១០:១–៣ (សូមមើល ការពន្យល់ក្នុង ៦:១–៣) ។

**២៤:៣** *សាដុក . . . អ័ប៊ីម៉ាលេក* សាដុក និងអ័បៀថើរ ពួកគេបានបម្រើការងារជាសម្តេចសង្ឃរបស់ដាវីឌ ។ នៅគ្រាចុងក្រោយនៃអាយុកាលរបស់ដាវីឌ អ័ហ៊ីម៉ាលេកបានទទួលខុសត្រូវលើកិច្ចការងារមួយរបស់អ័ប៊ីម៉ាលេកជាឪពុកគាត់(សូមមើល ៦:៨) ប៉ុន្តែសូមមើល ការពន្យល់ ២សយ ៨:១៧ ។

**២៤:៤** *១៦នាក់ . . . ៨នាក់* សរុបទាំងអស់មាន២៤នាក់ ។ ពួកគេអាចនឹងជ្រើសរើសតាមរយៈវិធីនៃការចាប់ឆ្នោត ។ ពួកគេអាចនឹងអនុញ្ញាត្តិឱ្យបម្រើការងារដោយផ្លាស់ប្តូររាល់ខែ ដូចអ្វីដែលពួកសង្ឃនៅស្រុកអេស៊ីព្ទបានបម្រើបណ្តោះអាសន្នក្នុងព្រះវិហារ ឬរយៈពេល២សប្តាហ៍មួយឆ្នាំម្តង ដូចដែលបង្ហាញប្រាប់នៅក្នុងគ្រាសញ្ញាថ្មី ។ សម្រាប់ឈ្មោះរបស់អ្នកទាំងនោះសូមមើល ៧–១៨ ។ ឈ្មោះទី១ ទី២ ទី៤ ទី៩ និងទី២៤ ក៏មាននិយាយនៅក្នុងក្រាំងសមុទ្រស្លាប់ដែរ ហើយឈ្មោះទី៨មាននិយាយនៅ លក ១:៥ នហ ១២:៧ ។

**២៤:១០** *អ័ប៊ីយ៉ា* គាត់គឺជាឪពុករបស់លោកយ៉ូហានបាទ្ទីស "មានសង្ឃ១ក្នុងពួកអ័ប៊ីយ៉ា"(សូមមើល លក ១:៥)។

**២៤:២០–៣១** ឈ្មោះនេះ គឺបន្ថែមលើមនុស្សដែលមាននិយាយនៅក្នុង ២៣:៧–២៣ ។

កូនរបស់យីសយ៉ា គឺសាការី ២៦ឯពួកកូនចៅរបស់ម្រ៉ារី[ត]
គឺម៉ាស់លី និងមូស៊ី ហើយកូនរបស់យ៉ាស៊ា ដែលជាកូន
របស់អ្នកនោះ ២៧គឺកូនចៅរបស់ម្រ៉ារីខាងយ៉ាស៊ាជាកូន
គាត់ នោះមានសូហាំ សាគើរ នឹងអ៊ីបរី ២៨ខាងម៉ាស់លី
មានអេលាសារ ដែលឥតមានកូនប្រុស ២៩ខាងគីស នោះ
កូនរបស់គាត់ គឺយេរ៉ាម្អែល ៣០ហើយខាងឯកូនរបស់មីស៊ី
មានម៉ាស់លី អេឌើរ និងយេរេម៉ូត នោះសុទ្ធតែជាកូន
ចៅរបស់លេវី តាមវង្សរបស់ឪពុកគេ ៣១ពួកនោះក៏បាន
ចាប់ឆ្នោតដែរ[ថ] គឺនៅចំពោះស្តេចដាវីឌនឹងសាដុក អ័ហ៊ីម៉ា
លេក ហើយនៅមុខពួកអ្នកដែលជាកំពូលលើវង្សរបស់ពួក
សង្ឃនឹងពួកលេវី ដូចជាកូនចៅអើរ៉ុន ជាបងប្អូនគេដែរ
ឯពួកវង្សរបស់អ្នកណាដែលជាមេ និងវង្សរបស់អ្នកណា
ដែលជាបន្ទាប់ នោះបានស្មើគ្នាទាំងអស់ ។

## ពួកតន្ត្រីករ

**២៥** 1ដាវីឌ និងពួកមេទ័ព ក៏ញែកពួកកូនចៅអេសាភ[ក]
ហេម៉ាន[ខ] និងយេឌូថិន[គ]ខ្លះ ចេញទុកសំរាប់ការងារ ឱ្យបាន
ពោល[ឃ]តាមស៊ុង ពិណ និងឈឹង[ង] ពួកអ្នក[ច]ដែលធ្វើការ
ងារនោះ[ឆ]មានចំនួនដូច្នេះ ២គឺក្នុងពួកកូន ចៅអេសាភ មាន
សាគើរ យ៉ូសែប នេថានា និងអ័សារេឡាសុទ្ធតែ ជាកូន
អេសាភ ក៏នៅក្នុងបង្គាប់អេសាភដែរ គឺជាអ្នកដែលពោល
តាមបង្គាប់ស្តេច ៣ខាងឯយេឌូថិន ពួកកូនចៅលោក[ជ] គឺ
កេដាលា សេរី យេសាយ៉ា ហាសាបយ៉ា ម៉ាធិធា និង
ស៊ីម៉ាយ ទាំងអស់មាន៦នាក់ គេកាន់ស៊ុង[ឈ]នៅក្នុងបង្គាប់
យេឌូថិន ជាឪពុកគេ ដែលជាអ្នកពោលពំនោល ដោយ
ពាក្យអរព្រះគុណ និងពាក្យសរសើរដល់ព្រះយេហូវ៉ា
៤ខាងឯហេម៉ាន ពួកកូនចៅលោក គឺប៊ូកគា ម៉ាថានា
អ៊ូស៊ាល សេមូល យេរីម៉ូត ហាណានា ហាណានី អេលាថា
គីដាលធី រ៉ូម៉ាមធី-អេសើរ យ៉ូសបេកាសា ម៉ាឡូធី ហូធារ

**២៤:២៦** ត ១រប ៦:១៩
**២៤:៣១** ថ ខ.៥
**២៥:១** ក ១រប ៦:៣៩ ខ ១រប ៦:៣៣ គ ១រប ១៦:៤១,៤២ នហ ១១:១៧ ឃ ១សយ ១០:៥ ២ពវ ៣:១៥ ង ១រប ១៥:១៦ ច ១រប ៦:៣១ ឆ ២រប ៥:១២ ៨:១៤ ៣៤:១២ ៣៥:១៥ អរ ៣:១០
**២៥:៣** ជ ១រប ១៦:៤១-៤២ ឈ លប ៤:២១ ទដ ៣៣:២
**២៥:៦** ញ ១រប ១៥:១៦ ដ ១រប ១៥:១៩ ឋ ២រប ២៣:១៨ ២៩:២៥
**២៥:៨** ឌ ១រប ២៦:១៣
**២៥:៩** ឍ ១រប ៦:៣៩

នឹងម៉ាហាស៊ីយ៉ូត ៥នោះសុទ្ធ តែជាកូនរបស់ហេម៉ាន ជា
អ្នកមើលធុតរបស់ស្តេច ខាងឯព្រះបន្ទូលនៃព្រះ សំរាប់
លើកស្នែងឡើងផ្លិ ព្រះទ្រង់ប្រោសឱ្យហេម៉ានបានកូនប្រុស
១៤និងកូនស្រី៣ ៦អ្នកទាំងនោះសុទ្ធតែនៅក្នុងបង្គាប់របស់
ឪពុក[ញ] សំរាប់ការចំរៀងក្នុងព្រះវិហារនៃព្រះយេហូវ៉ា
ដោយលេងឈឹង ពិណ និងស៊ុង ដើម្បីធ្វើការងាររបស់ព្រះ
វិហារនៃព្រះ ឯអេសាភ យេឌូថិននឹងហេម៉ាន[ដ] លោកនៅ
ក្នុងបង្គាប់របស់ស្តេច[ឋ] ៧អ្នកទាំងនោះ និងបងប្អូនគេដែល
បានហាត់ច្រៀងថ្វាយព្រះយេហូវ៉ា គឺអស់អ្នកដែលប្រសប់
នោះមានចំនួន២៨៨នាក់ ៨គេបានចាប់ឆ្នោត[ឌ] ឱ្យបានការ
ងាររបស់គេរៀងខ្លួន ទាំងតូចទាំងធំ ហើយទាំងគ្រូនឹង
សិស្ស ក៏ដូចគ្នាទាំងអស់ ។
៩ឆ្នោតមុនដំបូង ត្រូវលើឈ្មោះយ៉ូសែប សំរាប់ពួក
អេសាភ[ឍ] ទី២ ត្រូវលើកេដាលា ដែលខ្លួនគាត់ បងប្អូន
នឹងកូនគាត់ ទាំងអស់មាន ១២នាក់ ១០ទី៣ត្រូវសាគើរដែល
កូនគាត់នឹងបងប្អូនទាំងអស់មាន១២ នាក់ ១១ទី៤ត្រូវយីសរី
ដែលកូនគាត់ និងបងប្អូន ទាំងអស់មាន១២នាក់ ១២ទី៥ត្រូវ
នេថានា ដែលកូនគាត់ និងបងប្អូនទាំងអស់មាន១២នាក់
១៣ទី៦ត្រូវប៊ូកគា ដែលកូនគាត់ និងបងប្អូន ទាំងអស់មាន
១២នាក់ ១៤ទី៧ត្រូវយេសារេឡា ដែលកូនគាត់ និងបងប្អូន
ទាំងអស់មាន១២នាក់ ១៥ទី៨ត្រូវយេសាយ៉ា ដែលកូនគាត់
និងបងប្អូនទាំងអស់មាន១២នាក់ ១៦ទី៩ត្រូវម៉ាថានា ដែល
កូនគាត់ និងបងប្អូន ទាំងអស់មាន១២នាក់ ១៧ទី១០ត្រូវ
ស៊ីម៉ាយ ដែលកូនគាត់ និងបងប្អូនទាំងអស់ មាន១២នាក់
១៨ទី១១ត្រូវអ័សារាល ដែលកូនគាត់នឹងបង ប្អូនទាំងអស់
មាន១២នាក់ ១៩ទី១២ត្រូវហាសាបយ៉ាដែលកូនគាត់ នឹង
បងប្អូនទាំងអស់មាន១២នាក់ ២០ទី១៣ត្រូវស៊ូបាអែល ដែល
កូនគាត់ និងបងប្អូនទាំងអស់ មាន១២នាក់ ២១ទី១៤ត្រូវ

**២៥:១** *ពួកមេទ័ព* ជាញឹកញាប់ ស្តេចដាវីឌគាត់តែងតែស្វែងរកការពិគ្រោះយោបល់ពីសំណាក់មេទ័ពទាំងឡាយ (សូមមើល ១១:១០ ១២:៣២ ២៨:១) ទោះបីក្នុងពិធីសាសនាក៏ដោយ (សូមមើល ១៣:១ ១៥:២៥) ។ *អេសាភ ហេម៉ាន និងយេឌូថិន* សូមមើល ការពន្យល់ក្នុង ៦:៣១-៤៨ ទដ ៣៩ ។ *ពួកអ្នកដែលធ្វើការងារនោះ* មានអត្ថបទជាច្រើននៅក្នុងគម្ពីររបាក្សត្រ អ្នកដែលបម្រើការងារក្នុងព្រះវិហារ ត្រូវបានគេហៅថាជាហោរ៉ា (សូមមើល ២រប ២០:១៤-១៧ ២៩:៣០ ៣៥:១៥ ធៀប ២ពវ ២៣:២ ២រប ៣៤:៣០) ។ លោកសាការីដែលជាសង្ឃក៏មានតួរនាទីជាហោរាដែរ ។ អាចជាការឆ្លុះបញ្ចាំងពួកអ្នកដែលជាប់ជាឈ្លើយនៅក្រុងបាប៊ីឡូន ដែលពួកគេមានការចាប់អារម្មណ៍ចំពោះហោរា សង្ឃ និងស្តេចដែលដំណាងឱ្យព្រះមែស៊ីដែលគេរងចាំ ។ នៅក្នុងរបាក្សត្រ មិនមែនមានតែពួកសង្ឃ ជាហោរានោះទេ តែស្តេចក៏ជាសង្ឃដែរ (សូមមើល ១៥:២៧ ១៦:១-៣) ។ អ្នកលេងនៅក្នុងព្រះវិហារដែលដាវីឌបានរៀបចំឡើង ប្រហែលជាការសម្តែងពីចំណង់ចំណូលចិត្តរបស់គាត់ទៅលើតន្ត្រី (សូមមើល ១សយ ១៦:២៣ ១៨:១០ ១៩:៩ ២សយ ១:១៧-២៧ ៦:៥,១៤) ។

**២៥:៥** *កូនប្រុស១៤ និងកូនស្រី៣* ការដែលមានកូនចៅច្រើន គឺជានិមិត្តរូបនៃព្រះពររបស់ព្រះអម្ចាស់ (សូមមើល យប ១:២ ៤២: ១៣) ។ នេះគឺជាផលដ៏វិសេសសនៃសេចក្តីសញ្ញាម្រាប់ហេម៉ាន ដែលព្រះអម្ចាស់ទ្រង់សន្យាថា នឹងលើកតម្កើងគាត់ (សូមមើល ៣:១-៩ ១៤:២-៧ ២៦:៤-៥ ២រប ១១:១៨-២១ ១៣:២១ ២១:២ ២៤:៣) ។

ម៉ាធីធា ដែលកូនគាត់នឹងបងប្អូនទាំងអស់ មាន១២នាក់
២២ ទី១៥ត្រូវយេរេម៉ូត ដែលកូនគាត់ និងបងប្អូនទាំងអស់
មាន១២នាក់ ២៣ ទី១៦ត្រូវហា ណានា ដែលកូនគាត់ និង
បងប្អូនទាំងអស់ មាន១២នាក់ ២៤ ទី១៧ត្រូវយ៉ូសបេកាសា
ដែលកូនគាត់ និងបងប្អូនទាំងអស់ មាន១២នាក់ ២៥ ទី១៨
ត្រូវហាណានី ដែលកូនគាត់ និងបងប្អូនទាំងអស់ មាន១២
នាក់ ២៦ ទី១៩ត្រូវម៉ាឡូធីដែលកូនគាត់ និងបងប្អូនទាំងអស់
មាន១២នាក់ ២៧ ទី២០ត្រូវលោថា ដែលកូនគាត់ និងបងប្អូន
ទាំងអស់ មាន១២នាក់ ២៨ ទី២១ត្រូវហូធារ ដែលកូនគាត់
នឹងបងប្អូនទាំងអស់ មាន១២នាក់ ២៩ ទី២២ត្រូវគីដាលធី
ដែលកូនគាត់ និងបងប្អូនទាំងអស់មាន១២នាក់ ៣០ ទី២៣ត្រូវ
ម៉ាហាសីយ៉ូត ដែលកូនគាត់ និងបងប្អូនទាំងអស់ មាន១២
នាក់ ៣១ ទី២៤ត្រូវរ៉ូម៉ាមធី–អេស៊ើរ ដែលកូនគាត់ នឹងបង
ប្អូនទាំងអស់មាន១២នាក់[ណ] ។

## ពួកឆ្មាំទ្វារ

២៦ ១ ឯផ្នែករបស់ពួកឆ្មាំទ្វារ[ក] នោះក្នុងពួកកូរេមាន
មសេលេមា ជាកូនកូរេ ក្នុងវង្សារបស់អេសាភ ២ ហើយ
មសេលេមាមានកូន គឺសាការី[ខ] ជាកូនច្បង យេឌីអែលជា
ទី២ សេបាឌា ទី៣ យ៉ាតនាល ទី៤ ៣ អេឡាំ ទី៥ យ៉ូហាណាន
ទី៦ នឹងអេលីយ៉ូនាយ ទី៧ ៤ ឯអូបិឌ–អេដំមក៏មានកូន គឺ
សេម៉ាយ៉ា ជាកូនច្បង យ៉ូសាបាឌ ជាទី២ យ៉ូអា ទី៣ សាកើរ
ទី៤ នេថានេល ទី៥ ៥ អាំមាល ទី៦ អ៊ីសាខារទី៧ និង
ពេអ៊ូលថាយ ទី៨ ដ្បិតព្រះបានប្រទានពរដល់លោក[គ]
៦ ហើយសេម៉ាយ៉ាជាកូនលោក ក៏បានកូនដែរ អ្នកទាំងនោះ
បានត្រួតត្រាលើវង្សរបស់ឪពុកគេ ដ្បិតគេសុទ្ធតែជាមនុស្ស
ខ្លាំងពូកែ មានចិត្តក្លាហាន ៧ ឯកូនរបស់សេម៉ាយ៉ា គឺអូតនី
រេផែល អូបិឌ ដែលសាបាឌ និងបងប្អូនគេ ដែលជាមនុស្ស
ក្លាហាន គឺអេលីហ៊ូវ និងសេម៉ាគា ៨ នោះសុទ្ធតែជាកូនចៅ
របស់អូបិឌ–អេឌំមដែលខ្លួនគេ កូនចៅ និងបងប្អូនគេ សុទ្ធ

**២៥:៣១** ន ១រប ៩:៣៣
**២៦:១** ក ១រប ៩:១៧
**២៦:២** ខ ១រប ៩:២១
**២៦:៥** គ ២សយ ៦:១០ ១រប ១៣:១៣ ១៦:៣៨
**២៦:១០** ឃ ចទ ២១:១៦ ១រប ៥:១
**២៦:១២** ង ១រប ៩:២២
**២៦:១៣** ច ១រប ២៤:៥,៣១ ២៥:៨
**២៦:១៤** ឆ ១រប ៩:១៨ ជ ១រប ៩:២១
**២៦:១៥** ឈ ១រប ១៣:១៣ ២រប ២៥:២៤

តែជាមនុស្សមានកំឡាំងជំនាញក្នុងការងារ មាន៦២នាក់
ដែលកើតពីអូបិឌ–អេដំម ៩ ឯមសេលេមា គាត់មានកូន និង
បងប្អូន១៨នាក់ ដែលសុទ្ធតែជាមនុស្សក្លាហាន ១០ ហើយ
ហូសា ក្នុងវង្សម្រ៉ារីក៏មានកូន គឺស៊ីមរី ជាមេ (ដ្បិតទោះ
បើគាត់មិនមែនជាកូនច្បង គង់តែឪពុកបានតាំងឡើង ឱ្យ
ធ្វើជាមេដែរ)[ឃ] ១១ ហើយគីយ៉ា ជាទី២ ថេបាលយ៉ា ទី៣
សាការី ទី៤ ឯកូនចៅ និងបងប្អូនរបស់ហូសាទាំងអស់មាន
១៣នាក់ ។

១២ ក្នុងបណ្តាអ្នកទាំងនោះ បានរើសយកអ្នកឆ្មាំទ្វារ
សំរាប់ជាវេនតគ្នា ព្រមទាំងពួកមេដែលមានការងារ[ង] ដូច
ជាបងប្អូនគេដែរនោះផង ដើម្បីនឹងរក្សាក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា ១៣ គេក៏ចាប់ឆ្នោត[ច] ទាំងតូចទាំងធំ តាមវង្ស
របស់ឪពុកគេ ឱ្យបានត្រូវទ្វារនិមួយៗ ១៤ ឆ្នោតដែលត្រូវ
ទ្វារទិសខាងកើត[ឆ] នោះត្រូវលើសេលេមា រួចមកគេចាប់
ឆ្នោតឱ្យសាការី[ជ] ជាកូនគាត់ ដែលជាអ្នកជួយគំនិតយ៉ាង
ចំណាន ហើយឆ្នោតគាត់ត្រូវត្រង់ទ្វារខាងជើង ១៥ ឯឆ្នោត
របស់អូបិឌ–អេដំម[ឈ] ត្រូវត្រង់ទ្វារខាងត្បូង ហើយឆ្នោត
របស់ពួកកូនគាត់ ត្រូវខាងឃ្លាំង ១៦ ឆ្នោតរបស់ស៊ូភីម និង
ហូសានោះត្រូវត្រង់ទ្វារខាងលិច និងទ្វារសាលេគែត ត្រង់
ថ្នល់ដែលឡើងទៅ ឱ្យគ្រប់គ្នាបានចាំយាមទល់មុខគ្នា ១៧ ឯ
ខាងកើត មានពួកលេវី៦នាក់ ខាងជើងមាន៤នាក់រាល់តែ
ថ្ងៃ ខាងត្បូងមាន៤នាក់រាល់តែថ្ងៃ ហើយខាងឃ្លាំងមាន
៤នាក់ ១៨ ត្រង់ទ្វារប៉ារបើរ ខាងលិច មាន៤នាក់ចាំនៅ
ត្រង់ថ្នល់ ហើយ២នាក់នៅត្រង់ទ្វារប៉ារបើរនោះ ១៩ នេះ
ហើយ ជាវេនរបស់ពួកឆ្មាំទ្វារក្នុងពួកកូនចៅកូរេ និងពួក
កូនចៅម្រ៉ារី[ញ] ។

## រាជទ្រព្យ និងពួកត្រួត

២០ ហើយក្នុងពួកលេវី[ដ] មានអ័ហ៊ីយ៉ា ជាអ្នកត្រួតលើទ្រព្យ

**២៦:១៩** ញ ២រប ៣៥:១៥ នហ ៧:១ អគ ៤៤:១១ **២៦:២០** ដ ២រប ២៤:៥

**២៦:១–១៩** នៅក្នុងខ.គម្ពីរនេះពណ៌នាពីបញ្ជីឈ្មោះពួកឆ្មាំទ្វារដែលអ្នកកត់ត្រាពង្សាវតារក្សត្របានកត់ចុះ (សូមមើល ៩:១៧–២៧ ១៦:៣៧–៣៨) ។ ឈ្មោះឆ្មាំទ្វារដែលជាប់ជាឈ្លើយនៅបាប៊ីឡូន គឺមាននៅក្នុង អរ ២:៤២ (សូមមើល នហ ៧:៤៥) ។

**២៦:១** *អេសាភ* ឈ្មោះនេះគឺជាការបំព្រួញឱ្យខ្លីរបស់អេបៀសាប់ (សូមមើល ៦:២៣ ៩:១៩) ។

**២៦:៤–៥** ការមានកូនច្រើនគឺជានិមិត្តរូបនៃព្រះពររបស់ព្រះអម្ចាស់ (សូមមើល ២៥:៥) ។

**២៦:៤** *អូបិឌ–អេដំម* គាត់ជាអ្នកថែរក្សាហឹបនៃសេចក្តីសញ្ញា ក្នុងអំឡុងពេលដែលហឹបនោះស្ថិតនៅក្នុងផ្ទះរបស់គាត់ (សូមមើល ១៣:១៣) ។

**២៦:១២** *ការងារ* និយាយលំអិតពីកិច្ចការនេះ សូមមើល ៩:២២–២៩ ។

**២៦:១៤** *ទ្វារទិសខាងកើត* ទ្វារទិសខាងកើតគឺជាទ្វាចម្បង ដែលមានអ្នកយាម៦នាក់ ផ្ទុយពីកន្លែងឯទៀតមានតែ៤នាក់ប៉ុណ្ណោះ (សូមមើល ខ.១៧) ។

**២៦:១៥** *ទ្វារខាងត្បូង* រាជ្យវាំងរបស់ដាវីឌ និងសាឡូម៉ូន គឺស្ថិតនៅខាងត្បូងភ្នំនៃព្រះវិហារនៃព្រះយេហូវ៉ា ។ ទ្វារដែលនៅទិសខាងត្បូងគឺជាការសំខាន់មួយសម្រាប់ស្តេចប្រើ ហើយកិច្ចការទាំងអស់នេះប្រហែលជាសំដៅលើកិត្តិយសដ៏ធំសម្រាប់អូបិឌ–អេដំម (សូមមើល ២៦:៤–៥ និង អគ ៤៦:១–១០) ។

**២៦:១៦** *ទ្វារសាលេគែត* តាមការសន្មត់តែជាអំណះអំណាង គេគិតថាទ្វារនេះស្ថិតនៅទិសខាងលិច ។

វិសេស នៃព្រះវិហាររបស់ព្រះ ហើយលើឃ្លាំងនៃរបស់
ដែលបានថ្វាយទាំងប៉ុន្មាន[ថ] ។
២១ចំណែកឯកូនចៅរបស់ឡាអាដាន គឺជាកូនចៅនៃ
ពួកគើសុន ដែលកើតដោយសាឡាអាដាន ជាពួកមេលើ
វង្ស របស់ឪពុកគេរៀបខ្លួន ដែលត្រូវខាងឡាអាដាន ជា
ពួកគើសុន[ឍ] នោះមានយីអែលី ២២ឯកូនរបស់យីអែលី គឺ
សេថាម និងយ៉ូអែល ជាប្អូនគេ បានត្រួតលើទ្រព្យវិសេស[ឍ]
នៃព្រះវិហាររបស់ព្រះយេហូវ៉ា ២៣ហើយក្នុងពួកអាំរ៉ាម
ពួកយីតសារ ពួកហេប្រុន និងពួកអ៊ូស៊ាល[ណ] ២៤ព្រមទាំង
សេប៊ួល[ត] ជាកូនគើសុន ដែលជាកូនម៉ូសេ នោះសុទ្ធតែជា
អ្នកត្រួតលើទ្រព្យវិសេសទាំងអស់ ២៥ឯបងប្អូនគាត់ដែល
កើតដោយសារអេលាស៊ើរ នោះគឺរេ ហាបយ៉ា ដែលបង្កើត
យេសាយ៉ា១បង្កើតយ៉ូរ៉ាម យ៉ូរ៉ាមបង្កើតស៊ីកគ្រី១ ស៊ីកគ្រី
បង្កើតសឡូមិត[ថ] ២៦គឺសឡូមិតនេះនឹងបងប្អូនគាត់ ជាអ្នកត្រួត
លើឃ្លាំងនៃរបស់ដែលបានថ្វាយទាំងប៉ុន្មាន[ទ] ជារបស់
ដែលស្តេចដាវីឌ អស់ទាំងមេលើពួកវង្សានុវង្ស ពួកមេ
លើទាហាន១ពាន់នាក់ និងលើ១០០នាក់ ហើយពួកមេទ័ពធំ
បានថ្វាយ ២៧គឺជារបស់គេថ្វាយ ពីរឹបដែលចាប់យកបាន
ក្នុងចំបាំង សំរាប់នឹងជួសជុលព្រះវិហារនៃព្រះយេហូវ៉ា
២៨ហើយរបស់ទាំងប៉ុន្មាន ដែលសាំយ៉ូអែល ជាអ្នកមើល
ឆុត[ធ] សូល ជាបុត្រគីស អ័ប៊ីនើរ ជាកូននើរ និងយ៉ូអាប់
ជាកូនសេរូយ៉ាបានថ្វាយដែរ របស់អ្វីដែលអ្នកណាបាន
ថ្វាយក៏ដោយ នោះសុទ្ធតែនៅក្រោមអំណាចរបស់សឡូមិ

ថ ១របា ២៨:១២
**២៦:២១** ឍ ១របា ២៣:៧ ២៩:៨
**២៦:២២** ឍ ១របា ៩:២៦
**២៦:២៣** ណ ជន ៣:២៧
**២៦:២៤** ត ១របា ២៣:១៦
**២៦:២៥** ថ ១របា ២៣:១៨
**២៦:២៦** ទ ២សយ ៨:១១
**២៦:២៨** ធ ១សយ ៩:៩
**២៦:២៩** ន ចទ ១៧:៨–១៣ ១របា ២៣:៤
**២៦:៣០** ប ១របា ២៧:១៧

នឹងបងប្អូនគាត់ទាំងអស់ ។
២៩ខាងឯពួកយីតសារ នោះកេណានា នឹងកូនចៅគាត់
ជាអ្នក សំរាប់ការងារខាងក្រៅ ជាការត្រួតត្រាលើពួក
អ៊ីស្រាអែល គឺជាចៅក្រម[ន] និងសុភា ៣០ក្នុងពួកហេប្រុន
មានហាសាបយ៉ា[ប] និងបងប្អូនគាត់ ដែលសុទ្ធតែជាមនុស្ស
ក្លាហាន ចំនួន១៧០០នាក់ គេជាអ្នកត្រួតត្រា លើពួក
អ៊ីស្រាអែល ដែលនៅខាងនាយទន្លេយ័រដាន់ ទិសខាងលិច
សំរាប់កិច្ចការទាំងប៉ុន្មានរបស់ព្រះយេហូវ៉ា និងសំរាប់ការ
ខាងស្តេចផង ៣១ក្នុងពួកហេប្រុន[ផ] មានយេរីយ៉ា ជាមេលើ
ពួកហេប្រុននោះ តាមអស់ទាំងដំណនៃវង្សរបស់ឪពុកគេ
នៅឆ្នាំទី៤០[ព]ក្នុងរាជ្យដាវីឌ នោះគេរកពួកអ្នកនោះ ក៏បាន
ឃើញមានមនុស្សខ្លាំងពូកែ មានចិត្តក្លាហាន ក្នុងពួកគេនៅ
ក្រុងយ៉ាស៊ើរ ស្រុកកាឡាត ៣២ឯបងប្អូនយេរីយ៉ា ដែលសុទ្ធ
តែ ជាមនុស្សក្លាហាន នោះមានចំនួន២៧០០នាក់ ជាមេលើ
វង្សឪពុកគេ ជាអ្នកដែលស្តេចដាវីឌបានតាំងឱ្យត្រួតត្រាលើ
ពួករូបេន ពួកកាឌ់ និងពូជអំបូរម៉ាន៉ាសេ១ចំហៀង ខាងឯ
គ្រប់ការរបស់ព្រះ និងការរបិស់ស្តេចទាំងប៉ុន្មានផង ។

### ការបែងចែកកងទ័ព

**២៧** ១រីឯពួកកូនចៅអ៊ីស្រាអែល តាមចំនួនគេ គឺតាមពួក
មេលើវង្ស ឪពុកគេនិងពួកមេទ័ពធំតូច ហើយពួកនាយ
ដែលបំរើស្តេច ក្នុងគ្រប់ទាំងការ ខាងឯវេនគេដែលចេញ
ចូរលរាល់តែខែ នៅពេលក្នុងឆ្នាំ ដែលរាល់តែវេនមាន

**២៦:៣១** ផ ១របា ២៣:១០ ព ២សយ ៥:៤

**២៦:២០** *ទ្រព្យវិសេសនៃព្រះវិហាររបស់ព្រះ* ពួកលេវីគេមានតួនាទីជាអ្នកត្រួតត្រាលើរបស់ទ្រព្យដែលទទួលបានពីបណ្តាជន និងថែរក្សាបរិភ័ណ្ឌទ្រព្យដែលមានតម្លៃក្នុងព្រះវិហារ ។ *លើឃ្លាំងរបស់ទ្រព្យដែលបានថ្វាយ* គេក៏ជាអ្នកគ្រប់គ្រងលើរឹបដែលច្បាំងបានដែរ (សូមមើល ខ.២៧–២៨) ។ តាមរយៈឯកសារដែលបានមកពីពួកមេសូប៉ូតាមាបានបញ្ជាក់ថា ព្រះវិហារគឺបញ្ជាក់អំពីវត្តមានរបស់មន្ត្រីក្នុងព្រះវិហារ ដែលបានបម្រើការងារជាអ្នកវិភាគលើរបស់ទ្រព្យដែលមានតម្លៃ ដែលបានទទួលពីបណ្តាជន ។ និតិវិធីដែលជាអំណោះអំណាងលើដង្វាយដែលបណ្តាជនបានថ្វាយ ប្រហែលជាមាននៅក្នុងអំឡុងរាជស្តេចយ៉ូអាស (សូមមើល ២របា ២៤:៤–១៤ ២ពង្សា ១២:៤–១៦) ។ នៅមានអត្ថបទជាច្រើនទៀតដែលមានទំនាក់ទំនងលើការរៃទ្រព្យដ៏មានតម្លៃក្នុងព្រះវិហារ (សូមមើល ២៩:១–៩ ២របា ៤:១–២២ ៣៤:៩–១១ ៣៦:៧,១០,១៨–១៩ ១ពង្សា ១៤:២៥–២៨ ១៥:១៥,១៨ ២ពង្សា ១២:៤–១៨ ១៤:១៤ ១៦:៨ ២៥:១៣–១៧) ។

**២៦:២៦** *ត្រួតត្រាលើឃ្លាំងនៃរបស់ដែលបានថ្វាយទាំងប៉ុន្មាន ជារបស់ដែលស្តេចដាវីឌ* សូមមើល ការពន្យល់ក្នុង ១៨:១–២០:៨ និង ២របា ៥:១ ។

**២៦:២៧** *ពីរឹបដែលចាប់យកបានក្នុងចំបាំង* សូមប្រៀបធៀប លប ១៤:១៧–២០ ។

**២៦:២៩–៣២** នៅក្នុងខ.គម្ពីរទាំងនោះបាននិយាយថា មានពួកចៅក្រម និងសភាចំនួន៦ពាន់នាក់ (សូមមើល ២៣:៤) ដែលអាចនឹងធ្វើការនៅក្រៅទីក្រុងយេរូសាឡិម ។ ពួកគេបានចេញមកពីបក្សសម្ព័ន្ធ២ក្នុងអំបូរកេហាត់ (សូមមើល ៦:១៨) ។ នៅក្នុង ចទ ១៧:៨– ១៣ បាននិយាយថា ពួកសង្ឃ និងពួកលេវី មានតួនាទីដោះស្រាយបញ្ហាផ្សេងៗដែលនឹងកើតមានឡើងនៅថ្ងៃក្រោយ (សូមមើល ២របា ១៩:៤–១១) ។

**២៦:៣០,៣២** *សំរាប់កិច្ចការទាំងប៉ុន្មានរបស់ព្រះយេហូវ៉ា និងសំរាប់កិច្ចការខាងស្តេចផង . . . ខាងឯការគ្រប់គ្រងការរបស់ព្រះ និងការរបស់ស្តេចទាំងប៉ុន្មានផង* នៅក្នុងនរគរព្រះ គ្មានការបែងចែករវាង សាសនាទីបរិសុទ្ធ ការបប្រើរព្រះ ឬស្តេចឡើយ (សូមធៀប មថ ២២:១៥–២២ លក ១៦:១០–១៣ រម ១៣:១–៧ ១ធថ ២:១–៤ ១ពត ២:១៣–១៧)។

**២៦:៣១** *ឆ្នាំទី ៤០* គឺជាឆ្នាំចុងក្រោយនៃរាជដាវីឌ ។

**២៧:១–១៥** ឈ្មោះមេទ័ពទាំងប៉ុន្មានរបស់ដាវីឌ គឺដូចគ្នាដឹងឈ្មោះអ្នកខ្លាំងពូកែរបស់គាត់ដែរ (មើល ១១:១១–៤៧ ២សយ ២៣:៨–៣៩) ។ ពួកអ្នកទាំងនោះបានបម្រើដាវីឌ ក្នុងអំឡុងពេលដែលដាវីឌបានរត់គេចពីសូល ។

**២៧:១** *២ម៉ឺន ៤ពាន់នាក់* សូមមើលការពន្យល់ក្នុង ១២:២៣–៣៧ ។ ទោះបីជាមានចំនួនមនុស្ស១២ក្រុមហើយ១ក្រុមមាន២ម៉ឺន៤ពាន់នាក់ក៏ដោយ (ទាំង

២ម៉ឺន៤ពាន់នាក់ ២នោះមានយ៉ាសុបៀម[ក] ជាកូនសាបឌាល
ជាអ្នកត្រួតលើពួកវេនទី១ នៅខែចេត្រ ហើយក្នុងវេន
លោកមាន២ម៉ឺន៤ពាន់នាក់ ៣លោកកើតក្នុងពូជពង្ស
ពេរេស ជាមេលើពួកមេទ័ព សំរាប់ខែដំបូង ៤ដូដាយ[ខ]
ជាពួកអ័ហូអា ជាអ្នកត្រួតលើពួកវេនខែពិសាខ ហើយ
មីកឡូក ជាមេលើពួកវេនរបស់លោក ក្នុងពួកវេននេះមាន
២ម៉ឺន៤ពាន់នាក់ ៥មេទី៣ជាមេធំលើពួកទ័ពនៅ ខែជេស្ឋ
គឺបេណាយ៉ា[គ] ជាកូនយេហូយ៉ាដាដ៏ជាសង្ឃ ហើយនៅ
វេននេះមាន២ម៉ឺន៤ពាន់នាក់ ៦គឺបេណាយ៉ានេះ ជា
មនុស្សខ្លាំងពូកែក្នុងពួក៣០នាក់នោះ ហើយបានត្រួតលើ
គេផង ឯអាំមីសាបាឌ ជាកូនលោក ក៏នៅក្នុងវេននេះដែរ
៧មេទី៤ ដែលសំរាប់ខែអាសាឍ គឺអេសាអែល[ឃ] ជាប្អូន
យ៉ូអាប់ ហើយបន្ទាប់មកមានសេបាឌាជាកូនលោក ក្នុងវេន
នេះ មាន២ម៉ឺន៤ពាន់នាក់ ៨មេទី៥សំរាប់ខែស្រាពណ៍ គឺ
សាមហ៊ូត[ង] ជាពួកយីសរ៉ា ក្នុងវេននេះមាន២ម៉ឺន៤ពាន់
នាក់ ៩មេទី៦ សំរាប់ខែភត្របទ គឺអ៊ីរ៉ា[ច] ជាកូនអ៊ីកកេស
ជាអ្នកក្រុងត្កូអា ក្នុងវេននេះមាន ២ម៉ឺន៤ពាន់នាក់ ១០មេទី៧
សំរាប់ខែអាស្សុជគឺហេលែស[ឆ] ជាពួកពេឡូន ក្នុងពួកកូន
ចៅអេប្រាអិម ក្នុងវេននេះមាន២ម៉ឺន៤ពាន់នាក់ ១១មេទី៨
សំរាប់ខែកត្តិក គឺស៊ីបាកាយ[ជ] ជាពួកហ៊ូសាយ ក្នុងពូជពង្ស
សេរ៉ាស ក្នុងវេននេះមាន២ម៉ឺន៤ពាន់នាក់ ១២មេទី៩សំរាប់
ខែមិគ្គសិរ គឺអ័បៀសើរ[ឈ] ជាអ្នកក្រុងអាន៉ាថោត ពូជអំបូរ
បេនយ៉ាមីន ក្នុងវេននេះមាន២ម៉ឺន៤ពាន់នាក់ ១៣មេទី១០
សំរាប់ខែបុស្ស គឺម៉ាហារ៉ាយ[ញ] ជាអ្នកស្រុកនថូផាពូជពង្ស
សេរ៉ាស ក្នុងវេននេះមាន២ម៉ឺន៤ពាន់នាក់ ១៤មេទី១១
សំរាប់ខែមាឃ គឺបេណាយ៉ា[ដ] ជាអ្នកស្រុកពីរ៉ាថូន ក្នុងពូជ
អំបូរអេប្រាអិម ក្នុងវេននេះមាន២ម៉ឺន៤ពាន់នាក់ ១៥មេទី
១២ សំរាប់ខែផល្គុណ គឺហេលដាយ[ឋ] ជាអ្នកស្រុកនថូផា
ពូជពង្សអូធ្នាល[ឌ] ក្នុងវេននេះ ក៏មាន២ម៉ឺន៤ពាន់នាក់ដែរ ។

**២៧:២** ក ២សយ ២៣:៨
**២៧:៤** ខ ២សយ ២៣:៩
**២៧:៥** គ ២សយ ២៣:២០
**២៧:៧** ឃ ២សយ ២:១៨
**២៧:៨** ង ១រប ១១:២៧
**២៧:៩** ច ២សយ ២៣:២៦
**២៧:១០** ឆ ២សយ ២៣:២៦
**២៧:១១** ជ ២សយ ២១:១៨
**២៧:១២** ឈ ២សយ ២៣:២៧
**២៧:១៣** ញ ២សយ ២៣:២៨
**២៧:១៤** ដ ១រប ១១:៣១
**២៧:១៥** ឋ ២សយ ២៣:២៩ ឌ យស ១៥:១៧
**២៧:១៧** ឍ ១រប ២៦:៣០ ណ ២សយ ៨:១៧ ១រប ១២:២៨

## ពួកចៅហ្វាយពូជអំបូរ

១៦ឯពួកចៅហ្វាយ ក្នុងពូជអំបូរសាសន៍អ៊ីស្រាអែល
ទាំងប៉ុន្មាន នោះដូច្នេះ គឺក្នុងពួករូបេន មានអេលាសើរ
កូនស៊ីកគ្រី ដោយចៅហ្វាយ ក្នុងពួកស៊ីម្មាន គឺសេផាជាកូន
ម្អាកា ១៧ក្នុងពួកលេវី គឺហាសាបយ៉ា[ឍ] ជាកូនកេមយួល ក្នុង
វង្សរបស់អើរ៉ុន មានសាដុក[ណ] ១៨ក្នុងពួកយូដាគឺអេលីហ៊ូវ
ជាជេដ្ឋាដាវីឌ ក្នុងពួកអ៊ីសាខារ គឺអំរី ជាកូនមីកែល ១៩ក្នុង
ពួកសាប់យូឡូន គឺយីសម៉ាយ៉ា ជាកូនអូបាឌា ក្នុងពួកណែប
ថាលី គឺយេរីម៉ូត ជាកូនអាសរាល ២០ក្នុងពួកកូនចៅ
អេប្រាអិម គឺហូសេ ជាកូនអ័សាស៊ា ក្នុងពូជអំបូរម៉ាន៉ាសេ១
ចំហៀង គឺយ៉ូអែល ជាកូនពេដាយ៉ា ២១ក្នុងពូជអំបូរម៉ាន៉ា
សេ១ចំហៀង នៅស្រុកកាឡាត គឺយីដូរ ជាកូនសាការី ក្នុង
ពួកបេនយ៉ាមីនគឺយ្អាសៀល ជាកូនអ័ប៊ីនើរ ២២ក្នុងពួកដាន់
គឺអ័សារាល ជាកូនរបស់យេរ៉ូហាំ នេះសុទ្ធតែជាចៅហ្វាយ
នៃអស់ទាំងពូជអំបូរសាសន៍អ៊ីស្រាអែលទាំងអំបាលម៉ាន
២៣តែដាវីឌ មិនបានរាប់ចំនួនគេ ពីត្រឹមអាយុ២០ឆ្នាំ ចុះទៅ
ក្រោមទេ[ត] ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូលថា ទ្រង់នឹង
ចំរើនពួកអ៊ីស្រាអែល ឱ្យមានគ្នាច្រើន ដូចជាផ្កាយ[ថ] ដែល

**២៧:២៣** ត ២សយ ២៣:១ ១រប ២១:២–៥ ថ លប ១២:២

អស់មាន ២សែន៨ម៉ឺន៨ពាន់នាក់) ចំនួននេះមិនសមហេតុផលឡើយ ។ សេចក្ដីបញ្ជាក់ក្នុងអត្ថបទនេះទៅលើពួកកងទ័ព និងការបែងចែកបានបង្ហាញដូច្នេះថា នៅទីនេះភាសារសម្រាប់ពាក្យ"១ពាន់"ប្រហែលជាបានយកចំនួនពួកកងទ័ព ។ ការបង្ហាញនូវការបែងចែក "១ពាន់"គឺអាចក្លាយជាដែនកំណត់មួយលើចំនួនមនុស្ស ។

**២៧:២** *យ៉ាសុបៀម* សូមមើល ១១:១១ ។

**២៧:៤** *ដូដាយ* សូមមើល ១១:១២ ។

**២៧:៥** *បេណាយ៉ា* សូមមើល ១១:២២–២៥ ១៨:១៧ ។

**២៧:៩–១៥** សំណល់នៃពួកមេ គឺបានជ្រើសរើសក្នុងចំណោមពួកទាំង៣០នាក់ (សូមមើល ១១:២៥ ដែលឈ្មោះរបស់ពួកគេមាននិយាយនៅក្នុង ១១:២៧–៣១) ។

**២៧:១៦–២២** អ្នកកត់ត្រាពង្សាវតារមានចំណាប់អារម្មណ៍ទៅលើ"សាសន៍អ៊ីស្រាអែលទាំងអស់"ដែលមាននៅក្នុងខ.ទាំងនេះ សុទ្ធតែជាមន្ត្រី ដែលពួកគេមិនមែនមានតែ១២អំបូរប៉ុណ្ណោះនោះឡើយ (សូមមើល សេចក្ដីផ្ដើមៈ គោលបំណង និងផ្ទៃរឿង) ។ គេនៅរក្សាចំនួនអំបូរទាំង១២ ដោយលុបកាឌ់ និងអេសើរ (សូមមើល ២:១–២) ។

**២៧:១៧** *សាដុក* សូមមើល ការពន្យល់ក្នុង ៦:៨ និង ១២:២៨ ១៦:៣៩ ។

**២៧:១៨** *អេលីហ៊ូវ* ក្នុងចំណោមបងប្អូនរបស់ដាវីឌ គាត់មិនត្រូវបាននិយាយនៅកន្លែងណាទៀតឡើយ ។ ប្រហែលគាត់ជាកូនដែលគ្មានឈ្មោះដែលបាននិយាយក្នុង ២:១០–១៧ (សូមមើលទីនោះ) ។ អេលីហ៊ូវគាត់ប្រហែលជាកូនច្បងរបស់អ៊ីសាយដែលតែងតែប្តូរឈ្មោះជានិច្ច អាចជាអេលាភ ឬ សាច់ញ្ញាត្តិ ។

**២៧:២១** *អ័ប៊ីនើរ* ជាសាច់ញ្ញាត្តិរបស់ស្ដេចសូល (សូមមើល ២៦:២៨ ១សយ ១៤:៥០–៥១ ១៧:៥៥–៥៨ ២៦:៥–១៦ ២សយ ២:៨–៤:១) ។

**២៧:២៣–២៤** *ចំនួន* គឺសំដៅលើការធ្វើជំរឿនក្នុងជំពូក២១ (សូមមើល ២សយ ២៤) ។

**២៧:២៣** *ពីត្រឹម២០ឆ្នាំចុះទៅក្រោមទៅ* នៅក្នុង ១សយ ២១ និ ង២សយ ២៤ ចំនួនរបស់ពួកគេ គឺរាប់ចាប់ពីអាយុ២០ឆ្នាំឡើងទៅ ។ *ទ្រង់នឹងចំរើនពួកអ៊ីស្រាអែលឱ្យមានគ្នាច្រើន ដូចជាផ្កាយនៅលើមេឃ* សេចក្ដីសន្យាដែលទ្រង់បានសន្យាបានតាំងជាមួយពួកព្ទយុកោថា នឹងប្រទានពរឱ្យពួកកូនចៅអ៊ីស្រាអែលមានចំនួនច្រើនដូចជាផ្កាយ(សូមមើល លប ១២:២ ១៣:១៦ ១៥:៥ ២២:១៧) បានក្លាយជាទីសដៅមួយដើម្បីឱ្យយ៉ូអាប់ធ្វើជំរឿនបង្អើយ

នៅលើមេឃ ២៤យ៉ូអាប់ ជាកូនសេរូយ៉ា លោកចាប់តាំង
រាប់តែមិនបានបង្ហើយទេ ដ្បិតដំណើរនោះ បានបណ្តាលឱ្យ
មានសេចក្តីក្រោធ មកលើសាសន៍អ៊ីស្រាអែល ហើយចំនួន
ពួកគេ[ខ]នោះមិនបានកត់ទុក ក្នុងបញ្ជីពង្សាវតារនៃស្តេច
ដាវីឌទេ។

### អ្នករក្សាព្រះរាជទ្រព្យរបស់ស្តេច

២៥ឯអ្នករក្សាព្រះរាជទ្រព្យរបស់ស្តេច គឺអាសម៉ាវែត
ជាកូន អ័ឌីអែល ហើយយ៉ូណាថាន ជាកូនអ៊ូស៊ីយ៉ា ជាអ្នក
ត្រួតលើទ្រព្យសម្បត្តិ នៅស្រែចំការ នៅទីក្រុង និងភូមិ
ហើយនៅដំណាក់ទាំងប៉ុន្មាន ២៦អែសរីកូនកេលូបជាអ្នក
ត្រួតលើពួកអ្នកភ្ជួររាស់ នៅស្រែចំការ ២៧ស៊ីម៉ាយដែល
នៅក្រុងរ៉ាម៉ា ជាអ្នកត្រួតត្រាលើចំការទំពាំងបាយជូរ
ហើយសាប់ឌី ក្នុងពួកសេផាម ជាអ្នកត្រួតលើឃ្លាំងស្រា
ទំពាំងបាយជូរ ដែលនៅឯចំការ ២៨បាលហាន៉ាន់ដែលនៅ
ក្រុងកេឌើរ ជាអ្នកត្រួតលើចំការអូលីវ និងដើមឧទុម្ពរ[ធ]
ដែលដុះនៅស្រុកទំនាប ហើយយ៉ូអាស ជាអ្នកត្រួតលើឃ្លាំង
ប្រេងអូលីវ ២៩ស៊ីតរ៉ាយដែលនៅស្រុកសារ៉ុន ជាអ្នកត្រួត
លើហ្វូងសត្វ ដែលរកស៊ីនៅស្រុកសារ៉ុន[ន] ហើយសាផាត
កូនអ័ឌ្លាយ ជាអ្នកត្រួតលើហ្វូងសត្វ ដែលនៅច្រកភ្នំទាំង
ប៉ុន្មាន ៣០អូប៊ីលសាសន៍អ៊ីសម៉ាអែល ជាអ្នកត្រួតលើហ្វូងអូដ្ឋ
យេដាយ៉ា ដែលនៅស្រុកមេរ៉ូន ជាអ្នកត្រួតលើហ្វូងលា
យ៉ាស៊ីស ក្នុងពួកហាក់រេន[ប] ជាអ្នកត្រួតលើហ្វូងចៀម ៣១អ្នក
ទាំងនេះសុទ្ធតែជា អ្នកត្រួតលើព្រះរាជទ្រង់របស់ស្តេច

**២៧:២៤** ទ ២សយ ២៤:១៥ ១រប ២១:១៤
**២៧:២៨** ធ ១ពវ ១០:២៧
**២៧:២៩** ន ២:១ អស ៣៣:៩ ៣៥:២ ៦៥:១០ ប ១រប ៥:១០
**២៧:៣៣** ផ ២សយ ១៥:១២ ព ២សយ ១៥:៣៧
**២៧:៣៤** ភ ១សយ ២២:២០ ម ២សយ ២:១៣
**២៨:១** ក ១រប ២២:១៧ ខ ១រប ២៧:១–៣១ ២៩:៦
**២៨:២** គ ១សយ ១០:៧ ១រប ១៧:២ ឃ ២រប ៦:៤១ ង ទដ ៩៩:៥ ១៣២:៧ អស ៦០:១៣ ច ទដ ១៣២:១–៥
**២៨:៣** ឆ ២សយ ៧:៥ ជ ១រប ២២:៨ ឈ ១ពវ ៥:៣ ១រប ១៧:៤

ដាវីឌ ។
៣២ឯយ៉ូណាថាន ជាញាតិវង្សនឹងដាវីឌ ជាអ្នកជួយ
គំនិតជាមនុស្សមានយោបល់ និងប្រាជ្ញា យេហ៊ីអែលជា
កូនហាក់ម៉ូនី ជាអ្នកនៅជាមួយនឹងពួកបុត្ររបស់ស្តេច
៣៣អ័ហ៊ីថូផែល[ផ] ជាអ្នកដែលជួយគំនិតដល់ស្តេច ហើយ
ហ៊ូសាយ[ព] ជាពួកអើគី ជាអ្នកជិតស្និទ្ធនឹងស្តេច ៣៤បន្ទាប់ពី
អ័ហ៊ីថូផែលមក នោះមានយេហូយ៉ាដា ជាកូនបេណាយ៉ា
និងអ័បៀថើរ[ភ] ហើយយ៉ូអាប់[ម] ជាមេទ័ពធំរបស់ស្តេច ។

### ផែនការស្តេចដាវីឌសម្រាប់ព្រះវិហារ

២៨ ១គ្រានោះដាវីឌទ្រង់ប្រមូល[ក]ពួកអ្នកដែលជាប្រធាន[ខ]
ក្នុងសាសន៍អ៊ីស្រាអែល ពួកចៅហ្វាយនៃពូជអំបូរទាំង
ប៉ុន្មាន ពួកនាយដែលត្រួត លើពួកអ្នកផ្លាស់ផ្លង់ស្នៀងថ្វាយ
ស្តេចតាមវេន ពួកមេទ័ពធំតូច ពួកអ្នកដែលត្រួតលើព្រះ
រាជទ្រព្យរបស់ស្តេច និងពួកបុត្រាទ្រង់ទាំងប៉ុន្មាន និងពួក
ឧកញ៉ា គឺជាពួកខ្លាំងពូកែ មានចិត្តក្លាហានទាំងអស់មកប្រជុំ
គ្នានៅក្រុងយេរូសាឡិម ២រួចស្តេចដាវីឌទ្រង់ក្រោកឈរ
ឡើងមានបន្ទូលថា ឱបងប្អូន ជារាស្ត្ររបស់យើងអើយ
ចូរស្តាប់ចុះ ឯយើងបានមានបំណង[គ] ចង់ស្អាងព្រះវិហារ
សំរាប់ឱ្យហឹបនៃសេចក្តីសញ្ញាផងព្រះយេហូវ៉ាបានសំរាក[ឃ]
នៅ ហើយទុកជាទីកំណល់កល់ព្រះ បាទ[ង]របស់ព្រះនៃយើង
រាល់គ្នា យើងក៏បានត្រៀមទុកសំរាប់ការស្អាងនោះដែរ[ច]
៣តែព្រះទ្រង់មានបន្ទូលមកយើងថា[ឆ] ឯងមិនត្រូវស្អាងព្រះ
វិហារ សំរាប់ឈ្មោះអញឡើយ[ជ] ដ្បិតឯងជាមនុស្សធ្លាប់

(ខ.២៤ ហើយមើល ២១:៣ ២សយ ២៤:៣) ។

**២៧:២៤** *មិនបានបង្ហើយ* យ៉ូអាប់គាត់មិនបានរាប់ចំនួនមនុស្សដែលមានអាយុក្រោម២០ឆ្នាំឡើយ ក៏មិនបានរាប់ពួកលេវី និងបេនយ៉ាមីនដែរ (សូមមើល ២១:៦)។ *បញ្ជីពង្សាវតារនៃស្តេចដាវីឌ* សូមមើលសេចក្តីផ្តើម: អ្នកនិពន្ធកាលបរិច្ឆេទ និងប្រភព ។

**២៧:២៥–៣១** នៅក្នុងខ.ទាំងនេះ និយាយអំពីបញ្ជីឈ្មោះនៃអ្នកត្រួតត្រាលើទ្រព្យរបស់ដាវីឌ(ខ.៣១)។ ទីក្រុងធំៗរបស់ពួកអ្នកនៅក្បែរមជ្ឈឹមបូព៌ាសម័យបុរាណមានសេដ្ឋកិច្ចគ្រឹះសំខាន់ៗ៣ផ្នែក (ទី១) ស្តេច (ទី២) ព្រះវិហារ (ទី៣) ជាលក្ខណៈបុគ្គល ។ គ្មានភស្តុតាងណាមួយដែលបាននិយាយពីការបង់ពន្ធក្នុងអំឡុងកាលរាជ្យស្តេចដាវីឌឡើយ ។ នៅក្នុងដំណាក់របស់គាត់មានហិរញ្ញវត្ថុ ដោយសារការធ្វើកសិកម្មជិន្នូញ និងការចាប់របឹបក្នុងពេលមានសង្គ្រាមរួមទាំងរបស់ដែលប្រទេសចំនុះផ្សេងៗផ្តល់ឱ្យ ។

**២៧:២៧** *ឃ្លាំងស្រាទំពាំងបាយជូរ* សូមមើល ហាក ២:១៦ ។

**២៧:៣២–៣៤** នៅក្នុងខ.គម្ពីរនេះគឺរៀបរាប់ឈ្មោះប្រពន្ធចុងរបស់ស្តេចដាវីឌ បន្ថែមលើអ្វីដែលបាននិយាយនៅ ១៨:១៤–១៧ ។

**២៧:៣៣** *អ័ហ៊ីថូហែល* គាត់ត្រូវបានជិនួសដោយអ្នកផ្សេងៗបន្ទាប់ពីគាត់បានសម្រេចចិត្តធ្វើអត្តឃាត ដោយគាត់បានគាំទ្រចំពោះការក្បត់របស់អាប់ឡំម (សូមមើល ២សយ ១៥:១២,៣១–៣៧ ១៦:២០–១៧:២៣) ។

**២៧:៣៤** *បេណាយ៉ា* សូមមើល ខ.៥ ។

**២៨:១–២៩:៣០** នៅពេលគេធ្វើការប្រៀបធៀបនិទានកថានៃការស្នងរាជ្យនៅក្នុង ១ពវ ១–២ ជាមួយខ.គម្ពីរទាំងនេះគេឃើញថា នៅក្នុងចំនុចនេះដែលជាស្ពានចម្លងពីរាជ្យស្តេចដាវីឌមកក្នុងរាជ្យស្តេចសាឡូម៉ូន អ្នកកត់ត្រាពង្សាវតារគាត់បានធ្វើការពន្យល់បង្ហាញច្បាស់លាស់បំផុតអំពីរាជ្យរបស់គេ ។ ក្នុងគម្ពីរបាក្សត្រមិនបានធ្វើការផ្តោតលើគុណវិបត្តិពីជន្មាយុកន្លងបង់របស់ដាវីឌ(សូមមើល ១ពវ ១:១–៤) ការបះបោររបស់អ័ដូនីយ៉ា និងបុត្ររបស់ទ្រង់ (១ពវ ១:៥–១០) ល្បិចកល្បដណ្តើមរាជ្យពីសាឡូម៉ូន (១ពវ ១:១១–៣១ ឬតួរនាទីរបស់ដាវីឌ ផ្តល់ឱ្យសាឡូម៉ូនដើម្បីដាក់ទណ្ឌកម្មលើខ្មាំងសត្រូវនោះឡើយ (១ពវ ២:១–៩) ។

**២៨:១** ការជួបជុំនោះគឺបង្កើតឡើងដោយក្រុមមនុស្សដែលបាននិយាយនៅក្នុងជំពូក ២៧ ។ ការប្រកាសជាសាធារណៈនៅពេលនេះ(សូមមើលខ.៥) គឺធ្វើតាមរបៀបដែលបានប្រកាសជាលក្ខណៈផ្ទាល់ខ្លួន ពីការស្នងរាជ្យរបស់សាឡូម៉ូន ដែលបាននិយាយនៅក្នុងជំពូក២២ (សូមមើល ២២:២–១៩) ។

**២៨:៣** *ឯងជាមនុស្សធ្លាប់ធ្វើចំបាំងមក ហើយបានកំចាយឈាមផង* សូមមើលការពន្យល់ក្នុង ២២:៨–៩ ។

ធ្វើចំបាំងមក ហើយបានកំចាយឈាមផង[ឈ] ៤ប៉ុន្តែព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់បានរើស
យើង[ញ]ចេញ ពីពួកវង្ស[ដ]របស់បិតាយើងទាំង ប៉ុន្មានឱ្យបាន
ធ្វើជាស្តេចលើពួកអ៊ីស្រាអែលជាដរាបទៅ ដ្បិតទ្រង់បាន
រើសពួកយូដា[ឋ]ទុកជាមេ ហើយក្នុងពួកវង្សយូដានោះទ្រង់
បានរើសយកវង្សរបស់បិតាយើង ហើយក្នុងពួកបុត្ររបស់
បិតាយើង នោះទ្រង់បានសព្វព្រះហឫទ័យនឹងយើង ដើម្បី
លើកឡើងជាស្តេចលើសាសន៍អ៊ីស្រាអែលទាំងអស់[ឌ]
៥ហើយក្នុងពួកបុត្រយើងទាំងប៉ុន្មាន (ដ្បិតព្រះយេហូវ៉ាទ្រង់
បានប្រោសឱ្យយើងបានបុត្រជាច្រើន[ឍ]) នោះទ្រង់បានរើស
សាឡូម៉ូន[ណ] ជាបុត្រយើងឱ្យបានគង់លើបល្ល័ង្ករាជ្យ[ត]នៃព្រះ
យេហូវ៉ា ដើម្បីគ្រប់គ្រងលើសាសន៍អ៊ីស្រាអែល ៦ទ្រង់បាន
មានបន្ទូលមកយើងថា សាឡូម៉ូន ជាកូនឯងនឹងស្អាង[ថ]ព្រះ
វិហារ ព្រមទាំងទីលានឱ្យអញ ដ្បិតអញបានរើសវាឱ្យបាន
ធ្វើជាកូនអញ[ទ] ហើយអញនឹងធ្វើជាឪពុកដល់វា ៧អញនឹង
តាំងរាជ្យវា ឱ្យនៅជាប់ជានិច្ចទៅគឺបើវាកាន់ខ្ជាប់តាម
ក្រិត្យក្រម និងបញ្ញត្តទាំងប៉ុន្មានរបស់អញ[ធ] ដូចជាសព្វ
ថ្ងៃនេះ ៨ឥឡូវនេះ អ្នករាល់គ្នានៅចំពោះពួកអ៊ីស្រាអែល
ទាំងអំបាលម៉ាន[ន] ជាពួកជំនុំនៃព្រះយេហូវ៉ា ហើយនៅ
ចំពោះព្រះនៃយើងរាល់គ្នា ដូច្នេះ ចូរអ្នករាល់គ្នាស្វែងរក
ហើយកាន់តាមអស់ទាំងក្រិត្យក្រម[ប]នៃព្រះយេហូវ៉ាជាព្រះ
នៃអ្នករាល់គ្នាចុះ ដើម្បីឱ្យបានស្រុកល្អនេះ ទុកជាកេរ្តិ៍
អាករនៃអ្នករាល់គ្នា ហើយទុកជាមរដកដល់កូនចៅអ្នក
រាល់គ្នា ក្រោយតទៅ[ផ]។
៩ហើយឯងឯង ឱសាឡូម៉ូន ជាកូនអញអើយ ចូរឱ្យឯងបាន
ស្គាល់ព្រះនៃឪពុកឯងចុះ ព្រមទាំងប្រតិបត្តិតាមទ្រង់ ដោយ
អស់ពីចិត្ត[ព] ហើយស្ម័គ្រស្មោះផង ដ្បិតព្រះយេហូវ៉ាទ្រង់
ស្ទង់អស់ទាំងចិត្ត[ភ] ក៏យល់អស់ទាំងសេចក្តីដែលយើងគិត
ដែរ បើឯងរកទ្រង់[ម] នោះនឹងបានឃើញមែន តែបើឯង
បោះបង់ចោល[យ]ទ្រង់វិញ នោះទ្រង់ក៏នឹងបោះបង់ចោល[រ]
ឯងជាដរាបទៅ ១០ឥឡូវនេះ ចូរឯងប្រុងប្រយ័តដ្បិតព្រះ
យេហូវ៉ាបានរើសឯង ឱ្យបានស្អាងព្រះវិហារទុកជាទី
បរិសុទ្ធ ដូច្នេះ ចូរឯងមានកំឡាំងឡើង ហើយធ្វើសំរេចចុះ
១១នោះដាវីឌក៏ប្រគល់គំរូ[ល]នៃរបស់ទាំងប៉ុន្មាន ដល់
សាឡូម៉ូន ជាបុត្រទ្រង់ គឺជាគំរូនៃបាំងសាច មន្ទីរទាំង
ប៉ុន្មាន ឃ្លាំង បន្ទប់ខាងលើ បន្ទប់ខាងក្នុង និងកន្លែងដាក់ទី
សន្តោសប្រោះ ១២ហើយនឹងគំរូនៃរបស់ទាំងប៉ុន្មានដែល
ទ្រង់បានដោយព្រះវិញ្ញាណ[វ] សំរាប់ទីលានរបស់ព្រះវិហារ
នៃព្រះយេហូវ៉ា អស់ទាំងបន្ទប់នៅជុំវិញ ដែលសំរាប់ជា
ឃ្លាំងរបស់ព្រះវិហារនៃព្រះ និងឃ្លាំងនៃដង្វាយបរិសុទ្ធ
ទាំងប៉ុន្មាន[ស] ១៣ហើយសំរាប់វេនពួកសង្ឃ និងពួកលេវី
ហើយសំរាប់កិច្ចការ[ហ] នៃការងារទាំងអស់ ក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា ព្រមទាំងគ្រឿងប្រដាប់ ដែលប្រើក្នុងព្រះ
វិហារនៃព្រះយេហូវ៉ាដែរ ១៤ដាវីឌទ្រង់ក៏ប្រគល់គំរូនៃ
ប្រដាប់ដែលត្រូវធ្វើពីមាសសំរាប់ប្រើគ្រប់យ៉ាង ព្រមទាំង
ទំងន់នៃប្រដាប់និមួយៗនោះ នឹងគំរូនៃប្រដាប់ ដែលត្រូវធ្វើ
ពីប្រាក់សំរាប់ប្រើគ្រប់យ៉ាង ព្រមទាំងទំងន់នៃប្រដាប់និមួយ
ៗនោះដែរ ១៥គឺកំណត់ទំងន់មាសសំរាប់ធ្វើជើងចង្កៀង
មាសនឹងតួចង្កៀងនោះ[ឡ] គឺជាទំងន់ជើងចង្កៀងនិមួយៗ
នឹងតួចង្កៀងនិមួយៗ ហើយកំណត់ទំងន់ប្រាក់សំរាប់ធ្វើជើង
ចង្កៀងប្រាក់ ទាំងជើង នឹងតួចង្កៀងនោះផង តាមរបៀប
ប្រើជើងចង្កៀងនិមួយៗនោះ ១៦ហើយមាសសំរាប់ធ្វើ
តុនំបុ័ងតាំងទុក[អ] នឹងប្រាក់សំរាប់អស់ទាំងតុធ្វើពីប្រាក់ដែរ
១៧ព្រមទាំងសម ចានគោម និងពែងដែលធ្វើពីមាសសុទ្ធ
និងផ្តិលមាស[ក] តាមទំងន់និមួយៗ ហើយផ្តិលប្រាក់ទាំង
ប៉ុន្មានតាមទំងន់ ១៨នឹងមាសសុទ្ធសំរាប់អាសនាគ្រឿង
ក្រអូប[ខ]តាមទំងន់ផង ទ្រង់ក៏ប្រគល់គំរូ ដែលសំរាប់ធ្វើ
រទេះ[គ] និងចេរូប៊ីន ដែលត្រដាងស្លាបគ្របពីលើ[ឃ]ហឹបនៃ
សេចក្តីសញ្ញាផង ព្រះយេហូវ៉ាដែរ ១៩រួចទ្រង់មានបន្ទូលថា

**២៨:៤** ញ ២របា ៦:៦ ដ ១សយ ១៦:១-១៣ ឋ លប ៤៩:១០ ជន ២៤:១៧-១៩ ឌ ១របា ១១:១
**២៨:៥** ឍ ១របា ៣:១ ណ ១សយ ១២:២៤ ១របា ២៣:១ ត ១របា ១៧:១៤
**២៨:៦** ថ ១ពវ ៨:២០ ទ ២សយ ៧:១៣ ១របា ១៧:១៣
**២៨:៧** ធ ១របា ២២:១៣
**២៨:៨** ន ១របា ៩:១ ប ចទ ៦:១ ផ ចទ ៤:១ ១៧:១៤-២០
**២៨:៩** ព ១របា ២៩:១៩ ភ ១សយ ២:៣ ២របា ៦:៣០ ទដ ៧:៩ ម ១របា ១៦:១១ ទដ ៤០:១៦ យ ចទ ៤:៣១ យស ២៤:២០ ២របា ៧:១៩ ១៥:២ រ ១ពវ ៩:៧ ទដ ៤៤:២៣ ៧៤:១ ៧៧:៧
**២៨:១១** ល នក ២៥:៩ កច ៧:៤៤ ហព ៨:៥
**២៨:១២** វ ១របា ១២:១៨ ស ១របា ២៦:២០
**២៨:១១** ល នក ២៥:៩ កច ៧:៤៤ ហព ៨:៥
**២៨:១២** វ ១របា ១២:១៨ ស
**២៨:១៣** ហ ១របា ២៤:១ **២៨:១៥** ឡ នក ២៥:៣១
**២៨:១៦** អ នក ២៥:២៣ **២៨:១៧** ក នក ២៧:៣ **២៨:១៨** ខ នក ៣០:១-១០ គ នក ២៥:២០ ឃ នក ២៥:២០ **២៨:១៩** ង ១ពវ ៦:៣៨ ច នក ២៥:៩

**២៨:៥** *នោះទ្រង់បានជ្រើសរើសសាឡូម៉ូន ជាបុត្រយើង* សូមមើល២.៦,១០ ២៩:១ ។ នៅក្នុងសញ្ញាចាស់មានប្រើតែម្តងគត់ចំពោះកិរិយាស័ព្ទរបស់ហេព្រើរលើពាក្យថា "ជ្រើសរើស"ដែលសំដៅលើស្តេចផ្សេងៗទៀតបន្ទាប់ពីដាវីឌ(សូមមើលសេចក្តីផ្តើមៈគោលបំណង និងផ្ទៃរឿង) ។ *បល្ល័ង្ករាជ្យនៃព្រះយេហូវ៉ា* សូមមើល ១៧:១៤ ។

**២៨:៦** *ជាកូនអញ* សូមមើល ១៧:១២-១៤ និង ២២:១០ ។

**២៨:៨-៩** សូមមើលសេចក្តីផ្តើមៈ ពិពណ៌នារាជ្យដាវីឌ និងសាឡូម៉ូន ។

**២៨:១២** ស្តេចដាវីឌទ្រង់បានឱ្យគម្រោង នៃការសាងសង់ព្រះវិហារដល់សាឡូម៉ូន ។ ការនេះបានឆ្លុះបញ្ចាំងពីការត្រាប់តាមរបស់អ្នកកត់ត្រាពង្សាវតារចំពោះដាវីឌ បន្ទាប់ពីលោកម៉ូសេ ដែលដូចគ្នានឹងលោកម៉ូសេគាត់បានទទួលគម្រោងសម្រាប់សង់រោងឧបោសថមកពីព្រះអម្ចាស់ដែរ (សូមមើល នក ២៥-៣០) ក៏ដូចដែលដាវីឌបានទទួលគម្រោងសម្រាប់សាងសង់ព្រះវិហារដែរ។

**២៨:១៨** *រទេះ* ប្រហែលជាបល្ល័ង្គចល័តរបស់ព្រះអម្ចាស់ (សូមមើល ទដ ១៨:១០) ។

**២៨:១៩** *កត់ទុក ដោយព្រះយេហូវ៉ា* ប្រហែលអ្នកកត់ត្រាពង្សាវតារគាត់គ្មាន

បណ្ដាបែបយ៉ាងទាំងនេះ បានកត់ទុក ដោយព្រះហស្តព្រះ
យេហូវ៉ា ឱ្យអញបានយល់ហើយ គឺអស់ទាំង[ង] របៀបនៃគំរូ
ទាំងនេះឯង[ច] ។
២០ដាវីឌទ្រង់មានបន្ទូលនឹងសាឡូម៉ូនជាព្រះរាជបុត្រាថា
ចូរមានកំឡាំង និងចិត្តក្លាហានឡើង ហើយធ្វើសំរេចចុះ
កុំឱ្យខ្លាច ឬរសាយចិត្តឡើយ ដ្បិតព្រះយេហូវ៉ាដ៏ជាព្រះ
គឺជាព្រះនៃអញ ទ្រង់គង់នៅជាមួយនឹងឯង ទ្រង់មិនដែល
ខាននឹងជួយឯងឡើយ ក៏មិនបោះបង់ចោល[ឆ]ឯងដែរ ដរាប
ដល់អស់ទាំងការ ដែលធ្វើព្រះវិហារនៃព្រះយេហូវ៉ានេះ
បានសំរេច[ជ] ២១ហើយមើល មានវេនពួកសង្ឃនឹងពួកលេវី
សំរាប់គ្រប់ទាំងការងារក្នុងព្រះវិហារនៃព្រះដែរ ឯអស់
អ្នកណាដែលស្ម័គ្រចិត្ត ហើយមានថ្វីដៃ[ឈ]ខាងឯការអ្វីក៏
ដោយ គេនឹងនៅជាមួយនឹងឯង ដើម្បីនឹងសំរេចការនេះ
ចំណែកពួកចៅហ្វាយ និងបណ្ដាជនទាំងអស់គ្នា គេនឹងនៅ
ក្នុងបង្គាប់ឯងដែរ ។

## អំណោយទានស្អាងព្រះវិហារ

**២៩** ១លំដាប់មក ស្ដេចដាវីឌទ្រង់មានបន្ទូលដល់ពួកជំនុំ
ទាំងអស់គ្នាថា សាឡូម៉ូន ជាបុត្រយើងនេះ គឺជាបុត្រតែ១
ដែលព្រះបានរើសទុក ទ្រង់នៅក្មេងខ្ចីនៅឡើយ[ក] ហើយ
ការនេះធំណាស់ ដ្បិតព្រះវិហារនេះ មិនមែនសំរាប់មនុស្ស
គឺសំរាប់ព្រះយេហូវ៉ាដ៏ជាព្រះវិញ ២យើងបានត្រៀមការ
អស់ពីចិត្ត សំរាប់ព្រះវិហាររបស់ព្រះនៃយើង គឺជាមាស
សំរាប់ប្រដាប់ធ្វើពីមាស[ខ] ប្រាក់សំរាប់ប្រដាប់ធ្វើពីប្រាក់
លង្ហិន សំរាប់ប្រដាប់ធ្វើពីលង្ហិន ដែលសំរាប់ប្រដាប់ធ្វើពី
ដែក ឈើសំរាប់ប្រដាប់ធ្វើពីឈើថ្មអូនីក្យ[គ] និងត្បូងសំរាប់
បញ្ចុះ ដែលមានពណ៌ផ្សេងៗ និងត្បូងមានដំឡៃគ្រប់មុខ
ព្រមទាំងថ្មកែវជាបរិបូរ[ឃ] ៣មួយទៀត ដោយព្រោះយើង
មានចិត្តស្រលាញ់ ដល់ព្រះវិហាររបស់ព្រះនៃយើងបានជា
យើងប្រគល់មាស និងប្រាក់ទាំងប៉ុន្មាន ដែលជារបស់ផង
ខ្លួនយើង សំរាប់ព្រះវិហាររបស់ព្រះនៃយើងក្រៅអំពីរបស់
ទាំងប៉ុន្មាន ដែលយើងបានត្រៀមទុក[ង]សំរាប់ទីបរិសុទ្ធនេះ

**២៨:២០** ឆ ចទ ៣១:៦ ១រប ២២:១៣ ២រប ១៩:១១ ហក ២:៤ ជ ចទ ៤:៣១ យស ២៤:២០ ឈ ១ពវ ៦:១៤ ២រប ៧:១១
**២៨:២១** ញ នក ៣៥:២៤–៣៦:៥
**២៩:១** ក ១ពវ ៣:៧ ១រប ២២:៥ ២រប ១៣:៧
**២៩:២** ខ ខ.៧,១៤, ១៦ អរ ១:៤ ៦:៥ ហក ២:៨ គ អស ៥៤:១១ ឃ ១រប ២២:២–៥
**២៩:៣** ង ២រប ២៤:១០ ៣១:៣ ៣៥:៨
**២៩:៤** ច លប ១០:២៩ ឆ ១រប ២២:១៤
**២៩:៦** ជ ១រប ២៧:១ ២៨:១ ឈ ខ.៩ នក ២៥:១–៨ ៣៥:២០–២៩ ៣៦:២ ២រប ២៤:១០ អរ ៧:១៥
**២៩:៧** ញ នក ២៥:២ នហ ៧:៧០–៧១
**២៩:៨** ដ នក ៣៥:២៧ ឋ ១រប ២៦:២១
**២៩:៩** ឌ ១ពវ ៨:៦១
**២៩:១១** ឍ ២៤:៨ ៥៩:១១ ៦២:១១ ណ ទដ ៨៩:១១ ត វវ ៥:១២–១៣

៤គឺមាស៣ពាន់ហាប ជាមាសស្រុកអូភារ[ច]ប្រាក់ ដែលសំរង
ស្រាប់[ឆ]៧ពាន់ហាប សំរាប់នឹងស្រោបជញ្ជាំងមន្ទីរទាំង
ប៉ុន្មាន ៥ហើយមាសសំរាប់ប្រដាប់ធ្វើពីមាស នឹងប្រាក់
សំរាប់ប្រដាប់ធ្វើពីប្រាក់ ហើយសំរាប់គ្រប់ទាំងការ ដែល
ពួកជាងមានស្នាដៃនឹងធ្វើ ដូច្នេះ នៅថ្ងៃនេះ តើមានអ្នកណា
ចូលចិត្ត ចង់ថ្វាយដល់ព្រះយេហូវ៉ាដែរឬទេ ។
៦គ្រានោះពួកអ្នកដែលជាកំពូលលើវង្សរបស់ឪពុកគេ
ពួកចៅហ្វាយនៃពូជអំបូរអ៊ីស្រាអែលទាំងប៉ុន្មាន និងពួក
មេធំតូច ហើយពួកនាយ[ជ]ដែលត្រួតការរបស់ស្ដេច គេក៏
ថ្វាយដោយស្ម័គ្រពីចិត្ត[ឈ] ៧គេ[ញ]ថ្វាយសំរាប់ការងារក្នុង
ព្រះវិហារនៃព្រះ ជាមាស៥ពាន់ហាប និង១ម៉ឺនដី ប្រាក់១
ម៉ឺនហាប លង្ហិន១ម៉ឺន៨ពាន់ហាប និងដែក១សែនហាប
៨ហើយអ្នកណាដែលមានត្បូង[ដ] នោះក៏ថ្វាយទៅក្នុងឃ្លាំង
ព្រះវិហារនៃព្រះយេហូវ៉ា ក្រោមអំណាចយេហ៊ីអែលជា
ពួកគើសុន[ឋ] ៩នោះបណ្ដាជនទាំងឡាយក៏រីករាយសប្បាយ
ដោយបានថ្វាយស្ម័គ្រពីចិត្ត[ឌ] ពីព្រោះគេបានថ្វាយស្ម័គ្រពី
ចិត្តដល់ព្រះយេហូវ៉ា ដោយចិត្តស្មោះ ហើយស្ដេចដាវីឌ
ទ្រង់ក៏រីករាយសប្បាយ ដោយអំណរជាខ្លាំងដែរ ។

## សេចក្ដីអធិស្ឋានរបស់ស្ដេចដាវីឌ

១០ហេតុនោះ ដាវីឌទ្រង់ក៏បង្គំទូលដល់ព្រះយេហូវ៉ានៅ
ចំពោះពួកជំនុំទាំងអស់គ្នាថា ឱព្រះយេហូវ៉ា ជាព្រះនៃ
អ៊ីស្រាអែល ព្ធយុកោយើងរាល់គ្នាអើយ សូមឱ្យទ្រង់បាន
ព្រះពរនៅអស់កល្បជានិច្ច ១១ឱព្រះយេហូវ៉ាអើយភាពដ៏ធំ
នឹងព្រះចេស្ដា[ឍ] សិរីល្អ ជ័យជំនះ និងតេជានុភាព នោះសុទ្ធ
តែជារបស់ផងទ្រង់[ណ] ដ្បិតគ្រប់ទាំងអស់ដែលនៅលើមេឃ
និងនៅផែនដី ជារបស់ផងទ្រង់ ឱព្រះយេហូវ៉ាអើយ រាជ្យ
នេះក៏ជារបស់ផងទ្រង់ដែរ ហើយទ្រង់បានដំកើងឡើងជា
ប្រធានលើទាំងអស់[ត] ១២ទ្រព្យសម្បត្តិនឹងកេរ្តិ៍ឈ្មោះ[ថ]ក៏មក
អំពីទ្រង់ ហើយគឺទ្រង់ដែលគ្រប់គ្រង[ទ]លើទាំងអស់ នៅព្រះ
ហស្តទ្រង់មានទាំងព្រះចេស្ដា និងឥទ្ធឫទ្ធិ ហើយទ្រង់មាន

**២៩:១២** ថ ២រប ១:១២ ៣២:២៧ អរ ៧:២៧ សស ៥:១៩ ទ ២រប ២០:៦

ចេតនាទូន្មានថែមទៀតឡើយ ហេតុដូច្នេះហើយបានជាដាវីឌគាត់សរសេរ ចុះក្រោមការដឹកនាំរបស់ព្រះអម្ចាស់ ។ មួយទៀតប្រហែលជាគាត់ប្រៀបធៀបថាដាវីឌគាត់មានលក្ខណៈសម្បត្តិដូចជាលោកម៉ូសេដែរ បានទទួលឯកសារ និងក្រឹត្យវិន័យមកដោយព្រះហស្តនៃព្រះ (សូមមើល ២៥:៤០ ២៧:៨ ៣១:១៨ ៣២:១៦) ។

**២៨:២០** សូមមើលសេចក្ដីផ្ដើមៈ ពណ៌នារាជ្យដាវីឌ និងសាឡូម៉ូន ។

**២៩:១** *រើសទុក* មើល ២៨:៥ ។ *នៅក្មេងខ្ចី* មើលការពន្យល់ក្នុង ២២:៥។

**២៩:២–៩** បន្ទាប់ពីបានបរិច្ចាកទ្រព្យសម្បត្តិផ្ទាល់ខ្លួន សម្រាប់កសាងព្រះវិហារអស់ ស្ដេចដាវីឌទ្រង់បានមកឯបណ្ដាជនទាំងអស់ដើម្បីសុំជំនួយស្ម័គ្រចិត្តពីពួកគេ ។ ជាថ្មីម្ដងទៀត អ្នកកត់ត្រាពង្សាវតារបានតាក់តែងដំណើររឿងរបស់ស្ដេចដាវីឌ ដោយយកគំរូតាមព្រឹត្តិការណ៍ដែលមាននៅ ក្នុងជីវិតលោកម៉ូសេ (សូមមើល នក ២៥:១–៨,២០–២៩) ។ ប្រជាជនមានឆន្ទៈមោះមុតក្នុងការផ្ដល់ជំនួយដើម្បីសាងសង់ព្រះវិហារនិងរោងឧបោសថ ។

**២៩:៧** *ហាប* ហាបគឺជាកាក់របស់ពួកពើស៊ី ដែលប្រហែលជាសំដៅលើឈ្មោះ ដារីយុស (៥២២–៤៨៦ មុន គ.ស) ដែលបានលេចឡើងនៅក្នុងឆ្នាំទី១នៃរាជ្យរបស់ទ្រង់ (សូមមើល អរ ៨:២៧) ។

អំណាចនឹងលើកជាធំ ហើយប្រោសឱ្យមានកំឡាំងដល់
មនុស្សទាំងអស់ ១៣ដូច្នេះ ឱព្រះនៃយើងរាល់គ្នាអើយ យើង
ខ្ញុំអរព្រះគុណដល់ទ្រង់ ហើយក៏លើកសរសើរព្រះនាម
ទ្រង់ដ៏មានសិរីល្អ ១៤តែតើទូលបង្គំជាអ្វី ហើយរាស្ត្ររបស់
ទូលបង្គំនេះជាអ្វី ដែលយើងខ្ញុំរាល់គ្នា អាចនឹងថ្វាយដង្វាយ
យ៉ាងនេះ[ធ] ដោយស្ម័គ្រពីចិត្តបាន ដ្បិតគ្រប់របស់ទាំងអស់
មកពីទ្រង់ យើងខ្ញុំរាល់គ្នាបានយកតែពីព្រះហស្តទ្រង់
ថ្វាយដល់ទ្រង់វិញ[ន] ១៥ពីព្រោះយើងខ្ញុំរាល់គ្នាជាអ្នកដទៃ
សុទ្ធ[ប]នៅចំពោះទ្រង់ ហើយជាពួកអ្នកដែលគ្រាន់តែស្នាក់
នៅប៉ុណ្ណោះ ដូចជាពួកព្ធយុកោយើងខ្ញុំរាល់គ្នាដែរ វេលា
អាយុយើងខ្ញុំរាល់គ្នានៅផែនដីនេះ នោះប្រៀបដូចជា
ស្រមោលទេ[ផ] គ្មានអ្វីជាជាប់ស្ថិតស្ថេរបានឡើយ ១៦ឱព្រះ
យេហូវ៉ា ជាព្រះនៃយើងខ្ញុំរាល់គ្នាអើយ អស់ទាំងរបស់
បរិបូរទាំងនេះ ដែលយើងខ្ញុំរាល់គ្នាបានត្រៀមទុក ដើម្បី
នឹងស្អាងព្រះវិហារថ្វាយដល់ទ្រង់ សំរាប់ព្រះនាមបរិសុទ្ធ
ទ្រង់ នោះសុទ្ធតែមកពីព្រះហស្តទ្រង់ទេ ហើយជារបស់ផង
ទ្រង់ទាំងអស់ដែរ ១៧ឱព្រះនៃទូលបង្គំអើយ ទូលបង្គំក៏ដឹង
ហើយថា គឺទ្រង់ដែលល្បងលចិត្ត[ព] ហើយទ្រង់សព្វព្រះហឫ
ទ័យនឹងសេចក្តីទៀងត្រង់ ចំណែកទូលបង្គំ គឺដោយចិត្ត
ទៀងត្រង់នោះឯង ដែលទូលបង្គំបានថ្វាយរបស់ទាំងនេះ
ស្ម័គ្រពីចិត្ត ហើយឥឡូវនេះ ទូលបង្គំមានសេចក្តីអំណរ
ដោយឃើញរាស្ត្ររបស់ទ្រង់ ដែលប្រជុំនៅទីនោះគេថ្វាយ
ដល់ទ្រង់ ដោយស្ម័គ្រពីចិត្តដែរ[ភ] ១៨ឱព្រះយេហូវ៉ាជាព្រះនៃ
អ័ប្រាហាំ អ៊ីសាក និងអ៊ីស្រាអែល ជាព្ធយុកោយើងខ្ញុំរាល់
គ្នាអើយ សូមទ្រង់រក្សាទុកគំនិតនេះ នៅក្នុងចិត្តរបស់ពួក
រាស្ត្រទ្រង់ ឱ្យគេបានគិតឃើញជារៀងរាបដរាបទៅ
ហើយសូមទ្រង់តាំងចិត្តគេ ឱ្យនៅជាប់នឹងទ្រង់ ១៩ហើយសូម
ប្រទានឱ្យសាឡូម៉ូន ជាបុត្រទូលបង្គំ មានចិត្តស្មោះត្រង់[ម]
ដើម្បីឱ្យបានកាន់តាមអស់ទាំង ក្រិត្យក្រមសេចក្តីបន្ទាល់ និង
បញ្ញត្តនៃទ្រង់ទាំងប៉ុន្មាន[យ] ព្រមទាំងប្រព្រឹត្តតាមសេចក្តី
ទាំងនេះ ហើយស្អាងព្រះវិហារនេះ ដែលទូលបង្គំបាន
ត្រៀមទុកឱ្យ[រ] ។
២០ឯដាវីឌទ្រង់មានបន្ទូលដល់ពួកជំនុំទាំងអស់គ្នាថា
ចូរអ្នករាល់គ្នាបង្គំទូលដល់ព្រះយេហូវ៉ា ជាព្រះនៃអ្នក
រាល់គ្នាចុះ ដូច្នេះ ពួកជំនុំទាំងអស់ក៏សូមឱ្យព្រះយេហូវ៉ា
ជាព្រះនៃពួកព្ធយុកោគេបានព្រះពរ រួចគេឱនក្បាលថ្វាយ
បង្គំដល់ព្រះយេហូវ៉ា និងស្តេចផង ។

## ស្តេចសាឡូម៉ូនត្រូវរើសជាស្តេច

*២៩:២១–២៥ – ១ពវ ១:២៨–៥៣*

២១ដល់ថ្ងៃស្អែកឡើង គេក៏ថ្វាយយញ្ញបូជា និងដង្វាយដុត
ដល់ព្រះយេហូវ៉ា[ល] គឺគោឈ្មោល១ពាន់ ចៀមឈ្មោល
១ពាន់ កូនចៀម១ពាន់ និងដង្វាយ ច្រួចនៃដង្វាយទាំងនោះ
ហើយយញ្ញបូជាឯទៀតជាបរិបូរសំរាប់ពួកអ៊ីស្រាអែល
ទាំងអស់[វ] ២២គេក៏បរិភោគនៅចំពោះព្រះយេហូវ៉ាដោយ
សេចក្តីអំណរជាខ្លាំង[ស]នៅថ្ងៃនោះឯង ។
រួចគេតាំងសាឡូម៉ូន ជាព្រះរាជបុត្រានៃដាវីឌ ឡើងម្តង
នេះទៀត ឱ្យធ្វើជាស្តេច ក៏ចាក់ប្រេងញែកទ្រង់ចេញថ្វាយ
ដល់ព្រះយេហូវ៉ា ទុកជាអ្នកគ្រប់គ្រង ហើយសាដុកផង[ហ] ឱ្យ
ធ្វើជាសង្ឃ ២៣នោះសាឡូម៉ូនក៏ឡើងគង់[ឡ]លើបល្ល័ង្ក[អ]នៃ
ព្រះយេហូវ៉ា ជាស្តេចជំនួសដាវីឌ ព្រះបិតាទ្រង់ ក៏ចំរុំចំរើង
ឡើង ហើយពួកអ៊ីស្រាអែលទាំងអស់បានស្តាប់បង្គាប់ទ្រង់
២៤ចំណែកពួកអ្នកដែលជាកំពូលទាំងអស់ នឹងពួកខ្លាំងពូកែ
ព្រមទាំងបុត្រាទាំងប៉ុន្មានរបស់ស្តេចដាវីឌ[ក] នោះក៏ចុះចូល
នឹងស្តេចសាឡូម៉ូនទាំងអស់ដែរ ២៥ព្រះយេហូវ៉ាទ្រង់ក៏
ដំកើងសាឡូម៉ូនឡើង[ខ]យ៉ាងក្រៃលែង នៅភ្នែកនៃពួក
អ៊ីស្រាអែលទាំងអស់ ព្រមទាំងប្រោសប្រទាន ឱ្យទ្រង់មាន
តេជានុភាពដ៏ខ្ពង់ខ្ពស់ផង[គ] ដល់ម្ល៉េះបានជាកាល មុនជំនាន់
ទ្រង់ មិនដែលមានស្តេចណាក្នុងពួកអ៊ីស្រាអែលដែលមាន
យ៉ាងនោះឡើយ[ឃ] ។

**២៩:១៤** ធ ទដ ៨:៤ ១៤៤:៣ ន ឧ.២
**២៩:១៥** ប លប ១៧:៨ ២៣:៤ ទដ ៣៩:១២ ហព ១១:១៣ ផ យប ៧:៦ ៨:៩ ១៤:២ ៣២:៧ ទដ ១០២:១១ ១៤៤:៤ សស ៦:១២
**២៩:១៧** ព ទដ ១៣៩:២៣ សភ ១៥:១១ ១៧:៣ យរ ១១:២០ ១៧:១០ ភ ១រប ២៨:៩ ទដ ១៥:១–៥ សភ ១១:២០
**២៩:១៩** ម ១ពវ ៨:៦១ ១១:៤ ១រប ២៨:៩ អស ៣៨:៣ យ ទដ ៧២:១ រ ១រប ២:១៤
**២៩:២១** ល ១ពវ ៨:៦២ វ ១រប ១១:១
**២៩:២២** ស ១ប ១២:៤០ ហ ១សយ ២:៣៥
**២៩:២៣** ឡ ចទ ១៧:១៨ អ ១ពវ ២:១២ ១រប ១៧:១៤
**២៩:២៤** ក ១ពវ ១:៩
**២៩:២៥** ខ យស ៣:៧ គ ១ពវ ១០:៧ ២រប ១:១,១២ ឃ សស ២:៩

**២៩:២២** *បរិភោគ* សូមមើល ១២:៣៨–៤០ ។ ការចាក់ប្រេងតាំងសាឡូម៉ូន និងសាដុក ពិពណ៌នាពីកិត្តិយស សេចក្តីសុខចម្រើនចំពោះពួកគេ (សូមមើល សក ៤:១៤ ៦:១៣) ។ *ម្តងនេះទៀត* ប្រហែលការតែងតាំងសាឡូម៉ូនលើកទី១ត្រូវបានកត់ចុះក្នុង ១ពវ១:៣២–៣៦ ប៉ុន្តែអ្នកកត់ត្រាពង្សាវតារបានលុបចេញ (សូមមើល ២៨:១–២៩:៣០) ។ ទោះបីជាយ៉ាងណាក៏ដោយការតែងតាំងលើកទី២មិនបាននិយាយនៅក្នុងសិបធ្យូជីន (ការបកប្រែសញ្ញាចាស់របស់គ្រីស្ទបរិស័ទក្រិកជំនាន់មុន) បានបង្ហាញថា វាប្រហែលជាត្រូវបានដាក់បញ្ចូលទៅក្នុងអត្ថបទហេព្រើរក្នុងឃ្លាត្រង់នេះ ដោយក្រុមអ្នកនិពន្ធសម័យដើមបន្ទាប់ពីក្រុមសិបធ្យូជីន បានបកប្រែចប់សព្វគ្រប់ក្នុង គោលបំណងឱ្យព្រះគម្ពីរបាក្សត្រ និងពង្សាវតារក្សត្រមានការស្របគ្នា ។ ការតែងតាំងដែលស្ថិតនៅក្នុងករណីដដែលៗនេះចំពោះសូល (សូមមើល ១សយ ១០:១,២៤ ១១:១៤–១៥) ដាវីឌ (សូមមើល ១សយ ១៦:១៣,២សយ ២:៤ ៥:៣) ។

**២៩:២៤** *ពួកអ្នកជាកំពូលទាំងអស់ . . . នោះក៏ចុះចូល* សូមធៀបជាមួយការការបះបោររបស់អ័ដូនីយ៉ា ដែលជាមន្ត្រីធ្វើការក្នុងព្រះវិហារនិងបុត្ររបស់ស្តេច (សូមមើល ១ពវ ១:៩,១៩,២៥) ។

**២៩:២៥** *ពួកអ៊ីស្រាអែលទាំងអស់* សូមមើល ១១:១,១០ ១២:៣៨–៤០ និងសេចក្តីផ្តើមៈគោលបំណងនិងផ្ទៃរឿង ។

## ការសុគតរបស់ស្តេចដាវីឌ

*២៩:២៦–២៨ – ១ពវ ២:១០–១២*

២៦រីឯដាវីឌជាបុត្រអ៊ីសាយ ទ្រង់បានសោយរាជ្យលើ[ង]
សាសន៍អ៊ីស្រាអែលទាំងមូល[ច] ២៧ហើយពេលវេលាដែល
ទ្រង់សោយរាជ្យលើគេ នោះរួមទាំងអស់បាន៤០ឆ្នាំ គឺទ្រង់
សោយរាជ្យនៅក្រុងហេប្រុនបាន៧ឆ្នាំ[ឆ] ហើយនៅក្រុង
យេរូសាឡិមបាន៣៣ឆ្នាំ[ជ] ២៨រួចទ្រង់ក៏សុគត[ឈ] ទៅបានព្រះ
ជន្មវែងល្អ ហើយបានស្កប់ស្កល់នឹងព្រះជន្ម ទ្រព្យសម្បត្តិ
និងកិត្តិយសផង នោះសាឡូម៉ូន ជាព្រះរាជបុត្រាក៏ឡើង
សោយរាជ្យជំនួសព្រះបិតា[ញ] ២៩រីឯកិច្ចការរបស់ស្តេច
ដាវីឌទាំងអស់ ចាប់តាំងពីដើម រហូតដល់ចុង នោះសុទ្ធតែ
បានកត់ទុកក្នុងសៀវភៅរបស់សាំយូអែល ជាអ្នកមើលឆុត[ដ]
និងក្នុងសៀវភៅរបស់ហោរាណាថាន[ឋ] ហើយក្នុងសៀវ
ភៅរបស់កាឌ់[ឌ] ជាអ្នកមើលឆុតហើយ ៣០ព្រមទាំងរឿង
ពីរាជ្យ និងឥទ្ធានុភាពរបស់ទ្រង់ ពីជំនាន់ទ្រង់នឹងពួក
អ៊ីស្រាអែល ហើយអស់ទាំងរាជ្យរបស់នគរផ្សេងៗនោះ
ផង ។/

**២៩:២៦** ង ១របា ១៨:១៤ ច ១របា ១១:១
**២៩:២៧** ឆ លប ២៣:១៩ ជ ២សយ ៥:៤–៥ ១របា ៣:៤
**២៩:២៨** ឈ លប ១៥:១៥ កច ១៣:៣៦ ញ ១របា ២៣:១
**២៩:២៩** ដ ១សយ ៩:៩ ឋ ២សយ ៧:២ ឌ ១សយ ២២:៥

**២៩:២៧** សូមមើល ៣:១–៩ ។

**២៩:២៨** *បានព្រះជន្មវែងល្អ ហើយបានស្កប់ស្កល់នឹងព្រះជន្ម* លក្ខណៈផ្ទៃរឿងសំខាន់របស់អ្នកកត់ត្រាពង្សាវតារបានបង្ហាញថា អ្នកបះបោរនឹងស្លាប់មួយរំពេច (សូមមើល សេចក្តីផ្តើមៈគោលបំណង និងផ្ទៃរឿង) តែអ្នកសុចរិតនឹងរស់នៅដោយមានអំណរសប្បាយយូរអង្វែង(ធៀបជាមួយ ទដ ១២៨ សភ ៣:២,៤,៩–១០,១៦,២២,៣៣–៣៥) ។

**២៩:២៩** សូមមើល សេចក្តីផ្តើមៈ អ្នកនិពន្ធ កាលបរិច្ឆេទ និងប្រភព ។

**២៩:៣០** *ហើយអស់ទាំងរាជ្យរបស់នគរផ្សេងៗ* ពួកនៅជិតវិញនគររបស់ដាវីឌ ។

# ព្រះគម្ពីររបាក្សត្រទី២

## សេចក្តីផ្តើម

មើលសេចក្តីផ្តើម របាក្សត្រទី១ចំពោះគម្រោងសង្ខេបពតិមានប្រាប់ពីមុនមក ។

**ការសាងសង់ព្រះវិហារក្នុងកណ្ឌគម្ពីររបាក្សត្រ**

ពួកជិនុំនៅពេលនោះបានប្រើប្រាស់ប្រជារាស្ត្រនៃគម្ពីរបញ្ញកណ្ឌជាគំរូសម្រាប់ជាការគ្រប់គ្រង ក្នុងរជ្ជកាលស្តេចដាវីឌនិងស្តេចសាឡូម៉ូន ។ ការមានភាពដូចគ្នាមួយទៀតគឺជាគម្ពីរបញ្ញកណ្ឌ បានកត់ត្រាពីការសាងសង់រោងឧបោសថដែលបានជះឥទ្ធិពលដល់ការគ្រប់គ្រងនៃការកសាងព្រះវិហារ :

១. ការសាងសង់រោងឧបោសថក៏បានផ្អែកទៅលើ ឫទុកចិត្តចំពោះបេតសាលាលនិងអូហូលីអាប់ (នក ៣៥:៣០–៣៦:៧) ដែលពួកគេផ្តល់នូវគំរូនៃក្រុមវង្សរបាក្សត្រ សម្រាប់ទំនាក់ទំនងរបស់ស្តេចសាឡូម៉ូន និងជាងជំនាញការម្នាក់ឈ្មោះហ៊ីរ៉ាម (២របា ២:១៣) វាក៏បានបង្ហាញថា គឺលោកបែតសាលាល តាមរយៈផ្នែកខ្លះនៅខាងក្រៅខណ្ឌគម្ពីរនិក្ខមនំគឺនៅក្នុងកណ្ឌកម្ពីររបាក្សត្រវិញ(១របា ៣២:២០ ២របា ១:៥) ។

ស្តេចសាឡូម៉ូនគឺជាបេតសាលាលថ្មីមួយ(១)ទាំងស្តេចសាឡូម៉ូននិងលោកបេតសាលាល គឺត្រូវបានបង្ហាញឱ្យឃើញដោយឈ្មោះចំពោះកិច្ចការព្រះអម្ចាស់ គឺគេជាអ្នកបម្រើការងារដែលជ្រើសតាំងដោយឈ្មោះ (នក ៣១:២ ៣៥:៣០–៣៨:២២–២៣ ១របា ២៨:៦) (២) គេទាំងពីរមកពីពូជអំបូរយូដាតែមួយ (នក ៣១:២ ៣៥:២ ៣៥:៣០ ១របា ២:២០ ៣:១០) ។ (៣) ពួកគេទាំងពីរនាក់ក៏ទទួលបាននូវព្រះវិញ្ញាណ ដើម្បីជួយពួកគេដោយចំណេះដឹងមកពីព្រះ (នក ៣១:៣ ៣៥:៣០–៣១ ២របា ១:១–១៣) និងនិមិត្តរបស់ស្តេចសាឡូម៉ូននៅឯក្រុងកេបា (២របា ១:៣–១៣) ។ ឱ្យទទួលខុសត្រូវក្នុងការសាងសង់ព្រះវិហារ (២របា ២–៧) ។ (៤) គេទាំងពីរបានស្អាងអាសនាពីលង្ហិនសម្រាប់ជាទីបរិសុទ្ធ (២របា ១:៥ ៤:១ ៧:៧) ការបង្ហាញឱ្យច្បាស់នោះ គឺលង្ហិនអាសនាក៏ពុំបានបង្ហាញក្នុងកំណត់ហេតុសង្ខេបកិច្ចការបេស់លោកហ៊ីរ៉ាមទេ (៤:១២–៦) ។ ហើយលោកទាំងពីក៏បានធ្វើការតុបតែងបំពាក់យ៉ាងល្អស្អាត់សម្រាប់ជាទីបរិសុទ្ធ (នក ៣១:១–១០ ៣៧:១០–២៩ ២របា ៤:១៩–២២) ។

ដូចគ្នានេះដែរហ៊ីរ៉ាមក៏ប្រែក្លាយជា "អូហាសីអាប់" ថ្មីមួយទៀត :(១) គឺក្នុងការទទួលខុសត្រូវការសាងសង់ព្រះវិហារដូចនៅក្នុងកណ្ឌគម្ពីរពង្សាវតារក្សត្រ ហ៊ីរ៉ាមក៏ពុំបានបង្ហាញប្រាប់ច្បាស់រហូតដល់រឿងរាវការសាងសង់សំខាន់ៗនៃព្រះវិហារនិងរាជវាំងត្រូវបានគេប្រាប់ (១ពវ ៧:១៣–៤៥) ក្នុងគម្ពីររបាក្សត្រ ក៏បានកំណត់ត្រាបង្ហាញថាបានចូលរួមក្នុងកិច្ចការសាងសង់នោះ តាំងពីដំបូងមកម្លេះក៏ដូចជា អូហូលីអាប់បានធ្វើកិច្ចការរោងឧបោសថនោះផងដែរគឺតាំងពីដំបូង ។ (នក ៣១:៦ ២របា ២:១៣)។ (២)គឺព្រះមហាក្សត្របានមានបន្ទូលតែពីលោកហ៊ីរ៉ាមទេ ដែលមានជំនាញក្នុងការចាក់ពុម្ពលង្ហិន (១ពវ ៧:១៤) ក្នុវគម្ពីររបាក្សត្រគឺជាជីវិតមានជំនាញគឺដូចគ្នានិងជីវិត អូហូលីអាប់ដែរ (នក ៣១:២–៦ ៣៥:៣០–៣៦:២ ៣៨:២២–២៣ ២របា ២:១៤) ។ (៣) ព្រះមហាក្សត្របានមានបន្ទូលថាម្តាយរបស់លោកហ៊ីរ៉ាម គឺជាស្ត្រីមេមាយដែលចេញពីពួកពូជអំបូរណៃបថាលី (១ពវ ៧:១៤) ទោះជាយ៉ាងណាក៏ដោយក៏គម្ពីររបាក្សត្របញ្ជាក់ថានាងនោះជាស្ត្រីមេមាយចេញពីពូជអំបូរដាន់(របា ២:១៤) ក៏បង្ហាញថាហ៊ីរ៉ាមក៏ជាពូជពង្សដូចគ្នាទៅនិងអូហូលីអាប់(នក ៣១:៦ ៣៥:៣៤ ៣៨:២៣)។ មើលការពន្យល់ ២របា ២:១៣ ។

២. ផែនការសម្រាប់ការសាងសង់រោងឧបោសថនិងព្រះវិហារ គឺព្រះអម្ចាស់ជាអ្នកប្រទានផែនការទាំងនោះ ។ (នក ២៥:១–៣០:៣៧ សូមមើល នក ២៥:៩,៤០ ២៧:៨ សូមមើល ១របា ២៨:១១–១៩ ក៏មិនបានបង្ហាញឱ្យឃើញក្នុងគម្ពីរ សាំយូអែល និងពង្សាវតារក្សត្រនោះទេ) ។

៣. កំទេចបាក់បែកដែលពីសង្គ្រាមត្រូវបានគេប្រើសម្រាប់ធ្វើការសាងសង់ព្រះវិហារនិងរោងឧបោសថ (នក ៣:២១–២២ ១២:៣២–៣៦ មើល ១របា ១៨:៦ ក៏ពុំបានបង្ហាញក្នុងគម្ពីរ សាំយូអែលនិង ពង្សាវាតារក្សត្រដែរ) ។

៤. ជារាស្ត្រ (ប្រជាជន) បានផ្តល់វិភាគទានដោយចិត្តសប្បុរសសម្រាប់ការងារសាងសង់ទាំងពីរគម្រោង (នក ២៥:១–៧ ៣៦:៣–៧ មើល ១របា ២៩:១–៩ ក៏មិនបានបង្ហាញនៅក្នុងគម្ពីរ សាំយូអែល និងពង្សាវាតារក្សត្រដែរ ។

៥. ស្រមោលពពកនៃសេរីល្អបានលេចមកក្នុងកាធ្វើឱ្យសម្រេចការស្អាង(សាងសង)សំណង់ទាំងពីរគម្រោងនេះដែរ ។ (នក ៤០:៣៤–៣៥ ២របា ៧:១–៣) ។

## ស្តេចសាឡូម៉ូនទូលសូមប្រាជ្ញា

*១:២–១៣ – ១ពវ ៣:៤–១៥*

*១:១៤–១៧–១ពវ ១០:២៦–២៩ ២របា ៩:២៥–២៨*

**១** ១ រីឯសាឡូម៉ូន ជាព្រះរាជបុត្រាដាវីឌ ទ្រង់មានអំណាច
ក្នុងរាជ្យ[ក] ទ្រង់កាន់តែមាំមួនឡើង ហើយព្រះយេហូវ៉ា ជា
ព្រះនៃទ្រង់ ក៏បានគង់នៅជាមួយ[ខ] ព្រមទាំងលើកដំកើង
ទ្រង់ឡើងយ៉ាងក្រៃលែង[គ] ២ សាឡូម៉ូនក៏មានបន្ទូលនឹង
បណ្តាពួកអ៊ីស្រាអែល[ឃ] ពួកមេទ័ពធំតូច ពួកចៅក្រមនិង
ពួកចៅហ្វាយនៃសាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន ដែលជា
ប្រធានលើវង្សរបស់ឪពុកគេ ៣ រួចទ្រង់និងពួកជំនុំទាំងអស់
ក៏នាំគ្នាទៅឯទីខ្ពស់ ដែលនៅត្រង់ក្រុងគីបៀន[ង] ដ្បិតត្រសាល
ជំនុំនៃព្រះ[ច] ដែលលោកម៉ូសេ[ឆ] ជាអ្នកបំរើរបស់ព្រះ
យេហូវ៉ា បានធ្វើនៅទីរហោស្ថាន បាននៅទីនោះ ៤ តែឯ
ហឹបនៃព្រះ[ជ] នោះដាវីឌបាននាំយកពីក្រុងគាយ៉ាត–យារីម
ឡើងទៅឯកន្លែងដែលទ្រង់បានរៀបចំទុក ដ្បិតទ្រង់បាន
ដំឡើងត្រសាល១[ឈ] សំរាប់ឱ្យហឹបនោះ នៅក្នុងក្រុងយេរូ
សាឡិមវិញ ៥ រីឯអាសនាលង្ហិន[ញ] ដែលបេតសាលាល[ដ]
កូនយូរី ដែលជាកូនហើរបានធ្វើ នោះក៏នៅមុខរោង
ឧបោសថផងព្រះយេហូវ៉ា ត្រង់គីបៀន ហើយសាឡូម៉ូន
និងពួកជំនុំទាំងអស់គ្នាបាន សង្ឃាតរក[ឋ] អាសនានោះ ៦ ទ្រង់
ឡើងទៅថ្វាយដង្វាយដុត អស់១ពាន់ នៅលើអាសនា លង្ហិន
ដែលនៅចំពោះព្រះយេហូវ៉ា ត្រង់ត្រសាលជំនុំនោះ ។
៧ ក្នុងពេលយប់នោះ ព្រះទ្រង់លេចមក[ឌ] ឯសាឡូម៉ូនមាន
បន្ទូលថា ចូរឱ្យឯងសូមចុះ តើចង់ឱ្យអញឱ្យអ្វីដល់ឯង
៨ សាឡូម៉ូនទ្រង់ឆ្លើយថា ទ្រង់បានសំដែងសេចក្តីសប្បុរស
ជាធំ ដល់ដាវីឌ ជាបិតាទូលបង្គំ ក៏បានតាំងទូលបង្គំឡើង[ឍ]
ជាស្តេចជំនួសបិតាហើយ ៩ ឥឡូវនេះ ឱព្រះយេហូវ៉ាដ៏ជាះ
ព្រះអើយ សូមឱ្យសេចក្តីដែលទ្រង់បានសន្យា[ណ] នឹងដាវីឌ
ជាបិតាទូលបង្គំ បានតាំងខ្ជាប់ខ្ជួនឡើង ដ្បិតទ្រង់បានលើក
ទូលបង្គំឡើង ជាស្តេចលើសាសន៍១មានគ្នាច្រើនដូចជាផង់
ធូលីនៅផែនដី[ត] ១០ ដូច្នេះសូមប្រោសប្រទាន ឱ្យទូលបង្គំមាន
ប្រាជ្ញានឹងយោបល់ ដើម្បីឱ្យទូលបង្គំបានចេញចូលនាំ[ថ] មុខ
បណ្តាជននេះ ដ្បិតតើមានអ្នកឯណា អាចនឹងគ្រប់គ្រងលើ
រាស្ត្ររបស់ទ្រង់ ដែលមានច្រើនទាំងម្លេះនេះបាន ១១ ព្រះ
ទ្រង់មានបន្ទូលតបថា ដោយព្រោះឯងបានប្រាថ្នាដូច្នេះ
នៅក្នុងចិត្ត ហើយមិនបានសូមឱ្យបានទ្រព្យសម្បត្តិ[ទ] ឬធន
ធាន ឬកិត្តិយស ឬការប្រហារជីវិតនៃពួកអ្នកដែលស្អប់ឯង
ក៏មិនបានសូមអាយុឱ្យយឺនយូរឡើយ គឺបានសូមឱ្យមាន
ប្រាជ្ញា និងយោបល់វិញ ដើម្បីនឹងគ្រប់គ្រងលើរាស្ត្រអញ
ដែលអញបានតាំងឯងឱ្យធ្វើជាស្តេចលើគេ ១២ ដូច្នេះ អញ
ឱ្យឯងមានប្រាជ្ញា និងយោបល់ហើយ ថែមទាំងឱ្យមាន
ទ្រព្យសម្បត្តិធនធាន និងកិត្តិយសទៀតផង[ធ] ដល់ម្លេះបាន
ជាមុនឯង មិនដែលមានស្តេចណា បានយ៉ាងនោះឡើយ
ហើយក្រោយឯងទៅមុខទៀត ក៏មិនមានដែរ[ន] ១៣ ដូច្នេះ
សាឡូម៉ូនទ្រង់ក៏វិលត្រឡប់ពីទីខ្ពស់ ទៅត្រង់គីបៀន គឺពីមុខ
ត្រសាលជំនុំ មកឯក្រុងយេរូសាឡិមវិញ ហើយទ្រង់បាន
សោយរាជ្យលើសាសន៍អ៊ីស្រាអែល ។
១៤ សាឡូម៉ូនទ្រង់ប្រមូលបានរទេះចំបាំង[ប] និងពលសេះ
មានរទេះ១ពាន់៤រយ និងពលសេះ១មុឺន២ពាន់ក៏ដាក់ឱ្យ

**១:១** ក ១ពវ ២:១២,២៦ ២របា ១២:១ ខ លប ២១:២២ ៣៩:២ ជន ១៤:៤៣ គ ១របា ២៩:២៥
**១:២** ឃ ១របា ៩:១
**១:៣** ង យស ៩:៣ ច លវ ១៧:៤ ឆ នក ៤០:១៨
**១:៤** ជ ១របា ១៥:២៥ ឈ ២សយ ៦:១៧
**១:៥** ញ នក ៣៨:២ ដ នក ៣១:២ ឋ ១របា ១៣:៣
**១:៧** ឌ ២របា ៧:១២
**១:៨** ឍ ១របា ២៣:១
**១:៩** ណ ២សយ ៧:២៥ ១ពវ ៨:២៥ ត លប ១២:២
**១:១០** ថ ជន ២៧:១៧ ២សយ ៥:២ សភ ៨:១៥–១៦
**១:១១** ទ ចទ ១៧:១៧
**១:១២** ធ ១របា ២៩:១២ ន ១របា ២៩:២៥ ២របា ៩:២២ នហ ១៣:២៦

**១:១–៩:៣១** ការគ្រប់គ្រងរាជបល្ល័ង្ក របស់ស្តេចសាឡូម៉ូនក៏បានប្តូរផ្តាច់ ដើម្បីកសាងព្រះវិហារ (ជំពូក ២–៧) ស្តេចសាឡូម៉ូនគឺទទួលបានមកប្រាជ្ញាពីព្រះដើម្បីគ្រប់ការទាំងនោះ ។ គ្រប់ទាំសម្ភារៈណាដែលមិនទាក់ទង់សំខាន់ក្នុងការសាងសង់នោះ អ្នកកាលប្រវត្តិក៏មិនកត់ត្រាឱ្យឃើញដែរ ឧទាហរណ៍ គេពុំបានបង្ហាញពីការកាត់ទោសរវាងស្រីសំផឹង (១ពវ ៣:១៦–២៨) ឬក៏សាងសង់រាជវាំងស្តេច (១ពវ ៧:១–១២) ។

**១:១** *ទ្រង់មានអំណាចក្នុងរាជ្យទ្រង់កាន់តែមាំឡើង* សេចក្តីបញ្ជាក់នេះនិងភាពប្រែប្រួលផ្សេងៗ គឺវាជារឿងធម្មតាក្នុងកណ្ឌគម្ពីររបាក្សត្រ(១២:១៣, ១៣:៧–៨,២១ ១៥:៨ ១៦:៩ ១៧:១ ២១:៤ ២៣:១ ២៥:១១ ២៧:៦ ៣២:៥ ១របា ១១:១០ ១៩:១៣) ។ នៅក្នុងគម្ពីរនេះ ២១:៤ វាក៏បញ្ចូលពីការលុបបំបាត់នូវមាស ដែលនិងត្រូវជៀតជ្រែកដល់រាជ្យបល្ល័ង្គ (មើល ១ពវ ២ ជាពិសេស ខ.៤៦) ។

**១:២–១៣** មើល ១ពវ ៣:៤–១៥ និងការពន្យល់ ។ ខ.២–៦ បានបង្ហាញយ៉ាងច្បាស់ពីគម្ពីររបាក្សត្រ ក៏បង្ហាញពីថ្នាក់គំនិតរបស់អ្នកនិពន្ធផងដែរៈ ដូចជាការគាំទ្រពីរាស្ត្រអ៊ីស្រាអែលទាំងអស់(ខ.២) (គឺត្រូវបានបញ្ជាក់) មើលសេចក្តីផ្តើមនៃកណ្ឌគម្ពីររបាក្សត្រទី១ គឺមានដូចជា : គោលបំណង់នឹងនៃផ្ទៃរឿង ។ គឺខណៈដែលអ្នកនិពន្ធរបស់ព្រះមហាក្សត្រ ដែលលន់តួបាបពីការសួរសុខទុក្ខរបស់ស្តេចសាឡូម៉ូនទៅឯទីខ្ពស់បំផុត(១ពវ ៣:៣)អ្នកកាលប្រវត្តិបន្ថែមសេចក្តីពន្យល់ប្រាប់ពីទីតាំងរោងឧបោសថ ដែលបានសាងសង់ដោយលោកម៉ូសេ នៅក្នុងវាលរហោស្ថាន(ខ.៣)ដែលឱ្យសកម្មភាពស្តេចសាឡូម៉ូនទទួលបានច្បាប់ ដែលបានផ្តល់មកឱ្យទ្រង់(លវ ១៧:៨–៩) ។

**១:៥** *បេតសាលាល* មើលសេចក្តីផ្តើម ពីការសាងសង់ព្រះវិហារក្នុងគម្ពីររបាក្សត្រ ។ ដែលវាទាក់ទងនិងដង្វាយរបស់ទ្រង់ទៅលើការសាងសង់អាសនាដោយបេតសាលាល (នក ៣១:១–១១ ៣៨:១–២) ដែលស្តេចបានទទួលប្រាជ្ញាពីព្រះដើម្បីគ្រងរាជ្យ ។ ដោយព្រោះស្តេចសាឡូម៉ូនទទួលភារៈពីព្រះក្នុការសាងសង់ព្រះវិហារ គឺដូចបេតសាលាលដែលទទួលអំណោយទានពីព្រះផងដែរ ដើម្បីធ្វើជាសិប្បករដ៏ជំនាញដើម្បីតុបតែងរោងឧបោសថ ។

**១:៩** *ច្រើនដូចជាផង់ធូលីនៅលើផែនដី* គឺដូចជាការសម្រេចនូវព្រះបន្ទូលសន្យាដល់លោកអ័ប្រាហាំ (១៣:១៦ ២២:១៧ សូមមើលការពន្យល់ ១របា ២៧:២៣ ប្រៀបធៀប លប ២៨:១៤) ។

នៅអស់ទាំងទីក្រុង ដែលសំរាប់រទេះចំបាំង ហើយនៅជា
មួយនឹងស្តេចក្នុងក្រុងយេរូសាឡិម ១៥ហើយនៅទីក្រុងនោះ
ទ្រង់ធ្វើឱ្យមានប្រាក់ និងមាស[ផ]សម្បូរ ដូចជាថ្ម ហើយឱ្យ
មាន ដើមតាត្រៅសម្បូរ ដូចជាដើមឧទុម្ពរ ដែលដុះនៅដី
ទំនាបដែរ ១៦ឯសេះទាំងប៉ុន្មានរបស់សាឡូម៉ូននោះសុទ្ធតែ
មកពីស្រុកអេស៊ីព្ទ ពួកជំនួយរបស់ស្តេចគេទៅវិញ ដឹកនាំ
មកទាំងហ្វូងៗតាមដំឡៃ ១៧គេក៏នាំយករទេះ[ព]ពីស្រុក
អេស៊ីព្ទមក ១ដំឡៃជាប្រាក់៦០០រៀល ហើយសេះ១ដំឡៃជា
ប្រាក់១៥០រៀល គេក៏ដឹករទេះមកយ៉ាងនោះ ឱ្យដល់អស់
ទាំងស្តេចនៃសាសន៍ហេត និងស្តេចស្រុកស៊ីរីដែរ ។

## ការរៀបចំសាងសង់ព្រះវិហារ

*២:១-១៨ – ១ពវ ៥:១-១៦*

**២** ១ឯសាឡូម៉ូន ទ្រង់ក៏បង្គាប់ឱ្យស្អាងព្រះវិហារ[ក] សំរាប់
ព្រះនាមព្រះយេហូវ៉ា និងព្រះរាជវាំងសំរាប់នគរទ្រង់[ខ]
២រួចទ្រង់ដំរូវឱ្យមានមនុស្ស ៧ម៉ឺននាក់ សំរាប់លីសែង
និង៨ម៉ឺននាក់ សំរាប់កាប់ឈើនៅឯភ្នំ ហើយ៣ពាន់៦រយ
នាក់សំរាប់ជាអ្នកត្រួតលើគេ[គ] ៣ទ្រង់ក៏ចាត់សារទៅឯ
ហ៊ីរ៉ាម[ឃ]ជាស្តេចក្រុងទីរ៉ុសថា ពីដើមទ្រង់បានផ្ញើឈើ
តាត្រៅ[ង]មកថ្វាយដាវីឌ ជាបិតាទូលបង្គំ សំរាប់ធ្វើជា
ដំណាក់ឱ្យទ្រង់គង់ ឥឡូវនេះក៏សូមទ្រង់ប្រោសមេត្តាដល់
ទូលបង្គំដូច្នោះដែរ ៤មើលទូលបង្គំរៀបនឹងស្អាងព្រះ
វិហារ[ច] សំរាប់ព្រះនាមព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំ
ដើម្បីថ្វាយដល់ទ្រង់ទុកជាទីដុតគ្រឿងមានក្លិនក្រអូប[ឆ] នៅ
ចំពោះទ្រង់ និងជាទីដំកល់នំបុ័ងតាំងទុក[ជ]ជានិច្ច ព្រមទាំង
ថ្វាយដង្វាយដុត[ឈ]ទាំងពេលព្រឹកនឹងពេលល្ងាច ហើយនៅ
ថ្ងៃឈប់សំរាក[ញ] ថ្ងៃចូលខែ[ដ] និងនៅអស់ ទាំងបុណ្យមាន
កំណត់នៃព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំរាល់គ្នា ដូចជាបាន
បង្គាប់មកសាសន៍អ៊ីស្រាអែលឱ្យធ្វើជាដរាបតទៅ ៥ឯព្រះ
វិហារ ដែលទូលបង្គំគិតស្អាងនោះធំណាស់[ឋ] ដ្បិតព្រះនៃ
យើងខ្ញុំរាល់គ្នាទ្រង់ធំប្រសើរ លើសជាងអស់ទាំងព្រះ[ឌ]
៦ប៉ុន្តែតើមានអ្នកឯណាដែលអាច នឹងស្អាងព្រះវិហារថ្វាយ
ទ្រង់បាន ដ្បិតផ្ទៃមេឃ និងអស់ទាំងជាន់នៃផ្ទៃមេឃ មិន
ល្មមឱ្យទ្រង់គង់ចុះទៅហើយ[ឍ] ដូច្នេះ តើទូលបង្គំជាអ្វី[ណ]
ដែលអាចនឹងស្អាងព្រះវិហារថ្វាយទ្រង់បាន លើកតែល្មម
នឹងដុតគ្រឿងក្រអូបនៅចំពោះទ្រង់ប៉ុណ្ណោះ ៧ដូច្នេះ សូម
ចាត់ជាងម្នាក់មកជាអ្នក ដែលមានថ្វីដៃក្នុងការធ្វើមាស
ប្រាក់ លង្ហិន ដែកសំពតពណ៌ស្វាយ ពណ៌ក្រហម និង
ពណ៌ខៀវ ហើយដែលចេះឆ្លាក់ចំឡាក់គ្រប់ចំពូកផង ឱ្យ
បាននៅជាមួយនឹងពួកជាងប៉ិនប្រសប់[ត] ដែលនៅស្រុកយូដា
ហើយនៅក្រុងយេរូសាឡិម ជាមួយនឹងទូលបង្គំ ជាពួកអ្នក
ដែលដាវីឌបិតាទូលបង្គំបានផ្គត់ផ្គង់ ៨សូមបញ្ជូនឈើ
តាត្រៅ ឈើកកោះ និងឈើច័ន្ទន៍ពីភ្នំល្បាណូនមកឱ្យទូល
បង្គំ ដ្បិតទូលបង្គំដឹងថា ពួករបស់ទ្រង់ គេចេះកាប់ឈើនៅ
ព្រៃល្បាណូនស្រាប់ មើលពួកខាងទូលបង្គំនឹងធ្វើ ការជា
មួយនឹងគេ ៩ដើម្បីនឹងត្រៀមឈើទុកឱ្យទូលបង្គំជាបរិបូរ
ដ្បិតព្រះវិហារដែលទូលបង្គំបំរុងនឹងស្អាងនេះ ត្រូវតែបាន
ធំអស្ចារ្យ ១០នោះទូលបង្គំនឹងឱ្យស្រូវភោជ្ជសាលីបញ្ជាន់
ស្រាប់២ម៉ឺនរង្វាន់ ស្រូវឱក២ម៉ឺន រង្វាល់ ស្រាទំពាំងបាយ
ជូរ២ម៉ឺនរង្វាល់ និងប្រេង២ម៉ឺនរង្វាល់ ដល់ពួកជាងរបស់
ទ្រង់ដែលកាប់ឈើនោះ[ថ]។
១១ដូច្នេះ ហ៊ីរ៉ាម ជាស្តេចក្រុងទីរ៉ុស ទ្រង់ក៏ធ្វើសារផ្ញើ
មកឆ្លើយតបនឹងសាឡូម៉ូនថា ព្រះយេហូវ៉ាទ្រង់ស្រឡាញ់[ទ]

**១:១៤** ប ជន ១សយ ៨:១១ ១ពវ ៩:១៩
**១:១៥** ផ ១ពវ ៩:២៨ អស ៦០:៥
**១:១៧** ព បស ១:៩
**២:១** ក ចទ ១២:៥ ខ សស ២:៤
**២:២** គ ២រប ១០:៤
**២:៣** ឃ ២សយ ៥:១១ ង ១រប ១៤:១
**២:៤** ច ចទ ១២:៥ ឆ នក ៣០:៧ ជ នក ២៥:៣០ ឈ នក ២៩:៤២ ២រប ១៣:១១ ២៩:២៨ ញ លប ២៣:៣៨ ដ ជណ ២៨:១៤
**២:៥** ឋ ១រប ២២:៥ ឌ នក ១២:១២ ១រប ១៦:២៥
**២:៦** ឍ ១ពវ ៨:២៧ យរ ២៣:២៤ ណ នក ៣:១១
**២:៧** ត នក ៣៥:៣១ ១រប ២២:១៦
**២:១០** ថ អរ ៣:៧
**២:១១** ទ ១ពវ ១០:៩ ២រប ៩:៨

**១:១៤–១៧** អ្នកកាលប្រវត្តិ ក៏ពុំបានបញ្ចូលពីសម្ភារៈ ១ពវ ៣:១៦–៤:៣៤ ។ ទ្រង់បានបង្ហាញពីសម្បត្តិដ៏ច្រើនរបស់ស្តេចសាឡូម៉ូន (មើលការពន្យល់ ១រប ២៧:២៣ ប្រៀបធៀប លប ២៨:១៤) ។

**១:១៥** *ដើមឧទុម្ពរ* មើលការពន្យល់ អម ៧:១៤ ។

**១:១៦** *ស្រុកអេស៊ីព្ទ* មើលការពន្យល់ ១ពវ ១០:២៩ ។

**១:១៧** *សាសន៍ហេត* មើលការពន្យល់ លប ១០:១៥ *ស្រុកស៊ីរី* មើលការពន្យល់ ១រប ១៨:៥ ចទ ២៦:៥ ។

**២:១** *ព្រះរាជវាំង* ទោះបើជារឿយៗអ្នកកាលប្រវត្តិបង្ហាញបញ្ជាក់ពីការងារសាងសង់រាជវាំងដោយស្តេចសាឡូម៉ូន (មើល ១ពវ ៧:១–១២) ។

**២:២** មើល ខ.១៧–១៨ និងការពន្យល់ ។

**២:៣–១០** ការចាប់អារម្មណ៍អ្នកទេវសាស្ត្រ របស់អ្នកកាលប្រវត្តិគឺឆ្លើយតបនិងការគ្រប់គ្រងរបស់ស្តេចសាឡូម៉ូន ជាមួយនិងពួកហេត (១ពវ ៥:១) ។ តែអ្នកកាលប្រវត្តិបានលប់បំបាត់រឿងនេះចោល (និងឯកសារផ្សេងៗក្នុង ១ពវ ៥:៣–៥) ក៏ប៉ុន្តែ អ្វីដែលបន្ថែមពីឯកសារការដែលថ្វាយបង្គំក្នុងព្រះវិហារនោះ សូមមើល ខ.៣–៧ ។ ២:៤ មើល ១រប ២៣:២៨,២៨–៣២ និងការព្យល់ ។

**២:៧** មើលសេចក្តីផ្តើម: ការសាងសង់ក្នុងព្រះវិហារគម្ពីរបាក្សត្រ ។ ក្នុងគម្ពីរពង្សាវតារក្សត្រ គឺតម្រូវឱ្យមានសិប្បករ ដែលយើងឃើញក្នុងនោះរបៀបជានិទានកថា (១ពវ ៧:១៣) ក្នុងការសម្តែងចេញជាការអនុវត្តនូវហេតុការដូចៗគ្នារវាងអូហូលីអាប និងហ៊ីរ៉ាមតែអ្នកកាលប្រវត្តិក៏បានបញ្ចូលប្រវត្តិនោះទៅក្នុងកំណត់ត្រាផងដែរ ។ លើសពីនេះទៅទៀតគឺក្នុង ខ.១៣–១៤ ។

**២:១០** ការបង់ថ្វាយក្នុង ខនេះមានលក្ខណៈខុសប្លែកពីរបាយការណ៍ ១ពវ ៥:១១ ប៉ុន្តែអត្ថបទបាននិយាយពីការបង់ថ្វាយ ពីរបែបផ្សេងៗគ្នាក្នុងគម្ពីរពង្សាវតារក្សត្រ គឺសម្រាប់ការប្រចាំឆ្នាំ គឺទៅឱ្យជំពាក់នៃរាជវង្សហ៊ីរ៉ាម ដែលអ្នកកាលប្រវត្តិនិយាយពីការ បង់ថ្វាយចំពោះការកាត់ឈើហ៊ុប ។

រាស្ត្ររបស់ទ្រង់ បានជាតាំងព្រះករុណាឡើង ជាស្តេចលើ
គេ 12ក្នុងសារនោះហ៊ីរ៉ាមមានបន្ទូលទៀតថា សូមឱ្យ
ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ដែលបានបង្កើត
ផ្ទៃមេឃនឹងផែនដី[ធ] ទ្រង់បានព្រះពរ គឺជាព្រះដែល
បានប្រទាន ឱ្យស្តេចដាវីឌមានព្រះរាជបុត្រាប្រកបដោយ
ប្រាជ្ញាដំរិះ និងយោបល់ អាចនឹងស្អាងព្រះវិហារថ្វាយព្រះ
យេហូវ៉ា និងព្រះរាជវាំងសំរាប់នគរទ្រង់ 13ឥឡូវទូលបង្គំ
បានឱ្យជាងជំនាញការម្នាក់ឈ្មោះហ៊ីរ៉ាម[ន] ជាជាងរបស់
បិតាទូលបង្គំ ជាអ្នកប្រកបដោយយោបល់មក 14គឺជាកូន
របស់ស្រីស្រុកដាន់ម្នាក់[ប] ដែលឪពុកជាអ្នកក្រុងទីរ៉ុសអ្នក
នេះជាអ្នក ជំនាញក្នុងការ[ផ]ធ្វើមាសប្រាក់ លង្ហិន ដែកថ្ម
ឈើ និងសំពត់ពណ៌ស្វាយ ពណ៌ខៀវ[ព] សំពត់ទេសឯកយ៉ាង
ម៉ដ្ត ហើយនឹងសំពត់ពណ៌ក្រហម ក៏ចេះឆ្លាក់ចំឡាក់គ្រប់
ជំពូក ហើយចេះបង្កើតរបស់គ្រប់យ៉ាងដែរ ដើម្បីឱ្យបាន
ធ្វើការ ជាមួយនឹងពួកជាងយ៉ាងជំនាញរបស់ទ្រង់ ហើយ
និងពួកជាងយ៉ាងជំនាញរបស់ដាវីឌ ជាព្រះបិតាទ្រង់ ដែល
ជាព្រះអម្ចាស់នៃទូលបង្គំផង 15រីឯស្រូវភោជ្ជសាលី ស្រូវ
ឱកប្រេង[ភ] និងស្រាទំពាំងបាជូរ ដែលព្រះករុណា ជាព្រះ
អម្ចាស់បានមានបន្ទូលនោះ សូមបញ្ជូនមកឱ្យពួកខាងទូល
បង្គំចុះ 16នោះពួកទូលបង្គំនឹងកាប់ឈើ នៅព្រៃល្បាណូន
តាមដែលទ្រង់ត្រូវការបញ្ជូនមក ដោយក្បូនតាម សមុទ្រ
ដល់ក្រុងយ៉ុបប៉េ[ម] ថ្វាយដល់ទ្រង់ ឱ្យទ្រង់នាំឡើងទៅឯក្រុង
យេរូសាឡិមចុះ ។
17ដូច្នេះ សាឡូម៉ូនទ្រង់រាប់ពួកសាសន៍ដទៃ[យ] ដែលស្នាក់
នៅស្រុកអ៊ីស្រាអែលទាំងអស់ តាមបញ្ជីដែលដាវីឌជា
ព្រះបិតាបានរាប់[រ] កំណត់ទុក ឃើញមានចំនួន១សែន៥ម៉ឺន
៣ពាន់៦រយនាក់ 18ទ្រង់ក៏ដាក់[ល]ឱ្យ៧ម៉ឺននាក់ធ្វើការលី
សែង៨ម៉ឺននាក់ឱ្យកាប់ឈើនៅភ្នំ ហើយ៣ពាន់៦រយនាក់ឱ្យ
ធ្វើជាអ្នកត្រួតត្រាការ ។

## ស្តេចសាឡូម៉ូនស្អាងព្រះវិហារ

*៣:១–១៤ – ១ពវ ៦:១–២៩*

3 1រួចមកសាឡូម៉ូនទ្រង់ចាប់តាំងស្អាង[ក]ព្រះវិហារនៃព្រះ
យេហូវ៉ា[ខ] នៅលើភ្នំម៉ូរីយ៉ា ក្នុងក្រុងយេរូសាឡិម ត្រង់
កន្លែងដែលព្រះយេហូវ៉ាបានលេចមកឯដាវីឌ ព្រះបិតា
ទ្រង់ ជាកន្លែងដាវីឌបានដំរូវទុក នៅទីលានស្រូវរបស់
អ័រ៉ោណា[គ]ជាសាសន៍យេប៊ូស 2ទ្រង់ចាប់តាំងស្អាង នៅថ្ងៃទី
២ខែពិសាខ ក្នុងឆ្នាំទី៤នៃរាជ្យទ្រង់[ឃ] 3រីឯជើងជញ្ជាំង
ដែលសាឡូម៉ូន បានដាំសំរាប់នឹងស្អាងព្រះវិហារនៃព្រះ
នោះមានបណ្តោយ៦០ហត្ថ និងទទឹង២០ហត្ថ[ង] តាមហត្ថ
ពីបុរាណ 4ឯបាំងសាចដែលនៅពីមុខ នោះបណ្តោយ២០
ហត្ថ ឱ្យត្រូវនឹងទទឹងព្រះវិហារ ហើយកំពស់១២០ហត្ថទ្រង់
ក៏ស្រោបដោយមាសសុទ្ធខាងក្នុង 5ឯល្វែងធំទ្រង់ស្រោប
ដោយឈើកកោះ រួចស្រោបដោយមាសយ៉ាងល្អ ព្រមទាំង
ដាប់ជាក្បាច់ដើមលម៉ើ[ច] និងច្រវាក់ 6ទ្រង់ពាក់តែងល្វែង

**២:១២** ធ នហ ៩:៦ ទដ ៨:៣ ៣៣:៦ ៩៦:៥ ១០២:២៥ ១៤៦:៦
**២:១៣** ន ១ពវ ៧:១៣
**២:១៤** ប នក ៣១:៦ ផ នក ៣៥:៣១ ព នក ៣៥:៣៥
**២:១៥** ភ អរ ៣:៧
**២:១៦** ម យស ១៩:៤៦ យហ ១:៣
**២:១៧** យ ១រប ២២:២ ២សយ ២៤:២
**៣:១** ក កច ៧:៤៧ ខ លប ២៨:១៧ គ ២សយ ២៤:១៨
**៣:២** ឃ អរ ៥:១១
**៣:៣** ង អរ ៤១:២
**៣:៥** ច អរ ៤០:១៦

**២:១៣** *ហ៊ីរ៉ាម* មើលការពន្យល់ ខ.៧ កណ្ឌគម្ពីរពង្សាវតារបានបង្ហាញថា តំណរពូជពង្សរបស់លោកហ៊ីរ៉ាម គឺតាមរយៈស្ត្រីមេម៉ាយណែបថាលី (១ពវ ៧:១៤) ពង្សាវតារក្សត្រដែលបានកត់ត្រា បង្ហាញពីភាពខ្លាំងនៃហេតុដូចគ្នារវាងហ៊ីរ៉ាម និងអូហូលីអាប់ ដោយកំណត់ថាគេជាពូជអំបូរដាន់ ។ គឺហេតុការណ៍ទាំងនេះគ្មានភាពផ្ទុយគ្នា ដែលគួឱ្យកត់សំគាល់នោះឡើយ (១) ពូជរបស់ម្តាយនោះអាចជានាងដាន់ទោះជានាងរស់នៅក្នុងព្រំដីនៃតំបន់ណែបថាលីក៏ដោយឬ (២) ឪពុកម្តាយរបស់នាងអាចមកពីលោកដាន់ និងនាងណែបថាលីគ្រួសារដាន់ ពីមុនធ្លាប់មានទំនាក់ទំនងនិងពួកស្រុកកេនីស (ពច ១៨:៧) ។

**២:១៧–១៨** មើល ១ពវ ៥:១៣–១៨ និងការពន្យល់ ។ អ្នកកាលប្រវត្តិបញ្ជាក់ថាជាការកេណ្ឌកម្លាំងពលកម្ម ពីអ្នកស្រុកជាជនជាតិបរទេសក្នុងក្រុង គឺមិនមែនជាជនជាតិអ៊ីស្រាអែលទេ ។ ហេតុការណ៍នេះក៏ពុំបានបញ្ជាក់ ក្នុងអត្ថបទប្រៀបធៀបក្នុងគម្ពីរពង្សាវតារក្សត្រដែរ ។ ១ពវ ៩:២០–២២ បង្ហាញពីការប្រើប្រាស់កម្លាំងបរទេស (មើល ៨:៨) ។

**២:១៨** *៣ពាន់៦រយនាក់ ធ្វើជាអ្នកត្រួតត្រា* មើល ខ.២ ជាទូរលេខបានផ្តល់មកក្នុង ១ពវ ៥:១៦ គឺ៣៣០០ហើយក៏មានកំណត់ត្រាជាការសរសេដោយដៃមិនបានបោះពុម្ពនៃគ្រីស្ទបរិស័ទមុនដំបូង គឺការប្រែពីភាសាក្រិកក្នុងគម្ពីរសញ្ញាចាស់ក៏មានចំនួន៣៦០០ ។ ពួកអ្នកកាលប្រវត្តិក៏អាចយកតាមទំលៀមទម្លាប់សាសន៍ហេព្រើរ គឺចំណុចនេះហើយ (សូមមើល ១ពវ ៥:១៦) ។

**៣:១–១៧** អ្នកកាលប្រវត្តិបានត្រិះគិតពិចារណានូវការពណ៌នា នៃការសាងសង់ព្រះវិហារតាមរយៈគម្ពីតពង្សាតារក្សត្រ ក៏មិនបានបញ្ចូលទាំងស្រុងដែរ ១ពវ ៦:៤–២០ ។ ការសង្ខេបនេះហើយ ដែលបង្ហាញពីទស្សនិកជនរបស់អ្នកកាលប្រវត្តិមានភាពថ្មីក ឬបានដឹងច្បាស់ពីប្រវត្តិសាស្ត្រសង្ខេបពីមុនខណៈបន្ទាប់មកគឺជារយៈពេលសាងសង់ឡើងវិញនូវព្រះវិហារ (ហាក ២:៣) ម្យ៉ាងវិញទៀតអ្នកកាលប្រវត្តិ ក៏បានផ្តោតការសរសេទៅលើការតុបតែង និងបំពាក់គ្រឿងលំអរ ក្នុងព្រះវិហារវិញ (៣:៦–៩ ៤:១,៦–៩) ។

**៣:១** *លើភ្នំម៉ូរីយ៉ា* គឺជាភ្នំដែលព្រះយេហូវ៉ាបញ្ជាឱ្យ អ័ប្រាហាំយកអ៊ីសាកជាកូនដើម្បីថ្វាយជាដង្វាយដុត ។ (លប ២២:២,១៤) *ជាកន្លែងដាវីឌបានដំរូវទុក* មើល ១រប ២១:១៨–២២:១ ។

**៣:២** *នៅថ្ងៃទី២ខែពិសាខ ក្នុងឆ្នាំទី៤នៃរាជ្យទ្រង់* គឺក្នុងរដូវផ្ការីកនៃឆ្នាំ ៩៦៦ មុន គ.ស ( មើលការពន្យល់ ១ពវ ៦:១) ។

**៣:៣** *តាមហត្ថពីបុរាណ* គឺវែងជាងហត្ថធម្មតា ៣អ៊ីង ។

**៣:៤** *បាំងសាច* គឺជាផ្នែកតុបតែងខាងមុខ ដែលស្រោបដោយមាសសុទ្ធដែលលំអរដោយត្បូងមានតម្លៃ (ខ.៥) ។

**៣:៦** *ស្រុកផាវែម* គឺជាស្រុកដែលមានប្រភពមាសជាច្រើន គឺនៅតំបន់អារ៉ាប៊ីខាងត្បូងឈាងខាងកើត គឺជាមាសមានគុណភាពលេខ១ ។

នោះ ឱ្យមានលំអ ដោយត្បូងមានដំឡៃឯមាសនោះ បានមក
ពីស្រុកផារវែម ៧ទ្រង់ស្រោបព្រះវិហារ ព្រមទាំងធ្នឹម និង
ក្របទ្វារ ហើយជញ្ជាំង និងផ្ទាំងទ្វារទាំងប៉ុន្មានដោយមាស
ហើយឆ្លាក់រូបចេរូប៊ីន[ឆ]នៅជញ្ជាំង ។
៨ទ្រង់ធ្វើល្វែងទីបរិសុទ្ធបំផុត[ជ] បណ្តោយ២០ហត្ថ ត្រូវ
និងទទឹងព្រះវិហារ ដែលមាន២០ហត្ថដែរ រួចស្រោប
ដោយមាសយ៉ាងល្អ មានទំងន់៦០០ហាប ៩ហើយដែក
គោល[ឈ] គឺជាមាសមានទំងន់៥០ដំឡឹង ឯបន្ទាប់ខាងលើក៏
ស្រោបដោយមាសដែរ ។
១០នៅក្នុងល្វែងទីបរិសុទ្ធបំផុត ទ្រង់ធ្វើរូបចេរូប៊ីន២[ញ]
ជារូបឆ្លាក់ ហើយក៏ស្រោបដោយមាស ១១ស្លាបចេរូប៊ីន
ទាំង២នោះ បានត្រដាងទៅ២០ហត្ថ ឯស្លាបម្ខាងរបស់
ចេរូប៊ីន១ មានប្រវែង៥ហត្ថ ត្រដាងទៅទល់នឹងជញ្ជាំង
ល្វែង ហើយស្លាប១ទៀតប្រវែង៥ហត្ថ ត្រដាងទៅទល់នឹង
ស្លាបចេរូបប៊ីនម្ខាង ១២ឯស្លាបចេរូប៊ីនម្ខាងនោះ ក៏ប្រវែង
៥ហត្ថ ត្រដាងទៅទល់នឹងជញ្ជាំងម្ខាងល្វែងនោះ ហើយ
ស្លាប១ទៀត ក៏ប្រវែង៥ហត្ថ ត្រដាងទៅទល់នឹងស្លាប់
ចេរូប៊ីនម្ខាង ១៣ដូច្នេះ ស្លាបចេរូប៊ីន[ដ]ទាំង២បានត្រដាងទៅ
អស់ប្រវែង២០ហត្ថ ចេរូប៊ីនទាំង២ក៏ឈរ បែរមុខប្រទល់
គ្នា ១៤ឯវាំងនន[ឋ] ទ្រង់ធ្វើដោយសំពត់ទេសឯក យ៉ាងម៉ដ្ត
មានពណ៌ខៀវ ពណ៌ស្វាយ និងពណ៌ក្រហម ហើយក៏ប៉ាក់
ជារូបចេរូប៊ីន[ឌ]ដែរ ។

**៣:៧** ឆ លប ៣:២៤ អរ ៤១:១៨
**៣:៨** ជ នក ២៦:៣៣
**៣:៩** ឈ នក ២៦:៣២
**៣:១០** ញ នក ២៥:១៨
**៣:១៣** ដ នក ២៥:១៨
**៣:១៤** ឋ នក ២៦:៣១,៣៣ ឌ លប ៣:២៤
**៣:១៥** ឍ ១ពវ ៧:១៥ វវ ៣:១២ ណ ១ពវ ៧:២២
**៣:១៦** ត ១ពវ ៧:១៧ ថ ១ពវ ៧:២០
**៤:១** ក នក ២០:២៤ ៤០:៦ ១ពវ ៨:៦៤
**៤:២** ខ វវ ៤:៦ ១៥:២
**៤:៤** គ ជណ ២:៣–២៥ អគ ៤៨:៣០–៣៤ វវ ២១:១៣
**៤:៦** ឃ នក ៣០:១៨ ង ជន ១៣:៥,៩ អគ

១៥នៅខាងមុខព្រះវិហារ ទ្រង់ធ្វើសសរ២[ឍ] កំពស់៣៥
ហត្ថ ហើយក្បាច់ក្បាល[ណ]ដែលនៅលើកំពូលសសរទាំង២
នោះ មានកំពស់៥ហត្ថទៀត ១៦ក៏ធ្វើក្បាច់ច្រវាក់ ដូច
ច្រវាក់[ត]នៅក្នុងទីបរិសុទ្ធបំផុត ដាក់ភ្ជាប់នៅក្បាលសសរ
រួចក៏ធ្វើរូបផ្លែទទឹម១០០[ថ] ដាក់ភ្ជាប់នឹងច្រវាក់ ១៧ហើយ
លើកបញ្ឈរសសរទាំង២ ដាក់នៅមុខព្រះវិហារ ១ខាងស្តាំ
១ខាងឆ្វេង ទ្រង់ឱ្យឈ្មោះសសរខាងស្តាថា យ៉ាគិនឯសសរ
ខាងឆ្វេងថា បូអូស។

## ការតុបតែងព្រះវិហារ

*៤:២–៦,១០–៥:១ – ១ពវ ៧:២៣–២៦,៣៨–៥១*

**៤** ១ទ្រង់ធ្វើអាសនា[ក]លង្ហិន បណ្តោយ២០ហត្ថ ទទឹង២០ហត្ថ
ហើយកំពស់១០ហត្ថ ២ក៏សិតធ្វើសមុទ្រ[ខ]មានរាងមូល ទំហំ
១០ហត្ថពីមាត់ខាងទៅម្ខាង ហើយកំពស់៥ហត្ថ យកខ្សែ
វាស់ជុំវិញត្រូវជា៣០ហត្ថ ៣នៅពីក្រោមគែមមាត់សមុទ្រ
នោះ មានរូបផ្កាក្រពុំ១០ ក្នុងកាលដែលសិតសមុទ្រនោះ
តែម្តង ៤សមុទ្រនោះដាក់នៅលើរូបគោ ៣បែរទៅខាង
ត្បូង ហើយ៣បែរទៅខាងកើត[គ]សមុទ្រនៅពីលើ ហើយគោ
ទាំងនោះ បែរគូថទៅខាងក្នុងទាំងអស់ ៥សមុទ្រនោះមាន
កំរាស់១ទះ ហើយគែមក៏ធ្វើដូចជាមាត់ពែង រាងដូចជា
ផ្កាច័ន្ទរ ចំណុះបានទឹក៣ពាន់អំរែក ៦ទ្រង់ក៏ធ្វើចានក្លាំ១០[ឃ]
ដាក់៥ខាងស្តាំ និង៥ខាងឆ្វេង សំរាប់ការលាងសំអាត
របស់អ្វីដែលត្រូវខាងដង្វាយដុត[ង] នោះគេលាងក្នុង ចានក្លាំ

**៣:៧** *រូបចេរូប៊ីន* មើល ខ.១០–១៤ និងពន្យល់ លប ៣:២៤ អគ ១:១៥ ។
**៣:៨** *បណ្តោយ២០ហត្ថត្រូវនិងទទឹងព្រះវិហារ ដែលមាន២០ហត្ថដែរ* ក៏មានកំពស់២០ហត្ថដែរ (១ពវ ៦:២០) គឺជាទីបរិសុទ្ធបំផុតក៏ដូចជាមានក្នុងរោងឧបោសថផងដែរ ។ ក្នុងក្រុងយេរូសាឡិមថ្មីគឺគ្មានព្រះវិហារទេ (វវ ២១:២២) ដោយសារទីក្រុងទាំងមូលប្រែក្លាយជាទីបរិសុទ្ធទាំងអស់ ។
**៣:៩** *ដែកគោលគឺជាមាស* ការពិតដែកគោលវាមានភាពទន់ណាស់គឺវាមិនទំនងជាដែកគោលនោះធ្វើពីមាសទេ វាអាចជាមានលក្ខណៈចំនួន ១ភាគ ៤ តែប៉ុណ្ណោះ ។
**៣:១០–១៣** មើល ១ពវ ៦:២៣–២៧ និងការពន្យល់ ។
**៣:១៤** *វាំនន* គឺសម្រាប់បន្ទប់ទាំពីរនៃរោងឧបោសថ (នក ២៦:៣១) ។ ទ្វារដែលធ្វើពីឈើក៏អាចបិទកាត់ទីលំហរដែរ (៤:២២ ១ពវ ៣:៣១–៣២ ប្រៀបធៀប មថ ២៧:៥១ ហព ៩:៨) ។
**៣:១៥** *ទ្រង់ធ្វើសសរ២កំពស់៣៥ហត្ថ* គឺជាតម្រូវឱ្យស្របគ្នានិងរង្វាស់ ១៨ហត្ថ (មើល ១ពវ ៧:១៥ ២ពវ ២៥:១៧ យរ ៥២:២១) ដែលមានចន្លោះឆ្លាស់គ្នាពី១ទៅ១ទៀត ។
**៣:១៧** *សសរ* គឺជាសសរដែលសល់ពីការគាស់កកាយ រកឃើញពីទីកន្លែងព្រះវិហារជាច្រើននៅឯទីបរិសុទ្ធ វវ ៣:១២ ។ *យ៉ាគិន . . . បូអូស* ។
**៤:១** *អាសនាលង្ហិន* គឺមានអត្ថបទហេតុការណ៍ដូចគ្នាមួយក្នុង ១ពវ ក៏មិនបានបង្ហាញបញ្ជាក់ពីអាសនាដ៏សំខាន់នោះទេ នៅក្នុងព្រះវិហារនោះ (១ពវ ៧:២២–២៣) តាមរយៈអត្ថបទជាច្រើននៅក្នុងគម្ពីរពង្សាវតារក្សត្រក៏បង្ហាញនៅក្នុង (១ពវ ៨:៦៤ ៩:២៥ ២ពវ ១៦:១៤) ។ អាសនាដ៏សំខាន់នោះរបស់ព្រះវិហារសាឡូម៉ូន គឺស្រដៀងនិងអាសនាដែលមានជណ្តើរដូចដែលបានពណ៌នាក្នុង គម្ពីរ អគ ៤៣:១៣–១៧ ។
**៤:២** *ធ្វើសមុទ្រមានរាងមូល* គឺដែលមានទឹកជាច្រើនដាក់ក្នុងអាងលង្ហិននោះរបស់រោងឧបោសថ (នក ៣០:១៨) គឺសម្រាប់ពួកសង្ឃប្រើប្រាស់ក្នុងការសំអាតគឺសម្រាប់ពិធីបុណ្យស្រងរូបកាយ (ខ.៦ នក ៣០:២១) ក្នុងសញ្ញាថ្មីមានទស្សនះក្នុងការប្រារព ធ្វើជាទម្លាប់ដូចជាព្រះគ្រីស្ទបានបង្រៀនដែរ (ទន ៣:៥ ហព ៩:១១–១៤) ។ (ខ.១០ ក្នុងខ ខាងលើប្រាប់ពីសមុទ្រដែលនៅជ្រុងព្រះវិហារនៅខាងត្បូង ដែលនៅចំពីមុខព្រះវិហារ (ខ.១០) ដែលគេហៅថាជាទន្លេថ្វាយជីវិត ដែលហូចេញពីផ្នែកតំបន់ខាងត្បូងក្បែរវិហារនោះ (អគ ៤៧:១–១២ ប្រៀបធៀប យអ ២២:១–២) ។
**៤:៤** *រូបគោ១២* គឺជាតំណាងពូជ (អំបូរ) ទាំង១២ ដែលបានបោះទីតាំងបញ្ឈដើងបី។ ក្នុងពូជអំបូរនៃជ្រុងរោងឧបោសថនិមួយ។ គឺក្នុងពេលធ្វើដំណើរឯទីរហោរស្ថាន (ជន ២ ប្រៀបធៀប អគ ៤៨:៣០–៣៥) ។
**៤:៥** *ចំណុះបានទឹក៣ពាន់អំរែក* ១ពវ ៧:២១ មាន២០០០អំរែក ពូជអំបូរបុរាណ ក៏មានការអានច្រឡំពីភាសាហេព្រើរ ។

ទាំងនោះ តែឯសមុទ្រនោះ សំរាប់ឱ្យពួកសង្ឃលាងវិញ ។
៧ទ្រង់ធ្វើជើងចង្កៀង[ច]១០ពីមាស តាមច្បាប់[ឆ]នៃជើង
ចង្កៀងទាំង នោះក៏យកទៅដាក់ក្នុងព្រះវិហារ ៥ខាងស្តាំ
ហើយ៥ខាងឆ្វេង ៨ក៏ធ្វើតុ[ជ]១០ដាក់ក្នុងព្រះវិហារ ៥ខាង
ស្តាំ ហើយ៥ខាងឆ្វេង រួចធ្វើផ្តិលមាស១០០[ឈ] ៩ទ្រង់ធ្វើទី
លាន[ញ]សំរាប់ពួកសង្ឃ និងទីលានធំ ព្រមទាំងទ្វារសំរាប់
ទីលាន ហើយស្រោបទ្វារទាំងនោះដោយលង្ហិន ១០ទ្រង់
ដាក់សមុទ្រនៅខាងស្តាំ នៃចុងខាងកើតរបស់ព្រះវិហារ
គឺឆៀងទៅខាងត្បូង ១១ហ៊ីរ៉ាមធ្វើឆ្នាំង ចបចូក និងខ្ទះទាំង
ប៉ុន្មានដែរ ដូច្នេះហ៊ីរ៉ាបានធ្វើសំរេច[ដ]ការទាំងប៉ុន្មាននោះ
ដែលគាត់ធ្វើថ្វាយស្តេចសាឡូម៉ូន នៅក្នុងព្រះវិហារនៃព្រះ
១២គឺសសរទាំង២ តួក្បាលសសរទាំង២ ដែលនៅលើ
កំពូលសសរនោះ ព្រមទាំងក្បាច់រាងក្រឡាអួន សំរាប់
បាំងតួក្បាលសសរដែលនៅលើកំពូលនោះ ១៣និងផ្លែទទឹម
៤០០ សំរាប់ក្បាច់ក្រឡាអួនទាំង២ គឺជាផ្លែទទឹម២ជួរក្នុង
ក្បាច់ក្រឡាអួន១ សំរាប់នឹងបាំងតួក្បាលសសរ ដែលនៅ
ពីលើនោះ ១៤គាត់ក៏ធ្វើគ្រោង[ឋ] និងចានក្លាំ ដាក់នៅលើ
គ្រោងទាំងនោះ ១៥សមុទ្រ១ និងគោ១២ ទ្រពីក្រោម
១៦ឆ្នាំង ចបចូក សម និងគ្រឿងប្រដាប់ទាំងប៉ុន្មាន ឯ
បណ្តាការទាំងនោះ ហ៊ីរ៉ាម[ឌ]ជាមេជាង បានធ្វើពីលង្ហិន
យ៉ាងភ្លឺ ថ្វាយស្តេចសាឡូម៉ូន សំរាប់ព្រះវិហារនៃព្រះ
យេហូវ៉ា ១៧ស្តេចទ្រង់បានសិតធ្វើទាំងអស់ នៅក្នុងពុម្ពដីឥដ្ឋ
ត្រង់វាលទន្លេយ័រដាន់កណ្តាលភូមិសិកូត[ឍ] និងសារថាន
១៨គឺយ៉ាងនោះ ដែលសាឡូម៉ូនបានធ្វើប្រដាប់ប្រដាទាំង
នោះយ៉ាងសន្ធឹកណាស់ ដ្បិតលង្ហិន[ណ]ទាំងនោះរកដឹងទំងន់
មិនបាន ។
១៩សាឡូម៉ូនទ្រង់ធ្វើគ្រឿងប្រដាប់ទាំងប៉ុន្មាន ដែលនៅ
ក្នុងព្រះវិហារនៃព្រះ គឺអាសនាមាស នឹងតុ[ត]ទាំងប៉ុន្មាន
សំរាប់ដាក់នំបុ័ងតាំងទុក ២០ហើយនឹងជើងចង្កៀង[ថ] និង
តួចង្កៀងពីមាសសុទ្ធ សំរាប់ដុតតាមច្បាប់ នៅមុខទីទូល
សួរដល់ព្រះ ២១ហើយផ្កា ចង្កៀង និងឃ្នាបប្រឆេះ ក៏ធ្វើពី
មាសដែរ គឺជាមាសយ៉ាងសុទ្ធបំផុត ២២ឯគ្របប្រឆេះ ចាន
ក្លាំ កូនចាន[ទ] និងពាន[ធ] ក៏ធ្វើពីមាសសុទ្ធចំណែកទ្វារចូលក្នុង
ព្រះវិហារ និងទ្វារខាងក្នុងដែលសំរាប់ចូលទីបរិសុទ្ធបំផុត
ព្រមទាំងទ្វារ នៃព្រះវិហារទាំងប៉ុន្មាននោះសុទ្ធតែធ្វើពី
មាសទាំងអស់ ។
**៥** ១ដូច្នេះ ការទាំងប៉ុន្មានដែលសាឡូម៉ូនធ្វើ សំរាប់ព្រះ
វិហារនៃព្រះយេហូវ៉ា បានធ្វើរួចជាស្រេច[ក] ហើយទ្រង់នាំ
យករបស់ទាំងប៉ុន្មានដែលដាវីឌ ជាព្រះបិតាទ្រង់បានថ្វាយ[ខ]
ទាំងប្រាក់ទាំងមាស និងគ្រឿងប្រដាប់ទាំងអស់ ចូលទៅនៅ
ក្នុងឃ្លាំងព្រះវិហារនៃព្រះ ។

### ការនាំហឹបនៃសេចក្តីសញ្ញាចូលព្រះវិហារ

*៥:២–៦:១១ – ១ពស៍ ៨:១–២១*

២រួចមក សាឡូម៉ូនទ្រង់ប្រមូលពួកចាស់ទុំនៃសាសន៍
អ៊ីស្រាអែល និងពួកចៅហ្វាយនៃពូជអំបូរទាំងអស់ ហើយ
ពួកអ្នកដែលជាកំពូលលើវង្សរបស់ឪពុកគេ ក្នុងពួកកូន
ចៅអ៊ីស្រាអែល មកឯក្រុងយេរូសាឡិម ដើម្បីនឹងនាំយក
ហឹបនៃសេចក្តីសញ្ញា[គ]ផងព្រះយេហូវ៉ា ចេញពីក្រុងដាវីឌគឺ
ជាក្រុងស៊ីយ៉ូនមក ៣ដូច្នេះបណ្តាមនុស្សសាសន៍អ៊ីស្រាអែល
ទាំងប៉ុន្មាន[ឃ] ក៏មូលព្រមគ្នាមកឯស្តេច នៅវេលាបុណ្យក្នុង
ខែអស្សុជ ៤ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលទាំងអស់ក៏មក
ដែរ ហើយពួកលេវីគេលើកសែងហឹប ៥នាំយកទាំងហឹប

៤០:៣៨
**៤:៧** ច នក ២៥:៣១
ឆ នក ២៥:៤០
**៤:៨** ជ នក ២៥:២៣
ឈ ជន ៤:១៤
**៤:៩** ញ ១ពស៍ ៦:៣៦
២រប ៣៣:៥
**៤:១១** ដ ១ពស៍ ៧:១៤
**៤:១៤** ឋ ១ពស៍ ៧:២៧–៣០
**៤:១៦** ឌ ១ពស៍ ៧:១៣
**៤:១៧** ឍ លស៍ ៣៣:១៧
**៤:១៨** ណ ១ពស៍ ៧:២៣
**៤:១៩** ត នក ២៥:២៣,៣០
**៤:២០** ថ នក ២៥:៣១
**៤:២២** ទ ជណ ៧:១៤ ធ លស៍ ១០:១
**៥:១** ក ១ពស៍ ៦:១៤ ខ ២សយ ៨:១១
**៥:២** គ ជន ៣:៣១ ១រប ១៥:២៥
**៥:៣** ឃ ១រប ៩:១
**៥:៤** ង ជណ ៣:៣១ ១រប ១៥:២

**៤:៦** *ចានក្លាំ ១០* មើល ១ពស៍ ៧:៣៨–៣៩ ។
**៤:៧** *ជើងចង្កៀង១០ពីមាស* គឺជាចំនួនការមួយដូចក្នុងរោងឧបោសថ (នក ២៥:៣១–៤០) តាមច្បាប់នៃជើងចង្កៀងទាំងនេះ គឺមានលក្ខណៈ ទ្រង់ទ្រាយដូចបានពណ៌នាក្នុង នក ២៥:៣១–៤០ តែអាចមានលក្ខណៈ ដូចគ្នានៃប្រភេទចង្កៀងក្នុង សគ ៤:១–៦ ។
**៤:៨** *តុ១០* គឺរួមតែមួយដូចក្នុងរោងឧបោសថផងដែរ (នក ២៥:២៣–៣០ ៤០:៤ លស៍ ២៤:៥–៩ ១សយ ២១:១–៦ អរ ៤១:២២ ហព ៩:២ ប្រៀបធៀប ២រប ១៣ :១១ ២៩:១៨) ។
**៤:១១–១៦** មើល ១ពស៍ ៧:៤០–៤៥ ។
**៤:១១** *ខ្ទះ* មើលការពន្យល់ នក ២៧:៣ ១ពស៍ ៧:៤០ ។
**៤:១៧–២២** មើល ១ពស៍ ៧:៤៦–៥០ និងការពន្យល់ ។
**៤:១៧** *ពុម្ពដីឥដ្ឋ* គឺជាដីឥដ្ឋនៅឯទន្លេយ័រដាន់ត្រូវបានយកមកប្រើសម្រាប់ធ្វើពុម្ពមើលការពន្យល់ ១ពស៍ ៧:៥៦ ។
**៥:១** *យករបស់ទាំងប៉ុន្មានដែលដាវីឌ* មើលការពន្យល់ ១រប ១៨:១–២០:៨ ២២:២–១៦ ២៩:២–៥ មើល ១រប ២៦:១៦ និងការពន្យល់ ។
**៥:២–១៤** មើល ១ពស៍ ៨:១–១១ និងការពន្យល់ ។
**៥:២** *ហឹប* ក៏បានផ្តល់ទាំង១០សម្រាប់រយៈពេល៤០ឆ្នាំដំបូងនៅពេលស្តេចដាវីឌបាននាំយកដល់ក្រុងយេរូសាឡិម (១រប ១៥:១–១៦:៦) ។
**៥:៣** *វេលាបុណ្យក្នុងខែអស្សុជ* ជាបុណ្យបារាំង គឺខែដែលរៀបចំដោយសាសន៍ កាណានផ្ទាល់មើល ១ពស៍ ៨:២ ឈ្មោះជា ភាសាហេព្រើរគឺ "ទីស្រី" យោងទៅលើ ១ពស៍ ៦:៣៨ គឺព្រះវិហារបានសាងសង់ចប់សព្វគ្រប់ក្នុងរយៈពេលប្រាំបីខែនៃឆ្នាំទី១១ របស់ស្តេចសាឡូម៉ូនគឺខែកញ្ញា–ខែតុលា ៩៥៩ មុន គ.ស ។ ការធ្វើពិធីបុណ្យនេះអាចកើតឡើង១១ខែ បន្ទាប់ពីការងារទាំងឡាយបានចប់ហើយ (សូមមើលការពន្យល់ ១ពស៍ ៨:២) ។
**៥:៥** *នាំយកទាំងហឹប . . . នឹងត្រសាលជំនុំ* គឺរោងឧបោសថនៅឯក្រុងកេបា (មើល ១:១៣ មើលការពន្យល់១រប ១៦:៣៩ ផងដែរ) ។

នឹងត្រសាលជំនុំ ហើយនិងគ្រឿងប្រដាប់បរិសុទ្ធដែលនៅ
ក្នុងត្រសាលទាំងអស់ឡើងមក គឺជាពួកលេវី[ង]ដ៏ជាសង្ឃ
ដែលសែងយកមកនោះ ៦ឯស្តេចសាឡូម៉ូន និងពួកជំនុំនៃ
សាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន ដែលបានមូលគ្នាមកឯទ្រង់
គេនៅមុខហឹបទាំងថ្វាយយញ្ញបូជា ជាចៀម និងគោយ៉ាង
សន្ធឹក ដែលនឹងរាប់ចំនួនមិនបាន ៧រួចពួកសង្ឃនាំយក
ហឹប[ច]នៃ សេចក្ដីសញ្ញាផងព្រះយេហូវ៉ា ចូលទៅឯកន្លែង
នៅក្នុងទីទូលសួរដល់ព្រះក្នុងព្រះវិហារ គឺក្នុងល្វែងបរិសុទ្ធ
បំផុត នៅក្រោមស្លាបនៃចេរូប៊ីន ៨ពីព្រោះចេរូប៊ីន[ឆ]ទាំង
២ត្រដាងស្លាប ពីលើកន្លែងសំរាប់ដាក់ហឹបហើយក៏គ្រប
ពីលើហឹប និងឈើស្នែង ៩ឯឈើស្នែងនោះវែងល្មម បាន
ជាមើលពីត្រង់ទីទូលសួរដល់ព្រះទៅ ឃើញចុងសងខាង
ចេញមកពីហឹប តែខាងក្រោមមិនឃើញទេ ហើយក៏នៅ
ទីនោះ ដរាបដល់សព្វថ្ងៃនេះ ១០រីឯនៅក្នុងហឹប ឥតមានអ្វី
ទេ មានតែ[ជ]បន្ទះថ្ម២ផ្ទាំង[ឈ]ប៉ុណ្ណោះ ដែលលោកម៉ូសេ
បានដាក់ ពីកាលនៅភ្នំហោរែបនៅឡើយ គឺកាលព្រះ
យេហូវ៉ា ទ្រង់តាំងសេចក្ដីសញ្ញានឹងពួកកូនចៅអ៊ីស្រាអែល
នៅគ្រាដែលគេចេញពីស្រុកអេស៊ីព្ទមក ។
១១រួចកាលពួកសង្ឃបានចេញ ពីទីបរិសុទ្ធមកវិញ (ដ្បិត
ពួកសង្ឃទាំងអស់ដែលនៅទីនោះ បានញែកខ្លួនជាបរិសុទ្ធ
ហើយគេមិនបានចាំធ្វើការងារតាមវេនទេ[ញ] ១២ឯពួកលេវី
ជាពួកអ្នកចំរៀងទាំងប៉ុន្មាន[ដ] គឺអេសាភ ហេម៉ាន និង
យេឌូថិន ព្រមទាំងពួកកូនចៅ និងពួកបងប្អូន គេស្លៀកពាក់
សំពត់ទេសឯកទាំងអស់គ្នាឈរនៅខាង កើតអាសនា កាន់
ឈឹង ពិណ និងស៊ុង ហើយមានពួកសង្ឃ១២០នាក់ឈរជា
មួយកំពុងតែផ្លុំត្រែដែរ)[ឋ] ១៣នៅខណនោះ កាលពួកផ្លុំត្រែ
និងពួកចំរៀង គេប្រគំភ្លេងព្រមគ្នា ឮសំឡេងតែ១ ដើម្បី
លើក សរសើរ ហើយអរព្រះគុណដល់ព្រះយេហូវ៉ាគឺកាល
គេឡើងសំឡេង ដោយផ្លុំត្រែ វាយឈឹង ហើយលេង
ប្រដាប់ភ្លេងទាំងប៉ុន្មាន ព្រមទាំងលើក សរសើរដល់ព្រះ

**៥:៧** ច វវ ១១:១៩
**៥:៨** ឆ លប ៣:២៤
**៥:១០** ជ ហព ៩:៤ ឈ នក ១៦:៣៤ ចទ ១០:២
**៥:១១** ញ ១របា ២៤:១
**៥:១២** ដ ១ពវ ១០:១២ ១របា ៩:៣៣ ២៥:១ ទដ ៦៨:២៥ ឋ ១របា ១៣:៨
**៥:១៣** ឌ ១របា ១៦:៣៤,៤១ ២របា ៧:៣ ២០:២១ អរ ៣:១១ ទដ ១០០:៥ ១០៦:១ ១០៧:១ ១១៨:១ ១៣៦:១ យរ ៣៣:១១ ឍ នក ៤០:៣៤
**៥:១៤** ណ នក ៤០:៣៥ វវ ១៥:៨ ត នក ១៩:១៦ ថ នក ២៩:៣៤ ៤០:៣៥
**៦:១** ក នក ១៩:៩
**៦:២** ខ អរ ៦:១២ ៧:១៥ ទដ ១៣៥:២១
**៦:៦** គ ចទ ១២:៥ អស ១៤:១ ឃ នក ២០:២៤ ង ១របា ២៨:៤
**៦:៧** ច ១សយ ១០:៧ ១របា ១៧:២ កច ៧:៤៦

យេហូវ៉ា ដោយពាក្យថា ទ្រង់ប្រកបដោយករុណាគុណ
សេចក្ដីសប្បុរសទ្រង់នៅអស់កល្បជានិច្ច[ឌ] នោះស្រាប់តែ
ព្រះវិហារព្រះយេហូវ៉ា មានពេញដោយពពក[ឍ] ១៤ដល់ម្ល៉េះ
បានជាពួកសង្ឃឈរធ្វើការងារ[ណ]មិនបាន ដោយព្រោះ
ពពកនោះ[ត] ដ្បិតសិរីល្អ[ថ]នៃព្រះយេហូវ៉ា នៅពេលក្នុងព្រះ
វិហារនៃព្រះ ។
៦ ១ខណនោះ សាឡូម៉ូនពោលថា ព្រះយេហូវ៉ាទ្រង់បាន
មានបន្ទូលថា ទ្រង់នឹងគង់នៅក្នុងងងឹតយ៉ាងក្រាស់[ក] ២តែ
ទូលបង្គំបានស្អាងព្រះវិហារនេះ ទុកជាទីលំនៅថ្វាយទ្រង់
វិញ គឺជាកន្លែងសំរាប់ឱ្យទ្រង់គង់ នៅអស់កល្បជានិច្ច[ខ]
៣រួចស្តេចទ្រង់បែរព្រះភក្ត្រមក ឱ្យពរដល់ពួក ជំនុំនៃ
សាសន៍អ៊ីស្រាអែលទាំងអស់គ្នា ហើយពួកជំនុំនៃសាសន៍
អ៊ីស្រាអែលទាំងអស់ក៏ឈរឡើង ៤នោះទ្រង់មានបន្ទូលថា
សូមឱ្យព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល បានព្រះ
ពរដែលទ្រង់បានមានបន្ទូល និងដាវីឌ ជាបិតាយើង ដោយ
ព្រះឱសទ្រង់ ហើយបានសំរេចសេចក្ដី នោះដោយសារ
ព្រះហស្តទ្រង់ ដោយបន្ទូលថា ៥ចាប់តាំងពីថ្ងៃដែលអញ
បាននាំរាស្ត្រអញ ចេញពីស្រុកអេស៊ីព្ទមក នោះអញមិន
បានរើសទីក្រុងណាមួយ ក្នុងអស់ទាំងពូជអំបូរសាសន៍
អ៊ីស្រាអែល ទុកជាទីសំរាប់ស្អាងព្រះវិហារ ឱ្យឈ្មោះអញ
បាននៅទីនោះឡើយ ក៏មិនបានរើសមនុស្សណាមួយ ឱ្យ
បានធ្វើជាស្តេចលើសាសន៍អ៊ីស្រាអែល ជារាស្ត្រអញដែរ
៦តែ ឥឡូវនេះវិញ អញបានរើសក្រុងយេរូសាឡិម[គ] ដើម្បីឱ្យ
ឈ្មោះអញ[ឃ]បាននៅទីនោះ ហើយអញបានរើសដាវីឌ[ង]ឱ្យ
បានគ្រប់គ្រងលើអ៊ីស្រាអែល ជារាស្ត្រអញ ៧ឯដាវីឌជា
បិតាយើង ទ្រង់បានប្រាថ្នា ក្នុងព្រះទ័យ[ច] ចង់ស្អាងព្រះ
វិហារសំរាប់ព្រះនាមព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែលដែរ ៨តែព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងដាវីឌ
ជាបិតាយើងថា ដែលឯងបានប្រាថ្នានៅក្នុងចិត្ត ចង់ស្អាង
ព្រះវិហារសំរាប់ឈ្មោះអញ នោះក៏ល្អហើយ ដោយកើត

**៥:៦** ប្រៀបធៀបពីការដែលស្តេចដាវីឌ បាននាំយកហឹបសញ្ញាទៅក្រុងយេរូសាឡិម (១របា ១៥:២៦ ១៦:១–៣) ។

**៥:៩** *ក៏នៅទីនោះដរាប់ដល់សព្វថ្ងៃនេះ* មើលការពន្យល់ ១ពវ ៨:៨ មើល ៨:៨ ១០:១៩ ២០:២៦ ២១:១០ ៣៥:២៥ ១របា ៤:៤១,៤៣ ៥:២៦ ១៣:១១ ១៧:៥ ។

**៥:១០** *បន្ទះថ្ម២* មើល នក ៣១:១៨ និងការពន្យល់ មើល នក ៣២:១៥–១៦ ហឹបសញ្ញាកាលពីមុនក៏មានរាង្គដូចជាក្រឡមាស(សូមមើល នក ១៦:៣២–៣៤) និងជាមនុស្សរបស់អើរ៉ុន(សូមមើល ជន ១៧:១០–១១ ហព ៩:៤)។ គឺជាផ្នែកមួយចំនួនបានបាត់បង់ប្រហែលជាហឹបនោះស្ថិតនៅក្នុងដៃរបស់ពួកសាសន៍ភីលីស្ទីន ។

**៥:១២** *សំពត់ទេសឯក* មើល ១របា ១៥:១៧ និងការពន្យល់ ។

**៥:១៤** *ពពកនោះ.... សិរីល្អនៃព្រះយេហូវ៉ា* ប្រៀបធៀប ៧:១–១៣ ពពកដែលជាសិរីល្អតំណាងវត្តមាននៃព្រះអម្ចាស់ ។ ពពកនេះបាននាំរាស្ត្រអ៊ីស្រាអែលឱ្យចេញពីស្រុកអេស៊ីព្ទ ដោយឆ្លងកាត់វាលរហោស្ថាននិងពពកក៏ជាសិរីល្អនៅពីលើរោងឧបោសថ (នក ១៣:២១–២២ ៤០:៣៤–៣៨ ប្រៀបធៀប អរ ៤៣:១–៥ ហក ២:៩ សក ១:១៦ ២:១០ ៨:៣) ។

**៦:១–១១** មើលការពន្យល់ ១ពវ ៨:១២–២១ ។

**៦:៨–៩** ប្រៀបធៀបសម្ដីរបស់ស្តេចដាវីឌ សូមមើល ១របា ២៨:២–៣ ។

មានគំនិតយ៉ាងដូច្នោះ ៩ប៉ុន្តែ ឯងមិនត្រូវស្អាងព្រះវិហារ
នោះទេ គឺជាកូនដែលឯងនឹងបង្កើតវិញ កូននោះនឹងស្អាង
ព្រះវិហារ សំរាប់ឈ្មោះអញ ១០ដូច្នេះ ព្រះយេហូវ៉ាទ្រង់
បានសំរេចតាមព្រះបន្ទូលដែលទ្រង់មានបន្ទូលនោះហើយ
ដ្បិតយើងបានកើតឡើងជំនួសដាវីឌ ជាបិតា ហើយក៏អង្គុយ
លើបល្ល័ង្ករាជ្យនៃសាសន៍អ៊ីស្រាអែល ដូចជាព្រះយេហូវ៉ា
បានសន្យាទុក ហើយយើងបានស្អាងព្រះវិហារនេះ សំរាប់
ព្រះនាមព្រះយេហូវ៉ា ដែលក្នុងហឹបនោះ មានសេចក្ដី
សញ្ញា[ឆ]ផងព្រះយេហូវ៉ា ជាសញ្ញាដែលទ្រង់បានតាំងនឹង
ពួកកូនចៅអ៊ីស្រាអែល ។

## សេចក្ដីអធិស្ឋានរបស់សាឡូម៉ូនសម្រាប់ការឆ្លងព្រះវិហារ

*៦:១២–៤០ – ១ពវ ៨:២២–៥៣*
*៦:៤១–៤២ – ទដ ១៣២:៨–១០*

១២សាឡូម៉ូនទ្រង់ឈរនៅចំពោះអាសនា នៃព្រះយេហូវ៉ា
នៅមុខពួកជំនុំសាសន៍អ៊ីស្រាអែលទាំងអស់ ក៏លើកព្រះ
ហស្តព្រះទូលឡើង ១៣(ដ្បិតទ្រង់បានធ្វើទីថ្កល់ពីលង្ហិន[ជ]
បណ្ដោយ ៥ហត្ថ ទទឹង៥ហត្ថ និងកំពស់៣ហត្ថ ដាក់នៅ
កណ្ដាលទីលាន ហើយទ្រង់ឈរនៅលើទីនោះ ក៏លុតព្រះ
ជង្ឃ[ឈ] នៅមុខពួកជំនុំនៃសាសន៍អ៊ីស្រាអែលទាំងអស់
លើកព្រះហស្តប្រទូលឡើងទៅលើមេឃ) ១៤ទូលថា ឱព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលអើយ គ្មានព្រះឯណា
ឱ្យដូចទ្រង់ឡើយ[ញ] ទោះនៅលើមេឃឬនៅផែនដីក្តី ទ្រង់
កាន់តាមសេចក្ដីសញ្ញា នឹងសេចក្ដីសប្បុរស[ដ]ដល់ពួកអ្នក
បំរើទ្រង់ ដែលដើរនៅចំពោះទ្រង់ដោយចិត្តស្មោះត្រង់
១៥ទ្រង់បានរក្សាសេចក្ដីសន្យា[ឋ] ដែលទ្រង់បានមានបន្ទូល
នឹងអ្នកបំរើទ្រង់ គឺនឹងដាវីឌ ជាបិតាទូលបង្គំ ទ្រង់បានមាន
បន្ទូលដោយព្រះឱស្ឋទ្រង់ ហើយសំរេចសេចក្ដីនោះ ដោយ
ព្រះហស្តទ្រង់ ដូចជាមានមកសព្វថ្ងៃនេះ ១៦ដូច្នេះ ឱព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលអើយ សូមទ្រង់
រក្សាសេចក្ដី ដែលទ្រង់បានសន្យានឹងបិតាទូលបង្គំគឺនឹង
ដាវីឌ ជាអ្នកបំរើទ្រង់ថា នឹងមិនដែលខាន[ឌ]មានពូជ ឯង
អង្គុយលើបល្ល័ង្ករាជ្យនៃសាសន៍អ៊ីស្រាអែល នៅមុខអញ

**៦:១១** ឆ ចទ ១០:២ ទដ ២៥:១០ ៥០:៥
**៦:១៣** ជ នហ ៨:៤ ឈ ទដ ៩៥:៦
**៦:១៤** ញ នក ៨:១០ ១៥:១១ ដ ចទ ៧:៩
**៦:១៥** ឋ ១របា ២២:១០
**៦:១៦** ឌ ២សយ ៧:១៣,១៥ ២របា ២៣:៣ ឍ ទដ ១៣២:១២
**៦:១៨** ណ វវ ២១:៣ ត ទដ ១១:៤ អស ៤០:២២ ៦៦:១
**៦:២០** ថ នក ៣:១៦ ទដ ៣៤:១៥ ទ ចទ ១២:១១ ធ ២របា ៧:១៤ ៣០:២០
**៦:២១** ន ទដ ៥១:១ អស ៣៣:២៤ ៤០:២ ៤៣:២៥ ៤៤:២២ ៥៥:៧ មីក ៧:១៨
**៦:២២** ប នក ២២:១១
**៦:២៣** ផ អស ៣:១១ ៦៥:៦ មថ ១៦:២៧
**៦:២៤** ព លវ ២៦:១៧

ឡើយ ឱ្យតែកូនចៅឯងប្រុងប្រយ័តនឹងផ្លូវខ្លួន ដើម្បីនឹងដើរ
តាមក្រិត្យវិន័យ[ឍ]របស់អញ ដូចជា ឯងបានដើរនៅមុខអញ
ដែរ ១៧ដូច្នេះ ឱព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
អើយ ឥឡូវនេះ សូមទ្រង់បញ្ជាក់ព្រះបន្ទូលដែល ទ្រង់បាន
មានបន្ទូលនឹងដាវីឌ ជាអ្នកបំរើទ្រង់ចុះ ។
១៨យីអើ តើព្រះនឹងគង់នៅ[ណ]ជាមួយនឹងមនុស្ស នៅលើ
ផែនដីជាប្រាកដឬ មើល ផ្ទៃមេឃនឹងអស់ទាំងជាន់នៃផ្ទៃ
មេឃ[ត] មិនល្មមឱ្យទ្រង់ គង់ចុះទៅហើយ ចំណង់បើព្រះ
វិហារដែលទូលបង្គំបានស្អាងនេះ តើនឹងចង្អៀតអំបាល
ម៉ានទៅទៀត ១៩ប៉ុន្តែ ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំ
អើយ សូមទ្រង់ប្រោសមេត្តាទទួលពាក្យ ដែលទូលបង្គំជា
អ្នកបំរើ ទ្រង់អធិស្ឋាន ហើយទូលអង្វរ ដើម្បីនឹងស្ដាប់តាម
សំរែក និងសេចក្ដីអធិស្ឋាន ដែលទូលបង្គំទូលដល់ទ្រង់ផង
២០ប្រយោជន៍ឱ្យព្រះនេត្រ ទ្រង់[ថ]បានបើកទតមកឯព្រះ
វិហារនេះទាំងយប់ទាំងថ្ងៃ គឺទតមើលមកទីកន្លែងដែល
ទ្រង់បានមានបន្ទូលហើយថា ទ្រង់នឹងតាំងព្រះនាម[ទ]ទ្រង់
នៅទីនោះ ដើម្បីនឹងស្ដាប់[ធ]សេចក្ដីអធិស្ឋាន ដែលទូលបង្គំ
នឹងទូលដំរង់មកឯទីនេះ ២១ហើយកាលណាទូលបង្គំនឹង
ពួកអ៊ីស្រាអែលជារាស្ត្រ របស់ទ្រង់ អធិស្ឋានមកឯទីនេះ
នោះសូមទ្រង់ស្ដាប់សេចក្ដីទូល អង្វររបស់ យើងខ្ញុំផងគឺ
សូមទ្រង់ស្ដាប់ពីលើស្ថានសួគ៌ ជាទីលំនៅនៃទ្រង់ លុះកាល
ទ្រង់ព្រះសណ្ដាប់ហើយ នោះសូមអត់ទោសឱ្យផង[ន] ។
២២បើសិនជាអ្នកណាធ្វើបាបទាស់នឹងអ្នកជិតខាងខ្លួន
ហើយគេឱ្យអ្នកនោះស្បថ រួចអ្នកនោះក៏មកស្បថ[ប]នៅមុខ
អាសនានៃទ្រង់ក្នុងព្រះវិហារនេះ ២៣នោះសូមទ្រង់ប្រោស
ស្ដាប់ពីលើស្ថានសួគ៌ ហើយសំរេចការដោយជំនុំជំរះពួក
បាវបំរើទ្រង់ ទាំងដាក់ទោស[ផ]ដល់មនុស្សអាក្រក់ ដើម្បីនឹង
ទំលាក់អំពើអាក្រក់របស់គេ ទៅលើក្បាលគេវិញ ហើយ
សំរេចដល់មនុស្សសុចរិតទុកជាសុចរិត ដើម្បីនឹងសងគេ
តាមសេចក្ដីសុចរិតរបស់ខ្លួនគេទៅ ។
២៤បើកាលណាសាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ទ្រង់
ត្រូវចាញ់[ព] នៅមុខពួកខ្មាំងសត្រូវ ដោយព្រោះគេបានធ្វើ

**៦:១២–១២** មើលការពន្យល់ ១ពវ ៨:២២–៣០ ។
**៦:១៣** គឺមិនមែននៅក្នុង ១ពវ ៨ នោះទេ ។ អ្នកខ្លះគិតថាអ្នកកាលប្រវត្តិអាចមានប្រាថ្នាសុំឱ្យបង្ហាញការពិត ដែលថាស្ដេចសាឡូម៉ូន"ពុំបានឈរពីមុខអាសនាទេ"(ខ.១២)គឺជាការហាត់អនុវត្ត នូវភារៈកិច្ចជាសង្ឃ ។ ម្យ៉ាងវិញទៀតខទាំងនោះស្រងចេញពីគម្ពីរ ពវ ដោយមានការកត់ត្រាខុស ។
**៦:១៤** *ទ្រង់កាន់តាមសេចក្ដីសញ្ញា នឹងសេចក្ដីសប្បុរស* មើល ១ពវ ៨:២៣ និងការពន្យល់ ។
**៦:១៨** ប្រៀបធៀប ២:៦ ។
**៦:២២–៣៩** មើលការពន្យល់ ១ពវ ៨:៣១–៤៦ ។
**៦:២២–២៣** មើល នក ២២:១០–១១ លវ ៦:៣–៥ ។
**៦:២៤–២៥** មើល លវ ២៦:១៧,២៣ ចទ ២៨:២៥,៣៦–៣៧,៤៨–៥៧,៦៤ យស ៧:១១–១២ ។

បាបនឹងទ្រង់ នោះបើគេត្រឡប់មកវិញ ព្រមទាំងគោរព
ដល់ព្រះនាមទ្រង់ ហើយនឹងអធិស្ឋាន ទូលអង្វរ នៅចំពោះ
ទ្រង់ក្នុងព្រះវិហារនេះ ២៥នោះសូមទ្រង់ប្រោសស្តាប់ពី
លើស្ថានសួគ៌ និងអត់ទោសចំពោះអំពើបាបរបស់ពួក
អ៊ីស្រាអែលជារាស្ត្រទ្រង់ផង រួចសូមនាំគេត្រឡប់មក នៅ
ក្នុងស្រុកដែលទ្រង់ បានប្រទានដល់គេ និងពួកឰយុកោគេ
វិញ ។
២៦បើកាលណាមេឃរាំងភ្លៀង[ភ] ដោយព្រោះគេបាន
ធ្វើបាបនឹងទ្រង់ នោះបើគេអធិស្ឋានដំរង់មកឯទីនេះ ព្រម
ទាំងគោរពដល់ព្រះនាមទ្រង់ ហើយលះបង់ចោលអំពើ
បាបរបស់គេចេញ ដោយព្រោះទ្រង់បានផ្ចាញ់ផ្ចាលគេ
២៧នោះសូមទ្រង់ប្រោសស្តាប់ពីលើស្ថានសួគ៌ ហើយអត់
ទោស[ម] ចំពោះអំពើបាបរបស់ពួកអ្នកបំរើទ្រង់ គឺជាពួក
អ៊ីស្រាអែល ជារាស្ត្រទ្រង់ ដោយបង្រៀនឱ្យគេដឹងផ្លូវល្អ
ណាដែលត្រូវដើរ រួចសូមបង្អុរភ្លៀង ឱ្យមកលើស្រុករបស់
ទ្រង់ ដែលបានប្រទានមករាស្ត្រទ្រង់ទុកជាមរដកផង ។
២៨បើកាលណាកើតមានអំណត់[យ]នៅក្នុងស្រុក ឬបើមាន
អន្តរាយ ស្កកស្រូវ ក្រាចាប់ កណ្តូបឬដង្កូវស៊ី បើពួកខ្មាំង
សត្រូវលុកលុយមក ក្នុងស្រុកឡោមព័ទ្ធទីក្រុង ឬកើតមាន
សេចក្តីវេទនាណា ឬជំងឺណាក៏ដោយ ២៩នោះទោះបើ
មនុស្សណា ឬបណ្តាពួកអ៊ីស្រាអែលជារាស្ត្រទ្រង់ ដែល
ស្គាល់សេចក្តីវេទនា និងសេចក្តីទុកលំបាក នៅក្នុងចិត្តខ្លួន
គេលើកដៃប្រទូលដំរង់មកឯព្រះវិហារនេះ ហើយអធិស្ឋាន
ឬទូលសូមអ្វីក៏ដោយ ៣០នោះសូមទ្រង់ប្រោសស្តាប់ពីលើ
ស្ថានសួគ៌ ជាទីលំនៅរបស់ទ្រង់ ហើយអត់ទោស[រ] ព្រមទាំង
សងដល់គ្រប់គ្នាតាម អំពើប្រព្រឹត្តរបស់គេ តាមតែទ្រង់
ជ្រាបចិត្តគេ (ដ្បិតគឺទ្រង់តែមួយ ដែលជ្រាបចិត្តនៃពួក
មនុស្សលោកទាំងអស់)[ល] ៣១ដើម្បីឱ្យគេបានកោតខ្លាចដល់
ទ្រង់[វ] ប្រយោជន៍ឱ្យបានដើរតាមផ្លូវទ្រង់ នៅអស់១ជីវិត
ដែលគេរស់នៅក្នុងស្រុក ដែលទ្រង់បានប្រទានមកពួក
ឰយុកោយើងខ្ញុំរាល់គ្នា ។
៣២មួយទៀតត្រង់ឯពួកសាសន៍ដទៃ ដែលមិនមែនជាពូជ
ពង្សអ៊ីស្រាអែល ជារាស្ត្រទ្រង់ទេ បើកាលណាគេមក[ស]ពី
ស្រុកឆ្ងាយ ដោយព្រោះព្រះនាមទ្រង់ដ៏ជាធំ និងព្រះហស្ត
ដ៏មានឥទ្ធិឫទ្ធិ[ហ] ហើយព្រះពាហុ លើកសំរេចរបស់ទ្រង់
កាលណាគេអធិស្ឋានដំរង់មកឯព្រះវិហារនេះ ៣៣នោះសូម
ទ្រង់ប្រោសស្តាប់ពីលើស្ថានសួគ៌ គឺពីទីលំនៅរបស់ទ្រង់
ហើយធ្វើសព្វគ្រប់ តាមសេចក្តីដែលសាសន៍ដទៃ[ឡ]នោះ
នឹងសូមដល់ទ្រង់ផង ដើម្បីឱ្យគ្រប់ទាំងសាសន៍ នៅផែនដី
បានស្គាល់ព្រះនាមទ្រង់ ហើយកោតខ្លាចដល់ទ្រង់ដូចជា
សាសន៍អ៊ីស្រាអែល ជារាស្ត្រទ្រង់ដែរ ហើយឱ្យគេបាន
ដឹងថា ព្រះវិហារដែលទូលបង្គំបានស្អាងនេះ បានហៅ
តាមព្រះនាមទ្រង់ពិត ។
៣៤បើសិនជារាស្ត្ររបស់ទ្រង់ចេញទៅ ច្បាំងនឹងខ្មាំង
សត្រូវ[អ] តាមផ្លូវណាក៏ដោយ ដែលទ្រង់នឹងចាប់គេឱ្យទៅ
ហើយគេអធិស្ឋាន[ក]ដល់ទ្រង់ ទាំងបែរមកឯទីក្រុងនេះដែល
ទ្រង់បានរើសនិងព្រះវិហារ នេះដែលទូលបង្គំបានស្អាង
ថ្វាយដល់ព្រះនាមទ្រង់ ៣៥នោះសូមទ្រង់ប្រោសស្តាប់ពីលើ
ស្ថានសួគ៌ ចំពោះពាក្យដែលអធិស្ឋាន ហើយទូលអង្វរ ព្រម
ទាំងសំរេចតាមសេចក្តីត្រឹមត្រូវឱ្យគេផង ។
៣៦បើកាលណាគេធ្វើបាបនឹងទ្រង់ (ដ្បិតគ្មានមនុស្ស
ឯណាមួយដែលមិនធ្វើបាបឡើយ)[ខ] ហើយទ្រង់កើតមាន
សេចក្តីក្រោធ ព្រមទាំងប្រគល់គេទៅឱ្យពួកខ្មាំងសត្រូវ
ឱ្យបានដឹកនាំទៅជាឈ្លើយ[គ] នៅស្រុកណាទោះឆ្ងាយឬជិតក្តី
៣៧នោះបើគេនឹកចាំ[ឃ] នៅក្នុងស្រុកដែលបានដឹកនាំគេទៅ
ជាឈ្លើយនោះ ហើយបែរត្រឡប់មកវិញ ព្រមទាំងទូលអង្វរ
ដល់ទ្រង់នៅក្នុងស្រុក ដែលគេនៅជាឈ្លើយនោះថា យើង
ខ្ញុំបានធ្វើបាប ព្រមទាំងប្រព្រឹត្តក្រវិចក្រវៀន ហើយធ្វើការ
អាក្រក់ ៣៨បើសិនជាគេវិលត្រឡប់មកឯទ្រង់ អស់ពីចិត្ត អស់
ពីព្រលឹង នៅក្នុងស្រុកដែលគេនៅជាឈ្លើយគឺក្នុងស្រុក
ដែលខ្មាំងសត្រូវបានដឹកនាំទៅនោះ ហើយគេអធិស្ឋាន
ដំរង់មកឯស្រុកនេះ ដែលទ្រង់បានប្រទានដល់ពួកឰយុកោ
គេ និងទីក្រុងនេះដែលទ្រង់បានរើស ហើយព្រះវិហារនេះ
ដែលទូលបង្គំបានស្អាងថ្វាយដល់ព្រះនាមទ្រង់ ៣៩នោះសូម
ទ្រង់ប្រោសស្តាប់ ពីលើស្ថានសួគ៌ គឺពីទីលំនៅរបស់ទ្រង់
ចំពោះពាក្យដែលគេអធិស្ឋាន ហើយទូលអង្វរព្រមទាំង
សំរេចសេចក្តីត្រឹមត្រូវឱ្យគេផង ហើយអត់ទោស[ង]ដល់
រាស្ត្រទ្រង់ ដែលបានធ្វើបាបនឹងទ្រង់នោះ ។

**៦:២៦** ភ លវ ២៦:១៩ ចទ ១១:១៧ ២៨:២៤ ២សយ ១:២១
**៦:២៧** ម ខ.៣០,៣៩ ២រប ៧:១៤
**៦:២៨** យ ២រប ២០:៩
**៦:៣០** រ ខ.២៧ ល ១សយ ២:៣ ទដ ៧:៩ ៤៤:២១ សផ ១៦:២ ១៧:៣
**៦:៣១** វ ចទ ៦:១៣ ទដ ៣៤:៧,៩ ១០៣:១១,១៣ សភ ៨:១៣
**៦:៣២** ស ២រប ៩:៦ ហ នក ៣:១៩,២០
**៦:៣៣** ឡ នក ១២:៤៣
**៦:៣៤** អ ចទ ២៨:៧ ក ១រប ៥:២០
**៦:៣៦** ខ ១ពវ ៨:៤៦ យប ១១:១២ ១៥:១៤ ទដ ១៤៣:២ សស ៧:២០ យរ ៩:៥ ១២:២៣ ១៧:៩ រម ៣:៩ អភ ២:៣ គ លវ ២៦:៤៤
**៦:៣៧** ឃ ១ពវ ៨:៤៨ ២រប ៧:១៤ ១២:៦,១២ ៣០:១១ ៣៣:១២,១៩,២៣ ៣៤:២៧ ៣៦:១២ អស ៥៨:៣ យរ ២៤:៧ ២៩:១៣
**៦:៣៩** ឃ ខ.២៧ ២រប ៣០:៩

**៦:២៦–២៧** មើល លវ ២៦:១៩ ចទ ១១:១០–១៥ ២៨:១៨,២២–២៤ ។
**៦:២៨–៣១** មើល លវ ២៦:១៦,២០,២៥–២៦ ចទ ២៨:២០–២២,២៧–២៨ ៣៥:៤២ ។
**៦:៣២–៣៣** គឺពួកហោរាបានប្រមើលមើលពីសាសន៍ដទៃ ដែលមកទីក្រុងយេរូសាឡិមថ្វាយបង្គំព្រះយេហូវ៉ា (អស ២:៣ ៥៦:៦–៨ មើល ៤:២ សក ៨:២០–២៣ ១៤:១៦–២១ ប្រៀបធៀប ទដ ៨៧) ។
**៦:៣៦** *ដ្បិតគ្មានមនុស្សឯណាមួយ ដែលមិនធ្វើបាបឡើយ* សូមមើល យរ ១៣:២៣ រម ៣:២៣ *ប្រគល់ឱ្យពួកខ្មាំងសត្រូវ . . . ទោះឆ្ងាយជិតក្តី* សូមមើល ៣៦:១៥–២០ លវ ២៦:៣៣,៤៤–៤៥ ចទ ២៨:៤៩–៥២ ២ពវ ១៧:៧–២០ ២៥:១–២១ ។

[៤០]ឥឡូវនេះ ឱព្រះនៃទូលបង្គំអើយ សូមឱ្យព្រះនេត្រទ្រង់
បាន នៅតែបើក ហើយព្រះកាណ៌ទ្រង់ផ្ទៀងស្តាប់ជានិច្ច[ច]
ចំពោះសេចក្តីដែលគេអធិស្ឋាននៅទីនេះ [៤១]ដូច្នេះ ឱព្រះ
យេហូវ៉ាដ៏ជាព្រះអើយ សូមទ្រង់ឈរឡើង[ឆ] យាងចូលទៅ
ឯទីសំរាករបស់ទ្រង់ឥឡូវ[ជ] ព្រមទាំងហឹបរបស់ឥទ្ធានុភាព
របស់ទ្រង់ផង ឱព្រះយេហូវ៉ាដ៏ជាព្រះអើយ សូមឱ្យពួក
សង្ឃ[ឈ]នៃទ្រង់បានប្រដាប់ខ្លួន ដោយសេចក្តីសង្គ្រោះ
ហើយឱ្យពួកបរិសុទ្ធរបស់ទ្រង់បានរីករាយសប្បាយ ដោយ
សេចក្តីល្អ[ញ] [៤២]ឱព្រះយេហូវ៉ាដ៏ជាព្រះអើយ សូមកុំបំបែរ
មុខនៃអ្នកដែលទ្រង់បានចាក់ ប្រេងតាំងចេញឡើយ[ដ] សូម
នឹកចាំពីសេចក្តីសប្បុរស[ឋ] ដែលទ្រង់បាន ប្រោសដល់ដាវីឌ
ជាអ្នកបំរើទ្រង់ផង ។

## ការធ្វើបុណ្យឆ្លងព្រះវិហារ

*៧:១-១០ – ១ពវ ៨:៦២-៦៦*

**៧** [១]កាលសាឡូម៉ូនបានអធិស្ឋានស្រេចហើយ នោះភ្លើង[ក]ក៏
ចុះពីលើមេឃ មកបញ្ឆេះដង្វាយដុត និងយញ្ញបូជាទាំង
ប៉ុន្មានទៅ ហើយព្រះវិហារបានពេញ[ខ] ដោយសិរីល្អនៃព្រះ
យេហូវ៉ា[គ] [២]ពួកសង្ឃចូលទៅ[ឃ] ក្នុងព្រះវិហារនៃព្រះ
យេហូវ៉ាមិនបាន ដោយព្រោះសិរីល្អ[ង]នៃព្រះយេហូវ៉ា នៅ
ពេញក្នុងព្រះវិហារនោះ [៣]ឯពួកកូនចៅអ៊ីស្រាអែលទាំង
អស់គ្នា គេក៏មើលឃើញ ក្នុងកាលដែលភ្លើងចុះមក និង
សិរីល្អនៃទ្រង់បាននៅលើព្រះវិហារដែរ ហើយគេឱនខ្លួន
ក្រាបចុះផ្កាប់មុខដល់ដីថ្វាយបង្គំ នៅទីក្រាលថ្ម ព្រមទាំងអរ
ព្រះគុណដល់ព្រះយេហូវ៉ាថា ទ្រង់ប្រកបដោយករុណាគុណ
ឯសេចក្តីសប្បុរសរបស់ទ្រង់ ក៏នៅអស់កល្បជានិច្ច[ច] ។
[៤]រួចមកស្តេច និងបណ្តាជនទាំងឡាយ ក៏ថ្វាយយញ្ញបូជា
នៅចំពោះព្រះយេហូវ៉ា [៥]ស្តេចសាឡូម៉ូនទ្រង់ ថ្វាយយញ្ញ
បូជា ជាគោ២ម៉ឺន២ពាន់នឹងចៀម១សែន២ម៉ឺនគឺយ៉ាងនោះ
ដែលស្តេចនិងពួកជនបានធ្វើបុណ្យឆ្លងព្រះវិហារនៃ ព្រះ
[៦]ឯពួកសង្ឃ គេឈរនៅទីតាម ដំណែងរបស់គេ
រៀងខ្លួនព្រមទាំងពួកលេវីដែរ[ឆ] គេកាន់ប្រដាប់ភ្លេង នៃ
ព្រះយេហូវ៉ា[ជ] ដែលស្តេចដាវីឌបានធ្វើសំរាប់នឹងអរព្រះ
គុណដល់ព្រះយេហូវ៉ា ក្នុងកាលដែលដាវីឌបានសរសើរ
ដោយសារពួកនោះថា សេចក្តីសប្បុរសនៃទ្រង់នៅអស់
កល្បជានិច្ច ពួកសង្ឃក៏ផ្លុំត្រែឡើងនៅមុខគេ ហើយ
ពួកអ៊ីស្រាអែលទាំងអស់ក៏ឈរនៅ [៧]សាឡូម៉ូនទ្រង់ញែក
កន្លែងកណ្តាលទីលាន ដែលនៅមុខព្រះវិហារនៃព្រះ
យេហូវ៉ា ចេញជាបរិសុទ្ធដ្បិតគឺនៅទីនោះហើយ ដែលទ្រង់
ថ្វាយដង្វាយដុតទាំងប៉ុន្មាន ព្រមទាំងខ្លាញ់[ឈ]ដង្វាយមេត្រី
ផង ពីព្រោះអាសនាលង្ហិន ដែលសាឡូម៉ូនបានធ្វើនោះ
មិនល្មម និងទទួលអស់ទាំងដង្វាយដុតដង្វាយម្សៅ និងខ្លាញ់
ផងបានទេ ។
[៨]នៅគ្រានោះ សាឡូម៉ូន នឹងពួកអ៊ីស្រាអែលទាំងអស់
គ្នា[ញ] បានធ្វើបុណ្យ[ដ] អស់៧ថ្ងៃ ជាជំនុំយ៉ាងធំ ដែលមូលមក
ចាប់តាំងពីទ្វារចូលស្រុកហាម៉ាត[ឋ] រហូតដល់ជ្រោះស្រុក
អេស៊ីព្ទ[ឌ] [៩]នៅថ្ងៃទី៨ គេក៏ប្រជុំជាជំនុំមុតមាំ ពីព្រោះគេធ្វើ[ឍ]
បុណ្យឆ្លងអាសនាអស់៧ថ្ងៃ និងបុណ្យនោះ[ណ]៧ថ្ងៃទៀត

**៦:៤០** ង ១ពវ ៨:២៩,៥២ ២របា ៧:១៥ នហ ១:៦,១១ ទដ ១៧:១,៦ ១១៦:១ ១៣០:២ អស ៣៧:១៧
**៦:៤១** ច ទដ ៣:៧ ៧:៦ ៥៩:៤ អស ៣៣:១០ ឆ ១របា ២៣:២ ជ ទដ ១៣២:១៦ ឈ ទដ ១៣:៦ ២៧:១៣ ១១៦:១២ ១៤២:៧
**៦:៤២** ញ ទដ ២:២ ដ ទដ ៨៩:២៤,២៨
**៧:១** ក នក ១៩:១៨ លវ ៩:២៤ ១ពវ ១៨:៣៨ ខ នក ១៦:១០ គ ទដ ២៦:៨
**៧:២** ឃ ១ពវ ៨:១១ ង នក ២៩:៤៣ ៤០:៣៥
**៧:៣** ច ១របា ១៦:៣៤ ២របា ៥:១៣ អរ ៣:១១
**៧:៦** ឆ ១របា ១៥:១៦ ជ ១របា ១៥:២៤
**៧:៧** ឈ នក ២៩:១៣
**៧:៨** ញ ២របា ៣០:២៦ នហ ៨:១៧ ដ ១របា ៩:១ ឋ ជន ១៣:២១ ឌ

**៦:៤០-៤២** អ្នកកាលប្រវត្តិបានបញ្ចូលសេចក្តីអធិស្ឋានរបស់ស្តេចសាឡូម៉ូនទៅក្នុងគម្ពីរពង្សាវតារក្សត្រ(១ពវ ៨:៥០-៥៣) ជាមួយ ទដ ១៣២:៨-១០ ជាទំនុកដំកើងដែលទាក់ទងនឹងការនាំយកហឹបទៅក្នុងព្រះវិហារនិងផ្ទៃរឿងនេះក៏មាននៅក្នុងគម្ពីរ របាក្សត្រដែរ(៥:២-១៤) ។ ការអធិស្ឋានក្នុងគម្ពីរ ពវ បានបញ្ជាក់ដោយបង្ហាញឱ្យឃើញក្នុងគម្ពីរនិក្ខមនំ ដែលការចាកចេញដែលលោកម៉ូសេបានរំដោះ ។ គម្ពីររបាក្សត្រក៏បង្ហាញពីព្រះបន្ទូលសន្យាដ៏ជាមូលដ្ឋាន គឺព្រះបានសន្យាដល់ស្តេចដាវីឌ ។

**៧:១-២២** មើល ១ពវ ៨:៥៤-៩:៩ និងការពន្យល់ ។

**៧:១-៣** ក៏ពុំបានជួបប្រទះក្នុង ១ពវ ជំពូក៨ ទេ ។ ក៏បន្ថែមពីភ្លើងដែលធ្លាក់ចុះពីលើមេឃមកបញ្ឆេះដង្វាយដុត គឺមានទីសំគាល់ដូចៗគ្នានៅឯរោងឧបោសថ(លវ ៩:២៣-២៤)និងស្តេចដាវីឌ បានស្អាងអាសនា១ថ្វាយដង្វាយដុតនិងដង្វាយមេត្រី ហើយអំពាវនាវដល់ព្រះយេហូវ៉ាក៏តបពីស្ថានសួគ៌មកដោយភ្លើងនៅលើអាសនាដង្វាយដុត ។ (១របា ២១:២៦ សូមប្រៀបធៀប ១ពវ ៨:៥៥-៦១)។

**៧:១** *សិរីល្អនៃព្រះយេហូវ៉ា* មើល ៥:១៤ និងការពន្យល់ ។

**៧:៣** *ទ្រង់សប្បុរស . . . អសកល្បជានិច្ច* មើល ខ.៦ ៥:១៣ ។

**៧:៦** គឺជាខដែលស៊ីនឹងគម្ពីររបាក្សត្រ និងឆ្លុះបញ្ចាំងពីផលប្រយោជន៍រួមរបស់អ្នកនិពន្ធក្នុងពួកពូជអំបូរលេវី ជាពិសេសមានជាលក្ខណៈបទភ្លេង ។ (ប្រៀបធៀប ២៩:២៦-២៧ មើលការពន្យល់ ១របា ៦:៣១-៤៨) ។ *ពួកអ៊ីស្រាអែលទាំងអស់* មើលសេចក្តីផ្តើមក្នុងរបាក្សត្រទី១ពីគោលបំណងនិងផ្ទៃរឿង ។

**៧:៨** *ចាប់តាំងពីទ្វារចូលស្រុកហាម៉ាក រហូតដល់ជ្រោះស្រុកអេស៊ីព្ទ* គឺមិនគ្រាន់តែសេចក្តីសម្រេចតាមរយៈស្តេចដាវីឌ និងស្តេចសាឡូម៉ូនប៉ុណ្ណោះទេ (មើ ១:៩ ១របា ២៧:២៣-២៤ និងការពន្យល់) ក៏មានការសន្យាតាមរយៈផ្តល់ឱ្យមានស្រុក និងទឹកដីដល់រាស្ត្រទ្រង់ផងដែរ (លប ១៥:១៨-២១) ។

**៧:៩** *នៅថ្ងៃទី៨* គឺជាថ្ងៃចុងក្រោយនៃបុណ្យបារាំង (មើល ៥:៣ និងការពន្យល់ លវ ២៣:៣៦ ជន ២៩:៣៥) ។ *៧ថ្ងៃ . . . ៧ថ្ងៃទៀត* ការឆ្លងពីថ្ងៃទី៨ដល់ថ្ងៃទី១៤ក្នុងខែនោះនិងបុណ្យបារាំងចាប់ពីថ្ងៃទី១៥រហូតដល់ថ្ងៃទី២២ ។ ថ្ងៃនៃការលោះបាបគឺជាថ្ងៃទី១០ នៃខែទី៧ (លវ ១៦ ប្រៀបធៀប ១ពវ ៨:៦៥-៦៦) ។

១០រួចដល់ថ្ងៃទី២៣ខែអស្សុជ ទ្រង់ឱ្យពួកជនវិលទៅឯទីលំ
នៅរបស់គេវិញ ដោយរីករាយសប្បាយ ហើយមានចិត្ត
ត្រេកអរ ដោយព្រោះសេចក្តីសប្បុរស ដែលព្រះយេហូវ៉ា
បានប្រោសដល់ដាវីឌ ហើយដល់សាឡូម៉ូន នឹងអ៊ីស្រាអែល
ជារាស្ត្ររបស់ទ្រង់ ។

## ព្រះអម្ចាស់បង្ហាញអង្គទ្រង់ដល់សាឡូម៉ូន

*៧:១១-២២ – ១ពវ ៩:១-៩*

១១ដូច្នេះសាឡូម៉ូនបានស្អាងព្រះវិហារនៃព្រះយេហូវ៉ា
និងដំណាក់ស្តេចរួចជាស្រេច[ត] ហើយរបស់ទាំងប៉ុន្មានដែល
សាឡូម៉ូនមានព្រះទ័យចង់ធ្វើ ក្នុងព្រះវិហារនៃព្រះយេហូវ៉ា
ហើយក្នុងដំណាក់របស់ទ្រង់នោះ ក៏ធ្វើកើតទាំងអស់ ១២រួច
មក ព្រះយេហូវ៉ាទ្រង់លេចមក[ថ]ឯសាឡូម៉ូន នៅវេលាយប់
មានបន្ទូលថា អញបានទទួលសេចក្តីអធិស្ឋានរបស់ឯង
ហើយក៏បានរើស[ទ]ទីនេះ ទុកជាទីសំរាប់អញ[ធ] ឱ្យបានជា
ទីថ្វាយយញ្ញបូជា ១៣បើកាលណាអញបិទមេឃមិនឱ្យភ្លៀង
ធ្លាក់ចុះ[ន] ឬបើអញបង្គាប់កណ្តូបឱ្យស៊ីបំផ្លាញស្រុក ឬឱ្យមាន
អាសន្នរោគកើតឡើងក្នុងពួករាស្ត្រអញ ១៤នោះបើរាស្ត្រ
អញ ដែលបានហៅតាមឈ្មោះអញ[ប] គេបន្ទាបខ្លួន[ផ] ហើយ
អធិស្ឋានរកមុខអញ[ព] ព្រមទាំងងាកបែរ[ភ]ចេញពីផ្លូវអាក្រក់
របស់គេ នោះអញនឹងស្តាប់[ម]ពីលើស្ថានសួគ៌ ហើយនឹង
អត់ទោស[យ] អំពើបាបរបស់គេទាំងមើល[រ] ស្រុកគេឱ្យជាផង
១៥ឥឡូវនេះ ភ្នែកអញនឹងនៅតែបើកហើយត្រចៀកអញនឹង
នៅតែផ្ទៀងស្តាប់សេចក្តី ដែលគេអធិស្ឋាននៅទីនេះ[ល]
១៦ដ្បិតឥឡូវនេះ អញបានរើស[វ]ព្រះវិហារនេះ ហើយញែក
ចេញជាបរិសុទ្ធ ដើម្បីឱ្យឈ្មោះអញបានតាំងនៅទីនេះជា
ដរាបទៅឯភ្នែកនឹងចិត្តអញ ក៏នឹងនៅទីនោះជានិច្ច
១៧ចំណែកឯង បើសិនជាដើរនៅមុខអញ[ស] ដូចជាដាវីឌ
ជាឪពុកឯង ព្រមទាំងធ្វើតាម គ្រប់ទាំងសេចក្តីដែលអញ
បានបង្គាប់ឯង ហើយរក្សាបញ្ញត្ត[ហ] និងក្រិត្យក្រមទាំងប៉ុន្មាន
របស់អញ ១៨នោះអញនឹងតាំងរាជ្យនៃនគរឯង ឱ្យខ្ជាប់ខ្ជួន
ឡើង ដូចជាអញបានតាំងសញ្ញា[ឡ]នឹងដាវីឌ ជាឪពុកឯងថា
នឹង មិនដែលខានមានពូជឯង[អ]គ្រប់គ្រងលើអ៊ីស្រាអែល
ឡើយ[ក] ១៩ប៉ុន្តែបើឯងរាល់គ្នាងាកបែរចេញ[ខ] ហើយបោះ
បង់ចោល[គ]បញ្ញត្ត និងក្រិត្យក្រមទាំងប៉ុន្មាន ដែលអញបាន
ដាក់សំញែងនៅមុខឯងរាល់គ្នាទៅគោរព ប្រតិបត្តិថ្វាយ
បង្គំដល់ព្រះដទៃវិញ ២០នោះអញនឹងរំលើង[ឃ]គេ ចេញពី
ស្រុកដែលអញបានឱ្យដល់គេ[ង] រួចព្រះវិហារនេះ ដែល
អញបានញែកជាបរិសុទ្ធ ទុកសំរាប់ឈ្មោះអញ នោះអញ
នឹងបោះបង់ចោលពីភ្នែកអញចេញ ឱ្យបានត្រឡប់ជាទី
ប្រៀបផ្ទឹម ហើយជាទីត្មះតិះដៀល[ច] នៅក្នុងសាសន៍ដទៃ
ទាំងអស់ ២១ហើយព្រះវិហារនេះដែលខ្ពស់ទាំងម្លេះ នោះ
អស់អ្នកណាដែលដើរតាមនេះ នឹងមានសេចក្តីប្លែកក្នុង
ចិត្ត[ឆ]ថា[ជ] ហេតុអ្វីបានជាព្រះយេហូវ៉ាប្រព្រឹត្តនឹងស្រុកនេះ
ហើយនឹងព្រះវិហារនេះ ហើយនឹងព្រះវិហារនេះយ៉ាង
ដូច្នេះ ២២គេនឹងឆ្លើយឡើងថា គឺដោយព្រោះគេបានបោះ
បង់ចោលព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេ ដែលទ្រង់
បាននាំគេចេញពីស្រុកអេស៊ីព្ទមក ហើយបានទៅចាប់
កាន់តាមព្រះដទៃ ព្រមទាំងថ្វាយបង្គំ ហើយគោរពប្រតិបត្តិ
ដល់ព្រះទាំងនោះផង[ឈ] ហេតុនោះបានជាទ្រង់បណ្តាលឱ្យ
សេចក្តីអាក្រក់ទាំងនោះកើតឡើងដល់គេ ។

**៨** ១លុះកន្លងទៅបាន២០ឆ្នាំហើយ គឺអស់ពេលដែល
សាឡូម៉ូនកំពុង តែស្អាងព្រះវិហារនៃព្រះយេហូវ៉ា ហើយ
និងដំណាក់របស់ទ្រង់[ក] ២នោះទ្រង់ក៏សង់អស់ទាំងទីក្រុង
ឡើងជាទីក្រុងដែលហ៊ីរ៉ាមបានប្រគល់មកវិញ ហើយឱ្យពួក
កូនចៅអ៊ីស្រាអែល អាស្រ័យនៅក្នុងទីក្រុងទាំងនោះ ។

លប ១៥:១៨ **៧:៩** ឈ ២រប ៣០:២៣ ណ លវ ២៣:៣៦ **៧:១១** ត ១រប ២៨:២០ **៧:១២** ថ ២រប ១:៧ ទ ចទ ១២:១១ ធ ទ ១២:៥ **៧:១៣** ន ចទ ១១:១៧ អម ៤:៧ **៧:១៤** ប ជន ៦:២៧ ផ នក ១០:៣ លវ ២៦:៤១ ២រប ៦:៣៧ ព ១រប ១៦:១១ ភ ២ពវ ១៧:១៣ ងស ៥៥:៧ អគ ១៨:៣២ សក ១:៤ ម ២រប ៦:២០ យ ២រប ៦:២៧ រ នក ១៥:២៦ ២ប ៣០:២០ ទដ ៦០:២ អស ៣០:២៦ ៥៣:៥ ៥៧:១៨ យរ ៣៣:៦ មឡ ៤:២ **៧:១៥** ល ១ពវ ៨:២៩ ២រប ៦:៤០ នហ ១:៦ **៧:១៦** វ ចទ ១២:៥ ២រប ៣៣:៧ **៧:១៧** ស ១ពវ ៩:៤ ហ លវ ១៩:៣៧ **៧:១៨** ឡ អស ៩:៧ យរ ៣៣:១៧,២១ អ ១រប ៥:២ អស ៥៥:៤ មីក ៥:២ ក ២សយ ៧:១២ ២រប ១៣:៥ ២៣:៣ **៧:១៩** ខ ចទ ២៨:១៥ គ ១រប ២៨:៩ ២រប ១២:១ ២៤:១៨ យរ ៩:១៣ ១១:៨ **៧:២០** ឃ ចទ ២៩:២៨ ង ១ពវ ១៤:១៥ យរ ១២:១៤ ១៦:១៣ ៥០:១១ ច ចទ ២៨:៣៧ **៧:២១** ឆ យរ ១៩:៨ ជ ចទ ២៩:២៤ **៧:២២** ឈ យរ ១៦:១១ **៨:១** ក ២សយ ៧:២

**៧:១២** *លេចមកឯសាឡូម៉ូន* គឺជាលើកទី២ហើយដែលព្រះអម្ចាស់លេចមកឱ្យស្តេចសាឡូម៉ូនឃើញ ហើយឯលើកទី១នោះទ្រង់លេចមកឱ្យឃើញនៅឯក្រុងកេបា (១:៣–១៣ ១ពវ ៩:២) ។

**៧:១៣–១៥** ខទាំងនេះបង្ហាញបញ្ជាក់នូវគោលគំនិត ដែលសង្កត់ធ្ងន់ពីអ្នកនិពន្ធ (មើលសេចក្តីផ្តើម១របាក្សត្រពីគោលបំណងនិងផ្ទៃរឿង) ។ អ្នកកាលប្រវត្តិក៏បានពណ៌នាពីពង្សាវតារក្សត្រ ក្នុងរបៀបបង្ហាញច្បាស់នូវគោលការសំខាន់ៗ (មើល ខ.២២) ។

**៧:១៤** មើល ១២:៦–៧,១២ ។

**៧:១៧–១៨** មើល ១ពវ ៩:៤–៥ ។ ពាក្យនៅក្នុងវគ្គនេះ បានផ្តល់នូវសេចក្តីសង្ឃឹមបន្ថែមដល់ពួកអ៊ីស្រាអែលនៅក្នុងការរង់ចាំព្រះមែស៊ី តាមព្រះបន្ទូលសន្យា។

**៧:១៩–២២** សូមមើល ១ពវ ៩:៦–៩ ។

**៨:១–២** ក្នុង ១ពវ ៩:១០–១៤ ទីក្រុងមួយចំនួនបានប្រគល់ឱ្យទៅសាសន៍ហ៊ីរ៉ាម ដោយសារស្តេចសាឡូម៉ូន ហើយកាលប្រវត្តិនៃពង្សាវតារក្សត្រពេលនោះដូចជាផ្ទុយពីការពិត ។ ព្រោះអ្នកកាលប្រវត្តិពុំបានកត់ត្រានៅភាពពិតមួយចំនួន ដែលសាសន៍ ហ៊ីរ៉ាមបានរកឃើញទីក្រុងទាំងនោះ (១ពវ ៩:១១–១៣) អ្នកកាលប្រវត្តិបង្ហាញតែពេលដែលសាសន៍ហ៊ីរ៉ាមបានប្រគល់ទីក្រុងនោះមកឱ្យស្តេចសាឡូម៉ូនវិញ ។

៣ សាឡូម៉ូនទ្រង់ចេញទៅច្បាំង ហើយយកបានក្រុង
ហាម៉ាត-សូបា ៤ ក៏សង់ក្រុងថាត់ម៉ោរ នៅទីរហោស្ថាននិង
អស់ទាំងទីក្រុងសិរាប់ជាឃ្លាំងដែលទ្រង់បានធ្វើនៅស្រុក
ហាម៉ាតនោះដែរ[ខ] ៥ ទ្រង់ក៏សង់ក្រុងបេត-ហូរ៉ុន[គ]ខាងលើ
និងខាងក្រោមជាទីក្រុងមានបន្ទាយ ហើយមាន កំផែងមាន
ទ្វារ និងរនុកផង ៦ ព្រមទាំងក្រុងប្អាឡាត[ឃ] និងអស់ទាំងទី
ក្រុងសិរាប់ជាឃ្លាំងរបស់សាឡូម៉ូន ហើយទីក្រុងសិរាប់
រទេះចំបាំង និងទីក្រុងសិរាប់ពលសេះទ្រង់ ព្រមទាំងអ្វីៗ
ដែលស្ដេចប្រាថ្នាចង់ធ្វើ សំរាប់ជាទីគាប់ព្រះទ័យ នៅក្រុង
យេរូសាឡិម នៅភ្នំល្បាណូន ហើយនៅគ្រប់ក្នុងស្រុកដែល
នៅក្រោមអំណាចទ្រង់ផង ។

៧ ឯពួកជនទាំងប៉ុន្មាន ដែលសល់ពីពួកសាសន៍ហេត
សាសន៍អាម៉ូរី សាសន៍ពេរិស៊ីត សាសន៍ហេវី និងសាសន៍
យេប៊ូស[ង] ដែលមិនមែនជា ពូជអ៊ីស្រាអែល ៨ ព្រមទាំងពួក
កូនចៅគេ ដែលសល់នៅក្នុងស្រុក គឺដែលពួកកូនចៅ
អ៊ីស្រាអែលមិនបានបំផ្លាញបង់ នោះសាឡូម៉ូនទ្រង់បាន
កេណ្ឌទុក[ច]ជាបាវបំរើ ដរាបដល់សព្វថ្ងៃនេះ ៩ តែទ្រង់មិន
បានយកអ្នកណាក្នុងពួកកូនចៅអ៊ីស្រាអែល ឱ្យធ្វើជាអ្នក
បំរើសំរាប់ការទ្រង់ទេ គេសុទ្ធតែជាមនុស្សចំបាំង និងជា
មេលើពួកមេទ័ព ជានាយត្រួតលើរទេះចំបាំងនិងពួកពល
សេះរបស់ទ្រង់វិញ ១០ ឯពួកមេទ័ពធំរបស់ស្ដេចសាឡូម៉ូន
ទាំងអស់មាន២៥០នាក់ ដែលត្រួតត្រាលើពួកទ័ព ។

១១ រួចមក សាឡូម៉ូនទ្រង់នាំព្រះរាជបុត្រីផារ៉ោន[ឆ]ចេញ
ពីក្រុងដាវីឌ ឡើងមកឯដំណាក់ដែលទ្រង់បានសង់សំរាប់
ព្រះនាង ដ្បិតទ្រង់នឹកថា ប្រពន្ធរបស់អញមិនត្រូវនៅក្នុង
ដំណាក់នៃដាវីឌ ជាស្ដេចសាសន៍អ៊ីស្រាអែលទេ ពីព្រោះ
ទីកន្លែងដែលហឹបនៃព្រះយេហូវ៉ា បានចូលមក ទាំងនោះ
សុទ្ធតែបរិសុទ្ធទាំងអស់ ។

១២ គ្រានោះ សាឡូម៉ូនទ្រង់ថ្វាយដង្វាយដុត ដល់ព្រះ
យេហូវ៉ា នៅលើអាសនា[ជ] ដែលទ្រង់បានស្អាង នៅមុខបាំង
សាច ១៣ តាមកំណត់ដែលត្រូវការ[ឈ] រាល់តែថ្ងៃ គឺថ្វាយឱ្យ
ត្រូវនិងក្រិត្យក្រមរបស់លោកម៉ូសេទាំងថ្ងៃឈប់សំរាក[ញ] ថ្ងៃ
ចូលខែ[ដ] និងថ្ងៃបុណ្យមានកំណត់៣[ឋ]ដងក្នុង១ឆ្នាំ ជាបុណ្យ
នំបុ័ង[ឌ]ឥតដំបែ បុណ្យអាទិត្យទី៧[ឍ] និងនៅបុណ្យបារាំ[ណ]
១៤ ទ្រង់ក៏ដំរូវវេន[ត]ពួកសង្ឃ ឱ្យគេបានធ្វើការងារតាមច្បាប់
ដែលដាវីឌ ជាព្រះបិតាទ្រង់ បានកំណត់ទុក ទ្រង់ឱ្យពួក
លេវី[ថ] មានដំណែងរបស់គេ សំរាប់នឹងពោលសរសើរ
ហើយនឹងធ្វើជាជំនួយដល់ពួកសង្ឃ តាមត្រូវការរាល់តែ
ថ្ងៃឯពួកឆ្មាំទ្វារ[ទ]ក៏ដែរ តាមវេនគេនៅរាល់តែទ្វារ ដ្បិត
ដាវីឌជាអ្នកសំណប់របស់ព្រះ[ធ]បានបង្គាប់យ៉ាងដូច្នោះ[ន]
១៥ ហើយគេមិនបានធ្វើខុសពីច្បាប់របស់ស្ដេច ដែលទ្រង់
បានបង្គាប់ដល់ពួកសង្ឃ និងពួកលេវី ចំពោះការអ្វី ឬខាង
ឯទ្រព្យវិសេសណាឡើយ ។

១៦ រីឯការទាំងអស់ដែលសាឡូម៉ូនបានធ្វើ នោះសុទ្ធតែ
បានធ្វើទុកជាស្រេច តាំងពីថ្ងៃដែលគេដាំឫសជញ្ជាំងនៃ
ព្រះវិហារព្រះយេហូវ៉ា រហូតដល់បានហើយ ដូច្នេះ ព្រះ
វិហារនៃព្រះយេហូវ៉ាបានស្អាង ឡើងជាស្រេច ។

១៧ រួចមកសាឡូម៉ូនទ្រង់យាងទៅឯក្រុងអេស៊ាន-គេបើរ
នឹងក្រុងអេឡុត នៅមាត់សមុទ្រ ក្នុងស្រុកអេដំម ១៨ ចំណែក
ឯហ៊ីរ៉ាមទ្រង់ ផ្ញើសំពៅមក ដោយសារពួកទ្រង់ព្រមទាំង
ពួកអ្នកដែលស្គាល់ភាពសមុទ្រដល់សាឡូម៉ូនអ្នកទាំងនោះក៏
ទៅជាមួយនឹងពួករបស់សាឡូម៉ូនដល់ស្រុកអូភារ ហើយគេ

**៨:៤** ខ ២សយ ៨:៩
**៨:៥** គ យស ១០:១០
**៨:៦** ឃ យស ១៩:៤៤
**៨:៧** ង លប ១០:១៦ ១៥:១៨-២១ អរ ៩:១
**៨:៨** ច ២រប ២:១៨
**៨:១១** ឆ ១ពវ ៣:១
**៨:១២** ជ ១ពវ ៨:៦៤ ២រប ១៥:៨
**៨:១៣** ឈ នក ២៩:៣៨ ញ ជន ២៨:៩ ដ ជណ ១០:១០ ឋ នក ២៣:១៤ ឌ នក ១២:១៧ ជន ២៨:១៦-២៥ ឍ នក ២៣:១៦ ណ ជន ២៩:១២-៣៨ នហ ៨:១៧
**៨:១៤** ត ១រប ២៤:១ ថ ១រប ២៥:១ ទ ១រប ៩:១៧ ធ នហ ១២:២៤,៣៦ ន ១រប ២៣:៦ នហ ១២:៤៥
**៨:១៨** ប ២រប ៩:៩

**៨:៣-៤** អ្នកកាលប្រវត្តិបានកត់ត្រានូវយុទ្ធនាការផ្នែកបន្ថែមទៀតគឺឆ្ពោះទៅទិសខាងជើងតែពុំបានប្រាប់ឬកត់ត្រាក្នុងគម្ពីរ ពង្សាវតារក្សត្រទេ ។ ស្ដេចដាវីឌក៏បានធ្វើយុទ្ធនាការ ក្នុងភូមិភាគខាងជើងប្រឆាំងនិងសាសន៍ក្រុងហាម៉ាតសូបា (១៨:៣-៩ ១៩:៦ ២សយ ៨:៣-១២,៦-៨ ប្រៀបធៀប ១ពវ ១១:២៣-២៤) ។

**៨:៥** ក្រុងទាំងពីគឺក្រុង បេត-ហូរ៉ុន គឺជាទីក្រុងដែលមានផ្លូវជាក់លាក់ដល់ការធ្វើយុទ្ធនាការ នៅឯផ្នែកខាងជើងក្រុងយេរូសាឡិម ។

**៨:៧** *មិនមែនជាពួកអ៊ីស្រាអែល* មើល ២:១៧ ១រប ២២:២ ១ពវ ៩:២១ ។

**៨:៨** *ដរាបដល់សព្វថ្ងៃនេះ* មើលការពន្យល់ ៥:៩ ។

**៨:១១** *សុទ្ធតែបរិសុទ្ធ* គឺទាំងក្នុងការកត់ត្រា នៃពង្សាវតារក្សត្រនិងរបាក្សត្រដែលចេញពីបុត្រីនៃស្ដេចផារ៉ោនចំពោះផ្នែកសំខាន់ៗ មិនគ្រាន់តែនិយាយពីព្រះវិហារប៉ុណ្ណោះទេក៏និយាយពីរាជវាំង នៃស្ដេចដាវីឌដែរគឺត្រូវរាប់ជាបរិសុទ្ធទាំងអស់ដោយព្រោះវត្តមានរបស់ហឹបសញ្ញា (មើលការពន្យល់ លវ ១១:៤៤) ។

**៨:១២-១៦** ក្នុងភាពជាផលប្រយោជន៍រួមទាំងអស់ គឺអ្នកកាលប្រវត្តិបានបង្ហាញយ៉ាងច្បាស់អំពីការធ្វើយញ្ញបូជា និងការរៀបចំនៅក្នុងព្រះវិហារដែលធ្វើដោយស្ដេចសាឡូម៉ូន ។ គឺក្នុង ១ពវ ៩:២៥ បានបង្ហាញតែការធ្វើយញ្ញបូជាប្រចាំឆ្នាំតែបីប្រទេសប៉ុណ្ណោះ ដែលអ្នកកាលប្រវត្តិបានបន្ថែមពីការថ្វាយដង្វាយនៅថ្ងៃបុណ្យឬថ្ងៃឈប់សម្រាក និងសម្រាប់រាលខែដើម្បីទៅតាមសេចក្ដីនៃព្រះម៉ែស៊ី ។

**៨:១៧-១៨** មើល ១ពវ ៩:២៦-២៨ ការងារទំនាក់ទំនងនិងប្រចុយប្រថានរវៀងស្ដេចសាឡូម៉ូននិងស្ដេចហ៊ីរ៉ាម ដែលធានាបាននូវផលប្រយោជន៍នៃច្រកផ្លូវពាណិជ្ជកម្មតាមរយៈតំបន់មេឌីទែរ៉ានេរហូតដល់ ឧបទ្វិបអារ៉ាប៊ីខាងត្បូងស្ដេចសាឡូម៉ូនប្រែក្លាយជាអ្នកដៃគូរជំនួញនៅជាកណ្ដាលគេរវៀងទីបណ្ដាំសេដ្ឋកិច្ចត្រង់នោះ ។

**៨:១៧** *ក្រុងអេស៊ានគេបើរនឹងក្រុងអេឡុត* មើលការពន្យល់ ចទ ២:៨ ។

**៨:១៨** *ហ៊ីរ៉ាមទ្រង់ផ្ញើសំពៅមកដោយសាពួកទ្រង់* (មើល ៩:២១) ។

យកបានមាស៤៥០ហាប[ប] ពីស្រុកនោះ មកថ្វាយដល់ស្ដេច
សាឡូម៉ូន ។

### មហាក្សត្រីស្រុកសេបាយាងមកជួបស្ដេចសាឡូម៉ូន

*៩:១–១២ – ១ពវ ១០:១–១៣*

**៩** ១កាលមហាក្សត្រីនៃស្រុកសេបា[ក]បានឮកិត្តិនាមរបស់សា
ឡូម៉ូន នោះព្រះនាងក៏យាងមកដល់ក្រុងយេរូសាឡិម ដើម្បី
ល្បងសាឡូម៉ូន ដោយប្រស្នា មានមនុស្សដង្ហែមកយ៉ាងសន្ធឹក
ក៏មានសត្វអូដ្ឋជាច្រើន ផ្ទុកដោយគ្រឿងក្រអូប និងមាសជា
បរិបូរ ហើយត្បូងមានដំឡៃផង លុះកាលព្រះនាងចូលមក
គាល់សាឡូម៉ូនហើយ នោះក៏មានសវនីយ៍សន្ទនា និងទ្រង់ ពី
គ្រប់ទាំងសេចក្ដីដែលមាននៅក្នុងព្រះទ័យ ២ឯសាឡូម៉ូន
ទ្រង់ក៏ឆ្លើយស្រាយន័យគ្រប់អស់ទាំងសេចក្ដីដែលព្រះនាង
សួរ ឥតមាន អ្វីលាក់កំបាំង ដែលទ្រង់មិនបានស្រាយន័យ
ថ្វាយព្រះនាងនោះនេះ ៣កាលមហាក្សត្រីស្រុកសេបា បាន
ឃើញប្រាជ្ញា របស់សាឡូម៉ូន[ខ] និងដំណាក់ដែលទ្រង់បានធ្វើ
៤ព្រមទាំងព្រះសោយនៅលើតុទ្រង់ ទីលំនៅរបស់ពួកបំរើ
ទ្រង់ សណ្ឋានពួកបរិវាររបស់ទ្រង់ និងគ្រឿងតែងកាយ
របស់គេ ហើយពួកបំរើថ្វាយពែងរបស់ទ្រង់ និងសំលៀក
បំពាក់របស់គេ ហើយនិងដង្វាយដុត ដែលទ្រង់ថ្វាយក្នុង
ព្រះវិហារនៃព្រះយេហូវ៉ានោះព្រះនាងក៏ភាំងស្មារតី
៥រួចមានសវនីយ៍ ទៅស្ដេចថា ពាក្យដែលខ្ញុំម្ចាស់បានឮ
និយាយ នៅស្រុកខ្ញុំម្ចាស់ ពីព្រះរាជកិច្ច និងប្រាជ្ញារបស់
ទ្រង់ នោះក៏ពិតប្រាកដមែន ៦ប៉ុន្តែខ្ញុំម្ចាស់ មិនបានជឿទេ
លុះត្រាតែបានមក[គ]ឃើញ និងភ្នែកខ្លួនឯង ហើយមើល
ដំណឹងដែលខ្ញុំ ម្ចាស់បានឮ ពីប្រាជ្ញាដ៏ជាធំរបស់ទ្រង់នោះ
គេថ្លែងប្រាប់មិនដល់ត្រឹមទាំងពាក់កណ្ដាលផង ទ្រង់លើស
ហួសពីកិត្តិនាម ដែលខ្ញុំម្ចាស់បានឮទៅទៀត ៧មានពរ
ហើយ ពួកទ្រង់នឹងពួកអ្នកបំរើនេះ ដែលឈរនៅចំពោះ
ទ្រង់ជានិច្ចទាំងស្ដាប់ប្រាជ្ញារបស់ទ្រង់ ៨សូមឱ្យព្រះយេហូវ៉ា
ជាព្រះនៃទ្រង់បានព្រះពរដែលទ្រង់បានសព្វព្រះហឫទ័យ
នឹងព្រះករុណា ដើម្បីនឹងលើកព្រះករុណាឡើង ឱ្យគង់លើ

**៩:១** ក លប ១០:៧ អគ ២៣:៤២ មថ ១២:៤២ លក ១១:៣១
**៩:៣** ខ ១ពវ ៥:១២
**៩:៦** គ ២រប ៦:៣២
**៩:៨** ឃ ១ពវ ២:១២ ១រប ១៧:១៤ ២រប ១៣:៨ ង ២រប ២:១១
**៩:៩** ច ២រប ៨:១៨
**៩:១០** ឆ ២រប ៨:១៨
**៩:១៤** ជ ២រប ១៧:១១ អស ២១:១៣ យរ ២៥:២៤ អគ ២៧:២១ ៣០:៥

បល្ល័ង្ករាជ្យ[ឃ] ធ្វើជាស្ដេចថ្វាយព្រះយេហូវ៉ា ជាព្រះនៃទ្រង់
គឺដោយព្រោះព្រះនៃទ្រង់បានស្រឡាញ់សាសន៍អ៊ីស្រាអែល
ដោយប្រាថ្នានឹងតាំងគេឱ្យខ្ជាប់ខ្ជួនអស់កល្បជានិច្ច បានជា
តាំងទ្រង់ឡើងជាស្ដេច[ង]លើគេ ដើម្បីនឹងសំរេចសេចក្ដី
យុត្តិធម៌ និងសេចក្ដីសុចរិត ៩រួចព្រះនាងក៏ ថ្វាយមាស១២០
ហាប[ច] ហើយគ្រឿងក្រអូបយ៉ាងសន្ធឹក ព្រមទាំងត្បូង មាន
ដំឡៃដល់ស្ដេច មិនដែលមានគ្រឿងក្រអូបណា ដូចអស់
ទាំងគ្រឿងក្រអូប ដែលមហាក្សត្រីស្រុកសេបា បានថ្វាយ
ដល់ស្ដេចសាឡូម៉ូននោះឡើយ ។
១០រីឯពួកសំពៅរបស់ហ៊ីរ៉ាម និងពួករបស់សាឡូម៉ូន
ដែលនាំយកមាសពីស្រុកអូភារមក[ឆ] គេក៏យកឈើច័ន្ទន៍ និង
ត្បូងមានដំឡៃមកផងដែរ ១១ស្ដេចទ្រង់យកឈើច័ន្ទន៍នោះ
ធ្វើជាភ្នាក់ដៃសំរាប់ព្រះវិហារនៃព្រះយេហូវ៉ា ហើយ
សំរាប់ដំណាក់ស្ដេច ព្រមទាំងស៊ុង និងពិណ សំរាប់ពួក
ចំរៀងផង ពីដើមមិនដែលឃើញមានយ៉ាងដូច្នោះ នៅក្នុង
ស្រុកយូដាឡើយ ១២ស្ដេចសាឡូម៉ូនទ្រង់ក៏ប្រទានដល់
មហាក្សត្រីស្រុកសេបា តាមបំណងព្រះទ័យព្រះនាងគឺរបស់
អ្វីៗដែលព្រះនាងសូម លើសអំពីរបស់ទាំងប៉ុន្មានដែល
ព្រះនាងបានថ្វាយដល់ស្ដេច ដូច្នេះ ព្រះនាងព្រមទាំងពួក
បរិវារ ក៏វិលត្រឡប់ទៅឯស្រុករបស់ខ្លួនវិញទៅ ។

### ភាពសម្បូររុងរឿងរបស់ស្ដេចសាឡូម៉ូន

*៩:១៣–២៨ – ១ពវ ១០:១៤–២៩ ២រប ១:១៤–១៧*

១៣រីឯមាស ដែលមកដល់សាឡូម៉ូនក្នុង១ឆ្នាំ នោះមាន
ទំងន់៦៦៦ហាប ១៤ក្រៅពីនោះ មានមាសដែលមកដោយ
សារពួកលក់ដូរថែមទៀត ហើយអស់ទាំងស្ដេចស្រុក
អារ៉ាប់[ជ] និងពួកចៅហ្វាយស្រុក ក៏យកមាសនិងប្រាក់មក
ថ្វាយសាឡូម៉ូនដែរ ១៥ស្ដេចសាឡូម៉ូនទ្រង់ដែមាសធ្វើខែល
យ៉ាងធំ២០០ បានយកមាស៦០០ដំឡឹង ដើម្បីនឹងធ្វើខែល
មួយៗ ១៦ហើយក៏ដែមាសធ្វើខែលតូច៣០០[ឈ]ក្នុងខែល
មួយៗ មានមាស៣០០ដំឡឹង រួចដំកល់ទុកក្នុងដំណាក់

**៩:១៦** ឈ ២រប ១២:៩ ញ ១ពវ ៧:២

**៩:១–១២** មើល ១ពវ ១០:១–១៣ និងការពន្យល់ ។ គឺជាការទស្សនៈកិច្ច របស់ព្រះមហាក្សត្រីនៃស្រុកសេបា ដែលពណ៌នាពីសេចក្ដីសម្រេចនៃព្រះបន្ទូលសន្យា ដែលបានផ្ដល់ឱ្យស្ដេចសាឡូម៉ូនមានប្រាជ្ញាគ្រប់គ្រាន់ និងទ្រព្យសម្បត្តិ (១:១២) ។ ហើយការងារទស្សនៈកិច្ចរបស់ព្រះមហាក្សត្រីអាចជាហេតុផលផ្នែកហិរញ្ញវត្ថុខ្លះៗ ក៏បង្កើតជាយុទ្ធនាការផ្នែកខាងសមុទ្រឆ្ពោះទៅរកស្រុកវាលផ្នែកខាងត្បូង (៨:១៧–១៨) ។

**៩:១** *ស្រុកសេបា* មើលការពន្យល់ ១ពវ ១០:១ មើល យប ១:១៥ ៦:១៩ ទដ ៧២:១០,១៥ អស ៦០:៦ យរ ៦:២០ អគ ២៧:២២ ៣៨:១៣ យអ ៣:៨ ។

**៩:៨** *បល្ល័ង្ករាជ្យ* គឺបញ្ជាក់ពីការនៃទស្សនៈកិច្ច របស់ព្រះមហាក្សត្រី មើលក្នុង ១ពវ (១០:៩) យើងក៏ឃើញនៅអត្ថបទនេះដែរ ។ ការថ្លែងសន្ទរៈកថាក៏ប្រែក្លាយជាភាពមួយ ដែលសម្រួលដល់ការទំនាក់ទំនងនៃពង្សាវតារក្សត្រ ដែលរាជ្យបល័ង្កនៃរាស្ត្រអ៊ីស្រាអែលគឺជារាជ្យបល័ង្កនៃព្រះ (មើល ១៣:១៨ សូមមើលការពន្យល់ ១រប ១៧:១៤) ។

**៩:១៦,២០** *នៅដំណាក់ល្បាណូន* ជារាជវាំងស្ដេចក្នុងយេរូសាឡិម (ប្រៀបធៀប ១ពវ ៧:២) ។

ល្បាណូន[ញ] ១៧មួយទៀតស្តេចទ្រង់ធ្វើបល្ល័ង្កភ្លុក[ដ]១យ៉ាងធំ
ស្រោបដោយមាសសុទ្ធ ១៨មានជណ្តើរ៦ថ្នាក់ឡើងទៅ
បល្ល័ង្ក និងកំណល់កល់ជើងធ្វើពីមាស ដែល ជាប់នឹងបល្ល័ង្ក
ក៏មានកំណល់ដៃទាំងសងខាងទីអង្គុយ ហើយមានរូបសិង្ហ
២ឈរនៅក្បែរកំណល់ដៃនោះ ១៩នឹងរូបសិង្ហ១២ ឈរនៅ
ទាំងសងខាងនៃថ្នាក់ជណ្តើរទាំង៦នោះដែរ មិនដែលបាន
ធ្វើបល្ល័ង្ក នៅក្នុងនគរណាឱ្យដូចឡើយ ២០អស់ទាំងប្រដាប់
ដែលសំរាប់ឱ្យស្តេចសាឡូម៉ូនសោយគ្រឿងទឹក នោះសុទ្ធ
តែធ្វើពីមាសទាំងអស់ ហើយអស់ទាំងប្រដាប់ប្រដា នៅ
ដំណាក់ល្បាណូន ក៏ធ្វើពីមាសសុទ្ធដែរ នៅក្នុងរាជ្យនៃ
ស្តេចសាឡូម៉ូន នោះប្រាក់មិនសូវមានដំឡៃប៉ុន្មានទេ
២១ដ្បិតស្តេចមានក្រុមនាវា ដែលទៅឯតើស៊ីស ជាមួយនឹង
ពួកសំពៅរបស់ហ៊ីរ៉ាម ដឹកនាំមាស ប្រាក់ ភ្លុក ទោច និង
កោក មករាល់តែ៣ឆ្នាំត្រឡប់មកវិញម្តង ។
២២ដូច្នេះ ស្តេចសាឡូម៉ូនទ្រង់មានព្រះរាជ្យទ្រព្យ និង
ប្រាជ្ញាលើសជាងអស់ទាំងស្តេចនៅផែនដី[ឋ] ២៣ហើយអស់
ទាំងស្តេច[ឌ]នៅផែនដី ក៏រកចូលទៅគាល់សាឡូម៉ូន ដើម្បី
នឹងស្តាប់ប្រាជ្ញា ដែលព្រះបានប្រទាន មកក្នុងព្រះទ័យទ្រង់
២៤គ្រប់គ្នាក៏យកស្ពួយអាករមកថ្វាយ[ឍ] គឺជាគ្រឿងប្រាក់
គ្រឿងមាស សំលៀកបំពាក់ គ្រឿងសស្ត្រាវុធ គ្រឿងក្រអូប
សេះ និងលាកាត់ តាមកំណត់រាល់តែឆ្នាំ ។
២៥សាឡូម៉ូនទ្រង់មានរោងសំរាប់សេះ ហើយរទេះ
ចំបាំង[ណ]៤ពាន់ បន្ទប់ក៏មានពលសេះ១ម៉ឺន២ពាន់នាក់ទ្រង់
ញែកដាក់ឱ្យនៅក្នុងទីក្រុង ដែលសំរាប់រទេះចំបាំងទាំង
ប៉ុន្មាន ហើយនៅជាមួយនឹងទ្រង់ក្នុងក្រុងយេរូសាឡិមដែរ

**៩:១៧** ដ ១ពង្សាវតារក្សត្រ ២២:៣៩
**៩:២២** ឋ ១ពង្សាវតារក្សត្រ ៣:១២ ២របាក្សត្រ ១:១២
**៩:២៣** ឌ ១ពង្សាវតារក្សត្រ ៤:៣៤
**៩:២៤** ឍ ២របាក្សត្រ ៣២:២៣ ទំនុកដំកើង ៤៥:១២ ៦៨:២៩ ៧២:១០ អេសាយ ១៨:៧
**៩:២៥** ណ ១សាំយូអែល ៨:១១
**៩:២៦** ត ១ពង្សាវតារក្សត្រ ៤:២១ ថ ទំនុកដំកើង ៧២:៨–៩ ទ លោកុប្បត្តិ ១៥:១៨–២១
**៩:២៩** ធ ២សាំយូអែល ៧:២ ន ១ពង្សាវតារក្សត្រ ១១:២០ ប ២របាក្សត្រ ១០:២
**៩:៣១** ផ ១ពង្សាវតារក្សត្រ ២:១០
**១០:២** ក ២របាក្សត្រ ៩:២៩ ខ ១ពង្សាវតារក្សត្រ ១១:៤០

២៦ទ្រង់ក៏មានអំណាច[ត]លើអស់ទាំងស្តេច ចាប់តាំងពីទន្លេ[ថ]
រហូតដល់ស្រុកភីលីស្ទីន ហើយដល់ព្រំស្រុកអេស៊ីព្ទផង[ទ]
២៧ស្តេចទ្រង់ធ្វើឱ្យមានប្រាក់សំបូរ នៅក្រុងយេរូសាឡិមដូច
ជាថ្ម ហើយឱ្យមានដើមតាត្រៅជាបរិបូរ ដូចជាដើមឧទុម្ពរ
ដែលដុះនៅស្រុកទំនាប ២៨គេក៏នាំយកសេះពីស្រុកអេស៊ីព្ទ
ហើយពីស្រុកទាំងអស់មកថ្វាយទ្រង់ដែរ ។

## ការសុគតរបស់ស្តេចសាឡូម៉ូន

*៩:២៩–៣១ – ១ពង្សាវតារក្សត្រ ១១:៤១–៤៣*

២៩រីឯដំណើរឯទៀតពីសាឡូម៉ូនទាំងមុនទាំងក្រោយ
នោះសុទ្ធតែបានកត់ទុកនៅក្នុងពង្សាវតារ ដែលហោរា
ណាថាន់[ធ]បានតែង និងក្នុងសេចក្តីទំនាយនៃអ័ហ៊ីយ៉ា[ន] ជា
អ្នកស្រុកស៊ីឡូរ ហើយក្នុងរឿងពីការ ជាក់ស្តែងរបស់អ៊ីដោ
ជាអ្នកមើលឆុត ដែលលោកឃើញពីដំណើរ យេរ៉ូបោម[ប]
ជាកូននេបាតហើយ ៣០សាឡូម៉ូនទ្រង់សោយរាជ្យលើពួក
អ៊ីស្រាអែលទាំងអស់ នៅក្រុងយេរូសាឡិមបាន៤០ឆ្នាំ
៣១រួចសាឡិម ទ្រង់ផ្ទំលក់ទៅជាមួយនឹងពួកឰយុកោទ្រង់
ទៅ ហើយគេបញ្ចុះសពទ្រង់ នៅក្នុងក្រុងរបស់ដាវីឌ[ផ] ជា
ព្រះបិដាទ្រង់ នោះរេហូបោម ជាព្រះរាជបុត្រា ក៏ឡើង
សោយរាជ្យជំនួសព្រះបិតា ។

## ពួកអ៊ីស្រាអែលបះបោរប្រឆាំងនឹងរេហូបោម

*១០:១–១១:៤ – ១ពង្សាវតារក្សត្រ ១២:១–២៤*

**១០** ១ឯរេហូបោម ទ្រង់យាងទៅដល់ក្រុងស៊ីគែម ដ្បិតពួក
អ៊ីស្រាអែលទាំងអស់គ្នា បានមូលមកឯក្រុងស៊ីគែមដើម្បី
នឹងតាំងទ្រង់ឡើង ជាស្តេច ២រីឯយេរ៉ូបោម[ក] ជាកូននេបាត
ដែលនៅស្រុកអេស៊ីព្ទ ជាកន្លែងដែលបានរត់ទៅ[ខ]ឱ្យរួច

**៩:២៦** សូមមើល ៧:៨ និងការពន្យល់ ។

**៩:២៧** សូមមើល ១:១៥ ។

**៩:២៨** អ្នកកាលប្រវត្តិបានលប់ចោលពីកិច្ចការ នៃព្រះមហាក្សត្ររបស់ស្តេចសាឡូម៉ូននិងការបះបោរប្រឆាំង ពោលកាលចុងបញ្ចប់នៃអំណាចរាជ្យបល័ង្ករបស់ទ្រង់ (១ពង្សាវតារក្សត្រ ១១:១–៤០) ករណីទាំងពីរខាងលើធ្វើឱ្យភាពរុងរឿងរបស់ស្តេចសាឡូម៉ូនបានធ្លាក់ចុះយ៉ាងខ្លាំង ។ *នាំយកសេះពីស្រុកអេស៊ីព្ទ* មើលការពន្យល់ ១:១៦ ។

**៩:២៩–៣១** មើលការពន្យល់ ១ពង្សាវតារក្សត្រ ១១:៤១–៤៣ ។

**១០:១–៣៦:២៣** ឯកសាបានផ្តោតទៅលើរឿងរ៉ាវ ប្រវត្តិរាជធិបតេយ្យដែលព្រះបានរៀបចំនៅក្នុងកណ្ឌគម្ពីររបាក្សត្រ បានវែកញែកខ្លីជាគម្ពីរពង្សាវតារក្សត្រគឺមាន២៧ ជំពូកប្រៀបធៀបនិង៣៦ជំពូក(១ពង្សាវតារក្សត្រ ១២–២ពង្សាវតារក្សត្រ ២៥) ។ ម្យ៉ាងវិញទៀតពាក់កណ្តាលនៃឯសារនេះ គឺស៊ីគ្នាទៅនិងគម្ពីររបាក្សត្រ ហើយក៏បង្ហាញពីភាពមិនពឹងផ្អែកទៅលើព្រះមហាក្សត្រ ។ ក៏មានភាពជាក់លាក់ជាហេតុផលចំពោះករណីនេះបង្ហាញថា អ្នកកាលប្រវត្តិបានសរសេពីប្រវត្តិជាច្រើននៃខ្សែរាជ្យវង្សរបស់ស្តេចដាវីឌ ក្នុងស្រុកយូដា ។ ប្រវត្តិសាស្ត្រអាណាចក្រខាងជើង បានកន្លងផុតក្នុងភាពស្ងាត់ស្ងៀមមួយ គឺពេលវេលាពុំបានកត់ត្រា គឺលើកលែងនូវអ្វីដែលជាឥទ្ធពលអាក្រក់ទៅលើសាសន៍យូដានោះ យ៉ាងហោចណាស់ មានទស្សនៈពិចារណាពីបែបគឺព្រមគ្នានៃសកម្មភាពនគរបានបែងចែកគ្នា: ១ អ្នកកាលប្រវត្តិ គឺបានចាបអារម្មណ៍ទៅលើប្ញកត់ត្រាតែពីភាពសុចរិតរបស់ទ្រង់ ដល់ស្តេចដាវីឌដោយឥតបែកបែរឡើយ ឬខូចខាតដល់ពូជអំបូរដែលសោយរាជ្យក្នុងរាស្ត្រអ៊ីស្រាអែល ។ ២ ក្នុងខណ: ពេលនោះពួកពង្សាវតារក្សត្របានផ្សះផ្សាទំនាក់ទំនងនគរដំណាក់យូដាឡើងវិញ គឺគ្រប់គ្រងទាំងសាសន៍អ៊ីស្រាអែលទាំងអស់(មើលសេចក្តីផ្តើមគម្ពីរ របាក្សត្រទី១ : ត្រង់គោលបំណង និងផ្ទៃរឿង) ។

**១០:១–៩** មើល ១ពង្សាវតារក្សត្រ ១២:១–២០ និងការពន្យល់ ។ ករណីខ្លះក្នុងឧត្តមគតិរបស់ស្តេចសាឡូម៉ូន អ្នកកាលប្រវត្តិដាក់ការទិចទៀនចំពោះការរួមគំនិតនិងយេរ៉ូបោមក្នុការបះបោរ (ប្រៀបធៀប ១៣:៦–៧) ។

**១០:១** *រេហូបោម* បានសោយរាជ្យចាប់ពី ៩៣០ រហូតដល់៩០៩ មុន គ.ស ។

**១០:២** *យេរ៉ូបោម* បានសោយរាជ្យចាប់ពី ៩៣០ រហូតដល់៩០៩ មុន គ.ស ។

ពីស្តេចសាឡូម៉ូន កាលបានឮដំណឹងនោះ លោកក៏ចេញពី
ស្រុកអេស៊ីព្ទមកវិញ ៣ហើយគេចាប់ទៅហៅលោកមករួច
លោក និងពួកអ៊ីស្រាអែលទាំងអស់[ក] ក៏មកគាល់រេហូបោម
ទូលថា ៤ព្រះបិតាទ្រង់បានធ្វើឱ្យនឹមយើងខ្ញុំធ្ងន់ពេក[ឃ] ដូច្នេះ
សូមទ្រង់មេត្តាប្រោសឱ្យការតឹងរ៉ឹងរបស់ព្រះបិតាទ្រង់
នឹងនឹមយ៉ាងធន់ ដែលទ្រង់បានដាក់លើយើងខ្ញុំបានស្រាល
ចេញនោះ យើងខ្ញុំនឹងប្រតិបត្តិតាមទ្រង់ ៥ទ្រង់មានបន្ទូល
ឆ្លើយថា ចាំ៣ថ្ងៃទៀត សូមត្រឡប់មកឯយើងវិញ បណ្តាជន
ទាំងឡាយក៏បង្គំលាទៅ ។
៦ស្តេចរេហូបោម ទ្រង់ប្រឹក្សានឹងពួកចាស់ៗ[ង] ជាពួកជំនិត
នៃសាឡូម៉ូន ព្រះបិតាទ្រង់ ក្នុងកាលដែលមានព្រះជន្មនៅ
ឡើយថា តាមគំនិតអ្នករាល់គ្នា នោះតើត្រូវឆ្លើយនឹងពួក
រាស្ត្រនេះយ៉ាងដូចម្តេច ៧គេក៏ទូលឆ្លើយថា បើសិនជាទ្រង់
ប្រព្រឹត្តនឹងបណ្តាជននេះ ដោយសប្បុរស ហើយផ្គាប់ដល់
ចិត្តគេ ព្រមទាំងមានបន្ទូលនឹងគេ ដោយពាក្យផ្អែមល្ហែម[ច]
នោះគេនឹងនៅជាអ្នកបំរើរបស់ទ្រង់ជាដរាបទៅ ៨ប៉ុន្តែ
ទ្រង់មិនព្រម[ឆ]តាមគំនិតនៃពួកចាស់ៗទាំងនោះទេ[ជ] គឺទ្រង់
ទៅប្រឹក្សានឹងពួកក្មេងៗ ស្រករនឹងទ្រង់ ជាពួកជំនិតរបស់
ទ្រង់វិញ ៩ដោយបន្ទូលថា អ្នករាល់គ្នាគិតយ៉ាងណា តើត្រូវ
ឱ្យយើងឆ្លើយនឹងពួករាស្ត្រនេះដូចម្តេច ដែលគេបានសូម
យើងថា សូមមេត្តាប្រោស ឱ្យនឹមដែលព្រះបិតាទ្រង់ បាន
ដាក់លើយើងរាល់គ្នាបានស្រាលទៅ ១០រួចពួកក្មេងៗដែល
ស្រករនឹងទ្រង់គេទូលថា ឯពួករាស្ត្រនេះដែលមកទូលសូម
ទ្រង់ថា ព្រះបិតាទ្រង់បានធ្វើឱ្យនឹមយើងខ្ញុំរាល់គ្នាធន់ពេក
សូមទ្រង់មេត្តាប្រោសឱ្យ បានស្រាលដល់យើងខ្ញុំវិញដូច្នេះ
នោះត្រូវឱ្យទ្រង់មានបន្ទូលឆ្លើយនឹង គេយ៉ាងនេះវិញថា
កូនដៃយើងនឹងបានធំជាងភ្លៅរបស់ព្រះបិតាយើង ១១ឯព្រះ
បិតាយើង ទ្រង់បានដាក់នឹមយ៉ាងធ្ងន់ លើឯងរាល់គ្នា តែ
ឥឡូវនេះ យើងនឹងបន្ថែម ឱ្យនឹមឯងរាល់គ្នាបានធន់ជាង
ទៅទៀត ព្រះបិតាយើងបានវាយផ្ចាលឯងរាល់គ្នាដោយ
រំពាត់ តែយើងនឹងវាយ ផ្ចាលឯងរាល់គ្នាដោយខ្យាដំរីវិញ
១២លុះដល់ថ្ងៃទី៣ យេរ៉ូបោម នឹងបណ្តាជនទាំងឡាយ
ក៏មក គាល់រេហូបោម ដូចជាទ្រង់បង្គាប់ ដោយបន្ទូលថា
ដល់ថ្ងៃទី២ ចូរឯងរាល់គ្នាត្រឡប់មកឯយើងវិញ ១៣នោះ
ស្តេចទ្រង់មានបន្ទូលឆ្លើយ ដល់គេជាពាក្យគំរោះគំរើយ
ឥតតាមគំនិតរបស់ពួកចាស់ៗឡើយ ១៤គឺទ្រង់មានបន្ទូល
ទៅគេតាមគំនិតរបស់ពួកក្មេងៗនោះវិញថា បិតា យើងបាន
ធ្វើឱ្យនឹមឯងរាល់គ្នាមានទំងន់ តែយើងនឹងបន្ថែមឱ្យនឹមឯង
រាល់គ្នា បានធន់ជាងទៅទៀត បិតាយើងបានវាយផ្ចាលឯង
រាល់គ្នា ដោយរំពាត់ តែយើងនឹងវាយផ្ចាលឯងរាល់គ្នា
ដោយខ្យាដំរីវិញ ១៥ស្តេចទ្រង់មិនព្រមស្តាប់តាមបណ្តាជន
ទេ ដ្បិតការនោះកើតមកអំពីព្រះយេហូវ៉ា[ឈ] ដើម្បីនឹង
សំរេចតាមសេចក្តីដែលទ្រង់បានមានបន្ទូលនឹង យេរូបោម
ជាកូននេបាតដោយសារអ័ហ៊ីយ៉ា ជាអ្នកស្រុកស៊ីឡូរ[ញ]។
១៦លុះកាលពួកអ៊ីស្រាអែល[ដ]ទាំងប៉ុន្មានបានឃើញថា
ស្តេចមិនព្រមស្តាប់តាមគេដូច្នោះ នោះគេទូលតបថា
តើយើងរាល់គ្នាមានចំណែក អ្វីខាងដាវីឌ[ឋ] យើងក៏គ្មាន
មរដកជាមួយនឹងកូនចៅអ៊ីស្រាអែលដែរ ឱពួកអ៊ីស្រាអែល
ចូរយើងវិលទៅផ្ទះរៀងខ្លួនវិញទៅ ឥឡូវនេះ ដាវីឌ អើយ
ចូរមើលព្រះវង្សរបស់ខ្លួនឯងចុះ ដូច្នេះ ពួកអ៊ីស្រាអែល
ទាំងអស់ក៏ត្រឡប់ទៅឯទីលំនៅគេវិញទៅ ១៧តែឯងពួកកូន
ចៅអ៊ីស្រាអែល ដែលនៅក្នុងអស់ទាំងទីក្រុងរបស់ពួកយូដា
នោះរេហូបោមបានសោយរាជ្យលើគេវិញ ១៨រួចមកស្តេច
រេហូបោម ទ្រង់ចាត់អ័ដូរ៉ាម[ឌ]ដែលត្រួតលើពួកកំណែនឱ្យ
ទៅ តែពួកអ៊ីស្រាអែលទាំងអស់គ្នា គេចោលលោកនឹងថ្ម
សំឡាប់ទៅដូច្នេះ ស្តេចរេហូបោមក៏ប្រញាប់ប្រញាល់នឹង
ឡើងព្រះរាជរថរត់ទៅឯក្រុងយេរូសាឡិម ១៩គឺយ៉ាងនោះ
ដែលពួកអ៊ីស្រាអែលបានបះបោរនឹងរាជវង្សនៃដាវីឌ
ដរាបដល់សព្វថ្ងៃនេះ ។

**១១** ១រីឯកាលរេហូបោម ទ្រង់មកដល់យេរូសាឡិម
ហើយ[ក] នោះទ្រង់ក៏ប្រមូលពូជពង្សយូដាទាំងអស់ នឹងពូជ
អំបូរបេនយ៉ាមីនផង រួមទាំង អស់បាន១សែន៨ម៉ឺននាក់
សុទ្ធតែជាអ្នកជ្រើសរើស ហើយថ្មឹកចំបាំង ដើម្បីលើកទៅ

**១០:៣** ក ១រប ៩:១
**១០:៤** ឃ ២រប ២:២
**១០:៦** ង យប ៨:៨-៩ ១២:១២ ១៥:១០ ៣២:៧
**១០:៧** ច សភ ១៥:១
**១០:៨** ឆ ២សយ ១៧:៤ ២៥:១៦-២០ ជ ១ពវ ១១:២៩
**១០:១៥** ឈ ២រប ១១:៤ ២៥:១៦-២០ ញ ១ពវ ១១:២៩
**១០:១៦** ដ ១រប ៩:១ ឋ ២សយ ២០:១
**១០:១៨** ឌ ២សយ ២០:២៤ ១ពវ ៥:១៤
**១១:១** ក ១ពវ ១២:២១

ការបង្ហាញលើកទី២ ក្នុងគម្ពីររបាក្សត្រ (មើល ៩:២៩) ១ពវ ១១:២៦-៤០។
**១០:១៥** *អ័ហ៊ីយ៉ា* មើល ១ពវ ១១:២៦-៤០ ។
**១០:១៨** *ទ្រង់ចាត់អ័ដូរ៉ាម ដែលត្រួតត្រាលើពួកកំណែន* បានជួយផ្នែកដូចគ្នា និងក្រោមការគ្រប់គ្រងស្តេចសាឡូម៉ូន (១ពវ ៤:៦ ៥:១៤) ។
**១០:១៩** *ដរាបសព្វថ្ងៃនេះ* មើលការពន្យល់ ៥:៩ ។
**១១:១-២៣** ខ.១រហូតដល់ ខ.៤ គឺមានលក្ខណៈដូចគ្នាទៅនិង ១ពវ ១២:២១-២៤ ឬដូច ខ.៥-២៣ ក៏ស៊ីនិងគម្ពីររបាក្សត្រដែរ ។ តាមអ្នកកាលប្បវត្តិស្ដីពីស្ដេចរេហូបោម គឺជាគំរូមួយដ៏ល្អ (មើលសេចក្ដីផ្ដើមរបាក្សត្រទី១ គោលបំណងនិងផ្ទៃរឿង) ជំពូក១១ គឺផ្តោតទៅលើការស្តាប់បង្គាប់ព្រះអម្ចាស់គឺដើរតាមព្រះរាជបញ្ជារ (ខ.១-៤) រេហូបោមមានសេចក្ដីអំណរបានទទួលភាពសុខសាន្តនិងអំណាចព្រះចេស្តា (ខ.៥-១២) គឺមានការទំនុកបំរុងជាមួយ (ខ.១៣-១៧) និងតដល់កូនចៅក្រោយៗ (ខ.១៨-២៣) ។ ជំពូក ១២

ច្បាំង និងពួកអ៊ីស្រាអែល ដោយប្រាថ្នាចង់បង្វិលរាជ្យ មក
វិញ ២ប៉ុន្តែព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់
សេម៉ាយ៉ា[ខ] ជាអ្នកសំណប់របស់ព្រះថា ៣ចូរទៅប្រាប់ដល់
រេហូបោម ជាកូនសាឡូម៉ូន ស្តេចស្រុកយូដា ហើយដល់
សាសន៍អ៊ីស្រាអែល នៅខែត្រយូដា និងបេនយ៉ាមីនទាំង
អស់ថា ៤ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ កុំឱ្យឯងរាល់
គ្នាឡើងទៅច្បាំងនឹងពួកបងប្អូនឯងឡើយ[គ] ចូរវិលទៅឯ
ទីលំនៅឯងរៀងខ្លួនទៅ ដ្បិតការនេះ គឺអញបានបង្កើត
ឡើងទេ គេក៏ស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ា គឺគេវិល
ត្រឡប់ពីផ្លូវដែលគេឡើងទៅ ទាស់នឹងយេរ៉ូបោមនោះទៅ
វិញ ។

## រេហូបោមការពារស្រុកយូដា

៥ដូច្នេះ ស្តេចរេហូបោមទ្រង់គង់នៅក្រុងយេរូសាឡិម
ហើយក៏ សង់ទីក្រុងខ្លះនៅស្រុកយូដា សំរាប់ការពារស្រុក
៦ទ្រង់សង់ក្រុងបេថ្លេហិម អេថាមត្កូអា ៧បេត-សើរ សូគរ
អាឌូឡាម ៨កាថ ម៉ារីសា ស៊ីភ ៩អាដូរែមឡាគីស អាសេកា
១០សូរ៉ាស់ អាយ៉ាឡូន និងហេប្រុន ដែលនៅស្រុកយូដា
និងស្រុកបេនយ៉ាមីន សុទ្ធតែជាទីក្រុងមានបន្ទាយទាំងអស់[ឃ]
១១ទ្រង់ក៏ធ្វើបន្ទាយទាំងប៉ុន្មានឱ្យមាំមួនឡើង ហើយដាក់ឱ្យ
មានមេទ័ព លើគ្រប់បន្ទាយទាំងនោះ ព្រមទាំងឱ្យមាន
ស្បៀងអាហារ ប្រេង និងស្រាទំពាំងបាយជូរផង ១២ហើយ
នៅគ្រប់ទាំងទីក្រុង ទ្រង់បានបំរុងទុកខែលនឹងលំពែង ឱ្យ
ទីក្រុងទាំងនោះបាន មានកំឡាំងក្រៃលែង ឯស្រុកយូដា និង
ស្រុកបេនយ៉ាមីន នោះជារបស់ផងទ្រង់ ។

១៣ឯពួកសង្ឃ និងពួកលេវី ដែលនៅគ្រប់ក្នុងស្រុក
អ៊ីស្រាអែល គេក៏ចេញពីស្រុករបស់ខ្លួនមូលមកឯទ្រង់ទាំង
អស់ ១៤ពួកលេវី[ង]គេលះចោលទីលំនៅនឹងកេរ្តិ៍អាកររបស់
គេ[ច] មូលមកនៅស្រុកយូដា និងក្រុងយេរូសាឡិមទាំងអស់
ពីព្រោះយេរ៉ូបោម និងកូនចៅទ្រង់បានបោះ បង់ចោល
គេចេញ មិនឱ្យគេធ្វើការងារជាសង្ឃថ្វាយព្រះយេហូវ៉ា
ទេ ១៥ហើយក៏តាំង[ឆ]ពួកអ្នកដទៃឡើងជាសង្ឃ[ជ]វិញ សំរាប់
អស់ទាំងទីខ្ពស់ រូបពពែឈ្មោល[ឈ] និងកូនគោ[ញ]ដែល
ទ្រង់បានធ្វើ ១៦ឯពួកអ្នកនៅអស់ទាំងពូជអំបូរនៃសាសន៍
អ៊ីស្រាអែល[ដ] គឺជាអ្នកដែលតាំងចិត្តរកព្រះយេហូវ៉ា ជាព្រះ
នៃសាសន៍អ៊ីស្រាអែល នោះក៏តាមពួកលេវីនោះ មកឯក្រុង
យេរូសាឡិម ដើម្បីនឹងថ្វាយយញ្ញបូជាដល់ព្រះយេហូវ៉ា
ជាព្រះនៃពួកឰយុកោគេ ១៧យ៉ាងនេះគេបានចំរើនកំឡាំង[ឋ]
ដល់រាជ្យយូដា ក៏បានធ្វើឱ្យរេហូបោម ជាបុត្រសាឡូម៉ូន
មានកំឡាំងនៅអស់៣ឆ្នាំ ដ្បិតក្នុងរវាង៣ឆ្នាំនោះ គេបាន
ប្រព្រឹត្តតាមផ្លូវរបស់ដាវីឌ និងសាឡូម៉ូន ។

## គ្រួសាររបស់ស្តេចរេហូបោម

១៨ឯរេហូបោមទ្រង់យកភរិយា គឺនាងម៉ាហាឡាត់ ជា
បុត្រីនៃយេរីម៉ូតពូជពង្សដាវីឌ និងនៃអ័ប៊ីហែល ជាបុត្រី
អេលាប ដែលជាបុត្រអ៊ីសាយ ១៩ព្រះនាងនោះបង្កើតបាន
បុត្រាថ្វាយទ្រង់ គឺយេអ៊ូសសេ ម៉ារីយ៉ា និងសាហាំ
២០បន្ទាប់នឹងនាងនោះ ទ្រង់ក៏យកនាងម្អាកា[ឌ] ជាបុត្រី

**១១:២** ខ ១ពវ ១២:២២ ២រប ១២:៥-៧,១៥
**១១:៤** គ ២រប ២៨:៨-១១
**១១:១០** ឃ យស ១០:២០ ២រប ១២:៤ ១៧:២,១៩ ២១:៣
**១១:១៤** ង ជន ៣៥:២-៥ ច ១រប ៦:៨១
**១១:១៥** ឆ ១ពវ ១៣:៣៣ ជ ១ពវ ១២:៣១ ឈ លវ ១៧:៧ ញ ១ពវ ១២:២៨ ២រប ១៣:៨
**១១:១៦** ដ ២រប ១៥:៩
**១១:១៧** ឋ ២រប ១២:១
**១១:២០** ឌ ១ពវ ១៥:២ ឍ ២រប ១២:១៦ ១៣:២

បញ្ជាក់ឡើងពីភាពផ្ទុយ: គឺភាពមិនស្តាប់បង្គាប់នាំមកនូវការកាត់ទោស ។

**១១:២** *សេម៉ាយ៉ា* តួនាទីរបស់ហោរាមានលក្ខណៈដូចជាគាំពារផ្នែកទេវធិបតេយ្យ(នគរព្រះអម្ចាស់)ភាពអស្ចារ្យក្នុងគម្ពីររបាក្សត្រ គឺស្តេចសាន់យូដាច្រើនបានមានបន្ទូល ដូចជាបានទទួលប្រឹក្សាពីហោរា (មើលសេចក្តីផ្តើមក្នុង ១រប ត្រង់គោលបំណងនិងផ្ទៃរឿង) ។

**១១:៣** *សាសន៍អ៊ីស្រាអែល នៅខែត្រយូដា និងបេនយ៉ាមីន* គឺមានភាពខុសប្លែកពីគ្នាខដែលយើងឃើញក្នុង ១ពវ ១២:២៣ យោងតាមអ្នកកាលប្រវត្តិបានចាប់អារម្មណ៍លើ "រាស្ត្រអ៊ីស្រាអែលទាំងអស់" ។

**១១:៤** *អ្នកបានបង្កើតឡើងទេ* មើល ១០:១៥ ។

**១១:៥-១០** បញ្ជីពីឈ្មោះទីក្រុងពុំបានឃើញក្នុងគម្ពីរ ពង្សាវតារក្សត្រទេ ។ រេហូបោមសព្វព្រះហឫទ័យនិងព្រុំដីផ្នែកខាងកើតខាងលិច និងខាងត្បូង រួបរួមគ្នាឡើងវិញនៃនគរទាំងមូល គឺជាការគំរាមកំហែងមួយ ពីការឈ្លានពានពីប្រទេសអេស៊ីព្ទ ។

**១១:១៣-១៧** អ្នកកាលប្រវត្តិក៏បានបំព្រួញសន្ទតពីភាពស្មាត់ជំនាញនៃអ្នកអានជាមួយនិងគម្ពីរ ១ពវ ១២:២៦-៣៣ ។ ឯកសារនេះវាស៊ីគ្នាទៅនិងរបាក្សត្រនិងផ្ទុះបញ្ចាំងដែលទាក់ទងនិងអ្នកនិពន្ធទាក់ទងនិងព្រះវិហារនិងលក្ខណៈផ្ទាល់ខ្លួនរបស់គេ ក៏បានបញ្ជាក់ពីនគររបស់សាសន៍យូដា គឺមានសម្រាប់រាស្ត្រអ៊ីស្រាអែលទាំងអស់ ។

**១១:១៤** *ទីលំនៅនឹងកេរ្តិ៍អាកររបស់គេ* មើល ១រប ៦:៥៤-៨០ លវ ២៥:៣២-៣៤ ជន ៣:៥១ មើលសេចក្តីណែនាំក្នុងរបាក្សត្រទី១និងគោលបំណងនិងផ្ទៃរឿងរបស់គម្ពីរនោះ ។

**១១:១៥** *រូបពពែឈ្មោលនឹងកូនគោ* យោងតាមគម្ពីរពង្សាវតារក្សត្របង្ហាញពីការធ្វើព្រះពីមាសតែប៉ុណ្ណោះ ។ គឺសម្រាប់ធ្វើការថ្វាយបង្គំដល់រូបពពែជាព្រះរបស់គេ មើល លវ ១៧:៧ ។

**១១:១៧** *នៅអស់៣ឆ្នាំ* មើលការពន្យល់ ១២:២ *តាមផ្លូវរបស់ដាវីឌនិងសាឡូម៉ូន* លក្ខណៈសម្បត្តិគតិបណ្ឌិតរបស់ស្តេចសាឡូម៉ូន ១ពវ ១១:១-១៣ ។

**១១:១៨-២២** គឺជាពត៌មានពីរាជវង្សានុវង្ស របស់ស្តេចរេហូបោមក្នុងកណ្ឌគម្ពីររបាក្សត្រ ក៏បង្ហាញពីព្រះពរតាមរយៈការដែលស្តេចអង្គនេះបានស្តាប់បង្គាប់ដល់ព្រះអម្ចាស់ (សូមមើលការពន្យល់ ១១:១-២៣) ។ (មើល ១៣:២១ មើល ២១:២ ១រប ២៥:៥) ។

**១១:២០** *នាងម្អាកា ជាបុត្រីអាប់សាឡុំម* មើលការពន្យល់ ១ពវ ១៥:២ នាងមានលក្ខណៈដូចជីដូនរបស់អាប់សាឡុំមក៏ដូចជានាងតាម៉ា(២សយ ១៤:២៧ ១៨:១៨) គឺជាអ្នកដែលរៀបការជាមួយអ៊ូរី ជាសាសន៍ហេត (សូមមើល ២រប ១៣:២) ។

អាប់សាឡុំម នាងនោះបង្កើតអ័ប៊ីយ៉ា[ឍ] អ័ថាយ ស៊ីសា និង
សឡូមិត ថ្វាយទ្រង់ ២១ រេហូបោមទ្រង់ស្រឡាញ់នាងម្អាកា
ជាបុត្រីអាប់សាឡុំម លើសជាងអស់ទាំងភរិយា និងពួក
អ្នកម្នាងរបស់ទ្រង់ (ដ្បិតទ្រង់បានយកភរិយា១៨[ណ] និងអ្នក
ម្នាង៦០ ក៏បង្កើតបានបុត្រា២៨អង្គ និងបុត្រី៦០អង្គ)
២២ រេហូបោមទ្រង់តាំងអ័ប៊ីយ៉ា[ត] ជាបុត្រានៃនាងម្អាកាទុកជា
បុត្រធំ គឺជាប្រធានក្នុងពួកបងប្អូនទាំងប៉ុន្មាន ដើម្បីតាំង
ឡើងជាស្តេច ២៣ ទ្រង់ក៏ធ្វើដោយឆ្លាត គឺបានបាត់អស់ទាំង
បុត្រានៃទ្រង់ ឱ្យទៅនៅគ្រប់ក្នុងស្រុកយូដា និងស្រុក
បេនយ៉ាមីន ក្នុងអស់ទាំងទីក្រុងមានបន្ទាយ ក៏ប្រទានឱ្យមាន
ស្បៀងអាហារជាបរិបូរ[ថ] ហើយរកប្រពន្ធជាច្រើន ឱ្យដល់
បុត្រទាំងនោះដែរ ។

## ស៊ីសាកច្បាំងនឹងក្រុងយេរូសាឡិម

*១២:៩-១៦ – ១ពវ ១៤:២១,២៥-៣១*

**១២** ១ កាលរាជ្យរបស់រេហូបោមបានមាំមួន[ក] ហើយទ្រង់
មានអំណាចឡើង[ខ] នោះទ្រង់ និងពួកអ៊ីស្រាអែលទាំងអស់[គ]
ក៏បោះបង់ចោល[ឃ] ក្រិត្យវិន័យរបស់ព្រះយេហូវ៉ាចេញ ២ រួច
ដល់ឆ្នាំទី៥ ក្នុងរាជ្យស្តេចរេហូបោម នោះស៊ីសាក[ង] ជា
ស្តេចស្រុកអេស៊ីព្ទ បានឡើងមកច្បាំងនឹងក្រុងយេរូសាឡិម
ដោយព្រោះគេបានប្រព្រឹត្តរំលង[ច]នឹងព្រះយេហូវ៉ា ៣ មាន
ទាំងរទេះចំបាំង១ពាន់២០០ និងពលសេះ៦ម៉ឺននាក់ ឯពល
ទាហានដែល ចេញពីស្រុកអេស៊ីព្ទមកជាមួយនឹងទ្រង់ គឺជា
ពួកសាសន៍លីប៊ី[ឆ] សាសន៍ស៊ូគី និងសាសន៍អេធីអូពី[ជ] នោះ
រាប់មិនបានឡើយ ៤ ទ្រង់វាយយកបានអស់ទាំងទីក្រុង[ឈ]
មានបន្ទាយនៅស្រុកយូដា ហើយក៏ឡើងទៅត្រឹមក្រុង
យេរូសាឡិមទៀត ៥ គ្រានោះហោរាសេម៉ាយ៉ា[ញ] ក៏មកឯ
រេហូបោម និងពួកមេសាសន៍យូដា ដែលបានមូលគ្នានៅ
ក្រុងយេរូសាឡិម ដោយព្រោះស៊ីសាក លោកមានវាចា
ថាព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ឯងរាល់គ្នាបានបោះ
បង់ចោលអញ ហេតុនោះបានជាអញទុកឯងរាល់គ្នា
ចោល[ដ] នៅក្នុងកណ្តាប់ដៃនៃស៊ីសាក ៦ ដូច្នេះ ពួកមេនៃ
សាសន៍ អ៊ីស្រាអែលនិងស្តេចក៏បន្ទាបខ្លួនចុះ[ឋ] ពោលថា
ព្រះយេហូវ៉ា ទ្រង់សុចរិត[ឌ] ៧ រួចកាលព្រះយេហូវ៉ាទ្រង់
ឃើញថា គេបន្ទាបខ្លួនដូច្នោះ នោះព្រះបន្ទូលនៃព្រះ
យេហូវ៉ាក៏មកដល់សេម៉ាយ៉ាថា គេបានបន្ទាបខ្លួន ហើយ
ដូច្នេះ អញនឹងមិនបំផ្លាញគេទេ តែបន្តិចទៀតអញនឹង
ប្រោសឱ្យគេរួច[ឍ] ហើយអញមិនចាក់សេចក្តីក្រោធ[ណ]របស់
អញ ទៅលើក្រុងយេរូសាឡិម ដោយសារដៃស៊ីសាកឡើង
៨ ប៉ុន្តែគេនឹងត្រូវចំណុះ[ត]ទ្រង់វិញ ដើម្បីឱ្យគេអាចនឹងផ្ទឹម
ការបំរើដល់អញ និងការបំរើដល់នគរដទៃឱ្យដឹង ។
៩ ដូច្នេះ ស៊ីសាក ជាស្តេចអេស៊ីព្ទ ទ្រង់ឡើងមកទាស់នឹង
ក្រុងយេរូសាឡិម ក៏យកបានអស់ទាំងទ្រព្យវិសេសក្នុងព្រះ
វិហារនៃព្រះយេហូវ៉ា និងព្រះរាជទ្រព្យ ដែលនៅក្នុង
ដំណាក់ស្តេចអស់រលីងទៅ ព្រមទាំងខែលមាស[ថ]ទាំង

**១១:២១** ណ ចទ ១៧:១៧
**១១:២២** ត ចទ ២១:១៥-១៧
**១១:២៣** ថ ២រប ២១:៣
**១២:១** ក ខ.១២ ២រប ១:១ ខ ២រប ១១:១៧ គ ១រប ៩:១ ឃ ២រប ៧:១៩
**១២:២** ង ១ពវ ១១:៤០ ច ១ពវ ១៤:២២-២៤ ១រប ៥:២៥
**១២:៣** ឆ ដយ ១១:៤៣ ជ លប ១០:៦ ២រប ១៤:៩ ១៦:៨ អស ១៨:២ អម ៩:៧ ណាហ ៣:៩
**១២:៤** ឈ ២រប ១១:១០
**១២:៥** ញ ២រប ១១:២ ដ ចទ ២៨:១៥
**១២:៦** ឋ លវ ២៦:៤១ ២រប ៦:៣៧ ឌ នក ៩:២៧ អរ ៩:១៥ ទដ ១១:៧ ១១៦:៥ ដយ ៩:១៤
**១២:៧** ឍ ទដ ៧៨:៣៨ ណ ដយ ៩:១៩ ទដ ៦៩:២៤ យរ ៧:២០ ៤២:១៨ អគ ៥:១៣
**១២:៨** ត ចទ ២៨:៤៨ **១២:៩** ថ ២រប ៩:១៦

**១១:២១-២២** អត្ថបទទាំងនេះបានពន្យល់ពីមូលហេតុ ដែលកូនប្រុសច្បងពុំបានជ្រើសរើស ជាអ្នកស្នងរបស់រេហូបោម ។

**១១:២៣** *គឺបានបាតអស់ទាំងបុត្រានៃទ្រង់* រេហូបោមបានស្វែងរកសុវត្ថិភាពដល់ការស្នងរាជ្យរបស់អ័ប៊ីយ៉ា ដោយការចាត់ឱ្យបុត្រាមួយចំនួនទៅបោះទីតាំងតាមស្រុក គឺការជៀសវៀងការលំបាកខ្លះដែលត្រូវប្រឈមមុខនិងស្តេចដាវីឌដែលក្នុងរង្វង់រាជវង្សមានបុត្រាដាវីឌ (អាប់សាឡុំមនិងអ័ប៊ីយ៉ា) ដែលបានព្យាយាមដើម្បីរឹបអូសយកអំណាចរាជ្យវង្ស ។

**១២:១-១៤** មើលការពន្យល់ ១១:១-២៣ គឺជាការស្តាប់បង្គាប់ដល់ពួកហោរា (១១:១៤) បាននាំមកព្រះពរ (១១:៥-២៣) ឥឡូវពួកហោរាមកប្រកាស់ពីការកាត់ទោសចំពោះការដែលមិនស្តាប់បង្គាប់ (មើល ១ពវ ១៤:២០-២៨) ។ អ្នកនិពន្ធក៏បានបង្ហាញនូវភាពការបេះទង្គិចដល់ស្តេចស៊ីសាគីអ្នកកាលប្រវត្តិក៏បានបន្ថែមនៅភាពផ្សេងៗ ដោយសាការលុកលុយគេបានបោះបង់ចោល (ខ.១-២៥) ។

**២១:១** *ពួកអ៊ីស្រាអែលទាំងអស់* គឺប្រើបានច្រើនមានន័យច្រើនដូចក្នុង ២រប (១)គឺសំដៅទៅលើនគរទាំងពីរ (៩:៣០) (២) គឺសំដៅលើនគរផ្នែកខាងជើង (១០:១៦ ១១:១៣) ឬ (៣) គឺសំដៅលើនគរផ្នែកខាងត្បូងតែមួយប៉ុណ្ណោះ (ដូចជាក្នុង ១១:៣) ។ ក៏សូមមើលសេចក្តីផ្តើមរបាក្សត្រទីត្រង់គោលបំណងនិងផ្ទៃរឿង ។ *ក៏បោះបង់ចោល* គឺជាពាក្យផ្ទុយនិង"ការស្វែងរកព្រះយេហូវ៉ា" (ខ.១៤) មើលខ.៥ ក៏មើលកាពន្យល់ ២៤:១៨,២០,២៤ ។

**១២:២** *ស៊ីសា* អ្នករកឃើញខ្សែរាជវង្សរបស់រាជវង្សទី២២ នៃសាសន៍អេស៊ីព្ទស្តេចអង្គនោះបានដឹកនាំរាស្ត្រនៃសតវត្សទី ៩៤៥-៩២៤ មុន គ.ស ។ ព្រះគម្ពីរបានបង្ហាញពីការលុកលុយនោះ តែនៅលើក្រុងយេរូសាឡិមមួយទេរួចស៊ីសាបានចារព្រះបន្ទូលនៅលើកំផែងព្រះវិហារអាមុតនៅឯក្រុងកាណាក់ គឺបង្ហាញពីសកម្មភាពកងទ័ពរបស់គាត់នៅឯជើងក្រុងមេគីដោ ។ ឆ្នាំទី៥ ៩២៥ ឆ្នាំមុន គ.ស គឺអ្នកកាលប្រវត្តិ ជារឿយៗបានបង្ហាញ ណែនាំការសំគាល់ពីប្រវត្តិពង្សាវតារក្សត្រ ដែលបានឃើញក្នុងគម្ពីរ (ឧទាហរណ៍ ១១:១៧ ១៥:១០,១៩ ១៦:១,១២-១៣ ១៧:៧ ២១:២០ ២៤:១៥,១៧,២៣, ២៦:១៦ ២៧:៥,៨ ២៩:៣ ៣៤:៣ ៣៦:២១) ។ តាមប្រវត្តិខាងលើគឺជាផ្លូវដែលនាំព្រះពរតាមរយៈដំណាពង្សាវតារក្សត្រ ។

**១២:៣** *សាសន៍ស៊ូគី* គឺប្រហែលជាទាហានស៊ីឈ្នួលរបស់ពួកសាសន៍លីប៊ីដែលចេញពីប្រភពគឺឃើញក្នុងអត្ថបទគម្ពីរអេស៊ីព្ទ ។

**១២:៥** មើលកាពន្យល់ ខ.១-១៤,ខ.១ ។

**១២:៦-៧** មើល ខ.១២ អ្នកកាលប្រវត្តិបានចងចាំក្នុងអារម្មណ៍ ពីព្រះបន្ទូលសន្យាក្នុង ៧:១៤ ។

ប៉ុន្មាន ដែលសាឡូម៉ូនបានធ្វើផង ១០រួចស្តេចរេហូបោម
ទ្រង់ធ្វើខែលលង្ហិនជំនួសវិញ ហើយប្រគល់ទុកនៅដៃនៃ
ពួកមេទ័ពរក្សាអង្គ ដែលចាំមាត់ទ្វារដំណាក់ស្តេច ១១នៅ
វេលាណាដែល ស្តេចទ្រង់យាងចូលទៅក្នុងព្រះវិហារនៃ
ព្រះយេហូវ៉ា នោះពួកទ័ពរក្សាអង្គ ក៏កាន់ខែលទាំងនោះ
មករួចយកទៅទុកក្នុងបន្ទប់នៃពួកទ័ពរក្សាអង្គវិញ ១២នៅ
គ្រាដែលទ្រង់បានបន្ទាបអង្គ[ទ] នោះសេចក្តីក្រោធនៃព្រះ
យេហូវ៉ាក៏ងាកបែរចេញពីទ្រង់ទៅ ប្រយោជន៍មិនឲ្យទ្រង់
ត្រូវវិនាសអស់រលីងឡើយ ហើយ១ទៀត ក្នុងស្រុកយូដាក៏
នៅមានសេចក្តីល្អខ្លះ[ធ]ដែរ ។
១៣ស្តេចរេហូបោមទ្រង់ចំរើន[ន]កំឡាំងឡើង នៅក្រុង
យេរូសាឡិម ហើយក៏សោយរាជ្យតទៅ កាលរេហូបោម
ចាប់តាំងសោយរាជ្យ នោះទ្រង់មានព្រះជន្ម៤១ឆ្នាំ ហើយ
ក៏សោយរាជ្យបាន១៧ឆ្នាំនៅក្រុងយេរូសាឡិម ជាទីក្រុង
ដែលព្រះយេហូវ៉ាបានរើស ពីគ្រប់ទាំងពូជអំបូរនៃសាសន៍
អ៊ីស្រាអែល ដើម្បីនឹងទុកព្រះនាមទ្រង់[ប] ឯព្រះមាតាទ្រង់
ព្រះនាមជានាអាម៉ា ជាសាសន៍អាំម៉ូន ១៤ស្តេចទ្រង់បាន
ប្រព្រឹត្តអំពើដ៏លាមកអាក្រក់ ពីព្រោះទ្រង់មិនបានតាំង
ព្រះទ័យស្វែងរកព្រះយេហូវ៉ាឡើយ ។
១៥រីឯដំណើរទាំងប៉ុន្មាន ពីរេហូបោម ទាំងមុនទាំង
ក្រោយ នោះសុទ្ធតែបានកត់ទុកក្នុងពង្សាវតារ ដែល
ហោរាសេម៉ាយ៉ា[ផ] និងអ៊ីដោ ជាអ្នកមើលឆុត បានតែងតាម
របៀបរឿងរ៉ាវតៗមកហើយ ចំណែករេហូបោម និង
យេរ៉ូបោម ទ្រង់ចេះតែច្បាំងគ្នាជានិច្ច ១៦រេហូបោម[ព]ក៏ផុត

**១២:១២** ទ ២រប ៦:៣៧ ធ ១ពវ ១៤:១៣ ២រប ១៩:៣
**១២:១៣** ន ខ.១ ១ពវ ២:១២ ប នក ២០:២៤ ចទ ១២:៥
**១២:១៥** ផ ២រប ១១:២
**១២:១៦** ព ១រប ៣:១០ ភ ២រប ១១:២០
**១៣:២** ក ២រប ១៥:១៦ ខ ២រប ១១:២០ គ ១ពវ ១៥:៦
**១៣:៤** ឃ យស ១៨:២២ ង ១រប ១១:១
**១៣:៥** ច ២សយ ៧:១៣ ១រប ១៧:១២ ឆ លវ ២:១៣
**១៣:៦** ជ ១ពវ ១១:២៦
**១៣:៧** ឈ ពច ៩:៤ ញ ១រប ២៩:១

លក់ទៅនៅក្នុងក្រុងដាវីឌ រួចអ័ប៊ីយ៉ា[ភ] ជាព្រះរាជបុត្រាក៏
ឡើងសោយរាជ្យជំនួសព្រះបិតា ។

## អ័ប៊ីយ៉ាឡើងជាស្តេចស្រុកយូដា

*១៣:១-២,២២ – ១៤:១ – ១ពវ ១៥:១-២,៦-៨*

**១៣** ១នៅឆ្នាំទី១៨ ក្នុងរាជ្យស្តេចយេរ៉ូបោម នោះអ័ប៊ីយ៉ា
ចាប់តាំងសោយរាជ្យឡើងលើស្រុកយូដា ២ទ្រង់ក៏សោយ
រាជ្យ៣ឆ្នាំ នៅក្រុងយេរូសាឡិម ព្រះមាតាទ្រង់ព្រះនាមជា
មីកាយ៉ា[ក]ជាបុត្រីអ៊ូរាល អ្នកក្រុងគីបៀរ អ័ប៊ីយ៉ា[ខ] និង
យេរ៉ូបោម[គ]ក៏ច្បាំងគ្នាដែរ ៣ឯអ័ប៊ីយ៉ាទ្រង់ចាប់តាំងត
ចំបាំង មានពលទ័ពសុទ្ធតែមនុស្សថ្មឹកចំបាំង ហើយជ្រើស
រើស មានចិត្តក្លាហានចំនួន៤សែននាក់ ហើយយេរ៉ូបោម
ក៏ដំរៀបទ័ពច្បាំងនឹងទ្រង់ មានមនុស្សជ្រើសរើស ហើយ
ក្លាហាន៨សែននាក់ ៤ឯអ័ប៊ីយ៉ា ទ្រង់ឈរនៅលើភ្នំ
សេម៉ារែម[ឃ] ដែលនៅស្រុកភ្នំអេប្រាអិម មានបន្ទូលថា ឱ
យេរ៉ូបោមនឹងពួកអ៊ីស្រាអែល[ង]ទាំងអស់គ្នាអើយ ចូរស្តាប់
ចុះ ៥គួរឲ្យឯងរាល់គ្នាដឹងថា ព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែល បានប្រទានអំណាចលើសាសន៍
អ៊ីស្រាអែលដល់ដាវីឌ ឲ្យសោយរាជ្យជាដរាបទៅ[ច] គឺដល់
ទ្រង់នឹងវង្សានុវង្សរបស់ទ្រង់តទៅតាមសេចក្តីសញ្ញា ដែល
តាំងដោយអំបិល[ឆ] ៦ប៉ុន្តែយេរ៉ូបោម ជាកូននេបាត ដែលជា
អ្នកបំរើរបស់សាឡូម៉ូន បុត្រាដាវីឌ វាបានលើកខ្លួនឡើង
បះបោរ[ជ]នឹងចៅហ្វាយរបស់ខ្លួន ៧ហើយមានមនុស្សជា
អសារឥតការនឹងមនុស្សចោល ម្សៀត[ឈ]បានរួមគ្នាជាមួយ
នឹងវា ចំរើនកំឡាំងឡើងទាស់នឹងរេហូបោម ជាបុត្រា

---

**១២:១៣** *សោយរាជ្យបាន១៧ឆ្នាំ* មើលការពន្យល់ ១០:១ ។

**១២:១៥–១៦** សូមមើល ១ពវ ១៤:២៩–៣១ ។

**១៣:១–១៤:១** អ្នកកាលប្បវត្តិបានផ្តោតទៅលើរាជបល្ល័ង្ករបស់អ័ប៊ីយ៉ា ជាស្តេចបានសោយរាជ្យមានរយៈពេលវែងជាងស្តេចក្នុង ១ពវ ១៥:១–៨ បីដង (មើល ១៣:៤–១២ មើលការពន្យល់ ២៨:១–២៧) ។ តាមការប្រៀបធៀបគឺមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងនៃការ គ្រងរាជ្យរបស់ស្តេចអ័ប៊ីយ៉ាដូចជាក្នុងគម្ពីររបាក្សត្រដែលបានវាយតម្លៃចំពោះស្តេចនិមួយៗដូចជាក្នុងគម្ពីរពង្សាវតារក្សត្របានវាយតម្លៃមានលក្ខណៈវិជ្ជមានវិញ គឺជាទស្សនៈបាននិយាយពីការងាររបស់ស្តេចនោះ ។ ការសោយរាជ្យ បល្ល័ង្កគឺមានលក្ខណៈដូចជាប្រជារាស្ត្រធម្មតា ។ ជារឿយៗមានទាំងការអាក្រក់និងការល្អលាយគ្នា ។ គឺការប្រព្រឹត្តបែបផ្លូវព្រះនិងដើរតាមផ្លូវវង្វេង ។

**១៣:២** *សោយរាជ្យ៣ឆ្នាំ* ៩១៣–៩១០ មុន គ.ស *មីកាយ៉ា* មើលការពន្យល់ ១១:២០ ។

**១៣:៣** *ចំនួន៤សែននាក់ . . . ៨សែននាក់* មើល ១រប ២១:៥ (មើលការពន្យល់ផងដែរ និងសេចក្តីផ្តើម ជនគណនា) ។

**១៣:៤** *ភ្នំសេម៉ារែម* ក៏ជាទីក្រុងសេម៉ារែម គឺមានទីតាំងនៅព្រំប្រទល់ជិតបេនយ៉ាមីន (យស ១៨:២២) ដោយតែងតែមានសង្គ្រាមកើតឡើងនៅតាមបណ្តោយព្រំប្រទល់ដីបេនយ៉ាមីននិងអ៊ីស្រាអែល ។ *ពួកអ៊ីស្រាអែលទាំងអស់គ្នាអើយ* មើលការពន្យល់ក្នុង ១២:១ នៅទីនេះ ខ.១៥ ក្នុងពាក្យនេះសំដៅលើនគរអ៊ីស្រាអែលខាងជើង ។

**១៣:៥** មើល ៧:១៧–១៨ ១រប ១៧:១៣–១៤ *សេចក្តីសញ្ញាដែលតាំងដោយអំបិល* មើលការពន្យល់ ជន ១៨:១៩ ២ពវ ២:២០ ។

**១៣:៦** មើលការពន្យល់ ១០:១–១៩ ។

**១៣:៧** គឺមិនគ្រប់ទាំងអស់នៅក្នុងនគរផ្នែកខាងជើង ដែលបានស្តីបន្ទោស គឺមានតែអ្នកដឹកនាំតែប៉ុណ្ណោះ ដែលជាអ្នកប្រើល្បិចកលបញ្ចុះបញ្ចូលអ្នកនៅក្នុងភូមិភាគខាងជើង ដែលនាំឲ្យមានការបះបោរ ។ *មនុស្សចោលម្សៀត* មើលការពន្យល់ ចទ ១៣:១៣ ដែលមានមនុស្សទមិលល្មើសជាច្រើនបានលើកគ្នាប្រឆាំងនិងស្តេចដែលនៅខ្ចីខាងគំនិត ។ សូមប្រៀបធៀប ២២:៥ ២៩:១ រេហូបោម ទ្រង់មានព្រះជន្ម៤១ ព្រះវស្សា គឺក្នុងសម័យពេលដែលមានការខ្វែងគំនិត ។

សាឡូម៉ូន ក្នុងកាលដែលរេហូបោមនៅខ្ចីគំនិត ហើយចិត្ត
ទន់[ញ] មិនអាចទប់នឹងគេបានឡើយ ៨ឥឡូវនេះ ឯងរាល់គ្នា
គិតតតាំងនឹងនគររបស់ព្រះយេហូវ៉ា ដែលនៅក្នុងអំណាច
កូនចៅដាវីឌទៀត[ដ] ឯងរាល់គ្នាមានគ្នាសន្ធឹកណាស់[ឋ]
ហើយកូនគោមាស[ឌ] ដែលយេរ៉ូបោមបាន ធ្វើទុកជាព្រះ
របស់ឯង ក៏នៅជាមួយនឹងឯងដែរ ៩តើឯងរាល់គ្នាមិន
បានបណ្តេញពួកសង្ឃ[ឍ]ផងព្រះយេហូវ៉ា[ណ] គឺជាពួកកូនចៅ
អើរ៉ុន និងពួកលេវីចេញ ហើយបានតាំងពួកអ្នកដទៃឱ្យធ្វើ
ជាពួកសង្ឃ តាមរបៀបអស់ទាំងសាសន៍ដទៃទេឬអី ដល់
ម្ល៉េះបានជាអ្នកណាក៏ដោយ ដែលយកគោស្ទាវ[ត] និងចៀម
ឈ្មោល៧[ថ]មកចង់បំបួសខ្លួន នោះនឹងបានធ្វើជាសង្ឃដល់
ព្រះទាំងនោះ ដែលមិនមែនជាព្រះទេក៏បាន[ទ] ១០តែខាងឯ
យើងរាល់គ្នាវិញ គឺព្រះយេហូវ៉ារទង់ជាព្រះនៃយើង យើង
រាល់គ្នាមិនបានបោះបង់ចោលទ្រង់ទេ យើងមានពួកសង្ឃ
ជាពួកកូនចៅអើរ៉ុន និងពួកលេវីដែលធ្វើការងារថ្វាយ
ព្រះយេហូវ៉ាវិញ ១១រាល់តែព្រឹកល្ងាច[ធ] គេតែងដុតដង្វាយ
ដុតនឹងគ្រឿងក្រអូប[ន]ថ្វាយព្រះយេហូវ៉ាជានិច្ច ក៏រៀបនំបុ័ង
តាំងទុកដាក់លើតុបរិសុទ្ធ[ប] ព្រមទាំងថៃជើងចង្កៀងមាស
និងចង្កៀងទាំងប៉ុន្មាន[ផ] ដែលសំរាប់ដុតរាល់តែល្ងាច
ដ្បិតយើងរាល់គ្នា រក្សាបញ្ញើរបស់ព្រះយេហូវ៉ា ជាព្រះ
នៃយើងតែឯងរាល់គ្នា បានបោះបង់ចោលទ្រង់វិញ
១២ហើយមើល ព្រះទ្រង់គង់ជាមួយ ក៏ជាអ្នកនាំមុខយើង
ពួកសង្ឃរបស់ទ្រង់ក៏កាន់ត្រែ សំរាប់នឹងផ្លុំឱ្យស្លន់ឡើងទាស់
នឹងឯងរាល់គ្នា[ព] ឱពួកកូនចៅអ៊ីស្រាអែលអើយ កុំឱ្យច្បាំង
នឹងព្រះយេហូវ៉ា[ភ] ជាព្រះនៃពួកឰយុកោឯងរាល់គ្នាឡើយ
ពីព្រោះឯងរាល់គ្នានឹងមិនចំរើនទេ[ម] ។
១៣តែឯងយេរ៉ូបោមទ្រង់ចាប់ពួកទ័ពបង្កប់ ឱ្យវាងទៅ
ខាងក្រោយ ដូច្នេះ មានពួកគេនៅពីខាងមុខ និងពួកទ័ព
បង្កប់នៅពីខាងក្រោយ[យ]នៃពួកយូដា ១៤កាលពួកយូដាបាន
ក្រឡេកបែរមើលទៅក្រោយ នោះក៏ឃើញមានចំបាំង
ពីមុខពីក្រោយដូច្នេះ គេក៏អំពាវនាវ[រ]ដល់ព្រះយេហូវ៉ា
ហើយពួកសង្ឃក៏ផ្លុំត្រែឡើង ១៥ពួកទ័ពយូដា គេស្រែកឡើង
ហើយកំពុងដែលពួកយូដាស្រែកឡើងដូច្នោះ នោះព្រះទ្រង់
ក៏វាយយេរ៉ូបោម និងពួកអ៊ីស្រាអែលទាំងអស់[ល] នៅមុខ
អ័ប៊ីយ៉ា និងពួកយូដា ១៦ពួកកូនចៅអ៊ីស្រាអែល គេបាក់ទ័ព
រត់ពីមុខពួកយូដា ហើយព្រះទ្រង់ប្រគល់[វ]គេមកក្នុងកណ្តាប់
ដៃនៃពួកយូដា ១៧អ័ប៊ីយ៉ា និងពួកទ័ពទ្រង់ ក៏ប្រហារសំឡាប់
គេយ៉ាងសំបើម មានពួកអ៊ីស្រាអែល សុទ្ធតែជាមនុស្ស
ជ្រើសរើស បានដួលស្លាប់អស់៥សែននាក់ ១៨នៅវេលា
នោះពួកកូនចៅអ៊ីស្រាអែលត្រូវក្រាបចុះ ឯពួកកូនចៅ
យូដា គេមានជ័យជំនះ ដោយព្រោះគេបានពឹង[ស]ដល់ព្រះ
យេហូវ៉ា ជាព្រះនៃពួកឰយុកោគេ ១៩អ័ប៊ីយ៉ាទ្រង់ដេញតាម
យេរ៉ូបោម ដណ្តើមយកបានទីក្រុងខ្លះរបស់ទ្រង់គឺក្រុង
បេត-អែល និងដំបន់នៅជុំវិញ ក្រុងយេសាណា និងដំបន់
នៅជុំវិញ និងក្រុងអេប្រុន ព្រមទាំងដំបន់នៅជុំវិញដែរ
២០ហើយនៅក្នុងរាជ្យ អ័ប៊ីយ៉ា នោះយេរ៉ូបោមមិនបាន
ចំរើនកំឡាំងឡើងវិញទៀតឡើយ រួចព្រះយេហូវ៉ាប្រហារ
ទ្រង់ឱ្យសុគតទៅ ២១ឯអ័ប៊ីយ៉ាទ្រង់មានអំណាច កាន់តែខ្លាំង
ឡើង ទ្រង់យកភរិយា១៤ ហើយបង្កើតបានបុត្រា២២អង្គ
នឹងបុត្រ១៦អង្គ ២២រីឯដំណើរឯទៀតពីអ័ប៊ីយ៉ា ហើយពីការ
របស់ទ្រង់ និងព្រះបន្ទូលនៃទ្រង់ នោះសុទ្ធតែបានកត់ទុក
ក្នុងសៀវភៅបរិយាយ នៃហោរាអ៊ីដោហើយ ។

**១៤** ១អ័ប៊ីយ៉ាទ្រង់ផ្ទំលក់នៅជាមួយនឹងពួកឰយុកោទ្រង់
ទៅ ហើយ គេបញ្ចុះសពទ្រង់នៅក្នុងក្រុងដាវីឌ រួចអេសា
ជាព្រះរាជបុត្រាក៏ឡើង សោយរាជ្យ ជំនួសព្រះបិតា ហើយ
នៅក្នុងរាជ្យរបស់ទ្រង់ នោះស្រុកបានស្ងៀមសប់អស់១០ឆ្នាំ

### អេសាឡើងជាស្តេចស្រុកយូដា

*១៤:២-៣ – ១ពវ ១៥:១១-១២*

២ឯអេសាទ្រង់ប្រព្រឹត្តសេចក្តីដែលល្អ ហើយត្រឹមត្រូវ
នៅព្រះនេត្រព្រះយេហូវ៉ា ជាព្រះនៃទ្រង់[ក] ៣ដ្បិតទ្រង់បំបាត់

**១៣:៨** ដ ២រប ៩:៨ ឋ ១សយ ៤:៣ ឌ នក ៣២:៤
**១៣:៩** ឍ ១ពវ ១២:៣១ ណ ២រប ១១:១៤-១៥ ត នក ២៩:៣៥-៣៦ ថ នក ២៩:៣១ ទ យរ ២:១១ កទ ៤:៨
**១៣:១១** ធ នក ២៩:៣៩ ២រប ២:៤ ន នក ២៥:៦ ប ១រប ៩:៣២ ផ នក ២៥:៣៧
**១៣:១២** ព ជន ១០:៨-៩ ភ ពច ២:១៥ កច ៥:៣៩ ម យប ៩:៤ សភ ២១:៣០ ២៩:១
**១៣:១៣** យ យស ៨:៩ ២រប ២០:២២
**១៣:១៤** រ ១រប ៥:២០ ២រប ១៤:១១ ១៨:៣១
**១៣:១៥** ល ១រប ៩:១
**១៣:១៦** វ ២រប ១៦:៨
**១៣:១៨** ស ២រប ១៤:១១ ១៦:៧ ទដ ២២:៥
**១៤:២** ក ២រប ២១:១២

**១៣:៨** *នគររបស់ព្រះយេហូវ៉ា* ព្រះរាជ្យដំណាក់នៃស្តេចគឺតំណាងឱ្យនគររបស់ព្រះយេហូវ៉ាជាព្រះអម្ចាស់ (មើល ៩:៨ និងការពន្យល់) ។

**១៣:៩** មើល ១ពវ ១២:២៥-៣៣ *ចង់បំបួសខ្លួន* ប្រៀបធៀប នក ២៩:១ ។

**១៣:១០-១២** ក្នុងខនេះអ្នកកាលប្រវត្តិចង់បង្ហាញពីការថ្វាយបង្គំ ដែលអាចទទួលយកបាន គឺសម្តែងពីសង្ឃដែលមានក្រឹត្យវិន័យ ពីព្រះនិងពីធីផ្សេៗ ដែលបានចែងក្នុងក្រឹត្យវិន័យ(ប្រៀបធៀប ១រប ២៣:២៨-៣១) ។

**១៣:២១** មើលការពន្យល់ ១១:១៨-២២ ។

**១៤:២១** *ស្ងៀមស្ងាត់អស់១០ឆ្នាំ* គឺចំពោះអ្នកកាលប្រវត្តិបង្ហាញថា សន្តិភាពឬភាពស្ងៀមស្ងាត់និងភាពចម្រើន អាចទទួលបានដោយសាការប្រកាន់ខ្ជាប់នូវក្រឹត្យវិន័យដ៏សុចរិត ។ គឺមួយទសវត្សរ៍ដំបូងនៃការគ្រងរាជ្យរបស់ អេសា (ក្នុងឆ្នាំ ៩១០-៩00 មុន គ.ស) ដែលនាំឱ្យមានការឈ្លានពានដោយសាសន៍សេរ៉ាស(១៤:៩-១៥)និងនាំឱ្យទទួលបាននៅភាពស្ងៀមស្ងាត់ជាង ២0ឆ្នាំ គឺចាប់ពីឆ្នាំទី១៥(១៥:១០)រហូតដល់ឆ្នាំទី៣៥(១៥:១៩)គឺវាមានលក្ខណៈផ្ទុយនិងរយៈពេលគ្រងរាជ្យរបស់អេសា និងប្បសាតាមការកត់ត្រាគេបានធ្វើចម្បាំងនិងគ្នា គឺក្នុងពេលពួកគេកំពុងសោយរាជ្យ (មើល ១ពវ ១៥:១៦) និងការពន្យល់ ។ (១៦:១) មើល ១៥:៨ និងកាពន្យល់ ។

**១៤:២-១៦:១៤** ការគ្រងរាជ្យរបស់ស្តេចអាសា ក្នុងឆ្នាំ (៩១០-៨៦៩ មុន គ.ស)ក្នុងអត្ថបទនេះបានបង្ហាញពីការពង្រីកវិសាលភាព (ភាពរាលដាល)

អស់ទាំងអាសនាដទៃ[ខ] នឹងទីខ្ពស់ទាំងប៉ុន្មាន ឱ្យសូម្បីចេញក៏
បំបាក់បំបែកបង្គោលថ្ម[គ] ដែលសំរាប់គោរព ហើយកាប់
រំលំរូបព្រះបង់[ឃ] ៤ ទ្រង់ក៏បង្គាប់ដល់ពួកយូដា ឱ្យគេស្វែង
រកព្រះយេហូវ៉ា[ង] ជាព្រះនៃពួកឰយុកោគេ ហើយឱ្យប្រព្រឹត្ត
តាមក្រិត្យវិន័យ និងបញ្ញត្តទាំងប៉ុន្មានដែរ ៥ ទ្រង់បំបាត់ទី
ខ្ពស់ទាំងប៉ុន្មាន[ច] និងរូបព្រះអាទិត្យ[ឆ] ពីអស់ទាំងទីក្រុងស្រុក
យូដាចេញ នោះនគរបានស្ងៀមស្ងប់ នៅចំពោះទ្រង់ ៦ គ្រា
នោះទ្រង់សង់ទីក្រុងមានបន្ទាយនៅក្នុងស្រុកយូដា ដ្បិតស្រុក
បានស្ងៀមស្ងប់ ឥតមានចំបាំងក្នុង ប៉ុន្មានឆ្នាំនោះ ពីព្រោះ
ព្រះយេហូវ៉ាបានប្រោសប្រទាន ឱ្យទ្រង់មានសេចក្តីស្រាក
ស្រាន្ត[ជ] ៧ ដូច្នេះ ទ្រង់មានបន្ទូលនឹងពួកយូដាថា ចូរយើង
សង់ទីក្រុងទាំងនេះឡើង ហើយធ្វើកំផែងព័ទ្ធជិវិញព្រម
ទាំងប៉ម ទ្វារ និងរនុកផង ក្នុងពេលដែលគ្មានអ្វីឃាត់ឃាំង
នៅមុខយើងក្នុងស្រុកឡើង ដ្បិតយើងរាល់គ្នាបានស្វែង
រកព្រះយេហូវ៉ា ជាព្រះនៃយើង អើ យើងរាល់គ្នាបាន
ស្វែងរកទ្រង់ ហើយទ្រង់បានប្រទានឱ្យយើងមាន សេចក្តី
ស្រាកស្រាន្ត[ឈ]នៅព័ទ្ធជិវិញ ដូច្នេះ គេក៏សង់ឡើង ហើយ
បានចំរើនផង ៨ អេសាទ្រង់មានពួកពលទ័ព ដែលកាន់
ខែលនឹងលំពែង៣សែននាក់[ញ] ជាពួកយូដា ហើយ២សែន
៨ម៉ឺននាក់ ជាពួកបេនយ៉ាមីន ដែលកាន់ ខែលហើយបាញ់ធ្នូ
សុទ្ធតែជាមនុស្សមានចិត្តក្លាហាន ។

៩ នៅគ្រានោះ សេរ៉ាស ជាសាសន៍អេធីអូពី[ដ] ទ្រង់បាន
លើកទ័ព១លាននាក់ និងរទេះចំបាំង៣00 ចេញមកទាស់
នឹងពួកយូដា ក៏មកដល់ក្រុងម៉ារីសា[ឋ] ១០ ដូច្នេះ អេសាទ្រង់
ចេញទៅតទល់នឹងគេ ក៏ដំរៀបគ្នា ដើម្បីច្បាំងនៅក្នុងច្រក
ភ្នំសេផាថា ត្រង់ក្រុងមារីសា ១១ ឯអេសាទ្រង់ អំពាវនាវ[ឌ]
ដល់ព្រះយេហូវ៉ា ជាព្រះនៃទ្រង់ថា ឱព្រះយេហូវ៉ាអើយ
ការជួយឱ្យមានជ័យជំនះ ដល់ពួកមានគ្នាច្រើន ឬដល់ពួក
កំសោយនោះ ស្រេចនៅលើទ្រង់ទេ ឱព្រះយេហូវ៉ា ជាព្រះ
នៃយើងរាល់គ្នាអើយ សូមជួយយើងខ្ញុំផង[ឍ] ដ្បិតយើងខ្ញុំ
ផ្អែក[ណ]លើទ្រង់ជាទីពឹង គឺដោយនៅតែព្រះនាមទ្រង់[ត]
ប៉ុណ្ណោះ ដែលយើងរាល់គ្នាបានមក ទាស់នឹងពួកមានគ្នា
ច្រើនទាំងនេះ ឱព្រះយេហូវ៉ាអើយ ទ្រង់ជាព្រះនៃយើង
រាល់គ្នា សូមកុំឱ្យមនុស្សឈ្នះ[ថ]ទ្រង់ឡើយ ១២ ដូច្នេះ ព្រះ
យេហូវ៉ាទ្រង់ក៏វាយ[ទ]ពួកអេធីអូពី នៅចំពោះអេសា និងពួក
យូដា ឱ្យគេបាក់ទ័ពរត់ទៅ ១៣ រួចអេសា និងពួកពលដែល
នៅជាមួយ ក៏ដេញតាមទៅរហូតដល់ក្រុងកេរ៉ា[ធ] ហើយពួក
អេធីអូពី គេដួលស្លាប់ជាច្រើនណាស់ ដល់ម៉្លេះបានជាគេ
ងើបឡើង ឱ្យមានកំឡាំងទៀតមិនបាន ពីព្រោះគេត្រូវបាក់
បែក[ន]នៅចំពោះព្រះយេហូវ៉ា ហើយចំពោះពលទ័ពរបស់

**១៤:៣** ខ ពច ២:២
គ នក ២៣:២៤
ឃ នក ៣៤:១៣
**១៤:៤** ង ១រប
១៦:១១
**១៤:៥** ច ១ពវ
១៥:១៤ ឆ អស
២៧:៩ អគ ៦:៤
**១៤:៦** ជ ១រប
២២:៩
**១៤:៧** ឈ ១រប
២២:៩
**១៤:៨** ញ ១រប
២១:១
**១៤:៩** ដ ២រប
១២:៣ ឋ លប
១០:៨–៩ ២រប
១១:៨ ២៤:២៤
**១៤:១១** ឌ ១ពវ
៨:៤៤ ២រប ១៣:១៤
២៥:៨ ឍ ទដ
៦០:១១–១២ ៧៩:៩
ណ ២រប ១៣:១៨
ត ១សយ ១៧:៤៥
ថ ទដ ៩:១៩
**១៤:១២** ទ ១ពវ
៨:៤៥

**១៤:១៣** ធ លប ១០:១៩ ន ២សយ ២២:៣៨ នហ ៩:២៤ ទដ ៤៤:២,១៩
១៣៥:១០ ប ២រប ១៥:១១,១៨

និងគ្រងលើនគរមួយ សូមមើល ១ពវ ១៥:៩–២៤ ។ ការពង្រីកទឹកដីនេះគឺបង្ហាញពីចារិតលក្ខណៈមួយ នៃទស្សនៈរបស់អ្នកកាលប្រវត្តិដែលទាក់ទងប្រិយសម្ព័ន្ធរវាងការស្តាប់បង្គាប់និងព្រះពរការមិនស្តាប់បង្គាប់ និងការកាត់ទោស ។ អ្នកនិពន្ធណែនាំឱ្យឃើញនូវ ការកត់សំគាល់ពីប្រវត្តិដែលមានកត់បញ្ចូលប្រាប់ពីការគ្រប់គ្រងរាជ្យរបស់អេសា ដែលមកឯព្រះក្នុងរជ្ជកាលទាំងនោះ(មើលការពន្យល់ ១២:២) គឺរយៈពេល១០ឆ្នាំដែលស្តេច អេសាបានអនុវត្តភាពសុចរិតនិងភាពសុខសាន្ត(១៤:១–៧)និងមានការឈ្លានពានដោយកងទ័ពកូស៊ី ដ៏មានកម្លាំងខ្លាំងក្លាក៏បានវាយរុញច្រានដេញទៅវិញដោយសាទ្រង់អេសា បានអំពាវនាវរកព្រះយេហូវ៉ា(១៤:៨–១៥) ។ នៅក្នុងទី១៥ នៃការសោយរាជ្យនោះព្រះយេហូវ៉ាបានរៀបចំឱ្យមានសេចក្តីសញ្ញាឡើងវិញជាមួយនិងស្តេចអេសា(១៥:១០–១៨)ហើយស្តេចអង្គនេះក៏សប្បាយដោយអំណរពោរពេញ ដោយភាពស្ងប់ស្ងៀមរហូតដល់ឆ្នាំទី៣៥(១៥:១៩)ក៏ប៉ុន្តែក្រោយមកក៏មានការប្រែប្រួល គឺដោយពេលនោះមានការឈ្លានពានពីនគរផ្នែកខាងជើងក្នុងឆ្នាំទី៣៦ របស់អង្គស្តេចនោះ(១៦:១) ដោយបានជួលសាសន៍អើរ៉ាម ជាជាងទុកចិត្តលើព្រះយេហូវ៉ា(១៦:៧–១០) និងហោរាដែលបានបដិសេធដល់ទ្រង់ (១៦:៧–១០) ។ នៅក្នុងឆ្នាំទី៣៩ស្តេចអង្គនេះមានជម្ងឺយ៉ាងធ្ងន់ធ្ងរ (១៦:១២) តែស្តេចនេះនៅតែបដិសេធដល់ព្រះតែនៅក្នុងឆ្នាំទី៤១នៃការសោយរាជ្យស្តេចអង្គនេះក៏បានសុគតទៅ(១៦:១៣) ។

**១៤:៣** *បង្គោលថ្មសម្រាប់គោរព* មើលការពន្យល់ ១ពវ ១៤:២៣ ។

**១៤:៥** *បំបាត់ទីខ្ពស់* ១ពវ ១៥:១៤ ក៏បញ្ជាក់ថាស្តេច អេសាពុំបានបំផ្លាញទីដ៏ខ្ពស់នោះទេ ។ ភាពស្មុគស្មាញនេះបានដោះស្រាយ ដោយសេចក្តីផ្ទាល់របស់អ្នកកាលប្រវត្តិក្នុង ១៥:១៧ គឺកំណត់ត្រាដ៏ជាក់លាក់ពីហេតុការជាក់លាក់ចំពោះ ១ពវ ១៤:១៤ គឺតាំងពីការគ្រប់គ្រងរាជ្យដំបូងរបស់គាត់នោះគឺស្តេចអេសាក៏បានព្យាយាមរុះរើទីខ្ពស់នោះចេញ ប៉ុន្តែការថ្វាយបង្គំនៃពួកសាសន៍ដ៏ទៃគឺមាន លក្ខណៈរឹងមាំណាស់ ។ ភាពខិតខំរបស់ស្តេចនោះមិនបានជោគជ័យ (១៥:១៧) ។ យើងឃើញការបញ្ជាក់បង្ហាញពីការរុះរើឬក៏មិនរុះរើទីដ៏ខ្ពស់នោះដែរ តែយើងឃើញក្នុងរយៈពេលគ្រងរាជ្យរបស់ស្តេចយ៉ូសាផាត(១៧:៦ ២០:៣៣)ប្រៀបធៀប ចទ ១២:២–៣ ។

**១៤:៧** *ស្រាកស្រាន្តនៅព័ទ្ធជុំវិញ* មើលការពន្យល់ ២០:៣០ ។

**១៤:៩** *សេរ៉ាស* គឺជាថ្នាក់ដឹកនាំទូទៅក្នុងជួរកងទ័ពសាសន៍អេស៊ីព្ទដែលបម្រើការងារឱ្យស្តេចផារ៉ោន(អូសោខោន)ទី១ ។ ការលុកលុយបានកើតឡើងមានលក្ខណៈទំនងដូចកាលពីពេលវាយប្រហា នៃស្តេចស៊ីសាកតាំង៣0មុននោះទៀត(១២:១–១២)តែលទ្ធផល ដែលប្រឆាំនិងអេសាមានលក្ខណៈខុសគ្នាទាំងស្រុង *កូស៊ី* ជាសាសន៍នៃជាតិអំបូររបស់ណាប់បៀក្នុងតំបន់ដែលមានព្រំដីលើសមុទ្រអេស៊ីព្ទនៅផ្នែកខាត្បូង ។ មើលការពន្យល់ អស ១៨:១

**១៤:១០** *ច្រកភ្នំសេផាថា* ច្រកនេះបង្កើតបានជាច្រកចេញចូលជាផ្លូវឆ្ពោះទៅរកភ្នំនៃស្រុកយូដានិងក្រុងយេរូសាឡិម ។ ក្រុងម៉ារីសា គឺមុនស្តេចរេហូបោម (១១:៨) ។

**១៤:១៣** *ក្រុងកេរ៉ា* មើការពន្យល់ លប ២០:១ *របឹប* (ខ.១៤) (១៥:១៨) ។

ទ្រង់ ពួកខាងអេសាក៏ចាប់យកបានរបឹបយ៉ាងសន្ធឹក[ប]
១៤ហើយវាយអស់ទាំងទីក្រុង នៅជុំវិញក្រុងកេរ៉ាដែរ
ពីព្រោះសេចក្ដីស្ញែងខ្លាច[ផ]របស់ព្រះយេហូវ៉ា បានគ្រប
សង្កត់លើពួកក្រុងទាំងនោះ ពួកយូដាក៏ប្លន់ទីក្រុងទាំងនោះ
យកបានរបស់យ៉ាងសន្ធឹក ១៥ហើយវាយទាំងរោងសត្វ
នាំយកបានចៀមជាបរិបូរ ព្រមទាំងអូដ្ឋផង រួចត្រឡប់ទៅ
ឯក្រុងយេរូសាឡិមវិញ ។

## កំណែទម្រង់របស់ស្ដេចអេសា

*១៥:១៦–១៩ – ១ពវ ១៥:១៣–១៦*

**១៥** ១គ្រានោះ ព្រះវិញ្ញាណនៃព្រះក៏មកសណ្ឋិតលើ[ក]
អ័សារា ជាកូនអូដេឌ ២ហើយលោកចេញទៅទទួលអេសា
ទូលថា បពិត្រព្រះករុណា អេសា ព្រមទាំងពួកយូដា និង
ពួកបេនយ៉ាមីនទាំងអស់គ្នាអើយ សូមស្ដាប់ចុះ កំពុងដែល
អ្នករាល់គ្នា[ខ]នៅជាមួយនឹងព្រះយេហូវ៉ា នោះទ្រង់ក៏គង់ជា
មួយនឹងអ្នករាល់គ្នាដែរ[គ] បើអ្នករាល់គ្នាស្វែងរក[ឃ]ទ្រង់
នោះនឹងរកឃើញពិត តែបើអ្នករាល់គ្នាបោះបង់ចោល
ទ្រង់វិញ ទ្រង់ក៏នឹងបោះបង់ចោលអ្នករាល់គ្នាដែរ[ង] ៣រីឯ
នៅគ្រានោះ ពួកអ៊ីស្រាអែលឥតមាន ព្រះដ៏ជាពិតទេ ក៏គ្មាន
ពួកសង្ឃដែលបង្ហាត់បង្រៀន[ច] ហើយគ្មានក្រិត្យវិន័យដែរ[ឆ]
នៅអស់កាលជាយូរមកហើយ ៤តែកាលកើតមានសេចក្ដី
វេទនានោះ ហើយគេបានវិលមកឯព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែលវិញ ព្រមទាំងស្វែងរកទ្រង់ផង[ជ] នោះក៏
រកទ្រង់ឃើញ ៥នៅអស់ទាំងគ្រានោះ គ្មានសេចក្ដីសុខដល់
អ្នកណា ដែលចេញចូលទៅឯណាឡើយ[ឈ] គឺមានសុទ្ធតែ
សេចក្ដីប្រទុសរ៉ាយជាខ្លាំង ដល់អស់អ្នកនៅ ក្នុងស្រុកទាំង
នោះវិញ ៦គេត្រូវបាក់បែកខ្ទេចខ្ទីទៅ គឺនគរ១ទាស់នឹង

**១៤:១៤** ផ លប ៣៥:៥ ចទ ២:២៥ ១១:២៥
**១៥:១** ក ជន ១១:២៥,២៦
**១៥:២** ខ ២រប ២០:១៧ គ យក ៤:៨ ឃ ២រប ៧:១៤ ទដ ៧៨:៣៤ អស ៤៥:១៩ ៥៥:៦ យរ ២៩:១៣ ហស ៣:៥ ង ចទ ៣១:១៧ ១រប ២៨:៩
**១៥:៣** ច លវ ១០:១១ ឆ បទ ២:៩ អម ៨:១១
**១៥:៤** ជ ចទ ៤:២៩
**១៥:៥** ឈ ពច ៥:៦ ១៩:២០ សក ៨:១០
**១៥:៦** ញ អស ១៩:២ មថ ២៤:៧ មក ១៣:៨ លក ២១:១០
**១៥:៧** ដ យស ១:៧,៩ ឋ ១សយ ២៤:១៩ ទដ ១៨:២០ ៥៨:១១ សក ១៤:១៤ យរ ៣១:១៦
**១៥:៨** ឌ ១ពវ ១៥:១២ ឍ ២រប ១៧:២ ណ ១ពវ ៨:៦៤ ២រប ៨:១២
**១៥:៩** ត ២រប ១១:១៦–១៧

នគរ១ ហើយទីក្រុង១ទាស់នឹងទីក្រុង១ទៀត[ញ] ពីព្រោះព្រះ
ទ្រង់ធ្វើឱ្យមានសេចក្ដីប្រទុសរ៉ាយដល់គេ ដោយនូវសេចក្ដី
ទំនាស់គ្រប់យ៉ាង ៧តែឯអ្នករាល់គ្នា ចូរខំប្រឹងឡើង[ដ]
កុំឱ្យដៃថយកំឡាំងឡើយ ពីព្រោះការដែលអ្នករាល់គ្នាធ្វើ
នោះនឹងបានរង្វាន់[ឋ] ។
៨លុះកាលអេសាបានឮពាក្យទាំងនោះ គឺជាសេចក្ដី
ទំនាយរបស់ហោរាអូដេឌហើយ នោះទ្រង់មានព្រះទ័យ
ក្លាហានឡើង ក៏បំបាត់អស់ទាំងរបស់គួរស្អប់ខ្ពើម[ឌ] ពីក្នុង
ស្រុកយូដា និងស្រុកបេនយ៉ាមីនទាំងអស់ចេញ ហើយពីអស់
ទាំងទីក្រុងដែលទ្រង់ចាប់យកបាន[ឍ]នៅស្រុកភ្នំ អេប្រាអិម
ដែរ ទ្រង់ក៏រៀបអាសនា[ណ]នៃព្រះយេហូវ៉ា ដែលនៅមុខ
បាំងសាចព្រះវិហារនៃព្រះយេហូវ៉ាឡើងជាថ្មីវិញ ៩រួចទ្រង់
ប្រមូលពួកយូដា និងពួកបេនយ៉ាមីន ព្រមទាំងពួកអេប្រាអិម
ម៉ាន៉ាសេ និងស៊ីម្មាន ដែលនៅជាមួយទាំងប៉ុន្មានឱ្យមូលគ្នា
ដ្បិតមានពួកអ៊ីស្រាអែលជាច្រើន[ត] បានបាក់ចូលមកខាង
ទ្រង់ ដោយឃើញថា ព្រះយេហូវ៉ាជាព្រះ នៃទ្រង់គង់នៅជា
មួយនឹងទ្រង់ពិត ១០ដូច្នេះ គេក៏មូលគ្នាមកឯក្រុងយេរូសាឡិម
នៅខែជេស្ឋ[ថ]ឆ្នាំទី១៥ក្នុងរាជ្យអេសា ១១ហើយនៅថ្ងៃនោះ
ឯង គេថ្វាយយញ្ញបូជាដល់ព្រះយេហូវ៉ា ពីរបឹប[ទ]ដែលបាន
នាំយកមកគឺគោ៧រយនឹងចៀម៧ពាន់ ១២គេក៏ព្រមព្រៀងគ្នា
នឹងតាំងសេចក្ដីសញ្ញា[ធ] ឱ្យបានខំប្រឹងស្វែងរកតាមព្រះ
យេហូវ៉ា[ន] ជាព្រះនៃពួកឰយុកោគេ អស់ពីចិត្ត អស់ពីព្រលឹង
១៣ហើយថា អ្នកណាដែលមិនព្រមស្វែងរក ព្រះយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែល នោះនឹងត្រូវសំឡាប់បង់[ប]

**១៥:១០** ថ លវ ២៣:១៥–២១ **១៥:១១** ទ ២រប ១៤:១៣ **១៥:១២** ធ ២ពវ ១១:១៧ ន ១រប ១៦:១១ **១៥:១៣** ប នក ២:២០ ចទ ១៣:៩–១៦

**១៤:១៤** *សេចក្ដីស្ញែញខ្លាចរបស់ព្រះយេហូវ៉ា* មើលការពន្យល់ ១រប ១៤:១៧ ។

**១៥:១–១៩** ជំពូកនេះបង្ហាញឱ្យឃើញពីការរាយរ៉ាប់វគ្គក្នុងការសម្ដែងឡើងវិញដោយស្ដេចអេសា គឺភាពជោគជ័យទៅលើស្ដេចសេរ៉ាសនិងត្រូវបានលើកទឹកចិត្តដោយការអធិប្បាយរបស់(ខ.១) ។

**១៥:៣** *សង្ឃដែលបង្ហាត់បង្រៀន* កិច្ចការរបស់ពួកសង្ឃ គឺមិនគ្រាន់តែធ្វើជាអធិបតេយ្យនៅឯអាសនាប៉ុណ្ណោះទេ តែត្រូវមាននាទីជាគ្រូបង្រៀនក្រឹត្យវិន័យផងដែរ ។ (មើល ១៧:៧–៩,លវ ១០:១១ ចទ ១៧:៩–១១) ។

**១៥:៨** *ទីក្រុង ដែលទ្រង់ចាប់យកបាន នៅស្រុកភ្នំអេប្រាអិមដែរ* គឺក៏មានអ្នកចុះចូលជាមួយដែរ មានការច្បាំងគ្នារវាងបាសា និងអេសាក្នុងពេលដែលគ្រងរាជ្យនៃឆ្នាំទី ៣៦ របស់ស្ដេចអេសា(១៦:១) មើល ១៧:១ ។

**១៥:៩** *ប៉ុន្មានឱ្យមូលគ្នា . . . បានបាក់ចូលមកខាងទ្រង់* ប្រៀបធៀប ។ ជាការបោះបងពីភូមិភាគនៃនគរខាងជើង ដែលមកក្រោមការគ្រប់គ្រងរបស់ស្ដេចរេហូបោម (១១:១៣–១៧) ។

**១៥:១០** *នៅខែជេស្ឋ ឆ្នាំទី១៥ ក្នុងរាជ្យអេសា* គឺរដូវផ្ការីកនៅឆ្នាំ ៨៩៥ មុន គ.ស គឺជាឆ្នាំបន្ទាប់ពីការឈ្លានពានរបស់សេរ៉ាស(ខ.១៩) ។ បុណ្យបារាំង (ឬបុណ្យថ្ងៃទី៥០) គឺធ្វើឡើងក្នុងខែទី៣ (លវ ២៣:១៥–២១) និងក៏មានឱកាសសម្រាប់ការរួបរួមគ្នា ។

**១៥:១២** *តាំងសេចក្ដីសញ្ញា* គឺជាការតាំងជាថ្មីដែលធ្វើឡើងនៅ ឯភ្នំស៊ីណាយ គឺជាការស្រដៀងគ្នាទៅនិងការតាំងសញ្ញាជាថ្មី នៅឯស្រុកម៉ូអាប់(ចទ ២៩:១)ក្នុងភ្នំអេបាល(សយ ៨:៣០–៣៥)នាឯស្រុកស៊ីគែម(សស ២៤:២៥) និងនៅឯគីល្កាល(១សយ ១១:១៤ មើលការពន្យល់)ក្រោយមកទៀតសង្ឃយេហូយ៉ាដា(២៣:១៦)ក៏ដូចជាសង្ឃក្នុង(២៩:១០) (២៤:៣១) ។

**១៥:១៣** *មិនព្រមស្វែងរកព្រះយេហូវ៉ា* គេបែរជាងាកត្រឡប់ទៅរករូបព្រះផ្សេងៗដើម្បីថ្វាយបង្គំវិញ *នោះនិងត្រូវសំឡាប់បង់* គឺដោយផ្អែកទៅលើច្បាប់នៃសេចក្ដីសញ្ញាជាមូលដ្ឋាន (នក ២២:២០ ចទ ១៣:៦–៩) ។

ទោះតូចឬធំ ប្រុសឬស្រីក្តី ១៤គេក៏ស្បថដល់ព្រះយេហូវ៉ា
ដោយសំឡេងដ៏ខ្លាំង ហើយដោយស្រែកហ៊ោ ព្រមទាំងផ្លុំ
ត្រែ និងស្នែងផង ១៥ពួកយូដាទាំងអស់គ្នាមានសេចក្តីអំណរ
ដោយសេចក្តីសំបថនោះ ពីព្រោះ គេបានស្បថ ដោយចិត្ត
ស្មោះហើយស្វែងរកព្រះយេហូវ៉ា[ផ] ដោយពេញបំណងចិត្ត
ក៏រកទ្រង់ឃើញផង ព្រះយេហូវ៉ាទ្រង់ប្រទានឱ្យគេបាន
សេចក្តីស្រាកស្រាន្ត[ព] នៅព័ទ្ធជុំវិញ ។
១៦ឯនាងម្អាកា[ភ] ជាព្រះមាតាស្តេចអេសា ទ្រង់ក៏ដកពី
ដំណែង ជាមាតាហ្លួង[ម]ចេញ ដោយព្រោះព្រះនាងបានធ្វើ
រូបគួរស្អប់ខ្ពើមទុកជាព្រះ[យ] អេសាទ្រង់ក៏កាប់រំលំរូបនោះ
កិនកំទេចជាផង់ យកទៅដុតចោល នៅត្រង់ជ្រោះកេដ្រុន[រ]
១៧តែឯទីខ្ពស់ទាំងប៉ុន្មាន នោះមិនបានបំបាត់ចេញ ពីស្រុក
អ៊ីស្រាអែលទេ ប៉ុន្តែអេសាទ្រង់មានព្រះទ័យស្មោះទ្រង់អស់
១ព្រះជន្មទ្រង់ ១៨ទ្រង់ក៏នាំយកអស់ទាំងរបស់ដែលព្រះបិតា
ទ្រង់បានថ្វាយ និងរបស់ដែលអង្គទ្រង់បានថ្វាយផង មក
ដំកល់ទុក ក្នុងព្រះវិហារនៃព្រះ គឺប្រាក់មាស និងគ្រឿង
ប្រដាប់ផ្សេងៗ[ល] ១៩តពីនោះមកគ្មានចំបាំងទៀតឡើយ
ដរាប ដល់ឆ្នាំទីា៣៥ក្នុងរាជ្យអេសា ។

## ឆ្នាំចុងក្រោយរបស់ស្តេចអេសា

*១៦:១–៦ – ១ពាវ ១៥:១៧–២២*

*១៦:១១–១៧:១ – ១ពាវ ១៥:២៣–២៤*

**១៦** ១កាលដល់ឆ្នាំទី៣៦ ក្នុងរាជ្យអេសា នោះបាសា[ក] ជា
ស្តេចអ៊ីស្រាអែល ក៏ឡើងមកទាស់នឹងពួកយូដាទ្រង់សង់
ក្រុងរ៉ាម៉ា ដើម្បីឃាត់មិន ឱ្យអ្នកណាចេញចូលទៅឯអេសា
ជាស្តេចយូដាឡើយ ២ដូច្នេះ អេសា ទ្រង់យកប្រាក់នឹងមាស
ចេញពីឃ្លាំងរបស់ព្រះវិហារនៃព្រះយេហូវ៉ានឹង ពីក្នុងព្រះ
រាជដំណាក់ ផ្ញើទៅឯបេន–ហាដាឌ់ ជាស្តេចស្រុកស៊ីរី ដែល
នៅឯក្រុងដាម៉ាស[ខ] ដោយបន្ទូលថា ៣ទូលបង្គំនឹងទ្រង់បាន
ចុះសញ្ញានឹងគ្នាហើយ[គ]ដូចជាបិតាទូលបង្គំ និងព្រះបិតានៃ
ទ្រង់ដែរ ឥឡូវនេះ មើល ទូលបង្គំផ្ញើប្រាក់នឹងមាសមក
ថ្វាយទ្រង់ សូមឱ្យទ្រង់ទៅផ្តាច់សញ្ញាដែលទ្រង់បានតាំង
នឹងបាសាជាស្តេចពួកអ៊ីស្រាអែលចេញ ដើម្បី ឱ្យគេថយ
ចេញពីទូលបង្គំទៅ ៤បេន–ហាដាឌ់ក៏ស្តាប់តាមស្តេចអេសា
ទ្រង់ចាត់ពួកមេលើពលទ័ពរបស់ទ្រង់ ឱ្យទៅច្បាំងនឹងអស់
ទាំងទីក្រុង នៃពួកអ៊ីស្រាអែល គេក៏វាយក្រុងអ៊ីយ៉ូន ក្រុង
ដាន់ និងក្រុងអេបិល–ម៉ែម ព្រមទាំងទីក្រុងដែលសំរាប់
ជាឃ្លាំងទាំងប៉ុន្មាន នៅក្នុងស្រុកណែមថាលីផង[ឃ] ៥លុះ
កាលបាសាឮហើយ នោះទ្រង់ក៏លែងសង់ក្រុងរ៉ាម៉ា ឈប់
ចោលការទាំងនោះទៅ ៦រួចស្តេចអេសាទ្រង់នាំពួកយូដា
ទាំងអស់ចេញទៅ យកថ្មនឹងឈើទាំងប៉ុន្មានពីរ៉ាម៉ា ដែល
បាសាកំពុង តែសង់ទីក្រុងនោះទៅសង់ក្រុងកេបា និង
មីសប៉ាវិញ[ង] ។
៧នៅវេលានោះ ហាណានី[ច] ជាអ្នកមើលឆុត លោកមក
ឯអេសា ជាស្តេចយូដាទូលថា ដោយព្រោះទ្រង់បានពឹង[ឆ]
ដល់ស្តេចស៊ីរី មិនបាន ពឹងដល់ព្រះយេហូវ៉ា ជាព្រះនៃទ្រង់
នោះពួកពលទ័ពរបស់ស្តេចស៊ីរី បានរួចពីកណ្តាប់ព្រះ
ហស្តទ្រង់ហើយ ៨ឯពួកសាសន៍អេធីអូពី[ជ] និងពួកលីប៊ី តើគេ
មិនមែនជាពួកពលយ៉ាងធំ មានទាំងរទេះចំបាំង និងពល
សេះសន្ធឹក[ឈ]ទេឬអី ប៉ុន្តែដោយព្រោះទ្រង់បានពឹងដល់ព្រះ
យេហូវ៉ា បានជាព្រះទ្រង់ប្រគល់[ញ]គេមកក្នុងកណ្តាប់ព្រះ
ហស្តព្រះករុណាវិញ ៩ដ្បិតព្រះនេត្រ[ដ]នៃព្រះយេហូវ៉ាចេះ
តែទតច្រវាត់ នៅគ្រប់លើផែនដីទាំងមូល ដើម្បីនឹងសំដែង
ព្រះចេស្តា ជួយដល់អស់អ្នកណាដែលមាន ចិត្តស្មោះត្រង់
ចំពោះទ្រង់ ព្រះករុណាបានប្រព្រឹត្តបែបឆោតល្ងង់[ឋ] ហើយ

១១:១៦–១៧
**១៥:១៥** ផ ចទ ៤:២៩ ព ១របា ២២:៩
**១៥:១៦** ភ ២របា ១៣:២ ម ១ពាវ ២:១៩ យ នក ៣៤:១៣ រ ២សយ ១៥:២៣
**១៥:១៨** ល ២របា ១៤:១៣
**១៦:១** ក ២ពាវ ៩:៩ យរ ៤១:៩
**១៦:២** ខ ២របា ១៩:១–២០:៣៧ ២២:១–៩
**១៦:៣** គ ២របា ២០:៣៥ ២៥:៧
**១៦:៤** ឃ ២ពាវ ១៥:២៩
**១៦:៦** ង យរ ៤១:៩
**១៦:៧** ច ១ពាវ ១៦:១ ឆ ២របា ១៣:១៨
**១៦:៨** ជ លប ១០:៦,៨–៩ ២របា ១២:៣ ឈ ២របា ២៤:២៤ ញ ២របា ១៣:១៦
**១៦:៩** ដ យប ២៤:២៣ ទដ ៣៣:១៣–១៥ សភ ១៥:៣ យរ ១៦:១៧ សក ៣:៩ ៤:១០ ឋ ១សយ

**១៥:១៥** *ស្រាកស្រាន្ត* មើលការពន្យល់ ២០:៣០ ។

**១៥:១៦** *រូបដ៏ស្អប់ខ្ពើម* មើលការពន្យល់ ១៤:៣ *ជ្រោះកេដ្រុន* គឺនៅត្រង់ខាងកើតនៃក្រុងយេរូសាឡិម (មើលការពន្យល់ អស ២២:៧ ក៏មើល ១ពាវ ១៥:១៣ និងការពន្យល់) ។

**១៥:១៧** *តែឯទីខ្ពស់ទាំងប៉ុន្មាននោះមិនបានបំបាតចេញ* មើល ១៤:១៥ និងការពន្យល់ ។

**១៦:១** *ដល់ឆ្នាំទី៣៦ក្នុងរាជ្យអេសានោះបាសា* យោងតាមគម្ពីរពង្សាវតារក្សត្រ គឺស្តេចបាសាបានដឹកនាំគ្រប់គ្រងអស់រយៈពេល១៤ឆ្នាំ ក៏មានស្តេចអេសាដ៏មានកម្លាំងអាចសោយរាជ្យបាន ក្នុងពេលដែលស្តេចអេសាសោយរាជ្យបាន២៦ឆ្នាំ (១ពាវ ១៥:៣៣ ១៦:៨) តែស្តេចបាសា ក៏ពុំអាចរស់បានក្នុងរជ្ជកាលទី៣៦ នៃស្តេចអេសា ។ អត្ថបទក៏បញ្ជាក់ថាស្តេច អង្គនេះបានស្លាប់អស់រយៈពេលមួយទសវត្សរ៍មកហើយ ។ ការពណ៌នានៅទីនេះពុំបានកំណត់ពីកាលបរិច្ឆេទទេក្នុង ១ពាវ ១៥:១៧ ។ ប្រហែលវាក៏ជាលទ្ធផលមួយពីការកត់ត្រាខុសផងដែរ ។

**១៦:២–៩** ការជួលកងទ័ពបរទេសចូលមក ឯស្តេចអេសាដែលជាសម្ព័ន្ធភាពពីបរទេស គឺជាការបង្ហាញពីការបាត់បង់សេចក្តីពិត ក្នុងព្រះអម្ចាស់ជាព្រះយេហូវ៉ានៃយើង ។ ក៏មានគំរូមួយពីកងទ័ពបរទេសដែលបានកាត់ទោសយើងក្នុងរជ្ជកាលនៃស្តេចយ៉ូសាផាត ជាព្រះរាជបុត្រាអេសា (២០:៣៥–៣៧) (២២:១–៩) អ័ហាស៊ីយ៉ា (២០:១០) និង (២៨:១៦–២១) ។ គេបានជួយបឺនហាដា ទៅផ្នែកខាងជើងហើយស្តេចអេសា បានបើកច្រកផ្លូវខាងមុខពីសម្រាប់បាសា និងដើម្បីឱ្យគេដកទ័ពចេញ ។

**១៦:៣** *ចុះសញ្ញានឹងគ្នា ដូចជាបិតាទូលបង្គំ នឹងព្រះវបិតានៃទ្រង់ដែរ* ។

**១៦:៩** *ព្រះនេត្រនៃព្រះយេហូវ៉ាចេះតែទតច្រវាត់* សក ៤:១០ ។

ដ្បិតពីនេះទៅមុខ និងចេះតែមានចំបាំងជានិច្ច[ឌ] ១០នោះ
អេសាមានសេចក្តីក្រេវក្រោធនឹងអ្នកមើលឆុត យើងទ្រង់
ចាប់ដាក់គុក[ឍ] ពីព្រោះ ទ្រង់មានសេចក្តីឃោរឃៅជាខ្លាំង
ដោយព្រោះដំណើរនោះ នៅគ្រានោះ អេសាក៏សង្កត់
សង្កិនរាស្ត្រខ្លះដែរ ។
១១ហើយមើលដំណើរទាំងប៉ុន្មានពីអេសា ទាំងមុនទាំង
ក្រោយ នោះបានកត់ទុកក្នុងសៀវភៅ ដែលថ្លែងពីពួក
ស្តេចយូដា និងអ៊ីស្រាអែលហើយ ១២រីឯក្នុងឆ្នាំទី៣៩នៃ
រាជ្យអេសា នោះទ្រង់ចាប់ប្រឈួន[ណ] ត្រង់ព្រះបាទមាន
អាការៈដ៏ធ្ងន់ ប៉ុន្តែក្នុងការប្រឈួននោះ ទ្រង់មិនបានស្វែង
រក[ត]ព្រះយេហូវ៉ាទេ[ថ] គឺបានរកពឹងដល់ពួកគ្រូពេទ្យវិញ
១៣អេសាក៏ផ្ទិលក់ទៅ ជាមួយនឹងពួកព្ធយុកោទ្រង់ទៅ គឺបាន
សុគតនៅឆ្នាំទី៤១ ក្នុងរាជ្យរបស់ទ្រង់ ១៤គេបញ្ចុះសពនៅ
ក្នុងផ្នូររបស់ទ្រង់ ដែលបានដាប់ទុកសំរាប់ទ្រង់[ទ]នៅក្នុង
ក្រុងដាវីឌ ក៏ដំកល់សពនៅទីដែលបានអប់ ហើយមានពេញ
ដោយគ្រឿងក្រអូបផ្សេងៗ [ធ]ដែលពួកផ្សំគ្រឿងក្រអូបបាន
ធ្វើតាមវិជ្ជារបស់គេ ហើយគេថ្វាយព្រះភ្លើង[ន]ដល់ទ្រង់ ជា
ការយ៉ាងធំ ។

## យ៉ូសាផាតឡើងជាស្តេចស្រុកយូដា

**១៧** ១រួចយ៉ូសាផាត ជាព្រះរាជបុត្រា ឡើងសោយរាជ្យ
ជំនួសព្រះបិតា ទ្រង់ក៏ចំរើនកំឡាំង[ក]ឡើង ទាស់នឹងពួក
អ៊ីស្រាអែល ២ទ្រង់ដាក់ឱ្យមានពលទ័ព ក្នុងគ្រប់ទាំងក្រុង
មានបន្ទាយ[ខ]របស់ពួកយូដា ហើយក៏ដាក់ឱ្យមានក្រុមរក្សា
នៅស្រុកយូដា និងក្នុងទីក្រុងទាំងប៉ុន្មានរបស់ពួក អេប្រាអិម
ជាទីក្រុងដែលអេសាព្រះបិតាទ្រង់ចាប់យកបានដែរ[គ] ៣ព្រះ
យេហូវ៉ាទ្រង់ក៏គង់នៅជាមួយនឹងយ៉ូសាផាត ពីព្រោះស្តេច
បានប្រព្រឹត្ត តាមអស់ទាំងផ្លូវដើមរបស់ដាវីឌ[ឃ] ជាព្ធយុកោ
ទ្រង់ ឥតរកតាមព្រះបាលឡើយ ៤គឺបានស្វែងរក[ង]តាមតែ
ព្រះនៃពួកព្ធយុកោទ្រង់ ហើយប្រព្រឹត្តតាមបញ្ញត្តទ្រង់វិញ
ឥតធ្វើតាមអំពើរបស់សាសន៍អ៊ីស្រាអែលឡើយ ៥ហេតុ
នោះបានជាព្រះយេហូវ៉ាទ្រង់តាំងរាជ្យ ឱ្យមាំមួនក្នុង
អំណាចយ៉ូសាផាត ហើយពួកយូដាទាំងអស់គ្នាក៏នាំយក
គ្រឿងបណ្ណាការ[ច]មកថ្វាយស្តេច ទ្រង់មានព្រះរាជ្យទ្រព្យ
និងកិត្តិយសជាបរិបូរ[ឆ] ៦ព្រះទ័យទ្រង់បានតាំងឡើង[ជ] ក្នុង
អស់ទាំងផ្លូវនៃព្រះយេហូវ៉ាមួយទៀត ទ្រង់ក៏បំបាត់អស់
ទាំងទីខ្ពស់[ឈ] និងរូបព្រះ[ញ]ចេញពីស្រុកយូដាទៅ [ដ] ។
៧នៅឆ្នាំទី៣ ក្នុងរាជ្យទ្រង់ នោះទ្រង់ចាត់ពួកអ្នកដែលជា
ប្រធានរបស់ទ្រង់ គឺបេន-ហែល នឹងអូបាឌាសាការី
នេថានេល ហើយមីកាយ៉ា ឱ្យទៅបង្ហាត់បង្រៀន[ឋ]ក្នុងអស់
ទាំងទីក្រុងនៅស្រុកយូដា ៨ព្រមទាំងពួកលេវី[ឌ]ឱ្យទៅជា
មួយដែរ គឺសេម៉ាយ៉ា នេថានា សេបាឌា អេសាអែល
សេមីរ៉ាម៉ូត យ៉ូណាថាន អ័ដូនីយ៉ា ថូប៊ីយ៉ា និងថូប-
អ័ដូនីយ៉ា ដែលសុទ្ធតែពួកលេវី និងអេលីសាម៉ា ហើយ
យ៉ូរ៉ាម ជាពួកសង្ឃ ឱ្យទៅជាមួយនឹងគេ ៩ពួកអ្នកទាំងនោះ

១៣:១៣ ឌ ១ពវ ១៥:៦ ២រប ១៩:២ ២៥:៧ ២៨:១៦-២១ **១៦:១០** ឍ ១ពវ ២២:២៧ **១៦:១២** ណ ២រប ២១:១៨ ២៦:១៩ ទដ ១០៣:៣ ត ២រប ៧:១៤ ថ យរ ១៧:៥-៦ **១៦:១៤** ទ លប ៥០:៥ ធ លប ៥០:២ ន ២រប ២១:១៩ យរ ៣៤:៥ **១៧:១** ក ១ពវ ២:១២ **១៧:២** ខ ២រប ១១:១០ គ ២រប ១៥:៨ **១៧:៣** ឃ ១ពវ ២២:៤៣ **១៧:៤** ង ២រប ២២:៩ **១៧:៥** ច ១សយ ១០:២៧ ឆ ២រប ១៨:១ **១៧:៦** ជ ១ពវ ៨:៦១ ឈ ១ពវ ១៥:១៤ ២រប ១៩:៣ ២០:៣៣ ញ នក ៣៤:១៣ ដ ២រប ២១:១២ **១៧:៧** ឋ លវ ១០:១១ ចទ ៦:៤-៩ ២រប ១៩:៤-១១ ៣៥:៣ នហ ៨:៧ មឡ ២:៧ **១៧:៨** ឌ ២រប ១៩:៨ នហ ៨:៧-៨ ហស ៤:៦ **១៧:៩** ឍ ចទ ២៨:៦១

**១៦:១១** *ក្នុងសៀវភៅ ដែលថ្លែងពីពួកស្តេចយូដា នឹងអ៊ីស្រាអែលហើយ* មើលសេចក្តីផ្តើម នៅក្នុង ១រប អ្នកនិពន្ធកាលបរិច្ឆេទ ។

**១៦:១២** *ប្រឈួនត្រង់ព្រះបាទ* សម្រាប់ជាឧទាហរណ៍នៃជម្ងឺដែលទ្រង់មានក៏ដូចជាការកាត់ទោសនៃអំពើបាប មើល ២១:១៦-២០ ២៦:១៦-២៣ ចទ ១២:២៣ ប្រៀបធៀប ២ពវ ១៥:៥ *ទ្រង់មិនបានស្វែងរកព្រះយេហូវ៉ាទេ គឺបានរកពឹងពួកគ្រូពេទ្យវិញ* គឺមានភាពផ្ទុយនិងស្តេចអ័ហាស៊ីយ៉ា (អេសាយ ៣៨) ប្រៀបធៀប យរ ១៧:៥-៨ យក ៥:១៤-១៦ ។

**១៧:១-២១:៣** កិច្ចការរបស់អ្នកកាលប្រវត្តិស្តីពីការគ្រងរាជ្យ គឺមានរយៈពេលលើសការដែលបានបញ្ជាក់ក្នុងគម្ពីរ ពង្សាវតារក្សត្រ ពីរដងឯណោះ គឺជាការគួឱ្យចាប់អារម្មណ៍ទៅលើអ័ហាប់ និងអេលីយ៉ាដែលលប់លើទីតាំងខ្លះនៃចំណែករបស់ស្តេចយ៉ូសាផាត (១ពវ ២២:១-៤៦) ។ អ្នកកាលប្រវត្តិក៏បានប្រើរឿងរ៉ាវនៃការគ្រងរាជ្យរបស់ស្តេចយ៉ូសាផាត ដើម្បីបញ្ចាំងពីការកាត់ទោសសំខាន់ជាបន្ទាន់ ផ្ទៃរឿងនេះគឺបានបញ្ជាក់ក្នុង ១៩:១០ ក៏បញ្ជាក់ពីព្រះពរដែលបានទទួលតាមរយៈ សេចក្តីជំនឿដោយការស្តាប់បង្គាប់របស់ស្តេចយ៉ូសាផាត ក៏ប្រាប់ពីការប្រព្រឹត្តខុសឆ្គងរបស់ស្តេចនោះដែរ (១៩:២-៣ ២០:៣៥-៣៧) ស្តេចយ៉ូសាផាតបានសោយរាជ្យ គឺចាប់ពីឆ្នាំ៨៧២រហូត ៨៦៩ គឺមានលក្ខណៈដូចឪពុករបស់គាត់ គឺជាស្តេចអេសា (មើល ២០:៣) និងការពន្យល់ ។ ការគ្រប់គ្រងរាជ្យរបស់ទ្រង់ដូចជាគ្មានលក្ខណៈទៅតាមលំដាប់លំដោយនៃរបាក្សត្រ ។

**១៧:២** *ក្នុងក្រុងមានបន្ទាយរបស់ពួកយូដា . . . ពួកអេប្រាអិម* មើលការពន្យល់ (១០:៨) អ័ប៊ីយ៉ា (១៣:១៩) អេសានិងយ៉ូសាផាត បានព្យាយាមគ្រប់គ្រងទីក្រុងទាំងនោះហើយបាតបង់ទៅវិញ ក្រោមការដឹកនាំរបស់អ័ម៉ាស៊ីយ៉ា (២៥:១៧-២៤) ។

**១៧:៦** *បំបាត់អស់ទាំងទីខ្ពស់* ក៏ដូចជាព្រះបិតារបស់ទ្រង់ដែរ គឺស្តេចអេសា (២០:៣៣ ប្រៀបធៀប ១ពវ ២២:៤៣) តែមើលការពន្យល់ ១ពវ ៣:២ ១៥:១៤ *រូបព្រះចេញ* មើលការពន្យល់ ១៤:៣ ។

**១៧:៧-៩** ហេតុការយើងបានឃើញជាលក្ខណៈលំអិតក្នុង ១៩:៤-១១ ។ ក្នុងទេវធិតេយ្យ គឺច្បាប់ជាក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ដោយមានការអស់ទាំងនេះក្រឹត្យវិន័យដែលជាច្បាប់ នៃព្រះយេហូវ៉ានៅឯស្រុក ដែលជារបស់ទ្រង់ក៏ដូចជាមានពួកសង្ឃនិងហោរាគឺជាតំណាងដល់ភាពជាស្តេចរបស់ព្រះយេហូវ៉ាពីលើរាស្ត្ររបស់ទ្រង់ ។

**១៧:៧** *នៅឆ្នាំទី៣* ប្រហែលជាឆ្នាំដំបូងនៃរជ្ជកាលទ្រង់តែមួយប៉ុណ្ណោះ (មើល ២០:៣១ និងការពន្យល់) ។

**១៧:៩** *ក្រឹត្យវិន័យនៃព្រះយេហូវ៉ា* មើល ២៤:១៤-១៥ យស ៨:៣១ ២៣:៦

ក៏បង្ហាត់បង្រៀននៅស្រុកយូដា មានទាំងគម្ពីរក្រិត្យវិន័យ[ឈ]
នៃព្រះយេហូវ៉ានៅជាមួយផង គេនាំគ្នាដើរចុះឡើង ដល់
គ្រប់ទីក្រុងនៅស្រុកយូដា បង្រៀនដល់បណ្តាជន ។
១០ សេចក្តីស្ញែងខ្លាច[ញ]របស់ព្រះយេហូវ៉ា ក៏មកគ្របសង្កត់
លើអស់ទាំងនគរ នៅជុំវិញស្រុកយូដា ហើយគេមិនហ៊ាន
លើកគ្នាមកច្បាំងនឹងយ៉ូសាផាតទេ ១១ មានពួកភីលីស្ទីនខ្លះ
នាំយកគ្រឿង បណ្ណាការមកថ្វាយយ៉ូសាផាតព្រមទាំងប្រាក់
ទុកជាសួយអាករផង ឯពួកអារ៉ាប់[ដ] គេក៏នាំយកហ្វូងសត្វ[ឋ]
មកថ្វាយដែរ គឺចៀមឈ្មោល៧ពាន់ ៧រយនឹងពពែឈ្មោល
៦ពាន់៧រយ ១២ យ៉ូសាផាតទ្រង់បានចំរើនឡើង ជាធំក្រៃ
លែង ទ្រង់ក៏សង់ដំណាក់ និងទីក្រុងសំរាប់ជាឃ្លាំងទាំង
ប៉ុន្មាន នៅស្រុកយូដា ១៣ ទ្រង់មានក្រសួងងារការជាច្រើន
នៅក្នុងទីក្រុងស្រុកយូដាទាំងប៉ុន្មាន ហើយមានមនុស្សថ្មីក
ចំបាំង និងមនុស្សខ្លាំងពូកែ ដែលមានចិត្តក្លាហាននៅក្រុង
យេរូសាឡិម ១៤ តាមជិន្នូរវង្សរបស់ឪពុកគេ នោះមាន
ចំនួន[ទ]ដូចខាងក្រោមនេះ គឺខាងពួកយូដា ក្នុងពួកមេទ័ពធំ
មានអ័ឌណា ជាមេនៅក្រោម បង្គាប់លោកមានមនុស្ស
ខ្លាំងពូកែ ដែលមានចិត្តក្លាហាន៣សែននាក់ ១៥ បន្ទាប់មក
មានយ៉ូហាណានជាមេ នៅក្រោមបង្គាប់លោកមាន២សែន
៨ម៉ឺននាក់ ១៦ បន្ទាប់មកទៀត មានអ័ម៉ាស៊ីយ៉ា ជាកូនស៊ីកគ្រី
ដែលបានថ្វាយខ្លួនដល់ព្រះយេហូវ៉ាស្ម័គ្រពីចិត្ត[ធ] ហើយ
ក្រោមបង្គាប់លោកមានមនុស្សខ្លាំងពូកែ ដែលមានចិត្ត
ក្លាហានចំនួន២សែននាក់ ១៧ ខាងពួកបេនយ៉ាមីន[ន] មាន
អេលីយ៉ា ជាមនុស្សខ្លាំងពូកែមានចិត្តក្លាហាន ហើយក្រោម
បង្គាប់លោកមានមនុស្សកាន់ធ្នូ និងខែល២សែននាក់

**១៧:១០** ណ លប ៣៥:៥ ចទ ២:២៥
**១៧:១១** ត ២រប ៩:១៤ ថ ២រប ២១:១៦
**១៧:១៤** ទ ២សយ ២៤:២
**១៧:១៦** ធ ពច ៥:៩
**១៧:១៧** ន ជន ១:៣៦
**១៧:១៨** ប ២រប ១១:១០ ផ ២រប ២៥:៥
**១៨:១** ក ២រប ១៧:៥ ខ ២រប ១៩:១–៣ ២២:៣ គ ២រប ២១:៦

១៨ បន្ទាប់មកមានយ៉ូសាបាឌ ហើយក្រោមបង្គាប់លោកមាន
មនុស្ស១សែន៨ម៉ឺននាក់ ដែលចាំទទួលបំរើស្តេច ពួកទាំង
នេះក៏លើកពីពួកដែលស្តេចបានដាក់ឱ្យ នៅអស់ទាំងទីក្រុង
មានបន្ទាយពេញ[ប]ក្នុងអាណាខែត្រយូដា[ផ] ។

## ហោរាមីកាយ៉ាថ្លែងទំនាយទាស់នឹងស្តេចអ័ហាប់

*១៨:១–២៧ – ១ពវ ២២:១–២៨*

**១៨** ១ រីឯយ៉ូសាផាត ទ្រង់មានទ្រព្យសម្បត្តិ និងកិត្តិយ[ក]
ជាបរិបូរ ហើយទ្រង់ក៏ភ្ជាប់ពន្ធ[ខ]នឹងអ័ហាប់[គ] ២ លុះក្រោយ
មកពីរបីឆ្នាំ នោះទ្រង់យាងចុះ ទៅឯអ័ហាប់ នៅក្រុង
សាម៉ារី ឯអ័ហាប់ក៏សំឡាប់ចៀមនឹងគោជាបរិបូរ ជប់
លៀងទ្រង់ និងពួកអ្នកដែលតាមទ្រង់ទៅផង ៣ អ័ហាប់ជា
ស្តេចអ៊ីស្រាអែល ទ្រង់ទូលនឹងយ៉ូសាផាត ជស្តេចយូដាថា
តើទ្រង់ចង់ទៅឯក្រុងរ៉ាម៉ូត–កាឡាត ជាមួយនឹងទូលបង្គំ
ឬទេ នោះទ្រង់ទូលឆ្លើយថា ទូលបង្គំក៏ដូចជាទ្រង់ ហើយ
រាស្ត្ររបស់ទូលបង្គំ ក៏ដូចជារាស្ត្ររបស់ទ្រង់ដែរ យើង
រាល់គ្នានឹងនៅជាមួយនឹងទ្រង់ ក្នុងចំបាំងនេះ ។
៤ តែយ៉ូសាផាតទូលដល់ស្តេចអ៊ីស្រាអែលថា សូមទ្រង់
ទូលសួរ ព្រះបន្ទូលនៃព្រះយេហូវ៉ាជាមុនសិន ៥ ដូច្នេះស្តេច
អ៊ីស្រាអែលក៏ប្រមូលពួកហោរា បាន៤០០នាក់ មកសួរគេថា
តើត្រូវឱ្យយើងចេញទៅច្បាំង និងក្រុងរ៉ាម៉ូត–កាឡាត ឬ
ឈប់ខាន គេទូលឆ្លើយថា សូមយាងឡើងទៅចុះ ដ្បិតព្រះ
ទ្រង់នឹងប្រគល់គេមកក្នុងកណ្តាប់ព្រះហស្តនៃព្រះ ករុណា
ហើយ ៦ តែយ៉ូសាផាតសួរថា នៅទីនេះតើគ្មានហោរាណា
ម្នាក់របស់ព្រះយេហូវ៉ា ល្មមឱ្យយើងសួរពីគាត់ដែរទេឬអី
៧ ស្តេចអ៊ីស្រាអែលទូលឆ្លើយថា មានម្នាក់ទៀត ដែលល្មម

ក៏សូមមើលការពន្យល់ យស ១:៨ ២ពវ ២២:៨ នហ ៨:១ ។

**១៧:១០–១១** មើលការពន្យល់ ១រប ១៨:១–២០:៨ ។

**១៧:១៤–១៨** ៣00,000 . . . ២៨0,000 . . . ២00,000 . . . ២00,00 . . . ១៨0,000 មើលការបន្យល់ ១រប ១២:២៣–៣៧ ២៧:១ ។

**១៨:១–១៩:៣** មើល ១ពវ ២២:១–៤0 និងការពន្យល់ ។ ក្នុងសេចក្តីពិតទៅលើការចាប់អារម្មណ៍ ក្នុងនគរខាត្បូងនិងយ៉ូសាផាតអ្នកកាលប្រវត្តិបានលប់បំបាត់ចោលនូវ ពត៌មានពីការសុគតរបស់ស្តេច អ័ហាប់និងអ្នកដែលជាស្តេចស្នងរាជ្យរបស់ទ្រង់ (១ពវ ២២:៣៦–៤0) តែបានបន្ថែមឯកសារស្តីពីការកាត់ទោស ដែលជាទំនាយតម្រូវមកនៃការចូលរួមរបស់ យ៉ូសាផាត (១៩:១–៣) ។

**១៨:១** មិនបានជួបប្រទះក្នុង ១ពវ ២២ ។ ខនេះបង្ហាញពីភាពរុងរឿងរបស់ស្តេចយ៉ូសាផាតដោយការបង្ហាញពីព្រះពរ ដែលបានទទួលដូចជាទ្រព្យធនចំពោះភាពភក្តីរបស់គាត់ ក៏បង្ហាញពីផ្នែកខ្លះពីការកាត់ទោស ដល់ពួកបរទេសដោយហោរាមើលក្នុង ១៩:២–៣ ។ *ហើយទ្រង់ក៏ភ្ជាប់ពន្ធ នឹងអ័ហាប់* ពិធីភ្ជាប់ពន្ធគឺជាទំនាក់ទំនងសម្ព័ន្ធភាពនិងអ័ថាលា គឺជាកូនស្រីរបស់អ័ហាប់លទ្ធផលចុងក្រោយក៏ព្យាយាមបំផ្លាញដល់ខ្សែដាវីឌ (សូមមើល ២២:១0–២៣:២១) ។

**១៨:២** អ្នកកាលប្រវត្តិ បានបន្តទៀតថាស្ថានភាពរបស់ស្តេចយ៉ូសាផាតដោយការកត់ចំណាំនូវចំនួនយ៉ាងច្រើន នឹងចំនួនសត្វដែលស្តេចអ័ហាប់បានសម្លាប់ ។ អ្នកកាលប្រវត្តិក៏បានលប់បំបាត់ សេចក្តីទាក់ទងនិងការស្លាប់ឬសុគតរបស់ស្តេចអ័ហាប់ គឺក្នុងភាពដ៏ឧត្តមរបស់ទ្រង់គឺកំណត់ហេតុនេះក៏ពុំបានជួបប្រទះក្នុង ១ពវ ២២ ទេ ។ *ក៏បបួលទ្រង់* ឃើញក្នុងអត្ថបទប្រៀបប្រដូច ។ បើជាភាសារហេព្រើរពាក្យនេះប្រើក្នុងន័យជា "ការញុះញង់មើដ្បីធ្វើការអាក្រក់ណាមួយ" (មើល ១រប ២១:១) ក៏អាចបញ្ជាក់អំពីលក្ខណៈរបស់អ្នកកាលប្រវត្តិ ឆ្ពោះទៅរកការរួមចំណែកគាំទ្រនូវស្តេច យ៉ូសាផាត *ក្រុងរ៉ាម៉ូត–កាឡាត* មើលការពន្យល់ ២២:៥ ១ពវ ២២:៣ ។

**១៨:៤** *សួរព្រះបន្ទូលនៃព្រះយេហូវ៉ាជាមុនសិន* សេចក្តីស្នើរសុំនេះត្រូវគ្នានិងរូបទ្រង់ទ្រាយរបស់ស្តេចយ៉ូសាផាត ។

ឱ្យយើងទូលសួរដល់ព្រះយេហូវ៉ាបានដែរ គឺមីកាយ៉ា ជា
កូនយីមឡា តែទូលបង្គំស្អប់វា ដ្បិតវាមិនដែលទាយល្អពី
ទូលបង្គំសោះ គឺចេះតែទាយអាក្រក់ជាដរាបវិញ យ៉ូសាផាត
ទូលថា សូមទ្រង់កុំមានបន្ទូលដូច្នេះឡើយ ៨នោះស្ដេច
អ៊ីស្រាអែលទ្រង់ហៅមហាតលិកម្នាក់មកបង្គាប់ថា ចូរទៅ
នាំមីកាយ៉ា ជាកូនយីមឡាមកជាឆាប់ៗ ៩ឯស្ដេចអ៊ីស្រាអែល
នឹងយ៉ូសាផាត ជាស្ដេចយូដា ទ្រង់ព្រះពស្ដ្ររាជ្យគង់លើ
បល្ល័ង្ករៀងអង្គ ត្រង់ទីធ្លានៅទ្វារក្រុងសាម៉ារី ហើយពួក
ហោរាក៏ឈរទាយ នៅចំពោះទ្រង់ ១០ឯសេដេគា ជាកូនក្នា
ណា គាត់បានធ្វើស្នែងដែក ហើយក៏ទូលថា ព្រះយេហូវ៉ា
ទ្រង់មានបន្ទូល ដូច្នេះ ព្រះករុណានឹងជល់ពួកស៊ីរី ដោយ
ស្នែងនេះ ដរាបដល់គេវិនាសសូន្យទៅ ១១ហើយពួកហោរា
ទាំងអស់ ក៏ទាយដូច្នោះដែរថា សូមយាងឡើងទៅឯរ៉ាម៉ូត
–កាឡាត[ឃ] ហើយមានជ័យជំនះចុះ ដ្បិតព្រះយេហូវ៉ាទ្រង់
នឹងប្រគល់ក្រុងនោះមកក្នុងកណ្ដាប់ ព្រះហស្តនៃព្រះ
ករុណាហើយ ។

១២រីឯអ្នកដែលទៅហៅមីកាយ៉ាមក ក៏ប្រាប់គាត់ថា
មើលពួកហោរាទាំងអស់សុទ្ធតែទាយល្អ ដល់ស្ដេចព្រមគ្នា
ដូច្នេះ សូមឱ្យពាក្យ លោកបានដូចជាពាក្យរបស់ហោរា
ទាំងនោះ ដោយពោលតែសេចក្ដីល្អដែរ ១៣តែមីកាយ៉ា
ឆ្លើយថា ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់ថា
សេចក្ដីណាដែលព្រះនៃខ្ញុំទ្រង់មានបន្ទូលមក នោះខ្ញុំនឹង
បញ្ចេញតាមសេចក្ដីនោះឯង[ង] ១៤រួចកាលបានចូលទៅ
គាល់ស្ដេច ហើយនោះទ្រង់មានបន្ទូលសួរថា មីកាយ៉ាអើយ
តើត្រូវឱ្យយើងទៅច្បាំងនឹងរ៉ាម៉ូត–កាឡាត ឬឈប់ខាន
គាត់ទូលឡកថា សូមយាងទៅ ហើយមានជ័យជំនះចុះ ដ្បិត
ព្រះនឹងប្រគល់គេមក ក្នុងកណ្ដាប់ព្រះហស្តនៃព្រះករុណា
ហើយ ១៥រួចស្ដេចទ្រង់មានបន្ទូលថា អញបាន ស្ដីឯងប៉ុន្មាន
ដងហើយ ឱ្យបាននិយាយតែសេចក្ដីពិតប៉ុណ្ណោះ ដោយ
នូវព្រះនាមព្រះយេហូវ៉ា ១៦គាត់ទូលឆ្លើយថា ទូលបង្គំបាន
ឃើញពួកអ៊ីស្រាអែល[ច]ខ្ចាត់ខ្ចាយទៅ នៅលើភ្នំប្រៀបដូច
ជាហ្វូងចៀម ដែលគ្មានអ្នកគង្វាល[ឆ] ហើយព្រះយេហូវ៉ា
បានមានបន្ទូលថា ពួកទាំងនេះគ្មានចៅហ្វាយទេ ចូរឱ្យគេ
ត្រឡប់ទៅឯផ្ទះរៀងខ្លួនវិញ ដោយសេចក្ដីសុខចុះ ១៧ដូច្នេះ
ស្ដេចអ៊ីស្រាអែលទ្រង់ទូលទៅយ៉ូសាផាតថា តើទូលបង្គំ
មិនបានទូលដល់ទ្រង់ទេឬអីថា វាមិនដែលទាយល្អពីទូល
បង្គំឡើយ គឺទាយតែអាក្រក់ម្យ៉ាងប៉ុណ្ណោះ ១៨នោះមីកាយ៉ា

**១៨:១១** ឃ ២របា ២២:៥
**១៨:១៣** ង ជន ២២:១៨,២០,៣៥
**១៨:១៦** ច ១របា ៩:១ ឆ ជន ២៧:១៧
**១៨:១៨** ជ ដយ ៧:៩
**១៨:២១** ឈ ១របា ២១:១ យប ១:៦ សក ៣:១ យហ ៨:៤៤
**១៨:២២** ញ យប ១២:១៦ អគ ១៤:៩
**១៨:២៣** ដ កច ២៣:២
**១៨:២៦** ឋ ហព ១១:៣៦
**១៨:២៩** ឌ ១សយ ២៨:៨

ទូលថា ដូច្នេះ សូមស្ដាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាសិន
ទូលបង្គំបានឃើញព្រះយេហូវ៉ា ទ្រង់គង់លើបល្ល័ង្ក[ជ] មាន
ទាំងពួកពលបរិវារនៃស្ថានសួគ៌ទាំងអស់ឈរអមអង្គទាំង
ខាងស្ដាំនឹងខាងឆ្វេងផង ១៩ហើយព្រះយេហូវ៉ាទ្រង់ មាន
បន្ទូលថា តើអ្នកណានឹងចង់ទៅ បបួលឱ្យអ័ហាប់ជាស្ដេច
អ៊ីស្រាអែលឡើងទៅច្បាំង ហើយដួលស្លាប់នៅត្រង់ រ៉ាម៉ូ–
កាឡាត ម្នាក់ក៏ថាយ៉ាងនេះ ម្នាក់ក៏ថាយ៉ាងនោះ ២០រួចមាន
វិញ្ញាណ១ចេញមកឈរនៅ ចំពោះព្រះយេហូវ៉ាទូលថា
ទូលបង្គំចង់ទៅ ដូច្នេះ ព្រះយេហូវ៉ាទ្រង់ មានបន្ទូលសួរថា
ចុះឯងនឹងធ្វើយ៉ាងណាទៅ ២១វិញ្ញាណនោះទូលថា ទូល
បង្គំនឹងទៅធ្វើជាវិញ្ញាណភូតកុហក[ឈ] នៅក្នុងមាត់នៃ ពួក
ហោរាទាំងប៉ុន្មានរបស់ស្ដេច ព្រះយេហូវ៉ាទ្រង់មាន បន្ទូល
ថា ចូរចេញទៅធ្វើដូច្នោះចុះ ឯងនឹងបបួលវាឱ្យសំរេច
បាន ២២ដូច្នេះ មើលឥឡូវនេះ ព្រះយេហូវ៉ាទ្រង់បានដាក់
វិញ្ញាណភូតកុហកនៅក្នុងមាត់នៃពួកហោរារបស់ព្រះ
ករុណាទាំងនេះ[ញ] ហើយព្រះយេហូវ៉ាទ្រង់បានមានបន្ទូល
សំដែងពីសេចក្ដីអន្តរាយ ដែលនឹងកើតដល់ព្រះករុណា ។

២៣លំដាប់នោះ សេដេគា ជាកូនក្នាណា ក៏ចូលទៅទះ
កំភ្លៀង[ដ]មីកាយ៉ា សួរថា ព្រះវិញ្ញាណនៃព្រះយេហូវ៉ាបាន
ចេញពីអញ ទៅមានបន្ទូលនឹងឯងតាមផ្លូវណា ២៤នោះ
មីកាយ៉ាឆ្លើយថា ចាំមើល នៅថ្ងៃនោះ ឯងនឹងបានឃើញ
ច្បាស់ ក្នុងកាលដែលឯងរត់ទៅ ពួននៅក្នុងបន្ទប់ខាងក្នុង
២៥ស្ដេចអ៊ីស្រាអែលទ្រង់បង្គាប់ថា ចូរនាំយកមីកាយ៉ា ទៅ
ឯអាំម៉ូន ជាចៅហ្វាយទីក្រុង និងយ៉ូអាស ជាព្រះរាជបុត្រា
វិញទៅ ២៦ហើយប្រាប់គេថា ស្ដេចទ្រង់បង្គាប់ដូច្នេះ គឺឱ្យ
ដាក់មនុស្សនេះនៅក្នុងគុក[ឋ] ចិញ្ចឹមដោយនំបុ័ង និងទឹកដ៏
វេទនា ទាល់តែដល់វេលាអញមកវិញ ដោយសុខសាន្ត
២៧មីកាយ៉ាទូលថា បើសិនណាជាទ្រង់ដែលយាងមកវិញ
ដោយសុខសាន្តពិត នោះគឺព្រះយេហូវ៉ាមិនបានមាន បន្ទូល
ដោយសារទូលបង្គំទេ រួចគាត់ថែមពាក្យនេះថា ឱជនទាំង
ឡាយ អើយចូរស្ដាប់ចុះ ។

### ស្ដេចអ័ហាប់ត្រូវស្លាប់នៅក្រុងរ៉ាម៉ូត–កាឡាត

*១៨:២៨–៣៤ – ១ពវ ២២:២៩–៣៦*

២៨ដូច្នេះ ស្ដេចអ៊ីស្រាអែលនឹងយ៉ូសាផាត ជាស្ដេចយូដា
ក៏ឡើង ទៅឯក្រុងរ៉ាម៉ូត–កាឡាត ២៩ឯស្ដេចអ៊ីស្រាអែល
ទ្រង់ទូលទៅយ៉ូសាផាតថា ទូលបង្គំនឹងក្លែងខ្លួនចូលទៅ
ច្បាំងតែព្រះអង្គសូមឱ្យព្រះករុណា ទ្រង់គ្រឿងព្រះពស្ត្រ

**១៨:២២** *ដាក់វិញ្ញាណភូតកុហក់* មើលការពន្យល់ ១ពវ ២២:២៣ ។

**១៨:២៩** តាមការពិតអ័ហាប់ នាំស្ដេចយ៉ូសាផាតចូលលុកក្នុងសង្គ្រាម ដើម្បី

រាជ្យរបស់ទ្រង់វិញ ស្ដេចអ៊ីស្រាអែលក៏ក្លែងខ្លួន[ឌ] ចូលទៅ
ច្បាំងនឹងគេ ៣០រីឯខាងស្ដេចស៊ីរី បានបង្គាប់ដល់ពួក
មេទ័ពរទេះចំបាំងទ្រង់ថា កុំឱ្យតនឹងអ្នកណា ទោះតូចឬធំក្ដី
ចូរតតែ និងស្ដេចអ៊ីស្រាអែល១ប៉ុណ្ណោះ ៣១ដូច្នេះកាល
ពួលមេទ័ពទាំងនោះ បានឃើញយ៉ូសាផាត គេក៏នឹកថា
នេះជាស្ដេចអ៊ីស្រាអែលហើយ គេក៏បែរទៅបំរុងតនឹងទ្រង់
តែយ៉ូសាផាតទ្រង់ស្រែកឡើង [ឍ] ហើយព្រះយេហូវ៉ាក៏
ប្រោសជួយ បណ្ដាលឱ្យគេថយចេញពីទ្រង់ទៅ ៣២កាលពួក
មេទ័ពឃើញថា មិនមែនជាស្ដេចអ៊ីស្រាអែលទេ នោះក៏
លែងតាមតទៅ ៣៣តែមានមនុស្សម្នាក់ឃឹតធ្នូបាញ់ព្រាវទៅ
ត្រូវស្ដេចអ៊ីស្រាអែល ត្រង់ប្រឡោះអាវក្រោះនៃទ្រង់ ដូច្នេះ
ទ្រង់មានបន្ទូលបង្គាប់ ដល់អ្នកបរព្រះរាជរថទ្រង់ថា ចូរ
ញាក់បង្វៀរត្រឡប់រថនាំយើងចេញពីពលទ័ពទៅ ដ្បិត
យើងមានរបួសជាទំងន់ ៣៤នៅថ្ងៃនោះ ចំបាំងក៏កាន់តែ
ខ្លាំងឡើង ប៉ុន្តែស្ដេចអ៊ីស្រាអែលទ្រង់ផ្អែកអង្គ នៅក្នុងព្រះ
រាជរថទ្រង់ តស៊ូនឹងពួកស៊ីរី ដរាបដល់ល្ងាច លុះដល់ពេល
ប្រហែលជាថ្ងៃលិច នោះទ្រង់ក៏សុគតទៅ[ណ] ។
**១៩** ១រីឯយ៉ូសាផាត ជាស្ដេចយូដា ទ្រង់វិលទៅឯដំណាក់
នៅក្រុង យេរូសាឡិមវិញ ដោយសុខសាន្ត ២ខណនោះ
យេហ៊ូវ[ក] កូនហាណានី ជាអ្នកមើលឆុត ក៏ចេញទៅទទួល
ទ្រង់ទូលថា តើគួរគប្បីឱ្យទ្រង់ បានទៅជួយមនុស្សអាក្រក់[ខ]
ហើយស្រឡាញ់ដល់ពួកអ្នកដែលស្អប់ ព្រះយេហូវ៉ាឬអ៊ី[គ]
ដោយព្រោះហេតុនេះបានជាមានសេចក្ដីក្រេវក្រោធ[ឃ]
ចេញពីចំពោះព្រះយេហូវ៉ា មកលើទ្រង់ហើយ ៣ប៉ុន្តែ
ឃើញមានសេចក្ដីល្អខ្លះ[ង] នៅក្នុងទ្រង់ដែរ ដោយទ្រង់បាន
បំបាត់រូបព្រះទាំងប៉ុន្មាន[ច] ចេញពីស្រុកទៅ ហើយបានតាំង
ព្រះទ័យស្វែងរកព្រះពិតវិញ[ឆ] ។

**១៨:៣១** ឍ ២រប ១៣:១៤
**១៨:៣៤** ណ ២រប ២២:៥
**១៩:២** ក ១ពវ ១៦:១ ខ ២រប ១៦:២–៩ គ ទដ ១៣៩:២១–២២ ឃ ២រប ២៤:១៨ ៣២:២៥ ទដ ៧:១១
**១៩:៣** ង ១ពវ ១៤:១៣ ច ២រប ១៧:៦ ឆ ២រប ១៨:១ ២០:៣៥ ២៥:៧
**១៩:៥** ជ លប ៤៧:៦ នក ១៨:២៦
**១៩:៦** ឈ លប ១៩:១៥ ញ ចទ ១៦:១៨–២០ ១៧:៨–១៣
**១៩:៧** ដ លប ១៨:២៥ យប ៨:៣ ឋ នក ១៨:១៦ ចទ ១០:១៧ យប ១៣:១០ ៣២:២១ ៣៤:១៩
**១៩:៨** ឌ ១រប ២៣:៤ ឍ អគ ៤៤:២៤ ណ ២រប ១៧:៨–៩
**១៩:១០** ត ចទ ១៧:៨–១៣

## ស្ដេចយ៉ូសាផាតតែងតាំងពួកចៅហ្វាយ

៤យ៉ូសាផាតទ្រង់គង់នៅក្រុងយេរូសាឡិម ហើយទ្រង់
យាងចេញទៅកណ្ដាលអស់ទាំងពួកជនម្ដងទៀត គឺចាប់
តាំងពីក្រុងបៀរ–សេបា រហូតដល់ស្រុកភ្នំអេប្រាអិមនាំគេ
វិលមកឯព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេវិញ ៥ទ្រង់ក៏
តាំងឱ្យមានចៅក្រម[ជ] នៅក្នុងស្រុក គឺក្នុងគ្រប់ទាំងទីក្រុង
មានបន្ទាយរបស់ពួកយូដា ៦ទ្រង់មានបន្ទូលទៅចៅក្រម
ទាំងនោះថា ចូរពិចារណាការដែលអ្នករាល់គ្នាធ្វើចុះ[ឈ]
ដ្បិតអ្នករាល់គ្នា មិនមែនជំនុំជំរះឱ្យគាប់ចិត្តដល់មនុស្សទេ[ញ]
គឺឱ្យព្រះយេហូវ៉ាបានពេញព្រះហឫទ័យវិញ ហើយទ្រង់ក៏
គង់នៅជាមួយនឹងអ្នករាល់គ្នា ក្នុងការជំនុំជំរះនោះដែរ
៧ដូច្នេះ ចូរឱ្យអ្នករាល់គ្នាមានសេចក្ដីកោតក្លាច ដល់ព្រះ
យេហូវ៉ាចុះ ចូរប្រយ័ត្ន ហើយសំរេចការនោះទៅ ដ្បិតគ្មាន
សេចក្ដីទុច្ចរិត[ដ]ណា នៅនឹងព្រះយេហូវ៉ា ជាព្រះនៃយើង
រាល់គ្នាឡើយ ក៏គ្មានសេចក្ដីលំអៀងទៅខាងអ្នកណា[ឋ] ឬស៊ី
សំណូកផង ។
៨មួយទៀត យ៉ូសាផាតទ្រង់តាំងឱ្យមានពួកលេវី[ឌ] ពួក
សង្ឃ[ឍ] និងពួកអ្នកដែលជាកំពូលលើវង្សានុវង្ស នៃសាសន៍
អ៊ីស្រាអែលនៅក្រុងយេរូសាឡិម សំរាប់ការវិនិច្ឆ័យ[ណ]នៃ
ព្រះយេហូវ៉ា និងការកាត់រឿងក្ដី រួចគេត្រឡប់មកនៅ
ក្រុងយេរូសាឡិមវិញ ៩ទ្រង់ក៏បង្គាប់គេថា គឺយ៉ាងនោះ
ដែលអ្នករាល់គ្នាត្រូវសំរេចការងារ ដោយសេចក្ដីកោត
ខ្លាចដល់ព្រះយេហូវ៉ាយ៉ាងទៀងទាត់ ហើយដោយចិត្ត
ស្មោះត្រង់ ១០បើកាលណាមានដំណើរក្ដី រើមកដល់អ្នក
រាល់គ្នា អំពីពួកបងប្អូន ដែលនៅអស់ទាំងទីក្រុងគេ ជា
រឿងក្ដីពីការកាប់សំឡាប់គ្នា ឬការរំលងច្បាប់ ក្រិត្យក្រម
និងបញ្ញត្ត ឬសេចក្ដីវិនិច្ឆ័យណាមួយ នោះត្រូវឱ្យអ្នករាល់

ជាគោលបំណងក្នុងការគ្រប់គ្រងអំណាចរបស់ខ្លួន ។

**១៩:២** *តើគួរគប្បីឱ្យទ្រង់ បានទៅជួយមនុស្សអាក្រក់* ឪពុករបស់យេហ៊ូវគឺហាណានីក៏បានប្រមានយ៉ាងខ្លាំងដល់មាតារបស់ យ៉ូសាផាត (មើល ១៦:៧–៩) ក្រោយមកយ៉ូសាផាតបានប្រព្រឹត្តភាពដូចគ្នា គឺអំពើបាបដរដែលៗនិងទទួលបានការឈឺចាប់ពីវា (២០:៣៥–៣៧) ។

**១៩:៣** *បំបាត់រូបព្រះទាំងប៉ុន្មាន* មើលការពន្យល់ ១៤:១៣ ។

**១៩:៤** *យ៉ូសាផាត . . . យាងចេញទៅទាំងកណ្ដាលអស់ទាំងពួកជន* គឺព្រះមហាក្សត្របានធ្វើដំណើរ ទូទាំងរាជាណាចក្រដោយផ្ទាល់ព្រះអង្គដើម្បីផ្សព្វផ្សាយពីការប្រត្តិបត្តិទៅតាមសាសន៍ ។

**១៩:៥** *ទ្រង់ក៏តាំងឱ្យមានចៅក្រម* (ឈ្មោះថាយ៉ូសាផាតគឺមានន័យថាចៅក្រមរបស់ព្រះ) គឺជាភាពសមរម្យនិងទទួលការងារនេះដោយព្រះមហាក្សត្រគឺស្ដេចជាអ្នកកាត់ទោសគឺក្រោមការរៀបចំឡើង ដោយយ៉ូសាផាត (ខ.៥–១១) គឺជាការចាប់អារម្មណ៍ដ៏វិសេសវិសាល បំផុតដល់អ្នកស្ដាប់របស់អ្នកកាលប្រវត្តិ គឺចាប់តាំងពីប្រវត្តិសាស្ត្រ នៃពួកយូដារហូតដល់ពេលនៃពួកបាប៊ីឡូន ។

**១៩:៦** ប្រៀបធៀប ១៦:១៨–២០ ១៧:៨–១៣ ។

**១៩:៧** *ចូរឱ្យអ្នករាល់គ្នាមានសេចក្ដីកោតខ្លាច ដល់ព្រះយេហូវ៉ាចុះ* គឺជាបណ្ដាលឱ្យវិញ្ញាណ នៃការកោតខ្លាចដល់វត្តមាននៃព្រះយេហូវ៉ា បង្ខាំងឬបញ្ឈប់អ្នកពីភាពអយុត្តិធម៌ផ្សេងៗ (មើលការពន្យល់ ១រប ១៤:១៧) ។

**១៩:៨** *ពួកលេវីពួកសង្ឃ . . . សម្រាប់ការវិនិច្ឆ័យ* មើលការពន្យល់ ១រប ២៦:២៩–៣២ ។ ការវិនិច្ឆ័យកាត់ទោសដ៏មានប្រសិទ្ធភាព ដែលខ្លាយជាប្រព័ន្ធច្បាប់មួយដែលជាទំលៀមទំលាប់ គឺធ្វើឡើងដោយពួកចាស់ទុំក្នុងទីក្រុងនោះដោយមានការគ្រប់គ្រង់ យ៉ាងត្រឹមត្រូវពីពួកសង្ឃនិងសង្ឃហ្លួង ។

គ្នាប្រាមប្រាប់គេ ដើម្បីកុំឱ្យគេមានទោស នៅចំពោះព្រះ
យេហូវ៉ា[ត] ហើយដោយសារទោសនោះ និងមានសេចក្ដី
ក្រោធមកលើអ្នករាល់គ្នា និងពួកបងប្អូនផងនោះឡើយ
ចូរសំរេចការនេះទៅ នោះអ្នករាល់គ្នា នឹងគ្មានទោសទេ
១១ហើយមើល អ័ម៉ារា ជាសំដេចសង្ឃ លោកត្រួតលើអ្នក
រាល់គ្នាក្នុងអស់ទាំងកិច្ចការខាងឯព្រះយេហូវ៉ា ហើយសេ
បាឌា ជាកូនអ៊ីសម៉ាអែល លោកជាចៅហ្វាយលើពូជអំបូរ
យូដាក្នុងគ្រប់ទាំងការខាងឯស្ដេច ហើយពួកលេវីក៏នៅ
ចំពោះអ្នករាល់គ្នាទុកជាអាជ្ញា ចូរធ្វើការដោយចិត្តក្លា
ហានចុះ [ថ]សូមឱ្យព្រះយេហូវ៉ាគង់នៅខាងណាដែលត្រឹម
ត្រូវផង ។

## ស្ដេចយ៉ូសាផាតច្បាំងឈ្នះពួកម៉ូអាប់ និងអាំម៉ូន

**២០** ១ក្រោយនោះមក ពួកកូនចៅម៉ូអាប់ និងពួកកូនចៅ
អាំម៉ូន[ក] ព្រមទាំងពួកម៉ាអូន[ខ]ខ្លះ ក៏លើកគ្នាមកច្បាំងនឹង
យ៉ូសាផាត ២មានគេមកទូលដល់យ៉ូសាផាតថា មានកងទ័ព
យ៉ាងសន្ធឹក[គ]មកទាស់នឹងទ្រង់ គេមកពីស្រុកស៊ីរីខាងនាយ
សមុទ្រ មើលគេមកដល់ហាសាសូន-តាម៉ារ[ឃ] ហើយ
(នោះគឺជាស្រុកអេន-កេឌី)[ង] ៣យ៉ូសាផាតទ្រង់ក៏ភ័យខ្លាច
ហើយតាំងព្រះទ័យស្វែងរកព្រះយេហូវ៉ា ទ្រង់ប្រកាសប្រាប់
ឱ្យមានការតមអត់[ច] នៅពេញក្នុងស្រុកយូដា ៤ហើយពួក
យូដា[ឆ]ក៏មូលគ្នាមករកទីពឹងដល់ព្រះយេហូវ៉ា គឺគេចេញពី
អស់ទាំងទីក្រុងរបស់ស្រុកយូដាមក ដើម្បីស្វះស្វែងរកព្រះ។
៥រីឯយ៉ូសាផាត ទ្រង់ឈរនៅក្នុងព្រះវិហារនៃព្រះយេ
ហូវ៉ា ចំមុខពីលានថ្មី នៅកណ្ដាលជំនុំពួកយូដា និងពួកក្រុង
យេរូសាឡិមទូលថា ៦ឱព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោ
យើងខ្ញុំរាល់គ្នាអើយ[ជ] តើទ្រង់ មិនមែនជាព្រះនៅស្ថានសួគ៌
ទេឬអី[ឈ] តើទ្រង់មិនគ្រប់គ្រងលើអស់ទាំងនគររបស់សាសន៍
ដទៃ[ញ]ទេឬអី ហើយនៅព្រះហស្តទ្រង់ នោះក៏មានព្រះ
ចេស្ដា និងឥទ្ធិឫទ្ធិដែរ ដល់ម្ល៉េះបានជាគ្មានអ្នកណាអាចនឹង
ទប់ទល់នឹងទ្រង់បានឡើយ[ដ] ៧ឱព្រះនៃយើងខ្ញុំរាល់គ្នា
អើយតើទ្រង់មិនបានបណ្ដេញពួកអ្នកស្រុកនេះ[ឋ] ពីមុខពួក
អ៊ីស្រាអែល ជារាស្ត្រទ្រង់ចេញ ហើយប្រទានដល់ពូជ
អ៊ីស្រាអែលជារាស្ត្រទ្រង់ចេញ ហើយប្រទាន ដល់ពូជពង្ស
របស់លោកអ័ប្រាហាំ ជាមិត្រសំឡាញ់ទ្រង់ ជាដរាបតទៅ
ទេឬអី[ឌ] ៨គេបានអាស្រ័យនៅ ហើយក៏បានស្អាងទីបរិសុទ្ធ[ឍ]
នៅស្រុកនេះ សំរាប់ព្រះនាមទ្រង់ ដោយពាក្យថា ៩បើសិន
ជាមានសេចក្ដីអាក្រក់ណា មកសង្កត់លើយើងរាល់គ្នា ទោះ
បើជាដាវ ឬទុក្ខទោស អាសន្នរោគឬអំណត់ក្ដី[ណ] បើយើង
រាល់គ្នានឹងឈរនៅមុខព្រះវិហារនេះ ហើយនៅចំពោះ
ទ្រង់ (ដ្បិតព្រះនាមទ្រង់នៅក្នុងព្រះវិហារនេះ) ហើយយើង
រាល់គ្នាអំពាវនាវដល់ទ្រង់ ក្នុងសេចក្ដីវេទនារបស់យើង
នោះទ្រង់នឹងព្រមទទួល ហើយនឹងជួយសង្គ្រោះយើង
១០ឥឡូវនេះ មើលមាន ពួកកូនចៅអាំម៉ូន ម៉ូអាប់ និងពួក
ភ្នំសៀរ ដែលទ្រង់មិនបើកឱ្យអ៊ីស្រាអែលទន្ទ្រានចូលស្រុក
គេ ក្នុងកាលដែលចេញពីស្រុកអេស៊ីព្ទមក[ត] គឺបានឱ្យដើរ

**១៩:១១** ថ ១រប ២៨:២០ **២០:១** ក ទដ ៨៣:៦ ខ ១រប ៤:៤១ **២០:២** គ ២រប ២៤:២៤ ឃ លប ១៤:៧ ង ១សយ ២៣:២៩ ១:១៤ **២០:៣** ច ១សយ ៧:៦ អរ ៨:២៣ នហ ១:៤ នអ ៤:១៦អស ៥៨:៦ យរ ៣៦:៩ ដយ ៩:៣ យអ ១:១៤ ២:១៥ យហ ៣:៥,៧ **២០:៤** ឆ យរ ៣៦:៦ **២០:៦** ជ មថ ៦:៩ ឈ ចទ ៤:៣៩ ញ ១រប ២៩:១១-១២ ដ ២រប ២៥:៨ យប ២៥:២ ៤១:១០ ៤២:២ អស ១៤:២៧ យរ ៣២:២៧ ៤៩:១៩ **២០:៧** ឋ លប ១២:៧ ឌ អស ៤១:៨ យក ២:២៣ **២០:៨** ឍ ២រប ៦:២០ **២០:៩** ណ ២រប ៦:២៨ **២០:១០** ត ជន ២០:១៤-២១ ចទ ២:៤-៦,៩,១៨-១៩

**១៩:១១** *ទាំងកិច្ចការខាងឯព្រះយេហូវ៉ា . . . គ្រប់គ្រងការខាងឯស្ដេច* ការចែកដាច់នេះ គឺជាកិច្ចការសាសនានឹងការងាររបស់ព្រះមហាក្សត្រ ដែលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធ ជាប្រវត្តិសាស្ត្រតាំងពីសម័យសាសន៍យូដារហូតដល់សម័យពួកបាប៊ីឡូន និងសាដុក(១រប ២៩:២២)និងហើយជាប្រព័ន្ធគ្រប់គ្រងសហគមន៍តាមបែបសម័យពួកបាប៊ីឡូន ឬសាសន៍យូដាមកម្លេះដូចជាសូរ៉ូបាបិល ស្ដេចដាវីឌ គឺជាពូជអំបូរតែមួយ និងលោកយ៉ូស្វេគឺជាសង្ឃ ហ្លួង (សក ៤:១៤ ៦:៩-១៥) ។

**២០:១-៣០** ព្រឹត្តិការណ៍នេះហើយ ដែលនាំឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្លាចំពោះអ្នកកាលប្រវត្តិ ចាប់តាំងពីបានបង្រួបបង្រួមសហគមន៍ ដែលត្រូវរុកគួនបំផ្លាញ់ដោយពូជអំបូរមនុស្សឈាមជ័រតែមួយ(មើល នហ ២:១៩ ៤:១-៣,៧-៩) ក្នុងព្រះយេហូវ៉ា ហោរារបស់ផងទ្រង់ដូចជាយ៉ូសាផាតឬរាជបុត្រានៃស្ដេចដាវីឌ ដែលបានតម្កើងឡើង(ខ.២០) ក៏ជាខ្សែស្រឡាយដែលបានបញ្ជាក់យ៉ាងច្បាស់ ។ (ខ.១-៤,២៨-៣០) ក៏បានបែងចែកជាបីចំណែក(១)ការអធិស្ឋានរបស់យ៉ូសាផាត(ខ.៥-១៣) (២)ការឆ្លើយតបរបស់ប្រះយេហូវ៉ា(ខ.១៤-១៩) (៣) ការជោគជ័យដ៏អស្ចារ្យ(ខ.២០-២៧) គឺជាផ្នែករួមមួយៗនៃពត៌មានសំខាន់ៗ(ខ.៩)យើងនិងឈរពីមុខ វត្តមាននៃទ្រង់ពីខាងមុខព្រះវិហាររបស់ផងទ្រង់នេះ ខ.១៧ ។ ឈរ"ឱ្យឈរបានរឹងមាំនិងមើលពីការរំដោះ ដែលព្រះយេហូវ៉ាបានប្រទានមកឱ្យយើង"ខ.២៣ មនុស្សពួកក្រុមអាំម៉ូននិងម៉ូអាប់ បានក្រោកឈរឡើងតបប្រឆាំងនិងក្រុមមនុស្សដែលមកពីក្រុមភ្នំសៀរ ។

**២០:១** *ម៉ាអូន* គឺជាប្រជាជនមកពីតំបន់ភ្នំសៀរក្នុងស្រុកអេដំម (២៦:៧ រប ៤:១៤:៤) ប្រៀបធៀប រប ២០:១០,២២-២៣) ។

**២០:២** *ស្រុកស៊ីរី* តាមអត្ថបទគឺពុំបានបង្ហាញប្រាប់ពីអ្នកវាយប្រហាឱ្យបានច្បាស់លាស់ទេ ។ យើងក៏ឃើញភាពផ្ទុយគ្នារវាងស្រុក "អើរាម" និងស្រុក "អេដំម"ក្នុងភាសាហេព្រើរ ដែលមានសំបុត្រមួយមានភាពស្មុកស្មាញក្នុងការកត់ចំឡងតាម ។

**២០:៥-១២** ការអធិស្ឋានរបស់យ៉ូសាផាតបង្ហាញការសម្តែងជាព្រះវិញ្ញាណគឺជាព្រះរាជបុត្រារបស់ស្ដេចដាវីឌ ក៏ជាការរំលឹកដល់ព្រះមែស៊ី(មើលសេចក្ដីផ្ដើម ១រប ពីគោលបំណងនិងផ្ទៃរឿង) ។

**២០:៧** *លោកអ័ប្រាហាំ ជាមិត្តសំឡាញ់ទ្រង់* មើល អស ៤១:៨ យក ២:២៣ និងការពន្យល់ ។

**២០:៩** ការស្ដែងឱ្យឃើញពីការឆ្លើយតបពីព្រះយេហូវ៉ា និងជាព្រះបន្ទូលសន្យាគឺដោយការអធិស្ឋានរបស់ស្ដេចសាឡូម៉ូន (សូមមើល ៦:១៤-៤២ ៧:១២-២២) ។

វាងពីគេ ឥតបំផ្លាញគេឡើយ ១១សូមមើលបែបយ៉ាងណា
ដែលគេសងគុណ ដល់យើងខ្ញុំរាល់គ្នា គឺគេមកចង់បណ្តេញ
យើងខ្ញុំរាល់គ្នា ចេញពីកេរ្តិ៍អាកររបស់ទ្រង់[ថ] ដែលទ្រង់
បានប្រទានមកទុកជាមរដកដល់យើងខ្ញុំ ១២ឱព្រះនៃយើងខ្ញុំ
រាល់គ្នាអើយ សូមទ្រង់កាត់ទោសដល់គេ[ទ] ពីព្រោះយើង
ខ្ញុំរាល់គ្នាគ្មានកំឡាំង និងទប់ទល់ចំពោះពួកយ៉ាងធំ ដែល
មកទាស់នឹងយើងរាល់គ្នានេះបានទេ យើងខ្ញុំក៏មិនដឹង
ធ្វើដូចម្តេចដែរ ប៉ុន្តែភ្នែកយើងខ្ញុំទន្ទឹងមើលតែទ្រង់ទេ[ធ]
១៣ពួកយូដាទាំងអស់គ្នាក៏ឈរនៅចំពោះព្រះយេហូវ៉ា មាន
ទាំងកូនតូចៗនិងប្រពន្ធហើយក្មេងៗនៅជាមួយផង ។
១៤គ្រានោះ យ៉ាងហាសៀល ជាកូនសាការី ដែលជាកូន
បេនណាយ៉ាៗជាកូនយីអែលៗជាកូនម៉ាថានា[ន] ដែលជាពួក
លេវី ខាងពួកកូនចៅអេសាភ លោកនៅកណ្តាលពួកជំនុំ
ហើយព្រះវិញ្ញាណ[ប]នៃព្រះយេហូវ៉ា ក៏មកសណ្ឋិតលើលោក
១៥រួចលោកពោលថា ឱពួកយូដាទាំងអស់គ្នា និងពួកអ្នក
នៅក្រុងយេរូសាឡិម ព្រមទាំងព្រះករុណាយ៉ូ សាផាតអើយ
ចូរស្តាប់ចុះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអករាល់គ្នា
ដូច្នេះថា កុំឱ្យភ័យខ្លាចអ្វីឡើយ ក៏កុំឱ្យស្រយុតចិត្ត[ផ] ដោយ
ព្រោះពួកធំទាំងម៉្លេះនេះដែរ ដ្បិតចំបាំងនេះ[ព]មិនមែន
ស្រេចនៅអ្នករាល់គ្នាទេ គឺស្រេចនៅព្រះវិញ ១៦ស្អែកឡើង
ចូរអ្នករាល់គ្នាចុះទៅទាស់នឹងគេចុះ មើលគេកំពុងតែឡើង
មកតាមផ្លូវភ្នំស៊ីស អ្នករាល់គ្នានឹងជួបគេ នៅចុងច្រកភ្នំ
ទល់មុខនឹងទីរហោស្ថានយេរូល ១៧អ្នករាល់គ្នាមិន បាច់នឹង
តស៊ូក្នុងចំបាំងនេះទេ ឱ្យគ្រាន់តែដំរៀបគ្នាឈរសៀម
ហើយចាំមើល[ភ]សេចក្តីសង្គ្រោះ ដែលព្រះយេហូវ៉ានឹង
ប្រោសដល់អ្នករាល់គ្នា ប៉ុណ្ណោះ ឱពួកយូដានឹងពួកអ្នកនៅ
ក្រុងយេរូសាឡិមអើយ កុំឱ្យភ័យខ្លាចអ្វីឡើយ ក៏កុំឱ្យស្រយុត
ចិត្តដែរ ស្អែកនេះ ចូរចេញទៅទាស់នឹងគេចុះ ពីព្រោះព្រះ
យេហូវ៉ាទ្រង់គង់នៅជាមួយនឹងអ្នករាល់គ្នាហើយ ១៨នោះ
យ៉ូសាផាតទ្រង់ក្រាប[ម]ព្រះភក្ត្រចុះដល់ដី ហើយពួកយូដា និង

**២០:១១** ថ ទដ ៨៣:១–១២
**២០:១២** ទ ពច ១១:២៧ ធ ទដ ២៥:១៥ អស ៣០:១៥ ៤៥:២២ មីក ៧:៧
**២០:១៤** ន ១រប ៩:១៥ ប ១រប ១២:១៨
**២០:១៥** ផ ២រប ៣២:៧ ព ១សយ ១៧:៤៧ ទដ ៩១:៨
**២០:១៧** ភ នក ១៤:១៣
**២០:១៨** ម លប ២៤:២៦ ២រប ២៩:២៩
**២០:២០** យ អស ៧:៩ រ លប ៣៩:៣ សភ ១៦:៣
**២០:២១** ល ១រប ១៦:២៩ វ ២រប ៥:១៣ ទដ ១៣៦:១
**២០:២២** ស ២រប ១៣:១៣
**២០:២៣** ហ លប ១៩:៣៨ ឡ ២រប ២១:៨ អ ពច ៧:២២ ១សយ ១៤:២០ អគ ៣៨:២១

ពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នា ក៏ក្រាបថ្វាយបង្គំ
នៅចំពោះព្រះយេហូវ៉ាដែរ ១៩ឯពួកលេវី ខាងពួកកូនចៅ
កេហាត់ និងពួកកូនចៅកូរេគេឈរឡើង សរសើរដល់
ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ដោយសំឡេង
យ៉ាងខ្លាំងក្រៃលែង ។
២០ស្អែកឡើងគេក្រោកពីព្រលឹមស្រាង ចេញទៅឯ
ទីរហោស្ថាន ត្កូអា កំពុងតែគេចេញទៅ នោះយ៉ូសាផាត
ទ្រង់ឈរមានបន្ទូលថា ពួកយូដា និងពួកអ្នកនៅក្រុង
យេរូសាឡិមអើយ ចូរស្តាប់យើងចុះ ចូរឱ្យមានសេចក្តី
ជំនឿជឿ[យ]ដល់ព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នា ទើបអ្នក
រាល់គ្នានឹងបានខ្ជាប់ខ្ជួន ចូរជឿតាមពួកហោររបស់ទ្រង់
ទើបអ្នករាល់គ្នានឹងប្រកប ដោយសេចក្តីចំរើន[រ] ២១រួច
កាលទ្រង់បានពិគ្រោះនឹងបណ្តាជនហើយ នោះទ្រង់ក៏ដំរូវ
ឱ្យមានពួកអ្នកដែលត្រូវច្រៀងថ្វាយព្រះយេហូវ៉ា ហើយ
ពោលសរសើរ ដោយស្លៀកពាក់ជាប្រដាប់បរិសុទ្ធ[ល] ក្នុង
កាលដែលគេនាំមុខពួកទ័ពចេញទៅដោយពោលថា ចូរ
អរព្រះគុណដល់ព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសប្បុរសទ្រង់
នៅជាប់អស់កល្បជានិច្ច[វ] ២២ដូច្នេះកាលគេចាប់តាំងច្រៀង
ហើយសរសើរឡើង នោះព្រះយេហូវ៉ាទ្រង់បង្កប់ទ័ព[ស]ទាស់
នឹងពួកកូនចៅអាំម៉ូន ម៉ូអាប់និងពួកភ្នំសៀរ ដែលមកចង់
ច្បាំងនឹងពួកយូដាឱ្យគេត្រូវបាញ់ ២៣ដ្បិតពួកកូនចៅអាំម៉ូន[ហ]
និងម៉ូអាប់ គេលើកគ្នាបំផ្លាញពួកអ្នកនៅ ស្រុកភ្នំសៀរ[ឡ]
អស់រលីងទៅ រួចកាលគេបានបំផ្លាញពួកនោះអស់ហើយ
នោះ ក៏ព្រួតគ្នាបំផ្លាញដល់គ្នាទៅវិញទៅមកទៀត[អ] ។
២៤ដូច្នេះ កាលពួកយូដាមកដល់ប៉មចាំយាមនៅត្រង់ទីរ
ហោស្ថាន នោះគេក្រឡេកមើលទៅពួកធំនោះ ក៏ឃើញគេ
សុទ្ធតែជាខ្មោច ដេករដូកនៅដី គ្មានអ្នកណាមួយបានរួច
ជីវិតឡើយ ២៥រួចកាលយ៉ូសាផាត នឹងពលទ័ពរបស់ទ្រង់
បានទៅដល់ ដើម្បីយករបឹបនោះក៏ ឃើញមានទាំងរបស់
ទ្រព្យសំលៀកបំពាក់ និងប្រដាប់មានដំឡៃយ៉ាងសន្ធឹក

**២០:១៥** មើល ១៤:១៣–១៤ និងការពន្យល់ ១៤:១៤ ។
**២០:១៦** *តាមផ្លូវភ្នំស៊ីស* គឺមានប្រវែង ១១,២៦ គ.ឡ ពីស្រុក អេន–កេឌី ខាងជើងនិងទីរហោស្ថានដែលគេឃើញជាទួលខ្ពស់ ហើយដាច់ឆ្ងាយពីសមុទ្រ *ទីរហោស្ថានយេរូស* គឺជាវាលមួយស្ថិតនៅផ្នែកខាងត្បូងឈាងខាងកើតនៃទីរហោស្ថាន។
**២០:១៩** *ពួកលេវី* គឺអ្នកកាលប្រវត្តិតែងតែផ្តោតលើបញ្ហាពួកលេវីក្នុងពួកសង្ឃតែងតែបង្ហាញឱ្យឃើញ(ខ.១៤,២១–២២,២៨) ។
**២០:២០** *មានសេចក្តីជំនឿដល់ព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នាទើបអ្នក . . . ជឿតាមពាកយហោររបស់ទ្រង់* គឺជាពាក្យសំដី ជាក់លាក់ចំពោះការកើតឡើងហេតុការដូចៗគ្នា របស់អ្នកកាលប្រវត្តិដោយបានស្តាប់នូវព្រះបន្ទូលនៃព្រះរាជបុត្រានៃស្តេចដាវីឌ គឺដែលពួកគេសង្ឃឹមទៅលើព្រះយេហូវ៉ាតែមួយព្រះអង្គគត់ និងពាក្យពេជ្រដែលអាចទុកចិត្តបានចំពោះហោរារបស់ទ្រង់ ។
**២០:២១** *ដោយស្លៀកពាក់ជាប្រដាប់បរិសុទ្ធ* មើលការពន្យល់ ១រប ១៦:២៩
**២០:២២** *បង្កប់ទ័ពវាយ* លក្ខណៈនៃការពួនស្កាត់វាយឆ្មក់នេះ គឺបានបញ្ជាក់ក្នុង ខ.២៣ រាស្ត្រអ៊ីស្រាអែលបានវាយផ្តួលសត្រូវរបស់ខ្លួន ទាំងស្រុងនៅក្នុងសមរភូមិប្រយុទ្ធ គឺដូចជាជ័យជម្នះកាដែលលោកទទួលបានផងដែរ ដែលមានព្រះយេហូវ៉ាជួយ (ពច ៧:២២) ។

ហើយនាំគ្នាដោះចេញទុកសំរាប់ខ្លួន លើសពីកំឡាំងនឹង
យក ទៅបានមានរបឹបជាច្រើន ដល់ម្ល៉េះបានជាគេប្រមូល
យកអស់រវាង៣ថ្ងៃទើបហើយ ២៦ នៅថ្ងៃទី៤គេប្រជុំគ្នា នៅ
ច្រកភ្នំបេរ៉ាកា គឺដោយព្រោះនៅទីនោះគេបានសូម
ឱ្យព្រះយេហូវ៉ាបានព្រះពរ បានជាគេហៅទីនោះថា ច្រក
ភ្នំបេរ៉ាកា ដរាបដល់សព្វថ្ងៃនេះ ២៧ រួចមកពួកយូដា
និងអស់ពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នា មាន
ទាំងយ៉ូសាផាតយាងនាំមុខគេ ក៏វិលត្រឡប់ទៅឯក្រុង
យេរូសាឡិមវិញ ដោយអំណរ ពីព្រោះព្រះយេហូវ៉ាទ្រង់
បានបណ្តាលឱ្យគេមានសេចក្តីរីករាយ សប្បាយពីដំណើរ
ពួកខ្មាំងសត្រូវរបស់គេ ២៨ គេក៏ចូលទៅក្នុងព្រះវិហារនៃ
ព្រះយេហូវ៉ា នៅក្រុងយេរូសាឡិម ដោយលេងពិណ ស៊ុង
ហើយផ្លុំត្រែផង ២៩ កាលពួកនគរដែលនៅអស់ទាំងស្រុក
បានឮថា ព្រះយេហូវ៉ាទ្រង់ច្បាំង[ក]នឹងពួកខ្មាំងសត្រូវរបស់
អ៊ីស្រាអែលដូច្នោះ នោះគេក៏កើតមានសេចក្តីស្ញែងខ្លាច[ខ]
ដល់ព្រះទាំងអស់គ្នា ៣០ ដូច្នេះ នគររបស់យ៉ូសាផាតបានសុខ
សាន្ត ពីព្រោះព្រះនៃទ្រង់បានប្រោស ប្រទានឱ្យទ្រង់មាន
សេចក្តីស្រាកស្រាន្ត[គ]នៅព័ទ្ធជុំវិញ ។

### ទីបញ្ចប់នៃរាជ្យស្តេចយ៉ូសាផាត

*២០:៣១–២១:១ – ១ពវ ២២:៤១–៥០*

៣១ ឯយ៉ូសាផាតទ្រង់បានសោយរាជ្យ នៅស្រុកយូដាកាល
ទ្រង់ ចាប់តាំងសោយរាជ្យ នោះមានព្រះជន្ម៣៥ឆ្នាំ ព្រះ
មាតាទ្រង់ព្រះនាម ជាអ័ស៊ូបា ជាបុត្រីស៊ីលហ៊ី ៣២ ទ្រង់ដើរ
តាមផ្លូវរបស់អេសា ជាព្រះបិតាទ្រង់ ឥតងាកបែរចេញ
ឡើយ ក៏ប្រព្រឹត្តអំពើដែលត្រឹមត្រូវ នៅព្រះនេត្រព្រះ
យេហូវ៉ា ៣៣ ប៉ុន្តែមិនបានបំបាត់អស់ទាំងទីខ្ពស់ចេញ[ឃ]
ឡើយ ហើយពួកបណ្តាជន ក៏មិនទាន់បានតាំងចិត្តដល់ព្រះ
នៃពួកឰយុកោគេនៅឡើយដែរ ៣៤ រីឯដំណើរទាំងប៉ុន្មាន
ឯទៀតពីយ៉ូសាផាត ទាំងមុនទាំងក្រោយ នោះសុទ្ធតែបាន
កត់ទុកក្នុងសេចក្តីបរិយាយ ដែលយេហ៊ូវ[ង] ជាកូនហាណានី
បានតែង ដែលគេបានកត់បញ្ចូល ក្នុងពង្សាវតារនៃពួក
ស្តេចអ៊ីស្រាអែលហើយ ។
៣៥ ក្រោយនោះមក យ៉ូសាផាត ជាស្តេចយូដា ទ្រង់ក៏ចូល
ហ៊ុន[ច] ជាមួយនឹងអ័ហាស៊ីយ៉ា ស្តេចអ៊ីស្រាអែល ដែលជាអ្នក
ប្រព្រឹត្តលាមកអាក្រក់[ឆ] ៣៦ ទ្រង់ចូលហ៊ុនគ្នា ដើម្បីនឹងធ្វើ
នាវាទៅឯស្រុកតើស៊ីស គេក៏ធ្វើនាវាទាំងនោះនៅត្រង់
ក្រុងអេស៊ាន–គេប៊ើរ ៣៧ គ្រានោះ អេលាស៊ើរ ជាកូន
ដូដាវ៉ា អ្នកស្រុកម៉ារីសា លោកទាយទាស់នឹងយ៉ូសា ផាតថា
ដោយព្រោះព្រះករុណាបានចូលហ៊ុននឹងអ័ហាបស៊ីយ៉ានោះ
ព្រះយេហូវ៉ាទ្រង់បានបំផ្លាញការ ដែលព្រះករុណាបានធ្វើ
នេះទាំងអស់ចេញ ឯនាវា[ជ]នោះក៏ត្រូវបាក់បែកទៅ និងទៅ
ស្រុកតើស៊ីមិនបាន ឡើយ ។
**២១** ១ ឯយ៉ូសាផាត ទ្រង់ផ្ទំលក់ទៅ ជាមួយនឹងពួកឰយុកោ
ទ្រង់ គេបញ្ចុះសព នៅជាមួយនឹងពួកឰយុកោទ្រង់ នៅក្នុង
ក្រុងដាវីឌ រួចយ៉ូរ៉ាម[ក] ជាព្រះរាជបុត្រា ក៏ឡើងសោយ
រាជ្យជំនួសព្រះបិតា ២ យ៉ូរ៉ាមមានកនិដ្ឋាជាបុត្រារបស់
យ៉ូសាផាត គឺអ័សារា យេហ៊ីអែល សាការី អ័សារា មីកែល
និងសេផាធា នេះសុទ្ធតែជាបុត្រារបស់យ៉ូសាផាត ស្តេច
សាសន៍អ៊ីស្រាអែល ៣ ព្រះបិតាទ្រង់ក៏ចែករបស់ទ្រព្យជា
ច្រើន[ខ] ដល់បុត្រទាំងនោះ គឺប្រាក់មាសនឹងរបស់មានដំឡៃ
ព្រមទាំងទីក្រុងមានបន្ទាយ[គ] នៅស្រុកយូដាផង តែត្រង់ឯ
រាជ្យ នោះបានប្រទានដល់ យ៉ូរ៉ាមវិញពីព្រោះទ្រង់ជាព្រះ
រាជបុត្រច្បង ។

### យ៉ូរ៉ាមឡើងជាស្តេចស្រុកយូដា

*២១:៥–១០,២០ – ២ពវ ៨:១៦–២៤*

៤ កាលយ៉ូរ៉ាមបានឡើង[ឃ] គ្រប់គ្រងរាជ្យរបស់ព្រះបិតា

**២០:២៩** ក នក ១៤:១៤ ខ លប ៣៥:៥ ចទ ២:២៥
**២០:៣០** គ ១រប ២២:៩
**២០:៣៣** ឃ ២រប ១៧:៦
**២០:៣៤** ង ១ពវ ១៦:១
**២០:៣៥** ច ២រប ១៦:៣ ឆ ២រប ១៩:១–៣
**២០:៣៧** ជ ១ពវ ៩:២៦
**២១:១** ក ១រប ៣:១១
**២១:៣** ខ ២រប ១១:២៣ គ ២រប ១១:១០
**២១:៤** ឃ ១ពវ ២:១២ ង ពច ៩:៥

**២០:២៦** *ដល់សព្វថ្ងៃនេះ* មើលការពន្យល់ ៥:៩ ។

**២០:២៩** *សេចក្តីស្ញែងខ្លាចដល់ព្រះ* មើលការពន្យល់ ១រប ១៤:១៧ ។

**២០:៣០** *សេចក្តីស្រាកស្រាន្ត នៅព័ទ្ធជុំវិញ* ការសម្រាកពីការធ្វើសង្គ្រាម គឺជាព្រះពរដល់អ្នករាល់គ្នា ដែលស្តាប់បង្គាប់ក្នុងសម័យពង្សក្សត្រនោះ (១៤:៥–៧ ១៥:១៥ រប ២២:៨–៩,១៨) ។ ក៏មានស្តេចដ៏សុចរិតដែលបានជោគជ័យក្នុងសង្គ្រាមដូចជា អ័ប៊ីយ៉ាស្តេចអេសាស្តេចយ៉ូសាផាតអ៊ូវីអ័ហាស៊ីយ៉ា ។

**២០:៣១** *២៥ឆ្នាំ* ក្នុងកណ្ឌគម្ពីរ ពង្សាវតារក្សត្របានឃើញកំណត់ត្រាចំនួន ២២ដង (១៨ ដងក្នុង ២ពវ ៣:១ និងឃើញ៤ដងថែមទៀតក្នុង ៨:១៦) ទូរលេខទាំងនេះគឺជាដំណោះស្រាយ ដោយសន្ទត់ជាមួយព្រះបិតារបស់ទ្រង់ គឺស្តេចអេសាអស់រយៈពេលបីឆ្នាំ តែដោយព្រះបិតារបស់ទ្រង់បានប្រឈួនយ៉ាងខ្លាំងនិងតម្រូវឱ្យរៀបចំនូវអ្នកស្នងរាជ្យបន្ត (១៦:១០–១៤) ។ ឯកណ្ឌគម្ពីរពង្សាវតារក្សត្រ បានប្រាប់តែពេលស្តេចអង្គនោះកំពុងសោយរាជ្យនិងបន្ទាប់ពីព្រះវបិតារបស់ផងទ្រង់បានសុគត ។

**២០:៣៣** *មិនបានបំបាត់អស់ . . . ទីខ្ពស់* មើលការពន្យល់ ១៧:៦ ។

**២០:៣៤** *យេហ៊ូវជាកូនហាណានី* មើលការពន្យល់ ១៩ ។

**២០:៣៥** *អ័ហាស៊ីយ៉ា* បានសោយរាជ្យតាំងពីរ ៨៥៣–៨៥២ មុន គ.ស (មើល ១ពវ ២២:៥១ ២ពវ ១:១៨) (សម្រាប់កិច្ចការគ្រងរាជ្យ) ។

**២១:២** *បុត្រារបស់យ៉ូសាផាត* អ្នកកាលប្រវត្តិបានបង្ហាញ ព្រះពរមកដល់ស្តេច យ៉ូសាផាតតាមរយៈឱ្យស្តេចអង្គនេះមានក្រុមគ្រួសារ ដ៏ធំមួយថែមទាំងមានព្រះរាជបុត្រាចំនួន៧អង្គ (មើល ១១:១៨–២២ ១រប ២៥:៥ និងការពន្យល់) ។ បុត្រារបស់យ៉ូសាផាតជាច្រើនដែលមានលក្ខណៈផ្ទុយ យ៉ូរ៉ាមជាស្តេចអាក្រក់ ដែលបន្ទាប់ពីបានប្អូនសម្លាប់បងប្រុសរបស់ទ្រង់ (ខ.៤) ដែលបន្សល់តែបុត្រាពៅមួយ (ខ.១៧) ឯភរិយារបស់យ៉ូរ៉ាម គឺអថាលាក្រោយមកក៏បានប្រព្រឹត្តការកាប់សម្លាប់ដូច្នេះដែរ (២២:១០) ។

ហើយមានអំណាចចំរើនឡើងនោះទ្រង់ក៏សំឡាប់កនិដ្ឋា[ង]
ទាំងប៉ុន្មានដោយដាវទៅ ព្រមទាំងពួកដែលជាប្រធាន
ក្នុងសាសន៍អ៊ីស្រាអែលជាច្រើនដែរ ៥កាលយ៉ូរ៉ាមចាប់
តាំងសោយ រាជ្យឡើង នោះទ្រង់មានព្រះជន្ម៣២ឆ្នាំហើយ
ក៏សោយរាជ្យ នៅក្រុងយេរូសាឡិម៨ឆ្នាំ ៦ទ្រង់បានដើរ
តាមផ្លូវរបស់ពួកស្តេចអ៊ីស្រាអែល[ច] គឺបានប្រព្រឹត្តដូចជា
វង្សារបស់អ័ហាប់ដែរ ដ្បិតទ្រង់បានយកបុត្រីរបស់អ័ហាប់[ឆ]
ធ្វើជាភរិយា ទ្រង់ក៏ប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះ
នេត្រនៃព្រះយេហូវ៉ា ៧ប៉ុន្តែព្រះយេហូវ៉ាទ្រង់មិនសព្វព្រះ
ហឫទ័យ នឹងបំផ្លាញពួកវង្សរបស់ដាវីឌទេ[ជ] ដោយព្រោះ
សេចក្តីសញ្ញា ដែលទ្រង់បានតាំងនឹងដាវីឌ[ឈ] ហើយដោយ
ព្រោះបានសន្យានឹងទ្រង់ថា នឹងប្រោសប្រទានចង្កៀង១[ញ]
ដល់ទ្រង់ និងពួកកូនចៅទ្រង់ជាដរាបទៅ ។
៨នៅក្នុងរាជ្យយ៉ូរ៉ាម នោះសាសន៍អេដំម[ដ]បានបះបោរ
ដកខ្លួនពីអំណាចសាសន៍យូដាចេញ ហើយគេក៏តាំងឱ្យមាន
ស្តេចគ្រប់គ្រងលើខ្លួនវិញ ៩នោះទ្រង់យាងឆ្លងទៅឯគេ
មានទាំងពួកមេទ័ព និងរទេះចំបាំងទាំងប៉ុន្មានរបស់ទ្រង់
ផង ទ្រង់ក្រោកឡើងទាំងយប់ទៅវាយពលទ័ព និងពួកមេ
រទេះចំបាំងរបស់សាសន៍អេដំម ដែលបានមកឡោមព័ទ្ធ
ទ្រង់នោះ ១០ប៉ុន្តែសាសន៍អេដំមបានបះបោរ ដកខ្លួនពី
អំណាច សាសន៍យូដា ដរាបដល់សព្វថ្ងៃនេះ គ្រានោះ
ពួកក្រុងលិបណា[ឋ] ក៏បះបោរដកខ្លួន ពីក្រោមអំណាចទ្រង់
ដែរ ពីព្រោះទ្រង់បានបោះបង់ចោលព្រះយេហូវ៉ា ជាព្រះ
នៃពួកឰយុកោទ្រង់ ១១មួយទៀតទ្រង់ក៏ធ្វើទីខ្ពស់ នៅភ្នំស្រុក
យូដាទាំងប៉ុន្មាន ក៏បានបណ្តាលឱ្យពួកក្រុងយេរូសាឡិម
ផិតព្រះ ព្រមទាំងប្រទាញនាំពួកយូដាឱ្យវង្វេងដែរ ។
១២នោះមានសំបុត្រមកពីហោរាអេលីយ៉ា[ឌ]ដល់ទ្រង់ថា
ព្រះយេហូវ៉ា ជាព្រះនៃដាវីឌ ព្រះបិតាទ្រង់[ឍ] បានមាន
បន្ទូលថា ដោយព្រោះ ទ្រង់មិនបានដើរតាមផ្លូវរបស់
យ៉ូសាផាត ជាព្រះបិតាទ្រង់ និងផ្លូវរបស់អេសា[ណ] ជាស្តេច
យូដា ១៣គឺបានដើរតាមផ្លូវរបស់ពួកស្តេចអ៊ីស្រាអែល
វិញព្រមទាំងបណ្តាលឱ្យពួកយូដា និងពួកអ្នកនៅក្រុង
យេរូសាឡិម ផិតព្រះ ដូចជាពួកវង្សរបស់អ័ហាប់ដែរ[ត]
ហើយដោយព្រោះ ទ្រង់បានសំឡាប់កនិដ្ឋានទាំងប៉ុន្មាន ជា
ព្រះវង្សរបស់ព្រះបិតាទ្រង់ ដែលសុទ្ធតែល្អជាង[ថ]ទ្រង់ផង
១៤នោះមើល ព្រះយេហូវ៉ាទ្រង់នឹងវាយរាស្ត្រទ្រង់ ដោយ
សេចក្តីវេទនាជាខ្លាំងព្រមទាំងពួកបុត្រ និងភរិយាទ្រង់ទាំង
ប៉ុន្មាន ហើយរបស់ទ្រព្យនៃទ្រង់ផង ១៥ឯទ្រង់នឹងកើតមាន
ជំងឺ[ទ]ក្នុងពោះវៀនជាទំងន់ ឈឺរាល់តែថ្ងៃ ដរាបដល់ពោះ
វៀនធ្លាក់ ចេញមកដោយសារជំងឺនោះ ។
១៦ព្រះយេហូវ៉ាទ្រង់ក៏បណ្តាលចិត្តពួកភីលីស្ទីន និងពួក
អារ៉ាប់[ធ] ដែលនៅជិតសាសន៍អេធីអូពី ឱ្យគេកំរើកឡើង
ទាស់នឹងយ៉ូរ៉ាមដែរ ១៧គេឡើងសង្គ្រុញចូលមកក្នុងស្រុក
យូដា ប្លន់យកអស់ទាំងរបស់ទ្រព្យដែល ឃើញមានក្នុងព្រះ
រាជដំណាក់ទៅ ព្រមទាំងនាំយកពួកបុត្រ និងភរិយារបស់
ទ្រង់ទាំងប៉ុន្មានផង បានជាគ្មានបុត្រណា នៅសល់ដល់ទ្រង់

**២១:៦** ច ១ពវ ១២:២៨–៣០ ឆ ២រប ១៨:១ ២២:៣
**២១:៧** ជ ២សយ ៧:១៣ ឈ ២សយ ៧:១៥ ២រប ២៣:៣ ញ ២សយ ២១:១៧
**២១:៨** ដ ២រប ២០:២២–២៣
**២១:១០** ឋ ជន ៣៣:២០
**២១:១២** ឌ ២ពវ ១:១៦–១៧ ឍ ២រប ១៧:៣–៦ ណ ២រប ១៤:២
**២១:១៣** ត ១ពវ ១៦:២៩–៣៣ ថ ១ពវ ២:៣២
**២១:១៥** ទ ជន ១២:១០
**២១:១៦** ធ ២រប ១៧:១០–១១ ២២:១ ២៦:៧
**២១:១៧** ន ២ពវ ១២:១៨ ២រប ២២:១ យអ ៣:៥

**២១:៤** ការសម្លាប់បង្ហូរឈាមបែបនេះដែលសម្លាប់គូរបដិបក្ស ទាំងអស់ក៏ពុំបានបង្ហាញក្នុងគម្ពីរពង្សាវតារក្សត្រទេ (មើល ខ.៦) ។ ស្តេចនៃរាស្ត្រដោយបានដឹកនាំរាស្ត្រនៅក្នុងនគរដែលប្រឆាំង និងការគាំទ្រដែលមានព្រះមហាក្សត្របានរៀបការនិងបុត្រីរបស់អ័ហាប់ ។ ចំពោះការប្រើពាក្យថា "រាស្ត្រអ៊ីស្រាអែល" មើលការពន្យល់ ១២:១៩ ។

**២១:៥** *៨ឆ្នាំ* គឺរយៈពេល ៨៤៨–៨៤១ មុន គ.ស ។ រយៈពេល ៨៤៣–៨៤៨ គឺយ៉ូរ៉ាម គឺជាមួយព្រះបិតារបស់ទ្រង់គឺស្តេចយ៉ូសាផាត គឺជាឆ្នាំទី២របស់យ៉ូរ៉ាម (ប្រៀបធៀប ២ពវ ១:១៧ ៣:១) ។

**២១:៦** *យកបុត្រីរបស់អ័ហាប់ ធ្វើជាភរិយា* មើល ៨១:១ ដោយបានប្រើការពង្រីកសម្ព័ន្ធភាពរវាងយ៉ូសាផាតនិងអ័ហាប់ ។ វាដូចជាការរៀបការជានយោបានដូចជារឿងធម្មតា ។ ពិធីមង្គលការ (អភិសេធ) ដើម្បីជាទំនាក់ទំនងដូចជាអ័ហាក់បានរៀបអភិសេធនិង យេសិបិល ។

**២១:៨–១០** យ៉ូសាផាតដែលគួឱ្យស្រឡាញ់ហើយគោរព បានសប្បាយនិងជ័យជម្នះលើសាសន៏អេដំម (២០:១–៣០) ខណៈដែលយ៉ូរ៉ាមដ៏អាក្រក់គេបានយកជ័យជម្នះលើដោយការប៉ងប្រាថ្នាចង់កាន់កាប់ទឹកដីអេដំមក្នុង (មើលការពន្យល់ ២០:៣០) ។

**២១:១០** *ដរាប់ដល់សព្វថ្ងៃនេះ* មើលការពន្យល់ ៥:៩ *ក្រុងលិបណា* គឺមានទីតាំងចន្លោះស្រុកយូដា និងស្រុកភីលីស្ទីន ។ *ពីព្រោះទ្រង់បានបោះបង់ចោលព្រះយេហូវ៉ា* មើល ២ពវ ៨:២២ អ្នកកាលប្រវត្តិបានបង្ហាញការកាត់ទោសដល់ទង្វើនោះ (មើលការពន្យល់ ១២:១–១៤ ១២:២ មើលសេចក្តីផ្តើមគម្ពីររបាក្សត្រទី១ត្រង់ : គោលបំណងនិងផ្ទៃរឿងទាំងមូល) ។

**២១:១១** *ផិតព្រះ* មើល នក ៣៤:១៥ និងការពន្យល់ ។

**២១:១២–១៥** ការពោលសំអាងនេះ គឺចំពោះសំបុត្រពីអេលីយា ដែលបានបង្ហាញតែក្នុងរបាក្សត្រនៃហោរានោះតែនៅក្នុងគម្ពីរ ពង្សាវតារក្សត្រទើបមានច្រើនជាងគេ (១ពវ ១៧–២ពវ ២) ។ សំបុត្ររបស់អេលីយ៉ាដែលបានបង្ហាញជាក់លាក់នូវភាពមិនស្តាប់បង្គាប់របស់យ៉ូរ៉ាម ដែលឱ្យយ៉ូរ៉ាមទទួលបរាជ័យក្នុងសង្គ្រាម ហើយភរិយានិងបុត្រាបុត្រីក៏មានជម្ងឺរហូតដល់ស្លាប់ (មើលកាពន្យល់ ១៦:១២) ។ ប្រៀបធៀបនិងជម្ងឺរបស់អេសា (១៦:១២–១៤) និងជម្ងឺឃ្លង់របស់អ៊ូស៊ីវ (២៦:១៦–២៣) ។ ក្នុងគម្ពីរពង្សាវតារក្សត្រពុំបានប្រាប់ពីការសុគតរបស់យ៉ូរ៉ាម តើមកដោយសារអ្វីនោះទេ ។ សំបុត្រក៏បញ្ជាក់ថាអេលីយ៉ាត្រូវបានព្រះអម្ចាស់ យកគាត់ឡើងទៅឯស្ថានសួគ៌ដោយផ្ទាល់គឺមុនពេលយ៉ូរ៉ាមក្លាយជាស្តេច (មើល ២ពវ ១:១៧ និងមើលការពន្យល់ ២ពវ ៣:១១) ។

**២១:១៦** *សាសន៍អេធីអូពី* មើលការពន្យល់ ១៤:៩ និង ១៦:៨ ។

មានតែអ័ហាស៊ីយ៉ា ជាបុត្រពៅរបស់ទ្រង់ប៉ុណ្ណោះ[ន]។
18 ក្រោយការទាំងនោះមក ព្រះយេហូវ៉ាទ្រង់ប្រហារ
ស្តេចឱ្យ មានជំងឺក្នុងពោះវៀន ដែលមើលមិនចេះជាឡើយ
19 លុះវេលាកន្លងមកបាន២ឆ្នាំ នោះពោះវៀនទ្រង់ក៏ធ្លាក់
ចេញមក ដោយជំងឺនោះ ហើយទ្រង់សុគតទៅ ដោយរោគ
យ៉ាងអាក្រក់ណាស់ ឯពួករាស្ត្រទ្រង់ មិនបានថ្វាយព្រះភ្លើង
ដល់ទ្រង់[ប] ដូចបានថ្វាយដល់ពួកព្ឋយុកោទ្រង់ទេ 20 កាល
ទ្រង់ចាប់តាំងសោយរាជ្យឡើង នោះមានព្រះជន្ម៣២ឆ្នាំ
ហើយ ក៏សោយរាជ្យនៅក្រុងយេរូសាឡិមបាន៨ឆ្នាំ រួច
ទ្រង់លាចាកលោកទៅ ឥតមានអ្នកណាស្តាយឡើយ គេ
បញ្ចុះសព[ផ]ទ្រង់នៅក្នុងក្រុងដាវីឌ តែមិនមែនក្នុងផ្នូររបស់
ពួកស្តេចទេ ។

## អ័ហាស៊ីយ៉ាឡើងជាស្តេចស្រុកយូដា

*២២:១-៦ – ២ពវ ៨:២៥-២៩*

*២២:៧-៩ – ២ពវ ៩:២១-២៩*

**២២** 1 ពួកអ្នកក្រុង[ក] យេរូសាឡិម[ខ] គេតាំងអ័ហាស៊ីយ៉ាជាព្រ
ះរាជបុត្រាពៅរបស់ទ្រង់ ឡើងធ្វើជាស្តេចជំនួសព្រះបិតា
ដោយព្រោះកងទ័ព[គ] ខាងសាសន៍អារ៉ាប់ ដែលឡើងមកឯទី
បោះទ័ព គេបានសំឡាប់ព្រះជេដ្ឋាទ្រង់ទាំងអស់ទៅ គឺយ៉ាង
នោះដែលអ័ហាស៊ីយ៉ា ជាព្រះរាជបុត្រា យ៉ូរ៉ាម ស្តេចយូដា
បានសោយរាជ្យឡើង 2 កាលអ័ហាស៊ីយ៉ាចាប់ តាំងសោយ
រាជ្យឡើង នោះទ្រង់មានព្រះជន្ម៤២ឆ្នាំ ហើយក៏សោយ
រាជ្យនៅក្រុងយេរូសាឡិមបាន១ឆ្នាំ ព្រះមាតាទ្រង់ព្រះនាម
ជាអ័ថាលា ជាបុត្រីអំរី 3 ទ្រង់ក៏ដើរ[ឃ]តាមផ្លូវរបស់ពួកវង្ស
អ័ហាប់ដែរ[ង] ពីព្រោះព្រះមាតាទ្រង់ ជាអ្នកជួយគំនិតឱ្យធ្វើ
អំពើអាក្រក់ 4 ហើយទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់
នៅព្រះនេត្រនៃព្រះយេហូវ៉ាដូចជាពួកវង្សរបស់ អ័ហាប់
ដែរ ដ្បិតក្រោយដែលព្រះបិតាទ្រង់បានសុគតទៅហើយ
ពួកនោះជាអ្នកដឹកនាំគំនិតទ្រង់ ដរាបដល់ទ្រង់ត្រូវវិនាស
5 ទ្រង់ចេះតែប្រព្រឹត្តតាមដំបូន្មានរបស់គេ ក៏ទៅជាមួយនឹង
យ៉ូរ៉ាម ជាព្រះរាជបុត្រា អ័ហាប់ស្តេចអ៊ីស្រាអែល ដើម្បី
ច្បាំងនឹងហាសែល ជាស្តេចស្រុកស៊ីរី ទ្រង់ក្រុងរ៉ាម៉ូត-
កាឡាតដែរ[ច] ឯពួកស៊ីរី គេធ្វើឱ្យយ៉ូរ៉ាមមានរបួស 6 រួច
ទ្រង់វិលទៅក្រុងយេសរាលវិញ ដើម្បីមើលរបួសឱ្យជា
ដែលគេបានធ្វើទ្រង់នៅទ្រង់រ៉ាម៉ា ក្នុងកាលដែលទ្រង់ច្បាំង
និងហាសែល[ឆ]ស្តេចស៊ីរី រួចអ័ហាស៊ីយ៉ា ជាព្រះរាជបុត្រា
យ៉ូរ៉ាប ស្តេចយូដា ទ្រង់ក៏យាងទៅដល់យេសរាល គាល់
យ៉ូរ៉ាម ជាព្រះរាជបុត្រាអ័ហាប់ ដែលទ្រង់ប្រឈួន 7 រីឯ
ការដែលអ័ហាស៊ីយ៉ា[ជ]បានទៅគាល់យ៉ូរ៉ាម នោះកើតមក

**២១:១៩** ប ២រប ១៦:១៤
**២១:២០** ផ ២រប ២៤:២៥ ២៨:២៧ ៣៣:២០
**២២:១** ក ២រប ៣៣:២៥ ៣៦:១ ខ ២រប ២៣:២០-២១ ២៦:១ គ ២រប ២១:១៦-១៧
**២២:៣** ឃ ២រប ១៨:១ ង ២រប ២១:៦
**២២:៥** ច ២រប ១៨:១១,៣៤
**២២:៦** ឆ ១ពវ ១៩:១៥ ២ពវ ៨:១៣-១៥
**២២:៧** ជ ២ពវ ៩:១៦

**២១:២០** *៨ឆ្នាំ* មើលការពន្យល់ខ.៥ *តែមិនមែនក្នុងផ្នូររបស់ពួកស្តេចទេ* គឺមានតែអ្នកកាលប្រវត្តិបានបង្ហាញការនេះ គឺការបដិសេធពីប្រជារាស្ត្រដែលស្រប់និងឬតម្រូវឱ្យធ្វើពិធីបញ្ចុះដែលជាទំលាប់ នៃយ៉ូរ៉ាមក៏ដូចជាស្តេចដ៏ទៃទៀតនៃសាសន៍យូដាដែរ (ប្រៀបធៀប ២៤:២៥) ។

**២២:១-៩** កិច្ចការអ្នកកាលប្រវត្តិអំពីរាជបល្ល័ង្ក របស់អ័ហាស៊ីយ៉ាគឺមានរយៈពេលខ្លីជាអត្ថបទក្នុង ២ពវ ៨:២៤-៩:២៩ ដែលជាសេចក្តីពិតដែលក្រុមស្តេចបានគិតពីការបះបោរ ដូចជាយេហ៊ូវនិងការធ្លាក់ចុះរបស់បុត្រីអំរី (មើល ២ពវ ៨:២៦ មើល ១ពវ១៦:២១-២៨) ដូចជានៅផ្នែកនគរខាងជើងនោះគឺអ្នកកាលប្រវត្តិ ក៏ពុំបានចាប់អារម្មណ៍ ។ តែអ្នកកាលប្រវត្តិបានបង្ហាញពីការកាត់ទោស ពីព្រះអម្ចាស់តែប៉ុណ្ណោះ ។ ភាពខ្សោយរបស់អ័ហាស៊ីយ៉ាផ្ទាល់និងការដែលគាត់ចូលរួមបក្សសម្ព័ន្ធ ជាមួយសាសន៍ដ៏ទៃនាំមកនូវការកាត់ទោសជាលទ្ធផលទៅវិញ ហើយស្តេចអង្គនេះបានសោយរាជ្យតែមួយឆ្នាំប៉ុណ្ណោះ (មើលការពន្យល់ ១៦:២-៩ មើលសេចក្តីផ្តើមកណ្ឌគម្ពីររបាក្សត្រទី១ផងដែរ គឺត្រង់គោលបំណងនិងផ្ទៃរឿង) ។

**២២:១** *គេបានសំឡាប់ព្រះជេដ្ឋាទ្រង់ទាំងអស់* ហេតុការជាការដាក់ទោសពីរព្រះគឺយ៉ូរ៉ាមដែលបានសម្លាប់ប្អូនដល់បងប្រុសគាត់ទាំងអស់ក៏ត្រូវឃើញកូនប្រុសៗរបស់ទ្រង់បានសុគតដោយភ្លាមៗផងដែរ (២១:៤,១៣-១៧) ។

**២២:២** *៤២ឆ្នាំហើយ* គឺធ្វើឱ្យអ័ហាស៊ីយ៉ាចាស់ជាងព្រះបិតារបស់ទ្រង់ផងដែរ (២១:២០) ។

**២២:៣-៤** ឥទ្ធិពលនៃពួកសង្ឃអ៊ំរីក្នុងស្រុកយ៉ូដាក៏បង្ហាញពីអំណាចព្រះចេស្តារបស់ស្តេចអថាលា និងវត្តមានទីប្រឹក្សាដែលមកពីនគរខាងជើង (មើល ការពន្យល់ ១៨:២៩) ។

**២២:៥** *ក៏ទៅជាមួយនឹងយ៉ូរ៉ាម . . . ដើម្បីច្បាំង* សកម្មភាពនេះស្រដៀងនិងយ៉ូសាផាតដែលមានសេចក្តីក្រេវក្រោធចេញ ពីព្រះយេហូវ៉ា (មើល ១៩:២ និងការពន្យល់) ។ *ហាសែល* បានចាក់ប្រេងតាំងដោយអេលីសេ តែក្រោយមកទៀតក៏បានសម្លាប់មេរបស់គាត់ ក្នុងការចង់ដណ្តើមយករាជបល្ល័ង្ក (២ពវ ៨:១៣-១៥ ប្រៀបធៀប ១ពវ ១៩:១៥ និងការពន្យល់) *ក្រុងរ៉ាម៉ូតកាឡាត* គឺមានទីតាំងនៅតំបន់ព្រំដី នៃស្រុកយ័រដាន់គឺត្រង់ចន្លោះស្រុកអ៊ីស្រាអែលនិងអើរ៉ាម ។ ក្នុងរយៈពេល១០ឆ្នាំមុននោះស្តេចយ៉ូសាផាតបានចូលរួមជាមួយ អ័ហាប់ក្នុងការធ្វើសង្គ្រាមដែលធ្វើឱ្យ អ័ហាប់បាត់បង់ជីវិត (ជំពូក ១៨,១ពវ ២២) ។

**២២:៦** *រួចទ្រង់វិលទៅឯក្រុងយេសរាលវិញ* ក៏បានឃើញយ៉ូរ៉ាមនៅឯក្រុងរ៉ាម៉ូតកាឡាតហើយតាំងឱ្យយេហ៊ូវទទួលការងារនោះវិញ (២ពវ ៨:២៨ ៩:២៨) ។

**២២:៧** *ព្រះយេហូវ៉ាបានចាកប្រេងតាំងឡើង ឱ្យបានបំផ្លាញវង្សរបស់អ័ហាប់ចេញ* គឺអ្នកកាលប្រវត្តិបានសន្មតថាអ្នកអាន ឬអ្នកតាមដានដឹងច្បាស់ពីការចាក់ប្រេងតាំងដល់យេហ៊ូវ ហើយក៏បង្ហាញយ៉ាងច្បាស់ពីការធ្វើការបះបោផ្តួលរំលំដែលបានជាលទ្ធផលមកវិញ គឺការសុគតរបស់ស្តេចយ៉ូរ៉ាមនិងអ័ហាស៊ីយ៉ា (២ពវ ៨:២៨-៩:២៨) ។ ខណៈពេលដែលអ្នកនិពន្ធកណ្ឌគម្ពីរពង្សាវតារក្សត្រ ក៏បានបង្ហាញពីការចុងបញ្ចប់នៃខ្សែរាជវង្សរបស់ស្តេចអំរីគឺជាលទ្ធផលនៃការកាត់ទោសពីព្រះយេហូវ៉ា (១ពវ ២១:២០-២៩ ២ពវ ៩:២៤-១០:១៧) អ្នកកាលប្រវត្តិបានសំគាល់ថាការដាក់ទោសដល់

អំពីព្រះទេ ដើម្បីឱ្យទ្រង់ត្រូវវិនាស ដ្បិតកាលទ្រង់បានទៅ
ដល់ហើយ នោះក៏យាងចេញទៅជាមួយនឹងយ៉ូរ៉ាម ទាស់នឹង
យេហ៊ូវ ជាកូននីមស៊ី ជាអ្នកដែលព្រះយេហូវ៉ាបានចាក់
ប្រេងតាំងឡើងឱ្យបានបំផ្លាញវង្ស របស់អ័ហាប់ចេញ
៨ហើយកាលយេហ៊ូវកំពុងតែសំរេចទោស ដល់វង្សរបស់
អ័ហាប់[ឈ] នោះលោកក៏ប្រទះឃើញពួកអ្នកខ្លះ ដែលជាពូជ
ពង្សស្តេចយូដា គឺជាបុត្ររបស់ពួកជេដ្ឋាអ័ហាស៊ីយ៉ាដែល
ជាជិនិតទ្រង់ ហើយលោកសំឡាប់គេទាំងអស់ទៅ ៩លោក
ក៏រកអ័ហាស៊ីយ៉ាដែលពួន[ញ] នៅក្នុងក្រុងសាម៉ារីដែរ ហើយ
គេចាប់ទ្រង់ នាំមកដល់យេហ៊ូវ រួចគេសំឡាប់បង់ ហើយ
កប់សពទ្រង់ទៅ ដោយថា ទ្រង់ជាបុត្រយ៉ូសាផាតដែលបាន
ស្វែងរក[ដ]ព្រះយេហូវ៉ាអស់ពីព្រះទ័យ ដូច្នេះ ក្នុងវង្សរបស់
អ័ហាស៊ីយ៉ា គ្មានអ្នកណាមួយអាចនឹងគ្រប់គ្រងរាជ្យបាន
ឡើយ ។

## អ័ថាលា និងយ៉ូអាស

*២២:១០-២៣:២១ – ២ពស ១១:១-២១*

១០ឯព្រះនាងអ័ថាលា ជាព្រះមាតាអ័ហាស៊ីយ៉ា កាល
ឃើញថា ព្រះរាជបុត្របានសុគតហើយ នោះព្រះនាងក៏
ចាត់ចែងបំផ្លាញពូជពង្សហ្លួង ក្នុងវង្សានុវង្សនៃពួកយូដា
ទាំងអស់ទៅ ១១ប៉ុន្តែយ៉ូសេបា ជាព្រះរាជបុត្រីស្តេច នាង
លួចយកយ៉ូអាស ជាបុត្រាអ័ហាស៊ីយ៉ា ចេញពីពួកព្រះរាជ
បុត្រាដែលត្រូវគេសំឡាប់ទាំងប៉ុន្មាននោះ ទៅបំពួនទុក
ព្រមទាំងមេនំនៅក្នុងបន្ទប់ គឺយ៉ាងនោះដែលយ៉ូសេបា ជា
ព្រះរាជបុត្រីស្តេចយ៉ូរ៉ាម ប្រពន្ធរបស់យេហូយ៉ាដាដ៏ជា
សង្ឃត្រូវជាកនិដ្ឋារបស់អ័ហាស៊ីយ៉ា បានបំពួនទ្រង់ឱ្យរួចពី
ព្រះនាងអ័ថាលា ដើម្បីកុំឱ្យត្រូវស្លាប់ ១២ទ្រង់ក៏នៅជាមួយ
នឹងគេ លាក់ទុកក្នុងព្រះវិហារនៃព្រះអស់៦ឆ្នាំ កំពុងដែល
ព្រះនាងអ័ថាលាគ្រង់គ្រងរាជ្យនៅ ។

**២៣** ១នៅឆ្នាំទី៧ នោះយេហូយ៉ាដា លោកចំរើនអំណាច
ឡើយ ក៏នាមឱ្យពួកមេទ័ពចុះសញ្ញានឹងលោក គឺអ័សារា ជា
កូនយេរ៉ូហាំ អ៊ីសម៉ាអែល ជាកូនយ៉ូហាណានអ័សារា ជា
កូនអូបិឌ ម្អាសេយ៉ា ជាកូន អ័ដាយ៉ា និងអេលីសាផាត ជា
កូនស៊ីកគ្រី ២គេក៏ដើរទៅមកក្នុងស្រុកយូដា ប្រមូលពួក

**២២:៨** ឈ ២ពស ១០:១៣
**២២:៩** ញ ពច ៩:៥ ដ ២រប ១៧:៤
**២៣:២** ក ជន ៣៥:២-៥

អ័ហាស៊ីយ៉ា គឺជាការកាត់ទោសពីព្រះដែរ ។

**២២:៩** រឿងរ៉ាវនៃការសុគតរបស់ស្តេចអ័ហាស៊ីយ៉ា ក៏ឱ្យឃើញលក្ខណៈពីរផ្សេងៗគ្នា(ប្រៀបធៀប ២ពស ៩:២១-២៧ ១០:១២-១៤)។ (មើលការពន្យល់ ខ.៧) ក៏ជាការប្រសើដែលជ្រើសយក ព័ត៌មានលំអិតរបស់អ្នកកាលប្រវត្តិ ជាសេចក្តីបន្ថែមដល់កណ្ឌគម្ពីរ ពង្សាវតារក្សត្រ ដែលគ្មានលក្ខណៈផ្ទុយគ្នាទោះបីជាវាមានការលំបាកយល់ពីទីតាំងនិងពេលវេលាក្តី ។ ដោយឡែកពីនេះ ក៏ជាសេចក្តីរាយការណ៍របស់អ្នកកាលប្រវត្តិថា ស្តេចអ័ហាស៊ីយ៉ា បានទទួលការបញ្ចុះព្រះសពដ៏សមរម្យ ពីព្រោះនេះជាការគោរពដល់បិតារបស់ទ្រង់និងជាច្បាប់ទំលាប់ ជាជាងគិតពីព្រះអង្គទ្រង់ផ្ទាល់ ។ តែលក្ខណៈដែលផ្សេៗគ្នាក្នុងកិច្ចការ ពីនោះក៏មិនចាំបាច់ កត់ជាប្រវត្តិសាស្ត្រទេ ។

**២២:១០-១២** មើល ២ពស ១១:១-៣ គឺក្នុងប្រវត្តិសាស្ត្រនៃសាសន៍យូដា អ័ហាស៊ីយ៉ា ជាតំណាងនៃការបែកបាក់ ខ្សែរាជវង្សរបស់ស្តេចដាវីឌ ។ នាងជាមហាក្សត្រីមួយអង្គ ដែលដឹកនាំប្រជារាស្ត្រសម្រាប់តែកេរ្តិ៍ឈ្មោះនាងតែប៉ុណ្ណោះគឺក្នុងឆ្នាំ(៨៤១-៨៣៥ មុន គ.ស)សេចក្តីប៉ងប្រាថ្នារបស់នាងគឺលុបបំបាត់ចោលនូវខ្សែរាជ្យវង្សានុវង្សឱ្យអស់ នាងក៏អនុវត្តតាមយ៉ូរ៉ាមជាស្វាមីរបស់នាង(២១:៤)។ គឺជាការគំរាមកំហែងដល់ជីវិតខ្សែរាជវង្សរបស់ស្តេចដាវីឌ ហើយម្ចាស់ក្សត្រីនេះទទួលជោគជ័យវិញសាសន៍យូដាត្រូវប្រកាស់ទាមទារតាមរយៈខ្សែរាជវង្សនៃបុត្រីអំរី ក្នុងភូមិភាគខាងជើងតាំងពីអ័ហាស៊ីយ៉ាបានផ្តាច់ចេញ ពីខ្សែរាជវង្ស និងពុំមានបន្សល់ទុកនូវព្រះរាជបុត្រាឡើយនិងអ្នកទទួលមរដក ។

**២៣:១-២៤:២៧** មើលការពន្យល់ក្នុង ២ពស ១១:៤-១២:២១ និងការពន្យល់ ។ អ្នកកាលប្រវត្តិបានញែកកិច្ចការរាជបល្ល័ង្ក ទៅជាបីផ្នែកគឺតាំងពីឆ្នាំ(៨៣៥-៧៩៥ មុន គ.ស)ទី(១)គឺទាក់ទងនិងបល្ល័ង្កនៃរាជវង្សស្តេចដាវីឌ(ជំពូកទី២៣)ទី(២)យ៉ូអាសនិងយេហូយ៉ាដាគឺជាឆ្នាំល្អ(២៤:១-១៦)ទី(៣)យ៉ូអាសតែឯងគឺជាឆ្នាំអាក្រក់(២៤:១៧-២៧)។ ផ្នែកចុងក្រោយបង្អស់គឺស៊ីនិងកាលប្រវត្តិ ដែលមានការដាក់ទណ្ឌកម្មភ្លាមៗសូមបញ្ជាក់ថាការកំណត់ត្រាពីការប្រវត្តិបានបង្ហាញឱ្យឃើញ នូវរចនាសម្ព័ន្ធ ជាលក្ខណៈរង្វង់ខួបនូវការដែលចេះស្តាប់បង្គាប់ដល់ព្រះការ និងការមិនស្តាប់បង្គាប់ព្រះ(២៤:១៥-១៧,២៣) មើលការពន្យល់ ១២:២ ១៤:២-១៦:១៤ ។

**២៣:១-២១** មើល ២ពស ១១:៤-២០ អ្នកកាលប្រវត្តិបានតាមដានប្រភពទាំងនោះយ៉ាងប្រកៀកប្រកិត ប៉ុន្តែក៏បានណែនាំពីឯកសារ ដែលឆ្លុះបញ្ចាំងអំពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន របស់គេទៅលើផ្នែកទាំងបីនោះ (១)គឺជាកិច្ចការក្នុងពង្សាវតារក្សត្រ ដែលទាក់ទងច្រើនក្នុងរឿងធ្វើសង្គ្រាមនិងការផ្តួលរំលំដណ្តើមរាជ្យ ។ អ្នកកាលប្រវត្តិក៏បានបង្ហាញអំពីឯកសារនិងការងារព្រះវិហាររបស់ព្រះយេហូវ៉ា និងតួនាទីក្នុងពួកជំនុំ(ខ.២,៦,៨,១៣,១៨-១៩) ។ (២)អ្នកកាលប្រវត្តិក៏បង្ហាញ ពីភាពរីកដុះដាលនៃការប្រមូលកម្លាំងដើម្បីផ្តួលរំលំដណ្តើមរាជ្យ(ខ.៣,៥-៦,៨,១០,១៦-១៧) (៣)អ្នកកាលប្រវត្តិបានបង្ហាញពីការចាប់អារម្មណ៍ បន្ថែមទៀតចំភាពឧត្តម្ភនៃព្រះវិហារដែលបង្ហាញថាមានតែសង្ឃ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទីបរិសុទ្ធនោះបាន(ខ.៥-៦,១៩) ។

**២៣:១** *អ័សារា . . . អេលីសាផាត* អ្នកកាលប្រវត្តិបានប្រាប់ឈ្មោះមេទ័ពទាំងនោះដែលពុំមានក្នុង កណ្ឌគម្ពីរពង្សាវតារក្សត្រទេ តែមិនបង្ហាញប្រាប់ពីពួកមេទ័ពពួកនាយ និងអ្នកដែលបម្រើការជាទាហានពួកថ្មើជើង(មើលការពន្យល់ ២ពស ១១:៤) ។ ការបង្ហាញរបស់អ្នកកាលប្រវត្តិប្រាប់ថាការចូលទីលានបរិសុទ្ធព្រះវិហារគឺអាចចូលបានតែអ្នកដែលមានអំណាចមួយ ។

**២៣:២** *ពួកលេវីពីគ្រប់ . . . ក្នុងរាជវង្សានុវង្សនៃសាសន៍អ៊ីស្រាអែល* គឺជាការបញ្ជាក់ឱ្យឃើញ អ្នកគ្រប់គ្រងព្រះវិហារនិងការរីកដុះដាល ក្រុមចលនាផ្តួលរំលំរាជបល្ល័ង្កដល់ស្តេចអ័ថាលា ។

លេវី[ក]ពីគ្រប់ទាំងទីក្រុងស្រុកយូដា ព្រមទាំងពួកជាប្រធាន
ក្នុងវង្សានុវង្សនៃសាសន៍អ៊ីស្រាអែល ឱ្យមូលមកឯក្រុង
យេរូសាឡិម ៣រួចពួកជំនុំទាំងអស់គ្នាក៏ចុះសញ្ញា[ខ]នឹងស្ដេច
នៅក្នុងព្រះវិហារ នៃព្រះយេហូយ៉ាដាក៏ពោលឡើងថា
មើល ត្រូវឱ្យព្រះរាជបុត្រានៃ ស្ដេច បានសោយរាជ្យឡើង
ដូចជាព្រះយេហូវ៉ាបានមានបន្ទូលហើយ ពីដំណើរពួក
វង្សដាវីឌ[គ] ៤ឯអ្នករាល់គ្នាត្រូវធ្វើយ៉ាងដូច្នេះ ចំណែកពួក
សង្ឃ និងពួកលេវី ក្នុងពួកអ្នករាល់គ្នាដែលចូលមកនៅថ្ងៃ
ឈប់សំរាក នោះត្រូវឱ្យ១ភាគក្នុង៣ចាំយាមនៅមាត់ទ្វារ
៥មួយភាគក្នុង៣ទៀត ត្រូវនៅឯដំណាក់នៃស្ដេច ហើយមួយ
ភាគក្នុង៣ទៀត ត្រូវនៅត្រង់ទ្វារជើងជញ្ជាំង ឯបណ្ដាជន
ទាំងឡាយ ត្រូវនៅក្នុងទីលានរបស់ព្រះ វិហារនៃព្រះ
យេហូវ៉ាវិញ ៦កុំឱ្យអ្នកណាចូលទៅក្នុងព្រះវិហារនៃព្រះ
យេហូវ៉ាឡើយ លើកតែពួកសង្ឃ និងពួកអ្នកដែលជាជំនួយ
ដល់ពួក លេវីប៉ុណ្ណោះ អ្នកទាំងនោះចូលទៅបាន ពីព្រោះ
គេបរិសុទ្ធទាំងអស់ តែបណ្ដាជនទាំងឡាយត្រូវរក្សា
បញ្ញើ[ឃ]នៃព្រះយេហូវ៉ាវិញ ៧ត្រូវឱ្យពួកលេវីឈរព័ទ្ធជុំវិញ
ស្ដេច ដោយកាន់គ្រឿងសស្ត្រាវុធគ្រប់ៗគ្នា បើមានអ្នកណា
ចូលមកក្នុងព្រះវិហារ នោះត្រូវសំឡាប់បង់ត្រូវឱ្យអ្នករាល់
គ្នា នៅជាប់នឹងស្ដេច នៅអស់វេលាដែលទ្រង់យាងចេញ
ចូល ។

៨ដូច្នេះ ពួកលេវី និងពួកយូដាទាំងអស់គ្នា ក៏ធ្វើតាម
បង្គាប់យេហូយ៉ាដា ដ៏ជាសង្ឃគ្រប់ជំពូក[ង] គេនាំយកពួកគេ
រៀងខ្លួន ទាំងពួកដែលត្រូវចូលនៅថ្ងៃឈប់សំរាក និងពួក
ដែលចេញនៅថ្ងៃឈប់សំរាកដែរ ដ្បិតយេហូវ៉ាដា ក៏ជា
សង្ឃ លោកមិនឱ្យពួកវេនណាឈប់ទេ[ច] ៩លោកប្រគល់
លំពែង និងខែលធំតូចជារបស់ស្ដេចដាវីឌ ពីដើមដែល
ទុកនៅក្នុងព្រះវិហារនៃព្រះដល់ពួកមេទ័ព ១០រួចលោក
ដាក់មនុស្ស ទាំងអស់ឱ្យឈរព័ទ្ធនៅជុំវិញស្ដេច ទាំងកាន់
គ្រឿងសស្ត្រាវុធរបស់គេរៀងខ្លួន ចាប់តាំងពីខាងស្ដាំ
ព្រះវិហារ រហូតទៅដល់ខាងឆ្វេង ក្បែរអាសនា និង
ព្រះវិហារ ១១នោះគេនាំព្រះរាជបុត្រានៃស្ដេចចេញមក
បំពាក់មកុដលើទ្រង់ ហើយថ្វាយសេចក្ដីបន្ទាល់[ឆ] រួចតាំង

**២៣:៣** ខ ២ពវ ១១:១៧ គ ២សយ ៧:១២ ១ពវ ២:៤ ២របៈ ៦:១៦ ៧:១៨ ២១:៧
**២៣:៦** ឃ សក ៣:៧
**២៣:៨** ង ២ពវ ១១:៩ ច ១រប ២៤:១
**២៣:១១** ឆ ចទ ១៧:១៨
**២៣:១៣** ជ ១ពវ ១:៤១ ឈ ១ពវ ៧:១៥
**២៣:១៥** ញ យរ ៣១:៤០
**២៣:១៦** ដ ២រប ២៩:១០ ៣៤:៣១ នហ ៩:៣៨
**២៣:១៧** ឋ ចទ ១៣:៦–៩
**២៣:១៨** ឌ ១រប ២៣:២៨–៣២ ឍ ១រប ២៣:៦ ២៥:៦

ទ្រង់ឡើងជាស្ដេច ឯយេហូយ៉ាដា នឹងពួកកូនលោកក៏ចាក់
ប្រេងថ្វាយទ្រង់ ហើយពោលថា សូមឱ្យព្រះរាជាបាន
ប្រកប ដោយសេចក្ដីចំរើនចុះ ។

១២លុះកាលព្រះនាងអ័ថាលា បានឮសូរអឺងកងពីពួក
បណ្ដាជន ដែលរត់ទៅមកទាំងសរសើរដល់ស្ដេច នោះ
ព្រះនាងក៏យាងចូលទៅគេ ក្នុងព្រះវិហារនៃព្រះយេហូវ៉ា
១៣ព្រះនាងទតទៅឃើញស្ដេច[ជ] ទ្រង់ឈរនៅលើទីថ្កល់[ឈ]
ត្រង់ផ្លូវចូល ព្រមទាំងពួកមេទ័ព និងពួកផ្លុំត្រែ នៅអមទ្រង់
ឯពួកអ្នកស្រុកទាំងអស់គ្នា គេមានសេចក្ដីអំណរ ហើយ
ផ្លុំត្រែឡើង ពួកចំរៀងក៏កាន់ប្រដាប់ភ្លេង ហើយនាំមុខគេ
ច្រៀងទំនុកសរសើរ នោះព្រះនាងក៏ហែកព្រះពស្ត្រ ដោយ
បន្ទូលថា នេះជាការក្បត់ គឺជាការក្បត់ហើយ ១៤ឯ
យេហូយ៉ាដាដ៏ជាសង្ឃ លោកនាំពួកមេ ដែលត្រួតលើ
កងទ័ពចេញមកប្រាប់ថា ចូរនាំព្រះនាងចេញទៅក្រៅ
ហើយបើអ្នកណាតាមព្រះនាង នោះត្រូវសំឡាប់គេចោល
ចេញ ដ្បិតលោកបានហាមថាកុំឱ្យសំឡាប់ព្រះនាង នៅក្នុង
ព្រះវិហារនៃព្រះយេហូវ៉ាឡើយ ១៥ដូច្នេះ គេក៏ចៀសផ្លូវឱ្យ
ព្រះនាងចេញទៅ ហើយព្រះនាងយាងចេញទៅតាមទ្វារ[ញ]
ដែលសេះចូលទៅឯដំណាក់ស្ដេច រួចគេធ្វើគុកនៅទីនោះ។

១៦រីឯយេហូយ៉ាដា លោកនាំឱ្យខ្លួនលោក និងពួកបណ្ដា
ជន ហើយនិងស្ដេចចុះសញ្ញាគ្នា[ដ]ថា និងធ្វើជារាស្ត្រ
របស់ផងព្រះយេហូវ៉ា ១៧បន្ទាប់មក បណ្ដាជនទាំងឡាយគេ
ចូលទៅរំលំវិហាររបស់ព្រះបាលអស់ទៅ ហើយបំបាក់
បំបែកអស់ទាំងអាសនា នឹងរូបព្រះឱ្យខ្ទេចខ្ទី ក៏សំឡាប់[ឋ]
ម៉ាត់ថាន ជាសង្ឃរបស់ព្រះបាល នៅមុខអាសនានោះដែរ
១៨យេហូយ៉ាដា លោកក៏តាំងឱ្យមានពួកអ្នកថែទាំមើល
ព្រះវិហារនៃព្រះយេហូវ៉ា នៅក្រោមបង្គាប់នៃពួកលេវី[ឌ]
ដ៏ជាសង្ឃ ដែលដាវីឌបានដំរូវឱ្យមានដំណែង ក្នុងព្រះ
វិហារ[ឍ]នៃព្រះយេហូវ៉ា សំរាប់នឹងថ្វាយដង្វាយដុតដល់
ព្រះយេហូវ៉ា ដូចជាមានសេចក្ដីចែងទុកក្នុងក្រិត្យវិន័យ
របស់លោកម៉ូសេ គឺដោយសេចក្ដីរីយរាយសប្បាយ ហើយ
ច្រៀងចំរៀងតាមបង្គាប់ដវីឌ ១៩លោកក៏ដាក់ពួកឆ្មាំទ្វារ

**២៣:១៩** ណ ១រប ៩:២២

**២៣:៣** *ដូចជាព្រះយេហូវ៉ាមានបន្ទូលហើយ* មើល ២សយ ៧:១១–១៦ ។

**២៣:១១** *សេចក្ដីបន្ទាល់* វាជាលក្ខណៈសេចក្ដីបន្ទាល់ដែលក្រុមពួកមេទ័ពទាំងអស់បានចុះសញ្ញានិងស្បថនិងគ្នាជាក្រុម (ខ.១,៣ ប្រៀបធៀប ១៦) ឬស្បថចំពោះច្បាប់បញ្ញត្តនៃព្រះយេហូវ៉ា ចំពោះស្ដេចដែលត្រូវសោយរាជ្យផងដែរ (ចទ ១៧:១៨–២០)។ មើលការពន្យល់ ២ពវ ១១:១២ *សូមឱ្យព្រះរាជាបានប្រកប ដោយសេចក្ដីចំរើនចុះ* ។ មើលការពន្យល់ក្នុង ទដ ៦២:៤។

**២៣:១៣** *ពួកចម្រៀងក៏កាន់ប្រដាប់ភ្លេង* អ្នកកាលប្រវត្តិបន្ថែមពាក្យ (ហើយពុំបានឃើញក្នុង ២ពវ ១១:១៤) ពីវត្តមានរបស់ក្រុមតន្ត្រីពួកលេវីដែលដឹកនាំការសរសើរព្រះ (មើលការពន្យល់ ១រប ៦:៣១–៤៨) ។

**២៣:១៨–១៩** អ្នកកាលប្រវត្តិបានបន្ថែមពត៌មានអំពីទម្លាប់នៅក្នុងព្រះវិហារនិងកងផ្មើជើងប្រចាំការតាមច្រកទ្វារកំផែង (សូមមើលការពន្យល់ ខ.១–២១) ។

នៅអស់ទាំងទ្វារព្រះវិហារ[ណ]នៃព្រះយេហូវ៉ា ដើម្បីនឹង
ឃាត់ មិនឱ្យអ្នកណាដែលមិនស្អាតក្នុងការអ្វីមួយ បានចូល
ទៅឡើយ ២០រួចមកលោកប្រមូលពួកមេទ័ព ពួកអ្នកធំ ពួក
ចៅហ្វាយលើបណ្តាជន និងពួកអ្នកស្រុកទាំងអំបាលម៉ាន
មក ហើយនាំស្តេចចុះពីព្រះវិហារនៃព្រះយេហូវ៉ា ដង្ហែ
ចូលទៅក្នុងព្រះរាជដំណាក់តាមទ្វារខាងលើ[ត] លើកដំកល់
លើបល្ល័ង្ករាជ្យ ២១ដូច្នេះ ពួកអ្នកស្រុកទាំងអស់គ្នា ក៏មាន
សេចក្តីរីករាយសប្បាយ ហើយទីក្រុងបានសេចក្តីសាន្ត
ត្រាណ ឯព្រះនាងអ័ថាលា គេបានធ្វើគុតដោយដាវទៅ[ថ] ។

### ស្តេចយ៉ូអាសជួសជុលព្រះវិហារ

*២៤:១-១៤ – ២ពវ ១២:១-១៦*
*២៤:២៣-២៧ – ២ពវ ១២:១៧-២១*

**២៤** ១កាលយ៉ូអាសទ្រង់ចាប់តាំងសោយរាជ្យឡើង នោះ
មានព្រះជន្ម៧ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុងយេរូសាឡិម
បាន៤០ឆ្នាំ ព្រះមាតាទ្រង់ព្រះនាម ជាសីបយ៉ាជាអ្នកក្រុង
បៀរ-សេបា ២យ៉ូអាសទ្រង់ប្រព្រឹត្តសេចក្តីដ៏ត្រឹមត្រូវនៅ
ព្រះនេត្រព្រះយេហូវ៉ា[ក] គ្រប់១ជីវិតយេហូយ៉ាដា ដ៏ជាសង្ឃ
៣យេហូយ៉ាដាក៏រកបាននាង២នាក់ថ្វាយទ្រង់ជាភរិយា
ហើយទ្រង់បង្កើតបានបុត្រាបុត្រី ។
៤ក្រោយនោះមក យ៉ូអាសទ្រង់មានព្រះទ័យនឹកចង់ជួស
ជុលព្រះវិហារនៃព្រះយេហូវ៉ាឡើងដូចដើម ៥ទ្រង់ក៏ប្រមូល
ពួកសង្ឃ និងពួកលេវីមកបង្គាប់ថា ចូរចេញទៅឯអស់ទាំង
ទីក្រុងស្រុកយូដា រៃប្រាក់[ខ]ពីពួកអ៊ីស្រាអែលទាំងអស់រាល់
តែឆ្នាំ[គ] ដើម្បីនឹងជួសជុលព្រះវិហាររបស់ ព្រះនៃអ្នករាល់
គ្នា ហើយប្រឹងប្រែងឡើងផង ប៉ុន្តែពួកលេវី[ឃ]មិនបានប្រឹង
ប្រែងឡើយ ៦ដូច្នេះ ស្តេចទ្រង់ហៅយេហូយ៉ាដាដ៏ជាសំដេច
សង្ឃមកសួរថា ហេតុដូចម្តេចបានជាលោកមិនបង្ខំឱ្យពួក
លេវីទៅហូតពន្ធពីពួកយូដា និងពួកក្រុងយេរូសាឡិម ដូច
ជាលោកម៉ូសេ ជាអ្នកបំរើរបស់ព្រះយេហូវ៉ា និងពួកជំនុំ
នៃសាសន៍អ៊ីស្រាអែលបានបង្គាប់ទុក សំរាប់ត្រសាលនៃ
សេចក្តីបន្ទាល់ដូច្នេះ[ង] ៧ដ្បិតពួកបុត្ររបស់នាងអ័ថាលា
ជាស្រីដ៏អាក្រក់នោះ បានបំបាក់បំបែកព្រះវិហារនៃព្រះ
ហើយព្រមទាំងយកគ្រឿងប្រដាប់បរិសុទ្ធទាំងប៉ុន្មាន ដែល
នៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា ទៅថ្វាយដល់ព្រះបាល
វិញ ។
៨ដូច្នេះ ស្តេចទ្រង់ចេញបង្គាប់ ហើយគេក៏ធ្វើហឹប១
ដាក់នៅមាត់ទ្វារព្រះវិហារនៃព្រះយេហូវ៉ា ៩រួចប្រកាស
ប្រាប់នៅគ្រប់ក្នុងស្រុកយូដា និងនៅក្រុងយេរូសាឡិម ឱ្យគេ
យកពន្ធមកថ្វាយព្រះយេហូវ៉ា ដូចជាលោកម៉ូសេ ជាអ្នកបំរើ
របស់ព្រះបានបង្គាប់ដល់ពួកអ៊ីស្រាអែល នៅទីរហោស្ថាន
ដែរ ១០នោះពួកអ្នកដែលជាប្រធាន និងបណ្តាជនទាំង
ឡាយ ក៏រីករាយសប្បាយ[ច] ហើយយកប្រាក់មកដាក់ក្នុងហឹប
ដរាបដល់បានគ្រប់ ១១វេលាណាដែលពួកលេវី ឃើញមាន
ប្រាក់ច្រើនហើយ នោះក៏នាំយកហឹបចូលទៅឯពួកភ្នាក់ងារ
របស់ស្តេច ហើយស្មៀនហ្លួង និងអ្នកដំណាងសំដេចសង្ឃ
ក៏ចូលមកចាក់ចេញយកប្រាក់ទៅទុក រួចគេយកហឹបទៅ
ដាក់នៅកន្លែងដើមវិញ គេធ្វើដូច្នោះរាល់តែថ្ងៃ ហើយ
បានប្រាក់ជាបរិបូរ ១២ស្តេចនឹងយេហូយ៉ាដាក៏ប្រគល់ប្រាក់
នោះ ឱ្យដល់ពួកអ្នកដែលត្រួតមើលការងារក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា អ្នកទាំងនោះក៏ជួល[ឆ]ជាងដាប់ថ្ម និងជាង
ឈើឱ្យរៀបចំព្រះវិហារនៃព្រះយេហូវ៉ាឡើងជាថ្មី ព្រម
ទាំងពួកជាងដែក ជាងលង្ហិន ឱ្យជួសជុល ព្រះវិហារនៃព្រះ
យេហូវ៉ាដែរ ១៣ដូច្នេះ ពួកអ្នកទាំងនោះក៏ធ្វើការទៅហើយ
ការជួសជុលក៏ចំរើនឡើង ដោយសារដៃគេ គេបានរៀបចំ
ព្រះវិហារនៃព្រះតាមសណ្ឋានដើមវិញ ព្រមទាំងធ្វើឱ្យ

**២៣:២០** ត ១ពវ ១៥:៣៥
**២៣:២១** ថ ២រប ២២:១
**២៤:២** ក ២រប ២៥:២ ២៦:៥
**២៤:៥** ខ នក ៣០:១៦ នហ ១០:៣២-៣៣ មថ ១៧:២៤ គ ១រប ១១:១ ឃ ១រប ២៦:២០
**២៤:៦** ង នក ៣៨:២១
**២៤:១០** ច នក ២៥:២ ១រប ២៩:៣,៦,៩
**២៤:១២** ឆ ២រប ៣៤:១១

**២៣:២០** មើលការពន្យល់ ខ.១ ។

**២៤:១-១៤** មើល ២ពវ ១២:១-៧ និងការពន្យល់ ។

**២៤:១** *៤០ឆ្នាំ* ៨៣៥-៧៩៦ មុន គ.ស ។

**២៤:២** ជាការផ្តល់នូវគម្រោងសង្ខេប ចំពោះការប្រព្រឹត្តរបស់អ្នកកាលប្រវត្តិអំពីយ៉ូអាសឆ្នាំដ៏ល្អក្នុងខណៈពេលដែល យេហូយ៉ាដានៅរស់នៅឡើយ (ខ.១-១៦) តែមានការអាក្រក់កើតឡើង ខណៈពេលដែលស្តេចអង្គនេះបានសុគត (ខ.១៧-២៧) មើលការពន្យល់ ២៥:២ ។

**២៤:៣** តាមការបញ្ជាក់ពីក្រុមអ្នកកាលប្រវត្តិបានពោលថា ក្រុមគ្រួសារដ៏ច្រើនបែបនេះគឺបង្ហាញ ពីព្រះពរដែលបង្ហូរមក (មើល ខ.២៧ ក៏មើលការពន្យល់ ១រប ២៥:៥) ។

**២៤:៤** *ជួសជុលព្រះវិហារ* ដោយការបំផ្លាញ់ដោយភាពឃោឃៅ ក៏តម្រូវឱ្យមានការជួសជុលឡើងវិញគឺព្រះវិហាររបស់ព្រះយេហូវ៉ា (ខ.៧) ។

**២៤:៥** គឺជាអ្នកកាលប្រវត្តិ និងអ្នកនិពន្ធគណ្ពកម្ពីរ ពង្សាវតារក្សត្រទី២ បានបកស្រាយពីប្រភពផ្សេងពីគ្នាបីនៃកិច្ចការប្រមូលប្រាក់សម្រាប់សាងសង់ព្រះវិហា (២ពវ ១២:៤-៥) តែអ្នកកាលប្រវត្តិគ្រាន់តែបង្ហាញប្រាប់ពីការជំរឿនប្រមូលពន្ធ (នក ៣០:១៤ ៣៨:២៦ មថ ១៧:២៤) ។ តែហេតុផលនៃការយឺតយ៉ាវរបស់ពួកសង្ឃ ដើម្បីសាងសង់ព្រះវិហារឡើងវិញនោះក៏ពុំបានបង្ហាញឱ្យច្បាស់ដែរ (មើល ២ពវ ១២:៦-៨) អ្នកនិពន្ធគម្ពីរពង្សាវតារក្សត្រកត់សំគាល់ពីការចូលរួមពីប្រភពខាងក្រៅ ជាមួយពួកសង្ឃបានរៀបចំឡើងក្នុងឆ្នាំទី២៣ក្នុងរជ្ជកាលស្តេច យ៉ូអាសក៏ពុំឃើញមានចំណែកយេហូយ៉ាដាទៀតឡើយ ។

**២៤:៨** *ហឹប១* ក៏មានអត្ថបទមួយបានបង្ហាញពីការដាក់ដង្វាយរបៀបដូចគ្នានេះដែរ ដែលដាក់នៅឯទីព្រះវិហារ ក៏ជាតំណាងតួនាទីព្រះមហាក្សត្រនិងប្រាក់ក្នុងព្រះវិហារដែលត្រូវគ្រប់គ្រង (មើលការពន្យល់ ១រប ២៦:២០) ។

មាំមួនជាងទៅទៀត [១៤]កាលគេបានធ្វើការស្រេចហើយ
នោះក៏យកប្រាក់ដែលសល់នៅ ទៅថ្វាយដល់ស្ដេច និង
យេហូយ៉ាដា ហើយប្រាក់នោះក៏យកទៅ ធ្វើជាគ្រឿង
ប្រដាប់សំរាប់ព្រះវិហារនៃព្រះយេហូវ៉ា គឺជាគ្រឿងសំរាប់
ប្រើធ្វើការងារ ហើយថ្វាយដង្វាយ ព្រមទាំងកូនចាន និង
គ្រឿងប្រដាប់ឯទៀត ធ្វើពីមាសនឹងប្រាក់ រួចការថ្វាយ
ដង្វាយដុត នៅក្នុងព្រះវិហារ នៃព្រះយេហូវ៉ា ក៏មាននៅជា
និច្ចគ្រប់១ជីវិតរបស់យេហូយ៉ាដា ។
[១៥]តែយេហូយ៉ាដា លោកកាន់តែចាស់ទៅ លោកបាន
ស្កប់ចិត្តនឹងអាយុលោក ហើយក៏ស្លាប់ទៅ កាលលោក ស្លាប់
នោះមានអាយុ ១៣០ឆ្នាំហើយ [១៦]គេបញ្ចុះសពលោក
នៅជាមួយនឹងពួកស្ដេច នៅក្នុងក្រុងដាវីឌ ពីព្រោះលោក
បានធ្វើល្អ ក្នុងសាសន៍អ៊ីស្រាអែលហើយ ចំពោះព្រះ និង
ព្រះវិហារទ្រង់ផង ។

## អំពើទុច្ចរិតរបស់ស្ដេចយ៉ូអាស

[១៧]រីឯកាលយេហូយ៉ាដាបានស្លាប់ទៅហើយ នោះពួក
ដែលជាប្រធានក្នុងស្រុកយូដា គេចូលមកក្រាបថ្វាយបង្គំ
ដល់ស្ដេច ហើយទ្រង់ក៏ស្ដាប់តាមគេ [១៨]ដូច្នេះ គេបោះបង់
ចោល[ជ]ព្រះវិហាររបស់ព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោ
គេ ទៅគោរពប្រតិបត្តិតាមរូបព្រះ[ឈ] និងអ្នកតាវិញ
ហើយមានសេចក្ដីក្រោធ[ញ]មកលើពួកយូដា និងពួកក្រុង
យេរូសាឡិម ដោយព្រោះការកំហុសដែលគេប្រព្រឹត្តនោះ
[១៩]ប៉ុន្តែទ្រង់ក៏ចាត់ពួកហោរាទៅឯគេដែរ ដើម្បីនឹងទាញ
នាំគេមកឯព្រះយេហូវ៉ាវិញ ឯពួកហោរានោះ លោកក៏ចាប់
ទោសគេ តែគេមិនព្រមទទួលស្ដាប់ឡើយ[ដ] ។
[២០]គ្រានោះ ព្រះវិញ្ញាណ[ឋ]នៃព្រះទ្រង់មកសណ្ឋិតលើ
សាការី[ឌ] ជាកូនយេហូយ៉ាដាដ៏ជាសង្ឃ លោកឈរនៅមុខ
បណ្ដាជនពោលថា ព្រះទ្រង់មានបន្ទូលដូច្នេះ ហេតុអ្វីបាន
ជាអ្នករាល់គ្នា រំលងអស់ទាំងក្រឹត្យក្រម នៃព្រះយេហូវ៉ា
ដូច្នេះ ធ្វើយ៉ាងនោះមិនចំរើន[ឍ] គឺដោយព្រោះ អ្នករាល់គ្នា
បានបោះបង់ចោល[ណ]ព្រះយេហូវ៉ាចេញ បានជាទ្រង់ក៏បោះ
បង់ចោលអ្នករាល់គ្នាដែរ [២១]តែគេរួមគំនិតគ្នាគិតប្រទូស្ត
នឹងលោកវិញ ក៏ចោលលោកនឹងថ្ម[ត,ថ] នៅក្នុងទីលានព្រះ
វិហារនៃព្រះយេហូវ៉ា តាមបង្គាប់ស្ដេច[ទ] [២២]គឺយ៉ាងនោះ
ដែលស្ដេចយ៉ូអាសបានរមិលគុណរបស់យេហូយ៉ាដា ជា
ឪពុកសាការី ដែលលោកបានផ្តល់ចំពោះទ្រង់ គឺទ្រង់បាន
សំឡាប់កូនលោកវិញ កាលសាការីហៀបនឹងស្លាប់ទៅនោះ
ក៏ពោលថា សូមឱ្យព្រះយេហូវ៉ាទ្រង់ទតមើល ហើយសំរេច
តាមយុត្តិធម៌ចុះ[ធ] ។
[២៣]ដល់ចុងឆ្នាំនោះឯង នោះកងទ័ពសាសន៍ស៊ីរី គេ
ឡើងមកច្បាំងនឹងទ្រង់ គេលុតចូលមកក្នុងស្រុកយូដា និង
ក្រុងយេរូសាឡិម ក៏បំផ្លាញពួកដែលជាប្រធាន ក្នុង
បណ្ដាជនទាំងអស់ទៅ[ន] ហើយអស់ទាំងរបឹបដែលគេចាប់
បាន នោះគេផ្ញើទៅថ្វាយដល់ស្ដេចក្រុងដាម៉ាស [២៤]ពួកពល
ទ័ពស៊ីរីបានមកមានគ្នាតែបន្តិចទេ[ប] តែព្រះយេហូវ៉ាទ្រង់
ប្រគល់ពលទ័ពយ៉ាងសន្ធឹក ទៅក្នុងកណ្ដាប់ដៃគេ[ផ] ដោយ
ព្រោះពួកខាងយ៉ូអាសបានបោះបង់ចោលព្រះយេហូវ៉ា ជា
ព្រះនៃពួកឰយុកោខ្លួន ហើយគឺយ៉ាងនោះដែលបានសំរេច

**២៤:១៨** ជ យស ២៤:២០ ២រប ៧:១៩ ឈ ៣៤:១៣ ២រប ៣៣:៣ យរ ១៧:២ ញ ២រប ១៩:២
**២៤:១៩** ដ ជន ១១:២៩ យរ ៧:២៥ សក ១:៤
**២៤:២០** ឋ ពច ៣:១០ ១រប ១២:១៨ ឌ មថ ២៣:៣៥ លក ១១:៥១ ឍ ជន ១៤:៤១ ណ ចទ ៣១:១៧
**២៤:២១** ត យស ៧:២៥ ថ យរ ២៦:២១ ទ យរ ២០:២
**២៤:២២** ធ លប ៩:៥
**២៤:២៣** ន ២ពវ ១២:១៧–១៨
**២៤:២៤** ប ២រប ១៤:៩ ១៦:៨ ២០:២,១២ ផ លប ២៦:២៣–២៥ ចទ ២៨:២៥

**២៤:១៤** *ក៏មាននៅជានិច្ចគ្រប់១ជីវិតរបស់យេហូយ៉ាដា* ក៏មានសេចក្ដីសំគាល់បន្ថែមទៀតស្ដីអំពីផ្នែកខ្លះ នៃកិច្ចការរបស់អ្នកកាលប្រវត្តិដោយបង្ហាញពីភាពក្រឡាប់ចាក់ទៅជាភាពអាក្រក់ក្នុងការគ្រងរាជ្យរបស់ស្ដេចយ៉ូអាសរហូតដល់រជ្ជកាលស្ដេចយេហូយ៉ាដា និងការចូលទីវង្គតនៃស្ដេចអង្គនោះ (ខ.១៥–១៦) ។

**២៤:១៥–២២** ផ្នែកនេះក៏ស៊ីគ្នានិងអ្នកកាលប្រវត្តិ ដែលបង្ហាញនិងសង្កត់ធ្ងន់ទៅលើការកាត់ទោស គឺជាការដាក់ទោសកំហុស (មើលការពន្យល់ ២៣:១–២៤:២៧) បន្ទាប់ពីការគ្រប់គ្រង ដ៏បរិសុទ្ធសុចរិតរហូតដល់ការសុគតរបស់ស្ដេច យេហូយ៉ាដាមក យ៉ូអាសក៏បែត្រឡប់ទៅជាកាន់និងដើរតាមការអាក្រក់ និងគោរពរូបព្រះទៅវិញ ហើយក៏បានសម្លាប់ព្រះរាជបុត្រារបស់ស្ដេចយេហូយ៉ាដាផងដែរ ។ តែឆ្នាំក្រោយមកទៀតស្ដេចអង្គនោះត្រូវបានពួកអើរ៉ាម ពីព្រោះពួកយូដាដែលនៅក្រោមការដឹកនាំ របស់គាត់ដែលបានបោះបង់ចោលព្រះយេហូវ៉ា (ខ.២៤) ។

**២៤:១៨,២០,២៤** *គេបោះបង់ចោល... បោះបង់ចោល... បោះបង់ចោល* ពាក្យនេះជាភាសាអង់គ្លេសក៏ដូចក្នុងឃ្លានេះដែរ ក្នុងនេះវាជាកិរិយាស័ព្ទដែលអ្នកកាលប្រវត្តិប្រើពាក្យនេះ ដើម្បីសំគាល់នូវមូលហេតុដែលព្រះយេហូវ៉ាកាត់ទោសដល់មនុស្សលោក (មើលការពន្យល់ ១២:១ ក៏សូមមើល ៧:១៩,២២ ១២:៥ ១៣:១០–១១ ១៥:២ ២១:១០ ២៤:១៨,២០,២៤ ២៨:៦ ៣៤:២៥ ១រប ២៨:៩,២០) ។

**២៤:១៩** *ដើម្បីនឹងចេញនាំគេមកឯព្រះយេហូវ៉ាវិញឯពួកហោរា* ការធ្វេសប្រហែសរបស់ពួកអ៊ីស្រាអែល ដែលមិនគោរពជឿតាម ហោរារបស់ព្រះដែលនាំឱ្យពួកគេទទួលការកាត់ទោសពីព្រះអម្ចាស់ (មើលការពន្យល់ ១២:១ មើល ៧:១៩,២២ ១២:៥ ១៣:១០–១១ ១៥:២ ២១:១០ ២៤:១៨,២០,២៤ ២៨:៦ ៣៤:២៥ ១រប ២៨:៩,២០) ។

**២៤:២០** *សាការី* មើលការពន្យល់ មថ ២៣:៣៥ ។

**២៤:២៤** *មានគ្នាតែបន្តិចទេ* តែព្រះបានជួយក្រុមកងទ័ពតូចៗនោះក្នុងពួកយូដាឱ្យមានកម្លាំងខ្លាំងច្រើនក្រៃអាចវាយកំទេចអ្នកដែលពុំស្មោះត្រង់ហើយនិងព្រះយេហូវ៉ានោះពួកគេក៏បានចាញ់ក្នុងសង្គ្រាមដោយកងទ័ពគ្នាតែបន្តិចតែប៉ុណ្ណោះ (មើលការពន្យល់ ២០:៣០) ។

ទោសដល់យ៉ូអាស ។
២៥កាលពួកស៊ីរីបានថយចេញពីទ្រង់ទៅ ទុកទ្រង់ឱ្យនៅ
ទាំងឈឺខ្លាំង នោះពួកមហាតលិកទ្រង់មានគំនិតគិតក្បត់
ចំពោះទ្រង់ ដោយព្រោះឈាមនៃកូនយេហូយ៉ាដាដ៏ជា
សង្ឃ ក៏ធ្វើគុតទ្រង់ដែលកំពុងផ្ទំលើបន្ទំទី គេបញ្ចុះសព[ព]
ទ្រង់នៅក្នុងក្រុងដាវីឌ តែមិនមែនក្នុងផ្នូររបស់ពួកស្តេចទេ
២៦ឯពួកអ្នកដែលគិតក្បត់ចំពោះទ្រង់នោះ គឺសាបាឌ ជាកូន
នាងស៊ីមាត សាសន៍អាំម៉ូន១ និងយ៉ូសាបាឌ ជាកូននាង
ស៊ីមរីត[ភ]សាសន៍ម៉ូអាប់១[ម] ២៧រីឯដំណើរពីពួកព្រះរាជបុត្រា
ទ្រង់ និងបន្ទុកយ៉ាង ធន់ដែលបានពោលពីទ្រង់ព្រមទាំង
ការតាំងព្រះវិហារនៃព្រះឡើង ជាថ្មីផងនោះសុទ្ធតែបាន
កត់ទុក ក្នុងសៀវភៅបរិយាយ ពីពួកស្តេចហើយ រួច
អ័មាស៊ីយ៉ា ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួសព្រះ
បិតា ។

**អ័ម៉ាស៊ីយ៉ា**

*២៥:១-៤ – ២ពវ ១៤:១-៦*

*២៥:១១-១២ – ២ពវ ១៤:៧*

*២៥:១៧-២៨ – ២ពវ ១៤:៨-២០*

**២៥** ១ឯអ័ម៉ាស៊ីយ៉ា កាលចាប់តាំងសោយរាជ្យឡើង នោះ
ទ្រង់មានព្រះជន្ម២៥ឆ្នាំហើយ ក៏សោយរាជ្យនៅក្នុងក្រុង
យេរូសាឡិមបាន២៩ឆ្នាំព្រះមាតាទ្រង់ព្រះនាមជាយ៉ូអាដាន
ជាអ្នកក្រុងយេរូសាឡិម ២ទ្រង់ប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ
នៅព្រះនេត្រព្រះយេហូវ៉ា តែមិនមែន ដោយព្រះទ័យស្មោះ
ចំពោះទេ[ក] ៣កាលរាជ្យបានតាំងនៅជាប់ក្នុងអំណាចទ្រង់
ហើយ នោះទ្រង់ក៏សំឡាប់ពួកបំរើដែលបានធ្វើគុតស្តេច
ជាព្រះបិតាទ្រង់ទៅ ៤តែមិនបានសំឡាប់កូនចៅគេទេ គឺ
បានធ្វើតាមសេចក្តីដែលចែងទុកមក ក្នុងគម្ពីរក្រិត្យវិន័យ
របស់លោកម៉ូសេវិញ[ខ] ជាសេចក្តីដែលព្រះយេហូវ៉ាបាន
បញ្ញត្តថា ឪពុកមិនត្រូវស្លាប់ដោយព្រោះកូន ឬកូនដោយ
ព្រោះឪពុកឡើយ គឺគ្រប់គ្នាត្រូវស្លាប់ ដោយព្រោះអំពើ
បាបរបស់ខ្លួនរៀងខ្លួនវិញ[គ] ។
៥មួយទៀត អ័ម៉ាស៊ីយ៉ាទ្រង់ប្រមូលពួកយូដា ឱ្យមូលគ្នា
រួចផ្ដុំ គេតាមវង្សានុវង្សរបស់ឪពុកគេ នៅក្រោមអំណាច
នៃមេលើ១ពាន់នាក់ និងមេលើ១រយនាក់ គឺទាំងពួកយូដា
បេនយ៉ាមីនទាំងអស់ផង ក៏រាប់[ឃ]គេចាប់តាំងពីអាយុ២០
ឆ្នាំ[ង]ឡើងទៅលើ ឃើញមានមនុស្សជ្រើសរើស៣សែននាក់
ដែលសុទ្ធតែអាចនឹងទៅច្បាំងបាន[ច] ហើយចេះកាន់លំពែង
នឹងខែលផង ៦ទ្រង់ក៏ជួលមនុស្សខ្លាំងពូកែមានចិត្តក្លាហាន
ពីស្រុកអ៊ីស្រាអែល បានចំនួន១សែននាក់ អស់ដំឡើជា
ប្រាក់១00ហាប ៧តែមានអ្នកសំណប់របស់ព្រះម្នាក់មក
គាល់ទ្រង់ទូលថា បពិត្រព្រះករុណាអើយ កុំបើកឱ្យពលទ័ព
របស់ពួកអ៊ីស្រាអែល[ឆ] ទៅជាមួយនិងទ្រង់ឡើយ ដ្បិតព្រះ
យេហូវ៉ាទ្រង់មិនគង់នៅជាមួយនឹងពួកអ៊ីស្រាអែល គឺនឹង

**២៤:២៥** ព ២របា ២១:២០
**២៤:២៦** ភ ២ពវ ១២:២១ ម នរ ១:៤
**២៥:២** ក ១ពវ ៨:៦១ ២របា ២៤:២
**២៥:៤** ខ ចទ ២៨:៦១ គ ជន ២៦:១១
**២៥:៥** ឃ ២សយ ២៤:២ ង នក ៣0:១៤ ច ១របា ២១:១ ២របា ១៧:១៤-១៩
**២៥:៧** ឆ ២របា ១៦:២-៩ ១៩:១-៣

**២៤:២៥** *ក្បត់ចំពោះទ្រង់ . . . ក៏ធ្វើគត់ទ្រង់ . . .* គឺជាការដែលអ្នកកាលប្រវត្តិបង្ហាញថាការធ្វើឃាតនេះ គឺជាការសងសឹក ចំពោះការធ្វើឃាតសាការី *តែមិនមែនក្នុងផ្នូររបស់ស្តេចទេ* ការបញ្ចុះក្នុងផ្នូរស្តេច គឺជាលក្ខណៈពិសេសបើតាមជំនាន់យេហូយ៉ាដា (ខ.១៦) (មើល ២១:២0) ។

**២៤:២៦** *សាសន៍អាំម៉ូន១ . . . សាសន៍ម៉ូអាប់១* ជាដំណឹងដែលពុំមានក្នុងគម្ពីរពង្សាវតារក្សត្រតែក៏វាចាំបាច់ចំពោះអ្នកកាលប្រវត្តិ (មើលការពន្យល់ ២0:១-៣0) ។

**២៤:២៧** *សៀវភៅបរិយាយពីពួកស្តេច* មើលសេចក្តីផ្តើមគម្ពីរ របាក្សត្រទី១ ត្រង់ : អ្នកនិពន្ធកាលបរិច្ឆេទ និងប្រភពរបស់វា ។

**២៥:១-២៨** ជាពិសេសអ្នកកាលប្រវត្តិបានញែកការគ្រងរាជ្យ ទៅជាពីរប្រភេទក្នុងរឿងស្តេច : គឺ (១) ឆ្នាំដ៏ល្អប្រសើ ដោយសារតែការស្តាប់បង្គាប់ក៏បានទទួលពរពីព្រះ និងបានជ័យជម្នះ (ខ.១-១៣) និង (២) គឺជាឆ្នាំមិនល្អក្នុងការថ្វាយបង្គំរូបព្រះការបានធ្លាក់ចុះ (ខ.១៤-២៨) មើល ២ពវ ១៤:១-២0 និងការពន្យល់ ។

**២៥:១** *បាន២៩ឆ្នាំ* គឺចន្លោះ ៧៩៦-៧៦៧ មុន គ.ស ។

**២៥:២** អ្នកកាលប្រវត្តិបានបញ្ជាក់ថា អ័ម៉ាស៊ីយ៉ាពុំបានរើទីខ្ពស់ចេញទេ ហើយទុកទីនោះសម្រាប់ធ្វើជាទីថ្វាយយញ្ញរបស់ប្រជារាស្ត្រដដែល (មើល ២ពវ ១៤:៤) ប្រៀបធៀប ២៤:២ ជាមួយ ២ពវ ១២:២-៤ និង ២៦:៤ ជាមួយ ២ពវ ១៥:៣-៤ ។ អ្នកនិពន្ធចាប់អារម្មណ៍ទៅលើកាលនៅក្នុងឆ្នាំល្អរបស់ស្តេចមុនគេ បន្ទាប់មកទៀតនិយាយពីការបែរទៅរកការគោរពរូបព្រះនៃសាសន៍ដទៃ ។

**២៥:៥-១៦** ការរីកដុះដាលនៃគម្ពីរ ២ពវ ១៤:៧ គឺជាគម្ពីរពង្សាវតារក្សត្រ គឺបង្ហាញពីការជោគជ័យក្នុងសង្គ្រាមជាមួយនិងសាសន៍អេដំម គឺជាកិច្ចការដំបូងដែលបានផ្តល់នៅការលើកទឹកចិត្តដល់យេហូយ៉ាដា ប៉ុន្តែអ្នកកាលប្រវត្តិបានរៀបគំរោង ហើយផ្តោតទៅលើការកាត់ទោសពីព្រះយេហូវ៉ាវិញដូចជា: ការស្តាប់បង្គាប់នាំមកនៅជ័យជម្នះលើសាសន៍អេដំមខណៈពេលគេមានរូបព្រះជាគោល (ខ.១៤-១៦) ក៏នាំឱ្យមានការកាត់ទោសក្នុងយុទ្ធនាការប្រឆាំងនិងអ៊ីស្រាអែល ។ ការទទួលបន្ទុករបស់ក្រុមស្តេចក៏បង្ហាញពីភាពជោគជ័យពេលដែលគេគោរព និងស្តាប់បង្គាប់ដល់ព្រះ និងទទួលបានបរាជ័យនូវក្នុងគ្រាដែលពួកគេបែរចេញពីព្រះទៅគោរពរូបព្រះ ។

**២៥:៧** *កុំបើកឱ្យពលទ័ពរបស់ពួកអ៊ីស្រាអែល ទៅជាមួយនិងទ្រង់ឡើយ* មានគំរូមួយទៀតដែលអ្នកកាលប្រវត្តិ បានចង់បង្ហាញពីការកាត់ទោសដល់សម្ព័ន្ធភាពមួយដែលគេបានប្រព្រឹត្ត ដោយពុំមានសេចក្តីពិតក្នុងព្រះអម្ចាស់ (មើលការពន្យល់ ១៦:២-៩ ២២:៥) ។ ប្រៀបធៀបនិងសម្តីរបស់ពួកហោរាផ្សេងទៀត ដែលបានហៅមនុស្សឱ្យទុកចិត្តលើព្រះ (២0:១៥-១៧, ២0 ៣២:៧-៨) ។

ពួកកូនចៅអេប្រាអិមទាំងអំបាលម៉ានទេ ៨តែបើទ្រង់នាំ
គេទៅនោះស្រេចនឹងព្រះទ័យចុះ ត្រូវខំប្រឹងឱ្យមានកំឡាំង
ឡើង សំរាប់នឹងច្បាំងទៅ ព្រះនឹងធ្វើឱ្យទ្រង់ដួលនៅមុខ
ពួកខ្មាំងសត្រូវ ដ្បិតព្រះទ្រង់អាចនឹងជួយឬធ្វើឱ្យដួលក៏
បាន[ជ] ៩រួចអ័ម៉ាស៊ីយ៉ាទ្រង់សួរតប ទៅអ្នកសំណប់របស់ព្រះ
ថា ចុះចំណែកប្រាក់១០០ហាបដែលយើង បានប្រគល់ទៅ
ឱ្យពួកទ័ពអ៊ីស្រាអែល នោះដូចម្តេចទៅអ្នកសំណប់របស់
ព្រះទូលឆ្លើយថា ព្រះយេហូវ៉ាទ្រង់អាចនឹងប្រទាន ឱ្យទ្រង់
បានជាច្រើនលើសជាងនេះទៅទៀត[ឈ] ១០ដូច្នេះ អ័ម៉ាស៊ីយ៉ា
ក៏ញែកគេចេញពីគ្នា គឺញែកពួកទ័ពដែលមកពីស្រុក
អេប្រាអិម ឱ្យគេត្រឡប់ទៅឯផ្ទះវិញ គេក៏កើតមានសេចក្តី
កំហឹងឆួលក្តៅឡើងនឹងពួកយូដា ហើយគេត្រឡប់ទៅវិញ
ដោយសេចក្តីឃោរឃៅជាខ្លាំង[ញ] ១១ឯអ័ម៉ាស៊ីយ៉ាទ្រង់
មានព្រះទ័យក្លាំឡើង ក៏លើកទ័ពចេញទៅឯច្រកភ្នំអំបិល
ប្រហារសំឡាប់ពួកកូនចៅសៀរអស់១ម៉ឺននាក់ ១២ហើយ
១ម៉ឺនទៀត ពួកកូនចៅយូដា ក៏ចាប់ទាំងរស់ដឹកនាំទៅឯ
កំពូលថ្មភ្នំបោះទំលាក់ទៅក្រោមឱ្យបាក់បែកខ្ទេចខ្ទីអស់ទៅ
១៣តែឯពួកទ័ពដែលអ័ម៉ាស៊ីយ៉ាបានឱ្យទៅវិញ មិនឱ្យទៅ
ច្បាំងជាមួយនោះ គេក៏ចូលទៅវាយទីក្រុងស្រុកយូដាទាំង
ប៉ុន្មាន ចាប់តាំងពីស្រុកសាម៉ារីរហូតដល់ក្រុងបេត-ហូរ៉ូន
ប្រហារ សំឡាប់មនុស្សអស់៣ពាន់នាក់ ហើយចាប់យក
របឹបបានជាច្រើនដែរ[ដ]។

១៤រីឯម៉ាស៊ីយ៉ា កាលទ្រង់ត្រឡប់មក ពីការប្រហារ
សំឡាប់ពួកអេដំមវិញ នោះទ្រង់នាំយកអស់ទាំងព្រះរបស់
ពួកកូនចៅសៀមមក តាំងឡើងជាព្រះរបស់ទ្រង់[ឋ] ក៏ក្រាប
ថ្វាយបង្គំ ហើយដុតកំញានថ្វាយដល់ព្រះទាំងអស់នោះ
១៥ហេតុនោះសេចក្តីក្រេវក្រោធរបស់ព្រះយេហូវ៉ាបាន
ឆួលឡើង ទាស់នឹងអ័ម៉ាស៊ីយ៉ា ក៏ចាត់ហោរាម្នាក់ឱ្យទៅឯ
ទ្រង់ទូលថា ម្តេចក៏ទ្រង់រកតាមព្រះរបស់សាសន៍នោះ
ដែលមិនអាចនឹងជួយ[ឌ]ពួកគេ ឱ្យរួចពីកណ្តាប់ព្រះហស្តទ្រង់
ផងដូច្នេះ ១៦គ្រាកាលលោកកំពុងតែទូលនឹងស្តេចនៅ
ឡើយ នោះទ្រង់មានបន្ទូលកាត់ថា តើយើងបានតាំងឯង
ឱ្យធ្វើជាអ្នកជួយគំនិតស្តេចឬ ចូរនៅសៀមទៅ ឯងចង់ឱ្យ
គេប្រហារឯងបង់ធ្វើអី ដូច្នេះ លោកក៏លែងពោល ដោយ
ពាក្យនេះថា ទូលបង្គំដឹងពិតថា ព្រះទ្រង់បានសំរេចនឹង
បំផ្លាញព្រះករុណាទៅ ដោយព្រោះបានធ្វើអំពើយ៉ាងនេះ
ហើយមិនស្តាប់តាមសេចក្តីដាស់តឿនរបស់ទូលបង្គំ ។

១៧នៅគ្រានោះអ័ម៉ាស៊ីយ៉ា ជាស្តេចយូដា ទ្រង់ទទួលព្រម
តាម សេចក្តីប្រឹក្សារបស់គេ ក៏ចាត់សារឱ្យទៅឯយ៉ូអាហាស
ដែលជាបុត្រាយេហ៊ូវ ស្តេចពួកអ៊ីស្រាអែលថា ចូរចេញ
មកយើងមើលមុខគ្នា ១៨តែយ៉ូអាស ជាស្តេចអ៊ីស្រាអែល
ទ្រង់ចាត់សារទៅឯអ័ម៉ាស៊ីយា ជាស្តេចយូដាវិញថា ដើម
បន្លា[ឍ]ដែលដុះនៅលើភ្នំល្បាណូន បានចាត់សារទៅឯដើម
តាត្រៅនៅភ្នំល្បាណូនថា ចូរលើកកូនស្រីឯងមក ឱ្យធ្វើ
ជាប្រពន្ធរបស់កូនប្រុសអញ ក៏មានសត្វព្រៃដែលនៅភ្នំ
ល្បាណូន មកតាមនោះ ជាន់ឈ្លីដើមបន្លានោះទៅ ១៩ទ្រង់
មានបន្ទូលថា មើលយើងបានវាយឈ្នះពួកសាសន៍អេដំម
ហើយព្រះទ័យទ្រង់បានដំកើងទ្រង់ឡើង ឱ្យបានអួតខ្លួន ចូរ
នៅឯដំណាក់ទ្រង់ទៅ តើចង់រករឿង ដែលនឹងនាំឱ្យមាន
អន្តរាយ ឱ្យទ្រង់ត្រូវដួលព្រមទាំងពួកយូដាផងធ្វើអី ។

២០តែអ័ម៉ាស៊ីយ៉ាទ្រង់មិនព្រមស្តាប់តាមទេ ដ្បិតការនោះ
កើតមកពីព្រះ ដើម្បីឱ្យទ្រង់បានប្រគល់សាសន៍យូដាទៅក្នុង
កណ្តាប់ដៃគេ ដោយព្រោះបានស្វែងរកតាមអស់ទាំងព្រះ
របស់សាសន៍អេដំម[ណ] ២១ដូច្នេះយ៉ូអាសជាស្តេចអ៊ីស្រាអែល
ទ្រង់ក៏យាងឡើងទៅ រួចទ្រង់ និងអ័ម៉ាស៊ីយ៉ាជាស្តេចយូដា
ក៏មើលមុខគ្នា នៅត្រង់ក្រុងបេត-សេ មែសជាក្រុងរបស់
ពួកយូដា ២២ពួកយូដាក៏ចាញ់ពួកអ៊ីស្រាអែល ហើយរត់ទៅ
ទីលំនៅគេរៀងខ្លួនវិញ ២៣ឯយ៉ូអាស ជាស្តេចអ៊ីស្រាអែល
ទ្រង់ចាប់អ័ម៉ាស៊ីយ៉ា ស្តេចយូដា ជាបុត្រយ៉ូអាស ដែលជា
បុត្រអ័ហាស៊ីយ៉ា នៅត្រង់បេត-សេមែសបាន ក៏នាំទៅ
ឯក្រុងយេរូសាឡិម ហើយរំលំកំផែងក្រុងយេរូសាឡិមចាប់
តាំងពីទ្វារអេប្រាអិម[ត] រហូតដល់ទ្វារជ្រុងកំផែង[ថ]អស់៤០០

**២៥:៨** ជ ២រប ១៤:១១ ២០:៦
**២៥:៩** ឈ ចទ ៨:១៨ សភ ១០:២២
**២៥:១០** ញ ខ.១៣
**២៥:១២** ដ ទដ ១៤១:៦ អប ១:៣
**២៥:១៤** ឋ នក ២០:៣ ២រប ២៨:២៣ ងស ៤៤:១៥
**២៥:១៥** ឌ អស ៣៦:២០
**២៥:១៨** ឍ ពច ៩:៨-១៥
**២៥:២០** ណ ២រប ១០:១៥
**២៥:២៣** ត ២ពវ ១៤:១៣ នហ ៨:១៦ ១២:៣៩ ថ ២រប ២៦:៩ យរ ៣១:៣៨

**២៥:១៣** នេះគឺជាឧបទ្ទវហេតុ សម្រាប់សង្គ្រាមក្រោយៗទៀតជាមួយនិងពួកខាងជើងក្នុងស្រុកម៉ាសារី ។ ក្រុងឬស្រុកសាម៉ារីដែលស្ថិតនៅឯនគរខាងជើងដែលមិនសូវជាល្បីទេ ។

**២៥:១៤-២៥** ពត៌មានរបស់អ្នកកាលប្រវត្តិ អំពីសង្គ្រាមជាមួយផ្នែកឯនគរខាងជើងដែលមានភាពប្រហាក់ប្រហែលក្នុង ២ពវ ១៤:៨-១៤ លើកលែងតែករណីបន្ថែមខ្លះទៀតក្នុងផ្ទៃរឿងមួយចំនួន ដែលទាក់ទងនិងការដាក់ទោសកំហុស ។ អ្នកកាលប្រវត្តិក៏បង្ហាញ ពីភាពដែលគោរពដល់ព្រះជារូបដ៏ល្ងីល្ងើរបស់ស្តេចអ័ម៉ាស៊ីយ៉ា ។ ហើយពួកហោរាបានសម្តែងពីការកាត់ទោសដែលឃើញក្នុងគម្ពីរ ពង្សាវតារក្សត្រ ។ ហើយក៏បានបន្ថែមកំណត់សំគាល់ក្នុង ខ.២០,២៧ គឺដើម្បីបង្ហាញពីការថ្វាយបង្គំរូបព្រះរបស់ស្តេចអ័ម៉ា ស៊ីយ៉ា គឺជាអំពើដែលព្រះបានដាក់ទណ្ឌកម្ម ។

**២៥:១៨** ប្រៀបធៀបនិងពាក្យប្រៀបប្រដូចក្នុងគម្ពីរ ពច ៩:៧-១៥ ។

**២៥:២៣** *ទ្វារអេប្រាអិម រហូតដល់ទ្វារជ្រុងកំផែង* ទ្វារទាំងពីរនោះមានទីតាំងនៅផ្នែកទីក្រុងឯទ្វារអេប្រាអឹម គឺស្ថិតនៅខាងជើងឈាងខាងលិចនិងទ្វារជ្រុងកំផែងខាងជើងឈាងខាងកើត ។

ហត្ថ [២៤]ទ្រង់ក៏យកអស់ទាំងមាស ប្រាក់ និងគ្រឿងប្រដាប់
ទាំងប៉ុន្មាន ដែលឃើញមាន នៅក្រោមអំណាច អូបិឌ–
អេដំម[ទ] ក្នុងព្រះវិហារនៃព្រះ ហើយនៅក្នុងព្រះរាជទ្រព្យ
ទាំងប៉ុន្មាន ព្រមទាំងចាប់មនុស្សបញ្ចាំទុក រួចនាំទាំងអស់
ត្រឡប់ទៅឯក្រុងសាម៉ារីវិញ ។
[២៥]ក្រោយដែលយ៉ូអាស ជាបុត្រាយ៉ូអាហាស ស្តេច
អ៊ីស្រាអែលបានសុគតហើយ នោះអ័ម៉ាស៊ីយ៉ា ជាបុត្រា
យ៉ូអាស ស្តេចយូដាទ្រង់ មានព្រះជន្មរស់នៅបាន១៥ឆ្នាំ
ទៀត [២៦]រីឯដំណើរឯទៀត ពីអ័ម៉ាស៊ីយ៉ា ទាំងមុនទាំង
ក្រោយ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ពីពួកស្តេច
យូដា នឹងអ៊ីស្រាអែលហើយ [២៧]រីឯអ័ម៉ាស៊ីយ៉ា ចាប់តាំង
ពីវេលាដែលទ្រង់បានបែរចេញ លែងតាមព្រះយេហូវ៉ា
ទៅ នោះមានគេកើតមានគំនិតគិតក្បត់នឹងទ្រង់ នៅក្រុង
យេរូសាឡិម ទ្រង់ក៏រត់ទៅ ឯក្រុងឡាគីស[ធ] តែគេចាត់
មនុស្សទៅតាម ហើយធ្វើគុតទ្រង់នៅទីនោះ [២៨]រួចគេនាំ
យកសពទ្រង់ដាក់លើសេះមកវិញ បញ្ចុះនៅក្រុង ដាវីឌជា
មួយនឹងពួកព្វយុកោទ្រង់ទៅ ។

## អូសៀសឡើងជាស្តេចស្រុកយូដា

*២៦:១-៤ – ២ពវ ១៤:២១-២២ ១៥:១-៣*

*២៦:២១-២៣ – ២ពវ ១៥:៥-៧*

**២៦** [១]ពួកជនទាំងឡាយ នៅស្រុកយូដា[ក] ក៏លើកអូសៀស
ដែលមានព្រះជន្ម១៦ហើយ តាំងឡើងជាស្តេចជំនួស
អ័ម៉ាស៊ីយ៉ា ជាព្រះបិតា [២]អូសៀសក៏សង់ក្រុងអេឡុត បញ្ចូល
មកខាងពួកយូដាវិញ ក្នុងវេលាក្រោយដែលព្រះបិតាបាន
ផ្ទំលក់ទៅ ជាមួយនឹងពួកព្វយុកោទ្រង់ [៣]កាលអូសៀសចាប់
តាំងសោយរាជ្យឡើង នោះទ្រង់មានព្រះជន្ម១៦ ឆ្នាំហើយ
ក៏សោយរាជ្យនៅក្រុងយេរូសាឡិមបាន៥២ឆ្នាំ ព្រះមាតា
ទ្រង់ព្រះនាមជាយេកូលា ជាអ្នកក្រុងយេរូសាឡិម ។
[៤]ទ្រង់ប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ នៅព្រះនេត្រព្រះ
យេហូវ៉ា តាមគ្រប់ទាំងសេចក្តីដែលអ័ម៉ាស៊ីយ៉ា ជាព្រះបិតា
ទ្រង់បានធ្វើ [៥]ទ្រង់ក៏តាំងព្រះទ័យស្វែងរកព្រះយេហូវ៉ា
ចាប់តាំងពីគ្រាសាការី ជាអ្នកយល់ក្នុងការងារស្តែងពីព្រះ
តទៅហើយនៅវេលា ដែលទ្រង់ស្វែងរកព្រះយេហូវ៉ា[ខ]អស់
រវាងប៉ុណ្ណា នោះព្រះក៏បានធ្វើឱ្យទ្រង់បានចំរើនឡើង យូរ
ប៉ុណ្ណោះដែរ [គ]។
[៦]ទ្រង់ក៏ចេញទៅច្បាំងនឹងពួកភីលីស្ទីន[ឃ] ហើយទ្រង់
បំបាក់រំលំកំផែងក្រុងកាថ និងកំផែងក្រុងយ៉ាបនេ ហើយ
កំផែងក្រុងអាសដូឌ[ង]ផង រួចទ្រង់សង់ទីក្រុងក្នុងក្រវល់របស់

**២៥:២៤** ទ ១រប ២៦:១៥
**២៥:២៧** ធ យស ១០:៣
**២៦:១** ក ២រប ២២:១
**២៦:៥** ខ ២រប ២៤:២ គ ២រប ២៧:៦
**២៦:៦** ឃ អស ២:៦ ១១:១៤ ១៤:២៩ យរ ២៥:២០ ង អម ១:៨ ៣:៩

**២៥:២៤** ក្រុមគ្រួសារ អូបិត–អេដំម គឺមកពីគ្រួសារពួកលេវី ដែលជាអ្នកថែរក្សារទ្រព្យឃ្លាំងក្រុងព្រះវិហារដែលទុកចិត្តបាន (១រប ២៦:១៥ ប្រៀបធៀប ២សយ ៦:១០ និងការពន្យល់) ។

**២៥:២៧** មើលការពន្យល់ ខ.១៤-២៥ ។

**២៥:២៨** *ក្រុងដាវីឌ (ក្នុងយ៉ូដា)* ពីមុនឈ្មោះទីក្រុងយ៉ូដាតែឈ្មោះក្រោយមកទៀតឈ្មោះដាវីឌ (១៤:២០) ។

**២៦:១-២៣** មើល ២ពវ ១៥:១-៧ និងការពន្យល់ ។ អ្នកកាលប្រវត្តិបែងចែកចរិកលក្ខណះនៃការគ្រងរាជ្យរបស់ស្តេច អូសៀសទៅជាពីផ្នែកមានដូចជាឆ្នាំល្អនៃការគ្រប់គ្រង និងឆ្នាំនៃការគ្រប់គ្រងអាក្រក់និងប្រៀបធៀបទៅនិងការប្រព្រឹត្តរបស់បិតារបស់ទ្រង់ ឈ្មោះអ័ម៉ាស៊ីយ៉ា និងតារបស់ទ្រង់ឈ្មោះយ៉ូអាស (មើលការពន្យល់ ២៤:២ ២៥:១-២៨) អ្នកកាលប្រវត្តិបានពណ៌នាយ៉ាងល្អិតអំពីព្រះពរ និងការជំនួយពីព្រះរបស់ស្តេចអូសៀសនិងភក្តីភាពជាភាពស្មោះត្រង់ (ខ.៤-១៥) ផ្នែកខ្លះអ្នកនិពន្ធក្នុងគម្ពីរពង្សាវតារក្សត្របង្ហាញតែពីការ ដែលស្តេចនេះបានភក្តីភាព (២ពវ ១៥:៣)។ ផ្នែកខ្លះទៀតនៃគម្ពីរ ពង្សាវតារក្សត្របង្ហាញតែពីស្តេចអូសៀសមានជម្ងឺឃ្លង់ (២ពវ ១៥:៥) អ្នកកាលប្រវត្តិបាន បន្ថែមយ៉ាងលំអិតដើម្បីបង្ហាញថាជម្ងឺបានកើតឡើងក៏ដោយមូលហេតុនៃភាពពុំស្មោះត្រង់ (ខ.១៦-២១) ក្រោមការគ្រប់គ្រងរបស់អូសៀស និងអ្នកជាមនុស្សជំនាន់ទ្រង់នៅផ្នែកខាងជើងនិងយេរ៉ូបោមទី២ ឯព្រំដីស្រុកអ៊ីស្រាអែល និងយ៉ូដាដែលមានដីលាតសន្ធឹងនិងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្តេចដាវីឌ និងស្តេចសាឡូម៉ូន (ខ.៦-៨ ២ពវ ១៤:២៥) ការរីកចម្រើននៃនគរទាំងពីរនេះ ក៏ត្រូវបានរៀបចំគ្រប់គ្រងឡើងវិញដោយរុញច្រានការគំរាមកំហែងរបស់សាសន៍អើរ៉ាម គឺពួកស្រុកអាសើរដែលដឹកនាំដោយស្តេច អាដានីរ៉ារី ទី២ (៨០២ មុន ស.គ) តែក្រោយមកទៀតមានពួកសាសន៍ស្រុក ស៊ើរី គឺជារយៈពេលនៃភាពចុះខ្សោយ ។

**២៦:១** *អូសៀស* មើលការពន្យល់ (មើល ឧទាហរណ៍ ២ពវ ១៥:៦-៧ ១រប ៣:១២)។ វាទំនងជាឈ្មោះ អូសៀស គឺជាឈ្មោះក្នុងពេលដែលស្តេចនេះសោយរាជ្យ ហើយឈ្មោះថាអ័សារាគឺជាឈ្មោះផ្ទាល់ខ្លួនរបស់គាត់ ។

**២៦:៣** *៥២ឆ្នាំ* គឺចន្លោះ ៧៩២-៧៤០ មុន គ.ស ដែលមានអ្នកជំនាន់តែមួយជាមួយ អ័ម៉ាស៊ីយ៉ា គឺចាប់ពី ៧៩២ រហូតដល់ ៧៦៧ ។

**២៦:៤** អ្នកកាលប្រវត្តិក៏បានរៀបរាប់ពីការគ្រងរាជ្យបេស់អូសៀស គឺផ្តល់លក្ខណះលំនាំដូច អ័ម៉ាស៊ីយ៉ា និងយ៉ូអាស (មើលការពន្យល់ ខ.១-២៣) ។ រួចអ្នកកាលប្រវត្តិក៏តែងតែបង្ហាញពីពង្សាវតាក្សត្រ ដែលស្តេចទាំងនោះរមែងពុំបានរុះរើបំផ្លាញទីខ្ពស់ទេ (២ពវ ១៥:៤) ដូចជាស្តេចពីរអង្គផ្សេងទៀតក៏ធ្វើដូច្នេះដែរ (មើលការពន្យល់ ២៥:២ ) ។

**២៦:៥** *តាំងពីគ្រាសាការី* អ្នកនិពន្ធបានប្រើកំណត់សំគាល់អំពីប្រវត្តិក្សត្រដើម្បីបកស្រាយបង្ហាញខ្លួបនៃព្រះពរ និងការកាត់ទោសដែលទាក់ទងនិងការឆ្លើយតបរបស់ស្តេចនិមួយៗ ទៅនិងព្រះរាជបញ្ញារបស់ព្រះ (មើលការពន្យល់ ១២:២) ។

**២៦:៦-៨** ការច្បាំងដណ្តើមរបស់ស្តេចអូសៀសឆ្ពោះទៅកាន់តំបន់ខាងត្បូងឈាងខាងកើត និងខាងត្បូងឈាងខាងលិចគឺជាការ គ្រងអំណាចដ៏មានកម្លាំងខ្លាំងក្លារបស់ស្តេចយេរ៉ូបោមទី២ ដែលមានអំណាចគ្រប់គ្រងឯស្រុកយូដាខាងជើង ។

អាសដូឌ និងនៅកណ្ដាលពួកភីលីស្ទីន ៧ព្រះទ្រង់ក៏ជួយទាស់
និងពួកភលីស្ទីន ពួកអារ៉ាប់[ច] ដែលនៅស្រុកគើរ–បាល និង
ពួកម៉ាអូនផង[ឆ] ៨ឯពួកអាំម៉ូន[ជ]គេក៏យកសួយអាករមកថ្វាយ
អូសៀសដែរ ហើយទ្រង់មានកិត្តិនាមល្បីឮទួទៅ រហូតដល់
ប្រទល់ដែនចូលស្រុកអេស៊ីព្ទ ដ្បិតទ្រង់មានព្រះចេស្ដាកាន់
តែខ្លាំងឡើងក្រៃលែង ៩មួយទៀតអូសៀសទ្រង់សង់ប៉ម
នៅក្រុងយេរូសាឡិម ត្រង់ទ្វារជ្រុងទ្វារ[ឈ]ច្រកភ្នំ[ញ] ហើយ
នៅត្រង់រំពត់កំផែង ព្រមទាំងធ្វើឱ្យមាំមួនណាស់ ១០ទ្រង់ក៏
សង់ប៉មនៅទីរហោស្ថាន ជាច្រើនកន្លែង ព្រមទាំងជីក
អណ្ដូងផង ពីព្រោះទ្រង់មានហ្វូងសត្វយ៉ាងសន្ធឹក នៅស្រុក
ទំនាប និងស្រុកវាល ក៏មានពួកអ្នកធ្វើចំការនឹងពួកអ្នក
ថែរក្សាដើមទំពាំងបាយជូរនៅលើភ្នំនិងនៅស្រុកកើមែល
ដែរ ដ្បិតទ្រង់សព្វព្រះទ័យខាងឯការក្សេត្រកម្ម ១១មួយ
ទៀត អូសៀសទ្រង់មានពលទ័ព សុទ្ធតែជាមនុស្សចេះតស៊ូ
ដែលចេញទៅច្បាំងដោយកងៗ តាមចំនួនគេដែលយីអែល
ជាស្មៀន និងម្អាសេយ៉ា ជានាយបានរាប់នៅក្រោមអំណាច
ហាណានា ជាមេទ័ពរបស់ស្ដេច ១២ឯពួកអ្នក ដែលជា
កំពូលលើវង្សរបស់ឪពុកគេទាំងប៉ុន្មាន គឺជាមនុស្សខ្លាំង
ពូកែ ដែលមានចិត្តក្លាហាន នោះមានចំនួន២ពាន់៦រយ
នាក់ ១៣ហើយនៅក្រោមអំណាចគេ មានពលទ័ព៣សែន
៧ពាន់៥រយនាក់ ដែលចេញទៅច្បាំង ដោយមានកំឡាំង
យ៉ាងរឹងរបឹង សំរាប់នឹងជួយស្ដេចរាំងរាខ្មាំងសត្រូវ
១៤អូសៀសទ្រង់ក៏ចាត់ចែងធ្វើខែល លំពែងមួក សឹក និង
ក្រសសំរាប់បាញ់ឱ្យគេ គឺឱ្យពួកពលទ័ពទាំងអស់នោះ[ដ]
១៥ហើយនៅក្រុងយេរូសាឡិមទ្រង់ក៏ធ្វើយន្តដែល មនុស្ស
ប៉ិនប្រសប់បានបង្កើត ឡើងដាក់លើប៉មលើកំផែង សំរាប់
បាញ់ព្រួញនឹងថ្មធំៗ នោះព្រះនាមទ្រង់ក៏លាន់ឮ ទួទៅឆ្ងាយ

**២៦:៧** ច ២រប ២១:១៦ ឆ ២រប ២០:១
**២៦:៨** ជ លប ១៩:៣៨
**២៦:៩** ឈ ២ពវ ១៤:១៣ ២រប ២៥:២៣ ញ នហ ២:១៣ ៣:១៣
**២៦:១៤** ដ យរ ៤៦:៤
**២៦:១៦** ឋ ២ពវ ១៤:១០ ឌ ចទ ៣២:១៥ ឍ ១រប ៥:២៥ ណ ១ពវ ១៦:១២
**២៦:១៧** ត ១ពវ ៤:២
**២៦:១៨** ថ ជន ១៨:១–៧ ទ នក ៣០:៧ ធ ជន ១៦:៣៩ ន ១រប ៦:៤៩
**២៦:១៩** ប ជន ១២:១០
**២៦:២១** ផ នក ៤:៦ លវ ១៣:៤៦ ១៤:៨ ជន ៥:២ ១៩:១២

ពីព្រោះទ្រង់មានសេចក្ដីជំនួសយ៉ាងអស្ចារ្យ ដរាបដល់ទ្រង់
មានកំឡាំងខ្លាំង ។
១៦កាលទ្រង់មានកំឡាំងឡើងហើយ នោះព្រះទ័យទ្រង់ក៏
ប៉ោងធំឡើង[ឋ] ត្រឡប់ជាខូចអស់ទៅ[ឌ] ទ្រង់ក៏ប្រព្រឹត្តរំលង[ឍ]
នឹងព្រះយេហូវ៉ា ជាព្រះនៃទ្រង់ ដ្បិតទ្រង់បានយាងចូលទៅ
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ដុតកំញាន[ណ]នៅលើអាសនា
គ្រឿងក្រអូប ១៧តែអ័សារា[ត]ដ៏ជាសង្ឃ លោកចូលទៅតាម
នាំទាំងពួកសង្ឃនៃព្រះយេហូវ៉ា ដែលសុទ្ធតែមានចិត្តមុត
មាំ៨០នាក់ទៅជាមួយ ១៨សង្ឃទាំងនោះបានឃាត់ស្ដេច
អូសៀស ដោយពាក្យថា ឱព្រះករុណាអូសៀសអើយ ការ
ដុតកំញានថ្វាយព្រះយេហូវ៉ា នោះមិនសំរេចនៅទ្រង់ទេ គឺ
ជាការងាររបស់ពួកកូនចៅ[ថ]អើរ៉ុន[ទ]ដ៏ជាសង្ឃ[ធ] ដែលបាន
ញែកជាបរិសុទ្ធ សំរាប់នឹងដុតកំញាន[ន]វិញទេតើ ចូរចេញ
ពីទីបរិសុទ្ធនេះទៅ ពីព្រោះទ្រង់បានរំលងច្បាប់ហើយ
ការនេះក៏មិនបានរាប់ជាកិត្តិនាមដល់ទ្រង់ នៅចំពោះព្រះ
យេហូវ៉ាដ៏ជាព្រះដែរ ១៩ដូច្នេះ អូសៀសក៏ក្រេវក្រោធ រីឯ
ព្រះហស្តទ្រង់កាន់ពាន ប្រុងនឹងដុតកំញាន ហើយកំពុង
ដែលទ្រង់ក្រេវក្រោធនឹងពួកសង្ឃដូច្នេះ នោះរោគឃ្លង់[ប]
ក៏លេចឡើងត្រង់ព្រះនលាដទ្រង់ នៅមុខពួកសង្ឃក្បែរ
អាសនាគ្រឿងក្រអូប នៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា
២០អ័សារា ជាសំដេចសង្ឃ នឹងពួកសង្ឃឯទៀត លោកបាន
ពិនិត្យមើលឃើញ ទ្រង់កើតឃ្លង់នៅត្រង់ព្រះនលាដដូច្នោះ
ហើយ ក៏ច្រានទ្រង់ចេញពីទីនោះទៅជាប្រញាប់ ឯទ្រង់
ក៏ប្រញាប់ប្រញាល់នឹងចេញទៅដែរ ដោយព្រោះព្រះ
យេហូវ៉ាបានដាក់ទោសដល់ទ្រង់ ២១ស្ដេចអូសៀសទ្រង់មាន
រោគឃ្លង់ដរាបដល់ថ្ងៃសុគត ក៏គង់នៅក្នុងរោងទីទៃពីគេ[ផ]
ដោយព្រោះកើតឃ្លង់ ដ្បិតទ្រង់បានត្រូវកាត់កាល់ចេញពី

**២៦:៧** *ពួកម៉ាអូន* មើលការពន្យល់ ២០:១ ។
**២៦:៩** *ត្រង់ទ្វារជ្រុង . . . ទ្វារច្រកភ្នំ* គេប្រទះឃើញត្រង់តំបន់ខាងជើងឈាងខាងកើតនិងតំបន់ខាងត្បូងឈាងខាងលិច នៃកំផែងនេះ ទៅតាមកំផែងក្រុងយេរ៉ូសាឡិម គឺសំខាន់គិតពីផ្នែកការជុះជុលការបែកបាក់ដែលបានធ្វើដោយយ៉ូអាសគឺក្នុងការគ្រងរាជ្យរបស់ អ័ហាស៊ីយ៉ា (២៥:២៣) ។
**២៦:១០** *ប៉ម . . . ជីកអណ្ដូង* គឺមានប៉មនិងអណ្ដូងដែលមានជារាងមូលៗ គេបានរកឃើញជាច្រើន នៅឯការដ្ឋានជីកកាយរកវត្ថុសល់ពីបុរាណ ដូចជាក្នុងភូមិ (ភូមិរ៉ាន, ក្រុងគីបៀ, និងក្រុងបៀសេបា) ក៏មានឃើញចារឈ្មោះស្ដេចអូសៀសនៅនិងមាត់ អណ្ដូងនោះ ។
**២៦:១១** *អូសៀសទ្រង់មានពលទ័ព សុទ្ធតែជាមនុស្សចេះតស៊ូ* គឺជាស្ដេចទីក្លាភីលេសាទី២របស់ប្រទេសអាសើរ ដែលទ្រង់មានចលនាវាយប្រឆាំងទៅតំបន់ខាងលិច (ក្នុងឆ្នាំ ៧៤៣ មុន គ.ស) តាមរយៈការប្រមូលផ្ដុំរូបរួមអ្នកដឹកនាំតាមរយៈស្ដេច (អូសៀស) របស់យ៉ូដា ។
**២៦:១៥** *ធ្វើយន្ត . . . សំរាប់បាញ់ព្រួញនិងថ្មធំៗ* គឺពេលនោះ ម៉ាស៊ីនបាញ់គ្រាប់ថ្មធំៗ ក៏គេពុំបានស្គាល់ ក្នុងបច្ចេកវិជ្ជាយោធាទេគឺរយៈពេលបីសតវត្សរ៍ គឺរយៈពេលដែលការជ្រើសរើសអាវុធ នោះស្ថិតនៅមួយកន្លែងនៅតាមកំផែងធំៗ ដើម្បីការពារខ្មាំងសត្រូវដែលគេដាក់អាវុធនេះនៅលើកំពូលកំផែងធំៗ ។
**២៦:១៦** *កាលទ្រង់ (គឺស្ដេចអូសៀស) មានកម្លាំងឡើង* មើលការពន្យល់ ឧ.៥។
**២៦:១៩** *រោគឃ្លង់* មើលការពន្យល់ លវ ១៣:២ គឺជាប្រភេទជម្ងឺ ដែលជាការដាក់ទណ្ឌកម្មមួយទៅលើអំពើបាប ១៦:១២ ២១:១២–១៥ ។
**២៦:២១** *ស្ដេចអូសៀស . . . ថ្ងៃសុគត* មើល អស ៦:១ និងការពន្យល់ *គង់ក្នុងរោងទីទៃ* គឺដូចអត្ថបទមុនៗ ។

ព្រះវិហារព្រះយេហូវ៉ា រួចយ៉ូថាមជាព្រះរាជបុត្រាក៏ត្រួត
លើព្រះរាជវាំង ព្រមទាំងជំនុំជំរះពួកអ្នកស្រុកផង ២២រីឯ
ដំណើរឯទៀតពីអូសៀសទាំងមុនទាំងក្រោយ នោះហោរា
អេសាយ[ព] ជាកូនអ័ម៉ូស លោកបានកត់ទុកទាំងអស់ហើយ
២៣អូសៀស[ភ]ទ្រង់ផ្ទំលក់ទៅជាមួយនឹងពួកព្វយុកោទ្រង់
ហើយគេបញ្ចុះសពទ្រង់ ទៅទីបញ្ចុះសពរបស់ពួកស្តេច
ជាមួយនឹងពួកព្វយុកោទ្រង់ទៅ ដ្បិតគេថា ទ្រង់មានរោគ
ឃ្លង់ រួចយ៉ូថាម ជាព្រះរាជបុត្រក៏ឡើងសោយរាជ្យជំនួស
ព្រះបិតា[ម]។

### យ៉ូថាមឡើងជាស្តេចស្រុកយូដា

*២៧:១-៤,៧-៩ – ២ពវ ១៥:៣៣-៣៨*

**២៧** ១កាលយ៉ូថាម[ក]ចាប់តាំងសោយរាជ្យឡើង នោះ
ទ្រង់មានព្រះជន្ម២៥ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន១៦ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជាយេរូសា
ជាបុត្រីសាដុក ២ទ្រង់ប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ នៅ
ព្រះនេត្រព្រះយេហូវ៉ា តាមគ្រប់ទាំងសេចក្តីដែលអូសៀស
ជាព្រះបិតាបានធ្វើដែរ តែទ្រង់មិនបានយាងចូលទៅ ក្នុង
ព្រះវិហារនៃព្រះយេហូវ៉ាទេ ឯបណ្តាជន គេនៅតែប្រព្រឹត្ត
ខូចអាក្រក់នៅឡើយ ។
៣ទ្រង់ធ្វើទ្វារខាងលើរបស់ព្រះវិហារនៃព្រះយេហូវ៉ា ក៏
សង់កំផែងអូផែលឡើងជាច្រើន[ខ] ៤១ទៀតទ្រង់សង់ទីក្រុង
ខ្លះនៅស្រុកភ្នំយូដា ហើយនៅក្នុងព្រៃ ទ្រង់ក៏សង់បន្ទាយនឹង
ប៉មផង ៥ទ្រង់ក៏ច្បាំងឈ្នះស្តេចនៃពួកកូនចៅអាំម៉ូន[គ] ហើយ
ឆ្នាំនោះឯងពួកកូនចៅអាំម៉ូនក៏ថ្វាយប្រាក់១០០ហាប ស្រូវ
ភោជ្ជសាលី១ម៉ឺនរង្វាល់ នឹងស្រូវឱក១ម៉ឺនរង្វាល់ ដល់ទ្រង់
ដល់ឆ្នាំទី២ ហើយទី៣ គេក៏ថ្វាយប៉ុណ្ណោះដល់ទ្រង់ទៀត
៦ដូច្នេះ យ៉ូថាមមានកំឡាំងកាន់តែខ្លាំងឡើង[ឃ] ពីព្រោះទ្រង់
បានរៀប ផ្លូវទ្រង់ឱ្យត្រឹមត្រូវនៅចំពោះព្រះយេហូវ៉ាជាព្រះ
នៃទ្រង់ ៧រីឯដំណើរឯទៀតពីយ៉ូថាម នឹងអស់ទាំងការ
ចំបាំងរបស់ទ្រង់ ហើយអំពើប្រព្រឹត្តទាំងប៉ុន្មានរបស់ទ្រង់
នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ជារឿងពីពួកស្តេច
អ៊ីស្រាអែល និងយូដាហើយ ៨កាលទ្រង់ចាប់តាំងសោយ
រាជ្យឡើង នោះទ្រង់មានព្រះជន្ម២៥ឆ្នាំហើយ ក៏សោយ
រាជ្យនៅក្រុងយេរូសាឡិមបាន១៦ឆ្នាំ ៩យ៉ូថាមទ្រង់ផ្ទំលក់
ទៅជាមួយនឹងពួកព្វយុកោទ្រង់ ហើយគេបញ្ចុះសពទ្រង់
នៅក្នុងក្រុងដាវីឌ រួចអ័ហាស ជាព្រះរាជបុត្រាក៏ឡើង
សោយរាជ្យជំនួសព្រះបិតា ។

### អ័ហាសឡើងជាស្តេចស្រុកយូដា

*២៨:១-២៧ – ២ពវ ១៦:១-២០*

**២៨** ១កាលអ័ហាស[ក]ទ្រង់ចាប់តាំងសោយរាជ្យឡើងនោះ
ទ្រង់មានព្រះជន្ម២០ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន១៦ឆ្នាំ តែទ្រង់មិនបានប្រព្រឹត្តសេចក្តីដែល
ត្រឹមត្រូវ នៅព្រះនេត្រព្រះយេហូវ៉ា ដូចជាដាវីឌជាព្វយុកោ
ទ្រង់ទេ ២គឺទ្រង់បានដើរតាមផ្លូវរបស់ពួកស្តេចអ៊ីស្រាអែល

**២៦:២២** ព ២ពវ ១៥:១ អស ១:១ ៦:១
**២៦:២៣** ភ អស ១:១ ៦:១ ម ២ពវ ១៤:២១ អម ១:១
**២៧:១** ក ២ ពវ ១៥:៥,៣២ ១រប ៣:១២
**២៧:៣** ខ ២រប ៣៣:១៤ នហ ៣:២៦
**២៧:៥** គ លប ១៩:៣៨
**២៧:៦** ឃ ២រប ២៦:៥
**២៨:១** ក ១រប ៣:១៣ អស ១:១
**២៨:២** ខ នក ៣៤:១៧

**២៦:២២** *ហោរាអេសាយ... កត់ទុកទាំងអស់* ក៏ពុំមានសាក្សីណាបង្ហាញពេញពីសៀវភៅក្រឹត្យច្បាប់ របស់ពួកសង្ឃបង្ហាញពីហេតុការកត់ទុកនេះទេ ។
**២៦:២៣** *ហើយគេបញ្ចុះសពទ្រង់នៅទីបញ្ចុះសព របស់ពួកស្តេចជាមួយនិងពួកព្វយុកោទ្រង់* ប្រៀបធៀប ២ពវ ១៥:៧ ដោយឃើញសេចក្តីនេះ គឺស្តេចអូសៀស មានរោគឃ្លង់ហើតសុកតបានបញ្ចុះ នៅឯទីបញ្ចុះសពជាមួយនិងពួកស្តេច ទោះបីជាមិនមែនក្នុងផ្នូររបស់ពួកស្តេចក៏ដោយ ។
**២៧:១-៩** មើល ២ពវ ១៥:៣២-៣៨ និងការពន្យល់ ។
**២៧:១** *១៦ឆ្នាំ* គឺចន្លោះឆ្នាំ ៧៥០-៧៣៥ មុន គ.ស គឺមានទាំងអូសៀសចន្លោះឆ្នាំ(៧៥០-៧៤០) ។ ដែលការគ្រង់រាជ្យរបស់គាត់ ក៏ដូចជាការទទួលស្នងមរដកផងដែរ ។
**២៧:២** *តែទ្រង់មិនបានយាងចូល ទៅក្នុងវិហារ* អ្នកកាលប្បវត្តិបានបង្ហាញអំពីស្តេចយ៉ូថាម ដែលពុំបានធ្វើឱ្យមានកំហុសដដែលៗដូចជា អូសៀសបានធ្វើឡើយ(២៦:១៦)។ *ប្រព្រឹត្តខូចអាក្រក់* គឺចង់សំដែងពីការគោរពដល់ទីខ្ពស់(២ពវ ១៥:៣៥) ។
**២៧:៣-៦** គឺស៊ីគ្នាទៅនិងអ្នកកាលប្បវត្តិ និងឯកសារដែលបង្ហាញ ពីភក្តីភាពស្មោះស្ម័គ្រចំពោះព្រះ និងព្រះរាជបញ្ជាដែលនាំមកនូវព្រះពរក្នុងការរៀបចំនូវប្រព័ន្ធយោធាជោគជ័យ និងភាពសុខសាន្តដោយព្រោះស្តេចនេះជាអ្នករៀបចំផ្លូវជូនព្រះ(ខ.៦) ទំនាក់ទំនងជាមួយកូនចៅ អាំម៉ូនបានជាជំនួយដល់ផលប្រយោជន៍ យ៉ាងជាក់លាក់សម្រាប់កាលប្បវត្តិរបស់វង្សស្តេច(មើលការពន្យល់ ២០:១-៣០ ២៤:២៦) ។
**២៧:៧** *អស់ទាំងការចំបាំងរបស់ទ្រង់* មើល ឧទាហរណ៍ ២ពវ ១៥:៣៧ ។
**២៨:១-២៧** មើល ២ពវ ១៦:១-២០ និងការពន្យល់ ។ ទាំងសេចក្តីផ្តើម និងសេចក្តីបញ្ចប់ គឺជាពតីមានពីរដែលនាំឱ្យឃើញនូវហេតុការតែមួយស៊ីគ្នាត្រូវគ្នា ។ ការគ្រង់រាជ្យរបស់ស្តេច អ័ហាស នោះក្នុងគម្ពីរក៏ពុំបានបញ្ជាក់ការប្រាប់ឱ្យបានច្បាស់ទេ តែអ្នកកាលប្បវត្តិក៏បានរើសយកហេតុការកើតឡើងដូចៗគ្នា ដ៏ជាក់លាក់ចេញពីសម្តីរបស់អ័ប៊ីយ៉ា ដែលដាក់ទោសដល់នគរផ្នែកខាងជើង(ជំពូកទី១៣)គឺដើម្បីបង្ហាញថាកាលនៅក្រោមការគ្រប់គ្រងរបស់ស្តេចអ័ហាស នោះនគរខាងត្បូងបានលិចលង់ទៅ ដែលឃ្លាតឆ្ងាយពីក្រឹត្យវិន័យរបស់ព្រះ ។ ភាពស្មោះត្រង់ទៅលើសាសនារបស់ពួកយូដាដែលមានស្តេច អ័ប៊ីយ៉ាបានដម្កើងខ្លួនហួសធម្មតា ដែលនាំឱ្យស្តេចអ័ហាប់ផ្តួលរំលំចេញពីរាជបល្ល័ង្ក ។
**២៨:១** *បាន ១៦ឆ្នាំ* គឺក្នុង ៧៣២-៧១៥ មុន គ.ស គឺមិនរាប់បញ្ចូលពីស្តេចយ៉ូថាមទេ(៧៣៥-៧៣២) ។
**២៨:២** *សិតធ្វើរូបទុកជាព្រះ* ប្រៀបធៀប ១៣:៨ ។

វិញ ហើយបានសិតធ្វើរូប[ខ]ទុកជាព្រះ ៣មួយទៀតទ្រង់បាន
ដុតកំញាន នៅច្រកភ្នំរបស់កូនហ៊ីនណំម[គ] ព្រមទាំងដុតបុត្រ
ទ្រង់[ឃ]ក្នុងភ្លើង តាមទំលាប់គួរស្អប់ខ្ពើម[ង]របស់សាសន៍
ដទៃដែលព្រះយេហូវ៉ា បានបណ្តេញពីមុខពួកកូនចៅ
អ៊ីស្រាអែលចេញ ៤ក៏ថ្វាយយញ្ញបូជា ហើយដុតកំញាន នៅ
លើអស់ទាំងទីខ្ពស់នៅលើភ្នំ ហើយនៅក្រោមគ្រប់ទាំង
ដើមឈើខៀវផង ។
៥ហេតុនោះបានជាព្រះយេហូវ៉ាជាព្រះនៃទ្រង់ ក៏ប្រគល់
ទ្រង់ ទៅក្នុងកណ្តាប់ដៃនៃស្តេចស្រុកស៊ីរី[ច] គេក៏វាយពួក
ទ្រង់ ហើយចាប់យកជាច្រើននាំទៅជាឈ្លើយដល់ក្រុង
ដាម៉ាស ហើយទ្រង់ត្រូវប្រគល់ ទៅក្នុងកណ្តាប់ដៃនៃស្តេច
អ៊ីស្រាអែលដែរ ដែលស្តេចនោះក៏វាយពួកទ្រង់ប្រហារ
សំឡាប់មនុស្សយ៉ាងសន្ធឹក ៦ដ្បិតពេកា[ឆ] ជាបុត្រារេម៉ាលា
ទ្រង់បានសំឡាប់មនុស្ស ដែលមានចិត្តក្លាហាន នៅស្រុក
យូដា[ជ] អស់១សែន២ម៉ឺននាក់ក្នុង១ថ្ងៃ ពីព្រោះគេបានបោះ
បង់ចោលព្រះយេហូវ៉ា ជាព្រះនៃពួកព្ធយុកោ ៧ហើយ
ស៊ីកគ្រី ជាមនុស្សខ្លាំងពូកែ ពីស្រុកអេប្រាអិម ក៏សំឡាប់
ម្អាសេយ៉ា ជាបុត្រាស្តេច ហើយនិងអាសរីកាម ជាឧកញ៉ា
វាំង ព្រមទាំងអែលកាណា ជាឧបរាជស្តេចទៅផង។
៨ពួកកូនចៅអ៊ីស្រាអែល ក៏ដឹកនាំពួកបងប្អូនគេទៅជា
ឈ្លើយអស់២សែននាក់ មានទាំងស្រីៗ និងកូនប្រុសកូនស្រី
របស់គេ[ឈ] និងរបឹបជាច្រើនផង ទៅឯក្រុងសាម៉ារី[ញ] ៩ប៉ុន្តែ
ទីនោះមានហោរាម្នាក់របស់ព្រះយេហូវ៉ា ឈ្មោះអូដេឌ
លោកចេញទៅជួបនឹងពលទ័ព ដែលវិលមកឯក្រុងសាម៉ារី
ពោលថា មើល ដោយព្រោះព្រះយេហូវ៉ាជាព្រះនៃពួក
ព្ធយុកោអ្នករាល់គ្នា ទ្រង់មានសេចក្តីក្រោធ[ដ]ដល់ពួកយូដា
បានជាទ្រង់ប្រគល់គេមកក្នុងកណ្តាប់ដៃនៃអ្នករាល់គ្នា
ហើយអ្នករាល់គ្នាបានប្រហារជីវិតគេ ដោយមោហោចិត្ត
ដែលគរឡើងដល់ផ្ទៃមេឃហើយ[ឋ] ១០ឥឡូវនេះ អ្នករាល់គ្នា
គិតបង្ក្រាបពួកកូនចៅយូដា និងពួកក្រុងយេរូសាឡិម ទុកជា
បាវប្រុសបាវស្រី[ឌ]របស់អ្នករាល់គ្នាទៀត តែឯអ្នករាល់គ្នា
តើមិនមានអំពើរំលងចំពោះព្រះយេហូវ៉ាជាព្រះនៃអ្នករា
ល់គ្នាដែរទេឬអី ១១ដូច្នេះ ចូរស្តាប់ខ្ញុំឥឡូវចុះ ត្រូវបើកឱ្យ
ពួកបងប្អូនរបស់អ្នករាល់គ្នា ដែលបាននាំមកជាឈ្លើយនេះ
ត្រឡប់ទៅវិញទៅ ដ្បិតសេចក្តីក្រេវក្រោធដ៏សហ័សផងព្រះ
យេហូវ៉ា បានគ្របលើអ្នករាល់គ្នាហើយ[ឍ] ១២ដូច្នេះ ពួកមេ
ខ្លះក្នុងពួកអេប្រាអិម គឺអ័សារា ជាកូនយ៉ូហាណាន បេរេគា
ជាកូនមស៊ីលេម៉ូត យេហ៊ីសេគាជាកូនសាលូម និងអ័ម៉ាសា
ជាកូនហាឌឡាយ គេលើកគ្នាទាស់នឹងពួកអ្នកដែលមកពី
ច្បាំងនោះថា ១៣មិនត្រូវឱ្យឯងរាល់គ្នានាំពួកឈ្លើយចូល
មកក្នុងស្រុកនេះទេ ដ្បិត ឯងរាល់គ្នាគិតធ្វើការ ដែលនឹង
នាំឱ្យយើងមានទោស នៅចំពោះព្រះយេហូវ៉ា ទាំងបន្ថែម
ការនេះមកលើអំពើបាប នឹងការរំលងរបស់យើងរាល់គ្នា
ទៀត ដ្បិតទោសរបស់យើងធន់ណាស់ហើយ ក៏មានសេចក្តី
ក្រេវក្រោធយ៉ាងសហ័សគ្របលើពួកអ៊ីស្រាអែលដែរ
១៤ដូច្នេះ ពួកទាហានក៏លះបង់ឈ្លើយទាំងនោះ និងរបឹប
ចោលនៅមុខពួកចៅហ្វាយនិងពួកជំនុំទាំងអស់គ្នា ១៥ឯពួក
អ្នកដែលចេញឈ្មោះហើយគេក្រោក ឡើងនាំពួកឈ្លើយ
មករួចរើយកសំលៀកបំពាក់ពីក្នុងរបឹបនោះ ចែកដល់អស់
អ្នកណាដែលអាក្រាត ឱ្យគេស្លៀកពាក់ ព្រមទាំងឱ្យមាន

**២៨:៣** គ យស ១៥:៨ ឃ លវ ១៨:២១ ២ពវ ៣:២៧ អគ ២០:២៦ ង ចទ ១៨:៩ ២របា ៣៣:២
**២៨:៥** ច អស ៧:១
**២៨:៦** ឆ ២ពវ ១៥:២៥,២៧ ជ ខ.៨ អស ៩:២១ ១១:១៣
**២៨:៨** ឈ ចទ ២៨:២៥,៤១ ញ ២របា ២៩:៩
**២៨:៩** ដ អស ១០:៦ ៤៧:៦ សក ១:១៥ ឋ អរ ៩:៦ វវ ១៨:៥
**២៨:១០** ឌ លវ ២៥:៣៩–៤៦
**២៨:១១** ឍ ២របា ១១:៤
**២៨:១៥** ណ ២ពវ ៦:២២ សភ ២៥:២១–២២ ត ចទ ៣៤:៣ ពច ១:១៦ ថ លក ១០:២៥–៣៧

**២៨:៣** *ច្រកភ្នំរបស់កូនហ៊ីនណំម* មើល ៣៣:៦ និងការពន្យល់ នហ ១១:៣០ យរ ៧:៣១ ។ យ៉ូសៀសក៏បានបញ្ឈាក់ការអនុវត្តរបស់គាត់ក៏ឃើញ (២ពវ ២៣:១០) *ព្រមទាំងដុតបុត្រាទ្រង់ក្នុងភ្លើង* មើល លវ ២០:១–៥ យរ ៧:៣១–៣២ ២ពវ ១៦:៣ បានញែក "កូនប្រុសឬបុត្រា" សម្រាប់ថ្វាយជាភាពបរិសុទ្ធ ដែលញែកសម្រាប់ព្រះ តែការទាំងអស់នេះជាទង្វើ ដែលធ្វើឱ្យព្រះមិនសព្វព្រះហឫទ័យ ហើយទ្រង់ជាព្រះយេហូវ៉ា ក៏បានដេញពួកនោះឱ្យចេញពីមុខសាសន៍អ៊ីស្រាអែល(មើល ២ពវ ១៦:៣) ។

**២៨:៥** ប្រៀបធៀប ១៣:១៦–១៧ *ព្រះនៃទ្រង់ក៏ប្រគល់ទ្រង់ . . . នៃសាសន៍អេស៊ីព្ទ* យោងទៅលើអ្នកកាលប្រវត្តិ អំពីទស្សនះរបស់ពួកគេស្តីពីការកាត់ទោសភ្លាមៗ គឺការបរាជ័យក្នុងសង្គ្រាម នេះគឺជាលទ្ធផលនៃការពុំស្តាប់បង្គាប់(មើលការពន្យល់ ២០:៣០) ។ *ហើយទ្រង់ត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចអ៊ីស្រាអែលដែរ* ២ពវ ១៦:៥–៦ និង អស ៧ ក៏បង្ហាញច្បាស់ថាស្តេចរេស៊ីន (ជាស្តេចរបស់សាសន៍អើរ៉ាម) និងពេការពបានរួមគ្នាធ្វើសង្គ្រាមវាយប្រឆាំងនិងសាសន៍យូដា ។ អ្នកកាលប្រវត្តិក៏បានជ្រើសរើសហេតុការនេះមកពិចារណានិងញែកឱ្យដាច់ពីគ្នាឬក៏បង្ហាញពីព្រឹត្តិការណ៍នៃជីវិតរបស់ស្តេចស្រុក អើរ៉ាម–អ៊ីស្រាអែល) ទៅជាពីផ្នែកផ្សេៗពីរគ្នា ។

**២៨:៦** *ពេកា* ជាស្តេចដែលគ្រងរាជ្យនៅ ផ្នែកភូមិភាគនៃនគរខាងជើងគឺក្នុងឆ្នាំ ៧៥២–៧៣២ មុន ស.គ(មើល ២ពវ ១៥:២៧–៣១) *បានបោះបង់ចោលព្រះយេហូវ៉ា* គឺមានលក្ខណៈដូចស្តេច អ័ប៊ីយ៉ាដែលបង្កើតរឿងជម្លោះនិងនគរខាងជើង (១៣:១១) ។

**២៨:៩–១៥** សេចក្តីសប្បុរសរបស់អ្នក ជាម្ចាស់ឈ្លើយនៅឯនគរខាងជើងដល់ពួកឈ្លើយពីស្រុកយូដា ដូចជាបង្ហាញក្នុង ខ.១៤–១៥ វាជាប្រវត្តិរបស់ពាក្យប្រៀបប្រដូចរបស់ព្រះយេហូវ៉ា ចំពោះពួកស្រុកសាម៉ារី(លក ១០:២៥–៣៧)។ ចរិតលក្ខណៈរបស់អូដេឌ ចំពោះអ្នកស្រុកតំបន់ខាងជើងគឺបង្ហាញដោយឆន្ទះរបស់គាត់ដែល អាចកំណត់ហៅពួកគេថា"ពួកបងប្អូនរបស់អ្នករាល់គ្នា"(ខ.១១)ក្នុងករណីនេះការកំណត់ត្រាក្នុងជំពូក១៣ គឺមានលក្ខណៈបញ្ច្រាស់គឺពួកជពូជអំបូរនៅ ផ្នែកខាងជើងគឺមានភាពសុចរិត ជាងអំបូរខាងត្បូង ។

ស្បែកជើងពាក់ផង រួចចែកអាហារ[ឃ]ដល់គេឱ្យបរិភោគ
ក៏ចាក់ប្រេងលាបឱ្យផង ឯអស់អ្នកណាដែលមានកំឡាំងតិច
នោះគេបញ្ជិះលើសត្វលា បញ្ជូនត្រឡប់ទៅឯពួកបងប្អូនគេ
ត្រឹមក្រុងយេរីខូរ ជាទីក្រុងដើមលម៉ើទៅ[ង] រួចគេវិលមក
ឯក្រុងសាម៉ារីវិញ[ច] ។
១៦នៅគ្រានោះស្តេចអ័ហាសទ្រង់ចាត់សារទៅ សូមឱ្យ
ពួកស្តេចស្រុកអាសស៊ើរ[ទ]មកជួយ ១៧ពីព្រោះពួកអេដំម[ធ]
បានមកវាយស្រុកយូដាម្តងទៀត ព្រមទាំងនាំមនុស្សទៅជា
ឈ្លើយផង[ន] ១៨ឯពួកភីលីស្ទីន[ប]គេក៏បានលុកលុយចូលទីក្រុង
ទាំងប៉ុន្មាន នៅស្រុកទំនាប ហើយនឹងប៉ែក ស្រុកយូដាខាង
ត្បូង គេវាយយកបានក្រុងបេត–សេមែស ក្រុងអាយ៉ាឡូន[ផ]
ក្រុងកេដេរ៉ូត[ព] ក្រុងសូគរ[ភ] និងដំបន់នៅជុំវិញក្រុងធីបណា[ម]
និងដំបន់នៅជុំវិញ ព្រមទាំងក្រុងគីមសូរ និងដំបន់នៅ
ជុំវិញផង រួចគេក៏អាស្រ័យនៅទីក្រុងទាំងនោះ ១៩ដ្បិត
ព្រះយេហូវ៉ា ទ្រង់បាននាំឱ្យពួក យូដាបានទាបថោកដោយ
ព្រោះអ័ហាស ស្តេចសាសន៍អ៊ីស្រាអែល ពីព្រោះស្តេចបាន
នាំឱ្យពួកយូដាលែងមានសេចក្តីទប់ចិត្តខ្លាចបាបហើយ បាន
ប្រព្រឹត្តរំលងល្មើសយ៉ាងធំ[យ]ចំពោះព្រះយេហូវ៉ា ២០គ្រា
នោះទីកឡាត–ពីលេស៊ើរ[រ] ជាស្តេចស្រុកអាសស៊ើរ[ល]ក៏មក
ឯទ្រង់ តែមិនបានជួយចំរើនកំឡាំងទ្រង់ទេ[វ] គឺបានធ្វើឱ្យ
ទ្រង់មានសេចក្តីលំបាកវិញ[ស] ២១ដ្បិតអ័ហាស[ហ]បានបែងយក
ចំណែក ពីព្រះវិហារនៃព្រះយេហូវ៉ា ពីព្រះរាជដំណាក់
ហើយពីពួកចៅហ្វាយ ទៅថ្វាយដល់ស្តេចអាសស៊ើរ តែ
ការនោះក៏មិនបានជួយដល់ទ្រង់ដែរ[ឡ]។

**២៨:១៦** ទ ២ពវ ១៦:៧ អក ២៣:១២ **២៨:១៧** ធ ទដ ១៣៧:៧ អស ៣៤:៥ ៦៣:១ យរ ២៥:២១ អគ ១៦:៥៧ ២៥:២១ អម ១:១១ ន ២របា ២៩:៩ **២៨:១៨** ប អស ៩:១២ ១១:១៤ យរ ២៥:២០ អគ ១៦:២៧,៥៧ ២៥:១៥ ផ យស ១០:១២ ព យស ១៥:៤១ ភ ១សយ ១៧:១ ម លប ៣៨:១២ **២៨:១៩** យ ១របា ៥:២៥ **២៨:២០** រ ២ពវ ១៥:២៩ ១របា ៥:៦ ល អស ៧:១៧ ៨:៧ ១០:៥–៦ ៣៦:១ វ ២ពវ ១៦:៧ ស អស ១០:២០ **២៨:២១** ហ ២របា ១៦:២–៩ ឡ យរ ២:៣៦ **២៨:២២** អ យរ ៥:៣ ១៥:៧ ១៧:២៣ **២៨:២៣** ក ២របា

២២ហើយនៅគ្រាដែលមានសេចក្តីទុក្ខវេទនា នោះស្តេច
គឺអ័ហាសនេះឯង ទ្រង់បានប្រព្រឹត្តរំលង[អ]នឹងព្រះយេហូវ៉ា
ថែមទៀត ២៣គឺទ្រង់បានថ្វាយយញ្ញបូជា ដល់អស់ទាំងព្រះ[ក]
នៃពួកក្រុងដាម៉ាស ដែលគេបានវាយទ្រង់ ដោយនឹកថា
ដោយព្រោះព្រះនៃពួកស្តេចស៊ីរីបានជួយគេ[ខ] នោះយើង
នឹងថ្វាយយញ្ញបូជា ដល់ព្រះទាំងនោះដែរ ដើម្បី ឱ្យបាន
ជួយខាងយើង ប៉ុន្តែព្រះទាំងនោះជាហេតុនាំឱ្យទ្រង់នឹង
ពួកអ៊ីស្រាអែលទាំងអស់រួញថយវិញ[គ] ២៤អ័ហាសក៏ប្រមូល
អស់ទាំងគ្រឿងប្រដាប់[ឃ]របស់ព្រះវិហារនៃព្រះ[ង] មកកាត់
ផ្តាច់ជាដុំៗ ទ្រង់ក៏បិទទ្វារ[ច]ព្រះវិហារនៃព្រះយេហូវ៉ា
ចោល ហើយធ្វើអាសនា[ឆ]សំរាប់ទ្រង់ នៅគ្រប់ទីកៀនក្នុង
ក្រុងយេរូសាឡិមដែរ ២៥ឯនៅគ្រប់ទាំងទីក្រុងស្រុកយូដា
ទ្រង់ក៏ធ្វើទីខ្ពស់សំរាប់នឹងដុតកំញានថ្វាយព្រះដទៃ ទ្រង់បាន
បណ្តាលឱ្យព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោទ្រង់ មាន
សេចក្តីក្រោធ ២៦រីឯដំណើរឯទៀតពីទ្រង់ និងគ្រប់ទាំង
អំពើដែលទ្រង់ប្រព្រឹត្តទាំងមុនទាំងក្រោយ នោះសុទ្ធតែបាន
កត់ទុកក្នុងសៀវភៅ ពីពួកស្តេចយូដា និងអ៊ីស្រាអែលហើយ
២៧អ័ហាសក៏ផុតលក់ទៅ[ជ]ជាមួយនឹងពួកឰយុកោទ្រង់ ហើយ
គេបញ្ចុះសព[ឈ]ទ្រង់ នៅក្នុងទីក្រុង គឺក្នុងក្រុងយេរូសាឡិម
តែមិនមែនក្នុងផ្នូររបស់ពួកស្តេចសាសន៍អ៊ីស្រាអែលទេ រួច
ហាសេគា ជាព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួស
ព្រះបិតា ។

២៥:១៤ ខ អស ១០:២០ យរ ៤៤:១៧–១៨ គ ១របា ១១:១ យរ ១៨:១៥ **២៨:២៤** ឃ ២របា ២៩:១៩ ង ២ពវ ១៦:១៨ ច មឡ ១:១០ ឆ ២របា ៣០:១៤ **២៨:២៧** ជ អស ១៤:២៨–៣២ ឈ ២របា ២១:២០

**២៨:១៧–១៨** *ពួកអេដំមបានមកវាយស្រុកយូដាម្តងទៀត* គឺជាមនុស្សចំលែក (ខ.១៦) ដែលធ្វើឱ្យមានការបរាជ័យចំពោះអ័ហាស (មើលការពន្យល់ ១៦:២–៩) ។

**២៨:១៩** *ដ្បិតព្រះយេហូវ៉ា ទ្រង់បាននាំឱ្យពួកយូដាបានទាបថោកដោយព្រោះអ័ហាស* ។ គឺជាលក្ខណៈរួបមន្តតែមួយក្នុងការប្រើពាក្យពេជ្រក្នុងការវាយឈ្នះទៅលើពូជអំបូរខាងជើង ។ ក្នុងគម្ពីរ ២របា ១៣:១៨ គឺគ្រានោះដែលអ័ហាសបានបង្គាប់ដល់សាសន៍យូដា ។

**២៨:២០** *ទីកឡាត–ពីលេស៊ើរ* គឺជាស្តេចស្រុកអាសស៊ើរ ៧៤៥–៧២៧ មុន ស.គ (មើល ១របា ៥:២៦ និងការពន្យល់) *បានធ្វើឱ្យទ្រង់មានសេចក្តីលំបាកវិញ* ។ ឃើញថាមានលក្ខណៈផ្ទុយនិងហេតុក្នុង ២ពវ ១៦:៩ ដែលស្តេចទីឡាត–ពីលេស៊ើរ ក៏ឆ្លើយតបនិង សេចក្តីស្នើររបស់ស្តេច អ័ហាសនិងប្រើវិធីផ្សេងៗហើយសម្លាប់ស្តេចរេស៊ីន ។ អ្នកកាលប្បវត្តិបង្ហាញពីភាពថ្មីករបស់អ្នកអាន ដែលយល់ច្បាស់ពីប្រវត្តិវង្សានុវង្ស ដែលបានផ្តល់នូវផលប្រយោជន៍ដល់សាសន៍យូដា តាមរយៈពួកស្រុក អាសស៊ើរ ។

**២៨:២២–២៣** អ្នកកាលប្បវត្តិបង្ហាញ ពីភាពដឹងច្បាស់របស់អ្នកអានចំពោះដំណើររបស់ស្តេចអ័ហាស ទៅកាន់ក្រុងដាម៉ាស់និង ធ្វើអាសនានិងការគោរពវិញ្ញាណអាក្រក់នៅទីនោះ (២ពវ ១៦:១០–១៦) ។

**២៨:២៤–២៥** ក៏មានពត៌មានបន្ថែមទៀត ស្តីពីការកែប្រែរបស់ អ័ហាស ដែលយើងឃើញមានក្នុង ២ពវ ១៦:១៧–១៨ ។ អ្នកកាលប្បវត្តិក៏ប្រាប់ពីការប្រព្រឹត្តរបស់អ័ហាស៊ីយ៉ាដើម្បីកែតម្រងការរំលោបខ្លះៗ ពីការគ្រប់គ្រងរបស់ស្តេច អ័ហាស : គឺមិនតែបិទទ្វារទីបាំងសាចហើយពន្លត់ចង្កៀងក៏មិនបានដុតកំញាន ឬថ្វាយដង្វាយដុតក្នុងទីបរិសុទ្ធ (២៩:៧) គឺជាអាសនាដង្វាយដុត នឹងគ្រឿងប្រដាប់នៃអាសនាទាំងអស់ តុសម្រាប់នំបុ័ងតាំងទុកនិងគ្រឿងប្រដាប់នៃតុនោះទាំងអស់ផង (២៩:១៨–១៩) ។ គឺជាការរៀបចំពិធីដ៏ត្រឹមត្រូវដែលស្តេច អ័ប៊ីយ៉ា បានប្រព្រឹត្តដោយស្មោះត្រង់និងព្រះយេហូវ៉ា គឺជាសាសន៍យូដាដែលខុសពីពួកនៅផ្នែកខាង នគរខាងជើង (១៣:១១) ។ ឥឡូវការរៀបចំទៅតាមក្រឹត្យវិន័យចាស់ៗដែលមិននៅក្រោមការគ្រប់គ្រងរបស់ស្តេច អ័ហាសទេ និងធ្វើឱ្យនគរខាងត្បូងមានលក្ខណៈដូចជាសាសន៍ខាងជើងវិញ (មើលការពន្យល់ ខ.១–២៧) ។

**២៨:២៧** *តែមិនមែនក្នុងផ្នូររបស់ពួកស្តេច* គឺជាស្តេចទី៣ភាពខ្សោយរបស់គេគឺជាលទ្ធផលមួយដែលពុំមានការគោរព មានស្តេចផ្សេងៗទៀតដូចជាស្តេចយ៉ូរ៉ាម (២១:២០) និងយ៉ូអាស (២៤:២៥) អូសៀសដែលមានបាបនិង

## ហេសេគាញែកព្រះវិហារជាបរិសុទ្ធ

*២៩:១-២ - ២ពវ ១៨:២-៣*

**២៩** ១ រីឯកាលហេសេគា[ក]ចាប់តាំងសោយរាជ្យឡើង
នោះទ្រង់មានព្រះជន្ម២៥ឆ្នាំ ហើយក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន២៩ឆ្នាំ ព្រះមាតាទ្រង់ព្រះនាមជា អ័ប៊ីយ៉ា
ជាបុត្រីសាការី ២ ទ្រង់បានប្រព្រឹត្តសេចក្ដីដែលត្រឹមត្រូវ
នៅព្រះនេត្រព្រះយេហូវ៉ា តាមគ្រប់ទាំងសេចក្ដី ដែល
ដាវីឌ[ខ]ជាព្ធយុកោទ្រង់បានធ្វើដែរ ៣ នៅខែចែត្រ ក្នុងឆ្នាំទី
១នៃរាជ្យទ្រង់ នោះទ្រង់ក៏បើកទ្វារព្រះវិហារនៃព្រះ
យេហូវ៉ា ព្រមទាំងជួសជុល[គ]ទ្វារទាំងនោះឡើងវិញផង
៤ រួចទ្រង់នាំពួកសង្ឃ និងពួកលេវីមក ឱ្យមូលគ្នានៅទីធ្លា
ខាងកើត ៥ មានបន្ទូលថា ឱពួកលេវីអើយ ចូរស្ដាប់តាម
យើងចុះ ឥឡូវនេះ ចូរអ្នករាល់គ្នាញែកខ្លួនចេញជា
បរិសុទ្ធ[ឃ] ព្រមទាំងនាំយករបស់ស្មោកគ្រោកចេញពីទី
បរិសុទ្ធ ហើយញែកព្រះវិហារនៃព្រះយេហូវ៉ា ជាព្រះនៃ
ពួកព្ធយុកោអ្នករាល់គ្នាចេញជាបរិសុទ្ធដែរ ៦ ដ្បិតបិតា[ង]
ទាំងឡាយរបស់យើងរាល់គ្នាបានរំលង[ច] ដោយប្រព្រឹត្ត
អំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា ជាព្រះនៃ
យើង ព្រមទាំងបោះបង់ចោលទ្រង់ ហើយងាកមុខចេញពី
ទីលំនៅនៃព្រះយេហូវ៉ា បែរខ្នងទៅឱ្យវិញ ៧ គេបានទាំង
បិទទ្វារទីបាំងសាច ហើយពន្លត់ចង្កៀង ក៏មិនបានដុត
កំញាន[ឆ] ឬថ្វាយដង្វាយដុតក្នុងទីបរិសុទ្ធ ដល់ព្រះនៃសាសន៍
អ៊ីស្រាអែលឡើយ ៨ ហេតុនោះបានជាសេចក្ដីក្រោធរបស់
ព្រះយេហូវ៉ាមកគ្របលើពួកយូដា និងពួកក្រុងយេរូសាឡិម
ហើយទ្រង់ប្រគល់គេឱ្យត្រូវមានចលាចល ឱ្យត្រូវសេចក្ដី
អស្ចារ្យ[ជ] និងសេចក្ដីចំអកឡកឡឺយ[ឈ]របស់គេ ដូចជាអ្នក
រាល់គ្នាឃើញស្រាប់ ៩ ដ្បិតមើល ដោយហេតុនោះ បានជា
ឪពុកយើងរាល់គ្នាបានដួលដោយដាវ កូនប្រុស កូនស្រី និង
ប្រពន្ធយើងរាល់គ្នាបានត្រូវដឹកនាំទៅជាឈ្លើយ[ញ] ១០ ឥឡូវ
នេះ យើងមានចិត្តចង់តាំងសញ្ញា[ដ]នឹងព្រះយេហូវ៉ា ជាព្រះ
នៃសាសន៍អ៊ីស្រាអែល ដើម្បីឱ្យសេចក្ដីក្រោធ[ឋ]ដ៏សហ័ស
របស់ទ្រង់បានបែរចេញពីយើងរាល់គ្នាទៅ ១១ ដូច្នេះ ឱកូន
ទាំងឡាយអើយកុំឱ្យធ្វេសប្រហែសឡើយ ដ្បិតព្រះយេហូវ៉ា
បានរើសអ្នករាល់គ្នា ឱ្យឈរធ្វើការងារ[ឌ]នៅចំពោះទ្រង់
ហើយឱ្យបានទទួលភ្នាក់ងារ[ឍ] ជាអ្នកដុតកំញានរបស់ទ្រង់។
១២ នោះពួកលេវី[ណ]ក៏ប្រុងប្រៀបខ្លួន គឺក្នុងពួកកូនចៅ

**២៩:១** ក ១របា ៣:១៣
**២៩:២** ខ ២របា ៣៤:២
**២៩:៣** គ ២ពវ ១៨:១៦
**២៩:៥** ឃ លវ ១១:៤៤ នហ ១៣:៩
**២៩:៦** ង អរ ៩:៧ ទដ ១០៦:៦-៤៧ យរ ២:២៧ ១៨:១៧ អគ ២៣:៣៥ ដយ ៩:៥-៦ ច ១របា ៥:២៥
**២៩:៧** ឆ នក ៣០:៧
**២៩:៨** ជ ចទ ២៨:២៥ ឈ លវ ២៦:៣២ យរ ១៨:១៦ ១៩:៨ ២៥:៩,១៨
**២៩:៩** ញ ២របា ២៨:៥-៨,១៧
**២៩:១០** ដ ២ពវ ១១:១៧ ២របា ២៣:១៦ ឋ ជន ២៥:៤ ២របា ៣០:៨ អរ ១០:១៤ **២៩:១១** ឌ ជន ៣:៦ ៨:៦,១៤ ឍ ១របា ១៥:២ **២៩:១២** ណ ជន ៣:១៧-២០ ត ២របា ៣១:១៥

ជម្ងឺឃ្លង់ដែលនាំឱ្យមានលទ្ធផលដូចៗគ្នា ទោះបីមិនបានបង្ហាញឱ្យបានច្បាស់ ដោយប្រើពាក្យពេជដូចគ្នាក៏ដោយ (២៦:២៣) ប្រៀបធៀប (២៦:២៣) ប្រៀបធៀបម៉ានាសេ (៣៣:២០) ។

**២៩:១-៣២:៣៣** អ្នកកាលប្រវត្តិបានបង្ហាញ ឬផ្ដោតអារម្មណ៍ទៅលើអ័ហាស៊ីយ៉ាច្រើនជាទំនាប់ស្ដេចសាឡូម៉ូនក្រោមៗទៀត ។ ទោះជាពាក្យប្រៀបប្រដូចក្នុង (២ពវ ១៨:២០) គឺមានផ្នែកមួយចំនួនដូចគ្នាតែមានតែផ្នែកវគ្គទី៤គឺក៏មានភាពដូចៗគ្នា គឺមានខខ្លះដែលមានលក្ខណៈផ្ទុយ (២៩:១-២ ៣២:៣២-៣៣) ។ ក្នុងជំនាន់ស្ដេចដ៏អស្ចារ្យក្នុងជំណោមស្ដេចសាឡូម៉ូន បន្ទាប់ទៀតស្ដេចយ៉ូសៀសជាអ្នកទទួលវិញ (២ពវ ២២-២៣ ប្រៀបធៀប ១ពវ ១៣:២) និងការកត់ត្រាពីស្ដេចហេសេគា គឺតាំងពីការគ្រងរាជ្យដំបូងរបស់ទ្រង់នៃស្ដេចអង្គនេះ ដោយហ៊ានប្រឈមមុខពុះពារនិងស្ដេចសាសន៍ហេរីបជាស្ដេចស្រុកអាសេរី ។ ដោយលក្ខណៈផ្ទុយខ្លះអ្នកកាលប្រវត្តិបានសំគាល់អំពីការរៀបចំឡើងវិញនូវអាសនា របស់ហេសេគានិងការពុះពាររបស់ទ្រង់ចំពោះបញ្ហា នៃពិធីបុណ្យផ្សេៗ ។ មានអត្ថបទដែលជាហេតុការដូចគ្នាខ្លះ (២ពវ ១៨:១-៦) ដែលមានទំនាក់ទំនងដូចគ្នាទៅនឹងការរៀបចំឡើងវិញនោះអត្ថបទដូចគ្នាមួយចំនួន ក្នុងជំពូកទាំងនេះដែលលើកឡើងពីការគ្រងរាជ្យរបស់ស្ដេចសាឡូម៉ូន ដោយដឹងថាអ្នកកាលប្រវត្តិបង្ហាញទស្សនៈរបស់លោកហេសេគា គឺដូចជាស្ដេចសាឡូម៉ូនទី២ក្នុងការរៀបចំនូវពិធីបុណ្យរំលង (៣០:២,៥,២៣,២៥-២៦) ឬការរៀបចំរបស់ទ្រង់ក្នុងការថ្វាយបង្គំ (២៩:៧,១៨,៣៥ ៣១:២-៣) ឬការគ្រប់គ្រងរាជទ្រព្យរបស់ទ្រង់ (៣២:២៧-២៩) ក៏ធ្វើឱ្យសាសន៍ដ៏ទៃយើពីការនេះ (៣២:២៣) (៣០:២៥) ។

**២៩:១** *២៩ឆ្នាំ* ៧១៥-៦៨៦ មុន គ.ស (ប៉ុន្តែមើលការពន្យល់ អស ៣៦:១ បន្ថែម១៥ឆ្នាំជាឆ្នាំអាយុកើនដោយព្រះគុណព្រះ (២ពវ ២០:៦) ក៏ពុំបានបង្ហាញតាមរយៈអ្នកកាលប្រវត្តិទេ ។

**២៩:៣-៣០:២៧** ពុំបានជួបប្រទះក្នុង ពង្សាវតារក្សត្រទេ ។

**២៩:៣** *ក្នុងឆ្នាំទី១* ៧១៥ មុន គ.ស គឺជាឧទាហរណ៍មួយទៀតនៃការអនុវត្តរបស់អ្នកកាលប្រវត្តិដែលបង្ហាញការកត់ត្រាពីប្រវត្តិ វង្សក្សត្រទៅជាបែបនិទានកថាវិញ (មើលការពន្យល់ ១២:២) *បើកទ្វារព្រះវិហារ* គឺក្រោយពេលដែលស្ដេច អ័ហាស (២៨:២៤) *ជុសជុលទ្វារ* ការជុសជុលទ្វារគឺមានទាំងបំពាក់មាសសុទ្ធថ្មីៗផង (២ពវ ១៨:១៦) ។

**២៩:៥-១១** ព្រះបន្ទូលរបស់ស្ដេច ហេសេគា បង្ហាញជាថ្មីពីការកាត់ទោសរបស់អ្នកកាលប្រវត្តិស្ដីអំពីការ ជាប់ទាក់ទងគ្នាពីសកម្មភាពនិងឥទ្ធិពលៈអំពើបាបពីអតីតកាល នាំមកនូវការលំបាកនិងការកាត់ទោសប៉ុន្តែក៏មានការស្មោះត្រង់សុចរិតក៏នាំមកសេចក្ដីសង្គ្រោះ ។

**២៩:៧** ហេសេគាបានរៀបចំឡើងវិញ នៅវិហារទាំងនេះទៅតាមគំរូរបស់ ស្ដេចសាឡូម៉ូន (២:៤ ៤:៧) ។

**២៩:៨** *ត្រូវមានចលាចល ឱ្យត្រូវសេចក្ដីអស្ចារ្យ* ដោយមានលេចចេញសូរស័ព្ទភាសារបស់ពួកហោរា ជាពិសេសហោរាយេរេមា (មើល យរ ១៩:៨ ២៥:៩,១៨,២៩:១៨ ៥១:៣៧) ។ គឺផ្ដោយទៅលើភាពហឹនវិនាសរបស់ប្រទេសអាសសើរ នៃនគរផ្នែកខាងជើងនឹងពួកយូដាផងដែរ ។

**២៩:១២** *កូនចៅកេហាក់ មានម៉ាហាត ជាកូនអ័ម៉ាសាយ . . . ពួកគើសុន* គឺជាកូនទាំងបីរបស់លេវី (១របា ៦:១) ។

កេហាត់ មានម៉ាហាត ជាកូនអ័ម៉ាសាយ និងយ៉ូអែល ជា
កូនអ័សារា ក្នុងពួកកូនចៅម្រ៉ារី មានគីស ជាកូនអាប់ឌី និង
អ័សារា ជាកូនយេហាលែល ហើយក្នុងពួកគើសុនមាន
យ៉ូអា ជាកូនស៊ីម៉្មា និងអេដែន[ត] ជាកូនយ៉ូអា
១៣ក្នុងពួកកូន
ចៅអេលីសាផាន[ថ] មានស៊ីមរី និងយីអែល ក្នុងពួកកូនចៅ
អេសាភ[ទ] មានសាការី និងម៉ាថានា
១៤ក្នុងពួកកូនចៅ
ហេម៉ាន មានយីអែល និងស៊ីម៉ាយ ក្នុងពួកកូនចៅយេឌូថិន
មានសេម៉ាយ៉ា និងអ៊ូស៊ាល
១៥អ្នកទាំងនោះក៏ប្រមូលពួកបង
ប្អូនចេញជាបរិសុទ្ធ[ធ] រួចចូលទៅសំអាតព្រះវិហារនៃព្រះ
យេហូវ៉ាតាមព្រះបន្ទូលនៃព្រះយេហូវ៉ា ដោយសារស្តេច
១៦ពួកសង្ឃ គេចូលទៅក្នុងព្រះវិហារនៃព្រះយេហូវ៉ាប៉ែក
ខាងក្នុង ដើម្បីនឹងសំអាតទីនោះ ក៏នាំយករបស់ស្មោក
គ្រោកទាំងអស់ ដែលឃើញមានក្នុងព្រះវិហារនៃព្រះ
យេហូវ៉ា ចេញមកឯទីលានព្រះវិហារ រួចពួកលេវីនាំគ្នា
ជញ្ជូនពីទីនោះ យកទៅចោលនៅទ្រង់ជ្រោះកេដ្រុន[ន]
១៧គេចាប់តាំងញែកជាបរិសុទ្ធ នៅថ្ងៃដំបូងខែចេត្រ ហើយ
ដល់ថ្ងៃទី៨ក្នុងខែនោះ គេបានសំអាតមកដល់ទីបាំងសាច
ផងព្រះយេហូវ៉ា ដូច្នេះ គេបានញែកព្រះវិហារនៃព្រះ
យេហូវ៉ា ចេញជាបរិសុទ្ធ ក្នុងរវាងរួចជាស្តេច
១៨រួចគេ
ចូលទៅក្នុងព្រះរាជដំណាក់ គាល់ស្តេចហេសេគា ទូលថា
យើងខ្ញុំរាល់គ្នាបានសំអាតព្រះវិហារនៃព្រះយេហូវ៉ាស្រេច
ហើយ ព្រមទាំងអាសនាដង្វាយដុត និងគ្រឿងប្រដាប់នៃ
អាសនាទាំងអស់ តុសំរាប់នំបុ័ងតាំងទុក និងគ្រឿងប្រដាប់
នៃតុនោះទាំងអស់ផង
១៩មួយទៀត អស់ទាំងគ្រឿងប្រដាប់[ប]
ដែលស្តេចអ័ហាសបានចោលចេញក្នុងរាជ្យទ្រង់ នៅ
វេលាដែលទ្រង់បានប្រព្រឹត្តល្មើស នោះយើងខ្ញុំបានចាត់
ចែង ហើយញែកជាបរិសុទ្ធរួចជាស្រេច មើល របស់ទាំង
នោះនៅមុខអាសនានៃព្រះយេហូវ៉ាស្រាប់ ។
២០ឯស្តេចហេសេគា ទ្រង់ក្រោកឡើងពីព្រលឹម ទៅ
ប្រមូលពួកអ្នកជាប្រធានក្នុងទីក្រុង នាំគ្នាឡើងទៅឯព្រះ
វិហារព្រះយេហូវ៉ា
២១គេក៏នាំយកគោ៧ ចៀមឈ្មោល៧[ផ]

**២៩:១៣** ថ នក ៦:២២ ទ ១រប ៦:៣៩
**២៩:១៥** ធ ១រប ២៣:២៨ អស ១:២៥
**២៩:១៦** ន ២សយ ១៥:២៣
**២៩:១៩** ប ២រប ២៨:២៤
**២៩:២១** ផ អរ ៦:១៧ ៨:៣៥ ព លវ ៤:១៣–១៤
**២៩:២២** ភ លវ ៤:១៨ ជន ១៨:១៧
**២៩:២៣** ម លវ ១៦:៥ យ លវ ៤:១៥
**២៩:២៤** រ នក ២៩:៣៦ លវ ៤:២៦ ល ១រប ១១:១ អរ ៨:៣៥
**២៩:២៥** វ ១រប ២៥:៦ ២៨:១៩ ស ១សយ ២២:៥
**២៩:២៦** ហ ១រប ១៥:១៦ ឡ ១រប ១៥:២៤
**២៩:២៧** អ ១សយ ១៦:១៦
**២៩:២៨** ក ២រប ២:៤
**២៩:២៩** ខ ២រប ២០:១៨

កូនចៀម៧ និងពពែឈ្មោល៧ទៅផង សំរាប់ជាដង្វាយ
លោះបាប[ព]នៃនគរ និងបរិសុទ្ធ និងពួកយូដាទាំងប៉ុន្មាន
ទ្រង់ក៏បង្គាប់ដល់ពួកសង្ឃ ជាកូនចៅអើរ៉ុន ឱ្យថ្វាយសត្វ
ទាំង នោះនៅលើអាសនានៃព្រះយេហូវ៉ា
២២ដូច្នេះ គេក៏
បានសំឡាប់គោទាំងនោះ ហើយពួកសង្ឃទទួលយកឈាម
ទៅប្រោះលើអាសនា រួចគេសំឡាប់ចៀមឈ្មោល យក
ឈាមទៅប្រោះលើអាសនា ក៏សំឡាប់កូនចៀម យកឈាម[ភ]
ទៅប្រោះលើអាសនាដែរ
២៣បន្ទាប់មក គេនាំពពែ
ឈ្មោល[ម] ដែលសំរាប់ដង្វាយលោះបាបទាំងនោះ មកនៅ
ចំពោះស្តេច និងពួកជំនុំ ហើយអ្នកទាំងនោះក៏ដាក់ដៃ[យ]លើ
២៤ពួកសង្ឃសំឡាប់វាថ្វាយជាដង្វាយលោះបាប មានជាប់
ទាំងឈាមនៅលើអាសនា ដើម្បី ឱ្យធួននឹងបាប[រ]នៃពួក
អ៊ីស្រាអែលទាំងអស់ ដ្បិតស្តេចទ្រង់បានបង្គាប់ ឱ្យថ្វាយ
ដង្វាយដុត និងដង្វាយលោះបាបទាំងនោះ សំរាប់ពួក
អ៊ីស្រាអែលទាំងអស់[ល] ។
២៥ទ្រង់ក៏តាំងពួកលេវីឱ្យកាន់ឈឹង ពិណ និងស៊ុងនៅក្នុង
ព្រះវិហារនៃព្រះយេហូវ៉ា តាមបង្គាប់ដាវីឌ[វ] និងកាឌ់[ស]
ជាអ្នកមើលឆុតរបស់ទ្រង់ ហើយនឹងហោរាណាថាន់ ដ្បិត
សេចក្តីបង្គាប់នោះបានកើតមក ពីព្រះយេហូវ៉ា ដោយសារ
ពួកហោរាទ្រង់
២៦ដូច្នេះ ពួកលេវីក៏ឈរនៅមានទាំង
ប្រដាប់ភ្លេងរបស់ដាវីឌ[ហ] ហើយពួកសង្ឃក៏មានត្រែ[ឡ]
២៧រួចហេសេគាទ្រង់បង្គាប់ ឱ្យថ្វាយដង្វាយដុតនៅលើ
អាសនា រីឯកាលចាប់តាំងដុតដង្វាយ នោះចំរៀងនៃព្រះ
យេហូវ៉ា ក៏ផ្តើមឮឡើង ព្រមទាំងត្រែ និងគ្រឿងភ្លេង[អ]
របស់ដាវីឌ ជាស្តេចសាសន៍អ៊ីស្រាអែលផង
២៨ពួកជំនុំទាំង
អស់គ្នា គេក្រាបថ្វាយបង្គំ ពួកចំរៀងក៏ច្រៀង ពួកផ្លុំត្រែក៏ផ្លុំ
ឡើងព្រមគ្នា ដរាបដល់ដង្វាយដុត[ក]បានសុសហើយ ។
២៩កាលបានថ្វាយដង្វាយដុតរួចជាស្រេច នោះស្តេច
នឹងពួកអ្នកដែលនៅជាមួយទាំងប៉ុន្មាន ក៏ឱនខ្លួនក្រាបចុះ
ថ្វាយបង្គំ[ខ]
៣០មួយទៀត ស្តេចហេសេគា និងពួកអ្នកជា
ប្រធាន ក៏បង្គាប់ពួកលេវី ឱ្យច្រៀងសរសើរថ្វាយព្រះ

---

**២៩:១៣–១៤** *កូនចៅអេសាភ . . . ហេម៉ាន . . . កូនចៅយេឌូថិន* គឺជាអ្នកបង្កើតគ្រួសារទាំងបី នៃវង្សត្រកូលលេវី (១រប ៦:៣១–៤៨ ២៥:១–៣១) ។

**២៩:១៣** *ពួកកូនចៅអេលីសាផាន* គឺជាកំពូលលើកូនចៅរបស់ពួកគេហាត់ (ជន ៣:៣០) គឺជាពួកកូនចៅបង្កើតមកក្រោយៗទៀត (មើល ១រប ១៥:៨) និងមើលការពន្យល់ ១៥:៤–១០ ។

**២៩:១៦** *ជ្រោះកេដ្រុន* មើលការពន្យល់ អស ២២:៧ ក៏មើល ១ពវ ១៥:១៣ និងការពន្យល់ ។

**២៩:១៨** សកម្មភាពក្រោមការគ្រប់គ្រងស្តេច ហេសេគាជាកញ្ចក់នៃសាឡូម៉ូន (២:៤) ។

**២៩:២១** *ដង្វាយលោះបាប* មើល លវ ៤:១–៥:១៣ ។

**២៩:២២** *យកឈាមទៅប្រោះ* មើល ១៧:៦ ជន ១៨:១៧ ។

**២៩:២៣** *ដាក់ដៃលើ* មើល លវ ៤:១៣–១៥ ៨:១៤–១៥ ជន ៨:១២ ។

**២៩:២៥** *កាន់ . . . ហោរាណាថាន់* មើល ១សយ ២២:៥ និងការពន្យល់ ២សយ ៧,១២ ។

**២៩:២៦** *ប្រដាប់ភ្លេងរបស់ដាវីឌ* មើល ១រប ២៣:៥ ។

យេហូវ៉ា ដោយទំនុករបស់ដាវីឌ និងរបស់អេសាភ ជាអ្នក
មើលឆុត គេក៏ច្រៀងសរសើរដោយចិត្តរីករាយសប្បាយ
រួចឱនក្បាលថ្វាយបង្គំ ។
[៣១]នៅខណនោះ ហេសេគាទ្រង់មានបន្ទូលឡើងថា
ឥឡូវនេះ អ្នករាល់គ្នាបានថ្វាយខ្លួន ដល់ព្រះយេហូវ៉ាហើយ
ដូច្នេះ ចូរមកជិតនាំទាំងយញ្ញបូជា[គ] នឹងដង្វាយអរព្រះគុណ
ចូលមកក្នុងព្រះវិហារនៃព្រះយេហូវ៉ា ពួកជំនុំក៏នាំយក
យញ្ញបូជា និងដង្វាយអរព្រះគុណមក ហើយអស់អ្នកណា
ដែលស្ម័គ្រចិត្ត[ឃ] ក៏នាំយកដង្វាយដុតមកដែរ [៣២]ឯដង្វាយ
ដុត[ង]ដែលពួកជំនុំបានយកមក នោះមានចំនួនជាគោ៧០
ចៀមឈ្មោល១០០ និងកូនចៀម២០០ នោះឯងសុទ្ធតែ
សំរាប់ជាដង្វាយដុតថ្វាយ ដល់ព្រះយេហូវ៉ាទាំងអស់
[៣៣]ហើយដង្វាយដែលថ្វាយដាច់ទៅព្រះ នោះគឺគោ៦០០
និងចៀម៣ពាន់ [៣៤]ប៉ុន្តែមានពួកសង្ឃតិច មិនល្មមនឹង
ពន្លាត់ស្បែកដង្វាយដុតទាំងអស់បាន[ច] បានជាពួកលេវី ជា
បងប្អូន គេក៏ជួយរហូតដល់ការនោះបានសំរេចនឹងដល់
វេលាដែលពួកសង្ឃ បានញែកខ្លួនជាបរិសុទ្ធហើយ[ឆ] ដ្បិត
ពួកលេវីមានចិត្តស្មោះត្រង់ជាងពួកសង្ឃ ដេម្បីនឹងញែក
ខ្លួនចេញជាបរិសុទ្ធ [៣៥]មួយទៀត មានដង្វាយដុតជាច្រើន
ព្រមទាំងខ្លាញ់[ជ]ដង្វាយមេត្រី[ឈ] និងដង្វាយច្រួច[ញ] សំរាប់
គ្រប់ទាំងដង្វាយដុតផង ដូច្នេះ ការងារក្នុងព្រះវិហារនៃ
ព្រះយេហូវ៉ាបានតាំងឡើងវិញដូចដើម [៣៦]ហើយហេសេគា
នឹងពួកជនទាំងឡាយ ក៏មានសេចក្ដីរីករាយសប្បាយ ដោយ
ព្រោះព្រះបានបណ្ដាលឱ្យគេមាន ចិត្តព្រមព្រៀងគ្នាធ្វើ
ឡើង ដ្បិតការនោះស្រាប់តែធ្វើភ្លាម[ដ] ។

## ស្ដេចហេសេគាប្រារព្ធបុណ្យរំលង

**៣០** [១]ហេសេគាក៏ចាត់គេ ឱ្យទៅឯពួកអ៊ីស្រាអែល[ក]
ហើយនិងពួកយូដាទាំងអស់ ក៏ផ្ញើព្រះរាជសាសន៍ដល់ពួក
អេប្រាអិម និងពួកម៉ាន៉ាសេ[ខ] ឱ្យមកឯព្រះវិហារនៃព្រះ
យេហូវ៉ា នៅក្រុងយេរូសាឡិម ដើម្បីនឹងធ្វើបុណ្យរំលង[គ]
ថ្វាយព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល [២]ដ្បិត
ស្ដេចនឹងពួកអ្នកជាប្រធាន ហើយនឹងពួកជំនុំទាំងអស់គ្នា
ដែលនៅក្រុងយេរូសាឡិម បានប្រឹក្សាសំរេចនឹងធ្វើ[ឃ]
បុណ្យរំលងនៅខែទី២ [៣]ពីព្រោះគេធ្វើនៅវេលានោះឯង
ពុំបាន ដោយព្រោះពួកសង្ឃមិនទាន់ ញែកខ្លួនជាបរិសុទ្ធ[ង]
ឱ្យបានគ្នាល្មមនៅឡើយ ហើយពួកបណ្ដាជនក៏ មិនទាន់បាន
មូលគ្នានៅក្រុងយេរូសាឡិមផង [៤]តែដំណើរនោះ ស្ដេច
ព្រមទាំងពួកជំនុំទាំងអស់គ្នា ក៏យល់ឃើញថាត្រឹមត្រូវដែរ
[៥]ដូច្នេះក៏ចេញច្បាប់ ឱ្យប្រកាសប្រាប់ នៅពេញក្នុងស្រុក
អ៊ីស្រាអែល ចាប់តាំងពីក្រុងបៀរ-សេបា រហូតដល់ក្រុង
ដាន់[ច]ឱ្យមកធ្វើបុណ្យរំលងថ្វាយព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែល នៅក្រុងយេរូសាឡិម ដ្បិតជាយូរយារ
មកហើយ គេមិនបានធ្វើបុណ្យនោះ ដូចជាមានសេចក្ដីចែង

**២៩:៣១** គ ហព ១៣:១៥-១៦ ឃ នក ២៥:២ ៣៥:២២
**២៩:៣២** ង លវ ១:១-១៧
**២៩:៣៤** ច អគ ៤៤:១១ ឆ ២របា ៣០:៣,១៥
**២៩:៣៥** ជ លប ៤:៤ នក ២៩:១៣ ឈ លវ ៧:១១-២១ ញ លប ៣៥:១៤
**២៩:៣៦** ដ ២រប ៣៥:៨
**៣០:១** ក ១រប ៩:១ ខ លប ៤១:៥២ គ នក ១២:១១ ជន ២៨:១៦
**៣០:២** ឃ ជន ៩:១០
**៣០:៣** ង ជន ៩:៦-១៣ ២រប ២៩:៣៤
**៣០:៥** ច ពច ២០:១

**២៩:៣៥** *ដង្វាយដុតជាច្រើន . . . ដង្វាយមេត្រីនឹងដង្វាយច្រួច* គឺជាពិធីរំលឹកឧទ្ទិសរបស់ពួកជំនុំក្នុងការគ្រងរាជ្យ របស់ស្ដេចសាឡូម៉ូន(៧:៤-៦)ក៏សម្រាប់ជាច្បាប់ទាក់ទងនិងដង្វាយមេត្រី មើល លវ ៣,៧:១១-១២ ចំពោះដង្វាយច្រួចមើល ជន ១៥:១-១២ ។ *ការងារក្នុងព្រះវិហារនៃព្រះយេហូវ៉ាបានតាំងឡើងវិញដូចដើម* ការងារនេះគឺប្រហាក់ប្រហែលគ្នានូវការដែលគេបានប្រើពីមុន ៨:១៦ ដែលសំអាងទៅលើការងាររបស់ស្ដេចសាឡូម៉ូន ។

**៣០:១-២៧** វាស៊ីនិងការបង្ហាញរបស់អ្នកកាលប្រវត្តិប្រៀបធៀប និងពិធីបុណ្យរំលងតាមរយៈស្ដេចយ៉ូសៀស(៣៥:១-១៩ ២ពវ ២៣:២១-២៣)។ គឺជាការងាកចេញពីក្រឹត្យវិន័យ (នក ១២ ចទ ១៦:១-៨)គឺក្នុងការគោរពពិធីដូចជា:(១)ថ្ងៃក្នុងខែទី២(ខ.២)និង(២)ការរួចផុតពីសេចក្ដីតម្រូវនៃទំលៀនទំលាប់ខ្លះៗ (ខ.១៨-១៩) ។

**៣០:១** *ឯពួកអ៊ីស្រាអែលនឹងពួកយូដាទាំងអស់* មើលត្រង់សេចក្ដីផ្ដើមរបាក្សត្រទី១ ត្រង់គោលបំណងនិងផ្ទៃរឿង ។ គឺពួកនគរខាងជើងបានរលាយបាត់ទៅ គឺដោយសារតែការលុកលុយឈ្លានពាន និងការនិរទេស(ដែលជាការគួឱ្យសំគាល់ផង)(មើលខ.៥,១៨-១៩,២៥) ។

**៣០:២** *នៅខែទី២* បន្ទាប់ពីមានការបែងចែកនគរគឺស្ដេច យេរ៉ូបោម ធ្វើឱ្យមានការកំណត់ពេលធ្វើពីធីបុណ្យ ចំពោះនគរខាងជើងមានភាពផ្ទុយគ្នាខ្លះរហូតដល់១ខែ(១ពវ ១២:៣២) ក៏ជាពេលឈប់មួយរយៈគឺនៅក្នុងតំបន់ខាងជើងរហូតដល់ក្រុងយេរ៉ូសាឡិម ។ គឺការពន្យាពេលប្រារព្ធពិធីបុណ្យរំលងក្នុងរយៈពេលមួយខែស្ដេចហេសេគា មិនគ្រាន់តែអនុញ្ញាត្តិឱ្យមានពេលខ្លះសម្រាប់ពួកសង្ឃ ដើម្បីញែកខ្លួនជាបរិសុទ្ធប៉ុណ្ណោះទេ(ខ.៣) និងសម្រាប់ប្រជាជនមកជួបជុំគ្នា(ខ.៣,១៣)ប៉ុណ្ណោះទេក៏ប៉ុន្តែក៏សម្រេចឱ្យមានការរួបរួមនគរក្នុងថ្ងៃបុណ្យរំលងសម្រាប់រយៈពេលដំបូងនោះទេ គឺចាប់តាំងពីដំណើរបែបមូលមតិគ្នាអស់រយៈពេលជាង២សតវត្សរ៏មុនតំបូង ។ ក៏ពន្យាពេលដែលទាក់ទងនិងស្ដេចហេសេគា ដែលត្រូវចូលរួមគ្នាធ្វើបុណ្យរំលងដែលឆ្លុះបញ្ចាំង ពីទស្សនៈអ្នកកាលប្រវត្តិឃើញមានស្ដេចហេសេគាគឺជាសាឡូម៉ូនទីពីរ ។ ពិធីបុណ្យរំលងក៏បានកំណត់ឱ្យធ្វើនៅទី១៤ក្នុងខែទីមួយដើមឆ្នាំ(នក ១២:២,៦ ចទ ១៦:១-៨) ប៉ុន្តែ ពុំអាចធ្វើពិធីបុណ្យនោះ នៅពេលដែលបានកំណត់ដោយព្រោះមានភាពមិនស្អាតក្នុងព្រះវិហារនិងត្រូវសំអាតវិហារជាមុនសិន (២៩:៣,១៧) ។ ចំពោះការប្រារព្ធពិធីបុណ្យរំលងដោយ ការរួបរួមចិត្តកាយនិងត្រូវសាងសង់ព្រះវិហារឡើងវិញ អរ ៦:១៦-២២ ។

**៣០:៥** ពិធីបុណ្យគឺទាក់ទងនិងការប្រៀបធៀប ជាមួយជំនាន់ស្ដេច សាឡូម៉ូន (មើល ខ.២៦) នៅក្នុងពេលការចាប់ផ្ដើមឡើងវិញ គឺជាពិធីបុណ្យរំលងក៏មានការរៀបចំទៅតាមគ្រួសារ (នក ១២) តែក្រោយមកទៀតក៏ប្រែក្លាយជា

ទុកមកនោះទេ ៦ដូច្នេះ ពួករត់សំបុត្រក៏ទទួលយកសំបុត្រពី
ព្រះហស្តស្តេច និងពីពួកអ្នកជាប្រធាន ចេញទៅពេញក្នុង
ស្រុកអ៊ីស្រាអែល និងស្រុកយូដា តាមបង្គាប់ស្តេចដោយ
ពាក្យថា ពួកកូនចៅអ៊ីស្រាអែលអើយ ចូរត្រឡប់មកឯព្រះ
យេហូវ៉ា ជាព្រះនៃអ័ប្រាហាំ នៃអ៊ីសាក និងអ៊ីស្រាអែល
វិញ ដើម្បីឱ្យទ្រង់បានវិលមកឯសំណល់ពួកអ្នករាល់គ្នា
ដែលបានរួចពីកណ្តាប់ដៃនៃពួកស្តេចស្រុកអាសស៊ើរ
៧កុំឱ្យអ្នករាល់គ្នាធ្វើដូចជាពួកឪពុក[ឆ] និងពួកបងប្អូនអ្នក
រាល់គ្នា ដែលរំលង[ជ]នឹងព្រះយេហូវ៉ា ជាព្រះនៃពួក
ព្ធយុកោគេ ដល់ម៉្លេះបានជាទ្រង់បោះបង់ចោល គេឱ្យត្រូវ
វិងស៊ុង[ឈ] ដូចជាឯងរាល់គ្នាបានឃើញស្រាប់នោះឡើយ
៨ឥឡូវនេះ កុំឱ្យអ្នករាល់គ្នាមានចិត្តរឹងរូស[ញ] ដូចជាឪពុក
អ្នករាល់គ្នាឡើយ គឺត្រូវឱ្យប្រគល់ខ្លួនដល់ព្រះយេហូវ៉ាវិញ
ហើយចូលមកក្នុងទីបរិសុទ្ធរបស់ទ្រង់ ដែលទ្រង់បានញែក
ជាបរិសុទ្ធទុកជាដរាបទៅ ហើយត្រូវគោរពប្រតិបត្តិដល់
ព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នា ដើម្បីឱ្យសេចក្តីក្រោធ[ដ]
របស់ទ្រង់បានបែរពីអ្នករាល់គ្នាទៅ ៩ដ្បិតបើអ្នករាល់គ្នា
វិលមកឯព្រះយេហូវ៉ាវិញ[ឋ] នោះទាំងបងប្អូន នឹងកូនចៅអ្នក
រាល់គ្នាផង នឹងបានសេចក្តីមេត្តាករុណា[ឌ] នៅចំពោះពួក
អ្នកដែលបាននាំឯងទៅជាឈ្លើយ ហើយនឹងត្រឡប់វិលមក
ឯស្រុកនេះវិញ ពីព្រោះព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នា
ទ្រង់មានព្រះហឫទ័យទន់សន្តោស[ឍ] ហើយមេត្តាករុណា បើ
សិនជាអ្នករាល់គ្នាវិលមកឯទ្រង់វិញ នោះទ្រង់នឹងមិនបែរ
ព្រះភក្ត្រចេញពីអ្នករាល់គ្នាឡើយ ។
១០ដូច្នេះ ពួករត់សំបុត្រ ក៏ទៅពីក្រុង១ដល់ក្រុង១កាត់
ទាំងស្រុកអេប្រាអិម និងស្រុកម៉ានាសេផង រហូតដល់ស្រុក
សាប់យូល៉ូន តែអ្នកស្រុកទាំងនោះ គេសើចឡក[ណ]ឱ្យ ហើយ

**៣០:៧** ឆ ទដ ៧៨:៨,៥៧ ១០៦:៦ យរ ១១:១០ អគ ២០:១៨ ជ ១រប ៥:២៥ ឈ ចទ ២៨:២៥
**៣០:៨** ញ នក ៣២:៩ ដ ជន ២៥:៤ ២រប ២៩:១០
**៣០:៩** ឋ ចទ ៣០:២–៥ អស ១:១៦ ៥៥:៧ យរ ២៥:៥ អគ ៣៣:១១ ឌ នក ៣:២១ ១ពវ ៨:៥០ ឍ នក ២២:២៧ ចទ ៤:៣១ ២រប ៦:៣៩ មីក ៧:១៨
**៣០:១០** ណ ២រប ៣៦:១៦
**៣០:១១** ត ២រប ៦:៣៧ ថ ខ.២៥
**៣០:១២** ទ យរ ៣២:៣៩ អគ ១១:១៩
**៣០:១៣** ធ ជន ២៨:១៦
**៣០:១៤** ន ២រប ២៨:២៤
**៣០:១៤** ប ២សយ ១៥:២៣
**៣០:១៥** ផ ២រប ២៩:៣៤
**៣០:១៦** ព ២រប ៣៥:១០
**៣០:១៧** ភ ២រប ៣៥:១១ អរ ៦:២០
**៣០:១៨** ម នក ១២:៤៣–៤៩ ជន ៩:៦–១០

មើលងាយផង ១១ប៉ុន្តែមាន មនុស្សខ្លះក្នុងពួកអេស៊ើរ ពួក
ម៉ានាសេ និងពួកសាប់យូល៉ូន ដែលបន្ទាប[ត]ខ្លួនក៏មកឯក្រុង
យេរូសាឡិមដែរ[ថ] ១២ហើយព្រះហស្តនៃព្រះក៏មក បណ្តាល
ឱ្យពួកយូដាមានចិត្តព្រមព្រៀងគ្នា[ទ] នឹងធ្វើតាមបង្គាប់នៃ
ស្តេច និងពួកអ្នកជាប្រធាន តាមព្រះបន្ទូលនៃព្រះយេហូវ៉ា
១៣ដូច្នេះ មានមនុស្សជាច្រើនមកប្រជុំគ្នា នៅក្រុង
យេរូសាឡិម ជាជំនុំយ៉ាងធំ ដើម្បីនឹងធ្វើបុណ្យនំបុ័ងឥត
ដំបែរ[ធ]នៅខែទី២នោះ ១៤គេក៏ប្រុងប្រៀបនាំគ្នាទៅយកអស់
ទាំងអាសនា[ន] ដែលនៅក្រុងយេរូសាឡិម និងអាសនាទាំង
ប៉ុន្មាន ដែលសំរាប់ដុតកំញានបោះចោលទៅក្នុងជ្រោះ
កេដ្រុន[ប] ១៥រួចសំឡាប់ចៀមធ្វើបុណ្យរំលងនៅថ្ងៃ១៤ ក្នុង
ខែពិសាខ ឯពួកសង្ឃ និងពួកលេវី គេមានសេចក្តីខ្មាស ក៏
មកញែកខ្លួនចេញជាបរិសុទ្ធ[ផ] រួចយកដង្វាយដុតមក ក្នុងព្រះ
វិហារនៃព្រះយេហូវ៉ា ១៦គេក៏ឈរនៅកន្លែងរបស់គេ[ព]តាម
របៀបតាមក្រិត្យវិន័យរបស់លោកម៉ូសេជាអ្នកសំណប់
របស់ព្រះ គឺពួកសង្ឃគេទទួលឈាម ពីដៃពួកលេវីយកទៅ
ប្រោះ ១៧ដ្បិតមានគ្នាច្រើនក្នុងជំនុំនោះដែលមិនទាន់ញែក
ខ្លួនជាបរិសុទ្ធនៅឡើយ ដូច្នេះ ពួកលេវីត្រូវត្រួតលើការ
សំឡាប់[ភ]ចៀមធ្វើបុណ្យរំលង ឱ្យអស់អ្នកណាដែលមិនស្អាត
ដើម្បីនឹងញែក គេចេញជាបរិសុទ្ធថ្វាយព្រះយេហូវ៉ា
១៨មានបណ្តាជនយ៉ាងសន្ធឹកក្នុងពួកអេប្រាអិម ពួកម៉ានាសេ
ពួកអ៊ីសាខារ និងពួកសាប់យូល៉ូន ដែលមិនបានសំអាតខ្លួន
ទេ[ម] ប៉ុន្តែគេបានបរិភោគបុណ្យរំលងនោះដែរ ខុសនឹង
របៀបដែលចែងទុកមក ប៉ុន្តែហេសេគាទ្រង់អធិស្ឋានឱ្យគេ
ថា ១៩សូមព្រះយេហូវ៉ាដ៏ប្រកបដោយករុណាគុណ ទ្រង់អត់
ទោសដល់អស់អ្នកណាដែលតាំងចិត្តស្វែងរកព្រះ គឺជាព្រះ

ពិធីបុណ្យជាតិនៅឯព្រះវិហារវិញ (ខ.៨ មើល ចទ ១៦:១–៨)។

**៣០:៨** *ចូលមកក្នុងទីបរិសុទ្ធ* ពិធីបុណ្យរំលងគឺជាពិធីបុណ្យមួយក្នុងចំណោមបុណ្យធម្មយាត្រាទាំងបី ដែលតម្រូវឱ្យមានការចូលរួមនៅឯព្រះវិហារ (មើល ជន ២៨:៩–៣៩) ។

**៣០:៩** *បានសេចក្តីមេត្តាករុណា នៅចំពោះពួកអ្នកដែលនាំឯងទៅជាឈ្លើយ* ក្នុងការអធិស្ឋានរបស់ស្តេច សាឡូម៉ូនក្នុង ៦:៣៩ ហើយអ្នកកាលប្រវត្តិបានលុបនូវឃ្លាដែលមានលក្ខណៈដូចគ្នា (១ពវ ៨:៥០) ដែលអ្នកជាម្ចាស់ឈ្លើយរបស់គេបានបង្ហាញភាពមេត្តាករុណានេះ ជាឃ្លាបានឃើញនៅក្នុងសម្តីរបស់ស្តេចហេសេគា ដែលបង្ហាញថាទ្រង់ដូចជាសាឡូម៉ូនទី២ (មើល ២៦:៤០–៤២)។ *ហើយត្រឡប់មកឯស្រុកនេះវិញ* អ្នកដែលបានលន់តួបាបនឹងមានសេចក្តីសង្ឃឹមឡើងនិងបាន ត្រឡប់មកពីភាពជាឈ្លើយនៅស្រុកអាសស៊ើរ ។

**៣០:១៤** *ក្នុងជ្រោះកេដ្រុន* មើល ២៩:១៦ និងការពន្យល់ ។

**៣០:១៥** *ពួកសង្ឃនឹងពួកលេវី . . . ញែកខ្លួនចេញជាបរិសុទ្ធ* ដែលមានលក្ខណៈរិះគន់បន្ទោសដល់ពួកសង្ឃ (មើលខ.៣ ២៩:៣៤) គឺជាការតម្រូវឱ្យកិច្ចការថ្វាយយញ្ញបូជាមានវត្តមានពួកលេវីនិងពួកសង្ឃដែលផ្សាភ្ជាប់នូវសេចក្តីពិតសុចរិតក្នុងសេចក្តីជំនឿ ។

**៣០:១៧** *ពួកលេវីត្រូវលើកការសំឡាប់ចៀមធ្វើបុណ្យរំលង* មើល នក ១២:៦ ចទ ១៦:៦ ។ យោងតាមច្បាប់នៃគ្រួសារគឺត្រូវមានអំពើសម្លាប់ដើម្បីជាយញ្ញបូជាសម្រាប់ថ្ងៃបុណ្យរំលង។ គឺទំនងជាពួកលេវីបានធ្វើពិធីនេះដោយព្រោះពួកគេទើបមកពីនគរខាងជើងថ្មីៗ គឺដើម្បីញែកខ្លួនជាបរិសុទ្ធ ប្រៀបធៀប យហ ១១:៥៥ ។

**៣០:១៨–១៩** សេចក្តីជំនឿនិងការស្តាប់បង្គាប់ ដើម្បីគ្រប់គ្រងលើនិស្ស័យចាស់ (មើល មក ៧:១–២៣ យហ ៧:២២–២៣ ៩:១៤–១៦) ។

យេហូវ៉ា ជាព្រះនៃពួកព្ធយុកោគេ ទោះបើមិនបានសំអាត
ខ្លួនតាមរបៀបនៃទីបរិសុទ្ធក៏ដោយ [២០]ព្រះយេហូវ៉ាក៏ស្តាប់
តាម[យ]ហេសេគាទ្រង់ប្រោស[រ]ឱ្យគេបានជា[ល] [២១]ពួកកូនចៅ
អ៊ីស្រាអែលដែលបានមកឯក្រុងយេរូសាឡិម គេធ្វើបុណ្យ
នំបុ័ងឥតដំបែរ[វ]នោះអស់៧ថ្ងៃ ដោយសេចក្តីរីករាយជា
ខ្លាំង ហើយពួកលេវី និងពួកសង្ឃក៏ច្រៀងសរសើរថ្វាយ
ព្រះយេហូវ៉ារាល់ៗថ្ងៃ ផ្សំដោយភ្លេងមានសូរយ៉ាងខ្លាំង
ថ្វាយព្រះយេហូវ៉ា [២២]ឯហេសេគាទ្រង់ក៏មាន បន្ទូលព្រលួង
ព្រលោមចិត្តនៃពួកលេវីទាំងប៉ុន្មាន ដែលមានចំណេះ
ចេះស្ទាត់ក្នុងការងារនៃព្រះយេហូវ៉ា យ៉ាងនោះគេបានប
រិភោគទ្រង់ ទាំង៧ថ្ងៃនៃបុណ្យនោះ ហើយបានថ្វាយយញ្ញ
បូជាទុកជាដង្វាយមេត្រី ព្រមទាំងលន់តួដល់ព្រះយេហូវ៉ា
ជាព្រះនៃពួកព្ធយុកោគេ ។
[២៣]ពួកជំនុំទាំងអស់គ្នាក៏ប្រឹក្សាសំរេចនឹងធ្វើ[ស]បុណ្យនោះ
៧ថ្ងៃទៀត ដូច្នេះ គេក៏ធ្វើ៧ថ្ងៃទៀត ដោយរីករាយសប្បាយ
[២៤]ដ្បិត ហេសេគា ជាស្តេចយូដា ទ្រង់បានប្រទាន[ហ]គោ
១ពាន់និងចៀម៧ពាន់ ដល់ពួកជំនុំសំរាប់ជាដង្វាយ ហើយ
ពួកអ្នកជាប្រធានក៏ឱ្យគោ១ពាន់ នឹងចៀម១ម៉ឺនដល់គេដែរ
ក៏មានពួកសង្ឃជាច្រើនបានញែកខ្លួនជាបរិសុទ្ធ [២៥]នោះជំនុំ
ទាំងមូលនៃពួកយូដា ព្រមទាំងពួកសង្ឃ និងពួកលេវី
ហើយពួកជំនុំទាំងប៉ុន្មាន ដែលមកពីស្រុកអ៊ីស្រាអែល[ឡ]
និងពួកអ្នកដែលបានចេញពីស្រុកអ៊ីស្រាអែល មកតាំងទី
លំនៅក្នុងស្រុកយូដា គេក៏នាំគ្នាអរសប្បាយឡើយ [២៦]ដូច្នេះ
មានសេចក្តីអំណរជាខ្លាំង នៅក្នុងក្រុងយេរូសាឡិម ដ្បិត
ចាប់តាំងពីគ្រាសាឡូម៉ូន[អ] បុត្រដាវីឌ ជាស្តេចអ៊ីស្រាអែល
មក នោះមិនដែលមានការយ៉ាងនោះ នៅក្នុងក្រុង

**៣០:២០** យ ២របា ៦:២០ រ ២របា ៧:១៤ មទ្បូ ៤:២ ល យក ៥:១៦
**៣០:២១** វ នក ១២:១៥,១៧ ១៣:៦
**៣០:២៣** ស ២របា ៧:៩
**៣០:២៤** ហ ១ពវ ៨:៥ ២របា ៣៥:៧ អរ ៦:១៧ ៨:៣៥
**៣០:២៥** ឡ ខ.១១
**៣០:២៦** អ ២របា ៧:៨
**៣០:២៧** ក នក ៣៩:៤៣
**៣១:១** ក ២ពវ ១៨:៤ ២របា ៣២:១២ អស ៣៦:៧
**៣១:២** ខ ២របា ២៩:៩ គ ១របា ២៤:១ ឃ ១របា ១៥:២ ង ទដ ៧:១៧ ៩:២ ៤៧:៦ ៧១:២២ ច ១របា ២៣:២៨–៣២
**៣១:៣** ឆ ១របា ២៩:៣ ២របា ៣៥:៧ អគ ៤៥:១៧ ជ ជន ២៨:១–២៩:៤០
**៣១:៤** ឈ ជន ១៨:៨ ចទ ១៨:៨ ជន ១៣:១០

យេរូសាឡិមឡើយ [២៧]រួចមកពួកសង្ឃ នឹងពួកលេវី
ក៏ក្រោកឡើងឱ្យពរ[ក] ដល់ជនទាំងឡាយឯសេចក្តីអធិស្ឋាន
របស់គេ ក៏ឡើងទៅដល់ទីលំនៅបរិសុទ្ធរបស់ព្រះ គឺដល់
ស្ថានសួគ៌តែម្តង ហើយទ្រង់ក៏ទទួលស្តាប់តាម ។

**៣១** [១]រីឯវេលាដែលការទាំងនោះ បានរួចជាស្រេច
ហើយ នោះពួកអ៊ីស្រាអែលដែលមកប្រជុំគ្នា ក៏ចេញទៅឯ
អស់ទាំងទីក្រុងស្រុកយូដា បំបាក់បំបែក[ក]បង្គោលថ្មទាំង
ប៉ុន្មានដែលសំរាប់គោរព ហើយកាប់រំលំរូបព្រះ ព្រម
ទាំងបំផ្លាញទីខ្ពស់ និងអាសនាទាំងប៉ុន្មាន នៅពេញក្នុង
ស្រុកយូដា ស្រុកបេនយ៉ាមីន ស្រុកអេប្រាអិម និងស្រុក
ម៉ានៃសេដែរ ដរាបដល់បានលាញចេញទាំងអស់ទៅ រួច
មកពួកកូនចៅអ៊ីស្រាអែល ក៏វិលត្រឡប់ទៅឯកេរ្តិ៍អាករ
នៅក្នុងទីក្រុងរបស់គេរៀងខ្លួនវិញ ។

### ការថ្វាយបង្គំតាមរយៈដង្វាយស្ម័គ្រពីចិត្ត

*៣១:២០–២១ – ២ពវ ១៨:៥–៧*

[២]ហេសេគា[ខ]ទ្រង់ក៏តាំងវេនពួកសង្ឃ និងពួកលេវីតាម
ផ្នែកពួកគេ[គ] គឺគ្រប់គ្នាតាមការងារដែលខ្លួនត្រូវធ្វើ ទាំង
ពួកសង្ឃ និងពួកលេវីដែរ ដើម្បីឱ្យបានថ្វាយដង្វាយដុត
ដង្វាយមេត្រី ហើយធ្វើការងារផ្សេងៗ[ឃ] ព្រមទាំងពោល
ពាក្យសរសើរ[ង] នៅត្រង់អស់ទ្វារទីលំនៅនៃព្រះយេហូវ៉ា[ច]
[៣]ទ្រង់ក៏ថ្វាយ[ឆ]ព្រះរាជទ្រព្យ១ចំណែក ទុកសំរាប់ជាដង្វាយ
ដុត គឺដង្វាយដុតពេលព្រឹក និងពេលល្ងាច ដង្វាយដុតនៅ
ថ្ងៃឈប់សំរាក និងនៅថ្ងៃចូលខែ ហើយនៅថ្ងៃបុណ្យ
ដែលមានកំណត់ ដូចជាបានកត់ទុកក្នុងក្រិត្យវិន័យព្រះ
យេហូវ៉ា[ជ] [៤]មួយទៀតទ្រង់បង្គាប់ដល់ពួកមនុស្ស នៅក្រុង

---

**៣០:២០** គឺជាការឆ្លើយតបដល់ការអធិស្ឋានរបស់ស្តេច ហេសេគា គឺនឹកពីការអធិស្ឋានរបស់ស្តេចសាឡូម៉ូន (៧:១៤) ។

**៣០:២៣** *ធ្វើ៧ថ្ងៃទៀត* គឺពិធីបុណ្យត្រូវបានគេប្រារព្ធរយៈពេលពីរសប្តាហ៍ (អាទិត្យ) គឺជាពិធីបុណ្យថ្វាយព្រះវិហាររបស់ស្តេចសាឡូម៉ូន ដែលបានធ្វើរួចមកហើយ (៧:៨–៩) ។

**៣០:២៦** *ចាប់តាំងពីគ្រាសាឡូម៉ូន* គឺជាការថ្វាយដ៏ពិតប្រាកដនូវគំរូភាពក្នុងការគ្រងរាជ្យរបស់ស្តេច ហេសេគាគឺបន្ទាប់ពីស្តេចសាឡូម៉ូនបានធ្វើដ៏ល្អបែបនេះ (មើលការពន្យល់ ៣២:៣៣) ។

**៣០:២៧** *សេចក្តីអធិស្ឋានរបស់គេក៏ឡើងទៅដល់ទីលំនៅបរិសុទ្ធរបស់ព្រះ គឺដល់ស្ថានសួគ៌តែម្តង* ក៏យើងឃើញនូវភាពល្បីសុះសាយ មួយទៀតពីការអធិស្ឋានថ្វាយរបស់ស្តេចសាឡូម៉ូន (៦:២១,៣០,៣៣,៣៩) ។

**៣១:១–២១** គឺមានលក្ខណៈស្របៀងពី២ ដំបូងដែលជាហេតុការណ៍ ដូចគ្នានឹង ២ពវ ១៨:៤ សម្ភារៈជាឯកសារក្នុងជំពូកនេះ គឺស៊ីគ្នានិងកាលប្រវត្តិដែលចាប់អារម្មណ៍ក្នុងពួកលេវី និងភាពមានអទ្ធិភាពលើពួកជំនុំ ។ ការប្រឹងប្រែងរបស់ស្តេចហេសេគា ដើម្បីឱ្យមានការគាំទ្រដល់ពួកលេវី (ខ.៤) ។

**៣១:១** *ពួកកូនចៅអ៊ីស្រាអែល . . .* "រាស្ត្រអ៊ីស្រាអែលទាំងអស់" គឺអ្នកកាលប្រវត្តិបានចាប់អារម្មណ៍តែលើរាស្ត្រអ៊ីស្រាអែលទាំងអស់ជាពិសេសក្រោមការដឹកនាំរបស់ស្តេចហេសេគា *បង្គោលថ្ម* មើលការពន្យល់ ១ពវ ១៤:២៣ *កាប់រំលំរូបព្រះ* មើលការពន្យល់ ១៤:៣ ។

**៣១:២** ការព្ធសុះសាយ ៨:១៤ ។ អ្នកកាលប្រវត្តិក៏បង្ហាញប្រាប់ពីគំរូភាពរបស់ស្តេចហេសេគាថា ជាស្តេចសាឡូម៉ូនទី២ (មើលការពន្យល់ ២៩:៧, ១៨) ។

**៣១:៣** *ទ្រង់ក៏ថ្វាយជាព្រះរាជទ្រព្យ* គឺជាការថ្វាយព្រះរាជទ្រព្យផ្ទាល់របស់ផងទ្រង់គឺជាការឆ្លើយតបពីព្រះមហាក្សត្រា ចំពោះចិត្តសប្បុរសរបស់ប្រជារាស្ត្រទាំងនោះ ។ ដូចជាប្រជារាស្ត្រស្ថិតក្នុងការគ្រប់គ្រងរបស់ស្តេចដាវីឌផងដែរ (១របា ២៩:៣–៩) ។

យេរូសាឡិម ឱ្យគេចែកឱ្យពួកសង្ឃ និងពួកលេវីមាន
ចំណែកដែរ[ឈ] ដើម្បីឱ្យអ្នកទាំងនោះបានកាន់ខ្ជាប់តាម
ក្រិត្យវិន័យព្រះយេហូវ៉ា ៥កាលសេចក្ដីបង្គាប់នោះបាន
ឮសុសសាយទៅ ស្រាប់តែពួកកូនចៅអ៊ីស្រាអែលក៏ថ្វាយ
ដង្វាយជាបរិបូរ គឺជាផលដំបូង[ញ] ពីស្រូវពីទឹកទំពាំងបាយ
ជូរ[ដ] ពីប្រេង ពីទឹកឃ្មុំ ហើយពីផលនៃចំការទាំងអស់ គេក៏
យក១ភាគក្នុង១០ ពីរបស់ទាំងអស់មកជាបរិបូរដែរ ៦ឯពួក
កូនចៅអ៊ីស្រាអែល និងយូដា ដែលនៅអស់ទាំងទីក្រុងស្រុក
យូដា គេក៏យក១ភាគក្នុង១០ពីហ្វូងគោ ហ្វូងចៀម និង១
ភាគក្នុង១០[ឋ]ពីរបស់បរិសុទ្ធ ដែលបានថ្វាយដល់ព្រះ
យេហូវ៉ា ជាព្រះនៃគេ មកគរឡើងជាគំនរដែរ[ឌ] ៧គេចាប់
តាំងគរគំនរទាំងនោះ នៅក្នុងខែជេស្ឋ រួចដល់ខែអស្សុជ
ទើបបានហើយ[ឍ] ៨កាលហេសេគា និងពួកអ្នកជាប្រធាន
បានមកឃើញគំនរទាំងនោះ គេក៏សរសើរដំកើង[ណ]ដល់
ព្រះយេហូវ៉ា ព្រមទាំងអ៊ីស្រាអែលជារាស្ត្រទ្រង់ ៩ហើយ
ហេសេគាទ្រង់សាកសួរពួកសង្ឃ និងពួកលេវីពីដំណើរ
គំនរដង្វាយទាំងនោះ ១០នោះអ័សារា ជាសំដេចសង្ឃ ដែល
ជាវង្សសាដុក[ត] លោកទូលថា ចាប់តាំងពីវេលាដែលគេ
ផ្ដើមនាំយកដង្វាយមក ក្នុងព្រះវិហារនៃព្រះយេហូវ៉ា នោះ
យើងខ្ញុំបានទទួលទានឆ្អែត ហើយមាននៅសល់ជាបរិបូរ
ផង ដ្បិតព្រះយេហូវ៉ា ទ្រង់បានប្រទានដល់រាស្ត្រទ្រង់
ហើយសំណល់ដែលសល់នោះ គឺជាគំនរយ៉ាងធំទាំងនេះ
ឯង[ថ] ។

១១ដូច្នេះ ហេសេគាក៏បង្គាប់ឱ្យរៀបចំបន្ទប់ នៅក្នុងព្រះ
វិហារនៃព្រះយេហូវ៉ា គេក៏រៀបចំ ១២រួចនាំយកដង្វាយ
ស្ម័គ្រពីចិត្ត ដង្វាយ១ភាគក្នុង១០ និងដង្វាយបរិសុទ្ធមកទុក
ក្នុងបន្ទប់នោះ ដោយស្មោះត្រង់ មានកូណានា[ទ] ជាពួកលេវី
ជាអ្នកត្រួតលើរបស់ទាំងនោះ និងស៊ីម៉ាយប្អូនលោកជាអ្នក
ទី២ ១៣រួចយេហ៊ីអែល អ័សាស៊ា ណាហាត់ អេសាអែល
យេរីម៉ូត យ៉ូសាបាឌ[ធ] អេលាល យីសម៉ាគា ម៉ាហាត និង
បេណាយ៉ា គេសុទ្ធតែជាអ្នកត្រួតលើការនោះនៅក្រោម
អំណាចកូណានា និងស៊ីម៉ាយ ប្អូនលោក តាមមបង្គាប់ស្ដេច
ហេសេគា និងអ័សារ៉ា ជាអ្នកគ្រប់គ្រងនៅព្រះវិហារនៃព្រះ
១៤ហើយកូរេ កូនយីមន៉ា ជាពួកលេវី ដែលចាំទ្វារខាងកើត
លោកត្រួតលើដង្វាយដែលថ្វាយ ដល់ព្រះដោយស្ម័គ្រពីចិត្ត
ដើម្បីនឹងចែកដង្វាយរបស់ផងព្រះយេហូវ៉ា ព្រមទាំងរបស់
បរិសុទ្ធបំផុត ១៥នៅក្រោមអំណាចលោក នោះមាន
អេដែន[ន] មីនយ៉ាមីន យេសួរ សេម៉ាយ៉ា អ័ម៉ារា និង
សោកានា ដែលនៅអស់ទាំងទីក្រុង[ប]របស់ពួកសង្ឃជាអ្នក
ចែកដល់បងប្អូនគេទាំងធំទាំង តូចតាមវេនឱ្យស្មើគ្នា ដោយ
ចិត្តស្មោះត្រង់ ១៦គឺជាពួកប្រុសៗដែលបានកត់ក្នុងបញ្ជី[ផ]
ចាប់តាំងពីអាយុ៣ឆ្នាំឡើងទៅលើ ជាពួកអ្នកដែល ចូល
ទៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា តាមតែត្រូវការរាល់
តែថ្ងៃសំរាប់ការងារដែលផ្ញើទុកនឹងគេតាមវេនរៀងខ្លួន
១៧នឹងពួកអ្នកដែលបានរាប់តាមពង្សាវតារនៃពួកសង្ឃ
តាមវង្សរបស់ឪពុកគេ ហើយនិងពួកលេវី ចាប់តាំងពីអាយុ
២០ឆ្នាំឡើងទៅលើ តាមការងារ តាមវេនគេ ១៨ព្រមទាំង
ពួកអ្នកដែលបានរាប់ តាមពង្សាវតានៃពួកកូនតូចៗ ប្រពន្ធ
និងកូនប្រុស កូនស្រីរបស់គេ នៅគ្រប់ក្នុងពួកជំនុំ ដ្បិតអ្នក
ទាំងនោះ បានញែកខ្លួនចេញជាបរិសុទ្ធ ខំធ្វើការងារនោះ
ដោយឥតសៅហ្មង ១៩ហើយចំណែកពួកកូនចៅអើរ៉ុន ជា
ពួកសង្ឃដែលនៅចំការ ក្នុងក្រវល់ជុំវិញទីក្រុង[ព]របស់គេ
នោះមានមនុស្សដែលបានចេញឈ្មោះជា ស្រេចនៅគ្រប់
ទាំងទីក្រុង ទុកសំរាប់នឹងចែកចំណែកឱ្យដល់ពួកប្រុសៗ
ក្នុងពួកសង្ឃនោះ និងដល់អស់អ្នកដែលបានរាប់តាម
ពង្សាវតារពួកលេវី ។

២០ហេសេគាទ្រង់បានធ្វើដូច្នោះ នៅគ្រប់ក្នុងស្រុកយូដា
ទ្រង់ប្រព្រឹត្តសេចក្ដីដែលល្អត្រឹមត្រូវ ហើយស្មោះត្រង់[ភ]នៅ
ចំពោះព្រះយេហូវ៉ា ជាព្រះនៃទ្រង់ ២១ហើយគ្រប់ទាំងការ
ដែលទ្រង់ចាប់តាំងធ្វើសំរាប់ការងារក្នុងព្រះវិហារនៃព្រះ

**៣១:៥** ញ ជន ១៨:១២,២៤ នហ ១៣:១២ អគ ៤៤:៣០ ដ ចទ ១២:១៧
**៣១:៦** ឋ លវ ២៧:៣០ នហ ១៣:១០–១២ ឌ នរ ៣:៧
**៣១:៧** ឍ នក ២៣:១៦
**៣១:៨** ណ ទដ ១៤៤:១៣–១៥
**៣១:១០** ត ២សយ ៨:១៧ ថ នក ៣៦:៥ អគ ៤៤:៣០ មឡ ៣:១០–១២
**៣១:១២** ទ ២រប ៣៥:៩
**៣១:១៣** ធ ២រប ៣៥:៩
**៣១:១៥** ន ២រប ២៩:១២ ប យស ២១:៩–១៩
**៣១:១៦** ផ ១រប ២៣:៣
**៣១:១៩** ព ជន ៣៥:២–៥
**៣១:២០** ភ ២ពវ ២០:៣
**៣១:២១** ម ចទ ២៩:៩

**៣១:៥–៦** មើល ចទ ១២:៥–១៩ ១៤:២២–២៧ ។ គឺស្រាស្រូវនិងប្រេងត្រូវបានយកនាំទៅព្រះវិហារ (ចទ ១២:១៧) ។ ឯចំណែកអ្នកដែលមកពីចម្ងាយក៏ត្រូវយកទាំងរបស់មានតម្លៃនៅពេលដែលព្រះវិហារអាចដូរយករបស់ដែលត្រូវការ (ចទ ១៤:២៤) ។ ឯអ្នកដែលរស់នៅស្រុកយូដាក៏បានយកដង្វាយ១ភាគក្នុង១០នៃសត្វនិងសត្វផ្សេងៗ តែវាហាក់ដូចជាលំបាកសម្រាប់ដែលអ្នកនៅឆ្ងាយៗ គឺជាការធ្វើឱ្យប្រសើរឡើងវិញនូវការថ្វាយផលផ្លែដំបូងរបស់ពួកគេ ឬដង្វាយ១០ហូត១និងដង្វាយស្ម័គ្រពីចិត្ត ។ មើល ១០:៣៥–៣៩ ក៏មានការថ្វាយពុំបានត្រឹមត្រូវផងដែរ នហ ១៣:១០–១៣ មឡ ៣:៨–១០ ។

**៣១:៧** *ក្នុងខែជេស្ឋ* គឺខែឧសភា–មិថុនា ជាពេលបុណ្យថ្ងៃទី៥០និងបុណ្យចម្រូត*ទៅដល់ខែអស្សុជ* មានខែកញ្ញា,តុលា ។ គឺជាពេលវេលានៃបុណ្យបារាំងនិងបុណ្យចំរូតនិងការប្រមូលផលទំពាំងបាយជូរ (មើល ២៣:១៦) ។

**៣១:១៦** *៣ឆ្នាំឡើងទៅ* ទោះបីជាកណ្ឌសញ្ញាពីបុរាណមិនបានឯកភាពនិងទូរលេខនេះក៏ដោយ ក៏វាជាតំណាងនៃការកត់ត្រាខុសអស់រយៈពេល ៣០ ឆ្នាំដែលជាអាយុកាលដើម្បីបម្រើក្នុងព្រះវិហារ (១រប ២៣:៣) ។

**៣១:២០–២១** ក៏មានការបង្ហាញដ៏សង្ខេបមួយទៀត ចំពោះការបកស្រាយពីអ្នកកាលប្រវត្តិពីការលះបង់ជាច្រើន : គឺមិនគ្រាន់តែពុំស្តាប់បង្គាប់ដែលជាបន្ទាលនាំឱ្យទទួលទណ្ឌកម្មប៉ុណ្ណោះទេ ប៉ុន្តែអ្នកដែលស្តាប់បង្គាប់និងការស្វែងរកព្រះក៏នាំមកនូវវិបុលសុខផងដែរ ។

និងខាងឯក្រិត្យវិន័យ ហើយបញ្ញត្តិទាំងប៉ុន្មានផង ដើម្បីនឹង
ស្វែងរកតាមព្រះនៃទ្រង់ នោះទ្រង់ក៏បានធ្វើ ដោយអស់ពី
ព្រះទ័យ ហើយបានចំរើនដែរ[ម]។

## សានហេរីបគម្រាមទីក្រុងយេរូសាឡិម

*៣២:៩-១៩ - ២ពវ ១៨:១៧-៣៥ អស ៣៦:២-២០*

*៣២:២០-២១ - ២ពវ ១៩:៣៥-៣៧ អស ៣៧:៣៦-៣៨*

**៣២** ១ក្រោយគ្រប់ទាំងការ ជាអំពើស្មោះត្រង់ទាំងនោះ
មក នោះសានហេរីប[ក] ជាស្តេចស្រុកអាសស៊ើរ ទ្រង់ទន្ទ្រាន
ចូលមកក្នុងស្រុកយូដា បោះទ័ពច្បាំងនឹងអស់ទាំងទីក្រុង
មានបន្ទាយ ដោយប្រាថ្នាចង់ចាប់យកទីក្រុងទាំងនោះ
២កាលហេសេគាទ្រង់ឃើញថា សានហេរីប បានមកដូច្នោះ
ហើយមុខជាគិតមកច្បាំងនឹងក្រុងយេរូសាឡិមដែរ[ខ] ៣នោះ
ទ្រង់ក៏ប្រឹក្សានឹងពួកអ្នកជាប្រធាន ហើយនឹងពួកមនុស្សខ្លាំង
ពូកែរបស់ទ្រង់ សំរេចនឹងទប់ប្រឡាយទឹកទាំងប៉ុន្មាន ដែល
នៅខាងក្រៅទីក្រុង ហើយពួកអ្នកទាំងនោះក៏ជួយ ៤គេ
ប្រមូលមនុស្សជាច្រើន មកទប់អស់ទាំងប្រឡាយទឹក[គ] និង
ជ្រោះទឹកដែលហូរកាត់ស្រុកនោះ ដោយនិយាយគ្នាថា និង
ទុកឱ្យពួកស្តេចអាសស៊ើរមកដល់ទីនេះឃើញ មានទឹកជា
ច្រើនធ្វើអី ៥ទ្រង់មានព្រះទ័យក្លាយឡើយក៏សង់កំផែងដែល
បាក់បែកឡើងវិញ[ឃ] ហើយឱ្យស្មើនឹងប៉មទាំងប៉ុន្មាន ព្រម
ទាំងសង់កំផែងមួយទៀតនៅខាងក្រៅ ហើយធ្វើឱ្យប៉ម-
មីឡូរ[ង] ដែលនៅក្នុងក្រុងដាវីឌ បានមាំមួនឡើងផង ក៏ធ្វើ
គ្រឿងសស្ត្រាវុធ[ច] និងខែលជាបរិបូរ ៦ទ្រង់តាំងឱ្យមានមេ
ក្រសួងសឹកត្រួតលើបណ្តាជន ក៏ប្រមូលជនទាំងឡាយមក
ឯទ្រង់ នៅទីធ្លាត្រង់មាត់ទ្វារទីក្រុង មានបន្ទូលកំសាន្តចិត្ត
គេថា ៧ចូរមានកំឡាំងឡើង ហើយចិត្តក្លាហានចុះ[ឆ] កុំឱ្យ
ភ័យខ្លាច ឬស្រយុតចិត្ត[ជ] ដោយព្រោះស្តេចអាសស៊ើរ និង
ពួកពលទាំងហ្វូង ដែលមកជាមួយនោះឡើយ ដ្បិតនៅខាង
យើងមាន១អង្គ ដែលពូកែជាងពួកគេទៅទៀត[ឈ] ៨ចំណែក
គេមានតែដៃខាងសាច់ឈាមប៉ុណ្ណោះ[ញ] តែខាងយើងវិញ[ដ]
មានព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា សំរាប់នឹងជួយ
ហើយធ្វើចំបាំងជំនួសយើង[ឋ]ពួកបណ្តាជនក៏ផ្អែកចិត្តទៅលើ
ព្រះបន្ទូលនៃហេសេគា ជាស្តេចយូដា ។
៩ក្រោយនោះមកសានហើយ ជាស្តេចអាសស៊ើរ ទ្រង់
ចាត់រាជទូត នៅឯក្រុងយេរូសាឡិម (ចំណែកឯទ្រង់នឹង
ពលទ័ពទាំងអស់របស់ទ្រង់ ក៏នៅមុខក្រុងឡាគីស[ឌ]) រាជ
ទូតនោះក៏មកឯហេសេគា ជាស្តេចយូដា និងពួកយូដាទាំង
ប៉ុន្មាន ជាពួកអ្នកនៅក្រុងយេរូសាឡិម និយាយថា
១០សានហេរីប ជាស្តេចអាសស៊ើរ ទ្រង់មានបន្ទូលដូច្នេះ
ថា តើឯងរាល់គ្នាទុកចិត្ត[ឍ]អាងដល់អ្វី បានជាចេះតែនៅ
ក្នុងក្រុងយេរូសាឡិមនេះ ចង់ឱ្យយើងមកឡោមព័ទ្ធឯង
ដូច្នេះ ១១តើហេសេគាមិនបញ្ចុះបញ្ចូលឯងរាល់គ្នា ដើម្បី
តែនឹងប្រគល់ឯង[ណ]ឱ្យត្រូវស្លាប់ ដោយអត់បាយ អត់ទឹកទេ
ឬអីដោយពាក្យថា ព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា
ទ្រង់នឹងប្រោសឱ្យយើងរួចពីកណ្តាប់ដៃនៃស្តេចអាសស៊ើរ
១២តើមិនមែនហេសេគានេះឯង ដែលបានបំបាត់អស់ទាំង
ទីខ្ពស់ និងអាសនារបស់ព្រះនោះទេឬអី ហើយក៏បានបង្គាប់
ពួកយូដា និងពួកក្រុងយេរូសាឡិមថា ត្រូវឱ្យឯងរាល់គ្នា
ថ្វាយបង្គំនៅមុខអាសនា១នេះ តែប៉ុណ្ណោះ[ត] ព្រមទាំងដុត
កំញាននៅលើនោះផង ១៣ឯងរាល់គ្នាមិនដឹងទេឬអី ពីការ
ដែលអញ និងបិតាអញបានធ្វើ ដល់អស់ទាំងសាសន៍ ដែល
នៅស្រុកឯទៀតទាំងប៉ុន្មាន ឯព្រះទាំងប៉ុន្មានរបស់សាសន៍
ដទៃ ដែលនៅគ្រប់ស្រុកទាំងនោះ តើអាចនឹងជួយស្រុកគេ
ឱ្យរួចពីកណ្តាប់ដៃនៃអញបានឬទេ[ថ] ១៤តើមានព្រះណាមួយ
ក្នុងពួកព្រះរបស់សាសន៍ដទៃទាំងប៉ុន្មានដែលបិតាអញបាន
បំផ្លាញអស់រលីងនោះបាន អាចនឹងជួយសាសន៍គេឱ្យរួច
ពីកណ្តាប់ដៃអញបានឬ បានជាព្រះរបស់ឯងរាល់គ្នានឹង

**៣២:១** ក អស ៣៦:១ ៣៧:៩,១៧, ៣៧
**៣២:២** ខ អស ២២:៧ យរ ១:១៥
**៣២:៤** គ ២ពវ ១៨:១៧ អស ២២:៩,១១ ណហ ៣:១៤
**៣២:៥** ឃ អស ២២:១០ ង ១រប ១១:៨ ច អស ២២:៨
**៣២:៧** ឆ ចទ ៣១:៦ ជ ២រប ២០:១៥ ឈ ជន ១៤:៩ ២ពវ ៦:១៦
**៣២:៨** ញ យប ៤០:៩ អស ៥២:១០ យរ ១៧:៥ ៣២:២១ ដ ចទ ៣:២២ ១សយ ១៧:៤៥ ឋ ១រប ៥:២២ ទដ ២០:៧ អស ២៨:៦
**៣២:៩** ឌ យស ១០:២,៣១
**៣២:១០** ឍ អគ ២៩:១៦
**៣២:១១** ណ អស ៣៧:១០
**៣២:១២** ត ២រប ៣១:១
**៣២:១៣** ថ ខ.១៥

**៣២:១-២៣** ការកត់ត្រាអំពីការពុករលួយរបស់ស្តេចសានហេរីប គឺមានលក្ខណៈលំអិតក្នុងគម្ពីរ ពង្សាវតារក្សត្រទី២ និងគម្ពីរអេសាយ(មើលការពន្យល់ ២៩:១-៣២:៣៣) ។

**៣២:១** អ្នកកាលប្រវត្តិលប់ចោលនូវ ថ្ងៃខែរបស់ការលុកលុយ (៧០១ មុន ស.គ គឺជាឆ្នាំទី១៤ របស់ស្តេចហេសេគា អស ៣៦:១) ។

**៣២:២-៨** ការរៀបចំគំរោងដើម្បីឈ្លានពាន ។

**៣២:៣-៤** មើល ខ.៣០ ។

**៣២:៩** អ្នកកាលប្រវត្តិលប់ចោល ២ពវ ១៨:១៤-១៦ ដែលកត់ត្រាពីភាពសាកសមរបស់ស្តេចហេសេគា ដើម្បីសន្តិភាពជាមួយនិងកំណាប់ពីព្រះវិហារ ។

**៣២:១០** អ្នកកាលប្រវត្តិលប់ចោល ២ពវ ១៨:២០-២១ (អស ៣៦:៥-៦) គឺមានផ្នែកខ្លះនៃពាក្យសម្តីរបស់មេទ័ពអាស៊ើរនិងប្រជាជននៃក្រុងយេរូសាឡិមដោយព្រោះកាទុកចិត្តក្នុងការរស់ នៅស្រុកអេស៊ីព្ទនិងស្តេចផារ៉ោន ។ ក៏ជាការលើកឡើងពីអ្នកកាលប្រវត្តិ អំពីលក្ខណៈទេវសាស្ត្រដែលឆ្ពោះទៅរកអ្នកស្រុកបរទេស (មើលការពន្យល់ ១៦:២-៩)។ ក៏ជាទំនាក់ទំនងដដែលៗជាមួយ និងសាសន៍បរទេស ។ វាក៏ជាហេតុផលនៃការលប់បំបាត់នូវឯកសារក្នុង ២ពវ ១៨:២៣-២៧ (អស ៣៦:៨-១២) ដែលបង្ហាញពីសេចក្តីសង្ឃឹមដែលមាន អន្តរាគមន៍ពីសាសន៍អេស៊ីព្ទ(មើល ២ពវ ១៩:៩ ចំពោះការលុកលុយរបស់នារហាកា) ។

ជួយឯងឱ្យរួចពីកណ្ដាប់ដៃអញទៅបាន ១៥ដូច្នេះកុំឱ្យ
ហេសេគាល្បួងបញ្ឆោត[ទ]ឯងរាល់គ្នា ឬបញ្ចុះបញ្ចូលឯង
បែបយ៉ាងនេះទៀតឡើយ កុំឱ្យជឿឱ្យសោះ ដ្បិតគ្មានព្រះ
ណាមួយរបស់សាសន៍ឬនគរឯណា ដែលបានអាចនឹងជួយ[ធ]
រាស្ត្រគេឱ្យរួចពីកណ្ដាប់ដៃអញ ឬពីកណ្ដាប់ដៃនៃបិតាអញ
បានឡើយ[ន] ចំណង់បើព្រះរបស់ឯងរាល់គ្នា តើនឹងជួយឱ្យ
ឯងរាល់គ្នារួចពីកណ្ដាប់ដៃអញឯណាបាន ។
១៦ពួករាជ្យទូតរបស់ស្ដេចនោះ ក៏ប្រមាថមើលងាយដល់
ព្រះយេហូវ៉ាដ៏ជាព្រះនឹងហេសេគា ជាអ្នកបំរើទ្រង់ជាច្រើន
តទៅទៀត ១៧ក៏ធ្វើសំបុត្រ[ប]មួលបង្កាច់[ផ]ដល់ព្រះយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែល ព្រមទាំងពោលទាស់នឹងព្រះ
ដោយថា ឯព្រះ[ព]របស់សាសន៍ដទៃទាំងប៉ុន្មាន នៅស្រុក
ផ្សេងៗ មិនបានជួយរាស្ត្រគេឱ្យរួចពីកណ្ដាប់ដៃអញយ៉ាង
ណា នោះព្រះរបស់ហេសេគា ក៏មិនអាចនឹងជួយរាស្ត្រខ្លួន
ឱ្យរួចពីកណ្ដាប់ដៃអញបានដូច្នោះដែរ ១៨ពួកទូតនោះក៏
ស្រែកយ៉ាងខ្លាំង ជាភាសារបស់ពួកយូដា ដល់ពួកក្រុង
យេរូសាឡិម ដែលនៅលើកំផែង ដើម្បីនឹងគំរាមបំភ័យឱ្យ
គេរវល់គំនិត ប្រយោជន៍ឱ្យអាចនឹងយកទីក្រុងបាន ១៩គេបាន
និយាយពីព្រះនៃក្រុងយេរូសាឡិម ទុកដូចជាអស់ទាំងព្រះ
របស់សាសន៍ដទៃ ទាំងប៉ុន្មាននៅផែនដីជាព្រះដែលជា
ស្នាដៃរបស់មនុស្សលោកទេ[ភ] ។
២០ដូច្នេះ ស្ដេចហេសេគា និងហោរាអេសាយ ជាកូន
អ័ម៉ូស ក៏អធិស្ឋាន[ម]ពីដំណើរនោះ ហើយអំពាវនាវដល់
ស្ថានសួគ៌ ២១រួចព្រះយេហូវ៉ាទ្រង់ចាត់ទេវតា[យ]ឱ្យមក
បំផ្លាញមនុស្សខ្លាំងពូកែ ដែលមានចិត្តក្លាហានក្នុងទីបោះ
ទ័ពរបស់ស្ដេចអាសស៊ើរ ព្រមទាំងពួកអ្នកនាំមុខ និងពួក
មេទ័ពទាំងអស់ទៅ នោះស្ដេចទ្រង់ក៏វិលទៅឯនគររបស់

**៣២:១៥** ទ អស ៣៧:១០ ធ ដយ ៣:១៥ ន នក ៥:២
**៣២:១៧** ប អស ៣៧:១៤ ផ ទដ ៧៤:២២ អស ៣៧:៤,១៧ ព ២ពវ ១៩:១២
**៣២:១៩** ភ ទដ ១១៥:៤-៨ អស ២:៨ ១៧:៨ ៣៧:១៩ យរ ១:១៦
**៣២:២០** ម អស ១:១៥ ៣៧:១៥
**៣២:២១** យ លប ១៩:១៣
**៣២:២១** រ ២ពវ ១៩:៧ អស ៣៧:៧,៣៨ យរ ៤១:២
**៣២:២៣** ល ១សយ ១០:២៧ ២រប ៩:២៤ ទដ ៦៨:១៨,២៩ ៧៦:១១ អស ១៦:១ ១៨:៧ ៤៥:១៤ សផ ៣:១០ សក ១៤:១៦-១៧
**៣២:២៤** វ ខ.៣១
**៣២:២៥** ស ២ពវ ១៤:១០ ហ ២រប ១៩:២
**៣២:២៦** ឡ យរ ២៦:១៨-១៩ អ ២រប ៣៤:២៧, ២៨ អស ៣៩:៨

ទ្រង់វិញដោយសេចក្ដីអៀនខ្មាស ហើយកាលទ្រង់ក៏វិលទៅ
ឯនគររបស់ទ្រង់វិញ ដោយសេចក្ដីអៀនខ្មាស ហើយកាល
ទ្រង់បានចូលទៅក្នុងវិហារនៃព្រះរបស់ទ្រង់ នោះបុត្រ
បង្កើតរបស់ទ្រង់ក៏ធ្វើគុតទ្រង់ ដោយដាវនៅទីនោះ[រ] ២២គឺ
យ៉ាងនោះដែលព្រះយេហូវ៉ាទ្រង់ជួយសង្គ្រោះហេសេគា
និងពួកអ្នកនៅក្រុងយេរូសាឡិម ឱ្យរួចពីកណ្ដាប់ដៃនៃសាន
ហេរីប ជាស្ដេចស្រុកអាសស៊ើរ ហើយពីកណ្ដាប់ដៃនៃ
សត្រូវឯទៀត ព្រមទាំងការពារគេនៅគ្រប់ទិសផង ២៣ក៏
មានមនុស្សជាច្រើននាំយកដង្វាយមកថ្វាយដល់ព្រះយេហូវ៉ា
នៅក្រុងយេរូសាឡិម និងរបស់មានដំឡៃផ្សេងៗ[ល] ថ្វាយ
ដល់ហេសេគាជាស្ដេចយូដាដែរ ដល់ម៉្លេះបានជាទ្រង់បាន
ថ្កុំថ្កើងលើងនៅភ្នែកនៃអស់ទាំងសាសន៍ដទៃតរៀងទៅ ។

### សេចក្ដីអំនួត ជ័យជំនះនិងសេចក្ដីស្លាប់របស់ហេសេគា

*៣២:២៤-៣៣-២ពវ ២០:១-២១ អស ៣៧:២១-៣៨ ៣៨:១-៨*

២៤នៅគ្រានោះ ហេសេគាទ្រង់ចាប់ប្រឈួនជាធ្ងន់ហៀប
នឹងសុគត តែទ្រង់អធិស្ឋានដល់ព្រះយេហូវ៉ា ហើយព្រះ
យេហូវ៉ាទ្រង់មានបន្ទូលមក ព្រមទាំងប្រាប់ទីសំគាល់ដល់
ស្ដេច[វ] ២៥ប៉ុន្តែហេសេគាទ្រង់មិនបានសងព្រះគុណតាម
ដែលព្រះបានប្រោសដល់ទ្រង់នោះទេ ដ្បិត ទ្រង់មានព្រះ
ទ័យកំរើកធំឡើង[ស] បានជាមានសេចក្ដីក្រោធ[ហ]មកក្របលើ
ទ្រង់ និងពួកយូដា ហើយពួកក្រុងយេរូសាឡិមវិញ ២៦ប៉ុន្តែ
ហេសេគា ទ្រង់បានបន្ទាបព្រះទ័យចុះ[ឡ] ពីការដែលមាន
ចិត្តធំនោះទៅ ព្រមទាំងពួកអ្នកនៅក្រុងយេរូសាឡិមផង
បានជាសេចក្ដីក្រោធរបស់ព្រះយេហូវ៉ា មិនបានធ្លាក់មក
លើគេ នៅក្នុងគ្រាហេសេគាឡើយ[អ] ។
២៧ឯហេសេគា ទ្រង់មានព្រះរាជ្យទ្រព្យ និងកិត្តិនាម[ក]

**៣២:២៧** ក ១រប ២៩:១២ ២រប ៩:២៤

**៣២:១៦** *ក៏ប្រមាថមើលងាយ* អ្នកកាលប្រវត្តិបានយលពីការ ព្យាយាមប្រមាថរបស់ពួកស្រុកអាសស៊ើរដែលមានបង្ហាញក្នុងគម្ពីរ ពង្សាវតារក្សត្រ និង អេសាយ ។

**៣២:២០** *សេចក្ដីសំអាងនេះ* ចំពោះការអធិស្ឋានរបស់ស្ដេច ហេសេគា និង អេសាយដែលជាលក្ខណៈសង្ខេប នៃនិទានកថាដ៏វែង មើល ២ពវ ១៩:១-៣៤ (អស ៣៧:១-៣៥) ។

**៣២:២១** មើល ២ពវ ១៩:៣៥-៣៧ អស ៣៧:៣៦-៣៨ អ្នកកាលប្រវត្តិនិងភាពដូចគ្នាដែលឆ្លុះបញ្ចាំងនូវព្រឹត្តិការខ្លះៗដូចជា: ការលុកលុយដល់ស្រុកយូដាពីស្ដេចសានហេរីប គឺក្នុងឆ្នាំ ៧០១ មុន គ.ស ទ្រង់ក៏ត្រូវសុគតដោយដៃនៃព្រះរាជបុត្រាផ្ទាល់ គឺក្នុងឆ្នាំ ៦៨១ មុន ស.គ ។

**៣២:២៣** *ទ្រង់បានថ្កុំថ្កើងឡើងនៅភ្នែកនៃអ្នកទាំងសាសន៍ដ៏ទៃរៀងទៅ* មើលការប្រៀបធៀបរវាងស្ដេច ហេសេគានិងស្ដេចសាឡូម៉ូន (មើល ៩:២៣-២៤) ។

**៣២:២៤** អ្នកកាលប្រវត្តិក៏សង្ខេបជាថ្មីនូវនិទានកថា ក្នុងគម្ពីរ ២ពវ ២០:១-១១(និង អស ៣៨:១-៨)បំព្រួញពីភាពស្គាល់ច្បាប់នៃអ្នកអាន ពីតួនាទីរបស់អេសាយនិងការសម្ដែងនូវការ អស្ចារ្យនូវអ្វីដែលជាស្រមោលផ្អយពីជំហានទាំង១០ ។

**៣២:២៥-២៦** . . . *មានចិត្តធំ* អ្នកកាលប្រវត្តិពុំបានបញ្ជាក់ ពីនិស្ស័យចិត្តធំរបស់ស្ដេចហេសេគាទេ (សូមមើល ខ.៣១ ២ពវ ២០:១២-១៣ អស ៣៩:១-២)។ក៏ដូចជាស្ដេចសាឡូម៉ូនទី២ដូចជាស្ដេចហេសេគាដែលពុំស្គា ប់បង្គាប់ទាំមកការក្រោធពីព្រះយេហូវ៉ា ។

**៣២:២៧-២៨** អ្នកកាលប្រវត្តិដូច ស្ដេចហេសេគាទៅនិងស្ដេច សាឡូម៉ូនក៏បានកត់ត្រាអំពីព្រះរាជទ្រព្យរបស់ទ្រង់ផងដែរ (៩:១៣-១៤) ។

យ៉ាងក្រៃលែង ទ្រង់បានធ្វើឃ្លាំងសំរាប់ដាក់ប្រាក់ មាស
ត្បូងមានដំឡៃ គ្រឿងក្រអូប និងខែល ហើយនិងគ្រឿង
ប្រដាប់ល្អគ្រប់មុខ ២៨ក៏ធ្វើឃ្លាំងដាក់ស្រូវ ទឹកទំពាំង
បាយជូរ និងប្រេង ព្រមទាំងរោងសំរាប់ដាក់សត្វគ្រប់មុខ
និងក្រោលសំរាបហ្វូងចៀម ២៩ក៏សង់ទីក្រុងផ្សេងៗសំរាប់
ទ្រង់ ហើយមានហ្វូងគោ ហ្វូងចៀមជាបរិបូរ ដ្បិតព្រះបាន
ប្រោសប្រទាន ឱ្យទ្រង់មានទ្រព្យសម្បត្តិជាច្រើនណាស់[ខ]
៣០គឺហេសេគានេះឯង ដែលបានទប់[គ]រន្ធទឹកខាងលើ នៃ
ជ្រោះគីហុន[ឃ] បង្ហូរ[ង]ដំរង់ចុះមក ដល់ខាងលិចទីក្រុងដាវីឌ
ទ្រង់ចេះតែបានចំរើនឡើង ក្នុងគ្រប់ការទាំងអស់ ៣១ប៉ុន្តែ
ក្នុងការដែលរាជទូតនៃស្តេចបាប៊ីឡូន[ច] បានមកសើបសួរ
ទ្រង់ ពីការអស្ចារ្យ[ឆ]ដែលកើតឡើងក្នុងស្រុក នោះព្រះបាន
ទុកទ្រង់ចោល ដើម្បីនឹងល្បងល[ជ]ទ្រង់ ឱ្យបានជ្រាបគ្រប់
ទាំងគំនិត ដែលមាននៅក្នុងព្រះទ័យទ្រង់ ។
៣២រីឯដំណើរឯទៀតពីហេសេគា នឹងការល្អទាំងប៉ុន្មាន
ដែលទ្រង់ធ្វើ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅពីពួក
ស្តេចយូដានិងអ៊ីស្រាអែល ជាមួយនឹងការជាក់ស្តែងរបស់
ហោរាអេសាយ ជាកូនអ័ម៉ូសហើយ ៣៣ហេសេគាក៏ផ្ទំលក់
ទៅជាមួយនឹងពួកឰយុកោទ្រង់ ហើយគេបញ្ចុះសពទ្រង់
នៅទីខ្ពស់តាមផ្លូវឡើងទៅផ្នូររបស់ពួកវង្សនៃដាវីឌ ឯពួក
យូដា នឹងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នា ក៏ដំកើង
ទ្រង់ឡើង ក្នុងខណៈដែលសុគតនោះ រួចម៉ាន៉ាសេ ជាព្រះ
រាជបុត្រា ក៏ឡើងសោយរាជ្យជំនួសព្រះបិតា ។

### ម៉ាន៉ាសេឡើងជាស្តេចស្រុកអ៊ីស្រាអែល

*៣៣:១-១០ – ២ពវ ២១:១-១០*
*៣៣:១៨-២០ – ២ពវ ២១:១៧-១៨*

**៣៣** ១លុះកាលម៉ាន៉ាសេ[ក]ចាប់តាំងសោយរាជ្យឡើង
នោះ ទ្រង់មានព្រះជន្ម១២ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន៥៥ឆ្នាំ ២ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់
នៅព្រះនេត្រព្រះយេហូវ៉ា[ខ] តាមអស់ទាំងការគួរស្អប់ខ្ពើម[គ]
របស់សាសន៍ដទៃទាំងប៉ុន្មាន ដែលព្រះយេហូវ៉ាបាន
បណ្តេញចេញ ពីមុខពួកកូនចៅអ៊ីស្រាអែល ៣ដ្បិតទ្រង់បាន
ធ្វើអស់ទាំងទីខ្ពស់ឡើងវិញ ដែលហេសេគា ជាព្រះបិតា
ទ្រង់បានរំលំទៅនោះ ហើយក៏ស្អាងអាសនាថ្វាយព្រះបាល
ព្រមទាំងធ្វើរូបព្រះ[ឃ] ហើយថ្វាយបង្គំ[ង]គោរពដល់អស់ទាំង
ពួកពលបរិវារនៅលើមេឃផង ៤ទ្រង់ក៏ស្អាងអាសនា នៅ
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ដែលព្រះយេហូវ៉ាបានមាន
បន្ទូលពីទីនោះថា ឈ្មោះអញ[ច]នឹងនៅក្រុងយេរូសាឡិម
ជាដរាបតទៅ ៥ទ្រង់ធ្វើអាសនាសំរាប់គោរពដល់អស់ទាំង
ពួកពលបរិវារនៅលើមេឃ ត្រង់ទីលានទាំង២នៃព្រះ
វិហារព្រះយេហូវ៉ា[ឆ] ៦ក៏ធ្វើឱ្យបុត្រ[ជ]ទ្រង់ឆ្លងកាត់ភ្លើង នៅ
ក្នុងច្រកភ្នំរបស់កូនហ៊ីនណំម ក៏ប្រព្រឹត្តនក្ខត្តឫក្ស អង្គុយធម៌
អាបធ្មប់ ហើយរកគ្រូខាប[ឈ] និងគ្រូគាថា[ញ] ទ្រង់ប្រព្រឹត្តអំពើ
ដ៏អាក្រក់ជាច្រើន នៅព្រះនេត្រព្រះយេហូវ៉ា ជាហេតុដែល
បណ្តាលឱ្យព្រះមានសេចក្តីក្រោធ ៧ទ្រង់យករូបឆ្លាក់ជារូប
ព្រះដែលទ្រង់បានធ្វើ ទៅដំកល់ក្នុងព្រះវិហារនៃព្រះ[ដ]
ជាទីដែលព្រះបានមានបន្ទូលនឹងដាវីឌ ហើយនឹងសាឡូម៉ូន
ជាព្រះរាជបុត្រទ្រង់ថា អញនឹងតាំងឈ្មោះអញ នៅក្នុងព្រះ
វិហារនេះនៅក្រុងយេរូសាឡិម ជាទីដែលអញបានរើស
ក្នុងគ្រប់ទាំងពូជអំបូរសាសន៍អ៊ីស្រាអែលឱ្យនៅជា ដរាប
តទៅ ៨ហើយអញក៏មិនដែលដកជើងនៃពួកអ៊ីស្រាអែល
ចេញពីស្រុក[ឋ] ដែលអញបានឱ្យដល់ពួកឰយុកោឯងរាល់គ្នា
ទៀតឡើយ ឱ្យតែគេរក្សា ហើយធ្វើតាមគ្រប់ទាំងសេចក្តី
ដែលអញបានបង្គាប់ដល់គេ គឺជាក្រិត្យវិន័យទាំងមូល និង

**៣២:២៩** ខ អស ៣៩:២
**៣២:៣០** គ ២ពវ ១៨:១៧ ឃ ១ពវ ១:៣៣ ង ២សយ ៥:៨
**៣២:៣១** ច អស ១៣:១ ៣៩:១ ឆ ខ.២៤ អស ៣៨:៧ ជ លប ២២:១ ចទ ៨:១៦
**៣៣:១** ក ១រប ៣:១៣
**៣៣:២** ខ យរ ១៥:៤ គ ចទ ១៨:៩
**៣៣:៣** ឃ ចទ ១៦:២១-២២ ២រប ២៤:១៨ ង ចទ ១៧:៣
**៣៣:៤** ច ២រប ៧:១៦
**៣៣:៥** ឆ ២រប ៤:៩
**៣៣:៦** ជ លវ ១៨:២១ ចទ ១៨:១០ ឈ នក ២២:១៨ លវ ១៩:៣១ ញ ១សយ ២៨:១៣
**៣៣:៧** ដ ២រប ៧:១៦
**៣៣:៨** ឋ ២សយ ៧:១០

**៣២:៣០** មើល ខ.២-៤ ២ពវ ២០:២០ ។

**៣២:៣១** មើល ខ.២៥ ។ អ្នកកាលប្បវត្តិសន្និដ្ឋានពីចំណេះដឹងរបស់អ្នកអាន ចំពោះហេតុការទាំងមូលក្នុង ២ពវ ២០:១២-១៩ (អស ៣៩:១-៨) ។ រាជទូតមកពីស្រុកបាប៊ីឡូនក៏មានចិត្តចូលរួមចលនាប្រឹងប្រែង ប្រឆាំង និងសាសន៍អាសើរ ។

**៣៣:១-២០** មើល ២ពវ ២១:១-១៨ និងការពន្យល់។ ម៉ាន៉ាសេបានសោយរាជ្យមានរយៈពេលយូរជាងស្តេចនានា ក្នុងស្រុកយូដា គឺសរុបទៅមានរយៈពេល៥៥ឆ្នាំ (ខ.១) ។ ការសង្កត់ធ្ងន់ទៅលើកំណត់ហេតុខុសគ្នាពីរ : ដែលឃើញវិញ្ញាណអាក្រក់ជាវ្រត្តិសាស្ត្រ បានកើតឡើងក្នុងពេលគ្រងរាជ្យរបស់ម៉ាន៉ាសេ ក៏បានបង្ហាញពីដំណើររបស់ទ្រង់ទៅទីក្រុងបាប៊ីឡូន និងការលន់តួបាបដើម្បីទទួលក្រឹត្យវិន័យ ។ អ្នកនិពន្ធគម្ពីរ ពង្សាវតារក្សត្របានបង្ហាញពីរូបភាពមិនល្អក្នុងការគ្រងរាជ្យរបស់ ម៉ាន៉ាសេដែលបណ្តាលឱ្យនិរទេស (២ពវ ២១:១០-១៥ ២៣:២៦) ។ អ្នកកាត់ស្រាយខ្លះបានចាត់ពីឯកសាររបស់ម៉ាន៉ាសេ ដែលលន់តួបាបក្នុងរបាក្សត្រដោយអ្នកនិពន្ធបញ្ជាក់ថាគឺជាការកាត់ទោសភ្លាមៗ: ការគ្រងរាជ្យដ៏មានរយៈពេលវែងឆ្ងាយរបស់ម៉ាន៉ាសេគឺជាលទ្ធផលនៃការស្តាប់បង្គាប់ ដែលបាននាំមកនូវព្រះពរពីព្រះយេហូវ៉ាក៏ទទួលបានជោគជ័យ ក្នុងសង្គ្រាមនិងមានក្រុមគ្រួសាររាជវង្សដ៏ធំសំបើម ។

**៣៣:១** *បាន៥៥ឆ្នាំ* គឺ ៦៩៧-៦៤២ មុន គ.ស ។

**៣៣:៣,១៩** *រូបព្រះនិងរូបឆ្លាក់* មើលការពន្យល់ នក ៣៤:១៣ ។

**៣៣:៤** *ឈ្មោះអញនឹងនៅក្រុងយេរូសាឡឹមជាដរាបតទៅ* មើល ១ពវ ៣:២ និងការពន្យល់ ៩:៣ ទដ ១៣២:១៣-១៤ ។

**៣៣:៦** *ក៏ធ្វើឱ្យបុត្រទ្រង់ឆ្លងកាត់ភ្លើងនៅក្នុងច្រកភ្នំរបស់កូនហ៊ីនណំម* មើល ២៨:៣ និងការពន្យល់ ។

បញ្ញត្តិ ហើយច្បាប់ទាំងប៉ុន្មាន ដែលអញបានឱ្យដោយសារ
ម៉ូសេប៉ុណ្ណោះចុះ ៩តែម៉ានាសេទ្រង់ព្រលួងពួកយូដា និងពួក
អ្នកក្រុងយេរូសាឡិម ឱ្យបានធ្វើការអាក្រក់ លើសជាង
សាសន៍ដទៃទាំងប៉ុន្មានទៅទៀត ជាសាសន៍ដែលព្រះ
យេហូវ៉ាបានបំផ្លាញ ពីមុខពួកកូនចៅអ៊ីស្រាអែលចេញ[ឌ] ។
១០ព្រះយេហូវ៉ាទ្រង់ក៏មានបន្ទូលនឹងម៉ានាសេ ហើយ
និងរាស្ត្រទ្រង់ដែរ តែគេមិនព្រមទទួលស្តាប់តាមឡើយ
១១ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បណ្តាលឱ្យពួកមេទ័ព
របស់ស្តេចអាសស៊ើរ លើកគ្នាមកច្បាំងនឹងគេ ពួកនោះ
ចាប់[ឍ]ម៉ានាសេដាក់ខ្នោះ[ណ]ដាក់ច្រវាក់[ត] នាំទៅឯក្រុង
បាប៊ីឡូន ១២តែកាលទ្រង់មានសេចក្តីវេទនា នោះក៏ទូល
អង្វរដល់ព្រះយេហូវ៉ាជាព្រះនៃទ្រង់ ព្រមទាំងបន្ទាប
ព្រះទ័យចុះជាខ្លាំង[ថ] នៅចំពោះព្រះហឫទ័យ ស្តាប់តាម
សេចក្តីដែលទ្រង់ទូលអង្វរ ប្រោសនាំទ្រង់ មកឯរាជ្យក្នុង
ក្រុងយេរូសាឡិមវិញ ដូច្នេះ ទើបម៉ានាសេបានជ្រាបថា
ព្រះយេហូវ៉ាទ្រង់ជាព្រះពិតា ។
១៤ក្រោយនោះ ទ្រង់សង់កំផែង នៅខាងក្រៅកំផែងក្រុង
ដាវីឌទៀត គឺត្រង់ច្រកភ្នំខាងលិចជ្រោះគីហុន[ទ] រហូតដល់
មាត់ទ្វារផ្សារត្រី[ធ]ក៏ធ្វើព័ទ្ធជុំវិញប៉មអូផែល[ន]ដែរ ហើយបាន
ធ្វើឱ្យមានកំពស់លើងជាច្រើន រួចទ្រង់ដំរូវឱ្យមានមេទ័ព
នៅអស់ទាំងទីក្រុងមានបន្ទាយនៅស្រុកយូដា ១៥ទ្រង់យក
អស់ទាំងព្រះនៃសាសន៍ដទៃ និងរូបព្រះនោះចេញ[ប]ពីព្រះ
វិហារនៃព្រះយេហូវ៉ា ព្រមទាំងអាសនាទាំងប៉ុន្មានដែល
ទ្រង់បានស្អាង នៅលើភ្នំនៃព្រះវិហារព្រះយេហូវ៉ា នឹងនៅ
ក្រុងយេរូសាឡិមទៅបោះចោលនៅខាងក្រៅទីក្រុង ១៦រួច
ទ្រង់ស្អាងអាសនាព្រះយេហូវ៉ាឡើងវិញ ហើយថ្វាយយញ្ញ
បូជា ជាដង្វាយមេត្រី និងដង្វាយអរព្រះគុណ[ផ] នៅលើ
អាសនានោះ ក៏បង្គាប់ឱ្យពួកយូដាគោរពប្រតិបត្តិតាម
ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ១៧ប៉ុន្តែពួក
បណ្តាជននៅតែថ្វាយយញ្ញបូជានៅលើអស់ទាំងទីខ្ពស់នៅ
ឡើយតែគេថ្វាយដល់ព្រះយេហូវ៉ា ជាព្រះនៃគេវិញ ។
១៨រីឯដំណើរឯទៀតពីម៉ានាសេ និងសេចក្តីដែលទ្រង់
អធិស្ឋានដល់ព្រះនៃទ្រង់ ព្រមទាំងពាក្យទាំងប៉ុន្មានដែល
ពួកអ្នកមើលឆុតបានទូលទ្រង់ ដោយនូវព្រះនាមព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល នោះសុទ្ធតែបានកត់
ទុកក្នុងសៀវភៅ ពីកិច្ចការរបស់ពួកស្តេចអ៊ីស្រាអែល
ហើយ ១៩ឯសេចក្តីអធិស្ឋានរបស់ទ្រង់ និងការដែលព្រះ
បានទទន់ព្រះហឫទ័យទទួលតាមទ្រង់ ព្រមទាំងអំពើបាបនឹង
ការរំលងរបស់ទ្រង់ទាំងប៉ុន្មាន អស់ទាំងកន្លែងដែលទ្រង់
បានធ្វើទីខ្ពស់ ហើយដំកល់រូបព្រះនឹងរូបឆ្លាក់ មុនដែល
ទ្រង់បានបន្ទាបព្រះទ័យចុះ[ព] នោះសុទ្ធតែបានកត់ទុកក្នុង
ពង្សាវតារ ដែលពួកអ្នកមើលឆុតបានចារិកទុកហើយ[ភ]
២០ម៉ានាសេក៏ផុតលក់ទៅជាមួយនឹងពួកឰយុកោរបស់ទ្រង់
ហើយគេបញ្ចុះសពទ្រង់[ម] នៅក្នុងដំណាក់ទ្រង់ រួចអាំម៉ូនជា
ព្រះរាជបុត្រា ក៏ឡើងសោយរាជ្យជំនួសព្រះបិតា ។

**៣៣:៩** ឌ យរ ១៥:៤ អគ ៥:៧ **៣៣:១១** ឍ ចទ ២៨:៣៦ ណ ២ពវ ១៩:២៨ អស ៣៧:២៩ អគ ២៩:៤ ៣៨:៤ អម ៤:២ ត ទដ ១៤៩:៨ **៣៣:១២** ថ ២រប ៦:៣៧ **៣៣:១៤** ទ ១ពវ ១:៣៣ ធ នហ ៣:៣ ១២:៣៩ សផ ១:១០ ន ២រប ២៧:៣ នហ ៣:២៦ **៣៣:១៥** ប ២ពវ ២៣:១២ **៣៣:១៦** ផ លវ ៧:១១-១៨ **៣៣:១៩** ព ២រប ៦:៣៧ ភ ២ពវ ២១:១៧ **៣៣:២០** ម ២ពវ ២១:១៨ ២រប ២១:២០

**៣៣:១០** មើលការពន្យល់ ឧ.១-២០ អ្នកកាលប្រវត្តិបានបំព្រួញនូវអ្វីដែលព្រះយេហូវ៉ាមានបន្ទូលទៅកាន់ម៉ាន៉ាសេ និងរាស្ត្ររបស់ផងទ្រង់តាមរយៈពួកហោរាឯកសារបង្ហាញច្បាស់គឺក្នុង ២ពវ ២១:១០-១៥ ។

**៣៣:១១-១៧** គឺជាភាពផ្លែកចំពោះអ្នកកាលប្រវត្តិ ដែលបង្ហាញពីការបញ្ជាក់របស់គាត់ស្តីពីការកាត់ទោសដូចជា: ការអាក្រក់របស់ម៉ាន៉ាសេនិងការផ្ចាញ់តែខណៈដែលទ្រង់លន់តួបាប ក៏ឱ្យមានក្រឹត្យវិន័យឡើងវិញ ។

**៣៣:១១** *នាំទៅឯបាប៊ីឡូន* ក៏ពុំមានការកត់ត្រាណានៅក្នុងគម្ពីរ ឬសេចក្តីពោលណាចំពោះស្តេចម៉ាន៉ាសេដែលគេនាំទ្រង់ទៅឯបាប៊ីឡូន គឺដោយស្តេចស្រុកអាស៊ើរ ។ ស្តេចអេសារ-ហាដោន(៦៨១-៦៦៩ មុន គ.ស) ស្តេចម៉ាន៉ាសេក៏ចុះឈ្មោះ ក្នុងចំណោមស្តេចទាំង២២អង្គក៏បានរៀបចំគម្រោងឡើងក្នុងការប្រឆាំងនិងស្រុកអេស៊ីព្ទ ។ ការពិតខណៈពេលស្តេចអាស៊ើរដែលបានគេនាំទៅឯស្រុកបាប៊ីឡូន គឺការងារនេះបានកើតឡើងគឺខណៈពេលដែលមានការបះបោរប្រឆាំងរបស់(សាមមាស-សាម-អ៊ូគីន) ប្រឆាំងបងប្រុសនិងអធិរាជ្យ(អាស៊ីបឺនប៉ាល)ការបះបោរប្រឆាំងនេះមានរយៈពេលចាប់ពី ៦៥២-៦៤៨ មុន គ.ស ។ និងម៉ាន៉ាសេអាចចូលរួមហើយគេសង្ស័យថាជាអ្នកជំនួយ នៅក្នុងការរតចេញពីពួកបាប៊ីឡូនគឺពីពួកអាសស៊ើរ ។ ម៉ាន៉ាសេក៏បានគេសន្មតថាទ្រង់ពុំមានទោសទេហើយទ្រង់ត្រូវបានគេលើកលែងទោសឱ្យ ដោយឈរនៅលើការសន្យាជាថ្មីដោយភាពស្មោះត្រង់ ។ អេស៊ីព្ទគឺបានជាគន្លឹះមួយចេញពីក្រោមនឹម អាស៊ើរនៅក្រោមរាជវង្សទី២៦ថ្មី ដែលក្រោយមកគឺស្តេចម៉ាន៉ាសេដែលគ្រប់គ្រងជិតព្រំប្រទល់ស្រុកអេស៊ីព្ទ ។

**៣៣:១២** គឺជាភាសាដែលនឹកឃើញដល់ការអធិស្ឋានរប់ស្តេច សាឡូម៉ូន (៧:១៤) ។

**៣៣:១៤** *ទ្រង់សងកំផែងនៅក្រៅកំផែង* ចំពោះអ្នកកាលប្រវត្តិបង្កើតជាកម្មវិធីបែបនេះគឺជាសញ្ញានៃព្រះពរពីព្រះយេហូវ៉ា (៨:១-៦ ១១:៥-១២ ១៤:៦-៧ ២៦:៩-១០,១៤-១៥ ៣២:១-៥,២៧-៣០ ១រប ១១:៧-៩ ១៥:១ ១៤:៦-៧ ២៦:៩-១០,១៤-១៥ ៣២:១-៥,២៧-៣០ ១រប ១១:៧-៩ ១៥:១) ។

**៣៣:១៥-១៦** អ្វីៗក៏ដោយគឺជាការបង្កើតឡើងវិញនូវម៉ាន៉ាសេ ។ ស្តេចយ៉ូសៀសក្រោយមកទៀតត្រូវការរើយកអាសនាចេញ គឺជាអាសនានៅទីលានទាំងពីរនៃព្រះវិហារនៃព្រះយេហូវ៉ា(២ពវ ២៣:១២ ) ។

**៣៣:២០** *គេបញ្ចុះសពទ្រង់នៅក្នុងដំណាក់ទ្រង់* ប្រៀបធៀប ២ពវ ២១:១៨។ ការបញ្ចុះសពទ្រង់នេះ គឺនៅក្នុងសួនច្បារនៃព្រះរាជដំណាក់ដែលបង្កើតឡើងដោយម៉ាន៉ាសេជាស្តេចទី៥ ហើយអ្នកកាលប្រវត្តិក៏ប្រាប់ឈ្មោះស្តេច

## អាំម៉ូនឡើងជាស្តេចស្រុកយូដា

*៣៣:២១-២៥ – ២ពវ ២១:១៩-២៤*

២១កាលអាំម៉ូន[យ]ចាប់តាំងសោយរាជ្យឡើង នោះទ្រង់
មានព្រះជន្ម២២ឆ្នាំហើយ ទ្រង់សោយរាជ្យនៅក្រុង
យេរូសាឡិមបាន២ឆ្នាំ ២២ទ្រង់ប្រព្រឹត្តអំពើដ៏លាមកអាក្រក់
នៅព្រះនេត្រព្រះយេហូវ៉ា ដូចជាម៉ានាសេ ជាព្រះបិតាបាន
ប្រព្រឹត្តដែរ អាំម៉ូនទ្រង់ក៏ថ្វាយយញ្ញបូជា ហើយគោរព
ដល់អស់ទាំងរូបធ្លាក់ ដែលម៉ានាសេ ជាព្រះបិតា បានធ្វើ
២៣ឥតបន្ទាបព្រះទ័យចុះ នៅចំពោះព្រះយេហូវ៉ា ដូចជា
ម៉ានាសេជាព្រះបិតា ទ្រង់បានបន្ទាបនោះឡើយ[រ] គឺអាំម៉ូន
នេះទ្រង់បានប្រព្រឹត្តរំលងកាន់តែច្រើនឡើង ២៤ឯពួកអ្នក
បំរើទ្រង់ គេលើកគ្នាធ្វើគុកទ្រង់ នៅក្នុងព្រះរាជដំណាក់
ទៅ ២៥តែពួកអ្នកស្រុក[ល]គេសំឡាប់អស់អ្នក ដែលបានលើក
គ្នាក្បត់នឹងស្តេចអាំម៉ូននោះវិញ គេលើកយ៉ូសៀសជាព្រះ
រាជបុត្រា តាំងឡើងជាស្តេចជំនួសព្រះបិតា ។

## ការធ្វើកំណែទម្រង់របស់ស្តេចយ៉ូសៀស

*៣៤:១-២ – ២ពវ ២២:១-២*

*៣៤:៣-៧ – ២ពវ ២៣:៤-២០*

*៣៤:៨-១៣ – ២ពវ ២២:៣-៧*

**៣៤** ១ឯយ៉ូសៀស[ក] កាលចាប់តាំងសោយរាជ្យឡើង[ខ]
នោះទ្រង់មានព្រះជន្ម៨ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន៣១ឆ្នាំ ២ទ្រង់ប្រព្រឹត្តសេចក្តីដែលត្រឹម
ត្រូវ នៅព្រះនេត្រព្រះយេហូវ៉ា ព្រមទាំងដើរតាមអស់ទាំង
ផ្លូវរបស់ដាវីឌ[គ] ជាព្វយុកោទ្រង់ផង ឥតងាកបែរទៅខាង
ស្តាំឬខាងឆ្វេងឡើយ ៣ដ្បិតនៅឆ្នាំទី៨ក្នុងរាជ្យទ្រង់ កាល
ទ្រង់នៅក្មេងនៅឡើយ នោះទ្រង់ក៏ចាប់តាំងស្វែងរកតាម
ព្រះ[ឃ]នៃដាវីឌជាព្វយុកោទ្រង់ លុះដល់ឆ្នាំទី១២ នោះទ្រង់
ផ្តើមជំរះសំអាតស្រុកយូដា និងក្រុងយេរូសាឡិម ឱ្យរួចពី
អស់ទាំងទីខ្ពស់ រូបព្រះ រូបធ្លាក់ និងរូបសិតទាំងប៉ុន្មាន
ចេញ ៤គេក៏បំបាក់បំបែកអាសនាព្រះបាល នៅចំពោះទ្រង់
ក៏កាប់រំលំរូបព្រះអាទិត្យដែលនៅខ្ពស់ពីលើគេ ព្រមទាំង
រូបព្រះរូបធ្លាក់[ង] និងរូបសិតទាំងប៉ុន្មានផង ហើយកិន
កំទេចជាផង់ធូលី រួចរោយរុះលើផ្នូរខ្មោចរបស់ពួកអ្នក
ដែលបានថ្វាយយញ្ញបូជាដល់ព្រះទាំងនោះ[ច] ៥ទ្រង់យកឆ្អឹង
ពួកសង្ឃទាំងនោះ ទៅដុត[ឆ]លើអាសនារបស់គេដូច្នេះទ្រង់
បានជំរះសំអាតស្រុកយូដា និងក្រុងយេរូសាឡិមរួចហើយ
៦ទ្រង់ក៏ធ្វើយ៉ាងនោះនៅអស់ទាំងទីក្រុងរបស់ពួកម៉ានាសេ
ពួកអេប្រាអិម និងពួកស៊ីម្មាន រហូតដល់ស្រុករបស់ពួក
ណែបថាលី និងកន្លែងបាក់បែកនៅជុំវិញទាំងប៉ុន្មានដែរ
៧ក៏រំលំអាសនា បំបាក់បំបែករូបព្រះ និងរូបធ្លាក់ឱ្យ
ទៅជាផង់ធូលី[ជ] កាប់រំលំអស់ទាំងរូបព្រះអាទិត្យនៅគ្រប់
ក្នុងស្រុកអ៊ីស្រាអែលចេញ រួចទ្រង់វិលត្រឡប់មកឯក្រុង
យេរូសាឡិមវិញ ។

៨លុះដល់ឆ្នាំទី១៨ ក្នុងរាជ្យទ្រង់ កាលគេបានជំរះ
សំអាតស្រុក និងព្រះវិហាររួចជាស្រេចហើយ នោះទ្រង់

**៣៣:២១** យ ១រប ៣:១៤
**៣៣:២៣** រ នក ១០:៣ ២រប ៧:១៤ ទដ ១៨:២៧ ១៤៧:៦ សភ ៣:៣៤
**៣៣:២៥** ល ២រប ២២:១
**៣៤:១** ក ១រប ៣:១៤ ខ សជ ១:១
**៣៤:២** គ ២រប ២៩:២
**៣៤:៣** ឃ ១រប ១៦:១១
**៣៤:៤** ង នក ៣៤:១៣ ច នក ៣២:២០ លវ ២៦:៣០ ២ពវ ២៣:១១ មីក ១:៥
**៣៤:៥** ឆ ១ពវ ១៣:២
**៣៤:៧** ជ នក ៣២:២០

អង្គណាដែលមិនបានបញ្ចុះក្នុងផ្នូររបស់ពួកស្តេចនោះដែរ (សូមមើលការពន្យល់ ២៨:២៧) ។

**៣៣:២១-២៥** មើល ២ពវ ២១:១៩-២៦ អ្នកកាលប្រវត្តិ បានបង្ហាញពីការគ្រងរាជ្យរបស់អាំម៉ូន(៦៤២-៦៤០ មុន ស.គ)គឺមានស្រដៀងទៅនឹងក្រុមស្តេចដែលផ្ទុយពីរ (១)កំណត់សំគាល់បន្ថែមគឺចំពោះស្តេចអាំម៉ូនពុំបានលន់តួបាបដូចបិតាទ្រង់ទេគឺស្តេចម៉ានាសេ មើល(ខ.១២-១៣)និង (២)ការបាត់បងនូវរបៀបបញ្ចុះសព ។

**៣៤:១-៣៦:១** មើល ២ពវ ២២:១-២៣:៣០ និងការពន្យល់ ។ រឿងរ៉ាវទាំងពីររបស់ស្តេច យ៉ូសៀសក្នុងការគ្រងរាជ្យរបស់ទ្រង់ គឺមានរយៈពេលនិងការប្រព្រឹត្តដូចគ្នា តែបើយើងមើលឱ្យច្បាស់ភាពទាំងពីរនោះដែលទាក់ទងនឹងទស្សនៈផ្ទុយគ្នានិងការរៀបចំ (១)គឺការរុះរើអាសនាបរទេស (២)ការស្វែងរកសៀវភៅក្រឹត្យវិន័យ និងសេចក្តីសញ្ញាដែលមានសារជាថ្មី(៣)ការធ្វើពិធីបុណ្យរំលងឡើវិញ ។ នៅផ្នែកទី២គឺជាប្រវត្តិកាលពីរដែលមានលក្ខណៈស្រដៀងគ្នា ។ គឺផ្នែកទី១ អ្នកនិពន្ធបានបង្ហាញយ៉ាងវែង(២ពវ ២៣:៤-២០)គឺអ្នកកាលប្រវត្តិ សរសេរជាលក្ខណៈសង្ខេប (៣៤:៣-៧,៣៣) ។ រឿងរ៉ាវប្រារពបុណ្យរំលងក៏បានពង្រីកជាច្រើនក្នុងរបាក្សត្រ(៣៥:១-១៩) ពេលនោះក៏បានប្រាប់ច្រើនក្នុង (២ពវ ២៣:២១-២៣)។ មិនមែនតែផ្នែកខាងនោះមានការ ប្រព្រឹត្តឡើងនូវរយៈពេលផ្សេងគ្នានោះទេក៏មានការផ្លាស់ប្តូរជាលំដាប់លំដោយផងដែរ ។ ក្នុងគម្ពីរពង្សាវតារក្សត្រការរកគម្ពីរ ក្រឹត្យវិន័យនៅក្នុងព្រះវិហារនៅសតវត្សទី១៨ គឺជាឆ្នាំដែលបានបង្ហាញជាលើកដំបូង អ្នកសរសេរក៏បង្ហាញច្រើននូវឯកសារជាប្រវត្តិសាស្ត្រគឺថា : ក៏បានផ្សព្វផ្សាយក្នុងព្រះវិហារ ហើយទូទាំងទីក្រុងទាំងមូលនិងរហូតដល់ជាតិសាសន៍មួយចំនួន ។ ៣៤:៣(ការកត់សំគាល់ពីរក៏ពុំមានភាពដូចគ្នាក្នុងពង្សាវតារក្សត្រ)៣៤:៨(មើល ២ពវ ២២:៣) ៣៥:១៩(មើល ២ពវ ២៣:២៣ មើលការពន្យល់ ២ពវ ១២:២) ។ កាលប្រវត្តិបង្ហាញយ៉ាងច្បាស់ថាការរៀបចំគឺចាប់ផ្តើមក្នុងឆ្នាំទី១២ របស់ស្តេចយ៉ូសៀស(៣៤:៣)មុនពេលរកឃើញគម្ពីរក្រឹត្យវិន័យគឺ៦ឆ្នាំមុនទៅទៀត ។

**៣៤:១-២** មើល ២ពវ ២២:១-២ ។

**៣៤:១** *៣១ឆ្នាំ* ៦៤០-៦០៩ មុន គ.ស ។

**៣៤:៣-៧** អ្នកនិពន្ធគម្ពីរ ពង្សាវតារក្សត្រផ្តោតទៅលើទស្សនៈរបស់យ៉ូសៀសដែលបានរៀបចំឡើងវិញ ហើយមានលក្ខណៈលំអិត (២ពវ ២៣:៤-២០) ។ ទ្រង់ក៏ពន្យាពេលក្នុងការរុះរើបំផ្លាញសាសនាខុសឆ្គងរហូតដល់រកឃើញគម្ពីរក្រឹត្យវិន័យ ។

**៣៤:៧** *នៅគ្រប់ក្នុងស្រុកអ៊ីស្រាអែលចេញ* គឺជាការបង្ហាញដោយបញ្ជីឈ្មោះពូជអំបូរក្នុងខ.៦ ។

**៣៤:៨-២១** *មើល* ២ពវ ២២:៣-១៣ និងការពន្យល់ ។

ចាត់សាផាន ជាកូនអ័សាលា ម្អាសេយ៉ា ជាចៅហ្វាយទីក្រុង
និងយ៉ូអា កូនយ៉ូអាហាស ជាអ្នកតែងពង្សាវតារ ឱ្យទៅជួស
ជុលព្រះវិហារនៃព្រះយេហូវ៉ា ជាព្រះនៃទ្រង់ ៩ គេក៏ទៅ
ហ៊ីលគីយ៉ា[ឈ] ជាសំដេចសង្ឃប្រគល់ប្រាក់ដែលគេបាននាំ
យកមកក្នុងព្រះវិហារនៃព្រះ ជាប្រាក់ដែលពួកលេវីជា
អ្នកឆ្មាំទ្វារបានប្រមូលពីពួកម៉ាន៉ាសេ ពួកអេប្រាអិម និង
សំណល់ពួកអ៊ីស្រាអែលទាំងប៉ុន្មាន ហើយពីពួកយូដា ពួក
បេនយ៉ាមីន និងពួកអ្នកនៅក្នុងក្រុងយេរូសាឡិមផង ១០ គេ
ប្រគល់ប្រាក់នោះ ទៅក្នុងអំណាចនៃពួកមេជាង ជាអ្នក
ដែលត្រួតលើការក្នុងព្រះវិហារនៃព្រះយេហូវ៉ា ហើយពួក
អ្នកទាំងនោះក៏ប្រគល់ដល់ពួកជាងដែលធ្វើការ ក្នុងព្រះ
វិហារនៃព្រះយេហូវ៉ា សំរាប់នឹងជួសជុល ហើយរៀប
ចំព្រះវិហារជាថ្មីឡើងវិញ ១១ គឺប្រគល់[ញ]ដល់ពួកជាងឈើ
និងពួកជាងរៀបថ្ម ឱ្យគេទិញថ្មដាប់ស្រាប់ និងឈើសំរាប់
ជាធ្នឹម និងផ្ទាន ធ្វើមន្ទីរទាំងប៉ុន្មាន ដែលពួកស្តេចយូដា
បានបំផ្លាញទៅ[ដ] ១២ ពួកជាងទាំងនោះគេធ្វើការដោយ
ស្មោះត្រង់[ឋ] ឯអ្នកដែលត្រួតលើគេ គឺយ៉ាហាត និងអូបាឌា
ជាពួកលេវីខាងពួកកូនចៅម្រ៉ារី ហើយសាការី និង
មស៊ូឡាមខាងពួកកូនចៅកេហាត ដើម្បីនឹងបញ្ចៀនការ
នោះ ហើយមានពួកលេវីដែលប៉ិនប្រសប់នឹងលេងភ្លេង
ដែរ[ឌ] ១៣ គេក៏ត្រួតលើពួកអ្នកដែលលីសែង[ឍ] ហើយលើអស់
អ្នកដែលធ្វើការគ្រប់មុខផង ឯក្នុងពួកលេវីទាំងនោះមាន
ស្មៀន និងនាយហើយនឹងអ្នកឆ្មាំទ្វារដែរ ។

## គម្ពីរក្រិត្យវិន័យត្រូវបានរកឃើញ

*៣៤:១៤–២៨ – ២ពវ ២២:៨–២០*

*៣៤:២៩–៣២ – ២ពវ ២៣:១–៣*

១៤ កាលកំពុងតែយកប្រាក់ ដែលគេបានយកមកក្នុងព្រះ
វិហារនៃ ព្រះយេហូវ៉ាចេញទៅ នោះហ៊ីលគីយ៉ាដ៏ជាសង្ឃ
លោកប្រទះឃើញគម្ពីរក្រិត្យវិន័យរបស់ព្រះយេហូវ៉ាដែល
បានប្រទានមកដោយសារលោកម៉ូសេ ១៥ លោកក៏ប្រាប់ដល់
ស្មៀនសាផានថា ខ្ញុំបានប្រទះឃើញគម្ពីរក្រិត្យវិន័យ[ណ] នៅ
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា រួចលោកប្រគល់ គម្ពីរនោះ
ទៅសាផាន ១៦ ហើយសាផាននាំយកទៅថ្វាយដល់ស្តេច ទូល
ថា ឯការទាំងអស់ដែលទ្រង់បានប្រគល់ដល់ពួកអ្នកបំរើ
ទ្រង់ នោះគេកំពុងតែធ្វើហើយ ១៧ គេបានចាក់ប្រាក់ដែល
ឃើញមាននៅក្នុងព្រះវិហារ នៃព្រះយេហូវ៉ាចេញប្រគល់
ទៅក្នុងអំណាចនៃពួកមេជាង និងពួកជាងធ្វើការ ១៨ រួច
ស្មៀនសាផានទូលទៀតថា ហ៊ីលគីយ៉ាដ៏ជា សង្ឃបាន
ប្រគល់គម្ពីរនេះមកទូលបង្គំ ហើយសាផានក៏អានមើលក្នុង
គម្ពីរនោះថ្វាយស្តេច ១៩ កាលស្តេចទ្រង់ឮពាក្យរបស់ក្រិត្យ
វិន័យ[ត] ហើយ នោះទ្រង់ក៏ហែក[ថ]ព្រះពស្ត្រ ២០ ហើយបង្គាប់
ដល់ហ៊ីលគីយ៉ា អ័ហ៊ីកាម ជាកូនសាផាន[ទ] អាបដូន ជាកូន
មីកាយ៉ា ស្មៀនសាផាន និងអ័សាយ៉ា ជាអ្នកជិតទ្រង់ថា
២១ ចូរទៅសួរដល់ព្រះយេហូវ៉ាឱ្យយើងនឹងពួកអ្នក ដែល
សល់នៅក្នុងពួកអ៊ីស្រាអែល ហើយនិងពួកយូដា ឱ្យយើង
បានដឹងពីដំណើរពាក្យនៃគម្ពីរ ដែលប្រទះឃើញនេះ ដ្បិត
សេចក្តីក្រេវ ក្រោធរបស់ព្រះយេហូវ៉ាដែលបានចាក់មក[ធ]
លើយើងរាល់គ្នានោះសំបើមណាស់ ពីព្រោះពួកឰយុកោ
យើងរាល់គ្នា មិនបានកាត់តាមព្រះបន្ទូលនៃព្រះយេហូវ៉ា
ដើម្បីនឹងប្រព្រឹត្តតាមគ្រប់ទាំងសេចក្តីដែលកត់ ទុកក្នុងគម្ពីរ
នេះទេ ។

២២ ដូច្នេះ ហ៊ីលគីយ៉ា នឹងពួកអ្នកដែលស្តេចបានចាត់
ប្រើនោះ ក៏ទៅឯនាងហ៊ុលដា ជាហោរា[ន] ប្រពន្ធសាលូមកូន
ធីកវ៉ា ដែលជាកូន ហារហាស អ្នករក្សាព្រះពស្ត្ររាជ្យ
(នាងនោះអាស្រ័យនៅឃុំលេខ២ ក្នុងក្រុងយេរូសាឡិម)
និយាយនឹងនាងតាមដំណើររឿងនោះ ២៣ រួចនាងតបដល់
គេថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មាន
បន្ទូលដូច្នេះ ចូរទៅប្រាប់ដល់អ្នកដែលចាត់ឯងរាល់គ្នា
ឱ្យមកឯអញថា ២៤ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ មើល
អញនឹងធ្វើឱ្យមានសេចក្តីអាក្រក់[ប]មកលើទីនេះ ហើយលើ
ពួកអ្នកដែលនៅទីនេះផង[ផ] គឺគ្រប់ទាំងសេចក្តីបណ្តាសា[ព]
កត់ទុកក្នុងគម្ពីរ ដែលគេបានអានមើលថ្វាយស្តេចពួកយូដា
២៥ ដោយព្រោះគេបានបោះបង់ចោលអញ[ភ] ហើយបានដុត
កំញានថ្វាយព្រះដទៃ ដើម្បីនឹងបណ្តាលឱ្យអញខឹង ដោយ
អស់ទាំងការដែលដៃគេធ្វើទាំងប៉ុន្មាន ហេតុនោះបានជា
សេចក្តីកំហឹងរបស់អញបានចាក់មកលើទីនេះ ហើយនឹង
ពន្លត់មិនបានផង ២៦ តែឯស្តេចយូដាដែលចាត់ឱ្យឯងរាល់
គ្នាមកសួរដល់ព្រះយេហូវ៉ា នោះត្រូវទូលទ្រង់ថា ព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលពី

**៣៤:៩** ឈ ១របា ៦:១៣
**៣៤:១១** ញ ២របា ២៤:១២ ដ ២របា ៣:៤–៧
**៣៤:១២** ឋ ២ពវ ១២:១៥ ឌ ១របា ២៥:១
**៣៤:១៣** ឍ ១របា ២៣:៤
**៣៤:១៥** ណ ២ពវ ២២:៨ អរ ៧:៦ នហ ៨:១
**៣៤:១៩** ត ចទ ២៨:៣–៦៨ ថ អស ៣៦:២២ ៣៧:១
**៣៤:២០** ទ ២ពវ ២២:៣
**៣៤:២១** ធ បទ ២:៤ ៤:១១ អគ ៣៦:១៨
**៣៤:២២** ន នក ១៥:២០ ណហ ៦:១៤
**៣៤:២៤** ប សភ ១៦:៤ អស ៣:៩ យរ ៤០:២ ៤២:១០ ៤៤:២,១១ ផ ២របា ៣៦:១៤–២០ ព ចទ ២៨:១៥–៦៨
**៣៤:២៥** ភ ២របា ៣៣:៣–៦ យរ ២២:៩

**៣៤:៩** *ម៉ាន៉ាសេពួកអេប្រាអិមនិង សំណល់ពួកអ៊ីស្រាអែលទាំងប៉ុន្មាន* ដែល
គេមានទំនាក់ទំនងនិងរាស្ត្រអ៊ីស្រាអែល ការកត់សំគាលពីអ្នកកាលប្រវត្តិ
ថាអ្នកថ្វាយបង្គំពីពួកអ្នកស្រុកខាងជើងក៏នាំមកនូវដង្វាយចូលទៅឯព្រះ
វិហារផងដែរ (២ពវ ២២:៤) ។

**៣៤:១០–១៣** ប្រៀបធៀប ២៤:៨–១២ ។

**៣៤:១៤** *គម្ពីរក្រិត្យវិន័យរបស់ព្រះយេហូវ៉ា* មើលការពន្យល់ ១៧:៩ ។

**៣៤:២២–២៨** មើល ២ពវ ២២:១៤–២០ និងការពន្យល់ ។

**៣៤:២២** *នាងហ៊ុលដាជាហោរា* មើលការពន្យល់ ២ពវ ២២:១៤ ។

ដំណើរពាក្យដែលទ្រង់បានឮនោះថា ២៧ដោយព្រោះឯង
មានចិត្តទន់[ម] ហើយបានបន្ទាបខ្លួន[យ]នៅចំពោះព្រះ ដោយឮ
ព្រះបន្ទូលដែលទ្រង់មានបន្ទូលទាស់នឹងទីនេះ ហើយនឹងពួក
អ្នកនៅទីនេះផង ព្រមទាំងបន្ទ្រាមខ្លួនចុះនៅមុខអញក៏
ហែកអាវ ហើយយំនៅមុខអញ ដូច្នេះនោះអញបានទទួល
ស្តាប់តាមឯងហើយ នេះហើយជាព្រះបន្ទូល នៃព្រះ
យេហូវ៉ា ២៨មើលអញនឹងប្រមូលឯងទៅជាមួយនឹងពួក
ឰយុកោឯង[រ] ឯងនឹងទៅមូលគ្នា នៅក្នុងផ្នូរដោយសុខសាន្ត
ភ្នែកឯងនឹង មិនឃើញអស់ទាំងសេចក្តីអាក្រក់ដែលអញនឹង
នាំមកលើទីនេះ នឹងលើពួកអ្នកនៅទីនេះឡើយ[ល] ដូច្នេះ គេ
ក៏នាមយកពាក្យនោះទៅទូលដល់ស្តេចវិញ ។
២៩នោះស្តេចទ្រង់ចាត់គេ ឱ្យទៅប្រមូលពួកចាស់ទុំនៃ
ស្រុកយូដា និងក្រុងយេរូសាឡិមមកប្រជុំគ្នា ៣០រួចស្តេចទ្រង់
យាងលើងទៅឯព្រះវិហារនៃព្រះយេហូវ៉ា[វ] មានទាំងពួក
ស្រុកយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នា
ហើយពួកសង្ឃ ពួកលេវី និងបណ្តាជនទាំងឡាយ ទាំងធំ
ទាំងតូចផង នោះទ្រង់ក៏អានមើល ឱ្យគេស្តាប់អស់ទាំង
ពាក្យនៅក្នុងគម្ពីរនៃសេចក្តីសញ្ញា ដែលបានប្រទះឃើញ
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ៣១ឯស្តេចទ្រង់ឈរនៅ
កន្លែងទ្រង់[ស] ក៏ចុះសញ្ញា[ហ]នឹងព្រះយេហូវ៉ា ឱ្យបានដើរ
តាម[ឡ]ព្រះយេហូវ៉ា ព្រមទាំងកាន់តាម ក្រិត្យក្រមសេចក្តី
បន្ទាល់ និងបញ្ញត្តរបស់ទ្រង់ទាំងប៉ុន្មាន អស់ពីចិត្តអស់ពី
ព្រលឹង ដើម្បីនឹងសំរេចតាមអស់ទាំងពាក្យនៃសញ្ញាដែល
បានកត់ទុកក្នុងគម្ពីរនោះ ៣២ទ្រង់ក៏បង្គាប់ដល់អស់អ្នក ដែល
មាននៅក្នុងក្រុងយេរូសាឡិម ហើយស្រុកបេនយ៉ាមីន ឱ្យ
កាន់តាមសេចក្តីសញ្ញានោះ ដូច្នេះ ពួកក្រុងយេរូសាឡិមក៏
ធ្វើតាមសេចក្តីសញ្ញាផងព្រះ ជាព្រះនៃពួកឰយុកោគេ
៣៣រួចយ៉ូសៀស ទ្រង់ដកយកអស់ទាំងរបស់ គួរស្អប់
ខ្ពើម[អ]ចេញពីស្រុកទាំងប៉ុន្មាន ដែលជារបស់ផងពួកកូន

**៣៤:២៧** ម ២របា ៣២:២៦ យ នក ១០:៣ ២របា ៦:៣៧
**៣៤:២៨** រ ២របា ៣៥:២០–២៥ ល ២របា ៣២:២៦
**៣៤:៣០** វ ២ពវ ២៣:២
**៣៤:៣១** ស ១ពវ ៧:១៥ ហ ២ពវ ១១:១៧ ២របា ២៣:១៦ ឡ ចទ ១៣:៤
**៣៤:៣៣** អ ចទ ១៨:៩
**៣៥:១** ក នក ១២:១–៣០ ជន ២៨:១៦
**៣៥:៣** ខ ២របា ១៧:៧
**៣៥:៤** គ ខ.១០ ១របា ២៤:១ អរ ៦:១៨
**៣៥:៦** ឃ លវ ១១:៤៤
**៣៥:៧** ង ២របា ៣១:៣ ច ២របា ៣០:២៤

ចៅអ៊ីស្រាអែល ហើយក៏បង្គាប់ឱ្យអស់អ្នកដែលនៅស្រុក
អ៊ីស្រាអែល គោរពដល់ព្រះយេហូវ៉ា ជាព្រះនៃគេ ដូច្នេះ
នៅអស់រវាងព្រះជន្មទ្រង់ នោះគេមិនបានបែរចេញពី
ការគោរពតាមព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេ
ឡើយ ។

## យ៉ូសៀសធ្វើបុណ្យរំលង

*៣៥:១,១៨–១៩ – ២ពវ ២៣:២១–២៣*

**៣៥** ១យ៉ូសៀស ទ្រង់ក៏ធ្វើបុណ្យរំលង[ក]ថ្វាយព្រះយេហូវ៉ា
នៅក្រុងយេរូសាឡិម គេសំឡាប់ចៀមធ្វើបុណ្យ រំលងនោះ
នៅថ្ងៃ១៤ក្នុងខែចេត្រ ២ទ្រង់តាំងពួកសង្ឃឱ្យធ្វើការងារ
ក្នុងដំណែងគេ ហើយក៏ណែនាំគេឱ្យតាំងចិត្តធ្វើការងារ
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ៣ទ្រង់មានបន្ទូលទៅពួក
លេវី ជាអ្នកដែលបង្ហាត់បង្រៀន[ខ]ពួកអ៊ីស្រាអែលទាំង
ប៉ុន្មាន គឺជាពួកអ្នកបរិសុទ្ធដល់ព្រះយេហូវ៉ាថា ចូរយកហឹប
បរិសុទ្ធទៅតាំងនៅក្នុងព្រះវិហារដែលសាឡូម៉ូន ជាព្រះ
រាជបុត្រាដាវីឌ ស្តេចអ៊ីស្រាអែលបានស្អាង មិនចាំបាច់
ឱ្យឯងរាល់គ្នាសែងទៀតឡើយ ឥឡូវនេះ ចូរបំរើដល់ព្រះ
យេហូវ៉ាជាព្រះនៃឯងរាល់គ្នា ហើយដល់អ៊ីស្រាអែល ជា
រាស្ត្រទ្រង់ផង ៤ចូរបំរុងខ្លួនជាស្រេច តាមវង្សនៃឪពុក
ឯងរាល់គ្នាដោយវេនៗ[គ] ឱ្យត្រូវតាមសេចក្តី ដែលដាវីឌ ជា
ស្តេចអ៊ីស្រាអែល និងសាឡូម៉ូន ជាព្រះរាជបុត្រាទ្រង់បាន
កត់ទុក ៥ហើយឈរនៅក្នុងទីបរិសុទ្ធ តាមផ្នែកពួកវង្ស
របស់ឪពុកនៃបងប្អូនឯងរាល់គ្នា ដែលជាកូនចៅនៃបណ្តា
ពួកលេវី ៦រួចសំឡាប់ចៀមសំរាប់បុណ្យរំលង ហើយញែក
ខ្លួនចេញជាបរិសុទ្ធ[ឃ] រួចមករៀបចំឱ្យពួកបងប្អូនចុះ ដើម្បី
នឹងធ្វើតាមសេចក្តី ដែលព្រះយេហូវ៉ាបានមានបន្ទូលដោយ
សារលោកម៉ូសេ ។
៧យ៉ូសៀសទ្រង់ប្រទានកូនចៀម និងកូនពពែ ពីហ្វូងសត្វ
មាន ចំនួន៣ម៉ឺននិងគោ៣ពាន់ ដែលសុទ្ធតែជាព្រះរាជ

**៣៤:២៨** *នៅក្នុងផ្នូរដោយសុខសាន្ត* សូមមើលការសុគតនិងការបញ្ចុះ (៣៥:២០–២៥) ។

**៣៤:២៩–៣១** មើល ២ពវ ២៣:១–៣ និងការពន្យល់ ។

**៣៤:៣០** *ហើយពួកសង្ឃពួកលេវី* ប្រៀបធៀប ២ពវ ២៣:២ ដែលមានពួកសង្ឃនិងពួកហោរា ។

**៣៤:៣៣** *អស់អ្នកនៅស្រុកអ៊ីស្រាអែល* មើលការពន្យល់ ខ.៦ ។

**៣៥:១–១៩** អ្នកកាលប្រវត្តិបានផ្តល់ការយកចិត្តទុកដាក់ ផ្តោតទៅលើការប្រារពបុណ្យរំលងរបស់ យ៉ូសៀសច្រើនជាងសេចក្តីសង្ខេប ដែលមានក្នុងគម្ពីរពង្សាវតារក្សត្រ(២ពវ ២៣:២១–២៣) ។

**៣៥:១** *ក្នុងខែចេត្រ* ជាខែមួយជាប្រពៃណីយ៍ដែលផ្ទុយនិងថ្ងៃ បុណ្យរំលងរបស់ស្តេចហេសេគា (មើលការពន្យល់ ៣០:២) ។

**៣៥:៣** *ចូរយកហឹបបរិសុទ្ធ ទៅតាំងនៅក្នុងព្រះវិហារ* ក៏បង្ហាញថាវាបានផ្លាស់ប្តូរជាការ សម្រាប់ការពារក្នុងគ្រាគ្រងរាជ្យដែលមានការអាក្រក់របស់ស្តេចម៉ានាសេហើយនិងអាំម៉ូន ដែលជាអ្នក នាំមុខ យ៉ូសៀស ។

**៣៥:៤** *ដាវីឌ . . . សាឡូម៉ូន* អ្នកកាលប្រវត្តិប្រដូចលក្ខណៈពិសេស នៃស្តេចដាវីឌនិង ស្តេចសាឡូម៉ូនក្នុងករណីបីយ៉ាង ៧:១០ (ភាពផ្ទុយគ្នា ១ពវ ៨:៦៦ គឺបង្ហាញតែពីស្តេចដាវីឌទេ) ១១:១៧ និងអត្ថបទនេះក៏បង្ហាញដែរ ។ រឿងនេះក៏ទាក់ទងនិងកិត្តិគុណនិង ឧត្តមគតិនៃទ្រង់ (មើលសេចក្តីផ្តើម ១របា គឺបង្ហាញពីដាវីឌ និងស្តេចសាឡូម៉ូន) ។

**៣៥:៧–៩** បានបង្ហាញក្នុងកាលប្រវត្តិ ដោយចេតនានិងសេចក្តីអំណារ

ទ្រព្យ[ង]ដល់ពួកអ្នក ក្នុងបណ្ដាជនទាំងឡាយ គឺដល់អស់អ្នក
ដែលប្រជុំគ្នានៅទីនោះ សំរាប់ដង្វាយបុណ្យរំលង[ច] ៨ឯពួក
អ្នកដែលជាប្រធានរបស់ទ្រង់ គេឱ្យ[ឆ]ដល់ពួកជន ពួកសង្ឃ
និងពួកលេវីដោយស្ម័គ្រចិត្តដែរ ហើយហ៊ីលគីយ៉ា[ជ] សាការី
និងយេហ៊ីអែល ជាពួកមេលើព្រះវិហារនៃព្រះ ក៏ឱ្យចៀម
២ពាន់៦រយ និងគោ៣រយ ដល់ពួកសង្ឃសំរាប់ជាដង្វាយ
នៃបុណ្យរំលង ៩ឯកូណានា[ឈ] និងសេមាយ៉ា ហើយ
នេថានេល ជាបងប្អូនលោក ព្រមទាំងហាសាបយ៉ាយីអែល
និងយ៉ូសាបាឌ[ញ] ជាមេពួកលេវី គេក៏ឱ្យចៀម៥ពាន់ និង
គោ៥០០ដល់ពួកលេវីសំរាប់ជាដង្វាយបុណ្យរំលងទៀត។
១០យ៉ាងនោះ ការងារទាំងអស់បានរៀបចំជាស្រេចពួក
សង្ឃគេ ឈរនៅកន្លែងគេ ហើយពួកលេវីតាមវេនគេ
ដែរ[ដ]តាមបង្គាប់ស្ដេច[ឋ] ១១ពួកលេវីបានសំឡាប់ចៀមបុណ្យ
រំលង[ឌ] ហើយពួកសង្ឃក៏យកឈាម ពីដៃគេទៅប្រោះពួក
លេវីក៏ពន្លាត់ស្បែក ១២រួចគេរើយកដង្វាយទាំង នោះទៅ
ដំរៀបដាក់តាមផ្នែកពួកវង្សរបស់ឪពុក នៃអស់អ្នកក្នុង
បណ្ដាជន ដើម្បីនឹងជូនថ្វាយដល់ព្រះយេហូវ៉ា តាមសេចក្ដី
ដែលចែងទុកមក ក្នុងគម្ពីរលោកម៉ូសេ គេក៏ធ្វើដូច្នោះនឹង
គោទាំងនោះដែរ ១៣គេអាំងដង្វាយបុណ្យរំលងតាម
របៀប[ឍ] ហើយស្ងោរដង្វាយបរិសុទ្ធទាំងប៉ុន្មាន ក្នុងឆ្នាំង ថ្លាង
និងខ្ទះ រួចយកទៅចែកឱ្យដល់ពួកអស់អ្នក ក្នុងបណ្ដា
ជនជាប្រញាប់ ១៤ទើបរៀបចំសំរាប់ខ្លួនគេ និងពួកសង្ឃជា
ខាងក្រោយ ដ្បិតពួកសង្ឃជាកូនចៅអើរ៉ុន គេនៅជាប់ការ
ថ្វាយដង្វាយដុត និងខ្លាញ់ទាំងប៉ុន្មាន[ណ] ដរាបដល់យប់បាន
ជាពួកលេវីរៀបចំសំរាប់ខ្លួនគេ និងពួកសង្ឃ ជាកូនចៅ
អើរ៉ុនដែរ ១៥ឯពួកកូនចៅអេសាភ ជាពួកអ្នកចំរៀង[ត] គេ
ក៏ឈរនៅកន្លែងគេតាមបង្គាប់ដាវីឌ អេសាភ ហេម៉ាន និង
យេឌូថិន ជាអ្នកមើលឈុតរបស់ស្ដេច ហើយពួកឆ្មាំទ្វារក៏
នៅចាំរៀងរាល់តែទ្វារ មិនចាំបាច់នឹងលែងធ្វើការងារ

**៣៥:៨** ឆ ១រប ២៩:៣ ២រប ២៩:៣–៣៦ ជ ១រប ៦:១៣
**៣៥:៩** ឈ ២រប ៣១:១២ ញ ២រប ៣១:១៣
**៣៥:១០** ដ ខ.៤ ឋ ២រប ៣១:១៣
**៣៥:១១** ឌ ២រប ៣០:១៧
**៣៥:១៣** ឍ នក ១២:២–១១
**៣៥:១៤** ណ នក ២៩:១៣
**៣៥:១៥** ត ១រប ២៥:១ ២៦:១២–១៩ ២រប ២៩:៣០ នហ ១២:៤៦ ទដ ៦៨:២៥
**៣៥:២០** ថ អស ១០:៩ យរ ៤៦:២ ទលវ ២:១៤
**៣៥:២១** ធ ១ពវ ១៣:១៨ ២ពវ ១៨:២៥
**៣៥:២២** ន ១សយ ២៨:៨

របស់គេទេ ដ្បិតពួកលេវីជាបងប្អូនគេរៀបចំឱ្យ ។
១៦ដូច្នេះ ការងារនៃព្រះយេហូវ៉ាទាំងអស់បានរៀបចំ
ជាស្រេច នៅថ្ងៃនោះឯង ដើម្បីនឹងធ្វើបុណ្យរំលង ហើយ
នឹងថ្វាយដង្វាយដុតនៅលើអាសនាព្រះយេហូវ៉ា តាមបង្គាប់
ស្ដេចយ៉ូសៀស ១៧ឯពួកកូនចៅអ៊ីស្រាអែលដែលនៅទីនោះ
គេក៏ធ្វើបុណ្យរំលងនៅវេលានោះ ព្រមទាំងបុណ្យនំបុ័ង
ឥតដំបែអស់៧ថ្ងៃ ១៨មិនដែលមានបុណ្យរំលង យ៉ាងនោះ
នៅក្នុងស្រុកអ៊ីស្រាអែលឡើយ ចាប់តាំងពីគ្រាហោរាសាំ
យូអែលរៀងមក ក៏មិនដែលមានស្ដេចនៃពួកអ៊ីស្រាអែល
ណាមួយ បានធ្វើបុណ្យរំលង ឱ្យដូចជាបុណ្យរំលង ដែល
យ៉ូសៀស ពួកសង្ឃ ពួកលេវី ហើយពួកយូដា និងពួក
អ៊ីស្រាអែលទាំងអស់ដែលបានប្រជុំគ្នា ព្រមទាំងពួកអ្នក
ដែលនៅក្រុងយេរូសាឡិមបានធ្វើនោះដែរ ១៩គេបានធ្វើ
បុណ្យរំលងនោះ នៅក្នុងឆ្នាំ១៨នៃរាជ្យយ៉ូសៀស ។

## ការសុគតរបស់យ៉ូសៀស

*៣៥:២០–៣៦:១ – ២ពវ ២៣:២៨–៣០*

២០ក្រោយការទាំងនោះមក ក្នុងកាលដែលយ៉ូសៀសបាន
រៀបចំព្រះវិហារហើយ នោះនេកោ ជាស្ដេចអេស៊ីព្ទទ្រង់
ឡើងទៅច្បាំងនឹង ក្រុងកើកេមីស[ថ] នៅមាត់ទន្លេអឺប្រាត[ទ]
ហើយយ៉ូសៀសទ្រង់យាងចេញទៅស្ទាក់ផ្លូវ ២១តែនេកោ
ទ្រង់ចាត់រាជទូតមកទូលថា ឱស្ដេចយូដាអើយ តើយើងមាន
រឿងអ្វីនឹងគ្នា នៅថ្ងៃនេះ យើងមិនមែនមកទាស់នឹងទ្រង់
ទេ គឺទៅទាស់តែនឹងពួកវង្ស១ ដែលយើងមានសង្គ្រាមនឹង
គេទេតើ ព្រះក៏បានបង្គាប់[ធ]ឱ្យយើងប្រញាប់នឹងធ្វើដែរ
ដូច្នេះ កុំឱ្យឃាត់ឃាំងព្រះ ដែលគង់ជាមួយនឹងយើងឡើយ
ក្រែងព្រះបំផ្លាញទ្រង់ទៅ ២២ប៉ុន្តែយ៉ូសៀសមិនព្រមថយ
បែរចេញពីនេកោទេ គឺបានក្លែង[ន]ព្រះអង្គ ដើម្បីឱ្យបាន
ច្បាំងនឹងទ្រង់វិញ ឥតស្ដាប់តាមពាក្យរបស់នេកោ ដែលមក
ពីព្រះឱស្ឋនៃព្រះឡើយ ហើយយាងទៅច្បាំងនៅត្រង់ច្រក

(២៤:៨–១៤ ២៩:៣១–៣៦ ៣១:៣–២១ ១រប ២៩:៣–៩) ។

**៣៥:១៨** *ចាប់តាំពីគ្រាហោរាសាំយូអែលរៀងមក* ក៏បានជិនួយ ចាប់តាំងពីពួកចៅហ្វាយ(២ពវ ២៣:២២) ។ នេះជាការបង្ហាញ របស់អ្នកកាលប្រវត្តិពីភាពសំខាន់របស់ពួកហោរា(មើលសេចក្ដីណែនាំ ចំពោះគម្ពីររបាក្សត្រ ទី១ : ត្រង់គោលបំណង និងផ្ទៃរឿងទី៣ ។

**៣៥:១៩** *ក្នុងឆ្នាំ១៨* គឺក្នុងឆ្នាំដដែលដូចដែលបានរកឃើញក្នុងគម្ពីរក្រឹត្យវិន័យ (៣:៨,១៤) ។

**៣៥:២០–២៧** មើលការពន្យល់ ២ពវ ២៣:២៨–៣០ ក្នុងឆ្នាំ៦០៩ មុន ស.គ គឺផារ៉ោន–នេកោ ក៏បានឡើងទៅជួយស្ដេចសាសន៍អាសើរនៅក្នុងចម្បាំង (២ពវ ២៣:២៩) គឺច្បាំងនិងពួកសាសន៍បាប៊ីឡូន ។

**៣៥:២១–២២** គឺក្នុង២ ទាំងនេះអ្នកកាលប្រវត្តិបានបង្ហាញ នូវទស្សនៈរបស់គេពីវិភាគទាន ជាថ្មីមួយទៀត : ការសុគតរបស់ ស្ដេចយ៉ូសៀសក្នុងសង្គ្រាម គឺបង្ហាញពីលទ្ធផលនៃការពុំស្ដាប់បង្គាប់ ដូចជានៅឯភ្នំពួកសាសន៍ដ៏ទៃគឺផារ៉ោន ។

**៣៥:២១** *ពួកវង្ស១ ដែលយើងមានសង្គ្រាមនឹងគេទេតើ* គឺសំដៅលើពួកបាប៊ីឡូន គឺនាបូប៉ូឡាសាដែលស្ថិតក្នុងការគ្រងរាជ្យ ក្នុងស្រុកបាប៊ីឡូនខណៈពេលព្រះរាជបុត្រាទ្រង់ឈ្មោះ នេប៊ូក្នេសាបានទទួល តំណែងពីព្រះបិតាបន្ទាប់ពីធ្វើចម្បាំងជាមួយសាសន៍អេស៊ីព្ទក្នុង ៦០៥ មុន គ.ស យ៉ូសៀសបានចងសម្ព័ន្ធនិងបាប៊ីឡូន (មើល៣២:៣១ ៣៣:១១ និងការពន្យល់) ។

**៣៥:២២** *បានក្លែងព្រះអង្គ* ប្រៀបធៀប អ័ហាប់ យ៉ូសាផាត (មើល ១៨:១៩

ភ្នំមេគីដោ [២៣]ពួកពលធ្នូ[ប]ក៏បាញ់ត្រូវស្តេចយ៉ូសៀស រួច
ស្តេចបង្គាប់ដល់ពួកទ័ពទ្រង់ថា ចូរនាំយកអញចេញទៅ
ដ្បិតអញត្រូវរបួសជាទំងន់ណាស់ [២៤]ដូច្នេះ ពួកទ័ពទ្រង់ក៏
លើកយកទ្រង់ចេញពីព្រះ រាជរថទៅដាក់លើព្រះរាជរថ
១ទៀត នាំទៅឯក្រុងយេរូសាឡិមទ្រង់ក៏សុគតទៅ គេបញ្ចុះ
សពទ្រង់នៅក្នុងផ្នូររបស់ពួកឰយុកោទ្រង់ ឯពួកយូដា និង
ពួកក្រុងយេរូសាឡិមទាំងអស់គ្នាក៏កាន់ទុក្ខនឹងយ៉ូសៀស
[២៥]ឯយេរេមា លោកលើកបទទំនួញទួញពីយ៉ូសៀស ហើយ
ពួកចំរៀងប្រុសស្រីក៏ច្រៀងបទទំនួញពីយ៉ូសៀស[ផ] ដរាប
ដល់សព្វថ្ងៃនេះ ក៏តាំងការនោះទុកជាទំលាប់ក្នុងពួក
អ៊ីស្រាអែលតទៅ មើលបទទាំងនោះ បានកត់ទុកក្នុងគម្ពីរ
បរិទេវ[ព]ហើយ [២៦]រីឯដំណើរឯទៀត ពីយ៉ូសៀស ដែល
ទ្រង់ប្រព្រឹត្តសេចក្តីល្អ ឱ្យត្រូវនឹងសេចក្តីដែលកត់ទុកក្នុង
ក្រិត្យវិន័យព្រះយេហូវ៉ា [២៧]នឹងពីកិច្ចការទ្រង់ទាំងមុនទាំង
ក្រោយ នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅពីពួកស្តេច
អ៊ីស្រាអែលនឹងយូដាហើយ ។

**៣៦** [១]រួចពួកអ្នកស្រុក[ក]ក៏លើកយ៉ូអាហាស ជាព្រះរាជ
បុត្រាយ៉ូសៀស តាំងឡើងជាស្តេចជំនួសព្រះបិតា នៅក្រុង
យេរូសាឡិម ។

## យ៉ូអាហាសឡើងជាស្តេចស្រុកយូដា

*៣៦:២-៤ – ២ពវ ២៣:៣១-៣៤*

[២]កាលយ៉ូអាហាសចាប់តាំងសោយរាជ្យឡើង នោះ
ទ្រង់មានព្រះជន្ម២៣ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុង
យេរូសាឡិមបាន៣ខែ [៣]រួចនេកោជាស្តេចអេស៊ីព្ទក៏ទំលាក់

**៣៤:២៣** ប ១ពវ ២២:៣៤
**៣៤:២៥** ផ លប ៥០:១០ យរ ២២:១០ ១៥-១៦ ព ២របា ៣៤:២៨
**៣៦:១** ក ២របា ២២:១
**៣៦:៤** ខ យរ ២២:១០-១២ គ អគ ១៩:៤
**៣៦:៥** ឃ យរ ២២:១៨ ២៥:១ ២៦:១ ៣៥:១ ៣៦:១ ៤៥:១ ៤៦:២
**៣៦:៦** ង យរ ២៥:៩ ២៧:៦ អគ ២៩:១៨ ច អគ ១៩:៩ ដយ ១:១
**៣៦:៧** ឆ ខ.១៨ អរ ១:៧ យរ ២៧:១៦ ដយ ១:២
**៣៦:៩** ជ យរ ២២:២៤-២៨ ២៤:១ ២៧:២០ ២៩:២១ ៥២:៣១

ទ្រង់ចុះពីរាជ្យ នៅក្រុងយេរូសាឡិម ហើយពិន័យលក់ស្រុក
នោះ ឱ្យបង់ប្រាក់១០០ហាប និងមាស១ហាប [៤]ហើយស្តេច
អេស៊ីព្ទទ្រង់លើកអេលាគីមជាជេដ្ឋាយ៉ូអាហាសឡើង ជា
ស្តេចលើពួកយូដា និងពួកក្រុងយេរូសាឡិម ក៏ផ្លាស់ព្រះ
នាមទ្រង់ទៅជាយេហូយ៉ាគីមវិញ រួចនេកោ[ខ]ទ្រង់នាំយក
យ៉ូអាហាស ជាកនិដ្ឋា ទៅឯស្រុកអេស៊ីព្ទទៅ[គ] ។

## យេហូយ៉ាគីមឡើងជាស្តេចស្រុកយូដា

*៣៦:៥-៨ – ២ពវ ២៣:៣៦-២៤:៦*

[៥]លុះកាលយេហូយ៉ាគីម[ឃ] ចាប់តាំងសោយរាជ្យនៅក្រុង
យេរូសាឡិមបាន១១ឆ្នាំ ទ្រង់បានប្រព្រឹត្តអំពើដ៏លាមក
អាក្រក់ នៅព្រះនេត្រព្រះយេហូវ៉ា ជាព្រះនៃទ្រង់ [៦]ហើយ
នេប៊ូក្នេសា[ង] ជាស្តេចបាប៊ីឡូនបាន ឡើងមកទាស់នឹង
ទ្រង់ចាប់ដាក់ច្រវាក់នាំទៅស្រុកបាប៊ីឡូន[ច] [៧]នេប៊ូក្នេសាក៏
យកគ្រឿងប្រដាប់ខ្លះនៃព្រះវិហារព្រះយេហូវ៉ា ទៅឯក្រុង
បាប៊ីឡូនដាក់ក្នុងព្រះរាជដំណាក់របស់ទ្រង់[ឆ] [៨]រីឯដំណើរ
ឯទៀតពីយេហូយ៉ាគីម និងការគួរស្អប់ខ្ពើមទាំងប៉ុន្មាន
ដែលទ្រង់បានប្រព្រឹត្ត ហើយទោសទាំងប៉ុន្មាន ដែលឃើញ
មាន នោះសុទ្ធតែបានកត់ទុកក្នុងសៀវភៅ ពីពួកស្តេច
អ៊ីស្រាអែល និងយូដាហើយ រួចយ៉ូយ៉ាគីន ជាព្រះរាជបុត្រា
ក៏ឡើងសោយរាជ្យជំនួសព្រះបិតា ។

## យ៉ូយ៉ាគីនឡើងជាស្តេចស្រុកយូដា

*៣៦:៩-១០ – ២ពវ ២៤:៨-១៧*

[៩]កាលយ៉ូយ៉ាគីន[ជ]ចាប់តាំងសោយរាជ្យឡើង នោះទ្រង់
មានព្រះជន្ម១៨ឆ្នាំហើយ ក៏សោយរាជ្យនៅក្រុងយេរូសា

និងការពន្យល់) *ត្រង់ច្រកភ្នំមេគីដោ* មើលការពន្យល់ ពច ៥:១៩ ។

**៣៥:២៥** *យេរេមាលោកលើកបទទំនួញពីយ៉ូសៀស* យេរេមាបានជួបស្តេចយ៉ូសៀស ដោយគោរពខ្ពស់បំផុត(យរ ២២:១៥-១៦) ការពណ៌នាតាមរយៈលើកបទទំនុក គឺជាហេតុផលក្នុងគម្ពីរ បរិទេវដែលមានទំនាក់ទំនងនិងអង្គទ្រង់ផ្ទាល់រហូតមកដល់ពេលនេះ *ដរាបដល់សព្វថ្ងៃនេះ* សូមមើលការពន្យល់ ៥:៩ ។

**៣៦:២-១៤** យ៉ូសៀសគឺជាស្តេចមួយ របស់សាសន៍យូដាដែលបានស្នងមរដកដោយព្រះរាជបុត្រាបីអង្គ(ជេដ្ឋាយ៉ូអាហាស យ៉ូយ៉ាគីន និងស្តេចសេដេគា)របាយការណ៍ពីអ្នកកាលប្រវត្តិ អំពីការគ្រងរាជ្យពីស្តេចដែលនៅសល់ក្នុងស្រុកយូដាគឺជាការសង្ខេបត្រួសៗ ។

**៣៦:២** មើលការពន្យល់ ២ពវ ២៣:៣១-៣៥ គឺការសុគតរបស់យ៉ូសៀសគឺដោយសារថ្វីដៃរបស់ផារ៉ោននេកោ ហើយសាសន៍យូដាក៏ធ្លាប់ទៅក្នុងការត្រួតត្រារបស់សាសន៍អេស៊ីព្ទ (ខ.៣-៤)។ *បាន៣ខែ* ក្នុង៦០៩ មុន គ.ស ។ ភាពអះអាងរបស់នេកោពីអំណាច ទៅលើសាសន៍យូដារយៈពេល២០ឆ្នាំ ហើយបានឯករាជមកវិញ គឺរួចពីការគ្រប់គ្រង (២ពវ ២៣:៣២) ។

**៣៦:៤** គឺខណៈពេលដែលនេកោបាននាំយកយ៉ូអាហាសទៅជាពួក ឈ្លើយនិងជំនួសលោក អេលាគិមវិញដែលបានដូឈ្មោះទៅជា យេហូយ៉ាគីមវិញក៏ដូចជាស្តេច នេប៊ូក្នេសាតែក្រោយមកក៏បានយកស្តេចយ៉ូយ៉ាគីន ទៅឯស្រុកបាប៊ីឡូន ក៏ឱ្យម៉ាថានាជំនួសវិញ ហើយម៉ាថានាក៏ដូរទៅជាឈ្មោះ សេដេគាវិញ(២ពវ ២៤:១៥-១៧) ។ អ្នកគ្រប់គ្រងម្នាក់ៗតែងតែចងប្តូរដាក់ឈ្មោះពួកគេវិញតាមដែលគេចង់បាន ។

**៣៦:៥-៨** មើល ២ពវ ២៣:៣៦-២៤:៧។ យ៉ូយ៉ាគីនបានបៀតបៀនដល់ពួកហោរានិងហើយគឺជារឿងរ៉ាវមួយដែលលោក យេរេមាបានប្រឆាំងដាច់ខាត(យរ ២៥-២៦,៣៦)។ គឺបន្ទាប់ពី សាសន៍ស្រុកអេស៊ីព្ទទទួលបរាជ័យនៅឯស្រុកកើកេមីស(យរ ៤៦:២)ក្នុងឆ្នាំ ៦០៥ មុន គ.ស ។ តែស្តេចយ៉ូយ៉ាគីនបានផ្លាសប្តូរ បក្សសម្ព័ន្ធទៅនេប៊ូក្នេសា ក្នុងស្រុកបាប៊ីឡូន ។ តែនៅពេលក្រោយ ទៀតទ្រង់ក៏ធ្វើការបះបោរទាស់ប្រឆាំង និងសម្ព័ន្ធភាពទ្រង់ផ្ទាល់ជាមួយនិងសាសន៍អេស៊ីព្ទ នេប៊ូក្នេសាបានបញ្ជូនទាហានដើម្បីដាក់ទោសនិងគាត់ ។ យ៉ូយ៉ាគីនបានសុគតមុនពេលកងទ័ពនោះមកដល់និងនេប៊ូក្នេសាក៏យកព្រះរាជបុត្រា របស់ទ្រង់គឺស្តេច យ៉ូយ៉ាគីនទៅក្នុងពួកឈ្លើយ ។

**៣៦:៥** *បាន១១ឆ្នាំ* ៦០៩-៥៩៨ មុន គ.ស ។

ឡិមបាន៣ខែ១០ថ្ងៃ ទ្រង់បានប្រព្រឹត្តអំពើដ៏លាមកអាក្រក់
នៅព្រះនេត្រព្រះយេហូវ៉ា ១០ដល់ចូលឆ្នាំថ្មី នោះស្តេច
នេប៊ូក្នេសា ចាត់គេឱ្យទៅនាំទ្រង់មកឯក្រុងបាប៊ីឡូន[ឈ]
ហើយក៏យកគ្រឿងប្រដាប់យ៉ាងល្អទាំងប៉ុន្មាន នៃព្រះវិហារ
ព្រះយេហូវ៉ាមកផង រួចលើកសេដេគា ជាបិតុលាទ្រង់ឡើង
ជាស្តេចលើពួកយូដា និងពួកក្រុងយេរូសាឡិមវិញ ។

## សេដេគាឡើងជាស្តេចស្រុកយូដា

*៣៦:១១-១៦ – ២ពវ ២៤:១៨-២០ យរ ៥២:១-៣*

១១កាលសេដេគា[ញ]ចាប់តាំងសោយរាជ្យឡើង នោះទ្រង់
មានព្រះជន្ម២១ឆ្នាំ ហើយក៏សោយរាជ្យនៅក្រុងយេរូសា-
ឡិមបាន១១ឆ្នាំ ១២ទ្រង់បានប្រព្រឹត្តអំពើដ៏លាមកអាក្រក់
នៅព្រះនេត្រព្រះយេហូវ៉ា[ដ] ជាព្រះនៃទ្រង់ ឥតបន្ទាបព្រះ
ទ័យ[ឋ]នៅមុខហោរាយេរេមា ដែលលោកពោលសេចក្តី
ដែលមកពីព្រះឱស្ឋព្រះយេហូវ៉ាឡើយ ១៣ទ្រង់ក៏បះបោរ
ចំពោះស្តេចនេប៊ូក្នេសា ដែលស្តេចនោះបានចាប់ឱ្យទ្រង់
ស្បថ[ឌ]ដោយនូវព្រះ តែសេដេគាបានធ្វើករឹង[ឍ] ហើយតាំង
ព្រះទ័យរឹងបឹង មិនព្រមបែរមកឯព្រះយេហូវ៉ា ជាព្រះ
នៃសាសន៍អ៊ីស្រាអែលទេ ១៤មួយទៀតអស់ទាំងមេនៃពួក
សង្ឃ នឹងពួកបណ្តាជន ក៏ប្រព្រឹត្តរំលងយ៉ាងខ្លាំង[ណ]តាមអស់
ទាំងអំពើគួរស្អប់ខ្ពើមរបស់ពួកសាសន៍ដទៃ គេធ្វើបង្អាប់
ដល់ព្រះវិហារនៃព្រះយេហូវ៉ា ដែលទ្រង់បានញែកជា
បរិសុទ្ធ នៅក្រុងយេរូសាឡិម ។

## ការដួលរលំនៃក្រុងយេរូសាឡិម

*៣៦:១៧-២០ – ២ពវ ២៥:១-២១ យរ ៥២:៤-២៧*

*៣៦:២២-២៣ – អរ ១:១-៣*

១៥ព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេ ទ្រង់បានចាត់
ទូត[ត] ទ្រង់ឱ្យទៅឯគេ[ថ] ទាំងក្រោកពីព្រលឹមចាត់គេផង ដ្បិត
ទ្រង់មានព្រះហឫទ័យអាណិតមេត្តាដល់រាស្ត្រទ្រង់ ហើយ
ដល់ទីលំនៅទ្រង់ ១៦តែគេចំអកឱ្យពួកទូតនៃព្រះ ក៏មើល
ងាយដល់ព្រះបន្ទូលទ្រង់ ព្រមទាំងឡកឡឺយ[ទ]ឱ្យពួកហោរា
ទ្រង់វិញ ដរាបដល់សេចក្តីក្រោធ[ធ]របស់ព្រះយេហូវ៉ា បាន
ឆួលឡើងទាស់នឹងគេទាល់តែរកកែខៃមិនបានឡើយ[ន] ។
១៧ហេតុនោះ ព្រះទ្រង់នាំស្តេចពួកខាល់ដេមកលើគេ[ប]
ស្តេចនោះ បានសំឡាប់ពួកកំឡោះៗរបស់គេដោយដាវ
នៅក្នុងព្រះវិហារ ជាទីបរិសុទ្ធរបស់គេ ឥតមានមេត្តា
ករុណាដល់ទោះទាំងកំឡោះ[ផ] ក្រមុំ ចាស់ទុំ ឬសក់ស្កូវណា
ឡើយ[ព] ទ្រង់បានប្រគល់គេទាំងអស់ ទៅក្នុងកណ្តាប់ព្រះ
ហស្តនៃស្តេចនោះ[ភ] ១៨ឯអស់ទាំងគ្រឿងប្រដាប់[ម]របស់ព្រះ
វិហារនៃព្រះទាំងធំទាំងតូច នឹងរបស់ថ្លៃវិសេសទាំងប៉ុន្មាន
ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ព្រមទាំងព្រះរាជ្យទ្រព្យនៃ
ស្តេច និងទ្រព្យរបស់ពួកអ្នកជាប្រធានរបស់ទ្រង់ នោះក៏នាំ
យកទៅឯក្រុងបាប៊ីឡូនទាំងអស់ ១៩គេដុត[យ]ព្រះវិហារ[រ]នៃ
ព្រះបង់ហើយរំលំកំផែង[ល]ក្រុងយេរូសាឡិម ក៏ដុតអស់ទាំង
ព្រះរាជដំណាក់ ហើយបំផ្លាញ[វ]គ្រឿងប្រដាប់មានដំឡៃនៅ
ក្នុងដំណាក់ទាំងនោះដែរ[ស] ២០ឯអស់អ្នកដែលបានរួចពីដាវ
នោះទ្រង់ដឹកនាំ[ហ] ទៅឯស្រុកបាប៊ីឡូន ហើយគេក៏ធ្វើជាអ្នក
បំរើ[ឡ]របស់ទ្រង់ និងវង្សានុវង្សរបស់ទ្រង់តទៅ ដរាប

**៣៦:១០** ឈ ខ.១៨ ២ពវ ២០:១៧ អរ ១:៧ អស ៥២:១១ យរ ១៤:១៨ ២១:៧ ២២:២៥ ២៤:១ ២៧:១៦,២០,២២ ២៩:១ ៣៤:២១ ៤០:១ អគ ១៧:១២ ដយ ៥:២ **៣៦:១១** ញ ២ពវ ២៤:១៧ យរ ២៧:១ ២៨:១ ៣៤:២ ៣៧:១ ៣៩:១ **៣៦:១២** ដ យរ ៣៧:១-៣៩:១៨ ឋ ចទ ៨:៣ ២រប ៧:១៤ យរ ៤៤:១០ **៣៦:១៣** ឌ អគ ១៧:១៣ ឍ នក ៣២:៩ ចទ ៩:២៧ **៣៦:១៤** ណ ១រប ៥:២៥ **៣៦:១៥** ត អស ៥:៤ ៤៤:២៦ យរ ៧:២៥ ហក ១:១៣ សក ១:៤ មឡ ២:៧ ៣:១ មថ ៥:១២ ថ យរ ៧:១៣,២៥ ១១:៧ ២៥:៣-៤ ៣៥:១៤, ១៥ ៤៤:៤-៦ **៣៦:១៦** ទ ២ពវ ២:២៣ យប ៨:២ អស ២៨:១៤,២២ ២៩:២០ ៥៧:៤ យរ ៥:១៣ ៤៣:២ មីក ២:១១ ធ អរ ៥:១២ សភ ១:៣០-៣១ យរ ៤៤:៣ ន នហ ៩:៣០ សភ ២៩:១ យរ ៧:២៦ ២០:៨ ២៥:៤ ៣០:១២ ដយ ៩:៦ សក ១:២ **៣៦:១៧** ប លប ១០:១០ ផ យរ ៦:១១ ៩:២១ ១៨:២១ ៤៤:៧ ព ចទ ៣២:២៥ យរ ៥១:២២ ភ អរ ៥:១២ យរ ៣២:២៨ បទ ២:២១ អគ ៩:៦ ២៣:៤៧ **៣៦:១៨** ម ខ.៧ ខ.១០ យរ ២៧:២០ **៣៦:១៩** យ យរ ១១:១៦ ១៧:២៧ ២១:១០,១៤ ២២:៧ ៣២:២៩ ៣៩:៨ បទ ៤:១១ អគ ២០:៤៧ អម ២:៥ សក ១១:១ រ ១ពវ ៩:៨-៩ ល ២ពវ ១៤:១៣ វ បទ ២:៦ ស ទដ ៧៩:១-៣ **៣៦:២០** ហ លប ២៦:៤៤ ២ពវ ២៤:១៤ អរ ២:១ នហ ៧:៦ ឡ យរ ២៧:៧

**៣៦:៩-១០** មើល ២ពវ ២៤:៣-១៧ ក៏មើល យរ២២:២៤-២៨ ២៤:១ ២៩:២ ៥២:៣១ ទោះជាយ៉ូយ៉ាគីនក៏បាននាំយកទៅជាឈ្លើយក៏ដោយ គឺក្នុង ៥៩៧ មុន គ.ស ដែលមានការហែរហមក ដ៏ធំធេងដែលមានទាំងមាតាព្រះមហាក្សត្រាយានី នៅក្នុងភាពឧត្តម និងបានទទួលស្នងមរដកដោយស្តេចសេដេគាការជម្លៀសចេញ គឺក្នុងគ្រាដែលទ្រង់កាន់កាប់ (យរ ៥២:៣១ អគ ១:២ ប្រៀបធៀប នអ ២:៥-៦) ។

**៣៦:៩** *បាន៣ខែ១០ថ្ងៃ* ៥៩៨-៥៩៧ មុន គ.ស ។

**៣៦:១១-១៤** មើល ២ពវ ២៤:១៨-២០ យរ ៥២:១-៣ ក្នុង ខ.១៣-១៤ គឺស៊ីគ្នាទៅនិងកាលប្រវត្តិ(ប្រៀបធៀប ១:៣ ២១:១-៧ ២៤:៨ ២៧:១-១៥ ៣២:១-៥ ៣៤:១-៧ ៣៧:១-៣៩:៧) ។ ស្តេចសេដេគាបង្អោនអង្គទ្រង់ទៅតាមសេចក្តីល្បួងហើយនិងរក ប្រទេសអេស៊ីព្ទក្នុងការជួយទាស់ប្រឆាំងនេប៊ូក្នេសា ។ អ្នកស្រុកបាប៊ីឡូនក៏មានឡើងរហ័សឯក្រុងយេរូសាឡិមត្រូវបានគេឡោមព័ទ្ធ(យរ ២១:៣-៧)ក្នុងឆ្នាំ ៥៨៨ មុន គ.ស ហើយនៅមានស្មេរភាព តែរយៈពេលពីរឆ្នាំមុនពេល ត្រូវបានបំផ្លាញក្នុងរដូវប្រាំងនៃឆ្នាំ ៥៨៦ ។

**៣៦:១១** *១១ឆ្នាំ* ៥៩៧-៥៨៦ មុន គ.ស ។

**៣៦:១៥-១៦** មើល ២៤:១៩ និងការពន្យល់ ។

**៣៦:២០-២១** សេចក្តីបញ្ចប់ដែលជាប្រវត្តិសាស្ត្រគឺមានភាពផ្សេង គ្នាដែលគួឱ្យចាប់អារម្មណ៍ពីរផ្នែក(១)អ្នកនិពន្ធក្នុងពង្សវតារក្សត្រ បានបង្ហាញមូលហេតុនៃការជម្លៀសបានកើតឡើង និងឯកសារប្រវត្តិសាស្ត្រដ៏ជូចត់នៃសាសន៍អ៊ីស្រាអែល ដោយព្រោះភាពពុំស្តាប់បង្គាប់របស់រាស្ត្រអ៊ីស្រាអែលរហូតដល់និរទេសចោលស្រុក ក៏បញ្ជាក់ពីភាពបញ្ចប់ ។ អ្នកនិពន្ធក៏បានបង្ហាញពីភាពសុចរិត របស់ព្រះចំពោះព្រះបន្ទូលសន្យា ចំពោះស្តេចដាវីឌ (២ពវ ២៥:២៧-២០)ដោយជូនដារបាយការណ៍អំពីវិភាគទានកដ៏សុចរិតទៅឯពូជអំបូររបស់ផងទ្រង់ ។ (២) អ្នកកាលប្រវត្តិមិនគ្រាន់តែបង្ហាញពីភាពនិរទេសចេញពីស្រុក តែក៏បង្ហាញពីភាពមានសង្ឃឹមសម្រាប់នាថ្ងៃអនាគត

ដល់នគរពើស៊ីបានគ្រប់គ្រងរាជ្យឡើង
២១ ដើម្បីឱ្យបាន
សំរេចតាមព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដោយសារ
មាត់ហោរាយេរេមា ទាល់តែស្រុកនោះបានគំរប់ពេល
ដែលត្រូវឈប់សំរាក [អ,ក]ឱ្យបានគ្រប់៧០ឆ្នាំ[ខ] ដ្បិតក្នុងរវាង
ដែលចោលទទេ នោះស្រុកបានឈប់សំរាកទៅ ។
២២ រីឯនៅឆ្នាំដំបូងក្នុងរាជ្យស៊ីរូស[គ] ជាស្តេចស្រុកពើស៊ី
នោះព្រះយេហូវ៉ាទ្រង់បានបណ្តាព្រះទ័យទ្រង់ឡើង ដើម្បីឱ្យ
ស្តេចបានធ្វើសំរេចតាមព្រះបន្ទូលនៃព្រះយេហូវ៉ា ដែល
មកដោយសារមាត់ហោរាយេរេមា គឺឱ្យទ្រង់បានចេញ
ប្រកាសដល់អាណាខែត្ររបស់ទ្រង់ ហើយឱ្យសេចក្តីនោះ
បានកត់ទុកផងថា
២៣ ស៊ីរូសជាស្តេចពើស៊ី ទ្រង់មានព្រះ
រាជឱង្ការដូច្នេះថា ព្រះយេហូវ៉ា ជាព្រះនៃស្ថានសួគ៌ ទ្រង់
បានប្រទានអស់ទាំងនគរនៅផែនដី មកយើងហើយ ទ្រង់
បានបង្គាប់ឱ្យ[ឃ]យើងស្អាងព្រះវិហារថ្វាយទ្រង់ នៅក្រុង
យេរូសាឡិមក្នុងស្រុកយូដា ដូច្នេះ នៅក្នុងពួកប្រជាជនទាំង
ឡាយ បើមានអ្នកណាជារបស់ផង ព្រះយេហូវ៉ានោះ សូម
ឱ្យព្រះនៃអ្នកនោះបានគង់ជាមួយ ហើយឱ្យអ្នកនោះឡើង
ទៅចុះ ។/

**៣៦:២១** អ លវ ២៥:៤ ក ១រប ២២:៩ ខ យរ ១:១ ២៥:១១ ២៧:២២ ២៩:១០ ៤០:១ ដយ ៩:២ សក ១:១៣ ៧:៥
**៣៦:២២** គ អស ៤៤:២៨ ៤៥:១, ១៣ ដយ ១:២១ ៦:២៨ ១០:១
**៣៦:២៣** ឃ ច ៤:១០

គត់ ។ សម្រាប់អង្គទ្រង់មានភាពបរិសុទ្ធ នៅតែមានជានិច្ចក៏នាំឱ្យដីមានភាពបរិសុទ្ធផងដែរ (ខ.២២–២៣) និងគឺជាយុគសម័យថ្មីនៃក្តីសង្ឃឹមដែលកំពុងចាប់ផ្តើម ភាពនិរាសខ្ចាត់ព្រាត់នោះគឺមិនមែនតែរឿងកាត់ទោសប៉ុណ្ណោះទេប៉ុន្តែក៏ជាព្រះពរផង ដែលព្រះផ្តល់សារជាថ្មីឡើងវិញក៏នាំឱ្យស្រុកទាំងមូល បានសម្រាកក្នុងថ្ងៃបុណ្យឈប់សម្រាករបស់ពួកគេ (លវ ២៦:៤០–៤៥) ។ ឯព្រះអម្ចាស់ព្រះអង្គ ក៏មានព្រះទ័យចាំជានិច្ចនូវសេចក្តីសញ្ញារបស់ផងទ្រង់ (លវ ២៦:៤៥) នឹងឱ្យរាស្ត្ររបស់ទ្រង់មានទឹកដីជាស្រុកដែលអាចរស់នៅឡើងវិញ (ខ.២២–២៣) ។

**៣៦:២២–២៣** អត្ថន័យក្នុងខនេះក៏ពុំដែលបានឃើញនៅក្នុងគម្ពីរពង្សាវតារក្សត្រដែរ វាបង្ហាញឡើងវិញនៅសេចក្តីក្នុងគម្ពីរ អែសរ៉ា (១:១–៣) ក៏ជាការសរុបនូវប្រវត្តិសាស្ត្រដែលជាចំណុចដែល កាលប្រវត្តិបញ្ជាក់ក៏បង្ហាញថាអ្នកនិពន្ធគម្ពីរអែសរ៉ា គឺជាអ្នកនិពន្ធតែមួយ ។មើលត្រង់ហោរាយេរេមា (យរ ២៥:១–១៤ ប្រៀបធៀប ដយ ៩) ។ កោះគីប្រុសក៏បានយល់ថាវា ជាកោះសម្រាប់មនុស្សដែលជាឈ្លើយ ដែលបានឱ្យពួកគេចូលមកឯស្រុកគេវិញក្រោមការគ្រប់គ្រងពីព្រះដែលជាមហាក្សត្រ កិច្ចការប្រឹងប្រែងនេះគឺតាមរយៈស្តេចពើស៊ីជាស្តេចទទួលបានប្រជាប្រិយភាព ពីប្រជាជន ។ មើលការពន្យល់ អស ១:១–៤ ។

**៣៦:២២** *រាជ្យស៊ីរូសជាស្តេចស្រុកពើស៊ី* ។

**៣៦:២៣** *ជាព្រះនៃស្ថានសួគ៌* មើលការពន្យល់ អរ ១:២ ។

# ព្រះគម្ពីរអែសរ៉ា

## សេចក្ដីផ្ដើម

### អែសរ៉ា និងនេហេមា

ទោះបីជានៅក្នុងព្រះគម្ពីរនេហេមា ១:១ បាននិយាយថា "នេះជាពាក្យរបស់នេហេមា ជាកូនហាកាលា" បានបង្ហាញថា ព្រះគម្ពីរអែសរ៉ា និងគម្ពីរនេហេមា ជាព្រះគម្ពីរ២ផ្សេងៗគ្នាក៏ដោយ ប៉ុន្តែ កាលសម័យមុន គេបានយកព្រះគម្ពីរទាំង២នេះបញ្ចូលគ្នាជាគម្ពីរតែមួយ ។ លោកយ៉ូសែប "Joshepus" (គ.ស ៣៧–១០០) និងសៀវភៅក្រឹត្យវិន័យរបស់ពួកយូដា ក៏បាននិយាយអំពីព្រះគម្ពីរអែសរ៉ា ប៉ុន្តែមិនបាននិយាយថា គម្ពីរនេហេមា ជាគម្ពីរដែលគេបំបែកចេញពីគម្ពីរអែសរ៉ានោះទេ ។ ឯកសារដ៏ចំណាស់បំផុតដែលសរសេរដោយដៃរបស់សិបធូជីន (ការបកប្រែទៅជាភាសាក្រិចនៅក្នុងគម្ពីរសញ្ញាចាស់ ក្នុងសម័យកាល មុន គ.ស) ក៏បាននិយាយព្រះគម្ពីរអែសរ៉ានិងនេហេមា ជាគម្ពីរតែមួយដែរ ។

ប្រហែលជាក្នុងឆ្នាំ ១៨៥–២៥៣ នៃ គ.ស គឺជាឆ្នាំដែលអ្នកនិពន្ធដំបូងទទួលស្គាល់ថា ព្រះគម្ពីរអែសរ៉ា គឺមាន២ផ្សេងគ្នា ។ អ្នកនិពន្ធបានហៅថា ១អែសរ៉ានិង ២អែសរ៉ា ។ នៅក្នុងព្រះគម្ពីរកាត់ស្រាយដែលសរសេរជាភាសាឡាតាំង ដែលបកប្រែដោយលោកយេរ៉ូម (Jerome) (ប្រហែលក្នុងឆ្នាំ ៣៩០–៤០៥ គ.ស) បានហៅឈ្មោះគម្ពីរ២អែសរ៉ានេះថា ជាគម្ពីរនេហេមា ។ លោកហ្វាយគ្លីហ្វ៍ (Wycliffe ១៣៨២ គ.ស) និងលោក "ខូវឺដល" (Coverdal ១៥៣៥ គ.ស) ដែលជាអ្នកបកប្រែព្រះគម្ពីរនេះទៅភាសារអង់គ្លេសក៏បានដាក់ឈ្មោះព្រះនេះថា ជាគម្ពីរអែសរ៉ានិងគម្ពីរនេហេមាដែរ ។ ការបំបែកព្រះគម្ពីរនេះចេញជា២ក៏មានឃើញលើកដំបូងដែល សរសេរដោយដៃជាព្រះគម្ពីរភាសាហេព្រើរក្នុងឆ្នាំ ១៤៤៨ គ.ស ។

### លក្ខណៈអក្សរសាស្ត្រ និងអ្នកនិពន្ធ

មានភស្តុតាងផ្លូវការណ៍មួយបានបង្ហាញថា អ្វីដែលដូចគ្នាទៅនឹងគម្ពីរ ១–២ របាក្សត្រនោះ គឺ កំណត់ត្រាផ្សេងៗដែលមាននិយាយនៅក្នុងគម្ពីរអែសរ៉ា និងគម្ពីរនេហេមា ។ ព្រះគម្ពីរនេះក៏បាននិយាយអំពី (ទី១) គ្រឿងប្រដាប់ប្រដារព្រះវិហារ (សូមមើល អរ ១:៩–១១) (ទី២) និយាយពីការរួចពីសណ្ឋានជាឈ្លើយ (សូមមើល អែសរ៉ា ជំពូក ២ ដែលនិយាយដូចគ្នានិង នហ ៧:៦–៧៣) (ទី៣) ជិនួរវង្សអែសរ៉ា (អរ ៧:១–៥) (ទី៤) មេលើវង្សឪពុក (អរ ៨:១–១៤) (ទី៥) ការរៀបការជាមួយស្ត្រីសាសន៍ដទៃ (អរ ១០:១៨–៤៣) (ទី៦) ពួកអ្នកដែលបានជួយកសាងកំផែងក្រុង (សូមមើល នហ ជំពូក ៣) (ទី៧) ការបោះត្រានៃសេចក្ដីសញ្ញា (នហ ១០:១–២៧) (ទី៨) ពួកអ្នកតាំងលំនៅស្នាក់អាស្រ័យនៅក្រុងយេរូសាឡិមនិងក្រុងផ្សេងៗទៀត (នហ ១១:៣–៣៦) (ទី៩) ពួកសង្ឃ និងពួកលេវី (នហ ១២:១–២៦) ។ នៅក្នុងគម្ពីរអែសរ៉ាក៏មាននិយាយអំពីសំបុត្រផ្លូវការណ៍ទាំង៧ (សំបុត្រទាំងអស់សុទ្ធតែសរសេរជាភាសារអារ៉ាប់លើកលែងតែសំបុត្រទី១ប៉ុណ្ណោះ ដែលសរសេរជាព្រះគម្ពីរភាសារហេព្រើរ) ។ សំបុត្រនិងឯកសារទាំងនោះគឺ: (ទី១) ព្រះរាជឪង្ការរបស់ស្ដេចស៊ីរូស (១:២–៤) (ទី២) ការចោទប្រកាន់ និងទាស់ប្រឆាំងរបស់រេហ៊ូម និងអ្នកដទៃទៀតចំពោះពួកយូដា (១១–១៦) (ទី៣) ការឆ្លើយតបរបស់ស្ដេចអើថាស៊ើកសេស (៤:១៧–២២) (ទី៤) សេចក្ដីរាយការណ៍របស់ថាថ្នាយ (៥:៧–១៧) (ទី៥) ក្រាំងស្ដីពីរាជឪង្ការរបស់ស្ដេចស៊ីរូស (៦:២–៥) (ទី៦) ការឆ្លើយតបរបស់ដារីយ៉ុសចំពោះថាថ្នាយ (៦:៦–១២) (ទី៧) ស្ដេចអើថាស៊ើកសេសទី១ ប្រទានសិទ្ធិអំណាចឱ្យលោកអែសរ៉ា (៧:១២–២៦) ។ ឯកសារទាំងអស់នោះគឺមានភាពប្រហាក់ប្រហែលគ្នានឹងឯកសារក្រៅព្រះគម្ពីរពួកពើស៊ី ។

នៅពេលធ្វើការដកស្រង់កាលប្រវត្តិដែលគាត់បានសរសេរ (៧:២៧–២៨ ៨:១–៣៤ និងជំពូក ៩) គេសង្កេតឃើញថា លក្ខណៈអក្សរសាស្ត្រ ដែលប្រើក្នុងគម្ពីរអែសរ៉ានេះគឺប្រើទម្រងវេយ្យាករណ៍បុរសទី១ ហើយនៅផ្នែកខ្លះទៀតប្រើជាទម្រង់បុរសទី៣ (សូមមើលក្នុង ៧:១–២៦ ជំពូក១០ និង នហ ជំពូក ៨) ។ តាមការវិភាគភាសាវិទ្យា បានបង្ហាញថា ទម្រង់បុរសទី១ និងបុរសទី៣ វាមិនមានអ្វីដែលខុសគ្នាឡើយ ដូច្នេះ បង្ហាញ ព្រះគម្ពីរនេះគឺសរសេរឡើងដោយអ្នកនិពន្ធតែមួយ ។

ស្ទើរតែទាំងអស់នៃអ្នកប្រាជ្ញព្រះគម្ពីរ បានធ្វើការសន្និដ្ឋានថា អ្នកនិពន្ធព្រះគម្ពីរអែសរ៉ានិងនេហេមា គឺជាមនុស្សតែមួយជាមួយនឹងអ្នកនិពន្ធព្រះគម្ពីរ ១–២ របាក្សត្រដែរ ។ ទស្សនៈបែបនេះ គឺផ្អែកលើសេចក្ដីពិតសាមញ្ញមួយដែលមាននៅក្នុងគម្ពីររបាក្សត្រ អែសរ៉ា និងនេហេមា ។ ភស្តុតាងនៃសេចក្ដីពិតនោះគឺ នៅក្នុងខ.ចុងក្រោយនៃព្រះគម្ពីរ ២បាក្សត្របាននិយាយដូចគ្នានឹងខ.ចាប់ផ្ដើមក្នុងព្រះគម្ពីរអែសរ៉ា ។ ទាំងគម្ពីររបាក្សត្រ អែសរ៉ា និងនេហេមាបានពណ៌នាពីពិធីបុណ្យក្នុងសាសនារបស់ពួកគេ និងឃ្លាដែលបាននិយាថា "មេលើវង្សឪពុក"និង"តំណាក់របស់ព្រះអម្ចាស់" ។ ជាពិសេសអ្វីដែលគួរឱ្យកត់សំគាល់នៅក្នុងព្រះគម្ពីរទាំងនោះ គឺនិយាយពីពួកលេវីនិង

លក្ខណៈសម្បត្តិអ្នកបម្រើក្នុងព្រះវិហារ ។ ពាក្យ"អ្នកចម្រៀង" និង"ឆ្មាំទ្វារ" ព្រមទាំង"អ្នកបម្រើក្នុងព្រះវិហារ" គឺប្រើស្មើរតែគ្រប់ជំពូកក្នុងគម្ពីរនៅព្រះគម្ពីរអែសរ៉ានេហេមា និងរបាក្សត្រ ។ សូមមើលសេចក្តីផ្តើម ព្រះគម្ពីរ១របាក្សត្រត្រង់ចំនុចអ្នកនិពន្ធ កាលបរិច្ឆេទ និងប្រភព ។

**កាលបរិច្ឆេទ**

កាលបិរច្ឆេទនៃការសរសេរព្រះគម្ពីរអែសរ៉ា ប្រហែលជានៅក្នុងឆ្នាំ ៤៤0 មុនគ.ស (សូមមើល ៧:២៨) ហើយគម្ពីរនេហេមា ប្រហែលជានៅឆ្នាំ ៤៣0 មុន គ.ស ។ គេក៏យកព្រះគម្ពីរនេះបញ្ចូលគ្នាជាព្រះគម្ពីរតែមួយនៅពេលក្រោយទៀត (សូមមើលសេចក្តីផ្តើម ព្រះគម្ពីរ១របាក្សត្រ ត្រង់ចំនុចអ្នកនិពន្ធ កាលបរិច្ឆេទ និងប្រភព ។

**ការបង្កាប់បញ្ហារបស់អែសរ៉ានិងនេហេមា**

គេតែងតែយល់ឃើញថា លោកអែសរ៉ាបានធ្វើដំណើរត្រឡប់មកដល់ក្រុងយេរូសាឡិមវិញនៅក្នុងខែស្រាពណ៍ ក្នុងឆ្នាំទី៧នៃរាជ្យស្តេចអើថាស៊ើកសេសទី១ ដែលត្រូវនឹងឆ្នាំ ៤៥៨ មុន គ.ស (សូមមើល ៧:៨) ហើយលោកនេហេមាបានមកដល់ក្រុងយេរ៉ូសាឡិមនៅក្នុងឆ្នាំទី២០នៃរាជ្យស្តេចអើថាស៊ើកសេស (នៅក្នុងឆ្នាំ ៤៤៤ មុន គ.ស សូមមើល នហ ២:១,១១) ។

មានអ្នកខ្លះទៀតគេនិយាយថា លោកនេហេមានបានវិលត្រឡប់មកដល់ក្រុងយេរូសាឡិមវិញនៅក្នុងឆ្នាំ ៤៤៤ មុន គ.ស ហើយលោអែសរ៉ាបានវិលត្រឡប់មកដល់ក្រុងយេរ៉ូសាឡិមវិញនៅក្នុងឆ្នាំទី៧នៃរាជ្យស្តេចអើថាស៊ើកសេសទី២ ក្នុងឆ្នាំ ៣៩៨ មុន គ.ស ។ តាមរយៈបូកបន្ថែម "ឆ្នាំទី៧" (សូមមើល អរ ៧:៨) ដូច្នេះការវិលត្រឡប់របស់គាត់មកដល់ក្រុងយេរ៉ូសាឡិមគឺអាចក្នុងឆ្នាំទី២៧ ឬឆ្នាំទី៣៧ក្រោយលោកនេហេមា ប៉ុន្តែគេនៅតែមានគំនិតគិតថា អ្នកទាំង២ជាសហកាលិកនឹងគ្នា ។

ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើដំណើររបស់ពួកគេមកកាន់ក្រុងយេរូសាឡិមគឺពិតជាមានបញ្ហាជ្រៅជាងអ្វីដែលគេធ្លាប់គិតទៅទៀត ។ អ្វីដែលអត្ថបទគម្ពីរនិយាយគឺ លោកអែសរ៉ាគាត់បានធ្វើដំណើរមកដល់ក្រុងយេរូសាឡិមមុនលោកនេហេមា ហើយពួកគេបានលើកមកនិយាយជាមួយគ្នា ក្នុង នហ ៨:៩(ត្រង់ចំនុចដែលនិយាយថា អានមើលក្នុងគម្ពីរក្រឹត្យវិន័យ) និង នហ ១២:២៦,៣៦ (នៅពេលដែលគេរៀបចំបុណ្យ ឆ្លងកំផែងក្រុង) ។ សូមមើល ហន ១:១ ២:២ ។

**លក្ខណៈភាសា**

ព្រះគម្ពីរអែសរ៉ានិងព្រះគម្ពីរនេហេមាត្រូវបានគេសរសេរឡើងជាភាសាហេព្រើរសម័យក្រោយ ដោយលើកតែនៅក្នុង អរ ៤:៨–៦:៨ ៧:១២–២៦ ប៉ុណ្ណោះដែលសរសេរជាភាសាអារ៉ាមមិច ដែលជាភាសាការទូតអន្តរជាតិក្នុងសម័យកាលចក្រភពពើស៊ី ។ ព្រះគម្ពីរអែសរ៉ាទាំងមូលមាន ៦៧ខ. ដែលបានសរសេរជាភាសាអាប់រ៉ាមនោះមាន ៥២ខ បានកត់ទុកជាឯកសារ ឬក្នុងសំបុត្រ ។ លោកអែសរ៉ាគាត់បានរកឃើញឯកសារដែលសរសេរជាភាសាអាប់រ៉ាមទាំងនោះដោយយថាហេតុ ហើយគាត់ក៏ធ្វើការចម្លងឯកសារទាំងនោះហើយបានដាក់បញ្ចូលគ្នាជាភាសាអាប់រ៉ាម ។

**ផ្ទៃរឿងផ្នែកវិជ្ជាសិក្សាអំពីព្រះ**

ព្រះគម្ពីរអែសរ៉ា និងគម្ពីរនេហេមា បាននិយាយអំពីទំនាក់ទំនងរបៀបដែលរាស្ត្រនៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់បានស្តាបនាឡើងវិញ ចាប់តាំងពីពួកគេបានរួចពីសណ្ឋានជាឈ្លើយរបស់ពួកបាប៊ីឡូន រហូតដល់គ្រាដែលពួកគេបានមកដល់ទឹកដីនៃសេចក្តីសញ្ញា (នគររបស់ព្រះ) ទោះបីជាពួកគេកំពុងស្ថិតក្រោមការគ្រប់គ្រងរបស់សាសន៍ដទៃក៏ដោយ ។ ផ្ទៃរឿងចម្បងនៃវិជ្ជាសិក្សាពីព្រះអម្ចាស់គឺ:

១. កិច្ចការរបស់ព្រះអម្ចាស់ គឺស្តាបនារាស្ត្រអ៊ីស្រាអែលឡើងវិញ បន្ទាប់ពីគ្រាដែលពួកគេបានរួចពីសណ្ឋានជាឈ្លើយរបស់ពួកបាប៊ីឡូន ។ ព្រះអម្ចាស់ទ្រង់បានបំផ្លាស់បំប្រែទឹកចិត្តរបស់ពួកពើស៊ី ហើយព្រះអង្គទ្រង់ក៏បានបំផ្លាស់បំប្រែទឹកចិត្តពួកអ្នកដែលបានធ្វើមាតុភូមិនិវត្តនិងពួកអ្នកដែលបានចូលរួមគាំទ្រចំពោះពួកគេ ។ ព្រះអម្ចាស់ទ្រង់បានលើកពួកហោរាឡើងជាធំ ហើយបានគាំទ្រចំពោះអ្នកដែលធ្វើមាតុភូមិនិវត្ត នៅតាមផ្លូវព្រះអម្ចាស់ទ្រង់បានការពារពួកគេ ព្រមទាំងរំដោះគេឱ្យរួចពីពួកខ្មាំងសត្រូវ និងអ្នកដែលជំទាស់ប្រឆាំង ។ ព្រះអម្ចាស់ទ្រង់បានលើកអែសរ៉ា និងនេហេមាឡើងឱ្យពួកគេមានការងារធ្វើផ្សេងៗគ្នា មិនតែប៉ុណ្ណោះសោតព្រះអម្ចាស់ទ្រង់បានចម្រើន និងប្រទានមពរដល់ការសាងសង់ព្រះវិហារ និងក្រុងយេរ៉ូសាឡិមឡើងវិញ ។

២. ទឹកដីនៃសេចក្តីសញ្ញាត្រូវបានស្តាបនាឡើងរួចរាល់ហើយ ទោះបីជាមិនទាន់បានសម្រេចគោលនយោបាយឯករាជ្យ មិនអាស្រ័យលើអ្នកដទៃក៏ដោយ ក៏សំណល់នៃ"ពួកសាសន៍អ៊ីស្រាអែលទាំងអស់"ត្រូវបានធ្វើមាតុភូមិនិវត្តមកកាន់ទឹកដីរបស់ខ្លួនដោយជោគជ័យ ។ ព្រះវិហារនៃព្រះអម្ចាស់ ត្រូវបានកសាងឡើងវិញ និងកិច្ចការបម្រើ (យញ្ញបូជាការងារពួកសង្ឃ ការតែងតាំងពួកលេវីបុណ្យ

ប្រចាំឆ្នាំ) ត្រូវបានកែប្រែឡើងវិញ ដោយយោងទៅតាមច្បាប់របស់លោកម៉ូសេ និងច្បាប់ដែលស្ដេចដាវីឌបានចែង ។ ច្បាប់ ឬក្រឹត្យវិន័យទាំងនោះត្រូវបានធ្វើការកែទម្រង់ឡើងវិញ ទុកច្បាប់សម្រាប់ការរស់នៅរបស់ពួកសហគមន៍របស់ពួកគេ ។ យេរូសាឡិមដែលជា"ទីក្រុងបរិសុទ្ធ"ត្រូវបានកសាងរួចរាល់ ព្រមទាំងមានអ្នកមកស្នាក់អាស្រ័យនៅទៀតផង ហើយពួកបណ្ដាជនត្រូវបានសំអាតខ្លួនជាបរិសុទ្ធនូវចំពោះព្រះ មិនតែប៉ុណ្ណោះក្រឹត្យវិន័យក៏បានកែប្រែជាថ្មី ។

៣. ព្រះអម្ចាស់ទ្រង់បានប្រើអំណាចលោកិយដើម្បីដាក់ទណ្ឌកម្មដល់រាស្ត្ររបស់ទ្រង់ ដូច្នេះព្រះអម្ចាស់ទ្រង់ក៏នាំអ្នកទាំងនោះឱ្យមកស្ថាបនារាស្ត្ររបស់ទ្រង់ឡើងវិញដែរ ។ សកម្មភាព និងសិទ្ធិអំណាចដែលស្ដេចប្រទានឱ្យដោយចំ និងមិនចំក្ដីក៏បានបង្ហាញពីការការពារនិងគាំទ្រក្នុងការស្ថាបនាប្រទេសជាតិគេឡើងវិញ ។

៤. ការស្ថាបនាឡើងវិញរបស់ពួកអ៊ីស្រាអែល បានរំឭកពីភាពកាចសាហាវរបស់ពួកអ្នកដែលប្រឆាំងចំពោះការសាងសង់ព្រះវិហារនៃព្រះពីសំណាក់ខ្មាំងសត្រូវ ប៉ុន្តែកិច្ចការរបស់ពួកអ្នកទាំងនោះមិនបានសម្រេចឡើយ ។

៥. ការស្ថាបនាប្រទេសជាតិឡើងវិញ គឺជាការដាក់ទោសចំពោះបណ្ដាជន ប៉ុន្តែពួកគេក៏ត្រូវការ ការស្ដីបន្ទោស និងការកែរទម្រង់ដែ ។ ពួកអ៊ីស្រាអែលគឺជាប្រជាជនដែលមានឆន្ទះមុតមាំ ដោយព្រោះពួកគេបន្តរងចាំ "សេចក្ដីសញ្ញាថ្មី"ដែលហោរាយេរេមាបានទាយ (សូមមើល យរ ៣១) និងបំផ្លាស់បំប្រែឱ្យក្លាយជាថ្មីដោយវិញ្ញាណរបស់ព្រះដែលយ៉ូអែល (ជំពូក១) និងអេសេគាបាននិយាយ (អគ ជំពូក ៣៦) ។

**គម្រោងសង្ខេប**

**I. ការវិលត្រឡប់ពីនិរទេសលើកទី១ និងការស្ថាបនាព្រះវិហារឡើងវិញ (ជំពូក ១–៦)**

១. ការវិលត្រឡប់ពីនិរទេសលើកទី១ (ជំពូក១)

ក. បញ្ញត្តិរបស់ស្ដេចស៊ីរូស (១:១–៤)

ខ. ការវិលត្រឡប់ពីនិរទេសក្រោមការដឹកនាំរបស់សេសបាសារ (១:៥–១១)

២. ឈ្មោះពួកអ្នកដែលវិលត្រឡប់ពីនិរទេសវិញ (ជំពូក២)

៣. ការកែទម្រង់ព្រះវិហារឡើងវិញ (ជំពូក៣)

ក. ការស្អាងអាសនាឡើងវិញ (៣:១–៣)

ខ. ពិធីបុណ្យបារាំ (៣:៤–៦)

គ. ការចាប់ផ្ដើមសាងសង់ព្រះវិហារឡើងវិញ (៣:៧–១៣)

៤. ការបង្អាក់ខាន ការសាងសង់ព្រះវិហារ (៤:១–២៣)

ក. ការបង្អាក់ខាន ក្នុងយុគសម័យកាលស្ដេចស៊ីរូស (៤:១–៥)

ខ. ការបង្អាក់ខាន ក្នុងយុគសម័យកាលស្ដេច អ័ហាស៊ូត្រូស (៤:៦)

គ. ការបង្អាក់ខាន ក្នុងយុគសម័យកាលស្ដេចអ័ថាសើកសេស (៤:៧–២៣)

៥. ព្រះវិហារត្រូវបានកសាងរួចរាល់ (៤:២៤–៦:២២)

ក. បន្តការសាងសង់ព្រះវិហារក្នុងរាជ្យស្ដេចដារីយុស (៤:២៤)

ខ. ហោរាហាកាយ និងហោរាសាការីចាប់ផ្ដើមពីដំណើរស្រុកយូដា (៥:១–២)

គ. សេចក្ដីប្រកាសរបស់ ថាថ្នាយជាចៅហ្វាយខេត្ត (៥:៣–៥)

ឃ. សេចក្ដីរាយការណ៍ជូនចំពោះស្ដេចដារីយុស (៥:៦–១៧)

ង. ការស្រាវជ្រាវលើព្រះរាជឱង្ការរបស់ស្ដេចស៊ីរូស (៦:១–៥)

ច. ស្ដេចដារីយុសចេញបង្គាប់ឱ្យកសាងព្រះវិហារនៃព្រះអម្ចាស់ (៦:៦–១២)

ឆ. ព្រះវិហារបានកសាងចប់សព្វគ្រប់ (៦:១៣–១៥)

ជ. ការរៀបចំបុណ្យឆ្លងព្រះវិហារ (៦:១៦–១៨)

ឈ. បុណ្យរំលង (៦:១៩–២២)

**II. ដំណើរមាតុភូមិនិវត្តរបស់លោកអែសរ៉ា និងការកែទម្រង់ (ជំពូក ៧–១០)**

១. មាតុភូមិនិវត្តរបស់លោកអែសរ៉ាមកកាន់ក្រុងយេរូសាឡិម (ជំពូក ៧–៨)
   ក. ការណែនាំ (៧:១–១០)
   ខ. ស្តេចអើថាស៊ើកសេសប្រទានអំណាចដល់លោកអែសរ៉ា (៧:១១–២៦)
   គ. ការសរសើរតម្កើងរបស់លោកអែសរ៉ា (៧:២៧–២៨)
   ឃ. បញ្ជីឈ្មោះពួកអ្នកដែលវិលត្រឡប់មកជាមួយលោកអែសរ៉ា (៨:១–១៤)
   ង. ការស្វែងរកពួកកូនចៅលេវី (៨:១៥–២០)
   ច. សេចក្តីអធិស្ឋាន និងការតមអត់ (៨:២១–២៣)
   ឆ. គ្រឿងប្រដាប់ព្រះវិហារ (៨:២៤–៣០)
   ជ. ការធ្វើដំណើរ និងការវិលមកដល់ក្រុងយេរូសាឡិម (៨:៣១–៣៦)
២. ការកែទម្រង់របស់លោកអែសរ៉ា (ជំពូក ៩–១០)
   ក. ការរៀបការជាមួយស្ត្រីសាសន៍ដទៃ ដែលជាការប្រមាថដល់ខ្លួន (៩:១–៥)
   ខ. ការលន់តួរបស់លោកអែសរ៉ានិងអធិស្ឋាន (៩:៦–១៥)
   គ. ការទំនួលខុសត្រូវរបស់បណ្តាជន (១០:១–៤)
   ឃ. ការបង្គាប់ហៅជាផ្លូវការណ៍ឱ្យមកជួបជុំគ្នា (១០:៥–១៥)
   ង. ការពិនិត្យពិច័យរបស់អ្នកដែលបានធ្វើខុស (១០:១៦–១៧)
   ច. បញ្ជីរឈ្មោះអ្នកដែលបានប្រព្រឹត្តខុសតាមរយៈការរៀបការជាមួយស្ត្រីសាសន៍ដទៃ (១០:១៨–៤៣)
   ឆ. ការប្តេជ្ញាចិត្តរបស់អ្នកដែលបានរៀបការជាមួយស្ត្រីសាសន៍ដទៃ (១០:៤៤)

## ស្ដេចស៊ីរូសបានជួយឱ្យអ៊ីស្រាអែលវិលត្រឡប់វិញ

*១:១–៣ ២ពវ ៣៦:២២–២៣*

**១** [១]នៅឆ្នាំទី១ ក្នុងរាជ្យស៊ីរូស ជាស្ដេចពើស៊ី នោះព្រះ
យេហូវ៉ាទ្រង់បណ្ដាលព្រះទ័យ[ក]ស៊ីរូស ជាស្ដេចពើស៊ីឱ្យទ្រង់
បានចេញព្រះរាជឱង្ការ ផ្សាយទៅគ្រប់ក្នុងនគរទ្រង់ ដើម្បី
ឱ្យបានសំរេចតាមសេចក្ដី ដែលព្រះយេហូវ៉ាបានមាន
បន្ទូល ដោយសារមាត់ហោរាយេរេមា[ខ] ក៏បានកត់សេចក្ដី
នោះទុកថា [២]ស៊ីរូស ជាស្ដេចពើស៊ី ទ្រង់មានបន្ទូលដូច្នេះ
ព្រះយេហូវ៉ា ជាព្រះនៃស្ថានសួគ៌ ទ្រង់បានប្រទានអស់ទាំង
នគរនៅផែនដីមកយើងហើយ ក៏បានបង្គាប់[គ]ឱ្យយើងស្អាង[ឃ]
ព្រះវិហារថ្វាយទ្រង់ នៅក្រុងយេរូសាឡិម ក្នុងស្រុកយូដា
[៣]ដូច្នេះ នៅក្នុងបណ្ដាជនទាំងឡាយ បើមានអ្នកណាជា
របស់ផងទ្រង់ នោះសូមឱ្យព្រះនៃអ្នកនោះបានគង់ជាមួយ
ហើយឱ្យអ្នកនោះឡើងទៅឯក្រុងយេរូសាឡិម ដែលនៅ
ស្រុកយូដា ដើម្បីនឹងស្អាងព្រះវិហារនៃព្រះយេហូវ៉ាជាព្រះ
នៃសាសន៍អ៊ីស្រាអែលចុះ គឺជាព្រះដែលគង់នៅក្រុង
យេរូសាឡិមនោះ [៤]ឯអស់អ្នកដែលសល់[ង]នៅពីសាសន៍នេះ
ទោះបើនៅកន្លែងណាក៏ដោយ នោះត្រូវឱ្យពួកមនុស្សនៅ
ទីនោះជួយដល់គេ ជាប្រាក់ ជាមាស[ច] ជារបស់មានដំឡៃ
ព្រមទាំងសត្វ ក្រៅពីដង្វាយស្ម័គ្រពីចិត្ត[ឆ] ដែលសំរាប់ព្រះ
វិហារនៃព្រះ[ជ] ដែលនៅក្រុងយេរូសាឡិមផង[ឈ]។
[៥]ដូច្នេះ ពួកអ្នកដែលជាកំពូលលើវង្សានុវង្សរបស់ពួក
យូដា និងពួកបេនយ៉ាមីន[ញ] ហើយពួកសង្ឃនិងពួកលេវី គឺ
អស់អ្នកដែលព្រះបានបណ្ដាលចិត្ត[ដ] ឱ្យឡើងទៅស្អាងព្រះ
វិហារ[ឋ]នៃព្រះយេហូវ៉ា នៅក្រុងយេរូសាឡិមនោះ គេក៏
រៀបចំឡើង [៦]ហើយអស់អ្នកដែលនៅជុំវិញគេទាំងប៉ុន្មាន
ក៏ជួយផ្គត់ផ្គង់ ដោយគ្រឿងប្រាក់ គ្រឿងមាស[ឌ] និងវត្ថុ ឯ
ទៀត ព្រមទាំងសត្វ និងរបស់មានដំឡៃផ្សេងៗ ក្រៅពី
ដង្វាយទាំងប៉ុន្មាន ដែលបានថ្វាយស្ម័គ្រពីចិត្ត [៧]ឯស្ដេច
ស៊ីរូស ទ្រង់ក៏បញ្ចេញគ្រឿងប្រដាប់របស់ព្រះវិហារនៃ

**១:១** ក អរ ៦:២២ ៧:២៧ ខ យរ ២៥:១១–១២ ២៩:១០–១៤ សក ១:១២–១៦ **១:២** គ ពច ៤:១០ ទដ ៧២:១១ អស ៤១:២,២៥ ៤៤:២៨ ៤៥:១៣ ៤៦:១១ ៤៩:៧,២៣ ៦០:៣,១០ ឃ ហក ១:២ **១:៤** ង អស ១០:២០–២២ ច នក ៣:២២ ឆ ជន ១៥:៣ ទដ ៥០:១៤ ៥៤:៦ ១១៦:១៧ ជ ទដ ៧២:៨–១១ វវ ២១:២៤ ឈ អរ ៣:៧ ៤:៣ ៥:១៣ ៦:៣,១៤ **១:៥** ញ ២របា ១១:១,៣,១០,១២,២៣ ១៥:២,៨–៩ ២៥:៥ ៣១:១ ៣៤:៩ អរ ៤:១ ១០:៩ នហ ១១:៤ ១២:៣៤ ដ ខ.១ នក ២៥:២០–២២ ២របា ៣៦:២២ ហក ១:១៤ ភល ២:១៣ ឋ ទដ ១២៧:១ **១:៦** ឌ នក ៣:២២ **១:៧** ឍ ២ពវ ២៤:១៣ ២របា ៣៦:៧,១០ អរ ៥:១៤ ៦:៥ យរ ៥២:១៧–១៩

**១:១–៣ក** អ្វីដែលបានពណ៌នានៅក្នុងខ.ទាំងនេះ គឺមានភាពដូចគ្នានឹងអ្វីដែលបានពណ៌នានៅអត្ថបទគម្ពីរពីរខចុងក្រោយនៃគម្ពីរ២របាក្សត្រដែរ ។ សេចក្ដីពិតនេះធ្លាប់មានការជជែកវែកញែកថា ព្រះគម្ពីររបាក្សត្រ អែសរ៉ា និងនេហេមា គឺសរសេរឡើងដោយមនុស្សតែម្នាក់ដូច្នេះហើយគេហៅគាត់ថា អ្នកកត់ត្រាពង្សាវតារក្សត្រ ។ ទោះបីជាយ៉ាងណាក៏ដោយការលើកមកនិយាយដដែលៗបែបនេះ នោះប្រហែលជាអ្នកនិពន្ធ (ឬលោកអែសរ៉ា) មានបំណងចង់ឱ្យនិទានកថា នៃតំណវង្សនេះមានភាពស៊ីចង្វាក់គ្នា ។

**១:១** *នៅឆ្នាំទី១* ស្ដេចស៊ីរូសចាប់ផ្ដើមគ្រប់គ្រងលើពួកបាប៊ីឡូន ក្នុងខែមីនាឆ្នាំ៥៣៨ មុន គ.ស បន្ទាប់ពីវាយបានក្រុងបាប៊ីឡូនក្នុងខែតុលាឆ្នាំ ៥៣៩ មុន គ.ស ។ ស៊ីរ៉ូសជាស្ដេចចក្រភពពើស៊ី បានគ្រប់គ្រងលើពួកពើស៊ីពីឆ្នាំ ៥៥៩ ដល់ឆ្នាំ ៥៣០ មុន គ.ស ។ នៅក្នុង អស ៤៤:២៨ ៤៥:១ បាននិយាយថាគាត់ជា "អ្នកគង្វាលរបស់ព្រះ" និងជាអ្នកដែលទ្រង់"ចាក់ប្រេងតាំងឡើង"។ *ដើម្បីឱ្យបានសំរេច . . . ដោយសារមាត់ហោរាយេរេមា* ហោរាយេរេមាបានទាយថា ពួកយូដានឹងត្រូវជាប់ជាឈ្លើយនៅបាប៊ីឡូន៧០ឆ្នាំ (សូមមើល រយ ២៥:១១–១២ ២៩:១០) ។ ការនិទេសលើកទី១ ក្នុងឆ្នាំ ៦០៥ មុនគ.ស ដែលស្ថិតក្នុងឆ្នាំទី៣នៃរាជ្យស្ដេចយេហូយ៉ាគីម (សូមមើល ដយ ១:១) ។ រយៈពេល៧០ឆ្នាំក្រោយមកទៀត គឺប្រហែលជានៅក្នុងឆ្នាំ ៥៣៨ មុន គ.ស ប្រជាជនយូដាចាប់ផ្ដើមវិលត្រឡប់មកវិញ ។

**១:២–៤** សេចក្ដីបង្គាប់ផ្ទាល់មាត់របស់ស្ដេចស៊ីរូស ដែលបានប្រើជាមួយពួកឈ្លើយជនជាតិអ៊ីស្រាអែលនៅទីនេះ គឺសរសេរឡើងជាភាសារហេព្រើរ ដែលមានលក្ខណៈផ្ទុយពីសេចក្ដីបង្គាប់នៅក្នុង ៦:៣–៥ ដែលជាអនុស្សរណៈនោះសរសេរឡើងជាភាសារអារ៉ាម ។

**១:២** *ជាព្រះនៃស្ថានសួគ៌* គឺជាព្រះនាមដែលពួកពើស៊ីនិយាយសំដៅលើព្រះអម្ចាស់ ។ នៅក្នុងសញ្ញាចាស់ មានឃ្លានេះចំនួន ២២ដង ដែល ១៧ដងបាននិយាយនៅក្នុងគម្ពីរអែសរ៉ា នេហេមា និងដានីយ៉ែល ។ *ស្អាងព្រះវិហារថ្វាយទ្រង់ នៅក្រុងយេរូសាឡិម* ទីក្រុងយេរូសាឡិម និងការសាងសង់ដំណាក់របស់ព្រះអម្ចាស់ គឺជាប្រធានបទជាក់ស្ដែងដែលមាននិយាយនៅក្នុងគម្ពីរអែសរ៉ា និងគម្ពីរនេហេមា ។

**១:៣** ស្ដេចស៊ីរូសទ្រង់បានបង្កើតច្បាប់ និងគោលនយោបាយស្ដីពីការបង្រួបបង្រួមរូបព្រះ ដែលបណ្ដាជនទាំងឡាយរបស់គាត់បានគោរពថ្វាយបង្គំជាជាងបំផ្លាញ ឬបោះបង់រូបព្រះរបស់ពួកគេចោល ដូចអ្វីដែលពួកអាសស៊ើ និងពួកបាប៊ីឡូនបានធ្វើកាលពីគ្រាមុន ។ សណ្ដានចិត្តទូលាយរបស់គាត់ចំពោះពួកយូដា គឺមានការប្រហាក់ប្រហែលគ្នាទៅនឹងសណ្ដានចិត្តដែលគាត់បានធ្វើចំពោះពួកបាប៊ីឡូនជាជនជាតិរបស់គាត់ដែរ ។

**១:៤** *ទោះបើនៅកន្លែងណាក៏ដោយ* ប្រហែលជានិយាយសំដៅលើពួកយូដាជាច្រើន ដែលមិនមានចិត្តប្រាថ្នាចាកចេញពីស្រុកមេសូប៉ូតាមា ។ *ដង្វាយស្ម័គ្រពីចិត្ត* ការថ្វាយដង្វាយស្ម័គ្រ គឺជាចំនុចសំខាន់នៅក្នុងការស្ថាបនាព្រះវិហារនៃព្រះ និងកិច្ចការបម្រើទ្រង់ (សូមមើល ២:៦៨ ៣:៥ ៨:២៨) ។

**១:៥** *អ្នកដែលជាកំពូលលើវង្សានុវង្ស* នៅសម័យដើម ក្រុមគ្រួសាររបស់គេ គឺជាគ្រួសារធំ ដែលប្រៀបបានទៅនឹងកុលសម្ព័ន្ធ ។ អ្នកដែលមានសិទ្ធិអំណាចនេះ គឺជាពួកព្ឋយុកោដែលជា"អ្នកដែលជាកំពូលលើវង្សានុវង្ស" (សូមមើល ១០:១៦ ២:៥៩ នហ ៧:៦១ ១០:៣៤) ។ *ពួកយូដា និងពួកបេនយ៉ាមីន* អំបូរធំៗទាំង២នៃអាណាចក្រយូដានេះ បាននិរទេសទៅស្រុកបាប៊ីឡូន ។ *ពួកលេវី* សូមមើលសេចក្ដីផ្ដើម ក្នុងព្រះគម្ពីរលេវីវិន័យ ។

**១:៧** ការយកគ្រឿងប្រដាប់ព្រះវិហារ គឺជាទម្លាប់មួយដែលអ្នកមានជ័យជម្នះក្នុងសង្គ្រាមតែងតែយកពីទីក្រុងដែលគេច្បាំងបាន ។ ដូចច្នេះ ពួកយូដាគ្មានរូបចម្លាក់នៃព្រះយេហូវ៉ាទេ (ប៉ុន្តែសូមមើល នក ២០:៤ ព្រះទ្រង់បង្គាប់មិនឱ្យស្អាងរូបចម្លាក់អ្វីឡើយ) ដោយសារស្ដេចនេប៊ូក្នេសាបានចាប់យកគ្រឿង

ព្រះយេហូវ៉ា ដែលនេប៊ូក្នេសាបាននាំយកពីក្រុងយេរូសា
ឡិមមកដាក់ទុកនៅកន្លែងសំរាប់ព្រះនៃទ្រង់[ឃ] ក្នុងព្រះរាជ
ដំណាក់ ៨គឺស៊ីរូស ជាស្តេចពើស៊ី ទ្រង់បានបង្គាប់
ឱ្យមីត្រាដាតជាមេព្រះឃ្លាំង យកគ្រឿងទាំងនោះចេញ
មករាប់ប្រគល់ដល់សេសបាសារ[ណ] ជាចៅហ្វាយនៃពួក
យូដា ៩ឯចំនួននៃរបស់ទាំងនោះ គឺជាថាសមាស៣០ ថាស
ប្រាក់១ពាន់កាំបិត២៩ ១០ពែងមាស៣០ ពែងប្រាក់ថ្នាក់ទី២
មាន៤១០ នឹងគ្រឿងប្រដាប់ឯទៀតៗមួយពាន់ ១១រួមគ្រឿង
ប្រដាប់ទាំងមាសប្រាក់ទាំងអស់ មានចំនួន៥ពាន់៤០០ហើយ
សេសបាសារក៏នាំយកគ្រឿងទាំងនោះឡើងមក ក្នុងកាល
ដែលនាំពួកឈ្លើយ ត្រឡប់ពីក្រុងបាប៊ីឡូនឡើងមកឯក្រុង
យេរូសាឡិមវិញ ។

**១:៨** ណ ១រប ៣:១៨
**២:១** ក ២រប ៣៦:២០ ខ ២ពវ ២៤:១៦ ២៥:១២ គ ខ.៧០ ១រប ៩:២ នហ ៧:៧៣ ១១:៣
**២:២** ឃ ១រប ៣:១៩ មថ ១:១២ លក ៣:២៧ ង អរ ៣:២ ៥:២ ១០:១៨ នហ ១២:១,៨ ហក ១:១,១២ ២:៤ សក ៣:១–១០ ៦:៩–១៥ ច ១រប ៦:១៤

## បញ្ជីឈ្មោះអ្នកជាឈ្លើយដែលត្រឡប់មកវិញ

*២:១–៧០ – នហ ៧:៦–៧៣*

២ ១រីឯពួកអ្នករបស់ខេត្តនោះ ដែលចេញពីសណ្ឋានជា
ឈ្លើយ[ក] ឡើងត្រឡប់ទៅឯក្រុងយេរូសាឡិម នឹងស្រុក
យូដាគ្រប់គ្នា ដល់ទីក្រុងរបស់គេរៀងខ្លួន ក្នុងពួកអ្នក
ដែលនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន[ខ] បាននាំទៅជាឈ្លើយ
ដល់ស្រុកបាប៊ីឡូន[គ] ២គឺជាពួកអ្នកដែលមកជាមួយនឹង
សូរ៉ូបាបិល[ឃ] យេសួរ[ង] នេហេមា សេរ៉ាយ៉ា[ច] រេអេឡាយ៉ា
ម៉ាដេកាយ ប៊ីលសាន បិសផា ប៊ីកវ៉ាយ រេហ៊ូម នឹងប្អាណា
នោះមានចំនួនសាសន៍ អ៊ីស្រាអែលដូច្នេះ ៣គឺពួកប៉ារ៉ូស[ឆ]
មាន២១៧២នាក់ ៤ពួកសេផាធា មាន៣៧២នាក់ ៥ពួក

នហ ១០:២ ១១:១១ ១២:១ **២:៣** ឆ អរ ៨:៣ ១០:២៥ នហ ៣:២៥

ប្រដាប់ព្រះវិហារនៃព្រះអម្ចាស់ ។

**១:៨** *មីត្រាដាត* ឈ្មោះនេះសម្រាប់ពួកពើស៊ីមានន័យថា"ដាក់ឱ្យទៅមីត្រា" ជាព្រះរបស់ពួកពើស៊ី ដែលមានប្រជាប្រិយភាពក្នុងចំណោមពួកទាហានរ៉ូម ក្នុងអំឡុងពេលសតវត្សរ៍ទី២នៃគ.ស ។ *សេសបាសារ* ឈ្មោះនេះដាក់ឱ្យតាមរបៀបជនជាតិបាប៊ីឡូនដែលមានន័យ២យ៉ាងគឺ "ស៊ីន អ្នកការពារឪពុក" និង"សាំម៉ា ជាអ្នកការពារឪពុក" ។ ស៊ីន គឺជាព្រះច័ន្ទ ដែលគេគិតថា ជាព្រះ ហើយសាំម៉ា គឺជាព្រះអាទិត្យ ដែលគេគិតថាជាព្រះ ។ ក្រៅពីឈ្មោះតាមរបៀបពួកបាប៊ីឡូន ឈ្មោះសេសបាសារនេះប្រហែលជាចៅហ្វាយខេត្តយូដា ដែលបម្រើការងារជាឧបនាយករដ្ឋមន្ត្រីនៃប្រទេសយូដាក្រោមការគ្រប់គ្រងរបស់ពួកសាម៉ារី (សូមមើល ៥:១៤) ។ អ្នកខ្លះជឿថា សេសបាសារ និងសូរ៉ូបាបិល គឺជាមនុស្សតែមួយដោយសំអាងទៅលើហេតុផលដូចតទៅ: (ទី១) ពួកគេទាំង២នាក់ជាចៅហ្វាយខេត្ត (សូមមើល ៥:១៤ ហក ១:១ ២:២) (ទី២) ពួកគេទាំង២នាក់សុទ្ធតែជាអ្នកដែលបានដាក់ជើងជញ្ជាំងព្រះវិហារនៃព្រះ (៣:២–៨ ៥:១៦ ហក ១:១៤–១៥ សក ៤:៦–១០) (ទី៣) ពួកយូដា ដែលនៅក្រុងបាប៊ីឡូនទទួលបានឈ្មោះជាផ្លូវការ ដោយការដាក់ឈ្មោះតាមរបៀបជនជាតិបាប៊ីឡូន (សូមធៀប ដយ ១:៧) ។

មិនតែប៉ុណ្ណោះក៏មានអ្នកខ្លះទៀតបាននិយាយថា សេសបាសារ និងសេណាសារជាមនុស្សតែមួយ (១រប ៣:១៨) ជាបុត្រទី៤របស់ស្តេចយេហូយ៉ាគីន ។ សូរ៉ូបាបិលអាចជាក្មួយរបស់សេណាសារ (សូមធៀប ៣:២ ជាមួយ ១រប ៣:១៧–១៨) ។

**១:៩–១១** នៅពេលដែលពួកអាសស៊ើ និងពួកបាប៊ីឡូនទទួលជ័យជម្នះលើពួកយូដាគេក៏ចាប់យករបឹប ហើយអ្នកកត់ត្រារបស់គេក៏ចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌលើរបស់ដែលគេចាប់បាន ។ តួរលេខសរុបដែលនិយាយនៅ ក្នុង ខ.៩–១០ គឺមានតែចំនួន២ពាន់៤រយ៩៩ប៉ុណ្ណោះមិនមែនដូច ខ.១១ និយាយ ៥ពាន់៤រយនោះឡើយ ។ ការនេះប្រហែលជាគេរាប់តែភាជន៍ណា ដែលធំហើយសំខាន់ៗប៉ុណ្ណោះ ។

**១:១១** អ្នកនិពន្ធមិនអាចធ្វើការពណ៌នាឱ្យបានលំអិតបន្ថែមទៀតអំពីកាលបរិច្ឆេទនៃការធ្វើដំណើររបស់សេសបាសារបានឡើយ ។ ប្រហែលជាការធ្វើដំណើររបស់គាត់ស្ថិតនៅក្នុងឆ្នាំ ៥៣៧ មុន គ.ស ។ តាមការវិភាគលើដំណើរលើកក្រោយទៀតរបស់លោកអែសរ៉ា (៧:៨៩) បាននិយាយថាដំណើរនោះបានចំណាយពេលប្រមាណជា៤ខែ ។

**២:១–៧០** តាមរយៈខ.គម្ពីរទាំងនេះបង្ហាញថា ពួកមនុស្សដែលបានវិលត្រឡប់ពីការនិរទេសវិញ ដែលមាននិយាយនៅក្នុងជំពូក២នេះ គឺស្ទើរតែដូចគ្នានឹងពួកអ្នកដែលត្រឡប់ពីនិរទេសវិញ ដែលមាននិយាយក្នុង នហ ៧:៦–៧៣ ។ តាមរយៈឈ្មោះរបស់ទីកន្លែងទាំងនោះបានបង្ហាញថា ពួកអ្នកទាំងនោះគេបាននឹកចាំពីផ្ទះរបស់ពួកគេ ហើយការវិលត្រឡប់ពីនិរទេសនេះបានធ្វើឱ្យគេជួបជុំគ្រួសារទាំងមូល ភូមិដ្ឋាន និងទីក្រុងរបស់ពួកគេវិញ ។ នៅពេលដែលធ្វើការប្រៀបធៀបបញ្ជីឈ្មោះនៅទីនេះ ជាមួយគម្ពីរនេហេមាជំពូក៧គេឃើញថា មានការខុសគ្នាជាច្រើនពីបញ្ជាឈ្មោះនិងចំនួនពួកគេ ។ ប្រលែជា២០ភាគរយនៃចំនួនពួកគេមិនដូចគ្នារ វាំងគម្ពីរអែសរ៉ា និងគម្ពីរនេហេមាឡើយ ។ មូលហេតុនៃការខុសគ្នានោះប្រហែលជាបានពន្យល់រួចមកហើយ ប៉ុន្តែ ទោះបីជាបែបនេះក៏ដោយ បើតាមការសន្មត់បានបង្ហាញថា ប្រហែលជាមានការកត់ត្រាខុស ។

**២:១** *ខេត្ត* ប្រហែលជាខេត្តក្នុងស្រុកយូដា (សូមធៀប ៥:៨ ដែលភាសារអារ៉ាមិចបានបកប្រែពាក្យ "ខេត្ត" ថាជា "ស្រុក" មើល នហ ១:៣) ។

**២:២** *សូរ៉ូបាបិល* សូមមើល ការពន្យល់ក្នុង ៣:២ ៥:២ ។ *យេសួរ* មានន័យថា "ព្រះយេហូវ៉ាជួយសង្គ្រោះ" ហើយភាសាអារ៉ាមមិចក្លាយពីភាសារហេព្រើរគឺ "យូស្វេ" ។ នៅក្នុងទម្រង់ភាសារក្រិចគឺ "យេស៊ូវ" (សូមមើល មថ ១:២១) ។ យូស្វេ គឺដូចគ្នាយេសួរដែលនិយាយនៅក្នុង ហក ១:១ ជាកូនយេហូ៉សាដាកដ៏ជាសង្ឃ (យ៉ូសាដាក អរ ៣:២) ដែលត្រូវជាប់ជាឈ្លើយ (១រប ៦:១៥) ។ *នេហេមា* មិនមែនជានេហេមាដែលមាននិយាយនៅក្នុងកណ្ឌគម្ពីរនេហេមាឡើយ ។ *ម៉ាដេកាយ* ជាឈ្មោះបាប៊ីឡូនដែលមានលំនាំគ្រឹះតាម ម៉ាដាក់ជាព្រះពួកបាប៊ីឡូន (សូមធៀប យរ ៥០:២) ។ ជីដូនមួយរបស់ព្រះនាងអេសធើរក៏មានឈ្មោះម៉ាដេកាយដែរ (មើល អធ ២:៥) ។

**២:៣** *ប៉ារ៉ូស* មានន័យថា "ចៃ" (ជាញឹកញាប់ពួកអ៊ីស្រាអែល បានដាក់ឈ្មោះគេតាមរបៀបសត្វល្អិត និងសត្វពាហនះ) ។ សមាជិកផ្សេងៗទៀតក្នុងក្រុមគ្រួសារនេះ រួមទាំងក្រុមគ្រួសារជាច្រើនទៀត ដែលមានឈ្មោះក្នុង ខ.៦–១៤ គឺបានត្រឡប់មកក្រុងយេរ៉ូសាឡិមវិញជាមួយអែសរ៉ា ។

អើរ៉ាស មាន៧៧៥នាក់ ៦ពួកផាហាត–ម៉ូអាប់ ខាងកូនចៅ
យេសួរ និងយ៉ូអាប់ មាន២៨១២នាក់ ៧ពួកអេឡាំ មាន
១២៥៤នាក់ ៨ពួកសាធូរ មាន៩៤៥នាក់ ៩ពួកសាកាយ
មាន៧៦០នាក់ ១០ពួកបានី មាន៦៤២នាក់ ១១ពួកបេបាយមាន
៦២៣នាក់ ១២ពួកអាសកាឌ មាន១២២២នាក់ ១៣ពួក
អ័ដូនីកាម[ជ] មាន៦៦៦នាក់ ១៤ពួកប៊ីកវ៉ាយ មាន២០៥៦នាក់
១៥ពួកអេឌីន មាន៤៥៤នាក់ ១៦ពួកអេធើ ខាងហេសេគា
មាន៩៨នាក់ ១៧ពួកបេសាយ មាន៣២៣នាក់ ១៨ពួកយ៉ូរ៉ា
មាន១១២នាក់ ១៩ពួកហាស៊ូម មាន២២៣នាក់ ២០ពួកគីបារ
មាន៩៥នាក់ ២១ពួកបេថ្លេហិម[ឈ] មាន១២៣នាក់ ២២ពួក
នថូផា មាន៥៦នាក់ ២៣ពួកអាន៉ាថោត មាន១២៨នាក់
២៤ពួកអាសម៉ាវែត មាន៤២នាក់ ២៥ពួកគារយ៉ាត់–អើរីម
កេភីរ៉ា និងបៀរ៉ុត មាន៧៤៣នាក់ ២៦ពួករ៉ាម៉ា[ញ] និងកេបា
មាន៦២១នាក់ ២៧ពួកមីកម៉ាស មាន១២២នាក់ ២៨ពួក
បេត–អែល និងអៃយ[ដ] មាន២២៣នាក់ ២៩ពួកនេបូរ មាន
៥២នាក់ ៣០ពួកម៉ាកប៊ីស មាន១៥៦នាក់ ៣១ពួកនៅក្រុង
អេឡាំ១ទៀតមាន១២៥៤នាក់ ៣២ពួកហារីម មាន៣២០នាក់
៣៣ពួកឡូឌ ហាឌីឌ និងអូណូរមាន៧២៥នាក់ ៣៤ពួកយេរី
ខូរ[ឋ] មាន៣៤៥នាក់ ៣៥ពួកសេណាអា មាន៣៦៣០នាក់ ។
៣៦ឯពួកសង្ឃ នោះក្នុងពួកកូនចៅយេដាយ៉ា[ឌ]ខាងវង្ស
របស់យេសួរ មាន៩៧៣នាក់ ៣៧ពួកកូនចៅអ៊ីមមេរ[ឍ] មាន
១០៥២នាក់ ៣៨ពួកកូនចៅផាសហ៊ើរ[ណ] មាន១២៤៧នាក់
៣៩ពួកកូនចៅហារីម[ត] មាន១០១៧ នាក់ ។
៤០ចំណែកពួកលេវី[ថ] នោះក្នុងពួកកូនចៅយេសួរ[ទ] និង
កាឌមាល ខាងវង្សរបស់ហូដាវ៉ា មាន៧៤នាក់ ៤១ឯពួក
ចំរៀង[ធ] ជាពួកកូនចៅ អេសាភ នោះមាន១២៨នាក់ ៤២ឯ
ពួកកូនចៅរបស់ពួកអ្នកឆ្មាំទ្វារ[ន] ខាងវង្សរបស់សាលូម
អេធើ ថាលម៉ូន អ័កគូប ហាធីថា និងសូបាយ រួមទាំង

**២:១៣** ជ អរ ៨:១៣
**២:២១** ឈ មីក ៥:២
**២:២៦** ញ យស ១៨:២៥
**២:២៨** ដ កទ ១២:៨
**២:៣៤** ឋ ១ពវ ១៦:៣៤ ២រប ២៨:១៥
**២:៣៦** ឌ ១រប ២៤:៧
**២:៣៧** ឍ ១រប ២៤:១៤
**២:៣៨** ណ ១រប ៩:១២
**២:៣៩** ត ១រប ២៤:៨
**២:៤០** ថ លប ២៩:៣៤ ជន ៣:៩ ចទ ១៨:៦–៧ ១រប ១៦:៤ អរ ៧:៧ ៨:១៥ នហ ១២:២៤ ទ អរ ៣:៩ **២:៤១** ធ ១រប ១៥:១៦ **២:៤២** ន ១សយ ៣:១៥ ១រប ៩:១៧

**២:៥** *អើរ៉ាស* ប្រហែលមានន័យថា "គោព្រៃ" ។ នៅក្នុងពេលដែលឈ្មោះនេះកម្រមាននិយាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយត្រូវបានគេរកឃើញនៅក្នុងឯកសារដែលចេញពីស្រុកមេសូប៉ូតាមា ។ វាប្រហែលត្រូវបានរក្សាទុកក្នុងអំឡុងគ្រានិរទេស ។

**២:៦** *ផាហាត–ម៉ូអាប់* មានន័យថា "ចៅហ្វាយស្រុកម៉ូអាប់" ដែលប្រហែលជាសំដៅលើតំណែងនៃមន្ត្រីនោះ ។

**២:១២** *អាសកាឌ* សូមធៀបជាមួយ ៨:១២ ។ ឈ្មោះនេះមានន័យថា "ព្រះយេហូវ៉ាទ្រង់ជាកម្លាំង" ។ ឈ្មោះនេះសំដៅលើកាឌ់ (ព្រះមានលាភ "ជារូបព្រះ" ដែលមាននិយាយនៅក្នុង អស ៦៥:១១) និងពូជអំបូរកាឌ់ដែលបានឆ្លងទន្លេយ័រដាន់ ។

**២:១៦** *អេធើរ* មានន័យថា "ដៃឆ្វេង" ដូចដែលមាននិយាយនៅក្នុង ពច ៣:១៥ ២០:១៦ ។

**២:២១–៣៥** ដោយហេតុតែក្នុង ខ.៣–២០ និយាយពីឈ្មោះក្រុមគ្រួសាររបស់គេនោះ ២:២១–៣៥ និយាយអំពីភូមិ និងទីក្រុងរបស់គេ ដែលភាគច្រើននៃទីកន្លែងទាំងនោះស្ថិតក្នុងព្រំប្រទល់ពួកបេនយ៉ាមីន ដែលស្ថិតស្ថិតនៅភាគខាងជើងទីក្រុងយេរូសាឡិម ។ គួរឱ្យមានការកត់សំគាល់មួយ គឺពួកគេមិនបានទៅរស់នៅស្រុកត្បូង ដែលស្ថិតនៅភាគខាងត្បូងស្រុកយូដានោះឡើយ ។ នៅពេលដែលស្តេចនេប៊ូក្នេសាគ្រប់គ្រងលើស្រុកយូដាក្នុងឆ្នាំ ៥៩៧ មុន គ.ស (យរ ១៣:១៩) នោះពួកកូនចៅអេដំម (សូមមើលព្រះគម្ពីរអូបាឌា) បានឆក់យកឱកាសដ៏ល្អនេះ ហើយក៏បានចាប់តាំងលំនៅដ្ឋានក្នុងតំបន់នេះតែម្តង ។

**២:២៣** *អាន៉ាថោត* សូមមើលការពន្យល់ពីក្រុងនេះក្នុង យរ ១:១ ។

**២:២៨** *បេត–អែល* សូមមើលការពន្យល់ក្នុង លប ១២:៨ ។ ទីក្រុងបេត–អែល មីសប៉ា គីបៀន និងគីបៀរ គឺត្រូវបានពួកបាប៊ីឡូនចាប់បានក្នុងពេលមានចម្បាំង ។ ទោះបីជាបែបនេះក៏ដោយ ទីក្រុងបេត–អែលត្រូវបានគេបំផ្លាញក្នុងចន្លោះពេលដែលពួកបាប៊ីឡូន និងចក្រភពពើស៊ីកាន់កាប់ ។ ពួកអ្នកបុរាណវិទ្យាជាច្រើនបង្ហាញថា នៅក្នុងសម័យកាលលោកអែសរ៉ា ទីក្រុងនេះជាទីក្រុងដ៏តូចមួយ ។

**២:៣១** សូមមើល ខ.៧ ។

**២:៣៣** *ពួកឡូឌ* នៅក្នុងសម័យកាលទំនើបនេះ វាជាអ្នកភូមិលីដា ។

**២:៣៥** *ពួកសេណាអា* ពួកសេណាសាចំនួន៣៦៣០នាក់ (នហ ៧:៨ និយាយថាមានចំនួន៣៩៣០នាក់) បានមកកាន់ក្រុងយេរូសាឡិមវិញ ហើយពួកនេះមានចំនួនច្រើនជាងអ្នកណាទាំងអស់ ក្នុងចំណោមអ្នកដែលវិលត្រឡប់មកកាន់ទីក្រុងយេរូសាឡិមវិញ ។ ករណីរនេះក៏បានបង្ហាញថា ពួកជាអ្នកនៅក្នុងតំបន់ណាមួយពិតប្រាកដ ឬក្រុមគ្រួសារណាឡើយ ប៉ុន្តែ គ្រាន់តែដឹងថាពួកគេជាអ្នកក្រ និងមានឋានៈទាប ដោយយោងទៅតាមអត្ថន័យនៃឈ្មោះពួកគេដែលមានន័យថា "ជាអ្នកដែលគេស្អប់ខ្ពើម" ។

**២:៣៦–៣៩** ពួកសង្ឃទាំង៤វង្សនេះមានចំនួន៤២៨៩នាក់ ចំនួននេះប្រហែលជាស្ថិតក្នុងលំដាប់ទី១០ ឬ១០ភាគរយនៃសង្ឃទាំងអស់ ។

**២:៤០** *ពួកលេវី* មើលសេចក្តីផ្តើមព្រះគម្ពីរលេវីវិន័យត្រង់ចំណងជើង ។ *៧៤នាក់* ចំនួនពួក លេវីដែលវិលត្រឡប់មកវិញ មានចំនួនតិច ហើយប្រែប្រួល (សូមធៀប ៨:១៥) ។ នៅពេលដែលពួកលេវីបានប្រគល់គ្រឿងប្រដាប់ប្រដារមួយចំនួន សម្រាប់កិច្ចការបម្រើក្នុងព្រះវិហារ នោះប្រហែលជាពួកគេមានជីវិតរស់នៅ ប្រសើរជាងមុននៅក្នុងគ្រានិរទេស ។

**២:៤១** *អេសាភ* គាត់គឺជាម្នាក់ក្នុងចំណោមអ្នកទាំង៣នៃអំបូរលេវី ដែលស្តេចដាវីឌបានតែងតាំងឱ្យធ្វើជាអ្នកចម្រៀង (១រប ២៥:១ ២រប ៥:១២ ៣៥:១៥) ។ កិច្ចការ និងតួនាទីរបស់ពួកគេមាននិយាយលំអិតនៅក្នុង ១រប ១៥:១៦–១៤ ។

**២:៤២** *អ្នកឆ្មាំទ្វារ* ជានិច្ចកាល កិច្ចការយាមទ្វារនេះគឺជាភារៈកិច្ចរបស់ពួកលេវី (១រប ៩:២៦ ២រប ២៣:៤ ៣៥:១៥ នហ ១២:២៥ ១៣:២២) ។ នៅក្នុងគម្ពីរអែសរ៉ា និងនេហេមាមាននិយាយអំពីពួកគេចំនួន១៦ដង និង១៩ដងក្នុងគម្ពីរពង្សាវតារ ។ តួនាទីចម្បងរបស់ពួកគេ គឺយាមទ្វារព្រះវិហារ

អស់មាន១៣៩នាក់ ។
៤៣ឯពួកនេធីនិម[ប] គឺពួកកូនចៅស៊ីហា កូនចៅហាស៊ូផា
កូនចៅ ថាបាអូត ៤៤កូនចៅកេរ៉ូស កូនចៅស៊ីយ៉ាហា កូន
ចៅផាដូន ៤៥កូនចៅលេបាណា កូនចៅហាកាបា កូនចៅ
អ័កគូប ៤៦កូនចៅហាកាប កូនចៅសាលម៉ាយ កូនចៅ
ហាណាន ៤៧កូនចៅគីដេល កូនចៅកាហារ កូនចៅ
រីអាយ៉ា ៤៨កូនចៅរេស៊ីន កូនចៅនេកូដា កូនចៅកាសាម
៤៩កូនចៅអ៊ូសា កូនចៅផាសេហា កូនចៅបេសាយ ៥០កូន
ចៅអាសណា កូនចៅមេហ៊ូនីម កូនចៅនេភូស៊ីម ៥១កូនចៅ
បាកប៊ូក កូនចៅហាគូផា កូនចៅហាហ៊ើរ ៥២កូនចៅ
បាសលូត កូនចៅមេហ៊ីដា កូនចៅហាសា ៥៣កូនចៅបាកូស
កូនចៅស៊ីសេរ៉ា កូនចៅថាម៉ា ៥៤កូនចៅនេស៊ីយ៉ា និងកូន
ចៅហាធីផា ។
៥៥រីឯពួកកូនចៅ របស់ពួកមហាតលិកនៃសាឡូម៉ូន គឺកូន
ចៅសូថាយ កូនចៅសូផេរេត កូនចៅពេរូដា ៥៦កូនចៅ
យ៉ាឡា កូនចៅដាកុន កូនចៅគីដេល ៥៧កូនចៅសេផាធា
កូនចៅហាធីល កូនចៅផូកេរេត ពីសេបែម និងកូនចៅ
អាំម៉ូន ៥៨ឯពួកនេធីនិម[ផ] និងពួកកូនចៅរបស់ពួកមហា
តលិកនៃស្តេចសាឡូម៉ូន រួមទាំងអស់មានចំនួនជា៣៩២
នាក់ ។
៥៩ឯពួកអ្នកទាំងប៉ុន្មាន ដែលបានចេញពីក្រុងធេល
មែឡា ក្រុងធេល–ហារេសា ក្រុងកេរូប ក្រុងអ័ដាន និង
ក្រុងអ៊ីមមេរ ឡើងទៅ តែពុំអាចនឹងប្រាប់ពីជីដូនជីតា ឬពី
ពូជពង្ស[ព]របស់ខ្លួន ឱ្យដឹងជាពូជអ៊ីស្រាអែលឬមិនមែនបាន
ទេ ៦០នោះគឺពួកកូនចៅដេឡាយ៉ា កូនចៅថូប៊ីយ៉ា និង
កូនចៅនេកូដា រួមទាំងអស់ មាន៦៥២នាក់ ៦១ហើយខាង
កូនចៅពួកសង្ឃ មានកូនចៅហាបាយ៉ា កូនចៅហាកូស កូន
ចៅបារស៊ីឡាយ ជាអ្នកដែលយកកូនស្រីបារស៊ីឡាយ ជាអ្នក
ស្រុកកាឡាត[ភ] ធ្វើជាប្រពន្ធ ហើយក៏ត្រូវហៅតាមឈ្មោះគេ
៦២ពួកអ្នកទាំងនោះបានរកបញ្ជីជាតិរបស់ខ្លួន ក្នុងពួកអ្នក
ដែលបានរាប់តាមពង្សាវតារ តែរកមិនឃើញសោះឡើយ
ដូច្នេះ គេត្រូវរាប់ទុកដូចជាមានសៅហ្មងហើយ ក៏ត្រូវ
បណ្តេញចេញពីការងារជាសង្ឃទៅ[ម] ៦៣ហើយលោកចៅ
ហ្វាយបានហាមគេថា មិនត្រូវបរិភោគពីរបស់បរិសុទ្ធ
បំផុត[យ]ឡើយ ដរាបដល់គ្រាមានសង្ឃម្នាក់តាំងឡើង ដែល
មានយូរីម និងធូមីម[រ] ។
៦៤រីឯពួកជំនុំទាំងអស់រួមគ្នា មាន៤ម៉ឺន២ពាន់៣៦០នាក់
៦៥ឥតរាប់ពួកបាវប្រុសស្រីរបស់គេ ដែលមាន៧៣៣៧នាក់

**២:៤៣** ប ១របា ៩:២ នហ ១១:២១
**២:៥៨** ផ ១របា ៩:២
**២:៥៩** ព ជន ១:១៨
**២:៦១** ភ ២សាម ១៧:២៧
**២:៦២** ម ជន ៣:១០ ១៦:៣៩–៤០
**២:៦៣** យ លេវ ២:៣,១០ រ និក ២៨:៣០

(១របា ៩:១៧–២៧) និងជាអ្នកថែរក្សាភាជនៈផ្សេងៗទៀតក្នុងព្រះវិហារ (១របា ៩:២៨–២៣ ២បរ ៣១:១៤) ។

**២:៤៣–៥៨** ពួកមន្ត្រីដែលបម្រើក្នុងព្រះវិហារ និងពួកកូនចៅរបស់ពួកមហាតលិកនៃស្តេចសាឡូម៉ូនសរុបចូលគ្នាមានចំនួន៣៩២នាក់ (ខ.៥៨) មានចំនួនច្រើនជាងពួកលេវី អ្នកចំរៀង និងអ្នកឆ្មាំទ្វារ (ខ.៤០–៤២) ។

**២:៤៦** *ហាណាន* ឈ្មោះហាណានមានន័យថា "(ព្រះ) ទ្រង់មានមេត្តាករុណា" ។

**២:៥៥,៥៨** *ពួកកូនចៅ របស់ពួកមហាតលិកនៃស្តេចសាឡូម៉ូន* ឃ្លានេះមានតែនៅក្នុងកន្លែងនេះ និងគម្ពីរ នហ ៧:៥៧,៦០ ១១:៣ ប៉ុណ្ណោះ ។ ពួកអ្នកទាំងនោះប្រហែលជាពួកកូនចៅកាណាន ដែលសាឡូម៉ូនបានកេណ្ឌមកធ្វើជាបាវបម្រើ (១ពង្ស ៩:២០–២១) ។

**២:៥៩–៦៣** ពួកអ្នកទាំងនេះ គ្មានភស្តុតាងគ្រប់គ្រាន់ពីឰយុកោគេឡើយ ។

**២:៥៩** *ក្រុង* ជាទីកន្លែងមួយនៅក្នុងស្រុកមេសូប៉ូតាមា ដែលពួកយូដាបានតាំងលំនៅស្នាក់អាស្រ័យដោយពួកបាប៊ីឡូនជាអ្នកនិរទេសពួកគេកំណត់ឱ្យ ។ *ក្រុងធេល–ហារេសា* មានន័យថា "គំនរអំបិល" ដែលអាចជាអំបិលដែលបានបាច (សូមមើល ៩:៤៥) ។ ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា *ធេល* មានន័យថា ភ្នំ ឬគំនរ (សូមមើល យស ១១:១៣) ដែលមានសំណល់បាក់បែកនៅក្នុងទីក្រុង ។ ពួកឈ្លើយដែលជាជនជាតិយូដាបានតាំងលំនៅស្នាក់អាស្រ័យនៅមាត់ទន្លេកេបារ (អេគ ១:១) ប្រហែលជានៅក្បែរទីក្រុងនីបភូ ដែលជាទីក្រុងមួយស្ថិតនៅភាគខាងត្បូងស្រុកមេសូប៉ូតាមា ដែលជាទីកន្លែងពុំនួនរបស់អ្នកដែលបះបោរ ។ ប្រហែលជាពួកឈ្លើយយូដាបានស្នាក់អាស្រ័យនៅលើគំនរបាក់ក្នុងទីក្រុង ដែលពួកបាប៊ីឡូនបានវាយបង្ហិន ។

**២:៦៣** *លោកចៅហ្វាយ* ប្រហែលជាសេបាសារ ឬក៏សូរ៉ូបាបិល (សូមមើល ១:៨) ។ *យូរីម និងធូមីម* សូមមើលការពន្យល់ក្នុង និក ២៨:៣០ ។

**២:៦៤** *៤ម៉ឺន២ពាន់៣៦០នាក់* តាមការគិតឃើញ ប្រហែលជាមានចំនួនតួរលេខច្រើនជាងនេះទៅទៀត:

| **ប្រភេទមនុស្ស** | **គម្ពីរអែសរ៉ា** | **គម្ពីរនេហេមា** |
|---|---|---|
| កូនចៅអ៊ីស្រាអែល | ២៤១៤៤នាក់ | ២៥៤០៦នាក់ |
| ពួកសង្ឃ | ៤២៨៩នាក់ | ៤២៨៩នាក់ |
| ពួកលេវី អ្នកចម្រៀង និងអ្នកឆ្មាំទ្វារ | ៣៤១នាក់ | ៣៦០នាក់ |
| អ្នកបម្រើការងារក្នុងព្រះវិហារ ដែលជាពួកកូនចៅពួកមហាតលិកស្តេចសាឡូម៉ូន | ៣៩២នាក់ | ៣៩២នាក់ |
| អ្នកផ្សេងៗទៀត | ៦៥២នាក់ | ៦៤២នាក់ |
| **សរុប** | **២៩៨១៨នាក់** | **៣១០៨៩នាក់** |

វាមានការពិបាកក្នុងការពន្យល់ពីអំពីមូលហេតុ នៃការខុសគ្នានៃចំនួន ១០០០០–១២០០០នាក់ ។ ការនេះ ប្រហែលជានិយាយសំដៅទៅលើចំនួនមិនពិតប្រាកដពី១០០០០–១២០០០នៃពួកស្ត្រី និងកូនក្មេង ព្រមទាំងពួកសង្ឃដែលដែលមិនបានកើតមកពីអំបូរសង្ឃ ដែលមាននិយាយនៅក្នុង ខ.៦១–៦៣ ។ អ្នកខ្លះទៀតនិយាយថា ចំនួនទាំងនោះគឺគេរាប់តែពួកដែលបានរួចពីសណ្ឋានជាឈ្លើយ ដែលចេញពីពួកយូដា និងពួកបេនយ៉ាមីនប៉ុណ្ណោះ ហើយ

នាក់ទៀតឡើយ ហើយក្នុងពួកគេក៏មានពួកចំរៀងប្រុសស្រី
២០០នាក់ដែរ[ល] ៦៦ឯសេះរបស់គេ មាន៧៣៦[វ] លាកាត់
មាន២៤៥ ៦៧សត្វអូដ្ឋ មាន៤៣៥ និងលាមាន៦៧២០ ។
៦៨ឯពួកអ្នកខ្លះ ជាកំពូលលើវង្ស[ស]របស់ឪពុកគេ កាល
បានមកដល់ព្រះវិហារព្រះយេហូវ៉ា នៅក្រុងយេរូសាឡិម
ហើយ នោះគេក៏ថ្វាយដង្វាយស្ម័គ្រចិត្ត សំរាប់នឹងស្អាង
ព្រះវិហារនៃព្រះ នៅកន្លែងចាស់ឡើងវិញ ៦៩គឺគេថ្វាយ
មាស៦ម៉ឺន១ពាន់ដារីក ប្រាក់៥ពាន់ម៉ានេ និងសំលៀក
បំពាក់ពួកសង្ឃ១០០សំរាប់ ដាក់ក្នុងឃ្លាំងសំរាប់ការនោះ
តាមកំឡាំងរៀងខ្លួន ៧០ដូច្នេះ ពួកសង្ឃ ពួកលេវី
ពួកជនខ្លះ ពួកចំរៀង ពួកឆ្មាំទ្វារ និងពួកនេធីនិម ក៏បាន
នៅក្នុងទីក្រុងខ្លួន ហើយពួកអ៊ីស្រាអែលទាំងអស់បាននៅ
ក្នុងទីក្រុងរបស់ខ្លួនដែរ[ហ] ។

## ការស្អាងអាសនានៃព្រះ

៣ ១លុះដល់ខែអស្សុជ កាលពួកកូនចៅអ៊ីស្រាអែលទាំង
ប៉ុន្មាន បាននៅក្នុងទីក្រុងរបស់ខ្លួនហើយ[ក] នោះពួកបណ្តា
ជនក៏មូលគ្នា[ខ]នៅក្រុងយេរូសាឡិម មានចិត្តតែ១ ២គ្រានោះ
យេសួរ[គ] ជាកូនយ៉ូសាដាក[ឃ] ហើយពួកសង្ឃ ជាបងប្អូន
លោក និងសូរ៉ូបាបិល ជាកូនសាលធាល[ង] ហើយបងប្អូន
របស់លោក ក៏នាំគ្នាស្អាងអាសនានៃព្រះ ជាព្រះនៃសាសន៍
អ៊ីស្រាអែល ដើម្បីឱ្យបានថ្វាយដង្វាយដុត តាមដែលបាន
កត់ទុកក្នុងក្រិត្យវិន័យរបស់លោកម៉ូសេ[ច] ជាអ្នកសំណប់
របស់ព្រះ ៣គេក៏ដាក់អាសនានោះ ទៅលើជើងកំណល់
ពីព្រោះគេមានសេចក្តីភ័យខ្លាច[ឆ] ដល់ពួកអ្នកស្រុកនោះ
ហើយក៏ថ្វាយដង្វាយដុត ដល់ព្រះយេហូវ៉ានៅលើអាសនា
នោះ គឺដង្វាយដុតថ្វាយទាំងពេលព្រឹកនឹងពេលល្ងាចផង[ជ]
៤គេធ្វើបុណ្យបារាំ[ឈ] ដូចជាបានកត់ទុកហើយក៏ថ្វាយដង្វាយ
ដុតរាល់តែថ្ងៃ ឱ្យត្រូវចំនួនតាមរបៀប តាមដែលត្រូវការ
រាល់ៗថ្ងៃ ៥តពីនោះមក ក៏ថ្វាយដង្វាយដុតដែលត្រូវថ្វាយ
ជានិច្ច និងដង្វាយចូលខែ[ញ] ហើយដង្វាយថ្ងៃបុណ្យមាន
កំណត់ទាំងប៉ុន្មាននៃព្រះយេហូវ៉ា[ដ]ដែលបានតាំងឡើងជា
បរិសុទ្ធ ព្រមទាំងដង្វាយរបស់អស់អ្នកដែល ថ្វាយដល់ព្រះ
យេហូវ៉ា ដោយស្ម័គ្រពីចិត្តដែរ ៦គេចាប់តាំងថ្វាយដង្វាយ
ដុតដល់ព្រះយេហូវ៉ា គឺពីថ្ងៃដំបូង ក្នុងខែអស្សុជ តែជើង
ជញ្ជាំងរបស់ព្រះវិហារនៃព្រះយេហូវ៉ា មិនទាន់បានដាក់
នៅឡើយ ។

**២:៦៥** ល ២សយ ១៩:៣៥ **២:៦៦** វ អស ៦៦:២០ **២:៦៨** ស នក ២៥:២ **២:៧០** ហ ខ.១ ១របា ៩:២ នហ ១១:៣-៤ **៣:១** ក នហ ៧:៧៣ ខ លវ ២៣:២៤ **៣:២** ក អរ ២:២ ឃ ហក ១:១ សក ៦:១១ ង ១រប ៣:១៧ ច នក ២០:២៤ ចទ ១២:៥-៦ **៣:៣** ឆ អរ ៤:៤ ដយ ៩:២៥ ជ នក ២៩:៣៩ ន ២៨:១-៨ **៣:៤** ឈ នក ២៣:១៦ ជណ ២៩:១២-៣៨ នហ ៨:១៤-១៨ សក ១៤:១៦-១៩ **៣:៥** ញ ជន ២៨:៣,១១, ១៤ កល ២:១៦ ដ លវ ២៣:១-៤៤ ជន ២៩:៣៩

ក្រៅពីនោះ គឺចេញមកពីអំបូរផ្សេងៗទៀត ។

**២:៦៥** *ពួកបាវប្រុសស្រី* នៅក្នុងឃ្លានេះចង់និយាយថា ទំនាក់ទំនងរបស់ពួកអ្នកបម្រើចំពោះអ្នកដទៃទៀត គឺមានចំនួនខុសគ្នាឆ្ងាយណាស់(ពី១នាក់–៦នាក់) ។ សេចក្តីពិតមួយបានបង្ហាញដូច្នេះថា មានពួកអ្នកដែលបានរួចពីសណ្ឋានជាឈ្លើយ រួមនិងចៅហ្វាយរបស់គេ បាននិយាយអំពីក្តីមេត្តាករុណាដែលពួកយូដាបានធ្វើដល់ពួកអ្នកបម្រើ ។ *ពួកចំរៀង* ពួកអ្នកចម្រៀងប្រុសស្រីនៅទីនេះ ប្រហែលជាអ្នកចម្រៀងដែលច្រៀងនៅក្នុងពិធីផ្សេងៗដែលមានលក្ខណៈផ្លូវការណ៍ នៅក្នុងសង្គមដូចជាពិធីរៀបអាពាហ៍ពិពាហ៍និងពិធីបុណ្យខ្មោចជាដើម (សូមមើល ២រប ៣៥:២៥) ។

**២:៦៦** *សេះ* ប្រហែលជាអំណោយរបស់ស្តេចស៊ីរូសផ្តល់ជូនដល់ពួកវណ្ណៈអភិជន ។ *លាកាត់* សូមមើល ១ពវ ១:៣៣ ។

**២:៦៧** *លា* សត្វលាត្រូវបានគេប្រើសម្រាប់ផ្ទុកទំនិញពួកស្ត្រីៗ និងកូនក្មេង ។ នៅទីនេះមិនបាននិយាយអំពីសត្វចៀម ពពែ និងហ្វូងសត្វពាហនៈផ្សេងៗទៀតឡើយ ។

**២:៦៨** *កាលបានមកដល់ . . . នៅក្រុងយេរូសាឡិម* ផ្លូវដែលពួកគេបានធ្វើដំណើរវិលត្រឡប់ពីនិរទេសវិញ សូមមើលផែនទី ទី៨ដែលមាននៅចុងបញ្ចប់នៃព្រះគម្ពីរសិក្សា ។

**២:៦៩** មានអត្ថបទដែលមានភាពប្រហាក់ប្រហែលគ្នានេះ (នហ ៧:៧០–៧២) ដែលអាចផ្តល់ពត៌មានលំអិត ជាងរឿងដែលមាននិយាយនៅក្នុងគម្ពីរអែសរ៉ា ។ នៅក្នុងគម្ពីរអែសរ៉ាបាននិយាយថា ដង្វាយស្ម័គ្រចិត្តទាំងនោះ គឺបានមកពីពួកអ្នកដែលជាកំពូលលើវង្សរបស់ឪពុកគេ (ខ.៦៨) តែនៅក្នុងគម្ពីរនេហេមាវិញបាននិយាយថា ដង្វាយទាំងនោះបានមកពីប្រភព៣ផ្សេងៗគ្នាគឺ:ចេញពីពួកចៅហ្វាយខេត្ត ពីពួកអ្នកដែលជាកំពូលលើវង្សរបស់ឪពុកគេ និងពីប្រជាជនទាំងអស់ ។ *ដារីក* ដារីកគឺជាប្រាក់របស់ប្រទេសក្រិច ។ អ្នកខ្លះជឿថាកាក់ដែលនិយាយនៅទីនេះ គឺជាកាក់មាសរបស់ពួកពើស៊ីដែលគិតជាហាប(សូមមើល ១រប ២៩:៧) ។ *ម៉ានេ* ជារូបិយវត្ថុរបស់ស្រុកមេសូប៉ូតាមា ដែលក្នុង១ម៉ានេមាន ៦០តំឡឹង ហើយ៦០តំឡឹងស្មើ១ហាប ។

**២:៧០** នៅពេលក្រោយទៀត កាលណាមានអ្នកចូលមករស់នៅក្នុងទីក្រុងយេរូសាឡិម គឺត្រូវធ្វើការចាប់ឆ្នោត ដោយជ្រើសរើសយក១ក្នុងចំណោម១០នាក់ (នហ ១១:១–២) ។

**៣:១** *ខែអស្សុជ* នេះគឺជាខែទី១ក្នុងឆ្នាំរបស់ពួកយូដា (ចន្លោះខែកញ្ញាដល់ខែតុលា) ។

**៣:២** *យេសួរ . . . សូរ៉ូបាបិល* នៅក្នុងចំណុចនេះបង្ហាញថា សង្ឃមានអទិភាពគ្រប់គ្រងលើការសម្រេចចិត្តអ្នកដឹកនាំសមញ្ញ (ផ្ទុយពី ៣:៨ ៤:៣ ៥:២ ហក ១:១) ។

**៣:៤** *បុណ្យបារាំ* សូមមើលការពន្យល់នៅក្នុង លវ ២៣:៣៣–៤៣ ។

**៣:៥** *ដង្វាយចូលខែ* សូមមើលក្នុង ១សយ ២០:៥ ។ *ថ្ងៃបុណ្យមានកំណត់ទាំងប៉ុន្មាន* សូមមើលក្នុង លវ ២៣:២ ។ *ព្រមទាំងដង្វាយ . . . ដោយស្ម័គ្រពីចិត្ត* សម្រាប់ឃ្លាដែលនិយាយអំពីដង្វាយស្ម័គ្រចិត្ត សូមមើលការពន្យល់ ១:៤ ។ នៅកន្លែងនេះ មានការគួរឱ្យកត់សំគាល់មួយ គឺពួកកូនចៅអ៊ីស្រាអែល គេបានរៀបចំថ្វាយដង្វាយទៅចំពោះព្រះអម្ចាស់មុនកសាងព្រះវិហារថ្វាយទ្រង់ទៅទៀត ។

## ការស្អាងព្រះវិហារឡើងវិញ

៧គេជួលពួកជាងថ្ម និងពួកជាងឈើ[ឋ] ក៏ឱ្យស្បៀងអាហារ
និងគ្រឿងផឹក ហើយប្រេងដល់ពួកក្រុងស៊ីដូន និងពួកក្រុង
ទីរ៉ុស ឱ្យគេទៅនាំឈើតាត្រៅ[ឌ] ពីភ្នំល្បាណូន[ឍ] មកឯក្រុង
យ៉ុបប៉េតាមផ្លូវសមុទ្រ ដូចជាស៊ីរូស[ណ] ជាស្តេចពើស៊ី បាន
ប្រោសអនុញ្ញាតឱ្យ ។
៨នៅខែពិសាខ ក្នុងឆ្នាំទី២[ត] តាំងពីគេមកដល់ព្រះវិហារ
នៃព្រះ នៅក្រុងយេរូសាឡិម នោះសូរ៉ូបាបិល[ថ] ជាកូន
សាលធាល និងយេសួរ ជាកូនយ៉ូសាដាក ព្រមទាំងពួកសង្ឃ
និងពួកលេវី ជាបងប្អូនគេឯទៀត ហើយអស់ពួកអ្នកដែល
បានចេញពីសណ្ឋានជាឈ្លើយ មកដល់ក្រុងយេរូសាឡិម
ហើយគេចាប់តាំងធ្វើការឡើង ក៏ដំរូវឱ្យពួកលេវីចាប់ តាំង
ពីអាយុ២០[ទ] ឆ្នាំឡើងទៅ បានចាត់ចែងការរបស់ព្រះវិហារ
នៃព្រះយេហូវ៉ា ៩នោះយេសួរ[ធ] និងពួកកូនចៅ ហើយបង
ប្អូនយូដា និងពួកកូនរបស់ហោណាដាឌ ព្រមទាំងកូនចៅគេ
និងពួកលេវី ជាបងប្អូនគេផង ក៏ប្រឹងប្រែងត្រួតមើលពួក
ជាង ដែលធ្វើការក្នុងព្រះវិហារនៃព្រះ ។
១០កាលពួកជាងកំពុងតែដាក់[ន] ជើងជញ្ជាំង របស់ព្រះ
វិហារនៃព្រះយេហូវ៉ាចុះ នោះគេចាត់ពួកសង្ឃ ឱ្យស្លៀក
ពាក់ប្រដាប់សង្ឃ ហើយកាន់ត្រែ[ប] ព្រមទាំងពួកលេវី ជាកូន
ចៅអេសាភ ឱ្យកាន់ឈឹង ដើម្បីសរសើរ[ផ] ដល់ព្រះយេហូវ៉ា
តាមរបៀបរបស់ដាវីឌ[ព] ជាស្តេចអ៊ីស្រាអែល[ភ] ១១គេក៏
ច្រៀងឆ្លើយគ្នា ដោយពាក្យសរសើរ ហើយអរព្រះគុណ
ដល់ព្រះយេហូវ៉ាថា ទ្រង់ប្រកបដោយករុណាគុណ សេចក្តី
សប្បុរសនៃទ្រង់នៅអស់កល្បជានិច្ច[ម] ដល់ពួកអ៊ីស្រាអែល
រួចបណ្តាជនក៏ស្រែកឡើង ជាសិរែកយ៉ាងខ្លាំង[យ] ក្នុងកាល
ដែលគេសរសើរដល់ព្រះយេហូវ៉ាយ៉ាងនោះ ដោយព្រោះ
ជើងជញ្ជាំង[រ] ព្រះវិហារនៃព្រះយេហូវ៉ា បានដាក់ស្រេច
ហើយ ១២តែមានគ្នាច្រើន ក្នុងពួកសង្ឃ ពួកលេវី និងពួក
អ្នកជាកំពូលលើវង្សនៃពួកឰយុកោ ជាមនុស្សចាស់ដែល
ឃើញព្រះវិហារមុន[ល] គេក៏យំជាខ្លាំង[វ] ក្នុងកាលដែល
ឃើញ ដាក់ជើងជញ្ជាំងព្រះវិហារនេះ ក៏មានគ្នាជាច្រើន
បានស្រែកហ៊ោដោយសេចក្តីរីករាយដែរ ១៣ដល់ម្ល៉េះ បាន
ជាបណ្តាជនរកស្គាល់សូរសំឡេងណាដែលអរសប្បាយ[ស]
និងសូរសំឡេងរបស់អ្នកដែលយំនោះមិនបានទេ ពីព្រោះ
គេស្រែកជាយ៉ាងខ្លាំង ហើយសូរសិរែកនោះ ក៏ឮទៅឆ្ងាយ
ផង ។

## ការប្រឆាំងនឹងការស្អាងព្រះវិហារ

៤ ១រីឯពួកខ្មាំងសត្រូវរបស់ពួកយូដា និងបេនយ៉ាមីនកាល
ឮថា ពួកអ្នកដែលមកពីសណ្ឋានជាឈ្លើយ គេកំពុងតែ

**៣:៧** ឋ ១ រប ២២:១៥ ឌ ១ រប ១៤:១ ឍ អស ៣៥:២ ៦០:១៣ ណ អរ ១:២-៤ **៣:៨** ត ១ពវ ៦:១ ថ សក ៤:៩ ទ ជន ៤:៣ **៣:៩** ធ អរ ២:៤០ **៣:១០** ន អរ ៥:១៦ ៦:៣ ហក ២:១៥ ប ជន ១០:២ ២សយ ៦:៥ ១ រប ១៦:៦ ២ រប ៥:១៣ នហ ១២:៣៥ ផ ១ រប ២៥:១ ព ១ រប ៦:៣១ ភ សក ៦:១២ **៣:១១** ម ១ រប ១៦:៣៤,៤១ ២ រប ៧:៣ ទដ ៣០:៤ ១០៧:១ ១១៨:១ ១៣៨:៨ យ យស ៦:៥,១០ រ ហក ២:១៨ សក ៤:៩ ៨:៩ **៣:១២** ល ហក ២:៣,៩ វ យស ៣១:៩ ៥០:៤ **៣:១៣** ស យប ៨:២១ ៣៣:២៦ ទដ ២៧:៦ ៤២:៤ អស ១៦:៩ យរ ៤៨:៣៣ **៤:១** ក នហ ២:២០

**៣:៧** *ឈើតាត្រៅ* ការកសាងព្រះវិហារថ្វាយព្រះអម្ចាស់ឡើងវិញក្នុងពេលនេះ គឺមានលក្ខណៈដូចកាលពីគ្រាមុនដែរ ដែលកាលនោះពួកកូនចៅកាណានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្តេចសាឡូម៉ូនបានបញ្ជូនពួកជាង និងឈើតាត្រៅនៅលើភ្នំល្បាណូនមក ដើម្បីកសាងព្រះវិហារថ្វាយព្រះអម្ចាស់ (សូមមើល ១ពវ ៥:៦-១២) ។

**៣:៨** *ខែពិសាខ* នៅក្នុងសម័យកាលស្តេចសាឡូម៉ូន គាត់ក៏បានស្អាងព្រះវិហារ ថ្វាយព្រះអម្ចាស់នៅក្នុងខែពិសាខដែរ (សូមមើល ១ពវ ៦:១) ។ *ក្នុងឆ្នាំទី២* ឆ្នាំទី២ប្រហែលជាស្ថិតក្នុងឆ្នាំ៥៣៦ មុន គ.ស ព្រោះពួកយូដាគេបានត្រឡប់ពីនិរទេសវិញនៅក្នុងអំឡុងពេលនិទាឃរដូវ ក្នុងឆ្នាំ៥៣៧ មុន គ.ស ។ *អាយុ២០ឆ្នាំ* ពួកលេវីដែលបម្រើការងារកាលពីសម័យមុន ត្រូវមានអាយុ៣០ឆ្នាំ (សូមមើល ជន ៤:៣) ឬក៏២៥ឆ្នាំ(ជន ៨:២៤) ។ នៅសម័យក្រោយមកទៀត ដោយសារតែភាពកម្ររបស់ពួកលេវីដើម្បីបម្រើកិច្ចការក្នុងព្រះវិហារ គេក៏បន្ថយមកត្រឹមតែអាយុ២០ឆ្នាំប៉ុណ្ណោះ(សូមមើល ១ រប ២៣:២៤,២៧ ២ រប ៣១:១៧) ។

**៣:១០** *ត្រែ* ត្រែនោះគឺជាត្រែដែលគេធ្វើឡើងពីប្រាក់ដែលផែចូលគ្នា(មើល ជន ១០:២)។ គេប្រើត្រែតែនៅក្នុងឱកាសណា ដែលមានការសប្បាយរីករាយប៉ុណ្ណោះ ដាក់ស្តែងដូចជានៅក្នុងកន្លែងនេះជាដើម និងពិធីបុណ្យឆ្លងកសាងកំផែងក្រុងយេរូសាឡិមឡើងវិញ(មើល នហ ១២:៣៥ ហើយធៀបនឹង ២ រប ៥:១៣ ទដ ៩៨:៦)។ *ឈឹង* ពាក្យនេះ ក្នុងព្រះគម្ពីរភាសាហេព្រើរមានចំនួន១៣ដង ក្នុងសញ្ញាចាស់ ហើយក្រៅពីខនេះ និង នហ ១២:២៧ គឺមាននិយាយតែក្នុងបទគម្ពីរបាក្សត្រប៉ុណ្ណោះ ។

**៣:១១** *ច្រៀង* ប្រហែលជាចម្រៀងច្រៀងឆ្លងឆ្លើយ ដែលគេចែកជា២ក្រុម ។ *ទ្រង់ប្រកបដោយករុណាគុណ សេចក្តីសប្បុរសនៃទ្រង់នៅអស់កល្បជានិច្ច* សូមមើលក្នុងសេចក្តីផ្តើម ទដ ១៣៦ ។

**៣:១៣** *សំឡេងណាដែលអរសប្បាយ និងសូរសំឡេងរបស់អ្នកដែលយំ* ប្រជាជនអ៊ីស្រាអែលតែងតែមានទម្លាប់បង្ហាញពីអារម្មណ៍ពិតរបស់ពួកគេនៅកន្លែងណាដែលមានមនុស្សច្រើន (សូមមើល ១០:១ នហ ១:៤ ៨:៩) ។ ព្រះអម្ចាស់ទ្រង់ជាអ្នកដែលបណ្តាលឱ្យពួកគេនិរទេសទៅបាប៊ីឡូន ហើយពេលនេះព្រះអង្គទ្រង់ក៏ជាអ្នកនាំពួកគេត្រឡប់មកវិញដែរ ហើយអាចធ្វើឱ្យពួកគេមានសមត្ថភាពកសាងព្រះវិហារថ្វាយព្រះអម្ចាស់ ។ ពួកបាប៊ីឡូនគេបានអក្សរដែលសរសេរនៅលើជញ្ជាំងថ្មនូវពាក្យដែលថា "ទូលបង្គំបានចាប់ផ្តើមដោយយំ ហើយបញ្ចប់ដោយអំណរ"(ធៀបនឹង ទដ ១២៦:៥-៦)។

**៤:១-២៣** នៅក្នុងខ.គម្ពីរទាំងនេះ គឺជាការពណ៌នាដោយសង្ខេបអំពីល្បិចកលផ្សេងៗគ្នារបស់ពួកខ្មាំង ដែលគេប៉ុនប៉ងធ្វើឱ្យពួកយូដាបរាជ័យក្នុងការសាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់ ។ នៅក្នុង ខ.១-៥ អ្នកនិពន្ធគាត់បានពិពណ៌នាអំពីព្រឹត្តិការណ៍ ដែលកើតមាននៅក្នុងសម័យកាលស្តេចស៊ីរូស (គ្រប់គ្រងពីឆ្នាំ ៥៥៩-៥៣០ មុន គ.ស) ។ នៅក្នុង ខ.៦ អ្នកនិពន្ធបានពណ៌នាហេតុការណ៍ក្នុងសម័យកាលស្តេចអ័ហាស៊ូរុស (គ្រប់គ្រងពីឆ្នាំ ៤៨៦-៤៦៥ មុន គ.ស) ហើយចាប់ពី ខ.៧-២៣ គឺជាការពណ៌នាអំពីព្រឹត្តិការណ៍ដែលមាននៅក្នុងសម័យកាលស្តេចអើថាស៊ើកសេស (គ្រប់គ្រង

ស្អាង[ក]ព្រះវិហារថ្វាយព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែលដូច្នោះ ២នោះគេក៏ចូលមកឯសូរ៉ូបាបិល និង
ពួកអ្នកដែលជាកំពូលលើវង្សរបស់ពួកឰយុកោ និយាយថា
សូមឱ្យយើងរាល់គ្នាស្អាងជាមួយនឹងអ្នករាល់គ្នាផង ដ្បិត
យើងក៏ស្វែងរកតាមព្រះនៃអ្នករាល់គ្នា ដូចជាអ្នករាល់គ្នា
ដែរ យើងរាល់គ្នាបានថ្វាយយញ្ញបូជាដល់ទ្រង់ តាំងពីគ្រា
ដែលអេសារ–ហាដោន[ខ] ជាស្តេចស្រុកអាសស៊ើរ បាននាំ
យើងមកនៅស្រុកនេះ[គ] ៣តែសូរ៉ូបាបិល និងយេសួរ ហើយ
ពួកអ្នកឯទៀត ដែលជាកំពូលលើវង្សនៃពួកឰយុកោនៃ
សាសន៍អ៊ីស្រាអែល ក៏ឆ្លើយថា ឯការស្អាងព្រះវិហារថ្វាយ
ព្រះនៃយើង នោះមិនជាធុរៈរបស់អ្នករាល់គ្នាទេ គឺយើង
នឹងធ្វើការនេះតែគ្នាយើងថ្វាយព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែលវិញ ដូចជាព្រះរាជាស៊ីរូស ជាស្តេច
ពើស៊ី បានបង្គាប់មកយើងហើយ[ឃ] ៤ដូច្នេះ ពួកអ្នកស្រុក
នោះក៏ខំនាំឱ្យពួកយូដាខ្សោយដៃទៅ ហើយបង្អើលបង្អាក់
គេក្នុងការស្អាងនោះ[ង] ៥គេជួលពួកអ្នកប្រាជ្ញឱ្យជួយគំនិត
ដើម្បីនឹងបង្អាក់ការដែលផ្តើមធ្វើនោះ នៅអស់រវាងព្រះ
ជន្មស៊ីរូស ជាស្តេចពើស៊ី ដរាបដល់ដារីយុស បានគ្រង
រាជ្យឡើងនៅស្រុកពើស៊ី ។

## ការប្រឆាំងមួយទៀតក្នុងរាជ្យស្តេចអ័ហាស៊ូរុស និងស្តេចអើថាស៊ើកសេស

៦លុះដល់រាជ្យអ័ហាស៊ូរុស[ច]កាលទ្រង់បានសោយរាជ្យ
ឡើងហើយ នោះគេធ្វើសំបុត្រ ផ្ញើទៅថ្វាយ ពោលទោសពី
ពួកអ្នកស្រុកយូដា ហើយនិងពួកនៅក្រុងយេរូសាឡិម[ឆ] ។
៧រួចមក នៅក្នុងរាជ្យអើថាស៊ើកសេស[ជ]នោះប៊ីសឡាំ–
មិត្រាដាត ថាបេល និងគូកនរបស់គេ ក៏ធ្វើសំបុត្រផ្ញើទៅ
អើថាស៊ើកសេស ជាស្តេចពើស៊ី មានសេចក្តីកត់ទុកជា
អក្សរតាមភាសាអារ៉ាម[ឈ] ។
៨គឺចាងហ្វាងរេហ៊ូម និងស្មៀនស៊ីមសាយ គេធ្វើសំបុត្រ
ផ្ញើទៅស្តេចអើថាស៊ើកសេស ពោលទោសពីដំណើរក្រុង
យេរូសាឡិម បែបយ៉ាងនេះថា ៩រេហ៊ូម ជាចាងហ្វាង និង
ស៊ីមសាយជាស្មៀន ហើយពួកយើងខ្ញុំឯទៀត[ញ] គឺជាពួក
ឌីណា ពួកអ័ផារសាថាក់ ពួកថើផែល ពួកអ័ផារ៉ាស ពួក

**៤:២** ខ ២ពវ ១៧:២៤ ក ២ពវ ១៧:៤១
**៤:៣** ឃ អរ ១:១–៤
**៤:៤** ង អរ ៣:៣
**៤:៦** ច នអ ១:១ ដយ ៩:១ ឆ នអ ៣:១៣ ៩:៥
**៤:៧** ជ អរ ៧:១ នហ ២:១ ឈ ២ពវ ១៨:២៦ អស ៣៦:១១ ដយ ១:៤ ២:៤
**៤:៩** ញ ខ.២៣ អរ ៥:៦ ៦:៦,១៣

ជ លប ១០:១០ ឋ នហ ១:១ នអ ១:២ ដយ ៨:២

ពីឆ្នាំ(៤៦៥–៤២៤ មុន គ.ស) ។ អ្នកនិពន្ធគាត់ក៏ត្រឡប់មកនិយាយអំពីរាជ្យស្តេចដារីយុស ដែលក្នុងរាជ្យស្តេចនេះហើយដែលព្រះវិហារនៃព្រះអម្ចាស់ត្រូវបានកសាងរួចជាស្ថាបពរ (មើល ខ.២៤ ៥:១–២ ៦:១៣–១៥ ហាកាយ សក ១:១–១៧ ៤:៩) ។

**៤:១** *ពួកខ្មាំងសត្រូវ* ពួកខ្មាំងសត្រូវទាំងនោះ គឺជាមនុស្សដែលមានចិត្តចង់ "ជួយ"កសាងព្រះវិហារនៃព្រះអម្ចាស់(សូមមើល ខ.២) ហើយពួកគេ គឺពួកជាសាសន៍សាម៉ារី ។ *ពួកយូដា និងបេនយ៉ាមីន* សូមមើលការពន្យល់ក្នុង ១:៥ ១ពវ ១២:២១ ។

**៤:២** នៅក្នុងឆ្នាំ៧២២–៧២១ មុន គ.ស ពួកអាសស៊ើបានវាយឈ្នះពួកសាសន៍សាម៉ារី ។ ស្តេចអាស៊ើបានចាប់យកមនុស្សពីស្រុកមេសូប៉ូតាមា និងអាប់រាម (ជាសាសន៍ស៊ើរីសម័យទំនើប) ។ ពួកអ្នកទាំងនោះគេគោរពប្រត្តិបត្តិលើរូបព្រះរបស់ពួកគេ ហើយក៏គោរពប្រត្តិបត្តិដល់ព្រះយេហូវ៉ាដែរ ដោយព្រោះគេគិតថាព្រះអម្ចាស់ គឺជារូបព្រះដែលបានការពារទឹកដី (សូមមើល ២ពវ ១៧:២៤–៤១) ។ *អេសារ–ហាដោន* សូមមើលការពន្យល់អំពីស្តេចនេះក្នុង ២ពវ ១៩:៣៧ ។

**៤:៤** *បង្អើលបង្អាក់គេ* ជានិច្ចកាលក្នុងព្រះគម្ពីរភាសារហេព្រើរ ឃ្លានេះគឺតែងតែពណ៌នាពីសេចក្តីភ័យខ្លាច ដែលមាននៅពេលធ្វើសង្គ្រាម (សូមមើល ពច ២០:៤១ ២សយ ៤:១ ២រប ៣២:១៨) ។

**៤:៥** *ជួល* សូមធ្វើការប្រៀបធៀបពីការជួលនៅកន្លែងនេះ និងការជួលរបស់បាឡាម (សូមមើល ចទ ២៣:៤–៥ នហ ១៣:២) និងការជួលហោរ៉ាដើម្បីបំភ័យនេហេមា(នហ ៦:១២–១៣) ។

**៤:៦** *អ័ហាស៊ូរុស* សូមមើលអំពីគាត់នៅក្នុងព្រះគម្ពីរនាងអេសធើ ។ នៅពេលស្តេចដារីយុសទ្រង់សុគតក្នុងឆ្នាំ ៤៨៦ មុន គ.ស នោះពួកអេស៊ីព្ទបានវាយប្រឆាំង និងធ្វើការបះបោរ ហើយអ័ហាស៊ូរុសជាបុត្ររបស់ស្តេចដារីយុសបានសុំជំនួយពីពួកខាងលិចដើម្បីប្រឆាំងតបត ។

**៤:៧** *អើថាស៊ើកសេស* ស្តេចនៃសាសន៍ពើស៊ី៣អង្គ ដែលមានឈ្មោះដូចៗគ្នាគឺៈ អ័ថាស៊ើកសេសទី១ (គ្រប់គ្រងពីឆ្នាំ ៤៦៥–៤២៤ មុន គ.ស) អើថាស៊ើកសេសទី២(គ្រប់គ្រងពីឆ្នាំ ៤០៤–៣៥៨ មុន គ.ស) និងអើថាស៊ើកសេសទី៣ (គ្រប់គ្រងពីឆ្នាំ៣៥៨–៣៣៨ មុន គ.ស) ។ ស្តេចអើថាស៊ើកសេសដែលនិយាយនៅពេលនេះ គឺជាស្តេចទី១ ។ *មិត្រដាត* សូមមើលការពន្យល់អំពីគាត់នៅក្នុង ១:៨ ។ *ថាបេល* ឈ្មោះរបស់គាត់គឺបានដាក់តាមរបៀបពួកអារ៉ាម (សូមមើលការពន្យល់ក្នុង អស ៧:៦) ។ *ធ្វើសំបុត្រ* តាមរយៈឃ្លានេះបានបង្ហាញថាស្តេចទាំងអស់នៅក្បែរមជ្ឈឹមបុពាំ តែងតែអ្នករាយការណ៏ និងគិញសំខាន់របស់ពួកគេ ។ នៅក្នុងប្រទេសអេស៊ីព្ទគេតែងតែនិយាយថា "ត្រចៀក និងផ្នែករបស់ស្តេចផារ៉ោន" ។ ថើរថានទី២ជាស្តេចរបស់ពួកអាសស៊ើរមានភ្នាក់ងារសម្ងាត់ ដែលបម្រើការឱ្យបាននិយាយថា "ចូរកត់ចុះនូវអ្វីដែលឯងបានឮនិងឃើញ" ។ ភ្នែកនិងត្រចៀករបស់ស្តេចគឺជាមន្ត្រី២រូបដែលរាយការណ៏ជូនស្តេចពើស៊ី ។

**៤:៨–៦:១៨** រាល់ពាក្យពេចន៍ទាំងឡាយ ដែលមាននៅក្នុងខ.គម្ពីរទាំងនេះ អ្នកនិពន្ធបានដកស្រង់ចេញពីឯកសារ ដែលសរសេរជាភាសាអាប់រ៉ាម ។

**៤:៨** *ចាងហ្វាង* ចាងហ្វាង គឺជាមន្ត្រីម្នាក់ដែលគ្រប់គ្រងលើសេនាបតីឬចៅហ្វាយខេត្ត ។ ប្រហែលជារេហូមគាត់បាននិយាយតាមអ្វី ដែលស្តេចមានបន្ទូលហើយស៊ីមសាយជាអ្នកសរសេរចុះជាភាសាអាប់រ៉ាម (ប្រហែលស៊ីមសាយគាត់មានតួរនាទីខ្ពស់ជាងអ្វី ដែលនិយាយនៅទីនេះ) ។ សំបុត្រនោះគេអាចអាននៅចំពោះព្រះភ័ក្រស្តេច ដោយបកប្រែជាភាសាពួកពើស៊ី (សូមមើល ខ.១៨) ។

អើការវ[ដ] ពួកបាប៊ីឡូន ពួកស៊ូសាន[ឋ] ពួកដេហាវេ និងពួក
អេឡាំ ១០ព្រមទាំងសាសន៍ឯទៀត ដែលអ័ស្នាផារ[ឌ] ដ៏ជាធំ
ឧត្តុង្គឧត្តម លោកបាននាំមក ឱ្យអាស្រ័យនៅក្នុងទីក្រុង
ស្រុកសាម៉ារីទាំងប៉ុន្មាន និងក្នុងស្រុកឯទៀតនៅខាងនាយ
ទន្លេនេះ។ល។[ឍ] ១១នេះជាសំណៅពីសំបុត្រដែលបានផ្ញើទៅ
អើថាសើកសេស ជាស្តេច គឺថា យើងខ្ញុំ ជាពួកអ្នកនៅខាង
នាយទន្លេ។ល។ ១២យើងខ្ញុំសូមក្រាបថ្វាយបង្គំចូលមកព្រះ
ករុណា សូមទ្រង់ជ្រាបថា ពួកសាសន៍យូដា ដែលបានចេញ
ពីទ្រង់ឡើងមកឯយើងខ្ញុំ នៅក្រុងយេរូសាឡិម គេកំពុងតែ
សង់ទីក្រុងបះបោរ ហើយអាក្រក់នេះឡើងវិញ គេបានធ្វើ
កំផែងស្រេចហើយ ឥឡូវនេះ កំពុងតែរៀបចំជើងជញ្ជាំង
ទៀត[ណ] ១៣ដូច្នេះ សូមព្រះករុណាទ្រង់ជ្រាបថា បើទីក្រុង
នេះបានសង់ឡើងស្រេចហើយ កំផែងក៏បានលើកឡើងផង
នោះគេនឹងលែងបង់សួយអាករ ពន្ធខ្លួន និងពន្ធគយទៅ[ត]
ហើយដល់ទីបំផុត និងបង្កើតខូចខាតដល់ពួកស្តេចផង
១៤ឥឡូវនេះ ដោយព្រោះយើងខ្ញុំជ្រកកោនដោយព្រះគុណ
ទ្រង់ ហើយមិនគប្បីឱ្យយើងខ្ញុំព្រងើយបណ្តោយឱ្យគេបង្អាប់
ដល់ព្រះកិត្តិយសរបស់ព្រះករុណាឡើង បានជាយើងខ្ញុំផ្ញើ
សំបុត្រនេះមក ទូលដល់ព្រះករុណាថ្វាយទ្រង់ជ្រាបផង

**៤:១០** ឌ ២ពវ ១៧:២៤ ឍ ខ.១៧ នហ ៤:២
**៤:១២** ណ អរ ៥:៣,៩
**៤:១៣** ត អរ ៧:២៤ នហ ៥:៤
**៤:១៥** ថ អរ ៥:១៧ ៦:១ ទ នអ ៣:៨
**៤:១៧** ធ ខ.១០
**៤:១៩** ន ២ពវ ១៨:៧

១៥ដើម្បីឱ្យមានគេពិនិត្យរកក្នុងសៀវភៅ ជាពង្សាវតារ[ថ]
នៃពួកវង្សានុវង្សរបស់ទ្រង់ យ៉ាងនោះ ទ្រង់នឹងទតឃើញ
ក្នុងសៀវភៅទាំងនោះ ហើយជ្រាបថា ទីក្រុងនោះជា
ទីក្រុងតែងតែបះបោរ ហើយប្រទូសរ៉ាយដល់ពួកស្តេច
នឹងដល់អាណាខេត្តផង ហើយថា កាលពីចាស់បូរាណ
គេចេះតែបង្កើតការក្បត់ គឺដោយហេតុនោះបានជាទីក្រុង
នោះត្រូវបំផ្លាញចេញទៅ[ទ] ១៦យើងខ្ញុំសូមទូលបញ្ជាក់ដល់
ព្រះករុណាថ្វាយទ្រង់ជ្រាបថា បើគេសង់ទីក្រុងនោះឡើង
វិញ ហើយបានលើកកំផែងឡើងជាស្រេច នោះនឹងធ្វើឱ្យ
ព្រះករុណាលែងមានចំណែកណា នៅខាងនាយទន្លេទៀត
ហើយ ។

១៧ស្តេចទ្រង់ក៏ធ្វើព្រះរាជសាសន៍ តបទៅចាងហ្វាង
រេហ៊ូម នឹងស្មៀនស៊ីមសាយ ព្រមទាំងពួកគូកនគេដែលនៅ
ស្រុកសាម៉ារី នឹងស្រុកឯទៀត នៅខាងនាយទន្លេថា សូម
ឱ្យបានប្រកបដោយសេចក្តីសុខចុះ។ល។[ធ] ១៨ឯសំបុត្រដែល
អ្នករាល់គ្នាបានផ្ញើទៅយើង នោះបានអានមើលប្រែ
សេចក្តីយ៉ាងច្បាស់ នៅមុខយើងហើយ ១៩យើងក៏បាន
បង្គាប់ឱ្យគេពិនិត្យរក នោះឃើញថា កាលពីចាស់បូរាណ
ទីក្រុងនោះបានលើកគ្នាឡើង ទាស់នឹងពួកស្តេចក៏បង្កើត

**៤:៩** *ពួកអើការវ* សូមមើលការពន្យល់ពីនេះក្នុង លប ១០:១០ ។
**៤:១០** *អ័ស្នាផារ* អ័ស្នាផារគាត់គឺជាស្តេចចុងក្រោយដ៏ឆ្នើមរបស់ពួកអាសសើរ ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ផ្សេងៗទៀតមិនបាននិយាយអំពីឈ្មោះរបស់គាត់ឡើយ ប៉ុន្តែគ្រាន់តែនិយាយថា គាត់គឺជាស្តេចដែលបានលែងពួកម៉ានាសេពីការនិរទេសឱ្យមានសេរីភាពវិញ (សូមមើល ២របា ៣៣:១១-១៣)។ *នាំមក* នៅក្នុងឃ្លានេះបានបង្ហាញថា អ័ស្នាផារប្រហែលជាស្តេចអាសសើរដែលគ្មានឈ្មោះ ដែលបាននាំមនុស្សមកស្រុកសាម៉ារី ដែលមាននិយាយនៅក្នុងគម្ពីរ ២ពវ ១៧:២៤ ។ អ្វីដែលបាននិយាយខាងលើនេះ គឺជាភិនភាគរបស់បណ្តាជន ដែលបានចាកចេញពីស្រុកកំណើតជិត២សតវត្សរ៍ ហើយនៅចងចាំពីសណ្ឋានពិតរបស់ខ្លួន ។ *សាម៉ារី* គេជឿថា ស្តេចអាំម៉ូននៃនគរយូដាត្រូវគេធ្វើគុត(ពីឆ្នាំ៦៤២–៦៤០ មុន គ.ស មើលក្នុង ២ពវ ២១:២៣ និង ២របា ៣៣:២៤) បណ្តាលពីការប្រឆាំងជាមួយពួកអាសសើរក្នុងពេលមានការបះបោរនៅក្រុងអេឡាម និងក្រុងបាប៊ីឡូន ។ ប្រហែលជាពេលនោះហើយដែលពួកអាសសើរចាប់ពួកសាសន៍សាម៉ារីជាឈ្លើយ ហើយនិរទេសចេញទៅ ដោយការបះបោរយកទៅដាក់ជាមួយពួកបះបោរដែលនៅក្រុងឡោម និងពួកបាប៊ីឡូន ។
**៤:១២** *ពួកសាសន៍យូដា* សូមមើលការពន្យល់ពីពួកគេក្នុង សក ៨:២៣ ។ *គេបានធ្វើកំផែងស្រេចហើយ . . . ជើងជញ្ជាំង* ការនេះបានកើតឡើងដូចអ្វីដែលហោរាអេសាយបានទាយទុកជាមុនមែន(សូមមើល អស ៥៨:១២) ។
**៤:១៣** នៅក្នុងឃ្លានេះចង់បញ្ជាក់ប្រាប់ថា មាស និងប្រាក់ភាគច្រើនដែលជាសួយសារអាករដល់ពួកពើស៊ី គឺគេត្រូវរំលាយវាចូលគ្នាឱ្យក្លាសយជាដុំសិនទើបយកទៅថ្វាយ ។ ពន្ធដ៏តិចតួចទាំងនោះ ត្រូវបានគេទុកជាសម្បត្តិនៅក្នុងខេត្តនិមួយៗ ។
**៤:១៤** *ដោយព្រោះយើងខ្ញុំជ្រកកោនដោយព្រះគុណទ្រង់* តាមលក្ខណៈអក្សរសាស្ត្រគេនិយាយថា "យើងបរិភោគអំបិលទាំងនេះដោយព្រះគុណទ្រង់" ។ អំបិលត្រូវបានគេផលិតឡើង សម្រាប់ផ្តល់ឱ្យតែស្តេចប៉ុណ្ណោះ ដែលគេធ្វើឡើងដោយក្រុមមនុស្ស ដែលរស់នៅក្នុងស្រុកអេស៊ីព្ទ ហើយអាចរួមទាំងពួកពើស៊ីដែរ។
**៤:១៥** *ពិនិត្យរកក្នុងសៀវភៅ* សូមមើលក្នុង ៥:១៧ ៦:១ និងការពន្យល់ក្នុង នអ ២:២៣ ៦:១–២ ។ មានឃ្លាំងជាច្រើនសម្រាប់តម្កល់ឯកសារសំខាន់ៗទុកដូចជាឯកសារស្តីពីសេនាបតី និងកិច្ចការនៅក្នុងទីក្រុង ហើយឯកសារទាំងនោះគេរក្សាវាទុកជាច្រើនសតវត្សរ៍ ។ នៅក្នុងសតវត្សរ៍ទី៣ មុន គ.ស សង្ឃបាប៊ីឡូន បានលើកយកពង្សាវតារបាប៊ីឡូនមកនិយាយអំពីប្រត្តិសាស្ត្រដែលកើតមាននៅប្រទេសបាប៊ីឡូន ។ សៀវភៅនេះមានឥទ្ធិពលគ្របដណ្តប់ចាប់តាំងពីពួកអាសសើររហូតដល់តំបន់ហេឡិននីសធីក(Hellenistic) ។
**៤:១៨** *អាន* ពេលនោះប្រហែលជាស្តេចទ្រង់មិនអាចអានជាភាសាអាប់រ៉ាមបានទេ ប្រហែលជាទ្រង់មានស្មៀនអានឱ្យស្តាប់ ។ *មើលប្រែ* នៅក្នុងឃ្លានេះចង់មានន័យថា ស្តេចមានអ្នកបកប្រែរបស់ព្រះអង្គ ដែលបកប្រែពីភាសាអាប់រ៉ាមទៅភាសាពើស៊ី(សូមមើល ខ.៧ និង នហ ៨:៨) ។
**៤:១៩** *បង្កើតការបះបោរ* មានសេចក្តីពិតខ្លះៗក្នុងចំណោមពាក្យ ចោទប្រកាន់ផ្សេងៗពីគ្នា ដោយគេគិតថា ពួកក្រុងយេរូសាឡិមបានបះបោរប្រឆាំងជាមួយពួកអាសសើរនៅក្នុងឆ្នាំ៧០១ មុន គ.ស (មើល ២ពវ ១៨:៧)

ការបះបោរ[ទ]នឹងការកម្បត់មែន ២០ហើយមានស្ដេចដែល
មានឫទ្ធិយ៉ាងសន្ធឹក បានសោយរាជ្យនៅក្រុងយេរូសាឡិម
ហើយបានគ្រប់គ្រងលើអស់ទាំងស្រុកនៅខាងនាយទន្លេ[ប]
មនុស្សក៏បានបង់សួយអាករ ពន្ធខ្លួន និងពន្ធគយថ្វាយស្ដេច
ទាំងនោះដែរ ២១ដូច្នេះ ចូរអ្នករាល់គ្នាចេញបញ្ញត្តិ ឱ្យ
មនុស្សទាំងនោះឈប់ការនោះទៅ កុំឱ្យគេសង់ទីក្រុងនោះ
ឡើងឡើយ ដរាបដល់មានបង្គាប់ចេញពីយើងមកទៀត
២២ហើយត្រូវប្រយ័ត្ន កុំឱ្យអ្នករាល់គ្នា ធ្វេសប្រហែសចំពោះ
ការនោះដែរ នឹងឱ្យមានការខូចខាត កើតឡើងដល់ពួក
ស្ដេចធ្វើអី[ផ] ។
២៣កាលគេបានអានមើលព្រះរាជសាសន៍របស់ស្ដេច
អើថាសើកសេស នៅមុខរេហ៊ូម និងស៊ៀនស៊ីមសាយ
ព្រមទាំងពួកគូកនគេ[ព]ស្រេចហើយ ស្រាប់តែគេទៅឯពួក
សាសន៍យូដា នៅក្រុងយេរូសាឡិមជាប្រញាប់ ក៏បង្ខំឱ្យគេ
ឈប់ ដោយកំឡាំងនឹងអំណាច ២៤ដូច្នេះ គេលែងស្អាងព្រះ
វិហារនៃព្រះដែលនៅក្រុងយេរូសាឡិមទៅ ហើយការ
នោះក៏ខានធ្វើដរាបដល់ឆ្នាំទី២ក្នុងរាជ្យដារីយុស[ភ] ជាស្ដេច
ពើស៊ី ។

## សំបុត្រលោកថាថ្នាយដល់ស្ដេចដារីយុស

**៥** ១រីឯហោរាហាកាយ[ក] និងហោរាសាការី[ខ] ជាកូនអ៊ីដោ
ក៏ទាយ[គ] ដោយនូវព្រះនាមព្រះនៃសាសន៍អ៊ីស្រាអែល ដល់
ពួកយូដាដែលនៅស្រុកយូដា និងក្រុងយេរូសាឡិម ២គ្រា
នោះ សូរ៉ូបាបិល[ឃ] ជាកូនសាលធាល និងយេសួរ[ង] ជាកូន
យ៉ូសាដាក ក៏នាំគ្នាចាប់តាំង[ច]ស្អាងព្រះវិហារដែលនៅក្រុង
យេរូសាឡិម ក៏មានពួកហោរានៃព្រះជួយគ្នាដែរ ៣ហើយ
នៅវេលានោះឯង ថាថ្នាយ[ឆ] ជាចៅហ្វាយខេត្តខាងនាយ
ទន្លេនោះ ព្រមទាំងសេថារ-បូសណាយ[ជ] និងពួកគូកន
លោកក៏មកសួរថា តើអ្នកណាបានចេញបង្គាប់ឱ្យឯងរាល់
គ្នាស្អាងវិហារនេះ ហើយធ្វើកំផែងនេះឡើង[ឈ] ៤លោកក៏
សួរដូច្នេះទៀតថា មនុស្សដែលធ្វើការនេះ តើមានឈ្មោះ
អ្វីខ្លះ ៥ប៉ុន្តែព្រះនេត្រនៃព្រះ[ញ]បានទតមកលើពួកចាស់ទុំ

**៤:២០** ប លប ១៥:១៨-២១ នក ២៣:៣១ យស ១:៤ ១ពវ ៤:២១ ១រប ១៨:៣ ទដ ៧២:៨-១១ **៤:២២** ផ ដយ ៦:២ **៤:២៣** ព ខ.៩ **៤:២៤** ភ នហ ២:១-៨ ដយ ៩:២៥ ហាក ១:១,១៥ សក ១:១ **៥:១** ក អរ ៦:១៤ ហាក ១:១,៣,១២ ២:១,១០,២០ ខ សក ១:១ ៧:១ គ ហាក ១:១៤-២:៩ សក ៤:៩-១០ ៨:៩ **៥:២** ឃ ១រប ៣:១៩ ហាក ១:១៤ ២:២១ សក ៤:៦-១០
ង អរ ២:២ ច ខ.៨ ហាក២:២-៥ **៥:៣** ឆ អរ ៦:៦ ជ អរ ៦:៦ ឈ អរ ៤:១២

និងទាស់ប្រឆាំងជាមួយពួកបាប៊ីឡូនក្នុងឆ្នាំ៦០០ និង ៥៨៩ មុន គ.ស (២ពវ ២៤:១,២០) ។

**៤:២១-២៣** នៅក្នុងខ.ទាំងនេះ គឺនិយាយអំពីអន្តរាគន៍របស់នាយខាងទន្លេ និងស្ដេចអ័ថាសើកសេសទី១ (សូមមើល ខ.១១ និង ខ.៧) ដែលបានចេញក្រឹតឱ្យពួកយូដាបញ្ឈប់ការសាងសង់ព្រះវិហារ និងកំផែងក្រុងយេរូសាឡិម (សូមមើល នហ ១:៣) ។ ហេតុការណ៍ទាំងឡាយដែលបានកើតឡើងនៅក្នុង ខ.៧-២៣ ប្រហែលជាអាចកើតឡើងមុនឆ្នាំ ៤៤៤ មុន គ.ស ។

**៤:២៤** បន្ទាប់ពីធ្វើការអធិប្បាយយ៉ាងវែងអន្លាយក្រៅសាច់រឿងដែលស្ដីពីការជំទាស់លើពួកយូដា នោះអ្នកនិពន្ធគាត់បានត្រឡប់មកនិយាយពីគោលបំណងដើមក្នុងការសាងសង់កំផែងក្រុងឡើងវិញ(សូមមើលខ.១-៥)។ *ឆ្នាំទី២ក្នុងរាជ្យដារីយុស* ដោយយោងទៅតាមការគន់គូរមើលអំពីឆ្នាំ បានបង្ហាញថា ឆ្នាំទី២នៃរាជ្យស្ដេចដារីយុសទី១ គឺចាប់ផ្ដើមឡើងនៅក្នុងថ្ងៃទី៣ខែមេសាឆ្នាំ៥២០ មុន គ.ស រហូតដល់ថ្ងៃ២១ខែកុម្ភៈឆ្នាំ៥១៩ មុន គ.ស ។ នៅក្នុងឆ្នាំនោះ ហោរាហាកាយ (ហាក ១:១-៥) គាត់បានដាស់តឿនដល់សូរ៉ូបាបិល ឱ្យចាប់ផ្ដើមកសាងព្រះវិហារនៃព្រះអម្ចាស់នៅក្នុងថ្ងៃទី១នៃខែភទ្របុត្រ (ថ្ងៃទី២៩ខែសីហា) ។ កិច្ចការងារស្អាងព្រះវិហារនៃព្រះអម្ចាស់បានចាប់ផ្ដើមឡើងនៅក្នុងថ្ងៃទី២៤ខែភត្របុត្រ ដែលត្រូវនឹងថ្ងៃទី២១ខែកញ្ញា ក្នុងឆ្នាំទី២នៃរាជ្យស្ដេចដារីយុស (សូមមើល ហាក ១:១៥) ។ រយៈពេល២ឆ្នាំដំបូងនៃរាជ្យស្ដេចដារីយុស ទ្រង់បានប្រព្រឹត្តការដែលត្រឹមត្រូវចំពោះរាជ្យបល្ល័ង្គ ដោយព្រោះគាត់បានប្រឆាំងតបតនិងវាយប្រហារដល់ពួកឧទ្ទាមបះបោរជាច្រើន ដូចអ្វីដែលបានកត់ទុកក្នុងសិលាចារឹកដ៏ល្បីល្បាញមួយរបស់ទ្រង់ ។ ការអនុញ្ញាតិឱ្យចាប់ផ្ដើមកសាងព្រះវិហារ និងកំផែងក្រុង ឡើងវិញគឺបន្ទាប់ពីចក្រភពពើស៊ីមានស្ថេរភាពពិតប្រាកដ និងស្ថិតស្ថេរ ។

**៥:១** *ហោរាហាកាយ និងហោរាសាការី* ឃ្លានេះចង់បញ្ជាក់ប្រាប់ថា ហោរាហាកាយ និងហោរាសាការីបានចាប់ផ្ដើមថ្លែងទំនាយក្នុងថ្ងៃទី១ខែភទ្របុទ ដែលត្រូវនឹងថ្ងៃទី២៩ខែសីហាឆ្នាំ៥២០ មនុ គ.ស (សូមមើលក្នុង ហាក ១:១) រហូតដល់ថ្ងៃទី២១ខែអស្សុជដែលត្រូវនឹងថ្ងៃទី១៨ខែធ្នូ (សូមមើល ហាក ២:១,១០,២០) ហើយនៅក្នុងអំឡុងគ្រានោះ ហោរាហាកាយបានទទួលព្រះរាជ្យសារមកពីព្រះអម្ចាស់ជាបន្តបន្ទាប់ ដើម្បីនាំមកដល់បណ្ដាជន ឱ្យពួកបណ្ដាជនចាប់ផ្ដើមធ្វើការងារសាងសង់ព្រះវិហារ ។ ក្នុងរយៈពេលតែ២ខែបន្ទាប់ពីហោរាហាកាយបានថ្លែងព្រះរាជ្យសារលើកទី១ នោះសាការីក៏ចាប់ផ្ដើមថ្លែងទំនាយទៀត (សូមមើល សក ១:១ និងសេចក្ដីផ្ដើមព្រះគម្ពីរសាការី:កាលបរិច្ឆេទ) ។

**៥:២** *សូរ៉ូបាបិល* ឈ្មោះនេះបានដាក់តាមរបៀបជនជាតិបាប៊ីឡូន ដែលមានន័យថា "កូនចៅរបស់ពួកបាប៊ីឡូន" ដោយព្រោះគាត់បានកើតក្នុងគ្រានិរទេស ។ គាត់គឺជាកូនរបស់សាលធាស និងជាចៅរបស់យេហូយ៉ាគីន (សូមមើលក្នុង ១រប ៣:១៧) បន្ទាប់ពីស្ដេចចុងក្រោយរបស់ពួកយូដា ។ សេរ៉ូបាបិលគាត់គឺជាមនុស្សចុងក្រោយក្នុងជំនួរវង្សស្ដេចដាវីឌ ហើយគាត់ជាអ្នកដែលមានទំនុកចិត្តលើគោលនយោបាយ ដោយព្រោះគាត់បានប្រើអំណាចរបស់គាត់ ។ មិនត្រឹមតែប៉ុណ្ណោះ សូរ៉ូបាបិលគាត់គឺជាឰយុកោរបស់ព្រះយេស៊ូវគ្រីស្ទផងដែរ (សូមមើល មថ១:១២-១៣ លក ៣:២៧)។ *យេសួរ* សូមមើលការពន្យល់អំពីគាត់ក្នុង ២:២ ។

**៥:៣** *ថាថ្នាយ* យោងទៅតាមការបញ្ចេញសម្លេងលើឈ្មោះនេះ ប្រហែលគាត់ក៏បានដាក់ឈ្មោះតាមរបៀបជនជាតិបាប៊ីឡូនដែរ ។ *សេថារ-បូសណាយ* គាត់ប្រហែលជាមន្ត្រីរបស់ពួកពើស៊ី ។

**៥:៥** *មិនបានបញ្ឈប់* តាមរយៈឃ្លានេះ បង្ហាញថារដ្ឋមន្ត្រីរបស់ពួកពើស៊ីបានធ្វើឱ្យពួកយូដាមានការសង្ស័យ បញ្ឈប់ការសាងសង់ ដោយការចោទ

សាសន៍យូដា ហើយលោកចៅហ្វាយមិនបានបញ្ឈប់ការ
ដែលកំពុងតែធ្វើនោះទេ ចាំទំរាំបញ្ជូនរឿងនោះ ទៅដល់
ដារីយុស ហើយមានព្រះរាជសាសន៍តបមកកាត់សេចក្តី ។
[៦]នេះជាសំណៅនៃសំបុត្រ ដែលថាថ្នាយ ជាចៅហ្វាយ
ខេត្តខាងនាយទន្លេ និងសេថារ-បូសណាយ ព្រមទាំង
ពួកអ័ផាសាក ជាគូកនលោក នៅខាងនាយទន្លេ បានផ្ញើទៅ
ស្តេចដារីយុស [៧]ក្នុងសំបុត្រដែលផ្ញើទៅស្តេចនោះ មាន
សេចក្តីដូច្នេះថា សូមក្រាបថ្វាយបង្គំចូលមកដល់ព្រះ
ករុណាដារីយុស សូមឱ្យទ្រង់បានប្រកប ដោយសេចក្តីសុខ
ចំរើន [៨]សូមទ្រង់ព្រះករុណាជ្រាបថា យើងខ្ញុំបានទៅក្នុង
ខេត្តយូដា គឺទៅមើលព្រះវិហារនៃព្រះដ៏ធំ ដែលគេកំពុង
តែស្អាងដោយថ្មយ៉ាងធំៗ ឃើញថាគេដាក់ធ្នឹមលើជញ្ជាំង
រួចហើយ ការនោះ[ដ]ក៏ធ្វើយ៉ាងឆាប់រហ័ស ហើយចំរើន
ឡើង ដោយសារដៃគេដែរ [៩]ដូច្នេះ យើងខ្ញុំបានសាកសួរ
ពួកចាស់ទុំរបស់គេថា តើអ្នកណាបានចេញបង្គាប់ឱ្យស្អាង
ព្រះវិហារនេះ ហើយនិងធ្វើកំផែងនេះឡើង[ឋ] [១០]យើងខ្ញុំក៏
បានសួរឈ្មោះគេ ដើម្បីនឹងកត់ឈ្មោះមនុស្សទាំងប៉ុន្មាន
ដែលជាមេរបស់គេ ផ្ញើមកថ្វាយទ្រង់ឱ្យបានជ្រាប [១១]គេ
ឆ្លើយមកយើងខ្ញុំដូច្នេះថា យើងខ្ញុំជាពួកអ្នកបំរើរបស់ព្រះ
នៃស្ថានសួគ៌ និងផែនដី ហើយយើងខ្ញុំកំពុងតែស្អាងព្រះ
វិហារនេះឡើងវិញ[ឌ] ជាវិហារដែលស្តេចធំនៃសាសន៍
អ៊ីស្រាអែល១អង្គ បានស្អាងរួចជាស្រេច ជាយូរមកម្តង
ហើយ [១២]តែនៅគ្រាដែលពួកឰយុកោយើងខ្ញុំបានបណ្តាល
ឱ្យព្រះនៃស្ថានសួគ៌មានសេចក្តីក្រោធ[ឍ] នោះទ្រង់បាន
ប្រគល់គេទៅក្នុងកណ្តាប់ព្រះហស្តនៃប៊ូក្នេស ស្តេចបាប៊ីឡូន
ជាសាសន៍ខាល់ដេទៅ ស្តេចនោះបានបំផ្លាញព្រះវិហារ
នេះទៅ ក៏ដឹកនាំពួកបណ្តាជនទៅជាឈ្លើយ ដល់ក្រុង
បាប៊ីឡូន[ណ] [១៣]តែនៅឆ្នាំដំបូង ក្នុងរាជ្យស៊ីរូស ជាស្តេច
បាប៊ីឡូន នោះស្តេចទ្រង់បានចេញព្រះរាជឱង្ការ១ច្បាប់[ត]
ឱ្យស្អាងព្រះវិហារនេះឡើងវិញ [១៤]ហើយគ្រឿងប្រដាប់
មាស និងប្រាក់ទាំងប៉ុន្មាន របស់ព្រះវិហារនៃព្រះ ដែល
នេប៊ូក្នេសាបានយកចេញពីព្រះវិហារ ដែលនៅក្រុងយេរូ
សាឡិម នាំទៅដាក់ក្នុងព្រះវិហារ នៅក្រុងបាប៊ីឡូន[ថ]
នោះស្តេចស៊ីរូសបានយកចេញពីព្រះវិហារនោះ ប្រគល់
ទាំងអស់ដល់ម្នាក់ឈ្មោះ សេសបាសារ[ទ] ដែលទ្រង់បានតាំង
ឡើងជាចៅហ្វាយខេត្ត [១៥]ទ្រង់បង្គាប់ដល់លោកថា ចូរយក
គ្រឿងប្រដាប់ទាំងនេះ ទៅដាក់ក្នុងព្រះវិហារដែលនៅ
ក្រុងយេរូសាឡិមទៅ ហើយស្អាងព្រះវិហារនៃព្រះនៅ
កន្លែងដដែលនោះឡើងវិញ [១៦]ដូច្នេះ សេសបាសារក៏ទៅ
ដាក់ជើងជញ្ជាំងព្រះវិហារនៃព្រះ[ធ] ដែលធ្លាប់មាននៅក្រុង
យេរូសាឡិម ហើយចាប់តាំងពីវេលានោះ ដរាបដល់សព្វ
ថ្ងៃនេះ គេចេះតែធ្វើការស្អាងព្រះវិហារនោះឡើង តែមិន
ទាន់បានហើយនៅឡើយ [១៧]ដូច្នេះ បើព្រះករុណាយល់
ឃើញថាគួរដែរ នោះសូមឱ្យគេពិនិត្យរកក្នុងមន្ទីរលិខិត
ហ្លួង[ន] នៅក្រុងបាប៊ីឡូននេះ ឱ្យបានដឹងពិតជាស្តេចស៊ីរូស
ទ្រង់ចេញព្រះរាជឱង្ការ ឱ្យស្អាងព្រះវិហារនោះ ដែលនៅ
ក្រុងយេរូសាឡិម ឬមិនមែន រួចសូមទ្រង់ព្រះករុណាផ្ញើ
ទៅបង្គាប់ដល់យើងខ្ញុំ ឱ្យដឹងពីដំណើរនេះ តាមទ្រង់សព្វ
ព្រះហឫទ័យចុះ ។

## ក្រឹត្យរបស់ស្តេចដារីយុស

**៦** [១]ដូច្នេះ ស្តេចដារីយុសទ្រង់ចេញបង្គាប់ ហើយគេក៏
ពិនិត្យរកក្នុងមន្ទីរលិខិត[ក] ជាកន្លែងដែលរក្សាទុកនូវព្រះ
រាជទ្រព្យក្នុងក្រុងបាប៊ីឡូន [២]ហើយគេឃើញមានក្រាំង១

**៥:៥** ញ ២ពវ ២៥:២៨ អរ ៧:៦, ៩,២៨ ៨:១៨ ទដ ៣៣!៨ អស ៦៦:១៤
**៥:៨** ដ ខ.២
**៥:៩** ឋ អរ ៤:១២
**៥:១១** ឌ ១ពវ ៦:១ ២របា ៣:១-២
**៥:១២** ឍ ២របា ៣៦:១៦ ណ ចទ ២១:១០ ២៨:៣៦ ២ពវ ២៤:១ យរ ១:៣
**៥:១៣** ត អរ ១:២-៤
**៥:១៤** ថ អរ ១:៧ ទ ១របា ៣:១៨
**៥:១៦** ធ អរ ៣:១០
**៥:១៧** ន អរ ៤:១៥ **៦:១** ក អរ ៤:១៥

សំណួរ និងដាក់ពាក្យបណ្តឹងដល់ស្តេចដារីយុស ។

**៥:៦-៧** *បានផ្ញើទៅស្តេចដារីយុស . . . ក្នុងសំបុត្រដែលផ្ញើទៅស្តេចនោះមានសេចក្តីដូច្នេះថា* តាមរយៈអត្ថបទដែលមាននៅក្នុងព្រះរាជ្យដំណាក់របស់ស្តេចមួយឈ្មោះថា "ពើស៊ីប៉ូលីស" (Persepolis) បានបង្ហាញបញ្ជាក់ថា គាត់បានបញ្ជូនសំណួរនោះមកដល់ស្តេចដារីយុសដោយផ្ទាល់តែម្តង ដោយបានបរិយាយពីរឿងរ៉ាវដ៏លំអិត ។

**៥:៨** *ធ្នឹម* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា ធ្នឹមនេះប្រហែលជាសំដៅលើបន្ទះក្តាផ្នែកខាងក្នុង(១ពវ ៦:១៥-១៨) ឬក៏ឈើថ្មី និងថ្មយ៉ាងធំៗ (សូមមើល ៦:៤) ។

**៥:១១** *ស្តេចធំនៃសាសន៍អ៊ីស្រាអែល១អង្គ* ស្តេចធំនោះគឺសំដៅលើស្តេចសាឡូម៉ូន ។ ដោយយោងទៅតាមព្រះគម្ពីរ ១ពវ ៦:១ បាននិយាយថាស្តេចសាឡូម៉ូនបានចាប់ផ្តើមកសាងព្រះវិហារនៅក្នុងឆ្នាំទី៤ នៃរាជ្យរបស់ទ្រង់ (នៅក្នុងឆ្នាំ៩៦៦ មុន គ.ស) ហើយរយៈពេល៧ឆ្នាំក្រោយមកទៀតការសាងសង់ព្រះវិហារក៏បានរួចចប់គ្រប់ (សូមមើល ១ពវ ៦:៣៨) ។

**៥:១២** *ជាសាសន៍ខាល់ដេ* នៅក្នុងភាសាអាកាឌានមានន័យថា "អ្នកចម្បាំង" គេមិនបានដឹងពីដើមកំណើតដំបូងរបស់ពួកសាសន៍ខាល់ដេថា កើតចេញពីអំបូរណាច្បាស់លាស់ឡើយ ។ តាមរយៈអ្វីដែលឱពុករបស់នេប៊ូក្នេសានិយាយថា ពួកគេបានផ្តួលរំលំពួកអាសស៊ើរ និងបានបង្កើតទីក្រុងបាប៊ីឡូនថ្មីមួយទៀត(ពីឆ្នាំ ៦១២-៥៣៩ មុន គ.ស) ។

**៥:១៤** *សេសបាសារ . . .ជាចៅហ្វាយខេត្ត* សូមមើលការពន្យល់ពីគាត់នៅក្នុងព្រះគម្ពីរអែសរ៉ាក្នុង ១:៨ ។

**៦:១** *មន្ទីរលិខិត ជាកន្លែងរក្សាទុកនូវព្រះរាជទ្រព្យក្នុងក្រុងបាប៊ីឡូន* នៅក្នុងឃ្លានេះចង់និយាយថា មានឯកសារជាច្រើនដែលគេបានរកឃើញពីការសរសេរចុះពី "រាជទ្រព្យ" របស់ស្តេចដែលស្ថិតនៅក្នុងតំបន់ពើស៊ីនប៉ូលីស ។

នៅក្នុងព្រះរាជដំណាក់ នៅក្រុងអាក់មេថា ៣នៅឆ្នាំទី១ក្នុង
រាជ្យស្តេចស៊ីរូស នោះស្តេចទ្រង់បានចេញ ព្រះរាជឱង្ការ
ពីដំណើរព្រះវិហារនៃព្រះ ដែលនៅក្រុងយេរូសាឡិមថា
ត្រូវឱ្យស្អាងព្រះវិហារនោះឡើងវិញ គឺជាកន្លែងដែល
សំរាប់ថ្វាយយញ្ញបូជា ត្រូវដាក់ឱ្យជើងជញ្ជាំងវិហារនោះ
ឱ្យមាំមួន[ខ] ឯកំពស់ព្រះវិហារ ត្រូវជា៦០ហត្ថ ទទឹង៦០ហត្ថ
ដែរ ៤ដោយថ្មយ៉ាងធំៗ៣ជាន់[គ] និងឈើថ្មី១ជាន់ ឯប្រាក់
ចំណាយ នោះត្រូវបើកមកពីឃ្លាំងហ្លួង[ឃ] ៥ចំណែកគ្រឿង
ប្រដាប់មាសប្រាក់[ង]របស់ព្រះវិហារនៃព្រះ ដែលនេប៊ូក្នេសា
បានយកពីព្រះវិហារ នៅក្រុងយេរូសាឡិម នាំមកឯក្រុង
បាប៊ីឡូន នោះត្រូវប្រគល់ទៅវិញ ឱ្យបានយកទៅដាក់នៅ
កន្លែងធម្មតា ក្នុងព្រះវិហារ ដែលនៅក្រុងយេរូសាឡិមចុះ
ត្រូវដាក់ទាំងអស់ទៅក្នុងព្រះវិហារនៃព្រះ[ច]។
៦ដូច្នេះ ត្រូវឱ្យថាថ្វាយ[ឆ] ជាចៅហ្វាយខេត្តនៅខាង
នាយទន្លេ ហើយនិងសេថារ-បូសណាយ[ជ] ព្រមទាំងពួក
អ័ផារសាក ជាគូកនគេដែលនៅខាងនាយទន្លេ ឃ្លាតឆ្ងាយ
ពីទីនោះទៅ ៧កុំឱ្យឃាត់ឃាំងការ ស្អាងព្រះវិហារនេះ
ឡើយ ចូរទុកឱ្យចៅហ្វាយរបស់ពួកយូដា និងពួកចាស់ទុំ
របស់គេ ស្អាងព្រះវិហារនេះនៅកន្លែងធម្មតានោះចុះ
៨មួយទៀត យើងចេញបង្គាប់ ពីដំណើរដែលអ្នករាល់គ្នា
ត្រូវប្រព្រឹត្តនឹងពួកចាស់ទុំរបស់សាសន៍យូដានេះ សំរាប់នឹង
ជួយស្អាងព្រះវិហារនៃព្រះជាយ៉ាងណាដែរ គឺត្រូវបើក
ព្រះរាជទ្រព្យរបស់ស្តេច[ឈ] ពីសួយអាករនៅ ខាងនាយ
ទន្លេ ដល់អ្នកទាំងនោះទុកសំរាប់នឹងចំណាយ[ញ] ដើម្បីកុំឱ្យ
មានសេចក្តីអាក់ខានការនោះឡើយ ៩ព្រមទាំងរបស់អ្វី
ដែលគេត្រូវការផង ទោះទាំងគោស្ទាវ ចៀមឈ្មោល នឹង
កូនចៀម សំរាប់ជាដង្វាយដុត[ដ] ថ្វាយដល់ព្រះនៃស្ថានសួគ៌
ឬស្រូវ អំបិល ស្រាទំពាំងបាយជូរ និងប្រេង តាមដែលពួក
សង្ឃនៅក្រុងយេរូសាឡិមនឹងប្រាប់មក នោះត្រូវបើកឱ្យ
គេរាល់តែថ្ងៃជាកុំខាន ១០ដើម្បីឱ្យគេបានថ្វាយយញ្ញបូជា

**៦:៤** ក ១ពវ ៦:៣៦
ឃ ខ.៨ អរ ៧:២០
**៦:៥** ង ១របា ២៩:២
ច អរ ១:៧
**៦:៦** ឆ អរ ៥:៣
ជ អរ ៥:៣
**៦:៨** ឈ ខ.៤
ញ ១សយ ៩:២០
**៦:៩** ដ លវ ១:៣,១០
**៦:១០** ឋ អរ ៧:២៣
១ធថ ២:១-២

**៦:២** *ក្រុងអាក់មេថា* ទីក្រុងអាក់មេថា គឺជាទីក្រុង១ក្នុងចំណោមទីក្រុងធំៗទាំង៤ (ស្ថិតនៅតាមនៅជាប់ជាមួយក្រុងបាប៊ីឡូន ក្រុងពើសិប៉ូលីស និងក្រុងស៊ូសា) របស់ចក្រភពពើស៊ី ។ សព្វថ្ងៃនេះទីក្រុងអាក់មេថា ក្លាយជាទីក្រុងហាម៉ាដានប្រទេសអ៊ីរ៉ង ។ ខេត្តមេឌីគឺជាស្រុកកំណើតរបស់ពួកមេឌីដែលស្ថិតនៅប៉ែកខាងជើងនៃប្រទេសអ៊ីរ៉ង់ ។ ពួកមេឌីគឺជាអំបូរ ឥណ្ឌូ អឺរ៉ុប ហើយពួកគេមានទំនាក់ទំនងជិតស្និទ្ធិជាមួយពួកពើស៊ី ។ ពួកមេឌីក្លាយជាប្រជាជនចំណុះរបស់ចក្រភពពើស៊ី បន្ទាប់ពីគ្រាដែលស៊ីរ៉ុសក្លាយជាអ្នកគ្រប់គ្រងលើចក្រភពពើស៊ីក្នុងឆ្នាំ៥៥០ មុន គ.ស ។ នៅក្នុងសញ្ញាថ្មីឈ្មោះរបស់ខេត្តនេះត្រូវបានលើកមកនិយាយជាថ្មី (សូមធៀបជាមួយ កច ២:៩) ។

**៦:៣-៥** សូមធ្វើការប្រៀបធៀបអនុស្សារណៈ នៃព្រះរាជឱង្ការរបស់ស្តេចស៊ីរូសដែលបានសរសេរជាភាសាអាប់រ៉ាម ជាមួយនឹងព្រះរាជឱង្ការនៅក្នុងសំណៅភាសាហេព្រើរដែលបាននិយាយនៅក្នុង ១:២-៤ ។ នៅក្នុងភាសាអាប់រ៉ាម គឺគេសរសេរឡើង ដោយនិយាយពីមន្ត្រីច្រើនជាងនិយាយពីព្រះមានរបស់ព្រះអម្ចាស់(យ៉ាវេហ៍) ។ អនុស្សរនេះនេះមានភាពប្រហាក់ប្រហែល ទៅនឹងព្រះរាជឱង្ការដែលបានអនុញ្ញាត្តិឱ្យពួកយូដាកសាងព្រះវិហារឡើងវិញ ។

**៦:៣** *ឯកំពស់ព្រះវិហារ ត្រូវជា៦០ហត្ថ ទទឹង៦០ហត្ថដែរ* ខ្នាតនិងទំហំព្រះវិហារដែលត្រូវស្អាងឡើងវិញនៅពេលនេះ គឺខុសគ្នាពីខ្នាតទំហំព្រះវិហារដែលស្តេចសាឡូម៉ូនបានស្អាងឡើងកាលពីគ្រាមុន (សូមមើល ១ពវ ៦:៣) ។ ហេតុភេទនេះគឺប្រហែលដោយសារតែគេមិនបានកំណត់ឱ្យច្បាស់ពីទំហំព្រះវិហារដែលត្រូវស្អាងនោះឡើយ ប៉ុន្តែគឺធ្វើតាមការកំណត់របស់ស្តេចពើស៊ី ។ ព្រះវិហារដែលត្រូវស្អាងនៅពេលនេះ មិនធំដូចព្រះវិហារដែលស្តេចសាឡូម៉ូនបានស្អាងឡើយ (សូមមើល ៣:១២ ហក ២:៣) ។

**៦:៤** *ដោយថ្មយ៉ាងធំៗ . . . និងឈើថ្មី១ជាន់* សូមមើលការពន្យល់នៅក្នុង ៥:៨ ។ លក្ខណៈសំណង់នៅពេលនេះ គឺដូចគ្នានឹងសំណង់ដែលស្តេចសាឡូម៉ូនបានស្អាងឡើងក្នុងគ្រាមុនដែរ ដូចដែលបាននិយាយក្នុង ១ពវ ៦:៣៦ ៧:១២ ។ មូលហេតុដែលពួកគេចាក់គ្រឹះដោយមានរៀបធំៗបែបនេះ ប្រហែលដើម្បីការពារ នៅពេលរញ្ជួយផែនដី ។ *ឯប្រាក់ចំណាយ នោះត្រូវបើកមកពីឃ្លាំងហ្លួង* កាលពីឆ្នាំ១៩៧៣ ក្រុមអ្នកបុរាណវិទ្យាបានធ្វើការរុករកគ្រឹះរបស់ព្រះវិហារនៅឯទីក្រុងសានថូស (Xanthos) នៅភាគខាងត្បូងឆៀងខាងលិចនៃប្រទេសទួរគី ដោយបានឃើញថា ស្តេចពើស៊ីជិនាន់ក្រោយបានចេញធុម្មនុញ្ញា ពេលមានការសាងសង់ព្រះវិហារ ដូចគ្នានឹងអ្វីដែលស្តេចស៊ីរូសបានធ្វើដែរ ។ នៅក្នុងជំនាន់លោកអែសរ៉ា ចំនួនដង្វាយទាំងនោះ ព្រមទាំងឈ្មោះពួកសង្ឃ និងការទំនួលខុសត្រូវក្នុងព្រះវិហារគឺមាននិយាយយ៉ាងជាក់ច្បាស់ ។ ស្តេចចក្រភពពើស៊ី គាត់ហាក់បីដូចជាដឹងច្បាស់ពីកិច្ចការការងារព្រះវិហារបំផុត (សូមមើលការពន្យល់ក្នុង ខ.៨ ៧:២០) ។

**៦:៨** *បើករាជទ្រព្យរបស់ស្តេច* នៅក្នុងឃ្លានេះចង់បញ្ជាក់ថា ការប្រទានព្រះរាជទ្រព្យរបស់ស្តេចក្នុងការសាងសង់ព្រះវិហារដែលជាទីបរិសុទ្ធ នៅក្នុងសម័យកាលរបស់គេ គឺជាច្បាប់ដែលមានតាំងពីយូរណាស់មកហើយ ។ ជាក់ស្តែង ដូចជារាជក្រឹត្យដែលទាក់ទងទៅនឹងការសាងសង់ព្រះវិហារពួកយូដាឡើងវិញ គឺបានសរសេរឡើងដោយរដ្ឋមន្ត្រីពើស៊ីដែលគ្រប់គ្រងលើពួកយូដា និងពួកសាមារី។តាមប្រភពក្រៅព្រះគម្ពីរមួយ បាននិយាយថាស្តេចស៊ីរូសបានសាងសង់ព្រះវិហារជាច្រើននៅ ក្រុងអេរេក និងក្រុងអ៊ើរ។ កូនប្រុសច្បងរបស់ស៊ីរូសដែលត្រូវបន្តតំណែងពីគាត់ឈ្មោះថា អ័ហាស៊ូរុសបានផ្តល់ជំនួយដើម្បីកសាងព្រះវិហារនៅប្រទេសអេស៊ីព្ទ ។

**៦:៩** តាមរយៈឃ្លានេះបង្ហាញថា ស្តេចពើស៊ី គាត់បង្ហាញចំណាប់អារម្មណ៍ចំពោះព្រះរបស់ពួកអ៊ីស្រាអែល ដែលមិនមែនជាព្រះរបស់ខ្លួនដោយព្រោះស្តេចស៊ីរុសទី១ និងអ័ហាស៊ូរុសបានចេញបញ្ញត្តិឱ្យកសាងព្រះវិហារ និងសង្ឃនៅប្រទេសអេស៊ីព្ទ ។

**៦:១០** *ហើយអធិស្ឋានឱ្យស្តេច និងពួកព្រះរាជ្យបុត្រាស្តេចបានព្រះជន្មចំរើន*

ទុកជាក្លិនឈ្ងុយដល់ព្រះនៃស្ថានសួគ៌ ហើយអធិស្ឋានឱ្យ
ស្ដេច និងពួកព្រះរាជបុត្រាស្ដេចបានព្រះជន្មចំរើន[ឋ]
១១យើងក៏បានចេញបង្គាប់ថា បើអ្នកណាបំផ្លាស់បំប្រែ
ប្រកាសនេះ នោះត្រូវដោះធ្នឹម១ពីផ្ទះអ្នកនោះ បញ្ឈរឡើង
ចងកគេភ្ជាប់[ឌ]ទៅ រួចត្រូវប្រើផ្ទះគេទុកជាកន្លែងសំរាប់
និងបន្ទោលាមក ដោយព្រោះហេតុនោះឯង[ឍ] ១២ហើយ
សូមឱ្យព្រះដែលបានប្រោសប្រទាន ឱ្យព្រះនាមទ្រង់សណ្ឋិត
នៅទីនេះ[ណ]បានទំលាក់អស់ទាំងស្ដេចណា និងសាសន៍ណា
ដែលលូកដៃទៅធ្វើខុសនឹងប្រកាសនេះ ដើម្បីនឹងបំផ្លាញ
ព្រះវិហារនៃព្រះ ដែលនៅក្រុងយេរូសាឡិមនេះចេញផង
យើង ដារីយុស[ត] បានចេញប្រកាសហើយ ដូច្នេះ ត្រូវឱ្យ
សំរេចសព្វគ្រប់តាមដោយខ្នះខ្នែងចុះ ។
១៣ដូច្នេះ ថាថ្នាយ ជាចៅហ្វាយខេត្តនៅខាងនាយទន្លេ
និងសេថារ–បូសណាយ ព្រមទាំងពួកគូកន[ថ] គេក៏ធ្វើដោយ
ខ្នះខ្នែង តាមសេចក្ដីដែលស្ដេចដារីយុសបានផ្ញើមកគ្រប់
ចំពូក ១៤យ៉ាងនោះ ពួកចាស់ទុំនៃសាសន៍យូដាក៏ស្អាងឡើង
ដោយមានសេចក្ដីចំរើន ដោយនូវការទាយ[ទ]របស់ហោរា
ហាកាយ និងសាការី ជាកូនអ៊ីដោ គេបានស្អាងឡើងដរាប
ដល់ហើយ តាមបង្គាប់ផងព្រះនៃសាសន៍អ៊ីស្រាអែល ហើយ
តាមព្រះឱង្ការនៃស៊ីរូស[ធ] ដារីយុស[ន] និងអើថាសើកសេស[ប]
ជាស្ដេច ពើស៊ីផង ១៥នៅថ្ងៃទី៣ ខែផល្គុណ ក្នុងឆ្នាំទី៦នៃ
រាជ្យស្ដេចដារីយុស នោះព្រះវិហារបានស្អាងឡើងរួចជា
ស្រេច[ផ] ។
១៦គ្រានោះ ពួកកូនចៅអ៊ីស្រាអែល ពួកសង្ឃ និងពួកលេវី
ព្រមទាំងពួកអ្នកដែលត្រូវនាំទៅជាឈ្លើយឯទៀតក៏នាំគ្នា
ធ្វើបុណ្យឆ្លង[ព]ព្រះវិហារនេះដោយអំណរ ១៧គេបានថ្វាយ[ភ]

**៦:១១** ឌ ចទ ២១:២២–២៣ នអ ២:២៣ ៥:១៤ ៩:១៤ ឍ អរ ៧:២៦ ដយ ២:៥ ៣:២៩
**៦:១២** ណ នក ២០:២៤ ចទ ១២:៥ ២រប ៦:២ ត ឧ.១៤
**៦:១៣** ថ អរ ៤:៩
**៦:១៤** ទ អរ ៥:១ ធ អរ ១:១–៤ ន ឧ.១២ ប អរ ៧:១ នហ ២:១
**៦:១៥** ផ សក ១:១ ៤:៩
**៦:១៦** ព ១ពវ ៨:៦៣

នៅក្នុងសិលាចារិកដែលធ្វើពីដីឥដ្ឋមួយបាននិយាយថា ស្ដេចស៊ីរុសគាត់បានទូលសូមថា "សូមឱ្យព្រះទាំងអស់ដែលទូលបង្គំបានតាំងឡើងនៅទីសំងាត់ក្នុងទីក្រុងទាំងប៉ុន្មានប្រទានពរដល់ទូលបង្គំ" ។

**៦:១១** *បើអ្នកណាបំផ្លាស់បំប្រែប្រកាសនេះ* តាមរយៈពាក្យពេចន៍នេះបង្ហាញប្រាប់ឱ្យដឹងថា ជាទូទៅនៅក្នុងសេចក្ដីបញ្ចប់នៃសំបុត្រ ឬសន្ធិសញ្ញាផ្សេងៗ គេតែងតែបន្ថែមពាក្យគំរាម ប្រឆាំងដល់អ្នកណាដែលមានគំនិតទាស់ប្រឆាំងដល់ពួកគេ ។ *បញ្ឈរឡើងចងកគេ* តាមប្រភពមួយបាននិយាយថា នៅពេលដែលស្ដេចស៊ីរុសចាប់បានទីក្រុងបាប៊ីឡូន គាត់បានចាប់ពួកបាប៊ីឡូន ចំនួន៣ពាន់នាក់ចងក (សូមមើលការពន្យល់បន្ថែមក្នុង នអ ២:២៣) ។

**៦:១២** *សូមឱ្យព្រះ . . . បានទំលាក់អស់ទាំងស្ដេចណា និងសាសន៍ណា* នៅចុងបញ្ចប់នៃសិលាចារិកដ៏ល្បីល្បាញរបស់ស្ដេចស៊ីរុសទី១ គាត់បានធ្វើការព្រមានថា "បើសិនជាឯងបានឃើញសិលាចារិកនេះ ហើយបានបំផ្លាញវា ដោយមិនបានការពារថែរក្សា ក្នុងអំឡុងពេលដែលឯងមានកម្លាំងនោះ សូមឱ្យវិញ្ញាណរបស់អ័ហាមាដា ដែលជាព្រះដ៏យុត្តិធម៌វាយបំផ្លាញឯង ហើយឯងមិនបានឃើញក្រុមគ្រួសារឯងឡើយ ព្រមទាំងមិនបានសម្រេចលើកិច្ចការដែលឯងធ្វើដែរ" ។ *សូមឱ្យព្រះដែលបានប្រោសប្រទានឱ្យព្រះនាមទ្រង់សណ្ឋិតនៅទីនេះ* សូមមើលក្នុង ចទ ១២:៥ ។

**៦:១៣–១៤** មូលហេតុដែលធ្វើឱ្យយឺតក្នុងការសាងសង់ព្រះវិហារ មិនមែនបណ្ដាលមកពីការបង្អាក់រាំងស្ទះតែមួយប៉ុណ្ណោះនោះទេ ប៉ុន្តែដោយសារតែពួកអ្នកដែលត្រឡប់ពីនិរទេសវិញគេទៅសំងំស្ងៀមនៅក្នុងផ្ទះរបស់ពួកគេ (សូមមើល ហក ១:២–៩) ។ ដោយសារតែពួកគេនៅសំងំស្ងៀមក្នុងផ្ទះនោះព្រះអម្ចាស់ទ្រង់បានធ្វើឱ្យមានអំណត់អត់និងជំនុំជម្រះដល់ពួកគេ (សូមមើល ហក ១:៥–៦,១០–១១) ។ ដោយសារការព្រះបន្ទូលរបស់ព្រះតាមរយៈហោរាហាកាយ និងហោរាសាការី និងក្រោមការដឹកនាំរបស់សូរ៉ូបាបិល និងយេសួរ នោះគេចាប់ផ្ដើមកសាងព្រះវិហារនេះឡើងវិញ (សូមមើល ហក ១:១២–១៥) ។

**៦:១៤** *អើថាសើកសេស* នៅពេលដែលនិយាយអំពីអើថាសើកសេស ហាក់បីដូចជាមនុស្សដែលនៅក្រៅក្រុម ពីព្រោះគាត់មិនបានជួយអ្វីដល់ការសាងសង់ព្រះវិហារនៃព្រះឡើងវិញឡើយ ។ ហេតុដែលនិយាយអំពីគាត់នៅកន្លែងនេះប្រហែលពេលនេះគាត់បានជួយជាវិភាគទានខ្លះ ដើម្បីជួយកសាងព្រះវិហារនៃព្រះអម្ចាស់ នៅក្នុងសម័យកាលលោកអែសរ៉ា (សូមមើល ៧:២១–២៤) ។

**៦:១៥** *នោះព្រះវិហារបានស្អាងឡើងវិញរួចជាស្រេច* ព្រះវិហារនៃព្រះអម្ចាស់បានស្អាងរួចរាល់នៅថ្ងៃទី៣ខែផល្គុណ ដែលត្រូវនឹងថ្ងៃទី០៣ ខែមេសា ឆ្នាំ៥១៦ មុន គ.ស ។ តាំងពីពេលដែលព្រះវិហារនេះត្រូវបំផ្លាញរហូតដល់ពេលកសាងរួចរាល់ឡើងវិញ គឺត្រូវចំណាយពេលជិត៧០ឆ្នាំ ។ ការស្ថាបនាកសាងព្រះវិហារនេះឡើងវិញ គឺបានចាប់ផ្ដើមឡើងក្នុងថ្ងៃទី ២៤ ខែភទ្របទដែលត្រូវនឹងថ្ងៃទី ២១ខែកញ្ញា ឆ្នាំ៥២០ មុន គ.ស(សូមមើល ហក ១:១៥) ហើយត្រូវចំណាយពេលប្រហែលជា៣ឆ្នាំ៦ខែ ដើម្បីបញ្ចប់ការសាងសង់ ។ នៅក្នុងព្រះគម្ពីរហាកាយ ២:៣ បាននិយាយថា ពួកចាស់ទុំអ៊ីស្រាអែល ដែលបានធ្លាប់ឃើញសិរីល្អជាន់ដើមនៃព្រវិហារដែលស្ដេចសាឡូម៉ូនបានស្អាងឡើង មានការសោកស្ដាយចំពោះព្រះវិហារដែលកសាងលើកទី២ ដោយសូរ៉ូបាបិលពីព្រោះវាមានទំហំតូចជាង (សូមផ្ទៀបជាមួយ អរ ៣:១២) ។ ព្រះវិហារដែលកសាងលើកទី២នេះចំណាយពេលយូរជាងព្រះវិហារលើកទី១ និងតូចជាងក៏ដោយ ក៏បណ្ដាមនុស្សទាំងអស់គេមានអំណរក្នុងជីវិត ។ គម្រោងប្លង់សាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់លើកទី២ គឺប្រហាក់ប្រហែលគ្នានឹងគម្រោងប្លង់លើកទី១ ដែលស្ដេចសាឡូម៉ូនបានកសាងដែរ ប៉ុន្តែនៅក្នុងទីបរិសុទ្ធបំផុតគ្មានផ្ទុកអ្វីឡើយពីព្រោះហឹបនៃសេចក្ដីសញ្ញា បានបាត់ក្នុងអំឡុងពេលដែលពួកបាប៊ីឡូនចូលច្បាំងដណ្ដើមទឹកដី ។

**៦:១៦** *ពួកអ្នកដែលត្រូវនាំទៅជាឈ្លើយ . . . ធ្វើបុណ្យឆ្លងព្រះវិហារ* សូមប្រៀបធៀបពិធីបុណ្យឆ្លងព្រះវិហារនៅពេលនេះ និងពិធីបុណ្យឆ្លងព្រះវិហារ ដែលស្ដេចសាឡូម៉ូនបានរៀបចំឡើង(សូមមើល ១ពវ ជំពូក ៨) ។ ពួកចាស់ទុំទាំងអស់ដែលបានត្រឡប់ពីនិរទេសពេលនោះ មានទំនួលខុសត្រូវក្នុងការស្ថាបនាព្រះវិហារឡើងវិញឱ្យបានចប់សព្វគ្រប់ ។ ពាក្យថា "បុណ្យឆ្លង"គឺបកប្រែមកពីភាសាអារ៉ាមពីពាក្យ"*ហានូខា*" ។

គោឈ្មោល១០០ ចៀមឈ្មោល២០០ និងកូនចៀម៤០០ ជា
ដង្វាយឆ្លងព្រះវិហារ ហើយនិងពពែ១២ តាមចំនួនពូជ
អំបូរសាសន៍អ៊ីស្រាអែល សំរាប់ជាដង្វាយលោះបាបនៃ
ពួកអ៊ីស្រាអែលទាំងអស់ ១៨គេក៏តាំងពួកសង្ឃឡើងតាម
ផ្នែកពួកគេ[ម] ហើយពួកលេវីតាមវេន[យ] សំរាប់ធ្វើការងារ
នៃព្រះនៅក្រុងយេរូសាឡិម ដូចជាបានកត់ទុកក្នុងគម្ពីរ
លោកម៉ូសេហើយ[រ] ។

## បុណ្យរំលង

១៩ឯពួកអ្នកដែលត្រូវនាំទៅជាឈ្លើយនោះ គេក៏ធ្វើ
បុណ្យរំលងនៅថ្ងៃ១៤ខែចេត្រដែរ[ល] ២០ដ្បិតពួកសង្ឃ និង
ពួកលេវីបានសំអាតខ្លួនទាំងអស់គ្នារួចជាស្រេច គេសុទ្ធតែ
បានបរិសុទ្ធហើយ ដូច្នេះ គេបានសំឡាប់[វ]ចៀមសំរាប់ធ្វើ
បុណ្យរំលង ឱ្យពួកអ្នកដែលបាននាំទៅជាឈ្លើយទាំង
ប៉ុន្មាន ព្រមទាំងឱ្យពួកសង្ឃ ជាបងប្អូនគេ និងខ្លួនគេផង
២១រួចពួកកូនចៅអ៊ីស្រាអែល ដែលបានចេញពីសណ្ឋានជា
ឈ្លើយមកវិញ និងអស់អ្នកដែលបានញែកខ្លួន[ស]ចេញពី
សេចក្ដីស្មោកគ្រោក[ហ]របស់ពួកសាសន៍ដទៃ ដើម្បីនឹងស្វែង
រកព្រះយេហូវ៉ា[ឡ] ជាព្រះនៃសាសន៍អ៊ីស្រាអែល គេក៏
បរិភោគបុណ្យនោះ ២២គេធ្វើបុណ្យនំបុ័ងឥតដំបែ[អ] អស់
៧ថ្ងៃដោយអំណរ ដ្បិតព្រះយេហូវ៉ាបានធ្វើឱ្យរីករាយ
សប្បាយ ដោយបំបែរព្រះទ័យ[ក]ស្ដេចស្រុកអាសស៊ើរមក
កាន់ខាងគេ ដើម្បីនឹងចំរើនកំឡាំងដៃគេ ក្នុងការរបស់
ព្រះវិហារនៃព្រះដ៏ជាព្រះនៃសាសន៍អ៊ីស្រាអែល ។

## លោកអែសរ៉ាមកឯក្រុងយេរូសាឡិម

**៧** ១ក្រោយការទាំងនោះមក ក្នុងរាជ្យអើថាស៊ើកសេស[ក]
ជាស្ដេចពើស៊ី នោះអែសរ៉ាកូនសេរ៉ាយ៉ា[ខ] ដែលជាកូន

**៦:១៧** ភ ២សយ ៦:១៣ ២រប ២៩:២១ ៣០:២៤
**៦:១៨** ម ២រប ៣៥:៤ លក ១:៥ យ ១រប ២៤:១ រជន ៣:៦-៩ ៨:៩-១១ ១៨:១-៣២
**៦:១៩** ល នក ១២:១១ ជន ២៨:១៦
**៦:២០** វ ២រប ៣០:១៥,១៧ ៣៥:១១
**៦:២១** ស អរ ៩:១ នហ ៩:២ ហ ចទ ១៨:៩ អគ ៣៦:២៥ ឡ ១រប ២២:១៩ ទដ ១៤:២
**៦:២២** អ នក ១២:១៧ ក អរ ១:១ **៧:១** ក អរ ៤:៧ ៦:១៤ ខ ២ពវ ២៥:១៨ ក ២ពវ ២២:៤

**៦:១៧** *គោឈ្មោល១០០ ចៀមឈ្មោល២០០ និងកូនពពែ៤០០* នៅក្នុងឃ្លានេះចង់និយាយថា ចំនួនសត្វដែលគេយកមកថ្វាយជាយញ្ញបូជានៅចំពោះព្រះ គឺមានចំនួនតិចជាងយញ្ញបូជាក្នុងសម័យកាលស្ដេចសាឡូម៉ូន (សូមមើល ១ពវ ៨:៥,៦៣)ក្នុងគ្រាអេសេគា(សូមមើល ២រប ៣០:២៤) និងយ៉ូសៀស(២រប ៣៥:៧)គឺសម័យនោះគេចាប់ថ្វាយពី១ពាន់ឡើងទៅ មិនមែនពី១រយឡើងទៅឡើយ ។

**៦:១៨** *តាមផ្នែកពួកគេ* ពួកសង្ឃត្រូវបានបែងចែកជា២៤ក្រុម(សូមមើល ១រប ២៤:១-១៩) ហើយក្រុមនិមួយៗត្រូវបម្រើការនៅក្នុងព្រះវិហាររយៈពេល១សប្ដាហ៍ក្នុង១វេន(សូមធៀបជាមួយ លក ១:៥,៨) ។ *ដូចជាបានកត់ទុកក្នុងគម្ពីរលោកម៉ូសេ* នៅក្នុងឃ្លានេះប្រហែលនិយាយសំដៅទៅលើព្រះគម្ពីរ នក ជំពូក ២៩ លវ ជំពូក ៨ ជន ជំពូក ៣ ៨:៥-២៦ និងជំពូក ១៨ ។

**៦:១៩** *គេក៏ធ្វើបុណ្យរំលង នៅថ្ងៃ១៤ខែចេត្រ* ចំពោះថ្ងៃដែលពួកគេរៀបចំបុណ្យរំលងនោះប្រហែលជានៅក្នុងថ្ងៃ២១ខែមេសាឆ្នាំ៥១៦ មុន គ.ស ។ សម្រាប់អត្ថន័យពីពិធីបុណ្យរំលង និងពិធីបរិភោគនំបុ័ងឥតដំបែរដែលបាននិយាយនៅក្នុង ខ.២២ សូមមើលក្នុង នក ១២:១-៣០ ។

**៦:២០** *បានសំអាតខ្លួនទាំងអស់គ្នារួចជាស្រេច គេសុទ្ធតែបានបរិសុទ្ធហើយ* សូមមើលការពន្យល់ក្នុង លវ ៤:១៤ ។ ពួកសង្ឃ និងពួកលេវីត្រូវតែធ្វើពិធីសម្អាតដើម្បីបំពេញកិច្ចការតាមតួនាទីរបស់ពួកគេ ។

**៦:២១** *និងអស់អ្នកដែលបានញែកខ្លួនចេញពីសេចក្ដីស្មោគគ្រោក* ពួកបណ្ដាជនទាំងឡាយដែលវិលពីនិរទេសវិញ ម្នាក់ៗសុទ្ធតែមានចន្ទះទទួលពួកអ្នកដែលបានញែកខ្លួនចេញពីព្រះដទៃ ។

**៦:២២** *ស្ដេចស្រុកអាសស៊ើ* នៅពេលនេះងាររបស់ស្ដេចដារីយុសត្រូវបានគេហៅថា ស្ដេចស្រុកអាសស៊ើ ។ ទោះបីជាបន្ទាប់ពីការដួលរលំទីក្រុងនីនីវេក្នុងឆ្នាំ៦១២ មុន គ.ស ក៏ដោយ ក៏ទម្រង់ពាក្យសព្ទ "អាសស៊ើ"នៅតែបន្តប្រើសម្រាប់ព្រំប្រទល់របស់ពួកអាសស៊ើនៅកន្លែងណា ដែលគេតាំងលំនៅស្នាក់អាស្រ័យ ។ ស្ដេចពើស៊ីមានមុខងារផ្សេងៗគ្នា ក្នុងនោះរួមទាំងងារជា"ស្ដេចបាប៊ីឡូន" (សូមធៀបនឹង ៥:១៣ នហ ១៣:៦) ។

**៧:១-៥** នៅក្នុងខ.គម្ពីរទាំងអស់នេះ បាននិយាយពីជិន្នូរវង្សទាំង១៦នាក់របស់លោកអែសរ៉ា ហើយអ្នកទាំងអស់នោះជាពួកឰយុកោ ដែលកើតចេញពីលោកអើរ៉ុន ជាបងប្រុសលោកម៉ូសេ ។

**៧:១** *ក្រោយការទាំងនោះមក* ពាក្យថា ការទាំងនោះ ដែលអ្នកនិពន្ធបាននិយាយនៅក្នុងកន្លែងនេះ គឺគាត់និយាយសំដៅលើព្រឹត្តិការណ៏ដែលបានកើតឡើងនៅក្នុងជំពូកមុនៗ រួមទាំងព្រឹត្តិការណ៏នៃការស្ថាបនាព្រះវិហាររួចចប់គ្រប់នៅក្នុងឆ្នាំ ៥១៦ មុន គ.ស ។ *អើថាស៊ើកសេស* នៅពេលដែលគេនិយាយអំពីអត្តសញ្ញាណរបស់ស្ដេចអើថាស៊ើកសេស ដែលបាននិយាយក្នុងជំពូកនេះ ធ្វើឱ្យមានការជជែកវែកញែកជាច្រើនអំពីគាត់ ពីព្រោះគេមិនដឹងថា គាត់ជាអើថាស៊ើកសេសណាមួយឡើយ ។ បើសិនគាត់ជាស្ដេចអើថាស៊ើកសេសទី១ នោះលោកអែសរ៉ាអាចមកដល់យូដាក្នុងឆ្នាំ៤៥៨ មុន គ.ស ហើយចន្លោះពេលហេតុការណ៏ក្នុងជំពូក៦ ដល់ជំពូក៧ គឺមានរយៈពេលប្រមាណជា៦០ឆ្នាំ ។ មានព្រឹត្តិការណ៏តែមួយប៉ុណ្ណោះ ដែលគេបានកត់ចុះគឺការបណ្ដឹងចំពោះការសាងសង់ព្រះវិហារឡើងវិញ ក្នុងរាជ្យស្ដេចអ័ហាស៊ូរុស(៤៨៦-៥៦៥ មុន គ.ស) ដែលមាននិយាយក្នុង ៤:៦ ។ *អែសរ៉ា* ទម្រង់ឈ្មោះដើមរបស់គាត់ប្រហែលជាអ័សារ៉ា "មានន័យថា ព្រះយេហូវ៉ាទ្រង់ជាអ្នកជំនួយ" ដែលមាននិយាយ២ដងក្នុងជិន្នូរវង្សរបស់គេដែលមាននិយាយនៅទីនេះស្រាប់ ។ *សេរ៉ាយ៉ា* ឈ្មោះរបស់គាត់មានន័យថា "ព្រះយេហូវ៉ាទ្រង់ជាព្រះអម្ចាស់" ។ លោកសេរ៉ាយ៉ាគឺជាសម្ដេចសង្ឃដែលស្ដេចសេដេគាបានតាំងឡើយ ហើយក្រោយមកទៀតស្ដេចនេះទ្រង់ត្រូវស្ដេចនេប៊ូក្នេសាសម្លាប់ក្នុងឆ្នាំ៥៨៦ មុន គ.ស(សូមមើល ២ពវ ២៥:១៨-២១) ដែលមានមតិខ្លះបាននិយាយថា មានរយៈពេល១២៨ឆ្នាំ មុនពេលដំណើរមកស្រុកយូដារបស់លោកអែសរ៉ា ។ ដូច្នេះ លោកសេរ៉ាយ៉ាគាត់អាចនឹងជាពួកឰយុកោរបស់លោកអែសរ៉ាជាអ្នកនិយាយថា គាត់ជាឪពុកលោកអែសរ៉ាវិញ ។ ពាក្យថា "កូន"ជាញឹកញាប់ គឺនិយាយសំដៅលើពួកកូនចៅ (សូមមើល ១រប ៦:១៤-១៥) ។ *ហ៊ីគីយ៉ា* ឈ្មោះរបស់គាត់មានន័យថា "ព្រះអម្ចាស់ទ្រង់ជាមរដករបស់ខ្ញុំ" ។ ហ៊ីគីយ៉ាគាត់ គឺជាសម្ដេចសង្ឃដែលយ៉ូសៀសបានតាំង

អ័សារា។ជាកូនហ៊ីលគីយ៉ា[គ] ២ហ៊ីលគីយ៉ា ជាកូនសាលូម
សាលូមជាកូនសាដុក[ឃ]។ជាកូនអ័ហ៊ីទូប[ង] ៣អ័ហ៊ីទូប ជាកូន
អ័ម៉ារា។ជាកូនអ័សារា។ជាកូនមេរ៉ាយ៉ូត ៤មេរ៉ាយ៉ូត ជាកូន
សេរ៉ាហ៊ា។ជាកូនអ៊ូស៊ី។ជាកូនប៊ូកគី ៥ប៊ូកគីជាកូនអ័ប៊ីសួរ។
ជាកូនភីនេហាស[ច]។ ជាកូនអេលាសារ។ជាកូនអើរ៉ុនដ៏ជា
សំដេចសង្ឃ ៦អែសរ៉ា[ឆ]នេះ លោកឡើងមកពីក្រុងបាប៊ីឡូន
លោកជាស្មៀនស្ទាត់ជំនាញខាងក្រិត្យវិន័យ លោកម៉ូសេ
ដែលព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលបាន
ប្រទានមក ហើយដោយព្រោះព្រះហស្តនៃព្រះយេហូវ៉ា
ជាព្រះនៃលោក បានសណ្ឋិតលើលោកបានជាស្តេច ទ្រង់
អនុញ្ញាត[ជ]គ្រប់ទាំងសេចក្តីដែលលោកសូម[ឈ] ៧ក៏មានពួក
កូនចៅអ៊ីស្រាអែល ពួកសង្ឃ ពួកលេវី ពួកចំរៀង ពួកឆ្មាំ
ទ្វារ និងពួកនេធីនិមខ្លះ ឡើងទៅឯក្រុងយេរូសាឡិមនៅឆ្នាំ
ទី៧ក្នុងរាជ្យស្តេចអើថាស៊ើកសេសដែរ[ញ] ៨លោកបានមក
ដល់ក្រុងយេរូសាឡិម ក្នុងខែស្រាពណ៍នៅឆ្នាំទី៧ក្នុងរាជ្យ
ស្តេចនោះ ៩ដ្បិតលោកបានចេញពីក្រុងបាប៊ីឡូន នៅថ្ងៃ១
ខែចេត្រ ក៏មកដល់ក្រុងយេរូសាឡិមនៅថ្ងៃ១ខែស្រាពណ៍
ដោយព្រះហស្តល្អរបស់ព្រះនៃលោក បានសណ្ឋិតលើ
លោក[ដ] ១០ពីព្រោះអែសរ៉ាបានតាំងចិត្តស្វែងរកក្នុងក្រិត្យ
វិន័យរបស់ព្រះយេហូវ៉ា ដើម្បីនឹងប្រព្រឹត្តតាម ហើយបង្ហាត់
បង្រៀន[ឋ]តាមបញ្ញត្តិ និងសេចក្តីយុត្តិធម៌ក្នុងពួកអ៊ីស្រា
អែល ។

## សាររបស់ស្តេចអើថាស៊ើកសេសដល់លោកអែសរ៉ា

១១នេះជាសំណៅពីសំបុត្រ ដែលអើថាស៊ើកសេសដ៏ជា
ស្តេចទ្រង់បានប្រទានដល់អែសរ៉ាដ៏ជាសង្ឃ ជាស្មៀនចំឡង
អស់ទាំងព្រះបន្ទូល ក្នុងក្រិត្យក្រមទាំងប៉ុន្មាននៃព្រះយេហូវ៉ា
និងបញ្ញត្តនៃទ្រង់ ដល់ពួកអ៊ីស្រាអែល មានសេចក្តីថា
១២អើថាស៊ើកសេស ជាស្តេចលើអស់ទាំងស្តេច[ឌ]ប្រទាន
ដល់អែសរ៉ាដ៏ជាសង្ឃ ជាស្មៀនចំឡងក្រិត្យវិន័យរបស់ព្រះ
នៃស្ថានសួគ៌។ល។ ១៣យើងចេញព្រះរាជឱង្ការថា ឯអស់
អ្នកណាក្នុងពួកសាសន៍អ៊ីស្រាអែល ឬពួកសង្ឃ និងពួកលេវី
នៅក្នុងនគរយើង ដែលចង់ទៅឯក្រុងយេរូសាឡិម ជាមួយ

**៧:២** ឃ ១ពវ ១:៨ ២:៣៥ ១រប ៦:៨ អគ ៤០:៤៦ ៤៣:១៩ ៤៤:១៥ ង នហ ១១:១១
**៧:៥** ច ១រប ៦:៤
**៧:៦** ឆ នហ ១២:៣៦ ជ ២ពវ ២៥:២៨ ឈ អរ ៥:៥ អស ៤១:២០
**៧:៧** ញ អរ ៨:១
**៧:៩** ដ ខ.៦
**៧:១០** ឋ ចទ ៣៣:១០
**៧:១២** ឌ អគ ២៦:៧ ដយ ២:៣៧
**៧:១៤** ឍ នអ ១:១៤
**៧:១៥** ណ ១រប ២៩:៦ ត ចទ ១២:៥ ២រប ៦:២

ឡើង (សូមមើលក្នុង ២ពវ ២២:៤) ។

**៧:២** *សាដុក* ឈ្មោះរបស់គាត់មានន័យថា "សុចរិត" ។ គាត់គឺជាសង្ឃម្នាក់ដែលស្តេចដាវីឌតាំងឡើង(សូមមើល ២សយ ៨:១៧) ។ ក្រោយមកទៀតស្តេចសាឡូម៉ូនបានតាំងសាដុកឱ្យធ្វើជាសម្តេចសង្ឃ ជំនួសអ័បៀថើរ ដោយព្រោះអ័បៀថើរគាត់បានចូលរួមគាំទ្រជាមួយអ័ដូនីយ៉ា ដើម្បីធ្វើការបះបោរប្រឆាំង(សូមមើល ក្នុង ១ពវ ១:៧–៨ ២:៣៥) ។ លោកអេសេគាលគាត់បានដឹងថា ពួកកូនចៅសាដុកជាអ្នក ដែលបានរក្សាបញ្ញើទីបរិសុទ្ធរបស់ព្រះដោយគេចចេញពីរូបព្រះ(សូមមើលការពន្យល់ក្នុង អគ ៤៤:១៥) ។ ពួកគេនៅ តែបន្តរការងារជាសម្តេចសង្ឃរហូតដល់ឆ្នាំ១៧១ មុន គ.ស ។ បន្ទាប់ពីកូនចៅសាដុកមកប្រហែលជាមានពួកសាឌូស៊ី ដែលគេបានតែងតាំងដើម្បីឱ្យស្ថាបនាជំនួរវង្សសម្តេចសង្ឃសាដុកឡើងវិញ ។ *អ័ហ៊ីទូប* ឈ្មោះរបស់គាត់ប្រហែលជាមានន័យថា "បងប្រុសរបស់ខ្ញុំ(ព្រះអម្ចាស់) ល្អណាស់" ។ អ័ហ៊ីទូប គាត់គឺជាជីតារបស់សាដុក(សូមមើល នហ ១១:១១) ។

**៧:៥** *អេលាសារ* ឈ្មោះរបស់គាត់មានន័យថា"ព្រះយេហូវ៉ាទ្រង់ជាអ្នកជំនួយ" ។

**៧:៦** *ស្មៀន* មើលការពន្យល់ពាក្យនេះក្នុង នហ ៨:១,៤,៩,១៣ ១២:២៦,៣៦ ។ *ស្ទាត់ជំនាញ* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "ជំនាញ" ដូចដែលបាននិយាយក្នុង ទដ ៤៥:១ និង "ខ្នះខ្នែង"នៅក្នុង សភ ២២:២៩ ។ *ព្រះហស្តនៃព្រះយេហូវ៉ា* សូមប្រៀបធៀបពីអំណាចរបស់ព្រះអម្ចាស់ដែលបាននិយាយនៅក្នុង ខ.៩,២៨ ៨:១៨,២២,៣១ នហ ២:៨,១៨ ។

**៧:៧–៩** *នៅក្នុងឆ្នាំទី៧ . . . ក្នុងខែស្រាពណ៍នៅឆ្នាំទី៧ . . . នៅថ្ងៃទី១ខែស្រាពណ៍* លោកអែសរ៉ាគាត់ចាប់ផ្តើមចេញដំណើរពីបាប៊ីឡូនក្នុងថ្ងៃទី១ខែចេត្រដែលត្រូវនឹងថ្ងៃទី៨ខែមេសាឆ្នាំ៤៥៨ មុន គ.ស ហើយបានមកដល់ក្រុងយេរ៉ូសាឡិមក្នុងថ្ងៃទី១ខែស្រាពណ៍ ដែលត្រូវនឹងថ្ងៃទី ៤ខែសីហាឆ្នាំ៤៥៨ មុន គ.ស ដូច្នេះដំណើររបស់គាត់ បានចំណាយថេរវេលា៤ខែនិង១១ថ្ងៃ ។ និទាឃរដូវ គឺជាពេលមួយដែលមានអំណោយផលល្អក្នុងការធ្វើដំណើរ ហើយភាគច្រើនពួកខ្មាំងសត្រូវក៏ចូលមកជិរុំក្នុងខែនេះដែរ (សូមមើល ២សយ ១១:១) ។ ទោះបីជាចម្ងាយផ្លូវពីបាប៊ីឡូនទៅក្រុងយេរូសាឡិមមានចំងាយប្រមាណជា៨០៤ គ.ម(៥០០ម៉ៃយ៍)ក៏ដោយ ប៉ុន្តែអ្នកដំណើរទាំងឡាយគេបានធ្វើដំណើររហូតដល់ ១៤៤៨,១ គ.ម ឯណោះ(៩០០ម៉ៃយ៍) ដោយព្រោះគេធ្វើដំណើរចាប់តាំងពីភាគខាងជើង តាមបណ្តោយសមុទ្រអើប្រាត រហូតដល់ភាគខាងត្បូង ។ ការធ្វើដំណើរយឺតគឺអាចបណ្តាលមកពីមានពួកចាស់ៗ និងកូនក្មេង ។

**៧:១០** *ស្វែងរកក្នុងក្រិត្យវិន័យ . . . ដើម្បីនឹងប្រព្រឹត្តតាម ហើយបង្ហាត់បង្រៀន* សូមមើលការពន្យល់ក្នុង នេហេមាជំពូក៨ ។

**៧:១១** *សំបុត្រ* មានមនុស្សជាច្រើនបានគិតថា សំបុត្ររបស់អើថាស៊ើកសេសទី១ គឺជាចំណុចចាប់ផ្តើមនៃសេចក្តីអធិស្ឋានទាំង៦៩អាទិត្យដំបូងរបស់លោកដានីយ៉ែល (សូមមើល ដយ ៩:២៤–២៧) ។ អ្នកខ្លះទៀតគិតថាសំបុត្រនេះត្រូវបានប្រគល់ជូនលោកនេហេមា ដោយស្តេចអើថាស៊ើកសេស ដើម្បីយកវាមកធ្វើជាចំណុចចាប់ផ្តើម នៃការថ្លែងទំនាយរបស់គាត់(សូមមើល នហ ១:១,១១ ២:១–៨) ។

**៧:១២** *ជាស្តេចលើអស់ទាំងស្តេច* នៅក្នុងឃ្លានេះ គឺជាពាក្យពេចន៍ដំបូងដែលស្តេចអាសស៊ើគាត់បានប្រើ ក្នុងអំឡុងពេលដែលចក្រភពរបស់ពួកគេចូលរួមសហប្រត្តិបត្តិការណ៍ជាមួយនឹងនគរជាច្រើនផ្សេងៗទៀត ។ នៅក្នុងសម័យក្រោយៗមកទៀត ពួកបាប៊ីឡូនក៏ប្រើពាក្យពេចន៏នេះដែរ (សូមមើល អគ ២៦:៧ ដយ ២:៣៧) និងស្តេចចក្រភពពើស៊ី។សូមធៀបជាមួយ ១ធថ ៦:១៥ វវ ១៧:១៤ ១៩:១៦ ។

**៧:១៣** *ពួកសាសន៍អ៊ីស្រាអែល* នៅក្នុងឃ្លានេះចង់និយាយថា ពួកសាសន៏អ៊ីស្រាអែល មិនត្រូវបានគេនិយាយច្រើនដង ដូចជាពួកយូដានោះឡើយ ។ នៅក្នុងកន្លែងនេះ គឺជាបំណងរបស់លោកអែសរ៉ា ដែលចង់ហៅពួកអ្នក

នឹងអ្នក ដោយស្ម័គ្រពីចិត្ត នោះចូរឱ្យគេទៅចុះ ១៤ពីព្រោះ
ស្ដេច និងពួកសេនាបតីទាំង៧[ឋ] បានចាត់អ្នកឱ្យទៅត្រួតត្រា
មើលក្នុងស្រុកយូដា និងក្រុងយេរូសាឡិម តាមក្រិត្យវិន័យ
របស់ព្រះនៃអ្នក ជាច្បាប់ដែលនៅក្នុងកណ្ដាប់ដៃអ្នក
១៥ហើយឱ្យនាំយក[ណ]ប្រាក់ និងមាសដែលយើង ជាស្ដេចនិង
ពួកសេនាបតីទាំង៧ បានថ្វាយស្ម័គ្រចិត្ត ដល់ព្រះនៃសាសន៍
អ៊ីស្រាអែលជាព្រះ ដែលគង់នៅ[ត]ក្រុងយេរូសាឡិម ១៦ព្រម
ទាំងប្រាក់មាស[ថ]ទាំងប៉ុន្មានដែលអ្នកនឹងរៃបាន ពីគ្រប់
ក្នុងខេត្តបាប៊ីឡូន ជាមួយនឹងបណ្ណាការដែលពួកជនទាំង
អំបាលម៉ាន និងពួកសង្ឃថ្វាយដោយស្ម័គ្រពីចិត្ត សំរាប់
ព្រះវិហាររបស់ព្រះនៃគេ ដែលនៅ[ទ]ក្រុងយេរូសាឡិមទៅ
ជាមួយផង ១៧ដូច្នេះ ត្រូវឱ្យអ្នកមានចិត្តខ្នះខ្នែង យកប្រាក់
នោះទៅទិញគោ ចៀមឈ្មោល និងកូនចៀម[ធ] ព្រមទាំង
គ្រឿងដង្វាយម្សៅ និងដង្វាយច្រួច[ន]នោះផង នាំទៅថ្វាយ[ប]
នៅលើអាសនា ក្នុងព្រះវិហារនៃព្រះរបស់អ្នករាល់គ្នា
ដែលនៅក្រុងយេរូសាឡិមចុះ ១៨ឯប្រាក់និងមាសដែល
សល់នៅ នោះត្រូវឱ្យអ្នក និងពួកបងប្អូនអ្នក ប្រើការតាម
តែគិតឃើញថា ត្រឹមត្រូវ តាមព្រះហឫទ័យនៃព្រះរបស់អ្នក
រាល់គ្នាចុះ ១៩ហើយឯគ្រឿងប្រដាប់ទាំងប៉ុន្មាន ដែលបាន
ឱ្យដល់អ្នក សំរាប់ការងារក្នុងព្រះវិហារនៃព្រះរបស់អ្នក
នោះចូរអ្នកយកទៅប្រគល់[ផ] នៅចំពោះព្រះនៃក្រុងយេរូ
សាឡិមទៅ ២០ហើយរបស់អ្វីផ្សេងទៀតដែលខ្វះខាត ក្នុង
ព្រះវិហារនៃព្រះរបស់អ្នក ដែលអ្នកត្រូវការបញ្ចេញប្រាក់
ទិញ នោះត្រូវបញ្ចេញយកពីឃ្លាំងហ្លួងចុះ[ព] ២១មួយទៀត
យើងអើថាស៊ើកសេសជាស្ដេច យើងចេញព្រះរាជឱង្ការ
បង្គាប់ដល់គ្រប់ទាំងមេឃ្លាំង នៅខាងនាយទន្លេថា របស់
អ្វីៗដែលអែសរ៉ាដ៏ជាសង្ឃ ជាស្មៀនចំឡងក្រិត្យវិន័យ
របស់ព្រះនៃស្ថានសួគ៌ លោកនឹងសូមក៏ដោយនោះត្រូវតែ
ឃ្មាតខ្មីនឹងឱ្យចុះ ២២ទោះដល់ទៅប្រាក់១00ហាប ស្រូវ
១00រង្វាល់ ស្រាទំពាំងបាជូរ២00ប៉ោត ប្រេង២00ប៉ោត
និងអំបិលឥតមានកំណត់ក្តី ២៣ត្រូវឱ្យធ្វើសំរេចគ្រប់ទាំង
អស់ ដែលព្រះនៃស្ថានសួគ៌ទ្រង់បង្គាប់មក ដោយត្រូវចំពោះ
សំរាប់ព្រះវិហាររបស់ព្រះនៃស្ថានសួគ៌ចុះ តើនឹងឱ្យមាន
សេចក្តីក្រោធ ចំពោះរាជ្យស្ដេច និងព្រះរាជបុត្រា
ទ្រង់ធ្វើអី[ភ] ២៤មួយទៀត យើងបញ្ជាក់ដល់អ្នករាល់គ្នាថា
ចំណែកពួកសង្ឃ ពួកលេវី ពួកចំរៀង ពួកឆ្មាំទ្វារ ពួក
នេធីនិម និងពួកអ្នកបំរើ ក្នុងព្រះវិហារនៃព្រះនេះ[ម] នោះ
មិនត្រូវឱ្យទារសួយអាករ ពន្ធខ្លួន ឬពន្ធគយ[យ] ពីអ្នកទាំង
នោះឡើយ ២៥ឯអែសរ៉ាឯង តាមប្រាជ្ញារបស់ព្រះនៃអ្នក
ដែលសណ្ឋិតលើអ្នក នោះត្រូវឱ្យអ្នកតាំង[រ]ពួកអ្នកឡើងដែល
ជាអ្នកជំនាញក្នុងក្រិត្យវិន័យរបស់ព្រះនៃអ្នក ឱ្យធ្វើជាចៅ
ក្រមនិងសុភា ឱ្យជំនុំជំរះ ដល់អស់ទាំងសាសន៍នៅខាង

**៧:១៦** ថ នក ៣:២២
ទ សក ៦:១០
**៧:១៧** ធ ២ពវ ៣:៤
ន ជន ១៥:៥-១២
ប ចទ ១២:៥-១១
**៧:១៩** ផ អរ ៥:១៤
យរ ២៧:២២
**៧:២០** ព អរ ៦:៤
**៧:២៣** ភ អរ ៦:១០
**៧:២៤** ម អរ ៤:១៣
យ អរ ៨:៣៦
**៧:២៥** រ នក ១៨:២១,២៦
ល លវ ១០:១១

ដែលវិលត្រឡប់ពីនិរទេសវិញទាំងប៉ុន្មានថា ពួកអ៊ីស្រាអែល ។

**៧:១៤** *ពួកសេនាបតីទាំង៧* សូមធៀបជាមួយ នអ ១:១៤ ដែលនៅក្នុងខ.គម្ពីរនោះបាននិយាយពីអភិជនទាំង៧ដែល "ធ្លាប់នៅចំពោះស្ដេច" ។ *តាមក្រិត្យវិន័យរបស់ព្រះនៃអ្នក* ក្រឹត្យវិន័យដែលបាននិយាយនៅទីនេះ ប្រហែលជាសំដៅលើក្រឹត្យវិន័យ ដែលមាននៅក្នុងកណ្ឌគម្ពីរបញ្ញកណ្ឌ (សៀវភៅទាំង៥ដំបូងរបស់លោកម៉ូសេ សូមមើលការពន្យល់ក្នុង ខ.៦) ។

**៧:១៥** *ប្រាក់ និងមាស* សូមធៀបជាមួយ ហក ២:៨ ។ *ថ្វាយស្ម័គ្រពីចិត្ត* នៅក្នុងឃ្លានេះចង់បញ្ជាក់ប្រាប់ថា ដើម្បីបញ្ជាក់ពីទឹកចិត្តរបស់ទ្រង់ ស្ដេចពើស៊ីបានថ្វាយទ្រព្យជាច្រើន ដល់ពួកយូដាក្នុងការសាងសង់ព្រះវិហារនៃព្រះអម្ចាស់ ។

**៧:១៦** *បណ្ណាការដែលពួកជនទាំងអំបាលម៉ាន* ពួកយូដាដែលនៅក្រៅពីទឹកដីបរិសុទ្ធគេនៅតែបញ្ជូនបណ្ណាការទៅក្រុងយេរូសាឡិមរហូតដល់គ្រាដែលមានចម្បាំងពួករ៉ូម និងពួកយូដា (គ.ស ៦៦-៧៣) ។ នៅពេលដែលទាហានរ៉ូមវាយឈ្នះ នោះពួកយូដាគេបញ្ជូនបណ្ណាការជាច្រើនទៅព្រះវិហារនៃរូបព្រះសេយូស ។

**៧:២០** *នោះត្រូវបញ្ចេញយកពីឃ្លាំងហ្លួង* ពន្ធដែលបានទទួលពីទ្រព្យសម្បត្តិផ្សេងៗនៅត្រង់ពើស៊ីប៉ូលិស អាចជួយសម្រាលមិនឱ្យបញ្ចេញទ្រព្យរបស់ហ្លួងទាំងស្រុង ។

**៧:២២** *ប្រាក់១00ហាប* ប្រាក់១00ហាបជាចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ។ *១00រង្វាល់* ការថ្វាយស្រូវចំនួន១00រង្វាល់គឺជាចំនួនដ៏តិចតួចមួយ។ស្រូវនោះគឺគេប្រើសម្រាប់ជាដង្វាយម្សៅ ។ *អំបិលឥតមានកំណត់* សូមមើលក្នុង ៤:១៤ ។

**៧:២៣** *មានសេចក្តីក្រោធចំពោះរាជ្យស្ដេច* ពួកអេស៊ីព្ទគេបានប្រឆាំងបះបោរជាមួយពួកពើស៊ីនៅក្នុងឆ្នាំ៤៦0 មុន គ.ស ហើយដោយមានជំនួយពីពួកអ្នកក្រុងអាថែន នោះពួកអេស៊ីព្ទក៏បានបណ្តេញពួកពើស៊ីចេញពីទឹកដីរបស់ខ្លួននៅក្នុងឆ្នាំ៤៥៩ មុន គ.ស ។ នៅក្នុងឆ្នាំ៤៥៨ មុន គ.ស លោកអែសរ៉ាគាត់បានធ្វើដំណើរមកក្រុងយេរូសាឡិម ពេលនោះពួកពើស៊ីក៏បានធ្វើការបះបោរប្រឆាំងជាមួយពួកអ្នកដែលសង្កត់សង្កិនគេវិញ ។ គេមិនបានដឹងថា នៅពេលនោះស្ដេចអើថាស៊ើកសេសទ្រង់មានបុត្រប៉ុន្មានអង្គឡើយ ប៉ុន្តែដោយយោងទៅតាមទស្សនៈវិទូរក្រិចដែលបានសរសេរពីប្រវត្តិសាស្ត្ររបស់ពើស៊ីនិយាយថាពេលនោះស្ដេចអើថាស៊ើកសេសទ្រង់មានបុត្រទាំងអស់ចំនួន១៨អង្គ ។

**៧:២៤** *នោះមិនត្រូវឱ្យទារសួយអាករ ពន្ធខ្លួន ឬពន្ធគយ ពីអ្នកទាំងនោះឡើយ* ជាញឹកញាប់ពួកសង្ឃ និងអ្នកផ្សេងៗទៀតដែលបម្រើការងារនៅក្នុងព្រះវិហារ មិនត្រូវបានគេតម្រូវឱ្យបង់ពន្ធខ្លួន ពន្ធគយ ឬក៏ទារសួយអាករអ្វីឡើយ។មានរឿងរ៉ាវដែលប្រហាក់ប្រហែលគ្នានេះទៀតដែលគេបានរកឃើញក្នុងសិលាចារិកហ្គា ដេត (Gadate) ដែលនៅក្នុងសិលាចារិកនោះបាននិយាយថា ស្ដេចដារីយុសទី១ បានបង្គាប់ដល់ចៅហ្វាយខេត្តនៅភាគ

នាយទន្លេ ហើយត្រូវបង្ហាត់បង្រៀន[ល]ក្រិត្យវិន័យ ដល់អស់
អ្នកណាដែលមិនស្គាល់ផង ២៦ឯអ្នកណាដែលមិនព្រម
ប្រព្រឹត្តតាមក្រិត្យវិន័យ របស់ព្រះនៃអ្នក ហើយនិងច្បាប់
របស់ស្តេចផង នោះត្រូវតែកាត់ទោសជាប្រញាប់ចុះ ទោះ
ដល់ស្លាប់ ឬនិរទេស ឬរឹបយករបស់ទ្រព្យគេ ឬដាក់គុកក្តី[វ] ។
២៧សូមសរសើរដំកើងដល់ព្រះយេហូវ៉ា ជាព្រះនៃពួក
ព្ធយុកោយើងរាល់គ្នា ដែលទ្រង់បានបណ្តាលព្រះទ័យ
ស្តេច[ស] ឱ្យសំរេចនឹងតាក់តែង[ហ]ព្រះវិហារនៃព្រះយេហូវ៉ា
ដែលនៅក្រុងយេរូសាឡិមឱ្យល្អឡើងដូច្នេះ ២៨ព្រមទាំង
ប្រោសផ្តល់សេចក្តីសប្បុរសរបស់ទ្រង់[ឡ] ដល់ខ្ញុំនៅចំពោះ
ស្តេច ពួកសេនាបតីទ្រង់ ហើយពួកអ្នកប្រធានដ៏មាន
អំណាចរបស់ស្តេចផង ខ្ញុំក៏មានកំឡាំងចំរើនឡើង ដោយ
នូវព្រះហស្តនៃព្រះយេហូវ៉ា ជាព្រះនៃខ្ញុំ ដែលសណ្ឋិត
លើខ្ញុំ[អ] ហើយខ្ញុំបានទៅប្រមូលពួកអ្នក ដែលជាកំពូលក្នុង
សាសន៍អ៊ីស្រាអែល ឱ្យឡើងទៅជាមួយ ។

## បញ្ជីមេគ្រួសារដែលត្រឡប់មកវិញជាមួយលោកអែសរ៉ា

៨ ១រីឯពួកអ្នកជាប្រធានលើវង្សរបស់ឪពុក ហើយតាម
ពង្សាវតាររបស់ពួកអ្នក ដែលចេញពីក្រុងបាប៊ីឡូន ឡើង
ទៅជាមួយនឹងខ្ញុំ ក្នុងរាជ្យស្តេចអើថាស៊ើកសេស[ក] ២នោះ
ក្នុងពួកកូនចៅភីនេហាស មានគើសុន ក្នុងពួកកូនចៅ
អ៊ីថាម៉ារ មានដានីយ៉ែល ក្នុងពួកកូនចៅដាវីឌ មានហាធូស
៣ក្នុងពួកកូនចៅសេកានា[ខ] ខាងកូនចៅប៉ារ៉ូស[គ]នោះមាន
សាការី ហើយតាមបញ្ជីជាតិ នោះរាប់បានពួកប្រុស១៥០
នាក់ ដែលទៅជាមួយ ៤ក្នុងពួកកូនចៅផាហាត-ម៉ូអាប់[ឃ]
មានអេលីយ៉ូនាយ ជាកូនសេរ៉ាហ៊ា ហើយមានពួកប្រុសៗ
២០០នាក់ទៅជាមួយ ៥ក្នុងពួកកូនចៅសេកានា មានកូន
របស់យ៉ាហាសៀល ហើយមានពួកប្រុសៗ ៣០០នាក់
ទៅជាមួយ ៦ក្នុងពួកកូនចៅអេឌីន[ង]មានអេបេឌ ជាកូន
យ៉ូណាថាន ហើយមានពួកប្រុសៗ៥០នាក់ទៅជាមួយ ៧ក្នុង
ពួកកូនចៅអេឡាំ មានយេសាយ៉ា ជាកូនអ័ថាលា ហើយ
មានពួកប្រុសៗ៧០នាក់ទៅជាមួយ ៨ក្នុងពួកកូនចៅសេ
ផាធា មានសេបាឌា ជាកូនមីកែល ហើយមានពួកប្រុសៗ

**៧:២៦** វ អរ ៦:១១ **៧:២៧** ស អរ ១:១ ហ ១របា ២៩:១២ **៧:២៨** ឡ ២ពវ ២៥:២៨ អ អរ ៥:៥ **៨:១** ក អរ ៧:៧

**៨:៣** ខ ១រប ៣:២២ ក អរ ២:៣ **៨:៤** ឃ អរ ២:៦ **៨:៦** ង អរ ២:១៥នហ ៧:២០ ១០:១៦

ខាងលិចប្រទេសទួរគី មិនឱ្យទារសួយអាករពីពួកសង្ឃដែលនៅក្នុងតំបន់អាប៉ូឡូឡើយ ។ ស្តេចអាន់ទីកុសទី៣ គាត់ក៏បានតម្រូវមិនឱ្យទាមទារ សួយអាករពីពួកយូដាដែលជា "សង្ឃ ស្មៀន ដែលបម្រើការងារនៅក្នុងព្រះវិហារ ហើយពួកចម្រៀងក្នុងព្រះវិហារអាចបន្ធូរបន្ថយលើពន្ធ បោះឆ្នោត ពន្ធថ្វាយស្តេច និងពន្ធអំបិលដែលគេត្រូវថ្វាយ" ។

**៧:២៦** *ឯអ្នកណាដែលមិនព្រមប្រព្រឹត្តតាមក្រិត្យវិន័យ . . . នោះត្រូវតែកាត់ទោសជាប្រញាប់* នៅក្នុងឃ្លានេះចង់និយាយថា អំណាចដែលបានប្រទានមកលោកអែសរ៉ា គឺធ្វើឱ្យមានការគួរឱ្យកត់សំគាល់ និងមានចេតនាដើម្បីបង្ហាញពីអំណាចក្នុងផ្លូវលោកតែម្តង ។ ប្រហែលដោយសារ លក្ខខណ្ឌទាំងនោះបានបង្ករឱ្យមានការបះបោរជាច្រើន នៅក្នុងគ្រាដែលលោកអែសរ៉ាបានធ្វើដំណើរមកក្រុងយេរូសាឡិម ដូច្នេះ ទើបគេមិនបានពន្យល់ពីសកកម្មភាព ការធ្វើដំណើររបស់គាត់ និងដំណើររបស់លោកនេហេមាក្នុងពេល ១៣ឆ្នាំក្រោយមកទៀត ។ នៅមានរឿងរាវដែលនិយាយពីបេសកកម្មរបស់ស្តេចចំពោះលោកអែសរ៉ា ដែលមានភាពប្រហាក់ប្រហែលគ្នានេះទៀតគឺជាបេសកកម្មកាលពីគ្រាមុនរបស់លោកអែសរ៉ា ដែលស្តេចដារីយ៉ុសទី១ បានចេញបញ្ជាឱ្យលោកអែសរ៉ានាំពួកសង្ឃ និងពួកអ្នកប្រាជ្ញឱ្យវិលត្រឡប់ទៅស្រុកអេស៊ីព្ទវិញ ដោយបានយកលក្ខខណ្ឌដែលពួកអេស៊ីព្ទបានចែង ។ ការងារទាំងនោះបានកើតឡើងពីឆ្នាំ៥១៨ ដល់ ៥០៣ មុន គ.ស ។

**៧:២៨** *ដល់ខ្ញុំ* នៅក្នុងឃ្លានេះ នេះជាលើកដំបូងហើយដែលព្រះគម្ពីរអែសរ៉ាបានប្រើទម្រង់វេយ្យាករណ៍ជាបុរសទី១ ។ នេះគឺជាលក្ខណៈពិសេសមួយដែលបានចង្អុលបង្ហាញនៅក្នុងគម្ពីរអែសរ៉ា ដែលនឹងចាប់ផ្តើមនិយាយនៅក្នុង ខ.២៧ ហើយបន្តរហូតដល់ជំពូក ៩ ។

**៨:១–២១** នៅក្នុង ខ.១–១៤ លោកអែសរ៉ាគាត់បានស្រង់ឈ្មោះពួកអ្នកដែលធ្វើដំណើរត្រឡប់ពីស្រុកមេសូប៉ូតាមាវិញជាមួយនឹងគាត់ រួមទាំងកូនចៅរបស់ជិនួរវង្សទាំង១៥នោះថែមទៀត ។ ចំនួនពួកប្រុសៗសរុបទាំងអស់មានចំនួន១៤៩៦នាក់ ហើយក៏មានទាំងពួកស្ត្រីៗ និងកូនក្មេងថែមទៀត (សូមមើលក្នុង ខ.២១) ។ មិនត្រឹមតែប៉ុណ្ណោះក៏មានពួកកូនចៅលេវីប្រមាណជា៤០នាក់(សូមមើល ខ.១៨–១៩) ព្រមទាំងពួកអ្នកជំនួយការងាររបស់ពួកលេវីចំនួន២២០នាក់ថែមទៀត (សូមមើល ខ.២១) ។

**៨:២** *គើសុន* ឈ្មោះនេះមានន័យថា"អញជាអ្នកស្នាក់នៅក្នុងស្រុកដទៃ" (សូមមើលការពន្យល់ក្នុង នក ២:២២) ។ *អ៊ីថាម៉ារ* កូនប្រុសទី៤របស់អើរ៉ុនក៏មានឈ្មោះបែបនេះដែរ (សូមមើល ៦:២៣) ។

**៨:៣** *សាការី* សូមធៀបជាមួយ ខ.១១ ។ ឈ្មោះរបស់គាត់ មានន័យថា "ព្រះអម្ចាស់ទ្រង់នឹកចាំពីខ្ញុំ" ។ នៅក្នុងព្រះគម្ពីរទាំងមូលមានឈ្មោះថា សាការី ប្រមាណជា៣០នាក់ ហើយក្នុងនោះមានទាំងពួកហោរានៅក្នុងសញ្ញាចាស់ និងសាការីជាឪពុកលោកយ៉ូហានបាទីស្ទ (លក ១:៥–៥:៦៧) ។

**៨:៤** *អេលីយ៉ូនាយ* ឈ្មោះនេះមានន័យថា "ព្រះអម្ចាស់ទ្រង់ជាភ្នែកទាំងគូរបស់ទូលបង្គំ" ។ ឈ្មោះនេះមាននិយាយនៅតែកន្លែងនេះនិងក្នុង ១របា ២៦:៣ ប៉ុណ្ណោះ ( សូមធៀបជាមួយ ទដ ២៥:១៥) ។

**៨:៦** *អេបេឌ* ឈ្មោះពិតរបស់គាត់ប្រហែលជា អូបាឌា (សូមធៀប ខ.៩) ។ ប្រហែលដោយគេមិនចង់ហៅឈ្មោះរបស់គាត់ពេញទើបគេហៅថា អេបេឌ បែបនេះ ។ ឈ្មោះរបស់គាត់មានន័យថា"អ្នកបម្រើព្រះអម្ចាស់" ។ *យ៉ូណាថាន* ឈ្មោះនេះមានន័យថា"ព្រះអម្ចាស់ប្រទានឱ្យ"ហើយនៅក្នុងសញ្ញាចាស់ទាំងមូលឈ្មោះនេះមានចំនួន១៥នាក់ផ្សេងៗពីគ្នា ។

**៨:៧** *អ័ថាលា* អ័ថាលាគាត់គឺជាកូនរបស់យេសាយ៉ា (សូមមើល ខ.នេះ) ។ ម្ចាស់ក្សត្រីដ៏ល្បីល្បាញ ដែលជាកូនស្រីរបស់អ័ហាប់ក៏មានព្រះនាមថា អ័ថាលាដែរ (សូមមើលក្នុង ២ពវ ជំពូក១១) ។

**៨:៨** *មីកែល* ឈ្មោះរបស់គាត់មានន័យថា "តើនរណាដូចព្រះអម្ចាស់" ។

៨០នាក់ទៅជាមួយ ៩ក្នុងពួកកូនចៅយ៉ូអាប់ មានអូបាឌា
ជាកូនយេហ៊ីអែល ហើយមានពួកប្រុសៗ២១៨នាក់ទៅ
ជាមួយ ១០ក្នុងពួកកូនចៅសឡូមិត មានកូនរបស់យ៉ូសិភា
ហើយមានពួកប្រុសៗ១៦០នាក់ទៅជាមួយ ១១ក្នុងពួកកូនចៅ
បេបាយមានសាការី ជាកូនបេបាយ ហើយមានពួកប្រុសៗ
២៨នាក់ទៅជាមួយ ១២ក្នុងពួកកូនចៅអាសកាឌមាន
យ៉ូហាណាន ជាកូនហាកាថាន ហើយមានពួកប្រុសៗ១១០
នាក់ទៅជាមួយ ១៣ក្នុងពួកកូនចៅអ័ដូនីកាម[ច]ដែលនៅ
ក្រោយគេ នោះមានឈ្មោះដូច្នេះ គឺអេលីផាលេកយីអែល
និងសេម៉ាយ៉ា ហើយមានពួកប្រុសៗ៦០នាក់ទៅជាមួយ
១៤ក្នុងពួកកូនចៅប៊ីកវ៉ាយ មានអ៊ូថាយ និងសាប៊ូឌ ហើយ
មានពួកប្រុសៗ៧០នាក់ទៅជាមួយ ។

## ការត្រឡប់ទៅក្រុងយេរូសាឡិម

១៥ខ្ញុំបានប្រមូលអ្នកទាំងនោះ មកត្រង់មាត់ទន្លេដែល
ហូរទៅឯក្រុងអាហាវ៉ា[ឆ] យើងរាល់គ្នាក៏ដំឡើងត្រសាល
នៅទីនោះ ៣ថ្ងៃ កំពុងដែលខ្ញុំត្រួតមើលបណ្ដាជន និងពួក
សង្ឃ តែឥតមានឃើញពួកកូនចៅលេវី[ជ]ណាមួយ នៅទី
នោះឡើយ ១៦ដូច្នេះ ខ្ញុំចាត់គេឱ្យទៅហៅអេលាស៊ើរ
អើរាល សេម៉ាយ៉ា អែលណាថាន យ៉ារីប អែលណាថាន់
ណាថាន់ សាការី និងមស៊ូឡាម ជាពួកប្រធានមក ព្រមទាំង
យ៉ូយ៉ារីប និងអែលណាថាន ជាមនុស្សដែលប្រកបដោយ
ប្រាជ្ញា ១៧រួចខ្ញុំចាត់ពួកអ្នកទាំងនោះ ឱ្យទៅឯអ៊ីដោជាមេ
ដែលនៅកន្លែងហៅថា កាសិភា ដោយបង្គាប់ពាក្យដែល
គេត្រូវជំរាបដល់អ៊ីដោ និងពួកនេធីនិម ជាបងប្អូនលោក
នៅត្រង់កាសិភានោះ ដើម្បីនឹងនាំពួកអ្នកសំរាប់ធ្វើការ
ងារ[ឈ] ក្នុងព្រះវិហាររបស់ព្រះនៃយើងរាល់គ្នាមកជា១ផង
១៨ហើយតាមដែលព្រះហស្តល្អ របស់ព្រះនៃយើងរាល់គ្នា
បានសណ្ឋិតលើយើង[ញ] នោះគេបាននាំមនុស្សម្នាក់ប្រកប
ដោយប្រាជ្ញា មកឯយើង ពីពួកម៉ាសលី ជាកូនលេវី
ដែលជាកូនអ៊ីស្រាអែល ព្រមទាំងសេរេប៊ីយ៉ា[ដ] និងកូនចៅ
ហើយបងប្អូន ទាំងអស់មាន១៨នាក់ ១៩និងហាសាបយ៉ា
ហើយមានយេសាយ៉ា ពីពួកកូនចៅម្រ៉ារី និងបងប្អូន ហើយ
កូនចៅទាំងអស់រួមគ្នា២០នាក់មកជាមួយ ២០ឯពួកនេធីនិម
ដែលដាវីឌនិងអ្នកជាប្រធានបានថ្វាយសំរាប់ជួយការងារ[ឋ]
ពួកលេវី នោះមាន២២០នាក់ ដែលសុទ្ធតែបានដំរូវដោយ
ឈ្មោះរៀងខ្លួន ។
២១រួចមកខ្ញុំបានប្រកាសប្រាប់ ឱ្យមានការតមនៅមាត់
ទន្លេអាហាវ៉ានោះ[ឌ] ដើម្បីឱ្យយើងបានបន្ទាបខ្លួននៅចំពោះ

**៨:១៣** ច អរ ២:១៣
**៨:១៥** ឆ ខ.២១,៣១
ជ អរ ២:៤០
**៨:១៧** ឈ អរ ២:៤៣
**៨:១៨** ញ អរ ៥:៥
ដ ខ.២៤
**៨:២០** ឋ ១រប ៩:២
**៨:២១** ឌ ខ.១៥
ឍ ទជ ៥:៨
២៧:១១ ១០៧:៧

---

នៅក្នុងព្រះគម្ពីរក៏មានជនល្បីឈ្មោះ១០នាក់ទៀត មានឈ្មោះមីកែលហើយទេវតានៃព្រះក៏មានព្រះនាមថាមីកែលដែរ (សូមមើល ដយ ១០:១៣ យូដាស ខ.៩ វវ ១២:៧) ។

**៨:១០** *សឡូមិត* ឈ្មោះរបស់គាត់មានលក្ខណៈដូចស្ត្រីផង (សូមមើលក្នុង បស ៦:១៣) និងប្រុសផង ជាក់ស្តែងដូចជានៅកន្លែងនេះជាដើម ។ នៅក្នុងភាសាក្រិចឈ្មោះនេះសមមូលនិងពាក្យថាសាឡូម ។

**៨:១២** *អាសកាឌ* សូមមើលការពន្យល់អំពីគាត់ក្នុង ២:១២ ។ *យ៉ូណាថាន* សូមមើលការពន្យល់ក្នុង ២:៤៦ ។

**៨:១៥** *នៅត្រង់មាត់ទន្លេ ដែលហូរទៅក្រុងអាហាវ៉ា* ប្រហែលជាទន្លេនេះហូរចូលទៅក្នុងទន្លេអ៊ើប្រាត និងទន្លេហ៊ីដេកែល ដែលទន្លេទាំង២នេះស្ថិតនៅមិនឆ្ងាយប៉ុន្មានពីក្រុងបាប៊ីឡូន ។ *៣ថ្ងៃ* រយៈពេល៣ថ្ងៃដែលនិយាយនៅកន្លែងនេះ ប្រហែលចាប់រាប់ពីថ្ងៃទី៩ រហូតដល់ថ្ងៃទី១២ក្នុងខែចេត្រ ពីព្រោះនៅថ្ងៃទី១២ខែចេត្រ គេក៏ចាប់ផ្តើមធ្វើដំណើរចេញពីអាហាវ៉ាឆ្ពោះទៅកាន់ក្រុងយេរូសាឡិម (សូមមើល ខ.៣១) ។ *តែឥតឃើញមានពួកកូនចៅលេវីណាមួយ នៅទីនោះឡើយ* ក្នុងអំឡុងគ្រានិរទេស បែបផែននៃជីវិតរស់នៅរបស់ពួកកូនចៅលេវី អាចមានសភាពល្អប្រសើរជាងមុន ដោយព្រោះពួកគេជាអ្នក ដែលមានទំនួលខុសត្រូវបម្រើកិច្ចការងារនៅក្នុងព្រះវិហារ ។ នៅក្នុងសិលាចារិករបស់ពួកយូដា ដែលបានសរសេរជា ព្រះគម្ពីរភាសាហេព្រើរស្តីពីព្រឹត្តិការណ៍នៅក្នុងអត្ថបទគម្ពីរទំនុកដំកើង ១៣៧ ឈ្មោះថាមីតរ៉ាស (midrash) បានបង្ហាញថា ពួកកូនចៅលេវីក៏បានរួមដំណើរទៅក្រុងយេរូសាឡិមដែរ ប៉ុន្តែពួកគេគ្មានសមត្ថភាពធ្វើជាអ្នកដឹកនាំទេ ពីព្រោះពួកគេបានបដិសេធ មិនព្រមច្រៀងចម្រៀងអំពីក្រុងស៊ីយ៉ូនថ្វាយស្តេចនេប៊ូក្នេសា និងបានខាំចុងម្រាមដៃខ្លួនឯង ជាហេតុធ្វើឱ្យពួកកូនចៅលេវីលេងស៊ុងបានទៀតឡើយ ។ ចំណែកឯរឿងព្រេងរបស់ក្រិច (សរសេរឡើងបន្ទាប់ពីការស្លាប់របស់អាឡិចហ្សង់ឌឺ ក្នុងចម្បាំងដណ្តើមទឹកដីបរិសុទ្ធក្នុងឆ្នាំ៣៣៣ មុន គ.ស) បាននិយាយថាពួកលេវីបានបដិសេធមិនព្រមច្រៀងចម្រៀងពីក្រុងស៊ីយ៉ូន ឱ្យស្តេចនេប៊ូក្នេសារស្តាប់ឡើយ ។

**៨:១៦** *អើរាល* ឈ្មោះរបស់គាត់មានន័យថា "សិង្ហរបស់ព្រះ" ឬ "ជើងទម្រអាសនា" (សូមមើលការពន្យល់អំពីគាត់នៅក្នុង អស ២៩:១,២,៧) ។ ឈ្មោះរបស់គាត់ គឺមាននិយាយតែនៅកន្លែងនេះប៉ុណ្ណោះ ។ *មស៊ូឡាម* មានអ្នកខ្លះនិយាយពីគាត់ថា គាត់និងមស៊ូឡាមដែលបានជំទាស់ប្រឆាំងចំពោះច្បាប់រៀបអាពាហ៍ពិពាហ៍ (សូមមើល ១០:១៥) ។

**៨:១៧** *កាសិភា* អ្នកខ្លះនិយាយថា នៅសម័យក្រោយមកទៀត កាសិភាបានក្លាយជាទីក្រុងដ៏ល្បីល្បាញមួយនៅទន្លេហ៊ីឌីកែល ដែលស្ថិតនៅភាគខាងជើងនៅក្រុងបាប៊ីឡូន ។

**៨:១៨–១៩** *១៨នាក់ . . . ២០នាក់* នៅក្នុងកន្លែងនេះចង់បង្ហាញថា មានពួកកូនចៅលេវីដែលចេញពី២គ្រួសារ ចំនួន៣៨នាក់បានចូលរួមធ្វើដំណើរមកកាន់ក្រុងយេរ៉ូសាឡិមជាមួយលោកអែសរ៉ា ។

**៨:២០** *សំរាប់ជួយការងារ* សូមមើលក្នុង ២:៤៣–៥៧ ។

**៨:២១** *ដំរង់ផ្លូវ* នៅក្នុងឃ្លានេះចង់និយាយថា ការធ្វើដំណើររបស់ពួកគេមិនបានជួបឧបសគ្គ ឬមានអ្វីមករារាំង ក៏គ្មានគ្រោះថ្នាក់ណាមួយកើតដល់គេផង (សូមមើល ខ.៣១ ធៀបជាមួយ សភ ៣:៦) ។ *របស់ទ្រព្យ* នៅក្នុងឃ្លា

ព្រះនៃយើងរាល់គ្នា ប្រយោជន៍នឹងសូមទ្រង់ឱ្យដំរង់ផ្លូវ[ឈ]
យើង និងកូនចៅ ហើយរបស់ទ្រព្យយើងទាំងអស់ផង
២២ដ្បិតដែលសូមទាហាន[ណ] និងពលសេះ ពីស្តេចឱ្យទៅរាំង
រាពួកខ្មាំងសត្រូវតាមផ្លូវ នោះនឹងនាំឱ្យខ្ញុំមានសេចក្តីខ្មាស
ពីព្រោះយើងបានទូលស្តេចហើយថា ព្រះហស្តនៃព្រះ
របស់យើងរាល់គ្នា[ត] សណ្ឋិតនៅនឹងអស់អ្នកដែលស្វែងរក
ទ្រង់ ដើម្បីនឹងប្រោសឱ្យបានសេចក្តីល្អ តែព្រះចេស្តានឹង
សេចក្តីក្រេវក្រោធនៃទ្រង់ នោះទាស់នឹងអស់អ្នកដែលបោះ
បង់ចោលទ្រង់វិញ[ថ] ២៣ដូច្នេះ យើងរាល់គ្នាបានតម[ទ]
ហើយសូមអង្វរដល់ព្រះនៃយើងពីដំណើរនេះ ហើយទ្រង់ក៏
ទទួលស្តាប់តាមយើង ។
២៤រួចមក ខ្ញុំក៏ញែកមេពួកសង្ឃ១២នាក់ចេញទុក គឺ
សេរេប៊ីយ៉ា និងហាសាបយ៉ា[ធ] ព្រមទាំងបងប្អូនគេ១០នាក់ឯ
ទៀត ២៥រួចខ្ញុំថ្លឹង[ន]ប្រាក់ មាស និងគ្រឿងប្រដាប់ទាំងប៉ុន្មាន
ប្រគល់ដល់គេ គឺជាដង្វាយសំរាប់ ព្រះវិហារនៃព្រះរបស់
យើង ដែលស្តេច ពួកសេនាបតី ពួកអ្នកជាប្រធានរបស់
ទ្រង់ និងពួកអ៊ីស្រាអែលទាំងអស់ ដែលនៅទីនោះបាន
ថ្វាយ ២៦ខ្ញុំថ្លឹងប្រាក់៦៥០ហាប គ្រឿងប្រាក់១០០ហាប់នឹង
មាស១០០ហាប ២៧ព្រមទាំងពែងមាស២០ មានដំឡៃ១
ពាន់ដារីក ហើយប្រដាប់ប្រដាធ្វើពីទង់ដែងយ៉ាងភ្លឺ ដែល
មានដំឡៃដូចជាមាស ប្រគល់ដល់ដៃគេ ២៨រួចខ្ញុំនិយាយទៅ
គេថា អ្នករាល់គ្នាជាមនុស្សបរិសុទ្ធដល់ព្រះយេហូវ៉ា[ប]
ហើយគ្រឿងប្រដាប់ទាំងនេះក៏បរិសុទ្ធដែរ ឯប្រាក់នឹង
មាសនេះ ជាដង្វាយដែលថ្វាយស្ម័គ្រពីចិត្តដល់ព្រះយេហូវ៉ា
ជាព្រះនៃពួកឰយុកោអ្នករាល់គ្នា ២៩ដូច្នេះ ចូរប្រុងប្រយ័ត្ន
នឹងថែរក្សារបស់ទាំងនេះ ដរាបដល់អ្នករាល់គ្នាបានថ្លឹង
ទាំងអស់ នៅក្រុងយេរូសាឡិម ប្រគល់នៅចំពោះមេពួក
សង្ឃ និងពួកលេវី ហើយនិងពួកដែលជា កំពូលលើវង្ស
របស់ឪពុកសាសន៍អ៊ីស្រាអែល ដាក់ទៅក្នុងបន្ទប់នៃព្រះ
វិហាររបស់ព្រះយេហូវ៉ារួចជាស្រេច ៣០ពួកសង្ឃ ហើយ
និងពួកលេវី ក៏ទទួលយកប្រាក់មាស និងគ្រឿងប្រដាប់ទាំង
នោះ តាមទំងន់ ដើម្បីនឹងយកទៅដាក់ក្នុងព្រះវិហារនៃព្រះ
ជាព្រះរបស់យើងរាល់គ្នា នៅក្រុងយេរូសាឡិម ។
៣១រួចមក នៅថ្ងៃទី១២ខែចេត្រ នោះយើងរាល់គ្នា
បានធ្វើដំណើរចេញពីទន្លេអាហាវ៉ា[ផ] ដើម្បីនឹងទៅឯក្រុង
យេរូសាឡិម ព្រះហស្តនៃព្រះរបស់យើងក៏សណ្ឋិតនៅជា
មួយ[ព] ហើយទ្រង់ជួយឱ្យយើងរួច ពីកណ្តាប់ដៃនៃពួកខ្មាំង
សត្រូវ និងពួកចោរដែលបង្កប់ខ្លួនតាមផ្លូវផង ៣២យើង
រាល់គ្នាក៏បានដល់ក្រុងយេរូសាឡិម ហើយបាននៅទីនោះ
អស់៣ថ្ងៃ[ភ] ៣៣លុះដល់ថ្ងៃទី៤ នោះយើងថ្លឹង[ម]ប្រាក់ មាស
និងគ្រឿងប្រដាប់ទាំងប៉ុន្មាន ប្រគល់ដល់ដៃម្រេម៉ូត[យ] ជាកូន
អ៊ូរីយ៉ាដ៏ជាសង្ឃ នៅក្នុងព្រះវិហារនៃព្រះរបស់យើងរាល់
គ្នា មានអេលាសារ ជាកូនភីនេហាស ព្រមទាំងយ៉ូសាបាឌ[រ]
ជាកូនយេសួរ និងណូអាឌា ជាកូនប៊ីនុយ[ល] ជាពួកលេវី នៅ
ជាមួយដែរ ៣៤គេត្រួតមើលទាំងអស់តាម ចំនួនតាមទំងន់

**៨:២២** ណ នហ ២:៩ យរ ៤១:១៦ ត អរ ៥:៥ ថ ចទ ៣១:១៧
**៨:២៣** ទ ២របា ២០:៣ កច ១៤:២៣
**៨:២៤** ធ ខ.១៨
**៨:២៥** ន ខ.៣៣
**៨:២៨** ប លវ ២១:៦ ២២:២-៣
**៨:៣១** ផ ខ.១៥ ព អរ ៥:៥
**៨:៣២** ភ លប ៤០:១៣
**៨:៣៣** ម ខ.២៥ យ នហ ៣:៤,២១ រ នហ ១១:១៦ ល នហ ៣:២៤

នេះចង់និយាយថា កាលណាគេយកទ្រព្យសម្បត្តិច្រើនមកតាមខ្លួន អាចនឹងធ្វើឱ្យមានចោរប្លន់ ។

**៨:២២** *ខ្ញុំមានសេចក្តីខ្មាស* ជាញឹកញាប់នៅក្នុងបទគម្ពីរតែងតែនិយាយអំពីសេចក្តីខ្មាសដែលមិនបរិសុទ្ធ (សូមមើល យរ ៤៨:១៣ ៤៩:២៣ មក ៣:៧) ចំណែកកន្លែងនេះវិញ និយាយពីសេចក្តីខ្មាសដែលបរិសុទ្ធ ។ នៅពេលដែលលោកអែសរ៉ាមានសេចក្តីខ្មាស មុខរបស់គាត់ឡើងក្រហម (សូមមើល ៩:៦) ។ មូលហេតុដែលបណ្តាលឱ្យលោកអែសរ៉ាមានសេចក្តីអៀនខ្មាស់ក្នុងការសុំឱ្យមានមនុស្សការពារពួកអ្នកដំណើរទាំងនោះ ព្រោះលោកបានប្រកាសពីសេចក្តីជំនឿថា ព្រះអម្ចាស់មានអំណាចក្នុងការពារពួកអ្នកទាំងនោះ ។ គ្រោះថ្នាក់ដែលកំពុងតែប្រឈរមុខ គឺពួកអ្នកដំណើរទាំងនោះបានធ្វើដំណើរលើចំងាយផ្លូវយ៉ាងវែងអន្លាយ ចាប់តាំងពីស្រុកមេសូប៉ូតាមាមកទឹកដីបរិសុទ្ធ ។ ១៣ឆ្នាំក្រោយមកទៀត មានពួកទាហានបានរួមដំណើរមកជាមួយលោកនេហេមា ហើយតាមផ្លូវពួកគេក៏បានជួបប្រទះគ្រោះថ្នាក់ជាច្រើន ប៉ុន្តែមិនមែនមានន័យថាលោកនេហេមានិងមនុស្សរបស់គាត់ខ្វះជំនឿនោះឡើយ (សូមមើល នហ ២:៩) ។

**៨:២៣** *តមហើយសូមអង្វរ* សម្រាប់ការរួមគ្នាតម និងអធិស្ឋានសូមមើលក្នុង ២សយ ១២:១៦ នហ ១:៤ ដយ ៩:៣ មថ ១៧:២១ កច ១៤:២៣ ។

**៨:២៦** *ប្រាក់៦៥០ហាប . . . ១០០ហាប* នៅក្នុងឃ្លានេះចង់បង្ហាញថា ពួកបណ្តាជនគេបានថ្វាយដង្វាយស្ម័គ្រចិត្តជាច្រើន ដើម្បីកសាងព្រះវិហារ ដែលប្រាក់និងមាសទាំងនោះអាចស្មើនឹងមួយលានដុល្លារសព្វថ្ងៃនេះ ។ សូមមើលបន្ថែមក្នុង ៧:២២ ។

**៨:២៧** *ដារីក* សូមមើលការពន្យល់ពីខ្នាតនេះ ក្នុងព្រះគម្ពីរ ។ ខ្នាតទម្ងន់ដែលគិតជាដារីកនេះ គឺមាននិយាយនៅតែកន្លែងនេះនិងក្នុង ១របា ២៩:៧ ប៉ុណ្ណោះ (ប៉ុន្តែសូមមើលក្នុង ២:៦៩) ។ *ភ្លឺ* ទង់ដែងប្រភេទនេះប្រហែលជាមានពន្លឺពណ៌លឿងដែលភ្លឺចិញ្ចាច (ក្នុងព្រះគម្ពីរភាសាហេព្រើរ "ពណ៌លឿង" ដែលបាននិយាយនៅក្នុង លវ ១៣:៣០,៣២,៣៦ គឺមានទំនាក់ទំនងនឹងពាក្យ ភ្លឺដែលមាននិយាយនៅកន្លែងនេះ) ដែលកើតឡើងដោយការបន្សុំពីស្ពាន់ ដែលកាលពីសម័យបុរាណវាមានតម្លៃថ្លៃដូចមាសដែរ ។

**៨:៣១** *ថ្ងៃទី១២* សូមមើលការពន្យល់ក្នុង ខ.១៥ ៧:៧-៩ ។

**៨:៣២** *បាននៅទីនោះអស់៣ថ្ងៃ* បន្ទាប់ពីលោកនេហេមាមកដល់ក្រុងយេរូសាឡិមក៏បានសម្រាកចំនួន៣ថ្ងៃដែរ (សូមមើលក្នុង នហ ២:១១) ។

**៨:៣៣** *ម្រេម៉ូ ជាកូនអ៊ូរីយ៉ា* ប្រហែលគាត់ជាមនុស្សតែមួយនឹងម្នាក់ដែលបានរៀបចំជុសជុលកំផែងក្រុងឡើងវិញ ដែលមាននិយាយក្នុង នហ ៣:៤,២១ ។

**៨:៣៤** *កត់ទុក* តាមទំលៀមទម្លាប់របស់ពួកបាប៊ីឡូនបានបង្ហាញថា ស្ទើរតែ

ហើយក៏កត់ទុកនៅវេលានោះឯង ។
៣៥ ឯពួកអ្នកដែលបានត្រឡប់ពីសណ្ឋានជាឈ្លើយមកវិញ
គេក៏ថ្វាយដង្វាយដុតដល់ព្រះនៃសាសន៍អ៊ីស្រាអែល គឺគោ
ឈ្មោល១២[វ] ឱ្យពួកអ៊ីស្រាអែលទាំងអស់[ស] ព្រមទាំងចៀម
ឈ្មោល៩៦ កូនចៀម៧៧ និងពពែ១២[ហ] សំរាប់ជា
ដង្វាយលោះបាប នោះសុទ្ធតែជាដង្វាយដុត ថ្វាយដល់ព្រះ
យេហូវ៉ាទាំងអស់ ៣៦ គេក៏ប្រគល់ព្រះរាជសាសន៍[ឡ] ដល់
នាយកដំណាងស្តេច និងចៅហ្វាយខេត្តនៅខាងនាយទន្លេ[អ]
ហើយលោកទាំងនោះ ក៏ជួយចំរើនដល់ពួកបណ្តាជន និង
ព្រះវិហារនៃព្រះ[ក] ។

## លោកអែសរ៉ាអធិស្ឋានសម្រាប់ការរៀបការជាមួយសាសន៍ដទៃ

**៩** ១ កាលការទាំងនោះបានសំរេចអស់ហើយ នោះពួកអ្នក
ជាប្រធាន ក៏មកឯខ្ញុំនិយាយថា ពួកអ៊ីស្រាអែលទាំងប៉ុន្មាន
ព្រមទាំងពួកសង្ឃ និងពួកលេវី មិនបានញែកខ្លួន[ក] ចេញពី
ពួកអ្នកស្រុកនេះទេ គឺគេប្រព្រឹត្តតាមអំពើគួរស្អប់ខ្ពើមរបស់
ពួកសាសន៍កាណាន សាសន៍ហេត សាសន៍ពេរិស៊ីត
សាសន៍ យេប៊ូស[ខ] សាសន៍អាំម៉ូន[គ] សាសន៍ម៉ូអាប់[ឃ] សាសន៍
អេស៊ីព្ទ និងសាសន៍អាម៉ូរីវិញ[ង]
២ ដ្បិតគេបានយកកូនស្រី
ក្រមុំ[ច] នៃសាសន៍ទាំងនោះ សំរាប់ខ្លួនគេ និងសំរាប់កូន
ប្រុសគេដែរ យ៉ាងនោះពូជបរិសុទ្ធ[ឆ] បានលាយឡំ[ជ] និងពួក
អ្នកស្រុកទាំងនេះ ហើយគឺពួកអ្នកជាប្រធាន និងពួកចៅ
ហ្វាយជាលេខ១ ក្នុងការរំលងនេះដែរ[ឈ]
៣ កាលខ្ញុំបានឮ
សេចក្តីនោះ ខ្ញុំក៏ហែក[ញ] សំលៀកបំពាក់ បោចសក់ក្បាល

**៨:៣៥** វ លវ ១:៣ ស ២របា ២៩:២៤ ហ ២របា ២៩:២១ ៣០:២៤ **៨:៣៦** ឡ អរ ៧:២១–២៤ អ នហ ២:៧ ក នអ ៩:៣
**៩:១** ក អរ ៦:២១ ខ លប ១០:១៦ យស ១៥:៨ គ លប ១៩:៣៨ ឃ លប ១៩:៣៨ ង នក ១៣:៥ ២៣:២៨ ចទ ២០:១៧ យស ៣:១០ ពច ៣:៥ ១ពវ ៩:២០ ២របា ៨:៧ នហ ៩:៨ **៩:២** ច នក ៣៤:១៦ នរ ១:៤ ឆ នក ២២:៣១ លវ ២៧:៣០ ចទ ១៤:២ ជ ទដ ១០៦:៣៥ ឈ អរ ១០:២ **៩:៣** ញ ជន ១៤:៦ ដ នក ៣២:១៩ ៣៣:៤

ទាំងអស់នៃកិច្ចការជិន្នញជួញដូរនិងអាពាហ៍ពិពាហ៍ គឺសុទ្ធតែបានកត់ទុកយ៉ាងត្រឹមត្រូវ ។ ក្រោយពីបានទទួលទ្រព្យសម្បត្តិទាំងនោះរួចមក លោកអែសរ៉ា គាត់នឹងផ្ញើលិខិតមួយទៅស្តេចអ័ថាស៊ើកសេសវិញ ដើម្បីបង្ហាញថាលោកបានទទួលទ្រព្យសម្បត្តិទាំងនោះហើយ ។

**៨:៣៥** *ដង្វាយ* ដង្វាយជាសត្វពពែដែលគេបានថ្វាយនៅកន្លែងនេះ មិនបានបង្ហាញថា ជាពពែឈ្មោលឡើយ ។ ដង្វាយទាំងអស់ដែលពួកគេបានថ្វាយដល់ព្រះអម្ចាស់នៅកន្លែងនេះ មានចំនួនតិចជាងពួកអ្នកដែលវិលត្រឡប់ពីនិរទេសវិញ ក្រោមការដឹកនាំរបស់សូរ៉ូបាបិល (សូមមើលក្នុង ៦:១៧) ដោយកាលនោះក្រុមគ្រួសាររបស់ពួកគេម្នាក់បានថ្វាយដង្វាយជា ច្រើនដល់ព្រះអម្ចាស់ ។

**៩:១** *កាលការទាំងនោះបានសំរេចអស់ហើយ . . . មិនបានញែកខ្លួនចេញពីពួកអ្នកស្រុកនេះទេ* លោកអែសរ៉ា គាត់បានធ្វើដំណើរមកដល់ក្រុងយេរូសាឡិមនៅក្នុងខែទី៥ (សូមមើល ៧:) ។ ទំហំនៃបញ្ហាដែលស្តីពីការរៀបការជាមួយសាសន៍ដទៃ ត្រូវបានលើកមកនិយាយនៅក្នុងខែទី៩ (សូមមើល ១០:៩) ឬ៤ខែបន្ទាប់ពីមកដល់ក្រុងយេរូសាឡិម ។ ពួកអ្នកដែលបង្ករបញ្ហាដល់លោកអែសរ៉ានោះ ប្រហែលមិនមែនជាពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលឡើយ ប៉ុន្តែប្រហែលជាពួកជនសាមញ្ញវិញ ដែលនាំឱ្យខ្លួនឯងមិនបរិសុទ្ធ (សូមមើល ឧ.២) ។ ហោរ៉ាមាឡាគី ដែលបានរស់នៅក្នុងជំនាន់លោកអែសរ៉ាដែរ បានទាយពីដំណើរនេះថា និងមានពួកយូដាខ្លះ បានប្រព្រឹត្តខុសច្បាប់អាពាហ៍ពិបាហ៍ ដោយពួកគេទៅរៀបការជាមួយកូនស្រីរបស់ព្រះដទៃធ្វើជាប្រពន្ធ (សូមមើល មឡ២:១០–១៦) ដែលពួកស្រីៗទាំងនោះប្រហែលជាកូនរបស់ពួកអ្នកមានអំណាចនៅក្នុងស្រុកនោះ ។ មូលហេតុដែល បណ្តាលឱ្យមានការរៀបការជាមួយស្ត្រីសាសន៍ដទៃ ប្រហែលដោយសារតែពួកស្ត្រីៗពួកយូដា ដែលធ្វើដំណើរត្រឡប់ពីការនិរទេសវិញ ហើយដែលនៅក្រមុំនោះមានចំនួនតិច ។ បញ្ហាដែលបានកើតឡើងដល់សហគមន៍ពួកយូដា ដែលទៅរៀបការជាមួយស្ត្រីសាសន៍ដទៃនោះ គឺមានទំនាក់ទំនងជាមួយនឹងគំរូដែលមានតាំងពីយូរមកហើយ គឺតាំងពីពួកគេរស់នៅក្នុងស្រុកអេស៊ីព្ទមកម្ល៉េះ ហើយនៅតែបន្តរហូតដល់គ្រាលោកអែសរ៉ា និងលោកនេហេមា ។ ពេលដែលពួកយូដាគេរៀបការជាមួយកូនស្រីរបស់ព្រះដទៃធ្វើជាប្តីប្រពន្ធ បានបង្ហាញថាពួកគេត្រឡប់ទៅគោរពប្រត្តិបត្តិលើរូបព្រះដោយបន្ថែមលើព្រះអម្ចាស់ ជាព្រះនៃសេចក្តីពិត ។ *ពួកអ្នកស្រុក* ពួកអ្នកស្រុកទាំងនោះ គឺជាក្រុមមនុស្សទាំង៨ក្រុមដែលតំណាងឱ្យពួកអ្នកស្នាក់អាស្រ័យក្នុងទឹកដីកាណាន ដែលជាទឹកដីកំណើតរបស់ពួកគេមុនពេលដែលពួកអ៊ីស្រាអែលចូលច្បាំងដណ្តើមយកទឹកដ (សូមមើល នក ៣:៨) ។ ក្រោយពីពួកយូដានិរទេសពីបាប៊ីឡូនវិញ គេឃើញមានតែពួកសាសន៍អាំម៉ូនពួកសាសន៍ម៉ូអាប់ និងពួកអេស៊ីព្ទប៉ុណ្ណោះដែលរស់នៅក្នុងទឹកដីនោះ (សូម មើល ២របា ៨:៧–៨) ។ *ពួកសាសន៍កាណាន* សូមមើលការពន្យល់ក្នុង លប ១០:៦ ។ *សាសន៍ហេត* សូមមើលការពន្យល់ក្នុង លប ១០:១៥ ។ *សាសន៍ពេរិស៊ីត* សូមមើលការពន្យល់ក្នុង លប ១៣:៧ ។ *សាសន៍យេប៊ូស* សូមមើលការពន្យល់ក្នុង ឥលប ១០:១៦ ។ *សាសន៍អាំម៉ូន សាសន៍ម៉ូអាប់* សូមមើល ការពន្យល់ក្នុង លប ១៩:៣៦–៣៨ ។ *សាសន៍អាម៉ូរី* សូមមើលការពន្យល់ ក្នុង លប ១០:១៦ ។

**៩:២** *ពូជបរិសុទ្ធ* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "ពូជពង្សបរិសុទ្ធ" ដូចអ្វីដែលបាននិយាយនៅក្នុង អស ៦:១៣ ។ *បានយក* នៅកន្លែងនេះចង់និយាយថា ពួកគេបានធ្វើខុសនឹងបញ្ញត្តិរបស់ព្រះ (សូមមើល ១០:១៨) ។ *ការរំលង* សូមមើល ១០:៦ យស ២២:១៦ ដយ ៩:៧ នៅកន្លែងនេះចង់និយាយថា ពួកអ្នកដែលបាត់បង់អត្តសញ្ញាណជារាស្ត្ររបស់ទ្រង់នោះគឺជាពួកអ៊ីស្រាអែល ដោយព្រោះគេបានរៀបការជាមួយកូនស្រីរបស់ព្រះដទៃ ។

**៩:៣** *ខ្ញុំក៏ហែកសំលៀកបំពាក់* ការហែកសំលៀកបំពាក់គឺជាអត្ថន័យមួយដែលបង្ហាញថាមានទុក្ខព្រួយនិងមានអារម្មណ៍តានតឹង (សូមមើលការពន្យល់ក្នុង ឧ.៥ លប ៣៧:២៩,៣៤ យស ៧:៦ ពច ១១:៣៥ ២សយ ១៣:១៩ ២របា ៣៤:២៧ អធ ៤:១ យប ១:២០ អស ៣៦:២២ យរ ៤១:៥ មថ ២៦:៦៥) ។ *បោចសក់ក្បាល និងពុកចង្កា* ឃ្លាបែបនេះ មាននិយាយតែម្តងប៉ុណ្ណោះនៅព្រះគម្ពីរទាំងមូល ។ នៅកន្លែងផ្សេងៗទៀតគឺគ្រាន់តែនិយាយថា កោរសក់ ឬកោរពុកចង្កាប៉ុណ្ណោះ (សូមមើល យប ១:២០ យរ ៤១:៥

និងពុកចង្ការបស់ខ្ញុំ ហើយស្លុតចិត្តអង្គុយនៅ[ដ] ៤គ្រានោះ
អស់អ្នកណាដែលញាប់ញ័រ[ឋ] ចំពោះព្រះបន្ទូលនៃព្រះរបស់
សាសន៍អ៊ីស្រាអែល គេក៏មូលគ្នាមកឯខ្ញុំ ដោយព្រោះអំពើ
រំលងរបស់ពួកអ្នកដែលមកពីឈ្លើយនោះ តែខ្ញុំស្លុតចិត្ត
អង្គុយនៅ[ឌ] ដរាបដល់ពេលដង្វាយល្ងាច ។
៥នៅពេលថ្វាយដង្វាយល្ងាច[ឍ] នោះខ្ញុំបានក្រោកពីទុក្ខ
ព្រួយនោះឡើង មានទាំងអាវក្នុង និងអាវក្រៅរហែករួច
ខ្ញុំផ្ទួលខ្លួនក្រាបចុះ លើកដៃ[ណ]ប្រទូលទៅឯព្រះយេហូវ៉ា ជា
ព្រះនៃខ្ញុំទូលថា ៦ឱព្រះនៃទូលបង្គំអើយ ទូលបង្គំមានសេច
ក្ដីខ្មាស[ត] ហើយក៏ក្រហមមុខ និងងើបមើលទៅទ្រង់ជាព្រះ
នៃទូលបង្គំផង ពីព្រោះការទុច្ចរិតរបស់យើងខ្ញុំបានចំរើន
ជាច្រើនឡើង ដល់លិចក្បាលយើងខ្ញុំ ហើយទោសរបស់
យើងខ្ញុំក៏កើនឡើង ដល់ផ្ទៃមេឃដែរ[ថ] ៧ចាប់តាំងពីគ្រា
ពួកព្ធយុកោយើងខ្ញុំ[ទ] ដរាបមកដល់សព្វថ្ងៃនេះ យើងខ្ញុំមាន
ទោសជាទំងន់ក្រៃពេក ហើយដោយព្រោះអំពើទុច្ចរិត
របស់យើងខ្ញុំ បានជាយើងខ្ញុំព្រមទាំងពួកស្ដេច និងពួក
សង្ឃរបស់យើងខ្ញុំ បានត្រូវប្រគល់ទៅ ក្នុងកណ្ដាប់ដៃនៃ
ពួកស្ដេចស្រុកដទៃ ដល់ដាវ[ធ] ដល់សណ្ឋានជាឈ្លើយ[ន]ដល់
ការរឹបជាន់ ហើយដល់សេចក្ដីអាម៉ាស់ខ្មាស់[ប] ដូចជាមាន
សព្វថ្ងៃនេះ ៨ហើយឥឡូវ នៅវេលា១ភ្លែតនេះ មានព្រះ
គុណសំដែង[ផ]មកដល់យើងខ្ញុំ អំពីព្រះយេហូវ៉ា ជាព្រះនៃ
យើងខ្ញុំ ឱ្យបានអ្នកខ្លះរួចចេញ[ព] ហើយឱ្យបានបង្គោល១[ភ]
នៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ប្រយោជន៍ឱ្យព្រះនៃយើងខ្ញុំ
បានបំភ្លឺភ្នែក[ម]យើងខ្ញុំ ហើយប្រោសឱ្យយើងខ្ញុំបានរស់ឡើង
វិញបន្តិច នៅក្នុងការបំរើគេនេះ ៩ដ្បិតយើងខ្ញុំជាបាវបំរើ[យ]
គេមែន តែព្រះនៃយើងខ្ញុំមិនបានបោះបង់ចោលយើងខ្ញុំ
កំពុងដែលនៅបំរើគេនោះទេ គឺបានផ្ដល់សេចក្ដីសប្បុរស[រ]
មកយើងខ្ញុំ ឱ្យបានរស់ឡើងវិញបន្តិច នៅភ្នែកនៃពួកស្ដេច
សាសន៍ពើស៊ីផង ដើម្បីនឹងតាំងព្រះវិហារនៃព្រះរបស់

**៩:៤** ឋ អរ ១០:៣ ទដ ១១៩:១២០ អស ៦៦:២ ឌ នហ ១:៤ ទដ ១១៩:១៣៦ ដយ ១០:២ **៩:៥** ឍ នក ២៩:៤១ ណ នហ ៨:៦ ទដ ២៨:២ ១៣៤:២ **៩:៦** ត យរ ៣១:១៩ ថ ២រប ២៨:៩ យប ៤២:៦ ទដ ៣៨:៤ អស ៥៩:១២ យរ ៣:២៥ ១៤:២០ វវ ១៨:៥ **៩:៧** ទ ២រប ២៩:៦ ធ អគ ២១:១–៣២ ន ចទ ២៨:៦៤ ប ចទ ២៨:៣៧ **៩:៨** ផ ទដ ២៥:១៦ ៦៧:១ ១១៩:៥៨ អស ៣៣:២ ព លប ៤៥:៧ ភ សស ១២:១១ អស ២២:២៣ ម ទដ ១៣:៣ ១៩:៨ **៩:៩** យ នក ១:១៤ នហ ៩:៣៦ រ ២រប ២៥:២៨ ទដ ១០៦:៤៦ ល ទដ ៦៩:៣៥ អស ៤៣:១ ៤៤:២៦ ៤៨:២០ ៥២:៩ ៦៣:៩ យរ ៣២:៤៤ សក ១:១៦–១៧

៤៧:៥ អគ ៧:១៨ អម ៨:១០) ។ នៅពេលដែលលោកនេហេមាប្រឈរមុខចំពោះបញ្ហាដូចគ្នានេះ គាត់មិនបានបោចសក់របស់គាត់ទេ ប៉ុន្តែគាត់បោចសក់អ្នកដែលប្រព្រឹត្តខុសវិញ (សូមមើល នហ ១៣:២៥) ។

**៩:៤** *អស់អ្នកណាដែលញាប់ញ័រ* សូមធ្វើការប្រៀបធៀបការញាប់ញ័រនៅទីនេះនិងក្នុង នក ១៩:១៦ អស ៦៦:២ ហព ១២:២១ ។ *ស្លុតចិត្ត* សូមមើល ខ.៣ ហើយធៀបជាមួយ ដយ ៤:១៩ ៨:២៧ ។ *ដង្វាយពេលល្ងាច* សូមមើលការពន្យល់ក្នុង នក ១២:៦ ។ ប្រហែលជាអ្នកដែលនាំដំណឹងពីការរំលងរបស់ពួកបណ្ដាជន បានមកឯលោកអែសរ៉ានៅវេលាពេលព្រឹកដូច្នេះ លោកអែសរ៉ាគាត់ចំណាយពេលអង្គុយទាំងមានអារម្មណ៍ស្លុតចិត្តអស់រយៈពេលជាច្រើនម៉ោង ។ ជានិច្ចកាលដង្វាយពេលល្ងាច គឺនៅម៉ោងប្រមាណជា៣រសៀល ហើយក៏ជាពេលមួយដែលពួកបណ្ដាជនបានមូលគ្នា ដើម្បីអធិស្ឋានលន់តួនៅចំពោះព្រះ (សូមមើល កច ៣:១) ។

**៩:៥–១៥** សូមមើលសេចក្ដីអធិស្ឋាន ដែលមានភាពប្រហាក់ប្រហែលគ្នានេះនៅក្នុង នហ ៩:៥–៣៧ ដយ ៩:៣–១៩ ។

**៩:៥** *ទុក្ខព្រួយ* ក្នុងព្រះគម្ពីរភាសារហេព្រើរពាក្យនេះមានន័យថា "តម" សូមមើលសេចក្ដីពន្យល់ក្នុង លវ ១៦:២៩,៣១ ។ *ផ្ទួលខ្លួនក្រាបចុះ* សូមធៀបជាមួយ ១ពវ ៨:៥៤ ទដ ៩៥:៦ ដយ ៦:១០ ។ *លើកដៃប្រទូលទៅឯព្រះយេហូវ៉ា* សូមមើលការពន្យល់ក្នុង នក ៩:២៩ ។

**៩:៦** *សេចក្ដីខ្មាស និងក្រហមមុខ* សូមមើលក្នុង ៨:២២ លក ១៨:១៣ ។ លោកអែសរ៉ាគាត់មានអារម្មណ៍ខ្មាសអៀននៅខាងក្នុងចិត្ត និងខាងក្រៅចិត្តពីអំពើបាបដែលគាត់បានប្រព្រឹត្តិ និងអំពើបាបរបស់ពួកបណ្ដាជន នៅចំពោះព្រះអម្ចាស់ ។ ជាញឹកញាប់មានកិរិយាស័ព្ទហេព្រើរ២ដែលគេប្រើជាមួយគ្នា (សូមមើល ទដ ៣៥:៤ អស ៤៥:១៦ យរ ៣១:១៩) គឺ ("សេចក្ដីខ្មាស និងសេចក្ដីអៀនខ្មាស) ។ *ពីព្រោះការទុច្ចរិតរបស់យើងខ្ញុំ . . . ហើយទោសរបស់យើងខ្ញុំ* សូមធ្វើការប្រៀបធៀបក្នុង ខ.៧,១៣,១៥ ១០:១០,១៩ ១រប ២១:៣ ២រប ២៤:១៨ ទដ ៣៨:៤ ។ *កើនឡើងដល់ផ្ទៃមេឃ* ប៉ុន្តែសេចក្ដីស្រឡាញ់របស់ព្រះនោះធំជាងកំហុសរបស់យើងទៅទៀត (សូមមើលក្នុង ទដ ១០៣:១១–១២) ។

**៩:៧** *ចាប់តាំងពីគ្រាពួកព្ធយុកោយើងខ្ញុំ* នៅក្នុងឃ្លានេះចង់មានន័យថា ស្មារតីរបស់ពួកកូនចៅអ៊ីស្រាអែល គឺបានផ្សារភ្ជាប់ជាមួយនឹងស្មារតីពួកព្ធយុកោរបស់គេតាំងពីដើមរៀងមក ។ *ដាវ* សូមធៀបជាមួយ នហ ៤:១៣ នៅក្នុងអេសេគាលជំពូក២១ បាននិយាយថា ឧបករណ៍នៃសេចក្ដីជំនុំជម្រះរបស់ព្រះអម្ចាស់គឺជា "ដាវរបស់ស្ដេចបាប៊ីឡូន" (សូមមើលការពន្យល់ក្នុង អគ ២១:១៩) ។ *សេចក្ដីអាម៉ាសខ្មាស* សូមធ្វើការប្រៀបធៀប ជាមួយ ដយ ៩:៧–៨ ២ រប ៣២:២១ ។

**៩:៨** *បង្គោល* តាមលក្ខណៈអក្សរសាស្ត្រពាក្យថាបង្គោលគឺ "ដែកគោល" ឬ "ស្នឹង" ដែលប្រៀបបានទៅនឹងដែកគោលដែលបានបោះ ភ្ជាប់ទៅជញ្ជាំង (សូមមើល ក្នុង អស ២២:២៣) ឬក៏ជាស្នឹងនៃជំរុំដែលបានភ្ជាប់ទៅដី (សូមមើលក្នុង អស ៣៣:២០ ៥៤:២) ។ *បានភ្លឺភ្នែកយើងខ្ញុំ* អត្ថន័យពិតប្រាករបស់ឃ្លានេះមានន័យថា កាលណាមានពន្លឺច្រើន និងធ្វើឱ្យពួកគេមានសេចក្ដីស្វាហាប់ និងមានអំណររកថ្លែងពុំបាន (សូមមើលក្នុង ទដ ១៣:៣ ១៩:៨ សស ៨:១ ហើយ ទដ ៦:៧ ធៀបជាមួយ ទដ ២៧:១) ។

**៩:៩** *ស្ដេចសាសន៍ពើស៊ី* ជិន្នូរវង្សរបស់ស្ដេចពើស៊ីពីសម័យបុរាណ បានផ្ដល់សេចក្ដីមេត្តាករុណាដល់ពួកយូដាដូចតទៅ: ស្ដេចស៊ីរូស (៥៣៩–៥៣០ មុនគ.ស) បានសន្យាថា នឹងអនុញ្ញាតឱ្យពួកយូដាវិលត្រឡប់មកពីការនិរទេសវិញ (សូមមើលជំពូក១ ។ ទោះបីជាកូនរបស់គាត់ដែលឈ្មោះខាំប៊ីស៊ីស (៥៣០–៥២២ មុន គ.ស) ដែលមិនឃើញឈ្មោះគាត់ក្នុងព្រះគម្ពីរ ក៏បាននិយាយពីគាត់ថា គាត់មានសេចក្ដីមេត្តាករុណាដល់ពួកយូដាដែរ ។ ស្ដេច

យើងខ្ញុំ ហើយជួសជុលទីបាក់បែកឡើងវិញ[ល] ព្រមទាំងឱ្យ
មានកំផែង នៅស្រុកយូដា និងក្រុងយេរូសាឡិមឡើងផង
១០តែឥឡូវនេះ ឱព្រះនៃយើងខ្ញុំអើយ ដែលមានការយ៉ាង
នេះ នោះតើយើងខ្ញុំនឹងថាដូចម្ដេចទៅ ដ្បិតយើងខ្ញុំបាន
បោះបង់ចោលក្រិត្យក្រម[វ]ទាំងប៉ុន្មានរបស់ទ្រង់ចេញ ១១ជា
សេចក្ដីដែលទ្រង់បានបង្គាប់មក ដោយសារពួកហោរា
ជាអ្នកបំរើទ្រង់ថា ស្រុកដែលឯងរាល់គ្នាចូលទៅចាប់យក
នោះ[ស] ជាស្រុកស្មោកគ្រោក[ហ] ដោយព្រោះការស្មោក
គ្រោក[ឡ]របស់ពួកសាសន៍ដទៃ ដែលនៅស្រុកនោះ ហើយ
ដោយព្រោះការគួរស្អប់ខ្ពើម ដែលគេបានប្រព្រឹត្ត ឱ្យស្រុក
នោះបានពេញ ដោយសេចក្ដីស្មោកគ្រោករបស់គេ ចាប់
តាំងពីចុងម្ខាងដល់ចុងម្ខាង ១២ដូច្នេះ កុំឱ្យឯងរាល់គ្នាលើក
កូនស្រីរបស់ខ្លួន ឱ្យទៅកូនប្រុសរបស់គេឡើយ ក៏កុំឱ្យយក
កូនស្រីរបស់គេមកឱ្យកូនប្រុសរបស់ឯង ឬរកសេចក្ដីសុខ
ដល់គេ ឬឱ្យគេបានចំរើនឡើងដែរ[អ] ប្រយោជន៍ឱ្យឯងរាល់
គ្នាមានកំឡាំង[ក] ហើយឱ្យបានចំអែត ដោយផលល្អ[ខ]របស់
ស្រុកនោះ ព្រមទាំងទុកជាមរដកដល់កូន ចៅឯងរាល់គ្នា
តរៀងទៅ[គ] ១៣ដូច្នេះ ក្រោយអស់ទាំងការដែលបានកើត
ដល់យើង ខ្ញុំដោយព្រោះអំពើអាក្រក់[ឃ] នឹងទោសរបស់
យើងខ្ញុំ ដែលមានទំងន់ជាខ្លាំងម្ល៉េះ[ង] ទោះបើទ្រង់ ឱព្រះនៃ
យើងខ្ញុំអើយ ទ្រង់មិនបានធ្វើទោសដល់យើងខ្ញុំ ឱ្យស្មើនឹង
ការទុច្ចរិតរបស់យើងខ្ញុំទេ ហើយបានទាំងប្រោស
ឱ្យយើងខ្ញុំមានសំណល់រួចចេញដូច្នេះផង ១៤ឥឡូវនេះ តើ
យើងខ្ញុំនឹងវិល ទៅប្រព្រឹត្តរំលងក្រិត្យក្រមរបស់ទ្រង់ទៀត
ដោយភ្ជាប់ញាតិ[ច]និងពួកសាសន៍នោះឯង ដែលប្រព្រឹត្តការ
គួរស្អប់ខ្ពើមទាំងនោះឬអី បើធ្វើដូច្នោះតើទ្រង់មិនមាន
សេចក្ដីក្រោធដល់យើងខ្ញុំ ដរាបដល់ទ្រង់បានបំផ្លាញអស់
រលីងទេឬអី[ឆ] ឥតឱ្យមានសំណល់សល់[ជ] ឬអ្នកណាឱ្យបាន
រួចឡើយ ១៥ឱព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
អើយ ទ្រង់សុច្ចរិត[ឈ] ដ្បិតយើងខ្ញុំមានតែសំណល់ ដែលបាន
រួចប៉ុណ្ណោះទេ ដូចជាសព្វថ្ងៃនេះ មើល យើងខ្ញុំនៅចំពោះ
ទ្រង់ មានជាប់ទាំងទោសផង ដ្បិតក្នុងអំពើយ៉ាងនេះ គ្មាន
អ្នកណានឹងឈរ[ញ] នៅចំពោះទ្រង់បានឡើយ[ដ]។

## ការលន់តួបាបរបស់បណ្ដាជន

**១០** ១កាលអែសរ៉ាកំពុងតែអធិស្ឋាន ហើយលន់តួ[ក] ដោយ
យំ[ខ] ហើយផ្តួលខ្លួនក្រាបចុះ នៅមុខព្រះវិហារនៃព្រះ
ដូច្នោះ នោះមានពួកអ៊ីស្រាអែលយ៉ាងសន្ធឹក ទាំងប្រុសទាំង
ស្រី និងក្មេងៗប្រជុំគ្នាមកឯលោក ពីព្រោះពួកបណ្ដាជន
ក៏យំជាខ្លាំងដែរ ២នោះសេកានា កូនយេហ៊ីអែល ជាកូនចៅ
អេឡាំ[គ] គាត់និយាយទៅអែសរ៉ាថា យើងរាល់គ្នាបាន
រំលង[ឃ]ទាស់នឹងព្រះនៃយើងខ្ញុំហើយ ដោយបានយកប្រពន្ធ
ជាស្រីសាសន៍ដទៃ ជាពួកស្រីនៅស្រុកនេះ ប៉ុន្តែនៅមាន

**៩:១០** វ ចទ ១១:៨ អស ១:១៩–២០ **៩:១១** ស ចទ ៤:៥ ហ លវ ១៨:២៥–២៨ ឡ ចទ ៩:៤ ១៨:៩ ១ពវ ១៤:២៤ **៩:១២** អ នក ៣៤:១៥ ក ចទ ១១:៨ ខ លប ៤៥:១៨ គ ទដ ១០៣:១៧ អគ ៣៧:២៥ យអ ៣:២០ **៩:១៣** ឃ នក ៣២:២២ ង យប ១១:៦ ១៥:៥ ២២:៥ ៣៣:២៧ ទដ ១០៣:១០ **៩:១៤** ច នហ ១៣:២៧ ឆ ចទ ៩:៨ ជ ចទ ៩:១៤ **៩:១៥** ឈ លប ១៨:២៥ ២របា ១២:៦ នហ ៩:៨ ទដ ៥១:៤ ១២៩:៤ ១៤៥:១៧ អស ២៤:១៦ យរ ១២:១ ២៣:៦ ៣៣:១៦ បទ ១:១៨ ដយ ៩:៧ សផ ៣:៥ ញ ទដ ៧៦:៧ ១៣០:៣ មឡ ៣:២ ដ ១ពវ ៨:៤៧ **១០:១** ក ២របា ២០:៩ ដយ ៩:២០ ខ ជន ២៥:៦ **១០:២** គ ខ.២៦ ឃ អរ ៩:២ ង ចទ ៣០:៨–១០

ដារីយ៉ុសទី១ ទ្រង់បានធ្វើការកែប្រែលើព្រះរាជ្យក្រឹត្យរបស់ស្ដេចស៊ីរុស (សូមមើល ជំពូក៦) ។ ស្ដេចអ័ហាស៊ូរុស ជាកូនស្ដេចដារីយ៉ុសទី១ (៤៨៦–៤៦៦ មុន គ.ស) បានផ្ដល់ឯកសិទ្ធិ និងការពារដល់ពួកយូដា ( អធ ៨–១០) ។ កូនរបស់អ័ហាស៊ុរុស ឈ្មោះអើថាស៊ើកសេស (៤៦៥–៤២៤ មុន គ.ស) បានផ្ដល់សិទ្ធិដល់លោកអែសរ៉ា (ជំពូក៧) និងលោកនេហេមា (សូមមើល នហ ជំពូក២) ។ *ជួសជុលទីបាក់បែកឡើងវិញ* ហោរាអេសាយគាត់បានទាយថា ព្រះអម្ចាស់ទ្រង់នឹងសង់ទីបាក់បែកទីក្រុងយេរូសាឡិមឡើងវិញ (សូមមើល អស ៤៤:២៦) ដែលនឹងធ្លាយចេញពីសេចក្ដីអំណរ និងច្រៀងអរសប្បាយ (សូមមើល អស ៥២:៩ ផ្ទៀបជាមួយ ៥៨:១២ ៦១:៤) ។ *ព្រមទាំងឱ្យមានកំផែង* ប្រើពាក្យថា កំផែងគឺមានតែក្នុង មីក ៧:១១ ទេ ។ ការប្រើពាក្យនៅទីនេះគ្រាន់តែជាពាក្យប្រៀបប្រដូចប៉ុណ្ណោះ (សូមផ្ទៀប សគ ២:៤–៥) ។

**៩:១១–១២** នៅក្នុងសញ្ញាចាស់ ឃ្លានេះមិនមែនមាននិយាយតែម្ដងប៉ុណ្ណោះនោះឡើយ ប៉ុន្តែក៏នៅមានអត្ថបទគម្ពីរផ្សេងៗទៀតដែលបាននិយាយពីពាក្យនេះដែរ ដូចជានៅក្នុង ចទ ១១:៨–៩ អស ១:១៩ អគ ៣៧:២៥ ។

**៩:១១** *ពួកហោរា ជាអ្នកបំរើទ្រង់* សូមមើលការពន្យល់ក្នុង យរ ៧:២៥ សក ១:៦ ។ *ស្មោកគ្រោក* ដោយព្រោះពួកគេបានប្រព្រឹត្តអសិលធម៌ និងកំផិតដូចជាសាសន៍កាណាន (សូមមើល លវ ១៨:៣ ២របា ២៩:៥ បទ ១:១៧ អគ ៧:២០ ៣៦:១៧) ។

**៩:១៤** *សេចក្ដីក្រោធ* មូលហេតុដែលបណ្ដាលឱ្យព្រះអម្ចាស់ទ្រង់មានសេចក្ដីក្រោធចំពោះពួកអ៊ីស្រាអែល គឺដោយសារតែពួកគេបានប្រព្រឹត្តរំលងនឹងសេចក្ដីសញ្ញា ដែលគេបានតាំងជាមួយព្រះអម្ចាស់ (សូមមើល ចទ ៧:៤ ១១:១៦–១៧ ២៩:២៦–២៨ យស ២៣:១៦ ពច ២:២០) ។

**៩:១៥** *ទ្រង់សុចរិត* សូមមើលការពន្យល់អំពីភាពសុចរិតរបស់ព្រះអម្ចាស់ក្នុង ទដ ៤:១ ។ *មានជាប់ទាំងទោស* នៅក្នុងឃ្លានេះចង់មានន័យថា នៅពេលដែលយើងមើលឃើញពីភាពបរិសុទ្ធរបស់ព្រះ នោះធ្វើឱ្យយើងបានដឹងថា ខ្លួនយើងជាអ្នកមានទោស និងគ្មានតម្លៃនៅចំពោះព្រះអម្ចាស់ឡើយ (សូមមើលក្នុង អស ៦:១–៥ លក ៥:៨) ។ សូមមើលការប្រៀបធៀបពីទុក្ខសោករបស់ប្រជាជាតិក្នុង ទដ ជំពូក ៤៤ ៦០ ៧០–៨០ ៨៣ ៨៥ ៩០ ១០៨ ១២៦ ១២៩ និងជំពូក ១៣៧ ។

**១០:១** *យំ* លោកអែសរ៉ា គាត់បានអធិស្ឋានលន់តួដោយបន្លឺសម្លេងយំយ៉ាងខ្លាំងៗ មិនមែនយំនៅក្នុងចិត្តដោយស្ងប់ស្ងាត់ឡើយ (សូមមើលការពន្យល់ក្នុង ៣:១៣ នហ ១:៤ យអ ២:១២) ។ *ហើយផ្តួលខ្លួនក្រាបចុះ* ពួកហោរានិងពួកអ្នកដឹកនាំផ្សេងៗទៀតក៏ធ្លាប់ផ្តួលខ្លួនក្រាបចុះនៅចំពោះព្រះអម្ចាស់ និងសកម្មភាពចម្លែកផ្សេងៗទៀត ដើម្បីទាក់ទាញដល់ការសញ្ជឹងគិតរបស់ពួកបណ្ដាជន (សូមមើល ក្នុង អស ៧:៣ ៨:១–៤,១៨ យរ ១៣:១–១១,១៩ ២៧:២–១២ អគ ៤:១–៥:៤) ។

ទីសង្ឃឹមដល់ពួកអ៊ីស្រាអែល ពីដំណើរនេះដែរ[ង] ៣ដូច្នេះ
សូមឱ្យយើងរាល់គ្នាចុះសញ្ញា[ច]នឹងព្រះនៃយើងឥឡូវឱ្យ
លែង[ឆ]អស់ទាំងប្រពន្ធ និងកូនទាំងប៉ុន្មានដែលកើតពីនាង
ទាំងនោះ តាមឱវាទនៃលោកម្ចាស់ខ្ញុំ និងពួកអ្នកដែលញាប់
ញ័រ ចំពោះក្រិត្យក្រមរបស់ព្រះនៃយើងខ្ញុំ សូមឱ្យការនោះ
បានសំរេចតាមក្រិត្យវិន័យ ៤សូមលោកក្រោកឡើងពីព្រោះ
ការនេះស្រេចនៅលោក ហើយយើងខ្ញុំក៏នៅជាមួយនឹង
លោកដែរ សូមឱ្យមានចិត្តក្លាហានឡើង ហើយសំរេចការ
ទៅ ។
៥ដូច្នេះ អែសរ៉ាក៏ក្រោកឡើង ឱ្យអស់ទាំងមេពួកសង្ឃ
ពួកលេវី និងពួកអ៊ីស្រាអែលទាំងអស់ ស្បថ[ជ]នឹងធ្វើតាម
ពាក្យនោះ គេក៏ស្បថ ៦រួចអែលរ៉ាក្រោកឡើងនៅមុខព្រះ
វិហារនៃព្រះ ចូលទៅក្នុងបន្ទប់ របស់យ៉ូហាណានជាកូន
របស់អេលីយ៉ាស៊ីបទៅ តែកាលលោកបានចូលទៅហើយ
លោកមិនបានបរិភោគអាហារអ្វីឡើយ[ឈ] ដ្បិតលោកមាន
សេចក្តីសៅសោក ដោយព្រោះអំពើរំលងរបស់ពួកអ្នក
ដែលមកពីសណ្ឋានជាឈ្លើយ ៧ដូច្នេះ គេក៏ប្រកាសប្រាប់
ទូទៅគ្រប់ក្នុងស្រុកយូដា និងក្រុងយេរូសាឡិម ដល់ពួកអ្នក
ទាំងប៉ុន្មាន ដែលរួចពីសណ្ឋានជាឈ្លើយ ឱ្យគេមូលមកឯ
ក្រុងយេរូសាឡិមគ្រប់គ្នា ៨ហើយ បើអ្នកណាមិនមកក្នុង
កំណត់៣ថ្ងៃ តាមបង្គាប់របស់ពួកអ្នកប្រធាននឹងពួកចាស់ទុំ
នោះនឹងត្រូវរឹបយកទ្រព្យសម្បត្តិរបស់អ្នកនោះអស់រលីង
ទៅ ហើយខ្លួនអ្នកនោះនឹងត្រូវកាត់ចេញពីពួកជំនុំរបស់ពួក
អ្នក ដែលរួចពីសណ្ឋានជាឈ្លើយផង ។
៩ដូច្នេះ ពួកយូដា និងបេនយ៉ាមីន[ញ] ក៏មូលគ្នាមកឯក្រុង
យេរូសាឡិមទាំងអស់ ក្នុងកំណត់៣ថ្ងៃនោះ គឺត្រូវជាថ្ងៃ
២០ខែមិគ្គសិរ ឯមនុស្សទាំងនោះគេអង្គុយត្រង់ទីធ្លា នៅ
មុខព្រះវិហារនៃព្រះ ទាំងញ័រដោយព្រោះដំណើរនោះ

**១០:៣** ច ២ពវ ១១:១៧ ឆ នក ៣៤:១៦
**១០:៥** ជ នហ ៥:១២ ១៣:២៥
**១០:៦** ឈ នក ៣៤:២៨ ចទ ៩:១៨ ទដ ១០២:៤ យហ ៣:៧
**១០:៩** ញ អរ ១:៥

---

**១០:២** លោកអែសរ៉ា គាត់គឺជាគ្រូម្នាក់ដ៏វ័យឆ្លាត ដោយព្រោះគាត់បានរងចាំឱ្យមិត្តអ្នកអានរបស់គាត់ ធ្វើសេចក្តីបញ្ចប់ដោយខ្លួនឯង ពីអ្វីដែលនឹងត្រូវធ្វើបន្តទៀត ។ *សេកានា* សេកានាគាត់ជាកូនរបស់យេហ៊ីអែល ហើយយេហ៊ីអែលនេះ ប្រហែលជាម្នាក់ដែលបាននិយាយនៅក្នុង ខ.២៦ ហើយគាត់ក៏ជាកូនចៅរបស់អេឡាំដែរ ។ ប្រសិនជាឪពុកគាត់ជាយេហ៊ីអែលដែលបាននិយាយនៅក្នុង ខ.២៦ មែន នោះសេចក្តីទុក្ខព្រួយរបស់សេកានាគឺដោយសារឪពុកគាត់បានរៀបការជាមួយស្ត្រី ដែលមិនមែនជាពួកយូដាឡើយ ។ សមាជិក៦នាក់នៅក្នុងក្រុមគ្រួសាររបស់អេឡាំ គឺសុទ្ធតែបានរៀបការជាមួយស្ត្រីសាសន៍ដទៃ (សូមមើល ខ.២៦) ។

**១០:៣** *ប្រពន្ធ និងកូន* នៅពេលមានលែងលះគ្នាសិទ្ធិចិញ្ចឹមបីបាច់ថែរក្សាកូនគឺត្រូវបានផ្តល់ឱ្យស្ត្រីជាម្តាយ ។ ជាក់ស្តែង នៅពេលដែលនាងហាកាយត្រូវបានគេបណ្តេញចេញពីផ្ទះ នាងបានយកអ៊ីសម៉ាអែលមកជាមួយ (សូមមើល លប ២១:១៤) ។ នៅឯបាប៊ីឡូនវិញ នៅពេលមានការលែងលះស្ត្រីជាម្តាយជាអ្នកទទួលខុសត្រូវចំពោះកូនហើយត្រូវរងចាំរហូតដល់ពេល ដែលកូននោះធំពេញវ័យសិនមុននឹងរៀបការប្តីថ្មី ប៉ុន្តែនៅប្រទេសក្រិចវិញកូនត្រូវទៅរស់នៅជាមួយឪពុក នៅពេលមានការលែងលះគ្នា ។

**១០:៤** *ក្រោកឡើង* សូមផ្ទៀបជាមួយសេចក្តីបង្រៀនរបស់ដាវីឌ (សូមមើលក្នុង ១រប ២២:១៦) ។

**១០:៦** *បន្ទប់* បន្ទប់នេះមានលក្ខណៈដូចគ្នានឹងបន្ទប់ក្នុងព្រះវិហារដែរ ដែលប្រើសម្រាប់ផ្ទុកអីវ៉ាន់ (សូមមើល ៨:២៩ នហ ១៣:៤–៥) ។ *មិនបានបរិភោគអាហារអ្វីឡើយ* នៅក្នុងព្រះគម្ពីរកម្ររនឹងមានអ្នកណាតមមិនបរិភោគអាហារ និងមិនផឹកទឹកដូចជាគាត់ណាស់ ។ លោកម៉ូសេគាត់បានតមបែបនេះ ២ដងគត់ នៅក្នុងជីវិតរបស់គាត់ (សូមមើល នក ៣៤:២៨ ចទ ៩:១៩) ហើយពួកអ្នកក្រុងនីនីវេក៏បានតមបែបដូច្នេះដែរ (សូមមើល យណ ៣:៧) ។ ការតមរបស់ជនសាមញ្ញ គឺគ្រាន់តែតមមិនបរិភោគអាហារប៉ុណ្ណោះ (សូមមើល ១សយ ១:៧ ២សយ ៣:៣៥) ។ *មានសេចក្តីសៅសោក* ជាញឹកញាប់ក្នុងព្រះគម្ពីរភាសារហេព្រើរ ពាក្យថា "មានសេចក្តីសៅសោក" គឺជា ការពណ៌នាពីប្រតិកម្មរបស់ពួកអ្នកដែលបានដឹងថា ខ្លួនឯងទទួលការគំរាមកំហែង និងជំនុំជម្រះដែលសក្តិសមបំផុត (សូមមើល នក ៣៣:៤ ជន ១៤:៣៩) ។

**១០:៧–៨** នៅក្នុងខណៈពេលដែលលោកអែសរ៉ាគាត់កំពុងបន្តតមអត់ និងអធិស្ឋានដល់ព្រះអម្ចាស់ នោះពួកអ្នកជាប្រធាន និងពួកចាស់ទុំបានបង្គាប់ឱ្យពួកអ្នកដែលបានរួចពីសណ្ឋានជាឈ្លើយ ទៅប្រជុំគ្នានៅឯក្រុងយេរូសាឡិម ។ ស្តេចអើថាសើកសេស បានតែងតាំងលោកអែសរ៉ាឱ្យមានសិទ្ធិអំណាចដ៏ធំក្នុងការដឹកនាំពួកបណ្តាជន ដែលជាជនជាតិយូដា តែលោកស្ទើរតែពុំបានប្រើសិទ្ធិអំណាចនោះ ហើយនៅពេលដែលលោកប្រើ គឺប្រើដើម្បីឱ្យបណ្តាជនទាំងនោះមានការរីកចម្រើន តាមរយៈគំរូដ៏ល្អឥតខ្ចោះពីជីវិតរស់នៅរបស់គាត់ (សូមមើល ៧:២៥–២៦) ។

**១០:៨** *កំណត់៣ថ្ងៃ* ដោយព្រោះនៅក្នុងអំឡុងពេលដែលដែនដីរបស់ពួកយូដាត្រូវកាត់បន្ថយ ពួកគេជាច្រើនបានមករស់នៅក្នុងទីកន្លែងមួយដែលមានចំងាយមិនដល់៨០គ.មផងពីក្រុងយេរូសាឡិម ។ ព្រំប្រទល់របស់ពួកគេគឺ: ខាងជើងជាតំបន់បេតអែលភាគខាងត្បូង គឺតំបន់បៀសេបារខាងកើតគឺក្រុងយេរីខូ ហើយនៅភាគខាងលិច គឺទីក្រុងអ៊ើ (សូមផ្ទៀបជាមួយ នហ ៧:២៦–៣៨ ១១:២៥–៣៥) ។ *រឹបយក* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យ រឹបយក មានន័យថា "ហាមឃាត់មិនឱ្យប្រើប្រាស់របស់ទ្រព្យ ហើយត្រូវថ្វាយទៅចំពោះព្រះវិញ" ដោយគេអាចនឹងបំផ្លាញទ្រព្យនោះចោល (សូមមើល នក ២២:២០ ចទ ១៣:១២–១៨) ឬក៏ថ្វាយទ្រព្យទាំងនោះទុកជាសម្បត្តិព្រះអម្ចាស់ (សូមផ្ទៀប លវ ២៧:២៨ យស ៦:១៩ ៧:១–១៥) ។

**១០:៩** *ពួកយូដា និងបេនយ៉ាមីន* សូមមើលការពន្យល់ក្នុង ១:៥ ។ *ទីធ្លា* ដែលនិយាយនៅត្រង់កន្លែងនេះ អាចស្ថិតនៅក្រៅបរិវេណក្រុងយេរូសាឡិម ឬជាទីធ្លាស្ថិតក្នុងកន្លែងលំហមុខទ្វារទឹក (សូមមើល នហ ៨:១) ។ *ភ្លៀង* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យ "ភ្លៀង" គឺជាពហុវចនៈដែលបញ្ជាក់ថាមានភ្លៀងច្រើន ។ ខែមិគ្គសិរ (វិច្ឆិការ–ធ្នូ) គឺស្ថិតនៅក្នុងពាក់កណ្តាលនៃរដូវភ្លៀងធ្លាក់ (សូមមើល ខ.១៣) ដែលរដូវភ្លៀងបានចាប់ផ្តើមតិចៗតាំងពី

ហើយដោយព្រោះភ្លៀងធំផង ១០ នោះអែសរ៉ា[ដ]ដ៏ជាសង្ឃ
លោកឈរឡើងនិយាយទៅគេថា អ្នករាល់គ្នាបានប្រព្រឹត្ត
រំលង ដោយយកប្រពន្ធជាស្រីសាសន៍ដទៃ ជាការដែល
ចំរើនទោសដល់សាសន៍អ៊ីស្រាអែល[ឋ] ១១ ដូច្នេះ ចូរលន់តួ
ដល់ព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោអ្នករាល់គ្នា ឥឡូវ
ទៅ ហើយប្រព្រឹត្តតាមដែលទ្រង់សព្វព្រះហឫទ័យចុះ ត្រូវ
ឱ្យញែកខ្លួនពីពួកអ្នកនៅស្រុកនេះ ហើយពីស្រីសាសន៍ដទៃ
ចេញ[ឌ] ១២ ពួកជំនុំទាំងអស់គ្នាក៏ឆ្លើយតបឡើង ដោយ
សំឡេងយ៉ាងខ្លាំង[ឍ]ថា យើងខ្ញុំត្រូវតែធ្វើតាម ដូចជាលោក
មានប្រសាសន៍ហើយ ១៣ ប៉ុន្តែបណ្តាជននេះមានគ្នាច្រើន
ណាស់ ហើយនេះជារដូវភ្លៀងច្រើនផង យើងខ្ញុំឈរនៅ
ខាងក្រៅពុំបានទេ ហើយនេះក៏មិនមែនជាការដែលសំរេច
បានក្នុង១ថ្ងៃ ឬ២ថ្ងៃដែរ ពីព្រោះយើងខ្ញុំបានរំលងយ៉ាង
សន្ធឹក ក្នុងដំណើរនេះហើយ ១៤ ដូច្នេះ សូមឱ្យពួកអ្នកជា
ប្រធានក្នុងពួកយើងខ្ញុំបានឈរជំណាងពួកជំនុំទាំងអស់ រួច
ឱ្យអស់អ្នកនៅទីក្រុងយើងខ្ញុំទាំងប៉ុន្មាន ដែលបានយកប្រពន្ធ
ជាស្រីសាសន៍ដទៃ មកតាមវេលាកំណត់ ហើយឱ្យមានពួក
ចាស់ទុំក្នុងទីក្រុងនិមួយៗ និងពួកចៅក្រម[ណ]មកជាមួយផង
ដរាបដល់សេចក្តីក្រេវក្រោធដ៏សហ័ស[ត]របស់ព្រះនៃយើងខ្ញុំ
បានបែរចេញពីយើងខ្ញុំក្នុងដំណើរនេះទៅ ១៥ មានតែ
យ៉ូណាថាន ជាកូនអេសាអែល ហើយនិងយ៉ាហាសយ៉ា
ជាកូនធីកវ៉ា ដែលតាំងខ្លួនទាស់នឹងដំណើរនោះ ហើយ

**១០:១០** ដ អរ ៧:២១ ឋ ២រប ២៨:១៣
**១០:១១** ឌ ចទ ២៤:១ មឡ ២:១០-១៦
**១០:១២** ឍ យស ៦:៥
**១០:១៤** ណ ចទ ១៦:១៨ ត ជន ២៥:៤ ២រប ២៩:១០
**១០:១៥** ថ នហ ១១:១៦
**១០:១៨** ទ ពច ៣:៦ ធ អរ ២:២
**១០:១៩** ន ២ពវ ១០:១៥ ប លវ ៥:១៥ ៦:៦
**១០:២០** ផ ១រប ២៤:១៤
**១០:២១** ព ១រប ២៤:៨
**១០:២២** ភ ១រប ៩:១២

មានមស៊ូឡាម និងសាបថាយ[ថ] ជាពួកលេវីបានជួយខាង២
នាក់នោះដែរ ។
១៦ ពួកអ្នកដែលមកពីសណ្ឋានជាឈ្លើយ ក៏ធ្វើដូច្នោះ
គេរើសអែសរ៉ាដ៏ជាសង្ឃ និងពួកអ្នកជាកំពូលលើវង្ស
របស់ឪពុក ហើយតាមគ្រួឪពុកគេ តាមឈ្មោះរៀងខ្លួន
ហើយអ្នកទាំងនោះក៏ប្រជុំគ្នាពិភាក្សារឿងនោះ នៅថ្ងៃ១
ខែបុស្ស ១៧ លុះដល់ថ្ងៃ១ខែចេត្រ នោះក៏បានសំរេច
ដល់ពួកអ្នកទាំងអស់ ដែលបានយកប្រពន្ធជាស្រីសាសន៍
ដទៃនោះ ។

## ទោសនៃការរៀបការជាមួយសាសន៍ដទៃ

១៨ រីឯក្នុងបណ្តាកូនចៅពួកសង្ឃ នោះឃើញមានខ្លះ
បានយកប្រពន្ធ ជាស្រីសាសន៍ដទៃដែរ[ទ] គឺក្នុងពួកកូនចៅ
យេសួរ[ធ] ជាកូនយ៉ូសាដាក និងបងប្អូនលោក មានម្អាសេ
យ៉ា អេលាស៊ើរ យ៉ារីប និងកេដាលា ១៩ អ្នកទាំងនោះក៏
សន្យា[ន]យ៉ាងមុតមាំនឹងលែងប្រពន្ធចេញ ហើយដោយ
ព្រោះមានទោស បានជាគេថ្វាយចៀមឈ្មោល១សំរាប់
លោះទោសខ្លួន[ប] ២០ ក្នុងពួកកូនចៅអ៊ីមមើរ[ផ] នោះមាន
ហាណានី និងសេបាឌា ២១ ក្នុងពួកកូនចៅហារីម[ព]មាន
ម្អាសេយ៉ា អេលីយ៉ា សេម៉ាយ៉ា យេហ៊ីអែល និងអ៊ូស៊ីយ៉ា
២២ ក្នុងពួកកូនចៅរបស់ប៉ាសហ៊ើរ[ភ] នោះមានអេលីយ៉ូនាយ
ម្អាសេយ៉ា អ៊ីសម៉ាអែល នេថានេល យ៉ូសាបាឌ និង
អេលាសា ។

ខែតុលា ហើយបញ្ចប់នៅក្នុងពាក់កណ្តាលខែមេសា ។ ខែធ្នូ និងខែមករា គឺជាខែមួយដែលស្ថិតនៅក្នុងរដូវរងារ ដែលមានសីតុណ្ហភាព៥០អង្សា ហើយនៅក្រុងយេរូសាឡិមវិញ មានសីតុណ្ហភាព៤០អង្សា ។ ពួកបណ្តាជនគេមានការញាប់ញ័រ មិនមែនដោយព្រោះតែគេទទឹកជោកដោយភ្លៀងប៉ុណ្ណោះនោះទេ ប៉ុន្តែ ប្រហែលជាគេមានអារម្មណ៍ថា ព្រះអម្ចាស់ទ្រង់មិនសព្វព្រះទ័យចំពោះពួក បានជាទ្រង់បញ្ជូនឱ្យមានភ្លៀងខ្លាំងមកដល់ពួកគេ (សូមមើលការពន្យល់ក្នុង ១សយ ១២:១៧-១៨ អគ ១៣:១១,១៣) ។

**១០:១០** *ចំរើនទោសដល់សាសន៍អ៊ីស្រាអែល* សូមមើលការពន្យល់ក្នុង នក ៩:៣៤ ពច ៣:១២ ៤:១ ២រប ២៨:១៣ ។ អំពើបាប និងការធ្លាក់ចុះរបស់បណ្តាជនដែលបានរួចពីសណ្ឋានជាឈ្លើយ គឺធំមហាសែនធំទៅហើយ ប៉ុន្តែគេបានចំម្រើនអំពើបាបថែមទៀត ដែលធ្វើឱ្យសាសន៍បរិសុទ្ធអាម៉ាសមុខ ដោយព្រះគេបានរៀបការជាមួយស្ត្រីសាសន៍ដទៃ ។

**១០:១១** *ញែកខ្លួន* សូមមើលការពន្យល់ក្នុង ជន ១៦:២១ ២កថ ៦:១៤ ។

**១០:១២** *សំលេងយ៉ាងខ្លាំងៗ* សូមមើល នហ ៩:៤ ។

**១០:១៤** *ឱ្យមានពួកចាស់ទុំក្នុងទីក្រុងនិមួយៗ* សូមមើលការពន្យល់ក្នុង ចទ ១៦:១៨ ១៩:១២ ២១:៣,១៩ នរ ៤:២ ។

**១០:១៥** ពួកអ្នកទាំង៤នោះបដិសេធចំពោះវិធានការនេះ ដោយសារពួកគេម្នាក់ៗចង់ការពារកំហុសរបស់ខ្លួន ឬដើម្បីរក្សាទំនាក់ទំនងរបស់ពួកគេជាមួយសាច់ញាតិដែលជាសាសន៍ដទៃ ឬក៏គេគិតថា ការនេះជាការអាក្រក់ពេក ។ *ធីកវ៉ា* ឈ្មោះរបស់គាត់មានន័យថា"សេចក្តីសង្ឃឹម"ហើយឈ្មោះនេះមាននិយាយតែក្នុងកន្លែងនេះ និងក្នុង ២ពវ ២២:១៤ ប៉ុណ្ណោះ ។ *មស៊ូឡាម* សូមមើលក្នុង ៨:១៦ ។ បើសិនគាត់ជាមស៊ូឡាមដែលបាននិយាយនៅក្នុង ខ.២៩ នោះគាត់ក៏បានរៀបការជាមួយស្ត្រីសាសន៍ដទៃដែរ ។

**១០:១៦-១៧** កិច្ចការងារនោះបានដោះស្រាយចប់សព្វគ្រប់ក្នុងរយៈពេល៣ខែ ដោយគេបានរកឃើញថា មានបុរសចំនួន១១០នាក់បានរៀបការជាមួយស្ត្រីសាស៍ដទៃ ។

**១០:១៨-២២** សូមមើលក្នុង ២:៣៦-៣៩ ។

**១០:១៩** *ថ្វាយ* សូមធៀប ការថ្វាយដើម្បីបង្ហាញពីនិមិត្តរូបនៃការប្តេជ្ញាចិត្ត និងសន្យាយ៉ាងមុតមាំនៅទីនេះជាមួយ លប ១៤:២២ សភ ៦:១ ។ *ចៀមឈ្មោល* ដង្វាយដោយព្រោះការរំលង គឺថ្វាយដើម្បីលោះអំពើបាបដែលប្រព្រឹត្តដោយអចេតនា (សូមមើលការពន្យល់ក្នុង លវ ៥:១៤-១៩) និងអំពើបាបដែលប្រព្រឹត្តដោយចេតនា (សូមមើល លវ ៦:១-៧) ។ ដង្វាយដែលសក្តិសមបំផុតសម្រាប់លោះការរំលង គឺត្រូវយកសត្វចៀមឈ្មោល១ (សូមមើលការពន្យល់ក្នុង លវ ៥:១៥ ៦:៦) ។

២៣ខាងពួកលេវី[ម]នោះមានយ៉ូសាបាឌ និងស៊ីម៉ាយកេឡា
យ៉ា (អ្នកនោះគឺជាកេលីថា) ពេថាហ៊ីយ៉ា យូដា ហើយ
អេលាស៊ើរ ។
២៤ខាងពួកចំរៀង មានអេលីយ៉ាស៊ីប[យ]ហើយខាងពួកឆ្មាំ
ទ្វារ មានសាលូម ថេលែម និងអ៊ូរី ។
២៥ខាងពួកអ៊ីស្រាអែល គឺក្នុងពួកកូនចៅប៉ារូស[រ] នោះ
មានរ៉ាមា យីសយ៉ា ម៉ាលគា មីយ៉ាមីម អេលាសារ ម៉ាលគា
នឹងបេណាយ៉ា ២៦ក្នុងពួកកូនចៅអេឡាំ[ល] មានម៉ាថានា
សាការី យេហ៊ីអែល អាប់ឌី យេរេម៉ូត និងអេលីយ៉ា ២៧ក្នុង
ពួកកូនចៅសាធូរ មានអេលីយ៉ូន៉ាយ អេលីយ៉ាស៊ីប
ម៉ាថានា យេរេម៉ូត សាបាឌ និងអ័ស៊ីសា ២៨ក្នុងពួកកូនចៅ
បេបាយ មានយ៉ូហាណាន ហាណានា សាប់បាយ និង
អ័តឡាយ ២៩ក្នុងពួកកូនចៅបានី នោះមានមស៊ូឡាម ម៉ាលូក
អ័ដាយ៉ា យ៉ាសុប ស្អាល និងរ៉ាម៉ូត ៣០ក្នុងពួកកូនចៅ
ផាហាត-ម៉ូអាប់ នោះមានអ័ឌណា កេឡាល បេណាយ៉ា
ម្អាសេយ៉ា ម៉ាថានា បេសាលាល ប៊ីនុយ និងម៉ាន៉ាសេ
៣១ក្នុងពួកកូនចៅហារីម នោះមានអេលាស៊ើរ យីសយ៉ា
ម៉ាលគា សេម៉ាយ៉ា ស៊ីម្មាន ៣២បេនយ៉ាមីន ម៉ាលូក និង
សេម៉ារីយ៉ា ៣៣ក្នុងពួកកូនចៅហាស៊ូម នោះមានម៉ាថ្នាយ
ម៉ាត់ថាត់ថា សាបាឌ អេលីផាលេត យេរេម៉ាយ ម៉ាន៉ាសេ
និងស៊ីម៉ាយ ៣៤ក្នុងពួកកូនចៅបានី នោះមានម្អាដាយ
អាំរ៉ាម អ៊ូអែល ៣៥បេណាយ៉ា បេឌីយ៉ា កេលូហ៊ូវ
៣៦វ៉ានីយ៉ា ម្រេម៉ូត អេលីយ៉ាស៊ីប ៣៧ម៉ាថានា ម៉ាថ្នាយ
យ្អាសាយ ៣៨បានី ប៊ីនុយ ស៊ីម៉ាយ ៣៩សេលេមា ណាថាន់
អ័ដាយ៉ា ៤០ម៉ាកណាឌបាយ សាសាយ សារ៉ាយ ៤១អ័សារាល
សេលេមា សេម៉ារីយ៉ា ៤២សាលូម អ័ម៉ារា និងយ៉ូសែប
៤៣ក្នុងពួកកូនចៅនេបូរ នោះមានយីអែល ម៉ាធិធាសាបាឌ
សេប៊ីណា យ៉ាដាយ យ៉ូអែល និងបេណាយ៉ា ៤៤ឯមនុស្ស
ទាំងនោះ គេបានយកប្រពន្ធ ជាស្រីសាសន៍ដទៃ ប្រពន្ធគេ
ខ្លះក៏បានបង្កើតកូនហើយ ។/

**១០:២៣** ម នហ ៨:៧ ៩:៤ **១០:២៤** យ នហ ៣:១ ១២:១០ ១៣:៧,២៨ **១០:២៥** រ អរ ២:៣ **១០:២៦** ល ខ.២

**១០:២៤** មានការគួរឱ្យកត់សំគាល់មួយបង្ហាញថា នៅពេលនេះគឺមានតែអ្នកចម្រៀងម្នាក់ និងឆ្មាំទ្វារ៣នាក់ប៉ុណ្ណោះដែលបានលើកមកនិយាយ ។ គ្មានអ្នកដែលបម្រើកិច្ចការងារក្នុងព្រះវិហារទៀតទេ (សូមមើល ២:៤៣-៥៤) ហើយក៏គ្មានកូនចៅរបស់មហាតលិកសាឡូម៉ូនទៀតដែរ (សូមមើលក្នុង ២:៥៥-៥៧) ដោយព្រោះពួកគេបានប្រព្រឹត្តអំពើបាបតាមរយៈការរៀបការជាមួយស្ត្រីសាសន៍ដទៃ ។

**១០:២៥-៤៣** សូមមើលក្នុង ២:៣-២០ ។

**១០:៣០** *បេណាយ៉ា* សូមធ្វើការប្រៀបធៀបជាមួយ នក ៣១:២ ។

**១០:៣១** *ស៊ីម្មាន* ក្នុងព្រះគម្ពីរភាសាហេព្រើរ ឈ្មោះនេះ គឺសសេរដូចគ្នានឹងស៊ីម្មានជាកូនទី២របស់លោកយ៉ាកុប ដែលបាននិយាយនៅក្នុងគម្ពីរលោកុប្បត្តិ ២៩:៣៣ ។ ចំណែកឯភាសាក្រិកវិញ គឺស៊ីម៉ូន (មថ ៤:១៨) ។

**១០:៤៣** *នេបូរ* ក្នុងព្រះគម្ពីរភាសាហេព្រើរវិញ ឈ្មោះនេះ គឺសមមូលគ្នាជាមួយព្រះរបស់ពួកបាប៊ីឡូនឈ្មោះ ន៉ាបូរដែរ (សូមមើល អស ៤៦:១) ហើយឈ្មោះនេះ ក៏មាននិយាយតែម្តងប៉ុណ្ណោះ ។

**១០:៤៤** ពួកគេមួយចំនួនមានកូនតាមរយៈស្ត្រីសាសន៍ដទៃ ប៉ុន្តែនោះវាមិនមានជាមូលហេតុដែលមិនអាចឱ្យគេលែងលះគ្នាបាននោះឡើយ ។

# ព្រះគម្ពីរនេហេមា

## សេចក្តីផ្តើម

សូមមើលសេចក្តីផ្តើមព្រះគម្ពីរអែសរ៉ា ។

## គម្រោងសង្ខេប

**I. កិច្ចការងាររដ្ឋបាលលើកដំបូងរបស់លោកនេហេមា (ជំពូក១–១២)**

១. ការទទួលខុសត្រូវរបស់លោកនេហេមាចំពោះស្ថានការណ៍ ដែលមាននៅក្នុងទីក្រុងយេរូសាឡិម (ជំពូក១)

ក. ដំណឹងល្អពីស្ថានភាពនៅក្រុងយេរូសាឡិម (១:១–៤)

ខ. សេចក្តីអធិស្ឋានរបស់លោកនេហេមា (១:៥–១១)

២. ដំណើររបស់លោកនេហេមាឆ្ពោះទៅកាន់ក្រុងយេរូសាឡិម (២:១–១០)

ក. ព្រះរាជអនុញ្ញាតរបស់ស្តេចចំពោះដំណើរលោកនេហេមា (២:១–៨)

ខ. ការធ្វើដំណើរ (២:៩–១០)

៣. ការងារដំបូងរបស់លោកនេហេមា ចំពោះពួកអ្នកដែលបានមកដល់ក្រុងយេរូសាឡិម (២:១១–២០)

ក. ការត្រួតពិនិត្យមើលកំផែងក្រុងក្នុងរាត្រីរបស់លោកនេហេមា ( ២:១១–១៦)

ខ. លោកនេហេមាជំរុញចិត្តឱ្យពួកបណ្តាជនកសាងកំផែងក្រុង (២:១៧–១៨)

គ. ការឆ្លើយតបរបស់លោកនេហេមាចំពោះការជំទាស់ប្រឆាំង (២:១៩–២០)

៤. បញ្ជីឈ្មោះពួកកម្មករ កសាងកំផែងក្រុង (ជំពូក ៣)

ក. អំបូរមនុស្សនៅផ្នែកខាងជើង (៣:១–៧)

ខ. អំបូរមនុស្សនៅផ្នែកខាងលិច (៣:៨–១៣)

គ. អំបូរមនុស្សនៅផ្នែកខាងត្បូង (៣:១៤)

ឃ. អំបូរមនុស្សនៅផ្នែកខាងកើត (៣:១៥–៣២)

៥. ការជំទាស់ប្រឆាំងចំពោះការសាងសង់កំផែងក្រុងឡើងវិញ (ជំពូក ៤)

ក. ការមើលងាយរបស់សានបាឡាត់ និងថូប៊ីយ៉ា (៤:១–៥)

ខ. ការគំរាមកំហែងដោយការវាយប្រហារ (៤:៦–១៥)

គ. ការស្អាងកំផែងក្រុងឡើងវិញ (៤:១៦–២៣)

៦. បញ្ហាសង្គម និងបញ្ហាសេដ្ឋកិច្ច (ជំពូក ៥)

ក. ការត្អូញត្អែររបស់ពួកអ្នកក្រ (៥:១–៥)

ខ. ការលើកលែងចំពោះបំណុល (៥:៦–១៣)

គ. គំរូនៃភាពមិនអាត្មានិយមរបស់លោកនេហេមា (៥:១៤–១៩)

៧. គំនុំគំគួនរបស់អ្នកជំទាស់ប្រឆាំងការសាងសង់កំផែងក្រុង (ជំពូក ៦)

ក. ពួកប្រឆាំងព្យាយាមធ្វើអន្ទាក់ដាក់លោកនេហេមា (៦:១–៩)

ខ. ការស៊ីឈ្នួលរបស់ពួកហោរាក្លែងក្លាយ (៦:១០–១៤)

គ. ការបញ្ចប់នៃការសាងសង់កំផែងក្រុង (៦:១៥–១៩)

៨. បញ្ជីឈ្មោះអ្នកដែលនិរទេស (៧:១–៧៣ក)

ក. បំណែងចែកក្រុងយេរូសាឡិមឱ្យបណ្តាជនការពារ (៧១–៣)

ខ. លោកនេហេមាធ្វើការរុករកបញ្ជីឈ្មោះអ្នកដែលបានរួចពីសណ្ឋានជាឈ្លើយ (៧:៤–៥)

គ. ការពិពណ៌នាលើពួកអ្នកដែលបានរួចពីសណ្ឋានជាឈ្លើយ (៧:៦–៧២)

ឃ. ការតាំងលំនៅស្នាក់អាស្រ័យរបស់ពួកអ្នកដែលបានរួចពីសណ្ឋានជាឈ្លើយ (៧:៧ ៣ក)

៩. ការអធិប្បាយរបស់លោកអែសរ៉ា និងការកែរតម្រង់ឡើងវិញ (៧:៧៣ខ–១០:៣៩)

ក. សេចក្តីអធិប្បាយជាផ្លូវការណ៍ (៧:៧៣–៨:១២)

ខ. ពិធីបុណ្យបារាំ (៨:១៣-១៨)
គ. ថ្ងៃអធិស្ឋានតម ការលន់តួ និងសេចក្ដីអធិស្ឋាន (៩:១-៥ក)
ឃ.ការនិទានអំពីទំនាក់ទំនងរបស់ព្រះអម្ចាស់ជាមួយពួកអ៊ីស្រាអែល (៩:៥ខ-៣១)
ង. ការលន់តួចំពោះអំពើបាប (៩:៣២-៣៧)
ច. ការបង្ខំឱ្យចុះសន្ធិសញ្ញា (៩:៣៨)
ឆ. បញ្ជីឈ្មោះពួកអ្នកដែលបានបោះត្រា (១០:១-២៩)
ជ. កិច្ចព្រមព្រៀង (១០:៣០-៣៩)
១០. ពួកប្រធានក្នុងស្រុកយូដា និងក្រុងយេរូសាឡិម (ជំពូក ១១)
ក. ពួកប្រធានក្នុងក្រុងយេរូសាឡិម (១១:១-២៤)
១. ការណែនាំ (១១:១-៤ក)
២. ពួកអ្នកដែលនៅស្រុកយូដា (១១:៤ខ-៦)
៣. ពួកអ្នកដែលចេញមកពីពួកបេនយ៉ាមីន (១១:៧-៩)
៤. ពួកអ្នកដែលចេញមកពីអំបូរសង្ឃ (១១:១០-១៤)
៥. ពួកអ្នកដែលចេញមកពីអំបូរលេវី (១១:១៥-១៨)
៦. ពួកអ្នកដែលបម្រើការងារក្នុងព្រះវិហារ (១១:១៩-២៤)
ខ. ពួកអ្នកដែលជាប្រធានក្នុងស្រុកយូដា (១១:២៥-៣៦)
១. ទីកន្លែងដែលពួកយូដាតាំងលំនៅស្នាក់អាស្រ័យ (១១:២៥-៣០)
២. ទីកន្លែងដែលពួកបេនយ៉ាមីនតាំងលំនៅស្នាក់អាស្រ័យ (១១:៣១-៣៥)
៣. ការផ្លាស់ប្ដូរពួកលេវីចេញពីស្រុកយូដាទៅស្រុកបេនយ៉ាមីន (១១:៣៦)
១១. បញ្ជីឈ្មោះពួកសង្ឃ និងពិធីបុណ្យឆ្លងកំផែងក្រុង (ជំពូក ១២)
ក. ពួកសង្ឃ និងពួកលេវីដែលបានត្រឡប់ពីនិរទេសលើកទី១ (១២:១-៩)
ខ. ពួកសម្ដេចសង្ឃ និងពួកលេវីក្នុងគ្រាយ៉ូយ៉ាគីន (១២:១០-២៦)
គ. ពិធីបុណ្យឆ្លងកំផែងក្រុងយេរូសាឡិម (១២:២៧-៤៣)
ង. ច្បាប់ស្ដីពីការថ្វាយដង្វាយដល់ព្រះវិហារ និងកិច្ចការបម្រើ (១២:៤៤-៤៧)

**II.កិច្ចការងាររដ្ឋបាល ក្នុងដំណាក់កាលបន្ទាប់ទៀតរបស់លោកនេហេមា (ជំពូក ១៣)**

១. ការរំលោភបំពាន់ច្បាប់ក្នុងអំឡុងពេលដែលលោកនេហេមាអវត្តមាន (១៣:១-៥)
ក. អាពាហ៍ពិពាហ៍ជាមួយស្ត្រីសាសន៍ដទៃ (១៣:១-៣)
ខ. ការងារក្នុងព្រះវិហារមួយផ្នែកតូចរបស់ថូប៊ីយ៉ា (១៣:៤-៥)
២. ការវិលត្រឡប់របស់លោកនេហេមា (១៣:៦-៩)
ក. ការមកដល់ក្រុងយេរូសាឡិមរបស់លោកនេហេមា (១៣:៦-៧)
ខ. លោកនេហេមាបណ្ដេញថូប៊ីយ៉ាចេញពីព្រះវិហារ (១៣:៨-៩)
៣. ស្ថាប័នថ្មី និងការកែទម្រង់ឡើងវិញ (១៣:១០-៣១)
ក. ដង្វាយសម្រាប់អ្នកបម្រើការងារក្នុងព្រះវិហារ (១៣:១០-១៤)
ខ. ការរំលោភបំពានលើថ្ងៃឈប់សម្រាក (១៣:១៥-២២)
គ. អាពាហ៍ពិពាហ៍ជាមួយស្ត្រីសាសន៍ដទៃ (១៣:២៣-២៩)
ឃ. ដង្វាយឧស និងដង្វាយផលដំបូង (១៣:៣០-៣១)

## សេចក្ដីអធិស្ឋានរបស់លោកនេហេមា

**១** ១ នេះជាពាក្យរបស់នេហេមា ជាកូនហាកាលា ។
នៅខែមិគ្គសិរ[ក] ឆ្នាំទី២០ ក្នុងរាជ្យអើថាស៊ើកសេស
ដ៏ស្ដេច កំពុងដែលខ្ញុំនៅស៊ូសាន ជាព្រះរាជវាំង[ខ] ២ នោះ
ហាណានី[គ] ជាពួកបងប្អូនខ្ញុំ និងមនុស្សខ្លះទៀត ក៏មកដល់ពី
ស្រុកយូដា ហើយខ្ញុំសួរគេពីដំណើរ ពួកសាសន៍យូដាដែល
បានរួច[ឃ] ជាពួកអ្នកដែលសល់ ពីអស់អ្នកដែលត្រូវដឹក
នាំទៅជាឈ្លើយ ហើយពីដំណើរក្រុងយេរូសាឡិមផង
៣ គេប្រាប់មកខ្ញុំថា ឯពួកអ្នកដែលត្រូវដឹកនាំទៅជាឈ្លើយ
ដែលសល់នៅក្នុងខេត្តនោះ គេមានសេចក្ដីវេទនា ហើយ
ត្រូវសេចក្ដីត្មះតិះដៀលជាខ្លាំង ចំណែកកំផែងនៃក្រុង
យេរូសាឡិម ក៏បាក់បែក ហើយទ្វារបានឆេះអស់ផង[ង] ។
៤ កាលខ្ញុំឮពាក្យទាំងនោះ ខ្ញុំក៏អង្គុយយំ ហើយសៅ
សោកនៅ[ច]អស់ពីរបីថ្ងៃ ខ្ញុំក៏តម[ឆ] ហើយអធិស្ឋាន នៅ
ចំពោះព្រះនៃស្ថានសួគ៌ថា ៥ ឱព្រះយេហូវ៉ា ជាព្រះនៃស្ថាន
សួគ៌គឺជាព្រះដ៏ធំហើយគួរស្ញែងខ្លាច[ជ] ដែលរក្សាសេចក្ដី
សញ្ញានឹងសេចក្ដីសប្បុរស[ឈ] ដល់អស់អ្នកដែល ស្រឡាញ់
ដល់ទ្រង់ ហើយកាន់តាមអស់ទាំងក្រឹត្យក្រមរបស់ទ្រង់
អើយ ៦ សូមទ្រង់ផ្ទៀងព្រះកាណ៌មកឥឡូវ ហើយបើកព្រះ
នេត្រទតមក ដើម្បីឱ្យបានស្ដាប់[ញ]ពាក្យអធិស្ឋាន[ដ]របស់ទូល
បង្គំ ជាអ្នកបំរើទ្រង់ ដែលអធិស្ឋាន[ឋ]ដល់ទ្រង់ ទាំងយប់ទាំង
ថ្ងៃក្នុងគ្រានេះ ពីដំណើរពួកកូនចៅអ៊ីស្រាអែល ជាពួក
បំរើទ្រង់ ដោយលន់តួបាបរបស់ពួកកូនចៅអ៊ីស្រាអែល
ដែលយើងខ្ញុំរាល់គ្នាបានប្រព្រឹត្តនឹងទ្រង់ គឺទាំងខ្លួនទូលបង្គំ
និង វង្សរបស់ឰយុកោទូលបង្គំបានធ្វើបាបផង ៧ យើងខ្ញុំបាន
ប្រព្រឹត្តនឹងទ្រង់ ដោយខូចអាក្រក់ជាខ្លាំង[ឍ] ឥតរក្សាក្រឹត្យ

**១:១** ក សក ៧:១ ខ អរ ៤:៩ នអ ២:៨ **១:២** គ នហ ៧:២ ឃ ២ពវ ២១:១៤ នហ ៧:៦ យរ ៥២:២៨ **១:៣** ង លវ ២៦:៣១ ២ពវ ២៥:១០ នហ ២:៣,១៣,១៧ អស ២២:៩ យរ ៣៩:៨ ៥២:១៤ បទ ២:៩ **១:៤** ច ទដ ១៣៧:១ ឆ ២រប ២០:៣ អរ ៩:៤ ដយ ៩:៣ **១:៥** ជ ចទ ៧:២១ នហ ៤:១៤ ឈ ចទ ៧:៩ ១ពវ ៨:២៣ ដយ៩:៤ **១:៦** ញ ១ពវ ៨:២៩ ២រប ៧:១៥ ដ ១ពវ ៨:៣០ ឋ ១ពវ ៨:៤៧ **១:៧** ឍ ទដ ១០៦:៦

**១:១** *នេះជាពាក្យរបស់នេហេមា* នេះគឺជាសំណៅដើមនៃការណែនាំពីឋានៈរបស់អ្នកនិពន្ធ (សូមមើល យរ ១:១ និង អម ១:១) ទោះបីជាព្រះគម្ពីរអែសរ៉ា និងព្រះគម្ពីរនេហេមាដែលពីដើមឡើយជាព្រះគម្ពីរតែ១ ហើយក៏ពណ៌នាពីកិច្ចការតែ១ក៏ដោយ (សូមមើលសេចក្ដីផ្ដើមព្រះគម្ពីរអែសរ៉ា ត្រង់ចំណុច ដែលនិយាយអំពីលោកអែសរ៉ានិង នេហេមា) ។ *នេហេមា* ឈ្មោះរបស់គាត់មានន័យថា "ទ្រង់លួងលោម" ។ *ខែមិគ្គសិរឆ្នាំទី២០* គឺស្ថិតនៅក្នុង ខែវិច្ឆិការ–ធ្នូ ក្នុងឆ្នាំ ៤៤៥ មុន គ.ស ។ *ស៊ូសាន* សូមមើលការពន្យល់ពីទីកន្លែងនេះក្នុង អរ ៤:៩ ។

**១:២** *ហាណានី* ឈ្មោះរបស់គាត់ប្រហែលនិយាយក្នុងទម្រង់ខ្លីពីឈ្មោះហាណានា ដែលឈ្មោះហាណានានេះមានន័យថា "ព្រះអម្ចាស់ទ្រង់មានមេត្តាករុណា" ។ *ជាពួកបងប្អូនខ្ញុំ* សូមមើលការពន្យល់ ៧:២ ។ មានមនុស្សជាច្រើនបានជឿថា ដោយសារគាត់គឺជាប្អូនប្រុសរបស់លោកនេហេមា នោះប្រហែលគាត់គឺជាមន្ត្រីបន្ទាប់ពីលោកនេហេមា (សូមមើលការពន្យល់ ៧:២) ។ *ពួកសាសន៍យូដាដែលបានរួច* សូមមើលការពន្យល់ អរ ៩:៨ និង លប ៤៥:៧ ២ពវ ១៩:៣០–៣១ អស ១:៩ ១០:២០–២២ សក ៨:២៣ ។

**១:៣** *ក្នុងខេត្តនោះ* សូមមើលការពន្យល់ក្នុង អរ២:១ ។ *ចំណែកកំផែងនៃក្រុងយេរូសាឡិម ក៏បាក់បែក* តាមរយៈឃ្លានេះគឺចង់មានន័យថា កាលណាទីក្រុងគ្មានកំផែងការពារ នោះពួកបណ្ដាជនទាំងអស់គ្មានអ្វីសម្រាប់ទប់ទល់ប្រឆាំងជាមួយពួកខ្មាំងសត្រូវរបស់គេឡើយ ។ លោក (Thucydids) គាត់បានធ្វើការប្រៀបធៀបពីស្ថានភាពនៃក្រុងអាថែន ដែលគ្មានកំផែងការពារ បន្ទាប់ពីពើស៊ីវាយបំផ្លាញនៅក្នុងឆ្នាំ៤៨០–៤៧៩ មុន គ.ស មក ។ ការកំណាយនៅក្រុងយេរូសាឡិមក្នុងឆ្នាំ១៩៦១–១៩៦៧ នៃគ.ស បានបង្ហាញថា ទីក្រុងនេះខ្វះកំផែងក្រុងការពារនៅភាគខាងជើងនៃទីក្រុង ។ នៅក្នុងឆ្នាំ៥៨៦ មុន គ.ស ស្ដេចនេប៊ូក្នេសារ បានចូលមកឈ្លានពានក្រុងយេរូសាឡិម ហើយបានវាយបំផ្លាញកំផែងក្រុងជុំវិញទីក្រុងទាំងអស់ (សូមមើល ២ពវ ២៥:១០) ។ អ្នកកាត់ស្រាយនិងអ្នកបកប្រែជាច្រើនគេជឿថា ភាពតានតឹងរបស់នេហេមា គឺមិនមែនបណ្ដាលមកពីស្ដេចនេប៊ូក្នេសាវាយបំផ្លាញកំផែងក្រុងនោះឡើយ ប៉ុន្តែការឈឺចាប់ឬភាពតានតឹងដែលលោកមានគឺបណ្ដាលមកពីហេតុការណ៍ ដែលបានកើតឡើងក្នុង អស ៤:៧–២៣ ។ ពួកជនជាតិយូដាគេបានព្យាយាមកសាងកំផែងក្រុងឡើងវិញ នៅមុនរាជ្យស្ដេចអើថាស៊ើកសេសទី១ ប៉ុន្តែបន្ទាប់ពីមានការប្រឆាំងជំទាស់ពីរេហ៊ូម និងស៊ីមសាយមកស្ដេច អើថាស៊ើកសេសទ្រង់ចេញព្រះរាជក្រឹត្យបង្គាប់ឱ្យពួកយូដាផ្អាកការសាងសង់កំផែងក្រុង (សូមមើល អរ ៤:២១–២៣) ។

**១:៤** *អង្គុយ* សូមធ្វើការប្រៀបធៀបជាមួយ អរ៩:៣ យប ២:១៣ ។ *យំ* សូមមើលការពន្យល់ ៨:៩ អរ ៣:១៣ ១០:១ អធ ៨:៣ ។ *សៅសោក* សូមមើល អរ ១០:៦ ដយ ១០:២ ។ *ខ្ញុំក៏តម ហើយអធិស្ឋាន* សូមមើលការពន្យល់ អរ ៨:៣ ។ ក្នុងអំឡុងពេលនិរទេស ការតមគឺជាទម្លាប់មួយដែលពួកគេតែងតែធ្វើយ៉ាងឱឡារិក ដើម្បីរំឭកដល់ការដួលចុះក្រុងយេរូសាឡិម និងឃាតកម្មរបស់កេដាលា (សូមមើលការពន្យល់ សក ៨:១៩ អធ ៤:១៦ ដយ ៩:៣ ១០:៣ សក ៧:៣–៧) ។ *ព្រះនៃស្ថានសួគ៌* សូមមើលការពន្យល់ អរ ១:២ ។

**១:៥** *ដែលរក្សាសេចក្ដីសញ្ញា និងសេចក្ដីសប្បុរស* សូមមើល ៩:៣២ ចទ ៧:៩,១២ ។ *អស់អ្នកដែលស្រឡាញ់ដល់ទ្រង់ ហើយកាន់តាមអស់ទាំងក្រឹត្យក្រមរបស់ទ្រង់* សូមមើល ដយ ៩:៤ ធៀបជាមួយ នក ២០:៦ ។

**១:៦** *ដែលអធិស្ឋានដល់ទ្រង់ ទាំងយប់ទាំងថ្ងៃ* សូមធៀបជាមួយ ទដ ៤២:៣ ៨៨:១ យរ៩:១ ១៤:១៧ បទ ២:១៨ លក ២៨៨៣:៣៧ ១ថន ៣:១០ ១ធថ ៥:៥ ២ធថ ១:៣ ។ *បាប . . . គឺទាំងខ្លួនទូលបង្គំ និងវង្សរបស់ឰយុកោទូលបង្គំបានធ្វើបាបផង* នៅក្នុងន័យនេះ លោកនេហេមាមិនបានរាប់ថា ខ្លួនគាត់និងសមាជិកក្នុងផ្ទះរបស់លោកប្រព្រឹត្តបាបនោះឡើយ ។ នៅពេលដែលយើងមើលឃើញពីភាពបរិសុទ្ធរបស់ព្រះអម្ចាស់ ធ្វើឱ្យយើងទទួលស្គាល់ថាខ្លួនឯងជាអ្នកមានបាបនៅចំពោះព្រះ (មើល អស ៦:១–៥ លក ៥:៨) ។

**១:៧** *ក្រឹត្យក្រម សេចក្ដីបញ្ញត្តិ និងសេចក្ដីយុត្តិធម៌* សូមមើលការពន្យល់ក្នុង លប ២៦:៥ ។ *ដែលបានបង្គាប់មកដោយសារលោកម៉ូសេ ជាអ្នកបំរើទ្រង់* ចំពោះក្រឹត្យវិន័យរបស់លោកម៉ូសេ ដែលនិយាយនៅក្នុង អែសរ៉ា និង

ក្រុម សេចក្តីបញ្ញត្តិ និងសេចក្តីយុត្តិធម៌របស់ទ្រង់ ដែល
បានបង្គាប់មក ដោយសារលោកម៉ូសេ ជាអ្នកបំរើទ្រង់
ឡើយ ៨សូមទ្រង់នឹកចាំ[ឈ]ពីព្រះបន្ទូល ដែលទ្រង់បានបង្គាប់
ដល់លោកម៉ូសេ ជាអ្នកបំរើទ្រង់ថា បើឯងរាល់គ្នាប្រព្រឹត្ត
វិលង នោះអញនឹងកំចាត់កំចាយ[ណ]ឯង ឱ្យទៅនៅក្នុងអស់
ទាំងសាសន៍ ៩តែបើឯងរាល់គ្នាវិលមកឯអញ ព្រមទាំង
រក្សា ហើយប្រព្រឹត្តតាមអស់ទាំងក្រិត្យក្រមរបស់អញវិញ
នោះទោះបើពួកនិរទេសរបស់ឯងបានត្រូវខ្ចាត់ខ្ចាយ ទៅ
នៅដល់ជើងមេឃបំផុតក៏ដោយ គង់តែអញនឹងប្រមូល
គេ[ត]ពីនោះ នាំមកឯកន្លែងដែលអញបានរើស សំរាប់ឱ្យ
ឈ្មោះអញសណ្ឋិតនៅវិញ[ថ] ១០រីឯពួកអ្នកទាំងនេះ គេជា
បាវបំរើ ហើយជារាស្ត្ររបស់ទ្រង់ ដែលទ្រង់បានលោះ
មក ដោយព្រះចេស្តាដ៏ជាខ្លាំង និងព្រះហស្តដ៏មានឥទ្ធិឫទ្ធិ[ទ]
១១ឱព្រះអម្ចាស់អើយ សូមទ្រង់ផ្ទៀងព្រះកាណ៌[ធ] ស្តាប់
ចំពោះសេចក្តីអធិស្ឋានរបស់ទូលបង្គំ និងសេចក្តីអធិស្ឋាន
របស់ពួកអ្នកបំរើទ្រង់ ដែលកោតខ្លាចដល់ព្រះនាមទ្រង់
ដោយអំណរ ហើយសូមចំរើនដល់ទូលបង្គំជាអ្នកបំរើទ្រង់

**១:៨** ឈ លប ៨:១ ២ពវ ២០:៣ នហ ៤:១៤ ៥:១៩ ៦:១៤ ១៣:២២,២៩,៣១ ណ លវ ២៦:៣៣
**១:៩** ត ចទ ៣០:៤ ទដ ១០៦:៤៧ ១០៧:៣ អស ១១:១២ ៥៦:៨ យរ ៤២:១២ អគ ១១:១៧ ថ ១ពវ ៨:៤៨ យរ ២៩:១៤ អគ ១១:១៧ ២០:៣៤–៣៨ ៣៦:២៤–៣៨ មីក ២:១២
**១:១០** ទ នក ៣២:១១ អស ៥១:៩–១១
**១:១១** ធ ២របា ៦:៤០ ន នក ៣:២១ ប លប ៤០:១

ដោយប្រោស ប្រទានឱ្យមនុស្សនេះមានចិត្តមេត្តា[ន]ដល់
ទូលបង្គំនៅថ្ងៃនេះ (រីឯខ្ញុំជាអ្នកថ្វាយពែងដល់ស្តេច) ។

**ស្តេចអើថាសើសេសបញ្ជូនលោកនេហេមា ទៅក្រុងយេរូសាឡិម**

២ ១លុះដល់ខែចេត្រ ឆ្នាំទី២០ ក្នុងរាជ្យរបស់ស្តេចអើថា
សើសេស[ក] ក្នុងពេលដែលមានស្រាទំពាំងបាយជូរដាក់នៅ
ចំពោះស្តេច នោះខ្ញុំបានលើកថ្វាយដល់ទ្រង់ ឯពីមុន ខ្ញុំមិន
ដែលមានសេចក្តីព្រួយ នៅចំពោះទ្រង់ឡើយ ២ដូច្នេះ ស្តេច
ទ្រង់មានបន្ទូលសួរខ្ញុំថា អ្នកឥតមានឈឺសោះ ហេតុអ្វីបាន
ជាមានទឹកមុខព្រួយដូច្នេះ នេះកើតតែពីសេចក្តី ទុក្ខក្នុងចិត្ត
ទេ នោះខ្ញុំក៏ភ័យខ្លាចណាស់ ៣តែខ្ញុំទូលដល់ស្តេចថា សូមឱ្យ
ព្រះករុណាប្រកបដោយសេចក្តីចំរើនចុះ[ខ] ធ្វើដូចម្តេចមិន
ឱ្យ ទូលបង្គំមានទឹកមុខព្រួយបាន បើទីក្រុង[គ] ជាទីមានផ្នូរ
ខ្មោចរបស់ពួកព្ធយុកោរបស់ទូលបង្គំ នៅតែគ្រាំគ្រា ហើយ
ទ្វារក៏ឆេះអស់ហើយដូច្នេះ[ឃ] ៤ស្តេចទ្រង់មានបន្ទូលសួរខ្ញុំថា

**២:១** ក អរ ៤:៧ ៦:១៤ **២:៣** ខ ១ពវ ១:៣១ ដយ ២:៤ ៣:៩ ៥:១០ ៦:៦,២១ គ ទដ ១៣៧:៦ ឃ នហ ១:៣

នេហេមា សូមមើល អរ ៣:២ ៦:១៨ ៧:៦ នហ ១:៨ ៨:១,១៤ ៩:១៤ ១០:២៩ ១៣:១ ។

**១:៨** *នឹកចាំ* សូមមើលការពន្យល់ ១៣:៣១ លប ៨:១ ។ ពាក្យថា *នឹកចាំ* គឺជាពាក្យគន្លឹះនៅក្នុងព្រះគម្ពីរនេះ (សូមមើល ៤:១៤ ៥:១៩ ៦:១៤ ១៣:១៤,២២,២៩,៣១) ។ *ប្រព្រឹត្តិវិលង . . . កំចាត់កំចាយ* នៅក្នុងឃ្លានេះចង់និយាយថាការកំចាត់កំចាយវាជារឿងមួយ ដែលពួកអ្នកមិនស្មោះត្រង់មិនអាចគេចផុតឡើយ ។ នៅក្នុងគ្រាសញ្ញាថ្មី ពួកយូដាគេត្រូវកំចាត់កំចាយច្រើនជាងកាលដែលពួកគេរស់នៅក្នុងទឹកដីបរិសុទ្ធទៅទៀត ។

**១:៩** *គង់តែអញនឹងប្រមូលគេពីនោះ* សូមមើលការពន្យល់ ចទ ៣០:១–៥ ។ ជានិច្ចកាលព្រះអម្ចាស់ទ្រង់តែងតែសន្យាបែបនេះ ជាពិសេសក្នុងកណ្ឌគម្ពីរពួកហោរា (ឧ. អស ១១:១២ យរ ២៣:៣ ៣១:៨–១០ អគ ២០:៣៤,៤១ ៣៦:២៤ មីក ២:១២) ។ *ដែលអញបានរើស សំរាប់ឈ្មោះអញ សណ្ឋិតនៅ* សូមមើលការពន្យល់ ចទ ១២:៥ ទដ ១៣២:១៣ ។

**១:១០** *ជារាស្ត្ររបស់ទ្រង់ ដែលទ្រង់បានលោះមក* នៅក្នុងឃ្លានេះចង់និយាយថា ទោះបីជាពួកគេជាមនុស្សមានបាប ហើយធ្លាក់ចុះយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែជារាស្ត្ររបស់ព្រះអម្ចាស់ ដោយព្រោះទ្រង់បានលោះពួកគេតាំងពីដំបូងមកម្ល៉េះ (សូមមើលការពន្យល់ ចទ ៤:៣៤ ៩:២៩) ។

**១:១១** *សូមចំរើនដល់ទូលបង្គំជាអ្នកបំរើទ្រង់* សូមផ្ទៀបឃ្លានេះជាមួយ លប ២៤:១២ ។ *អ្នកថ្វាយពែង* តាមលក្ខណៈអក្សរសាស្ត្រគេនិយាយថា "ជាម្នាក់ដែលថ្វាយអ្វីមួយឱ្យស្តេចទ្រង់សោយ" ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ទាំងមូលមានប្រើពាក្យ"អ្នកថ្វាយពែង"នេះចំនួន១១ដងនៅកន្លែងផ្សេងៗគ្នា (សូមមើល លប ៤០:១–២,៥,៩,១៣,២០–២១,២៣ ៤១:៩ ១ពវ ១០:៥ ២របា ៩:៤) ។ យោងទៅតាមអ្នកប្រវត្តិសាស្ត្រក្រិចឈ្មោះ "អ៊ិច អ៊ីនអូហ្វូន" (Xenophon) បាននិយាយថា កិច្ចការរបស់អ្នកថ្វាយពែង គឺជាអ្នកជ្រើសរើស និងភ្លក់ស្រារបស់ស្តេចដើម្បីឱ្យដឹងថា មានជាតិពុលឬក៏គ្មាន (សូមមើល ២:១) ។ ដូច្នេះហើយ លោកនេហេមាគាត់គឺជាមនុស្សជិតដ៏ស្មោះត្រង់របស់ស្តេច ។ សេចក្តីត្រូវការលើភាពស្មោះត្រង់នៅក្នុងព្រះរាជដំណាក់ គឺមិនត្រូវបានក្រុមអ្នកដែលមានចិត្តក្បត់យកចិត្តទុកដាក់ឡើយ ។ អ័ហាស៊ូរុសជាបិតារបស់ស្តេចអើថាសើកសេសទី១ ត្រូវបានពួកកងព័ទដែលក្បត់សម្លាប់នៅលើគ្រែរបស់គាត់ ។

**២:១** *ខែចេត្រ ឆ្នាំទី២០* គឺស្ថិតនៅក្នុងចន្លោះពីខែមីនា–មេសា ក្នុងឆ្នាំ ៤៤៤ មុន គ.ស ។ *ក្នុងរាជ្យរបស់ស្តេចអើថាសើកសេស* សូមមើលតារាងក្នុងទំព័រ ៤៧០ ។ *មានសេចក្តីព្រួយ នៅចំពោះទ្រង់* នៅក្នុងឃ្លានេះចង់មានន័យថា នៅពេលអ្នកណាម្នាក់មានបញ្ហា នោះអ្នកបម្រើរបស់ស្តេចត្រូវទទួលយកបញ្ហានិងអារម្មណ៍ដែលអ្នកដទៃមានទុកដូចជាបញ្ហាផ្ទាល់ខ្លួន ហើយត្រូវបង្ហាញមកវិញនូវអារម្មណ៍អរសប្បាយនៅចំពោះមុខស្តេច ។

**២:៣** *សូមឱ្យព្រះករុណាប្រកបដោយសេចក្តីចំរើនចុះ* នៅក្នុងឃ្លានេះ គឺជាទម្រង់បែបគួរសមមួយ ដែលគេប្រើក្នុងការប្រស្រ័យទាក់ទងជាមួយស្តេច (សូមផ្ទៀបជាមួយ ទដ ៦២:៤) ។ *ទីក្រុង* លោកនេហេមាមិនបាននិយាយដោយចំថា ទីក្រុងនោះគឺជាទីក្រុងយេរូសាឡិមឡើយ (សូមមើល ខ.៥) ។ បំណងប្រាថ្នារបស់គាត់ប្រហែលជាចង់ឱ្យស្តេចមានការភ្ញាក់ផ្អើល ដោយគាត់បានលើកយកផ្នូរខ្មោចរបស់ពួកព្ធយុកោគាត់មកនិយាយ ។

**២:៤** *អធិស្ឋាន* នៅក្នុងឃ្លានេះចង់មានន័យថា មុនពេលឆ្លើយនូវសំនួរដែលស្តេចចោទសួរ លោកនេហេមាគាត់បានបន្លឺសម្លេងឡើង អធិស្ឋានដោយភាពស្រង្ងួតស្រងាត់ទៅចំពោះព្រះអម្ចាស់ ។ ការមួយដែលគួរឱ្យកត់សំគាល់អំពីលោកនេហេមា គឺជាញឹកញាប់គាត់តែងតែពឹងពាក់លើសេចក្តី

ដូច្នេះ តើអ្នកចង់បានអ្វី ខ្ញុំក៏អធិស្ឋាន ដល់ព្រះនៃស្ថានសួគ៌
៥ រួចខ្ញុំទូលដល់ស្ដេចថា បើព្រះករុណាសព្វព្រះទ័យយ៉ាង
នេះ ហើយបើទ្រង់អាណិតមេត្តាដល់ទូលបង្គំ នោះសូម
ទ្រង់ចាត់ទូលបង្គំ ឱ្យទៅឯស្រុកយូដា ដល់ទីក្រុងជាទីមាន
ផ្នូរខ្មោច របស់ឰយុកោទូលបង្គំ ឱ្យបានសង់ទីក្រុងនោះ
ឡើងវិញចុះ ៦ ឯស្ដេច[ង] ទ្រង់មានបន្ទូលមកខ្ញុំ កំពុងដែល
អគ្គមហេសីគង់នៅក្បែរ ទ្រង់ថា តើអ្នកចង់ទៅជាយូរប៉ុន្មាន
កាលណានឹងត្រឡប់មកវិញ ដូច្នេះ ស្ដេចទ្រង់សព្វព្រះទ័យ
នឹងចាត់ឱ្យខ្ញុំទៅ ហើយខ្ញុំក៏កំណត់ពេលថ្វាយទ្រង់ជ្រាប
៧ មួយទៀតខ្ញុំបានទូលដល់ស្ដេចថា បើព្រះករុណាសព្វព្រះ
ទ័យ នោះសូមឱ្យទូលបង្គំបានព្រះរាជសាសន៍កាន់យកទៅ
ជូនពួកចៅហ្វាយខេត្តនៅខាងនាយទន្លេ[ច] ឱ្យលោកបាន
បើកឱ្យទូលបង្គំឆ្លងទៅ រហូតដល់ស្រុកយូដា ៨ នឹងព្រះរាជ
សាសន៍ មួយច្បាប់ដល់អេសាភ ជាមេព្រៃហ្លួង ឱ្យលោក
បានបើកឈើដល់ទូលបង្គំ សំរាប់ធ្វើធ្នឹមទ្វារបន្ទាយ[ឆ] ដែល
នៅក្បែរព្រះវិហារ និងទ្វារកំផែងនៃទីក្រុង ហើយសំរាប់
ផ្ទះ ដែលទូលបង្គំត្រូវអាស្រ័យនៅផង ស្ដេចក៏អនុញ្ញាត
ឱ្យតាម[ជ] ដែលព្រះហស្តល្អរបស់ព្រះនៃខ្ញុំបានសណ្ឋិតលើ
ខ្ញុំ[ឈ] ៩ រួចមកខ្ញុំបានទៅដល់ពួកចៅហ្វាយ នៅខាងនាយទន្លេ
ជូនព្រះរាជសាសន៍នោះដល់គេ ឯស្ដេចទ្រង់បានចាត់
មេទ័ព និងទ័ពសេះ[ញ] ឱ្យទៅជាមួយនឹងខ្ញុំដែរ ១០ ដូច្នេះ កាល
សានបាឡាត[ដ] ជាអ្នកស្រុកហូរ៉ូណែម និងថូប៊ីយ៉ា[ឋ] សាសន៍
អាំម៉ូន ជាអ្នកជិនិតលោកបានឮហើយ សេចក្ដីនោះក៏នាំឱ្យ
ទំនាស់ចិត្តគេជាខ្លាំង ដោយព្រោះមានមនុស្សម្នាក់បំរុង

**២:៦** ង នហ ៥:១៤ ១៣:៦
**២:៧** ច អរ ៨:៣៦
**២:៨** ឆ នហ ៧:២ ជ អរ ៤:២៤ ឈ អរ ៥:៥
**២:៩** ញ អរ ៨:២២
**២:១០** ដ ខ.១៩ នហ ៤:១,៧ ៦:១–២,៥,១២,១៤ ១៣:២៨ ឋ នហ ៤:៣ ១៣:៤–៧

អធិស្ឋាន (មើល ១:៤ ៤:៤,៩ ៥:១៩ ៦:៩,១៤ ១៣:១៤,២២,២៩,៣១) ។

**២:៦** *អគ្គមហេសី* នៅក្នុងភាសាហេព្រើរ ពាក្យនេះមានប្រើតែកន្លែងនេះ និងក្នុងគម្ពីរទំនុកដំកើង ៤៥:៩ ប៉ុណ្ណោះ ("ព្រះនាង") ។ ពាក្យនេះកម្ចីមកពីភាសាអាកាឌានដែលមានន័យថា "ពន្លឺ" (ស្ត្រី) ក្នុងព្រះរាជវាំង ។ ភាសាអារ៉ាមមិចដែលមានតម្លៃស្មើនឹងពាក្យនេះគឺ "ភរិយា" ដែលមានប្រើក្នុងគម្ពីរដយ ៥:២–៣,២៣ ។ ស៊ីធីសាក (Ctesias) ជាជនជាតិក្រិកដែលបានរស់នៅក្នុងរាជ្យដំណាក់ (Achaemenid) បាននិយាយថា អគ្គមហេសីរបស់អើថាស៊ើកសេសទី១ មានព្រះនាមថា ដាម៉ាស្ប៊ា (Damaspia) ហើយយ៉ាងហោចណាស់អើថាស៊ើកសេសគាត់មានស្រីស្នំ៣នាក់ទៀត ។ នាងដាម៉ាស្ប៊ាក៏ដូចជាព្រះនាង អែសធើដែរ (សូមមើល នអ ជំពូក៥) ប្រហែលជានាងបាននាំនូវសេចក្ដីចម្រុងចម្រើនដល់ស្ដេច ។ *តើអ្នកចង់ទៅជាយូរប៉ុន្មាន* ប្រហែលជាលោកនេហេមាគាត់សុំក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ ហើយបន្ទាប់មកគាត់ទៅយ៉ាងយូរវិញ ។ យើងអាចធ្វើការសន្និដ្ឋានតាមរយៈ ៥:១៤ ថា លោកនេហេមាចំណាយពេលអស់១២ខែនៅក្នុងពេលលើកដំបូងរបស់គាត់ធ្វើជាចៅហ្វាយស្រុកយូដា នៅក្នុងឆ្នាំទី៣២នៃរាជ្យស្ដេចអើថាស៊ើកសេស នេហេមាគាត់បានធ្វើដំណើរត្រឡប់មកវិញដើម្បីរាយការណ៍ថ្វាយស្ដេច ហើយបន្ទាប់មកទៀតគាត់ក៏ត្រឡប់ទៅស្រុកយូដាវិញ ជាដំណាក់កាលលើកទី២ (សូមមើល ១៣:៦–៧) ។

**២:៧** *បានព្រះរាជសាសន៍កាន់យកទៅ . . . ដែលទូលបង្គំត្រូវស្នាក់អាស្រ័យ* ឯកសារជាអចិន្ត្រៃយ៍មកពី "អាសាមម៉ីស" (Arsames) បាននិយាថា មន្ត្រីដែលគ្រប់គ្រងលើប្រទេសអេស៊ីព្ទ គឺជាម្នាក់ដែលបានធ្វើការនៅក្នុងទីលានរបស់ស្ដេចពើស៊ី និងជាអ្នកដែលបានធ្វើដំណើរវិលត្រឡប់ទៅប្រទេសអេស៊ីព្ទវិញ ដោយគាត់បានតម្រូវឱ្យមន្ត្រីពើស៊ីផ្គត់ផ្គង់ដល់គាត់ជាស្បៀងអាហារ និងភាសជះក្នុងដំណើររបស់គាត់ ។ *ពួកចៅហ្វាយខេត្តនៅខាងនាយទន្លេ* សូមមើលការពន្យល់ អរ ៤:១០ ។

**២:៨** *ព្រៃ* នៅក្នុងភាសាហេព្រើរវិញពាក្យនេះគឺ "ផាដេស" (pardes) ដែលជាពាក្យកម្ចីមកពីពួកពើស៊ីសម័យមុនដែលមានន័យថា "ព័ទ្ធរបង" ក្នុងដំណើរកំសាន្តគួរឱ្យរីករាយ ឬជាការព័ទ្ធរបងជុំវិញសួនច្បារ ។ នៅក្នុងគម្ពីរសញ្ញាចាស់ទាំងមូលពាក្យនេះ មានប្រើតែនៅក្នុង សស ២:៥ (សួនច្បារ) និង បស ៤:១៣ (ចំការ) ប៉ុណ្ណោះ ។ នៅក្នុងសិបធ្យូជីន (ការបកប្រែព្រះគម្ពីរសញ្ញាចាស់ជាភាសាក្រិករបស់គ្រីស្ទបរិសទ័ មុន គ.ស) បានសរសេរទៅភាសាក្រិកគឺ "ផារ៉ាឌីស័រ" (paradeisos) គឺមានប្រើនៅទីនេះ ។

**២:៩** *មេទ័ព និងទ័ពសេះ* ផ្ទុយពីលោកអែសរ៉ា (សូមមើលក្នុង អរ៨:២២) ។ លោកនេហេមាគាត់មានមេទ័ព និងទ័ពសេះជូនដំណើររបស់គាត់ព្រោះគាត់ជាចៅហ្វាយស្រុកយូដា ។

**២:១០** *សានបាឡាត* ឈ្មោះនេះគឺដាក់ឱ្យតាមរបៀបជនជាតិតបាប៊ីឡូន ដែលមានន័យថា "ស៊ីន (គោរពនិងថ្វាយង្គំព្រះចន្ទ័ពីព្រោះគេយល់ថា ព្រះចន្ទ័ក៏ជាព្រះមួយដែរ) ជាអ្នកផ្ដល់ជីវិត" ។ *អ្នកស្រុកហូរ៉ូណែម* មានគេ និយាថា គាត់មកពី (ទី១) ស្រុកហាវរ៉ុន (អគ ៤៧:១៦) ដែលស្ថិតនៅភាគខាងកើតសមុទ្រកាលីឡេ (ទី២) ស្រុកម៉ូអាប់ក្រុងហូរ៉ូណែម (យរ ៤៨:៣៤) (ទី៣) អាចមកពីភាគខាងលើ និងភាគខាងក្រោមនៃបេត–ហូរ៉ុន ដែលជាទីក្រុងសំខាន់ៗ២ ស្ថិតនៅភាគខាងជើងក្រុងយេរូសាឡិមប្រមាណជា១៧,៦៩ គ.ម ហើយផ្លូវតាមទីក្រុងនេះ ជាផ្លូវមួយមានសុវត្ថិភាពបំផុត ពេលឆ្ពោះមកកាន់ក្រុងយេរូសាឡិម (សូមមើលការពន្យល់ក្នុង យស ១០:១០ ១៦:៣,៤) ។ លោកសានបាឡាត គាត់គឺជាមន្ត្រីច្បាប់ដែលបានជំទាស់ប្រឆាំងចំពោះលោកនេហេមា (សូមមើល ខ.១៩ ៤:១,៧ ៦:១–២,៥,១២,១៤ ១៣:២៨) ។ មិនតែប៉ុណ្ណោះសោត លោកសានបាឡាតគាត់ជាចៅហ្វាយខេត្តស្រុកសាម៉ារីទៀតផង (សូមផ្ទៀបជាមួយ ៤:១–២) ។ រយៈពេល ៥សតវត្សរ៍ មុន គ.ស ក្រោយមកទៀត សំបុត្ររបស់ Elephantine ប៉ាប៉ីរូស បាននិយាយថា ចៅហ្វាយខេត្តស្រុកសាម៉ារីគឺ "លើដេឡាយ៉ា និងសេលេមា ជាកូនរបស់សានបាឡាតដែលជាចៅហ្វាយស្រុកសាម៉ារី" ។ ក្នុងសតវត្សរ៍ទី៤ មុន គ.ស នាឆ្នាំ១៩៦២ គេបានរកឃើញ ប៉ាប៉ីរូសនៅក្នុងគុហារមួយ ដែលស្ថិតនៅភាគខាងជើងក្រុងយេរីខូ ដោយបានសរសេរជាឈ្មោះសានបាឡាត ដូច្នេះហើយប្រហែលគេត្រូវជាកូនចៅរបស់នេហេមា ។ *ថូប៊ីយ៉ា* ឈ្មោះរបស់គាត់មានន័យថា "ព្រះអម្ចាស់ទ្រង់ល្អ" ។ តាមរយៈអត្ថន័យនៃឈ្មោះរបស់គាត់ និងកូនរបស់គាត់យ៉ូហាណាដែលមានន័យថា "ព្រះអម្ចាស់ទ្រង់មានមេត្តាករុណា" (សូមមើល ៦:១៧–១៨) នោះគាត់ប្រហែលជាអ្នកគោរពកោតខ្លាចនិងថ្វាយបង្គំដល់ព្រះអម្ចាស់ (ព្រះយេហូវ៉ា) ។ លោកយ៉ូហាណាបានរៀបការជាមួយកូនស្រីរបស់មស៊ូឡាម ជាកូនបេរេគា ដែលជាអ្នក ដឹកនាំម្នាក់ក្នុងចំណោមអ្នកដឹកនាំកសាងកំផែងក្រុងដទៃទៀត (សូមមើល ៣:៤,៣០

ឱ្យពួកកូនចៅអ៊ីស្រាអែលបានសណ្ដានល្អឡើង[ឌ] ។

## លោកនេហេមាត្រួតពិនិត្យកំផែងក្រុងយេរូសាឡិម

១១យ៉ាងនោះ ខ្ញុំបានមកដល់ក្រុងយេរូសាឡិម ក៏នៅ
ទីនោះអស់៣ថ្ងៃ[ឍ] ១២រួចខ្ញុំ និងអ្នកខ្លះទៀតក៏ក្រោកឡើងជា
មួយគ្នានៅពេលយប់ តែខ្ញុំមិនបានប្រាប់ឱ្យអ្នកណាដឹង ពី
ការដែលព្រះនៃខ្ញុំទ្រង់បានបណ្ដាចិត្តខ្ញុំឱ្យធ្វើសំរាប់ក្រុង
យេរូសាឡិមឡើយ ក៏គ្មានសត្វណានៅជាមួយនឹងខ្ញុំដែរ
លើកតែសត្វមួយ ដែលខ្ញុំជិតប៉ុណ្ណោះ ១៣ខ្ញុំបានចេញទៅ
ទាំងយប់តាមទ្វារច្រកភ្នំ[ណ] ដំរង់ទៅឯអណ្ដូងនាគ[ត] ដល់ទ្វារ
សំរាមពិនិត្យមើលកំផែង[ថ]ក្រុងយេរូសាឡិម ដែលបាក់បែក
និងទ្វារទាំងប៉ុន្មានដែលឆេះហើយ ១៤រួចខ្ញុំក៏ហួសទៅដល់
ទ្វារក្បាលទឹក[ទ] និងស្រះហ្លួង[ធ] តែគ្មានផ្លូវឱ្យសត្វដែលខ្ញុំជិះ
ដើរទៅបានទេ ១៥ដូច្នេះ ខ្ញុំក៏ឡើងទៅតាមជ្រោះទឹក បាន
ពិនិត្យមើល កំផែងទាំងយប់ រួចវិលទៅចូលតាមទ្វារច្រក
ភ្នំយ៉ាងនោះបានដល់ផ្ទះវិញ ១៦ឯពួកដំរួតទីក្រុង ឥតបាន
ដឹងជាខ្ញុំទៅឯណា ឬបានធ្វើអ្វីទេ ខ្ញុំក៏មិនទាន់បានប្រាប់ដល់
ពួកយូដា ពួកសង្ឃ ឬពួកអ្នកមានត្រកូលខ្ពស់ ពួកដំរួត ឬពួក
អ្នកឯទៀត ដែលរកស៊ីធ្វើការនៅឡើយដែរ ។
១៧រួចមក ខ្ញុំនិយាយនឹងគេថា អ្នករាល់គ្នាឃើញសណ្ដាន
អាក្រក់របស់យើងរាល់គ្នានេះ ហើយថា ក្រុងយេរូសាឡិម
នៅតែគ្រាំគ្រា ហើយទ្វារក្រុងទាំងប៉ុន្មានភ្លើងឆេះអស់[ន]
ដូច្នេះចូរមក យើងសង់កំផែង[ប]ក្រុងយេរូសាឡិមឡើង
ដើម្បីកុំឱ្យមានគេត្មះតិះដៀលដល់យើងទៀត[ផ] ១៨រួចខ្ញុំ
និយាយប្រាប់គេ ពីព្រះហស្តដ៏ល្អរបស់ព្រះនៃខ្ញុំ ដែល
សណ្ឋិតនៅលើខ្ញុំ[ព] និងពីព្រះបន្ទូលនៃស្តេច ដែលទ្រង់បាន
មានបន្ទូលមកខ្ញុំ ដូច្នេះ គេក៏និយាយឡើងថា ចូរយើង

**២:១០** ឌ នអ ១០:៣
**២:១១** ឍ លប ៤០:១៣
**២:១៣** ណ ២របា ២៦:៩ ត នហ ៣:១៣ ១២:៣១ ថ នហ ១:៣
**២:១៤** ទ នហ ៣:១៥ ១២:៣៧ ធ ២ពវ ១៨:១៧
**២:១៧** ន នហ ១:៣ ប ទដ ១០២:១៦ អស ៣០:១៣ ៥៨:១២ ផ អគ ៥:១៤
**២:១៨** ព អរ ៥:៥

៦:១៨) ។ ជាមួយគ្នានោះផងដែរ ថូប៊ីយ៉ាគាត់ក៏មានទំនាក់ទំនងជិតស្និតជាមួយសង្ឃអេលីយ៉ាស៊ីបថែមទៀត (សូមមើលការពន្យល់ ១៣:៤–៧) *សាសន៍អាំម៉ូន* សូមមើលការពន្យល់ អរ ៩:១ និងការពន្យល់ លប ១៩:៣៦–៣៨ ។ លោកថូប៊ីយ៉ា គាត់ប្រហែលជាចៅហ្វាយខេត្តនៃអ្នកដែលរស់នៅជុំវិញទន្លេយ័រដាន់ ក្រោមការគ្រប់គ្រងពីចក្រភពពេរ្ស៊ី ។ *ស៊ើចចំអក* មូលហេតុដែលបណ្ដាលឱ្យសានបាឡាត និងថូប៊ីយ៉ាគាត់ជំទាស់ប្រឆាំងក្នុងការកសាងកំផែងក្រុងឡើងវិញ គឺកើតឡើងដោយសារគោលនយោបាយក្នុងសម័យកាលនោះ មិនមែនដោយព្រោះតែជាប់ទាក់ទងផ្នែកសាសនារបស់ពួកគេនោះឡើយ ។ នៅពេលដែលលោកនេហេមាគាត់បានមកដល់ក្រុងយេរូសាឡិមសិទ្ធិអំណាចរបស់ចៅហ្វាយខេត្តសាម៉ារីត្រូវបានគំរាមកំហែងពីសំណាក់លោកនេហេមា ។

**២:១១** *៣ថ្ងៃ* សូមមើលការពន្យល់ អរ ៨:៣២ ។

**២:១២** លោកនេហេមាគាត់មានការប្រយ័ត្នប្រយែង និងមិនសម្ងែងអំពីខ្លួនគាត់ឡើយ ដូច្នេះការចាំបាច់សម្រាប់គាត់គឺត្រួតពិនិត្យសឹកសត្រូវដែលមាននៅក្នុងទីក្រុង ។ *សត្វមួយដែលខ្ញុំជិះ* សត្វដែលលោកនេហេមាជិះនោះប្រហែលជាលាកាត់ ឬជាសត្វលាធម្មតា ។

**២:១៣** លោកនេហេមាគាត់មិនបានត្រួតពិនិត្យមើលកំផែងក្រុងយេរូសាឡិមឱ្យបានគ្រប់ជ្រុងជ្រោយនោះទេ គឺគាត់ត្រួតពិនិត្យមើលតែផ្នែកខាងត្បូងប៉ុណ្ណោះ ។ ជាទូរទៅទីក្រុងយេរូសាឡិមចាប់ផ្ដើមទទួលការវាយប្រហារតែភាគខាងជើងប៉ុណ្ណោះ ពីព្រោះនៅកន្លែងនោះគ្មានអ្នកការពារអ្វីឡើយ ដូច្នេះប្រហែលជាកំផែងក្រុងផ្នែកខាងនោះ ត្រូវបានគេបំផ្លាញអស់ទៅហើយ ។ *ទ្វារច្រកភ្នំ* សូមមើល ៣:១៣ ។ ដោយយោងទៅតាមបទគម្ពីរ ២របា ២៦:៩ បាននិយាយថា យ៉ូសៀសបានកសាងប៉មជាច្រើននៅខាងលិចកំផែងក្រុងយេរូសាឡិម ដែលអាចត្រួតពិនិត្យមើលឃើញចំណុចកណ្ដាលនៃច្រកភ្នំ ដោយចាប់តាំងច្រកភ្នំហ៊ីនណំម រហូតដល់ជ្រោះកេដ្រុន ។ កំណាយរកក្នុងឆ្នាំ១៩២៧–១៩២៨ មិនបានរកឃើញទ្វារច្រកភ្នំដែលមាននិយាយក្នុងសម័យកាលចក្រភពពើស៊ីនោះឡើយ ។ *អណ្ដូងនាគ* មានអ្នកកាត់ស្រាយ និងអ្នកបកប្រែជាច្រើននិយាយថា អណ្ដូងនាគនេះគឺជាអេន–រ៉ូកែល (សូមមើលការពន្យល់ក្នុង យស ១៥:៧–៨ ១ពវ ១:៩) ដែលជាអណ្ដូងមួយដែលស្ថិតនៅទីប្រសព្វច្រកភ្នំហ៊ីនណំម និងជ្រោះកេដ្រុន ដែលមានចំងាយប្រមាណជា ៤៧,៣២ម ភាគខាងត្បូងនៃក្រុងយេរូសាឡិម ។ អ្នកខ្លះទៀតនិយាយថា អណ្ដូងនាគដែលនិយាយនៅកន្លែងនេះ គឺជាស្រះស៊ីឡោម ។ *ទ្វារសំរាម* ប្រហែលទ្វារនោះ គឺឆ្ពោះទៅកន្លែងចាក់សំរាមនៅច្រកភ្នំហ៊ីនណំម (សូមធៀបជាមួយ ៣:១៣–១៤ ១២:៣១ ២ពវ ២៣:១០) ។ ទ្វារសំរាមនេះមានចំងាយប្រមាណជា ៤៥០ម ភាគខាងត្បូងទ្វារច្រកភ្នំ (សូមមើល ៣:១៣) ។

**២:១៤** *ទ្វារក្បាលទឹក* ទ្វារនេះគឺស្ថិតនៅទិសខាងត្បូងឆៀងខាងកើត ឆ្ពោះតម្រង់ទៅអេន–រ៉ូកែល (សូមមើល ៣:១៥ ១២:៣៧) ។ *ស្រះហ្លួង* ប្រហែលជាលោកហេសេគា គាត់និយាយបង្វែស្រះស៊ីឡោម (សូមធៀប ២ពវ ២០:២០ ២របា ៣២:៣០) ថាជាស្រះហ្លួង (២ពវ ២៥:៤) ។ ស្រះហ្លួងនេះមានទីតាំងស្ថិតនៅខាងក្រៅកំផែងក្រុងត្រង់ទីប្រសព្វព្រោះកេដ្រុន និងច្រកភ្នំហ៊ីណំម ។ ដូច្នេះសរុបសេចក្ដីមក ស្រះហ្លួងប្រហែលជាស្រះស៊ីឡោម (សូមមើល ៣:១៥) ឬមួយក៏ជិតគ្នានឹង Birket-Hamra ។ *គ្មានផ្លូវ* មូលហេតុដែលបណ្ដាលឱ្យគ្មានផ្លូវពីព្រោះផ្លូវទាំងនោះមានសភាពទ្រុឌទ្រោមអស់ទៅហើយ (សូមធៀបជាមួយ ២សយ ៥:៩ ១ពវ ៩:១៥,២៤) ។ ផ្លូវដែលលោកនេហេមានិយាយនោះគឺស្ថិតនៅភាគខាងកើតនៃទីក្រុង ។

**២:១៥** *ជ្រោះទឹក* ជ្រោះទឹកដែលលោកនេហេមានិយាយនៅទីនេះ គឺសំដៅលើជ្រោះកេដ្រុន ។

**២:១៦** *ពួកអ្នកមានត្រកូលខ្ពស់* នៅក្នុងភាសាហេព្រើរពាក្យនេះមានន័យថា "សេរីភាព" (សូមមើល ៤:១៤,១៩ ៥:៧ ៦:១៧ ៧:៥ ១៣:១៧ និង ៣:៥) ។

**២:១៧** *គ្រាំគ្រា* នៅក្នុងឃ្លានេះចង់និយាយថា ពួកគេមានការគ្រាំគ្រាដោយព្រោះគេបានឃើញស្ថានភាពកំផែងក្រុង និងទ្វារនៃទីក្រុងត្រូវបានស្តេចនេប៊ូក្នេសារបំផ្លាញក្នុងឆ្នាំ៥៨៦ មុន គ.ស ។ ដូច្នេះ ដោយសារគំនិតដែលពួកគេមានបានជំរុញឱ្យគេព្យាយាមកសាងកំផែងក្រុង និងទ្វារក្រុងនេះឡើងវិញ ។

**២:១៨** *ព្រះនៃខ្ញុំ . . . និងព្រះបន្ទូលនៃស្តេច* នៅក្នុងន័យនេះចង់និយយាថា លោកនេហេមាគាត់អាចធ្វើការបញ្ជាក់ដោយផ្ទាល់អំពីព្រះអម្ចាស់ថា ទ្រង់ជាព្រះដែលមានព្រះជន្មរស់នៅ និងកំពុងធ្វើសកម្មភាពរាល់ថ្ងៃ ។ ដូច្នេះហើយគាត់ (លោកនេហេមា) បានមកទីនេះដោយអំណាចនិងការយល់ព្រម

លើកគ្នាធ្វើឡើង យ៉ាងនោះគេបានចំរើនកំឡាំងគ្នា ដើម្បី
នឹងធ្វើការល្អនោះ ១៩ តែកាលសានបាឡាត[ភ] ជាអ្នកស្រុក
ហូរ៉ូណៃម និងថូប៊ីយ៉ា សាសន៍អាំម៉ូន ជាជិនិតលោក
ហើយកេសែម[ម] ជាសាសន៍អារ៉ាប់បានឮ នោះគេក៏សើច
ចំអក ហើយមើលងាយដល់យើង[យ]ថា តើឯងរាល់គ្នាធ្វើអ្វី
នេះ តើគិតបះបោរនឹងស្តេចឬអី ២០ ខ្ញុំក៏ឆ្លើយទៅគេថា ព្រះ
នៃស្ថានសួគ៌ទ្រង់នឹងជួយចំរើនដល់យើងរាល់គ្នា ហេតុ
នោះយើងរាល់គ្នា ជាពួកបំរើទ្រង់ នឹងលើកគ្នាឡើងធ្វើ
តែឯអ្នករាល់គ្នាវិញ គ្មានចំណែក[ល] គ្មានច្បាប់ ឬទីនឹករឭក
នៅក្រុងយេរូសាឡិមឡើយ ។

## ជាងសង់កំផែង

**៣** ១ គ្រានោះ អេលីយ៉ាស៊ីប[ក] ជាសំដេចសង្ឃ និងពួកសង្ឃ
ជាបងប្អូនលោកក៏ នាំគ្នាសង់[ខ]ទ្វារចៀមឡើង[គ] គេក៏ធ្វើពិធី
ឆ្លងទ្វារនោះ ហើយដាក់ផ្ទាំងសន្លឹកទ្វារឡើង គេក៏ធ្វើពិធី
ឆ្លងនោះ រហូតដល់ប៉មហាមេអា ហើយដល់ប៉មហាណា-
នាលផង[ឃ] ២ បន្ទាប់នឹងគេមានពួកក្រុងយេរីខូរ[ង] បានសង់
ហើយបន្ទាប់ពីនោះ មានសាគើរ ជាកូនអ៊ីមរីបានសង់ ។
៣ ឯទ្វារត្រី[ច]នោះ ពួកកូនចៅសេណាអាក៏សង់ គេបាន
ដាក់ធ្នឹមឡើង ហើយដាក់ផ្ទាំងសន្លឹកទ្វារ ព្រមទាំងគន្លឹះ
ហើយនឹងរនុកផង ៤ បន្ទាប់ពីពួកនោះ ម្រេម៉ូត[ឆ] ជាកូន
អ៊ូរីយ៉ា ដែលជាកូនហាកូស គាត់ក៏ជួសជុល ហើយបន្ទាប់
នឹងគាត់មានមស៊ូឡាម ជាកូនបេរេគា ដែលជាកូន
មសេសា-បេល គាត់ជួសជុល ហើយបន្ទាប់ពីគាត់មាន

**២:១៩** ភ ខ.១០ ម នហ ៦:១,២,៦ យ ទដ ៤៤:១៣-១៦ **២:២០** រ អរ ៤:១ ល អរ ៤:៣ កច ៨:២១
**៣:១** ក អរ ១០:២៤ ខ អស ៥៨:១២ គ ខ.៣២ នហ ១២:៣៩ យហ ៥:២ ឃ នហ ១២:៣៩ ទដ ៤៨:១២ យរ ៣១:៣៨ សក ១៤:១០
**៣:២** ង នហ ៧:៣៦ **៣:៣** ច ២របា ៣៣:១៤ **៣:៤** ឆ អរ ៨:៣៣

ពីព្រះអម្ចាស់មក ។

**២:១៩** *សានបាឡាត . . . ថូប៊ីយ៉ា* សូមមើលការពន្យល់ ខ.១០ ។ *កេសែម* តាមរយៈសិលាចារិកដែលបានមកពីក្រុងដេដាន់ ស្ថិតនៅភាគខាងជើងឆៀងខាងលិចប្រទេសអារ៉ាប់ និងមកពី ថែល អ៊ែល ម៉ាគូតា (Tell el-Maskutah) ស្ថិតនៅក្បែរក្រុងអ៉ីសមេលាក្នុងប្រទេសអេស៊ីព្ទ បាននិយាយថា កេសែមគាត់ជាអ្នកមានតួនាទីក្នុងសហព័ន្ធអារ៉ាម ដែលរស់នៅភាគខាងជើង ហើយគាត់បានគ្រប់គ្រងលើតំបន់ដ៏ធំទូលាយមួយ ចាប់តាំងពីទិសខាងជើងឆៀងខាងកើតនៃប្រទេសអេស៊ីព្ទ រហូតដល់ភាគខាងជើងនៃប្រទេសអារ៉ាប់ និងរួមទាំងភាគខាងត្បូងនៃទឹកដីបរិសុទ្ធទៀតផង ។ ប្រហែលជាកេសែមអាចនឹងប្រឆាំងជិទាស់ដល់ការអភិវឌ្ឍន៍របស់លោកនេហេមា ក្នុងកាលដែលលោកនេហេមាគាត់ចង់ឱ្យពួកអ៊ីស្រាអែល រស់នៅក្នុងរដ្ឋឯករាជ្យមួយ ពីព្រោះកេសែមគាត់មានការភ័យខ្លាច និងព្រួយបារម្ភថា វាអាចនឹងបង្អាក់ដល់ការរកកម្រៃរបស់គាត់ក្នុងពាណិជ្ជកម្ម ។

**៣:១-៣២** នៅក្នុងចំណោមព្រះគម្ពីរសញ្ញាចាស់ទាំងមូល ជំពូកនេះជាជំពូក១ដែលមានសារៈសំខាន់ជាងគេបំផុត ដើម្បីធ្វើការពណ៌នាពីស្ថានភាពពិតពីក្រុងយេរូសាឡិម ។ និទានកថានៃការសាងសង់កំផែងក្រុង គឺបានចាប់ផ្តើមឡើងនៅត្រង់ទ្វារចៀម (ស្ថិតនៅទិសឦសាននៃក្រុងយេរូសាឡិម) ហើយបន្តការសាងសង់បញ្ច្រាសទិសមកវិញ ជុំវិញកំផែងក្រុងទាំងមូលតែម្តង ។ មានមនុស្សប្រមាណជា៤០នាក់ ដែលសុទ្ធតែជាមនុស្សសំខាន់ៗក្នុងការសាងសង់សំណង់ជាង៤៥ប្រភេទត្រូវបានកត់ចុះនៅទីនេះ ។ តាមរយៈឈ្មោះទីក្រុងដែលជាផ្ទះរបស់ពួកអ្នកចូលរួមកសាងទ្វារក្រុងទាំងនោះ ប្រហែលជាបានបង្ហាញពីពីប្រព័ន្ធគ្រប់គ្រង ដែលមាននៅក្នុងខេត្តយូដា ។ ទ្វារដែលពួកគេកសាងទាំងអស់មាន ចំនួន១០គឺ: (១).ទ្វារចៀម (ខ.១) (២).ទ្វារត្រី (ខ.៣) (៣).ទ្វារចាស់ (ខ.៦) (៤).ទ្វារច្រកភ្នំ (ខ.១៣) (៥). ទ្វារសំរាម (ខ.១៤) (៦). ទ្វារក្បាលទឹក (ខ.១៥) (៧). ទ្វារទឹក (ខ.២៦) (៨).ទ្វារសេះ (ខ.២៨) (៩).ទ្វារ ទិសខាងកើត (ខ.២៩) និង (១០). ទ្វារមីបកាឌ (ខ.៣១) ។ តាមរយៈបញ្ជីរឿងទាំងនេះបានបង្ហាញថា ភាគច្រើននៃសំណង់ដែលគេសង់ឡើងវិញ គឺជាទ្វារក្រុងដែលជាកន្លែងមួយដែលពួកខ្មាំងសត្រូវតែងតែប្រមូលគ្នាវាយលុកឈ្លានពាន ។ មិនមែនគ្រប់ទាំងអស់នៃទ្វារ ឬកំផែងក្រុងយេរូសាឡិមសុទ្ធតែទ្រុឌទ្រោមទាំងអស់នោះឡើយ គោលការណ៍នៃការសាងសង់ទាំងអស់នេះ មើលទៅហាក់បីដូចជាបានដកស្រង់ចេញពី ២ពវ ២៥:៩ ។

**៣:១** *អេលីយ៉ាស៊ីប ជាសំដេចសង្ឃ* ឃ្លានេះចង់និយាយថា វាជាការសក្តិសមបំផុតសម្រាប់សម្តេចសង្ឃដែលគួរតែបង្ហាញពីគំរូមុនគេក្នុងការដឹកនាំ ។ កាលពីជំនាន់ដើមព្រះមហាក្សត្រទ្រង់បានបង្ហាញគំរូរបស់ព្រះអង្គ ដល់ពួកសាម៉ារីដោយយកឥដ្ឋដោយផ្ទាល់ក្នុងកាសាងសង់ព្រះវិហារ ឬប្រាសាទ ។ *ទ្វារចៀម* សូមមើលការពន្យល់ ខ.៣២ ១២:៣៩ ។ នៅក្នុងគម្ពីរសញ្ញាថ្មី (យហ ៥:២) គេបានដឹងថាទ្វារនេះស្ថិតនៅជិតស្រះបេថែសដា (ស្ថិតនៅទិសឦសាននៃក្រុងយេរូសាឡិម) ហើយសព្វថ្ងៃនេះ ទីផ្សារសត្វចៀមត្រូវបានគេយកមកដាក់លក់យ៉ាងពេញក្នុងដំបន់នោះ ។ ប្រហែលជាទ្វារចៀម គឺជាការប្តូរឈ្មោះរបស់ទ្វារពួកបេនយ៉ាមីន (សូមមើលការពន្យល់ក្នុង យរ ៣៧:១៣ ៣៨:៧ សក ១៤:១០) ។ *ប៉មហាមេអា* សូមមើល ១២:៣៩ ។ ពាក្យថា "ហាមេអា" ប្រហែលសំដៅលើ (១).ច្រើន (១០០ហត្ថ) (២). ជាចំនួននៃជំហាន (៣).ជាសហគមន៍កងប្រដាប់អាវុធ (សូមធ្វើការប្រៀប ធៀបជាមួយ ចទ ១:១៥) ។ *ប៉មហាណានាល* ប៉មនេះគឺជាប៉មមួយ ដែលមានទំនាក់ទំនងជាមួយ "បន្ទាយដែលនៅក្បែរព្រះវិហារ (២:៨)" សម្រាប់ការពារទីក្រុងផ្នែកខាងជើងមិនឱ្យពួកខ្មាំងសត្រូវមើលងាយ ។

**៣:៣** *ទ្វារត្រី* សូមមើលការពន្យល់ ១២:៣៩ ។ ក្នុងសម័យកាលព្រះវិហារជាន់ដើម (ព្រះវិហារដែលស្តេចសាឡូម៉ូនកសាង) ទ្វារត្រីនេះគឺជាទ្វារច្រកក្រុងយេរូសាឡិមដ៏សំខាន់បំផុត (សូមមើលការពន្យល់ ២របា ៣៣:១៤ សផ ១:១០) ។ ម្ចាលដែលនៅត្រង់ទ្វារសមុទ្រគេបានយកត្រីមកពីក្រុងទីរ៉ុស និងសមុទ្រកាលីឡេទៅលក់នៅទីផ្សា (១៣:១៦) ដោយឆ្លងកាត់ទ្វារនេះដែលមានទីតាំងស្ថិតនៅភាគខាងជើងនៃកំផែងក្រុងយេរូសាឡិម (សូមមើលក្នុង សផ ១:១០) ។

**៣:៤** *ម្រេម៉ូត* សូមមើលការពន្យល់អំពីគាត់ក្នុង អរ ៨:៣៣ ។ *មស៊ូឡាម* នៅក្នុងវគ្គទី២ នឹងឃើញឈ្មោះរបស់គាត់ម្តងទៀត (មើល ខ.៣០) ។ លោកនេហេមាគាត់បានត្អូញត្អែរនិងរអ៊ូរទាំពីរឿងដែលមស៊ូឡម បានឱ្យកូនស្រីរបស់ខ្លួនទៅកូនរបស់ថូប៊ីយ៉ាធ្វើជាប្រពន្ធ (មើល ៦:១១៧-១៨ ២:១០) ។

សាដុក ជាកូនប្អាណាបានជួសជុល ៥បន្ទាប់ពីនោះទៅមាន
ពួកត្កូអា[ជ]បានជួសជុល តែពួកអ្នកមានត្រកូលខ្ពស់ក្នុងពួក
គេ ឥតបានជួយធ្វើការរបស់ព្រះអម្ចាស់នៃគេឡើយ ។
៦យ៉ូយ៉ាដា ជាកូនផាសេហា[ឈ] និងមស៊ូឡាម ជាកូន
បេសូឌា បានជួសជុលទ្វារចាស់ គេដាក់ធ្នឹមនឹងផ្ទាំងសន្លឹក
ទ្វារទាំងគន្លឹះ ហើយនិងរនុកឡើង ៧បន្ទាប់នឹងគេមាន
មេឡាទា ជាអ្នកក្រុងគីបៀន[ញ] និងយ៉ាដោន ជាអ្នកក្រុង
មេរ៉ុន ពួកក្រុងគីបៀន និងពួកក្រុងមីសប៉ា ជាស្រុកដែល
នៅក្រោមអំណាច របស់ចៅហ្វាយខេត្ត នៅខាងនាយទន្លេ
គេបានជួសជុល ៨បន្ទាប់ពីនោះ មានអ៊ូស៊ាល ជាកូនហារ
ហាយ៉ា ជាពួកជាងទងបានជួសជុល ហើយបន្ទាប់នឹងគាត់
មានហាណានា ជាម្នាក់ក្នុងពួកលាយគ្រឿងក្រអូបគាត់បាន
ជួសជុល គេធ្វើឱ្យក្រុងយេរូសាឡិមបានមាំមួនរហូតដល់
កំផែងធំ[ដ] ៩បន្ទាប់នឹងគេមានរេផាយ៉ា ជាកូនហើរ ដែលជា
នាយដំរួតលើស្រុក យេរូសាឡិម១ចំហៀង គាត់បានជួស
ជុល ១០បន្ទាប់ពីគាត់ មានយេដាយ៉ា ជាកូនហារូម៉ាប គាត់
ជួសជុលប្រទល់មុខនឹងផ្ទះគាត់ ហើយបន្ទាប់នឹងគាត់ នោះ
មានហាធូស ជាកូនហាសាបនា បានជួសជុល ១១ម៉ាលគា
ជាកូនហារីម និងហាស៊ូប ជាកូនផាហាត-ម៉ូអាប់ គេបាន
ជួសជុលមួយដុំទៀត ព្រមទាំងប៉មត្រង់គុកភ្លើង[ឋ] ១២បន្ទាប់
ពីនោះ សាលូម ជាកូនរបស់ហាឡូហេស ជានាយដំរួតលើ
ស្រុកយេរូសាឡិម១ចំហៀង គឺគាត់នឹងពួកកូនស្រីរបស់
គាត់បានជួសជុល ។
១៣ឯទ្វារច្រកភ្នំ[ឌ] គឺហានូន និងពួកស្រុកសាណូអា[ឍ]
បានជួសជុល គេបានសង់ទ្វារនោះ ហើយដាក់ផ្ទាំងសន្លឹក
ទ្វារ ព្រមទាំងគន្លឹះ និងរនុកឡើង ក៏ធ្វើកំផែង១ពាន់ហត្ថ
រហូតដល់ទ្វារសំរាមទៀត[ណ] ។
១៤ឯទ្វារសំរាមនោះ គឺម៉ាលគា កូនរេកាប ជានាយ
ដំរួតឃុំបេត-ហាកេរែម[ត]បានជួសជុល គាត់បានសង់ទ្វារ
នោះ ហើយដាក់ផ្ទាំងសន្លឹកទ្វារ ព្រមទាំងគន្លឹះ និងរនុក
ឡើង ។
១៥ឯទ្វារក្បាលទឹក គឺសាលូន កូនកុល-ហូសេ ជានាយ

**៣:៥** ជ ខ.២៧ ២សយ ១៤:២
**៣:៦** ឈ នហ ១២:៣៩
**៣:៧** ញ យស ៩:៣
**៣:៨** ដ នហ ១២:៣៨
**៣:១១** ឋ នហ ១២:៣៨
**៣:១៣** ឌ ២រប ២៦:៩ ឍ យស ១៥:៣៤ ណ នហ ២:១៣
**៣:១៤** ត យរ ៦:១

**៣:៥** *ត្កូអា* ត្កូអាគឺជាទីក្រុងដ៏តូចមួយដែលមានចំងាយប្រមាណជា ៩,៦៥ គ.ម ភាគខាងត្បូងភូមិបេថ្លេហិម និងមានចំងាយប្រមាណជា ១៧,៦៩ គ.ម ពីក្រុងយេរ៉ូសាឡិម ។ មិនតែប៉ុណ្ណោះសោត ត្កូអាគឺជាស្រុកកំណើតរបស់ហោរាអេម៉ុស ។ *ពួកអ្នកមានត្រកូលខ្ពស់* នៅក្នុងភាសាហេព្រើរពាក្យដែលប្រើត្រង់នេះមានការខុសគ្នានិងពាក្យដែលប្រើ ២:១៦ (សូមមើលទីនោះ) ដែលមានន័យថា "អំណាច" ឬ "រុងរឿង" (សូមមើលការពន្យល់ ១០:២៩ ២រប ២៣:២០ យរ ១៤:៣) ។ ពួកអ្នកអភិជនទាំងនោះមានការមើលងាយមើលថោកដល់ពួកអ្នកកម្មករស៊ីឈ្នួលបំផុត ។ *ឥតបានជួយធ្វើការ* តាមលក្ខណៈអក្សរសាស្ត្រគេនិយាយថា"ដាក់លើករ" ។ គេប្រើពាក្យនេះដោយប្រើធ្វើការស្រម៉ៃដល់សត្វគោដែលមិនព្រមទទួលនឹមមកដាក់លើក (សូមមើលការពន្យល់ យរ ២៧:១២) ។

**៣:៦** *ទ្វារចាស់* ទ្វារនេះស្ថិតនៅភាគខាងជើងឆៀងខាងលិចនៃក្រុងយេរ៉ូសាឡិម។ទ្វារនេះប្រហែលឈ្មោះមួយផ្សេងទៀតរបស់ទ្វារអេប្រាអិម (សូមមើលការពន្យល់ ១២:៣៩) បើមិនដូច្នេះទេទ្វារអេប្រាអិមនេះមិនបាននិយាយនៅក្នុងជំពូក៣ឡើយ ។

**៣:៨** *ជាងទង* សូមមើល ខ.៣១-៣២ ។ *ពួកលាយគ្រឿងក្រអូប* សូមមើលការពន្យល់ ១សយ ៨:១៣ ។ *កំពង់ផែ* សូមមើលការពន្យល់ ១២:៣៨ ។ នៅក្នុងឆ្នាំ១៩៧០-១៩៧១ ពួកអ្នកបុរាណវិទ្យាបានធ្វើកំណាយនៅក្រុងយេរូសាឡិម ហើយលទ្ធផល គឺអវិជ្ជមានដោយព្រោះគេមិនបានរកឃើញកំផែងក្រុងនៅភាគខាងលិចនោះឡើយ ។ កំពង់ផែនេះប្រហែលជាកសាងឡើងនៅដើមសតវត្សរ៍ទី៧ មុន គ.ស ដោយលោកហេសេគា (សូមមើល ២របា ៣២:៥) ។ ការកើតឡើងកំពង់ផែជាច្រើននោះមានសារៈសំខាន់ណាស់ ពីព្រោះវាធ្វើឱ្យពួកជនជាតិសាម៉ារីដែលដួលរលំបានហូរចូលមកវិញ នៅក្នុងឆ្នាំ៧២២-៧២១ ។

**៣:១០** *យេដាយ៉ា . . . គាត់ជួសជុលប្រទល់នឹងមុខផ្ទះរបស់គាត់* សូមមើល ខ.២៣,២៨-៣០ ។ វាជាការងាយស្រួលសម្រាប់លោកយេដាយ៉ា ក៏ដូចជាអ្នកជួសជុលឯទៀតៗផងដែរ ក្នុងការជួសជុលកំផែងក្រុងក៏ដូចជាទ្វារក្រុងដែលនៅជិតផ្ទះរបស់ខ្លួនបំផុត ។

**៣:១១** *ប៉មត្រង់គុកភ្លើង* ប៉មនេះមានទីតាំងនៅភាគខាងលិចនៃកំផែងក្រុង ប៉មនេះប្រហែលជាមានទីតាំងដូចគ្នានឹងប៉មដែលអូសៀសបានកសាងឡើង (សូមមើលការពន្យល់ក្នុង ២របា ២៦:៩) ។ គុកភ្លើងនោះអាចស្ថិតនៅ លើ "ផ្លូវនៃពួកដុតនំ"ដូចដែលបាននិយាយនៅ យរ ៣៧:២១ ។

**៣:១២** *ពួកកូនស្រី* ពួកកូនស្រីដែលបាននិយាយនៅទីនេះ គឺកូនរបស់ពួកអ្នកដែលកសាងកំផែងក្រុងឡើងវិញ ។ នៅពេលដែលពួកក្រុងអាថែនព្យាយាមសាងកំផែងក្រុងឡើងវិញ បន្ទាប់ពីពួកពើស៊ីបានវាយបំផ្លាញមក គេបានចេញក្រឹត្យមួយគឺ"គ្រប់ទាំងអស់នៃមនុស្សដែលរស់នៅក្នុងទីក្រុង មិនថាប្រុស មិនថាស្រីឬក៏ជាកូនក្មេងឡើយ ត្រូវតែមានចំណែកក្នុងការកសាងកំផែងក្រុង" ។

**៣:១៣** *ទ្វារច្រកភ្នំ* សូមមើលការពន្យល់ ២:១៣ ។ *១ពាន់ហត្ថ* នៅក្នុងឃ្លានេះចង់មានន័យថា រយៈប្រវែងនៃកំផែងក្រុងនេះគឺវែងហួសពីធម្មតា ប្រហែលភាគច្រើននៃកំផែងក្រុងទាំងនោះមិនខូចខាតទាំងស្រុងនោះទេ *ទ្វារសំរាម* សូមមើលការពន្យល់ ២:១៣ ។

**៣:១៤** *បេត-ហាកេរែម* ឈ្មោះរបស់ឃុំនេះមានន័យថា"ដំណាក់ចំការទំពាំងបាយជូរ" ។ ឃុំនេះត្រូវបាន"ដុតដោយភ្លើងទុកជាទីសំគាល់"(សូមមើលការពន្យល់ក្នុង យរ ៦:១) ហើយវាក៏មានឈ្មោះថា រ៉ាម៉ាត-រ៉ាហែល ដែលមានចំងាយប្រមាណជា ៣,២១ គ.ម ភាគខាងត្បូងក្រុងយេរូសាឡិម នៅក្នុងអំឡុងពេលដែលចក្រភពពើស៊ីគ្រប់គ្រងលើពួកយូដាឃុំនេះ គឺប្រហែលកន្លែងដែលពួកចៅហ្វាយខេត្តមកស្នាក់អាស្រ័យនៅ ។

**៣:១៥** *ទ្វារក្បាលទឹក* សូមមើលការពន្យល់ក្នុង ២:១៤ ។ *ស្រះស៊ីឡោម* ស្រះនេះប្រហែលជាស្រះខាងក្រោម ដែលមាននិយាយនៅក្នុងគម្ពីរអេសាយ

ដំរួតឃុំ មីសប៉ាបានជួសជុល គាត់បានសង់ ហើយប្រក់
ដំបូលទ្វារនោះ ក៏ដាក់ផ្ទាំងសន្លឹកទ្វារ ព្រមទាំងគន្លឹះនិង
រនុកឡើង រួចគាត់ធ្វើកំផែងត្រង់ស្រះស៊ីឡោម[ថ] ដែលនៅ
ក្បែរសួនច្បារស្តេច រហូតដល់ជណ្តើរ ដែលចុះពីទីក្រុង
ដាវីឌ ១៦បន្ទាប់នឹងគាត់មាននេហេមា កូនអាសប៊ូក
ជានាយដំរួតឃុំបេត-ស៊ើរ[ទ]មួយចំហៀង គេបានជួសជុល
រហូតដល់ទល់មុខនឹងផ្នូរ[ធ]ដាវីឌ ហើយដល់ស្រះដែលគេ
បានជីក និងដល់ផ្ទះពួកមនុស្សខ្លាំងពូកែ ១៧បន្ទាប់នឹងគាត់
មានពួកលេវី គឺរេហ៊ូម ជាកូនរបស់បានី បានជួសជុល
ហើយបន្ទាប់មកទៀត មានហាសាបយ៉ា ជានាយដំរួត
លើឃុំកៃឡា[ន]មួយចំហៀងបានជួសជុល ជំនួសពួកអ្នកស្រុក
គាត់ ១៨បន្ទាប់នឹងគាត់មានពួកបងប្អូនរបស់គេបានជួសជុល
គឺបាវ៉ាយ កូនហេណាដាឌ ជានាយដំរួតឃុំកៃឡាមួយ
ចំហៀង ១៩បន្ទាប់នឹងគាត់ មានអេស៊ើរ កូនយេសួរជានាយ
ដំរួតលើស្រុកមីសប៉ា គេបានជួសជុលមួយដុំទៀតទល់មុខ
នឹងផ្លូវឡើងទៅឃ្លាំងគ្រឿងសស្ត្រាវុធ ត្រង់រំពត់កំផែង
២០បន្ទាប់នឹងគាត់ មានបារូក ជាកូនសាប់បាយបានខ្នះខ្នែង
ធ្វើមួយដុំទៀត ចាប់តាំងពីរំពត់កំផែង រហូតដល់ទ្វារផ្ទះ
អេលីយ៉ាស៊ីប ជាសំដេចសង្ឃ ២១បន្ទាប់ពីគាត់ មានម្រេម៉ូត[ប]
កូនអ៊ូរីយ៉ា ដែលជាកូនហាកូស បានជួសជុលមួយដុំទៀត
គឺចាប់តាំងពីទ្វារផ្ទះអេលីយ៉ាស៊ីប រហូតដល់ចុងផ្ទះលោក
២២បន្ទាប់នឹងគាត់មានពួកសង្ឃបានជួសជុល គឺជាពួកសង្ឃ
ដែលនៅស្រុកជុំវិញ ២៣បន្ទាប់នឹងគេ មានបេនយ៉ាមីន និង
ហាស៊ូបបានជួសជុល ទល់មុខនឹងផ្ទះខ្លួន ហើយបន្ទាប់នឹងគេ
នោះមានអ័សារា កូនម្អាសេយ៉ា ដែលជាកូនអ័ណានាបាន
ជួសជុលក្បែរផ្ទះខ្លួន ២៤បន្ទាប់នឹងគាត់ មានប៊ីនុយ[ផ] ជាកូន
ហេណាដាឌបានជួសជុលមួយដុំទៀត គឺចាប់តាំងពីផ្ទះ
អ័សារារហូតដល់រំពត់កំផែង ហើយទៅដល់ទីជ្រុងផង
២៥ប៉ាឡាល ជាកូនអ៊ូសាយបានធ្វើ នៅមុខរំពត់កំផែង និង
ប៉មដែលលយចេញពីដំណាក់ស្តេចខាងលើ ដែលនៅក្បែរ
ទីធ្លារបស់ក្រុមរក្សាអង្គ[ព] ហើយបន្ទាប់នឹងគាត់មានពេដាយ៉ា
ជាកូនប៉ារ៉ូស[ភ]បានធ្វើ ២៦រីឯពួកនេធីនិម[ម]ដែលនៅត្រង់
អូផែល[យ] គេក៏ធ្វើរហូតដល់ទីទល់មុខនឹងទ្វារទឹក[រ]ខាងកើត
ហើយមកដល់ប៉មដែលលយចេញនោះ ២៧បន្ទាប់នោះមាន
ពួកត្កូអា[ល]បានជួសជុលមួយដុំទៀត ទល់មុខនឹងប៉មធំ[វ] ដែល
លយចេញរហូតដល់កំផែងអូផែល ។

**៣:១៥** ថ អស ៨:៦ យហ ៩:៧
**៣:១៦** ទ យស ១៥:៥៨ ធ កច ២:២៩
**៣:១៧** ន យស ១៥:៤៤
**៣:២១** ប អរ ៨:៣៣
**៣:២៤** ផ អរ ៨:៣៣
**៣:២៥** ព យរ ៣២:២ ៣៧:២១ ៣៩:១៤ ភ អរ ២:៣
**៣:២៦** ម នហ ៧:៤៦ ១១:២១ យ ២របា ៣៣:១៤ រ នហ ៨:១,៣, ១៦ ១២:៣៧
**៣:២៧** ល ខ.៥ វ ទដ ៤៨:១២

២២:៩ (សូមមើលការពន្យល់ទីនោះ និង អស ៨:៦) ។ *សួនច្បារស្តេច* សូមមើលការពន្យល់ក្នុង ២:១៤ ។ *ក្រុងដាវីឌ* សូមមើលការពន្យល់ ១២:៣៧ ២សយ ៥:៧ ។

**៣:១៦** *បេត-ស៊ើរ* ឃុំបេត-ស៊ើរនេះគឺស្ថិតនៅក្នុងទីរួមស្រុកតែម្តង ដែលមានចំងាយប្រមាណជា២០,៩១ គ.ម ភាគខាងត្បូងក្រុងយេរូសាឡិម ។ ការកំណាយនៅក្នុងឆ្នាំ១៩៣១ និងឆ្នាំ១៩៥៧ បានបង្ហាញថាអ្នកដែលរស់នៅទីកន្លែងនោះក្នុងសម័យកាលចក្រភពពើស៊ី ភាគតិចណាស់ដែលមានមុខរបរ ប៉ុន្តែនៅក្នុងសតវត្សរ៍ទី៥ មុន គ.ស កន្លែងនេះបានផ្តល់ការងារជាច្រើនវិញ ។ *ផ្នូរដាវីឌ* សូមធៀបជាមួយ ២:៥ ។ នៅពេលដែលស្តេចដាវីឌសុគតត្រូវគេយកគាត់មកបញ្ចុះនៅទីក្រុងនេះ (សូមមើលក្នុង ១ពរ ២:១០ ២របា ២១:២០ ៣២:៣៣ កច ២:២៩) ។ ដូច្នេះផ្នូររបស់ស្តេចដាវីឌ ដែលស្ថិតនៅលើភ្នំស៊ីយ៉ូនដែលជាទីសក្ការៈរបស់ពួកយូដារហូតដល់សព្វថ្ងៃនេះ គឺគ្រាន់តែជាផ្នូរដែលគេអនុម័តកសាងឡើងក្នុងសតវត្សរ៍ទី ១៤នៃគ.ស ប៉ុណ្ណោះ ។ ដូច្នេះសរុបមក ផ្នូររបស់ដាវីឌគេទើបលើកមកនិយាយនៅក្រោយសតវត្សរ៍ទី៩នៃគ.សប៉ុណ្ណោះ ។ *ផ្ទះពួកមនុស្សខ្លាំងពូកែ* ផ្ទះពួកមនុស្សខ្លាំងពូកែដែលបាននិយាយនៅត្រង់កន្លែងនេះ ប្រហែលជាផ្ទះពួកមនុស្សរបស់ដាវីឌ (សូមមើលការពន្យល់ក្នុង ២សយ ២៣:៨-៣៩) ដែលជាអ្នកមកស្នាក់អាស្រ័យនៅជាមួយ ឬជាពួកទាហាន ។

**៣:១៧-១៨** *កៃឡា* ឃុំកៃឡាមានចំងាយប្រមាណជា ២៤,១៣ គ.ម នៅទិសខាងត្បូងឆៀងខាងលិចពីក្រុងយេរូសាឡិម ។ ឃុំនេះជាទីកន្លែងដ៏សំខាន់មួយក្នុងយុគសម័យកាលជាប្រវត្តិសាស្ត្ររបស់ស្តេចដាវីឌ កាលពីសម័យមុន (សូមមើលការពន្យល់ ១សយ ២៣:១-១៣) ។

**៣:១៩** *គ្រឿងសស្ត្រាវុធ* សូមមើលការពន្យល់ ខ.១៦ ។ *រំពត់* សូមមើលការពន្យល់ក្នុង ២របា ២៦:៩ ។

**៣:២០-២១** អត្ថន័យនៅក្នុងខ.ទាំងនេះចង់និយាយថា ទីកន្លែងស្នាក់អាស្រ័យរបស់ពួកសម្តេចសង្ឃ និងពួកពលបរិវាសង្ឃទាំងនោះ គឺស្ថិតនៅក្រៅទីក្រុងតាមបណ្តោយកំផែងក្រុងនៅភាគខាងជើង ។

**៣:២៥** *ដំណាក់ស្តេចខាងលើ* ដំណាក់ស្តេចខាងលើដែលបាននិយាយនៅកន្លែងនេះ ប្រហែលជាសំដៅលើដំណាក់ចាស់របស់ស្តេចដាវីឌ (សូមមើលការពន្យល់ក្នុង ១២:៣៧ ។ ដំណាក់នេះ មានពួកទាហានចាំយាមដូចជាដំណាក់របស់ស្តេចសាឡូម៉ូនដែរ (សូមមើលការពន្យល់ យរ ៣២:២) ។

**៣:២៦** *អូផែល* សូមមើលការពន្យល់ក្នុងខ.២៧។ពាក្យនេះមានន័យថា "ហើម" ឬ "ប៉ោង" ចេញពី"ភ្នំ"(ដូចដែលមាននិយាយនៅក្នុង មីក ៤:៨) ជាពិសេសជួរភ្នំនៅភាគខាងជើង នៃតំបន់ជួរភ្នំនៅទិសខាងត្បូងឆៀងខាងកើតពីក្រុងយេរូសាឡិម ដែលជាទីក្រុងដំបូងរបស់ស្តេចដាវីឌ ដែលសព្វថ្ងៃនេះនៅភាគខាងត្បូងព្រះវិហារ (សូមមើលការពន្យល់ ២របា ២៧:៣) ។ *ទ្វារទឹក* មូលហេតុដែលបណ្តាលឱ្យគេហៅទ្វារនេះថាជាទ្វារទឹក ពីព្រោះទ្វារនេះជាប្រភពចម្បងក្នុងការផ្គត់ផ្គង់ទឹកដល់ក្រុងយេរូសាឡិម។ទ្វារនេះវាគឺជាទ្វារដែលមានទំហំធំ ពីព្រោះពួកគេបានអានគម្ពីរក្រិត្យវិន័យនៅត្រង់កន្លែងនេះ (សូមមើល ៨:១,៣,១៦ ១២:៣៧) ។ *ប៉មដែលលយចេញ* ប៉មដែលលយចេញនេះ ប្រហែលជាប៉មមួយដែលមានទំហំធំ ដែលពួកក្រុមអ្នកបុរាណវិទ្យាបានធ្វើការរុករកនៅលើកំពូលភ្នំអូផែលកាលពីឆ្នាំ ១៩២៣-១៩២៥ នៃ គ.ស ។ ការកំណាយរកអំពីប៉មនេះនៅក្នុងឆ្នាំ១៩៧៨ បានផ្តល់ឱ្យគេបានដឹងថា អាយុកាលរបស់ប៉មនេះ គឺក្នុងអំឡុងពេលដែលពួកពើស៊ីគ្រប់គ្រងមកម្ល៉េះ ។

**៣:២៧** *ពួកត្កូអា* ប្រជាជនត្កូអាគេមានកិច្ចការងារនិងទំនួលខុសត្រូវ២ ព្រោះ

២៨ឯខាងលើទ្វារសេះ[ស] នោះពួកសង្ឃបានជួសជុលទល់
មុខនឹងផ្ទះគេរៀងខ្លួន ២៩បន្ទាប់នឹងគេ នោះមានសាដុក ជា
កូនអ៊ីមមើរ បានជួសជុល ទល់មុខនឹងផ្ទះខ្លួន ហើយបន្ទាប់
នឹងគាត់មានសេម៉ាយ៉ា កូនសេកានា ជាអ្នកឆ្មាំទ្វារទិសខាង
កើតបានជួសជុល ៣០បន្ទាប់នឹងគាត់ មានហាណានា ជាកូន
សេលេមា និងហានូន ជាកូនទី៦របស់សាឡាប គេបានជួស
ជុលមួយជុំទៀត បន្ទាប់នឹងគេនោះមានមស៊ូឡាម ជាកូន
បេរេគា បានជួសជុលទល់មុខនឹងបន្ទាប់របស់ខ្លួន ៣១បន្ទាប់
នឹងគាត់មានម៉ាលគា ជាម្នាក់ក្នុងពួកជាងទងបានជួសជុល
រហូតដល់ផ្ទះពួកនេធីនិមនឹងពួកជំនួញ ទល់មុខនឹងទ្វារ
មីបកាឌ ហើយដល់ផ្លូវឡើង ត្រង់ជ្រុងកំផែង ៣២ហើយមួយ
ជុំនៅកណ្ដាលទីដណ្ដើរ ឡើងត្រង់ជ្រុងកំផែងនិងទ្វារចៀម
[ហ]នោះគឺពួកជាងទង និងពួកជំនួញបានជួសជុលឡើង ។

## ការជិទាស់នឹងការសាងសង់

**៤** ១កាលសានបាឡាត់[ក]បានឮថា យើងកំពុងតែសង់កំផែង
ឡើងដូច្នោះ នោះលោកមានចិត្តក្រោធ ហើយគ្នាន់ក្នាញ់
ក្នុងចិត្តជាខ្លាំង ព្រមទាំងចំអកឡកឡឺយដល់ពួកយូដា ២ក៏
និយាយនៅមុខពួកបងប្អូនខ្លួន[ខ] និងពួកពលទ័ពស្រុកសាម៉ារី
ថា ពួកយូដាកំសោយនេះធ្វើអ្វីដូច្នេះ គេគិតការពារខ្លួនឬ
តើគេនឹងថ្វាយយញ្ញបូជាដែរឬ តើគេនឹងធ្វើបង្ហើយក្នុង
មួយថ្ងៃបានឬ តើគេនឹងធ្វើឱ្យថ្មទាំងប៉ុន្មានចេញពីគំនរ
សំរាម[គ] ដែលឆេះអស់ហើយ បានកើតឡើងដែរឬ ៣នោះ
ថូប៊ីយ៉ា[ឃ] ជាសាសន៍អាំម៉ូន ដែលឈរជិតលោក ក៏និយាយ

**៣:២៨** ស ២ពវ ១១:១៦
**៣:៣២** ហ ខ.១ យហ ៥:២
**៤:១** ក នហ ២:១០
**៤:២** ខ អរ ៤:៩–១០ គ ទដ ៧៩:១ យរ ២៦:១៨
**៤:៣** ឃ នហ ២:១០ ង យប ១៣:១២ ១៥:៣
**៤:៤** ច ទដ ៤៤:១៣ ១២៣:៣–៤ យរ ៣៣:២៤
**៤:៥** ឆ អស ២:៩ បទ ១:២២ ជ ២ពវ ១៤:២៧ ទដ ៥១:១ ៦៩:២៧–២៨ ១០៩:១៤ យរ ១៨:២៣
**៤:៧** ឈ នហ ២:១០
**៤:៨** ញ ទដ ២:២ ៨៣:១–១៨
**៤:១០** ដ ១រប ២៣:៤

ឡើងថា បើគ្រាន់តែមានចចកមួយឡើងទៅលើកំផែងថ្ម
ដែលគេ កំពុងតែធ្វើនោះនឹងធ្វើឱ្យរលំទៅហើយ[ង]។
៤ឱព្រះនៃយើងខ្ញុំអើយ សូមទ្រង់ស្ដាប់ចុះ ដ្បិតគេមើល
ងាយយើងខ្ញុំណាស់[ច] សូមទំលាក់សេចក្ដីដំនៀលរបស់គេ
ទៅលើក្បាលគេវិញ ហើយប្រគល់គេទៅឱ្យត្រូវរឹបជាន់
នៅក្នុងស្រុកដែលគេត្រូវដឹកនាំទៅជាឈ្លើយនោះ ៥សូម
ទ្រង់កុំគ្របបាំងសេចក្ដីទុច្ចរិតរបស់គេ[ឆ] ឬលុបបាបគេ ពី
ចំពោះទ្រង់ចេញឡើយ[ជ] ពីព្រោះគេបានបណ្ដាលឱ្យមាន
សេចក្ដីកំហឹង នៅចំពោះពួកអ្នកដែលធ្វើការ ៦ដូច្នោះ
យើងខ្ញុំបានសង់កំផែងឡើង ដរាបដល់បានជាប់ជុំវិញត្រឹម
កំពស់ពាក់កណ្ដាលធម្មតា ដ្បិតពួកបណ្ដាជនគេមានចិត្ត
ឧស្សាហ៍ ។
៧កាលសានបាឡាត និងថូប៊ីយ៉ា[ឈ] ព្រមទាំងពួកអារ៉ាប់
នឹងពួកអាំម៉ូន ហើយពួកអាសដូឌបានឮថាការជួសជុល
កំផែងក្រុងយេរូសាឡិមចេះតែបានចំរើនឡើង ហើយថា
កន្លែងបាក់បែកបានចាប់តាំងបិតភ្ជិតទៅវិញ នោះគេក៏
មានសេចក្ដីក្រោធជាខ្លាំង ៨ហើយគេប្រឹក្សាព្រមគ្នា[ញ]នឹង
មកច្បាំងនឹងក្រុងយេរូសាឡិម ឱ្យបង្កើតការច្របល់ឡើង
៩ហើយដោយព្រោះគេ បានជាយើងខ្ញុំអធិស្ឋាន ដល់ព្រះនៃ
យើងរាល់គ្នា ហើយតាំងពួកចាំយាម ឱ្យរវាំងទាំងយប់ទាំង
ថ្ងៃ ១០ឯពួកយូដាគេនិយាយថា កំឡាំងរបស់ពួកអ្នកលីសែង
[ដ]បានអន់ថយទៅហើយ សំរាមក៏មានយ៉ាងសន្ធឹកដល់ម្លេះ
បានជាយើងនឹងសង់កំផែងឡើងវិញពុំបាន ១១មួយទៀត

ពួកអ្នកមានត្រកូលខ្ពស់នៅត្កូអា គេមិនព្រមទទួលខុសត្រូវលើកិច្ចការងារ
របស់គេ (សូមមើល ខ.៥) ។

**៣:២៨** *ទ្វារសេះ* ទ្វារសេះនេះជាទីកន្លែងដែលគេធ្វើគតព្រះនាងអ័ថាលា (សូមមើលការពន្យល់ក្នុង ២រប ២៣:១៥) ។ ទ្វារសេះនេះប្រហែលស្ថិតនៅភាគខាងជើងបំផុតនៃកំផែងក្រុង ហើយវាទ្វារមួយដែលបន្តរហូតដល់ជ្រោះកេដ្រុន(សូមមើលការពន្យល់ក្នុង យរ ៣១: ៤០) ។

**៣:២៩** *ទ្វារទិសខាងកើត* ឥឡូវនេះទ្វារនេះប្រហែលជាដូរឈ្មោះមកជាទ្វារមាស (ទ្វារដែលធ្វើអំពីមាស) ។

**៣:៣១** *ជាងទង* សូមមើលការពន្យល់ក្នុង ខ.៨ ។ *ទ្វារមីបកាឌ* ទ្វារនេះស្ថិតនៅភាគខាងជើងបង្អស់នៃកំផែងក្រុងទ្វារខាងជើង ។

**៣:៣២** *ទ្វារចៀម* ទ្វារចៀមនេះគឺជាទ្វារច្រកចេញ និងចូល(មើល ខ.១) ។

**៤:១** *ពួកយូដា* សូមមើលការពន្យល់ក្នុង សក ៨:២៣ ។

**៤:២** *ក៏និយាយ* នៅក្នុងឃ្លានេះចង់និយាយថាជានិច្ចកាលពួកមន្ត្រីពើស៊ីតែងតែមានជម្លោះឈ្លោះប្រកែកគ្នា ។ លោកសានបាឡាត់គាត់បានសួរសំនួរជាច្រើន ដែលជាការចំអកឡកឡឺយដល់ពួកយូដាហើយធ្វើឱ្យពួកគេធ្លាក់ទឹកចិត្តក្នុងការសាងសង់កំផែងក្រុង ។ *ឆេះអស់* នៅទីនេះចង់និយាយថា ភ្លើងអាចធ្វើឱ្យថ្មមហ្គរាយបាន ដែលថ្មនោះប្រហែលជាថ្មកំបោរ ។

**៤:៤–៥** នៅក្នុងខ.ទាំង២នេះ គេអាចហៅវាថាជាទំនុកដំកើងនៃបណ្ដាសារ (សូមមើលការពន្យល់ក្នុង ៥:១០) ពីព្រោះលោកនេហេមាគាត់មិនបានធ្វើការទាស់ប្រឆាំងចំពោះគូបក្សដិបក្សរបស់គាត់ដោយខ្លួនឯងឡើយ ប៉ុន្តែគាត់បានអំពាវនាវ សូមឱ្យព្រះអម្ចាស់ទ្រង់បានសេចក្ដីដំនៀលរបស់គេទៅលើក្បាលគេវិញ ។ នៅក្នុងខ.៥លោកនេហេមាគាត់បានធ្វើការអធិស្ឋានដល់ព្រះអម្ចាស់ដូចគ្នានឹង យរ១៨:២៣ ។

**៤:៧** *អាសដូឌ* សូមមើលការពន្យល់ អស ២០:១ ។ នៅក្នុងយុគស័មដែលពួកពើស៊ីកាន់កាប់ ពួកគេបានយកតំបន់កន្លែងនេះធ្វើជាទីរួមស្រុកមួយ ។

**៤:៩** *អធិស្ឋាន . . . តាំងពួកចាំយាម* នៅកន្លែងនេះចង់មានន័យថា គេបានអធិស្ឋានដល់ព្រះអង្គ លាយឡំនិងការគ្មានជំនឿទុកចិត្តដល់ព្រះអង្គឡើយ បានជា គេពឹងលើព្រះអង្គផង និងមនុស្សមនុស្សដូច្នេះ ។

**៤:១០** *អន់ថយ* នៅត្រង់ចំនុចនេះចង់និយាយថា ដោយសារការអន់ថយកម្លាំងរបស់ពួកអ្នកលីសែង បានធ្វើឱ្យពួកគេដើរទាំងទ្រេតទ្រោឌ ដោយព្រោះទំនង់នៃបន្ទុកដែលពួកគេលី ហើយក៏មានពួកគេមួយចំនួនបានដើរដួលហើយដែរ ។

ពួកខ្មាំងសត្រូវរបស់យើង គេនិយាយថា យើងនឹងលោ
ចូលទៅដល់កណ្តាលគេ រួចសំឡាប់គេបង់ហើយបញ្ឈប់
ការនោះ មុនដែលគេដឹងខ្លួន ឬឃើញអ្វីផង ១២ឯពួកសាសន៍
យូដា ដែលមានទីលំនៅជិតគេ នោះក៏មកពីគ្រប់ទីកន្លែង
របស់ខ្លួន ប្រាប់យើងរាប់គ្នាដល់ទាំង១០ដងថា គេនឹងសង្ស
ក៏មកលើយើង ១៣ដូច្នេះ ខ្ញុំក៏ដាក់ពួកបណ្តាជន ឱ្យកាន់ដាវ
លំពែងនឹងធ្នូរបស់គេ ឈរនៅត្រង់កន្លែងកំផែងទាបៗ
ហើយនៅខាងលើផង តាមវង្សរបស់គេ ១៤ខ្ញុំក៏ត្រួតមើល
រួចចូលទៅជិត ប្រាប់ដល់ពួកអ្នកធំ និងពួកមេ ព្រមទាំងពួក
បណ្តាជនទាំងប៉ុន្មានថា កុំឱ្យខ្លាច[ឋ]គេឡើយ ចូរនឹករឭក[ឌ]
ដល់ព្រះអម្ចាស់ដែលទ្រង់ធំ ហើយគួរស្ញែងខ្លាចវិញ[ឍ] រួច
តស៊ូការពារ[ណ]ពួកបងប្អូនកូនប្រុសកូនស្រី ហើយប្រពន្ធនឹង
ផ្ទះសំបែងរបស់អ្នករាល់គ្នាចុះ ។
១៥កាលពួកខ្មាំងសត្រូវបានឮថា យើងរាល់គ្នាដឹងក្នុង
គំនិតគេ ហើយថា ព្រះបាននាំឱ្យសេចក្តីប្រឹក្សារបស់គេខូច
បង់ទៅដូច្នោះ[ត] នោះយើងទាំងអស់គ្នា ក៏វិលទៅធ្វើកំផែង
តាមការយើងរៀងខ្លួន ១៦ដូច្នេះ ចាប់តាំងពីវេលានោះទៅ
ពួករបស់ខ្ញុំពាក់កណ្តាលក៏ធ្វើការ ហើយពាក់កណ្តាលទៀត
ក៏កាន់លំពែង ខែល ធ្នូ និងអាវក្រោះ ឯពួកមេ ក៏ជួយទប់
ទល់ពួកវង្សរបស់យូដាទាំងប៉ុន្មានដែរ ១៧ចំណែកពួកអ្នក
ដែលធ្វើកំផែង និងពួកអ្នកដែលលីសែង ហើយពួកអ្នក
ដែលជញ្ជូនដាក់ គេធ្វើការដោយដៃម្ខាង ហើយដៃម្ខាង
ទៀតកាន់គ្រឿងសស្ត្រាវុធ[ថ] ១៨ពួកជាងថ្មគេក្រវាត់ដាវនៅ
ចង្កេះ ហើយក៏ធ្វើការទាំង ដូច្នោះ ឯអ្នកដែលផ្លុំត្រែ[ទ] នោះ
ក៏នៅជិតខ្ញុំ ១៩ហើយខ្ញុំប្រាប់ដល់ពួកអ្នកធំ ពួកមេ និងពួក
បណ្តាជនទាំងពួងថា ការនេះជាការធំវែងពេកណាស់
យើងរាល់គ្នាឃ្លាតឆ្ងាយពីគ្នា នៅលើកំផែងផង ២០ដូច្នេះ
នៅកន្លែងណាដែលអ្នករាល់គ្នាឮសូរត្រែ[ធ] នោះត្រូវឱ្យអ្នក
រាល់គ្នាមូលមកឯយើងនៅទីនោះ ព្រះនៃយើងរាល់គ្នា
ទ្រង់នឹងតស៊ូ[ន]ជំនួសយើង ។
២១យ៉ាងនោះ យើងរាល់គ្នាចេះតែធ្វើការទៅ មនុស្ស
ពាក់កណ្តាល បានកាន់លំពែងចាប់តាំងពីថ្ងៃរះ ដរាបដល់
ផ្កាយលេចចេញមក ២២នៅគ្រានោះ ខ្ញុំក៏ប្រាប់ពួកជនថា
ត្រូវឱ្យគ្រប់គ្នា ព្រមទាំងអ្នកបំរើរបស់ខ្លួនដេកនៅក្នុងក្រុង
យេរូសាឡិម ដើម្បីនឹងជួយការពារយើងរាល់គ្នា នៅពេល
យប់ ហើយធ្វើការនៅពេលថ្ងៃ ២៣ដូច្នេះ ទោះខ្ញុំ ឬបងប្អូន
ពួកអ្នកបំរើខ្ញុំ ឬពួកចាំយាមដែលតាមខ្ញុំក្តី គ្មានអ្នកណាបាន
ដោះសំលៀកបំពាក់ចេញឡើយ លើកតែមានការបោកទឹក
ប៉ុណ្ណោះ ។

### លោកនេហេមាជួយដល់ពួកអ្នកក្រ

**៥** ១នៅគ្រានោះ មានសូរសំរែកជាខ្លាំងនៃពួកជន និង

**៤:១៤** ឋ លប ២៨:១៥ ចទ ១:២៩ ឌ នហ ១:៨ ឍ នហ ១:៥ ណ ២សយ ១០:១២ **៤:១៥** ត ២សយ ១៧:១៤ យប ៥:១២ **៤:១៧** ថ ទដ ១៤៩:៦ **៤:១៨** ទ ជន ១០:២ **៤:២០** ធ អគ ៣៣:៣ ន នក ១៤:១៤ ចទ ២០:៤ យស ១០:១៤

**៤:១១** *ពួកខ្មាំងសត្រូវរបស់យើង គេនិយាយថា* នៅកន្លែងនេះចង់និយាយថា ប្រហែលលោកនេហេមាមានអ្នកនាំដំណឹងយ៉ាងល្អ ឬមួយពួកខ្មាំងសត្រូវទាំងនោះ គេបានផ្សាយដំណឹងជាពាក្យចាមរាម ។

**៤:១២** *១០ដង* នៅក្នុងចំណុចនេះចង់និយាយថា ពួកយូដាគេបានប្រាប់ដល់លោកនេហេមាច្រើនដងមកហើយ ។

**៤:១៣** *នៅត្រង់កំផែងទាបៗ* លោកនេហេមាគាត់បានដាក់ឱ្យមនុស្សទាំងនោះឈរជ្រងោរនៅកន្លែងដែលគ្មានអ្នកការពារតាមបណ្តោយកំផែងក្រុង ។ *លំពែង* លំពែងគឺគេប្រើជាអាវុធសម្រាប់បុកទម្លុះ(សូមមើលការពន្យល់ ជន ២៥:៧–៨ ១ពរ ១៨:២៨) ។

**៤:១៤** *កុំឱ្យខ្លាចគេឡើយ ចូរនឹករឭកដល់ព្រះអម្ចាស់* សូមមើលការពន្យល់ក្នុង ១:៨ ។ នៅក្នុងឃ្លានេះចង់និយាយថា ការនឹករឭកដល់ព្រះអម្ចាស់ គឺជាមធ្យោបាយដ៏ល្អតែមួយគត់ដែលមិនឱ្យយើងមានសេចក្តីខ្លាចចំពោះខ្មាំងសត្រូវ ពីព្រោះមានតែព្រះអម្ចាស់១ប៉ុណ្ណោះ ដែលគួរឱ្យយើងកោតខ្លាច (សូមមើលការពន្យល់ ចទ ៣:២២ ២០:៣ ៣១:៦ ទដ ៥៦:៣–៤) ។

**៤:១៦** *ខែល* ខែលគឺជាប្រដាប់ការពារខ្លួនដែលធ្វើឡើងពីឈើ ឬឈើស្រួយម្យ៉ាង ដូច្នេះវាងាយនឹងឆេះណាស់(សូមមើលការពន្យល់ អគ ៣៩:៩) ។ *អាវក្រោះ* នៅក្នុងភាសាហេព្រើរពាក្យថា អាវក្រោះ គឺសំដៅលើលោហធាតុដែលជាប្រដាប់បាំងដើមទ្រូង (មើលការពន្យល់ ២របា ១៨:៣៣) ។

**៤:១៧** *គេធ្វើការដោយដៃម្ខាង ហើយដៃម្ខាងទៀតកាន់គ្រឿងសស្ត្រាវុធ* នៅក្នុងឃ្លានេះចង់មានន័យថា ពួកជាងទាំងនោះធ្វើការដោយដៃម្ខាង ហើយដៃម្ខាងទៀតកាន់គ្រឿងសាស្ត្រាវុធ និយាយឱ្យស្រួលស្តាប់គឺ គ្រឿងសាស្ត្រាវុធត្រូវនៅជាប់នឹងខ្លួនគេជានិច្ច ។

**៤:១៨** *ពួកអ្នកផ្លុំត្រែ* មើលការពន្យល់ អស ១៨:៣ យស ៦:៤,៦, ៨,១៣ ។

**៤:២០** *ព្រះនៃយើងរាល់គ្នា ទ្រង់នឹងតស៊ូជំនួសយើង* សូមមើលអំពីបរិបទដែលនិយាយអំពីចំបាំងបរិសុទ្ធ ដែលព្រះអម្ចាស់ទ្រង់ច្បាំងជំនួសរាស្ត្ររបស់ទ្រង់ ក្នុង យស ១០:១៤,៤២ ពច ៤:១៤ ២០:៣៥ ២សយ ៥:២៤ ។

**៤:២១** *ដរាបដល់ផ្កាយលេចចេញមក* នៅក្នុងឃ្លានេះចង់និយាយថា ពួកគេម្នាក់ៗបានធ្វើការយ៉ាងអស់ពីចិត្ត ពីព្រោះជានិច្ចកាលពួកកម្មករឈប់សម្រាក់ពីការងារនៅពេលថ្ងៃលិចប៉ុណ្ណោះ (សូមមើលការពន្យល់ ចទ ២៤:១៥ មថ ២០:៨) ។

**៤:២២** *ដើម្បីនឹងជួយការពារយើងរាល់គ្នា នៅវេលាយប់* នៅក្នុងឃ្លានេះចង់និយាយថា សូម្បីតែពួកអ្នកដែលនៅក្រៅក្រុងយេរូសាឡិម ក៏មកស្នាក់នៅក្នុងក្រុងនៅពេលយប់ដែរ ដូច្នេះពួកគេខ្លះមានកិច្ចការងារជាអ្នកយាម ។

**៤:២៣** នៅក្នុងខ.នេះចង់និយាយថា ទោះបីជាអត្ថន័យដ៏សង្ខេបនៅចុងបញ្ចប់នៃខ.នេះមានលក្ខណៈមិនច្បាស់លាស់ក៏ដោយ គឺអ្វីដែលទាក់ទងនោះដែលជាបរិច្ឆភាព វាគឺជាច្បាប់មួយដែលបានកំណត់រួចទៅហើយ ។

**៥:១–១៩** នៅក្នុងអំឡុងពេលដែលគាត់ខិតខំប្រឹងប្រែងកសាងកំផែងក្រុងយេរូសាឡិម លោកនេហេមាគាត់បានប្រឈរមុខជាមួយនឹងវិបត្តិសេដ្ឋកិច្ច

ប្រពន្ធគេ កើតឡើងទាស់នឹងពួកបងប្អូន ជាសាសន៍យូដា
២ មានខ្លះនិយាយថា ពួកយើងខ្ញុំ និងកូនប្រុសកូនស្រីយើងខ្ញុំ
មានគ្នាច្រើន សូមឱ្យយើងបានអាហារ ដើម្បីទទួលទាន
ហើយរស់នៅ ៣ មានខ្លះទៀតថា យើងខ្ញុំបានបញ្ចាំស្រែ[ក]
ចំការ និងផ្ទះសំបែងរបស់យើងខ្ញុំហើយសូមឱ្យយើងខ្ញុំ បាន
អាហារទទួលទាន នៅគ្រាអំណត់នេះផង[ខ] ៤ ហើយមានខ្លះ
ផ្សេងទៀតថា យើងខ្ញុំបានបញ្ចាំស្រែចំការរបស់យើងខ្ញុំ
ដើម្បីយកប្រាក់បង់ពន្ធ[គ]ថ្វាយស្តេច ៥ ប៉ុន្តែយើងខ្ញុំ និងពួក
បងប្អូននោះ មានសាច់[ឃ]ដូចគ្នា កូនចៅយើងខ្ញុំ ក៏ដូចជា
កូនចៅរបស់គេដែរ តែមើលយើងខ្ញុំ នាំឱ្យកូនប្រុសកូនស្រី
យើងខ្ញុំទៅជាខ្ញុំគេ[ង] ហើយកូនស្រីរបស់យើងខ្ញុំ ខ្លះក៏បាន
ជាប់ជាខ្ញុំគេហើយ យើងខ្ញុំក៏ចៀសមិនរួចដែរ ដ្បិតអ្នកឯ
ទៀតបានស្រែចំការរបស់យើងខ្ញុំទៅហើយ[ច] ។
៦ កាលខ្ញុំបានឮសំរែករបស់គេ និងពាក្យទាំងនោះហើយ
នោះខ្ញុំ ក៏មានចិត្តឈឺចាប់ជាខ្លាំង ៧ ខ្ញុំក៏ពិចារណាក្នុងខ្លួន
រួចបន្ទោសដល់ពួកអ្នកធំ និងពួកមេទាំងប៉ុន្មានដោយពាក្យ

**៥:៣** ក ទដ ១០៩:១១ ខ លប ៤៧:២៣
**៥:៤** គ អរ ៤:១៣
**៥:៥** ឃ លប ២៩:១៤ ង លវ ២៥:៣៩–៤៣,៤៧ ២ពវ ៤:១ អស ៥០:១ ច ចទ ១៥:៧ –១១ ២ពវ ៤:១

ដែលមានទំនាក់ទំនងទៅនឹងផ្នែកសិលធម៌ ។ នៅពេលដែលការកសាងកំផែងក្រុងបានចំណាយពេលអស់ត្រឹមតែ២៥ថ្ងៃ (សូមមើលការពន្យល់ ៦:១៥) ប៉ុណ្ណោះ នោះមានការភ្ញាក់ផ្អើលមួយបានកើតឡើង គឺលោកនេហេមាគាត់បាន "ប្រជុំជំនុំយ៉ាងធំ"មួយ ។ ប្រហែល បណ្តាលមកពីសម្ពាធនៃការគាប់សង្កត់ឱ្យកសាងកំផែងក្រុងឡើងវិញ និងកិច្ចការពីមុនមកជាហេតុធ្វើឱ្យមានបញ្ហានៃការប្តឹងផ្តល់គ្នាអស់រយៈពេលយូរបែបនេះកើតឡើង ។ នៅក្នុងចំណោមប្រភេទនៃឥទ្ធិពលដែលបណ្តាលមកពីវិបត្តិទាំងនោះមាន (ទី១)ពួកអ្នកដែលគ្មានអាហារបរិភោគ ពីព្រោះពួកគេគ្មានដីស្រែចំការ(សូមមើលក្នុង ខ.២) (ទី២)បណ្តាលមកពីពួកអ្នកដែលមានដីបានបង្ខំចិត្តបញ្ចាំដីឱ្យពួកអ្នកមាន(ខ.៣) ហើយ(ទី៣)ពួកគេបានបញ្ចាំដីស្រែចំការ ដើម្បីយកប្រាក់ថ្វាយពន្ធដល់ស្តេច ហើយក៏បានលក់កូនរបស់ពួកគេឱ្យធ្វើជាទាសករ(ខ.៤–៥) ។

**៥:១** *ប្រពន្ធ* នៅក្នុងខ.នេះចង់និយាយថា បញ្ហានេះគួរឱ្យគ្រោះថ្នាក់ណាស់ ដែលមានប្រពន្ធរបស់ពួកគេចូលរួមប្រឆាំង ចំពោះអ្វីដែលពួកគេបានជួបប្រទះក្នុងរយៈពេលដ៏ខ្លី ពីបញ្ហាថវិការ និងការផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ហើយពួកគេបានរអ៊ូរទាំ ដោយដឹងថាមិនមែនព្រោះរដ្ឋអំណាចជនបរទេសឡើយ ប៉ុន្តែអ្វីដែលពួកគេរអ៊ូរទាំនោះគឺដោយព្រោះមនុស្សដែលជាអ្នកស្រុករបស់ពួកគេបានយកគុណសម្បត្តិរបស់ពួកអ្នកក្រ ដែលជាអ្នកជិតខាងរបស់ខ្លួនក្នុងអំឡុងពេល ដែលពួកគេទាំងអស់ត្រូវការ ដើម្បីការពារប្រទេសជាតិ ។

**៥:២** *អាហារ* ជាធម្មតាក្នុង១ខែៗពួកគេត្រូវការអាហារពី៦–៧ ល្អីដើម្បីផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់ពួកគេ ។

**៥:៣** *បញ្ចាំ* នៅក្នុងឃ្លានេះចង់និយាយថា ទោះបីជាពួកគេមានទ្រព្យសម្បត្តិដើម្បីបញ្ចាំក៏ដោយ ក៏ប៉ុន្តែពួកគេបានទទួលកំរៃនៃការបញ្ចាំនោះយ៉ាងតិចបំផុត(សូមធៀបជាមួយ អស ៥:៨) ។ ក្នុងអំឡុងពេលដែលប្រទេសគេកំពុងជួបវិបត្តិសេដ្ឋកិច្ច នោះពួកអ្នកមានកាន់តែមានទៅ ហើយអ្នកក្រកាន់តែក្រទៅ ។ *គ្រាអំណត់* ដោយសារលក្ខខ័ណ្ឌធម្មជាតិនៃអំណត់អត់ បានធ្វើឱ្យពួកគេជួបប្រទះវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរទៅៗ ។ ក្នុងរយៈពេលប្រមាណជាមុនអំណត់៧៥ឆ្នាំ ហោរាហាកាយ លោកបានថ្លែងទំនាយអំពីភាពរាំងស្ងួតនៅក្នុងអំឡុងពេលដែលប្រទេសជាតិគេកំពុងខ្វះខាតអាហារ(សូមមើលការពន្យល់ក្នុង ហក ១:៥–១១) ។ ដូច្នេះ ក្នុងសម័យកាលដែលគេកំពុងតែជួបបញ្ហានេះ អាចនិយាយថាវាជាសេចក្តីជំនុំជំរះរបស់ព្រះអម្ចាស់(សូមមើលការពន្យល់ អស ៥១:១៩ យរ ១៤:១៣–១៨ អម ៤:៦) ។ ជាញឹកញាប់អំណត់អត់តែងតែកើតមាននៅក្នុងស្រុកកាណាន ហើយអំណត់អត់ទាំងនោះក៏បានកើតឡើងក្នុងសម័យកាលលោកអ័ប្រាហាំ(លប ១២:១០) អ៊ីសាក (លប ២៦:១) យ៉ូសែប ( លប ៤១:២៧,៥៤) នាងរស់(នរ ១:១) ដាវីឌ (២សយ ២១:១) អេលីយ៉ា (១ពវ ១៨:២) អេលីសេ (២ពវ ៤:៣៨) និងអ័ក្កាបុស(សូមមើល កច ១១:២៨) ។

**៥:៤** *ពន្ធ* តាមការប៉ាន់ស្មានបង្ហាញថា ព្រះមហាក្សត្រចក្រភពពើស៊ីបានប្រមូលពន្ធប្រមាណជា ២០លានដារីកក្នុង១ឆ្នាំ(សូមមើល អរ ៨:២៧) ។ ប្រាក់ពន្ធដ៏តិចតួចទាំងនោះ ត្រូវបានគេរាប់ជាទ្រព្យសម្បត្តិក្នុងខេត្តរបស់ពួកគេ ពីព្រោះភាគច្រើននៃរបស់ទ្រព្យទាំងនោះត្រូវគេប្រមូលមកដុតរំលាយហើយតម្កល់ទុកតាំងដុំៗ ។ ស្តេចអាឡិចហ្សង់ឌឺ គាត់គឺជាអ្នកប្រមូលពន្ធយ៉ាងល្បីល្បាយ នៅស្រុកស៊ូសាន ដោយប្រមូលបាន ៩០០០ហាបជាកាក់មាស (ប្រមាណជា ៣៤០តោន) និងប្រាក់ដុំប្រមាណជា ៤០០០០ហាប(ប្រមាណជា១៥០០តោន) ។

**៥:៥** *ខ្ញុំគេ* នៅក្នុងឃ្លានេះចង់និយាយថា នៅក្នុងអំឡុងពេលដែលប្រទេសជាតិគេកំពុងជួបវិបត្តិសេដ្ឋកិច្ច ក្រុមគ្រួសាររបស់គេនិមួយៗអាចនឹងរខ្ចីបុលពីអ្នកដទៃ ដែលមានលក្ខណៈជាក្រុម ជាមួយនឹងក្រុមគ្រួសាររបស់គេ ហើយក្នុងអំឡុងពេលខ្ចីបុលនោះ បើសិនបុរសដែលជាមេគ្រួសារមិនអាចសងបំណុលនោះទេ នោះប្រពន្ធកូន ឬក៏បុរសនោះឯងត្រូវលក់ខ្លួនធ្វើជាទាសការគេ ដើម្បីដោះបំណុល ។ ពួកអ៊ីស្រាអែលដែលធ្លាក់ខ្លួនខ្ចីបំណុលគេនោះត្រូវតែបម្រើដល់ម្ចាស់បំណុលរបស់ខ្លួនក្នុងនាមជា"អ្នកស៊ីឈ្នួល" (សូមមើលការពន្យល់ក្នុង លវ ២៥:៣៩–៤០) ។ នៅក្នុងឆ្នាំទី៧ពួកគេមានសិទ្ធិឈប់សម្រាក់ពីភាពជាអ្នកបម្រើស៊ីឈ្នួលនោះ (សូមមើលការពន្យល់ ចទ ១៥:១២–១៨) និងបានរួចពីភាពជាអ្នកបប្រើទៀតផង លើកលែងតែអ្នកនោះបានស្ម័គ្រចិត្តក្នុងការបម្រើបន្តទៀត ។ នៅក្នុងអំឡុងពេលដែលប្រទេសអេស៊ីព្ទជួបប្រទះគ្រោះអំណត់អត់រយៈ៧ឆ្នាំ មានបនុស្សជាច្រើនបានសុំឱ្យលោកយ៉ូសែបទទួលយកដីចំការ និងខ្លួនរបស់គេដើម្បីដោះដូរជាមួយស្បៀងអាហារ(សូមមើលការពន្យល់ក្នុង លប ៤៧:១៨–១៩) ។ អ្វីដែលជាកត្តានាំឱ្យមានសេចក្តីចំអកឡកឡឺយដល់ពួកអ៊ីស្រាអែលនោះ គឺកាលពីគ្រាមុនក្រុមគ្រួសាររបស់ពួកគេបាននិរទេសទៅស្រុកមេសូប៉ូតាមា តែឥឡូវនេះគឺដោយព្រោះបញ្ហាសេដ្ឋកិច្ច បានធ្វើឱ្យពួកគេលក់កូនរបស់ខ្លួនធ្វើជាទាសករ ។

**៥:៦** *នោះខ្ញុំក៏មានចិត្តឈឺចាប់ជាខ្លាំង* នៅក្នុងឃ្លានេះចង់និយាយថា ពេលខ្លះការឈឺចិត្តរបស់មនុស្សសុចរិតចំពោះបញ្ហាពុករលួយដែលមាននៅក្នុងសង្គម ក៏មានសារៈសំខាន់មួយដែរ(សូមធ្វើការប្រៀបធៀបជាមួយ មក ១១:១៥–១៨ អភ ៤:២៦) ។

**៥:៧** *យកការ* សូមមើលការពន្យល់ នក ២២:២៥–២៧ លវ ២៥:៣៦ ចទ

ថាអ្នករាល់គ្នាតែងតែយកការ [ឆ] គឺគ្រប់គ្នាយកពីពួកបងប្អូន
ផង ខ្ញុំក៏ប្រជុំជំនុំយ៉ាងធំទាស់នឹងគេ ៨រួចខ្ញុំនិយាយទៅគេថា
តាមកំឡាំងរបស់យើងរាល់គ្នា នោះយើងបានលោះពួក
បងប្អូនជាសាសន៍យូដា ដែលត្រូវលក់[ជ]ដល់សាសន៍ដទៃ ឱ្យ
រួចមកវិញ ចុះតើអ្នករាល់គ្នាចង់លក់បងប្អូនខ្លួនទៀតឬអី
ដែលនឹងលក់គេក្នុងពួកគ្នាយើង នោះតើគួរគប្បីដែរឬ
ដូច្នេះ គេក៏សៀមនៅ រកឆ្លើយមិនបាន[ឈ] ៩ខ្ញុំក៏និយាយថា
ការដែលអ្នករាល់គ្នាធ្វើនេះមិនល្អទេ គួរគប្បីឱ្យអ្នករាល់គ្នា
បានប្រព្រឹត្ត ដោយសេចក្ដីកោតខ្លាចដល់ព្រះនៃយើងរាល់
គ្នាវិញទេតើ គឺដោយព្រោះសេចក្ដីត្មះតិះដៀល[ញ]នៃពួក
សាសន៍ដទៃជាខ្មាំងសត្រូវយើង ១០ចំណែកខ្ញុំ ពួកបងប្អូន
និងពួកអ្នកបំរើខ្ញុំ ក៏អាចនឹងឱ្យគេខ្ចីប្រាក់នឹងស្រូវឱ្យបាន
ការដូចគ្នាបានដែរ ដូច្នេះ ខ្ញុំសូមឱ្យអ្នករាល់គ្នាលែងយក
ការទៅ[ដ] ១១សូមប្រគល់ស្រែចំការ ដំណាំនឹងផ្ទះគេទៅគេ
វិញ នៅថ្ងៃនេះឯង ព្រមទាំង១ភាគក្នុង១០០ នៃប្រាក់ ស្រូវ
ទឹកទំពាំងបាយជូរ និងប្រេងដែលអ្នករាល់គ្នាបានយកការ[ឋ]
ពីគេផង ១២នោះគេឆ្លើយថា យើងខ្ញុំនឹងប្រគល់ទៅវិញ
ហើយនឹងលែងយកការពីគេតទៅ យើងខ្ញុំនឹងធ្វើដូច
ជាលោកមានប្រសាសន៍ រួចខ្ញុំហៅពួកសង្ឃមកចាប់ឱ្យអ្នក
ទាំងនោះស្បថ[ឌ]ថា នឹងធ្វើតាមពាក្យសន្យានោះ ១៣ខ្ញុំក៏
រលាស់[ឍ]ថ្នក់អាវខ្ញុំពោលថា បើអ្នកណាមិនប្រព្រឹត្តតាម
ពាក្យសន្យានេះ នោះសូមឱ្យព្រះរលាស់អ្នកនោះ ចេញពី
ផ្ទះនិងពីការរបស់ខ្លួនយ៉ាងនេះដែរ សូមតែឱ្យគេត្រូវ
រលាស់ចេញចុះ ហើយចោលនៅទទេផង ពួកជំនុំទាំងអស់
គ្នាក៏ឆ្លើយឡើងថា អាម៉ែន[ណ] ហើយគេសរសើរដល់ព្រះ
យេហូវ៉ា រួចក៏ធ្វើតាមពាក្យសន្យានោះ ។
១៤រីឯចាប់តាំងពីថ្ងៃដែលស្ដេចបានតាំងខ្ញុំឡើងធ្វើជា
ចៅហ្វាយលើគេនៅស្រុកយូដា គឺពីឆ្នាំទី២០ដរាបដល់ឆ្នាំ
៣២ ក្នុងរាជ្យស្ដេចអើថាស៊ើកសេស[ត] រួមជា១២ឆ្នាំនោះខ្ញុំ
នឹងបងប្អូនខ្ញុំមិនបានទទួលទាន ភោជនាហារដោយអាង
បុណ្យជាចៅហ្វាយ[ថ]នោះទេ ១៥ឯពួកចៅហ្វាយ ដែលនៅ
មុនខ្ញុំ នោះបាននៅដោយសារពួករាស្ត្រ គេបានទារយក

**៥:៧** ឆ នក ២២:២៥–២៧ លវ ២៥:៣៥–៣៧ចទ ២៣:១៩–២០ ២៤:១០–១៣
**៥:៨** ជ លវ ២៥:៤៧ ឈ យរ ៣៤:៨
**៥:៩** ញ អស ៥២:៥
**៥:១០** ដ នក ២២:២៥
**៥:១១** ឋ អស ៥៨:៦
**៥:១២** ឌ អរ ១០:៥
**៥:១៣** ឍ មថ ១០:១៤ ណ ចទ ២៧:១៥–២៦
**៥:១៤** ត នហ ២:៦ ថ លប ៤២:៦ អរ ៦:៧ យរ ៤០:៧ ហក ១:១

២៣:២០ ។

**៥:៨** *ពួកបងប្អូនសាសន៍យូដា ដែលត្រូវលក់* នៅក្នុងន័យនេះចង់និយាយថា នៅពេលដែលពួកយូដាមានការធ្លាក់ចុះ ពួកគេត្រូវបានលក់ឱ្យធ្វើជាអ្នកស៊ីឈ្នួល មិនមែនលក់ឱ្យធ្វើជាទាសករនោះឡើយ(សូមមើលការពន្យល់ក្នុង លវ ២៥:៣៩–៤០) ។ *ដល់សាសន៍ដទៃ* នៅក្នុងន័យនេះចង់បញ្ជាក់ប្រាប់ថា ព្រះអម្ចាស់ទ្រង់មានបំរាមមិនឱ្យលក់ពួកសាសន៍ហេព្រើរឱ្យទៅធ្វើទាសករពួកប្រទេសក្រៅឡើយ (សូមមើលការពន្យល់ នក ២១:៨) ។ *គេក៏នៅស្ងៀម* មូលហេតុដែលពួកគេនៅមាត់ស្ងៀម គឺដោយសារតែអំពើបាបរបស់គេត្រូវបានបើកសម្ដែងច្បាស់មិនអាចបដិសេធ និងដោះសារបានឡើយ (សូមធ្វើការប្រៀបធៀប ជាមួយ យហ ៨:៧–១០) ។

**៥:៩** *មិនល្អទេ* នៅក្នុងកន្លែងនេះចង់មានន័យថា ពួកគេបានព្យាបាទចំពោះអ្នកដទៃ ដោយការប្រមាថមើលងាយចំពោះសេចក្ដីមេត្តាករុណា និងធ្វើបន្ទាល់ទាស់ជាមួយគេ(សូមធៀប សភ ១៤:៣១ ១ពត ២:១២–១៥) ។

**៥:១០** *សូមឱ្យអ្នករាល់គ្នាលែងយកការទៅ* នៅក្នុងសញ្ញាចាស់ បានហាមឃាត់ចំពោះការលោភលន់ដែលយកចំណេញលើគ្នាទៅវិញទៅមក(សូមមើលការពន្យល់ ទដ ១១៩:៣៦ អស ៥៦:៩–១២ ៥៧:១៧ យរ ៦:១៣ ៨:១០ ២២:១៣–១៧ អរ ២២:១២–១៣ ៣៣:៣១) ។ នៅពេលដែលបណ្ដាជនរបស់គាត់កំពុងប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច លោកនេហេមាបានបង្ខំពួកម្ចាស់បំណុលប្រព្រឹត្តការត្រឹមត្រូវ ដោយឈប់ទារការនិងសងការប្រាក់ដែលគេបានទារដល់ពួកកូនបំណុលរបស់ខ្លួនវិញ ។

**៥:១១** *១ភាគក្នុង១០០* នៅក្នុងកន្លែងនេះប្រហែលជាចង់មានន័យថា ពួកគេយកការប្រាក់១ភាគរយក្នុង១ខែ ដែលការប្រាក់សរុបប្រចាំឆ្នាំមានចំនួន ១២ភាគរយ ។ *ស្រូវ ទឹកទំពាំងបាយជូរ និងប្រេង* សូមមើលការពន្យល់ ១០:៣៧ ចទ ៧:១៣ ។

**៥:១៣** *ខ្ញុំក៏រលាស់ថ្នក់អាវខ្ញុំ* ទង្វើរបែបនេះគឺជានិមិត្តរូបនៃការសម្បថ និងធ្វើឱ្យពាក្យបណ្ដាសាកាន់តែមានសុពលភាព ចំពោះអ្នកណាដែលមិនស្មោះត្រង់ ដោយមិនព្រមធ្វើតាមពាក្យសម្បថនេះ។ *អាម៉ែន* សូមមើលការពន្យល់ពាក្យនេះ ៨:៦ ជន ៥:២២ ចទ ២៧:១៥ ។

**៥:១៤** *ឆ្នាំទី៣២* ចាប់តាំងពីថ្ងៃទី១ខែមេសាឆ្នាំ៤៣៣ មុន គ.ស រហូតដល់ថ្ងៃទី១៩ ខែមេសាឆ្នាំ ៤៣២ មុន គ.ស លោកនេហេមាគាត់មានការងារក្នុងនាមជាចៅហ្វាយខេត្តអស់រយៈពេល១២ខែ មុនពេលដែលគាត់ត្រឡប់មកដំណាក់ស្ដេចវិញ(សូមមើលការពន្យល់ ១៣:៦) បន្ទាប់ពីគាត់ត្រឡប់មកក្រុងយេរូសាឡិម(១៣:៧)ជាលើកទី២ ហើយក្នុងដំណើរនេះគេមិនអាចពណ៌នាពីរយៈពេលបានឡើយ ។ *ទទួលទានភោជនាហារដោយអាងបុណ្យជាចៅហ្វាយនោះ* សូមមើលការពន្យល់ខ.១៨ ។ ជាធម្មតាពួកចៅហ្វាយខេត្តតែងតែធ្វើការប៉ាន់ប្រមាណចំនួនប្រជាជន ដែលមាននៅក្នុងខេត្តរបស់ពួកគេដើម្បីផ្គត់ផ្គង់ដល់ពួកគេ ។ ប៉ុន្តែលោកនេហេមានិងលោកសាវកប៉ុល (សូមមើល ១កថ ៩ ២ ធថ ៣:៨–៩) ពួកគាត់បានថ្វាយដង្វាយទាំងនោះដើម្បីធ្វើជាគំរូដល់ពួកបណ្ដាជន ។

**៥:១៥** *ពួកចៅហ្វាយ* នៅក្នុងភាសាហេព្រើរពាក្យនេះត្រូវបានគេប្រើសម្រាប់និយាយអំពីសេសបាសា(សូមមើល អរ ៥:១៤) និងសូរ៉ូបាបិល (សូមមើល ហក ១:១,១៤ ២:២) រួមទាំងមន្ត្រីពួកពើស៊ីមុនៗទៀតផងដែរ (សូមមើលការពន្យល់ អរ ៥:៣,៦ ៦:៦–៧,១៣ ៨:៣៦ ជន ២:៧,៩ ៣:៧) នៅក្នុងកន្លែងនេះ មិនបាននិយាយអំពីលោកនេហេមាថា ជាមនុស្សរបស់សូរ៉ូបាបិលឡើយ ។ អ្នកខ្លះគេមានជំនឿថា មុនលោកនេហេមាពួកយូដាគេគ្មានចៅហ្វាយឡើយ ហើយពាក្យថា ចៅហ្វាយនៅកន្លែងនេះគឺសំដៅលើចៅហ្វាយនៃពួកសាមារី ប៉ុន្តែបើតាមភស្តុតាងថ្មីរបស់អ្នកកត់ត្រាពង្សាវតារបានបង្ហាញថា ចៅហ្វាយដែលនិយាយនៅក្នុងកន្លែងនេះគឺសំដៅលើពួកចៅហ្វាយរបស់ពួកយូដាកាលពីគ្រាមុន ។ *នៅដោយសារ* នេះគឺជាទម្លាប់មួយរបស់ពួកពើស៊ីដែលបានកំណត់ទារកពន្ធពីពួកអ្នក ដែលបម្រើការងារក្នុង

អាហារ នឹងស្រាទំពាំងបាយជូររបស់ខ្លួនពីរាស្ត្រព្រមទាំង
ប្រាក់៤០រៀលផង អើ សូម្បីតែពួកអ្នកបំរើរបស់គេក៏មាន
អំណាចលើបណ្តាជនដែរ តែខ្ញុំមិនបានធ្វើដូច្នោះទេ ដោយ
មានសេចក្តីកោតខ្លាចដល់ព្រះ[ទ]វិញ ១៦ ប្រការមួយទៀត[ធ]
ខ្ញុំបាននៅជាប់នឹងការសង់កំផែងនេះឡើងដែរ យើងរាល់
គ្នាមិនបានទាំងទិញដីឯណាផង ហើយពួកបំរើរបស់ខ្ញុំបាន
មូលមក ជួយធ្វើការនេះដែរ ១៧ ហើយនេះទៀត មានពួក
យូដា និងពួកនាយដំរួត១៥០នាក់ បរិភោគអាហារនៅតុ
ខ្ញុំផង ឥតរាប់ពួកអ្នកដែល មកឯយើងរាល់គ្នាពីពួកសាសន៍
ដទៃនៅជុំវិញឡើយ ១៨ រីឯភោជនាហារដែលត្រូវរៀប
ក្នុង១ថ្ងៃ នោះគឺគោ១ និងចៀមសំរាំង៦ ព្រមទាំង សត្វបក្សី
[ន]ដែលគេរៀបឱ្យខ្ញុំដែរ ហើយក្នុង១០ថ្ងៃនោះគេយកស្រា
ទំពាំងបាយជូរគ្រប់យ៉ាងមក១ដង ប៉ុន្តែទុកជាច្រើនដល់
ម្ល៉េះ គង់តែខ្ញុំមិនបានអាងបុណ្យជាចៅហ្វាយ និងទារ
ភោជនាហារដែរ ពីព្រោះពួកបណ្តាជនមានបន្ទុកធ្ងន់
ណាស់ទៅហើយ ១៩ ឱព្រះនៃទូលបង្គំអើយ សូមទ្រង់នឹក
រឭក[ប] ដោយចំរើនព្រះគុណដល់ទូលបង្គំផងដោយព្រោះ
គ្រប់ទាំងសេចក្តី ដែលទូលបង្គំបានអនុគ្រោះដល់បណ្តាជន
នេះ ។

## ការប្រឆាំងបន្ថែមទៀតចំពោះការសាងសង់

៦ ១ លុះកាលដំណឹងបានឮទៅដល់សានបាឡាត និងថូប៊ីយ៉ា
[ក]ព្រមទាំងកេសែម[ខ] ជាសាសន៍អារ៉ាប់ នឹងពួកខ្មាំងសត្រូវ
យើងឯទៀតថា ខ្ញុំបានធ្វើកំផែងរួចជាស្រេច ឥតមានទីបាក់
បែកណានៅសល់ទៀតឡើយ ទោះបើគ្រានោះមិនទាន់បាន
ដាក់ផ្ទាំងសន្លឹកទ្វារឡើង ក្នុងអស់ទាំងទ្វារនៅឡើយក៏
ដោយ ២ នោះសានបាឡាត នឹងកេសែមចាត់គេមក ឯខ្ញុំ

**៥:១៥** ទ លប ២០:១១
**៥:១៦** ធ ២ថន ៣:៧-១០
**៥:១៨** ន ១ពវ ៤:២៣
**៥:១៩** ប លប ៨:១ ២ពវ ២០:៣ នហ ១:៨
**៦:១** ក នហ ២:១០ ខ នហ ២:១៩

ព្រះវិហារ ដែលជាបន្ទុកដ៏ធ្ងន់មួយសម្រាប់មនុស្សធម្មតា ។ *ពួកអ្នកបំរើរបស់គេ* បើសិនជាចៅហ្វាយខ្លួនឯងផ្ទាល់បានប្រើការគម្រាមបោកដល់ពួកអ្នកបម្រើ នោះបានសឱ្យឃើញថា ពួកអ្នកបម្រើរបស់ពួកគេកាន់តែទទួលនូវការគម្រាមកំហែង និងមានសេចក្តីខ្លាចកាន់តែខ្លាំងឡើងៗ (សូមធ្វើការប្រៀបធៀបជាមួយ មថ ១៨:២១-៣៥ ២០:២៥-២៨) ។ *កោតខ្លាចដល់ព្រះ* ទោះបីជាពួកអ្នកដែលមានមុខងារ និងបុណ្យសក្តិធំក៏ដោយ ក៏ពួកគេស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ដោយទទួលការធ្វើទុក្ខបៀតពីសំណាក់ពួកមានអំណាច បើសិនជាពួកគេបានភ្លេចថាខ្លួនជាអ្នកបម្រើរបស់"ចៅហ្វាយដែលគង់នៅស្ថានសួគ៌"(សូមមើល កល៤:១ ធៀបជាមួយ លប ៣៩:៩ ២កថ ៥:១១) ។

**៥:១៦** *មិនបានទិញដីឯណាផង* អត្តចរិតរបស់លោកនេហេមាក្នុងនាមជាចៅហ្វាយ គឺលោកបានយកគោលការណ៍នៃអ្នកបម្រើមកដឹកនាំ ជាងឱកាសនិយមរបស់គាត់ ។

**៥:១៧** *បរិភោគអាហារនៅតុខ្ញុំផង* នៅក្នុងឃ្លានេះចង់និយាយថា ផ្នែកមួយនៃទំនួលខុសត្រូវរបស់គាត់នៅក្នុងសង្គមគឺ គាត់បានអញ្ជើញពួកអ្នកជាប្រធាន និងពួកជាចៅហ្វាយឱ្យចូលរួមពិធីជប់លៀងដោយមានបរិភោគអាហារជាមួយគ្នា ។ មានអត្ថបទមួយដែលគេរកឃើញនៅ Nimrud ដែលស្តីអំពី Ashurnasiarpal ទី២ បានផ្គត់ផ្គង់អាហារដល់ពួកភ្ញៀវចំនួន៦៩៥៧៤នាក់ក្នុងពិធីជប់លៀងដ៏ធំមួយដែលប្រព្រឹត្តទៅអស់រយៈពេល១០ថ្ងៃ ។ នៅពេលដែលស្តេចសាឡូម៉ូនរៀបចំពិធីបុណ្យឆ្លងព្រះវិហារ គាត់បានថ្វាយដង្វាយជាគោចំនួន២ម៉ឺន២ពាន់ និងចៀមចំនួន១សែន២ម៉ឺន ហើយ២មានពិធីជប់លៀងដ៏ធំមួយរយៈពេល១៤ថ្ងៃ (មើលការពន្យល់ ១ពវ ៨:៦២-៦៥) ។ នៅទីនេះគេមិនបានដឹងថា តើលោកនេហេមាគាត់បានផ្គត់ផ្គង់អាហារដល់ភ្ញៀវប៉ុន្មាននាក់នោះឡើយ(ធៀបជាមួយ ១ពវ ៤:២៧) ។

**៥:១៨** *ក្នុង១ថ្ងៃ* នៅក្នុងកន្លែងនេះចង់និយាយថា តាមឈ្មោះម្ហូបអាហារដែលបាននិយាយនៅទីនេះ គឺអាចផ្គត់ផ្គង់ចំនួនមនុស្សពី ៦រយ ទៅ ៨០០នាក់ក្នុង១ថ្ងៃ រួមទាំងពីយូដា១៥០នាក់ និងពួកមន្ត្រីដែលមាននិយាយនៅក្នុងខ.១៧ទៀតផង ។ សូមធ្វើការប្រៀបធៀបការផ្គត់ផ្គង់ម្ហូបអាហារក្នុង១ថ្ងៃនៅទីនេះនិងម្ហូបអាហារក្នុង១ថ្ងៃដែលស្តេចសាឡូម៉ូនបានផ្គត់ផ្គង់ គឺបាននិយាយនៅក្នុង ១ពវ ៤:២២-២៣ ។ *ចៀមសំរាំង* សូមធៀបជាមួយ មឡ ១:៨ ។ *បក្សី* កាលពីឆ្នាំ២០០ មុន គ.ស សត្វមាន់ត្រូវបានគេយកមកផ្សាំងនៅតំបន់ស្ទឹង វ៉ាលី ហើយត្រូវនាំទៅលក់ក្នុងប្រទេសអេស៊ីព្ទក្នុងគ្រាថូមូសទី៣ (កាលពីសតវត្សរ៍ទី១៥ មុន គ.ស) ។ បក្សីទាំងនោះត្រូវបានគេទទួលស្គាល់នៅក្នុងសតវត្សរ៍ទី៨នៃ គ.ស នៅក្នុងតំបន់មេសូប៉ូតាមា និងប្រទេសក្រិក ។ មានភស្តុតាងដ៏ចំណាស់មួយដែលពណ៌នាអំពីសត្វបក្សីថា នៅក្នុងទឹកដីកាណានឃ្នាសានាបានយកមាន់ដល់ធ្វើជាត្រារបស់ខ្លួន (ប្រហែលជានៅឆ្នាំ ៦០០ មុន គ.ស) ។

**៥:១៩** *សូមទ្រង់នឹករឭក* សូមមើលការពន្យល់នៅក្នុង ១:៨ ហើយធៀបជាមួយ ហព ៦:១០ ។ នៅក្នុងកន្លែងនេះចង់មានន័យថា ប្រហែលជាកំណត់ត្រារបស់នេហេមា(សូមមើលសេចក្តីផ្តើមព្រះគម្ពីរអែសរ៉ា ត្រង់ចំនុចទម្រង់អក្សរសាស្ត្រ និងអ្នកនិពន្ធ)ត្រូវបានចារិតទុកនៅក្នុងព្រះវិហារ ដើម្បីឱ្យពួកគេចងចាំ ។ មានការគួរឱ្យកត់សំគាល់មួយអំពីសេចក្តីអធិស្ឋានរបស់លោកនេហេមា គឺមានភាពប្រហាក់ប្រហែលគ្នានឹងសេចក្តីអធិស្ឋានរបស់ស្តេចនេប៊ូក្នេសារដែរ ដោយសេចក្តីរបស់ស្តេចនេប៊ូក្នេសារបានរៀបរាប់ថា "ឱ! ព្រះម៉ាដាក់ ជាព្រះនៃទូលបង្គំអើយ តើទ្រង់មាននឹករឭកពីទង្វើរល្អរបស់ទូលបង្គំដែរឬទេ ? សូមព្រះអង្គទ្រង់នឹករឭកពីទង្វើរល្អរបស់ទូលបង្គំផង"(ស្តេចនេប៊ូក្នេសារគាត់គោរពប្រត្តិលើរូបព្រះម៉ាដាក់) ។

**៦:១** *សានបាឡាត និង ថូប៊ីយ៉ា ព្រមទាំងកេសែម* សូមមើលការពន្យល់ក្នុង ២:១០,១៩ ។

**៦:២** *ភ្នំអូណូ* ភ្នំនេះមានចំងាយប្រមាណជា ១១,២៦ គ.ម ភាគខាងត្បូងក្រុងយ៉ុបប៉េ ក្បែរក្រុងឡូឌ(ក្រុងលីដា សូមមើលក្នុង អរ ២:៣៣) ដែលជាទីក្រុងមួយស្ថិតនៅភាគខាងលិចបង្អស់ ដែលពួកយូដាតាំងលំនៅស្នាក់អាស្រ័យក្នុងគ្រាដែលគេបានរួចពីសណ្ឋានជាឈ្លើយ(សូមមើលការពន្យល់ នហ ៧:៣៧ ១១:៣៥) ។ ក្នុងកាលដែលលោកសានបាឡាតអញ្ជើញលោកនេហេមាមកកាន់ច្រកភ្នំអូណូនេះ ប្រហែលជាគេយកច្រកភ្នំនោះធ្វើជាអព្យាក្រិត្យភាពរបស់ពួកគេ ប៉ុន្តែសម្រាប់លោកនេហេមាវិញគាត់និយាយថា នោះគឺជាអន្ទាក់មួយប៉ុណ្ណោះ (សូមធៀបជាមួយ លប ៤:៨ យរ ៤១:១-៣) ។

និយាយថា អញ្ជើញមក យើងនឹងពិគ្រោះគ្នានៅភូមិណា
មួយក្នុងច្រកភ្នំអូណូរ[ក] គឺគេគិតប្រទូស្តដល់ខ្ញុំទេ ៣ តែខ្ញុំចាត់
មនុស្សឱ្យទៅប្រាប់វិញថា ខ្ញុំកំពុងតែធ្វើការមួយយ៉ាងធំ ខ្ញុំ
នឹងចុះមកមិនបាន នឹងឱ្យខ្ញុំលះចោលការនេះឱ្យឈប់នៅ
ដើម្បីនឹងចុះទៅឯអ្នកធ្វើអី ៤ គេក៏ចាត់មនុស្សមកនិយាយនឹង
ខ្ញុំយ៉ាងនោះអស់វារៈ៤ដង ហើយខ្ញុំក៏ឆ្លើយពាក្យដដែល
ដល់គេ ៥ រួចមកសានបាឡាត[ឃ] បាត់អ្នកបំរើម្នាក់មកឯខ្ញុំ
តាមបែបដដែល នោះជាគំរប់៥ដង មានទាំងសំបុត្របើក
ចំហនៅដៃផង ៦ ក្នុងសំបុត្រនោះមានសេចក្តីថា មានឮ
ដំណឹងនៅគ្រប់ទាំងសាសន៍ ហើយលោកកេសែម[ង] ជាសាក្សី
ថា អ្នកហើយនិងពួកយូដា គិតបះបោរ បានជាសង់កំផែង
នេះឡើង គឺថា អ្នកចង់ធ្វើជាស្តេចគេ តាមដែលឮនិយាយ
នោះ ៧ អ្នកក៏បានដំរូវឱ្យមានពួកហោរាប្រកាស ប្រាប់ពីអ្នក
នៅក្រុងយេរូសាឡិមថា មានស្តេចគ្រងរាជ្យនៅស្រុកយូដា
ហើយ ពាក្យយ៉ាងនោះយើងនឹងបញ្ជូនដល់ស្តេចឥឡូវ

**៦:២** ក ១របៈ ៨:១២
**៦:៥** ឃ នហ ២:១០
**៦:៦** ង នហ ២:១៩
**៦:១០** ច ជន ១៨:៧

ដូច្នេះ ចូរមកឱ្យយើងបានពិគ្រោះគ្នាសិន ៨ ខ្ញុំតបទៅថា
គ្មានអ្វីដូចជាអ្នកថានោះទេ គឺអ្នកបង្កើតរឿងនេះតាមតែ
ចិត្តអ្នកវិញប៉ុណ្ណោះ ៩ ពួកអ្នកទាំងនោះ ចង់តែគំរាម ឱ្យ
យើងភ័យខ្លាច ដោយគិតថា យើងនឹងថយកំឡាំងដៃឱ្យ
សំរេចការមិនបាន ឥឡូវនេះឱព្រះអង្គអើយ សូមចំរើន
កំឡាំងដៃទូលបង្គំវិញ ។
១០ គ្រានោះ ខ្ញុំបានទៅឯផ្ទះរបស់សេម៉ាយ៉ា កូនដេឡាយ៉ា
ដែលជាកូនមហេថាបែល គាត់កំពុងបំពួនខ្លួន គាត់និយាយ
ឡើងថា សូមយើងទៅជួបគ្នា នៅក្នុងព្រះវិហារ[ច] នៃព្រះ
គឺក្នុងទីបរិសុទ្ធ ហើយបិទទ្វារភ្ជិតទៅ ដ្បិតគេនឹងមកសំឡាប់
លោក គឺគេនឹងមកនៅពេលយប់ជាមិនខាន ដើម្បីនឹង
សំឡាប់លោកបង់ ១១ តែខ្ញុំឆ្លើយថា គួរគប្បីឱ្យមនុស្សបែប
យ៉ាងខ្ញុំរត់ឬអី តើមានអ្នកឯណាមួយដូចខ្ញុំ ដែលនឹងចូល
ទៅក្នុងព្រះវិហារ ឱ្យតែរួចជីវិតនោះ ខ្ញុំមិនព្រមចូលទៅទេ
១២ ខ្ញុំក៏ពិចារណាយល់ឃើញថា មិនមែនជាព្រះដែលបង្គាប់

**៦:៣** ភាពឆ្លាតវៃនៃការឆ្លើយតបរបស់លោកនេហេមា មើលទៅ ហាក់បីដូចជាមានភាពក្រអឺតក្រទមចំពោះការអញ្ជើញនោះ ប៉ុន្តែអ្វីដែលគាត់ធ្វើ គឺត្រឹមត្រូវបំផុតព្រោះគាត់បានយល់ដឹងថា ខ្មាំងសត្រូវរបស់គាត់គ្មានភាពស្មោះត្រង់ឡើយ ។ គាត់បានបដិសេធចំពោះការអញ្ជើញនោះដើម្បីជៀសចេញពីការបន្លំមិនឱ្យ កសាងកំផែងក្រុងឡើងវិញ ។

**៦:៤** *៤ដង* នៅក្នុងកន្លែងនេះចង់និយាយថា ហេតុដែលបច្ចាមិត្តរបស់លោកនេហេមាចាត់មនុស្សមកចំនួន៤ដង ពីព្រោះគេគិតថាគេ គឺជារដ្ឋមន្ត្រី ប៉ុន្តែលោកនេហេមាបានយកភាពជារដ្ឋមន្ត្រីរបស់គាត់មកទប់ទល់នឹងសត្រូវរបស់គាត់វិញ ។

**៦:៥** *សំបុត្របើកចំហរ* នៅក្នុងកន្លែងនេះចង់និយយាថា ក្នុងដំណាក់កាលនេះ សានបាឡាតបានសរសេរជាសំបុត្រធម្មតាមួយនៅលើក្រដាសប៉ាមីរីស ឬលើស្បែកសត្វ ហើយរុំវាដោយមានចងចំណង និងមានបោះត្រាពីលើដើម្បីធានាថា សំបុត្រនេះគឺជាសំបុត្ររបស់គាត់ជាពិតប្រាកដគ្មានការក្លែងបន្លំឡើយ ។ មើលទៅសានបាឡាត គឺគាត់ត្រូវការឱ្យគេទទួលស្គាល់សំបុត្ររបស់គាត់ជាផ្លូវការណ៍មួយ ។

**៦:៦** *ស្តេចគេ* នៅក្នុងឃ្លានេះចង់និយាយបញ្ជាក់ថា ស្តេចពើស៊ីទាំងអស់គេមិនអត់ឱនឱ្យអ្នកណាដែលធ្វើពុតអះអាងថា ខ្លួនជាស្តេចនោះឡើយ ហើយនៅក្នុងព្រះរាជ្យក្រិត្យរបស់ស្តេចដារីយ៉ុសទី១ក៏បាននិយាយបែបនេះដែរ ។ នៅក្នុងគ្រាសញ្ញាថ្មី ពួកចក្រភពរ៉ូមក៏មានការមន្ទិលសង្ស័យថា មានអ្នកមានអំណាចជាច្រើនបានប្រកាសថា ខ្លួនគេជាពូជស្តេចដែរ (សូមមើល យហ ១៩:១២ ធៀបជាមួយ មថ ២:១–១៣) ។

**៦:៨** *គ្មានអ្វី* នៅទីនេះលោកនេហេមាគាត់មិនបានប្រើពាក្យដែលមានលក្ខណៈសើរៗនោះឡើយ ប៉ុន្តែគាត់បាននិយាយដោយចំៗតែម្តង ដោយគាត់បាននិយាយថា អ្នកនាំសារនោះគេកុហក បង្កើតរឿងតាមចិត្តគេ ។ លោកនេហេមាអាចនឹងបញ្ជូនអ្នកនាំសាររបស់គាត់ផ្ទាល់ទៅស្តេចពើស៊ី ដើម្បីធានាពីភាពស្មោះត្រង់របស់គាត់ចំពោះស្តេច ។

**៦:៩** *ថយកំឡាំងដៃ* នៅក្នុងឃ្លានេះចង់បញ្ជាក់ថា គេប្រើឃ្លានេះដើម្បីពណ៌នាពីគំនិតបង្ខូចទឹកចិត្តពីសំណាក់អ្នកដទៃចំពោះលោកនេហេមា ។ ឃ្លានេះក៏មានប្រើនៅក្នុង អរ ៤:៤ យរ ៣៨:៤ ផងដែរ ។

**៦:១០** *សេម៉ាយ៉ា . . . គាត់កំពុងបំពួនខ្លួន* នៅក្នុងឃ្លានេះចង់និយាយថា មូលហេតុដែលសេម៉ាយ៉ាបំពួនខ្លួនរបស់គាត់ គឺគាត់បានគិតថា ជីវិតរបស់គាត់ពេលនេះពោរពេញទៅដោយគ្រោះថ្នាក់ ដូច្នេះហើយទើបគាត់និយាយថាលោកនេហេមានិងខ្លួនគាត់ផ្ទាល់ ត្រូវតែមកជ្រកកោនក្នុងព្រះវិហារ (សម្រាប់អត្ថន័យផ្សេងៗទៀតនៃការជ្រកកោនក្នុងព្រះវិហារ សូមមើល ក្នុង ១ពវ ២២:១១ អស ២០:២–៤ យរ ២៧:២–៧ ២៨:១០–១១ អគ ៤:១–១៧ ១២:៣–១១ កច ២១:១១) ។ ក្នុងអំឡុងពេលដែលសេម៉ាយ៉ា គាត់បានមកស្នាក់អាស្រ័យក្នុងព្រះវិហារ នោះប្រហែលគាត់អាចក្លាយជាសង្ឃ ។ សេម៉ាយ៉ា គាត់ជាមិត្តភក្ត័របស់ថូប៊ីយ៉ា (សូមធៀបជាមួយ ខ.១២) ដូច្នេះគាត់គឺជាខ្មាំងសត្រូវរបស់លោកនេហេមា ។ លោកសាម៉ាយ៉ាគាត់សុំឱ្យលោកនេហេមាមកជ្រកកោនត្រង់អាសនា ដែលនៅក្នុងបរិវេណនៃព្រះវិហារ (សូមមើល នក ២១:១៣–១៤) មិនមែនក្នុងព្រះវិហារដែលជា"ដំណាក់នៃព្រះ"នោះឡើយ ។

**៦:១១** ទោះបីជាការប៉ុនប៉ងព្យាបាទជីវិតគាត់ហាក់បីដូចជាច្បាស់នឹងភ្នែក ប៉ុន្តែលោកនេហេមា មិនបានខ្លាចចំពោះអ្នកដែលលបពួនយកជីវិតគាត់នោះឡើយ ហើយគាត់ក៏មិនបានបំពានក្រិត្យវិន័យដែលអាចនឹងជួយជីវិតគាត់នោះដែរ ។ លោកនេហេមាគាត់មិនអនុញ្ញាត្តិឱ្យជនសាមញ្ញចូលទៅក្នុងទីបរិសុទ្ធនៃព្រះបានឡើយ (សូមមើលការពន្យល់ក្នុង ជន ១៨:៧) ។ ព្រះអម្ចាស់ទ្រង់បានដាក់ទោសដល់ស្តេចយ៉ូសៀសឱ្យកើតរោគឃ្លង់ ដោយព្រោះការរំលងដែលទ្រង់បានចូលក្នុងព្រះវិហារ នៃព្រះថ្វាយគ្រឿងក្រអូប (សូមមើល ២របៈ ២៦:១៥–១២១) ។

**៦:១២** សេចក្តីពិតដែលមាននៅក្នុងខ.នេះ គឺចង់និយាយថា សាម៉ាយ៉ាមានគោលបំណងបង្កើតគំនិត ទាស់ប្រឆាំងចំពោះព្រះបន្ទូលរបស់ព្រះអម្ចាស់

ដល់គាត់ដូច្នោះទេ គឺគាត់បានទាយទំនាយនេះទាស់នឹងខ្ញុំ[ឆ]
វិញ ហើយតូប៊ីយ៉ា និងសានបាឡាត[ជ]បានជួលគាត់ផង
១៣គេបានជួលគាត់ប្រាថ្នាចង់គំរាមឱ្យខ្ញុំភ័យ ដើម្បីឱ្យខ្ញុំបាន
ធ្វើតាម ហើយមានបាបដូច្នោះ ប្រយោជន៍ឱ្យគេបានរឿង
នឹងបង្ខូចឈ្មោះខ្ញុំ ហើយត្មះតិះដៀលដល់ខ្ញុំ[ឈ] ១៤ឱព្រះនៃ
ទូលបង្គំអើយ សូមទ្រង់នឹកចាំ[ញ]ពីតូប៊ីយ៉ា និងសានបាឡាត[ដ]
តាមការដែលគេធ្វើទាំងនេះ ហើយពីនាងណូអាឌា ជា
ហោរា[ឋ] និងពួកហោរា[ឌ]ឯទៀត ដែលចង់ឱ្យទូលបង្គំកើត
មានសេចក្ដីភ័យខ្លាចផង ។

### ការបញ្ចប់ការសាងសង់

១៥ដូច្នេះ នៅថ្ងៃ២៥ខែភទ្របទ នោះកំផែងបានធ្វើរួច
ជាស្រេច គឺក្នុងរវាង៥២ថ្ងៃ ១៦កាលពួកខ្មាំងសត្រូវរបស់
យើងទាំងប៉ុន្មានបានឮ នោះសាសន៍ដទៃទាំងប៉ុន្មានដែល
នៅជុំវិញយើងក៏ភ័យខ្លាច ហើយគេទ្រោមចុះជាខ្លាំងនៅ
ភ្នែកខ្លួនគេ ដោយយល់ឃើញថា ការនោះ កើតឡើង
អំពីព្រះនៃយើងទេ ១៧ក្នុងរវាងនោះ ពួកអ្នកធំក្នុងសាសន៍
យូដា គេក៏ផ្ញើសុំបុត្រជាច្រើនច្បាប់ទៅតូប៊ីយ៉ា ហើយមាន
សំបុត្ររបស់តូប៊ីយ៉ាមកដល់គេវិញដែរ ១៨ដ្បិតមានមនុស្ស
ជាច្រើននៅស្រុកយូដា បានស្បថនឹងគាត់ ដោយព្រោះគាត់
ជាកូនប្រសារបស់សេកានា ជាកូនអើរ៉ាស មួយទៀត
យ៉ូហាណាន ជាកូនប្រុសរបស់គាត់ បានយកកូន ស្រីរបស់
មស៊ូឡាម ជាកូនបេរេគា ធ្វើជាប្រពន្ធ ១៩គេក៏និយាយពីការ
ល្អរបស់គាត់នៅចំពោះមុខខ្ញុំ ហើយក៏នាំយកពាក្យខ្ញុំទៅ
ប្រាប់គាត់ដែរ គឺតូប៊ីយ៉ានេះហើយ ដែលផ្ញើសំបុត្រមក
គំរាម ឱ្យខ្ញុំភ័យ ។

៧ ១រីឯកាលកំផែងបានសង់ឡើងជាស្រេច ហើយខ្ញុំបាន
ដាក់ផ្ទាំងសន្លឹកទ្វារទាំងប៉ុន្មាន រួចបានដំរូវពួកឆ្មាំទ្វារ[ក]ពួក
ចំរៀង[ខ] និងពួកលេវី[គ] ឱ្យធ្វើការងារទៅ ២នោះខ្ញុំបាន
ប្រគល់អំណាចត្រួតត្រាក្រុងយេរូសាឡិម ដល់ហាណានី[ឃ]
ជាបងប្អូនខ្ញុំ និងហាណានា[ង] ជាមេបន្ទាយ[ច] ដ្បិតគាត់ជា
មនុស្សស្មោះត្រង់ ក៏កោតខ្លាច[ឆ]ដល់ព្រះលើសជាងមនុស្ស
ជាច្រើន ៣ហើយខ្ញុំបានហាមគេថា កុំឱ្យបើកទ្វារក្រុង
យេរូសាឡិម មុនដែលថ្ងៃភ្លឺក្តៅឡើយ ហើយកាលគេនៅ
ចាំយាម នោះត្រូវបិទហើយ ខ្ទាស់រនុកទៅវិញ ក៏ត្រូវដំរូវ
ពួកអ្នកខ្លះនៅក្រុងយេរូសាឡិម ឱ្យចាំយាមតាមវេនគេនៅ
ទល់មុខនឹងផ្ទះគេរៀងខ្លួន ។

### បញ្ជីឈ្មោះពួកឈ្លើយដែលវិលត្រឡប់

*៧:៦-៧៣-អរ ២:១-៧០*

៤រីឯទីក្រុងក៏ធំទូលាយណាស់ តែបណ្ដាជនមានគ្នាតិច
ពេក[ជ] ហើយផ្ទះសំបែងមិនទាន់បានសង់នៅឡើយ ។
៥គ្រានោះ ព្រះនៃខ្ញុំទ្រង់បណ្ដាលចិត្តខ្ញុំ ឱ្យប្រមូលពួកអ្នក
ធំ ពួកមេ និងពួកជន ដើម្បីនឹងរាប់គេតាមពង្សាវតារខ្ញុំក៏
រកឃើញបញ្ជីពង្សាវតារ នៃពួកអ្នកដែលឡើងមកជាន់មុន
ហើយខ្ញុំឃើញមានសេចក្ដីកត់ទុក ក្នុងបញ្ជីនោះថា ៦នេះជា
ពួកអ្នកស្រុក ដែលចេញពីសណ្ឋានជាឈ្លើយ[ឈ] ពីពួកអស់
អ្នកដែលនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន បានដឹកនាំទៅនោះ
ហើយបានវិលមកឯក្រុងយេរូសាឡិម និងស្រុកយូដាវិញ

**៦:១២** ឆ អក ១៣:២២-២៣ ជ នហ ២:១០
**៦:១៣** ឈ យរ ២០:១០
**៦:១៤** ញ ជន ១:៨ ដ នហ ២:១០ ឋ នក ១៥:២០ អគ ១៣:១៧-២៣ កច ២១:៩ វវ ២:២០ ឌ យរ ២៣:៩-៤០ សក ១៣:២-៣
**៧:១** ក ១របា ៩:២៧ ២៦:១២-១៩ ខ ទដ ៦៨:២៥ គ នហ ៨:៩
**៧:២** ឃ នហ ១:២ ង នហ ១០:២៣ ច នហ ២:៨ ឆ ១ពវ ១៨:៣
**៧:៤** ជ នហ ១១:១
**៧:៦** ឈ ២របា ២៦:២០ នហ ១:២

ដែលបានបើកសម្ដែងដល់គាត់ថា ជាហោរាខុសឆ្គង (សូមធ្វើការប្រៀបធៀប ចទ ១៨:២០ អស ៨:១៩-២០ និងការពន្យល់ក្នុង ចទ ១៣:១-៥) ។

**៦:១៣** នៅក្នុងខ.នេះចង់និយាយថា បើសិនជាលោកនេហេមាគាត់បានលំអៀងទៅចំពោះបញ្ហាដែលកំពុងប្រឈរមុខ នោះភាពជាអ្នកដឹកនាំរបស់គាត់នឹងត្រូវបង្ខូច ហើយបណ្ដាជននឹងឈប់ទទួលយកដំបូន្មានរបស់គាត់ ។

**៦:១៤** *សូមទ្រង់នឹកចាំ* សូមមើលការពន្យល់ក្នុង ១:៨ ។ *ហោរា* សូមមើលការពន្យល់ នក ១៥:២០ ។

**៦:១៥** *ថ្ងៃទី២៥ ខែភទ្របទ* គឺស្ថិតនៅក្នុងថ្ងៃទី២ ខែតុលា ឆ្នាំ៤៤៤ មុន គ.ស *៥២ថ្ងៃ* នៅក្នុងឃ្លានេះចង់និយាយថា កំផែងក្រុងបាក់បែកដែលគេបានទុកចោលជិត១សតវត្សរ៍កន្លះទៅហើយ បានបណ្ដាជនដែលដឹកនាំដោយលោកនេហេមានាំគ្នាករសាងឡើងវិញ មិនដល់២ខែផង ។ តាមការស៊ើបអង្កេតពីក្រុមបុរាណវិទ្យាបានបង្ហាញថា បរិវេណកំផែងក្រុងយេរូសាឡិមក្នុងសម័យកាលលោកនេហេមាគឺបានបង្រួមឱ្យខ្លីយ៉ាងខ្លាំង ។ លោកយ៉ូសែបហ្វីសបាននិយាយថា រយៈពេលនៃការកសាងកំផែងក្រុងឡើងវិញ គឺបានចំណាយពេល២ឆ្នាំ៤ខែ ពិធីបុណ្យឆ្លងកំផែងក្រុងមាននិយាយនៅ សូមមើល ១២:២៧-៤៧ ។

**៦:១៧-១៨** នៅក្នុងខ.ទាំង២នេះចង់និយាយថា តូប៊ីយ៉ាគាត់ជាប់សាច់ញាតិជាមួយគ្រួសារយូដាដែលមានឥទ្ធិពល ព្រោះកូនប្រុសរបស់គាត់បានរៀបការជាមួយកូនស្រីមស៊ូឡាម ដែលជាអ្នកមានចិត្តខ្នះខ្នែងជួយកសាងកំផែងក្រុងយេរូសាឡិមឡើងវិញ (សូមមើល ៣:៤,៣០) ។

**៧:២** *អំណាចត្រួតត្រាក្រុងយេរូសាឡិម* លោកនេហេមាគាត់មានអំណាចត្រួតត្រាលើរេផាយ៉ា និង សាលូមដែលពួកគេជាអ្នកត្រួតលើក្រុងយេរ៉ូសាឡិម១ចំហៀង (សូមមើលការពន្យល់ ៣:៩,១២) ។ *ហាណានី* សូមមើលការពន្យល់ក្នុង ១:២ ។ *បន្ទាយ* សូមមើលការពន្យល់ ២:៨ ៣:១ ។

**៧:៣** *មុនដែលថ្ងៃភ្លឺក្តៅឡើយ* តាមធម្មតាគេបើកទ្វារក្រុងនៅពេលថ្ងៃទើបនឹងរះឡើង ប៉ុន្តែពេលនេះគេបានពន្យាពេលបើកទ្វារក្រុងរហូតដល់ថ្ងៃក្តៅ ដើម្បីការពារ ការវាយប្រហារពីសំណាក់ពួកខ្មាំងសត្រូវ មុនពេលដែលពួកគេភាគច្រើនមិនទាន់ភ្ញាក់ពីដំណេក ។

**៧:៦-៧៣** នៅក្នុងខ.ទាំងអស់នេះ គឺមានសារៈសំខាន់ដូចគ្នានឹងព្រះគម្ពីរអែសរ៉ាជំពូក២ដែរ ។ សូមមើលការពន្យល់នៅទីនោះដែលនិយាយអំពីឈ្មោះនិងមូលហេតុដែលបណ្ដាលឱ្យមានការប្រែប្រួលឈ្មោះជាច្រើនទាំងអស់នោះ ។

គ្រប់គ្នាដល់ទីក្រុងរបស់គេរៀងខ្លួន ៧ជាពួកអ្នកដែលបាន
មកជាមួយនិងសូរ៉ូបាបិល[ញ] យេសួរ នេហេមា អ័សារា
រ៉ាអាមា ណាហាម៉ានី ម៉ាដេកាយ ប៊ីលសាន មីសពេរែត
ប៊ីកវ៉ាយ នេហ៊ូម និងប្អាណា ។
៨នេះជាចំនួននៃពួកមនុស្សសាសន៍អ៊ីស្រាអែល គឺពួក
ប៉ារ៉ូស មាន២១៧២នាក់ ៩ពួកសេផាធា មាន៣៧២នាក់
១០ពួកអើរ៉ាស មាន៦៥២នាក់ ១១ពួកផាហាត-ម៉ូអាប់
ខាងកូនចៅយេសួរ និងយ៉ូអាប់ មាន២៨១៨នាក់ ១២ពួក
អេឡាំ មាន១២៥៤នាក់ ១៣ពួកសាធូរ មាន៨៤៥នាក់ ១៤ពួក
សាកាយ មាន៧៦០នាក់ ១៥ពួកប៊ីនុយ មាន៦៤៨នាក់ ១៦ពួក
បេបាយមាន៦២៨នាក់ ១៧ពួកអាសកាឌ មាន២៣២២នាក់
១៨ពួកអ័ដូនីកាម មាន៦៦៧នាក់ ១៩ពួកប៊ីកវ៉ាយ មាន២០៦៧
នាក់ ២០ពួកអេឌីន[ដ] មាន៦៥៥នាក់ ២១ពួកអេធើ ខាង
ហេសេគា មាន៩៨នាក់ ២២ពួកហាស៊ូម មាន៣២៨នាក់
២៣ពួកបេសាយ មាន៣២៤នាក់ ២៤ពួកហារេប មាន១១២
នាក់ ២៥ពួកគីបៀន មាន៩៥នាក់ ២៦ពួកបេថ្លេហិម និង
ពួកនថូផា[ឋ] មាន១៨៨នាក់ ២៧ពួកអានាថោត[ឌ] មាន១២៨
នាក់ ២៨ពួកបេតអាសម៉ាវែត មាន៤២នាក់ ២៩ពួកគារ
យ៉ាត-យារីម កេភីរ៉ា[ឍ] និងបៀរ៉ុត[ណ] មាន៧៤៣នាក់ ៣០ពួក
រ៉ាម៉ា និងកេបា មាន៦២១នាក់ ៣១ពួកមីកម៉ាស មាន១២២
នាក់ ៣២ពួកបេត-អែល និងអៃយ[ត] មាន១២៣នាក់ ៣៣ពួក
នៅក្រុងនេបូរ១ទៀត មាន៥២នាក់ ៣៤ពួកអេឡាំ១ទៀត
មាន១២៥៤នាក់ ៣៥ពួកហារីម មាន៣២០នាក់ ៣៦ពួក
យេរីខូរ[ថ] មាន៣៤៥នាក់ ៣៧ពួកឡូឌ ហាឌីឌ និងអូណូរ[ទ]
មាន៧២១នាក់ ៣៨ពួកសេណាអា មាន៣៩៣០នាក់ ។
៣៩ឯពួកសង្ឃ ក្នុងពួកកូនចៅយេដាយ៉ា ខាងវង្សរបស់
យេសួរ មាន៩៧៣នាក់ ៤០កូនចៅអ៊ីមមើរ មាន១០៥២នាក់
៤១កូនចៅផាសហើរ មាន១២៤៧នាក់ ៤២កូនចៅហារីម
មាន១០១៧នាក់ ។
៤៣ឯពួកលេវី ក្នុងពួកកូនចៅយេសួរ នឹងកាឌមាលខាង
វង្សរបស់ ហូដាវ៉ា មាន៧៤នាក់ ៤៤ឯពួកចំរៀង[ធ] ក្នុងពួក
កូនចៅអេសាភ មាន១៤៨នាក់ ៤៥ឯពួកឆ្មាំទ្វារ[ន] ក្នុងពួកកូន
ចៅសាលូម កូនចៅអេធើ កូនចៅថាលម៉ូន កូនចៅអ័កគូប
កូនចៅហាធីថា និងកូនចៅសូបាយ រួមទាំងអស់ មាន១៣៨
នាក់ ។
៤៦ឯពួកនេធីនិម[ប] គឺមានពួកកូនចៅស៊ីហា កូនចៅ
ហាស៊ូផា និងកូនចៅថាបាអូត ៤៧កូនចៅកេរ៉ូស កូនចៅ
ស៊ីយ៉ាហា កូនចៅផាដូន ៤៨កូនចៅលេបាណា កូនចៅ
ហាកាបា កូនចៅសាលម៉ាយ ៤៩កូនចៅហាណាន កូនចៅ
គីដេល កូនចៅកាហារ ៥០កូនចៅរីអាយ៉ា កូនចៅរេស៊ីន
កូនចៅនេកូដា ៥១កូនចៅកាសាម កូនចៅអ៊ូសា កូនចៅផា
សេហា ៥២កូនចៅបេសាយ កូនចៅមេហ៊ូនីម កូនចៅ
នេភូស៊ីម ៥៣កូនចៅបាកប៊ូក កូនចៅហាគូផា កូនចៅ
ហាហ៊ើរ ៥៤កូនចៅបាសលូត កូនចៅមេហ៊ីដា កូនចៅ
ហាសា ៥៥កូនចៅបាកូស កូនចៅស៊ីសេរ៉ា កូនចៅថាម៉ា
៥៦កូនចៅនេស៊ីយ៉ា និងកូនចៅហាធីផា ។
៥៧ឯពួកកូនចៅរបស់ពួកអ្នកបំរើសាឡូម៉ូន គឺកូនចៅ
សូថាយ កូនចៅសូផេរេត កូនចៅពេរូដា ៥៨កូនចៅយ្អាឡា
កូនចៅដាកុន កូនចៅគីដេល ៥៩កូនចៅសេផាធា កូនចៅ
ហាធីល កូនចៅផូកេរេត ពីសេបែម និងកូនចៅអាំម៉ូន
៦០ឯពួកនេធីនិម និងកូនចៅរបស់ពួកអ្នកបំរើសាឡូម៉ូន[ផ]
ទាំងអស់រួមគ្នា មាន៣៩២នាក់ ។
៦១ឯពួកអ្នកដែលចេញពីក្រុងធេល-មែឡា ធេល-
ហារេសា កេរូប អ័ដាន និងអ៊ីមមើរ តែពុំអាចនឹងបង្ហាញ
ពីពង្សាវតារ ឬចំនួនវង្សរបស់ខ្លួន ថាជាពូជអ៊ីស្រាអែល
ឬមិនមែន ៦២នោះគឺពួកកូនចៅដេឡាយ៉ា កូនចៅថូប៊ីយ៉ា
និងកូនចៅនេកូដាទាំងអស់ មាន៦៤២នាក់ ៦៣ហើយខាង
ពួកសង្ឃ មានកូនចៅហាបាយ៉ា កូនចៅហាគូស កូនចៅ
បារស៊ីឡាយ ជាអ្នកដែលបានយកពួកកូនស្រីរបស់បារ
ស៊ីឡាយ នៅស្រុកកាឡាត ធ្វើជាប្រពន្ធ ហើយក៏ត្រូវហៅ
តាមឈ្មោះគេ ៦៤អ្នកទាំងនោះបានរកពង្សាវតារជាតិរបស់
ខ្លួនមិនឃើញសោះ ហេតុនោះគេត្រូវបណ្តេញចេញពី
ការងារជាសង្ឃ ទុកដូចជាមានសៅហ្មង ៦៥ហើយលោក
ចៅហ្វាយក៏ប្រាប់គេថា មិនត្រូវឱ្យគេបរិភោគពីរបស់
បរិសុទ្ធបំផុតឡើយ ចាំទំរាំដល់មានសង្ឃម្នាក់តាំងឡើង
ដែលមាន យូរីម និងធូមីម[ព] ។
៦៦ពួកជំនុំទាំងអស់គ្នា មាន៤ម៉ឺន២ពាន់៣៦០នាក់ ៦៧ឥត
រាប់ពួកអ្នកបំរើប្រុសស្រីរបស់គេ ដែលមានចំនួន៧៣៣៧
នាក់ទៀតនោះទេ ក៏មានពួកចំរៀងទាំងប្រុសទាំងស្រីចំនួន
២៤៥នាក់ដែរ ៦៨ឯសេះរបស់គេមាន៧៣៦ លាកាត់ មាន
២៤៥ ៦៩អូដ្ឋ មាន៤៣៥ និងលា មាន ៦៧២០ ។
៧០មានពួកអ្នកជាកំពូលលើវង្សឪពុកគេខ្លះ បានថ្វាយ

**៧:៧** ញ ១រប ៣:១៩
**៧:២០** ដ អរ ៨:៦
**៧:២៦** ឋ ២សយ ២៣:២៨ ១រប ២:៥៤
**៧:២៧** ឌ យស ២១:១៨
**៧:២៩** ឍ យស ១៨:២៦ ណ យស ១៨:២៥
**៧:៣២** ត លប ១២:៨
**៧:៣៦** ថ នហ ៣:២
**៧:៣៧** ទ ១រប ៨:១២
**៧:៤៤** ធ នហ ១១:២៣
**៧:៤៥** ន ១រប ៩:១៧
**៧:៤៦** ប នហ ៣:២៦
**៧:៦០** ផ ១រប ៩:២
**៧:៦៥** ព នក ២៨:៣០

**៧:៤៣** *៧៤នាក់* សូមមើលការពន្យល់ក្នុង អរ ២:៤០ ។
**៧:៥៧,៦០** *កូនចៅរបស់អ្នកបំរើសាឡូម៉ូន* សូមមើលការពន្យល់ក្នុង អរ ២:៥៥,៥៨ ។
**៧:៧០** *សំលៀកបំពាក់ពួកសង្ឃ* សូមមើលក្នុង អរ ២:៦៩ ។

ដង្វាយសំរាប់ការ នោះ លោកចៅហ្វាយថ្វាយដាក់ក្នុងឃ្លាំង
ជាមាស១ពាន់ដារីក ពែងមាស៥០ សំលៀកបំពាក់ពួក
សង្ឃ៥៣០សំរាប់ ៧១ហើយពួកអ្នកជាកំពុលលើវង្ស[ភ] របស់
ឪពុកខ្លះ ក៏ថ្វាយមាស២ម៉ឺនដារីក និងប្រាក់២២០០នាលិ
ដាក់ក្នុងឃ្លាំងសំរាប់ការ ៧២ឯដង្វាយរបស់ពួកបណ្ដាជន
ឯទៀត គឺមាស២ម៉ឺនដារីក ប្រាក់២ពាន់នាលិ ហើយ
សំលៀកបំពាក់ពួកសង្ឃ៦៧សំរាប់[ម] ៧៣ដូច្នេះ ពួកសង្ឃ
ពួកលេវី ពួកឆ្មាំទ្វារ ពួកចំរៀង ពួកបណ្ដាជនខ្លះ ពួក
នេធីនិម[យ] និងពួកអ៊ីស្រាអែល ទាំងអស់បាននៅក្នុងទីក្រុង
របស់គេរៀងខ្លួនហើយ[រ] ។

## លោកអែសរ៉ាអានក្រិត្យវិន័យ

**៨** ១លុះដល់ខែអស្សុជ នោះពួកកូនចៅអ៊ីស្រាអែល គេនៅ
ក្នុងទីក្រុង[ក] គេទាំងអស់ ហើយបណ្ដាជនទាំងឡាយក៏មូលគ្នា
មក នៅទីធ្លាដែលនៅមុខទ្វារទឹក[ខ] ដោយមានចិត្តតែមួយ
ហើយ គេសូមស្មៀនអែសរ៉ា ឱ្យយកគម្ពីរក្រិត្យវិន័យរបស់
លោកម៉ូសេ[គ] ដែលព្រះយេហូវ៉ាបានបង្គាប់ដល់ពួកអ៊ីស្រា
អែលមក ២រួចនៅថ្ងៃដំបូងខែអស្សុជ[ឃ] នោះអែសរ៉ា
ដ៏ជាសង្ឃ លោកយកក្រិត្យវិន័យមក[ង] នៅចំពោះមុខនៃពួក
ជំនុំទាំងប្រុសទាំងស្រី និងអស់អ្នកដែលល្មមនឹងស្ដាប់បាន
៣ហើយចាប់តាំងពីព្រលឹម ដរាបដល់ថ្ងៃត្រង់ នោះលោកក៏
អានមើលក្នុងគម្ពីរនោះ នៅមុខគេទាំងអស់គ្នា ត្រង់ទីធ្លា
ដែលនៅមុខទ្វារទឹក[ច] ឯបណ្ដាជនទាំងឡាយ គេក៏ផ្ទៀង
ត្រចៀកស្ដាប់ ក្នុងគម្ពីរក្រិត្យវិន័យនោះ ៤ស្មៀនអែសរ៉ា
លោកឈរលើទីថ្កល់[ឆ] ធ្វើពីឈើ ដែលគេបានធ្វើសំរាប់
ការនោះមានម៉ាធិធា សេម៉ា អ័ណាយ៉ា អ៊ូរីយ៉ា ហ៊ីលគីយ៉ា
និងម្អាសេយ៉ា ឈរនៅខាងស្តាំលោក ហើយពេដាយ៉ា
មីសាអែល ម៉ាលគា ហាស៊ូម ហាសបាដានា សាការី និង
មស៊ូឡាម ក៏ឈរនៅខាងឆ្វេងលោក ៥អែសរ៉ាក៏បើកគម្ពីរ
នៅមុខបណ្ដាជនទាំងឡាយ ដ្បិតលោកនៅខ្ពស់[ជ] ជាង
គេទាំងអស់ កាលលោកបានបើកគម្ពីរឡើង នោះពួក
បណ្ដាជនទាំងឡាយក៏ក្រោកឈរ ៦រួចអែសរ៉ាលោកក៏
សូមឱ្យព្រះយេហូវ៉ា ជាព្រះដ៏ធំ បានប្រកបដោយព្រះពរពួក

**៧:៧១** ភ ១របា ២៩:៧
**៧:៧២** ម នក ២៥:២
**៧:៧៣** យ នហ ១:២០ ទដ ៣៤:២២ ១០៣:២១ ១១៣:១ ១៣៥:១ រ អរ ៣:១ នហ ១១:១
**៨:១** ក អរ ៣:១ ខ នហ ៣:២៦ គ ចទ ២៨:៦១ ២របា ៣៤:១៥
**៨:២** ឃ លវ ២៣:២៣–២៥ ជន ២៩:១–៦ ង ចទ ១៣:១១
**៨:៣** ច នហ ៣:២៦
**៨:៤** ឆ ២របា ៦:១៣
**៨:៥** ជ ពច ៣:២០

---

**៧:៧៣** *បាននៅក្នុងទីក្រុងរបស់គេរៀងខ្លួន* សូមមើលការពន្យល់ក្នុង អរ ២:៧០ ។

**៨:១–១៨** នៅក្នុងខ.ទាំងនេះចង់និយាយថា នៅពេលដែលលោកអែសរ៉ាបានអានគម្ពីរក្រិត្យវិន័យរបស់លោកមូសេ នោះទើបតែលើកដំបូងប៉ុណ្ណោះដែលបាននិយាយពីគាត់ព្រោះតាំងពីគាត់វិលត្រឡប់មកកាន់ក្រុងយេរូសាឡិម ក្នុងឆ្នាំ ៤៥៨ មុន គ.ស រហូតមកដល់ពេលនេះ (ឆ្នាំ៤៤៤ មុន គ.ស) គឺមានរយៈពេលប្រមាណ១៣ឆ្នាំ ហើយមិនដែលមាននិយាយពីគាត់ឡើយ ។

**៨:១** *ខែអស្សុជ* ខែនេះគឺស្ថិតនៅក្នុងចន្លោះខែ តុលា–វិច្ឆិកា ឆ្នាំ៤៤៤ មុន គ.ស ។ *បណ្ដាជនទាំងឡាយក៏មូលគ្នាមក* សូមមើលការពន្យល់ក្នុង អរ ៣:១ នៅក្នុងកន្លែងនោះបាននិយាយថា បណ្ដាជនទាំងឡាយក៏បានមូលគ្នានៅក្រុងយេរូសាឡិម ក្នុងខែអស្សុជដែលជាខែចាប់ផ្ដើមចូលឆ្នាំថ្មីជាឆ្នាំធម្មតា *នៅទីធ្លាដែលនៅមុខទ្វារទឹក* សូមមើលការពន្យល់ក្នុងខ.៣,១៦ ៣:២៦ អរ ១០:៩ ។ ជានិច្ចកាលទីធ្លាគឺមានទីតាំងស្ថិតនៅក្បែរទ្វារក្រុងតែម្ដង (សូមមើលការពន្យល់ក្នុង ២របា ៣២:៦) ។ *ស្មៀន* សូមមើលការពន្យល់ក្នុង អរ ៧:៦ ។ *គម្ពីរក្រិត្យវិន័យរបស់លោកម៉ូសេ* សូមធៀបជាមួយ ខ.២–៣,៥,៨–៩,១៣–១៥,១៨ ។ មានទស្សនៈជាច្រើនដែលនិយាយអំពីគម្ពីរក្រឹត្យវិន័យនេះថា (ទី១) ជាក្រឹត្យវិន័យដែលមាននៅក្នុងគម្ពីរ និក្ខមនំ និង លេវីវិន័យ (ទី២) ជាក្រឹត្យវិន័យដែលមាននៅក្នុងគម្ពីរ ចោទិយកថា (ទី៣) ជាក្រឹត្យវិន័យដែលមាននៅក្នុងកណ្ឌគម្ពីរបញ្ចកណ្ឌទាំងមូល (សូមមើលការពន្យល់ យស ១:៨ ២ពវ ២២:៨) ។

**៨:២** *ថ្ងៃដំបូងខែអស្សុជ* គឺស្ថិតនៅក្នុងថ្ងៃទី៨ ខែតុលា ឆ្នាំ៤៤៤ មុន គ.ស ជាថ្ងៃចូលឆ្នាំថ្មីនៃឆ្នាំធម្មតា (សូមមើលការពន្យល់ លវ ២៣:២៤) ហើយជាថ្ងៃបុណ្យផ្លុំត្រែរំពូក (សូមមើលក្នុង ជន ២៩:១–៦) ដែលនៅក្នុងថ្ងៃបុណ្យនេះបណ្ដាជនមិនត្រូវធ្វើការរកស៊ីឡើយ ប៉ុន្តែគឺត្រូវប្រជុំជំនុំបរិសុទ្ធវិញ ។ *ស្រី* សូមមើលការពន្យល់ក្នុង ១០:២៨ ។ តាមធម្មតាគេមិនអនុញ្ញាត្តិឱ្យពួកស្រីៗចូលរួមប្រជុំជាលក្ខណៈពិសេសណាមួយឡើយ (សូមមើលក្នុង នក ១០:១១) ប៉ុន្តែនៅពេលនេះគេអនុញ្ញាត្តិឱ្យចូលរួមប្រជុំទាំងអស់គ្នា ទាំងពួកស្រីៗ រួមទាំងកូនក្មេងថែមទៀត ប្រៀបដូចជាចូលរួមក្នុងឱកាសដ៏ធំមួយ (សូមមើល ចទ ៣១:១២ យស ៨:៣៥ ២ពវ ២៣:២) ។

**៨:៣** *អានមើល* សូមមើលការពន្យល់ នក ២៤:៧ កច ៨:៣០ ១ធថ ៤:១៣ *តាំងពីព្រលឹម ដរាបដល់ថ្ងៃត្រង់* នៅក្នុងឃ្លានេះចង់និយាយថា បណ្ដាជនគេបានឈរចំនួន៥–៦ម៉ោងហើយស្ដាប់លោកអែសរ៉ាអានគម្ពីរក្រឹត្យវិន័យដោយអស់ពីចិត្ត (សូមមើល ខ.៧–៨,១២) ។

**៨:៥** *គម្ពីរ* គម្ពីរដែលនិយាយនៅកន្លែងនេះគឺមានលក្ខណៈជាក្រាំង (សូមមើលការពន្យល់ក្នុង នក ១៧:១៤) ។ *ពួកបណ្ដាជនទាំងឡាយក៏ក្រោកឈរ* នៅក្នុងឃ្លានេះចង់និយាយថា មូលហេតុដែលបណ្ដាជន ក្រោកឈរពីព្រោះលោកអែសរ៉ាដែលជាគ្រូបង្រៀនរបស់ពួកគេបានរកឃើញថា សេចក្ដីបង្រៀននៅក្នុងខ.នេះ គឺបានប្រាប់ឱ្យបណ្ដាជនទាំងអស់ត្រូវតែក្រោកឈរដើម្បីស្ដាប់ការអានមើលគម្ពីរក្រឹត្យវិន័យ ។ នៅក្នុងពួកជំនុំអ័រធើដក់ខាងកើត (Eastern Orthodox) សមាជិកពួកជំនុំទាំងអស់តែងតែក្រោកឈរនៅពេលថ្វាយបង្គំ ។

**៨:៦** *ប្រទូលដៃឡើង* សូមមើលការពន្យល់ក្នុង នក ៩:២៩ ទដ ២៨:២ ១៣៤:២ ១ធថ ២:៨ ។ *អាម៉ែនៗ* សូមមើលការពន្យល់ក្នុង ចទ ២៧:១៥ រម ១:២៥ ។ នៅពេលដែលគេនិយាយពាក្យថា អាម៉ែនៗស្ទួនគ្នាបែបនេះ គឺដើម្បីបង្ហាញពីសពលភាព នៃការព្រមទទួលយកសេចក្ដីប្រកាសនោះ (ពាក្យស្ទួនផ្សេងៗទៀតសូមមើល លប ២២:១១ ហើយធៀបជាមួយ ២ពវ ១១:១៤ លក ២៣:២១) ។ *ថ្វាយបង្គំ* នៅទម្រង់ដើមនៃភាសាហេព្រើរ ពាក្យនេះមានន័យថា "ក្រាបចុះផ្កាប់មុខដល់ដី" ។ ការថ្វាយបង្គំផ្ទាល់ខ្លួនជាញឹកញាប់គឺតែងតែ "ផ្កាប់មុខដល់ដី" ដូចជាបាវរបស់លោកអ័ប្រាហាំដែរ (សូមមើល លប ២៤:៥២) ម៉ូសេ (នក ៣៤:៨) យ៉ូស្វេ (យស ៥:១៤)

បណ្ដាជនក៏ទទួលថា អាម៉ែនៗ ដោយប្រទូលដៃឡើង[ឈ] រួច
ឱនក្បាល ហើយក្រាបចុះផ្កាប់មុខដល់ដី ថ្វាយបង្គំដល់ព្រះ
យេហូវ៉ា ៧ឯយេសួរ បានី សេរេប៊ីយ៉ា យ៉ាមីន អ័កគូប
សាបថាយ ហូឌា ម្អាសេយ៉ា កេលីថា អ័សារា យ៉ូសាបាឌ
ហាណាន ពេឡាយ៉ា និងពួកលេវី[ញ] គេពន្យល់[ដ]ក្រិត្យវិន័យ
ដល់ពួកជន កំពុងដែលពួកជនឈរនឹងនៅកន្លែងរបស់គេ
៨ពួកអ្នកទាំងនោះបានអានមើល ក្នុងគម្ពីរក្រិត្យវិន័យរបស់
ព្រះ ព្រមទាំងស្រាយន័យសេចក្ដី ឱ្យគេបានយល់បទដែល
អានមើលនោះ ។
៩ឯនេហេមា ដែលជាចៅហ្វាយទីក្រុង និងស្មៀនអែសរ៉ា
ដ៏ជាសង្ឃ ព្រមទាំងពួកលេវី[ឋ]ដែលបង្ហាត់បង្រៀនដល់ពួក
ជន គេក៏និយាយ និងពួកជនទាំងឡាយថា ថ្ងៃនេះជាថ្ងៃ
បរិសុទ្ធដល់ព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា កុំឱ្យសុប
សៅ ឬយំយែកអ្វីឡើយ[ឌ] នេះដ្បិតជនទាំងឡាយបានយំ
ដោយឮពាក្យក្នុងក្រិត្យវិន័យនោះ ១០លោកក៏ប្រាប់ដល់គេ
ថា ចូរទៅចុះ ចូរបរិភោគរបស់ចំងាញ់ និងគ្រឿងបង្អែម
ទៅ ហើយជូនខ្លះដល់អ្នកណាដែលគ្មានអ្វីរៀបឱ្យផង[ឍ] ដ្បិត
ថ្ងៃនេះជាថ្ងៃបរិសុទ្ធ ដល់ព្រះអម្ចាស់នៃយើងរាល់គ្នា ក៏កុំ
ឱ្យមានចិត្តព្រួយឡើយ ពីព្រោះសេចក្ដីអំណរ[ណ]របស់ព្រះ
យេហូវ៉ាជាកំឡាំងនៃអ្នករាល់គ្នា ១១យ៉ាងនោះពួកលេវីបាន
លួងលោម ឱ្យបណ្ដាជននៅសៀម ដោយពាក្យថា ចូរអ្នក
រាល់គ្នាសៀមទៅ ដ្បិតថ្ងៃនេះជាថ្ងៃបរិសុទ្ធ កុំឱ្យព្រួយចិត្ត
ឡើយ ១២ដូច្នេះ ពួកជនក៏នាំគ្នាទៅបរិភោគភោជន៍ ព្រម
ទាំងជូនជំនូនដល់គេ ហើយតាំងចិត្តអរសប្បាយឡើងជា
ខ្លាំង[ត] ដោយព្រោះបានយល់ន័យសេចក្ដីទាំងប៉ុន្មាន ដែល
បានថ្លែងប្រាប់ដល់ខ្លួន ។
១៣លុះដល់ថ្ងៃទី២ នោះពួកអ្នកជាកំពូលលើវង្សរបស់
ឪពុកក្នុង ពួកជន ព្រមទាំងពួកសង្ឃ និងពួកលេវី ក៏មូលគ្នា
មកឯស្មៀនអែសរ៉ា ដើម្បីផ្ចង់ចិត្តស្ដាប់ពាក្យក្នុងក្រិត្យវិន័យ
១៤ហើយគេឃើញមានសេចក្ដីកត់ទុកក្នុងក្រិត្យវិន័យ ជា
សេចក្ដីដែលព្រះយេហូវ៉ាទ្រង់បានបង្គាប់មក ដោយសារ
លោកម៉ូសេថា ពួកកូនចៅអ៊ីស្រាអែលត្រូវនៅក្នុងបារាំ[ថ]
នៅវេលាបុណ្យខែអស្សុជ ១៥ហើយត្រូវប្រកាសប្រាប់នៅ
អស់ទាំងទីក្រុងគេ និងនៅក្រុងយេរូសាឡិមថា ចូរចេញ
ទៅឯភ្នំ កាប់យកមែកដើម អូលីវស្រុក និងដើមអូលីវព្រៃ
មែកយីថោ ធាងចាក និងមែកឈើ ញឹកស្និទ្ធមកធ្វើបារាំ
តាមសេចក្ដីដែលបានចែងទុកមក ១៦ដូច្នេះពួកជនក៏ចេញ
ទៅកាប់យកមែកទាំងនោះមកធ្វើបារាំ នៅលើដំបូលផ្ទះគេ

**៨:៦** ឈ អរ ៩:៥ ១ធថ ២:៨
**៨:៧** ញ អរ ១០:២៣ ដ លវ ១០:១១ ២រប ១៧:៧
**៨:៩** ឋ នហ ៧:១,៦៦,៧០ ឌ ចទ ១២:៧,១២ ១៦:១៤–១៥
**៨:១០** ឍ ១សយ ២៥:៨ ២សយ ៦:១៩ នអ ៩:២២ លក ១៤:១២–១៤ ណ លវ ២៣:៤០ ចទ ១២:១៨ ១៦:១១,១៤–១៥
**៨:១២** ត នអ ៩:២២
**៨:១៤** ថ នក ២៣:១៦

និងយ៉ូប (យប១:២០) ។ មានរបៀបថ្វាយបង្គំដែលបន្ទាបខ្លួន៣យ៉ាងនៅក្នុងនិក្ខមនំ (៤:៣១ ១២:២៧ ៣៣:១០) ។ នៅក្នុងព្រះគម្ពីរ ២រប ២០:១៨ យ៉ូសាផាត និងពួកបណ្ដាជនយូដាបាន"ផ្កាប់មុខដល់ដី ថ្វាយបង្គំចំពោះព្រះយេហូវ៉ា" នៅពេលដែលគេបានឮ សេចក្ដីសន្យាដែលព្រះអម្ចាស់សន្យាថា នឹងឱ្យគេមានជ័យជម្នះលើពួកខ្មាំងសត្រូវ ។

**៨:៧** *ពន្យល់* សូមមើលក្នុង ខ.៨ និង អរ៨:១៦ ។

**៨:៨** *អានមើល* សូមមើលការពន្យល់ក្នុង ខ.៣ ។ *បានយល់បទ* សូមមើលការពន្យល់ ខ.១២ ។

**៨:៩** *ឯនេហេមា... អែសរ៉ា* នៅក្នុងឃ្លានេះចង់និយាយថា លោកនេហេមា និងលោកអែសរ៉ា គឺជាមនុស្សដែលរស់នៅក្នុងជំនាន់ជាមួយគ្នា (សូមមើលការពន្យល់ ១២:២៦,៣៦) ។ *កុំឱ្យសុបសៅ* សូមមើលការពន្យល់ អរ ១០:៦ នអ ៩:២២ អស ៥៧:១៨–១៩ យរ ៣១:១៣ ។ *យំយែក* សូមមើលការពន្យល់ ១:៤ អរ ៣:១៣ ១០:១ ។ *យំ ដោយឮពាក្យនៅក្នុងក្រិត្យវិន័យនោះ* នៅក្នុងឃ្លានេះចង់និយាយថា ពួកគេយំដោយព្រោះអំពើបាប និងការធ្លាក់ចុះរបស់ពួកគេផ្ទាល់ ព្រមទាំងពួកឰយុកោរបស់ពួកគេ ។

**៨:១០** *បរិភោគអាហារចំងាញ់* នៅក្នុងឃ្លានេះចង់និយាយថា អាហារដ៏ឆ្ងាញ់ក្នុងពិធីជប់លៀងនេះ គឺគេរៀបចំអិនជាមួយខ្លាញ់យ៉ាងច្រើន ។ ខ្លាញ់នៃយញ្ញបូជារបស់សត្វត្រូវថ្វាយទៅចំពោះព្រះអម្ចាស់ ទុកដូចជាក្លិនឈ្ងុយនៃដង្វាយដុតទៅចំពោះព្រះអម្ចាស់ (សូមមើលការពន្យល់ក្នុង លវ ១:៨,១២) ដង្វាយមេត្រី (លវ ៣:៩–១០) ដង្វាយលោះបាប (លវ ៤:៨–១០) និងដង្វាយដោយព្រោះការរំលង (សូមមើល លវ ៧:៣–៤) ។ ដូច្នេះបើតាមសេចក្ដីពិត ពួកគេមិនត្រូវបរិភោគខ្លាញ់ និងគ្រឿងទាំងនោះឡើយ ។ *ហើយ ជូនខ្លះដល់អ្នកណាដែលគ្មានអ្វីរៀបឱ្យផង* នៅក្នុងឃ្លានេះចង់និយាយថា ទង្វើបែបនេះ គឺជាទម្លាប់មួយទៅហើយ ដែលរាស្ត្ររបស់ទ្រង់តែងតែនឹកចាំដល់អ្នកដែលខ្វះខាត ឬដែលគ្មានឱកាសចូលរួមសប្បាយក្នុងពិធីបុណ្យដ៏ធំបែបនេះ (សូមមើលការពន្យល់ ២សយ ៦:១៩ នអ ៩:២២ នៅកន្លែងនេះមានការផ្ទុយពី ១កថ ១១:២០–២២ យក ២:១៤–១៦) ។

**៨:១៤** *បារាំ* សូមមើលការពន្យល់ នក ២៣:១៦ លវ ២៣:៣៤ ២៣:៣៤ យហ ៧:៣៧ ។

**៨:១៥** *មែកយីថោ* មែកយីថោនេះគឺមានពណ៌ខៀវស្រងាត់គ្រប់រដូវកាល ហើយបែកមែកសាខា សម្រាប់ជាសិរីល្អដល់ព្រះ (សូមមើល អស ៤១:១៩ ៥៥:១៣ សក ១:៨,១០–១១) ។ *ធាងចាក* ដើមចាកត្រូវបានគេដាំនៅជុំវិញក្រុងយេរីខូ (សូមមើលក្នុង ចទ ៣៤:៣ ២រប ២៨:១៥) ។ *មែឈើញឹក* សូមធ្វើការប្រៀបធៀបជាមួយ អគ ៦:១៣ ២០:២៨ ។ នៅសម័យក្រោយមកទៀតពួកយូដាគេប្រារព្ធពិធីបុណ្យបារាំនេះ គឺគេបានយកធាងចាក មែកយីថោ និងស្លឹកញឹកមកចងជាបាច់ហើយលើកគ្រវីនៅក្នុងដៃស្ដាំ ហើយដៃឆ្វេងកាន់មែកក្រូចឆ្មានៅក្នុងប្រទេសកាណាន ។

**៨:១៦** *នៅទីលានព្រះវិហារនៃព្រះ* សូមមើលការពន្យល់ ១៣:៧ ។ ព្រះវិហារដែលហោរ៉ាអេសេគាលបានឃើញ ក្នុងសុបិន្តនិមិត្តគឺមានទីលាននៅខាងក្រៅ និងខាងក្នុង ។ ព្រះវិហារដែលហោរាអេសេគាលបានសាងសង់ គឺមានទំហំប្រហាក់ប្រហែលគ្នាជាមួយព្រះវិហារដែលស្ដេចសាឡូម៉ូនបានសាងឡើងដែរ ដោយព្រះវិហារនោះមានទីលានខាងក្នុងសម្រាប់សង្ឃ និង

រៀងខ្លួន នៅទីធ្លាផ្ទះគេ នៅទីលានព្រះវិហារនៃព្រះ
នៅទីធ្លា ត្រង់ទ្វារទឹក[ទ] និងនៅទីធ្លាត្រង់ទ្វារអេប្រាអិម[ធ]
១៧ពួកជំនុំទាំងអស់ដែលបានវិលពីសណ្ឋានជាឈ្លើយមក
វិញ ក៏ធ្វើបារាំគ្រប់ៗគ្នា ហើយគេអាស្រ័យនៅក្រុងបារាំ
ទាំងនោះ[ន] ដ្បិតចាប់តាំងពីគ្រាយ៉ូស្វេ ជាកូននុន ដរាបដល់
វេលានោះ ពួកកូនចៅអ៊ីស្រាអែលមិនដែលបានធ្វើ[ប]
ដូច្នោះឡើយ ដូច្នេះ មានសេចក្ដីរីករាយកើតឡើងជាខ្លាំង
១៨ហើយរាល់ៗថ្ងៃ ចាប់តាំងពីថ្ងៃដំបូង ដរាបដល់ថ្ងៃចុង
បំផុត នោះលោកក៏អាន[ផ]មើលក្នុងគម្ពីរក្រិត្យវិន័យ[ព]របស់
ព្រះ គេធ្វើបុណ្យនោះអស់៧ថ្ងៃ រួចដល់ថ្ងៃទី៨នោះក៏ប្រជុំ
ជំនុំមុតមាំ[ភ]តាមរបៀប[ម]។

## ពួកកូនចៅអ៊ីស្រាអែលលន់តួបាប

**៩** ១លុះដល់ថ្ងៃ២៤ ក្នុងខែនោះឯង ពួកកូនចៅអ៊ីស្រាអែល
គេបាន មូលគ្នាកាន់ត្រណម ដោយស្លៀកពាក់សំពត់ធ្មៃ
ហើយព្រលាំងដីនៅខ្លួន[ក] ២ឯពូជអ៊ីស្រាអែលក៏ញែកខ្លួន
ចេញពីពួកសាសន៍ដទៃទាំងប៉ុន្មាន[ខ] ហើយឈរឡើងលន់
តួអំពើបាបរបស់ខ្លួន ព្រមទាំងសេចក្ដីទុច្ចរិត របស់ពួក
ឰយុកោផង[គ] ៣រួចគេឈរនៅកន្លែងគេរៀងខ្លួន ហើយ
ពេលថ្ងៃនោះ១ភាគក្នុង៤ មានម្នាក់អានមើលក្នុងគម្ពីរ
ក្រិត្យវិន័យរបស់ព្រះយេហូវ៉ា ជាព្រះនៃខ្លួន រួចពេល១ភាគ
ក្នុង៤ទៀតក៏លន់តួ ព្រមទាំងថ្វាយបង្គំដល់ព្រះយេហូវ៉ា
ជាព្រះនៃខ្លួន ៤ខណនោះ យេសួរ បានី កាឌមាល សេបានា
ប៊ូននី សេរេប៊ីយ៉ា បានី និងកេណានី ជាពួកលេវី[ឃ] ក៏ឈរ
លើថ្នាក់ជណ្ដើរ បន្លឺសំឡេងអំពាវនាវដល់ព្រះយេហូវ៉ា ជា
ព្រះនៃខ្លួន ។
៥រួចយេសួរ កាឌមាល បានី ហាសាបនា សេរេប៊ីយ៉ា
ហូឌា សេបានា និងពេថាហ៊ីយ៉ា ជាពួកលេវី គេប្រកាសថា
ចូរឈរឡើង សូមឱ្យព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នា[ង]
ដែលគង់នៅអស់កល្ប រៀងទៅដល់អស់កល្បជានិច្ច បាន
ប្រកបដោយព្រះពរ ត្រូវតែសូមឱ្យព្រះនាមរបស់ទ្រង់ ជា
ព្រះនាមដ៏រុងរឿង[ច]បានពរដែរ ជាពរដែលខ្ពស់ លើស
ជាងអស់ទាំងពរ និងសេចក្ដីសរសើរផង ៦គឺទ្រង់តែ១ដែល
ជាព្រះឯកអង្គ[ឆ] ទ្រង់បានបង្កើតផ្ទៃមេឃ និងអស់ទាំងជាន់

**៨:១៦** ទ នហ ៣:២៦ ធ នក ២របា ២៥:២៣ **៨:១៧** ន ហស ១២:៩ ប ១ពវ ៨:២ ២របា ៧:៨ ៨:១៣ **៨:១៨** ផ ចទ ៣១:១១ ៣៣:១០ ព ចទ ២៨:៦១ ភ លវ ២៣:៣៦ ម លវ ២៣:៣៦ ,៤០ អរ ៣:៤ **៩:១** ក លវ ២៦:៤០–៤៥ យស ៧:៦ ២របា ៧:១៤–១៦ **៩:២** ខ អរ ៦:២១ នហ ១០:២៨ ១៣:៣,៣០ គ លវ ២៦:៤០ អរ ១០:១១ ទដ ១០៦:៦ **៩:៤** ឃ អរ ១០:២៣ **៩:៥** ង ទដ ៧៨:៤ ច ២សយ ៧:២៦ **៩:៦** ឆ ចទ ៦:៤

ទីលានខាងក្រៅ (សូមមើល ១ពវ ៦:៣៦ ៧:១២ ២ពវ ២១:៥ ២៣:១២ ២របា ៤:៩ ៣៣:៥) ។ ព្រះវិហារនៅក្នុងគ្រាសញ្ញាថ្មី គឺមានទីលានសម្រាប់សាសន៍ដទៃនៅខាងក្រៅ និងទីលានខាងក្នុងបែងចែកជាទីលានតូចៗ សម្រាប់ពួកស្ត្រីៗ ពួកអ៊ីស្រាអែល និងពួកសង្ឃ ។ *ទ្វារអេប្រាអិម* ទ្វារនេះគឺជាទ្វារដ៏ចំណាស់ជាងគេក្នុងចំណោមទ្វារនៅក្រុងយេរូសាឡិម (សូមមើលក្នុង ៣:៦ ២ពវ ១៤:១៣) ។ ទ្វារនេះត្រូវបានលោកនេហេមាកសាងនិងជួសជុលឡើងវិញ (សូមមើល ១២:៣៩) ។

**៨:១៧** *ដ្បិតចាប់តាំងពីគ្រាលោកយ៉ូស្វេ . . . ដរាបដល់វេលានោះ* នៅក្នុងឃ្លានេះចង់មានន័យថា ទោះបីជាពិធីបុណ្យបារាំនេះបានប្រារព្ធធ្វើឡើងបន្ទាប់ពីបុណ្យឆ្លងព្រះវិហាររបស់ស្ដេចសាឡូម៉ូន (សូមមើលការ ពន្យល់ក្នុង ២របា ៧:៨–១០) និងបន្ទាប់ពីគ្រាដែលពួកគេបានរួចពីសណ្ឋានជាឈ្លើយ (សូមមើល អរ ៣:៤) ក៏ដោយ ក៏នៅក្នុងឃ្លានេះមិនមែនមានន័យថា នៅក្នុងសម័យកាលលោកយ៉ូស្វេ ពួកអ៊ីស្រាអែលមិនដែលប្រារព្ធធ្វើពិធីបុណ្យបារាំនោះឡើយ ។ អត្ថន័យពិតប្រាកដរបស់ឃ្លានេះគឺចង់មានន័យថា ពិធីបុណ្យកាលពីសម័យមុន មិនដែលមានក្ដីអំណរយ៉ាងខ្លាំងបែបនេះឡើយ (សូមធ្វើការប្រៀបធៀបជាមួយ ២របា ៣០:២៦ ៣៥:១៨) ។

**៨:១៨** *ប្រជុំជំនុំ* សូមមើលការពន្យល់ក្នុង ជនគណនា ២៩:៣៥ ។

**៩:១–៣៧** នៅក្នុងខ.ទាំងនេះចង់និយាយថា ដោយសារអំពើបាបទាំងប៉ុន្មានដែលពួកអ៊ីស្រាអែសបានប្រព្រឹត្តក្នុងព្រះគម្ពីរអែសរ៉ាជំពូក៩ បានធ្វើឱ្យលោកនេហេមា និងលោកដានីយ៉ែលចូលខ្លួនមកអធិស្ឋានសុំការប្រោសប្រណីពីព្រះអម្ចាស់ដើម្បី អត់ទោសដល់សេចក្ដីកំហុសខុសឆ្គងទាំងប៉ុន្មានដែលពួកគេបានប្រព្រឹត្ត ។

**៩:១** *ថ្ងៃ២៤ ក្នុងខែនោះ* បើនៅឆ្នាំស៊ីវិលវិញ គឺថ្ងៃទី ៣០ខែ តុលា ឆ្នាំ៤៤៤ មុនគ.ស គឺជាថ្ងៃមួយដែលវិញ្ញាណរបស់ពួកគេពេញពោរទៅដោយសេចក្ដីទុក្ខព្រួយ និងត្រូវបញ្ឈឺចិត្តខ្លួនក្នុងថ្ងៃឱ្យធួននឹងបាប ដែលបានប្រព្រឹត្តិឡើងនៅថ្ងៃទី១០ខែអស្សុជ (សូមមើលការពន្យល់ក្នុង លវ ១៦:២៩–៣០) ។ *ត្រណម . . . សំពត់ធ្មៃ . . . ព្រលាំងដី* សូមមើលការពន្យល់ លប ៣៧:៣៤ អរ ៨:២៣ ១០:៦ យអ ១:១៣–១៤ ។ ការត្រណម ស្លៀកពាក់សំពត់ធ្មៃ និងព្រលាំងដីលើក្បាល គឺជានិមិត្តរូបនៃការទុក្ខព្រួយ និងការសោកស្ដាយនៅអំពើបាបរបស់ខ្លួន ។

**៩:៣** *ពេលថ្ងៃនោះ១ភាគក្នុង៤* រយៈពេល១ភាគក្នុង៤ក្នុងថ្ងៃនោះ គឺប្រហែលជា៣ម៉ោង ។

**៩:៥–៣៧** នៅក្នុងខ.ទាំងអស់នេះ គឺជាសេចក្ដីអធិស្ឋានដ៏ល្អឯកមួយក្នុងចំណោមសេចក្ដីអធិស្ឋានផ្សេងៗទៀតក្រៅព្រះគម្ពីរទំនុកដំកើង ។ សេចក្ដីអធិស្ឋាននេះបានបង្ហាញឡើងវិញពីព្រះគុណ និងអំណាចចេស្ដារបស់ព្រះអង្គដូចតទៅ: (ទី១) ការបង្កើត(ខ.៦) (ទី២) សេចក្ដីសញ្ញាជាមួយលោកអ័ប្រាហាំ (សូមមើល ខ.៧–៨) (ទី៣) នៅក្នុងស្រុកអេស៊ីព្ទ និងនៅត្រង់សមុទ្រក្រហម (ខ.៩–១១) (ទី៤) នៅទីរហោស្ថាន និងភ្នំស៊ីណាយ (ខ.១២–២១) (ទី៥) ក្នុងសម័យកាលចម្បាំងដណ្ដើមទឹកដីជាមួយពួកកាណាន (ខ.២២–២៥) (ទី៦) តាមរយៈការជំនុំជម្រះ (ខ.២៦–២៨) (ទី៧) តាមរយៈពួកហោរា (ខ.២៩–៣១) និង (ទី៨) កិច្ចការបច្ចុប្បន្ន (ខ.៣២–៣៧) សូមធៀបជាមួយ ទដ ៧៨:១០៥–១០៦ ។ សូមមើលសេចក្ដីអធិស្ឋានប្រហាក់ប្រហែលគ្នានេះក្នុង អរ ៩:៥–១៥ ដយ ៩:៣–១៩ ។

**៩:៦** *គឺទ្រង់តែ១ដែលជាព្រះឯកអង្គ* នៅក្នុងកន្លែងនេះចង់និយាយថាទោះបីជាឃ្លានេះ មិនមែនជាគំនិតដែលបានដកចេញពី ចទ ៦:៤ ដែលនៅក្នុងខ.នោះនិយាយពីចំណុចច្បងនៃសេចក្ដីជំនឿរបស់ពួកអ៊ីស្រាអែលក៏ដោយ ក៏សេចក្ដីអធិស្ឋាននៅត្រង់កន្លែងនេះបានចាប់ផ្ដើមឡើងដោយពាក្យប្រហាក់ប្រហែលគ្នាដែរ (សូមធៀបជាមួយ ២ពវ ១៩:១៥ ទដ ៨៦:១០) ។ *អស់ទាំង*

នៃផ្ទៃមេឃ[ជ] ព្រមទាំងពួកពលបរិវារនៅលើនោះ[ឈ] និង
ផែនដី[ញ] ហើយសមុទ្រ[ដ] និងរបស់សព្វសារពើ ដែលនៅ
ស្ថានទាំងនោះផង[ឋ] ទ្រង់ក៏ទប់ទល់ជីវិតនៃរបស់ទាំងនោះ
ហើយពួកពលនៅលើមេឃ[ឌ] ក៏ថ្វាយបង្គំដល់ទ្រង់ ៧ឱព្រះ
យេហូវ៉ាដ៏ជាព្រះអើយ គឺទ្រង់ហើយ ដែលបានរើស
អាប់រ៉ាម[ឍ] ព្រមទាំងនាំលោក ចេញពីក្រុងអើរ របស់ពួក
សាសន៍ខាល់ដេ[ណ] ហើយប្រទានឱ្យលោក មានឈ្មោះជា
អ័ប្រាហាំវិញ[ត] ៨ទ្រង់បានឃើញថា លោកមានចិត្តស្មោះ
ត្រង់នៅចំពោះទ្រង់ រួចតាំងសញ្ញានឹងលោកថា និងប្រទាន
ស្រុករបស់ពួកសាសន៍កាណាន សាសន៍ហេត សាសន៍អាម៉ូរី
សាសន៍ពេរិស៊ីត សាសន៍យេប៊ូស និងសាសន៍គើកាស៊ី[ថ]
ដល់ពូជរបស់លោក ទ្រង់ក៏បានសំរេចតាមព្រះបន្ទូល[ទ]ទ្រង់
ហើយ ដ្បិតទ្រង់សុច្ចរិត[ធ]។

៩ទ្រង់បានទតឃើញសេចក្ដីវេទនារបស់ពួកឰយុកោ
យើងខ្ញុំ នៅស្រុកអេស៊ីព្ទ[ន] ហើយបានឮសំរែក ដែលគេ
ស្រែកនៅត្រង់សមុទ្រក្រហម[ប] ១០ក៏សំដែងទីសំគាល់[ផ] និង
ការអស្ចារ្យ[ព]ទៅលើផារ៉ោន ពួកមហាតលិក និងបណ្ដាជន
នៃស្រុកនោះទាំងអស់ ដោយជ្រាបថា គេបានប្រព្រឹត្ត និង
ពួកឰយុកោទាំងនោះ ដោយចិត្តព្រហើន ហើយទ្រង់បាន
ល្បី[ភ]ព្រះនាម[ម] ដូចមានសព្វថ្ងៃនេះ ១១ទ្រង់បានធ្វើឱ្យសមុទ្រ
ញែកចេញជាពីរ នៅមុខអ្នកទាំងនោះ[យ] ឱ្យបានឆ្លងទៅនៅ
កណ្ដាលសមុទ្រ ដោយដីគោក តែទ្រង់បានបោះពួកអ្នក
ដែលដេញតាម ចោលទៅក្នុងទីជំរៅ[រ] ដូចជា បោះថ្មទៅ
ក្នុងទឹកដ៏មានកំឡាំង[ល] ១២មួយទៀត នៅពេលថ្ងៃ[វ] ទ្រង់បាន
នាំ[ស]ពួកឰយុកោនោះ ដោយសារបង្គោលពពក[ហ] ហើយ
ពេលយប់ដោយសារបង្គោលភ្លើង ដើម្បីនឹងបំភ្លឺផ្លូវដែល
គេត្រូវដើរ ១៣ទ្រង់បានយាងចុះមកលើភ្នំស៊ីណាយ[ឡ] ហើយ
មានបន្ទូល[អ] និងគេពីលើមេឃមក[ក] ព្រមទាំងប្រទានឱ្យមាន
ច្បាប់យុត្តិធម៌[ខ]ដ៏ត្រឹមត្រូវនិងក្រិត្យវិន័យដ៏ពិត ហើយបញ្ញត្តិ
និងក្រិត្យក្រមដ៏ល្អដល់គេ[គ] ១៤ទ្រង់បានធ្វើឱ្យគេស្គាល់ថ្ងៃ
ឈប់សំរាក[ឃ]ដ៏បរិសុទ្ធរបស់ទ្រង់ ព្រមទាំងតាំងឱ្យគេមាន
ក្រិត្យក្រមបញ្ញត្តិ និងវិន័យ ដោយសារលោកម៉ូសេ ជាអ្នក
បំរើទ្រង់ ១៥ទ្រង់បានប្រទាននំបុ័ងពីលើមេឃ[ង]មកចំអែត
ដល់គេ ហើយបណ្ដាលឱ្យមានទឹកហូរចេញពីថ្ម[ច]មក ឱ្យគេ
ផឹក ក៏បានបង្គាប់ឱ្យគេចូលទៅចាប់យកស្រុក ដែលទ្រង់
បានស្បថ[ឆ]ថានឹងឱ្យដល់គេ[ជ]។

១៦ប៉ុន្តែគេ និងពួកឰយុកោរបស់យើងខ្ញុំតរៀងមកបាន
ប្រព្រឹត្ត ដោយចិត្តព្រហើន ព្រមទាំងតាំងករឹង[ឈ] ឥតស្ដាប់
តាមក្រិត្យក្រមទាំងប៉ុន្មានរបស់ទ្រង់ទេ[ញ] ១៧គេមិនព្រមធ្វើ
តាមបង្គាប់ឡើយ ក៏មិននឹកចាំ[ដ]ពី អស់ទាំងការអស្ចារ្យ[ឋ]
ដែលទ្រង់បានធ្វើ នៅកណ្ដាលពួកគេផង គឺគេបានតាំង
ករឹង[ឌ]វិញ ក្នុងគ្រាបះបោរនោះ គេបានដំរូវម្នាក់ឱ្យធ្វើជាមេ
ដើម្បីនឹងនាំវិលទៅឯសណ្ឋានជាបាវបំរើវិញ[ឍ] តែទ្រង់ជា
ព្រះដែលប្រុងនឹងអត់ទោស[ណ] ទ្រង់ក៏សន្ដោស ហើយមេត្តា
ករុណា[ត]ទ្រង់យឺតនឹងខ្ញាល់[ថ] ហើយមានសេចក្ដីសប្បុរស
ជាបរិបូរ[ទ] បានជាទ្រង់មិនបោះបង់ចោលគេឡើយ[ធ] ១៨ទោះ

**៩:៦** ជ នក ៨:១៩ ឈ អស ៤០:២៦ ៤៥:១២ ញ លវ ១:១ អស ៣៧:១៦ ដ ទដ ៩៥:៥ ១៤៦:៦ យហ ១:៩ ឋ ចទ ១០:១៤ កច ៤:២៤ វវ ១០:៦ ឌ ទដ ១០៣:២០ ១៤៨:២ **៩:៧** ឍ លវ ១៦:១១ ណ លវ ១១:២៨ ត លប ១៧:៥ **៩:៨** ថ លវ ១៥:១៨–២១ អរ ៩:១ ទ យស ២១:៤៥ ធ លវ ១៥:៦ អរ ៩:១៥ **៩:៩** ន នក ២:២៣–២៥ ៣:៧ ប នក ១៤:១០–៣០ **៩:១០** ផ នក ១០:១ ទដ ៧៤:៩ ព នក ៣:២០ ៦:៦ ភ យរ ៣២:២០ ដយ ៩:១៥ ម ជន ៦:២៧ **៩:១១** យ ទដ ៧៨:១៣ រ នក ១៤:២៨ ល នក ១៥:៤–៥,១០ ហព ១១:២៩ **៩:១២** វ ចទ ១:៣៣ ស នក ១៥:១៣ ហ នក ១៣:២១ **៩:១៣** ឡ នក ១៩:១១ អ នក ១៩:១៩ ក នក ២០:២២ ខ ទដ ១១៩:១៣៧ គ នក ២០:១ ចទ ៤:៧–៨ **៩:១៤** ឃ លប ២:៣ នក ២០:៨–១១ **៩:១៥** ង នក ១៦:៤ ទដ ៧៨:២៤–២៥ យហ ៦:៣១ ច នក ១៧:៦ ជន ២០:៧–១៣ ឆ លប ១៤:២២ ជ ចទ ១:៨,២១ **៩:១៦** ឈ នក ៣២:៩ យរ ៧:២៦ ១៧:២៣ ១៩:១៥ ញ ចទ ១:២៦–៣៣ ៣១:២៩ **៩:១៧** ដ ពច ៨:៣៤ ទដ ៧៨:៤២ ឋ ទដ ៧៧:១១ ៧៨:១២ ១០៥:៥ ១០៦:៧ ឌ យរ ៧:២៦ ១៩:១៥ ឍ ជន ១៤:១–៤ ណ ទដ ១៣០:៤ ដយ ៩:៩ ត ចទ ៤:៣១ ថ នក ៣៤:៦ ទដ ១០៣:៨ ណហ ១:៣ ទ នក ២២:២៧ ជន ១៤:១៧–១៩ ទដ ៨៦:១៥ ធ ទដ ៧៨:១១ អគ ៥:៦

*ជាន់ផ្ទៃមេឃ* សូមមើលក្នុង ចទ ១០:១៤ ១ពរ ៨:២៧ ២របា ២:៦ ទដ ១៤៨:៤ ។ *ពួកពលនៅលើមេឃ ក៏ថ្វាយបង្គំដល់ទ្រង់* សូមមើលការពន្យល់ក្នុង ទដ ៨៩:៥–៧ ។

**៩:៧** *ក្រុងអើរ របស់ពួកសាសន៍ខាល់ដេ* សូមមើលក្នុង លប ១១:២៨ ។ *ប្រទានឱ្យលោកមានឈ្មោះជាអ័ប្រាហាំវិញ* សូមមើលការពន្យល់ក្នុង លប ១៧:៥ ។

**៩:៨** *ចិត្តស្មោះត្រង់* សូមធ្វើការប្រៀបធៀបរម ៤:១៦–២២ ជាមួយ យប ២:២១–២៣ ។ *រួចតាំងសញ្ញានឹងលោក* សូមមើលក្នុង លប ១៥:១៨ ។ *សាសន៍កាណាន . . . សាសន៍គើកាស៊ី* សូមមើលការពន្យល់ លប ១០:៦, ១៥–១៨ ១៣:៧ នក ៣:៨ អរ ៩:១ ។

**៩:៩** *សមុទ្រក្រហម* សូមមើលការពន្យល់ នក ១៣:១៨ ១៤:២ ។

**៩:១១** *ធ្វើឱ្យសមុទ្រញែកចេញជាពីរ* មើលការពន្យល់ នក ១៤:២១–២២ ១កថ ១០:១ ។

**៩:១៤** *ថ្ងៃឈប់សំរាកដ៏បរិសុទ្ធ* ដោយទៅតាមគ្រូប្រដៅពួកយូដា បាននិយាយថា "ថ្ងៃឈប់សម្រាក គឺវិសេសជាងគេទាំងអស់ក្នុងចំណោមបញ្ញត្តិទាំងឡាយនៅក្នុងសញ្ញាចាស់" (សូមមើល ១០:៣១–៣៣ ១៣:១៥–២២) ។

**៩:១៥** *នំបុ័ងពីលើមេឃ* សូមមើលការពន្យល់ នក ១៦:៤ ។ *ហើយបណ្ដាលឱ្យមានទឹកចេញពីថ្មដាមក* សូមមើលការពន្យល់ នក ១៧:៦ *ទ្រង់បានស្បថថានឹងឱ្យគេ* សូមមើលការពន្យល់ លប ១៤:២២ និង ២២:១៥–១៧ នក ៦:៨ អគ ២០:៦ ៤៧:១៤ ។

**៩:១៦** *ករឹង* សូមមើលការពន្យល់ ខ.១៧,២៩ និងការពន្យល់ ៣:៥ នក ៣២:៩ ។

**៩:១៧** *ដំរូវម្នាក់ឱ្យធ្វើជាមេ* នៅក្នុងកន្លែងនេះចង់និយាយប្រាប់យើងថា ចេតនារបស់ពួកគេ គឺមានកត់ចុះក្នុង ជន ១៤:៤ ។ *សន្ដោស . . . សេចក្ដីសប្បុរសជាបរិបូរ* សូមមើលការពន្យល់ នក ៣៤:៦–៧ ។

**៩:១៨** *ទំនាស់* សូមមើលខ.២៦ នក ៣២:៤ អគ ៣៥:១២ ។

ទាំងកាលដែលគេបានបណ្តាលទំនាស់ទ្រង់ជាខ្លាំង ដោយ
សិតធ្វើរូបកូនគោ[ន] ហើយនិយាយថា នេះជាព្រះរបស់យើង
ដែលបាននាំយើងឡើងពីស្រុកអេស៊ីព្ទមកដូច្នេះក្តី[ប] 19គង់
តែទ្រង់មិនបានបោះបង់ចោល[ផ]គេ នៅទីរហោស្ថានដែរ គឺ
ដោយទ្រង់មានសេចក្តីមេត្តាករុណាដ៏ក្រៃលែង ឯបង្គោល
ពពក[ព]មិនបានថយចេញ លែងនាំផ្លូវគេ នៅវេលាថ្ងៃឡើយ
ហើយបង្គោលភ្លើងក៏មិនលែងបំភ្លឺគេនៅវេលាយប់ ដើម្បី
នឹងបង្ហាញផ្លូវ ដែលគេត្រូវដើរដែរ 20ទ្រង់បានប្រទានព្រះ
វិញ្ញាណដ៏ល្អ[ភ]របស់ទ្រង់ មកបង្ហាត់បង្រៀន[ម]គេ ទ្រង់មិន
ដែលបង្អត់នំម៉ានា[យ]ចំពោះគេទេ ហើយបានប្រទានទឹក[រ]
ឱ្យគេផឹកផង 21គឺទ្រង់បានចិញ្ចឹមគេ នៅទីរហោស្ថាន អស់
40ឆ្នាំ[ល] គេឥតមានខ្វះខាតអ្វីឡើយ[វ] សំលៀកបំពាក់របស់គេ
ក៏មិនដែលសឹក ហើយជើងគេមិនពុរពងដែរ[ស] 22មួយទៀត
ទ្រង់បានប្រទាននគរ និងសាសន៍ផ្សេងៗ ហើយចែកស្រុក
ទាំងនោះដល់គេ គឺយ៉ាងនោះដែលគេបានស្រុករបស់
ស៊ីហុន[ហ] ជាស្រុករបស់ស្តេចក្រុងហែសបូន និងស្រុក
របស់អុក ជាស្តេចស្រុកបាសាន[ឡ] 23ទ្រង់ក៏ធ្វើឱ្យគេកើតកូន
ចំរើនឡើង ដូចជាផ្កាយនៅលើមេឃ[អ] ហើយបាននាំគេ
ចូលមកក្នុងស្រុក ដែលទ្រង់ប្រាប់ដល់ពួកឰយុកោថា ត្រូវឱ្យ
គេចូលទៅចាប់យកនេះ 24ដូច្នេះ ពួកកូនចៅគេក៏ចូលទៅ
ចាប់យកស្រុក[ក] ហើយទ្រង់បានបង្ក្រាប[ខ]សាសន៍កាណាន ជា
កូនអ្នកស្រុកនេះ នៅមុខគេ ព្រមទាំងប្រគល់ពួកនោះ និង
ស្តេច ហើយបណ្តាជនទាំងឡាយ មកក្នុងកណ្តាប់ដៃគេ
ឱ្យបានប្រព្រឹត្តនឹងសាសន៍នោះ តាមអំពើចិត្ត 25គេចាប់យក
បានទាំងទីក្រុងមានបន្ទាយ និងស្រុកមានដីជាតិ[គ] ក៏បានផ្ទះ
ជាច្រើន ពេញដោយរបស់ល្អគ្រប់មុខ[ឃ]និងអណ្តូងជីកស្រាប់
ចំការទំពាំងបាយជូរ ដំណាំអូលីវនឹងដើមឈើផ្លែជាបរិបូរ
យ៉ាងនោះគេបានបរិភោគឆ្អែត ហើយត្រឡប់ជាមានសាច់
ធាត់[ង] ក៏មានចិត្តរីករាយ ដោយសារសេចក្តីសប្បុរសដ៏ជា
ធំរបស់ទ្រង់[ច] ។
26ប៉ុន្តែគេមានចិត្តរឹងចចេស ហើយបានបះបោរនឹង
ទ្រង់វិញ គេបោះបង់ចោលក្រិត្យវិន័យទ្រង់ទៅក្រោយខ្នង[ឆ]
ហើយបានសំឡាប់[ជ]ពួកហោរាទ្រង់[ឈ] ដែលធ្វើបន្ទាល់ដល់
គេដោយប្រាថ្នាចង់នាំគេមកឯទ្រង់វិញ គេក៏ប្រព្រឹត្តទំនាស់
ជាខ្លាំងដែរ[ញ] 27ហេតុនោះទ្រង់បានប្រគល់គេទៅក្នុង
កណ្តាប់ដៃនៃពួកសត្រូវ[ដ] ដែលញាំញីសង្កត់សង្កិនគេ តែ
កាលគេកើតមានសេចក្តីវេទនា[ឋ] ហើយបានអំពាវនាវរក
ទ្រង់ នោះទ្រង់ក៏ឮពីលើមេឃ ហើយបានប្រទានឱ្យគេមាន
ពួកអ្នកជួយសង្គ្រោះ[ឌ] ឱ្យរួចពីកណ្តាប់ដៃនៃពួកសត្រូវនោះ
ដោយសេចក្តីមេត្តាករុណាដ៏ក្រៃលែងរបស់ផងទ្រង់ 28តែ
កាលគេមានសេចក្តីស្រាកស្រាន្តបន្តិច នោះគេបានប្រព្រឹត
សេចក្តីអាក្រក់ នៅចំពោះទ្រង់វិញទៀត[ឍ] បានជាទ្រង់ទុក
គេ នៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ ឱ្យពួកនោះមាន្ត

**៩:១៨** ន នក ៣២:៤ ប នក ២០:២៣ **៩:១៩** ផ នក ១៣:២២ ព នក ១៣:២១ **៩:២០** ភ ជន ៩:១៧ ១១:១៧ អស ៦៣:១១,១៤ ហក ២:៥ សក ៤:៦ ម ទដ ២៣:៣ ១៤៣:១០ យ នក ១៦:១៥ រ នក ១៧:៦ **៩:២១** ល នក ១៦:៣៥ វ ចទ ២:៧ ស ចទ ៨:៤ **៩:២២** ហ ជន ២១:២១ ឡ ជន ២១:៣៣ ចទ ២:២៦–៣:១១ **៩:២៣** អ លប ១២:២ លវ ២៦:៩ ជន ១០:៣៦ **៩:២៤** ក យស ១១:២៣ ខ ពច ៤:២៣ ២របា ១៤:១៣ **៩:២៥** គ ចទ ១១:១១ ឃ នក ១៨:៩ ង ចទ ៦:១០–១២ ច ៨:៨–១១ ៣២:១២–១៥ **៩:២៦** ឆ ១ពវ ១៤:៩ យរ ៤៤:១០ ជ យស ៧:២៥ ឈ យរ ២:៣០ ២៦:៨ មថ ២១:៣៥–៣៦ ២៣:២៩–៣៦ កច ៧:៥២ ញ ពជ ២:១២–១៣ **៩:២៧** ដ ជន ២៥:១៧ ពច ២:១៤ ឋ ទដ ៥១:១ ១០៣:៨ ១០៦:៤៥ ១១៩:១៥៦ ឌ ពច ៣:៩ **៩:២៨** ឍ នក ៣២:២២ ពច ២:១៧

**៩:១៩** *សេចក្តីមេត្តាករុណា* សូមមើល ខ.២៧–២៨ ។

**៩:២០** *ព្រះវិញ្ញាណដ៏ល្អ* សូមមើល នក ៣១:៣ ។

**៩:២១** *សំលៀកបំពាក់របស់គេ ក៏មិនដែលសឹក* នៅក្នុងឃ្លានេះគឺជាភស្តុតាងដ៏វិសេសនៃការផ្គត់ផ្គង់របស់ព្រះអម្ចាស់ចំពោះពួកគេ (សូមមើល ចទ ៨:៤ ២៩:៥ នៅកន្លែងនេះផ្ទុយពី យស ៩:១៣) ។ *ពុរពង* ចំពោះពាក្យនេះនៅក្នុងភាសាហេព្រើរឃ្លា គឺឃើញមានតែនៅក្នុង ចទ ៨:៤ និងទីនេះប៉ុណ្ណោះ ។

**៩:២២** *ស៊ីហុន . . . អុក* សូមមើល ជន ២១:២១–៣៥ ។

**៩:២៣** *ចំរើនឡើង ដូចជាផ្កាយនៅលើមេឃ* សូមមើលការពន្យល់ក្នុង លប ១៣:១៦ ១៥:៥ ២២:១៧ ។

**៩:២៥** សូមមើលការពន្យល់នៅ ចទ ៦:១០–១២ យស ២៤:១៣ ។ *បន្ទាយ* សូមមើលការពន្យល់ ខ.៣៥ ធៀបជាមួយ ជន ១៤:៧ ជន ៨:៧ យស ២៣:១៣ ។ *អណ្តូងជីកស្រាប់* ស្ទើរតែរាល់ឆ្នាំនៅស្រុករបស់គេខ្សត់ទឹកភ្លៀងជាមូលហេតុដែលធ្វើឱ្យពួកគេជីកអណ្តូង ឬអាងផ្ទុកទឹកផ្ទាល់ខ្លួន ដើម្បីផ្ទុកទឹកប្រើប្រាស់ ក្នុងកំឡុងពេលរដូវភ្លៀងធ្លាក់(សូមមើល ២ពវ ១៨:៣១ សភ ៥:១៥) ។ នៅក្នុងឆ្នាំ១២០០ មុន គ.ស ជាពេលមួយដែលគេមានយុទ្ធសាស្ត្រអភិវឌ្ឍន៍លើអាងទឹក ដោយបានអនុញ្ញាត្តិឱ្យមានអាងទឹកធំជាងមុនហើយ បាននៅចំណុចកណ្តាលនៃភ្នំស្រុកយូដា ។ *ចំការទំពាំងបាយជូរដំណាំអូលីវ និងដើមឈើផ្លែជាបរិបូរ* សូមធ្វើការប្រៀបធៀបជាមួយ ចទ ៨:៨ ។ ពួកអេស៊ីព្ទគេរៀងដែលនិយាយប្រទេសកាណានថា "នៅក្នុងប្រទេសនេះសម្បូរដោយល្វានិងទំពាំងបាយជូរ ។ មិនតែប៉ុណ្ណោះសោធ នៅក្នុងប្រទេសនេះសម្បូរទឹកទំពាំងបាយជូរជាងទឹក ហើយមានទឹកឃ្មុំយ៉ាងបរិបូរ និងមានប្រេងអូលីវគ្រប់គ្រាន់ ។ ផ្លែឈើគ្រប់ប្រភេទគឺបានបេះចេញពីដើមរបស់វា" *ចិត្តរីករាយ* នៅក្នុងភាសាហេព្រើរពាក្យនេះ គឺសំដៅលើភាពសម្បូរសប្បាយ ។

**៩:២៦–២៨** សូមមើលការពន្យល់ខ.នេះនៅក្នុង ពច ២:៦–៣:៦ ។

**៩:២៦** *គេបោះបង់ចោលក្រិត្យវិន័យទ្រង់ទៅក្រោយខ្នង* នៅកន្លែងនេះមានន័យថា ពួកគេមិនទុកចិត្តហើយធ្វេសប្រហែសនឹងក្រិត្យវិន័យរបស់ព្រះអម្ចាស់ (ប្រៀបធៀបជាមួយ ទដ ៥០:១៧ យរ ២:២៧ ៣២:៣៣ អគ ២៣:៣៥) ។ *សំឡាប់ពួកហោរាទ្រង់* សូមមើលការពន្យល់ ១ពវ ១៨:៤,១៣ ១៩:១០,១៤ ២របា ២៤:២០–២១ យរ ២:៣០ ២៦:២០–២៣ ហើយធៀបជាមួយ លក ១១:៥០–៥១ ហាព ១១:៣២,៣៦–៣៨ ។

**៩:២៧** *ជួយសង្គ្រោះ* សូមមើលការពន្យល់ក្នុងសេចក្តីផ្តើមពួកចៅហ្វាយត្រង់ចំណងជើង ។

អំណាចលើគេ ប៉ុន្តែកាលគេបានវិលមកអំពាវនាវរកទ្រង់
ទៀត នោះទ្រង់ក៏ឮពីលើមេឃដែរ ហើយបានប្រោស
ឱ្យគេ[ណ] រួចជាច្រើនដង តាមសេចក្តីមេត្តាករុណា[ត] របស់
ទ្រង់ ២៩ ទ្រង់បានធ្វើបន្ទាល់[ថ] ដល់គេ ដើម្បីនឹងនាំគេមកឯ
ក្រិត្យវិន័យទ្រង់វិញ ទោះបើយ៉ាងនោះ គង់តែគេបាន
ប្រព្រឹត្តដោយចិត្តព្រហើន[ទ] ឥតព្រមស្តាប់តាមក្រិត្យក្រមនៃ
ទ្រង់ដែរ គឺបានធ្វើបាបទទឹងនឹងច្បាប់យុត្តិធម៌របស់ទ្រង់
(ជាច្បាប់ដែលអ្នកណាប្រព្រឹត្តតាម នោះបានរស់នៅ
ដោយសេចក្តីនោះឯង[ធ]) ហើយគេដកស្មាចេញ[ន] តាំងក
រឹង[ប] មិនព្រមស្តាប់តាមឡើយ[ផ] ៣០ ប៉ុន្តែទ្រង់បានអត់ទ្រាំនឹង
គេជាយូរឆ្នាំ ព្រមទាំងធ្វើបន្ទាល់ដល់គេ ដោយសារព្រះ
វិញ្ញាណទ្រង់ ដែលសណ្ឋិតលើពួកហោរា[ព] នោះបើយ៉ាង
នោះ គង់តែគេមិនផ្ទៀងត្រចៀកស្តាប់ដែរ បានជាទ្រង់
ប្រគល់គេ ទៅក្នុងកណ្តាប់ដៃនៃអស់ទាំងសាសន៍របស់
ស្រុកដទៃ[ភ] ៣១ ប៉ុន្តែដោយព្រោះសេចក្តីមេត្តាករុណាដ៏
ក្រៃលែងរបស់ទ្រង់ បានជាទ្រង់មិនបានបំផ្លាញគេអស់
រលីងទៅឬ[ម] បោះបង់ចោលគេឡើយ ដ្បិតទ្រង់ជាព្រះដ៏
មានព្រះហឫទ័យសន្តោស ហើយមេត្តាករុណា[យ] ។
៣២ ដូច្នេះ ឱព្រះនៃយើងខ្ញុំរាល់គ្នា ជាព្រះដ៏ធំ ហើយ
មានឥទ្ធានុភាព[រ] ដែលគួរស្ញែងខ្លាចដល់ទ្រង់[ល] ជាព្រះដែល
រក្សាសេចក្តីសញ្ញា និងសេចក្តីសប្បុរសអើយ[វ] ឯសេចក្តី
វេទនាទាំងប៉ុន្មាន[ស] ដែលបានកើតដល់យើងខ្ញុំ ព្រមទាំង
ស្តេច ពួកមេ ពួកសង្ឃ ពួកហោរា ពួកឰយុកោ យើងខ្ញុំនិង
ពួករាស្ត្ររបស់ទ្រង់ ចាប់តាំងពីគ្រាពួកស្តេចនៃស្រុកអាស
ស៊ើរ ដរាបដល់សព្វថ្ងៃនេះ នោះសូមទ្រង់កុំរាប់ថា ជាការ
តិចតួចឡើយ ៣៣ ប៉ុន្តែក្នុងសេចក្តីទាំងប៉ុន្មាន ដែលបានកើត
ដល់យើងខ្ញុំ នោះទ្រង់សុចរិតទេ ដ្បិតទ្រង់បានប្រព្រឹត្ត
ដោយស្មោះត្រង់[ហ] តែយើងខ្ញុំបានប្រព្រឹត្ត ដោយលាមក
អាក្រក់វិញ[ឡ] ៣៤ ទោះទាំងស្តេចនៃយើងខ្ញុំ[អ] ឬពួកមេពួក
សង្ឃ និងពួកឰយុកោរបស់យើងខ្ញុំ[ក] ក៏មិនបានរក្សាក្រិត្យ
វិន័យរបស់ទ្រង់ ឬស្តាប់តាមក្រិត្យក្រម និងសេចក្តីបន្ទាល់
ដែលទ្រង់បានធ្វើនៅចំពោះគេដែរ ៣៥ ពីព្រោះគេមិនបាន
គោរពប្រតិបត្តិដល់ទ្រង់ នៅក្នុងនគរនៃខ្លួន នៅកណ្តាល
អស់ទាំងសេចក្តីល្អក្រៃលែង[ខ] ដែលទ្រង់បានប្រោសដល់គេ
នៅក្នុងស្រុកធំទូលាយមានដីជាតិ ដែលទ្រង់បានដាក់នៅ
មុខគេនោះឡើយ[គ] គេក៏មិនបានបែរចេញពីអំពើ អាក្រក់
របស់ខ្លួនដែរ ៣៦ មើល យើងខ្ញុំរាល់គ្នាជាបាវបំរើ[ឃ] របស់គេ
ដរាប ដល់សព្វថ្ងៃនេះ គឺជាបាវបំរើ នៅក្នុងស្រុកនេះ
ដែលទ្រង់បានប្រទាន ដល់ពួកឰយុកោយើងខ្ញុំ ឱ្យបាន
បរិភោគផលនឹងសេចក្តីល្អនោះផង ៣៧ ស្រុកនេះក៏បង្កើត
ផលជាច្រើនដល់ពួកស្តេច ដែលទ្រង់បានតាំង ឱ្យគ្រប់គ្រង
លើយើងខ្ញុំ ដោយព្រោះអំពើបាបរបស់យើងខ្ញុំ ស្តេចទាំង
នោះមានអំណាច លើទាំងខ្លួនប្រាណយើងខ្ញុំ និងហ្វូងសត្វ
របស់យើងខ្ញុំផង តាមតែព្រះទ័យ ហើយយើងខ្ញុំមានសេចក្តី
វេទនាជាខ្លាំង[ង] ។

### ការចុះសញ្ញារបស់បណ្តាជន

៣៨ ទោះបើមានសេចក្តីយ៉ាងនោះក៏ដោយ គង់តែយើងខ្ញុំ
រាល់គ្នាចុះសញ្ញាមាំមួន[ច] ហើយក៏កត់ទុកផង[ឆ] មានទាំងពួក
មេ ពួកលេវី និងពួកសង្ឃរបស់យើងខ្ញុំ ជាអ្នកបោះត្រា
ចំពោះសេចក្តីសញ្ញានោះ ។

**១០** ១ រីឯពួកអ្នកដែលបោះត្រា នោះគឺនេហេមា កូន
ហាកាលា ជាចៅហ្វាយទីក្រុង បន្ទាប់មក សេដេគា ២ រួច
សេរ៉ាយ៉ា[ក] អ័សារា យេរេមា ៣ ផាសហ៊ើរ[ខ] អ័ម៉ារា
ម៉ាលគា ៤ ហាធូស សេបានា ម៉ាលូក ៥ ហារីម[គ] ម្រេម៉ូត
អូបាឌា ៦ ដានីយ៉ែល គីនេថោន បារូក ៧ មស៊ូឡាម អ័ប៊ីយ៉ា

ណ ទដ ២២:៤ ១០៦:៤៣ ១៣៦:២៤
ត ២សយ ២៤:១៤
**៩:២៩** ថ ពច ៦:៨
ទ ខ.១៦–១៧ ទដ ៥:៥ អស ២:១១ យរ ៤៣:២
ធ ចទ ៣០:១៦
ន ១សយ ៨:៣
ប យរ ១៩:១៥
ផ សក ៧:១១–១២
**៩:៣០** ព ២ពវ ១៧:១៣–១៨ ២របា ៣៦:១៦ ភ យរ ១៦:១១ សក ៧:១២
**៩:៣១** ម អស ៤៨:៩ ៦៥:៩ យ ចទ ៤:៣១
**៩:៣២** រ យប ៩:១៩ ទដ ២៤:៨ ៨៩:៨ ៩៣:៤ ល ចទ ៧:២១ វ ចទ ៧:៩ ១ពវ ៨:២៣ ដយ ៩:៤ ស នក ១៨:៨
**៩:៣៣** ហ លប ១៨:២៥ ឡ យរ ៤៤:៣ ដយ ៩:៧–៨,១៤
**៩:៣៤** អ ២ពវ ២៣:១១
ក យរ ៤៤:១៧
**៩:៣៥** ខ អស ៦៣:៧ គ ចទ ២៨:៤៥–៤៨
**៩:៣៦** ឃ អរ ៩:៩
**៩:៣៧** ង ចទ ២៨:៣៣ បទ ៥:៥
**៩:៣៨** ច ២របា ២៣:១៦ ឆ អស ៤៤:៥ **១០:២** ក អរ ២:២ **១០:៣** ខ ១របា ៩:១២ **១០:៥** គ ១របា២៤:៨

**៩:២៩** *អ្នកណាដែលប្រព្រឹត្តតាម នោះនឹងបានរស់នៅ* សូមមើលការពន្យល់ក្នុង លវ ១៨:៥ ។ *គេដកស្មាចេញ* សូមមើលការពន្យល់ក្នុង សក ៧:១១ ហើយធៀបជាមួយ ទង្វើប្រហាក់ប្រហែលគ្នាក្នុង ខ.៦ ៣:៥ ហស ៤:១៦ ។

**៩:៣២** *ជាព្រះដែលរក្សាសេចក្តីសញ្ញា* សូមមើលការពន្យល់ ១:៥ ចទ ៧:៩,១២ ។ *ពួកស្តេចស្រុកអាសស៊ើរ* ពួកស្តេចអាសស៊ើរដែលនិយាយកន្លែងនេះ គឺរាប់ទាំងស្តេច ទីកឡាត–ពីលេស៊ើរទី៣ ដែលគេតែងតែស្គាល់ថា ស្តេចប៉ូលនោះ (សូមមើល ១របា ៥:២៦) និងសាលម៉ានេស៊ើរទី៥ (សូមមើល ២ពវ ១៨:៩) ស៊ើរកុនទី២ (សូមមើល អស ២០:១) សានហេរីប (សូមមើល ២ពវ ១៨:១៣) អេសារ–ហាដោន (សូមមើល អរ ៤:២) និង អ័ស្នាផារ (អរ ៤:១០) ។

**៩:៣៧** *គ្រប់គ្រងលើយើងខ្ញុំ* សូមមើលការពន្យល់ ១សយ ៨:១១–១៣ ។ នៅពេលដែលពួកពើស៊ីគ្រប់គ្រងលើពួកអ៊ីស្រាអែល ពួកគេបាននាំយកគោលការណ៍នៃការដឹកនាំរបស់គេទៅលើផ្នែកយោធា ។ មានពួកយូដាខ្លះអាចចូលរួមជាមួយស្តេចអ័ហាស៊ូរុសដើម្បីធ្វើការឈ្លានពានប្រទេសក្រិកក្នុងឆ្នាំ ៤៨០ មុន គ.ស ។

**១០:១–២៧** នៅក្នុងខ.ទាំងនេះគឺចង់និយាយអំពីបញ្ជីឈ្មោះមនុស្សចំនួន ៨៤នាក់ដែលបានបោះត្រាស្របច្បាប់ទុកជាទីសំគាល់ ។

**១០:២–៨** ប្រហែលជាជាងពាក់កណ្តាលនៃឈ្មោះរបស់ពួកគេដែលបាននិយាយនៅក្នុងខ.ទាំងនេះ នឹងលើកមកនិយាយម្តងទៀតនៅ ១២:១–៧ ។

មីយ៉ាមីន ៨ម្អាស៊ា ប៊ីលកាយ សេម៉ាយ៉ា នោះសុទ្ធតែជា
ពួកសង្ឃ[ឃ] ។
៩ឯពួកលេវី[ង] គឺយេសួរ ជាកូនអ័សានា និងប៊ីនុយ ឯខាង
ពួកកូនចៅហេណាដាឌ មានកាឌមាល ១០និងពួកបងប្អូនគេ
គឺសេបានា ហូឌា កេលីថា ពេឡាយ៉ា ហាណាន ១១មីកា
រេហុប ហាសាបយ៉ា ១២សាគើរ សេរេប៊ីយ៉ា សេបានា
១៣ហូឌា បានី និងបេនីនូ ។
១៤ឯពួកដែលជាកំពូលលើបណ្ដាជន នោះគឺប៉ារ៉ូស
ផាហាត-ម៉ូអាប់ អេឡាំ សាធូវ បានី ១៥ប៊ូននី អាសកាឌ
បេបាយ ១៦អ័ដូនីយ៉ា ប៊ីកវ៉ាយ អេឌីន[ច] ១៧អេធើ ហេសេគា
អ័សើរ ១៨ហូឌា ហាស៊ូម បេសាយ ១៩ហារីប អ័ណាថូត
នេបាយ ២០ម៉ាកពីអាស មស៊ូឡាម ហេស៊ារ[ឆ] ២១មសេ-
សាបេល សាដុក យ៉ាឌួរ ២២ពេឡាធា ហាណាន អ័ណាយ៉ា
២៣ហូសេ ហាណានា[ជ] ហាស៊ូប ២៤ហាឡូហេស ពីឡាហា
សូបេក ២៥រេហ៊ូម ហាសាបណា ម្អាសេយ៉ា ២៦អ័ហ៊ីយ៉ា
ហាណាន អ័ណាន ២៧ម៉ាលូក ហារីម និងប្អាណា ។
២៨ឯពួកបណ្ដាជនឯទៀត ពួកសង្ឃ ពួកលេវី ពួកឆ្មាំទ្វារ
ពួកចំរៀង ពួកនេធីនិម[ឈ] និងអស់អ្នកដែលបានញែកខ្លួន
ចេញ ពីពួកសាសន៍នៃស្រុកទាំងនោះ[ញ] ចូលខាងក្រិត្យវិន័យ
របស់ព្រះវិញ ព្រមទាំងប្រពន្ធ និងកូនប្រុសកូនស្រីគេ គឺអស់
អ្នកណាដែលមានចំណេះមានយោបល់ ២៩គេក៏កាន់ខ្ជាប់
តាមបងប្អូន និងពួកអ្នកមានត្រកូលខ្ពស់ក្នុងពួកគេដែរ គេ
តាំងសេចក្ដីផ្ដាសាដល់ខ្លួន ដោយស្បថ[ដ]ថា និងកាន់តាម
ក្រិត្យវិន័យរបស់ព្រះ ដែលបានប្រទានមកដោយសារលោក

**១០:៨** ឃ នហ១២:១
**១០:៩** ង នហ ១២:១
**១០:១៦** ច អរ ៨:៦
**១០:២០** ឆ ១រប ២៤:១៥
**១០:២៣** ជ នហ ៧:២
**១០:២៨** ឈ ទដ ១៣៥:១ ញ ២រប ៦:២៦ នហ ៩:២
**១០:២៩** ដ ជន ៥:២១ ទដ ១១៩:១០៦
**១០:៣០** ឋ នក ៣៤:១៦ នហ ១៣:២៣
**១០:៣១** ឌ នហ ១៣:១៦,១៨ យរ ១៧:២៧ អគ ២៣:៣៨ អម ៨:៥ ឍ នក ២៣:១១ លវ ២៥:១-៧ ណ ចទ ១៥:១
**១០:៣៣** ត លវ ២៤:៦ ថ ជន ១០:១០ ទដ ៨១:៣ ១:១៤ ទ ២រប ២៤:៥

ម៉ូសេ ជាអ្នកបំរើទ្រង់ ហើយឱ្យរក្សានឹងប្រព្រឹត្តតាមគ្រប់
ទាំងក្រិត្យក្រមរបស់ព្រះយេហូវ៉ា ជាព្រះអម្ចាស់នៃយើង
រាល់គ្នា ព្រមទាំងច្បាប់យុត្តិធម៌ និងបញ្ញត្តទ្រង់ផង
៣០ហើយថាយើងមិនឱ្យកូនស្រីយើងទៅសាសន៍ទាំងប៉ុន្មាន
ដែលនៅក្នុងស្រុក ឬយកកូនស្រីរបស់គេមកឱ្យកូនប្រុស
យើងឡើយ[ឋ] ៣១ហើយបើសាសន៍ដទៃ ដែលនៅក្នុងស្រុក
គេយកទំនិញ ឬស្រូវអង្ករអ្វីមកលក់ នៅថ្ងៃឈប់សំរាក[ឌ]
នោះយើងមិនព្រមទិញពីគេនៅថ្ងៃនោះ ឬនៅថ្ងៃបរិសុទ្ធ
ណាឡើយ ហើយថាយើងរាល់គ្នានឹងផ្អាក ទុកឆ្នាំទី៧[ឍ]
ព្រមទាំងលើកលែងទារបំណុលទាំងអស់ផង[ណ] ។
៣២មួយទៀត យើងរាល់គ្នាក៏តាំងច្បាប់ ឱ្យត្រូវបង់១
ភាគក្នុង៣ ក្នុង១រៀលរាល់តែឆ្នាំ សំរាប់ការងារព្រះ
វិហាររបស់ព្រះនៃយើងរាល់គ្នា ៣៣ជាដំឡៃនៃនំបុ័ងតាំង
ទុក[ត]ដង្វាយម្សៅដែលថ្វាយជានិច្ច និងដង្វាយដុតជានិច្ច
ហើយនៅថ្ងៃឈប់សំរាក ថ្ងៃចូលខែ[ថ] និងថ្ងៃបុណ្យ មាន
កំណត់ទាំងប៉ុន្មាន ព្រមទាំងរបស់បរិសុទ្ធ ដង្វាយលោះ
បាបដែលថ្វាយឱ្យធួននឹងបាបពួកអ៊ីស្រាអែល និងគ្រប់ទាំង
ការងារក្នុងព្រះវិហារ របស់ព្រះនៃយើងរាល់គ្នាទាំង
អស់ផង[ទ] ៣៤យើងរាល់គ្នា ជាពួកសង្ឃពួកលេវី និងពួក
បណ្ដាជនក៏ចាប់ឆ្នោត[ធ]ពីដំណើរដង្វាយឧស[ន] ដើម្បីនឹងយក
មកក្នុងព្រះវិហាររបស់ព្រះនៃយើង តាមវង្សរបស់ឪពុក
យើង តាមពេលកំណត់រាល់តែឆ្នាំ សំរាប់នឹងដុតនៅលើ
អាសនានៃព្រះយេហូវ៉ា ជាព្រះរបស់យើង ដូចមានសេចក្ដី

**១០:៣៤** ធ លវ ១៦:៨ ន នហ ១៣:៣១

**១០:៩-១៣** នៅក្នុងខ.នេះចង់និយាយថា ភាគច្រើននៃឈ្មោះពួកលេវី ដែលបាននិយាយនៅក្នុងខ.ទាំងនេះ ក៏បាននិយាយនៅក្នុង ៨:៧ ៩:៤-៥ ដែរ ។
**១០:១៤-២៧** ភាគច្រើននៃមនុស្សដែលនិយាយនៅកន្លែងនេះ ក៏មាននិយាយនៅក្នុង ៧:៦-៦៣ និង អរ ២:១-៦១ ដែរ ។
**១០:២៨** *ឯពួកបណ្ដាជនឯទៀត* ពួកអ្នកទាំងនោះគឺជាពួកអ្នកដែលមិនបានបោះត្រាដៅចំណាំ ពីការចុះសញ្ញាមាំមួននោះឡើយ (សូមធៀប ជាមួយ ៩:៣៨-១០:១) ។ *ពួកលេវី* សូមមើលសេចក្ដីផ្ដើមព្រះគម្ពីរលេវីវិន័យ ត្រង់ចំណុចចំណងជើង ។ *ពួកឆ្មាំទ្វារ* សូមមើលការពន្យល់ក្នុង អរ ២:៤២ ។ *ព្រមទាំងប្រពន្ធ និងកូនប្រុសកូនស្រីគេ* សូមមើល ៨:២ ។
**១០:៣១-៣៣** នៅត្រង់កន្លែងនេះ ប្រហែលជាលោកនេហេមាគាត់ចែងក្បួនច្បាប់នេះឡើងដើម្បី កែតម្រង់ពីការរំលោភបំពាន់ច្បាប់ដែលមាននិយាយនៅក្នុង ១៣:១៥-២២ ។
**១០:៣១** *មកលក់ នៅថ្ងៃឈប់សំរាក* ទោះបីនៅក្នុង កន ២០:៨-១១ ចទ ៥:១២-១៥ មិនបានចែង មិនឱ្យប្រកបរបរក្នុងថ្ងៃឈប់សម្រាកក៏ដោយ តែសូមមើល យរ ១៧:១៩-២៧ អម ៨:៥ ។ *ឆ្នាំទី៧ ព្រមទាំងលើកលែងទារបំណុលទាំងអស់ផង* សូមមើលការព្យល់ លវ ២៥:៤ ។
**១០:៣២** *១ភាគក្នុង៣* នៅក្នុងព្រះគម្ពីរ នក ៣០:១៣-១៤ បាននិយាយថា ពួកគេអ្នកដែលមានអាយុពី២០ឆ្នាំ ឬលើសពីនេះត្រូវបង់៥កាក់ម្នាក់ជា "ដង្វាយថ្វាយព្រះយេហូវ៉ា" ទុកដូចជាតម្លៃនៃការប្រោសលោះ ។ នៅសម័យកាលក្រោយមកទៀត ស្ដេចយ៉ូសៀស គាត់យកដង្វាយទាំងនោះប្រើប្រាស់ក្នុងការសាងសង់ព្រះវិហារឡើងវិញ (សូមមើលក្នុង ២រប ២៤:៤-១៤) ។ នៅក្នុងគ្រាសញ្ញាថ្មី ពួកជនជាតិយូដាគ្រប់ទីកន្លែងទាំងអស់គេបានផ្ញើប្រាក់ចំនួន៥កាក់ ដើម្បីជួយដល់កិច្ចការងារនៅព្រះវិហារក្រុងយេរូសាឡិម (សូមមើលក្នុង មថ ១៧:២៤) ។ ពាក្យសន្យាជាផ្លូវការណ៍ដែលបណ្ដាជនសន្យាថានឹងបង់១ភាគក្នុង៣ នៅក្នុងសម័យកាលលោកនេហេមា នោះប្រហែលបណ្ដាលពីបញ្ហាសេដ្ឋកិច្ចសម័យកាលនោះ ។
**១០:៣៣** *នំបុ័ង* សូមមើលការពន្យល់ លវ ២៤:៨ ។
**១០:៣៤** *ចាប់ឆ្នោត* សូមមើលក្នុង ១១:១ យហ ១:៧ ។ *ដង្វាយឧស* ទោះបីនៅក្នុងកណ្ឌគម្ពីរបញ្ញកណ្ឌ មិនបាននិយាយចំៗពីដង្វាយជាឧសក៏ដោយ ក៏មាននិយាយថា "ភ្លើងនៅលើអាសនាត្រូវតែឆេះជានិច្ចឥតរលត់ឡើយ" (សូមមើល លវ ៦:១២-១៣) ។ ដើម្បីឱ្យភ្លើងឆេះរហូតបាន ទាមទារត្រូវការផ្គត់ផ្គង់ឧស ។ លោកយ៉ូសែបហ្វីស គាត់បានកំណត់ថា បុណ្យដង្វាយឧស

កត់ទុកក្នុងក្រិត្យវិន័យ ៣៥ហើយឱ្យយកផលដំបូង ពីស្រែ
ចំការរបស់យើង និងផលដំបូង[ប]ពីឈើគ្រប់មុខ[ផ] មកឯព្រះ
វិហារនៃព្រះយេហូវ៉ារាល់ៗឆ្នាំ ៣៦ព្រមទាំងកូនច្បង[ព]
របស់ខ្លួនយើង និងរបស់សត្វយើងផង ដូចជាបានកត់ទុក
ក្នុងក្រិត្យវិន័យហើយ និងកូនច្បងក្នុងហ្វូងគោ ហ្វូងចៀម
របស់យើង មកឯព្រះវិហាររបស់ព្រះនៃយើង ឱ្យដល់
ពួកសង្ឃដែលធ្វើការងារក្នុងព្រះវិហាររបស់ព្រះនៃយើង[ភ]
៣៧ហើយឱ្យយកផលនៃម្សៅលាយដំបូង ដង្វាយលើកចុះ
ឡើង ផ្លែឈើគ្រប់មុខ ទឹកទំពាំងបាយជូរ និងប្រេង[ម] មកឱ្យ
ពួកសង្ឃ នៅក្នុងបន្ទប់ព្រះវិហាររបស់ព្រះនៃយើង ព្រម
ទាំងដង្វាយ១ភាគក្នុង១០[យ]ពីផលដីយើង មកឱ្យពួកលេវីផង[រ]
ដ្បិតនៅក្នុងទីក្រុងទាំងប៉ុន្មាន នោះគឺជាពួកលេវី ដែល
ទទួលយកដង្វាយ១ភាគ ក្នុង១០ពីផលនៃស្រែចំការយើង[ល]
៣៨ហើយពួកកូនចៅអើរ៉ុនដ៏ជាសង្ឃ ក៏នៅជាមួយនឹងពួក
កូនចៅលេវី ក្នុងកាលដែលគេទទួលយកដង្វាយ ១ភាគក្នុង
១០នោះដែរ រួចពួកលេវីត្រូវយក១ភាគក្នុង១០[វ] ពីដង្វាយ
១ភាគក្នុង១០នោះ មកឯព្រះវិហាររបស់ព្រះយេហូវ៉ា ជា
ព្រះនៃយើង ដាក់ក្នុងបន្ទប់ ជាឃ្លាំងនៃព្រះវិហារដែរ
៣៩ដ្បិតពួកកូនចៅអ៊ីស្រាអែល ព្រមទាំងពួកកូនចៅលេវី
ត្រូវយកដង្វាយលើកចុះឡើង ពីស្រូវទឹកទំពាំងបាយជូរ និង
ប្រេងមកដាក់ក្នុងបន្ទប់ ជាកន្លែងដែលទុកគ្រឿង ប្រដាប់
របស់ទីបរិសុទ្ធទាំងប៉ុន្មាន ហើយពួកសង្ឃដែលធ្វើការងារ
ពួកឆ្មាំទ្វារ និងពួកចំរៀងក៏នៅទីនោះដែរ យើងរាល់គ្នា
មិនព្រមបោះ បង់ចោលព្រះវិហាររបស់ព្រះនៃយើង
ឡើយ[ស] ។

**១០:៣៥** ប នក ២២:២៩ ជន ១៨:១២ ផ ចទ ២៦:១-១១
**១០:៣៦** ព នក ១៣:២ ជន ១៨:១៤-១៦ ភ នហ ១៣:៣១
**១០:៣៧** ម ជន ១៨:១២ យ លវ ២៧:៣០ ជន ១៨:២១ រ ចទ ១៤:២២-២៩ ល អរ ៤៤:៣០
**១០:៣៨** វ ជន ១៨:២៦
**១០:៣៩** ស នហ ១៣:១១,១២
**១១:១** ក នហ ៧:៤ ខ អស ៤៨:២ ៥២:១ ៦៤:១០ សក ១៤:២០-២១ គ នហ ៧:៧៣
**១១:៣** ឃ អរ ២:១
**១១:៤** ង អរ ២:៧០ ច អរ ១:៥

## អ្នកចូលមកនៅថ្មីក្នុងក្រុងយេរូសាឡិម

*១១:៣-១៩ - ១រប ៩:១-១៧*

**១១** ១ឯពួកប្រធានក្នុងបណ្ដាជន នោះក៏នៅក្នុងក្រុង
យេរូសាឡិម ហើយពួកបណ្ដាជនឯទៀត គេចាប់ឆ្នោតយក
១នាក់ក្នុង១០ ឱ្យមកនៅក្រុងយេរូសាឡិម[ក] ជាទីក្រុងបរិសុទ្ធ
ដែរ[ខ] ហើយ៩នាក់ ឱ្យនៅអស់ទាំងទីក្រុងឯទៀត[គ] ២ពួក
បណ្ដាជនក៏ឱ្យពរដល់មនុស្សទាំងប៉ុន្មាន ដែលប្រគល់ខ្លួន
ឱ្យមកនៅក្រុងយេរូសាឡិម ដោយស្ម័គ្រពីចិត្ត ។
៣នេះជាពួកនាយក្នុងខេត្ត ដែលអាស្រ័យនៅក្រុង
យេរូសាឡិម ឯទីក្រុងនៃស្រុកយូដាឯទៀត នោះគ្រប់គ្នាក៏
នៅក្នុងកេរ្តិ៍អាករ ត្រង់ទីក្រុងរបស់គេរៀងខ្លួន គឺទាំងពួក
អ៊ីស្រាអែល ពួកសង្ឃ ពួកលេវី ពួកនេធីនិម និងកូន
ចៅរបស់ពួកអ្នកបំរើរបស់សាឡូម៉ូនផង[ឃ] ៤ឯនៅក្នុងក្រុង
យេរូសាឡិម[ង] នោះមានពួកកូនចៅយូដា និងពួកកូនចៅ
បេនយ៉ាមីន[ច]ខ្លះដែរ ខាងកូនចៅយូដា មានអ័ថាយ៉ា ជា
កូនអ៊ូស៊ីយ៉ា ដែលជាកូនសាការីៗ ជាកូនអ័ម៉ារាៗជាកូន
សេផាធាៗជាកូនម៉ាលេលាល នេះក្នុងពួកកូនចៅពេរេស

គឺប្រព្រឹត្តទៅនៅថ្ងៃទី១៤ នៃខែទី១៥ ។

**១០:៣៥** *ផលដំបូងពីផ្លែឈើគ្រប់មុខ* ពួកគេបានយកផលនោះមកក្នុងទីបរិសុទ្ធ ដើម្បីឧបត្ថម្ភដល់ពួកសង្ឃ និងពួកលេវី(សូមមើលការពន្យល់ក្នុង នក ២៣:១៩ ជន ១៨:១៣ ចទ ២៦:១-១១ អគ ៤៤:៣០) ។

**១០:៣៦** *កូនច្បង* សូមមើលការពន្យល់ក្នុង នក ១៣:១៣ ។

**១០:៣៧** *បន្ទប់* មន្ទីរប្រជុំដែលមាននៅក្នុងព្រះវិហារត្រូវបានគេប្រើធ្វើជាបន្ទប់ដើម្បីផ្ទុកប្រាក់ មាស និងគ្រឿងប្រដាប់បរិសុទ្ធ (សូមធៀបជាមួយ ខ. ៣៨-៣៩ ១២:៤៤ ១៣:៤-៥,៩ អរ ៨:២៨-៣០) ។ *ទឹកទំពាំងបាយជូរ* សូមមើលការពន្យល់ក្នុង ចទ ៧:១៣ ។ ទោះបីជានៅក្នុងភាសាហេព្រើរពាក្យនេះគឺសំដៅលើផ្លែទំពាំងបាយជូរ១ចង្កោមដែលពេញទៅដោយទឹកក៏ដោយ(សូមមើលក្នុង អស ៦៥:៨ មីក ៦:១៥) ក៏វាអាចនិយាយថា វាជាទឹកទំពាំងបាយជូរបានដែរ(សូមមើល ហស ៤:១១) ។ *១ភាគក្នុង១០* សូមមើលការពន្យល់ក្នុង លប ១៤:២០ ២៨:២២ លវ ២៧:៣០ អម ៤:៤ ។ *ពួកលេវី* ដង្វាយ១ភាគក្នុង១០ដែលពួកគេថ្វាយ គឺដើម្បីជួយឧបត្ថម្ភដល់ពួកលេវី (សូមមើលការពន្យល់ ១៣:១២-១៣ ជន ១៨:២១-៣២) ។

**១០:៣៩** អត្ថន័យនៅក្នុងខ.នេះសូមមើល ១៣:១១ ។ *យើងរាល់គ្នាមិនព្រមបោះបង់ចោល* នៅក្នុងព្រះគម្ពីរហាកាយ(សូមមើល ហក ១:៤-៩) បាននិយាយទាស់នឹងបណ្ដាជនថា ពួកគេបានបោះបង់ចោលព្រះវិហារនៃព្រះយេហូវ៉ា ។

**១១:១** *ចាប់ឆ្នោត* សូមមើលការពន្យល់ក្នុង ១០:៣៤ ។ ជានិច្ចកាល ឆ្នោតនោះគឺគេធ្វើឡើងពីដុំថ្មតូចៗ ឬចំរៀកឈើ ហើយពេលខ្លះទៀតគេយកព្រួញធ្វើជាឆ្នោត(សូមមើល អគ ២១:២១) ។ *១នាក់ក្នុង១០ ឱ្យមកនៅក្នុងក្រុងយេរូសាឡិម* លោកនេហេមាគាត់បានដឹងថា នៅទីក្រុងមានមនុស្សរស់នៅតិច ដូច្នេះគាត់ក៏ចាប់ផ្ដើមបង្ខំពួកសង្ឃ និងពួកលេវីដែលរស់នៅក្រៅក្រុងឱ្យមករស់នៅក្នុងទីក្រុង ត្បិតអីលោកនេហេមាគាត់នឹងរៀបចំផ្ទះសំបែងឱ្យពួកគេដោយគាត់ជាអ្នកចំណាយលើការសាងសង់នេះ ហើយ "ការបង្កើនមនុស្សមករស់នៅទីក្រុងនេះ ក៏ដើម្បីកសាងស្ថាបនាប្រទេសក្រិក និងទីក្រុងជាច្រើន" ។ ពួកគេត្រូវបានបង្ខំឱ្យចាកចេញពីទីជនបទ មករស់នៅក្នុងទីក្រុងពួកសាសន៍ដទៃគេបានស្នាក់អាស្រ័យនៅក្នុងស្រុកទីបេរាស ក្នុងដែនសមុទ្រកាលីឡេ និងបន្តរស់នៅរហូតដល់គ្រាហេរ៉ូឌ អាន់ទីប៉ាស់ក្នុងឆ្នាំ១៨ នៃគ.ស *ទីក្រុងបរិសុទ្ធ* សូមមើលក្នុង អស ៤៨:២ ដយ ៩:២៤ មថ ៤:៥ ២៧:៥៣ វវ ១១:២ ហើយធៀបជាមួយ យអ ៣:១៧ ។

**១១:២** នៅពេលបន្ថែមពួកអ្នកដែលបានចាប់ឆ្នោតថែម ទៀតឱ្យមករស់នៅក្នុងក្រុង (សូមមើល ខ.១) នោះមានពួកគេខ្លះបានស្ម័គ្រចិត្តមិនព្រមចូលរួមក្នុងការចាប់ឆ្នោតនោះឡើយ ប៉ុន្តែភាគច្រើននៃពួកគេគឺចូលចិត្តរស់នៅក្នុងស្រុករបស់គេវិញ ។

**១១:៣-១៩** បញ្ជីឈ្មោះនៃពួកមនុស្សដែលបានធ្វើជំរឿននៅទីនេះ គឺមានចំនួនប្រហាក់ប្រហែលគ្នានឹងបញ្ជីជំរឿនដែលបានធ្វើក្នុង ១រប ៩:២-២១

៥និងម្អាសេយ៉ា ជាកូនបារូក ដែលជាកូនកុល–ហូសេ។
ជាកូនហាសាយ៉ា។ជាកូនអ័ដាយ៉ា។ជាកូនយ៉ូយ៉ារីប។ជាកូន
សាការី។ជាកូនស៊ីឡូនី ៦អស់ទាំងកូនចៅរបស់ពេរេស
ដែលនៅក្រុងយេរូសាឡិម នោះមានមនុស្សក្លាហានចំនួន
៤៦៨នាក់ ។
៧ឯពួកកូនចៅរបស់បេនយ៉ាមីន គឺសាលូវ ជាកូន
មស៊ូឡាម ដែលជាកូនយ៉ូអេឌ។ជាកូនពេដាយ៉ា។ជាកូន
កូឡាយ៉ា។ជាកូនម្អាសេយ៉ា។ជាកូនអ៊ីធាល។ជាកូនយេសា
យ៉ា ៨ហើយបន្ទាប់នឹងគាត់ នោះមានកាបាយ និងសាឡាយ
រួមទាំងអស់មាន៩២៨នាក់ ៩ហើយយ៉ូអែល ជាកូនស៊ីកគ្រី
លោកជាអ្នកត្រួតលើគេ និងយូដាជាកូនសេនួរ លោកជា
ភូឈ្មួយនៃទីក្រុង ។
១០ក្នុងពួកសង្ឃ នោះមានយេដាយ៉ា ជាកូនយ៉ូយ៉ារីប និង
យ៉ាគិន ១១សេរ៉ាយ៉ា[ឆ] ជាកូនហ៊ីលគីយ៉ា ដែលជាកូន
មស៊ូឡាម។ជាកូនសាដុក។ ជាកូនមេរ៉ាយ៉ូត។ជាកូនអ័ហ៊ីទូប[ជ]
ដែលជាមេត្រួតលើព្រះវិហារនៃព្រះ ១២ព្រមទាំងពួកបង
ប្អូនគេ ដែលធ្វើការនៅព្រះវិហារ ទាំងអស់មាន៨២២
នាក់ ហើយមានអ័ដាយ៉ា ជាកូនយេរ៉ូហាំ ដែលជាកូន
ពេឡាលា។ជាកូនអាំស៊ី។ជាកូនសាការី។ជាកូនផាសហើរ។
ជាកូនម៉ាលគា ១៣ហើយពួកបងប្អូនលោកដែលជាពួកលើ
វង្សរបស់ឪពុកគេ រួមទាំងអស់ មាន២៤២នាក់ ហើយមាន
អ័ម៉ាសាយ ជាកូនអ័សារាល ដែលជាកូនរបស់អ័ហាសាយ។
ជាកូនមស៊ីលេម៉ូត។ជាកូនអ៊ីមមេរ ១៤ហើយពួកបងប្អូនគេ
ជាអ្នកខ្លាំងពូកែមានចិត្តក្លាហាន រួមទាំងអស់មាន១២៨
នាក់ ឯអ្នកដែលត្រួតលើគេ គឺសាបឌាល ជាកូនកេដូលីម ។
១៥ក្នុងពួកលេវី មានសេម៉ាយ៉ា ជាកូនហាស៊ូប ដែល
ជាកូនរបស់អាសរីកាម។ជាកូនហាសាបយ៉ា។ជាកូនប៊ូនី
១៦ព្រមទាំងសាបថាយ[ឈ] និងយ៉ូសាបាឌ[ញ] ជាពួកមេក្នុងពួក
លេវី ដែលត្រួតត្រាលើការងារខាង ក្រៅព្រះវិហារនៃព្រះ
១៧ហើយម៉ាថានា[ដ] ជាកូនមីកា ដែលជាកូន សាប់ឌី។ជាកូន
អេសាភ[ឋ]។ជាមេនាំគេ ក្នុងការអរព្រះគុណកំពុងដែល
អធិស្ឋាន និងបាប៊ូគា ជាអ្នកបន្ទាប់ក្នុងពួកបងប្អូនខ្លួន ហើយ
អាប់ដា ជាកូនសាំមួរដែលជាកូនកាឡាល។ជាកូនយេឌូថិន[ឌ]
១៨ឯពួកលេវីទាំងប៉ុន្មាន ដែលនៅក្នុងក្រុងបរិសុទ្ធ[ឍ] នោះ
មាន២៨៤នាក់ ។
១៩ឯពួកឆ្មាំទ្វារ នោះមានអ័គូប ថាលម៉ូន និងបងប្អូនគេ
ដែលចាំយាមនៅមាត់ទ្វារផ្សេងៗ ទាំងអស់មាន១៧២នាក់
២០ឯពួកអ៊ីស្រាអែល ខាងពួកសង្ឃ និងពួកលេវីដែលសល់
គេនៅអស់ទាំងទីក្រុង ក្នុងស្រុកយូដា គ្រប់គ្នាតាមរដកគេ
រៀងខ្លួន ២១តែពួកនេធីនិម[ណ] គេនៅត្រង់អូផែល មានស៊ីហា
និងគីសប៉ា ជាអ្នកត្រួតលើគេ ។
២២ឯអ្នកដែលត្រួតលើពួកលេវី នៅក្រុងយេរូសាឡិម
នោះគឺអ៊ូស៊ី ជាកូនបានី ដែលជាកូនហាសាបយ៉ា។ជាកូន
ម៉ាថានា[ត]។ជាកូនមីកា ក្នុងពួកកូនចៅអេសាភ ដែលជា
ពួកចំរៀង ជាអ្នកត្រួតត្រាលើកិច្ចការ ក្នុងព្រះវិហារនៃព្រះ
២៣ដ្បិតមានច្បាប់ដែលស្តេចបានតាំងពីដំណើរ ពួកនោះ

**១១:១១** ឆ ២ពវ ២៥:១៨ អរ ២:២ ជ អរ ៧:២
**១១:១៦** ឈ អរ ១០:១៥ ញ អរ ៨:៣៣
**១១:១៧** ដ ១របា ៩:១៥ នហ ១២:៨ ឋ ២របា ៥:១២ ឌ ១របា ២៥:១
**១១:១៨** ឍ វវ ២១:២
**១១:២១** ណ អរ ២:៤៣ នហ ៣:២៦
**១១:២២** ត ១របា ៩:១៥

ដែរ ដែលជាបញ្ជីជីរឿនលើកដំបូងចំពោះពួកអ្នកដែលមកស្នាក់នៅក្នុងក្រុងយេរូសាឡិម បន្ទាប់ពីពួកគេរួចពីសណ្ឋានជាឈ្លើយនៅបាប៊ីឡូនវិញ ។ ប្រហែលជាពាក់កណ្តាលនៃឈ្មោះមនុស្ស ដែលបានកត់ចុះក្នុងបញ្ជីទី២ (ខ.៧–៩) គឺមានដូចគ្នានឹងជីរឿនក្នុង ១របា ៩:២–២១ ដែរ ។

**១១:៨** *៩២៨* គេឃើញថាចំនួនមនុស្សដែលក្លាហានចេញពីអំបូរបេនយ៉ាមីន គឺមានចំនួន២ដងច្រើនជាងអំបូរផ្សេងៗទៀត ដូចជាចំនួនមនុស្សដែលក្លាហានចេញពីអំបូរយូដាដែរ (សូមមើលក្នុង ខ.៦) បានមករស់នៅក្នុងទីក្រុងយេរូសាឡិមដើម្បីការពារទីក្រុង ។

**១១:៩** *ភូឈ្មួយនៃទីក្រុង* សូមមើលការពន្យល់ក្នុង ២របា ៣៤:២២ (នៅភាសាហេព្រើរដែលនិយាយនៅក្នុងព្រះគម្ពីរ សផ ១:១០ បានបកប្រែថា "ឃុំទី២" ។ ដូចជា សផ ១:១១ ដែរគេបាននិយាយថា "ម៉ាថេក" ប្រហែលឈ្មោះស្រុក "ទីរ៉ូភីអន" (Tyropeoen) ដែលជាឃុំទី២ស្ថិតនៅក្រៅទីក្រុងដែលទើប នឹងបង្កើតឡើង។ការកំណាយមួយបានបង្ហាញថា នៅក្រោយសតវត្សរ៍ទី៨ មុន គ.ស ទីក្រុងនេះស្ថិតនៅខាងក្រៅកំផែងក្រុង ។ នៅមុនពេលនេះវាត្រូវគេហៅជាកំផែងក្រុងដ៏ធំមួយ ដែលស្តេចហេសេគាបានកសាងឡើងក្នុងកំឡុងឆ្នាំ៧០០ មុន គ.ស (សូមមើលការពន្យល់ក្នុង ៣:៨) ។

**១១:១៦** *ការងារខាងក្រៅ* ការងារខាងក្រៅដែលបាននិយាយនៅកន្លែងនេះ គឺសំដៅលើកិច្ចការងារទាំងឡាយណាដែលនៅក្រៅព្រះវិហារ (សូមធៀបជាមួយ ១របា ២៦:២៩) ប៉ុន្តែវាក៏ទាក់ទងគ្នាខ្លះៗដែរ ។

**១១:១៧** *អេសាភ* សូមមើលការពន្យល់ក្នុង អរ ២:៤១ និងចំណងជើងព្រះគម្ពីរ ទំនុកដំកើង ៥០:៧៣–៨៣ ។ *យេឌូថិន* សូមមើលការពន្យល់ក្នុង ១របា ១៦:៤២ ២៥:១,៣ ២របា ៥:១២ ចំណងជើង ៣៩ ៦២ ៧៧ ។

**១១:១៨** *២៨៤* នេះគឺជាចំនួនដ៏តិចតួចមួយដែលគួរឱ្យកត់សំគាល់របស់ពួកលេវីបើប្រៀបជាមួយ ពួកសង្ឃគឺគេមានចំនួនរហូតដល់១១៩២នាក់ឯណោះ (ដោយយកចំនួន៨២២ នាក់និង២៤២ ព្រមទាំង១២៨ដែលនិយាយក្នុង ខ. ១២–១៣ បូកចូលគ្នា) (សូមមើលការពន្យល់ អរ ២:៤០) ។

**១១:២០** *តាមមរតកគេរៀងៗខ្លួន* ដោយព្រោះគេមរតករបស់គេមិនអាចលក់ដូរបានឡើយ ទោះបីជាដី ផ្ទះសំបែង ទំនិញផ្សេងៗទៀត ដែលគេម្នាក់ៗមានទោះបីជាបានមកដោយសារការច្បាំងដណ្តើមក្នុងសង្គ្រាម ឬ ជាមរតកមកពីដូនតាមក (សូមមើល លប ៣១:១៤ ជន ១៨:២១ ២៧:៧ ៣៤:២ ៣៦:៣ ១ពវ ២១:១–៤) ។

**១១:២១** *អូផែល* សូមមើលការពន្យល់ ៣:២៦ ។

**១១:២៣** *ច្បាប់ដែលស្តេចបានតាំង . . . ជាច្បាប់យ៉ាងតឹងរ៉ឹង* ស្តេចដាវីឌទ្រង់បានចែងច្បាប់យ៉ាងតឹងរ៉ឹងពីកិច្ចការងាររបស់ពួកលេវី និងពួកអ្នក

ជាច្បាប់យ៉ាងតឹងរ៉ឹង ឱ្យចែកស្បៀងអាហារដល់ពួក
ចំរៀង[ថ] តាមដែលគេត្រូវការរាល់ៗថ្ងៃ ២៤ហើយមាន
ពេថាហ៊ីយ៉ា ជាកូនមសេសាបេល ក្នុងពួកកូនចៅសេរ៉ាស[ទ]
ជាកូនយូដា លោកជាអ្នកជិនិតស្ដេច ក្នុងគ្រប់ការចំពោះ
ពួករាស្ត្រ ។
២៥ត្រង់ឯទីក្រុងទាំងប៉ុន្មាន និងស្រែចំការជុំវិញ នោះ
មានពួកយូដាខ្លះ នៅត្រង់គារយ៉ាត់-អើបា[ធ] និងដំបន់នៅ
ជុំវិញ នៅឌីបូន[ន] និងដំបន់នៅជុំវិញ នៅយេកាបសៀលនិង
ដំបន់នៅជុំវិញ ២៦នៅត្រង់យេសួរ ម៉ូឡាដា[ប] បេត-
ផាលែត[ផ] ២៧ហាសា-ស៊ូអាល[ព] បៀរ-សេបា[ភ] និងដំបន់
នៅជុំវិញ ២៨នៅស៊ីកឡាក់[ម] មេកូណា និងដំបន់នៅជុំវិញ
២៩នៅអេន-រីម៉ូន សូរ៉ាស់[យ] យ៉ារមុត[រ] ៣០សាណូអា[ល]
អាឌូឡាម[វ] និងដំបន់នៃក្រុងទាំងនោះ ឡាគីស[ស] និងស្រែ
ចំការនៅជុំវិញ អាសេកា[ហ] និងដំបន់នៅជុំវិញ ដូច្នេះ
គេបានតាំងទីលំនៅ ចាប់តាំងពីបៀរ-សេបា[ឡ] រហូតដល់
ច្រកភ្នំហ៊ីនណំម ៣១ហើយពួកកូនចៅបេនយ៉ាមីន គេនៅចាប់
តាំងពីកេបា[អ]រៀងទៅ គឺនៅមីកម៉ាស[ក] អៃយ បេត-អែល[ខ]
និងដំបន់នៅជុំវិញ ៣២និងនៅអានាថោត[គ] ណូប[ឃ] ហាណានា

**១១:២៣** ថ ១របា ១៥:១៦ នហ ៧:៤៤ **១១:២៤** ទ លប ៣៨:៣០ **១១:២៥** ធ លប ៣៥:២៧ ន ជន ២១:៣០ **១១:២៦** ប យស ១៥:២៦ ផ យស ១៥:២៧ **១១:២៧** ព យស ១៥:២៨ ភ លប ២១:១៤ **១១:២៨** ម ១សយ ២៧:៦ **១១:២៩** យ យស ១៥:៣៣ រ យស ១០:៣ ១៥:៣៥ **១១:៣០** ល យស ១៥:៣៤ វ យស ១៥:៣៥ ស យស ១០:៣ ១៥:៣៩ ហ យស ១០:១០ ឡ យស ១៥:២៨ **១១:៣១** អ យស ២១:១៧ អស ១០:២៩ ក ១សយ ១៣:២ ខ យស ១២:៩ **១១:៣២** គ យស ២១:១៨ អស ១០:៣០ យរ ១:១ ឃ ១សយ ២១:១

ចម្រៀង(សូមមើលការពន្យល់ក្នុង ១របា ជំពូក២៥) ។ ស្ដេចពើស៊ី ព្រះមានដារីយ៉ុសទី១ទ្រង់ក៏បានប្រោសប្រទានជាប្រាក់ខែដល់ពួកយូដា ជាហេតុធ្វើឱ្យពួកចាស់ទុំយូដា អាចនឹង"អធិស្ឋានឱ្យស្ដេច និងពួកព្រះរាជ្យបុត្រាស្ដេចបានព្រះជន្មចម្រើន"(សូមមើល អរ ៦:១០) ។ ប្រហែលជាស្ដេចពើស៊ីដែលមានព្រះនាមថា អ័ថាស៊ើកសេសទី១ ទ្រង់ក៏បានធ្វើដល់ពួកអ្នកចម្រៀងលេវីដូចគ្នា និងស្ដេចដារីយ៉ុសបានធ្វើចំពោះពួកយូដាដែរ ។

**១១:២៥-៣០** នៅក្នុងខ.ទាំងនេះអ្នកនិពន្ធគាត់បានលើកយកឈ្មោះទីក្រុងសំខាន់ៗមកនិយាយដែលដូចគ្នានឹងទីក្រុងទាំងប៉ុន្មានរបស់ពួកយូដាដែលបាននិយាយកាលពីគ្រាមុន ។ ឈ្មោះរបស់ពួកគេទាំងអស់នោះក៏មាននិយាយនៅក្នុងព្រះគម្ពីរយ៉ូស្វេជំពូក១៥ផងដែរ ដោយលើកលែងតែក្រុង ឌីបូន យេកាបសៀស (ប៉ុន្តែសូមមើល ក្រុងកាបសៀល ក្នុង យស ១៥:២១) យេសួរ មេកូណា និងអេន-រីម៉ូន(ប៉ុន្តែសូមមើលឈ្មោះក្រុង អាយីន និងរីម៉ូន ដែលនិយាយនៅក្នុង យស ១៥:៣២) ។ ទោះបីជាយ៉ាងណាក៏ដោយក៏ឈ្មោះទីក្រុងទាំងប៉ុន្មាននោះ មិនជាទូរលំទូរលាយណាស់ណាទេ ពីព្រោះទីក្រុងទាំងប៉ុន្មានដែលនិយាយនៅក្នុង ជំពូក៣ អរ ២:២១-២២ គឺមានមនុស្សរស់ នៅតិចតួចប៉ុណ្ណោះ។គេមិនបានរកឃើញឈ្មោះរូបបិយវត្ថុរបស់ពួកយូដានិយាយនៅ ខ.២៥-៣០ ឡើយ ។

**១១:២៥** *គារយ៉ាត់-អើបា* សូមមើលការពន្យល់ លប ២៣:២ ។ នៅក្នុងយុគសម័យកាលដែលប្រទេសនេះទទួលឥទ្ធិពលពីប្រទេសក្រិក ក្នុងអំឡុងពេលដែលពួកអេដំមគ្រប់គ្រង គេយកទីក្រុងនេះដាក់បញ្ចូលជាមួយក្រុងផ្សេងៗទៀតរបស់ពួកយូដា ។

**១១:២៦** *ម៉ូដាឡា* ទីក្រុងនេះស្ថិតនៅជិត បៀរ-សេបា ហើយសម័យកាលក្រោយមកទៀតទីក្រុងនេះត្រូវបានពួកអេដំមគ្រប់គ្រង ។ *បេត-ផាលែត* ទីក្រុង នេះមានន័យថា"ដំណាក់នៃទីជ្រកកោន" ដែលមានទីតាំងស្ថិតនៅក្បែរបៀរ-សេបា ។

**១១:២៧** *បៀរ-សេបា* សូមមើលការពន្យល់ក្នុង លប ២១:៣១ ។ ការកំណាយរករបស់អ្នកបុរាណវិទ្យាមួយ បានបង្ហាញថា ទីក្រុងបៀរ-សេបា នេះត្រូវបានស្ដេចសាន ហេរីប ជាស្ដេចស្រុកអាសស៊ើរវាយបំផ្លាញចោលក្នុងឆ្នាំ៧០១ មុន គ.ស ហើយទីក្រុងនេះត្រូវបានកសាងឡើងវិញ ក្នុងសម័យកាលដែលពួកពើស៊ីគ្រប់គ្រង ។

**១១:២៨** *ស៊ីកឡាក់* ទីក្រុងនេះត្រូវបានស្ដេច អ័គីសជាស្ដេចក្រុងកាថប្រទានឱ្យស្ដេចដាវីឌ (សូមមើល ១សយ ២៧:៦) ហើយត្រូវពួកអាម៉ាលេកវាយដណ្ដើមយកវិញ (សូមមើល ១សយ ៣០:១ យស ១៥:៣១) ។

**១១:២៩** *អេន-រីម៉ូន* ទីក្រុងនេះមានន័យថា"សំបូរដោយផ្លែទទឹម" ។ ទីក្រុងនេះស្ថិតនៅខាងជើងបំផុតដែលមានចំងាយប្រមាណជា ១៤,៤៨ គ.ម ពីទីក្រុង បៀរ-សេបា (សូមមើលការពន្យល់ក្នុង យស ១៥:៣២) ។ *សូរ៉ាស់* សូមមើលការពន្យល់ ១៣:២ ។ *យ៉ារមុត* ទីក្រុងនេះមានចំងាយប្រមាណជា ១២,៨៧ គ.ម ភាគខាងកើតបំផុតនៃទីក្រុង (Eleutheropo lish) ។ ទីក្រុងនេះគឺជាទីក្រុង១ក្នុងចំណោមទីក្រុងទាំង៥ របស់ប្រទេសកាណាន ដែលស្ថិតនៅភាគខាងត្បូង ហើយគេបានកសាងឡើងដើម្បីព្យាយាមបញ្ឈប់ការ វាយលុករបស់លោកយ៉ូស្វេ (សូមមើលការពន្យល់ក្នុង យស ១០:៣-៥) ។

**១១:៣០** *សាណូអា* នេះគឺជាឈ្មោះរបស់ភូមិមួយដែលស្ថិតនៅក្នុងស្រុកទំនាប ចន្លោះពីស្រុកយូដា និងស្រុកភីលីស្ទីន។មានមនុស្សម្នាក់ឈ្មោះសាណូអាក៏ជាអ្នកដែលបានចូលរួមរៀបកសាងទ្វារច្រកភ្នំ ឡើងវិញដែរ (សូមមើលក្នុង ៣:១៣) ។ ទីតាំងនេះបានបង្ហាញពីអត្តសញ្ញាណរបស់ស្រុកគីបេត-សានូ (Khirbet Zanu) ដែលមានចំងាយប្រមាណជា៤,៨២ គ.ម ភាគខាងត្បូងក្រុងបេត-សេមែស ។ *អាឌូឡាម* សូមមើលការពន្យល់ក្នុង លប ៣៨:១ ។ *ឡាគីស* សូមមើលការពន្យល់ក្នុង យស ១០:៣ និងការពន្យល់ក្នុង អស ៣៦:២ មីក ១:១៣ ។ *អាសេកា* សូមមើលការពន្យល់ក្នុង យរ ៣៤:៧ ។ *ច្រកភ្នំហ៊ីនណំម* គឺជាឈ្មោះភូមិមួយដែលស្ថិតនៅភាគខាងត្បូងក្រុងយេរូសាឡិម ។

**១១:៣១-៣៥** ភាគច្រើននៃទីក្រុងពួកបេនយ៉ាមីនដែលនិយាយ នៅកន្លែងនេះ ក៏មាននិយាយនៅក្នុង ៧:២៦-៣៨ អរ ២:២៣-៣៥ ។

**១១:៣១** *កេបា* សូមមើលក្នុង ១២:២៩ និង ១សយ ១៣:៣ ។ *មីកម៉ាស* សូមមើលការពន្យល់ក្នុង ១សយ ១៣:២ ។ *អៃយ* សូមមើលក្នុង យស៧:២ *បេត-អែល* សូមមើលការពន្យល់ក្នុង លប ១២:៨ យស ៧:២ អរ ២:២៨ អម៤:៤ ។

**១១:៣២** *អានាថោត* សូមមើលការពន្យល់ក្នុង យរ ១:១ ។ *ណូប* សូមមើលការពន្យល់ក្នុង ១សយ ២១:១ ។ *ហាណានា* ទីក្រុងនេះ ប្រហែលជាឈ្មោះរបស់ភូមិបេថានី ដែលមានន័យថា"ដំណាក់របស់ហាណានា"(សូមមើលការពន្យល់ មថ ២១:១៧)។

៣៣ហាសោរ[ង] រ៉ាម៉ា[ច] គីថែម[ឆ] ៣៤ហាឌីឌ សេបោម[ជ]
នេបាឡាត ៣៥ឡូឌ អូណូរ[ឈ] ហើយនៅក្នុងច្រកភ្នំពួកជាង
រចនា ៣៦ចំណែកខាងពួកលេវី នោះមានខ្លះដែលត្រូវខាង
ស្រុកយូដា គេបានទៅនៅខាងស្រុកបេនយ៉ាមីនវិញ ។

## ពួកសង្ឃ និងពួកលេវី

១២ ១រីឯពួកសង្ឃ[ក] និងពួកលេវី[ខ] ដែលឡើងមកជាមួយ
និងសូរ៉ូបាបិល[គ] ជាកូនសាលធាល[ឃ] ហើយនិងយេសួរ[ង]
គឺសេរ៉ាយ៉ា[ច]យេរេមា អែសរ៉ា ២អ័ម៉ារា ម៉ាលូក ហាធូស
៣សេកានា រេហ៊ូម ម្រេម៉ូត ៤អ៊ីដោ[ឆ] គីនេថោន អ័ប៊ីយ៉ា[ជ]
៥មីយ៉ាមីន ម្អាឌា ប៊ីលកា ៦សេម៉ាយ៉ា យ៉ូយ៉ារីប យេដាយ៉ា[ឈ]
៧សាលូវ អ័ម៉ុក ហ៊ីលគីយ៉ា និងយេដាយ៉ា នោះសុទ្ធតែជា
មេពួកសង្ឃ ហើយនិងបងប្អូនគេនៅក្នុងគ្រាយេសួរ ។
៨ឯពួកលេវី នោះមានយេសួរ[ញ] ប៊ីនុយ កាឌមាលសេរេ–
ប៊ីយ៉ា យូដា និងម៉ាថានា[ដ] គឺលោកនេះ និងបងប្អូនលោក
ដែលត្រួតលើការងារអរព្រះគុណ ៩ក៏មានបាកប៊ូគា និងអ៊ូនី
ជាបងប្អូនគេ ដែលឈរប្រទល់មុខនឹងអ្នកទាំងនោះ ក្នុង

**១១:៣៣** ង យស ១១:១ ច យស ១៨:២៥ ឆ ២សយ ៤:៣ **១១:៣៤** ជ ១សយ ១៣:១៨ **១១:៣៥** ឈ ១រប ៨:១២ **១២:១** ក នហ ១០:១–៨ ខ នហ ១០:៩ គ ១រប ៣:១៩ អរ ៣:២ សក ៤:៦–១០ ឃ អរ ៣:២ ង អរ ២:២ ច អរ ២:២ **១២:៤** ឆ ខ.១៦ សក ១:១ ជ ១រប ២៤:១០ លក ១:៥ **១២:៦** ឈ ១រប ២៤:៧ **១២:៨** ញ អរ ២:២ ដ នហ ១១:១៧

ការងាររបស់គេ ១០ឯយេសួរ លោកបង្កើតយ៉ូយ៉ាគិម។
បង្កើតអេលីយ៉ាស៊ីប។[ឋ] បង្កើតយ៉ូយ៉ាដា ១១យ៉ូយ៉ាដាបង្កើត
យ៉ូណាថាន ហើយយ៉ូណាថានបង្កើតយ៉ាឌួរ ។
១២នៅគ្រាយ៉ូយ៉ាគីម ក៏មានពួកសង្ឃ ជាកំពូលលើពួក
វង្សរបស់ឪពុកគេ ខាងវង្សសេរ៉ាយ៉ា មានមេរ៉ាយ៉ា ខាង
យេរេមា មានហាណានា ១៣ខាងអែសរ៉ា មានមស៊ូឡាម
ខាងអ័ម៉ារា មានយ៉ូហាណាន ១៤ហើយខាងមេលីគូរ មាន
យ៉ូណាថាន ខាងសេបានា មានយ៉ូសែប ១៥ខាងហារីម
មានអ័ឌណា ខាងមេរ៉ាយ៉ូត មានហេលកាយ ១៦ខាងអ៊ីដោ[ឌ]
មានសាការី ខាងគីនេថោន មានមស៊ូឡាម ១៧ខាង
អ័ប៊ីយ៉ា[ឍ] មានស៊ីកគ្រី ខាងមីនយ៉ាមីន គឺខាងម៉ូអាឌា
មានពីលថាយ ១៨ខាងប៊ីលកា មានសាំមួរ ខាងសេម៉ាយ៉ា
មានយ៉ូណាថាន ១៩ខាងយ៉ូយ៉ារីប មានម៉ាថ្នាយ ខាងយេ–
ដាយ៉ាមានអ៊ូស៊ី ២០ខាងសាឡាយ មានកាឡាយ ខាងអ័ម៉ុក
មានហេប៊ើរ ២១ខាងហ៊ីលគីយ៉ា មានហាសាបយ៉ា ហើយ

**១២:១០** ឋ អរ ១០:២៤ នហ ៣:២០ **១២:១៦** ឌ ខ.៤ **១២:១៧** ឍ ១រប ២៤:១០

**១១:៣៣** *គីថែម* ទីកន្លែងពិតប្រាកដរបស់ក្រុងនេះ មិនដឹងឡើយ ។

**១១:៣៤** *ហាឌីឌ* ទីក្រុងនេះមានចំងាយប្រមាណជា៤,៨២ ទៅ ៦,៣៤ គ.ម ភាគខាងជើងក្រុងឡូឌ (សូមមើលការពន្យល់ ៧:៣៧ អរ២:៣៣) ។

**១១:៣៥** *ឡូឌ* សូមមើល អរ២:៣៣ ។ *អូណូរ* សូមមើលការពន្យល់ ៦:២ *ច្រកភ្នំពួកជាងរចនា* សូមមើល ១រប ៤:១៤ ។ ច្រកភ្នំនេះគឺជាផ្លូវច្រកមួយមានទំហំវែងអន្លាយ ដែលស្ថិតនៅចន្លោះក្រុងឡូឌ និងក្រុងអូណូរ ។ តាមរយៈឈ្មោះនៃច្រកភ្នំនេះ ប្រហែលគេអាចដឹងថា ពួកព្យុកោរបស់ពួកភីលីស្ទីនកាលពីជំនាន់មុន គឺជាងលោហៈ (សូមមើលការពន្យល់ក្នុង ១សយ ១៣:១៩–២០) ។

**១២:១** *សូរ៉ូបាបិល ជាកូនសាលធាស* សូមមើលការពន្យល់ក្នុង អរ ៣:២,៨ ៥:២ និង ហាក ១:១ ។ *យេសួរ* យេសួរគាត់គឺជាមនុស្សម្នាក់ដែលបានរួចពីសណ្ឋានជាឈ្លើយនៅបាប៊ីឡូនវិញ ក្នុងឆ្នាំ៥៣៨,៥៣៧ មុន គ.ស (សូមមើល ខ.១០,២៦ ៧:៧ អរ២:២ និងការពន្យល់ ហាក ១:១ អគ ៣:១ ។ *អែសរ៉ា* លោកអែសរ៉ាដែលនិយាយនៅកន្លែងនេះ មិនមែនជាលោកអែសរ៉ា ដែលបាននិយាយនៅក្នុងគម្ពីរអែសរ៉ា ដែលជាអ្នកដឹកនាំក្នុងអំឡុងពេលនិរទេស ដែលនឹងវិលត្រឡប់ពីនិរទេសវិញនៅ៨០ឆ្នាំក្រោយមកទៀតនោះឡើយ ។

**១២:៧** *ជាមេពួកសង្ឃ* បំណែងចែកពួកសង្ឃទាំង២៤នាក់នេះ ជាក្រុមតូចៗបែបនេះ គឺមានតាំងពីសម័យកាលស្តេចដាវីឌមកម្ល៉េះ (សូមមើលក្នុង ១រប ២៤:៣,៧–១៩ និង ២៤:៤) ។ នៅក្នុងខ.១–៧ បាននិយាយថា មានមេនៃពួកសង្ឃទាំងអស់គឺ២២នាក់។ក្នុងកាលដែលឯកសារនិយាយថា មានពួកមេនៃសង្ឃរហូតដល់២៤បែបនេះ ប្រហែលដើម្បីបង្ហាញថានៅក្នុងទឹកដីបរិសុទ្ធមានសាលាប្រជុំច្រើន ។ ជាងនេះទៅទៀត មានតែការបែងចែកសិលាចារិកនេះជា២ផ្នែកប៉ុណ្ណោះ ដែលបញ្ជាប់បញ្ហានេះបានគឺ ទី១ សិលាចារិកចេញពីក្រុងអាសកាឡូនក្នុងឆ្នាំប្រមាណជា ១៩២០–១៩២៩ មុន គ.ស ហើយទី២ ចេញពីក្រុងកាសារា ក្នុងឆ្នាំ ១៩៦០–១៩៦៩ ។

**១២:៩** *ប្រទល់មុខនឹងអ្នកទាំងនោះ* សូមមើលក្នុង ខ.២៤ អរ ៣:១១ ហើយផ្ទៀបជាមួយ ២រប ៧:៦ ។ ពួកអ្នកចម្រៀងត្រូវបានគេបែងចែកជា២ក្រុមឱ្យឈរប្រទល់មុខគ្នា ។ *ការងារ* នៅក្នុងភាសាហេព្រើរពាក្យនេះគឺ មីសម៉ារ៉ុត (Mishamrot) គឺជាប្រភេទការងារមួយដែលបានដកស្រង់ចេញពីសៀវភៅហ្គាំរ៉ាន់ (Qumran) ដែលនៅក្នុងសៀវភៅនោះបានពណ៌នាយ៉ាងលំអិតពីកិច្ចការងាររបស់ពួកសង្ឃទាំងនោះ ។

**១២:១០** *យេសួរ* សូមមើលការពន្យល់ក្នុង ខ.១ ។ *យូយ៉ាគីម* សូមមើល ខ.១២,២៦ ។ *អេលីយ៉ាស៊ីប* សូមមើល ខ.២២–២៣ ។ អេលីយ៉ាស៊ីបគាត់គឺជាសម្តេចសង្ឃដែលបានជួយដល់កិច្ចការងារសាងសង់កំផែងក្រុងឡើងវិញ (សូមមើល ៣:១,២០–២១ ១៣:២៨) ។ មានសង្ឃម្នាក់ដែលមានឈ្មោះអេលីយ៉ាស៊ីប ត្រូវជាប់ទោសដោយព្រោះបានធ្វើឱ្យព្រះវិហារនៃព្រះត្រឡប់ជាស្មោគគ្រោកដោយព្រោះបានផ្តល់បន្ទប់ឱ្យទៅថូប៊ីយ៉ា ដែលជាពួកសាសន៍អាំម៉ូនស្នាក់អាស្រ័យ (មើល ១៣:៤,៤) ។ ទោះបីជាបែបនេះមែនក៏ដោយ ក៏គេមិនបានដឹងថា តើអ្នកទាំង២នេះជាមនុស្សតែ១ឬយ៉ាងណានោះទេ ។

**១២:១១** *យ៉ូណាថាន* ដោយព្រោះនៅក្នុង ខ.២២ បាននិយាយអំពីយ៉ូហាណានក្រោយ យ៉ូយ៉ាដា និងមុនយ៉ាដួរ ហើយនៅក្នុង ខ.២៣ បាននិយាយថា យ៉ូណាហានជាកូន"អេលីយ៉ាស៊ីប"នោះបានធ្វើឱ្យអ្នកខ្លះជឿថា "យ៉ូណាថាន"គឺជាវីរៈបុរសរបស់"យ៉ូហាណាន" ។ អ្វីដែលធ្វើឱ្យកាន់តែមានការស្មុគស្មាញជាងនេះទៅទៀតនោះ គឺលោកយ៉ូសែបហ្វីស បាននិយាយថា យ៉ូណាថាន ជាអ្នកបម្រើការងារក្នុងព្រះវិហារ ។

**១២:១២–២១** គេឃើញថានៅក្នុងខ.ទាំងនេះ គឺមានឈ្មោះគ្រប់ទាំងអស់នៃពួកសង្ឃដែលបាននិយាយនៅក្នុងខ.១–៧ (រេហ៊ូមដែលនិយាយនៅក្នុងខ.៣កាលពីមុនគាត់មានឈ្មោះថា ហារីមដែលនិយយនៅក្នុងខ.១៥ ។ មីយ៉ាមីនដែលនិយាយនៅក្នុងខ.៥ កាលពីដើមឡើយគាត់ឈ្មោះថា មីនយ៉ាមីនដែលនិយាយនៅក្នុង ខ.១៧) ។ ឈ្មោះបន្ទាប់ទៀតនេះ ពួកគេរស់នៅក្នុងសម័យ

ខាងយេដាយ៉ា មាននេថានេល ។
២២ចំណែកពួកលេវី ក្នុងគ្រាអេលីយ៉ាស៊ីប យ៉ូយ៉ាដា
យ៉ូហាណាន និងយ៉ាឌួរ នោះបានកត់ឈ្មោះពួកដែលជា
កំពូលលើវង្សរបស់ឪពុកគេ ព្រមទាំងពួកសង្ឃដែរ ដរាប
ដល់រាជ្យដារីយុស ជាស្តេចសាសន៍ពើស៊ី ២៣ពួកកូនចៅ
លេវីនោះ ដែលជាកំពូលលើវង្សរបស់ឪពុកគេបានកត់ទុក
ក្នុងសៀវភៅរបាក្សត្រហើយ ដរាបដល់គ្រាយ៉ូហាណាន
ជាកូនអេលីយ៉ាស៊ីប ២៤ឯពួកមេក្នុងពួកលេវី[ណ] នោះគឺ
ហាសាបយ៉ា សេរេប៊ីយ៉ា និងយេសួរ ជាកូនកាឌមាល
ហើយមានពួកបងប្អូនគេ ឈរប្រទល់មុខនឹងគេ ដើម្បីនឹង
សរសើរ ហើយអរព្រះគុណ ដោយ ពួកទល់មុខគ្នា តាម
បង្គាប់របស់ដាវីឌ ជាអ្នកសំណប់របស់ព្រះ[ត] ២៥ឯម៉ាថានា–
បាកប៊ូគា អូបាឌា មស៊ូឡាម ថាលម៉ូន និងអ័កគូប គេជា
អ្នកឆ្មាំទ្វារ ដែលចាំយាមនៅឃ្លាំងត្រង់មាត់ទ្វារ ២៦ពួកអ្នក
ទាំងនោះ មាននៅក្នុងគ្រាយ៉ូយ៉ាគីម ជាកូនរបស់យេសួរ
ដែលជាកូនយ៉ូសាដាក និងគ្រានេហេមា ជាចៅហ្វាយ
ទីក្រុង ហើយនិងគ្រាស្មៀនអែសរ៉ាដ៏ជាសង្ឃ ។

**១២:២៤** ណ អរ ២:៤០ ត ២រប ៨:១៤

**១២:២៧** ថ ចទ ២០:៥ ទ ២សយ ៦:៥ ធ ១រប ១៥:១៦,២៨ ២៥:៦ ទដ ៩២:៣

## ពិធីឆ្លងកំផែងក្រុងយេរូសាឡិម

២៧នៅគ្រាដែលគេធ្វើពិធីឆ្លង[ថ]កំផែងក្រុងយេរូសាឡិម
នោះគេស្វែងរកពួកលេវី ពីគ្រប់កន្លែងរបស់គេ នាំមក
ឯក្រុងយេរូសាឡិម ដើម្បីនឹងធ្វើបុណ្យឆ្លងនោះដោយ
អំណរព្រមទាំងមានពាក្យអរព្រះគុណ និងការចំរៀងផ្សំ
ដោយឈឹង[ទ] ពិណ និងស៊ុងផង[ធ] ២៨ឯកូនចៅរបស់ពួក
ចំរៀងគេក៏មូលគ្នាពីស្រុកជុំវិញក្រុងយេរូសាឡិម ហើយ
ពីអស់ទាំងភូមិនៃពួកនថូផា[ន] ២៩ពីបេត–គីលកាល ពីស្រុក
ស្រែចំការ កេបា និងអាសម៉ាវេតដែរ ពីព្រោះពួកចំរៀង
គេបានធ្វើភូមិ នៅព័ទ្ធជុំវិញក្រុងយេរូសាឡិម ៣០ពួកសង្ឃ
នឹងពួកលេវីបានញែកខ្លួនជាបរិសុទ្ធ រួចក៏ញែកពួកបណ្តា
ជន[ប] ព្រមទាំងទ្វារទាំងប៉ុន្មាន និងកំផែងផង ចេញជា
បរិសុទ្ធ ។
៣១គ្រានោះ ខ្ញុំបាននាំពួកអ្នកជាប្រធាន ក្នុងពួកយូដា
ឡើងទៅ លើកំផែង ក៏ដំរូវឱ្យមាន២ពួកធំៗ ដែល
ពោលពាក្យអរព្រះគុណ ហើយដង្ហែគ្នា ពួក១ទៀតខាង

**១២:២៨** ន ១រប ២:៥៤ ៩:១៦ **១២:៣០** ប នក ១៩:១០ យប ១:៥

កាលយ៉ូយ៉ាគីម(ខ.១២)គឺជាពួកសម្តេចសង្ឃដែលរស់នៅក្នុងចុងសតវត្សរ៍ទី៦ ឬដើមសតវត្សទី៥ មុន គ.ស ។

**១២:២២** *រាជ្យដារីយ៉ុស ជាស្តេចសាសន៍ពើស៊ី* ស្តេចដារីយ៉ុសដែលនិយាយនៅកន្លែងនេះ មិនមែនជាដារីយ៉ុសទី២ ដែលសោយរាជ្យក្នុងឆ្នាំ ៤២៣–៤០៣ មុន គ.ស ហើយក៏មិនមែនជាដារីយុសទី៣ ដែលគ្រប់គ្រងពីឆ្នាំ ៣៣៦–៣៣១ មុន គ.ស នោះដែរ ។

**១២:២៣** *ច្បាប់យ៉ាងតឹងរ៉ឹង* សូមធៀបជាមួយ ៧:៥ ។ ច្បាប់នេះប្រហែលនិយាយពីពង្សាវតារទាំងឡាយ ដែលបានបម្រើរការងារក្នុងព្រះវិហារ ។ សូមធ្វើការប្រៀបធៀបច្បាប់របស់ស្តេចពើស៊ី (អរ ៤:១៥ នអ ២:២៣ ៦:១ ១០:២) និង"សៀវភៅជាពង្សាវតារនៃពួកស្តេច"ដែលមាននិយាយនៅក្នុង ១–២ពង្សាវតារក្សត្រជាមួយច្បាប់តឹងរ៉ឹងដែលបាននិយាយនៅកន្លែងនេះ ។

**១២:២៦** *នេហេមា . . . អែសរ៉ា* សូមមើលការពន្យល់ ៨:៩ ។

**១២:២៧** *ពីធីឆ្លង* សូមមើលការពន្យល់ក្នុង អរ ៦:១៦ ។ *ឈឹង* សូមមើលការពន្យល់ អរ ៣:១០ ។ នៅត្រង់កន្លែងនេះចង់បង្ហាញថា ជានិច្ចកាលនៅពេលមានបុណ្យក្នុងព្រះអម្ចាស់ ប្រជាជនអ៊ីស្រាអែលគេតែងតែប្រើឈឹងលេងអបអរសាទរក្នុងពិធីនោះ(សូមមើលក្នុង ១រប ១៦:៤២ ២៥:១ ២រប ៥:១២ ២៩:២៥) ។ គំរូនៃការប្រើឈឹងលេងថ្វាយព្រះអម្ចាស់កាលពីសម័យមុន គឺមាននៅត្រង់ បេត–សេមែស និងនៅត្រង់ ថែល អាប់យូ ហាវ៉ឹម (Tell Abu Hawam) ។ *ពិណ* សូមមើលការពន្យល់ លប ៣១:២៧ ពិណគឺជាឧបករណ៍ភ្លេងដ៏ចម្បង ហើយសំខាន់ជាងគេក្នុងពិធីបុណ្យនៃព្រះអម្ចាស់(សូមមើលក្នុង ១សយ ១០:៥ ២សយ ៦:៥ ទដ ១៥០:៣) ។ ពិណកាលពីសម័យបុរាណ ត្រូវបានបង្កើតឡើងវិញ ដោយគេយកសំណល់ពិណដែលសល់ពីក្រុងអ៊ើរ ។ *ស៊ុង* ជាប្រភេទឧបករណ៍ភ្លេងដែលមានខ្សែ (សូមមើល ១រប ១៥:១៦ ដយ ៣:៥) ។

**១២:២៨** *ពួកនថូផា* ពួកគេគឺជាក្រុមមនុស្សដែលរស់នៅក្នុងភូមិថូផាដែលជាភូមិមួយនៅក្បែរភូមិបេថ្លេហិម (សូមមើល ៧:២៦) ។

**១២:២៩** *បេត–គីលកាល* ប្រហែលជាគីលកាលដែលនៅជិតក្រុងយេរីខូ (សូមមើលការពន្យល់ក្នុង យស ៤:១៩) ឬក៏ជាគីលកាលជាទីកន្លែងដែលហោរ៉ាអេលីយ៉ារស់នៅ(សូមមើល ២ពវ ២:១)ដែលមានចំងាយប្រមាណជា ១១,២៦ គ.ម ភាគខាងជើងក្រុងបេត–អែល ។

**១២:៣០** *ញែកខ្លួនជាបរិសុទ្ធ* សូមមើលការពន្យល់ក្នុង លវ ៤:១២ ។ ក្នុងអំឡុងពេលមានការកែទម្រង់ ពួកលេវីគេបាននិយាយថា គ្រប់ទាំងអស់នៃអ្នកដែលចូលក្នុងទីបរិសុទ្ធនៃព្រះត្រូវតែញែកខ្លួនជាបរិសុទ្ធ(សូមមើល ២រប ២៣:២៨) ហើយនិងព្រះវិហារក៏ត្រូវសម្អាតដែរ(២រប ២៩:១៥) ។ គោលបំណងចម្បងនៃពិធីញែកខ្លួនជាបរិសុទ្ធនេះ គឺដើម្បីបង្រៀនប្រជាជនឱ្យស្គាល់ពីភាពបរិសុទ្ធរបស់ព្រះយេហូវ៉ា និងដើម្បីញែកចេញជាស្អាតពីអំពើបាបទាំងអស់(សូមមើល លវ ១៦:៣០) ។

**១២:៣១** *ក៏ដំរូវឱ្យមាន២ពួកធំៗ* សូមមើលការពន្យល់ក្នុងខ.៣៨ ។ នៅក្នុងកន្លែងនេះចង់និយាយថា ប្រហែលក្បួនដង្ហែទាំងពួកធំៗនេះ បានចាប់ផ្តើមហែរចេញពីទ្វារច្រកភ្នំ(សូមមើលក្នុង ២:១៣,១៥ ៣:១៣)ដែលមានទីតាំងនៅក្បែរកំផែងក្រុងផ្នែកខាងលិច។លោកអែសរ៉ា គាត់គឺជាអ្នកដឹកនាំក្បួនដង្ហែលើកទី១ (សូមមើលក្នុង ខ.៣៦–៣៧) ដោយក្បួនដង្ហែនោះចេញដោយការបញ្ច្រាសទិស និងឆ្ពោះតម្រង់ឡើងលើកំផែងក្រុង។ក្បួនដង្ហែលើកទី២ជាក្បួនដង្ហែដែលមានលក្ខណៈស្របទិសក្រោមការដឹកនាំដោយលោកនេហេមា(សូមមើល ខ.៣៨) ។ ក្បួនដង្ហែទាំង២ នេះនឹងមកជួបគ្នានៅត្រង់ទ្វារគុក(សូមមើលក្នុង ខ.៣៩) ហើយគេក៏នាំគ្នាចូលក្នុងបរិវេណព្រះវិហារតែម្តង(សូមធៀបជាមួយ ទដ ១៤៨:១២–១៣) ។ *ខាងស្តាំ* បើនិយាយឱ្យចំទៅគឺ "ខាងត្បូង" ។ ដោយសារពួកកូនចៅរបស់សិមគេបានតម្រង់ឆ្ពោះទៅ

ស្តាំនៅលើកំផែង ដំរង់ទៅឯទ្វារចាក់សំរាម[ផ] ៣២មាន
ហូសាយ៉ានឹងពួកជាប្រធានលើពួកយូដាពាក់កណ្តាល គេ
ដើរតាមក្រោយ ៣៣ព្រមទាំងអ័សារា អែសរ៉ា មស៊ូឡាម
៣៤យូដា បេនយ៉ាមីន[ព] សេម៉ាយ៉ា និងយេរេមាដែរ ៣៥ហើយ
កូនចៅពួកសង្ឃ ខ្លះដែលកាន់ត្រែ[ភ] គឺសាការី ជាកូន
យ៉ូណាថាន ដែលជាកូនសេម៉ាយ៉ា។ ជាកូនម៉ាថានា។
ជាកូនមីកាយ៉ា។ ជាកូនសាគើរ។ជាកូនអេសាភ ៣៦និងពួក
បងប្អូនលោកគឺសេម៉ាយ៉ា អ័សារាល មីឡាឡាយ គីឡា
ឡាយ ម៉ាអាយ នេថានេល យូដា និងហាណានី ដែលកាន់
ប្រដាប់ភ្លេង[ម] របស់ដាវីឌ ជាអ្នកសំណប់របស់ព្រះ[យ] ហើយ
មានស្មៀន អែសរ៉ា[រ] ជាអ្នកនាំមុខ ៣៧គេក៏ដង្ហែគ្នាតាមទ្វារ
ក្បាលទឹក[ល] ដំរង់ទៅខាងមុខ ឡើងជណ្តើរនៃទីក្រុងដាវីឌ
តាមកន្លែងឡើងទៅលើកំផែង ត្រង់ពីលើព្រះរាជដំណាក់
ដាវីឌ រហូតទៅដល់ទ្វារទឹក[វ] ដែលនៅខាងកើត ៣៨ឯពួក១
ទៀត ដែលពោលពាក្យអរព្រះគុណ នោះក៏ដង្ហែទៅជួបគ្នា
ខ្ញុំក៏ដើរតាមពួកនេះ មានទាំងបណ្តាជនពាក់កណ្តាលនៅ
លើកំផែង ត្រង់ពីលើប៉មគុកភ្លើង[ស] រហូតដល់ទីខ្នងកំផែងធំ
ទូលាយ[ហ] ៣៩ហើយពីលើទ្វារអេប្រាអិម[ឡ] និងទ្រង់ទ្វារ
ចាស់[អ] ទ្វារត្រី[ក] ប៉មហាណានាល[ខ] និងប៉មហាមេអា[គ] រហូត
ដល់ទ្វារចៀម[ឃ] រួចដល់ទ្វារគុកនោះ ក៏ឈប់ឈរនៅ
៤០យ៉ាងនោះ ពួកអ្នកដែលពោលពាក្យអរព្រះគុណ ក្នុងព្រះ
វិហារនៃព្រះ ទាំង២ពួកក៏ឈរនៅដំរៀបគ្នា មានទាំងខ្ញុំ
នឹងពួកមេពាក់កណ្តាល ដែលនៅជាមួយនឹងខ្ញុំផង ៤១ក៏មាន
ពួកសង្ឃ គឺអេលាគីម ម្អាសេយ៉ា មីនយ៉ាមីន មីកាយ៉ា
អេលីយ៉ូនាយ សាការី និងហាណានា ដែលកាន់ត្រែ
ដែរ ៤២ហើយម្អាសេយ៉ា សេម៉ាយ៉ា អេលាសារ អ៊ូស៊ី
យ៉ូហាណាន ម៉ាលគា អេឡាំ និងអេស៊ើរដែរ ឯពួកចំរៀង
គេក៏ច្រៀងឡើងជាខ្លាំង តាមយីសរ៉ាហ៊ា ដែលនាំមុខគេ
៤៣នៅថ្ងៃនេះ គេក៏ថ្វាយដង្វាយយ៉ាងសន្ធឹក ហើយមានសេច
ក្តីរីករាយ ពីព្រោះព្រះទ្រង់បានធ្វើឱ្យគេអរសប្បាយយ៉ាង
ខ្លាំង ឯពួកស្រី។ និងកូនក្មេង ក៏សប្បាយព្រមគ្នា ដល់ម្ល៉េះ
បានជាសេចក្តីអំណរដែលមាននៅក្នុង យេរូសាឡិម បានឮ
ផ្សាយទៅឆ្ងាយ ។

៤៤នៅថ្ងៃនោះ គេក៏តាំងមនុស្សត្រួតត្រាលើបន្ទប់[ង] ដែល
សំរាប់របស់ថ្លៃវិសេស ដង្វាយលើកចុះឡើង ផលដំបូង
និងដង្វាយ១ភាគក្នុង១០[ច] ដើម្បីនឹងប្រមូលចំណែកដែល
ក្រិត្យវិន័យបានដំរូវឱ្យទុកសំរាប់ពួកសង្ឃ និងពួកលេវីពី
អស់ទាំងស្រែចំការ និងទីក្រុង មកទុកក្នុងបន្ទប់ទាំងនោះ
ដ្បិតពួកយូដាគេមានសេចក្តីអំណរចំពោះពួកសង្ឃនិងពួក
លេវី[ឆ] ដែលឈរនៅដំណែងគេ ៤៥ព្រមទាំងរក្សាបញ្ញើ
របស់ព្រះនៃគេ និងការងារញែកជាបរិសុទ្ធ ពួកចំរៀង
និងពួកឆ្មាំទ្វារក៏ធ្វើដូច្នោះដែរ តាមបង្គាប់ដាវីឌ[ជ] និង
សាឡូម៉ូន[ឈ] ជាព្រះរាជបុត្រាទ្រង់ ៤៦ដ្បិតកាលពីដើមក្នុងគ្រា
ដាវីឌ និងអេសាភ[ញ] នោះមានមេលើពួកចំរៀង ក៏មាន
ទំនុកច្រៀងសរសើរដំកើង[ដ] ហើយអរព្រះគុណដល់ព្រះ
៤៧ហើយនៅគ្រាសូរ៉ូបាបិល និងនេហេមា នោះពួកអ៊ីស្រា–
អែលទាំងអស់គ្នាក៏ថ្វាយចំណែកសំរាប់ពួកចំរៀង និងពួក
ឆ្មាំទ្វារ តាមដែលត្រូវការរាល់។ថ្ងៃ គេក៏លៃទុក១ចំណែក
ឱ្យពួកលេវី ហើយពួកលេវីក៏លៃ ទុក១ចំណែក ឱ្យពួកកូន
ចៅអើរ៉ុន[ឋ] ។

**១២:៣១** ផ នហ ២:១៣ **១២:៣៤** ព អរ ១:៥ **១២:៣៥** ភ អរ ៣:១០ **១២:៣៦** ម ១របា ១៥:១៦ យ ២របា ៨:១៤ រ អរ ៧:៦ **១២:៣៧** ល នហ ២:១៤ វ នហ ៣:២៦ **១២:៣៨** ស នហ ៣:១១ ហ នហ ៣:៨ **១២:៣៩** ឡ ២ពវ ១៤:១៣ អ នហ ៣:៦ ក ២របា ៣៣:១៤ ខ នហ ៣:១ គ នហ ៣:១ ឃ នហ ៣:១ **១២:៤៤** ង នហ ១៣:៤,១៣ ច លវ ២៧:៣០ ឆ ចទ ១៨:៨ **១២:៤៥** ជ ២របា ៨:១៤ ឈ ១របា ៦:៣១ ២៣:៥ **១២:៤៦** ញ ២របា ៣៥:១៥ ដ ២របា ២៩:២៧ ទដ ១៣៧:៤ **១២:៤៧** ឋ ចទ ១៨:៨

ទិសខាងកើត ដូច្នេះហើយខាងស្តាំដៃ គឺសំដៅលើទិសខាងត្បូង(សូមមើលក្នុង យស ១៧:៧ ១សយ ២៣:២៤ យប ២៣:៩) ។ *ទ្វារចាក់សំរាម* សូមមើលក្នុង ២:១៣ ។

**១២:៣៥** *ត្រែ* សូមមើលការពន្យល់ក្នុង អរ ៣:១០ ។ នៅក្នុងន័យនេះចង់បង្ហាញថា រាល់ក្រុមចម្រៀងនិមួយ។គឺមានពួកសង្ឃជាអ្នកផ្លុំត្រែ ហើយពួកលេវីលេងឧបករណ៍ភ្លេងផ្សេង។ទៀត ។ *អេសាភ* សូមមើលការពន្យល់ក្នុង ១១:១៧ ។

**១២:៣៧** *ទ្វារក្បាលទឹក* សូមមើលការពន្យល់ក្នុង ២:១៤ ។ *ទីក្រុងដាវីឌ* សូមមើល ៣:១៥ ២សយ ៥:៧ ។ *ព្រះរាជ្យដំណាក់ដាវីឌ* ព្រះរាជ្យដំណាក់នេះប្រហែលជាដំណាក់របស់ដាវីឌ ឬជាដំណាក់របស់សាឡូម៉ូនកាលពីសម័យមុន ។ *ទ្វារក្បាលទឹក* សូមមើលការពន្យល់ ៣:២៦ ។

**១២:៣៨** *អរព្រះគុណ* សូមមើលខ.៤០ ។ *ប៉មគុកភ្លើង* សូមមើលក្នុង ៣:១១ ។ *កំផែងធំទូលាយ* សូមមើល ៣:៨ ។

**១២:៣៩** *ទ្វារអេប្រាអិម* សូមមើលក្នុង ៣:៦ ៨:១៦ ។ *ទ្វារចាស់* សូមមើលក្នុង ៣:៦ ។ *ទ្វារត្រី* សូមមើលក្នុង ៣:៣ ។ *ប៉មហាណានាល និងប៉មហាមេអា រហូតដល់ទ្វារចៀម* សូមមើល ៣:១ ។ *ទ្វារគុក* សូមផ្ទៀបជាមួយ យរ ៣២:២ ។

**១២:៤៣** *ព្រះបានធ្វើឱ្យពួកគេអរសប្បាយយ៉ាងខ្លាំង* សូមមើលក្នុង ១របា ២៩:៩ ។ *ពួកស្រី។* សូមមើលក្នុង ៨:២ នក ១៥:២០ ។ *ផ្សាយទៅឆ្ងាយ* សូមមើលក្នុង អរ ៣:១៣ ហើយផ្ទៀបជាមួយ ១ពវ ១:៤០ ២ពវ ១១:១៣ ។

**១២:៤៤** *ពួកយូដាគេមានសេចក្តីអំណរ* នៅកន្លែងនេះចង់និយាយថាពួកបណ្តាជនទាំងអស់ គេមានអំណរចំពោះការថ្វាយដង្វាយលើកចុះឡើងទុកជាការឧបត្ថម្ភដល់ពួកសង្ឃ និងពួកលេវី (ផ្ទៀបជាមួយ ២កថ ៩:៧) ។ *ឈរនៅដំណែងគេ* សូមមើលការពន្យល់ក្នុង ចទ ១០:៨ ។

**១២:៤៦** *អេសាភ* សូមមើលការពន្យល់ ១១:១៧ ។

**១២:៤៧** *សូរ៉ូបាបិល* សូមមើលក្នុង អរ១:២ ។ *ថ្វាយ* នៅក្នុងកិរិយាស័ព្ទភាសាហេព្រើរចំពោះពាក្យនេះ គឺជាការប្រៀបផ្ទៀបចំពោះការថ្វាយដង្វាយ ។

## ការកែទម្រង់ចុងក្រោយរបស់លោកនេហេមា

**១៣** ១នៅថ្ងៃនោះឯង គេបានអានមើលក្នុងគម្ពីរ លោក
ម៉ូសេ នៅចំពោះបណ្ដាលជន ហើយគេប្រទះឃើញសេចក្ដី
ដែលចែងទុកមកថា ពួកសាសន៍អាំម៉ូន និងពួកសាសន៍
ម៉ូអាប់ មិនត្រូវចូលទៅក្នុងពួកជំនុំនៃព្រះឡើយ[ក] ២ដោយ
ព្រោះគេមិនបានរាក់ទាក់ទទួលពួកកូនចៅអ៊ីស្រាអែល
ដោយនំបុ័ងនឹងទឹកទេ គឺបានជួលបាឡាម[ខ] ឱ្យមកដាក់
បណ្ដាសាដល់គេវិញ[គ] ប៉ុន្តែព្រះនៃយើងរាល់គ្នា ទ្រង់បាន
បំផ្លាស់សេចក្ដីបណ្ដាសានោះឱ្យទៅជាពរវិញ[ឃ] ៣ដូច្នេះ
កាលគេបានឮក្រិត្យវិន័យនោះហើយ គេក៏ញែកពួកលាយ
ពូជចេញពីសាសន៍អ៊ីស្រាអែលទៅ[ង]។
៤រីឯកាលមុនដំណើរនេះ អេលីយ៉ាស៊ីបដ៏ជាសង្ឃដែល
បានតាំងឡើង ឱ្យត្រួតលើបន្ទប់[ច]ព្រះវិហាររបស់ព្រះនៃ
យើងរាល់គ្នា លោកបានភ្ជាប់ញាតិនឹងថូប៊ីយ៉ា[ឆ] ៥ដូច្នេះ
លោកបានរៀបចំបន្ទប់ធំ១ ទុកសំរាប់ថូប៊ីយ៉ា ជាបន្ទប់ដែល
ពីដើមគេដាក់ដង្វាយម្សៅ កំញាន គ្រឿងប្រដាប់ទាំងប៉ុន្មាន
និងដង្វាយ១ភាគក្នុង១០[ជ] ពីស្រូវ ទឹកទំពាំង បាយជូរ និង
ប្រេង ដែលគេយកមកថ្វាយ តាមបង្គាប់សំរាប់ពួកលេវី
ពួកចំរៀង និងពួកឆ្មាំទ្វារ ព្រមទាំងដង្វាយលើកចុះឡើង
សំរាប់ពួកសង្ឃដែរ ៦តែនៅអស់រវាងវេលានោះ ខ្ញុំមិន
បាននៅក្រុងយេរូសាឡិមទេ ដ្បិត នៅឆ្នាំទី៣២ក្នុងរាជ្យ
អើថាសើកសេស[ឈ] ជាស្តេចបាប៊ីឡូន នោះខ្ញុំបាន វិលទៅឯ
ស្តេច រួចក្រោយយូរបន្តិចមក ខ្ញុំបានសូមច្បាប់ស្តេចឱ្យបាន
មកវិញ ៧កាលខ្ញុំមកដល់ក្រុងយេរូសាឡិមហើយ នោះខ្ញុំ
ឃើញការអាក្រក់ ដែលអេលីយ៉ាស៊ីប[ញ]បានធ្វើ ដោយរៀប
ចំបន្ទប់១សំរាប់ថូប៊ីយ៉ា[ដ] នៅក្នុងទីលានព្រះវិហារនៃព្រះ
៨ការនោះបានទំនាស់ចិត្តខ្ញុំជាខ្លាំង ហេតុនោះខ្ញុំក៏យកអស់
ទាំងប្រដាប់ប្រដាររបស់ថូប៊ីយ៉ា បោះទៅខាងក្រៅបន្ទប់
ចេញ[ឋ] ៩ខ្ញុំក៏បង្គាប់ឱ្យគេសំអាតបន្ទប់[ឌ] រួចខ្ញុំយកគ្រឿង
ប្រដាប់របស់ព្រះវិហារនៃព្រះ ព្រមទាំងដង្វាយម្សៅ និង
កំញាន ទៅដាក់ទុកក្នុងនោះវិញ[ឍ]។
១០ខ្ញុំក៏យល់ឃើញថាគេមិនបានចែកចំណែកឱ្យដល់ពួក

**១៣:១** ក ខ.២៣ ចទ ២៣:៣ **១៣:២** ខ ជន ២២:៣–១១ គ ជន ២៣:៧ ចទ ២៣:៣ ឃ ជន ២៣:១១ ចទ ២៣:៤–៥ **១៣:៣** ង ខ.២៣ នហ ៩:២ **១៣:៤** ច នហ ១២:៤៤ ឆ នហ ២:១០ **១៣:៥** ជ លវ ២៧:៣០ ជន ១៨:២១ **១៣:៦** ឈ នហ ២:៦ **១៣:៧** ញ អរ ១០:២៤ ដ នហ ២:១០ **១៣:៨** ឋ មថ ២១:១២–១៣ មក ១១:១៥–១៧ លក ១៩:៤៥–៤៦ យហ ២:១៣–១៦ **១៣:៩** ឌ ១រប ២៣:២៨ ២រប ២៩:៥ ឍ លវ ២:១

**១៣:១–២** សូមមើលការពន្យល់អំពីខ.ទាំង២នេះក្នុង ចទ ២៣:៣–៦ ។
**១៣:២** *បាឡាម* សូមមើលការពន្យល់អំពីគាត់ ជន ២២:៥ ។ សិលាចារិកមួយដែលសរសេរជាភាសាអាប់រ៉ាម ដែលគេរកឃើញនៅត្រង់ ឌីអើរអាឡា (Deir Alla) ស្ថិតនៅភាគខាងកើតទន្លេយ័រដាន់ និងភាគខាងជើងនៃស្ទឹងយ៉ាបុកក្នុងអំឡុងពេលសតវត្សរ៍ទី៦ មុន គ.ស ក៏បាននិយាយពីការដែលបាឡាមបានធ្វើដែរ ។
**១៣:៤** *អេលីយ៉ាស៊ីប* សូមមើលការពន្យល់អំពីគាត់ក្នុង ១២:១០ ។ *ថូប៊ីយ៉ា* សូមមើល ២:១០ ។
**១៣:៥** *រៀបចំបន្ទប់ធំ១* នៅក្នុងអំឡុងពេលដែលលោកនេហេមាគាត់មិនបានស្នាក់នៅក្នុងក្រុងដោយព្រោះគាត់វិលត្រឡប់ទៅឯស្ដេចពេរ្ស៊ីវិញ នោះថូប៊ីយ៉ា ជាម្នាក់ក្នុងចំណោមសត្រូវធំៗរបស់គាត់ បានឆ្លៀតយកឱកាសប្រើអំណាចរបស់គាត់ រួមទាំងមានអេលីយ៉ាស៊ីប បានចូលមកស្នាក់នៅក្នុងបន្ទប់ដែលជាឃ្លាំងផ្ទុកដង្វាយ១ភាគក្នុង១០ និងដង្វាយផ្សេងៗទៀត(សូមមើលក្នុង ១០:៣៧ ហើយសូមធៀបជាមួយ ជន ១៨:២១–៣២ ចទ ១៤:២៨–២៩ ២៦:១២–១៥) ។ សូមមើលក្នុង ៣:៣០ ដែលនិយាយពីបន្ទប់របស់មស៊ូឡាម និង អរ ១០:៦ និយាយអំពីបន្ទប់របស់យ៉ូហាណាន ។
**១៣:៦** *នៅឆ្នាំទី៣២ ក្នុងរាជ្យស្ដេចអើថាសើកសេស* សូមមើលការពន្យល់ក្នុង ៥:១៤ ។ *ជាស្ដេចបាប៊ីឡូន* ងារជាស្ដេចបាប៊ីឡូន ប្រហែលជាស្ដេចស៊ីរូសជាអ្នកដាក់បន្ទាប់ពីទ្រង់ បានធ្វើចម្បាំងដណ្ដើមទឹកដីជាមួយពួកបាប៊ីឡូនមក (សូមមើល អរ ៥:១៣) ។
**១៣:៧** *មកដល់ក្រុងយេរូសាឡិម* ដំណើរវិលត្រឡប់មកកាន់ទីក្រុងយេរូសាឡិមលើកទី២របស់លោកនេហេមា គឺត្រូវតែមកដល់មុនឆ្នាំ៤០៧ មុន គ.ស ក្នុងពេលដែលប៊ីកវ៉ាយ គឺជាចៅហ្វាយស្រុកយូដា ។ មានមតិមួយចំនួនទៀតនិយាយថា បន្ទាប់ពីលោកនេហេមាគាត់បានមកដល់ក្រុងយេរូសាឡិមក្នុងដំណាក់កាលទី១ នោះប្អូនប្រុសរបស់គាត់ឈ្មោះ ហាណានី (សូមមើលក្នុង ១:២) ក៏មកដល់ដែរ ។ *ទីលាន* សូមមើលក្នុង ៨:១៦ ព្រះវិហារដែលសេរ៉ូបាបិលបានកសាង គឺមានទីលាន២ (សូមមើលក្នុង សក ៣:៧ ហើយធៀប អស ៦២:៩) ។
**១៣:៨** *ទំនាស់ចិត្ត . . . បោះទៅក្រៅបន្ទប់* នៅក្នុងកន្លែងនេះលោកនេហេមាគាត់បានសម្ដែងពីការចូលចិត្ត តាមរយៈសកម្មភាព(សូមធៀបជាមួយខ.២៤–២៥ ៥:៦–៧) ។ លោកនេហេមា គាត់មានចរិតផ្ទុយពីលោកអែសរ៉ាដែលលោកគ្រាន់តែ "ស្លុតចិត្តហើយអង្គុយ"ប៉ុណ្ណោះ (សូមមើលក្នុង អរ៩:៣) ។ ទង្វើរនិងសមកម្មភាពរបស់លោកនេហេមា បានរំឭកយើងអំពីការដែលព្រះយេស៊ូវទ្រង់បានបណ្ដេញពួកអ្នកលក់ដូរចេញពីព្រះវិហារ (សូមមើល មថ ២១:១២–១៣) ។
**១៣:៩** *បន្ទប់* ទោះបីជានៅក្នុងខ.៥–៨ បាននិយាយថា អេលីយ៉ាស៊ីបបានរៀបចំបន្ទប់តែ១មែន ប៉ុន្តែតាមពិតវាក៏អាចមានបន្ទប់ច្រើនជាង១ដែរដែលលីយ៉ាស៊ីបបានរៀបចំឱ្យថូប៊ីយ៉ា ។ នៅមានរឿង១ទៀតដែលនិយាយពីការប្រមាថមើលងាយដល់ព្រះវិហារពីសំណាក់ថូប៊ីយ៉ា នៅក្នុងប្រទេសអេស៊ីព្ទ កាលពីអំឡុងពេលដើមសតវត្សរ៍នេះ ដែលព្រះវិហារនោះជាកន្លែងដែលពួកទាហានស៊ីឈ្នួលជនជាតិក្រិក បានតាំងលំនៅស្នាក់អាស្រ័យនៅ ។
**១៣:១០** ក្នុងខ.នេះលោកនេហេមា បានកែតម្រង់លើការរំលោភបំពាន់ដែលមានជាយូរមកហើយ ។ ច្បាប់តឹងរ៉ឹងមួយសម្រាប់ពួកលេវី គឺពួកគេម្នាក់ៗមិនត្រូវទទួលបានកេមរតអ្វីឡើយ (សូមមើលការពន្យល់ក្នុង ជន ១៨:២០,២៣–២៤ ចទ ១៤:២៩ ១៨:១) ប៉ុន្តែពួកគេមួយចំនួនទៀតអាចមានចំណូលផ្ទាល់ខ្លួន(សូមមើល ចទ ១៨:៨) ។ ដូច្នេះការរស់នៅរបស់ពួកលេវី គឺត្រូវពឹងផ្អែកលើ ការជួយឧបត្ថម្ភពីពួកអ្នកដែលមានសេចក្ដីជំនឿលើលើព្រះអម្ចាស់ ។ ដោយសារកត្តានេះហើយបានធ្វើឱ្យពួកលេវីជាច្រើនមាន

លេវីទេ[ណ] បានជាពួកលេវី និងពួកចំរៀង ដែលធ្វើការងារ
គេបានរត់ទៅឯស្រែចំការរបស់ខ្លួនវិញ[ត] ១១ដូច្នេះ ខ្ញុំបាន
តវ៉ាដល់ពួកមេថា ហេតុអ្វីបានជាបោះបង់ចោលព្រះវិហារ
នៃព្រះដូច្នេះ[ថ] រួចខ្ញុំក៏ប្រមូលពួកលេវី មកតាំងទុកនៅ
ដំណែងរបស់គេវិញ ១២ហើយពួកយូដាទាំងអស់គ្នា គេយក
ដង្វាយ១ភាគក្នុង១០[ទ]ពីស្រូវ ទឹកទំពាំងបាយជូរ និងប្រេង
មកដាក់ក្នុងឃ្លាំង[ធ] ១៣ហើយខ្ញុំក៏តាំងឱ្យមានពួកអ្នកត្រួតលើ
ឃ្លាំងទាំងនោះ គឺសេលេមាដ៏ជាសង្ឃ ស្មៀនសាដុក ហើយ
ពេដាយ៉ា ជាពួកលេវី បន្ទាប់មកមានហាណាន ជាកូន
សាគើរ ដែលជាកូនម៉ាថានា ដ្បិតអ្នកទាំងនោះបានរាប់ជា
មនុស្សស្មោះត្រង់ ហើយការងាររបស់គេ គឺជាអ្នកចែក
ចំណែកដល់បងប្អូនខ្លួន[ន] ១៤ឱព្រះនៃទូលបង្គំអើយ សូមនឹក
រឭក[ប]ដល់ទូលបង្គំ ពីដំណើរការនេះផង សូមកុំលុបអំពើល្អ
ដែលទូលបង្គំបានធ្វើ សំរាប់ព្រះវិហាររបស់ព្រះនៃទូល
បង្គំ និងសំរាប់ការដែលត្រូវធ្វើ ក្នុងទីនោះចេញឡើយ ។
១៥នៅគ្រានោះខ្ញុំបានឃើញមនុស្សខ្លះនៅស្រុកយូដា
កំពុងតែជាន់ធុងផ្លែទំពាំងបាយជូរ នៅថ្ងៃឈប់សំរាកព្រម
ទាំងដឹកកណ្តាប់ ស្រូវចូលមក និងផ្ទុកសត្វលា ដោយស្រា
ទំពាំងបាយជូរ ផ្លែទំពាំង បាយជូរផ្លែល្វា និងបន្ទុកគ្រប់មុខ
ដែលគេដឹកមកក្នុងក្រុងយេរូសាឡិម នៅថ្ងៃឈប់សំរាក[ផ]
ខ្ញុំបានធ្វើបន្ទាល់ដល់គេ នៅថ្ងៃដែលគេលក់ ស្បៀងអាហារ
១៦ក៏មានមនុស្សពីក្រុងទីរ៉ុស នៅក្នុងទីក្រុងដែរ គេតែង យក
ត្រី និងទំនិញគ្រប់មុខ មកលក់ឱ្យពួកកូនចៅយូដា នៅក្នុង
ក្រុងយេរូសាឡិមក្នុងថ្ងៃឈប់សំរាក[ព] ១៧នោះខ្ញុំតវ៉ាដល់ពួក
អ្នកធំនៃសាសន៍យូដាថា ហេតុដូចម្តេចបានជាអ្នករាល់គ្នា
បង្អាប់ដល់ថ្ងៃឈប់សំរាក ១៨ដោយប្រព្រឹត្តអំពើអាក្រក់
យ៉ាងនេះធ្វើអី ឯពួកឰយុកោរបស់អ្នករាល់គ្នា តើមិនបាន
ធ្វើដូច្នេះទេឬអី ហេតុនោះបានជាព្រះនៃយើងរាល់គ្នា ទ្រង់
បាននាំអស់ទាំងសេចក្តីអាក្រក់នេះ មកលើយើងនឹងលើ
ទីក្រុងនេះផង[ភ] ប៉ុន្តែអ្នករាល់គ្នានាំឱ្យមានសេចក្តីក្រោធ
មកលើពួកអ៊ីស្រាអែលថែមទៀត ដោយបង្អាប់ដល់ថ្ងៃឈប់
សំរាកដូច្នេះ[ម]។
១៩ក្រោយនោះមក កាលណាអស់ទាំងទ្វារនៃក្រុង
យេរូសាឡិម ចាប់តាំងងងឹត ហៀបនឹងចូលថ្ងៃឈប់សំរាក
ហើយ[យ] នោះខ្ញុំក៏បង្គាប់ឱ្យបិទទ្វារ ហើយហាមមិនឱ្យបើក

**១៣:១០** ណ ចទ ១២:១៩ ត ២រប ៣១:៤
**១៣:១១** ថ នហ ១០:៣៧–៣៩ ហក ១:១–៩ មឡ ៣:៨–៩
**១៣:១២** ទ ២រប ១៣:៦ ធ ចទ ១៨:៨ ១ពវ ៧:៥១ ២រប ៣១:៥ នហ ១០:៣៧–៣៩ មឡ ៣:១០
**១៣:១៣** ន នហ ១២:៤៤ កច ៦:១–៥
**១៣:១៤** ប លប ៨:១ ២ពវ ២០:៣
**១៣:១៥** ផ នក ២០:៨–១១ ៣៤:២១ ចទ ៥:១២–១៥
**១៣:១៦** ព នហ ១០:៣១
**១៣:១៨** ភ យរ ៤៤:២៣ ម នហ ១០:៣១ **១៣:១៩** យ លវ ២៣:៣២

ការស្ទាក់ស្ទើរក្នុងការសម្រេចចិត្តចាកចេញពីប្រទេសបាប៊ីឡូន ដើម្បីឱ្យរួចពីសណ្ឋានជាឈ្លើយ (សូមមើល អរ ៨:១៥–២០) ។ សូមមើលការ រទូរទាំរបស់ពួកអ្នកដែលរកគុណសម្បត្តិក្នុងការបម្រើដល់ព្រះ ដែលមាននិយាយនៅក្នុង មឡ ២:១៧ ៣:១៣–១៥ ។

**១៣:១១** *បោះបង់ចោល* សូមមើលការពន្យល់ ១០:៣៩ ។

**១៣:១២** *១ភាគក្នុង១០* សូមមើល ១២:៤៤ ។ នៅក្នុងព្រះវិហារនៅស្រុកមេសូប៉ូតាមា ក៏បានតម្រូវឱ្យថ្វាយ១ភាគក្នុង១០ ដើម្បីជួយឧបត្ថម្ភដល់ពួកបុគ្គលិករសប់ពួកគេដែរ ។

**១៣:១៣** នៅក្នុងខ.នេះចង់និយាយថា មូលហេតុដែលលោកនេហេមាគាត់តាំងឱ្យមានអ្នកទាំង៤នេះឡើង គឺដោយសារតែមានទ្រព្យសម្បត្តិសម្រាប់មនុស្ស៤ប្រភេទដែរគឺ: ១សម្រាប់ពួកសង្ឃ ១សម្រាប់ពួកលេវី ១សម្រាប់ស្មៀន និង១ទៀតសម្រាប់បណ្តាជនធម្មតា ។ *ត្បិតអ្នកទាំងនោះបានរាប់ជាមនុស្សស្មោះត្រង់* នៅក្នុងឃ្លានេះចង់មានន័យថា លោនេហេមាគាត់បានតាំងឱ្យមនុស្សដែលស្មោះត្រង់ដើម្បីត្រួតត្រាលើឃ្លាំងដើម្បីឱ្យមានភាពច្បាស់ថា ពួកគេចែកទ្រព្យដែលបានដល់គ្នាទៅវិញទៅមក ដោយមានស្មើៗគ្នានិងយុត្តិធម៌ដូចអ្វីដែលជាគោលបំណងអ្នកត្រួតត្រាលើទ្រព្យរបស់ព្រះវិហារដែរ (សូមមើលក្នុង ចក ៦:១–៥) ។

**១៣:១៥** *កំពុងតែជាន់ធុងផ្លែទំពាំងបាយជូរ* សូមមើលការពន្យល់ អស ៥:២ ១៦:១០ ។ *ថ្ងៃឈប់សំរាក* សេចក្តីល្បួងដែលបណ្តាលឱ្យមានការរំលោភបំពានលើថ្ងៃឈប់សម្រាក ជានិច្ចកាលគឺតែងតែកើតមានឡើងដល់ពួកអ្នកដែលមិនមែនជាពួកយូដា (សូមមើលក្នុង ១០:៣១ អស ៥៦:១–៨) ។ មួយវិញទៀត ប្រហែលថ្ងៃឈប់សម្រាកនេះ ជាថ្ងៃដែលគេចាត់ទុកថាថ្ងៃសំខាន់បំផុត ពីព្រោះឪពុកម្តាយរបស់គេ បានហៅកូនគេថា សាបថាយ (សូមមើល ៨:៧ ១១:១៦ អរ ១០:១៥) ។

**១៣:១៦** *ក្រុងទីរ៉ុស* សូមមើលការពន្យល់ក្នុង អស ២៣:១ ។ *ត្រី* នៅក្នុងឃ្លានេះចង់និយាយថា ភាគច្រើននៃត្រីដែលពួកអ្នកក្រុងទីរ៉ុសបាននាំចូលមក (សូមមើល អគ ២៦:៤–៥,១៤) គឺជាត្រីងៀត ត្រីឆ្អើរ ។ ភាគច្រើននៃត្រីទាំងនោះគឺគេនេសាទបានពីសមុទ្រកាលីឡេ ហើយត្រីគឺជាម្ហូបមួយដែលមានសារៈសំខាន់សម្រាប់ពួកអ៊ីស្រាអែល (សូមមើល លវ ១១:៩ ជន ១១:៥ មថ ១៥:៣៤ លក ២៤:៤ យហ ២១:៥–១៣) ។

**១៣:១៧–១៨** *បង្អាប់ដល់ថ្ងៃឈប់សំរាក* សូមធៀបជាមួយ នក ១៦:២៨–២៩ ជន ១៥:៣២–៣៦ អស ៥៨:១៣–១៤ យរ ១៧:១៩–២៧ អម ៨:៥, ៧–៨ ។ "បង្អាប់"មានន័យថា ងាកចេញពីសាសនា ហើយក្លាយជាមនុស្សមិនជឿ និងក្បត់ព្រះ (សូមមើល មឡ ២:១០–១១) ។

**១៣:១៧** *តវ៉ាដល់ពួកអ្នកធំ* មូលហេតុដែលលោកនេហេមាគាត់តវ៉ាពីព្រោះពួកអ្នកធំទាំងនោះ ជាអ្នកដឹកនាំការបង្អាប់ដល់ថ្ងៃឈប់សម្រាក ។

**១៣:១៩** *កាលណាអស់ទាំងទ្វារនៃក្រុងយេរូសាឡិម ចាប់តាំងងងឹត* លោកនេហេមាគាត់បិទទ្វារក្រុងនៅមុនថ្ងៃលិច ពេលឈានចូលដល់ថ្ងៃឈប់សម្រាក ពួកអ៊ីស្រាអែលនិងបណ្តាជនបាប៊ីឡូនដែរគេចាប់តាំងរាប់ថ្ងៃឈប់សម្រាករបស់គេចាប់តាំងពីថ្ងៃលិចទៅ (ពួកអេស៊ីព្ទគេរាប់ពេលថ្ងៃជិតភ្លឺ) ។ បច្ចុប្បន្ននេះ ពេលថ្ងៃឈប់សម្រាកឈានមកដល់ គឺមានពួកសង្ឃដើរនាំមុខដោយការផ្លុំត្រែ ។ យោងទៅតាមការពិភាក្សាគ្នាលើក្រិត្យវិន័យលោកម៉ូសេ (Mishnah) របស់ពួកយូដាគេបាននិយាយថា "នៅក្នុងថ្ងៃឈប់សម្រាកគេធ្លាប់ឱនក្បាលដល់ដីចំនួន៦ដង ដោយ៣ដងដើម្បី ប្រាប់ដល់បណ្តាជនឱ្យឈប់សម្រាកពីការងារ ហើយ៣ដងទៀតបំបែករវាងការជឿ និងត្រឡប់ជាមិនជឿ" ។ លោកយ៉ូសែបហ្វីស គាត់បាននិយាយអំពីទីតាំងនៃបង្កាន់ដៃព្រះ

ដរាបដល់ផុតថ្ងៃឈប់សំរាកនោះ ខ្ញុំក៏ដាក់ពួកអ្នកបំរើរបស់
ខ្ញុំខ្លះ ឱ្យត្រួតលើទ្វារទាំងប៉ុន្មាន ដើម្បីកុំឱ្យមានអ្នកណាយក
បន្ទុកអ្វី ចូលមកនៅថ្ងៃឈប់សំរាកឡើយ 20 នោះពួកឈ្មួញ
និងពួកអ្នកដែលលក់ដូរផ្សេងៗ ក៏ដេកនៅខាងក្រៅក្រុង
យេរូសាឡិមម្តងពីរដែរ 21 រួចខ្ញុំបានធ្វើបន្ទាល់ដល់គេថា
អ្នករាល់គ្នាដេកនៅក្បែរកំផែងនេះធ្វើអី បើនៅតែធ្វើ
ដូច្នេះទៀត នោះខ្ញុំនឹងចាប់អ្នករាល់គ្នាហើយ តាំងពីនោះ
តទៅ គេក៏លែងមកនៅថ្ងៃឈប់សំរាកទៀត 22 ខ្ញុំក៏បង្គាប់
ដល់ពួកលេវី ឱ្យគេបានញែកខ្លួនចេញជាបរិសុទ្ធ ហើយឱ្យ
គេមកចាំយាម នៅអស់ទាំងទ្វារក្រុង ដើម្បីញែក ថ្ងៃឈប់
សំរាកចេញជាបរិសុទ្ធ ឱព្រះនៃទូលបង្គំអើយសូមនឹកចាំ[រ]
ពីទូលបង្គំក្នុងការនេះផង ហើយសូមអាណិតមេត្តាដល់ទូល
បង្គំ ដោយសេចក្តីសប្បុរសទ្រង់ដ៏ធំ ។
23 នៅគ្រានោះ ខ្ញុំក៏ឃើញពួកយូដាខ្លះ ដែលបានយក
ប្រពន្ធ[ល] ជាស្រីសាសន៍អាសដូឌ អាំម៉ូននិងម៉ូអាប់[វ] 24 ហើយ
កូនគេពាក់កណ្តាល និយាយជាភាសាអាសដូឌឥតចេះ
និយាយភាសា[ស] របស់ពួកយូដាឡើយ គឺគេនិយាយតាមតែ
ភាសារបស់សាសន៍គេរៀងខ្លួន 25 ខ្ញុំក៏តវ៉ានឹងគេ ព្រមទាំង
ដាក់បណ្តាសា ក៏វាយគេខ្លះ ហើយបោចសក់គេផង ខ្ញុំចាប់
ឱ្យគេស្បថ[ហ] ដោយនូវព្រះនាមរបស់ព្រះ ហើយហាមគេថា
មិនត្រូវឱ្យ អ្នករាល់គ្នាឱ្យកូនស្រីទៅកូនប្រុសរបស់គេ ឬយក
កូនស្រីរបស់គេមក ឱ្យកូនប្រុសរបស់ខ្លួន ឬសំរាប់ខ្លួននោះ
ឡើយ[ឡ] 26 តើសាឡូម៉ូន ជាស្តេចសាសន៍អ៊ីស្រាអែលមិន
បានធ្វើបាប ដោយអំពើយ៉ាងនេះឯងទេឬអី នៅក្នុងអស់
ទាំងសាសន៍ដទៃ គ្មានស្តេចណា១ ដូចទ្រង់ឡើយ[អ] ហើយ
ព្រះនៃទ្រង់ក៏បានស្រឡាញ់ទ្រង់[ក] ព្រមទាំងតាំងឡើងឱ្យ
ធ្វើជាស្តេចលើសាសន៍អ៊ីស្រាអែលទាំងមូលផង ប៉ុន្តែស្ត្រី
សាសន៍ដទៃបាននាំឱ្យទ្រង់ធ្វើបាបដែរ[ខ] 27 ដូច្នេះ តើគួរឱ្យ
យើងស្តាប់តាមអ្នករាល់គ្នា និងប្រព្រឹត្តសេចក្តីអាក្រក់ជាធំ
ទាំងនេះ ហើយប្រព្រឹត្តរំលងនឹងព្រះនៃយើង ដោយយក
ប្រពន្ធ[គ] ជាសាសន៍ដទៃឬអី ។
28 ឯយ៉ូយ៉ាដា ជាកូនអេលីយ៉ាស៊ីប[ឃ] ជាសំដេចសង្ឃ
លោកមានកូនប្រុស១ ដែលជាកូនប្រសាសានបាឡាត[ង] ជា
អ្នកស្រុកហូរ៉ូណែម ហេតុនោះខ្ញុំក៏បណ្តេញវាចេញពីខ្ញុំទៅ
29 ឱព្រះនៃទូលបង្គំអើយ សូមទ្រង់និងចាំ[ច] ពីគេ គឺព្រោះគេ
បានបង្អាប់ការងារជាសង្ឃ និងសេចក្តីសញ្ញានៃការងារ
នោះ និងពួកលេវីដែរ[ឆ] ។
30 គឺយ៉ាងដូច្នេះដែលខ្ញុំបានញែកសំអាតគេ គឺគ្រប់ទាំង

**១៣:២២** រ លប ៨:១ នហ ១:៨
**១៣:២៣** ល អរ ៩:១-២ មឡ ២:១១ វ ឧ.១ ឧ.១,៣ នក ៣៤:១៦ នរ ១:៤ នហ ១០:៣០
**១៣:២៤** ស នអ ១:២២ ៣:១២ ៨:៩
**១៣:២៥** ហ អរ ១០:៥ ឡ នក ៣៤:១៦
**១៣:២៦** អ ១ពវ ៣:១៣ ២របា ១:១២ ក ២សយ ១២:២៥ ខ នក ៣៤:១៦ ១ពវ ១១:៣
**១៣:២៧** គ អរ ៩:១៤
**១៣:២៨** ឃ អរ ១០:២៤ ង នហ ២:១០
**១៣:២៩** ច នហ ១:៨ ឆ ជន ៣:១២
**១៣:៣០** ជ ជន ៩:២

វិហារ ជាកន្លែងដែលពួកសង្ឃ "ផ្តល់ជាសញ្ញាមុន ដោយការផ្លុំត្រែ រាល់ពេលឈានចូលថ្ងៃទី៧ នៅក្នុងពេលល្ងាចនៃថ្ងៃអស់ស្តង្គត់ ហើយនិង រាល់ពេលព្រឹក ដើម្បីប្រាប់ដល់ពួកបណ្តាជនឱ្យឈប់សម្រាកពីកិច្ចការងារ និងពេលដែលត្រូវបន្តកិច្ចការងារ" ។ ក្រុមអ្នកកំណាយមួយក្រុមបាន ចំណាយពេលដើម្បីធ្វើកំណាយក្នុងព្រះវិហារលើភ្នំ ហើយជាលទ្ធផលពួកគេ បានរកឃើញថ្ម១ដុំ ដែលគេបាននាំមកពីទិសខាងត្បូងឆៀងខាងលិចនៃ បង្កាន់ដៃ ដែលបានបាក់ធ្លាក់ដល់ដី ។

**១៣:២២** *សូមនឹកចាំពីទូលបង្គំ* សូមមើលការពន្យល់ក្នុង ១:៨ ។

**១៣:២៣** លោកអែសរ៉ាគាត់ក៏មានបញ្ហាដូចលោកនេហេមាដែរ ។ បញ្ហា ដែលគេជួបប្រទះ គឺបញ្ហាការរៀបការជាមួយសាសន៍ដទៃ ក្នុងសម័យកាល ប្រមាណជា២៥ឆ្នាំមុន(សូមមើលក្នុង អរ ៩:១) ។ *សាសន៍អាសដូឌ* សូម មើលក្នុង ៤:៧ អស ២០:១ ។ *អាំម៉ូន និងម៉ូអាប់* សូមមើលការពន្យល់ក្នុង លប ១៩:៣៦–៣៨ ។

**១៣:២៤** នៅក្នុងខ.នេះចង់បង្ហាញថា ពួកអ៊ីស្រាអែលគេទទួលស្គាល់អ្នកណា ម្នាក់ថាជាសាសន៍ដទៃ តាមរយៈភាសាដែលពួកគេនិយាយ(សូមមើលក្នុង ចទ ៣:៩ ពច ១២:៦ ទដ ១១៤:១ អស ៣៣:១៩ អគ ៣:៥–៦) ។

**១៣:២៥** *បោចសក់គេ* សូមមើលការពន្យល់ក្នុង អរ ៩:៣ អស ៥០:៦ ។*មិន ត្រូវឱ្យអ្នករាល់គ្នាឱ្យ* ទង្វើនិងសកម្មភាពរបស់លោកនេហេមា គឺគាត់បង្ការ ការរៀបការជាមួយស្ត្រីសាសន៍ដទៃនៅថ្ងៃអនាគត ។

**១៣:២៦** *សាឡូម៉ូន* សាឡូម៉ូន គឺជាស្តេចដ៏ល្អបំផុតរបស់ពួកអ៊ីស្រាអែល ខាងឯទ្រព្យសម្បត្តិ និងគោលនយោបាយ(សូមមើលក្នុង ១ពវ ៣:១៣ ២របា ១:១២) ។ សាឡូម៉ូនបានក្លាយជាស្តេច តាមរយៈការទូលសូមប្រាជ្ញាដោយ ការបន្ទាបខ្លួននៅចំពោះព្រះ(សូមមើលក្នុង ១ពវ ៣:៥–៩) ។ *ធ្វើបាប* នៅក្នុងសម័យកាលក្រោយមកទៀត ស្តេចសាឡូម៉ូនត្រូវបានប្រពន្ធគាត់ដែល ជាស្ត្រីសាសន៍ដទៃបានបង្វែព្រះទ័យឱ្យទៅគោរពប្រត្តិដល់ព្រះដទៃ ហើយ ស្តេចសាឡូម៉ូនក៏បានកសាងទីខ្ពស់ដល់ព្រះកេមូស ដែលជាព្រះរបស់សាសន៍ ម៉ូអាប់(សូមមើលក្នុង ១ពវ ១១:៧) ។

**១៣:២៨** *កូនប្រសារសានបាឡាត* យោងទៅតាមព្រះគម្ពីរលេវីវិន័យ ២១:១៤ បានចែងថា ពួកសង្ឃមិនត្រូវរៀបការជាមួយស្ត្រីសាសន៍ដទៃ ឡើយ ។ ដូច្នេះការបណ្តេញកូនប្រុសរបស់ យ៉ូយ៉ាដាចេញពីព្រះវិហារ គឺបានធ្វើឡើងដោយយោងទៅតាមបំរាមឃាត់ ដ៏ពិសេសនេះឬក៏ដោយ យោងតាមច្បាប់ ទូទៅដែលបានហាមមិនឱ្យរៀបការជាមួយស្ត្រីសាសន៍ដទៃ សហគមន៍ ដែលបានពណ៌នានៅក្នុងខ.នេះ គឺមានលក្ខណៈពិសេសណាស់ ចំពោះលោកនេហេមា ដោយលោកនេហេមាផ្ទាល់គាត់ជាសត្រូវរបស់សាន បាឡាត (សូមមើលក្នុង ២:១០) ។ លោកយ៉ូសែបហ្វីសគាត់បានបង្ហាញថា ភាគច្រើននៃឧបករណ៍ ដែលនិយាយនៅកន្លែងនេះ គឺទាក់ទងទៅនឹង អាពិបាហ៍កូនស្រីរបស់សានបាឡាត ដែលជាពួកសាសន៍សាម៉ារីជាមួយបង ប្អូនប្រុសរបស់សង្ឃយូដា ក្នុងអំឡុងពេលសតវត្សរ៍ក្រោយមកទៀតនាពេល ដែលអ័លេក្សានត្រុស ជាស្តេចដ៏ឆ្នើមគ្រប់គ្រង ។

**១៣:៣០** *ការងារ* ការងារដែលនិយាយនៅក្នុងខ.នេះគឺសំដៅលើលំហាត់ នៃកិច្ចការងារដ៏ពិសេក្នុងក្រុមនៃពួកសង្ឃ និងពួកកូនចៅលេវី ហើយដែល ការងាររបស់ពួកគេជាប្តូរវេណគ្នា(សូមមីលេការពន្យល់ក្នុង ១២:៩) ។

សាសន៍ដទៃ[ដ] ហើយក៏តាំងការងារ ដែលពួកសង្ឃនិងពួក
លេវីត្រូវរក្សាទុកឡើងវិញ គ្រប់គ្នាតាមដំណែងគេរៀងខ្លួន
៣១ ហើយសំរាប់ដង្វាយឱស[ឈ]នៅវេលាកំណត់ និងសំរាប់
ផលផ្លែដំបូងដែរ[ញ] ឱព្រះនៃទូលបង្គំអើយ សូមទ្រង់នឹកចាំ[ដ]
ពីទូលបង្គំ ដើម្បីនឹងប្រោសឱ្យទូលបង្គំបានប្រកប ដោយ
សេចក្ដីល្អផង។/

**១៣:៣១** ឈ នហ ១០:៣៤ ញ នហ ១០:៣៥–៣៦ ដ លប ៨:១ នហ ១:៨

**១៣:៣១** *ឧស* សូមមើលក្នុង ១០:៣៤។ *សូមទ្រង់នឹកចាំពីទូលបង្គំ ដើម្បីនឹងប្រោសឱ្យទូលបង្គំបានប្រកបដោយសេចក្ដីល្អផង* នៅក្នុងឃ្លានេះចង់បង្ហាញថា ពាក្យសម្ដីចុងក្រោយរបស់លោកនេហេមា គឺគាត់បានធ្វើការសរុបសេចក្ដីលើផ្ទៃរឿងទាំងមូលដែលបាននិយាយនៅក្នុងជំពូកចុងក្រោយនៃព្រះគម្ពីរនេហេមា (សូមមើលក្នុង៦.១៤,២២ និងការពន្យល់ក្នុង ១:៨)។ចំណង់របស់គាត់ ដែលមានពេញនៅក្នុងកិច្ចការងារបម្រើរបស់លោក គឺគាត់មានអំណរក្នុងការបម្រើដល់ព្រះដែលគាត់ថ្វាយបង្គំ ។

# ព្រះគម្ពីរនាងអេសធើរ

## សេចក្តីផ្តើម

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

ទោះបីជាយើងមិនដឹងថា នរណាជាអ្នកនិពន្ធព្រះគម្ពីរនេះក៏ដោយ ក៏យើងអាចកំណត់អត្តសញ្ញាណរបស់អ្នកនិពន្ធ និងកាលបរិច្ឆេទនៃការនិពន្ធព្រះគម្ពីរនេះ ដោយផ្អែកទៅលើភស្តុតាងដែលយើងអាចរកបាននៅក្នុងព្រះគម្ពីរនេះ ។ គេអាចដឹងច្បាស់ថា អ្នកនិពន្ធគឺជាសាសន៍យូដា ព្រោះព្រះគម្ពីរនេះបាននិយាយសង្កត់ធ្ងន់អំពីដើមកំណើតនៃពិធីបុណ្យមួយរបស់ពួកសាសន៍យូដា ហើយមានលក្ខណៈជាតិនិយមរបស់ពួកយូដា ។ ដោយយោងទៅលើការយល់ដឹងរបស់អ្នកនិពន្ធអំពីប្រពៃណីរបស់សាសន៍ពើរស៊ី ការនិយាយអំពីរឿងនាងអេសធើរ ដែលកើតឡើងនៅក្រុងស៊ូសាន និងការមិនបានលើកឡើងអំពីស្ថានភាពនៅស្រុកយូដា នោះគេអាចសន្និដ្ឋានបានថា អ្នកនិពន្ធជាដែលមានទីលំនៅនៅទីក្រុងរបស់សាសន៍ពើរស៊ី ។ អ្នកនិពន្ធបានសរសេរព្រះគម្ពីរនេះ បន្ទាប់ពីព្រឹត្តិការណ៍ដែលបានរៀបរាប់ក្នុងរឿងនេះទើបតែបានបញ្ចប់មិនទាន់បានយូរប៉ុន្មាន គឺប្រហែលនៅឆ្នាំ ៤៦០ មុនគ.ស (មុនពេលលោកអែសរ៉ាធ្វើដំណើរវិលត្រឡប់ទៅក្រុងយេរូសាឡិមវិញ មើលការពន្យល់ ៨:១២)។ តាមភស្តុតាងដែលមាននៅក្នុងព្រះគម្ពីរនេះ យើងអាចដឹងថា ចាប់ពីពេលដែលគេផ្តើមធ្វើពិធីបុណ្យពោរ រហូតដល់ព្រះគម្ពីរនេះត្រូវបាននិពន្ធឡើង (៩:១៩) គឺមានរយៈពេលមិនយូរប៉ុន្មានទេ ហើយនៅពេលនោះស្តេចអ័ហាស៊ូរុសបានសុគតហើយ (មើល ១០:២ និងការពន្យល់)។ អ្នកជំនាញខាងព្រះគម្ពីរខ្លះបានកំណត់យកឆ្នាំ ៣៣០ មុនគ.ស ជាកាលបរិច្ឆេទនៃការនិពន្ធព្រះគម្ពីរនេះ ប៉ុន្តែ ដោយសារព្រះគម្ពីរនេះមិនបានប្រើពាក្យជាភាសាក្រិក ហើយបានមានរចនាបទនៃការសរសេរតាមបែបគ្រាមភាសាហេព្រើររបស់អ្នកនិពន្ធ នោះគេសន្និដ្ឋានថា ព្រះគម្ពីរនេះប្រាកដជា ត្រូវបាននិពន្ធឡើងមុនពេលដែលចក្រភពពើរស៊ីត្រូវធ្លាក់នៅក្រោមការគ្រប់គ្រងរបស់ចក្រភពក្រិកនៅឆ្នាំ ៣៣១ មុនគ.ស ។

### គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ

គោលបំណងជាចំបងរបស់អ្នកនិពន្ធ គឺដើម្បីកត់ត្រាអំពីប្រវត្តិនៃការប្រារព្ធធ្វើពិធីបុណ្យពោរ នឹងដើម្បីកត់ចំណាំ ដើម្បីកុំឱ្យសាសន៍យូដាជំនាន់ក្រោយៗភ្លេចការប្រោសលោះ ដែលព្រះទ្រង់បានធ្វើដល់សាសន៍យូដា នៅក្នុងសម័យនៃការគ្រប់គ្រងរបស់ស្តេចអ័ហាស៊ូរុស ។ ព្រះគម្ពីរនេះបកស្រាយអំពីដើមកំណើតនៃការធ្វើពិធីបុណ្យនេះ ហើយក៏បានបង្រៀនអំពីកាតព្វកិច្ចដែលពួកយូដាត្រូវបន្តធ្វើពិធីបុណ្យនេះជានិច្ច ដើម្បីឱ្យពួកគេនៅតែចងចាំជានិច្ច (៣:៧ ៩:២៦-៣២) ។

នៅក្នុងផ្នែកជាច្រើននៃរឿងនេះ អ្នកនិពន្ធបានរំឭកអំពីជម្លោះជាតិសាសន៍រវាង ពួកអ៊ីស្រាអែល និងពួកអាម៉ាឡេក (មើលការពន្យល់ ២:៥ ៣:១-៦ ៩:៥-១០) ជាជម្លោះដែលបានចាប់ផ្តើមតាំងពីសម័យនិក្ខមនំ (នក ១៧:៨-១៦ ចទ ២៥:១៧-១៩) ហើយបានបន្តនៅសម័យក្រោយៗទៀត នៅក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល (១សយ ១៥ ១របា ៤:៤៣ និងក្នុង ព្រះគម្ពីរនាងអេសធើរតែម្តង)។ ដោយសារពួកសាសន៍អាម៉ាឡេកជាសាសន៍ដំបូងគេដែលធ្វើសង្គ្រាមទាស់នឹងពួកអ៊ីស្រាអែល នៅពេលដែលពួកគេបានរួចពីភាពជាទាសករនៅនគរអេស៊ីព្ទ នោះគេបានហៅពួកសាសន៍នេះថា (អ្នកនិពន្ធព្រះគម្ពីរនាងអេសធើរក៏បានហៅផងដែរថា) គឺជាគំរូនៃគ្រប់ទាំងអំណាចលោកិយដែលនាំគ្នាទាស់ប្រឆាំងនឹងរាស្ត្ររបស់ព្រះ (មើល ជន ២៤:២០ ១សយ ១៥:២-៣ ២៨:១៨)។ នៅពេលដែលពួកអ៊ីស្រាអែលបានទទួលការប្រោសលោះមួយលើកនេះទៀត ព្រះរាជក្រឹត្យដែលស្នើរដោយហាម៉ាន បានបញ្ជាក់ពីការប្រឹងប្រែងដ៏ធំចុងក្រោយរបស់ពួកអាម៉ាឡេក នៅក្នុងការប៉ុនប៉ងបំផ្លាញពួកអ៊ីស្រាអែល នៅគ្រាសញ្ញាចាស់ ។

នៅក្នុងការធ្វើសង្គ្រាមទាស់នឹងពួកសាសន៍អាម៉ាឡេក ព្រះទ្រង់ភ្ជាប់នូវសេចក្តីសន្យាប្រទានសេចក្តីសម្រាកដល់ពួកអ៊ីស្រាអែលផងដែរ (ចទ ២៥:១៩)។ នៅពេលដែលហាម៉ានត្រូវបរាជ័យ ពួកយូដាបានទទួលសេចក្តីសម្រាកដោយអំណរ ដោយបានរួចផុតពីការប៉ុនប៉ងរបស់ពួកខ្មាំងសត្រូវ (៩:១៦,២២)។

អ្នកនិពន្ធក៏បានលើកឡើងអំពីភាពជាសំណល់នៃសាសន៍ ដែលមាននិយាយនៅក្នុងព្រះគម្ពីរជាច្រើនដង (គ្រោះធម្មជាតិ ជម្ងឺ សង្គ្រាម ឬមហន្តរាយផ្សេងៗទៀត បានគម្រាមកំហែងដល់ការរស់រាននៃរាស្ត្ររបស់ព្រះ ហើយពួកដែលបានរួចជីវិតគឺជាពួកសំណល់)។ ព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្រុងស៊ូសាន គឺបានគម្រាមកំហែងទៅដល់ ការបន្តនៃផែនការព្រះ នៅក្នុងប្រវត្តិសាស្ត្រនៃការប្រោសលោះ មានន័យថា ព្រះរាជក្រឹត្យដែលហាម៉ានបានស្នើ ដើម្បីបំផ្លាញពួកយូដា គឺជាឧបសគ្គនៃការបន្តរស់រាននៅពេលអនាគត របស់រាស្ត្រជ្រើសតាំងនៃព្រះ និងជាពិសេសជាឧបសគ្គដល់ការយាងមកនៃព្រះមែស៊ី ។ អ្នកនិពន្ធព្រះគម្ពីរនាងអេសធើរបានរៀបរាប់អំពីផ្នែកជាច្រើននៃរឿងនេះ ដោយយកគំរូតាមការរៀបរាប់នៅក្នុងរឿងលោកយ៉ូសែប (មើលការពន្យល់ ២:៣-៤,៩,២១-២៣ ៣:៤ ៤:១៤ ៦:១,

៨,១៤ ៨:៦) ដែលក្នុងនោះ ការលើកឡើងអំពីភាពជាសំណល់សាសន៍ ក៏ជាខ្លឹមសារសំខាន់នៃពិពណ៌នាផងដែរ (មើល លប ៤៥:៧ និងការពន្យល់) ។

ការធ្វើពិធីជប់លៀង ក៏ជាខ្លឹមសារសំខាន់នៃព្រះគម្ពីរនាងអេសធើរផងដែរ ដូចដែលបានបង្ហាញនៅក្នុងគម្រោងសង្ខេបខាងក្រោម ។ ពិធីជប់លៀងទាំងអស់ គឺមាន១០ដង: (១). ១:៣–៤ (២).១:៥–៨ (៣).១:៩ (៤).២:១៨ (៥).៣:១៥ (៦).៥:៥–៦ (៧).៧:១–១០ (៨).៨:១៧ (៩).៩:១៧ (១០).៩:១៨ ។ មានពិធីជប់លៀងបីគូ ដែលគូនីមួយៗមាននិយាយនៅកន្លែងផ្សេងៗពីគ្នា ដូចជានៅក្នុងវគ្គដំបូង វគ្គកណ្ដាល និងវគ្គបញ្ចប់នៃរឿងនេះ ។ ស្ដេចអ័ហាស៊ូរុសបានប្រទានពិធីជប់លៀងពីរដង នាងអេសធើរបានរៀបចំពីរដង ហើយពីរដងទៀតគឺដើម្បីប្រារព្ធពិធីពោរ ។

អ្នកនិពន្ធបានលើកចំណុចខ្លះ និយាយម្ដងទៀតនៅក្នុងព្រះគម្ពីរនេះ ដែលជាលក្ខណៈនៃការនិពន្ធរបស់គាត់ ។ ក្រៅពីពិធីជប់លៀងដែលមានបីគូ គឺមានបញ្ជីឈ្មោះអ្នកបម្រើស្ដេចពីរ (១:១០,១៤) មានការលាក់អត្តសញ្ញាណរបស់នាងអេសធើរពីរដង (២:១០, ២០) ការជួបជុំរបស់ពួកស្ត្រីពីរដង (២:៨,១៩) ការអធិស្ឋានតមពីរដង (៤:៣,១៦) ទីប្រឹក្សាពីរនាក់របស់ហាម៉ាន ដែលប្រជុំគ្នាជាមួយនឹងប្រពន្ធ និងមិត្រភ័ក្ររបស់គាត់ (៥:១៤ ៦:១៣) នាងអេសធើរចូលទៅគាល់ស្ដេចពីរដង ដោយមិនបានទូលទ្រង់ជាមុន (៥:២ ៨:៣) លោកម៉ាដេកាយបានទទួលមុខដំណែងធំពីរដង (៦:១០–១១ ៨:១៥) ហាម៉ាគ្រលំមុខពីរដង (៦:១២ ៧:៨) ស្ដេចចេញព្រះរាជក្រឹត្យពីរដង (៣:១២–១៥ ៨:១–១៤) ការអន់ថយនៃសេចក្ដីក្រោធរបស់ស្ដេច (២:១ ៧:១០) មានការនិយាយពីរដងអំពីច្បាប់របស់ពួកពើរស៊ីដែលមិនអាចកែប្រែបាន (១:១៩ ៨:៨) ពួកសាសន៍យូដាធ្វើការសងសឹកអស់ពីរថ្ងៃ (៩:៥–១២,១៣–១៥) និងមានសំបុត្រពីរច្បាប់ដែលនិយាយអំពីការធ្វើបុណ្យពោរ (៩:២០–២៨,២៩–៣២) ។

ព្រះគម្ពីរនេះមានលក្ខណៈពិសេសម្យ៉ាង ដែលនាំឱ្យមានការពិភាក្សាវែកញែកស៊ីជម្រៅ គឺព្រះគម្ពីរនេះមិនបាននិយាយអំពីព្រះ ការថ្វាយបង្គំ អធិស្ឋាន ឬការថ្វាយយញ្ញបូជាឡើយ ។ ការនេះបាននាំឱ្យមានអ្នករិះគន់ថា ព្រះគម្ពីរនេះមានលក្ខណៈខាងឯវិញ្ញាណតិចពេក ។ តែទោះជាយ៉ាងណាក៏ដោយ ការមិននិយាយនេះហាក់ដូចជា ដោយសារអ្នកនិពន្ធចង់លើកកំពស់ការយល់ដឹងអំពីសេចក្ដីពិតថា ព្រះទ្រង់មិនអនុញ្ញាតិឱ្យផែនការប្រោសលោះរបស់ទ្រង់ត្រូវបរាជ័យ ដោយឱ្យរាស្ត្រទ្រង់ត្រូវវិនាសបង់ មុនដែលដែលព្រះរាជបុត្រាទ្រង់ត្រូវយាងមកនោះឡើយ ដូចនេះ ព្រះដ៏មានព្រះចេស្ដា ទ្រង់បានគ្រប់គ្រងគ្រប់ហេតុការណ៍ទាំងអស់ ហើយបានឱ្យមានហេតុការណ៍ដែលកើតឡើងជួនពេលគ្នា (មើលឧទាហរណ៍ក្នុងការពន្យល់ ៦:១) ដើម្បីឱ្យផែនការទ្រង់បានសម្រេច ។ ម្យ៉ាងទៀត នៅពេលដែលគេមិននិយាយអំពីព្រះនៅក្នុងព្រះគម្ពីរនេះទាល់តែសោះ នោះមានន័យថាគេ កាន់តែងាយសន្និដ្ឋានថា ព្រះដ៏មានគ្រប់ចេស្ដាទ្រង់គ្រប់គ្រងហេតុការណ៍ទាំងអស់ (មើលការពន្យល់ ៤:១២–១៦) ។ នៅពេលដែលគេសិក្សាព្រះគម្ពីរនេះយ៉ាងប្រុងប្រយ័ត្ន នោះគេអាចដឹងថា ព្រះទ្រង់ជាមហាក្សត្រដ៏ជាធំ ទ្រង់ប្រើអំណាចគ្រប់គ្រងលើគ្រោះមហន្តរាយដែលតាមបៀតបៀនរាស្ត្រនៃសេចក្ដីសញ្ញារបស់ទ្រង់ ។

**គម្រោងសង្ខេប**

I. ពិធីជប់លៀងរបស់ស្ដេចអ័ហាស៊ូរុស (១:១–២:១៨)
- ក. ការទម្លាក់នាងវ៉ាសធីពី ពីតំណែងជាអគ្គមហេសី (ជំពូក ១)
- ខ. នាងអេសធើរបានទទួលឋានៈជាអគ្គមហេសី (២:១–១៨)

II. ពិធីជប់លៀងរបស់នាងអេសធើរ (២:៩–៧:១០)
- ក. លោកម៉ាដេកាយបកអាក្រាតអំពីផែនការក្បត់ (២:១៩–២៣)
- ខ. ផែនការរបស់ហាម៉ាន (ជំពូក ៣)
- គ. ម៉ាដេកាយសូមឱ្យនាងអេសធើរជួយ (ជំពូក ៤)
- ឃ. នាងអេសធើរទូលសូមស្ដេច អំពីពិធីជប់លៀង (៥:១–៨)
- ង. យប់ដែលស្ដេចផ្ទំមិនលក់ (៥:៩–៦:១៤)
- ច. ហាម៉ានត្រូវព្យួករ: នាងអេសធើរជប់លៀងម្ដងទៀត (ជំពូក ៧)

III. ពិធីបុណ្យពោរ (ជំពូក ៨–១០)
- ក. ស្ដេចចេញព្រះរាជក្រឹត្យ ដើម្បីសង្គ្រោះពួកយូដា (ជំពូក ៨)
- ខ. ការបង្កើតពិធីបុណ្យពោរ (ជំពូក ៩)
- គ. លោកម៉ាដេកាយឡើងតំណែង (ជំពូក ១០)

## ព្រះនាងវ៉ាសធីបដិសេធ

**១** ១ រីឯនៅគ្រាអ័ហាស៊ូរុស[ក] ជាស្តេចដែលសោយរាជ្យលើ
១២៧ខេត្ត[ខ] ចាប់តាំងពីស្រុកក្លិង្គរហូតដល់អេធីយ៉ូពី[គ] ២ ក្នុង
គ្រានោះ កាលស្តេចអ័ហាស៊ូរុសទ្រង់គង់លើបល្ល័ង្ករាជ្យនៅ
ស៊ូសាន ជាទីក្រុងហ្លួង[ឃ] ៣ គឺនៅឆ្នាំទី៣ក្នុងរាជ្យទ្រង់នោះ
ទ្រង់បានជប់លៀង[ង]ដល់ពួកអ្នកជាប្រធាន នឹងពួកជំនិតទ្រង់
មានទាំងពួកមេទ័ពសាសន៍ពើស៊ី និងសាសន៍មេឌី ពួកអ្នកធំ
និងពួកចៅហ្វាយខេត្តទាំងប៉ុន្មាននៅចំពោះទ្រង់ដែរ ៤ ទ្រង់
ក៏បង្ហាញអស់ទាំងមហាសម្បត្តិនៃនគរដ៏ឧត្តុង្គឧត្តមរបស់
ទ្រង់ និងកិត្តិយសនៃអានុភាពដ៏វិសេសរបស់ទ្រង់ ឱ្យគេ
ឃើញជាយូរថ្ងៃ គឺអស់១៨០ថ្ងៃ ៥ លុះកាលផុតថ្ងៃទាំងនោះ
ហើយ ស្តេចទ្រង់ជប់លៀងដល់ពួកជនទាំងអស់ ទាំងធំទាំង
តូច ដែលនៅស៊ូសានជាក្រុងហ្លួងអស់៧ថ្ងៃ[ច] នៅត្រង់ទីធ្លា
ក្នុងព្រះរាជឧទ្យាន[ឆ]នៃដំណាក់ស្តេច ៦ ដែលមានសំពត់ស
បៃតង និងខៀវ ចងដោយខ្សែខ្លូតទេសពណ៌ស្វាយភ្ជាប់ និង
សសរថ្មកែវដោយក្រវិលប្រាក់ ក៏មានកៅអីធ្វើពីមាស និង
ពីប្រាក់ ដាក់លើកំរាលថ្មកែវពណ៌ក្រហម ស លឿង ហើយ
ខ្មៅដែរ ៧ គេឱ្យផឹកដោយប្រដាប់[ជ]មាសដែលផ្សេងពីគ្នា
ទាំងអស់ ហើយមានស្រាទំពាំងបាយជូររបស់ហ្លួងជា
បរិបូរតាមសណ្ឋានស្តេច[ឈ] ៨ តែគ្មានអ្នកណាបង្ខំឡើយ
ដ្បិតស្តេចទ្រង់បានចេញច្បាប់ បង្គាប់ដល់ពួកភ្នាក់ងាររបស់
ទ្រង់ ឱ្យបានធ្វើតាមចិត្តរបស់មនុស្សនីមួយៗ ។
៩ ឯព្រះនាងវ៉ាសធី ជាអគ្គមហេសី ក៏ជប់លៀង[ញ]ដល់ពួក
ស្រីៗ នៅក្នុងព្រះរាជដំណាក់របស់ស្តេចអ័ហាស៊ូរុសដែរ
១០ លុះដល់ថ្ងៃទី៧ ក្នុងកាលដែលស្តេចទ្រង់មានព្រះទ័យ
សប្បាយ[ដ]ដោយស្រា[ឋ] នោះទ្រង់បង្គាប់ដល់មហ៊ូម៉ានប៊ីលថា
ហាបូណា[ឌ] ប៊ីកថា អ័បាកថា សេថារ និងកើកាស ជាពួក
ក្រមវាំងទាំង៧នាក់ ជាអ្នកដែលបំរើនៅចំពោះ ស្តេច
អ័ហាស៊ូរុស ១១ ឱ្យទៅនាំ[ឍ]ព្រះនាងវ៉ាសធី ជាអគ្គមហេសី
មកនៅចំពោះទ្រង់ មានទាំងពាក់មកុដផង ដើម្បីនឹងសំដែង
លំអព្រះរូប[ណ]ដល់បណ្តាជន និងដល់ពួកអ្នកជាប្រធានទាំង
ឡាយ ពីព្រោះព្រះនាងមានរូបឆោមល្អពេកណាស់ ១២ តែ
ព្រះនាមវាសធីមិនព្រមមកតាមបង្គាប់ស្តេច ដោយសារពួក
ក្រមវាំងនោះទេ ហេតុនោះស្តេចទ្រង់ក្រេវក្រោធ ជាខ្លាំង
ហើយសេចក្តីកំហឹងនោះក៏ឆួលឆេះឡើងក្នុងព្រះទ័យទ្រង់[ត]

**១:១** ក អរ ៤:៦ ខ នអ ៩:៣០ ដយ ៣:២ ៦:១ គ នអ ៨:៩
**១:២** ឃ អរ ៤:៩ នអ ២:៨
**១:៣** ង ១ពវ ៣:១៥
**១:៥** ច ពច ១៤:១៧ ឆ ២ពវ ២១:១៨
**១:៦** ជ នអ ៧:៨ អគ ២៣:៤១ អម ៣:១២ ៦:៤
**១:៧** ឈ នអ ២:១៨ ដយ ៥:២
**១:៩** ញ ១ពវ ៣:១៥
**១:១០** ដ ពច ១៦:២៥ នរ ៣:៧ ឋ លប ១៤:១៨ នអ ៣:១៥ ៥:៦ ៧:២ សភ ៣១:៤–៧ ដយ ៥:១–៤ ឌ នអ ៧:៩
**១:១១** ឍ ២:៤ ណ ទដ ៤៥:១១ អគ ១៦:១៤
**១:១២** ត លប ៣៩:១៩ នអ ២:២១ ៧:៧ សភ ១៩:១២

**១:១** *អ័ហាស៊ូរុស* ស្តេចចក្រភពពើស៊ី អង្គនេះ បានស្នងរាជ្យពីព្រះបិតាព្រះនាម ដារីយ៉ូស ហើយបានសោយរាជ្យពីឆ្នាំ ៤៨៦ ដល់ ៤៦៥ មុនគ.ស ។ *១២៧ ខេត្ត* មើល ៨:៩ ។ តាមការកត់ត្រារបស់អ្នកប្រវត្តិសាស្ត្រក្រិកឈ្មោះ ហេរ៉ូដូទ័ស (Herodotus) ស្តេចដារីយ៉ូស ដែលជាព្រះបិតារបស់ស្តេចអ័ហាស៊ូរុស បានបែងចែកការគ្រប់គ្រងចក្រភពរបស់ទ្រង់ជា ២០ ខេត្ត ។ (បទគម្ពីរ ៣:១២ ៨:៩ ៩:៣ បាននិយាយអំពីពួកចៅហ្វាយខេត្ត)។ បណ្តាខេត្តទាំងនោះ គឺសម្រាប់គ្រប់គ្រងដោយរដ្ឋបាលថ្នាក់បន្ទាប់ ។

**១:២** *ស៊ូសាន ជាទីក្រុងហ្លួង* ជាទីមានកំផែងការពារ និងបរិវេណព្រះរាជវាំង គឺខុសពីទីក្រុងដែលនៅជុំវិញ ដែលមាននិយាយនៅក្នុង ៣:១៥ ៨:១៤–១៥ ។ មានការស្រាវជ្រាវផ្នែកបុរាណវត្ថុវិជ្ជា នៅតំបន់នោះ នៅពាក់កណ្តាលនៃសតវត្សទី ១៩ ។ ស្តេចអ័ហាស៊ូរុស បានធ្វើការជួសជុលសំណង់នៃព្រះរាជវាំង ជាទ្រង់ទ្រាយធំ ។ *ស៊ូសាន* គឺជាដំណាក់រដូវរងាររបស់ពួកស្តេចចក្រភពពើស៊ី (មើលការពន្យល់ អរ ៤:៩)។ ទីក្រុងបីទៀតមានដូចជា អាក់បេថា (មើល អរ ៦:២ និងការពន្យល់) បាប៊ីឡូន និងព័រសេប៉ូលីស (Persepolis)។ លោកដានីយ៉ែលបានទទួលការបើកសម្តែង នៅក្រុងស៊ូសាន (ដយ ៨:២) ហើយលោកនេហេមាក៏បានធ្វើការបម្រើស្តេច នៅទីនោះផងដែរ (នហ ១:១)។

**១:៣–៤** ដោយយោងទៅលើ ឆ្នាំនៃការប្រជុំ (៤៨៣–៤៨២ មុនគ.ស) អ្នកដែលចូលរួម និងរយៈពេលនៃការប្រជុំនោះ គេសន្និដ្ឋានថា ការជួបជុំគ្នាអាចដើម្បីធ្វើផែនការបង្កវិនាសកម្មដោយសង្គ្រាមនៅឆ្នាំ ៤៨២–៤៧៩ មុនគ.ស មកលើនគរក្រិក ។

**១:៣** *ជប់លៀង* ខ្លឹមសារសំខាន់ នៅក្នុងព្រះគម្ពីរនាងអេសធើរ គឺនិយាយអំពីពិធីជប់លៀង (មើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ)។

**១:៥–៦** ការស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យានៅក្រុងស៊ូសាន បានរកឃើញអត្ថបទមួយ ដែលក្នុងនោះ ស្តេចដារីយ៉ូសដែលជាបិតាស្តេចអ័ហាស៊ូរុស បានពិពណ៌នាជាលម្អិតអំពីសំណង់នៃព្រះរាជវាំងទ្រង់ ។ ស្តេចអ័ហាស៊ូរុស បានបន្តការរាជកិច្ចដែលបិតាទ្រង់បានចាប់ផ្តើម ។

**១:៩** *ព្រះនាងវ៉ាសធី* ព្រះនាងត្រូវបានទម្លាក់ពីតំណែងនៅឆ្នាំ ៤៨៤ ឬ ៤៨៣ មុនគ.ស ហើយនាងអេសធើរបានក្លាយជាអគ្គមហេសីនៅឆ្នាំ ៤៧៩ ឬ ៤៧៨ មុនគ.ស (២:១៦–១៧)។ ពួកប្រវត្តវិទូក្រិកបានហៅអគ្គមហេសីរបស់ស្តេចអ័ហាស៊ូរុសថា ព្រះនាងអាមេសទ្រីស (Amestris) ហើយបានកត់ត្រាអំពីឥទ្ធិពលដែល ព្រះនាងមាននៅផ្នែកដំបូងនៃរាជ្យស្តេចអង្គនេះ និងអំពីការធ្វើជាព្រះមាតា នៃស្តេចអើថាស៊ើកសេស (អរ ៧:១,៧,១១–១២,២១ ៨:១ នហ ២:១ ៥:១៤ ១៣:៦) នៅក្នុងរជ្ជកាលទ្រង់ រហូតដល់ព្រះនាងសុគតប្រហែលជានៅឆ្នាំ ៤២៤ មុនគ.ស ។ ស្តេចអើថាស៊ើកសេសឡើងសោយរាជ្យ នៅពេលដែលទ្រង់មានព្រះជន្ម ១៨ ឆ្នាំ ដូចនេះ ទ្រង់ប្រហែលជាបានប្រសូត្រនៅឆ្នាំ ៤៨៤ ឬ៤៨៣ មុនគ.ស ប្រហែលជានៅពេលដែលព្រះនាងវ៉ាសធីត្រូវធ្លាក់ពីមុខតំណែង ។ ដោយសារទ្រង់ជាបុត្រាទីបីនៃព្រះនាងអាមេសទ្រីស (Amestris) ដូចនេះ ឈ្មោះ អាមេសទ្រីស មិនមែនជាឈ្មោះរបស់នាងអេសធើរទេ ហើយគេត្រូវដឹងថា ឈ្មោះនេះ គឺជាព្រះនាមរបស់ព្រះនាងវ៉ាសធី ដែលគេហៅតាមភាសាក្រិក ។ គេពុំទាន់បានដឹងច្រើនអំពីផ្នែកចុងក្រោយនៃរាជ្យស្តេចអ័ហាស៊ូរុស ឬអាចកំណត់អំពីព្រឹត្តការណ៍ជាបន្តបន្ទាប់ ដែលកើតឡើងនៅក្នុងជីវិតរបស់នាងអេសធើរនៅឡើយទេ ។ គេជឿថា បន្ទាប់ពីនាងអេសធើរស្លាប់ ឬលែងមានការគាំទ្រ នោះព្រះនាងវ៉ាសធីមានអំណាចឡើងវិញ ហើយបន្តមានឥទ្ធិពលលើរាជ្យនៃបុត្រាទ្រង់។

[១៣]ដូច្នេះ ស្ដេចទ្រង់មានបន្ទូលសួរ ដល់ពួកអ្នកប្រាជ្ញាដែល
ស្គាល់សម័យប្រព្រឹត្ត ដ្បិតតាមទំលាប់របស់ស្ដេចទ្រង់តែង
តែពិគ្រោះនឹងពួកអ្នកដែលចេះស្ទាត់ខាងច្បាប់ និងសេចក្ដី
វិនិច្ឆ័យ[ថ] [១៤]រីឯបន្ទាប់នឹងទ្រង់មានកើសេណា សេថារ
អ័ឌម៉ាថា តើសីស មេរេស ម៉ាសេណា និងមមូកាន ជា
នាយក[ទ]នៃសាសន៍ពើស៊ី និងសាសន៍មេឌីទាំង៧នាក់ ដែល
ធ្លាប់នៅចំពោះស្ដេច ហើយជាអ្នកលេខ១ក្នុងនគរ [១៥]ទ្រង់
សួរថា តាមច្បាប់ តើត្រូវធ្វើដូចម្ដេចដល់ព្រះនាងវ៉ាសធី ជា
អគ្គមហេសី ដ្បិត ព្រះនាងមិនបានធ្វើតាមបង្គាប់យើង
ដោយសារពួកក្រមវាំងទេ [១៦]នោះមមូកាន លោក
ទូលឆ្លើយនៅចំពោះស្ដេច និងពួកនាយកទាំងប៉ុន្មានថា
អគ្គមហេសី ព្រះនាងបានប្រព្រឹត្តខុស មិនមែនត្រឹមតែនឹង
ព្រះករុណាប៉ុណ្ណោះ គឺដល់ទាំងពួកអ្នកជាប្រធាន និង
បណ្ដាជនទាំងឡាយ ដែលនៅអស់ទាំងខេត្តរបស់ព្រះ
ករុណាទៀត [១៧]ដ្បិតការដែលអគ្គមហេសីប្រព្រឹត្តនេះ នឹង
ឮទៅដល់ពួកស្រីៗទាំងអស់ បណ្ដាលឱ្យគេមើលងាយដល់ប្ដី
របស់ខ្លួនគ្រប់គ្នា ដោយដំណឹងនេះបានផ្សាយទៅថា ស្ដេច
អ័ហាស៊ូរុសបានបង្គាប់ឱ្យគេនាំព្រះនាង ជាអគ្គមហេសី មក
ចំពោះទ្រង់ តែព្រះនាងមិនព្រមស្ដេចមកទេ [១៨]ហើយនៅ
ថ្ងៃនេះ ពួកខុនណាងសាសន៍ពើស៊ី និងសាសន៍មេឌីទាំង
ប៉ុន្មាន ដែលឮនិយាយ ពីការអគ្គមហេសីបានធ្វើនេះ គេនឹង
ប្រកែកដល់ប្ដីខ្លួន ជាពួកប្រធាននៃស្ដេចដូច្នោះដែរ យ៉ាង
នោះនឹងកើតមានសេចក្ដីមើលងាយ និងសេចក្ដីកំហឹងជា
ច្រើន[ធ] [១៩]បើសិនជាព្រះករុណាសព្វព្រះទ័យ[ន] នោះសូម
ទ្រង់ចេញព្រះរាជឱង្ការ ព្រមទាំងឱ្យគេកត់ទុកក្នុងច្បាប់
របស់សាសន៍ពើស៊ី និងសាសន៍មេឌីផង ដើម្បីកុំឱ្យផ្លាស់
បានឡើយ[ប] ហាមមិនឱ្យព្រះនាងចូលមកចំពោះព្រះករុណា
ទៀត ហើយសូមព្រះករុណាប្រគល់ដំណែងយសហ្លួងរបស់
ព្រះនាងដល់ស្ត្រីម្នាក់ទៀតដែលវិសេសជាង [២០]ដូច្នេះ កាល
ណាព្រះរាជឱង្ការរបស់ស្ដេចបានប្រកាសផ្សាយទៅគ្រប់
ក្នុងនគរទ្រង់ (រីឯនគរទ្រង់នោះធំណាស់) នោះស្ត្រីទាំង
អស់នឹងគោរពប្រតិបត្តិដល់ប្ដីខ្លួន ទោះទាំងធំទាំងតូចផង
[២១]សេចក្ដីនោះក៏គាប់ដល់ព្រះទ័យស្ដេច និងចិត្តនៃពួក
នាយកផង រួចស្ដេចទ្រង់ក៏ធ្វើតាមពាក្យរបស់មមូកាន
[២២]ទ្រង់ផ្ញើព្រះរាជសារទៅ ដល់អស់ទាំងខេត្តរបស់ស្ដេច
គឺដល់គ្រប់ទាំងខេត្តតាមអក្សរជាតិរបស់គេ ហើយទៅគ្រប់
ទាំងសាសន៍ តាមភាសារបស់គេ បង្គាប់ថា មនុស្សប្រុសៗ
ត្រូវធ្វើម្ចាស់លើផ្ទះរបស់ខ្លួន ហើយសេចក្ដីនោះក៏បាន
ប្រកាសទូទៅ តាមភាសារបស់ជនគ្រប់ជាតិ ។

## នាងអេសធើរត្រូវតែងតាំងជាមហេសី

**២** [១]ក្រោយការទាំងនោះមក កាលសេចក្ដីក្រោធរបស់
ស្ដេចអ័ហាស៊ូរុសបានសប់ហើយ[ក]នោះទ្រង់ក៏នឹករឭកដល់ព្រ
ះនាងវ៉ាសធី និងការដែលព្រះនាងបានធ្វើ ព្រមទាំងខ
សេចក្ដី ដែលបានសំរេចដល់ព្រះនាងផង [២]នោះពួក
មហាតលិកទាំងឡាយដែលបំរើស្ដេចក៏ទូលទ្រង់ថា សូម
ទ្រង់ឱ្យគេទៅរកស្ត្រីក្រមុំ ដែលមានរូបស្រស់ល្អមកថ្វាយ
ទ្រង់ [៣]សូមព្រះករុណាចាត់ដំរូវឱ្យមានភ្នាក់ងារ នៅគ្រប់
ខេត្តក្នុងនគរទ្រង់ ដើម្បីនឹងប្រមូលស្ត្រីក្រមុំ ដែលស្រស់ល្អ
ទាំងប៉ុន្មាន មកឯស៊ូសាន ជាទីក្រុងហ្លួង ឱ្យនៅក្នុងមន្ទីរ
សំរាប់ពួកស្រីៗ ក្រោមអំណាចហេកាយ ជាក្រមវាំងរបស់
ស្ដេច ជាអ្នករក្សាពួកស្រីៗ រួចឱ្យគេបើកគ្រឿងសំរាប់ជិរះ

**១:១៣** ថ ១របា ១២:៣២
**១:១៤** ទ អរ ៧:១៤
**១:១៨** ធ សភ ១៩:១៣ ២៧:១៥
**១:១៩** ន សស ៨:៤ ប នអ ៨:៨ ដយ ៦:៨,១២
**១:២២** ផ នហ ១៣:២៤
**២:១** ក នអ ៧:១០

**១:១៣–១៤** តាម អរ ៧:១៤ និងប្រវត្តវិទូ ឈ្មោះហេរ៉ូដូទ័ស (Herodotus) អ្នកទាំងប្រាំពីរនាក់នោះ មានតួនាទីជាទីប្រឹក្សាផ្ទាល់ដែលត្រូវត្រៀមថ្វាយការប្រឹក្សាដល់ស្ដេចភ្លាមៗ ។

**១:១៩** *ដើម្បីកុំឱ្យផ្លាសបានឡើយ* លក្ខណៈមិនអាចកែប្រែបាននៃច្បាប់របស់ចក្រភពពើស៊ី មានចែងនៅក្នុង ៨:៨ និង ដយ ៦:៨,១២ ។ *ហាមមិនឱ្យព្រះនាងចូលមក... ទៀត* ព្រះនាងវ៉ាសធីបានប្រព្រឹត្តបទឧក្រិដ្ឋ ដោយបដិសេធមិនព្រមចូលមកតាមបង្គាប់ស្ដេច នាំឱ្យទទួលទោស ដែលមិនអាចចូលគាល់ទ្រង់ទៀត ។ ជាងនេះទៅទៀត នៅក្នុងព្រះគម្ពីរនាងអេសធើរ ចាប់ពេលនោះមកព្រះនាងត្រូវបាត់បង់តំណែងជាអគ្គមហេសី ។

**១:២២** *បង្គាប់ថា... ផ្ទះ* ឬមានន័យថា "មនុស្សប្រុសៗជាប្ដីត្រូវធ្វើជាម្ចាស់លើផ្ទះរបស់ខ្លួន ហើយត្រូវប្រើពួកអ្នកផ្ទះត្រូវប្រើភាសាកំណើតរបស់ពួកប្រុសៗជាប្ដី"។ ន័យនេះគឺសំដៅទៅលើប្រពៃណីយរៀបអាពាហ៍ពិពាហ៍រវាងសាសន៍ផ្សេងគ្នា ដោយប្រើភាសារបស់ប្ដី ជាសញ្ញាបញ្ជាក់ថា ប្ដីជាអ្នកគ្រប់គ្រងផ្ទះ (មើល នហ ១៣:២៣–២៥) ។

**២:១** *ក្រោយការទាំងនោះមក* គេបានយកនាងអេសធើរទៅថ្វាយស្ដេចអ័ហាស៊ូរុស "នៅឆ្នាំទី៧នៃរាជ្យទ្រង់" (ខ.១៦) នៅខែធ្នូ ឆ្នាំ ៤៧៩ មុនគ.ស ឬមករា ឆ្នាំ ៤៧៨ មុនគ.ស ។ ចក្រភពពើស៊ីបានលូកដៃចូលក្នុងសង្គ្រាមរបស់ពួកក្រិក មុនពេលជ្រើសរើសអគ្គមហេសីថ្មី (ការពន្យល់ ១:៣–៤) ។

**២:២** *ស្ត្រីក្រមុំ* ដើម្បីបញ្ចូលបន្ថែមក្នុងដំណាក់ពួកស្នំរបស់ទ្រង់ ។

**២:៣–៤** វគ្គនេះ បានប្រើពាក្យស្រដៀងគ្នានឹងបទគម្ពីរ លប ៤១:៣៤–៣៧។ ដោយយោងទៅលើបទគម្ពីរទាំងនេះ និងបទគម្ពីរយោងផ្សេងៗទៀត គេបានសន្និដ្ឋានថា អ្នកនិពន្ធព្រះគម្ពីរនាងអេសធើរបាននិពន្ធព្រះគម្ពីរនេះ ដោយយកគំរូតាមការនិពន្ធនៃរឿងលោកយ៉ូសែប (សេចក្ដីផ្ដើមត្រង់ចំណុចគោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ)។ រឿងទាំងពីរសុទ្ធតែបាននិយាយអំពីជីវិតនៅក្នុងរាជវាំងនៃពួកស្ដេចនៃសាសន៍ដទៃ ហើយបានពិពណ៌នាអំពីវីរៈបុរស និងនារីនៃសាសន៍អ៊ីស្រាអែលដែលបានទទួលមុខតំណែងធំ ហើយបានប្រើមុខតំណែងនោះដើម្បីជួយសង្គ្រោះសាសន៍របស់ខ្លួន (មើលការពន្យល់ ខ.៩,២១–២៣ ៣:៤ ៤:១៤ ៦:១,៨,១៤ ៨:៦) ។

ខ្លួនដល់នាងទាំងនោះ ៤រួចមកឯនាងណាដែលសព្វព្រះ
ទ័យដល់ព្រះករុណា នោះសូមទ្រង់តាំងឡើងឱ្យធ្វើជា
អគ្គមហេសី ជំនួសព្រះនាងវ៉ាសធីនោះ ស្ដេចទ្រង់សព្វព្រះ
ទ័យនឹងសេចក្ដីនោះ ហើយក៏ធ្វើតាមដូច្នោះ ។
៥រីឯនៅស៊ូសាន ជាទីក្រុងហ្លួង មានសាសន៍យូដាម្នាក់
ឈ្មោះម៉ាដេកាយ ជាកូនយ៉ាអ៊ារ ដែលជាកូនស៊ីម៉ាយៗជា
កូនគីស ក្នុងពូជបេនយ៉ាមីន[ខ] ៦គាត់ត្រូវដឹកនាំចេញពីទីក្រុង
យេរូសាឡិមជាមួយនឹងពួកឈ្លើយ ដែលបាននាំទៅ ក្នុង
គ្រាដែលនេប៊ូក្នេសា ជាស្ដេចបាប៊ីឡូនបានចាប់យេកូនាស[គ]
ជាស្ដេចយូដានាំយកទៅ[ឃ] ៧គាត់បានចិញ្ចឹមនាង ហាដាសា
គឺអេសធើរ[ង] ជាកូនរបស់មាគាត់ ដ្បិតនាងគ្មានឪពុកម្ដាយ
នាងមានរូបឆោមឆាយ ហើយមុខស្រស់ល្អ[ច] កាលឪពុក
ម្ដាយនាងស្លាប់ទៅហើយ នោះម៉ាដេកាយបានយកនាង
មកចិញ្ចឹមទុកជាកូនខ្លួន ។
៨ដូច្នេះ កាលគេបានប្រកាសប្រាប់ព្រះរាជឱង្ការ និង
ច្បាប់របស់ស្ដេច ហើយបានប្រមូលស្រីក្រមុំជាច្រើនមក
ឯស៊ូសាន[ឆ] ជាក្រុងហ្លួង ប្រគល់ក្រោមអំណាចហេកាយ
នោះគេក៏នាំយកអេសធើរទៅក្នុងដំណាក់ស្ដេច ប្រគល់
ក្រោមអំណាចហេកាយ ជាអ្នករក្សាពួកស្រីៗដែរ ៩នាង
ជាទីពេញចិត្តដល់គាត់ណាស់[ច] គាត់ក៏សំដែងសេចក្ដី
សប្បុរសដល់នាង[ឈ] ក៏ប្រញាប់នឹងចែកគ្រឿង សំរាប់ឱ្យ
នាងជំរះខ្លួននឹងប្រដាប់តែងកាយ ដែលជាចំណែករបស់
នាង ព្រមទាំងយកស្ត្រីក្រមុំ៧នាក់ ពីព្រះរាជដំណាក់មកឱ្យ
បំរើនាង ហើយគាត់ក៏ផ្លាស់នាង និងស្រីបំរើទាំងនោះ ឱ្យ
ទៅនៅក្នុងបន្ទប់ល្អបំផុតក្នុងបន្ទប់ល្អបំផុតក្នុងមន្ទីរពួក ស្រីៗ

**២:៥** ខ ១សយ ៩:១
**២:៦** គ ២ពវ ២៤:៦,១៥ ឃ ដយ ១:១-៥ ៥:១៣
**២:៧** ង លប ៤១:៤៥ ច លប ៣៩:៦
**២:៨** ឆ នហ ១:១ នអ ១:២ ដយ ៨:២
**២:៩** ជ លប ៣៩:២១ ឈ លប ៣៧:៣ ១សយ ៩:២២-២៤ ២ពវ ២៥:៣០ នអ ៩:១៩ អគ ១៦:៩-១៣ ដយ ១:៥

**២:៥** *ស៊ូសាន ជាទីក្រុងហ្លួង មានសាសន៍យូដាម្នាក់* តាំងពីយូរមកហើយ ចក្រភពអាសសើរបាននិរទេស ពួកសាសន៍អ៊ីស្រាអែលទៅទីក្រុងរបស់សាសន៍មេឌី(២ពវ ១៧:៦) បន្ទាប់ពីនគរខាងជើងត្រូវដួលរលំនៅឆ្នាំ ៧២២-៧២១ មុនគ.ស ។ គេជឿថា បន្ទាប់ពីស្ដេចស៊ីរុស នៃចក្រភពពើស៊ី បានវាយកាន់កាប់បានចក្រភពបាប៊ីឡូន ក្នុងឆ្នាំ ៥៣៩ មុនគ.ស ពួកសាសន៍យូដាមួយចំនួនដែលពួកបាប៊ីឡូនបានចាប់ជាឈ្លើយ(ឆ្នាំ ៦០៤-៥៨៦ មុនគ.ស)បញ្ជូនទៅក្រុងបាប៊ីឡូន បាននាំគ្នាធ្វើដំណើរទៅទិសខាងកើតឆ្ពោះទីក្រុងមេដូ-ពើស៊ី ។ មានតែពួកអ៊ីស្រាអែល ៥ ម៉ឺននាក់ប៉ុណ្ណោះ ដែលបានវិលត្រឡប់ទៅទឹកដីអ៊ីស្រាអែល ដើម្បីស្អាងព្រះវិហារឡើងវិញនៅឆ្នាំ ៥៣៨ ឬ ៥៣៧ មុនគ.ស(អរ ២:៦៤-៦៥)។ មានពួកសាសន៍អ៊ីស្រាអែលជាច្រើនបានរស់នៅក្នុងក្រុងមេដូ-ពើស៊ី នោះបើតាមការបញ្ជាក់ពីអត្ថបទដែលគេរកឃើញនៅតំបន់នីពួរ (Nippur ភូមិភាគខាងជើងនៃតំបន់មេសូប៉ូតាមា) ដែលបានសរសេរ នៅចន្លោះរាជ្ជកាលស្ដេចអើថាស៊ើកសេស ទី១(៤៦៥-៤២៤ មុនគ.ស) និងរជ្ជកាលស្ដេចដារីយ៉ូ ទី២(ឆ្នាំ ៤២៤-៤០៥ មុនគ.ស)។ នៅក្នុងអត្ថបទនោះ មានសរសេរឈ្មោះពួកអ៊ីស្រាអែលប្រហែល ១០០ នាក់ ដែលបានរស់នៅក្នុងទីក្រុងនោះ និងមានខ្លះជាឥសរៈជន ហើយមានទ្រព្យច្រើន ។ នៅក្នុងទីក្រុងជាច្រើនទៀតរបស់សាសន៍មេដូ-ពើស៊ី ក៏មានពួកអ៊ីស្រាអែលរស់នៅច្រើនផងដែរ ។ *ម៉ាដេកាយ* ឈ្មោះនេះក្លាយមកពីពាក្យម៉ាឌូក(Marduk) ដែលជានាមរបស់ព្រះនៃសាសន៍បាប៊ីឡូន ។ នៅក្នុងព្រះគម្ពីរមានឧទាហរណ៍ជាច្រើនទៀតអំពី ការដែលពួកអ៊ីស្រាអែលខ្លះមានឈ្មោះពីរ គឺឈ្មោះមួយជាភាសាហេព្រើ ហើយមួយទៀតជាភាសាសាសន៍ដទៃ ។ ព្រះគម្ពីរនេះមិនបាននិយាយអំពីឈ្មោះជាភាសាហេព្រើ របស់លោកម៉ាដេកាយទេ តែគេជឿថា លោកម៉ាដេកាយមានឈ្មោះជាភាសាហេព្រើផងដែរ គឺដូចដែលនាងអេសធើរ(ខ.៧) លោកដានីយ៉ែល និងមិត្រភ័ក្ត្ររបស់គាត់(ដយ ១:៦-៧) លោកយ៉ូសែប(លប ៤១:៤៥)និងអ្នកផ្សេងទៀតសុទ្ធតែមានឈ្មោះជាភាសាហេព្រើ ។ តាមបន្ទះដីឥដ្ឋដែលមានចារិកអក្សរមួយផ្ទាំង ដែលគេរកឃើញនៅតំបន់បូរស៊ីបប៉ា(Borsippa) ដែលមានទីតាំងនៅក្បែទីក្រុងបាប៊ីឡូន មានអ្នកប្រាជ្ញច្បាប់ម្នាក់ឈ្មោះ ម៉ាឌូកាយ៉ា (Mardukaya) ជាហិរញ្ញិក ឬរដ្ឋមន្ត្រីដែលធ្វើការនៅរាជវាំងនៅក្រុងស៊ូសាន នៅផ្នែកដំបូងនៃរាជ្យស្ដេចអ័ហាស៊ូរុស ។ អ្នកកាត់ស្រាយខ្លះបានជឿថា គាត់គឺជាលោកម៉ាដេកាយ ។ *កូនយ៉ាអ៊ារ ដែលជាកូនស៊ីម៉ាយៗ ជាកូនគីស* ដែលមានឈ្មោះទាំងប៉ុន្មានអ្នកនេះអាចជាអ្នកជំនាន់មុនៗ ដែលក្នុងនោះ លោកម៉ាដេកាយគឺជាចៅទួតរបស់លោកគីស ដែលជាអ្នកដែលបាននិទេសខ្លួនជាមួយនឹងស្ដេចយេហូយ៉ាគីមនៅឆ្នាំ ៥៩៧ មុនគ.ស ប៉ុន្តែ ឈ្មោះទាំងនេះអាចជារបស់អ្នកជំនាន់មុន ដែលបានរស់នៅក្នុងសម័យដ៏យូរលុងនៅក្នុងពូជអំបូបេនយ៉ាមីន(មើល ២សយ ១៦:៥ ចំពោះឈ្មោះ ស៊ីម៉ាយ ហើយ ១សយ ៩:១ ចំពោះឈ្មោះ គីស)។ ការជាប់ខ្សែរស្រឡាយនឹងពូជអំបូ និងរាជវង្សរបស់ស្ដេចសូលនេះ បាននាំឱ្យបន្តពួកអ៊ីស្រាអែល និងពួកអាម៉ាឡេកបន្តធ្វើជាសត្រូវនឹងគ្នា(មើលការពន្យល់ ៣:១-៦)។ បើពួកគាត់ជាអ្នកជំនាក់មុនដែលបានរស់នៅក្នុងសម័យដ៏យូលុងមែននោះ នោះពាក្យ "គាត់"នៅក្នុង ខ.៦ គឺមិនមែនសំដៅទៅលើលោកម៉ាដេកាយទេ តែសំដៅទៅលើគ្រួរបស់គាត់វិញ ដែលត្រូវដឹកនាំចេញពីទីក្រុងយេរូសាឡិម ជាមួយនឹងពួកឈ្លើយ ។

**២:៦** *ត្រូវដឹកនាំចេញ... ពួកឈ្លើយ* គឺនៅឆ្នាំ ៥៩៧ មុនគ.ស ។ *យេកូនាសជាស្ដេចយូដា* មើល ២ពវ ២៤:៨-១៧ ២របា ៣៦:៩-១០ ។

**២:៧** *នាងហាដាសា* គឺជាឈ្មោះជាភាសាហេព្រើ របស់នាងអេសធើរ ដែលមានន័យថា "ចុល្លព្រឹក្សាម្យ៉ាង ដែលមានផ្កាពណ៌ស"។ គេជឿថា ឈ្មោះ អេសធើរ មានប្រភពមកពីពាក្យ "ផ្កាយ" នៃភាសាពើស៊ី តែអ្នកខ្លះជឿថា ឈ្មោះរបស់នាង មានប្រភពមកពីពាក្យ "អ៊ីសតា" ដែលជាឈ្មោះនៃព្រះស្រីនៃពួកបាប៊ីឡូន(មើលការពន្យល់ យរ ៧:១៨)។

**២:៨** *នាំយកនាងអេសធើរ* នាងអេសធើរ និងលោកម៉ាដេកាយសុទ្ធតែគ្មានជម្រើស នៅក្នុងរឿងនេះ(ធៀបនឹង ២សយ ១១:៤)។

**២:៩** *ចែកគ្រឿង* ការផ្ដល់ឱ្យដូចនេះ គឺជាសញ្ញាបញ្ជាក់ពីការពេញចិត្តដ៏ពិសេស (១សយ ៩:២២-២៤ ២ពវ ២៥:២៩-៣០ ដយ ១:៥-១០ ចំពោះការមិនពេញចិត្ត មើល យរ ១៣:២៥) ដែលមាននៅក្នុងការពិពណ៌នាអំពីលោកយ៉ូសែបផងដែរ(ធៀបនឹង លប ៤៣:៣៤ និងការពន្យល់)។ ការផ្ដល់ឱ្យ ឬធ្វើទាន មាននិយាយម្ដងទៀត នៅក្នុងការនិយាយអំពីពិធីបុណ្យពោរ (មើល ៩:១៩,២២)។

១០ឯអេសធើរ នាងមិនបានប្រាប់ឱ្យអ្នកណាដឹងថា គ្រួ
និងជំនួរវង្សរបស់នាងជាសាសន៍អ្វីទេ ដ្បិតម៉ាដេកាយបាន
ហាមមិនឱ្យនាងប្រាប់ឱ្យគេដឹងឡើង[ញ] ១១ឯម៉ាដេកាយគាត់
ក៏តែងដើរទៅ មកនៅមុខទីធ្លាមន្ទីរពួកស្រីៗជារាល់ថ្ងៃ
ដើម្បីឱ្យដឹងជាអេសធើរជាយ៉ាងណា ហើយនឹងបានទៅ
ជាអ្វី ។
១២រីឯតាមទំនៀមពួកស្រីៗ នោះពេលដែលជិរះខ្លួន
ត្រូវអស់រវាង១២ខែ គឺ៦ខែដោយប្រេងល្វីងទេស ហើយ
៦ខែដោយគ្រឿងក្រអូប[ដ]ផ្សេងៗ ព្រមទាំងគ្រឿងអ្វីៗដែល
សំរាប់ឱ្យពួកស្រីៗបានស្អាតបរិសុទ្ធផង ដូច្នេះ ក្រោយដែល
គេបានធ្វើដល់នាងទាំងនោះតាមទំនៀម ហើយពេលដែល
នាងណាត្រូវចូលទៅឯស្តេចអ័ហាស៊ូរុសបានមកដល់
១៣នោះនាងបានចូលទៅឯស្តេចបែបយ៉ាងនោះឯង គឺអ្វីៗ
ដែលនាងប្រាថ្នាចង់បាន នោះក៏បានបើកឱ្យនាង ដើម្បីនឹង
យកពីមន្ទីរពួកស្រីៗទៅឯដំណាក់ស្តេច ១៤នៅពេលល្ងាច
នាងបានចេញទៅ ហើយដល់ព្រឹកឡើងនាងវិលមកវិញ
ចូលក្នុងមន្ទីរទី២របស់ពួកស្រីៗ នៅក្រោមអំណាចស្អាស
កាស ជាភ្នាក់ងាររបស់ស្តេចដែលរក្សាពួកស្រីអ្នកម្នាង[ឋ] នាង
នោះលែងបានចូលទៅចំពោះស្តេចទៀតហើយ លើកតែ
ស្តេចទ្រង់សព្វព្រះទ័យនឹងនាង ហើយហៅតាមឈ្មោះ
វិញ[ឌ]។
១៥ឯអេសធើរ កូនអ័ប៊ីហែល[ឍ] ជាមារបស់ម៉ាដេកាយ
ដែលបាន យកមកចិញ្ចឹមទុកជាកូនខ្លួន កាលដល់ពេល
ដែលនាងត្រូវចូលទៅឯស្តេច[ណ] នោះនាងមិនបានសូមអ្វី
ក្រៅពីរបស់ដែលហេកាយ ជាក្រមវាំងរបស់ស្តេច ជា
អ្នករក្សាពួកស្រីៗបានឱ្យនោះទេ ហើយអស់អ្នកណាដែល
ឃើញនាងក៏ពេញចិត្ត[ត]នឹងនាង ១៦គេក៏នាំអេសធើរចូល
ទៅថ្វាយស្តេចអ័ហាស៊ូរុស នៅក្នុងព្រះរាជដំណាក់ នៅខែ
ទី១០ គឺជាខែបុស្ស ក្នុងឆ្នាំទី៧នៃរាជ្យទ្រង់ ១៧ស្តេចទ្រង់ក៏
ស្រឡាញ់អេសធើរលើសជាងស្ត្រីឯទៀត ហើយនាងទទួល
បានព្រះគុណ និងសេចក្តីប្រោសប្រាណ នៅចំពោះទ្រង់
លើសជាងពួកស្រីក្រមុំទាំងប៉ុន្មាន ដល់ម៉្លេះបានជាទ្រង់
បំពាក់មកុដរាជ្យ តាំងនាងលើងជាអគ្គមហេសី[ថ]ជំនួស
វ៉ាសធី ១៨រួចស្តេចទ្រង់ជប់លៀងជាយ៉ាងធំ[ទ] ដល់អស់ទាំង
ពួកអ្នកជាប្រធាន និងពួកជំនិតទ្រង់ទាំងអស់[ធ] គឺជាការជប់
លៀងរបស់អេសធើរ ទ្រង់ក៏ប្រោស ឱ្យមនុស្សនៅគ្រប់ខេត្ត
បានឈប់សំរាក ហើយទ្រង់ដាក់ទានតាមសណ្ឋានស្តេច[ន]។

## លោកម៉ាដេកាយដឹងពីការក្បត់

១៩លុះដល់ពួកនាងក្រមុំបានប្រជុំគ្នាលើកទី២ នោះ
ម៉ាដេកាយ គាត់អង្គុយនៅត្រង់មាត់ទ្វារព្រះរាជវាំង[ប] ២០ឯ
អេសធើរ នាងមិនបានប្រាប់ឱ្យអ្នកណាដឹងពីគ្រួ និងពួក
ជំនួរវង្សរបស់ខ្លួនទេ តាមបង្គាប់របស់ម៉ាដេកាយ ពីព្រោះ
នាងនៅតែស្តាប់បង្គាប់ម៉ាដេកាយ ដូចនៅគ្រាដែលគាត់
ចិញ្ចឹមនៅឡើយ[ផ] ២១រីឯនៅគ្រានោះ កាលម៉ាដេកាយ
កំពុងតែអង្គុយនៅមាត់ទ្វារព្រះរាជវាំង នោះមានភ្នាក់ងា[ព]
របស់ស្តេច២នាក់ ឈ្មោះប៊ីកថាន និងថេរែស ក្នុងពួកអ្នក
ចាំយាមនៅមាត់ទ្វារព្រះរាជវាំង គេមានសេចក្តីកំហឹង[ភ]

**២:១០** ញ ខ.២០
**២:១២** ដ សភ ២៧:៩ ១:៣ អស ៣:២៤
**២:១៤** ឋ ១ពវ ១១:៣ ៦:៨ ដយ ៥:២ ឌ នអ ៤:១១
**២:១៥** ឍ នអ ៩:២៩ ណ ទដ ៤៥:១៤
ត លប ១៨:៣ ៣០:២៧ នអ ៥:៨ ៧:៣ ៨:៥
**២:១៧** ថ អគ ១៦:៩–១៣
**២:១៨** ទ ១ពវ ៣:១៥ ធ លប ៤០:២០ ន នអ ១:៧
**២:១៩** ប នអ ៤:២ ៥:១៣
**២:២០** ផ ខ.១០
**២:២១** ព លប ៤០:២ ភ នអ ១:១២ ៣:៥ ៥:៩ ៧:៧

**២:១០** មូលហេតុដែលនាងអេសធើរលាក់អត្តសញ្ញាណរបស់ខ្លួន មាននិយាយពីរដង គឺនៅក្នុងខនេះ និងខ.២០ (ចំពោះការនិយាយឡើងវិញរបស់អ្នកនិពន្ធអំពីចំណុចដដែល មើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ) ។

**២:១៤** *ចូលក្នុងមន្ទីរទី២* គឺទៅក្នុងដំណាក់របស់ពួកស្នំ ។

**២:១៣** ការដែលនាងអេសធើរចូលទៅឯស្តេច គឺពុំមានបាបឡើយ ។

**២:១៦** *នៅខែទី ១០ . . . ក្នុងឆ្នាំទី ៧* គឺនៅខែធ្នូ ឆ្នាំ ៤៧៩ មុនគ.ស ឬខែមករា ឆ្នាំ ៤៧៨ មុនគ.ស (មើលការពន្យល់ ១:៣–៤ ២:១) ។ ព្រះគម្ពីរនេះបាននិយាយបន្ត អំពីរយៈពេលនៃការធ្វើជាអគ្គមហេសីរបស់នាងអេសធើរ ដែលមានរហូតដល់ឆ្នាំ ៤៧៣ មុនគ.ស (មើល ៣:៧ និងការពន្យល់ និងមើល ៨:៩–១៣ ៩:១) ។ នាងអេសធើរប្រហែលជាស្លាប់ ឬលែងមានការគាំទ្រ នៅពេលដ៏ខ្លីក្រោយមក (មើលការពន្យល់ ១:៩) ។

**២:១៨** *ឈប់សំរាក* តាមព្រះគម្ពីរភាសាហេព្រើ ពាក្យនេះគឺសំដៅទៅលើការឱ្យរួចពន្ធ ការដោះលែងទាសករ ការលប់ចោលបំណុល ឬការឱ្យរួចពីកាតព្វកិច្ចចូលបម្រើកងទ័ព ។

**២:១៩** មើលសេចក្តីផ្តើមត្រង់ចំណុចគោលរឿង និងលក្ខណៈអក្សរសាស្ត្រ ។ ការពង្រើកដំណាក់ពួកស្នំ ការប្រជុំគ្នាជាលើកទី២ប្រហែលជាមូលហេតុដែលនាំឱ្យមានការរៀបគម្រោងធ្វើគុតស្តេច (ខ.២១–២៣) ដើម្បីជួយដល់ព្រះនាងវ៉ាសធីដែលធ្លាក់ពីដំណែងនោះ។ *មាត់ទ្វារព្រះរាជវាំង* នៅសម័យបុរាណ មាត់ទ្វារនៃទីក្រុង គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងច្បាប់នៃទីក្រុងនោះ ព្រោះមាត់ទ្វារគឺមានទីផ្សារ ហើយមានពួកធ្វើការនៅក្នុងតុលាការក៏អង្គុយ នៅទីនោះដើម្បីធ្វើអាជីវកម្មផងដែរ (មើល ចទ ២១:១៨–២០ យស ២០:៤ រម ៤:១–១១ ទដ ៦៩:១២) ។ ស្តេចអាចមានការប្រជុំជាផ្លូវការនៅទីនោះផងដែរ (មើល ២សយ ១៩:៨ ១ពវ ២២:១០) ។ លោកដានីយ៉ែលបានក្លាយជាអ្នកប្រចាំការនៅមាត់ទ្វាររបស់ស្តេច (រាជវាំងស្តេច) ក្នុងឋានៈជាចៅហ្វាយក្រុងបាប៊ីឡូន (ដយ ២:៤៨–៤៩) ។ ការដែលលោកម៉ាដេកាយអង្គុយនៅមាត់ទ្វាររបស់ស្តេច គឺបញ្ជាក់ថា គាត់មានមុខតំណែងធំនៅក្នុងការងារស៊ីវិល នៃចក្រភពនោះ (មើលការពន្យល់ ខ.៥) ។ គឺនៅទីនោះហើយ ដែលគាត់បានដឹងពីគម្រោងធ្វើគុតស្តេច ។

**២:២១–២៣** ក្នុងវគ្គនេះ ចំណុចដែលអាចប្រៀបធៀបនឹងការពិពណ៌នាអំពីលោកយ៉ូសែប គឺរឿងទាំងពីរសុទ្ធតែបាននិយាយអំពីអ្នកមើលការខុសត្រូវក្នុងរាជវាំង (លប ៤០:១–៣ មើលការពន្យល់ ខ.៣–៤) ។

ហើយរកឱកាសដល់ព្រះជន្មស្ដេច អ័ហាស៊ូរុស ២២រឿង
នោះក៏បានដឹងដល់ម៉ាដេកាយ ហើយគាត់ទូលអេសធើរ
ជាអគ្គមហេសី រួចអេសធើរ នាងទូលដល់ស្ដេច ដោយនូវ
ឈ្មោះម៉ាដេកាយ ២៣លុះកាលគេស៊ើបសួររកពីរឿងនោះ
ទៅ ក៏ឃើញពិតដូច្នោះមែន រួចគេចងកអ្នកទាំង២ព្យួរ[ម]
នៅដើមឈើ ហើយគេកត់រឿងនោះទុកក្នុងរបាក្សត្រ[យ]នៅ
ចំពោះស្ដេច[រ] ។

## គម្រោងរបស់ហាម៉ាន ដើម្បីបំផ្លាញពួកយូដា

៣ ១ក្រោយនោះមក ស្ដេចអ័ហាស៊ូរុសទ្រង់លើកដំកើង
ហាម៉ាន កូនហាំម្ដាថា ជាសាសន៍អ័កាក់[ក] ទាំងលើកលោក
ឡើងតាំងឱ្យមានងារជាធំលើសអស់ទាំងអ្នក ជាប្រធាន
ដែលនៅចំពោះទ្រង់ ២ដូច្នេះ ពួកមហាតលិករបស់ស្ដេច
ដែលនៅត្រង់មាត់ទ្វារព្រះរាជវាំង គេឱនខ្លួនចុះគោរព
ដល់ហាម៉ានទាំងអស់គ្នា ពីព្រោះស្ដេចទ្រង់បានចេញ
បង្គាប់ ពីដំណើរលោកយ៉ាងនោះ តែម៉ាដេកាយមិនបាន
ឱនខ្លួនទេ ក៏មិនគោរពផង ៣ដូច្នេះ ពួកមហាតលិករបស់
ស្ដេចដែលនៅត្រង់មាត់ទ្វារព្រះរាជវាំង គេសួរគាត់ថា
ហេតុអ្វីបានជាអ្នកទទឹងនឹងបង្គាប់ស្ដេច[ខ]ដូច្នេះ ៤រួចកាល
គេបានរំឭកដល់គាត់រាល់តែថ្ងៃ តែគាត់មិនព្រមស្ដាប់
តាម[គ] នោះគេក៏ជំរាបដល់ហាម៉ាន ដើម្បីនឹងលមើលបើ
សេចក្ដីដែល ម៉ាដេកាយប្រព្រឹត្តដូច្នោះ នឹងបាន ឬមិនបាន
ពីព្រោះគាត់បានប្រាប់ឱ្យគេដឹងហើយ ថាគាត់ជាសាសន៍
យូដា ៥កាលហាម៉ានឃើញថា ម៉ាដេកាយមិនឱនគោរព
ដល់ខ្លួនទេ នោះលោកមានចិត្តពេញដោយសេចក្ដីក្រោធ[ឃ]
៦តែលោកតោះតើយនឹងចង់ចាប់ម៉ាដេកាយតែ១ ប៉ុណ្ណោះ
ដ្បិតគេបានជំរាបឱ្យលោកជ្រាបពីសាសន៍របស់ម៉ាដេកាយ
ហើយ បានជាលោករកឱកាស[ង]នឹងបំផ្លាញ[ច]សាសន៍យូដា[ឆ]
ទាំងអស់បង់ ដែលមាននៅពេញក្នុងនគររបស់អ័ហាស៊ូរុស
ទាំងមូលវិញ គឺជាជាតិរបស់ម៉ាដេកាយទាំងប៉ុន្មាន ។
៧រីឯនៅឆ្នាំ១២ក្នុងរាជ្យអ័ហាស៊ូរុស គឺនៅខែទី១ ជា
ខែចេត្រ នោះគេវាយលេខតាមរបៀន[ជ] "ពោរ"[ឈ] នៅមុខ

**២:២៣** ម លប ៤០:១៩ ចទ ២១:២២–២៣ ទដ ៧:១៤–១៦ សភ ២៦:២៧ សស ១០:៨ យ នអ ៦:១ ១០:២ រ នអ ៦:២
**៣:១** ក នក ១៧:១៧:៨–១៦ ជន ២៤:៧ ចទ ២៥:១៧–១៩ ១សយ ១៤:៤៨
**៣:៣** ខ នអ ៥:៩ ដយ ៣:១២
**៣:៤** គ លប ៣៩:១០
**៣:៥** ឃ នអ ២:២១
**៣:៦** ង សភ ១៦:២៥ ច ទដ ៧៤:៨ ៨៣:៤ ឆ នអ ៩:២៤
**៣:៧** ជ នអ ៩:២៤,២៦ ឈ លវ ១៦:៨ ១សយ

**២:២៣** *ចងក* សំដៅទៅលើប្រពៃណីនៃការប្រហារជីវិតរបស់ពួកពើរស៊ីដោយព្យួរអ្នកទោស ហើយចាក់ដោយអាវុធស្រួច ទុកឱ្យឈើចាប់ និងហូរឈាមស្លាប់ ។ តាមប្រវត្តិវិទូ លោកហេរូដូទូស (Herodotus) នៅពេលដែលស្ដេចដារីយ៉ូសចូលវាយកាន់កាប់ក្រុងបាប៊ីឡូន ទ្រង់បានប្រហារជីវិតពួកបាប៊ីឡូន ៣000 នាក់ តាមរបៀបនេះ ដោយដៃទ្រង់ផ្ទាល់ ហើយបានឱ្យគេកត់ត្រាអំពីព្រឹត្តិការណ៍នេះនៅលើសិលាចារិកបេហ៊ុសទូន (Behistun) ។ តាមប្រពៃណីរបស់ពួកអ៊ីស្រាអែល និងពួកកាណាន ការព្យួរករគឺធ្វើឡើងដោយយកសាកសពមកព្យួរបង្ហាញដល់សាធារណៈជន គឺមិនជាការព្យួរករប្រហាជីវិតនោះទេ (ចទ ២១:២២–២៣ យស ៨:២៩ ១០:២៦ ១សយ ៣១:៨–១០ ២សយ ៤:១២) ។ គេបានសម្លាប់ពួកកូនប្រុសរបស់ហាម៉ានដោយដាវ ហើយព្យួរសពរបស់ពួកគេនៅលើបង្គោល (៩:៥–១៤) ។ ការពិពណ៌នាអំពីការប្រហាជីវិតនេះ គឺស្រដៀងនឹងការពិពណ៌នាអំពីការប្រហារជីវិតអ្នកដុតនំរបស់ស្ដេចផារ៉ោនផងដែរ (លប ៤0:១៩) ។ *របាក្សត្រ* អ្នកនិពន្ធបានសរសេររឿងនាងអេសធើរឱ្យមានលក្ខណៈស្មើរគ្នា ដោយនិយាយអំពីការកត់ត្រាទុកនៅក្នុងរបាក្សត្រនៅផ្នែកដំបូង (ខនេះ) ផ្នែកកណ្ដាល (៦:១) និងផ្នែកចុងក្រោយ (១០:២) ។ វគ្គដែលនិយាយអំពីអំពើក្បត់របស់អ្នកទាំងពីរនាក់នេះ បានបង្ហាញថា ព្រះទ្រង់បានគ្រប់គ្រងហេតុការណ៍តាមផែនការទ្រង់ ។

**៣:១** *ក្រោយនោះមក* មានន័យថា បន្ទាប់ពីនាងអេសធើរបានទទួលការតែងតាំងជាអគ្គមហេសីបានបួនឆ្នាំហើយ (ខ.៧ ២:១៦–១៧) ។ *កូនហាំម្ដា–ថា ជាសាសន៍អ័កាក់* ឈ្មោះហាំម្ដាថា គឺជាភាសាពើស៊ី ហើយគេជឿថាឈ្មោះអ័កាក់អាចសំដៅទៅលើព្រះនាមស្ដេចអ័កាក់ នៃសាសន៍អាម៉ាលេក (១សយ ១៥:២0) ។ ពួកអាម៉ាលេកបានច្បាំងទាស់នឹងពួកអ៊ីស្រាអែល នៅពេលដែលពួកអ៊ីស្រាអែលភាសខ្លួនចេញពីស្រុកអេស៊ីព្ទ (នក ១៧:៨–១៦ ១សយ ១៥:២) ដោយហេតុនេះ ព្រះអម្ចាស់ទ្រង់ "ច្បាំងទាស់នឹងពួកសាសន៍អាម៉ាលេក ពីមួយជំនាន់ទៅមួយជំនាន់ទៀត" (នក ១៧:១៦) ។ ពួកអ៊ីស្រា–អែលត្រូវលុបសេចក្ដីនឹកចាំចំពោះសាសន៍អាម៉ាលេក ពីក្រោមមេឃចេញ (ចទ ២៥:១៩) ។ ស្ដេចសូលបានវាយលុកពួកអាម៉ាលេក (១សយ ១៥) បណ្ដាលឱ្យស្លាប់ប្រជារាស្ត្រភាគច្រើនរបស់ស្ដេចអ័កាក់ (១របា ៤:៤២–៤៣) ហើយក្រោយមកស្ដេចអ័កាក់ក៏ត្រូវសុគតផងដែរ ។ សង្គ្រាមទាស់នឹងពួកអាម៉ាលេកកាលពីរ៉ាប់រយឆ្នាំមុន ត្រូវបានដឹកនាំដោយស្ដេចសូលដែលជាពួកបេនយ៉ាមីន ហើយនៅពេលនេះលោកម៉ាដេកាយ ដែលជាពួកបេនយ៉ាមីន (មើលការពន្យល់ ២:៥) បានបន្តសង្គ្រាមនោះទៀត ។ *លើកដំកើង* ខនេះមិនបានប្រាប់អំពីមូលហេតុនៃការលើកតម្កើងនោះទេ ដូចនេះអ្នកនិពន្ធប្រហែលជាចង់បង្ហាញពីភាពខុសគ្នានៃមូលហេតុនៃការលើកតម្កើងលោកម៉ាដេកាយ (២:២១–២៣ ៦:៣) ដោយសារការល្អរបស់គាត់ និងលោកហាម៉ាន ដោយសារការអាក្រក់ ។

**៣:២–៦** លោកម៉ាដេកាយមិនឱនខ្លួនចុះ មិនមែនដោយសារក្រឹត្យវិន័យទី២នៃក្រឹត្យវិន័យទាំងដប់ប្រការទេ (នក ២0:៤–៥) ព្រោះពួកអ៊ីស្រាអែលព្រមឱនកាយគោរពចំពោះពួកស្ដេច (១សយ ២៤:៨ ២សយ ១៤:៤ ១ពវ ១:១៦) និងចំពោះអ្នកផ្សេងទៀត (មើល លប ២៣:៧ ៣៣:៣ ៤៤:១៤) ។ ការមិនឱនកាយនេះ គឺដោយសារតែពួកអ៊ីស្រាអែល និងពួកអាម៉ាលេកគឺជាសត្រូវនឹងគ្នាជាយូរមកហើយ ហើយការហាម៉ានប៉ុនប៉ងលប់បំបាត់ជាតិសាសន៍អ៊ីស្រាអែល ក៏ដោយសារមូលហេតុនៃផងដែរ (ខ.៥–៦) ។ ការគម្រាមកំហែងមកលើពួកយូដា "ទូទាំងចក្រភព" (ខ.៦) ក៏ជាការគម្រាមកំហែងមកលើផែនការសង្គ្រោះផងដែរ (មើលសេចក្ដីផ្ដើមត្រង់ចំណុច គោលបំណងគោលរឿង និងលក្ខណៈអក្សរសាស្ត្រ) ។

**៣:៤** សូមផ្ទៀបការរៀបរាប់ក្នុងខនេះ និងការរៀបរាប់ក្នុងរឿងលោកយ៉ូសែប (មើល លប ៣៩:១0) ។

**៣:៧** *ឆ្នាំ ១២ . . . ខែទី១* គឺត្រូវនឹង ខែមេសា ឬឧសភា ឆ្នាំ ៤៧៤ មុនគ.ស

ហាម៉ាន ដេញរកថ្ងៃខែ ទៅទល់នឹងខែ១២ ទើបត្រូវគឺជា
ខែផល្គុន[ញ] ៨នោះហាម៉ានទូលដល់ ស្ដេចអ័ហាស៊ូរុសថា
មានសាសន៍១ ដែលខ្ចាត់ខ្ចាយនៅកណ្ដាលសាសន៍ទាំង
ប៉ុន្មាន ក្នុងគ្រប់ទាំងអាណាខេត្តរបស់ទ្រង់ គេមានច្បាប់[ដ]
ខុសពីច្បាប់នៃសាសន៍ទាំងអស់ ក៏មិនកាន់តាម[ឋ]ច្បាប់របស់
ព្រះករុណាផង ដូច្នេះ មិនគួរឱ្យព្រះករុណាទុកឱ្យគេនៅ
ទៀតទេ[ឌ] ៩បើសិនជាព្រះករុណាទ្រង់សព្វព្រះទ័យ នោះ
សូមទ្រង់បង្គាប់ឱ្យមានច្បាប់កត់ទុក ឱ្យបំផ្លាញពួកនោះ
ចេញយ៉ាងនោះទូលបង្គំនឹងប្រគល់ប្រាក់១ម៉ឺន ហាបទៅក្នុង
ឃ្លាំងហ្លួងទាំងប៉ុន្មាន សំរាប់ពួកអ្នកដែលចាត់ចែងការ
នោះ[ឍ] ១០ដូច្នោះ ស្ដេចទ្រង់ដោះព្រះទំរង់[ណ]ពីព្រះហស្ដ
ប្រគល់ដល់ហាម៉ាន ជាកូនហាំម្ដាថា សាសន៍អ័កាក់ ជាខ្មាំង
សត្រូវពួកយូដា ១១ដោយបន្ទូលថា ប្រាក់នោះយើងបាន
អនុញ្ញាតឱ្យអ្នកហើយ ព្រមទាំងសាសន៍នោះផង ដើម្បីឱ្យ
អ្នកធ្វើដល់គេ តាមតែគិតឃើញថាល្អចុះ ។
១២នៅថ្ងៃ១៣ខែចេត្រ គេបានហៅពួកស្មៀនហ្លួងមក
កត់គ្រប់ទាំងសេចក្ដីដែលហាម៉ានបង្គាប់ដល់ពួកចៅហ្វាយ
ខេត្តរបស់ស្ដេច ពួកចៅហ្វាយដែលត្រួតនៅគ្រប់តែស្រុក
នឹងពួកមេនៃគ្រប់ទាំងសាសន៍ គឺដល់គ្រប់ខេត្តតាមអក្សរ
ជាតិ[ត]របស់គេ ហើយដល់គ្រប់សាសន៍ តាមភាសារបស់គេ
ច្បាប់នោះបានកត់ទុកដោយនូវព្រះនាមស្ដេចអ័ហាស៊ូរុស
ក៏បោះត្រា[ថ]ដោយព្រះទំរង់របស់ស្ដេចដែរ ១៣ហើយគេផ្ញើ
សំបុត្រទាំងនោះ ទៅគ្រប់ទាំងខេត្តរបស់ស្ដេច ដោយសារ
ពួកអ្នករត់សំបុត្រ បង្គាប់ឱ្យបំផ្លាញសំឡាប់ ហើយធ្វើឱ្យពួក
សាសន៍យូដា[ទ] ទាំងអស់វិនាសបង់ទោះទាំងចាស់ទាំងក្មេង
និងកូនង៉ែត ហើយស្ត្រីៗផង ក្នុងរវាង១ថ្ងៃកំណត់នោះ
ដែលត្រូវជាថ្ងៃ១៣ខែ១២ គឺជាខែផល្គុន[ធ] ព្រមទាំងរឹប
ជាន់[ន]យកទ្រព្យសម្បត្តិគេផង ១៤ឯសំបុត្រទាំងនោះ មាន
ចំឡងព្រះរាជឱង្ការ ដែលត្រូវប្រកាសប្រាប់ដល់គ្រប់ទាំង
សាសន៍នៅអស់ទាំងខេត្តផង ឱ្យគេបានប្រុងប្រៀបជា
ស្រេចនៅថ្ងៃនេះ[ប] ១៥ពួករត់សំបុត្រក៏ចេញទៅជាប្រញាប់
តាមបង្គាប់របស់ស្ដេច ហើយព្រះរាជឱង្ការនោះបាន
ប្រកាសប្រាប់ នៅក្នុងស៊ូសាន[ផ] ជាក្រុងហ្លួងដែរ រួចស្ដេច
នឹងហាម៉ានក៏នាំគ្នាបរិភោគ[ព]ស្រា តែទីក្រុងស៊ូសានមាន
សេចក្ដីស្រឡាំងកាំងនៅ[ភ] ។

**៣:៧** ១០:២១ ញ ខ.១៣ នអ ៩:១៩
**៣:៨** ដ កច ១៦:២០-២១ ឋ យស ២៩:៧ ឌយ ៦:១៣ ឌ អរ ៤:១៥
**៣:៩** ឍ នអ ៧:៤
**៣:១០** ណ លប ៤១:៤២
**៣:១២** ត នហ ១៣:២៤ ថ លប ៣៨:១៨
**៣:១៣** ទ ១សយ ១៥:៣ អរ ៤:៦ ធ ខ.៧ ន នអ ៨:១១ ៩:១០
**៣:១៤** ប នអ ៨:៨ ៩:១
**៣:១៥** ផ នអ ៨:១៤ ព នអ ១:១០ ភ នអ ៨:១៥

ដែលជាឆ្នាំ ទី៥ នៃការឡើងធ្វើជាអគ្គមហេសីនៃនាងអេសធើរ។ *គេ* មើល ៥:១០,១៤ ៦:១២–១៣ ។ "*ពោរ*" មើល ៩:២៤,២៦ ។ ទម្រង់នៃពាក្យនេះជាពហុវចនៈ គឺ "ពោរ"(Purim) ដែលជាឈ្មោះនៃបុណ្យមួយរបស់ពួកយូដា(មើល ៩:២៦)។ ហាម៉ានបានចាប់ផ្ដើមរៀបគម្រោងបំផ្លាញពួកយូដា នៅក្នុងខែដែលពួកគេធ្វើពិធីអបអរបុណ្យរំលង ដែលនាំមកនូវសេចក្ដីប្រោសលោះនៅស្រុកអេស៊ីព្ទ(នក ១២:២–១១)។ *ខែ ១២* ចាប់ពីពេលរៀបចំច្បាប់ រហូតដល់ពេលដែលអនុវត្តច្បាប់ នៅក្នុងខែគម្ពុះ និងមិនា គឺមានរយៈពេល១១ខែ ។

**៣:៨** *មានសាសន៍១* ហាម៉ានមិនបញ្ចេញឈ្មោះសាសន៍ដែលខ្លួនប៉ងបំផ្លាញនោះឡើយ ព្រោះចង់មានន័យថា ពួកយូដាជាសាសន៍ដែលគ្មានប្រពៃណីឬច្បាប់អ្វីទេ ប៉ុន្តែ ពួកគេមិនស្ដាប់បង្គាប់ស្ដេចឡើយ(យរ ២៩:៧)។ *ខ្ចាត់ខ្ចាយនៅកណ្ដាលសាសន៍* មើល ៨:១១,១៧ ៩:២,១២,១៦,១៩–២០,២៨ ។

**៣:៩** *ប្រាក់ ១ ម៉ឺនហាប* តាមការកត់ត្រារបស់ប្រវត្តិវិទូឈ្មោះ ហេរ៉ូដូទូស (Herodotus) ប្រាក់ចំណូលរបស់ចក្រភពពើស៊ីក្នុង១ឆ្នាំ គឺ ១ម៉ឺន ៥ ពាន់ហាប ។ បើសិនជាដូចនេះមែន នោះហាម៉ានបានថ្វាយប្រាក់ ២ ភាគ ៣ នៃបរិមាណប្រាក់ចំណូលជាតិ គឺជាចំនួនដ៏ច្រើនសណ្ធិកសន្ធាប់ ។ គេសន្និដ្ឋានថា ហាម៉ានគម្រោងប្រមូលប្រាក់ទាំងនោះ ពីពួកយូដា ដែលនឹងត្រូវរងគ្រោះ ដោយសារព្រះរាជក្រឹត្យនោះ ។ មើល ខ.១៣ បានបង្ហើបថា អ្នកដែលអនុវត្តរាជក្រឹត្យនោះ នឹងបានទទួលការអនុញ្ញាតិឱ្យប្រមូលទ្រព្យពីពួកយូដាទុកជាសម្បត្តិខ្លួន មានន័យថា ព្រះរាជក្រឹត្យនោះ បានលើកទឹកចិត្តដល់អ្នកអនុវត្ត ដោយអនុញ្ញាណឱ្យពួកគេប្រមូលទ្រព្យទុកជារបស់ផងខ្លួន ព្រោះស្ដេចអ័ហាស៊ូរ៉ុសមិនមានទាក់ទងអ្វីនឹងរឿងកើបប្រាក់ទាំងនោះឡើយ(ខ.១១)។ ម្យ៉ាងវិញទៀត ៤:៧ អាចបង្ហើបផងដែរថា ស្ដេចក៏បានរៀបគម្រោងនៅក្នុងការប្រមូលទ្រព្យទាំងនោះផងដែរ(មើល ៧:៤ មិនការពន្យល់)។ *ពួកអ្នកដែលចាត់ចែងការ* ឃ្លានេះប្រហែលជា សំដៅទៅលើពួកមន្ត្រីផ្នែកហិរញ្ញវត្ថុដែលនឹងប្រមូលទ្រព្យចូលក្នុងព្រះរាជឃ្លាំង ឬអាចសំដៅទៅលើពួកអ្នកដែលអនុវត្តព្រះរាជក្រឹត្យ ។ កាលពីមុន ពួកអាម៉ាឡេកធ្លាប់បានវាយលុក ហើយប្រមូលរឹបពីពួកអ៊ីស្រាអែលម្ដងមកហើយ(១សយ ១៤:៤៨) នៅពេលនេះហាម៉ានបានគ្រោងធ្វើការនោះម្ដងទៀត ។

**៣:១០** *ដោះព្រះទំរង់ . . . ប្រគល់ដល់ហាម៉ាន* មានន័យថា ប្រគល់សិទ្ធិដល់ហាម៉ាន នៅក្នុងការបោះត្រាស្ដេច នៅលើព្រះរាជក្រឹត្យ(ខ.១២)។ *ខ្មាំងសត្រូវពួកយូដា* អ្នកនិពន្ធបានប្រើពាក្យនេះក្នុងន័យរិះគន់ដល់ហាម៉ាន ហើយបានប្រើពាក្យនេះនៅក្នុងខផ្សេងទៀតផងដែរ(៨:១ ៩:១០ ធៀបនឹង ៧:៦ ៩:២៤ )។

**៣:១២** *ថ្ងៃ ១៣ ខែចេត្រ* គឺនៅក្នុងឆ្នាំទី១២ នៃរជ្ជកាលស្ដេចអ័ហាស៊ូរុស(ខ.១៧) គឺត្រូវនឹង ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ៤៧៤ មុនគ.ស ។

**៣:១៣** ព្រះទ្រង់ធ្លាប់បង្គាប់ឱ្យបំផ្លាញសាសន៍អាម៉ាលេក ឱ្យអស់រលីង(១សយ ១៥:៣) ដូចនេះ ហាម៉ានចង់ឱ្យសាសន៍អ៊ីស្រាអែលត្រូវរលាយសាបសូន្យ ដោយសារព្រះរាជក្រឹត្យផងដែរ ។ *ថ្ងៃ ១៣ ខែ ១២* គឺត្រូវនឹងថ្ងៃទី ៧ ខែមិនា ឆ្នាំ ៤៧៣ មុនគ.ស(មើល ៨:១២)។

**៣:១៥** ហាម៉ាន និងស្ដេច នឹងបរិភោគស្រាជាមួយគ្នា ម្ដងទៀត នៅពេលដែលការកំណត់ជោគវាសនារបស់ពួកយូដានឹងត្រូវមានជាលើកទី២(មើល ៧:១–២) ប៉ុន្តែ នៅពេលនោះ ទំនាក់ទំនងរបស់ពួកគេទាំងពីរនឹងត្រូវរលាយ ហើយព្រះរាជក្រឹត្យដែលពួកគេកំពុងតែអបអរនៅពេលនេះ នឹងត្រូវក្រឡាស់វិញផងដែរ ។ ការស៊ីផឹកអបអរសាទរនៅក្នុងខនេះ គឺជាទង្វើរដែលផ្ទុយនឹងការអធិស្ឋានតម និងកាន់ទុក្ខរបស់ពួកយូដា(៤:១–៣,១៦)។

## លោកម៉ាដេកាយសូមឱ្យនាងអេសធើរជួយ

**៤** ១ចំណែកម៉ាដេកាយ កាលបានដឹងពីការដែលកើតមក
ទាំងនោះ ហើយនោះគាត់ហែកអាវខ្លួន[ក] ហើយស្លៀក
សំពត់ធ្មៃរោយផេះផង[ខ] រួចចេញទៅកណ្តាលទីក្រុងស្រែក
ឡើង[គ] ជាសំរែកយ៉ាងខ្លាំង ហើយជូរចត់ ២គាត់ក៏ទៅរហូត
ដល់មុខទ្វារព្រះរាជវាំង[ឃ] ដ្បិតគ្មានច្បាប់នឹងចូលទៅក្នុង
ព្រះរាជវាំងទាំងស្លៀកសំពត់ធ្មៃបានឡើយ ៣ហើយនៅ
គ្រប់តែខេត្ត ទ្រង់កន្លែងណាក៏ដោយ ដែលព្រះរាជឱង្ការ
នឹងបង្គាប់នៃស្តេចបានទៅដល់ នោះមានសេចក្តីសៅសោក
ជាខ្លាំង នៅក្នុងពួកសាសន៍យូដា ព្រមទាំងការតមអត់
យំយែក ហើយស្រែកទ្រហោ ក៏មានគ្នាច្រើនបានគ្រលំ
ដោយសំពត់ធ្មៃដេកនៅគំនរផេះផង ។

៤ពួកស្រីបំរើ និងពួកភ្នាក់ងាររបស់អគ្គមហេសី នាង
អេសធើរ ក៏មកទូលសេចក្តីនោះដល់ព្រះនាង ដូច្នេះ ព្រះ
នាងមានសេចក្តីថប់ព្រួយជាខ្លាំង ក៏ផ្ញើសំលៀកបំពាក់ទៅ
ជូនដល់ម៉ាដេកាយ ដើម្បីឱ្យគាត់បានផ្លាស់សំពត់ធ្មៃចេញ
តែគាត់មិនព្រមទទួលទេ ៥អេសធើរក៏ហៅហាថាក់ ជា
ភ្នាក់ងាររបស់ស្តេច ដែលទ្រង់បានដំរូវឱ្យបំរើព្រះនាង មក
បង្គាប់ឱ្យទៅឯម៉ាដេកាយ ដើម្បីសួរឱ្យដឹងពីរឿងនោះ
ហើយពីហេតុអ្វីបានជាកើតដូច្នេះ ៦ហាថាក់ក៏ចេញទៅ
ឯម៉ាដេកាយ នៅត្រង់ទីធ្លាក្រុង ដែលនៅមុខព្រះរាជវាំង
៧ហើយម៉ាដេកាយប្រាប់គាត់ ពីគ្រប់ទាំងដំណើរដែលបាន
កើតមកដល់ខ្លួន និងពីចំនួនប្រាក់ដែល ហាម៉ានបានសន្យា
បញ្ចេញទៅឯឃ្លាំងហ្លួងទាំងប៉ុន្មាន ឱ្យបានបំផ្លាញដល់
ពួកសាសន៍យូដា[ង] ៨ក៏ឱ្យសំណៅព្រះរាជឱង្ការ១ច្បាប់ ជា
សេចក្តីដែលបានប្រកាសប្រាប់នៅក្រុងស៊ូសាន បង្គាប់ឱ្យ
សំឡាប់គេដល់ភ្នាក់ងារនោះ ឱ្យនាំយកទៅបង្ហាញដល់
អេសធើរ ហើយរាប់រៀបទូល ព្រះនាងឱ្យជ្រាប ព្រមទាំង
ផ្តាំឱ្យព្រះនាងចូលទៅទូលអង្វរចំពោះស្តេច ថ្វាយពាក្យ
សំណូមជំនួសសាសន៍របស់ខ្លួនផង ។

៩ហាថាក់ក៏ទៅក្រាបទូលដល់អេសធើរ តាមពាក្យរបស់
ម៉ាដេកាយ ១០រួចអេសធើរមានសវនីយ៍នឹងហាថាក់ផ្តាំឱ្យ
ទៅជំរាបម៉ាដេកាយថា ១១អស់ទាំងពួកបំរើរបស់ស្តេច
នឹងពួកបណ្តាជន នៅគ្រប់ទាំងខេត្តរបស់ទ្រង់ សុទ្ធតែដឹងថា
បើស្តេចមិនបានហៅរក[ច] នោះអ្នកណាក៏ដោយទោះប្រុសឬ
ស្រីក្តី ដែលនឹងចូលទៅឯស្តេច ក្នុងព្រះរាជរោងខាងក្នុង
នោះមានច្បាប់តែ១[ឆ]ចំពោះអ្នកនោះ គឺត្រូវសំឡាប់បង់
លើកតែអ្នកណាដែលទ្រង់នឹងហុចព្រះដំបងមាស[ជ] មក
ប្រោសឱ្យបានរស់ប៉ុណ្ណោះ តែស្តេចមិនបានហៅខ្ញុំឱ្យចូល
ទៅចំពោះទ្រង់អស់៣០ថ្ងៃនេះហើយ ១២រួចគេក៏ទៅជំរាប
ម៉ាដេកាយ តាមពាក្យរបស់អេសធើរវិញ ។

១៣ឯម៉ាដេកាយ ក៏ប្រាប់ឱ្យគេ ចូលទៅទូលឆ្លើយនឹង
អេសធើរថា កុំឱ្យគិតស្មានថាព្រះនាងនឹងរួចជីវិត នៅក្នុង
ដំណាក់ស្តេច ជាជាងពួកសាសន៍យូដាឯទៀតនោះឡើយ
១៤ដ្បិតបើព្រះនាងនឹងសៀម[ឈ]នៅក្នុងវេលានេះ នោះនឹង
កើតមានសេចក្តីសង្គ្រោះ[ញ] និងសេចក្តីប្រោសឱ្យរួច[ដ]ដល់
ពួកយូដាពីកន្លែងផ្សេងទៀត តែព្រះនាងនិងញាតិវង្ស

**៤:១** ក ជន ១៤:៦ ខ ២សយ ១៣:១៩ អគ ២៧:៣០–៣១ គ នក ១១:៦ ទដ ៣០:១១
**៤:២** ឃ នអ ២:១៩
**៤:៧** ង នក ៧:៤
**៤:១១** ច នក ២:១៤ ឆ ដយ ២:៩ ជ នអ ៥:១,២ ៨:៤ ទដ ១២៥:៣
**៤:១៤** ឈ យប ៣៤:២៩ ទដ ២៨:១ ៣៥:២២ សស ៣:៧ អស ៤២:១៤ ៥៧:១១ ៦២:១ ៦៤:១២ អម ៥:១៣ ញ នអ ៩:១៦,២២

**៤:២** *ទ្វារព្រះរាជវាំង* មើលការពន្យល់ ២:១៩ ។

**៤:៣** មើលការពន្យល់ ៣:១៥ ។ នៅក្នុងព្រះគម្ពីរនេះ មានការស៊ីលាងពីរដង ដែលត្រូវបានធ្វើឡើងស្របពេលការអធិស្ឋានតមទាំងពីរលើក (មើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ មើលការពន្យល់ ៩:៣១)។

**៤:៥–១៥** លោកហាថាក់បាននាំពាក្យឆ្លើយឆ្លងរវាងព្រះនាងអេសធើរ និងលោកម៉ាដេកាយ ហើយការនេះបញ្ជាក់ថា គេមិនអនុញ្ញាតិឱ្យលោកម៉ាដេ–កាយ ចូលក្នុងព្រះរាជវាំង ទាំងសំលៀកបំពាក់កាន់ទុក្ខឡើយ (ខ.២) ។

**៤:៧** មើលការពន្យល់ ៣:៩ ។ លោកម៉ាដេកាយបានដឹងពីបរិមាណនៃប្រាក់ដែលហាម៉ានបានសន្យាថ្វាយដល់ស្តេច ហើយការនេះបានរំឭកអំពីមុខតំណែងខ្ពស់ដែលគាត់មាននៅក្រុងស៊ូសាន (២:២១–២៣ និងការពន្យល់ ២:៥) ។

**៤:១១** ប្រវត្តវិទូឈ្មោះ ហេរូដូទូស (Herodotus) ក៏បានកត់ត្រាផងដែរថា អ្នកណាក៏ដោយ ដែលចូលគាល់ស្តេចពើរស៊ី ដោយទ្រង់មិនបានហៅ នោះនឹងត្រូវទទួលទោសប្រហារជីវិត បើទ្រង់បានមិនលើកលែងទោសឱ្យភ្លាមៗទេនោះ។

**៤:១២–១៦** វគ្គនេះបានបង្ហាញយ៉ាងច្បាស់អំពី គោលរឿងសំខាន់ៗនៃព្រះគម្ពីរនេះ ។ បានជាលោកម៉ាដេកាយមានជំនឿថា ពួកយូដានឹងបានទទួលការប្រោសលោះ ព្រោះគាត់ដឹងថា ព្រះដ៏មានព្រះចេស្តា ទ្រង់បានសន្យានឹងរាស្ត្រទ្រង់ ហើយបំណងព្រះហឫទ័យទ្រង់នឹងបានសម្រេច ហើយទ្រង់មានមធ្យោបាយជាច្រើន ដើម្បីប្រោសលោះរាស្ត្រទ្រង់ ទោះបីជាមិនមានវត្តមាននាងអេសធើរក៏ដោយ ។ តែព្រះទ្រង់សព្វព្រះទ័យឱ្យនាងអេសធើរមានការទទួលខុសត្រូវផ្ទាល់ខ្លួន បើមិនដូចនោះទេ នោះសាសន៍របស់នាងមុខជាត្រូវវលាយបង់ជាមិនខាន ។ ចំពោះការបង្រៀនស្រដៀងគ្នាអំពីទំនាក់ទំនងរវាងអំណាចគ្រប់គ្រងរបស់ព្រះ និងការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ សូមធៀបនឹង មថ ២៦:២៤ កច ២:២៣ ។

**៤:១៤** *ពីកន្លែងផ្សេងទៀត* ត្រង់ចំណុចនេះ ព្រះគម្ពីរនាងអេសធើរមិនបាននិយាយសំដៅទៅលើព្រះ ដោយផ្ទាល់ទេ (មើលសេចក្តីផ្តើមត្រង់ចំណុចគោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ)។ តាមប្រពៃណីពួកយូដា គេអាចប្រើពាក្យ "កន្លែង" សំដៅទៅលើព្រះនាមព្រះ ។ *សំរាប់ពេលនេះឯងទេដឹង* ធៀបនឹងការពិពណ៌នាអំពីលោកយ៉ូសែបនៅក្នុង លប ៤៥:៥–៧។

របស់បិតានៃព្រះនាង នឹងត្រូវវិនាសវិញ ហើយប្រហែល
ជាព្រះនាង បានតាំងឡើងក្នុងរាជ្យ សំរាប់ពេលនេះឯងទេ
ដឹង[ឋ] ១៥ដូច្នេះ អេសធើរក៏បង្គាប់ឱ្យគេទៅជំរាបម៉ាដេកាយ
ថា ១៦សូមទៅប្រមូលពួកសាសន៍យូដា ដែលនៅក្រុងស៊ូសាន
ឱ្យប្រជុំគ្នាតមអត់[ឱ]ឱ្យខ្ញុំ កុំឱ្យបរិភោគអ្វីទាំងយប់ទាំងថ្ងៃ អស់
រវាង៣ថ្ងៃ ឯខ្ញុំនឹងពួកស្រីបំរើរបស់ខ្ញុំក៏នឹងតបដូច្នោះដែរ
យ៉ាងនោះខ្ញុំនឹងចូលទៅគាល់ស្តេច ដែលជាការខុសច្បាប់
ហើយបើខ្ញុំត្រូវស្លាប់ក៏ស្លាប់ទៅចុះ[ឍ] ១៧នោះម៉ាដេកាយក៏
ទៅធ្វើតាមគ្រប់សេចក្តីដែលអេសធើរបានបង្គាប់មក ។

## ព្រះនាងអេសធើរទូលសូមដល់ស្តេច

**៥** ១លុះដល់ថ្ងៃទី៣ នោះអេសធើរក៏ទ្រង់គ្រឿងមហេសី[ក]
ចូលទៅឈរក្នុងព្រះរាជរោងខាងក្នុង ដែលទល់មុខនឹង
ដំណាក់ស្តេច[ខ] ឯស្តេចទ្រង់គង់លើបល្ល័ង្ករាជ្យ ក្នុងមហា
មន្ទីរ ប្រឈមនឹងផ្លូវចូលទៅឯព្រះរាជដំណាក់ ២កាលស្តេច
ទ្រង់ទតឃើញអេសធើរ ជាអគ្គមហេសីឈរក្នុងព្រះរាជ
រោងដូច្នោះ នោះទ្រង់ក៏ប្រោសដល់ព្រះនាង ហើយហុច
ព្រះដំបងមាស ដែលកាន់នៅព្រះហស្ត ទៅឯព្រះនាង រួច
ព្រះនាងយាងចូលទៅពាល់ចុងព្រះដំបងនោះ[គ] ៣ស្តេចទ្រង់
មានបន្ទូលសួរថា អេសធើរ អគ្គមហេសីអើយ តើព្រះនាង
មកចង់បានអ្វី តើគិតចង់សូមអ្វី យើងនឹងបើកឱ្យតាមព្រះ
នាងសូម ទោះបើដល់នគរ១ចំហៀងផង[ឃ] ៤អេសធើរទូល
ថា បើព្រះករុណាសព្វព្រះហឫទ័យ នោះសូមព្រះករុណា
និងហាម៉ានយាងទៅសោយលៀង ដែលខ្ញុំម្ចាស់បានរៀប
ថ្វាយនៅថ្ងៃនេះ ។

៥ដូច្នេះ ស្តេចទ្រង់ក៏បង្គាប់គេថា ចូរទៅប្រាប់ហាម៉ាន
ឱ្យប្រញាប់ឡើង ដើម្បីឱ្យបានសំរេចដូចព្រះនាងបានថា
យ៉ាងនោះស្តេចនឹងហាម៉ានបានមកសោយលៀង ដែល
អេសធើរបានរៀបចំថ្វាយ ៦កំពុងតែលៀងស្រាទំពាំង
បាយជូរ[ង] នោះស្តេចមានបន្ទូលសួរអេសធើរថា តើព្រះ
នាងចង់បានអ្វី យើងនឹងបើកឱ្យ តើគិតសូមអ្វី ទោះបើដល់
នគរ១ចំហៀងក៏ដោយ[ច] គង់តែបានសំរេចឱ្យព្រះនាងដែរ[ឆ]
៧អេសធើរទូលឆ្លើយថា សេចក្តីសំណូមរបស់ខ្ញុំម្ចាស់ និង
សេចក្តីដែលខ្ញុំម្ចាស់ចង់បាន ៨គឺបើព្រះករុណាប្រោស
មេត្តា[ជ]ដល់ខ្ញុំម្ចាស់ហើយបើព្រះករុណា សព្វព្រះទ័យនឹង
ប្រោសប្រទានដល់ខ្ញុំម្ចាស់ តាមសេចក្តីសំណូម ហើយ
សំរេចតាមសេចក្តីដែលខ្ញុំម្ចាស់ចង់បានដែរ នោះសូមព្រះ
ករុណា និងហាម៉ានយាងមកសោយលៀង[ឈ] ដែលខ្ញុំម្ចាស់
នឹងរៀបចំថ្វាយនៅថ្ងៃស្អែកទៀត នោះខ្ញុំម្ចាស់នឹងធ្វើតាម
ដែលព្រះករុណា បានមានបន្ទូលហើយ ។

## កំហឹងរបស់ហាម៉ានទាស់នឹងម៉ាដេកាយ

៩នៅថ្ងៃនោះ ហាម៉ានក៏ចេញទៅ ដោយមានចិត្តអំណរ
អររីករាយ តែកាលលោកឃើញម៉ាដេកាយនៅត្រង់មាត់
ទ្វារព្រះរាជវាំង ដែលមិនឈរឡើង ឬកំរើកគោរពនៅ
មុខខ្លួន នោះលោកមានពេញ ដោយសេចក្តីឃោរឃៅ[ញ]
ចំពោះម៉ាដេកាយ[ដ] ១០ប៉ុន្តែលោកទ្រាំអត់នៅ ហួសទៅឯផ្ទះ
ខ្លួនទៅ រួចចាត់គេឱ្យទៅហៅពួកមិត្រសំឡាញ់ និង
សេរែស[ឋ]ជាប្រពន្ធខ្លួនមក ១១ហើយថ្លែងពីសេចក្តីរុងរឿង[ឱ]
នៃទ្រព្យសម្បត្តិខ្លួន ពីកូនចៅដែលមានច្រើនដល់ម្ល៉េះ[ឍ] និង
ពីស្តេចបានដំកើងងារខ្លួន ហើយតាំងឡើងខ្ពស់ជាងអស់
ពួកអ្នកជាប្រធាន និងពួកជំនិតទ្រង់ទាំងប៉ុន្មាន ១២លោកក៏
ថ្លែងនេះទៀតថា អេសធើរអគ្គមហេសី មិនបើកឱ្យអ្នកណា
ចូលទៅជាមួយនឹងស្តេច ដើម្បីបរិភោគលៀង ដែលព្រះ
នាងរៀបចំនោះទេ បើកឱ្យតែអញ១ប៉ុណ្ណោះ[ណ] ហើយដល់

**៤:១៤** ដ លប ៤៥:៧ ចទ ២៨:២៩ ឋ លប ៥០:២០
**៤:១៦** ឱ ២របា ២០:៣ នអ ៩:៣១ ឍ លប ៤៣:១៤
**៥:១** ក អគ ១៦:១៣ ខ សភ ២១:១
**៥:២** គ នអ ៤:១១
**៥:៣** ឃ នអ?៧:២ ដយ ៥:១៦ មក ៦:២៣
**៥:៦** ង នអ ១:១០ ច ដយ ៥:១៦ មក ៦:២៣ ឆ នអ ៩:១២
**៥:៨** ជ នអ ២:១៥ ឈ ១ពវ ៣:១៥
**៥:៩** ញ នអ ២:២១ សភ ១៤:១៧ ដ នអ ៣:៣,៥
**៥:១០** ឋ នអ ៦:១៣
**៥:១១** ឱ សភ ១៣:១៦ ឍ នអ ៩:៧–១០,១៣
**៥:១២** ណ យប ២២:២៩ សភ ១៦:១៨ ២៩:២៣

**៤:១៦** *តមអត់* មើលការពន្យល់ ខ.៣ ។ គេសន្និដ្ឋានថា ការតមអត់នេះ គឺធ្វើឡើយ ដោយការអធិស្ឋានផងដែរ (មើល ពច ២០:២៦–២៧ ១សយ ៧:៦ ២សយ ១២:១៦ អរ ៨:២១–២៣ នហ ៩:១–៣ អស ៥៨:៣–៤ យរ ១៤:១២ យអ ១:១៤ ២:១២–១៧ យហ ៣:៧–៨)។ អ្នកនិពន្ធមិនបានប្រើពាក្យ អធិស្ឋាន ឬព្រះ នៅក្នុងព្រះគម្ពីរនេះ ដើម្បីបង្ហាញពីការពិតថា ព្រះទ្រង់សកម្មជានិច្ច នៅក្នុងដំណើររឿងនេះ (មើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ) ។

**៥:២** ខនេះបានបង្ហាញអំពីផែនការរបស់ព្រះ ដែលទ្រង់បានរៀបចំ ដើម្បីសង្គ្រោះរាស្ត្រទ្រង់ ដោយបណ្តាលចិត្តស្តេច (ដូចនៅក្នុង សភ ២១:១) ។

**៥:៦–៧** នាងអេសេធើរមិនបានឆ្លើយនូវសំណួររបស់ស្តេច នៅពេលនេះ ហើយថ្វាយចម្លើយនៅព្រឹកស្អែកវិញ អាចដោយសារនាងចង់ឱ្យស្តេចទ្រង់ចាប់ចិត្តលើកនាងកាន់តែខ្លាំង ហើយដោយសារនាងចង់បង្ហាញឱ្យស្តេចបានជ្រាបថា រឿងនោះមិនមែនធម្មតាឡើយ ។ ការពន្យាពេលឆ្លើយនៅពេលនេះ ក៏ដើម្បីរង់ចាំឱកាសល្អជាងនេះ ។

**៥:៩** លោកម៉ាដេកាយមិនគោរពហាម៉ាន ដោយសារគាត់បានទុកចិត្តលើព្រះ ដែលទ្រង់នឹងរំដោះរាស្ត្រទ្រង់ពីគ្រោះមហន្តរាយ ដែលហាម៉ានបានគ្រោងនឹងបង្កឡើងនោះ ។

**៥:១១** *កូនចៅដែលមានច្រើនដល់ម្ល៉េះ* ហាម៉ានមានកូនប្រុសដប់នាក់ (៩:៧–១០) ។ តាមការកត់ត្រារបស់លោកហេរ៉ូដូទូស (Herodotus) ដែលជាប្រវត្តិវិទូ ពួកសាសន៍ពើរស៊ីបានឱ្យតម្លៃបំផុតទៅលើវីរៈភាពនៅក្នុងសង្គ្រាម ហើយឱ្យតម្លៃបន្ទាប់ទៅលើការមានកូនប្រុសច្រើន ។ ដូចនេះហើយ ស្តេចពើរស៊ីប្រទានរង្វាន់ដល់បណ្តារាស្ត្រពើរស៊ីដែលមានកូនប្រុសច្រើន (ធៀបនឹង ទដ ១២៧:៣–៥) ។

**៥:១២–១៣** មើល សភ ១៦:១៨ ២៩:២៣ ។

ថ្ងៃស្អែក ព្រះនាងក៏អញ្ជើញអញទៅ ជាមួយនឹងស្តេចម្តង
ទៀត ១៣ប៉ុន្តែ ដែលអញនៅឃើញម៉ាដេកាយ ជាសាសន៍
យូដានោះអង្គុយនៅមាត់ទ្វារព្រះរាជវាំងដរាបណានោះ
សគុណទាំងប៉ុន្មាននេះមិនបានអ្វីដល់អញទេ[គ] ១៤នោះ
សេរែស ជាប្រពន្ធលោក និងពួកសំឡាញ់ទាំងប៉ុន្មាន ក៏
និយាយឡើងថា ត្រូវឱ្យគេដំឡើងឈើកំពស់៥០ហត្ថ រួចដល់
ព្រឹកឡើង ឱ្យចូលទៅទូលសូមច្បាប់ស្តេច ដើម្បីយក
ម៉ាដេកាយនេះទៅចងកព្យួរទៅ[ថ] ដូច្នេះ លោកនឹងចូលទៅ
ពិសាលៀងជាមួយនឹងស្តេច ដោយអំណរបានដំណើរនោះ
បានពេញចិត្តដល់ហាម៉ាន លោកក៏ឱ្យគេដំឡើងឈើសំរាប់
ព្យួរនោះឡើង ។

## លោកម៉ាដេកាយទទួលយស

៦ ១នៅវេលាយប់ថ្ងៃនោះឯង ស្តេចទ្រង់ផ្ទំមិនលក់ទេ[ក]
ដូច្នេះ ទ្រង់បង្គាប់ឱ្យគេយកសៀវភៅ ដែលកត់អស់ទាំង
រឿងទុកសំរាប់ពង្សាវតារ[ខ]មក រួចគេក៏អានមើលថ្វាយ
ស្តេច ២នោះឃើញមានសេចក្តីកត់ទុក ពីម៉ាដេកាយបានប្តឹង
ពីប៊ីកថាន និងថេរែស ជាភ្នាក់ងារ២នាក់របស់ស្តេច ក្នុង
ពួកអ្នកឆ្មាំទ្វារ ដែលបានរកឱកាសដល់ព្រះជន្មនៃស្តេច
អ័ហាស៊ូរុស[គ] ៣ស្តេចមានបន្ទូលសួរថា តើបានប្រោសឱ្យ
ម៉ាដេកាយ នេះបានរង្វាន់ និងយសជាយ៉ាងណាខ្លះ ដោយ
ព្រោះការនោះ ពួកមហាតលិក ដែលបំរើស្តេច ទូលតបថា
មិនបានប្រោសអ្វីដល់គាត់ឡើយ[ឃ] ៤ខណនោះ ស្តេចមាន
បន្ទូលសួរថា តើអ្នកណានៅឯទីធ្លានោះ រីឯហាម៉ានបាន
មកដល់ទីធ្លាខាងក្រៅនៃព្រះរាជដំណាក់ហើយ ចង់សូម
ច្បាប់ស្តេចឱ្យចងកម៉ាដេកាយព្យួរនឹងឈើ ដែលលោកបាន
ដំឡើងទុកនោះទៅ ៥ដូច្នេះ ពួកមហាតលិកទូលទ្រង់ថា
គឺជាលោកហាម៉ានដែលឈរនៅទីធ្លានោះ ស្តេចមាន
បន្ទូលថា ចូរឱ្យលោកចូលមកចុះ ៦ហាម៉ានក៏ចូលមករួច
ស្តេចទ្រង់សួរថា តើគួរប្រោសជាយ៉ាងណា ដល់អ្នកដែល
ស្តេចសព្វព្រះទ័យចង់លើកមុខ ហាម៉ាននឹកក្នុងចិត្តថា តើ
មានអ្នកណាក្រៅពីអញ ដែលស្តេចសព្វព្រះទ័យនឹងលើក
មុខឱ្យ ៧ដូច្នេះ ហាម៉ានទូលឆ្លើយថា ឯមនុស្សដែលព្រះ
ករុណាសព្វព្រះទ័យចង់លើកមុខឱ្យ ៨នោះគួរតែយកព្រះ
ពស្ត្រារាជ្យ[ង] ដែលព្រះករុណាធ្លាប់ទ្រង់ និងសេះ[ច] ដែល
ព្រះករុណាទ្រង់ ព្រមទាំងមកុដរាជ្យ ដែលពាក់លើព្រះសិរ
មក ៩ហើយប្រគល់ប្រដាប់ទាំងនោះ និងសេះដល់ម្នាក់ ជា
អ្នកប្រធានវិសេសបំផុតរបស់ស្តេច ឱ្យគេបំពាក់ដល់អ្នក
ដែលព្រះករុណាទ្រង់សព្វព្រះទ័យចង់លើកមុខនោះ រួច
បញ្ជិះសេះបណ្តើរនាំទៅតាមផ្លូវទីក្រុង ហើយស្រែក
ប្រកាសនៅមុខអ្នកនោះថា អ្នកដែលស្តេចសព្វព្រះទ័យ
ចង់លើកមុខនោះបានដូច្នេះហើយ[ឆ] ១០ដូច្នេះ ស្តេចទ្រង់មាន
បន្ទូលបង្គាប់ហាម៉ានថា ចូរប្រញាប់ឡើង ទៅយកព្រះ
ពស្ត្រារាជ្យ និងសេះ ដូចជាអ្នកបានថានោះ ទៅធ្វើដូច្នោះ
ដល់ម៉ាដេកាយ ជាសាសន៍យូដា ដែលអង្គុយនៅមាត់ទ្វារ
ព្រះរាជវាំង កុំឱ្យខានធ្វើអ្វីមួយដែលអ្នកបានថានោះឱ្យ

**៥:១៣** គ នអ ២:១៩
**៥:១៤** ថ នអ ៧:៩ ទ នរ ៦:១១ឱ
**៦:១** ក ដយ ២:១ ៦:១៨ ខ នអ ២:២៣
**៦:២** គ នអ ២:២១–២៣
**៦:៣** ឃ សស ៩:១៣–១៦
**៦:៨** ង លប ៤១:៤២ អស ៥២:១ ច ១ពវ ១:៣៣
**៦:៩** ឆ លប ៤១:៤៣

**៥:១៣** *ម៉ាដេកាយ ជាសាសន៍យូដានោះ* មើលការពន្យល់ ៦:១០ ៧:៦ ។
**៥:១៤** *កំពត់ ៥០ ហត្ថ* ត្រូវជា២៣ម៉ែត្រ ជាកំពស់ដែលគេស្ញោចសរសើរ ។ ទោះជាយ៉ាងណាក៏ដោយ មានអ្នកខ្លះយល់ថា គេសង់បង្គោលនោះនៅពីលើសំណង់ផ្សេងទៀត ដើម្បីឱ្យបានកំពស់ដូចនេះ គឺមិនខុសពីរបៀបសង់កំផែងក្រុងទេ(មើល ១សយ ៣១:១០)។ *ចងកព្យួរ* មើលការពន្យល់ ២:២៣ ។
**៦:១** ខនេះគឺជាចំណុចសំខាន់ៗការពិពណ៌នា នៅក្នុងព្រះគម្ពីរនេះ ។ ព្រះគម្ពីរនេះបានធ្វើបន្ទាល់អំពីការគ្រប់គ្រងរបស់ព្រះលើផ្នែកទាំងអស់នៃរឿងនេះ ដោយលើកឡើងអំពី ការផ្ទំមិនលក់របស់ស្តេច ការដែលស្តេចបង្គាប់ឱ្យគេអានកំណត់ត្រានៅក្នុងពង្សាវតា កំណត់ត្រាអំពីគុណសម្បត្តិដែលលោកម៉ាដេកាយធ្លាប់មានពីមុន(ខ.២) ការត្រៀមខ្លួនរបស់ហាម៉ាននៅពេលព្រលឹម(៥:១៤) ការដែលគាត់ចូលទៅក្នុងទីធ្លាខាងក្រៅភ្លាមៗ(៦:៥) ហើយការសន្និដ្ឋានរបស់គាត់ អំពីការដែលស្តេចសព្វព្រះទ័យនឹងលើកមុខគាត់(ខ.៦)។ ដូចនៅក្នុងរឿងលោកយ៉ូសែប(លប ៤១:១–៤៥) បញ្ហានៃការផ្ទំរបស់ស្តេច បាននាំឱ្យមានការផ្លាស់ប្តូរស្ថានភាពរបស់វីរបុរស ពីអាក្រក់មកល្អឡើងវិញ(ធៀបនឹង ដយ ២:១ ៦:១៨)។
**៦:២** ក្នុងខនេះ គេអានអំពីព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីប្រាំឆ្នាំមុន (ធៀប ៣:៧ នឹង ២:១៦)។
**៦:៤–៦** នៅក្នុងវគ្គនេះ ស្តេចបានលាក់(ដោយគ្មានចេទនា)មិនឱ្យហាម៉ានដឹងអំពី "អ្នកដែលស្តេចសព្វព្រះទ័យនឹងលើកមុខ"ឡើយ គឺដូចកាលដែលហាម៉ានមិនបានទូលស្តេចអំពីអត្តសញ្ញាណរបស់សាសន៍មួយ(មើល ៣:៨ និងការពន្យល់)។
**៦:៨** *ព្រះពស្ត្រារាជ្យ ដែលព្រះករុណាធ្លាប់ទ្រង់* មើល ៨:១៥ មើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណះអក្សរសាស្ត្រ ។ ធៀបនឹងរឿងរបស់លោកយ៉ូសែប នៅក្នុង លប ៤១:៤១–៤៣ ។ នៅសម័យបុរណ ការទទួលព្រះពស្ត្រារាជ្យរបស់ស្តេចមកពាក់ គឺជាការទទួលការសព្វព្រះទ័យដ៏ពិសេសពីទ្រង់(១សយ ១៨:៤)។ ការពាក់អាវរបស់អ្នកណាម្នាក់ គឺមានន័យថា បានទទួលចំណែកនៃអំណាច កេរ្តិ៍ឈ្មោះ កិត្តិយស ឬមុខមាត់របស់អ្នកនោះ(២ពវ ២:១៣–១៤ អស ៦១:៣,១០ សក ៣:៣–៧ ធៀបនឹង មក ៥:២៧–២៨)។ ការទូលសូមរបស់ហាម៉ាននៅក្នុងខនេះ គឺមិនគ្រាន់តែដើម្បីឱ្យអ្នកទទួលនោះមានកិត្តិយសដ៏ខ្ពង់ខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីលើកតម្កើងស្តេច ដោយចិត្តមិនស្មោះត្រង់ផងដែរ ព្រោះការពាក់ព្រះពស្ត្រស្តេច គឺប្រសើរជាងទទួលទ្រព្យសម្បត្តិពីទ្រង់ ។
**៦:១០** *ម៉ាដេកាយ ជាសាសន៍យូដា* ក្នុងវគ្គមុន ហាម៉ានបានប្រើពាក្យនេះ ក្នុងន័យវាយប្រហារដល់លោកម៉ាដេកាយ(៥:១៣ មើលការពន្យល់ ៧:៦)។

សោះ ១១ហាម៉ានក៏យក[ជ]ព្រះពស្ត្រារាជ និងសេះនោះមក
រួចបំពាក់ឱ្យម៉ាដេកាយ ហើយបញ្ជិះ គាត់បណ្តើរនាំទៅ
តាមផ្លូវទីក្រុង ដោយស្រែកប្រកាសនៅមុខគាត់ថា អ្នក
ដែលស្តេចទ្រង់សព្វព្រះទ័យចង់លើកមុខ នោះបានដូច្នេះ
ហើយ ១២រួចហើយ ម៉ាដេកាយក៏វិលត្រឡប់មកឯទ្វារព្រះ
រាជវាំងវិញ តែឯហាម៉ានលោកប្រញាប់ប្រញាល់ទៅឯផ្ទះ
ដោយសៅសោក ហើយគ្រលុំ[ឈ]ក្បាល ១៣លោកក៏រាប់រៀប
ប្រាប់ដល់សេរែស[ញ] ជាប្រពន្ធ និងពួកមិត្រសំឡាញ់ទាំង
ប៉ុន្មានពីអស់ទាំងការដែលបានកើតមកដល់ខ្លួន ដូច្នោះ ពួក
អ្នកប្រាជ្ញារបស់លោក និងសេរែស ជាប្រពន្ធ ក៏និយាយទៅ
លោកថា បើសិនជាម៉ាដេកាយនេះជាតិជាសាសន៍យូដា
ដែលលោកបានចាប់តាំងដួល[ដ]នៅចំពោះគាត់ហើយ នោះ
លោកនឹងឈ្នះ គាត់មិនបានឡើយ គឺនឹងត្រូវដួលនៅចំពោះ
គាត់ជាពិតប្រាកដ[ឋ] ១៤កាលគេកំពុងតែនិយាយនឹងលោក
នៅឡើយ នោះមានពួកភ្នាក់ងាររបស់ ស្តេចមកដល់ ដាស់
តឿនហាម៉ាន ឱ្យទៅបរិភោគលៀង[ឌ] ដែលអេសធើរបាន
រៀបចំទុក ។

## ហាម៉ានត្រូវព្យួរករ

៧ ១ដូច្នេះ ស្តេចនិងហាម៉ាន ក៏ចូរទៅសោយ[ក]ជាមួយនឹង
អេសធើរ ជាអគ្គមហេសី ២ហើយនៅថ្ងៃទី២នោះ កំពុង
ពេលលៀងស្រាទំពាំងបាយជូរ[ខ] នោះស្តេចទ្រង់មានបន្ទូល
នឹងអេសធើរម្តងទៀតថា អេសធើរ អគ្គមហេសីអើយ ព្រះ
នាងចង់បានអ្វី យើងនឹងបើកឱ្យ តើគិតសូមអ្វី ទោះបើដល់
នគរ១ចំហៀងក៏ដោយ[គ] គង់តែនឹងបានសំរេចឱ្យ[ឃ] ៣នោះ
អេសធើរ ជាអគ្គមហេសី ទូលឆ្លើយថា បពិត្រព្រះករុណា
បើទ្រង់ប្រោសមេត្តា[ង]ដល់ខ្ញុំម្ចាស់ ហើយបើព្រះករុណា បើ
ទ្រង់ប្រោសមេត្តាដល់ខ្ញុំម្ចាស់ ហើយបើព្រះករុណាសព្វព្រះ
ទ័យ នោះសូមប្រោសឱ្យខ្ញុំម្ចាស់បានរួចជីវិត តាមសេចក្តី
សំណូម ព្រមទាំងសាសន៍ខ្ញុំម្ចាស់ផង តាមសេចក្តីបំណង
របស់ខ្ញុំម្ចាស់ ៤ដ្បិតមានគេលក់ខ្ញុំម្ចាស់នឹងពួក សាសន៍របស់
ខ្ញុំម្ចាស់ហើយ ឱ្យយើងខ្ញុំត្រូវបំផ្លាញសំឡាប់ ហើយវិនាស
អស់ទៅ[ច] បើសិនជាគេបានលក់យើង ខ្ញុំឱ្យគ្រាន់តែធ្វើជា
បាវប្រុសស្រីប៉ុណ្ណោះ នោះខ្ញុំម្ចាស់ឥតបើថាទេ ទោះបើ
ខ្មាំងសត្រូវនឹងសងការខូចខាងដែលនឹងកើតឡើងដល់
ស្តេចមិនបានក៏ដោយ ៥ស្តេចអ័ហាស៊ូរុស ទ្រង់មានបន្ទូល
សួរព្រះនាងអេសធើរ ជាអគ្គមហេសីថា តើអ្នកណាដែល
ហ៊ានធ្វើការដូច្នោះ តើគេនៅឯណា ៦នោះអេសធើរទូល
តបថា នុ៎ះន៍ អ្នកដែលធ្វើទុក្ខ ហើយស្អប់ដល់យើងខ្ញុំ គឺ
ហាម៉ាន ជាមនុស្សអាក្រក់នេះឯង ដូច្នេះហាម៉ានក៏ភ័យស្លុត
នៅចំពោះស្តេច និងអគ្គមហេសី ៧ឯស្តេចទ្រង់មានសេចក្តី
ក្រោធ[ឆ] ដល់ម៉្លេះបានជាទ្រង់ក្រោកពី ទីលៀងស្រាទំពាំង
បាយជូរ យាងចេញទៅឯសួនច្បារក្នុងព្រះរាជវាំង[ជ] ហើយ
ហាម៉ានលោកឈរឡើង សូមអង្វរដល់អេសធើរ ជាអគ្គ
មហេសីឱ្យបានរួចជីវិត ពីព្រោះលោកយល់ឃើញថា ស្តេច
ទ្រង់បានសំរេចនឹងធ្វើទោសដល់ខ្លួនហើយ[ឈ] ៨បានជាផ្តួល

**៦:១១** ជ លប ៤១:៤២
**៦:១២** ឈ ២សយ ១៥:៣០ នអ ៧:៨ យរ ១៤:៣,៤ មីក ៣:៧
**៦:១៣** ញ នអ ៥:១០ ដ ទដ ៥៧:៦ សក ២៦:២៧ ២៨:១៨ ឋ នអ ៧:៧
**៦:១៤** ឌ ១ពវ ៣:១៥
**៧:១** ក លប ៤០:២០–២២ មថ ២២:១–១៤
**៧:២** ខ នអ ១:១០ គ នអ ៥:៣ ឃ នអ ៩:១២
**៧:៣** ង នអ ២:១៥
**៧:៤** ច នអ ៣:៩ ៤:៧
**៧:៧** ឆ លប ៣៤:៧ នអ ១:១២ សភ ១៩:១២ ២០:១–២ ជ ២ពវ ២១:១៨ ឈ នអ ៦:១៣

**៦:១៣** *ប្រពន្ធ និងពួកមិត្រសំឡាញ់ទាំងប៉ុន្មាន* មើល ៥:១៤ ។ មើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ ។

**៦:១៤** តាមធម្មតាគេជូនភ្ញៀវ ទៅកន្លែងជប់លៀង(មើលការពិពណ៌នាអំពីរឿងលោកយ៉ូសែបក្នុង លប ៤៣:១៥–២៦ ធៀបនឹង មថ ២២:១–១៤)។

**៧:២** មើល ៥:៣,៦ និងការពន្យល់ ៥:៦–៧ ។

**៧:៣** *បើព្រះករុណាសព្វព្រះហឫទ័យ* មើល ២:១៥,១៧ ។

**៧:៤** *លក់* ត្រង់ចំណុចនេះ នាងអេសធើរនិយាយសំដៅទៅលើ សំណូករបស់ហាម៉ាន ដែលសន្យាថ្វាយដល់ស្តេច(៣:៩ ៤:៧) ហើយនាងបានលើកឡើង ពីព្រះរាជក្រឹត្យបង្គហាម៉ានបានបង្ករឡើងផងដែរ (៣:១៣)។ *ទោះបីខ្មាំងសត្រូវ . . . ដែលនឹងកើតឡើងដល់ស្តេចមិនបានក៏ដោយ* គេជឿថាឃ្លានេះ គឺមានន័យថា (១).ការធ្វើទុក្ខដល់សាសន៍យូដា ដោយឱ្យពួកគេធ្វើជាទាសករ នឹងមិននាំឱ្យខាតបង់ខ្លាំង ដូចការរំលាយពូជសាសន៍យូដាឡើយ ឬ(២).នាងអេសធើរនឹងមិនរំខានស្តេចទេ បើគេគ្រាន់តែឱ្យពួកយូដាជាប់ជាទាសករទេនោះ ។

**៧:៦** *ភ័យស្លុត* ហាម៉ានដល់ពេលដែលត្រូវភ័យស្លុត ព្រោះអគ្គមហេសីគឺជាដើមបណ្តឹង ស្តេចជាតុលាការ ហើយសម្បជញ្ញៈរបស់គាត់បានធ្វើបន្ទាល់ទាស់នឹងខ្លួនគាត់ ។

**៧:៧** *យាងចេញទៅ* ការយាងចេញនេះ គឺដើម្បីបន្ធូរបន្ថយភាពតានតឹង និងសេចក្តីក្រោធ ហើយដើម្បីពិចារណាពីទោសកំហុស ដែលត្រូវសម្រាច់ជាយ៉ាងណាដល់ហាម៉ាន ។

**៧:៨** *ផ្តួលខ្លួនក្រាបចុះនៅលើព្រះទែន ដែលអេសធើរផ្អែក* នៅសម័យនោះ គេមានប្រពៃណីយ ទទួលទានអាហារ ដោយតម្រេតខ្លួនលើកៅអីវែង(មើល អម ៦:៤,៧ យហ ១៣:២៣ និងការពន្យល់)។ ការនេះបានក្លាយជាការចំអកដល់ហាម៉ាន ដែលខឹងសម្បានឹងលោកម៉ាដេកាយ ដែលជាសាសន៍យូដាដែលមិនព្រមឱនក្បាលគោរពខ្លួន តែបែរជាត្រូវផ្តួលខ្លួនក្រាបចុះនៅចំពោះនាងអេសធើរដែលជាសាសន៍យូដាផងដែរវិញ(មើល ៦:១៣)។ *គ្របមុខហាម៉ាន* មើល ៦:១២ មើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ ។

**៧:៩** គេមិនដឹងថា មុនពេលហេតុការណ៍នេះកើតឡើង នាងអេសធើរបានដឹងអំពីជ័យជម្នះរបស់លោកម៉ាដេកាយមុនថ្ងៃនោះឬយ៉ាងណាទេ (៦:១–១១) ហើយពេលនេះនាងបានទូលអង្វរសូមឱ្យសាសន៍របស់នាងបានរួចជីវិត ។ លោកហាបូណាបានលើកឡើងអំពីបង្គោលសម្រាប់ព្យួរករ ដើម្បីនាំឱ្យមានការចោទទី២ មកលើប្រកាន់ហាម៉ាន ពីបទប៉ុនប៉ងសម្លាប់អ្នកដែលស្តេចសព្វព្រះទ័យនឹងលើកមុខនោះ ។

ខ្លួនក្រោបចុះនៅលើព្រះទែន[ញ] ដែលអេសធើរផ្អែក[ដ]
ខណនោះឯង ស្តេចទ្រង់យាងត្រឡប់ពីសួនច្បារ ចូលមក
ក្នុងទីលៀងវិញ ឃើញដូច្នោះ ក៏មានបន្ទូលថា យើះ វាគិត
ទាំងបង្ខូចអគ្គមហេសីអញ នៅមុខអញក្នុងដំណាក់ផងឬ[ឋ]
កាលស្តេច កំពុងមានបន្ទូលនៅឡើយនោះគេក៏គ្របមុខ
ហាម៉ាន[ឌ] ៩ រួចហាបូណា[ឍ] ជាពួកភ្នាក់ងារម្នាក់ទូលនៅ
ចំពោះស្តេចថា ហ្ន៎ មានឈើកំពស់៥០ហត្ថ[ណ] ដែលហាម៉ាន
បានដំឡើង ទុកសំរាប់ព្យួរម៉ាដេកាយ ជាអ្នកដែលបាន
ទទួលជាគុណដល់ព្រះករុណា នោះនៅឯផ្ទះវាស្រាប់ ស្តេច
ទ្រង់មានបន្ទូលតបថា ដូច្នោះ ចូរព្យួរវានឹងឈើនោះទៅ[ត]
១០ គេក៏ចងក[ថ]ហាម៉ាន[ទ]ព្យួរនៅលើឈើ[ធ] ដែលលោកបាន
ដំឡើងសំរាប់ចងព្យួរម៉ាដេកាយនោះទៅ[ន] ដូច្នេះសេចក្តី
ក្រោធរបស់ស្តេចក៏ស្ងប់បង់[ប]។

## ព្រះរាជបញ្ជាស្តេចដល់ពួកយូដា

**៨** ១ នៅថ្ងៃនោះឯង ស្តេចអ័ហាស៊ូរុស ទ្រង់ប្រទានផ្ទះ
របស់ហាម៉ាន[ក] ជាខ្មាំងសត្រូវរបស់សាសន៍យូដា ដល់
អេសធើរជាអគ្គមហេសី ឯម៉ាដេកាយក៏ចូលទៅចំពោះ
ស្តេច ពីព្រោះអេសធើរបានទូលពីគាត់ជាអ្វី ដល់ព្រះនាង
២ ស្តេចទ្រង់ក៏ដោះព្រះទំរង់[ខ] ដែលបានដកយកពីហាម៉ាន
ប្រគល់ទៅម៉ាដេកាយវិញ ហើយអេសធើរក៏តាំងលោក
ឡើង ឱ្យត្រួតលើផ្ទះរបស់ហាម៉ាន[គ]។
៣ អេសធើរក៏ទូលនៅចំពោះស្តេចម្តងទៀត ដោយ
ក្រាបនៅទៀបព្រះបាទទ្រង់ អង្វរទាំងទឹកភ្នែក ឱ្យទ្រង់
លើកចោលការអាក្រក់របស់ហាម៉ាន ជាសាសន៍អ័កាក់[ឃ]
ព្រមទាំងឧបាយ ដែលវាបានបង្កើត ទាស់នឹងពួកយូដា
៤ ខណនោះ ស្តេចទ្រង់ក៏ហុចព្រះដំបងមាស[ង]ដល់ អេសធើរ
ដូច្នេះ ព្រះនាងក្រោកឡើង ឈរនៅចំពោះស្តេច ៥ ទូលថា
បើព្រះករុណាសព្វព្រះទ័យ ហើយបើទ្រង់ប្រោសមេត្តា[ច]
ដល់ខ្ញុំម្ចាស់ ព្រមទាំងរាប់សេចក្តីនេះថាជាគួរ ហើយបើ
ខ្ញុំម្ចាស់ជាទីពេញព្រះទ័យដល់ទ្រង់ នោះសូមទ្រង់ចេញព្រះ
រាជឱង្ការ១ច្បាប់ លើកចោលសំបុត្រទាំងប៉ុន្មាន ដែ
លហាម៉ាន ជាកូនហាំម្ដាថា សាសន៍អ័កាក់ បានធ្វើនោះ
ជាសំបុត្រដែលវាផ្ញើទៅ បង្គាប់ឱ្យបំផ្លាញពួកសាសន៍យូដា
នៅគ្រប់ទាំងខេត្តរបស់ព្រះករុណា ៦ ដ្បិតធ្វើដូចម្តេចឱ្យខ្ញុំ
ម្ចាស់ទ្រាំមើលសេចក្តីវេទនា ដែលនឹងកើតដល់ជាតិរបស់
ខ្ញុំម្ចាស់ ឬទ្រាំមើលញាតិសន្តានរបស់ខ្ញុំម្ចាស់ត្រូវវិនាសទៅ
បាន[ឆ] ៧ នោះស្តេចអ័ហាស៊ូរុសទ្រង់ មានបន្ទូលទៅ
អេសធើរអគ្គមហេសី និងម៉ាដេកាយ ជាសាសន៍យូដា ថា
នេះនែ យើងបានឱ្យផ្ទះរបស់ហាម៉ានដល់អេសធើរ ហើយ ក៏
បានចងកវាព្យួរ[ជ]នឹងឈើផង ដោយព្រោះវាលូកដៃទៅ
ទាស់នឹងសាសន៍យូដា ៨ ឥឡូវនេះ ចូរសរសេរ[ឈ]ដោយព្រះ
នាមយើងផ្ញើទៅសាសន៍យូដា តាមតែចិត្តចុះ ហើយប្រថាប់
ត្រាដោយព្រះទំរង់យើងផង[ញ] ដ្បិតសេចក្តីណាដែលបានកត់
ចុះដោយនូវព្រះនាមនៃស្តេច ហើយប្រថាប់ត្រា ដោយព្រះ
ទំរង់រាជ្យ[ដ] នោះនឹងលើកចោលចោញពុំបានឡើយ[ឋ]។
៩ ដូច្នេះ នៅវេលានោះឯង គឺថ្ងៃ២៣ខែទី៣ ជាខែជេស្ឋ
នោះគេបានហៅពួកស្មៀនហ្លួងមក កត់អស់ទាំងសេចក្តី

**៧:៨** ញ នអ ១:៦ ដ លប ៣៩:១៤ យហ ១៣:២៣ ឋ លប ៣៤:៧ ឌ នអ ៦:១២
**៧:៩** ឍ នអ ១:១០ ណ នអ ៥:១៤ ត ចទ ២១:២២–២៣ ទដ ៧:១៤–១៦ ៩:១៦ សភ ១១:៥–៦ ២៦:២៧ មថ ៧:២
**៧:១០** ថ លប ៤០:២២ ទ សភ ១០:២៨ ធ នអ ៩:២៥ ន ដយ ៦:២៤ ប នអ ២:១
**៨:១** ក សភ ២២:២២–២៣
**៨:២** ខ លប ២៤:២២ ៤១:៤២ គ លប ៤១:៤១ សភ ១៣:២២ ១៤:៣៥ ដយ ២:៤៨
**៨:៣** ឃ នក ១៧:៨–១៦
**៨:៤** ង នអ ៤:១១
**៨:៥** ច នអ ២:១៥
**៨:៦** ឆ លប ៤៤:៣៤
**៨:៧** ជ ចទ ២១:២២–២៣
**៨:៨** ឈ នអ ៣:១២–១៤ ញ លប ៣៨:១៨ ដ លប ៤១:៤២ ឋ នអ ១:១៩ ដយ ៦:១៥

**៧:១០** *ក៏ស្ងប់បង់* មើល ២:១ និងសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ ។

**៨:១–១៧** វគ្គនេះអ្នកនិពន្ធបានរៀបរាប់ឱ្យដោយនិយាយសង្កត់ធ្ងន់ អំពីរបៀបដែលសាច់រឿងនៅក្នុងវគ្គ ៣:១–៤:៣ បានប្រែជាផ្ទុយស្រឡះ ។

**៨:១** *ប្រទានផ្ទះ . . . ដល់អេសធើរជាអគ្គមហេសី* ប្រវត្តវិទូមានដូចជាលោកហេរូដូទូស (Herodotus) និងលោកយ៉ូសេភើស (Josephus) បានបញ្ជាក់ថា ទ្រព្យសម្បត្តិរបស់អ្នកប្រព្រឹត្តអំពើក្បត់ម្នាក់ ត្រូវធ្លាក់ជាសម្បត្តិរបស់ពួករាជវង្ស គឺឆ្លុះបញ្ចាំងពីការដែលស្តេចអ័ហាស៊ូរុស ប្រទានទ្រព្យសម្បត្តិរបស់ហាម៉ានដល់នាងអេសធើរ ។

**៨:២** ធៀបនឹង ៣:១០–១១ ដែលនិយាយអំពីការដែលហាម៉ានទទួលព្រះទម្រង់ និងទ្រព្យសម្បត្តិដែលត្រូវប្រមូល ហើយក្នុងខនេះលោកម៉ាដេកាយក្លាយជាអ្នកទទួលព្រះទម្រង់ និងទ្រព្យសម្បត្តិរបស់ហាម៉ានវិញ ។

**៨:៣–៦** នាងអេសធើរ និងម៉ាដេកាយមានសុវត្ថភាពហើយ (៧:៤–៨:២) តែព្រះរាជក្រឹត្យដែលមិនអាចកែប្រែបាន នៅតែគម្រាមកំហែងដល់អាយុជីវិតនៃសាសន៍ពួកយូដាជាទូទៅ ។

**៨:៣** *សាសន៍អ័កាក់* មើលការពន្យល់ ៣:១ ។

**៨:៥** *សព្វព្រះទ័យ* មើល ៤:១១ ៥:២ ។

**៨:៦** ធៀបនឹងរឿងរបស់លោកយ៉ូសែប (មើល លប ៤៤:៣៤) ។

**៨:៨** *ចូរសរសេរ . . . ផ្ញើ* មើល ១:១៩ និងការពន្យល់ និងសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ ។ ការនេះបានកើតឡើងចំពោះស្តេចដារីយ៉ូស ដែលជាសាសន៍មេឌី ក្នុងរឿងដានីយ៉ែលផងដែរ (ដយ ៦:៨,១២,១៥) ។ ដំណោះស្រាយ គឺត្រូវចេញព្រះរាជក្រឹត្យថ្មីមួយទៀត (ធៀបនឹង ដយ ៦:២៥–២៧) ដែលអាចទប់ទល់នឹងគ្រោះភ័យនៃព្រះរាជក្រឹត្យចាស់ ដែលហាម៉ានបានបង្ករឡើង (៣:១២ ធៀបនឹង ដយ ៦:៧–៩) ហើយមិនអាចកែប្រែ ឬលុបចោលបាន (ការពន្យល់ ៩:២–៣) ។

**៨:៩–១៣** វគ្គនេះមានការរៀបរាប់តាមបែបវគ្គ ៣:១២–១៤ ។ សេចក្តីអន្តរាយដែលព្រះរាជក្រឹត្យចាស់បានកំណត់ គឺមិនខុសពីការកំណត់របស់ព្រះរាជក្រឹត្យរបស់ ស្តេចសូលដែលបានចេញទាស់នឹងសាសន៍អាម៉ាឡេកឡើយ (មើលការពន្យល់ ៣:១៣) ។

**៨:៩** *ថ្ងៃ២៣ ខែទី៣* គឺនៅឆ្នាំទី១២ នៃរាជ្ជកាលស្តេចអ័ហាស៊ូរុស ត្រូវនឹងថ្ងៃ ២៥ ខែ មិថុនា ឆ្នាំ ៤៧៤ មុនគ.ស គឺមានរយៈពេល ២ខែ ១០ថ្ងៃបន្ទាប់ពីហាម៉ានប្រកាសព្រះរាជក្រឹត្យ (មើលការពន្យល់ ៣:១២) ។

ដែលម៉ាដេកាយបង្គាប់ដល់ពួកសាសន៍យូដា ពួកចៅហ្វាយ
ខេត្ត និងពួកចៅហ្វាយស្រុក ហើយពួកអ្នកជាប្រធាននៅ
គ្រប់ទាំង១២៧ខេត្ត ចាប់តាំងពីស្រុកក្លិង្គ រហូតដល់ស្រុក
អេធីយ៉ូពី[ឌ] គឺដល់គ្រប់ទាំងខេត្តតាមអក្សរជាតិ និងដល់គ្រប់
ទាំងសាសន៍ តាមភាសារបស់គេ ហើយដល់សាសន៍យូដា
តាមអក្សរ តាមភាសារបស់គេដែរ[ឍ] ១០លោកបានធ្វើ
សំបុត្រនោះ ដោយនូវព្រះនាមនៃស្តេចអ័ហាស៊ូរុស ព្រម
ទាំងប្រថាប់ត្រាដោយព្រះរាជទំរង់ រួចផ្ញើទៅដោយសារ
ពួកអ្នករត់សំបុត្រ ដែលជិះសេះ ជាសត្វយ៉ាងលឿន ដែល
នៅក្នុងក្រសួងស្តេច ១១ឯក្នុងសំបុត្រទាំងនោះ ស្តេចទ្រង់
អនុញ្ញាតឱ្យពួកសាសន៍យូដា ដែលនៅគ្រប់ទីក្រុងបានមូល
គ្នា ដើម្បីការពារជីវិតខ្លួន ហើយឱ្យបំផ្លាញ សំឡាប់ និងធ្វើ
ឱ្យវិនាសដល់គ្រប់ទាំងអំណាចរបស់បណ្តាជន នៅខេត្តណា
ដែលនឹងលើកគ្នាមកធ្វើបាបខ្លួន ទោះទាំងកូនក្មេង និង
ពួកស្រីៗផង ហើយឱ្យរឹបជាន់[ណ]យកទ្រព្យ សម្បត្តិរបស់គេ
ទុកជារបឹបដែរ ១២នៅគ្រប់ទាំងអាណាខេត្តនៃស្តេច
អ័ហាស៊ូរុស ក្នុងថ្ងៃ១នោះឯង គឺជាថ្ងៃ១៣ខែ១២ ដែលជា
ខែផល្គុន[ត] ១៣សំបុត្រទាំងនោះមានចំឡងព្រះរាជឱង្ការ
ដែលត្រូវប្រកាសប្រាប់ដល់គ្រប់ទាំងសាសន៍ នៅអស់ទាំង
ខេត្តផងថា ពួកសាសន៍យូដាត្រូវប្រុងប្រៀបនឹងសងសឹក
ដល់ពួកខ្មាំងសត្រូវរបស់ខ្លួន នៅថ្ងៃនោះ[ថ]ឯង ១៤ដូច្នេះ
ពួកអ្នករត់សំបុត្រទាំងនោះ ដែលជិះសត្វយ៉ាងលឿន ជាសត្វ
ដែលប្រើក្នុងក្រសួងនៃស្តេច គេរួសរាន់ចេញទៅ ដោយ
ប្រញាប់ប្រញាល់ មានទាំងបង្គាប់ស្តេចបង្ខំផង ហើយព្រះ
រាជឱង្ការនោះ ក៏បានផ្សាយចេញទៅ នៅត្រង់ស៊ូសានជា
ទីក្រុងហ្លួងដែរ[ទ] ។
១៥ឯម៉ាដេកាយ[ធ]លោកចេញពីចំពោះស្តេចទៅ ទាំង
ស្លៀកពាក់ប្រដាប់របស់ក្រមហ្លួងពណ៌ខៀវ ហើយសមាន
ពាក់មកុដមាសយ៉ាងធំ[ន] និងអាវវែង សំពត់ខ្លួនទេសពណ៌
ស្វាយផង[ប] នោះពួកអ្នកក្រុងស៊ូសានក៏ស្រែកឡើង ដោយ
អំណរ[ផ] ១៦ដូច្នេះ ពួកសាសន៍យូដា គេមានចិត្តជ្រះថ្លារីក
រាយសប្បាយ[ព] ព្រមទាំងមានសេចក្តីថ្កុំថ្កើងផង[ភ] ១៧ហើយ
នៅគ្រប់ទាំងខេត្ត និងទីក្រុងនៅកន្លែងណា ដែលបាន
ប្រកាសប្រាប់ព្រះរាជឱង្ការ និងបង្គាប់របស់ស្តេច នោះ
ពួកសាសន៍យូដាក៏មានសេចក្តីរីករាយសាទរ[ម] ព្រមទាំង
ជប់លៀង ហើយមានថ្ងៃសប្បាយ មានពួកសាសន៍ដទៃជា
ច្រើន ដែលនៅក្នុងស្រុកបានចូលជាតិជាសាសន៍យូដា
ដោយកើតមានសេចក្តីកោតខ្លាច[យ]ដល់គេ[រ] ។

## ជ័យជំនះរបស់ពួកយូដា

**៩** ១លុះដល់ថ្ងៃ១៣នៅខែ១២ជាខែផល្គុន[ក] កាលព្រះរាជ
ឱង្ការ និងបង្គាប់របស់ស្តេចបានជិតដល់កំរិតហើយ គឺជា
ថ្ងៃដែលពួកខ្មាំងសត្រូវរបស់សាសន៍យូដា បានសង្ឃឹមថា
នឹងឡើងមានអំណាចលើគេបាន (តែពួកយូដាបានត្រឡប់
ជាមានអំណាច[ខ]លើពួកអ្នកដែលស្អប់ដល់គេវិញ[គ]) ២នោះ
ពួកសាសន៍យូដា ក៏មូលគ្នានៅទីក្រុងខ្លួនទាំងប៉ុន្មាន[ឃ] នៅ
អស់ទាំងអាណាខេត្តរបស់ស្តេចអ័ហាស៊ូរុស ដើម្បីនឹងតស៊ូ
ចំពោះពួកអ្នកដែលរកធ្វើបាបដល់គេ ហើយគ្មានអ្នកណា
អាចនឹងទ្រាំនៅចំពោះគេបានឡើយ[ង] ដ្បិតសាសន៍ទាំងអស់
បានកើតមានសេចក្តីកោតខ្លាចដល់គេហើយ ៣ឯពួកអ្នកជា
ប្រធាន នៅគ្រប់ទាំងខេត្ត ពួកចៅហ្វាយខេត្ត ពួកចៅហ្វាយ
ស្រុក និងពួករាជការទាំងប៉ុន្មាន ក៏ជួយដល់ពួកយូដា[ច]
ដោយមានសេចក្តីកោតខ្លាចដល់ម៉ាដេកាយ[ឆ] ៤ពីព្រោះម៉ា
ដេកាយ[ជ]បានឡើងជាអ្នកធំ[ឈ] ក្នុងព្រះរាជដំណាក់ ហើយ
កិត្តិនាមលោក ក៏ផ្សាយសុសសាយទូទៅ គ្រប់ទាំងខេត្ត ដ្បិត
ម៉ាដេកាយនេះបានកាន់ តែមានអំណាចឡើងជាដរាប[ញ]

**៨:៩** ឌ នអ ១:១
ឍ នហ ១៣:២៤
**៨:១១** ណ លប ១៤:២៣ នអ ៣:១៣ ៩:១០,១៥,១៦
**៨:១២** ត នអ ៣:១៣ ៩:១
**៨:១៣** ថ នអ ៣:១៤
**៨:១៤** ទ នអ ៣:១៥
**៨:១៥** ធ នអ ៩:៤ ១០:២ ន ២សយ ១២:៣០ ប លប ៤១:៤២ ផ នអ ៣:១៥
**៨:១៦** ព ទដ ៩៧:១០–១២ ភ នអ ៤:១–៣ ទដ ១១២:៤ យរ ២៩:៤–៧
**៨:១៧** ម ទដ ៣៥:២៧ ៤៥:១៥ ៥១:៨ សភ ១១:១០ យ នក ១៥:១៤,១៦ ដយ ១១:២៥ ដយ ៦:២៦ រ នអ ៩:៣
**៩:១** ក នអ ៨:១២ ខ យរ ២៩:៤–៧ គ នអ ៣:១២–១៤ សភ ២២:២២–២៣
**៩:២** ឃ លប ២២:១៧ ង ទដ ៣៥:២៦ ៤០:៤១ ៧០:២ ៧១:១៣,២៤
**៩:៣** ច អរ ៨:៣៦ ឆ នអ ៨:១៧
**៩:៤** ជ នអ ៨:១៥ ឈ នក ១១:៣ ញ ២សយ ៣:១ ១រប ១១:៩

**៨:១២** *ថ្ងៃ ១៣ ខែ ១២* គឺត្រូវនឹង ថ្ងៃ ៧ ខែមិនា ឆ្នាំ ៤៧៣ មុនគ.ស (មើល ៣:១៣ និងការពន្យល់) ។ ប្រហែលជា ១៥ឆ្នាំ បន្ទាប់ពីការប្រារព្ធពិធីបុណ្យពោរជាលើកដំបូង លោកអែសរ៉ាបានដឹកនាំពួកអ៊ីស្រាអែលមួយក្រុម ទៅក្រុងយេរូសាឡិម នៅឆ្នាំ ៤៥៨ មុនគ.ស (អរ ៧:៩) ។

**៨:១៤–១៧** ពាក្យក្នុងវគ្គនេះ គឺមានលំនាំដូចវគ្គ ៣:១៥–៤:៣ ។

**៨:១៥** *ស្លៀកពាក់ប្រដាប់របស់ក្រមហ្លួង* មើលការពន្យល់ ៦:៨ ។ លោកម៉ាដេកាយបានទទួលការតែងតាំងជាលើកទីពីរទៀត (មើល ៦:៧–១១ និងមើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ) ។

**៩:១** ក្នុងរយៈពេល ៨ ខែ និង ២០ ថ្ងៃក្រោយមក ពួកសាសន៍យូដាបានអនុវត្តតាមព្រះរាជក្រឹត្យ ដែលស្នើដោយលោកម៉ាដេកាយ (មើល ៨:៩) ។ *ត្រឡប់ជាមានអំណាចលើពួកអ្នក ដែលស្អប់គេវិញ* អ្នកនិពន្ធបាននិយាយអំពីស្ថានភាពដែលប្រែជាផ្ទុយស្រឡះ ដើម្បីឱ្យសាច់រឿងមានភាពស្មើគ្នា ដោយនិយាយលម្អិតសាច់រឿងនៅក្នុងផ្នែកពាក់កណ្តាលដំបូងនៃរឿងនេះ កុំឱ្យមានភាពលើសបួខ្វះ នឹងផ្នែកទីពីរនៃរឿងនេះ ដែលនិយាយអំពី ភាពផ្ទុយស្រឡះនៃដំណើររឿងនោះ ។

**៩:២–៣** វគ្គនេះបានបកស្រាយអំពីបទគម្ពីរ លប ១២:៣ ។ នៅពេលដែលគេចេញព្រះរាជក្រឹត្យពីរដែលប្រាសចាកគ្នា (ព្រះរាជក្រឹត្យតាមសំណើររបស់ហាមាន និងព្រះរាជក្រឹត្យតាមសំណើររបស់លោកម៉ាដេកាយ) យ៉ាងដូចនេះ ពួកអភិបាលបាននាំគ្នាអនុវត្តតាមព្រះរាជក្រឹត្យថ្មីវិញ ។

**៩:៣** "សាសន៍ដទៃបានកោតខ្លាចដល់សាសន៍យូដា" (៨:១៧) គឺមិនខុសពីការដែលពួកមន្ត្រីដែល"កោតខ្លាចដល់លោកម៉ាដេកាយនោះឡើយ"។

៥ដូច្នេះ ពួកសាសន៍យូដាបានប្រហារ ពួកខ្មាំងសត្រូវដោយ
ដាវ ព្រមទាំងសំឡាប់បំផ្លាញគេ[ដ] ហើយបានប្រព្រឹត្តនឹងពួក
អ្នកដែលស្អប់ខ្លួនតាមតែអំពើចិត្ត ៦នៅស៊ូសាន ជាទីក្រុង
ហ្លួង ពួកសាសន៍យូដាក៏បានសំឡាប់ ហើយបំផ្លាញមនុស្ស
អស់៥០០នាក់ដែរ ៧ឯផើសានដាថា ដាលផូន អ័សផាថា
៨ផូរ៉ាថា អ័ដាលា អើរីដាថា ៩ផើម៉ាសថា អើរីសាយ
អើរីដាយ និងវ៉ាយេសាថា ១០ជាកូនទាំង១០[ឋ]របស់ហាម៉ាន
កូនហាំម្តាថា ដែលជាខ្មាំងសត្រូវនឹងពួកសាសន៍យូដា[ឌ] នោះ
គេក៏សំឡាប់ទៅដែរ តែគេមិនបានប៉ះ ពាល់ដល់របឹប
ទេ[ឍ]។
១១នៅថ្ងៃនោះឯង គេមកទូលដល់ស្តេច ពីចំនួនមនុស្ស
ដែលគេបានសំឡាប់នៅក្នុងស៊ូសាន ជាក្រុងហ្លួង ១២រួច
ស្តេចទ្រង់មានបន្ទូលនឹងអេសធើរ ជាអគ្គមហេសីថា ពួក
សាសន៍យូដាបានសំឡាប់ហើយ បំផ្លាញមនុស្ស អស់៥០០
នាក់ នៅស៊ូសាន ជាក្រុងហ្លួង ព្រមទាំងកូនរបស់ហាម៉ាន
ទាំង១០ផង ដូច្នេះ នៅព្រះរាជខេត្តឯទៀត គេបានធ្វើយ៉ាង
ណាទៅឥឡូវនេះ តើព្រះនាងចង់សូមអ្វីទៀត យើងនឹងបើក
ឱ្យ តើប្រាថ្នាចង់បានអ្វី នោះនឹងបានសំរេច[ណ] ១៣អេសធើរ
ទូលថា បើព្រះករុណាទ្រង់សព្វព្រះទ័យ នោះសូមបើកឱ្យ
ពួកយូដា ដែលនៅក្រុងស៊ូសានបានធ្វើតាមច្បាប់ដដែល
នៅថ្ងៃស្អែកទៀត ហើយឱ្យគេព្យួរ[ត]ខ្មោចកូន[ថ]របស់ហាម៉ាន
ទាំង១០នាក់និងឈើទៅ ១៤ស្តេចទ្រង់ក៏ បង្គាប់ឱ្យធ្វើដូច្នោះ
ហើយគេប្រកាសប្រាប់ព្រះរាជឱង្ការនៅក្រុងស៊ូសាន រួច
បានព្យួរ[ទ]ខ្មោចកូនហាម៉ានទាំង១០នាក់នោះទៅ ១៥ពួក
សាសន៍យូដា ដែលនៅក្រុងស៊ូសាន ក៏មូលគ្នានៅថ្ងៃ១៤
ខែផល្គុននោះឯង ហើយគេសំឡាប់មនុស្ស៣០០នាក់ទៀត
នៅស៊ូសាន តែគេមិនប៉ះពាល់ដល់របឹបទេ[ធ] ១៦ឯពួកយូដាឯ
ទៀតទាំងប៉ុន្មានដែលនៅអស់ទាំងព្រះរាជខេត្ត គេបាន
មូលគ្នា ដើម្បីការពារជីវិតខ្លួន ហើយគេមានសេចក្តីសាន្ត
ត្រាណ[ន] ពីពួកខ្មាំងសត្រូវរបស់គេតទៅ[ប] គេបានសំឡាប់
ពួកអ្នក[ផ]ដែលស្អប់គេអស់៧ម៉ឺន៥ពាន់នាក់ តែឥតបានប៉ះ
ពាល់ដល់របឹបទេ[ព]។
១៧គេបានធ្វើការនោះនៅថ្ងៃ១៣ខែផល្គុន លុះដល់ថ្ងៃ
១៤ ទើបគេឈប់សំរាក ហើយក៏តាំងថ្ងៃនោះ ជាថ្ងៃសំរាប់
ជប់លៀង[ភ] ហើយមានសេចក្តីរីករាយសាទរ។

## ការធ្វើបុណ្យពោរ

១៨តែពួកសាសន៍យូដា ដែលនៅក្រុងស៊ូសាន គេបាន
មូលគ្នានៅថ្ងៃ១៣ ក្នុងខែនោះ នឹងនៅថ្ងៃ១៤ដែរ លុះដល់
ថ្ងៃ១៥ ទើបគេឈប់សំរាក ហើយតាំងថ្ងៃនោះឡើង សំរាប់
ជាថ្ងៃជប់លៀង ហើយមានសេចក្តីរីករាយសាទរ ១៩គឺ
ដោយហេតុនោះបានជាពួកសាសន៍យូដា ដែលនៅអស់
ទាំងទីក្រុងឥតកំផែងនៅស្រុកក្រៅ គេកាន់ថ្ងៃ១៤ខែផល្គុន[ម]
ជាថ្ងៃសំរាក់រីករាយសាទរ ហើយជប់លៀងជាថ្ងៃសប្បាយ
ហើយជាពេលជូនជំនូនទៅវិញទៅមក[យ]។
២០ឯម៉ាដេកាយ លោកក៏តែងសេចក្តីទាំងនេះទុក ហើយ
ផ្ញើសំបុត្រទៅដល់ពួកសាសន៍យូដាទាំងអស់ ដែលនៅគ្រប់
ទាំងខេត្តនៃស្តេចអ័ហាស៊ូរុស ទាំងជិតទាំងឆ្ងាយ ២១ដើម្បី
នឹងបញ្ជាក់ដលគេ ឱ្យបានកាន់ថ្ងៃ១៤ ខែផល្គុននឹងថ្ងៃ១៥ផង
រាល់តែឆ្នាំ ២២ទុកជាថ្ងៃដែលពួកសាសន៍យូដាបានសេចក្តី

**៩:៥** ដ ចទ ២៥:១៧–១៩ ១សយ ១៥:៣ អរ ៤:៦
**៩:១០** ឋ នអ ៥:១១ ទដ ១២៧:៣–៥ ឌ ១សយ ១៥:៣៣ ឍ លប ១៤:២៣ ១សយ ១៤:៣២ នអ ៣:១៣
**៩:១២** ណ នអ ៥:៦ ៧:២
**៩:១៣** ត ចទ ២១:២២–២៣ ថ នអ ៥:១១
**៩:១៤** ទ អរ ៦:១១
**៩:១៥** ធ លប ១៤:២៣ នអ ៨:១១
**៩:១៦** ន នអ ៤:១៤ ប ចទ ២៥:១៩ ផ ១របា ៤:៤៣ ព នអ ៨:១១
**៩:១៧** ភ ១ពវ ៣:១៥
**៩:១៩** ម នអ ៣:៧ យ ចទ ១៦:១១,១៤ នអ ២:៩ វវ ១១:១០

**៩:៥–១០** នៅក្នុងវគ្គនេះ ពួកយូដាបានបន្តអនុវត្តតាមផែនការលុបបំបាត់សាសន៍អាម៉ាឡេក ដែលមិនទាន់បានសម្រេច(នក ១៧:១៤–១៦ ចទ ២៥:១៧–១៩ និងការពន្យល់ ៣:១–៦)។ តែលើកនេះ ពួកគេធ្វើខុសពីលើកមុន(មើល ១សយ ១៥) គឺពួកគេមិនចាប់យករបឹបទេ ទោះបីជាស្តេចបានអនុញ្ញាតហើយក៏ដោយ(៨:១១)។ កាលពីសតវត្សមុនការចាប់យករបឹបនៅក្នុងសង្គ្រាមទាស់នឹងពួកអាម៉ាឡេក បានបណ្តាលឱ្យស្តេចសូលត្រូវបាត់បង់រាជបល្ល័ង្ក(១សយ ១៥:១៧–១៩,២៣) ហើយក្នុងរឿងនេះវិញ ការមិនចាប់យករបឹបបាននាំឱ្យលោកម៉ាដេកាយបានទទួលអំណាចពីស្តេច សាសន៍របស់គាត់បានទទួលស្គាល់គាត់ ដោយការដឹងគុណ(ខ.២០–២៣)។ មើល ខ.១៥–១៦ ធៀបនឹង លប ១៤:២២–១៥:១ ។

**៩:១២** មើល ៥:៣,៦ ៧:២ ។

**៩:១៣–១៤** ការព្យួរករនៅក្នុងវគ្គនេះ សំដៅទៅលើការយកសាកសពមកព្យួរបង្ហាញដល់សាធារណៈជន គឺមិនសំដៅទៅលើការព្យួរករប្រហាជីវិតនោះទេ(មើល ខ.៧–១០ និងការពន្យល់ ២:២៣)។

**៩:១៣** *ស៊ូសាន* គឺសំដៅទៅលើទីក្រុងនេះទាំងមូល មិនមែនទៅលើទីមានកំផែងការពារក្នុងទីក្រុងនេះទេ(ខ.១១–១២ និងការពន្យល់ ១:២)។

**៩:១៥–១៦** មើលការពន្យល់ ខ.៥–១០ ។

**៩:១៦,២២** *មានសេចក្តីសាន្តត្រាណ ពីពួកខ្មាំងសត្រូវរបស់គេ* ការសងសឹកមកលើពួកខ្មាំងសត្រូវរបស់ពួកអ៊ីស្រាអែល គឺមានភ្ជាប់នឹងសេចក្តីសន្យាប្រទាននូវការសម្រាកសម្រាប់ពួកគេ(ចទ ២៥:១៩)។ បរាជ័យរបស់ហាម៉ាន បាននាំឱ្យពួកយូដាបានទទួលនូវការសម្រាក(មើលសេចក្តីផ្តើមត្រង់ចំណុច គោលបំណង គោលរឿង និងលក្ខណៈអក្សរសាស្ត្រ ធៀននឹង ១របា ២២:៦–១០ ទដ ៩៥:៧–១១ អស ៣២:១៨ ហាព ៣:៧–៤:១១)។

**៩:១៨–១៩** អ្នកនិពន្ធបាននិយាយអំពីការធ្វើពិធីបុណ្យពោរនៅថ្ងៃពីរផ្សេងគ្នាគឺ ពួកយូដាដែលរស់នៅតាមទីក្រុងភាគច្រើនធ្វើនៅថ្ងៃទី១៤ ប៉ុន្តែ ពួកយូដាដែលរស់នៅក្រុងស៊ូសានធ្វើនៅថ្ងៃទី១៥ ។ វគ្គនេះនិយាយអំពីការប្រារព្ធធ្វើនៅថ្ងៃទី១៤ ដែលលើកលែងតែនៅក្រុងយេរូសាឡិមដែលធ្វើនៅថ្ងៃទី១៥ ។

**៩:២០** *ម៉ាដេកាយ លោកក៏តែងសេចក្តីទាំងនេះទុក* អ្នកខ្លះយល់ថា តាមខនេះ លោកម៉ាដេកាយជាអ្នកនិពន្ធព្រះគម្ពីរនេះ ប៉ុន្តែ បើតាមន័យត្រង់វិញ

សាន្តត្រាណ[រ] ពីពួកខ្មាំងសត្រូវរបស់គេនឹងជាខែ ដែល
សេចក្ដីទុក្ខព្រួយរបស់គេបានត្រឡប់ទៅជាសេចក្ដីរីករាយ
សាទរ ហើយសេចក្ដីសោកសៅបានទៅជាថ្ងៃសប្បាយវិញ[ល]
ប្រយោជន៍ ឱ្យគេបានតាំងថ្ងៃទាំង២នោះ ទុកជាថ្ងៃសិរាប់
ជប់លៀង ហើយមានសេចក្ដីរីករាយសាទរព្រមទាំងជូន
ជំនូន[វ]ទៅវិញទៅមក ហើយដាក់ទានដល់មនុស្សទាល់ក្រ
ផង[ស] ២៣ដូច្នេះ ពួកសាសន៍យូដាក៏សំរេចនឹងធ្វើតាម ដូចជា
គេបានចាប់តាំងធ្វើមកហើយ គឺដូចជាម៉ាដេកាយបាន
សរសេរផ្ញើមកដែរ ២៤ពីព្រោះហាម៉ាន ជាកូនហាំម្ដាថា
សាសន៍អ័កាក់[ហ] ដែលជាខ្មាំងសត្រូវនឹងពួកសាសន៍យូដា
បានបង្កើតឧបាយនឹងបំផ្លាញគេ ក៏បានវាយលេខតាម
របៀនពោរ[ឡ] គឺបានបោះឆ្នោត[អ]ដើម្បីនឹងបំផ្លាញគេ ហើយ
គេឱ្យគេវិនាសបង់[ក] ២៥តែកាលព្រះនាងអេសធើរ បានចូល
ទៅគាល់ស្តេច នោះទ្រង់ក៏ចេញបង្គាប់ដោយសំបុត្រឱ្យ
ឧបាយដ៏អាក្រក់ ដែលហាម៉ានបានបង្កើតទាស់នឹងពួកយូដា
នោះ បានវិលជះទៅលើក្បាលវាវិញ[ខ] ហើយឱ្យព្យួរវា[គ]
និងពួកកូនវាទាំងអស់ភ្ជាប់លើឈើផង[ឃ] ២៦ហេតុនោះបាន
ជាគេហៅថ្ងៃទាំង២នោះថា "បុណ្យពោរ" តាមពាក្យ
"ពោរ"[ង]នោះឯង ហើយដោយព្រោះសេចក្ដីទាំងប៉ុន្មាន
ក្នុងសំបុត្រនោះ និងការទាំងប៉ុន្មានដែលគេបានឃើញ
ពីដំណើរនោះ ព្រមទាំងការដែលបានកើតដល់គេផង
២៧បានជាពួកសាសន៍យូដា គេតាំងទំនៀមនោះទុកហើយ
ក៏ទទួលថា ខ្លួនគេ ពួកកូនចៅ និងអស់អ្នកណាដែលចូល
សាសន៍គេ និងរក្សាថ្ងៃទាំង២នោះ តាមសេចក្ដីដែលបាន
សរសេរទុក ហើយតាមវេលាកំណត់នោះរាល់ តែឆ្នាំឥត
ខានឡើយ ២៨ហើយថា គេនឹងនឹកចាំ ហើយរក្សាថ្ងៃទាំង២
នោះ នៅគ្រប់ទាំងដំណ គ្រប់ទាំងគ្រួរ នៅអស់ទាំងខេត្ត
និងទីក្រុងទាំងប៉ុន្មានជាដរាបទៅ មិនឱ្យបាត់ពីពួកសាសន៍
យូដាឡើយ ឬឱ្យកូនចៅគេលែងនឹងចាំពីថ្ងៃនោះដែរ ។

២៩គ្រានោះ អេសធើរ ដ៏ជាអគ្គមហេសី ជាបុត្រី
អ័ប៊ីហែល[ច] ព្រមទាំងម៉ាដេកាយ ជាសាសន៍យូដាក៏
សរសេរម្តងទៀត ផ្ញើទៅដោយអាងគ្រប់អំណាចរបស់ខ្លួន
ដើម្បីនឹងតាំងសំបុត្រពីបុណ្យពោរនោះ ទុកជាច្បាប់តទៅ
៣០លោកក៏ផ្ញើសំបុត្រទៅពួកសាសន៍យូដាទាំងអស់ ដែល
នៅក្នុងអាណាខេត្ត[ឆ]ទាំង១២៧ នៃនគររបស់អ័ហាស៊ូរុស
មានទាំង ពាក្យស្រគត់ស្រគំ និងពាក្យដ៏ទៀតត្រង់ពិតផង
៣១ដើម្បីនឹងបញ្ជាក់ ថ្ងៃបុណ្យពោរ នៅវេលាកំណត់ ដូចជា
ម៉ាដេកាយ ជាសាសន៍យូដា និងអេសធើរ អគ្គមហេសី បាន
តាំងឡើងដល់គេហើយ ដូចជាគេក៏បានតាំងឡើងសិរាប់
ខ្លួនគេ និងកូនចៅគេតទៅ ខាងឯដំនើរការតមអត់[ជ] និង
អំពាវនាវរបស់គេដែរ[ឈ] ៣២ដូច្នេះ ក្រិត្យរបស់ព្រះនាង
អេសធើរបានបញ្ជាក់ពីរបៀបបុណ្យពោរនោះ ហើយ
ក្រិត្យនោះក៏បានកត់ចុះទុកក្នុងសៀវភៅ ។

## សក្តិយសរបស់ម៉ាដេកាយ

**១០** ១ឯស្តេចអ័ហាស៊ូរុស ទ្រង់ដាក់ឱ្យមានពន្ធដារដល់
ពួកអ្នកស្រុក និងពួកដែលនៅកោះសមុទ្រទាំងប៉ុន្មាន[ក] ២រីឯ
អស់ទាំងកិច្ចការនៃព្រះចេស្តា និងឥទ្ធិឫទ្ធិរបស់ទ្រង់ព្រម
ទាំងរឿងសព្វគ្រប់ពីសក្តិយសរបស់ម៉ាដេកាយ[ខ] ដែលស្តេច
បានតាំងលោកឡើងដល់ថ្នាក់ណា[គ] នោះសុទ្ធតែបានកត់ទុក
ក្នុងសៀវភៅរបាក្សត្រ[ឃ]របស់ពួកស្តេចសាសន៍មេឌីនឹង
សាសន៍ពើស៊ីហើយ ៣ដ្បិតម៉ាដេកាយ ជាសាសន៍យូដា
លោកជាអ្នកបន្ទាប់[ង,ច]នឹងស្តេចអ័ហាស៊ូរុសនោះឯង[ឆ]
ហើយក៏ជាអ្នកធំក្នុងពួកសាសន៍យូដា ព្រមទាំងមានពួកបង
ប្អូនលោកយ៉ាងសន្ធឹករាប់អានផង ដោយលោករកតែ
សេចក្ដីល្អដល់សាសន៍របស់ខ្លួន ហើយនិយាយជាពាក្យ
ស្រគត់ស្រគំដល់ជាតិផង[ជ] ។/

**៩:២២** រ នអ ៤:១៤ ល នហ ៨:១២ ទជ ៣០:១១-១២ វ ២ពវ ២៥:៣០ ស នហ ៨:១០
**៩:២៤** ហ នក ១៧:៨-១៦ ឡ នអ ៣:៧ អ លវ ១៦:៨ ក នអ ៣:៦
**៩:២៥** ខ ន ទជ ៧:១៦ គ ចទ ២១:២២-២៣ ឃ នអ ៧:១០
**៩:២៦** ង នអ ៣:៧
**៩:២៩** ច នអ ២:១៥
**៩:៣០** ឆ នអ ១:១
**៩:៣១** ជ នអ ៤:១៦ ឈ នអ ៤:១-៣
**១០:១** ក ទជ ៧២:១០ ៩៧:១
**១០:២** ខ នអ ៨:១៥ គ លប ៤១:៤៤ ឃ នអ ២:២៣
**១០:៣** ង ដយ ៥:៧ ច លប ៤១:៤៣ ឆ លប ៤១:៤០ ជ នហ ២:១០ យរ ២៩:៤-៧ ដយ ៦:៣

នៅត្រង់ចំណុចនេះ លោកម៉ាដេកាយបានកត់ត្រាទុក អំពីព្រឹត្តិការណ៍ទាំងឡាយ នៅក្នុងសំបុត្រដែលគាត់បានផ្ញើទៅ ។

**៩:២២** *ជូនជំនូន* មើលការពន្យល់ ២:៩ ធៀបនឹង នហ ៨:១០,១២ ។

**៩:២៤,២៦** *បុណ្យពោរ* មើលការពន្យល់ ៣:៧ ។

**៩:២៥** *បានវិលជះទៅលើក្បាលវាវិញ* មើលការពន្យល់ ខ.១ ។

**៩:៣១** *តមអត់* មើលការពន្យល់ ៤:៣,១៦ ។ ព្រះគម្ពីរនេះមិនបានបញ្ជាក់ថាការតមអត់នេះ ត្រូវធ្វើនៅថ្ងៃណាទេ ។ តាមទំនៀមទម្លាប់របស់ពួកយូដា ពួកគេកំណត់យកថ្ងៃទី ១៣ ខែ អ័ដារ (Adar) ដែលជាថ្ងៃជ័យជម្នះរបស់ហាម៉ាន (មើល ៣:៧,១៣) ជាថ្ងៃតមអត់ ("ការតមរបស់នាងអេសធើរ") មុនថ្ងៃបុណ្យពោរ ។ គេធ្វើពិធីបុណ្យអបអរជ័យជម្នះនេះអស់បីថ្ងៃ ចាប់ពីថ្ងៃទី ១៣ ដល់ ១៥ ខែអ័ដារ (Adar) ក៏ដើម្បីឱ្យមានភាពតុល្យភាពនឹងការតមអត់ដែលនាងអេសធើរបានធ្វើអស់បីថ្ងៃ មុនចូលទៅគាល់ស្តេច ដើម្បីស្វែងរកដំណោះស្រាយ (៤:១៦) ។

**១០:១-២** អ្នកនិពន្ធបានលើកឡើងអំពីការបង់ពន្ធនេះ ដើម្បីផ្តល់ដល់អ្នកអាន (មើលការពន្យល់ ២:២៣) នូវពត៌មាន ឬការបញ្ជាក់បន្ថែមទៀត ។

**១០:២** តាមខនេះ គេអាចសន្និដ្ឋានថា ការនិពន្ធព្រះគម្ពីរនាងអេសធើរ គឺមានកាលបរិច្ឆេទ នៅក្រោយពេលស្តេចអ័ហាស៊ូរុសចូលទីវង្គត់ (ធៀបនឹង ១ពវ ១១:៤១ ១៤:១៩,២៩) ។

# ព្រះគម្ពីរយ៉ូប

## សេចក្ដីផ្ដើម

### ចំណងជើង

ទោះជាក្នុងគម្ពីរនេះភាគច្រើនមានឈ្មោះលោកយ៉ូប និងមិត្តភ័ក្ររបស់គាត់ក៏ដោយ គឺថាមិនមែនលោកយ៉ូបផ្ទាល់ជាអ្នកនិពន្ធ ។ វាប្រាកដជាសាសន៍អ៊ីស្រាអែល គឺជារឿយៗប្រើឈ្មោះជាសេចក្ដីសញ្ញាដល់រាស្ត្រអ៊ីស្រាអែលសម្រាប់ព្រះអម្ចាស់ គឺជាព្រះ (Yahweh យ៉ាវេ៌)ក្នុងគម្ពីរសិក្សា "គឺជាព្រះយេហូវ៉ា ។ នៅក្នុងបុរេកថា (ជំពូក ១–២)ការថ្លែងពីព្រះ (៣៨:១–៤២:៦) និងបុរេកថា(៤២:៧–១៧) "ព្រះយេហូវ៉ា"បានលេចមកឱ្យឃើញ មានរហូតដល់២៥ដង ហើយផ្នែកខាងចុងគម្ពីរនេះក្នុងជំពូក (ជំពូក ៣–៣៧)ក៏មានលេចមកមួយផងដែរ (១២:៩) ។

អ្នកនិពន្ធដែលពុំស្គាល់ឈ្មោះនេះបានរាប់ចូលជាប្រពៃណី ឬទម្លាប់ (នៃការសរសេរ) ស្ដីអំពីមនុស្សសុចរិតពីបុរាណដែលទទួលការឈឺចាប់យ៉ាងខ្លាំងដែលគួរឱ្យភ្ញាក់ផ្អើល "និងការលះបង់ "(យក ៥:១១ មើលការពន្យល់នៅទីនោះ) ដែលពុំបែរត្រឡប់ទាស់និងព្រះឡើយ (មើល អគ ១៤:១៤–២០) ភាពជាប្រពៃណីដែលទ្រង់ប្រើសម្រាប់ជាគោលបំណងទ្រង់ផ្ទាល់ ។ គឺអ្នកនិពន្ធ លះបង់អ្វីជាមានលក្ខណៈហួសសម័យ និងអ្វីដែលរាស្ត្រអ៊ីស្រាអែលពុំពេញចិត្ត ក្នុងការ ប្រើភាសារបស់លោកយ៉ូប និងមិត្តភក្រ្កគាត់ គាត់ក៏បង្ហាញបែបបទផ្ទាល់ខ្លួនរបស់គាត់ ដូចជាផ្នែកនៃការសរសេរអក្សរសាស្ត្រ និងគុណភាពនៃការបង្ហាញពីទេពកោសល្យនៃការនិពន្ធ គឺជាទេពកោសល្យរបស់អ្នកនិពន្ធ ។

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

គឺជាទំនាក់ទំនងពេលវេលាពីរ (១)គឺជាលោកយ៉ូបផ្ទាល់(២) គឺទាក់ទំនងនឹងការតែងនិពន្ធគម្ពីរនេះ ។ គឺសំបុត្រអាចមានទំនាក់ទំនងគ្រប់ពេលតាំងពីរាជកាលស្ដេចសាឡូម៉ូន រហូតដល់នារទេសរាស្ត្រអ៊ីស្រាអែល ក្នុងស្រុកបាប៊ីឡូន ។ ទោះជាអ្នកនិពន្ធជារាស្ត្រអ៊ីស្រាអែលក៏គេពុំបានបង្ហាញពីប្រវត្តិ អ៊ីស្រាអែលបានច្រើនទេ ។ អ្នកនិពន្ធបានប្រាប់អំពីយ៉ូប ជាអ្នកគ្រប់លក្ខណ៍ដែលមិនមែនរាស្ត្រអ៊ីស្រាអែល (១:១) ដែលរស់មានជីវិតនៅក្នុងសហស្សវត្សរ៍ទី២ មុន គ.ស (២០០–១០០០)។ គាត់ក៏ដូចជាចាស់ព្រឹទ្ធាចារ្យមួយរូប ឬមេពូជអំបូរហេព្រើរ ដែលមានអាយុជាង ១០០ឆ្នាំ (៤២:១៦)។ គាត់ដូចជាអ្នកមានធំមួយ មានសម្បត្តិ សត្វស្រុក សត្វព្រៃ មានបាវបំរើ (១:៣) គាត់ដូចជាសង្ឃសម្រាប់គ្រួសារ (១:៥)។ មានពួកសាសន៍សេបាមកប្លន់ពង្រត់យកទៅ(១:១៥) និងពួកសាសន៍ខាល់ដេ(១:១៧) ដែលពូជអំបូរត្រូវពេលសហស្សវត្សរ៍ទី២ ដូចបានបង្ហាញក្នុង Kesitah"ឱ្យប្រាក់១ដុំ" ក្នុង ៤២:១១ (មើល លប ៣៣:១៩ យស ២៤: ៣២) ការរកឃើញពីសេចក្ដីអធិប្បាយដ៏វែងស្ដីពីលោកយ៉ូប ដែលបានចុះពីការបរិច្ឆេទនៅសតវត្សរ៍ទី១ និងទី២ មុន គ.ស ។

### ភាសា និង អត្ថបទ

មានកន្លែងខ្លះគម្ពីរយ៉ូប មានការលំបាកក្នុងការបកប្រែ ដោយព្រោះតែពាក្យគេពុំស្គាល់ ឬពុំយល់ និងបែបបទនៃការសរសេររបស់គម្ពីរនេះ ។ ដោយហេតុផលនេះហើយ ការបកប្រែសម័យទំនើបជារឿយៗ មានលក្ខណៈផ្ទុយគ្នាខ្លះៗ ។ សូម្បីតែគ្រីស្ទបរិស័ទសម័យដើមដែលជាអ្នកបកប្រែគម្ពីរយ៉ូបទៅជាភាសាក្រិកជារឿយៗ ក៏ច្រឡំ ឬស្មុគស្មាញ ។ សញ្ញានៃគម្ពីរយ៉ូបដែលមានប្រហែល ៤០០បន្ទាត់ដែលខ្លីជាងសញ្ញាដែលទទួលពីអត្ថបទគម្ពីរហេព្រើរ និងអ្នកបកប្រែខ្លះអាចលុបចោលនូវឃ្លាណាដែលពួកគេពុំយល់ ។ អ្នកបកប្រែមុនៗក៏មានការលំបាកដូចគ្នា និងអ្នកបកប្រែសម័យនោះដែរ... ។

### ការកំណត់ និង ទស្សនៈវិស័យ

គឺជាខណៈដែលអ្នកនិពន្ធមានបំណងឱ្យគម្ពីររបស់ពួកគេមានសណ្ឋានជាប្រភពទេវសាស្ត្រ ដ៏សំខាន់ដែលមានវិភាគទានមានកំរិតខ្ពស់ក្នុងការចូលរួមដ៏សកម្មនៃអ្នកដែលទទួលការអប់រំ ដែលជារឿងដែលប្រាប់ពី អ្នកដែលរងទុក្ខដែលមានព្រះគង់ជាមួយ ដូចជាលោកយ៉ូបដែលទទួលការឈឺចាប់ ដែលមានវិបត្តិ ដែលមានការអួសបន្ទាយយ៉ាងវែងអន្លាយ។ លោកយ៉ូបបានអង្គុយក្នុងគំនរទុក្ខ ។

លោកក៏បានឮនូវអ្វីៗជាទេវសាស្ត្រ នូវថ្ងៃរបស់គាត់ដែលសំដែងពីផ្លូវរបស់ព្រះ និងផ្លូវដែលនាំឱ្យឈឺចាប់ ។ លោកក៏នាំឱ្យមានសម្លេងឮឡើង ។ ហើយលោកក៏ដឹងដែរថា អ្នកដែលឈឺចាប់ គឺអ្នកដែលមានព្រះការពារ លោកក៏បានយល់ពីប្រាជ្ញា នៃអ្វីដែលបានរៀតសូត្រ និងមានភាពអស់កល្ប ក៏ដូចជាប្រាជ្ញានៃយុគ្គសម័យមួយ ។ លោកយ៉ូបក៏បានស្គាល់ពីការអស្ចារ្យ បានកម្សាន្តចិត្ត (១៦:២) ដែលហៅថាប្រាជ្ញាដែលបានផ្តល់មតិ ដូចជាការដែលដុះអំបិលក្នុងដីបៅ និងបង្កើតបានជាឧបសគ្គដល់សេចក្តីជំនឿ ។ ក៏ជាការផ្ទុយពីប្រាជ្ញាដែលលោកបានទំនាស់ដោយពុំមានហេតុផលចំពោះអ្នកដែលជាធំជាង ប៉ុន្តែ លោកក៏មានរឿងដើម្បីប្រាប់ថា គឺជាសេចក្តីល្បួងក៏ជាឫសគល់របស់អ្នករងគ្រោះ ដែលមានព្រះគង់ជាមួយ ។

## ផ្នែករឿងបែបជាទេវសាស្ត្រ និងអត្ថបទជាដំណឹង

ខណៈពេលមនុស្សល្អគឺអ្នកដែលកោចខ្លាចដល់ព្រះ និងជៀសចេញពីសេចក្តីអាក្រក់ "១:១" បានឈឺចាប់ គឺជាផ្នែកខាងវិញ្ញាណរបស់មនុស្សដែលពុះពារ ដើម្បីស្វែងយល់នៅអ្វីៗ ដោយយោងតាមប្រវត្តិសាស្ត្រដែលបានកត់ត្រា គឺមនុស្សបានចោទជាសំណួរថា ***តើការងារនេះអាចមានដំណើរការយ៉ាងដូចម្តេច?*** ប្រសិនជាព្រះដែលមានព្រះចេស្តា និង "ភពផែនដីទាំងមូលក៏នៅក្នុងព្រះហស្តទ្រង់"។ ហើយចុះបើទ្រង់ពិតជាល្អពិតប្រាកដមែន ហេតុដូចម្តេចទ្រង់បណ្តាលឱ្យមានអំពើទ្រគោះយង់ឃ្នង់ខ្លាំងយ៉ាងនេះ? ហើយសំណួរក៏បានចំណោទសួររកហេតុផល ដោយមានចំណុចជាអត្ថន័យសមហេតុផល បីយ៉ាងគឺ :

១. ព្រះអម្ចាស់ក៏មិនមែនជាព្រះមានគ្រប់ព្រះចេស្តា គ្រប់ការទាំងអស់នោះទេ ។

២. ព្រះអម្ចាស់មិនគ្រាន់តែ ល្អសុទ្ធសាតនោះទេ ក៏ប៉ុន្តែ ក៏មានភាពអាក្រក់ក្នុងអង្គទ្រង់ដែរ ។

៣. មនុស្សលោកមិនត្រូវមានទោស ទោះជាយ៉ាងណាអ៊ីស្រាអែលសម័យដើម ក៏មិនអាចជជែកតវ៉ាបានដែរ ព្រោះព្រះចេស្តាដែលមានតេជះដែលមានឥទ្ធិឫទ្ធិ ទ្រង់ក៏ជាព្រះគ្រប់លក្ខណ៍ ហើយក៏គ្មានមនុស្សណាបរិសុទ្ធក្នុងព្រះភក្ត្រទ្រង់ដែរ ។ សេចក្តីសន្និដ្ឋានទាំងបីខាងលើនេះគឺជាគ្រឹះដល់ផ្នែកទេវសាស្ត្ររបស់លោកយ៉ូប និងមិត្តភ័ក្ត្ររបស់គាត់ ។ ភាពឡូស៊ីកជាក់ស្តែង ដែលបានបង្ហាញពីចុងបញ្ចប់ : គ្រប់ទាំងសេចក្តីវេទនារបស់មនុស្ស គឺបញ្ជាក់ពីរង្វាស់ដែលត្រូវទទួលពីអំពើអាក្រក់ ដែលពួកគេបានប្រព្រឹត្តក្នុងព្រះភក្ត្ររបស់ផងទ្រង់ ។ តាមរយៈការសង្ខេបដែលបានសន្និដ្ឋាន បានលេចឱ្យឃើញនូវភាពចាំបាច់ និងជាការសមតាមបំណងនៃលក្ខណៈទេវសាស្ត្រ ។ ប៉ុន្តែអ្វីៗដែលបង្ហាញឱ្យឃើញដល់សាក្សីផ្ទាល់ដល់ផ្នែកទេវសាស្ត្រ និងភាពដែលមិនអាចវាយយកបានក្នុងភាពអរូបិយ៍ គឺជារឿយៗប្រឈមនិងកាលៈទេសៈផ្សេងៗ ជាមួយនិងបទពិសោធន៍ របស់ដែលតែងតែទទួលបានក្នុងឆាកជីវិតរបស់មនុស្ស ។ ដូចជាមានអ្នកដែលសុចរិតទៀងត្រង់ ដែលមានចរិតត្រឹមត្រូវ ដែលឈរក្នុងភាពទៀងត្រង់ ក៏ជាអ្នកដែលរក្សាខ្លួនរបស់គេឱ្យឃ្លាតឆ្ងាយពីការប្រព្រឹត្តបំពាន ក៏ជាអ្នកដែលទទួលការឈឺចាប់រងទុក្ខ (មើល ទដ ៧៣)។ តាមរយៈទីបន្ទាល់ដោយផ្ទាល់នេះគឺជាផ្នែកទេវសាស្ត្រនាំមកនូវក្តីសង្ឃឹម ហើយបាត់បង់លំនាំដើម ។ វាក៏ជាប្រចុយនិងសំណួរប្រស្នាដ៏ច្រើន ហើយផ្នែកទេវសាស្ត្រនេះ បានបន្យល់នូវភាពអត់មានកំហុសដែលជាអ្នកត្រូវទទួលរងទុក្ខទៅវិញ ដែលត្រូវគ្មានបង្អួច ហើយទទួលការរងទុក្ខ ដោយវិបត្តិនៃសេចក្តីជំនឿរបស់ពួកគេ ។ ក្នុងការបើកសម្តែងក្នុងជំពូក ៣-៣៧ ។ (មើលការពន្យល់ ៥:២៧) គឺជាទេវសាស្ត្រ ដែលពួកគេបានសិក្សា ពុំបានជួយឬលើកទឹកចិត្ត ឬក៏កំសាន្តចិត្ត ចំពោះអ្នកដែលរងទុក្ខក្នុងការបំរើព្រះ ឬបំរើសេចក្តីពិតនោះទេ ។ អ្នកនិពន្ធក្នុងកណ្ឌគម្ពីរយ៉ូប ក៏បានបំបែកនូវចំណងដែលជាផ្នែកពិតនៃទេវសាស្ត្រ (Orthodox ជាពួកប្រកាន់វិន័យចាស់ តាំងតែសម័យពួកគេមកម្លេះ ។ គាត់ក៏ធ្វើឱ្យសេចក្តីស្លាប់បានបញ្ចប់ ក៏ពុំស្វែងរកផ្លូវលៃលកជាមួយ និងការរងទុក្ខឈឺចាប់របស់មនុស្ស របស់ព្រះ ។ វាគឺជាការបដិសេធ ដែលមានទាំងការឈឺចាប់ដែលចូលមកបន្ថែមទៀតក្នុងអ្នករងទុក្ខ ។ ក៏មានជម្លោះមកជំនួសវិញ, គាត់និទានរឿងហើយក្នុងសាច់រឿងរបស់គាត់ គាត់ក៏បំផ្លាស់បំប្រែ ទស្សនៈនៃទេព្ធតា ។ គ្រប់ទាំងអស់ដែលនៅជុំវិញគាត់ ក្នុងចំណោមទេវសាស្ត្រ និងរាស្ត្រធម្មតា ក៏ដូចជាអ្នកមានបំណងដើម្បីដោះស្រាយ ដំណោះស្រាយបញ្ហានៃព្រះ ។ តាមការពិតនៃការឈឺចាប់របស់មនុស្ស (គឺក្នុងផ្លូវរបស់ព្រះ) ការខាត់បង់របស់មនុស្ស(ពួកគេត្រូវទទួលយ៉ាងសមរម្យនូវអ្វីដែលគេបានទទួលនោះ)ទោះជាអ្នករងទុក្ខត្រូវយល់ពីបញ្ហានៃពន្លឺ ។ អ្នកនិពន្ធកណ្ឌយ៉ូប ក៏ផ្តល់នូវការលើកទឹកចិត្តដល់អ្នករងគ្រោះដែលមានព្រះគង់ជាមួយ ដោយបង្ហាញពួកគេថា ការរងទុក្ខរបស់ពួកគេ ក៏ផ្តល់នូវឱកាសដែលពុំដូចអ្នកផ្សេងទេ គឺជាការបង្ហាញអ្វីដែលជាភាពស្រឡាញ់ព្រះយ៉ាងពិតប្រាកដ គឺសម្រាប់មនុស្សលោក ។

លោកក៏បានចាប់ផ្តើមបង្ហាញពីក្រុមមនុស្សប្រភេទទី៣ ថាមានលក្ខណៈប្រហាក់ប្រហែលគ្នា ដូចគ្នា។ ក្នុងចំណោមស្នាព្រះហស្តទ្រង់ក៏មានសត្រូវមួយដ៏ធំ (មើល ជំពូក ១-២ )។ គឺភាពគ្មានសមត្ថភាពប្រឆាំងជាមួយព្រះអម្ចាស់ដោយតតាំងនឹងព្រះហស្តទ្រង់ឡើយ គឺកម្លាំង

ទ្រង់ និងអំណាចព្រះចេស្ដា គេនោះបានក្បត់ និងរារាំងស្ថានព្រះហស្តទ្រង់ ដែលជាទីកន្លែងដែលមានទំនាក់ទំនងរវាងមនុស្ស និងព្រះ គឺជាស្ថានព្រះហស្តរបស់ផងទ្រង់ ដែលមានលក្ខណៈដូចជាអង្គទ្រង់ ។ ក្នុងនាមជាអ្នកមេល្បួង ក៏ព្យាយាមល្បួងមនុស្សឱ្យបែកចេញពីព្រះ ក្បត់ព្រះ (មើល លប ៣,មថ ៤:១) ក្នុងនាមជាអ្នកចោទប្រកាន់(គឺជាម្នាក់ដែលមានឈ្មោះសាតាំង មានន័យថា "អ្នកចោទប្រកាន់" វាក៏ព្យាយាមបំបែកព្រះពីមនុស្ស(មើល សក ៣:១ វវ ១២:៩-១០) ។ ហើយអារក្សវាមានគោលបំណងបំបែកបំបាក់ព្រះ និងមនុស្សលោក ឱ្យដាច់ទំនាក់ទំនងគ្នា ។ ហើយឥទ្ធិពលរបស់មនុស្សលោក ដែលចេញពីព្រះនាំឱ្យមនុស្សមិនអាចផ្សះផ្សារជាមួយព្រះបានវិញ ។ នៅក្នុងផ្ទៃរឿងរបស់គាត់ អ្នកនិពន្ធបានរ៉ាយរ៉ាប់ពីសត្រូវក្នុងភាពក្លាហាន និងការវាយសម្រុកយ៉ាងខ្លាំងទៅលើព្រះអម្ចាស់ និងមនុស្ស ដែលមានព្រះគង់ជាមួយ មានលក្ខណៈពិសេស និងមានទំនាក់ទំនងយ៉ាងស្និទ្ធស្នាល ដែលជាភាពល្អចំពោះភាគីទាំងពីរ ។ នៅពេលដែល ព្រះបានហៅលោកយ៉ូប នៅពេលមានវត្តមានអារក្សសាតាំង ហើយបង្ហាញពីភាពសុចរិតរបស់ផងទ្រង់ គឺជាស្ថានព្រះហស្តដែលព្រះ សព្វព្រះហឫទ័យ ។ សាតាំងក៏ល្បួង ដោយប្រើឧបាយកលវាយប្រហារដោយកំហឹងចំពោះស្ងួនភ្ជារបស់ព្រះ វាក៏បង្ហាញពីជីវិតដូចជាឆ្កួត ឱ្យទ្រង់ឃើញ ។ វាបានចោទប្រកាន់លោកយ៉ូបពីមុខព្រះភក្ត្រទ្រង់ ។ វាក៏ចោទពីភាពបរិសុទ្ធរបស់លោកយ៉ូប គឺជាអំពើអាក្រក់ទៅវិញ ។ ស្ងួនភ្ជាដ៏សុចរិតដែលព្រះអម្ចាស់ពេញចិត្ត សព្វព្រះហឫទ័យ កំពុងតែបាត់បង់ភាពសុខសាន្ត ដែលជាអ្នកកោចខ្លាចអំពើបាប ។ ភាពសុចរិតរបស់លោកយ៉ូបគ្រាន់តែជាការបំរើព្រះប៉ុណ្ណោះ ។ វាគឺជាសេចក្ដីល្បួង ដែលធ្វើឱ្យដឹងពីសត្រូវ ។ ទ្រង់ជ្រាប់ថា ទ្រង់ត្រូវបញ្ចប់នូវគោលបំណងរបស់ផងទ្រង់ក្នុងរាល់ស្ថានព្រះហស្ត ។ ដោយមនុស្សត្រូវពឹងផ្អែកលើព្រះទាំងការរស់នៅ និងភាពសុសាន្ត ដែលជាឱកាសមួយ គឺជាសេចក្ដីល្បួងដ៏ធំបំផុតដល់មនុស្សជាតិ :
កុំឱ្យស្រឡាញ់ទ្រព្យជាជាងធ្វើជាអ្នកថ្វាយដែលជាការគាប់ព្រះហឫទ័យព្រះ ក៏ជាប្រយោជន៍មួយសម្រាប់ជាផល "នៃការជឿទុកចិត្ត" ពីព្រោះវាជាការចេញសង ។ ការចោទប្រកាន់របស់សាតាំងចំពោះលោកយ៉ូប គឺជាការចោទប្រកាន់ទៅលើមនុស្សសុចរិតដែលជាទីស្ងួនភ្ជារបស់ព្រះ ។ បើសិនជាគាត់ត្រឹមត្រូវ, សុចរិតដែលព្រះពេញព្រះទ័យក៏បង្ហាញពីភាពអាក្រក់ ហើយក៏ជាភាពបាក់បែក ធ្វើឱ្យមានភាព ចន្លោះរវាងព្រះ និងមនុស្សដែលមិនអាចជាស្ពានទចំលង ។

ខណៈនៃការលោះបាបរបស់មនុស្សដែលមិនអាចស្មានដល់ គឺជាភាពដែលមានព្រះវិញ្ញាណក្នុងចំណោមពួកគេក៏បង្ហាញឱ្យ ឃើញភាពអវិជ្ជមាន គឺជាសញ្ញាដែរ គឺអវិជ្ជមានខាងព្រះវិញ្ញាណ ។ ព្រះហឫទ័យទ្រង់បានបង្កើត និងលោះបាប នេះគឺជាគុណវិបត្តមួយ និងព្រះអម្ចាស់ក៏អាចបំបាក់អស់ទាំងអំពើបាប ។

ការចោទប្រកាន់ ដែលអារក្សបានបង្កើត គឺមិនត្រូវឱ្យការនេះនៅស្ងៀមទេ គឺមិនគ្រាន់តែបំផ្លាញវាប៉ុណ្ណោះទេ តែក៏ត្រូវបំផ្លាញ វាឱ្យនៅទីជម្រៅនៃទីដែលព្រះបានបង្កើត គឺផែនដី ។ ដូច្នេះព្រះអម្ចាស់អនុញ្ញាត្តិឱ្យសាតាំង ដែលជាសត្រូវមានផ្លូវរបស់វាជាមួយលោក យ៉ូប (Within Specified Limits ដោយមានដែនកំណត់និងលក្ខខ័ណ្ឌច្បាស់លាស់) គឺដើម្បីព្រះ និងលោកយ៉ូបដ៏សុចរិត ក៏បង្ហាញថាគ្មាន ទោសហើយអាមេចោទប្រកាន់ត្រូវបំបិទមាត់ ។ ការរវាតចិត្តនេះ ជាការប៉ះទង្គិចយ៉ាងខ្លាំងដល់លោកយ៉ូប ក៏ត្រូវបានទទួលការសង្កត់ពី សាំតាំង ភាពស៊ូទ្រាំយ៉ាងនេះ ធ្វើឱ្យព្រះអម្ចាស់សព្វព្រះទ័យ ហើយក៏មានសំណួរចោទឡើង ។ និងភាពសុចរិតរបស់គាត់ត្រូវបានអារក្ស មកបំពាននៅលើផែនដី តាមរយៈជាក់ស្ដែងនៃទេវសាស្រ្ត Orthodox របស់ពួកអ្នកប្រកាន់វិន័យចាស់របស់មិត្តភ័ក្រគាត់ លោកក៏ទទួល ការឈឺចាប់ដែរ ។ តែលោកយ៉ូបដឹងពីភាពសុចរិត និងទឹកចិត្តទៀងត្រង់របស់លោក ហើយថ្ងៃណាមួយគាត់នឹងបង្ហាញពីភាពគ្មានកំហុស (មើល ១៣:១៨ ១៤:១៣-១៧ ១៦:១៩ ១៩:២៥-២៧) ហើយផ្ទុយពីនោះ លោកយ៉ូបក៏បើកមាត់ ពោលពាក្យប្រទេសផ្ដាសាដល់ថ្ងៃ កំណើតរបស់ខ្លួន(ជំពូក ៣)និងស្ដីបន្ទោសព្រះដែលបានប្រព្រឹត្តអំពើពុំគាប់បីមកលើគាត់ (៩:២៨-៣៥)(ឯប្រពន្ធលោកយ៉ូប នាង និយាយថា អ្នកនៅតែរក្សាលក្ខណៈខ្លួនឬ ចូរប្រមាថដល់ព្រះហើយស្លាប់ចុះ (មើល ២:៩)។ តាមពិតអ្វីដែលធ្វើឱ្យគាត់ឈឺចាប់បំផុត គឺការបំបែកព្រះចេញពីលោកយ៉ូប ។

ដូច្នេះសត្រូវបានបិទមាត់ ហើយព្រះសព្វព្រះហឫទ័យក៏សម្ដែងឱ្យឃើញ ។ ឯលោកក៏បដិសេធមិនព្រមទទួលស្គាល់ អ្នកដែល បង្កើតគាត់សោះ ។ គាត់បែកទៅរកព្រះដោយភាពរកាំចិត្ត ហើយព្រួយ កំហឹង និងភាពត្អូញត្អែរ តែគាត់ក៏ពុំដែលបែកចេញពីព្រះ ឬបែកចេញពីភាពជាសង្ឃព្រះ ក៏ដើរទៅរកភាពងងឹតនៅកណ្ដាលរាត្រីដែរ ។ (ប្រៀបធៀប ទដ ៨៣) លោកយ៉ូបដែលមានព្រះគង់ជា មួយ គឺពឹងផ្អែកទៅលើស្ថានព្រះហស្ត ដែលគាត់បានឆ្លងកាត់ការសាកល្បងពីព្រះតាមរយៈ អាមេចោទប្រកាន់ដែលជាសត្រូវនោះ ។

ការសាកល្បងជាលើកដំបូងទៅលើភាពសុចរិតរបស់លោកយ៉ូប ហើយការល្បួងល ពីសេចក្ដីជំនឿមួយដងជាពីរដង ដូចជាការល្បួងលសេចក្ដីជំនឿក្នុងលើកទី២ ក៏មិនខ្សោយជាងលើកទី១ដែរ ។ ការល្បួងលដែលមានប្រភពចេញពីការចោទប្រកាន់របស់

សាតាំង គឺជាការពិតមួយ ដែលលោកយ៉ូបស្ថិតនៅក្នុងសភាពដ៏ខ្មៅងងឹត ក៏ស្ថិតក្នុងក្រសែភ្នែករបស់ព្រះអម្ចាស់ដែរ ។ ប៉ុន្តែលោកយ៉ូប ក៏ក្លាយជាជាតិសាសន៍របស់ស្នាព្រះហស្តទ្រង់ ដែលមានទាំងប្រាជ្ញា ការយល់ដឹង (ដែលមានលក្ខណៈជាព្រះដោយហេតុនោះ លោកយ៉ូបក៏បាត់បង់អស់ទាំងអ្វីៗទាំងអស់ គឺជាការល្បងលដ៏ខ្លាំងមួយ ។មិត្តភ័ក្ររបស់លោកយ៉ូបបានសន្និដ្ឋានយ៉ាងទុកចិត្តបំផុតថា ភាពសុក្រិត្យទៅលើទេវសាស្ត្រ អាចជាផ្លូវរបស់ព្រះ ។ ទោះយ៉ាងណា បទពិសោធនរបស់លោកយ៉ូប ធ្វើឱ្យមានច្បាស់ពីភាពស្ទីងជូរចត់ចំពោះលោកដែលប្រាជ្ញារបស់ពួកគេពុំអាចស៊ីជម្រៅដល់សេចក្តីពិតនៃស្ថានភាពរបស់គាត់បានទេ ។ គេក៏ត្រូវឱ្យព្រះអម្ចាស់ ពន្យល់បកស្រាយពីហេតុផលឱ្យសមរម្យ ។ គឺនៅពេលដែលមានការសន្ទនារវាងលោកយ៉ូបនិងមិត្តសំឡាញ់ទាំងបីរបស់គាត់ និងការបញ្ជាក់ជាចុងក្រោយ និងមុនដែលការពារចុងក្រោយ របស់លោកយ៉ូប (ជំពូក ២៩–៣១) គឺជាការប្រឹងប្រែងដ៏ឥតមានន័យ ចំពោះសំលេងដ៏ឆើតឆាយដែលបានពន្យល់ពីស្ថានភាពរបស់លោកយ៉ូប និងព្រះយេហូវ៉ាផ្ទាល់ (Yahweh´s Own ) បានបំបែកទស្សនីយភាពអ្នកនិពន្ធបានបង្ហាញណែនាំពីអត្ថបទ ការបន្ទាន់ដែលពឹងផ្អែកទៅលើប្រាជ្ញា (ជំពូក ២៨) ដែលសំដែងចេញនូវ ការកំណត់ព្រំដែនរបស់ប្រាជ្ញានាមមនុស្សលោកិយ៍ ។ ប្រាជ្ញាដែលព្រះបានឱ្យមកមនុស្ស គឺយល់បានខ្លះពីស្នាព្រះហស្ត ដែលចេញពីស្នាព្រះហស្តទ្រង់ទាំងអស់នោះ ប៉ុន្តែ មនុស្សមិនអាចយល់បានទាំងអស់ពីផ្លូវរបស់ព្រះទេ ។ តែគេត្រូវទទួលបានប្រាជ្ញានោះដោយចុះចូលគោរពកោតខ្លាចដល់ព្រះយេហូវ៉ាហើយទប់ស្កាត់ដល់ការអាក្រក់ទាំងឡាយ (មើល ១.២៨) គឺជាប្រាជ្ញាដែលកំណត់សំគាល់មួយដែលធ្វើឱ្យជីវិតលោកយ៉ូបគ្រប់កាលៈទេសៈ(មើល ១:៨)។ គឺជាជីវិតដែលឈរនៅទីកណ្តាល ជាអ្នកផ្សារភ្ជាប់ដល់មនុស្សទាំងឡាយ ។

ដំណាក់ការឆ្លងកាត់មួយ គឺជាដំណាក់ការចុងក្រោយ គឺជាការធ្វើតេស សាកល្បងដ៏ធំទី២ ទៅលើភាពសុចរិតរបស់លោកគាត់ គឺការមានជីវិតរស់ដោយប្រាជ្ញាដែលព្រះអម្ចាស់បានប្រទានឱ្យមកលើកយ៉ូប (២៨:២៨) គឺខណៈដែល ធ្វើការទទួលស្គាល់ដែនកំនត់ នៃប្រាជ្ញារបស់មនុស្ស ។ ប៉ុន្តែផ្នែកខាងក្នុង និងការទទួលរបស់លោកយ៉ូប គឺបង្ហាញឱ្យឃើញក្នុងពេលយប់ដ៏យូរដែលជាយប់នៃការឈឺចាប់យ៉ាងខ្លាំងដែលមានសំឡេងសូរសៀងរបស់ព្រះអទិករ កំពុងមានបន្ទូលពីខាងក្រោយវាំងននសិរីល្អនៃស្នាព្រះហស្តទ្រង់ ។ គឺជាការបញ្ចប់របស់សត្រូវដោយភាពស្ងៀមស្ងាត់ មិត្តភ័ក្រយ៉ូបទាំងអស់បាននៅស្ងៀម ហើយលោកយ៉ូបត្រឹងស្ងៀម តែទ្រង់មិននៅស្ងៀមទេ ។ ហើយព្រះយេហូវ៉ាក៏មានបន្ទូលទៅកាន់អ្នកជាស្នួនភ្ជា គឺលោកយ៉ូប ដោយភាពអាណិតអាសូរ ក្នុងគ្រាដែលមានការឈឺចាប់ ទ្រង់បានបង្ហាញនៅអំណាចព្រះចេស្តាឱ្យឃើញ (មើល ៣៨: ១–៤២:៦) ។ លើសពីនេះទៅទៀតក្នុងនាមជាមិត្តស្មានស្មូគ៍ គឺព្រះអម្ចាស់ពួពាក្យទូលអង្វររបស់លោកយ៉ូបសម្រាប់ចូលរួមបម្រើព្រះ និងចុះចូលគ្រប់ការទាំងអស់ (៤២:៨–១០) ទ្រង់ក៏រៀបចំឱ្យលោកយ៉ូបទទួលព្រះពរមួយជាពីរឡើងវិញ (៤២:១០–១៧) ។

ដោយនិយាយរួមមក ពាក្យពេជ្រដ៏មានផលផ្លែរបស់អ្នកនិពន្ធចំពោះការរងការឈឺចាប់ដែលមានព្រះគង់ជាមួយ គឺនាំឱ្យទ្រង់ប្រទានភោគសម្បត្តិ នូវភាពសុចរិតរបស់គេលើសជាងអ្វីៗទាំងអស់ ។ អារក្សសាតាំងដឹងថា ប្រសិនបើវាធ្វើឱ្យខកខាននូវផែនការដែលពុំអាចប៉ាន់ស្មានដឹងរបស់ព្រះ វាត្រូវតែរំលោភបំពានភាពសុចរិតរបស់មនុស្ស(មើល ១។២១–២២ ២:៩–១០ ២៣:៨–១០ ប្រៀបធៀប ១៥:៦)។ ក្នុងខណៈនៃការឈឺចាប់ចំពោះអ្នកដែលមានព្រះ គឺបង្ហាញចេញនូវភាពពុះពារឧបសគ្គដ៏ធំរវាងមាសត្រូវដ៏ធំ និងព្រះអម្ចាស់ ។ ក្នុងពេលតែមួយអ្នកនិពន្ធបានឮអំពីភាពឈឺចាប់ ដែលជាប្រាជ្ញាមកពីព្រះដែលជាសេចក្តីពិត គឺដើម្បីព្រះនៃសេចក្តីស្រឡាញ់ និងគោរពកោតខ្លាច គឺលើសពីអំណោយទានរបស់គាត់ និងចំពោះសេចក្តីពិតនៃព្រះ តាមរយៈផ្លូវរបស់ទ្រង់ក្នុងពេលអតីតកាល គឺអំណាចរបស់ប្រាជ្ញារបស់មនុស្ស គឺមានដែនកំណត់ ។ ដូច្នេះទីនេះ ក៏បង្ហាញឱ្យឃើញ គ្រាន់តែជាវគ្គមួយនៃការអនុវត្តបញ្ជាក់ដោយប្រាជ្ញា និងការវិនិច្ឆ័យនៃការដឹកនាំពីព្រះមហាក្សត្រ ដ៏មានព្រះចេស្តា ។ អ្នករងសេចក្តីឈឺចាប់ ដ៏សុចរិតត្រូវមានសេចក្តីពិត ដោយទទួលស្គាល់នូវចម្បាំងខាងឯព្រះវិញ្ញាណ រវាងអាណាចក្ររបស់ព្រះ និងអាណាចក្ររបស់សាតាំង ក៏ជាចំបាំងរវាងអាណាចក្រពន្លឺ និងអាណាចក្រនៃភាពងងឹត(ប្រៀបធៀប អស ៦:១០–១៨) ។

## បែបបទអក្សរសាស្ត្រ និងបែបបទផ្ទៃរឿង

ក៏មានលក្ខណៈនៃការនិពន្ធបែបបុរាណដទៃទៀត គឺជាសៀវភៅលោកយ៉ូបមានលក្ខណៈបែបបទអក្សរសាស្ត្រច្របាច់បញ្ចូនគ្នា : ជាបុរេកថា គឺជាតួសេចក្តីដ៏សំខាន់មួយ(នៃកវីនិពន្ធ) និងបានបង្ហាញពីកំរងនិពន្ធប្រកបទៅដោយគំនិតច្នៃប្រឌិតខ្ពស់ គឺមិនមែនតាមទំនើងចិត្តពួកគេឡើយ ក្នុងការតែងនិពន្ធនោះ ។ ពាក្យសំដីរបស់លោកយ៉ូបខ្លះទៀត គឺបង្ហាញពីភាពទុរគត និងការសោកសៅ (ប្រៀបធៀបក្នុងជំពូក៣ និងកំរងកំណាព្យខ្លីៗជាច្រើនទៀតហើយពាក្យកាព្យ សោកសៅខ្លះគឺត្រូវនិងខ្សែជីវិតរបស់លោកយ៉ូប ជារឿយៗមិនដូចបែបបទធម្មតាក្នុងគម្ពីរទំនុកដំកើងដែលជាពាក្យទួញទុក្ខរបស់លោកយ៉ូប ។ កំណាព្យប្រាជ្ញា ក្នុងជំពូក ២៨ បានលេចមកពីពាក្យពេចន៍អ្នកនិពន្ធ

ដែលឃើញភាពបរាជ័យរបស់ភាពរំខានដែលជាសាក្សីនៃកង្វះខាតប្រាជ្ញា ។ ដូច្នេះការសរសើរដំកើងនៃប្រាជ្ញាជាសេចក្ដីពិតដែលគេកំណត់ជាចំណុចកណ្ដាលនៃទីខ្ពស់របស់គ្រោង ឬទ្រង់ទ្រាយចន្លោះខួបទាំងបីរបស់ជម្លោះនៃបទសន្ទនា (ជំពូក ៣-២៧) និងជាចំណុចឯកវាទទាំងបី : គឺមានចំពោះលោកយ៉ូបគឺ (ជំពូក ២៩-៣១) ចំពោះ (៣៨:១-៤២:៦) ។ ចំណុចឯកវាទរបស់លោកយ៉ូបបានបែរចេញត្រឡប់ទៅរកព្រះ ចំពោះការសម្រេចចិត្តត្រឹមត្រូវ : ដែលគាត់ពុំមានទោសកំហុសដែលត្រូវប្រឆាំងនិងគាត់ឡើយ ។ អេលីហ៊ូវ ឬភាពឯកវាទរបស់អេលីហ៊ូវ ឬទស្សនៈរបស់មនុស្សដទៃទៀត ខណៈពេល ឬហេតុផលមនុស្សឈឺចាប់ ឬការស្ដីបន្ទោសដល់លោកយ៉ូប តែផ្ទៃរឿងក៏ទំលាក់កំហុសនិងវាយតម្លៃចំពោះការកែលំអរ ឬការដាក់ទោសពីព្រះ និងគោលដៅនៃការលោះបាបពីព្រះអម្ចាស់ផ្ដល់បានជាទស្សនៈដែលជាព្រះ ឯលោកយ៉ូបមិនត្រូវបានកាត់ទោសទេ តែមានសំណួរចម្លើយខ្លះថា **ហេតុអ្វីបានជាលោកយ៉ូបទទួលការឈឺចាប់ ?** គឺនៅតែមានភាពអាថ៌កំបាំងចំពោះករណីលោកយ៉ូបដដែល ទោះជាអ្នកអានត្រៀមខ្លួនចំពោះការធ្វើឱ្យលោកយ៉ូបបានរួចពីការលំបាកឡើងវិញ ក្នុងសេចក្ដីបញ្ចាក់ដោយព្រោះគេមានភាពប្រៀបពីស្ថានសួគ៌ ដែលជាសញ្ញាយូរណាស់មកហើយ ។ ដូច្នេះការតុបតែង ផ្នែកអក្សរសាស្ត្រ និងសេចក្ដីបញ្ជាក់ពីគម្ពីរទេវសាស្ត្រ ក៏បានបញ្ចូលគ្នាយ៉ាងល្អ ។

## គំរោងសង្ខេប

**I.** បុរេកថា (ជំពូក១-២)

ក. ភាពអំណរសប្បាយរបស់លោកយ៉ូប (១:១-៥) ។

ខ. ការល្បងលដល់លោកយ៉ូប (១:៦-២:១៣) ។

1. ការចោទប្រកាន់លើកដំបូងរបស់សាតាំង (១:៦-១២) ។
2. តែផ្ទុយទៅវិញសេចក៏ជំនឿរបស់លោកយ៉ូបធ្វើឱ្យបាត់បង់គ្រួសារនិងទ្រព្យសម្បត្តិ (១:៣-២២) ។
3. ការចោទប្រកាន់ជាលើកទីពីររបស់អារក្សសាតាំង (២:១-៦) ។
4. ជំនឿរបស់លោកយ៉ូបខណៈពេលមានភាពឈឺចាប់ចំពោះរូបលោក (២:៧-១០) ។
5. មិត្តសំឡាញ់ទាំងបីមកដល់ (២:១១-១៣) ។

**II.** ការសន្ទនា -ជម្លោះ (ជំពូក៣-២៧) ។

ក. ការសំដែងភាពសោកសៅរបស់លោកយ៉ូប (ជំពូក ៣) ។

ខ. ពាក្យត្អូញត្អែរជាលើកដំបូង (ជំពូក ៤-១៤) ។

1. អេលីផាស (ជំពូក ៤-៥) ។
2. ការឆ្លើយតបរបស់លោកយ៉ូប (ជំពូក ៦-៧) ។
3. ប៊ីលដាឌ (ជំពូក ៨) ។
4. ការឆ្លើយតបរបស់លោកយ៉ូប (ជំពូក ៩-១០) ។
5. សូផារ (ជំពូក ១១) ។
6. ការឆ្លើយតបរបស់លោកយ៉ូប (ជំពូក ១២-១៤) ។

គ. ពាក្យត្អូញត្អែរជាលើកទី២ (ជំពូក ១៥-២១) ។

1. អេលីផាស (ជំពូក ១៥) ។
2. ការឆ្លើយតបរបស់លោកយ៉ូប (ជំពូក ១៦-១៧) ។
3. ប៊ីលដាឌ (ជំពូក ១៨) ។
4. ការឆ្លើយតបរបស់លោកយ៉ូប (ជំពូក ១៩) ។
5. សូផារ (ជំពុក ២០) ។
6. យ៉ូបឆ្លើយតប (ជំពូក ២១) ។

ឃ. ពាក្យត្អូញត្អែរលើកទី៣ (ជំពូក ២២-២៦) ។

1. អេលីផាស (ជំពូក ២២) ។

2. កាឆ្លើយតបរបស់លោកយ៉ូប (ជំពូក ២៣–២៤) ។
3. ប៊ីលដាឌ (ជំពូក ២៥) ។
4. ការឆ្លើយតបរបស់លោកយ៉ូប (ជំពូក ២៦) ។

ង. សេចក្ដីបញ្ជាក់និងការបញ្ចប់របស់លោកយ៉ូប (ជំពូក ២៧) ។

**II.** ចន្លោះពេលដែលផ្អែកលើប្រាជ្ញា (ជំពូក ២៨) ។

**IV.** បុរេកថា (២៩:១–៤២:៦) ។

ក. ការត្រាសហៅលោកយ៉ូបពីភាពគ្មានទោស (ជំពូក ២៩–៣១) ។

1. ភាពសុចរិតទៀងត្រង់ពីអត់ទោសរបស់លោកយ៉ូប និងព្រះពរ (ជំពូក ២៩) ។
2. ភាពអាម៉ាស់ពេលបច្ចុប្បន្នរបស់លោកនិងការឈឺចាប់ (ជំពូក ៣០) ។
3. ការប្រកាសពីភាពអត់កំហុស និងពាក្យសច្ចាចុងក្រោយ (ជំពូក ៣១) ។

ខ. ការបង្ហាញ បញ្ជាក់ពីព្រះ (៣៨:១–៤២:៦) ។

1. ព្រះបានសម្ដែងជាលើកទី១ (៣៨:១–៤០:២) ។
2. ការឆ្លើយតបរបស់លោកយ៉ូប (៤០:៣–៥) ។
3. ការសំដែងលើកទី២របស់ព្រះ (៤០:៦–៤១:៣៤) ។
4. ការលន់តួរបស់លោកយ៉ូប (៤២:១–៦) ។

**V.** សេចក្ដីបញ្ចប់ (៤២:៧–១៧) ។

ក. សេចក្ដីសម្រេចរបស់ព្រះ (៤២:៧–៩) ។

ខ. ការធ្វើឱ្យបានប្រសើរឡើងវិញរបស់លោកយ៉ូប (៤២:១០–១៧) ។

**១** ១នៅស្រុកអ៊ូស[ក] មានមនុស្សម្នាក់ឈ្មោះយ៉ូប[ខ] ជាអ្នកគ្រប់
លក្ខណ៍[គ] ហើយទៀតត្រង់[ឃ] ដែលគោរពកោតខ្លាចដល់
ព្រះ[ង] ក៏ចៀសចេញពីសេចក្តីអាក្រក់[ច] ២លោកបង្កើតបាន
កូនប្រុស៧[ឆ] និងកូនស្រី៣[ជ] ៣លោកមានចៀម៧ពាន់ អូដ្ឋ៣
ពាន់ គោ៥០០នឹម និងលាញី៥០០[ឈ] ក៏មានបាវព្រាវយ៉ាង
សន្ធឹក[ញ] បានជាលោកធំជាងអស់ទាំងមនុស្ស[ដ] នៅប្រទេស
ខាងកើត[ឋ]។

៤ឯកូនប្រុសៗរបស់លោក គេតែងជប់លៀងគ្នា[ឌ] នៅផ្ទះ
គេរៀងខ្លួនតាមវេន គេក៏ចាត់ឱ្យទៅហៅប្អូនស្រីគេទាំង
៣នាក់ ឱ្យមកបរិភោគជាមួយគ្នា ៥លុះកាលបានជប់លៀង
គ្នារួចហើយ នោះយ៉ូបក៏ចាត់ទៅញែកគេចេញជាបរិសុទ្ធ[ឍ]
រួចក្រោកឡើងពីព្រលឹមស្រាង ថ្វាយដង្វាយដុត[ណ]តាមចំនួន
កូនទាំងប៉ុន្មាន ដោយនឹកថា ក្រែងកូនអញបានធ្វើបាប[ត]
ហើយមានចិត្តលះចោលព្រះ[ថ]យ៉ាងណា លោកតែងតែធ្វើ
ដូច្នេះជាដរាប ។

## ការល្បងលោកយ៉ូបលើកទី១

៦រីឯមានកាល១ថ្ងៃ ដែលពួកកូនព្រះ[ទ]បានទៅគាល់នៅ
ចំពោះព្រះយេហូវ៉ា ហើយអារក្សសាតាំង[ធ]ក៏មកនៅក្នុង
ចំណោមគេដែរ[ន] ៧នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរ
សាតាំងថា ឯងមកពីណា សាតាំងទូលឆ្លើយថា មកពីដើរ
ចុះឡើងទៅមកនៅផែនដី[ប] ៨រួចព្រះយេហូវ៉ាទ្រង់សួរ
សាតាំងថា ឯងបានសង្កេតមើលយ៉ូប[ផ] ជាអ្នកបំរើអញឬទេ
ដ្បិតគ្មានអ្នកណាមួយ នៅផែនដីឱ្យដូចគាត់ឡើយ ជាអ្នក
ដែលគ្រប់លក្ខណ៍ហើយទៀងត្រង់ ក៏កោតខ្លាចដល់ព្រះ[ព]
ហើយចៀសចេញពីសេចក្តីអាក្រក់ផង[ភ] ៩សាតាំងទូលឆ្លើយ
ដល់ព្រះយេហូវ៉ាថា ដែលយ៉ូបកោតខ្លាចដល់ព្រះអង្គ តើ
ឥតមានប្រយោជន៍ទេឬ[ម] ១០តើទ្រង់មិនបានធ្វើរបង[យ]ព័ទ្ធ
ជុំវិញ ព្រមទាំងគ្រួ និងរបស់ដែលគាត់មានទាំងប៉ុន្មានផង
ទេឬអី[រ] ទ្រង់បានប្រទានពរ ដល់ការដែលដៃគាត់ធ្វើ ទ្រព្យ
សម្បត្តិគាត់ក៏បានចំរើនឡើងនៅលើផែនដី[ល] ១១ដូច្នេះចូរ

**១:១** ក លប ១០:២៣ ខ អគ ១៤:១៤,២០ យក ៥:១១ គ លប ៦:៩ យប ២៣:១០ ឃ យប ២៣:៧ ទដ ១១:៧ ១០៧:៤២ សភ ២១:២៩ មីក ៧:២ ង លប ២២:១២ ច ខ.៨ ចទ ៤:៦ យប ២:៣ ១ថន ៥:២២ **១:២** ឆ នរ ៤:១៥ ជ ខ.១៣,១៨ យប ៤២:១៣ ទដ ១២៧:៣ ១៤៤:១២ **១:៣** ឈ លប ១៣:២ ញ លប ១២:១៦ ដ ខ.៨ យប ២៩:២៥ ឋ លប ២៥:៦ យប ៤២:១០ ទដ ១០៣:១០ **១:៤** ឌ ខ.១៣,១៨ **១:៥** ឍ នហ ១២:៣០ ណ លប ៨:២០ ត យប ៨:៤ ថ ១ពវ ២១:១០,១៣ ទដ ១០:៣ ៧៤:១០ **១:៦** ទ ១ពវ ២២:១៩ លប ៦:២ ធ ២សយ ២៤:១ ២របា ១៨:២១ ទដ ១០៩:៦ លក ២២:៣១ ន យប ២:១ **១:៧** ប លប ៣:១ ១ពត ៥:៨ **១:៨** ផ យស ១:៧ ព ទដ ២៥:១២ ១១២:១ ១២៨:៤ ភ ខ.១ នក ២០:២០ **១:៩** ម ១ធថ ៦:៥ **១:១០** យ ១សយ ២៥:១៦ រ ខ.១២ យប ២:៤ ទដ ៣៤:៧ ល ខ.៣ យប ៨:៧ ២៩:៦ ៤២:១២,១៧

**១:១** *នៅស្រុកអ៊ូស* គឺជាព្រំដីដ៏ធំទូលាយ នៅផ្នែកខាងកើតស្រុកយ័រដាន់ជាជ្រលងមួយ (មើល ខ.៣) មានទាំងស្រុកអេដំមនៅតំបន់ខាងត្បូង (មើល លប ៣៦:២៨បទ ៤:២១) និងស្រុកអើរ៉ាមនៅផ្នែកខាងជើង (មើល លប ១០:២៣ ២២:២១ មើលការពន្យល់ ១របា ១៨:៥)។ *គ្រប់លក្ខណ៍ ហើយទៀងត្រង់* (មើលការពន្យល់ ទដ ២៦:១)។ ខនេះមិនមែនមានន័យថា លោកយ៉ូបគ្មានបាបនោះទេ ។ តែគាត់ព្យាយាមរក្សាសេចក្តីសុចរិតរបស់គាត់ ហើយគាត់ក៏ព្រមទទួលអំពើបាបរបស់គាត់ដែរ គឺជាអ្នកមានបាប ។ (សូម មើល ៦:២៤ ៧:២១ និងការពន្យល់ផង) ។ *គោរពកោតខ្លាចដល់ព្រះ* សូម មើល ២៨:២៨ សក ៣:៧ និងការពន្យល់ លប ២០:១១) ។

**១:២** *កូនប្រុស៧* ជាចំនួនដែលច្រើនល្មម សូមមើលការពន្យល់ ៤២:១៣ នរ ៤:១៥ ។

**១:៣** *អូដ៣ពាន់* មើលការពន្យល់ ៤២:១២ គឺជាទ្រព្យសម្បត្តិដ៏មហាសាលរបស់លោកយ៉ូប គឺជាបសុសត្វ (សត្វចិញ្ចឹមជាច្រើនប្រភេទ) គឺមិនមែនជាដីទេ (មើល លប ១២:១៦ និងការពន្យល់ ១២:២ ២៦:១៤) ។ *លា* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះ គឺសំដៅលើលាញី ជាសត្វលាដែលបង្កើតបានកូនចៅគឺមានតម្លៃដ៏លើសលុប ។ *មនុស្សនៅប្រទេសខាងកើត* ព្រះគម្ពីរភាសាហេព្រើរប្រែមកមានន័យថា អ្នកដែលរស់នៅតំបន់ខាងកើត (មើល លប ២៩:១ ពច ៦:៣ និងការពន្យល់) ។

**១:៥** *លុះកាលបានជប់លៀងគ្នារួចហើយ* គឺជាឱកាសដ៏ពិសេសមួយ បុណ្យឬពិធីជប់លៀង អាចប្រើរយះពេលមួយសប្តាហ៍ (មើល លប ២៩:២៧ ពច ១៤:១២) ។ *បរិសុទ្ធ* គឺដើម្បីធ្វើឱ្យពិធីបុណ្យ ស្អាតបរិសុទ្ធជាការរៀបចំយញ្ញបូជាចំពោះកូនគាត់ (មើល នក ១៩:១០,១៤) តែក្នុងព្រះគម្ពីរភាសាហេព្រើរក្នុងកិរិយាស័ព្ទនេះមានន័យថា "ញែកជាបរិសុទ" ។ *ថ្វាយដង្វាយ* ពីមុនច្បាប់នៃពិធីនេះ គឺជាលោកម៉ូសេបានប្រាប់ពីការនេះ គឺឪពុកដែលជាមេគ្រួសារមានតួនាទីជាអ្នករៀបចំពិធីនេះ (មើល លប ១៥:៩–១០) ។

**១:៦** *ពួកកូនព្រះបានទៅគាល់ចំពោះ* មើលាការពន្យល់ ២:១ ៣៨:៧ ពួកគេបានមកមានលក្ខណៈជាសមាជិកទីប្រឹក្សាពីស្ថានសួគ៌ ដែលឈរក្នុងវត្តមានព្រះ (មើល ១ពវ ២២:១៩ និងការពន្យល់ ទដ ៨៩:៥–៧ យរ ២៣:៨) ។ *អារក្សសាតាំង* ជាអ្នកចោទប្រកាន់ មើល វវ ១២:១០ និងការ ពន្យល់)។ សូមមើល ១របា ២១:១ ពាក្យថា "អារក្សសាតាំង" ប្រែក្លាយជាអសា–ធារណៈនាម ។

**១:៧** *ព្រះយេហូវ៉ា* គឺមានន័យថា យ៉ាវេ (Yahweh) គឺមានជាសេចក្តីសញ្ញាសម្រាប់សម្គាល់ពីព្រះនាមព្រះអម្ចាស់ (មើលសេចក្តីផ្តើមៈ អ្នកនិពន្ធ សូមមើលការពន្យល់ លប ២:៤) ។

**១:៨** *ឯងបានសង្កេតមើលយ៉ូប . . .* គឺជាព្រះយេហូវ៉ា មិនមែនអារក្សសាតាំងទេ ដែលផ្តើមឱ្យមានសេចក្តីល្បងលដល់លោកយ៉ូប ។ តែទ្រង់លើកឡើងពីលោកយ៉ូបដោយមិនឱ្យមានចំណុចណាដែលអាចចោទប្រកាន់បាន ។ *អ្នកបម្រើអញ* មើល ៤២:៧–៨ និងការពន្យល់ដែលជាអ្នកឈរក្នុង លក្ខណៈមានទំនាក់ទំនងដ៏ពិសេសជាមួយនិងព្រះអម្ចាស់ ដោយមានភាពស្មោះត្រង់ក្នុងការបម្រើទ្រង់ (ឧទាហរណ៍ លោកម៉ូសេ ជន ១២:៧ ស្តេចដាវីឌ ២សយ ៧:៥ មើល ១សយ ៤២:១ និងការពន្យល់ ៥២:១៣ ៥៣:១១) ។

**១:៩** ខនេះនិយាយពីការចោទប្រកាន់ដ៏មោះមុត ដល់មនុស្សដែលព្រះរៀបចំនិយាយ ពីភាពសុចរិតរបស់លោកយ៉ូបគឺព្រះសព្វព្រះហឬទ័យ ។

**១:១០** *របង* ជានិមិត្តសញ្ញានៃការការពារ (មើល ៥:៥ ដែលផ្ទុយ និងករណីលោកយ៉ូប ៣:២៣) ។

**១:១១** *ទ្រង់គ្រាន់តែលូកព្រះហស្ត ទៅពាល់* មើល ៤:៥ ។

ទ្រង់គ្រាន់តែលូកព្រះហស្ត ទៅពាល់របស់ផងគាត់ទាំង
ប៉ុន្មានចុះ[វ] នោះគាត់នឹងប្រមាថដល់ទ្រង់ នៅចំពោះព្រះ
ភក្ត្រ[ស] ១២ព្រះយេហូវ៉ាទ្រង់មានបន្ទូលតបថា មើល អញ
ប្រគល់របស់ដែលគាត់មានទាំងប៉ុន្មាន[ហ]ទៅក្នុងបំណាចឯង
ហើយ កុំឱ្យតែដាក់ដៃលើខ្លួនគាត់ឡើយ[ឡ] ដូច្នេះ សាតាំងក៏
ចេញពីចំពោះព្រះយេហូវ៉ាទៅ ។
១៣មាន១ថ្ងៃ កាលពួកកូនប្រុសកូនស្រី[អ]របស់លោក
កំពុងតែបរិភោគ[ក] ហើយផឹកស្រាទំពាំងបាយជូរ នៅឯផ្ទះ
បងច្បង ១៤នោះគាប់ចួនជាមានម្នាក់នាំដំណឹងមកជំរាប
យ៉ូបថា កំពុងដែលគោនៅភ្ជួរ ហើយហ្វូងលារកស៊ី[ខ]ជិត
ខាង ១៥នោះស្រាប់តែពួកសាសន៍សេបា[គ] មកប្លន់ពង្រត់យក
ទៅក៏បានកាប់សំឡាប់ពួកបាវព្រាវ ដោយមុខដាវ មានតែ
ខ្ញុំ១ទេ ដែលបានរត់រួច មកជំរាបលោក ១៦កាលអ្នកនោះ
កំពុងនិយាយនៅឡើយ នោះមានម្នាក់ទៀតមកជំរាបថា
ភ្លើងរបស់ព្រះបានធ្លាក់ពីលើមេឃ[ឃ]មកបញ្ឆេះហ្វូងចៀម
និងពួកបាវព្រាវអស់ទៅ[ង]ហើយ មានតែខ្ញុំ១ទេ ដែលរួច
មកជំរាបលោក ១៧កាលអ្នកនោះកំពុងនិយាយនៅឡើយ
ក៏មានម្នាក់ទៀតមកជំរាបថា ពួកសាសន៍ខាល់ដេ[ច]បានចែក
គ្នាជា៣កង លុកចូលមកប្លន់ពង្រត់យកអូដ្ឋទាំងប៉ុន្មានទៅ
ហើយគេកាប់សំឡាប់ពួកបាវព្រាវដោយមុខដាវ មានតែខ្ញុំ
១ទេ ដែលរត់រួចមកជំរាបលោក ១៨កាលអ្នកនោះកំពុង
និយាយនៅឡើយ នោះមានម្នាក់ទៀតមកជំរាបថា ពួកកូន
ប្រុសកូនស្រី[ឆ]របស់លោកកំពុងតែបរិភោគ[ជ] នៅក្នុងផ្ទះ

**១:១១** វ យប ១៩:២១ លក ២២:៣១ ស លវ ២៤:១១
យប ២:៥ អស ៣:៨ ៦៥:៣ វវ ១២:៩–១០
**១:១២** ហ ខ.១០ ឡ យប ២:៦ ១កថ ១០:១៣
**១:១៣** អ ខ.២ ក ខ.៤
**១:១៤** ខ លប ៣៦:២៤
**១:១៥** គ លប ១០:៧ យប ៩:២៤
**១:១៦** ឃ ១ពវ ១៨:៣៨ ២ពវ ១:១២ យប ២០:២៦ ង លប ១៨:១៧ លវ ១០:២ ជន ១១:១–៣
**១:១៧** ច លប ១១:២៨,៣១ យប ៩:២៤
**១:១៨** ឆ ខ.២ ជ ខ.៤
**១:១៩** ឈ ទដ ១១:៦ អស ៥:២៨ ២១:១ យរ ៤:១១ ១៣:២៤ ១៨:១៧ អគ ១៧:១០

បងច្បង ១៩ស្រាប់តែមានខ្យល់គំហុកជាខ្លាំង[ឈ]បក់មកពីទី
រហោស្ថាន បោកប្រមុំផ្ទះទាំង៤ជ្រុង រំលំនៅលើកូនលោក
ស្លាប់[ញ]អស់ទៅហើយ មានតែខ្ញុំ១ទេ ដែលរួច ដើម្បីមក
ជំរាបលោក[ដ]។
២០នោះយ៉ូបក៏ក្រោកឡើងហែកអាវខ្លួន[ឋ] ហើយកោរ
សក់[ឌ] រួចផ្តួលខ្លួនក្រាបចុះដល់ដីថ្វាយបង្គំ[ឍ] ២១ដោយពាក្យ
ថា ទូលបង្គំបានចេញពីផ្ទៃម្តាយមកដោយខ្លួនទទេ[ណ] ហើយ
នឹងត្រឡប់ទៅវិញដោយទទេដែរ ព្រះយេហូវ៉ាទ្រង់បាន
ប្រទានមក ហើយទ្រង់ក៏បានដកយកទៅវិញ[ត] សូមឱ្យព្រះ
នាមព្រះយេហូវ៉ាបានព្រះពរចុះ[ថ] ២២ក្នុងគ្រប់សេចក្តីទាំង
នោះយ៉ូបមិនបានធ្វើបាបឡើយ ក៏មិនបានប្រកាន់ទោស
ដល់ព្រះដែរ[ទ]។

## ការល្បងលោកយ៉ូបជាលើកទី២

២ ១រួចមក មានកាល១ថ្ងៃទៀត ដែលពួកកូនព្រះ[ក]បានទៅ
គាល់នៅចំពោះព្រះយេហូវ៉ា ហើយសាតាំងក៏នៅក្នុង
ចំណោមនោះ[ខ] ដើម្បីគាល់ព្រះយេហូវ៉ាដែរ ២ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលសួរសាតាំងថា ឯងមកពីណា សាតាំងទូល

ហស ១៣:១៥ មថ ៧:២៥ ញ យប ១៦:៧ ១៩:១៣–១៥ ដ អគ ២៤:២០ **១:២០** ឋ លប ៣៧:២៩ មក ១៤:៦៣ ឌ អស ៣:២៤ ១៥:២ ២២:១២ យរ ៧:២៩ ១៦:៦ អគ ២៧:៣១ ២៩:១៨ មីក ១:១៦ ឍ ១ពត ៥:៦ **១:២១** ណ សស ៥:១៥ ១ធថ ៦:៧ ត នរ ១:២១ ១សយ ២:៧ ថ ពច ១០:១៥ យប ២:១០ សស ៧:១៤ យរ ៤០:២ អភ ៥:២០ ១ថន ៥:១៨ យក ៥:១១ **១:២២** ទ យប ២:១០ ទដ ៣៩:១ សភ ១០:១៩ ១៣:៣ អស ៥៣:៧ រម ៩:២០ **២:១** ក លប ៦:២ ខ យប ១:៦

**១:១២** *សាតាំង* ជាអ្នកចោទប្រកាន់ ក៏បានផ្តល់អំណាចឱ្យវាដើម្បីធ្វើទុកបុកម្នេញ (ខ.១២ក) តែក៏ផ្សាភ្ជាប់គ្នា (ខ.១២ខ) ។ គឺទាំងអស់ស្ថិតក្នុងការអាក្រក់ ដែលមានឥទ្ធិពលលើមនុស្សលោក (ខ.១៥,១៧) ឬក៏ក្នុងលក្ខណៈនិស្ស័យ (ខ.១៦,១៩) សាតាំង គឺស្ថិតនៅក្រោមអំណាចរបស់ព្រះ (ប្រៀបធៀប ១រប ២:១ ជាមួយ ២សយ ២៤:១៦ ១កថ ៥:៥ និងការពន្យល់ ២កច ១២:៧ ហព ២:១៤) គឺជាការប្រឆាំង វាមិនមែនជាការក្លែងបន្លំឡើង ។ តើលោកយ៉ូបដាក់បណ្តាសាព្រះចំពោះព្រះភក្ត្រទ្រង់ បើលោកយ៉ូបមិនធ្វើដូច្នេះទេនោះមេចោទប្រកាន់នឹងបង្ហាញភស្តុងតាងពីកំហុស និងព្រះសព្វព្រះហឫទ័យក្នុងភាពដែលគ្មានកំហុសរបស់លោកយ៉ូប ។

**១:១៥** *ពួកសាសន៍សេបា* ប្រហែលជាពួកអារ៉ាបខាងត្បូងដែលចេញពីស្រុកសេបា គឺជាពូជមួយប្រែក្លាយជាអ្នកជំនួញ ដែលមានទ្រព្យសម្បត្តិច្រើនមានមាស ត្បូងមានតម្លៃ (មើលពីម្ចាស់ក្សត្រីសេបា ក្នុង ១ពវ ១០:១–១៣ ទដ ៧២:១០,១៥ អស ៦០:៦ យរ ៦:២០ អគ ២៧:២២ យអ ៣:៨) យ៉ូប ៦:១៩ ក៏បានហៅសេបា "អ្នកជំនួញធ្វើដំណើរទៅមក" និងទំនាក់ទំនងពួកគេជាមួយថេម៉ា (ប្រវែង ៥៦៣.១៥ គ.ម) គឺនៅផ្នែកខាងត្បូងឈាងខាងកើតក្រុងយេរូសាឡិម ។

**១:១៦** *ភ្លើងរបស់ព្រះ* (មើល ជន ១១:១ និងការពន្យល់ ១ពវ ១៨:២៨ ២ពវ ១:១២) ។

**១:១៧** *ពួកសាសន៍ខាល់ដេ* គឺប្រជាជនដែលជាពួកជនពនេចរ មានលំនៅពុំច្បាស់លាស់ គឺប្រហែលក្នុងកំឡុង១000 មុន គ.ស ក្នុងខណៈពេលពួកគេបោះជំរុំក្នុងទឹកដីមេសូប៉ូតាមា និងក្រោយមកក៏ប្រែក្លាយជានេប៊ូក្នេសាររបស់ចក្រភពបាប៊ីឡូន (មើលការពន្យល់នៅ អរ ៥:១២) ។

**១:១៩** *ខ្យល់គំហុកជាខ្លាំង* គឺជាខ្យល់គួច ។

**១:២០** *នោះយ៉ូបក៏ក្រោកឡើង* ត្រង់ចំណុចនេះ លោកយ៉ូបសរក្សាភាពស្ងាត់ស្ងៀម រហូតដល់ពេលដែលកូនៗរបស់លោកទាំងអស់ត្រូវបាត់បង់ជីវិត ។ *ហែកអាវខ្លួន ហើយកោរសក់* គឺដើម្បីកាន់ទុក្ខការបាត់បង់ទាំងអស់នោះ (មើលការពន្យល់ លប ៣៧:៣៤ អស ១៥:២) ។

**១:២១** *ត្រឡប់ទៅវិញ* មើលការពន្យល់ លប ២:៧ ៣:១៩ ។ *ព្រះយេហូវ៉ាទ្រង់បានប្រទានមក ហើយទ្រង់ក៏បានដកយកទៅវិញ* ។ សេចក្តីជំនឿរបស់លោកយ៉ូបបាននាំលោកឱ្យទៅឃើញព្រះហស្តទ្រង់ ដែលជាព្រះមហាក្សត្រដែលបានដាក់មក ក៏បានឆ្លើយតប ។

**២:១–៣** គឺជាការទទួលចំពោះប្រយោគចុងអត្ថបទ ក៏ចង់បញ្ជាក់ចំពោះ ១:៦–៨ ។ គឺបានចោទប្រកាន់លោកយ៉ូបដែលមានការប្រព្រឹត្តអំពើបោកប្រាស់ គឺប្រព្រឹត្តដោយខ្លួនឯង ។

ឆ្លើយថា មកពីដើរចុះឡើងទៅមកនៅផែនដី[គ] ៣រួចព្រះ
យេហូវ៉ាទ្រង់សួរថា ឯងបានសង្កេតមើលយ៉ូប ជាអ្នកបំរើ
អញឬទេ ដ្បិតគ្មានអ្នកណាមួយនៅផែនដីឱ្យដូចគាត់ឡើយ
ជាអ្នកដែលគ្រប់លក្ខណ៍ហើយទៀងត្រង់ ក៏កោតខ្លាចដល់
ព្រះ ហើយចៀសចេញពីសេចក្តីអាក្រក់ផង[ឃ] មួយទៀត
ទោះបើឯងបណ្តាលឱ្យអញទាស់ និងគាត់ ដើម្បីនឹងបំផ្លាញ
ចេញ ដោយឥតហេតុក៏ដោយ[ង] គង់តែគាត់ នៅរក្សា
លក្ខណៈខ្លួនដដែល[ច] ៤សាតាំងទូលតបថា ស្បែកឱ្យធួននឹង
ស្បែកចុះ មនុស្សនឹងសុខចិត្តលះបង់ទាំងអស់ចោល[ឆ] ដើម្បី
ឱ្យបានជីវិតគង់នៅ ៥ចូរទ្រង់គ្រាន់តែលូកព្រះហស្តទៅ
ពាល់ដល់ឆ្អឹង និងសាច់គាត់ចុះ[ជ] នោះគាត់នឹងប្រមាថដល់
ទ្រង់ នៅចំពោះព្រះភក្ត្រ[ឈ] ៦ព្រះយេហូវ៉ាមានបន្ទូលថា
មើល អញប្រគល់គាត់ទៅក្នុងអំណាចឯងទៀត[ញ] ចូរប្រណី
ដល់តែជីវិតគាត់ប៉ុណ្ណោះ[ដ]។
៧ដូច្នេះ សាតាំងក៏ចេញពីចំពោះព្រះយេហូវ៉ា ទៅវាយ
យ៉ូបឱ្យកើតដំបៅដ៏អាក្រក់ ចាប់តាំងពីបាតជើងរហូតដល់
ក្រយៅក្បាល[ឋ] ៨នោះលោកយកអំបែងឆ្នាំងសិរាប់កោស
ខ្លួន ទៅអង្គុយនៅក្នុងផេះ[ឌ] ៩ឯប្រពន្ធលោក នាងនិយាយថា
អ្នកនៅតែរក្សាលក្ខណៈខ្លួនទៀតឬ[ឍ] ចូរប្រមាថដល់ព្រះ
ហើយស្លាប់ទៅចុះ[ណ] ១០តែលោកឆ្លើយថា ឯងនិយាយដូច
ជាស្រីឆោតល្ងង់ទេ ម៉េច យើងទទួលសេចក្តីល្អមកពីព្រះ
តើមិនត្រូវទទួលសេចក្តីអាក្រក់ដែរទេឬ[ត] ក្នុងគ្រប់ទាំង
សេចក្តីទាំងនោះ យ៉ូបមិនបានធ្វើឱ្យខ្លួនសៅហ្មង ដោយ
បបូរមាត់ទេ[ថ]។

## មិត្រសំឡាញ់ទាំងបីរបស់លោកយ៉ូប

១១រីឯមិត្រសំឡាញ់របស់យ៉ូបទាំង៣នាក់ កាលបានឮ
និយាយពីសេចក្តីអាក្រក់ទាំងនោះ ដែលកើតដល់លោក
នោះគេក៏មកពីលំនៅរបស់គេរៀងខ្លួន គឺអេលីផាស ជា
សាសន៍ថេម៉ាន១[ទ] ប៊ីលដាឌ ជាសាសន៍ស៊ូអា១[ធ] និងសូផារ
ជាសាសន៍នាអាម៉ា១[ន] គេសន្មតគ្នានឹងមករួមទុក្ខជាមួយ
ហើយជួយឱ្យលោកក្សាន្តចាកទុក្ខ[ប] ១២កាលគេងើបភ្នែក
មើលពីចំងាយទៅឃើញ តែមិនបានស្គាល់[ផ]លោកនោះក៏
ឡើងសំឡេងយំ[ព] ហើយហែកអាវខ្លួនគ្រប់គ្នា[ភ] ព្រមទាំង
បាចធូលីដីទៅលើអាកាស ពីលើក្បាលរបស់ខ្លួនដែរ[ម]

**២:២** គ លប ៣:១
**២:៣** ឃ នក ២០:២០ យប ១:១,៨ ង យប ៩:១៧ ទដ ៤៤:១៧ ច យប ៦:២៩ ១៣:១៨ ២៧:៦ ៣១:៦ ៣២:១ ៤០:៨
**២:៤** ឆ យប ១:១០
**២:៥** ជ យប ១៦:៨ ១៩:២០ ៣៣:២១ ទដ ១០២:៥ បទ ៤:៨ ឈ នក ២០:៧ យប ១:១១
**២:៦** ញ ២កថ ១២:៧ ដ យប ១:១២
**២:៧** ឋ ចទ ២៨:៣៥ យប ១៦:១៦
**២:៨** ឌ លប ១៨:២៧ នក ៤:៣ យប ១៦:១៥ ១៩:៩ ៣០:១៩ ៤២:៦ ទដ ៧:៥ អស ៥៨:៥ ៦១:៣ យរ ៦:២៦ ទ ៣:២៩ អគ ២៦:១៦ យហ ៣:៥–៨,៦ មថ ១១:២១ **២:៩** ឍ យប ៦:២៩ ១៣:១៥ ២៧:៥ ៣៣:៩ ៣៥:២ ១ថន ៥:៨ ណ នក ២០:៧ ២ពវ ៦:៣៣ **២:១០** ត យប ១:២១ សស ២:២៤ បទ ៣:៣៨ ថ យប ១:២២ ៦:២៤ យក ១:១២ ៥:១១ **២:១១** ទ លប ៣៦:១១ ធ លប ២៥:២ ន យប ១១:១ ២០:១ ប លប ៣៧:៣៥ យប ៦:១០ យហ ១១:១៩ **២:១២** ផ យប ១៧:៧ អស ៥២:១៤ ព ២សយ ១៥:២៣ ភ លប ៣៧:២៩ មក ១៤:៦៣ ម យស ៧:៦ ២សយ ១:២

**២:៣** *បណ្តាលឱ្យអញទាស់នឹងគាត់* ព្រះអម្ចាស់ក៏ពុំអាចកកូរកកាយប្រឆាំងនឹងគាត់ឡើយ ដោយឃើញមានភាពមិនច្បាស់លាស់ចំពោះអ្វីៗដែលកើតឡើង គឺជាផ្នែកនៃគោលដៅពីព្រះអម្ចាស់(មើល ៤២:២ និងការពន្យល់) ។
**២:៤** *ស្បែកឱ្យធួននឹងស្បែកចុះ* ជាឃ្លាសុភាសិតដែលសាតាំងបានពណ៌នា ។
**២:៥** *លូកព្រះហស្តទៅពាល់ដល់ឆ្អឹង និងសាច់គាត់* (មើល ១:១១–១២ ប្រៀបធៀប លប ២:២៣ លក ២៤:៣៩) ។
**២:៦** *ចូរប្រណីដល់តែជីវិតគាត់* គឺព្រះទ្រង់នៅតែមិនឱ្យសាតាំងធ្វើហួសល្បត់ ។ ការនៅរស់របស់លោកយ៉ូបបញ្ជាក់ថា ព្រះបន្ទូលទ្រង់គឺត្រឹមត្រូវ ។
**២:៧** ជម្ងឺរបស់លោកយ៉ូប គឺមានលក្ខណៈមិនច្បាស់លាស់ ប៉ុន្តែរោគសញ្ញាគឺជំងឺដែលមានដំបៅខ្ទុះដ៏ឈឺចាប់គ្រប់ទាំងរូបរាងកាយទាំងមូល(៧:៥) ដែលជាសុបិនអាក្រក់(៧:១៤) គឺជាដំបៅច្រើនកន្លែងដែលដំបៅខ្លះ របើកចេញក៏ក្លាយជាស្នាមខ្មៅៗ(៣០:២៨,៣០) ដែលធ្វើឱ្យខូចរូបរាង (២:១២១ ៩:១៩) ក៏មានដង្ហើមដែលក្លិនមិនល្អ(១៩:១៧) ហើយឆ្អឹងនៅជាប់នឹងស្បែក (១៧:៧ ១៩:២០) គ្រុនក្តៅ(៣០:៣០) ហើយឈឺចាប់ទាំងថ្ងៃទាំងយប់ ។ *ដំបៅអាក្រក់* តាមព្រះគម្ពីរភាសាហេព្រើរ គឺមានន័យថា "បូសទ្រនិច" ក្នុង នក ៩:៩ លវ ១៣:១៨ ២ពវ ២០:៧ ។
**២:៨** *ផេះ* គឺជាសញ្ញានៃភាពទុក្ខព្រួយជាខ្លាំង(មើល ៤២:៦ នអ ៤:៣ ប្រៀបធៀប យហ ៣:៦ ដែលនិយាយពីការអង្គុយក្នុងធូលីដី ឬផេះ)។
**២:៩** *ចូរប្រមាថដល់ព្រះ* ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះវគ្គស័ព្ទនេះ គឺនៅក្នុង ១:៥ អារក្សសាតាំងបានប្រើប្រពន្ធលោកយ៉ូបដើម្បីល្បួងលោកយ៉ូបដូចដែលបានល្បួងនាងអេវ៉ាឱ្យល្បួងអ័ដាម ។ *ហើយស្លាប់ទៅចុះ* ក៏គ្មានអ្វីបានទទួលសោះ ក្រៅពីសេចកីស្លាប់សម្រាប់លោកយ៉ូប ភរិយារបស់លោកយ៉ូបចង់ឱ្យលោកយ៉ូបប្រមាថព្រះអម្ចាស់(លវ ២៤:១០–១៦)។
**២:១០** *ម៉េច យើងទទួលសេចក្តីល្អមកពីព្រះ តើមិនទទួលសេចក្តីអាក្រក់ដែរ ឬ* គន្លឹះនៃផ្ទៃរឿងក្នុងកណ្ឌគម្ពីរ: ការមានបញ្ហា ការឈឺចាប់ គឺមិនគ្រាន់តែជាទណ្ឌកម្មសម្រាប់អំពើបាបប៉ុណ្ណោះទេ តែវាក៏ជាការដាក់វិន័យដែលមានលក្ខណៈកំពូលក្នុងគោលបំណងកើនខាងឯព្រះវិញ្ញាណ (មើលការពន្យល់ ៥:១៧–២៦ ចទ ៥:៥ ២សយ ៧:១៤ ទដ ៩៤:១២ និងការពន្យល់) ។ លោកយ៉ូបបានឆ្លើយតបទៅប្រពន្ធរបស់គាត់ដោយស្ងៀមស្ងាត់ ហើយអ្នកចោទប្រកាន់ក៏មិនអាចឮដែរ ។ ការឈឺចាប់រងទុក្ខជាយូរយារ ក៏មិនបណ្តាលឱ្យលោកយ៉ូបងាកបែរចេញពីព្រះដែរ គឺបន្តដើរក្នុងផ្លូវរបស់ព្រះដដែល ។
**២:១១** *មិត្រសំឡាញ់របស់យ៉ូបទាំង៣នាក់* ដែលមានចំណាស់ចាស់ជាងលោកយ៉ូប (មើល ១៥:១០) ។ អេលីផាស គឺជាឈ្មោះរបស់សាសន៍អេដំម (មើលការពន្យល់ លប ៣៦:១១) ជាសាសន៍ថេម៉ាន ថេម៉ានជាឈ្មោះភូមិក្នុងស្រុកអេដំម ផ្នែកខាងត្បូងសមុទ្រស្លាប់ (មើល លប ៣៦:១១ យរ ៤៩:៧ អក ២៥:១៣ អប ១:១២ និងការពន្យល់) ។ *ប៊ីលដាឌ* ជាសាសន៍ស៊ូអាប៊ីលដាឌដែលជាពូជរបស់ស៊ូអា គឺជាកូនពៅរបស់អ័ប្រាហាំ និងនាងកិទូរ៉ា(លប ២៥:២)។
**២:១២** *ឃើញ តែមិនស្គាល់លោក* ធៀបនឹង អស ៥២:១៤ ៥៣:៣ ។ *ហើយហែកអាវខ្លួនគ្រប់គ្នា ព្រមទាំងបាចធូលីដីទៅលើអាកាស ពីលើក្បាលរបស់*

១៣រួចគេអង្គុយនៅដី[យ] ជាមួយនឹងលោកអស់៧យប់៧ថ្ងៃ[រ]
ឥតមានអ្នកណានិយាយទៅលោក១ម៉ាត់សោះ[ល] ដោយ
ឃើញថា លោកមានសេចក្ដីទុក្ខជាទំងន់ណាស់ ។

**លោកយ៉ូបនិយាយឡើង**

**៣** ១ក្រោយនោះមក យ៉ូបក៏បើកមាត់ពោលពាក្យប្រទេច
ផ្ដាសា ដល់ថ្ងៃកំណើតរបស់ខ្លួន[ក] ២លោកពោលពាក្យថា
៣សូមឱ្យថ្ងៃដែលខ្ញុំកើតមកត្រូវវិនាសទៅ គឺជាយប់ដែលគេ
ប្រកាសថា មានកូនមកចាប់ទំផ្ទៃនោះ[ខ] ៤សូមឱ្យថ្ងៃនោះបាន
សូន្យទៅ សូមកុំឱ្យព្រះនឹករកពីស្ថានលើឡើយ ក៏កុំឱ្យមាន
ពន្លឺចាំងមកបំភ្លឺឱ្យសោះ ៥សូមឱ្យសេចក្ដីងងឹត និងម្លប់នៃ
សេចក្ដីស្លាប់[គ]មកទទួលធ្វើជាម្ចាស់ សូមឱ្យមានពពកនៅ
ជាប់ពីលើ ហើយសូមឱ្យសូរ្យគ្រាសមកបំភ័យផង ៦ឯយប់
នោះ សូមឱ្យសេចក្ដីងងឹតសូន្យសុង[ឃ]ចាប់ទុក កុំឱ្យយប់នោះ
មានកន្លែង នៅជាមួយនឹងថ្ងៃឯទៀតក្នុងឆ្នាំឡើយ ក៏កុំឱ្យ
បានរាប់ក្នុងខែនោះដែរ ៧អើ សូមឱ្យយប់នោះបានទៅជា
អសារឥតការ ឥតមានឮសៀងអរសប្បាយឡើយ[ង] ៨សូម
ឱ្យពួកអ្នកដែលស្អប់ពេលថ្ងៃ[ច] បានដាក់បណ្ដាសាដល់យប់
នោះ ព្រមទាំងពួកអ្នកដែលប្រុងនឹងដាស់ក្រពើឡើងផង[ឆ]
៩សូមឱ្យអស់ទាំងផ្កាយ ដែលភ្លឺនៅពេលព្រលប់ក្នុងយប់
នោះបានងងឹតវិញ ឱ្យបានរកពន្លឺឥតមានឡើយ ក៏កុំឱ្យ
បានឃើញបើកពន្លឺ នៅពេលបច្ចូសកាលដែរ[ជ] ១០ពីព្រោះ
មិនបានបិទទ្វារផ្ទៃម្ដាយខ្ញុំទេ ក៏មិនបានបិទបាំងសេចក្ដី
វេទនា ពីភ្នែកខ្ញុំដែរ ។
១១ហេតុអ្វីបានជាខ្ញុំមិនបានស្លាប់ ចាប់តាំងពីក្នុងផ្ទៃ
ហើយប្រគល់វិញ្ញាណទៅវិញ ក្នុងកាលដែលម្ដាយខ្ញុំបាន
សំរាលមកនោះ[ឈ] ១២ម្ដេចក៏មានភ្លៅទទួលទ្រខ្ញុំ[ញ] ហើយនិង
ដោះឱ្យខ្ញុំបៅ ១៣កុំតែមានដូច្នោះ នោះខ្ញុំបានដេកទៅដោយ
សុខស្រួល[ដ] ខ្ញុំនឹងបានដេកលក់ទៅ ដោយមានសេចក្ដី
ស្រាន្តហើយ[ឋ] ១៤នៅជាមួយពួកស្ដេច និងពួកអ្នកប្រាជ្ញនៃ
លោកិយ[ឌ] ជាពួកអ្នកដែលបានសង់ទីសំងាត់សំរាប់ខ្លួន[ឍ]
១៥ឬនៅជាមួយនឹងពួកអ្នកជាប្រធាន[ណ] ដែលមានមាស
ហើយបានបំពេញផ្ទះគេដោយប្រាក់[ត] ១៦ឬនឹងឥតមានខ្ញុំ
សោះ ដូចជាកូនរំលូតលាក់កំបាំង[ថ] គឺជាកូនដែលមិនបាន
ឃើញពន្លឺឡើយ[ទ] ១៧នៅទីនោះពួកអាក្រក់លែងធ្វើទុក្ខ នៅ
កន្លែងនោះ[ធ] ពួកនឿយហត់មានសេចក្ដីស្រាកស្រាន្ត[ន] ១៨នៅ
ទីនោះ ពួកអ្នកទោស[ប]មានសេចក្ដីសំរាកព្រមគ្នា គេមិនឮ
សូរកំហែងនៃអ្នកនាយដំរួត[ផ]ទៀតទេ[ព] ១៩មានទាំងអ្នកតូច
អ្នកធំនៅទីនោះ[ភ] ហើយបាវក៏បានរួចពីចៅហ្វាយខ្លួនដែរ ។
២០ហេតុអ្វីបានជាឱ្យមានពន្លឺភ្លឺ ដល់មនុស្សរងវេទនា
ព្រមទាំងឱ្យជីវិត ដល់អ្នកដែលមានសេចក្ដីជូរចត់ក្នុងចិត្ត
ដូច្នេះ[ម] ២១គេទន្ទឹងចាំតែស្លាប់ តែសេចក្ដីស្លាប់មិនមកដល់
សោះ[យ] ទោះបើគេសង្វាតរកលើស ជាងរកទ្រព្យសម្បត្តិ
ផងក៏ដោយ[រ] ២២គេមានសេចក្ដីរីករាយក្រៃលែង ហើយក៏
អរសប្បាយ ក្នុងកាលដែលប្រទះនឹងផ្នូរហើយ[ល] ២៣ហេតុអ្វី
បានជាឱ្យពន្លឺភ្លឺដល់មនុស្ស ដែលផ្លូវរបស់ខ្លួនសុទ្ធតែងងឹត

**២:១៣** យ អស ៣:២៦ ៤៧:១ យរ ៤៨:១៨ បទ ២:១០ អក ២៦:១៦ យហ ៣:៦ ហក ២:២២ រ លប ៥០:១០ ល សភ ១៧:២៨ អស ២៣:២ ៤៧:៥
**៣:១** ក យរ ១៥:១០ ២០:១៤
**៣:៣** ខ ខ.១១,១៦ យប ១០:១៨-១៩ សស ៤:២ ៦:៣ យរ ២០:១៤-១៨ មថ ២៦:២៤
**៣:៥** គ យប ១០:២១,២២ ៣៤:២២ ៣៨:១៧ ទដ ២៣:៤ ៤៤:១៩ ៨៨:១២ យរ ២:៦ ១៣:១៦
**៣:៦** ឃ យប ២៣:១៧ ៣០:២៦
**៣:៧** ង ទដ ២០:៥ ៣៣:៣ ៦៥:១៣ អស ២៦:១៩ យរ ៥១:៤៨
**៣:៨** ច យប ១០:១៨ យរ ២០:១៤ ឆ លប ១:២១ យប ៤១:១,៨,១០,២៥ ទដ ៧៤:១៤ ១០៤:២៦
**៣:៩** ជ យប ៤១:១៨ ហព ៣:៤
**៣:១១** ឈ ខ.៣

**៣:១២** ញ លប ៤៨:១២ អស ៦៦:១២ **៣:១៣** ដ យប ១៧:១៣ ៣០:២៣ ឋ ខ.១៧យប ៧:៨-១០ ២១ ១០:២២ ១៣:១៩ ១៤:១០-១២ ១៩:២៧ ២១:១៣,២៣ ២៧:១៩ ទដ ១៣៩:១១ អស ៨:២២ **៣:១៤** ឌ យប ៩:២៤ ១២:១៧ អស ១៤:៩ អក ៣២:២៨-៣២ ឍ យប ១៥:២៨ យរ ៥១:៣៧ ណហ ៣:៧ **៣:១៥** ណ យប ១២:២១ អស ៤៥:១ ត យប ១៥:២៩ ២០:១០ ២៧:១៧ ទដ ៤៩:១៦-១៧ សភ ១៣:២២ ២៨:៨ សស ២:២៦ អស ២:៧ សជ ១:១១ **៣:១៦** ថ ទដ ៥៨:៨ សស ៤:៣ ៦:៣ ទ ខ.៣ ទដ ៧១:៦ **៣:១៧** ធ ខ.២៦ យប ៣០:២៦ សស ៤:២ អស ១៤:៣ ន ខ.១៣ **៣:១៨** ប អស ៥១:១៤ ផ លប ១៥:១៣ ព យប ៣៩:៧ **៣:១៩** ភ យប ៩:២២ ១៧:១៦ ២១:៣៣ ២៤:២៤ ៣០:២៣ សស ១២:៥ **៣:២០** ម ១សយ ១:១០ អក ២៧:៣០-៣១ **៣:២១** យ វវ ៩:៦ រ ទដ ១១៩:១២៧ សភ ២:៤ **៣:២២** ល យប ៧:១៦ សស ៤:៣ យរ ៨:៣

*ខ្លួនដែរ* គឺជាទិដ្ឋភាពនៃការកាន់ទុក្ខ (មើលការពន្យល់ ១:២០) ។
**២:១៣** *អង្គុយនៅលើដី ជាមួយនឹងលោក* មើល អក ៣:១៥ គឺជាលក្ខណៈបង្ហាញនូវភាពចាប់អារម្មណ៍ ។ *៧យប់៧ថ្ងៃ* គឺជាចំនួនសរុប (មើល ១:២ លប ៥០:១០ ១សយ ៣១:១៣ និងការពន្យល់ នរ ៤:១៥) ។ *ឥតមានអ្នកណានិយាយទៅលោក១ម៉ាត់សោះ* គឺជាពាក្យឆ្លើយតបដើម្បីបញ្ជាក់ (មើល ១៦:២-៣) ។
**៣:១-២៦** *ការសម្ដែងលើកទី១* គឺដើម្បីបង្ហាញពីភាពត្អូញត្អែរចំពោះសេចក្ដីស្លាប់នៃភាពឈឺចាប់របស់គាត់ ។
**៣:៣** *សូមឱ្យថ្ងៃដែលខ្ញុំកើតត្រូវវិនាសទៅ* ភាពមានជីវិតរបស់លោកយ៉ូបដែលជាទីសព្វព្រះហឫទ័យដល់ព្រះ ឥឡូវនេះបន្ទុកដ៏ធ្ងន់ក៏លែងទ្រាំបានទៀតហើយ លោកយ៉ូបក៏ដេរ និងដាក់បណ្ដាសាទៅព្រះ តែលោកយ៉ូបពុំធ្វើការនេះទេ ។ (មើល យរ ២០:១៤-១៨ និងការពន្យល់) ។
**៣:៤** *សូមឱ្យថ្ងៃនោះបានសូន្យទៅ* ព្រះអម្ចាស់ក៏មានបន្ទូលនៅក្នុង លប ១:៣ ថា "ចូរឱ្យមានពន្លឺឡើង"។ លោកយ៉ូបក៏ប្រើពាក្យ ដែលផ្ទុយនឹងពាក្យដែលនិយាយអំពីស្នាព្រះហស្តរបស់ផងទ្រង់ ។
**៣:៨** *អ្នកដែលស្អប់ពេលថ្ងៃ* គឺជាគ្រូទាយដែលមកពីតំបន់ខាងកើត ដូចជាលោកបាឡាម (មើល ជន ២២-២៤) ដែលបានប្រកាសពាក្យបណ្ដាសាទៅលើប្រជាជនក៏ជាកម្មបទ និងជាថ្ងៃ ។ អ្នកដែលប្រុងដាស់ក្រពើឡើងផង (មើលការពន្យល់ អស ២៧:១) គឺដើម្បីលេបបំបាត់ពេលថ្ងៃនិងយប់នៃកំណើតរបស់គាត់ (មើល ខ.៣) ។
**៣:១១-១២,១៦:២០-២៣** គឺជាផ្នែកសំណួរខាងវោហាសាស្ត្រ ។
**៣:១៦** គឺចាប់តាំងពីកំណើតគាត់ ចាប់ផ្ដើមដំបូង ដូចជាកូនដែលស្លាប់ក្នុងពោះ គឺមានជីវិតតែក្នុងស្ថានភាពក្នុងស្ថានឃុំព្រលឹង (ខ.១៣-១៩ មើលការពន្យល់ លប ៣៧:៣៥) គឺជាស្ថានភាពដែលប្រសើរជាងបច្ចុប្បន្ន (ខ.២៦) ។
**៣:១៨** *កំហែងនៃអ្នកនាយដំរួត* គឺដូចនៅស្រុកអេស៊ីព្ទ (នក ១៣-១៤) ។
**៣:២៣** *អ្នកដែលព្រះបានធ្វើរបងព័ទ្ធ* ព្រះអម្ចាស់បានដាក់របងការពារ

ដូច្នេះ[វ] គឺជាអ្នកដែលព្រះបានធ្វើរបងព័ទ្ធជុំវិញហើយ[ស]
២៤ ព្រោះសេចក្តីដំអូញ[ហ] របស់ខ្ញុំ ទុកដូចជាអាហារ[ឡ] ហើយ
ដំងូរ[អ] ខ្ញុំក៏ហូរចេញដូចជាទឹក[ក] ២៥ ដ្បិតសេចក្តីដែលខ្ញុំខ្លាច
នោះបានកើតដល់ខ្ញុំ សេចក្តីដែលនាំឱ្យខ្ញុំភ័យ[ខ] នោះ ក៏មក
ដល់ខ្ញុំហើយ[គ] ២៦ ខ្ញុំគ្មានសេចក្តីសុខ[ឃ] គ្មានសេចក្តីក្សេមក្សាន្ត
ក៏គ្មានសេចក្តីសំរាកឡើយ[ង] គឺមានតែសេចក្តីទុក្ខប៉ុណ្ណោះ[ច] ។

## លោកអេលីផាស

៤ ១ អេលីផាស ជាសាសន៍ថេម៉ាន[ក] គាត់ឆ្លើយតបថា ២ បើ
សិនជាយើងស៊ិកឆ្លើយនឹងអ្នក នោះតើអ្នកនឹងអន់ចិត្តឬទេ
តែតើអ្នកឯណានឹងទ្រាំមិននិយាយបាន[ខ] ៣ មើលអ្នកបាន
ទូន្មានប្រដៅដល់មនុស្សជាច្រើន[គ] ក៏បានធ្វើឱ្យដៃខ្សោយ
មានកំឡាំងឡើង[ឃ] ៤ ពាក្យសំដីរបស់អ្នកបានទប់ទល់ពួកអ្នក
ដែលកំពុងតែដួល[ង] ហើយអ្នកបានចំរើនកំឡាំង ដល់ជង្គង់
ខ្សោយ[ច] ៥ តែឥឡូវនេះ សេចក្តីនោះបានមកដល់អ្នកវិញ
ហើយអ្នកទ្រាំមិនបាន[ឆ] ក៏ពាល់ប៉ះ[ជ] នឹងអ្នកហើយអ្នកមាន
សេចក្តីស្រយុតចុះ[ឈ] ៦ ដែលអ្នកកោតខ្លាចដល់ព្រះ នោះតើ
មិនមែនជាទីអាងរបស់អ្នក[ញ] ហើយដែលផ្លូវប្រព្រឹត្តរបស់
អ្នកសុទ្ធតែទៀងត្រង់[ដ] នោះតើមិនមែនជាទីសង្ឃឹមដល់អ្នក
ទេឬអី ៧ ចូរអ្នកនឹកចាំចុះ បើអ្នកណាឥតទោស តើដែល
វិនាសដែរឬអី[ឋ] តើមានកន្លែងណា ដែលមនុស្សទៀងត្រង់
ត្រូវកាត់ចេញនោះ[ឌ] ៨ តាមដែលខ្ញុំបានឃើញ[ឍ] នោះគឺអស់
អ្នកដែលភ្ជួរបំផុលសេចក្តីទុច្ចរិតឡើង[ណ] ហើយសាបព្រោះ
សេចក្តីកំណាចចុះ គេរមែងច្រូតបានសេចក្តីនោះឯងវិញ[ត]
៩ គេត្រូវវិនាសទៅ ដោយអស្សាសៈរបស់ព្រះ[ថ] ហើយខ្យល់
ចំហួលនៃសេចក្តីក្រោធរបស់ទ្រង់ក៏បញ្ឆេះគេអស់ទៅ[ទ]
១០ ឯសូរគ្រហឹម[ធ] របស់សិង្ហ និងសំឡេងរបស់សិង្ហសាហាវ
នោះត្រូវបាត់ ហើយចង្កូមរបស់សិង្ហស្ទាវ[ន] ត្រូវបាក់[ប] ១១ ឯ
សិង្ហចាស់ វាស្លាប់ទៅដោយអត់រំពា[ផ] ហើយកូនរបស់មេសិង្ហ
ត្រូវខ្ចាត់ខ្ចាយទៅ[ព] ។
១២ រីឯមានសេចក្តី១[ភ] បានឮមកដល់ខ្ញុំ ដោយសំងាត់
ត្រចៀកខ្ញុំបានទទួលពាក្យខ្សឹប[ម] ពីដំណើរនោះ[យ] ១៣ នៅ
វេលាដែលការជាក់ស្តែង កំពុងតែបណ្តាលឱ្យគំនិតកំរើក
ឡើងនៅពេលយប់ ក្នុងកាលដែលមនុស្សកំពុងដេកលក់ស៊ប់[រ]
១៤ នោះសេចក្តីភ័យខ្លាច ហើយញ័ររន្ធត់[ល] បានកើតដល់ខ្ញុំ
ក៏ធ្វើឱ្យអស់ទាំងឆ្អឹងខ្ញុំរញ្ជួយផង[វ] ១៥ រួចមានវិញ្ញាណ១កាត់
មុខខ្ញុំទៅ ខ្ញុំក៏ព្រឺរោមឡើង[ស] ១៦ វិញ្ញាណនោះក៏ឈប់នឹងនៅ

**៣:២៣** វ សភ ៤:១៩ អស ៥៩:១០ យរ ១៣:១៦ ២៣:១២ ស យប ៦:៤ ១៦:១៣ ១៩:៦,៨,១២ ទដ ៨៨:៨ បទ ២:៤ ៣:៧ ហស ២:៦ **៣:២៤** ហ ទដ ៥:១ ៣៨:៩ អស ៣៥:១០ ឡ យប ៦:៧ ៣៣:២០ ទដ ១០៧:១៨ អ ទដ ២២:១ ៣២:៣ ៣៨:៨ ក ១សយ ១:១៥ យប ៣០:១៦ ទដ ៦:៦ ២២:១៤ ៤២:៣,៤ ៨០:៥ អស ៥៣:១២ បទ ២:១២ **៣:២៥** ខ យប ៧:៩ ៩:២៨ ៣០:១៥ ហស ១៣:៣ គ លប ៤២:៣៦ **៣:២៦** ឃ អស ៤៨:២២ យហ ១៤:២៧ ង យប ៧:៤,១៤ ទដ ៦:៦ ដយ ៤:៥ មថ ១១:២៨ ច ខ.១៧ យប ១០:១៨ ១៩:៨ **៤:១** ក លប ៣៦:១១ យប ១៥:១ ២២:១ **៤:២** ខ យប ៣២:២០ យរ ៤:១៩ ២០:៩ **៤:៣** គ ចទ ៣២:២ យប ២៩:២៣ ហស ៦:៣ ឃ យប ២៩:១១,១៥ អស ៣៥:៣ យរ ៣១:៨ ហព ១២:១២ **៤:៤** ង យប ១៦:៥ ២៩:១៦,២៥ អស ១:១៧ ច យប ២៩:១១,១៥ អស ៣៥:៣ យរ ៣១:៨ ហព ១២:១២ **៤:៥** ឆ យស ១:៩ ជ រន ១:១៣ យប ១:១១ ១៩:២១ ៣០:២១ ទដ ៣៨:២ អស ៥៣:៤ ឈ យប ៦:១៤ សភ ២៤:១០ **៤:៦** ញ ២ពវ ១៨:១៩ ទដ ២៧:៣ ៧១:៥ សភ ៣:២៦ ដ លប ៦:៩ **៤:៧** ឋ យប ៥:១១ ៣៦:៧ ទដ ៤១:១២ ២ពវ ២:៩ ឌ យប ៨:២០ ទដ ៣៧:២៥ ៩១:៩–១០ សភ ១២:២១ ១៩:២៣ **៤:៨** ឍ យប ៥:៣ ១៥:១៧ ណ ពច ១៤:១៨ យប ៥:៦ ១៥:៣៥ ទដ ៧:១៤ អស ៥៩:៤ ត ទដ ៧:១៥ ៩:១៥ សភ ១១:១៨ ២២:៨ អស ១៧:១១ ហស ៨:៧ ១០:១៣ កទ ៦:៧–៨ **៤:៩** ថ នក ១៥:១០ យប ៤១:២១ ២ថន ២:៨ ទ លវ ២៦:៣៨ យប ៤០:១៣ អស ២៥:៧ **៤:១០** ធ ទដ ២២:១៣ ន ទដ ១៧:១២ ២២:២១ សភ ២៨:១៥ ប យប ៥:១៥ ២៩:១៧ ៣៦:៦ ៣៨:១៥ ទដ ៣៥:១០ ៥៨:៦ **៤:១១** ផ ចទ ២៨:៤១ យប ២៧:១៤ ២៩:១៧ ទដ ៣៤:១០ ៥៨:៦ សភ ៣០:១៤ ព យប ៥:៤ **៤:១២** ភ ខ.១៧–២១ យប ៣២:១៣ យប ៩:២៣ ម យប ២៦:១៤ យ យប ៣៣:១៤ **៤:១៣** រ យប ៣៣:១៥ **៤:១៤** ល យប ២១:៦ ទដ ៤៨:៦ ៥៥:៥ ១១៩:១២០, ១៦១ យរ ៥:២២ ហព ៣:១៦ ២កថ ៧:១៥ វ យរ ២៣:៩ ដយ ១០:៨ ហព ៣:១៦ **៤:១៥** ស ដយ ៥:៦ ៧:១៥,២៨ ១០:៨ មថ ១៤:២៦

ពួកគេឱ្យរួចពីការរុកកួនផ្សេងៗ ។ (មើល ១:១០ និងការពន្យល់) (មើល ខ.២១) ។

**៤:១** *អេលីផាស ជាសាសន៍ថេម៉ាន* មើលការពន្យល់ ២:១១ គឺជាបុរសនៅក្រុងអេដំម ក៏កំណត់ពីប្រាជ្ញា (មើល យរ ៤០:៧) ការបញ្ចោញសំដីរបស់មិត្តសំឡាញ់ទាំងបីរបស់លោកយ៉ូប ដែលមានសេចក្តីពិត តែពួកគេត្រូវបកប្រែដោយប្រុងប្រយ័ត្នពីក្នុងអត្ថបទ ។ តែបញ្ហាដែលកើតឡើងក៏មិនច្រើនជាងអ្វីដែលមិត្តសំឡាញ់ទាំងនោះបានឮដែរ តែអ្វីដែលគេពុំបានដឹងនោះគឺ : គោលបំណងដ៏អស្ចារ្យរបស់ព្រះអម្ចាស់ គឺអនុញ្ញាតឱ្យអារក្សសាតាំងប៉ះទង្គិច ដល់លោកយ៉ូប ។

**៤:២** *ស៊ិកឆ្លើយ* គឺជាលោកអេលីផាស ហាក់ដូចជាចាប់អារម្មណ៍ផ្តោតទៅលើការប្រព្រឹត្តក្នុងជីវិតល្អ ហើយថ្វាយប្រគល់នូវពាក្យពេចន៍ដែលកោតសរសើរ (ខ.៣,៤) អន់ចិត្តឬទេ មើលការពន្យល់ ៩:២–៣ ។

**៤:៥** *ក៏ពាល់ប៉ះនឹងអ្នក* មើល ១:១១ ២:៥ ១៩:២១ ។

**៤:៦–៧** លោកអេលីផាសប្រឹក្សាដល់លោកយ៉ូប ឱ្យទុកចិត្តទៅលើភាពកោតខ្លាចដល់ព្រះ គឺតាមរយៈការដាក់ទណ្ឌកម្មតែលំអមកពីព្រះនាំឱ្យមានលទ្ធផលល្អប្រសើរក្នុងពេលចុងបញ្ចប់ (មើល ខ.១៧ ៥:១៧) ហើយគាត់ក៏អាចសន្និដ្ឋានថាព្រះនឹងមិនបំផ្លាញគាត់ទេ ។

**៤:៦** *កោតខ្លាច* គឺសំដៅទៅលើការកោតខ្លាចដល់ព្រះ (សូមមើលការពន្យល់ ១:១) ។ គឺលោកអេលីផាស បានប្រើពាក្យនេះ (សូមមើល ១៥:៤ ២២:៤) ។

**៤:៧–៩** បើសិនលោកយ៉ូបពិតជាគ្មានទោសមែន គាត់មិនត្រូវបំផ្លាញទេ ។

**៤:៨–១១** ដូចជាសត្វតោដ៏ខ្លាំងបំផុត បានងាប់ដោយចៃដន្យ (ខ.១០–១១) ដូច្នេះការអាក្រក់បានបំផ្លាញ ។

**៤:៩** *ខ្យល់ចំហួលពីសេចក្តីក្រោធ* មើល នក ១៥:៧–៨ ។ ការកាត់ទោសរបស់ព្រះ គឺគួរឱ្យខ្លាច ។

**៤:១២–២១** *អេលីផាស* ប្រាប់ពីការព្រឺរោមឡើង (ខ.១៥) គឺជាការបង្ហាញឱ្យឃើញតាមរយៈសុបិន (មើល ខ.១៣) គឺគាត់បានទទួលការបើកសម្តែងពីព្រះ ជាការប្រឹក្សាដល់លោកយ៉ូប ។

**៤:១៤** *អស់ទាំងឆ្អឹងខ្ញុំរញ្ជួយផង* គឺជាសញ្ញានូវភាពគ្រៀមគ្រំយ៉ាងខ្លាំង (មើល យរ ២៣:៩) ។

តែខ្ញុំរកសិគាល់ថាជាមានរូបភាពយ៉ាងណាមិនបាន មានតែ
ភាពជារូបនៅមុខខ្ញុំប៉ុណ្ណោះ ខ្ញុំក៏ឮសំឡេងរសាវៗពោល
មកថា[ហ] ១៧ មនុស្សដែលតែងតែស្លាប់ តើនឹងបានសុចរិតនៅ
ចំពោះព្រះឬ[ឡ] តើនឹងបានបរិសុទ្ធនៅចំពោះព្រះដែលបាន
បង្កើតខ្លួនមកឬអី[អ] ១៨ មើល ទ្រង់មិនទុកចិត្តនឹងពួកបរិវារ
ទ្រង់ទេ[ក] ឯពួកទេវតាទ្រង់ នោះក៏ប្រកាន់ថាមានសេចក្ដីអួត
អាងដែរ[ខ] ១៩ ចំណង់បើមនុស្សដែលនៅក្នុងភាជនៈដី[គ]
ដែលមានកំណើត[ឃ]មកពីធូលីដី[ង] ហើយដែលត្រូវល្អិ[ច]ទៅ
ដូចជាដង្កូវ[ឆ] នោះតើយ៉ាងណាទៅ ២០ ពីព្រឹកដល់ល្ងាចវា
ត្រូវបំផ្លាញទៅ វាសូន្យទៅអស់កល្ប ឥតមានអ្នកណាសង្កេត
ឡើយ[ជ] ២១ ខ្សែជ្រែងរបស់គេត្រូវដាច់ចេញ[ឈ]ហើយ គេក៏
ស្លាប់ទៅ[ញ] ឥតទាន់បានប្រាជ្ញាផង[ដ]។

៥ ១ ចូរអំពាវនាវឥឡូវចុះ តើមានអ្នកណានឹងឆ្លើយមកឬ
ទេ[ក] តើអ្នកនឹងបែរទៅរកតួបរិសុទ្ធ[ខ]ណាទៀត ២ គឺជា
សេចក្ដីមួម៉ៅ[គ] ដែលប្រហារមនុស្សឥតបើគិត ហើយសេចក្ដី
ច្រណែនក៏សំឡាប់មនុស្សឆោតខ្លៅ[ឃ] ៣ ខ្ញុំបានឃើញ[ង]មនុស្ស
ឥតបើគិតចាក់ឫសចុះ[ច] តែខ្ញុំបានប្រទេចផ្ដាសា[ឆ] ដល់ទី
លំនៅគេភ្លាម[ជ] ៤ កូនចៅ[ឈ]គេនៅឆ្ងាយពីសេចក្ដីសង្គ្រោះ[ញ]
វាត្រូវជាន់ឈ្លីនៅត្រង់ទ្វារក្រុង[ដ] ឥតមានអ្នកណានឹងជួយ
ឡើយ[ឋ] ៥ ឯផលចំរូតរបស់គេ[ឌ] នោះពួកអត់ឃ្លានស៊ីអស់
រលីងទៅ ពួកនោះច្រូតយក ទាល់តែដល់ក្នុងគុម្ពបន្លាផង
ហើយមនុស្សទាល់ក្រលេបទ្រព្យសម្បត្តិគេទៅ ៦ ដ្បិតសេចក្ដី
ទុក្ខលំបាកមិនកើតពីធូលីទេ ហើយសេចក្ដីវេទនា ក៏មិនដុះ
ចេញពីដីដែរ[ឍ] ៧ មនុស្សកើតមកតែងមានសេចក្ដីវេទនា[ណ]
ដូចជាផ្កាភ្លើងចេះតែហើរទៅលើដែរ ។
៨ បើជាខ្លួនខ្ញុំវិញ ខ្ញុំនឹងស្វែងរកព្រះ ខ្ញុំនឹងស្នើប្រគល់
រឿងខ្ញុំដល់ព្រះ[ត] ៩ ដែលទ្រង់ធ្វើការយ៉ាងធំ[ថ] រកគិតមិន
យល់[ទ]ជាការយ៉ាងអស្ចារ្យឥតគណនា[ធ] ១០ ទ្រង់បង្អុរភ្លៀង
មកលើផែនដី[ន] ហើយឱ្យទឹកហូរមកក្នុងស្រែ[ប] ១១ ដើម្បីនឹង
លើកមនុស្សទាបថោកដាក់នៅទីខ្ពស់វិញ[ផ] ហើយឱ្យមនុស្ស
ដែលក្រំក្នុងចិត្ត[ព] បានដំកើងឡើង[ភ]ដល់ទីសុខ ១២ ទ្រង់ធ្វើឱ្យ
ថ្លស់ឧបាយ[ម]របស់មនុស្សឆ្លាត មិនឱ្យដៃគេសំរេចការ

**៤:១៦** ហ ១ពវ ១៩:១២ **៤:១៧** ឡ យប ៩:២ ១៣:១៨ ទដ ១៤៣:២ អ យប ៨:៣ ១០:៣ ១៤:៤ ១៥:១៤ ២១:១៤ ២៥:៤ ៣១:១៥ ៣២:២២ ៣៥:១០ ៣៦:៣,១៣ ៣៧:២៣ ៤០:១៩ ទដ ១៨:២៦ ៥១:៥ ១១៩:៧៣ សភ ២០:៩ សស ៧:២០ អស ៥១:១៣ មឡ ២:១០ កច ១៧:២៤ **៤:១៨** ក ហព ១:១៤ ខ យប ១៥:១៥ ២១:២២ ២៥:៥ **៤:១៩** គ យប ១០:៩ ៣៣:៦ អស ៦៤:៨ រម ៩:២១ ២កថ ៤:៧ ៥:១ ឃ យប ២២:១៦ ង លប ២:៧ ច យប ៥:៤ ឆ យប ៧:១៧ ១៥:១៦ ១៧:១៤ ២៥:៦ ទដ ២២:៦ អស ៤១:១៤ **៤:២០** ជ យប ១៤:២,២០ ១៥:៣៣ ២០:៧ ២៤:២៤ ទដ ៨៩:៤៧ ៩០:៥–៦ យក ៤:១៤ **៤:២១** ឈ យប ៨:២២ អស ៣៨:១២ ញ យប ៨:២៤ ដ យប ១៨:២១ ៣៦:១២ សភ ៥:២៣ យរ ៩:៣ **៥:១** ក ហព ១:២ ខ យប ១៥:១៥ ទដ ៨៩:៥,៧ **៥:២** គ យប ២១:១៥ ៣៦:១៣ ឃ សភ ១២:១៦ កទ ៥:២៦ **៥:៣** ង យប ៤:៨ ច ទដ ៣៧:៣៥ អស ៤០:២៤ យប ១២:២ អក ១៧:៦ ឆ យប ២៤:១៨ ទដ ៣៧:២២,៣៥–៣៦ ១០៩:៩–១០ សភ ៣:៣៣ ជ សភ ៦:១៥ **៥:៤** ឈ យប ២០:១០ ២៧:១៥ ញ យប ៤:១១ ដ យប ៤:១៩ អម ៥:១២ ឋ ទដ ១០៩:១២ អស ៩:១៧ ១យហ ២:១ **៥:៥** ឌ លប ២៦:១៦ ពច ២:១៥ យប ២០:១៨ ៣១:៨ មីក ៦:១៥ **៥:៦** ឍ យប ៤:៨ **៥:៧** ណ លប ៣:១៧ យប ១០:១៧ ១៥:៣៥ ទដ ៥១:៥ ៥៨:៣ ៩០:១០ សភ ២២:៨ **៥:៨** ត យប ៨:៥ ១១:១៣ ១៣:៣,១៥ ២៣:៤ ៤០:១ ទដ ៣៥:២៣ ៥០:១៥ យរ ១២:១ ១កថ ៤:៤ **៥:៩** ថ ទដ ៧៨:៤ ១១១:២ ទ ចទ ២៩:២៩ យប ៩:៤,១០ ១១:៧ ២៥:២ ២៦:១៤ ៣៣:១២ ៣៦:៥,២២,២៦ ៣៧:៥,១៤,១៦, ២៣ ៤២:៣ ទដ ៤០:៥ ៧១:១៧ ៧២:១៨ ៨៦:១០ ១៣១:១ ១៣៩:៦,១៧ ១៤៥:៣ អស ៤០:២៨ រម ១១:៣៣ ធ ទដ ៧១:១៥ **៥:១០** ន មថ ៥:៤៥ ប លវ ២៦:៤ យប ៣៦:២៨ ៣៧:៦,១៣ ៣៨:២៨,៣៤ ទដ ១៣៥:៧ យរ ១៤:២២ **៥:១១** ផ ១សយ ២:៧–៨ យប ៤:៧ ទដ ៧៥:៧ ១១៣:៧–៨ ព អស ៦១:២ មថ ៥:៤ រម ១២:១៥ ភ មថ ២៣:១២ យក ៤:១០ **៥:១២** ម នហ ៤:១៥ ទដ ៣៣:១០ អស ៨:១០ ១៩:៣ យរ ១៩:៧

**៤:១៧–២១** គ្រប់ទាំងអំពើរបស់មនុស្ស គឺជាអំពើបាបតែព្រះមានឯកសិទ្ធិក្នុងការដាក់ទោសដល់ពួកគេ ។ លោកយ៉ូបគួរតែអរគុណចំពោះការកែតម្រង់របស់ព្រះដែលធ្វើចំពោះគាត់(មើល ៥:១៧–២៦ និងការពន្យល់) ។

**៤:១៨–១៩** មើល ១៥:១៥–១៦ ។

**៤:១៨** *ពួកបរិវារ* ក៏ដូចជាទេវតានោះដែរ ។

**៤:១៩** *ភាជនៈដី* គឺជាតួគ្រោងធ្វើពីដី(មើល ១០:៩ ៣៣:៦ មើលការពន្យល់ លប ២:៧)។ *ដូចជាដង្កូវ* គឺជាសញ្ញានៃភាពបាក់បែក(ប្រៀបធៀប ២៧:១៨) ។

**៤:២០** គឺបង្ហាញពីភាពរុះរោយទៅវិញ ជារូបភាពរស់រវើកនៅក្នុងជីវិតដ៏ខ្លីមួយ ។

**៤:២១** *ខ្សែជ្រែង* គឺជាកន្លែងស្នាក់នៅបណ្ដោះអាសន្ន ក៏ដូចជារូបរាងកាយមនុស្សទាំងមូល(មើល ២កថ ៥:១,៤ ២ពត ១:១៣ និងការពន្យល់) ។ *ឥតទាន់បានប្រាជ្ញា* (មើល ៦.២០) ។

**៥:១** *តើអ្នកនឹងបែរ ... ណាទៀត* គឺជារឿងដែលទាក់ទងនឹងព្រះអម្ចាស់ ។ គឺជាគំនិតអ្នកទូលអង្វរ ជាអ្នកដែលធ្វើជាអាជ្ញាកណ្ដាលរវាងព្រះអម្ចាស់ និងលោកយ៉ូប គឺជាការសំខាន់មួយក្នុងកណ្ឌគម្ពីរ(មើល ៩:៣៣ ១៦:១៩–២០ និងការពន្យល់មើលអត្ថបទខាងលើផងដែរ ១៩:២៥) បរិសុទ្ធណាទៀត ។ ទេវតាបរិសុទ្ធ គឺជាព្រះរាជបុត្រានៃព្រះ(មើលការពន្យល់ ១:៦ ២:១) ។

**៥:២** ពុំបានបញ្ជាក់ពីគាត់ទេ លោកអេលីផាសបានបញ្ជាក់ថា លោកបានប្រឆាំងនឹងព្រះដែលធ្វើឱ្យគ្រោះថ្នាក់ដល់គាត់ ។ *មនុស្សឆោតខ្លៅ* គឺជាអ្នកដែលពុំបានគិតពីព្រះ(មើលការពន្យល់ ២:១០ សភ ១:៧) ។

**៥:៣** *មនុស្សឥតបើគិតចាក់ឫសចុះ* គឺជាមនុស្សអាក្រក់បានទទួលភាពសុខសាន្តដូចដើមឈើចាក់ឫស(មើល ទដ ១:៣) ។

**៥:៦** គឺមិនដូចជារុក្ខជាតិតូចៗដែលព្រោះហើយនិងបានផល ។

**៥:៧** *មនុស្សកើតមកតែងមានសេចក្ដីវេទនា* គឺបញ្ជាក់ថាគ្មាននរណាសុចរិតចំពោះព្រះភក្ត្រទ្រង់(មើលការពន្យល់ ៤:១៧–២១ ១៣:២៨–១៤:១)។ លោកយ៉ូបគួរតែបញ្ឈប់ចរិតដូចមនុស្សឆ្កួតទៀត(មើល ៦.១–៧)ហើយគួរតែបន្ទាបខ្លួនគាត់ ។ ខណៈនោះហើយដែលព្រះប្រទានពរ (មើល ១៦)ផ្កាភ្លើង " កូនប្រុសរបស់ រេសែប "ក្នុងទន្លាប់ពួកកាណាន គឺរេសែប ជាព្រះនៃសេចក្ដីហិនវិនាស (កូនប្រុសរបស់រេសែប) ទដ ៧៨:៤៨ (ចទ ៣២:២៤ ហប ៣:៥) ។

**៥:៩** មើលក្នុង ៩:១០ ។

ដែលគេផ្ដើមធ្វើនោះឡើយ[យ] ១៣ទ្រង់ចាប់មនុស្សឆ្លៀតឆ្លាត[រ]
ដោយឧបាយរបស់ខ្លួនគេ[ល] ហើយក៏បង្អូចដំបូន្មានកោង
របស់មនុស្សវាងវៃ[វ] ១៤អ្នកទាំងនោះប្រទះនឹងសេចក្ដីងងឹត[ស]
នៅវេលាថ្ងៃ ហើយគេដើរស្ទាបៗនៅពេលថ្ងៃត្រង់ ដូចជា
នៅពេលយប់[ហ] ១៥តែទ្រង់ជួយឱ្យរួចពីដាវនៃមាត់គេ គឺជា
មនុស្សកំសត់ទុគ៌ត[ឡ] ឱ្យរួចពីកណ្ដាប់ដៃនៃមនុស្សខ្លាំងពូកែ[អ]
១៦យ៉ាងនោះមនុស្សក្រខ្សត់[ក]មានទីសង្ឃឹម ហើយសេចក្ដី
ទុច្ចរិតត្រូវបិទមាត់ទៅ[ខ] ។
១៧មើល សប្បាយហើយអ្នកណាដែលព្រះទ្រង់បានកែ
ឡើង[គ] ដូច្នេះ កុំឱ្យមើលងាយសេចក្ដីផ្ចាញ់ផ្ចាល[ឃ]របស់ព្រះ
ដ៏មានព្រះចេស្ដាបំផុតឡើយ[ង] ១៨ដ្បិតទ្រង់ធ្វើឱ្យមានរបួស
រួចក៏រុំឱ្យ[ច] ទ្រង់វាយកំទេច ហើយព្រះហស្តទ្រង់ក៏មើលឱ្យ
ជាឡើងវិញ[ឆ] ១៩ទ្រង់នឹងប្រោសឱ្យអ្នករួច[ជ]ពីសេចក្ដីវេទនា៦
មុខ អើ ដល់គំរប់៧ផង នោះសេចក្ដីអាក្រក់នឹងមិនមកពាល់
ប៉ះអ្នកឡើយ[ឈ] ២០នៅគ្រាអំណត់[ញ] ទ្រង់នឹងលោះអ្នកឱ្យរួចពី
សេចក្ដីស្លាប់ ហើយនៅគ្រាសឹកសង្គ្រាមឱ្យរួចពីអំណាចដាវ
ផង[ដ] ២១អ្នកនឹងបានលាក់កំបាំងពីរំពាត់នៃអណ្ដាតគេ[ឋ]
ហើយកាលគ្រោះថ្នាក់មកដល់[ឌ] នោះអ្នកមិនត្រូវខ្លាច[ឍ]
ឡើយ ២២អ្នកនឹងសើចឡក[ណ]ដល់គ្រោះថ្នាក់ និងគ្រាអំណត់[ត]
ហើយមិនខ្លាចសត្វកំណាចនៅផែនដីផង[ថ] ២៣ដ្បិតអ្នក និង
ថ្ម[ទ]នៅស្រែ នឹងបានជាមិត្រនឹងគ្នា[ធ] ហើយទាំងសត្វព្រៃនឹង
នៅជាមេត្រីនឹងអ្នកដែរ[ន] ២៤អ្នកនឹងបានទុកចិត្តថា លំនៅ
របស់អ្នកនឹងមានសេចក្ដីសុខ[ប] កាលអ្នកចេញទៅមើល
ក្រោលសត្វរបស់អ្នក នោះនឹងឃើញថាមិនខ្វះខាតអ្វីឡើយ[ផ]
២៥អ្នកនឹងឃើញពូជពង្សអ្នកចំរើនជាច្រើនឡើង[ព] ហើយកូន
ចៅអ្នកបានគ្នាច្រើន ដូចជាស្មៅនៅផែនដី[ភ] ២៦លុះអ្នកមាន
អាយុគ្រប់គ្រាន់ហើយ[ម] ទើបនឹងដល់មរណភាពទៅ ឧបមា
ដូចជាកណ្ដាប់ស្រូវ ដែលគេយកចូលមកត្រូវរដូវកាល[យ]
២៧នេះហើយ ជាសេចក្ដីដែលយើងបានស្ទង់មើលឱ្យដឹង
ហើយ ក៏ឃើញយ៉ាងនោះពិតមែន ដូច្នេះចូរអ្នកស្ដាប់[រ]
យកចុះ ហើយទទួល សំរាប់ជាប្រយោជន៍ដល់ខ្លួនផង[ល] ។

## លោកយ៉ូប

៦ ១នោះយ៉ូបលោកឆ្លើយឡើងថា ២ឱបើសេចក្ដីមួម៉ៅ
របស់ខ្ញុំបានថ្លឹងមើល ដោយដាក់នៅជញ្ជីង ជាមួយនឹង
សេចក្ដីទុក្ខលំបាករបស់ខ្ញុំទៅអេះ[ក] ៣នោះនឹងបានធ្ងន់ជាង

**៥:១២** យ យប ១២:២៣ ទដ ៧៨:៥៩ ១៤០:៨ **៥:១៣** រ យប ៣៧:២៤ អស ២៩:១៤ ៤៤:២៥ យរ ៨:៨ ១៨:១៨ ៥១:៥៧ ល យប ១៥:៥ ទដ ៣៦:៣ លក ២០:២៣ ១កថ ៣:១៩ ២កថ ១១:៣ អភ ៤:១៤ វ យប ៩:៤ ១៨:៧ សភ ២១:៣០ ២៩:៦ យរ ៨:៩ **៥:១៤** ស យប ១៥:២២,៣០ ១៨:៦,១៨ ២០:២៦ ២២:១១ ២៧:២០ អស ៨:២២ យហ ១២:៣៥ ហ ចទ ២៨:២៩ យប ១៨:៥ អម ៨:៩ **៥:១៥** ឡ នក ២២:២៣ យប ៨:៦ ២២:២៧ ៣៣:២៦ ៣៦:១៥ អ យប ៤:១០ ៣១:២២ **៥:១៦** ក យប ២០:១៩ ៣១:១៦ សភ ១៧:៥ ២២:២២ អស ១១:៤ ៤១:១៧ ៦១:១ ខ ទដ ៦៣:១១ ១០៧:៤២ រម ៣:១៩ **៥:១៧** គ ចទ ៨:៥ យប ៣៣:១៩៣៦:១០ សផ ៣:៧ យក ១:១២ ឃ ទដ ៩៤:១២ សភ ៣:១១ យរ ៣១:១៨ ង លប ១៧:១ យប ១៥:១១ ហព ១២:៥–១១ **៥:១៨** ច ទដ ១៤៧:៣ អស ៥៧:១៥ ៦១:១ ហស ៦:១ ឆ ចទ ៣២:៣៩ **៥:១៩** ជ ដយ ៣:១៧ ៦:១៦ ឈ ទដ ៣៤:១៩ ៩១:១០ សភ ៣:២៥–២៦ ២៤:១៥–១៦ **៥:២០** ញ ខ.២២ ទដ ៣៣:១៩ ៣៧:១៩ ដ ទដ ២២:២០ ៩១:៧ ១៤០:៧ ១៤៤:១០ យរ ៣៩:១៨ **៥:២១** ឋ ទដ ១២:២–៤ ៣១:២០ ឌ ខ.១៥ ឍ ទដ ២៣:៤ ២៧:១ ៩១:៥ **៥:២២** ណ យប ៨:២១ ៣៩:៧,១៨,២២ ៤១:២៩ ត ខ.២០ ថ លវ ២៥:១៨ ទដ ៩១:១៣ ហស ២:១៨ មក ១:១៣ **៥:២៣** ធ ២ពវ ៣:១៩,២៥ ទដ ៩១:១២ មថ ១៣:៨ ន អស ២៨:១៥ ហស ២:១៨ ប យប ៤០:២០ អស ១១:៦–៩ ៦៥:២៥ អក ៣៤:២៥ **៥:២៤** ផ យប ១២:៦ ២១:៩ ព យប ៨:៦ ២២:២៣ **៥:២៥** ភ ចទ ២៨:៤ ទដ ១១២:២ ម ទដ ៧២:១៦ អស ៤៤:៣–៤ ៤៨:១៩ **៥:២៦** យ លប ១៥:១៥ ចទ ១១:២១ សស ៨:១៣ រ សភ ៣:២១–២៦ **៥:២៧** ល យប ៣២:១០,១៧ វ យប ៨:៥ ១១:១៣ ២២:២៧ **៦:២** ក យប ៣១:៦ សភ ១១:១ ដយ ៥:២៧

**៥:១៣** គឺជាសេចក្ដីសំរងក្នុងកណ្ឌគម្ពីរ ១កថ ៣:១៩ ហើយជាសេចក្ដីបញ្ជាក់របស់គម្ពីរយ៉ូប ។

**៥:១៧–២៦** គឺជាបទទំនុកនាំមុខ (ខ.៨–១៦) ដែលសម្ដែងពីភាពបរិសុទ្ធរបស់ព្រះ ហើយកំណាព្យនេះ ក៏សម្ដែងពីព្រះពរដែលទ្រង់ប្រទានឱ្យអ្នកដែលព្រះបានកែតម្រង់ (មើល សភ ១:២,៧ ៣:១២ និងការពន្យល់ ៥:១២ ២៣:១៣,២៣) ។ *អេលីផាស* មានជំនឿថាការដាក់វិន័យតម្រង់ គឺមានលក្ខណៈបណ្ដោះអាសន្នប៉ុណ្ណោះ តែនិងនាំមកការប្រោសលោះជាក្រោយវិញ (ខ.១៨) ហើយអ្នកដែលបានប្រព្រឹត្តល្អនឹងបាននូវការបាត់បង់ ហើយកូនគាត់ក៏បានស្លាប់ គឺជាពាក្យទាក់ទងនិងសន្តិសុខ (ខ.២៤) និងកូន (ខ.២៥) ។

**៥:១៧** *ព្រះចេស្ដា* យើងឃើញពាក្យនេះលេចមក ៣១ដង គឺឃើញលើកទី១ដែលប្រើក្នុងគម្ពីរយ៉ូប (មើល ១៧:១) ។

**៥:១៨–១៩** មើល ហស ៦:១–២ ។

**៥:១៩** *សេចក្ដីវេទនា៦មុខ . . . ៧ផង* មើល ៣៣:២៩ ៤០:៥ សភ ៦:១៦ និងការពន្យល់ ៣០:១៥,១៨,២១,២៩ សស ១១:២ អម ១:៣ និងការពន្យល់ ៦,៩,១១,១៣ ២:១,៤,៦ និងការពន្យល់ សូមចំណាំក៏មានគំរូខ្លះមិនបានបង្ហាញចំៗទេ តែគេក៏បកស្រាយតាមរយៈកំណាព្យជាច្រើន ។

**៥:២៣** *ថ្ម* គឺជារបៀបប្រៀបធៀបពីពាក្យសំដីដែលបង្ហាញថាថ្ម "គឺសន្តិភាពក្នុងអ្នក" ដែលមិនត្រូវខូចខាតឡើយ (មើល ២ពវ ៣:១៩ អស ៥:២ មថ ១៣:៥) ។

**៥:២៥** *ដូចជាស្មៅនៅផែនដី* គឺច្រើនដូចជាធូលីដី និងស្មៅនៅលើផែនដី (មើលការពន្យល់ ១៣:១៦) ។

**៥:២៦** ពាក្យរបស់លោកអេលីផាស គឺមានភាពត្រឹមត្រូវហួសពីការស្មានរបស់គាត់ទៅទៀត (មើល ៤២:១៦–១៧) ។

**៥:២៧** *សំរាប់ជាប្រយោជន៍ដល់ខ្លួនផង* ការសរុបចុងក្រោយរបស់លោកអេលីផាស ថាលោកយ៉ូបគួរតែងាកបែរចេញពីភាពមិនសុចរិត (៤:៧) ដូចជាការត្អូញត្អែរប្រឆាំងនឹងព្រះ (ខ.២) ដើម្បីបន្ទាបខ្លួន (ខ.១១) ហើយព្រមទទួលការដាក់វិន័យសុចរិតរបស់ព្រះ (ខ.១៧) ។ គោលបំណងរបស់លោកអេលីផាស គឺផ្ដល់ឱ្យនូវការកម្សាន្តចិត្តខាងទេវសាស្ត្រ និងពិគ្រោះយោបល់ចំពោះយ៉ូប (២:១១) ប៉ុន្តែធ្វើឱ្យលោកយ៉ូបរបួសស្នាមដោយធ្វើការចោទប្រកាន់ខុសឆ្គងទៅវិញ ។

**៦:២–៣** លោកយ៉ូបបានសម្ដែងពីការយល់ដឹង ដែលគួរឱ្យអាណិតចំពោះពាក្យពេចន៍ពុំល្អដែលគាត់និយាយក្នុងជំពូក ៣ ។

ខ្សាច់[ខ]សមុទ្រទៅទៀត គឺហេតុនោះបានជាពាក្យខ្ញុំ បាន
ជ្រួសហួសទៅ[គ] ៤ពីព្រោះព្រួញ[ឃ]របស់ព្រះដ៏មានគ្រប់ព្រះ
ចេស្តា[ង]នៅជាប់ក្នុងខ្លួនខ្ញុំ[ច] វិញ្ញាណខ្ញុំក៏អកផឹក[ឆ]ថ្នាំពិស[ជ]
នៃព្រួញទាំងនោះទៅ អស់ទាំងសេចក្ដីស្ញែងខ្លាច[ឈ]របស់
ព្រះបានដំរៀបគ្នាទាស់នឹងខ្ញុំហើយ[ញ] ៥បើលាព្រៃ[ដ]មាន
ស្មៅស៊ី តើវាស្រែកដែរឬ[ឋ] តើគោរោទ៍កំពុងដែលស៊ី
ចំបើងឬ[ឌ] ៦ឯរបស់ដែលគ្មានរសជាតិ តើនឹងបរិភោគឥត
អំបិលបានឬទេ តើសរបស់ពងមានរសឬទេ[ឍ] ៧សេចក្ដី
ដែលចិត្តខ្ញុំមិនព្រមប៉ះពាល់ នោះទុកដូចជាអាហារដែល
គួរឆ្អើមដល់ខ្ញុំ[ណ]។
៨ឱបើសិនជាខ្ញុំនឹងបានដូចសេចក្ដីសំណូម ហើយព្រះ
នឹងប្រោសប្រទានឱ្យខ្ញុំបាន តាមបំណងចិត្តទៅអេះ[ត] ៩គឺឱ្យ
ព្រះបានសព្វព្រះហឫទ័យនឹងកិនកំទេច[ថ]ខ្ញុំទៅ ហើយគ្រវី
ព្រះហស្តទ្រង់ ឱ្យខ្ញុំត្រូវកាត់ដាច់ចេញ[ទ] ១០យ៉ាងនោះខ្ញុំនឹង
នៅមានសេចក្ដីរដោះទុក្ខ[ធ] ខ្ញុំនឹងមានសេចក្ដីរីករាយក្នុង
សេចក្ដីឈឺចាប់នេះ[ន] ដែលមិនចេះប្រណីសោះ ពីព្រោះខ្ញុំ
មិនបានលាក់ទុកព្រះបន្ទូល[ប]នៃព្រះដ៏បរិសុទ្ធឡើយ[ផ] ១១តើ
កំឡាំងខ្ញុំជាអ្វី ដែលខ្ញុំនឹងនៅចាំទៀត តើចុងបំផុតខ្ញុំជា
យ៉ាងណា បានជាត្រូវឱ្យទ្រាំអត់[ព] ១២តើកំឡាំងខ្ញុំជាកំឡាំង
នៃថ្មឬអី ឯសាច់ខ្ញុំ តើជាលង្ហិនដែរឬ[ភ] ១៣នេះតើមិនមែន
ដោយព្រោះគ្មានទីពឹងក្នុងខ្លួនខ្ញុំទេឬ[ម] ហើយប្រាជ្ញា ក៏បាន
ត្រូវបណ្ដេញឆ្ងាយពីខ្ញុំដែរឬ ។
១៤ឯអ្នកណាដែលកំពុងតែរងទុក្ខវេទនា[យ] នោះគួរឱ្យ
មិត្រសំឡាញ់[រ]ខ្លួនសំដែងសេចក្ដីអាណិតអាសូរដែរ[ល] ទោះ
បើជាអ្នកដែលលែងកោតខ្លាច ដល់ព្រះដ៏មានគ្រប់ព្រះ
ចេស្ដាក៏ដោយ[វ] ១៥ឯបងប្អូនខ្ញុំវិញ គេបានប្រព្រឹត្តដោយចិត្ត
វៀចដូចជាជ្រោះទឹក[ស] គឺដូចជាបាតនៃជ្រោះទឹកដែលបាត់
អស់ទៅ ១៦ជាទឹកដែលមើលទៅខ្មៅៗ ដោយព្រោះកក
ហើយក៏មានហិមៈនៅកប់ក្នុងនោះដែរ[ហ] ១៧លុះមានពេល
ក្ដៅក៏រលាយទៅ រួចដល់រដូវក្ដៅ[ឡ] ទឹកនោះរីងបាត់ពី
កន្លែងអស់រលីង ១៨ពួកដំណើរដែលដើរតាមផ្លូវនោះក៏
បែរចេញ គេកប់បាត់ទៅក្នុងទីរហោស្ថាន ហើយត្រូវ
វិនាសសូន្យទៅ ១៩ពួកដំណើរសាសន៍ថេម៉ាន[អ] គេដើរមក
រក ពួកសាសន៍សេបា[ក]ក៏ទន្ទឹងចាំ ២០គេមានសេចក្ដីខ្មាស
ដោយព្រោះបានទុកចិត្ត គេបានទៅដល់ទីនោះ តែត្រូវ
ទាល់បើគិត[ខ] ២១គឺអ្នករាល់គ្នាយ៉ាងនោះឯង អ្នករាល់គ្នា
ឃើញសេចក្ដីវេទនារបស់ខ្ញុំ ហើយក៏ស្លុតក្នុងចិត្ត[គ] ២២តើខ្ញុំ
បានថា សូមមេត្តាឱ្យអ្វីមកខ្ញុំ ឬថា សូមយកទ្រព្យសម្បត្តិខ្លះ
របស់អ្នក[ឃ]ថ្វាយជាដង្វាយ[ង]ឱ្យខ្ញុំផងឬអី ២៣តើបានថា សូម
ជួយឱ្យខ្ញុំរួចពីកណ្ដាប់ដៃនៃពួកសត្រូវ ឬថា សូមលោះខ្ញុំពី
កណ្ដាប់ដៃនៃអ្នកដែលសង្កត់សង្កិនឬអី[ច] ។
២៤សូមបង្រៀនខ្ញុំចុះ នោះខ្ញុំនឹងឈប់និយាយហើយ[ឆ]
សូមពន្យល់ឱ្យខ្ញុំដឹងជាបានធ្វើខុសឆ្គងអ្វី[ជ] ២៥ពាក្យសំដីត្រឹម
ត្រូវ នោះពូកែបណ្ដាលយ៉ាងណាហ្ន៎[ឈ] តែសេចក្ដីបន្ទោស
របស់អ្នករាល់គ្នា បានបន្ទោសអ្វីខ្លះ ២៦ដែលឃើញថា
ពាក្យរបស់មនុស្សឥតសង្ឃឹមជាខ្យល់ទទេ[ញ] នោះតើអ្នកគិត
បន្ទោសដល់ពាក្យសំដីឬអី ២៧អើ អ្នករាល់គ្នាគ្របសង្កត់[ដ]

**៦:៣** ខ ១ពារ ៤:២៩ សភ ២៧:៣ គ ខ.១១,២៦ យប ៧:១១ ១៦:៦ ២១:៤ ២៣:២ **៦:៤** ឃ ចទ ៣២:២៣ ទដ ៣៨:២ ង លប ១៧:១ ច យប ៧:២០ ១៦:១២,១៣ ១៩:១២ បទ ៣:១២ ឆ យប ២១:២០ ជ ចទ ៣២:៣២ យប ៣០:២១ ៣៤:៦ យរ ១៥:១៨ ៣០:១២ ឈ យប ៩:៣៤ ១៣:២១ ១៨:១១ ២៣:៦ ២៧:២០ ៣០:១៥ ៣៣:១៦ ញ យប ៣:២៣ ទដ ៨៨:១៥–១៨ **៦:៥** ដ លប ១៦:១២ ឋ យប ៣០:៧ ឌ យប ២៤:៦ អស ៣០:២៤ **៦:៦** ឍ យប ៣៣:២០ ទដ ១០៧:១៨ **៦:៧** ណ យប ៣:២៤ **៦:៨** ត យប ១៤:១៣ **៦:៩** ថ យប ១៩:២ ទ ជន ១១:១៥ ទដ ៣១:២២ **៦:១០** ធ យប ២:១១ ១៥:១១ ទដ ៩៤:១៩ ន ទដ ៣៨:១៧ យរ ៤:១៩ ៤៥:៣ ប យប ២២:២២ ២៣:១២ ទដ ១១៩:១០២ មក ៨:៣៨ ផ លវ ១១:៤៤ ២ពារ ១៩:២២ អស ៣១:១ **៦:១១** ព ខ.៣ **៦:១២** ភ យប ២៦:២ **៦:១៣** ម យប ២៦:២ **៦:១៤** យ យប ៤:៥ រ យប ១២:៤ ១៧:២,៦ ១៩:១៩,២១ ២១:៣ ៣០:១,១០ ទដ ៣៨:១១ ៦៩:២០ ១យហ ៣:១៧ ល ១សយ ២០:៤២ យប ១៥:៤ វ លប ១៧:១ **៦:១៥** ស យប ១៣:៤ ១៦:២ ២១:៣៤ ទដ ២២:១ ៣៨:១១ យរ ១៥:១៨ **៦:១៦** ហ ទដ ១៤៧:១៨ **៦:១៧** ឡ យប ២៤:១៩ **៦:១៩** អ លប ២៥:១៥ ក លប ១០:៧,២៨ **៦:២០** ខ យរ ១៤:៣ យអ ១:១១ **៦:២១** គ ទដ ៣៨:១១ **៦:២២** ឃ យរ ១៥:១០ ង ជន ៣៥:៣១ យប ៣៣:២៤ ទដ ៤៩:៧ **៦:២៣** ច ២ពារ ១៩:១៩ **៦:២៤** ឆ យប ២:១០ ៣៣:៣៣ ទដ ៣៩:១ ១៤១:៣ សភ ១០:១៩ ១១:១២ ១៧:២៧ សស ៥:២ ជ យប ១៩:៤ **៦:២៥** ឈ សស ១២:១១ អស ២២:២៣ **៦:២៦** ញ ខ.៣ លប ៤១:៦ យប ៨:២ ១៥:៣ ១៦:៣ យរ ៥:១៣ **៦:២៧** ដ អគ ២៤:៦ យអ ៣:៣ អប ១:១១ ណហ ៣:១០

**៦:៤** មានគ្រប់ព្រះចេស្ដា លោកយ៉ូបបានចែកចាយពីព្រះទេវសាស្ត្របុរាណនិយមរបស់លោកអេលីផាស និងសេចក្ដីជំនឿដែលព្រះកាត់ទោសគាត់ពុំបានដឹងហេតុ(មើល ៧:២០ ការពន្យល់ ១៦:១២–១៣ មើល ពទ ៣:១២ ធៀបនឹង ចទ ៣២:២៣ ទដ ៧:១៣ ៣៨:២) ។

**៦:៥–៦** លោកយ៉ូបបានប្រកាសសិទ្ធិផ្ទាល់ខ្លួន ដោយស្រែកទ្រហូរជាខ្លាំងខណៈពេលដែលគាត់មានដំបៅជាច្រើនដោយព្រះអម្ចាស់ ហើយបានទទួលទានអាហារឥតរសជាតិ(ពាក្យសំដី)ពីមិត្តភក្តិរបស់គាត់ ។

**៦:៨–៩** លោកយ៉ូបរំលឹកពីការដែលចិត្តបានទន្ទិចតាមរយៈ ៣:២០–២៦ ។

**៦:១០** *យ៉ាងនោះ* ក្នុងជីវិតថ្ងៃខាងមុខ លោកយ៉ូបមានសេចក្ដីអំណរនិងនៅតែមានសេចក្ដីពិតជាមួយព្រះអម្ចាស់ ។

**៦:១១–១៣** ដោយឥតមានប្រភពមនុស្សនៅសល់ លោកយ៉ូបបានគិតថាលក្ខខ័ណ្ឌរបស់លោកគឺសេចក្ដីអស់សង្ឃឹម ។

**៦:១១** *ទ្រាំអត់* មើលការពន្យល់ ៩:២–៣ ។

**៦:១៤–១៧** លោកយ៉ូបត្រូវជិនួយខាងឯព្រះវិញ្ញាណ តែមិត្តរបស់លោកផ្ដល់មកនូវភាពពុំអាចពឹងពាក់បាន (ប្រៀបធៀប ៦:១) ។

**៦:១៥** *បងប្អូន* ដោយហៅមិត្តរបស់លោកថាជា "បងប្អូនវិញ" លោកយ៉ូបមានជំហរយ៉ាងរឹងមាំ ។

**៦:១៩** *សាសន៍ថេម៉ាន* មើលការពន្យល់ អស ២១:១៤ ពួកសាសន៍សេបា មើលការពន្យល់ ១:១៥ ។

**៦:២២–២៣** លោកយ៉ូបពុំបានសុំឱ្យពួកគេជួយអ្វីសោះ លើកលែងតែការងារណាដែលមានប៉ះពាល់ដល់រូបគេ : គឺជាមិត្តភាពរបស់គេ និងការប្រឹក្សាយោបល់ ។

**៦:២៥** *ពាក្យសំដីត្រឹមត្រូវ* លោកយ៉ូបចង់សំដៅទៅលើពាក្យផ្ទាល់ខ្លួនគាត់ ។

**៦:២៦** *ខ្យល់* មើល ៨:២ ។

លើពួកកំព្រា[ឋ] ហើយធ្វើទុក្ខបៀតបៀនដល់មិត្រសំឡាញ់ខ្លួន
ផង ២៨ដូច្នេះ ឥឡូវនេះ សុំអ្នករាល់គ្នាមើលមកខ្ញុំ ឱ្យពេញ
ភ្នែកចុះ ដ្បិតខ្ញុំមិនហ៊ានកុហកប្រទល់មុខនឹងអ្នករាល់គ្នាទេ[ឌ]
២៩សូមឱ្យអ្នកគិតជាថ្មីវិញចុះ កុំឱ្យមានសេចក្តីអយុត្តិធម៌
ឡើយ[ឍ] អើ សូមត្រឡប់មកគិតជាថ្មីឡើងវិញចុះដំណើរខ្ញុំ
នៅខាងសេចក្តីសុចរិត[ណ]ទេ[ត] ៣០តើមានសេចក្តីទុច្ចរិតណា
នៅអណ្តាតខ្ញុំឬ[ថ] តើខ្ញុំមិនចេះភ្លក់ដឹង[ទ]សេចក្តីខូចកាចទេ
ឬអី ។

**៧** ១តើគ្មានពេលកេណ្ឌមនុស្ស[ក] ដែលនៅផែនដីទេឬ[ខ] តើ
ជីវិតគេមិនមែនដូចជាជីវិតនៃអ្នកស៊ីឈ្នួលទេឬអី[គ] ២បែប
ដូចជាអ្នកបំរើ ដែលទន្ទឹមចាំពេលងងឹត[ឃ] ហើយដូចជាអ្នក
ស៊ីឈ្នួល ដែលចាំតែបើកប្រាក់ឈ្នួល[ង] ៣គឺយ៉ាងនោះដែល
ការរងវេទនាបានចែកដល់ខ្ញុំទាំងខែៗ ហើយខ្ញុំក៏ប្រកប
ដោយសេចក្តីនឿយហត់រាល់តែយប់[ច] ៤កាលណាខ្ញុំទៅ
ដេក នោះខ្ញុំតែងតែនឹកថា តើកាលណានឹងដល់វេលា
ក្រោយឡើង[ឆ] កាលណាហ្ន៎បានវេលាយប់នឹងអស់ទៅ ខ្ញុំក៏
ចេះតែប្លាក់ខ្លួនទៅមកដរាបដល់ភ្លឺឡើង[ជ] ៥សាច់ខ្ញុំស្លៀក
ពាក់ដោយដង្កូវ[ឈ] និងក្រមរធូលីដី ស្បែកខ្ញុំធ្លាយមក
ហើយក៏គួរខ្ពើម[ញ] ៦អស់ទាំងថ្ងៃអាយុរបស់ខ្ញុំ លឿនជាង
ត្រល់ដំបាញផង[ដ] ហើយក៏កន្លងទៅ ឥតមានទីសង្ឃឹម
ឡើយ[ឋ] ។

៧ឱព្រះអើយ សូមនឹកចាំថា ជីវិតទូលបង្គំជាខ្យល់ទទេ[ឌ]
ភ្នែកទូលបង្គំនឹងមិនដែលឃើញសេចក្តីល្អទៀត[ឍ] ៨ឯភ្នែក
ពួកអ្នកដែលធ្លាប់ឃើញទូលបង្គំ នោះនឹងមិនឃើញទៀត
ឡើយ ព្រះនេត្រនៃទ្រង់នឹងទតមកលើទូលបង្គំ តែទូលបង្គំ
មិនមានទៀតទេ[ណ] ៩អ្នកណាដែលចុះទៅឯស្ថានឃុំព្រលឹង
មនុស្សស្លាប់[ត] នោះនឹងមិនដែលឡើងមកវិញឡើយ[ថ] ឧបមា
ដូចជាពពកដែលរលាយទៅ[ទ] ហើយមើលមិនឃើញទៀត
១០អ្នកនោះនឹងមិនដែលត្រឡប់មកឯផ្ទះខ្លួនទៀតឡើយ ទី
កន្លែង[ធ]របស់គេក៏នឹងលែងស្គាល់គេផង[ន] ១១ហេតុនោះ
ទូលបង្គំនឹងមិនទប់មាត់[ប] គឺទូលបង្គំនឹងនិយាយដោយសេចក្តី
វេទនា[ផ] ក្នុងវិញ្ញាណទូលបង្គំ ហើយនិងត្អូញត្អែរ[ព]ដោយ
សេចក្តីជូរចត់ នៅក្នុងចិត្តទូលបង្គំដែរ[ភ] ១២តើខ្ញុំជាសមុទ្រ[ម]
ឬជាសត្វសំបើមនៅក្នុងសមុទ្រឬអី[យ] បានជាទ្រង់តាំងយាម
ឱ្យមើលទូលបង្គំ[រ] ១៣កាលណាទូលបង្គំនឹកថា គ្រែរបស់ទូល
បង្គំនឹងជួយរំសាយទុក្ខ ដំណោកទូលបង្គំនឹងកំសាន្តសេចក្តី
តប់ប្រមល់ទៅ[ល] ១៤នោះទ្រង់បណ្តាលឱ្យទូលបង្គំខ្លាច ដោយ
ពន្យល់សប្តិវិញ ហើយបំភ័យ[វ]ទូលបង្គំ ដោយការជាក់ស្តែង

**៦:២៧** ឋ នក ២២:២២,២៤ យប ៣១:១៧, អស ១០:២ **៦:២៨** ឌ យអ ៩:១៥ ២៤:២៥ ២៧:៤ ៣២:១០ ៣៣:១,៣ ៣៤:៦ ៣៦:៣,៤ **៦:២៩** ឍ យប ១៩:៦ ២៧:២ ៤០:៨ អស ៤០:២៧ ណ យប ២:៣ ត យប ៩:២១ ១០:៧ ១១:២ ១២:៤ ២៣:៧,១០ ៣៣:៩,៣២ ៣៤:៥,៣៦ ៣៥:២ ៤២:៦ ទដ ៦៦:១០ សក ១៣:៩ **៦:៣០** ថ យប ២៧:៤ ទ យប ១២:១១ **៧:១** ក យប ១៤:១៤ អស ៤០:២ ខ យប ៥:៧ គ លវ ២៥:៥០ **៧:២** ឃ យប ១៤:១ សស ២:២៣ ង លវ ១៩:១៣ យប ១៤:៦ **៧:៣** ច យប ១៦:៧ ទដ ៦:៦ ៤២:៣ ៥៦:៨ សស ៤:១ អស ១៦:៩ យរ ៩:១ បទ ១:២,១៦ **៧:៤** ឆ ចទ ២៨:៦៧ ជ ខ.១៣–១៤ **៧:៥** ឈ យប ១៧:១៤ ២១:២៦ ២៤:២០ ២៥:៦ អស ១៤:១១ ញ ចទ ២៨:៣៥ **៧:៦** ដ យប ៩:២៥ ទដ ៣៩:៥ អស ៣៨:១២ ឋ យប ១៣:១៥ ១៤:១៩ ១៧:១១,១៥ ១៩:១០ ទដ ៣៧:៤ ៥២:៩ **៧:៧** ឌ ខ.១៦ លប ២៧:៤៦ ទដ ៣៩:៤,៥,១១ ៦២:៩ ៧៨:៣៩ ៨៩:៤៧ ១៤៤:៤ សស ៧:១៥ យក ៤:១៤ ឍ យប ១០:២០ **៧:៨** ណ យប ៣:១៣ ៨:១៨ ១៥:២៩ ២០:៧,៩,២១ ២៧:១៧ ទដ ៣៧:៣៦ ១០៣:១៦ អស ៤១:១២ យហ ១៦:១៦ កច ២០:២៥ **៧:៩** ត យប ៣:១៣ ១១:៨ ១៤:១៣ ១៧:១៦ ២៦:៦ ៣៨:១៧ អម ៩:២ ថ ២សយ ១២:២៣ ទ យប ៣:២៥ **៧:១០** ធ យប ១៨:២១ ២១:១៨ ២៧:២១,២៣ ទដ ៥៨:៩ យរ ១៨:១៧ ១៩:៨ ន ខ.៨ ទដ ៣៧:១០ ១០៤:៣៥ **៧:១១** ប យប ៩:៣៥ ១៣:១៣ ទដ ២២:២ ៤០:៩ ផ យប ១០:១ ទដ ៦:៣ អស ៣៨:១៥,១៧ ព ខ.១៣ យប ៩:២៧ ២១:៤ ២៣:២ ភ ១សយ ១:១០ យប ៦:៣ **៧:១២** ម យប ៣៨:៨–១១ យ លប ១:២១ រ ខ.២០ អស ១:១៤ **៧:១៣** ល ខ.១១ **៧:១៤** វ យប ៩:៣៤

**៦:២៧** ក្នុងសេចក្តីបន្ថែមលោកយ៉ូបចំពោះការពុំស្មោះត្រង់ លោកយ៉ូបចោទប្រកាន់មិត្តរបស់លោកចំពោះភាពឃោរឃៅដែលមានក្នុងចិត្ត ។

**៦:២៩** លោកយ៉ូបបានបន្ទន់ពាក្យសំដីរបស់គាត់ ដើម្បីឱ្យមិត្តរបស់គាត់ដែលចោទប្រកាន់ខុសឱ្យងាកបែរមករកគាត់វិញលែងរករឿងគាត់ ។

**៧:១–២១** បានឆ្លើយតបទៅលោកអេលីផាស គឺឥឡូវលោកយ៉ូបបានបង្ហាញពីការរអ៊ូរបស់គាត់ដល់ព្រះអម្ចាស់ ។

**៧:១** *ជីវិតនៃអ្នកស៊ីឈ្នួល* មើល ១៤:១៤ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះ ជួនកាលបញ្ជាក់ពីការបម្រើយោធា ។ ប្រើសម្រាប់ពោលសំអាងទៅលើការនិរទេសរបស់សាសន៍បាប៊ីឡូន (អស ៤០:២ និងការពន្យល់) ។

**៧:២** *ចាំពេលងងឹត* គឺជាការចុងបញ្ចប់ពេលធ្វើការ ។

**៧:៧** *ជីវិតទូលបង្គំជាខ្យល់* ក្នុងនាមដែលជាអ្នកទទួលការឈឺចាប់រ៉ាំរ៉ៃដែលលោកបានបាត់បង់នូវឧត្តមគតិសម្រាប់ទិសដៅនៃជីវិត (មើល ខ.៣ ទដ ១៤៤:៣–៤) ។ គាត់ពុំមានសង្ឃឹមថានឹងបានប្រោសលោះជាពីជំងឺ និងមើលឃើញសេចក្តីស្លាប់ថាផ្លូវតែមួយដែលអាចរួចពីការឈឺចាប់នោះ ។

**៧:៨** *ធ្លាប់ឃើញ . . . មិនមានទៀតទេ* មើល ខ.១២ ។

**៧:៩** *អ្នកណាដែលចុះនៅស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះនឹងមិនដែលឡើងមកវិញឡើយ* ជាផ្នែកនៃហេតុការណ៍ជាទៅលើការអង្កេតរួមមួយ គឺមិនមែនមានន័យថា យកគំនិតតាមតែខ្លួនគិតឃើញនូវអ្វីដែលបានកើតឡើងបន្ទាប់ពីសេចក្តីស្លាប់មានមក ។ តាមការពណ៌នាអ្នកនៅតំបន់ចន្លោះទន្លេថាវាជាស្ថានខាងក្រោមដី "ជាទីកន្លែងមិនអាចវិលវិញបាន" មើលការពន្យល់ ខ.២១ ។ ចំពោះទស្សនៈនៃសញ្ញាចាស់ស្តីពីជីវិត បន្ទាប់ពីបានស្លាប់ហើយនោះ សូមមើល ទដ ៦:៥ និងការពន្យល់ ។

**៧:១១** *នឹងមិនទប់មាត់* លោកយ៉ូបថានឹងឃំជាថ្មីទៀតក្នុងពេលវត្តមានព្រះដែលមានភាពអយុត្តធម៌ តែទ្រង់ហាក់ដូចជាពុំបោះបង់លោកយ៉ូបទេ (ខ.១៧–២០) ។ *និយាយដោយសេចក្តីវេទនា* មើល យរ៤:១៩ ។ *សេចក្តីជូរចត់* មើល ១០:៣១ និងការពន្យល់ ២១:៣២,៥ ២៧:៣២ ។

**៧:១២** *សមុទ្រឬជាសត្វសំបើមនៅក្នុងសមុទ្រ* មើល ៣ះ ។ ជាសត្វសំបើមនៅក្នុងទឹកដែលជាតំណាងសញ្ញានូវភាពអាសន្ន ឬការច្របូកច្របល់ (មើល ទដ ៧:៣,១៣–១៤ និងការពន្យល់ អស ២៧:១ និងការពន្យល់ គោលបំណងលោកយ៉ូបត្រូវបានគំរាមកំហែងដូច្នេះដែរ ។

ផង[ស] ១៥បានជាចិត្តនៃទូលបង្គំស៊ូស្លាប់[ហ] ដោយច្របាច់ក
ហើយក៏រើសយកសេចក្ដីស្លាប់ជាជាងឆ្អឹងទាំងនេះ[ឡ] ១៦ទូល
បង្គំខ្ពើមជីវិតណាស់[អ] ទូលបង្គំនឹងមិនរស់ជាដរាបទេ[ក] ដូច្នេះ
សូមទុកឱ្យទូលបង្គំចុះ[ខ] ដ្បិតអស់ទាំងថ្ងៃអាយុរបស់ទូលបង្គំ
ជាអសារឥតការទទេ[គ] ១៧តើមនុស្សជាអ្វី ដែលទ្រង់នឹង
រវល់ដល់គេ ហើយតាំងព្រះហឫទ័យនឹកពីគេ[ឃ] ១៨ព្រម
ទាំងមកសួរគេរាល់តែព្រឹក[ង] ហើយល្បងល[ច] គេរាល់វេលា
ដូច្នេះ[ឆ] ១៩តើដល់កាលណាទើបទ្រង់បែរព្រះនេត្រចេញពី
ទូលបង្គំ[ជ] ហើយមិនទុកទូលបង្គំតែឯង ល្មមតែឱ្យលេបទឹក
មាត់បានផង[ឈ] ២០ឱព្រះដ៏ចាំយាមមនុស្សអើយ បើទូលបង្គំ
បានធ្វើបាប នោះតើទូលបង្គំត្រូវធ្វើអ្វីដល់ទ្រង់[ញ] ហេតុអ្វី
បានជាទ្រង់បានដាក់ទូលបង្គំទុកដូចជាទីបាញ់វង់របស់
ទ្រង់[ដ] ដល់ម្ល៉េះបានជាទូលបង្គំជាបន្ទុកធ្ងន់ដល់ខ្លួនទូលបង្គំ
ផង[ឋ] ២១ហេតុអ្វីបានជាទ្រង់មិនអត់ទោសចំពោះសេចក្ដី
រំលងរបស់ទូលបង្គំ[ឌ] ហើយដោះសេចក្ដីទុច្ចរិតរបស់ទូល
បង្គំចេញ ដ្បិតទូលបង្គំនឹងដេកទៅក្នុងធូលីដីឥឡូវ[ឍ] នោះ
ទ្រង់នឹងស្វែងរកទូលបង្គំ តែទូលបង្គំមិនមានទៀតទេ[ណ]។

## លោកប៊ីលដាឌ

**៨** ១នោះប៊ីលដាឌ សាសន៍ស៊ូអា[ក] គាត់ឆ្លើយឡើងថា ២តើ
អ្នកនឹងពោលសេចក្ដីយ៉ាងដូច្នេះ[ខ] ដល់កាលណាទៀត ព្រម
ទាំងបញ្ចេញវាចាដូចជាខ្យល់ព្យុះដូច្នេះ[គ] ៣តើព្រះទ្រង់
ដែលបង្វែរសេចក្ដីយុត្តិធម៌ចេញឬទេ[ឃ] តើព្រះដ៏មានគ្រប់
ព្រះចេស្ដា ទ្រង់ដែលបង្វែរសេចក្ដីសុចរិតដែរឬ[ង] ៤បើសិន
ជាកូនទាំងឡាយរបស់អ្នកបានធ្វើបាបនឹងទ្រង់ ហើយទ្រង់
បានប្រគល់វា ទៅក្នុងអំណាចនៃសេចក្ដីកំហុសរបស់វា[ច]
៥បើអ្នកនឹងស្វែងរកព្រះអស់ពីចិត្ត ហើយទូលអង្វរ[ឆ]ដល់
ព្រះដ៏មានគ្រប់ព្រះចេស្ដា[ជ] ៦បើខ្លួនអ្នកក៏បរិសុទ្ធ ហើយ
ទៀងត្រង់ នោះពិតប្រាកដជាទ្រង់នឹងតើនឡើងជួយដល់
អ្នក[ឈ] ព្រមទាំងប្រោសឱ្យទីលំនៅដ៏សុចរិតរបស់អ្នកបាន
ប្រកបដោយសេចក្ដីចំរើនផង[ញ] ៧យ៉ាងនោះ ទោះបើខាង
ដើមនៃអ្នកបានតូចទាបក៏ដោយ គង់តែដល់ចុងបំផុតអ្នក
នឹងបានចំរើន[ដ]ជាធំឡើង[ឋ]។
៨ចូរស៊ើបសួររកពីដំណមនុស្សដែលកន្លងទៅហើយ[ឌ]
ត្រូវឱ្យយកចិត្តទុកដាក់នឹងសេចក្ដី ដែលពួកឰយុកោគេបាន
ស្វែងរកឱ្យចេះចុះ ៩ដ្បិតយើងរាល់គ្នាទើបតែនឹងកើតមក

**៧:១៤** ស លប ៤១:៨ យប ៣:២៦ **៧:១៥** ហ ១ពវ ១៩:៤ យហ ៤:៣ ឡ យប ៦:៩ វវ ៩:៦ **៧:១៦** អ ១ពវ ១៩:៤ យប ៩:២១ ក យប ៣:២២ ខ ខ.១៩ យប ១០:២០ ទដ ៣៩:១៣ គ ខ.៧ **៧:១៧** ឃ យប ៤:១៩ ២២:២ ទដ ៨:៤ ១៤៤:៣ ហព ២:៦ **៧:១៨** ង ទដ ៧៣:១៤ ច យប ២៣:១០ ទដ ១៣៩:២៣ ឆ យប ១៤:៣ ទដ ១៧:៣ ២៦:២ ៦៦:១០ ១៣៩:១–៦ ១៤៣:២ **៧:១៩** ជ ខ.១៦ ឈ យប ៩:១៨ ១៣:២៦ ១៤:៦ ២៧:២ ទដ ១៣៩:៧ **៧:២០** ញ យប ៣៥:៦ យរ ៧:១៩
ដ យប ៦:៤ ឋ ខ.១២ **៧:២១** ឌ យប ៩:២៨ ១០:១៤ ១៦:៦ ទដ ១១៩:១២០ អស ៤៣:២៥ យរ ៣១:៣៤ ហព ១:៣ ឍ លប ៣:១៩ យប ១០:៩ ៣៤:១៥ ទដ ៧:៥ ២២:១៥ ៩០:៣ ១០៤:២៩ ណ ខ.៨ យប ៣:១៣ **៨:១** ក លប ២៥:២ យប ១៨:១ ២៥:១ **៨:២** ខ យប ១១:២ ១៨:២ គ ២រប ៣៦:១៦ យប ៦:២៦ **៨:៣** ឃ យប ៤:១៧ ៣៤:១២ អស ២៩:១៥ រម ៣:៥ ង លប ១៨:២៥ យរ ១២:១ **៨:៤** ច យប ១:១៩ **៨:៥** ឆ យប ៩:១៥ ជ យប ៥:៨,២៧ **៨:៦** ឈ យប ៥:១៥ ២២:២៧ ៣៣:២៦ ៣៤:២៨ អស ៥៨:៩ ៦៥:២៤ ញ យប ៥:២៤ **៨:៧** ដ យប ២១:១៣ ២២:២១ ៣៦:១១ ទដ ២៥:១៣ ឋ យប ១:១០ យរ ២៩:១១ ៣១:១៧ **៨:៨** ឌ ចទ ៣២:៧ ទដ ៧១:១៨

**៧:១៣–១៥** លោកយ៉ូបគិតថា សូម្បីតែសុបិន្តនិមិត្តក៏ជាការរំខានដំណេករបស់គាត់ដែរ ព្រោះវាគឺមកពីព្រះដែរ ។

**៧:១៦** *ទូលបង្គំខ្ពើមជីវិតណាស់* មើលការពន្យល់ ៩:២១ ។

**៧:១៧** *តើមនុស្សជាអ្វី ដែលទ្រង់រវល់ដល់គេ* មើល ទដ ១៤៤:៣ ប្រៀបធៀប ទដ ៨:៤–៨ គឺជាមនុស្សលោកទ្រង់បានបង្កើតដែលមានទ្រង់ទ្រាយដូចព្រះដើម្បីគ្រប់គ្រងលើផែនដី (មើលការពន្យល់ លប ១:២៦–២៨ ទដ ៨:៦–៨) ។ ពាក្យសំដីលោក (ខ.១៨–២១) គឺជាពាក្យរិះគន់នៅលើផ្ទៃរឿង ។

**៧:១៩** *ល្មមតែលេបទឹកមាត់* គឺជារយៈពេលតែល្មមនឹងលេបទឹកមាត់ ។

**៧:២០** *បើទូលបង្គំបានធ្វើបាប* ទូលបង្គំពុំបានគ្រប់លក្ខណទេ តែអ្វីដែលជាអំពើបាបដែលទូលបង្គំបានប្រព្រឹត្តនោះ គឺសមនិងទទួលនូវប្រភេទនៃការឈឺចាប់នេះហើយ ។ *ឱព្រះដ៏ចាំយាមមនុស្សអើយ* ចំពោះពាក្យនេះជាព្រះគម្ពីរភាសាហេព្រើរ គេប្រើវាជាញឹកញយណាស់ក្នុង អស ២៧:៣ តែនៅត្រង់នេះ លោកយ៉ូបពោលត្អូញត្អែរថាព្រះអម្ចាស់ចាំតែចាប់កំហុស ។ *ទ្រង់បានដាក់ទូលបង្គំ* មើលការពន្យល់ ៦:៤ ។ *ជាបន្ទុក* ភាសាហេព្រើរជំនាន់ដើមមានការប្រែប្រួលក្នុងន័យខ្លះ ។

**៧:២១** *សេចក្ដីរំលង . . . សេចក្ដីទុចរិត* លោកយ៉ូបដឹងខ្លួនលោកមានបាប តែលោកពុំយល់នូវព្រះហឫទ័យទ្រង់ដែលពុំលើកលែងទោសដូច្នេះ ។ *ដេកទៅក្នុងធូលីដីឥឡូវ* ក៏ដូចជាស្ថាននរកមួយ គឺតាមរយៈអ្នកបកស្រាយរបស់អ្នករស់នៅតាមដងទន្លេ (មើលការពន្យល់ ខ.៩) ។

**៨:២** *ដល់កាលណា* មើល ១៨:២ មានលក្ខណៈផ្ទុយទៅនឹងអេលីផាស ដែលចាស់ជាង ឯប៊ីលដាឌជាសាសន៍ស៊ូអា ពុំមានការអត់ធ្មត់ ។

**៨:៣** *តើព្រះដែលបង្វែលសេចក្ដីយុត្តិធម៌ចេញឬទេ* តែលោកពុំបានចោទប្រកាន់ទ្រង់ជាក់ស្ដែងពិតប្រាកដនៅឡើយទេ ដែលថាព្រះជាព្រះអយុត្តិធម៌នោះ ។

**៨:៥–៦** ហេតុផលប៊ីលដាឌមានលក្ខណៈដូចខាងក្រោម ព្រះមិនអាចមានលក្ខណៈមិនយុត្តិធម៌នោះទេ ដូច្នេះយ៉ូបនិងក្រុមគ្រួសារគាត់ត្រូវទទួលការឈឺចាប់ដោយសារលទ្ធផលនៃអំពើបាប លោកយ៉ូបគួរតែសុំនូវក្ដីអាណិតមេត្តាពីព្រះហើយ បើគាត់ត្រឹមត្រូវនោះព្រះនឹងសង្គ្រោះគាត់ឡើងវិញ ឱ្យគាត់ទទួលព្រះពរឡើងវិញ ។

**៨:៦** *បើខ្លួនអ្នកក៏បរិសុទ្ធ ហើយទៀងត្រង់* យើងបានស្គាល់សាលក្រមក្រឹត្យវិន័យព្រះអំពីលោកយ៉ូបហើយ (មើល ១:៨ ២:៣) ប៉ុន្តែប៊ីលដាឌមានជំនឿជឿជាក់ថា លោកយ៉ូបគឺជាមនុស្សមានពុតត្បុត (មើល ខ.១៣) ។

**៨:៧** មើល ខ.២១ ប៊ីលដាឌបាននិយាយមានលក្ខណៈពិតជាងអ្វីដែលជាការដែលគាត់បានគិត (មើល ៤២:១០–១៧) ។

**៨:៨** *ចូរស៊ើបសួររកពីដំណមនុស្សដែលកន្លងទៅ* អេលីផាសបានសម្ដែងបង្ហាញពីគំនិតរបស់លោកិយ (មើល ៤:១២–២១) គឺខណៈដែលប៊ីលដាឌបានប្រមូលប្រាជ្ញាគំនិតពីទម្លាប់របស់គេ ។

ពីម្សិលមិញនេះឯង ឥតដឹងអ្វីឡើយ[ឍ] ពីព្រោះអាយុយើង
នៅផែនដីនេះ ជាស្រមោលប៉ុណ្ណោះ[ត] ១០ឯអ្នកទាំងនោះ តើ
មិនបង្រៀន[ថ] ហើយថ្លែងប្រាប់ដល់អ្នក ព្រមទាំងពោល
ពាក្យបញ្ចេញពីចិត្តគេទេឬអី[ទ] ១១តើដើមកក់ដុះដោយឥត
ភក់បានឬ[ធ] ឯដើមផ្អក់ទឹក[ន] តើនឹងដុះដោយឥតទឹកបានឬទេ
១២កាលដើមនោះនៅខៀវស្រស់ ឥតអ្នកណាកាត់នៅឡើយ
នោះក៏នឹងស្វិតក្រៀមទៅមុនតិណជាតិឯទៀត[ប] ១៣ឯអស់
ទាំងផ្លូវ[ផ]របស់មនុស្សដែលភ្លេចព្រះ[ព] នោះក៏ដូច្នោះដែរ
ហើយសេចក្តីសង្ឃឹមរបស់មនុស្សទមិលល្មើសនឹងត្រូវ
វិនាសទៅដែរ[ភ] ១៤ជាពួកមនុស្សដែលទីពឹងរបស់គេនឹង
ត្រូវបាក់ដាច់ចេញ ឯទីសង្ឃឹមរបស់គេ គឺជាមងនៃពីង
ពាងប៉ុណ្ណោះ[ម] ១៥អ្នកនោះនឹងផ្អែកទៅលើផ្ទះខ្លួន[យ] តែផ្ទះ
នោះនឹងរលំទៅ គេនឹងចាប់យឹតផ្ទះនោះ តែមិនធន់នៅទេ[រ]
១៦អ្នកនោះខៀវខ្ចី នៅក្រោមពន្លឺថ្ងៃ ក៏បែកមែកលូត[ល]ទៅ
ក្នុងសួនច្បារ[វ] ១៧ឯឫសចាក់ស្រេះទៅក្នុងថ្ម ក៏រករហូត
ដល់បានប្រទះនឹងដុំថ្ម ១៨បើកាលណាត្រូវរំលើងចេញពី
កន្លែង នោះកន្លែងរបស់វាមិនព្រមស្គាល់[ស]ទៀតឡើយ គឺ
ដោយពាក្យថា អញមិនបានឃើញឯងទេ[ហ] ១៩មើល នេះ
ហើយជាផលដែលកើត[ឡ]ពីផ្លូវរបស់វា រួចមកមានផ្សេង
ទៀតពន្លកចេញពីដីឡើង[អ] ២០មើល ព្រះទ្រង់មិនដែលលះ
បង់មនុស្សគ្រប់លក្ខណ៍[ក] ឬទប់ទល់មនុស្សដែលប្រព្រឹត្ត
អាក្រក់ឡើយ[ខ] ២១ដល់ចុងបំផុត ទ្រង់នឹងឱ្យមាត់អ្នកបាន
ពេញដោយសេចក្តីសំណើច[គ] ហើយឱ្យបបូរមាត់អ្នកបាន
ស្រែកឡើង ដោយអំណរវិញ[ឃ] ២២ឯពួកដែលស្អប់អ្នក គេ
នឹងមានសេចក្តីខ្មាសរួបរឹតខ្លួន[ង] នោះទីលំនៅ[ច]របស់មនុស្ស
អាក្រក់នឹងសូន្យបាត់ទៅ[ឆ]។

## លោកយ៉ូប

**៩** ១នោះយ៉ូបក៏ឆ្លើយឡើងថា ២ខ្ញុំដឹងប្រាកដថាជាយ៉ាង
នោះហើយ ប៉ុន្តែ ធ្វើដូចម្តេចឱ្យមនុស្សបានសុចរិតនៅ
ចំពោះព្រះបាន[ក] ៣បើគេចង់តវ៉ានឹងទ្រង់[ខ] នោះក្នុង១ពាន់
គេរកឆ្លើយតែ១ក៏មិនបានផង[គ] ៤ទ្រង់មានព្រះហឫទ័យ
ប្រកបដោយប្រាជ្ញា[ឃ] ក៏មានឥទ្ធិឫទ្ធិដ៏ក្រៃលែង[ង] តើមានអ្នក
ណាដែលរឹងទទឹង[ច]នឹងទ្រង់ ហើយមានសេចក្តីសុខឬទេ[ឆ]
៥ទ្រង់លើកភ្នំ[ជ]ឱ្យឃ្លាតចាកទីទៅឥតឱ្យដឹងផង ទ្រង់ក៏ផ្កាប់

**៨:៩** ឍ លប ៤៧:៩ ត ១រប ២៩:១៥ ២រប ១០:៦ ទដ ៣៩:៦ **៨:១០** ថ សភ ១:៨ ទ សភ ២:១–២ ៤:១ **៨:១១** ធ យប ៤០:២១ ន នក ២:៣ អស ១៩:៦ ៣៥:៧ **៨:១២** ប ខ.១៩ ២ពវ ១៩:២៦ យប ១៨:១៦ ២០:៥ ទដ ៩០:៥–៦ ២០:៥ ទដ ៩០:៥–៦ ១០២:១១ អស ៣៤:៤ ៤០:៧,២៤ **៨:១៣** ផ ទដ ៣៧:៣៨ ៧៣:១៧ ព ទដ ៩:១៧ ៥០:២២ អស ៥១:១៣ យរ ១៧:៦ ភ យប ៦:៩ ១១:២០ ១៣:១៦ **៨:១៤** ម ខ.១៥ យប ២៧:១៨ អស ៥៩:៥ **៨:១៥** យ ខ.១៤ រ ទដ ៤៩:១១ មថ ៧:២៦–២៧

**៨:១៦** ល ទដ ៨០:១១ អស ១៦:៨ ទដ ៣៧:៣៥ យរ ១១:១៦ **៨:១៨** ស យប ២០:៩ ទដ ១០៣:១៦ ហ យប ៧:៨ ១៤:២០ **៨:១៩** ឡ ខ.១២ យប ១៥:៣០ អ ទដ ១១៩:៩០ សស ១:៤ **៨:២០** ក យប ១:១ ខ លប ១៨:២៥ **៨:២១** គ យប ៥:២២ ឃ អរ ៣:១៣ យប ៣៥:១០ ទដ ៤៧:៥ ១០៧:២២ ១១៨:១៥ ១២៦:២ ១៣២:១៦ អស ៣៥:៦ **៨:២២** ង យប ២៧:៧ ទដ ៦:១០ ៣៥:២៦ ៤៤:៧ ៥៣:៥ ៧១:១៣ ៨៦:១៧ ១០៩:២៩ ១៣២:១៨ អគ ៧:២៧ ២៦:១៦ ច យប ៤:២១ ឆ ១សយ ៨:៣ យប ១៨:៦, ១៤,២១ ២១:២៨ ២៧:៨,១៨ ៣៤:២៦ ៣៦:៦ ៣៨:១៣ ទដ ៥២:៥ សភ ១៤:១១ **៩:២** ក យប ៤:១៧ រម ៣:២០ **៩:៣** ខ ខ.៣២ យប ៤០:៥ គ ខ.១២,១៤,២៩,៣២ យប ១០:២ ១២:១៤ ១៣:៩,១៤ ២២:៤ ២៣:៧,១៣ ៣៧:១៩ ៤០:២ ទដ ៤៤:២១ អស ១៤:២៤ **៩:៤** ឃ យប ១១:៦ ២៨:១២, ២០,២៣ ៣៨:៣៦ ទដ ៥១:៦ សភ ២:៦ សស ២:២៦ ង ខ.១៩ យប ៥:៩ ១២:១៣,១៦ ២៣:៦ ២៤:២២ ២៦:១២ ៣០:១៨ ទដ ៩៣:៤ ៩៥:៣ សភ ៨:១៤ អស ៤០:២៦ ៦៣:១ ដយ ២:២០ ៤:៣៥ ច យប ៥០:២៤ ឆ ២រប ១៣:១២ យប ៥:១៣ **៩:៥** ជ មថ ១៧:២០

**៨:៩** *ព្រោះអាយុយើង . . . ជាស្រមោលប៉ុណ្ណោះ* គឺជាគំនិតធម្មតាមួយក្នុងគំនិតឯផ្នែកអក្សរសាស្ត្រ (មើល ១៤:២ និងការពន្យល់ ១រប ២៩:១៥ ទដ ១០២:១១ ១៤៤:៤ សស ៦:១២ ៨:១៣) ។

**៨:១១–១៩** គឺជាឃ្លាកំណាព្យ ដែលជាប្រាជ្ញាសម្រាប់រៀនពីមនុស្សសម័យមុនៗ (ខ.៨ វាក៏បង្ហាញក្នុង ខ.១០ដែរ) ហើយក៏ឃើញអនុវត្តក្នុងជីវិតលោកយ៉ូប ខ២០–២២ ។

**៨:២០** ប៊ីលដាឌបាននិយាយចំៗចំពោះការប្រព្រឹត្ត ជាអ្នកធ្វើការអាក្រក់របស់លោកយ៉ូប ដោយលោកអេលីផាសបានពឹងផ្អែកទៅលើពាក្យបព្វាជិតបញ្ចៀងទាំងនោះ (មើល ៤:៧–៩) ។

**៨:២២** *មានសេចក្តីខ្មាសរួបរឹតខ្លួន* មើលការពន្យល់ ទដ ១០៩:២៩ ។

**៩:២–៣** លោកយ៉ូបពុំជឿជាក់ថា គាត់ពុំមានបាបនោះទេ (មើលការពន្យល់ ១:១) តែគាត់ចង់បានថ្ងៃដែលកាត់ទោសដើម្បីគាត់បានបង្ហាញ បញ្ជាក់ថាគាត់ពុំមានទោសឡើយ ដែលអាចធន់នឹងការឈឺចាប់ ។ ក្នុងគ្រាដែលលោកយ៉ូបអស់សង្ឃឹម លោកបានបន្លឺសំលេងពីភាពតូញត្អែរដ៏ខ្លាំងទាស់នឹងព្រះអម្ចាស់ (មើល ខ.២០–២២,២៤ ២៩–៣៥ ១០:១–៧ ១៣–១៧) ។ តែគាត់នៅតែពុំបោះបង់ចោលព្រះទេ គាត់ក៏ពុំដេរបន្ទោសដល់ព្រះដែរ (មើល ១០:២ ៨–១២ ក៏មើលសេចក្តីផ្តើម : នៃរឿងផ្នែកទេវសាស្ត្រ និងសារអត្ថបទ) ដូចជាអារក្សសាតាំងបាននិយាយ (មើល ១:១១,២៥ ប្រៀបធៀប ២:៩ និងជំពូក៤២ ដែលបង្ហាញថា លោកយ៉ូបមានស្មារតីលះបង់ ប៉ុន្តែ ជំពូក ៩–១០ បង្ហាញថាគាត់មានការអត់ធ្មត់ច្រើន (មើល ៤:២ ៦:១១ ២១:៤) ។ ប្រៀបធៀប យក ៥:១១ ដែលជាការនិយាយពីភាពលះបង់របស់លោកយ៉ូប គឺមិនដូចទម្លាប់ពីភាពអត់ធ្មត់តាមធម្មតាទេ ។

**៩:៣** *តវ៉ា* មើល ខ.១៤ ការថ្លែងរបស់លោកយ៉ូប គឺពេញដោយភាពច្បាស់លាស់ "ឆ្លើយដល់ទ្រង់" (មើល វវ ៣,១៥,៣២) ទាស់ទទឹងនឹងព្រះ (ខ.១៤) ការគ្មានទោស . . . ការសុំរកយុត្តធម៌ . . .(ខ.១៥) "ដែលរួមផ្ទុំ"(ខ.១៦,១៩) បង្ហាញថាខ្ញុំវៀចវេរហើយ (ខ.២០) ពួកចៅក្រម (ខ.២៤) រឿងក្តី (ខ ៣២) សូមកុំកាត់ទោសដល់ខ្ញុំ (១០:២) "សាក្សីថ្មី" (១០:១៧) ។ លោកយ៉ូប ខឹងនឹងភាពស្អាតស្អំរបស់លោក តែលោកដឹងថាដោយព្រោះព្រះអម្ចាស់ មានអំណាចព្រះចេស្តាយ៉ាងខ្លាំង ដូច្នេះវាគ្មានប្រយោជន៍អ្វីក្នុងការដែលទាស់ប្រឆាំងនឹងព្រះទេ (ខ.១៤) ភាពឥតមានកំហុសរបស់លោកយ៉ូបក៏មិនធ្វើឱ្យលោកយ៉ូបប្រសើរទេ (ខ.១៥) ។

**៩:៥–១០** ជាបទទំនុកអំពីភាពធំឧត្តម តែលោកយ៉ូបក៏ពុំបានទទួលព្រះពរដោយបទទំនុកនេះដែរ ដោយគាត់ពុំបានឃើញអំណាចព្រះចេស្តានៃព្រះដែលទ្រង់គ្រប់គ្រងដោយភាពសុចរិត និងយុត្តធម៌ ។

វាដោយសេចក្ដីក្រោធរបស់ទ្រង់[ឈ] 6ទ្រង់ចាប់អង្រួន
ផែនដី[ញ]ឱ្យចេញពីកន្លែងធម្មតា ហើយអស់ទាំងសសរនៃ
ផែនដីក៏ញ័រ[ដ] 7ទ្រង់ហាមដល់ថ្ងៃ នោះថ្ងៃក៏មិនរះ[ឋ] ហើយ
ទ្រង់បិទបាំងអស់ទាំងផ្កាយផង[ឌ] 8គឺទ្រង់តែ១អង្គឯងដែល
លាតត្រដាងមេឃ[ឍ] ហើយយាងទៅលើរលកសមុទ្រ[ណ]
9ទ្រង់បានបង្កើត[ត]ផ្កាយក្រពើ ផ្កាយនាយព្រាន ហើយផ្កាយ
កូនមាន់ ព្រមទាំងប្រឡោះនៃមេឃខាងត្បូង[ថ] 10ទ្រង់ធ្វើការ
យ៉ាងធំក្រៃលែង[ទ] ដែលរកយល់មិនបាន និងការអស្ចារ្យ
ឥតគណនា[ធ] 11មើល ទ្រង់យាងកាត់មុខខ្ញុំ តែខ្ញុំមិនឃើញទេ
ទ្រង់ក៏យាងហួសទៅ តែខ្ញុំមិនដឹងសោះ[ន] 12បើទ្រង់ចាប់យក
ទៅ តើអ្នកណានឹងឃាត់ទ្រង់បាន[ប] តើអ្នកណានឹងហ៊ានទូល
សួរទ្រង់ថា តើទ្រង់ធ្វើអ្វីនោះ[ផ] ។

13ព្រះទ្រង់មិនព្រមដកសេចក្ដីក្រោធទ្រង់ទៅវិញទេ[ព] ឯ
ពួកជំនួយដ៏មានចិត្តអួតអាង[ភ] គេត្រូវក្រាបចុះនៅក្រោមទ្រង់
14ចំណង់បើខ្ញុំ តើនឹងទូលឆ្លើយដល់ទ្រង់តិចជាងគេអំបាល
ម៉ានទៅទៀត ទោះបើខំរើសពាក្យទូលនឹងទ្រង់ក៏ដោយ[ម]
15ឯខ្ញុំ សូម្បីបើខ្ញុំបានសុចរិត គង់តែមិនហ៊ានទូលឆ្លើយដល់
ទ្រង់ផង[យ] ខ្ញុំនឹងអង្វរ[រ]ដល់ចៅក្រម[ល]នៃខ្ញុំវិញ[វ] 16បើសិនជាខ្ញុំ
បានអំពាវនាវ ហើយទ្រង់បានឆ្លើយមកខ្ញុំគង់តែខ្ញុំមិនជឿ
ថា ទ្រង់បានទទួលស្ដាប់សំឡេងរបស់ខ្ញុំដែរ[ស] 17ដ្បិតទ្រង់
បំបែកបំបាក់ខ្ញុំ[ហ]ដោយសារខ្យល់ព្យុះ[ឡ] ក៏ចំរើនរបួសខ្ញុំឱ្យ
ច្រើនឡើង[អ]ដោយឥតហេតុ[ក] 18ទ្រង់មិនបើកឱ្យខ្ញុំដកទាំង
ដង្ហើមផង គឺទ្រង់ចំអែតខ្ញុំដោយសេចក្ដីជូរល្វីងវិញ[ខ] 19បើ
នឹងគិតប្រើកំឡាំង នោះមើល ទ្រង់ក៏ខ្លាំងជាងទៅទៀត[គ] ឬ
បើគិតពីសេចក្ដីជំនុំជំរះ នោះទ្រង់មានបន្ទូលមកថា តើអ្នក
ណានឹងកោះហៅអញ[ឃ] 20បើខ្ញុំនឹងតាំងខ្លួនជាសុចរិត នោះ
មាត់ខ្ញុំនឹងបានកាត់ទោសដល់ខ្លួនវិញ បើខ្ញុំថា ខ្ញុំទៀងត្រង់
នោះនឹងបង្ហាញច្បាស់ថា ខ្ញុំវៀចវេរហើយ[ង] 21ទោះបើខ្ញុំ
បានគ្រប់លក្ខណ៍[ច] គង់តែមិនពឹងដល់ខ្លួនឯងទេ[ឆ] ខ្ញុំស្អប់ជីវិត
នៃខ្ញុំ[ជ] 22សេចក្ដីទាំងនោះត្រូវគ្នាទាំងអស់ បានជាខ្ញុំថា ទ្រង់
បំផ្លាញទាំងមនុស្សគ្រប់លក្ខណ៍ និងមនុស្សអាក្រក់ផង[ឈ]
23បើសិនជាសេចក្ដីវេទនាណា[ញ]នាំឱ្យស្លាប់ភ្លាម នោះទ្រង់
នឹងសើចឡក ដល់សេចក្ដីល្បងលរបស់មនុស្សឥតទោស[ដ]

**៩:៥** ឈ ទដ ១៨:៧ ៤៦:២–៣ អស ១៣:១៣ មីក ១:៤ **៩:៦** ញ នក ១៩:១៨ អស ២:២១ ១៣:១៣ ២៤:១៨–២០ អម ៨:៨ ហព ១២:២៦ ដ ២សយ ២២:៨ យប ២៦:១៤ ៣៦:២៩ ៣៧:៤–៥ ទដ ៧៥:៣ ហព ៣:៤ **៩:៧** ឋ អស ៣៤:៤ យរ ៤:២៨ យអ ២:២,១០,៣១ ៣:១៥ សផ ១:១៥ សក ១៤:៦ ឌ អស ១៣:១០ យរ ៤:២៣ អគ ៣២:៨ **៩:៨** ឍ លប ១:១,៨ អស ៤៨:១៣ ណ យប ៣៨:១៦ ទដ ៧៧:១៩ សភ ៨:២៨ ហព ៣:១៥ មថ ១៤:២៥ មក ៦:៤៨ យហ ៦:១៩ **៩:៩** ត យប ៣២:២២ ៤០:១៥, ១៩ ថ លប ១:១៦

**៩:១០** ទ ចទ ៦:២២ ទដ ៧២:១៨ ១៣៦:៤ យរ ៣២:២០ ធ យប ៥:៩ **៩:១១** ន យប ២៣:៨–៩ ៣៥:១៤ **៩:១២** ប ជន ២៣:២០ យប ១១:១០ អស ១៤:២៧ ៤៣:១៣ ផ ខ.៣ ចទ ៣២:៣៩ អស ២៩:១៦ ៤៥:៩ ដយ ២:២១ ៤:៣២ រម ៩:២០ **៩:១៣** ព ចន ១៤:១៨ យប ១០:១៥ ទដ ៧៨:៣៨ អស ៣:១១ ៦:៥ ៤៨:៩ ភ យប ២៦:១២ ទដ ៨៧:៤ ៨៩:១០ អស ៣០:៧ ៥១:៩ **៩:១៤** ម ខ.៣ **៩:១៥** យ យប ១០:១៥ ១៣:១៩ ៣៤:៥–៦ ៤០:៥ ៤២:៧ រ យប ៨:៥ ល លប ១៨:២៥ ១សយ ២៤:១២ ទដ ៥០:៦ ៩៦:១៣ វ ខ.២០,២៩ យប ១៥:៦ ២៣:៤ ៤០:២ **៩:១៦** ស យប ១៣:២២ រម ៩:២០–២១ **៩:១៧** ហ យប ១៦:១២ ៣០:១៦ ទដ ១០:១០ អស ៣៨:១៣ ឡ យប ៣០:២២ ទដ ៨៣:១៥ យហ ១:៤ អ យប ១៦:១៤ ក យប ២:៣ **៩:១៨** ខ យប ៧:១៩ ១០:១ **៩:១៩** គ ខ.៤ នហ ៩:៣២ ឃ ខ.៣៣ យរ ៤៩:១៩ **៩:២០** ង ខ.១៥**៩:២១** ច លប ៦:៩ យប ៣៤:៦,៧ ឆ ខ.១៤ យប ៦:២៩ ១០:១ ១៣:១៣ ជ ជន ១១:១៥ យប ៧:១៦ **៩:២២** ឈ យប ៣:១៩ ១០:៨ សស ៩:២,៣ អគ ២១:៣ **៩:២៣** ញ ហព ១១:៣៦ ដ យប ២៤:១,១២ ទដ ៦៤:៤ ហព ១:៣ ១ពត ១:៧

**៩:៦** សម្រាប់ជាពាក្យប្រៀបប្រដូចនៃភពផែនដីដែលមានគ្រឹះមាំមួន មើល ៣៨:៦ ១សយ ២:៨ និងការពន្យល់ ទដ ២៤:២ ៧៥:៣ ១០៥:៥ ។

**៩:៨** *លាតត្រដាងមេឃ* មាន២ផ្នែក :(១).បានបង្កើតផ្ទៃមេឃ(ស្ថានសួគ៌) មើល អស ៤៤:២៤ ឬក៏ប្រហែល ។ (២).ធ្វើឱ្យមានពន្លឺថ្ងៃលេចឡើង ដូចអ្នកណាម្នាក់ដែលលាតត្រដាង(មើល ទដ ១០៤:២) ហើយយាងទៅលើរលកសមុទ្រអត្ថបទរបស់សាសន៍កាណានពណ៌នាពីព្រះ ដែលគួរឱ្យស្អប់ខ្ពើមដែលយាងនៅលើសមុទ្រ(ឬជាព្រះគង្គា) គឺដើម្បីបង្ក្រាបទឹករលកឱ្យស្ងាត់វិញ ។ គឺមានលក្ខណៈប្រហែលនឹងព្រះអម្ចាស់បានកំហែងគំរាមដល់ទឹករលក ដើម្បីគ្រប់គ្រងសមុទ្រដែលមានរលកទឹក ។

**៩:៩** *ផ្កាយក្រពើ ផ្កាយនាយព្រាន* គឺមានក្រុមផ្កាយទាំងបីក្រុមដែលបានបង្ហាញឱ្យឃើញឡើងវិញក្នុង ៣៨:៣១–៣២ និងផ្កាយពីរចុងក្រោយក៏បង្ហាញក្នុង អម ៥:៨(មើលការពន្យល់ទីនោះ) ផ្ទុយទៅវិញ ចំណេះដឹងដែលមានកំនត់របស់អ្នកតារាវិទូផ្នែកតារាសាស្ត្រ ជាពួកអ៊ីស្រាអែលសម័យបូរាណ គឺបានទទួលការខ្លាចក្រែងដោយសេចក្ដីពិតដោយព្រះបានបង្កើតឱ្យមានពួកក្រុមផ្កាយឡើងនោះ ។

**៩:១០** គឺពាក្យពេចន៍តែមួយដែលនិយាយដោយលោកអេលីផាស ។

**៩:១២** *តើអ្នកណានឹងឃាត់ទ្រង់បាន* លោកយ៉ូបជំទាស់នឹងព្រះថាធ្វើគ្រប់យ៉ាងតាមតែព្រះទ័យដែលទ្រង់កំណត់ ។

**៩:១៣** *មានចិត្តអួតអាង* ទ្រង់ធ្វើឱ្យសមុទ្រកំរើកឡើងដោយឥទ្ធិពលរបស់ទ្រង់ ហើយក៏វាយកំទេចសេចក្ដីឆ្មើងឆ្មៃ (មើល ២៦:១២) ឬពួកជំនឿខុសឆ្គងការមាននៅទីខ្លះ គេប្រើជាសញ្ញានៃសាសន៍អេស៊ីព្ទ(មើល អស ៣០:៧ និងការពន្យល់)ឬពាក្យថា"រ៉ាហាប" គឺមានន័យថាអ្នកដែលអង្គុយនៅតែស្ងៀម មើល ៣:៨,១២ និងការពន្យល់ ។

**៩:១៥** *យ៉ូប* ជឿជាក់ក្នុងជំនឿជាគ្រឿងជួយដោះបន្ទាល់តែមួយគត់របស់គាត់នៅពីមុខព្រះតេជះដ៏ឧត្តមភាពរបស់ព្រះ គឺតាមរយៈខ្លួនលោកផ្ទាល់ចំពោះភាពព្រះមេត្តាករុណារបស់ព្រះអម្ចាស់ ។

**៩:១៧** លោកយ៉ូបពុំបានដឹងជាព្រះអម្ចាស់បានអនុញ្ញាត្តិឱ្យអារក្សសាតាំងបំផ្លាញគាត់ទេ ។

**៩:២០** *មាត់ខ្ញុំបានកាត់ទោសដល់ខ្ញុំវិញ* មើល ១៥:៦ ។

**៩:២១** *ខ្ញុំស្អប់ជីវិតនៃខ្ញុំ* មើល ៧:១៦ គឺលោកយ៉ូបសម្ដែងពីការលន់តួបាបរបស់លោក ដែលជាមនុស្សមាននិស្ស័យស្លាប់ហើយជៀសមិនផុតពីសេចក្ដីស្លាប់ (មើល ៤២:៦ និងការពន្យល់) ។

**៩:២២–២៤** ព្រះអម្ចាស់ប្រែក្លាយជាសត្រូវដ៏ធំរបស់លោកយ៉ូប ។ លោកយ៉ូបពណ៌នាពីវិញ្ញាណដែលពុំមានចុងបញ្ចប់ លើកលែងតែក្នុងគំនិតរបស់លោកយ៉ូប ។ ព្រះបន្ទូលរបស់ព្រះនៅក្នុង ៣៨:២ និងការឆ្លើយតបរបស់លោកយ៉ូប ក្នុង ៤២:៣ ។

២៤ផែនដីនេះបានប្រគល់ទៅក្នុងកណ្ដាប់ដៃ នៃមនុស្ស
អាក្រក់ហើយ[ឋ] ទ្រង់ក៏បាំងមុខពួកចៅក្រមនៃផែនដី[ឌ] បើមិន
មែនជាទ្រង់ទេ នោះតើជាអ្នកណាវិញ[ឍ]។
២៥ឯថ្ងៃទាំងឡាយនៃអាយុខ្ញុំ នោះលឿនជាងអ្នករត់
សំបុត្រ[ណ] ក៏រត់បាត់ទៅ ឥតដែលឃើញសេចក្ដីល្អអ្វីឡើយ[ត]
២៦ក៏កន្លងហួសទៅ[ថ] ដូចជាទូកធ្វើពីឫស្សី[ទ] ឧបមាដូចជាឥន្ទ្រី
ដែលបោះពួយចាប់រំពា[ធ] ២៧បើសិនជាខ្ញុំថា ខ្ញុំនឹងបំភ្លេច
សេចក្ដីដំអូញរបស់ខ្ញុំ[ន] ក៏នឹងបំផ្លាស់បំប្រែទឹកមុខព្រួញចេញ
ហើយនិងមានចិត្តធូរឡើងវិញ ២៨នោះខ្ញុំខ្លាច[ប]អស់ទាំង
សេចក្ដីទុក្ខព្រួយរបស់ខ្ញុំ ហើយដឹងថា អ្នកមិនរាប់ខ្ញុំជាឥត
ទោសទេ[ផ] ២៩ខ្ញុំនឹងត្រូវមានទោសមែន ដូច្នេះខ្ញុំនឹងនឿយ
ហត់ជាឥតប្រយោជន៍ធ្វើអ្វី[ព] ៣០បើសិនជាខ្ញុំនឹងសំអាតខ្លួន
ដោយទឹកហិមៈ[ភ] ហើយលាងដៃ[ម]ឱ្យស្អាតយ៉ាងណាក៏ដោយ[យ]
៣១គង់តែអ្នកនឹងបោះខ្ញុំចុះទៅក្នុងភក់ជ្រាំវិញ[រ] នោះទាំង
សំលៀកបំពាក់ខ្ញុំនឹងខ្ពើមខ្ញុំផង[ល] ៣២ដ្បិតព្រះទ្រង់មិនមែន
ជាមនុស្ស[វ]ដូចជាខ្ញុំ ដែលខ្ញុំនឹងហ៊ានឆ្លើយដល់ទ្រង់[ស] ឬដែល
នឹងជួបគ្នាដោយរឿងក្ដីនោះទេ[ហ] ៣៣គ្មានអ្នកណាជាអ្នក
កណ្ដាល[ឡ] ដែលនឹងដាក់ដៃលើយើងទាំង២សង្រួបសង្រួម
ឡើយ[អ] ៣៤ឱ្យទ្រង់ដកដំបងពីខ្ញុំចេញ[ក] ហើយកុំឱ្យសេចក្ដី
ស្ញែងខ្លាចរបស់ទ្រង់មកបំភ័យខ្ញុំទៀត[ខ] ៣៥នោះខ្ញុំនឹងទូល
ដល់ទ្រង់ឥតភ័យខ្លាច[គ] ដ្បិតដែលខ្លួនខ្ញុំនៅតែយ៉ាងនេះ នោះ
ខ្ញុំមិនហ៊ានទេ[ឃ]។

# ១០

១ចិត្តខ្ញុំជិនណាយនឹងជីវិតរបស់ខ្ញុំ[ក] ខ្ញុំនឹងឱ្យសេចក្ដី
ដំអូញរបស់ខ្ញុំចេញហូរហែ ខ្ញុំនឹងនិយាយ ដោយសេចក្ដី
ជូរល្វីងក្នុងចិត្ត[ខ] ២ខ្ញុំនឹងទូលដល់ព្រះ[គ]ថា សូមកុំកាត់ទោស
ទូលបង្គំ សូមបង្ហាញហេតុ[ឃ]ដែលទ្រង់តតាំងនឹងទូលបង្គំ
វិញ[ង] ៣ដែលសង្កត់សង្កិនដូច្នេះ[ច] តើមានប្រយោជន៍ ដល់
ទ្រង់ឬ បានជាទ្រង់មើលងាយដល់ស្នាដៃរបស់ទ្រង់[ឆ] ហើយ
ប្រោសឱ្យពន្លឺទ្រង់ មកបំភ្លឺគំនិតរបស់មនុស្សអាក្រក់វិញ[ជ]
៤តើព្រះនេត្រទ្រង់ជាភ្នែកសាច់ឈាម ឬទ្រង់ទតឃើញដូច
ជាមនុស្សឬអី[ឈ] ៥តើព្រះជន្មនៃទ្រង់ដូចជាអាយុរបស់មនុស្ស
ឬអស់ទាំងឆ្នាំនៃទ្រង់ត្រូវនឹងថ្ងៃរបស់មនុស្សឬទេ[ញ] ៦បាន
ជាទ្រង់ស៊ើបសួររកសេចក្ដីទុច្ចរិតរបស់ទូលបង្គំ ហើយ
ស្វែងរកអំពើបាបនៃទូលបង្គំដូច្នេះ[ដ] ៧ទ្រង់ជ្រាបហើយថា
ទូលបង្គំមិនមែនអាក្រក់[ឋ] ហើយថា គ្មានអ្នកណាអាចនឹង

**៩:២៤** ឋ យប ១:១៥,១៧ ១០:៣ ១៦:១១ ២១:១៦ ២២:១៨ ២៧:២ ៤០:៨ ទដ ៧៣:៣ ឌ យប ៣:១៤ ១២:៦ ១៩:៧ ២១:៧ ២៤:២៣ ៣១:៣៥ ៣៤:១៥ ទដ ៧៣:១២ សស ៨:១១ យរ ១២:១ បទ ៣:៩ ឍ យប ១២:៩ ១៣:១ ២៤:១២ អស ៤១:២០ **៩:២៥** ណ យប ៧:៦ ត យប ៧:៧ ១០:២០ **៩:២៦** ថ យប ២៤:១៨ ទដ ៨៦:៣ ទ អស ១៨:២ ធ យប ៣៩:២៩ ហាព ១:៨ **៩:២៧** ន យប ៧:១១ **៩:២៨** ប យប ៣:២៥ ផ នក ៣៤:៧ យប ៧:២១ **៩:២៩** ព ខ.៣,១៥ ទដ ៣៧:៣៣ **៩:៣០** ភ មទ្ឋ ៣:២ ម យប ១៧:៩ ៣១:៧ អស ១:១៥ យ យប ១៤:៤,១៧ ៣៣:៩ អស ១:១៨ យរ ២:២២ ហស ១៣:១២ **៩:៣១** រ ទដ ៣៥:៧ ៤០:២ ៥១:៩ យរ ២:២២ ណាហ ៣:៦ មទ្ឋ ២:៣ ល យប ៧:២០ ៣៤:៩ ៣៥:៣ ទដ ៧៣:១៣ **៩:៣២** វ ជន ២៣:១៩ ស ខ.៣ រម ៩:២០ ហ ទដ ១៤៣:២ សស ៦:១០ **៩:៣៣** ឡ ១សយ ២:២៥ អ ខ.១៩ **៩:៣៤** ក យប ២១:៩ ទដ ៣៩:១០ ៧៣:៥ ខ យប ៦:៤ ៧:១៤ ៣៣:៧ ទដ ៣២:៤ **៩:៣៥** គ យប ៧:១១ ឃ យប ៧:១៥ ១៣:២១ **១០:១** ក ជន ១១:១៥ ១ពវ ១៩:៤ ខ ១សយ ១:១០ យប ៧:១១ ៩:១៨,២១ **១០:២** គ យប ១៣:៣ ៤០:១ ឃ អស ៣:១៣ ហស ៤:១ ៥:១ ១២:២ មីក ៦:២ រម ៨:៣៣ ង យប ៩:៣ **១០:៣** ច យប ៩:២២ ១៦:៩,១៤ ១៩:៦,២១ ២២:១០ ៣០:១៣,២១ ៣១:២៣ ៣៤:៦ ឆ ខ.៨ លប ១:២៦ យប ៤:១៧ ១៤:១៥ ៣៤:១៩ ទដ ៨:៦ ៩៥:៦ ១០០:៣ ១៣៨:៨ ១៤៩:២ ឯស ៦០:២១ ៦៤:៨ ជ យប ៩:២៤ **១០:៤** ឈ អស ១៦:៧ យប ១១:១១ ១៤:១៦ ២៤:២៣ ២៨:២៤ ៣១:៤ ៣៤:២១ ៤១:១១ ទដ ១១:៤ ៣៣:១៥ ១១៩:១៦៨ ១៣៩:១២ សភ ៥:២១ ១៥:៣ យរ ១១:២០-២៣ ១៦:១៧ **១០:៥** ញ យប ៣៦:២៦ ទដ ៣៩:៥ ៩០:២,៤ ១០២:២៤ ២ពត ៣:៨ **១០:៦** ដ យប ១៤:១៦ **១០:៧** ឋ ខ.១៥ យប ៦:២៩ ១១:៤ ១៦:១៧ ២៧:៥,៦, ៣១ ៣២:១

**៩:២៤** *បាំងមុខពួកចៅក្រមនៃផែនដី* ស្ថានភាពយុត្តិធម៌របស់ទ្រង់គឺបាំងមុខក៏បង្ហាញថាទ្រង់កាត់ទោសដោយមិនលំអៀង តែលោកយ៉ូបបានចោទប្រកាន់នឹងព្រះ ដូច្នេះគាត់បានបាំងមុខការកាត់ទោសដោយឱ្យគេឃើញនូវភាពគ្មានបទល្មើស ឬគ្មានកំហុស ។

**៩:២៦** *ទូកធ្វើពី ឫស្សី* មើលការពន្យល់ នក ២:៣ ។

**៩:២៨** *អ្នកមិនរាប់ខ្ញុំជាឥតទោសទេ* លោកយ៉ូបចង់ឈរពីមុខព្រះអម្ចាស់ក្នុងនាមជាមនុស្សឥតមានកំហុស មិនមែនមានបាបតិចតួចទេ តែអត់មានទោសក្នុងការប្រព្រឹត្តនូវអំពើបាបក្នុងការដែលគាត់រងនូវការឈឺចាប់ ។

**៩:២៩** *ខ្ញុំនឹងត្រូវមានទោសមែន* ដូចដែលគាត់ទទួលការឈឺចាប់ ហើយបានស៊ូទ្រាំ ។

**៩:៣០** *ទឹកហិមៈ* គឺប្រើសម្រាប់សម្អាតលាងដៃឬខ្លួន ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះគឺស្មើ "សាប៊ូ " ក្នុង យរ ២:២២ មទ្ឋ ៣:២ ។

**៩:៣៣** *អ្នកជាអ្នកកណ្ដាល ដែលនិងដាក់ដៃលើយើងទាំង២សង្រួបសង្រួមឡើយ* មើលការពន្យល់ ៥:១ ព្រះអម្ចាស់មានលក្ខណៈមហិមាដែលលោកយ៉ូបចង់បានអ្នកណាម្នាក់ដែលអាចជួយគាត់ គឺជាអ្នកដែលអាចញែកចេញពីក្ដីរបស់គាត់ក្នុងតុលាការ ។ ការត្រាស់ហៅលោកយ៉ូបគឺមិនមែនជាលក្ខណៈដោយផ្ទាល់ទេ គឺជាអ្នកបង្រួបបង្រួមរបស់ព្រះគ្រីស្ទ ។ លោកយ៉ូបបានរុករកអ្នក ជួយបញ្ជាក់ពីភាពអត់កំហុសរបស់លោកយ៉ូប (មើល ១៦:១៨–២១ ១៩:២៥–២៦ និងការពន្យល់) ។

**៩:៣៤** មីល ១៣:២១ ។ *ដកដំបងពីខ្ញុំចេញ* ជាសញ្ញានៃការកាត់ទោសពីព្រះ និងសេចក្ដីក្រោធរបស់ផងទ្រង់ (មើលឧទាហរណ៍ ទដ ៨៩:៣០–៣៧ បទ ៣:១ និងការពន្យល់) ។

**១០:១** *ចិត្តខ្ញុំជិនណាយនឹងជីវិតរបស់ខ្ញុំ* មើលការពន្យល់ ៩:២១ ។ *សេចក្ដីជូរល្វីងក្នុងចិត្ត* ដោយជីវិតលោកយ៉ូប គឺពោរពេញដោយភាពជូរល្វីង គឺជាអារម្មណ៍របស់លោកកំពុងមើលទៅឯព្រះក្នុងការមិនល្អ ។

**១០:៣** លោកយ៉ូបស្រមៃនឹកថាព្រះអម្ចាស់ក្រោធព្រះទ័យនិងលោក គឺជាមួយនិងមនុស្សគ្មានកំហុស (មើល ៩:២៨ និងការពន្យល់) ដោយនាំឱ្យលោកយ៉ូបបានឈានដំណើរទៅរកការមិនល្អ ។ ដូចជាពាក្យរំឭកបន្ទប់អ្នកជម្ងឺ គឺមិនមែនជាកន្លែងបញ្ចូលផ្នែកទេវសាស្ត្រទេ ។ ក្នុងគ្រាដែលមានការឈឺចាប់យ៉ាងខ្លាំង ប្រជារាស្ត្រគួរពោលពីតម្រូវការឆ្លើយតបនូវសេចក្ដីស្រឡាញ់និងការស្វែងយល់ គឺលោកយ៉ូបផ្ទាល់ និងត្រូវលន់តួបាបនឹងព្រះអម្ចាស់ដើម្បីព្រះអម្ចាស់បានអត់ទោសបាបឱ្យ (៤៣:១–៦) ។

ដោះឱ្យរួចពីព្រះហស្ដរបស់ទ្រង់បាន[ឱ] ៨ គឺព្រះហស្ដនៃទ្រង់
ដែលបង្កើត[ឍ]រាងកាយ ហើយសំរេចរូបទូលបង្គំឱ្យជាប់គ្នា
គ្រប់ផ្នែក តែទ្រង់បំផ្លាញទូលបង្គំវិញ[ណ] ៩ សូមទ្រង់នឹកចាំថា
ទ្រង់បានសូនរូបទូលបង្គំ ដូចជាគេសូនដីឥដ្ឋ[ត] ចុះតើទ្រង់
គិតឱ្យទូលបង្គំត្រឡប់ទៅជាធូលីដីវិញឬ[ថ] ១០ តើទ្រង់មិនបាន
ចាក់ទូលបង្គំចេញដូចជាទឹកដោះហើយឱ្យទូលបង្គំកកខន់
ដូចជាផែនទឹកដោះទេឬអី ១១ ទ្រង់បានបំពាក់ទូលបង្គំដោយ
សាច់នឹងស្បែក ព្រមទាំងថ្លាន់ទូលបង្គំឱ្យជាប់គ្នា[ទ]ដោយ
ឆ្អឹងនឹងសរសៃ ១២ ទ្រង់បានប្រោសផ្ដល់ជីវិត[ធ] និងសេចក្ដី
សប្បុរសដល់ទូលបង្គំ[ន] ហើយការឃុំគ្រងរបស់ទ្រង់[ប]បាន
គាំពារ[ផ]ជីវិតទូលបង្គំ ។
១៣ ប៉ុន្តែសេចក្ដីទាំងនេះទ្រង់បានលាក់ទុកនៅក្នុងព្រះ
ហឫទ័យវិញ ទូលបង្គំដឹងហើយថា នេះនៅតែក្នុងទ្រង់ទេ[ព]
១៤ គឺថា បើទូលបង្គំធ្វើបាប នោះទ្រង់ចំណាំទូលបង្គំទុក[ភ]
ហើយទ្រង់មិនលែងឱ្យទូលបង្គំបានរួចពីទោសឡើយ[ម]
១៥ បើទូលបង្គំអាក្រក់មែន[យ] នោះវរហើយ[រ] តែបើសុច្ចរិត
វិញ នោះក៏មិនបានងើបក្បាលឡើងដែរ[ល] ដោយមានពេញ
ជាសេចក្ដីខ្មាស ហើយមើលតែសេចក្ដីវេទនារបស់ទូលបង្គំ[វ]
១៦ បើកាលណាក្បាលទូលបង្គំងើបឡើង នោះទ្រង់ដេញទូល
បង្គំដូចជាសិង្ហ[ស] រួចទ្រង់សំដែងព្រះចេស្ដាយ៉ាងអស្ចារ្យ
លើទូលបង្គំទៀត[ហ] ១៧ ទ្រង់ចេះតែមានសាក្សីថ្មីទាស់នឹង
ទូលបង្គំ[ឡ] ក៏ចំរើនសេចក្ដីក្នាន់ក្នាញ់ទាស់នឹងទូលបង្គំ[អ] គឺមាន
សេចក្ដីប្រែប្រួល និងសេចក្ដីតតាំងនៅជាប់នឹងទូលបង្គំ
ជានិច្ច[ក]។
១៨ យ៉ាងនោះ ម្ដេចក៏ទ្រង់បានធ្វើឱ្យទូលបង្គំ ចេញពីផ្ទៃ
ម្ដាយមក[ខ] ឱបើទូលបង្គំបានស្លាប់វិញ ឥតមានអ្នកណា
ឃើញទៅអេះ[គ] ១៩ នោះទូលបង្គំនឹងបានដូចជាមិនដែលកើត
មកសោះ គេនឹងបាននាំយកទូលបង្គំពីផ្ទៃម្ដាយទៅកប់
តែម្ដង[ឃ] ២០ តើអស់ទាំងថ្ងៃ[ង]អាយុនៃទូលបង្គំមិនមែនតិច
ណាស់ទេឬអី[ច] ដូច្នេះ សូមឈប់ ទុកឱ្យទូលបង្គំ[ឆ]នៅតែឯង
ចុះ ដើម្បីឱ្យបានសំរាកបន្តិច[ជ] ២១ មុនដែលទូលបង្គំទៅឯទី
ដែលមិនត្រឡប់មកវិញឡើយ[ឈ] គឺដល់ស្ថាននៃសេចក្ដីងងឹត
និងម្លប់នៃសេចក្ដីស្លាប់[ញ] ២២ ជាស្ថានដែលងងឹតឈឹង ដូចជា
យប់ជ្រៅ[ដ] ជាទីម្លប់នៃសេចក្ដីស្លាប់ ដែលឥតមានរបៀបអ្វី
ជាកន្លែងដែលទាំងពន្លឺ ក៏ដូចជាកណ្ដាលអធ្រាត្រដែរ[ឋ]។

### លោកសូផារ

**១១** ១ នោះសូផារ សាសន៍នាអាម៉ា[ក] ក៏ឆ្លើយឡើងថា
២ ដែលមានពាក្យសំដីជាច្រើនដល់ម្ល៉េះ តើមិនគួរឆ្លើយ
តទេឬអី[ខ] តើគួររាប់មនុស្សហៃនិយាយទុកជាសុច្ចរិតឬ[គ]
៣ តើពាក្យអំនួត[ឃ]របស់អ្នកនឹងធ្វើឱ្យមនុស្សនៅស្ងៀមបានឬ
កាលណាអ្នកឡកឡឺយយ៉ាងនេះ តើមិនត្រូវឱ្យមានគេធ្វើ
ឱ្យអ្នកខ្មាសដែរទេឬ[ង] ៤ ដ្បិតអ្នកថា គោលលទ្ធិរបស់អ្នកជា
ស្អាតសុទ្ធ[ច] ឥតខុសឆ្គង[ឆ]នៅចំពោះព្រះនេត្រនៃព្រះ ៥ ឱបើ

**១០:៧** ឱ ចទ ៣២:៣៩
**១០:៨** ឍ លប ២:៧ ណ ខ.៣ ២សយ ១៤:១៤ យប ៣០:១៥
**១០:៩** ត យប ៤:១៩ អស ២៩:១៦ ថ លប ២:៧ យប ៧:២១
**១០:១១** ទ ទដ ១៣៩:១៣,១៥
**១០:១២** ធ លប ២:៧ ន លប ២៤:១២ ប លប ៤៥:៥ ផ ១ពត ២:២៥
**១០:១៣** ព យប ២៣:១៣ ទដ ១១៥:៣
**១០:១៤** ភ យប ១៣:២៧ ម នក ៣៤:៧ យប ៧:២១
**១០:១៥** យ ខ.៧ រ យប ៩:១៣ ល យប ៩:១៥ វ ទដ ២៥:១៦
**១០:១៦** ស ១សយ ១៧:៣៤ ទដ ៧:២ អស ៣៨:១៣ យរ ៥:៦ ២៥:៣៨ បទ ៣:១០ ហស ៥:១៤ ១៣:៧ ហ យប ៥:៩
អស ២៨:២១ ២៩:១៤ ៦៥:៧ **១០:១៧** ឡ ១ពវ ២១:១០ យប ១៦:៨ អ រម ១:២១ ក យប ៥:៧ **១០:១៨** ខ យប ៣:៨ ទដ ២២:៩ គ យប ៣:២៦ សស ៤:២ ៧:១ **១០:១៩** ឃ យប ៣:៣ យរ ១៥:១០ **១០:២០** ង យប ១៤:១ សស ៦:១២ ច យប ៧:៧ ឆ យប ៧:១៦ ជ យប ៩:២៥ **១០:២១** ឈ ២សយ ១២:២៣ យប ៣:១៣ ១៦:២២ ទដ ៣៩:១៣ សស ១២:៥ ញ យប ៣:៥ **១០:២២** ដ យប ៣:៥ ឋ ១សយ ២:៩ យប ៣:១៣ **១១:១** គ យប ២:១១ **១១:២** ខ យប ៨:២ ១៦:៣ គ លប ៤១:៦ យប ៦:២៩ **១១:៣** ឃ អភ ៤:២៩ ៥:៤ ង យប ១២:៤ ១៦:១០ ១៧:២ ២១:៣ ៣០:១ ទដ ១:១ **១១:៤** ច យប ៩:២១ ឆ យប ១០:៧

**១០:៨–១៧** លោកយ៉ូបនៅតែបន្តចោទសំនួរទៅចំពោះព្រះ ដូចជាទ្រង់គឺជាប្រឹក្សាមួយនៅការក្រុមជំនុំជម្រះ ។ គាត់ចង់ដឹងថា តើព្រះហេតុអ្វីបានជាអស្ចារ្យយ៉ាងនេះ គឺទ្រង់បានបង្កើត (មើល ខ.១៣) ដើម្បីនឹងដាក់ទណ្ឌកម្មទោះបីជាអ្នកគ្មានកំហុសក៏ដោយ ។

**១០:៨–១១** គឺឃ្លាកំណាព្យពណ៌នាពីព្រះអម្ចាស់បានបង្កើតទារកក្នុងផ្ទៃម្ដាយ (មើល ទដ ១៣៩:១៣–១៦ និងការពន្យល់ ) ។

**១០:៨** សូមមើល ទដ ១១៩:៧៣ ។

**១០:៩** *សូនរូបទូលបង្គំ ដូចជាគេសូនដីឥដ្ឋ* មើលការពន្យល់ ៤:១៩ ។ *ទូលបង្គំត្រឡប់ទៅជាធូលីវិញ* មើលការពន្យល់ លប ៣:១៩ ។

**១០:១០** *ដូចជាទឹកដោះ* ជាការបង្កើតមានទឹកបន្តពូជ (ទឹកកាម) ចូលទៅក្នុងស្បូនក៏បង្កឱ្យមានកូនក្នុងស្បូន ។

**១០:១៥–១៦** លោកយ៉ូបនិយាយថា ទោះគាត់ប្រព្រឹត្ត ឬពុំមានកំហុស គឺទ្រង់ដែលមានអំណាចព្រះចេស្ដា ក៏មិនយកទោសពៃ ។

**១០:១៧** *សាក្សីថ្មីទាស់* មើលការពន្យល់ ៩:៣ ។

**១០:១៨–២២** មើលការពន្យល់ នៅជំពូក ៣ ។

**១០:២១** *ទីដែលមិនត្រឡប់មកវិញឡើយ* មើលការពន្យល់ ៧:៩ ។ *ស្ថាននៃសេចក្ដីស្លាប់ និងម្លប់នៃសេចក្ដីស្លាប់* មើលការពន្យល់ ៣៨:១៧ តាមឯកសាររបស់ពួកមេសូប៉ូតាមា ដែលសំអាងទៅលើស្ថានឃុំព្រលឹង ឬស្ថាននរក គឺមានលក្ខណៈដែលដូចជា "ទីស្ថាននៃភាពងងឹត" មើលការពន្យល់ ១២:៥) ។

**១១:១–២០** ដូចជា អេលីផាស(មើលការពន្យល់ ៤:៧–១១) និងប៊ីលដាឌ (មើល ៨:៣–៦) បានអះអាងថា អំពើបាបរបស់លោកយ៉ូបបាននាំឱ្យមានបញ្ហា ។

**១១:៤** *អ្នកជាស្អាតសុទ្ធ* ១០:៧,១៥ លោកយ៉ូបបានប្រកែកថាមិនបានប្រព្រឹត្តការអាក្រក់ទេ ហើយក្នុង ៩:២១ លោកពោលថាលោក "គ្មានការបន្ទោសបាន" ព្រះបន្ទូលរបស់ព្រះបានប្រើសម្រាប់ពណ៌នាពីគាត់(យ៉ូប)ក្នុង ១:៨ ២:៣ ។ *សូផារ* បានបញ្ជាក់ថា លោកយ៉ូបបានប្រកាសប្រកែក ។

**១១:៥** លោកសូផារគិតថាព្រះគួរតែមានបន្ទូលប្រឆាំងនិងលោកយ៉ូប តែតាមការពិតព្រះបានមានបន្ទូលប្រឆាំងនឹងលោកសូផារខ្លួនគាត់ផ្ទាល់(មើល ៤២:៧–៩ និងការពន្យល់) ។

ព្រះនឹងមានបន្ទូលមក[ជ] ហើយបើកព្រះឱស្ឋទាស់នឹងអ្នក
៦ដើម្បីនឹងបង្ហាញឱ្យអ្នកស្គាល់សេចក្ដីអាថ៌កំបាំងនៃប្រាជ្ញា
ទៅអេះ[ឈ] នោះអ្នកនឹងឃើញថា ខ្លឹមនៃសេចក្ដីនឹងយល់បាន
ច្រើនយ៉ាង ដូច្នេះ ចូរដឹងថា ព្រះទ្រង់យកទោសស្រាលជាង
សេចក្ដីដែលសំណាំនឹងអំពើទុច្ចរិតរបស់អ្នកវិញ[ញ]។
៧បើអ្នកខំស្វែងរក[ដ] តើអាចនឹងស្គាល់សភាពនៃព្រះ
បាន ឬយល់ដល់សេចក្ដីគ្រប់លក្ខណ៍របស់ព្រះដ៏មានគ្រប់
ព្រះចេស្ដាបានដែរឬ ៨នោះខ្ពស់ជាង[ឋ]ស្ថានសួគ៌[ឌ]ទៅទៀត
តើ អ្នកអាចនឹងធ្វើយ៉ាងណាបាន ក៏ជ្រៅជាងស្ថានឃុំព្រលឹង
មនុស្សស្លាប់ផង[ឍ] ធ្វើដូចម្ដេចឱ្យអ្នកយល់បាន[ណ] ៩បើនឹង
វាស់[ត] នោះក៏វែងជាងផែនដី ហើយធំជាងសមុទ្រទៅទៀត[ថ]
១០បើទ្រង់យាងកាត់ទៅ ហើយកោះឃុំអ្នកណា ព្រមទាំង
ហៅប្រជុំជំនុំជំរះ នោះតើអ្នកណាអាចនឹងឃាត់ទ្រង់បាន[ទ]
១១ដ្បិតទ្រង់ស្គាល់មនុស្សកំភូត ទ្រង់ក៏ឃើញសេចក្ដីទុច្ចរិត
ឥតចាំពិចារណាផង[ធ] ១២មនុស្សមោឃគេឥតមានយោបល់
សោះ អើ មនុស្សសុទ្ធ[ន]តែកើតមកដូចជាកូនលាព្រៃ[ប]។
១៣បើអ្នកតាំងចិត្ត[ផ]ត្រឹមត្រូវឡើង ហើយប្រវាដៃ[ព]ទៅ
ឯទ្រង់[ភ] ១៤ព្រមទាំងបោះបង់[ម]សេចក្ដីអាក្រក់ដែលនៅដៃអ្នក
ចេញ ហើយមិនឱ្យមានសេចក្ដីទុច្ចរិត[យ]ណានៅក្នុងទីលំនៅ
របស់អ្នកឡើយ[រ] ១៥នោះប្រាកដជាអ្នកនឹងងើបមុខ[ល]ឡើង
ឥតមានប្រឡាក់អ្វីសោះ អើ អ្នកនឹងបានមាំមួន[វ]ឥតភ័យខ្លាច
អ្វីផង[ស] ១៦ដ្បិតអ្នកនឹងភ្លេចសេចក្ដីវេទនារបស់អ្នកទៅ រួច[ហ]
អ្នកនឹងនឹកចាំពីសេចក្ដីនោះ ដូចជាចាំពីទឹកដែលហូរបាត់
ហើយ[ឡ] ១៧នោះជីវិតនៃអ្នកនឹងបានត្រចះថ្លាជាងពេលថ្ងៃ
ត្រង់[អ] បើសិនជាមានសេចក្ដីងងឹតខ្លះ នោះនឹងបានដូចជា
ពេលព្រឹកព្រាងឡើងវិញ[ក] ១៨អ្នកនឹងបានសាន្តត្រាណដោយ
ព្រោះមានទីសង្ឃឹម អើ អ្នកនឹងស្វែងរកជុំវិញ រួចនឹង
ដេកសំរាក[ខ]ទៅដោយសុខសាន្ត[គ] ១៩អ្នកនឹងដេកទៅឥតមាន
អ្នកណាបំភ័យអ្នកឡើយ[ឃ] ហើយមនុស្សជាច្រើននឹងមកអង្វរ
ដល់អ្នក[ង] ២០ឯភ្នែកនៃពួកមនុស្សអាក្រក់វិញនោះនឹងត្រូវ
ងងឹតទៅ[ច] គេនឹងរកទីពឹងគ្មាន[ឆ] ហើយសេចក្ដីសង្ឃឹមរបស់
គេនឹងបានជាសេចក្ដីស្លាប់នោះឯង[ជ]។

## លោកយ៉ូប

**១២** ១នោះយ៉ូបក៏ឆ្លើយឡើងថា ២គ្មានផ្លូវសង្ស័យឡើយ
មានតែអ្នករាល់គ្នាទេដែលជាមនុស្ស ហើយប្រាជ្ញានឹង

**១១:៥** ជ នក ២០:១៩ យប ២៣:៥ ៣២:១៣ ៣៨:១ **១១:៦** ឈ យប ៩:៤ ១កថ ២:១០ ញ អរ ៩:១៣ យប ១៥:៥ **១១:៧** ដ យប ៥:៩ សស ៣:១១ **១១:៨** ឋ អភ ៣:១៨ ឌ លប ១៥:៥ យប ២២:១២ ២៥:២ ទដ ៥៧:១០ អស ៥៥:៩ ឍ យប ៧:៩ ណ យប ១៥:១៣,២៥ ៣៣:១៣ ៤០:២ ទដ ១៣៩:៨ **១១:៩** ត អភ ៣:១៩–២០ ថ យប ២២:១២ ៣៥:៥ ៣៦:២៦ ៣៧:៥,២៣ អស ៤០:២៦ **១១:១០** ទ យប ៩:១២ វវ ៣:៧ **១១:១១** ធ យប ១០:៤ ៣១:៣៧ ៣៤:១១,២៥ ៣៦:៧ ទដ ១០:១៤ **១១:១២** ន ២របា

៦:៣៦ ប លប ១៦:១២ **១១:១៣** ផ ១សយ ៧:៣ ទដ ៧៨:៨ ព នក ៩:២៩ ភ យប ៥:៨,២៧ **១១:១៤** ម យស ២៤:១៤ យ ទដ ១០១:៤ រ យប ២២:២៣ **១១:១៥** ល យប ២២:២៦ វ ១សយ ២:៩ ទដ ២០:៨ ៣៧:២៣ ៤០:២ ១១៩:៥ អភ ៦:១៤ ស លប ៤:៧ ទដ ៣:៦ **១១:១៦** ហ អស ២៦:១៦ ៣៧:៣ ៦៥:១៦ ឡ យស ៧:៥ យប ២២:១១ ទដ ៥៨:៧ ១១២:១០ អគ ២១:៧ **១១:១៧** អ យប ២២:២៨ ទដ ៣៧:៦ ងស ៥៨:៨,១០ ៦២:១ ក យប ១៧:១២ ១៨:៦ ២៩:៣ ទដ ១៨:២៨ ១១២:៤ ១១៩:១០៥ អស ៥:២០ យហ ៨:១២ **១១:១៨** ខ ទដ ៣:៥ ៤:៨ ១២៧:២ សស ៥:១២ គ លវ ២៦:៦ សភ ៣:២៤ អស ១១:១០ ១៤:៣ ២៨:១២ ៣០:១៥ ៣២:១៨ សក ៣:១០ **១១:១៩** ឃ លវ ២៦:៦ ង អស ៤៥:១៤ **១១:២០** ច ចទ ២៨:៦៥ យប ១៧:៥ ឆ យប ១២:១០ ១៨:១៨ ២៧:២២ ៣៤:២២ ៣៦:៦ ទដ ១៣៩:១១–១២ យរ ១១:១១ ២៣:២៤ ២៥:៣៥ អម ២:១៤ ៩:២–៣ ជ យប ៨:១៣

**១១:៦** ប្រាជ្ញាយ៉ាងតិចមានពីរសណ្ឋាន ។ ប្រាជ្ញាក្នុងគ្រាសញ្ញាចាស់ផ្នែកអក្សរសាស្ត្រ (ជាពិសេស សុភាសិត) ជាការបោះនៃការប្រើនៃពាក្យពេចន៍ក្នុង (សុភាសិត "ពាក្យប្រដៅ និងពាក្យប្រស្នា" ដែលមានលក្ខណៈបង្កប់ន័យជ្រៅៗ លោកសូផារបានយល់ថា លោកយ៉ូបមានការយល់ដឹងរាក់ និងស្ទើៗពីនិស្ស័យរបស់ព្រះ (មើល ខ.៧–៩) ។

**១១:៧** ដោយលក្ខណៈពុំស៊ីជម្រៅ លោកស៊ូផារសង្ឃឹមការថ្លែងពីព្រះយេហូវ៉ាក្នុង ៣៨:១–៤២:៦ ។

**១១:៨–៩** គឺក្នុងរបៀបតែមួយដែលលោកសូផារនិយាយអំពី កំពស់ ជម្រៅ បណ្ដោយ និងទទឹងរបស់ព្រះតំរិះពីព្រះ គឺលោកប៉ុលនិយាយពីសេចក្ដីស្រឡាញ់នៃព្រះ (មើល អភ ៣:១៨) ។

**១១:៨** *តើអ្នកអាចនឹងធ្វើយ៉ាងណាបាន* តើអ្នកអាចឡើងទៅឯនគរស្ថានសួគ៌ ហើយស្វែងរកព្រះតម្រេះនៃព្រះបានទេ ?

**១១:១១–១២** *មនុស្សកំភូត . . . មោឃ* លោកសូផារបានប្រកាសថា គឺតម្រូវឱ្យមានការអស្ចារ្យដើម្បីបំផ្លាស់បំប្រែលោកយ៉ូប ។

**១១:១២** តាមរយៈអត្ថបទគម្ពីរសិក្សានេះ មានលក្ខណៈពីរផ្ទែកផ្ទុយពីអ្វីដែលមានទំនាក់ទំនងគ្នា ប៉ុន្តែ វាជាសត្វដែលមានលក្ខណៈផ្ទុយពីអ្វីដែលនៅក្នុងព្រះគម្ពីរ ដូចជាសត្វលាព្រៃ និងសត្វលាក្នុងស្រុក ។ ដែលមានលក្ខណៈដូចជាមនុស្សមោឃ ពុំអាចឆ្លាតវៃជាងសត្វលាព្រៃដែលអាចយកកំណើតជាលាស្រុក ។

**១១:១៣–២០** សូផារក៏សន្មត់ថា បញ្ហារបស់លោកយ៉ូបគឺបានចាក់ឫសគល់ក្នុងអំពើបាបរបស់គាត់ ។ តែអ្វីដែលលោកយ៉ូបត្រូវធ្វើគឺត្រូវលន់តួអំពើបាបរបស់គាត់ នោះហើយជាឱកាសដែលជីវិតគាត់ទទួលព្រះពរសារជាថ្មី និងភាពសុខសាន្ត ។ ហើយព្រះអម្ចាស់ក៏ធានាឱ្យជីវិតលោកយ៉ូបភ្លឺស្វាងជាងថ្ងៃត្រង់ទៅទៀត (ខ.១៧) ដែលត្រូវទទួលភាពជាកូនព្រះ ។ គឺទ្រង់មានផែនការដែលលើសពីយើងគិត (ខ.១៩) ។ អ្នកទស្សនវិជ្ជាគឺ លោកសូផារហាក់ដូចជាចង់ប្រឆាំងនឹងទស្សនៈក្នុងគម្ពីរ ទដ ៧៣ ។

**១១:១៣** *ហើយប្រវាដៃទៅឯទ្រង់* ដើម្បីអធិស្ឋានរកជំនួយ (មើល នក ៩:២៩ ,១៧,១១ និងការពន្យល់ ទដ ២៨:២ ៤៤:២០ ១៧:២ ៨៨:៩ ១៤១:២ ១៤៣:៦ អស ១:៥ ១ធថ ២:៨) ។

**១១:១៥** *អ្នកនឹងងើបមុខឡើងឥតមានប្រឡាក់អ្វីសោះ* លោកសូផារបានបន្លឺសូរពីគំនិតរបស់លោកយ៉ូប ។

**១១:២០** ប៊ីលដាឌបានបញ្ចប់ការថ្លែងរបស់គាត់ក្នុងរបៀបតែមួយ (សូមមើល ៨:២២) ។

**១២:១–១៤:២២** ដូចពីមុនមកដូច្នេះដែរ ការឆ្លើយរបស់លោកយ៉ូបម្ដងមួយៗទៅចំពោះប្រភពពីរ គឺទៅកាន់មិត្តគាត់ទាំងបី ហើយនិងព្រះអម្ចាស់ (១២:២–១៩:៩ ១៣:២០–១៤:២២) ។

រលត់ទៅជាមួយនឹងអ្នករាល់គ្នាជាពិត[ក]
៣ប៉ុន្តែខ្ញុំក៏មាន
យោបល់ដូចជាអ្នករាល់គ្នាដែរ ខ្ញុំមិនថោកថយជាងអ្នក
រាល់គ្នាទេ តើមានអ្នកណាដែលមិនស្គាល់សេចក្តីយ៉ាង
នោះ[ខ]
៤ខ្ញុំជាទីសើចឡក[គ]ដល់មិត្រសំឡាញ់ខ្ញុំ[ឃ] ជាអ្នកដែល
បានអំពាវនាវដល់ព្រះ ហើយទ្រង់ក៏ឆ្លើយមកផង[ង] គឺជា
មនុស្សសុចរិតត្រឹមត្រូវ ដែលត្រូវគេសើចឡកឱ្យ[ច]
៥ក្នុង
គំនិត[ឆ]នៃអ្នកដែលមានសេចក្តីសុខ នោះតែងមានសេចក្តី
មើលងាយចំពោះគ្រោះថ្នាក់គេ សេចក្តីនោះឯងប្រុង
ប្រៀបសំរាប់អ្នកណាដែលភ្លាត់ជើង[ជ]
៦ទីលំនៅរបស់ពួក
ចោរចេះតែមានសេចក្តីចំរើន[ឈ] ហើយពួកអ្នកដែលធ្វើឱ្យ
ព្រះថ្នាំងថ្នាក់ព្រះហឫទ័យ ក៏តែងមានសេចក្តីសុខ[ញ] គឺជា
ពួកអ្នកដែលទទួលតែអំណាចរបស់ខ្លួនទុកជាព្រះហើយ ។
៧ចូរអ្នកសួរសត្វតិរច្ឆានឥឡូវចុះ វានឹងបង្រៀនអ្នក[ដ]
ហើយសត្វស្លាប ដែលហើរលើអាកាសផង[ឋ] វានឹងប្រាប់ឱ្យ
អ្នកដឹង[ឌ]
៨ឬឱ្យនិយាយនឹងដីចុះ នោះនឹងបង្រៀនអ្នកដែរ
ហើយត្រីនៅសមុទ្រនឹងថ្លែងប្រាប់មកអ្នក
៩ក្នុងពួកទាំងនោះ
តើមានណាមួយដែលមិនដឹង[ឍ]ថា ព្រះហស្តនៃព្រះយេហូវ៉ា
បានបង្កើតទាំងអស់[ណ]
១០ដែលជីវិត[ត]នៃសត្វទាំងឡាយ សុទ្ធ
តែនៅក្នុងព្រះហស្តទ្រង់ ព្រមទាំងខ្យល់ដង្ហើមរបស់មនុស្ស
ផងដូច្នេះ[ថ]
១១ឯត្រចៀក តើមិនស្តាប់លពាក្យសំដី ដូចជា
មាត់ភ្លក់ឱ្យដឹងរសអាហារដែរទេឬអី[ទ]
១២មនុស្សចាស់ៗ
តែងមានប្រាជ្ញា[ធ] ហើយមនុស្សមានអាយុយឺន ទើបមាន
យោបល់[ន]។
១៣ឯព្រះទ្រង់មានទាំងប្រាជ្ញា[ប]និងឥទ្ធិឫទ្ធិផង[ផ] ទ្រង់ក៏
មានព្រះដំរិះ និងយោបល់ដែរ[ព]
១៤មើល ទ្រង់រំលំ[ភ] ហើយ
គេនឹងសង់ឡើងវិញមិនបាន[ម] ទ្រង់រាំងផ្លូវដល់មនុស្ស
ហើយគ្មានអ្នកណាអាចនឹងបើកបានឡើយ[យ]
១៥មើល ទ្រង់
ទប់ទឹក[រ] ហើយទាំងអស់ក៏រីងស្ងួតទៅ[ល] រួចទ្រង់បើកវិញ
នោះក៏ហូរបង្ខូចផែនដីអស់[វ]
១៦ទ្រង់មានកំឡាំងឫទ្ធិ ហើយ
និងប្រាជ្ញា[ស] ក៏កំរាបបានទាំងមនុស្សឆោត និងមនុស្ស
ឆបោកផង[ហ]
១៧ទ្រង់ដឹកនាំពួកអ្នកជួយគំនិតទៅតែខ្លួនទទេ[ឡ]
ហើយប្រគល់ពួកចៅក្រមទៅក្នុងសេចក្តីល្ងីល្ងើ[អ]
១៨ទ្រង់
រំលាយអំណាច[ក]នៃពួកស្តេច ហើយចងខ្សែភ្ជាប់នៅចង្កេះ
ផង[ខ]
១៩ទ្រង់ក៏ដឹកនាំពួកសង្ឃទៅតែខ្លួនទទេ[គ] ហើយទំលាក់
ងារពួកមានអំណាច[ឃ]
២០ទ្រង់ដកពាក្យសំដីពីពួកអ្នកដែល
គួរទុកចិត្តបាន ហើយក៏ដោះយកយោបល់ពីពួកចាស់ទុំ
ចេញ[ង]
២១ទ្រង់ចាក់សេចក្តីមើលងាយទៅលើពួកសេដ្ឋី[ច]

**១២:២** ក យប ១៥:៨ ១៧:១០ **១២:៣** ខ យប ១៣:២ ១៥:៩ **១២:៤** គ លប ៣៨:២៣ ឃ យប ៦:១៤ ១១:៣ ១៦:១០ ១៩:១៤ ង ទដ ៩១:១៥ ច លប ៦:៩ យប ៦:២៩ ១៥:១៦ **១២:៥** ឆ ទដ ១២៣:៤ ជ ទដ ១៧:៥ ៣៧:៣១ ៣៨:១៦ ៦៦:៩ ៧៣:២ ៩៤:១៨ **១២:៦** ឈ យប ៥:២៤ ញ យប ៩:២៤ **១២:៧** ដ យប ៣៥:១១ ឋ មថ ៦:២៦ ឌ យប ១៨:៣ រម ១:២០ **១២:៩** ឍ អស ១:៣ ណ យប ៩:២៤ **១២:១០** ត ដយ ៥:២៣ ថ លប ២:៧ ជន ១៦:២២ យប ១១:២០ កច ១៧:២៨ **១២:១១** ទ យប ៣៤:៣ **១២:១២** ធ ១ពវ ៤:២ យប ១៥:១០ ន ខ.២០ យប ១៧:៤ ៣២:៧,៩ ៣៤:៤,១០ **១២:១៣** ប សភ ២១:៣០ អស ៤៥:៩ ផ យប ៩:៤ យរ ៣២:១៩ ១កថ ១:២៤ ព ជន ២៣:១៩ ១ពវ ៣:១២ យប ៣២:៨ ៣៨:៣៦ សភ ២:៦ អស ៤០:១៣–១៤ ដយ ១:១៧ **១២:១៤** ភ យប ១៦:៩ ១៩:១០ ម ចទ ១៣:១៦ ទដ ១២៧:១ អស ២៤:២០ ២៥:២ អគ ២៦:១៤ យ យប ៩:៣ អស ២២:២២ វវ ៣:៧ **១២:១៥** រ យប ២៨:២៥ អស ៤០:១២ ល ចទ ២៨:២២ ១ពវ ១៧:១ វ លប ៧:២៤ **១២:១៦** ស យប ៩:៤ ហ ២របា ១៨:២២ យប ១៣:៧,៩ ២៧:៤ រម ២:១១ **១២:១៧** ឡ ខ.១៩ យប ១៩:៩ អស ២០:៤ អ យប ៣:១៤ ១កថ ១:២០ **១២:១៨** ក ទដ ១០៧:១៤ ១១៦:១៦ ណហ ១:១៣ ខ ខ.២១ យប ៣៤:១៨ ទដ ១០៧:៤០ អស ៥:២៧ ៤០:២៣ **១២:១៩** គ ខ.១៧ ឃ ចទ ២៤:១៥ យប ៩:២៤ ១៤:២០ ២២:៨ ២៤:១២, ២២ ៣៤:២០,២៨ ៣៥:៩ អស ២:២៣ ៣១:៨ ៤០:១៧,២៣ យរ ២៥:១៨ ដយ ២:២១,៣៤ លក ១:៥២ **១២:២០** ង ខ.១២,២៤ ដយ ៤:៣៣–៣៤ **១២:២១** ច ខ.១៨ អស ៣៤:១២

**១២:៣** *តើអ្នកណាដែលមិនស្គាល់សេចក្តីយ៉ាងនោះ* មើល ខ.៩ គឺជាសេចក្តីប្រឹក្សារបស់មិត្តសំឡាញ់លោកយ៉ូបជាលក្ខណៈធម្មតា ។

**១២:៤** *ទ្រង់ក៏ឆ្លើយមក* គឺក្នុងថ្ងៃមុនៗពេលដែលគាត់ទទួលរងការឈឺចាប់ (ផ្ទុយពី ៩:១៦) ។

**១២:៥** ការប្រមាថ ឬមើលងាយអ្នកមានសេចក្តីសុខ ដូចជាលោកយ៉ូបដែលមានបញ្ហា ។

**១២:៦** ក៏មានសេចក្តីបង្ហាញ (មើល ៩:២១–២៤) បានធ្វើឱ្យអ្នកប្រឹក្សាធុញថប់ដែលធ្វើឱ្យគេសម្គាល់ពីលោកយ៉ូប គឺជាមនុស្សដែលដឹងខ្លួនថាកំពុងតែដួល (មើល ខ.៥) ឬភ្លាត់ជើងដួល ។

**១២:៧–១២** លោកបានបង្ហាញពីការពេញចិត្តនូវស្នាព្រះហស្តរបស់ទ្រង់ដែលធ្វើឱ្យលោកពេញចិត្ត ។

**១២:៩** *ព្រះយេហូវ៉ា* បានលេចឱ្យឃើញក្នុងរឿងលោកយ៉ូប និងការសម្តែងពីមិត្តគាត់ (ជំពូក ៣–៣៧) ដែលមានឈ្មោះពីព្រះយេហូវ៉ា (ព្រះគម្ពីរភាសាហេព្រើរប្រើពាក្យ យ៉ាវេ៍) ដែលបានគេប្រើ (មើលសេចក្តីផ្តើមៈអ្នកនិពន្ធ) ។

**១២:១១** ការផ្សព្វផ្សាយដោយលោកអេលីហ៊ូវក្នុង ៣៤:៣ ប្រៀបធៀប ៦:៦ ដែលលោកយ៉ូបនិយាយថា ពាក្យអេលីផាស គឺទំនងដូចជា "អាហារដែលឥតមានរសជាតិ" ។

**១២:១២** លោកយ៉ូបស្តីបន្ទោស ប្រមាថទីប្រឹក្សារបស់គាត់ចំពោះភាពជាចាស់ទុំ និងដែលខ្វះប្រាជ្ញាដ៏ពិតប្រាកដ ។

**១២:១៣–២៥** ផ្ទៃរឿងក្នុងផ្នែកនេះ គឺបានបង្ហាញក្នុង ខ.១៣ ព្រះអម្ចាស់គឺជាព្រះមហាក្សត្រនៃពិភពលោកនេះ ស្នាព្រះហស្តទ្រង់នឹងជាពិសេសនៅក្នុងប្រវត្តិសាស្ត្រទាំងមូល ។ ក៏មានផ្នែកខ្លះនៃកំណាព្យដែលជាប់ក្នុងទស្សនៈអវិជ្ជមានរបស់អំណាចព្រះចេស្តា និងប្រាជ្ញានៃព្រះ ឧទាហរណ៍កម្លាំងជានិស្ស័យខូចខាត បាត់បង់ (ខ.១៤–១៥) តើពួកចៅហ្វាយទៅជាល្ងីល្ងើដោយរប្រៀបណា (ខ.១៧) តើពួកសង្ឃប្រែក្លាយជាអាម៉ាសមុខ (ខ.១៩) តើអ្នកប្រឹក្សាដែលមានសេចក្តីនៅស្ងៀមស្ងាត់ និងភាពជាចាស់ទុំបានធ្លាក់ទឹកចិត្តចេញពីការល្អដោយវិធីណា (ខ.២០) ។ ក៏មានការផ្ទុយពីការប្រកាសរបស់អេលីផាស ដែលព្រះតែតែងប្រើអំណាចព្រះចេស្តារបស់ផងទ្រង់ក្នុងផ្លូវដែលបង្កើតឱ្យមានន័យ (៥:១០–១៦) ។

**១២:២០** មើលការពន្យល់នៅ ខ.២ ។

**១២:២១ក ២៤ខ** ជាភាសាហេព្រើរជួរបន្ទាត់អត្ថបទនេះ គឺបានរំឭកឡើងវិញត្រង់ក្រោមពាក្យគ្មានល្បៀងក្នុង ទដ ១០៧:៤០ និងការពន្យល់ ។

ក៏បន្ធូរខ្សែក្រវាត់នៃពួកខ្លាំងពូកែ[ឆ] ២២ ទ្រង់បើកអស់ទាំង
សេចក្ដីជ្រៅជ្រះចេញពីងងឹតមក[ជ] ក៏នាំយកម្លប់[ឈ]សេចក្ដី
ស្លាប់ចេញមក ដាក់នៅពន្លឺដែរ[ញ] ២៣ ទ្រង់ចំរើនសាសន៍
ទាំងប៉ុន្មាន[ដ] ហើយក៏បំផ្លាញគេវិញ ទ្រង់ពង្រីកឱ្យគេធំ
ឡើង[ឋ] រួចក៏ដឹកនាំគេទៅជាឈ្លើយ[ឌ] ២៤ ទ្រង់ដកប្រាជ្ញាពីពួក
អ្នកជាប្រធាននៃបណ្ដាជនផែនដីចេញ[ឍ] ហើយបណ្ដាល
ឱ្យគេដើរសាត់ព្រាត់ នៅទីរហោស្ថានដែលឥតមានផ្លូវ
សោះ[ណ] ២៥ គេដើរទ្រាបក្នុងទីងងឹតឥតមានពន្លឺសោះ[ត]ទ្រង់ក៏
ធ្វើឱ្យគេដើរទ្រេតទ្រោតដូចជាមនុស្សស្រវឹងផង[ថ]។

**១៣** ១ មើល គ្រប់ទាំងអស់នេះភ្នែកខ្ញុំបានឃើញហើយ[ក]
ត្រចៀកខ្ញុំក៏បានឮ ហើយយល់ផង ២ អ្វីៗដែលអ្នករាល់គ្នា
ដឹង នោះខ្ញុំក៏ដឹងដែរ ខ្ញុំមិនថោកថយជាងអ្នករាល់គ្នាទេ[ខ]
៣ តែខ្ញុំចង់ទូលដល់ព្រះដ៏មានគ្រប់ព្រះចេស្ដាវិញ[គ] ខ្ញុំប៉ងនឹង
តតបនឹងព្រះតែម្ដង[ឃ] ៤ ឯអ្នករាល់គ្នាសុទ្ធតែជាអ្នកបង្កើត
សេចក្ដីកំភូតទទេ[ង] អ្នករាល់គ្នាជាគ្រូពេទ្យឥតប្រយោជន៍[ច]
ទាំងអស់[ឆ] ៥ ឱបើអ្នករាល់គ្នានឹងនៅស្ងៀមវិញទៅអេះ[ជ]
នោះនឹងសំដែងថា អ្នករាល់គ្នាមានប្រាជ្ញាមែន[ឈ] ៦ ដូច្នេះ
ចូរស្ដាប់សេចក្ដីតតបរបស់ខ្ញុំ ហើយផ្ទៀងត្រចៀកស្ដាប់
សេចក្ដីអង្វររបស់បបូរមាត់ខ្ញុំសិន[ញ] ៧ តើអ្នករាល់គ្នានឹង
និយាយសេចក្ដីទុច្ចរិត ដោយយល់ដល់ព្រះ ព្រមទាំងសេចក្ដី
កំភូតផងឬអី[ដ] ៨ តើចង់យោគយល់ខាងព្រះ[ឋ] ហើយតាំង
ខ្លួនជាអ្នកកាន់ក្ដីជំនួសទ្រង់ឬ ៩ អ្នករាល់គ្នាសុខចិត្តឱ្យទ្រង់
ស្ទង់ចិត្តនៃអ្នកឬទេ[ឌ] ឬអ្នករាល់គ្នាគិតបញ្ឆោតទ្រង់ដូចជា
បញ្ឆោតមនុស្សដែរ[ឍ] ១០ បើអ្នករាល់គ្នាលំអៀង[ណ] ទៅខាង
ណាដោយសំងាត់ នោះប្រាកដជាទ្រង់នឹងបន្ទោសដល់អ្នក
រាល់គ្នាហើយ ១១ តើតេជានុភាព[ត]របស់ទ្រង់មិននាំឱ្យអ្នក
រាល់គ្នាកោតខ្លាច ហើយសេចក្ដីស្ញែងខ្លាចរបស់ទ្រង់មិន
គ្របលើអ្នករាល់គ្នាទេឬ[ថ] ១២ សេចក្ដីដែលអ្នករាល់គ្នា
ពោលអាង នោះសុទ្ធតែជាផេះទាំងអស់ សេចក្ដីដោះសា
របស់អ្នករាល់គ្នា សុទ្ធតែជាភក់ទទេ[ទ]។
១៣ សូមនៅស្ងៀមសិន[ធ] កុំធ្វើខ្ញុំ ខ្ញុំចង់និយាយនឹងអ្នក
រាល់គ្នា[ន] រួចតាមតែកើតជាយ៉ាងណាក៏ដោយចុះ[ប] ១៤ ខ្ញុំនឹង
ចាប់ពាំសាច់របស់ខ្ញុំ ហើយកាន់ជីវិតរបស់ខ្ញុំទុកនៅដៃ
ដូច្នេះធ្វើអី[ផ] ១៥ ទោះបើទ្រង់សំឡាប់ខ្ញុំក៏ដោយ គង់តែខ្ញុំនឹង
ទុកចិត្ត[ព]ដល់ទ្រង់ដែរ[ភ] ប៉ុន្តែខ្ញុំនឹងចេះតែជជែក ពីសេចក្ដី
សុច្ចរិតនៃផ្លូវខ្ញុំនៅចំពោះទ្រង់[ម] ១៦ ហើយនេះនឹងបានជា
សេចក្ដីសង្គ្រោះដល់ខ្ញុំដែរ[យ] គឺថាមនុស្សទមិលល្មើស[រ]នឹង
ចូលទៅនៅចំពោះទ្រង់មិនបាន[ល] ១៧ ចូរប្រុងស្ដាប់សេចក្ដី
របស់ខ្ញុំចុះ[វ] ហើយឱ្យសេចក្ដីថ្លែងប្រាប់របស់ខ្ញុំបានចូលក្នុង
ត្រចៀកអ្នករាល់គ្នាផង ១៨ មើល ឥឡូវនេះ ខ្ញុំបានរៀបរៀង
រឿងខ្ញុំដោយលំដាប់[ស] ខ្ញុំដឹងហើយ ថាខ្ញុំនៅខាងសុច្ចរិត[ហ]
១៩ តើមានអ្នកណាហ៊ានតវ៉ានឹងខ្ញុំ[ឡ] បើមាន នោះខ្ញុំនឹងនៅ
ស្ងៀម[អ] ហើយព្រមប្រគល់វិញ្ញាណទៅវិញ[ក]។

**១២:២១** ឆ យបប ៣:១៥ **១២:២២** ជ ១កថ ៤:៥ ឈ យប ៣:៥ ញ ទដ ១៣៩:១២ ដយ ២:២២ **១២:២៣** ដ ទដ ២:១ ៤៦:៦ អស ១៣:៤ យរ ២៥:៩ ឋ នក ៣៤:២៤ ទដ ១០៧:៣៨ អស ៩:៣ ២៦:១៥ ៥៤:៣ ឌ យប ៥:១២ កថ ១៧:២៦ **១២:២៤** ឍ ខ.២០ ណ ទដ ១០៧:៤០ **១២:២៥** ត ចទ ២៨:២៩ យប ១៨:៦ ២១:១៧ ២៩:៣ ថ ទដ ១០៧:២៧ អស ២៤:២០ **១៣:១** ក យប ៩:២៤ **១៣:២** ខ យប ១២:៣ **១៣:៣** គ យប ៥:១៧ ៤០:២ ឃ យប ៥:៨ ៩:១៤–២០ ១០:២ **១៣:៤** ង ទដ ១១៩:៦៩ អស ៩:១៥ យរ ២៣:៣២ ច យរ ៨:២២ ឆ យប ៦:១៥ **១៣:៥** ជ ខ.១៣ ពច ១៨:១៩ ឈ សភ ១៧:២៨ **១៣:៦** ញ យប ៣៣:១ ៣៦:៤ **១៣:៧** ដ យប ១២:១៦ ១៦:១៧ **១៣:៨** ឋ លវ ១៩:១៥ **១៣:៩** ឌ យប ៩:៣ ឍ យប ១២:១៦ កទ ៦:៧ **១៣:១០** ណ លវ ១៩:១៥ ២របា ១៩:៧ **១៣:១១** ត យប ៣១:២៣ ថ នក ៣:៦ **១៣:១២** ទ នហ ៤:២–៣ **១៣:១៣** ធ ខ.៥ ន យប ៧:១១ ប យប ៩:២១ **១៣:១៤** ផ ពច ៩:១៧ **១៣:១៥** ព យប ៧:៦ ភ ទដ ២៣:៤ ២៧:១ សភ ១៤:៣២ អស ១២:២ ដយ ៣:២៨ ម យប ៥:៨ ២៧:៥ **១៣:១៦** យ ទដ ៣០:៥ អស ១២:១ ៥៤:៧–៨ ហស ១៤:៤ ភល ១:១៩ រ យប ៨:១៣ ល លប ៣:៨ **១៣:១៧** វ យប ២១:២ **១៣:១៨** ស ខ.៣ យប ២៣:៤ ៣៧:១៩ ហ យប ២:៣ ៩:២១ **១៣:១៩** ឡ យប ៤០:៤ អស ៥០:៨ រម ៨:៣៣ អ យប ៩:១៥ ក យប ៣:១៣ ១០:៨

**១២:២២** ព្រះអម្ចាស់ទ្រង់មានញាណដឹង ពីគ្រប់ទាំងផែនការសម្ងាត់របស់អារក្សសាតាំង ។

**១២:២៥** *ក្នុងទីងងឹត* លោកយ៉ូបបញ្ចប់ផ្នែកនេះដោយប្រើពាក្យ ត្រាប់កំប្លែងរិះគន់ ជាការអះអាងយ៉ាងទុកចិត្តរបស់អេលីផាស ក្នុង ៥:១៤ ។

**១៣:១–១២** លោកយ៉ូបមានអារម្មណ៍ថា ទីប្រឹក្សារបស់គាត់ប្រែក្លាយជាអ្នកដែលគួរឱ្យទុកចិត្តបាន (មើល ខ.១២) លោកយ៉ូបហៅពួកគេថា ជាពួកពស់វែក គឺជាពួកស្រែកកោកៗដែលពូកែខាងអួត (មើល ខ.៤ ១៦:២ និងការពន្យល់) ការចោទប្រកាន់ពួកគេដែលបង្ហាញពីការលំអៀងចំពោះព្រះ តាមរយៈការចោទប្រកាន់ក្លែងក្លាយរបស់ពួកគេ (សូមមើល ខ.៧–៨) គឺថ្ងៃណាមួយព្រះនឹងពិនិត្យសាកល្បងពួកគេ និងដាក់ទណ្ឌកម្មពួកគេ (សូមមើល ខ.៩–១១) ។

**១៣:១** *គ្រប់ទាំងអស់នេះ* សកម្មភាពជាព្រះមហាក្សត្ររបស់ព្រះអម្ចាស់គឺបានបង្ហាញក្នុងជំពូក ១២ ។

**១៣:២** មើល ៥:៩ ។ *ខ្ញុំមិនថោកថយជាងអ្នករាល់គ្នាទេ* មើល ១២:៣ និងការពន្យល់ ។

**១៣:៥** មើល ខ.១៣ ពេលដំបូងបង្អស់មិត្តសំឡាញ់លោកយ៉ូបពុំបាននិយាយទៅកាន់លោកយ៉ូបទេ (មើល ២:១៣ និងការពន្យល់) ការស៊ើកសំដីរបស់គាត់ថ្មីៗគឺជាការសើចចំអកប៉ុណ្ណោះ (ប្រៀបធៀប ទដ ១៧:២៨) ។

**១៣:១២** *សេចក្ដីដោះសា* គឺជាជម្លោះក្នុងការដោះសាររបស់ពួកគេចំពោះការកាត់ទោសពីព្រះ ។

**១៣:១៥** ការបញ្ជាក់ពីអ្នកអានទាំងពីរ ដូចជាគ្មានរឿងអ្វីកើតឡើងសោះ ។ តែលោកយ៉ូបកំពុងស្វែងរកភាពយុត្តធម៌ពីព្រះ ហើយលោកសង្ឃឹមថានឹងបានភាពយុត្តធម៌នោះពីព្រះ (មើល ខ.១៨) ។

**១៣:១៦** ដ្បិតខ្ញុំដឹងថា ការនេះបានត្រឡប់ជាសេចក្ដីសង្គ្រោះដល់ខ្ញុំវិញ ដោយអ្នករាល់គ្នាអធិស្ឋានឱ្យខ្ញុំ . . . ភល ១:១៩ (គឺប្រហែលជាលោកប៉ូលចង់និយាយពីបទពិសោធន៍របស់លោកយ៉ូប) ។

**១៣:១៧** លោកយ៉ូបសួរមិត្តរបស់គាត់ឱ្យស្ដាប់នូវអ្វីៗដែលគាត់នឹងនិយាយប្រាប់នោះ ហើយនិយាយទៅកាន់ព្រះអម្ចាស់ក្នុង ១៣:២០–១៤:២២ ។

២០ឱសូមព្រះទ្រង់ប្រោសសេចក្ដីតែ២មុននេះ ដល់ទូល
បង្គំចុះ នោះទូលបង្គំនឹងមិនលាក់ខ្លួនពីព្រះភក្ត្រទ្រង់ឡើយ
២១គឺសូមទ្រង់ដកព្រះហស្ត[ខ]ឱ្យឆ្ងាយពីទូលបង្គំចេញ ហើយ
សូមកុំឱ្យសេចក្ដីស្ញែងខ្លាចរបស់ទ្រង់ មកបំភ័យទូលបង្គំ
ទៀត[គ] ២២នោះសូមទ្រង់ហៅទូលបង្គំចុះ ទូលបង្គំនឹងឆ្លើយ
តប[ឃ] ឬសូមឱ្យទូលបង្គំទូលដល់ទ្រង់ ហើយទ្រង់មានបន្ទូល
ឆ្លើយមកវិញ[ង] ២៣តើសេចក្ដីទុច្ចរិត និងអំពើបាបរបស់ទូល
បង្គំមានប៉ុន្មាន[ច] សូមទ្រង់សំដែងឱ្យទូលបង្គំបានស្គាល់អស់
ទាំងសេចក្ដីរំលង និងអំពើបាបរបស់ទូលបង្គំផង[ឆ] ២៤ហេតុ
អ្វីបានជាទ្រង់លាក់ព្រះភក្ត្រ[ជ] ហើយទុកទូលបង្គំដូចជាខ្មាំង
សត្រូវដូច្នេះ[ឈ] ២៥ទ្រង់នឹងវាយ[ញ]ស្លឹកឈើដែលខ្យល់ផាត់
ទៅមកធ្វើអី[ដ] ហើយដេញតាម[ឋ]ចំបើងក្រៀមឬអី[ឌ] ២៦ហេតុអ្វី
បានជាទ្រង់បានកត់ទុកអស់ទាំងសេចក្ដីជូរល្វីងទាស់នឹងទូល
បង្គំ ហើយឱ្យទូលបង្គំទទួលទោសនៃបាបដែលបានធ្វើពី
កាលនៅក្មេងមកដូច្នេះ[ឍ] ២៧ទ្រង់ដាក់ជើងទូលបង្គំជាប់នៅ
ខ្នោះ[ណ] ក៏ចំណាំមើល អស់ទាំងផ្លូវច្រក[ត]នៃទូលបង្គំ ហើយ
ទ្រង់គូសព្រំដែន មិនឱ្យដានជើងទូលបង្គំរំលងឡើយ
២៨ទោះបើទូលបង្គំប្រៀបដូចជាឈើ ដែលខ្ទូតស៊ីសុស
ហើយដូចជាអាវ[ថ] ដែលកន្លាតបានកាត់អស់ហើយផង[ទ]។

# ១៤

១មនុស្សដែលកើតពីស្រីមក[ក] សុទ្ធតែមានអាយុខ្លីទាំង
អស់ហើយ[ខ]ក៏មានចេក្ដីលំបាកជានិច្ចផង[គ] ២គេចេញមកដូច
ជាផ្កា[ឃ] រួចត្រូវកាត់ដាច់ទៅ[ង] គេរួញថយបាត់ទៅ ដូចជា
ស្រមោល[ច] ឥតនៅស្ថិតស្ថេរឡើយ[ឆ] ៣តើទ្រង់បើកព្រះនេត្រ
ទតមកលើមនុស្សបែបយ៉ាងទូលបង្គំនេះ[ជ] នឹងកោះនាំទូល
បង្គំទៅជាគូក្តីនឹងទ្រង់ឬ[ឈ] ៤តើអ្នកណាអាចនឹងដកយក
របស់ស្អាត[ញ]ចេញពីរបស់ស្មោកគ្រោកបាន[ដ] គ្មានអ្នកណា
ធ្វើបានឡើយ[ឋ] ៥បើថ្ងៃអាយុរបស់មនុស្សនោះបានកំណត់
ស្រេច[ឌ] ហើយចំនួនអស់ទាំងខែ[ឍ]នៃជីវិតរបស់គេបានកត់
នៅនឹងទ្រង់ បើទ្រង់បានដំរូវព្រំខណ្ឌរបស់គេ មិនឱ្យគេ
រំលងហួសឡើយ[ណ] ៦នោះសូមទ្រង់បែរព្រះភក្ត្រចេញពីគេ
ទៅ[ត] ដើម្បីឱ្យគេបានឈប់សំរាកចុះ គឺបែរចេញដរាបដល់
គេបានសំរេចពេលកំណត់ ដូចជាដើងឈ្នួល[ថ] ៧ដ្បិតបើ

**១៣:២១** ខ នក ៩:៣ ហាព ១០:៣១ គ យប ៦:៤ **១៣:២២** ឃ យប ៩:៣៥ ១៤:១៥ ង យប ៩:១៦ **១៣:២៣** ច ១សយ ២៦:១៨ ឆ យប ៧:២១ ៩:២១ ១៤:១៧ ៣៣:៩ **១៣:២៤** ជ ចទ ៣២:២០ ឈ យប ១៦:៩ ១៩:១១ ៣៣:១០ ទដ ៨៨:១៤–១៥ យរ ៣០:១៤ បទ ២:៥ **១៣:២៥** ញ យប ១៩:២ ដ លវ ២៦:៣៦ ឋ យប ១៩:២២,២៨ ឌ យប ២១:១៨ ទដ ១:៤ ៣៥:៥ ៨៣:១២ អស ១៧:១៣ ៤២:៣ ៤៣:១៧ ហស ១៣:៣ **១៣:២៦** ឍ យប ១៨:៧ ២០:១១ ២១:២៣

ទដ ២៥:៧ **១៣:២៧** ណ លប ៣០:១៥ យប ៣៣:១១ យរ ២០:២ កច ១៦:២៤ ត យប ១០:១៤ **១៣:២៨** ថ ទដ ១០២:២៦ មក ២:២១ ទ ចទ ២៨:៣៥ ទដ ៣៩:១១ អស ៥០:៩ ៥១:៨ ហស ៥:១២ យក ៥:២ **១៤:១** ក យប ១៥:១៤ មថ ១១:១១ ខ យប ១០:២០ គ លប ៣:១៧ យប ៧:២ **១៤:២** ឃ ទដ ១០៣:១៥ យក ១:១០ ង ទដ ៣៧:២ ៩០:៥–៦ អស ៤០:៦–៨ ច យប ៨:៩ ទដ ៣៩:៤ ១០២:១១ ១០៩:២៣ ១៤៤:៤ សស ៦:១២ ឆ យប ៤:២០ ទដ ៤៩:១២ **១៤:៣** ជ ទដ ៨:៤ ១៤៤:៣ ឈ យប ៧:១៨ **១៤:៤** ញ ទដ ៥១:១០ ដ យប ៤:១៧ អភ ២:១–៣ ឋ យប ៩:៣០ យហ ៣:៦ រម ៥:១២ ៧:១៤ **១៤:៥** ឌ យប ២៤:១ ទដ ៣១:១៥ ១៣៩:១៦ ឍ យប ២១:២១ ទដ ៣៩:៤ ៩០:១២ ទដ ៣៩:៤ ៩០:១២ ណ កច ១៧:២៦ **១៤:៦** ត យប ៧:១៩ ថ យប ៧:១,២ ទដ ៣៩:១៣ អស ១៦:១៤ ២១:១៦

**១៣:២០** *សេចក្ដីតែ២មុននេះ* គឺលោកយ៉ូបចង់ឱ្យព្រះ (១). ដកព្រះហស្តទ្រង់ចេញកុំដាក់ទណ្ឌកម្មគាត់ទៀត (ខ.២១) និង (២). គឺឱ្យមានទំនាក់ទំនងជាមួយលោកឡើងវិញ (ខ.២២) ។

**១៣:២១** សូមមើល ៩:៣៤ ។

**១៣:២៣** ពាក្យសំដីរបស់លោកយ៉ូបគឺផ្អែកទៅលើចំណុចប្រឹក្សាដែលការឈឺចាប់តែងតែបានកើតដល់អ្នកដែលមានបាប ។ តែលោកយ៉ូបពុំយល់នូវអ្វីៗដែលព្រះមានផែនការសម្រាប់រូបគាត់ គឺដោយការឈឺចាប់ជាមុនសិន ។ *ទាំងសេចក្ដីរំលង និងអំពើបាប* គឺជាការសំខាន់បីពីភាសាហេព្រើរចំពោះពាក្យថា"អំពើបាប" ដែលគេបានបកប្រែមកនេះ (មើល នក ៣៤:៧ មើលការពន្យល់ ទដ ៣២:៥ ៥១:១–២ អស ៥៩:១២) ។

**១៣:២៤** *ទ្រង់លាក់ព្រះភក្ត្រ* (មើលការពន្យល់ ទដ ១៣:១ ) ។

**១៣:២៥** *ស្លឹកឈើដែលខ្យល់ផាត់ទៅមកធ្វើអី . . . ចំបើងក្រៀមឬអី* មើលការពន្យល់ ទដ ១:៤ ។

**១៣:២៦** *ទទួលទោសនៃបាបដែលបានធ្វើពីកាលនៅក្មេងមកដូច្នេះ* គឺតាំងពីលោកយ៉ូបដឹងថា គាត់គ្មានអំពើបាបក្នុងជីវិតទេ គឺព្រះអម្ចាស់បានទទួលរងបាបរបស់លោក មិនឱ្យលោកទទួលរងបាបនោះឡើយ ទ្រង់បានកត់ទុកអស់ទាំងសេចក្ដីជូរល្វីង ។ មើល ទដ ១៣០:៣ ហស ១៣:១២ ដែលផ្ទុយនិង ១កថ ១៣:៥ ។

**១៣:២៧** *ទ្រង់ដាក់ជើងទូលបង្គំជាប់នៅខ្នោះ ក៏ចំណាំមើលអស់ទាំងផ្លូវច្រកទូលបង្គំ* ក្រោយមកលោកអេលីហ៊ូវជាមិត្តលោកយ៉ូប(មើល ៣៣:១១) ក៏ចំណាំមើលអស់ទាំងច្រកនៃទូលបង្គំ ។ គឺជាសញ្ញាត្រារបស់ស្ដេចស្រុកស៊ីណើរ គឺស្ដេចអាំរ៉ាផែល ដែលតាមទម្លាប់គេបោះសញ្ញានេះ នៅលើពួកទាសករ ។ លោកយ៉ូបមានអារម្មណ៍ថា គាត់ត្រូវបានគេធ្វើការរុកកួនតាមរយៈព្រះអម្ចាស់ ដែលយកគាត់ទុកជាឈ្លើយ និងធ្វើទុកបុកម្នេញគាត់ (មើល ខ.២៥) ។

**១៣:២៨–១៤:១** សេចក្ដីផ្ដើមចំពោះជំពូក ១៤ បង្ហាញបញ្ជាក់អំពីផ្ទៃរឿងដែលពោរពេញដោយភាពទុទិដ្ឋនិយម ដែលជាមរតកកេរ្ដិ៍តំណែលសម្រាប់មនុស្សលោក គឺជាបញ្ហាចំពោះមុខ និងវាសនារបស់ពួកគេគឺជាសេចក្ដីស្លាប់ ។

**១៣:២៨** *ដូចជាអាវ ដែលកន្លាតបានកាត់អស់* មើល មថ ៦:១៩–២០ និងការពន្យល់ លក ១២:៣៣ ។

**១៤:១** មើល ៥:៧ និងការពន្យល់ ។

**១៤:២–៦** គឺចំណុចរួមដែលស៊ីចង្វាក់គ្នាត្រង់ ខ.៤ (ខ.២ ដែលឆ្លើយតបនិង ខ.៥ និង ខ.៣,៦) ។ លោកយ៉ូបបានរអ៊ូរត្អូញត្អែរចំពោះព្រះ ដូចជា(មើល ១៣: ២៥) ។

**១៤:២** *ចេញមកដូចជាផ្កា រួចត្រូវកាត់ដាច់ទៅ* ជាជីវិតដែលមានភាពសុខសាន្តដ៏ខ្លីបំផុត(មើល ៨:៩ ទដ ៣៧:២ អស ៤០:៧,២៤ ធៀបនឹង ១:១០)។ *ដូចជាស្រមោល ឥតនៅស្ថិតស្ថេរឡើយ* មើលការពន្យល់ ៨:៩ ។

ដើមឈើត្រូវកាប់រំលំទៅ នោះមានសង្ឃឹមថា[ទ] នឹងពន្លក
ឡើងទៀត ហើយថា នឹងមិនខានមានមែកខ្ចី[ធ]ទៀតឡើយ[ន]
៨ហើយទោះបើឫសក្រៀមទៅ ហើយគល់[ប]ងាប់នៅក្នុងដី
៩គង់តែនឹងប៉ិចឡើង ដោយធុំក្លិនទឹក[ផ] ព្រមទាំងបែកមែក
ដូចជា ដើមថ្មីវិញ[ព] ១០ឯមនុស្សវិញ គេស្លាប់ ហើយក៏ពុក
រលួយទៅ[ភ] អើ មនុស្សប្រគល់វិញ្ញាណទៅ នោះតើគេនៅ
ឯណា[ម] ១១ឯទឹកភ្លៀងខានមកពីសមុទ្រ រួចស្ទឹងរីងស្ងួតទៅ
យ៉ាងណា[យ] ១២នោះមនុស្សក៏ដេកទៅឥតក្រោកឡើងទៀត
យ៉ាងនោះដែរ[រ] គេនឹងមិនភ្ញាក់ឡើងវិញ[ល] ឬអ្នកណាដាស់
ឱ្យគេភ្ញាក់ពីដេកឡើងឡើយ ដរាបដល់ផ្ទៃមេឃសូន្យបាត់
ទៅ[វ]។

១៣ឱបើទ្រង់នឹងលាក់ទូលបង្គំ នៅស្ថានឃុំព្រលឹងមនុស្ស
ស្លាប់ទៅអេះ[ស] ហើយទុកទូលបង្គំនៅទីស្ងាត់កំបាំងដរាប
ដល់សេចក្ដីក្រោធរបស់ទ្រង់ កន្លងបាត់ទៅ[ហ] ហើយដំរូវ
ឱ្យមានពេលកំណត់ដល់ទូលបង្គំ រួចនឹកចាំ[ឡ]ពីទូលបង្គំផង[អ]
១៤បើមនុស្សស្លាប់ទៅ តើនឹងមានជីវិតរស់ឡើងទៀតឬ[ក]
បើមាន នោះទូលបង្គំនឹងរង់ចាំអស់រវាងសង្គ្រាមវេទនា[ខ]
របស់ទូលបង្គំ ដរាបដល់កំណត់ដែលទូលបង្គំបានរតល
ចេញទៅ ១៥នោះទ្រង់នឹងហៅ ហើយទូលបង្គំនឹងទូលតប[គ]
ហើយទ្រង់នឹងមានបំណងព្រះហឫទ័យដល់ស្នាដៃដែល
ទ្រង់បានធ្វើ[ឃ] ១៦តែសព្វថ្ងៃនេះ ទ្រង់រាប់អស់ទាំងជំហាន
ទូលបង្គំវិញ[ង] តើទ្រង់មិនត្រួតមើលអស់ទាំងអំពើបាបរបស់
ទូលបង្គំផងទេឬអី[ច] ១៧សេចក្ដីរំលងរបស់ទូលបង្គំបានខ្ចប់
បិទត្រា[ឆ]ទុក[ជ] ហើយទ្រង់បិទភ្ជាប់អំពើអាក្រក់របស់ទូល
បង្គំផង[ឈ]។

១៨ឯភ្នំដែលរលុះបាក់ចុះ នោះត្រូវខ្ទេចខ្ទី[ញ] ហើយថ្ម
ត្រូវខ្ទាត់ចេញពីកន្លែងទៅ[ដ] ១៩ឯទឹកក៏ហូរបន្សឹកថ្ម ហើយ
ជំនន់[ឋ]ក៏ហូរចំរោះដី[ឌ] គឺយ៉ាងនោះដែលទ្រង់បំផ្លាញសេចក្ដី
សង្ឃឹមរបស់មនុស្សទៅ[ឍ] ២០ទ្រង់កំរាបគេជាដរាប រួចគេ
បាត់ទៅ[ណ] ទ្រង់បំផ្លាស់បំប្រែភាពរបស់គេ ហើយកំចាត់គេ
ទៅ[ត] ២១កូនចៅរបស់គេមានកិត្តិយសឡើង តែគេមិនដឹងទេ
វាត្រូវបន្ទាបចុះ តែគេមិនសំគាល់ដឹងអ្វីសោះ[ថ] ២២គេដឹង
ឈឺតែចំពោះខ្លួនគេ[ទ] ហើយមានសេចក្ដីទុក្ខព្រួយតែចំពោះ
ចិត្តខ្លួនប៉ុណ្ណោះ[ធ]។

## លោកអេលីផាស

**១៥** ១នោះអេលីផាស សាសន៍ថេម៉ាន[ក] ក៏ឆ្លើយឡើងថា
២តើគួរឱ្យអ្នកប្រាជ្ញឆ្លើយ ដោយសេចក្ដីចេះដឹងអសារឥត
ការ ឬបំពេញចិត្តដោយខ្យល់ពីខាងកើតឬទេ[ខ] ៣តើគួរនឹង
ជជែកដោយសំដីឥតប្រយោជន៍ ឬដោយពាក្យអធិប្បាយ
ដែលបង្កើតសេចក្ដីល្អមិនបានឬអី[គ] ៤អើ អ្នកបំផ្លាញសេចក្ដី
កោតខ្លាចដល់ព្រះ ហើយឃាត់ឃាំងសេចក្ដីនឹកជញ្ជឹង
នៅចំពោះព្រះផង[ឃ] ៥ដ្បិតសេចក្ដីអាក្រក់[ង]របស់អ្នកបញ្ចេះ
ឱ្យមាត់អ្នកនិយាយចេញមក[ច] ហើយអ្នកប្រើពាក្យសំដីរបស់
មនុស្សឧបាយអាក្រក់[ឆ] ៦គឺមាត់របស់អ្នកដែលកាត់ទោស
ដល់ខ្លួនហើយ មិនមែនជាខ្ញុំទេ អើ បបូរមាត់របស់អ្នកធ្វើ
បន្ទាល់ទាស់នឹងខ្លួនអ្នក[ជ]។

**១៤:៧** ទ យបប ១៩:១០ ២៤:២០ ទដ ៥២:៥ ធ អស ១១:១ ៥៣:២ ៦០:២១ ន អស ៦:១៣
**១៤:៨** ប អស ៦:១៣ ១១:១ ៥៣:២
**១៤:៩** ផ យប ២៩:១៩ ទដ ១:៣ យរ ១៧:៨ អគ ៣១:៧ ព លវ ២៦:៤ អគ ៣៤:២៧ សក ១០:១
**១៤:១០** ភ ខ.១២ ម យប ១០:២១ ១៣:១៩
**១៤:១១** យ ២សយ ១៤:១៤
**១៤:១២** រ ខ.១០ ល កច ៣:២១ វ ទដ ១០២:២៦ វវ ២០:១១ ២១:១
**១៤:១៣** ស យប ៧:៩ ហ ទដ ៣០:៥ អស ២៦:២០ ៥៤:៧ ឡ លប ៨:១ អ យប ៦:៨
**១៤:១៤** ក ២ពវ ៦:៣៣ ខ យប ៧:១
**១៤:១៥** គ យប ១៣:២២ ឃ យប ១០:៣
**១៤:១៦** ង យប ១០:៤ ទដ ១៣៩:១–៣ សភ ៥:២១ យរ ១៦:១៧ ៣២:១៩ ច យប ១០:៦ ១កថ ១៣:៥
**១៤:១៧** ឆ យរ ៣២:១០ ជ ចទ ៣២:៣៤ ឈ យប ៩:៣០ ១៣:២៣ **១៤:១៨** ញ អគ ៣៨:២០ ដ យប ១៨:៤ **១៤:១៩** ឋ អគ ១៣:១៣ ឌ លប ៧:២៣ ឍ យប ៧:៦ **១៤:២០** ណ យប ៤:២០ ត យប ៧:១០ ៨:១៨ ១២:១៩ ២៧:១៩ យក ១:១០ **១៤:២១** ថ យប ២១:២១ សស ៩:៥ អស ៦៣:១៦ **១៤:២២** ទ ទដ ៣៨:៧ អស ២១:៣ យរ ៤:១៩ ធ យប ២១:២១ **១៥:១** ក យប ៤:១ **១៥:២** ខ លប ៤១:៦ **១៥:៣** គ នហ ៤:២–៣ យប ៦:២៦ **១៥:៤** ឃ យប ២៥:៦ **១៥:៥** ង យប ១១:១៦ ២២:៥ ច សភ ១៦:៣៣ ឆ យប ៥:១៣ **១៥:៦** ជ យប ៩:១៥ ១៨:៧ ទដ ១០:២ មថ ១២:៣៧ លក ១៩:២២

**១៤:៧–១២** មនុស្សគឺដូចជាផ្កាដែលមានជីវិតរយៈពេលខ្លីបំផុត ហើយក៏បាត់បង់ទៅវិញ (ខ.២) គឺមិនដូចជាដើមឈើដែលបានលូតលាស់ឡើងវិញ បន្ទាប់ពីបានកាត់ទម្លាក់ចុះ ។

**១៤:៧** *ពន្លក* ឫសគល់ចេញពីព្រះគម្ពីរភាសាហេព្រើរ ចំពោះពាក្យនេះបកប្រែមក មានន័យថា "បង្កើតឡើងវិញ" ក្នុង ខ.១៤ ។

**១៤:១៣–១៧** វិញ្ញាណលោកយ៉ូប ឥឡូវបង្ហាញឱ្យឃើញពីភាពលេចឡើងនូវការអស់សង្ឃឹមដែលទាក់ទង និងរូបកាយដែលអាចពុករលួយទៅវិញ ។ ទោះបីការរស់ឡើងវិញពុំបានបង្រៀននៅផ្នែកនេះក៏ដោយ ក៏លោកយ៉ូបថា ព្រះទ្រង់អាចលាក់លោកក្នុងផ្នូរ និងរស់ឡើងវិញក្នុងខណៈពេលមួយនោះ ។

**១៤:១៤** ភាពវេទនារបស់ទូលបង្គំ ។

**១៤:១៨–២២** ភាពទុទិដ្ឋនិយមរបស់លោកយ៉ូបក៏មិនមែនជាមនុស្សដែលចេះតែសង្ស័យអំពីលទ្ធផលនៃការរស់ឡើងវិញពីការស្លាប់ ក៏ប៉ុន្តែវាប្រសើរជាងការដែលមិនមែនជាព្រះហឫទ័យរបស់ព្រះអម្ចាស់ក្នុងការធ្វើអ្វីៗភ្លាមៗ ដូចជាបុគ្គលដូចគាត់ដូច្នេះដែរ ដែលមានជីវិតក្លាយជាអ្នកមានក្ដីស្រមៃពីការឈឺចាប់ និងការកាន់ទុក្ខ ។

**១៥:១–៥** មកដល់ចំណុចនេះ លោកអេលីផាស បានសង្កត់ទៅលើទីប្រឹក្សាបីនាក់ តែឥឡូវបានរត់ចេញពីភាពឈឺចាប់ជាមួយលោកយ៉ូប ក៏ប្រកាសបដិសេធពីលោក ។

**១៥:២** *អសារឥតការ* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះត្រូវគេបកប្រែមកថា "ខ្យល់រយៈពេលវែង" ក្នុង ១៦:៣ គឺកន្លែងនោះដែលលោកយ៉ូបបកត្រឡប់ទៅវិញយ៉ាងខ្លាំង ចំពោះលោកអេលីផាស ។ *ខ្យល់ពីទិសខាងកើត* គឺជាខ្យល់ជំនោរដែលបក់មកពីវាលរហោស្ថាន (២៧:២១ ៣៨:២៤ សូមមើលការពន្យល់ លប ៤១:៦ យរ ៤:១១) ។

**១៥:៤** មើលការពន្យល់ ៤:៦ ។

**១៥:៥** មើលការពន្យល់ មថ ១៥:១១,១៧–១៨ ។

**១៥:៦** *គឺមាត់របស់អ្នកដែលកាត់ទោសដល់ខ្លួន* មើល ៩:២០ ។

៧តើអ្នកជាមនុស្សមុនដំបូងដែលកើតមកឬ[ឈ] តើអ្នកបាន
លេចមកមុនអស់ទាំងភ្នំដែរឬ[ញ] ៨តើអ្នកបានឮសេចក្តី
ប្រឹក្សាដ៏កំបាំងរបស់ព្រះឬ[ដ] តើអ្នកស្មានថា មានតែខ្លួនអ្នក
១ទេ ដែលមានប្រាជ្ញាឬអី[ឋ] ៩តើអ្នកចេះអ្វីដែលពួកយើងមិន
ចេះដែរ ឬយល់អ្វីដែលពួកយើងមិនបានយល់ផងនោះ[ឌ]
១០ខាងយើងមានទាំងមនុស្សក្បាលស្កូវ និងមនុស្សអាយុ
ច្រើន[ឍ] ដែលចាស់ជាងឪពុកអ្នកទៅទៀត[ណ] ១១តើអ្នករាប់
សេចក្តីកំសាន្ត[ត]របស់ព្រះថា មិនគ្រាន់ដល់អ្នក ព្រមទាំង
សេចក្តី[ថ]ដែលទ្រង់មានបន្ទូលមកអ្នក ដោយផ្អែមពីរោះ
ផងឬអី[ទ] ១២ហេតុអ្វីបានជាអ្នកបណ្តោយទៅតាមចិត្ត[ធ] ហើយ
មិចភ្នែកដូច្នេះ ១៣ហេតុអ្វីបានជាអ្នកបំបែរចិត្តទៅទាស់[ន]
នឹងព្រះ ហើយបណ្តោយឱ្យមាត់ពោលសេចក្តី[ប]យ៉ាងនេះ
ចេញមក[ផ] ១៤តើមនុស្សជាអ្វីដែលនឹងត្រូវបានបរិសុទ្ធ
ជាមនុស្សកើតមកពីមនុស្សស្រី[ព] ដែលនឹងត្រូវបានសុច្ចរិត
នោះ[ភ] ១៥មើល ទ្រង់មិនទុកចិត្តនឹងពួកបរិសុទ្ធរបស់ទ្រង់[ម]
ហើយផ្ទៃមេឃក៏មិនបរិសុទ្ធ នៅព្រះនេត្រទ្រង់ដែរ[យ]
១៦ចំណង់បើម្នាក់ដែលគួរតែខ្ពើម ហើយស្មោកគ្រោក[រ] ជា
អ្នកដែលផឹកសេចក្តីអាក្រក់[ល]ដូចជាទឹក[វ] តើនឹងជាយ៉ាងណា
ទៅ ។

១៧ខ្ញុំនឹងសំដែងឱ្យអ្នកដឹង ចូរស្តាប់ចុះ ខ្ញុំនឹងថ្លែងប្រាប់ពី
សេចក្តីដែលខ្ញុំបានឃើញហើយ[ស] ១៨គឺជាសេចក្តីដែលពួក
អ្នកប្រាជ្ញបានពោលមក តាំងតែពីពួកឰយុកោគេ ឥតលាក់
ទុកឡើយ[ហ] ១៩ជាពួកតែ១ដែលបានទទួលគ្រងស្រុក[ឡ] ឥត
មានសាសន៍ដទៃណាចូលមកក្នុងពួកគេឡើយ ២០គឺថា
មនុស្សអាក្រក់រមែងរងទុក្ខ[អ] ដោយឈឺចាប់គ្រប់១ជីវិត
របស់គេ ឯអស់ចំនួនឆ្នាំគេបានលាក់ទុកសំរាប់មនុស្ស
គំហកកំហែង[ក] ២១មានសូរគួរស្ញែងខ្លាចឮដល់ត្រចៀកគេ[ខ]
ក្នុងពេលដែលកំពុងតែចំរើន នោះមេបំផ្លាញនឹងមកលើ
គេ[គ] ២២គេគ្មានសង្ឃឹមនឹងត្រឡប់ពីទីងងឹតមកវិញទេ[ឃ]
ហើយក៏ស្មានថា មានដាវនៅរង់ចាំគេដែរ[ង] ២៣គេដើរ
ចេញទៅឯទីនេះផងនោះផង[ច] រកអាហារបរិភោគ[ឆ]ទាំង
សួរថា តើនៅឯណា គេស្មានប្រាកដថា វេលាលំបាក[ជ]ជិត
មកដល់គេហើយ[ឈ] ២៤មានទុក្ខលំបាក និងសេចក្តីចង្អៀត
ចិត្ត[ញ]មកបំភ័យគេ[ដ] ក៏បង្ក្រាបឈ្នះគេ ដូចជាស្តេច[ឋ]ណា ដែល
រៀបជាស្រេចនឹងទៅច្បាំង ២៥ពីព្រោះគេបានលូកដៃ[ឌ]ទៅ
ទាស់នឹងព្រះ ហើយក៏ប្រព្រឹត្តដោយឆ្មើងឆ្មៃ នៅចំពោះព្រះ

**១៥:៧** ឈ យប ៣៨:២១ ញ ១សយ ២:៨ ទដ ៩០:២ សភ ៨:២៥ **១៥:៨** ដ យប ២៩:៤ អស ៩:៦ ៤០:១៣ ៤១:២៨ យរ ២៣:១៨ រម ១១:៣៤ ១កថ ២:១១ ឋ យប ១២:២ **១៥:៩** ឌ យប ១២:៣ **១៥:១០** ឍ យប ១២:១២ ណ ២របា ១០:៦ **១៥:១១** ត លប ៣៧:៣៥ យប ៦:១០ ២កថ ១:៣–៤ ថ សក ១:១៣ ទ ចទ ៨:៣ ៣២:៣៩ យប ៥:១៧ ២២:២២ ២៣:១២ ៣៦:១៦ ទដ ១១៩:១១,៧២ យរ ១៥:១៦ **១៥:១២** ធ យប ១១:១៣ ៣៦:១៣ **១៥:១៣** ន សភ ២៩:១១ ដយ ១១:៣០ ប ទដ ៩៤:៤ ផ យប ១១:៨

២២:៥ ៣២:៣ **១៥:១៤** ព យប ១៤:១ ភ ២របា ៦:៣៦ យប ៤:១៧ **១៥:១៥** ម យប ៥:១ យ យប ៤:១៨ **១៥:១៦** រ លវ ៥:២ យប ៤:១៩ ទដ ១៤:១ ល យប ២០:១២ វ យប ១២:៤ ៣៤:៧ **១៥:១៧** ស យប ៤:៨ **១៥:១៨** ហ ចទ ៣២:៧ **១៥:១៩** ឡ លប ១២:១ យប ២២:៨ **១៥:២០** អ ខ.២៤ អស ៨:២២ ៥០:១១ ៦៦:២៤ ក យប ២៤:១ ២៧:១៣–២៣ អស ២:១២ យរ ៤៦:១០ អប ១:១៥ សផ ១:៧ **១៥:២១** ខ ខ.២៤ ១សយ ៣:១១ យប ១៨:១១ ២០:២៥ យរ ៦:២៥ ២០:៣ គ យប ២២:១០ ២៧:២០ អស ១៣:៣ យរ ៥១:២៥,៥៣, ៥៦ ១ថន ៥:៣ **១៥:២២** ឃ ខ.២៣ យប ៥:១៤ ២៤:១៧ ៣៨:១៥ ទដ ៩១:៥ ៣:៨ ង យប ១៦:១៣ ១៨:១៩ ១៩:២៩ ២០:២៤ ២៧:១៤ ៣៣:១៨ ៣៦:១២ សភ ៧:២៣ អស ១:២០ យរ ៤៤:២៧ ហស ៩:១៣ អម ៥:១៩ **១៥:២៣** ច ទដ ១០៩:១០ ឆ សភ ៣០:១៧ អគ ៣៩:១៧ មថ ២៤:២៨ លក ១៧:៣៧ ជ ខ.២២ ឈ យប ១៨:១២ **១៥:២៤** ញ អស ៨:២២ ៩:១ ដ ខ.២០ ឋ យប ១៨:១៤ **១៥:២៥** ឌ ទដ ៤៤:១៦ អស ១០:៣២ ៣៧:២៣

**១៥:៧–១០** លោកយ៉ូបបាននិយាយថា លោកអេលីផាសបានសង្ឃឹមថា គាត់មានភាពឆ្លាតដែលអាចអង្គុយក្នុងចំណោមសមាជិកក្រុមប្រឹក្សានៃព្រះ ឯនគរស្ថានសួគ៌(មើលការពន្យល់ ១:៦)តែតាមលក្ខណៈពិតជាក់ស្តែងគាត់ពុំបានឆ្លាតគ្រប់ល្មមដូចពួកចាស់ទុំ ឬអ្នកប្រាជ្ញធម្មតាផង នៅលើផែនដីនេះ ។

**១៥:១០** ក្នុងយុគ្គសម័យដើម ប្រាជ្ញាបានទាក់ទងនឹងអាយុកាលដែលបានកើតឡើង(ប្រៀបធៀប ៣២:៦–៩) ។

**១៥:១១–១៣** លោកអេលីផាសក៏ស្តីបន្ទោសលោកយ៉ូបចំពោះការឆ្លើយតបដោយកំហឹងទៅការប្រឹងប្រែងរបស់មិត្តគាត់ ដែលគេឱ្យជាយោបល់ដល់គាត់ ដោយពាក្យស្លូតបូត(ខ.១១) ។ តែលោកអេលីផាសបានធ្វើបាបប្រព្រឹត្តបាបពីការពោលពាក្យបញ្ឆិតបញ្ឆៀងដ៏អាក្រក់(ជំពូក ៥) និងប្រឹក្សាពីរនាក់ទៀត ក៏បានព្យាបាទខ្លាំងណាស់ដែរ ។ ពាក្យសម្តីត្រង់ៗនៃការកម្សាន្តចិត្តលោកយ៉ូប(មើល ៤:២–៦)។

**១៥:១៤–១៦** មើល ២៥:៤–៦ គឺលោកអេលីផាសបានរំឭកនៅអ្វីដែលគាត់បាននិយាយ ក្នុង ៤:១៧–១៩ (មើលការពន្យល់ ៤:១២–២១) ។ គឺជាសំដីបើកសំដែងពីព្រះ(មើលការពន្យល់ ៤:១២–២១) ។

**១៥:១៤** *កើតមកពីមនុស្សស្រី* គឺជាការលេចចេញពីពាក្យរបស់លោកយ៉ូប មើល ១៤:១ ។

**១៥:១៥** *ពួកបរិសុទ្ធ* ទេវតាទាំងឡាយ (មើលការពន្យល់ ៥:១) ។

**១៥:១៦** *ជាអ្នកដែលផឹកសេចក្តីគ្រោត* ត្រង់ចំណុចនេះ មើលការពណ៌នារបស់លោកអេលីហ៊ូវ អំពីលោកយ៉ូប ក្នុង ៣៤:៧ ។

**១៥:១៧–២៦** ឥឡូវលោកអេលីផាសមានសេចក្តីអួតពីការប្រឹក្សារបស់គាត់តាំងពីដំបូងបង្អស់ទៅនិងប្រាជ្ញាដែលជាប្រពៃណី : ដូចជា ការអាក្រក់ក៏ពុំអាចគេចចេញពីសេចក្តីឈឺចាប់ដែលគេបានប្រព្រឹត្តដែរ ។

**១៥:២០–៣៥** គឺជាកំណាព្យសម្តែងពីវាសនារបស់ពួកអាក្រក់(មើល ៨:១១–១៩)។ លោកអេលីផាសបន្តទាក់ទងនឹងផ្នែកជាច្រើន : ជាអ្នកមានបាបដែលលោភសង្គ្រាមប្រឆាំងនឹងព្រះ(ខ.២៤–២៦) អ្នកអាក្រក់គេនិងទទួលរងទុក្ខសមដែលពួកគេបានធ្វើ(ខ.២៧–៣២)ដើមទំពាំងបាយជូរគេចងមុនពេលផ្លែរបស់វាទុំ(ខ.៣៣)ក៏ដូច្នេះដែរ គឺរហូតដល់លោកអេលីផាសបដិសេធនូវការរឹងរូសរបស់លោកយ៉ូប ។ គឺខណៈដែលមនុស្សនៅតែទទួលនូវភាពសុខសាន្ត ហើយគាត់ក៏មិនបានប្រទូសារ៉ាយជាមួយនិងការជ្រែកចូលរំខានដែរ : ក៏ជាអាថ៌កំបាំងចំពោះអ្នកដែលគ្មានកំហុស ជួនកាលបែរជាត្រូវជាអ្នកទទួលរងទោសទៅវិញ ។

**១៥:២៣–៣០** *ទីងងឹតមក* ជាសេចក្តីស្លាប់ ជាចរិតលក្ខណៈមួយដោយការធ្វើដំណើរទៅឯស្ថានក្រោមដី គឺជាស្ថាននៃសេចក្តីងងឹត និងម្លប់នៃ

ដ៏មានគ្រប់ព្រះចេស្ដា[ឍ] ២៦ គេរត់ទៅលើទ្រង់ដោយកត្រង់
ហើយបាំងខ្លួននឹងពកខែលយ៉ាងក្រាស់[ណ] ២៧ ព្រោះគេមាន
សាច់មុខធាត់ពេញ ហើយបានឡើងសាច់ខ្ទន់ៗនៅចង្កេះ
ផង[ត] ២៨ គេអាស្រ័យនៅក្នុងទីក្រុងស្ងាត់ឈឹង ក្នុងផ្ទះឥតមាន
មនុស្សនៅ[ថ] ដែលហៀបនឹងរលំហើយ[ទ] ២៩ គេនឹងមិនដែល
បានជាអ្នកមាន ហើយទ្រព្យសម្បត្តិគេក៏មិនគង់នៅដែរ[ធ]
ឯធនធានរបស់គេ ក៏មិនបានដុះដាល នៅផែនដីឡើយ[ន]
៣០ គេនឹងចេញពីសេចក្ដីងងឹតមិនរួច[ប] អណ្ដាតភ្លើង[ផ]នឹងធ្វើ
ឱ្យមែកគេស្វិតក្រៀមទៅ[ព] ហើយគេនឹងត្រូវផាត់បាត់ទៅ[ភ]
ដោយខ្យល់ពីព្រះឱស្ឋ[ម]នៃទ្រង់ ៣១ កុំបីឱ្យគេបញ្ឆោត[យ]ខ្លួន
ដោយទុកចិត្តនឹងសេចក្ដីអសារឥតការឡើយ[រ] ដ្បិតយ៉ាង
នោះ សេចក្ដីអសារឥតការនឹងបានជារង្វាន់ដល់គេ[ល]
៣២ ការនោះនឹងបានសំរេចមុនពេលកំណត់[វ]របស់គេផង[ស]
ឯមែក គេនឹងមិនបានខៀវស្រស់ទៀតទេ[ហ] ៣៣ គេនឹង
រលាស់ជិរុះផ្លែខ្ចីរបស់ខ្លួនអស់ទៅ ដូចជាដើមទំពាំងបាយ
ជូរ[ឡ] ហើយនិងឱ្យផ្កាខ្លួនជ្រុះចុះ ដូចជាដើមអូលីវដែរ[អ]
៣៤ ដ្បិតពួកមនុស្សទមិលល្មើស[ក]នឹងកើតផលមិនបាន ហើយ
ភ្លើងនឹងឆេះបន្សុស[ខ]ទីលំនៅរបស់ពួកដែលស៊ីសំណូកផង[គ]
៣៥ គេមានគភ៌បង្កើតជាសេចក្ដីអាក្រក់[ឃ] ហើយក៏សំរាល
ចេញមកជាសេចក្ដីទុច្ចរិត[ង] ឯចិត្តគេ តែងតែរៀបឧបាយ
ទុក ។

## លោកយ៉ូប

**១៦** ១ នោះយ៉ូបក៏ឆ្លើយឡើងថា ២ ខ្ញុំបានឮសេចក្ដីយ៉ាង
នោះជាច្រើនហើយ អ្នករាល់គ្នា[ក]សុទ្ធតែជាអ្នកកំសាន្តចិត្ត[ខ]
ដែលនាំឱ្យល្វើយវិញ ៣ តើពាក្យជាអសារឥតការទាំងនេះ
នឹងចប់ចុះត្រឹមណា[គ] តើមានអ្វីបណ្ដាលឱ្យអ្នករាល់គ្នាតប
មកដូច្នេះ[ឃ] ៤ ខ្ញុំក៏និយាយដូចជាអ្នករាល់គ្នាបានដែរ បើ
សិនជាព្រលឹងនៃអ្នករាល់គ្នា នៅក្នុងសណ្ឋាននៃព្រលឹងខ្ញុំ
នោះខ្ញុំនឹងប្រមុំពាក្យមកទាស់នឹងអ្នករាល់គ្នា ព្រមទាំង
គ្រវីក្បាល[ង]នឹងអ្នកបានដែរ ៥ ប៉ុន្តែខ្ញុំនឹងបញ្ចេញពាក្យចំរើន
កំឡាំង[ច]ដល់អ្នករាល់គ្នាវិញ ហើយបបូរមាត់ខ្ញុំនឹងរកបន្ធូរ
ទុក្ខរបស់អ្នករាល់គ្នាដែរ[ឆ]។
៦ តែឥឡូវនេះ ទោះបើខ្ញុំនិយាយទៅ គង់តែសេចក្ដីទុក្ខ
ព្រួយរបស់ខ្ញុំមិនអន់ថយដែរ ហើយបើស្ងៀមនៅ នោះតើ
ខ្ញុំបានធូរយ៉ាងណា[ជ] ៧ ព្រះទ្រង់បានធ្វើឱ្យខ្ញុំល្វើយទៅ[ឈ] ឱ
ព្រះអង្គអើយ ទ្រង់បានបំភាំងពួកមិត្ររបស់ទូលបង្គំទាំង
អស់ហើយ[ញ] ៨ ក៏បានធ្វើឱ្យទូលបង្គំជ្រួញសាច់ នោះជាទី
បន្ទាល់១ ហើយអាការៈស្គាំងស្គម[ដ]របស់ទូលបង្គំ ក៏ឡើងធ្វើ
បន្ទាល់នៅមុខទូលបង្គំទៀត[ឋ] ៩ ព្រះទ្រង់បានហែកហួរ[ឌ]ខ្ញុំ
ដោយសេចក្ដីកំហឹង[ឍ]របស់ទ្រង់ ព្រមទាំងស្អប់ខ្ញុំផង ទ្រង់
សង្កៀតធ្មេញដាក់ខ្ញុំ[ណ] ខ្មាំងសត្រូវរបស់ខ្ញុំបានសំលៀងភ្នែក
ទាស់នឹងខ្ញុំ[ត] ១០ ពួកគេបានហាមាត់[ថ]គំរាមខ្ញុំ[ទ] គេបានទះ
កំផ្លៀងបង្អៀនខ្ញុំ[ធ] ហើយប្រមូលគ្នាទាស់នឹងខ្ញុំ[ន] ១១ ព្រះទ្រង់
បានប្រគល់ខ្ញុំទៅឯអាទមិលល្មើស ហើយបានបោះបង់
ចោលខ្ញុំទៅក្នុងកណ្ដាប់ដៃនៃមេកំណាច[ប] ១២ ពីដើមខ្ញុំមាន
សេចក្ដីសុខ តែទ្រង់បានបំបាក់បំបែកខ្ញុំ អើ ទ្រង់បានចាប់
កញ្ចឹងកខ្ញុំ ទាំងបោកខ្ញុំកំទេចផង[ផ] ក៏បានបញ្ឈរខ្ញុំឡើង
ទុកជាទីវង់របស់ទ្រង់[ព] ១៣ ពួកពលធ្នូរបស់ទ្រង់ឡោមព័ទ្ធខ្ញុំ[ភ]

**១៥:២៥** ឍ យប ១១:៨ ៣៥:១២ ៣៦:៩ ៤០:៨ ទដ ២:២–៣ ៧៣:៩ ៧៥:៥ សភ ២១:៣០ អស ៣:១៦ ៤៥:៩ **១៥:២៦** ណ យរ ៤៤:១៦ **១៥:២៧** ត ពច ៣:១៧ **១៥:២៨** ថ អស ៥:៩ ទ យប ៣:១៤ **១៥:២៩** ធ យប ៣:១៥ ៧:៨ ន អស ៥:៨ **១៥:៣០** ប យប ៥:១៤ ផ ខ.៣៤ យប ១៦:៧ ២០:២៦ ២២:២០ ៣១:១២ ព ខ.៣២ យប ៨:១៩ ១៨:១៦ ២៩:១៩ ហស ៩:១–១៦ មឡ ៤:១ ភ អស ៤០:២៣–២៤ ម នក ១៥:១០ **១៥:៣១** យ យប ៣១:៥ សភ ១:១៦ ៦:១៨ អស ៤៤:២០ ៥៩:៧ មីក ២:១១ មក ១៣:៥ យក ១:១៦ រ អស ៣០:១២ ៤៧:១០ ៥៩:៤ យរ ៧:៤,៨ មថ ៦:១៩ ល យប ២០:៧ ២២:១៣ ២៧:៩ ៣៥:១៣ សភ ១៥:២៩ អស ១:១៥ យរ ១១:១១ មីក ៣:៤ **១៥:៣២** វ សស ៧:១៧ ស យប ២២:១៦ ៣៦:១៤ ទដ ៥៥:២៣ ១០៩:៨ សភ ១០:២៧ ហ ខ.៣០ **១៥:៣៣** ឡ ហព ៣:១៧ អ យប ៤:២០ **១៥:៣៤** ក យប ៨:១៣ ខ ខ.៣០ ហព ១០:២៧ គ នក ២៣:៨ ១សយ ៨:៣ **១៥:៣៥** ឃ យប ៥:៧ ង យប ៤:៨ ងស ២៩:២០ កទ ៦:៧ យក ១:១៥ **១៦:២** ក ទដ ៦៩:២០ ខ យប ៦:១៥ **១៦:៣** គ យប ១១:២ ១៨:២ ឃ យប ៦:២៦ **១៦:៤** ង ២ពវ ១៩:២១ ទដ ២២:៧ អស ៣៧:២២ យរ ៤៨:២៧ បទ ២:១៥ សផ ២:១៥ មថ ២៧:៣៩ **១៦:៥** ច យប ២៩:២៥ ឆ លប ៣៧:៣៥ **១៦:៦** ជ យប ៦:៣ ៧:២១ **១៦:៧** ឈ ពច ៨:៥ យប ៧:៣ ញ យប ១:១៩ **១៦:៨** ដ យប ១៧:៧ ១៩:២០ ៣៣:២១ ទដ ៦:៧ ២២:១៧ ៨៨:៩ ១០២:៥ ១០៩:២៤ បទ ៥:១៧ ឋ យប ១០:១៧ **១៦:៩** ឌ យប ១២:១៤ ហស ៦:១ ឍ យប ៩:៥ ១៨:៤ ១៩:១១ ណ យប ៣០:២១ ទដ ៣៥:១៦ ៣៧:១២ ១១២:១០ បទ ២:១៦ កច ៧:៥៤ ត យប ១៣:២៤ **១៦:១០** ថ ទដ ២២:១៣ ៣៥:២១ ទ យប ១២:៤ ១៩:១៨ ២១:៣ ៣០:១,៩ ទដ ២២:១៣ ៦៩:១២ ១១៩:៥១ ធ អស ៥០:៦ បទ ៣:៣០ មីក ៥:១ កច ២៣:២ ន ខ.៧ យប ១១:៣ ១៩:១២ ៣០:១២ ទដ ២៧:៣ ៣៥:១៥ កច ៧:៥៧ **១៦:១១** ប យប ៩:២៤ **១៦:១២** ផ យប ៩:១៧ ព យប ៦:៤ បទ ៣:១២ **១៦:១៣** ភ យប ៣:២៣

សេចក្ដីស្លាប់វិញ (មើលការពន្យល់ ១០:២១)។

**១៥:៣៥** *គេមានគ៌ភបង្កើតជាសេចក្ដីអាក្រក់ ហើយក៏សំរាលចេញមកជាសេចក្ដីទុច្ចរិត* មើល អស ៥៩:៤ និងការពន្យល់ ។ គឺជាគំនិតជាអំពើ បាប បង្កើតបានទៅជាការអាក្រក់យ៉ាងលឿនទៅ (ប្រៀបធៀប យក ១:១៥ និងការពន្យល់) ។

**១៦:២–៥២** ប្រឹក្សាដែលជាជំនួយ ជារឿយៗមានលក្ខណៈខ្លីៗ និងការលើកទឹកចិត្តមិនវែង ឬជាការកាត់ទោសទេ ។

**១៦:២** *ជាអ្នកកំសាន្តចិត្ត* មើលការពន្យល់ ១៣:១–១២ ។ លោកយ៉ូបត្រូវបានលើកទឹកចិត្ត ប៉ុន្តែមិនមែនដោយមិត្តទាំងបីរបស់គាត់នោះទេ (មើល ៤២:១១) ។

**១៦:៣** *ចប់ចុះត្រឹមណា* មើលការពន្យល់ ១៥:២ ។

**១៦:៩** គ្រវីក្បាល គឺអាចជាកាយវិការប្រមាថមើលងាយ (ទដ ២២:៧ យរ ៤៨:២៧ មថ ២៧:៣៩) ។

**១៦:១០–១៤** លោកមើលខ្លួនគាត់ពីទីតាំងរបស់ព្រះ និងទស្សនៈអំពីស្ថានភាពរបស់គាត់ ដូចមានលក្ខណៈបញ្ជាក់ទៅនឹងការពណ៌នារបស់លោកអេលីផាស ក្នុង ១៥:២៥–២៦ ។

**១៦:១២** *ពីដើមខ្ញុំមានសេចក្ដីសុខ តែទ្រង់បានបំបាក់បំបែកខ្ញុំ* មើល ២:៣ និងការពន្យល់ ៦:៤ ។

ទ្រង់ពុះ[ម]ចិត្តថ្លើមខ្ញុំជា២ឥតត្រាប្រណីឡើយ ទាំងចាក់ទឹក
ប្រមាត់ខ្ញុំចុះដល់ដី ១៤ទ្រង់ទំលាយខ្ញុំជាចន្លោះខ្វាន់ៗ[យ] ក៏រត់
ចូលមកលើខ្ញុំ ដូចជាមនុស្សខ្លាំងពូកែ[រ] ១៥ខ្ញុំបានដេរសំពត់
ធ្មៃ[ល]ភ្ជាប់លើសាច់ខ្ញុំ ហើយបានដាក់អំណាចខ្ញុំចុះក្នុងធូលី
ដី[វ] ១៦មុខខ្ញុំក្រហមដោយយំ[ស] ហើយមានម្លប់នៃសេចក្ដីស្លាប់
នៅត្របកភ្នែកខ្ញុំ[ហ] ១៧ទោះបើខ្ញុំគ្មានសេចក្ដីអយុត្តិធម៌[ឡ] នៅ
ក្នុងដៃ ហើយសេចក្ដីអធិស្ឋានខ្ញុំជាបរិសុទ្ធក៏ដោយ[អ]។
១៨ផែនដីអើយ កុំគ្របបាំងឈាមខ្ញុំឡើយ[ក] ហើយកុំឱ្យ
សំរែក[ខ]របស់ខ្ញុំ បានឈប់ឈរ[គ] នៅកន្លែងណាឡើយ
១៩ឥឡូវនេះ មើលចុះ ទីបន្ទាល់[ឃ]របស់ខ្ញុំនៅលើស្ថានសួគ៌[ង]
ហើយសាក្សីរបស់ខ្ញុំនៅលើស្ថានដ៏ខ្ពស់[ច] ២០ឯពួកមិត្រ[ឆ]របស់
ខ្ញុំគេឡកឡឺយ[ជ]ឱ្យខ្ញុំ តែខ្ញុំស្រក់[ឈ]ទឹកភ្នែក[ញ]នៅចំពោះព្រះ
វិញ ២១ព្រមទាំងសូម[ដ]ឱ្យទ្រង់ធ្វើជាអ្នកកណ្ដាលនៃមនុស្ស
នឹងព្រះ ហើយកណ្ដាលមនុស្សជាតិ១ និងអ្នកជិតខាងខ្លួនផង
២២ដ្បិត កាលណាកំណត់ឆ្នាំតែបន្តិចនេះ បានមកដល់ហើយ
នោះខ្ញុំនឹងទៅតាមផ្លូវដែលមិនត្រឡប់មកវិញឡើយ[ឋ]។

១៧ ១ជីវិត[ក]ខ្ញុំស្បើយអស់ហើយ ថ្ងៃអាយុខ្ញុំក៏ផុតទៅ[ខ] ផ្នូរក៏
រង់ចាំខ្ញុំ[គ] ២នៅជាមួយនឹងខ្ញុំមានសុទ្ធ[ឃ]តែជាមនុស្សឡកឡឺយ[ង]
ហើយភ្នែកខ្ញុំត្រូវមើលសេចក្ដីចាក់រុករបស់គេជានិច្ច ។
៣សូមទ្រង់ប្រោសមេត្តា ធានាឱ្យទូលបង្គំចំពោះព្រះអង្គ
ទ្រង់ផង[ច] បើពុំនោះ តើមានអ្នកណានឹងចាប់ដៃយល់ព្រម[ឆ]
នឹងទូលបង្គំបាន[ជ] ៤ដ្បិតទ្រង់បានបង្ខាំងចិត្តគេចេញពី
យោបល់[ឈ] ហេតុនោះទ្រង់នឹងមិនដំកើងគេឡើងឡើយ
៥គេលួងលោមមិត្រសំឡាញ់ខ្លួនឱ្យតែបានរបឹប[ញ] ហើយ
កូនចៅគេកាន់តែងងឹតភ្នែកទៅ[ដ]។
៦ប៉ុន្តែទ្រង់បានធ្វើឱ្យខ្ញុំទៅជាសេចក្ដីប្រៀបធៀប[ឋ]ដល់
មនុស្ស[ឌ]ទូទៅ ហើយគេស្ដោះដាក់ចំមុខខ្ញុំ[ឍ] ៧ភ្នែកខ្ញុំក៏ស្រ
វាំង ដោយសេចក្ដីទុក្ខព្រួយ[ណ] ហើយអវយវៈរូបកាយខ្ញុំទាំង
អស់ទុកដូចជាស្រមោលទទេ[ត] ៨មនុស្សទៀងត្រង់នឹងមាន
សេចក្ដីអស្ចារ្យពីដំណើរនេះ ហើយមនុស្សផូរផង់[ថ] គេនឹង
លើកគ្នាទាស់នឹងមនុស្សទមិលល្មើស ៩ចំណែកអ្នកសុច្ចរិត[ទ]
គេនឹងព្យាយាមក្នុងផ្លូវគេ ហើយអ្នកណាដែលមានដៃស្អាត[ធ]
អ្នកនោះនឹងមានកំឡាំងកាន់តែខ្លាំងឡើង[ន] ១០ត្រង់ឯអ្នក
រាល់គ្នា អញ្ជើញមកវិញ អើ សូមមកចុះ តែក្នុងពួកអ្នក
រាល់គ្នា ខ្ញុំមិនឃើញអ្នកណាមួយដែលមានប្រាជ្ញាឡើយ[ប]
១១អស់ទាំងថ្ងៃនៃអាយុខ្ញុំបានកន្លងហួសទៅ[ផ] ឯសេចក្ដីតាំង

**១៦:១៣** ម យប ២០:២៤ សក ៧:២៣ បទ ៣:១៣ **១៦:១៤** យ យប ៩:១៧ រ យប ១០:៣ យអ ២:៧ **១៦:១៥** ល លប ៣៧:៣៤ វ យប ២:៨ **១៦:១៦** ស ខ.២០ ទដ ៦:៦ ហ យប ២:៧ ១៧:៧ ៣០:១៧,៣០ ៣៣:១៩ អស ៥២:១៤ **១៦:១៧** ឡ អស ៥៥:៧ ៥៩:៦ ១៨:១១ យហ ៣:៨ អ យប ៦:២៨ ១០:៧ ១៣:៧ អស ៥៣:៩ សផ ៣:១៣ **១៦:១៨** ក លប ៤:១០ អស ២៦:២១ ខ ទដ ៥:២ ១៨:៦ ១០២:១ ១១៩:១៦៩ គ យប ១៩:២៤ ទដ ៦៦:១៨–១៩ ហព ១១:៤ **១៦:១៩** ឃ លប ៣១:៥០ រម ១:៩ ១ថន ២:៥ ង យប ២២:១២ ៤២:២ ច យប ១៩:២៧ ២១:១៧ ២៥:២ ២៧:១៣ ៣១:២ ទដ ១១៣:៥ អស ៣៣:៥ ៥៧:១៥ ៥៨:៤ ៦៦:១ មក ១១:១០ **១៦:២០** ឆ យហ ១៥:១៥ ជ រម ៨:៣៤ ឈ បទ ២:១៩ ញ ខ.១៦ **១៦:២១** ដ ១ពវ ៨:៤៥ ទដ ៩:៤ ១៤០:១២ **១៦:២២** ឋ យប ១០:២១ **១៧:១** ក ទដ ១៤៣:៤ ខ អស ៣៨:១២ គ ទដ ៨៨:៣–៤ សស ១២:១–៧ **១៧:២** ឃ យប ១១:៣ ង យប ៦:១៤ ទដ ២២:៧ ១១៩:៥១ យរ ២០:៧ បទ ៣:១៤ **១៧:៣** ច ទដ ៣៥:២៧ ១១៩:១២២ ឆ សភ ៦:១ ជ ទដ ៣៥:២ ៤០:១៧ អស ៣៨:១៤ **១៧:៤** ឈ យប ១២:១២ **១៧:៥** ញ នក ២២:១៥ ដ យប ១១:២០ **១៧:៦** ឋ ១ពវ ៩:៧ យប ៣០:៩ យរ ១៥:៤ ឌ ខ.២ ឍ ជន ១២:១៤ **១៧:៧** ណ យប ១៦:៨ ត យប ២:១២ ១៦:១៦ **១៧:៨** ថ នក ៤:១៤ **១៧:៩** ទ សភ ៤:១៨ ធ ២សយ ២២:២១ យប ៩:៣០ ន ១សយ ២:៤ ទដ ៨៤:៧ **១៧:១០** ប យប ១២:២ **១៧:១១** ផ ខ.១៥ អស ៣៨:១០

**១៦:១៥–១៧** លោកយ៉ូបបានរៀបរាប់ពីភាពវេទនារបស់គាត់ដោយសង្ខេប ទោះបីជាគាត់អត់មានកំហុសក៏ដោយ តែគាត់នៅតែទទួលការឈឺចាប់ ។

**១៦:១៥** *ដេរសំពត់ធ្មៃ . . . ធូលីដី* គឺជាសញ្ញានៃការកាន់ទុក (មើលការពន្យល់ លប ៣៧:៣៤ យហ ៣:៥–៦) ។

**១៦:១៨–២១** ខ.១៨ (មើល ខ.២២ ១៧:១) គឺជាការបញ្ជាក់ថាលោកយ៉ូបពុំអាចរស់បានយូរទេ ដើម្បីបង្ហាញឫសគល់ដែលមាន ។ គាត់សង្ឃឹមថាមានមិត្តនៅស្ថានសួគ៌ (ខ.២០) គឺជាអ្នកបរិសុទ្ធ (មើល ៥:១) គឺជាអ្នកធ្វើបន្ទាល់ពីគាត់ "គឺជាអ្នកគាំទ្រគាត់ " គឺជាអ្នកទូលអង្វរដល់គាត់និងអង្វរដល់ព្រះអម្ចាស់ ក្នុងនាមទ្រង់ដ៏ឧត្ដម (ខ.២១ មើល ៥:១ ៩:៣០ និងការពន្យល់) ។

**១៦:១៨** *ឈាមខ្ញុំឡើង . . . សំរែក* លោកយ៉ូបដឹងថាឈាមរបស់គាត់ដូចលោកអេបិល (មើល លប ៤:១០ និងការពន្យល់) គឺពុំមានកំហុសហើយនិងស្រែកចេញពីដីបន្ទាប់គាត់បានមរណៈភាពទៅ ។

**១៦:២០** *គេឡកឡឺយខ្ញុំ* បើជាភាសាហេព្រើរ ចំពោះពាក្យនេះបកមកថាជាទេវតាវិញ ក្នុង ៣៣:២៣ (មើលការពន្យល់ ៣៣:២៣–២៨) ។

**១៦:២២** *កំណត់ឆ្នាំតែបន្តិចនេះ បានមកដល់ហើយ* លោកយ៉ូបក៏មិនសង្ឃឹមថាគាត់ត្រូវស្លាប់ភ្លាមៗនោះទេ ។ និងទៅតាមផ្លូវមិនត្រឡប់មក គឺសំដៅដល់ស្ថានឃុំព្រលឹង (មើលការពន្យល់ ៧:៩ ១០:២១) ។

**១៧:១** *ផ្នូរក៏រង់ចាំខ្ញុំ* មើលការពន្យល់ ខ.១០–១៦ ។

**១៧:៣** *សូមទ្រង់ប្រោសមេត្តា ធានាឱ្យទូលបង្គំ . . .* លោកយ៉ូបសុំឱ្យព្រះអម្ចាស់ធានាពីភាពស្មោះត្រង់របស់លោកដែលបង្ហាញថាគាត់ពុំមានទោសដូចដែលគេបានបង្ខូចនោះទេ ។

**១៧:៥** លោកយ៉ូបបានចំណាំពីសុភាសិតដែលនិយាយពីការចោទប្រកាន់ខុសរបស់មិត្តគាត់ ។

**១៧:៦–៩** គឺជាសេចក្ដីធានាដែលលោកយ៉ូបសុំចំពោះព្រះ (ខ.៣) ដែលពុំបានផ្ដល់ឱ្យលោកទៅតាមសេចក្ដីស្នើសុំនោះទេ តែក៏យកលោកជាកម្មបទមួយសម្រាប់ធ្វើការផ្ចាញ់ទៅវិញ ។ បើសិនជាសំដីក្នុង ខ.៨–៩ គឺជាឃ្លាដែលពោលប្រមាថ (ដូចក្នុង ខ.១០ ដែលត្រូវបញ្ជាក់) "ក៏មិនបង្ហាញថាឥតមានកំហុស" (ខ.៨) គឺអ្នកដែលឱ្យយោបល់តាមទាំងបីនាក់ ។

**១៧:៦** សេចក្ដីប្រៀបធៀប មើល ៣០:៩ គឺជាកម្មវត្ថុរបស់គ្រាំដែលជាពាក្យចំអក (មើល បណ្ដាសា ក្នុង ចទ ២៨:៣៧) ។ *ហើយគេស្ដោះដាក់ចំមុខខ្ញុំ* មើល ៣០:១០ អស ៥០:៦ និងការពន្យល់ មថ ២៧:៣០) ។

**១៧:៧** *ទុកដូចជាស្រមោលទទេ* មើលការពន្យល់ ២:៧ ។

**១៧:១០–១៦** លោកសូផារបានសន្យាថា ការលន់តួបាបរបស់លោកយ៉ូប

ចិត្តរបស់ខ្ញុំ គឺអស់ទាំងបំណងរបស់ខ្ញុំបានកាត់ផ្ដាច់ហើយ[ព]
១២ក៏ធ្វើឱ្យយប់ដូចជាថ្ងៃវិញ[ភ] ឯពន្លឺក៏ប្រហែលគ្នានឹងងងឹត
ដែរ[ម] ១៣បើកាលណាខ្ញុំសង្ឃឹមនឹងឱ្យបានស្ថានឃុំព្រលឹង
មនុស្សស្លាប់ទុកជាទីលំនៅខ្ញុំ[យ] បើខ្ញុំក្រាលកន្ទេលដេក[រ]
របស់ខ្ញុំនៅស្ថានងងឹត[ល] ១៤បើខ្ញុំពោលដល់ផ្នូរ[វ]ថា ឯងជា
ឪពុកអញ ហើយដល់ដង្កូវ[ស]ថា ឯងជាម្ដាយ ឬជាបងប្អូនស្រី
អញ ១៥យ៉ាងនោះតើមានសេចក្ដីសង្ឃឹមឯណា[ហ] ចំណែកឯ
សេចក្ដីសង្ឃឹមរបស់ខ្ញុំ[ឡ] តើអ្នកណានឹងឃើញបាន ១៦នោះ
នឹងចុះទៅឯទ្វារនៃស្ថានឃុំព្រលឹងមនុស្សស្លាប់[អ] ក្នុងកាល
ដែលយើងបានសំរាកជាមួយគ្នាក្នុងធូលីដី[ក]។

## លោកប៊ីលដាឌ

១៨ ១នោះប៊ីលដាឌ សាសន៍ស៊ូអា[ក] ក៏ឆ្លើយឡើងថា ២តើ
អ្នករាល់គ្នានឹងនៅតែនិយាយដល់កាលណាទៀត[ខ] ចូរ
ពិចារណាចុះ រួចមកសឹមយើងនិយាយ ៣ហេតុអ្វីបានជា
យើងត្រូវរាប់ទុកដូចជាសត្វតិរច្ឆាន[គ] ហើយបានត្រឡប់ជា
ស្មោកគ្រោកនៅភ្នែកអ្នកដូច្នេះ[ឃ] ៤ឱអ្នកដែលហែកហួរខ្លួន[ង]
ដោយសេចក្ដីកំហឹង[ច] តើផែនដីត្រូវចោលស្ងាត់ដោយព្រោះ
អ្នក ឬថ្មត្រូវរើចេញពីកន្លែងទៅឬអី[ឆ]។
៥ឯពន្លឺនៃមនុស្សអាក្រក់នឹងរលត់ទៅ[ជ] ហើយរងើក
ភ្លើងរបស់គេនឹងលែងភ្លឺ[ឈ] ៦ពន្លឺនៅក្នុងទីលំនៅ[ញ]គេ និង
ត្រូវងងឹតវិញ[ដ] ហើយចង្កៀងនៅពីលើគេនឹងរលត់ទៅ[ឋ]
៧អស់ទាំងជំហាននៃកំឡាំង[ឌ]គេនឹងកាន់តែអន់ថយ[ឍ] ហើយ
គំនិតរបស់ខ្លួន[ណ]នឹងផ្ដួលគេផង[ត] ៨ដ្បិតជើងខ្លួនគេនាំឱ្យគេ
ជាប់មង[ថ]គេដើរលើរង្វង់អន្ទាក់ជានិច្ច ៩អន្ទាក់នឹងរួតជាប់
កែងជើងគេ ហើយអន្ទាក់[ទ]សាងនឹងវាត់ឡើងជាប់គេ[ធ]
១០មានខ្សែរូត[ន]បង្កប់ក្នុងដីសំរាប់ចាប់គេ ហើយមាន
អង្គប់[ប]រង់ចាំគេនៅផ្លូវ[ផ] ១១សេចក្ដីស្ញែងខ្លាច[ព]នឹងបំភ័យគេ
នៅគ្រប់ទិស[ភ] ហើយនិងដេញតាមប្រកិត[ម]នៅកែងជើងគេ
១២កំឡាំងគេហេវទៅដោយអត់ឃ្លាន[យ] ហើយសេចក្ដីអន្ត
រាយ[រ,ល]នឹងប្រុងប្រៀបជាស្រេចនៅខាងគេ[វ] ១៣អវយវៈរូប
កាយគេនឹងត្រូវលេបបាត់ទៅ[ស] គឺកូនច្បងនៃសេចក្ដីស្លាប់
នឹងស៊ីអវយវៈគេអស់រលីង[ហ] ១៤គេនឹងត្រូវរលើងចេញពី
ទីលំនៅ[ឡ] ដែលបានយកជាទីពឹង ហើយនឹងត្រូវនាំទៅ
ចំពោះស្ដេច[អ]នៃសេចក្ដីស្ញែងខ្លាច[ក] ១៥មនុស្សក្រៅវង្ស
ត្រកូលរបស់គេ និងមកនៅក្នុងទីលំនៅគេវិញ[ខ] ហើយនិង
មានស្ពាន់ធ័រ[គ]រោយចុះមកលើទីអាស្រ័យរបស់គេ ១៦នៅ
ខាងក្រោម ឫសគេនឹងត្រូវក្រៀមស្ងួតទៅ[ឃ] ហើយខាងលើ

**១៧:១១** ព យប ៧:៦ **១៧:១២** ភ អស ៥០:១១ ម យប ៥:១៧–២៦ ១១:១៧ **១៧:១៣** យ ២សយ ១៤:១៤ យប ៣:១៣ រ ទដ ១៣៩:៨ ល ទដ ៨៨:១៨ **១៧:១៤** វ យប ១៣:២៣ ៣០:២៨, ៣០ ទដ ១៦:១០ ៤៩:៩ ស យប ៤:១៩ ៧:៥ **១៧:១៥** ហ យប ៧:៦ ឡ ទដ ៣១:២២ បទ ៣:១៨ អគ ៣៧:១១ **១៧:១៦** អ យប ៧:៩ ៣៣:២៨ ទដ ៩:១៣ ៣០:៣ ១០៧:១៨ អស ៣៨:១០,១៧ យហ ២:៦ ក លប ២:៧ យប ៣:១៩ ២០:១១ ២១:២៦ **១៨:១** ក យប ៨:១ **១៨:២** ខ យប ៨:២ ១៦:៣ **១៨:៣** គ យប ១២:៧ ឃ ទដ ៧៣:២២ **១៨:៤** ង យប ១៣:១៤ ច យប ១៦:៩ ឆ យប ១៤:១៨ **១៨:៥** ជ យប ២១:១៧ ៣៥:១៥ សភ ១៣:៩ ២០:២០ ២៤:២០ យរ ២៥:១០ មថ ២៥:៨ យហ ៨:១២ ឈ យប ៥:១៤ ១២:២៥ ២៤:១៧ ៣៨:១៥ **១៨:៦** ញ យប ៨:២២ ដ យប ៥:១៤ ឋ យប ១១:១៧ ១២:២៥ **១៨:៧** ឌ យប ១៣:២៦ ឍ ទដ ១៨:៣៦ សភ ៤:១២ ណ យប ៥:១៣ ត យប ១៥:៦ **១៨:៨** ថ យប ១៩:៦ ទដ ៩:១៥ ១០:៩ ៣៥:៧ ៥៧:៦ ៦៦:១១ ១៤០:៥ បទ ១:១៣ មីក ៧:២ ហព ១:១៥ **១៨:៩** ទ យប ២២:១០ ៣០:១២ អស ២៤:១៨ យរ ៤៨:៤៤ អម ៥:១៩ ធ សភ ៥:២២ **១៨:១០** ន សភ ៧:២២ អស ៥១:២០ ប ១សយ ២៨:៩ ផ ទដ ១៤០:៥ **១៨:១១** ព ខ.១៤ យប ៦:៤ ២០:២៥ ២៤:១៧ ទដ ៥៥:៤ ៨៨:១៥ អស ២៨:១៩ យរ ១៥:៨ បទ ២:២២ ភ យប ១៥:២១ ទដ ៣១:១៣ ម ខ.១៨ យប ២០:៨ អស ២២:១៨ **១៨:១២** យ អស ៨:២១ ៩:២០ ៦៥:១៣ រ យប ៣១:៣ ល យប ២១:១៧ វ យប ១៥:២៣ **១៨:១៣** ស ជន ១២:១២ ហ សក ១៤:១២ **១៨:១៤** ឡ យប ៨:២២ អ យប ១៥:២៤ ក ខ.១១ **១៨:១៥** ខ ខ.១៨ យប ២០:២៦ គ លប ១៩:២៤ **១៨:១៦** ឃ អស ៥:២៤ ហស ៥:១២ អម ២:៩

និងបានប្ដូរភាពងងឹតរបស់លោកយ៉ូបឱ្យទៅជាពន្លឺវិញ(១១:១៧)។ (ខ.១២–១៦)។ សេចក្ដីសង្ឃឹមរបស់គាត់គឺជាផ្នូរដែលកំពុងរងចាំ(មើល ខ.១) គឺមិនមែនដូចផ្ទះរបស់លោកឡើយ(ខ.១៣–១៥) ។

**១៧:១៣** *ទីលំនៅ* មើល សស ១២:៥ និងការពន្យល់ ។*នៅស្ថានងងឹត* គឺជាស្ថានឃុំព្រលឹង(មើល ១០:២១ ១៨:១៨ និងការពន្យល់ ) ។

**១៧:១៤** នៅក្នុងផ្នូរក្រុមគ្រួសារមួយ គឺមានទៅដោយភាពស្អុយរលួយ ហើយនិងដង្កូវ ។

**១៧:១៥** *សេចក្ដីសង្ឃឹមឯណា* មើល ១៤:១៩

**១៧:១៦** *ឯទ្វារនៃស្ថានឃុំព្រលឹងមនុស្សស្លាប់* មើល ៣៨:១៧ មថ ១៦:១៨ គឺក្នុងផ្នែកអក្សរសាស្ត្រ អ្នកដែលរស់នៅតាមដងទន្លេ និងចំពោះអ្នកដែលចូលទៅផ្នែកខាងក្រោមដែលឆ្លងកាត់ទ្វារចំនួនប្រាំពីរ ។ *ធូលីដី* មើល ការពន្យល់ ៧:២១ ។

**១៨:១–៤** *ប៊ីលដាឌ* បានពិចារណានៅអ្វីដែលគាត់បានដឹងភាពដែលគ្មានតម្លៃ ។ គាត់ពិចារណានូវភាពមានប្រតិកម្មជាផ្នែកមនោរម្មណ៍ ឬអារម្មណ៍របស់លោកយ៉ូបក្នុងចិត្តរបស់ពួកគេ ។

**១៨:៥–២១** គឺជាផ្នែកបទកំណាព្យជាទំនុកសម្ដែងពីវាសនាអ្នកធ្វើការអាក្រក់ (មើល ៨:១១–១៩ ១៥:២០–៣៥) ។ លោកប៊ីលដាឌចង់បង្ហាញប្រាប់លោកយ៉ូបថា គាត់មានកំហុសពេលគាត់ប្រកាសថា អ្នកសុចរិតត្រូវឈឺចាប់ ឯមនុស្សអាក្រក់ ក៏បានទទួលពរជ័យ ។ លោកប៊ីលដាឌ ក៏បានកំណត់ដឹងច្បាស់ថា គ្រប់ទាំងមនុស្សអាក្រក់និងត្រូវមកវិញ នូវការកាត់ទោសដោយពេញទំហឹងចំពោះអំពើអាក្រក់របស់ពួកគេ ។

**១៨:៥** *ឯពន្លឺនៃមនុស្សអាក្រក់នឹងរលត់ទៅ* មើល ២១:៧ សភ ១៣:៩ និងការពន្យល់ ។ ជីវិតជានិមិត្តសញ្ញា ពន្លឺក៏ត្រូវរលត់ទៅវិញ ។

**១៨:១៣** *កូនច្បងនៃសេចក្ដីស្លាប់* វាអាចមានលក្ខណៈជាជម្ងឺនៃសេចក្ដីស្លាប់ (ប្រៀបធៀប ៥:៧ និងការពន្យល់ ) ។

**១៨:១៤** *នៃសេចក្ដីស្ញែងខ្លាច* គឺជាតួលេខចំៗសម្ដែងពីការស្លាប់ ឃើញក្នុង ខ.១៣ ដែលជារូបភាពរបស់ពួកកាណាន ដែលបានស្លាប់ដូចព្រះនៃការស៊ីបំផ្លាញ ។ តែទ្រង់ជាព្រះយេហូវ៉ាបានបំផ្លាញសេចក្ដីស្លាប់ឱ្យសូន្យបាត់ទៅជាដរាប ហើយព្រះយេហូវ៉ាទ្រង់នឹងជូតទឹកភ្នែកពីមនុស្សទាំងអស់ ហើយទ្រង់និងដកសេចក្ដីត្មះតិះដៀលចំពោះរាស្ត្រទ្រង់ (មើល អស ២៥:៨ និងការពន្យល់ មើល ១កថ ១៥:៥៤) ។

**១៨:១៦** *ឫសគេ... មែកគេ...* គឺតំណាងពូជអំបូរ (មើល ពច ៥:១៤

មែកគេនឹងត្រូវកាច់ចេញ[ង] ១៧ទាំងសេចក្តីនឹកចាំពីគេ និង
សូន្យបាត់ពីផែនដីទៅ[ច] ហើយនិងលែងឮនិយាយពីឈ្មោះ[ឆ]
គេតាមផ្លូវតទៅ[ជ] ១៨គេនឹងត្រូវដេញចេញ ពីពន្លឺទៅក្នុងទី
ងងឹត[ឈ] ហើយត្រូវប្រដេញចេញ[ញ]ពីលោកីយផង[ដ] ១៩គេនឹង
គ្មានកូន[ឋ]ឬចៅ[ឌ]ក្នុងវង្សត្រកូលរបស់គេ ឬអ្នកណាសល់
នៅ[ឍ] ក្នុងកន្លែងដែលគេអាស្រ័យនោះឡើយ[ណ] ២០ពួកជំនាន់
ក្រោយនឹងមានសេចក្តីអស្ចារ្យ[ត]ពីប្រវត្តិរបស់គេ[ថ] ដូចជា
ជំនាន់មុនបានភ័យខ្លាចដែរ ២១ប្រាកដជាយ៉ាងនោះហើយ
ដែលជាទីលំនៅ[ទ]របស់មនុស្សអាក្រក់[ធ] នេះហើយជាកន្លែង
នៃអ្នកដែលមិនស្គាល់ព្រះ[ន] ។

## លោកយ៉ូប

**១៩** ១នោះយ៉ូបក៏ឆ្លើយឡើងថា ២អ្នករាល់គ្នានឹងធ្វើទុក្ខ[ក]
ដល់ព្រលឹងខ្ញុំ ហើយឈ្លីឈ្លក់[ខ]ខ្ញុំដោយពាក្យសំដីដល់កាល
ណាទៀត ៣មានទាំង១០ដង[គ]នេះហើយ ដែលអ្នករាល់គ្នា
បានដៀលត្មះខ្ញុំ[ឃ] ព្រមទាំងបញ្ឈឺចិត្តខ្ញុំដោយឥតខ្មាស ៤បើ
សិនជាខ្ញុំបានធ្វើខុសមែន សេចក្តីកំហុសនោះ[ង]ក៏នៅជាប់តែ
នឹងខ្លួនខ្ញុំទេ ៥បើសិនជាអ្នករាល់គ្នាចង់ធ្វើធំលើខ្ញុំ[ច] ហើយ
ជជែកយកខុសត្រូវពីសេចក្តីអាម៉ាស់ខ្មាសរបស់ខ្ញុំនេះ ៦នោះ
ត្រូវដឹងថា គឺព្រះដែលបានផ្តួលខ្ញុំ[ឆ] ហើយបានព័ទ្ធខ្ញុំជុំវិញ[ជ]
ដោយមង[ឈ]របស់ទ្រង់ ។
៧មើល ខ្ញុំស្រែកឡើងថា ខ្ញុំត្រូវគេធ្វើអាក្រក់ហើយ តែ
គ្មានអ្នកណាឮសោះ[ញ] ខ្ញុំស្រែកឱ្យគេជួយ[ដ] តែគ្មានសេចក្តី
យុត្តិធម៌ឡើយ[ឋ] ៨ទ្រង់បានធ្វើរបងរាំងផ្លូវខ្ញុំ មិនឱ្យទៅណា
បាន[ឌ] ក៏បានធ្វើឱ្យផ្លូវច្រករបស់ខ្ញុំងងឹតតទៅ[ឍ] ៩ទ្រង់បាន
ដោះ[ណ]កេរ្តិ៍ឈ្មោះ[ត]ខ្ញុំចេញ ព្រមទាំងចាប់យកមកុដពីក្បាល
ខ្ញុំចេញផង[ថ] ១០ទ្រង់បានបំផ្លាញ[ទ]ខ្ញុំពីគ្រប់ទិស ហើយខ្ញុំកំពុង
តែទៅបាត់ ឯសេចក្តីសង្ឃឹម[ធ]របស់ខ្ញុំ នោះទ្រង់បានរំលើង
ចេញ ដូចជាដើមឈើ[ន] ១១ទ្រង់បានបង្កាត់សេចក្តីក្រោធ[ប]
របស់ទ្រង់ទាស់នឹងខ្ញុំ ក៏រាប់ខ្ញុំ ទុកដូចជាសត្រូវនឹងទ្រង់[ផ]
១២ពលទ័ពរបស់ទ្រង់ចូលមកព្រមៗគ្នា[ព] ហើយលើកថ្នល់[ភ]
មកទាស់នឹងខ្ញុំ ក៏បោះទ័ពព័ទ្ធជុំវិញទីលំនៅ[ម]របស់ខ្ញុំដែរ ។
១៣ទ្រង់បានញែកពួកបងប្អូន[យ]ខ្ញុំចេញឆ្ងាយពីខ្ញុំ ហើយ
ពួកអ្នកដែលខ្ញុំស្គាល់ ក៏ត្រឡប់ទៅជាអ្នកដទៃទាំងអស់[រ]
១៤ញាតិសន្តានខ្ញុំបានទុកខ្ញុំចោល ហើយមិត្រសំឡាញ់[ល]ដែល

**១៨:៣១៦** ង លប ២៧:២៨ យប ៨:១២ ១៥:៣០ **១៨:១៧** ច ចទ ៣២:២៦ ឆ ចទ ៩:១៤ ទដ ៩:៥ ៦៩:២៨ សភ ១០:៧ អស ១៤:២២ ជ យប ២៤:២០ ទដ ៣៤:១៦ សភ ២:២២ ១០:៧ អស ៤៩:១៥ **១៨:១៨** ឈ យប ៥:១៤ ញ ខ.១១ ដ យប ១១:២០ ៣០:៨ **១៨:១៩** ឋ ទដ ៣៧:២៨ អស ១:៤ ១៤:២០ យរ ២២:៣០ ឌ ទដ ២១:១០ ១០៩:១៣ អស ១៤:២២ ឍ ២ពវ ១០:១១ អគ ១៧:៨ ណ យប ២៧:១៤–១៥ **១៨:២០** ត ទដ ២២:៦–៧ អស ៥២:១៤ ៥៣:២–៣ អគ ២៧:៣៥ ថ ទដ ៣៧:១៣ យរ ៤៦:២១ ៥០:២៧, ៣១ អគ ៧:៧ **១៨:២១** ទ យប ២១:២៨ ធ អស ៥៧:២០ ន យប ៧:១០ ប យប ៤:២១ ១ថន ៤:៥ **១៩:២** ក យប ១៣:២៥ ខ យប ៦:៩ **១៩:៣** គ លប ៣១:៧ ឃ យប ២០:៣ **១៩:៤** ង យប ៦:២៤ **១៩:៥** ច ទដ ៣៥:២៦ ៣៨:១៦ ៥៥:១២ **១៩:៦** ឆ យប ៦:២៩ ជ យប ១០:៣ ឈ យប ១៨:៨ **១៩:៧** ញ យប ៣០:២០ ទដ ២២:២ ដ យប ៣០:២៤,២៨ ៣១:៣៥ ទដ ៥:២ ឋ យប ៩:២៤ ហព ១:២–៤ **១៩:៨** ឌ បទ ៣:៧ ហស ២:៦ ឍ យប ៣:២៦ ២៣:១៧ ៣០:២៦ សស ៦:៤ អស ៥៩:៩ យរ ៨:១៥ ១៤:១៩ បទ ៣:២ **១៩:៩** ណ យប ១២:១៧ ត លប ៤៣:២៨ នក ១២:៤២ ទដ ១៥:៤ ៥០:២៣ សភ ១៤:៣១ ថ យប ២:៨ ២៩:១៤ ទដ ៨៩:៣៩,៤៤ បទ ៥:១៦ **១៩:១០** ទ យប ១២:១៤ ធ យប ៧:៦ ន យប ១៤:៧ **១៩:១១** ប យប ១៦:៩ ផ យប ១៣:២៤ **១៩:១២** ព យប ១៦:១៣ ភ យប ១៦:១០ ម យប ៣:២៣ **១៩:១៣** យ ទដ ៦៩:៨ រ ខ.១៩ យប ១៦:៧ ៤២:១១ ទដ ៣១:១១ ៣៨:១១ ៨៨:៨ **១៩:១៤** ល ខ.១៩ ២សយ ១៥:១២ យប ១២:៤ ១៦:២០ ទដ ៨៨:១៨

អស ១៤:១៥ អស ១៤:២៩) មើល អម ២:៩ និងការពន្យល់ ។

**១៨:១៧** *ទាំងសេក្តីនឹកចាំពីគេ នឹងសូន្យបាត់ពីផែនដី* ក៏បង្ហាញឱ្យឃើញពីលោកប៊ីលដាឌ ដែលត្រូវដាក់ទោសកំហុសដល់ស្លាប់ពុំមានសល់នៅផែនដី (មើល ខ.១៩) ។

**១៨:១៨** *ក្នុងទីងងឹត* គឺជាស្ថាននៃសេចក្តីងងឹត (មើល ១០:២១ និងការពន្យល់ ១៧:១៣) ។

**១៨:២១** *មនុស្សអាក្រក់ . . . ដែលមិនស្គាល់ព្រះ* ពុំមានភាពសិទ្ធ ឬស្គាល់ចំណេះពីព្រះ (មើល ហស ៤:១–២,៦) ។

**១៩:៣** *ទាំង១០ដង* គឺមានលក្ខណៈជាច្រើនដងច្រើនសារ ។ ពាក្យថា ដប់ជារឿយៗ ត្រូវបានគេប្រើជាចំនួនខួប (មើល លប ៣១:៤១ ១សអ ១:៨) ។

**១៩:៤** *ជាប់តែនឹងខ្លួនខ្ញុំទេ* មិត្តសំឡាញ់លោកយ៉ូបពុំមានសិទ្ធជ្រៀតជ្រែក ឬក៏ធ្វើខ្លួនដូចជាព្រះ (មើល ខ.២២) ។

**១៩:៦** *បានផ្តួលខ្ញុំ* ផ្ទៀប ៤០:៨ នឹងការពន្យល់ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យកិរិយាស័ព្ទនេះ គឺប្រែបានជាន័យពីរ "ប្រែលំអៀង" ក្នុង ៨:៣ មើលសេចក្តីពន្យល់នៅទីនោះ ។ ដែលឃើញលោកប៊ីលដាឌ បានបដិសេធថាព្រះបានបង្វែរសេចក្តីយុត្តិធម៌ ។ តែលោកយ៉ូបបានពុះពារដែលមានប្រស្នាពាក្យសួរចំពោះការឈឺចាប់របស់គាត់ ដោយក្រោយមកដឹងថា ព្រះអម្ចាស់ជាមាសត្រូវនិងលោកទៅវិញ តែតាមការពិតលោកយ៉ូប គឺជាទីពេញចិត្តដល់ព្រះណាស់ (មើល ១:៨ ២:៣) តែសត្រូវពិតរបស់លោកយ៉ូប គឺអារក្សសាតាំងវិញ ជាអាមេចោទប្រកាន់ (មើលការពន្យល់ ១:៦,១២) ។ *ព័ទ្ធខ្ញុំជុំវិញដោយមងរបស់ទ្រង់* អ្នកធ្វើការអាក្រក់បាននាំឱ្យខ្លួនគេទទួលនូវបញ្ហា ដូចលោកប៊ីលដាឌដែលបានបង្ហាញស្រាប់ (មើល ១៨:៨–១០) ប៉ុន្តែលោកយ៉ូបបានបន្ទោសការឈឺចាប់របស់គាត់ទៅលើព្រះវិញ ។

**១៩:៧** *ខ្ញុំស្រែកឡើងថា ខ្ញុំត្រូវគេធ្វើអាក្រក់ហើយ* ជាឃ្លាអក្សរសាស្ត្រ "ខ្ញុំស្រែកឡើងថា គឺខ្ញុំមានគេរំលោភបំពានហើយ" មើល ហប ១:២–៤ និងការពន្យល់ ។

**១៩:៨–១២** ក្នុងអារម្មណ៍របស់លោកយ៉ូប គឺគិតថាព្រះកំពុងធ្វើសង្គ្រាម និងលោកហើយ (មើល ១៦:១០–១៤ និងការពន្យល់) ។

**១៩:១០** *ទ្រង់បានរំលើងចេញ ដូចជាដើមឈើ* មិនមានលក្ខណៈដូច ១៤:៧–៩ ដែលលោកយ៉ូបបានប្រើនិមិត្តពីដើមឈើដែលបានកាត់ទម្លាក់ តែក្រោយមកក៏បានលូតលាស់ឡើងវិញ មើល ២៤:២០ ។

**១៩:១២** សូមមើល ២៤:២០ ។

**១៩:១៣–១៩** មើល យរ ១២:៦ និងការពន្យល់ គឺជាជីវិតទទួលការឈឺចាប់ហើយគេបោះបង់ចោល កូនលោកយ៉ូបបានស្លាប់អស់ និងភរិយាលោកផង

ជិតស្និទ្ធ ក៏ភ្លេចខ្ញុំអស់ហើយ ១៥ទាំងពួកអ្នកនៅផ្ទះខ្ញុំ[វ] និង
បាវស្រី[ស] ក៏ទុកខ្ញុំដូចជាអ្នកដទៃ ខ្ញុំដូចជាអ្នកកន្សៀតដល់ភ្នែក
គេ ១៦ខ្ញុំហៅអ្នកបំរើខ្ញុំ តែវាមិនឆ្លើយសោះ ទោះបើខ្ញុំសូម
អង្វរវាផង ១៧ខ្យល់មាត់របស់ខ្ញុំជាទីស្អប់ខ្ពើមដល់ប្រពន្ធខ្ញុំ
ហើយសេចក្ដីអង្វររបស់ខ្ញុំជាទីខ្ពើម[ហ]ដល់បងប្អូនពោះ១នឹង
ខ្ញុំដែរ ១៨ទោះទាំងកូនក្មេង[ឡ]ក៏មើលងាយដល់ខ្ញុំ បើកាល
ណាខ្ញុំក្រោកឡើង នោះវានិយាយបង្កាច់ខ្ញុំ[អ] ១៩ពួកមិត្រ
សំឡាញ់ជិតស្និទ្ធ[ក]ក៏ខ្ពើមឆ្អើមខ្ញុំ[ខ] ហើយទាំងពួកអ្នកដែល
ខ្ញុំបានស្រឡាញ់ថ្នម ក៏ប្រែជាទាស់នឹងខ្ញុំវិញ[គ] ២០ឆ្អឹងខ្ញុំនៅ
ជាប់នឹងស្បែក ហើយនិងសាច់ខ្ញុំ[ឃ] ខ្ញុំរួចបានតែជីវិត
ប៉ុណ្ណោះ ២១ឱអ្នករាល់គ្នា ជាសំឡាញ់ខ្ញុំអើយ[ង] សូមអាណិត
ខ្ញុំ សូមអាណិតខ្ញុំផង ដ្បិតព្រះហស្តនៃព្រះបានពាល់[ច]ខ្ញុំ
ហើយ ២២ហេតុអ្វីបានជាអ្នករាល់គ្នាដេញតាម[ឆ]ខ្ញុំដូចជាព្រះ
ដែរ[ជ] ហើយមិនទាន់ឆ្អែតនឹងសាច់ខ្ញុំទៀត[ឈ] ២៣ឱបើសិនជា
ពាក្យខ្ញុំបានសរសេរចុះ ឱបើបានកត់ទុកក្នុងសៀវភៅទៅ
អេះ[ញ] ២៤គឺបានឆ្លាក់នៅនឹងថ្មដោយដែកឆ្លាក់[ដ] ហើយនិង
សំណទុកជារៀងរាបតទៅ[ឋ] ២៥ប៉ុន្តែខ្ញុំៗដឹងថា អ្នកដែល
លោះខ្ញុំ[ឌ]ទ្រង់មានព្រះជន្មរស់នៅ[ឍ] ហើយដល់ជាន់ក្រោយ
ទ្រង់នឹងមកឈរនៅលើផែនដី ២៦ហើយក្រោយដែលសំបក
កាយខ្ញុំនេះត្រូវរលាយទៅ គឺក្រៅពីរាងកាយ នោះខ្ញុំនឹង
បានឃើញព្រះ[ណ] ២៧ដែលខ្ញុំ គឺខ្លួនខ្ញុំនេះ[ត] និងឃើញ
ដោយខ្លួនខ្ញុំ មិនមែនអ្នកណាទៀត គឺភ្នែកខ្លួនខ្ញុំ និងបាន
ឃើញទ្រង់ ចិត្តខ្ញុំក៏ហេវទៅ[ថ]នៅក្នុងខ្លួន ដោយរង់ចាំពេល
នោះ ២៨ដូច្នេះ បើអ្នករាល់គ្នាពោលថា ចាំមើលយើងនឹង
ធ្វើទុក្ខ[ទ]វាយ៉ាងណា ដោយយល់ឃើញថា ដើមហេតុនៃ
សេចក្ដីនេះនៅក្នុងខ្លួនខ្ញុំ ២៩យ៉ាងនោះត្រូវឱ្យខ្លាចចំពោះ
ដាវចុះ ដ្បិតសេចក្ដីក្តៅក្រហាយនឹងនាំឱ្យមានទោស ដោយ
ដាវនោះឯង[ធ] ដើម្បីឱ្យអ្នករាល់គ្នាបានដឹងថា មានសេចក្ដី

**១៩:១៥** វ លប ១៤:១៤ ស សស ២:៧
**១៩:១៧** ហ ទដ ៣៨:៥
**១៩:១៨** ឡ ២ពវ ២:២៣ អ យប ១៦:១០
**១៩:១៩** ក ខ.១៤ យប ៦:១៤ ទដ ៥៥:១២–១៣ ខ យប ៣០:១០ គ ខ.១៣ យហ ១៣:១៨
**១៩:២០** ឃ យប ២:៥
**១៩:២១** ង យប ៦:១៤ ច ពច ២:១៥ យប ៤:៥ ១០:៣ បទ ៣:១
**១៩:២២** ឆ យប ១៣:២៥ ជ ខ.៦ ឈ ២របា ២៨:៩ ទដ ១៤:៤ ២៧:២ ៦៩:២៦ សភ ៣០:១៤ អស ៥៣:៤ **១៩:២៣** ញ នក ១៧:១៤ ទដ ៤០:៧ អស ៨:១**១៩:២៤** ដ យរ ១៧:១ ឋ យប ១៦:១៨ **១៩:២៥** ឌ នក ៦:៦ លវ ២៥:២៥ ទដ ៦៨:៥ ៧៨:៣៥ សភ ២៣:១១ អស ៤១:១៤ ៤៣:១៤ ៤៤:៦,២៤ ៤៧:៤ ៤៨:១៧ ៤៩:២៦ ៥៤:៥ ៥៩:២០ ៦០:១៦ ឍ ១សយ ១៤:៣៩ យប ១៦:១៩ **១៩:២៦** ណ ជន ១២:៨ មថ ៥:៨ ១កថ ១៣:១២ ១យហ ៣:២ **១៩:២៧** ត លក ២:៣០ ថ ទដ ៤២:១ ៦៣:១ ៨៤:២ **១៩:២៨** ទ យប ១៣:២៥ **១៩:២៩** ធ យប ១៥:២២

ដែរ ហើយនិងមិត្តគាត់ អ្នកបម្រើក៏ឈប់រវល់នឹងគាត់ដែរ ។

**១៩:១៧** *ខ្យល់មាត់របស់ខ្ញុំជាទីស្អប់ខ្ពើម* មើលការពន្យល់ ២:៧ ។

**១៩:១៨** *កូនក្មេងក៏មើលងាយដល់ខ្ញុំ* គឺជាការមើលងាយក្នុងសង្គមបុព្វបុរសដែលមនុស្សចាស់ត្រូវគោរពតាំងពីដើមមក (មើល នក ២០:១២ និងការពន្យល់) ។

**១៩:២០** *ឆ្អឹងខ្ញុំនៅជាប់នឹងស្បែក* មើលការពន្យល់ ២:៧ អត្ថបទពន្យល់នេះក៏យល់ពីឃ្លាដែលអនុវត្តនូវព្រឹត្តការណ៍របស់លោកយ៉ូបកន្លងទៅ ។

**១៩:២១** *ដ្បិតព្រះហស្តនៃព្រះបានពាល់ខ្ញុំហើយ* មើលការពន្យល់ ខ.៦ ក៏មើល ១:១១ ២:៤–៦ ។

**១៩:២៣–២៧** គឺជាឃ្លាអត្ថបទដ៏ពេញនិយមបំផុតក្នុងកណ្ឌគម្ពីរលោកយ៉ូបដែលជាកំរិតកំពូលក្នុងការស្វែងយល់ពីលោកយ៉ូប នៃស្ថានភាពផ្ទាល់ខ្លួនរបស់គាត់និងភាពមានទំនាក់ទំនងជាមួយព្រះអម្ចាស់ ។ គឺជាទីតាំងពីរផ្នែកនៃរឿងរ៉ាវដែលលោកយ៉ូបស្នើរសុំ (មើល ខ.២១–២២) និងការព្រមាន (ខ.២៨–២៩) ។

**១៩:២៣** *ជាពាក្យខ្ញុំ* លោកយ៉ូបប្រាថ្នាថា ការដែលគាត់ទូលសូម គឺបានជាការកត់ត្រាទុកនូវព្រឹត្តការណ៍ក្រោយពេលដែលលោកយ៉ូបស្លាប់ ហើយក៏បានបង្ហាញឃើញរឿងលោកយ៉ូបក្នុងគ្រាជាបន្ទាល់ មើលការពន្យល់ នក ១៧:១៤ ។

**១៩:២៤** *ដែកឆ្លាក់* មើល ២០:២៤ ២៨:២ ៤០:១៨ ៤១:២៧ ដែកដែលពុំបានប្រើជាលក្ខណៈធម្មតាទេ ក្នុងជិតមជ្ឈឹមបូព៌ារហូតដល់ ស.វ ១២ មុន គ.ស គឺតាំងពី២000ឆ្នាំ មុន គ.ស ។

**១៩:២៥** *ប៉ុន្តែខ្ញុំៗដឹងថា អ្នកដែលលោះខ្ញុំទ្រង់មានព្រះជន្មរស់* ការលន់តួដ៏ស្មោះត្រង់នេះ គឺជាសេចក្ដីជំនឿដែលមានជាច្រើនជំនាន់មកក្នុងពួកគ្រីស្ទបរិស័ទ ជាពិសេសតាមរយៈព្រះហស្តនៃព្រះមែស៊ី ។ ប៉ុន្តែការលោះបាបដែលរៀបចំឡើងចេញពីការអាក្រក់ និងការវិនិច្ឆ័យទោសលោកយ៉ូបមានរឿងរ៉ាវក្នុងអារម្មណ៍ ។ ទោះជាក្នុងផ្នែកខ្លះទៀតគាត់ក៏ចង់បានអ្នកការពារគាត់ មើល ទដ ២៣:១១ និងការពន្យល់) ។ ក្នុងនាមជាអ្នកការពារនគរស្ថានសួគ៌ គឺអ្នកទូលអង្វរកព្រះ (មើល ៩:៣៣–៣៤ ១៦:១៨–២១) និងការពន្យល់ មើលការពន្យល់ ៥:១) ទីនេះការលោះហាក់ដូចជាគ្មានអ្នកណាក្រៅពីព្រះអម្ចាស់ផ្ទាល់នោះទេ (មើលការពន្យល់ នរ ២:២០) ។ លោកយ៉ូបបានបញ្ជាក់ពីភាពជឿជាក់ថា ព្រះអម្ចាស់បង្ហាញថាគាត់ជាបាវបម្រើដ៏ស្មោះត្រង់នៅចំមុខអ្នកដែលជាមេចោទប្រកាន់ទាំងអស់ ។ *ទ្រង់នឹងមកឈរ* ដើម្បីគាំទ្រដល់ខ្ញុំថាគ្មានកំហុស(៤២:៧–១០ និងការពន្យល់) ។

**១៩:២៦** *សំបកកាយខ្ញុំនេះត្រូវរលាយទៅ* ក្នុងអារម្មណ៍របស់លោកយ៉ូបបានដឹងថា ការរាតត្បាតនៃជម្ងឺ និងនាំសេចក្ដីស្លាប់មកលើរូបគាត់ ។ *ខ្ញុំនឹងបានឃើញព្រះ* លោកយ៉ូបបានជឿជាក់ក្នុងខ្លួនថា សេចក្ដីស្លាប់ពុំមានភាពអស់កល្បទេសម្រាប់រូបលោក គឺលោកដឹងថាថ្ងៃមួយលោកនិងឈរមានវត្តមាននៅមុខអ្នកដែលសង្គ្រោះរូបលោក និងឃើញព្រះយេហូវ៉ាដោយភ្នែកផ្ទាល់ (សូមមើល ខ.២៧ និង មថ ៥:៨ ១យហ ៣:២ និងការពន្យល់ ៤២:៥) ។

**១៩:២៨** *ធ្វើទុក្ខ* ក្នុងព្រះគម្ពីរភាសាហេព្រើរ ចំពោះកិរិយាស័ព្ទនេះបកប្រែមកដោយមានន័យថា "ដេញតាម" ក្នុង ខ.២២ ។ ជាកិច្ចការនាំទៅរកការរិះគន់របស់លោកយ៉ូបប្រឆាំងនឹងអ្នកទូន្មានចំពោះគាត់(ខ.២៣–២៧) ។

**២០:១–២៩** ក៏មានអត្ថបទកំណាព្យមួយទៀត ស្តីអំពីវាសនាមនុស្សអាក្រក់តាមរយៈផ្នែកទេវសាស្ត្រដែលជាទំនៀមទម្លាប់របស់មិត្តលោកយ៉ូប(មើល ៨:១១–១៩ ១៥:២០–៣៥ ១៨:៥–២១) ។

យុត្តិធម៌ដែរ[ន] ។

## លោកសូផារ

**២០** ១នោះសូផារ ជាសាសន៍ណាអាម៉ា[ក] ក៏ឆ្លើយឡើងថា
២គឺដោយហេតុនោះបានជាគំនិតខ្ញុំបណ្ដាលឱ្យឆ្លើយដោយ
ព្រោះសេចក្ដីរួសរាន់នៅក្នុងចិត្តខ្ញុំ[ខ] ៣ខ្ញុំបានឮសេចក្ដី
បន្ទោសនោះ[គ] ដែលជាសេចក្ដីទំនាស់ចិត្តខ្ញុំ វិញ្ញាណនៃ
សេចក្ដីចេះដឹងរបស់ខ្ញុំក៏បណ្ដាលឱ្យខ្ញុំឆ្លើយឡើង ៤តើអ្នក
មិនបានដឹងសេចក្ដីនេះទេឬអី ថាតាំងពីចាស់បុរាណមក[ឃ]
គឺពីកាលព្រះបានដាក់មនុស្សឱ្យមាននៅផែនដី ៥នោះការ
ជ័យជំនះរបស់មនុស្សអាក្រក់[ង]នៅមិនយូរប៉ុន្មាន ហើយ
សេចក្ដីរីករាយរបស់មនុស្សទមិលល្មើស[ច]ក៏នៅតែ១ភ្លែត
ទេ[ឆ] ៦ទោះបើគេមានកំពស់[ជ]ដល់ផ្ទៃមេឃ[ឈ] ហើយក្បាល
គេលូតឡើងដល់ពពកក៏ដោយ[ញ] ៧គង់តែនឹងត្រូវវិនាសទៅ
ជានិច្ច[ដ]ដូចជាលាមករបស់ខ្លួនគេដែរ ឯពួកអ្នកដែលធ្លាប់
ឃើញគេ នោះនឹងសួរថា តើគេនៅឯណា[ឋ] ៨គេនឹងហោះ
ហើរទៅបាត់[ឌ]ដូចជាសប្តិ[ឍ] ឥតមានអ្នកណាឃើញទៀត
ឡើយ អើ នឹងត្រូវបណ្ដេញទៅ[ណ]ដូចជាការជាក់ស្ដែងនៅ
ពេលយប់ផង[ត] ៩នោះភ្នែកដែលធ្លាប់ឃើញគេ នឹងមិន
ឃើញគេទៀតទេ ហើយទីកន្លែងរបស់គេនឹងលែងឃើញ
គេដែរ[ថ] ១០កូនចៅ[ទ]គេនឹងសូមអង្វរដល់ពួកទាល់ក្រ ដៃ
របស់ខ្លួនគេនឹងត្រូវប្រគល់ទ្រព្យសម្បត្តិទៅវិញ[ធ] ១១ឆ្អឹងគេ[ន]
ពេញកំឡាំង[ប]ដោយសណ្ឋាននៅក្មេង ប៉ុន្តែនឹងត្រូវដេកចុះ
ទៅក្នុងធូលីដី ជាមួយនឹងខ្លួនគេដែរ[ផ] ។
១២ទោះបើសេចក្ដីអាក្រក់[ព]មានរសផ្អែមនៅក្នុងមាត់គេ
ទោះបើគេលាក់សេចក្ដីនោះនៅក្រោមអណ្ដាត[ភ] ១៣ទោះបើ
លែលកសំចៃទុក មិនចង់លេបចុះទៅ គឺបៀមទុកនៅតែក្នុង
មាត់វិញក៏ដោយ[ម] ១៤គង់តែអាហារនៅក្នុងពោះ[យ]គេបាន
ប្រែក្លាយទៅ ឱ្យបានជាពិសនៃពស់ហនុមាន[រ]នៅក្នុងខ្លួន
គេដែរ ១៥គេបានលេបទ្រព្យសម្បត្តិ[ល]ចូលទៅ ហើយនិង
ត្រូវក្អួតចេញមកវិញ ព្រះទ្រង់នឹងកំចាត់របស់ទាំងនោះ
ចេញពីពោះ[វ]គេ ១៦គេនឹងជញ្ជក់ពិស[ស]របស់ពស់ហនុមាន
ហើយនឹងស្លាប់ ដោយសារអណ្ដាតពស់វែក[ហ] ១៧គេនឹង
លែងមើលទឹកឃ្មុំ[ឡ] ដែលហូរដូចទឹកទន្លេ[អ] និងទឹកដោះ[ក]
ដែលហូរដូចទឹកស្ទឹងទៀត ១៨អ្វីៗដែលគេខ្វល់ខ្វាយរកបាន
នោះនឹងត្រូវប្រគល់ទៅវិញ ឥតទំពារលេបបានទេ[ខ] គេនឹង
ប្រគល់ទៅវិញតាមចំនួន ឥតដែលបានសប្បាយចិត្តដោយ
សាររបស់ទាំងនោះឡើយ[គ] ១៩ពីព្រោះគេបានសង្កត់សង្កិន
ឥតរមិលដល់ពួកទាល់ក្រ[ឃ,ង] ក៏បានរឹបជាន់យកផ្ទះ[ច]១ដែល
ខ្លួនមិនបានសង់ផង ។
២០មុខជាគេនឹងគ្មានសេចក្ដីសុខក្នុងចិត្តទេ[ឆ] ហើយនឹង
ទុករបស់ដែលគេពេញចិត្ត ឱ្យគង់នៅមិនបានឡើយ[ជ]
២១គ្មានសល់អ្វី ដែលគេមិនបានត្របាក់លេបចូលទៅនោះ
ទេ ហេតុនោះសេចក្ដីចំរើនរបស់គេនឹងមិននៅស្ថិតស្ថេរ

**១៩:២៩** ន យប ២៧:១៣–២៣ ទដ ១:៥ ៩:៧ ៥៨:១១ សស ៣:១៧ ១១:៩ ១២:១៤
**២០:១** ក យប ២:១១
**២០:២** ខ ទដ ៤២:៥ បទ ១:២០
**២០:៣** គ យប ១៩:៣
**២០:៤** ឃ ចទ ៤:៣២ ៣២:៧
**២០:៥** ង ទដ ៩៤:៣ ច យប ៨:១៣ ឆ យប ៨:១២ ទដ ៣៧:៣៥–៣៦ ៧៣:១៩
**២០:៦** ជ យប ៣៣:១៧ អស ១៦:៦ ឈ លប ១១:៤ ញ អស ១៤:១៣–១៤ អប ១:៣–៤
**២០:៧** ដ យប ៤:២០ ឋ យប ៧:៨ ១៤:២០
**២០:៨** ឌ ទដ ៩០:១០ សស ៦:១២ ១២:៧ ឍ ទដ ៧៣:២០ សស ៥:៣ ណ យប ១៨:១១ ត យប ២៧:២០ ៣៤:២០ ទដ ៩០:៥ អស ១៧:១៤ ២៩:៧
**២០:៩** ថ យប ៧:៨
**២០:១០** ទ យប ៥:៤ ធ ខ.១៥,១៨,២០ យប ៣:១៥ ៣១:៨ **២០:១១** ន យប ២១:២៤ ប យប ១៣:២៦ ផ យប ១៧:១៦ **២០:១២** ព យប ១៥:១៦ ភ ទដ ១០:៧ ១៤០:៣ **២០:១៣** ម ជន ១១:១៨–២០ **២០:១៤** យ សភ ២០:១៧ យរ ២:១៩ ៤:១៨ វវ ១០:៩ រ ជន ២១:៦ **២០:១៥** ល ខ.១០ វ លវ ១៨:២៥ **២០:១៦** ស ចទ ៣២:៣២ ហ ចទ ៣២:២៤ **២០:១៧** ឡ ចទ ៣២:១៣ អ ទដ ៣៦:៨ ក ចទ ៣២:១៤ យប ២៩:៦ **២០:១៨** ខ ខ.១០ យប ៥:៥ គ ទដ ១០៩:១១ **២០:១៩** ឃ យប ៥:១៦ ទដ ១០:២ ៩៤:៦ ១០៩:១៦ ង ចទ ១៥:១១ ២៤:១៤ យប ២៤:៤,១៤ ៣៥:៩ សភ ១៤:៣១ ២៨:២៨ អម ៨:៤ ច អស ៥:៨ **២០:២០** ឆ សស ៥:១២–១៤ ជ ខ.១០ សភ ១១:៤ សផ ១:១៨ លក ១២:១៥

**២០:២–៣** លោកសូផារបានយកពាក្យសម្ដីលោកយ៉ូប ជាពិសេសពាក្យបញ្ចប់របស់គាត់ក្នុង ១៩:២៨–២៩ គឺមានលក្ខណៈជាការជេរប្រមាថ ។ លោកយ៉ូបក៏ហ៊ានប្រកាសពោលអះអាងថា ទ្រឹស្ដីរបស់សូផារចំពោះការផ្ដន្ទាទោសរបស់សូផារខ្លួនឯងវិញ ។

**២០:៤–១១** លោកសូផារមានភាពអំនួតចំពោះសុខភាព និងភាពសុខសាន្តក្នុងទស្សនៈរបស់គាត់ដែលបង្ហាញភាពល្អរបស់គាត់និងភាពសុចរិត ។ ប៉ុន្តែសេចក្ដីអំណរ និងភាពខ្លាំងរបស់មនុស្សអាក្រក់ និងត្រូវចប់ក្នុងរយៈពេលខ្លីបំផុតដែលមានលក្ខណៈបត់បែន (មើល ទដ ៧៣:១៨–២០ និងការពន្យល់) ។

**២០:៦** *ក្បាលគេលូតឡើងដល់ពពក* មើល លប ១១:៤ និងការពន្យល់ ។

**២០:៧** *លាមក* គឺជាសញ្ញានៃភាពបណ្ដោះអាសន្ននិងភាពឥតន័យ (មើល ១ពវ ១៤:១០) ។

**២០:១០,១៩** ការគាបសង្កត់ទៅលើអ្នកក្រខ្សត់ គឺជាសញ្ញាពីការអាក្រក់យ៉ាងពិតប្រាកដ (មើល អម ២:៦–៨ និងការពន្យល់ ៨:៤–៨) ។ ក្នុងករណីនេះលោកយ៉ូបពុំមានបញ្ហាជាមួយសូផារទេ (មើល ៣១:១៦–២៣) ។

**២០:១១** *ធូលីដី* មើលការពន្យល់ ៧:២១ ។

**២០:១២–១៥** អំពើអាក្រក់របស់មនុស្សអាក្រក់ គឺដូចជាអាហារដែលមានរសជាតិហើយក៏ប្រែត្រឡប់ឱ្យគេទទួលភាពឈឺចាប់ក្នុងក្រពះទៅវិញ ។

**២០:១៥** *គេបានលេបទ្រព្យសម្បត្តិចូលទៅ* គឺជាការដែលគេយកទ្រព្យអ្នកក្រខ្សត់ (មើលការពន្យល់ ខ.១០,១៩) ។

**២០:១៧** *ទឹកឃ្មុំ . . . និងទឹកដោះគោ* មើល ២៩:៦ និងការពន្យល់ធៀប ចទ ៦:៣ និងការពន្យល់ ។

**២០:១៨** *គេខ្វល់ខ្វាយរកបាន . . . ឥតបានសប្បាយចិត្ត* គឺជាផ្ទៃរឿងមានលក្ខណៈរួមមួយក្នុងបែបអក្សរសាស្ត្រ ដែលជាប្រាជ្ញាអាចដោះស្រាយរាល់ការទាំងអស់ (មើល ឧទាហរណ៍ សស ២:១៨–២៣) ។

**២០:២០–២៥** ទោះជាមនុស្សអាក្រក់ខិតខំរកបំពេញក្រពះរបស់ពួកគេ គឺជាពេលដែលព្រះអម្ចាស់បញ្ចេញកំហឹងមកលើពួកគេ ក៏នាំឱ្យពួកគេគ្មានរកអ្វីបានទទួលទានឡើយ ។

ឡើយ[ឈ] 22 កាលណាដល់កំពូលនៃសេចក្តីបរិបូរ នោះគេ
នឹងត្រូវខ្វះខាតវិញ[ញ] ដៃនៃអស់អ្នកដែលមានសេចក្តីលំបាក
នឹងមកលើគេ[ដ] 23 ព្រះទ្រង់នឹងបោះសេចក្តីក្រោធ[ឋ]ដ៏សហ័ស
មកសំរាប់ចំអែតពោះគេ[ឌ] ហើយនឹងទំលាក់មកលើគេ[ឍ]
ទុកសំរាប់ជាអាហារ 24 គេនឹងរត់ចេញ[ណ]ពីគ្រឿងដែក
ហើយធ្នូលង្ហិននឹងបាញ់ទំលុះខ្លួន[ត] 25 គេនឹងដកព្រួញចេញ
ពីខ្លួនមក អើ មុខព្រួញដែលភ្លឺផ្លេកនឹងចេញពីពោះគេមក
នោះសេចក្តីតក់ស្លុត[ថ]នឹងកើតឡើងដល់គេ[ទ] 26 អស់ទាំង
សេចក្តីងងឹត[ធ]បានមកបំរុងនឹងបង្ខូចទ្រព្យសម្បត្តិគេ និង
មានភ្លើង[ន]ដែលឥតមនុស្សផ្លុំបានឆេះបំផ្លាញគេ[ប] ព្រមទាំង
បន្សុសទាំងអស់ដែលសល់នៅក្នុងទីលំនៅគេផង[ផ] 27 ឯផ្ទៃ
មេឃក៏នឹងសំដែងពីសេចក្តីទុច្ចរិតរបស់គេ ហើយទាំង
ផែនដីនឹងក្រោកឡើងទាស់នឹងគេដែរ[ព] 28 ផលចំរើននៃពួក
គ្រួគេនឹងចាកចេញទៅ[ភ] ទាំងអស់នឹងហូរទៅបាត់នៅថ្ងៃ
នៃសេចក្តីក្រោធរបស់ទ្រង់[ម] 29 នេះហើយជាចំណែកដែល
មនុស្សអាក្រក់ត្រូវទទួលអំពីព្រះ ជាមរដកដែលព្រះទ្រង់
ចែកឱ្យដល់គេ[យ]។

## លោកយ៉ូប

**២១** 1 នេះយ៉ូបក៏ឆ្លើយឡើងថា 2 សូមផ្ទង់ចិត្តស្តាប់ពាក្យខ្ញុំ
សិន[ក] ឱ្យខ្ញុំបានក្សាន្តទុក្ខត្រឹមប៉ុណ្ណោះ[ខ] 3 សូមទ្រាំឱ្យខ្ញុំនិយាយ
ខ្លះផង រួចក្រោយដែលខ្ញុំបាននិយាយចប់ហើយ នោះសឹម
ឡកឡឺយចុះ[គ] 4 ចំណែកខ្ញុំ តើសេចក្តីដំអូញ[ឃ]ខ្ញុំបានដំរង់ដល់
មនុស្សឬអី បើដូច្នេះ ធ្វើដូចម្តេចនឹងឱ្យខ្ញុំមិនមានសេចក្តីអន់
ចិត្តបាន[ង] 5 ចូរចំណាំមើលខ្ញុំ ហើយមានសេចក្តីអស្ចារ្យចុះ
រួចដាក់ដៃខ្ទប់មាត់ទៅ[ច] 6 កាលណាខ្ញុំនឹកពីសេចក្តីទាំងនេះ
នោះខ្ញុំមានសេចក្តីតក់ស្លុត[ឆ] ហើយសេចក្តីភ័យខ្លាចក៏បំព្រឺ
សាច់ខ្ញុំ[ជ] 7 គឺជា ហេតុអ្វីបានជាពួកមនុស្សអាក្រក់មានជីវិត
រស់នៅ អាយុក៏វែង អើ គេក៏ឡើងជាមានអំណាចយ៉ាងធំ
ផង[ឈ] 8 ពូជពង្សរបស់គេក៏បានតាំងឡើងជាមួយ នៅភ្នែក
គេ ហើយកូនចៅគេនៅចំពោះគេដែរ[ញ] 9 ទីលំនៅគេនៅ
ជាសុខឥតភ័យខ្លាច[ដ] ហើយដំបងនៃព្រះមិនដែលប៉ះពាល់
គេឡើយ[ឋ] 10 គោឈ្មោលរបស់គេវាជាន់មេឥតខាន គោ
ញីក៏សំរាលកូនឥតរលូតដែរ[ឌ] 11 គេឱ្យកូនតូចៗរបស់គេ
ចេញទៅដូចជាហ្វូងចៀម[ឍ] ហើយកូនធំៗក៏លោតកញ្ឆ្លាត់
កញ្ឆ្លេងផង 12 វារាល់គ្នាច្រៀងតាមចង្វាក់គែននិងស៊ុង[ណ]
ហើយក៏អរសប្បាយតាមសំឡេងខ្លុយ[ត] 13 រាល់តែថ្ងៃគេតែង
បង្ហួសពេលទៅ ដោយអ្វីៗដែលគេពេញចិត្ត[ថ] ហើយក្នុង១
រំពេច[ទ] គេចុះទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់[ធ] 14 គេទូល

**២០:២១** ឈ យប ៧:៨
**២០:២២** ញ ពច ២:១៥ លក ១២:១៦–២០ ដ ខ.២៩ យប ២១:១៧,៣០ ៣១:២–៣
**២០:២៣** ឋ បទ ៤:១១ អគ ៥:១៣ ៦:១២ ឌ ជន ១១:១៨–២០ ឍ ខ.១៤ ទដ ៧៨:៣០–៣១
**២០:២៤** ណ អស ២៤:១៨ យរ ៤៦:២១ ៤៨:៤៤ ត យប ១៥:២២
**២០:២៥** ថ យប ១៨:១១ ទ យប ១៥:២១ ទដ ៨៨:១៥–១៦
**២០:២៦** ធ យប ៥:១៤ ន យប ១:១៦ ប យប ១៥:៣៤ ២៦:៦ ២៨:២២ ៣១:១២ ទដ ២១:៩ ផ យប ១៨:១៥
**២០:២៧** ព ចទ ៣១:២៨
**២០:២៨** ភ ចទ ២៨:៣១ មថ ៧:២៦–២៧ ម ខ.២៩ ជន ១៤:២៨–៣២ យប ២១:១៧,២០,៣០ ៤០:១១ ទដ ៦០:៣ ៧៥:៨ សភ ១៦:៤ អស ២៤:១៨ ៥១:១៧ អម ៥:១៨ យហ ៣:៣៦ រម ១:១៨ អភ ៥:៦
**២០:២៩** យ ខ.២២ យប ១៥:២០ ២២:៥ ៣១:២ ៣៦:១៧ យរ ១៣:២៥ វវ ២១:៨
**២១:២** ក យប ១៣:១៧ ខ ខ.៣៤
**២១:៣** គ យប ៦:១៤ ១១:៣ ១៦:១០
**២១:៤** ឃ យប ៧:១១ ង យប ៦:៣
**២១:៥** ច ពច ១៨:១៩ យប ២៩:៩ ៤០:៤
**២១:៦** ឆ លប ៤៥:៣ ជ យប ៤:១៤
**២១:៧** ឈ ខ.១៣ យប ៩:២៤ ១២:១៩ ទដ ៣៧:១ ៧៣:៣ សស ៧:១៥ ៨:១៤ ហព ១:១៣ មឡ ៣:១៥
**២១:៨** ញ ទដ ១៧:១៤ មឡ ៣:១៥
**២១:៩** ដ យប ៥:២៤ ឋ យប ៩:៣៤
**២១:១០** ឌ នក ២៣:២៦
**២១:១១** ឍ ទដ ៧៨:៥២ ១០៧:៤១
**២១:១២** ណ ទដ ៣៣:២ ត លប ៤:២១ ១របា ១៥:១៦ ទដ ៧១:២២ ៨១:២ ១០៨:២ អស ៥:១២ មថ ១១:១៧
**២១:១៣** ថ ខ.៧ យប ៨:៧ ទដ ១០:១–១២ ៩៤:៣ ទ យប ៣:១៣ ធ យប ២៤:១៩ ទដ ៤៩:១៤ អស ១៤:១៥

**២០:២៤** *គ្រឿងដែក* មើលការពន្យល់ ១៩:២៤ ។
**២០:២៦** *សេចក្តីងងឹត* មើលការពន្យល់ ១០:២១ ។
**២០:២៧** មើល ចទ ៣០:១៩ និងការពន្យល់ ។
**២០:២៨** គឺជាភាពហិនវិនាសមួយក្នុងកំឡុងពេលមានភ្លៀងក៏បានបំផ្លាញអ្វីៗជាច្រើន(មើល ៦:១៥–១)។
**២០:២៩** គឺដូចជាលោកប៊ីលដាឌក្នុង ១៨:២១ (មើលការពន្យល់នៅទីនោះ) លោកសូផារបានបញ្ចប់សម្តីដោយសង្ខេបថា ការដែលព្រះមានផែនការដើម្បីកាត់ទោសអ្នកមានបាប ។ *ជាចំណែកដែលមនុស្សអាក្រក់ត្រូវទទួលអំពីព្រះ* ជាសម្តីនិយាយឡើងវិញដោយលោកយ៉ូប ដែលនិយាយចំៗ មើល ២៧:១៣ ។
**២១:២** *ខ្ញុំបានក្សាន្តទុក្ខ* មើល ខ.៣៤ "ចង់ជួយកំសាន្តខ្ញុំធ្វើអ្វី" ដែលជាពាក្យសម្តីរបស់លោកយ៉ូបឆ្លើយទៅរកលោកសូផារ ។
**២១:៤** *តើសេចក្តីដំអូញខ្ញុំបានដំរងដល់មនុស្សឬអី* លោកយ៉ូបបានពោលថា ទេខ្ញុំមានសេចក្តីដំអូញទៅរកព្រះទេតើ ដោយព្រះទ្រង់ជាអង្គមួយដែលរ៉ាបរងនិងធានាដល់លក្ខខណ្ឌជីវិតរបស់ខ្ញុំ ហើយយ៉ាងហោចណាស់លោកយ៉ូបក៏បានដឹងផងដែរ ។ *សេចក្តីអន់ចិត្ត* មើលការពន្យល់ ៩:២–៣ ។
**២១:៥** *ចូរចំណាំមើលខ្ញុំ* លោកយ៉ូបបង្ហាញពីមិត្តទាំងបីនាក់របស់គាត់ ។
**២១:៦** *សេចក្តីទាំងនេះ* ជាការដំអូញទៅឯព្រះអម្ចាស់ ។ *សេចក្តីតក់ស្លុត* គឺជាស្ថានភាពក្រឡាប់ចក្រដែលក្នុងនោះ មនុស្សអាក្រក់ត្រូវបានជោគជ័យ ។
**២១:៧–១៥** អ្នកឱ្យយោបល់ដល់លោកយ៉ូបក៏បាននិយាយរ៉ាយរ៉ាប់ពីវាសនារបស់មនុស្សអាក្រក់ (មើល ៨:១១–១៩ ១៥:២០–៣៥ ១៨:៥–២១ ជំពូក ២០) តែលោកយ៉ូបបង្ហាញនូវភាពផ្ទុយនូវអ្វី ដែលមិត្តរបស់គាត់បាននិយាយ មនុស្សអាក្រក់ពុំបានដឹងអ្វីជាផ្លូវរបស់ព្រះ ហើយគេយល់ថាការអធិស្ឋានដែលឥតប្រយោជន៍(ខ.១៤–១៥)តែមានភាពរីកចម្រើននូវគ្រប់ផ្លូវដែលគេធ្វើ ។ ដែលខុសឆ្ងាយពីលោកសូផារដែលមានទំនាក់ទំនងនិងរឿងព្រះនោះ(មើល ២០:១១) ពួកគេមានជីវិតរស់វែងឆ្ងាយនិងបានកើនឡើងនូវអំណាច(ខ.៧)ប៊ីលដាឌបានប្រកាសថា មនុស្សអាក្រក់ពុំមានកូនចៅឬបន្តពូជ ឬពូជអំបូរ (សូមមើល ១៨:១៩) លោកយ៉ូបបដិសេធយ៉ាងអង់អាច (ខ.៨,១១) ។
**២១:៩** *ដំបងនៃព្រះ* មើលការពន្យល់ ៩:៣៤ ។
**២១:១៣** *ពេញចិត្ត* គឺមានឫសគល់ពីភាសាហេព្រើរដែលវិភាគន័យមកថា "អ្នកដែលបានរស់នៅប្រកបដោយភាពសុខសាន្ត" ក្នុង ទដ ៣៥:២០ ។

ដល់ព្រះថា ចូរថយចេញពីយើងទៅ[ន] ពីព្រោះយើងមិនចូល
ចិត្តស្គាល់ផ្លូវទ្រង់ទេ[ប] ១៥ តើព្រះដ៏មានគ្រប់ព្រះចេស្តាជាអ្វី
ដែលយើងត្រូវគោរពដល់ទ្រង់ ហើយបើយើងអធិស្ឋាន
ដល់ទ្រង់[ផ] តើនឹងមានប្រយោជន៍អ្វី ១៦ ដូច្នេះ ធ្វើដូចម្តេចទៅ
គឺសេចក្តីចំរើនរបស់គេមិនស្រេចនៅដៃគេទេ ឱសូមឱ្យ
គំនិតនៃពួកមនុស្សអាក្រក់បាននៅឆ្ងាយពីខ្ញុំទៅ[ព] ។
១៧ សេចក្តីនេះក៏កើតឡើងជាញឹកញយដែរទេតើ គឺ
ចង្កៀងនៃមនុស្ស អាក្រក់រលត់ទៅ[ភ] ក៏មានសេចក្តីលំបាក[ម]
កើតដល់គេ ដ្បិតព្រះទ្រង់ចែកសេចក្តីវេទនា ដោយសេចក្តី
ក្រោធរបស់ទ្រង់ដែរ[យ] ១៨ គឺជាច្រើនដង គេដូចជាចំបើង
បណ្តោយខ្យល់ ហើយដូចជាអង្កាម[រ] ដែលខ្យល់ព្យុះ[ល] ផាត់
យកទៅ[វស] ១៩ មនុស្សថា ព្រះទ្រង់ប្រមូលទុកសេចក្តីទុច្ចរិត
របស់មនុស្ស សំរាប់កូនចៅតទៅ[ហ] តែត្រូវឱ្យទ្រង់ដាក់ទោស
ដល់ខ្លួនអ្នកនោះវិញ ឱ្យគេបានដឹងផង[ឡ] ២០ ត្រូវឱ្យភ្នែករបស់
អ្នកនោះឯងឃើញសេចក្តីវិនាសរបស់ខ្លួន[អ] ព្រមទាំងផឹក[ក]
ស្រូបសេចក្តីក្រោធ របស់ព្រះដ៏មានគ្រប់ព្រះចេស្តាផង[ខ]
២១ ដ្បិតកាលណាចំនួនអស់ទាំងខែ[គ] នៃជីវិតគេបានផុតទៅ
ហើយ[ឃ] នោះតើគេនឹងរវល់អ្វីដល់ពួកវង្សខ្លួនដែលនៅ
ខាងក្រោយ[ង] ២២ តើនឹងមានអ្នកណាបង្រៀនចំណេះដល់ព្រះ
ឬទេ[ច] ដ្បិតគឺទ្រង់ហើយ ដែលជំនុំជំរះដល់ទាំងពួកអ្នកធំៗ
ផង[ឆ] ២៣ អ្នក១ដែលមានសេចក្តីស្រណុក[ជ] ហើយសុខសាន្តក៏
ស្លាប់បាត់ទៅ ក្នុងកាលដែលនៅមានកំឡាំងពេញប្រាណ[ឈ]
២៤ គឺក្នុងកាលដែលសាច់គេនៅស្រស់ល្អ[ញ] ហើយខួរឆ្អឹង[ដ] ក៏
នៅសើមៗនៅឡើយ[ឋ] ២៥ ម្នាក់ទៀតស្លាប់ទៅទាំងមានចិត្ត
ជូរល្វីង[ឌ] ឥតដែលភ្លក់រសនៃសេចក្តីល្អឡើយ ២៦ ទាំង២ពួក
ដេកទៅក្នុងធូលីដី[ឍ] ដូចគ្នា ហើយដង្កូវ[ណ] ក៏ចុះពេញខ្មោច
គេដែរ[ត] ។
២៧ នែ ខ្ញុំស្គាល់គំនិតរបស់អ្នករាល់គ្នាហើយ ក៏យល់
ឧបាយដែលគិតធ្វើអាក្រក់ដល់ខ្ញុំដែរ ២៨ ដ្បិតអ្នករាល់គ្នាថា
តើផ្ទះរបស់សេដ្ឋី[ថ] នៅឯណាឥឡូវ គឺជាទីលំនៅរបស់មនុស្ស
អាក្រក់នោះ តើនៅឯណា[ទ] ២៩ តើអ្នករាល់គ្នាមិនបានសួរ
ពួកអ្នកដំណើរដូច្នេះទេឬអី ៣០ គឺថា មនុស្សអាក្រក់ត្រូវបំរុង
ទុកដល់ថ្ងៃអន្តរាយ[ធ] គេត្រូវនាំចេញទៅឯថ្ងៃនៃសេចក្តី
ឃោរឃៅ[ន] ៣១ តើអ្នកណានឹងប្រាប់ផ្ចាល់រូបគេពីផ្លូវរបស់
គេ តើអ្នកណានឹងសងគេ តាមការដែលគេបានប្រព្រឹត្ត[ប]
៣២ ប៉ុន្តែនិងត្រូវសែងគេនាំយកទៅឯទីកប់ខ្មោច ហើយនិង
មានមនុស្សចាំយាមផ្នូរដែរ[ផ] ៣៣ គំនរដុំដីនៅច្រកភ្នំនឹងបាន
ស្រួលដល់គេ[ព] ហើយអស់ទាំងមនុស្សនឹងទៅតាមគេ ដូចជា
មានមនុស្សឥតគណនាបានទៅមុនគេដែរ[ភ] ៣៤ ចុះអ្នករាល់
គ្នាយកសេចក្តីឥតប្រយោជន៍មក ចង់ជួយកំសាន្តចិត្តខ្ញុំធ្វើអី[ម]
ដែលពាក្យចំឡើយរបស់អ្នករាល់គ្នាសុទ្ធតែជាសេចក្តីកំភូត
ដូច្នេះ[យ] ។

### លោកអេលីផាស

**២២** ១ នោះអេលីផាស សាសន៍ថេម៉ាន[ក] ក៏ឆ្លើយឡើងថា
២ តើមនុស្សនឹងមានប្រយោជន៍ដល់ព្រះបានឬទេ[ខ] ឯមនុស្ស
ប្រាជ្ញ គេមានប្រយោជន៍ចំពោះតែខ្លួនគេប៉ុណ្ណោះ[ខ] ៣ បើអ្នក
ជាមនុស្សសុច្ចរិត[គ] នោះតើចំរើនសេចក្តីអំណរដល់ព្រះដ៏

**២១:១៤** ន យប ៤:១៧ ២២:១៧ អស ៣០:១១ ប ចទ ៣២:១៥ ១សយ ១៥:១១ ទដ ៩៥:១០ សភ ១:២៩ យរ ២:២០,៣១ **២១:១៥** ផ យប ៥:២ ៣៤:៩ ៣៥:៣ ទដ ៧៣:១៣ ១៣៩:២០ អស ៤៨:៥ យរ ៩:៦ ៤៤:១៧ **២១:១៦** ព យប ២២:១៨ ទដ ១:១ ២៦:៥ ៣៦:១ **២១:១៧** ភ យប ១៨:៥ ម យប ១៨:១២ យ យប ២០:២២,២៨ **២១:១៨** រ យប ១៣:២៥ ល លប ៧:២៣ វ យប ៧:១០ សភ ១០:២៥ ស លប ១៩:១៥ **២១:១៩** ហ នក ២០:៥ យរ ៣១:២៩ អគ ១៩:២ យហ ៩:២ ឡ យរ ២៥:១៤ ៥០:២៩ ៥១:៦,២៤,៥៦ **២១:២០** អ នក ៣២:៣៣ ជន ១៦:២២ ២ពវ ១៤:៦ យរ ៤២:១៦ ក យប ៦:៤ ខ យប ២០:២៨ យរ ២៥:១៥ វវ ១៤:១០ **២១:២១** គ យប ១៤:៥ ឃ យប ១៤:២២ ង យប ១៤:២១ សស ៩:៥–៦ **២១:២២** ច យប ៣៥:១១ ៣៦:២២ ៣៩:១៧ ទដ ៩៤:១២ អស ៤០:១៣–១៤ យរ ៣២:៣៣ រម ១១:៣៤ ឆ យប ៤:១៨ ទដ ៨២:១ ៨៦:៨ ១៣៥:៥ **២១:២៣** ជ លប ១៥:១៥ យប ១៣:២៦ ឈ យប ៣:១៣ **២១:២៤** ញ ទដ ៧៣:៤ ដ យប ២០:១១ ឋ សភ ៣:៨ **២១:២៥** ឌ យប ១០:១ **២១:២៦** ឍ យប ១៧:១៦ ណ យប ៧:៥ ត យប ២៤:២០ សស ៩:២–៣ អស ១៤:១១ **២១:២៨** ថ យប ១:៣ ១២:២១ ២៩:២៥ ៣១:៣៧ ទ យប ៨:២២ **២១:៣០** ធ យប ៣១:៣ ន យប ២០:២២,២៨ អស ៥:៣០ រម ២:៥ ២ពត ២:៩ **២១:៣១** ប យប ៣៤:១១ ទដ ៦២:១២ សភ ២៤:១១–១២ អស ៥៩:១៨ **២១:៣២** ផ អស ១៤:១៨ **២១:៣៣** ព យប ៣:២២ ភ យប ៣:១៩ **២១:៣៤** ម ខ.២ យ យប ៦:១៥ ៨:២០ **២២:២** ក លក ១៧:១០ ខ យប ៧:១៧ **២២:៣** គ ទដ ១៤៣:២

**២១:១៦** មើល ២២:១៨ លោកយ៉ូបមិនទទួលស្គាល់អ្នកផ្តល់ដំបូន្មានរបស់មនុស្សអាក្រក់ ហើយក៏ដឹងថាព្រះទ្រង់ដឹងគ្រប់ការទាំងអស់ (ខ.១៧) ក៏ជាប្រាជ្ញាធ្វើឱ្យព្រះបង្កើតបាននូវពាក្យប្រៀបធៀបចំពោះគាត់ ។

**២១:១៧** *ចង្កៀងនៃមនុស្សអាក្រក់រលត់ទៅ* មើល ១៨:៥ និងការពន្យល់ ។

**២១:២០** *ផឹកស្រូបសេចក្តីក្រោធរបស់ព្រះដ៏មានគ្រប់ព្រះចេស្តា* មើលការពន្យល់ អស ៥១:១៧ ។

**២១:២២** *នឹងមានអ្នកណាបង្រៀនចំណេះដល់ព្រះ* មើល អស ៤០:១៤ ។ ផ្ទុយទៅវិញ ព្រះជាអ្នកបង្រៀន (មើល ៣៥:១១ ៣៦:២២ ជំពូក ៣៨–៤១) ។

**២១:២៦** *ធូលីដី* មើលការពន្យល់ ៧:២១ ។

**២១:៣៤** *ចង់ជួយកំសាន្តចិត្តខ្ញុំធ្វើអី* មើល ១៦:២ និងការពន្យល់ ។

**២២:១–២៦:១៤** គឺជាខួបទី៣នៃសេចក្តីថ្លែង វាពុំដូច (ជំពូក ៤–១៤) និងផ្នែកទី២ (ជំពូក ១៥–២១) ក៏បានគេកាត់ជាវគ្គខ្លះៗនិងសង្ខេប ។ ការបើកសម្តែងរបស់លោកប៊ីលដាឌ គឺមានលក្ខណៈសង្ខេបណាស់ (២៥:១–៦) និងលោកសូផារពុំបាននិយាយអ្វីទាំងអស់ ។ បទសន្ទនារវាងលោកយ៉ូបនិងមិត្តភ័ក្ត្ររបស់លោកក៏បានបញ្ចប់ ពីព្រោះមិត្តនោះមិនអាចចុះចូលនិងភាពខុសឆ្គងរបស់គាត់ ឯលោកយ៉ូបក៏មិនទទួលស្គាល់អ្វីជាការពិតឡើយ ។

**២២:២–៤** ហេតុការណ៍ដ៏សមរម្យ គឺមានដូចខាងក្រោម : គឺគ្រប់ការទាំងអស់គឺមានប្រភពដើមរបស់វាក្នុងព្រះអម្ចាស់ ។ ដូច្នេះពេលដែលប្រជាជនបានថ្វាយអ្វីដល់ព្រះវិញ គឺជាអ្វីដែលព្រះបានឱ្យពួកគេ ។ គឺអ្វីដែលមិនមែនជាការរីកចម្រើដល់ព្រះឡើយ គឺក្នុងពេលខ្លះ ។ តាមការពិតព្រះអម្ចាស់មានលក្ខណៈផ្ទុយស្រលះពីភាពល្អរបស់មនុស្ស ព្រោះភាពល្អបានសង្ឃឹមក្នុងពួកគេ ។ គឺពេលដែលមនុស្សបានទទួលគ្រោះអាក្រក់នោះព្រះក៏មានវត្តមាន

មានគ្រប់ព្រះចេស្ដាឬអី[ឃ] បើអ្នកកែផ្លូវអ្នកឱ្យត្រឹមត្រូវឡើង
នោះតើជាកំរៃដល់ទ្រង់ឬ[ង] ៤ តើដោយព្រោះតែអ្នកមាន
សេចក្ដីកោតខ្លាចដល់ព្រះ បានជាទ្រង់បន្ទោសអ្នក ហើយ
រួមចូលជាគូក្ដីជាមួយនឹងអ្នកឬ[ច] ៥ ឯអំពើអាក្រក់របស់អ្នក
តើមិនមែនធំសំបើមវិញទេឬអី ហើយសេចក្ដីទុច្ចរិត[ឆ]របស់
អ្នកក៏មិនចេះអស់ដែរ[ជ] ៦ ដ្បិតអ្នកបានបង្អត់[ឈ]ដល់បងប្អូនអ្នក
ដោយឥតហេតុ[ញ] ហើយបានសំរាតយកពីមនុស្សកំសត់ទុគ៌ត
ផង[ដ] ៧ អ្នកមិនបានឱ្យទឹក[ឋ]ដល់មនុស្សហេវផឹកឡើយ ក៏បាន
បង្អត់អាហារដល់មនុស្សឃ្លានដែរ[ឌ] ៨ មនុស្សខ្លាំងពូកែបាន
ជាម្ចាស់លើផែនដី[ឍ] មនុស្សមានបណ្ដាសក្ដិ[ណ]បានតាំងទីលំ
នៅនៅក្នុងស្រុក[ត] ៩ អ្នកបានបណ្ដេញស្រីមេម៉ាយ[ថ]ឱ្យទៅ
ដោយដៃទទេ[ទ] ហើយបានបំបាក់ដៃនៃពួកកំព្រា[ធ] ១០ ហេតុ
នោះបានជាមានអន្ទាក់[ន]នៅព័ទ្ធជុំវិញអ្នក[ប] ហើយមាន
សេចក្ដីស្ញែងខ្លាចភ្លាមៗមកបំភ័យអ្នក[ផ] ១១ ឬជាសេចក្ដីងងឹត[ព]
ឱ្យអ្នកមើលមិនឃើញ ឬជាទឹកជនសាយមកគ្របលើអ្នក
វិញ[ភ] ។
១២ ឯព្រះ តើទ្រង់មិនគង់នៅជាន់ខ្ពស់ នៅស្ថានសួគ៌ទេឬ
អី[ម] ចូរមើលផ្កាយដ៏ខ្ពស់ទាំងប៉ុន្មាន ដែលជាខ្ពស់ដល់ណា
ទៅ ១៣ អ្នកពោលថា តើព្រះទ្រង់ជ្រាបអ្វីខ្លះ[យ] តើទ្រង់អាច
ទតទំលុះសេចក្ដីងងឹតមកជំនុំជំរះបានដែរឬ[រ] ១៤ មានពពក
យ៉ាងក្រាស់[ល]នៅហុំទ្រង់ជុំវិញ មិនឱ្យឃើញអ្វីឡើយ[វ] ហើយ
ទ្រង់ក៏យាងនៅតែលើផ្ទៃមេឃ[ស] ១៥ តើអ្នករក្សាទុកផ្លូវចាស់
ដែលមនុស្សអាក្រក់[ហ]បានដើរ ហើយឬអី[ឡ] ១៦ ជាពួកមនុស្ស
ដែលត្រូវឆក់យកទៅមុនកំណត់[អ] ដែលទីពឹង[ក]គេបានហូរ
ទៅបាត់ដូចជាទឹកជ្រោះ[ខ] ១៧ គេបានទូលដល់ព្រះថា ចូរថយ
ចេញពីយើងទៅ ហើយថា តើព្រះដ៏មានគ្រប់ព្រះចេស្ដា
ទ្រង់អាចនឹងប្រោសដល់យើងយ៉ាងណាបាន[គ] ១៨ ប៉ុន្តែគឺទ្រង់
ដែលបានបំពេញផ្ទះគេ ដោយអស់ទាំងរបស់ល្អផង[ឃ] តែ
សូមឱ្យគំនិតនៃមនុស្សអាក្រក់នៅឆ្ងាយពីខ្ញុំទៅ[ង] ១៩ ពួក
មនុស្សសុច្ចរិតក៏ឃើញ ហើយមានសេចក្ដីអំណរ[ច]ពួក
មនុស្សផូរផង់នឹងសើចឡកឱ្យ[ឆ]គេថា ២០ ពួកអ្នកដែលបាន
លើកគ្នាទាស់នឹងយើង គេត្រូវសាបសូន្យហើយ[ជ] ឯសំណល់
របស់គេ នោះភ្លើង[ឈ]បានឆេះអស់ទៅ ។
២១ ដូច្នេះ ចូរអ្នកផ្គាប់ផ្គុនទ្រង់ ហើយមានសេចក្ដីមេត្រី[ញ]

**២២:៣** ឃ អស ១:១១ ហក ១:៨ ង យប ៣៥:៧ សផ ៩:១២ **២២:៤** ច យប ៩:៣ ១៩:២៩ ទដ ១៤៣:២ អស ៣:១៤ អក ២០:៣៥ **២២:៥** ឆ អរ ៩:១៣ យប ១៥:៥ ជ យប ១៥:១៣ ២០:២៩ ២៩:១៧ **២២:៦** ឈ នក ២២:២៦ ញ ២ពវ ៤:១ ដ នក ២២:២៧ ចទ ២៤:១២–១៣ **២២:៧** ឋ មថ ១០:៤២ ឌ ខ.៩ យប ២៩:១២ ៣១:១៧, ២១,៣១ អស ៥៨:៧,១០ អគ ១៨:៧ មថ ២៥:៤២ **២២:៨** ឍ យប ១៥:១៩ ណ អស ៣:៣ ៥:១៣ ៩:១៥ ត យប ១២:១៩ **២២:៩** ថ យប ២៩:១៣ ៣១:១៦ ទដ ១៤៦:៩ ទ យប ២៤:៣,២១ អស ១០:២ លក ១:៥៣ ធ ខ.៧ យប ៦:២៧ អស ១:១៧ **២២:១០** ន យប ១៨:៩ ប យប ១០:៣ ផ យប ១៥:២១ **២២:១១** ព យប ៥:១៤ ភ លប ៧:២៣ យប ៣៦:២៨ ៣៨:៣៤,៣៧ ទដ ៦៩:១–២ ១២៤:៤–៥ អស ៥៨:១០–១១បទ ៣:៥៤ **២២:១២** ម យប ១១:៨ ១៦:១៩ **២២:១៣** យ ខ.១៤ ទដ ១០:១១ ៥៩:៧ ៦៤:៥ ៧៣:១១ ៩៤:៧ អស ២៩:១៥ អគ ៩:៩ សផ ១:១២ រ ទដ ១៣៩:១១ អគ ៨:១២ អភ ៦:១២ **២២:១៤** ល យប ២៦:៩ ទដ ៩៧:២ ១០៥:៣៩ វ ខ.១៣ ២ពវ ២១:១៦ ស យប ៣៧:១៨ ទដ ១៨:១១ សភ ៨:២៧ អស ៤០:២២ យរ ២២:២៣–២៤ **២២:១៥** ហ យប ២៣:១០ ៣៤:៣៦ ឡ យប ៣៤:៨ ទដ ១:១ ៥០:១៨ **២២:១៦** អ យប ១៥:៣២ ក យប ៤:១៩ ខ លប ៧:២៣ មថ ៧:២៦–២៧ **២២:១៧** គ យប ២១:១៥ **២២:១៨** ឃ យប ១២:៦ ង យប ២១:១៦ **២២:១៩** ច ទដ ៥:១១ ៩:២ ៣២:១១ ៥៨:១០ ៦៤:១០ ៩៧:១២ ១០៧:៤២ ឆ យប ២១:៣ ទដ ៥២:៦ **២២:២០** ជ ទដ ១៨:៣៩ ឈ យប ១៥:៣០ **២២:២១** ញ អស ២៦:៣,១២ ២៧:៥ រម ៥:១

ជីវិតគេផងដែរ ។

**២២:៤** *សេចក្ដីកោតខ្លាច* មើលការពន្យល់ ៤:៦ ។ *រួមចូលជាគូក្ដីជាមួយនឹងអ្នក* មើលការពន្យល់ ៩:៣ ។

**២២:៥–១១** សំដីពីដំបូងលោកអេលីផាសមានភាពច្បាស់លាស់តិចតួច និងព្រឹត្តការណ៍ដំបូងក៏មានលក្ខណៈលួងលោមចិត្ត ។ (៤:៦ ៥:១៧) តែខុសពីអ្វីៗដែលលោកបាននិយាយពីមុនៗ ៤:៣–៤ ។ លោកអេលីផាស ឥឡូវក៏បានស្ដីបន្ទោសដល់លោកយ៉ូប (ខ.៦–៧) និងប្រឆាំងនិងស្ដ្រីមេម៉ាយនិងអ្នកឥតមានឪពុក (ខ.៩) គឺពួកកូនកំព្រា ។ ការចោទប្រកាន់របស់លោកអេលីផាស គឺសំដៅលើភាពឈឺចាប់របស់លោកយ៉ូបនាពេលបច្ចុប្បន្ន (ខ.១០–១១) ក្នុងជំពូក ២៩ លោកយ៉ូបបង្ហាញពីឥរិយាបទរបស់លោកអេលីផាសមកលើរូបលោក ។

**២២:៦** *ដ្បិតអ្នកបានបង្អត់ដល់បងប្អូនអ្នកដោយឥតហេតុ . . . សំរាតយកពីមនុស្ស កំសត់ទុគ៌តផង* អំពើកាត់ទោសដោយពួកហោរា (មើល ឧ. អម ២:៨ និងការពន្យល់ ) ។

**២២:៩** *ស្រីមេម៉ាយ . . . ពួកកូនកំព្រា* មើល ២៤:៣ អស ១:១៧ និងការពន្យល់ យក ១:២៧ ។ *បំបាក់ដៃ* ជាពាក្យអក្សរសាស្ត្រមានន័យថាបំបាក់កម្លាំង (ដូចជា ៣៨:១៥) ។

**២២:១០** *អន្ទាក់* មើល ១៩:៦ និងការពន្យល់ ។

**២២:១១** *សេចក្ដីងងឹត . . . ជន់សាយមកគ្របលើអ្នកវិញ* គឺជាពាក្យកង្វល់ពីរផ្សេងគ្នានៃបញ្ហានិងការឈឺចាប់ (មើល ទដ ៤២:៧ និងការពន្យល់ អស ៨:៧–៨ និងការពន្យល់ ៨:២២ ៤៣:២) ។

**២២:១២–២០** ការបង្ហាញចេញពីលោកអេលីផាសចុងក្រោយគឺការគាំទ្រដល់ជម្លោះរបស់ប៊ីលដាឌនិងសូផារ គឺជាអ្នកដែលសម្ដែងថាលោកយ៉ូប គឺជាមនុស្សអាក្រក់ ។ លោកអេលីផាស ធ្វើការចោទប្រកាន់យ៉ាងតឹងរឹង គឺថាលោកយ៉ូបដើរក្នុងផ្លូវដែលពុំមានព្រះ (ខ.១៥) តើអ្នកណាប្រុងនឹងប្រឆាំងតបនិងអំណាចចេស្ដារបស់ព្រះ ហើយនិយាយថា តើព្រះដែលមានគ្រប់ព្រះចេស្ដាអាចនិងធ្វើអ្វីចំពោះយើងទៅ (ខ.១៧ មើល ខ.១៣–១៤) ។ គេថែមទាំងមើលងាយចំពោះភាពល្អរបស់ព្រះអម្ចាស់ (ខ.១៨) ។

**២២:១៨** មើល ២១:១៦ និងការពន្យល់ ។

**២២:២១–៣០** អេលីផាសបានប្រឹងប្រែងចុងក្រោយដើម្បីទៅរកលោកយ៉ូបក្នុងផ្លូវជាច្រើន គឺជាការត្រាស់ហៅក្នុងការកាត់ទោសដើម្បីលន់តួបាប គឺជាការចុះចូលនិងព្រះ (ខ.២១) ដាក់ដាំព្រះបន្ទូលក្នុងចិត្តអ្នក (ខ.២២) ត្រឡប់ទៅរកព្រះដែលមានគ្រប់ព្រះចេស្ដា ហើយបោះបង់ចោលការអាក្រក់ (ខ.២៣) ស្វែងរកតម្រូវការរបស់អ្នកក្នុងព្រះជាជាងក្នុងមាសប្រាក់ (ខ.២៤–២៦) អធិស្ឋាននិងស្ដាប់បង្គាប់ (ខ.២៧) និងប្រែក្លាយជាមានទំនាក់ទំនងនិងអំពើបាបមនុស្សមានបាប (ខ.២៩–៣០) ។ តែដំបូងមានរួមពីលោក

នឹងទ្រង់ចុះ[ដ] នោះនឹងបានចំរើនប្រយោជន៍ដល់ខ្លួន[ឋ] ២២ខ្ញុំ
សូមឱ្យអ្នកទទួលសេចក្ដីបង្រៀនពីព្រះឱស្ឋទ្រង់[ឌ] ហើយ
ប្រមូលទុកអស់ទាំងព្រះបន្ទូលនៃទ្រង់[ឍ]នៅក្នុងចិត្តចុះ[ណ]
២៣បើអ្នកវិលត្រឡប់មក[ត]ឯព្រះដ៏មានគ្រប់ព្រះចេស្ដាវិញ
នោះនឹងបានតាំងឡើងហើយ[ថ] គឺបើអ្នកកំចាត់សេចក្ដីទុច្ចរិត
ឱ្យឆ្ងាយចេញពីទីលំនៅរបស់អ្នកទៅ[ទ] ២៤ហើយបោះបង់
ចោលទ្រព្យវិសេស[ធ]របស់អ្នកទៅក្នុងធូលីដី ព្រមទាំងមាស[ន]
ពីស្រុកអូភារ[ប]ទៅក្នុងថ្មនៅបាតជ្រោះទឹកផង[ផ] ២៥នោះ
ព្រះដ៏មានគ្រប់ព្រះចេស្ដាទ្រង់នឹងបានជាទ្រព្យវិសេស[ព] និង
ជាប្រាក់មានសាច់សុទ្ធដល់អ្នកហើយ[ភ] ២៦ដ្បិតយ៉ាងនោះ
អ្នកនឹងបានពេញចិត្ត ដោយសារព្រះដ៏មានគ្រប់ព្រះចេស្ដា
វិញ[ម] ក៏នឹងអាចងើបមុខ[យ]មើលចំទៅឯទ្រង់ផង[រ] ២៧អ្នកនឹង
អធិស្ឋានដល់ទ្រង់[ល] ហើយទ្រង់នឹងទទួល[វ] យ៉ាងនោះអ្នកនឹង
បានលាបំណន់របស់អ្នក[ស] ២៨កាលណាអ្នកសំរេចនឹងធ្វើ
ការអ្វី នោះនឹងបានសំរេចដូចបំណង[ហ] និងមានពន្លឺ[ឡ]ភ្លឺមក
លើផ្លូវរបស់អ្នកដែរ[អ] ២៩កាលណាគេបន្ទាបទៅ[ក] នោះអ្នក
នឹងនឹកថា មានការលើកឡើងវិញ ឯមនុស្ស សុភាពទ្រង់នឹង
ជួយសង្គ្រោះ[ខ] ៣០ទ្រង់នឹងជួយទាំងមនុស្សដែលមិនមែន
ឥតទោសឱ្យរួចផង[គ] អើ អ្នកនោះនឹងបានរួចដោយសារ
សេចក្ដីបរិសុទ្ធរបស់ដៃអ្នក[ឃ]។

## លោកយ៉ូប

**២៣** ១នោះយ៉ូបក៏ឆ្លើយឡើងថា ២នៅថ្ងៃនេះសេចក្ដី
ដំអូញ[ក]របស់ខ្ញុំទុកជាសេចក្ដីបះបោរទៀត[ខ] តែព្រះហស្ត
ដែលសង្កត់លើខ្ញុំ នោះធ្ងន់ជាងអស់ទាំងដំងូរខ្ញុំផង[គ] ៣ឱបើខ្ញុំ
បានដឹងជា ប្រទះឃើញទ្រង់នៅទីណា ដើម្បីឱ្យខ្ញុំបានទៅ
ដល់បល្ល័ង្កទ្រង់ទៅអេះ[ឃ] ៤នោះខ្ញុំនឹងបានរៀបរាប់ពី
ដំណើរ[ង]ខ្ញុំ ដោយលំដាប់ទូលនៅចំពោះទ្រង់ ហើយនឹង
បំពេញមាត់ខ្ញុំដោយសេចក្ដីជជែកតវ៉ា[ច] ៥ខ្ញុំនឹងបានស្គាល់
ពាក្យណាដែលទ្រង់នឹងឆ្លើយមកខ្ញុំ[ឆ] ហើយយល់សេចក្ដី
ដែលទ្រង់ចង់មានបន្ទូលតប ៦តើទ្រង់នឹងតវ៉ានឹងខ្ញុំដោយនូវ
អំណាចទ្រង់ដ៏ធំឬអី[ជ]ទេ គឺទ្រង់នឹងប្រុងស្តាប់ខ្ញុំវិញជាពិត[ឈ]
៧នៅទីនោះ មនុស្សទៀងត្រង់[ញ]នឹងប្រឹក្សានឹងទ្រង់បាន[ដ]យ៉ាង
នោះខ្ញុំនឹងបានរួចជាដរាប ពីអំណាចចៅក្រមដែលជំនុំជំរះ
ខ្ញុំ[ឋ] ៨តែមើល ខ្ញុំដើរទៅខាងមុខ តែទ្រង់មិនមែននៅទីនោះ
ក៏ថយទៅក្រោយ តែរកសំគាល់ទ្រង់មិនបាន ៩ក៏ទៅខាង
ឆ្វេងក្នុងកាលដែលទ្រង់ប្រកបកិច្ចការ តែខ្ញុំ មើលទ្រង់មិន
ឃើញ ហើយទ្រង់ពួននៅខាងស្តាំមិនឱ្យខ្ញុំឃើញឡើយ[ឌ]។
១០ប៉ុន្តែទ្រង់ស្គាល់ផ្លូវដើររបស់ខ្ញុំ[ឍ] ហើយកាលណាទ្រង់

**២២:២១** ដ លប ១៧:១ យរ ៩:២៤ ឋ យប ៨:៧ ទដ ៣៤:៨–១០ សភ ៣:១០ ១ពត ៥:៦ **២២:២២** ឌ ចទ ៨:៣ ឍ យប ៦:១០ ណ យប ១៥:១១ ២៨:២៣ ទដ ៣៧:៣១ ៤០:៨ សភ ២:៦ អគ ៣:១០ **២២:២៣** ត អស ៣១:៦ ៤៤:២២ ៥៥:៧ ៥៩:២០ យរ ៣:១៤,២២ អគ ១៨:៣២ សក ១:៣ មឡ ៣:៧ ថ យប ៥:២៤ អស ១៩:២២ កច ២០:៣២ ទ យប ១១:១៤ **២២:២៤** ធ យប ២៨:៦ ន ទដ ១៩:១០ ប លប ១០:២៩ ផ យប ១:១០ ៣១:២៥ អស ២:២០ ៣០:២២ ៣១:៧ ៤០:១៩–២០ មថ ៦:១៩ **២២:២៥** ព យប ៣១:២៤ ទដ ៤៩:៦ ៥២:៧ សភ ១១:២៨ ភ ២ពវ ១៨:៧ អស ៣៣:៦ មថ ៦:២០–២១ **២២:២៦** ម យប ២៧:១០ ទដ ២:៨ ១៦:៦ ៣៧:៤ អស ៥៨:១៤ ៦១:១០ យ យប ១១:១៥ រ យប ១១:១៧ ៣៣:២៦ ទដ ២៧:៦ ១០០:១ **២២:២៧** ល យប ៥:២៧ វ យប ៥:១៥ ទដ ៨៦:៧ អស ៣០:១៩ ស ជន ៣០:២ **២២:២៨** ហ ទដ ១០៣:១១ ១៤៥:១៩ ឡ យប ៣៣:២៨ ទដ ៩៧:១១ សភ ៤:១៨ អ យប ១១:១៧ **២២:២៩** ក នអ ៥:១២ ខ ទដ ១៨:២៧ មថ ២៣:១២ **២២:៣០** គ អស ១:១៨ រម ៤:៥ ឃ ២សយ ២២:២១**២៣:២** ក យប ៧:១១ ខ ១សយ ១:១០ យប ៦:៣ គ ទដ ៦:៦ ៣២:៤ យរ ៤៥:៣ អគ ២១:៧**២៣:៣** ឃ ចទ ៤:២៩ **២៣:៤** ង យប ១៣:១៨ ច យប ៩:១៥ **២៣:៥** ឆ យប ១១:៥ **២៣:៦** ជ យប ៩:៤ ឈ យប ៦:៤ **២៣:៧** ញ យប ១:១ ដ លប ៣:៨ យប ៩:៣ ១៣:៣ ឋ យប ៦:២៩ **២៣:៩** ឌ យប ៩:១១ **២៣:១០** ឍ យប ១:១ ២៧:៦ ៣១:៦ ៣៦:៧ ទដ ៧:៩

អេលីផាស(១)ដែលយ៉ូបជាមនុស្សអាក្រក់បំផុត(២)និងការគិតគូរចំពោះលោកយ៉ូបគឺការទទួលបានការសម្អាតរួចហើយ ក្នុង ១៩:២៥–២៧ គឺលោកយ៉ូបមកគិតនិងព្រះ និងមិត្តរបស់លោក ។

**២២:២២** មើលការឆ្លើយតបរបស់លោកយ៉ូបក្នុង ២៣:១២ ។ *ប្រមូលទុកអស់ទាំងព្រះបន្ទូលនៃទ្រង់នៅក្នុងចិត្តចុះ* ។ អ្នកនិពន្ធកណ្ឌគម្ពីរ ទដ ១១៩ គឺសរសេរស្រដៀងទៅនឹងព្រះបន្ទូលដែលប្រទានឱ្យរាស្ត្រអ៊ីស្រាអែល (មើល ទដ ១១៩:១១) ។

**២២:២៤** *មាសពីស្រុកអូភារ* ជាមាសល្អបំផុត (មើលការពន្យល់ ១ពវ ៩:២៨ ១០:១១ ទដ ៤៥:៩ អស ១៣:១២) ។

**២២:២៨** *មានពន្លឺភ្លឺមកលើផ្លូវរបស់អ្នកដែរ* គឺតាមរយៈការស្តាប់បង្គាប់ព្រះបន្ទូលព្រះ(មើល ខ.២២,២៧ ២៩:៣ ប្រៀបធៀប ទដ ១១៩:១០៥) ។

**២២:៣០** *សេចក្ដីបរិសុទ្ធរបស់ដៃអ្នក* មើលការពន្យល់ ទដ ២៤:៤ ។

**២៣:២** *សេចក្ដីដំអូញរបស់ខ្ញុំ* មើល ២១:៤ និងការពន្យល់ ។ *ព្រះហស្តដែលសង្កត់លើខ្ញុំ* មើលការពន្យល់ ៣៣:៧ និងការពន្យល់ មើលការពន្យល់ ១សយ ៥:៦ ។

**២៣:៣** *ប្រទះឃើញទ្រង់នៅទីណា* មើលការពន្យល់ ខ.៨–៩ ។

**២៣:៦** *ទ្រង់នឹងតវ៉ានឹងខ្ញុំ . . . អំណាចទ្រង់ដ៏ធំឬអី* លោកយ៉ូបកំពុងស្វែងរកការកាត់ទោសដោយសមរម្យយុត្តិធម៌ ។ ក្នុង ៩:១៤–២០ គឺលោកយ៉ូបកោតខ្លាចតែគាត់ពុំអាចរកពាក្យដើម្បីប្រឆាំងតវ៉ាជាមួយព្រះ ។ តែគាត់មានទំនុកចិត្តថាបើព្រះឱ្យគាត់ឮព្រះសូរសៀង គឺគាត់អាចរួចខ្លួន(មើល ១៣:១៣–១៩ មើល ទដ ១៧:១–៣ ៣៦:១–៣ និងការពន្យល់ផងដែរ )។

**២៣:៨–៩** *ខាងមុខ . . . ទៅក្រោយ . . . ឆ្វេង . . . ស្តាំ* ទោះជាលោកយ៉ូបមានទិសដៅជាច្រើនក៏គាត់ពុំអាចស្វែងរកព្រះឃើញបានដែរ (គឺផ្ទុយនិង ទដ ១៣៩:៧–១០) ។

**២៣:៨–១០** *តែរកសំគាល់ទ្រង់មិនបាន . . . ប៉ុន្តែទ្រង់ស្គាល់ផ្លូវរបស់ខ្ញុំ* លោកយ៉ូបក៏ពុំបានសម្រេចចំពោះការជាក់ស្តែងដើម្បីមាននូវឯកសិទ្ធជាមួយនិងព្រះតែអ្នកណាដឹងថាលោកយ៉ូបជាបុរសបរិសុទ្ធត្រឹមត្រូវ ។ លោកយ៉ូបឆ្លើយតបពីការដាស់តឿនប្រមានរបស់លោកអេលីផាស ក្នុង ២២:២១ គឺ "ការចុះចូលនឹងព្រះ . . . និងបានព្រះពរសុខសាន្តនិងមកជាក្រោយ " លោកយ៉ូបឆ្លើយថានេះជាការដែលគាត់ធ្លាប់ប្រព្រឹត្ត (ខ.១១–១២) ។ គឺគាត់ទទួល ទ្រព្យកំណប់មកពីព្រះគឺច្រើនជាងអ្វីដែលគាត់អាចរកបានជាអាហារប្រចាំថ្ងៃ ។ គាត់ក៏ទទួលស្គាល់ថាព្រះបានធ្វើការសាកល្បងទៅលើរូបគាត់ គឺមិនមែនកំចាត់ព្រាត់គាត់ដោយសារអំពើបាបគាត់នោះទេ តែដើម្បីបង្ហាញថា លោកយ៉ូបជាមាសសុទ្ធ (មើល ទដ ១១៩:១១,១០១,១៦៨

បានសាកលខ្ញុំស្រេចហើយ[ណ] នោះខ្ញុំនឹងចេញមកដូចជា
មាស[ត] ១១ជើងខ្ញុំបានដើរជាប់តាមដំហានទ្រង់[ថ] ខ្ញុំបានកាន់
តាមផ្លូវទ្រង់ ឥតងាកបែរទៅខាងណាឡើយ[ទ] ១២ខ្ញុំមិនដែល
គេចថយចេញពីបង្គាប់នៃព្រះរឹមទ្រង់ទេ[ធ] ខ្ញុំបានខំប្រមូល
ទុកព្រះបន្ទូលនៃព្រះឱស្ឋទ្រង់ ជាជាងអាហារដែលខ្ញុំត្រូវ
ការផង[ន] ១៣ទ្រង់មានគំនិតតែ១ តើអ្នកណានឹងបំផ្លាស់បំប្រែ
ព្រះហឫទ័យទ្រង់បាន[ប] ការអ្វីដែលទ្រង់ចង់ធ្វើ នោះក៏ធ្វើ
ទៅ[ផ] ១៤ដ្បិតទ្រង់ធ្វើសំរេចសេចក្តីដែលបានដំរូវទុកសំរាប់
ខ្ញុំ ហើយមានសេចក្តីយ៉ាងនោះជាច្រើនទៀតនៅនឹងទ្រង់
ដែរ[ព] ១៥ដូច្នេះ ខ្ញុំក៏ភ័យស្លុតនៅចំពោះទ្រង់[ភ] បើកាលណាខ្ញុំ
គ្រាន់តែនឹកពិចារណា នោះខ្ញុំខ្លាចទ្រង់ណាស់[ម] ១៦ដ្បិតព្រះ
ទ្រង់បានធ្វើឱ្យខ្ញុំស្រយុតចិត្ត[យ] ព្រះដ៏មានគ្រប់ព្រះចេស្តា[រ]
ទ្រង់បានធ្វើឱ្យខ្ញុំស្ញែងខ្លាច[ល] ១៧ដោយព្រោះទ្រង់មិនបាន
កាត់ខ្ញុំចេញពីមុខសេចក្តីងងឹតនេះ[វ] ក៏មិនបានលាក់សេចក្តី
ងងឹតយ៉ាងក្រាស់នេះនឹងខ្ញុំដែរ ។

**២៤** ១អស់ទាំងពេលវេលា[ក] មិនបានលាក់នឹងព្រះដ៏មាន
គ្រប់ព្រះចេស្តាទេ[ខ] ចុះហេតុអ្វីបានជាអស់ពួកអ្នកដែល
ស្គាល់ទ្រង់ មិនដែលឃើញថ្ងៃរបស់ទ្រង់ខ្លះ[គ] ២មានពួក
មនុស្សដែលបន្ថយគោលចារិក[ឃ] គេរឹបជាន់យកហ្វូងចៀម
ទៅចិញ្ចឹមវិញ[ង] ៣គេពង្រត់សត្វលារបស់ពួកកំព្រាទៅបាត់
គេទទួលបញ្ចាំយកគោរបស់ស្រីមេម៉ាយ[ច] ៤គេបង្ខំមនុស្ស
កំសត់[ឆ]ឱ្យចៀសពីផ្លូវចេញ ពួកអ្នកក្រីក្រ[ជ]នៅផែនដី ក៏គេច
ពួនទាំងអស់គ្នា[ឈ] ៥មើល អ្នកទាំងអស់នោះប្រៀបដូចជាលា
ព្រៃ[ញ]នៅទីរហោស្ថាន គេចេញទៅឯការរបស់គេ[ដ] ហើយ
ខំខ្នីឃ្មាតរករបឹប គេបានអាហារសំរាប់ខ្លួនគេ និងពួកកូន
ចៅគេ អំពីទីរហោស្ថាន[ឋ]នោះមក ៦គេច្រូតសំណល់ស្រូវ[ឌ]
ដែលសល់នៅក្នុងស្រែ ក៏បេះសន្សំផលទំពាំងបាយជូរ[ឍ]
របស់មនុស្សអាក្រក់នោះ[ណ] ៧គេដេកនៅខ្លួនទទេ១យប់ទាល់
ភ្លឺ ឥតមានអ្វីដណ្តប់ខ្លួននៅពេលរងា[ត] ៨គេត្រូវហាលភ្លៀង[ថ]
ដែលមកពីភ្នំ ក៏អែប[ទ]នឹងថ្មដា ដោយឥតមានទីជ្រកឡើយ[ធ]
៩មានមនុស្សដែលកន្ត្រាក់យក[ន]កូនកំព្រាឪពុក[ប] ចេញពីដោះ
ម្តាយ ហើយទទួលបញ្ចាំ[ផ]ទុកទាំងសំលៀកបំពាក់របស់ពួក
អ្នកក្រីក្រផង[ព] ១០ជាពួកដែលត្រូវដើរសាត់ព្រាត់នៅខ្លួន
ទទេ[ភ] ឥតមានអ្វីពាក់សោះ ហើយដោយព្រោះឃ្លាន បាន

**២៣:១០** ១១:៥ ៣៤:១៥ ៣៧:១៨ ៩៤:១១ ១១៩:១៦៨ ១៤៦:៨ ណ យប ៧:១៨ ទដ ១៣៩:១–៣ ត យប ៦:២៩ ២២:១៥ ទដ ១២:៦ ១ពត ១:៧ **២៣:១១** ថ ទដ ១៧:៥ ទ យប ៣១:៧ ទដ ៤០:៤ ៤៤:១៨ ១១៩:៥១,៥៩,១៥៧ ១២៥:៥ យរ ១១:២០ **២៣:១២** ធ យប ៦:១០ ន យប ១៥:១១ មថ ៤:៤ យហ ៤:៣២,៣៤ **២៣:១៣** ប យប ៩:៣ ផ យប ១០:១៣ អស ៥៥:១១ **២៣:១៤** ព ១ថន ៣:៣ ១ពត ៤:១២ **២៣:១៥** ភ លប ៤៥:៣ ម យស ២៤:១៤ ទដ ៣៤:៩ ៣៦:១ ១១១:១០ សភ ១:៧ សស ៣:១៤ ១២:១៣ ២កថ ៥:១១ **២៣:១៦** យ ចទ ២០:៣ រ យប ២៧:២ ល នក ៣:៦ វវ ៦:១៦ **២៣:១៧** វ យប ៣:៦ ១៩:៨ **២៤:១** ក យប ១៤:៥ ខ យប ៩:២៣ ២ពត ៣:៧ គ យប ១៥:២០ កច ១:៧ **២៤:២** ឃ ចទ ១៩:១៤ ង នក ២០:១៥ ចទ ២៨:៣១**២៤:៣** ច យប ៦:២៧ ២២:៩ **២៤:៤** ឆ យប ២៩:១៦ ៣១:១៩ជ យប ២៩:១២ ៣០:២៥ ទដ ១២:៥ ៤១:១ ៨២:៣,៤ អស ១១:៤ ឈ យប ២០:១៩ សភ ២៨:១២ **២៤:៥** ញ លប ១៦:១២ ដ ទដ ១០៤:២៣ ឋ យប ៣០:៣ **២៤:៦** ឌ យប ៦:៥ ឍ ខ.១៨ ណ នរ ២:២២ ១ពវ ២១:១៩ **២៤:៧** ត នក ២២:២៧ **២៤:៨** ថ ដយ ៤:២៥, ៣៣ ទ បទ ៤:៥ ធ ពច ៦:២ **២៤:៩** ន យប ២៤:១៧ ប ចទ ២៤:១៧ ផ ទដ ១៤:៤ សភ ៣០:១៤ អស ៣:១៤ ១០:១–២ អគ ១៨:១២ ព លវ ២៥:៤៧ ២ពវ ៤:១ **២៤:១០** ភ ចទ ២៤:១២–១៣ ម លវ ១៩:៩

១ពត ១:៧ និងការពន្យល់) ។

**២៣:១២** ការឆ្លើយតបរបស់លោកយ៉ូបទៅនិងដំបូន្មានរបស់លោកអេលីផាសក្នុង ២២:២២ ។ *ទុកព្រះបន្ទូលនៃព្រះឱស្ឋទ្រង់ ជាជាងអាហារដែលខ្ញុំត្រូវការផង* មើល ចទ ៨:៣ មថ ៤:៤ និងការពន្យល់ ។

**២៣:១៣** *ទ្រង់មានគំនិតតែមួយ* "គឺជាទ្រង់តែមួយអង្គគត់ដែល" ទោះបីជាលោកយ៉ូបមិនមែនជារាស្ត្រអ៊ីស្រាអែល គឺលោកយ៉ូបថ្វាយបង្គំព្រះអង្គពិតតែមួយព្រះអង្គ ហើយក៏គ្មានព្រះអង្គណាផ្សេងទៀតដែរ (មើល ចទ ៦:៤ និងការពន្យល់)។ *ព្រះហឫទ័យទ្រង់បាន ការអ្វីដែលទ្រង់ចង់ធ្វើ* ទ្រង់ជាព្រះមហាក្សត្រ (មើល ១១៥:៣ ១៣៥:៦ និងការពន្យល់ ២១:៦)។ គឺជាសេចក្តីជំនឿមួយរបស់លោកយ៉ូបដែលទទួលស្គាល់អ្វី ដែលទ្រង់មានព្រះទ័យដោយមានលក្ខណៈផ្ទុយនឹងការព្យាយាមរបស់អ្នកឱ្យដំបូន្មានដើម្បីបង្កើតជាទំនាយទុកជាមុនបាន ។

**២៣:១៧** *ក៏មិនបានលាក់សេចក្តីងងឹតយ៉ាងក្រាស់* លោកយ៉ូបឆ្លើយតបនិងការចោទប្រកាន់របស់លោកអេលីផាស ក្នុង ២២:១១ (មើលការពន្យល់នៅទីនោះ) ។

**២៤:១–១២** លោកយ៉ូបបានរ៉ាយរ៉ាប់នូវភាពអយុត្តិធម៌ដ៏សាហាវ ដែលជារឿយៗបានកើតឡើងក្នុងលោកិយនេះ ។ ការបួន់ទាំងពីរករណីគឺមាននៅក្នុង (មើល ខ.២) និងពុំមានក្នុង (ខ.៣–៤) ជាហេតុឱ្យលោកយ៉ូបខ្ពើម រអើមតែជាការឈឺចាប់របស់លោកយ៉ូបដែលអាចបញ្ជាក់ពីអ្នកក្រដែលខិតខំប្រឹងប្រែងរកអាហារសម្រាប់ជីវិត (ខ.៥) គឺដូចជាការទទួលផលពីមនុស្សអាក្រក់ (ខ.៦)។ គឺជាភាពទទេស្អាតនៃជីវិតដែលអាក្រាតគ្មានទីពឹងសោះ (ខ.៧–៨) ដូចជាអ្នកកំព្រាជាក្មេងអភ័ព្វ (ខ.៩) ដូចជាអ្នកស្រែកឃ្លាន ហើយប្រមូលសំណល់ពីវាលស្រែ (ខ.១០) គេធ្វើការឱ្យដោយស្រេកឃ្លាន (ដោយរងសំរេក) (ខ.១១) គេក៏ថ្ងូរពីក្នុងទីក្រុង (ខ.១២)។ តែមានជនរងគ្រោះម្នាក់ដែលព្រះអម្ចាស់គាប់ព្រះហឫទ័យជាងអ្នករងគ្រោះជាច្រើនទៀត ដោយពួកគេកំពុងឃ្លាតចេញពីផ្លូវនៃសេចក្តីពន្លឺរបស់ទ្រង់ (សូមមើល ខ.១៣–១៧) ។

**២៤:១** មើលការពន្យល់ ខ.២១–២៤ ។

**២៤:២** *បន្ថយគោលចារិក* គឺជាបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរក្នុងសម័យបូរាណ (មើលការពន្យល់ ចទ ១៩:១៤) ។

**២៤:៣** *ពួកកំព្រា . . . ស្រីមេម៉ាយ* មើល ២៩:៩ អស ១:១៧ និងការពន្យល់ យក ១:២៧ ។

**២៤:៥** *លាព្រៃ* មើល ៣៩:៥–៨ ។

**២៤:៦** *សន្សំផល* មើលការពន្យល់ នរ ១:២២ ។

**២៤:៧,១០** លោកយ៉ូបបានបង្ហាញពីការបដិសេធនៅការចោទប្រកាន់របស់លោកអេលីផាស (មើល ២២:៦) ។

ជាត្រូវរែកជញ្ជូនកណ្ដាប់ស្រូវ[ម] ១១ គេត្រូវចំរាញ់ធ្វើប្រេង
នៅខាងក្នុងរបង នៃមនុស្សទាំងនោះ ព្រមទាំងជាន់ធុង
ទំពាំងបាយជូរ[យ] ដោយរងសំរេក[រ] ១២ មានឮមនុស្សថ្ងូរពី
ក្នុងទីក្រុង ហើយព្រលឹងនៃមនុស្សដែលត្រូវរបួសក៏ស្រែក
ឡើង[ល] ប៉ុន្តែព្រះទ្រង់មិនយកព្រះហឫទ័យទុកដាក់នឹងការ
អាក្រក់នោះឡើយ[វ] ។

១៣ ពួកនេះជាពួកអ្នកដែលមិនព្រមទទួលពន្លឺ[ស] គេមិន
ស្គាល់អស់ទាំងផ្លូវនោះ ឬកាន់ខ្ជាប់តាមផ្លូវច្រកនៃពន្លឺ
នោះឡើយ[ហ] ១៤ មនុស្សឃាតកម្មគេក្រោកពីព្រលឹមស្រាង
ក៏សំឡាប់[ឡ]មនុស្សក្រីក្រនឹងមនុស្សកំសត់ទុគ៌ត[អ] ហើយនៅ
ពេលយប់គេធ្វើជាចោរវិញ[ក] ១៥ ភ្នែករបស់មនុស្សកំផិត[ខ]ក៏
រង់ចាំពេលព្រលប់[គ] ដោយនឹកថា គ្មានអ្នកណាឃើញអញ
ទេ[ឃ] គេក៏គ្រលុំក្បាលទៅ ១៦ នៅពេលងងឹតគេគាស់ទំលុះផ្ទះ
ចូល[ង] ហើយនៅវេលាថ្ងៃគេពួនលាក់ខ្លួន ឥតដែលស្គាល់
ពន្លឺឡើយ[ច] ១៧ ពេលព្រឹកទុកដូចជាម្លប់នៃសេចក្ដីស្លាប់ដល់
ពួកទាំងនោះ ដ្បិតគេស្គាល់ សេចក្ដីស្ញែងខ្លាច[ឆ]របស់ម្លប់នៃ
សេចក្ដីស្លាប់នោះហើយ[ជ] ។

១៨ គេអណ្តែត[ឈ]លើទឹកទៅបាត់យ៉ាងឆាប់[ញ] ឯចំណែក
របស់គេនៅផែនដី នោះមានតែសេចក្ដីបណ្ដាសាទេ[ដ] គេ
មិនដែលបែរទៅ ចូលតាមផ្លូវចំការទំពាំងបាយជូរឡើយ[ឋ]
១៩ បែបដូចជាទឹកពីហិមៈរីងហួតទៅ[ឌ] ដោយរាំងរីះ ហើយ
ក្ដៅយ៉ាងណា នោះស្ថានឃុំព្រលឹងមនុស្សស្លាប់[ឍ] ក៏ស្រូប
មនុស្សមានបាបទៅយ៉ាងនោះដែរ ២០ ផ្ទៃម្ដាយនឹងភ្លេចអ្នក
នោះទៅ ហើយដង្កូវ[ណ]នឹងចុះគេដោយឆ្ងាញ់[ត] នឹងគ្មានអ្នក
ណានឹកចាំពីគេតទៅ[ថ] យ៉ាងនោះសេចក្ដីទុច្ចរិតនឹងត្រូវកាច់
ផ្ដាច់ចេញ ដូចជាដើមឈើ[ទ] ។

២១ គេចិញ្ចឹមស្រីអារដែលមិនបង្កើតកូន តែឥតមេត្តា
ដល់ស្រីមេម៉ាយឡើយ[ធ] ២២ ឯព្រះទ្រង់ធ្វើឱ្យពួកធំៗទាំងនោះ
មានអាយុវែង ដោយសារព្រះចេស្ដាទ្រង់[ន] ចំណែកពួកអ្នក
ដែលគ្មានសង្ឃឹមក្នុងជីវិតនេះ[ប] គេបានឡើងជាធំ[ផ] ២៣ ទ្រង់
ប្រទានឱ្យគេបានសេចក្ដីសុខ[ព] ហើយគេពឹងពាក់លើសេចក្ដី
នោះ តែព្រះនេត្រ[ភ]ទ្រង់ទតឃើញអស់ទាំងផ្លូវរបស់គេ[ម]
២៤ គេបានឡើងជាធំ ប៉ុន្តែក្នុងពេលតែ១ភ្លែតទេ គេនឹងបាត់
ទៅ[យ] អើ គេត្រូវធ្លាក់ចុះ ហើយសែងយកទៅដូចជាមនុស្ស
ដទៃទាំងអស់[រ] គេត្រូវកាត់ចេញដូចជាគួរស្រូវតែម្ដង[ល]
២៥ បើមិនមែនដូច្នោះទេ នោះតើអ្នកណានឹងហ៊ានថា ខ្ញុំ
កុហក ហើយធ្វើឱ្យសំដីខ្ញុំនេះ ឥតខ្លឹមសារបាន[វ] ។

## លោកប៊ីលដាឌ

២៥ ១ នោះប៊ីលដាឌ សាសន៍ស៊ូអា[ក] គាត់ឆ្លើយឡើងថា
២ ព្រះចេស្ដា និងសេចក្ដីស្ញែងខ្លាចនៅនឹងទ្រង់[ខ]ក៏ធ្វើឱ្យមាន
សេចក្ដីសុខនៅស្ថានដ៏ខ្ពស់របស់ទ្រង់[គ] ៣ ឯចំនួនពលទ័ពទ្រង់
តើនឹងរាប់បានឬ តើមានអ្នកឯណាដែលពន្លឺទ្រង់មិនរះ
ឡើងបំភ្លឺដល់គេនោះ[ឃ] ៤ ដូច្នេះ ធ្វើដូចម្ដេចឱ្យមនុស្សបាន
សុច្ចរិតនៅចំពោះព្រះបាន ឬធ្វើដូចម្ដេចឱ្យមនុស្សដែល

**២៤:១១** យ អស ៥:២ ១៦:១០ ហក ២:១៦ រ មីក ៦:១៥ **២៤:១២** ល យប ១២:១៩ ៣០:២៨ ទដ ៥:២ ២២:២៤ ៣៩:១២ ១១៩:១៤៧ អស ៣០:១៩ យរ ៥០:៤៦ ៥១:៥២,៥៤ អគ ២៦:១៥ វវ ៦:១០ វ យប ៩:២៣ **២៤:១៣** ស ខ.១៦ យប ៣៨:១៥ យហ ៣:១៩–២០ ១ថន ៥:៤–៥ ហ យប ១៧:១២ ៣៨:២០ ទដ ១៨:២៨ អស ៥:២០ អភ ៥:៨–១៤ **២៤:១៤** ឡ អស ៣:១៥ មីក ៣:៣ អ យប ២០:១៩ ទដ ៣៧:៣២ ក ទដ ១០:៩ **២៤:១៥** ខ យប ៣១:៩,២៧ សភ ១:១០ គ សភ ៧:៨–៩ ឃ ទដ ១០:១១ **២៤:១៦** ង នក ២២:២ មថ ៦:១៩ ច ខ.១៣ **២៤:១៧** ឆ យប ១៨:១១ ជ យប ១៥:២២ ១៨:៥ **២៤:១៨** ឈ យប ៩:២៦ យដ ១:១៣ ញ យប ២២:១៦ អស ៥៧:២០ ដ យប ៥:៣ ឋ ខ.៦ **២៤:១៩** ឌ យប ៦:១៧ ឍ យប ២១:១៣ **២៤:២០** ណ យប ៧:៥ ត យប ២១:២៦ ថ យប ១៨:១៧ ទ យប ១៤:៧ ទដ ៣១:១២ ដយ ៤:១៤ **២៤:២១** ធ យប ២២:៩ **២៤:២២** ន យប ៩:៤ ប យប ១២:១៩ ផ ចទ ២៨:៦៦ មថ ៦:២៧ យក ៤:១៤ **២៤:២៣** ព យប ៩:២៤ អម ៦:១ ភ ២របា ១៦:៩ ម យប ១០:៤ **២៤:២៤** យ ២ពវ ១៩:៣៥ យប ៤:២០ ទដ ៣៧:១០ ៨៣:១៣ អស ៥:២៤ ១៧:១៣ ៤០:២៤ ៤១:២,១៥ រ យប ៣:១៩ ល អស ១៧:៥ **២៤:២៥** វ យប ៦:២៨ ១៦:១៧ **២៥:១** ក យប ៨:១ **២៥:២** ខ យប ៩:៤ ទដ ៤៧:៩ ៨៩:១៨ សក ៩:៧ វវ ១:៦ គ ២របា ២០:៦ យប ១១:៨ ១៦:១៩ **២៥:៣** ឃ មថ ៥:៤៥ យក ១:១៧ **២៥:៤** ង យប ៤:១៧

**២៤:១៣–១៧** ជាការពណ៌នាពីមនុស្សដែលត្រូវទទួលការឈឺចាប់ គឺមានបញ្ហាក្នុង ខ.២–១២ : មានមនុស្សកំផិតក្បត់ (ខ.១៥)មានពួកចោរប្លន់ (ខ.១៦) ។ សេចក្ដីងងឹតគឺជាសារធាតុរបស់ពួកគេ ហើយគេថាវាជាសេចក្ដីល្អរបស់ពួកគេទៅវិញ(មើល ខ.១៤–១៧ យហ ៣:១៩ រម ១:២១) ។

**២៤:១៨–២០** ក្នុងវគ្គនេះលោកយ៉ូបហាក់ដូចជាចុះចូលនិងអ្នកឱ្យដំបូន្មាន ប៉ុន្តែ វាមានលក្ខណៈត្រឹមត្រូវក្នុងការប្រែសម្រួលក្នុងអត្ថបទខគម្ពីរដែលជាការត្រាស់ហៅលោកយ៉ូបឱ្យប្រឆាំងនឹងអ្នកធ្វើការអាក្រក់ ។"សុំឱ្យទឹកជីពួកគេទទួលបណ្តាសា . . . នោះស្ថានឃុំព្រលឹងមនុស្សស្លាប់ក៏ស្រូបគេទៅ . . . ឯផ្ទៃម្ដាយក៏ភ្លេចអ្នកនោះទៅ . . . ដង្កូវនឹងចុះគេដោយឆ្ងាញ់ . . . ឯមនុស្សអាក្រក់ ក៏ ទៅជាយ៉ាងនោះដែរ គឺត្រូវដឹងថាពួកគេនឹងកាប់ទំលាក់ចុះដូចជាដើមឈើ ដូច្នេះដែរ " ។

**២៤:២០** *ដង្កូវនឹងចុះគេដោយឆ្ងាញ់* មើល ២១:២៦ អស ១៤:១១ ៦៦:២៤ និងការពន្យល់ មក ៩:៤៨ និងការពន្យល់ ។ *កាច់ផ្ដាច់ចេញ ដូចជាដើមឈើ* មើលការពន្យល់ ១៩:១០ ។

**២៤:២១–២៤** គឺជាលក្ខណៈសង្ខេប លោកយ៉ូបក៏និយាយថា ព្រះអម្ចាស់កាត់ទោសដល់មនុស្សអាក្រក់ ហើយលោកក៏ដឹងជាក់ថាព្រះយេហូវ៉ានឹងផ្ដល់នូវភាពសុចរិតបរិសុទ្ធដោយព្រះទ័យពេញចិត្តទតឃើញហេតុការណ៍កើតឡើង(ខ.២) ។

**២៥:១–៦** មើលការពន្យល់ ២២:១–២៦:១៤ ។ លោកប៊ីលដាឌក៏ពុំបានបង្ហាញអ្វីជាការប្លែកសោះ នៅផ្នែកនេះ ហើយលោកសូផារក៏ទទួលស្គាល់អ្វីដែលជាការរំខានដល់គាត់(មើល ២០:២) ។

**២៥:២** *ធ្វើឱ្យមានសេចក្ដីសុខនៅស្ថានដ៏ខ្ពស់របស់ទ្រង់* អ្នកដែលបង្កើតការអស្ចារ្យទាំងនេះ គឺជាព្រះមហាក្សត្រដែលមានអំណាចលើគ្រប់ទាំងអស់ទាំងស្នាព្រះហស្តទ្រង់ ។

**២៥:៣** *ឯចំនួនពលទ័ពទ្រង់* គឺសំដៅលើទេវតា *ពន្លឺទ្រង់មិនរះ* គឺជាព្រះអាទិត្យ ។

**២៥:៤–៦** លោកប៊ីលដាឌប្រកាសពីសម្ដីនៃលោកអេលីផាសតាំងពីដំបូងអំពីភាពអាក្រក់និងពុករលួយរបស់មនុស្សលោក (៤:១៧–១៩ ១៥:១៤–១៦)។

កើតពីស្ត្រីមកបានបរិសុទ្ធ[ង] ⁵មើល ទាំងខែក៏មិនភ្លឺដែរ[ច]
ហើយផ្កាយ ទាំងប៉ុន្មានក៏មិនជ្រះថ្លានៅព្រះនេត្រទ្រង់ផង[ឆ]
៦ចំណង់បើមនុស្សដែលជាដង្កូវទទេ និងកូនមនុស្ស[ជ]ដែល
ជាដង្កូវដែរ តើនឹងបានយ៉ាងណាទៅ[ឈ]។

**លោកយ៉ូប**

**២៦** ១នោះយ៉ូបក៏ឆ្លើយឡើងថា ២អ្នកពូកែមែន អ្នកបាន
ជួយមនុស្សដែលគ្មានអំណាច[ក] បានទប់ទល់ដៃដែលគ្មាន
កំឡាំង[ខ] ៣បានទាំងទូន្មានមនុស្សដែលគ្មានប្រាជ្ញា ក៏បាន
ផ្សាយប្រាជ្ញា[គ]សុសសាយហើយ ៤តើអ្នកបានពោលពាក្យ
ទាំងនេះដល់អ្នកណា តើជាវិញ្ញាណរបស់អ្នកណា ដែល
បណ្តាលឱ្យអ្នកនិយាយ[ឃ]។

៥ទោះទាំងមនុស្សស្លាប់ ក៏ញ័ររន្ធត់នៅចំពោះព្រះ[ង] គឺ
នៅក្នុងស្ថានក្រោមទឹក ព្រមទាំងពួកនៅទីនោះផង ៦ស្ថាន
ឃុំព្រលឹងមនុស្សស្លាប់[ច]ក៏អាក្រាតទទេនៅចំពោះព្រះ
ហើយទីជង្ហុកជ្រៅ[ឆ]គ្មានអ្វីគ្របបាំងឡើយ[ជ] ៧ទ្រង់ត្រដាងទិស
ខាងជើង[ឈ]ពីលើទីល្ហល្ហេវ ហើយក៏ព្យួរផែនដីនៅទទេ
ធេង[ញ] ៨ទ្រង់ចងទប់ទឹក[ដ]នៅក្នុងពពក[ឋ]យ៉ាងក្រាស់របស់ទ្រង់
ហើយពពកមិនធ្លាយពីក្រោមទេ ៩ទ្រង់បាំងខាងមុខបល្ល័ង្ក
ទ្រង់ ហើយត្រដាងពពក[ឌ]របស់ទ្រង់ពីលើ ១០ទ្រង់បានធ្វើ
របងព័ទ្ធជុំវិញទឹក[ឍ] ដរាបដល់ពន្លឺ ហើយនិងងងឹតផុតទៅ
ហើយ[ណ] ១១សសរនៃផ្ទៃមេឃញញ័រ[ត] ហើយមានសេចក្តី
អស្ចារ្យ ដោយទ្រង់បន្ទោស ១២ទ្រង់ធ្វើឱ្យសមុទ្រកំរើក
ឡើង[ថ] ដោយឥទ្ធឫទ្ធិ[ទ]របស់ទ្រង់ ហើយក៏វាយកំទេចសេចក្តី
ឆ្មើងឆ្មៃ[ធ] ១៣ទ្រង់តុបតែងផ្ទៃមេឃ[ន] ដោយសារព្រះវិញ្ញាណ
ទ្រង់ ហើយព្រះហស្តទ្រង់បានចាក់ទំលុះពស់ ដែលកំពុងតែ
លឿនទៅ[ប] ១៤មើល ការទាំងនេះគ្រាន់តែជាកិច្ចខាងក្រៅ
របស់ទ្រង់ទេ ហើយយើងឮនិយាយពីទ្រង់[ផ] ជាសំឡេង
ខ្សាវៗ[ព]យ៉ាងណាទៅ ឯសំឡេងលាន់ឮពីឥទ្ធិឫទ្ធិរបស់ទ្រង់
នោះតើអ្នកណានឹងយល់បាន[ភ]។

**២៧** ១ឯយ៉ូបក៏បន្តសេចក្តីអធិប្បាយរបស់លោកទៅទៀត[ក]
ថា ២ខ្ញុំស្បថដោយនូវព្រះដ៏មានព្រះជន្មរស់នៅ ដែលទ្រង់
បានដកសេចក្តីយុត្តិធម៌ពីខ្ញុំចេញ[ខ] គឺជាព្រះដ៏មានគ្រប់ព្រះ

**២៥:៥** ច យប ៣១:២៦ ឆ យប ៤:១៨ **២៥:៦** ជ ទដ ៨០:១៧ ១៤៤:៣ អគ ២:១ ឈ យប ៤:១៩ ៧:៥ **២៦:២** ក យប ៦:១២ ខ យប ៤:៣ **២៦:៣** គ យប ៣៤:៣៥ **២៦:៤** ឃ ១ពវ ២២:២៤ **២៦:៥** ង ទដ ៨៨:១០ អស ១៤:៩ ២៦:១៤ **២៦:៦** ច ទដ ១៣៩:៨ ឆ យប ៩:១១ ជ យប ១០:២២ ១១:៨ ៣៨:១៧ ៤១:១១ ទដ ១៣៩:១១–១២ សភ ១៥:១១ ហព ៤:១៣ **២៦:៧** ឈ យប ៩:៨ ញ យប ៣៨:៦ ទដ ១០៤:៥ សភ ៣:១៩–២០ ៨:២៧ អស ៤០:២២ **២៦:៨** ដ សភ ៣០:៤ ឋ លប ១:២ យប ៣៦:២៧ ៣៧:១១ ទដ ១៤៧:៨ **២៦:៩** ឌ ២សយ ២២:១០ យប ២២:១៤ **២៦:១០** ឍ សភ ៨:២៧,២៩ អស ៤០:២២ ណ លប ១:៤ យប ២៨:៣ ៣៨:៨–១១ **២៦:១១** ត ២សយ ២២:៨ **២៦:១២** ថ នក ១៤:២១ ទ យប ១២:១៣ ធ យប ៩:១៣ **២៦:១៣** ន យប ៩:៨ ប អស ២៧:១ **២៦:១៤** ផ យប ៤២:៥ ហព ៣:២ ១កថ ១៣:១២ ព យប ៤:១២ ភ យប ៩:៦ **២៧:១** ក យប ២៩:១ **២៧:២** ខ យប ៦:២៩ ៩:២៤ អស ៤៥:៩ ៤៩:៤,១៤

**២៦:២–៤** គឺជាការចំអកបញ្ឈឺចិត្ត គឺលោកយ៉ូបបានឆ្លើយតបចំពោះលោកប៊ីលដាឌតែប៉ុណ្ណោះ (ជាភាសាហេព្រើរចំពោះឃ្លានេះ គឺសំដៅលើបុរសជាពហុវចនៈគឺបង្ហាញថាមានលោកអេលីផាស និងសូផារគឺពុំបាននិយាយអ្វីឡើយ) ។

**២៦:២** *បានទប់ទល់ដៃដែលគ្មានកំឡាំង* មើល ៤:៣–៤ អស ៣៥:៣ ហព ១២:១២ ។

**២៦:៥–១៤** ការពណ៌នាបង្ហាញពីភាពខ្លាំងអស្ចារ្យដ៏ឧត្តមនៃអំណាចព្រះចេស្តារបស់ព្រះអម្ចាស់ក៏មានក្នុងផ្ទៃរឿងរបស់ប៊ីលដាឌផងដែរ គឺជាការបង្ហាញចុងក្រោយ (ជំពូក ២៥) ។

**២៦:៥** *មនុស្សស្លាប់* មើលអត្ថបទពន្យល់ គឺជាតួនៃតំណាងតួអង្គដែលគេលើកជាស្តេចនៃភាពភិតភ័យមើល ១៨:១៤ និងការពន្យល់) ។ *ទីជង្ហុកជ្រៅ* គឺស្មើនឹងទីហិនវិនាស មើល ២៨:២២ ៣១:១២ សភ ១៥:១១ និងការពន្យល់ ។ *វវ* ៩:១១ អាបាដូន គឺជាឈ្មោះ "ទេវតានៃជង្ហុកធំ" ។

**២៦:៧** មើល ៣៧:១៨ ។ *ទ្រង់* គឺសំដៅទៅលើព្រះអម្ចាស់ ។*ត្រដាងទិសខាងជើងពីលើទីល្ហល្ហេវ ហើយក៏ព្យួរផែនដីនៅទទេធេង* ដោយលោកយ៉ូបបានសម្គាល់ថា ផ្លូវដែលអាចទទួលយកបានគឺជាទីដ៏ធំធេងដែលមានសន្តិសុខគ្រប់គ្រាន់ដោយអំណាចព្រះចេស្តានៃព្រះ ។

**២៦:១២** *ធ្វើឱ្យសមុទ្រកំរើកឡើង* មើល អស ៥១:១៥ យរ ៣១:៣៥ ។ *សេចក្តីឆ្មើងឆ្មៃ* មើលការពន្យល់ ៩:១៣ ។

**២៦:១៣** *ចាក់ទំលុះពស់* គឺជាកាពណ៌នាសត្វចម្លែកសមុទ្រធំម្យ៉ាង ដូចជាក្រពើ (មើលការពន្យល់ ៣:៨ អស ២៧:១) ។

**២៦:១៤** *ការទាំងនេះគ្រាន់តែជាកិច្ចខាងក្រៅរបស់ទ្រង់ទេ* គឺជាអ្វីសព្វបែបយ៉ាងដែលព្រះអម្ចាស់បានបើកសម្តែងឱ្យឃើញនូវទីតាំងត្រួតត្រាលើគ្រប់ទាំងនិស្ស័យធម្មជាតិ និងកម្លាំងអធិធម្មជាតិទាំងឡាយ ដែលមានច្រើនលើសអស់ទាំងការដែលយើងបានដឹងបានឮទៅទៀត ។ លោកយ៉ូបបានបង្ហាញនូវលក្ខណៈសម្បត្តិ ដែលចេញពីការយល់ដឹងរបស់មនុស្សតែប៉ុណ្ណោះលោកសូផារបានស្តីបន្ទោសដល់លោកយ៉ូប ពីការដែលស្តែងឱ្យឃើញភាពអសមត្ថភាពរបស់គាត់ ដែលពុំអាចស៊ីជម្រៅទៅលើអាថ៌កំបាំងរបស់ព្រះបានឡើយ (១១:៧–៩) ប៉ុន្តែចំណេះដឹងក៏មានកើតតាមរយៈមិត្តលោកយ៉ូបក៏មិនមានភាពអស្ចារ្យជាងលោកយ៉ូបផ្ទាល់ខ្លួនដែរ (មើល ១២:៣ ១៣:២) ។ *សំឡេងលាន់ឮពីឥទ្ធិឫទ្ធិរបស់ទ្រង់* ដែលហាក់ដូចជាមានការលំបាកក្នុងការយល់បានខ្លះពីព្រះអម្ចាស់ តើមានទំហំប៉ុនណាទៀតដែលខ្ញុំពុំទាន់យល់ បានពីភាពធំឧត្តមរបស់ទ្រង់ទៅ ។

**២៧:១–២៣** គឺជាបទសន្ទនា គឺជាផ្នែកជម្លោះតវ៉ាដែលកណ្ឌនេះផ្តើមឡើងដោយការទួញសោករបស់លោកយ៉ូប (ជំពូក ៣) ដែលបន្តមានការអធិប្បាយចំនួនបីលើក (ជំពូក ៤–១៤,១៥–២១,២២–២៦) ដែលបញ្ចប់ដោយវគ្គអត្ថបទលោកយ៉ូប (ជំពូក ២៧) ក្នុងនោះនិយាយាអះអាងឡើងវិញនូវភាពគ្មានកំហុសរបស់គាត់ (ខ.២–៦) ហើយក៏ជាការសម្តែងចុងក្រោយនៃមនុស្សអាក្រក់ (ខ.១៣–២៣) ។

**២៧:២** *ខ្ញុំស្បថដោយនូវព្រះនាមដ៏មានព្រះជន្មរស់* គឺជាពាក្យសម្បថដ៏ឧឡារិក (មើលការពន្យល់ លប ៤២:១៥) គឺជាសេចក្តីជំនឿរបស់លោកយ៉ូបគឺបន្តជានិច្ច ។

ចេស្តា[គ] ដែលទ្រង់បានធ្វើឱ្យព្រលឹងខ្ញុំជូរចត់[ឃ] ថា ៣កាលខ្ញុំ
នៅមានដង្ហើមចេញចូល ហើយមានខ្យល់វិញ្ញាណនៃព្រះ[ង]
នៅក្នុងរន្ធច្រមុះខ្ញុំនៅឡើយ ៤នោះបបូរមាត់ខ្ញុំនឹងមិន
ពោលសេចក្តីអាក្រក់ ហើយអណ្តាតខ្ញុំក៏មិនបញ្ចេញពាក្យ
ភូតភរឡើយ[ច] ៥ដែលខ្ញុំនឹងព្រមថា អ្នករាល់គ្នានិយាយត្រូវ
នោះសូមឱ្យនៅឆ្ងាយពីខ្ញុំទៅ ខ្ញុំមិនព្រមលះចោលសិរីដី
ដែលថាខ្លួនខ្ញុំត្រឹមត្រូវឡើយ ដរាបដល់ខ្ញុំស្លាប់ផង[ឆ] ៦ខ្ញុំនឹង
ប្រកាន់សេចក្តីសុចរិត[ជ]របស់ខ្ញុំ ឱ្យជាប់លាប់ឥតលែងតទៅ
ក្នុងកាលដែលខ្ញុំរស់នៅឡើយ នោះចិត្ត[ឈ]មិនប្រកាន់ទោស
ខ្ញុំជាដរាប[ញ]។

៧សូមឱ្យសត្រូវខ្ញុំបានរាប់ជាមនុស្សអាក្រក់ចុះ[ដ] ហើយឱ្យ
អ្នកដែលទាស់នឹងខ្ញុំ[ឋ]បានរាប់ជាទុច្ចរិតផង ៨ដ្បិតទោះបើ
មនុស្សទមិលល្មើស[ឌ]បានកំរៃក៏ដោយ នោះតើនឹងមាន
សេចក្តីសង្ឃឹមអ្វី ក្នុងកាលដែលព្រះទ្រង់ដកយកព្រលឹងគេ
ទៅ[ឍ] ៩តើព្រះនឹងឮសំរែករបស់គេ ក្នុងកាលដែលគេកើត
មានសេចក្តីលំបាកឬ[ណ] ១០តើគេនឹងយកព្រះដ៏មានគ្រប់ព្រះ
ចេស្តាជាទីពេញចិត្តដល់គេ[ត] ហើយអំពាវនាវដល់ទ្រង់រាល់
ពេលវេលាដែរឬ ១១ខ្ញុំនឹងបង្ហាញឱ្យអ្នករាល់គ្នាយល់ពី
ដំណើរព្រះហស្តនៃព្រះ ឯអ្វីៗដែលមាន[ថ]នៅនឹងព្រះដ៏មាន
គ្រប់ព្រះចេស្តា នោះខ្ញុំមិនគ្របបាំងឡើយ[ទ] ១២មើល អ្នក
រាល់គ្នាក៏បានឃើញសេចក្តីទាំងនេះហើយ ដូច្នេះ ហេតុអ្វី
បានជាអ្នករាល់គ្នាកើតមានគំនិតផ្តេសផ្តាសអីម្ល៉េះ ១៣នេះ
ហើយជាចំណែកដែលព្រះបំរុងទុកដល់មនុស្សអាក្រក់ គឺជា
សេចក្តីដែលមនុស្សសង្កត់សង្កិន ត្រូវទទួលពីព្រះដ៏មានគ្រប់
ព្រះចេស្តា[ធ] ១៤បើកាលណាកូនចៅគេបានចំរើនជាច្រើន
ឡើង[ន] នោះគឺសំរាប់តែដាវប៉ុណ្ណោះ[ប] ហើយពូជពង្សគេមិន
បានបរិភោគឆ្អែតទេ[ផ] ១៥ពួកគេដែលសល់នៅនឹងត្រូវស្លាប់
ហើយកប់ទៅ ឯប្រពន្ធដែលនៅមេម៉ាយ នោះមិនយំសោក
ទេ[ព] ១៦ទោះបើគេប្រមូលប្រាក់ទុកដូចជាធូលីដី[ភ] ក៏ត្រៀម
ទុកសំលៀកបំពាក់ដូចជាភក់[ម] ១៧នោះគេនឹងរៀបចំ[យ]បាន
តែគឺពួកសុចរិតជាអ្នកស្លៀកពាក់វិញ[រ] ហើយពួកអ្នកដែល
ផូរផង់គេនឹងចែកប្រាក់គ្នា[ល] ១៨ពួកអាក្រក់នោះគេសង់ផ្ទះ[វ]
ខ្លួន ដូចជាមេអំបៅ[ស] ហើយដូចជាបង្ហា[ហ]ដែលអ្នកចាំយាម
ធ្វើ ១៩គេដេកទៅទាំងមានទ្រព្យ តែគ្មានអ្នកណារៀបចំកប់
ឱ្យទេ[ឡ] គេបើកភ្នែកឡើង ហើយគ្មានខ្លួនគេទៀត[អ] ២០សេច
ក្តីស្ញែងខ្លាច[ក]ក៏តាមគេទាន់ ដូចជាទឹកជន់[ខ] ខ្យល់កួចនាំយក
គេទៅបាត់ទាំងយប់[គ] ២១ខ្យល់ពីខាងកើត[ឃ]ផាត់យកគេ ឱ្យ
គេបាត់ទៅ[ង] ក៏បោសរំលីងគេចេញពីទីកន្លែងរបស់គេ[ច]
២២ព្រះទ្រង់បោះទៅលើគេឥតប្រណី[ឆ] គេចង់រត់គេចចេញ
ឱ្យរួច[ជ]ពីព្រះហស្តទ្រង់ទៅ[ឈ] ២៣មនុស្សទាំងឡាយទះដៃ[ញ]
នឹងគេ ព្រមទាំងធ្វើសឹសស៊ូស បណ្តេញគេចេញ ពីកន្លែង
ទៅផង[ដ]។

**២៨** ១ពិតប្រាកដជាមានកន្លែងជីករកប្រាក់បាន ក៏មានទី

**២៧:២** គ យប ២៣:១៦ ឃ ១សយ ១:១០ យប ៧:១៩ ១០:១
**២៧:៣** ង លប ២:៧ យប ៣២:៨ ៣៣:៤ ៣៤:១៤ ទដ ១៤៤:៤
**២៧:៤** ច យប ៦:២៨ ១២:១៦ ១៦:១៧
**២៧:៥** ឆ យប ២:៩ ១០:៧ ៣២:២
**២៧:៦** ជ យប ២៩:១៤ ទដ ១១៩:១២១ ១៣២:៩ អស ៥៩:១៧ ៦១:១០ ឈ កច ២៣:១ រម ២:១៥ ញ យប ២:៣ ១០:៧ ២៣:១០ ៣៤:១៧
**២៧:៧** ដ យប ៨:២២ ឋ យប ៣១:៣៥
**២៧:៨** ឌ យប ៨:១៣ ឍ ជន ១៦:២២ យប ៨:២២ ១១:២០ លក ១២:២០
**២៧:៩** ណ ចទ ១:៤៥ ១សយ ៨:១៨ យប ១៥:១៣
**២៧:១០** ត យប ២២:២៦
**២៧:១១** ថ យប ៣៦:២៣ ទ ខ.១៣ **២៧:១៣** ធ យប ១៦:១៩ ២០:២៩ **២៧:១៤** ន យប ៥:៤ ប យប ១៥:២២ បទ ២:២២ ផ យប ៤:១១ **២៧:១៥** ព ទដ ៧៨:៦៤ **២៧:១៦** ភ ១ពវ ១០:២៧ ម សក ៩:៣ **២៧:១៧** យ ទដ ៣៩:៦ ៤៩:១០ សស ២:២៦ រ យប ៧:៨ សភ ១៣:២២ ២៨:៨ សស ២:២៦ ល នក ៣:២២ យប ៣:១៥ **២៧:១៨** វ យប ៨:២២ ស យប ៨:១៤ ហ អស ១:៨ ២៤:២០ **២៧:១៩** ឡ យប ៣:១៣ ៧:៨ អ យប ១៤:២០ **២៧:២០** ក យប ៦:៤ ខ យប ១៥:២១ គ យប ២០:៨ **២៧:២១** ឃ យប ៣៨:២៤ យរ ១៣:២៤ ២២:២២ ង យប ៣០:២២ ច យប ៧:១០ **២៧:២២** ឆ យរ ១៣:១៤ អគ ៥:១១ ២៤:១៤ ជ ២ពវ ៧:១៥ ឈ យប ១១:២០ **២៧:២៣** ញ ជន ២៤:១០ ណហ ៣:១៩ ដ យប ៧:១០

**២៧:៥** *អ្នក* ក្នុងព្រះគម្ពីរជាភាសាហេព្រើរ ជាពហុវចនៈ គឺក្នុងសេចក្តីសង្ខេបរបស់គាត់ គឺលោកយ៉ូបបាននិយាយម្តងទៀតទៅកាន់មិត្តទាំងបីរបស់គាត់ គឺជាបទសន្ទនាជាក្រុម ។

**២៧:៦** *ប្រកាន់សេចក្តីសុចរិតរបស់ខ្ញុំ* ព្រះអម្ចាស់បានមានបន្ទូលស្រដៀងនិងលោកយ៉ូបផងដែរ (មើល ២:៣) ។

**២៧:៧** *សូមឱ្យសត្រូវខ្ញុំបានរាប់ជាមនុស្សអាក្រក់ចុះ* លោកយ៉ូបបានហៅមិត្តរបស់គាត់ដែលបានចោទប្រកាន់ខុសចំពោះគាត់ថា ជាមនុស្សអាក្រក់ (ប្រៀបធៀប ១០៩:៦–១៥ ១៣៧:៨–៩) ។

**២៧:១១** *ខ្ញុំនឹងបង្ហាញឱ្យអ្នករាល់គ្នា* លោកយ៉ូបក៏បានរំឭកដល់អ្នកឱ្យដំបូន្មានអំពីស្ថានភាពទាំងអស់នោះដែលពួកគេត្រូវទទួលស្គាល់ : គឺជាការពិត ដែលពួកមនុស្សអាក្រក់ទាំងនោះសាកសមនឹងទទួលកំហឹងយ៉ាងខ្លាំង (ខ.១៣–២៣) មិត្តលោកយ៉ូបទាំងបីនាក់គឺយល់ខុសហើយក៏ចោទលោកយ៉ូបថាជាមនុស្សដែលត្រូវទទួលការអាក្រក់នោះទៅវិញ ។

**២៧:១៣–២៣** ជាផ្នែកកំណាព្យដែលមានឥទ្ធិពលទៅលើការត្រាស់ហៅលោកយ៉ូបពីរលើកដំបូងដើម្បីទទួលនូវសម្លៀកបំពាក់វិញ ។

**២៧:១៣** លោកយ៉ូបបានផ្សព្វផ្សាយពាក្យសម្តីលោកសូផារក្នុង ២០:២៩ (មើលការពន្យល់នៅទីនោះ) ។

**២៧:១៨** *មេអំបៅ . . . បង្ហា* គឺបង្ហាញភាពងាយបាក់បែកពុកផុយ (មើលការពន្យល់ ៤:១៩ អស ១:៨ និងការពន្យល់ ២៤:២០) ។

**២៧:២១** *ខ្យល់ពីខាងកើត* សូមមើល ១៥:២ និងការពន្យល់ ។

**២៨:១–២៨** ការអនុវត្តរបស់មិត្តលោកយ៉ូបចំពោះប្រាជ្ញាដែលជាទំនៀមទម្លាប់ ចំពោះការឈឺចាប់របស់មនុស្សក៏ជាការមិនពេញចិត្តដែលលោកយ៉ូបឆ្លើយតបដោយពុំផ្អែកលើទំនៀមទម្លាប់ ។ ការព្យាយាមទាំងពីរដើម្បីឆ្លុះបញ្ចាំងនូវភាពអាថ៌កំបាំងដែលជឿទុកចិត្តក៏ជាបទសន្ទនានាំឱ្យមានជារបាយការណ៍ ។ ពោលគឺអ្នកនិពន្ធក្នុងកណ្ឌគម្ពីរបានបញ្ជូននូវប្រាជ្ញាដ៏ចំណានក្នុងកំណាព្យគឺការឆ្លើយសំនួរ "តើយើងអាចស្វែងរកប្រាជ្ញានៅទីណា" (ខ.១២ មើល ខ.២០) ។ បទកំណាព្យមានផ្ទុកទៅដោយបីភាគ : (១). បង្ហាញពីត្បូងពេជ្រមានតម្លៃ និងលោហៈដែលអាចរកបានក្នុងទីរ៉ែ

ដែលរកបានមាស សំរាប់យកទៅសំរង[ក] ២ឯដែកគេយក
ពីដីមក ហើយទង់ដែង គេរំលាយមកពីថ្ម[ខ] ៣មនុស្សគេ
កំចាត់សេចក្តីងងឹតចេញ[គ] គេស្វែងរកថ្មលាក់កំបាំងក្នុង
ទីងងឹតសូន្យសុង រហូតដល់ទីជ្រៅបំផុត[ឃ] ៤គេជីករន្ធនៅ
ឆ្ងាយពីទីលំនៅរបស់មនុស្ស[ង] ជើងមនុស្សដើរពីលើឥតមាន
ដឹងឡើយ គេត្រូវសំរូតចុះទៅនៅឆ្ងាយពីមនុស្សជាតិ ហើយ
ក៏រត់ទៅរត់មកនៅទីនោះ ៥ពីក្នុងដីនោះ មានចេញជា
អាហារ[ច] ហើយនៅខាងក្រោមក៏ត្រឡប់ត្រឡិន ដូចជាត្រូវ
ភ្លើងឆេះ ៦ក្នុងថ្មទាំងនោះជាកន្លែងមានត្បូងកណ្តៀង[ឆ]
ហើយក៏មានផង់មាសដែរ[ជ] ៧ផ្លូវច្រកនោះគ្មានសត្វហើរ
ណាដែលចាប់រំពាបានស្គាល់ទេ ឯភ្នែកអាតក៏មើលមិន
ឃើញផង[ឈ] ៨អស់ទាំងសត្វហានក្លា[ញ]មិនដែលបានជាន់ ឯ
សិង្ហកំណាចក៏មិនបានដើរនៅទីនោះឡើយ[ដ] ៩មនុស្សគេ
លូកដៃទៅឯថ្មរឹង[ឋ] ក៏គាស់ភ្នំឱ្យបាតត្រឡប់ឡើងទៅលើ
វិញ[ឌ] ១០គេចោះរូងទៅក្នុងថ្មដា[ឍ] ហើយភ្នែកគេក៏ឃើញ
គ្រប់ទាំងអស់ដែលមានដំឡៃ[ណ] ១១គេទប់រន្ធទឹក[ត] មិនឱ្យហូរ
ចូល ឯរបស់ដែលនៅកំបាំង[ថ] គេនាំយកចេញមកដាក់នៅ
ពន្លឺ ។

១២ប៉ុន្តែចំណែកប្រាជ្ញា តើនឹងរកឯណាបាន[ទ] ហើយ
យោបល់ តើមានកន្លែងនៅឯណា[ធ] ១៣មនុស្សលោកមិន
ស្គាល់ដំឡៃនៃប្រាជ្ញាទេ[ន] ក៏រកមិនឃើញនៅក្នុងស្ថានរបស់
មនុស្សរស់ដែរ[ប] ១៤ទីជំរៅ[ផ]ពោលថា មិនមែននៅក្នុងខ្ញុំទេ
ហើយសមុទ្រ[ព]ក៏ថា មិនមែននៅនឹងខ្ញុំដែរ ១៥និងទិញយក
ដោយមាសមិនបាន គេក៏មិនថ្លឹងប្រាក់ចេញថ្លៃឱ្យបានដែរ[ភ]
១៦និងយកមាសពីស្រុកអូភារ[ម] ឬត្បូងអូនីក្ស ត្បូងកណ្តៀង
មករាប់ដំឡៃនៃប្រាជ្ញាមិនបាន[យ] ១៧មាស ហើយនិងពេជ្រ
នឹងផ្ទឹមស្មើមិនបាន[រ] ឬនឹងប្តូរដោយគ្រឿងមាសសុទ្ធក៏មិន
បានដែរ[ល] ១៨មិនបាច់នឹងនិយាយដល់ផ្កាថ្ម[វ] ឬពីកែវមុក្តា[ស]
ទេដ្បិតប្រាជ្ញាមានដំឡៃច្រើន លើសជាងត្បូងទទឹមទៅ
ទៀត[ហ] ១៩ត្បូងទោប៉ុត[ឡ]ពីស្រុកអេធីយ៉ូពី[អ]ក៏មិនស្មើផង
ហើយដំឡៃនោះ និងរាប់ដោយមាសមិនបាន[ក] ២០ដូច្នេះ
តើប្រាជ្ញាមកពីណា ហើយទីកន្លែងរបស់យោបល់នៅឯ
ណា[ខ] ២១ដ្បិតទីនោះកំបាំងនឹងភ្នែករបស់មនុស្ស ហើយបិទ
ទុកមិនឱ្យសត្វ ហើរលើអាកាសឃើញឡើយ[គ] ២២ស្ថាន
វិនាស[ឃ] និងស្ថានស្លាប់[ង]ពោលថា ត្រចៀករបស់យើងបាន
គ្រាន់តែឮនិយាយប៉ុណ្ណោះ ។

២៣ព្រះទ្រង់[ច]ជ្រាបផ្លូវនៃប្រាជ្ញា ហើយក៏ស្គាល់ទីកន្លែង
ដែរ[ឆ] ២៤ដ្បិត ទ្រង់ទតមើលទៅដល់ចុងផែនដីបំផុត[ជ] ក៏
ឃើញទាំងអស់ដែលនៅក្រោមផ្ទៃមេឃ[ឈ] ២៥ទ្រង់បានធ្វើឱ្យ

**២៨:១** ក ទដ ១២:៦ ៦៦:១០ យរ ៩:៧ ដយ ១១:៣៥ មឡ ៣:៣ **២៨:២** ខ ដយ ៨:៩ **២៨:៣** គ សស ១:១៣ ៧:២៥ ៨:១៧ ឃ យប ២៦:១០ ៣៨:១៩ **២៨:៤** ង ខ.១០ ២សយ ៥:៨ **២៨:៥** ច លប ១:២៩ ទដ ១០៤:១៤ ១៤៥:១៥ **២៨:៦** ឆ ខ.១៦ ៥:១៤ អស ៥៤:១១ ជ យប ២២:២៤ **២៨:៧** ឈ ខ.២១ **២៨:៨** ញ យប ៤១:៣៤ ដ អស ៣៥:៩ **២៨:៩** ឋ ចទ ៨:១៥ ឌ យប ២:៦ **២៨:១០** ឍ ខ.៤ ណ សភ ២:៤ **២៨:១១** ត លប ៧:១១ ថ អស ៤៨:៦ យរ ៣៣:៣ **២៨:១២** ទ ខ.២៨ សភ ១:២០ ៣:១៣–២០ ៨:១ ៩:១–៣

សស ៧:២៤ ធ ខ.២០,២៣ **២៨:១៣** ន សភ ៣:១៥ មថ ១៣:៤៤–៤៦ ប ចទ ២៩:២៩ ទដ ២៧:១៣ ៥២:៥ ១១៦:៩ ១៤២:៥ អស ៣៨:១១ យរ ១១:១៩ អគ ២៦:២០ ៣២:២៤ **២៨:១៤** ផ ទដ ៤២:៧ រម ១០:៧ ព ចទ ៣០:១៣ **២៨:១៥** ភ ខ.១៧ សភ ៣:១៣–១៤ ៨:១០–១១ ១៦:១៦ កច ៨:២០ **២៨:១៦** ម លប ១០:២៩ យ ខ.៦ នក ២៤:១០ **២៨:១៧** រ ទដ ១១៩:៧២ សភ ៨:១០ ល ខ.១៥ **២៨:១៨** វ អគ ២៧:១៦ ស វវ ២១:១១ ហ សភ ៣:១៥ ៨:១១ **២៨:១៩** ឡ នក ២៨:១៧ អ អស ១១:១១ ក សភ ៣:១៤–១៥ ៨:១០–១១,១៩ **២៨:២០** ខ យប ៩:៤ **២៨:២១** គ ខ.៧ **២៨:២២** ឃ យប ២០:២៦ វវ ៩:១១ ង សភ ៨:៣២–៣៦ **២៨:២៣** ច សស ៣:១១ ៨:១៧ ឆ យប ៩:៤ ២២:២២ សភ ៨:២២–៣១ **២៨:២៤** ជ យប ៣៦:៣២ ៣៧:៣ ៣៨:១៨,២៤,៣៥ ទដ ៣៣:១៣–១៤ ៦៦:៧ អស ១១:១២ ឈ យស ៣:១១ យប ១០:៤ ហព ៤:១៣

ដ៏ជ្រៅ (ខ.១–១១) (២).ប្រាជ្ញាគឺពុំអាចស្វែងរកបានក្នុងទីរ៉ែ ឬក៏អាចទិញដោយប្រើត្បូងពេជ្រឬលោហៈមានតម្លៃ (ខ.១២–១៩) (៣).ប្រាជ្ញាអាចរកបានតាមរយៈព្រះអម្ចាស់តែប៉ុណ្ណោះ (ខ.២០–២៧) ។ ព្រះមានបន្ទូលប្រាប់មនុស្សដែលមានប្រាជ្ញាដ៏ពិតតាមរយៈ "ការកោតខ្លាចដល់ព្រះយេហូវ៉ា និងគេចចេញពីការអាក្រក់ " (ខ.២៨) ។ ជំពូកនេះប្រាប់ទុកជាមុនពីផ្ទៃរឿងនៃព្រះបន្ទូលថ្លែងពីព្រះអម្ចាស់ផ្ទាល់ (៣៨:១–៤២:៦) និងបានផ្សាយពីការប៉ាន់ប្រមាណចំពោះលោកយ៉ូប ដែលព្រះអម្ចាស់បានផ្តល់ឱ្យតាំងពីដំបូង ។

**២៨:១–១១** ជាផ្នែកអត្ថបទដែលធ្វើឱ្យចាប់អារម្មណ៍មធ្យោបាយពីបូរាណ ។

**២៨:២** *ដែក* មើលការពន្យល់ ១៩:២៤ ។

**២៨:៣** *កំចាត់សេចក្តីងងឹតចេញ* គឺដោយប្រើប្រភពសិប្បនិម្មិត្តនៃពន្លឺដូចជាចង្កៀង ។

**២៨:៤** *ត្រូវសំរូតចុះ . . . រត់ទៅរត់មក* គឺជាការងារជីករ៉ែ ក្នុងពេលនោះបើដូចជាឥឡូវក៏មានការលំបាក និងជាការងារគ្រោះថ្នាក់ ។ គឺប្រជាជននិងត្រូវផ្សងព្រេងរាល់ឧបសគ្គក្នុងការជីករកកំណប់ទ្រព្យក្នុងផែនដីនោះ ។

**២៨:៦** *ត្បូងកណ្តៀង* មើល ខ.១៦ ក៏មើលការពន្យល់ អស ៥៤:១១ ។

**២៨:៩** *ថ្មរឹង* អ្នកនិពន្ធកំណាព្យបង្ហាញពីការសង្កត់ទៅលើទីជម្រៅដ៏ជ្រៅ (ប្រៀបធៀប យហ ២:៦) ។ *គាស់ភ្នំឱ្យបាតត្រឡប់ឡើង* គឺក្នុងសតវត្សរ៍ទី៨ មុន គ.ស គេបានរក ឃើញអក្សរចារិកនៅឯអណ្តូងក្រុងយេរូសាឡិម ឬហៅថាស្រះស៊ីឡោម ដែលបង្ហាញពីបច្ចេកវិជ្ជាពីបូរាណ ។

**២៨:១២** គឺជាអត្ថបទសំនួរ សារចុះសារឡើងស្ទើរតែត្រង់ៗចំៗតែម្តងក្នុង ខ.២០ គឺជាចម្លើយ ។

**២៨:១៦** *យកមាសពីស្រុកអូភារ* មើល ២២:២៤ និងការពន្យល់ ។

**២៨:១៨** *ប្រាជ្ញាមានតម្លៃច្រើន* ធៀបនឹងដំឡៃ "ជាប្រពន្ធដែលមានចរិយាល្អ" (សភ ៣១:១០) ដែលកោតខ្លាចដល់ព្រះយេហូវ៉ា (សភ ៣១:៣០) និងចំពោះប្រាជ្ញា (មើល ខ.២៨) ។

**២៨:១៩** *អេធីយ៉ូ* គឺជាតំបន់ទន្លេនីលផ្នែកខាងលើ គឺនៅអេស៊ីព្ទខាងត្បូង ។

**២៨:២១** *ហើយបិទទុកមិនឱ្យសត្វហើរលើអាកាសឃើញឡើយ* ដូចជាត្បូងមានតម្លៃនិងលោហៈមានតម្លៃ (មើល ខ.៧) ។

**២៨:២២** *ស្ថានវិនាស និងស្ថានស្លាប់* មើលការពន្យល់ ២៦:៦ ។

**២៨:២៥–២៧** ប្រាជ្ញានៅនិងព្រះពីពេលដែលព្រះបានបង្កើតគ្រប់ទាំងអ្វីៗ

ខ្យល់មានកំណត់ទំងន់ ហើយបានកំណត់រង្វាល់ទឹកដែរ[ញ]
26 ក្នុងកាលដែលទ្រង់បានដាក់កំរិតដល់ទឹកភ្លៀង[ដ] ហើយឱ្យ
មានផ្លូវសំរាប់ផ្លេកបន្ទោរនៃផ្គរលាន់[ឋ] 27 ក្នុងកាលនោះ
ទ្រង់បានឃើញប្រាជ្ញាហើយ ក៏ថ្លែងប្រាប់ឱ្យស្គាល់ដែរ គឺ
ទ្រង់ដែលតាំងឱ្យមានប្រាជ្ញា អើ ទ្រង់បានស្វែងប្រមូលទុក[ឌ]
28 រួចមានបន្ទូលដល់មនុស្សយើងថា មើល សេចក្តីកោត
ខ្លាចដល់ព្រះអម្ចាស់ នោះហើយជាប្រាជ្ញា ហើយដែលថយ
ឆ្ងាយពីការអាក្រក់ [ឍ]នោះឯងជាយោបល់[ណ] ។

**២៩** 1 យ៉ូបក៏បន្តសេចក្តីអធិប្បាយរបស់លោកតទៅទៀត
ថា[ក] 2 ឱបើសិនជាខ្ញុំបានដូចជាកាលពីដើម[ខ] ដូចនៅគ្រា
ដែលព្រះទ្រង់ការពាររក្សាខ្ញុំទៅអេះ[គ] 3 គឺកាលចង្កៀងនៃ
ទ្រង់បានភ្លឺមកលើក្បាលខ្ញុំ[ឃ] ហើយខ្ញុំបានដើរកាត់ទីងងឹត
ដោយសារពន្លឺទ្រង់ 4 គឺដូចកាលខ្ញុំនៅក្នុងវ័យនៃជីវិត
ហើយមានមិត្រភាព[ង]នៃព្រះ នៅក្នុងទីលំនៅរបស់ខ្ញុំ[ច] 5 ក្នុង
គ្រាដែលព្រះដ៏មានគ្រប់ព្រះចេស្តា ទ្រង់គង់ជាមួយនឹងខ្ញុំ
នៅឡើយ ហើយខ្ញុំមានកូនចៅ[ឆ]នៅជុំវិញ[ជ] 6 ជាវេលាដែល
ខ្ញុំបានលាងជើង ដោយខ្លាញ់ទឹកដោះ[ឈ]ហើយទាំងថ្ម[ញ] ក៏
បញ្ចេញប្រេងហូរមកឱ្យខ្ញុំ[ដ] 7 គ្រានោះខ្ញុំបានចេញទៅឯ
ទ្វារ[ឋ]ទីក្រុង ហើយបានរៀបចំទីអង្គុយនៅទីធ្លា 8 ពួកកំឡោះ
ៗបានឃើញខ្ញុំ ហើយក៏រំលៀកចេញ[ឌ] ពួកចាស់ៗបានក្រោក
ឈរឡើង[ឋ] 9 ពួកដែលជាកំពូលក៏ឈប់និយាយ[ណ] ហើយយក
ដៃខ្ទប់មាត់[ត] 10 សំឡេងនៃពួកអ្នកមានត្រកូលខ្ពស់ក៏ពោល
ដោយខ្សឹបគ្នា[ថ] អណ្តាតគេបានជាប់នៅនឹងក្រអូមមាត់ផង[ទ]
11 ដ្បិតកាលត្រចៀកបានឮខ្ញុំ នោះក៏ឱ្យពរដល់ខ្ញុំ ហើយ
កាលភ្នែកបានឃើញខ្ញុំ នោះក៏ធ្វើបន្ទាល់ពីខ្ញុំ[ធ] 12 ពីព្រោះខ្ញុំ
បានជួយដោះមនុស្សក្រីក្រ[ន]ឱ្យបានរួច ដែលគេស្រែកឡើង
ព្រមទាំងពួកកំព្រា[ប]ដែលគ្មានអ្នកណាជួយផង[ផ] 13 ពររបស់
មនុស្សដែលហៀបនឹងវិនាសទៅក៏ផ្តល់មកខ្ញុំ[ព] ខ្ញុំក៏បណ្តាល
ឱ្យចិត្តស្រីមេម៉ាយ[ភ]ច្រៀងដោយអំណរ 14 ខ្ញុំបានតែងកាយ
ដោយសេចក្តីសុចរិត[ម] ហើយសេចក្តីនោះក៏ហ៊ុមបាំងខ្ញុំ
សេចក្តីយុត្តិធម៌របស់ខ្ញុំបានប្រៀបដូចជាអាវនឹងមកុដដល់
ខ្ញុំ[យ] 15 ខ្ញុំជាភ្នែក[រ]ដល់មនុស្សខ្វាក់ ហើយជាជើងដល់មនុស្ស

**២៨:២៥** ញ យប ១២:១៥ ៣៨:៨-១១ **២៨:២៦** ដ យប ៣៦:២៨ ៣៧:៦ យរ ៥១:១៦ ឋ យប ៣៦:៣៣ ៣៧:៣,៨, ១១ ៣៨:២៥,២៧ ទដ ៦៥:១២ ១០៤:១៤ ១៤៧:៨ អស ៣៥:៧ **២៨:២៧** ឌ សភ ៣:១៩ ៨:២២-៣១ **២៨:២៨** ឍ ទដ ១១:៥ ៩៧:១០ សភ ៣:៧ ៨:១៣ ណ នក ២០:២០ ចទ ៤:៦ យប ៣៧:២៤ **២៩:១** ក យប ២៧:១ **២៩:២** ខ លប ៣១:៣០ គ យរ ១:១២ ៣១:២៨ ៤៤:២៧ **២៩:៣** ឃ យប ១១:១៧ ១២:២៥ **២៩:៤** ង យប ១៥:៨ ច ទដ ២៥:១៤ សភ ៣:៣២ **២៩:៥** ឆ ទដ ១២៧:៣-៥ ១២៨:៣ ជ នរ ៤:១ **២៩:៦** ឈ យប ២០:១៧ ញ ទដ ៨១:១៦ ដ លប ៤៩:២០ ចទ ៣២:១៣ **២៩:៧** ឋ ខ.២១ យប ៥:៤ ៣១:២១ យប ២០:២ ៣៨:៧ **២៩:៨** ឌ ១ធថ ៥:១ ឍ លវ ១៩:៣២ **២៩:៩** ណ ខ.២១ យប ៣១:១២ ត ពច ១៨:១៩ យប ៤០:៤ សភ ៣០:៣២ **២៩:១០** ថ ខ.២២ ទ ទដ ១៣៧:៦ **២៩:១១** ធ យប ៤:៤ ហព ១១:៤ **២៩:១២** ន យប ២៤:៤ ប ចទ ២៤:១៧ យប ៣១:១៧,២១ ផ ទដ ៧២:១២ សភ ២១:១៣ **២៩:១៣** ព យប ៣១:២០ ភ ចទ ១០:១៨ យប ២២:៩ **២៩:១៤** ម ២សយ ៨:១៥ យប ២៧:៦ អភ ៤:២៤ ៦:១៤ យ យប ១៩:៩ **២៩:១៥** រ ជន ១០:៣១ ល យប ៤:៤

ទាំងអស់(មើល សភ ៨:២២-៣១ និងការពន្យល់) ។

**២៨:២៨** *សេចក្តីកោតខ្លាចដល់ព្រះអម្ចាស់ នោះហើយជាប្រាជ្ញា ហើយដែលថយឆ្ងាយពីការអាក្រក់* មើលការពណ៌នានៃចរិតលក្ខណៈរបស់យ៉ូបក្នុង ១:១,៨ ២:៣ ។ *នោះហើយជាប្រាជ្ញា* ការកោតខ្លាចដល់ព្រះយេហូវ៉ាគឺជាប្រាជ្ញាហើយ (សភ ១១១:១០ សភ ៩:១០ មើល ១:៧) ។

**២៩:១-៣១:៤០** លោកយ៉ូបចុះចូលការពារជីវិតចុងក្រោយរបស់គាត់ក្នុងសេចក្តីបន្ថែមចុងក្រោយទាំងបីផ្នែក : មានផ្នែកទី១ (ជំពូក ២៩) គឺជាការរំឭកពីភាពអាឡោះអាល័យ ពីភាពរីករាយរបស់គាត់ពីទ្រព្យសម្បត្តិនិងការគោរព ។ ផ្នែកទី២(ជំពូក ៣០) ការរាលដាលរហូតដល់បាត់បង់នូវអ្វីៗទាំងអស់ជាពិសេសកិត្តិយស ។ ផ្នែកទី៣ (ជំពូក ៣១) គឺជាការការពារចំពោះភាពគ្មានកំហុសរបស់គាត់ ។

**២៩:១-២៥** គឺជាឧទាហរណ៍គំរូមួយនៃវោហាសាស្ត្រដោយប្រើប្រព័ន្ធគំរូស៊ីមេទ្រីស្របគ្នាៈ ដូចជាព្រះពរ (ខ.២-៦) កិត្តិយស (ខ.៧-១០) ដែលមានចិត្តសប្បុរសធម៌ (ខ.១១-១៧) ព្រះពរ (ខ.១៨-២០) កិត្តិយស (មើល ខ.២១-២៥) ។

**២៩:២-៦** ពាក្យដែលគេចេញដោយអារម្មណ៍ ។ ក្នុងថ្ងៃជិនាន់ដំបូងដែលព្រះគឺជាមិត្តរបស់លោកយ៉ូបនិងជាដៃគូរ ។

**២៩:៣** *ដើរកាត់ទីងងឹតដោយសារពន្លឺទ្រង់* មើលការពន្យល់ ២២:២៨ ។

**២៩:៤** *វ័យនៃជីវិតហើយមានមិត្រភាពនៃព្រះ នៅក្នុងទីលំនៅរបស់ខ្ញុំ* "ក្នុងពេលព្រះបានផ្តល់ដំបូន្មានពេលដែលខ្ញុំនៅក្នុងត្រសាលរបស់ខ្ញុំ" ដែលជាអនុប្រយោគបង្ហាញឱ្យដឹងពីស្ថានភាពស្រដៀងគ្នា និង លប ១៨ ខណៈដែលព្រះនិងសមាជិកស្ថានសួគ៌បានសោយ និងទទួលទានភេសជ្ជៈនៅឯត្រសាលរបស់លោកអ័ប្រាហាំ ហើយនៅទីនោះព្រះអម្ចាស់ក៏បង្ហាញពីមិត្តទ្រង់ពីការដែលចាប់កំណើតនឹងមកដល់របស់ព្រះរាជបុត្រា ដែលទ្រង់បានសន្យាថានឹងប្រសូត ហើយព្រះអម្ចាស់ចាប់អារម្មណ៍ទៅលើក្រុងសូដុំមនិងក្រុងកូម៉ូរ៉ា ។

**២៩:៥** *ហើយខ្ញុំមានកូនចៅនៅជុំវិញ* មើល ១:២ និងការពន្យល់ ។

**២៩:៦** *ខ្លាញ់ទឹកដោះ ហើយទាំងថ្មក៏បញ្ចេញប្រេងហូរមកឱ្យខ្ញុំ* គឺជានិមិត្តរូបនៃភាពសម្បូរហូរហៀរ (មើល ២០:១៧ អរ ១៦:១៩) ។

**២៩:៧** ចេញទៅឯទ្វារទីក្រុង គឺជាទីកន្លែងប្រភពពាណិជ្ជកម្មជាច្រើនទាក់ទងគ្នានៅទីនោះក៏ជាកន្លែងកាត់ទោសធំៗនៅទីនោះ(មើលការពន្យល់ នរ ៤:១) រៀបចំអង្គុយ គឺជាទីក្រុងទីមួយ(ច្បង)ក៏ជាសមាជិកនៃក្រុមប្រឹក្សាច្បាប់ (មើលការពន្យល់ លប ១៩:១) ។

**២៩:១២-១៣** *ខ្ញុំបានជួយដោះមនុស្សក្រីក្រ. . . ព្រមទាំងពួកកំព្រា. . . ឱ្យចិត្តស្រីមេម៉ាយច្រៀងដោយអំណរ* គឺជាការឆ្លើយតបចំពោះការចោទប្រកាន់របស់អេលីផាស ក្នុង ២២:៩ លោកយ៉ូបបញ្ជាក់ពីការចាប់អារម្មណ៍របស់គាត់ពីជិនួយនឹងភាពអត់មានសំណាង (មើល ២៤:៩,៣១,១៦-១៨,២១) ។

**២៩:១៤** *ខ្ញុំបានតែងកាយពីសេចក្តីសុចរិត. . . សេចក្តីយុត្តធម៌របស់ខ្ញុំប្រៀបដូចអាវនឹងមកុដដល់ខ្ញុំ* គឺមានលក្ខណៈដូចគ្នាទៅនិង មើល ទដ ១៣២:៩,១៦ អស ៥៩:១៧ ៦១:១០ រម ១៣:១៤ អភ ៤:២៤ ៦:១៤,១៧ និងការពន្យល់ ទដ ១០៩:២៩ ។

ខ្ញុំន[ល] ១៦ក៏ជាឪពុកដល់ពួកអ្នកកំសត់[វ] ហើយខ្ញុំក៏ខំពិនិត្យរក
ខុសត្រូវ[ស] ក្នុងរឿងក្ដីរបស់អ្នកដែលខ្ញុំមិនស្គាល់ផង[ហ] ១៧ខ្ញុំ
បានបំបាក់ថ្គាមរបស់មនុស្ស ទុច្ចរិតព្រមទាំងកន្ត្រាក់យក
រំពា[ឡ]ពីធ្មេញរបស់គេចេញ[អ] ១៨នោះខ្ញុំបាននឹកថា ខ្ញុំនឹង
ស្លាប់ក្នុងសំបុកខ្ញុំ ហើយនិងចំរើនថ្ងៃអាយុខ្ញុំដូចជាខ្សាច់[ក]
១៩ឫសខ្ញុំបានចាក់ទៅដល់ទឹក[ខ] ហើយទឹកសន្សើមក៏នៅលើ
មែកខ្ញុំទាល់ព្រឹក[គ] ២០កិត្តិនាមខ្ញុំចេះតែនៅថ្មី[ឃ] ហើយ
ធ្នូ[ង]ខ្ញុំក៏ចេះតែចំរើនកំឡាំងនៅដៃខ្ញុំជានិច្ច[ច] ២១មនុស្ស
បានផ្ទៀងត្រចៀកស្ដាប់ខ្ញុំ គេនៅស្ងៀមចាំស្ដាប់គំនិតខ្ញុំ[ឆ]
២២កាលខ្ញុំពោលចប់ហើយ នោះគេឥតថាអ្វីទៀត[ជ] ពាក្យខ្ញុំ
បានស្រក់ដោកទៅលើគេ[ឈ] ២៣គេបានរង់ចាំខ្ញុំដូចជាចាំ
ភ្លៀង ព្រមទាំងហាមាត់យ៉ាងធំ បែបដូចជាទន្ទឹងចាំទទួល
ភ្លៀងចុងរដូវ[ញ] ២៤កាលគេឥតមានទីសង្ឃឹម នោះខ្ញុំបាន
ញញឹមដល់គេ ហើយគេមិនបានធ្វើឱ្យភាពមុខ[ដ] រីករាយ
របស់ខ្ញុំបាត់ចេញឡើយ[ឋ] ២៥ខ្ញុំបានរើសផ្លូវឱ្យគេ ហើយបាន
អង្គុយជាប្រធាន[ឌ] ក៏នៅកណ្ដាលគេដូចជាស្ដេច[ឍ]នៅ
កណ្ដាលកងទ័ព ក៏ជាអ្នកដែលជួយកំសាន្តចិត្តនៃពួកអ្នក
សោកសៅ[ណ] ។

៣០ ១ប៉ុន្តែឥឡូវនេះ ពួកអ្នកដែលក្មេងជាងខ្ញុំ គេចំអកឱ្យ[ក]
ជាពួកអ្នកដែលខ្ញុំមិនព្រមទាំងដាក់ឪពុកគេឱ្យនៅជាមួយ
នឹងឆ្កែរក្សាហ្វូងសត្វរបស់ខ្ញុំផង[ខ] ២អើ កំឡាំងដៃគេ តើ
ដែលមានប្រយោជន៍អ្វីដល់ខ្ញុំ គេនឹងរស់ដរាបដល់ចាស់មិន
បានទេ ៣គេស្គាំងស្គមដោយខ្វះខាត ហើយនិងពេលអំណត់
គេទេះស៊ីនៅទីហួតហែង[គ] ដែលពីដើមជាកន្លែងសូន្យ
ឈឹង[ឃ] ហើយចោលស្ងាត់[ង] ៤គេបេះស្លឹកប្រង់ដែលដុះនៅ
ក្បែរគុម្ពឈើតូចៗ[ច] ហើយមានតែមើមក្តួចជាអាហារដល់
គេ[ឆ] ៥គេត្រូវបណ្ដេញចេញពីចំណោមមនុស្ស ហើយមនុស្ស
ស្រែកដេញតាមគេ ដូចជាស្រែកតាមចោរ ៦ឱ្យទៅនៅក្នុង
ហប់ភ្នំគួរស្ញែងខ្លាច ក្នុងរូងដី ហើយរអាងថ្ម[ជ] ៧គេស្រែក
ឡើង[ឈ]នៅកណ្ដាលគុម្ពឈើ[ញ] ដូចជាសត្វលា គេប្រជុំគ្នា
នៅនាគុម្ពផ្កាវ ៨គេសុទ្ធតែជាកូនរបស់មនុស្សដែលឥតគំនិត
អើ ជាកូននៃមនុស្សទាបថោកបំផុត[ដ] គេត្រូវបណ្ដេញចេញ
ពីស្រុកទៅ[ឋ] ។

៩ឥឡូវនេះ ខ្ញុំ[ឌ]បានត្រឡប់ទៅជាបទចំរៀងរបស់គេ[ឍ]
ហើយជាពាក្យ[ណ]ដែលគេពោលបង្អាប់ ១០គេខ្ពើមឆ្អើមខ្ញុំ[ត]
ក៏ឈរឃ្លាតឆ្ងាយពីខ្ញុំ ហើយក៏ស្ដោះដាក់មុខខ្ញុំឥតទប់មាត់
ឡើយ[ថ] ១១ពីព្រោះព្រះទ្រង់បានដំឡោះខ្សែធ្នូបាញ់[ថ]ធ្វើទុក្ខ
ខ្ញុំ[ទ] ឯគេបានលែងចោលខ្សែបង្ហៀរ[ធ]នៅមុខខ្ញុំ ១២នៅខាង
ស្ដាំ[ន]ខ្ញុំកើតមានពួកពាល គេមកទង្គិច[ប]ជើងខ្ញុំ[ផ] ហើយបង្កើត
ផ្លូវវិនាសរបស់គេទាស់នឹងខ្ញុំ[ព] ១៣គេបំផ្លាញផ្លូវច្រករបស់
ខ្ញុំ[ភ]គេបញ្ឆេនសេចក្ដីអន្តរាយដល់ខ្ញុំ[ម] ឥតត្រូវការមានអ្នក
ណាជួយគេឡើយ ១៤គេចូលមកទាស់នឹងខ្ញុំតាមកន្លែងបាក់
បែកយ៉ាងធំ[យ] ហើយនៅក្នុងកន្លែងបាក់បែកគ្រាំគ្រា នោះគេ
ប្រមៀលខ្លួនគ្របមកលើខ្ញុំ ១៥មានសេចក្ដីស្ញែងខ្លាច[រ]
សង្កុញចូលមកលើខ្ញុំ[ល] ក៏ដេញតាមកិត្តិនាមរបស់ខ្ញុំ ដូចជា
ខ្យល់ ហើយសេចក្ដីសុខរបស់ខ្ញុំ បានរលាយបាត់ទៅដូចជា
ពពក[វ] ។

១៦ឥឡូវនេះ ព្រលឹងខ្ញុំត្រូវរលាយទៅ នៅក្នុងខ្លួនខ្ញុំ[ស]

**២៩:១៦** វ យប ២៤:៤ ស នក ១៨:២៦ ហ យប ៤:៤ សភ ២២:២២–២៣ **២៩:១៧** ឡ យប ២៤:៩ អ យប ៤:១០,១១ ទដ ៣:៧ **២៩:១៨** ក ទដ ១:១០៣ ១៥:៥ ១៦:៨ ៣០:៦ ៦២:២ ១៣៩:១៨ សភ ៣:១–២ **២៩:១៩** ខ ជន ២៤:៦ យប ១៤:៩ គ លប ២៧:៨ យប ១៥:៣០ ទដ ១៣៣:៣ **២៩:២០** ឃ ទដ ៩២:១៤ ង យប ៣០:១១ ទដ ១៨:៣៤ អស ៣៨:១២ ច លប ៤៩:២៤ **២៩:២១** ឆ ខ.៧,៩ **២៩:២២** ជ ខ.១០ ឈ ចទ ៣២:២ **២៩:២៣** ញ យប ៤:៣ **២៩:២៤** ដ ជន ៦:២៥ ឋ សភ ១៦:១៤,១៥ **២៩:២៥** ឌ យប ២១:២៨ ឍ យប ១:៣ ណ យប ៤:៤ **៣០:១** ក យប ៦:១៤ ១១:៣ ទដ ១១៩:២១ ខ អស ៥៦:១០ **៣០:៣** គ អស ៨:២១ ឃ យប ២៤:៥ ង យរ ១៧:៦ **៣០:៤** ច យប ៣៩:៦ ឆ ១ពវ ១៩:៤ **៣០:៦** ជ អស ២:១៩ ហស ១០:៨ **៣០:៧** ឈ យប ៦:៥ ញ យប ៣៩:៥–៦ **៣០:៨** ដ ពច ៩:៤ ឋ យប ១៨:១៨ **៣០:៩** ឌ យប ១៦:១០ ទដ ៦៩:១១ ឍ យប ១២:៤ បទ ៣:១៤,៦៣ ណ យប ១៧:៦ **៣០:១០** ត យប ១៩:១៩ ថ ចទ ២៥:៩ មថ ២៦:៦៧ **៣០:១១** ទ យប ២៩:២០ ធ លប ១២:១៧ នរ ១:២១ ន យប ៤១:១៣ ទដ ៣២:៩ **៣០:១២** ប ទដ ១០៩:៦ សក ៣:១ ផ យប ១៨:៩ ព ទដ ១៤០:៤–៥ ភ យប ១៦:១០ **៣០:១៣** ម អស ៣:១២ យ យប ១០:៣ **៣០:១៤** រ ២ពវ ២៥:៤ **៣០:១៥** ល យប ៦:៤ វ នក ៣:៦ យប ១០:៨ ៣១:២–៣,២៣ ទដ ៥៥:៤–៥ យប ៣:២៥ **៣០:១៦** ស យប ៣:២៤

**២៩:១៨** *ខ្ញុំបាននឹកថា* លោកយ៉ូបគិតពីការអ្វីដែលអាចជាទិសដៅសម្រាប់ជីវិតរបស់គាត់ ។

**២៩:២១–២៥** អ្នកឱ្យដំបូន្មានលោកយ៉ូបបានវាយតម្លៃ (ខ.២១–២៣) សម្រេកបញ្ជាក់របស់គាត់ (ខ.២៤) និងអ្នកដឹកនាំទីក្រុងរបស់គាត់ទទួលដោយគោរព (ខ.២៥)។

**២៩:១–៣០** ក្នុងលក្ខណៈផ្ទុយចំពោះកំណត់សម្គាល់វិជ្ជមានពីព្រះពរ និងសំឡេងគួរឱ្យគោរព ។ ក្នុងជំពូកនេះយ៉ូបនេះសេចក្ដីសោកស្ដាយ ការឈឺចាប់និងការមិនគោរព គឺគាត់(យ៉ូប) បានបង្ហឹឱ្យប្រឈមមុខចំពោះការអត់ធ្មត់ ។

**៣០:១,៩** *ប៉ុន្តែឥឡូវនេះ ពួកអ្នកដែលក្មេងជាងខ្ញុំ គេចំអកឱ្យ* គឺទាំងក្មេងទាំងមនុស្សចាស់ គេមានលក្ខណៈផ្ទុយពីគាត់ (២៩:៨–១១,២១–២៥) ។

**៣០:៤** *ស្លឹកប្រង់* ជារុក្ខជតិម្យ៉ាងដែលដុះនៅដីតំបន់សម្បូរជីវជាតិ គឺដូចជាលោកយ៉ូបនិងមិត្តរបស់គាត់រស់នៅ ។ ប្រៀបធៀបដើមអំបោស គឺជាប្រភេទគុម្ពព្រៃបោះធំៗដែលដុះនៅតំបន់មជ្ឈឹមបូព៌ា (មើល ១ពវ ១៩:៤ ទដ ១២០:៤ និងការពន្យល់) ។

**៣០:៩** *ជាពាក្យ* មើលការពន្យល់ ១៧:៦ ។

**៣០:១១** *ព្រះទ្រង់បានដំឡោះខ្សែធ្នូបាញ់ធ្វើទុក្ខខ្ញុំ* គឺជាលក្ខណៈផ្ទុយស្រលះចំពោះ ២៩:២០ ដែលលោកយ៉ូបមានការទុកចិត្តលើខ្សែធ្នូរបស់គាត់ថាវានៅតែថ្មីហើយខ្លាំង ។

**៣០:១២** *បង្កើតផ្លូវវិនាស* មើល ១៩:១២ ។

**៣០:១៤** *កន្លែងបាក់បែក* គឺនៅក្នុងកំផែងទីក្រុង ។

**៣០:១៥** *ក៏ដេញតាមកិត្តិនាមរបស់ខ្ញុំ ដូចជាខ្យល់* មើល ខ.២២ ។

ហើយគ្រាវេទនាបានចាប់តោងខ្ញុំជាប់[ហ] ១៧នៅវេលាយប់
ឆ្អឹងនៅក្នុងខ្លួនខ្ញុំត្រូវចាក់ទំលុះ ហើយសេចក្ដីឈឺចាប់ដែល
ស៊ីរេះខ្ញុំ នោះមិនចេះសំរាកទេ[ឡ] ១៨អាវខ្ញុំត្រូវផ្លាស់ភាពទៅ
ដោយអំណាច[អ]នៃរោគនេះ ក៏រឹតរួតខ្លួនខ្ញុំ ដូចជាកអាវខ្ញុំ
១៩ទ្រង់បានបោះខ្ញុំទៅក្នុងទីល្បាប់[ក] ខ្ញុំក៏បានត្រឡប់ទៅដូច
ជាធូលីដីនឹងផេះហើយ[ខ] ២០ឱព្រះអង្គអើយ ទូលបង្គំអំពាវ
នាវរកទ្រង់[គ] តែទ្រង់មិនឆ្លើយមកទូលបង្គំសោះ[ឃ] ទូលបង្គំ
ឈរឡើង តែទ្រង់គ្រាន់តែសំឡឹងមើលទូលបង្គំប៉ុណ្ណោះ
២១ទ្រង់បានត្រឡប់ទៅជាសាហាវដល់ទូលបង្គំ[ង] ក៏បៀត
បៀនទូលបង្គំ[ច] ដោយអានុភាពនៃព្រះហស្តទ្រង់[ឆ] ២២ទ្រង់
លើកទូលបង្គំឡើងឱ្យត្រូវខ្យល់[ជ] ហើយបណ្តែតទូលបង្គំ
ទៅតាម ទ្រង់រំលាយទូលបង្គំដោយខ្យល់ព្យុះ[ឈ] ២៣ដ្បិតទូល
បង្គំដឹងថា ទ្រង់នឹងនាំទូលបង្គំឱ្យត្រូវស្លាប់[ញ] គឺឱ្យទៅឯទី
សំណាក់ដែលទុកសំរាប់ឱ្យមនុស្សរស់ទាំងអស់ចូលទៅ[ដ]។
២៤ប៉ុន្តែកាលមនុស្សដួលចុះ តើមិនយកដៃទប់ខ្លួនទេឬ
អី[ឋ] ឬកាលណាមានសេចក្ដីអន្តរាយ តើមិនស្រែករកគេជួយ
ដែរឬ[ឌ] ២៥ឯខ្ញុំ តើមិនបានស្រក់ទឹកភ្នែកនឹងមនុស្សដែលមាន
សេចក្ដីលំបាក ហើយព្រួយ[ឍ]ចិត្តនឹងពួកអ្នកទុគ៌តទេឬអី[ណ]
២៦តែកាលខ្លួនខ្ញុំសង្ឃឹមនឹងបានសេចក្ដីល្អ នោះសេចក្ដី
អាក្រក់បានមកដល់ កាលខ្ញុំបានទន្ទឹងចាំពន្លឺ នោះមានសុទ្ធ
តែសេចក្ដីងងឹតវិញ[ត] ២៧ចិត្តខ្ញុំខ្ទោលចុះឡើងឥតឈប់ឈរ[ថ]
មានគ្រាលំបាកបានមកលើខ្ញុំហើយ[ទ] ២៨ខ្ញុំដើរទៅដោយ
មានមុខខ្មៅ[ធ] ដែលមិនមែនខ្មៅដោយថ្ងៃចាំងទេ ខ្ញុំក្រោក
ឡើងនៅកណ្ដាលជំនុំ ស្រែករកគេជួយ[ន] ២៩ខ្ញុំជាបងប្អូននឹង
ឆ្កែព្រៃ[ប] ហើយជាភឿនមិត្រនឹងសត្វអូសទ្រីចផង[ផ] ៣០សាច់
ខ្ញុំខ្មៅ[ព] ហើយក៏របេះពីខ្ញុំទៅ[ភ] ឆ្អឹងខ្ញុំក៏ឆេះដោយគ្រុនក្ដៅ[ម]
៣១ហេតុនោះបានជាស៊ុងខ្ញុំបានត្រឡប់ជាសេចក្ដីសោក
សៅ[យ] ហើយខ្លុយខ្ញុំបានទៅជាសំឡេងនៃពួកអ្នកដែល
យំទួញវិញ ។

**៣១** ១ខ្ញុំបានតាំងសញ្ញានឹងភ្នែក[ក]ខ្ញុំហើយ ដូច្នេះ ធ្វើដូច
ម្តេចឱ្យខ្ញុំមើលស្ត្រីក្រមុំដោយចាប់ចិត្តបាន[ខ] ២ដ្បិតយ៉ាង
នោះ តើនឹងមានចំណែកអ្វី[គ]ពីព្រះដ៏គង់នៅស្ថានលើ ហើយ
តើនឹងមានមរដកអ្វី ពីព្រះដ៏មានគ្រប់ព្រះចេស្ដា នៅស្ថាន
ដ៏ខ្ពស់នោះ[ឃ] ៣តើមិនមែនជាសេចក្ដីអន្តរាយ[ង] ដល់មនុស្ស
ទុច្ចរិត ហើយជាសេចក្ដីវេទនា[ច]ដល់ពួកអ្នក ដែលប្រព្រឹត្ត
អាក្រក់ទេឬអី[ឆ] ៤តើទ្រង់មិនឃើញផ្លូវខ្ញុំ[ជ] ហើយរាប់អស់
ទាំងជំហាននៃខ្ញុំទេឬអី[ឈ] ។
៥បើខ្ញុំបានដើរដោយសេចក្ដីភូតភរ ហើយជើងខ្ញុំបាន

**៣០:១៦** ហ ខ.២៧ យប ៩:១៧ **៣០:១៧** ឡ ចទ ២៨:៣៥ យប ១៦:១៦ **៣០:១៨** អ យប ៩:៤ **៣០:១៩** ក ទដ ៤០:២ ៦៩:២,១៤ ១៣០:១ យរ ៣៨:៦,២២ ខ លប ៣:១៩ យប ២:៨ **៣០:២០** គ ១ពវ ៨:៥២ ទដ ៣៤:១៧ សភ ២:៣ មីក ៤:៩ ឃ យប ១៩:៧ បទ ៣:៨ **៣០:២១** ង យរ ៦:២៣ ៣០:១៤ ៥០:៤២ ច យប ៤:៥ ៦:៤ ១០:៣ ឆ អស ៩:១២ ១៤:២៦ ៣១:៣ អគ ៦:១៤ **៣០:២២** ជ យប ២៧:២១ យដ ១:១២ ឈ យប ៩:១៧ **៣០:២៣** ញ ២សយ ១៤:១៤ យប ៣:១៣ ១០:៣ ដ យប ៣:១៩ **៣០:២៤** ឋ ទដ ១៤៥:១៤ អស ៤២:៣ ៥៧:១៥ ឌ យប ១៩:៧ **៣០:២៥** ឍ លក ១៩:៤១ សភ ៣:១៨ ណ យប ២៤:៤ ទដ ៣៥:១៣–១៤ រម ១២:១៥ **៣០:២៦** ត យប ៣:៦ ,១៧ ១៩:៨ ទដ ៨២:៥ យរ ៤:២៣ **៣០:២៧** ថ ទដ ៣៨:៨ បទ ២:១១ ទ ខ.១៦ **៣០:២៨** ធ យប ១៧:១៤ បទ ៤:៨ ន យប ១៩:៧ ២៤:១២ **៣០:២៩** ប ទដ ៤៤:១៩ អស ៣៤:១៣ យរ ៩:១១ ផ ទដ ១០២:៦ មីក ១:៨ **៣០:៣០** ព យប ១៧:១៤ ភ បទ ៣:៤ ៤:៨ ម ចទ ២៨:៣៥ យប ១៦:១៦ ទដ ១០២:៣ បទ ១:១៣ ៥:១០ **៣០:៣១** យ លប ៨:៨ ទដ ១៣៧:២ អស ១៦:១១ ២៤:៨ អគ ២៦:១៣ រ លប ៤:២១ **៣១:១** ក សភ ៤:២៥ ១៧:២៤ ២ពត ២:១៤ ខ នក ២០:១៤, ១៧ ចទ ៥:១៨ មថ ៥:២៨ **៣១:២** គ ជន ២៦:៥៥ ទដ ១១:៦ ៥០:១៨ សស ៣:២២ ៥:១៩ ៩:៩ ឃ យប ១៦:១៩ ២០:២៩ **៣១:៣** ង យប ២១:៣០ ច យប ១៨:១២ ឆ យប ៣៤:២២ រម ២:៩ **៣១:៤** ជ ២របា ១៦:៩ ទដ ១៣៩:៣ ដយ ៤:៣៧ ៥:២៣ ឈ ខ.១៤ យប ១០:៤

**៣០:១៧** *សេចក្ដីឈឺចាប់ដែលស៊ីរេះ* មើលការពន្យល់ ២:៧ ។

**៣០:១៨** *ដូចជាកអាវខ្ញុំ* គឺសម្រាប់ចងភ្ជាប់កអាវ ។

**៣០:១៩** *ជាធូលីដីនិងផេះ* ជាតំណាងពីភាពអាម៉ាស(មើលការពន្យល់ លប ១៨:២៧) លោកយ៉ូបគឺនៅថ្ងៃណាមួយក៏ត្រូវប្រើពាក្យ "ធូលី និងផេះ" សម្រាប់ជានិមិត្តនៃការលន់តួអំពើបាប (៤២:៦) ។

**៣០:២០–២៣** ឥឡូវនេះលោកយ៉ូបបានផ្លាស់ប្ដូរចិត្តគំនិតគាត់ ពីនិស្ស័យមនុស្សទៅរកភាពជាព្រះ ។ លោកបានចោទប្រកាន់ព្រះថារំលោភកេងប្រវ័ញ្ចហួសកំរិតដល់លោក ដែលខុសពីធាតុដើមរបស់ទ្រង់ដែលមានសេចក្ដីអាណិត និងមេត្តាករុណាតែប៉ុណ្ណោះ ។

**៣០:២៤** លោកយ៉ូបមានអារម្មណ៍ថារូបលោកត្រូវបានគេប្រព្រឹត្តមកលើរូបលោកដោយភាពអយុត្តធម៌ជាទីបំផុត គឺមានទាំងព្រះ ឬមានទាំងមនុស្សដែលដាក់កំហុសមកលើរូបលោក ។

**៣០:២៦** ប្រៀបធៀប អស ៥:២,៧ ។

**៣០:២៩** *ភឿនមិត្រនិងសត្វអូសទ្រីច* មានហោរាមីកាដែលប្រើការប្រៀបធៀបស្រដៀងទៅនឹងរូបគាត់ក្នុងគម្ពីរ មីក ១:៨ ។

**៣១:១–៤០** គឺជាផ្នែកដែលបានបង្កើតពីឧត្តមគតិពីសំណាក់មិត្តទាំងបីរបស់លោក(មើលការពន្យល់ ២៩:១–៣១:៤០) ។ វាដូចជាភាពអវិជ្ជមានដែលផ្ទុះក្នុងគំនិតដែលបណ្ដាលឱ្យលោកយ៉ូបបដិសេធរាល់អំពើបាបរបស់គាត់ តែវាក៏ជាគោលបំណងដ៏វិជ្ជមានល្អប្រសើរ ដើម្បីជាបន្ទាល់ស្ដែងឱ្យឃើញពីភាពស្មោះចំពោះព្រះអម្ចាស់ដែលទ្រង់ជាព្រះមហាក្សត្រគឺជាព្រះយេហូវ៉ា ។ មានផ្នែកនៃពាក្យពេចន៍ដែលប្រើជាផ្នែកនៃពាក្យសម្បត់ផ្ទាល់ខ្លួន លោកយ៉ូបក៏មានពាក្យដើម្បីការពាររូបលោក(ខ.៤០,៤៥) ។ គាត់ក៏បានបង្ហាញពីភស្តុតាងថា លោកជាអ្នកមានបាបទុរគ៌តភាពក៏សម្រាកជាមួយព្រះ ។ ការត្រាស់ហៅលោកយ៉ូបបានទៅកាន់ភាពឧត្តមមួយ ក្នុង ២៧:២–៦ ។ លោកយ៉ូបក៏បង្ហាញច្រើនថែមទៀតពីជីវិតគាត់ដែលមានព្រះគង់ជាមួយ ។ (ខ.៥ ៧,១៣,១៦–២១,២៤–២៧,២៩–៣៤,៣៨–៣៩) ដែលមានទៅដោយពាក្យសម្បត់(ខ.៨,១០–១២,១៤–១៥,២២–២៣,២៨,៤០) ។ គោលការការងារគេហៅថាច្បាប់សងសឹក (មើល នក ២១:២៣–២៥ លវ ២៤:២០ និងការពន្យល់) ។

**៣១:១–១២** ក្នុងនេះលោកយ៉ូបមានបាបតាមរយៈចិត្ត ជាពិសេសការចំណង់តណ្ហា(ខ.១–៤) គឺជាការកេងប្រវ័ញ្ច(ខ.៥–៨,៩–១២) ។

**៣១:៤** ក៏រឹកដាលតាមរយៈលោកអេលីហ៊ូវ មើល ៣៤:២១ ។

រហ័សទៅតាមសេចក្ដីល្បួង[ញ] ៦ នោះសូមឱ្យព្រះថ្លឹងខ្ញុំ[ដ]
ដោយជញ្ជីង[ឋ]ត្រឹមត្រូវ ដើម្បីឱ្យទ្រង់បានជ្រាបគំនិតទៀង
ត្រង់របស់ខ្ញុំ[ឌ] ៧ បើជើងខ្ញុំបានឈានចេញពីផ្លូវ[ឍ] ហើយចិត្ត
បានទៅតាមភ្នែក បើមានសេចក្ដីស្មោកគ្រោកអ្វីជាប់នៅ
ដៃ[ណ]ខ្ញុំ[ត] ៨ នោះសូមឱ្យខ្ញុំសាបព្រោះ[ថ] ហើយម្នាក់ទៀតស៊ីផល
ចុះ អើ ខ្ញុំសុខចិត្តឱ្យគេរំលើងផលក្នុងស្រែចំការខ្ញុំទាំងអស់
ទៅផង[ទ] ៩ បើចិត្តខ្ញុំបានចុះចូលនឹងសេចក្ដីល្បួងលោម[ធ]របស់
ស្ត្រីណា[ន] ហើយខ្ញុំបានលបចាំនៅមាត់ទ្វារអ្នកជិតខាងខ្ញុំ
១០ នោះសូមឱ្យប្រពន្ធខ្ញុំបានកិនស្រូវ[ប]ឱ្យម្នាក់ទៀត ហើយឱ្យ
មនុស្សឯទៀតរួមរសជាមួយចុះ[ផ] ១១ ដ្បិតយ៉ាងនោះជាការ
មានទោសយ៉ាងធ្ងន់[ព] ជាសេចក្ដីទុច្ចរិតដែលគួរឱ្យពួកចៅ
ក្រមធ្វើទោស[ភ] ១២ នោះជាភ្លើង[ម]ដែលឆេះបន្សុស[យ] រហូត
ដល់ស្ថានវិនាស ហើយនិងរំលើងអស់ទាំងផលចំរើនរបស់
ខ្ញុំ[រ] ១៣ បើខ្ញុំដែលមើលងាយរឿងរបស់បាវប្រុសបាវស្រីខ្ញុំ[ល]
ក្នុងកាលដែលវាបានតវ៉ានឹងខ្ញុំ[វ] ១៤ យ៉ាងនោះ តើខ្ញុំនឹងធ្វើ
ដូចម្តេច ក្នុងកាលដែលព្រះទ្រង់ក្រោកឡើង[ស] កាលណា
ទ្រង់ពិចារណាសួរខ្ញុំ នោះតើខ្ញុំនឹងឆ្លើយដល់ទ្រង់ដូចម្តេច[ហ]
១៥ ឯព្រះដែលបានបង្កើតខ្ញុំនៅក្នុងពោះម្តាយ[ឡ] តើមិនបាន
បង្កើតបាវនោះដែរទេឬ តើមិនមែនជាព្រះតែ១ដែលស្អាង
យើងទាំង២នៅក្នុងផ្ទៃម្តាយទេឬអី[អ]។
១៦ បើខ្ញុំបានឃាត់មិនឱ្យពួកក្រីក្រ[ក]បានតាមបំណងចិត្ត
ឬបានធ្វើឱ្យភ្នែកនៃស្រីមេម៉ាយ[ខ]ស្រវាំងទៅ[គ] ១៧ ឬបើបាន
ទទួលទានអាហារតែឯងម្នាក់ ឥតចែកឱ្យដល់ពួកកំព្រា
ផង[ឃ] ១៨ (ប៉ុន្តែគ្មានទេ គឺតាំងពីខ្ញុំនៅក្មេងមក គេបានធំ
ឡើងជាមួយនឹងខ្ញុំ ដូចជានៅនឹងឪពុកជាមួយគ្នា ហើយតាំង
ពីខ្ញុំចេញពីផ្ទៃម្តាយមក នោះខ្ញុំតែងតែនាំផ្លូវស្រីមេម៉ាយ
វិញ)[ង] ១៩ បើខ្ញុំដែលឃើញអ្នកណាវិនាសទៅ ដោយឥតមាន
អ្វីស្លៀកពាក់[ច] ឬអ្នកកំសត់ទុគ៌ត[ឆ]ឥតមានអ្វីដណ្តប់ខ្លួន ២០ បើ
ចង្កេះគេមិនបានឱ្យពរដល់ខ្ញុំ[ជ] បើគេមិនបានកក់ក្តៅដោយ
រោម[ឈ]ចៀមរបស់ខ្ញុំទេ ២១ បើខ្ញុំបានលើកដៃទាស់នឹងពួក
កំព្រា[ញ] ដោយឃើញមនុស្សដែលបានជួយខ្ញុំនៅមាត់ទ្វារ[ដ]
២២ នោះសូមឱ្យស្មាខ្ញុំ បានសណ្តកចេញពីឆ្អឹងស្លាបប្រចៀវ
ហើយឱ្យដៃខ្ញុំភ្លាត់ពីឆ្អឹងចេញចុះ[ឋ] ២៣ ដ្បិតសេចក្តីអន្តរាយ
ដែលមកពីព្រះ[ឌ] នោះនាំឱ្យខ្ញុំស្ញែងខ្លាចណាស់[ឍ] ហើយ
ដោយព្រោះទ្រង់ខ្ពស់ទាំងម្ល៉េះបានជាខ្ញុំធ្វើអ្វីមិនកើត[ណ]
២៤ បើសិនជាខ្ញុំបានយកមាសជាទីសង្ឃឹម[ត] ហើយបានពោល
ដល់មាសសុទ្ធថា ឯងជាទីទុកចិត្តរបស់អញ[ថ] ២៥ បើខ្ញុំបាន
រីករាយសប្បាយដោយព្រោះមានទ្រព្យសម្បត្តិច្រើន[ទ] ហើយ
ដោយព្រោះដៃខ្ញុំបានប្រមូលជាបរិបូរ[ធ] ២៦ បើខ្ញុំបានមើល
ទៅព្រះអាទិត្យ[ន] ក្នុងកាលដែលចាំងមក ឬទៅព្រះចន្ទ[ប]
ដែលភ្លឺត្រសែតទៅ ២៧ រួចចិត្តខ្ញុំមានសេចក្តីល្បួងដោយ
សំងាត់[ផ] ហើយមាត់ក៏បានថើបដៃរបស់ខ្ញុំ[ព] ២៨ យ៉ាងនោះក៏
ជាការគួរឱ្យពួកចៅក្រមធ្វើទោសដែរ[ភ] ដ្បិតដូច្នោះ ខ្ញុំបាន
លះចោលព្រះដែលគង់នៅស្ថានលើហើយ[ម] ២៩ បើខ្ញុំដែល
រីករាយសប្បាយ ដោយឃើញសេចក្តីហិនវិនាសរបស់អ្នក
ដែលស្អប់ខ្ញុំ[យ] ឬបំប៉ោងចិត្តឡើង ក្នុងកាលដែលសេចក្តី
អាក្រក់បានមកដល់គេ[រ] ៣០ (ប៉ុន្តែគ្មានទេ គឺខ្ញុំមិនបានឱ្យមាត់

**៣១:៥** ញ យប ១៥:៣១ **៣១:៦** ដ ទដ ១៣៩:២៣ ឋ លវ ១៩:៣៦ យប ៦:២ ឌ លប ៦:៩ យប ២:៣ ២៣:១០ **៣១:៧** ឍ យប ២៣:១១ ណ យប ៩:៣០ ត ទដ ៧:៣ **៣១:៨** ថ យប ៥:៥ ២០:១០ យហ ៤:៣៧ ទ ខ.១២ មីក ៦:១៥ **៣១:៩** ធ ចទ ១១:១៦ យប ២៤:១៥ យក ១:១៤ ន សភ ៥:៣ ៧:៥ **៣១:១០** ប ពច ១៦:២១ ផ ចទ ២៨:៣០ **៣១:១១** ព សភ ៦:៣២-៣៣ ភ លប ៣៨:២៤ នក ២១:១២ យហ ៨:៤-៥ **៣១:១២** ម យប ១៥:៣០ យ យប ២៦:៦ រ ខ.៨ **៣១:១៣** ល ចទ ៥:១៤ វ នក ២១:២-១១ លវ ២៥:៣៩-៤៦ ចទ ២៤:១៤-១៥ **៣១:១៤** ស យប ៣៣:៥ ហ ខ.៤,៣៧ ទដ ១០:១៣,១៥ ៩៤:៧ អស ១០:៣ យរ ៥:៣១ ហស ៩:៧ មីក ៧:៤ កល ៤:១ **៣១:១៥** ឡ យប ៤:១៧ សភ ២២:២ អ យប ១០:៣ អភ ៦:៩ **៣១:១៦** ក លវ ២៦:១៧ យប ៥:១៦ ខ យប ២២:៩ យក ១:២៧ គ យប ២២:៧ **៣១:១៧** ឃ យប ៦:២៧ ២២:៧ **៣១:១៨** ង អស ៥១:១៨ **៣១:១៩** ច យប ២២:៦ អស ៥៨:៧ ឆ យប ២៤:៤ **៣១:២០** ជ យប ២៩:១៣ ឈ ពច ៦:៣៧ **៣១:២១** ញ យប ២២:៧ យក ១:២៧ ដ យប ២៩:៧,៩ **៣១:២២** ឋ ជន ១៥:៣០ យប ៥:១៥ ៣៨:១៥ ទដ ១០:១៥ ៣៧:១៧ ១៣៧:៥ **៣១:២៣** ឌ យប ១០:៣ ៣០:១៥ ឍ យប ១៣:១១ ណ លប ២០:១១ **៣១:២៤** ត យប ២២:២៥ ថ មថ ៦:២៤ លក ១២:១៥ **៣១:២៥** ទ លប ១២:១៦ ទដ ៤៩:៦ ៥២:៧ ៦២:១០ អស ១០:១៤ ធ យប ២២:២៤ អគ ២៨:៥ លក ១២:២០-២១ **៣១:២៦** ន លប ១:១៦ ប យប ២៥:៥ **៣១:២៧** ផ ចទ ១១:១៦ យប ២៤:១៥ យក ១:១៤ ព យរ ៨:២ ១៦:១១ **៣១:២៨** ភ លប ៣៨:២៤ ចទ ១៧:២-៧ ម ជន ១១:២០ អគ ៨:១៦ **៣១:២៩** យ ជន ១៤:១ ទដ ៣៥:១៥ អប ១:១២ មថ ៥:៤៤ រ សភ ១៧:៥ ២៤:១៧-១៨

**៣០:៦** *ព្រះថ្លឹងខ្ញុំដោយជញ្ជីងត្រឹមត្រូវ* មើល ៦:២ សភ ១៦:១១ និងការពន្យល់ ២១:២ ២៤:១២ អម ៨:៥ មីកា ៦:១១ ។ *គំនិតទៀងត្រង់* គឺមិនប្រព្រឹត្តបាបទោះតិចក្តី(មើលការពន្យល់ ១:១) ។

**៣១:១២** *ស្ថានវិនាស* មើលការពន្យល់ ២៦:៦ ។

**៣១:១៣-២៣** លោកយ៉ូបបង្ហាញចំៗពីការយល់ដឹងទាក់ទងនិងរឿងរ៉ាវយុត្តធម៌សង្គម : ភាពស្មើភាពរបស់មនុស្សគឺសំដៅលើស្នាព្រះហស្ត(ខ.១៣-១៥) គឺទ្រង់មានមេត្តាករុណាឆ្ពោះទៅរកអ្នកណាដែលត្រូវការ (ខ.១៦-២០) អំណាចព្រះចេស្តាទ្រង់(ខ.២១-២៣) ។

**៣១:១៦-១៧** *ស្ត្រីមេម៉ាយ... កូនកំព្រា* មើលការពន្យល់ ២០:១២-១៣ ។

**៣១:២៤-២៨** ជាសេចក្តីលោភ (ខ.២៤-២៥)និងអ្នកទទួលវិញ្ញាណអារក្ស (ខ.២៦-២៧) គឺសាកសមនិងទទួលការកាត់ទោសក្នុងព្រះភក្ត្រទ្រង់ (ខ.២៨ មើល មថ ៦:១៩-២១ និងការពន្យល់ កល ៣:៥) ។

**៣១:២៥** *មានទ្រព្យសម្បត្តិច្រើន* មើល ១:៣ និងការពន្យល់ ១:១០ ។

**៣១:២៦-២៨** ព្រះអាទិត្យនិងព្រះច័ន្ទមិនមែនជាវត្ថុសម្រាប់ថ្វាយបង្គំទេ (សូមមើលការពន្យល់ លប ១:១៦ ចទ ៤:១៩ ១៧:៣ អគ ៨:១៦-១៧) ។

**៣១:២៧** *ថើប* គឺជាកាយវិការថ្វាយបង្គំតាំងពីសម័យបូរាណ (មើល ១ពវ ១៩:១៨ ហស ១៣:២ និងការពន្យល់) ។

**៣១:២៩-៣២** អំពើបាបប្រមើលទៅលើសត្រូវអ្នកណាម្នាក់ ក៏បានកាត់ទោសដោយលោកម៉ូសេ(មើល នក ២៣:៤-៥ និងការពន្យល់) និងដោយព្រះគ្រីស្ទ (មើល មថ ៥:៤៣-៤៧) ។

ធ្វើបាប ដោយដាក់បណ្ដាសា ដល់ជីវិតគេឡើយ[ល]) ៣១បើ
សិនណាជាពួកមនុស្សនៅទីលំនៅខ្ញុំ មិនបានពោលថា តើ
មានអ្នកឯណាដែលមិនបានឆ្អែត ដោយអាហាររបស់គាត់[វ]
៣២(សូម្បីតែពួកដំណើរក៏មិនបានដេកនៅនាផ្លូវដែរ ដ្បិតខ្ញុំ
បានបើកទ្វារទទួលគេឱ្យស្នាក់នៅវិញ[ស]) ៣៣បើខ្ញុំបានគ្រប
បាំង[ហ]សេចក្តីរំលងរបស់ខ្ញុំ ដូចជាមនុស្សលោក ដោយ
លាក់[ឡ]សេចក្តីអាក្រក់ខ្ញុំនៅក្នុងទ្រូង ៣៤ព្រោះតែខ្លាចចំពោះ
ហ្វូងមនុស្ស[អ] ហើយសេចក្តីមើលងាយរបស់គ្រួផ្សេងៗបាន
នាំឱ្យខ្ញុំភ័យ ដល់ម្ល៉េះបានជាខ្ញុំនៅស្ងៀម[ក] ឥតដែលចេញ
តាមមាត់ទ្វារសោះ ៣៥ឱបើមានអ្នកណាមួយស្ដាប់ខ្ញុំទៅ
អេះ[ខ] មើល ខ្ញុំចុះឈ្មោះហើយ សូមឱ្យព្រះដ៏មានគ្រប់ព្រះ
ចេស្ដាឆ្លើយមកខ្ញុំចុះ ឱបើអ្នកដែលតតាំង[គ]នឹងខ្ញុំបានធ្វើ
ពាក្យថ្លែងការទៅអេះ ៣៦នោះប្រាកដជាខ្ញុំនឹងយកទៅ
ដោយភ្ជាប់នឹងស្មា[ឃ] ហើយចងភ្ជាប់នៅក្បាលដូចជាក្បាំង[ង]
៣៧ខ្ញុំនឹងទូលទ្រង់ពីចំនួនជំហានខ្ញុំ[ច] ហើយនិងចូលទៅជិត
ទ្រង់ដូចអ្នកប្រធាន[ឆ]ណាមួយ ៣៨បើសិនជាដីរបស់ខ្ញុំស្រែក
ឡើងទាស់នឹងខ្ញុំ[ជ] ហើយគន្លងទាំងប៉ុន្មានយំ[ឈ]ជាមួយគ្នា
៣៩បើខ្ញុំបានបរិភោគផលនៃដីនោះឥតបង់ថ្លៃ[ញ] ឬបានធ្វើឱ្យ
ម្ចាស់ដើមបង់ជីវិតទៅ[ដ] ៤០នោះសូមឱ្យមានតែបន្លា[ឋ]ដុះឡើង
ជំនួសស្រូវភោជ្ជសាលី[ឌ] ហើយស្រងែជំនួសស្រូវឱកវិញ
ចុះ ។

ពាក្យរបស់យ៉ូបចប់តែប៉ុណ្ណោះ[ឍ] ។

## អេលីហ៊ូវ

៣២ ១ដូច្នេះ អ្នកទាំង៣នោះក៏លែងឆ្លើយនឹងយ៉ូប[ក] ពី
ព្រោះលោករាប់ខ្លួនថាជាសុចរិតហើយ[ខ] ២នៅខណនោះ
អេលីហ៊ូវ ជាកូនបារ៉ាកាល សាសន៍ប៊ូស[គ] ក្នុងពូជពង្សរ៉ាម
ក៏កើតមានសេចក្តីកំហឹងឡើង គឺគាត់ខឹងនឹងយ៉ូប ដោយ
ព្រោះលោករាប់ខ្លួនជាសុចរិត[ឃ]នៅចំពោះព្រះ[ង] ៣គាត់ក៏
ខឹងនឹងសំឡាញ់របស់យ៉ូបទាំង៣នាក់នោះដែរ[ច] ពីព្រោះគេ
បានកាត់ទោសដល់យ៉ូប[ឆ] តែរកឆ្លើយតបនឹងលោកមិន
បាន[ជ] ៤រីឯអេលីហ៊ូវ គាត់បានរង់ចាំឱកាសនឹងនិយាយជា
មួយនឹងយ៉ូប ពីព្រោះគេសុទ្ធតែចាស់ៗជាងខ្លួន[ឈ] ៥ដូច្នេះ
កាលអេលីហ៊ូវឃើញថា អ្នកទាំង៣នោះរកឆ្លើយមិនបាន
នោះគាត់ក៏កើតមានសេចក្តីកំហឹងឡើយ ។

៦នោះអេលីហ៊ូវ ជាកូនបារ៉ាកាល សាសន៍ប៊ូស គាត់
ឆ្លើយឡើងថា ខ្ញុំនៅក្មេង ហើយអ្នករាល់គ្នាមានអាយុ

**៣១:៣០** ល យប ៥:៣ រម ១២:១៤ **៣១:៣១** វ យប ២២:៧ **៣១:៣២** ស លប ១៩:២–៣ ពច ១៩:២០ មថ ២៥:៣៥ រម ១២:១៣ **៣១:៣៣** ហ ទដ ៣២:៥ សភ ២៨:១៣ ឡ លប ៣:៨ **៣១:៣៤** អ នក ២៣:២ ក ទដ ៣២:៣ ៣៩:២ **៣១:៣៥** ខ យប ៩:២៤ ៣០:២៨ គ យប ២៧:៧ **៣១:៣៦** ឃ នក ២៨:១២ ង យប ២៩:១៤ **៣១:៣៧** ច ខ.១៤ យប ១១:១១ ឆ យប ២១:២៨ **៣១:៣៨** ជ លប ៤:១០ ឈ ទដ ៦៥:១០ **៣១:៣៩** ញ ១ពវ ២១:១៩ ដ លវ ១៩:១៣ យក ៥:៤ **៣១:៤០** ឋ លប ៣:៨ មថ ១៣:៧ ឌ សផ ២:៩ មថ ១៣:២៦ ឍ ទដ ៧២:២០ យរ ៥១:៦៤ **៣២:១** ក ខ.១៥ ខ យប ២:៣ ១០:៧ **៣២:២** គ លប ២២:២១ ឃ ខ.១ ង យប ១៣:១៩ ២៧:៥ ៣០:២១ ៣៥:២ **៣២:៣** ច យប ៤២:៧ ឆ ខ.១២–១៣ ជ យប ១៥:១៣ **៣២:៤** ឈ លវ ១៩:៣២

**៣១:៣៣–៣៤** ជាការប្រកែកយ៉ាងខ្លាំងចំពោះមនុស្សមានពុតត្បុត ។

**៣១:៣៣** *ដូចជាមនុស្សលោក* លប ៣:៨–១០ ហស ៦:៧ ។

**៣១:៣៥–៣៧** ការត្រាស់ហៅលោកយ៉ូបចុងក្រោយដើម្បីកាត់ទោស ។ ការប្រគល់នូវការយល់ព្រមរបស់គាត់គ្រប់ទាំងពាក្យសម្បត់ដែលគាត់មាន ។

**៣១:៣៥** *អ្នកណាមួយស្ដាប់ខ្ញុំទៅអេះ* មើលការពន្យល់ ៥:១ ៩:៣៣ ១៦:១៨–២១ ១៩:២៥ ។ *សូមឱ្យព្រះដ៏មានគ្រប់ទាំងព្រះចេស្ដាឆ្លើតមកខ្ញុំចុះ* មើលការពន្យល់ ៣៨:១។ *អ្នកដែលតតាំង* ក្នុងព្រះគម្ពីរជាភាសាហេព្រើរចំពោះឃ្លាពាក្យនេះ គឺខុសពីពាក្យ "សាតាំង" (មើលការពន្យល់ ១:៦) នៅទីនេះឃើញមានអ្នកតតាំងនិងលោកយ៉ូបគឺមានទាំង (១).សត្រូវដែលជាមនុស្ស (ដូចជាមិត្តសំឡាញ់គាត់ទាំងបីនាក់) ឬ(២).គឺព្រះអម្ចាស់ជាព្រះផ្ទាល់ ក្នុងពេលខ្លះលោកយ៉ូបគឺមានទាំងការចោទប្រកាន់ប្រឆាំង ដែលបានកត់ទុកនៅមុខតុលាការស្ថានសួគ៌ និងមានវត្តមានព្រះឆ្លើយតបនិងការកាត់ទោស។

**៣១:៣៦** *នឹងស្មា* គឺជាលក្ខណៈចំណាំ ជួនកាលដូចជាពាក់នៅលើស្មាសម្រាប់ជាគ្រឿងចងចាំនៃភាពសំខាន់របស់ពួកគេ (មើល នក ២៨:១២) ។

**៣១:៣៨–៤០** ជាពាក្យសម្បត់ដែលផ្ដើមឡើងដើម្បីបំពេញផ្ទៃរឿងពីដំបូងមកក៏បង្កើតបាននូវការសង្កត់ន័យ ។ លោកយ៉ូបបានអំពាវនាវឱ្យបណ្ដាសាមកលើរូបលោកចុះបើលោកពុំបានបំពេញភាពសុចរិតជូនព្រះ (មើល ខ.១៣–១៥) ។

**៣១:៤០** *ពាក្យរបស់លោកយ៉ូបចប់តែប៉ុណ្ណោះ* លោកយ៉ូបត្អូញត្អែរ ការឈ្លោះប្រកែកចប់ហើយ ។ គឺលោកយ៉ូបគ្រាន់តែបង្ហាញដោយសង្ខេប(មើល ៤០:៣–៥ ៤២:១–៦ និងការពន្យល់) ។

**៣២:១–៣៧:២៤** គឺអ្នកឱ្យដំបូន្មានទី៤មានឈ្មោះថាលោកអេលីហ៊ូវដែលមានវ័យក្មេងជាងអ្នកឱ្យដំបូន្មានបីនាក់ដំបូង (៣២:៤,៦–៧,៩) បានឈរនៅតាមខ្សែបណ្ដោយដើម្បីជាការបង្ហាញភាពខុសគ្នានៃអាយុ និងស្ដាប់ពីការតវ៉ានៃការសន្ទនា ។ ឥឡូវគាត់និយាយខ្លួនឯងផ្ទាល់ថា ទាំងលោកយ៉ូបនិងអ្នកឱ្យដំបូន្មានដទៃទៀត គឺស្ថិតក្នុងភាពខុស ។ អ្នកនិពន្ធណែនាំសម្ដីតាមរយៈកំណាព្យទាំងបួនរបស់លោកអេលីហ៊ូវ (៣២:៥–៣៣:៣៣ ជំពូក ៣៤, ៣៥,៣៦–៣៧ ៣២:១–៤) ។

**៣២:១** *លោករាប់ខ្លួនថាជាសុចរិតហើយ* លោកទទួលថាលោកគ្មានកំហុសហើយផ្ទុយពីភាពវេទនា ការឈឺចាប់ដែលលោកបានជួបប្រទេះ ។

**៣២:២–៣** *សេចក្តីកំហឹង* សេចក្តីបញ្ជាក់របស់លោកអេលីហ៊ូវអំពីការបង្ហាញរបស់លោកយ៉ូបថា ខ្លួនគ្មានកំហុសដែលពុំមែនព្រះជាអ្នកបញ្ជាក់ តែយ៉ូបដឹងថា មិត្តរបស់គាត់អត់លទ្ធភាពទាស់ប្រឆាំងទេ ។

**៣២:២** *អេលីហ៊ូវ* មានន័យថា ទ្រង់ជាព្រះអម្ចាស់នៃខ្ញុំ ។ ការសម្ដែងរបស់អេលីហ៊ូវបង្ហាញឱ្យឃើញជាមុន នូវបន្ទូលព្រះចេញពីថ្ម (៣៨:១–៤២:៦) សាសន៍ប៊ូស គឺជាពួកកូនចៅប៊ូសនៅវាលរហោស្ថានផ្នែកខាងកើត (មើល យរ ២៥:២៣) ។

**៣២:៦,១០,១៧** *ខ្ញុំនឹងសំដែងគំនិតរបស់ខ្ញុំដែរ* អេលីហ៊ូវមានបំណងចែកចាយចំណេះដឹងដែលអាចឱ្យគាត់មានការទំនាក់ទំនងមានប្រសិទ្ធភាព (មើលការពន្យល់ ៣៦:៤)។

ច្រើន[ញ] ហេតុនោះបានជាខ្ញុំ ខ្លាចមិនហ៊ានសំដែងគំនិតខ្ញុំ
៧ខ្ញុំបាននឹកថា គប្បីឱ្យចាស់ៗនិយាយ ហើយគួរឱ្យអ្នកដែល
មានអាយុច្រើនបង្រៀនពីប្រាជ្ញា[ដ] ៨ប៉ុន្តែមនុស្សលោកសុទ្ធ
តែមានវិញ្ញាណ[ឋ]សណ្ឋិតនៅ ហើយខ្យល់ដង្ហើមនៃព្រះដ៏
មានគ្រប់ព្រះចេស្តា[ឌ]ក៏ឱ្យមានយោបល់[ឍ] ៩មិនមែនសុទ្ធតែ
ជាអ្នកសំខាន់ៗដែលមានប្រាជ្ញា[ណ] ឬជាពួកចាស់ៗ[ត]ប៉ុណ្ណោះ
ដែលយល់សេចក្តីយុត្តិធម៌នោះទេ[ថ] ១០ហេតុនោះបានជា
ខ្ញុំថា សូមស្តាប់ខ្ញុំសិន[ទ] ខ្ញុំនឹងសំដែងគំនិតរបស់ខ្ញុំដែរ[ធ]។
១១មើល ខ្ញុំបានរង់ចាំពាក្យអ្នករាល់គ្នា ខ្ញុំបានប្រុងស្តាប់
ហេតុផលទាំងប៉ុន្មានរបស់អ្នករាល់គ្នា កំពុងដែលអ្នករាល់
គ្នាស្វែងរកសេចក្តីដែលត្រូវនិយាយ ១២អើ ខ្ញុំបានប្រុង
ស្តាប់អ្នករាល់គ្នាឱ្យយល់ដែរ ហើយមើល គ្មានអ្នកណាមួយ
ក្នុងពួកអ្នករាល់គ្នាបានអធិប្បាយផ្ចាញ់យ៉ូប ឬឆ្លើយសប
នឹងសំដីលោកទេ[ន] ១៣ប៉ុន្តែកុំឱ្យថា យើងបានរកប្រាជ្ញា
ឃើញ[ប]ហើយនោះឡើយ ដ្បិតព្រះទ្រង់នឹងឈ្នះ[ផ]លោកបាន
ឯមនុស្សឈ្នះមិនបានទេ ១៤លោកមិនបានពោលពាក្យមក
ចំលើខ្ញុំទេ[ព] ហើយខ្ញុំក៏មិនឆ្លើយតបតាមពាក្យរបស់អ្នក
រាល់គ្នាដែរ ១៥ដូច្នេះ អ្នកទាំង៣នោះក៏គាំងនៅឥតមាន
ឆ្លើយទៀតឡើង គេរកផ្លូវនឹងនិយាយមិនបានផង[ភ]។
១៦តើគួរឱ្យខ្ញុំរង់ចាំទៀត ដោយព្រោះតែគេមិនពោល
ទៀត ហើយស្ងៀមនៅ ឥតឆ្លើយតទៅទៀតឬអី ១៧ទេ
ចំណែកខាងខ្ញុំ ចង់ឆ្លើយដែរ ខ្ញុំនឹងសំដែងគំនិតរបស់ខ្ញុំ[ម]
១៨ដ្បិតខ្ញុំមានពេញហើយ ដោយខសេចក្តី ឯវិញ្ញាណ[យ]ដែល

**៣២:៦** ញ យប ១៥:១០
**៣២:៧** ដ ១របា ២៩:១៥ ២របា ១០:៦
**៣២:៨** ឋ ខ.១៨ ឌ យប ២៧:៣ ឍ យប ១២:១៣ ទដ ១១៩:៣៤ យក ១:៥
**៣២:៩** ណ ១កថ ១:២៦ ត ទដ ១១៩:១០០ ថ យប ១២:១២,២០ លក ២:៤៧ ១ថន ៤:១២
**៣២:១០** ទ យប ៣៣:១,៣១,៣៣ ៣៤:២,១៦ ៣៧:២,១៤ ទដ ៣៤:១១ ធ យប ៥:២៧
**៣២:១២** ន ខ.៣
**៣២:១៣** ប យប ៤:១២ សស ៩:១១ ផ យប ១១:៥
**៣២:១៤** ព យប ២៣:៤
**៣២:១៥** ភ ខ.១
**៣២:១៧** ម យប ៥:២៧ ៣៣:៣ ៣៦:៤
**៣២:១៨** យ ខ.៨ រ កថ ៤:២០

សណ្ឋិតនៅនឹងខ្ញុំ ក៏បណ្តាលខ្ញុំផង[រ] ១៩មើល ចិត្តខ្ញុំប្រៀប
ដូចជាស្រាទំពាំងបាយជូរ ដែលឥតមានផ្លូវឱ្យខ្យល់ចេញ
ដូចជាថង់ស្បែកថ្មីដែលរៀបនឹងធ្លាយហើយ[ល] ២០ខ្ញុំនឹង
និយាយចេញ ដើម្បីឱ្យបានធូរចិត្ត ខ្ញុំនឹងបើកបបូរមាត់ឆ្លើយ
តទៅ[វ] ២១សូមកុំឱ្យខ្ញុំយល់ដល់មុខ[ស]អ្នកណា[ហ] ឬលើកមុខ
អ្នកណាដោយពាក្យបញ្ចើចឡើយ[ឡ] ២២ដ្បិតខ្ញុំមិនចេះ
បញ្ចើចបញ្ចើទេ បើយ៉ាងនោះ ព្រះដែលបង្កើតខ្ញុំ[អ] ទ្រង់នឹង
ដកយកខ្ញុំចេញទៅភ្លាម[ក]។

**៣៣** ១ដូច្នេះ លោកយ៉ូបអើយ ខ្ញុំសូមឱ្យលោកស្តាប់[ក]
សេចក្តីអធិប្បាយរបស់ខ្ញុំ ហើយផ្ទៀងត្រចៀកចំពោះអស់
ទាំងពាក្យរបស់ខ្ញុំចុះ ២មើល ខ្ញុំបានបើកមាត់ហើយអណ្តាត
ក៏បានរលាស់និយាយនៅក្នុងមាត់ខ្ញុំ ៣ពាក្យសំដីខ្ញុំនឹងសំដែង
ចេញ ជាសេចក្តីទៀងត្រង់នៃចិត្តខ្ញុំ[គ] ហើយបបូរមាត់ខ្ញុំនឹង
និយាយយ៉ាងច្បាស់ ពីសេចក្តីដែលខ្ញុំដឹង[ឃ] ៤ព្រះវិញ្ញាណ[ង]
នៃព្រះបានបង្កើតខ្ញុំ[ច] ហើយខ្យល់ដង្ហើមនៃព្រះដ៏មានគ្រប់
ព្រះចេស្តា[ឆ]បានប្រោសឱ្យខ្ញុំមានជីវិត[ជ] ៥បើលោកអាចនឹង
ឆ្លើយបាន[ឈ] នោះសូមឆ្លើយមកចុះ សូមរៀប[ញ]លំដាប់

១កថ ៩:១៦ ២កថ ៥:១៤ **៣២:១៩** ល យរ ២០:៩ អម ៣:៨ មថ ៩:១៧ **៣២:២០** វ យប ៤:២ យរ ៦:១១ **៣២:២១** ស លវ ១៩:១៥ ២របា ១៩:៧ យប ១៣:១០ ហ មថ ២២:១៦ ឡ សភ ២៩:៥ ១ថន ២:៥ **៣២:២២** អ យប ៤:១៧ ៩:៩ ក ទដ ១២:២–៤ **៣៣:១** ក យប ៣២:១០ ខ យប ៦:២៨ ១៣:៦ **៣៣:៣** គ ១ពវ ៣:៦ ទដ ៧:១០ ១១:២ ៦៤:១០ ឃ យប ៦:២៨ **៣៣:៤** ង លប ១:២ ច យប ១០:៣ ឆ យប ២៧:៣ ជ ជន ១៦:២២ យប ១២:១០ **៣៣:៥** ឈ ខ.៣២ ញ យប ១៣:១៨

**៣២:៦** *នៅក្មេង . . . ខ្លាចមិនហ៊ានសំដែង* យរ ១:៦–៨ ១ពត ៤:១២ ២ពត ១:៧ និងការពន្យល់ ។
**៣២:៨** *ខ្យល់ដង្ហើមនៃព្រះដ៏មានគ្រប់ព្រះចេស្តា* មើល ៣៣:៤ ។
**៣២:១៤** *លោកមិនបានពោលពាក្យមកចំលើខ្ញុំទេ* លោកអេលីហ៊ូវគិតថា ការដែលសំខាន់គេពុំបានយល់ឡើយ តែគេត្រូវលើខ្យល់ដកដង្ហើមនៃព្រះដ៏មានគ្រប់ព្រះចេស្តាវិញ (មើលការពន្យល់ ខ.៨) ដែលនាំឱ្យអាចយល់បាន ហើយផ្តល់នូវចំលើយត្រឹមត្រូវ ។
**៣២:១៥–២២** លោកអេលីហ៊ូវចែកចាយខ្លាំងៗទៅនឹងខ្លួនគាត់ តែវាក៏ជាប្រយោជន៍មួយសម្រាប់អ្នកចង់ស្តាប់ដែរ ។
**៣២:១៥–១៦** *ឥតមានឆ្លើយទៀតឬអី . . . ហើយស្ងៀមនៅ ឥតឆ្លើយតទៅទៀត* មើល ខ.៥ ។ គឺជាការបរាជ័យចំពោះខួបសន្ទនាទីបី ពាក្យចុងក្រោយរបស់ប៊ីលដាឌនាំឱ្យសូផារនិយាយពុំបាន (មើលការពន្យល់ ២២:១–២៦:១៤) ។
**៣២:១៨** *ដ្បិតខ្ញុំមានពេញហើយ ដោយខសេចក្តី* ការអធិប្បាយរបស់លោកអេលីហ៊ូវបន្តដោយឥតចុះចាញ់ ដោយឥតឈប់ឈរពេញមួយជំពូកទី ៣៧ ។ គាត់បានចែកចាយត្រង់ៗបង្កើតជាបញ្ហាឡើងដល់លោកយ៉ូប ។ ក្នុងពេលតែមួយគាត់ក៏ពុំឈប់ចោទប្រកាន់លោកយ៉ូបពីជីវិតពីមុននោះទេ ប៉ុន្តែជារឿយៗការនោះត្រូវបានបង្ខំដោយលោកយ៉ូបវិញ ។ នេះប្រហែលជាហេតុផលដែលព្រះធ្វើការបញ្ចប់និងកាត់ទោសអេលីហ៊ូវតែមួយនោះទេ ក៏មានទាំងមិត្តបីនាក់ទៀត (មើល ៤២:៧–៩ និងការពន្យល់) ។
**៣២:១៩** *ដូចជាថង់ស្បែកថ្មីដែលរៀបនឹងធ្លាយហើយ* គឺជាថង់ស្បែកចាស់ៗដែលត្រូវធ្លាយវិញ (មើល មថ ៩:១៧ និងការពន្យល់) គឺមិនមែនថង់ថ្មីនោះទេ ។ លោកអេលីហ៊ូវក៏ចង់បង្ហាញមតិ ។
**៣៣:១–៣៣** លោកអេលីហ៊ូវងាកបែរទៅរកលោកយ៉ូប ហើយនិយាយចំទៅរកគាត់ ។ គឺខុសពីមិត្តទាំងបីរបស់លោកយ៉ូប ហើយគាត់បង្ហាញពីលោកយ៉ូបដោយប្រើឈ្មោះចំៗតែម្តង (ខ.១,៣១ ៣៧:១៤) ។
**៣៣:១** *ផ្ទៀងត្រចៀកចំពោះអស់ទាំងពាក្យរបស់ខ្ញុំចុះ* គឺគាត់កំពុងតែផ្តោតសំខាន់ទៅលើប្រាជ្ញាដែលជាប្រភពដំបូន្មាន (មើល ៣១,៣៣) ។
**៣៣:៤** *ព្រះវិញ្ញាណនៃព្រះបានបង្កើតខ្ញុំ* លប ១:២ និងការពន្យល់ ។ *ខ្យល់ដង្ហើមនៃព្រះដ៏មានគ្រប់ព្រះចេស្តា* មើល ៣២:៨ ។ *ឱ្យខ្ញុំមានជីវិត* មើល ២៧:៣ មើល លប២:៧ និងការពន្យល់ ។
**៣៣:៥** *សូមឆ្លើយមកចុះ* គាត់បើកហើយនិងបិទការអធិប្បាយរបស់គាត់ (មើល ខ.៣២) ដែលមានការអង្វរករ ។ *បើលោកអាចនិងឆ្លើយបាន* គាត់បង្ហាញឥរិយាបថដ៏រំភើប ។

សេចក្ដីនៅមុខខ្ញុំ រួចឈរឡើង[ដ] ៦មើល លោកហើយនិង
ខ្ញុំក៏ដូចគ្នានៅចំពោះព្រះ[ឋ] ខ្ញុំបានកើតពីដីឥដ្ឋមកដែរ[ឌ]
៧មើល ខ្ញុំឥតមានសេចក្ដីស្ញែងខ្លាចណា និងនាំឱ្យលោកភ័យ
ទេ ហើយអំណាចខ្ញុំក៏នឹងមិនសង្កត់លើលោកជាធ្ងន់ដែរ[ឍ]។
៨ប៉ុន្តែលោកបាននិយាយឱ្យត្រចៀកខ្ញុំឮ ហើយខ្ញុំបានឮ
សំឡេងនៃពាក្យលោកថា ៩លោកស្អាត[ណ] ឥតមានមន្ទិល
ឡើយ[ត] លោកគ្មានទោស[ថ] ក៏គ្មានសេចក្ដីទុច្ចរិតណានៅក្នុង
ខ្លួនដែរ ១០មើល ព្រះទ្រង់រកហេតុទាស់នឹងលោកហើយ
ក៏រាប់លោកទុកដូចជាខ្មាំងសត្រូវដល់ទ្រង់[ទ] ១១ទ្រង់បានដាក់
ជើងលោកភ្ជាប់ដោយខ្នោះ[ធ] ហើយក៏ចំណាំមើល អស់ទាំង
ផ្លូវរបស់លោក[ន] ១២ដូច្នេះ ខ្ញុំនឹងឆ្លើយដល់លោកថា ក្នុង
សេចក្ដីនេះលោកមិនសុចរិតទេ ដ្បិតព្រះទ្រង់ធំជាងមនុស្ស[ប]
១៣ហេតុអ្វីបានជាលោកតតាំងនឹងទ្រង់[ផ] ដ្បិតទ្រង់មិនបាច់
នឹងរៀបរាប់ប្រាប់ ពីការណាមួយរបស់ទ្រង់ទេ[ព] ១៤តែព្រះ
ទ្រង់ក៏មានបន្ទូល[ភ]មកម្ដង២ដងផង[ម] ឥតមានអ្នកណាស្ញែង
រកន័យសេចក្ដីទេ[យ] ១៥គឺក្នុងពេលយល់សប្តិ[រ] ឬក្នុងការជាក់
ស្តែង[ល]នៅពេលយប់[វ] ក្នុងកាលដែលមនុស្សដេកលក់ស៊ប់[ស]
នៅដំណេកហើយ ១៦នៅវេលានោះទ្រង់បើក[ហ]ត្រចៀក
មនុស្ស ហើយក៏បោះត្រា[ឡ]សេចក្ដីដែលទ្រង់ប្រដៅគេ[អ]
១៧ដើម្បីនឹងទាញមនុស្សចេញពីការដែលគេគិតធ្វើ ហើយ
រាំងរាគេពីសេចក្ដីអំនួត[ក] ១៨ទ្រង់ឃាំងព្រលឹងគេឱ្យរួចពី
ជង្ហុក[ខ] ហើយជីវិតគេឱ្យរួចពីការវិនាសដោយដាវ[គ]។
១៩គេត្រូវវាយផ្ចាល់[ឃ] ដោយឈឺចាប់ដេកនៅដំណេក[ង]
ហើយអស់ទាំងឆ្អឹងគេក៏ឈឺដែរ[ច] ២០ដល់ម៉្លេះបានជាជីវិត
គេធុំអាហារ[ឆ] ហើយព្រលឹងគេក៏ខ្ពើមចំណី[ជ] ២១សាច់គេក៏
ស្គាំងស្គមទៅ ហើយឆ្អឹងគេ[ឈ]ដែលពីដើមមើលមិនឃើញ
នោះក៏លេចឡើងរគាម[ញ] ២២អើ ព្រលឹងគេចូលទៅជិត
រណ្ដៅស្លាប់[ដ] ហើយជីវិតគេក៏ជិតដល់មេបំផ្លាញហើយ[ឋ]។

**៣៣:៥** ដ យប ៣១:១៤ **៣៣:៦** ឋ កច ១៤:១៥ យក ៥:១៧ ឌ យប ៤:១៩ **៣៣:៧** ឍ យប ៩:៣៤ ២កថ ២:៤ **៣៣:៩** ណ យប ១០:៧ ត យប ៩:៣០ ១៣:២៣ ថ យប ២:៩ **៣៣:១០** ទ យប ១៣:២៤ **៣៣:១១** ធ យប ១៣:២៧ ន យប ១៤:១៦ សភ ៣:៦ អស ៣០:២១ **៣៣:១២** ប យប ៥:៩ ទដ ៨:៤ ៥០:២១ សស ៧:២០ អស ៥៥:៨-៩ **៣៣:១៣** ផ យប ៤០:២ អស ៤៥:៩ ព យប ១១:៨

**៣៣:១៤** ភ ទដ ៦២:១១ ម ខ.២៩ យ យប ៤:១២ **៣៣:១៥** រ លប ២០:៣ យប ៤:១៣ មថ ២៧:១៩ ល កច ១៦:៩ វ លប ១៥:១ ដយ ២:១៩ ស លប ២:២១ **៣៣:១៦** ហ យប ៣៦:១០,១៥ ឡ ទដ ៨៨:១៥-១៦ អ យប ៦:៤ **៣៣:១៧** ក យប ២០:៦ **៣៣:១៨** ខ ខ.២២,២៤,២៨,៣០ ទដ ២៨:១ ៣០:៩ ៦៩:១៥ ៨៨:៦ ១០៣:៤ សភ ១:១២ អស ១៤:១៥ ៣៨:១៧ យហ ២:៦ សក ៩:១១ គ យប ១៥:២២ មថ ២៦:៥២ **៣៣:១៩** ឃ យប ៥:១៧ ង លប ១៧:១ ចទ ៨:៥ ២កថ ១២:៧-១០ យក ១:៣ ច យប ១៦:១៦ ទដ ៦:២ ៣៨:៣ អស ៣៨:១៣ **៣៣:២០** ឆ ទដ ១០២:៤ ១០៧:១៨ ជ យប ៣:២៤ ៦:៦ **៣៣:២១** ឈ យប ២:៥ ញ យប ១៦:៨ **៣៣:២២** ដ ខ.១៨ ឋ យប ៣៨:១៧ ទដ ៩:១៣ ៨៨:៣ ១០៧:១៨ ១១៦:៣

**៣៣:៦** *ខ្ញុំបានកើតពីដីឥដ្ឋមកដែរ* មើលការពន្យល់ ៤:១៩ ។

**៣៣:៧** *មិនសង្កត់លើលោកជាធ្ងន់ដែរ* គឺជាវោហាស័ព្ទឃើញជាញឹកញាប់គឺសម្រាប់កិច្ចការព្រះ (មើល ២៣:២ និងការពន្យល់) ក៏មើលការពន្យល់ ១សយ ៥:៦ ។

**៣៣:៨** *ប៉ុន្តែលោកបាននិយាយ* ជាវិធីសាស្ត្ររបស់លោកអេលីហ៊ូវ ដើម្បីសម្គាល់លោកយ៉ូប (ខ.៩-១១ ៣៤:៥-៦,៩ ៣៥:២-៣) ហើយក៏ដើម្បីបង្ហាញពីកំហុស ។ ការសម្គាល់នោះមិនមែនឥតល្អៀងនោះទេ ។

**៣៣:១១** លោកអេលីហ៊ូវស្រង់សំដីរបស់លោកយ៉ូបស្ទើរតែគ្មានល្អៀង ឬខុសឡើយ ។

**៣៣:១២** *លោកមិនសុចរិតទេ* លោកអេលីហ៊ូវគិតថា លោកយ៉ូបត្រូវតែកែខ្លួនឱ្យបានល្អ ។ ការពិតការយល់ដឹងរបស់លោកយ៉ូបពីព្រះអម្ចាស់ គឺទុកជាសត្រូវរបស់គាត់ទៅវិញ (មើល ខ.១០ ១៣:២៤ ១៩:១១) គឺយល់ខុស ។ តែលោកអេលីហ៊ូវជារឿយៗ ក៏គិតតាមតែការប្រកាសរបស់លោកយ៉ូបដែរ ដើម្បីញែកជាបរិសុទ្ធ (មើល ខ.៩) តែលោកយ៉ូបក៏មិនដែលប្រកាសខ្លួនថាបរិសុទ្ធរហូតដែរ ហើយគ្មានបាបរហូតនោះទេ ទោះសម្ដីខ្លះយល់ពីលោកអេលីផាស (មើល ១៥:១៤-១៦) ។ លោកយ៉ូបទទួលស្គាល់ថាមានបាប (៧:២១ ១៣:២៦) ប៉ុន្តែមិនបានប្រកាសថាវាជាអំពើបាបហួសហេតុ ឬធ្ងន់ធ្ងរពេកដែរ ដែលនាំគាត់ទោសនោះទេ ។ គាត់ក៏រអ៊ូរពីភាពស្ងាត់ស្ងៀមរបស់ព្រះដែលមិនឆ្លើយតបមកគាត់ (មើល ខ.១៣) ហើយក៏ប្រព្រឹត្តបំពានចំពោះលោកអេលីហ៊ូវ តែគាត់ទម្លាក់កំហុសទៅលើលោកយ៉ូបពីភាពគ្របបាំងការពិតដោយថា ព្រះមិនដែលមានបន្ទូលមកមនុស្សក្នុងស្ថានភាពដូចលោកយ៉ូប គឺព្រះអម្ចាស់បានបង្ហាញភាពស្ងៀមស្ងាត់ក្នុងពេលលោកយ៉ូបមានបទពិសោធន៍ដ៏ឈឺចាប់ក្នុងជីវិត ។

**៣៣:១៥** *គឺក្នុងពេលយល់សប្តិ . . . ស៊ប់នៅដំណេកហើយ* គឺលោកអេលីហ៊ូវបាននិយាយពីលោកអេលីផាស (មើល ៤:១៣) ។

**៣៣:១៨** *ពីជង្ហុក* គឺប្រៀបទៅនឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ (មើល ខ.២២,២៤,២៨,៣០) ដូចជាឃើញជាញឹកញាប់នៅក្នុងគម្ពីរទំនុកដំកើង ។ វិនាសដោយដាវ មើល ៣៦:១២ ។ ការអានសង្កេតក្នុងខគម្ពីរទាំងពីរគឺសំដៅទៅលើការប្រៀបធៀបដូចជាផ្លូវទឹករវាងទឹកដីសម្រាប់រស់នៅនិងនគរអាណាចក្រនៃសេចក្ដីស្លាប់ ។ បើជាភាសាហេព្រើរក្នុងពាក្យថា "ទន្លេ"នៅទីនោះគឺជា សេឡា (ពីឫសគល់អត្ថន័យនៃពាក្យនេះមានន័យថា "បញ្ជូនផ្ញើរ" ហើយពេលខ្លះមានន័យថា "ប្រឡាយផ្លូវទឹក" (មើល នហ ៣:១៥ និងការពន្យល់) គឺជាបំពង់សម្រាប់បញ្ជូនទឹកហូរ "បញ្ជូន" (មើល យហ ៩:៧ និង ការពន្យល់) តាមរយៈ ឬពីប្រភពទឹកមក ។ "ទន្លេ" ពោលគឺចង់បញ្ជាក់អត្ថន័យរវាងពិភពលោកនេះទៅនិងភពផ្សេងទៀត ។

**៣៣:១៩** *គេត្រូវវាយផ្ចាល ដោយឈឺចាប់ដេកនៅដំណេក* គឺជាសុបិន្ត ឬការស្រមៃ (មើល ខ.១៥) មិនមែនជាមធ្យោបាយមួយដែលទ្រង់មានបន្ទូលមកនោះទេ គឺទ្រង់បង្ហាញតាមវិធីផ្សេងៗ ។ ទ្រង់អាចមានបន្ទូលមកកាន់យើងទាំងអស់គ្នាតាមដែលវិធីសាស្ត្រមួយដែលយើងពុំមានវិញ្ញាណដឹងគ្រប់គ្រាន់ (មើល ខ.១៤) ។ លោកអេលីហ៊ូវបានបញ្ជាក់យ៉ាងពិតត្រង់ថា ព្រះអម្ចាស់មានបន្ទូលមកកាន់មនុស្សក្នុងគោលបំពងបង្វែពួកមនុស្សឱ្យងាកចេញពីអំពើបាប ។ តែទ្រង់មើលរំលងលោកយ៉ូប ដោយចង់មានចំណែកខ្លះ និងលោកយ៉ូបដើម្បីរកឱ្យឃើញពីការចោទប្រកាន់ពីសំណាក់មនុស្សដែលថា លោកយ៉ូបជាមនុស្សមានបាប (មើល ១៣:២២-២៣) ។

២៣ បើសិនជាមានទេវតា១នៅនឹងគេ ដើម្បីថ្លែងការ[ឱ]
គឺ១ក្នុង១ពាន់ សំរាប់នឹងបង្ហាញឱ្យមនុស្សស្គាល់ផ្លូវដែល
ត្រូវប្រព្រឹត្ត[ឍ] ២៤ នោះទ្រង់ប្រោសមេត្តាដល់គេ ដោយបន្ទូល
ថា ចូរជួយឱ្យរួច កុំឱ្យធ្លាក់ចុះក្នុងរណ្តៅឡើយ[ណ] ដ្បិតអញ
រកបានថ្លៃលោះគេហើយ[ត] ២៥ យ៉ាងនោះសាច់គេនឹងបាន
ស្រស់ជាង[ថ]សាច់របស់កូនក្មេង ក៏នឹងប្រែទៅដូចកាលនៅ
ក្មេងវិញ[ទ] ២៦ គេនឹងអធិស្ឋានដល់ព្រះ ហើយទ្រង់នឹងប្រោស
ដល់គេ[ធ] ឱ្យគេបានឃើញព្រះភក្ត្រទ្រង់ដោយសេចក្តីរីក
រាយ[ន] ហើយទ្រង់នឹងប្រគល់សេចក្តីសុចរិតដល់គេវិញ[ប]
២៧ នោះគេនឹងច្រៀងនៅមុខមនុស្ស ដោយពាក្យថា ខ្ញុំបាន
ធ្វើបាប[ផ] ហើយរំលងនឹងសេចក្តីត្រឹមត្រូវ[ព] ជាការដែលឥត
មានប្រយោជន៍ដល់ខ្ញុំឡើយ[ភ] ២៨ ប៉ុន្តែទ្រង់បានលោះ[ម]
ព្រលឹងខ្ញុំមិនឱ្យធ្លាក់ទៅក្នុងរណ្តៅទេ[យ] ជីវិតខ្ញុំក៏នឹងឃើញ
ពន្លឺដែរ[រ] ។
២៩ មើល បណ្តាការទាំងនេះ គឺព្រះទ្រង់ធ្វើ ទ្រង់ធ្វើ
ដល់មនុស្ស[ល]២ដង ហើយ៣ដងផង[វ] ៣០ ដើម្បីនឹងទាញ[ស]
ព្រលឹងគេពីរណ្តៅមកវិញ[ហ] ប្រយោជន៍ឱ្យគេបានភ្លឺ[ឡ]ដោយ
ពន្លឺនៃមនុស្សរស់[អ] ៣១ ឱយ៉ូបអើយ សូមផ្ទៀងត្រចៀកស្តាប់[ក]
ខ្ញុំសិន[ខ] សូមឱ្យលោកស្ងៀមនៅ[គ] នោះខ្ញុំនឹងនិយាយ ៣២ បើ
លោកមានអ្វីនឹងពោល សូមឆ្លើយតបមកចុះ[ឃ] សូមពោល
ចេញមក ដ្បិតខ្ញុំចង់កែឱ្យលោកបានសុចរិតវិញ[ង] ៣៣ បើ
គ្មានទេ នោះសូមស្តាប់ខ្ញុំចុះ[ច] សូមលោកស្ងៀមនៅ[ឆ]ខ្ញុំនឹង
បង្រៀនឱ្យលោកមានប្រាជ្ញា[ជ] ។

**៣៤** ១ អេលីហ៊ូវក៏ពោលឡើងទៀតថា ២ ឱមនុស្សប្រាជ្ញ
រាល់គ្នាអើយ សូមស្តាប់ពាក្យខ្ញុំ[ក] ឱពួកអ្នកដែលមាន
យោបល់អើយ សូមផ្ទៀងត្រចៀកចំពោះខ្ញុំចុះ ៣ ដ្បិត ត្រ
ចៀកតែងតែល្បងលពាក្យសំដី ដូចជាមាត់តែងភ្លក់រសជាតិ
អាហារដែរ[ខ] ៤ សូមឱ្យយើងរាល់គ្នារើសយកសេចក្តីណា
ដែលត្រឹមត្រូវ[គ]សំរាប់ពួកយើង ហើយឱ្យយើងបានស្គាល់
សេចក្តីដែលល្អនៅក្នុងចំណោមយើង[ឃ] ៥ ដ្បិត លោកយ៉ូប
បានពោលថា លោកសុចរិត[ង] ឯព្រះទ្រង់បានដកយកសេច
ក្តីយុត្តិធម៌ចេញពីលោកហើយ[ច] ៦ ទោះបើលោកសុចរិត

**៣៣:២៣** ឱ កទ ៣:១៩ ហព ៨:៦ ៩:១៥ ឍ យប ៣៦:៩–១០ មីក ៦:៨ **៣៣:២៤** ណ ខ.១៨ ត យប ៦:២២ **៣៣:២៥** ថ ទដ ១០៣:៥ ទ ២ពវ ៥:១៤ **៣៣:២៦** ធ យប ៥:១៥ សភ ៨:៣៥ ១២:២ ១៨:២២ លក ២:៥២ ន អរ ៣:១៣ យប ២២:២៦ ប ទដ ១៣:៥ ៥០:១៥ ៥១:១២ ១យហ ១:៩ **៣៣:២៧** ផ ជន ២២:៣៤ ព លក ១៥:២១ ភ អរ ៩:១៣ ទដ ២២:២៧ ៥១:១៣ រម ៦:២១ យក ២:១៣ **៣៣:២៨** ម នក ១៥:១៣ ទដ ៣៤:២២ ១០៧:២០ យ ខ.១៨ យប ១៧:១៦ រ យប ២២:២៨ **៣៣:២៩** ល ទដ ១៣៩:១៦ សភ ១៦:៩ ២០:២៤ យរ ១០:២៣ ១កថ ១២:៦ អភ ១:១១ ភល ២:១៣ វ ខ.១៤ **៣៣:៣០** ស យក ៥:១៩ ហ ខ.១៨ ឡ អស ៦០:១ អភ ៥:១៤ អ ទដ ៤៩:១៩ ៥៦:១៣ ១១៦:៩ អស ៥៣:១១ **៣៣:៣១** ក យរ ២៣:១៨ ខ យប ៣២:១០ គ ខ.៣៣ **៣៣:៣២** ឃ ខ.៥ ង យប ៦:២៩ ៣៥:២ **៣៣:៣៣** ច យប ៣២:១០ ឆ ខ.៣១ ជ យប ៦:២៤ សភ ១០:៨ ១០:១៩ **៣៤:២** ក យប ៣២:១០ **៣៤:៣** ខ យប ១២:១១ **៣៤:៤** គ យប ១២:១២ ហព ៥:១៤ ឃ ១ថន ៥:២១ **៣៤:៥** ង យប ១០:៧ ច យប ៦:២៩

**៣៣:២៣–២៨** គឺបានបង្ហាញបញ្ជាក់ពីភាពសំខាន់នៃទស្សនៈក្នុងការតែងលំអរនៃការឈឺចាប់ ហើយចំណុចសង្ខេបគឺតាមរយៈលោកអេលីផាស (មើល ៥:១៧ មើលការពន្យល់ ៥:១៧–២៦ ផងដែរ) អេលីហ៊ូវធ្វើឱ្យមានការប្រែប្រួលតាមរយៈពួកទេវតា (មើល ៥:១) គឺគាត់បាននិយាយបន្តសូមការអនុញ្ញាត្តិឱ្យព្រះឆ្លើយតបដោយព្រះគុណរបស់ព្រះ ដើម្បីសុំការលើកលែង ទោសពីទ្រង់ ។ ខណៈដែលមានវត្តមានការលន់តួបាប (ខ.២៧–២៨) ប៉ុន្តែ អេលីហ៊ូវនៅតែមិនបានទទួលស្គាល់និស្ស័យពិត ដែលជាទំនាក់ទំនងរបស់លោកយ៉ូប និងព្រះអម្ចាស់ដែលទទួលស្គាល់ថាជាអ្នកឱ្យដំបូន្មានពីព្រះ (ជំពូក ១–២) ។

**៣៣:២៤** *កុំឱ្យធ្លាក់ចុះក្នុងរណ្តៅឡើយ* មើល អស ៣៨:១៧ និងការពន្យល់ ។ *ថ្លៃលោះ* មើល ទដ ៤៩:៧–៩ និងការពន្យល់ ។

**៣៣:២៥** *នឹងបានស្រស់ជាសាច់របស់កូនក្មេង ក៏នឹងប្រែទៅដូចកាលនៅក្មេងវិញ* គឺឃ្លានេះមានលក្ខណៈស្រដៀងគ្នាដែលបានប្រើក្នុង ២ពវ ៥:១៤ គឺបង្ហាញពីការប្រោសលោះឱ្យជាពីជម្ងឺឃ្លង់ ។

**៣៣:២៦** *ព្រះភក្ត្រទ្រង់* មើលការពន្យល់ លប ១៦:១៣ ។

**៣៣:២៩** *មនុស្ស២ដង ហើយ៣ដងផង* មើលការពន្យល់ ៥:១៩ ។

**៣៣:៣០** *ទាញព្រលឹងគេពីរណ្តៅមកវិញ* លោកអេលីហ៊ូវបង្រៀនថា ភាពតឹងរឹងបង្ហាញឱ្យឃើញពីព្រះ ដើម្បីកែតម្រង់មនុស្សឱ្យមានសេចក្តីស្រឡាញ់ជាមុន គឺស្រឡាញ់ដោយពិតប្រាកដ តាំងពីគេពុំបានដែលទទួលទណ្ឌកម្ម (មើល ខ.២៧) ។ *ពន្លឺនៃមនុស្សរស់* គឺសុខខាងឯព្រះវិញ្ញាណ (មើល ៤៩:១៩) ការមានព្រះជន្មរស់ឡើងវិញ (មើលការពន្យល់ អស ៥៣:១១) ។

**៣៣:៣២** *ដ្បិតខ្ញុំចង់កែឱ្យលោកបានសុចរិតវិញ* ការងារនេះនិងកើតឡើងគឺលោកអេលីហ៊ូវទទូចចង់បាន បើលោកយ៉ូបលន់តួបាប ។

**៣៤:១–៣៧** ផ្នែកទី២របស់ការអធិប្បាយបួនលើករបស់លោកអេលីហ៊ូវ (មើលការពន្យល់ ៣២:១–៣៧:២៤) ដែលជាបីផ្នែក : (១).ថ្លែងប្រាប់ទៅក្រុមអ្នកប្រាជ្ញ (ខ.២–១៥) ភាពមានការសង្ស័យមានដូចជាមិត្តទាំងបីនាក់ (២).ក៏បង្ហាញពី លោកយ៉ូប (ខ.១៦–៣៣) (៣).ក៏បង្ហាញពីខ្លួនគាត់ផ្ទាល់ (ខ.៣៤–៣៧) ដូចជាក្នុង ៣២:១៥–២២ (មើលការពន្យល់ទីនោះ) ។

**៣៤:២,១០** *សូមស្តាប់ពាក្យខ្ញុំ* ទោះបីជាវាអាចមានលទ្ធភាពក៏ដោយ លោកអេលីផាសបាននិយាយយ៉ាងច្បាស់ដោយប្រាជ្ញាផ្ទាល់របស់គាត់ក៏ដោយក៏វាទំនងដូចជាចោទខ្លួនគាត់ថាជាអ្នកនាំសារពីព្រះ ជាពិសេសក្នុងពន្លឺរបស់អត្តចរិតបន្ទាបខ្លួនរបស់គាត់ ខ.៤ ។

**៣៤:២** *ឱមនុស្សប្រាជ្ញរាល់គ្នាអើយ* គឺនិយាយចំពោះមនុស្សទាំងឡាយដែលយល់ដឹង (ខ.១០,៣៤) ។

**៣៤:៣** លោកអេលីហ៊ូវបានប្រកាសផ្សព្វផ្សាយពាក្យសម្តីរបស់លោកយ៉ូប (មើល១២:១១ និងការពន្យល់) ។

**៣៤:៥,៩** *ដ្បិតលោកយ៉ូបបានពោលថា . . . ដ្បិតលោកពោលថា* លោកអេលីហ៊ូវបង្ហាញសារជាថ្មីពីលោកយ៉ូប ហើយបន្តនិយាយការពារពីការកាត់ទោសរបស់ព្រះចំពោះកំហុសរបស់គាត់ តាមការនិយាយបែបទេវសាស្ត្រ (៩:១៤–២៤ ១៦:១១–១៧ ១៩:៧ ២១:១៧–១៨) ។ ខ.៥ គឺច្បាស់ (ធៀបនឹង

គង់តែបានរាប់ជាអ្នកកំភូតវិញ[ឆ] របួសរបស់លោក មើល
មិនជាទេ[ជ] ទោះបើលោកឥតទោសក៏ដោយ[ឈ] ៧តើមានអ្នក
ឯណាដូចលោកយ៉ូបនេះ ដែលលោកផឹកសេចក្តីឡកឡឺយ
ដូចជាផឹកទឹក[ញ] ៨លោកសេពគប់នឹងពួកអ្នកដែលប្រព្រឹត្ត
ការទុច្ចរិត ក៏ដើរជាមួយនឹងមនុស្សអាក្រក់[ដ] ៩ដ្បិតលោក
ពោលថា ដែលមនុស្សបានពេញចិត្តនឹងព្រះ នោះគ្មាន
ប្រយោជន៍សោះ[ឋ]។
១០ដូច្នេះ ឱមនុស្សមានយោបល់អើយ[ឌ] សូមស្តាប់ខ្ញុំចុះ[ឍ]
កុំឱ្យយើងថាព្រះទ្រង់ធ្វើអាក្រក់[ណ] ឬថាព្រះដ៏មានគ្រប់ព្រះ
ចេស្តា ទ្រង់ប្រព្រឹត្តសេចក្តីទុច្ចរិតនោះឡើយ[ត] ១១ដ្បិតទ្រង់
នឹងសងដល់មនុស្សតាមការដែលគេធ្វើ[ថ] ហើយនឹងឱ្យគ្រប់
គ្នាបានទទួលតាមផ្លូវរបស់ខ្លួន[ទ] ១២អើ ពិតប្រាកដជាព្រះ
ទ្រង់មិនដែលប្រព្រឹត្តអាក្រក់ឡើយ[ធ] ព្រះដ៏មានគ្រប់ព្រះ
ចេស្តាទ្រង់នឹងមិនបង្វែរសេចក្តីយុត្តិធម៌ដែរ[ន] ១៣តើអ្នកណា
បានដំរូវ[ប]ឱ្យទ្រង់គ្រប់គ្រងផែនដី ឬផ្ទុកលោកីយទាំងមូល
ទៅលើទ្រង់[ផ] ១៤បើទ្រង់ផ្ចង់ព្រះហឫទ័យចំពោះតែព្រះអង្គ
ទ្រង់ ហើយប្រមូលវិញ្ញាណ[ព] និងខ្យល់ដង្ហើមទ្រង់[ភ] ត្រឡប់
ទៅវិញ ១៥នោះគ្រប់ទាំងសាច់នឹងត្រូវវិនាសទៅ[ម] ទាំងអស់
ហើយមនុស្សនឹងត្រូវត្រឡប់ទៅជាធូលីដីវិញ[យ]។
១៦ឥឡូវនេះ បើមានយោបល់ពិត[រ] នោះសូមស្តាប់
សេចក្តីនេះទៀត សូមផ្ទៀងត្រចៀកចំពោះសំឡេងនៃពាក្យ
របស់ខ្ញុំចុះ[ល] ១៧ឯអ្នកណាដែលស្អប់សេចក្តីសុចរិត តើនឹង
គ្រប់គ្រងបានឬ[វ] តើអ្នកហ៊ានថា ព្រះដ៏សុចរិតជាទីបំផុតទ្រង់
មានទោសឬ[ស] ១៨ឯអ្នកណាដែលទូលដល់ស្តេចថា ទ្រង់ជា
មនុស្សចោលម្សៀត ឬចំពោះពួកត្រកូល[ហ]ខ្ពស់ថា លោក
រាល់គ្នាជាមនុស្សអាក្រក់[ឡ] ១៩អ្នកណាដែលមិនកោតខ្លាច[អ]
ដល់ពួកអ្នកជាប្រធាន ឬមិនយល់ដល់ពួកអ្នកមានជាជាង
អ្នកក្រ[ក] ដោយព្រោះគេសុទ្ធតែជាការនៃព្រះហស្តទ្រង់ធ្វើ
ទាំងអស់[ខ] ២០អ្នកនោះនឹងត្រូវស្លាប់ទៅក្នុង១រំពេចភ្លាមនៅ
កណ្តាលអធ្រាត្រ[គ] ពួកជននឹងរន្ធត់ ហើយបាត់ទៅ ឯមនុស្ស
សំខាន់ៗក៏ត្រូវដកចេញទៅ ដោយឥតមានដៃអ្នកណាធ្វើ
ដែរ[ឃ]។
២១រីឯព្រះនេត្រទ្រង់ បានទតមើលគ្រប់ទាំងផ្លូវរបស់
មនុស្ស[ង] ក៏ឃើញអស់ទាំងដំណើរដែលគេដើរដែរ[ច]
២២គ្មានទីងងឹត[ឆ] ឬម្លប់យ៉ាងក្រាស់ឯណា[ជ] ដែលពួកអ្នក
ប្រព្រឹត្តការទុច្ចរិតនឹងពួនខ្លួនបានទេ[ឈ] ២៣ដ្បិត ព្រះមិនចាំ

**៣៤:៦** ឆ យប ៦:២៨ ជ យប ៦:៤ ១០:៣ យរ ១០:១៩ ឈ យប ៩:២១ **៣៤:៧** ញ យប ៩:២១ ១៥:១៦ **៣៤:៨** ដ យប ២២:១៥ **៣៤:៩** ឋ យប ៩:២៩–៣១ ២១:១៥ **៣៤:១០** ឌ ខ.១៦ យប ១២:១២ ឍ យប ៣២:១០ ណ លប ១៨:២៥ ត ខ.១២ ចទ ៣២:៤ យប ៨:៣ ៣៦:២៣ ទដ ៩២:១៥ រម ៣:៥ ៩:១៤ **៣៤:១១** ថ យប ២១:៣១ មថ ១៦:២៧ ទ យរ ១៧:១០ ៣២:១៩ អគ ៣៣:២០ **៣៤:១២** ធ ខ.១០ ទត ១:២ ហព ៦:១៨ ន យប ៨:៣ ទដ ៩:១៦ កល ៣:២៥ ២ថន ១:៦ **៣៤:១៣** ប ហព ១:២ ផ យប ៣៦:២៣ ៣៨:៤,៦ អស ៤០:១៤ **៣៤:១៤** ព លប ៦:៣ ភ ជន ១៦:២២ យប ២៧:៣ **៣៤:១៥** ម លប ៦:១៣ បទ ៣:២២ យ លប ២:៧ យប ៧:២១ ៩:២២ ទដ ៩០:១០ **៣៤:១៦** រ ខ.១០ ល យប ៣២:១០ **៣៤:១៧** វ ខ.៣០ ២សយ ២៣:៣–៤ សភ ២០:៨,២៦ ២៤:២៣–២៥ ២៨:២៨ ស ខ.២៩ យប ១០:៧ ៤០:៨ រម ៣:៥–៦ **៣៤:១៨** ហ យប ១២:១៨ ឡ នក ២២:២៨ អស ៤០:២៤ **៣៤:១៩** អ យប ១៣:១០ កច ១០:៣៤ ក លវ ១៩:១៥ យក ២:៥ ខ យប ១០:៣ **៣៤:២០** គ ខ.២៥ នក ១១:៤ យប ២០:៨ ឃ យប ១២:១៩ **៣៤:២១** ង យរ ៣២:១៩ ច យប ១៤:១៦ សភ ១៥:៣ ហព ៤:១៣ **៣៤:២២** ឆ ទដ ៧៤:២០ ជ យប ៣:៥ ឈ លប ៣:៨ យប ១១:២០

១២:១៤ ១៣:១៨ ២៧:៦) និងបន្ថែមទៀតផងក្នុង ខ.៦ ។ តំណាងឱ្យភាពសមរម្យរបស់លោកយ៉ូប (មើល ២១:៣៤ ២៧:៥ ក៏មើល ៦:៤ និងការពន្យល់) ទោះជាលោកយ៉ូបពុំដែលបានប្រកាសថា ពុំមានកំហុសអ្វីទេ ។ ខ.៩ គឺជាការសម្គាល់ផ្ទាល់ពីលោកយ៉ូបដែលស្រម៉ៃយ៉ាងច្បាស់ពីភាពស្រដៀងគ្នា (មើល ២១:១៥) ប៉ុន្តែប្រហែលជាលោកអេលីហ៊ូវបានស្រង់វាចេញពីសេចក្តីថ្លែងឡើងមកវិញរបស់លោកយ៉ូប ដែលព្រះអម្ចាស់ធ្វើចំពោះអ្នកសុចរិតនិងការអាក្រក់ក្នុងរបៀបតែមួយ (ធៀបនឹង ៩:២២ ២១:១៧ ២៤:១–២) ដែលនាំមកនៅទីចុងក្រោយ ដែលវាពុំបានធ្វើឱ្យព្រះសព្វព្រះហឫទ័យទេ ។

**៣៤:៧** *ផឹកសេចក្តីឡកឡឺយដូចជាផឹកទឹក* មើលការពណ៌នារបស់លោកអេលីផាសចំពោះនិស្ស័យមនុស្ស (មើល ១៥:១៦) ។

**៣៤:១០** *កុំឱ្យយើងថាព្រះទ្រង់ធ្វើអាក្រក់ . . . ប្រព្រឹត្តសេចក្តីទុច្ចរិតនោះឡើយ* មើល លប ១៨:២៥ និងការពន្យល់ ។ លោកអេលីផាសពិតជាបារម្ភថា លោកយ៉ូបអាចនឹងចាត់ទុកព្រះអម្ចាស់ ជាអ្នករៀបចំឡើងនូវការអាក្រក់ដោយព្រះហឫទ័យអាក្រក់ទុកជាមុន ។ ការឈឺចាប់ដ៏ខ្លាំងរបស់លោកយ៉ូបស្ទើរតែនាំឱ្យគាត់ចោទប្រកាន់ព្រះធ្វើខុស (១២:៤–៦ ២៤:១–១២) ។ គាត់សន្មត់ថានេះគ្រាន់តែជាសេចក្តីបញ្ជាប់ គាត់អាចទៅរកមូលដ្ឋានមួយនៃចំណេះដឹងរបស់គាត់ និងបទពិសោធន៍ (៩:២៤) ។

**៣៤:១១** សូមមើល សស ១២:១៤ រម ២:៦–១១ ២កថ ៥:១០ និងការពន្យល់ ។

**៣៤:១៣–១៥** អេលីហ៊ូវគឺច្រណែននិងសិរីល្អរបស់ព្រះ ដែលជាព្រះមហាក្សត្រដែលបង្ហាញពីព្រះគុណទ្រង់ដល់មនុស្សជាតិ ។

**៣៤:១៥** *ត្រូវត្រឡប់ទៅជាធូលីដីវិញ* មើល សស ១២:៧ មើល លប ៣:១៩ និងការពន្យល់ ។

**៣៤:១៦** *សូមស្តាប់ . . . សូមផ្ទៀងត្រចៀក* ក្នុងព្រះគម្ពីរភាសាហេព្រើទំរង់ជាឯកវចនៈដែលសំដៅទៅលើលោកយ៉ូប ។ លោកអេលីហ៊ូវបានគិតថាការបង្ហាញឥរិយាបថពីលោកទៅចំពោះវត្តមានព្រះ គឺជាការត្រឹមត្រូវពុំមានល្បៀង គឺក្នុងនាមជាព្រះយេហូវ៉ាលើគ្រប់ទាំងអស់ ជាពិសេសការកាត់ទោសមនុស្សអាក្រក់នៅឯទីខ្ពស់ (មើល ខ.១៨–២០) ។

**៣៤:១៨** *ចោលម្សៀត* មើលការពន្យល់ ចទ ១៣:១៣ ។

**៣៤:២១–២៨** ព្រះទ្រង់ជាព្រះសព្វញ្ញូញ្ញាណ ទ្រង់នឹងមិនធ្វើអ្វីឱ្យ មានកំហុសទេ ខណៈពេលដែលទ្រង់ដាក់ទណ្ឌកម្មដល់អ្នកដែលប្រព្រឹត្តការអាក្រក់ ។ ដោយទ្រង់ពុំអាចញែកពេល ឬលើកពេលដើម្បីកំណត់ពេលកាត់ទោសនោះទេ (មើល ខ.២៨ ផ្ទុយនិង ២៤:១) ។

**៣៤:២១** លោកអេលីហ៊ូវបានប្រកាសពីអត្ថន័យពាក្យ ដែលលោកយ៉ូបបាននិយាយ ។

បាច់ពិចារណាមើលមនុស្សជាយូរ[ញ] ឱ្យបានកោះនាំគេមក
ជំនុំជំរះនៅចំពោះទ្រង់នោះទេ[ដ] ២៤ទ្រង់សង្ការ[ឋ]មនុស្ស
សំខាន់ៗ[ឌ]បែបរកយល់មិនបាន រួចទ្រង់តាំងម្នាក់ទៀតឡើង
ជំនួសគេ[ឍ] ២៥គឺដោយព្រោះទ្រង់ជ្រាបអស់ទាំងអំពើរបស់
គេ[ណ] ទ្រង់ក៏ធ្វើឱ្យការទាំងនោះត្រឡប់ត្រឡិន[ត] ឱ្យគេវិនាស
ទៅ[ថ] ២៦ទ្រង់ប្រហារគេទុកដូចជាមនុស្សអាក្រក់[ទ] នៅ
កណ្ដាលជំនុំ ចំពោះមុខគេ ២៧ដោយព្រោះគេបានបែរ
ចេញមិនតាមទ្រង់ទៀត[ធ] ហើយមិនព្រមប្រព្រឹត្តតាមផ្លូវ
ណាមួយរបស់ទ្រង់ឡើយ[ន] ២៨ដល់ម្ល៉េះបានជាគេបណ្ដាលឱ្យ
ដំងូររបស់មនុស្សក្រីក្របានឮទៅដល់ទ្រង់ ទ្រង់ក៏បានឮ
សំរែករបស់មនុស្សដែលត្រូវសង្កត់សង្កិនដែរ[ប] ២៩កាល
ណាទ្រង់ប្រោសឱ្យមានសេចក្ដីស្រាកស្រាន្តហើយ[ផ] នោះតើ
អ្នកណានឹងបណ្ដាលឱ្យកំរើកឡើងទៀតបាន[ព] កាលណា
ទ្រង់លាក់ព្រះភក្ត្រ នោះ[ភ]តើអ្នកណានឹងមើលទ្រង់ឃើញ
ហើយនេះក៏ដូចគ្នា ទោះបើនិយាយចំពោះនគរទាំងមូល
ឬចំពោះមនុស្សតែម្នាក់ក្ដី[ម] ៣០ដើម្បីកុំឱ្យមានមនុស្សទមិល
ល្មើស[យ]បានគ្រប់គ្រងឡើង[រ] ប្រយោជន៍កុំឱ្យមានអ្នកណា
ដាក់អន្ទាក់ចាប់ពួកជនឡើយ[ល]។
៣១ដ្បិតគួរឱ្យទូលដល់ព្រះថា ទូលបង្គំបានទ្រាំរងទោស
ហើយ[វ] ទូលបង្គំលែងធ្វើខុសទៀត ៣២បទណាដែលទូលបង្គំ
មិនដឹង[ស] នោះសូមទ្រង់បង្រៀនដល់ទូលបង្គំផង បើទូលបង្គំ
បានប្រព្រឹត្តអំពើទុច្ចរិត នោះទូលបង្គំនឹងមិនធ្វើទៀតទេ[ហ]
៣៣តើទ្រង់ត្រូវប្រទានរង្វាន់មក ឱ្យត្រូវតាមបំណងចិត្ត
លោកឬ បានជាលោកមិនព្រមទទួលដូច្នេះ[ឡ] ឯការដែល
ទទួលឬមិនទទួល នោះស្រេចនៅលោក មិនមែនស្រេចនឹង
ខ្ញុំទេ ដូច្នេះ សេចក្ដីដែលលោកជ្រាប សូមពោលមកចុះ
៣៤ឯមនុស្សដែលមានយោបល់ គេនឹងនិយាយមកខ្ញុំ អើ គ្រប់
ទាំងមនុស្សមានប្រាជ្ញាដែលស្ដាប់ខ្ញុំ គេនឹងថា ៣៥លោកយ៉ូប
ពោលពាក្យឥតបើគិត[អ] សេចក្ដីរបស់លោកឥតខ្លឹមសារផង[ក]
៣៦ខ្ញុំចូលចិត្តឱ្យលោកយ៉ូបទ្រាំរងសេចក្ដីល្បង រហូតដល់
ចុង ដោយព្រោះចំឡើយរបស់លោក ប្រៀបដូចជាពាក្យ
ពោលរបស់មនុស្សអាក្រក់[ខ] ៣៧ដ្បិតលោកបន្ថែមសេចក្ដី
បះបោរ ទៅលើអំពើបាបរបស់លោកទៀត លោកទះដៃ
បង្អាប់[គ] នៅកណ្ដាលពួកយើងហើយក៏ចំរើនពាក្យ[ឃ]ពោល
ទាស់នឹងព្រះផង[ង]។

**៣៥** ១មួយទៀត អេលីហ៊ូវនិយាយថា ២សេចក្ដីនេះ តើ
លោកស្មានថា គួរគប្បីឬ ដែលលោកចង់ថា សេចក្ដី
សុចរិតរបស់លោក[ក] នោះលើសជាងសេចក្ដីសុចរិតរបស់
ព្រះ[ខ] ៣ដោយពាក្យថា តើមានប្រយោជន៍អ្វីដល់ខ្ញុំ ហើយ
បើខ្ញុំមិនបានធ្វើបាប នោះតើនឹងបានកំរៃជាជាងយ៉ាងណា
ទៅ[គ] ៤ខ្ញុំនឹងតបឆ្លើយដល់លោក ហើយដល់ពួកម៉ាករបស់
លោកនេះដែរ ៥សូមពិចារណាមើលស្ថានសួគ៌ចុះ[ឃ] ហើយ
រំពឹងមើលផ្ទៃមេឃ ដែលខ្ពស់ជាងលោកជាយ៉ាងណា[ង]
៦បើលោកបានធ្វើបាប នោះតើលោកបានធ្វើឱ្យដាបដល់

**៣៤:២៣** ញ ទដ ១១:៤ ដ យប ១១:១១ **៣៤:២៤** ឋ អស ៨:៩ ៩:៤ យរ ៥១:២០ ដយ ២:៣៤ ឌ យប ១២:១៩ ឍ ដយ ២:២១ **៣៤:២៥** ណ យប ១១:១១ ត ខ.២០ ថ សភ ៥:២១–២៣ **៣៤:២៦** ទ លប ៦:៥ យប ៨:២២ ២៨:២៤ ទដ ៩:៥ យរ ៤៤:៥ **៣៤:២៧** ធ ទដ ១៤:៣ ន ១សយ ១៥:១១ **៣៤:២៨** ប នក ២២:២៣ យប ៥:១៥ ១២:១៩ **៣៤:២៩** ផ ទដ ២៨:១ ៨៣:១ ១០៩:១ ព ខ.១៧ រម ៨:៣៤ ភ ទដ ១៣:១ ម ទដ ៨៣:១៨ ៩៧:៩ **៣៤:៣០** យ យប ៨:១៣ រ ខ.១៧ ល ទដ ២៥:១៥ ៣១:៤ ៩១:៣ ១២៤:៧ ១៤០:៥ សភ ២៩:២–១២ **៣៤:៣១** វ ទដ ៥១:៥ លក ១៥:២១ រម ៧:២៤ ១យហ ១:៨,១០ **៣៤:៣២** ស នក ៣៣:១៣ យប ៣៥:១១ ៣៨:៣៦ ទដ ១៥:២ ២៥:៤ ២៧:១១ ៥១:៦ ៨៦:១១ ១៣៩:២៣–២៤ ១៤៣:៨ ហ យប ៣៣:២៧ លក ១៩:៨ **៣៤:៣៣** ឡ ២ពវ ១៧:១៣ យប ៣៣:២៣ ៣៦:១០, ១៥,១៨,២១ ៤១:១១ ៤២:៦ សភ ១៧:២៣ យហ ៣:៨ **៣៤:៣៥** អ យប ៣៥:១៦ ៣៨:២ ៤២:៣ ក យប ២៦:៣ **៣៤:៣៦** ខ យប ៦:២៩ ២២:១៥ **៣៤:៣៧** គ យប ២៧:២៣ ឃ យប ៣៥:១៦ ង យប ២៣:២ **៣៥:២** ក យប ៣៣:៣២ ខ យប ២:៩ ៣២:២ **៣៥:៣** គ យប ៩:២៩–៣១ ២១:១៥ **៣៥:៥** ឃ លប ១៥:៥ ចទ ១០:១៤ ង យប ១១:៧–៩ ទដ ១៩:១–៤

**៣៤:២៩** *ឱ្យមានសេចក្ដីស្រាក . . . នោះតើអ្នកណានឹងបណ្ដាលឱ្យកំរើកឡើង* លោកអេលីហ៊ូវក៏ព្យាយាមឆ្លើយនិងការប្ដឹងរបស់លោកយ៉ូបចំពោះភាពស្ងៀមស្ងាត់របស់ព្រះ (ជំពូក ២៣) ។ ព្រះបានទតព្រះនេត្រមកលើរាស្ត្ររបស់ផងទ្រង់ និងសាស្ត្រទាំងឡាយដើម្បីពិនិត្យមើលការត្រឹមត្រូវដែលគេបានធ្វើ (ខ.២៩–៣០) ។
**៣៤:៣១–៣៣** ពីដំបូងគឺនិយាយដោយមិនផ្ទាល់ (ខ.៣១–៣២) តែក្រោយមកនិយាយដោយផ្ទាល់ (ខ.៣៣) លោកអេលីហ៊ូវកាត់ទោសយ៉ូប ហើយសុំឱ្យលោកយ៉ូបលន់តួកំហុស ។
**៣៤:៣៥** *លោកយ៉ូបពោលពាក្យឥតបើគិត* គឺជាគំរូពីសេចក្ដីថ្លែងលើកទី១របស់ព្រះយេហូវ៉ា (មើល ៣៨:២ និងការពន្យល់) ហើយនៅពេលក្រោយមកក៏ឆ្លើតតបចំពោះលោកយ៉ូប (មើល ៤២:៣) ។
**៣៥:១–១៦** ការថ្លែងជាលើកទី៣របស់លោកអេលីហ៊ូវ (មើលការពន្យល់ ៣២:១–៣៧:២៤) បញ្ជាក់ដល់លោកយ៉ូប ។
**៣៥:២** *ចង់ថា* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "បញ្ជាក់ប្រាប់" គឺដូចនៅក្នុងសម្ដីរបស់គាត់ក្នុង ១៣:១៨ ។ ឯលោកអេលីហ៊ូវ គិតថា វាជាភាពអយុត្តិធម៌ហើយប្រែប្រួល ឬអស្ចារ្យភាពចំពោះជីវិតលោកយ៉ូបដែលសង្ឃឹមថាមានការបង្ហាញពីព្រះថាឥតមានកំហុស តែក្នុងពេលនោះព្រះទ្រង់ពុំបានចាប់អារម្មណ៍ចំពោះភាពបរិសុទ្ធថាមាន ឬអត់នោះឡើយ (មើល ខ.៣) ប៉ុន្តែភាពមាននោះត្រូវបានធ្វើចំពោះបុគ្គល ដើម្បីបង្ហាញពីអារម្មណ៍របស់គាត់ ។ ឯអ្នកនិពន្ធបទទំនុកអ្នកស្រេកឃ្លាន ឬប្រវេប្រវារកព្រះ (ទដ ៤២:១–២) ក៏បានចោទជាសំនួរថា ហេតុអ្វីបានជាព្រះបំភ្លេចរូបគាត់ (ទដ ៤២:៩) ហើយបានបដិសេធរូបគាត់ ។
**៣៥:៥** *សូមពិចារណាមើលស្ថានសួគ៌ចុះ ហើយរំពឹងមើល* លោកអេលីហ៊ូវពោលអះអាងថា ព្រះអម្ចាស់នៅឆ្ងាយពីមនុស្សលោកដែលពុំមានព្រះទ័យលើអ្វីដែលមនុស្សបានប្រព្រឹត្តល្អឬអាក្រក់ទេ ដែលជាឥទ្ធិពលទៅលើនិស្ស័យដ៏សំខាន់របស់ព្រះអម្ចាស់ (មើល ខ.៦) ។

ទ្រង់យ៉ាងណាខ្លះ បើអំពើរំលងរបស់លោកបានចំរើន
កាន់តែច្រើនឡើង នោះតើលោកបានធ្វើឱ្យដាបដល់ទ្រង់
ជាយ៉ាងណា[ច] ៧ឬបើលោកសុចរិតវិញ នោះតើលោកបាន
បន្ថែមអ្វីដល់ទ្រង់[ឆ] ឬទ្រង់ទទួលអ្វី[ជ]ពីដៃលោក[ឈ] ៨អំពើ
អាក្រក់របស់លោកអាចនឹងធ្វើបង្ខូចដល់អ្នកដទៃបាន ជា
មនុស្សដូចជាលោកដែរ[ញ] ហើយសេចក្តីសុចរិតរបស់
លោកនឹងមានប្រយោជន៍ដល់កូនរបស់មនុស្សដទៃបាន
ដែរ[ដ]។

៩មានគេថ្ងូរ[ឋ] ដោយព្រោះសេចក្តីសង្កត់សង្កិនយ៉ាង
សន្ធឹក[ឌ] ក៏មានគេស្រែករកមនុស្សជួយ ដោយព្រោះតែដៃ
របស់មនុស្សមានអំណាចមែន[ឍ] ១០តែឥតមានអ្នកណាថា
ឯព្រះដ៏ជាព្រះអង្គបង្កើតខ្ញុំមក ដែល[ណ]ទ្រង់បណ្តាលឱ្យ
ច្រៀង[ត]នៅវេលាយប់[ថ] ១១ហើយបង្រៀន[ទ]ដល់[ធ]យើង ជា
ជាងសត្វតិរច្ឆាននៅផែនដី ក៏ឱ្យមានប្រាជ្ញាលើសជាង
សត្វហើរលើអាកាស តើទ្រង់នៅឯណានោះទេ ១២គេ
ស្រែកនៅទីនេះ ឥតមានអ្នកណាឆ្លើយឡើង[ន] ដោយព្រោះ
សេចក្តីឆ្មើងឆ្មៃ[ប]របស់មនុស្សអាក្រក់[ផ] ១៣ពិតប្រាកដជាព្រះ
ទ្រង់មិនព្រមស្តាប់សំរែកដែលស្រែកជាទទេៗដែរ ព្រះដ៏
មានគ្រប់ព្រះចេស្តា ទ្រង់មិនព្រមទាំងក្រឡេកមើលផង[ព]
១៤ចំណង់បើលោក ដែលពោលថាលោកមើលទ្រង់មិន
ឃើញ[ភ] នោះតើយ៉ាងណាទៅ ឯរឿងរ៉ាវនោះ[ម]ក៏នៅ
ចំពោះទ្រង់ ហើយគឺលោកវិញដែលត្រូវរង់ចាំទ្រង់ទេតើ[យ]

**៣៥:៦** ច យប ៧:២០
**៣៥:៧** ឆ រម ១១:៣៥ ជ យប ២២:២–៣ លក ១៧:១០ ឈ ១កថ ៤:៧
**៣៥:៨** ញ អគ ១៨:២៤ ដ អគ ១៨:៥–៩ សក ៧:៩–១០
**៣៥:៩** ឋ នក ២:២៣ ឌ យប ២០:១៩ ឍ យប ៥:១៥ ១២:១៩
**៣៥:១០** ណ យប ៤:១៧ ត យប ៨:២១ ថ ទដ ៤២:៨ ៧៧:៦ ១១៩:៦២ ១៤៩:៥ កច ១៦:២៥
**៣៥:១១** ទ យប ២១:២២ លក ១២:២៤ ធ យប ១២:៧
**៣៥:១២** ន ១សយ ៨:១៨ ប យប ១៥:២៥ ផ ទដ ៦៦:១៨
**៣៥:១៣** ព ចទ ១:៤៥ ១សយ ៨:១៨

១៥ប៉ុន្តែ ឥឡូវនេះដែលយ៉ូបថា ទ្រង់មិនធ្វើទោស[រ] ដោយ
សេចក្តីក្រោធទេ ក៏មិនសូវរវល់នឹងសេចក្តីឆ្មើងឆ្មៃដែរ[ល]
១៦នោះខ្ញុំថាលោកបានបើកមាត់បញ្ចេញតែសេចក្តីឥត
ប្រយោជន៍[វ] ហើយបានចំរើនពាក្យសំដីឥតបើគិតវិញ[ស]។

## ៣៦

១អេលីហ៊ូវក៏ពោលតទៅថា ២សូមទ្រាំចាំខ្ញុំបន្តិចសិន
ខ្ញុំនឹងបង្ហាញលោក ដ្បិតខ្ញុំនៅមានសេចក្តីខ្លះនឹងពោល
ដំកើងពីព្រះ ៣ខ្ញុំនឹងនាំយកសេចក្តីចេះដឹងរបស់ខ្ញុំមកពី
ចំងាយ[ក] ហើយនិងសំដែងច្បាស់ថា ព្រះដែលបង្កើតខ្ញុំទ្រង់
សុចរិត[ខ] ៤ដ្បិតពិតជាពាក្យខ្ញុំ មិនមែនជាពាក្យកំភូតទេ[គ]
គឺមានព្រះដ៏មានដំរិះសព្វគ្រប់[ឃ] ទ្រង់គង់នៅជាមួយនឹងខ្ញុំ
វិញ[ង] ៥មើល ព្រះទ្រង់មានព្រះចេស្តា[ច] តែទ្រង់មិនមើល
ងាយដល់អ្នកណាឡើយ[ឆ] ទ្រង់មានឥទ្ធឫទ្ធិដោយកំឡាំងនៃ
ព្រះដំរិះ[ជ] ៦ទ្រង់មិនគាំពារជីវិតរបស់មនុស្សអាក្រក់ នោះ
ទេ[ឈ] តែទ្រង់ប្រោសមនុស្ស ដែលត្រូវវេទនាតាមត្រឹមត្រូវ[ញ]
៧ទ្រង់មិនដកព្រះនេត្រចេញពីមនុស្សសុចរិតឡើយ[ដ] គឺទ្រង់

យប ១៥:៣១ សភ ១៥:៨ **៣៥:១៤** ភ យប ៩:១១ ម ទដ ៣៧:៦ យ យប ៣១:៣៥ **៣៥:១៥** រ យប ៩:២៤ ល យប ១៨:៥ ទដ ១០:១១ ហស ៧:២ អម ៨:៧ **៣៥:១៦** វ ទត ១:១០ ស យប ៣៤:៣៥,៣៧ ១កថ ៤:២០ យដ ១:១០ **៣៦:៣** ក យប ៦:២៨ ខ យប ៤:១៧ **៣៦:៤** គ យប ៦:២៨ ១៣:៦ ឃ យប ៣៧:៥,១៦,២៣ ង យប ៣២:១៧ **៣៦:៥** ច យប ៩:៤ ឆ ទដ ៥:២ ២២:២៤ ៣១:២២ ៦៩:៣៣ ១០២:១៧ ១០៣:១០ ជ ជន ២៣:១៩ រម ១១:២៩ **៣៦:៦** ឈ យប ៣៤:២៦ ញ យប ៤:១០ **៣៦:៧** ដ យប ១១:១១ ទដ ១១:៥ ៣៣:១៨ ៣៤:១៥ មថ ៦:១៨

**៣៥:៩** *មានគេថ្ងូរ . . . គេស្រែករកមនុស្សជួយ* លោកអេលីហ៊ូវបញ្ជាក់ថា មនុស្សដូចលោកយ៉ូប គឺអ្នកអធិស្ឋានរកជំនួយក្នុងគ្រាលំបាកដែលគ្មានកំហុសហើយក៏ពុំបានដឹង ។ ក៏បើកឱ្យគេស្គាល់ហើយប្រព្រឹត្តតាមនោះ គេនឹងរស់នៅដោយសេចក្តីអំណរ (មើល ខ.១០–១១) ភាពបរាជ័យក៏ជាប្រភេទនៃសេចក្តីឆ្មើងឆ្មៃរបស់មនុស្សអាក្រក់ (មើល ខ.១២) ដូច្នេះ ភាពត្អូញត្អែររបស់លោកយ៉ូបប្រឆាំងនិងភាពយុត្តិធម៌របស់ព្រះ ដែលជាកិច្ចសន្ទនាពុំមានន័យ (មើល ខ.១៣–១៦) ។

**៣៥:១០–១១** *ទ្រង់បណ្តាលឱ្យច្រៀងនៅវេលាយប់ . . . ហើយបង្រៀនដល់យើង . . . ឱ្យមានប្រាជ្ញាលើស . . . សត្វហើរលើអាកាស* ព្រះអម្ចាស់បានជ្រើសការបន្ទាបខ្លួន ដើម្បីបង្រៀនដល់រាស្ត្ររបស់ទ្រង់ក្នុងសេចក្តីស្រឡាញ់ព្រះ ។

**៣៥:១២** ពាក្យជាខគម្ពីរពិបាកណាស់ ការដកឃ្លាក្នុងបន្ទាត់ទី១ និងអាចដូរអត្ថន័យនិងធ្វើឱ្យមានន័យជាច្រើន ។ មនុស្សអាក្រក់មានពេញដោយអំណួតក្អេងក្អាង នោះព្រះទ្រង់ក៏ពុំស្តាប់ពួកគេដែរ (មើល ខ.១៣) ។ រឿងនេះដែលលោកយ៉ូបបានទទួលលទ្ធផលដូចពួកនោះដែរ ពោលគឺគាត់ពុំបានទទួលតាមពាក្យទូលសូមទេ ព្រោះបានទូលដោយមិនត្រឹមត្រូវ (មើល ខ.១៤) ។

**៣៥:១៦** *សេចក្តីឥតប្រយោជន៍* មើល ៣៨:២ និងការពន្យល់ ។ *ចំរើនពាក្យសំដីឥតបើគិត* គឺជាការប្រឆាំងនឹងព្រះ (មើល ៣៤:៣៧) ។

**៣៦:១–៣៧:២៤** ជាពាក្យសម្តីរបស់លោកអេលីហ៊ូវលើកទី៤និងលើកចុងក្រោយ (មើល ៣៦:២) មើលការពន្យល់ ៣២:១–៣៧:២៤ (មើលការពន្យល់ ៣៧:២) ។

**៣៦:២–៤** លោកអេលីហ៊ូវមានបំណងគាំទ្រភាពល្អរបស់ព្រះ និងភាពយុត្តធម៌របស់ទ្រង់ ។

**៣៦:៤** *ដំរិះសព្វគ្រប់* គឺពាក្យសន្ទនាដែលលោកអេលីហ៊ូវបានប្រើខ្លួនឯងក្នុង ៣៧:១៦ ដែលគាត់សម្តែងទៅកាន់ព្រះ ហើយចង់ប្រៀបខ្លួនឱ្យស្មើនឹងព្រះ តែតាមព្រះគម្ពីរភាសាហេព្រើរវិញ ពាក្យ "ដំរិះ" នេះគឺពុំមានលក្ខណៈដូចន័យនៅទីនេះទេ ដូចជាក្នុង ៣៧:១៦ ។ លោកអេលីហ៊ូវប្រហែលជាចង់បង្ហាញសំដៅទៅលើសមត្ថភាពរបស់គាត់ ក្នុងនាមជាអ្នកមានការទំនាក់ទំនងល្អ ពោលគឺមានន័យថា គាត់បានប្រកាសដោយប្រើវោហាស័ព្ទដ៏សុក្រិដ្ឋក្នុងដំរិះនៃការអធិប្បាយ (មើលការពន្យល់ ៣២:៦,១០,១៧) ។

**៣៦:៥** អំណាចព្រះចេស្តាព្រះ បង្ហាញឱ្យឃើញពីទិសដៅនៃព្រះរាជកិច្ចរបស់ផងទ្រង់ ។

**៣៦:៦–៩** គឺជាសេចក្តីថ្លៃថ្នូរដ៏បរិសុទ្ធនៃភាពយុត្តិធម៌របស់ព្រះក្នុងការឱ្យរង្វាន់អ្នកបរិសុទ្ធនិងដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តបាប (ដែលជាលក្ខណៈផ្ទុយទៅនិងអ្វីដែលលោកយ៉ូបគាត់បានប្រកាស) ។ ក្នុង ខ.៧ លោកអេលីហ៊ូវប្រហែលជាមានគំនិតថា ការត្អូញត្អែររបស់លោកយ៉ូបថា ព្រះនឹងមិនបោះ

តាំងឱ្យគេអង្គុយលើបល្ល័ង្ក[ឋ] ជាមួយនឹងពួកស្ដេច ឱ្យនៅអស់
កល្បជានិច្ចវិញ ហើយគេបានថ្កើងឡើង[ឌ] ៨បើកាលណាគេ
ត្រូវជាប់ច្រវាក់[ឍ] ឬជាប់ចំណងនៃសេចក្ដីវេទនា[ណ] ៩នោះ
ទ្រង់ក៏បង្ហាញឱ្យគេឃើញអំពើរបស់គេ ព្រមទាំងសេចក្ដី
រំលងរបស់គេ ដែលគេប្រព្រឹត្តដោយហួសល្បត់[ត] ១០ទ្រង់
ក៏បើកត្រចៀកគេឱ្យស្ដាប់[ថ]សេចក្ដីដំបូន្មាន[ទ] ហើយបង្គាប់ឱ្យ
គេវេះចេញពីសេចក្ដីទុច្ចរិតវិលមកវិញ[ធ] ១១បើគេស្ដាប់តាម
ហើយគោរពប្រតិបត្តិដល់ទ្រង់[ន] នោះគេនឹងរស់នៅអស់
ទាំងថ្ងៃនៃអាយុគេ ដោយសេចក្ដីរុងរឿង[ប] ហើយអស់ទាំង
ឆ្នាំគេ ដោយសេចក្ដីអំណរ[ផ] ១២ប៉ុន្តែបើគេមិនស្ដាប់វិញ
នោះគេនឹងត្រូវវិនាសទៅដោយដាវ[ព] ហើយនឹងស្លាប់ទៅ
ដោយខ្វះប្រាជ្ញា[ភ] ១៣ឯពួកអ្នកដែលមានចិត្តទមិលល្មើស[ម]
គេប្រមូលទុកសេចក្ដីខ្ញាល់[យ] ហើយកាលណាទ្រង់ចងគេ
នោះគេមិនអំពាវនាវទេ[រ] ១៤ព្រលឹងគេស្លាប់ទៅក្នុងវ័យ
នៅក្មេងនៅឡើយ[ល] ហើយជីវិតគេក៏នៅរួមនឹងពួកស្មោក
គ្រោក[វ] ១៥ទ្រង់ជួយអ្នកដែលមានសេចក្ដីទុក្ខ[ស] ឱ្យរួចដោយ
ការរងទុក្ខរបស់គេនោះ[ហ] ក៏បើកត្រចៀក[ឡ]គេក្នុងគ្រាដែល
កើតមានសេចក្ដីសង្កត់សង្កិន[អ] ១៦អើ ទ្រង់សព្វព្រះហឫទ័យ
ចង់នាំ[ក]លោកចេញពីទីចង្អៀត ទៅឯទីធំទូលាយវិញ[ខ] ជាទី
គ្មានសេចក្ដីតឿតត្បុលឡើយ[គ] យ៉ាងនោះ អាហារដែលបាន
ដាក់លើតុលោក[ឃ] និងបានជារបស់មានរសដ៏ប្រសើរ[ង]។
១៧ប៉ុន្តែលោកបានសំរេចពេញទី តាមសេចក្ដីជំនុំជំរះ
របស់មនុស្សអាក្រក់[ច] ដូច្នេះ សេចក្ដីយុត្តិធម៌ និងសេចក្ដី
សុចរិតបានចាប់លោកហើយ[ឆ] ១៨កុំបីលោកទុកឱ្យសេចក្ដី
ក្រោធបណ្ដាលឱ្យទាស់ទទឹង និងការរាងចាលឡើយ ក៏កុំឱ្យ
ថ្លៃលោះយ៉ាងធំក្រៃលែងនេះ[ជ] នាំឱ្យលោកវង្វេងចេញ

**៣៦:៧** ឋ ទដ ១១៣:៨ អស ២២:២៣ ឌ ១សយ ២:៧-៨ យប ៤:៧ **៣៦:៨** ឍ ២សយ ៣:៣៤ ២ពវ ២៣:៣៣ ទដ ១០៧:១០,១៤ ណ ខ.១០,១៥,២១ ទដ ១១៩:៦៧,៧១ **៣៦:៩** ត យប ១៥:២៥ **៣៦:១០** ថ យប ៣៣:១៦ ទ យប ៥:១៧ ធ ខ.៨ ពច ៦:៨ យប ៣៤:៣៣ ១ថន ៥:២២ **៣៦:១១** ន លវ ២៦:៣៣ ចទ ២៨:១ អស ១:១៩ ហក ១:១២ ប ចទ ៣០:១៥ យប ៨:៧ ផ នក ៨:២២ ចទ ៨:១ យហ ១៤:២១ ១ថន ៤:៨ **៣៦:១២** ព លវ ២៦:៣៨ យប ១៥:២២ ភ យប ៤:២១ អភ ៤:១៨ **៣៦:១៣** ម យប ១៥:១២ រម ២:៥ យ យប ៥:២រ យប ៤:១៧ អម ៤:១១

ដែរ[ឈ] ១៩តើសំរែករបស់លោក[ញ] ឬឫទ្ធិនៃកំឡាំងលោក
នឹងបានល្មម អាចនឹងជួយឱ្យលោករួចពីសេចក្ដីទុក្ខនេះ
បានឬទេ ២០កុំឱ្យសង្វាតចង់បានពេលយប់[ដ] ជាពេលដែល
ពួកជនត្រូវដកចេញពីកន្លែងគេនោះឡើយ ២១ត្រូវឱ្យប្រយ័ត្ន
នឹងចៀសចេញពីសេចក្ដីទុច្ចរិត[ឋ] ដ្បិតលោកបានរើស
សេចក្ដីនោះជំនួសការរងទុក្ខវិញ[ឌ]។
២២មើល ព្រះទ្រង់ធ្វើការយ៉ាងខ្ពស់វិសេស ដោយឫទ្ធិ
របស់ទ្រង់[ឍ] តើមានគ្រូឯណាដែលប្រៀបផ្ទឹមនឹងទ្រង់បាន[ណ]
២៣តើអ្នកណាបានបង្គាប់បង្ហាញផ្លូវ[ត] ដែលទ្រង់ត្រូវដើរ[ថ]
ឬអ្នកណាហ៊ានថា ទ្រង់បានប្រព្រឹត្តការទុច្ចរិត[ទ] ២៤ត្រូវឱ្យ
លោកនឹកចាំ នឹងលើកដំកើងការទ្រង់វិញ[ធ] គឺជាការដែល
មនុស្សលោកបានច្រៀងសរសើរដែរ[ន] ២៥មនុស្សផង
ទាំងឡាយរំពឹងមើលការនោះ[ប] តែគេមើលពីចំងាយទេ
២៦មើលព្រះទ្រង់ធំណាស់ យើងរាល់គ្នាមិនស្គាល់ទ្រង់ទេ[ផ]
ចំនួនឆ្នាំនៃព្រះជន្មទ្រង់ នោះរកកំណត់មិនបាន[ព] ២៧គឺទ្រង់
ដែលជក់ទឹកនៅលើ ឱ្យប្រែជាចំហាយ[ភ] រួចទំលាក់ជា

**៣៦:១៤** ល យប ១៥:៣២ វ ចទ ២៣:១៧ **៣៦:១៥** ស យប ៥:១៥ ហ ២កថ ១២:១០ ឡ យប ៣៣:១៦ អ ខ.៨ យប ៣៤:៣៣ **៣៦:១៦** ក ហស ២:១៤ ខ ២សយ ២២:២០ ទដ ១៨:១៩ គ ទដ ១១៨:៥ ឃ ទដ ២៣:៥ ៧៨:១៩ ង លប ១៧:១ យប ១៥:១១ **៣៦:១៧** ច យប ២០:២៩ ឆ យប ២២:១១ **៣៦:១៨** ជ នក ២៣:៨ អម ៥:១២ ឈ យប ៣៤:៣៣ **៣៦:១៩** ញ ទដ ៤៩:៦ យរ ៩:២៣ **៣៦:២០** ដ យប ៣៤:២០,២៥ **៣៦:២១** ឋ យប ៣៤:៣៣ ទដ ៦៦:១៨ ឌ ខ.៨ ហព ១១:២៥ **៣៦:២២** ឍ យប ៥:៩ ៩:៤ ណ យប ២១:២២ រម ១១:៣៤ **៣៦:២៣** ត យប ២៧:១១ ថ យប ៣៤:១៣ រម ១១:៣៣ ទ លប ១៨:២៥ យប ៣៤:១០ **៣៦:២៤** ធ ១របា ១៦:២៤ ទដ ៣៥:២៧ ៩២:៥ ១១១:២ ១៣៨:៥ ១៤៥:១០ ន នក ១៥:១ វវ ១៥:៣ **៣៦:២៥** ប រម ១:២០ **៣៦:២៦** ផ យប ៥:៩ ១កថ ១៣:១២ ព លប ២១:៣៣ យប ១០:៥ ហព ១:១២ **៣៦:២៧** ភ យប ២៦:៨

បង់ចោលគាត់ទេ (មើល ៧:១៧-១៩) និងក្នុង ខ.៩ គាត់អាចគិតពីលោកយ៉ូប ដែលថាព្រះនឹងមិនមានវត្តមានចំពោះភស្តុតាងប្រឆាំងនឹងគាត់ (មើល ៣១:៣៥-៣៦) ។

**៣៦:១០** *ក៏បើកត្រចៀកគេឱ្យស្ដាប់សេចក្ដីដំបូន្មាន* លោកអេលីហ៊ូវបញ្ជាក់ថាព្រះអម្ចាស់ប្រើបញ្ហា ដើម្បីឱ្យមានការចាប់អារម្មណ៍របស់រាស្ត្រទ្រង់ ។

**៣៦:១២** មើលការពន្យល់ ៣៣:១៨ ។

**៣៦:១៣-១៥** លោកអេលីហ៊ូវយល់ថា តម្រូវការវិញ្ញាណដែលជាមូលដ្ឋាននៃមនុស្សលោកគឺកើតមកពីការរឹងទទឹងរបស់គេ ឬការមិនចុះសម្រុងរបស់ពួកគេក្នុងការទទួលព្រះ ឬការទួញរកព្រះចំពោះភាពកង្វល់របស់ពួកគេ (មើល ទដ ១០៧:៦) ឬក្នុងការញព្រះសូរសៀងក្នុងគ្រាពួកគេជួបប្រទះភាពឈឺចាប់ ។

**៣៦:១៤** *ហើយជីវិត . . . ស្មោកគ្រោក* មើលការពន្យល់ ១ពវ ១៤:២៤ ។

**៣៦:១៦-២១** លោកអេលីហ៊ូវប្រមានលោកយ៉ូបឱ្យឆ្លើយតបចំពោះវិន័យរបស់ព្រះ ដោយការបែរចេញពីសេចក្ដីអាក្រក់ (មើល ខ.២១) ខ.១៦ បង្ហាញថាគាត់នៅតែលើកពីលោកយ៉ូបថា ជាមនុស្សមានសង្ឃឹម ។

**៣៦:១៦** *ទ្រង់សព្វព្រះហឫទ័យ . . . ទី ចង្អៀត* គឺដោយសេចក្ដីស្រឡាញ់មេត្តាករុណារបស់ព្រះអម្ចាស់ បាននាំរាស្ត្ររបស់ផងទ្រង់ត្រឡប់ទៅកន្លែងគេវិញ (មើល ហស ២:១៤ និងការពន្យល់) ។

**៣៦:២១** *ចៀសចេញពីសេចក្ដីសុចរិត* គឺជាការវាយតម្លៃរបស់លោកអេលីហ៊ូវចំពោះលោកយ៉ូប គឺផ្ទុយនិងកិច្ចការរបស់ព្រះ (មើល ១:៨ និងការពន្យល់ ២:៣) ។

**៣៦:២២-២៣** លោកអេលីហ៊ូវគិតទុកជាមុននូវសេចក្ដីខ្លះក្នុងសេចក្ដីថ្លែងបញ្ជាក់ក្នុងជំពូក ៣៨-៤១ ។

**៣៦:២៤** *គឺជាការដែលមនុស្សលោកបានច្រៀងសរសើរដែរ* មើលឧទាហរណ៍ ការពន្យល់ នក ១៥:១-១៨ ពច ៥:១-៣១ ។

**៣៦:២៦** *យើងរាល់គ្នាមិនស្គាល់ទ្រង់ទេ* មើល ៣៧:៥ គឺផ្លូវរបស់ព្រះនិងព្រះហឫទ័យទាំងដំរិះនោះរកកំណត់មិនបាន គឺខ្ពស់ឧត្តមជាងអ្វីដែលយើងមានក្នុងជំពូក ៣៨-៤១ (មើល អស ៥៥:៨,៩ រម ១១:៣៣-៣៦) ។

ភ្លៀងវិញ[ម] ២៨ជាទឹកដែលពពកចាក់ចុះមក ឱ្យធ្លាក់ជា
បរិបូរ[យ] ស្រោចស្រប់លើមនុស្សលោក[រ] ២៩អើ តើមានអ្នក
ណាយល់ពីការរាចពពក ឬពីសៀងផ្គរ[ល]នៅឯពន្លារបស់
ទ្រង់បាន[វ] ៣០មើលទ្រង់បំព្រាចពន្លឺរស្មី[ស]ព័ទ្ធជុំវិញទ្រង់
ហើយក៏គ្របបាំងទាំងបាតសមុទ្រផង[ហ] ៣១ដ្បិតគឺដោយសារ
ការទាំងនោះ ដែលទ្រង់ពិចារណាមើលអស់ទាំងសាសន៍[ឡ]
ទ្រង់ប្រោសប្រទានអាហារ[អ]ឱ្យជាបរិបូរ[ក] ៣២ទ្រង់យករន្ទះ
កាន់នៅព្រះហស្ត ហើយក៏បាញ់ទៅចំពួកខ្មាំងសត្រូវ[ខ]
៣៣សូរគ្រាំគ្រេងនោះសំដែងពីទ្រង់[គ] ដូចជាក៏ឱ្យពពួកសត្វ
ដឹងពេលដែលត្រូវភ្លៀងផ្គរនោះដែរ [ឃ]។

**៣៧** ១អើ ដំណើរនេះធ្វើឱ្យចិត្តខ្ញុំញ័រ[ក] ក៏ឱ្យកំរើកឃ្លាតពី
កន្លែងទៅ ២ចូរស្តាប់[ខ] ឱសូមស្តាប់សូរគឹកកងនៃសំឡេង
ទ្រង់ផង[គ] គឺជាសូររំពងពីព្រះឱស្ឋទ្រង់[ឃ] ៣ទ្រង់តែងកំចាយ
ឱ្យឮពេញក្រោមផ្ទៃមេឃ ទ្រង់ឱ្យឃើញផ្លេកបន្ទោរ[ង]របស់
ទ្រង់ទៅដល់ចុងផែនដីបំផុត[ច] ៤រួចមកមានឮសូរគំរាមគ្រាំ
គ្រេង ទ្រង់បញ្ចេញផ្គរ[ឆ]ដោយសំឡេងនៃឫទ្ធានុភាពទ្រង់[ជ]
រួចទ្រង់មិនឃាត់ផ្លេកបន្ទោរ ក្នុងកាលដែលសំឡេងទ្រង់
បានឮនោះទេ ៥ព្រះទ្រង់បញ្ចេញសំឡេងជាផ្គរលាន់យ៉ាង
អស្ចារ្យ[ឈ] ក៏ធ្វើការយ៉ាងធំ[ញ] ដែលយើងរាល់គ្នារកយល់
មិនបាន[ដ] ៦ដ្បិតទ្រង់បង្គាប់ដល់ហិមៈ[ឋ]ថា ចូរធ្លាក់ទៅលើ
ផែនដី ក៏បង្គាប់ដល់ភ្លៀង១មេ និងភ្លៀងធំរបស់ទ្រង់យ៉ាង
ដូច្នោះដែរ[ឌ] ៧នោះទ្រង់បំបិទដៃនៃមនុស្សទាំងឡាយ[ឍ]
ដើម្បីឱ្យមនុស្សទាំងប៉ុន្មានដែលទ្រង់បានបង្កើតបានដឹង[ណ]
៨គ្រានោះសត្វព្រៃរកទីជ្រក[ត] ហើយក៏នៅតែក្នុងរូងរបស់
វា[ថ] ៩ខ្យល់ព្យុះផាត់មកពីទិសខាងត្បូង[ទ] ហើយរងាក៏មកពី
ខាងជើង[ធ] ១០ព្រះទ្រង់ប្រទានឱ្យមានទឹកកក ដោយសារ

**៣៦:២៧** ម ២សយ ១:២១ យប ២៨:២៦ ៣៨:២៨ អស ៥៥:១០ **៣៦:២៨** យ ទដ ៦៥:១០ ៧២:៦ យអ ២:២៣ រ យប ៥:១០ ២២:១១ ២៨:២៦ មថ ៥:៤៥ **៣៦:២៩** ល ទដ ២៩:៣ យរ ១០:១៣ វ យប ៩:៦ ៣៧:១៦ ទដ ១៨:៧–១៥ ១៩:៤,៥ ១០៤:២ សភ ៨:២៨ អស ៤០:២២ **៣៦:៣០** ស នក ១៩:១៦ យប ៣៧:១១,១៥ ទដ ១៨:១២,១៤ ៩៧:៤ យរ ១០:១៣ ហព ៣:១១ ហ ទដ ៦៨:២២ អស ៥១:១០ **៣៦:៣១** ឡ ចទ ២៨:២៣–២៤ ១ពវ ១៧:១ យប ៣៧:១៣ អម ៤:៧–៨ អ ទដ១៤៥:១៥ ក ទដ ១០៤:១៤–១៥,២៧–២៨ អស ៣០:២៣ កច ១៤:១៧ **៣៦:៣២** ខ យប ២៨:២៤ ៣៧:១២, ១៥ ទដ ១៨:១៤

ខ្យល់ដង្ហើមទ្រង់ ឯទីទឹកទាំងប៉ុន្មានក៏កករួញទៅដែរ[ន]
១១ទ្រង់ផ្ទុកពពកយ៉ាងក្រាស់ ដោយចំហាយទឹក[ប] ហើយទ្រង់
ផ្សាយពពកនៃផ្លេកបន្ទោរ[ផ]ទ្រង់ឱ្យសុសសាយ[ព] ១២ពពក
នោះក៏អណ្តែតត្រសែតទៅតាមព្រះហឫទ័យទ្រង់ ដើម្បីឱ្យ
បានធ្វើគ្រប់ទាំងអស់ដែលទ្រង់បង្គាប់ នៅលើទីផ្សេងៗនៅ
ផែនដី ដែលមានមនុស្សនៅ[ភ] ១៣ទ្រង់ធ្វើឱ្យកើតយ៉ាងដូច្នេះ
ដើម្បីជាការផ្ចាញ់ផ្ចាល[ម] ឬសំរាប់ស្រោចដីគេ ដោយសេច
ក្តីសប្បុរសរបស់ទ្រង់[យ]។
 ១៤ឱយ៉ូបអើយ សូមស្តាប់[រ]សេចក្តីនេះចុះ សូមឈរឱ្យនឹង
ហើយពិចារណាអស់ទាំងការអស្ចារ្យរបស់ព្រះសិន[ល] ១៥តើ
លោកជ្រាប ពីព្រះទ្រង់ដាក់កិរិតរបស់ទាំងនោះ ជាយ៉ាង
ណា ពីទ្រង់ធ្វើឱ្យផ្លេកបន្ទោរ[វ]នៃពពកទ្រង់ភ្លឺផ្លេកៗ ដូចម្តេច
ឬទេ[ស] ១៦តើលោកយល់ពីទំងន់នៃពពកជាយ៉ាងណា[ហ] គឺជា
កិច្ចការអស្ចារ្យរបស់ព្រះដ៏មានដំរិះសព្វគ្រប់ឬទេ[ឡ] ១៧តើ
លោកជ្រាបឬ ពីហេតុអ្វីដែលសំលៀកបំពាក់លោកក្តៅពេក
ក្នុងកាលដែលផែនដីស្ងប់ដោយខ្យល់បក់មកពីខាងត្បូង[អ]

២៩:៧–៩ **៣៦:៣៣** គ យប ៣៧:៥ ៤០:៩ ឃ យប ២៨:២៦ **៣៧:១** ក ទដ ៣៨:១០ អស ១៥:៥ យរ ៤:១៩ ហព ៣:១៦ **៣៧:២** ខ យប ៣២:១០ គ ខ.៥ ឃ ទដ ១៨:១៣ ២៩:៣–៩ **៣៧:៣** ង ២សយ ២២:១៣ ទដ ១៨:១៤ ច យប ៣៦:៣២ មថ ២៤:២៧ លក ១៧:២៤ **៣៧:៤** ឆ ១សយ ២:១០ ជ នក ២០:១៩ **៣៧:៥** ឈ ១សយ ២:១០ យហ ១២:២៩ ញ យប ៣៦:៣៣ ដ យប ៥:៩ ១១:៧–៩ ៣៦:៤ **៣៧:៦** ឋ ចទ ២៨:១២ យប ៣៨:២២ ឌ លប ៧:៤ យប ៥:១០ ២៨:២៦ **៣៧:៧** ឍ ទដ ១០៩:២៧ ណ ទដ ១០៤:១៩–២៣ ១១១:២ **៣៧:៨** ត យប ២៨:២៦ ថ យប ៣៨:៤០ ទដ ១០៤:២២ **៣៧:៩** ទ ទដ ៥០:៣ ធ ទដ ១៤៧:១៧ **៣៧:១០** ន យប ៣៨:២៩–៣០ ទដ ១៤៧:១៧ **៣៧:១១** ប យប ២៦:៨ ផ យប ៣៦:៣០ ព យប ២៨:២៦ **៣៧:១២** ភ ខ.៣ ទដ ១៤៧:១៦ ១៤៨:៨ **៣៧:១៣** ម លប ៧:៤ នក ៩:២២–២៣ ១សយ ១២:១៧ យ ១ពវ ១៨:៤៥ យប ៥:១០ ៣៦:៣១ ៣៨:២៧ **៣៧:១៤** រ យប ៣២:១០ ល យប ៥:៩ **៣៧:១៥** វ យប ៣៦:៣០ ស យប ៣៦:៣២ **៣៧:១៦** ហ យប ៣៦:២៩ ឡ យប ៥:៩ ៣៦:៤ **៣៧:១៧** អ កច ២៧:១៣

**៣៦:៣០** គឺជាលក្ខណៈពន្លឺ ។

**៣៦:៣១** *មើលអស់* គឺជាការគ្រប់គ្រងការស្វែងយល់ពីខគម្ពីរ ដែលបង្ហាញថាព្រះយេហូវ៉ាបានថែរក្សាផ្គត់ផ្គង់ដល់ជាតិសាសន៍ទាំងឡាយ ដែលបានបង្ហាញក្នុងខទាំងនេះ ខ.២៧–៣០ ។

**៣៧:១–១៣** គឺជាការបន្តបទទំនុកចម្រៀងរបស់លោកអេលីហ៊ូវ ក៏ជាការពណ៌នានៃភាពដ៏ស្ញប់ស្ញែងក្នុងបរិយាកាសនៅលើផែនដី ដែលផ្តើមបង្ហាញតាមរយៈ ៣៦:២៧ ។ គាត់ក៏កំរើកមានចិត្តញ័រ (មើល ខ.១) ។ អត្ថបទក៏បានបង្ហាញពីការអង្កេតនៃលក្ខខណ្ឌបរិយាកាស និងឥទ្ធិពលរបស់ពួកគេ ដូចជា : ការដែលទ្រង់បានជប់ទឹកទៅលើឱ្យប្រែជាចំហាយ រួចទំលាក់ជាភ្លៀងវិញ (មើល ៣៦:២៧ និងការពន្យល់) គឺពពកមានជាចំហាយ (មើល ៣៦:២៨ ៣៧:១១) និងភាពដែលជាពពកប្រែប្រួល (មើល ខ.២) គឺជាកម្លាំងមួយប្រភេទពីព្រះរាជបញ្ជា និងតែងតែសម្តែងព្រះទ័យចំពោះមនុស្សទោះជាការល្អ ឬភាពមានការឈឺចាប់ក្តី (ខ.១៣) ។

**៣៧:២** *ចូរស្តាប់* បើចំពោះព្រះគម្ពីរភាសាហេព្រើរវិញ ពាក្យនេះមានលក្ខណៈជាពហុវចនៈ គឺបញ្ជាក់ទៅលើមនុស្សផ្សេងៗគ្នាជាច្រើន (រួមទាំងមិត្តសំឡាញ់ទាំងបីរបស់លោកយ៉ូបផងដែរ) ក្រៅពីរឿងលោកយ៉ូប ក៏បានបញ្ជាក់នៅទីនេះដែរ (មើលការពន្យល់ ៣៦:១–៣៧:២៤) ។ *សូរគឹកកងនៃសំឡេងទ្រង់ផង គឺជាសូររំពងពីព្រះឱស្ឋទ្រង់* ផ្គរ (មើល ខ.៤) ។

**៣៧:៥** *យើងរាល់គ្នារកយល់មិនបាន* មើលការពន្យល់ ៣៦:២៦ ។

**៣៧:១០** *ខ្យល់ដង្ហើមទ្រង់* គឺជាពាក្យប្រៀបធៀបប្រដូចចំពោះខ្យល់សន្ទាប់ខ្លាំង ។

**៣៧:១៤–១៨** លោកអេលីហ៊ូវលើកទឹកចិត្តដល់លោកយ៉ូប សង្ឃឹមថាអំណាចព្រះចេស្តារបស់ព្រះអម្ចាស់ចំពោះការថ្លែងបញ្ជាក់នេះ (ជំពូក ៣៨–៤១) ។

**៣៧:១៦** *មានដំរិះសព្វគ្រប់* មើលការពន្យល់ ៣៦:៤ ។

១៨ តើលោកអាចនឹងជួយទ្រង់ក្នុងការផែផ្ទៃមេឃ[ក]ដែលរឹង
ជាងផែនកញ្ចក់សិតបានឬទេ[ខ] ១៩ សូមបង្ហាញសេចក្តីដែល
យើងរាល់គ្នាត្រូវទូលដល់ទ្រង់[គ] ដ្បិតនៅក្នុងសេចក្តីងងឹត
ដែលគ្របលើយើង[ឃ] នោះយើងមិនចេះរៀបចំពាក្យសំដី
ទេ[ង] ២០ តើត្រូវឱ្យមានអ្នកណាទូលទ្រង់ពីខ្ញុំកំពុងតែទូលឬអី
បើអ្នកណា ទូល នោះនឹងត្រូវលេបបាត់ជាពិតប្រាកដ ។
២១ រីឯមនុស្ស គេមើលថ្ងៃ[ច]ដែលភ្លឺនៅលើមេឃមិន
ឃើញទេ ទាល់តែមានខ្យល់បក់មកផាត់ពពកឱ្យស្រឡះទៅ
២២ ពីទិសខាងជើងមានចេញជារស្មីដ៏រុងរឿង[ឆ] តែព្រះទ្រង់
មានឫទ្ធានុភាពគួរស្ញែងខ្លាច[ជ] ២៣ ឯព្រះដ៏មានគ្រប់ព្រះ
ចេស្តា[ឈ] យើងរាល់គ្នាពុំអាចនឹងរកទ្រង់ឃើញទេ ទ្រង់មាន
តេជានុភាពដ៏ខ្ពស់បំផុត តែដោយទ្រង់មានសេចក្តីយុត្តិ
ធម៌[ញ]នឹងសេចក្តីសុចរិតពោរពេញ បានជាទ្រង់នឹងមិនធ្វើ
ទុក្ខទេ[ដ] ២៤ ហេតុនេះបានជាមនុស្សតែងតែកោតខ្លាច នៅ
ចំពោះទ្រង់[ឋ] តែទ្រង់មិនយោគយល់អ្នកណា ដោយគេមាន
ចិត្តប្រាជ្ញ[ឌ]ព្រោកទេ ។

**៣៧:១៨** ក លប ១:១,៨ យប ២២:១៤ ខ ចទ ២៨:២៣ **៣៧:១៩** គ រម ៨:២៦ ឃ យប ៩:៣ ង យប ១៣:១៨ **៣៧:២១** ច ពច ៥:៣១ កច ២២:១១ ២៦:១៣ **៣៧:២២** ឆ ទដ ១៩:៥ ជ នក ២៤:១៧ **៣៧:២៣** ឈ យប ៥:៩ ៣៦:៤ រម ១១:៣៣ អគ ១៨:២៣,៣២ ញ យប ៨:៣ ដ យប ៤:១៧ ទដ ៤៤:១ អស ៦៣:៩ យរ ២៥:៥ បទ ៣:៣៣

## ព្រះអម្ចាស់មានបន្ទូល

៣៨ ១ ខណៈនោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលពីក្នុងខ្យល់
កួច[ក]តបនឹងយ៉ូប[ខ]ថា ២ តើអ្នកណានេះដែលបង្អាប់ព្រះដំរិះ[គ]
ដោយសារពាក្យសំដីឥតប្រាជ្ញាដូច្នេះ[ឃ] ៣ ចូរក្រវាត់ចង្កេះ
ឯង ដូចជាមនុស្សក្លាហានឥឡូវចុះ អញនឹងសួរឯងហើយ
ឯងត្រូវប្រាប់ដល់អញ[ង] ៤ តើឯងនៅឯណាក្នុងកាលដែល
អញចាប់តាំងបង្កផែនដីឡើង[ច] ចូរប្រាប់មក បើឯងមាន
យោបល់[ឆ] ៥ បើឯងដឹង តើអ្នកណាបានកំណត់ទំហំផែនដី[ជ]
តើអ្នកណាបានសន្ធឹងខ្សែ[ឈ]ទៅវាស់ ៦ តើឫសផែនដីបាន
ជាប់នៅលើអ្វី[ញ] តើអ្នកណាបានបញ្ចុះថ្មជ្រុងនោះ[ដ] ៧ ក្នុង

អគ ១៨:២៣,៣២ **៣៧:២៤** ឋ លប ២២:១២ យប ២៨:២៨ សស ១២:១៣ មីក ៦:៨ មថ ១០:២៨ ឌ យប ៥:១៣ អភ ៥:១៥ **៣៨:១** ក យប ១១:៥ ខ នក ១៤:២១ ១សយ ២:១០ យប ៤០:៦ អស ២១:១ អគ ១:៤ **៣៨:២** គ ១ពវ ២២:៥ អស ៤០:១៣ ឃ យប ៣៤:៣៥ មក ១០:៣៨ ១ធថ ១:៧ **៣៨:៣** ង យប ៤០:៧ ៤២:៤ មក ១១:២៩ **៣៨:៤** ច ខ.៥ លប ១:១ ១សយ ២:៨ ឆ ខ.១៨ យប ៣៤:១៣ សភ ៣០:៤ **៣៨:៥** ជ ខ.៤ ទដ ១០២:២៥ សភ ៨:២៩ អស ៤០:១២ ៤៨:១៣ យរ ៣១:៣៧ ឈ យរ ៣១:៣៩ សក ១:១៦ ៤:៩–១០ **៣៨:៦** ញ សភ ៨:២៥ ដ យប ២៦:៧

**៣៧:១៨** មើល ២៦:៧ ។

**៣៧:១៩** *យើងមិនចេះរៀបចំពាក្យសំដី* លោកយ៉ូបហ៊ានការពារភាពស្អាតស្អំរបស់ខ្លួន(មើល ៣១:៣៥)។ ដូចនេះហើយបានជា លោកអេលីហ៊ូវស្វែងរកកំហុសដែលនាំឱ្យលោកយ៉ូបខ្មាសវិញ ប៉ុន្តែ គាត់បានបន្ទន់ពាក្យសម្តីដោយលើកឡើងថា ខ្លួនគាត់ក៏ត្រូវកោតខ្លាច ព្រះចេស្តាព្រះផងដែរ ។

**៣៧:២២** *ពីទិសខាងជើងមានចេញជារស្មីដ៏រុងរឿង* មើលការពន្យល់ ទដ ៤៨:២ ។ តែព្រះទ្រង់មានឫទ្ធានុភាព លោកអេលីហ៊ូវរៀបចំលោកយ៉ូបដើម្បីទទួលវត្តមានព្រះក្នុងពេលមានព្យុះ(ជំពូក ៣៨–៤១) ។

**៣៧:២៤** *កោតខ្លាច* ភ័យខ្លាច (មើល ២៨:២៨ លប ២០:១១ និងការពន្យល់)។

**៣៨:១–៤២:៦** ព្រះអម្ចាស់បានបង្ហាញសម្តែងឱ្យលោកយ៉ូបឃើញ គឺជាការសរសេរទុករបស់ព្រះយេហូវ៉ា (៣៨:១–៤០:២ ៤០:៦ ៤១:៣៤) ផ្នែកនិមួយៗ ក៏ត្រូវបានលោកយ៉ូបឆ្លើយតបដោយសង្ខេប ៤០:៣–៥,៤២:១–៦ ។

**៣៨:១** *ព្រះយេហូវ៉ា* មាននៃសេចក្តីសញ្ញារាស្ត្រអ៊ីស្រាអែលគឺជានាមសម្រាប់ព្រះអម្ចាស់ (មើលសេចក្តីផ្តើមត្រង់ : អ្នកនិពន្ធ)។ *ខ្យល់កួច* មើល ៤០:៦ ។ អេលីហ៊ូវដោយគិតថា ការបង្ហាញឱ្យឃើញនូវវត្តមានដ៏បរិសុទ្ធនៃព្រះមានអនុភាពគួរស្ញែងខ្លាច(៣៧:២២) ។ ទ្រង់ក៏ធ្វើការនេះឱ្យដឹងជាមុនតាមរយៈព្យុះនិងខ្យល់(មើលការពន្យល់ ៣៧:២២)ដែលជាព្រះសូរសៀងដែលទទួលបាន ។ លោកយ៉ូបក៏មានប្រសាន៍ថា "សូមឱ្យព្រះដ៏មានគ្រប់ព្រះចេស្តាឆ្លើយនូវសេចក្តីសំណើររបស់ខ្ញុំ" (៣១:៣៥)ឥឡូវនេះព្រះមានបន្ទូលទៅកាន់លោកយ៉ូប តែទ្រង់ពុំបានផ្តល់នូវសេចក្តីបញ្ជាក់ពីហេតុផលទ្រង់ដែលលោកយ៉ូបពុំបានសុំឡើយ ។ ការអ្វីដែលស្តែងចេញឫទ្ធានុភាពដ៏គួរឱ្យស្ញែងខ្លាចតាមរយៈផ្គរលាន់ ឬព្យុះផ្គរ ។ ទ្រង់បានរំឭកពីប្រាជ្ញាដែលមកពីទ្រង់គឺហួសឆ្ងាយដែលមនុស្សពុំអាចយល់បាន គឺប្រាជ្ញារបស់មនុស្សពុំមានលក្ខណៈដូចព្រះឡើយ ។

**៣៨:២** មើលការពន្យល់ ៣៥:១៦ ក្នុង ៤២:៣ លោកបាននិយាយឡើងវិញពីបន្ទូលរបស់ព្រះ ។ ព្រះអម្ចាស់បញ្ជាក់ថា ការប្រឆាំងនិងកំហឹងរបស់លោកយ៉ូបចំពោះព្រះគឺពុំយុត្តិធម៌ គឺវាបានមកពីការយល់ដឹងដែលមានកំណត់របស់មនុស្ស ។

**៣៨:៣** និយាយឡើងវិញក្នុង ៤០:៧ (មើល ៤២:៤)។ ការឆ្លើយតបរបស់ព្រះចំពោះលោកយ៉ូប ដែលមានសំនួរ តម្រូវឱ្យលោកយ៉ូបមានលក្ខណៈអវិជ្ជាមាន ឬភាពឥតដឹងអ្វីសោះ ។ ព្រះអង្គពុំបានមានបន្ទូលអ្វីអំពីភាពឈឺចាប់របស់លោកយ៉ូបទេ ឬក៏មិនបានបញ្ជាក់អំពីបញ្ហារបស់លោកយ៉ូបស្តីពីភាពយុត្តិធម៌ពីព្រះ ។ លោកយ៉ូបបានទទួលនូវលិខិតភស្តុតាង ឬក៏សាលក្រមនៃភាពគ្មានទោស តែអ្វីដែលសំខាន់នោះគឺព្រះអង្គធ្វើឱ្យអាម៉ាសមុខ ឬត្រូវកាត់ទោសគាត់ តែបើអ្នកឱ្យដំបូន្មានត្រឹមត្រូវនោះ ។ ការជំពាក់ទាក់ទងនឹងលោកយ៉ូបក៏បានបង្ហាញឱ្យឃើញច្បាស់(មើល ៤២:៧–៩ និងការពន្យល់)។ បទសន្ទនាបរិសុទ្ធ ខណៈនោះនាំឱ្យលោកយ៉ូបបានទទួលសេចក្តីជំនឿដ៏ពេញលេញក្នុងប្រាជ្ញារបស់ព្រះ និងភាពជាប្រសើរដោយពុំចាំបាច់ទទួលចម្លើយដោយផ្ទាល់ឡើយចំពោះចម្លើយរបស់គាត់ ។

**៣៨:៤–៣៨** ស្នាព្រះហស្តដែលជាអជីវចលគ្មានវិញ្ញាណក៏បញ្ជាក់អំពីភាពជាព្រះមហាក្សត្ររបស់អង្គទ្រង់ផ្ទាល់ និងអំណាចព្រះចេស្តា (ផែនដី ខ.៤–៧,១៨ សមុទ្រ ខ.៨–១១,១៦ ព្រះសូរិយា ខ.១២–១៥ និងការពិភពខាងការងងឹត ខ.១៧ គឺជាពន្លឺនិងភាពងងឹត ខ.១៩–២០ អាកាសធាតុ ខ.២២–៣០,៣៨ ក្រុមផ្កាយ ខ.៣១–៣៣) ។ មើលាការពន្យល់ ៣៨:៣៩–៣៩:៣០ ។

**៣៨:៤–៥** សូមមើលសំណួរស្រដៀងៗគ្នាក្នុសេចក្តីទាមទារ (មើល សភ ៣០:៤ អស ៤០:១២ និងការពន្យល់) ។

**៣៨:៧** មើល ទដ ១៤៨:២–៣ និងការពន្យល់ ទដ ៦៥:១៣ នៅពេលដែលផែនដីបានបង្កើតឡើងទេវតាក៏មាននៅទីនោះដើម្បីច្រៀងសរសើរដល់ព្រះអាទិករ តែលោកយ៉ូបអត់ទេ(មើល ខ.៤–៥) ។ គឺយ៉ូបមានប្រាជ្ញា ឬទស្សនៈ

កាលដែលផ្កាយព្រឹក[ឋ]បានច្រៀងជាមួយគ្នា[ឌ] ហើយអស់ទាំង
កូនព្រះ[ឍ]បានស្រែកអរសាទរ[ណ]។
៨ តើអ្នកណាបានបិទទ្វារទប់សមុទ្រទុក[ត] ក្នុងកាលដែល
ធ្លាយចេញមក បែបដូចជាសិរាលចេញពីផ្ទៃម្តាយ[ថ] ៩ គឺក្នុង
កាលដែលអញបានហ៊ុមដោយពពក ទុកដូចជាអាវ ហើយ
រុំព័ទ្ធនឹងសេចក្តីងងឹតជាយ៉ាងក្រាស់ ទុកជាកន្សែង[ទ] ១០ ព្រម
ទាំងដាក់គោលចារិកឱ្យ[ធ] ហើយក៏ដាក់រនុក និងទ្វារផង[ន]
១១ ដោយពាក្យថា ឯងនឹងមកបានតែត្រឹមនេះ និងហួសទៅ
ទៀតមិនបាន[ប] រលកដ៏អង់អាចរបស់ឯងត្រូវឈប់ទៅ
ទីនេះ[ផ]។
១២ តាំងពីឯងកើតមក តើឯងដែលបង្គាប់ដល់ពេល
ព្រឹក[ព] ឬឱ្យបច្ចូសកាលដឹងកំណត់[ភ] ១៣ ដើម្បីឱ្យបានចាប់ចុង
ផែនដីបំផុត ឱ្យមនុស្សអាក្រក់[ម] ត្រូវរលាស់ចេញទៅឬទេ[យ]
១៤ ពន្លឺនោះក៏ប្រែទៅបែបដូចជាដីឥដ្ឋ[រ]នៅក្រោមត្រា ហើយ
ផែនដីមានភាពដូចជាពាក់អាវ ១៥ ឯពួកមនុស្សអាក្រក់ គេ
ត្រូវបង្អត់ពន្លឺ[ល] ហើយដៃគេដែលបានលើកឡើងជាស្រេច
នោះបានត្រូវបាក់វិញ[វ]។
១៦ តើឯងដែលចូលទៅក្នុងរន្ធនៃទឹកសមុទ្រ ឬបានដើរ
ចុះទៅរកទីជិះរៅនៃបាតសមុទ្រឬទេ[ស] ១៧ ឯទ្វារនៃសេចក្តី
ស្លាប់[ហ] តើបានសំដែងមកឱ្យឯងឃើញ ឬឯងបានឃើញ
ទ្វារនៃប្លប់សេចក្តីស្លាប់ហើយឬនៅ[ឡ] ១៨ តើឯងបាន
ពិចារណាឃើញទទឹងបណ្តោយនៃផែនដីឬ[អ] ចូរប្រាប់មក
ចុះ បើឯងដឹងសេចក្តីទាំងអស់នេះហើយ[ក]។
១៩ តើផ្លូវឯណាដែលនាំទៅដល់សំណាក់នៃពន្លឺ ឯសេចក្តី
ងងឹត តើមានកន្លែងនៅឯណា[ខ] ២០ ដើម្បីឱ្យឯងបាននាំទៅ
ដល់ព្រំដែន ហើយឱ្យឯងបានស្គាល់ផ្លូវ[គ]ទៅឯទីលំនៅនៃ
សេចក្តីនោះ ២១ ប្រាកដជាឯងដឹងមែន ដ្បិតនៅគ្រានោះ
ឯងបានកើតមកហើយ[ឃ] ឯអាយុឯង ក៏វែងយូរណាស់ផង
២២ តើឯងបានចូលទៅក្នុងឃ្លាំងនៃហិមៈហើយឬ[ង] តើបាន
ឃើញឃ្លាំង[ច]នៃព្រិល[ឆ] ២៣ ដែលអញបានបំរុងទុកសំរាប់
គ្រាអន្តរាយឬ[ជ] គឺដល់ថ្ងៃតតាំងគ្នាក្នុងគ្រាមានចំបាំង[ឈ]
២៤ តើពន្លឺបានចែកទៅ[ញ] ឬខ្យល់ពីខាងកើត[ដ]បានផ្សាយទៅ
លើផែនដីតាមផ្លូវណា[ឋ]។
២៥ តើអ្នកណាបានជីកផ្លូវឱ្យទឹកធំហូរមក ឬផ្លូវឱ្យផ្លេក
បន្ទោរនៃផ្គរ[ឌ] ២៦ ដើម្បីនឹងបង្អុរភ្លៀង[ឍ]មកលើស្រុកដែល
ឥតមានអ្នកណានៅ ឬមកលើទីរហោស្ថាន ដែលគ្មាន
មនុស្សអាស្រ័យនោះឡើយ[ណ] ២៧ ប្រយោជន៍តែនឹងចំអែត
ដីចោលទទេ ហើយហួតហែង នឹងធ្វើឱ្យស្មៅពន្លកដុះឡើង
នោះ[ត] ២៨ តើភ្លៀងមានឪពុកឬ[ថ] តើអ្នកណាបានបង្កើតដំណក់
សន្សើម ២៩ តើទឹកកកបានចេញពីផ្ទៃអ្នកណា តើអ្នកណាបាន
បង្កើតសន្សើមកកដែលមកពីលើមេឃ[ទ] ៣០ ឯទឹកក៏ក្លាយទៅ
ដូចជាថ្ម ហើយខាងលើទីជិះរៅ នោះទឹកបានកកហើយ[ធ]។
៣១ តើឯងអាចនឹងចងទុកនូវកញ្ចុំនៃផ្កាយកូនមាន់ ឬ
ស្រាយចំណងនៃផ្កាយនាយព្រានបានឬ[ន] ៣២ តើឯងអាចនឹង
នាំរាសីច័ក្រ[ប]ទាំងប៉ុន្មានចេញតាមរដូវបាន ឬនឹងដំរង់ផ្កាយ
ក្រពើ ព្រមទាំងកូនផងបានឬ[ផ] ៣៣ តើឯងស្គាល់របៀប[ព]នៅ
លើផ្ទៃមេឃ[ភ]ហើយឬ តើឯងនឹងបង្គាប់អំណាចនៃរបស់
ទាំងនោះលើផែនដីបានដែរឬ ។
៣៤ តើឯងនឹងបន្លឺសំឡេងឡើង បង្គាប់ដល់ពពក ឱ្យបាន

**៣៨:៧** ឋ លប ១:១៦ ឌ ទដ ១៩:១–៤ ១៤៨:២–៣ ឍ ១ពវ ២២:១៩ ណ ចទ ១៦:១៥ **៣៨:៨** ត ឧ.១១ ទដ ៣៣:៧ សភ ៨:២៩ យរ ៥:២២ ថ លប ១:៩–១០ **៣៨:៩** ទ លប ១:២ **៣៨:១០** ធ យប ២៨:២៥ ទដ ៣៣:៧ ១០៤:៩ អស ៤០:១២ ន នហ ៣:៣ យប ៧:១២ ២៦:១០ **៣៨:១១** ប ឧ.៨ ផ ទដ ៦៥:៧ ៨៩:៩ ១០៤:៦–៩ **៣៨:១២** ព ទដ ៥៧:៨ ភ ទដ ៧៤:១៦ អម ៥:៨ **៣៨:១៣** ម ទដ ១០៤:៣៥ យ យប ៨:២២ **៣៨:១៤** រ នក ២៨:១១ **៣៨:១៥** ល ចទ ២៨:២៩ យប ១៥:២២ ១៨:៥ វ លប ១៧:១៤ យប ៤:១០ ៣១:២២ **៣៨:១៦** ស លប ១:៧ យប ៩:៨ **៣៨:១៧** ហ យប ៣៣:២២ មថ ១៦:១៨ វវ ១:១៨ ឡ យប ៧:៩ **៣៨:១៨** អ យប ២៨:២៤ អស ៤០:១២ ក ឧ.៤ **៣៨:១៩** ខ លប ១:៤ យប ២៨:៣ ទដ ១៣៩:១១–១២ **៣៨:២០** គ យប ២៤:១៣ **៣៨:២១** ឃ យប ១៥:៧ **៣៨:២២** ង យប ៣៧:៦ ច ចទ ២៨:១២ ឆ ទដ ១០៥:៣២ ១៤៧:១៧ **៣៨:២៣** ជ ទដ ២៧:៥ អស ២៨:១៧ ៣០:៣០ អគ ១៣:១១ ឈ នក ៩:២៦ យស ១០:១១ អគ ១៣:១៣ វវ ១៦:២១ **៣៨:២៤** ញ យប ២៨:២៤ ដ យប ២៧:២១ ឋ យរ ១០:១៣ ៥១:១៦ **៣៨:២៥** ឌ យប ២៨:២៦ **៣៨:២៦** ឍ យប ៣៦:២៧ ណ ទដ ៨៤:៦ ១០៧:៣៥ អស ៤១:១៨ **៣៨:២៧** ត យប ២៨:២៦ ៣៧:១៣ ទដ ១០៤:១៤ **៣៨:២៨** ថ ២សយ ១:២១ យប ៥:១០ **៣៨:២៩** ទ ទដ ១៤៧:១៦–១៧ **៣៨:៣០** ធ យប ៣៧:១០ **៣៨:៣១** ន យប ៩:៩ អម ៥:៨ **៣៨:៣២** ប ២ពវ ២៣:៥ អស ១៣:១០ ៤០:២៦ ៤៥:១២ យរ ១៩:១៣ ផ លប ១:១៦ **៣៨:៣៣** ព ទដ ១៤៨:៦ យរ ៣១:៣៦ ភ លប ១:១៦

តិចតួចណាស់ដែលយល់ពីព្រះ ឬយល់ពីនិស្ស័យមនុស្ស ។ ទេវតា មើលការពន្យល់ ១:៦,២:១ ។

**៣៨:១០–១១** មើល ទដ ៣៣:៧ និងការពន្យល់ យរ ៥:២២ ។

**៣៨:១១** *ដោយពាក្យថា* ព្រះអម្ចាស់ជាព្រះវបិតាដែលគ្រប់គ្រងសមុទ្រ ដោយមានបន្ទូលទៅកាន់សមុទ្រ គឺដូចព្រះរាជបុត្រាធ្វើដូច្នេះដែរ (មើល មក ៤:៤ និងការពន្យល់ លក ៨:២៤–២៥) ។

**៣៨:១៤** *ដីឥដ្ឋនៅក្រោមត្រា* គឺជារាងស៊ីឡាំង (មើលការពន្យល់ លប ៣៨:១៨) ឬក៏ត្រាសម្រាប់ព្រះ ។

**៣៨:១៥** *បង្អត់ពន្លឺ* ពេលរាត្រីជាពេលនៃពួកអាក្រក់មានសកម្មភាព (មើល យហ ៣:១៩ ក៏ដូចជាការងារធ្វើរូបព្រះ ប្រៀបធៀប លក ១១:៣៥)។ *ហើយដៃដែលបានលើកឡើងជាស្រេចនោះ ត្រូវបាក់វិញ* មើល ២២:៩ និងការពន្យល់ ។

**៣៨:១៦** *ក្នុងរន្ធទឹកសមុទ្រ* មើល លប ៧:១១,៨,២ ។

**៣៨:១៧** *ទ្វារនៃសេចក្តីស្លាប់* សូមមើលការពន្យល់នៅក្នុង ១៧:១៦ មើល ២៦:៥–៦ ។

**៣៨:២២–២៣** *ឃ្លាំងនៃហិមៈ . . . ហើយឃ្លាំងនៃព្រិល* មើលឧទាហរណ៍ យស ១០:១១ អស ២៨:២ និងការពន្យល់ ។

**៣៨:២៤** *ខ្យល់ពីខាងត្បូង* មើលការពន្យល់ ១៥:២ ។

**៣៨:៣១–៣២** *មានកញ្ចុំផ្កាយកូនមាន់ . . . នឹងដំរង់ផ្កាយព្រឹក* មើលការពន្យល់ ៩:៩ ។

ទឹកជាបរិបូរធ្លាក់មកលើឯងបានឬ[ម] ៣៥ តើអាចនឹងបញ្ជូន
ផ្លេកបន្ទោរ ឱ្យបានចេញទៅ[យ] ដោយឆ្លើយមកឯងថា
"បាទ" បានឬទេ ៣៦ តើអ្នកណាបានដាក់ប្រាជ្ញា[រ] នៅក្នុងចិត្ត
ឬឱ្យមានយោបល់[ល] នៅក្នុងវិញ្ញាណ ៣៧ តើអ្នកណានឹងរាប់
ពពកដោយប្រាជ្ញាបាន ឬនឹងផ្អៀងដប[វ] នៃផ្ទៃមេឃ[ស] ឱ្យទឹក
ចេញមក ៣៨ ដើម្បីឱ្យធូលីបានហូរប្រសព្វគ្នា[ហ] ហើយឱ្យដុំដី
បានរលាយជាប់គ្នាវិញ[ឡ] ។
៣៩ តើឯងនឹងរករំពាឱ្យសិង្ហញី ឬចំអែតដល់កូនសិង្ហ
ដែលឃ្លាន[អ] ៤០ ក្នុងកាលដែលដេកនៅក្នុងរូងរបស់វា[ក] ឬ
ម៉បចាំសង្រ្គុបនៅទីកំបាំងបានឬទេ[ខ] ៤១ តើអ្នកណាផ្គត់ផ្គង់
អាហារ[គ] ឱ្យក្អែក[ឃ] ក្នុងកាលដែលកូនវា ស្រែកសូមដល់ព្រះ
ហើយហើរចុះឡើង ដោយព្រោះខ្វះអាហារ[ង] ។

**៣៩** ១ តើឯងដឹងជាវេលាណាដែលពពែព្រៃ[ក] នៅភ្នំថ្ម
សំរាលកូន ឬនឹងចំណាំបានពេលដែលក្តាន់ញីទំលាក់កូន
ឬទេ[ខ] ២ តើឯងនឹងកំណត់ដឹងជាវាត្រូវបានទំងន់ប៉ុន្មានខែ
ឬរដូវដែលនឹងកើតកូនមកឬទេ[គ] ៣ វាចំកោងខ្លួនសំរាលកូន
មក រួចផុតពីសេចក្តីឈឺចាប់របស់វា ៤ កូនវាត្រឡប់ជារឹង
ប៉ឹង ហើយក៏ធំឡើងនៅវាលស្រឡះ រួចឃ្លាតចេញពីមេទៅ
ឥតត្រឡប់មកវិញឡើយ ។
៥ តើអ្នកណាបានលែងលាព្រៃ[ឃ] ឱ្យមានសេរីភាព ឬអ្នក
ណាបានស្រាយចំណងលាផ្លាង ៦ ដែលអញបានឱ្យមាន
ទីកន្លែងនៅទីរហោស្ថាន[ង] ហើយទីមានដីប្រៃ[ច] ជាលំនៅវា[ឆ]
៧ វាតោះតើយ[ជ] នឹងការអឺកធឹកនៅទីក្រុង ក៏មិនឮសំរែកនៃ
អ្នកបញ្ជូរវាឡើយ[ឈ] ៨ ដងភ្នំ[ញ] ជាទីរកស៊ីរបស់វា វាខំស្វែង
រកអស់ទាំងស្លឹកខៀវខ្ចី ។
៩ តើគោព្រៃ[ដ] នឹងសុខចិត្តឱ្យឯងប្រើឬ[ឋ] តើវានឹងនៅជាប់
ក្បែរទ្រុងស្មៅ[ឌ] របស់ឯងឬ ១០ ឯងអាចនឹងចងគោព្រៃឱ្យភ្ជួរ
តាមគន្លងបានឬទេ[ឍ] តើវានឹងព្រមរាស់វាលច្រកភ្នំតាមឯង
ទៅឬទេ ១១ តើឯងនឹងទុកចិត្តដល់វា ដោយព្រោះមាន
កំឡាំងខ្លាំង[ណ] ឬនឹងទុកការឯងឱ្យវាធ្វើបានឬទេ ១២ តើឯង
នឹងពឹងវាឱ្យដឹកស្រូវឯងចូលមក ព្រមទាំងប្រមូលស្រូវនៅ
លានឯងឬទេ ។
១៣ ឯស្លាបសត្វអូសទ្រីចញី វាទទះដោយអំណរ តែ
ចំអេង និងស្លាបវា តើជារបស់សត្វកុកឬ[ត] ១៤ វាពងចោល
នៅលើដី ក៏បង្ហប់ពងឱ្យក្តៅដោយសារខ្សាច់ ១៥ ដោយឥត
នឹកថា ជើងគេនឹងជាន់បំបែកបង់ ឬសត្វព្រៃណានឹងជាន់ឈ្លី
ទៅទេ[ថ] ១៦ វាទុរជនចំពោះកូន[ទ] ដូចជាមិនមែនរបស់ខ្លួន
ទេ ហើយដែលវាពងជាឥតប្រយោជន៍នោះ ក៏មិនរវល់ផង
១៧ ពីព្រោះព្រះទ្រង់បង្អត់ប្រាជ្ញាដល់វា ក៏មិនបានប្រទានឱ្យ
វាមានយោបល់ដែរ[ធ] ១៨ វេលាណាដែលវាចំអើតខ្លួនខ្ពស់
ឡើង នោះវាមើលងាយ[ន] ដល់ទាំងសេះ និងអ្នកជិះផង ។
១៩ តើឯងឬអី ដែលឱ្យសេះមានកំឡាំង[ប] តើឯងឬអីដែល

**៣៨:៣៤** ម យប ៥:១០ ២២:១១ **៣៨:៣៥** យ យប ៣៦:៣២ **៣៨:៣៦** រ យប ៩:៤ ៣៤:៣២ យក ១:៥ ល យប ១២:១៣ **៣៨:៣៧** វ យប ៣:១៦ ស យប ២២:១១ **៣៨:៣៨** ហ លវ ២៦:១៩ ឡ ១ពវ ១៨:៤៥ **៣៨:៣៩** ឡ លប ៤៩:៩ **៣៨:៤០** អ យប ៣៧:៨ ក លប ៤៩:៩ **៣៨:៤១** ខ លប ១:៣០ គ លប ៨:៧ លក ១២:២៤ ឃ ទដ ១៤៧:៩ មថ ៦:២៦ **៣៩:១** ក ចទ ១៤:៥ ខ លប ៤៩:២១ **៣៩:២** គ លប ៣១:៧–៩ **៣៩:៥** ឃ លប ១៦:១២ **៣៩:៦** ង យប ២៤:៥ ទដ ១០៧:៣៤ យរ ២:២៤ ច យប ៣០:៤ ឆ យប ៣០:៧ យរ ១៤:៦ ១៧:៦ **៣៩:៧** ជ យប ៥:២២ ឈ យប ៣:១៨ **៣៩:៨** ញ អស ៣២:២០ **៣៩:៩** ដ ជន ២៣:២២ ឋ នក ២១:៦ ឌ លប ៤២:២៧ **៣៩:១០** ឍ យប ៤១:១៣ ទដ ៣២:៩ **៣៩:១១** ណ ខ.១៩ យប ៤០:១៦ ៤១:១២,២២ ទដ ១៤៧:១០ **៣៩:១៣** ត សក ៥:៩ **៣៩:១៥** ថ ២ពវ ១៤:៩ **៣៩:១៦** ទ ខ.១៧ បទ ៤:៣ **៣៩:១៧** ធ ខ.១៦ យប ២១:២២ **៣៩:១៨** ន យប ៥:២២ **៣៩:១៩** ប ខ.១១

**៣៨:៣៦** *ក្នុងចិត្ត . . . នៅក្នុងវិញ្ញាណ* ដែលក្នុងនោះពាក្យទីមួយបានបកប្រែ (សត្វបក្សី) និងទីពីរគឺ "មានដុល" បក្សីពីរក្បាលដែលជាទម្លាប់នូវពេលខ្លះគេបានអង្កេតឃើញដោយមនុស្សដែលចង់ផ្សាយពីអាកាសធាតុ ។ បើដូច្នេះ ពាក្យនេះបង្ហាញជាលក្ខណៈប្រែប្រួលទៅឯផ្នែកមួយទៀត នៃអត្ថបទពីព្រះជាមុន ។

**៣៨:៣៩–៣៩:៣០** ការបង្កើតជាស្នាព្រះហស្ត ក៏បញ្ជាក់ពីភាពជាក្សត្រនៃព្រះអម្ចាស់របស់យើង ដែលមានអំណាចព្រះចេស្តា សេចក្តីស្រឡាញ់ថ្នាក់ថ្នម (សិង្ហ ៣៨:៣៩–៤០ ក្អែក ៣៨:៤១ ពពែព្រៃ ៣៩:១–៤ ក្តាន់ញី ខ.៥–៨ គោព្រៃ ខ.៩–១២ សត្វអូទ្រី ខ.១៣–១៨ សត្វសេះ ខ.១៩–២៥ សត្វអក ខ.២៦ ឥន្ទ្រី ខ.២៧–៣០) មើលការពន្យល់ ៣៨:៤–៣៨ ។

**៣៨:៤១** *ផ្គត់ផ្គង់អាហារឱ្យក្អែក* ព្រះអម្ចាស់ទ្រង់បានថែរក្សា និងផ្គត់ផ្គង់គ្រប់អស់ទាំងសត្វស្រុក ហើយនិងសត្វហើរលើអាកាស ដែលមានសត្វក្អែកគឺជាតំណាងមួយ (ឧ.ប្រៀបធៀប លក ១២:២៤ ជាមួយ មថ ៦:២៦) ។

**៣៩:៥** *លាព្រៃ* មើល ២៤:៥ ក៏បានបង្ហាញពណ៌នាក្នុង លប ១៦:១២ និងការពន្យល់ ។

**៣៩:៩–១២** ការសម្តែងមានលក្ខណៈផ្ទុយគ្នារវាងលាព្រៃ និងលាស្រុក (មើល ខ.៧) ខគម្ពីរទាំងនោះក៏បង្ហាញពីភាពផ្ទុយគ្នារវាងគោព្រៃ និងសត្វគោស្រុកផងដែរ ។

**៣៩:១១** *កំឡាំងខ្លាំង* ក្នុងគម្ពីរសញ្ញាថ្មី ដូចជាគោព្រៃ (គឺជាឃ្លាតំណាងឱ្យភាពខ្លាំងជាកម្លាំងដ៏អស្ចារ្យ) មើល ឧ. ជន ២៣:២២ និងការពន្យល់ ២៩:៦) ។ ក្រោយមកមានដំរីនិងដាយណូស៊ី សត្វគោព្រៃគឺជាសត្វដីគោកដែលជាពពួកសត្វដែលមានកម្លាំងខ្លាំងក្លា ហើយធំបំផុតដែលមានឃើញនៅគម្ពីរសញ្ញាចាស់ ។

**៣៩:១៣–១៨** វគ្គនេះ (គាថា) ស៊ីទៅនិងអត្ថបទសន្ទនា ពីព្រោះក្នុងវគ្គនេះព្រះយេហូវ៉ាបានសួរលោកយ៉ូបដោយគ្មានសំណួរច្បាស់លាស់ ។

**៣៩:១៣** *ចំអេង និងស្លាបវា តើជារបស់សត្វកុកឬ* ក៏បង្ហាញឱ្យឃើញដូចជាស្លាបសត្វក្រសាដែលត្រដាងស្លាប (មើល សក ៥:៩) ។

**៣៩:១៨** *ទាំងសេះ និងអ្នកជិះផង* បង្កើតបានជាការប្រែប្រួលចំពោះវគ្គបន្ទាប់ទៀត ។

**៣៩:១៩–២៥** សត្វសេះ គឺសំដៅទៅលើសត្វពាហនៈក្នុងស្រុកតែប៉ុណ្ណោះតាមពិតការបំភ្លឺ គឺមិនមែនជាសេះសម្រាប់បម្រើព្រះទេ តែវាជាប្រភេទសេះសម្រាប់ធ្វើសង្គ្រាមវិញ ។

តាក់តែង ឱ្យសេះមានសក់ដែលរលាស់ ដោយខ្យល់ ២០តើ
ឯងឬអី ដែលធ្វើឱ្យវាអាចលោត ដូចជាកណ្ដូប[ផ] ឯអាការៈ
កំញើញ[ព]របស់វា នោះគួរស្ញែងខ្លាច[ភ] ២១វាកាយឫលដីនៅ
វាលច្រកភ្នំ ហើយក៏អរសប្បាយដោយកំឡាំង[ម]វាក៏ចេញ
ទៅប្រទល់នឹងមនុស្ស ដែលពាក់គ្រឿងសស្ត្រាវុធ[យ] ២២វា
មើលងាយ[រ]សេចក្ដីភិតភ័យ ហើយមិនចេះរុញរាឡើយ
ក៏មិនដែលគេចចេញពីដាវដែរ ២៣បំពង់ព្រួញ[ល]ក៏ឮក្រុក
ក្រាក់នៅលើវា ព្រមទាំងលំពែង[វ]ដែលភ្លឺផ្លេកៗ និងដែក
ពួយផង ២៤វាកញ្ច្រោលអន្ទះសាទាំងតន្ត្រំដី ហើយកាលឮ
សូរត្រែនោះទប់វាមិនបានឡើយ[ស] ២៥វេលាណាដែលវាឮ
សូរត្រែ[ហ] នោះវាស្រែកថា ហេះហេ វាស្រង់ក្លិនចំបាំងពី
ចំងាយ ក៏ស្គាល់សំរែកនៃពួកមេទ័ព និងសូរទ្រហឹង
អឺងអាប់[ឡ]។

២៦តើអកហើរសំកាំងស្លាប ហើយត្រដាងស្លាបវាទៅ
ទិសខាងត្បូង ដោយប្រាជ្ញារបស់ឯងឬ[អ] ២៧តើឥន្ទ្រីហើរទៅ
លើ ហើយធ្វើសំបុកនៅទីខ្ពស់តាមបង្គាប់ឯងឬអី[ក] ២៨វានៅ
លើទីចំហុងភ្នំ ក៏ធ្វើសំបុកនៅទីនោះ គឺនៅទីបំផុតនៃញកភ្នំ[ខ]
ជាទីមាំមួន ២៩ពីទីនោះវាក្រឡេកគន់រករំពា[គ] ភ្នែកវាមើល
ទៅឃើញឆ្ងាយ ៣០កូនវាក៏ជញ្ជក់ស៊ីឈាម ឯកន្លែងណា
ដែលមានគេសំឡាប់គ្នា នោះវាក៏មាននៅទីនោះ[ឃ]។

**៤០** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលដល់យ៉ូបទៀតថា[ក] ២ឯង
ដែលប្រកាន់ទោសដូច្នេះ តើនឹងធ្វើឱ្យព្រះដ៏មានគ្រប់ព្រះ
ចេស្ដា[ខ]រាងចាលឬ[គ] ឯងដែលបន្ទោសដល់ព្រះដូច្នេះ ចូរ
ឆ្លើយមកចុះ[ឃ]។

៣នោះយ៉ូបទូលឆ្លើយដល់ព្រះយេហូវ៉ាថា ៤មើលទូល
បង្គំថោកទាបណាស់[ង] តើនឹងទូលដល់ទ្រង់ដូចម្ដេចបាន ទូល
បង្គំនឹងដាក់ដៃខ្ទប់មាត់វិញ[ច] ៥ទូលបង្គំបាននិយាយម្ដងហើយ
ឥឡូវមិនឆ្លើយទៀតឡើយ[ឆ] អើ បាននិយាយ២ដងផង តែ
លែងពោលអ្វីទៀតហើយ[ជ]។

៦នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលពីក្នុងខ្យល់កួច តប
ដល់យ៉ូបថា[ឈ] ៧ចូរក្រវាត់ចង្កេះឯង ដូចជាមនុស្សក្លាហាន
ឥឡូវចុះ ដ្បិតអញនឹងសួរឯង ហើយឯងត្រូវប្រាប់ដល់អញ[ញ]
៨តើឯងចង់រំលុបរំលាងទាំងសេចក្ដីវិនិច្ឆ័យរបស់អញផង
ឬ[ដ] តើឯងនឹងកាត់ទោសដល់អញឱ្យតែឯងបានសុចរិតឬអី[ឋ]
៩តើឯងមានដៃដូចព្រះដែរឬ[ឌ] តើឯងចេះបញ្ចេញសំឡេង[ឍ]
ជាផ្គរដូចជាទ្រង់បានឬទេ[ណ]។

១០ចូរឯងតែងខ្លួន ដោយសេចក្ដីរុងរឿង និងសេចក្ដី
ខ្ពង់ខ្ពស់ឥឡូវ ចូរប្រដាប់ខ្លួនដោយកិត្តិយស និងសិរីល្អចុះ[ត]
១១ចូរឱ្យឯងកំចាយសេចក្ដីកំហឹងឯង[ថ] ឱ្យសុសសាយទៅ
ហើយបង្រ្កាបគ្រប់ទាំងមនុស្ស ដែលមានឫកខ្ពស់ ដោយ១
ក្រឡេកភ្នែកចុះ[ទ] ១២ចូរមើលទៅគ្រប់ទាំងមនុស្សឆ្មើងឆ្មៃ[ធ]

**៣៩:២០** ផ យអ ២:៤–៥ វវ ៩:៧ ព យប ៤១:២៥ ភ យរ ៨:១៦ **៣៩:២១** ម ខ.១១ យ យរ ៨:៦ **៣៩:២២** រ យប ៥:២២ **៣៩:២៣** ល អស ៥:២៨ យរ ៥:១៦ វ នហ ៣:៣ **៣៩:២៤** ស ជន ១០:៩ យរ ៤:៥,១៩ អគ ៧:១៤ អម ៣:៦ **៣៩:២៥** ហ យស ៦:៥ ឡ យរ ៨:៦ អម ១:១៤ ២:២ **៣៩:២៦** អ យរ ៨:៧ **៣៩:២៧** ក យរ ៤៩:១៦ អប ១:៤ ហព ២:៩ **៣៩:២៨** ខ យរ ៤៩:១៦ អប ១:៣ **៣៩:២៩** គ យប ៩:២៦ **៣៩:៣០** ឃ មថ ២៤:២៨ លក ១៧:៣៧ **៤០:១** ក យប ៥:៨ ១០:២ **៤០:២** ខ យប ១៣:៣ គ យប ៩:១៥ ១១:៨ ៣៣:១៣ រម ៩:២០ ឃ យប ៩:៣ **៤០:៤** ង យប ៤២:៦ ច ពច ១៨:១៩ យប ២៩:៩ **៤០:៥** ឆ យប ៩:៣ ជ យប ៩:១៥ **៤០:៦** ឈ នក ១៤:២១ យប ៣៨:១ **៤០:៧** ញ យប ៣៨:៣ **៤០:៨** ដ យប ១៥:២៥ ២៧:២ រម ៣:៣ ឋ យប ២:៣ ៣៤:១៧ **៤០:៩** ឌ ២រប ៣២:៨ ទដ ៩៨:១ ឍ អស ៦:៨ អគ ១០:៥ ណ នក ២០:១៩ យប ៣៦:៣៣ **៤០:១០** ត ទដ ២៩:១–២ ៤៥:៣ ៩៣:១ ៩៦:៦ ១០៤:១ ១៤៥:៥ **៤០:១១** ថ យប ២០:២៨ ទដ ៧:១១ អស ៥:២៥ ៩:១២,១៩ ១០:៥ ១៣:៣,៥ ៣០:២៧ ៤២:២៥ ៥១:២០ យរ ៧:២០ នហ ១:៦ សផ ១:១៨ ទ ទដ ១៨:២៧ អស ២:១០,១២, ១៧ ២៣:៩ ២៤:១០ ២៥:១២ ២៦:៥ ៣២:១៩ **៤០:១២** ធ ទដ ១០:៤ អស ២៥:១១ យរ ៤៨:២៩ ៤៩:១៦ សផ ២:១០

**៣៩:២០** *ដូចជាកណ្ដូប* សត្វសេះ និងសត្វកណ្ដូបត្រូវបានគេប្រៀបធៀបក្នុងកណ្ឌគម្ពីរ យរ ៥១:២៧ វវ ៩:៧ ប្រៀបធៀប យអ ២:៤ និងការពន្យល់ ។
**៣៩:២៦** *អក* ក៏ជាប្រភេទសត្វចាបម្យ៉ាង ដែលធ្លាប់មាននៅឯទឹកដីបរិសុទ្ធវាឈប់នៅទីនោះដោយសារការបំលាស់ប្ដូរទីតាំងក្នុងរដូវធ្លាក់ខ្យល់ ។
**៣៩:២៧** *ឥន្ទ្រី* ឬក៏អាចជា "សត្វត្មាត" (មើល ខ.៣០) ។
**៤០:១–២** សេចក្ដីបញ្ចប់នៃការថ្លែងពីព្រះដ៏បំផុតបង្អស់ ព្រះអម្ចាស់បានជំរុញលោកយ៉ូបឱ្យឆ្លើយសំនួររបស់ទ្រង់ ។
**៤០:៣–៥** លោកយ៉ូបកំណត់ទុកដាក់នូវកំរិត និងពុំមានលក្ខណៈជាព្រះមហាក្សត្រទេ ក៏ពុំមានពោលពាក្យទាស់ប្រឆាំងទៀតដែរ ។
**៤០:៤** *ថោកទាបណាស់* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "តូចទាប ឬក៏គ្មានតម្លៃ" ។
**៤០:៥** *ម្ដងហើយ . . . និយាយ២ដងផង* មើលការពន្យល់ ៥:១៩ ។
**៤០:៦** មើល ៣៨:១ និងការពន្យល់ ។
**៤០:៧** ដែលនិយាយឡើងវិញពី ៣៨:៣ (មើលការពន្យល់នៅទីនោះ) ។
**៤០:៨–១៤** មានលក្ខណៈជាអត្ថបទបុរេកថា ចំពោះផ្នែកថ្លែងបញ្ជាក់ពីព្រះលើកទី២ដែលត្រូវបញ្ចប់វិញនៅ ៤១:៣៤ គឺមានលក្ខណៈមិនដូចការថ្លែងបង្ហាញនូវស្ថានភាពដ៏យុត្តិធម៌របស់ព្រះអង្គផ្ទាល់ ។ ក្នុងជំពូកទី២១ និង២៤ លោកយ៉ូបបានតវ៉ាប្រឆាំងនឹងភាពមិនខុសគ្នារបស់ព្រះ ឆ្ពោះទៅរកសកម្មភាពអាក្រក់នៃពួកអាក្រក់ ។ ក្នុងវគ្គនេះ ព្រះអម្ចាស់ក៏សម្ដែងពីសមត្ថភាពគ្រប់គ្រងនៃអង្គទ្រង់ ជាពិសេសករណីលោកយ៉ូប ។ គឺជាអ្វីដែលទាក់ទងទៅនឹងលោកយ៉ូប (មើល ខ.១៤ និង ខ.៩) ។
**៤០:៨** *តើឯងនឹងកាត់ទោសដល់អញឱ្យតែឯងបានសុចរិតឬអី* ក្នុង ១៩:៦ លោកយ៉ូបបាននិយាយថា "ព្រះអម្ចាស់បានដាក់កំហុសលើគាត់" ។
**៤០:១០** *ចូរឯងតែងខ្លួន ដោយសេចក្ដីរុងរឿង និងសេចក្ដីខ្ពង់ខ្ពស់ឥឡូវ* គឺដូចជាពាក្យហេព្រើរដែលវែកញែកពីអនុប្រយោគពណ៌នាពីព្រះអម្ចាស់ ទដ ១០៤:១ ។ ឯងត្រូវតែងខ្លួនដោយភាពសង្ហា និងភាពខ្ពង់ខ្ពស់ ។ ក្នុងខនេះ ព្រះឱ្យលោកយ៉ូបឱ្យធ្វើខ្លួនឱ្យបានល្អឡើង តាមគំរូនៃលក្ខណៈរបស់ទ្រង់ បើសិនជាគាត់អាចធ្វើបាន ។ *តែងខ្លួន* មើលការពន្យល់ ទដ ១០៩:២៩ ។
**៤០:១១–១២** មើល អស ១៣:១១ គឺព្រះយេហូវ៉ាដែលបានធ្វើការពិពណ៌នាពីអង្គទ្រង់ ។

ហើយបន្ទាបគេ[ន] ចូរជាន់ឈ្លី[ប]ពួកមនុស្សអាក្រក់នៅកន្លែង
ដែលគេឈរតែម្តង ១៣ចូរកប់គេទាំងអស់គ្នានៅក្នុងដី
ហើយចង[ផ]គ្រលុំមុខគេ ទុកក្នុងទីងងឹតនៃផ្នូរ[ព] ១៤នោះអញ
នឹងថ្លែងប្រាប់ពីឯងថា ដៃស្តាំនៃឯងអាចនឹងជួយសង្គ្រោះ
ឯងបាន[ភ] ។

១៥មើលដំរីទឹក ដែលអញបានបង្កើតមក[ម] ដូចឯងដែរ
វាស៊ីស្មៅដូចគោ[យ] ១៦មើល កំឡាំង[រ]វានៅត្រង់ចង្កេះ
ហើយសេចក្តីប្រឹងប្រែងរបស់វានៅត្រង់សរសៃពោះ[ល]
១៧វាបក់កន្ទុយ ដូចជាដើមតាត្រៅ ហើយអស់ទាំងសរសៃ
លោងរបស់វាព័ន្ធពាក់លើគ្នា[វ] ១៨ឆ្អឹងវាដូចជាបំពង់លង្ហិន
ហើយឆ្អឹងជំនីរ[ស]ដូចជាចំរឹងដែក[ហ] ១៩វាជាការយ៉ាងសំខាន់
របស់ព្រះ[ឡ] ហើយព្រះដែលបង្កើតវា[អ]ក៏បានប្រទានឱ្យមាន
ចង្កូម[ក] ២០ឯអាហារវា ក៏ដុះនៅលើភ្នំ[ខ] ជាកន្លែងដែលសត្វ
ព្រៃទាំងឡាយប្រឡែង[គ]គ្នា[ឃ] ២១វាដេកនៅក្រោមម្លប់ឈើ[ង]
ជាទីកំបាំងក្នុងព្រៃកក់[ច] ២២ដើមឈើបាំងម្លប់គ្របលើវា
ហើយដើមចាកតាមមាត់ទឹក[ឆ]ក៏ព័ទ្ធវាជុំវិញ ២៣មើល បើ
កាលណាទន្លេជន់ឡើង[ជ] វាមិនភ័យទេ ទោះបើទន្លេដូច
យ៉ាងទន្លេយ័រដាន់[ឈ] ឡើងលិចមាត់ច្រាំងក៏ដោយ គង់តែវា
មានចិត្តរឹងត្អឹងដែរ ២៤តើនឹងចាប់បានក្នុងកាលដែលកំពុង
នៅភ្នែកបើក ឬនឹងខ្ចះច្រមុះវាដោយដែកចោះបានឬទេ[ញ] ។

**៤១** ១តើឯងនឹងស្ទូច[ក]ចាប់ក្រពើ[ខ]បាន ឬនឹងយកខ្សែទៅ
ចងអណ្តាតវាបានឬទេ ២តើឯងនឹងដាក់កន្ទុះនៅច្រមុះវា[គ]
ឬយកទំពក់ផ្តក់ថ្គាមវាបានឬ[ឃ] ៣តើវានឹងអង្វរឯងជាច្រើន
ឬនឹងនិយាយពាក្យស្រទន់ដល់ឯងឬទេ[ង] ៤តើវានឹងចុះសន្យា
នឹងឯង ឱ្យឯងបានយកវាទៅបំរើជាដរាបឬ[ច] ៥តើឯងនឹង
លេងជាមួយនឹងវា ដូចជាលេងនឹងចាប ឬចងវាទុក ឱ្យពួក
ទាសីឯងឬទេ ៦តើពួកនេសាទនឹងចាប់វាលក់ដោយបែក
ចំណែកទៅឱ្យពួកឈ្មួញឬអី ៧តើឯងអាចនឹងចាក់ស្បែកវា
ពេញដោយផ្លែច្បូក ឬក្បាលវាដោយស្នចាក់ត្រីបានឬទេ[ឆ]
៨ចូរឯងដាក់ដៃពាល់វាមើល រួចឱ្យនឹកចាំទុក កុំឱ្យធ្វើ
ទៀត[ជ] ៩មើល ដែលចាំចាប់វា នោះស៊ុនខ្លួនហើយ គ្រាន់
តែឃើញភាពវាប៉ុណ្ណោះ នោះល្មមស្លុតចិត្តទៅ[ឈ] ១០គ្មាន
អ្នកណាអាចហ៊ានដាស់វាឡើងឡើយ[ញ] បើដូច្នេះ តើមាន
អ្នកណាអាចឈរនៅមុខអញបាន[ដ] ១១តើអ្នកណាដែលឱ្យអ្វី
មកអញជាមុន បានជាអញត្រូវសងគេវិញ[ឋ] សារពើទាំង
ប៉ុន្មានដែលនៅក្រោមមេឃជារបស់ផងអញទេតើ[ឌ] ។

១២អញមិនទាន់ឈប់និយាយពីជើង[ឍ] និងកំឡាំង[ណ]វា
ឬពីរាងដ៏សមសួនរបស់វានៅឡើយ ១៣តើមានអ្នកណាអាច
នឹងពន្លាត់ស្បែកវាបាន តើអ្នកណាហ៊ានដាក់បង្ហៀរក្នុង
មាត់វា[ត] ១៤តើអ្នកណាអាចនឹងបើកមាត់វាបាន[ថ] ធ្មេញវានៅ
ព័ទ្ធជុំវិញគួរស្ញែងខ្លាច ១៥ស្រកាវាជាទីអំនួតដល់វាក៏ជាប់
គ្នាដូចជាត្រា[ទ] ១៦មួយៗជិតស្និទ្ធគ្នា ដល់ម៉្លេះបានជាខ្យល់

**៤០:១២** ន ១សយ ២:៧ ទដ ៥២:៥ ១ពត ៥:៥ ប ទដ ៦០:១២ អស ២២:៥ ២៨:៣ ៦៣:២-៣,៦ ដយ ៥:២០ មីក ៥:៨ ៧:១០ សក ១០:៥ មឡ ៤:៣ **៤០:១៣** ផ ជន ១៦:៣១-៣៤ ព យប ៤:៩ **៤០:១៤** ភ នក ១៥:៦,១២ ទដ ១៨:៣៥ ២០:៦ ៤៨:១០ ៦០:៥ ១០៨:៦ អស ៤១:១០ ៦៣:៥ **៤០:១៥** ម យប ៩:៩ យ អស ១១:៧ ៦៥:២៥ **៤០:១៦** រ យប ៣៩:១១ ល យប ៤១:៩ **៤០:១៧** វ យប ៤១:១៥ **៤០:១៨** ស យប ៤១:១២ ហ អស ១១:៤ ៤៩:២ **៤០:១៩** ឡ យប ៤១:៣៣ ទដ ៤០:៥ ១៣៩:១៤ អស ២៧:១ អ យប ៤:១៧ ៩:៩ ក លប ៣:២៤

**៤០:២០** ខ ទដ ១០៤:១៤ គ ទដ ១០៤:២៦ ឃ យប ៥:២៣ **៤០:២១** ង លប ៤១:២ ទដ ៦៨:៣០ អស ៣៥:៧ ច យប ៨:១១ **៤០:២២** ឆ ទដ ១:៣ អស ៤៤:៤ **៤០:២៣** ជ អស ៨:៧ ១១:១៥ ឈ យស ៣:១ **៤០:២៤** ញ ២ពវ ១៩:២៨ យប ៤១:២,៧,២៦ អស ៣៧:២៩ **៤១:១** ក អម ៤:២ ខ យប ៣:៨ **៤១:២** គ យប ៤០:២៤ ឃ អគ ១៩:៤ **៤១:៣** ង ១ពវ ២០:៣១ **៤១:៤** ច នក ២១:៦ **៤១:៧** ឆ យប ៤០:២៤ **៤១:៨** ជ យប ៣:៨ **៤១:៩** ឈ យប ៤០:១៦ **៤១:១០** ញ យប ៣:៨ ដ ២របា ២០:៦ អស ៤៦:៥ យរ ៥០:៤៤ វវ ៦:១៧ **៤១:១១** ឋ យប ៣៤:៣៣ រម ១១:៣៥ ឌ ទដ ២៤:១ ៥០:១២ យស ៣:១១ យប ១០:៤ កច ៤:២៤ ១កថ ១០:២៦ **៤១:១២** ឍ យប ៤០:១៨ ណ យប ៣៩:១១ **៤១:១៣** ត យប ៣០:១១ ៣៩:១០ **៤១:១៤** ថ ទដ ២២:១៣ **៤១:១៥** ទ យប ៤០:១៧

**៤០:១៣** *ក្នុងដី* មើលការពន្យល់ ៧:២១ ។
**៤០:១៤** *ដៃស្តាំនៃឯងអាចនឹងជួយសង្គ្រោះឯងបាន* តាមលក្ខណៈផ្ទុយនឹង ទដ ៤៩:៧-៩ (មើលការពន្យល់) ។
**៤០:១៥-២៤** គឺជាផ្នែកដំបូងនៃកំណាព្យទាំងពីរ (ជំពូក ៤១ បន្តទៅផ្នែកទី២) គឺជាអត្ថបទពណ៌នាទាំងសត្វព្រៃធំសាហាវ និងសត្វពាហនៈនៅជំពូកទី៣៩ ។
**៤០:១៥** *ដំរីទឹក* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "សត្វសាហាវ" ក៏សំដៅទៅលើសត្វពណ៌នាពីគាត់ក្នុង ខ.១៦-២៤ អ្នកនិពន្ធកំណាព្យកំរិតខ្ពស់អញ បានបង្កើតមក គឺជាអ្នកដែលជាស្នាព្រះហស្តទ្រង់ ។
**៤០:១៨** *ចំរឹងដែក* មើលការពន្យល់ ១៩:២៤ ។
**៤០:១៩** ចំពោះភាសាហេព្រើរ វិភាគឃ្លានេះត្រូវបានគេបកប្រែមក "ព្រះបន្ទូលដំបូង" ក្នុង សភ ៨:២២ គឺសំដៅទៅលើការបង្កើតឱ្យមានប្រាជ្ញា (មើល សភ ៨:១៧) នេះគឺជាឃ្លាបានពណ៌នាបញ្ជាក់ពីភាពសំខាន់នៃសត្វដំរីទឹកដែលជាសត្វដ៏ធំសំបើម គឺស្ថិតនៅក្រោមការគ្រប់គ្រងពីព្រះអម្ចាស់ ។
**៤០:២១-២៣** *ក្នុងព្រៃកក់ . . . ទន្លេយ័រដាន់* តំបន់ដែលបានពណ៌នានេះ គឺប្រហែលជានៅតំបន់ហូលិចខាងជើងសមុទ្រកាលីឡេ ។
**៤០:២៤** ការនាំឱ្យចាប់ដំរីទឹក ក៏មានសណ្ឋានប្រែប្រួលស្រដៀងទៅនឹងសត្វក្រពើក្នុង ៤១:១ ។
**៤១:១-៣៤** វគ្គទី២នៃអត្ថបទកំណាព្យទាំងពីរក្នុងសេចក្តីថ្លែងរបស់ព្រះយេហូវ៉ាចុងក្រោយ (មើលការពន្យល់ ៤០:១៥-២៤) ។
**៤១:១** *ក្រពើ* ការពណ៌នារបស់អត្ថបទ ក្នុងជំពូកនេះបញ្ជាក់ថា វាជាព្រឹត្តិការណ៍ ដែលគួរឱ្យរន្ធត់យ៉ាងខ្លាំងជាងសត្វដំរីទឹក ក្នុងជំពូក ៤០ ។
**៤១:១០** *សត្វក្រពើ* មានកម្លាំងមហិមា ប៉ុន្តែព្រះអម្ចាស់មានអំណាចចេស្តាច្រើន ។
**៤១:១១** គឺជាការនិយាយប្រៀបធៀបដោយលោកសាវ័កប៉ូល មើលក្នុងគម្ពីររម ១១:៣៥ ។
**៤១:១៤-១៥** *បើកមាត់វាបាន . . . ធ្មេញវានៅព័ទ្ធជុំវិញគួរស្ញែងខ្លាច . . .* មើលការពន្យល់ ខ.១ ។

ចូលមិនបានផង ១៧ មួយប្រទល់នឹងមួយ ហើយក៏ជាប់ៗគ្នា
នឹងផ្តាច់ចេញពីគ្នាមិនបានឡើយ ១៨ កាលណាវាព្រួសទឹក
ចេញ នោះក៏បែកជាពន្លឺ ភ្នែកវាក៏ដូចជាអរុណរះ[ធ] ១៩ មាន
អណ្តាតភ្លើង[ន] ចេញពីមាត់វា ហើយផ្កាភ្លើងហើរចេញមក
ដែរ ២០ មានផ្សែងចេញពីរន្ធច្រមុះវា[ប] ដូចពីឆ្នាំង ឬពីថ្លាង
ដែលពុះ ២១ ខ្យល់ដង្ហើមវា[ផ] បង្កាត់ភ្លើងឡើង ហើយមាន
អណ្តាតភ្លើងចេញពីមាត់វាមក[ព] ២២ នៅត្រង់កវាមានកំឡាំង
ណាស់[ភ] ហើយសេចក្តីស្ញែងខ្លាច ក៏លោតកញ្ឆេងនៅមុខវា
២៣ សាច់ស្រទាប់របស់វាក៏ជាប់ៗគ្នា ក៏មាំណាស់ នឹងបក
ចេញមិនបាន ២៤ បេះដូងវារឹងដូចជាថ្ម អើ ក៏រឹងដូចថ្មត្បាល់
កិន[ម] ២៥ កាលណាវាចំកោងខ្លួនឡើង នោះមនុស្សខ្លាំង
ពូកែក៏ភ័យខ្លាច[យ] ហើយរត់ទៅដោយភាំងស្មារតី[រ] ២៦ បើអ្នក
ណានឹងយកដាវទៅកាប់វា ក៏មិនឈ្នះ ហើយលំពែង ដែក
ពួយ ឬស្នក៏ឥតប្រយោជន៍[ល,វ] ២៧ វារាប់ដែកដូចជាចំបើង[ស]
ហើយលង្ហិនដូចជាឈើពុក ២៨ ព្រួញនឹងធ្វើឱ្យវារត់មិន
បាន[ហ] ហើយថ្មបាញ់ក៏ត្រឡប់ដូចជាជញ្ជ្រាំងដល់វា ២៩ វា
រាប់មោងដូចជាចំបើង[ឡ] ហើយក៏សើចឡក[អ] ដល់ដែកដែល
គេពួយមក ៣០ ពោះវាមានដូចជាអំបែងឆ្នាំង ក៏ធ្វើស្នាមដូច
ជារនាស់នៅលើភក់[ក] ៣១ វាធ្វើឱ្យទឹកជ្រៅចេញពពុះឡើង
ដូចជាឆ្នាំង[ខ] ក៏ធ្វើឱ្យទឹកសមុទ្រត្រឡប់ដូចជាក្រឡពេញ
ដោយការយក់[គ] ៣២ វាធ្វើឱ្យមានផ្លូវភ្លឺតាមក្រោមវា គេនឹង
ស្មានថាទីជំរៅមានសក់ស្កូវហើយ ៣៣ នៅលើផែនដីគ្មាន
សត្វណាដូចវាឡើយ[ឃ] ជាសត្វដែលកើតមកឥតមានភ័យ
ខ្លាច ៣៤ វាមើលទៅឃើញគ្រប់ទាំងអស់ដែលខ្ពស់[ង] ជាសត្វ
ដែលគ្រប់គ្រងលើអស់ទាំងសត្វដែលមានសេចក្តីអំនួត[ច] ។

**៤១:១៨** ធ យប ៣:៩
**៤១:១៩** ន ដយ ១០:៦
**៤១:២០** ប ទដ ១៨:៨
**៤១:២១** ផ យប ៤:៩ អស ១១:៤ ៤០:៧ ព ទដ ១៨:៨ អស ១០:១៧ ៣០:២៧ ៣៣:១៤ ៦៦:១៤–១៦ យរ ៤:៤
**៤១:២២** ភ យប ៣៩:១១
**៤១:២៤** ម មថ ១៨:៦
**៤១:២៥** យ យប ៣៩:២០ រ យប ៣:៨
**៤១:២៦** ល យប ៨:១៨ វ យប ៣០:២៤
**៤១:២៧** ស ខ.២៩
**៤១:២៨** ហ ទដ ៩១:៥
**៤១:២៩** ឡ ខ.២៧ អ យប ៥:២២
**៤១:៣០** ក អស ២៨:២៧ ៤១:១៥ អម ១:៣
**៤១:៣១** ខ ១សយ ២:១៤ គ អគ ៣២:២
**៤១:៣៣** ឃ យប ៤០:១៩

## លោកយ៉ូប

**៤២** ១ លំដាប់នោះ យ៉ូបក៏ទូលឆ្លើយដល់ព្រះយេហូវ៉ាថា
២ ទូលបង្គំដឹងថាទ្រង់ធ្វើទាំងអស់កើត[ក] ហើយថា និងឃាត់
ព្រះដំរិះទ្រង់ណាមួយមិនបាន[ខ] ៣ តើអ្នកណានេះដែលបង្អាប់
ព្រះដំរិះដោយឥតប្រាជ្ញាដូច្នេះ[គ] គឺទូលបង្គំនេះឯងបាន
ពោលពាក្យដែលទូលបង្គំមិនបានយល់ ជាសេចក្តីដែល
អស្ចារ្យហួសល្បត់ទូលបង្គំ ដែលទូលបង្គំមិនបានស្គាល់
ឡើយ[ឃ] ៤ ទ្រង់មានបន្ទូលថា ចូរស្តាប់ចុះ អញនឹងនិយាយ
សិន អញនឹងសួរឯង ចូរឯងឆ្លើយប្រាប់អញ[ង] ៥ កាលពីដើម
ត្រចៀកទូលបង្គំបាន[ច] គ្រាន់តែឮថ្លែងពីទ្រង់ប៉ុណ្ណោះ តែ
ឥឡូវនេះ ភ្នែកទូលបង្គំបានឃើញទ្រង់ជាក់វិញ[ឆ] ៦ បានជា
ទូលបង្គំខ្ពើមដល់ខ្លួន[ជ] ហើយក៏ប្រែចិត្ត[ឈ] ដោយក្រាបនៅ
ក្នុងធូលីដី ហើយនឹងផេះ[ញ] ។

## សេចក្តីបញ្ចប់

៧ ក្រោយដែលព្រះយេហូវ៉ាបានមានបន្ទូលពាក្យទាំង
នេះដល់យ៉ូប[ដ] ហើយ នោះទ្រង់មានបន្ទូលដល់អេលីផាសជា
សាសន៍ថេម៉ានថា អញមានសេចក្តីកំហឹងខឹងនឹងឯងហើយ
ព្រមទាំងគូកនឯងទាំង២នេះផង[ឋ] ដ្បិតឯងរាល់គ្នាមិនបាន
និយាយសេចក្តីដែលត្រឹមត្រូវពីអញ ដូចជាយ៉ូប ជាអ្នកបំរើ

**៤១:៣៤** ង ទដ ១៨:២៧ ១០១:៥ ១៣១:១ សភ ៦:១៧ ២១:៤ ៣០:១៣ ច យប ២៨:៨ **៤២:២** ក លប ១៨:១៤ មថ ១៩:២៦ ខ ២របា ២០:៦ យប ១៦:១៩ កច ៤:២៨ អភ ១:១១ **៤២:៣** គ យប ៣៨:៣៥ ឃ យប ៥:៩ **៤២:៤** ង យប ៣៨:៣ **៤២:៥** ច យប ២៦:១៤ រម ១០:១៧ ឆ ពច ១៣:២២ អស ៦:៥ មថ ៥:៨ លក ២:៣០ អភ ១:១៧–១៨ **៤២:៦** ជ យប ៤០:៤ អគ ៦:៩ រម ១២:៣ ឈ យប ៣៤:៣៣ ញ នក ១០:៣ អរ ៩:៦ យប ២:៨ ៦:២៩ **៤២:៧** ដ យស ១:៧ ឋ យប ៣២:៣

**៤១:១៨–២១** គឺជាវគ្គកំណាព្យហួសពីការពិត ។
**៤១:២៧** *ដែក* មើលការពន្យល់ ១៩:២៤ ។
**៤១:៣០** *អំបែងឆ្នាំង* ជាចំណែកបាក់បែកចោលទៅ ។
**៤១:៣៤** *ជាសត្វដែលគ្រប់គ្រងលើអស់ទាំងសត្វដែលមានសេចក្តីអំនួត* មានតែព្រះយេហូវ៉ាអាចបន្ទាបអង្គទ្រង់ លោកយ៉ូបក៏ពុំអាចសង្ឃឹមធ្វើបែបនោះបានទេ តែព្រះបានលើកទឹកចិត្តលោកយ៉ូបឱ្យបន្ទាបខ្លួន (មើល ៤០:១១–១២ និងការពន្យល់) ។
**៤២:១–៦** ពាក្យសម្តីចុងក្រោយរបស់លោកយ៉ូប ដែលបានឆ្លើយតបចំពោះការសម្តែងពីព្រះជាលើកទី២ ។
**៤២:២** ការយល់ឃើញចុងក្រោយរបស់លោកយ៉ូប ជាមួយព្រះអម្ចាស់ និងព្រះទ័យ ដែលជាគោលបំណងសំខាន់បំផុត ។
**៤២:៣** *តើអ្នកណា* លោកយ៉ូបកត់សម្គាល់ការងារព្រះរាជកិច្ចរបស់ព្រះយេហូវ៉ាក្នុង ៣៨:២–៤០:៧ ។
**៤២:៥** លោកយ៉ូប និងមិត្តទាំងពីររបស់គាត់មាន លោកអេលីហ៊ូវដែលមានទឹកចិត្តជាព្រះ តែឥឡូវលោកយ៉ូបបានរកឃើញព្រះ (មើល អស ៦:៥) ដែលមានភ្នែកជាសេចក្តីជំនឿ និងការយល់ពីព្រលឹងវិញ្ញាណ ។ ដែលគាត់ទទួលផ្លូវព្រះទុកក្នុងខ្លួនគាត់ (មើល ខ.២) ដែលរងការឈឺចាប់ ។ ភ្នែកទូលបង្គំបានឃើញទ្រង់ជាក់វិញ មើល ១៩:២៦ និងការពន្យល់នោះ ។
**៤២:៦** *ទូលបង្គំខ្ពើមដល់ខ្លួន* មើលការពន្យល់ ៩:២១ ភាពបន្ទាបខ្លួនរបស់គាត់ (មើល ៤០:៤–៥) ។ លោកយ៉ូបបានបន្ថែមនូវពាក្យសម្តីចំពោះព្រះយេហូវ៉ា ។ *ធូលីដី ហើយនិងផេះ* មើល ៣០:១៩ និងការពន្យល់ ។
**៤២:៧–៩** ការផ្ទុយនូវអ្វីៗ ដែលលោកយ៉ូបមានកំហុសក្នុងពាក្យពេចន៍ឥរិយាបថប្រព្រឹត្តក្នុងខណៈពេលដែលលោកទទួលការឈឺចាប់ ។ ឥឡូវនេះគាត់បានទទួលយក និងអ្នកឱ្យដំបូន្មានត្រូវបានផ្ចាញ ហេតុអ្វី ? គឺដោយព្រោះក្នុងពេលមានកំហឹងខ្លាំង ទោះក្នុងគ្រាគាត់សរសើរព្រះ (លោកយ៉ូប) ក៏លោកយ៉ូបនិយាយដោយភាពស្មោះត្រង់បំផុតពីមុខព្រះភក្ត្រទ្រង់ ។ ទោះជាអ្នកឱ្យដំបូន្មាន ក៏បង្ហាញនូវភាពត្រឹមត្រូវ គឺពួកគេត្រូវពឹងលើប្រាជ្ញាពីព្រះដែលបង្ហាញពីភាពកោតខ្លាច ។ លោកយ៉ូបនិយាយទៅព្រះគឺតែការដែលព្រះសម្តែង ។ តែពេលខ្លះគេថាហេតុអ្វី លោកយ៉ូបទទួលការឈឺចាប់ ។
**៤២:៧–៨** *យ៉ូបជាអ្នកបំរើអញអើយ* ឃ្លានេះបានប្រើរហូតដល់៤ដង (មើល

អញទេ[ឌ] ៨ដូច្នេះ ចូរឯងរាល់គ្នាយកគោឈ្មោល៧ និងពពែ
ឈ្មោល៧[ឍ]នាំទៅឯយ៉ូប[ណ] ជាអ្នកបំរើអញឥឡូវ រួចថ្វាយ
ដង្វាយដុត[ត]សំរាប់ខ្លួនទៅ នោះយ៉ូប ជាអ្នកបំរើអញ និង
អធិស្ឋានឱ្យឯងរាល់គ្នា ដ្បិតអញនឹងទទួលវា[ថ] ក្រែងអញ
ប្រព្រឹត្តនឹងឯងរាល់គ្នាតាមអំពើចំកួតរបស់ឯង[ទ] ពីព្រោះ
ឯងរាល់គ្នាមិនបាននិយាយសេចក្ដីដែលត្រឹមត្រូវពីអញ ដូច
ជាយ៉ូប ជាអ្នកបំរើអញទេ[ធ] ៩ដូច្នេះ អេលីផាស សាសន៍
ថេម៉ាន ប៊ីលដាឌ សាសន៍ស៊ូអា និងសូផារ សាសន៍
ន៉ាអាម៉ា[ន] គេក៏ទៅធ្វើតាមបង្គាប់ព្រះយេហូវ៉ា ហើយទ្រង់ក៏
ទទួលព្រមតាមយ៉ូប[ប]។
១០កាលយ៉ូបបានអធិស្ឋានឱ្យពួកមិត្រសំឡាញ់ខ្លួនហើយ
នោះ ព្រះយេហូវ៉ាទ្រង់ប្រោសឱ្យលោករួចពីចំណងទៅ
ហើយទ្រង់ប្រទានឱ្យមាន[ផ]លើសជាងដើម១ជា២ផង[ព] ១១គ្រា
នោះ ពួកបងប្អូនប្រុសស្រីរបស់លោក និងពួកអ្នកទាំង
ប៉ុន្មានដែលលោកបានស្គាល់កាលពីដើម[ភ] គេមកសួរលោក
ក៏បរិភោគនៅក្នុងផ្ទះជាមួយនឹងលោក គេសំដែងសេចក្ដី
អាសូរដល់លោក ហើយក៏ជួយកំសាន្តចិត្តពីគ្រប់ទាំងការ
អាក្រក់ ដែលព្រះយេហូវ៉ាបានឱ្យកើតដល់លោក[ម] គ្រប់គ្នា
ក៏ឱ្យប្រាក់១ដុំៗ និងកង់មាសមួយវង់ៗ ដល់លោករៀងខ្លួន ។
១២ព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់យ៉ូប នៅជាន់
ក្រោយនេះ ជាជាងជាន់ដើមទៅទៀត លោកក៏មានចៀម១
ម៉ឺន៤ពាន់ អូដ្ឋ៦ពាន់ គោ១ពាន់នឹម និងលាញី១ពាន់
១៣លោកក៏បង្កើតបានកូនប្រុស៧ កូនស្រី៣ទៀត ១៤កូនស្រី
ទី១ លោកឱ្យឈ្មោះយេមីម៉ា ទី២ឈ្មោះកេសៀយ៉ា ហើយ
ទី៣ឈ្មោះកេរេន-ហាពូក ១៥រីឯនៅគ្រប់ក្នុងស្រុកនោះ
គ្មានឃើញស្ត្រីណាដែលមានរូបឆោមពិសី ដូចជាកូនស្រី
របស់យ៉ូបនោះទេ ហើយឪពុកក៏បែងចែកមរដកដល់កូន
ស្រីទាំងនោះ ដូចជាដល់បងប្អូនប្រុសដែរ ១៦ក្រោយពីនោះ
មក យ៉ូបរស់នៅបាន១៤០ឆ្នាំទៀត លោកក៏ឃើញកូនចៅ
ខ្លួនតទៅដល់៤ដំណ ១៧នោះយ៉ូបស្លាប់ទៅ ដោយមានអាយុ
ជាយឺនយូរ ហើយស្កប់ស្កល់នឹងជីវិតផង[យ]។

**៤២:៧** ឌ ខ.៨ យប ៩:១៥
**៤២:៨** ឍ ជន ២៣:១,២៩ អគ ៤៥:២៣ ណ យប ១:៨ ត លប ៨:២០ ថ យក ៥:១៥-១៦ ១យហ ៥:១៦ ទ លប ២០:៧ យប ២០:៣០ ធ ខ.៧
**៤២:៩** ន យប ២:១ ប លប ១៩:២១ ២០:១៧ អគ ១៤:១៤
**៤២:១០** ផ ចទ ៣០:៣ ទដ ១៤:៧ ព យប ១:៣ ទដ ៨៥:១-៣ ១២៦:៥-៦ ភល ២:៨-៩ យក ៥:១១
**៤២:១១** ភ យប ១៩:១៣ ម លប ៣៧:៣៥
**៤២:១៧** យ លប ១៥:១៥

ការពន្យល់ ១:៨) ។

**៤២:១០** ការអធិស្ឋានរបស់លោកយ៉ូប គឺជាការអធិស្ឋានចំពោះអ្នកណាដែលធ្វើទុកនៅក្នុងខគម្ពីរ ចំពោះគ្រីស្ទបរិស័ទដែលមានសេចក្ដីជំនឿរឹងមាំក៏ជាវគ្គ ដែលព្រះគ្រីស្ទបានបង្រៀនក្នុង មថ ៥:៤៤ ។ សេចក្ដីអធិប្បាយរបស់លោកយ៉ូបបាននាំមកវិញនូវវិបុលសុខ និងព្រះពរជាថ្មីសម្រាប់គាត់ ។ *មានលើសជាងដើម* ចំពោះភាសាហេព្រើរក្នុងវោហាស័ព្ទនេះ គឺបានប្រែមកថា "ឱ្យមានជាភ័ព្វសំណាងលើសពីមុន" ក្នុង ទដ ១៤:៧ ។

**៤២:១១** ភាពផ្ទុយ ១៦:២ ១៩:១៣ ប្រាក់១ដុំៗ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ ឃ្លានេះគឺមានតែនៅក្នុងគម្ពីរសញ្ញាចាស់ ក្នុង លប ៣៣:១៩ និង យស ២៤:៣២ ។

**៤២:១២-១៦** គឺជាការប្រឆាំងតវ៉ានឹងសាតាំង ជាមេចោទប្រកាន់លើអ្វីៗត្រូវបញ្ចប់ ហើយលោកយ៉ូបត្រូវបានអ្វីៗឡើងវិញ ក៏ពុំមានហេតុផលអ្វីដែលឱ្យលោកយ៉ូបទទួលការឈឺចាប់តទៅទៀតទេ លើកលែងតែគាត់មានបាប ។ ព្រះមិនចង់ឱ្យយើងទទួលការឈឺចាប់ ដោយគ្មានហេតុផលនោះទេ ទោះជាហេតុផលបានលាក់កំបាំងក៏ដោយ គឺក្នុងការកំបាំងនៃទិសដៅរបស់ព្រះ (មើល អស ៥៥:៨-៩) ក៏មិនចាំបាច់ឱ្យយើងស្គាល់ក្នុងជីវិតនេះដែរ តែយើងត្រូវមានសេចក្ដីពិតក្នុងព្រះដែលធ្វើការ តែសេចក្ដីពិតមួយប៉ុណ្ណោះ ។

**៤២:១២** ចំនួនសត្វពាហនៈគឺមានច្រើនដូចកាលដែលគាត់ធ្លាប់មានអញ្ចឹង (សូមមើល ខ.១០) ដូចជាលោកយ៉ូបធ្លាប់មានពីមុនមកដូច្នេះដែរ (មើល ១:៣) ។

**៤២:១៣** *កូនប្រុស៧ កូនស្រី៣ទៀត* គឺមកជំនួសកូនដែលបានបាត់បង់ពីមុននោះមក(មើល ១:២,១៨-១៩) ។

**៤២:១៤** គឺជាការដាក់ឈ្មោះឱ្យកូនស្រីយេមីម៉ាមានន័យថា "អ្នកស្វែងរកសន្តិភាព " កេសៀយ៉ា គឺមានន័យថា "ដើមយីហ៊ុប" ឈ្មោះកេរេន-ហាពូក មានន័យថា ចានអង់ទីមន(មើលការពន្យល់ យរ ៤:៣០) ។

**៤២:១៥** ក៏បែងចែកមរដកដល់កូនស្រីទាំងនោះដូចជាដល់បងប្អូនប្រុសដែរ ផ្ទុយនឹង ជន ២៧:៨ ។

**៤២:១៦** រស់នៅបាន១៤០ឆ្នាំទៀត គឺជាពួកចាស់ទុំដ៏ពិតប្រាកដ (មើលការពន្យល់ នក ៦:១៦ លោកឃើញកូនចៅខ្លួនតទៅដល់៤ដំណ មើល លប ៥០:២៣ និងការពន្យល់ ។

**៤២:១៧** គឺមានអាយុយឺនយូរ ហើយស្កប់ស្កល់នឹងជីវិតផង មើល ៥:២៦ លប ២៥:៨ និងការពន្យល់ ។

## សេចក្ដីផ្ដើម

### ចំណងជើង

ចំណងជើងនៃព្រះគម្ពីរនេះជាភាសាអង់គ្លេសគឺ "សាម"(Psalm) ឬ "សលធ័រ"(Psalter) មានប្រភពចេញពីការបកប្រែព្រះគម្ពីរសញ្ញាចាស់មកជាភាសាក្រិកដំបូងនៅសម័យមុនគ្រីស្ទសករាជ ដែលគេហៅថា "សែបទូជីន"(Septuagint)។ ដំបូងឡើយ គេបានដាក់ចំណងជើងដូចនោះ ដោយសំដៅទៅលើ ឧបករណ៍ភ្លេងដែលប្រើខ្សែ(ដូចជា ស៊ុង ពិណបុរាណ ជាដើម) ហើយសំដៅទៅលើទំនុកដែលគេច្រៀងជាមួយនឹងឧបករណ៍ទាំងនោះ ។ គេហៅផ្នែកជាច្រើន នៃព្រះគម្ពីរទំនុកដំកើង ជាភាសាហេព្រើថា "ធេភីលល៉ុត"(Tephillot, មានន័យថា "សេចក្ដីអធិស្ឋាន") តែតាមទំនៀមទម្លាប់ ចំណងជើងព្រះគម្ពីរនេះ នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរគឺ "ធែលហ៊ីលីម"(Tehillim, ដែលមានន័យថា "ការសរសើរតម្កើង", មើលការពន្យល់ ទដ ១៤៥ ត្រង់ចំណុចចំណងជើង)។ ជាការពិតណាស់ នៅក្នុងវគ្គមួយនៃក្រុមដំបូងនៃព្រះគម្ពីរនេះ មានចំណងជើងថា "ពាក្យអធិស្ឋានរបស់ដាវីឌ ជាបុត្រអ៊ីសាយ"(៧២:២០)។

### ការចងក្រងការរៀបចំ និងកាលបរិច្ឆេទ

អ្នកនិពន្ធទំនុកដំកើងបានប្រមែប្រមូលនៅការចងក្រងជាច្រើន មកទុកជាតំណាង ជាឯកសារតំកល់ទុក ដែលជានិច្ចកាលចុងក្រោយវាជាភាពនាំឱ្យ មានវិសាលគម ជាចំណែកដែលបន្សល់ទុកជាច្រើនសតវត្សតៗមក ។ ព្រះគម្ពីរទំនុកដំកើងនេះ ក៏ត្រូវបានគេរៀបចំឱ្យមានជាបែបបទត្រឹមត្រូវចុងក្រោយ ទៅតាមសម័យកាល គឺចាប់តាំពីប្រវត្តិសាស្ត្រនាសម័យសាសន៍យូដា រហូតដល់សម័យនិរទេសក្នុងសម័យបាប៊ីឡូន ក៏មានព្រះវិហារដែរ ហើយកិច្ចការទាំងនោះបានចប់សព្វគ្រប់ក្នុងសតវត្សទី៣ មុនគ.ស ។ គេតែងតែហៅព្រះគម្ពីរនេះថា ជាសៀងភៅអធិស្ឋាន"ទីពីរ"របស់ព្រះវិហារ (ស្ដេចសូរ៉ូបាបិល និងស្ដេច ហេរ៉ូ) ហើយក៏បានគេយកទៅច្រៀងក្នុងសាលាប្រជុំដែរ ។ ក៏ប៉ុន្តែបទទំនុកនេះមានលក្ខណៈសំខាន់ចំពោះការទាំងឡាយណាដែលជាការភ្ជាប់ទំនាក់ទំនង និងព្រះ ។ លក្ខខ័ណ្ឌទាំងពីរនៃរឿងរ៉ាវក្នុងប្រធានបទ និងការរៀបចំនៅអ្វីដែលបានចងក្រងនោះ គឺផ្ដោតសំខាន់ទៅលើសេចក្ដីណែនាំ ដោយប្រកាន់លើសេចក្ដីជំនឿឱ្យបានរឹងមាំ និងពេញដោយសេចក្ដីសុចរិតចំពោះសេចក្ដីជំនឿ ទៅតាមបញ្ញត្តិច្បាប់របស់ទ្រង់ ឬតាមពួកហោរា និងបែបផែនអក្សរសាស្ត្រនៃប្រាជ្ញា ។ រហូតដល់សតវត្សរ៍នៃគ្រីស្តសរាជ គឺសំដៅទៅលើ"កណ្ឌគម្ពីរទំនុកដំកើង"(លក ២០:៤២ កច ១:២០)។ ខណៈពេលនោះ កណ្ឌគម្ពីរទំនុកដំកើងបានបង្ហាញពីការប្រើជាលក្ខណៈចំណងជើង នៃគម្ពីរសញ្ញាចាស់ជាភាសាហេព្រើរ (សូមមើល លក ២៤:៤៤ និងការ ពន្យល់)។

ការចងក្រងជាច្រើនទាំងនេះបានធ្វើឡើង មុនសេចក្ដីបកស្រាយចុងក្រោយរបស់គម្ពីរទំនុកដំកើង ។ តាមការពិតការរៀបចំរបស់អ្នកនិពន្ធទំនុកដំកើងអាចត្រឡប់ទៅជំនាន់ដំបូងបង្អស់តាំងពីព្រះវិហារមុនគេ (របស់ស្ដេចសាឡូម៉ូន ឬក៏ដូចជាក្នុងជំនាន់ស្ដេចដាវីឌ) គឺខណៈពេលមានការថ្វាយបង្គំ និងអធិស្ឋានសរសើរតម្កើង ដែលបានកើតឡើងដំបូងបង្អស់ គឺមានជារូបរាងថ្វាយបង្គំព្រះឡើង ។ មានការសម្អាងខ្លះបានសរសេរឡើងចំពោះ "ការអធិស្ឋានរបស់ស្ដេចដាវីឌ"។ ឯការចងក្រងខ្លះទៀងបានបង្ហាញនៅក្នុងប្រធានបទរបស់អ្នកនិពន្ធទំនុកដំកើងគឺមាន : (១).ចម្រៀង ឬបទទំនុកដំកើងរបស់ "កូនប្រុសលោកកូរេ" (ទដ ៤២-៤៩,៨៤-៨៥,៨៧-៨៨) (២).ផ្នែកទីពីរគឺជាទំនុកដំកើង ឬចម្រៀងរបស់"លោកអេសាភ" (ទដ ៥០,៧៣-៨២) និង (៣)."ជាបទចម្រៀងសម្រាប់សរសើរ"(ទដ ១២០-១៣៤)។

មានសាក្សីខ្លះទៀតបានចង្អុលបង្ហាញពីការបកស្រាយបន្ថែមនៅក្នុង ទដ ១-៤១ ជា"សៀវភៅទី១" ដែលតែងតែប្រើព្រះនាមព្រះយេហូវ៉ា គឺព្រះ "យ៉ាវេ៍" (Yahweh) គឺស្មើនឹង ("ព្រះយេហូវ៉ា") ឯកណ្ឌគម្ពីរ ទដ ៤២-៧២ (សៀវភៅទី២) តែងតែប្រើពាក្យថា "អ៊ីឡូហ៊ីម" (Elohim) មានន័យថា ("ព្រះអម្ចាស់") ។ ហេតុដែលនាំឱ្យធ្វើការប្រមែប្រមូលពាក្យថា"អ៊ីឡូហ៊ីម" (Elohim) ក្នុងលក្ខណៈផ្សេងពីពាក្យ "យ៉ាវេ៍" (Yahweh) គឺដើម្បីស្វែងយល់ឱ្យច្បាស់ពីភាពខុសគ្នា តែកិច្ចការនេះក៏មិនទាន់ប្រមូលបានលទ្ធផលច្បាស់នៅឡើយ ។ ម្យ៉ាងវិញទៀត ទដ ៩៣-១០០ គឺជាជំពូកដែលបង្ហាយពីទំនាមទម្លាប់ (មើល"ព្រះយេហូវ៉ាគ្រងរាជ"ក្នុង ៩៣:១ ៩៦:១០ ៩៧:១ ៩៩:១)។ ផ្នែកជាក្រុមៗខ្លះទៀតមាន ទដ ១១១-១១៨ (បង្ហាញផ្ទៃរឿងជាខ្សែពីពាក្យ ហាលេលូយ៉ា ក្នុងបទទំនុក សូមមើលសេចក្ដីផ្ដើមក្នុងជំពូក ១១៣) ទដ ១៣៨-១៤៥ (ជំពូកទាំងអស់នេះមានបញ្ចូលពី"ស្ដេចដាវីឌ"ក្នុងចំណងជើង) និង ទដ ១៤៦-១៥០ (ជារៀយៗជំពូកទាំងនេះជាវគ្គ"សរសើរដំកើងដល់ព្រះយេហូវ៉ា" សូមមើលការពន្យល់ ១១១:១)។ តែមាន"បទទំនុក"ជាច្រើនពុំសូវគេបានឃើញ តែត្រូវបានគេទទួលស្គាល់ ។ នៅក្នុងវគ្គសំរិតសំរាំងចុងក្រោយ គឺមាន១៥០ ជំពូក ។ (ឯនៅគ្រាសម័យសញ្ញាចាស់ នៃគ្រីស្ទបរិស័ទក្រិកមុនដំបូងបង្អស់) គឺភាសាក្រិក និងព្រះគម្ពីរជាភាសាហេព្រើរ ឃើញថា មានលេខជំពូក ឬលំដាប់លេខផ្សេងៗខុសគ្នា ។ នៅគ្រាសញ្ញាចាស់ គ្រីស្ទបរិស័ទក្រិកមុនគេបង្អស់ មានកណ្ឌគម្ពីរទំនុកដំកើងសេសសល់ផ្សេងទៀត គឺនៅខាងចុងព្រះគម្ពីរ (ប៉ុន្តែ លេខលំដាប់ពុំមានលក្ខណៈខុសគ្នា ឬដាច់

ពីគ្នាទេដូចជា ទដ ១៥០) គឺស៊ីគ្នានឹង ទដ ៩-១០ (មើលការពន្យល់ ទដ ៩) និង ទដ ១១៤-១១៥ និងចែក ទដ ១១៦ និង ទដ ១៤៧ ទៅជាបទពីរទៀត មើលការពន្យល់ ទដ ៤២) ។

ក្នុងការប្រមូលផ្តុំចុងក្រោយរបស់គម្ពីរទំនុកដំកើង គឺអ្នកនិពន្ធបានញែកគម្ពីរនេះទៅជាកណ្ឌធំៗ (ទដ ១-៤១,៤២-៧២, ៧៣-៨៩,៩០-១០៦,១០៧-១៥០) ឯវគ្គជាកណ្ឌធំៗនិមួយៗ មានសេចក្តីបញ្ចប់ដោយបទទំនុកដំកើង(សូមមើល ៤១:១៣ ៧២:១៨-១៩ ៨៩:៥២ ១០៦:៤៨)។ ពីរកណ្ឌធំៗ ដំបូងមានសេចក្តីកត់ចំណាំ ឬការពន្យល់រួចហើយពីចំណុចសំខាន់ ។ នៅមានការបែងចែកគម្ពីរទំនុកដំកើង ដែលនៅសេសសល់ទៅជា៣កណ្ឌធំៗទៀត ហើយមាន៥កណ្ឌទៀតគឺគម្ពីរទាំង៥កណ្ឌរបស់លោកម៉ូសេ(ដែលតាមការកំណត់ថា វាជាគម្ពីរក្រឹត្យវិន័យ)។ តែយ៉ាងហោចណាស់ក៏មានវគ្គមួយក្នុង ចំណោមវគ្គទាំងនេះ ដែលមានសណ្ឋានដាច់ពីគេ (គឺចន្លោះ ទដ ១០៦-១០៧) (សូមមើលសេចក្តីផ្តើម ទដ ១០៧) ។ ក្រៅពីការចែកជា៥កណ្ឌនេះអ្នកនិពន្ធ បានគិតយ៉ាងច្បាស់ថា វាមានលក្ខណៈតែមួយវិញ ដែលមានជាសេចក្តីផ្តើម (ទដ ១-២) និងសេចក្តីបញ្ចប់ (ទដ ១៤៦-១៥០) ។ ចំពោះការពន្យល់ក្នុងគម្ពីរ ទំនុកដំកើងទាំងមូលបានផ្តល់នៅការចង្អុលបង្ហាញបន្ថែម នៅការប្រកបដោយស្មារតី និងមានមនសិការខ្ពស់បំផុត ។

**ការងារអ្នកនិពន្ធ និងចំណងជើង (ឬក៏អត្ថបទសំរិតសំរាំង)**

គឺមាន ១៥០ជំពូកក្នុងទំនុកដំកើង តែមានតែ ៣៤ជំពូកទេដែលពុំបានសំរិតសំរាំងល្អ (ក្នុងនោះមាន ១៧ ជំពូកជាគម្ពីរភាសាក្រិកដែលបានបក ប្រែមកចាប់តាំងពីសម័យគ្រាសញ្ញាចាស់ដំបូង) ។ ដែលគេហៅថាបទទំនុកដំកើង "កូនកំព្រា"ដែលបានជួបប្រទះនៅក្នុងសៀវភៅទី៣-៥ មានលក្ខណៈវគ្គ ឬជាក្រុម : ទដ ៩១,៩៣-៩៧,៩៩,១០៤-១០៧,១១១-១១៩,១៣៥,១៤៦-១៥០ ។ (ក្នុងសៀវភៅទី១-២ មានតែ ទដ ១-២,១០,៣៣,៤៣,៧១ ប៉ុណ្ណោះដែល ពុំមានចំណងជើង និង ទដ ១០,៤៣ នៅតែបន្តជាបទទំនុកដំកើងនាំមុខគេ)។ ចំពោះបញ្ជីរឿងដែលមានភាពប្លែកៗគ្នានោះ គឺត្រូវបានគេសំរិតសំរាំងទុក ដើម្បីរៀបចំជាវគ្គមួយចំនួនទៀត: (១).វគ្គអ្នកនិពន្ធ (២).វគ្គឈ្មោះដែលបានប្រមូលចងក្រង (៣).ប្រភេទទំនុកដំកើង (៤).ការកំណត់ពីតន្ត្រី (៥).សេចក្តីកត់ត្រាពីការសូត្រ ឬអធិស្ឋាន (៦).សេចក្តីបញ្ចប់សង្ខេបពីការនិពន្ធតែង ។

សិស្សដែលជាអ្នកសិក្សាចំពោះគម្ពីរទំនុកដំកើងគេមិនបានឯកភាពលើចំណុចខ្លះ ដែលមាននៅក្នុសម័យបុរាណ និងការសំរិតសំរាំងនេះទេ ។ ពួកគេមួយចំនួនសំអាងទៅលើហេតុការណ៍ ដែលជាព្រឹត្តការណ៍ប្រវត្តិសាស្ត្រដើម ជាសាក្សីចេញឱ្យឃើញជាក់លាក់ អំពីការបកប្រែ ពីភាសាក្រិកនាសម័យដើម ហើយមានផ្នែកខ្លះមានភាពមិនច្បាស់លាស់សមនឹងន័យដែលពួកគេចង់បាន ។ ម្យ៉ាងវិញទៀតដូចជាបូកបញ្ចូលនៅគ្រប់ទាំងចំណងជើងរួមបញ្ចូល ទាំងឈ្មោះរបស់អ្នកនិពន្ធនាសម័យបុរាណ ។ ម្យ៉ាងវិញទៀតការប្រៀបធៀបរវាងការបកប្រែពីភាសាក្រិកនៃគម្ពីរសញ្ញាចាស់របស់គ្រីស្ទបរិស័ទដំបូងបង្អស់ និងអត្ថបទគម្ពីរជាភាសាហេព្រើរបានបង្ហាញថា មាតិកាចំណងជើងខ្លះក៏តម្រូវឱ្យផ្លាស់ប្តូរទៅតាមរយៈពេលវេលាជាក់លាក់ គឺចាប់តាំងពីពេលជាប្រវត្តិ សាស្ត្រនៃពួកយូដារហូតដល់សម័យបញ្ជូនជាឈ្លើយទៅឯក្រុងបាប៊ីឡូន ។ ឯការពិគ្រោះគ្នាប្តូរយោបល់គឺផ្តោតលើលំដាប់ថ្នាក់នីមួយៗ គឺក្នុងចំណោមវគ្គទី១ និងវគ្គទី៦ដែលបានបង្ហាញខាងលើ ។

បើតាមអត្ថបទសំរិតសំរាំងដែលទាក់ទងនឹងឱកាស ឬពេលវេលាតែងនិពន្ធ និងតាមសេចក្តីកត់ត្រាសង្ខេបខ្លះទៀត គឺហាក់ដូចជាគម្ពីរនេះបានដក់ស្រង់ចេញពីគម្ពីរសាំយូអែលទី១ និងទី២ ។ លើសពីនេះទៅទៀតពេលខ្លះមានលក្ខណៈមិនងាយស្រួល ដើម្បីធ្វើឱ្យសាច់រឿងស៊ីគ្នា ឬទាក់ទងគ្នានោះទេ ។

ទាក់ទងនឹងកិច្ចការអ្នកនិពន្ធ ក៏មានយោបល់ផ្សេងៗពីគ្នាដែរ ។ តាមការកត់ចំណាំរបស់អ្នកនិពន្ធ គឺមានភាពមិនច្បាស់លាស់ខ្លះខណៈពេលអ្នកនិពន្ធបានប្រើពីរបៀបសរសេរឃ្លាឃ្លោងជាភាសាហេព្រើរ ដូចជាការប្រើពាក្យមានលក្ខណៈទូទៅពេកដូចជាពាក្យ "កម្មសិទ្ធិ" ក៏អាចមានន័យថា "ទាក់ទងនឹង" ឬក៏ "សម្រាប់ប្រើ" ឬក៏មានន័យថា "ថ្វាយចំពោះ"។ មានជាឈ្មោះអាចសំដៅលើចំណងជើងរបស់គម្ពីរទំនុកដំកើងដែលបានចងក្រង គឺគេបានប្រមូលទុក ដែលឈ្មោះជាក់លាក់វិញ(ដូចជាឈ្មោះថា"លោកអេសាភ" ឬជា "របស់នៃពួកកូនប្រុសកូរេ")។ រឿងរ៉ាវជាកិច្ចការយ៉ាងសាំញ៉ាំនេះ ដែលឃើញមានកើតឡើងក្នុងចំណោមអ្នកនិពន្ធទំនុកដំកើង ហេតុនេះហើយយ៉ាងហោចណាស់ក៏មានប្រធានបទខ្លះត្រូវត្រួតពិនិត្យកែសម្រួលឡើងវិញ ។ ដូចជាខណៈពេល ស្តេចដាវីឌស្ថិតក្នុងភាពជាអ្នកនិពន្ធ ក៏មានភាពគួរឱ្យឆ្ងល់ថាអ្នកនិពន្ធ បាននិពន្ធបទទំនុកដំកើងដោយបានបង្ហាញពីអ្នកចម្រៀង និងឧបករណ៍តន្ត្រីដែលទាក់ទង និងស្តេចដាវីឌ ដែលគ្រងរាជ្យហើយទ្រង់ក៏ជាអ្នកនិពន្ធ ។ សូមមើល ទដ ៣០ និងមើលសេចក្តីផ្តើម ទដ ៦៩ និងការពន្យល់ ទដ ១២២ ត្រង់ចំណងជើង ។ លើសពីនេះទៅទៀត"ស្តេចដាវីឌ"ជួនកាលប្រើ ឬយកពីប្រភពផ្សេងៗដូចជាភាពជាស្តេចវង្សានុវង្សដ៏ពិត ដែលមានក្នុងចំណងជើងទំនុកដំកើង។

ពាក្យថាក្រុងសេឡាក៏ឃើញមាន ៣៩ ដង ក្នុងទំនុកដំកើង តែមានច្រើននៅក្នុង(ទដ ១៤០,១៤៣ ទាំងពីរជំពូកនេះ គឺផ្តោត

សំខាន់ទៅលើវង្សា នុវង្សរបស់ដាវីឌ" គឺមានក្នុងសៀវភៅទី១ និងទី៣ ។ ឃើញមានក្នុង ហប ៣ តែជាទំនុកដំកើងដូចជាកំណាព្យ ។

**ប្រភេទនៃគម្ពីរទំនុកដំកើង**

ជាអត្ថបទសំរិត សំរាំងពីភាសាហេព្រើរដែលជាគម្ពីរទំនុកដំកើង ដែលយើងស្គាល់ប្រកបដោយបែបផែនបុរាណចំពោះការរៀបចំតាមលំដាប់ ដូចជាពាក្យ (១).មីម៉រេ (Mismor) មានន័យថា (ទំនុកដំកើង) (២).ស៊ីហ្គូន (សូមមើល ទដ ៧ ជាចំណងជើង) (៣).មីលតាម (Miktam) (សូមមើល ការពន្យល់ ទដ ១៦ ជាចំណងជើង) (4).ស៊ីរ (Shir) មានន័យថា (បទចំរៀង) (៥).ម៉ាលគីល (Maskil) (សូមមើលការពន្យល់ ទដ ៣២ ជាចំណង ជើង) (៦).ថែលពីឡា (Tephillah) មានន័យថា (អធិស្ឋាន) (៧).ថែលហីឡា (Tehillah) មានន័យថា (ការសរសើរដំកើង) (៨).សេហាគី (Lehazkir) (គឺសំរាប់ជាការចងចាំ ពោលគឺនៅត្រង់ខាងមុខព្រះភ័ក្ត្រទ្រង់គឺមានការអង្វរ) (៩).លេតូដា (Letodah) (គឺសម្រាប់សរសើរដំកើង "ឬក៏" សម្រាប់អរព្រះគុណ) (១០). លេឡែម (សម្រាប់បង្រៀន) និង (១១).ស៊ីរយែឌីដូត (ចំរៀងនៃសេចក្ដីស្រឡាញ់) ពោលគឺដូចជាចម្រៀងអាពាហ៍ពិពាហ៍ ។ ពាក្យពេជ្រខាងលើនេះ មានមួយចំនួនពុំមានលក្ខណៈជាក់លាក់ត្រឹមត្រូវ ។ ក៏មានចំណងជើងខ្លះសរសេរដោយពាក្យពីរដូចជាពាក្យ មីម៉រ (Mymor) និងពាក្យស៊ី (Shir) គឺជាការបង្ហាញបញ្ជាក់ថា វាជាប្រភេទពាក្យផ្សេងៗពីគ្នា និងមានលក្ខណៈត្រួតគ្នា ឬតម្រួតគ្នា ។

តាមកាលវិភាគទៅលើមាតិការរឿងនាំឱ្យគេរៀបជាប្រភេទផ្សេងៗគ្នា ជាហេតុទទួលការសិក្សាបានល្អ ។ ឯប្រភេទសំខាន់ដែលអាចបញ្ជាក់បាន នោះគឺ: (១).សេចក្ដីអធិស្ឋានដោយឡែកៗ (ឧទាហរណ៍ ទដ ៣–៧) (២).ការសរសើរដោយផ្ទាល់ចំពោះការសង្គ្រោះរបស់ព្រះអម្ចាស់(ឧទាហរណ៍ ទដ ៣០,៣៤) (៣).ការសរសើររបស់សហគមន៍(ឧទាហរណ៍ ទដ ១២,៤៤,៧៩) (៤).ការសរសើររស់សហគមន៍ចំពោះការសង្គ្រោះរបស់ព្រះ (ឧទាហរណ៍ ទដ ៦៦,៧៥) (៥).ការលន់តួបាបនៃការទុកចិត្តចំពោះព្រះយេហូវ៉ា(ទដ ១១,១៦, ៥២) (៧).លើកទំនុកភ្លេងសរសើរដល់ការដែលព្រះគ្រងរាជនៅក្នុង បល្ល័ង្ករបស់ផងទ្រង់(ទដ ៤៧,៩៣,៩៩) (៨).ច្រៀងពីក្រុងស៊ីយ៉ូនគឺជាទីក្រុងរបស់ព្រះ(ទដ ៤៦,៤៨,៧៦,៨៤,១២២,១២៦,១២៩,១៣៧) (៩).ទំនុកដំកើង ពីការចាក់ប្រេងតាំងរបស់ព្រះយេហូវ៉ា (ឧទាហរណ៍ ទដ ២,១៨,២០,៤៥,៧២,៨៩,១១០) (១០).ចម្រៀងធម្មយាត្រា (ទដ ១២០–១៣៤) (១១).ចម្រៀង ថ្វាយបង្គំ (ឧទាហរណ៍ ១៥,២៤,៦៨) (១២).ចម្រៀងសម្រាប់ប្រៀនប្រដៅ"ជាការណែនាំ" (ឧទាហរណ៍ ទដ ១,៣៤,៣៧,១១២,១១៩, ១២៨,១៣៣)។

ការរៀបចំនេះក៏ទាក់ទងនឹងភាពដូចគ្នា ស៊ីគ្នា ។ ឧទាហរណ៍"ការអធិស្ឋានដោយឡែកៗ"ក៏អាចរាប់បញ្ចូលការអធិស្ឋានរបស់ព្រះស្ដេច(ក្នុងលក្ខណៈពិសេសនៃមុខងារជាស្ដេច) ដែលមានសណ្ឋានការអធិស្ឋានជាសហគមន៍ ជាការនិយាយក្នុងបែបរួមតែមួយជាបុរសទី១ ក្នុងច្បាប់អក្សរសាស្ត្រ ។ គឺកណីនេះហើយដែលជួយក្នុងការសិក្សាបទទំនុកដំកើងក្នុងលក្ខណៈតភ្ជាប់គ្នា ជាអ្នកផ្សេងទៀតក្នុងទិសដៅតែមួយ ។ គឺជាការព្យាយាមដើម្បីបំពេញនូវការ អធិស្ឋានទូលអង្វរឱ្យបានល្អ សម្រាប់គ្រប់ទាំងសណ្ឋានអធិស្ឋាន ។

គ្រប់ទាំងប្រភេទទំនុកដំកើងទាំងនេះ ការអធិស្ឋាន(ផ្ទាល់ខ្លួន និងទាំងសហគមន៍) គឺមានភាពស្មុកស្មាញ ។ គ្រប់ទាំងតួនាទីនៃការអធិប្បាយជាច្រើន គឺសំដៅទៅលើការទំនាក់ទំនងជាមួយនឹងព្រះអម្ចាស់ : (១).ការថ្លែងទៅរកព្រះដូចជាពាក្យ"ឱព្រះយេហូវ៉ាអើយ" "ព្រះអម្ចាស់នៃទូលបង្គំអើយ" "ឱព្រះដ៏ប្រោសលោះទូលបង្គំអើយ"(២).ការហៅអំពាវនាវជាដំបូង "សូមទ្រង់យកព្រះទ័យ" "ឆ្លើយតបទូលបង្គំ" "ជួយ" "សង្គ្រោះទូលបង្គំ" (៣).ពណ៌នាពី សេចក្ដីទុក្ខព្រួយ "សត្រូវទូលបង្គំបានប្រឆាំងទូលបង្គំ" "ពួកមនុស្សអាក្រក់វាយប្រហារទូលបង្គំ""ទូលបង្គំកំពុងរងទុក្ខ" (៤).ត្អូញត្អែរចំពោះព្រះអម្ចាស់ : "ហេតុអ្វីបានព្រះអម្ចាស់បានបោះបង់ទូលបង្គំចោល" "តើទ្រង់លាក់ព្រះភ័ក្ត្រចំពោះទូលបង្គំដល់ណា?" (៥).ពាក្យអង្វរ"សូមទ្រង់កុំនៅឆ្ងាយពីទូលបង្គំ" "សូមឱ្យទូលបង្គំរួចពីអំពើបាប" (៦).ការជំរុញឱ្យព្រះឮនូវការទូលអង្វរ" សូមផ្ដល់ជម្រកឱ្យទូលបង្គំ"ក៏ដោយព្រះនាមទ្រង់"(៧).ការចោទប្រកាន់មាសត្រូវ "ឥតមានសេចក្ដីពិតក្នុងមាត់របស់ពួកគេ" "ពួកមនុស្សគ្មានមេត្តាតែងស្វែងរកជីវិត" "ពួកមនុស្សអាក្រក់តែងរករឿងចាប់កំហុស" (៨).ការអំពាវនាវសុំការលាងអំពើបាបដោយភាពសុចរិតរបស់ផងទ្រង់" "ត្រូវឱ្យពួកគេត្រូវខ្មាស" "សូមហៅពួកគេមកទទួលរ៉ាបរងនូវរាល់អំពើអាក្រក់របស់គេ" (៩).ប្រកាស់ពីភាពគ្មានកំហុស "ទូលបង្គំបានដើរក្នុងភាពសុចរិត""ពួកគេស្អប់ទូលបង្គំដោយគ្មានហេតុផល" (១០).ការលន់តួអំពើបាប "ទូលបង្គំបានធ្វើបាបទាស់នឹងទ្រង់""ទូលបង្គំលន់តួអំពើអាក្រក់របស់ទូលបង្គំ" (១១).ការពឹងអាងលើសេចក្ដីពិត : "ទ្រង់ជាខែលលើរូបកាយទូលបង្គំ" ។ "ទ្រង់និងឆ្លើយតបមកទូបង្គំ" (១២).សច្ចាក្នុងការសរសើរដំកើងចំពោះការប្រោសលោះ : "ទូលបង្គំច្រៀងពីភាពឧត្ដម្ភរបស់ផងទ្រង់" "បបូរមាត់ទូលបង្គំ និងសរសើរដល់ទ្រង់" "ដោយព្រោះទ្រង់បានប្រោសទូលបង្គំ""ចំពោះទ្រង់ជាព្រះយេហូវ៉ា ឮពីការដែលទូលបង្គំខ្វះខាត" ។

មានការខ្លះពុំបានឃើញមាននៅក្នុងការអធិស្ឋានទូលទៅព្រះដែរ តែវាក៏មាននៅក្នុងការអធិស្ឋានជាលក្ខណៈធំៗ តាមរយៈអ្នកនិពន្ធគម្ពីរទំនុកដំកើង គឺជាសេចក្ដីអធិស្ឋានសង្ខេប ជាការអធិស្ឋានចុងក្រោយ ។ ក្នុងលក្ខណៈរួមគឺសំដៅលើការជំនុំជម្រះថ្មីៗឯអ្នកនិពន្ធ

ទំនុកដំកើងក៏សម្តែងពីរឿងរ៉ាវរបស់ពួកគេ នៅខាងមុខព្រះមហាក្សត្រដែលជាចៅក្រមស្ថានសួគ៌ ។ នៅពេលដែលពួកសត្រូវបានហ៊ុមព័ទ្ធជុំវិញ ខណៈនោះក៏មានការទូលទៅព្រះសុំឱ្យព្រះទទួលនៅសេចក្តីអធិស្ឋាន ពីស្ថានភាពរបស់ពួកគេ អត់ទោសឱ្យពួកគេ និងដោះពួកគេឱ្យរួចផុតពីគ្រោះថ្នាក់ ក៏សុំសេចក្តីមេត្តាករុណាពីព្រះដែរ ។តែគួរសម្គាល់ដែរថា"ការដាក់ទណ្ឌកម្មខ្លួនឯង "ជាបណ្តាសារ" គម្ពីរទំនុកដំកើង គឺមានលក្ខណៈជាគម្ពីរទំនុកដំកើងបែបផ្សេងពីរគ្នា" ប្រភេទផ្សេងៗ ក៏គ្មានមូលដ្ឋានគ្រឹះច្បាស់លាស់ ។ ពីមុនមក(ការដាក់ទណ្ឌកម្មខ្លួនឯង)សំដៅលើការប្រមូលផ្តុំនៃគម្ពីរទំនុកដំកើងទាំងប្រាំពីរកណ្ឌ នាសម័យដើម (មើល ៦,៣២,៣៨,៥១,១០២,១៣០,១៤៣) គឺសម្រាប់ការសូត្រទន្ទេញពីភាពទុក្ខព្រួយទាំងឡាយ ដែលយោងតាមការកាត់យល់ខុសពីការថ្លែងប្រាប់ ដែលគេតែងតែប្រើក្នុងការអធិស្ឋាន ។ ឯអ្វីដែលបានលេចចេញយ៉ាងជាក់លាក់ចំពោះចៅក្រមស្ថានសួគ៌ ដែលបានកែខៃឱ្យត្រឹមត្រូវពោពេញទៅដោយភាពមានវិចារណញ្ញាណ(ឯតួទាំង៨ដែលកត់សំគាល់ខាងលើ) គឺការចាប់ផ្តើមទទួលបណ្តាសា ("សេចក្តីបណ្តាសា "មានន័យថា" ការដេរប្រមាថ") នេះជាពាក្យសម្តីរបស់អ្នកនិពន្ធនៃបទទំនុក បានបញ្ជាក់ប្រាប់ចំពោះពួកសត្រូវ សូមមើលការពន្យល់ ៥:១០ ។

**លក្ខណៈអក្សរសាស្ត្រ**

ការតែងនិពន្ធ គឺចាប់ពីកំណាព្យដំបូងដល់កំណាព្យចុងក្រោយ ទោះជាគម្ពីរនេះមានសរសេរច្រើនពីការអធិស្ឋាន និងពុំមានការអធិស្ឋាន ដែលស្រង់ចេញពីគម្ពីរសញ្ញាចាស់ក៏ដោយ តែការអធិស្ឋាននោះមានរបៀបជាកំណាព្យវិញ (សូមមើល ១ពវ ៨:២៣–៥៣ អរ ៩:៦–១៥ នហ ៩:៥–៣៧ ដយ ៩:៤–១៩) ឬក៏វាមិនមែនជាកិច្ចការធ្ងន់ធ្ងរក៏ដោយ តែកិច្ចការសំខាន់គឺជាកំណាព្យនឹងការសរសើរ (សូមមើល ១ពវ ៨:១៥–២១)។ គម្ពីរទំនុកដំកើង មានលក្ខណៈជាព្រះបន្ទូលដាស់តឿនរស់រវើក ច្បាស់លាស់ និងមានភាពរុងរឿងក្នុងលក្ខណៈអរូបិយ៍ ឬមានលក្ខណៈប្រៀបប្រដូច និងមានសូរសម្លេងស្រះដូចគ្នាច្រើន គឺមានសម្លេងជូនអក្សរដើមព្យាង្គ ក្នុងលក្ខណៈអត្ថបទភាសាហេព្រើរ ។ ការប្រើដែលមានប្រសិទ្ធភាពជាលក្ខណៈជូនគ្នា និងការបង្កើតឱ្យមាន ជាពាក្យសទិសន័យ និងការបំពេញន័យបន្ថែម ដើម្បីឱ្យឃើញពីលក្ខណៈសម្បត្តិ ។

ឯពាក្យជាព្រះបន្ទូលគន្លឹះតាមលក្ខណៈទូទៅបានគូសបញ្ជាក់នូវផ្ទៃរឿងសំខាន់ នៅក្នុងការអធិស្ឋាន ឬនៅក្នុងបទចំរៀង ។ ការចងក្រងប្រមូលទុក នូវការតែងនិពន្ធ ឬក៏រៀបតាមវគ្គរបស់វា ។

ជាផ្នែកកំណាព្យនៃភាសាហេព្រើរដែលពុំមានភាពជាលក្ខណៈចុងជួនច្បាស់លាស់ តែកំណាព្យនេះវាមានសំឡេងស្របគ្នា។ បទទំនុដំកើងបាននិពន្ធឡើង គឺភាគច្រើនមានពីរទៅបីវគ្គ(តែតាមការវាយតម្លៃនោះជារឿយៗ បានអត្ថន័យខ្លះនៅវគ្គទី២ ក៏សរសេរខ្លីជាងវគ្គទី១)។ វគ្គទី២(ជាវេចនៈសព្ទ ជាឃ្លាន័យដូចគ្នា ស្របគ្នា) ដែលផ្ទុយ(មានភាពស្របសូរតែអត្ថន័យផ្ទុយគ្នាវិញ) ។ វគ្គទាំងបីប្រភេទសរុបរួមទាំងអស់ ហើយក៏មិនល្មមទាំងស្រុងដែលក្នុង ការពណ៌នាពីភាពល្អៗប្លែកពីគ្នាដែលជាធាតុផ្សំពោរពេញដោយភាពប្លែកពីគ្នាដែលជាធាតុផ្សំពោពេញដោយភាពឆ្នៃប្រឌិតខ្ពស់នៃកំណាព្យដែលនាំឱ្យ សម្រេចបាននៅស្នាដៃ តាមរយៈការសរសេរតុបតែងឱ្យមានជាវគ្គធំៗពីរជាមូលដ្ឋាន ។ ខណៈពេលដែលវគ្គទី២ ឬទី៣របស់កំណាព្យមានឃ្លាខ្លះ ឬបន្ទាត់ខ្លះមានលក្ខណៈស៊ីគ្នា ដូចគ្នានោះវាមិនកំរិតជាសេចក្តីបញ្ជាក់ដែលគេបានរៀបចំមក ។

សូមកំណត់មើលតើបន្ទាត់កំណាព្យជាភាសាហេព្រើរត្រូវបញ្ចប់នៅវគ្គណា គឺពេលខ្លះវាជារឿងរ៉ាវដ៏មិនជាក់លាក់ ។ សូម្បីតែ (គ្រីស្ទបរិស័ទនាសាសន៍ក្រិកដំបូងក្នុងគ្រាសញ្ញាចាស់) ពេលនោះគេបានវិភាគពេលកាលប្រវត្តិដែលបង្ហាញពីភាពផ្ទុយផ្សេងគ្នាក៏ដោយ ក៏អត្ថបទភាសាហេព្រើរដែលជាគ្រា ឥឡូវនេះនាំឱ្យយើងឃើញច្បាស់ ។

ឯរឿងរ៉ាវដែលពាក់ព័ន្ធនោះមានជាឈុតឆាកជាកំណាព្យភាសាហេព្រើរ ។ ជាការទាក់ទងរវាងភាសាមួយទៅភាសាមួយទៀត ។ មានប្រយោគសំណង់ឃ្លាបែបជាវគ្គគាថានៃកំណាព្យ ជាភាសាហេព្រើរក៏ជារឿងដែលស្មុគស្មាញដែរ ។ ហើយក៏មានការគូសក្រិត្យពីវគ្គគាថា ផ្សេងៗផងដែរដូចជា ទដ ៤២–៤៣,៥៧ ។ ក្នុង ទដ ១១០ មានវគ្គគាថាពីរវគ្គ ដែលជាអត្ថបទទំនាយបែបជាសេចក្តីផ្តើម ទដ ១៣២ ក៏មាន ទដ ១១៩ បាន សម្រាំងជា៨បន្ទាត់តាមលំដាប់អក្ខរៈក្រមភាសាហេព្រើរ ។

តាមការសិក្សាយ៉ាតច្បាស់អំពីព្រះគម្ពីរទំនុកដំកើងក៏បង្ហាញថាអ្នកនិពន្ធជារឿយៗ និពន្ធតាមការរៀបចំនៅគំនិតរួម ។ វាជាការពិតណាស់ដែល ការនិពន្ធទៅតាមលំដាប់អក្សរអក្ខរៈក្រមដែលមានចុងជួនអក្សរហេព្រើរ(ដូចនៅក្នុង ទដ ២៥,៣៤,១៤៥) ឬក៏២បន្ទាត់ (ដូចជា ទដ ៣៧) ឬ៨បន្ទាត់ (ដូច ជាក្នុង ទដ ១១៩) ។ ក្នុងសេចក្តីបន្ថែម ទដ ៣៣,៣៨,១០៣ ជំពូកនិមួយៗមាន២២ បន្ទាត់គឺពុំបាច់ឆ្ងល់ឡើយ ដោយវាជាចំនួនអក្សរក្នុងអក្ខរៈក្រមនៃភាសាហេព្រើរ(សូមមើលសេចក្តីផ្តើមក្នុងគម្ពីរបរិទេវ : ដែលបង្ហាញពីរូបភាពអក្សរសាស្ត្រ)។ តាមពិតទៅមនុស្សគ្រាមសម័យបុរាណនោះងាយនឹងចាំនៅគ្រប់ ព្រឹត្តិការណ៍បានច្រើនជាងសម័យនេះ ។ ដែលអក្ខរៈក្រមអក្សរសាស្ត្រទំនងជាមានលក្ខណៈដែលបានបង្កើតឡើងថ្មីជានិមិត្តមួយរួមក្នុងការតែងនិពន្ធ ។

ក៏មានទម្រង់មួយបែបផ្សេងទៀតគឺគេបានប្រើ ទដ ៤៤ គឺជាទម្រង់នៃការអធិស្ឋានបន្ទាប់ពីរចនាសាងសង់ប្រាសាទពីរ៉ាមីតនៅក្រុងបាប៊ីឡូន(សូមមើល លប ១១:៤) ។ ជាអត្ថន័យនៃភាពស៊ីគ្នា និងភាពល្បីល្បាញសុះសាយ ក៏មានគម្ពីរទំនុកដំកើងដែលផ្តល់នូវលេខដូចគ្នាក្នុងបន្ទាត់ចំពោះវគ្គគាថា និមយៗ (ដូចមានក្នុង ទដ ១២:៤១) ក៏មានឃើញផងដែរក្នុងសេចក្តីផ្តើម (ដូចជា ទដ ៣៨:៨៣,៩៤) ។ មានវគ្គគាថាខ្លះដែលមានលក្ខណៈផ្តើមសេចក្តី និងលក្ខណៈបញ្ចប់សេចក្តីឯចំណុចរួមនោះមានក្នុង ទដ ៣៣,៨៦ ។ នៅមានផ្នែកខ្លះគួរឱ្យចាប់អារម្មណ៍ ដែលជាឃ្លាបន្ទាត់ផ្ទៃរឿងជាគន្លឹះ នៅត្រង់ចំណុចកណ្តាលនៃអត្ថបទ(សូមមើលការពន្យល់ ៦:៦) ។ ក៏នៅមានបទទំនុកដែលបានសរសេរឡើងពីចំណុចពិសេសដែលគេបានបង្ហាញពីលក្ខណៈពិសេសក្នុងការពន្យល់ ។ អ្នកនិពន្ធគម្ពីរទំនុកដំកើង បានបង្ហាញពីទេពកោសល្យរបស់គេក្នុងការតែងនិពន្ធដោយប្រុងប្រយ័ត្នជាទីបំផុត ។ ពួកគេបានទទួលមរដកពីស្នាដៃ សិល្បៈ(ក្នុងការបង្ហាញយ៉ាងលំអិតថា ពួកគេទទួលបានមរដកបន្តពីចាស់ព្រឹទ្ធាចារ្យនាសម័យដើមគឺជិនាញខាងកំណាព្យមានបែបទំនុកដំកើង) ហើយអ្នកនិពន្ធទាំងនោះក៏បានរៀបចំការងារនិពន្ធទៅជាបែបទំនើបថ្មីមួយ គឺជាការអភិវឌ្ឍន៍កិច្ចការនិពន្ធ ។ កិច្ចការរបស់អ្នកនិពន្ធត្រូវបានគេកោតសរសើរយ៉ាងខ្លាំង ខណៈពេលដែលគេបានសិក្សាស៊ីជម្រៅ និងសញ្ជឹងគិតទៅលើកិច្ចការនោះ ។

### វិទ្យាអ្នកនិពន្ធ (ទេវសាស្ត្រ) : សេចក្តីផ្តើម

គម្ពីរទំនុកដំកើងផ្នែកភាគច្រើនគឺសម្រាប់អធិស្ឋាន និងសរសើរដំកើង ។ ក្នុងគម្ពីរនេះបង្ហាញពីសេចក្តីជំនឿតាមរយៈការអានព្រះបន្ទូលព្រះ ក្នុងការអធិស្ឋាន និងការសរសើរដំកើងព្រះ ។ ក៏មានគម្ពីរទំនុកដំកើងខ្លះទៀតដែលមានព្រះបន្ទូលទូន្មានប្រដៅណែនាំយ៉ាងជាក់លាក់(ជាសេចក្តីបំភ្លឺណែនាំ) ក្នុងគោលបំណង និងទិសដៅ(បង្រៀនឱ្យដើរក្នុងផ្លូវនៃសេចក្តីសប្បុរសរបស់ផងទ្រង់)។ ដូចជាបានកត់សំគាល់នៅខាងលើ(មានការប្រមូលចងក្រង) ការរៀបចំ និងកាលបរិច្ឆេទ) លក្ខណៈនៃការប្រមូលចងក្រងក៏បានគេរៀបចំនិងផ្តល់ជាសេចក្តីអធិស្ឋានថាទិសដៅសំខាន់ទីមួយនោះគឺ ការអប់រំណែ នាំជីវិតក្នុងសេចក្តីជំនឿ គឺជាជំនឿឱ្យមានភាពធំធាត់ ដោយសាក្រឹត្យវិន័យដោយព្យាការី និងអក្សរសាស្ត្រដែលជាព្រះបន្ទូលជាប្រាជ្ញាខាងក្រឹត្យវិន័យ ។

ជាងនេះទៅទៀតក៏មានការសរុបសេចក្តីបង្ហាញឱ្យឃើញនៅបញ្ហាជាច្រើន ។ គម្ពីរទំនុកដំកើងបានប្រមូលផ្តុំចងក្រង ជាច្រើនប្រភេទក៏មានជាច្រើនខុសៗគ្នា និងមានអ្នកនិពន្ធចំណាយពេលជាច្រើនសតវត្សរ៍ ។ មិនគ្រាន់តែមានការសង្ខេប "វិទ្យាអ្នកនិពន្ធ (ទេវសាស្ត្រ)ប៉ុណ្ណោះទេ"តែវាមានលក្ខណៈ ចាំបាច់ផងក្នុងការឱ្យមានភាពកែច្នៃ ។ វាមានជាការឱ្យយោបលដែលគម្ពីរទំនុកដំកើងនិមួយៗ និងមានការឆ្លុះបញ្ចាំង ឬក៏យ៉ាងហោចណាស់ក៏មានសន្មត់ទុក ជាមុននៅគម្រោងសង្ខេប"វិទ្យាអ្នកនិពន្ធ"(ទេវសាស្ត្រ) ដែលពុំមានភាពតានតឹងផ្នែក"វិទ្យាអ្នកនិពន្ធ"ឬដំណើរការក្នុងចំណោមគម្ពីរទំនុកដំកើងទេ ។ ភាពពុំមានការជាក់លាក់ ក៏មានការជួបប្រទះដែរ។

ក៏មានអ្នកត្រួតពិនិត្យចុងក្រោយនៃគម្ពីរទំនុកដំកើង ក៏បានសិរាំងក្នុងប្រភពជ្រើសរើស ។ ពួកគេបានស្គាល់ ពួកគេណាមួយដែលមិនស៊ីគ្នា ឬមិនស្របគ្នានឹងក្រឹត្យវិន័យនឹងសេចក្តីទំនាយឡើយ ។ ពុំបាច់ឆ្ងល់ឡើយ ពួកអ្នកត្រួតពិនិត្យ ក៏បានសន្មត់រួមថា គម្ពីរទំនុកដំកើងនិមួយៗត្រូវបានគេយល់ថា វាជាការចងក្រងប្រមែប្រមូលដ៏ល្អមួយ ។ ការសន្មត់ទាំងនោះយើងក៏អាចចែកពីភាពសំខាន់៧ គឺផ្ទៃរឿងផ្នែកខាងវិជ្ជាអ្នកនិពន្ធដែលបានទទួលស្គាល់ ក៏មានការកែច្នៃខ្លះដែល មិនត្រូវការការបកស្រាយខុសដែលវាជាជំនួយក្នុងការសិក្សាគម្ពីរទំនុកដំកើង ។

### វិទ្យាសិក្សាព្រះគម្ពីរ : ផ្ទៃរឿងសំខាន់ៗ

១. ចំណុចកណ្តាលដែលជាខ្លឹមសារនៃវិជ្ជាសិក្សាពីគម្ពីរទំនុកដំកើង គឺជាវិន័យមួយនៃមជ្ឈមណ្ឌលសេចក្តីស្រឡាញ់ និងជីវិត (ការស្វែងយល់ពីសិទ្ធិមនុស្ស ពីសេចក្តីពិត ពីសេចក្តីសង្ឃឹម ពីការបម្រើរ ពីសីលធម៌សង្គម ពីសេចក្តីស្រឡាញ់គោរព) ប៉ុន្តែ វាក៏ជាប្រវត្តិសាស្ត្រមួយ និងការបង្កើតដែលជាស្នាព្រះហស្តរបស់ផងទ្រង់ទាំងអស់ ។ (ប៉ុន្តែវាក៏ជាប្រវត្តិសាស្ត្រមួយ និងការបង្កើតដែលជាស្នាព្រះហស្តរបស់ទ្រង់ទាំងអស់)។ (មានទាំងផ្ទៃមេឃ និងផែន ដី) គឺជាព្រះអម្ចាស់ "ព្រះយ៉ាវេ" (Yahweh) "ជាព្រះយេហូវ៉ា"សូមមើល ចទ ៦:៤ និងការពន្យល់ ។ ទ្រង់គឺជាព្រះមហាក្សត្រដ៏មានព្រះចេស្តាលើគ្រប់ទាំង អស់ ។ ទ្រង់បានបង្កើតគ្រប់ទាំងអស់ហើយទ្រង់រក្សានូវរបស់ឬជីវិតទាំងនោះ ហើយរបស់ទាំងនោះគឺជាអាវផាយនៃសេរីល្អដែលទ្រង់បានយកមកដណ្តប់ អង្គទ្រង់ ។ ដោយព្រោះទ្រង់បានរៀបចំពួកគេឱ្យមានន័យសំខាន់ និងមានសេចក្តីពិត មានអត្តសញ្ញាណច្បាស់លាស់(ក៏គ្មានភាពវឹកវរទេ) ។ ដោយសារតែ ទ្រង់ថែរក្សាពួកគេត្រូវបានព្រះអម្ចាស់ទ្ររទ្រង់នឹងថែរក្សាឱ្យរួចពីភាពមហន្តរាយ ភាពវឹកវរ ឬក៏ភាពសូន្យសុង ។ ដោយសារទ្រង់ជាអង្គតែមួយគត់ ក៏ជាព្រះមហាក្សត្រ ដែលកំពុងសោយរាជ្យ ។ នៅក្រោមការបង្កើតរបស់ទ្រង់គឺជាលោហៈធាតុ ដែលទ្រង់បានធ្វើជារូបអង្គឡើង ។ តាមរយៈការ

បង្កើត តាមរយៈ សិរីល្អដ៏មានតេជៈរបស់ព្រះមហាក្សត្របានបើកសម្ដែងឡើង ។ ទ្រង់ល្អ (ដែលប្រកបដោយប្រាជ្ញាញាណ សុចរិត បរិសុទ្ធ គួរឱ្យស្ញែងខ្លាច និងមានមេត្តា ករុណា និងសេចក្ដីពិត) ហើយទ្រង់អស្ចារ្យ (ទ្រង់មានភាពឧត្តមប្រសើរលើសពីសមត្ថភាពមនុស្ស) គ្រប់ការទាំងអស់គឺបង្ហាញពីភាពបរិសុទ្ធរបស់ផងទ្រង់ ។

២. ក្នុងនាមជាព្រះមហាក្សត្រក៏មានព្រះចេស្ដាដោយសារការបង្កើតត្រឹមត្រូវ និងមានភាពជាព្រះមហាក្សត្រដ៏ស្ថិតស្ថេរ នៅគ្រាចុងក្រោយទ្រង់ នឹងមិនអត់ធន់ចំពោះអំណាចលោកិយតទៅទៀតទេ ពីព្រោះពួកគេប្រឆាំង ឬបដិសេធន៍ ឬធ្វើព្រងើយនឹងព្រះអម្ចាស់ ។ ដោយទ្រង់យាងមកដើម្បីគ្រប់គ្រងអស់ទាំងពូជសាសន៍ ត្រូវតែទទួលស្គាល់ទ្រង់ជាព្រះរបស់ពួកគេ ។ សេចក្ដីសង្ឃឹមនេះបាននាំមកនូវភាពទុកចិត្តដោយសារមានឫសគល់ និងវិសាលភាពដ៏ធំធេង ចំពោះទស្សនៈដ៏វែងឆ្ងាយរបស់អ្នកនិពន្ធបទទំនុកនាថ្ងៃអនាគត ។ ដោយសារព្រះយេហូវ៉ាគឺជាព្រះមហាក្សត្រដ៏មានព្រះចេស្ដាលើសពីអ្វីៗដែលមនុស្សលោក មានភាពសុចរិតរបស់ផងទ្រង់ និងនគរដ៏សុខសាន្តរបស់ទ្រង់នឹងមកដែលនាំឱ្យពួកប្រឆាំងនឹងទ្រង់ភ័យស្លុតខ្លាច និងកំចាត់បង់ពួកប្រឆាំងទ្រង់ ។

៣. ក្នុងនាមជាព្រះមហាក្សត្រដ៏មានព្រះចេស្ដាដែលជីវិតមនុស្សលោកតែងតែពឹងផ្អែកលើទ្រង់ គឺទ្រង់ប្រឆាំងនឹង"សេចក្ដីអំនួត" គឺចំពោះអ្នកដែលពឹងផ្អែកទៅលើប្រភពធនធានរបស់គេ(និងថ្វាយបង្គំរូបព្រះ) ឬគេប្រថុយដោយពឹងផ្អែកលើព្រេងវាសនារបស់ពួកគេ ។ ក៏មានមនុស្សគ្មានមេត្តា ទោះជាអំណាចណាក៏ដោយក៏ពួកគេទាស់ប្រឆាំងដែរ ។ មានរូបបដិមាករ និងសន្តិសុខគឺជាច្បាប់សម្រាប់តែពួកគេ ហើយពួកគេយកផលចំណេញពីមនុស្សផ្សេងទៀត ឯក្នុងគម្ពីរទំនុកដំកើងស្ដេចនៃសេចក្ដី"អំណួត"គឺជាឫសគល់នៃការអាក្រក់ទាំងអស់ ។ តែបើអ្នកណាដែលអោប(ឱប)ក្រសោបការអាក្រក់ទាំងអស់នោះ និងនាំធ្លាក់ទៅក្នុងសេចក្ដីស្លាប់គឺជាជីវិតចុងក្រោយរបស់ពួកគេ ។ ឯអ្នក "បន្ទាបខ្លួន"" អ្នកកំសត់ និងអ្នកខ្វាក់"គឺជាអ្នកទទួលស្គាល់ និងពឹងផ្អែកលើព្រះយេហូវ៉ា នៅគ្រប់ការទាំងអស់ គឺអ្នកទាំងនោះហើយដែលព្រះទ្រង់សព្វព្រះទ័យ ។ ហេតុនេះហើយ "ការកោតខ្លាចដល់ព្រះយេហូវ៉ា" ដូចជាបានចុះចូលស្ដាប់បង្គាប់ ចំពោះព្រះយេហូវ៉ា គឺជាអ្នកកំពុងស្វែងរកគ្រប់ទាំងប្រាជ្ញា(១១១:១០) ។ នៅឯគ្រាចុងក្រោយអ្នកណាដែលឱបក្រសោបទុកនៅមរដករបស់លោកិយ គេមិនគ្រាន់តែមានសេចក្ដីស្លាប់ទេ ក៏គ្រប់អស់ទាំងអ្វីៗដែលគេបានធ្វើមិនផុតពីព្រះនេត្រទ្រង់ដែរ ។

សេចក្ដីសង្ឃឹមរបស់អ្នកនិពន្ធទំនុកដំកើងចំពោះថ្ងៃអនាគតសម្រាប់ព្រះអម្ចាស់ និងនគររបស់ទ្រង់នាថ្ងៃអនាគតនៃវត្ថុមានលក្ខណៈច្បាស់លាស់ ទោះជាពេលខ្លះមានលក្ខណៈទូទៅ ។ ពុំមានអ្នកណាម្នាក់នៃអ្នកនិពន្ធបទទំនុនដំកើងផ្ដល់នៅអារម្មណ៍ចំពោះនិមិត្តពីអាយុកាល ពីបែបនៃថ្ងៃអនាគតទេ(យុគ្គសម័យនៃការអាក្រក់ផ្ដល់ជាផ្លូវចំពោះយុគ្គស័យថ្មីនៃភាពសុចរិត និងសន្តិភាពចំពោះភាគីម្ខាងទៀតជាចំណែកសកម្មភាព) ។ ដូចជាទស្សនៈបានបង្ហាញក្នុងអក្សរសាស្ត្ររួម ឬជាទស្សនៈ ដែលបានមើលមកក្នុងអក្សរវប្បធម៌បង្ហាញជាទស្សនៈដែលជាប្រផ្នូលចំពោះដានីយែល(សូមមើល ១២:២-៣) និងដោយអ៊ីសាយ(សូមមើល ៦៥:១៧-២៥ ៦៦:២២-២៤) រួចហើយក្រោយមកទៀតក៏ទទួលនៅការចាប់អារម្មណ៍យ៉ាងពេញទំហឹងក្នុងការបង្រៀននៃព្រះយេស៊ូវ និងពួកហោរា ។ តែការបើកសម្ដែងនេះបង្ហាញពីក្ដីសង្ឃឹមដល់ជីវិតរស់នៅរបស់អ្នកនិពន្ធបទទំនុក ។

៤. ដោយព្រះអម្ចាស់គឺជាព្រះមហាក្សត្រដ៏មានព្រះចេស្ដា ទ្រង់គឺជាអ្នកលើកលែងទោសចុងក្រោយនៃការជំនុំជម្រះទៅលើមនុស្សលោក(ការសងសឹកអ្នកណាម្នាក់ គឺជាសកម្មភាពនៃ"សេចក្ដីអំនួត"ព្រះអម្ចាស់ទ្រង់គឺជាតុលាការ ឧទាហរណ៍ខណៈពេលមនុស្សណាមួយត្រូវបានគេគំរាមកំហែង ឬក៏មានអំពើខុសឆ្គងជាពិសេសនៅពេលលោកិយពុំមានតុលាការ ។ ទ្រង់បង្កើតសាលាក្ដី(ក្នុងគ្រាដែលមានជម្លោះរវាងជាតិសាសន៍ផ្សេងៗ) ដែលទ្រង់នឹងកាត់ទោស(ដូចជានៅពេលអ្នកណាម្នាក់ប្រព្រឹត្តខុសដោយរឿងអាស្រូវ ឬក៏មានបំណងប្រព្រឹត្តតាមអំពើចិត្ត ឬអំពើអាក្រក់) ។ ទ្រង់ជាអ្នកការពារដ៏ស្មោះ ត្រង់ និងមានព្រះចេស្ដាដល់អ្នកដែលពុំមានអ្វីជាទីពឹង ។ ទ្រង់បានស្គាល់នៅគ្រប់ទាំងអំពើ និងភាពអាថ៌កំបាំងរបស់ចិត្តមនុស្សគ្រប់គ្នា គ្មានអ្វីមួយដែលកំបាំង ពីព្រះភ័ក្ត្រទ្រង់ឡើយ ។ ព្រះយេហូវ៉ាទ្រង់ក៏ឮពីការទូលអង្វររបស់រាស្ត្រទ្រង់ ។ ក្នុងនាមជាចៅក្រមដ៏ស្មោះត្រង់ទ្រង់បានដោះលោះអស់អ្នកដែលបានគេគាប សង្កត់សង្កិន(សូមមើលការពន្យល់ ៥:១០) ។

៥. ក្នុងនាមទ្រង់ជាព្រះមហាក្សត្រដ៏មានអំណាចចេស្ដាលើអស់ទាំងលោកិយ ព្រះយេហូវ៉ាបានជ្រើសរើសរាស្ត្រអ៊ីស្រាអែលធ្វើជាបាវបម្រើរបស់ទ្រង់ ក្នុងកាលដែលទ្រង់ប្រទានមរដកដល់ជាតិសាសន៍ទ្រង់ ។ ទ្រង់បានប្រោសលោះ ឬរំដោះពួកគេឱ្យរួចពីអំណាចលោកិយទ្រង់ក៏បានប្រទានឱ្យប្រជារាស្ត្រ ទ្រង់មានទឹកដីផ្ទាល់ខ្លួន(គឺជាតំបន់ត្រួតត្រាជាដីកម្មសិទ្ធិ ដែលទ្រង់បានយកពីជាតិផ្សេង មកឱ្យរាស្ត្រទ្រង់ "ជាកេរ្តិ៍មរដកផ្ទាល់ខ្លួន" នៅក្នុងលោកិយនេះ) ។ ទ្រង់ក៏បានបង្រួបបង្រួមពួកគេតាមដែលសេចក្ដីសញ្ញាមានតំណាងរបស់នគរដែលទ្រង់បានសង្គ្រោះ ។ ដូច្នេះ ទាំងវាសនា និងភាពឧត្តមរបស់ពួកគេក៏ក្លាយជាភាព មានទំនាក់ទំនងតែមួយ ។ ចំពោះរាស្ត្ររបស់ផងទ្រង់ព្រះអម្ចាស់ក៏ប្រទាននៅព្រះបន្ទូលពីការបើកសម្ដែងឱ្យដឹងនូវហេតុការណ៍ផ្សេងៗ ដែលបង្ហាញពីអង្គទ្រង់ ។ ទ្រង់ក៏មានព្រះបន្ទូលសន្យាដ៏

ជាក់លាក់ និងប្រកាសពីព្រះទ័យទ្រង់ តាមរយៈសេចក្ដីសញ្ញារបស់ទ្រង់ គឺរាស្ត្រអ៊ីស្រាអែលបានរស់នៅក្នុងចំណោមគ្រប់ ទាំងពូជសាសន៍ដែលជាអ្នកស្មោះចំពោះព្រះមហាក្សត្រនៃស្ថានសួគ៌តែប៉ុណ្ណោះ ។ ដោយរាស្ត្រអ៊ីស្រាអែលជាសាសន៍ដែលព្រះការពារតាមព្រះបន្ទូលសន្យា រាស្ត្រអ៊ីស្រាអែលក៏ច្រៀងសរសើរដល់ព្រះនៃពិភពលោកទាំងមូល ដែលមានអត្ថន័យដ៏ពិសេសក្នុងការបើកសម្ដែង ពីកិច្ចការដែលព្រះបានរៀបចំទុកដាក់រាស្ត្រអ៊ីស្រាអែល ក្នុងការនាំដំណឹងល្អទៅដល់ជាតិសាសន៍ផ្សេងទៀតក្នុងលោក ។

៦. ក្នុងនាមជាព្រះមហាក្សត្រដ៏មានព្រះចេស្ដា ជាព្រះយេហូវ៉ាដែលមានសេចក្ដីសញ្ញាដល់ពួកអ៊ីស្រាអែល ព្រះអម្ចាស់ដែលជ្រើសរើសស្ដេចដាវីឌ ដើម្បីជាតំណាងរាជ្យវង្សរបស់ទ្រង់នៅលើផែនដី។ ក្នុងខណៈនេះហើយដែលទ្រង់ប្រទាននៅអំណាច និងសមត្ថភាពដល់ស្ដេចដាវីឌជាអ្នកបម្រើព្រះ "យេហូវ៉ា" ទ្រង់គឺជាសមាជិកនៃរដ្ឋបាលរបស់ព្រះមហាក្សត្រដ៏មានអំណាចចេស្ដា ។ ព្រះយេហូវ៉ាផ្ទាល់បានអភិសេកដាវីឌ និងរើសដាវីឌ"ព្រះរាជបុត្រា" នៃរាជវង្សដើម្បីដឹកនាំក្នុងភាពជាដំណាងនាមទ្រង់ជាព្រះអម្ចាស់ ។ ហើយតាមរយៈអង្គទ្រង់ព្រះអម្ចាស់បានថែរក្សាសុវត្ថិភាពនៅក្នុងទឹកដីសន្យា និងបង្គាប់គ្រប់អស់ទាំងអំណាចដែលគំរាមកំហែងដល់ពួកគេ ។ ហើយលើសពីនេះទៀតទ្រង់បានតាំងសញ្ញាដើម្បីរៀបចំលើរាជ្យវង្សស្ដេចដាវីឌ ។ មិនតែប៉ុណ្ណោះ ខណៈពេលនគររបស់ផងព្រះនៅលើផែនដីមិនបានពឹងផ្អែកលើដំណាក់ដាវីឌ គឺបានភ្ជាប់ទំនាក់ទំនងការងារផ្សេងៗ ដោយការសម្រេចមកពីព្រះ និងការតស៊ូរផ្ទាល់ ។ ក្នុងលក្ខណៈជាប់គ្នារហូតនេះ និងកម្លាំងដាក់ឱ្យមានភាពសុខសាន្តដល់រាស្ត្រអ៊ីស្រាអែល និងសេចក្ដីសង្ឃឹមខណៈពេលរាស្ត្រទ្រង់ប្រឈមមុននឹងលោកិយដ៏កាចសាហាវ ។ ហើយក្នុងខណៈពេលរាជវង្សនៃស្ដេចដាវីឌបានជាតំណាងពីព្រះយេហូវ៉ានៅក្នុងលោកិយ គឺមានតួនាទីអង្គុយនៅខាងស្ដាំព្រះហស្តទ្រង់(១១០:១) ក៏កំណត់អំណាចគ្រប់គ្រងទូទាំងពិភពលោក (សូមមើល ទដ ២) ។

ការចាក់ប្រេងតាំងរបស់ព្រះយេហូវ៉ា គឺប្រសើរជាងស្ដេចចម្បាំង ព្រះបានផ្ដល់ទ្រព្យសម្បត្តិឱ្យទ្រង់ ដើម្បីគ្រប់គ្រងរាស្ត្ររបស់ផងទ្រង់ ដែលមានភាពសុចរិតដូចជាព្រះដើម្បីប្រោសលោះការពារអ្នកគ្មានទីពំនាក់ ក៏កំចាត់សត្រូវនឹងប្រទានពរដល់គ្រប់ជាតិសាសន៍ឱ្យមានសន្តិភាព និងសេចក្ដីសុខសាន្តនៅផ្ទៃខាងក្នុង ។ ទ្រង់ក៏ទូលអង្វរដល់ព្រះក្នុងនាមជាអ្នកតំណាងឱ្យជាតិសាសន៍របស់ខ្លួន និងតំណាងឱ្យអ្នកកសាងនឹងអ្នកថែរក្សាព្រះវិហាររបស់ទ្រង់(ដូចជា ព្រះរាជវាំងសម័យដើម និងជាដំណាក់សម្រាប់ការអធិស្ឋាន) ជាទីដែលព្រះយេហូវ៉ាបានត្រាស់ហៅរាស្ត្ររបស់ទ្រង់មកថ្វាយបង្គំព្រះ ។

៧. ក្នុងនាមជាព្រះមហាក្សត្រដ៏មានព្រះចេស្ដា ជាព្រះនៃសេចក្ដីសញ្ញារបស់រាស្ត្រអ៊ីស្រាអែលព្រះអម្ចាស់ (ដែលជាព្រះអង្គបានជ្រើសរើសស្ដេចដាវីឌ និងវង្សានុវង្សរបស់ទ្រង់ ដើម្បីធ្វើជាតំណាងរបស់ព្រះ) ក៏បានជ្រើសរើសក្រុងយេរូសាឡិម(ជាទីក្រុងនៃស្ដេចដាវីឌ) ទុកជាព្រះរាជធានីរបស់ផងទ្រង់ដែរ ។ គឺជាបល្ល័ង្ករាជនៅក្នុងលោកិយនេះ មានក្រុងយេរូសាឡិម(ស៊ីយ៉ូន) ដោយសាររាជធានី (និងជានិមិត្តសញ្ញា)នគររបស់ព្រះ ។ ក្នុងព្រះរាជដំណាក់ (ព្រះវិហារ) ទ្រង់បានគ្រងរាជ្យក្នុងចំណោមប្រជាជន ។ ទីនោះរាស្ត្ររបស់ទ្រង់អាចជួបសន្ទាជាមួយនឹងទ្រង់តាមរយៈការសរសើរ ការអធិស្ឋាន និងបានទទួលសេរី ល្អដោយអំណាចចេស្ដានៃព្រះ ។ ទ្រង់ក៏នាំមកនៅការសង្គ្រោះ ព្រះពរ និងការជិនុំជម្រះដល់ជាតិសាសន៍ ។

ព្រះទ័យដ៏ស្មូរសរបស់ទ្រង់ និងភាពបរិសុទ្ធមានចំពោះរាស្ត្រទ្រង់ គឺបន្ទាល់យ៉ាងច្បាស់ដោយមានជាព្រះបន្ទូលសន្យាដល់រាស្ត្រទ្រង់នៅក្នុងព្រះវិហារឯក្រុងយេរូសាឡិម"ជាទីក្រុងរបស់ព្រះមហាក្សត្រដ៏មានព្រះចេស្ដា" (៤៨:២)។ តែទ្រង់បានសម្ដែងព្រះទ័យយ៉ាងមុតមាំចំពោះអស់អ្នកដែលបន្ទាបខ្លួនលន់តួបាបហើយជីវិតចំពោះទ្រង់ នោះទ្រង់នឹងលើកលែងទោសចំពោះពួកគេ ។ ដូចដែលក្នុងគ្រា ពួកគេមានការថប់អារម្មណ៍ ឬតានតឹងផ្លូវចិត្តដោយ ព្រោះអំពើបាបរបស់ពួកគេ នោះអ្នកនិពន្ធក៏ចងចាំពីព្រះបន្ទូលសន្យា ឬជាសេចក្ដីសញ្ញារបស់ព្រះយេហូវ៉ាមានបន្ទូលជាពាក្យ : អញជាព្រះយ៉ាវេ (Yahweh) (ជាព្រះយេហូវ៉ា) គឺជាព្រះអម្ចាស់ដែលមានព្រះករុណា និងព្រះដែលមានភាពសមគួរ ទ្រង់ជាព្រះដែលយឺតនឹងខឹងមានសេចក្ដីស្រឡាញ់បរិបូរ និងមានភាពសប្បុរសដោយទ្រង់រក្សាសេចក្ដីស្រឡាញ់រាប់ពាន់នៃសេចក្ដីស្រឡាញ់ ទ្រង់នឹងលើកលែងទោសដល់មនុស្សអាក្រក់ មនុស្សទាស់ប្រឆាំងព្រះ និងអំពើបាប(នក ៣៤:៦–៧)។ គឺគ្រាន់តែពួកគេហ៊ានទទួលទ្រង់ក្នុងនាមជារាស្ត្ររបស់ទ្រង់ ដោយ "កោតខ្លាច"ទ្រង់ (សូមមើល ១៣០:៣–៤) ។

**វិជ្ជាសិក្សាព្រះគម្ពីរ : ការសង្ខេប,ការកំណត់របស់ព្រះមែស៊ី និងសេចក្ដីបញ្ចប់**

គឺគ្មានអ្វីឆ្ងល់ឡើយភាពជាព្រះមហាក្សត្រដ៏ឧត្ដមនៃព្រះ"យ៉ាវេ"(Yahweh) (ដែលទ្រង់ដាក់តាំងនៅភាពឧត្ដមរបស់ទ្រង់)ជាពាក្យប្រៀបធៀប ជាមូលដ្ឋានគ្រិះ និងពេញដោយទស្សនៈទេវសាស្ត្រក្នុងគម្ពីរដូចជាក្នុងគម្ពីរសញ្ញាចាស់បង្ហាញទូទៅ ។ វាផ្ដល់នូវទស្សនៈនៃមូលដ្ឋានគ្រីស្ទដែលគេបានពីការបង្កើតអ្វីៗក្នុងលក្ខណៈ "និស្ស័យ" និងប្រវត្តិសាស្ត្រនាពេលអនាគត ។ ហើយគ្រប់ទាំងការបង្កើត គឺនគរមួយរបស់ព្រះ"យ៉ាវេ"(Yahweh)។ ដែលជាការបង្កើតក្នុងពិភពលោក គឺជាចំណែកនៃនគររបស់ទ្រង់ និងក្រោមការដឹកនាំរបស់ទ្រង់ ដើម្បី

ធ្វើជាមនុស្សជាតិក្នុងលោកិយ គឺពឹងផ្អែកលើការផានាខុសត្រូវចំពោះទ្រង់ ។ ក្នុងការបដិសេធន៍ការពិតដែលជាឫសគល់នៃការអាក្រក់ ហើយឥឡូវនេះគ្រប់គ្រងលោកិយទាំងមូល ។ ការរើសតាំងរបស់ព្រះចំពោះរាស្ត្រ អ៊ីស្រាអែលតាមរយៈវង្សដាវីឌ និងក្រុងស៊ីយ៉ូន ក៏ទ្រង់បានផ្តល់នូវព្រះបន្ទូលជាតំណាងដើម្បីកែប្រែការខូចខាតនៅនាលោកិយនេះ គេបានប្រឆាំងនឹងព្រះ ឬមានវិញ្ញាណអាក្រក់ ។ ក៏មានការបែងចែករវាងជាតិសាសន៍សុចរិត និងជាតិសាសន៍អាក្រក់មានគំនិតជ្រៅៗរវាងភាពសុចរិត និងអាក្រក់ ។

មានសំនួរមួយដែលគួរតែបង្ហាញគឺ : តើគម្ពីរទំនុកដំកើងនិយាយពីព្រះគ្រីស្ទឬទេ? តាមពិធីផ្សេងៗ តែមិនមែនជាពួកហោរាជាអ្នកនិយាយទេ ។ គម្ពីរមិនដែលកំណត់ចំនួន "នូវគម្ពីរហោរាទេ" ម្យ៉ាងវិញទៀតគ្រាគម្ពីរបានផ្តល់នូវបែបបទចុងក្រោយនូវអ្វីៗ ដែលគម្ពីរទំនុកដំកើងសម្តែងអំពីព្រះយេហូវ៉ា និងផ្លូវរបស់ទ្រង់ ជាមួយប្រជាជនរបស់ទ្រង់អំពីព្រះយេហូវ៉ា និងផ្លូវរបស់ទ្រង់រួមទាំងជាតិសាសន៍ទាំងឡាយ ដែលនិយាយពីសកម្មភាពរបស់ព្រះយេហូវ៉ា និងផ្លូវរបស់ទ្រង់ ដែលមានភាពសុចរិតនឹងពួកមនុស្សអាក្រក់ទាំងអស់ និងកិច្ចការអ្វីៗពីអ្នកនិពន្ធទំនុកបាននិយាយពីការដែលព្រះយេហូវ៉ាចាក់ប្រេងតាំង ឬពីកិច្ចការព្រះវិហារ និងទីក្រុងបរិសុទ្ធគឺគ្រប់កិច្ចការនោះគេបានយល់ថា វាគឺជាពន្លកនៃផ្នែកអក្សរពីសេចក្តីទំនាយ(មានពីទំនាយដើមដំបូង និងក្រោយមកទៀត)។ ការទាក់ទងនឹងរឿងរ៉ាវទាំងអស់នោះមានអត្ថបទគម្ពីរ និងសេចក្តីទំនាយគឺមានលក្ខណៈទំនាក់ទំនងគ្នាជាច្រើន និងការបកស្រាយដូចគ្នា ។

ខណៈពេលគម្ពីរទំនុកដំកើងនិយាយអំពីស្តេចដែលគង់នៅលើបល្ល័ង្កស្តេចដាវីឌ ពួគេនិយាយពីព្រះមហាក្សត្រដែលនឹងយាងមកទទួលមកុដរាជ្យ (ដូមមានក្នុង ទដ ២,៧២,១១០) ឬក៏ជាស្តេចដែលកំពុងសោយរាជ្យ (ទដ ៤៥) ។ គេបានប្រកាសបីស្ថានភាពរបស់ទ្រង់ដែលជាការដែលព្រះយេហូវ៉ាបានចាក់ប្រេងតាំង និងប្រកាសនូវអ្វីៗដែលព្រះបានសម្រេចព្រះរាជកិច្ចតាមរយៈអង្គទ្រង់ និងវង្សានុវង្សរបស់ទ្រង់ ។ ក៏បាននិយាយពីរាជបុត្រា ដែលនឹងយាងមក ហើយក្នុងគ្រាដែលគេនិរទេស និងពេលគ្រាសករាជនាសម័យពួកយូដារហូតដល់សម័យជាប់ជាឈ្លើយនៅបាប៊ីឡូន ពេលនោះជារយៈពេលឥតមានស្តេច សោយរាជ្យ ក៏មានហោរានិយាយពីការនោះថា មានតែរាស្ត្រអ៊ីស្រាអែលទេគឺជាព្រះរាជបុត្រានៃហ្លួងដាវីឌ ដែលហោរាបានប្រកាស់ថា ជាអង្គមួយដែលមាននៅក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់ និងស្តេចដាវីឌដែលត្រូវសម្រាក ។ ដូច្នេះ ក្នុងគ្រាសញ្ញាថ្មីបានបង្ហាញបញ្ជាក់ថា គម្ពីរទំនុកដំកើងជាទីបន្ទាល់ពីព្រះគ្រីស្ទ ដែលទ្រង់បានផ្តល់ជាផ្លូវមកដល់មនុស្សលោក តាមរយៈអង្គទ្រង់ត្រូវបានសម្រេចគ្រប់ការទាំងអស់ ។

សេចក្តីទួញសង្រេងទាំងនេះពីព្រោះការអធិស្ឋានរបស់អ្នកត្រូវគេជិះជាន់"ជាសង្ឃព្រះ" គេក៏បង្កើតបានជាសៀវភៅអធិស្ឋានរបស់ក្រុងយេរូសាឡិម ។ ខណៈពេលព្រះគ្រីស្ទមកយកនិស្ស័យជាសាច់ឈាមទ្រង់បានបញ្ជាក់ថាអង្គទ្រង់ជាព្រះអម្ចាស់ ទ្រង់ក៏មានចំណែករងនៅការឈឺចាប់នៅក្នុងដៃរបស់ មនុស្សអាក្រក់ ។ ការអធិស្ឋានទាំងនេះក៏ក្លាយជាការអធិស្ឋានរបស់ទ្រង់តែម្តងទៅ ។

ក៏មានលក្ខណៈស្រដៀងគ្នាមួយ គឺក្នុងការនិយាយរបស់រាស្ត្រតាមសេចក្តីសញ្ញារបស់ព្រះអម្ចាស់ នៃទីក្រុងរបស់ព្រះ និងពីព្រះវិហារដែលជាទីព្រះអម្ចាស់គង់សណ្ឋិត ដែលគម្ពីរទំនុកដំកើងនិយាយអំពីព្រះវិហាររបស់ព្រះគ្រីស្ទគឺជាពួកជំនុំ ។ គម្ពីរទំនុកដំកើងមិនគ្រាន់តែជាគម្ពីរអធិស្ឋានរបស់ព្រះវិហារទីពីរប៉ុណ្ណោះទេ តែក៏ជាគម្ពីរពីការអធិស្ឋានរបស់រាស្ត្រនៃព្រះអម្ចាស់ ។ ឥឡូវនេះវាប្រើជាពន្លកថ្មីនៃយុគ្គសម័យនៃការប្រោសលោះ ដែលមានការយាងមក ជាលើកទីមួយនៃព្រះមេស៊ី និងក៏ត្រូវមានការយាងមកជាលើកទីពីរ ។

# ការរៀបចំវគ្គសំខាន់ៗរបស់គម្ពីរទំនុកដំកើង
# សេចក្ដីណែនាំអំពីជីវិតដែលមានព្រះក្រោមការគ្រប់គ្រងរាជរបស់ព្រះអម្ចាស់
# សៀវភៅទី១

**ទដ ១–២** សេចក្ដីផ្ដើម រៀបជារូបរាង្គឡើងជាពីរវគ្គ (មានព្រះពរ)ការប្រកាសប្រាប់ :

១– ការអំពាវនាវសូម(ច្បាប់)ភាសាហេព្រើរថា "ថូរ៉ាស" (Torah) និងប្រាជ្ញា ភាសាក្រិកថា "ហូគម៉ា" (Hokmah)

២– ការអំពាវនាវសូមឱ្យមានហោរាមុន និងហោរាក្រោយទៀត (មានព្រះយ៉ាវេ និងការចាក់ប្រេងតាំងរបស់ទ្រង់ ក្នុងគ្រារាស្ត្រអ៊ីស្រាអែលមានភាពជ្រួលច្រាល) ។

ដូច្នេះ ១. អត្ថបទគម្ពីរបានអានក្នុងបុព្វបទនៅផ្នែកផ្សេងៗទៀតនៃគោលការណ៍គម្ពីរសញ្ញាចាស់ ។

២. បទគម្ពីរបង្ហាញថាអស់អ្នកដែលព្យាយាមក្នុងការអធិស្ឋាន សរសើដំកើងដល់ព្រះនោះ ពួកគេមានលក្ខណៈរឹងមាំដូចជាសសរនៃព្រះវិហារ ដោយជីវិតពួកគេមានបានសម្រួចឱ្យមុតមាំដោយសារបញ្ញត្តិច្បាប់ ឬដល់ប្រាជ្ញាពីព្រះហើយពួកគេ"មានទីជម្រក" ក្នុងព្រះយេហូវ៉ា ហើយព្រះយេហូវ៉ាក៏ បានចាក់ប្រេងតាំងដល់ពួកគេ ដោយព្រោះពួកគេកោតខ្លាចដល់"ព្រះយេហូវ៉ា" ។

---

**ទដ ៣–៤**

៣– ការទូលអង្វរសូមឱ្យដោះលែងចេញពីពួកសត្រូវ

៤– ការទូលអង្វរសូមឱ្យភាពរាំងស្ទួតកន្លងបាត់ទៅ

៥– ការទូលអង្វរសូមឱ្យដោះឱ្យរួចពីកណ្ដាប់ដៃ នៃពួកខ្មាំងសត្រូវ ។

៦– ការទូលអង្វរសូមឱ្យព្រះអម្ចាស់ប្រោសឱ្យជា

៧– ការទូលអង្វរសូមឱ្យព្រះដោះចេញពីពួកសត្រូវ

**៨– ការសរសើចំពោះព្រះអទិករ (សិរីល្អរបស់ព្រះអម្ចាស់ និងការផ្គត់ផ្គង់ទៅឱ្យមនុស្ស)**

៩–ការទូលអង្វរសូមឱ្យព្រះដោះលែងចេញពីជាតិសាសន៍ដែលជាសត្រូវ

១០– ការទូលអង្វរសូមឱ្យរួចពីមនុស្សអាក្រក់

១១– ការទុកចិត្តលើការដឹកនាំដ៏សុចរិត

១២–ការអំពាវនាវសូមជំនួយក្នុងគ្រាឥតមានវគ្គមានព្រះ

១៣–ការអំពាវនាវសូមព្រះប្រោសលោះឱ្យរួចពីជម្ងឺធ្ងន់ធ្ងរនឹងពីពួកសត្រូវ

**១៤– អំពើដ៏លាមករបស់មនុស្សលោក ("ព្រះយេហូវ៉ាមើលមកឃើញមនុស្សងាកបែរចេញពីទ្រង់")**

---

**ទដ ១៥–២៤**

**១៥– តើអ្នកណាចូលទៅក្នុងព្រះវិហារ?**

១៦– ការលន់តួចំពោះសេចក្ដីពិតក្នុងព្រះយ៉ាវេ

១៧–ការអំពាវនាវសូមឱ្យព្រះជួយសង្គ្រោះឱ្យរួចពីសត្រូវ ។

១៨–ការសរសើរចំពោះព្រះក្នុងការប្រោសលោះ

**២៤–អ្នកណាដែលឡើលើកំពូលភ្នំបាន?**

២៣–ការសារភាពទោសដោយទុកចិត្តដល់ព្រះយ៉ាវេ

២២–ការសូមការដោះលែរពីសត្រូវ

២០–២១ អធិស្ឋានសម្រាប់ជ័យជម្នះរបស់ស្ដេច និងការសរសើរ

**១៩–សិរីល្អរបស់ព្រះយ៉ាវេ ក្នុងការបង្កើត និងពាក្យប្រដៅ**

(ព្រះអាទិត្យនាពោលរដូវប្រាំង បានវិលឆ្លងកាត់ផ្ទៃអាកាសពីទិសខាងកើតទៅទិសខាងលិច)

---

**ទដ ២៥–៣៣**

**២៥–កំណាព្យតាមលំនាំអក្សរ**

២៦–ការអធិស្ឋានពីការប្រៀនប្រដៅ

២៧–ការប្រឆាំង និងពួកចោទប្រកាន់ក្លែងក្លាយ ។ "សូមមានកម្លាំង និងត្រៀមចិត្តគំនិត រងចាំព្រះយេហូវ៉ា"

២៨–ការអធិស្ឋានចំពោះអ្នកដែលធ្លាតចុះទៅរណ្ដៅ "មានកម្លាំង . . . មានកម្លាំង" ខ.៧–៨ ។

២៩–ការសរសើរចំពោះស្ដេចនៃការបង្កើត (ព្យុះ ផ្គរ រន្ទះ បានធ្វើចលនាកាត់ផ្ទៃមេឃ ពីទិសខាងលិចទៅទិសកើត) ។

៣០–ការសរសើរតម្កើងចំពោះការដែលបានរួច"ពីការធ្លាក់ចុះ""ឱ្យឈររឹងមាំ" (រឹងមាំ) ខ.៧ ។

## សៀវភៅទី១ (បន្ត)

៣១–បង្ហាញពីការប្រឆាំងនិងពួកចោទប្រកាន់ខុសឆ្គង"សូមឱ្យរឹងមាំ និងត្រៀមចិត្ត"ឱ្យគ្រប់គ្នាមានសង្ឃឹមក្នុងព្រះយេហូវ៉ា"។

៣២–ព្រះពរដោយព្រោះការលន់តួបាប

**៣៣–កំណាព្យតាមលំដាប់អក្ខរៈក្រម**

**ការសរសើរចំពោះការដឹកនាំល្អរបស់ព្រះ**

**ទដ ៣៤–៣៧**

**៣៤–កំណាព្យតាមលំដាប់អក្ខរៈក្រម**

**សេចក្តីផ្តើមចំពោះប្រាជ្ញាដែលមានពីព្រះ**

៣៥–ការបង្ហាញពីការប្រឆាំងនឹងពួកនិយាយបង្ខូច

**៣៧–កំណាព្យតាមលំដាប់អក្ខរៈក្រម**

៣៦–ការបង្ហាញពីការប្រឆាំងរបស់ពួកមនុស្សអាក្រក់ ។

**ទដ ៣៨–៤១**

៣៨–ការអធិស្ឋានសូមឱ្យព្រះអម្ចាស់រំដោះឱ្យរួចពីជម្ងឺធ្ងន់ធ្ងរ និងមាសត្រូវការលន់តួអំពើបាប ។

៤០–អធិស្ឋានឱ្យរួចផុតពីភាពកង្វល់ (ជម្ងឺយ៉ាងធ្ងន់) និងពួកសត្រូវ : ជាការលន់តួបាប ។

៤១–អធិស្ឋានសូមឱ្យរួចផុតពីជម្ងឺដ៏សាហាវ និងពួកសត្រូវ : គឺជាការលន់តួបាប ។

**៤០:៤** (ព្រះពរមានដល់ . . .) អ្នកដែលទុកចិត្តដល់ព្រះយេហូវ៉ា

**៤១:១** (ព្រះពរមានដល់ . . .) គឺអស់អ្នកដែល"យល់ថាខ្លួនមានភាពខ្សោយ"

## សៀវភៅទី២

### ទដ ៤២–៤៥ សេចក្តីអធិស្ឋានបីដែលមានបទទំនុកដំកើងនៃរាជវង្ស ភ្ជាប់ទៅនឹង (ទដ ៦៩–៧២)

៤២–សេចក្តីអធិស្ឋានផ្ទាល់ខ្លួនម្នាក់ៗ (ថាហេតុអ្វីបានជាទ្រង់ភ្លេចទូលបង្គំ"ក្នុងគ្រាដែលសត្រូវបានធ្វើទុក្ខទោសដល់ទូលបង្គំ?)

៤៣–សេចក្តីបន្តនៃបទ ទដ ៤២

៤៤–សេចក្តីអធិស្ឋានរួមជាសហគមន៍ (ថាហេតុអ្វីបានជាទ្រង់លាក់ព្រះភ័ក្ត្រ ហើយភ្លេចទូលបង្គំក្នុងគ្រាដែលពួកសត្រូវបៀតបៀនធ្វើបាបទូលបង្គំ។

**៤៥–ជាបទចម្រៀងនៃការសរសើរនៃស្តេចជាព្រះមហាក្សត្រ ក្នុងទិវាសិរីរុងរឿងរបស់ទ្រង់** (គឺជាព្រះវិធីបង្គលការព្រះមហាក្សត្រយានី)

(". . . ការឆ្ពោះទៅមុខ . . . ក្នុងនាមឱ្យតំណាងសេចក្តីពិត ការបន្ទាបខ្លួន និងភាពសុចរិត")

(រាជបល្ល័ង្ក . . . និងស្ថិតស្ថេររៀងរហូត"។

**ទដ ៤៦–៤៨ ការធ្វើពិធីសុខសាន្តរបស់ក្រុងស៊ីយ៉ូន**

៤៦–ភាពសុខសាន្តរបស់ក្រុងស៊ីយ៉ូន

៤៧–ព្រះមហាក្សត្រដ៏មានព្រះចេស្តារបស់ក្រុងស៊ីយ៉ូន ដ៏មានជោគជ័យលើអស់ទាំងពូជសាសន៍ ។

៤៨–សន្តិសុខរបស់ក្រុងស៊ីយ៉ូន ។

**ទដ ៤៩–៥៣ ឥរិយាបថយ៉ាងជាក់លាក់ចំពោះព្រះ**

៤៩–ពួកមនុស្សល្ងីល្ងើដែល"ទុកចិត្តទៅលើទ្រព្យរបស់ពួកគេ" ដែលមានសេចក្តីអំនួតចំពោះភាពស្តុកស្តម្ភដ៏អស្ចារ្យរបស់ពួកគេ ។

៥០–ព្រះត្រាស់ហៅប្រជារាស្ត្ររបស់ទ្រង់ឱ្យគ្រប់គ្រងលើទ្រព្យទាំងអស់នោះ ។

៥១–ការអធិស្ឋានដោយបន្ទាបខ្លួនដើម្បីធ្វើការលើកលែងទោស និងការសំអាតឱ្យស្អាត ។

៥២–មនុស្សល្ងីល្ងើរដែល"ទុកចិត្ត និងទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹក" ដែលមានសេចក្តីអំនួតក្នុងផ្លូវអាក្រក់

## សៀវភៅទី២ (បន្ត)

៥៣–មនុស្សល្ងីល្ងើដែលរស់នៅពុំមានព្រះ (និយាយឡើងវិញក្នុង ទដ ១៤) ។

**ទដ ៥៤–៦០ ការអធិស្ឋានទាំងប្រាំពីរ នៅកណ្ដាលសៀវភៅទី២** (អារុធដ៏ចំបងក្នុង ទដ ៥៤–៥៩ គឺក្នុងមាត់)

៥៤–ការអធិស្ឋានម្នាក់ៗសូមឱ្យមានជំនួយប្រឆាំងសត្រូវ (ពាក្យអធិស្ឋានជាគំរូ) ។

៥៥–ការអធិស្ឋានសូមជំនួយ : ការរួមគំនិតនៅក្នុងក្រុងយេរូសាឡិម ("ពួកគេដើរក្រវែលកំផែងក្រុងយេរូសាឡិម") ("ព្រះបន្ទូល . . . បង្កើតបានជាដាវ")

៥៦–អធិស្ឋានសូមជំនួយប្រឆាំង និងពួកសត្រូវ

៥៧–អធិស្ឋានសូមឱ្យដោះលែងចេញពីពួកសត្រូវ (សូឱ្យព្រះអម្ចាស់ដ៏ខ្ពស់ឧត្តមបំផុត"បានគេលើកដំកើងឡើង") (អណ្ដាតគឺជាអាវុធដ៏មុតស្រួច)

៥៨–អធិស្ឋានចំពោះចៅក្រមពីស្ថានសួគ៌ ដើម្បីប្រទាននូវភាពត្រឹមត្រូវ ដែលអ្នកដឹកនាំលោកិយពុំទាន់មានឡើយ ។

៥៩–ការអធិស្ឋានសូមជំនួយ : គឺគ្រាពួកសត្រូវឡោមព័ទ្ធទីក្រុងយេរូសាឡិម ("ពួកគេដើរក្រវែលទីក្រុង") (បញ្ចេញដាវពីបបូរមាត់របស់ពួកគេ)

៦០–ការអធិស្ឋានជាសហគមន៍សូមជំនួយ បន្ទាប់ពីមានការឈឺចាប់ដោយការវាយបំផ្លាញ (ប្រៀបធៀបទដ ៤៤) (ដោយទ្រង់ . . . បានបដិសេធពួកទូលបង្គំ ក៏មិនយូរប៉ុន្មាន ទូលបង្គំចេញទៅជាមួយសត្រូវ) ។

**ទដ ៦១–៦៤ សេចក្ដីអធិស្ឋានទាំងមុននៃព្រះមហាក្សត្រ ដែលមានគ្រប់ទាំងរឿងរ៉ាវបញ្ចូលគ្នា**

៦១–បង្ហាញពីវត្តមាននៃព្រះអម្ចាស់ ("ដុំថ្ម""មានជាជម្រក""ប៉មយ៉ាងរឹងមាំ""នៅក្នុងទីជម្រនៃស្លាបរបស់ទ្រង់")

៦២–បង្ហាញពីការរំដោះចេញពីពួកខ្មាំងសត្រូវ ("ថ្ម""បន្ទាយ""ថ្មមានអំណាច""ទីជម្រក"ក៏និងមានរង្វាន់ដល់មនុស្សដែលយោងតាមអ្វីៗដែលពួកគេបានធ្វើ")

៦៣–ការបង្ហាញពីវត្តមានថ្មីៗរបស់ព្រះខណៈពេលពួកសត្រូវបានគំរាមកំហែង ("ច្រៀងក្នុងចំអេងស្លាបរបស់ទ្រង់")"ពួកគេស្វែងរកជីវិតទូលបង្គំ . . . គេនឹងធ្លាក់ចុះទៅលើផែនដី ។

៦៤–ការបង្ហាញពីការថែរក្សារបស់ព្រះអម្ចាស់ប្រឆាំងនឹងពួករួមគំនិតគ្នាប្រឆាំង (ពួកគេបាញ់ . . . ជាប្រញាប់ . . . ព្រះអម្ចាស់នឹងបាញ់ពួកគេ . . . ប្រញាប់)

**ទដ ៦៥–៦៨ "សេចក្ដីភ័យខ្លាច"របស់ព្រះធ្វើឱ្យមនុស្សកោតខ្លាច ក៏អង្រួនការសរសើរដំកើងទាំងអស់"គ្រប់ទាំងផែនដី"**

៦៥–ព្រះអម្ចាស់ប្រទានពរដល់លោកិយឱ្យមានជាផលផ្លែរីកចម្រើន ក៏បានបង្ហាញឱ្យឃើញច្បាស់ ("សេចក្ដីសង្ឃឹមនៅគ្រាចុងបញ្ចប់របស់លោកិយ")

៦៦–ព្រះរាជកិច្ចរបស់ព្រះអម្ចាស់ក្នុងការសង្គ្រោះមនុស្សលោកក្នុងនោះមានជារាស្ត្រអ៊ីស្រាអែលត្រូវបានបញ្ជាក់)"ស្រែកដោយក្ដីអំណរចំពោះព្រះចំពោះលោកិយទាំងអស់") ។

៦៧–ព្រះពររបស់ព្រះអម្ចាស់ចំពោះលោកិយឱ្យមានផលផ្លែ ("គ្រប់ទាំងមនុស្សត្រូវសរសើរតម្កើង . . . រហូតដល់ទីបញ្ចប់នៃផែនដី . . . មានសេចក្ដីភ័យខ្លាច") ។

៦៨–សេចក្ដីសង្គ្រោះរបស់ព្រះក្នុងនាមជារាស្ត្រអ៊ីស្រាអែល គឺបានបញ្ជាក់ដែរ ("ព្រះមហាក្សត្រ . . . នាំមកនូវអំណោយទាន . . . ច្រៀងសរសើរព្រះនាមនរគរលោកិយ") ។

**ទដ ៦៩–៧២ សេចក្ដីអធិស្ឋានបីបែប ដែលមានបញ្ចូលបទទំនុកដំកើងសរសើរទាក់ទងនិង (ទដ ៤២–៤៥)**

៦៩–សេចក្ដីអធិស្ឋាននៃព្រះមហាក្សត្រចំពោះការប្រោសលោះ ក្នុងគ្រាដែលមានការវាយប្រហារដ៏កាចសាហាវ ។

៧០–ជាសេចក្ដីអធិស្ឋានខ្លីៗ (បង្ហាញឡើងវិញពីរ ទដ ៤០ សូមមើលសេចក្ដីផ្ដើម ទដ ៧១) ។

## សៀវភៅទី២ (បន្ត)

៧១–ជាសេចក្ដីអធិស្ឋានរបស់ព្រះមហាក្សត្រដើម្បីសូមជំនួយដូចជាក្នុងយុគ្គសម័យដើមដំបូង នៅពេលមានការវាយប្រហារ ។

៧២–ការអធិស្ឋានដែលមានព្រះមហាក្សត្រ គឺដែលមានអំណោយទានពិសេសក្នុងការដឹកនាំដោយភាពយុត្តិធម៌

(. . . "មានគ្រប់ទាំងជំនាន់")   (. . . "គ្រប់ជាតិសាសន៍ . . . មានពរតាមរយៈទ្រង់")

---

## សៀវភៅទី៣

វគ្គនេះបង្កើតបានជាបីក្រុមក្នុងចំណោមគម្ពីរទំនុកដំកើងទាំង៦ជំពូក (មាន ៧៣–៧៨)

---

**ទដ ៧៣–៧៨**

៧៣–សេចក្ដីណែនាំផ្អែកទៅលើបទពិសោធន៍ផ្ទាល់ខ្លួន ។

៧៤–ការអធិស្ឋានជាលក្ខណៈសហគមន៍ : ព្រះអម្ចាស់"បានបដិសេធន៍"រាស្ត្ររបស់ផងទ្រង់ ។

៧៥–អរព្រះគុណដល់ព្រះអម្ចាស់ : "ព្រះនាមទ្រង់នៅជិតបង្កើយ"ហើយទ្រង់បានកាច់ចង្កូមរបស់មនុស្សអាក្រក់ និងបានតម្កើងស្នែងរបស់មនុស្សសុចរិត"គឺទ្រង់លើកមនុស្សសុចរិតឡើង" ។

៧៦–ការប្រារព្ធពិធីផ្សេងៗ : គឺព្រះអម្ចាស់អស្ចារ្យក្នុងប្រទេសអ៊ីស្រាអែល"ទ្រង់បានបំបែបកវិញ្ញាណរបស់ពួកមាសត្រូវ" ។

៧៧–ការអធិស្ឋានរៀៗខ្លួន : ព្រះបានបដិសេធទ្រង់

៧៨–សេចក្ដីណែនាំយោងលើបទពិសោធន៍សហគមន៍

---

**ទដ ៧៩–៨៣**

៧៩–ការអធិស្ឋានជាសហគមន៍ :

គឺក្នុងខណៈពេលពួកសត្រូវឈ្លានពាន

៨០–អធិស្ឋានចំពោះព្រះដើម្បីសូមឱ្យទ្រង់បំពេញរាស្ត្រទ្រង់មានជីវិតរស់ឡើងវិញ

បន្ទាប់ពីពួកសត្រូវធ្វើទុក្ខបុកម្នេញ ។

៨៣–អធិស្ឋានសម្រាប់តំបន់

នៅពេលក្នុងការព្រួតគ្នាវាយចូល

៨២–អធិស្ឋានសម្រាប់ការកាត់ក្ដីមនុស្សអាក្រក់

ដែលគ្រប់គ្រងផែនដី

**៨១–ការលើកតម្កើងដល់រាស្ត្រអ៊ីស្រាអែល :**

**"បើពួកអ៊ីស្រាអែលដើរតាមផ្លូវអញនោះអញនឹងវាយកំទេចពួកសត្រូវគេយ៉ាងរហ័ស"**

---

**ទដ ៨៤–៨៩**

៨៤–ការបង្ហាញពីសេចក្ដីចង់បាន"ការកាត់ទោសពីព្រះយេហូវ៉ា និងអធិស្ឋានចំពោះព្រះអម្ចាស់"ដោយការគោរព"នៅលើខែល"របស់ទូលបង្គំ "ការចាក់ប្រេងតាំងរបស់ទ្រង់" ។

៨៥–អធិស្ឋានឱ្យព្រះទាញរាស្ត្ររបស់ទ្រង់ចេញពី

ភាពទុក្ខព្រួយវេទនាទាំងឡាយ ។

៨៩–អធិស្ឋានសូមឱ្យព្រះជួយសង្គ្រោះរាស្ត្រទ្រង់

ចងចាំនៅសន្ធិសញ្ញាជាមួយដាវីឌ

៨៦–ការអធិស្ឋានរៀងខ្លួន សូមជំនួយពីព្រះ

ក្នុងគ្រាសត្រូវបានវាយប្រហារ ។

៨៨–ការអធិស្ឋានរៀងខ្លួនសូមជំនួយពីព្រះ

ក្នុងការដោះលែងជាថ្មីឱ្យរួចពីសេចក្ដីស្លាប់

**៨៧–បទចម្រៀងដែលលើកពីសេចក្ដីសប្បុរសរបស់ផងទ្រង់**

**ដ៏វិសេសចំពោះក្រុងស៊ីយ៉ូន និងប្រជារាស្ត្ររបស់ទីក្រុងនោះ**

## សៀវភៅទី៤ និងទី៥

---

**ទដ ៩០–១០០ បទទំនុកដំកើងទាំង១១ជំពូកបានចងក្រងដោយ"អាដូណៃ . . . ជាព្រះមានបន្ទូលថាទីកន្លែងគង់សណ្ឋិតរបស់អញគឺនៅក្នុងមនុស្ស**

១១៧ របស់ជនជាតិអ៊ីស្រាអែល
១១៨

១១៩–ជាការអធិស្ឋានរបស់អ្នកពេញចិត្ត និងទទួលសេចក្តីបញ្ញត្តិរបស់ព្រះអម្ចាស់ (ខ.៣៥)

---

**ទដ ១២០–១៣៧ ចំរៀងនៃការឡើងទំនុកមានពីរវគ្គ**

១២០–១៣៤ "ការលើកបទទំនុក"

១៣៥–១៣៦ បទទំនុកដំកើងមានទំនាក់ទំនងនឹងពួកសាសន៍យូដា

១៣៧–ចំរៀងសេចក្តីស្រឡាញ់ចំពោះក្រុងស៊ីយ៉ូនដែលបានចេញរួចពីការនិរទេសនេះ គឺក្រុងបាប៊ីឡូន ។

---

**ទដ ១៣៨–១៤៥ ទំនុកដំកើងទាំង៨ដែលបង្ហាញពីស្តេចដាវីឌ : ជាការអធិស្ឋានដោយការច្រៀងសរសើរ ។**

១៣៨–ការសរសើររបស់ព្រះយ៉ាវេ "ពេលទូលបង្គំហៅរកទ្រង់ ទ្រង់ក៏បានឆ្លើយតប"សូមឱ្យគ្រប់ស្តេចទាំងអស់សរសើរដល់ព្រះយេហូវ៉ា ។

១៣៩–ការទទួលស្គាល់ភាពស្អាតស្អំពីខាងមុខភាពសព្វញ្ញូញាណ និងវត្តមានរបស់ព្រះអម្ចាស់ ។

១៤០–១៤៤ មានបែបបទអធិស្ឋានបែបសម្រាប់ការប្រោសលោះចេញពីរ :

១៤០ : មនុស្សអាក្រក់ មនុស្សសាហាវ ពួកអាក្រក់

១៤១ : អ្នកប្រព្រឹត្តការអាក្រក់គ្រប់យ៉ាង

១៤២ : តាមរកអ្នកដែល "ខ្លាំងចំពោះខ្ញុំ"

១៤៣ : មាសត្រូវ

១៤៤ : ពួកបរទេស

១៤៥–ជាការសរសើរនៃព្រះយ៉ាវេ "ជាព្រះមហាក្សត្រ" ដែលទ្រង់គង់នៅជិតអស់អ្នកដែលអំពាវនាវរកទ្រង់ ។

---

**ទដ ១៤៦–១៥០ បទទំនុកដំកើងទាំង៨មានន័យថា ហាលេលូយ៉ា ឬក៏មានន័យថា "សរសើរដល់ព្រះយេហូវ៉ា ដែលរួមបញ្ចូលក្នុងគម្ពីរទំនុកដំកើង ។**

**១** មានពរ ហើយ អ្នកណា[ក]ដែលមិនដើរ[ខ]តាមដំបូន្មាន
របស់មនុស្សអាក្រក់[គ]
ក៏មិនឈរ នៅក្នុងផ្លូវ[ឃ] របស់មនុស្សមានបាប[ង]
ឬអង្គុយ[ច]នៅជាមួយនឹងពួកមនុស្សដែលមើលងាយ[ឆ]
២អ្នកនោះត្រេកអរ[ជ]តែនឹងក្រិត្យវិន័យរបស់ព្រះយេហូវ៉ា
វិញ[ឈ] ក៏រំពឹងគិត[ញ]ក្នុងក្រិតវិន័យទ្រង់ទាំងយប់ទាំងថ្ងៃដែរ
៣អ្នកនោះនឹងដូចជាដើមឈើ[ដ] ដែលដុះនៅក្បែរផ្លូវ[ឋ]ទឹក[ឌ]
ដែលបង្កើតផល[ឍ]តាមរដូវកាល
ហើយស្លឹក[ណ]ក៏មិនចេះស្រពោនឡើយ
ឯការអ្វីដែលអ្នកនោះធ្វើ នោះនឹងចំរើនឡើងទាំងអស់[ត]

**១:១** ក ចទ ៣៣:២៩ ទដ ៤០:៤ ១២៨:៤ ខ ទដ ៨៩:១៥ គ យប ២១:១៦ ទដ ១០:២-១១ ឃ លប ៤៩:៦ ង ទដ ២៦:៩ ៣៧:៣៨ ១:១៣ ១០៤:៣៥ ច ទដ ២៦:៤ ឆ យប ១១:៣ សភ ១:២២ អស ២៨:១៤ ហស ៧:៥ **១:២** ជ ទដ ១១២:១ ១១៩:១៦,៣៥ រម ៧:២២ ឈ ទដ ១៩:៧ ១១៩:១ អក ១១:២០ ១៨:១៧ ញ លប ២៤:៦៣ **១:៣** ដ ទដ ៥២:៨ ៩២:១២ ១២៨:៣ យរ ១១:១៦ សក ៤:៣ ឋ ទដ ៤៦:៤ ៦៥:៩ អស ៣៣:២១ យរ ៣១:៩ ឌ ជន ២៤:៦ យប ១៤:៩ អក ១៧:៥ ឍ ទដ ៩២:១៤ អក ៤៧:១២ ណ អស ១:៣០ ៦៤:៦ ត លប ៣៩:៣

**ទដ ជំពូក១-២** នៅក្នុងព្រះគម្ពីរទំនុកដំកើងបែប "កំព្រា"នេះ (ពីពោះព្រះគម្ពីរទាំង២ជំពូកនេះគ្មានចំណងជើង) បានចងភ្ជាប់ជាមួយគ្នាដោយបានប្រើឃ្លា("មានពរ ហើយ . . . អ្នកនោះត្រេកអរតែនឹងក្រិត្យវិន័យរបស់ព្រះយេហូវ៉ា" និងឃ្លា "មានពរ ហើយអស់អ្នកណាដែលយកទ្រង់ជាទីពឹងជ្រក"។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គាត់បានយកផ្នែកដ៏សំខាន់នេះមកធ្វើជាសេចក្តីផ្តើមនៅក្នុងព្រះគម្ពីរទំនុកដំកើងទាំងមូល ។ នៅក្នុងព្រះគម្ពីរទំនុកដំកើងទាំង២ជំពូកនេះ បាននិយាយសំខាន់លើក្រិត្យវិន័យរបស់ព្រះយេហូវ៉ានិងការបង្រៀនរបស់គ្រូដែលប្រកបដោយគតិបណ្ឌិត (ជំពូក១) មួយវិញទៀតក៏បានពណ៌នាពីផ្ទៃរឿងសំខាន់នៅក្នុងពួកហោរាតាំងពីអតីតកាល រហូតដល់អនាគតកាល ពីអ្វីដែលព្រះយេហូវ៉ាទ្រង់បានស្បថនឹងព្រះអង្គទ្រង់ថានឹងបំពេញ និងសម្រេចសេចក្តីសន្យារបស់ទ្រង់តាមរយៈការចាក់ប្រេងតាំងរបស់ព្រះអម្ចាស់ចំពោះអ្នកផ្ទះដាវីឌ (ជំពូក ២) ។ នៅក្នុងហេតុការណ៍នេះ ព្រះគម្ពីរទំនុកដំកើងទាំង២ជំពូកនេះបានភ្ជាប់ជាមួយលក្ខណៈអក្សរសាស្ត្រជាច្រើន ព្រមទាំងបានបញ្ជាក់អារម្មណ៍ដល់អ្នកដែលបានកាន់ព្រះគម្ពីរនេះនៅក្នុងដៃ ឱ្យស្តាប់ឮ និងយល់ពីអ្វីដែលព្រះគម្ពីរនេះបង្រៀន ។ មិនត្រឹមតែប៉ុណ្ណោះសោត តាមរយៈចំណុចចាប់ផ្តើមនៅក្នុងព្រះគម្ពីរទំនុកដំកើងនេះ ពួកគេត្រូវតែយល់ច្បាស់ថា ពួកអ្នកដែលស្វែងរកសម្លេងផ្ទាល់ខ្លួនរបស់ពួកគេ ដែលមាននៅក្នុងព្រះគម្ពីរទំនុកដំកើង គឺជាអ្នកដែលធ្វើបន្ទាល់ពីសេចក្តីជំនឿផ្ទាល់ខ្លួន ត្រូវតែធ្វើខ្លួនឱ្យសក្តិសមនឹងពាក្យដែលបាននិយាយថា "មានពរ ហើយ"ដែលមាននិយាយនៅក្នុងបទគម្ពីរទាំង២ជំពូកនេះ (សូមមើលការពន្យល់ក្នុង ទដ ជំពូក ៤០-៤១) ។

**ទដ ជំពូក១** អ្នកនិពន្ធ និងកាលបរិច្ឆេទនៃការសរសេរព្រះគម្ពីរទំនុកដំកើងជំពូក១នេះមិនដឹងច្បាស់ថា ជានរណាពេលណាឡើយ ។ គតិបណ្ឌិតរបស់អ្នកដែលស្រឡាញ់ព្រះនៅទីនេះ បានធ្វើការអះអាងពីលទ្ធផលចុងបញ្ចប់នៃ "ផ្លូវ" ទាំង២គឺ "ផ្លូវរបស់មនុស្សមានបាប"(ខ.១)និង "ផ្លូវរបស់មនុស្សសុចរិត"(ខ.៦)ហើយសូមមើលក្នុង ៣៤:១៩-២២ និងជំពូក ៣៧ ។ ព្រះគម្ពីរទំនុកដំកើងនៅក្នុងជំពូកនេះបានរំឮកអ្នកអានថា (១).ពួកអ្នកដែលព្រះគម្ពីរទំនុកដំកើងនេះនិយាយមកកាន់ គឺជារាស្ត្ររបស់ព្រះ ជាអ្នកដែលទទួលបានវត្តមានរបស់ព្រះគង់នៅជាមួយ និងសេចក្តីសង្គ្រោះ ព្រមទាំងព្រះពររបស់ព្រះត្រូវតែបង្ហាញលក្ខណៈជារាស្ត្ររបស់ព្រះ តាមរយៈការត្រេកអរនូវអ្វីដែលព្រះអង្គមានបន្ទូលមកកាន់ដោយដឹងថា ពួកអ្នកដែលដើរតាមផ្លូវរបស់មនុស្សមានបាប មិនអាចឈរក្នុងគ្រាជំនុំជម្រះ ឬគ្មានចំណែកជាមួយកូនរបស់ព្រះឡើយ (សូមមើលក្នុង ខ.៥ ទដ ជំពូក ១៥ និងជំពូក ២៤) (២).ពួកអ្នកស្រឡាញ់ព្រះដែលមាន និយាយនៅក្នុងគម្ពីរទំនុកដំកើងនេះ គឺជាពួកដែលមានសេចក្តីជំនឿក្នុងការទទួលខុសត្រូវ ចំពោះអ្វីដែលព្រះអង្គមានបន្ទូលមកកាន់ជីវិតរបស់យើងនោះហើយ គឺផ្លូវដែលនាំឱ្យបានព្រះពរ ។ សូមធ្វើការប្រៀបធៀបពាក្យដែលប្រើនៅដើមឃ្លា និងចុងបញ្ចប់នៃឃ្លា "មានពរ ហើយ . . . វិនាស" ដែលជាការដឹកនាំនៅក្នុងចំណុចស្នូលនៃផ្ទៃរឿងក្នុងព្រះគម្ពីរនេះ ។

**១:១** នៅក្នុងខ.គម្ពីរនេះ នៅតែបន្តនិយាយពីទំនាក់ទំនងរបស់មនុស្សអាក្រក់និងការប្រព្រឹត្តរបស់ពួកគេ ។ *មានពរ ហើយ* នៅក្នុងឃ្លានេះចង់និយាយអំពីសុភមង្គលដែលមានលក្ខខណ្ឌចំពោះអ្នកដែលស្រឡាញ់ និងធ្វើតាមបំណងព្រះទ័យនៃព្រះ (សូមមើលក្នុង ទដ ៩៤:១២ ១១២:១ ១១៩:១-២ ១២៨:១ សភ ២៩:១៨ ហើយធៀបជាមួយ ទដ ៤១:១ ១០៦:៣ សភ ១៤:២១ អស ៥៦:២) ព្រមទាំងអ្នកដែលទុកចិត្តក្នុងទ្រង់ (សូមមើលក្នុង ទដ ៤០:៤ ៨៤:៥, ១២ ១៤៤:១៥ សភ ១៦:២០ អស ៣០:១៨ យរ ១៧:៧ ហើយធៀបជាមួយ ទដ ២:១២ ៣៤:៨) ។ អ្វីដែលព្រះអង្គមានបន្ទូលនៅក្នុងខនេះ មិនមែនគ្រាន់តែនិយាយអំពីសុខភាព ឬទ្រព្យសម្បត្តិនោះឡើយ ប៉ុន្តែក៏ជាការធានាពីការពិសោធន៍នៃជីវិតរបស់ពួកគេដែលរស់នៅក្នុងការគ្រប់គ្រង និងការថែរក្សាពីព្រះគុណរបស់ព្រះ ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង បានចាប់ផ្តើមប្រកាស និងអះអាងពីព្រះពររបស់ពួកអ្នកដែលស្រឡាញ់ព្រះ និងបញ្ចប់ដោយហៅឱ្យ គ្រប់ទាំងជីវិតទាំងឡាយមកសរសើរដំកើងព្រះ (ជំពូក ១៥០) *ដើរតាម* នៅក្នុងឃ្លានេះចង់និយាយអំពីសណ្តាប់ធ្នាប់នៃការដើរនិងប្រព្រឹត្តរបស់អ្នកណាម្នាក់ ។ *ដំបូន្មាន* ឃ្លានេះចង់និយាយសំដៅលើការសញ្ជឹងគិត ការប្រព្រឹត្តតាម ឬការណែនាំ (សូមមើលក្នុង សភ ១:១០-១៩) ។ *ឈរ* ពាក្យថាឈរនៅកន្លែងនេះគឺសំដៅលើតួនាទី ឬមុខងារដំណែងរបស់អ្នកណាម្នាក់ ។ *មនុស្សមានបាប* ភាពកំសោយនិងការអាក្រក់របស់មនុស្សមានបាប គឺជាទម្លាប់នៃការរស់នៅរបស់ពួកគេ ដោយពួកគេមិនយកចិត្តទុកដាក់នឹងផ្លូវដែលនាំឱ្យបានជីវិត (មើលក្នុង ខ.៥) ។ *អង្គុយ* ពាក្យថាអង្គុយនៅកន្លែងនេះ គឺសំដៅលើការតាំងលំនៅស្នាក់អាស្រ័យនៅជាមួយនរណាម្នាក់ ។ *ពួកមនុស្សដែលមើលងាយ* មនុស្សប្រភេទនេះគឺសំដៅលើក្រុមមនុស្សដែលមើលងាយ និងសើចចំអកឡកឡឺយដល់ព្រះយេហូវ៉ា ហើយជាអ្នកដែលរឹងទទឹងមិនព្រមទទួលយកសេចក្តីបង្រៀន ដែលមាននៅក្នុងក្រិត្យវិន័យរបស់ព្រះអង្គ (សូមមើលក្នុង សភ ១:២២ និងការពន្យល់) ។ *រំពឹងគិតក្នុងក្រិត្យវិន័យទ្រង់* នៅក្នុងឃ្លានេះចង់និយាយថា ការស្វែងរកផ្លូវដែលនាំឱ្យបានជីវិត តាមរយៈការសញ្ជឹងគិតលើក្រឹត្យវិន័យរបស់ព្រះអម្ចាស់ នោះវាប្រសើរជាងទទួលយក និងការប្រព្រឹត្តតាមផ្លូវរបស់មនុស្សអាក្រក់ ។ *ទាំងយប់ទាំងថ្ងៃដែរ* សូមមើល យស ១:៨ ។

**១:៣** *ដូចជាដើមឈើ . . . ហើយស្លឹកមិនដែលស្រពោនឡើយ* មើល ក្នុង យរ ១៧:៨ ។ ឃ្លានេះវាគឺជាការប្រៀបធៀបពីព្រះពរ និងសេចក្តីសុខសាន្ត

៤ចំណែកមនុស្សអាក្រក់ មិនដូច្នោះទេ
គឺគេដូចជាអង្កាមវិញ[ឋ] ដែលខ្យល់ផាត់ខ្ចាត់ខ្ចាយទៅ
៥ដូច្នេះ ពួកមនុស្សអាក្រក់នឹងមិនធន់នៅ[ទ]ក្នុងគ្រាជំនុំជំរះទេ[ធ]
ឯពួកមានបាប ក៏ឈរក្នុងជំនុំ[ន]មនុស្សសុចរិតមិនបានដែរ
៦ដ្បិតព្រះយេហូវ៉ាទ្រង់ជ្រាប[ប]ផ្លូវរបស់មនុស្សសុចរិត
តែផ្លូវរបស់មនុស្សអាក្រក់នឹងវិនាសទៅវិញ[ផ] ។

**២** ហេតុអ្វីបានជាអស់ទាំងសាសន៍ជ្រួលជ្រើមឡើង
ហើយជនជាតិទាំងពួងមានគំនិត[ក]ជាឥតសារដូច្នេះ
២ពួកមហាក្សត្រ[ខ]នៅផែនដីលើកគ្នាឡើង
ពួកគ្រប់គ្រងទាំងប៉ុន្មាន ក៏ប្រឹក្សាគ្នាទាស់នឹងព្រះយេហូវ៉ា
ហើយទាស់នឹងព្រះអង្គ ដែលទ្រង់បានលាបប្រេងឱ្យ[គ]
ដោយពាក្យថា[ឃ]

**១:៤** ឋ យប ១៣:២៥ អស ៤០:២៤ យរ ១៣:២៤ ទ ទដ ៥:៥ ធ យប ១៩:២៩ ន ទដ ២៦:១២ ៣៥:១៨ ៨២:១ ៨៩:៥ ១០៧:៣២ ១១១:១ ១៤៩:១

**១:៦** ប ទដ ៣៧:១៨ ១២១:៥ ១៤៥:២០ ណាហ ១:៧ ផ លវ ២៦:៣៨ ទដ ៩:៦ **២:១** ក ទដ ២១:១១ ៨៣:៥ សភ ២៤:២ **២:២** ខ ទដ ៤៨:៤ គ ១សយ ៩:១៦ យហ ១:៤១ ឃ កច ៤:២៥-២៦

របស់មនុស្សសុចរិត ។ ជាការពិតណាស់នៅពេលដែលគេដាំដើមឈើវាតែងតែមានការប៉ះទង្គិច ពីខ្យល់ហើយវាក៏បានធំធាត់ឡើងនៅពេលវាធំវាបានផ្តល់ជាពរមួយដល់មនុស្ស សត្វពាហនៈ បក្សាបក្សី តាមរយៈផលផ្លែ និងម្លប់ដ៏ត្រឈឹងត្រឈៃរបស់ដើមឈើនោះ ។

**១:៤** *ដូចជាអង្កាម . . . ខ្ចាត់ខ្ចាយទៅ* ឃ្លានេះ គឺជាការប្រៀបធៀបអំពីសេចក្តីទាល់ក្ររបស់មនុស្សអាក្រក់ ។ នៅពេលមានខ្យល់បក់បោកមកអង្កាមតែងតែរសាត់ឬខ្ចាត់ទៅឆ្ងាយ ហើយវាជារបស់ដែលគ្មានប្រយោជន៍ទៀតឡើយ (សូមមើលការពន្យល់ក្នុង នរ ១:២២) ។

**១:៥** *មិនធន់ក្នុងគ្រាជំនុំជំរះទេ* នៅក្នុងឃ្លានេះចង់និយាយថា មនុស្សអាក្រក់មិនអាចធន់ និងស៊ូទ្រាំចំពោះសេចក្តីក្រោធរបស់ព្រះអម្ចាស់ ក្នុងគ្រាជំនុំជម្រះបានឡើយ (សូមមើលក្នុង ៧៦:៧ ១៣០:៣ អរ ៩:១៥ មឡ ៣:២ មថ ២៥:៣១-៤៦ វវ ៦:១៧) ។ *ឈរក្នុងជំនុំ* នៅក្នុងឃ្លានេះគឺចង់និយាយសំដៅលើការឈរច្រៀងសរសើរតម្កើង និងថ្វាយបង្គំព្រះក្នុងទីបរិសុទ្ធរបស់ព្រះអង្គ (សូមមើលក្នុង ២២:២៥ ២៦:១២ ៣៥:១៨ ៤០:៩-១៩ ១១១:១ ១៤៩:១ និងជំពូក ១៥ ជំពូក ២៤) ។ *មនុស្សសុចរិត* ពាក្យនេះគឺជាងារមួយ ក្នុងចំណោមងារជាច្រើនទៀតនៃរាស្ត្ររបស់ទ្រង់ដែលមាននៅក្នុងសញ្ញាចាស់ ។ ពួកគេគឺជាអ្នកដែលលើកតម្កើងព្រះនាមរបស់ព្រះអម្ចាស់ ហើយថ្វាយជីវិតរស់នៅរបស់ពួកគេ និងអ្វីៗទាំងអស់ទៅតាមបំណងព្រះហឫទ័យរបស់ព្រះ ។ ចំពោះទំនាក់ទំនងជាមួយមនុស្សនិងមនុស្សទូទៅ ពួកគេមានភាពស្មោះត្រង់ ហើយបានបំពេញការតព្វកិច្ចដ៏សំខាន់របស់ពួកគេ ។ ពួកគេបានចងចាំដូច្នេះថាអំណាច និងសិទ្ធិអំណាចរបស់ពួកគេ (រួមទាំងកេហដ្ឋានសង្គម គោលនយោបាយ សេដ្ឋកិច្ច សាសនា និងគតិបណ្ឌិត) ទាំងអស់នោះ គឺសុទ្ធតែជារបស់ដែលព្រះប្រទានមកដើម្បីឱ្យប្រើប្រាស់តាមផ្លូវល្អមិនមែន ដើម្បីយកផលចំណេញលើគ្នានោះឡើយ ។

**១:៦** *ផ្លូវ . . . ផ្លូវ* នៅក្នុងខនេះ គឺនិយាយពី "ផ្លូវ"២ ដែលមានទំនាក់ទំនងជាមួយគ្នា និងក្រុមមនុស្សដែលជ្រើសរើសផ្លូវនោះដែរ (សូមមើលក្នុង ៣៧:២០) ។

**ទដ ជំពូក២** អ្នកនិពន្ធ និងកាលបរិច្ឆេទនៃការសរសេរព្រះគម្ពីរទំនុកដំកើងជំពូក២នេះ មិនដឹងច្បាស់ថាជានរណា ពេលណាឡើយ (នៅក្នុង កច ៤:២៥ បាននិយាយថា លោកពេត្រុស និងលោកយ៉ូហានបានគិតថា ជាស្តេចដាវីឌជាអ្នកសរសេរព្រះគម្ពីរទំនុកដំកើងជំពូកនេះឡើង ការនេះវាអាចជាការពិតដែរ ដោយសារសំអាងលើពួកយូដា គេតែងតែលើកដំកើងស្តេចដាវីឌថាជាអ្នកដែលចាប់ផ្តើមតែងព្រះគម្ពីរទំនុកដំកើងនេះ) ។ ទំនុកនៃស្តេច គឺជាការតាក់តែងដើមដំបូង ដើម្បីអបអរសាទរក្នុងពិធីតែងតាំងកូនចៅស្តេចដាវីឌឱ្យធ្វើជាស្តេច ដូចអ្វីដែលព្រះអម្ចាស់បានតាំងសញ្ញាជាមួយដាវីឌ (មើលក្នុង ២សយ ៧) ។ នៅសម័យកាលក្រោយមកទៀត នៅពេលដែលពួកហោរាទាយទំនាយទាស់នឹងពួកអ្នកផ្ទះរបស់ស្តេចដាវីឌ និងការប្រកាសប្រាប់ពីការប្រោសលោះរបស់ព្រះអម្ចាស់ ដល់រាស្ត្រទ្រង់នៅថ្ងៃអានាគតតាមរយៈការតែងតាំងបុត្ររបស់ស្តេចដាវីឌជាស្តេចនោះ គឺដើម្បីចង់បញ្ជាក់ថា ព្រះមែស៊ីជាអ្នកបណ្តាលឱ្យមានការតាក់តែងសរសេរព្រះគម្ពីរទំនុកដំកើងនេះឡើង ។ នៅក្នុងផ្នែកទី២ពាក់កណ្តាលវគ្គទី២នៃសេចក្តីផ្តើមព្រះគម្ពីរទំនុកដំកើង គឺអ្នកសំណប់របស់ព្រះបានធ្វើការអះអាងបញ្ជាក់ពីព្រះពររបស់ពួកអ្នក ដែលព្រមទទួលការដឹកនាំរបស់ព្រះអម្ចាស់ និងអ្នកដែលទ្រង់ចាក់ប្រេងតាំង និងអ្នកដែល"ពឹងជ្រកក្នុងទ្រង់" (សូមមើលក្នុង ខ.១២ និងសេចក្តីផ្តើម ទដ ជំពូក ១-២ ព្រមទាំង ទដ ជំពូក១ ហើយនិងការពន្យល់ ១:១) ។ ជាញឹកញាប់នៅក្នុងសញ្ញាថ្មី គេតែងតែឃើញមានការដកស្រង់ចេញពីបទគម្ពីរទំនុកដំកើង ជាពិសេសនៅត្រង់ឃ្លាដែលបាននិយាយថា ព្រះយេស៊ូវគ្រីស្ទជាវង្សារបស់ស្តេចដាវីឌ និងជាអ្នកដែលព្រះបានចាក់ប្រេងតាំង ។

**២:១-៣** នៅក្នុងខ.ទាំងនេះ គឺបានពណ៌នាពីការបះបោររបស់មនុស្សជាតិចំពោះព្រះអម្ចាស់ ។ នៅក្នុងដំបន់ក្បែរមជ្ឈឹមបុព៌ាកាលពីសម័យបូរាណ នៅពេលមានការតែងតាំងស្តេចថ្មីឱ្យឡើងគ្រងរាជ្យ ប្រជាជននិងស្តេចផ្សេងៗ ទៀតតែងតែធ្វើការប្រឆាំងបះបោរជាមួយស្តេចថ្មី ។ ស្តេចថ្មីដែលទទួលការតែងតាំងនៅកន្លែងនេះ គឺតែងតាំងឱ្យធ្វើជាអ្នកគ្រប់គ្រងលើនគរទាំងអស់ ។

**២:១-២** សូមមើលក្នុង កច ៤:២៥-២៨ ។

**២:១** *ហេតុអ្វី . . . ?* សំណួរនេះគឺជាសំណួរបែបថ្លែងបញ្ឆិតដែលចង់ចោទសួរថា "តើពួកគេហ៊ាន. . .?" ។

**២:២** *ព្រះយេហូវ៉ា . . . ដែលទ្រង់លាបប្រេងឱ្យ* នៅក្នុងឃ្លានេះចង់និយាយថា ការប្រឆាំងនឹងការចាក់ប្រេងតាំងរបស់ព្រះ គឺមានន័យថាទាស់ប្រឆាំងនឹងអ្នកដែលលាបប្រេងដល់ទ្រង់ដែរ ។ *លាបប្រេងឱ្យ* សូមមើលការពន្យល់នៅត្រង់នេះ និងក្នុង ខ.៦-៧ ។ អ្នកដែលព្រះយេហូវ៉ាលាបប្រេងឱ្យនៅកន្លែងនេះគឺសំដៅលើពង្សានុវង្សរបស់ស្តេចដាវីឌ និងបានសម្រេចគ្រប់លក្ខណ៍នៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងភាសាខ្មែរពាក្យថា "ព្រះមែស៊ី" គឺក្លាយមកពីភាសាហេព្រើរដែលមានន័យថា "អ្នកដែលទទួលការចាក់ប្រេងតាំង" ហើយពាក្យថា"យេស៊ូវ" គឺក្លាយមកពីភាសាក្រិច ក៏មានន័យថា "អ្នកដែលព្រះចាក់ប្រេងតាំង"ដែរ (សូមមើលការពន្យល់ក្នុង មថ ១:១៧) ។

៣ចូរ យើងផ្ដាច់ចំណងទ្រង់[ង]
ហើយបោះខ្សែចងរបស់ទ្រង់ពីយើងចេញ[ច]
៤ឯព្រះដែលគង់[ឆ]នៅស្ថានសួគ៌ ទ្រង់នឹងសើច[ជ]
ព្រះអម្ចាស់ទ្រង់នឹងចំអកឱ្យគេ
៥រួចទ្រង់នឹងមានបន្ទូលដល់គេដោយសេចក្ដីក្រោធ[ឈ]នៃ
ទ្រង់ ព្រមទាំងបំភ័យគេ ដោយសេចក្ដីឃោរឃៅផង[ញ]ថា
៦អញបានតាំងស្ដេចរបស់អញឡើងហើយ[ដ] គឺនៅស៊ីយ៉ូន[ឋ]
ជាភ្នំបរិសុទ្ធរបស់អញ[ឌ]។
៧អញនឹងថ្លែងប្រាប់ពីច្បាប់នេះ
គឺព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងអញថា ឯងជាកូនអញ[ឍ]
អញបានបង្កើតឯងនៅថ្ងៃនេះ[ណ]
៨ចូរសូមពីអញ នោះអញនឹងឱ្យសាសន៍ទាំងឡាយ[ត]ដល់ឯង
ទុកជាមរដក[ថ]
ហើយអស់ទាំងចុងផែនដី[ទ]ទុកជាកេរ្ដិ៍អាកររបស់ឯង
៩ឯងនឹងបំបាក់បំបែកគេ ដោយដំបងដែក[ធ]
ព្រមទាំងបោកកំទេចគេទៅ[ន]ដូចជាភាជនៈរបស់ជាងស្មូន[ប]

១០ដូច្នេះ ឱពួកមហាក្សត្រទាំងប៉ុន្មានអើយ
ចូរប្រព្រឹត្តដោយប្រាជ្ញាចុះ[ផ]
ឱពួកអស់ទាំងចៅក្រម[ព]នៅផែនដីអើយ
ចូរទទួលសេចក្ដីផ្ចាលចុះ
១១ចូរគោរពដល់ព្រះយេហូវ៉ា ដោយកោតខ្លាច[ភ]
ហើយមានអំណរ[ម] ដោយញ័ររន្ធត់[យ]
១២ចូរថើបព្រះរាជបុត្រា[រ] ក្រែងទ្រង់ខ្ញាល់ឡើង
ហើយឯងរាល់គ្នា ត្រូវវិនាសតាមផ្លូវ ដ្បិតបន្តិចទៀត
សេចក្ដីខ្ញាល់[ល]របស់ទ្រង់នឹងឆួលឡើង មានពរ[វ]ហើយ
អស់អ្នកណាដែលយកទ្រង់ជាទីពឹងជ្រក[ស]។

**២:៣** ង យប ៣៦:៨ ច ២សយ ៣:៣៤ **២:៤** ឆ អស ៣៧:១៦ ៤០:២២ ៦៦:១ ជ ទដ ៣៧:១៣ សភ ១:២៦ **២:៥** ឈ ទដ ៦:១ ២៧:៩ ៣៨:១ ញ ទដ ២១:៩ ៧៩:៦ ៩០:៧ ១១០:៥ **២:៦** ដ ទដ ១០:១៦ ២៤:១០ ឋ ២ពវ ១៩:៣១ ទដ ៩:១១ ៤៨:២,១១ ៧៨:៦៨ ១១០:២ ១៣៣:៣ ឌ នក ១៥:១៧ **២:៧** ឍ មថ ៣:១៧ ៤:៣ ណ ២សយ ៧:១៤ កច ១៣:៣៣ ហព ១:៥ ៥:៥ **២:៨** ត វវ ២:២៦ ថ យប ២២:២៦ មថ ២១:៣៨ ទ ទដ ២២:២៧ ៦៧:៧ **២:៩** ធ លប ៤៩:១០ វវ ១២:៥ ន នក ១៥:៦ ន អស ៣០:១៤ យរ ១៩:១០ វវ ២:២៧ ១៩:១៥ **២:១០** ប សភ ២៧:១១ ផ ទដ ១៤១:៦ សភ ៨:១៥ អម ២:៣ **២:១១** ភ ទដ ១០៣:១១ ម ទដ ៩:២ ៣៥:៩ ១០៤:៣៤ អស ៦១:១០ យ ១របា ១៦:៣០ **២:១២** រ ខ.៧ ល ចទ ៩:៨ វវ ៦:១៦ វ ទដ ៨៤:១២ ស ទដ ៥:១១ ៣៤:៨ ៦៤:១០

**២:៤–៦** នៅក្នុងខទាំងនេះចង់និយាយអំពីការសើចចំអករបស់ព្រះអម្ចាស់ចំពោះពួកអ្នកដែលធ្វើការបះបោរនឹងទ្រង់ ។ . . .

**២:៤** សូមមើលក្នុង ៥៩:៨ ។

**២:៥** *សេចក្ដីក្រោធ . . . សេចក្ដីឃោរឃៅ* ជានិច្ចកាលសេចក្ដីក្រោធរបស់ព្រះតែងតែសម្ដែងចេញពីសេចក្ដីសុចរិតរបស់ទ្រង់ (សូមមើលក្នុង ៧:១១ និងការពន្យល់ក្នុង ៤:១) ។

**២:៦** *ភ្នំបរិសុទ្ធ* ភ្នំបរិសុទ្ធនៅកន្លែងនេះ គឺសំដៅលើព្រះវិហារក្រុងយេរូសាឡិម (សូមមើលក្នុង ២របា ៣៣:១៥ និង ទដ ៣:៤ ១៥:១ ៤៣:៣ ("ភ្នំបរិសុទ្ធ") ៩៩:៩ ("ភ្នំបរិសុទ្ធ") ។

**២:៧–៩** នៅក្នុងខនេះ គឺនិយាយពីការប្រកាសពីការចាក់ប្រេងលាបរបស់អម្ចាស់ និងការថ្លែងពីច្បាប់របស់ព្រះអង្គ ។ សូមមើលពីដំណើរនៃការរស់ឡើងវិញរបស់ព្រះយេស៊ូវក្នុង កច ១៣:៣៣ និងការដែលព្រះយេស៊ូវទ្រង់ប្រសើរជាងពួកទេវតាក្នុង ហព ១:៥ ជាសម្ដេចសង្ឃ ក្នុង ហព ៥:៥ ។

**២:៧** *ឯងជាកូនអញ អញបានបង្កើតនៅថ្ងៃនេះ* នៅតំបន់មជ្ឈិមបូព៌ាកាលពីសម័យបុរាណ ទំនាក់ទំនងរវាងស្ដេចដែលធំជាងគេ ជាមួយនឹងមន្ត្រីរបស់ទ្រង់ ដែលធ្វើការក្រោមបង្គាប់បញ្ជាពីព្រះមហាក្សត្រអង្គនោះ និងកូនបំណុលដែលស្មោះត្រង់នឹងព្រះមហាក្សត្រនោះ មិនគ្រាន់តែនិយាយថា "ចៅហ្វាយ" និង"អ្នកបម្រើ"ឡើយ ប៉ុន្តែគឺប្រើពាក្យថា "អញបានបង្កើត" (ឪពុក) និង "កូន" ។ កូនចៅរបស់ស្ដេចដាវីឌ គឺជា"អ្នកបម្រើ"និងជា"កូន"របស់ព្រះអម្ចាស់ (សូមមើលក្នុង ២សយ ៧:៥,១៤) ។

**២:៨** *ទុកជាមរដក* នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់ឱ្យសាសន៍ទាំងឡាយទុកជាកម្មសិទ្ធិដល់ពួកកូនរបស់ព្រះ ដូចជាទឹកដីសន្យាដែលជាចំណែក"មរដក"របស់ព្រះយេហូវ៉ាដែរ (សូមមើលក្នុង នក ១៥:១៧ យស ២២:១៩ ទដ ២៨:៩ ៧៩:១ ៨២:៨) ។ *ហើយអស់ទាំងចុងបំផុតផែនដី* នៅក្នុងឃ្លានេះចង់និយាយថា ចុងក្រោយបំផុតនៃអំណាចគ្រប់គ្រង របស់អ្នកដែលព្រះយេហូវ៉ាទ្រង់ចាក់ប្រេងលាប និងបង្ហាញឱ្យឃើញពីអំណាចគ្រប់គ្រងរបស់ព្រះ ។

**២:៩** ដោយយោងទៅព្រះគម្ពីរ វវ ១២:៥ និង ១៩:១៥–១៦ បានបង្ហាញថា ពាក្យទាំងអស់នៅក្នុង ទដ ២:៩ នេះបានសម្រេចនៅពេលដែលមនុស្សទាំងឡាយគេបានស្រែកអបអរសាទរពីរាជ្យព្រះគ្រីស្ទយេស៊ូវ ហើយនៅក្នុង វវ ២:២៦–២៧ ព្រះយេស៊ូវទ្រង់បានប្រកាសថា ទ្រង់នឹងតាំងអ្នកណាដែលកាន់ការស្មោះត្រង់ចំពោះទ្រង់ឱ្យមានអំណាចលើពួកសាសន៍ដទៃ ។ *ព្រមទាំងបោកកំទេចគេទៅ ដូចជាភាជនៈរបស់ជាងស្មូន* មើលក្នុង យរ ១៩:១១ ។

**២:១០–១២** នៅក្នុងខនេះព្រះអម្ចាស់ទ្រង់បានធ្វើការព្រមាន និងផ្ដាំផ្ញើផ្ដាលដល់ពួកចៅក្រមដែលប្រឆាំងបះបោរនឹងទ្រង់ ។

**២:១១** *សេចក្ដីអំណរ* នៅក្នុងឃ្លានេះគឺចង់និយាយថា ចូរឱ្យមនុស្សទាំងឡាយ គោរពប្រតិបត្តិដល់ព្រះយេហូវ៉ា ដែលទ្រង់ជាមហាក្សត្រដោយអំណរ ។ *ដោយញ័ររន្ធត់* នៅក្នុងឃ្លានេះគឺចង់និយាយថា ពួកគេត្រូវតែគោរពដល់ព្រះអម្ចាស់ដោយការស្ញើចសរសើរ និងអស់អំពីចិត្ត ។

**២:១២** *ថើប* ថើបគឺជានិមិត្តសញ្ញានៃការចុះចូល (សូមមើលក្នុង ១សយ ១០:១ ១ពវ ១៩:១៨ ហស ១៣:២ ព្រមទាំងការពន្យល់ក្នុង លប ៤១:៤០) ។ បណ្ដាជនទាំងឡាយដែលចុះចូលជាមួយស្ដេចពួកអាសស៊ើរ គេបានបង្ហាញពីការចុះចូលរបស់ពួកគេតាមរយៈការថើបព្រះបាទរបស់ស្ដេចនោះ ។ *ទ្រង់ . . . ទ្រង់ . . . ទ្រង់* ពាក្យទាំងអស់នេះគឺសំដៅលើ "ព្រះយេហូវ៉ា" (សូមមើលក្នុង ខ.១១) ដែលទ្រង់បានចាក់ប្រេងលាបដល់ "ព្រះរាជបុត្រា" ។ *ឯងរាល់គ្នាត្រូវវិនាសតាមផ្លូវ* មើលក្នុង ១:៦ និងការពន្យល់ ។ *មានពរហើយ* សូមមើលក្នុង ១:១ និងការពន្យល់ ។ *យកទ្រង់ជាទីពឹងជ្រក* សូមមើលក្នុង ៥:១១ ៣៤:៨ ៦៤:១០ ហើយធៀប ១០៤:១៨ ។

៣ចូរ យើងផ្តាច់ចំណងទ្រង់[ង]
ហើយបោះខ្សែចងរបស់ទ្រង់ពីយើងចេញ[ច]
៤ឯព្រះដែលគង់[ឆ]នៅស្ថានសួគ៌ ទ្រង់នឹងសើច[ជ]
ព្រះអម្ចាស់ទ្រង់នឹងចំអកឱ្យគេ
៥រួចទ្រង់នឹងមានបន្ទូលដល់គេដោយសេចក្តីក្រោធ[ឈ]នៃ
ទ្រង់ ព្រមទាំងបំភ័យគេ ដោយសេចក្តីឃោរឃៅផង[ញ]ថា
៦អញបានតាំងស្តេចរបស់អញឡើងហើយ[ដ] គឺនៅស៊ីយ៉ូន[ឋ]
ជាភ្នំបរិសុទ្ធរបស់អញ[ឌ] ។
៧អញនឹងថ្លែងប្រាប់ពីច្បាប់នេះ
គឺព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងអញថា ឯងជាកូនអញ[ឍ]
អញបានបង្កើតឯងនៅថ្ងៃនេះ[ណ]
៨ចូរសូមពីអញ នោះអញនឹងឱ្យសាសន៍ទាំងឡាយ[ត]ដល់ឯង
ទុកជាមរដក[ថ]
ហើយអស់ទាំងចុងផែនដី[ទ]ទុកជាកេរ្តិ៍អាកររបស់ឯង
៩ឯងនឹងបំបាក់បំបែកគេ ដោយដំបងដែក[ធ]
ព្រមទាំងបោកកំទេចគេទៅ[ន]ដូចជាភាជនៈរបស់ជាងស្មូន[ប]

**២:៣** ង យប ៣៦:៨ ច ២សយ ៣:៣៤ **២:៤** ឆ អស ៣៧:១៦ ៤០:២២ ៦៦:១ ជ ទដ ៣៧:១៣ សភ ១:២៦ **២:៥** ឈ ទដ ៦:១ ២៧:៩ ៣៨:១ ញ ទដ ២១:៩ ៧៩:៦ ៩០:៧ ១១០:៥ **២:៦** ដ ទដ ១០:១៦ ២៤:១០ ឋ ២ពវ ១៩:៣១ ទដ ៩:១១ ៤៨:២,១១ ៧៨:៦៨ ១១០:២ ១៣៣:៣ ឌ នក ១៥:១៧ **២:៧** ឍ មថ ៣:១៧ ៤:៣ ណ ២សយ ៧:១៤ កច ១៣:៣៣ ហព ១:៥ ៥:៥ **២:៨** ត វវ ២:២៦

១០ដូច្នេះ ឱពួកមហាក្សត្រទាំងប៉ុន្មានអើយ
ចូរប្រព្រឹត្តដោយប្រាជ្ញាចុះ[ផ]
ឱពួកអស់ទាំងចៅក្រម[ព]នៅផែនដីអើយ
ចូរទទួលសេចក្តីផ្ចាលចុះ
១១ចូរគោរពដល់ព្រះយេហូវ៉ា ដោយកោតខ្លាច[ភ]
ហើយមានអំណរ[ម] ដោយញ័ររន្ធត់[យ]
១២ចូរថើបព្រះរាជបុត្រា[រ] ក្រែងទ្រង់ខ្ញាល់ឡើង
ហើយឯងរាល់គ្នា ត្រូវវិនាសតាមផ្លូវ ដ្បិតបន្តិចទៀត
សេចក្តីខ្ញាល់[ល]របស់ទ្រង់នឹងឆួលឡើង មានពរ[វ]ហើយ
អស់អ្នកណាដែលយកទ្រង់ជាទីពឹងជ្រក[ស] ។

ថ យប ២២:២៦ មថ ២១:៣៨ ទ ទដ ២២:២៧ ៦៧:៧ **២:៩** ធ លប ៤៩:១០ វវ ១២:៥ ធ នក ១៥:៦ ន អស ៣០:១៤ យរ ១៩:១០ វវ ២:២៧ ១៩:១៥ **២:១០** ប សភ ២៧:១១ ផ ទដ ១៤១:៦ សភ ៨:១៥ អម ២:៣ **២:១១** ភ ទដ ១០៣:១១ ម ទដ ៩:២ ៣៥:៩ ១០៤:៣៤ អស ៦១:១០ យ ១រប ១៦:៣០ **២:១២** រ ខ.៧ ល ចទ ៩:៨ វវ ៦:១៦ វ ទដ ៨៤:១២ ស ទដ ៥:១១ ៣៤:៨ ៦៤:១០

**២:៤–៦** នៅក្នុងខទាំងនេះចង់និយាយអំពីការសើចចំអករបស់ព្រះអម្ចាស់ចំពោះពួកអ្នកដែលធ្វើការបះបោរនឹងទ្រង់ ។ . . .

**២:៤** សូមមើលក្នុង ៥៩:៨ ។

**២:៥** *សេចក្តីក្រោធ . . . សេចក្តីឃោរឃៅ* ជានិច្ចកាលសេចក្តីក្រោធរបស់ព្រះតែងតែសម្តែងចេញពីសេចក្តីសុចរិតរបស់ទ្រង់ (សូមមើលក្នុង ៧:១១ និងការពន្យល់ក្នុង ៤:១) ។

**២:៦** *ភ្នំបរិសុទ្ធ* ភ្នំបរិសុទ្ធនៅកន្លែងនេះ គឺសំដៅលើព្រះវិហារក្រុងយេរូសាឡិម (សូមមើលក្នុង ២រប ៣៣:១៥ និង ទដ ៣:៤ ១៥:១ ៤៣:៣ ("ភ្នំបរិសុទ្ធ") ៩៩:៩ ("ភ្នំបរិសុទ្ធ") ។

**២:៧–៩** នៅក្នុងខនេះ គឺនិយាយពីការប្រកាសពីការចាក់ប្រេងលាបរបស់អម្ចាស់ និងការថ្លែងពីច្បាប់របស់ព្រះអង្គ ។ សូមមើលពីដំណើរនៃការរស់ឡើងវិញរបស់ព្រះយេស៊ូវក្នុង កច ១៣:៣៣ និងការដែលព្រះយេស៊ូវទ្រង់ប្រសើរជាងពួកទេវតាក្នុង ហព ១:៥ ជាសម្តេចសង្ឃ ក្នុង ហព ៥:៥ ។

**២:៧** *ឯងជាកូនអញ អញបានបង្កើតនៅថ្ងៃនេះ* នៅតំបន់មជ្ឈិមបូព៌ាកាលពីសម័យបុរាណ ទំនាក់ទំនងរវាងស្តេចដែលធំជាងគេ ជាមួយនឹងមន្ត្រីរបស់ទ្រង់ ដែលធ្វើការក្រោមបង្គាប់បញ្ជាពីព្រះមហាក្សត្រអង្គនោះ និងកូនបំណុលដែលស្មោះត្រង់នឹងព្រះមហាក្សត្រនោះ មិនគ្រាន់តែនិយាយថា "ចៅហ្វាយ" និង"អ្នកបម្រើ"ឡើយ ប៉ុន្តែគឺប្រើពាក្យថា "អញបានបង្កើត" (ឪពុក) និង "កូន" ។ កូនចៅរបស់ស្តេចដាវីឌ គឺជា"អ្នកបម្រើ"និងជា"កូន"របស់ព្រះអម្ចាស់ (សូមមើលក្នុង ២សយ ៧:៥,១៤) ។

**២:៨** *ទុកជាមរដក* នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់ឱ្យសាសន៍ទាំងឡាយទុកជាកម្មសិទ្ធិដល់ពួកកូនរបស់ព្រះ ដូចជាទឹកដីសន្យាដែលជាចំណែក"មរដក"របស់ព្រះយេហូវ៉ាដែរ (សូមមើលក្នុង នក ១៥:១៧ យស ២២:១៩ ទដ ២៨:៩ ៧៩:១ ៨២:៨) ។ *ហើយអស់ទាំងចុងបំផុតផែនដី* នៅក្នុងឃ្លានេះចង់និយាយថា ចុងក្រោយបំផុតនៃអំណាចគ្រប់គ្រង របស់អ្នកដែលព្រះយេហូវ៉ាទ្រង់ចាក់ប្រេងលាប និងបង្ហាញឱ្យឃើញពីអំណាចគ្រប់គ្រងរបស់ព្រះ ។

**២:៩** ដោយយោងទៅព្រះគម្ពីរ វវ ១២:៥ និង ១៩:១៥–១៦ បានបង្ហាញថា ពាក្យទាំងអស់នៅក្នុង ទដ ២:៩ នេះបានសម្រេចនៅពេលដែលមនុស្សទាំងឡាយគេបានស្រែកអបអរសាទរពីរាជ្យព្រះគ្រីស្ទយេស៊ូវ ហើយនៅក្នុង វវ ២:២៦–២៧ ព្រះយេស៊ូវទ្រង់បានប្រកាសថា ទ្រង់នឹងតាំងអ្នកណាដែលកាន់ការស្មោះត្រង់ចំពោះទ្រង់ឱ្យមានអំណាចលើពួកសាសន៍ដទៃ ។ *ព្រមទាំងបោកកំទេចគេទៅ ដូចជាភាជនៈរបស់ជាងស្មូន* មើលក្នុង យរ ១៩:១១ ។

**២:១០–១២** នៅក្នុងខនេះព្រះអម្ចាស់ទ្រង់បានធ្វើការព្រមាន និងផ្ទាញ់ផ្ចាលដល់ពួកចៅក្រមដែលប្រឆាំងបះបោរនឹងទ្រង់ ។

**២:១១** *សេចក្តីអំណរ* នៅក្នុងឃ្លានេះគឺចង់និយាយថា ចូរឱ្យមនុស្សទាំងឡាយ គោរពប្រតិបត្តិដល់ព្រះយេហូវ៉ា ដែលទ្រង់ជាមហាក្សត្រដោយអំណរ ។ *ដោយញ័ររន្ធត់* នៅក្នុងឃ្លានេះគឺចង់និយាយថា ពួកគេត្រូវតែគោរពដល់ព្រះអម្ចាស់ដោយការស្ញើចសរសើរ និងអស់អំពីចិត្ត ។

**២:១២** *ថើប* ថើបគឺជានិមិត្តសញ្ញានៃការចុះចូល (សូមមើលក្នុង ១សយ ១០:១ ១ពវ ១៩:១៨ ហស ១៣:២ ព្រមទាំងការពន្យល់ក្នុង លប ៤១:៤០) ។ បណ្តាជនទាំងឡាយដែលចុះចូលជាមួយស្តេចពួកអាសស៊ើរ គេបានបង្ហាញពីការចុះចូលរបស់ពួកគេតាមរយៈការថើបព្រះបាទរបស់ស្តេចនោះ ។ *ទ្រង់ . . . ទ្រង់ . . . ទ្រង់* ពាក្យទាំងអស់នេះគឺសំដៅលើ "ព្រះយេហូវ៉ា" (សូមមើលក្នុង ខ.១១) ដែលទ្រង់បានចាក់ប្រេងលាបដល់ "ព្រះរាជ្យបុត្រា" ។ *ឯងរាល់គ្នាត្រូវវិនាសតាមផ្លូវ* មើលក្នុង ១:៦ និងការពន្យល់ ។ *មានពរហើយ* សូមមើលក្នុង ១:១ និងការពន្យល់ ។ *យកទ្រង់ជាទីពឹងជ្រក* សូមមើលក្នុង ៥:១១ ៣៤:៨ ៦៤:១០ ហើយធៀប ១០៤:១៨ ។

ទំនុកនៃស្តេចដាវីឌ
ដែលទ្រង់លើក កាលរត់ពីអាប់សាឡំម ជាព្រះរាជបុត្រា[ក]។
**៣** ឱព្រះយេហូវ៉ាអើយ ពួកខ្មាំងនៃទូលបង្គំមានគ្នា
កាន់តែច្រើនឡើងយ៉ាងណាហ្ន៎
មានមនុស្សជាច្រើនបានលើកគ្នាទាស់នឹងទូលបង្គំហើយ
២ មានគ្នាច្រើននិយាយពីព្រលឹងទូលបង្គំថា នៅក្នុងព្រះ
គ្មានសេចក្តីសង្គ្រោះដល់វាទៀតទេ[ខ]។ បង្អង់
៣ ប៉ុន្តែ ឱព្រះយេហូវ៉ាអើយ
ទ្រង់ជាខែលបាំង[គ]ទូលបង្គំជុំវិញ ក៏ជាសិរីល្អនៃទូលបង្គំ
ហើយជាអ្នកលើកក្បាលទូលបង្គំឡើងដែរ[ឃ]
៤ ខ្ញុំឡើងសំឡេងអំពាវនាវដល់ព្រះយេហូវ៉ា[ង]
ទ្រង់ក៏ឆ្លើយតបមកខ្ញុំ ពីលើភ្នំបរិសុទ្ធរបស់ទ្រង់[ច]។ បង្អង់
៥ ខ្ញុំបានដេកលក់ទៅ[ឆ] ហើយក៏ភ្ញាក់ឡើងវិញ[ជ]
ដ្បិតព្រះយេហូវ៉ាទ្រង់ ទប់ទល់ខ្ញុំ
៦ ខ្ញុំមិនខ្លាច[ឈ]ដល់មនុស្សទាំងសល់សែន
ដែលបានតាំងខ្លួនព័ទ្ធជុំវិញ ទាស់នឹងខ្ញុំឡើយ[ញ]។

**៣:ចំណាំងជើង**
ក ២សយ ១៥:១៤
**៣:២** ខ ទដ ២២:៨ ៧១:១១ អស ៣៦:១៥ ៣៧:២០
**៣:៣** គ លប ១៥:១ ឃ ទដ ២៧:៦
**៣:៤** ង យប ៣០:២០ ច ទដ ២:៦
**៣:៥** ឆ លវ ២៦:៦ ជ ទដ ១៧:១៥ ១៣៩:១៨
**៣:៦** ឈ យប ១១:១៥ ទដ ២៣:៤ ២៧:៣ ញ ទដ ១១៨:១១

**ដទ៣–១៤** នេះគឺជាក្រុមទំនុកដំកើងទាំង១២បទ ដែលមានសេចក្តីអធិស្ឋានចំនួន១០ (ប៉ុន្តែសូមមើលសេចក្តីផ្តើម ទដ ជំពូក ១១) ហើយបានចែកជា២ ផ្នែកក្នុងចំណោមផ្នែកទាំង៥ (ទដ ជំពូក ៣–៧ និង ជំពូក ៩–១៣) ។ នៅក្នុងក្រុមនិមួយៗបានបទនៃទំនុកដំកើងឱ្យបានចំនួន៦ស្មើៗគ្នា ដែលបានចង្អុលបង្ហាញពីលក្ខណៈសម្បត្តិ នៃអត្តចរិតរបស់មនុស្ស (បន្ថែម ជំពូក ៨ និង ជំពូក ១៤) ។ សូមមើលក្នុងសេចក្តីផ្តើម ទដ ជំពូក៨ និង ១៤ ដែលនិយាយអំពីភាពផ្ទុយគ្នា នៃចរិត្តលក្ខណៈទាំង២នេះ និងរបៀបដែលគេបានគ្រប់លក្ខណៈដោយផ្អែក លើជម្រើសនៃសេចក្តីអធិស្ឋានដែលមានភ្ជាប់មកជាមួយ ។

**ទដជំពូក៣** នៅក្នុងទំនុកដំកើងជំពូកនេះចង់និយាយថា ទោះបីជាមានខ្មាំងសត្រូវជាច្រើនបៀតបៀនយ៉ាងណាក៏ដោយ ក៏អ្នកនិពន្ធព្រះគម្ពីរ ទដ គាត់នៅតែអធិស្ឋានដល់ព្រះយេហូវ៉ាដោយមានទំនុកចិត្តថា ទ្រង់នឹងឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់គាត់ដែរ ។ ទំនុកដំកើង ជំពូក ៣–៤ បានភ្ជាប់នូវពាក្យដែលថា "ជាសិរីល្អ" (សូមមើលក្នុង ខ.៣ ៤:២ និងការពន្យល់ក្នុងខទាំងនេះ) និងការផ្ទុំដំណេកក្នុងពេលរាត្រីដ៏សែនមានន័យ របស់ស្តេចដាវីឌ (សូមមើលក្នុង ខ.៥ ៤:៨)។ នៅក្នុង ខ.៥ ព្រះបាទដាវីឌទ្រង់បានបន្ទូលពីការភ្ញាក់ពីដំណេកវិញ ដោយមានសេចក្តីសុខសាន្តត្រាណ ពីព្រោះព្រះយេហូវ៉ាទ្រង់ជាអ្នកថែរក្សា និងទប់ទល់ដល់ទ្រង់ក្នុងអំឡុងពេលដែលស្តេចទ្រង់ផ្ទុំលក់ ហើយចំណែកនៅក្នុង ៤:៨ ឯណោះវិញ ទ្រង់បានមានបន្ទូលពីសេចក្តីស្ងប់ស្ងាត់ក្នុងពេលដែលទ្រង់ផ្ទុំលក់ទៅ ពីព្រោះមានព្រះយេហូវ៉ាជាអ្នកថែរក្សាការពារ ។ ការដាក់សេចក្តីអធិស្ឋានទាំង២នេះចូល ដោយមួយនិយាយសំដៅលើការភ្ញាក់ឡើងវិញ (នៅពេលព្រឹក) និងមួយទៀតសំដៅលើការផ្ទុំលក់ (ក្នុងពេលរាត្រីដ៏សែនត្រជាក់) នៅក្នុងចំណុចចាប់ផ្តើមនៃសេចក្តីអធិស្ឋានក្នុងបទទំនុកដំកើងនេះបង្ហាញថា ព្រះយេហូវ៉ាទ្រង់មានសេចក្តីស្មោះត្រង់ ទ្រង់ថែរក្សាពួកអ្នកដែលស្រឡាញ់ព្រះអង្គ ២៤ ម៉ោងលើ ២៤ម៉ោង(ទាំងយប់ទាំងថ្ងៃ) ទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ។

**ជំពូក៣ ត្រង់ចំណុចចំណាំងជើង** *កាលរត់* សូមមើលក្នុង ២សយ ១៥:១៣–១៧:៣៣ ។ ឃ្លានេះគឺនិយាយសំដៅលើហេតុការណ៍ ដែលកើតមាននៅក្នុងខ្សែជីវិតរបស់ស្តេចដាវីឌ ដំណាងឱ្យបទទំនុកដំកើងដ៏ល្បីល្បាញទាំង ១៣បទ (សូមមើលក្នុងជំពូក ៣,៧,១៨,៣៤,៥១–៥២,៥៤,៥៦–៥៧,៥៩–៦០,៦៣ ,១៤២) ដែលបទទាំងនោះមាននៅក្នុងផ្នែកទី១ និងផ្នែកទី២ ដោយលើកលែងមួយគឺ ទដ ១៤២ ។ សូមមើលក្នុងសេចក្តីផ្តើម ត្រង់ចំណុចអ្នកនិពន្ធ និង ចំណាំងជើង) ។

**៣:១–២** នៅក្នុងខទាំង២នេះ និយាយអំពីសេចក្តីតម្រូវការរបស់ស្តេចដាវីឌ នៅពេលដែលស្តេចទ្រង់ជួបការបៀតបៀន ពីសំណាក់ពួកខ្មាំងសត្រូវជាច្រើន ។

**៣:២** សូមមើលក្នុង ២២:៧–៨ ៧១:១០–១១ ។ ជាញឹកញាប់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង តែងតែដកស្រង់ និងលើកយកពីភាពទន់ខ្សោយរបស់អ្នកដែលត្រូវគេជិះជាន់មកនិយាយ ដើម្បីមកពិពណ៌នាថា តើពួកខ្មាំងសត្រូវមើលងាយគេយ៉ាងដូចម្តេច (មើលការពន្យល់ ១:១) ចំពោះព្រះយេហូវ៉ា និងអ្នកបម្រើរបស់ទ្រង់ (មើលការពន្យល់ ១០:១១) ។ *បង្អង់* សូមមើលការពន្យល់ក្នុងសេចក្តីផ្តើមត្រង់ចំណុចអ្នកនិពន្ធ និងចំណាំងជើង) ។

**៣:៣–៤** នៅក្នុងខនេះ បានពិពណ៌នាពីទំនុកចិត្តរបស់ស្តេចដាវីឌលើព្រះយេហូវ៉ា ដែលទ្រង់តែងតែឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ទ្រង់ ។

**៣:៣** *ខែល* សម្រាប់ពួកអ៊ីស្រាអែលកាលពីសម័យបុរាណ នៅពេលដែលគេនិយាយពាក្យនេះ (ខែល) គឺគេចង់និយាយសំដៅលើស្តេចដែលទ្រង់ជាខែល (ជាអ្នកការពារ) សម្រាប់ប្រជានុរាស្ត្ររបស់ទ្រង់ (សូមមើលការពន្យល់ក្នុង ៧:១០ ៤៧:៩ ៥៩:១១ ៨៤:៩ ៨៩:១៨ លប ១៥:១) ។ ដូច្នេះហើយទើបមានការអះអាងជាច្រើន (មើល ៨៤:១១ ៩១:៤ ១១៥:៩–១១ ចទ ៣៣:២៩ សភ ៣០:៥) និងប្រកាសថា (មើល ១៨:២,៣០ ២៨:៧ ៣៣:២០ ១១៩:១១៤ ១៤៤:២) ព្រះយេហូវ៉ាទ្រង់ គឺជាខែលសម្រាប់រាស្ត្ររបស់ទ្រង់ ។ *ក៏ជាសិរីល្អដល់ទូលបង្គំ* នៅក្នុងឃ្លានេះ ចង់និយាយថា ស្តេចដាវីឌទ្រង់មានសេចក្តីអំណរចំពោះព្រះយេហូវ៉ា ដែលទ្រង់គឺជាអ្នកផ្គត់ផ្គង់ និងជាអ្នកថែរក្សាដល់គាត់ ហើយជាអ្នកដែលបាន តាំងឱ្យទ្រង់មានកិត្តិយសដ៏ធំបែបនេះ ។ *ហើយជាអ្នកលើកក្បាលទូលបង្គំឡើងដែរ* ចង់មានន័យថា ព្រះយេហូវ៉ា ទ្រង់ជាអ្នកដែលធ្វើឱ្យស្តេចដាវីឌមានជ័យជម្នះ លើពួកខ្មាំងសត្រូវរបស់គាត់ (សូមមើលការពន្យល់ ១១០:៧) ។

**៣:៤** *ខ្ញុំឡើងសំលេង . . . ទ្រង់ក៏ឆ្លើយតបមកខ្ញុំ* សូមមើលការពន្យល់ក្នុង ១១៨:៥ ។ *ភ្នំបរិសុទ្ធ* ភ្នំបរិសុទ្ធគឺជាទីកន្លែងដ៏បរិសុទ្ធរបស់ព្រះយេហូវ៉ា នៅលើផែនដីនេះ ដែលប្រៀបបានទៅនឹងឋានសួគ៌ដែរ (សូមមើលការពន្យល់ក្នុង ២:៦) ។

**៣:៥–៦** នៅក្នុងខទាំងនេះ គឺជាការពណ៌នាពីសុវត្ថិភាពខាងឯវិញ្ញាណរបស់ស្តេចដាវីឌ ។

**៣:៥** នៅក្នុងខនេះចង់និយាយថា ទោះបីជាស្តេចដាវីឌទ្រង់ផ្ទុំដោយសេចក្តីស្ងប់ក៏ដោយ ក៏ព្រះយេហូវ៉ាទ្រង់នៅតែការពារដល់គាត់ដែរ (សូមមើលក្នុង ៤:៨) ។

៧ ឱព្រះយេហូវ៉ាអើយ សូមទ្រង់ក្រោកឡើង[ដ]
ឱព្រះនៃទូលបង្គំអើយ សូមទ្រង់ជួយសង្គ្រោះទូលបង្គំផង[ឋ]
ដ្បិតគឺទ្រង់ដែលទះ[ឌ]កំផ្លៀង អស់ទាំងខ្មាំងសត្រូវនៃទូល
បង្គំ ទ្រង់បំបាក់ធ្មេញ[ឍ]របស់ពួកមនុស្ស អាក្រក់ដែរ
៨ ឯសេចក្ដីសង្គ្រោះ នោះស្រេចនៅព្រះយេហូវ៉ា[ណ]
សូមឱ្យព្រះពរ[ត]ទ្រង់បាននៅលើរាស្ត្រទ្រង់ចុះ ។ បង្អង់

ទំនុករបស់ស្ដេចដាវីឌ

ដែលទ្រង់លើកសំរាប់មេភ្លេង ត្រូវលេងដោយប្រដាប់មានខ្សែ ។

**៤** ឱព្រះនៃសេចក្ដីសុចរិតរបស់ទូលបង្គំអើយ
កាលណាទូលបង្គំអំពាវនាវ
នោះសូមទ្រង់មានបន្ទូលឆ្លើយមក[ក]
វេលាណាដែលទូលបង្គំបានកើតមានសេចក្ដីចង្អៀត[ខ]
នោះទ្រង់តែងបន្ធូរឱ្យបានទូលាយវិញ
ដូច្នេះ សូមមេត្តាប្រោស[គ]ដល់ទូលបង្គំ
ហើយស្ដាប់សេចក្ដីអធិស្ឋានរបស់ទូលបង្គំផង[ឃ] ។

**៣:៧** ដ ២របា ៦:៤១ ឋ ទដ ៦:៤ ៧:១ ៥៩:១ ១០៩:២១ ១១៩:១៥៣ អស ២៥:៩ ៣៣:២២ ៣៥:៤ ៣៦:១៥ ៣៧:២០ យរ ៤២:១១ មថ ៦:១៣ ឌ យប ១៦:១០ ឍ យប ២៩:១៧ ទដ ៥៧:៤ សភ ៣០:១៤ បទ ៣:១៦

**៣:៨** ណ ទដ ២៧:១ ៣៧:៣៩ ៦២:១ អស ៤៣:៣,១១ ៤៤:៦,៨ ៤៥:២១ ហស ១៣:៤ យហ ២:៩ វវ ៧:១០ ត ជន ៦:២៣ ទដ ២៩:១១ ១២៩:៨ **៤:១** ក ទដ ១៣:៣ ២៧:៧ ៦៩:១៦ ៨៦:៧ ១០២:២ ខ លប ៣២:៧ ពច ២:១៥ គ ទដ ៣០:១០ ឃ ទដ ១៧:៦ ៥៤:២ ៨៤:៨ ៨៨:២

**៣:៧–៨** នៅក្នុងខនេះ បានពណ៌នាពីសេចក្ដីអធិស្ឋានរបស់ស្ដេចដាវីឌ ។ **៣:៧** *សូមទ្រង់ក្រោកឡើង . . . សូមទ្រង់ជួយសង្គ្រោះទូលបង្គំផង* ជាញឹកញាប់សំនួនវោហារនៃភាសាហេព្រើរអារម្មកថា (សូមមើលក្នុង នក ១២:៣១ "ក្រោកឡើង" ចទ ២:១៣ ពច ៧:៩ "ចូរឯងក្រោកឡើង") ។ ជាញឹកញាប់នៅក្នុងកំណាព្យ អារម្មកថានៃសំនួនវោហារតែងតែពណ៌នាពីការបំផុសគំនិត២ផ្សេងគ្នា ។ ហេតុដូច្នេះហើយ ទើបស្ដេចដាវីឌទ្រង់បានអធិស្ឋានថា "សូមទ្រង់ក្រោកឡើង" និង "សូមទ្រង់ជួយសង្គ្រោះទូលបង្គំផង" ។ *ឱព្រះយេហូវ៉ា . . . ជាព្រះនៃទូលបង្គំ* នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាជាព្រះនៃទូលបង្គំ ។ ជាញឹកញាប់ការបញ្ចូលព្រះនាមរបស់ព្រះអម្ចាស់២ឱ្យ ចូលគ្នាតែ១បែបនេះ គឺជាការពណ៌នាពីកិច្ចការងាររបស់អ្នកនិពន្ធ២ខុសគ្នា ។ *បំបាក់ធ្មេញ* នៅកន្លែងនេះប្រហែលជាអ្នកនិពន្ធចង់ ប្រៀបធៀបពួកខ្មាំងសត្រូវទៅនឹងសត្វព្រៃ ដែលគេតែងវាយបំបាក់ធ្មេញ (សូមមើលការពន្យល់ក្នុង ៧:២) ។

**៣:៨** *ឯសេចក្ដីសង្គ្រោះ នោះស្រេចនៅព្រះយេហូវ៉ា* តាមរយៈឃ្លានេះបង្ហាញថា លក្ខណៈពិសេសនៃសេចក្ដីអធិស្ឋានដែលមាននៅក្នុងព្រះគម្ពីរទំនុកដំកើងគឺពួកអ្នកដែលអធិស្ឋាន ឬអំពាវនាវដល់ព្រះនាមព្រះគេមានទំនុកចិត្តថា ព្រះអម្ចាស់ទ្រង់នឹងស្ដាប់ពួនូវអ្វីដែលពួកគេបានអំពាវនាវរកទ្រង់ (សូមមើលក្នុង ៦:៨–១០ ៧:១០–១៧ ១០:១៦–១៨ ១២:៧ ១៣:៥–៦ ហើយសូមមើលការពន្យល់ក្នុង ១២:៥–៦) ។ ទំនុកចិត្តក្នុងសេចក្ដីអធិស្ឋានរបស់ស្ដេចដាវីឌនៅត្រង់កន្លែងនេះ បានក្លាយជាទីបន្ទាល់ដ៏ធំមួយដល់ប្រជារាស្ត្រផ្សេងៗទៀតរបស់ព្រះអម្ចាស់ ។ *សូមព្រះពររបស់ទ្រង់បាននៅលើរាស្ត្រទ្រង់ចុះ* សូមមើលក្នុង ២៥:២២ ២៨:៨–៩ ៥១:១៨ ។ ពួកមនុស្សទាំងឡាយ ដែលព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងឱ្យធ្វើជាអ្នកគ្រប់គ្រងលើពួកអ៊ីស្រាអែល គេបានក្រោកឈរឡើងទូលបង្គំនៅចំពោះមុខស្ដេចនៃស្ថានសួគ៌ក្នុងនាមជាអ្នកបម្រើព្រះ ដែលមានទំនួលខុសត្រូវលើសេរីភាពសម្រាប់ប្រជារាស្ត្ររបស់ព្រះ ។

**ទដ ជំពូក៤** នៅក្នុងព្រះគម្ពីរទំនុកដំកើងជំពូក ៤នេះ គឺជាសេចក្ដីអធិស្ឋានមួយ ដែលស្ដេចដាវីឌទ្រង់បានទូលសូមដល់ព្រះអម្ចាស់ឱ្យមានបន្ទូលឆ្លើយតបមកគាត់ក្នុងវេលា ដែលគាត់មានសេចក្ដីទុក្ខលំបាកនៅក្នុងខ្លួន ដោយព្រោះពួកមនុស្សអាក្រក់បាននិយាយបង្កាច់ និងការរៀបរាប់ពីគាត់(ការរៀបរាប់នេះ ប្រៀបបានទៅនឹងអំណត់មួយ មើល ខ.៧) ដែលជាការបំភ័យដល់ប្រជាជាតិទាំងមូល ធ្វើឱ្យឋានៈរបស់ទ្រង់អាប់យស ("សិរីល្អ" របស់ទ្រង់ ខ.២) និងធ្វើឱ្យរាជបល្ល័ង្ករបស់ព្រះអង្គ ។ ការរាលដាលនៃពួកអ្នកដែលពោលពាក្យកុហកឬសេចក្ដីភូតភរទាំងអស់នោះ (មើល ខ.២ និងការពន្យល់) បានធ្វើឱ្យស្ដេចដាវីឌទ្រង់រៀបចំផែនការបង្ការ មិនឱ្យប្រជាជាតិជួបប្រទះមហន្តរាយ ជាជាងការដែលគាត់ស្វែងរកព្រះ (សូមមើលសេចក្ដីផ្ដើម ទដ ជំពូក ៣,៥ ដែលបានភ្ជាប់មកជាមួយនឹងទដនេះ) ។

**ជំពូក៤ ចំណងជើង** សូមមើលក្នុង ហព ៣:១៩ ។ *សំរាប់មេភ្លេង* ឃ្លានេះប្រហែលជាចង់និយាយសំដៅលើភ្លេង ដែលគេលេងសរសើរព្រះក្នុងព្រះវិហារ ដើម្បីឧទ្ទិសថ្វាយទៅដល់បទនៃទំនុកដំកើងនេះដែលពួកមេភ្លេងបានជ្រើសរើយកមកប្រើក្នុងការថ្វាយបង្គំនៅក្នុងជំនុំពួកអ៊ីស្រាអែល ឬមួយនៅពេលដែលបទនៃទំនុកដំកើងនេះ គេយកមកប្រើក្នុងការថ្វាយបង្គំនៅក្នុងព្រះវិហារ នោះអ្នកចម្រៀងពួកលេវី ឬពួកចម្រៀងផ្សេងៗទៀតជាអ្នកច្រៀង (សូមមើលក្នុង ១របា ២៣:៥,៣០ ជំពូក ២៥ នហ ១១:១៧) ។ នៅពេលដែលគេច្រៀងសរសើរតម្កើងព្រះ ពួកលេវីមានតួនាទីជាអ្នកដឹកនាំមុខក្នុងការថ្វាយបង្គំដល់ព្រះអម្ចាស់ ហើយប្រហែលពួកបណ្ដាជននិយាយជាពាក្យ "អាម៉ែន" ឬ "សូមសរសើរតម្កើងដល់ព្រះ" (ហាលេលូយ៉ា) (សូមមើលក្នុង ១របា ១៦:៣៦ នហ ៥:១៣ ហើយធៀបជាមួយ ១កថ ១៤:១៦ វវ ៥:១៤ ៧:១២ ១៩:១៤) ជាការឆ្លើយតបចំពោះពួកដឹកនាំរបស់ពួកគេ ។ *ត្រូវលេងដោយប្រដាប់មានខ្សែ* សូមមើលក្នុង ទដ ជំពូក ៦,៥៤,៥៥,៦១,៦៧,៧៦ ត្រង់ចំណងជើង (ធៀបនឹង ហព ៣:១៩ និងការពន្យល់) ។ តាមរយៈឃ្លានេះចង់និយាយថា ពួកលេវីគេច្រៀងចម្រៀងនេះ ដោយការពោលតាមស៊ុង និងពិណ (មើល ១របា ២៣:៥ ២៥:១,៣,៦ ធៀបនឹង ទដ ៣៣:២ ៤៣:៤ ៧១:២២ និងការពន្យល់ ទដ ជំពូក ៣៩,៤២ ត្រង់ចំណងជើង) ។

**៤:១** នៅក្នុងខនេះចង់និយាយថា គោលបំណងរបស់ស្ដេចដាវីឌក្នុងសេចក្ដីអធិស្ឋាននេះ គឺចង់ប្រាថ្នាឱ្យព្រះយេហូវ៉ាបានស្ដាប់ឮសំរែក ដែលគាត់អធិស្ឋាន ។ *កាលណាទូលបង្គំអំពាវនាវ នោះសូមទ្រង់មានបន្ទូលឆ្លើយមក* មើលការពន្យល់ ១១៨:៥ ។ *សេចក្ដីសុចរិត* ជាញឹកញាប់ពាក្យថា "សេចក្ដីសុចរិត" របស់ព្រះដែលមាននិយាយនៅក្នុងព្រះគម្ពីរទំនុកដំកើង (ជាពិសេសនៅក្នុងសញ្ញាចាស់ទាំងមូល) គឺសំដៅលើសេចក្ដីស្មោះត្រង់របស់ព្រះអម្ចាស់ ។ សេចក្ដីស្មោះត្រង់នេះ គឺពោរពេញទៅដោយការប្ដេជ្ញាចិត្តចំពោះរាស្ត្ររបស់ទ្រង់ និងស្ដេចដែលទ្រង់បានតែងតាំងឡើង ។ សម្រាប់អ្នកដែលគ្មានអំណាច និងកម្លាំងពួកគេប្រហែលជាត្រូវការការពារ *សេចក្ដីចង្អៀត* នៅក្នុងឃ្លានេះគឺចង់និយាយលើការគំរាមកំហែងដែលធ្វើឱ្យខូចយសរបស់ទ្រង់ ពីសំណាក់ពួកអ្នកដែលពោលពាក្យមូលបង្កាច់ដែលធ្វើឱ្យប្រទេសជាតិមានបញ្ហា ។

២ ឱពួកមនុស្សជាតិអើយ តើឯងរាល់គ្នានឹងធ្វើឱ្យកិត្តិយស[ង]
របស់អញ ក្លាយប្រែទៅជាអាប់យស[ច] ដល់កាលណាទៀត
តើនឹងស្រឡាញ់ការឥតប្រយោជន៍ ហើយស្វែងរកសេចក្តី
ភូតភរ ដល់កាលណាទៀត[ឆ] ។ បង្អង់
៣ ប៉ុន្តែត្រូវឱ្យដឹងថា ព្រះយេហូវ៉ាទ្រង់បានញែកមនុស្ស
ដែលកោតខ្លាច[ជ]ដល់ទ្រង់ចេញ ទុកសំរាប់ទ្រង់
ព្រះយេហូវ៉ាទ្រង់នឹងស្តាប់[ឈ]ក្នុងកាលដែលអញអំពាវនាវ
ដល់ទ្រង់
៤ ដូច្នេះ ចូរមានចិត្តញ័រចុះ តែកុំឱ្យធ្វើបាបឡើយ[ញ]
ចូររំពឹងគិតនៅក្នុងចិត្ត ក្នុងកាលដែលដេកលើដំណេក[ដ]
ហើយនៅស្ងៀមចុះ ។ បង្អង់
៥ ចូរថ្វាយគ្រឿងបូជានៃសេចក្តីសុចរិត
ហើយទុកចិត្តដល់ព្រះយេហូវ៉ាចុះ[ឋ]
៦ មានមនុស្សជាច្រើនដែលនិយាយថា
តើអ្នកណានឹងសំដែងឱ្យយើង ឃើញសេចក្តីល្អ
ឱព្រះយេហូវ៉ាអើយ សូមទ្រង់ប្រោសឱ្យរស្មីនៃ
ព្រះភក្ត្រទ្រង់ បានភ្លឺមកលើយើងខ្ញុំរាល់គ្នា[ឌ]
៧ ទ្រង់បានប្រោសឱ្យចិត្ត[ឍ]ទូលបង្គំមានសេចក្តីអំណរ[ណ]
លើសជាងពួកទាំងនោះ ក្នុងកាលដែលស្រូវ
នឹងទឹកទំពាំងបាយជូរ[ត]របស់គេបានសំបូរផង
៨ ទូលបង្គំនឹងសំរាកកាយ ហើយដេក[ថ]លក់ទៅ[ទ]
ដោយសេចក្តីស្ងប់ ដ្បិតឱព្រះយេហូវ៉ាអើយ
មានតែទ្រង់ទេ ដែលប្រោសឱ្យទូលបង្គំ
នៅដោយសាន្តត្រាណបាន[ធ] ។

ទំនុកនៃស្តេចដាវីឌ

ដែលទ្រង់លើកឱ្យមេភ្លេង ត្រូវលេខដោយខ្លុយ ។

**៥** ឱព្រះយេហូវ៉ាអើយ

**៤:២** ង នក ១៦:៧ ១សយ ៤:២១ ច ២ពវ ១៩:២៦ យប ៨:២២ ទដ ៣៥:២៦ ឆ ពច ២:១៧ ទដ ៣១:៦ ៤០:៤ យរ ១៣:២៥ ១៦:១៩ អម ២:៤ **៤:៣** ជ ទដ ១២:១ ៣០:៤ ៣១:២៣ ៧៩:២ មីក ៧:២ ១ធច ៤:៧ ២ពត ៣:១១ ឈ ទដ ៦:៨ មីក ៧:៧ **៤:៤** ញ អភ ៤:២៦ ដ ទដ ៦៣:៦ ដយ ២:២៨ **៤:៥** ឋ ទដ ៣១:៦ ១១៥:៩ សភ ៣:៥ ២៨:២៦ អស ២៦:៤ យហ ១៤:១ **៤:៦** ឌ ជន ៦:២៥ **៤:៧** ឍ កច ១៤:១៧ ណ អស ៩:៣ ៣៥:១០ ៦៥:១៤,១៨ ត លប ២៧:២៨ ចទ ២៨:៥១ **៤:៨** ថ លវ ២៦:៦ ទ ជន ៦:២៦ យប ១១:១៨ ធ ចទ ៣៣:២៨ យរ ៣២:៣៧

**៤:២-៣** នៅក្នុងខនេះ ស្តេចដាវីឌទ្រង់បានឈ្លោះប្រកែកជាមួយពួកអ្នកដែលបង្កជម្លោះជានឹងទ្រង់ ហើយព្រមានពួកអ្នកទាំងនោះថា ព្រះយេហូវ៉ាទ្រង់នឹងស្តាប់ឮ ឆ្លើយតបចំពោះការអំពាវនាវរបស់ទ្រង់ ហើយរំដោះទ្រង់ឱ្យរួចពីពួកអ្នកដែលបៀតបៀនគាត់ (មើលការពន្យល់ ៥:៩) ។

**៤:២** *ដល់កាលណាទៀត* សូមមើលក្នុងសេចក្តីផ្តើមត្រង់ចំណុចផ្ទៃរឿងសំខាន់ៗក្នុងចំណុចទី៤ និងសេចក្តីពន្យល់ ៦:៣ ។ *ធ្វើឱ្យកិត្តិយសអញប្រែក្លាយទៅជាអាប់យស* ដោយសារការនិយាយបង្ខូចបង្កាច់កិត្តិយសនេះហើយ បានធ្វើឱ្យស្តេចដាវីឌទ្រង់រស់នៅដោយអំណរ ក្រោមព្រះពរនិងការថែរក្សាមកពីព្រះអម្ចាស់ (មើល ៣:៣ និងការពន្យល់) ហើយក៏បានធ្វើឱ្យគាត់បែរជាអាប់យសដែរ (ប៉ុន្តែសូមមើលការពន្យល់ក្នុងព្រះគម្ពីរ)។ *ការឥតប្រយោជន៍* ការឥតប្រយោជន៍នៅកន្លែងនេះ គឺសំដៅលើពាក្យចចាមអារ៉ាម និងការចោទប្រកាន់ផ្សេងៗដែលធ្វើសេចក្តីពិតផ្សេងៗ ត្រឡប់ជាមិនបានផល ។

**៤:៣** *មនុស្សដែលកោតខ្លាចទ្រង់* ឃ្លានេះនៅក្នុងព្រះគម្ពីរ ភាសាហេព្រើរ គឺគេប្រើពាក្យ ហាស៊ីត "hasid" ដែលមានចំនួន២៦ដងនៅក្នុងព្រះគម្ពីរទំនុកដំកើងទាំងមូល(ពាក្យនេះមានន័យថា ជារបស់ព្រះ ១៤៥:១៧ "សប្បុរស" សូមធៀបជាមួយ ១៨:២៥) ហើយជាញឹបញាប់នៅក្នុងគម្ពីរតែងតែងនិយាយថា "មនុស្សដែលកោតខ្លាចទ្រង់ " ឬ "មនុស្សបរិសុទ្ធ" ។ ពាក្យនេះ គឺជាពាក្យមួយក្នុងចំណោមពាក្យជាច្រើនទៀត នៅក្នុងព្រះគម្ពីរភាសាហេព្រើរដែលនិយាយសំដៅលើរាស្ត្ររបស់ព្រះ ដែលពួកគេត្រូវតែថ្វាយខ្លួន និងស្មោះត្រង់ចំពោះព្រះអម្ចាស់ ។

**៤:៤-៥** សេចក្តីបង្រៀននៅក្នុងខ.នេះមិនមែនឱ្យយើងចេះខឹងឬភ័យខ្លាច ហើយទៅរកម្នាក់ដែលជាអ្នកទទួលរងកំហុស (ស្តេច) ឱ្យទទួលយកបញ្ហាដែលកំពុងតែកើតមានឡើងនោះឡើយ ប៉ុន្តែគឺឱ្យយើងចេះរំពឹងគិតនៅក្នុងចិត្តហើយទុកចិត្តដល់ព្រះអម្ចាស់ ។

**៤:៤** *ដូច្នេះ ចូរមានចិត្តញ័រចុះ តែកុំឱ្យធ្វើបាបឡើយ* នៅក្នុងសញ្ញាថ្មីលោកសាវ័កប៉ូលក៏បានប្រើឃ្លានេះដែរ (សូមមើលក្នុង អភ ៤:២៦) ។

**៤:៦** នៅក្នុងខ.នេះស្តេចដាវីឌ ទ្រង់បានអធិស្ឋានសូមឱ្យព្រះយេហូវ៉ាទ្រង់ប្រទានពរដល់គាត់ ។ *តើអ្នកណា . . .* នៅក្នុងឃ្លានេះចង់បង្ហាញថា ដោយសារតែពួកអ្នក ដែលនិយាយពាក្យបង្ខូចបង្កាច់គេចាប់ផ្តើមកើនឡើង ហើយមានគ្នាកាន់តែច្រើន នោះបានធ្វើឱ្យមនុស្សជាច្រើនគេទន្ទឹងរងចាំអ្នកដឹកនាំផ្សេងទៀតដើម្បីជំនួសកន្លែងរបស់ស្តេច ។ *សំដែងឱ្យយើងឃើញសេចក្តីល្អ* មើល ៣៤:១០ ៨៤:១១ ៨៥:១២ ១០៣:៥ ១០៧:៩ ធៀបនឹង ១២:២ យប ១:១៧ ។ *សូម... បានភ្លឺមកលើយើងរាល់គ្នា* ស្តេចដាវីឌទ្រង់បានលេចឡើងនូវចំពោះព្រះម្ចាស់ ដើម្បីកសាងប្រទេសជាតិឱ្យមានស្ថេរភាពឡើងវិញ (មើលការពន្យល់ ១៣:១) ។

**៤:៧-៨** នៅក្នុងខ.ទាំងនេះគឺនិយាយពីទំនុកចិត្តរបស់ស្តេចដាវីឌ (សូមមើលការពន្យល់ក្នុង ៣:៨) ។

**៤:៧** *ចិត្ត* នៅក្នុងព្រះគម្ពីរ ចិត្តគឺស្ថិតនៅក្នុងចំណុចកណ្តាលនៃវិញ្ញាណរបស់មនុស្សដែលបានបង្ហាញចេញជាអារម្មណ៍ គំនិតគិតការច្នៃប្រឌិតការលើកទឹកចិត្ត និងការប្រព្រឹត្ត ហើយចិត្តគឺជា "ផលនៃជីវិត" (សូមមើល សភ ៤:២៣) ។

**៤:៨** *ទូលបង្គំនឹងសំរាកកាយ ហើយដេកលក់ទៅ* មើល ៣:៥ និងការពន្យល់ ។ *ដោយសេចក្តីស្ងប់* គឺចង់មានន័យថា គ្មានការថប់បារម្ភអ្វីឡើយ ។

**ទដ ជំពូក៥** នៅក្នុងជំពូកនេះពណ៌នាពីទំនួញសោករបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង ដែលគាត់ទូលសូមសេចក្តីជំនួយពីព្រះយេហូវ៉ាក្នុងអំឡុងពេលដែលពួកខ្មាំងសត្រូវកំពុងតែនិយាយពាក្យបង្ខូច និងពាក្យកំភូតក្នុងគោលបំណងបំផ្លាញគាត់ ។ គាត់បានអធិស្ឋានទូលសូមដល់ព្រះយេហូវ៉ានៅពេលព្រឹកព្រលឹមដែលពេលវេលានោះ ប្រហែលជាពេលដែលគាត់ត្រូវថ្វាយយញ្ញបូជានៅពេលព្រឹកតែម្តង ។

**ជំពូក៥ ចំណងជើង** *លើកឱ្យមេភ្លេង* មើលការពន្យល់ ជំពូក៤ត្រង់ចំណងជើង ។ *ខ្លុយ* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានប្រើតែកន្លែងនេះ

សូមផ្ទៀងព្រះកាណ៌[ក]ស្ដាប់ពាក្យរបស់ទូលបង្គំ
សូមពិចារណាការរំពឹងគិតរបស់ទូលបង្គំ[ខ]
២ឱបរមក្សត្រដ៏ជាព្រះនៃទូលបង្គំអើយ[គ]
សូមប្រុងស្ដាប់សំឡេងនៃពាក្យ ដែលទូលបង្គំអំពាវនាវ[ឃ]
ដ្បិតទូលបង្គំអធិស្ឋានដល់ទ្រង់
៣ឱព្រះយេហូវ៉ាអើយ នៅពេលព្រឹក[ង]
ទ្រង់នឹងឮសំឡេងរបស់ទូលបង្គំ គឺនៅពេលព្រឹក
ទូលបង្គំនឹងទូលដល់ទ្រង់ ដោយលំដាប់
ព្រមទាំងរក្សាពេលចាំយាមផង[ច]
៤ដ្បិតទ្រង់មិនមែនជាព្រះដែលសព្វព្រះហឫទ័យ
នឹងសេចក្ដីល្មើសទេ
ឯងសេចក្ដីអាក្រក់[ឆ] នឹងនៅជាមួយនឹងទ្រង់មិនបាន
៥ពួកឆ្មើងឆ្មៃ[ជ]នឹងឈរ[ឈ]នៅចំពោះព្រះនេត្រទ្រង់មិនបាន
ទេ ទ្រង់ក៏ស្អប់[ញ]បណ្ដាអ្នកដែលប្រព្រឹត្តអំពើទុច្ចរិត
៦ទ្រង់នឹងបំផ្លាញពួកអ្នកដែលពោលពាក្យភូតភរ[ដ]
ព្រះយេហូវ៉ា ទ្រង់ខ្ពើមឆ្អើម ចំពោះមនុស្សដែលតែង
តែកំចាយឈាម ហើយបោកប្រាសគេ
៧ឯទូលបង្គំវិញ ទូលបង្គំនឹងចូលទៅក្នុងដំណាក់នៃទ្រង់
ដោយសារសេចក្ដីមេត្តាករុណាដ៏បរិបូររបស់ទ្រង់[ឋ]
ទូលបង្គំនឹងថ្វាយបង្គំ[ឌ]នៅក្នុងព្រះវិហារដ៏បរិសុទ្ធរបស់
ទ្រង់[ឍ] ដោយចិត្តកោតខ្លាចដល់ទ្រង់
៨ឱព្រះយេហូវ៉ាអើយ
សូមណែនាំទូលបង្គំក្នុងសេចក្ដីសុចរិត[ណ]របស់ទ្រង់
ដោយព្រោះពួកខ្មាំងសត្រូវនៃទូលបង្គំ
សូមធ្វើឱ្យផ្លូវ[ត]ទ្រង់ត្រង់នៅមុខទូលបង្គំ
៩ដ្បិតនៅក្នុងមាត់ពួកនោះ គ្មានសេចក្ដីពិតឡើយ
ខាងក្នុងគេមានសុទ្ធតែសេចក្ដីកាចអាក្រក់
បំពង់កគេជាផ្នូរខ្មោច[ថ]នៅចំហ
គេពោលបញ្ចើចដោយសារអណ្ដាត[ទ]

**៥:១** ក ១ពវ ៨:២៩ ទដ ១៧:១ ៤០:១ ១១៦:២ ដយ ៩:១៨ ខ ទដ ៣៨:៩ អស ៣៥:១០ ៥១:១១ **៥:២** គ ទដ ៤៤:៤ ៦៨:២៤ ៨៤:៣ ឃ យប ១៩:៧ ២៤:១២ ៣៦:៥ **៥:៣** ង អស ២៨:១៩ ៥០:៤ យរ ២១:១២ អគ ៤៦:១៣ សផ ៣:៥ ច ទដ ៦២:១ ១១៩:៨១ ១៣០:៥ ហព ២:១ រម ៨:១៩ **៥:៤** ឆ ទដ ១:៥ ១១:៥ ១០៤:៣៥ សភ ២:២២ **៥:៥** ជ ២ពវ ១៩:៣២ ទដ ៧៣:៣ ៧៥:៤ អស ៣៣:១៩ ៣៧:៣៣ ឈ ទដ ១:៥ ញ ទដ ៤៥:៧ ១០១:៣ ១១៩:១០៤ សភ ៨:១៣ **៥:៦** ដ សភ ១៩:២២ យហ ៨:៤៤ កច ៥:៣ វវ ២១:៨ **៥:៧** ឋ ចទ ១៣:៤ យរ ៤៤:១០ ដយ ៦:២៦ ឌ ២សយ ១២:១៦ ទដ ១៣៨:២ ឍ ១ពវ ៨:៤៨ **៥:៨** ណ ទដ ២៣:៣ ៣១:១ ៧១:២ ៨៥:១៣ ៨៩:១៦ សភ ៨:២០ ត ១ពវ ៨:៣៦ យហ ១:២៣ **៥:៩** ថ យរ ៥:១៦ លក ១១:៤៤ ទ ទដ ១២:២ ២៨:៣ ៣៦:៣ សភ ១៥:៤ យរ ៩:៨ រម ៣:១៣

ប៉ុណ្ណោះ ដែលមានន័យថា មិនច្បាស់លាស់ ។

**៥:១–៣** គោលបំណងរបស់ស្ដេចដាវីឌ ដែលគាត់អធិស្ឋាននៅពេលនេះ គឺគាត់ចង់ឱ្យព្រះយេហូវ៉ាទ្រង់ស្ដាប់ឮពាក្យដែលគាត់បានអំពាវនាវ ហើយឆ្លើយតបមកដល់គាត់ ។

**៥:២** *បរមក្សត្រ* សូមមើលការពន្យល់ក្នុងសេចក្ដីផ្ដើមត្រង់ចំណុចផ្ទៃរឿងសំខាន់ៗ ។

**៥:៣** *នៅពេលព្រឹក* សូមមើលសេចក្ដីផ្ដើម ទដ ជំពូក ៥៧ ធៀបនឹង យរ ២១:១២ និងការពន្យល់ ។

**៥:៤–៥** នៅក្នុងខទាំងនេះ ស្ដេចដាវីឌគាត់ទូលសូមឱ្យសេចក្ដីសុចរិតរបស់ព្រះយេហូវ៉ាបានគ្រប់គ្រងលើមនុស្សលោកទាំងមូល ។

**៥:៥** *ពួកឆ្មើងឆ្មៃ* សូមមើលការពន្យល់ ៣១:៣២ ។

**៥:៦** *ពោលពាក្យភូតភរ* ពួកអ្នកទាំងនោះគេតែងតែបំផ្លាញអ្នកដទៃដោយការនិយាយពាក្យមិនពិត មួលបង្កាច់ ឬជាអ្នកដែលក្លែងទីបន្ទាល់ (សូមមើល ខ.៩ និងការពន្យល់) ។

**៥:៧–៨** អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គាត់បានថ្វាយសេចក្ដីអធិស្ឋានរបស់គាត់ទៅចំពោះព្រះយេហូវ៉ា ដោយការថ្វាយបង្គំយ៉ាងបន្ទាបខ្លួន (ខ.៧) ហើយដោយការទុកចិត្តលើសេចក្ដីមេត្តាករុណាដ៏បរិបូរ (ខ.៧) ព្រមទាំងសេចក្ដីសុចរិតរបស់ទ្រង់ (ខ.៨) ។

**៥:៧** *សេចក្ដីមេត្តាករុណាដ៏បរិបូរ* សូមមើលការពន្យល់ ៦:៤ ។

**៥:៨** *សូមណែនាំទូលបង្គំ* នៅក្នុងឃ្លានេះចង់និយាយថា ស្ដេចដាវីឌទូលសូមឱ្យព្រះយេហូវ៉ាធ្វើជាអ្នកគង្វាលរបស់ទ្រង់ (មើល ២៣:៣) ។ *សេចក្ដីសុចរិត* មើលការពន្យល់ ៤:១ ។ *សូមធ្វើឱ្យផ្លូវរបស់ទ្រង់ត្រង់នៅមុខទូលបង្គំ* នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យទ្រង់បានតម្រង់ផ្លូវ ដែលទូលបង្គំបានដើរសូមឱ្យផ្លូវនោះជាផ្លូវដែលរលីងស្អាត ហើយគ្មានឧបសគ្គនឹងគ្មានសេចក្ដីល្បួងផ្សេងៗឡើយ ។ អ្នកនិពន្ធគាត់បានទូលសូមឱ្យព្រះយេហូវ៉ា ទ្រង់ដឹកនាំគាត់ ដែលពេលនោះពួកខ្មាំងសត្រូវរបស់គាត់នឹង មិនគ្មានដីសម្រាប់ឱ្យពួកគេស្នាក់នៅបន្តនិយាយចោទប្រកាន់ទៀតឡើយ (មើល ២៥:៤ ២៧:១១ ១៣៩:២៤ ១៤៣:៨–១០) ។

**៥:៩–១០** នៅក្នុងខនេះស្ដេចដាវីឌ ទ្រង់ទូលដល់ព្រះពីការចោទប្រកាន់ពីសំណាក់ពួកខ្មាំងសត្រូវ ហើយគាត់ក៏អំពាវនាវទូលសូមឱ្យព្រះយេហូវ៉ាទ្រង់កាត់ទោសដល់ពួកគេ (បញ្ហាទាំង២នេះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងតែងតែអធិស្ឋាននៅពេលដែលគាត់ជួបប្រទះការវាយប្រហារ ឬបៀតបៀនពីសំណាក់ពួកមនុស្សអាក្រក់) ។

**៥:៩** *ក្នុងមាត់ពួកនោះ* ជាញឹកញាប់អាវុធដែលគេតែងតែយកមកធ្វើការវាយប្រហារ ឬទាស់ទទឹងជាមួយអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគឺ "អណ្ដាត" (មើលជាឧទាហរណ៍ ទដ ជំពូក ១២ និងការពន្យល់ ១០:៧) ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បានពិសោធន៍ថា អណ្ដាតគឺជាសេចក្ដីស្លាប់ ប្រៀបបានទៅនឹងដាវ និងលំពែង (មើល ៥៥:២១ ៥៩:៧ ៦៤:៣–៤ ធៀបនឹង សភ ១២:១៨ ២៥:១៨) ។ ជានិច្ចកាលនៅក្នុងព្រះគម្ពីរទំនុកដំកើងបានបង្ហាញថា ព្រះយេហូវ៉ាទ្រង់នឹងទាស់ប្រឆាំងនឹងពួកមនុស្ស ដែលនិយាយមិនពិត ពីព្រោះមានតែនៅក្នុងដំណាក់នៃការជំនុំជម្រះរបស់ព្រះអង្គប៉ុណ្ណោះ ដែលមនុស្សអាចទទួលការផ្ដន្ទាទោសចំពោះការអាក្រក់បាន ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។ *បំពង់កគេជាផ្នូរខ្មោច* មើលការពន្យល់ ៤៩:១៤ ។ *គេពោលបញ្ចើច* មើល ទដ ជំពូក ១៧,២៥,២៧–២៨,៣១,៣៥,៤១,៥២,៥៤–៥៧,៥៩,៦៣–៦៤,៧១,៨៦,១០៩,១៤០–១៤១ ដែលនិយាយអំពីឧបាយកលរបស់ពួកខ្មាំងសត្រូវដែលតែងតែនិយាយពាក្យកំភូត ដើម្បីបង្ខូចកិត្តិយសដល់ស្ដេចនិងធ្វើឱ្យទ្រង់ត្រូវដួលចុះ ដែលបញ្ហាទាំងអស់នេះគឺនិយាយសំដៅលើព្រះបាទដាវីឌ ។ ជាញឹកញាប់ពួកគេបានវាយប្រហារ ឬបៀតបៀនទៅ

១០ ឱព្រះអង្គអើយ សូមទ្រង់កាត់ទោសដល់គេ
សូមឱ្យគេដួលចុះ ដោយឧបាយរបស់ខ្លួនគេ
សូមបណ្ដេញគេចេញ
ដោយព្រោះអំពើរំលងរបស់គេ ដែលច្រើនឥតគណនា[ធ]
ដ្បិតគេបានបះបោរ[ន]នឹងទ្រង់ហើយ
១១ នោះអស់អ្នកដែលពឹងដល់ទ្រង់ គេនឹងរីករាយឡើង
គេនឹងច្រៀងដោយអំណរជានិច្ច[ប]
ពីព្រោះទ្រង់តែងការពារគេ
ហើយអស់អ្នកដែលស្រឡាញ់ដល់ព្រះនាម[ផ]ទ្រង់
នឹងបានត្រេកអរ ដោយសារទ្រង់[ព]
១២ ដ្បិត ឱព្រះយេហូវ៉ាអើយ
ទ្រង់នឹងប្រទានពរដល់មនុស្សសុចរិត[ភ]
ទ្រង់នឹងបាំងអ្នកទាំងនោះនៅជុំវិញ[ម] ដោយព្រះគុណ
ទុកដូចជាខែល[យ] ។

**៥:១០** ធ បទ ១:៥ ន ទដ ៧៨:៤០ ១០៦:៧ ១០៧:១១ បទ ៣:៤២
**៥:១១** ប ទដ ៣៣:១ ៨១:១ ៩០:១៤ ៩២:៤ ៩៥:១ ១៤៥:៧ ផ ទដ ៦៩:៣៦ ១១៩:១៣២ ព យប ២២:១៩
**៥:១២** ភ ទដ ១១២:២

ទំនុកនៃស្ដេចដាវីឌ
ដែលទ្រង់លើកឱ្យមេភ្លេង ត្រូវលេងដោយប្រដាប់មានខ្សែ៨ ។

**៦** ឱព្រះយេហូវ៉ាអើយ សូមកុំបន្ទោសទូលបង្គំ

ម ទដ ៣២:៧ យ លប ១៥:១

ចំពោះស្ដេចនៅពេលណា ដែលស្ដេចកំពុង "ទន់ខ្សោយ" ហើយជាពិសេសនៅពេលដែលព្រះទ្រង់បានបោះបង់ ឬបំភ្លេចគេចោល (មើល ទដ ជំពូក ២៥,៣៥,៤១,៧១,៨៦,១០៩) ។ ស្ថិតនៅក្នុងស្ថានការណ៍បែបនេះទ្រង់គិតឃើញថា ទ្រង់មិនសក្តិសមធ្វើជាស្ដេចទៀតឡើយ ហើយព្រះទ្រង់មិនបានគង់នៅជាមួយគាត់ទៀតដែរ (ដូច្នេះហើយគាត់មិនអាចធានាសុខសុវត្ថិភាពជូនប្រជាជាតិបានឡើយ មើល ១សយ ៨:២០ ១១:១២ ១២:១២ ២៥:២៨ ២សយ ៣:១៨ ៧:៩–១១) ។ នៅក្នុងស្ថានភាពផ្សេងៗទៀតគាត់ងាយនឹងទទួលរងនូវការវាយប្រហារណាស់ (មើល ៣:២ ២២:៧–៨ ៧១:១១) ។ មើលការពន្យល់ ៨៦:១៧ ហើយនិងការប្រើខនេះរបស់លោកសាវកប៉ុលក្នុង រម ៣:១៣ ។

**៥:១០** នៅក្នុងខនេះចង់និយាយថា ការដែលប្រឈមមុខចំពោះពាក្យប្រមាថ ឬការមើលងាយ (បណ្ដាសា) ដែលតែងតែមាននិយាយនៅក្នុងព្រះគម្ពីរទំនុកដំកើង វាគឺជាឱកាសមួយដែលគេលើកមកនិយាយ មិនចេះចប់មិនចេះហើយ ហើយវាក៏ជាដើមចម ដែលបណ្ដាលឱ្យគ្រីស្ទបរិស័ទជាច្រើនបានទទួលជ័យជម្នះដែរ ពីព្រោះសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវ ទ្រង់បានបង្រៀនគេឱ្យគេងាកចេញពីអ្នកណា ដែលបង្ករជម្លោះហើយឱ្យគេអធិស្ឋានសម្រាប់ពួកខ្មាំងសត្រូវរបស់គេ (មើល មថ ៥:៣៩,៤៤) និងគំរូរបស់ព្រះអង្គនៅលើឈើឆ្កាង (មើល លក ២៣:៣៤) ។ ជាការពិតណាស់ "បណ្ដាសា" ទាំងនោះមិនទាន់គ្រប់គ្រាន់សម្រាប់ពួកគេឡើយ ពួកគេបានអំពាវនាវចំពោះព្រះយេហូវ៉ា ដើម្បីឱ្យព្រះអង្គបានអត់ទោសកំហុសដ៏ធ្ងន់ដែលគេប្រព្រឹត្តខុសចំពោះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង ថែមទៀតតាមរយៈការប្រៀបធៀបពីទំហំកំហុសដែលគេប្រព្រឹត្ត (មើល ២៨:៤) និងតាមរយៈកាត់ក្តីដ៏សុចរិតរបស់ពួកចៅក្រមនៅក្នុងលោកិយ (មើល ចទ ២៥:១–៣ និង ២ថន ១:៦ វវ ៦:១០ ១៩:២) ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បានដឹងថា ពួកអ្នកដែលប្រព្រឹត្តកំហុសខុសឆ្គងគេមិនបានសងសឹកចំពោះកំហុសនោះ ដោយដៃគេផ្ទាល់ឡើយ ប៉ុន្តែគេបែរជាទូលសូមឱ្យព្រះជាអ្នកដោះស្រាយបញ្ហា នោះសម្រាប់គេវិញ គឺជាពួកអ្នកដែលនិយាយថា "គឺសេចក្ដីសងសឹក និងសេចក្ដីសងគុណនោះស្រេចនៅអញ" (មើល ចទ ៣២:៣៥ សភ ២០:២២ រម ១២:១៩) ។ ដូច្នេះមានន័យថា មនុស្សអាក្រក់ទាំងនោះ គេបានថ្វាយបញ្ហាទាំងនោះដល់ព្រះយេហូវ៉ាឱ្យព្រះអង្គជាអ្នកជំនុំជម្រះរឿងក្តីរបស់ពួកគេ (មើល យរ ១៥:១៥) ។ *សូមបណ្ដេញគេចេញ* នៅក្នុងឃ្លានេះពួកមនុស្សអាក្រក់ គេទូលសូមឱ្យបណ្ដេញចេញពីព្រះវត្តមានរបស់ព្រះ គឺចេញពីផ្លូវដែលនាំឱ្យព្រះពរនិងជីវិត (មើល លប ៣:២៣) ។ *ដ្បិតគេបានបះបោរនឹងទ្រង់ហើយ* គឺតាមរយៈការទាស់ប្រឆាំងចំពោះអ្នកនិពន្ធក្នុងព្រះគម្ពីរទំនុកដំកើង ។

**៥:១១** នៅក្នុងខនេះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បាននិយាយបន្ថែមពីពួកអ្នកដែលស្រឡាញ់ព្រះនៅក្នុងសេចក្ដីអធិស្ឋានរបស់គាត់ថែមទៀត (សូមមើលការពន្យល់ ៣:៨) ។ *ព្រះនាមទ្រង់* នៅក្នុងឃ្លានេះចង់និយាយថា ព្រះនាមរបស់ព្រះយេហូវ៉ា បានសម្ដែងពីចរិតលក្ខណៈរបស់ព្រះផ្ទាល់ (មើលការពន្យល់ ៣:១៤–១៥ ៣៤:៦–៧) ។ ការនេះមិនមែនមានន័យថា ព្រះនាមរបស់ព្រះដាច់ចេញពីគ្នានោះឡើយ ប៉ុន្តែវាគឺជាសទិសន័យនៃព្រះនាមរបស់ព្រះក្នុងការបើកសម្ដែង ពីព្រះគុណរបស់ព្រះមកលើរាស្ត្រទ្រង់ប៉ុណ្ណោះ ។ ព្រះវិហារក្រុងយេរូសាឡិម គឺជាលំនៅនៃព្រះនាមរបស់ ព្រះដែលទ្រង់គង់នៅជាមួយរាស្ត្ររបស់ទ្រង់នៅលើផែនដីនេះ (មើល ៧៤:៧ ចទ ១២:៥,១១ ២សយ ៧:១៣) ហើយរាស្ត្ររបស់ព្រះអង្គអាចអំពាវនាវដល់ទ្រង់ តាមរយៈការហៅដោយនូវព្រះនាមទ្រង់ (មើល ៧៩:៦ ០:១៨ ៩៩:៦ ១០៥:១ ១១៦:៤,១៣,១៧) ។ ព្រះនាមរបស់ព្រះ បានការពារគេ (មើល ២០:១ សភ ១៨:១០) ព្រះនាមរបស់ព្រះ បានសង្គ្រោះពួកគេ (មើល ៥៤:១) សេចក្ដីសង្គ្រោះរបស់ព្រះបានធ្វើបន្ទាល់ថា ព្រះនាមទ្រង់គង់បង្កើយនឹងគេ (មើល ៥២:៩) ។ ពួកអ្នកដែលស្រឡាញ់ព្រះបាន "ទុកចិត្ត"លើព្រះនាមរបស់ព្រះអម្ចាស់ (២០:៧ ៣៣:២១) សង្ឃឹមលើព្រះនាមព្រះ (មើល ៥២:៩) ច្រៀងសរសើរ "ព្រះនាមព្រះ" (៧:១៧ ៩:២ ១៨:៤៩) ហើយមានអំណរចំពោះ "ព្រះនាមព្រះ" (មើល ៨៩:១៦) ។ ទាំង "សេចក្ដីស្រឡាញ់" និង"សេចក្ដីសុចរិត" ដែលជារបស់ព្រះអម្ចាស់តែ១គត់ គឺមានភាពប្រហាក់ប្រហែលគ្នានឹងព្រះនាមរបស់ព្រះតែម្តង (សេចក្ដីស្រឡាញ់ មើល ៦៩:៣៦ ១១៩:១៣២ ហើយសេចក្ដីសុចរិត មើល ៦១:៥ ៨៦:១១ ១០២:១៥) ។

**៥:១២** មើលការពន្យល់ ៣:៨ ។ *សេចក្ដីសុចរិត* មើលការពន្យល់ ១:៥ ។

**ទដ ជំពូក៦** នៅក្នុងជំពូកនេះគឺចង់និយាយពីការអធិស្ឋានក្នុងគ្រាដែលពួកគេមានជំងឺធ្ងន់ធ្ងរ និងការដែលពួកខ្មាំងសត្រូវរបស់ស្ដេចដាវីឌគេបញ្ចេញសេចក្ដីកំហឹងរបស់ពួកគេ ។

**ទដជំពូក៦ ចំណងជើង** សូមមើលការពន្យល់ ទដ ជំពូក ៤ ត្រង់ចំណុចចំណងជើង ។

**៦:១–៣** គោលបំណងទី១ក្នុងសេចក្ដីអធិស្ឋាននេះ គឺចង់ឱ្យព្រះអម្ចាស់ទ្រង់ផ្តល់សេចក្ដីមេត្តារបស់ទ្រង់ ។ ទោះបីជាព្រះយេហូវ៉ាទ្រង់បានបណ្ដាលឱ្យគាត់មានជំងឺ ជាការបន្ទោសដល់គាត់ដោយព្រោះអំពើបាបដែលគាត់ប្រព្រឹត្តក៏ដោយ (មើល ៣២:៣–៥ ៣៨:១–៨,១៧–១៨) ក៏ដាវីឌទ្រង់បានទូលសូម

ក្នុងកាលដែលទ្រង់ខ្ញាល់[ក]
ហើយកាលណាទ្រង់មានព្រះហឫទ័យឃោរឃៅនោះ
សូមកុំផ្ចាញ់ផ្ចាលទូលបង្គំឡើយ
២ ឱព្រះយេហូវ៉ាអើយ សូមប្រោសមេត្តាដល់ទូលបង្គំផង[ខ]
ដ្បិតទូលបង្គំខ្សោយ[គ]
ឱព្រះយេហូវ៉ាអើយ សូមប្រោសទូលបង្គំ[ឃ]
ឱ្យជាដ្បិតឆ្អឹងទូលបង្គំញ័ររន្ធត់[ង]
៣ ព្រលឹងទូលបង្គំក៏ថប់បារម្ភជាខ្លាំងដែរ[ច]
ឯទ្រង់ ឱព្រះយេហូវ៉ាអើយ តើដល់កាលណា[ឆ]
៤ ឱព្រះយេហូវ៉ាអើយ សូមទ្រង់យាងមកវិញ[ជ]
ហើយប្រោសព្រលឹងទូលបង្គំឱ្យរួច
សូមទ្រង់ជួយសង្គ្រោះទូលបង្គំ
ដោយយល់ដល់សេចក្ដីសប្បុរសនៃទ្រង់[ឈ]
៥ ដ្បិតក្នុងមរណភាព គ្មានសេចក្ដីនឹកចាំពីទ្រង់ទៀតឡើយ
នៅស្ថានឃុំព្រលឹងមនុស្សស្លាប់នោះតើអ្នកណានឹង

**៦:១** ក ទដ ២:៥ **៦:២** ខ ទដ ៤:១ ២៦:១ យរ ៣:១២ ១២:១៥ ៣១:២០ គ ទដ ៦១:២ ៧៧:៣ ១៤២:៣ អស ៤០:៣១ យរ ៨:១៨ អគ ២១:៧ ឃ ជន ១២:១៣ ង ទដ ២២:១៤ ៣១:១០ ៣២:៣ ៣៨:៣ ៤២:១០ ១០២:៣

**៦:៣** ច យប ៧:១១ ទដ ៣១:៧ ៣៨:៨ ៥៥:៤ យហ ១២:២៧ រម ៩:២ ២កថ ២:៤ ឆ ១សយ ១:១៤ ១ពវ ១៨:២១ ទដ ៤:២ ៨៩:៤៦ អស ៦:១១ យរ ៤:១៤ ហព ១:២ សក ១:១២ **៦:៤** ជ ទដ ២៥:១៦ ៣១:២ ៦៩:១៦ ៧១:២ ៨៦:១៦ ៨៨:២ ១០២:២ ១១៩:១៣២ ឈ ទដ ១៣:៥ ៣១:១៦ ៧៧:៨ ៨៥:៧ ១១៩:៤១ អស ៥៤:៨,១០

កុំឱ្យព្រះអម្ចាស់ព្រះយេហូវ៉ាទ្រង់ខ្ញាល់ និងដាក់ទោសទាំងស្រុងចំពោះកំហុសដ៏ធ្ងន់របស់គាត់ឡើយ ពីព្រោះគាត់បានដឹងថាព្រះទ្រង់នឹងបញ្ជូនសេចក្ដីស្លាប់មក (មើល ខ.៥,១៣០:៣) ។

**៦:១** ការចាប់សេចក្ដីអធិស្ឋានក្នុងខនេះ ក៏មានការប្រហាក់ប្រហែលគ្នានឹងសេចក្ដីអធិស្ឋាននៅក្នុង ជំពូក ៣៨ ដែរ ។ *បន្ទោស... កុំផ្ចាញ់ផ្ចាល* នៅក្នុងឃ្លានេះចង់និយាយថា ស្ដេចដាវីឌទូលសូមកុំឱ្យព្រះទ្រង់ស្ដីបន្ទោសនិងផ្ចាញ់ផ្ចាល់ (មើល ៣៩:១១ និងការពន្យល់ ៣:៧) ។ *ខ្ញាល់... ឃោរឃៅ* មើលការពន្យល់ ២:៥ ។

**៦:២** *ឆ្អឹង* ឆ្អឹងគឺជាអវៈយវៈ១នៅខាងក្នុងខ្លួនមនុស្ស ហើយឆ្អឹងដែលគេនិយាយនៅពេលនេះ គឺសំដៅលើរូបកាយទាំងមូលតែម្ដង ។

**៦:៣** *ព្រលឹង* ព្រលឹងដែលនិយាយនៅត្រង់កន្លែងនេះមិនមែនជាទ្រង់ទ្រាយវិញ្ញាណ ដែលមានតួនាទីផ្សេងៗក្នុងរូបកាយមនុស្សនោះទេ ហើយក៏មិនមែនជា"ក្នុង"របស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងចាប់ផ្ដើម ។ *តើដល់កាលណា* សូមមើលសេចក្ដីផ្ដើមត្រង់ចំណុចផ្ទៃរឿងសំខាន់ៗចំណុចទី៤ ។ ការមិនចេះអត់ធ្មត់ និងការរអ៊ូរទាំងតែងតែមានឃើញនៅក្នុងសេចក្ដីអធិស្ឋានដែលអ្នកនិពន្ធគាត់បានអធិស្ឋានក្នុងព្រះគម្ពីរទំនុកដំកើង (ជាញឹកញាប់តែងតែឃើញមានពាក្យថា "តើដល់កាលណា" "ពេលណា" ឬ "ហេតុអ្វី") ។ ពាក្យនេះវាបានពណ៌នាបង្ហាញពីសេចក្ដីទុក្ខព្រួយ ដែលមិនបានស្រាកស្រាន្តដោយគេមានភាពក្លាហានចំបាច់ជាមួយព្រះ ដោយផ្អែកលើគ្រឹះនៃទំនាក់ទំនងរបស់ពួកគេជាមួយព្រះអម្ចាស់ និងសេចក្ដីសញ្ញានៃសេចក្ដីសុចរិតរបស់ព្រះអម្ចាស់ (មើលការពន្យល់ ៤:១) ។

**៦:៤–៥** នៅក្នុងខទាំងនេះ ស្ដេចដាវីឌទ្រង់អធិស្ឋានទូលសូមឱ្យព្រះយេហូវ៉ាទ្រង់បានរំដោះគាត់ចេញពីសេចក្ដីស្លាប់ ។

**៦:៤** *សេចក្ដីសប្បុរស* ក្នុងព្រះគម្ពីរភាសាហេព្រើរ ឃ្លានេះចង្អុលប្រាប់ពីមេត្រីចិត្តដ៏ជ្រៅ ជាពិសេសអាចនឹងឈប់សម្រាកនៅពេលណាដែលគេត្រូវការ ។ ជានិច្ចកាលនៅក្នុងសញ្ញាចាស់គេតែងតែនិយាយពី "សេចក្ដីសប្បុរស"របស់ព្រះ ពីព្រោះវាជាការសង្ខេបសេចក្ដីសញ្ញារបស់ព្រះដែលព្រះអម្ចាស់បានតាំងសញ្ញាជាមួយគេ ដើម្បីបង្ហាញឱ្យពួកអ៊ីស្រាអែលបានដឹង (មើល ចទ ៧:៩,១២) រួមទាំងដាវីឌ និងជំនួរវង្សរបស់គាត់ទៀតផង (មើល ៨៩:២៤,២៨,៣៣,៤៩ ២សយ ៧:១៥ អស ៥៥:៣) ។

**៦:៥** នៅក្នុងខនេះស្ដេចដាវីឌគាត់បាននិយាយថា ការសរសើរដំកើងដល់ព្រះ គឺមានតែនៅត្រង់បង្គោលស្នឹងប៉ុណ្ណោះ ។ គាត់ចង់មានន័យថា មានតែពួកមនុស្សដែលនៅរស់ទេ ដែលនឹកចាំពីសេចក្ដីសប្បុរសនិងសរសើរដំកើងពីការរំដោះរបស់ព្រះបាន មនុស្សដែលស្លាប់ទៅហើយគេមិនអាចធ្វើបានឡើយ ។ ពួកកូនចៅអ៊ីស្រាអែលគេតែងតែនិយាយពីសេចក្ដីស្លាប់ដែលគេបានឃើញ ដែលសេចក្ដីស្លាប់នេះជាការផ្ទុយនឹងជីវិត ។ ការរស់ពីស្លាប់ឡើងវិញមិនទាន់ក្លាយជាបទពិសោធន៍មួយ របស់ពួកគេក្នុងការពិសោធន៍ជាមួយព្រះអម្ចាស់ឡើយ ឯស្ថានឃុំព្រលឹងមនុស្សស្លាប់ក៏មិនអាចរត់គេចចេញពីព្រះភ័ក្ត្រព្រះអម្ចាស់បានឡើយ (មើល ទដ ១៣៩:៨) ប៉ុន្តែស្ថានឃុំព្រលឹងមនុស្សស្លាប់ គឺគ្រាន់តែបង្ហាញពីលក្ខណខ័ណ្ឌនៃសេចក្ដីស្លាប់របស់ពួកអ្នកដែលស្រឡាញ់ព្រះថា ការស្លាប់របស់គេមិនច្បាស់លាស់ឡើយ (ភស្តុតាងក្រៅព្រះគម្ពីរ ដែលគេបានពីតំបន់ក្បែរមជ្ឈឹមបូព៌ាកាលពីសម័យបុរាណ១បានបង្ហាញពីគំនិតទូទៅថា ហេតុការណ៍អាក្រក់ និងអំពើអាក្រក់ផ្សេងៗ គឺរៀបចំទុកសម្រាប់ពួកអ្នកថ្វាយបង្គំរូបព្រះ ប៉ុន្តែ ឯសេចក្ដីស្លាប់បន្តបង្ហាញពីស្រមោល នៃការរងទុក្ខដ៏សោកសង្រេងនៅពេលដែលព្រះទ្រង់ជំនុំជម្រះ លើកទី២បន្ទាប់ការស្លាប់លើកទី១) ។ អ្នកនិពន្ធនៅក្នុងសញ្ញាចាស់គាត់បានដឹងថា ព្រះអម្ចាស់ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បានបង្កើតមនុស្សមក ដើម្បីឱ្យគេមានជីវិតរស់នៅ ដូចច្នោះមានន័យថាបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ចំពោះរាស្ត្ររបស់ទ្រង់ គឺឱ្យពួកគេបានជីវិតមានអំណាចលើសេចក្ដីស្លាប់ ពីព្រោះព្រះអម្ចាស់ទ្រង់មានអំណាចលើសេចក្ដីស្លាប់ ។ មិនតែប៉ុណ្ណោះសោតពួកគេក៏បានដឹងទៀតថា សេចក្ដីស្លាប់គឺជាជោគវាសនារបស់មនុស្សគ្រប់គ្នា សេចក្ដីស្លាប់គឺវេលាមួយដ៏ប្រសើរត្រឹមត្រូវសម្រាប់ពួកអ្នក ដែលស្រឡាញ់ព្រះបានសម្រាកអស់កល្បជានិច្ចមួយព្រះអម្ចាស់ប្រកបដោយភាពសុខសាន្តត្រាណ (សូមមើល លប ១៥:១៥ ២៥:៨ ៤៧:៣០ ៤៩:៣៣ ១ពវ ២:២) ។ សេចក្ដីស្លាប់គឺជាព្រះពរមួយសម្រាប់ពួកអ្នកសុចរិត ពីព្រោះបានធ្វើឱ្យគេរួចចេញពីសេចក្ដីអាក្រក់ដ៏ក្រាសក្រៃដែលនឹងមក (មមើលក្នុង ២ពវ ២២:២០ អស ៥៧:១–២) ។ មួយវិញទៀតសេចក្ដីស្លាប់របស់មនុស្សសុចរិត គឺមានភាពប្រសើរជាងសេចក្ដីស្លាប់របស់ពួកមនុស្សអាក្រក់ (មើល ជន ២៣:១០) ។ ការនេះហាក់បីដូចជាចង់និយាយថា សេចក្ដីស្លាប់មិនមែនជាចុងបញ្ចប់ នៃសេចក្ដីសង្ឃឹមរបស់ពួកមនុស្សសុចរិតឡើយ (មើល ១៦:៩–១១ ១៧:១៥ ៤៩:១៤–១៥ ៧៣:២៤ និងការពន្យល់ ៥:២៤) ។ ប៉ុន្តែនៅពេលដែលអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បានទូលសូមឱ្យព្រះអម្ចាស់ រក្សាទុកជីវិតរបស់ពួកគេ វាគឺជាសេចក្ដីស្លាប់មួយដែលគេធ្លាប់ឃើញ ដែលសេចក្ដីស្លាប់នោះជាឫសគល់នៃ

សរសើរដល់ទ្រង់[ញ]
៦ទូលបង្គំអស់កំឡាំង[ដ] ដោយថ្ងូរ[ឋ]
ដំណេកទូលបង្គំត្រូវទទឹកដោកទាល់ភ្លឺ[ឌ]
ទឹកភ្នែកទូលបង្គំហូរស្រោចដាបគ្រែ[ឍ]
៧ភ្នែកទូលបង្គំស្រវាំងទៅ[ណ] ដោយថប់ព្រួយ
ក៏ទៅជាចាស់ ដោយព្រោះពួកដែលតតាំងនឹងទូលបង្គំ ។
៨នែ អស់អ្នកដែលប្រព្រឹត្តអំពើទុច្ចរិតអើយ[ត]
ចូរថយចេញពីអញទៅ[ថ]
ដ្បិតព្រះយេហូវ៉ាទ្រង់បានស្តាប់សំឡេងអញយំ
៩ព្រះយេហូវ៉ាបានស្តាប់ពាក្យដែលអញទូលអង្វរ ហើយ[ទ]
ព្រះយេហូវ៉ាទ្រង់នឹងទទួលពាក្យដែលអញអធិស្ឋានផង
១០អស់ពួកខ្មាំងសត្រូវរបស់អញនឹងត្រូវអៀនខ្មាស[ធ]
ហើយថប់បារម្ភជាខ្លាំង គេនឹងថយចេញ
ព្រមទាំងមានសេចក្តីខ្មាសភ្លាម១រំពេច[ន] ។

បទទំនួញ[ក]នៃស្តេចដាវីឌ ដែលទ្រង់
ច្រៀងថ្វាយព្រះយេហូវ៉ា ពីរឿងគុស ជាពូជពង្សបេនយ៉ាមីន ។

**៧** ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ
ទូលបង្គំយកទ្រង់ជាទីជ្រកកោន[ខ]
សូមទ្រង់ជួយសង្គ្រោះទូលបង្គំ[គ]
ឲ្យរួចពីអស់អ្នកដែលដេញតាមទូលបង្គំផង[ឃ]
២ក្រែងគេហែកព្រលឹងនៃទូលបង្គំ
ដូចជាសិង្ហ[ង]ព្រមទាំងហែកឲ្យខ្ទេចខ្ទីផង
ក្នុងកាលដែលគ្មានអ្នកណានឹងដោះ[ច]ឲ្យរួច
៣ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ
បើសិនជាទូលបង្គំបាន ធ្វើដូច្នេះ
គឺបើមានអំពើទុច្ចរិតណានៅដៃទូលបង្គំ[ឆ]
៤បើទូលបង្គំធ្វើការអាក្រក់
ស្នងដល់អ្នកណាដែលមេត្រីនឹងទូលបង្គំ
បើទូលបង្គំបានរឹបជាន់អ្នកដែលតតាំងនឹងទូលបង្គំ
ដោយឥតហេតុ[ជ]
៥នោះសូមឲ្យខ្មាំងសត្រូវដេញតាមព្រលឹងទូលបង្គំទាន់[ឈ] ចុះ

**៦:៥** ញ ទដ ៣០:៩ ៨៨:១០–១២ ១១៥:១៧ សស ៩:១០ អស ៣៨:១៨ **៦:៦** ដ ពច ៨:៥ ឋ យប ៣:២៤ ២៣:២ ទដ ១២:៥ ៧៧:៣ ១០២:៥ បទ ១:៨,១១,២១,២២ ឌ យប ១៦:១៦ ឍ យប ៧:៣ លក ៧:៣៨ កច ២០:១៩ **៦:៧** ណ យប ១៦:៨ ទដ ៣១:៩ ៦៩:៣ ១១៩:៨២ អស ៣៨:១៤ **៦:៨** ត ទដ ១១៩:១១៥ ១៣៩:១៩ ថ ទដ ៥:៥ មថ ៧:២៣ **៦:៩** ទ ទដ ២៨:៦ ១១៦:១ **៦:១០** ធ ២ពវ ១៩:២៦ ន ទដ ៤០:១៤ **៧:ចំណងជើង** ក ហាព ៣:១ **៧:១** ខ ទដ ២:១២ ១១:១ ៣១:១ គ ទដ ៣:៧ ឃ ទដ ៣១:១៥ ១១៩:៨៦ ១៥៧:១៦១ **៧:២** ង លប ៤៩:៩ វវ ៤:៧ ច ទដ ៣:២ ៧១:១១ **៧:៣** ឆ អស ៥៩:៣ **៧:៤** ជ ទដ ៣៥:៧,១៩ សភ ២៤:២៨ **៧:៥** ឈ នក ១៥:៩

ការជិទាស់ប្រឆាំងដើម្បីឲ្យបានជីវិត ដូច្នេះហើយទើបពួកគេអធិស្ឋានទូលសូមឲ្យព្រះទ្រង់រំដោះពួកគេ ។

**៦:៦–៧** នៅក្នុងខនេះ ស្តេចដាវីឌទ្រង់មានការថប់បារម្ភណ៍នៅពេលយប់ ពីព្រោះគាត់នៅតែមានជំងឺប្រចាំកាយ និងពួកខ្មាំងសត្រូវគេនៅតែមើលងាយ ។

**៦:៦** *ទូលបង្គំអស់កំឡាំងដោយថ្ងូរ* ឃ្លានេះគឺជាចំណុចស្នូលនៅក្នុងកណ្ឌកំនាព្យ ដូច្នេះហើយ ទើបអ្នកនិពន្ធលើកមកនិយាយទើបឲ្យយើងមានអារម្មណ៍រំភើបក្នុងសេចក្តីអធិស្ឋាននេះ (មើលការពន្យល់ ៨:៤ ២១:៧ ២៣:៤ ៣៤:៨–១៤ ៤២:៨ ៤៧:៥–៦ ៤៨:៨ ៥៤:៤ ៧១:១៤ ៧៤:១២ ៧៦:៧ ៨២:៥ក ៨៦:៩ ៩២:៨ ៩៧:៧ ១១៣:៥ ១៣៨:៤–៥ ១៤១:៥ និងសេចក្តីផ្តើម ត្រង់ចំណុចលក្ខណៈអក្សរសាស្ត្រ) ។

**៦:៧** *ភ្នែកទូលបង្គំស្រវាំងទៅ . . . ក៏ទៅជាចាស់* នៅក្នុងភាសាដែលប្រើក្នុងសញ្ញាចាស់បាននិយាយថា ភ្នែកអត់ខ្សោយគឺបណ្តាលមកពីកម្លាំងអន់ (សូមមើល ៣៨:១០ ១សយ ១៤:២៧,២៩ និងការពន្យល់ រយ ១៤:៦) បណ្តាលមកពីសេចក្តីទុក្ខព្រួយ (មើល ៣១:៩ ៨៨:៩ យប ១៧:៧ បទ ២:១១) ដោយការល្ងើយ (មើល ៦៩:៣ ១១៩:៨២,១២៣ ចទ ២៨:៣២ អស ៣៨:១៤) ។ *ដោយព្រោះពួកដែលតតាំងនឹងទូលបង្គំ* មើលការពន្យល់ ៥:៩ ។

**៦:៨–១០** នៅក្នុងចុងបញ្ចប់នៃសេចក្តីអធិស្ឋាន ស្តេចដាវីឌមានទំនុកចិត្តលើព្រះអម្ចាស់យ៉ាងខ្លាំង ចំពោះពាក្យដែលគាត់អំពាវនាវ (មើលការពន្យល់ ៣:៨) ។

**៦:១០** នៅក្នុងខនេះចង់និយាយថា នៅក្នុងគ្រាដែលព្រះអម្ចាស់លើកស្តេចដាវីឌឡើងវិញ នោះពួកខ្មាំងសត្រូវរបស់ទ្រង់នឹងទទួលភាពអាម៉ាសមុខ ។

**ទដជំពូក៧** នៅក្នុងជំពូកនេះ ស្តេចដាវីឌទ្រង់អធិស្ឋានអំពាវនាវសូមសេចក្តីយុត្តិធម៌មកពីព្រះ ពេលដែលពួកខ្មាំងសត្រូវបៀតបៀនគាត់ ។

**ជំពូក៧ចំណងជើង** *បទទំនួញ* ពាក្យនេះមានឃើញប្រើតែកន្លែងនេះប៉ុណ្ណោះ (ប៉ុន្តែសូមមើលទម្រង់ពហុវចនៈនៃពាក្យនេះនៅក្នុង ហាប ៣:១) ។ *គុស* គ្មាននរណាបានដឹងពីរឿងពិតប្រាកដរបស់គុសឡើយ ប៉ុន្តែគ្រាន់តែដឹងថាគេជាពូជពង្សរបស់បេនយ៉ាមីនប៉ុណ្ណោះ ។ ប្រហែលគុសគាត់គឺជាអ្នកដែលបានជួយគាំទ្រដល់ស្តេចសូល ក្នុងការតាមសម្លាប់ស្តេចដាវីឌ ។ នៅក្នុងចំណងជើងនេះរំឭកដល់ការដែលស្តេចសូល ព្យាយាមសម្លាប់ស្តេចដាវីឌ (សូមមើលក្នុងសេចក្តីផ្តើម ត្រង់ចំណុចអ្នកនិពន្ធ និងចំណងជើង) ។

**៧:១–២** នៅក្នុងខទាំងនេះស្តេចដាវីឌនៅបន្តទូលសូមដល់ព្រះ នូវអ្វីដែលទ្រង់ជួបប្រទះកាលពីគ្រាមុន ។

**៧:២** *ដូចជាសិង្ហ* ក្នុងនាមជាអ្នកគង្វាលក្មេងវ័យ ស្តេចដាវីឌតែងតែជួបប្រទះការវាយប្រហារពីសំណាក់សត្វសិង្ហ (មើល ១សយ ១៧:៣–៣៥) ។ នៅក្នុងព្រះគម្ពីរទំនុកដំកើង នៅពេលដែលពួកខ្មាំងសត្រូវវាយប្រហារគេតែងតែប្រៀបធៀបការវាយប្រហារ ជាការវាយប្រហាររបស់សត្វសាហាវជាពិសេសសត្វសិង្ហ (មើល ១០:៩ ១៧:១២ ២២:១២–១៣,១៦,២០–២១ ៣៥:១៧ ៥៧:៤ ៥៨:៦ ១២៤:៦) ។

**៧:៣–៥** នៅក្នុងខនេះស្តេចដាវីឌ ទ្រង់បានប្តឹងពីសេចក្តីសុចរិតរបស់គាត់នៅចំពោះព្រះ គាត់មិនបានបណ្តោយឲ្យខ្មាំងសត្រូវរបស់គាត់មើលងាយ ហើយវាយប្រហារគាត់ដោយគ្មានមូលហេតុ តាមតែក្បាលវ៉ាលចិត្តពួកគេនោះឡើយ ។

**៧:៥** *ទូលបង្គំ* នៅក្នុងភាសាអក្សរសាស្ត្រគេនិយាយ “កិត្តិយសនៃទូលបង្គំ” ការនិយាយបែបនេះ គឺជារបៀបដែលគេនិយាយសំដៅលើចំណុចស្នូលនៃការចាប់ផ្តើមរបស់អ្នកណាម្នាក់ (សូមមើល ១៦:៩ ៣០:១២ ៥៧:៨ ១០៨:១ និងការពន្យល់) ។

អើ សូមឱ្យគេញាំញីជីវិតទូលបង្គំចុះដល់ដី[ញ]
ហើយបង្អាប់យសទូលបង្គំ នៅក្នុងធូលីដីផង[ដ]។ បង្អង់
៦ ឱព្រះយេហូវ៉ាអើយ សូមតើនឡើង[ឋ]
ដោយសេចក្តីខ្ញាល់របស់ទ្រង់ សូមងើបឡើង
ទាស់នឹងសេចក្តីឃោរឃៅរបស់ពួកតតាំងនឹងទូលបង្គំ[ឌ]
សូមទ្រង់តើនឡើង[ឍ]ជួយទូលបង្គំ
ដោយសេចក្តីយុត្តិធម៌ដែលទ្រង់បានបង្គាប់ហើយ
៧ យ៉ាងនោះ ជំនុំនៃបណ្តាជនទាំងឡាយ
នឹងមកនៅព័ទ្ធជុំវិញទ្រង់ សូមទ្រង់ឡើងលើទីខ្ពស់[ណ]
ពីលើគេវិញ
៨ ព្រះយេហូវ៉ាទ្រង់តែងជំនុំជំរះ[ត]បណ្តាជនទាំងឡាយ
ឱព្រះយេហូវ៉ាអើយ សូមទ្រង់ជំនុំជំរះទូលបង្គំ
តាមសេចក្តីសុចរិត[ថ]
និងសេចក្តីទៀតត្រង់[ទ]របស់ទូលបង្គំផង[ធ]
៩ ឱសូមឱ្យការអាក្រក់របស់មនុស្សល្មើសបានផុតទៅ[ន]
តែសូមតាំង មនុស្សសុចរិតឱ្យខ្ជាប់ខ្ជួនឡើង
ដ្បិតព្រះដ៏សុចរិត[ប]ទ្រង់សាកលចិត្តថ្លើម[ផ]
១០ ខែល[ព]នៃទូលបង្គំនៅជាមួយនឹងព្រះដែលទ្រង់ជួយ
សង្គ្រោះមនុស្សមានចិត្តទៀតត្រង់[ភ]
១១ ព្រះទ្រង់ជាចៅក្រមសុចរិត[ម] អើ
ទ្រង់ជាព្រះដែលមានសេចក្តីខ្ញាល់[យ]
ចំពោះមនុស្សអាក្រក់រាល់តែថ្ងៃ
១២ បើអ្នកណាមិនប្រែចិត្ត[រ] នោះទ្រង់នឹងសំលៀងដាវ[ល]
ទ្រង់បានយឹតដំឡើងធ្នូជាស្រេច[វ]
១៣ ទ្រង់ក៏រៀបចំគ្រឿងដែលសំរាប់សំឡាប់គេ
ទុករួចហើយទ្រង់ធ្វើព្រួញឆេះ ទុកសំរាប់បាញ់[ស]។
១៤ មើលគេឈឺនឹងសំរាលការទុច្ចរិតរបស់គេក៏មានផ្ទៃ
ពោះជាសេចក្តីអាក្រក់
ហើយសំរាល[ហ]ចេញជាសេចក្តីកំភូត
១៥ គេបានជីកធ្វើរណ្តៅ
ហើយខ្លួនគេបានធ្លាក់ទៅក្នុងរណ្តៅ[ឡ] ដែលគេធ្វើនោះ[អ]
១៦ សេចក្តីអាក្រក់របស់គេ នឹងត្រឡប់មកលើក្បាលគេវិញ
ហើយសេចក្តីច្រឡោតរបស់គេ នឹងចុះមកលើក្រយៅ
ក្បាលគេដែរ
១៧ ខ្ញុំនឹងសរសើរដល់ព្រះយេហូវ៉ា តាមសេចក្តីសុចរិត[ក]
ទ្រង់ ហើយនិងច្រៀងដំកើង[ខ]ថ្វាយព្រះនាមព្រះយេហូវ៉ាដ៏

**៧:៥** ញ ២សយ ២២:៤៣ ២ពវ ៩:៣៣ អស ១០:៦ បទ ៣:១៦ ដ យប ៧:២១ **៧:៦** ឋ ២របា ៦:៤១ ឌ ទដ ១៣៨:៧ ឍ ទដ ៣៥:២៣ ៤៤:២៣ **៧:៧** ណ ទដ ៦៨:១៨ **៧:៨** ត ១រប ១៦:៣៣ ថ ១រប ២៦:២៣ ទដ ១៨:២០ ទ លប ២០:៥ ធ លប ៣:៥ ជន ២៤:១៦ មក ៥:៧ **៧:៩** ន ទដ ៣៧:២៣ ៤០:២ ប យរ ១១:២០ ផ ១រប ២៨:៩ ទដ ២៦:២ វវ ២:២៣ **៧:១០** ព ទដ ៣:៣ ភ យប ៣៣:៣ **៧:១១** ម លប ១៨:២៥ ទដ ៩:៨ ៦៧:៤ ៧៥:២ ៩៦:១៣ ៩៨:៩ អស ១១:៤ យរ ១១:២០ យ ចទ ៩:៨ **៧:១២** រ អគ ៣:១៩ ៣៣:៩ ល ចទ ៣២:៤១ វ ២សយ ២២:៣៥ ទដ ២១:១២ អស ៥:២៨ ១៣:១៨ **៧:១៣** ស ទដ ១១:២ ១៨:១៤ ៦៤:៣ **៧:១៤** ហ អស ៥៩:៤ យក ១:១៥ **៧:១៥** ឡ ទដ ៣៥:៧,៨ ៤០:២ ៩៤:១៣ សភ ២៦:២៧ អ យប ៤:៨ **៧:១៧** ក ទដ ៥:៨ ខ ២របា ៣១:២ រម ១៥:១១ ហព ២:១២

**៧:៦–៩** នៅពេលនេះ ស្តេចដាវីឌទូលសូមឱ្យគ្រប់ទាំងអស់នៃចៅក្រមដែលនៅក្នុងលោកិយនេះ ឱ្យកាត់ក្តីចំពោះសាលក្រមរបស់គាត់នៅចំពោះពួកបណ្តាជន សូមឱ្យមានភាពយុត្តិធម៌ត្រឹមត្រូវ ។
**៧:៦** *សូមតើនឡើង... សូមងើបឡើង* មើលការពន្យល់ ៣:៧ ។ *សេចក្តីខ្ញាល់* មើល ខ.១១ និងការពន្យល់ ២:៥ ។ *សូមតើនឡើង* ព្រះយេហូវ៉ាជាព្រះនៃយើងទ្រង់មិនមែនជាព្រះដែលផ្ទំលក់នោះឡើយ (មើល ១២១:៤) រីឯមនុស្សអាក្រក់ និងពួកអ្នកដែលជិះជាន់គេបានអំពាវនាវដល់ព្រះអម្ចាស់ជាការបែបអសាឥតការ (ដូចដែលគេធ្វើជាមួយព្រះបាលដែរ មើល ១ពវ ១៨:២៧) ។ ប៉ុន្តែសេចក្តីអធិស្ឋានជាបន្ទាន់ របស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបានពណ៌នាពីការថប់បារម្ភណ៍ របស់ពួកគេដោយមិនអត់ធ្មត់ចំពោះដំណោះស្រាយរបស់ព្រះ (មើល ៨០:២ ៧៨:៦៥ អស ៥១:៩) ។
**៧:៨** *សេចក្តីសុចរិតរបស់ទូលបង្គំ* សូមមើល ខ.៣–៥ ។ *សេចក្តីទៀងត្រង់របស់ទូលបង្គំ* សូមមើលការពន្យល់ ១៥:២ ។
**៧:៩** *សុចរិត* មើលការពន្យល់ ៤:១ ។ *ចិត្តថ្លើម* តាមភាសាអក្សរសាស្ត្រគេនិយាយថា "ចិត្ត និង អង្គញ់" ។ ពួកជនជាតិអ៊ីស្រាអែលគេប្រើពាក្យទាំងនេះជាសទិសន័យដែលមានឋានៈស្មើគ្នា (ប៉ុន្តែជាញឹកញាប់ "ចិត្ត") គឺសំដៅលើចំណុចកណ្តាលនៃសតិស្មារតីរបស់អ្នកណាម្នាក់ (មើលការពន្យល់ ៤:៧) ។ ការ "សាកលចិត្តថ្លើម" គឺជាការសាកល្បងរបស់ព្រះក្នុងការស្វែងរកចរិតលក្ខណៈ ដែលលាក់កំបាំងរបស់អ្នកណាម្នាក់ (មើល យរ ១១:២០ ១៧:១០ ២០:១២) ។ *សុចរិត* មើលការពន្យល់ ១:៥ ។
**៧:១០–១៣** នៅក្នុងខនេះស្តេចដាវីឌគាត់មានទំនុកចិត្តថា ព្រះយេហូវ៉ាទ្រង់តបឆ្លើយ និងស្តាប់ពាក្យសំរែកដែលគាត់អធិស្ឋាន (មើលការពន្យល់ ៣:៨) ។
**៧:១០** *ខែល* មើលការពន្យល់ ៣:៣ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។
**៧:១១** *រាល់តែថ្ងៃ* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអង្គទ្រង់នឹងជំនុំជម្រះមនុស្សអាក្រក់រាល់ថ្ងៃដោយមិនបានរង់ចាំដល់ថ្ងៃអនាគតឡើយ ។
**៧:១២–១៣** *ដាវ... ធ្នូ... ព្រួញ* វត្ថុទាំង៣នេះគឺជាអាវុធរបស់មេទ័ពនៃស្ថានសួគ៌ប្រើដើម្បីការពារប្រជារាស្ត្ររបស់ព្រះ (មើល នក ១៥:៣ និងការពន្យល់) ហើយក៏ប្រើវត្ថុនោះដើម្បីជំនុំជម្រះផងដែរ ។
**៧:១២** *ធ្នូ* សូមមើលការពន្យល់ លប ៩:១៣ ។
**៧:១៤–១៦** នៅក្នុងខទាំងនេះ ស្តេចដាវីឌបានលើកទឹកចិត្តខ្លួនឯងថា ក្រោមការគ្រប់គ្រងរបស់ព្រះអម្ចាស់នោះ "ពួកខ្មាំងសត្រូវមិនអាចធ្វើអ្វីបានឡើយ" ។
**៧:១៥** *ជីកធ្វើរណ្តៅ* ពាក្យនេះគឺជាការប្រៀបធៀប ដែលគេយកចេញពីពួកអ្នកប្រមាញ់ ។ រណ្តៅគេប្រើដើម្បីជាអន្ទាក់ចាប់សត្វ (សូមមើល ៩:១៥ និងការពន្យល់) ។
**៧:១៧** នៅក្នុងខនេះគឺជាការប្តេជ្ញារបស់ស្តេចដាវីឌ ក្នុងការសរសើរដំកើងដល់ព្រះយេហូវ៉ា ។ ភាគច្រើននៃសេចក្តីអធិស្ឋានដែលមាននិយាយនៅក្នុងព្រះគម្ពីរទំនុកដំកើង គឺសុទ្ធតែមាននិយាយពីការប្តេជ្ញាចិត្តពិសេសហើយសង្ឃឹមថា ព្រះទ្រង់នឹងឆ្លើយតបចំពោះសេចក្តីអធិស្ឋាននោះ ។ ពួកគេបានឆ្លុះបញ្ចាំងពីការស្រឡាញ់ព្រះរបស់ពួកអ៊ីស្រាអែល ដែលសេចក្តី

ខ្ពស់បំផុត[គ] ។

ទំនុកនៃស្ដេចដាវីឌ ដែលទ្រង់
លើកឱ្យមេភ្លេង ត្រូវលេងដោយប្រដាប់ភ្លេងគីធីត ។
**៨** ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់នៃយើងខ្ញុំអើយ
ព្រះនាម[ក] ទ្រង់ប្រសើរ គ្រប់លើផែនដីយ៉ាងណាទៅ
ទ្រង់បានដំកល់សិរីល្អ[ខ] ទ្រង់ទុកនៅលើស្ថានសួគ៌[គ]
២ ទ្រង់បានតាំងឱ្យមានសេចក្ដីសរសើរ[ឃ]
ដោយសារមាត់កូនក្មេង និងកូនដែលនៅបៅដោះ
ដោយព្រោះពួកតតាំងនឹងទ្រង់
ដើម្បីនឹងធ្វើឱ្យពួកខ្មាំងសត្រូវ[ង]
ព្រមទាំងពួកសងសឹកបានស្ងៀមនៅ
៣ កាលណាទូលបង្គំពិចារណាមើលផ្ទៃមេឃ[ច]
ជាការដែលព្រះហស្ត ទ្រង់បានធ្វើ[ឆ] គឺទាំងខែ និងផ្កាយ[ជ]
ដែលទ្រង់បានប្រតិស្ឋានទុក
៤ នោះតើមនុស្សជាអ្វី ដែលទ្រង់នឹករឭកដល់គេ
ហើយកូនមនុស្សផង ដែលទ្រង់ប្រោសដូច្នេះ[ឈ]
៥ ដ្បិតទ្រង់បានធ្វើឱ្យគេទាបជាងពួកទេវតាតែបន្តិចទេ[ញ]
ក៏បានបំពាក់សិរីល្អ និងកេរ្ដិ៍ឈ្មោះឱ្យ ទុកជាមកុដ[ដ]
៦ ទ្រង់បានតាំងគេ ឱ្យត្រួត[ឋ] លើអស់ទាំងការនៃព្រះហស្ត
ទ្រង់[ឌ]
ក៏បានបញ្ចុះបញ្ចូលគ្រប់ទាំងអស់ឱ្យនៅក្រោមជើងគេ[ឍ,ណ]
៧ គឺអស់ទាំងចៀម និងគោ[ត] អើ ទាំងសត្វព្រៃផង[ថ]
៨ អស់ទាំងសត្វហើរលើអាកាស និងត្រីនៅសមុទ្រ[ទ]

**៧:១៧** គ លប ១៤:១៨ **៨:១** ក ១របា ១៦:១០ ខ នក ១៥:១១ លក ២:៩ គ ទដ ៥៧:៥ ១០៨:៥ ១១៣:៤ ១៤៨:១៣ ហាព ៣:៣ **៨:២** ឃ មថ ២១:១៦ ង ទដ ១៤៣:១២ **៨:៣** ច លប ១៥:៥ ចទ ១០:១៤ ឆ នក ៨:១៩ ១របា ១៦:២៦ ២របា ២:១២ ទដ ១០២:២៥ ជ លប ១:១៦ ១កថ ១៥:៤១ **៨:៤** ឈ ១របា ២៩:១៤ **៨:៥** ញ លប ១:២៦ ដ ទដ ២១:៥ ១០៣:៤ **៨:៦** ឋ លប ១:២៨ ឌ យប ១០:៣ ទដ ១៩:១ ១០២:២៥ ១៤៥:១០ អស ២៦:១២ ២៩:២៣ ៤៥:១១ ហាព ១:១០ ឍ ហាព ២:៦–៨ ណ ១ពត ៥:៣ ១កថ ១៥:២៥,២៧ អភ១:២២ **៨:៧** ត លប ១៣:៥ ២៦:១៤ ថ លប ២:១៩ **៨:៨** ទ លប ១:២៦

អធិស្ឋានរបស់ពួកគេត្រូវតែមាននិយាយពីការរំដោះ ហើយចេញពីការត្រូវការរបស់ពួកគេ ។ ជានិច្ចកាលនៅក្នុងការសរសើរដំកើងគឺគេតែងតែនាំមកជាមួយនូវដង្វាយ នៃការអរគុណហើយក៏ទាក់ទងនឹងសេចក្ដីសង្គ្រោះរបស់ព្រះយេហូវ៉ាទ្រង់បានធ្វើចំពោះមុខពួកអ្នក ដែលចូលរួមសរសើរដំកើងនៅក្នុងរោងឧបោសថ (មើល ៥០:១៤–១៥,២៣ និងការពន្យល់ ៩:១) ។ *ព្រះនាមព្រះយេហូវ៉ា* មើលការពន្យល់ ៥:១១ ។ *ទីខ្ពស់បំផុត* មើលការពន្យល់ លប ១៤:១៩ ។

**ទំនុកដំកើងជំពូក៨** នៅក្នុងជំពូកនេះ គឺនិយាយពីការសរសើរដំកើងចំពោះព្រះអទិករ ចំពោះអធិបតេយ្យភាពរបស់ព្រះ ក្នុងការគ្រប់គ្រងលើទាំងអស នៃការបង្កើតរបស់ទ្រង់ ។ នៅក្នុង លប ជំពូក ១ (ជាពិសេស ខ.២៦–២៨) បានបង្ហាញឱ្យយើងឃើញច្បាស់ ពីភស្ដុងតាងនៃការបង្កើតរបស់ទ្រង់ ប៉ុន្តែស្ដេចដាវីឌបានសរសើរដំកើងពីអ្វី ដែលទ្រង់បានពិសោធន៍ជាក់ស្ដែងនាពេលនេះ (ប្រហែលតាមរយៈពន្លឺយប់នៅពេលដែលលាតសន្ធឹងលើផ្ទៃមេឃដ៏ធំធេង ។ មានរឿងរ៉ាវពិសេសៗ២ដែលគួរឱ្យសរសើរដំកើងចំពោះព្រះ (១). សិរីល្អនៃព្រះដែលបានចាំងជះដូចជាផ្កាយយ៉ាងច្រើននៅលើផ្ទៃមេឃ (២)... ។

**ជំពូក៨ត្រង់ចំណងជើង** *លើកឱ្យមេភ្លេង* មើលការពន្យល់ ទដ ជំពូក ៤ ត្រង់ចំណងជើង ។ *ត្រូវលេង* មើល ដទ ជំពូក៦ ត្រង់ចំណងជើង ។ *ប្រដាប់ភ្លេងគីធីត* មើល ទដ ជំពូក ៨១,៨៤ ត្រង់ចំណងជើងនៅក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះ ប្រហែលនិយាយសំដៅលើទាំងធុងគាបទំពាំងបាយជូរ ("បទចម្រៀងនៃអ្នកគាបទំពាំងបាយជូរ" ឬក៏និយាយសំដៅលើទីក្រុងកាថជាទីក្រុងរបស់ពួកភីលីស្ទីន (មើល ២សយ ១៥:១៨) ។

**៨:១ក** *ព្រះនាម* មើលការពន្យល់ ៥:១១ ។

**៨:១ខ–២** នៅក្នុងខ.នេះចង់និយាយថា សិរីល្អរបស់ព្រះយេហូវ៉ានៃពួកពលបរិវា បានតាំងនៅពេញពាសផ្ទៃមេឃបាន (រំឭក) តាំងឱ្យមានសេចក្ដីសរសើរដោយសារកូនក្មេង បានធ្វើឱ្យអំណាចនៃសេចក្ដីងងឹត ដែលទាស់ប្រឆាំងទ្រង់បាននៅស្ងៀម (មើល មថ ២១:១៦) ។

**៨:២** *សងសឹក* មើល ៤៤:១៦ ដែលនិយាយអំពីអ្នកដែលត្រូវទទួលការសងសឹក (មិនដូច ៩:១២ ទេ)។

**៨:៣–៥** នៅក្នុងខទាំងនេះចង់និយាយថា ភាពធំល្វឹងល្វើយ និងវិសាលភាពរបស់លំហរអាកាស គឺជាស្នាព្រះហស្តដែលព្រះបានបង្កើតដោយផ្ទាល់ (មើល ១៩:១–៦ ១០៤:១៩–២៣) ហើយបានរំឭកពីការអស្ចារ្យចំពោះម្នាក់ដែលបានបង្កើតពួកគេទាំងនោះមក (អ្វីដែលព្រះបង្កើតមក) សម្រាប់មនុស្សដែលព្រះបានបង្កើត ដែលថ្ងៃនេះគេមានជីវិតរស់នៅ ហើយថ្ងៃស្អែកត្រូវបាត់បង់ទៅវិញ (ស្លាប់) (មើល ១៤៤:៣–៤) ។ មើល យប ៧:១៧–២១ ដែលនិយាយពីការរអ៊ូរទាំរបស់លោកយ៉ូបថា ព្រះបានបង្កើតមនុស្សមកបែបគ្រោះថ្នាក់ ។

**៨:៣** *ព្រះហស្ត* សូមមើលការពន្យល់ នក ៨:១៩ ។

**៨:៤–៦** នៅក្នុងព្រះគម្ពីរ ហាព ២:៦–៨ បានដកស្រង់ចេញសិបធ្យូជីន (ការបកប្រែព្រះគម្ពីរសញ្ញាចាស់ទៅជាភាសាក្រិក របស់គ្រីស្ទបរិស័ទជំនាន់មុន) បាននិយាយសំដៅលើព្រះយេស៊ូវគ្រីស្ទថា ព្រះគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះជាអ្នកតំណាងឱ្យមនុស្ស និងជាអ្នកដែលធ្វើឱ្យមនុស្សបានទទួលសេចក្ដីសម្រាកពិតប្រាកដ ។ អ្នកនិពន្ធព្រះគម្ពីរហេព្រើរបានប្រើខទាំងនេះ ដើម្បីធ្វើបន្ទាល់ពីព្រះគ្រីស្ទយេស៊ូវ ហើយលោកប៉ុលក៏បាននិយាយដូចគ្នាពី ខ.៦ ដោយគាត់បានលើកមកនិយាយនៅ ១កថ ១៥:២៧ (មើល អភ ១:២២) ។

**៨:៤** *ជាអ្វី* ក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានន័យថា "យ៉ាងណា" (ក្នុង ខ.១,៩) និងការចាប់ផ្ដើមនៅក្នុងបន្ទាត់នេះ ដែលជាចំណុចសំខាន់ក្នុងជំពូកនេះ(មើលការពន្យល់ ៦:៦) ។ *នឹករឭក* នៅក្នុងភាសាសាស្ត្រពាក្យនេះ មានន័យថា "នឹកចាំ"(មើលការពន្យល់ លប ៨:១)។ *កូនមនុស្ស* ពាក្យនេះ គឺជាការបកប្រែចំៗមកពីព្រះគម្ពីភាសាហេព្រើរ ដែលគេប្រើនិយាយសំដៅលើពួកមនុស្សដែលព្រះបង្កើតមក(មើល ៨០:១៧ ១៤៤:៣ និងការពន្យល់ អគ ២:១) ។

**៨:៥** *ពួកទេវតា* ការអួតអាងពីពួកទេវតាដែលនៅជុំវិញព្រះយេហូវ៉ានៅ ឯនគរស្ថានសួគ៌ (អស ៦:២) ។

**៨:៦–៨** សូមមើលក្នុង លប ១:២៦–២៧ ។ អំណាចដែលព្រះប្រទានឱ្យគ្រប់គ្រងលើរបស់ខ្លះៗដែលទ្រង់បង្កើតមក គឺជា"សិរីល្អ និងកិត្តិយស"របស់ពួក

គឺសត្វផងទាំងពួងដែលហែលនៅផ្លូវទឹក
⁹ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់នៃយើងខ្ញុំអើយ
ព្រះនាមទ្រង់ប្រសើរ នៅគ្រប់លើផែនដីយ៉ាងណាទៅ[ធ]។

ទំនុកនៃស្តេចដាវីឌ ដែលទ្រង់
លើកឱ្យមេភ្លេង ត្រូវលេងតាមបទ "កូនប្រុសស្លាប់ហើយ" ។

**៨:៩** ធ ខ.១
**៩:១** ក ទដ ៨៦:១២ ១១១:១ ១១៩:២,១០,១៤៥ ១៣៨:១
**៩:១** ខ ទដ ៨៦:១២ ១១១:១ ១១៩:២,១០
**៩:២** គ យប ២២:១៩

# ៩

¹ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្ត[ក]
ទូលបង្គំនឹងនិទាន ពីអស់ទាំងការអស្ចារ្យរបស់ទ្រង់[ខ]
²ទូលបង្គំនឹងអរសប្បាយ ហើយរីករាយ[គ]ឡើងក្នុងទ្រង់
ឱព្រះដ៏ខ្ពស់បំផុតអើយ

ទដ ១៤:៧ ៣១:៧ ៧០:៤ ៩៧:៨ ១២៦:៣ សភ ២៣:១៥ អស ២៥:៩ យរ ៣០:១៩ យអ ២:២១ សផ ៣:១៤ មថ ៥:១២ វវ ១៩:៧

គេ (សូមមើល ខ.៥) ។ ការសម្រោកដ៏ពិតប្រាកដ ដែលមើលមិនទាន់ឃើញ គឺជាកម្មសិទ្ធិរបស់មនុស្ស ប៉ុន្តែអំណាចនិងការសំរាកនេះមិនទានពេញលេញ ឬក៏ឯករាជ្យនោះឡើយ ។

**៨:៩** នៅក្នុងខនេះគឺជាការនិយាយឡើងវិញពី ខ.១ ក (មើលការពន្យល់ទីនោះ) ។

**ទំនុកដំកើងជំពូក៩** តាមការអះអាងរបស់សិបធូជីន (ការបកប្រែព្រះគម្ពីរសញ្ញាចាស់ទៅភាសាក្រិករបស់គ្រីស្ទបរិស័ទសម័យមុន) បានអះអាងថាពេលខ្លះនៅក្នុងព្រះគម្ពីរ ទដ ជំពូក ៩,១០ មានទស្សនៈ (ឬប្រើ) តែមួយដូចគ្នា ។ ទោះបីជាយ៉ាងណាក៏ដោយ គំនិតដែលថាព្រះគម្ពីរទាំង២ នេះជាគម្ពីរដើមតែ១ នោះគ្មានឯកសារណាបញ្ជាក់ច្បាស់លាស់ ឬដឹងពិតប្រាកដនោះឡើយ សូម្បីចំនួននៃអ្នកច្រៀងនៅក្នុងចំណុចនេះ ក៏មិនបានដឹងដែរ ។ នៅក្នុងទំនុកដំកើងជំពូក ១០ គឺជាជំពូកតែ១គត់ក្នុងចំណោមជំពូក ៣–៣២ ដែលគ្មានចំណងជើង ឬសេចក្តីផ្តើម ហើយនៅក្នុងអត្ថបទជាភាសាហេព្រើរនៃព្រះគម្ពីរទាំង២ជំពូកនេះ គឺមានលក្ខណៈមិនគ្រប់គ្រាន់ (ឬបាត់) សូរ ឬសវនៈក្នុងសំណង់ប្រយោគ ។ ឃ្លាទី១នៃខនិមួយៗ ឬ២ខគឺមានលក្ខណៈទោរ ឬលំអៀងទៅអក្ខរក្រមនៃភាសាហេព្រើរ ជាពិសេសនៅក្នុងការចាប់ផ្តើមនៃព្រះគម្ពីរជំពូក ៩,១០ ។ គំនិតគិតនៅក្នុងជំពូកទាំង២ នេះក៏ទោរទៅរកការវិវឌ្ឍន៍២ខម្តងដែរ ។ នៅក្នុងជំពូក ៩ គឺពណ៌នាពីការសរសើរដំកើងដ៏អស់អំពីចិត្ត(ស្តេចដាវីឌជាអ្នកសរសើរ) ចំពោះព្រះអម្ចាស់ក្នុងការដែលព្រះអង្គបានរំដោះទ្រង់ និងប្រជារាស្ត្រទ្រង់ឱ្យរួចពីចំបាំង (គេច្រៀងពេលណានោះមិនដឹងឡើយ ប៉ុន្តែក្នុងអំឡុងគ្រាដែលមិនបាននិយាយពីអំណះអំណាងពីជ័យជម្នះរបស់ពួកអ៊ីស្រាអែលនោះ ប្រហែលជាព្រះអម្ចាស់ទ្រង់បានបញ្ជូនអ្នកផ្សេងទៀត ឱ្យមកបំផ្លាញពួកគេ) ។ នៅចុងបញ្ចប់ជំពូកនេះបានបញ្ចប់យ៉ាងខ្លីដោយការអធិស្ឋាន សូមឱ្យព្រះអង្គជំនុំជម្រះដោយយុត្តិធម៌(ខ.៤)មកលើប្រជាជាតិទាំងមូល ។ នៅក្នុងជំពូក១០ បានពណ៌នាពីការអធិស្ឋានទាស់ប្រឆាំងចំពោះការលោភលន់ ចង់បានរបស់ពួកមនុស្សក្បត់ក្នុងនគររបស់ទ្រង់ គឺជាពួកមនុស្សអាក្រក់កំណាចដែលគេបានធ្វើការអាក្រក់ចំពោះ"មនុស្សក្រីក្រ"(មើល ខ.២) ហើយជាប្រជាជាតិដែលព្យាយាមបំផ្លាញពួកអ៊ីស្រាអែល (មើល ខ.២–១១) ។ ឧទានស័ព្ទនៅក្នុងព្រះគម្ពីរទំនុកដំកើងទាំង២ជំពូកនេះ ក្នុងពេលដែលវាស្ថិតក្នុងកណ្តូគម្ពីរតែ១ គឺបាននិយាយពីគំនិតដ៏ស្មានមិនដល់របស់មនុស្ស "អាក្រក់" (៩:៥ ១០:៤) ។ នៅសហគមន៍នៃអ្នកជឿព្រះ (រូបព្រះ) គឺសុទ្ធតែវាយប្រហារ ឬព្យាបាទពួកអ៊ីស្រាអែលដូចៗគ្នា ។ ជាញឹកញាប់ការសរសើរដល់ការរំដោះរបស់ព្រះដែលព្រះធ្លាប់ធ្វើចំពោះពួកគេនាអតីតកាល គឺតែងតែមាននៅក្នុងការអធិស្ឋានរបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង (មើល ៣:៣–៤,៨ និងការពន្យល់ ២៥:៦ ៤០:១–៥) ហើយការនេះក៏ដូចគ្នានឹងមនុស្សដែលរស់នៅក្នុងតំបន់មជ្ឈឹមបូព៌ាកាលពីសម័យបុរាណដែរ ។ ដូច្នេះរាល់ទាំងការសរសើរតម្កើងដល់ព្រះ គឺពណ៌នាពីសេចក្តីសង្ឃឹមរបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងដែលគាត់សង្ឃឹមថា រាល់ការអធិស្ឋានរបស់គាត់នាពេលនេះនោះព្រះអម្ចាស់ទ្រង់នឹងឆ្លើយតប ហើយក៏មានតួនាទីជាការជំរុញដល់ព្រះអម្ចាស់សូមឱ្យធ្វើការអស្ចារ្យទ្វេរដងចំពោះរាស្ត្រ និងអ្នកបម្រើទ្រង់ ។ មើល ទដ ៤០,៤៤,៨៩ ដែលនិយាយពីការអធិស្ឋានយ៉ាងយូរ ។ ប្រហែលព្រះគម្ពីរ ទដ ៩,១០ បែងចែកពីគ្នាដោយព្រោះ គោលបំណងផ្សេងៗគ្នាដូចជា ទដ ៤២–៤៣ដែរ ។

**ទំនុកដំកើងជំពូក ៩ត្រង់ចំណងជើង** *លើកឱ្យមេភ្លេង* សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ត្រូវលេងតាមបទ* មើលចំណងជើង ទដ ២២,៤៤, ៥៦–៦០,៦៩,៧៥,៨០ និងការពន្យល់ចំណងជើង ទដ ៨៨ ។ គេមិនដឹងពីចំណងជើងនៃបទចម្រៀងនោះឡើយ ។

**៩:១** *ចិត្ត* មើលការពន្យល់ ៤:៧ ។ *និទាន* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះគឺ "សំដែង"(ខ.១៤)។ នៅក្នុងការសរសើរតម្កើងដល់ព្រះក្នុងព្រះគម្ពីរទំនុកដំកើង គឺកម្រនឹងមាននិយាយពីបញ្ហាផ្ទាល់ខ្លួនរបស់អ្នកនិពន្ធជាមួយព្រះអម្ចាស់ណាស់ ។ ជាញឹកញាប់ការសរសើរដំកើងនោះ គឺតែងតែប្រារព្ធទៅជាផ្លូវការណ៍ (នៅព្រះវិហារ) ដែលសរសើរដំកើងចំពោះគុណធម៌របស់ព្រះអង្គ ឬអំពីសេចក្តីសង្គ្រោះរបស់ព្រះអង្គ និងព្រះគុណនៃទ្រង់ក្នុងកាលដែលទ្រង់ប្រទានពរដល់ពួកគេ ។ នៅទីនេះ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គាត់បានពោលពាក្យសរសើរដំកើងចំពោះសិរីល្អ និងសេចក្តីសុចរិតនៃព្រះ (មើលការពន្យល់ ៤:១) ឬ ទង្វើរល្អរបស់ទ្រង់ (មើល ២២:២២–៣១ ៥៦:១២–១៣ ៦១:៨ ៦៥:១ ៦៩:៣០–៣៣) ។ ជានិច្ចកាលនៅក្នុងការនេះ គឺតែងតែមានបន្ថែមនូវការអំពាវនាវដល់មនុស្សទាំងអស់ឱ្យមកចូលសរសើរដំកើងដល់ព្រះអម្ចាស់ ទទួលស្គាល់និងមានអំណរចំពោះសិរីល្អរបស់ទ្រង់និងសេចក្តីសប្បុរសនៃទ្រង់ ជាពិសេសគ្រប់ទាំងអស់នៃសេចក្តីសប្បុរសនៃព្រះ ។ *ការអស្ចារ្យ* ភាគច្រើននៃការអស្ចារ្យ គឺនិយាយសំដៅលើសេចក្តីសង្គ្រោះរបស់ព្រះ ដែលពេលខ្លះមានការទាក់ទងទៅនឹងការអស្ចារ្យ ដូចជាក្នុងគ្រាដែលពួកកូនចៅអ៊ីស្រាអែល ចាកចេញពីស្រុកអេស៊ីព្ទមក និងការអស្ចារ្យនៅក្នុងទីរហោស្ថាន រួមទាំងការអស្ចារ្យជាច្រើនទៀតក្នុងពេលដែលពួកគេចូលក្នុងទឹកដីសន្យា ។ ពេលខ្លះការអស្ចារ្យនោះវាមិនពាក់ព័ន្ធនឹងការសម្តែងឫទ្ធានុភាពអ្វីឡើយ ប៉ុន្តែភាគច្រើនវាមានទំនាក់ទំនង ទៅនឹងការបើកសម្តែងភាពជាអ្នកដឹកនាំរបស់ព្រះជាអម្ចាស់តែម្តង ។ ការអស្ចារ្យនៅទីនេះ គឺនិយាយសំដៅការដែលព្រះអង្គបំផ្លាញពួកខ្មាំងសត្រូវរបស់ស្តេចដាវីឌក្នុងទំនុកដំកើងនេះ ។

**៩:២,១០** *ព្រះនាមទ្រង់* សូមមើលការពន្យល់ ៥:១១ ។

**៩:២** *ដ៏ខ្ពស់បំផុត* សូមមើលការពន្យល់ លប ១៤:១៩ ។

ទូលបង្គំនឹងច្រៀងដំកើង[ឃ]ដល់ព្រះនាម[ង]ទ្រង់
៣ កាលណាពួកខ្មាំងសត្រូវទូលបង្គំថយចេញទៅ
នោះគេស្ទុតជង្គង់ដួល ហើយវិនាសបាត់នៅចំពោះទ្រង់
៤ ដ្បិតទ្រង់បានរាំងពារសេចក្ដីទៀតត្រង់[ច] នឹងរឿងក្ដីរបស់
ទូលបង្គំ[ឆ] ទ្រង់គង់លើបល្ល័ង្ក[ជ]កំពុងតែជំនុំជំរះដោយ
យុត្តិធម៌[ឈ]
៥ ទ្រង់បានបន្ទោសដល់សាសន៍ដទៃ[ញ]ទាំងប៉ុន្មាន ក៏បាន
បំផ្លាញពួកមនុស្សអាក្រក់ចេញទ្រង់បានលុបឈ្មោះ[ដ]គេ
ឱ្យបាត់បង់ទៅជាដរាបរៀងតទៅ
៦ ឱខ្មាំងសត្រូវអើយ ការហិនវិនាសបានផុតទៅជានិច្ច
ឯទីក្រុងទាំងប៉ុន្មានដែលឯងបានបំផ្លាញ[ឋ]
នោះទាំងសេចក្ដីនឹកចាំ[ឌ]ពីគេបានបាត់ឈឹងទៅដែរ
៧ ប៉ុន្តែព្រះយេហូវ៉ាទ្រង់គង់នៅអស់កល្បជានិច្ច[ឍ]
ទ្រង់បានតាំងបល្ល័ង្កទ្រង់[ណ] ទុកសំរាប់នឹងជំនុំជំរះហើយ
៨ ទ្រង់នឹងជំនុំជំរះមនុស្សលោកដោយយុត្តិធម៌[ត]
ក៏នឹងវិនិច្ឆ័យអស់ទាំងសាសន៍ ដោយសេចក្ដីសុចរិត[ថ]
៩ ព្រះយេហូវ៉ាទ្រង់នឹងបានជាទីពឹងជ្រក[ទ]
ដល់អស់អ្នកណាដែលត្រូវគេសង្កត់សង្កិន[ធ]
គឺជាទីពឹងនៅគ្រាលំបាក[ន]
១០ ឯអស់អ្នកដែលស្គាល់ព្រះនាម[ប]ទ្រង់ គេនឹងទុកចិត្តដល់
ទ្រង់ ដ្បិត ឱព្រះយេហូវ៉ាអើយ ទ្រង់មិនបានបោះបង់
ចោល[ផ]ពួកអ្នកដែលស្វែងរកទ្រង់ឡើយ[ព]

**៩:២** ឃ ២របា ៣១:២ ង ទដ ៩២:១ **៩:៤** ច ១ពាវ ៨:៤៥ ឆ យប ១៦:២១ ជ ទដ ១១:៤ ៤៧:៨ អស ៦:១ ឈ ទដ ៧:១១ ៦៧:៤ ៩៨:៩ ១ពត ២:២៣ **៩:៥** ញ លប ២០:៧ ៣៧:១០ ១របា ១៦:២១ ទដ ៥៩:៥ ១០៥:១៤ អស ២៦:១៤ ៦៦:១៥ ដ យប ១៨:១៧ **៩:៦** ឋ ចទ ២៩:២៨ យរ ២:៣ ៤៦:១–៥១:៥៨ សផ ២:៨–១០ ឌ ទដ ៣៤:១៦ ១០៩:១៥ សស ៩:៥ អស ១៤:២២ ២៦:១៤ **៩:៧** ឍ ១របា ១៦:៣១ វវ ១៩:៦ ណ ទដ ១១:៤ ៤៧:៨ **៩:៨** ត ទដ ១១:៧ ៤៥:៦ ៧២:២ ថ ខ.៤ ទដ ៧:១១ **៩:៩** ទ ចទ ៣៣:២៧

១១ ចូរច្រៀងទំនុកសរសើរ[ភ]ដល់ព្រះយេហូវ៉ា
ដែលទ្រង់គង់នៅក្រុងស៊ីយ៉ូនចុះ[ម]
ចូរថ្លែងប្រាប់ពីការនៃទ្រង់[យ]
នៅក្នុងចំណោមបណ្ដាជនផង[រ]
១២ ដ្បិតកាលណាទ្រង់ស៊ើបសួរពីឈាម[ល]
នោះទ្រង់នឹងនឹកចាំពីពួកអ្នកទាំងនោះ
ទ្រង់មិនដែលភ្លេចសំរែករបស់ពួកមនុស្សក្រីក្រឡើយ[វ]
១៣ ឱព្រះយេហូវ៉ាអើយ សូមទ្រង់មេត្តា[ស]ប្រោសទូលបង្គំ
សូមទ្រង់ទតមើលសេចក្ដីទុក្ខលំបាករបស់ទូលបង្គំផង
ជាការដែលទូលបង្គំទ្រាំរងនេះ
ដោយសារពួកអ្នកដែលស្អប់[ហ]ទូលបង្គំ គឺទ្រង់ហើយ
ដែលលើកទូលបង្គំឡើង ឱ្យរួចពីទ្វារនៃសេចក្ដីស្លាប់[ឡ]
១៤ ដើម្បីឱ្យទូលបង្គំបានសំដែងចេញអស់ទាំងសេចក្ដី
សរសើរ[អ]នៃទ្រង់ នៅគ្រប់ទាំងទ្វារនៃកូនស្រីស៊ីយ៉ូន[ក]

២សយ ២២:៣ ធ ទដ ១០:១៨ ៧៤:២១ ន ទដ ៣២:៧ ១២១:៧ **៩:១០** ប ទដ ៩១:១៤ ផ លប ២៨:១៥ ចទ ៤:៣១ ទដ ២២:១ ៣៧:២៥ ៧១:១១ អស ៤៩:១៤ យរ ១៥:១៨ ហព ១៣:៥ ព ទដ ៧០:៤ **៩:១១** ភ ទដ ៧:១៧ ម ទដ ២:៦ យ ទដ ១០៥:១ រ ទដ ១៨:៤៩ ៤៤:១១ ៥៧:៩ ១០៦:២៧ អស ២៤:១៣ អគ ២០:២៣ ១ធថ ៣:១៦ **៩:១២** ល ២សយ ៤:១១ វ ខ.១៨ ទដ ១០:១៧ ២២:២៤ ៧២:៤ អស ៤៩:១៣ **៩:១៣** ស ទដ ៦:២ ៤១:៤ ៥១:១ ៨៦:៣,១៦ ១១៩:១៣២ ហ ជន ១០:៩ ទដ ៣:៧ ១៨:៣ ឡ យប ១៧:១៦ មថ ១៦:១៨ **៩:១៤** អ ទដ ៥១:១៥ ១ពត ២:៩ ក ២ពាវ ១៩:២១ អស ១:៨ ១០:៣២ ៣៧:២២ ៦២:១១ យរ ៤:៣១ ៦:២ បទ ១:៦ មីក ១:១៣ សផ ៣:១៤ សក ២:១០ មថ ២១:៥ យហ ១២:១៥

**៩:៣–៤** នៅក្នុងខទាំងនេះចង់មានប្រសាសថា ដើម្បីបំផ្លាញពួកខ្មាំងសត្រូវ នោះព្រះយេហូវ៉ាទ្រង់បានធ្វើឱ្យពួកខ្មាំងសត្រូវទាំងនោះ មកទាស់ប្រឆាំងចំពោះស្ដេចដាវីឌ (និងពួកអ៊ីស្រាអែល) ។

**៩:៤** *បល្ល័ង្ក* សូមមើការពន្យល់ ខ.៧ ។

**៩:៥** *ទ្រង់បានលុបឈ្មោះគេចេញ* គឺជាការលុបចេញពីបញ្ជីរដែលបានសរសេរនៅក្នុងក្រាំងប៉ាមរីស (មើល ជន ៥:២៣ និង ចទ ៩:១៤ ២៥:១៩ ២៩:២០ ២ពាវ ១៤:២៧) ។

**៩:៧–១០** នៅក្នុងខទាំងនេះ គឺនិយាយថា ការអបអរសាទរចំពោះការគ្រប់គ្រងដ៏សុចរិតរបស់ព្រះអម្ចាស់ព្រះយេហូវ៉ា (មើលការពន្យល់ ៤:១ ទដ ៩៣,៩៦–៩៩) បានធ្វើឱ្យពួកអ្នកដែលទន្ទឹងរងចាំព្រះមានទំនុកចិត្តលើព្រះអម្ចាស់ ។

**៩:៧** *បល្ល័ង្កទ្រង់* គឺជាបល្ល័ង្កដែលនៅស្ថានសួគ៌ (សូមមើល ១១:៤ និង ទដ ៩:៤) ។

**៩:៨** សូមមើល កច ១៧:៣១ ។

**៩:១០** *អស់អ្នកដែលស្គាល់ព្រះនាមទ្រង់* គឺជាពួកអ្នកដែលទទួលស្គាល់ថាមានព្រះនៅក្នុងចិត្តគេ (មើល ៩១:១៤ និងការពន្យល់ ៥:១១) ។

**៩:១១–១២** នៅក្នុងខទាំងនេះ គឺជាការហៅមនុស្សទាំងអស់ឱ្យមកប្រជុំគ្នានៅត្រង់ព្រះវិហារ ដើម្បីសរសើរដំកើងដល់ព្រះនាមរបស់ព្រះចំពោះសេចក្ដីជំនុំជម្រះដ៏សុចរិតរបស់ទ្រង់ (មើលការពន្យល់ ខ.១) ។

**៩:១១** *ទ្រង់គង់នៅក្រុងស៊ីយ៉ូន* បល្ល័ង្ករបស់ព្រះនៅស្ថានសួគ៌ (មើល ខ.៧) គឺមានតម្លៃដូចគ្នានឹងបល្ល័ង្កដែលព្រះគង់នៅលើផែនដីដែរ ដូចជានៅក្នុងក្រុងយេរូសាឡិម គឺជាចំណុចកណ្ដាលដែលទ្រង់បានគង់នៅលើលោកកិយ ដើម្បីគ្រប់គ្រងរាស្ត្ររបស់ទ្រង់ (មើល ២:៦ ៣:៤ និងការពន្យល់ ២០:២) ។ សូមមើលពីការដែលព្រះបានរើសយកក្រុង ស៊ីយ៉ូនធ្វើជាបល្ល័ង្ករបស់ទ្រង់ ១៣២:១៣ ។

**៩:១២** *កាលណាទ្រង់ស៊ើបសួរពីឈាម* មើល ចទ ៣២:៤១,៤៣ ។

**៩:១៣–១៤** នៅក្នុងជំពូកនេះ ប្រហែលជាការរំឭកពីសេចក្ដីអធិស្ឋានរបស់ស្ដេចដាវីឌឡើងវិញ ("សំរែករបស់ពួកមនុស្សក្រីក្រ" ខ.១២) ហើយដែលឥឡូវនេះព្រះអម្ចាស់ទ្រង់បានតបឆ្លើយ ។

**៩:១៣** *ទ្វារនៃសេចក្ដីស្លាប់* មើល យប ១៧:១៦ និងការពន្យល់ ។

**៩:១៤** *សំដែង* មើលការពន្យល់ ខ.១ ៧:១៧ ។ *ទ្វារ* នៅក្នុងឃ្លានេះចង់និយាយថា ដោយការដែលគាត់បាបទទួលជោគជ័យចំពោះការវាយប្រហារពីដំណាក់ពួកខ្មាំងសត្រូវ "មកដល់ទ្វារនៃសេចក្ដីស្លាប់" (ខ.១៣) នោះស្ដេចដាវីឌត្រូវសរសើរដំកើងដល់ព្រះចំពោះការដែល ព្រះជួយរំដោះគាត់ (មើលការពន្យល់ ខ.១) នៅត្រង់ទ្វារក្រុងស៊ីយ៉ូន ។ *កូនស្រីក្រុងស៊ីយ៉ូន* គឺជានិមិត្តរូបនៃក្រុងយេរូសាឡិម (មើលការពន្យល់ ២ពាវ ១៩:២១) ។

ទូលបង្គំនឹងរីករាយឡើង ក្នុងសេចក្ដីសង្គ្រោះរបស់ទ្រង់[ខ]
១៥ អស់ទាំងសាសន៍ដទៃបានផុងទៅក្នុងរណ្ដៅដែលខ្លួន
បានជីក[គ]
ជើងគេជាប់នៅក្នុងអន្ទាក់វាត់ ដែលខ្លួនគេបានបង្កប់ទុក[ឃ]
១៦ ព្រះយេហូវ៉ាទ្រង់បានសំដែងមកឱ្យស្គាល់
ទ្រង់បានសំរេចតាមសេចក្ដីយុត្តិធម៌
ពួកមនុស្សអាក្រក់បានជាប់អន្ទាក់ដោយការដែលដៃ
គេធ្វើ[ង] ។
–វាយភ្លេងស្រង៉ូតទទួល–បង្អង់
១៧ ពួកមនុស្សអាក្រក់នឹងត្រូវបំបែរទៅឯស្ថានឃុំព្រលឹង
មនុស្សស្លាប់វិញ[ច] គឺគ្រប់ ទាំងសាសន៍ដែលភ្លេចព្រះបង់[ឆ]
១៨ ដ្បិតមនុស្សកំសត់មិនត្រូវគេភ្លេចជាដរាបទេ
ហើយសេចក្ដីសង្ឃឹម[ជ] របស់មនុស្សទ័លក្រ[ឈ]ក៏មិនត្រូវ
វិនាសបាត់ជានិច្ចដែរ
១៩ ឱព្រះយេហូវ៉ាអើយ សូមទ្រង់តើនឡើង[ញ]
សូមកុំឱ្យមនុស្សឈ្នះឡើយ[ដ]
សូមឱ្យសាសន៍ដទៃទាំងប៉ុន្មានត្រូវជំនុំជំរះ[ឋ]នៅចំពោះទ្រង់
២០ ឱព្រះយេហូវ៉ាអើយ សូមបណ្ដាលឱ្យគេតក់ស្លុត[ឌ]
សូមឱ្យគ្រប់សាសន៍បានដឹងខ្លួនថា គេជាមនុស្សទេ[ឍ] ។
–បង្អង់

**១០** ឱព្រះយេហូវ៉ាអើយ
ហេតុអ្វីបានជាទ្រង់គង់នៅឆ្ងាយម្ល៉េះ[ក]
ហេតុអ្វីបានជាទ្រង់ពួនព្រះអង្គ[ខ]
នៅគ្រាដែលមានសេចក្ដីទុក្ខលំបាកដូច្នេះ
២ មនុស្សអាក្រក់ គេបៀតបៀនដល់មនុស្សក្រីក្រ[គ]ដោយ
សេចក្ដីឆ្មើងឆ្មៃ សូមឱ្យគេជាប់នៅក្នុងឧបាយ ដែលគេ
បង្កើតនោះ
៣ ដ្បិតមនុស្សអាក្រក់ គេអួត[ឃ]ពីបំណងក្នុងចិត្តគេ
ឯមនុស្សលោភ ក៏លះបង់ព្រះយេហូវ៉ា
អើ គេមើលងាយដល់ទ្រង់ផង[ង]
៤ មនុស្សអាក្រក់ពោលដោយឫកអំនួតរបស់ខ្លួនគេថា

**៩:១៤** ខ ទដ ១៣:៥ ៣៥:៩ ៥០:២៣ ៥១:១២ **៩:១៥** គ យប ៤:៨ ទដ ៣៥:៧ ឃ ទដ ៣៥:៨ ៥៧:៦ **៩:១៦** ង សភ ៥:២២ **៩:១៧** ច ជន ១៦:៣០ សភ ៥:៥ ឆ យប ៨:១៣ **៩:១៨** ជ ទដ ២៥:៣ ៣៩:៧ ៧១:៥ សភ ២៣:១៨ យរ ១៤:៨ ឈ ខ.១២ ទដ ៧៤:១៩ **៩:១៩** ញ ទដ ៣:៧ ដ ២របា ១៤:១១ ឋ ទដ ១១០:៦ អស ២:៤ យអ ៣:១២ **៩:២០** ឌ លប ៣៥:៥ ទដ ៣១:១៣ អស ១៣:៨ លក ២១:២៦ឍ ទដ ៦២:៩ អស ៣១:៣ អគ ២៨:២ **១០:១** ក ទដ ២២:១,១១ ៣៥:២២ ៣៨:២១ ៧១:១២ ខ ទដ ១៣:១ **១០:២** គ ខ.៩ យប ២០:១៩ **១០:៣** ឃ ទដ ៤៩:៦ ៩៤:៤ យរ ៤៩:៣០ ង យប ១:៥

**៩:១៥–១៨** នៅក្នុងខទាំងនេះចង់និយាយថា ដោយស្ថិតក្រោមការដឹកនាំដោយយុត្តិធម៌របស់ព្រះយេហូវ៉ា នោះពួកមនុស្សអាក្រក់ និងធ្លាក់ក្នុងអន្ទាក់ និងត្រូវបំផ្លាញខ្លួនឯងវិញ (មើល ៧:១៤–១៦ និងការពន្យល់) ហើយនៅចុងបញ្ចប់របស់ពួកគេ និងបានស្ថានឃុំព្រលឹងមនុស្សស្លាប់ជាមរដក ប៉ុន្តែពួកអ្នកដែលត្រូវគេឈ្លានពាន (មនុស្សកំសត់) សេចក្ដីសង្ឃឹមរបស់គេនឹងមិនអសាឥតការឡើយ ។

**៩:១៥** *រណ្ដៅ . . . ជីក . . . អន្ទាក់ . . . បង្កប់* ជានិច្ចកាលអ្នកនិពន្ធគាត់តែងតែទាញរូបភាពនៃពាក្យប្រៀបប្រដូចចេញពីពួកប្រមាញ់ (មាន១៤ទំនុកដំកើង) ដែលនិយាយសំដៅលើល្បិចកល ដ៏ប៉ិនប្រសប់របស់ពួកខ្មាំងសត្រូវ ដែលមានគំនិតចង់បំផ្លាញអ្នកដទៃ ដោយការបង្កប់ ឬវាយប្រហារ ដោយការភ្ញាក់ផ្អើល ហើយជាពិសេស អណ្ដាតគឺជាអាវុធរបស់គេ ដែលគេតែងតែប្រើ (មើល ៥:៩ និងការពន្យល់) ។ កាលពីសម័យកាលបុរាណពួកព្រានព្រៃបានប្រើអន្ទាក់ សំណាញ់ អន្លង់ ដើម្បីចាប់សត្វ ហើយជាញឹកញាប់គឺប្រើវត្ថុទាំងនេះរួមគ្នាតែម្ដង ។

**៩:១៧** *ភ្លេច* គឺមិននឹកចាំមិននិយាយពី ។

**៩:១៨** *មនុស្សកំសត់ . . . ទាល់ក្រ* នៅក្នុងព្រះគម្ពីរទំនុកដំកើងជំពូកនេះ ចង់និយាយថា ស្ដេចដាវីឌនិងពួកអ៊ីស្រាអែលនឹងរាប់បញ្ចូលក្នុងចំណោមពួកគេ ពីព្រោះពួកគេបានទទួលរងការវាយប្រហារ ពីសំណាក់ពួកខ្មាំងសត្រូវ ។ *មិនត្រូវគេភ្លេច* នៅក្នុងឃ្លានេះចង់និយាយថា ពួកអ្នកដែលបំភ្លេចព្រះចោលនោះ និងមិនបានអ្វីឡើយ ប៉ុន្តែពួកមនុស្សកំសត់ និងមនុស្សទាល់ក្រនោះព្រះអម្ចាស់ទ្រង់នឹងចាំពីគេ (មើល ខ.១២) ។

**៩:១៩–២០** នៅក្នុងខទាំងនេះគឺជាសេចក្ដីអធិស្ឋានចុងក្រោយ ដែលអ្នកនិពន្ធគាត់បានអធិស្ឋានសូមឱ្យព្រះអម្ចាស់ព្រះយេហូវ៉ា នៃពួកពលបរិវារទ្រង់គ្រប់គ្រងលើពួកប្រជាជាតិ ដូចដែលទ្រង់ធ្លាប់បានធ្វើកាលពីគ្រាកន្លងមក និងដូចដែលបាននិយាយនៅត្រង់នេះថា"អ្នកណាដែលភ្លេចព្រះអម្ចាស់" (មើល ខ.១៧) ដើម្បីឱ្យគេបានដឹងថា ពួកគេគ្រាន់តែជាមនុស្សកំសោយម្នាក់ប៉ុណ្ណោះ គ្មានព្រះឯណាដែលយកឈ្នះលើព្រះ នៃពួកអ៊ីស្រាអែលបានឡើយ (សូមមើល ១០:១៨) ។

**៩:១៩** *តើនឡើង* សូមមើលការពន្យល់ ៣:៧ ។

**ទដ ១០** នៅក្នុងជំពូកនេះ គឺជាសេចក្ដីអធិស្ឋានដែលអ្នកនិពន្ធគាត់បានអធិស្ឋានសូមឱ្យព្រះទ្រង់ជួយរំដោះពីពួកខ្មាំងសត្រូវ ពីមនុស្សកំណាច ហើយអ្នក និពន្ធគាត់ក៏បានភ្ជាប់មកជាមួយអាកប្បកិរិយារបស់ពួកមនុស្សអាក្រក់ដែរ (មើល ខ.៤ និងមើលក្នុងសេចក្ដីផ្ដើម ទដ ជំពូក ៩ ដែរ) ។

**១០:២–១១** នៅក្នុងខទាំងនេះអ្នកនិពន្ធគាត់បានរ៉ាយរ៉ាប់ ចោទប្រកាន់ចំពោះជនដែលសង្កត់សង្កិនគេ (មើលការពន្យល ៥:៩–១០) ។ មិនតែប៉ុណ្ណោះសោត អ្នកនិពន្ធគាត់បានពណ៌នាពីចរិតលក្ខណៈទូរទៅរបស់ពួកមនុស្សដែលតែងតែសង្កត់សង្កិនគេ ។ ទង្វើររបស់ពួកអ្នកទាំងនោះ គឺពេញដោយលាក់កំពុត ដូចជាឆ្មាលាក់ក្រចក ថែមទាំងអាក្រក់ជួរជាតិទៀតផង (សូមមើល ខ.២–៥) មិនតែប៉ុណ្ណោះគេថែមទាំងមិនជឿលើព្រះថែម ទៀត (មើល ខ.៣–៤,១៣ ជាពិសេសពាក្យសំដីរបស់ពួកគេក្នុង ខ.៦,១១,១៣) ។ ពួកគេលោភលន់ ស្រេកឃ្លាន (មើល ខ.៣) ដោយការវាយប្រហារពួកអ្នកដទៃ រួមទាំងមើលងាយដល់ព្រះថែមទៀត (ខ.៤) រួមទាំងក្រឹត្យវិន័យរបស់ទ្រង់ (មើល ខ.៥) ។

**១០:២** *បៀតបៀន . . . ឧបាយ* ជានិច្ចកាលអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងតែងតែលើករូបភាពរបស់មនុស្សអាក្រក់ ចេញពីពួកប្រម៉ាញ់ (មើល ខ.៨–៩ និងការពន្យល់ ខ.៩) ។

**១០:៣** *ចិត្ត* មើលការពន្យល់ ៤:៧ ។

**១០:៤** នៅក្នុងខនេះចង់និយាយថា ពួកមនុស្សអាក្រក់គេគ្មានព្រះនៅក្នុងខ្លួន

ព្រះទ្រង់នឹងមិនធ្វើទោសទេ ឯអស់ទាំងគំនិតរបស់គេ
នោះតែងគិតថា គ្មានព្រះណាសោះ[ច]
៥ អស់ទាំងផ្លូវរបស់គេសុទ្ធតែលំបាកជាដរាប[ឆ]
ឯអស់ទាំងច្បាប់របស់ទ្រង់ នោះខ្ពស់ហួសពីភ្នែកគេ
គេក៏បួញមាត់ឡកឡឺយឱ្យពួកអ្នកដែលតតាំងនឹងគេ
៦ គេនឹកក្នុងចិត្តថា អញនឹងមិនត្រូវរង្គើឡើង
ក៏មិនត្រូវអន្តរាយ[ជ] ដរាបដល់អស់ទាំងដំណមនុស្សតទៅ
៧ មាត់គេពេញដោយពាក្យជេរប្រមាថ[ឈ] ព្រមទាំងសេចក្តី
បញ្ឆោត និងសេចក្តីកំណាចផង[ញ]
នៅក្រោមអណ្តាតគេមានសុទ្ធតែ
កិច្ចកលនឹងសេចក្តីទុច្ចរិត[ដ]
៨ គេអង្គុយនៅអស់ទាំងទីលបចាំ[ឋ] នៃភូមិទាំងប៉ុន្មាន
នៅត្រង់កន្លែងស្ងាត់កំបាំង នោះគេសំឡាប់មនុស្ស
ជាមនុស្សដែលឥតមានទោស[ឌ]
ភ្នែកគេរំពៃមើលមនុស្សទុគ៌ត
៩ គេឈ្លបលបនៅទីសំងាត់ ដូចជាសិង្ហនៅក្នុងរូងគេលបចាំ
ចាប់មនុស្សក្រីក្រ[ឍ] ក៏ចាប់មនុស្សក្រនោះក្នុងកាលដែល
ទាញគេមកក្នុងមង[ណ]
១០ គេបំព្រួញខ្លួន ហើយឱនចុះនោះមនុស្សទុគ៌តធ្លាក់[ត] ទៅ
ក្នុងអំណាចគេ
១១ គេគិតក្នុងចិត្តថាព្រះទ្រង់ភ្លេច[ថ] ហើយទ្រង់លាក់ព្រះភក្ត្រ
ទតមិនឃើញឡើយ[ទ]
១២ ឱព្រះយេហូវ៉ាអើយ សូមទ្រង់ក្រោកឡើង[ធ] ឱព្រះអើយ
សូមលើកព្រះហស្តទ្រង់ឡើង[ន]
សូមកុំភ្លេចមនុស្សក្រលំបាកឡើយ[ប]
១៣ ហេតុអ្វីបានមនុស្សអាក្រក់ គេមើលងាយដល់ព្រះ[ផ]
ហើយគិតក្នុងចិត្តថាទ្រង់មិនធ្វើទោសទេដូច្នេះ[ព]
១៤ ទ្រង់បានទតឃើញហើយ
ដ្បិតទ្រង់ទតឃើញកិច្ចកល[ភ] និងសេចក្តីរំលោភ
ដើម្បីនឹងសងគេដោយព្រះហស្តទ្រង់ មនុស្សទុគ៌ត
គេផ្ញើខ្លួននឹងទ្រង់[ម] ដ្បិតទ្រង់បានធ្វើជាអ្នកជំនួយ[យ]
ដល់មនុស្សកំព្រា
១៥ សូមទ្រង់បំបាក់ដៃនៃមនុស្សអាក្រក់ ឯមនុស្សពាល[រ]
នោះសូមរកអស់ទាំងការអាក្រក់របស់គេទាល់តែមិន
ឃើញមានទៀត
១៦ ព្រះយេហូវ៉ាទ្រង់ជាមហាក្សត្រដ៏គង់នៅអស់កល្បជានិច្ច[ល]
អស់ទាំងសាសន៍ដទៃ[វ] បានសូន្យបាត់ចេញពីផែនដីរបស់
ទ្រង់ហើយ

**១០:៤** ច ទដ ៣៦:១ **១០:៥** ឆ ទដ ១៨:២៧ ១០១:៥ សភ ៦:១៧ អស ១៣:១១ យរ ៤៨:២៩ **១០:៦** ជ វវ ១៨:៧ **១០:៧** ឈ រម ៣:១៤ ញ ទដ ៧៣:៨ ១១៩:១៣៤ សស ៤:១ អស ៣០:១២ ដ យប ២០:១២ **១០:៨** ឋ ទដ ៣៧:៣២ ៥៩:៣ ៧១:១០ សភ ១:១១ យរ ៥:២៦ មីក ៧:២ ឌ ហស ៦:៩ **១០:៩** ឍ ខ.២ ណ យប ១៨:៨ **១០:១០** ត យប ៩:១៧ **១០:១១** ថ យប ២២:១៣ ទដ ៤២:៩ ៧៧:៩ ទ យប ២២:១៤ **១០:១២** ធ ទដ ៣:៧ ន ទដ ១៧:៧ ២០:៦ ១០៦:២៦ អស ២៦:១១ មីក ៥:៩ ប ទដ ៩:១២ **១០:១៣** ផ ខ.៣ ព យប ៣១:១៤ **១០:១៤** ភ ខ.៧ ទដ ២២:១១ ម ទដ ៣៧:៥ យ ចទ ៣៣:២៩ **១០:១៥** រ យប ៣១:២២ **១០:១៦** ល នក ១៥:១៨ វ ចទ ៨:២០

ឡើយ(មើល ខ.១១ ១៤:១ ៣៦:១ ៥៣:១) ។

**១០:៦** មើល ខ.១១,១៣ និងការពន្យល់ ៣:២ ។ *ក្នុងចិត្ត* នេះគឺជាភាសាអក្សរសាស្ត្រ (មើល ខ.១១,១៣ និងការពន្យល់ ៤:៧) ។ *រង្គើរ* គឺសំដៅលើការដកចេញការបំផ្លាញ ។

**១០:៧** *ពាក្យជេរប្រមាថ . . . សេចក្តីបញ្ឆោត . . . សេចក្តីកំណាច* ទាំង៣នេះ គឺជាអាវុធរបស់អណ្តាត ដែលអ៊ីស្រាអែលធ្លាប់ហែលឆ្លងកាត់ (មើលការពន្យល់ ៥:៩) ។ *ពាក្យជេរប្រមាថ* នៅតំបន់ជម្ញឹមបូព៌ាពួកគេបានគិតថា កាលណាអ្នកណាម្នាក់បញ្ចេញពាក្យជេរប្រមាថដល់អ្នកណាម្នាក់ នោះនឹងធ្វើឱ្យអំណាចរបស់អ្នកនោះត្រូវដួលចុះជាមិនខាន ។ *សេចក្តីបញ្ឆោត* គឺពួកគេនិយាយបង្ខូច និងធ្វើបន្ទាល់ក្លែងក្លាយ ក្នុងគោលបំណងអាក្រក់ (មើល ១ពវ ២១:៨–១៥) ។

**១០:៩** មើលការពន្យល់ ៧:២ ។ *បំព្រួញខ្លួន ហើយឱនចុះ* រូបភាពនៃពាក្យប្រៀបប្រដូចនេះ គឺដកស្រង់ចេញពីរូបភាពរបស់សិង្ហដែលលបឆ្មក់ដល់នាយព្រាន(មើលការពន្យល់ ៩:១៥) ។

**១០:១១** មើលការពន្យល់ ៣:២ ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងតែងតែបង្ហាញពីពួកមនុស្សអាក្រក់ គេតែងតែនិយាយអាក្រក់ (មើល ១៧:១០) ហើយជាពិសេសគេងាយនឹងភ្លេច ចំណេះដឹងរបស់ព្រះ ដោយព្រោះការអាក្រក់របស់គេ និងការដែលទ្រង់នឹកចាំពីការអាក្រក់របស់មនុស្សកំណាចទាំងនេះ (មើល ខ.១៣ ១២:៤ ៤២:៣,១០ ៥៩:៧ ៦៤:៥ ៧១:១១ ៧៣:១១ ១១៥:២ អស ២៩:១៥ អគ ៨:១២) ។

**១០:១២–១៥** នៅក្នុងខទាំងនេះ អ្នកនិពន្ធគាត់បានអធិស្ឋានដោយមានទំនុកចិត្តថា ព្រះទ្រង់នឹងហៅពួកមនុស្សអាក្រក់មកជំនុំជម្រះ ។

**១០:១២** *ក្រោកឡើង* មើលការពន្យល់ ៣:៧ ។ *ភ្លេច* មើល ៩:១៨ ។ *មនុស្សក្រលំបាក* គឺជាពួកមនុស្សដែលសូមការប្រោសប្រណីពីអ្នកដែលសង្កត់សង្កិន (មើល ខ.៩) ។

**១០:១៣** *ហេតុអ្វី . . .* មើលការពន្យល់ ៦:៣ ។

**១០:១៤** នៅក្នុងខនេះ អ្នកនិពន្ធគាត់ទទូចចង់បានការគ្រប់គ្រងមកពីព្រះ (មើល ៥:៤–៦) ។

**១០:១៥** *បំបាក់ដៃ* គឺចង់និយាយថា សូមឱ្យព្រះបំបាក់អំណាចជនដែលសង្កត់សង្កិនគេ ។ *សូមរក* នៅក្នុងឃ្លានេះចង់និយាយថា សូមទ្រង់បន្ទាបមនុស្សអាក្រក់ (សូមមើល ខ.១៣) ទៅតាមការជំនុំជម្រះដោយសុចរិតរបស់ទ្រង់ចុះ ។

**១០:១៦–១៨** នៅក្នុងខទាំងនេះ អ្នកនិពន្ធគាត់មានទំនុកចិត្តលើសេចក្តីសុចរិតរបស់ព្រះយេហូវ៉ា (មើលការពន្យល់ ៣:៨) ។ ដោយព្រោះជំពូកនេះបាននិយាយពីពួកសាសន៍ដទៃ (មើល ខ.១៦) និងការទំលាក់មនុស្សអំណួត (មើល ខ.១៨ និង ៩:១៩–២០) បានបង្ហាញថា ព្រះគម្ពីរទំនុកដំកើងជំពូកនេះមានទំនាក់ទំនងជាមួយ ទដ ជំពូក ៩ ។ នៅក្នុងសេចក្តីបញ្ចប់ ទដ ជំពូក ១០ នេះបានបង្ហាញពីការគ្រប់គ្រងដោយសុចរិតរបស់ព្រះលើលោកិយទាំងមូលទាំងដែនកំណត់ និងការសំអាតទឹកដីរបស់ព្រះ និងពួកសាសន៍ដទៃដែលមិនព្រមទទួលស្គាល់ព្រះ (មើល ខ.១៦) ។

១៧ឱព្រះយេហូវ៉ាអើយ ទ្រង់បានស្ដាប់សេចក្ដីបំណងរបស់
មនុស្សរាបទាប[ស] ទ្រង់នឹងតាំងចិត្តគេឱ្យមាំមួន
ហើយនិងផ្ទៀងព្រះកាណ៌ទ្រង់ស្ដាប់ផង[ហ]
១៨ដើម្បីនឹងកាត់សេចក្ដីឱ្យមនុស្សកំព្រា[ឡ]
និងមនុស្សដែលត្រូវគេសង្កត់សង្កិន[អ]
ប្រយោជន៍ឱ្យមនុស្សដែលកើតពីដីមកបានលែង
គំហកកំហែងគេតទៅទៀត ។

ទំនុកនៃស្ដេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**១១** ខ្ញុំយកព្រះយេហូវ៉ាជាទីពឹងជ្រក[ក] ធ្វើដូចម្ដេចឱ្យអ្នក
បាននិយាយនឹងខ្ញុំថា ចូររត់[ខ]ទៅឯភ្នំរបស់ឯង
ដូចជាសត្វហើរចុះ[គ]
២ដ្បិតមើល ពួកមនុស្សអាក្រក់គេយឹតធ្នូ[ឃ] គេដំឡើងព្រួញ[ង]
នៅជាប់នឹងខ្សែ ដើម្បីបាញ់ពីទីងងឹត[ច]
ចំអស់អ្នកដែលមានចិត្តទៀតត្រង់[ឆ]
៣បើសិនជាគោលប្រធាន[ជ]ត្រូវបំផ្លាញ
នោះតើមនុស្សសុចរិតនឹងអាចធ្វើអ្វីបាន
៤ព្រះយេហូវ៉ាទ្រង់គង់ក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់[ឈ]
ឯបល្ល័ង្កនៃព្រះយេហូវ៉ា នោះនៅលើស្ថានសួគ៌[ញ]
ព្រះនេត្រទ្រង់ទតមើល ត្របកព្រះនេត្រទ្រង់ពិចារណា
មើល[ដ]មនុស្សជាតិទាំងឡាយ[ឋ]
៥ព្រះយេហូវ៉ាទ្រង់ល្បងលមនុស្សសុចរិត[ឌ]
តែទ្រង់មានព្រះហឫទ័យស្អប់ដល់មនុស្សអាក្រក់
នឹងពួកអ្នកដែលចូលចិត្តខាងសេចក្ដីច្រឡោតវិញ[ឍ]
៦ទ្រង់នឹងបង្អុរឱ្យភ្លៀងជាអន្ទាក់មកលើមនុស្សអាក្រក់
គឺជាភ្លើងឆេះ និងស្ពាន់ធ័រ[ណ] ហើយខ្យល់[ត]ក្ដៅក្រហាយ
នោះនឹងបានជាចំណែកក្នុងពែងរបស់គេ
៧ដ្បិតព្រះយេហូវ៉ាទ្រង់សុចរិត[ថ]
ទ្រង់ក៏ស្រឡាញ់សេចក្ដីសុចរិតដែរ[ទ]
មនុស្សទៀងត្រង់[ធ]នឹងបានឃើញព្រះភក្ត្រទ្រង់[ន] ។

**១០:១៧** ស ទដ ៩:១២ ហ នក ២២:២៣ **១០:១៨** ឡ ចទ ២៤:១៧ ទដ ១៤៦:៩ អ ទដ ៩:៩ **១១:១** ក ទដ ៧:១ ខ លប ១៤:១០ គ ទដ ៥០:១១ **១១:២** ឃ ២សយ ២២:៣៥ ង ទដ ៧:១៣ ៥៨:៧ ច ទដ ១០:៨ ឆ យប ៣៣:៣ ទដ ៧:១០ **១១:៣** ជ ទដ ១៨:១៥ ៨២:៥ អស ២៤:១៨ **១១:៤** ឈ ១ពវ ៨:៤៨ ទដ ១៨:៦ ២៧:៤ យហ ២:៧ មីក ១:២ ហាព២:២០ ញ ២រប ៦:១៨ ទដ ៩:៧ មថ ៥:៣៤ ២៣:២២ វវ ៤:២ ដ ទដ ៣៣:១៨ ៦៦:៧ ឋ សក ១៥:៣ **១១:៥** ឌ ចទ ៧:១៣ យប ២៣:១០ ឍ យប ២៨:២៨ ទដ ៥:៥ ៤៥:៧ អស ១:១៤ **១១:៦** ណ លប ១៩:២៤ វវ ៩:១៧ ត លប ៤១:៦ យប ១:១៩ **១១:៧** ថ ២រប ១២:៦ អរ ៩:១៥ ២ធថ ៤:៨ ទ ទដ ៩:៨ ៣៣:៥ ៩៩:៤ អស ២៨:៧ ៣០:១៨ ៥៦:១ ៦១:៨ យរ ៩:២៤ ធ យប ១:១ លក ២៣:៥០ ន ទដ ១៧:១៥ ១៤០:១៣

**១០:១៨** *ប្រយោជន៍ឱ្យមនុស្សដែលកើតពីដីមក* នៅក្នុងឃ្លានេះចង់និយាយសំដៅលើអ្នកដែលមិនបានកើតមកពីព្រះ និងជាអ្នកដែលបានបង្កើតការទាស់ប្រឆាំង (មើល ៤៩:១២,២០ ៥៦:៤,១១ ៦២:៩ ៧៨:៣៩ ១០៣:១៤–១៦ ១១៨:៦,៨–៩ ១៤៤:៤ អស ៣១:៣ យរ ១៧:៥) ។

**ទដ ១១** នៅក្នុងជំពូកនេះ ពណ៌នាពីការទុកចិត្តចំពោះការគ្រប់គ្រងដោយសុចរិតរបស់ព្រះយេហូវ៉ា ក្នុងពេលដែលពួកមនុស្សអាក្រក់ហាក់បីដូចជាកាន់តែប្រសើរឡើង ។

**១១ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ជំពូក ៤ ត្រង់ចំណងជើង ។

**១១:១–៣** នៅក្នុងខទាំងនេះ ស្ដេចដាវីឌគាត់បានធ្វើបន្ទាល់ថា គាត់នឹងទុកចិត្តចំពោះទ្រង់ជានិច្ច(ព្រះអម្ចាស់ជាទីពំនឹង) ដើម្បីកំសាន្តចិត្តដល់ពួកបណ្ដាជនដែលនៅជុំវិញគាត់ដែលមានអារម្មណ៍ភ័យខ្លាច ។ ពួកបណ្ដាជនទាំងនោះគេឃើញថា អំណាច និងការអយុត្តិធម៌របស់ពួកខ្មាំងសត្រូវ (គេដំឡើងព្រួញនៅជាប់នឹងខ្សែ ដើម្បីបាញ់ពីទីងងឹត មើល ខ.២) ធ្វើឱ្យពួកគេភ័យខ្លាចក្រែងគោលប្រធាន (ខ.៣) ដួលចុះហើយរត់ទៅជ្រកនៅភ្នំដើម្បីឱ្យបានជីវិតតែខ្លួនឯង ។ ស្ដេចដាវីឌទ្រង់បានបណ្ដេញសេចក្ដីភ័យខ្លាច និងការមើលងាយរបស់បណ្ដាជនទាំងនោះ ។

**១១:២** នៅក្នុងខនេះមិនច្បាស់ថា តើពួកអ្នកដែលយឹតធ្នូ និងពួកដែលដំឡើងព្រួញ នោះជាអ្នកកាន់ធ្នូ ឬគ្រាន់តែជាការចោទប្រកាន់នោះឡើយ (មើល ៥៧:៤ ៦៤:៣–៤ និងការពន្យល់ ៥:៩) ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**១១:៣** *គោលប្រធាន* នេះគឺសំដៅលើព្រះបន្ទូលនៃព្រះ (មើល ៨២:៥) ចំពោះពួកអ្នកដែលបានឱ្យដឹបូន្មានដើម្បីគេចខ្លួន គឺជាពួកដែលមានអំណាចគេបានបញ្ចេរឡើងថា និងគ្មានមនុស្សសុចរិត្តទៀតទេ ។ *មនុស្សសុចរិត* សូមមើលការពន្យល់ ១:៥ ។

**១១:៤–៧** នៅក្នុងខទាំងនេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់ជាព្រះដែលបានគង់នៅលើបល្ល័ង្ករបស់ទ្រង់នៅស្ថានសួគ៌ជាពិតប្រាកដ ។ ព្រះយេហូវ៉ាដែលទ្រង់សុចរិត (មើល ខ.៧) បានផ្ទុះបញ្ចាំងពីមនុស្សសុចរិត (មើល ខ.៥) ដែលទ្រង់បានប្រទានឱ្យគេនៅចំពោះព្រះភក្ត្រទ្រង់ មើល ខ.៧) ហើយក្នុងថ្ងៃជំនុំជម្រះរបស់ទ្រង់ ទ្រង់នឹងបញ្ជូន "ភ្លៀង" មកលើមនុស្សសុចរិត ។

**១១:៤** *ព្រះយេហូវ៉ាទ្រង់គង់នៅក្នុងវិហារបរិសុទ្ធរបស់ទ្រង់* ឃ្លានេះនឹងនិយាយម្ដងទៀត ហប ២:២០ ។ វិហារដែលនិយាយនៅទីនេះគឺសំដៅលើវិហារនៅស្ថានសួគ៌ ។

**១១:៦** អ្វីដែលនិយាយនៅក្នុងខនេះ ប្រហែលនិយាយសំដៅលើថ្ងៃដែលទ្រង់បានជំនុំជម្រះលើក្រុងសូដុំម និងក្រុងកូម៉ូរ៉ា(មើល លប ១៩:២៤, ២៨ និង វវ ១៤:១០ និងការពន្យល់, និងមើល វវ ២០:១០ ២១:៨) ។ *ជាចំណែកក្នុង ពែងរបស់គេ* ឃ្លានេះគឺជាភាសារអក្សរសាស្ត្រ (មើល ៧៥:៨ និងការពន្យល់ ១៦:៥) ។

**១១:៧** *សុចរិត* មើលការពន្យល់ ៤:១ ។ *មនុស្សទៀងត្រង់* ពាក្យនេះ គឺនិយាយសំដៅលើពួកអ្នកដែលអស់សង្ឃឹម ដោយព្រោះភ័យខ្លាច (មើល ខ.២)។ *ឃើញព្រះភក្ត្រទ្រង់* ក្នុងព្រះគម្ពីរភាសាហេព្រើរ កាលណានិយាយពីការ "ឃើញព្រះភក្ត្រស្ដេច" គឺចង់ពណ៌នាពីការដែលបានចូលទៅចំពោះព្រះភក្ត្រស្ដេចផ្ទាល់ (មើល លប ៤៣:៣,៥ ៤៤:២៣,២៦ ២សយ ៣:១៣ "ឃើញមុខយើង" ១៤:៣២៤,២៨,៣២) ។ ពេលខ្លះឃ្លានេះ ក៏និយាយសំដៅលើអ្នកណាដែលបម្រើនៅចំពោះស្ដេចតែម្ដង (មើល ២ពវ ២៥:១៩ "ធ្លាប់ឃើញព្រះភក្ត្រ" នអ ១:១៤ "ធ្លាប់នៅចំពោះស្ដេច") ។ នៅទីនេះស្ដេចដាវីឌទ្រង់បានបន្ទូលពីសិទ្ធិពិសេស ដែលយើងនឹងចូលចំពោះព្រះភក្ត្រស្ដេច

ទំនុកនៃស្ដេចដាវីឌ

ដែលទ្រង់លើកឱ្យមេភ្លេង ត្រូវលេងដោយប្រដាប់មានខ្សែ៨ ។

**១២** ឱព្រះយេហូវ៉ាអើយ សូមទ្រង់ជួយផង
ដ្បិតមនុស្សដែលកោតខ្លាចដល់ព្រះគេកំពុងតែរួញថយទៅ[ក]
ហើយពួកមនុស្សស្មោះត្រង់ក៏កាន់តែសូន្យបាត់ពីចំណោមមនុស្សដែរ
២ គ្រប់គ្នាពោលតែសេចក្ដីភូតភរ[ខ] ដល់អ្នកជិតខាងខ្លួន
គេពោលដោយបបូរមាត់បញ្ចើច ហើយដោយមានចិត្ត២[គ]
៣ ព្រះយេហូវ៉ាទ្រង់នឹងកាត់អស់ទាំងបបូរមាត់បញ្ចើចចេញ[ឃ] ព្រមទាំងអណ្ដាតដែលពោលពាក្យធំនោះផង[ង]
៤ ជាពួកមនុស្សដែលបានថា យើងនឹងឈ្នះដោយអណ្ដាត[ច]
បបូរមាត់យើងស្រេចនៅយើងទេតើ
តើអ្នកណាជាចៅហ្វាយលើយើង
៥ ដូច្នេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថាអញនឹងក្រោកឡើងឥឡូវ[ឆ] ដោយព្រោះមានការសង្កត់សង្កិន[ជ]ដល់មនុស្សក្រលំបាក ហើយដោយព្រោះដំងូរ[ឈ]របស់មនុស្សកំសត់ទុគ៌ត
អញនឹងដាក់គេ[ញ]ឱ្យនៅទីសាន្តត្រាណ ដែលគេដង្ហក់រកនោះ
៦ ឯព្រះបន្ទូលនៃព្រះយេហូវ៉ា នោះសុទ្ធស្អាតទាំងអស់[ដ]
គឺដូចប្រាក់ដែលគេសាក[ឋ]ក្នុងបាវធ្វើពីដី[ឌ] ហើយបានសំរងអស់៧ដងផង
៧ ឱព្រះយេហូវ៉ាអើយ ទ្រង់នឹងថែរក្សាអ្នកទាំងនោះ[ឍ]
ទ្រង់នឹងជួយទំនុកបំរុងគេ ចាប់តាំងពីដំណនេះជារៀងរាបតទៅ[ណ]
៨ កាលណាមនុស្សលើកដំកើង[ត]សេចក្ដីលាមកអាក្រក់ឡើង
នោះមនុស្សអាក្រក់ក៏ដើរតែពាសគ្រប់កន្លែង ។

ទំនុកនៃស្ដេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**១៣** ឱព្រះយេហូវ៉ាអើយ
តើទ្រង់នឹងភ្លេចទូលបង្គំ[ក]ដល់កាលណាទៀត[ខ]

**១២:១** ក អស ៥៧:១ មីក ៧:២ **១២:២** ខ ទដ ៥:៦ ៣៤:១៣ ១៤១:៣ សភ ៦:១៩ ១២:១៧ ១៣:៣ អស ៣២:៧ គ ទដ ៥:៩ រម ១៦:១៨ **១២:៣** ឃ សភ ២៦:២៨ ២៨:២៣ ង ទដ ៧៣:៩ ដយ ៧:៨ យក ៣:៥ វវ ១៣:៥ **១២:៤** ច សភ ១៨:២១ យក ៣:៦ **១២:៥** ឆ ទដ ៣:៧ ជ ទដ ៤៤:២៤ ៦២:១០ ៧២:១៤ ៧៣:៨ សស ៤:១ ៥:៨ អស ៣:១៥ ៥:៧ ៣០:១២ ៥៩:១៣ កច ៧:៣៤ ឈ ទដ ៦:៦ ញ ទដ ៣៤:៦ ៣៥:១០ **១២:៦** ដ ២សយ ២២:៣១ ទដ ១៨:៣០ ឋ យប ២៣:១០ ២៨:១ អស ៤៨:១០ សក ១៣:៩ ឌ ទដ ១១៩:១៤០ **១២:៧** ឍ ទដ ១៦:១ ២៧:៥ **១២:៧** ណ ទដ ៣៧:២៨ យហ ១៧:១២**១២:៨** ត ទដ ៥៥:១០–១១ **១៣:១** ក ទដ ៤២:៩ បទ ៥:២០ ខ ទដ ៦:៣

នៃស្ថានសួគ៌ ។ អ្វីដែលបានពណ៌នានៅទីនេះគឺសំដៅលើព្រះវត្តមានរបស់ទ្រង់នៅត្រង់ព្រះវិហារ (ដំណាក់របស់ព្រះលើផែនដី) ប៉ុន្តែទោះបីជាទ្រង់គង់នៅលើផែនដីមែនក៏ដោយ ក៏ព្រះអង្គទ្រង់មានវត្តមាន និងគង់លើបល្ល័ង្កនៅស្ថានសួគ៌ដែរ ។ ទោះបីពួកអ្នកមិនជឿជាច្រើនដែលនៅជុំវិញពួកអ៊ីស្រាអែលក៏គេជឿថា មានជីវិតរស់នៅបន្ទាប់ពីបានស្លាប់ទៅហើយដែរ ដែលជីវិតនោះគ្រាន់តែជាស្រមោល១ នៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់ (មើល អស ១៤:៩–១៧) ។

**ទដ ១២** នៅក្នុងជំពូកនេះ អ្នកនិពន្ធគាត់បានអធិស្ឋានសូមសេចក្ដីជំនួយមកពីព្រះ នៅក្នុងគ្រាដែលមនុស្សគ្រប់គ្នាហាក់បីដូចជាគ្មានជំនឿ ហើយគ្រប់ទាំងអណ្ដាតបានពោលពាក្យបង្ខូច (មើល មីក ៧:១–៧) ។ នៅក្នុងជំពូកនេះ អ្នកនិពន្ធបានតែងឡើងជា៤គូ (ខ.១–២,៣–៤,៥–៦,៧–៨) ដោយបានលើកយកពីមនុស្សរបស់មនុស្សអាក្រក់ដែលនៅ "កណ្ដាលមនុស្ស" (មើល ខ.១,៨) ។

**១២ត្រង់ចំណងជើង** *លើកឱ្យមេភ្លេង* សូមមើលការពន្យល់ក្នុង ទដ ៤ ត្រង់ចំណងជើង ។ *ត្រូវលេងដោយប្រដាប់មានខ្សែ* មើលការពន្យល់ ជំពូក ៦ ត្រង់ចំណងជើង ។

**១២:២** សូមមើល ៥:៩ និងការពន្យល់ ។

**១២:៣–៤** នៅក្នុងខទាំងនេះ គឺជាសេចក្ដីអធិស្ឋាន ។

**១២:៣** *កាត់* ពាក្យនេះចង់និយាយសំដៅលើការបរាជ័យ ។ *សេចក្ដីភូតភរ* សូមមើលការពន្យល់ ១០:២–១១ ។

**១២:៤** សូមមើលការពន្យល់ ៣:២ ១០:១១ ។

**១២:៥–៦** នៅក្នុងខទាំងនេះ គឺជាព្រះបន្ទូលនៃការធានារ៉ាប់រងមកពីព្រះយេហូវ៉ា ។ ដូច្នេះគ្រប់ទាំងពាក្យអធិស្ឋាន ដែលមាននៅក្នុងព្រះគម្ពីរទំនុកដំកើងប្រហែលជាពាក្យសម្ដីរបស់ពួកសង្ឃ (មើល ១សយ ១:១៧) ឬជាហោរា (មើល ៥១:៨ និងការពន្យល់ ២សយ ១២:១៣) ។ តាមរយៈខនេះប្រហែលជាស្ពានចំលងពីសេចក្ដីអធិស្ឋាន ឈានមកនិយាយពីទំនុកចិត្ត (មើលការពន្យល់ ៣:៨) ដែលការនេះប្រហែលជាពាក្យដែលថ្លែង ដោយសង្ឃ ឬហោរាទោះជាមិនបាននិយាយនៅក្នុងជំពូកនេះក៏ដោយ ។ នៅទីនេះស្ដេចដាវីឌ ប្រហែលរំឭកពីព្រះបន្ទូលមកពីព្រះយេហូវ៉ា ដែលជាការធានាពីការគ្រប់គ្រងដោយសុចរិតរបស់ព្រះអម្ចាស់ (មើលការពន្យល់ ៤:១) ។

**១២:៥** *អញនឹងក្រោកឡើងឥឡូវ* សូមមើល អស ៣៣:១០ ។

**១២:៦** *ព្រះបន្ទូលនៃព្រះយេហូវ៉ា* ព្រះបន្ទូលនៃព្រះយេហូវ៉ាផ្ទុយពីអ្វីដែលជាការអួតអាងរបស់មនុស្សអាក្រក់ ។ ពួកគេល្អឥតខ្ចោះ ដូចជាប្រាក់ដែលបានសាកហើយ ។ *សាកក្នុងបាវធ្វើពីដី* ការធ្វើលោហៈឧស្សាហកម្មកាលពីសម័យបុរាណរបស់ពួកអ្នកដែលរស់នៅក្នុងតំបន់មជ្ឈឹមបូព៌ា ដែលយកលោហៈនោះទៅកំដៅក្នុងចង្ក្រានពិសេស គឺដើម្បីទាញយកប្រាក់និងមាសចេញកំទេចលោហៈ ហើយរែងពីអាចម៍រ៉ែ ។ វិធីនេះបានក្លាយជាការពណ៌នាពីកំណាព្យរបស់ពួកអ៊ីស្រាអែលជាច្រើន (មើល ៦៦:១០ សភ ១៧:៣ ២៧:២១ អស ១:២២,២៥ ៤៨:១០ យរ ៦:២៧–៣០ ៩:៧ អគ ២២:១៧–២២ សក ១៣:៩ មឡ ៣:៣) ។ *៧ដង* ចំនួននេះជាចំនួនដ៏គ្រប់លក្ខណ ។

**១២:៧–៨** នៅក្នុងខនេះ គឺជាសេចក្ដីបញ្ចប់នៃសេចក្ដីអធិស្ឋានដែលបង្ហាញពីទំនុកចិត្តចំពោះព្រះ (មើលការពន្យល់ ៣:៨) ។

**១២:៨** នៅក្នុងខនេះ ស្ដេចដាវីឌគាត់បានបង្ហាញពីទំនុកចិត្តដល់ព្រះអម្ចាស់ ទោះបីជាពេលឥឡូវនេះ មើលទៅពួកមនុស្សអាក្រក់គេហាក់ជារីកចម្រើន និងមានកម្លាំងខ្លាំងជាងក៏ដោយ (សូមមើល ១–៤) ។

**ទដ ១៣** នៅក្នុងជំពូកនេះអ្នកនិពន្ធបានស្រែកអំពាវនាវដល់ព្រះអម្ចាស់ សូមឱ្យទ្រង់បានរំដោះគាត់ចេញពីជំងឺដ៏សាហាវ ដែលកំពុងតែព្យាបាទដល់គាត់

តើដល់អស់កល្បឬអី
តើនឹងលាក់ព្រះភក្ត្រ[គ] ទ្រង់ចំពោះទូលបង្គំដល់កាលណា
២ តើត្រូវឱ្យទូលបង្គំពិគ្រោះនៅតែក្នុងខ្លួន[ឃ]ដល់កាលណា
ដោយមានចិត្តព្រួយវាល់ព្រឹកវាល់ល្ងាចដូច្នេះ
ខ្មាំងសត្រូវនឹងលើកខ្លួនឡើងទាស់នឹងទូលបង្គំដល់កាល
ណាទៅ[ង]
៣ ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ[ច]
សូមពិចារណាមើល ហើយឆ្លើយមកទូលបង្គំផង[ឆ]
សូមបំភ្លឺភ្នែកទូលបង្គំ[ជ]
ក្រែងទូលបង្គំដេកលក់ទៅក្នុងសេចក្តីស្លាប់[ឈ]
៤ ក្រែងខ្មាំងសត្រូវរបស់ទូលបង្គំថា អញបានឈ្នះវាហើយ[ញ]
ហើយអ្នកដែលតតាំងនឹងទូលបង្គំ
មានសេចក្តីអំណរ ដោយទូលបង្គំត្រូវរឥលចេញ[ដ]

៥ ប៉ុន្តែទូលបង្គំបានទុកចិត្តនឹងសេចក្តីសប្បុរសរបស់ទ្រង់[ឋ]
ចិត្តទូលបង្គំ នឹងរីករាយសប្បាយឡើងដោយសេចក្តី
សង្គ្រោះរបស់ទ្រង់ដែរ[ឌ]
៦ ទូលបង្គំនឹងច្រៀង[ឍ]ថ្វាយព្រះយេហូវ៉ា
ដ្បិតទ្រង់បានប្រោសការល្អជាបរិបូរដល់ទូលបង្គំហើយ ។

*១៤:១–៧ – ទដ ៥៣:១–៦*

ទំនុកនៃស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**១៤** មនុស្សល្ងង់ខ្លៅតែងគិតក្នុងចិត្តថា គ្មានព្រះទេ[ក]
គេសុទ្ធតែជាមនុស្សខូចអាក្រក់
គេបានប្រព្រឹត្តការដែលគួរស្អប់ខ្ពើម
ឥតមានអ្នកណាមួយដែលប្រព្រឹត្តល្អសោះ

**១៣:១** គ ចទ ៣១:១៧ ទដ ២២:២៤ អស ៨:១៧ ៥៤:៩ **១៣:២** ឃ ទដ ៤២:៤ ៥៥:២ ១៣៩:២៣ អស ៣៣:១៨ ដយ ៧:២៨ ង ទដ ៩៤:៣ **១៣:៣** ច ទដ ៩:១២ ២៥:១៨ ៣១:៧ ៣៥:២៣ ៥៩:៤ ៨០:១៤ ១០៧:៤១ ១១៩:៥០,១៥៣ ឆ ទដ ៤:១ ជ អរ ៩:៨ ឈ ទដ ៧៦:៥ ៩០:៥ យរ ៥១:៣៩ **១៣:៤** ញ ១ពវ ១៩:២ ទដ ២៥:២ ដ ទដ ៣៨:១៦ ១១៨:១៣ **១៣:៥** ឋ ទដ ៦:៤ ឌ យប ៣៣:២៦ ទដ ៩:១៤ អស ២៥:៩ ៣៣:២ **១៣:៦** ឍ នក ១៥:១ ទដ ៧:១៧ **១៤:១** ក ទដ ១០:៤

ដែលអាចឱ្យគាត់ស្លាប់បាន (មើល ខ.៣) ហើយបណ្តាលឱ្យខ្មាំងសត្រូវរបស់គាត់ធ្វើអ្វីតាមដែលចិត្តគេចង់ធ្វើ ។ មើលសេចក្តីផ្តើម ទដ ជំពូក ៦ ។

**១៣ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ត្រង់ចំណងជើង ។

**១៣:១–២** នៅក្នុងជំពូកនេះ អ្នកនិពន្ធបន្តការរអ៊ូរទាំចំពោះជំងឺដែលមាននៅក្នុងជីវិតរបស់គាត់ ។

**១៣:១** *តើដល់កាលណា* មើលការពន្យល់ ៦:៣ ។ *ភ្លេច* គឺមានន័យថា មិនយកចិត្តទុកដាក់ ឬមិនអើពើជាមួយ ។ *លាក់ព្រះភក្ត្រ* ការប្រើឃ្លានេះជាមួយពាក្យ "ភ្លេច" មើល ៤៤:២៤ ។ នៅក្នុងស្ថានភាពត្រូវការបែបនេះ ជានិច្ចកាលអ្នកនិពន្ធគាត់បានអធិស្ឋានសួរព្រះអង្គថា ហេតុអ្វីបានជាព្រះអង្គទ្រង់លាក់ព្រះភ័ក្ត្រនឹងទូលបង្គំដូច្នេះ (មើល ៣០:៧ ៤៤:២៤ ៨៨:១៤) ឬទូលអង្វរសូមកុំឱ្យទ្រង់បោះបង់ចោលគេ (មើល ២៧:៩ ៦៩:១៧ ១០២:២ ១៤៣:៧) ។ នៅពេលដែលទ្រង់លាក់ព្រះភក្ត្រទ្រង់នោះ បានធ្វើឱ្យអ្នកដែលពឹងជ្រកក្នុងទ្រង់មានការអស់សង្ឃឹម (មើល ៣០:៧ ១០៤:២៩) ។ នៅពេលដែលព្រះភក្ត្រទ្រង់បានភ្លឺចាំងមកលើមនុស្សនោះ មានន័យថា ព្រះអង្គបាននាំសេចក្តីសង្គ្រោះនឹងព្រះពរមកដល់គេ (មើល ៤:៦ និងការពន្យល់ ៣១:១៦ ៤៤:៣ ៦៧:១ ៨០:៣,៧,១៩ ១១៩:១៣៥ និង ជន ៦:២៥ និងការពន្យល់) ។

**១៣:២** *ចិត្ត* មើលការពន្យល់ ៤:៧ ។

**១៣:៣–៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធគាត់បានអធិស្ឋានសូមឱ្យព្រះអង្គទ្រង់បាននាំគាត់ឱ្យចេញផុតពីសេចក្តីស្លាប់ ។

**១៣:៣** *សូមបំភ្លឺភ្នែកទូលបង្គំ* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា សូមឱ្យព្រះអង្គទ្រង់បានស្រង់គាត់ឡើងវិញ (មើលការពន្យល់ ៦:៧) ។

**១៣:៤** មើលការពន្យល់ ៣:២ ៥:៩ ។ *រឥលចេញ* គឺនិយាយសំដៅលើសេចក្តីស្លាប់ (ដូចជានិយាយនៅ ១៨:៣៨ ៨២:៧ ១០៦:២៦ ពច ៥:២៧ ២សយ ១:១៩ យប ១៨:១២) ។

**១៣:៥–៦** នៅក្នុងខទាំងនេះ គឺជាសេចក្តីបញ្ចប់ ហើយអ្នកនិពន្ធបានបញ្ចប់ដោយបង្ហាញពីទំនុកចិត្តដល់ព្រះ (មើលការពន្យល់ ៣:៨) ។

**១៣:៥** *សេចក្តីសប្បុរស* មើលការពន្យល់ ៦:៤ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។ *រីករាយ* ស្តេចដាវីឌនឹងត្រូវមានអំណរ មិនមែនជាពួកខ្មាំងសត្រូវនោះឡើយ ។

**១៣:៦** មើលការពន្យល់ ៧:១៧ ។

**ទដ ១៤** នៅក្នុងជំពូកនេះ គឺជាទីបន្ទាល់ទាក់ទងទៅនឹងការចំកួតរបស់មនុស្សដែលជីវិតរស់នៅរបស់គេគ្មានព្រះ ហើយពួកគេមានសិទ្ធពេញលេញក្នុងការប្រព្រឹត្តិបែបព្រៃផ្សៃដល់មនុស្សទន់ខ្សោយ ដែលមកពឹងពាក់គេ (ទដ ៥៣ មានលក្ខណៈដូចគ្នាខ្លះ) ។ ដោយព្រោះទំនុកដំកើងក្នុងជំពូកនេះបានពណ៌នាពីមនុស្សកំណាចដែលគ្មានព្រះ នោះបង្ហាញថា ទំនុកដំកើងជំពូកនេះមានទំនាក់ទំនងជាមួយ ទដ ១០,១២ (មើល ២៨:៣–៥) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះក៏មានចំណែកជាមួយ ទដ ១១ ដែរដោយព្រោះបាននិយាយថា សេចក្តីសុចរិតរបស់ព្រះយេហូវ៉ា បានគង់នៅលើបល្ល័ង្កឧត្តុង្គឧត្តមរបស់ទ្រង់ ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ បានបញ្ចប់ដោយការប្រមូលយកសេចក្តីអធិស្ឋានដែលបាននិយាយនៅដើម ជំពូក ៣ (សម្រាប់ទំនាក់ទំនងជាមួយក្រុម ផ្សេងទៀតនៃទំនុកដំកើង សូមមើលក្នុងសេចក្តីផ្តើម ទដ ១៥–២៤) ។ បទ គម្ពីរទំនុកដំកើងជំពូកនេះ គឺជាបទទី៥ (និងមានកំណាព្យហេព្រើរ៦៥) បន្ទាប់ពី ទំនុកដំកើងជំពូក៨ដែលបានរំឭកឱ្យឃើញពី "សិរីល្អ និងកេរ្តិ៍ឈ្មោះ" របស់មនុស្ស (មើល ៨:៥) នោះជំពូកនេះគឺនិយាយពីភាពអាម៉ាស់មុខ (សូមមើលសេចក្តីផ្តើម ទដ ៨) ។

**១៤ ជាចំណងជើង លើកសម្រាប់មេភ្លេង** សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។

**១៤:១–៣** ជាលក្ខណៈសម្បត្តិរបស់មនុស្សអាក្រក់ ដែលលោកប៉ុលប្រើខទាំងនេះនៅក្នុងអត្ថបទផ្សេងគ្នា មើល រម ៣:១០–១២ ។

**១៤:១** *មនុស្សល្ងង់ខ្លៅ* ក្នុងព្រះគម្ពីរភាសាហេព្រើរគឺ "នែបប៊ិល" (Nabal) ឯចំពោះអត្ថបទពាក្យនេះ សូមមើល ១សយ ២៥:២៥ ១៣:១៣ អស ៣២:៥–៧ (ក្នុងសុភាសិត "ពាក្យថាមនុស្សល្ងង់ខ្លៅ" ជាមនុស្សទុយស ដែលលះបង់ចោលព្រះ ។ ចំពោះពាក្យជាភាសាហេព្រើរពីរទៀត មើល សភ ១:៧, ២២)។ *ថា* ពាក្យនេះ មើលការពន្យល់ ៣:២ ។ ពាក្យថា ចិត្ត មើលការ

២ ព្រះយេហូវ៉ាទ្រង់បានទតមើលពីលើស្ថានសួគ៌[ខ] ចំពោះ
ពួកកូនមនុស្ស
ដើម្បីឱ្យបានជ្រាបថា មានអ្នកណាខ្លះដែលមានគំនិត[គ]
ស្វែងរកព្រះឬទេ[ឃ]
៣ តែគ្រប់គ្នាបានវង្វេងចេញ[ង] បានត្រឡប់ទៅជាស្មោក
គ្រោក[ច] ទាំងអស់
គ្មានអ្នកណាមួយដែលប្រព្រឹត្តល្អ[ឆ] ឡើយសូម្បីតែ១ក៏គ្មាន
ផង[ជ]
៤ ឯអស់អ្នកដែលប្រព្រឹត្តការទុច្ចរិតដូច្នេះ
តើគ្មានប្រាជ្ញាទេឬអី[ឈ] ជាពួកអ្នកដែលស៊ីរាស្ត្រអញ[ញ]
ដូចជាស៊ីអាហារ ហើយមិនដែលអំពាវនាវដល់ព្រះ
យេហូវ៉ាឡើយ[ដ]
៥ យ៉ាងនោះ គេមានសេចក្ដីភិតភ័យជាខ្លាំង
ដ្បិតព្រះទ្រង់គង់នៅនឹងដំណមនុស្សសុចរិត
៦ ឯឯងរាល់គ្នា បានបន្ទច់គំនិតនៃមនុស្សក្រីក្រឱ្យមាន
សេចក្ដីខ្មាស ពីព្រោះគេបានពឹងផ្អែកដល់ព្រះយេហូវ៉ា[ឋ]
៧ ឱបើសិនជាសេចក្ដីសង្គ្រោះនៃសាសន៍អ៊ីស្រាអែលបាន
ចេញពីស៊ីយ៉ូនមកទៅអេះ[ឌ] ក្នុងកាលដែលព្រះយេហូវ៉ា
ទ្រង់នាំពួកឈ្លើយ[ឍ] នៃរាស្ត្រទ្រង់មកវិញ
នោះយ៉ាកុបនឹងអរសប្បាយឡើង
ហើយអ៊ីស្រាអែលនឹងរីករាយសាទរ ។

**១៤:២** ខ យប ៤១:៣៤ ទដ ៨៥:១១ ១០២:១៩ បទ ៣:៥០ គ ទដ ៩២:៦ ឃ អរ ៦:២១
**១៤:៣** ង ១សយ ៨:៣ ១ធថ ៥:១៥ ច ២ពត ២:៧ ឆ ១ពវ ៨:៤៦ ទដ ១៤៣:២ សស ៧:២០ ជ រម ៣:១០–១២
**១៤:៤** ឈ ទដ ៨២:៥ យរ ៤:២២ ញ ទដ ២៧:២ មីក ៣:៣ ដ ទដ ៧៩:៦ អស ៦៤:៧ ៦៥:១ យរ ១០:២៥ ហស ៧:៧
**១៤:៦** ឋ ២សយ ២២:៣

ទំនុកនៃស្តេចដាវីឌ ។

**១៥** ឱព្រះយេហូវ៉ាអើយ
តើអ្នកណានឹងនៅ[ក] ក្នុងរោងឧបោសថរបស់ទ្រង់[ខ]
តើអ្នកណានឹងនៅលើភ្នំបរិសុទ្ធនៃទ្រង់បាន[គ]

**១៤:៧** ឌ ទដ ២:៦ ឍ ចទ ៣០:៣ យរ ៤៨:៤៧ **១៥:១** ក នក ២៩:៤៦ ទដ ២៣:៦ ២៧:៤ ៦១:៤ ខ នក ២៥:៨ ១រប ២២:១៩ ទដ ២០:២ ៧៨:៦៩ ១៥០:១ គ នក ១៥:១៧

ពន្យល់ ៤:៧ ។ ពាក្យថា គ្មានព្រះទេ ជាការបដិសេធន៍ដែលមនុស្សទម្លាប់ធ្វើ (មើល ១០:៤,៦,១១,១៣ ៣៦:១ និងការពន្យល់ ១០:៤) ។ *ឥតមានអ្នកណាមួយដែលប្រព្រឹត្តល្អសោះ* គឺជាឃ្លាកំណត់ពីសេចក្ដីសំអាងក្នុង ខ.៣ ដែលនិយាយចំពោះ "មនុស្សល្ងង់ខ្លៅ" ដែលពុំបានទទួលខុសត្រូវចំពោះព្រះអម្ចាស់ ក៏ពុំមានភាពស្មោក់ស្មើរក្នុងការបង្ហាញពីសេចក្ដីសម្រេចចិត្តរបស់ពួកគេឆ្ពោះទៅរក "ចំណែកនៃភាពសុចរិត" (សូមមើល ខ.៤–៥) និងមើល ៩:១៩–២០ ១០:២–១១,១៣,១៨ ១២:១–៤,៧–៨ (ជាស្ថានភាពដែល ទដ ១១ បានពណ៌នាដែរ) ។ ក៏មានគោលបំណងឱ្យ គម្ពីរទំនុកដំកើងនេះ គឺមានអ្នកនិពន្ធទំនុកដំកើងបានដាក់ខ្លួនរបស់ពួកគេក្នុងចំណោមពួកមនុស្សដែលមិនមានលក្ខណៈបរិសុទ្ធចំពោះព្រះនេត្រទ្រង់ (សូមមើល ១៣០:៣ ១៤៣:២ សូមមើល ១ពវ ៨:៤៦ យប ៩:២ សស ៧:២០) ។

**១៤:២** *ព្រះយេហូវ៉ា* ជាពាក្យបញ្ជាក់ពីរពាក្យផ្ទុយនឹងពាក្យ "មនុស្សល្ងង់ខ្លៅ" (ខ.១) ។ *ទតមើលពីលើស្ថានសួគ៌* សូមមើល ៣៣:១៣–១៤ ។ *ស្វែងរកព្រះ* "ការស្វែងរកព្រះ" ជាការពិត គឺការស្វែងរកការល្អ "ឬអ្វីដែលជាការល្អ" (អម ៥:១៤–១៥) គឺជាការស្វែងរកភាពយុត្តិធម៌នៅក្នុងគ្រប់ការទាំងអស់ដែលមានការទំនាក់ទំនងមនុស្សគ្រប់សណ្ឋាន (សូមមើល អស ១:១៧ និង ទដ ១៤) ។

**១៤:៣** *ត្រឡប់ទៅ* គឺជាការបែរត្រឡប់ពីព្រះ និងការប្រព្រឹត្តល្អទៅរកការអាក្រក់ ហើយនិងនិស្ស័យចាស់ ។

**១៤:៤–៦** គឺសេចក្ដីសំញែងការអាក្រក់យ៉ាងច្បាស់ ។

**១៤:៤** *ជាស៊ីអាហារ . . . មិនដែលអំពាវនាវដល់ព្រះយេហូវ៉ាឡើង* ជាការបង្ហាញវិញនៅចរិតលក្ខណៈរបស់មនុស្សអាក្រក់ : គឺពួកគេរស់នៅដោយពឹងផ្អែកលើភាពឃោរឃៅ និងរស់ដោយដៃរបស់ពួកគេ ដោយមិនបានពឹងផ្អែកលើព្រះយេហូវ៉ាឡើង (សូមមើល ១០:២–៤) ។

**១៤:៥** គឺព្រះបានការពារមនុស្សសុចរិត (សូមមើល ១០:២–៤) ។

**១៤:៦** *មនុស្សក្រីក្រ* គឺអស់អ្នកដែលពុំមានលទ្ធភាពការពារអាយុជីវិតរបស់ពួកគេ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ គឺមានន័យថា "ខ្សោយ ឬមិនពូកែ" មើលក្នុង ១០:២ និងពាក្យ "គ្មានទីពឹង" ក្នុង ១០:៩,១២ ។

**១៤:៧** អ្នកនិពន្ធបទទំនុកដំកើង ក៏ទន្ទឹងរង់ចាំនូវការរំដោះរាស្ត្រអ៊ីស្រាអែលឱ្យរួចពីកណ្ដាប់ដៃពួកសត្រូវទាំងស្រុង ហើយពេលនោះព្រះបានមកជួយអ្នកមានលក្ខណៈដូចក្នុង ១០:១៦–១៨ និងការពន្យល់ ។ *ស៊ីយ៉ូន* សូមមើលការពន្យល់ ៩:១១ ។ *យ៉ាកុប . . . អ៊ីស្រាអែល* មានន័យដូច (សូមមើល លប ៣២:២៨) ។

**ទដ ១៥–២៤** ទដ ១៥ និងការបង្ហាញភាពច្បាស់លាស់របស់វា ទដ ២៤ គឺគម្ពីរទំនុកដំកើងមានលក្ខណៈជាក្រុម ដែលបានចងក្រងជាបែបគំរូមានចំណុចរួមមួយដែលមាន ទដ ១៩ បានប្រើសម្រាប់ការទំនាក់ទំនង (ការភ្ជាប់ផ្ទៃរឿងរវាង ទដ ១៦ និង ២៣ ។ និងរវាង ទដ ១៧ និង ២២ ដែលជាចន្លោះ ទដ ១៨ និង ២០–២១ សូមមើលសេចក្ដីផ្ដើមនៃបទគម្ពីរទំនុកដំកើងទាំងអស់នោះ) ។ មានការចងក្រងព្រះគម្ពីរទំនុកដំកើង (១៥:២៤) ដែលមានទំនាក់ទំនងដោយហេតុការណ៍របស់ព្រះតេជះ ដែលជាសេចក្ដីតម្រូវទៅលើភាពបរិសុទ្ធនៃព្រះ បើមនុស្សពុំដើរតាមព្រះក៏ពួកគេគ្មានឱកាស ឬអត្ថិភាពអាចឃើញព្រះបានឡើយ (ហព ១២:១៤) ។ នៅចំណុចកណ្ដាល ទដ ១៩ មានទំនាក់ទំនងតែមួយ គឺការអបអរសាវទរពីព្រះតេជះ នៃក្រមសិលធម៌ តាមរយៈច្បាប់បញ្ញត្តិរបស់ទ្រង់ និងការលើកលែងទោស ការថែរក្សាហ្វូងចៀមរបស់ទ្រង់ ។ រួមទាំងទំនុកដំកើងទាំងបីនេះ (៧៥:១៩,២៤) បានផ្ដល់នូវពាក្យណែនាំទាក់ទងនឹងទឹកចិត្តទូលអង្វរក្នុងទំនុកដំកើង ។ មានក្នុង ទដ ១៤ និងបានបន្ថែមសេចក្ដីណែនាំក្នុងជិពូក ១ ។

**ទដ ១៥** សេចក្ដីណែនាំទាក់ទងនឹងអ្នក ដែលប្រាថ្នាចង់បានខិតចូលទៅជិតព្រះ គឺក្នុងព្រះវិហាររបស់ទ្រង់ (មើល ២៤:៣–៦ អស ៣៣:១៤–១៦) ។ និងមើលសេចក្ដីផ្ដើម ទដ ១៥–២៤ ។

**១៥:១** *និងនៅក្នុង . . . របស់ទ្រង់* គឺមិនដូចជាពួកសង្ឃទេ តែមានលក្ខណៈជាភ្ញៀវដែលរង់ចាំទទួលស្វាគមន៍ព្រះ ក្នុងភាពបរិសុទ្ធរបស់ទ្រង់ជាព្រះរាជដំណាក់ ជាព្រះវិហារ (សូមមើល ២៣:៦ ២៧:៤–៦ ៦១:៤ ៨៤:១០ ២សយ ១២:២០) ។ *ភ្នំបរិសុទ្ធ* សូមមើលការពន្យល់ ២:៦ ។

២ គឺជាអ្នកណាដែលដើរ ដោយទៀតត្រង់[ឃ] ហើយប្រព្រឹត្ត
សេចក្ដីសុចរិត ព្រមទាំងពោលសេចក្ដីពិត[ង]ពីក្នុងចិត្តផង
៣ ជាអ្នកដែលមិនពោលបង្កាច់[ច] ដោយអណ្ដាត
ឬធ្វើអាក្រក់ដល់មិត្រសំឡាញ់
ឬយករឿងបកកេរ ពីអ្នកជិតខាងខ្លួនឡើយ
៤ ជាអ្នកដែលមានភ្នែកមើលមនុស្សពាលដោយសេចក្ដី
ស្អប់ខ្ពើម តែលើកមុខ[ឆ]អស់អ្នកដែលកោតខ្លាចដល់ព្រះ
យេហូវ៉ាវិញ ជាអ្នកដែលហ៊ានទាំងស្បថ[ជ]
ដល់បង់ប្រយោជន៍ខ្លួនផងឥតប្រែប្រួលឡើយ
៥ ជាអ្នកដែលមិនបញ្ចេញប្រាក់ខ្លួន
ដើម្បីយកការ សោះ[ឈ]ក៏មិនទទួលសំណូក[ញ]ទាស់នឹងមនុស្ស
ឥតមានទោស
អ្នកណាដែលប្រព្រឹត្តយ៉ាងដូច្នេះ អ្នកនោះនឹងមិនត្រូវ
រង្គើឡើយ[ដ] ។

ទំនុកនៃស្ដេចដាវីឌ ។

**១៦** ឱព្រះអង្គអើយ សូមការពារទូលបង្គំផង[ក]
ដ្បិតទូលបង្គំយកទ្រង់ជាទីពឹង[ខ]
២ ខ្ញុំបានទូលដល់ព្រះយេហូវ៉ាថា
ទ្រង់ជាព្រះអម្ចាស់នៃទូលបង្គំ[គ]
ក្រៅពីទ្រង់ ទូលបង្គំរកសេចក្ដីល្អមិនបានឡើយ[ឃ]
៣ ចំណែកពួកបរិសុទ្ធ[ង]ដែលនៅផែនដី
នោះជាពួកប្រសើរ ដែលគាប់ចិត្តទូលបង្គំគ្រប់ជីពូក[ច]
៤ ឯពួកអ្នកដែលអាល័យ[ឆ]តែតាមព្រះដទៃ[ជ]
នោះសេចក្ដីទុក្ខលំបាកនឹងចំរើនជាច្រើនឡើងដល់គេ
ទូលបង្គំមិនព្រមច្រួចឈាមថ្វាយដល់ព្រះទាំងនោះឡើយ
ក៏មិនព្រមទាំងចេញឈ្មោះ[ឈ]របស់ព្រះទាំងនោះ ដោយ
បបូរមាត់ទូលបង្គំផង
៥ ព្រះយេហូវ៉ាទ្រង់ជាចំណែកនៃមរដក ហើយជាចំណែក[ញ]
ក្នុងពែងរបស់ទូលបង្គំ[ដ] គឺទ្រង់ហើយ

**១៥:២** ឃ លប ៦:៩ ទដ ១៨:៣២ អភ ១:៤ ១ថន ៣:១៣ ទត ១:៦ ង សភ ១៦:១៣ អស ៤៥:១៩ យរ ៧:២៨ ៩:៥ សក ៨:៣,១៦ រម ៩:១ អភ ៤:២៥ **១៥:៣** ច លវ ១៩:១៦ **១៥:៤** ឆ យប ១៩:៩ កច ២៨:១០ ជ ចទ ២៣:២១ យស ៩:១៨ មថ ៥:៣៣ **១៥:៥** ឈ នក ២២:២៥ ញ នក ១៨:២១ ១សយ ៨:៣ កច ២៤:២៦ ដ យប ២៩:១៨ ទដ ២១:៧ ១១២:៦ កច ២:២៥ ហព ១២:២៨ ២ពត ១:១០

**១៦:១** ក ទដ ១២:៧ ខ ទដ ២:១២ **១៦:២** គ ទដ ៣១:១៤ ១១៩:២៨ ១៤០:៦ ឃ ទដ ៧៣:២៥ **១៦:៣** ង ចទ ៣៣:៣ ទដ ៣០:៤ ៨៥:៨ ដយ ៧:១៨ កច ៩:១៣ រម ១:៧ ច ទដ ១០១:៦ **១៦:៤** ឆ ទដ ៣២:១០ សភ ២៣:២៩ ជ នក ១៨:១១ ២០:៣ ចទ ៨:១៩ ៣១:២០ ឈ នក ២៣:១៣ **១៦:៥** ញ លវ ២:២ ដ ទដ ២៣:៥ ៧៥:៨ ១១៦:១៣ អស ៥១:១៧ បទ ៤:២១ អគ ២៣:៣២–៣៤

**១៥:២–៥** ពុំបានថ្វាយជាយញ្ញបូជា ឬក៏ភាពបរិសុទ្ធ ជាច្បាប់ក្រម(ដូចជាជំនឿសាសនារបស់អ្នកភូមិភាគមជ្ឈឹមបូព៌ា) ប៉ុន្តែភាពសុចរិតដោយបន្ទាបខ្លួន គឺជាផ្លូវដែលអាចចូលទៅជិតព្រះ ជាព្រះនៃរាស្ត្ររបស់ជនជាតិអ៊ីស្រាអែល (សូមមើលច្បាប់សេចក្ដីព្រមព្រៀងជាមូលដ្ឋាន នក ២០:១–៧ សូមមើល អស ១:១០–១៧ ៣៣:១៤–១៦ ៥៨:៦–១០ យរ ៧:២–៧ អដ ១៨:៥–៩ ហស ៦:៦ អម ៥:១៤–១៥,២១–២៤ មីក ៦:៦–៨ សក ៧:១០ ៨:១៦–១៧) ។

**១៥:២** *គឺជាអ្នក . . . ប្រព្រឹត្តសេចក្ដីសុចរិត* គឺជាសេចក្ដីសង្ខេបអំពីសេចក្ដីផ្ដើម តាមលំដាប់លំដោយ ។ *ដោយទៀងត្រង់* ពោលគឺមានចិត្តស្លូតត្រង់ចំពោះព្រះ និងស្មោះត្រង់ចំពោះសេចក្ដីសញ្ញា សូមមើល លប ១៧:១ និងការពន្យល់ និងមើល ១៨:២៨ ៣៧:១៨ ៨៤:១ ១០១:២,៦ ១១៩:១,៨០ យស ២៤:១៤ ។ (មានសេចក្ដីស្មោះត្រង់គ្រប់ទាំងអស់) ពច ៩:១៦,១៩ (ភាពគួរគោរព)។ *សេចក្ដីសុចរិត* សូមមើល ការពន្យល់ ១:៥ ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**១៥:៣** *អណ្ដាត* សូមមើលការពន្យល់ ៥:៩ ។

**១៥:៤** *មនុស្សពាល* គឺជាមនុស្សត្រូវបានគេស្អប់ គេពុំបានឱ្យតម្លៃ គឺជាមនុស្សដែលព្រះពុំគាប់ព្រះហឫទ័យផងដែរ ពីព្រោះពួកគេប្រមាថមើលងាយដល់ព្រះ ។ *អ្នកដែលកោតខ្លាចដល់ព្រះ* គឺអ្នកដែលដើរតាមផ្លូវព្រះ គោរពព្រះឯជីវិតរបស់ពួកគេរស់នៅដោយពឹងផ្អែកលើព្រះហឫទ័យទ្រង់ (សូមមើល សប ២០:១១) ដោយព្រោះសេចក្ដីលន់តួរបស់ពួកគេចំពោះព្រះ ។

**១៥:៥** *យកការ* សូមមើលការពន្យល់ នក ២២:២៥–២៧ ។ *និងមិនត្រូវរង្គើឡើយ* សូមមើលការពន្យល់ ១០:៦ ។

**ទដ ១៦** គឺជាការអធិស្ឋានដើម្បីសុំភាពសុខសាន្ត គឺធាតុផ្សំពីការអធិស្ឋានទូលអង្វរក្នុងគម្ពីរទំនុកដំកើង ពីការអធិស្ឋានជារឿយៗ វគ្គអធិស្ឋានដែលមានទំនាក់ទំនងគ្នាខ្លីៗ (សូមមើល ៣:៧ ២២:១៩–២១ ៤៤:២៣–២៦) ។ ការសុំព្រះអម្ចាស់ការពារ និងគំរាមកំហែងដល់សេចក្ដីស្លាប់ ។ យោងទៅលើផ្ទៃរឿងជាអំណាចនោះ ក៏យើងអាចហៅបានថាវាជាទំនុកដំកើងនៃសេចក្ដីពិត ក្នុងការទំនាក់ទំនង និង ទដ ២៣ (ប្រៀបធៀប ១៦:២ ២៣:១ ១៦:៥ ២៣:៥ ១៦:៧–៨ និង ២៣:៤ ១៦:១១ និង ២៣:៦) ។ ឯបទទំនុកដំកើងទាំងពីរនេះ គឺសង្កត់ទៅលើសេចក្ដីជំនឿ ឬសេចក្ដីពិតដូចជាផ្នែកលក្ខណៈសម្បត្តិសំខាន់ទីពីរ (ដែលឈានទៅរកច្បាប់របស់ព្រះ មើលសេចក្ដីផ្ដើម ទដ ១៥–២៤) ចំពោះអ្នកដែលបានអធិស្ឋានទៅរកព្រះអម្ចាស់ (មើលសេចក្ដីផ្ដើម ទដ ១–២ សូមមើលការពន្យល់ ៣៤:៨–១៤) ។

**១៦:១** ខនេះផ្ដោតទៅលើការទូលអង្វរ និងមូលដ្ឋានសំខាន់ៗ ។ ឯផ្នែកចុងក្រោយនៃទំនុកដំកើងក៏បង្ហាញលំអិតទៅលើធាតុផ្សំទាំងអស់ ឬអត្ថន័យរឿងជាលក្ខណៈរួម ។

**១៦:២–៤** ព្រះយេហូវ៉ាគឺជាអង្គតែមួយគត់ដែលស្ដេចដាវីឌត្រូវការ គឺជាព្រះដ៏ពិតប្រាកដ មិនមែនជាព្រះក្លែងក្លាយទេ (សូមមើល ៤:២) ។

**១៦:៣** សូមមើល ទដ ១០១ និងការពន្យល់ ។

**១៦:៤** *សេចក្ដីទុក្ខលំបាក់នឹងចំរើន* តែក្នុងលក្ខណៈផ្ទុយភាពល្អរបស់ស្ដេចដាវីឌ"ជាចំណែក"(ខ.៥ និងការពន្យល់ ១១:៦) ដែលជំរុញឱ្យទ្រង់មានសេចក្ដីអំណរ (សូមមើល ៧៣:១៨–២៦) ។ *ច្រួចឈាមថ្វាយ* គឺជាការធ្វើយញ្ញបូរជាឈាមថ្វាយដែលពួកសង្ឃបានច្រួច ឬចាក់ទៅលើអាសនា ។ *ទាំងចេញឈ្មោះ* គឺបង្ហាញពីសកម្មភាពអ្វីមួយ ឬជាសកម្មភាពថ្វាយបង្គំរូបព្រះ (សូមមើល យស ២៣:៧) ។

**១៦:៥–៦** គឺជាសេចក្ដីអំណរចំពោះកេរ្តិ៍មរដក ដែលទទួលបានពីព្រះយេហូវ៉ា ។ ដូចជាស្ដេចដាវីឌ ដែលព្រះបានប្រទានពរដល់ទ្រង់ និងប្រជារាស្ត្ររបស់ទ្រង់ក្នុងទឹកដីសន្យា (សូមមើល ជន ១៦:១៤ ៧៣:២៦ ១១៩:៥៧

ដែលត្រួតមើលចំណែក[ប]ទូលបង្គំ
៦ខ្សែរង្វាស់[ផ]បានធ្លាក់នៅទីកន្លែងគាប់ចិត្តឱ្យទូលបង្គំ អើ
ទូលបង្គំបានទទួលមរដកល្អណាស់[ព]
៧ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ា ដែលទ្រង់ជួយគំនិត
ទូលបង្គំ[ណ] អើ ចិត្តក៏បង្គាប់ដល់ទូលបង្គំនៅវេលាយប់[ត]ដែរ
៨ទូលបង្គំបានតាំងព្រះយេហូវ៉ា នៅមុខទូលបង្គំជាដរាប
ហើយដោយព្រោះទ្រង់គង់នៅខាងស្តាំទូលបង្គំ[ថ]
បានជាទូលបង្គំមិនត្រូវរង្គើឡើយ[ទ]
៩ហេតុនោះចិត្តទូលបង្គំអរសប្បាយ[ធ]
ហើយកិត្តិយសនៃទូលបង្គំបានរីករាយឡើង
រូបសាច់នៃទូលបង្គំក៏នឹងនៅដោយសាន្តត្រាណដែរ[ន]
១០ដ្បិតទ្រង់មិនទុកឱ្យព្រលឹងទូលបង្គំ នៅក្នុងស្ថានឃុំព្រលឹង
មនុស្សស្លាប់ទេ[ប] ក៏មិនព្រមឱ្យអ្នកបរិសុទ្ធ[ផ]
របស់ទ្រង់ឃើញសេចក្តីពុករលួយដែរ[ព]
១១ទ្រង់នឹងបង្ហាញឱ្យទូលបង្គំឃើញផ្លូវជីវិតវិញ[ភ] នៅចំពោះ
ទ្រង់[ម]មានសេចក្តីអំណរ[យ]ដ៏ពោរពេញនៅព្រះហស្តស្តាំ
ទ្រង់មានសេចក្តីអរសប្បាយជាដរាបតទៅ[រ] ។

សេចក្តីអធិស្ឋានរបស់ស្តេចដាវីឌ ។

**១៧** ឱព្រះយេហូវ៉ាអើយ សូមស្តាប់[ក]សេចក្តីដែលទៀង
ត្រង់ សូមប្រុងស្តាប់សំរែកនៃទូលបង្គំផង[ខ]
សូមផ្ទៀងព្រះកាណ៌[គ] ស្តាប់សេចក្តីអធិស្ឋានរបស់ទូលបង្គំ
ជាសេចក្តីអធិស្ឋាន ដែលមិនចេញពីបបូរមាត់មានពុតទេ[ឃ]
២សូមឱ្យការសំរេចក្តី[ង]របស់ទូលបង្គំ
បានចេញពីចំពោះទ្រង់មក
សូមឱ្យព្រះនេត្រទ្រង់ទតចំពោះសេចក្តីទៀតត្រង់[ច]
៣ទ្រង់បានសាកលចិត្ត[ឆ]ទូលបង្គំហើយ
ទ្រង់បានពិចារណាទូលបង្គំនៅវេលាយប់
ទ្រង់បានពិនិត្យរឿងទូលបង្គំ[ជ] ឥតឃើញកំហុសអ្វីសោះ[ឈ]
ទូលបង្គំបានសំរេចចិត្តថា មិនឱ្យមាត់រំលងច្បាប់ឡើយ[ញ]

**១៦:៥** ឋ យប ៣១:២ ហព ២:១៦ **១៦:៦** ឌ ចទ ១៩:១៤ ទដ ១០៤:៩ សភ ៨:២៩ យរ ៥:២២ ឍ យប ២២:២៦ **១៦:៧** ណ ទដ ៧៣:២៤ សភ ១៥:២២ អស ១១:២ ត យប ៣៥:១០ ទដ ៤២:៨ ៧៧:៦ **១៦:៨** ថ ១ពវ ២:១៩ ១រប ៦:៣៩ ទដ ៧៣:២៣ ទ ទដ ១៥:៥ **១៦:៩** ធ ទដ ៤:៧ ១៣:៥ ២៨:៧ ៣០:១១ ន ចទ ៣៣:២៨ **១៦:១០** ប ជន ១៦:៣០ ទដ ៣០:៣ ៣១:១៧ ៨៦:១៣

ហស ១៣:១៤ ផ ២ពវ ១៩:២២ ព យប ១៧:១៤ កច ២:៣១ ១៣:៣៥ **១៦:១១** ភ ទដ ១៣៩:២៤ មថ ៧:១៤ ម កច ២:២៥–២៨ យ ទដ ២១:៦ រ ទដ ៨០:១៧ **១៧:១** ក ទដ ៣០:១០ ៦៤:១ ៨០:១ ១៤០:៦ ខ ទដ ៥:២ ៣៩:១២ ១៤២:៦ ១៤៣:១ **១៧:១** គ ទដ ៥:១ ឃ អស ២៩:១៣ **១៧:២** ង ទដ ២៤:៥ ២៦:១ អស ៤៦:១៣ ៥០:៨–៩ ៥៤:១៧ ច ទដ ៩៩:៤ **១៧:៣** ឆ ទដ ១៣៩:១ យរ ១២:៣ ជ យប ៧:១៨ ឈ យប ២៣:១០ យរ ៥០:២០ ញ ទដ ៣៩:១

១៤២:៥ បទ ៣:២៤) ។

**១៦:៥** *ពែង* ជាពាក្យប្រៀបប្រដូច និងការថ្វាយរបស់ម្ចាស់កម្មវិធីក្នុងការធ្វើបុណ្យប្រារព្ធអ្វីមួយ ទៅឱ្យភ្ញៀវដែលចូលរួមឱ្យទទួលទានភេសជ្ជៈ ។ គឺជាព្រះពរដែលព្រះយេហូវ៉ាប្រទានឱ្យ (សូមមើល ២៣:៥) ឬក៏សេចក្តីសង្គ្រោះ (សូមមើល ១១៦:១៣) ទ្រង់ក្រោធ(មើល យរ ២៥:១៥ វវ ១៤:១០ ១៦:១៩) ។ *ត្រួតមើល* ដូចជាពួកគ្រួរាស្ត្រអ៊ីស្រាអែល ដែលទទួលបានមរដក ដូចជាទឹកដីសន្យាដើម្បីត្រួតត្រា (សូមមើល លវ ២៥ ជន ៣៦:៧) ។

**១៦:៧–៨** ជាការសរសើរព្រះយេហូវ៉ាដែលបានប្រទានជាតម្រុយឱ្យដើរ ។

**១៦:៧** *ជួយគំនិត* ជាការបង្ហាញផ្លូវដើម្បីឆ្ពោះទៅរកជីវិត (មើល ខ.១១) ។ *ចិត្ត* សំដៅលើភាព"សប្បុរស" (សូមមើលការពន្យល់ ៧:៩) ។ សេចក្តីខាងលើគឺសំដៅលើភាពមានមនសិការ ។

**១៦:៨** *ទ្រង់គង់នៅខាងស្តាំទូលបង្គំ* គឺទ្រង់ជាព្រះតែងតែទ្រទ្រង់ទូលបង្គំ ឬជាអ្នកការពារទូលបង្គំ (សូមមើល ៧៣:២៣ ១០៩:៣១ ១១០:៥ ១២១:៥ គឺការបំពេញន័យដោយការសំអាងលើពាក្យថា ទ្រង់គង់នៅខាងស្តាំទូលបង្គំ មានក្នុង ខ.១១ ។ *មិនត្រូវរង្គើឡើយ* សូមមើលការពន្យល់ ១០:៦ ។

**១៦:៩–១១** ពណ៌នាពីសេចក្តីអំណរនៃភាពសុខសាន្តរួម ដែលព្រះផ្តល់នូវការថែរក្សាដ៏ស្មោះត្រង់ពីទ្រង់ ។ ស្តេចដាវីឌបាននិយាយដោយអង្គទ្រង់ផ្ទាល់ និងពីជីវិតដែលទ្រង់មានអំណរដោយព្រះគុណបានប្រទានមក និងការការពាររបស់ព្រះអម្ចាស់ ។ គឺព្រះយេហូវ៉ានេះហើយដែលអ្នកនិពន្ធបទទំនុកដំកើងយកជាទីជ្រកកោន និងថ្វាយជីវិត (សូមមើល ១៧:១៥ ៧៣:២៤ សូមមើលការពន្យល់ ១១:៧) ។ ក៏មានការអធិស្ឋានរបស់ស្តេចដាវីឌ ដូចជាពាក្យសន្យារបស់ទ្រង់ផ្ទាល់ និងដូចជាលោកពេត្រុសដែលបានកត់សំគាល់នៅក្នុង ខ.៨–១១ និងការប្រកាសថាពាក្យពេជ្រទាំងនេះ ដែលដាវីឌបានថ្លែងពីទំនាយនៃព្រះគ្រីស្ទ និងការដែលទ្រង់មានព្រះជន្មរស់ឡើងវិញ (កច ២:២៥–២៨ សូមមើលការប្រើពាក្យរបស់លោកប៉ុល ដែលមានលក្ខណៈស្រដៀងក្នុង ខ.១០ កច ១៣:៣៥ និងការពន្យល់ ៦:៥) ។

**១៦:៩** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**១៦:១០** *អ្នកបរិសុទ្ធ* (សូមមើលការពន្យល់ ៤:៣ និង ២:២) ។

**១៦:១១** *ផ្លូវជីវិត* សូមមើល សភ ១៥:២៤ ។ *ព្រះហស្តស្តាំទ្រង់* សូមមើលការពន្យល់ ខ.៨ ។

**ទដ ១៧** ស្តេចដាវីឌក៏បង្ហាញចំពោះព្រះយេហូវ៉ា ក្នុងនាមព្រះជាចៅក្រម គឺគ្រាដែលស្តេចដាវីឌត្រូវបានសត្រូវវាយប្រហារនោះ ។ ហើយនៅក្នុងខណៈនោះស្តេចដាវីឌបានអធិស្ឋានទូលអង្វរ សូមឱ្យព្រះជួយការពារផងដែរ មើល ២២ (សូមមើលសេចក្តីផ្តើម ទដ ១៥–២៤) ។

**១៧ ចំណងជើង** គឺជាការអធិស្ឋាន សូមមើលចំណងជើង ទដ ៨៦:៩០,១០២, ១៤២ សូមមើល ៧២:២០ ។

**១៧:១–២** បង្ហាញពីភាពយុត្តិធម៌ ។

**១៧:១** *សេចក្តីដែលទៀងត្រង់ សូមប្រុងស្តាប់សំរែកនៃទូលបង្គំ* គឺជាការទាមទាសុំឱ្យមានភាពយុត្តិធម៌ឯការថែរក្សារបស់ទ្រង់ គឺមានភាពយុត្តិធម៌មិនតាមពួកមានបបូរមាត់ភូតភរឡើយ (ចំពោះស្ថានភាពដូចគ្នានេះដែរសូមមើល ១សយ ២៤:១៥) ។

**១៧:៣–៥** ជាវគ្គស្តេចដាវីឌបានប្រកាសពីភាពគ្មានកំហុស ដែលតែងតែគាំទ្រភាពសុចរិតដូចជាអង្គទ្រង់ផ្ទាល់ ដែលដើរក្នុងភាពសុចរិត ។ ស្តេចដាវីឌពុំបាន ឬមានការអាក្រក់ណាមួយប្រឆាំងនឹងព្រះយេហូវ៉ាឡើយ តែស្តេចដាវីឌយកព្រះជាគំរូ (ប្រៀបធៀប ១៣៩:២៣–២៤) ។

**១៧:៣** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

៤ឯត្រង់ការប្រព្រឹត្តរបស់មនុស្ស នោះទូលបង្គំបានរវាំងខ្លួន
ឱ្យរួចពីផ្លូវនៃមនុស្សច្រឡោត ដោយសារព្រះបន្ទូល
ពីព្រះឱស្ឋទ្រង់
៥ទូលបង្គំបានឈានជាប់ទៅតាមផ្លូវច្រករបស់ទ្រង់[ដ]
ជើងទូលបង្គំមិនបានរឥលឡើយ[ឋ]
៦ឱព្រះអង្គអើយ ទូលបង្គំបានអំពាវនាវដល់ទ្រង់
ដ្បិតទ្រង់នឹងមានបន្ទូលឆ្លើយមកទូលបង្គំ[ឌ]
សូមទ្រង់ផ្ទៀងព្រះកាណ៌[ឍ]
មកស្តាប់ពាក្យរបស់ទូលបង្គំផង[ណ]
៧ឱព្រះដ៏ជួយសង្គ្រោះដោយព្រះហស្តស្តាំ[ត]
ចំពោះអស់អ្នកដែលពឹង[ថ]ទ្រង់ឱ្យគេបានរួចពីពួកអ្នកតតាំង
អើយ
សូមទ្រង់សំដែងសេចក្តីសប្បុរសដ៏ប្រាកដច្បាស់មកផង[ទ]
៨សូមការពាររក្សា[ធ]ទូលបង្គំ ដូចជាប្រស្រីភ្នែក[ន]
សូមបាំងទូលបង្គំ[ប] នៅក្រោមម្លប់ចំអេងស្លាបរបស់ទ្រង់[ផ]
៩ឱ្យទូលបង្គំបានរួចពីមនុស្សអាក្រក់ដែលសង្កត់សង្កិនទូល
បង្គំ ជាពួកសត្រូវយ៉ាងសាហាវ
ដែលឡោមព័ទ្ធទូលបង្គំជុំវិញ[ព]
១០គេបិតភ្ជិតជុំវិញ ដោយខ្លាញ់របស់គេ[ភ]
ហើយមាត់គេពោលតែពាក្យព្រហើន[ម]
១១ឥឡូវនេះគេបានព័ទ្ធយើងខ្ញុំជុំវិញ[យ]
នៅអស់ទាំងជំហានរបស់យើងខ្ញុំហើយ
គេផ្តោតភ្នែកជាប់នឹងយើងខ្ញុំ ដើម្បីផ្តួលដល់ដី
១២គេដូចជាសត្វសិង្ហ[រ] ដែលរវះរវាមនឹងហែកស៊ី[ល]
ហើយដូចជាកូនសិង្ហ ដែលលបចាំនៅទីសាត់ចំបាំង
១៣ឱព្រះយេហូវ៉ាអើយ សូមទ្រង់ក្រោកឡើង[វ] រាំងផ្លូវគេ
សូមផ្តួលគេចុះ[ស]
ហើយជួយព្រលឹងទូលបង្គំឱ្យរួចពីមនុស្សអាក្រក់
ដោយសារដាវនៃទ្រង់
១៤ឱ្យរួចពីមនុស្សដោយព្រះហស្តទ្រង់ ឱព្រះយេហូវ៉ាអើយ
គឺឱ្យរួចពីមនុស្សនៅលោកីយនេះ[ហ]ដែលមានចំណែក
របស់គេនៅតែក្នុងជីវិតនេះប៉ុណ្ណោះ[ឡ]
ហើយដែលពោះគេបានឆ្អែត ដោយសារទ្រព្យរបស់ទ្រង់
គេបានស្កប់ចិត្តដោយមានកូនច្រើន
ហើយក៏ចែកសំណល់នៃសម្បត្តិ[អ]គេដល់កូនចៅតរបស់ខ្លួន
១៥ឯទូលបង្គំវិញ ទូលបង្គំនឹងរំពឹងមើលព្រះភក្ត្រទ្រង់ដោយ
សេចក្តីសុចរិត កាលណាទូលបង្គំភ្ញាក់ឡើង[ក]
នោះនឹងបានស្កប់ចិត្ត ដោយឃើញរូបអង្គទ្រង់[ខ] ។

**១៧:៥** ដ យបប ២៣:១១ ទដ ៤៤:១៨ ១១៩:១៣៣ ឋ ចទ ៣២:៣៥ ទដ ៧៣:២ ១២១:៣
**១៧:៦** ឌ ទដ ៨៦:៧ ឍ ទដ ១១៦:២ ណ ទដ ៤:១
**១៧:៧** ត ទដ ១០:១២ ថ ទដ ២:១២ ទ ទដ ៣១:២១ ៦៩:១៣ ១០៦:៤៥ ១០៧:៤៣ ១១៧:២
**១៧:៨** ធ ជន ៦:២៤ ន ចទ ៣២:១០ សភ ៧:២ ប ទដ ២៧:៥ ៣១:២០ ៣២:៧ ផ នរ ២:១២ ទដ ៣៦:៧ ៦៣:៧ អស ៣៤:១៥
**១៧:៩** ព ទដ ១០៩:៣
**១៧:១០** ភ ទដ ៧៣:៧ ១១៩:៧០ អស ៦:១០ ម ១សយ ២:៣
**១៧:១១** យ ទដ ៨៨:១៧

**១៧:១២** រ ទដ ៧:២ យរ ៥:៦ ១២:៨ បទ ៣:១០ ល លប ៤៩:៩ **១៧:១៣** វ ជន ១០:៣៥ ស ទដ ៣៥:៨ ៥៥:២៣ ៧៣:១៨ **១៧:១៤** ហ លក ១៦:៨ ឡ ទដ ៤៩:១៧ លក ១៦:២៥ អ អស ២:៧ ៥៧:១៧ **១៧:១៥** ក ទដ ៣:៥ ខ ជន ១២:៨ មថ ៥:៨ ១យហ ៣:២

**១៧:៤** *ដោយសារព្រះបន្ទូលពីព្រះឱស្ឋទ្រង់* ជាព្រះទ័យទ្រង់ដែលបានបើកសម្តែង ដែលធ្វើឱ្យស្គាល់"ផ្លូវ" ហើយចំណែកឯមនុស្សទាំងឡាយដែលជារាស្ត្រទ្រង់ជាអ្នកដើរ ។

**១៧:៦–៩** ជាអត្ថបទបែបទូលសូម ដែលស្តេចដាវីឌចង់បានទូលសូមឱ្យព្រះយេហូវ៉ាសម្រេចទៅតាមសេចក្តីសប្បុរសរបស់ទ្រង់ (មើល ខ.២) ។

**១៧:៦** *ទូលបង្គំបានអំពាវនាវ . . . ឆ្លើយមកទូលបង្គំ* សូមមើលការពន្យល់ ១១៨:៥ ។

**១៧:៧** ជាភាពអស្ចារ្យរបស់ផងទ្រង់ដែលបានសម្តែង សូមមើល ៩:១ ។ *សេចក្តីស្បុរស* សូមមើលការពន្យល់ ៦:៤ ។

**១៧:៨** *ប្រស្រីភ្នែក* សូមមើលការពន្យល់ ចទ ៣២:១០ ។ *ម្លប់* ព្រះគម្ពីរភាសាហេព្រើរប្រើពាក្យនោះ ប្រៀបប្រដូចទៅនឹងការការពារនៅពេលដែលមានការគៀបសង្កត់ គឺដូចជាម្លប់ការពារកំដៅថ្ងៃនៅឯទីរហោរស្ថានផងដែរ ។ ឯព្រះមហាក្សត្រគេចាត់ទុកថា ជាអង្គមួយដែលជាម្លប់ដល់អស់អ្នកណាដែលពឹងផ្អែកលើទ្រង់ (មើល ជន ១៤:៩ "ការការពារ" តាមបែបអក្សរសាស្ត្រមានន័យថា "ម្លប់" បទ ៤:២០ អគ ៣១:៦,១២,១៧) ។ គឺមានសណ្ឋានដូចអង្គព្រះយេហូវ៉ាដែលការពាររាស្ត្ររបស់ទ្រង់ ដោយទ្រង់គឺជាម្លប់ដ៏ត្រជាក់ដល់រាស្ត្រទ្រង់ (សូមមើល ៩១:១ ១២១:៥ អស ២៥:៤ ៤៩:២ ៥១:១៦) ។ *ចំអេងស្លាប* ជាពាក្យប្រៀបប្រដូចនៅនឹងពាក្យថា"ការការពារ" ដោយសារអំណាចចេស្តារបស់ទ្រង់ ដើម្បីឈោងចាប់យករាស្ត្រទ្រង់និងការពារឱ្យផុតពីអំណាចងងឹតរបស់លោកិយ (សូមមើល ៣៦:៧ ៥៧:១ ៦១:៤ ៦៣:៧ ៩១:៤ នរ ២:១២ និង មថ ២៣:៣៧) ។

**១៧:១០–១២** ជាវគ្គតតាំងប្រឆាំងនឹងពួកសត្រូវដ៏សាហាវ (សូមមើលការពន្យល់ ៥:៩–១០) ។

**១៧:១០** *មាត់* សូមមើលការពន្យល់ ៥:៩ ។ *ពោលពាក្យព្រហើន* សូមមើលការពន្យល់ ១០:១១ ។

**១៧:១២** *សត្វសិង្ហ* សូមមើលការពន្យល់ ៧:២ ។

**១៧:១៣–១៤ក** គឺជាវគ្គទូលអង្វរ : ឃើញថាតើស្តេចដាវីឌចង់ឱ្យព្រះយេហូវ៉ាដោះស្រាយចំពោះបញ្ហារឿងជម្លោះដោយវិធីណា ។

**១៧:១៣** *សូមទ្រង់ក្រោកឡើង* សូមមើលការពន្យល់ ៣:៧ ។ *សូមផ្តួលគេចុះ* សូមមើលការពន្យល់ ៥:១០ ។ *ដាវនៃទ្រង់* សូមមើល ៧:១២–១៣ និងការពន្យល់ ។

**១៧:១៤** *ពីមនុស្ស* សូមមើល ៩:១៩–២០ ១០:១៨ ១២:១–៤ ១៤:១–៣ ។

**១៧:១៤ខ–១៥** ការបង្ហាញពីការលន់តួបាប (សូមមើលការពន្យល់ ៣:៨)។

**១៧:១៥** *ដោយសេចក្តីសុចរិត* សំដៅលើការកាត់ទោសដោយភាពសុចរិត (សូមមើលការពន្យល់ ៤:១) ដែលទទួលស្គាល់ និងបង្ហាញថាឥតមានកំហុសដល់អ្នកសុចរិត ដែលជាអ្នកទូលអង្វរ ។ *មើលព្រះភក្ត្រទ្រង់* សូមមើលការពន្យល់ ១១:៧ ។ *កាលណាទូលបង្គំភ្ញាក់ឡើង* គឺជាការភ្ញាក់ពីរាត្រីនៃសេចក្តីស្លាប់ (សូមមើលការពន្យល់ ១១:៧) គឺមានលក្ខណៈផ្ទុយស្រឡះ

*១៨:ចំណងជើង–៥០ – ២សយ ២២:១–៥១*

ទំនុកសិរាប់មេភ្លេង ដែលស្ដេចដាវីឌ ជាអ្នកបំរើនៃព្រះយេហូវ៉ា បានលើក ទ្រង់បានទូលអស់ទាំងពាក្យនៃទំនុកនេះដល់ព្រះយេហូវ៉ា នៅវេលាដែលព្រះបានជួយឱ្យរួចពីដៃនៃគ្រប់ទាំងពួកខ្មាំងសត្រូវ ហើយពីកណ្ដាប់ដៃសូល គឺទ្រង់ទូលថា–

**១៨** ឱព្រះយេហូវ៉ាដ៏ជាកំឡាំង[ក]នៃទូលបង្គំអើយ
ទូលបង្គំស្រឡាញ់ទ្រង់
២ ព្រះយេហូវ៉ាទ្រង់ជាថ្មដា[ខ] ជាបន្ទាយ[គ] ហើយជាអ្នកជួយ
សង្គ្រោះ[ឃ] របស់ទូលបង្គំ គឺជាព្រះនៃទូលបង្គំ
ជាថ្មដាដែលទូលបង្គំយកជាទីពឹង[ង] ក៏ជាខែល[ច]
ជាស្នែងនៃសេចក្ដីសង្គ្រោះ[ឆ]របស់ទូលបង្គំហើយ
ជាប៉មយ៉ាងខ្ពស់ផង
៣ ទូលបង្គំនឹងអំពាវនាវដល់ព្រះយេហូវ៉ាដែលទ្រង់គួរ
សរសើរ[ជ] យ៉ាងនោះទូលបង្គំនឹងបានសង្គ្រោះ
រួចពីពួកសត្រូវរបស់ទូលបង្គំ[ឈ] ។
៤ ឯចំណងនៃសេចក្ដីស្លាប់[ញ]បានរុំជុំវិញទូលបង្គំ
ហើយជំនន់នៃសេចក្ដីទុច្ចរិត[ដ]បានបំភ័យទូលបង្គំ
៥ ចំណងនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ក៏រួបជុំវិញទូលបង្គំ
អន្ទាក់នៃសេចក្ដីស្លាប់[ឋ]បានទាក់ទូលបង្គំ
៦ ក្នុងគ្រាដែលទូលបង្គំមានសេចក្ដីវេទនា[ឌ]
នោះបានអំពាវនាវដល់ព្រះយេហូវ៉ា[ឍ]
ទូលបង្គំបានស្រែកទូលដល់ព្រះនៃទូលបង្គំ
ទ្រង់ក៏ឮសំឡេងទូលបង្គំ[ណ] ពីក្នុងព្រះវិហារទ្រង់
ហើយសំរែកដែលទូលបង្គំស្រែក[ត]
នៅចំពោះទ្រង់ក៏ឮដល់ព្រះកាណ៌ទ្រង់
៧ នោះផែនដីបានកក្រើក[ថ] ឫសភ្នំទាំងប៉ុន្មានក៏ញ័ររញ្ជួយ[ទ]

**១៨:១** ក នក ១៥:២ ចទ ៣៣:២៩ ១សយ ២:១០ ទដ ២២:១៩ ២៨:៧ ៥៩:៩ ៨១:១ អស ១២:២ ៤៩:៥ យរ ១៦:១៩ **១៨:២** ខ នក ៣៣:២២ គ ទដ ២៨:៨ ៣១:២,៣ អស ១៧:១០ យរ ១៦:១៩ ឃ ទដ ៤០:១៧ ង ទដ ២:១២ ៩:៩ ៩៤:២២ ច លប ១៥:១ ទដ ២៨:៧ ៨៤:៩ ១១៩:១១៤ ១៤៤:២ ឆ ១សយ ២:១ លក ១:៦៩ **១៨:៣** ជ ១របា ១៦:២៥ ឈ ទដ ៩:១៣ **១៨:៤** ញ ទដ ១១៦:៣ ដ ទដ ៩៣:៤ ១២៤:៤ អស ៥:៣០ ១៧:១២ យរ ៦:២៣ ៥១:៤២, ៥៥ អក ៤៣:២ **១៨:៥** ឋ សភ ១៣:១៤ **១៨:៦** ឌ ចទ ៤:៣០ ឍ ទដ ៣០:២ ៩៩:៦ ១០២:២ ១២០:១ ណ ទដ ៦៦:១៩ ១១៦:១ ត យប ១៦:១៨ **១៨:៧** ថ ទដ ៩៧:៤ អស ៥:២៥ ៦៤:៣ ទ ពច ៥:៤

ពី"វាសនារបស់លោកិយ"(ខ.១៤ មើលការពន្យល់ ៦:៥ ១៦:៩–១១) ។ *ដោយឃើញរូបទ្រង់* គឺដូចជាលោកម៉ូសេ ដែលជាអ្នកបម្រើរបស់ព្រះយេហូវ៉ាបានឃើញរូបអង្គទ្រង់ដូច្នេះដែរ (សូមមើល ជន ១២:៨) ។

**ទដ ១៨** គឺជាចម្រៀងរបស់ស្ដេចដាវីឌ បានបង្ហាញឱ្យឃើញក្នុងការតែងនិពន្ធ ដែលមានខុសពីវគ្គក្នុងសេចក្ដីផ្ដើម និងវគ្គបញ្ចប់ (ខ.១–៣)និង (ខ.៤៦–៥០) បទចម្រៀងបានតែងឡើង ដោយចែកជាបីវគ្គសំខាន់ៗ (១). ព្រះយេហូវ៉ាបានរំដោះ និងសង្គ្រោះស្ដេចដាវីឌឱ្យរួចពីពួកខ្មាំងសត្រូវដ៏សាហាវ គឺក្នុងខណៈពេលដែលស្ដេចដាវីឌស្រែកអំពាវនាវរកទ្រង់ ដើម្បីជួយ (ខ.៤–១៩) ។ (២).ពីមូដ្ឋានសីលធម៌ចំពោះការជួយសង្គ្រោះរបស់ព្រះយេហូវ៉ា (ខ.២០–២៩) ។ (៣).សេចក្ដីជំនួយពីព្រះបង្ហាញបញ្ជាក់ (ខ.៣០–៤៥) ការអបអរសាទររបស់ស្ដេចដាវីឌចំពោះការជួយសង្គ្រោះរបស់ព្រះអម្ចាស់ក្នុងការឆ្លើយតប និងការអធិស្ឋានក្នុងគ្រាត្រូវបានពួកសត្រូវបៀតបៀនធ្វើទុក្ខ (ទដ ២០–២១ មើលសេចក្ដីផ្ដើម ទដ ១៥–២៤) ។

**១៨ ជាចំណងជើង** *ទំនុកសំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ជាអ្នកបំរើនៃព្រះយេហូវ៉ា* សូមមើល ៧៨:៧០ ៨៩:៣,២០, ៣៩ ១៣២:១០ ១៤៤:១០ ដូចជាការត្រាស់ហៅស្ដេចដាវីឌទុកជាមុន ដើម្បីគ្រងរាជ្យជាស្ដេចគ្រប់គ្រងលើគ្រប់អស់ទាំងរាស្ត្រ (សូមមើល ២សយ ៧:៥) ដូចជាលោកម៉ូសេ (សូមមើល នក ១៤:៣១ និងការពន្យល់) លោកយ៉ូស្វេ (សូមមើល យស ២៤:២៩) និងពួកហោរា(អេលីយ៉ា ២ពវ ៩:៣៦ លោកយ៉ូណាស ២ពវ ១៤:២៥ លោកអេសាយ អស ២០:៣ លោកដានីយ៉ែល ដយ ៦:២០) ។ *ពាក្យនៃទំនុក* សូមមើលការពន្យល់ ទដ ៣០ ចំណងជើង ។ *ទ្រង់បានទទួលអស់ទាំងពាក្យនៃទំនុកនេះ* គឺក្នុងខណៈពេលដែលស្ដេចដាវីឌបានទទួលជ័យជម្នះលើពួកខ្មាំសត្រូវប្រទេសក្រៅ ទ្រង់ក៏និពន្ធបទទំនុកនេះឡើង (២សយ ៨:១–១៤) ។

**១៨:១–៣** ការសរសើរតម្កើង ។

**១៨:១** ក៏ពុំមានឃើញក្នុង ២សយ ២២ ។ *ទូលបង្គំស្រឡាញ់ទ្រង់* គឺដកស្រង់ចេញពីព្រះគម្ពីរភាសាហេព្រើរ ដែលសង្កត់ធ្ងន់ទៅលើសេចក្ដីស្រឡាញ់របស់ស្ដេចដាវីឌ ។

**១៨:២** *ជាថ្មដា . . . ជាថ្មដា* មានការបកប្រែចេញពីភាសាហេព្រើរពីរបែបខុសគ្នាពីពាក្យថា"ថ្មដា"វាជាអត្ថបទកំណាព្យរួមមួយ សម្គាល់ទៅលើព្រះ (រូបព្រះ) ផ្សេងៗ ចទ ៣២:៣១,៣៧ អស ៤៤:៨ ។ គឺជានិមិត្តមួយបង្ហាញពីភាពឥតប្រែប្រួលនៃព្រះ (សូមមើល អស ២៦:៤) ភាពមានកម្លាំងដូចជាបន្ទាយលាក់ខ្លួនយ៉ាងរឹងមាំ (សូមមើល ខ.៣១,៤៦ ៣១:២–៣ ៤២:៩ ៦២:៧ ៧១:៣ ៩៤:២២ អស ១៧:១០) ដូចជាអ្នករំដោះសង្គ្រោះ (សូមមើល ១៩:១៤ ៦២:២ ៧៨:៣៥ ៨៩:២៦ ៩៥:១ ចទ ៣២:១៥) ក៏បង្ហាញពីភាពមានបទពិសោធន៍របស់ស្ដេចដាវីឌ (សូមមើល ១សយ ២៣:១៤,២៥ ២៤:២, ២២ ២៦:២០) ដោយព្រោះព្រះយេហូវ៉ា គឺជាទីសន្តិភាពដល់ជីវិតទ្រង់យ៉ាងពិតប្រាកដ សូមមើលការពន្យល់ ២សយ ២២:២ ។

**១៨:៤–៦** ដោយព្រះអម្ចាស់ឮនូវការអំពាវនាវរបស់ស្ដេចដាវីឌ ដើម្បីសុំជំនួយមកពីព្រះ ។

**១៨:៤** *ចំណង* ២សយ ២២:៥ មានដូចជាចំណងនៃសេចក្ដីស្លាប់ ។ *ជំនន់នៃសេចក្ដីទុច្ចរិតបានបំភ័យ* សូមមើលការពន្យល់ ៣០:១ ។

**១៨:៥** *ចំណងនៃស្ថានឃុំព្រលឹងមនុស្សស្លាប់* សូមមើល ១១៦:៣ អន្ទាក់នៃសេចក្ដីស្លាប់ក៏បានទាក់ជាប់ដល់ស្ដេចដាវីឌ ហើយក៏មានសណ្ឋានដូចជាអ្នកទោសនៃស្ថានឃុំព្រលឹង (សូមមើល យប ៣៦:៨) ។

**១៨:៦** *ព្រះវិហារទ្រង់* គឺជាស្ថានសួគ៌របស់ព្រះ ក៏ជាទីកន្លែងដែលទ្រង់សោយរាជ្យ (សូមមើល ១១:៤ ១១៣:៥ អស ៦:១ ៤០:២២) ។

**១៨:៧–១៥** ព្រះយេហូវ៉ាយាងមកជួយសង្គ្រោះ បានបម្រើរបស់ទ្រង់ ក៏នាំយកទ័ពស្ថានសួគ៌ចុះមកប្រយុទ្ធនឹងសត្រូវរបស់ស្ដេចដាវីឌ (សូមមើល ៥:៤–៥ ៦៨:១–៨ ៧៧:១៦–១៩ មីក ១:៣–៤ ណាហ ១:២–៦ ហាប ៣:៣–១៥) ។ ទ្រង់យាងចុះមកដូចជាភ្លើង ព្យុះ ផ្គរ រន្ទះ (សូមមើល យស ១០:១១ ពច ៥:២០–២២ ១សយ ២:១០ ៧:១០ ២សយ ៥:២៤ អស ២៩:៦) ។

ហើយរំពើកឡើង[ធ] ពីព្រោះទ្រង់មានសេចក្តីក្រោធ[ន]
៨ មានផ្សែងហុយចេញពីព្រះនាសាទ្រង់[ប]
ហើយមានភ្លើង[ផ] ចេញពីព្រះឱស្ឋទ្រង់មកបញ្ឆេះ[ព]
បំផ្លាញក៏កាត់ឡើងជារងើកដែរ
៩ ទ្រង់បានបន្ទាបផ្ទៃមេឃ
ហើយយាងចុះមក[ភ] មានងងឹត[ម] យ៉ាងក្រាស់
នៅក្រោមព្រះបាទទ្រង់
១០ ទ្រង់គង់លើចេរូប៊ីន[យ] ហោះមក
អើ ទ្រង់ក៏សំកាំង[រ] នៅលើខ្យល់[ល]
១១ ទ្រង់បានយកសេចក្តីងងឹតធ្វើជាទីបាំងអង្គទ្រង់[វ]
ជាពន្លា[ស] នៅព័ទ្ធជុំវិញ គឺជាទីងងឹតនៃទឹក
ជាពពកយ៉ាងក្រាស់នៅលើមេឃ
១២ ពពកយ៉ាងក្រាស់របស់ទ្រង់ក៏រសាត់ចេញ
ដោយរស្មីនៅចំពោះ[ហ] ទ្រង់
ព្រមទាំងព្រឹល[ឡ] និងរងើកភ្លើងផង[អ]
១៣ ព្រះយេហូវ៉ាទ្រង់បញ្ចេញជាផ្គរ[ក] នៅលើមេឃ
ព្រះដ៏ខ្ពស់បំផុត ទ្រង់បញ្ចេញព្រះសូរសៀង
ព្រមទាំងព្រឹល នឹងរងើកភ្លើងផង
១៤ ក៏បាញ់ព្រួញ[ខ] នៃទ្រង់ទៅកំចាត់កំចាយគេ
និងរន្ទះជាច្រើន[គ] ទៅបំបាក់ពួកគេ[ឃ]
១៥ នោះបាតផ្លូវទឹកក៏លេចឡើង
ហើយឫស[ង] លោកីយបានបើកឱ្យឃើញ
ដោយទ្រង់បន្ទោស[ច] ឱព្រះយេហូវ៉ាអើយ
គឺដោយឮសូរខ្យល់គំហុក ចេញពីព្រះនាសាទ្រង់[ឆ]
១៦ ទ្រង់បានចាត់ពីលើស្ថានដ៏ខ្ពស់មក
ចាប់ស្រង់ទូលបង្គំចេញពីទឹកធំ[ជ]
១៧ ទ្រង់បានដោះទូលបង្គំឱ្យរួចពីខ្មាំងសត្រូវដ៏ខ្លាំងពូកែ[ឈ]
ហើយពីអស់អ្នកដែលស្អប់ទូលបង្គំដែរ
ដ្បិតគេមានកំឡាំងជាងទូលបង្គំ[ញ]
១៨ នៅថ្ងៃដែលទូលបង្គំត្រូវវេទនា[ដ]
នោះគេបានសង្កត់មកលើទូលបង្គំ
ប៉ុន្តែព្រះយេហូវ៉ា ទ្រង់ជាជន្ទល់នៃទូលបង្គំ[ឋ]
១៩ ទ្រង់បាននាំទូលបង្គំចេញទៅនៅឯទីធំទូលាយ[ឌ]
ទ្រង់បានដោះទូលបង្គំឱ្យរួច
ដ្បិតទ្រង់ស្រឡាញ់ដល់ទូលបង្គំ[ឍ]
២០ ព្រះយេហូវ៉ាទ្រង់បានប្រទានរង្វាន់មក
តាមសេចក្តីសុចរិតរបស់ទូលបង្គំ[ណ]
ទ្រង់បានសងទូលបង្គំ[ត] តាមសេចក្តីបរិសុទ្ធនៃដៃទូលបង្គំ[ថ]

**១៨:៧** ធ ពច ៥:៥ ន យប ៩:៥ យរ ១០:១០ **១៨:៨** ប យប ៤១:២០ ផ នក ១៥:៧ ១៩:១៨ យប ៤១:២១ ទដ ៥០:៣ ៩៧:៣ ដយ ៧:១០ ព សភ ២៥:២២ រម ១២:២០ **១៨:៩** ភ លប ១១:៥ ទដ ៥៧:៣ ម នក ២០:២១ ចទ ៣៣:២៦ ទដ ១០៤:៣ **១៨:១០** យ លប ៣:២៤ អគ ១០:១៨ រ ចទ ៣៣:២៦ ល ទដ ១០៤:៣ **១៨:១១** វ នក ១៩:៩ ចទ ៤:១១ ស យប ២២:១៤ អស ៤:៥ យរ ៤៣:១០ **១៨:១២** ហ ទដ ១០៤:២ ឡ យប ១០:១១ អ យប ៣៦:៣០ **១៨:១៣** ក នក ៩:២៣ ១សយ ២:១០ **១៨:១៤** ខ ចទ ៣២:២៣ គ យប ៣៦:៣០ វវ ៤:៥ ឃ ពច ៤:១៥ **១៨:១៥** ង ទដ ១១:៣ ច ទដ ៧៦:៦ ១០៤:៧ ១០៦:៩ អស ៥០:២ ឆ នក ១៥:៨ **១៨:១៦** ជ នក ១៥:៥ ទដ ៦៩:២ សភ ១៨:៤ ២០:៥ **១៨:១៧** ឈ ខ.៤៨ ទដ ៣៨:១៩ ៥៩:១ ១៤៣:៩ ញ ពច ១៨:២៦ **១៨:១៨** ដ សភ ១:២៧ ១៦:៤ យរ ១៧:១៧ ៤០:២ អប ១:១៣ ឋ ទដ ២០:២ អស ៣:១ **១៨:១៩** ឌ ទដ ៣១:៨ **១៨:១៩** ឍ ជន ១៤:៨ **១៨:២០** ណ ១សយ ២៦:២៣ ត នរ ២:១២ ២រប ១៥:៧ ១កថ ៣:៨ ថ យប ២២:៣០ ទដ ២៤:៤

**១៨:៨** ភាពមានតេជះរបស់ផងទ្រង់ ក៏បានពណ៌នាបង្ហាញស្រដៀង និងអំណាចនៃសត្វដ៏ធំសំបើមដែលអស្ចារ្យ (យប ៤១:១៩–២១) ។

**១៨:៩** *បន្ទាបផ្ទៃមេឃ ហើយយាងចុះមក* សូមមើល អស ៦៤:១ និងការពន្យល់ ។

**១៨:១០** *ចេរូប៊ីន* មានសណ្ឋានជារទេះម្យ៉ាងរបស់ស្តេច ដែលប្រើជាយានជំនិះក្នុងពេលស្តេចយាងធ្វើដំណើរទៅណាមកណា (សូមមើល ៨០:១ ៩៩:១ និងការពន្យល់ លប ៣:២៤ នក ២៥:១៨) ។ នៅក្នុងគម្ពីរ អគ ជំពូក ១និង ១០ ចេរូប៊ីនបានបង្ហាញរូបមានលក្ខណៈដូចជារទេះរបស់ស្តេច ។

**១៨:១៣** *សូរសៀង* គឺមានលក្ខណៈដូចជាផ្គរលាន់ គឺជាព្រះសូរសៀងរបស់ព្រះអម្ចាស់នៃយើង សូមមើល ទដ ២៩ យប ៣៧:២–៥ ។ *ខ្ពស់បំផុត* សូមមើលការពន្យល់ ១៤:១៩ ។

**១៨:១៤** *ព្រួញ* ដូចមានខ្សែនៃផ្លេកបន្ទោរ មានលក្ខណៈជាព្រួញរបស់ព្រះ សូមមើល ៧៧:១៧ ១៤៤:៦ ហប ៣:១១ និងការពន្យល់ លប ៩:១៣ ។

**១៨:១៥** គឺមានលក្ខណៈដូចជាការអំពាវនាវហៅអ្នកចម្បាំងពីស្ថានសួគ៌ បន្ទាប់ពីទ្រង់បានយកជ័យជម្នះលើពួកសត្រូវរបស់សាស្ត្រអ៊ីស្រាអែល នៅឯសមុទ្រក្រហម (សូមមើល នក ១៥:១–១២) ។

**១៨:១៦–១៩** ការប្រោសលោះ ។

**១៨:១៦** *ទឹកធំ* សូមមើលការពន្យល់ ៣២:៦ ។

**១៨:១៩** *ទីធំទូលាយ* សូមមើល ៤:១ និងការពន្យល់ ជាទីកន្លែងដែលមានសេរីភាព ក្នុងការដើរដោយពុំមានការភ័យខ្លាចចំពោះការគំរាមកំហែង ឬគ្រោះថ្នាក់អ្វីឡើយ (ខ.៤–៦,១៦–១៨) ។ ដែលធ្វើឱ្យក្តៅក្រហាយ ឬធ្វើទុក្ខបុកម្នេញ ដូចត្រូវបានជាប់ចំណងឡើយ (យប ៣៦:៨,១៣) ការរំដោះនោះគឺជាការធ្វើឱ្យមានសេរីភាព (យប ៣៦:១៦) ។ *ដ្បិតទ្រង់ស្រឡាញ់ដល់ទូលបង្គំ* គឺព្រះទ្រង់សព្វព្រះទ័យនឹងស្តេចដាវីឌ ដែលទ្រង់ជាអ្នកដែលដើរតាមព្រះទ័យរបស់ព្រះ (១សយ ១៣:១៤ ១៥:២៨ ១ពវ ១៤:៨ ១៥:៥)គឺជាមនុស្សដែលទ្រង់បានរើសតាំងតាមសេចក្តីសញ្ញា (សូមមើល ២សយ ៧ ខ.២០–២៩) ។

**១៨:២០–២៤** ភាពសុចរិតរបស់ស្តេចដាវីឌ គឺជារង្វាន់របស់ទ្រង់ (មានលក្ខណៈដូចលោកសាំយូអែល ១សយ ១២:៣ ដូចជាស្តេចហេសេគា ២ពវ ២០:៣ លោកយ៉ូប យប ១៣:២៣ ២៧:៦,៣១ និងមើល ទដ ១៧:៣–៥,២៦ ៤៤:១៧–១៨) គឺមិនប្រកាន់ថាខ្លួនគ្រាន់បើ ឬខ្លួនមានកម្លាំងខ្លាំងចំពោះសត្រូវឡើយ តែស្តេចដាវីឌទ្រង់បានលះបង់កម្លាំងកាយ និងកម្លាំងចិត្តដើម្បីបម្រើរដល់ព្រះយេហូវ៉ា ។ ពេលនោះព្រះដ៏មានព្រះចេស្តាធ្វើការក្នុងចិត្តរបស់ស្តេចដាវីឌ (សូមមើល ៥១:១០–១២) ។

**១៨:២០–២៤** *តាមសេចក្តីសុចរិតរបស់ទូលបង្គំ* មើលការពន្យល់ ១:៥ ។ *ប្រទានរង្វាន់មក* ដូចព្រះមហាក្សត្រឱ្យរង្វាន់ដល់មនុស្សដែលបានឈ្មោះ

២១ ដ្បិតទូលបង្គំបានកាន់តាមអស់ទាំងផ្លូវរបស់ព្រះ
យេហូវ៉ា[ទ] ហើយមិនបានថយចេញ[ធ]ពីព្រះនៃទូលបង្គំ
ដោយប្រព្រឹត្តសេចក្ដីអាក្រក់ឡើយ
២២ ពីព្រោះគ្រប់ទាំងច្បាប់របស់ទ្រង់ក៏នៅចំពោះមុខទូល
បង្គំ[ន] ហើយទូលបង្គំមិនបានងាកចេញពីក្រិត្យលណាមួយ
របស់ទ្រង់ឡើយ
២៣ ទូលបង្គំបានគ្រប់លក្ខណ៍[ប] នៅចំពោះទ្រង់
ហើយបានរក្សាខ្លួនឱ្យរួចពីសេចក្ដីទុច្ចរិតរបស់ទូលបង្គំ
២៤ ហេតុនោះ ព្រះយេហូវ៉ា ទ្រង់ប្រទានរង្វាន់មកទូលបង្គំ
តាមសេចក្ដីសុចរិតរបស់ទូលបង្គំ[ផ]
គឺតាមសេចក្ដីបរិសុទ្ធនៃដៃទូលបង្គំ
នៅចំពោះព្រះនេត្រទ្រង់
២៥ នៅចំពោះអ្នកមានចិត្តមេត្តា[ព]
នោះទ្រង់នឹងសំដែងអង្គទ្រង់ជាអ្នកមានចិត្តមេត្តាដែរ[ភ]
នៅចំពោះមនុស្សគ្រប់លក្ខណ៍
នោះទ្រង់នឹងសំដែងអង្គទ្រង់ជាអ្នកគ្រប់លក្ខណ៍
២៦ នៅចំពោះអ្នកបរិសុទ្ធ[ម]
នោះទ្រង់នឹងសំដែងអង្គទ្រង់ជាអ្នកបរិសុទ្ធដូចគ្នា
ហើយនៅចំពោះមនុស្សក្រវិចក្រវៀន
នោះទ្រង់នឹងសំដែងអង្គទ្រង់ជាអ្នកប្រទាំងនឹងគេវិញ[យ]
២៧ ដ្បិតទ្រង់នឹងជួយសង្គ្រោះមនុស្សដែលរងវេទនា[រ]
តែឯមនុស្សឆ្មើងឆ្មៃ នោះទ្រង់នឹងបន្ទាបគេចុះវិញ[ល]
២៨ ដ្បិតទ្រង់នឹងអុជប្រទីប[វ]របស់ទូលបង្គំ
ព្រះយេហូវ៉ាដ៏ជាព្រះនៃទូលបង្គំ
ទ្រង់នឹងធ្វើឱ្យសេចក្ដីងងឹតនៃទូលបង្គំភ្លឺឡើង[ស]
២៩ ពីព្រោះ ដោយពឹងទ្រង់[ហ]
នោះទូលបង្គំនឹងរត់ចូលទៅតនឹងកងទ័ព
ហើយដោយសារព្រះនៃទូលបង្គំ
នោះទូលបង្គំនឹងលោតរំលងកំផែងបាន
៣០ ឯព្រះ ផ្លូវនៃទ្រង់គ្រប់លក្ខណ៍[ឡ]
ព្រះបន្ទូលនៃព្រះយេហូវ៉ាបានសាកមើលហើយ[អ]
ទ្រង់ជាខែល[ក]ដល់អស់អ្នកណាដែលពឹងជ្រក[ខ]ក្នុងទ្រង់
៣១ ដ្បិតតើអ្នកណាជាព្រះ[គ] បើមិនមែនជាព្រះយេហូវ៉ាទេ
ហើយក្រៅពីព្រះនៃយើងខ្ញុំ នោះតើអ្នកណាជាថ្មដា[ឃ]
៣២ គឺជាព្រះដែលក្រវាត់ទូលបង្គំដោយកំឡាំង[ង]
ហើយក៏ធ្វើផ្លូវឱ្យទូលបង្គំបានគ្រប់លក្ខណ៍ដែរ[ច]
៣៣ ទ្រង់ធ្វើឱ្យជើងទូលបង្គំបានដូចជាជើងក្ដាន់[ឆ]
ក៏ដាក់ទូលបង្គំឱ្យឈរ នៅកន្លែងខ្ពស់របស់ទូលបង្គំ[ជ]
៣៤ ទ្រង់បង្ហាត់ដៃទូលបង្គំឱ្យស្ទាត់ច្បាំង[ឈ]
ឱ្យដៃទូលបង្គំអាចដំឡើងធ្នូលង្ហិនបាន ។
៣៥ ទ្រង់បានប្រទានខែល
ជាសេចក្ដីសង្គ្រោះរបស់ទ្រង់មកទូលបង្គំ[ញ]
ព្រះហស្តស្តាំទ្រង់បានទប់ទល់ទូលបង្គំ
ហើយសេចក្ដីស្រទន់របស់ទ្រង់ក៏ធ្វើឱ្យទូលបង្គំបានជាធំ
៣៦ ទ្រង់បានធ្វើឱ្យជំហាន[ដ] ទូលបង្គំបានទូលាយចេញទៅ
ហើយជើងទូលបង្គំមិនបានរឥលភ្លាត់ឡើយ[ឋ]
៣៧ ទូលបង្គំនឹងដេញតាមពួកខ្មាំងសត្រូវ[ឌ]ឱ្យទាន់

**១៨:២១** ទ ២រប ៣៤:៣៣ ទដ ៣៧:៣៤ ១១៩:២ សភ ៨:៣២ ២៣:២៦ ធ ទដ ១១៩:១០២ **១៨:២២** ន ទដ ១១៩:៣០ **១៨:២៣** ប លប ៦:៩ **១៨:២៤** ផ ១សយ ២៦:២៣ **១៨:២៥** ព ទដ ៣១:២៣ ៣៧:២៨ ៥០:៥ សភ ២:៨ ភ ទដ ២៥:១០ ៤០:១១ ៨៩:២៤ ១៤៦:៦ **១៨:២៦** ម សភ ១៥:២៦ មថ ៥:៨ ភល ១:១០ ១ធថ ៥:២២ ទត ១:១៥ ១យហ ៣:៣ យ សភ ៣:៣៤ មថ ១០:១៦ លក ១៦:៨ **១៨:២៧** រ ២រប ៣៣:២៣ មថ ២៣:១២ ល យប ៤១:៣៤ ទដ ១០:៥ សភ ៣:៣៣–៣៤ **១៨:២៨** វ ១ពវ ១១:៣៦ ទដ ១៣២:១៧ ស យប ២៩:៣ ទដ ៩៧:១១ ១១២:៤ យហ ១:៥ កថ ២៦:១៨ ២ពត ១:១៩
**១៨:២៩** ហ ខ.៣២,៣៩ អស ៤៥:៥ ហត ១១:៣៤ **១៨:៣០** ឡ ចទ ៣២:៤ អ ទដ ១២:៦ សភ ៣០:៥ ក ទដ ៣:៣ ខ ទដ ២:១២ **១៨:៣១** គ ចទ ៤:៣៥ ៣២:៣៩ ទដ ៣៥:១០ ៨៦:៨ ៨៩:៦ អស ៤៤:៦,៨ ៤៥:៥,៦,១៤,១៨, ២១ ៤៦:៩ ឃ លប ៤៩:២៤ **១៨:៣២** ង ខ.២៩ ១ពត ៥:១០ **១៨:៣២** ច ទដ ១៥:២ ១៩:១៣ ហត ១០:១៤ យក ៣:២ **១៨:៣៣** ឆ ទដ ៤២:១ សភ ៥:១៩ អស ៣៥:៦ ហត ៣:១៩ ជ ចទ ៣២:១៣ **១៨:៣៤** ឈ ទដ ១៤៤:១ **១៨:៣៥** ញ ទដ ៣:៥ ៣៧:៥,១៧ ៤១:៣ ៥១:១២ ៥៤:៤ ៥៥:២២ ១១៩:១១៦ អស ៤១:៤, ១០,១៣ ៤៣:២ ៤៦:៤ **១៨:៣៦** ដ ទដ ៣១:៨ ឋ យប ១៨:៧ ទដ ៦៦:៩ **១៨:៣៧** ឌ លវ ២៦:៧

ស្មោះនឹងទ្រង់ ។
**១៨:២១** *ផ្លូវរបស់ព្រះយេហូវ៉ា* សូមមើល ២៥:៤ និងការពន្យល់ ។
**១៨:២៣** *បានគ្រប់លក្ខណ៍* សូមមើលការពន្យល់ ១៥:២ ។
**១៨:២៥–២៩** ពីព្រោះព្រះអម្ចាស់ឆ្លើយតបចំពោះមនុស្ស តាមផ្លូវរបស់ពួកគេ (សូមមើល យប ៣៤:១១ ៣:៣៤) ឯស្ដេចដាវីឌមានបទពិសោធន៍ទទួលសេចក្ដីសប្បុរសរបស់ទ្រង់ ។
**១៨:២៦** *មនុស្សក្រវិចក្រវៀន* ពួកគេដើរក្នុងផ្លូវគ្មានសេចក្ដីពិត ឬសុចរិតឡើយ ។ *អ្នកប្រទាំង* គឺព្រះបានឆ្លើយតបទាំងប្រឆាំងនឹងពួកមនុស្សអាក្រក់ (សូមមើល ២ពវ ២២:២៣ និងការពន្យល់ ១១:៣៥) ។
**១៨:២៧** តាមរយៈគំនិតដែលមាននៅក្នុងខនេះ វាសមនឹងស្ថានភាពរបស់ស្ដេចដាវីឌ និងស្ដេចសូល ។ ដូចជាមាននៅក្នុងរឿងរបស់នាងហាណា ដែលមានជាបទចម្រៀង (១សយ ២:១–១០) ។ ដែលមានអ្នកនិពន្ធរបស់សាំយូអែលប្រើសម្រាប់សម្គាល់បញ្ចាក់ នៅផ្ទៃរឿងសំខាន់។ ។
**១៨:២៨** *អុជប្រទីបរបស់ទូលបង្គំ* ព្រះទ្រង់ថែរក្សាជីវិតស្ដេចដាវីឌ ឱ្យមានអំណាច មានពន្លឺជីវិត ក្នុងខ្សែរាជ្យវង្សនៃទ្រង់ឱ្យរីកចម្រើន (សូមមើល យប ១៨:៥–៦ ២១:១៧) ។ *ភ្លឺ* សូមមើលការពន្យល់ ២៧:១ ។
**១៨:៣០–៣៦** ដោយព្រះបានប្រទានពរដល់ស្ដេចដាវីឌ ជាស្ដេចនៃជាតិសាសន៍ ។
**១៨:៣០** *ទ្រង់គ្រប់លក្ខណ៍* គឺទ្រង់មិនដែលធ្លាក់ចុះឡើយ ដោយសារទ្រង់មានពរពិត ឯផ្លូវរបស់ស្ដេចដាវីឌក៏មិនត្រូវធ្លាក់ដែរ (សូមមើល ខ.៣២) ។ *ព្រះបន្ទូលនៃព្រះយេហូវ៉ា* គឺសំដៅលើព្រះបន្ទូលទូទៅ ក៏បានផ្ដោតសំខាន់លើព្រះបន្ទូលសន្យាចំពោះស្ដេចដាវីឌ (សូមមើល ២សយ ៧:៨–១៦) ។ ព្រះបន្ទូលនៃព្រះយេហូវ៉ាជាព្រះបន្ទូលដែលមានភាពបរិសុទ្ធ គ្មានកំហុស គ្មានល្បៀងឡើយ មើលការពន្យល់ ១២:៦ ។ *ខែល* មើលការពន្យល់ ៣:៣ ។
**១៨:៣៧–៤២** ជាវគ្គដែលព្រះជួយស្ដេចដាវីឌអាចឈ្នះអស់ទាំងឧបសគ្គ និងសត្រូវទាំងឡាយ ។

ក៏មិនងាកបែរមកវិញ ដរាបដល់គេវិនាសបង់អស់រលីង
៣៨ ទូលបង្គំនឹងចាក់ទំលុះគេ[ឍ] ឱ្យគេក្រោកឡើងវិញមិនរួច[ណ]
គេនឹងដួលនៅក្រោមជើងទូលបង្គំ[ត]
៣៩ ដ្បិតទ្រង់បានក្រវាត់ទូលបង្គំ
ដោយកំឡាំង[ថ]សំរាប់ធ្វើចំបាំង
ទ្រង់បានបង្ក្រាបពួកអ្នកដែលលើកគ្នាទាស់នឹងទូលបង្គំឱ្យ
គេនៅក្រោម[ទ]ទូលបង្គំវិញ
៤០ ទ្រង់បានធ្វើឱ្យពួកខ្មាំងសត្រូវបែរខ្នង[ធ]នៅមុខទូលបង្គំ
ដើម្បីឱ្យទូលបង្គំបានប្រហារ[ន]អស់អ្នកដែលស្អប់ទូលបង្គំ
៤១ គេបានស្រែកឡើង តែគ្មានអ្នកណាជួយសោះ[ប]
ក៏អំពាវនាវដល់ព្រះយេហូវ៉ា តែទ្រង់មិនឆ្លើយមកឡើយ[ផ]
៤២ ទូលបង្គំបានវាយគេកំទេចឱ្យល្អិតដូចផង់ធូលី[ព]
ដែលផាត់ដោយខ្យល់
ទូលបង្គំបានបោះគេចោលចេញដូចជាភក់ពីផ្លូវ
៤៣ ទ្រង់បានជួយទូលបង្គំ ឱ្យរួចពីសេចក្តីទាស់ទែងនៃ
ប្រជាជន ទ្រង់បានតាំងទូលបង្គំឡើង
ជាកំពូលលើអស់ទាំងនគរសាសន៍១[ភ]
ដែលទូលបង្គំមិនទាន់ស្គាល់[ម]
នឹងមកគោរពប្រតិបត្តិដល់ទូលបង្គំ
៤៤ វេលាណាដែលបានឮនិយាយពីទូលបង្គំនោះគេនឹង
ស្តាប់តាមភ្លាម
ពួកសាសន៍ដទៃ[យ]នឹងគោរពចុះចូលចំពោះទូលបង្គំ
៤៥ ពួកសាសន៍ដទៃនឹងត្រូវស្រពោនបាត់ទៅ[រ]
ហើយនិងចេញពីទីសំងាត់របស់ខ្លួន[ល] ដោយភ័យញ័រ[វ]
៤៦ ព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់[ស] នៅសូមសរសើរ
ដល់ថ្មដានៃទូលបង្គំ[ហ] ក៏សូមឱ្យព្រះ[ឡ]ដ៏ជួយសង្គ្រោះរបស់
ទូលបង្គំ បានថ្កើងឡើង[អ]
៤៧ គឺជាព្រះដ៏ជួយសងសឹកជំនួសទូលបង្គំ[ក]
ហើយបង្ក្រាបអស់ទាំងសាសន៍[ខ]ឱ្យបានចំណុះទូលបង្គំដែរ
៤៨ ទ្រង់បានជួយ[គ]ទូលបង្គំ ឱ្យរួចពីពួកខ្មាំងសត្រូវ[ឃ]
អើ ទ្រង់បានលើកទូលបង្គំឡើង
ខ្ពស់ជាងពួកអ្នកដែលលើកគ្នាទាស់នឹងទូលបង្គំទៅទៀត
ទ្រង់ក៏ជួយសង្គ្រោះទូលបង្គំ ឱ្យរួចពីមនុស្សច្រឡោតផង[ង]
៤៩ ហេតុនោះ ឱព្រះយេហូវ៉ាអើយ
ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់
នៅកណ្តាលអស់ទាំងសាសន៍ដទៃ[ច]
ហើយនិងច្រៀង[ឆ]សរសើរដល់ព្រះនាមទ្រង់[ជ]
៥០ ទ្រង់ប្រោសសេចក្តីសង្គ្រោះយ៉ាងធំដល់ស្តេចរបស់ទ្រង់
ក៏សំដែងសេចក្តីសប្បុរស
ដល់អ្នកដែលទ្រង់បានចាក់ប្រេងតាំងឱ្យ[ឈ] គឺដល់ដាវីឌ[ញ]
និងពូជពង្សតរៀងទៅ[ដ] ។

ទំនុកនៃស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។
**១៩** ផ្ទៃមេឃ[ក]សំដែង[ខ]ពីសិរីល្អនៃព្រះ[គ]
ហើយលំហអាកាស[ឃ] ក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ[ង]

**១៨:៣៨** ឍ ទដ ៦៨:២១ ១១០:៦ ណ ទដ ៣៦:១២ ១៤០:១០ អស ២៦:១៤ ត ទដ ៤៧:៣ **១៨:៣៩** ថ ខ.៣២ អស ៤៥:៥,២៤ ទ ខ.៤៧ ទដ ៤៧:៣ ១៤៤:២ **១៨:៤០** ធ យស ៧:១២ ន ខ.៣៧ **១៨:៤១** ប ២ពវ ១៤:២៦ ទដ ៥០:២២ ផ ១សយ ៨:១៨ ១៤:៣៧ យរ ១១:១១ **១៨:៤២** ព ចទ ៩:២១ អស ២:២២ **១៨:៤៣** ភ ២សយ ៨:១–១៤ ម អស ៥៥:៥ **១៨:៤៤** យ ទដ ៥៤:៣ ១៤៤:៧,១១ អស ២៥:៥ **១៨:៤៥** រ ១សយ ១៧:៣២ ២កថ ៤:១ ហាព ១២:៣ ល ទដ ៩:៩ មីក ៧:១៧ វ អស ៦៦:២ ហស ៣:៥ ១១:១០ **១៨:៤៦** ស យស ៣:១០ ១សយ ១៤:៣៩ ២កថ ១៣:៤ ហ ខ.៣១ នក ៣៣:២២ ឡ ទដ ២១:១៣ ៣៥:២៧ ៤០:១៦ ១០៨:៥ អ ១របស ១៦:៣៥ លក ១:៤៧ **១៨:៤៧** ក លប ៤:២៤ ខ ខ.៣៩ ពច ៤:២៣ **១៨:៤៨** គ ទដ ៧:១០ ៣៧:៤០ ដយ ៣:១៧ ឃ ខ.១៧ ង ទដ ១៤០:១ **១៨:៤៩** ច ទដ ៩:១១ ឆ ទដ ៧:១៧ ៩:២ ១០១:១ ១០៨:១ ១៤៦:២ ជ រម ១៥:៩ **១៨:៥០** ឈ ២សយ ២៣:១ ញ ទដ ១៤៤:១០ ដ ទដ ៨៩:៤ **១៩:១** ក ទដ ៨៩:៥ អស ៤០:២២ ខ ទដ ៥០:៦ ១៤៨:៣ រម ១:១៩ គ ទដ ៤:២ ៨:១ ៩៧:៦ អស ៦:៣ ឃ លប ១:៨ ង ទដ ៨:៦ ១០៣:២២

**១៨:៤៣–៤៥** ព្រះទ្រង់រើសតាំងស្តេចដាវីឌឱ្យធ្វើជាមេដឹកនាំ លើគ្រប់ទាំងសាសន៍ (មើល ២សយ ៥,៨,១០) ។

**១៨:៤៣** *សេចក្តីទាស់ទែងនៃប្រជាជន* គ្រប់ទាំងភាពគំរាមកំហែងទាស់ទែងគឺបង្កហេតុចេញពីប្រជារាស្ត្ររបស់ទ្រង់ ដូចជាជំនាន់ស្តេចសូល ឬក៏អាចមានអាបសាឡំម ដែលបះបោរប្រឆាំងនឹងព្រះបិតារបស់ខ្លួន ។ *ទូលបង្គំមិនទាន់ស្គាល់* គឺអស់អ្នកពុំមានទំនាក់ទំនងល្អ ។

**១៨:៤៦** *ព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់នៅ* ក៏មានអត្តរាគមន៍ពីព្រះយេហូវ៉ា និងព្រះពរក្នុងនាមជាស្តេចដាវីឌ ក៏បានបង្ហាញពីព្រះមានព្រះជន្មរស់ (សូមមើល ចទ ៥:២៦) ។

**១៨:៤៧** *ព្រះដ៏ជួយសងសឹកជំនួសទូលបង្គំ* គឺដល់អស់អ្នកដែលបានប្រឆាំងនឹងទូលបង្គំ (សូមមើល ចទ ៣២:៤១) ។

**១៨:៤៩** ពាក្យសច្ចារបស់ស្តេចដាវីឌក្នុងការរក្សាសរសើរតម្កើងដល់ព្រះយេហូវ៉ា នៅក្នុងគ្រប់សាសន៍ទាំងអស់ (សូមមើលការពន្យល់ ៩:១) ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**១៨:៥០** *ស្តេចរបស់ទ្រង់ . . . ទ្រង់បានចាក់ប្រេងតាំងឱ្យ* ស្តេចដាវីឌបានបង្ហាញប្រាប់ថា ទ្រង់បានរើសតាំងដោយព្រះយេហូវ៉ា (សូមមើល ១សយ ១៦:១៣ និងការពន្យល់ ១សយ ១០:២៥ ១២:១៤–១៥) ។

**ទដ ១៩** ជាបទចំរៀងសរសើរពីភាពតេជះរបស់ទ្រង់ "សិរីល្អរបស់ព្រះអម្ចាស់" (ខ.១) ការដាក់ ឬព្យួរស្ថានសួគ៌នៅលើមេឃ ជាពិសេសក្នុងរដូវប្រាំងដ៏ស្រស់ស្អាត គឺជាព្រះអាទិត្យបានដើរពីទិសខាងកើតឆ្លងកាត់ផ្ទៃមេឃដ៏ធំ គឺទិសខាងកើតទៅទិសខាងលិច (សូមមើល ខ.១–៦ និងសេចក្តីផ្តើម ទដ ២៩) និង"ច្បាប់បញ្ញត្តិរបស់ព្រះយេហូវ៉ា"(ខ.៧) ដែលមានពរចំពោះអស់ទាំងជីវិតដែលដើរតាមច្បាប់នោះ (សូមមើល ខ.៧–១៣) ។ ក៏សូមឱ្យព្រះប្រទាននូវអំពើអ្វីខ្លះ ដែលច្បាប់ទ្រង់ពុំអាចមានការលើកលែងទោសចំពោះកំហុសដែលលាក់កំបាំង "និងការថែរក្សាឱ្យផុតពី" អំពើបាបដែលលោភលន់ជ្រុល ឯវគ្គក្រោយៗមាន ទដ ១៨ ទំនុកនេះជាការអធិស្ឋានខួបចំពោះសកម្មភាពដែលព្រះជួយសង្គ្រោះ ។

**១៩:១–៤ក** ពីភាពស្ងាត់ស្ងៀមនៃស្ថានសួគ៌ ក៏ប្រាប់ពីសេរីល្អរបស់ព្រះដែលបង្កើតពួកគេមកនៅក្នុងលោកិយនេះ (សូមមើល ១៤៨:៣) ឯពន្លឺនៅលើស្ថានសួគ៌ (សូមមើល លក ១:១៦ និងការពន្យល់ ចទ ៤:១៩ ១៧:៣) ឬក៏

២ ថ្ងៃ១ពោលប្រាប់តដល់ថ្ងៃ១ទៀត
ហើយយប់១ក៏សំដែងចំណេះដល់យប់១ទៀតដែរ[ច]
៣ ឯពាក្យសំដី ឬភាសា នោះគ្មានឮឡើយ
គ្មានអ្នកណាដែលឮសំឡេងនៃរបស់ទាំងនោះទេ
៤ ប៉ុន្តែដំណឹងដែលរបស់ទាំងនោះផ្សាយមក
ក៏បានចេញទៅគ្រប់លើផែនដី[ឆ]
ហើយសេចក្ដីនោះបានឮទៅដល់ទីបំផុតលោកីយ
នៅលើមេឃ ទ្រង់បានដំឡើងត្រសាល[ជ]
សំរាប់ព្រះអាទិត្យ[ឈ]
៥ ដែលទុកដូចជាប្ដីថ្មោងថ្មី[ញ]កំពុងតែចេញពីបន្ទប់ដេក[ដ]
ទាំងមានសេចក្ដីអំណរនឹងរត់តាមផ្លូវខ្លួនដូចជាមនុស្ស
ខ្លាំងពូកែ[ឋ]
៦ ព្រះអាទិត្យក៏រះពីជើងមេឃ[ឌ]ម្ខាងហើយដើរវង់ទៅដល់
ជើងមេឃម្ខាង[ឍ]គ្មានរបស់អ្វីលាក់កំបាំងពីកំដៅនៃព្រះ
អាទិត្យទេ ។
៧ ឯក្រិត្យវិន័យរបស់ព្រះយេហូវ៉ា[ណ]នោះគ្រប់លក្ខណ៍[ត]ក៏
កែព្រលឹងឡើង[ថ]វិញ
សេចក្ដីបន្ទាល់នៃព្រះយេហូវ៉ាជាពិត[ទ]ក៏ធ្វើឱ្យមនុស្សខ្លៅ
ល្ងង់មានប្រាជ្ញា[ធ]
៨ សេចក្ដីបញ្ញត្តរបស់ព្រះយេហូវ៉ាសុទ្ធតែទៀតត្រង់[ន]ក៏
បណ្ដាលឱ្យចិត្តរីករាយសប្បាយ[ប]
ក្រិត្យក្រមនៃព្រះយេហូវ៉ាជាសុទ្ធសាធ ក៏បំភ្លឺភ្នែក[ផ]
៩ សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា[ព]
នោះជាបរិសុទ្ធ ក៏នៅជាប់ជារៀងរាបដរាប
អស់ទាំងខច្បាប់របស់ព្រះយេហូវ៉ាសុទ្ធតែពិតត្រង់
ហើយសុចរិតគ្រប់ជំពូក[ភ]
១០ សេចក្ដីទាំងនោះគួរចង់បានលើសជាងមាស[ម]
អើ ជាជាងមាសសុទ្ធ ជាច្រើនផង ក៏ផ្អែមជាងទឹកឃ្មុំ[យ]
ហើយជាងដំណក់ស្រក់ពីសំណុះផង[រ]
១១ មួយទៀត ទូលបង្គំ ជាអ្នកបំរើទ្រង់
ក៏ចេះប្រយ័ត្នដោយសារសេចក្ដីទាំងនោះដែរ
ហើយដែលកាន់តាម នោះក៏មានរង្វាន់យ៉ាងធំ
១២ តើអ្នកណានឹងស្គាល់អំពើខុសឆ្គងរបស់ខ្លួនបាន
សូមជំរះទូលបង្គំឱ្យជ្រះស្អាតពីអំពើលាក់កំបាំងផង[ល]
១៣ សូមរាំងទូលបង្គំ ជាអ្នកបំរើទ្រង់
ឱ្យរួចពីបាប[វ]ដែលធ្វើដោយ ល្មើសដែរ
កុំឱ្យបាបនោះមានអំណាចលើទូលបង្គំឡើយ[ស]
នោះទូលបង្គំនឹងបានទៀងត្រង់[ហ]
ហើយនិងបានរួចពីអំពើរំលងយ៉ាងធំផង
១៤ ឱព្រះយេហូវ៉ា ជាថ្មដា[ឡ]
ហើយជាអ្នកប្រោសលោះនៃទូលបង្គំអើយ[អ]សូមឱ្យពាក្យសំដី
ដែលចេញមកពីមាត់ទូលបង្គំ នឹងការរំពឹងគិតក្នុង
ចិត្តរបស់ទូលបង្គំបានគួរគាប់[ក]នៅព្រះនេត្រទ្រង់ ។

**១៩:២** ច ទដ ៧៤:១៦ **១៩:៤** ឆ រម ១០:១៨ ជ យប ៣៦:២៩ ទដ ១០៤:២ ឈ ពច ៥:៣១ **១៩:៥** ញ យអ ២:១៦ ដ យប ៣៦:២៩ ឋ អស ១៧:៤ **១៩:៦** ឌ ចទ ៣០:៤ ឍ ទដ ១១៣:៣ សស ១:៥ **១៩:៧** ណ ទដ ១:២ ត ទដ ១១៩:១៤២ យក ១:២៥ ថ ទដ ២៣:៣ ទ ទដ ៩៣:៥ ១១១:៧ ១១៩:១៣៨ ១៤៤ ធ ចទ ៤:៦ ទដ ១១៩:១៣០ **១៩:៨** ន ទដ ៣៣:៤ ១១៩:១២៨ ប ទដ ១១៩:១៤ ផ អរ ៩:៨ ទដ ៣៨:១០ **១៩:៩** ព ទដ ៣៤:១១ ១១១:១០ សភ ១:៧ សស ១២:១៣ អស ៣៣:៦ ភ ទដ ១១៩:១៣៨, ១៤២ **១៩:១០** ម យប ២២:២៤ ទដ ១១៩:៧២ សភ ៨:១០ យ ទដ ១១៩:១០៣ ៤:១១ អគ ៣:៣ រ ១សយ ១៤:២៧ **១៩:១២** ល ទដ ៥១:២ ៩០:៨ សស ១២:១៤ **១៩:១៣** វ ជន ១៥:៣០ ស ទដ ១១៩:១៣៣ ហ លប ៦:៩ ទដ ១៨:៣២ **១៩:១៤** ឡ ទដ ១៨:៣១ អ នក ៦:៦ យប ១៩:២៥ ក ទដ ១០៤:៣៤

ពុំមានការត្រួតត្រាក្ដី ។
**១៩:៤** បានបកស្រាយការប្រកាសអំពីនគរស្ថានសួគ៌នេះ ពីពន្លឺនៃព្រះគ្រីស្ទ ឯលោកសាវកប៉ុលបានប្រើខនេះដើម្បីប្រកាសពីដំណឹងល្អ សម្រាប់ផ្ទាល់ខ្លួនរបស់គាត់ (សូមមើល រម ១០:១៨) ។
**១៩:៤ខ–៦** ឯនគរស្ថានសួគ៌គឺជាកន្លែងបរិសុទ្ធសម្រាប់ព្រះយេហូវ៉ា ហើយក៏មានគេថ្វាយបង្គំជាច្រើននៅក្នុងតំបន់មជ្ឈឹមបូព៌ាបុរាណ (ប្រៀប ធៀប ចទ ៤:១៩ ១៧:៣ ២ពវ ២៣:៥,១១ យរ ៨:២ អគ ៨:១៦) ។ ប៉ុន្តែនៅកន្លែងនេះក៏ដូចក្នុង ១៣៦:៧–៨ សប ១:១៦ គឺជាការបង្កើតរបស់ព្រះដ៏ធំធេង គឺជាការបង្កើតនៃអំណាចក្រៃនៃព្រះ (សូមមើល ៨៤:១១ អស ៦០:១៩–២០) ។ មានខ្យល់បក់បោកប្រចាំថ្ងៃកាត់តាមលំហរស្ថានសួគ៌ដ៏ធំធេង និងចាក់ភាពកក់ក្ដៅលើគ្រប់សត្វលោក ។
**១៩:៧–៩** ការបង្ហាញបញ្ជាក់ពីការអបអរសាទរ ពីការដែលព្រះបានបីបាច់ថែរក្សា តាមរយៈការដែលព្រះបានបើកសម្ដែង (សូមមើល ទដ ១១៩) ។
**១៩:៧** *ជាពិត* ឯច្បាប់របស់ព្រះមានលក្ខណៈ"ដ៏ពិតត្រង់" (សូមមើល ១១១:៧ ១១៩:៨៦) ឬក៏"ពិតប្រាកដ" (១៩:៩) ឬក៏ "ពិត" (១១៩:១៤២, ១៥១,១៦០) ក្នុងអត្ថន័យភាពបរិសុទ្ធរបស់ទ្រង់"ឈររឹងមាំ" (មើល ៩៣:៥ ១១៩:៩១,១៥២,១៦០) ។
**១៩:៨** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។
**១៩:៩** *សេចក្ដីកោតខ្លាចដល់ព្រះ* ជាសេចក្ដីដែលច្បាប់តម្រូវចង់បាន (សូមមើលការពន្យល់ ១៥:៤) ។
**១៩:១០–១១** ព្រះបន្ទូលព្រះជាព្រះបន្ទូលមិនអាចប្រៀបផ្ទឹមបាន វាមានតម្លៃសម្រាប់ជីវិត (សូមមើល ចទ ៥:៣៣) ។
**១៩:១០** *ក៏ផ្អែមជាងទឹកឃ្មុំ* ដោយផ្ទុយចំពោះអ្នកដែលបានបោះបង់ច្បាប់ចោល ដែលនាំឱ្យមានភាពល្វីងជូរចត់វិញ (សូមមើល អម ៥:៧ ៦:១២) ។
**១៩:១២–១៣** គឺជាសេចក្ដីដឹងខុសត្រូវ ជាសីលធម៌របស់មនុស្សលោក ត្រូវបានខូចខាត ឬជួបវិបត្តិជីវិតបើសិនជាគេមិនបានពឹងផ្អែកទៅលើព្រះយេហូវ៉ា (ខ.១២ លវ ៥:២–៤) ។
**១៩:១៤** អ្នកនិពន្ធបទទំនុកនេះ បានបកស្រាយបទនេះគឺមានលក្ខណៈសរសើរចំពោះព្រះយេហូវ៉ា ។ *ក្នុងចិត្ត* សូមមើលការពន្យល់ ៤:៧ ។ *ជាថ្មដា . . . ជាអ្នកប្រោសលោះនៃទូលបង្គំ* សូមមើល ៧៨:៣៥ ។ *ថ្មដា* សូមមើលការពន្យល់ ១៨:២ លប ៤៩:២៤ ។ *អ្នកប្រោសលោះ* សូមមើលការពន្យល់ នក ៦:៦ អស ៤១:១៤ ។

ទំនុកនៃស្ដេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**២០** សូមឱ្យព្រះយេហូវ៉ាមានបន្ទូលឆ្លើយដល់ព្រះករុណា
នៅថ្ងៃមានចលាចល[ក]
សូមឱ្យព្រះនាមនៃព្រះរបស់យ៉ាកុប[ខ] បានតាំងទ្រង់ឡើង
នៅលើទីខ្ពស់[គ]
២ ព្រមទាំងចាត់សេចក្ដីជំនួយ[ឃ] ពីទីបរិសុទ្ធ[ង] មកជួយទ្រង់
ហើយចំរើនកំឡាំង[ច] ទ្រង់ពីក្រុងស៊ីយ៉ូនមក[ឆ]
៣ ទាំងនឹកចាំ[ជ] ពីបណ្ដាដង្វាយរបស់ទ្រង់
ហើយទទួលយញ្ញបូជារបស់ទ្រង់ផង[ឈ] ។ –បង្អង់
៤ សូមឱ្យព្រះបានប្រោសដល់ទ្រង់តាមបំណងព្រះទ័យ[ញ]
ហើយធ្វើសំរេចតាមគ្រប់ទាំងគំនិតរបស់ព្រះករុណា[ដ]
៥ យើងខ្ញុំនឹងអរសប្បាយ[ឋ] ដោយទ្រង់មានជ័យជំនះ
ហើយនិងលើកទង់ជ័យ[ឌ] ឡើងដោយនូវព្រះនាមនៃព្រះ
របស់យើងខ្ញុំ
សូមឱ្យព្រះយេហូវ៉ាធ្វើសំរេចតាមអស់ទាំងសេចក្ដី
សំណូមរបស់ព្រះករុណាផង[ឍ] ។
៦ ឥឡូវនេះ ខ្ញុំដឹងហើយ
ថាព្រះយេហូវ៉ាទ្រង់ជួយសង្គ្រោះដល់អ្នក
ដែលទ្រង់បានចាក់ប្រេងតាំងឱ្យ[ណ] ទ្រង់នឹងមានបន្ទូល
ឆ្លើយពីស្ថានសួគ៌ដ៏បរិសុទ្ធរបស់ទ្រង់
ដោយផ្សាយកំឡាំងនៃព្រះហស្តស្តាំដែលតែងតែជួយ[ត]
៧ អ្នកខ្លះពឹងនឹងរទេះចំបាំង[ថ] ខ្លះទៀតពឹងនឹងសេះ[ទ]
តែយើងខ្ញុំនឹងនឹកចាំពីព្រះនាមព្រះយេហូវ៉ា
ជាព្រះនៃយើងខ្ញុំវិញ[ធ]
៨ ឯអ្នកទាំងនោះ គេត្រូវឱន ហើយដួលចុះ[ន]
តែយើងខ្ញុំបានក្រោកឈរ[ប] ត្រង់ឡើង[ផ]
៩ ឱព្រះយេហូវ៉ាអើយ សូមជួយសង្គ្រោះផង[ព]
សូមឱ្យមហាក្សត្របានមានបន្ទូលឆ្លើយ
ក្នុងកាលដែលយើងខ្ញុំអំពាវនាវរកទ្រង់ ។

ទំនុកនៃស្ដេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**២១** ឱព្រះយេហូវ៉ាអើយ ទូលបង្គំដ៏ជាស្ដេច
នឹងមានសេចក្ដីអំណរចំពោះឫទ្ធានុភាពនៃទ្រង់[ក]
ហើយនិងរីករាយសប្បាយជាខ្លាំងចំពោះសេចក្ដី
សង្គ្រោះនៃទ្រង់យ៉ាងណាហ្ន៎[ខ]
២ ទ្រង់បានប្រោសឱ្យបានដូចបំណង[គ]
ហើយមិនបានរង់នឹងប្រទាន

**២០:១** ក ទដ ៤:១ ខ នក ៣:៦ ទដ ៤៦:៧,១១ គ ទដ ៥៩:១ ៦៩:២៩ ៩១:១៤ **២០:២** ឃ ទដ ៣០:១០ ៣៣:២០ ៣៧:៤០ ៤០:១៧ ៥៤:៤ ១១៨:៧ ង ជន ៣:២៨ ច ទដ ១៨:១៨ ឆ ទដ ២:៦ ១២៨:៥ ១៣៤:៣ ១៣៥:២១ **២០:៣** ជ កច ១០:៤ ឈ ចទ ៣៣:១១ **២០:៤** ញ ទដ ២១:២ ៣៧:៤ ១៤៥:១៦,១៩ អស ២៦:៨ អគ ២៤:២៥ រម ១០:១ ដ ទដ ១៤០:៨ សភ ១៦:៣ ដយ ១១:១៧ **២០:៥** ឋ យប ៣:៧ ឌ ជន ១:៥២ ទដ ៦០:៤ អស ៥:២៥ ១១:១០,១២ ១៣:២ ៣០:១៧ ៤៩:២២ ៦២:១០ យរ ៥០:២៥១:១២,២៧ ឍ ១សយ ១:១៧ **២០:៦** ណ ២សយ ២៣:១ ទដ ២៨:៨ ត យប ៤០:១៤ ហព ៣:១៣ **២០:៧** ថ ២ពវ ១៩:២៣ ទ ទដ ១៧:១៦ ទដ ៣៣:១៧ ១៤៧:១០ សភ ២១:៣១ អស ៣១:១ ៣៦:៨,៩ ធ ២របា ៣២:៨ **២០:៨** ន ទដ ២៧:២ អស ៤០:៣០ យរ ៤៦:៦ ៥០:៣២ ប មីក ៧:៨ ផ យប ១១:១៥ ទដ ៣៧:២៣ សភ ១០:២៥ អស ៧:៩ **២០:៩** ព ទដ ១៧:៦ **២១:១** ក ១សយ ២:១០ ខ ២សយ ២២:៥១ **២១:២** គ ទដ ២០:៤

**ទដ ២០** ជាបទអធិស្ឋានសម្រាប់ព្រះមហាក្សត្រ មុនពេលស្ដេចនោះចេញទៅធ្វើសង្គ្រាម ទប់ទល់នឹងពួកសត្រូវដែលមកឈ្លានពាន (សូមមើល ២របា ២០:១–៣០) ។ ទដ ២០–២១ ខគម្ពីរនេះមានលក្ខណៈស៊ីគ្នានឹង ១៨ ក្នុងការរៀបចំ ទដ ១៥–២៤ (សូមមើលសេចក្ដីផ្ដើម ទដ ១៥–២៤) នៅក្នុង ទដ ១៨ យើងឮសម្លេងរបស់ព្រះមហាក្សត្រ តែក្នុង ទដ ២០–២១ យើងឮសម្រែករបស់ប្រជារាស្ត្រវិញ ។

**២០ ចំណងជើង** *លើសំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ ជាចំណងជើង ។

**២០:១–៥** ប្រជាជន (ប្រហែលជាការប្រមូលផ្ដុំកងទ័ព) ដើម្បីបង្ហាញប្រាប់ដល់ស្ដេច គឺដើម្បីអធិស្ឋានសូមជ័យជម្នះក្នុងសង្គ្រាម ។

**២០:១** *ឆ្លើយដល់ព្រះករុណា* ឮពីសេចក្ដីអធិស្ឋានថ្វាយជូន ក្នុងគ្រាមានភាពទុក្ខព្រួយ ដោយមានទាំង"ពិធីយញ្ញបូជា"(ខ.៣) មើល ខ.៩ ។ *ព្រះនាម* មើល ខ.៥,៧ និងការពន្យល់ ៥:១១ ។ *យ៉ាកុប* មើលការពន្យល់ ១៤:៧ ។

**២០:២** *ក្រុងស៊ីយ៉ូន* សូមមើលការពន្យល់ ៩:១១ ។

**២០:៤** *ព្រះទ័យ* សូមមើលការពន្យល់ ៤:៧ ។

**២០:៥** *យើងខ្ញុំនឹងសប្បាយ . . . ព្រះនាមនៃព្រះរបស់យើង* មើលការពន្យល់ ៧:១៧ ។ *ទង់ជ័យ* គឺសំដៅលើក្រុមកងទ័ពឈរជាជួរ ដើម្បីហ៊ឹកហាត់ ។

**២០:៦** គឺជាការចូលរួមក្នុងការទន្ទេញសូត្រទូលអង្វរ (ដែលមានក្នុង ២របា ២០:១៤) ជាការប្រកាសពីការធានារ៉ាប់រងពីការអធិស្ឋានរបស់ស្ដេច ហើយពួកគេបានឮ ។ ការចាក់ប្រេងតាំងរបស់ទ្រង់គឺដោយព្រះយេហូវ៉ាដើម្បីដឹកនាំក្នុងនាមទ្រង់ (សូមមើល ២:២ និងការពន្យល់) ។

**២០:៧–៨** ការអធិស្ឋានលន់តួបាបក្នុងការទុកចិត្តដល់ព្រះយេហូវ៉ា ជាជាងទុកចិត្តលើរទេះចំបាំង (ប្រៀបធៀប ៣៣:១៦–១៧) ឯពួកសត្រូវអាចមានលក្ខណៈខ្លាំងក្លា ប៉ុន្តែចំពោះស្ដេចដាវីឌគឺនៅតែទុកចិត្តលើព្រះយេហូវ៉ាដដែល ដោយដឹងថាទ្រង់ជាប្រភពនៃកម្លាំង ហើយជាពិសេសគឺមើលពីលក្ខណៈរបស់ស្ដេចដាវីដែលបានប្រឈមមុខនឹងកូលីយ៉ាត (មើល ១សយ ១៧:៤៥–៤៧) ។

**២០:៩** ការទូលអង្វរដោយអធិស្ឋានចុងក្រោយរបស់កងទ័ព ។ *បន្ទូលឆ្លើយ . . . ក្នុងការដែល* សូមមើលការពន្យល់ ខ.១ ទំនុកដំកើងបញ្ចប់ដូចកាលចាប់ផ្ដើមដែរ ។

**ទដ ២១** ទំនុកដំកើងនៃការសរសើរ ដើម្បីទទួលជ័យជម្នះចំពោះពួកស្ដេចមួយចំនួន ។ វាមានទំនាក់ទំនងនឹង ទដ ២០ តែព្រឹត្តិការណ៍ទាំងពីរគឺស្ថិតក្នុងកាលៈទេសៈតែមួយ ដែលស្ថិតក្នុងភាពអាថ៌កំបាំង ។ នៅក្នុងខនេះបានឃើញប្រជារាស្ត្រអធិស្ឋាសរសើរដំកើង(សូមមើល ខ.១) មាន (ទដ ២០) ជាការអធិស្ឋានរបស់ប្រជារាស្ត្រ ហើយមានទាំងការអធិស្ឋានរបស់ស្ដេចដែរ ។ នេះជាវគ្គដែលបង្ហាញថាព្រះយេហូវ៉ាជាកម្លាំងរបស់អ្នក ខ.៧ ជាចំណុចរួមក្នុងអត្ថន័យដែលបង្ហាញពីព្រះមហាក្សត្រ មានទំនុកចិត្តលើព្រះយេហូវ៉ា សូមមើលសេចក្ដីផ្ដើម ទដ ២០ និង ទដ ១៥–២៤ ។

**២១ ជាផ្នែកចំណងជើង** សូមមើល ទដ ៤ ។

**២១:២–៦** ប្រជារាស្ត្របានអបអរសាទរដល់ព្រះយេហូវ៉ា ដែលបានការ

តាមសេចក្តីដែលបបូរមាត់សូមឡើយ ។ –បង្អង់
៣ដ្បិតទ្រង់បានស្ទាក់ប្រទានពរនៃព្រះគុណ
ទ្រង់បានបំពាក់មកុដមាសសុទ្ធ[ឃ]នៅលើក្បាល[ង]
៤ទូលបង្គំបានសូមជីវិតពីទ្រង់ ហើយទ្រង់ក៏ប្រទានឱ្យ
គឺជាអាយុយឺនយូរដ៏នៅជាប់អស់កល្បជានិច្ចផង[ច]
៥សិរីល្អនៃទូលបង្គំបានធំណាស់ ដោយសារសេចក្តី
សង្គ្រោះ[ឆ] របស់ទ្រង់ ទ្រង់ក៏តាំងឱ្យមានកិត្តិយស
ហើយនិងអានុភាពដែរ[ជ]
៦ដ្បិតទ្រង់បានតាំងទូលបង្គំ
ឱ្យមានពរយ៉ាងបណ្តាច់នៅអស់កល្ប
ទ្រង់ក៏បណ្តាលឱ្យមានសេចក្តីអំណរ[ឈ]ដ៏ពោរពេញនៅ
ចំពោះទ្រង់[ញ]
៧ដ្បិតទូលបង្គំដ៏ជាស្តេច បានទុកចិត្តនឹងព្រះយេហូវ៉ា[ដ]
ហើយដោយសេចក្តីសប្បុរស[ឋ]នៃព្រះដ៏ខ្ពស់បំផុត[ឌ]
នោះទូលបង្គំមិនត្រូវរង្គើឡើយ[ឍ]
៨ព្រះហស្តទ្រង់នឹងស្វែងរក[ណ]
ទាល់តែឃើញអស់ទាំងខ្មាំងសត្រូវរបស់ទ្រង់
ព្រះហស្តស្តាំទ្រង់នឹងរកឃើញអស់អ្នកណាដែលស្អប់
ទ្រង់ដែរ
៩នៅវេលាដែលទ្រង់គង់នៅចំពោះគេ
នោះទ្រង់នឹងធ្វើឱ្យគេបានដូចជាគុកភ្លើងដែលឆេះក្តៅ
ព្រះយេហូវ៉ាទ្រង់នឹងលេបគេ
ដោយសេចក្តីក្រោធរបស់ទ្រង់
ហើយភ្លើងនឹងឆេះបំផ្លាញគេអស់ទៅ[ត]
១០ទ្រង់នឹងបំផ្លាញជីនូវវង្សគេ ឱ្យវិនាសបាត់ពីផែនដីចេញ
ហើយពូជពង្សគេ ពីកណ្តាលពួកមនុស្សជាតិទៅដែរ[ថ]
១១ដ្បិតគេបានគិតប៉ងអាក្រក់[ទ]ដល់ទ្រង់
គេកើតមានគំនិត[ធ]ដែលធ្វើទៅមិនបាន
១២ពីព្រោះទ្រង់នឹងធ្វើឱ្យគេត្រឡប់បែរខ្នងវិញ[ន]
ទ្រង់នឹងដំឡើងធ្នូដំរង់ចំមុខគេ
១៣ឱព្រះយេហូវ៉ាអើយ សូមឱ្យទ្រង់បានថ្កើងឡើង[ប]
ដោយឥទ្ធិឫទ្ធិរបស់ទ្រង់[ផ]
នោះយើងខ្ញុំនឹងច្រៀងសរសើរពីព្រះចេស្តានៃទ្រង់ ។

ទំនុករបស់ស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង
ត្រូវលេងតាមបទ "ក្តាន់ញីពេលព្រលឹម" ។
**២២** ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ
ហេតុអ្វីបានជាទ្រង់លះចោលទូលបង្គំ[ក] ហើយគង់ឆ្ងាយ[ខ]
ឥតជួយទូលបង្គំ ឬស្តាប់សេចក្តីដំងូររបស់ទូលបង្គំដូច្នេះ[គ]
២ឱព្រះនៃទូលបង្គំអើយ
ទូលបង្គំអំពាវនាវនៅពេលថ្ងៃតែទ្រង់
មិនមានបន្ទូលឆ្លើយមកសោះ[ឃ] ក៏ស្រែកនៅពេលយប់ផង[ង]
តែទូលបង្គំមិនចេះស្រាកស្បើយឡើយ

**២១:៣** ឃ ២សយ ១២:៣០ វវ ១៤:១៤ ង សក ៦:១១ **២១:៤** ច ទដ ១០:១៦ ៤៥:១៧ ៤៨:១៤ ១៣៣:៣ **២១:៥** ឆ ខ.១ ទដ ១៨:៥០ ៤៤:៤ ជ ទដ ៨:៥ ៤៥:៣ ៩៣:១ ៩៦:៦ ១០៤:១ **២១:៦** ឈ ទដ ៤៣:៤ ១២៦:៣ ញ ១រប ១៧:២៧ **២១:៧** ដ ២ពវ ១៨:៥ ឋ ទដ ៦:៤ ឌ លប ១៤:១៨ ឍ ទដ ១៥:៥ ៥៥:២២ **២១:៨** ណ អស ១០:១០ **២១:៩** ត ចទ ៣២:២២ ទដ ៥០:៣ យរ ១៥:១៤ **២១:១០** ថ ទដ ២៨:១៨ **២១:១១** ទ ទដ ២:១ ធ យប ១០:៣ ទដ ១០:២ ២៦:១០ ៣៧:៧ **២១:១២** ន នក ២៣:២៧ **២១:១៣** ប ទដ ១៨:៤៦ ផ ទដ ១៨:១ **២២:១** ក យប ៦:១៥ ទដ ៩:១០ មថ ២៧:៤៦ មក ១៥:៣៤ ខ ទដ ១០:១ គ យប ៣:២៤ **២២:២** ឃ យប ១៩:៧ ង ទដ ៤២:៣ ៨៨:១

ពារស្តេចរបស់ពួកគេ (ខ.២) ប្រកាសពីផ្ទៃរឿង ខ.៣–៤ អភិវឌ្ឍន៍ពីផ្ទៃរឿង ។
**២១:២** *ដូចបំណង* សូមមើលការពន្យល់ ៤:៧ ។
**២១:៣** *បានស្ទាក់ប្រទានពរ* គឺខណៈពេលទ្រង់ត្រឡប់ពីសមរភូមិវិញ ។ *បំពាក់មកុដមាសសុទ្ធនៅលើក្បាល* គឺជាពិធីបំពាក់មកុដមាសសុទ្ធថ្មី ដែលទើបវាយបានពីពួកសត្រូវ គឺពីស្តេចដែលចាញ់ក្នុងសង្គ្រាម (សូមមើល ២សយ ១២:៣០) ។
**២១:៤** ព្រះជន្មព្រះមហាក្សត្រក៏មានព្រះជន្មរស់បានយូរអង្វែងតទៅ (សូមមើល ១ពវ ១:៣១ ដយ ២:៤ ៣:៩ ១សយ ១០:២៤ ១ពវ ១:២៥,៣៤,៣៩ ។
**២១:៥** *មានកិត្តិយសហើយនឹងអនុភាព* សូមមើល ៤៥:៣ ក៏ដូចជាអធិរាជ្យនៃស្ថានសួគ៌ដែរ ។
**២១:៦** *មានពរយ៉ាងបណ្តាច់នៅអស់កល្ប* គឺមានទាំង : (១).ព្រះពរនៃតម្កើ ឬក៏ (២).ព្រះពរដែលហូរមកមិនចេះឈប់ ។ ដ្បិតព្រះវត្តមានរបស់ទ្រង់បាននាំមកនូវព្រះពរជាបរិបូរហូរហៀរ ។
**២១:៧** ចំណុចកណ្តាលបទទំនុកដំកើង (សូមមើលការពន្យល់ ៦:៦) ។ គឺជាការចូលរួមធ្វើការអធិស្ឋានសូត្រទន្ទេញបទសរសើរ (មានទាំងពួកសង្ឃ ឬពួកលេវី) និងការប្រកាសពីហេតុផលនៃសន្តិសុខរបស់ព្រះមហាក្សត្រ ។ *ព្រះយេហូវ៉ា . . . ព្រះដ៏ខ្ពស់បំផុត* (សូមមើល ៧:១៧ ) ។ *នៃព្រះដ៏ខ្ពស់បំផុត* សូមមើលការពន្យល់ លប ១៤:១៩ ។ *ត្រូវរង្គើ* មើលការពន្យល់ ១០:៦ ។
**២១:៩** *ដោយសេចក្តីក្រោធរបស់ទ្រង់* (សូមមើលការពន្យល់ ២:៥) ។
**២១:១០** សត្រូវរបស់ព្រះមហាក្សត្រក៏ចាកចេញទៅបាត់ ក៏ពុំមានពួកចាស់ទុំណាងើបឡើងប្រឆាំងនឹងសត្រូវនោះសោះ ។
**២១:១២** *ដំឡើងធ្នូដំរង* សូមើល លប ៩:១៣ ។
**២១:១៣** វគ្គនៃសេចក្តីបញ្ចប់ ហើយត្រឡប់ទៅការចាប់ផ្តើម : ព្រះយេហូវ៉ាបានផ្តល់កម្លាំងដែលមានព្រះមហាក្សត្រមានសេចក្តីអំណរ (ខ.១,៧) ក៏បានសរសើរព្រះដ៏មានព្រះចេស្តា ។
**ទដ ២២** ការអធិស្ឋានដ៏ប៉ះពាល់ចិត្តរបស់ស្តេចដាវីឌ ក្នុងនាមជាអ្នករងគ្រោះដោយសារមានសេចក្តីជំនឿលើព្រះ ដែលត្រូវពួកសត្រូវវាយប្រហារលើស្តេចដាវីឌ តែទ្រង់នៅតែទុកចិត្តហើយពឹងផ្អែកលើព្រះយេហូវ៉ាដ៏ដែលទោះបីពួកមនុស្សនិយាយចំអកឱ្យក៏ដោយ ។
**២២ ជាផ្នែកចំណាងជើង** សូមមើលការពន្យល់ ទដ ៤,៩ ត្រងចំណាងជើង ។
**២២:១** *ហេតុអ្វី* សូមមើលការពន្យល់ ៦:៣ ។
**២២:២** *ទូលបង្គំអំពាវនាវ . . . តែទ្រង់មិនមានបន្ទូលឆ្លើយមកសោះ* សូមមើលការពន្យល់ ១១៨:៥ ។

៣ប៉ុន្តែ ឱព្រះដែលបានតាំងឡើង
ក្នុងទំនុកសរសើរ[ច]របស់អ៊ីស្រាអែលអើយ ទ្រង់បរិសុទ្ធ[ឆ]
៤ពួកព្ធយុកោយើងខ្ញុំបានទុកចិត្តនឹងទ្រង់ គេបានទុកចិត្ត
ហើយទ្រង់បានប្រោសឱ្យរួច[ជ]
៥គេបានអំពាវនាវដល់ទ្រង់[ឈ] ហើយបានរួចចេញ
គេបានទុកចិត្តនឹងទ្រង់[ញ] ហើយមិនត្រូវខ្មាសឡើយ[ដ]
៦ចំណែកទូលបង្គំៗជាដង្កូវ[ឋ] មិនមែនជាមនុស្សទេ
ជាទីត្មះតិះដៀលរបស់មនុស្ស[ឌ]
ហើយជាទីស្អប់ខ្ពើម[ឍ]នៃពួកបណ្តាជន
៧អស់អ្នកដែលឃើញទូលបង្គំក៏ឡកឡឺយឱ្យ[ណ]គេបូញមាត់[ត]
ហើយគ្រវីក្បាល ដោយថា[ថ]
៨វាបានទុកចិត្តនឹងព្រះយេហូវ៉ា ថាទ្រង់នឹងប្រោសឱ្យរួច[ទ]
ចូរឱ្យទ្រង់ជួយសង្គ្រោះវាចុះ[ធ]
ដ្បិតវាបានយកទ្រង់ជាទីគាប់ចិត្ត[ន]ហើយ
៩ប៉ុន្តែគឺទ្រង់ដែលបានធ្វើឱ្យទូលបង្គំចេញពីផ្ទៃម្តាយមក[ប]
ទ្រង់បានឱ្យទូលបង្គំទុកចិត្ត[ផ] ក្នុងកាលដែលនៅបៅដោះ
ម្តាយនៅឡើយ
១០ទូលបង្គំបានត្រូវទំលាក់លើទ្រង់ តាំងពីផ្ទៃម្តាយមក
តាំងពីម្តាយសំរាល[ព]ទូលបង្គំមក
នោះទ្រង់ជាព្រះនៃទូលបង្គំហើយ
១១សូមកុំគង់ឆ្ងាយពីទូលបង្គំឡើយ[ភ]
ដ្បិតសេចក្តីទុក្ខមកជិត[ម]ហើយ ឥតមានអ្នកណានឹងជួយ
សោះ[យ]
១២មានគោឈ្មោលជាច្រើន[រ]បានព័ទ្ធទូលបង្គំជុំវិញ[ល]
គឺគោឈ្មោលយ៉ាងខ្លាំងពីស្រុកបាសាន[វ]វាបានឡោមទូល
បង្គំជុំវិញ
១៣វាហាមាត់[ស]ដាក់ទូលបង្គំ ប្រៀបដូចជាសិង្ហ[ហ]
ដែលហែកស៊ី[ឡ]ទាំងគ្រហឹម
១៤ទូលបង្គំត្រូវច្រួចចេញ ដូចជាទឹក
ហើយអស់ទាំងឆ្អឹងនៃទូលបង្គំសណ្តកចេញពីគ្នា[អ]
ចិត្តទូលបង្គំទុកដូចជាក្រមួន[ក]ដែលរលាយ[ខ] នៅក្នុងខ្លួន
ហើយ
១៥កំឡាំងទូលបង្គំហួតខ្សោះទៅ[គ]
ដូចអំបែងឆ្នាំងអណ្តាតទូលបង្គំជាប់នៅក្រអូមមាត់[ឃ]
ទ្រង់បាននាំទូលបង្គំចុះទៅក្នុងធូលី[ង]នៃសេចក្តីស្លាប់
១៦ព្រោះមានឆ្កែ[ច]មកឡោមព័ទ្ធទូលបង្គំហើយ
មានពួកមនុស្សអាក្រក់ ដើរក្រវែលជុំវិញទូលបង្គំ
គេបានចាក់ទំលុះ[ឆ]ដៃជើងនៃទូលបង្គំ
១៧អស់ទាំងឆ្អឹងក្នុងរាងកាយនៃទូលបង្គំរាប់បានទាំងអស់
គេគន់មើល ហើយសំឡឹង[ជ]មកទូលបង្គំ[ឈ]
១៨គេយកសំលៀកបំពាក់ទូលបង្គំចែកគ្នា
ឯអាវវែងរបស់ទូលបង្គំ[ញ] គេក៏ធ្វើឆ្នោតចាប់យក[ដ]

**២២:៣** ច ២ពវ ១៩:២២ ទដ ៧១:២២ មក ១:២៤ ឆ នក ១៥:២ ទដ ១៤៨:១៤ **២២:៤** ជ ទដ ៧៨:៥៣ ១០៧:៦ **២២:៥** ឈ ១រប ៥:២០ ញ អស ៨:១៧ ២៥:៩ ២៦:៣ ៣០:១៨ ដ ២រប ១៣:១៨ ទដ ២៥:៣ ៣១:១៧ ៧១:១ អស ៤៩:២៣ រម ៩:៣៣ **២២:៦** ឋ យប ៤:១៩ ឌ ២សយ ១២:១៤ ទដ ៣១:១១ ៦៤:៨ ៦៩:១៩ ១០៩:២៥ ឍ ទដ ១១៩:១៤១ អស ៤៩:៧ ៥៣:៣ ៦០:១៤ មឡ ២:៩ មថ ១៦:២១ **២២:៧** ណ យប ១៧:២ ទដ ៣៥:១៦ ៦៩:១២ ៧៤:១៨ មថ ២៧:៤១ មក ១៥:៣១ លក ២៣:៣៦ ត មថ ២៧:៣៩,៤៤ មក ១៥:៣២ លក ២៣:៣៩ ថ មក ១៥:២៩ **២២:៨** ទ ទដ ៩១:១៤ ធ ទដ ៣:២ ន ២សយ ២២:២០ មថ ៣:១៧ ២៧:៤៣ **២២:៩** ប យប ១០:១៨ ទដ ៧១:៦ ផ ទដ ៧៨:៧ ណហ ១:៧ **២២:១០** ព ទដ ៧១:៦ អស ៤៦:៣ ៤៩:១ **២២:១១** ភ ខ.១៩ ទដ ១០:១ ម ទដ ១០:១៤ យ ២ពវ ១៤:២៦ អស ៤១:២៨ **២២:១២** រ ទដ ៦៨:៣០ ល ទដ ១៧:៩ ២៧:៦ ៤៩:៥ ១០៩:៣ ១៤០:៩ វ ចទ ៣២:១៤ អស ២:១៣ អគ ២៧:៦ ៣៩:១៨ អម ៤:១ **២២:១៣** ស ខ.២១ អគ ២២:២៥ សផ ៣:៣ ហ បទ ៣:៤៦ ឡ លប ៤៩:៩ **២២:១៤** អ ទដ ៦:២ ក យប ២៣:១៦ ទដ ៦៨:២ ៩៧:៥ មីក ១:៤ ខ យស ៧:៥ ទដ ១០៧:២៦ ដយ ៥:៦ **២២:១៥** គ អស ៤៥:៩ ឃ ទដ ១៣៧:៦ បទ ៤:៤ អគ ៣:២៦ ហ ១៩:២៨ ង យប ៧:២១ ទដ ១០៤:២៩ **២២:១៦** ច ភល ៣:២ ឆ អស ៥១:៩ ៥៣:៥ សក ១២:១០ យហ ២០:២៥ **២២:១៧** ជ លក ២៣:៣៥ ឈ ទដ ២៥:២ ៣០:១ ៣៥:១៩ ៣៨:១៦ បទ ២:១៧ មីក ៧:៨ **២២:១៨** ញ មក ៩:១២ ដ លវ ១៦:៨ មថ ២៧:៣៥ មក ១៥:២៤ យហ ១៩:២៤

**២២:៣–៥** ក្នុងផ្នែកនេះជាវគ្គប្រមូលផ្តុំសំរិតសម្រាំងនូវអ្វីៗដែលជាព្រះរាជកិច្ចធ្វើចំពោះរាស្ត្រអ៊ីស្រាអែល (សូមមើលការពន្យល់ ខ.៩–១០) ។

**២២:៣** *បានតាំងឡើង* សូមមើល ៩:១១ ។ *ទ្រង់បរិសុទ្ធ* សូមមើល លវ ១១:៤៤ និងការពន្យល់ ។ *ការសរសើររបស់អ៊ីស្រាអែល* អ្នកដែលរាស្ត្រអ៊ីស្រាអែលសរសើរនោះគឺជាទ្រង់តែមួយ ដែលជួយសង្គ្រោះរាស្ត្រអ៊ីស្រាអែល (សូមមើល ១៤៨:១៤ ចទ ១០:២១ យរ ១៧:១៤) ។

**២២:៦** *ជាដង្កូវមិនមែនជាមនុស្សទេ* សូមមើល យប ២៥:៦ អស ៤១:១៤ ។

**២២:៧** *ក៏ឡកឡឺយ . . . គ្រវីក្បាល* សូមមើល មថ ២៧:៣៩ មក ១៥:២៩ សូមមើលការពន្យល់ ៥:៩ ។

**២២:៨** ជាសេចក្តីដកស្រង់ក្នុង មថ ២៧:៤៣ និងការពន្យល់ ៣:២ ។

**២២:៩–១០** អត្ថបទនេះជាការប្រមូលនូវសកម្មភាព ដែលព្រះយេហូវ៉ាធ្វើការចំពោះគាត់ (សូមមើលការពន្យល់ ខ.៣–៥) ។

**២២:១២–១៨** ភាពមានទុក្ខសោកយ៉ាងជ្រាលជ្រៅរបស់អ្នកនិពន្ធបទទំនុកមានក្នុង ខ.១២–១៣,១៦–១៨ ។ កាត់ប្រើតួរលេខ៤ដើម្បីបញ្ជាក់បង្ហាញពីការវាយប្រយុទ្ធរបស់ពួកសត្រូវ ក្នុង ខ.១៤–១៥ ដែលបានពណ៌នាអត្ថន័យខាងក្នុងនៃភាពឥតមានអំណាច ការប្រយុទ្ធដ៏សាហាវរបស់ពួកគេ ។

**២២:១២** *ស្រុកបាសាន* មើលការពន្យល់ ចទ ៣២:១៤ អគ ៣៩:១៨ និងការពន្យល់ អម ៤:១ ។

**២២:១៤** *ឆ្អឹងនៃទូលបង្គំ . . . ចិត្តទូលបង្គំ* សូមមើលការពន្យល់ ៤:៧ ។

**២២:១៥** សូមមើលក្នុង ១៩:២៨ និងការពន្យល់ ។ *ក្នុងធូលីនៃសេចក្តីស្លាប់* សូមមើល ខ.២៩ និងការពន្យល់ ។

**២២:១៦** *ទំលុះដៃជើងទូលបង្គំ* ដូចជា "ឆ្កែ" សូមមើល អស ៥៣:៥ សក ១២:១០ យហ ១៩:៣៤,៣៧ ។

**២២:១៧** *អស់ទាំងឆ្អឹងក្នុងរាងកាយនៃទូលបង្គំរាប់បាន* ប្រហែលយកល្អខ្ញុំត្រូវតែយលឆ្អឹងខ្ញុំដាក់ចេញឱ្យអស់ គឺជាផ្នែករូបភាពមួយអាចជាការវាយប្រហារដោយពួកសត្រូវ ចោរប្លន់ ទាហានដែលទាញអាវទ្រង់ចេញ (សូមមើល ខ.១៨ និងការពន្យល់ ខ.២០–២១) ។

**២២:១៨** មើលសេចក្តីផ្តើមក្នុងគម្ពីរទំនុកដំកើង មើល យហ ១៩:២៣–២៤។

១៩ ឱព្រះយេហូវ៉ាអើយ សូមកុំគង់ឆ្ងាយពីទូលបង្គំឡើយ[ឋ]
ឱព្រះដ៏ជាកំឡាំង[ឌ]នៃទូលបង្គំអើយ
សូមយាងមកជួយទូលបង្គំ[ឍ]ជាប្រញាប់[ណ]ផង
២០ សូមដោះព្រលឹងទូលបង្គំឱ្យរួចពីដាវ[ត] ហើយដួងជីវិតនៃ[ថ]
ទូលបង្គំឱ្យរួចពីអំណាចឆ្កែ[ទ]
២១ សូមជួយសង្គ្រោះទូលបង្គំចេញពីមាត់សិង្ហ[ធ]
អើ ឱ្យរួចពីស្នែងគោព្រៃផង[ន] ដ្បិតទ្រង់បានស្ដាប់ទូលបង្គំ
ហើយ ។
២២ ទូលបង្គំនឹងប្រកាសប្រាប់ពីព្រះនាមទ្រង់ដល់ពួកបងប្អូន
ទូលបង្គំនឹងសរសើរដំកើងទ្រង់[ប] នៅកណ្ដាលពួកជំនុំ[ផ]
២៣ ឯអ្នករាល់គ្នាដែលកោតខ្លាចដល់ព្រះយេហូវ៉ាអើយចូរ
សរសើរទ្រង់ចុះ[ព] អស់អ្នកដែលជាពូជយ៉ាកុបអើយ
ចូរដំកើងទ្រង់ឡើង[ភ] អស់ពូជពង្សនៃអ៊ីស្រាអែលអើយ
ចូរកោតខ្លាចនៅចំពោះទ្រង់ចុះ[ម]
២៤ ដ្បិតទ្រង់មិនបានមើលងាយ[យ] ឬខ្ពើមឆ្អើម
ចំពោះសេចក្ដីទុក្ខលំបាករបស់មនុស្សដែលគេរងទុក្ខ
នោះឡើយ[រ] ក៏មិនបានលាក់ព្រះភក្ត្រ[ល]នឹងអ្នកនោះដែរ
គឺកាលអ្នកនោះបានអំពាវនាវរកទ្រង់នោះទ្រង់បានស្ដាប់
តាម[វ]
២៥ ទ្រង់ជាដើមហេតុនៃការដែលទូលបង្គំសរសើរនៅក្នុង
ជំនុំធំ[ស] ទូលបង្គំនឹងលាបំណន់របស់ទូលបង្គំ[ហ]
នៅចំពោះមុខពួកអ្នកដែលកោតខ្លាចដល់ទ្រង់
២៦ ឯមនុស្សរាបទាប គេនឹងបានបរិភោគ[ឡ]ឆ្អែត
អស់អ្នកដែលស្វែងរកព្រះយេហូវ៉ា នឹងសរសើរដល់ទ្រង់[អ]
សូមឱ្យចិត្តអ្នករាល់គ្នាប្រកបដោយសេចក្ដីចំរើនជានិច្ច
២៧ គ្រប់ទាំងទីបំផុតនៃផែនដី[ក] នឹងនឹកដល់ព្រះយេហូវ៉ា
ហើយ ត្រឡប់បែរមកឯទ្រង់ អស់ទាំងពូជពង្សនៃនគរ
ទាំងឡាយ នឹងថ្វាយបង្គំនៅចំពោះទ្រង់[ខ]
២៨ ដ្បិតអំណាចគ្រប់គ្រងជារបស់ផងព្រះយេហូវ៉ា[គ]
ទ្រង់ជាចៅហ្វាយលើអស់ទាំងនគរ
២៩ អស់អ្នកមាន[ឃ]ចិត្តស្កប់ស្កល់នៅផែនដីនឹងបរិភោគព្រម
ទាំងថ្វាយបង្គំផង[ង] អស់អ្នកដែលចុះទៅក្នុងធូលី[ច]
និងឱនក្រាបនៅចំពោះទ្រង់
ហើយទាំងអ្នកដែលមិនអាចនឹងរក្សាជីវិតខ្លួនបានផង[ឆ]

**២២:១៩** ឋ ខ.១១ ឌ ទដ ១៨:១ ឍ ទដ ៤០:១៣ ណ ទដ ៣៨:២២ ៧០:៥ ១៤១:១ **២២:២០** ត យប ៥:២០ ទដ ៣៧:១៤ ថ ទដ ៣៥:១៧ ទ ភល ៣:២ **២២:២១** ធ ខ.១៣ យប ៤:១០ ន ខ.១២ ជន ២៣:២២ **២២:២២** ប ទដ ៣៥:១៨ ហព ២:១២ ផ ទដ ២៦:១២ ៤០:៩, ១០ ៦៨:២៦ **២២:២៣** ព ទដ ៣៣:២ ៦៦:៨ ៨៦:១២ ១០៣:១ ១០៦:១ ១១៣:១ ១១៧:១ ១៣៥:១៩ ភ ទដ ៥០:១៥ អស ២៤:១៥ ២៥:៣ ៤៩:២៣ ៦០:៩ យរ ៣:១៧ ម ចទ ១៤:២៣ ទដ ៣៣:៨

**២២:២៤** យ ទដ ១០២:១៧ រ ទដ ៩:១២ ល ទដ ១៣:១ ២៧:៩ ៦៩:១៧ ១០២:២ ១៤៣:៧ វ យប ២៤:១២ ៣៦:៥ ហព ៥:៧ **២២:២៥** ស ទដ ២៦:១២ ៣៥:១៨ ៤០:៩ ៨២:១ ហ ជន ៣០:២ **២២:២៦** ឡ ទដ ១០៧:៩ អ ទដ ៤០:៦ **២២:២៧** ក ទដ ២:៨ ខ ទដ ៨៦:៩ ១០២:២២ ដយ ៧:២៧ មីក ៤:១ **២២:២៨** គ ទដ ៤៧:៧–៨ សក ១៤:៩ **២២:២៩** ឃ ទដ ៤៥:១២ ង ទដ ៩៥:៦ ៩៦:៩ ៩៩:៥ អស ២៧:១៣ ៤៩:៧ ៦៦:២៣ សក ១៤:១៦ ច អស ២៦:១៩ ឆ ទដ ៨៩:៤៨

**២២:២០–២១** ការអធិស្ឋានរបស់អ្នកនិពន្ធទំនុកដំកើង ដែលអំពាវនាវម្ដងទៀតហើយមានលក្ខណៈផ្ទុយពីតួរលេខទាំង៤ ដោយមានការបញ្ជាក់ពីអ្នកប្រឆាំងទ្រង់ មាននៅក្នុង ខ.១២–១៣,១៦–១៨ "ដាវ""ឆ្កែ""សិង្ហ""គោព្រៃ"នៅទីនេះពាក្យថា"ដាវ" គឺសំដៅទៅលើទស្សនៈដែលមានពណ៌នាក្នុង ខ.១៧–១៨ ក៏មានការបកស្រាយខ្លះថា វាគឺជាការវាយប្រហារដោយពួកចោរប្លន់ ឬពួកសត្រូវ ពួកទាហាន ឯពាក្យថា "ដាវ" ជារឿយៗគេប្រើបង្ហាញពីការស្លាប់ដោយភាពឃោរឃៅ ។

**២២:២១** *សូមជួយសង្គ្រោះទូលបង្គំ* សូមើលការពន្យល់ ៣:៨ ។ *គោព្រៃ* ពីមុនគឺជាគោព្រៃតែសព្វថ្ងៃកូនពួកវាជាច្រើនដំណរក៏ក្លាយទៅជាសត្វស្រុកដែលរស់នៅជាមួយមនុស្សបាន ។

**២២:២២–៣១** ការសច្ចា ស្បត់ ដើម្បីសរសើរចំពោះព្រះយេហូវ៉ា ក្នុងខណៈពេលដែលការប្រោសលោះរបស់ព្រះយេហូវ៉ាបានមកដល់ (សូមមើលការពន្យល់ ៧:១៧) ។ សេចក្ដីសច្ចាឃើញក្នុង ខ.២២,២៥ និង ខ.២៣–២៤ ក៏ជាការសរសើររបស់អ្នកនិពន្ធទំនុដដំកើង (សូមើលការពន្យល់ ៧:១៧) ។ ការសច្ចាក៏មានក្នុងខមួយចំនួនទៀតគឺ ខ.២៣–២៤ ជាការសរសើររួមមួយរបស់អ្នកនិពន្ធទំនុកដំកើង (សូមមើលការពន្យល់ ៩:១) ។ ឯខ.២៦–៣១ ពណ៌នាពីការសរសើរដំកើងជាលក្ខណៈគ្រប់សណ្ឋានជីវិត ពីមួយជំនាន់ទៅមួយជំនាន់ ។ ក៏គ្មានគម្ពីរទំនុកដំកើងមួយណា ឬសេចក្ដីទំនាយណាមួយបានសរសេរនូវទស្សនៈផ្សេងៗទាក់ទងនឹងការថ្វាយបង្គំ ចំពោះអ្នកដែលចូលរួមការសរសើរដំកើងនូវការដែលព្រះបានជួយសង្គ្រោះ ។

**២២:២២** សូមមើល ហព ២:១២ និងការពន្យល់ ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**២២:២៣** *កោតខ្លាចដល់ព្រះយេហូវ៉ា* មើល ខ.២៥ និងការពន្យល់ ១:៥ ។

**២២:២៥** *នៅក្នុងជំនុំធំ* សូមមើលការពន្យល់ ១:៥ ។

**២២:២៦** *នឹងបានបរិភោគឆ្អែត* ពាក្យនេះដូចកាលគេបានចែកចាយក្នុងពិធីអបអរសាទរនូវពិធីបុណ្យសរសើរដំកើង(មើល លវ ៧:១១–២៧) ។

**២២:២៧** *គ្រប់ទាំងទីបំផុតនៃផែនដី* គឺពួកគេនឹងប្រាប់ពីដំណឹងនៃសេចក្ដីសង្គ្រោះរបស់ផងទ្រង់ (សូមមើល ១៨:៤៩ និងការពន្យល់ ៩:១) ។ ជាដំណឹងល្អដែលព្រះនៃរាស្ត្រអ៊ីស្រាអែល បានឮនូវសេចក្ដីអធិស្ឋានរបស់រាស្ត្រទ្រង់ និងជួយសង្គ្រោះពួកគេឱ្យងាកបែរពីការគោរពរូបព្រះ មកឯព្រះដ៏ពិតវិញ (ប្រៀបធៀប ១ថន ១:៩) ។

**២២:២៨** ច្បាប់ទម្លាប់របស់ព្រះនៃរាស្ត្រអ៊ីស្រាអែល គឺមានលក្ខណៈទូទៅក៏តម្រូវគ្រប់ទាំងសណ្ឋានមនុស្ស ហើយអស់ទាំងពូជសាសន៍ក៏មកយក ឬទទួលបញ្ញត្តិទាំងនោះតាមរយៈទីបន្ទាល់ពីទ្រង់បានមានគំរូស្រាប់ក្នុងនាមជារាស្ត្រទ្រង់ (សូមមើល ទដ ៤៧ លប ១២:២–៣ ចទ ៣២:២១ រម ១០:១៩ ១១:១៣–១៤) ។

**២២:២៩** *អស់អ្នកមាន . . . អស់អ្នកចុះទៅ* គឺជាសេចក្ដីសុខសាន្តយ៉ាងសន្ធឹកសន្ធាប់ និងអស់អ្នកដែលស្ថិតនៅលើដែនកំណត់នៃសេចក្ដីស្លាប់ និងអស់អ្នកមានស្ថានភាពជីវិតដែលចូលទៅក្នុងចន្លោះកិច្ចការទាំងពីរ ដែលដាច់ស្រឡះពីគ្នាទាំងស្រុងនោះ ។ *ធូលី* មើល ខ.១៥ យស ៧:២១ និងការ ពន្យល់ ។

៣០ នឹងមានពូជពង្ស១[ជ] គោរពប្រតិបត្តិដល់ទ្រង់
គេនឹងថ្លែងប្រាប់ពីព្រះអម្ចាស់
ដល់ដំណមនុស្ស[ឈ] ក្រោយតទៅ
៣១ គេនឹងមក ហើយនិងប្រាប់ពីសេចក្ដីសុចរិត[ញ] របស់ទ្រង់
ដល់មនុស្ស១ពួក ដែលមិនទាន់កើតមក[ដ] ថា
គឺទ្រង់ដែលបានធ្វើការ នោះ[ឋ] ។

ទំនុកនៃស្តេចដាវីឌ ។

**២៣** ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ[ក]
ខ្ញុំនឹងមិនខ្វះអ្វីសោះ[ខ]
២ ទ្រង់ឱ្យខ្ញុំដេកសំរាកនៅទីមានស្មៅខៀវខ្ចី
ទ្រង់នាំខ្ញុំទៅក្បែរមាត់ទឹកដែលហូរគ្រឿនៗ[គ]
៣ ទ្រង់កែព្រលឹងខ្ញុំឡើងវិញ[ឃ] ទ្រង់នាំខ្ញុំ[ង] ទៅតាមផ្លូវសុចរិត[ច]
ដោយយល់ដល់ព្រះនាមទ្រង់[ឆ] ។
៤ អើ ទោះបើទូលបង្គំដើរកាត់ច្រកភ្នំនៃម្លប់សេចក្ដីស្លាប់
ក៏ដោយ[ជ] គង់តែមិនខ្លាចសេចក្ដីអាក្រក់ណាឡើយ[ឈ]
ដ្បិត ទ្រង់គង់នៅជាមួយនឹងទូលបង្គំ[ញ]
ព្រនង់ ហើយនិងដំបងរបស់ទ្រង់កំសាន្តចិត្តទូលបង្គំ
៥ ទ្រង់រៀបតុ[ដ] នៅមុខទូលបង្គំ ចំពោះពួកខ្មាំងសត្រូវផង

**២២:៣០** ជ អស ៥៣:១០ ៥៤:៣ ៦១:៩ ៦៦:២២ ឈ ទដ ១០២:១៨ **២២:៣១** ញ ទដ ៥:៨ ៤០:៩ ដ ទដ ៧១:១៨ ៧៨:៦ ១០២:១៨ ៧៨:៦ ១០២:១៨ ឋ លក ១៨:៣១ ២៤:៤៤ **២៣:១** ក លប ៤៨:១៥ ទដ ២៨:៩ យហ ១០:១១ ខ ទដ ៣៤:៩,១០ ៨៤:១១ ១០៧:៩ ភល ៤:១៩

**២៣:២** គ ទដ ៣៦:៨ ៤៦:៤ *វវ* ៧:១៧ **២៣:៣** ឃ ទដ ១៩:៧ ង ទដ ២៥:៩ ៧៣:២៤ អស ៤២:១៦ ច ទដ ៥:៨ ឆ ទដ ២៥:១១ ៣១:៣ ៧៩:៩ ១០៦:៨ ១០៩:២១ ១៤៣:១១ **២៣:៤** ជ យប ៣:៥ ទដ ១០៧:១៤ ឈ ទដ ៣:៦ ២៧:១ ញ ទដ ១៦:៨ អស ៤៣:២ **២៣:៥** ដ យប ៣៦:១៦

**២២:៣១** *សេចក្ដីសុចរិត* សូមមើល ៤:១ ។

**ទដ ២៣** ការអះអាងពីក្ដីអំណរយ៉ាងពិតក្នុងព្រះយេហូវ៉ា ដែលទ្រង់ដូចជាព្រះមហាក្សត្រមានចិត្តជាអ្នកគង្វាល ។ ក្នុងការរៀបចំក្នុង ទដ ១៥–២៤ វាបានធ្វើកិច្ចការដូចជាស្រដៀងទៅនឹង ទដ ១៦ ដែលមានផ្ទៃរឿងភ្ជាប់គ្នាទំនាក់ទំនងគ្នា (សូមមើលសេចក្ដីផ្ដើម ទដ ១៦ និងមើលសេចក្ដីផ្ដើម ទដ ១៥–២៤) ។ គម្ពីរទំនុកដំកើងក៏មានអមទៅដោយពិធីអបអរសារទរនូវការសរសើរតម្កើងនៅឯតំណាក់នៃព្រះយេហូវ៉ា (ខ.៦) ក៏មានការប្រោសលោះដូចជាជញ្ជីងគិតក្នុង ២២:២៥–៣១ (សូមមើលការពន្យល់ ៧:១៧) ។ ទំនុកដំកើងអាចចែកជាពីរវគ្គធំៗ : ឯវគ្គនិមួយៗក៏ចែកចេញជាបួនផ្នែក (មានកំណាព្យជាភាសាហេព្រើរ) (១).វគ្គគាថាទី១ : ខ.១–២ក ២ខ–៣ក ៣ខ–គ៤ក–គ (ខ.៤ក–ខ គឺជាពាក្យកាព្យពាក់កណ្ដាលវគ្គ) (២).វគ្គគាថាទី២ : ខ.៥ក–ខ,៥ក–គ,៦ក–ខ,៦ក–ខ ។ វាមានលក្ខណៈត្រីគុណនៅក្នុងវគ្គពាក់កណ្ដាល (ខ.៤ខ–ច) គឺជាជួរបន្ទាត់កណ្ដាល (សូមមើលការពន្យល់ ៦:៦) គឺផ្ដោតទៅលើការការពារធានារ៉ាប់រងរបស់ព្រះមហាក្សត្រ ដែលមានចិត្តជាអ្នកគង្វាលដល់រាស្ត្ររបស់ទ្រង់ ។ វាគឺជាវគ្គគាថាពីរ ដែលបង្ហាញពីភាពជាអ្នកគង្វាល ។

**២៣:១** *ជាអ្នកគង្វាល* គឺជាពាក្យប្រៀបប្រដូចទៅនឹងស្តេចដែលគ្រប់គ្រងប្រជារាស្ត្រក្នុងសម័យមជ្ឈិមបូព៌ាបុរាណ ក៏មាននៅក្នុងស្រុកអ៊ីស្រាអែលដែរ (សូមមើល ៧៨:៧០–៧២ ២សយ ៥:២ អស ៤៤:២៨ យរ ៣:១៥ ២៣:១–៤ មីក ៥:៤ និងការពន្យល់ យរ ២:៨) ។ ដោយព្រោះព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលរាស្ត្រអ៊ីស្រាអែល សូមមើល ២៨:៩ ៧៩:១៣ ៨០:១ ៩៥:៧ ១០០:៣ លប ៤៨:១៥ អស ៤០:១១ យរ ១៧:១៦ ៣១:១០ ៥០:១៩ អរ ៣៤:១១–១៦ ។ នៅក្នុងនេះស្ដេចដាវីឌក៏ទទួលស្គាល់ថា ព្រះយេហូវ៉ាគឺជាអ្នកគង្វាលក៏ល្អរបស់ទ្រង់ដែរ សូមមើល យហ ១០:១១,១៤ ហព ១៣:២០ ។ *នឹងមិនខ្វះសោះ* គឺមានលក្ខណៈផ្ទុយវិញ ដោយទ្រង់បានទទួលភាពល្អប្រសើរក្នុងជីវិតរបស់ទ្រង់ និងសេចក្ដីអំណរពេញបរិបូរ ។

**២៣:២** *ដេកសំរាក* គឺសំដៅចំពោះហ្វូងចៀមដែលទទួលបានភាពសុខសាន្តដោយដេកសម្រាកនៅលើវាលស្មៅដ៏ខ្ចីស្រស់ ដែលពុំមានភាពខ្វះខាតឡើយ សូមមើល អស ១៤:៣០ ១៧:២ យរ ៣៣:១២ អគ ៣៤:១៤–១៥ សផ ២:៧ ៣:១៣ ។ *មានស្មៅខៀវខ្ចី* តាមលក្ខណៈពាក្យប្រៀបប្រដូចគឺជាការធ្វើឱ្យជីវិតមានភាពលូតលាស់ មានផលផ្លែ (មើល អគ ៣៤:១៤ យហ ១០:៩) ។ *នាំខ្ញុំ* គឺមានលក្ខណៈជាគ្រូគង្វាល (សូមមើល អស ៤០:១១) ។ *ទឹកដែលហូរគ្រឿន* គឺតាមបែបអក្សរសាស្ត្រ គឺទឹកជាទឹកកន្លែងសម្រាក់សុខសាន្ត ពោលគឺជាលិទ្ធផលដែលទ្រង់ផ្ដល់ឱ្យមានភាពស្រស់ស្រាយ ស្ថានភាពល្អ (សូមមើល អស ៤៩:១០) ។

**២៣:៣** *កែព្រលឹងខ្ញុំឡើងវិញ* ការសុំឱ្យព្រលឹងស្រស់ថ្លារួចផុតពីភាពហ្មងសៅផ្សេងៗ (មើល ១៩:៧ នរ ៤:១៥ សភ ២៥:១៣ បទ ១:១៦) ។ *នាំខ្ញុំទៅតាមផ្លូវសុចរិត* គឺមានលក្ខណៈដូចអ្នកគង្វាលចៀមដឹកនាំហ្វូងចៀមរបស់គាត់អញ្ចឹង (សូមមើល ៧៧:២០ ៧៨:៧២) ក៏ដូចស្ដេចដាវីឌ អ្នកគង្វាលរបស់ទ្រង់បាននាំទ្រង់ទៅតាមផ្លូវនៃសេចក្ដីសុខ ។ ចំពោះអត្ថន័យ "ភាពសុចរិត" សូមមើល សភ ៨:១៨ (វិបុលសុខ) ២១:២១ (វិបុលសុខ) អស ៤៨:១៨ និងមើល សភ ៨:២០–២១ ។ តាមការអនុវត្តន៍ជាក់ស្ដែង ពាក្យថា "ភាពសុចរិត" មានន័យពីរ ពោលគឺវាសំដៅលើផ្លូវនៃការគ្រាប់តាមជីវិតអ្នកនិពន្ធទំនុកដំកើង ចំពោះចិត្តគំនិតដែលមានសីលធម៌ល្អ (ផ្ទៀបនឹង សភ ៤:១១ និងការពន្យល់) ។ *ដោយយល់ដល់ព្រះនាមទ្រង់* ភាពមិនវិបុសសុខនៃអ្នកបម្រើរបស់ព្រះយេហូវ៉ា ក៏នាំមកសិរីល្អជូនដល់ព្រះ នាមព្រះយេហូវ៉ាយ៉ាងពិត (សូមមើល ១ពវ ៨:៤១–៤២ អស ៤៨:៩ យរ ១៤:២១ អគ ២០:៩ ១៤:២២) ។

**២៣:៤** *ព្រនង់ហើយ . . . កំសាន្តចិត្តទូលបង្គំ* គឺជាវគ្គត្រង់ចំណុចរួមកណ្ដាលក្នុងគម្ពីរទំនុកដំកើងនេះ សូមមើលសេចក្ដីផ្ដើមនៃការពន្យល់ខាងលើ ។ *គង់នៅជាមួយនឹងទូលបង្គំ* សូមមើល ១៦:៨ និងការពន្យល់ និងមើល ចទ ៣១:៦,៨ មថ ២៨:២០ ។ *ព្រនង់* គឺជាឧបករណ៍នៃអំណាចចេស្ដា (ដូចមានក្នុង ២:៩ ៤៥:៦ នក ២១:២០ ២សយ ៧:១៤ យប ៩:៣៤) ក៏ប្រើសម្រាប់រាប់ឬនាំផ្លូវជួយសង្គ្រោះ និងការពារចៀមបានដែរ (សូមមើល លវ ២៧:៣២ អគ ២០:៣៧) ។ *ដំបង* គឺជាឧបករណ៍ការពារទ្រទ្រង់ (ដូចជាក្នុង នក ២១:១៩ ពច ៦:២១ ២ពវ ៤:២៩ សក ៨:៤) ។ *កំសាន្តចិត្តទូលបង្គំ* គឺទ្រង់រាប់ដល់ជីវិតទូលបង្គំ (ដូចមានក្នុង ៧១:២១ ៨៦:១៧ នរ ២:១៤ អស ១២:១ ៤០:១ ៤៩:១៣) ។

**២៣:៥** ជាព្រះមហាក្សត្រនៃអ្នកគង្វាលពីស្ថានសួគ៌ បានទទួលស្ដេចដាវីឌនៅឯតុទ្រង់ក្នុងនាមជាព្រះមបហាក្សត្រក្រោមចំណុះពីស្ថានសួគ៌ និងការពារ

ទ្រង់ចាក់ប្រេងលាបលើក្បាលទូលបង្គំ[ឋ]
ពែង[ឌ]នៃទូលបង្គំក៏ពេញហៀរ ។
៦ ប្រាកដជាសេចក្តីសប្បុរស និងសេចក្តីមេត្តាករុណា[ឍ]
នឹងជាប់តាមខ្ញុំ រាល់តែថ្ងៃ ដរាបដល់អស់១ជីវិតខ្ញុំ
ហើយខ្ញុំនឹងនៅក្នុងដំណាក់នៃព្រះយេហូវ៉ាជារៀងរាប
ដរាបទៅ ។

ទំនុកនៃស្តេចដាវីឌ ។

**២៤** ផែនដី និងសារពើនៅផែនដី
ជារបស់ផងព្រះយេហូវ៉ា[ក] ព្រមទាំងលោកីយ
និងបណ្តាអ្នកដែលនៅលោកីយផង[ខ]
២ ដ្បិតទ្រង់បានប្រតិស្ឋានផែនដីនៅលើសមុទ្រ[គ]
ហើយបានតាំងឱ្យមាំមួននៅលើទឹកទាំងពួង ។
៣ តើអ្នកណានឹងឡើងទៅឯភ្នំ[ឃ]នៃព្រះយេហូវ៉ា
តើអ្នកណានឹងឈរនៅក្នុងទីបរិសុទ្ធរបស់ទ្រង់បាន[ង]
៤ គឺជាអ្នកដែលមានដៃ[ច]ស្អាត និងចិត្តបរិសុទ្ធ[ឆ]
ជាអ្នកដែលមិនបណ្តោយឱ្យព្រលឹងខ្លួននៅតាមសេចក្តី
ភូតភរ[ជ] ហើយមិនបានស្បថប្រវ័ញ្ចគេឡើយ
៥ អ្នកនោះនឹងទទួលពរ[ឈ]ពីព្រះយេហូវ៉ា
ហើយនិងសេចក្តីសុចរិត[ញ]ពីព្រះដ៏ជួយសង្គ្រោះខ្លួន
៦ នោះហើយ ជាពួកអ្នកដែលរកតាមទ្រង់
គឺដែលស្វែងរកព្រះភក្ត្រទ្រង់[ដ]ក្នុងពួកយ៉ាកុប ។ បង្អង់

**២៣:៥** ឋ ទដ ៤៥:៧ ៩២:១០ លក ៧:៤៦ ឌ ទដ ១៦:៥ **២៣:៦** ឍ នហ ៩:២៥ **២៤:១** ក នក ៩:២៩ យប ៤១:១១ ខ ១កថ ១០:២៦ **២៤:២** គ លប ១:៦ ទដ ១៤:៣ ២ពត ៣:៥ **២៤:៣** ឃ ទដ ២:៦ ង ទដ ១៥:១ ៦៥:៤ **២៤:៤** ច ២សយ ២២:២១ ឆ ទដ ៥១:១០ ៧៣:១ មថ ៥:៨ ជ អគ ១៨:១៥ **២៤:៥** ឈ ចទ ១១:២៦ ញ ទដ ១៧:២ **២៤:៦** ដ ទដ ២៧:៨ ១០៥:៤ ១១៩:៥៨ ហស ៥:១៥

ស្តេចដាវីឌ ។ ក្នុងសម័យមជ្ឈឹមបូព៌ាបុរាណ មាសេចក្តីសញ្ញាដែលបញ្ចូលទាំងពេលទទួលទានអាហារនៃចំណងមិត្តភាព (សូមមើល ៤១:៩ លប ៣១:៥៤) ក្នុងករណីដែលមានសេចក្តីសញ្ញាមួយនៅក្រោមចំណុះរបស់ព្រះនៃព្រះអធិរាជ្យ (សូមមើល នក ២៤:៨–១២) ។ *ទ្រង់បានចាក់ប្រេងលាបលើក្បាលទូលបង្គំ* បើតាមទម្លាប់គឺជាការព្យាបាលទៅលើភាពដ៏ស្មោះក្នុងពិធីជប់លៀង (សូមមើល លក ៧:៤៦ ២សយ ១២:២០ សស ៩:៨ ដយ ១០:៣) ។ *ពែង* ជាពែងនៃពិធីជប់លៀងព្រះអម្ចាស់ (សូមមើលការពន្យល់ ១៦:៥) ។

**២៣:៦** *សេចក្តីសប្បុរស និងសេចក្តីមេត្តាករុណា* តាមធម្មតាគឺសំដៅទៅលើសេចក្តីសញ្ញាជាផលប្រយោជន៍ (មើលការពន្យល់ ៦:៤) ទីនេះក៏កំណត់ឱ្យឃើញពីគំនិត (សូមមើល ២៥:២១ ៤៣:៣ ៧៩:៨ ៨៩:១៤) ។ *និងជាប់តាម* តាមន័យអក្សរសាស្ត្រគឺជា "ការស្វែងរក" ជាពិសេសជាមួយបំណងនៃពួកសត្រូវ ។ ដូចជាករណីស្តេចដាវីឌដែលពួកស្តេចសូលដេញតាមចាប់សម្លាប់ (សូមមើល ១សយ ២៣:២៥ ២៤:១៤ ២៦:១៨,២០) ដោយសេចក្តីសប្បុរសនៃទ្រង់នៅជាមួយនឹងស្តេចដាវីឌ ។ *នៅក្នុងដំណាក់នៃព្រះយេហូវ៉ា* មើលការពន្យល់ ១៥:១ ។ *ជារៀងរាបដរាបទៅ* ចំពោះព្រះគម្ពីរជាភាសាហេព្រើរឃ្លានេះ គឺមានន័យដូចជា "ជាច្រើនឆ្នាំរហូត" ដូចមានក្នុង សភ ២៨:១៦ ("គឺសប្បាយនឹងជីវិតរស់ដ៏យូរវែងអន្លាយ") ប៉ុន្តែ ក៏សូមមើលការពន្យល់ ១១:៧ ១៦:៩–១១ ។

**ទដ ២៤** ជាការសូត្របទទំនុកដំកើងបែបអាជីព (សូមមើល ទដ ៤៧,៦៨, ១១៨,១៣២) ជាការប្រារព្ធពិធីដង្ហែរចូលទៅទីក្រុងស៊ីយ៉ូន ក៏បាននិពន្ធឡើងសម្រាប់ក្នុងឱកាស ដែលស្តេចដាវីឌបាននាំហឹបសញ្ញាចូលទៅក្នុងក្រុងយេរូសាឡិម ឬក៏ព្រឹត្តិការណ៍ដែលត្រូវចងចាំមួយ ដែលមាន ទដ ១៥ ក៏ជាទំនុកដំកើងដែលប្រមូលឡើង ដើម្បីសរសើរតម្កើងជាហេតុដែលខិតចូលទៅជិតព្រះបាន ដើម្បីឱ្យបាន "នៅឯព្រះរាជដំណាក់ព្រះយេហូវ៉ា" (២៣:៦ សូមមើលសេចក្តីផ្តើម ទដ ១៥–២៤) ។ ឯពួកជំនុំបានប្រើទំនុកនេះជាយូរមកហើយ ដើម្បីប្រារព្ធពិធីពេលព្រះបានយាងទៅស្ថានសួគ៌របស់ព្រះគ្រីស្ទ ឬជាទីក្រុងយេរូសាឡិមថ្មី ឬសម្រាប់ទៅកាន់ទីបរិសុទ្ធជាទីខ្ពស់បំផុត (សូមមើលសេចក្តីផ្តើម ទដ ៤៧) ។

**១៤:១** *ផែដី និងសារពើនៅផែនដី* ជាការប្រើពាក្យរបស់លោកប៉ុលពីការប្រកាសដំណឹងល្អ សូមមើល ១កថ ១០:២៥–២៦ ។

**២៤:២** តាមរយៈ លប ១:១–១០ ។ *ប្រតិស្ឋាន . . . បានតាំងឱ្យមាំមួន* ជាពាក្យប្រៀបប្រដូចជាទីក្រុង (សូមមើល យស ៦:២៦ ១ពវ ១៦:២៤ ៤៤:២៨ ហក ២:១៨ សក ៤:៩ ៨:៩) ។ មានលក្ខណៈដូចជាព្រះវិហារ (សូមមើល ១ពវ ៥:១៧ ៦:៣៧ អគ ៣:៦–១២ អស ៤៤:២៨ ហក ២:១៨ សក ៤:៩ ៨:៩) ។ មានលក្ខណៈដូចជាព្រះវិហារ នៅពីភពលោកក៏មានគេពិពណ៌នាថាវាមានមូលដ្ឋានមួយ (សូមមើល ១៨:១៥ ៨២:៥ ១សយ ២:៨ សភ ៨:២៩ អស ២៤:១៨) និងមានសរសេរ (សូមមើល ៧៥:៣ យប ៩:៦) ។ នៅឯមជ្ឈឹមបូព៌ា វិហារត្រូវបានគេសន្មត់ថា មានលក្ខណៈជាអតិសុខុមលោក (ជាធាតុបង្រួញចូលគ្នា) នៃការបង្កើតពិភពលោក (សូមមើលការពន្យល់ នក ២៦:១) ។ *នៅលើ* (សូមមើល ១០៤:៥–៩ លប ១:៩ ៧:១១ ៤៩:២៥ នក ២០:៤ ចទ ៣៣:១៣) ។

**២៤:៣–៦** សេចក្តីផ្តើមទាក់ទងនឹងអស់អ្នក ដែលចូលទៅឯទីបរិសុទ្ធ (ជាពាក្យសម្តីរបស់ពួកសង្ឃដែលបាននិយាយ) ។

**២៤:៣** *ភ្នំនៃព្រះយេហូវ៉ា* សូមមើល ២:៦ និងការពន្យល់ ។

**២៤:៤** *មានដៃស្អាត* គឺអ្នកមានសកម្មភាព ឬការប្រព្រឹត្តក្នុងជីវិតដោយពុំមានបទឧក្រិដ្ឋ ។ *ចិត្តបរិសុទ្ធ* គឺអស់អ្នកដែលមានចរិតនឹងសេចក្តីបំណងត្រឹមត្រូវ (មើល ៥១:១០ ៧៣:១) ។ ព្រះយេហូវ៉ាមានបន្ទូលថា "អ្នកមានចិត្តបរិសុទ្ធនឹងបានឃើញព្រះ" (មថ ៥:៨) ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ បណ្តោយឱ្យព្រលឹងខ្លួនទៅ ដូចជាការថ្វាយបង្គំ ឬយកសេចក្តីពិតចេញពីខ្លួន (សូមមើល ២៥:១–២ ៨៦:៤ ១៤៣:៨) ។ *ព្រលឹង* សូមមើលការពន្យល់ ៦:៣ ។ *សេចក្តីភូតភរ* គឺដោយសាតែព្រះក្លែងក្លាយ (ធៀបនឹង អស ១៩:១៨ យរ ៧:៩ សផ ១:៥) ។ គឺមានលក្ខណៈដូចគ្នានឹង នក ២០:១៦ និងការពន្យល់ លវ ១៩:១២ យរ ៥:២ ៧:៩ សក ៥:៤ មឡ ៣:៥) ។

**២៤:៥** *ជួយសង្គ្រោះ* ពោលគឺផលផ្លែនៃការជួយសង្គ្រោះ ដូចជាសេចក្តីសង្គ្រោះនៃភាពសុចរិតពីព្រះដ៏សប្បុរស នៅត្រង់នេះគឺជាអត្ថន័យពីព្រះពរ (សូមមើល ២៣:៣ និងការពន្យល់) ។

**២៤:៦** *ជាពួកអ្នកដែលរកតាមទ្រង់* ឬថា "កងធំៗ" ដូចជាមានក្នុង ១៤:៥ (គឺអស់អ្នកដែលមានចិត្តគំនិតតែមួយ) មើល ១១២:២ សភ ៣០:១១–១៤ និងការពន្យល់ ទដ ៧៣:១៥ ៧៨:៨ ។ ពួកយ៉ាកុប មើលការពន្យល់ ១៤:៧ ។

៧ ឱទ្វារទាំងឡាយអើយ ចូរងើបក្បាលឡើង[ឋ]
ឱទ្វារដ៏នៅអស់កល្បជានិច្ចអើយ ចូរនៅជាចំហចុះ
នោះមហាក្សត្រ[ឌ]ដ៏មានសិរីល្អ[ឍ] ទ្រង់នឹងយាងចូលមក[ណ]
៨ តើមហាក្សត្រដ៏មានសិរីល្អនេះជាអ្នកណា
គឺព្រះយេហូវ៉ាដ៏មានព្រះចេស្តា[ត] នឹងឥទ្ធិឫទ្ធិ
ជាព្រះយេហូវ៉ាដ៏មានឥទ្ធិឫទ្ធិក្នុងចំបាំង[ថ]
៩ ឱទ្វារទាំងឡាយអើយ ចូរងើបក្បាលឡើង
ឱទ្វារដ៏នៅអស់កល្បជានិច្ចអើយ ចូរនៅជាចំហចុះ
នោះមហាក្សត្រដ៏មានសិរីល្អ ទ្រង់នឹងយាងចូលមក
១០ តើមហាក្សត្រដ៏មានសិរីល្អនេះជាអ្នកណា
គឺព្រះយេហូវ៉ានៃពួកពលបរិវារ[ទ]
ទ្រង់ជាមហាក្សត្រដ៏មានសិរីល្អនោះឯង ។ បង្អង់

ទំនុកនៃស្តេចដាវីឌ ។

**២៥** ឱព្រះយេហូវ៉ាអើយ
ទូលបង្គំសូមលើកព្រលឹងថ្វាយដល់ទ្រង់[ក]
២ ឱព្រះនៃទូលបង្គំអើយ ទូលបង្គំទុកចិត្ត[ខ]នឹងទ្រង់
សូមកុំឱ្យទូលបង្គំត្រូវខ្មាសឡើយ
សូមកុំឱ្យពួកខ្មាំងសត្រូវមានសេចក្តីអំណរដោយឈ្នះទូល
បង្គំឱ្យសោះ
៣ ប៉ុន្តែអស់អ្នកដែលមានចិត្តសង្ឃឹមដល់ទ្រង់នោះមិនត្រូវ
ខ្មាសឡើយ[គ] គឺពួកអ្នកប្រព្រឹត្តក្បត់[ឃ]
ដោយឥតហេតុដែលត្រូវខ្មាសវិញ
៤ ឱព្រះយេហូវ៉ាអើយ
សូមបង្ហាញអស់ទាំងផ្លូវរបស់ទ្រង់ដល់ទូលបង្គំ
សូមបង្រៀនទូលបង្គំក្នុងផ្លូវច្រករបស់ទ្រង់[ង]
៥ សូមនាំ ហើយបង្រៀនទូលបង្គំ ក្នុងសេចក្តីពិតរបស់ទ្រង់
ផង[ច] ដ្បិតទ្រង់ជាព្រះដ៏ជួយសង្គ្រោះទូលបង្គំ[ឆ]
ទូលបង្គំសង្ឃឹមដល់ទ្រង់[ជ]ដរាបរាល់ថ្ងៃ

**២៤:៧** ឋ ទដ ១១៨:១៩,២០ អស ២៦:២ ៦០:១១,១៨ ៦២:១០ ឌ ទដ ៤៤:៤ ៧៤:១២ ឍ ទដ ២៩:៣ កច ៧:២ ១កថ ២:៨ ណ សក ៩:៩ មថ ២១:៥ **២៤:៨** ត ១កថ ២៩:១១ ទដ ៨៩:១៣ យរ ៥០:៣៤ អភ ៦:១០ ថ នក ១៥:៣,៦ ចទ ៤:៣៤ **២៤:១០** ទ ១សយ ១:១១ **២៥:១** ក ទដ ៨៦:៤ ១៤៣:៨ **២៥:២** ខ ទដ ៣១:៦ ១៤៣:៨ **២៥:៣** គ ទដ ២២:៥ អស ២៩:២២ ឃ អស ២១:១៦ ហាព ១:១៣ សផ ៣:៤ ២ធថ ៣:៤ **២៥:៤** ង យប ៣៤:៣២ **២៥:៥** ច ទដ ៣១:៣ ៤៣:៣ យហ ១៦:១៣ ឆ ទដ ២៤:៥ ជ ខ.៣ ទដ ៣៣:២០ ៣៩:៧ ៤២:៥ ៧១:៥ ១៣០:៧ ១៣១:៣

**២៤:៧** *ចូរងើបក្បាលឡើង* គឺការសម្តែងដែលនាំឱ្យមានការសប្បាយ ក្នុងការទទួលព្រះមហាក្សត្រដែលមានជ័យជម្នះនៃសេរីល្អ (សូមមើល ៣:៣ ២៧:៦ ១១០:៧) ។ *ទ្វារ* ក៏អាចសំដៅទៅលើទ្វារនៃទីក្រុង ឬក៏ទ្វារនៃទីបរិសុទ្ធផងដែរ ។ ឯពាក្យសទិសន័យចំពោះពាក្យថា"ទ្វារ"នេះជាទ្វារជារបង (ដូចមានក្នុង ពច ១៦:៣ ១សយ ២១:១៣) ។ គឺជាទ្វាររបងបង្ហាញពីឥទ្ធិពលនៃភាពគ្រោះថ្នាក់ដូចក្នុង អស ១៤:៣១ ។

**២៤:១០** *ព្រះយេហូវ៉ានៃពួកពលបរិវារ* មើលការពន្យល់ ១សយ ១:៣ ។

**ទដ ២៥–៣៣** ជាក្រុមនៃទំនុកដំកើងទាំង៩ក្រុម ដែលរៀបចំឡើង(ព្រឹត្តការចំពោះអ្នកនិពន្ធបទទំនុក) ដោយផ្តោតទៅលើ "សេចក្តីមេត្តាករុណា" (២៥:១៦ ២៦:១១ ២៧:៧ ២៨:២ ៣០:៨,១០ ៣១:៩) ដោយផ្អែលើ"សេចក្តីពិត"(២៥:២ ២៦:១ ២៧:៣ ២៨:៧ ៣១:៦,១៤ ៣២:១០ ៣៣:២១) ក៏ឃើញពីការអបអរសាទរពី"សេចក្តីសប្បុរស"របស់ព្រះយ៉ាវេ (២៥:៦–៧,១០ ២៦:៣ ៣១:៧,១៦,២១ ៣២:១០ ៣៣:៥,១៨,២២) ។ បទទំនុកដំកើងចាប់ផ្តើមដោយតាមលំដាប់អក្ខរៈក្រមពីការអធិស្ឋាន ចំពោះការដែលព្រះបានជួយសង្គ្រោះ (ទដ ២៥) និងទំនុកដែលលើឡើងក្នុង ២២ មានខ(តាមលេខអក្សរនៃព្រះគម្ពីរភាសាហេព្រើរជាលក្ខណៈអក្ខរៈក្រម)។ ចង្វាក់នៃការសរសើរ តម្កើងដល់ព្រះយ៉ាវេ ដែលដឹកនាំក្នុងភាពជាព្រះមហាក្សត្របានជួយសង្គ្រោះ(ទដ ៣៣)។ ក៏មានបន្ទាត់បង្ហាញពីវិជ្ជាអ្នកនិពន្ធរវាងទំនុកដំកើងទាំងពីរ សូមមើលការពន្យល់ ២៥:៣,៦ ។

**ទដ ២៥** ស្តេចដាវីឌអធិស្ឋានសូមនូវព្រះមេត្តាករុណាដែលជាសេចក្តីសញ្ញាពីព្រះនៅពេលទទួលការឈឺចាប់ដោយអំពើបាប និងនៅពេលដែលមានសត្រូវវាយប្រហារ ឬដោយការបង្ខូចកិត្យានុភាពដល់ព្រះមហាក្សត្រតាមរយៈការចោទប្រកាន់ ការនិយាយបង្ខូច(សូមមើលការពន្យល់ ៥:៩) ។ ក៏អំពាវនាវចំពោះព្រះអម្ចាស់ ដែលជាព្រះមានព្រះទ័យមេត្តាករុណា (សូមមើល ខ.៦–៨,១០,១៦) និងពឹងផ្អែលើព្រះយេហូវ៉ា (សូមមើល ខ.១,៥,១៥,២០–២១) ។ ទ្រង់ក៏អធិស្ឋានសូមឱ្យព្រះប្រោសលោះចេញពីសត្រូវរបស់ទ្រង់ (មើល ខ.២,១៩) គឺជាការដែលនាំទៅតាមព្រះទ័យរបស់ព្រះអម្ចាស់ (សូមមើល ខ.៤–៥,២១ និង ខ.៨–១០,១២) ចំពោះការអត់ទោសនៅអំពើបាបរបស់គាត់ (សូមមើល ខ.៧,១១,១៨) ហើយនិងការរំដោះឱ្យផុតពីការឈឺចាប់ ឬទុក្ខវេទនា (សូមមើល ខ.២,១៦–១៨,២០) ។ មានការអត់ទោសរបស់ព្រះ និងបង្ហាញវគ្គទំនុកដំកើងផ្ទាល់ពីការចលនានៃភាពទុក្ខព្រួយ ហើយបន្ទាប់មកសត្រូវរបស់ទ្រង់ ក៏លែងមានឱកាសប្រើពាក្យមូលបង្កាច់ទ្រង់ទៀត ។ រួចព្រះទ្រង់បាននាំដាវីឌឱ្យដើរក្នុង"ផ្លូវទ្រង់" (ខ.៩) ពោលគឺ "យោងទៅលើសេចក្តីសញ្ញារបស់ទ្រង់" (ខ.១០)ពេលនោះក៏គ្មានផ្លូវណាធ្វើឱ្យទ្រង់ដើរផ្សងព្រេងទៅក្នុង"ភាពបះបោរឡើយ" (ខ.៧) ។ ទំនុកដំកើងនេះបានភ្ជាប់ទំនាក់ទំនងនឹង ទដ ២៤ សំដៅទៅលើការពឹងផ្អែកលើព្រះអម្ចាស់ (សូមមើល ខ.១ ២៤:៤) ។

**២៥:១–៣** ការអធិស្ឋានសូមការរំដោះចេញពីភាពវេទនា ឬក៏ឈឺថ្កាត់ និងពីការមួលបង្កាច់របស់សត្រូវ ។

**២៥:៣** *ចិត្តសង្ឃឹម* មានអំណះអំណាងបីចំពោះពាក្យ"ចិត្តសង្ឃឹម"ក្នុងព្រះអម្ចាស់ឃើញក្នុងខនេះ (ខ.៣,៥,២១) ក៏មានអំណះអំណាងបីទៀតចំពោះពាក្យ"ចិត្តសង្ឃឹម" មើល ៣៣:១៨,២០,២២ ។ *ដោយឥតហេតុ* គឺស្តេចដាវីឌឥតមានហេតុអ្វីសម្រាប់នឹងជិទាស់ជាមួយពួកសត្រូវរបស់ទ្រង់ឡើយ ។

**២៥:៤–៧** ជាការអធិស្ឋានសូមព្រះដឹកនាំ និងសូមការលើលែងទោស ។

**២៥:៤** *ផ្លូវរបស់ទ្រង់ . . . ផ្លូវច្រករបស់ទ្រង់* ជាពាក្យប្រៀបប្រដូចក្នុងការ "ទូលសូមឱ្យមានសេចក្តីសញ្ញារបស់ទ្រង់" (ខ.១០ មើល ចទ ៨:៦ ១០:១២–១៣ ២៦:១៧ ៣០:១៦ យស ២២:៥ និងមើល ខ.៨–៩ ១៨:២១ ៥១:១៣ ៨១:១៣ ៩៥:១០ ១១៩:៣,១៥ ១២៨:១ និងការពន្យល់នៅ ១១៩:២៩) ។

**២៥:៥** *សេចក្តីពិតរបស់ទ្រង់ផង* នៅក្នុងឃ្លានេះគឺជាសទិសន័យនៃពាក្យ "ផ្លូវរបស់ទ្រង់" (សូមមើលការពន្យល់ ខ.៤ និង ១៩:៧) ។

៦ឱព្រះយេហូវ៉ាអើយ សូមទ្រង់នឹកចាំពីសេចក្ដីមេត្តាដ៏ទន់
សន្ដោស និងសេចក្ដីសប្បុរសរបស់ទ្រង់[ឈ]
ដ្បិតសេចក្ដីទាំងនោះមាននៅពីបុរាណរៀងមក
៧សូមកុំនឹកចាំពីបាបដែលទូលបង្គំប្រព្រឹត្តកាលនៅក្មេង[ញ]
ឬអំពើរំលង[ដ]របស់ទូលបង្គំនោះឡើយ ឱព្រះយេហូវ៉ា
អើយ សូមទ្រង់នឹកចាំពីទូលបង្គំដោយសេចក្ដីសប្បុរស[ឋ]នៃ
ទ្រង់វិញ ដោយយល់ដល់ព្រះគុណ[ឱ]របស់ទ្រង់
៨ព្រះយេហូវ៉ាទ្រង់ល្អ ហើយទៀងត្រង់[ឍ] ដូច្នេះ ទ្រង់នឹង
បង្ហាត់[ណ]មនុស្សមានបាបឱ្យតាមផ្លូវទ្រង់វិញ
៩ទ្រង់នឹងនាំ[ត]មនុស្សសុភាពក្នុងសេចក្ដីយុត្តិធម៌ ហើយនិង
បង្រៀនមនុស្សរាបទាប[ថ]ឱ្យស្គាល់ផ្លូវទ្រង់
១០អស់ទាំងផ្លូវនៃព្រះយេហូវ៉ា
សុទ្ធតែប្រកបដោយសេចក្ដីសប្បុរស និងសេចក្ដីពិត[ទ]
ចំពោះអស់អ្នកដែលកាន់តាមសេចក្ដីសញ្ញា
និងសេចក្ដីបន្ទាល់របស់ទ្រង់[ធ]
១១ឱព្រះយេហូវ៉ាអើយ សូមអត់ទោស[ន]ការទុច្ចរិតដ៏មាន
ទំងន់[ប] របស់ទូលបង្គំផង ដោយយល់ដល់ព្រះនាមទ្រង់[ផ]
១២តើមានមនុស្សណាដែលកោតខ្លាចដល់ព្រះយេហូវ៉ា[ព]
ទ្រង់នឹងបង្ហាញឱ្យអ្នកនោះស្គាល់ផ្លូវ[ភ]ដែលត្រូវរើសយក
១៣ព្រលឹងអ្នកនោះនឹងនៅដោយសុខសាន្ត[ម] ហើយ
ពូជពង្សរបស់អ្នកនោះនឹងបានផែនដីជាមរដក[យ]
១៤សេចក្ដីមេត្រីមិត្រ[រ]របស់ព្រះយេហូវ៉ានៅជាមួយនឹង
អ្នកណាដែលកោតខ្លាចដល់ទ្រង់ ទ្រង់នឹងសំដែងឱ្យគេ
ស្គាល់[ល] សេចក្ដីសញ្ញារបស់ទ្រង់

**២៥:៦** ឈ ទដ ៥:៧ ៩៨:៣ អស ៦៣:៧,១៥ យរ ៣១:២០ ហស ១១:៨ **២៥:៧** ញ យប ១៣:២៦ អស ៥៤:៤ យរ ៣:២៥ ៣១:១៩ ៣២:៣០ អគ ១៦:២២,៦០ ២៣:៣ ២ធថ ២:២២ ដ នក ២៣:២១ ទដ ១០៧:១៧ ៧៣:១ ឋ ទដ ៦:៤ ៥១:១ ៦៩:១៦ ១០៩:២៦ ១១៩:១២៤ ឱ ១របា ១៦:៣៤ ទដ ៣៤:៨ **២៥:៨** ឍ ទដ ៩២:១៥ អស ២៦:៧ ណ ទដ ៣២:៨ អស ២៨:២៦ **២៥:៩** ត ទដ ២៣:៣ ថ ខ.៤ ទដ ២៧:១១ **២៥:១០** ទ ទដ ១៨:២៥ ធ ទដ ១០៣:១៨ ១៣២:១២ **២៥:១១** ន នក ៣៤:៩ ប នក ៣២:៣០ ទដ ៧៨:៣៨ ផ នក ៩:១៦ ទដ ៣១:៣ ៧៩:៩ យរ ១៤:៧

១៥ភ្នែកទូលបង្គំមើលទៅឯព្រះយេហូវ៉ាជាដរាប[វ]
ដ្បិតទ្រង់នឹងដោះជើងទូលបង្គំឱ្យរួចពីអន្ទាក់[ស]
១៦សូមទ្រង់បែរមក[ហ]មានសេចក្ដីមេត្តាដល់ទូលបង្គំផង[ឡ]
ដ្បិតទូលបង្គំនៅតែឯង[អ] ហើយមានសេចក្ដីវេទនា
១៧សេចក្ដីទុក្ខព្រួយ[ក]ក្នុងចិត្តទូលបង្គំបានកើនឡើងជាខ្លាំង
ឱសូមនាំទូលបង្គំចេញពីសេចក្ដីទុក្ខលំបាកនៃទូលបង្គំ[ខ]
១៨សូមពិនិត្យមើលសេចក្ដីវេទនា[គ] និងសេចក្ដីនឿយ
ព្រួយ[ឃ] របស់ទូលបង្គំ
ហើយអត់ទោសអស់ទាំងបាបរបស់ទូលបង្គំផង[ង]
១៩សូមពិចារណាមើលពួកខ្មាំង[ច]ទូលបង្គំដែលមានគ្នាច្រើន
ហើយមានសេចក្ដីសំអប់ស្អប់ដល់ទូលបង្គំដោយចិត្ត
សាហាវណាស់[ឆ]
២០ឱសូមរក្សាព្រលឹង[ជ]នៃទូលបង្គំ ហើយជួយឱ្យរួចផង[ឈ]
សូមកុំឱ្យទូលបង្គំត្រូវខ្មាសឡើយ[ញ]ដ្បិតទូលបង្គំពឹង[ដ]ដល់ទ្រង់
២១សូមឱ្យសេចក្ដីសុចរិត[ឋ] និងសេចក្ដីទៀតត្រង់[ឱ]
ការពារទូលបង្គំទុក

**២៥:១២** ព យប ១:៨ ភ ខ.៨ **២៥:១៣** ម ចទ ៣០:១៥ ១ពវ ៣:១៤ យប ៨:៧ យ ជន ១៤:២៤ មថ ៥:៥ **២៥:១៤** រ សភ ៣:៣២ ល លប ១៧:២ យហ ៧:១៧ **២៥:១៥** វ ២របា ២០:១២ ទដ ១២៣:២ ហព ១២:២ ស យប ៣៤:៣០ ទដ ១១៩:១១០ **២៥:១៦** ហ ទដ ៦:៤ ឡ ជន ៦:២៥ អ ទដ ៦៨:៦ **២៥:១៧** ក ១ពវ ១:២៩ ទដ ៣៤:៦,១៧ ៤០:១២ ៥៤:៧ ១១៦:៣ ខ ទដ ៦:៣ ៣៩:២ **២៥:១៨** គ ទដ ១៣:៣ រម ១២:១២ ឃ ២សយ ១៦:១២ ង ទដ ១០៣:៣ **២៥:១៩** ច ទដ ៣:១ ៩:១៣ ឆ ទដ ៣៥:១៩ ៣៨:១៩ ៦៩:៤ **២៥:២០** ជ ទដ ៨៦:២ ឈ ទដ ១៧:១៣ ២២:២១ ៤៣:១ ៧១:២ ១១៦:៤ ១៤០:១ ១៤២:៦ ១៤៤:១ ញ ខ.៣ ដ ទដ ២:១២ **២៥:២១** ឋ លប ២០:៥ សភ ១០:៩ ឱ ១ពវ ៩:៤ ទដ ៨៥:១០ ១១១:៨ អស ៦០:១៧ មឡ ២:៦

**២៥:៦-៧** *សូមទ្រង់នឹកចាំពីសេចក្ដីមេត្តា . . . សូមកុំនឹកចាំពីបាប* សូមចងចាំពីការដែលទ្រង់គង់សណ្ឋិតដ៏យូរអង្វែង ដោយ"សេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់" ក៏កុំឱ្យនឹកឃើញពីអំពើបាបដ៏យូរលង់របស់ទូលបង្គំ ។ *សេចក្ដីសប្បុរស* សូមមើល ខ.១០ និងការពន្យល់ ៦:៤ ។

**២៥:៨-១៥** ការទុកចិត្តក្នុងសេចក្ដីសប្បុរស ជាសេចក្ដីសញ្ញារបស់ព្រះយេហូវ៉ា ។ ក្នុងអត្ថបទនេះគឺផ្ដោតទៅលើការអធិស្ឋានសូមការលើកលែងទោស ដោយស្ដេចដាវីឌបានបញ្ជាក់ថា ខ្លួនទ្រង់មានបាប (មើល ខ.៨) ទ្រង់ក៏បន្ទាបខ្លួន (មើល ខ.៩) ក៏ជាអ្នករក្សាសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ (សូមមើល ខ.១០,១៤) ដូចជាអ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ា (សូមមើល ខ.១២,១៤) ។ ក្នុងនាមជាអ្នកមានបាប គឺចង់បាននៅភាពលើកលែងទោសពីព្រះអម្ចាស់ ។

**២៥:៩** *មនុស្សសុភាព* គឺអស់អ្នកដែលពុំមានប្រភពពឹងផ្អែក គឺអ្នកដែលទទួលស្គាល់ភាពកម្សោយរបស់ខ្លួន ។

**២៥:១០** *ផ្លូវនៃព្រះយេហូវ៉ា* សេចក្ដីមេត្តាករុណារបស់ព្រះយេហូវ៉ាមានចំពោះអ្នកដែលមានសេចក្ដីពិត ចំពោះផ្លូវនៃព្រះ (សូមមើល ១០៣:៧ ១៣៨:៥) សូមមើលការពន្យល់ ខ.៤ ។

**២៥:១១** *ដោយយល់ដល់ព្រះនាមទ្រង់* សូមមើលការពន្យល់ ២៣:៣ ១យហ ២:១២ ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**២៥:១២** *ស្គាល់ផ្លូវដែលត្រូវរើសយក* ឬក៏ចោលផ្លូវមួយ"ដែលត្រូវតែជ្រើសរើសយក" ។

**២៥:១៣** *បានផែនដីជាមរដ* គឺគ្រួសារគេបានទទួលចំណែកក្នុងទឹកដីសន្យា (សូមមើល ៣៧:៩,១៨,២២,៣៤,៣៦,៦៣ អស ៦០:២១) ។

**២៥:១៤** *សេចក្ដីមេត្រីមិត្រ* គឺទ្រង់បានឃុំគ្រងពួកគេរក្សាគេដូចជាមិត្តសម្លាញ់ (សូមើល លប ១៨:១៧-១៩ យប ២៩:៤) ។ *កោតខ្លាច* សូមមើលការពន្យល់ ១៥:៤ ។

**២៥:១៥** *អន្ទាក់* ជាអន្ទាក់ដែលពួកសត្រូវបានដាក់ (ខ.២ សូមមើលការពន្យល់ ៩:១៥) ។

**២៥:១៦-២១** ជាការអធិស្ឋានដើម្បីដោះលែងពីភាពវេទនា (ជាពិសេសការឈឺថ្កាត់) ឱ្យរួចផុតពីពួកខ្មាំងសត្រូវ ។

**២៥:១៧** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**២៥:២១** *សេចក្ដីសុចរិត និងសេចក្ដីទៀងត្រង់ការពារទូលបង្គំទុក* គឺជាព្រះគុណ ឬគុណធម៌ដ៏លើសលប់ពីព្រះ (សូមមើល ២៣:៦ និងការពន្យល់) ។

ដ្បិតទូលបង្គំសង្ឃឹមដល់ទ្រង់[ល]
២២ឱព្រះអង្គអើយ សូមលោះសាសន៍អ៊ីស្រាអែល[ណ]
ឱ្យរួចពីគ្រប់សេចក្ដីវេទនារបស់គេផង ។

ទំនុកនៃស្ដេចដាវីឌ ។

**២៦** ឱព្រះយេហូវ៉ាអើយ សូមទ្រង់វិនិច្ឆ័យឱ្យទូលបង្គំ[ក]
ដ្បិតទូលបង្គំបានដើរតាមចិត្តគ្រប់លក្ខណ៍របស់ទូលបង្គំ[ខ]
ក៏បានទុកចិត្ត[គ]នឹងព្រះយេហូវ៉ាឥតល្អៀងឡើយ[ឃ]
២ឱព្រះយេហូវ៉ាអើយ សូមពិនិត្យទូលបង្គំមើល
ព្រមទាំងល្បងលទូលបង្គំ[ង]
ហើយសាកចិត្តថ្លើមរបស់ទូលបង្គំផង[ច]
៣ដ្បិតសេចក្ដីសប្បុរស[ឆ]នៃទ្រង់នៅចំពោះភ្នែកទូលបង្គំ
ហើយទូលបង្គំបានដើរតាម[ជ]សេចក្ដីពិតរបស់ទ្រង់[ឈ]
៤ទូលបង្គំមិនបានអង្គុយ[ញ]រួមជាមួយនឹងមនុស្សភូតភរឡើយ
ក៏មិនបានសមាគមជាមួយនឹងមនុស្សមានពុតដែរ[ដ]
៥ទូលបង្គំស្អប់[ឋ]ចំពោះជំនុំនៃពួកមនុស្សដែលប្រព្រឹត្តអាក្រក់
ក៏មិនព្រមអង្គុយជាមួយនឹងពួកមានចិត្តអាក្រក់ឡើយ
៦ទូលបង្គំនឹងលាងដៃ ជាសំគាល់ថា ឥតមានទោសទេ[ឌ]
យ៉ាងនោះ ឱព្រះយេហូវ៉ាអើយ
ទូលបង្គំនឹងដើរក្រឡឹងអាសនាទ្រង់
៧ដើម្បីនឹងបានបន្លឺសំឡេងអរព្រះគុណ[ឍ]
ហើយថ្លែងប្រាប់ពីគ្រប់ទាំងការអស្ចារ្យរបស់ទ្រង់[ណ]
៨ឱព្រះយេហូវ៉ាអើយ ទូលបង្គំស្រឡាញ់[ត]ទីឈប់សំរាកនៅ
ដំណាក់ទ្រង់ ជាទីសណ្ឋិតនៅនៃសិរីល្អទ្រង់[ថ]

**២៥:២១** ឍ ខ.៣ **២៥:២២** ណ ទដ ១៣០:៨ លក ២៣:២១ **២៦:១** ក ១សយ ២៤:១៥ ខ ទដ ១៥:២ សភ ២០:៧ គ ទដ ២២:៤ ៤០:៤ អស ១២:២ ២៥:៩ យរ ១៧:៧ ដយ ៣:២៨ ឃ ២ពវ ២០:៣ ហព ១០:២៣ **២៦:២** ង ទដ ៦៦:១០ ច ចទ ៦:៦ ទដ ៧:៩ យរ ១១:២០ ២០:១២ អគ ១១:៥ **២៦:៣** ឆ ទដ ៦:៤ ជ ១ពវ ២:៤ ឈ ទដ ៤០:១១ ៤៣:៣ ៨៦:១១ ១១៩:៣០ **២៦:៤** ញ ទដ ១:១ ដ ទដ ២៨:៣ មថ ៦:២ **២៦:៥** ឋ ទដ ១៣៩:២១ **២៦:៦** ឌ ទដ ៧៣:១៣ មថ ២៧:២៤ **២៦:៧** ឍ អស ៤២:១២ ៦០:៦ណ យស ៣:៥ ទដ ៩:១ **២៦:៨** ត ទដ ១២២:៦ អស ៦៦:១០ ថ នក ២៩:៤៣ ២របា ៧:១ ទដ ៩៦:៦

ការលើកលែងទោសក៏មិនទាន់គ្រប់គ្រាន់ដែរ ដូច្នេះស្ដេចដាវីឌក៏ទូលសូមឱ្យព្រះយេហូវ៉ាជួយឱ្យជីវិតទ្រង់ឱ្យរស់ដោយព្រះគុណរបស់ព្រះ (ខ.៨ មើល ៥១:១០–១២) ។ *សេចក្ដីសុចរិត* សូមមើលការពន្យល់ ១៥:២ ។

**២៥:២២** ជាការអធិស្ឋានរួមចុងក្រោយ ក្នុងនាមជារាស្ត្ររបស់ព្រះអម្ចាស់ (សូមមើល ៣:៨ និងការពន្យល់) ។

**ទដ ២៦** ជាការអធិស្ឋានសូមឱ្យព្រះប្រទាននូវសេចក្ដីមេត្តាករុណាដល់អ្នកបម្រើទ្រង់ឱ្យផុតពីសេចក្ដីស្លាប់ ការអធិស្ឋាននេះគឺសម្រាប់ការការពារ (ខ.១) ពីព្រោះអ្នកនិពន្ធទំនុកដំកើង បានបណ្ដាលឱ្យមាន "ជីវិតមិនអាចបន្ទោសបាន"(ខ.១១) ក៏បានបដិសេធមិនអង្គុយជាមួយនឹងមនុស្សអាក្រក (ខ.៥) ក៏មានការបង្ហាញពីភាពផ្ទុយគ្នា (ក្នុងការរៀបចំដែលមានចំណុចរួមតែមួយនៃ ទដ ២៥–៣៣ សូមមើលសេចក្ដីផ្ដើម ទដ ២៥–៣៣) ក្នុង ទដ ៣២ បានប្រារព្ធពិធីទទួលព្រះពរចំពោះអស់អ្នក ដែលបានលន់តួបាប និងត្រូវបានលើកលែងទោសឱ្យ ។ ការអធិស្ឋានរបស់ស្ដេចដើម្បីជាការដោះស្រាយចំពោះការគំរាមកំហែង ដោយពួកបោកបញ្ឆោត (ខ.៤) និង"ពួកស្រេកឈាម" (ខ.៩) ដូចមានក្នុង (ទដ ២៣,២៥,២៧,២៨) ។ គម្ពីរទំនុកដំកើងនេះគឺមានទំនាក់ទំនងនឹង ទដ ២៧–២៨ (សូមមើល ទដ ២៣–២៤) ដោយមានផ្ទៃរឿងនិយាយពីដំណាក់របស់ព្រះយេហូវ៉ា : ក្នុងនេះក៏មានបង្ហាញពី"សេចក្ដីស្រឡាញ់"របស់ស្ដេចដាវីឌ(ខ.៨) ចំពោះព្រះវិហារ (ឬរោងឧបោសថ) បង្ហាញពីសភាវៈនៃការពិត នៃភាពមានព្រះមេត្តាករុណាក្នុង ទដ ២៧ ។ ឯព្រះវិហាររបស់ព្រះយេហូវ៉ា គឺជាទីបរិសុទ្ធរបស់ស្ដេចដាវីឌដែលជាទីឆ្ងាយពីសត្រូវរបស់ទ្រង់ ។ ក្នុង ទដ ២៨ ស្ដេចដាវីឌបង្ហាញពីភាពទុក្ខព្រួយ ឬទួញសោកសុំជំនួញពីដំណាក់បល្ល័ង្កនៃព្រះយេហូវ៉ា ("គឺជាទីបរិសុទ្ធបំផុតរបស់ទ្រង់" ២៨:២) ក្នុងព្រះវិហារ ។ មានពាក្យជាកិរិយាសព្ទសំខាន់ៗដែលបង្ហាញពីផ្ទៃរឿងទាំងបីមានដូចជា("ដើរ" ខ.៣ "អង្គុយ" ក្នុង ខ.៤–៥ "ឈរ"ក្នុង ខ.១២) ។

**២៦:១** *គ្រប់លក្ខណ៍* គឺជាការប្រកាសពីភាពសុចរិត ភាពមានក្រមសីលធម៌ (សូមមើល ២–៥ ១៥:២) ។ *បានទុកចិត្តនឹង* គឺជាការស្ដាបបង្គាប់ និងការទុកចិត្តគឺជាផ្នែកពីនៃភាពដូចជាព្រះ ដែលប្រៀបប្រដូចទៅនឹងរឿងលោកអ័ប្រាហាំ (មើល លប ១២:៤ និងការពន្យល់ ២២:១២ ទដ ២៤:៨–១៤) ។

**២៦:២** *ចិត្តថ្លើម* សូមមើលការពន្យល់ ៧:៩ ។

**២៦:៣** *សេចក្ដីសប្បុរសនៃទ្រង់ . . . សេចក្ដីពិតរបស់ទ្រង់* គឺជាសេចក្ដីស្រឡាញ់ និងសេចក្ដីពិត (សូមមើល ៤០:១០) ។ ស្ដេចដាវីឌទ្រង់បានផ្ដង់ព្រះនេត្រទ្រង់ជាប់ជានិច្ចទៅលើសេចក្ដីស្រឡាញ់របស់ព្រះយេហូវ៉ា (សូមមើលការពន្យល់ ៦:៤) និងសេចក្ដីពិត (សូមមើល ២៥:១០) គឺសម្រាប់អស់អ្នកណាដែលរក្សានូវសេចក្ដីទាមទាពីសេចក្ដីសញ្ញារបស់ទ្រង់ (២៥:១០) ។ *បានដើរតាម* គឺដើម្បីទទួលនូវផលប្រយោជន៍ពីសេចក្ដីសញ្ញា ។

**២៦:៤** *មនុស្សមានពុត* នៅក្នុងបទគម្ពីរនេះចង់បង្ហាញពីពួកមនុស្សដែលមានភាពលួចបន្លំ ឬក៏មនុស្សមានលក្ខណៈដូចពួកអ្នកដែលបានពណ៌នាក្នុង សភ ៦:១២–១៤ ។

**២៦:៦** *ទូលបង្គំនឹងលាងដៃជាទីសំគាល់ថាឥតមានទោសទេ* គឺសំដៅទៅលើការបង្ហាញចេញនូវភាពគ្មានកំហុសយ៉ាងជាក់លាក់ ។ "ការសម្អាតដៃ និងទឹកចិត្តបរិសុទ្ធ" ក៏បានតម្រូវការនេះចំពោះអ្នកដែលស្វែងរកព្រះដែរ (សូមមើល ២៤:៤ និងការពន្យល់) ។ *ដើរក្រឡឹងអាសនាទ្រង់* គឺជាការអបអរសាទរពីព្រះបានសង្គ្រោះអ្នកនៅជុំវិញអាសនាទ្រង់ និងបានមកជុំគ្នាធ្វើការថ្វាយបង្គំ និងសរសើរទ្រង់ (សូមមើល ៤៣:៤) ។

**២៦:៧** ឃ្លាពីនៃការសរសើរពីព្រះគុណទ្រង់ និងការអស្ចារ្យនៃទ្រង់ សូមមើលការពន្យល់ ៩:១ ។

**២៦:៨** *ជាទីសណ្ឋិតនៅនៃសិរីល្អទ្រង់* ប្រៀបធៀបការពន្យល់ អគ ១:១–២៨ គឺជាវត្តមានសិរីល្អរបស់ទ្រង់ ដែលបានបង្ហាញជាសញ្ញាដោយអង្គទ្រង់ផ្ទាល់ (មើល នក ២៤:១៦ ៣៣:២២) និងឥឡូវនេះ ឬក្រោយមកក៏ក្លាយជាព្រះវិហារនៃទ្រង់ (មើល ១ពវ ៨:១១) ដោយទឹកដីអ៊ីស្រាអែលគឺជាទីបរិសុទ្ធរបស់ព្រះយេហូវ៉ា យហ ១:១៤ ការប្រកាសនេះមានលក្ខណៈដូចការបង្ហាញក្នុងពាក្យថា ប្រែក្លាយជាសាច់ឈាម និងជាអង្គដែលមានទីដំណាក់នៃទ្រង់ក្នុងចំណោមយើងទាំងអស់គ្នា ។

៩ សូមកុំដកព្រលឹងទូលបង្គំចេញ
ជាមួយនឹងពួកមានបាបឬជីវិតទូលបង្គំ
ជាមួយនឹងមនុស្សដែលកំចាយឈាម[ទ]
១០ ដែលសុទ្ធតែមានការអាក្រក់ជាប់នៅដៃគេ[ធ]
ហើយដៃស្តាំរបស់គេពេញដោយសំណូកផង នោះឡើយ[ន]
១១ ចំណែកទូលបង្គំៗនឹងដើរ ដោយចិត្តគ្រប់លក្ខណ៍របស់
ទូលបង្គំតទៅ
សូមលោះ ហើយមេត្តាប្រោសដល់ទូលបង្គំ[ប]ផង
១២ ជើងទូលបង្គំឈរនៅក្នុងផ្លូវទៀងត្រង់ហើយ[ផ]
ទូលបង្គំនឹងលើកសរសើរដល់ព្រះយេហូវ៉ានៅក្នុងពួក
ជំនុំ[ព]ទាំងប៉ុន្មាន ។

ទំនុកនៃស្តេចដាវីឌ ។

**២៧** ព្រះយេហូវ៉ាទ្រង់ជាពន្លឺ[ក]
ហើយជាសេចក្តីសង្គ្រោះ[ខ]របស់ខ្ញុំ
តើខ្ញុំនឹងត្រូវខ្លាចចំពោះអ្នកណា
ព្រះយេហូវ៉ាទ្រង់ជាទីពឹងពំនាក់[គ]នៃជីវិតខ្ញុំ
តើត្រូវឱ្យខ្ញុំភ័យចំពោះអ្នកណា[ឃ]
២ កាលមនុស្សអាក្រក់ គឺជាពួកទាស់ទទឹង
ហើយជាខ្មាំងសត្រូវនៃខ្ញុំបានសង្ឃុកមកលើខ្ញុំដើម្បីនឹង
ស៊ីសាច់ខ្ញុំ នោះគេបានជំពប់ដួលទាំងអស់គ្នា[ង]
៣ ទោះបើមានពួកពលមកបោះទ័ពច្បាំងនឹងខ្ញុំគង់តែចិត្តខ្ញុំ
មិនភ័យឡើយ[ច] ទោះបើកើតមានចំបាំងទាស់នឹងខ្ញុំគង់តែ
ខ្ញុំនឹងមានចិត្តសង្ឃឹមបានដែរ[ឆ]
៤ ខ្ញុំបានសូមសេចក្តីតែ១[ជ]ពីព្រះយេហូវ៉ា ហើយនិងស្វែង
រកសេចក្តីនោះឯង
គឺឱ្យខ្ញុំបាននៅក្នុងដំណាក់នៃព្រះយេហូវ៉ារាល់តែថ្ងៃ
អស់១ជីវិតខ្ញុំ[ឈ]
ដើម្បីនឹងរំពឹងមើលសេចក្តីលំអនៃព្រះយេហូវ៉ា
ហើយនិងពិនិត្យពិចារណានៅក្នុងព្រះវិហាររបស់ទ្រង់

**២៦:៩** ទ ទដ ៥:៦ ២៨:៣ ៥៥:២៣ ១៣៩:១៩ សភ ២៩:១០ **២៦:១០** ធ ទដ ២១:១១ ន យប ៣៦:១៨ អស ១:២៣ អគ ២២:១២ **២៦:១១** ប ទដ ៣១:៥ ៦៩:១៨ ១១៩:១៣៤ ទត ២:១៤ **២៦:១២** ផ ទដ ២៧:១១ ៤០:២ ១៤៣:១០ អស ២៦:៧ ៤០:៣–៤ ៤៥:១៣ សក ៤:៧ លក ៦:១៧ ព ទដ ២២:២៥ **២៧:១** ក ២សយ ២២:២៩ ខ នក ១៥:២ ទដ ៣:៨ **២៧:១** គ ទដ ៩:៩ ឃ យប ១៣:១៥ ទដ ៥៦:៤,១១ ១១៨:៦ **២៧:២** ង ទដ ៩:៣ ២០:៨ ៣៧:២៤ ដយ ១១:១៩ រម ១១:១១ **២៧:៣** ច លប ៤:៧ ទដ ៣:៦ ឆ យប ៤:៦ **២៧:៤** ជ លក ១០:៤២ ឈ ទដ ២៣:៦ ៦១:៤

**២៦:៩–១១** ក៏បង្ហាញចេញថា ព្រះទ្រង់មិននាំស្តេចដាវីឌឱ្យចប់ជីវិតឡើង ។
**២៦:៩** *ព្រលឹង* សូមមើលការពន្យល់ ៦:៣ ។
**២៦:១១** *ដើរដោយចិត្តគ្រប់លក្ខណ៍* គឺការបែរទៅរកការល្អ សុចរិតដូចជាស្តេចដាវីឌ (សូមមើល ខ.១) ។ *លោះ* សូមមើលការពន្យល់ ២៥:២២ ។
**២៦:១២** ការបញ្ចប់ដោយការលន់តួបាប (សូមមើលការពន្យល់ ៣:៨) និងការស្បថសច្ចាពីការសរសើរតម្កើង (សូមមើលការពន្យល់ ៧:១៧) ។
**ទដ ២៧** ការអធិស្ឋានយ៉ាងទុកចិត្តដោយជំនឿ ប្រកបដោយជោគជ័យរបស់ស្តេចដាវីឌចំពោះព្រះអម្ចាស់ក្នុងការជួយរំដោះទ្រង់ជាស្តេច ឱ្យចេញពីអ្នកដែលរួមគ្នាក្បត់ក្នុងការព្យាយាមទម្លាក់ទ្រង់ចេញ ។ តែក៏មានសេចក្តីសន្មត់ទុកជាមុននៅសេចក្តីសញ្ញារបស់ព្រះយេហូវ៉ាជាមួយនឹងស្តេចដាវីឌ (សូមមើល ២សយ ៧) ។ ការសម្តែងពីខ្លួនឯងដោយសេចក្តីជំនឿ (នៅក្នុងវគ្គគាថាពីរ ខ.១–៣,៤–៦) ដែលបង្ហាញយ៉ាងច្បាស់ពីរស្តេចអង្គនេះ ដែលទុកចិត្តចំពោះព្រះ ក៏មានសេចក្តីផ្តើមអំពីការអធិស្ឋានក្នុង ខ.៧–១២ ។ ចំពោះសេចក្តីបញ្ចប់ (ខ.១៣–១៤) ស្តេចដាវីឌក៏បង្ហាញពីសេចក្តីជំនឿដោយទន្ទឹងរងចាំអស់រយៈពេលយូរអង្វែង (មើល ទដ ៤២–៤៣ ហាយ ១១:១) ។ សូមមើលសេចក្តីផ្តើមបន្តទៀតនៅ ទដ ២៦ ការរៀបចំពីការតែងនិពន្ធគឺមានការផ្តោតទៅលើចំណុចសំខាន់តែមួយមានក្នុង ទដ ២៥–៣៣ (សូមមើលសេចក្តីផ្តើមនៅ ទដ ២៥–៣៣) ទដ ២៧ គឺឈរក្នុងភាពខុសគ្នាខ្លះនិង ទដ ៣១ គឺមានលក្ខណៈអធិស្ឋានដោយយកចិត្តទុកដាក់ដែលមានលក្ខណៈស្រដៀងៗគ្នាចំពោះការសង្គ្រោះរបស់ព្រះ"យ៉ាវេ" (Yahweh) ចំពោះការជួយផ្តល់ទីជម្រករបស់អ្នកនិពន្ធបទទំនុកក្នុងខណៈ ពួកគេស្ថិតក្នុងការវាយប្រហារពីពួកសត្រូវ ។ ក្នុងលក្ខណៈទាំងពីរនៃពួកសត្រូវដែលព្យាយាមបំផ្លាញអ្នកនិពន្ធគម្ពីរទំនុកដំកើងតាមរយៈពង្រីកការភូតភរ មូលបង្កាច់ ។ ទាំងការនិយាយក្នុងគម្ពីរទំនុកដំកើងពីការរក្សា "សុវត្ថិភាព" ក្នុងការគង់សណ្ឋិតនៃព្រះយ៉ាវេ (២៧:៥ ៣១:២០) និងការលាក់កំបាំងក្នុងទីជម្រករបស់ត្រសាលនៃព្រះយ៉ាវេ (២៧:៥) ឬក៏"វត្តមាន"(៣១:២០) ។ ក៏សរុបទាំងផ្នែកដែលមាន"ការលើកតម្កើង" ដើម្បីមានភាពខ្លាំង និងការអស់សង្ឃឹមក្នុងព្រះអម្ចាស់ ។ ជាលក្ខណៈបន្ថែមគេក៏បានចែកចាយនៅពាក្យពេជ្រជាសេចក្តីបញ្ជាក់ថែមទៀត ឧទាហរណ៍ ការសំអាងទៅលើ"ភាពសប្បុរស"របស់ព្រះយ៉ាវេ (២៧:១៣ ៣១:១៩) ។
**២៧:១–៣** វគ្គនេះបង្ហាញសន្តិសុខ សុវត្ថិភាពរបស់ព្រះមហាក្សត្រដែលបានទុកចិត្តលើព្រះយេហូវ៉ាក្នុងគ្រាដែលប្រឈមមុខនឹងពួកមាសត្រូវ ដែលពួកវាកំពុងធ្វើសកម្មភាពសព្វបែបយ៉ាង (សូមមើល ទដ ២) ។
**២៧:១** *ពន្លឺ* ជារឿយៗជាតំណាងឱ្យភាពល្អប្រសើរទាំងឡាយ (សូមមើល ៩៧:១១ យប ១៨:៥–៦ ២២:២៨ ២៩:៣ សភ ១៣:៩ បទ ៣:២) ឬក៏ជីវិត និងសេចក្តីសង្គ្រោះ(សូមមើល ១៨:២៨ អស ៩:២ ៤៩:៦ ៥៨:៨ ៥៩:៩ យរ ១៣:១៦ អម ៥:១៨–២០) ។ ដោយមានបន្ទូល"ព្រះយេហូវ៉ាជាពន្លឺរបស់ខ្ញុំ" ដោយលន់តួបាបដែលជាប្រភពនៃប្រយោជន៍សម្រាប់ជីវិត (សូមមើល អស ១០:១៧ ៦០:១–២,១៩–២០ មីក ៧:៨–៩ ប្រៀបធៀបការពន្យល់ កល ១:១២) ។ *សេចក្តីសង្គ្រោះរបស់ទូលបង្គំ* ដោយទ្រង់ជាព្រះអង្គសង្គ្រោះ (សូមមើល ខ.៩) ។
**២៧:២** *ស៊ីសាច់ខ្ញុំ* សូមមើល ៧:២ និងការពន្យល់ ។
**២៧:៣** *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។
**២៧:៤–៦** នៅក្នុងខនេះចង់និយាយថា ព្រះវិហាររបស់ព្រះ (ឬព្រះពន្លា) គឺជាទីពឹងពំនាក់របស់ស្តេច ពីព្រោះព្រះយេហូវ៉ាផ្ទាល់ទ្រង់គឺជាទីពំនាក់ (សូមមើលក្នុង ខ.១ និងការពន្យល់ ៩:១១ ១៨:២) ។
**២៧:៤** *នៅក្នុងដំណាក់* សូមមើលការពន្យល់ក្នុង ១៥:១ ។ *សេចក្តីលំអរបស់ព្រះយេហូវ៉ា* នៅក្នុងឃ្លានេះគឺចង់និយាយសំដៅលើសេចក្តីមេត្តាករុណាដ៏នៅអស់កល្បរបស់ព្រះយេហូវ៉ា (សូមមើល ៩០:១៧ ត្រង់ឃ្លា "ព្រះគុណនៃព្រះយេហូវ៉ា") ។

៥ ដ្បិតនៅថ្ងៃអាក្រក់[ញ] ទ្រង់នឹងថែរក្សា[ដ]ខ្ញុំ
ដោយកំបាំងនៅក្នុងព្រះពន្លាទ្រង់
ក៏នឹងបំពួន[ឋ]ខ្ញុំនៅទីសំងាត់ក្នុងត្រសាលទ្រង់
ហើយនិងលើកខ្ញុំឡើងដាក់លើថ្មដា[ឌ]
៦ ឥឡូវនេះ ខ្ញុំបានងើបក្បាលឡើងហើយ[ឍ]
គឺខ្ពស់ជាងពួកខ្មាំងសត្រូវដែលព័ទ្ធជុំវិញខ្ញុំទៅទៀត[ណ]
ហើយខ្ញុំនឹងថ្វាយគ្រឿងបូជា[ត]នៃសេចក្ដីអំណរ[ថ]នៅ
ក្នុងរោងឧបោសថទ្រង់ ខ្ញុំនឹងច្រៀង[ទ]
អើ ខ្ញុំនឹងច្រៀងសរសើរ[ធ]ដល់ព្រះយេហូវ៉ា ។
៧ ឱព្រះយេហូវ៉ាអើយ សូមស្ដាប់កាលទូលបង្គំអំពាវនាវ[ន]
សូមអាណិតមេត្តាឆ្លើយតបមកទូលបង្គំផង[ប]
៨ កាលទ្រង់បានមានបន្ទូលថា ចូរស្វែងរកមុខអញនោះ[ផ]
ឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំបានទូលតបថា
ទូលបង្គំនឹងស្វែងរកព្រះភក្ត្រទ្រង់ពិត
៩ សូមកុំលាក់ព្រះភក្ត្រ[ព]នឹងទូលបង្គំ
ហើយកុំផាត់អ្នកបំរើទ្រង់ចេញ ដោយខ្ញាល់ឡើយ[ភ]
ទ្រង់បានតែងធ្វើជាជំនួយរបស់ទូលបង្គំ[ម]
ឱព្រះដ៏ជួយសង្គ្រោះទូលបង្គំអើយ[យ]
សូមកុំប្រាសចេញឬបោះបង់ចោល[រ]ទូលបង្គំឡើយ
១០ បើកាលណាឪពុកម្ដាយលះចោលទូលបង្គំ
នោះព្រះយេហូវ៉ាទ្រង់នឹងទទួលទូលបង្គំទុកវិញ
១១ ឱព្រះយេហូវ៉ាអើយ សូមបង្រៀនផ្លូវទ្រង់ដល់ទូលបង្គំ[ល]
ហើយដោយព្រោះមានពួកខ្មាំងសត្រូវ[វ]
នោះសូមនាំទូលបង្គំទៅតាមផ្លូវរាបស្មើ[ស]
១២ សូមកុំប្រគល់ទូលបង្គំទៅតាមបំណងចិត្តនៃពួកអ្នក
ដែលតតាំងនឹងទូលបង្គំឡើយ
ដ្បិតមានស្មរបន្ទាល់[ហ]ក្លែងបានលើកគ្នាទាស់នឹងទូលបង្គំ
ព្រមទាំងមានមនុស្សដែលដកដង្ហើមចេញជាសេចក្ដី
ច្រឡោតទទេផង
១៣ បើសិនជាទូលបង្គំមិនបានជឿថា
នឹងឃើញសេចក្ដីសប្បុរសនៃព្រះយេហូវ៉ា[ឡ]
នៅស្ថានរបស់មនុស្សរស់នេះ[អ] នោះតើយ៉ាងណាទៅ
១៤ ចូររង់ចាំ[ក]ព្រះយេហូវ៉ាចុះ ចូរមានកំឡាំង[ខ]
ហើយឱ្យចិត្តក្លាហានឡើង
អើ គួររង់ចាំព្រះយេហូវ៉ាទៅ ។

ទំនុកនៃស្ដេចដាវីឌ ។

**២៨** ឱព្រះយេហូវ៉ាអើយ ទូលបង្គំនឹងអំពាវនាវដល់ទ្រង់
ឱថ្មដាទូលបង្គំអើយ សូមកុំព្រងើយ[ក]ចំពោះទូលបង្គំឡើយ

**២៧:៥** ញ យប ៣៨:២៣ ដ ទដ ១២:៧ ឋ ទដ ១៧:៨ ឌ ទដ ៤០:២ **២៧:៦** ឍ ២សយ ២២:៤៩ ទដ ៣:៣ ១៨:៤៨ ណ ទដ ២២:១២ ត ទដ ៥០:១៤ ៥៤:៦ ១០៧:២២ ១១៦:១៧ ថ អរ ៣:១៣ យប ២២:២៦ ទ នក ១៥:១ ធ ទដ ៣៣:២ ៩២:១ ១៤៧:៧ អភ ៥:១៩ **២៧:៧** ន ទដ ៥:៣ ១៨:៦ ៥៥:១៧ ១១៩:១៤៩ ១៣០:២ អស ២៨:២៣ ប ទដ ៤:១ **២៧:៨** ផ ១របា ១៦:១១ **២៧:៩** ព ចទ ៣១:១៧ ទដ ២២:២៤ ភ ទដ ២:៥ ម លប ៤៩:២៥ ចទ ៣៣:២៩ យ ទដ ១៨:៤៦ រ ចទ ៤:៣១ ទដ ៣៧:២៨ ១១៩:៨ អស ៤១:១៧ ៦២:១២ យរ ១៤:៩ **២៧:១១** ល នក ៣៣:១៣ វ ទដ ៧២:៤ ៧៨:៤២ ១០៦:១០ យរ ២១:១២ ស អរ ៨:២១ ទដ ៥:៨ **២៧:១២** ហ ចទ ១៩:១៦ មថ ២៦:៦០ កច ៦:១៣ ១កថ ១៥:១៥ **២៧:១៣** ឡ នក ៣៣:១៩ ២របា ៦:៤១ ទដ ២៣:៦ ៣១:១៩ ១៤៥:៧ អ យប ២៨:១៣ **២៧:១៤** ក ទដ ៣៣:២០ ១៣០:៥,៦ អស ៨:១៧ ៣០:១៨ ហព ២:៣ សផ ៣:៨ កច ១:៤ ខ ចទ ១:២១ ៣ច ៥:២១ អភ ៦:១០ **២៨:១** ក ចទ ១:៤៥

**២៧:៥** *បំពួនខ្ញុំនៅទីសំងាត់ក្នុងត្រសាលទ្រង់* សូមមើលក្នុង ៣១:២០ ៣២:៧ ៦១:៤ ៩១:១ ។

**២៧:៦** *ខ្ញុំនឹងថ្វាយគ្រឿងបូជា* សូមមើលការពន្យល់ក្នុង ៧:១៧ ។ *ខ្ញុំនឹងច្រៀង* សូមមើលការពន្យល់ក្នុង ៩:១ ។

**២៧:៧–១២** នៅក្នុងខទាំងនេះ ស្ដេចដាវីឌទ្រង់បានអធិស្ឋានសូមឱ្យព្រះយេហូវ៉ារំដោះទ្រង់ឱ្យរួចពីពួកខ្មាំងសត្រូវ ។ គេមិនបានដឹងពីសញ្ញាណពិតរបស់ពួកសំណល់ទាំងនោះឡើយ មិនដឹងថាពួកគេមកពីខាងក្រៅ ឬជាមនុស្សនៅក្នុងនគរ ឬមួយពួកគេគឺជាក្រុមមនុស្សដែលមកពីខាងក្រៅផង ។ អាវុធយុទ្ធភ័ណ្ឌចៅហ្វាយគេ គឺជាការនិយាយបង្កាច់បង្ខូចកិត្តិនាមរបស់ស្ដេច (សូមមើលការពន្យល់ក្នុង ៥:៩) ។

**២៧:៧** *កាលណាទូលបង្គំអំពាវនាវ . . . ឆ្លើយតប* មើលការពន្យល់ក្នុង ១១៨:៥ ។

**២៧:៩** *លាក់ព្រះភក្ត្រ* សូមមើលការពន្យល់ក្នុង ១៣:១ ។ *ខ្ញាល់* សូមមើលការពន្យល់ក្នុង ២:៥ ។ *ទ្រង់បានតែងធ្វើជាជំនួយរបស់ទូលបង្គំ* ឃ្លានេះគេអាចនិយាយម្យ៉ាងទៀតថា "ជាអ្នកជួយទូលបង្គំ " ។

**២៧:១០** *ព្រះយេហូវ៉ាទ្រង់នឹងទទួលទូលបង្គំ* ឬក៏"សូមឱ្យព្រះយេហូវ៉ាទទួលទូលបង្គំផង" ។

**២៧:១១** *សូមបង្រៀនផ្លូវទ្រង់ដល់ទូលបង្គំ* ព្រះអង្គទ្រង់នឹងទទួលហើយឆ្លើយតបចំពោះសេចក្ដីអធិស្ឋានរបស់អ្នកណាដែលស្គាល់ និងធ្វើតាមបំណងព្រះហឫទ័យព្រះអង្គប៉ុណ្ណោះ (មើលក្នុង ទដ ២៤–២៦ ២សយ ៧:១៤) ។ *សូមបង្រៀនផ្លូវទ្រង់ដល់ទូលបង្គំ* សូមមើលក្នុង ៥:៨ និងការពន្យល់ ។

**២៧:១៣–១៤** នៅក្នុងខនេះអ្នកនិពន្ធបានបញ្ចប់សេចក្ដីអធិស្ឋាន ដោយមានទំនុកចិត្តចំពោះព្រះយេហូវ៉ាបំផុត (សូមមើលការពន្យល់ក្នុង ៣:៨) ។

**២៧:១៣** *សេចក្ដីសប្បុរសនៃព្រះយេហូវ៉ា* "សេចក្ដីសប្បុរស"គឺជាអ្វីដែលព្រះយេហូវ៉ាទ្រង់បានសន្យាក្នុងពេលតាំងសញ្ញាជាមួយដាវីឌ (សូមមើល ២សយ ៧:២៨ និង ៣១:១៩ និងការពន្យល់) ។ *ស្ថានរបស់មនុស្សរស់* គឺជាពេលវេលាដែលយើងរស់នៅពេលនេះ ។

**២៧:១៤** *គួររងចាំព្រះយេហូវ៉ា* ដោយសារសេចក្ដីជំនឿ ស្អាងចិត្តយើងឱ្យរងចាំព្រះយេហូវ៉ាដោយជំនឿ (សូមមើល ៤២:៥,១១ ៤៣:៥ ៦២:៥) ។

**ទំនុកដំកើងជំពូក២៨** នៅក្នុងជំពូកនេះ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់អធិស្ឋានទូលសូម ឱ្យព្រះយេហូវ៉ារំដោះគាត់ចេញពីទុក្ខភ័យទាំងឡាយ ដែលអាចបណ្ដាលឱ្យគាត់បាត់បង់ជីវិត ដែលបង្ករឡើងដោយពួកមនុស្សកំណាចនិងខ្មាំងសត្រូវអ្នកសំណប់ព្រះ ។ ដូចជានៅក្នុងទដជំពូក២៥ដែរ អ្នកនិពន្ធគាត់បានបញ្ចប់សេចក្ដីអធិស្ឋាន ដោយការអង្វរជួសចំពោះរាស្ត្ររបស់ព្រះទាំងអស់ (សូមមើល ៣:៨ និងការពន្យល់) ។ មានអំណះអំណាង១នៅចុងបញ្ចប់នៃខដែលនិយាយថា ព្រះយេហូវ៉ាជាអ្នកគង្វាលចំពោះរាស្ត្រទ្រង់

បើទ្រង់នៅតែស្ងៀមនឹងទូលបង្គំ[ខ]
នោះក្រែងទូលបង្គំនឹងបានដូចជាអស់អ្នកដែលចុះទៅក្នុងរណ្ដៅ[គ]
២សូមស្ដាប់សំឡេងដែលទូលបង្គំទូលអង្វរ[ឃ]
ក្នុងកាលដែលទូលបង្គំអំពាវនាវដល់ទ្រង់
គឺក្នុងកាលដែលទូលបង្គំប្រទូលដៃ[ង]ទៅឯទីបរិសុទ្ធរបស់ទ្រង់[ច]
៣សូមកុំទាញទូលបង្គំទៅជាមួយនឹងមនុស្សអាក្រក់
ឬជាមួយនឹងមនុស្សដែលប្រព្រឹត្តការទុច្ចរិត
ជាអ្នកដែលពោលពាក្យដោយមេត្រីនិងអ្នកជិតខាង
តែមានគំនិតកាចអាក្រក់នៅក្នុងចិត្តវិញ នោះឡើយ[ឆ]
៤សូមសងគេតាមការដែលគេធ្វើ
ហើយតាមសេចក្ដីអាក្រក់នៃអំពើដែលគេប្រព្រឹត្តនោះ[ជ]
សូមសងគេតាមស្នាដៃរបស់គេ ហើយតបឱ្យសំណងនឹងទោសរបស់គេ[ឈ]
៥ដ្បិតគេមិនយកចិត្តទុកដាក់នឹងការនៃព្រះយេហូវ៉ាឬនឹង
ស្នាដៃនៃព្រះហស្តទ្រង់នោះឡើយ[ញ]
ទ្រង់មិនស្អាងគេឡើងទេ គឺនឹងរំលំគេទៅវិញ។
៦សូមលើកសរសើរដល់ព្រះយេហូវ៉ា[ដ]
ពីព្រោះទ្រង់បានឮសំឡេងដែលខ្ញុំទូលអង្វរ[ឋ]
៧ព្រះយេហូវ៉ាទ្រង់ជាកំឡាំង[ឌ] ហើយជាខែលនៃខ្ញុំ
ចិត្តខ្ញុំបានសង្ឃឹម[ឍ] ដល់ទ្រង់
ហើយបានសេចក្ដីជំនួយហេតុនោះចិត្តខ្ញុំមានសេចក្ដីរីករាយជាខ្លាំង[ណ] ខ្ញុំនឹងសរសើរដល់ទ្រង់
ដោយបទចំរៀងរបស់ខ្ញុំ[ត]
៨ព្រះយេហូវ៉ាទ្រង់ជាកំឡាំង[ថ] ហើយជាទីមាំមួន
សំរាប់នឹងជួយសង្គ្រោះ[ទ]
ដល់ពួកអ្នកដែលទ្រង់បានចាក់ប្រេងតាំងឱ្យ[ធ]

**២៨:១** ខ នរ ៤:១៤ គ យប ៣៣:១៨ **២៨:២** ឃ ទដ ១៧:១ ៦១:១ ១១៦:១ ១៣០:២ ១៤២:១ ១៤៣:១ ង អរ ៩:៥ ទដ ៦៣:៤ ១៤១:២ បទ ២:១៩ ១ធថ ២:៨ ច ទដ ៥:៧ ១១:៤ **២៨:៣** ឆ ទដ ១២:២ ២៦:៤ ៥៥:២១ យរ ៩:៨ **២៨:៤** ជ ទដ ៦២:១២ ២ធថ ៤:១៤ វវ ២២:១២ ឈ បទ ៣:៦៤ វវ ១៨:៦ **២៨:៥** ញ អស ៥:១២ **២៨:៦** ដ លប ២៤:២៧ ២កថ ១:៣ អភ ១:៣ ១ពត ១:៤ ឋ ខ.២ **២៨:៧** ឌ ទដ ១៨:១ ឍ ទដ ១៣:៥ ១១២:៧ អស ២៦:៣ ណ ចទ ១៦:១៥ ទដ ១៦:៩ ត ទដ ៣៣:៣ ៤០:៣ ៦៩:៣០ ១៤៤:៩ ១៤៩:១ **២៨:៨** ថ ទដ ១៨:១ ទ នក ១៥:២ ទដ ២៧:១ ហាព ៣:១៣ ធ ទដ ២០:៦

បានភ្ជាប់គ្នាជាមួយបទគម្ពីរ ទដ ជំពូក ២៣ ។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងការភ្ជាប់គ្នារវាងទំនុកដំកើង ២៥-៣៣ (សូមមើលសេចក្ដីផ្ដើម ទដ ២៥-៣៣) បទនៃទំនុកនេះ វាមានទំនាក់ទំនងយ៉ាជិតស្និតជាមួយ ទដ ជំពូក ៣០ ។ នៅក្នុងព្រះគម្ពីរ ទដ ២៨ អ្នកនិពន្ធបានអំពាវនាវដល់ព្រះយេហូវ៉ាដើម្បីទូលសូម"សេចក្ដីមេត្តាករុណា"នៃព្រះ (មើល ខ.២,៦) នៅពេលដែលគាត់មើលទៅឃើញថា ដូចជា"ចុះទៅក្នុងរណ្ដៅ" (មើល ខ.១) ។ នៅក្នុង ទដ ជំពូក ៣០ អ្នកនិពន្ធគាត់បានអធិស្ឋានដល់ព្រះយេហូវ៉ាទ្រង់មាន "មេត្តាករុណា" (ខ.៨,១១) និងសូមឱ្យព្រះទ្រង់ជួយឱ្យគាត់រួចពី "រណ្ដៅ" (ខ.៣) ។ ទំនុកដំកើងទាំង២នេះបានមានទំនាក់ទំនងជាមួយគ្នា តាមរយៈសញ្ញានៃភាសាសាស្ត្រ : សូមធៀបជាមួយ ២៨:១ ជាមួយ ៣០:៨ (ឱព្រះយេហូវ៉ាអើយ ទូលបង្គំនឹងអំពាវនាវដល់ទ្រង់) ២៨:២ ជាមួយ ៣០:២ ("ទូលបង្គំអំពាវនាវដល់ទ្រង់") ។ ២៨:៧ ("បានសេចក្ដីជំនួយ") និង ៣០:១០ ("សូមទ្រង់បានធ្វើជាអ្នកជំនួយដល់ទូលបង្គំ") ។

**២៨:១-២** សេចក្ដីអធិស្ឋានក្នុងខនេះ គឺចង់ឱ្យតែព្រះទ្រង់ស្ដាប់ឮពាក្យដែលគាត់អំពាវនាវប៉ុណ្ណោះ ។

**២៨:១** *ថ្មដា* មើលការពន្យល់ ១៨:២ ។ *នៅតែស្ងៀម* នៅក្នុងឃ្លានេះចង់និយាយថា សូមកុំធ្វើការនោះជំនួសទូលបង្គំ ។ *រណ្ដៅ* នេះគឺជាប្រៀបប្រដូចអំពីស្ថានឃុំព្រលឹងមនុស្សស្លាប់ (មើលការពន្យល់ ៣០:១) ។

**២៨:២** *ទូលបង្គំប្រទូលដៃទៅ* ការប្រទូលដៃគឺគេធ្វើឡើងក្នុងពេលថ្វាយបង្គំនិងអធិស្ឋាន (សូមមើលក្នុង ៦៣:៤ ១៣៤:២ ១៤១:២) ។ *ឯទីបរិសុទ្ធរបស់ទ្រង់* គឺជាទីដែលនៅក្នុងនៃព្រះវិហារ (សូមមើលក្នុង ១ពវ ៦:៥) ហើយជាកន្លែងដែលទុកហឹបនៃសេចក្ដីសញ្ញា (សូមមើលក្នុង ១ពវ ៨:៦-៨) ហើយទីបរិសុទ្ធបំផុតគឺជាបល្ល័ង្កនៃព្រះលើផែនដីនេះ ។

**២៨:៣-៥** នៅក្នុងខនេះ គឺជាសេចក្ដីអធិស្ឋានទូលសូមឱ្យព្រះអម្ចាស់ព្រះយេហូវ៉ាយាងមកគង់នៅក្នុងព្រះវិហារនៃទ្រង់ ហើយសូមឱ្យព្រះអង្គទ្រង់រំដោះអ្នកបំរើទ្រង់ ហើយជំនុំជំរះពួកអ្នកដែលតែងតែព្យាបាទដល់ស្ដេចនិងរាស្ត្ររបស់ទ្រង់ ។

**២៨:៣** *មនុស្សអាក្រក់* មើលការពន្យល់ ៥:៩ ។ *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។

**២៨:៤** *សងគេ* សូមមើលការពន្យល់ក្នុង ៥:១០ និង មថ ១៦:២៧ ២ធថ ៤:១៤ វវ ២០:១២-១៣ ២២:១២ ។

**២៨:៥** *ការនៃព្រះយេហូវ៉ា* គឺជាការដែលទ្រង់បានសង្គ្រោះប្រជារាស្ត្រអ៊ីស្រាអែល និងការសាងសង់ប្រជារាស្ត្រអ៊ីស្រាអែល ដែលជានគររបស់ព្រះអម្ចាស់ (តាមរយៈការតាំងសញ្ញា នក ១៩-២៤) ហើយនិងការតាំងពួកផ្ទះរបស់ដាវីឌ (តាមរយៈការតាំងសញ្ញា ២សយ ជំពូក ៧) ដែលជារាជានុសិទ្ធរបស់ព្រះក្នុងការគ្រប់គ្រងលើរាស្ត្រព្រះលើផែនដីនេះ ។ *ស្នាដៃនៃព្រះហស្តទ្រង់* "ការដែលគេធ្វើ"(ខ.៤) គឺជាការប្រព្រឹត្ត "ការទុច្ចរិត" (មើល ខ.៣) បានបង្ហាញថា គេមិនទទួលស្គាល់ដំណែងរាជានុសិទ្ធរបស់ពួកអ៊ីស្រាអែល និងដាវីឌថាជាការដែលព្រះបានធ្វើឡើយ ។ *នឹងរំលំ* ឬអាចនិយាយថា ទ្រង់អាចរំលំ ។

**២៨:៦-៧** នៅក្នុងខទាំងនេះ អ្នកនិពន្ធគាត់មានអំណរក្នុងការសរសើរដំកើងដល់ព្រះអម្ចាស់ ដោយមានទំនុកចិត្តលើព្រះអម្ចាស់ (សូមមើលការពន្យល់ក្នុង ៣:៨) ។

**២៨:៧** *ខែល* មើលការពន្យល់ ៣:៣ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។ *ខ្ញុំនឹងច្រៀងសរសើរដល់ទ្រង់* មើលការពន្យល់ ៧:១៧ ។

**២៨:៨-៩** នៅក្នុងខទាំងនេះ និយាយពីទំនាក់ទំនងរវាងព្រះនិងរាស្ត្ររបស់ទ្រង់ (សូមមើលការពន្យល់ ៣:៨) ។

**២៨:៨** *ជួយសង្គ្រោះ . . . ប្រទានពរ* នៅក្នុងឃ្លានេះគឺជាការគ្រឹះ២របស់ព្រះអម្ចាស់ក្នុងការទំនាក់ទំនងជាមួយរាស្ត្ររបស់ទ្រង់ ។ ព្រះយេហូវ៉ាតែងតែជួយសង្គ្រោះគេជានិច្ចនៅពេលណា ដែលគេត្រូវការឱ្យព្រះអង្គជួយ ។

៩ សូមទ្រង់ជួយសង្គ្រោះរាស្ត្រ[ន] របស់ទ្រង់
ហើយប្រទានពរដល់មរដក[ប] នៃទ្រង់
សូមធ្វើជាអ្នកគង្វាល[ផ]ដល់គេព្រមទាំងបីទ្រគេ[ព]ជា
ដរាបតទៅ ។

ទំនុកនៃស្តេចដាវីឌ ។

**២៩** នែ អស់ទាំងកូននៃព្រះដ៏មានឥទ្ធិឫទ្ធិអើយ[ក]
ចូរសរសើរព្រះយេហូវ៉ា[ខ] ចូរសរសើព្រះយេហូវ៉ាថា
ទ្រង់មានសិរីល្អ[គ] ហើយនិងព្រះចេស្តា
២ ចូរសរសើរពីសិរីល្អនៃព្រះយេហូវ៉ាឱ្យសមនឹងព្រះនាម
ទ្រង់ ចូរពាក់គ្រឿងលំអបរិសុទ្ធ
នាំគ្នាថ្វាយបង្គំដល់ព្រះយេហូវ៉ាចុះ[ឃ] ។
៣ ព្រះសូរសៀង[ង]នៃព្រះយេហូវ៉ាឮរតាមទឹក
ព្រះដ៏មានសិរីល្អ[ច]ទ្រង់ បញ្ចេញផ្គរលាន់[ឆ]
គឺព្រះយេហូវ៉ាទ្រង់គង់លើទឹកធំ[ជ]
៤ ព្រះសូរសៀងរបស់ព្រះយេហូវ៉ាមានអំណាច[ឈ]ព្រះសូរ
សៀងនៃព្រះយេហូវ៉ាមានឫទ្ធានុភាព
៥ ព្រះសូរសៀងរបស់ព្រះយេហូវ៉ាក៏បំបាក់ដើមតាត្រៅ

**២៨:៩** ន ១របា ១៦:៣៥ ទដ ១០៦:៤៧ ១១៨:២៥ ប នក ៣៤:៩ ផ ១របា ១១:២ ទដ ២៣:១ ៧៨:៥២,៧១ ៨០:១ អស ៤០:១១ យរ ៣១:១០ អគ ៣៤:១២–១៦,២៣,៣១ មីក ៧:១៤ ព ចទ ១:៣១ ៣២:១១ អស ៤៦:៣ ៦៣:៩ **២៩:១** ក ២សយ ១:១៩ ទដ ១០៣:២០ អស ១០:១៣ ខ ខ.២ ១របា ១៦:២៨ **២៩:១** គ ទដ ៨:១ **២៩:២** ឃ ១របា ១៦:២៩ ទដ ៩៦:៧–៩ **២៩:៣** ង យប ៧:៥ ច ទដ ២៤:៧ កច ៧:២ ឆ ១សយ ២:១០ ទដ ១៨:១៣ ៤៦:៦ ៨:៣៣ ៧៧:១៧ យរ ១០:១៣ ២៥:៣០ យអ ២:១១ អម ១:២ ជ នក ១៥:១០ **២៩:៤** ឈ ទដ ៦៨:៣៣

ព្រះយេហូវ៉ាទ្រង់ក៏ប្រទានពរពួកគេជានិច្ចផងដែរ ដើម្បីឱ្យពួកគេបានរស់នៅនិងបង្កើតផលក្នុងកម្លាំងពលកម្មរបស់ពួកគេ ។ *មរដក នៃទ្រង់* មើលក្នុង ចទ ៩:២៩ ។ *អ្នកគង្វាល* មើលសេចក្ដីផ្ដើម និង ៨០:១ អស ៤០:១១ យរ ៣១:១០ អគ ជំពូក ៣៤ មីក ៥:៤ និង ការពន្យល់ក្នុង ទដ ២៣:១ ។ ព្រះអម្ចាស់ទ្រង់ស្ដាប់ឮ និងឆ្លើយតបពាក្យដែលគាត់អំពាវនាវ និងជាចម្លើយពេញលេញចុងក្រោយ គឺបានមកនៅក្នុងការងារ "អ្នកគង្វាលល្អ" (មើល យហ ១០:១១,១៤) ។

**ទំនុកដំកើង២៩** នៅក្នុងជំពូកនេះ គឺជាបទចម្រៀងសរសើរតម្កើងចំពោះស្ដេចនៃការបង្កើត ដែលសិរីល្អរបស់ទ្រង់បានតាំងឡើងតាមរយៈបញ្ចេញផ្គរលាន់យ៉ាងរំពងអឺងកង ក្នុងរដូវមានព្យុះភ្លៀងធ្លាក់ដូចដែលមានឃើញនៅលើសមុទ្រមេឌីទែរ៉ាណេ ("ឮរតាមទឹក" ខ.៣) ហើយឆ្លងពីលើលំហរអាកាសពីទិសខាងលេចមកទិសខាងកើត បក់ផាត់ជួរភ្នំល្បាណូន (ខ.៥–៦) មកដល់(ភាគខាងជើង)ទីរហោស្ថានកាដេស (ខ.៨) ។ សិរីល្អនៃព្រះមិនគ្រាន់តែមើលឃើញតាមរយៈការបង្កើតរបស់ទ្រង់ប៉ុណ្ណោះទេ (១៩:១–៦ និងសេចក្ដីផ្ដើមទំនុកដំកើងជំពូកនេះ និង ទដ ១០៤) ប៉ុន្តែក៏អាចឮសម្លេងគួរឱ្យខ្លាចដែលមាននៅក្នុងការបង្កើតភាគច្រើនថែមទៀតផងដែរ (ការញ័ររញ្ជួយនៃសមុទ្រ ព្រមទាំងការធ្លាក់ព្រិលយ៉ាងច្រើន) ។ បទចម្រៀងសរសើរដំកើងចំពោះព្រះយេហូវ៉ា (ព្រះអម្ចាស់) គឺជាបន្ទាល់ និងជាការទាស់ប្រឆាំងចំពោះការថ្វាយបង្គំដល់ព្រះបាលជាព្រះពួកកាណាន ដែលគេគិតថា ខ្លួនគេជាព្រះដែលមានអំណាចចេស្ដាដែលបានបង្ហាញតាមរយៈផ្គរលាន់នោះ (សូមធៀបជាមួយ ៣១:៦) ។ នៅក្នុងចំណុចកណ្ដាលនៃសេចក្ដីអធិស្ឋាន និងការសរសើរដំកើងនេះបានរំឭកដល់ពួកអ្នកដែលសញ្ជឹងគិត លើព្រះគម្ពីរទំនុកដំកើង ហើយយកវាមកអនុវត្តន៍ក្នុងជីវិតផ្ទាល់ខ្លួនពួកគេ និងជាអ្នកដែលពួកគេត្រូវតែគោរពថ្វាយបង្គំចំពោះ "ព្រះយេហូវ៉ានៃពួកពលបរិវ៉ា" ។ គ្រប់ទាំងអស់ដែលព្រះអម្ចាស់ទ្រង់បានបង្កើតមកគឺសុទ្ធតែបានបង្ហាញពីអំណាចចេស្ដា និងសិរីល្អនៃព្រះ ហើយបានរំឭកដល់មនុស្សទាំងអស់ឱ្យមានការកោតសរសើរ និងថ្វាយការសរសើរដំកើង (ខ.១–២) ប៉ុន្តែឯព្រះគុណ និងសេចក្ដីមេត្តាករុណានៃព្រះបាននៅជាប់ជាមួយរាស្ត្ររបស់ទ្រង់ (មើលក្នុង ខ.១១) ព្រមទាំងធ្វើឱ្យគេមានទំនុកចិត្តក្នុងការអធិស្ឋាន រាល់វេលាណាដែលគេត្រូវការ ។

នៅក្នុងប្រយោគនេះ មាន២ខ.ដែលជាសេចក្ដីផ្ដើម និង២ខទៀតជាសេចក្ដីបញ្ចប់ ដែលមានទំនាក់ទំនងជិតស្និតជាមួយខទាំង៧នៃល្បះទាំងនោះ ។ ទាំងសេចក្ដីផ្ដើមនិងទាំងសេចក្ដីបញ្ចប់ គឺបាននិយាយពីព្រះនាម "ព្រះយេហូវ៉ា"(ព្រះអម្ចាស់)ចំនួន៤ដង ។ នៅក្នុងតួរសេចក្ដីនៃទំនុកដំកើងនេះមានពាក្យថា"ព្រះយេហូវ៉ា"ចំនួន១០ដង ។ ឃ្លាថា"ព្រះសូរសៀងនៃព្រះ" មាននិយាយម្ដងហើយម្ដងទៀតចំនួន៧ដង ហើយមាន៧ទៀតដែលនិយាយពីផ្គរលាន់នៃព្រះ (លេខ ខ.៤,៧,១០ ជាញឹកញាប់ក្នុងសញ្ញាចាស់ គឺជាសញ្ញាណ នៃភាពគ្រប់លក្ខណ៍) ។

**២៩:១–២** នៅក្នុងខនេះ គឺហៅដល់ពួកកូននៃព្រះទាំងអស់(មើលការពន្យល់ ខ.១) ឱ្យចូលមកសរសើរដំកើងព្រះអម្ចាស់ដោយយកគំរូតាមការហៅឱ្យមកសរសើរដំកើងក្នុងព្រះវិហារ (មើល ៩៦:៧–៩ ១របា ១៦:២៨–២៩) ។

**២៩:១** *ដ៏មានឥទ្ធិឫទ្ធិ* តាមភាសាអក្សរសាស្ត្រគឺ "កូននៃព្រះ"(រូបព្រះ) ។ ពាក្យនេះប្រហែលនិយាយសំដៅលើវិញ្ញាណនៃពួកទេវតា (សូមមើលក្នុង ១០៣:២០ ១៤៨:២ យប ១:៦ និងការពន្យល់ ២:១ និងការពន្យល់ អស ៦:២) ឬនិយាយសំដៅលើពួកមនុស្សឆ្កួតលីលាទាំងអស់ដែលគិតថា ខ្លួនជាព្រះដូចជានិយាយនៅក្នុង ទដ ជំពូក ៩៧ (មើលក្នុង ៩៧:៧) ដែលជាញឹកញាប់តែងតែមានទំនាក់ទំនងជាមួយទំនុកនេះ ។ មានតែព្រះយេហូវ៉ាប៉ុណ្ណោះដែលគួរទទួលស្គាល់ថាជាព្រះអទិករ ។

**២៩:២** *ព្រះនាម* មើលការពន្យល់ ៥:១១ ។ *ពាក់គ្រឿងលំអរបរិសុទ្ធ* ឃ្លានេះប្រហែលជាការកាត់ស្រាយដ៏ពិបាកមួយនៃព្រះគម្ពីរភាសាហេព្រើរ (មើល ៩៦:៩ ១១០:៣ ១របា ១៦:២៩ ២របា ២០:២១)។ ពាក្យនេះគេមិនបានដឹងច្បាស់ថា តើនិយាយពណ៌នាពីព្រះ ឬជាទីបរិសុទ្ធ ឬសំលៀកបំពាក់ពួកសង្ឃ ដែលពួកសង្ឃស្លៀកពាក់នៅពេលដែលគេចូលមកឯព្រះនោះឡើយ ។ ការប្រើឃ្លាដែលស្ទើរតែដូចគ្នានេះនៅក្នុង ទដ ១១០:៣ "ប្រដាប់ដោយគ្រឿងបរិសុទ្ធ" ដែលឃ្លានេះមើលទៅហាក់បីដូចជាគាំទ្រដល់ការបំលាស់ប្តូរចុងក្រោយ ។ ប៉ុន្តែអត្ថបទហេព្រើរនិងបរិបទនៃ គម្ពីរ ២របា ២០:២១ គឺមានលក្ខណះស្របគ្នានឹងឃ្លាថា "ពាក់គ្រឿងលំអរបរិសុទ្ធ"។

**២៩:៣–៩** នៅក្នុងខទាំងនេះ គឺជាការសរសើរដំកើងដល់ព្រះយេហូវ៉ា ដែលព្រះអង្គបានបញ្ចេញព្រះសូរសៀងរបស់ទ្រង់មក ឱ្យឮលាន់រំពងដូចជាផ្គរលាន់(មើល ៦៨:៤,៣៣) ។ សូរសៀង និងសេចក្ដីក្រោធរបស់ព្រះនៃការបង្កើតទាំងឡាយដែលគួរឱ្យភ័យខ្លាច នោះគឺជាការបង្ហាញពីអំណាចចេស្ដារបស់ព្រះនៃពួកអ៊ីស្រាអែល ។

អើ ព្រះយេហូវ៉ាទ្រង់បំបាក់កំទេចដើមតាត្រៅនៅភ្នំ
ល្បាណូន[ញ]
៦ ទ្រង់បណ្ដាលឱ្យដើមទាំងនោះបោលលោត[ដ]ដូចជាកូន
គោ ហើយឱ្យភ្នំល្បាណូន និងភ្នំសីរាន[ឋ]បោលដូចជាគោ
ព្រៃស្ទាវ[ឌ]
៧ ព្រះសូរសៀងនៃព្រះយេហូវ៉ាធ្វើឱ្យមានអណ្ដាតភ្លើង
ផុសឡើង[ឍ]
៨ ព្រះសូរសៀងរបស់ព្រះយេហូវ៉ាធ្វើឱ្យទីរហោស្ថានញ័រ
កក្រើក ព្រះយេហូវ៉ាទ្រង់អង្រួនទីរហោស្ថានកាដេស[ណ]
៩ ព្រះសូរសៀងរបស់ព្រះយេហូវ៉ាធ្វើឱ្យក្ដាន់ញី[ត]សំរាល
កូនមក ក៏ជិរុះស្លឹកឈើនៅព្រៃអស់រលីង
ហើយនៅក្នុងព្រះវិហារនៃទ្រង់
នោះសព្វសារពើក៏បន្លឺឡើងថា "ស្រីសួស្ដី"[ថ]
១០ ព្រះយេហូវ៉ាទ្រង់បានគង់នៅវេលាជំនន់លោកីយ៍[ទ]
អើ ព្រះយេហូវ៉ាទ្រង់គង់ជាព្រះមហាក្សត្រនៅអស់កល្ប
ជានិច្ច[ធ]
១១ ព្រះយេហូវ៉ាទ្រង់នឹងចំរើនកំឡាំងដល់រាស្ត្រទ្រង់[ន]
ព្រះយេហូវ៉ា ទ្រង់នឹងប្រទានពរដល់រាស្ត្រទ្រង់ឱ្យបាន
សេចក្ដីសុខសាន្តត្រាណ[ប] ។

ទំនុកនៃស្ដេចដាវីឌ ដែលទ្រង់លើកសំរាប់ច្រៀងឆ្លងព្រះវិហារ ។

**៣០** ឱព្រះយេហូវ៉ាអើយ ទូលបង្គំសរសើរ[ក]ទ្រង់
ដ្បិតទ្រង់បានលើកទូលបង្គំឡើងវិញ[ខ]

**២៩:៥** ញ ពច ៩:១៥ **២៩:៦** ដ ទដ ១១៤:៤ ឋ ចទ ៣:៩ ឌ ជន ២៣:២២ យប ៣៩:៩ ទដ ៩២:១០ **២៩:៧** ឍ អក ១:១៤ វវ ៨:៥ **២៩:៨** ណ ជន ១៣:២៦ ២០:១ **២៩:៩** ត អស ២:១៣ អក ២៧:៦ អម ២:៩ ថ ទដ ២៦:៨ **២៩:១០** ទ លប ៦:១៧ ធ នក ១៥:១៨ **២៩:១១** ន ទដ ១៨:១ ២៨:៨ ៦៨:៣៥ ប លវ ២៦:៦ ជន ៦:២៦ **៣០:១** ក នក ១៥:២ ខ យប ១១:៨ ទដ ៦៣:៩ ១០៧:២៦ សក ៩:១៨ អស ១៤:១៥

**២៩:៥** *ដើមតាត្រៅនៅភ្នំល្បាណូន* ដើមតាត្រៅគឺជាដើមឈើដែលមានអំណាចនិងជាដើមដែលមានតម្លៃបំផុតនៅក្នុងតំបន់មជ្ឈឹមបូព៌ា (សូមមើលក្នុង បស ៥:១៥ និងការពន្យល់) ។

**២៩:៦** *បោលលោត* សូមមើលក្នុង ១១៤:៤ និងការពន្យល់ក្នុង ។

**២៩:៩** *ព្រះវិហារ* ព្រះវិហារគឺជាផ្ទៃរឿងនៃព្រះគម្ពីរទំនុកដំកើង ២៣–២៨ ។ ព្រះវិហារដែលនិយាយនៅកន្លែងនេះប្រហែលសំដៅលើព្រះវិហារនៅក្រុងយេរូសាឡិម ឬជានគរស្ថានសួគ៌ ដែលជាបល្ល័ង្កទ្រង់គង់លើ (មើល ២:៤ ១១:៤ ១១៣:៥ អស ៦:១ ៤០:២២) ធ្វើជាព្រះនៃការបង្កើតទាំងអស់ ។ ប៉ុន្តែឃ្លានេះក៏អាចសំដៅលើគ្រប់របស់ទាំងឡាយ ដែលព្រះបង្កើតមកហើយ ដែលនៅទីនេះរបស់ទាំងនោះមានឈ្មោះថា ព្រះវិហារនៃព្រះ (សូមមើលការពន្យល់ក្នុង ២៤:២) ។ ដូច្នេះពាក្យថា "សព្វសារពើ"ក៏បន្លឺឡើងថា"ស្រីសួស្ដី" គឺពិតជានិយាយសំដៅលើគ្រប់របស់ទាំងអស់ ដែលព្រះយេហូវ៉ាបង្កើតមក ហើយគ្រប់របស់ទាំងនោះគឺត្រូវស្រែកថ្វាយសិរីល្អដល់ព្រះ (សូមផ្ទៀបជាមួយ ១៥០:៦) ។ *ស្រីសួស្ដី* សូមមើលការពន្យល់ក្នុង ២៦:៨ ។

**២៩:១០–១១** នៅក្នុងខទាំងនេះចង់និយាយថា សេចក្ដីពិតនឹងការគ្រប់គ្រងដ៏អស់កល្បជានិច្ចរបស់ព្រះយេហូវ៉ា គឺព្រះអង្គទ្រង់បានសម្រេចព្រះទ័យថាទ្រង់នឹងប្រទានពរឱ្យរាស្ត្ររបស់ទ្រង់ ទទួលបានសេចក្ដីសង្គ្រោះពេលលេញ និងប្រទានពរ ដែលជាពរលើអស់ទាំងពរដល់ពួកគេឱ្យពួកគេបានបំពាក់នូវមកុដនៅលើផែនដី ជាកន្លែងដែលមានទឹកជំនន់ធំហើយដែលទឹកនោះ បានធ្វើឱ្យរាស្ត្រទ្រង់មិនទុកចិត្តលើព្រះអង្គ ។

**២៩:១០** *គង់នៅវេលាមានជំនន់* ព្រះយេហូវ៉ាទ្រង់គឺជាម្នាក់ ដែលព្រះបន្ទូលរបស់ទ្រង់បានធ្វើគ្រប់របស់ ដែលទ្រង់បង្កើតមកមានពេញដោយសណ្ដាប់ធ្នាប់លែងមានភាពទទេនៅលើ "ទីជំរៅ" ទៀតហើយ (សូមមើល លប ១:២,៦–១០) ។

**ទដ ៣០** នេះគឺជាបទចម្រៀងសរសើរដំកើងដល់ព្រះយេហូវ៉ា ក្នុងការដែលទ្រង់បានជួយរំដោះពួកគេឱ្យរួចពីសេចក្ដីស្លាប់ ហើយប្រហែលសេចក្ដីស្លាប់នោះបណ្ដាលមកពីរាំរៃ ("ទ្រង់ប្រោសឱ្យទូលបង្គំបានជា"ខ.២ ហើយសូមមើលការពន្យល់ក្នុង ៧:១៧) ។ មើលទំនាក់ទំនងព្រះគម្ពីរ ទដ ជំពូកនេះជាមួយ ទដ ២៨ ក្នុងសេចក្ដីផ្ដើមព្រះគម្ពីរនេះ ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះបានបង្ហាញយើងឱ្យឃើញច្បាស់ ពីការប្ដេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះយេហូវ៉ា (សូមមើល ខ.១,១២) ។

**ទដ ៣០ក្រង់ចំណងជើង** *ទំនុក* សូមមើលចំណងជើង ទដ ១៨,៤៥–៤៦,៤៨,៦៥–៦៨,៧៥–៧៦,៨៣,៨៧–៨៨,៨២ ១០៨ និងគ្រប់ទាំងអស់នៃទំនុកដំកើងនៃការសរសើរ ដោយលើកលែងតែ ទដ ៨៣,៨៨ ប៉ុណ្ណោះ ។ ជាងនេះទៅទៀតនៅក្នុង ទដ ទាំងមូលក៏មានការបន្ថែមនូវ "ទំនុកច្រៀងតាមថ្នាក់"ថែមទៀតដែរ (សូមមើល ទដ ១២០–១៣៤) ។ *សំរាប់ច្រៀងឆ្លងព្រះវិហារ* បើសិនជាគេច្រៀងបទចម្រៀងនេះ ក្នុងឱឆ្លង"ព្រះវិហាររបស់ដាវីឌ"មែននោះមានន័យថា បទទំនុកក្នុងជំពូកនេះគឺបានកត់ចុះក្នុង ១រប ២១:១–២២:៦ នៅក្នុង ១រប ២២:១–៦ ស្ដេចដាវីឌគាត់បានធ្វើពិធីឆ្លងព្រះវិហារគាត់និងសំភារៈផ្សេងៗទៀតក្នុងព្រះវិហារ ហើយប្រហែលជាគាត់មានចេតនានឹងយកព្រះគម្ពីរ ទដ ជំពូក ៣០ មកច្រៀងឆ្លងព្រះវិហារនេះតែម្ដង ។ បើសិននេះជាមូលហេតុមែននោះ ខ.២–៣ គឺពិតជានិយាយសំដៅលើការនិយាយអះអាងរបស់ស្ដេចដាវីឌដែលមាននិយាយនៅក្នុង ១រប ២១:១៧–៣០ ។ "ព្រះគុណ" ដែលនិយាយនៅក្នុង ខ.៥ គឺអាចជាការដកស្រង់ចេញពីពាក្យ ថា"សេចក្ដីមេត្តាករុណា"ដែលនិយាយនៅក្នុង ១រប ២១:១៣ ហើយ ខ.៦ គឺអាចសំដៅលើអំពើបាបរបស់គាត់ក្នុងការ ដែលគាត់បានបាត់ការទុកចិត្តចំពោះព្រះដែលមេទ័ពដ៏អស្ចារ្យ (សូមមើល ១រប ២១:១–៨) ។

ចុងក្រោយ ព្រះគម្ពីរក្នុងជំពូកនេះក៏និយាយសំដៅលើការនិរទេសរបស់ពួកអីស្រាអែលដែរ ។ នៅក្នុងការច្រៀងសរសើររបស់ពួកយូដាដែលពួកគេចាប់អនុវត្តន៍តាំងពីគ្រា តាលម៉ូឌិច (Talmudic) ហើយគេបានច្រៀងនៅក្នុងពិធីបុណ្យសាសនាយូដា ។ ពួកយូដាម៉ាកាប៊ីអ៊ីស (១៦៥ មុន គ.ស) គេបានធ្វើពីជប់លៀងអបអរពិធីឆ្លងព្រះវិហាររបស់គេ ហើយក្រោយមកទៀតត្រូវបានពួកអាន់ទីកុស អេភីប( Antiochus Epiphanes) ជាប្រមាថមើលងាយវិញ (១៦៨) ។ នៅក្នុងក្រុមទី"១"នៃព្រះគម្ពីរទំនុកដំកើងបានក្លាយជាការបញ្ចូលគ្នានៃ"មនុស្ស"ក្នុងពួកអីស្រាអែល ដែលការនេះជាការនិយាយយ៉ាងសាមញ្ញក្នុងសញ្ញាចាស់ ។

**៣០:១–៣** នៅក្នុងខ.ទាំងនេះគឺជាសេចក្ដីផ្ដើមនៃការសរសើរដំកើងចំពោះព្រះយេហូវ៉ា ។

មិនបានបើកឱ្យពួកខ្មាំងសត្រូវ
មានសេចក្ដីអំណរ ដោយឈ្នះទូលបង្គំឡើយ[គ]
២ ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ
ទូលបង្គំបានអំពាវនាវ ដល់ទ្រង់[ឃ]
ហើយទ្រង់ប្រោសឱ្យទូលបង្គំបានជា[ង]
៣ ឱព្រះយេហូវ៉ាអើយ ទ្រង់បាននាំព្រលឹងទូលបង្គំឡើង
រួចពីស្ថានឃុំព្រលឹងមនុស្សស្លាប់[ច]
ទ្រង់បានប្រោសឱ្យទូលបង្គំរស់នៅ
ដើម្បីកុំឱ្យទូលបង្គំចុះទៅរណ្ដៅឡើយ[ឆ]
៤ ឱពួកអ្នកបរិសុទ្ធ[ជ]របស់ទ្រង់អើយចូរច្រៀងសរសើរ[ឈ]
ដល់ព្រះយេហូវ៉ា ចុះ ចូរអរព្រះគុណ
ដោយនឹកចាំពីសេចក្ដីបរិសុទ្ធនៃទ្រង់[ញ]
៥ ដ្បិតសេចក្ដីខ្ញាល់[ដ]របស់ទ្រង់នៅតែ១ភ្លែតទេ[ឋ]
តែព្រះគុណនៃទ្រង់ នោះនៅអស់១ជីវិតវិញ[ឌ]
ទឹកភ្នែកនឹង[ឍ]មាននៅជាប់អស់មួយយប់ក៏បាន
តែព្រឹកឡើង គង់នឹងមានសេចក្ដីអំណរឡើងដែរ[ណ]
៦ ចំណែកខាងទូលបង្គំៗបានពោលក្នុងគ្រានៃសេចក្ដីចំរើន
របស់ទូលបង្គំថា ទូលបង្គំមិនត្រូវរង្គើឡើយ[ត]
៧ ដ្បិត ឱព្រះយេហូវ៉ាអើយ ទ្រង់បានតាំងភ្នំនៃទូលបង្គំឡើង
ឱ្យមាំមួនដោយព្រះគុណទ្រង់ កាលទ្រង់បានលាក់ព្រះ
ភក្ត្រ[ថ]ទៅ នោះទូលបង្គំមានសេចក្ដីតក់ស្លុត
៨ តែ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់ទ្រង់
គឺទូលបង្គំបានទូលអង្វរដល់ព្រះយេហូវ៉ាថា
៩ តើមានប្រយោជន៍អ្វី ដែលទ្រង់កំចាយឈាមទូលបង្គំ
ហើយឱ្យទូលបង្គំចុះទៅក្នុងរណ្ដៅនោះ[ទ]
តើធូលីនឹងសរសើរដល់ទ្រង់ដែរឬ

**៣០:១** គ ទដ ២២:១៧ **៣០:២** ឃ ទដ ៥:២ ៨៨:១៣ ង ជន ១២:១៣ **៣០:៣** ច ទដ ១៦:១០ ៥៦:១៣ ឆ ទដ ២៨:១ ៥៥:២៣ ៦៩:១៥ ៨៦:១៣ ១៤៣:៧ សភ ១:១២ អស ៣៨:១៧ យហ ២:៦ **៣០:៤** ជ ទដ ១៦:៣ ឈ ទដ ៣៣:១ ៤៧:៧ ៦៨:៤ ញ នក ៣:១៥ ទដ ៣៣:២១ ១០៣:១ ១៤៥:២១

**៣០:៥** ដ ទដ ១០៣:៩ ឋ យប ១៤:១៣ **៣០:៥** ឌ អរ ៣:១១ ឍ ២សយ ១៥:៣០ ទដ ៦:៦ ១២៦:៦ យរ ៣១:១៦ ណ ២កថ ៤:១៧ **៣០:៦** ត យប ២៩:១៨ **៣០:៧** ថ ចទ ៣១:១៧ **៣០:៩** ទ យប ៣៣:១៨ អស ៣៨:១៨

**៣០:១** *ដ្បិតទ្រង់បានលើកទូលបង្គំឡើងវិញ* នេះគឺជាឃ្លាប្រៀបធៀបមួយ ដែលមានលក្ខណៈរស់រវើក ដែលជាប់ទាក់ទងនឹងសេចក្ដីទុក្ខព្រួយលំបាក ដែលធៀបបាននឹងការជាប់ "ល្បាប់ដ៏ជ្រៅ" ដែលការនេះគឺជាការពណ៌នាពីបទពិសោធន៍នៃសង្គមមនុស្សហើយការពិពណ៌នាបែបនេះគឺជារឿងដ៏សាមញ្ញមួយរបស់អ្នកនិពន្ធក្នុងសញ្ញាចាស់ (សូមមើលក្នុង ៦៩:២,១៥ ៧១:២០ ៨៨:៦ ១៣០:១ បទ ៣:៥៥ យហ ២:២) ។ ល្បាប់ជ្រៅ ជានិច្ចកាលគឺមានទំនាក់ទំនងជាមួយ ("ស្ថានឃុំព្រលឹងមនុស្សស្លាប់"ខ.៣ និង "រណ្ដៅ" ខ.៣) ។ ទាំងស្ថានឃុំព្រលឹងមនុស្សស្លាប់ និងរណ្ដៅគឺជាចង្កោមតែមួយ ដែលមានទំនាក់ទំនងទៅនឹងៈ ភាពស្ងប់ស្ងៀម(មើលក្នុង ៣១:១៧ ៩៤:១៧ ១១៥:១៧ ១សយ ២:៩) សេចក្ដីងងឹត(មើលក្នុង ៨៨:៦,១២ ១៤៣:៣ យប ១០:២១–២២) ១៧:១៣ សស ៦:៤ បទ ៣:៦) កំចាយ (ខ.៩ ១៨:៤ ៥៥:២៣ "ទីហិនវិនាស" ៨៨:១១ អស ៣៨:១៧ ហស ១៣:១៤) ធូលី(ខ.៩ ៧:៥ ២២:១៥,២៩ យប ១៧:១៦ ៤០:១៣ អស ២៦:១៩ ២៩:៤) អន្លង់ (៤០:២ ៦៩:២,១៤) ភក់ស្អិត (៤០:២) និងភក់ (៤០:២ យប ៣០:១៩) ហើយសូមមើលការពន្យល់ក្នុង ៤៩:១៤ ។ *ខ្មាំងសត្រូវមានសេចក្ដីអំណរដោយឈ្នះទូលបង្គំ* សូមមើលសេចក្ដីផ្ដើម ទដ ជំពូក៦ ។

**៣០:៣** *ស្ថានឃុំព្រលឹងមនុស្សស្លាប់* គឺជាការប្រៀបធៀបអំពីការជិតចូលដល់សេចក្ដីស្លាប់ដូចដែលមាននិយាយនៅក្នុង ១៨:៥ យហ ២:២ ។ *រណ្ដៅ* សូមមើលការពន្យល់ក្នុង ២៨:១ ។

**៣០:៤–៥** នៅក្នុងខ.ទាំងនេះគឺជាការហៅ ឬអំពាវនាវឱ្យមនុស្សទាំងអស់ចូលមកលើកសរសើរដំកើងដល់ព្រះយេហូវ៉ា (មើលការពន្យល់ ៩:១) ។

**៣០:៤** *អ្នកបរិសុទ្ធ* សូមមើលការពន្យល់ក្នុង ៤:៣ ។ *ព្រះនាម* តាមភាសាអក្សរសាស្ត្រគឺ "រំឭក" ឬ "ជាទីរំឭកដល់សេចក្ដីបរិសុទ្ធ" (៩៧:១២ ១៣៥:១៣ អស ២៦:៨ ហស ១២:៥) ។ ព្រះគម្ពីរភាសាហេព្រើរបានរំឭកឱ្យចាំពីបទគម្ពីរ នក ៣:១៥ ហើយនិយាយសំដៅលើឈ្មោះមនុស្សទូទៅដែលព្រះយេហូវ៉ាទ្រង់ធ្លាប់ធ្វើការអស្ចារ្យចំពោះពួកគេ ជាពិសេសនៅក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល ។

**៣០:៥** *សេចក្ដីខ្ញាល់* សូមមើលការពន្យល់ក្នុង ២:៥ ។ *នៅតែ១ភ្លែតទេ* សូមមើលក្នុងអស ៥៤: ៧ ។ *នៅជាប់អស់១យប់* តាមភាសាអក្សរសាស្ត្រ គឺ "មកដល់នៅពេលល្ងាចហើយស្នាក់នៅក្នុងផ្ទះសំណាក់" ។ អត្ថន័យនៃឃ្លានេះគឺចង់និយាយអំពីភ្ញៀវ ដែលមកស្នាក់អាស្រ័យក្នុងផ្ទះសំណាក់រយៈពេល១យប់ ។

**៣០:៦–១០** នៅក្នុងខទាំងនេះ គឺជាការពណ៌នាពីការរីកសាយនៃព្រះគុណ និងសេចក្ដីមេត្តាករុណា នៃការជួយរំដោះរបស់ព្រះយេហូវ៉ា ចំពោះប្រជារាស្ត្រទ្រង់។

**៣០:៦–៧** នៅក្នុងគ្រានៃសេចក្ដីចម្រើនរបស់ស្ដេចដាវីឌ ទ្រង់បែរមានសេចក្ដីអំណួតអួតអាង ហើយភ្លេចអ្នកដែលបាន "តាំងភ្នំឱ្យមាំមួនឡើង"ទៅវិញ ប៉ុន្តែឯព្រះយេហូវ៉ាទ្រង់មិនបានភ្លេចពីគាត់នោះឡើយ ។

**៣០:៦** *មិនត្រូវរង្គើរឡើយ* ឃ្លានេះគឺជាការអួតអាងរបស់ស្ដេចដាវីឌ ដែលទ្រង់បានអួតដូចជាពួកមនុស្សអាក្រក់អួតពីថ្ងៃរបស់គេដែរ (សូមមើលក្នុង ១០:៦) ដោយហេតុនោះហើយ បានជាទ្រង់បាត់បង់ព្រះពរ នៃសេចក្ដីសុចរិតដែលព្រះឱ្យមកទ្រង់(សូមមើលក្នុង ១៥:៥) ។

**៣០:៧** *តាំងភ្នំនៃទូលបង្គំឡើងឱ្យមាំមួន* ឃ្លានេះប្រហែល និយាយសំដៅលើសេចក្ដីចម្រើនរបស់ស្ដេចដាវីឌ នៅភ្នំស៊ីយ៉ូន ឬមួយពាក្យនេះគឺជាការប្រៀបធៀបអំពីនគរដ៏រឹងមាំ និងជ័យជម្នះទាំងឡាយរបស់ទ្រង់ហើយ ភ្នំជាទីកន្លែងដែលស្ដេចដាវីឌទ្រង់គង់ប្រថាប់ ដែលទទួលបាននូវសេចក្ដីចម្រើនរុងរឿងនោះ បានធ្វើឱ្យស្ដេចដាវីឌទ្រង់មានទំនុកចិត្តលើព្រះយេហូវ៉ា ។ *លាក់ព្រះភក្ត្រ* សូមមើលការពន្យល់ក្នុង ១៣:១ ។

**៣០:៨–១០** នៅក្នុងខនេះចង់និយាយថា នៅពេលដែលស្ដេចដាវីឌបាត់បង់កំឡាំង និងការជឿជាក់ពីសមត្ថភាពរបស់ខ្លួន ហើយសេចក្ដីស្លាប់បានមកដល់ នោះស្ដេចដាវីឌបានអំពាវនាវសូមឱ្យព្រះយេហូវ៉ាទ្រង់ផ្ដល់សេចក្ដីមេត្តាករុណាមកដល់ទ្រង់ ។

**៣០:៩** សូមមើលការពន្យល់ក្នុង ៦:៥ ។ *សេចក្ដីស្មោះត្រង់របស់ទ្រង់* នៅក្នុងឃ្លានេះចង់និយាយពីសេចក្ដីស្មោះត្រង់ចំពោះសេចក្ដីសញ្ញា ។

តើនឹងនិទានពីសេចក្តីស្មោះត្រង់របស់ទ្រង់ឬទេ[ធ]
[១០]ឱព្រះយេហូវ៉ាអើយ សូមទ្រង់ស្តាប់[ន] ហើយ
ប្រោសមេត្តាដល់ទូលបង្គំ[ប] ឱព្រះយេហូវ៉ាអើយ
សូមទ្រង់ធ្វើជាអ្នកជំនួយដល់ទូលបង្គំផង[ផ]
[១១]នោះទ្រង់បានផ្លាស់ការយំសោក[ព] របស់ទូលបង្គំឱ្យទៅជា
សេចក្តីត្រេកអរទៅវិញ[ភ] ទ្រង់បានផ្លាស់សំពត់សំរាប់កាន់
ទុក្ខ[ម] ចេញ ឱ្យទូលបង្គំបានស្លៀកពាក់សេចក្តីអំណរឡើង[យ]
[១២]ដើម្បីឱ្យចិត្តទូលបង្គំបានច្រៀងសរសើរដល់ទ្រង់ឥតនៅ
ស្ងៀមឡើយ ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ
ទូលបង្គំនឹងអរព្រះគុណ[រ] ដល់ទ្រង់ជាដរាបទៅ[ល] ។

*៣១:១-៤ – ទដ ៧១:១-៣*

ទំនុកនៃស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។
**៣១** ឱព្រះយេហូវ៉ាអើយ ទូលបង្គំពឹងជ្រក[ក] ក្នុងទ្រង់
សូមកុំឱ្យទូលបង្គំត្រូវខ្មាសឡើយ សូមជួយទូលបង្គំឱ្យរួច
ដោយសេចក្តីសុចរិតរបស់ទ្រង់[ខ]
[២]សូមផ្ទៀងព្រះកាណ៌មកស្តាប់ទូលបង្គំ[គ] ហើយជួយឱ្យទូល
បង្គំរួចជាប្រញាប់ សូមទ្រង់ធ្វើជាថ្មដាមាំមួនដល់ទូល
បង្គំ[ឃ] គឺជាបន្ទាយសំរាប់ជួយសង្គ្រោះទូលបង្គំផង[ង]
[៣]ដ្បិតទ្រង់ជាថ្មដា ហើយជាបន្ទាយនៃទូលបង្គំពិត[ច]
ហេតុនោះ សូមទ្រង់នាំ ហើយដំរង់ទូលបង្គំដោយយល់
ដល់ព្រះនាមទ្រង់[ឆ]
[៤]សូមទ្រង់ដោះទូលបង្គំចេញពីអន្ទាក់[ជ] ដែលគេបានដាក់
ដោយលួចលាក់ ដើម្បីនឹងចាប់ទូលបង្គំ
ដ្បិតទ្រង់ជាទីពឹងរបស់ទូលបង្គំហើយ[ឈ]
[៥]ទូលបង្គំប្រគល់ព្រលឹងវិញ្ញាណ[ញ] នៅក្នុងព្រះហស្តទ្រង់
ឱព្រះយេហូវ៉ា ជាព្រះនៃសេចក្តីពិត[ដ]
អើយទ្រង់បានលោះទូលបង្គំទុក

**៣០:៩** ធ ទដ ៦:៥ ៨៨:១១ **៣០:១០** ន ទដ ១៧:១ ប ទដ ៤:១ ផ ទដ ២០:២ **៣០:១១** ព នអ ៤:១ ភ នក ១៥:២០ ម ២សយ ៣:៣១ ទដ ៣៥:១៣ យ ចទ ១៦:១៥ ទដ ១៦:៩ **៣០:១២** រ ទដ ៣៥:១៨ ៧៥:១ ១១៨:២១ វវ ១១:១៧ ល ទដ ៤៤:៨ ៥២:៩ **៣១:១** ក ទដ ៧:១ ខ ទដ ៥:៨ **៣១:២** គ ទដ ៦:៤ ឃ ២សយ ២២:៣ ទដ ១៨:២ ង នក ២:១៧ **៣១:៣** ច ទដ ១៨:២ ឆ ទដ ២៣:៣ **៣១:៤** ជ ១សយ ២៨:៩ យប ១៨:១០ ឈ ទដ ៩:៩ **៣១:៥** ញ លក ២៣:៤៦ កច ៧:៥៩ ដ អស ៤៥:១៩ ៦៥:១៦

**៣០:១១-១២** នៅក្នុងខទាំងនេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់បានឆ្លើយតបចំពោះការអធិស្ឋានរបស់ស្តេចដាវីឌ ហើយស្តេចដាវីឌទ្រង់បានប្តេជ្ញាថានឹងសរសើរតម្កើងដល់ព្រះជារៀងរហូត (មើលការពន្យល់ក្នុង ៧:១៧) ។ ពេលនោះសម្លេងនៃការយំ និងការស្លៀកសំពត់ធ្មៃត្រូវបានជំនួសដោយការលោតរាំនិងអំណរអរសប្បាយ ស្រែកច្រៀងសរសើរដល់ព្រះមិនស្ងប់ស្ងៀមទៀតឡើយ ។
**៣០:១១** *សំពត់ធ្មៃ* សំពត់ធ្មៃមានសណ្ឋានគ្រើមមានពណ៌ខ្មៅ (សូមមើលក្នុង អស ៥០:៣ វវ ១១:៣ និងការពន្យល់) ត្បាញឡើងពីរោមពពែ ហើយប្រើធ្វើជាថង់យាម ។ ការស្លៀកសំពត់ធ្មៃគឺបង្ហាញពីការកាន់ទុក្ខ (សូមមើលក្នុង ៣៥:១៣ ៦៩:១១ និងការពន្យល់ក្នុង លប ៣៧: ៣៤) ។
**៣០:១២** *ចិត្ត* តាមភាសាអក្សរសាស្ត្រគឺ "សិរីល្អ" (សូមមើលការពន្យល់ក្នុង ៧:៥) ។
**ទំនុកដំកើង ៣១** នៅក្នុងជំពូកនេះ ស្តេចដាវីឌទ្រង់បានអធិស្ឋានទូលសូមឱ្យព្រះយេហូវ៉ាជួយរំដោះទ្រង់ ក្នុងគ្រាដែលទ្រង់កំពុងតែប្រឈរមុខចំពោះអំណាចដ៏ឃោរឃៅរបស់ពួកមនុស្សក្បត់ និងក្នុងគ្រាដែលពួកភឿនសំឡាញ់ទ្រង់បានបោះបង់ទ្រង់ចោលចេញ ។ យោងទៅតាមព្រះគម្ពីរ លក ២៣:៤៦ បាននិយាយថា នៅពេលដែលព្រះយេស៊ូវទ្រង់ជាប់ឆ្កាងព្រះអង្គបានមានបន្ទូលដូចនៅក្នុង ទដ ៣១:៥ ។ ដូច្នេះហើយ អស់អ្នកណាដែលរងទុក្ខលំបាកដោយព្រោះព្រះគ្រីស្ទយេស៊ូវ អ្នកនោះត្រូវបានលើកទឹកចិត្តឱ្យស្តាប់និងប្រើព្រះបន្ទូលព្រះអង្គក្នុងទំនុកដំកើងជំពូកនេះ ដើម្បីឱ្យព្រះបន្ទូលព្រះអង្គក្លាយជាពន្លឺថ្មីក្នុងជីវិតគេ (មើល កច ៧:៥៩ ១ពត ៤:១៩) ។ គ្មានទំនុកដំកើងណាទៀត ពណ៌នាពីការទុកចិត្តដល់ព្រះយេហូវ៉ាក្នុងគ្រាជួបការបៀតបៀនពីសំណាក់មនុស្សអាក្រក់នោះឡើយ ។ ចំណុចស្នូលសំខាន់ក្នុងសេចក្តីអធិស្ឋានក្នុងជំពូកនេះគឺមានក្នុង ខ.៩-១៨ ដោយមានកំណាព្យភាសាហេព្រើរចំនួន៩ក្នុងការបំផុសគំនិត ដែលនិយាយពីផ្ទៃរឿងនៃការទុកចិត្តចំពោះព្រះ (មើល ខ.១៤) ។ នៅក្នុង ខ.១៣ ដែលជាចំណុចកណ្តាលនៃទំនុកដំកើងជំពូកនេះ បានប្រាប់យ៉ាងច្បាស់ពីហេតុផលនៃសេចក្តីអធិស្ឋាន ។ ទំនាក់ទំនងបទនៃទំនុកនេះជាមួយ ទដ ជំពូក ២៧ សូមមើលសេចក្តីផ្តើមព្រះគម្ពីរទដជំពូកនេះ ។
**៣១ ត្រង់ចំណងជើង** *លើកសំរាប់មេភ្លេង* សូមមើលការពន្យល់ក្នុង ទដជំពូក ៤ ត្រង់ចំណងជើង ។
**៣១:១-៥** នៅក្នុងខទាំងនេះ គឺជាការអំពាវនាវសូមពឹងជ្រកក្នុងព្រះអង្គដោយសេចក្តីស្មោះត្រង់ ។
**៣១:១** *សេចក្តីសុចរិត* សូមមើលការពន្យល់ក្នុង ៤:១ ។
**៣១:២** *ថ្មដា* សូមមើលការពន្យល់ក្នុង ១៨:២ ។
**៣១:៣** *ដោយយល់ដល់ព្រះនាមទ្រង់* នៅក្នុងឃ្លានេះចង់មានន័យថា ព្រះកិត្តិនាមរបស់ព្រះយេហូវ៉ា គឺអាស្រ័យលើសេចក្តីសុខសាន្តរបស់បាវបម្រើទ្រង់ដែលឥឡូវនេះពួកគេជួបប្រទះនូវការវាយប្រហារវិញ (សូមមើលការពន្យល់ក្នុង ២៣:៣) ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។ *នាំហើយដំរង់* នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យព្រះអង្គធ្វើជាអ្នកគង្វាល (សូមមើលក្នុង ២៣:២-៣ និងការពន្យល់) ។
**៣១:៤** *អន្ទាក់ដែលគេបានដាក់* អន្ទាក់ទាំងនោះគឺពួកខ្មាំងសត្រូវរបស់គាត់ជាអ្នកដាក់ (សូមមើលក្នុង ខ.១១ និងការពន្យល់ក្នុង ៩:១៥) ។
**៣១:៥** *ទូលបង្គំបានប្រគល់ព្រលឹងវិញ្ញាណនៅក្នុងព្រះហស្តទ្រង់* នៅក្នុងឃ្លានេះគឺជាការអះអាងពីការទុកចិត្តចំពោះព្រះ ហើយព្រះយេស៊ូវគ្រីស្ទទ្រង់ក៏បានមានបន្ទូលដូចគ្នានេះនៅក្នុង លក ២៣:៤៦ ដែរ ។ *ប្រគល់* តាមភាសាអក្សរសាស្ត្រពាក្យនេះគឺ "ផ្ញើទុក" (ដូចមាននិយាយនៅក្នុង យរ ៣៦:២០ "ដាក់ទុក") ។ ដោយការរស់នៅក្នុងព្រះហស្តរបស់ព្រះ នោះបានធ្វើឱ្យពួកគេមានទំនុកចិត្តចំពោះការថែរក្សារបស់ព្រះអម្ចាស់ (មើល លវ ៦:៤ ១ពវ ១៤:២៧) ។ *ព្រលឹងវិញ្ញាណ* នៅក្នុងឃ្លានេះ គឺចង់និយាយសំដៅលើជីវិតរស់នៅប្រចាំថ្ងៃរបស់គាត់ ។ *លោះ* មើលការពន្យល់ ២៥:២២ ។ *ព្រះនៃសេចក្តីពិត* គឺចង់និយាយអំពីសេចក្តីស្មោះត្រង់ និងសេចក្តីពិតរបស់ព្រះ

៦ទូលបង្គំស្អប់ចំពោះអស់អ្នកដែលយកចិត្តទុកដាក់នឹង
សេចក្តីភូតភរ[ឋ] ឯទូលបង្គំវិញ បានពឹងដល់ព្រះយេហូវ៉ា[ឌ]
៧ទូលបង្គំនឹងមានចិត្តអំណរ ហើយរីករាយដោយសេចក្តី
សប្បុរសរបស់ទ្រង់ ដ្បិតទ្រង់បានឃើញសេចក្តីវេទនា[ឍ]
របស់ទូលបង្គំហើយ ក៏បានជ្រាបពីសេចក្តីថប់ព្រួយ[ណ]
ក្នុងព្រលឹងទូលបង្គំដែរ
៨ទ្រង់មិនបានឃុំឃាំងទូលបង្គំ នៅក្នុង[ត]កណ្តាប់ដៃនៃពួក
ខ្មាំងសត្រូវទេ គឺទ្រង់បានដាក់ជើងទូលបង្គំ
ឱ្យនៅទីធំទូលាយវិញ[ថ]
៩ឱព្រះយេហូវ៉ាអើយ សូមប្រោសមេត្តាចំពោះទូលបង្គំ
ដ្បិតទូលបង្គំមានសេចក្តីទុកលំបាក[ទ]
ភ្នែកទូលបង្គំកាន់តែខ្សោយទៅដោយសេចក្តីសោយ
សោក[ធ] ព្រមទាំងចិត្តនិងខ្លួនប្រាណ[ន]នៃទូលបង្គំផង
១០ដ្បិតជីវិតទូលបង្គំនឹងផុតទៅ ដោយសេចក្តីទុក្ខព្រួយ[ប]
ហើយអស់ទាំងឆ្នាំនៃអាយុទូលបង្គំ ដោយដំងូរផង[ផ]
កំឡាំងនៃទូលបង្គំចេះតែខ្សោយទៅ[ព]ដោយព្រោះសេចក្តី
ទុច្ចរិតនៃទូលបង្គំ[ភ]
ហើយអស់ទាំងឆ្អឹងទូលបង្គំក៏ខ្សោះទៅដែរ[ម]
១១ទូលបង្គំបានត្រឡប់ជាទីដៀលត្មះដោយព្រោះពួកតតាំង[យ]
នឹងទូលបង្គំ អើ ដល់ទាំងពួកអ្នកជិតខាង[រ]នៃទូលបង្គំជា
ខ្លាំង[ល] ហើយជាសេចក្តីគួរខ្លាចដល់ពួកដែលធ្លាប់ស្គាល់
ទូលបង្គំផង ពួកអ្នកដែលបានឃើញ
ទូលបង្គំនៅខាងក្រៅនោះក៏រត់ចេញពីមុខទូលបង្គំទៅ
១២មនុស្សបានភ្លេចទូលបង្គំបង់ ដូចជាគេលែងនឹកពីមនុស្ស
ណាដែលស្លាប់បាត់ហើយ[វ]
ទូលបង្គំក៏ដូចជាឆ្នាំងដែលបែកធ្លាយដែរ
១៣ដ្បិតទូលបង្គំបានឮពាក្យបង្កាច់[ស]របស់មនុស្សជាច្រើន
មានសេចក្តីស្ញែងខ្លាចនៅគ្រប់ជុំវិញ[ហ]
ហើយកំពុងដែលគេពិគ្រោះគ្នាទាស់នឹងទូលបង្គំ[ឡ]
នោះក៏បង្កើតកិច្ចកលនឹងដកជីវិតទូលបង្គំចេញ[អ]
១៤តែ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានទុកចិត្ត[ក]ដល់ទ្រង់
ទូលបង្គំបានថា ទ្រង់ជាព្រះនៃទូលបង្គំ
១៥ឯថ្ងៃអាយុ[ខ]របស់ទូលបង្គំ សុទ្ធតែនៅក្នុងព្រះហស្តទ្រង់
សូមជួយទូលបង្គំ ឱ្យរួចពីកណ្តាប់ដៃនៃពួកសត្រូវរបស់
ទូលបង្គំ ហើយពីអស់អ្នកដែលបៀតបៀនដល់ទូលបង្គំដែរ
១៦សូមឱ្យព្រះភក្ត្រទ្រង់ភ្លឺ[គ]មកលើអ្នកបំរើទ្រង់
សូមជួយសង្គ្រោះទូលបង្គំ ដោយសេចក្តីសប្បុរសនៃទ្រង់[ឃ]
១៧ឱព្រះយេហូវ៉ាអើយ សូមកុំឱ្យទូលបង្គំត្រូវខ្មាសឡើយ[ង]
ដ្បិតទូលបង្គំបានអំពាវនាវដល់ទ្រង់

**៣១:៦** ឋ ចទ ៣២:២១ ឌ ទដ ៤:៥ **៣១:៧** ឍ ទដ ១៣:៣ ណ ទដ ២៥:១៧ លក ២២:៤៤ **៣១:៨** ត ចទ ៣២:៣០ ថ ២សយ ២២:២០ **៣១:៩** ទ ទដ ៤:១ ធ ទដ ៦:៧ ន ទដ ៦៣:១ **៣១:១០** ប ខ.៧ ផ ទដ ៦:៦ ព ទដ ២២:១៥ ៣២:៤ ៣៨:១០ ៧៣:២៦ ភ ទដ ២៥:១៨ ម ទដ ៦:២ **៣១:១១** យ ចទ ៣០:៧ ទដ ៣:៧ ២៥:១៩ ១០២:៨ រ ទដ ២២:៦ ល ទដ ៣៨:១១ **៣១:១២** វ ទដ ២៨:១ ៨៨:៤ **៣១:១៣** ស លវ ១៩:១៦ ទដ ៥០:២០ ហ យប ១៨:១១ អស ១៣:៨ យរ ៦:២៥ ២០:៣,១០ ៤៦:៥ ៤៩:៥ បទ ២:២២ ឡ ទដ ៤១:៧ ៥៦:៦ ៧១:១០ ៨៣:៣ អ លប ៣៧:១៨ មថ ១២:១៤ **៣១:១៤** ក ទដ ៤:៥ **៣១:១៥** ខ យប ១៤:៥ **៣១:១៦** គ ជន ៦:២៥ ឃ ទដ ៦:៤ **៣១:១៧** ង ទដ ២២:៥

យេហូវ៉ានៃពួកពលបរិវារ (មើលការពន្យល់ ៣០:៩) ។

**៣១:៦–៨** នៅក្នុងខ.ទាំងនេះ គឺជាការពណ៌នាពីការទុកចិត្តចំពោះព្រះយេហូវ៉ា ដែលព្រះអង្គទ្រង់បានធ្លាប់ផ្តល់សេចក្តីមេត្តាករុណាចំពោះស្តេចដាវីឌ ក្នុងគ្រាដែលពួកខ្មាំងសត្រូវធ្វើទុក្ខបៀតបៀនដល់ទ្រង់ ។

**៣១:៦** *ស្អប់* ពាក្យនេះចង់និយាយថា គាត់បដិសេធមិនចូលរួមជាមួយពួកមនុស្សអាក្រក់ ។ *អស់អ្នកដែលយកចិត្តទុកដាក់នឹងសេចក្តីភូតភរ* សូមមើលក្នុងយហ ២:៨ ។ *យកចិត្តទុកដាក់* តាមភាសាសាស្ត្រគឺ "ចាំយាម" (រងចាំការជិនួយ សូមមើលក្នុង ៥៩:៩ និងការពន្យល់) ។

**៣១:៧** *សេចក្តីសប្បុរស* សូមមើលក្នុង ខ.១៦,២១ និងការពន្យល់ ៦:៤ ។ *ព្រលឹង* សូមមើលការពន្យល់ក្នុង ៦:៣ ។

**៣១:៨** *ទីធំទូលាយ* សូមមើលការពន្យល់ក្នុង ១៨:១៩ ។

**៣១:៩–១៣** នៅក្នុងខ.ទាំងនេះ គឺជាការពណ៌នាពីសេចក្តីវេទនាទាំងឡាយរបស់អ្នកនិពន្ធ ហើយគាត់បានបន្លឺសម្លេងឡើងអធិស្ឋានពណ៌នាពីសណ្ឋានរូបកាយរបស់គាត់ (សូមមើលក្នុង ខ.៩–១០ និង ២២:១៤–១៥) ។ ពួកភឿនមិត្តសម្លាញ់ទាំងអស់របស់គាត់ បានបោះបង់ចោលគាត់បាក់បែកគ្នាប្រៀបបាក់បែកគ្នាប្រៀបដូចជាអំបែងបែកបាក់ដែរ (សូមមើលក្នុង ខ.១១–១២) ។ ការទាំងអស់នេះគឺដោយព្រោះតែពួកខ្មាំងសត្រូវនិងអ្នកក្បត់គាត់ បានទាស់ប្រឆាំងនិងវាយប្រហារគាត់យ៉ាងខ្លាំង (ខ.១៣) ។

**៣១:៩** *ភ្នែកទូលបង្គំកាន់តែខ្សោយទៅ* សូមមើលការពន្យល់ ១៣:៣ ។ *ព្រលឹង* សូមមើលការពន្យល់ក្នុង ៦:៣ ។

**៣១:១០** *ឆ្អឹង* សូមមើលការពន្យល់ក្នុង ៦:២ ។

**៣១:១១–១២** នៅក្នុងខ.ទាំងនេះចង់និយាយថា ការដែលភឿនមិត្តបោះបង់អ្នកណាម្នាក់ចោល នោះគឺជាបទពិសោធន៍សាមញ្ញាមួយទៅហើយនៅពេលដែលព្រះយេហូវ៉ាទ្រង់ហាក់បីដូចជាបោះបង់ចោល ឬដកក្តីស្រឡាញ់ចេញពីអ្នកនោះ (៣៨:១១ ៤១:៩ ៦៩:៨ ៨៨:៨,១៨ យប ១៩:១៣–១៩ យរ ១២:៦ ១៥:១៧) ។

**៣១:១៣** *ពាក្យបង្កាច់* សូមមើលការពន្យល់ ៥:៩ ។ *មានសេចក្តីស្ញែងខ្លាចនៅគ្រប់ជុំវិញ* សូមមើលការពន្យល់ក្នុង យរ ៦:២៥ ២០:៣ ។

**៣១:១៤–១៨** នៅក្នុងខទាំងនេះ ចង់និយាយអំពីទំនុកចិត្តជារៀងរហូតរបស់ស្តេចដាវីឌនៅចំពោះព្រះ ។ ស្តេចដាវីឌទ្រង់មានសង្ឃឹមលើសេចក្តីស្មោះត្រង់របស់ព្រះយេហូវ៉ាថា ព្រះអង្គនឹងជួយឱ្យការពារគាត់ពីការវាយប្រហាររបស់ពួកខ្មាំងសត្រូវ ហើយសូមឱ្យព្រះទ្រង់វិនិច្ឆ័យដោយយុត្តិធម៌ ។

**៣១:១៤** សូមធៀបជាមួយ ខ.២២ ។

**៣១:១៥** *ឯថ្ងៃអាយុរបស់ទូលបង្គំ សុទ្ធតែនៅក្នុងព្រះហស្តទ្រង់* នៅក្នុងឃ្លានេះចង់និយាយថា គ្រប់ទាំងហេតុការណ៍និងការលះទេសៈនៃជីវិត គឺស្ថិតក្នុងព្រះហស្តនៃព្រះយេហូវ៉ាជា "ព្រះនៃទូលបង្គំ" (សូមមើលក្នុង ខ.១៤) ។

**៣១:១៦** *ព្រះភក្ត្រទ្រង់ភ្លឺ* សូមមើលការពន្យល់ក្នុង ១៣:១ ។

**៣១:១៧–១៨** *សូមឱ្យពួកមនុស្សអាក្រក់...សូមឱ្យគេស្ងៀម* សូមមើលការ

សូមឱ្យពួកមនុស្សអាក្រក់មានសេចក្ដីខ្មាសវិញ
សូមឱ្យគេស្ងៀម[ច] នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់
១៨ សូមឱ្យបបូរមាត់[ឆ]កំភូតបានទៅជាគ គឺបបូរមាត់ដែល
ពោលទាស់នឹងមនុស្សសុចរិតដោយឆ្មើងឆ្មៃ ចិត្តធំ[ជ] និង
សេចក្ដីមើលងាយ
១៩ ឱសេចក្ដីសប្បុរស[ឈ]នៃទ្រង់ជាធំអម្បាលណាទៅដែល
ទ្រង់បានត្រៀមទុកសំរាប់អស់អ្នកដែលកោតខ្លាចដល់
ទ្រង់[ញ] ជាសេចក្ដីដែលទ្រង់បានបង្កើតនៅមុខមនុស្សលោក
សំរាប់អស់អ្នកដែលពឹងជ្រក[ដ]ក្នុងទ្រង់
២០ ទ្រង់នឹងលាក់[ឋ] គេទុកនៅទីកំបាំង[ឌ]ចំពោះទ្រង់ឱ្យបានរួច
ពីឧបាយរបស់មនុស្ស[ឍ] ទ្រង់នឹងថែរក្សាគេ ដោយសំងាត់
នៅក្នុងពន្លាទ្រង់ ឱ្យរួចពីសេចក្ដីទាស់ទែងនៃអណ្ដាត
ទាំងឡាយ
២១ សូមលើកសរសើរដល់ព្រះយេហូវ៉ា[ណ]
ដ្បិតទ្រង់បានសំដែងសេចក្ដីសប្បុរស[ត]ដ៏អស្ចារ្យរបស់
ទ្រង់ដល់ទូលបង្គំ នៅក្នុងទីក្រុងមាំមួន[ថ]
២២ ឯទូលបង្គំ បាននិយាយដោយប្រញាប់ពេក[ទ]ថា
ទូលបង្គំត្រូវកាត់ចេញ[ធ]ពីចំពោះព្រះនេត្រទ្រង់ហើយ
ប៉ុន្តែទ្រង់បានឮសំឡេងដែលទូលបង្គំទូលអង្វរ[ន]ក្នុងកាល
ដែលអំពាវនាវដល់ទ្រង់
២៣ ឱអស់អ្នកបរិសុទ្ធរបស់ទ្រង់អើយ[ប]
ចូរស្រឡាញ់ដល់ព្រះយេហូវ៉ាចុះ
ព្រះយេហូវ៉ាទ្រង់ការពារមនុស្សស្មោះត្រង់[ផ]
ហើយក៏សង[ព]ដល់មនុស្សឆ្មើងឆ្មៃជាបរិបូរ
២៤ ឱអស់អ្នកដែលសង្ឃឹមដល់ព្រះយេហូវ៉ាអើយ
ចូរមានកំឡាំងឡើង[ភ]
ហើយឱ្យចិត្តអ្នករាល់គ្នាបានក្លាហានចុះ ។

**៣១:១៧** ច ១សយ ២:៩ ទដ ៩៤:១៧ ១១៥:១៧
**៣១:១៨** ឆ ទដ ១២០:២ សភ ១០:១៨ ២៦:២៤ ជ ១សយ ២:៣ យដ ១:១៥
**៣១:១៩** ឈ ទដ ២៧:១៣ រម ១១:២២ ញ ទដ ២៣:៥ ដ ទដ ២:១២
**៣១:២០** ឋ ទដ ១៧:៨ ឌ ទដ ៥៥:៨ ឍ លប ៣៧:១៨
**៣១:២១** ណ ទដ ២៨:៦ ត ទដ ១៧:៧ ថ ១សយ ២៣:៧
**៣១:២២** ទ ទដ ១១៦:១១ ធ យប ៦:៩ ១៧:១

ទំនុកនៃស្ដេចដាវីឌ ជាសេចក្ដីបង្រៀន ។
**៣២** មានពរហើយ មនុស្សណាដែលការរំលងច្បាប់
របស់ខ្លួនបានអត់ទោសឱ្យ គឺដែលបាបរបស់ខ្លួនបានគ្រប

ទដ ៣៧:៩ ៨៨:៥ អស ៣៨:១២ ន ទដ ៦:៩ ៦៦:១៩ ១១៦:១ ១៤៥:១៩
**៣១:២៣** ប ទដ ៤:៣ ផ ទដ ១៨:២៥ វវ ២:១០ ព ចទ ៣២:៤១ ទដ ៩៤:២
**៣១:២៤** ភ ទដ ២៧:១៤

ពន្យល់ក្នុង ៥:១០ ។
**៣១:១៨** *បបូរមាត់កំភូត* សូមមើលការពន្យល់ក្នុង ៥:៩ ។ *មនុស្សសុចរិត* សូមមើលការពន្យល់ក្នុង ១:៥ ។
**៣១:១៩–២០** នៅក្នុងខនេះ គឺពណ៌នាពីសេចក្ដីសង្ឃឹមទុកជាមុនរបស់ស្ដេចដាវីឌលើការសង្គ្រោះរបស់ព្រះអង្គ (សូមមើលការពន្យល់ក្នុង ៣:៨) ។
**៣១:១៩** *ត្រៀមទុក* នៅក្នុងឃ្លានេះចង់និយាយថា ស្ដេចដាវីឌទ្រង់បានប្រគល់ជីវិតរបស់ទ្រង់ទៅក្នុងព្រះហស្តនៃព្រះយេហូវ៉ា ដើម្បីរួមចំណែកទទួលយកនូវផលកម្រៃដែលព្រះអម្ចាស់បានត្រៀមទុក សម្រាប់អ្នកបម្រើដ៏ស្មោះត្រង់របស់ទ្រង់នូវ("សេចក្ដីសប្បុរស"សូមមើលក្នុង ២៧:១៣ នក ១៨:៩ ជន ១០:២៩,៣២ ចទ ២៦:១១ យស ២១:៤៥ ២៣:១៤–១៥ ២របា ៦:៤១ នហ ៩:២៥,៣៥ អស ៦៣:៧ យរ ៣៣:៩ និង យរ ៣១:១២,១៤ "សេចក្ដីសប្បុរស") ។ *កោតខ្លាច* សូមមើលការពន្យល់ក្នុង ១៥:៤ ។ *នៅចំពោះមុខមនុស្សលោក* ធ្វើដូច្នេះគឺបង្ហាញពីការយល់ព្រមរបស់ព្រះអម្ចាស់និងការគង់ប្រថាប់របស់ទ្រង់ជាមួយពួកអ្នកបម្រើដ៏ស្មោះត្រង់របស់ទ្រង់ ផ្ទុយពីការចោទប្រកាន់របស់ពួកមនុស្សអាក្រក់ចំពោះពួកគេ (សូមមើល ៨៦:១៧) ។
**៣១:២០** *លាក់គេទុកនៅទីកំបាំងចំពោះទ្រង់* សូមមើលការពន្យល់ក្នុង ២៧:៥ ។ *សេចក្ដីទាស់ទែងនៃអណ្ដាតទាំងឡាយ* សូមមើលពាក្យថា "ពាក្យបង្កាច់"(ខ.១៣) និងពាក្យ "បបូរមាត់កំភូត"(ខ.១៨) ។
**៣១:២១–២២** នៅក្នុងខទាំងនេះ គឺស្ដេចដាវីឌអធិស្ឋានសូមឱ្យព្រះយេហូវ៉ាទ្រង់ជួយរំដោះគាត់ឱ្យរួចពីពួកខ្មាំងសត្រូវ (មើលការពន្យល់ ១២:៥–៦) ។
**៣១:២១** *ក្នុងទីក្រុងមាំមួន* នេះគឺជាពាក្យប្រៀបប្រដូច១ដែលគាត់ចង់និយាយសំដៅលើការដែលគាត់ធ្លាប់ជួបការបៀតបៀន ។
**៣១:២២** *កាត់ចេញពីចំពោះព្រះនេត្រទ្រង់* សូមមើលការពន្យល់ ១៣:១ ។
**៣១:២៣–២៤** នៅក្នុងខនេះគឺជាការសរសើរតម្កើង និងលើកទឹកចិត្តដល់ពួកបរិសុទ្ធទាំងឡាយឱ្យមកសរសើរតម្កើងចំពោះព្រះយេហូវ៉ា (សូមមើលក្នុង ៦២:៨) ។
**៣១:២៣** *អស់ពួកបរិសុទ្ធ* សូមមើលការពន្យល់ក្នុង ៤:៣ ។*មនុស្សស្មោះត្រង់* ពួកអ្នកស្មោះត្រង់ទាំងនោះគឺជាក្រុមមនុស្សដែលប្រព្រឹត្តិការស្របច្បាប់ ។ *មនុស្សឆ្មើងឆ្មៃ* ពួកអ្នកទាំងនោះគឺជាក្រុមមនុស្សដែលបដិសេធមិនព្រមរស់នៅដោយការបន្ទាបខ្លួន និងពឹងលើព្រះអង្គឡើយ ។ ការអាក្រក់របស់អ្នកទាំងនោះគឺពួកគេព្យាយាមបង្កើតផ្លូវ ឬមធ្យោបាយផ្សេងៗដែលមាននៅក្នុងលោកិយនេះ ទោះដោយយកចេញពីច្បាប់ឬខ្លួនគេក្ដី (សូមមើលក្នុង ខ.១៨ ១០:២–១១ ៧៣:៦ ៩៤:២–៧ ចទ ៨:១៤ អស ២:១៧ អគ ២៨:២,៥ ហស ១៣:៦) ឬដោយការពឹងលើរូបព្រះ (សូមមើល យរ ១៣:៩–១០) ។ ការនិយាយអំពី "មនុស្សឆ្មើងឆ្មៃ" ជានិច្ចកាលគឺមានន័យដូចគ្នានឹងពាក្យថា "មនុស្សអាក្រក់" ។
**ទំនុកដំកើង ៣២** នៅក្នុងជំពូកនេះពណ៌នាពីទីបន្ទាល់ដ៏អស្ចារ្យមួយនៃសេចក្ដីអំណរ ចំពោះអំណោយទាននៃការអត់ទោសរបស់ព្រះអង្គ ដែលទ្រង់បានអត់ទោសចំពោះពួកមនុស្សសុចរិតណា ដែលលន់តួអំពើបាបរបស់គេ និងជាអ្នកអនុញ្ញាត្តិឱ្យព្រះដឹកនាំក្នុងជីវិតរបស់គេ ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះបានបង្ហាញពីការអធិស្ឋានបែបសន្ទនារវាងស្ដេចដាវីឌ និងព្រះយេហូវ៉ានៃពួកពលបរិវារនៅចំពោះមុខមនុស្សទាំងអស់ ដែលបានចូលរួមថ្វាយបង្គំព្រះអង្គក្នុងទីបរិសុទ្ធនៃព្រះ ។ នៅក្នុង ខ.១–២ ហើយនិង ខ.១១ ស្ដេចដាវីឌទ្រង់បានមានព្រះបន្ទូលទៅកាន់ពួកជំនុំទាំងមូល ហើយនៅក្នុង ខ.៣–៧ ស្ដេចដាវីឌទ្រង់បានមានបន្ទូលទៅកាន់ព្រះយេហូវ៉ា (តាមការឮរបស់ពួកគេ) ហើយមិនតែប៉ុណ្ណោះសោតនៅក្នុង ខ.៨–១០ មានសង្ឃរបស់ព្រះអម្ចាស់ម្នាក់ បានថ្លែងទៅកាន់ស្ដេចដាវីឌ(ប៉ុន្តែសូមមើលការពន្យល់ក្នុង ខ.៨–១០) ។ តាមទំនៀមទម្លាប់របស់គ្រីស្ទបរិស័ទ ដែលមាន

បាំងហើយ[ក]
២មានពរហើយ មនុស្សណាដែលព្រះយេហូវ៉ាមិនរាប់ថា
ជាអ្នកមានទោស[ខ] ជាអ្នកដែលគ្មានកលឧបាយនៅក្នុងចិត្ត
សោះ[គ]
៣កាលទូលបង្គំបានស្ងៀមនៅ[ឃ] នោះឆ្អឹងទូលបង្គំបានខ្សោះ
ទៅ[ង] ដោយសារដំងូរដែលទូលបង្គំថ្ងូរ[ច]ជាដរាបរាល់ថ្ងៃ
៤ដ្បិតព្រះហស្តនៃទ្រង់បានសង្កត់លើទូលបង្គំជាធ្ងន់[ឆ]ទាំង
យប់ទាំងថ្ងៃ ធាតុទឹករបស់ទូលបង្គំបានត្រឡប់ទៅជារីង
ហួត[ជ]ដូចនៅរដូវក្តៅ ។
៥ទូលបង្គំបានរ៉ាប់ទទួលអំពើបាបរបស់ទូលបង្គំនៅចំពោះ
ទ្រង់ ឥតលាក់ការទុច្ចរិតរបស់ទូលបង្គំទុកឡើយ[ឈ]
ទូលបង្គំបាននិយាយថា ទូលបង្គំនឹងលន់តួ[ញ]អស់ទាំងការ
រំលង[ដ]របស់ទូលបង្គំដល់ព្រះយេហូវ៉ា
ឯទ្រង់ក៏បានអត់ទោសចំពោះអំពើបាប[ឋ]នៃទូលបង្គំទៅ ។
–បង្អង់
៦ដូច្នេះ ត្រូវឱ្យអស់អ្នកដែលកោតខ្លាចដល់ព្រះ
បានអធិស្ឋានដល់ទ្រង់ នៅវេលាដែលនឹងរកទ្រង់ឃើញ
យ៉ាងនោះ[ឌ] កាលណាជំនន់[ឍ]ធំជន់ឡើង[ណ] នោះប្រាកដ
ជានឹងមិនដែល លិចមកដល់អ្នកនោះឡើយ[ត]
៧ទ្រង់ជាទីពំនួន[ថ]នៃទូលបង្គំ
ទ្រង់នឹងការពារទូលបង្គំឱ្យរួចពីសេចក្តីទុក្ខលំបាក[ទ]
ទ្រង់នឹងព័ទ្ធទូលបង្គំជុំវិញដោយទំនុកនៃសេចក្តីសង្គ្រោះ[ធ] ។
–បង្អង់
៨អញនឹងបង្ហាត់បង្រៀន[ន]ឱ្យឯងស្គាល់ផ្លូវដែលឯងត្រូវដើរ

**៣២:១** ក ទដ ៨៥:២ ១០៣:៣ **៣២:២** ខ រម ៤:៧–៨ គ យប ១:៤៧ វវ ១៤:៥ **៣២:៣** ឃ យប ៣១:៣៤ ង ទដ ៣១:១០ ច យប ៣:២៤ ទដ ៦:៦ **៣២:៤** ឆ ១សយ ៥:៦ យប ៩:៣៤ ទដ ៣៨:២ ៣៩:១០ ជ ទដ ២២:១៥ **៣២:៥** ឈ យប ៣១:៣៣ ញ សភ ២៨:១៣ **៣២:៥** ដ ទដ ១០៣:១២ ឋ លវ ២៦:៤០ ១យហ ១:៩ **៣២:៦** ឌ ទដ ៦៩:១៣ អស ៥៥:៦ ឍ នក ១៥:១០ ណ ទដ ៦៩:១ ត អស ៤៣:២ **៣២:៧** ថ ពច ៩:៣៥ ទ ទដ ៩:៩ ធ ពច ៥:១ **៣២:៨** ន ទដ ២៥:៨

ការនិយមប្រើប្រាស់ព្រះគម្ពីរទំនុកដំកើង គេបានចាត់ទុកជំពូកនេះជាច្បាប់ដ៏ល្អមួយក្នុងចំណោម ច្បាប់ផ្សេងៗទៀតដែលមាននៅក្នុងព្រះគម្ពីរទំនុកដំកើងទាំងអស់ (មើលសេចក្តីផ្តើម ជំពូក ៦) ។ ទំនាក់ទំនងរបស់ព្រះគម្ពីរទំនុកដំកើងជំពូកនេះ ជាមួយក្រុមនៃទំនុកដំកើង ២៥–៣៣ បានបង្ហាញថា អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់មានចេតនា យកជំពូកនេះជំនួសឱ្យជំពូក ២៦ (សូមមើលសេចក្តីផ្តើមជំពូកនោះ) ។

**ទំនុកដំកើង៣២ត្រង់ចំណងជើង** *សេចក្តីបង្រៀន* ពាក្យនេះក៏មាននិយាយនៅក្នុងចំណងជើង ទដ ៤២,៤៤–៤៥ ៥២–៥៥ ៧៨ ៨៨–៨៩ ១៤២ ដែរ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ ការប្រើពាក្យនេះ ប្រហែលជាចង់និយាយថាផ្ទៃរឿងនៃព្រះគម្ពីរទំនុកដំកើងទាំងនោះ ចង់បង្រៀនពីភាពបរិសុទ្ធរបស់ព្រះ (សូមមើល ១៤:២ ៤១:១ "អ្នកណាដែលមានអធ្យាស្រ័យ" ៥៣:២ "មានអ្នកណាខ្លះដែលមានគំនិត" ប៉ុន្តែសូមមើលក្នុង ៤៧:៧ និងការពន្យល់) ។

**៣២:១–២** នៅក្នុងខទាំងនេះ គឺចង់និយាយអំពីសេចក្តីអំណរដ៏ពន់ពេករបស់ពួកអ្នកដែលព្រះយេហូវ៉ាបានអត់ទោឱ្យ ។ *មានពរហើយ . . . មានពរហើយ* មើលការពន្យល់ ទដ ១:១ ។ ឃ្លានេះគឺជាការស្រង់ឡើងវិញពីជំពូក ១:១ ។ *បានអត់ទោសឱ្យ . . . បានគ្របបាំង . . . ជាអ្នកដែលព្រះយេហូវ៉ាមិនរាប់ថា ជាអ្នកមានទោស* ឃ្លានេះជាការនិយាយឡើងវិញពីជំពូក១ដែរដោយមានបម្រែបម្រួលខ្លះ ។ លោកប៉ុលក៏បានប្រើឃ្លានេះដែរ សូមមើល រម ៤:៦–៨) ។

**៣២:២** *គ្មានកលឧបាយក្នុងចិត្ត* សេចក្តីសុចរិតរបស់ពួកគេបានមកដោយការអត់ទោសរបស់ព្រះប៉ុណ្ណោះ ។

**៣២:៣–៥** នៅក្នុងខនេះ គឺចង់និយាយពីទីបន្ទាល់នៃបទពិសោធន៏ផ្ទាល់ខ្លួនអំពីការអត់ទោសរបស់ព្រះយេហូវ៉ា ។ ព្រះហស្តនៃព្រះបានដាក់សង្កត់"ទាំងយប់ទាំងថ្ងៃ"មកលើអ្នកណាដែលមានចិត្តរឹងចចេស ហើយព្យាយាមលាក់កំបាំងអំពើបាបដែលខ្លួនប្រព្រឹត្តិ ឱ្យមានពេញដោយការស្រែកថ្ងូរ ប៉ុន្តែ ពួកអ្នកដែលលន់តួអំពើបាប ដែលខ្លួនប្រព្រឹត្តិនោះព្រះអម្ចាស់ទ្រង់នឹងប្រទានពរដល់ពួកគេឱ្យបានសម្រាកជាបរិបូរណ៍ ។

**៣២:៤** *ធាតុទឹករបស់ទូលបង្គំបានរីងស្ងួត* នៅក្នុងឃ្លានេះចង់និយាយថា នៅពេលដែលព្រះយេហូវ៉ា ទ្រង់បានដាក់ព្រះហស្តសង្កត់មកលើគាត់បានធ្វើឱ្យជីវិតរបស់គាត់ឈឺចាប់ដូចជារុក្ខជាតិក្រៀមស្វិតក្នុងរដូវក្តៅដែរ ។

**៣២:៥** ឃ្លានេះនឹងបាននិយាយម្តងទៀត (មើលការពន្យល់ ខ.១–២) ។ *អំពើបាប . . . ការទុច្ចរិត . . . អំពើបាប* មើល ៥១:១–២ ។ នេះគឺជាពាក្យទាំង៣ ដែលនៅក្នុងសញ្ញាចាស់គេប្រើសំដៅលើគំនិតគិត និងការប្រព្រឹត្តិរបស់ពួកមនុស្សអាក្រក់(មើល អស ៥៩:១២)។ *លន់តួ* មើល ទដ ជំពូក ៥១ ២សយ ១២:១៣ ។

**៣២:៦** នៅក្នុងខនេះចង់និយាយថា ទោះបីជាពួកគេអធិស្ឋានលន់តួទៅចំពោះព្រះអម្ចាស់ក៏ដោយ ។ *អស់អ្នកដែលកោតខ្លាចដល់ព្រះ* មើលការពន្យល់ ៤:៣ ។ *ជំនន់ធំ* ពាក្យនេះគឺចង់និយាយសំដៅលើអំណាចនៃការវាយប្រហាររបស់ពួកខ្មាំងសត្រូវ ឬព្រឹត្តិការណ៍អាក្រក់ទាំងឡាយនៃជីវិតរបស់ទ្រង់ ។ ពាក្យប្រៀបនេះ និងពាក្យប្រៀបផ្សេងៗទៀត ដែលមាននិយាយនៅក្នុងព្រះគម្ពីរទំនុកដំកើង គឺបានយកគំនិតតាមរឿងព្រេងនៃការបង្កើតរបស់អ្នកដែលរស់នៅតំបន់មជ្ឈឹមបូព៌ាកាលពីសម័យបុរាណ ។ ទឹកជំនន់ដ៏ធំទាំងនោះ (ភាគច្រើននៃការរងទុក្ខដោយការវាយប្រហារ និងការបំផ្លាញជាញឹកញាប់ គឺប្រៀបធៀបទៅនឹងសត្វចម្លែកនៅក្នុងទឹក មើល ៧៤:១៣–១៤ និងការពន្យល់) ត្រូវបានបង្ក្រាប ដោយព្រះអទិករមុន (រូបព្រះ) ពេលដែលទ្រង់បង្កើតលោកិយឡើង ឬមុនពេលដែលទ្រង់គ្រប់គ្រងពិភពលោកជាស្តេចនៅលើផែនដី ។ ទោះបីជាគំនិតក្នុងរឿងព្រេងនោះ ទឹកជំនន់ធំត្រូវបានបង្ក្រាបនៅពេលដែលព្រះបង្កើតលោកិយនេះឡើងក៏ដោយ ។

**៣២:៧** *ទ្រង់នឹងព័ទ្ធទូលបង្គំជុំវិញដោយទំនុកនៃសេចក្តីសង្គ្រោះ* នៅក្នុងឃ្លានេះចង់និយាយថា ដោយសារមានសេចក្តីជំនួយមកពីទ្រង់ នោះមនុស្សទាំអស់ដែលចូលរួមសរសើរតម្កើង ចំពោះសេចក្តីសង្គ្រោះរបស់ព្រះគេនឹងព័ទ្ធទូលបង្គំជុំវិញ ដូច្នេះហើយទូលបង្គំនឹងពោលពាក្យអរព្រះគុណចំពោះទ្រង់ (មើលការពន្យល់ ៧:១៧ ៩:១ និង ៣៥:២៧ ៥១:៨) ។

**៣២:៨–១០** នៅក្នុងខទាំងនេះ គឺពណ៌នាពីសេចក្តីបង្រៀនរបស់ពួកសង្ឃដល់ស្តេចដាវីឌ (កុំឱ្យមានសេចក្តីល្ងង់ល្ងើនៅចំពោះអញទៀតឡើយ) ឬចំពោះអ្នកដែលទើបនឹងទុកចិត្តចំពោះព្រះអម្ចាស់ (ទាំងការទុកចិត្ត និងការ

អញនឹងទូន្មាន[ប]ឯង ដោយភ្នែកអញមើល[ផ]ឯងជាប់
៩ កុំឱ្យឯងធ្វើដូចជាសេះ ឬលាកាត់ ដែលគ្មានប្រាជ្ញា
ដែលគេត្រូវដាក់បង្ហៀរ ហើយនិងបង្ហៀរ[ព]
ដើម្បីទប់វាក្រែងវាមិនព្រមមកឯងនោះឡើយ
១០ ឯមនុស្សអាក្រក់[ភ] គេនឹងមានទុក្ខព្រួយជាច្រើនតែអ្នកណា
ដែលទុកចិត្ត[ម]នឹងព្រះយេហូវ៉ា
នោះនឹងមានសេចក្តីសប្បុរសនៅព័ទ្ធជុំវិញខ្លួន
១១ ឱមនុស្សសុចរិតរាល់គ្នាអើយ ចូរមានចិត្តសប្បាយ
ហើយរីករាយឡើងក្នុងព្រះយេហូវ៉ា[យ]ចុះ
អស់អ្នកដែលមានចិត្តទៀងត្រង់អើយ
ចូរនាំគ្នាស្រែកឡើងដោយអំណរចុះ ។

**៣២:៨** ប ទដ ៣៤:១១ ផ ទដ ៣៣:១៨ **៣២:៩** ព យប ៣០:១១ ៣៩:១០ យក ៣:៣ **៣២:១០** ភ រម ២:៩ ម ទដ ៤:៥ សភ ១៦:២០ **៣២:១១** យ ទដ ៥:១១
**៣៣:១** ក ទដ ៥:១១ ១០១:១ ខ ទដ ១៤៧:១ គ ទដ ១១:៧

**៣៣** ឱពួកអ្នកសុចរិតអើយ ចូរមានចិត្តរីករាយ[ក]ក្នុង
ព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសរសើរ
នោះសំណំ[ខ]ដល់មនុស្សទៀតត្រង់[គ]
២ ចូរអរព្រះគុណដល់ព្រះយេហូវ៉ា ដោយចាប់ស៊ុង[ឃ]
ហើយច្រៀងសរសើរថ្វាយទ្រង់ ដោយដេញពិណខ្សែ១០[ង]
៣ ចូរច្រៀងទំនុកថ្មី[ច]ថ្វាយទ្រង់ ហើយលេងភ្លេងឱ្យពីរោះ
ដោយប៉ិនប្រសប់[ឆ]
៤ ដ្បិតព្រះបន្ទូលនៃព្រះយេហូវ៉ាត្រឹមត្រូវ[ជ,ឈ]

**៣៣:២** ឃ លប ៤:២១ ១កថ ១៤:៧ វវ ៥:៨ ង ទដ ៩២:៣ ១៤៤:៩ **៣៣:៣** ច ទដ ៤០:៣ អស ៤២:១០ វវ ៥:៩ ឆ យប ៣:៧ ទដ ៣៥:២៧ ៤៧:១ **៣៣:៤** ជ ទដ ១៩:៨ ឈ ទដ ១១៩:១៤២ វវ ១៩:៩ ២២:៦

ស្តាប់បង្គាប់) ។ មានអ្នកខ្លះជឿថា នៅទីនេះអ្នកនិពន្ធទំនុកដំកើងគាត់បានព្រមានអ្នកដទៃទៀតមិនឱ្យដើរតាមផ្លូវខុស ដែលគាត់បានប្រព្រឹត្ត (មើល ៥១:១៣) ។

**៣២:៩** នៅក្នុងខនេះចង់និយាយថា អ្នកបម្រើរបស់ព្រះយេហូវ៉ាត្រូវតែមានប្រាជ្ញាជាងសត្វ ហើយធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ ជាងការដែលសេះឬលាកាត់ធ្វើតាមបំណងចិត្តចៅហ្វាយវាទៅទៀត (សូមមើល អស ១:៣) ។

**៣២:១០** *សេចក្តីសប្បុរសព័ទ្ធជុំវិញខ្លួន* សូមមើលការពន្យល់ក្នុង ៦:៤ ។

**៣២:១១** នៅក្នុងខនេះគឺជាឃ្លាបញ្ចប់ចុងក្រោយ ដែលស្តេចដាវីឌទ្រង់មានបន្ទូលទៅកាន់ពួកជំនុំដែលចូលរួមប្រជុំសរសើរដល់ព្រះយេហូវ៉ា ដែលទ្រង់មានបន្ទូលថា "ចូរនាំគ្នាស្រែកច្រៀងដោយអំណរចុះ" (មើលការពន្យល់ក្នុង ៩:១ និងការពន្យល់ក្នុង ១:៥) ។ *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។

**ទំនុកដំកើងជំពូក៣៣** នៅក្នុងជំពូកនេះ គឺជាការច្រៀងសរសើរដំកើងដល់ព្រះយេហូវ៉ា ជាព្រះនៃពួកសាសន៍អ៊ីស្រាអែល ។ នៅក្នុងជំពូកនេះវាមានលក្ខណៈ និងខ្លឹមសារដូចគ្នានឹងសេចក្តីអធិស្ឋានក្នុង ជំពូក ២៥ ដែរ ។ បទទំនុកដំកើងទាំង២ជំពូកនេះ (ជំពូក ២៥,៣៣) គឺជាគ្រឹះមួយដែលបានបង្ហាញចេញក្នុងចំណោមទំនុកដំកើងផ្សេងៗទៀត (សូមមើលសេចក្តីផ្តើម ទដ ២៥–៣៣) ។ នៅក្នុងបទគម្ពីរទំនុកដំកើង កាលណា និយាយអំពីការហៅឱ្យមកសរសើរតម្កើងដល់ព្រះ (ដូចជាមាននិយាយនៅក្នុង ខ.១–៣) និងពីហេតុផលដែលត្រូវសរសើរតម្កើង (ដូចជាមាន និយាយនៅក្នុង ខ.៤,១៩) នោះវាគឺជាភាសានៃការសរសើរតម្កើងដល់ព្រះអម្ចាស់ ។ សម្លេងនៃការអំពាវដល់ព្រះយេហូវ៉ា នៅក្នុងព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺវាស្ទើរតែដូចគ្នាទាំងស្រុង និងសម្លេងអំពាវនាវរបស់ក្រុមចម្រៀងក្នុងពួកកូនចៅលេវីដែរ (មើល ១រប ១៦:៧–៣៦ ២៥:១) ។ នៅក្នុងជំពូកនេះ ប្រហែលពួកអ្នកដឹកនាំចម្រៀងជាអ្នកច្រៀងពី ខ.១–៣ ពួកច្រៀងសរសើរពី ខ.៤–១៩ ហើយបណ្តាជនទាំងឡាយផ្សេងៗ ទៀតបានតបឆ្លើយចំពោះចម្រៀងនេះនៅ ខ.២០–២២ ។ ឱកាសនិងមូលហេតុដើមដំបូងនៃការច្រៀងសរសើរតម្កើង គេមិនបានដឹងពិតប្រាកដនោះឡើយ ប៉ុន្តែដោយយោងទៅតាមឃ្លាដែលថា "ចូរច្រៀងទំនុកថ្មីថ្វាយទ្រង់" (មើលការពន្យល់ ខ.៣) បានបង្ហាញថា គេច្រៀងក្នុងពេលដែលប្រទេសជាតិរបស់ពួកគេបានរំដោះ ដូចជាពួកយូដាបានរំដោះក្នុងគ្រាស្តេចយ៉ូសាផាត (មើល ២រប ជំពូក ២០) ឬក្នុងគ្រាស្តេចហេសេគា (មើល ២ពវ ជំពូក ១៩ មើល ខ.៩–១១,១៦–១៧) ព្រះគម្ពីរទដជំពូកនេះគឺជាគម្ពីរ ១ក្នុងចំណោមព្រះគម្ពីរទំនុកដំកើងទាំង៤ជំពូក គឺជំពូក ១–២ និងជំពូក ១០ (ប៉ុន្តែ មើលសេចក្តីផ្តើម ទដ ជំពូក ៩) ដែលគ្មានចំណងជើង ។

ទោះបីជាសំណង់ប្រយោគក្នុងព្រះគម្ពីរទំនុកដំកើង ជំពូកនេះគ្មានតួក្រមអក្សរចំណាប់ចុងចួនជាប់គ្នា ដូចព្រះគម្ពីរទំនុកដំកើងផ្សេងៗទៀតក៏ដោយ ក៏ព្រះគម្ពីរក្នុងជំពូកនេះមានរហូតដល់ ២២ខដែលបានបញ្ជាក់ន័យយ៉ាងច្បាស់ដោយតួក្រមអក្សរហេព្រើរដែរ (មាន២២តួរអក្សរ) សូមមើល ទដ ៣៨,១០៣ និងបទជំពូក ៥ ។ សេចក្តីផ្តើមព្រះគម្ពីរទំនុកដំកើងជំពូកនេះបានធ្វើឱ្យមានការចាប់អារម្មណ៍ ដោយមាន៣ខដំបូងជាសេចក្តីផ្តើម ដែលនិយាយពីការហៅឱ្យចូលមកសរសើរតម្កើង និង៣ខទៀតជាសេចក្តីបញ្ចប់ដែលនិយាយពីការឆ្លើយតប ចំពោះការហៅឱ្យចូលសរសើរតម្កើងក្នុង ខ.៤៩ គឺនិយាយពីការសរសើរដំកើងដល់ព្រះដែលមាន២ផ្នែក ហើយក្នុង១ផ្នែកមាន ៨ខ (ខ.៤–១១,១២–១៩) ។ នៅក្នុងផ្នែកទី១មាន៤ល្បះ (ខ.៦–៩) ដែលបានជ្រៀតខ្លួនចូលក្នុងល្បះសំខាន់ៗ២ (ខ.៤–៥,១០–១១) ដើម្បីពង្រីកផ្ទៃរឿងឱ្យបានល្អ ។ នៅក្នុងជំពូក ៧៧ ក៏បានប្រើទម្រង់ប្រហាក់ប្រហែលគ្នានេះដែរ (មើលសេចក្តីផ្តើមទំនុកដំកើង ៧៧) ។

**១ដ ៣៣:១–៣** នៅក្នុងខទាំងនេះ គឺនិយាយពីការហៅឱ្យមនុស្សទាំងអស់ចូលមកសរសើរតម្កើងដល់ព្រះអម្ចាស់ (សូមធៀបនឹង អភ ៥:១៩) ។

**៣៣:១** *អ្នកសុចរិត* អ្នកសុចរិតដែលនិយាយនៅកន្លែងនេះ គឺសំដៅលើក្រុមមនុស្សដែលជាអ្នកថ្វាយបង្គំព្រះយេហូវ៉ា (មើលការពន្យល់ ១:៥) ។

**៣៣:៣** *ទំនុកថ្មី* គឺសំដៅទៅលើការសរសើរតម្កើងដល់ព្រះ ចំពោះសេចក្តីសង្គ្រោះរបស់ទ្រង់ ដូចជាមាននិយាយនៅក្នុង ៤០:៣ ៩៦:១ ៩៨:១ ១៤៤:៩ ១៤៩:១ អស ៤២:១០ វវ ៥:៩ ១៤:៣ និងការពន្យល់ក្នុង ៧:១៧ ។

**៣៣:៤–១៩** នៅក្នុងខទាំងនេះ គឺពណ៌នាពីការការសរសើរដំកើងដល់ព្រះដែលមាន៨ខក្នុង១ផ្នែក ។

**៣៣:៤–១១** នៅក្នុងខទាំងនេះចង់និយាយថា ដោយសារការគ្រប់គ្រងរបស់ព្រះតាមរយៈអំណាចនៃ "ព្រះបន្ទូលទ្រង់" (ខ.៤) និង "ផែនការ" របស់ទ្រង់ចំពោះរាស្ត្រទ្រង់ "ជាប់នៅអស់កល្បជានិច្ច" (ខ.១១) នោះសូម្បីតែការបង្កើតផ្សេងៗទៀត "ក៏មាននៅ" (ខ.៩) ពីព្រោះព្រះអង្គបានបង្កើតរបស់ទាំងនោះដោយសារ "ព្រះបន្ទូល" ដ៏មានអំណាចរបស់ទ្រង់ (ខ.៦) ។ ការនិយាយ

ហើយបណ្ដាកិច្ចការនៃទ្រង់បានធ្វើដោយស្មោះត្រង់[ញ]ដែរ
៥ ទ្រង់ស្រឡាញ់សេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌[ដ]
ផែនដីមានពេញដោយសេចក្ដីសប្បុរសនៃព្រះយេហូវ៉ា[ឋ]
៦ ផ្ទៃមេឃបានកើតមក ដោយសារព្រះបន្ទូល[ឌ]ព្រះ
យេហូវ៉ា[ឍ] ហើយពួកបរិវារ[ណ]នៅលើនោះ
បានកើតដោយសារខ្យល់ពីព្រះឱស្ឋទ្រង់
៧ ទ្រង់បង្គរទឹកសមុទ្រ[ត]ឡើង ដូចជាគំនរ[ថ]
ទ្រង់យកទីជំរៅដាក់ទុកក្នុងឃ្លាំង
៨ ចូរឱ្យគ្រប់ផែនដីខ្លាចចំពោះព្រះយេហូវ៉ា[ទ]
ហើយឱ្យគ្រប់មនុស្សនៅលោកីយ[ធ]កោតក្រែងដល់ទ្រង់ចុះ[ន]
៩ ដ្បិតទ្រង់គ្រាន់តែមានបន្ទូល
នោះក៏កើតមានដូច្នោះទ្រង់បានបង្គាប់[ប]នោះក៏មាននៅ
១០ ព្រះយេហូវ៉ាទ្រង់ធ្វើឱ្យសេចក្ដីប្រឹក្សា[ផ]នៃអស់ទាំងនគរ[ព]
បានថ្លស់ការ[ភ]ទ្រង់ធ្វើឱ្យគំនិតនៃជនទាំងឡាយបានទៅជា
ឥតការ
១១ ឯដំបូន្មានផងព្រះយេហូវ៉ាវិញ នោះនៅជាប់ជានិច្ច[ម]
ហើយដំរិះ[យ]ក្នុងព្រះហឫទ័យទ្រង់ក៏នៅជាដរាបដល់អស់
ទាំងដំណតទៅ
១២ មានពរហើយ នគរណាដែលយកព្រះយេហូវ៉ាទុកជា
ព្រះរបស់ខ្លួន[រ] គឺជាសាសន៍ដែលទ្រង់បានរើស[ល]
ទុកជាមរដករបស់ទ្រង់[វ]
១៣ ព្រះយេហូវ៉ាទ្រង់ទតមក[ស]ពីលើស្ថានសួគ៌
ទ្រង់ឃើញមនុស្សលោកទាំងអស់[ហ]
១៤ ទ្រង់ទតមកពីស្ថានដ៏ជាទីលំនៅ[ឡ]របស់ទ្រង់
ក៏ឃើញអស់អ្នកដែលនៅផែនដីផង
១៥ គឺទ្រង់ហើយ ដែលស្ពាង[អ]ចិត្តគេ ក៏ពិចារណាមើលអស់
ទាំងការដែលគេធ្វើដែរ[ក]
១៦ គ្មានស្ដេចណាបានសង្គ្រោះ ដោយមានពលទ័ពច្រើន
ឡើយ[ខ] មនុស្សខ្លាំងពូកែក៏មិនបានរួច ដោយមានកំឡាំង
យ៉ាងខ្លាំងនោះដែរ
១៧ ឯសេះ[គ] នោះឥតប្រយោជន៍នឹងពឹងឱ្យបានសាន្តត្រាណ
ក៏មិនអាចនឹងជួយឱ្យអ្នកណារួចដោយសារកំឡាំងដ៏ខ្លាំង
របស់វាដែរ
១៨ មើល ព្រះនេត្រ[ឃ]នៃព្រះយេហូវ៉ាទតមកលើអស់អ្នក

**៣៣:៤** ញ ទដ ១៨:២៥ ២៥:១០ **៣៣:៥** ដ ទដ ១១:៧ ឋ ទដ ៦:៤ **៣៣:៦** ឌ លប ១:៣ ហព ១១:៣ ឍ នក ៨:១៩ ២របា ២:១២ ណ លប ១:១៦ **៣៣:៧** ត លប ១:១០ ថ យស ៣:១៦ **៣៣:៨** ទ ចទ ៦:១៣ ទដ ២:១១ ធ ទដ ៤៩:១ អស ១៨:៣ មីក ១:២ ន ចទ ១៤:២៣ **៣៣:៩** ប ទដ ១៤៨:៥ **៣៣:១០** ផ យប ៥:១២ ព ទដ ២:១ ភ អស ៤៤:២៥ **៣៣:១១** ម ជន ២៣:១៩ យ យរ ៥១:១២,២៩ **៣៣:១២** រ ទដ ១៤៤:១៥ ល នក ៨:២២ ចទ ៧:៦ ទដ ៤:៣ ៦៥:៤ ៨៤:៤ វ នក ៣៤:៩ **៣៣:១៣** ស ទដ ៥៣:២ ១០២:១៩ ហ យប ២៨:២៤ ទដ ១១:៤ ១៤:២ ហព ៤:១៣ **៣៣:១៤** ឡ លវ ១៥:៣១ ១ពរ ៨:៣៩ **៣៣:១៥** អ យប ១០:៨ ទដ ១១៩:៧៣ ក យប ១០:៤ យរ ៣២:១៩ **៣៣:១៦** ខ ១សយ ១៤:៦ **៣៣:១៧** គ ទដ ២០:៧ **៣៣:១៨** ឃ នក ៣:១៦ ទដ ១១:៤ ១ពត ៣:១២

អំពីរាស្ត្រដែលព្រះបានជ្រើសរើស គឺចង់និយាយថាប្រជាជាតិនោះបានទទួលនូវព្រះពររបស់ព្រះអម្ចាស់ (សូមមើល ខ.១២–១៩) ។

**៣៣:៤** *ព្រះបន្ទូល* ពាក្យនេះគឺចង់និយាយសំដៅលើគ្រប់ទាំងព្រះបន្ទូលទ្រង់ដែលទ្រង់មានបន្ទូលដើម្បីគ្រប់គ្រងលើទាំងអស់ ដែលព្រះអង្គបានបង្កើតមក (សូមមើលក្នុង ១០៧:២០ ១៤៧:១៥,១៨) ។ *ត្រឹមត្រូវ* ចង់និយាយថា ព្រះបន្ទូលរបស់ព្រះគឺស្ថិតស្ថេរជានិច្ច មិនប្រែផ្លាស់ឡើយ ។ ក្រោមការគ្រប់គ្រងរបស់ព្រះ សណ្ដាប់ធ្នាប់ និងសេចក្ដីសប្បុរសទាំងអស់នេះគឺដំណាងឱ្យការបង្កើតរបស់ទ្រង់ ។

**៣៣:៥** *ស្រឡាញ់* មានន័យថា ព្រះយេហូវ៉ាទ្រង់សព្វព្រះទ័យនិងមានអំណរក្នុងការផ្ដល់សេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌មកលើរាស្ត្រទ្រង់ ។ *សេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌* មើលការពន្យល ៤:១ ។ *មានពេញដោយសេចក្ដីសប្បុរស* នៅកន្លែងនេះចង់មានន័យថា ព្រះយេហូវ៉ាទ្រង់បានផ្ដល់សេចក្ដីសប្បុរសរបស់ទ្រង់ មកលើគ្រប់របស់ទាំងអស់ដែលទ្រង់បានបង្កើតមក (មើល ៣៦:៥–៩ ១០៤:២–២៨ និងការពន្យល់ ៦:៤) ។

**៣៣:៦** *ព្រះបន្ទូល* គឺជាព្រះបន្ទូលដែលទ្រង់មានបន្ទូលបង្គាប់បញ្ជាក្នុងការបង្កើតគ្រប់ទាំងអស់ឡើង (មើល ខ.៩ ១០៤:៧ ១១៩:៨៩ លប ជំពូក ១យប ៣៨:៨–១១ ហព ១១:៣) ។

**៣៣:៧** *ដូចជាគំនរ . . . ដាក់ទុកក្នុងឃ្លាំង* នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់នឹងធ្វើការនោះ ដូចជាម្ចាស់ផ្ទះបានប្រមូលប្រេងអូលីវ និងគ្រាប់ធញ្ញជាតិមកទុកក្នុងឃ្លាំងរបស់គេដែរ (មើល ១០៤:៩ លប ១:៩–១០ យប ៣៨:៨–១១ សភ ៨:២៩ យរ ៥:២២) ។

**៣៣:៨** *គ្រប់ផែនដី . . . គ្រប់មនុស្សនៅលោកីយ* នៅក្នុងឃ្លានេះមានន័យថា មិនមែនមានតែពួកអ៊ីស្រាអែលប៉ុណ្ណោះទេ ដែលត្រូវកោតខ្លាចព្រះប៉ុន្តែត្រូវឱ្យមនុស្សទាំងអស់ដែលធ្លាប់ទទួលសេចក្ដីសប្បុរសពីព្រះយេហូវ៉ា (មើលការពន្យល់ ៩:១) ប៉ុន្តែព្រះអង្គទ្រង់បានធ្វើឱ្យថ្លស់ការគ្រប់ទាំងអស់ នៃគំនិតរបស់ពួកគេ (មើល ខ.១០–១១) ។ *ខ្លាចចំពោះព្រះយេហូវ៉ា* មើល ខ.១៨ និងការពន្យល់ ១៥:៤ ។

**៣៣:១១** *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។

**៣៣:១២–១៩** នៅក្នុងខទាំងនេះចង់និយាយថា ដោយសារការការពាររបស់ព្រះយេហូវ៉ា នោះទើបពួកអ៊ីស្រាអែលបានសេចក្ដីសុខសាន្ត និងមានសុវត្ថិភាព ។

**៣៣:១២** *មានពរហើយ* មើលការពន្យល់ ១:១ ។ *សាសន៍ដែលទ្រង់បានរើសទុកជាមរដករបស់ទ្រង់* សាសន៍នោះគឺជាសាសន៍អ៊ីស្រាអែល (មើល ចទ ៩:២៩) ។

**៣៣:១៦** *ស្ដេច* នៅក្នុងខនេះគឺចង់និយាយថា សារពាង្គកាយនៃសហគមន៍របស់សង្គមមួយបានកើតឡើង គឺដោយសារមានប្រជារាស្ត្រក្នុងនគរ (សូមមើល ខ.៩) និងស្ដេច (មើល ២៨:៨ និងការពន្យល់) ។

**៣៣:១៨–១៩** នៅក្នុងខនេះ គឺជាសេចក្ដីបញ្ចប់នៃផ្នែកទី២នៃការសរសើរតម្កើងដល់ព្រះដែលមាន៨ខ នៅក្នុងផ្នែកនេះផ្ទុយគ្នានឹងផ្នែកទី១ (មើល ខ.១០–១១) ។ ផ្នែកទាំង២នៃជំពូកនេះ (៤–១១,១២–១៩) គឺពណ៌នាការសរសើរដំកើងដល់ព្រះយេហូវ៉ានៃពួកពលបរិវារ ។

**៣៣:១៨,២២** *សេចក្ដីសប្បុរស* ឃ្លានេះគឺចង់និយាយសំដៅសេចក្ដីសញ្ញា

ដែលកោតខ្លាចដល់ទ្រង់
គឺមកលើពួកអ្នកដែលសង្ឃឹមដល់សេចក្តីសប្បុរសទ្រង់[ង]
១៩ ដើម្បីនឹងជួយឱ្យព្រលឹងគេរួចពីស្លាប់[ច]
ហើយការពារឱ្យគេរស់នៅក្នុងគ្រាអំណត់[ឆ]
២០ ព្រលឹងនៃយើងខ្ញុំសង្ឃឹម[ជ]ដល់ព្រះយេហូវ៉ា ទ្រង់ជាជំនួយ
ហើយជាខែលរបស់យើងខ្ញុំ
២១ ដ្បិតចិត្តយើងខ្ញុំនឹងរីករាយឡើងក្នុងទ្រង់[ឈ]
ពីព្រោះយើងខ្ញុំបានទុកចិត្តដល់ព្រះនាមបរិសុទ្ធរបស់ទ្រង់
ហើយ[ញ]
២២ ឱព្រះយេហូវ៉ាអើយ សូមឱ្យសេចក្តីសប្បុរស[ដ]របស់ទ្រង់
សណ្ឋិតនៅលើយើងខ្ញុំ តាមដែលយើងខ្ញុំបានសង្ឃឹមដល់
ទ្រង់ ។

ទំនុកនៃស្តេចដាវីឌ
ដែលទ្រង់លើកក្នុងកាលដែលទ្រង់ក្លែងធ្វើជាឆ្កួត
នៅចំពោះអ័ប៊ីម៉ាឡិច ហើយត្រូវបណ្តេញចេញទៅ ។

៣៤ ខ្ញុំនឹងលើកសរសើរដល់ព្រះយេហូវ៉ាគ្រប់ពេល
វេលា[ក] សេចក្តីសរសើរពីទ្រង់នឹងនៅក្នុងមាត់ខ្ញុំជានិច្ច
២ ព្រលឹងរបស់ខ្ញុំនឹងអួត[ខ]តែពីព្រះយេហូវ៉ា
មនុស្សរាបទាបនឹងឮ ហើយនិងមានសេចក្តីអំណរដែរ[គ]
៣ ចូរដំកើងព្រះយេហូវ៉ា[ឃ]ជាមួយនឹងខ្ញុំចុះ
ចូរយើងព្រមគ្នាលើក[ង]ព្រះនាមទ្រង់ឡើង
៤ ខ្ញុំបានស្វែងរកព្រះយេហូវ៉ា[ច]
ហើយទ្រង់ក៏ឆ្លើយតបមកខ្ញុំក៏ប្រោស[ឆ]ឱ្យ
ខ្ញុំរួចពីអស់ទាំងសេចក្តីភ័យរបស់ខ្ញុំ
៥ អ្នកណាដែលពឹងដល់ទ្រង់
នោះក៏មានសេចក្តីអំណរដ៏ព្រោងព្រាយ[ជ]

**៣៣:១៨** ង ទដ ៦:៤ **៣៣:១៩** ច ទដ ៥៦:១៣ កច ១២:១១ ឆ យប ៥:២០ **៣៣:២០** ជ ទដ ២៧:១៤ **៣៣:២១** ឈ ១សយ ២:១ យអ ២:២៣ ញ ទដ ៣០:៤ ៩៩:៣ **៣៣:២២** ដ ទដ ៦:៤ ក ទដ ៧១:៦ អភ ៥:២០ ១ថន ៥:១៨ **៣៤:២** ខ ទដ ៤៤:៨ យរ ៩:២៤ ១កថ ១:៣១ គ ទដ ៦៩:៣២ ១០៧:៤២ ១១៩:៧៤ **៣៤:៣** ឃ ទដ ៦៣:៣ ៨៦:១២ ដយ ៤:៣៧ យហ ១៧:១ រម ១៥:៦ ង នក ១៥:២ **៣៤:៤** ច នក ៣២:១១ ទដ ៧៧:២ ឆ ខ.១៧ ទដ ១៨:៤៣ ២២:៤ ៥៦:១៣ ៨៦:១៣ **៣៤:៥** ជ នក ៣៤:២៩

ដែលព្រះយេហូវ៉ាទ្រង់បានតាំងជាមួយអ៊ីស្រាអែល (មើល ៦:៤) ។

**៣៣:២០-២២** នៅក្នុងខទាំងនេះ គឺនិយាយពីការទទួលខុសត្រូវនិងការតបឆ្លើយរបស់ពួកបណ្តាជនចំពោះព្រះ ដោយពួកគេបាននិយាយពីជំនឿ (ខ.២០-២១) និងការទូលសូមរបស់គេ ។

**៣៣:២០** *ខែល* សូមមើលការពន្យល់ ៣:៣ ។

**៣៣:២១** *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។ *ព្រះនាម* សូមមើលការពន្យល់ក្នុង ៥:១១ ។

**ទដ ៣៤-៣៧** នេះគឺជាក្រុមនៃទំនុកដំកើងដ៏តូចមួយ ដែលមាន៤ទំនុកហើយមានក្រុមចុងចួន២ភ្ជាប់មកជាមួយនឹងប្រាជ្ញា ជាការបង្រៀនដើម្បីឱ្យបានដូចជាព្រះ និងការព្រមានដល់ពួកមនុស្សអាក្រក់ ដែលសេចក្តីបង្រៀននិងការព្រមាននេះ គឺជាគន្លឹះគ្រឹះមួយដើម្បីពង្រឹងផ្ទៃរឿងឱ្យបានល្អ ដោយមានបញ្ចូលការអធិស្ឋានចំនួន២ទៀតផង (ទដ ៣៥,៣៦) ។

**ទំនុកដំកើងជំពូក៣៤** នៅក្នុងជំពូកនេះមានអក្ខរក្រមចុងចួនដែលចាប់ផ្តើមនិយាយដោយការសរសើរតម្កើងចំពោះព្រះអម្ចាស់ ពីកិច្ចការដែលទ្រង់បានរំដោះពួកគេចេញពីស្រុកអេស៊ីព្ទ ក្នុងកាលដែលពួកគេអំពាវនាវរកទ្រង់ (ខ.១-៧) បន្ទាប់មកទៀត គឺពណ៌នាពីប្រាជ្ញា ។ ការផ្លាស់ប្តូរនៃភាពរំកិលនេះ គឺខុសប្លែកដ៏ចម្លែកមួយនៅក្នុងជីវិតអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង (ប៉ុន្តែ សូមមើលក្នុងព្រះគម្ពីរ ទដ ៩២) ។ ភាគច្រើននៅក្នុងព្រះគម្ពីរទំនុកដំកើង គឺនិយាយពីការហៅឱ្យចូលមកសរសើរតម្កើងចំពោះព្រះអម្ចាស់ ដូចជាបាននិយាយនៅក្នុង ខ.៣ (សូមមើលការពន្យល់ក្នុង ៩:១) ព្រះគម្ពីរទំនុកដំកើងជំពូកនេះ និងជំពូក ៣៧ បានចូលជ្រៀតជ្រែកក្នុងព្រះគម្ពីរទំនុកដំកើងដទៃទៀត (សូមមើលការពន្យល់ក្នុង ទដ ៣៤-៣៧) ។ សំណង់ប្រយោគនៃ ទដ ជំពូក ៣៤ គឺមានលក្ខណៈស្មុគស្មាញបន្តិច ប៉ុន្តែវាងាយយល់បាន។ព្រះគម្ពីរជំពូក នេះបានបែងចែកដូចតទៅ សេចក្តីផ្តើមមាន ៣ខ ហើយផ្ទៃរឿងបន្ទាប់ទៀត នៅក្នុងល្បះមាន ៤ខ (ខ.៤-៧) ៧ខ (៨-១៤) ៤ខ (ខ.១៥-១៨) ហើយចុង ក្រោយគឺមាន ៤ខ (១៩-២២) ។

**៣៤ ត្រង់ចំណងជើង** ចំណងជើងព្រះគម្ពីរទំនុកដំកើងជំពូកនេះបានតាក់តែងឡើងដោយមានជាប់ទាក់ទងនឹងជីវិតរស់នៅរបស់ស្តេចដាវីឌ (មើលការពន្យល់ ជំពូក ៣ ត្រង់ចំណងជើង) ហើយក៏ទាក់ទងទៅនឹងការរៀបរាប់ដែលមាននិយាយក្នុង ១សយ ២១:១០-១៥ ដែរ ប៉ុន្តែសូមកត់សម្គាល់ពីឈ្មោះ "អ័ប៊ីម៉ាឡិច" ជាងឈ្មោះ "អ័គីស"(ប្រហែលអ័ប៊ីម៉ាឡិច គឺនាមដែលគេដាក់ឱ្យតាមជំនួរវង្សស្តេចសាសន៍ភីលីស្ទីន ដោយព្រោះទំលៀមទម្លាប់របស់ពួកគេ មើល លប ជំពូក ២០ ២១:២២-៣៤ និងជំពូក ២៦)។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គេមិនយល់ស្របចំពោះទំនៀមទម្លាប់នេះទាំងអស់គ្នានោះដែរពួកគេគ្រាន់តែមានអារម្មណ៍ថា អ្នកត្រួតពិនិត្យភាសាហេព្រើរក្នុងព្រះគម្ពីរទំនុកដំកើងបានភ្ជាប់ទំនាក់ទំនងព្រះគម្ពីរ ១សយ ២១ ជាមួយ ទដ ៣៤ ដោយផ្អែកលើគ្រឹះនៃការរួបរួម (ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា "ក្លែងធ្វើជាឆ្កួត" ១សយ ២១:១៣ គឺដូចគ្នានិងភាសាហេព្រើរដែលប្រើពាក្យ "ភ្លក់"ដែលប្រើនៅទីនេះដែរ (ខ.៨) ។

**៣៤:១-៧** នៅក្នុងខទាំងនេះ ចង់និយាយអំពីការសរសើរតម្កើងចំពោះសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ ដែលទ្រង់បានឆ្លើយតបចំពោះពាក្យអធិស្ឋានរបស់ពួកគេ ។

**៣៤:១-៣** នៅក្នុងខទាំងនេះចង់និយាយថា ការប្តេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះនាមទ្រង់ នោះពួកអ្នកដែលស្រឡាញ់ព្រះគឺជាពួកមនុស្សរាបទាបនឹងបានការកំសាន្តចិត្ត (ខ.២ ហើយសូមមើលក្នុងសេចក្តីបង្រៀនបន្តបន្ទាប់ទៀតក្នុង ខ.៨-២២) ។

**៣៤:២** *ព្រលឹង* មើលការពន្យល់ ៦:៣ ។ *អួតតែពីព្រះយេហូវ៉ា* នៅក្នុងឃ្លានេះចង់និយាយថា គេនឹងលើកតម្កើងចំពោះព្រះយេហូវ៉ាគ្រប់ពេល ។

**៣៤:៣** *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**៣៤:៤-៧** នៅក្នុងខទាំងនេះ គឺចង់និយាយពីគ្រាដែលព្រះអម្ចាស់ទ្រង់បានជួយសង្គ្រោះគេ ក្នុងកាលដែលគេអំពាវនាវដល់ព្រះអង្គ ។

**៣៤:៥** *សេចក្តីអំណរដ៏ព្រោងព្រាយ* គឺចង់និយាយពីសេចក្តីអំណរ ដោយ

ហើយមុខគេមិនដែលត្រូវខ្មាសឡើយ[ឈ]
៦ ខ្ញុំ ជាមនុស្សវេទនានេះ បានអំពាវនាវទៅ
នោះព្រះយេហូវ៉ាទ្រង់បានស្តាប់តាម
ហើយជួយសង្គ្រោះឱ្យរួចពីសេចក្តីលំបាកទាំងប៉ុន្មាន
របស់ខ្លួន[ញ]
៧ ទេវតានៃព្រះយេហូវ៉ា[ដ] ចោមរោមនៅជុំវិញនៃអស់អ្នក
ដែលកោតខ្លាចដល់ទ្រង់ ហើយក៏ជួយ[ឋ] គេឱ្យរួច
៨ ឱសូមភ្លក់មើលឱ្យដឹងថា ព្រះយេហូវ៉ាទ្រង់ល្អចុះ[ឌ]
មានពរហើយ មនុស្សណាដែលពឹងជ្រក[ឍ] ក្នុងទ្រង់
៩ ឱពួកបរិសុទ្ធរបស់ទ្រង់អើយ
សូមកោតខ្លាចដល់ព្រះយេហូវ៉ា[ណ]
ដ្បិតអស់អ្នកដែលកោតខ្លាចដល់ទ្រង់មិនខ្វះអ្វីឡើយ[ត]
១០ ឯអស់ទាំងសិង្ហស្ទាវ វាតែងតែខ្វះ ហើយក៏ឃ្លាន
តែអស់អ្នកដែលស្វែងរកព្រះយេហូវ៉ា
នោះនឹងមិនខ្វះអ្វីដែលល្អឡើយ[ថ]
១១ កូនទាំងឡាយអើយ ចូរមកស្តាប់[ទ] អញចុះ
អញនឹងបង្រៀនឯងរាល់គ្នា[ធ]
ពីសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា[ន]

**៣៤:៥** ឈ ទដ ២៥:៣ ៤៤:១៥ ៦៩:៧ ៨៣:១៦ **៣៤:៦** ញ ទដ ២៥:១៧ **៣៤:៧** ដ លប ៣២:១ ដយ ៣:២៨ មថ ១៨:១០ ឋ ទដ ២២:៤ ៣៧:៤០ ៤១:១ ៩៧:១០ អស ៣១:៥ កច ១២:១១ **៣៤:៨** ឌ ហព ៦:៥ ១ពត ២:៣ ឍ ទដ ២:១២ **៣៤:៩** ណ ចទ ៦:១៣ វវ ១៤:៧ ត ទដ ២៣:១ **៣៤:១០** ថ ទដ ២៣:១ **៣៤:១១** ទ ទដ ៦៦:១៦ ធ ទដ ៣២:៨ ន ទដ ១៩:៩ **៣៤:១២** ប សស ៣:១៣

១២ តើមានអ្នកឯណាដែលចង់បានជីវិត[ប]
ហើយស្រឡាញ់អាយុយឺនយូរ ដើម្បីឱ្យបានឃើញសេចក្តីល្អ
១៣ ត្រូវឱ្យរក្សាអណ្តាតខ្លួន[ផ] ឱ្យរួចពីសេចក្តីអាក្រក់
ហើយបបូរមាត់ផង មិនឱ្យពោលពាក្យកំភូត[ព]
១៤ ចូរថយចេញពីការអាក្រក់ ហើយប្រព្រឹត្តការល្អវិញ[ភ]
ចូរស្វែងរកសេចក្តីសុខ[ម] ហើយដេញជាប់តាមចុះ
១៥ ព្រះនេត្រព្រះយេហូវ៉ា[យ] ទតទៅចំពោះមនុស្សសុចរិត[រ]
ហើយព្រះកាណ៌ទ្រង់ក៏ប្រុងស្តាប់[ល] សំរែករបស់គេ
១៦ ព្រះភក្ត្រព្រះយេហូវ៉ាទាស់ទទឹង[វ] នឹងពួកអ្នកដែលប្រព្រឹត្ត
អាក្រក់[ស]
ដើម្បីនឹងដកយកសេចក្តីនឹកចាំ[ហ] ចំពោះគេពីផែនដីចេញ
១៧ ឯមនុស្សសុចរិត គេអំពាវនាវ
ហើយព្រះយេហូវ៉ាទ្រង់ទទួលស្តាប់[ឡ]

**៣៤:១៣** ផ ទដ ៣៩:១ ១៣១:៣ សភ ១៣:៣ ២១:២៣ យក ១:២៦ ព ទដ ១២:២ ១ពត ២:២២ **៣៤:១៤** ភ ទដ ៣៧:២៧ អស ១:១៧ ៣យហ ១:១១ ម រម ១៤:១៩ **៣៤:១៥** យ ទដ ៣៣:១៨ រ យប ២៣:១០ ៣៦:៧ ល មឡ ៣:១៦ យហ ៩:៣១ **៣៤:១៦** វ លវ ១៧:១០ យរ ២៣:៣០ ស ១ពត ៣:១០–១២ ហ នក ១៧:១៤ ទដ ៩:៦ **៣៤:១៧** ឡ ទដ ១៤៥:១៩

ការរីករាយ (សូមមើលក្នុង អស ៦០:៥) ។

**៣៤:៦** *មនុស្សវេទនា* មនុស្សក្រនៅទីនេះក៏ដូចជាមនុស្សក្រដែលមាននិយាយនៅក្នុង ទដ ត្រង់កន្លែងផ្សេងៗទៀតដែរ គឺមិនមែនជាម្នាក់ដែលគ្មានទ្រព្យសម្បត្តិនោះឡើយ ប៉ុន្តែគឺអ្នកដែលគ្មានសមត្ថភាពរំដោះខ្លួនចេញពីគ្រោះថ្នាក់ ឬក៏គ្មានសមត្ថភាពការពារខ្លួនរបស់គេ ក្រៅពីពឹងជ្រកលើព្រះអម្ចាស់ប៉ុណ្ណោះ ។

**៣៤:៧** *ទេវតានៃព្រះយេហូវ៉ា* ពួកគេគឺជាអ្នកដំណាងរបស់ព្រះ "ជាអ្នកនាំសារ"របស់ព្រះអម្ចាស់ដែលទ្រង់បញ្ជូនទៅ ដើម្បីបំពេញបំណងព្រះទ័យរបស់ទ្រង់នៅលើផែនដី (សូមមើលក្នុង ៣៥:៥–៦ និងការពន្យល់ក្នុង លប ១៦:៧) ។ *ចោមរោមជុំវិញ* នៅក្នុងឃ្លានេះចង់និយាយពីសុវត្ថិភាព និងសេចក្តីសុខសាន្តរបស់ទ្រង់ដែលទ្រង់បានការពារជុំវិញពួកគេ ទោះបីជាពួកគេនៅតែឯងក្តី ឬនៅជាសហគមន៍ក៏ដោយ ។ *អស់អ្នកដែលកោតខ្លាចដល់ទ្រង់* គឺជាពួកអ្នកដែលបានពណ៌នានៅក្នុង ខ.៨–១៤ ។

**៣៤:៨–១៤** នៅក្នុងខ.ទាំងនេះជាសេចក្តីផ្តើមមួយដែលពណ៌នាពី"អ្នកដែលកោតខ្លាចដល់ព្រះ" ។ ខ.ទាំងនេះគឺជាផ្ទៃរឿងមួយដែលបានភ្ជាប់មកជាមួយនឹងឋានៈ(សូមមើលក្នុង ខ.១១) នៅចំណុចកណ្តាលនៃជំពូកនេះ ។ ការនេះបង្ហាញថា ជាញឹកញាប់អ្នកនិពន្ធបានយកព្រះគម្ពីរភាសាហេព្រើរធ្វើជាចំណុចស្នូល នៃផ្ទៃរឿងនេះ(មើលការពន្យល់ក្នុង ៦:៦)។ សូមកត់ចំណាំនូវពាក្យបង្គាប់បញ្ជានេះ "សូមភ្លក់មើល" (ខ.៨) "សូមកោតខ្លាច" (ខ.៩) "ចូរមក"(ខ.១១) "ត្រូវរក្សា"(ខ.១៣)"ចូរថយ"(ខ.១៤) ។ សទីសន័យនៃពាក្យថា"ល្អ"គឺមានពាសពេញល្បះ។ពីព្រោះព្រះយេហូវ៉ាទ្រង់ល្អ (ខ.៨) នោះពួកអ្នកដែលទុកចិត្តចំពោះទ្រង់នឹងខ្វះអ្វីដែលល្អឡើយ (ខ.១០) ប៉ុន្តែដើម្បីឱ្យបានឃើញសេចក្តីល្អ (ខ.១២) ពួកគេត្រូវតែថយចេញពីការអាក្រក់ហើយប្រព្រឹត្តិការល្អវិញ (ខ.១៤) ។ ការទុកចិត្តនិងការកោតខ្លាចនោះគឺជាអាកប្បកិរិយាមួយដែល "អ្នកកោតខ្លាចព្រះ"ត្រូវតែមាន ។ សូមមើលសេចក្តីផ្តើមនៃល្បះនេះក្នុង ទដ ជំពូក ៣៧ ។ លោកពេត្រុសបានលើកយកខនេះមកនិយាយដែរ (សូមមើលក្នុង ១ពត ៣:៨–១២) ។

**៣៤:៨** *មានពរហើយ* សូមមើលការពន្យល់ក្នុង ១:១ ។

**៣៤:៩** *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើលក្នុង ខ.១១ និងការពន្យល់ក្នុង ១៥:៤ ។ *ពួកបរិសុទ្ធ* សូមមើលការពន្យល់ក្នុង ៤:៣ ។

**៣៤:១១** *កូនទាំងឡាយអើយចូរ មកស្តាប់អញចុះ* នេះគឺជាពាក្យសាមញ្ញមួយរបស់គ្រូដែលប្រកបដោយគតិបណ្ឌិតតែងតែប្រើ(សូមមើលសេចក្តីផ្តើមព្រះគម្ពីរសុភាសិតត្រង់គោលបំណង និងសេចក្តីបង្រៀន) ។

**៣៤:១៣** សូមមើលក្នុង ១៥:២–៣ យក ៣:៥–១០ ។ សូមមើលឃ្លាដែលនិយាយថា អណ្តាតគឺជាអាវុធមួយ នៅក្នុងការពន្យល់ ៥:៩ ។

**៣៤:១៤** *ថយចេញពីការអាក្រក់ ហើយប្រព្រឹត្តការល្អវិញ* ឃ្លានេះគឺជាគ្រឹះមួយដើម្បីភ្ជាប់ជាមួយ ទដ ៣៧ (សូមមើលក្នុង ៣៧:២៧) ។ *ចូរស្វែងរកសេចក្តីសុខ* សូមមើលក្នុង ៣៧:៣៧ ១២០:៧ សភ ១២:២០ សក ៨:១៩ សក ៨:១៦–១៧ មថ ៥:៩ រម ១២:១៨ ១កថ ៧:១៥ ២កថ ១៣:១១ ១ថន ៥:១៣ ហព ១២:១៤ យប ៣:១៧–១៨ ។

**៣៤:១៥–១៨** នៅក្នុងខទាំងនេះគឺជាការធានាអះអាងថា ព្រះយេហូវ៉ាទ្រង់នឹងស្តាប់ឮសម្រែកសេចក្តីអធិស្ឋានរបស់ពួកមនុស្សសុចរិត ។ ព្រះយេហូវ៉ាទ្រង់ក៏ទាស់ទទឹងនឹងពួកអ្នកដែលប្រព្រឹត្តការអាក្រក់ ទោះបីជាពួកគេបានបំភ្លេចវាចោលក៏ដោយ (ខ.១៦) ។

**៣៤:១៥** *មនុស្សសុចរិត* សូមមើលក្នុង ខ.៨–១៤ និងការពន្យល់ក្នុង ១:៥ ។

**៣៤:១៦** *ព្រះភក្ត្រព្រះយេហូវ៉ា* សូមមើលការពន្យល់ក្នុង ១៣:១ ។

ទ្រង់ក៏ប្រោសគេឱ្យរួចពីគ្រប់សេចក្ដីលំបាករបស់គេ
១៨ ព្រះយេហូវ៉ាទ្រង់គង់ជិតបង្កើយ[អ]នឹងអស់អ្នកដែលមាន
ចិត្តសង្រេង[ក] ហើយទ្រង់ជួយសង្គ្រោះដល់អស់អ្នកដែល
មានវិញ្ញាណទន់ទាប
១៩ មនុស្សសុចរិតតែងកើតមានសេចក្ដីលំបាកជាច្រើន[ខ]
តែព្រះយេហូវ៉ាទ្រង់ជួយឱ្យរួចពីសេចក្ដីទាំងនោះ[គ]
២០ ទ្រង់រក្សាអស់ទាំងឆ្អឹងរបស់អ្នកនោះ
មិនឱ្យឆ្អឹងណាមួយត្រូវបាក់ឡើយ[ឃ]
២១ សេចក្ដីអាក្រក់នឹងសំឡាប់មនុស្សដែលប្រព្រឹត្តអាក្រក់[ង]
ហើយពួកអ្នកដែលស្អប់ដល់មនុស្សសុចរិតនឹងត្រូវមាន
ទោស
២២ ព្រះយេហូវ៉ាទ្រង់លោះ[ច]ព្រលឹងនៃអស់អ្នកដែលគោរព
ប្រតិបត្តិដល់ទ្រង់
ហើយក្នុងពួកអស់អ្នកដែលពឹងជ្រក[ឆ]ក្នុងទ្រង់
នោះគ្មានអ្នកណាមួយនឹងត្រូវទោសឡើយ ។

ទំនុកនៃស្ដេចដាវីឌ ។

**៣៥** ឱព្រះយេហូវ៉ាអើយ សូមទ្រង់ការពារ[ក]ទូលបង្គំ
ចំពោះពួកអ្នកដែលតតាំងនឹងទូលបង្គំ
សូមទ្រង់តស៊ូ[ខ]នឹងពួកអ្នកដែលតស៊ូនឹងទូលបង្គំផង
២ សូមចាប់យកទាំងខែលតូចធំ[គ]
ហើយក្រោកឡើង[ឃ]ជួយទូលបង្គំ[ង]
៣ សូមងាលំពែង[ច,ឆ]រាំងផ្លូវពួកអ្នកដែលដេញតាមទូលបង្គំ

**៣៤:១៨** អ ចទ ៤:៧ ទដ ១១៩:១៥១ ១៤៥:១៨ អស ៥០:៨ ក ទដ ៥១:១៧ ១០៩:១៦ ១៤៧:៣ អស ៦១:១ **៣៤:១៩** ខ ខ.១៧ ទដ ២៥:១៧ គ យប ៥:១៩ ២ធថ ៣:១១ **៣៤:២០** ឃ យប ១៩:៣៦ **៣៤:២១** ង ទដ ៧:៩ ៩:១៦ ១១:៥ ៣៧:២០ ៧៣:២៧ ៩៤:២៣ ១០៦:៤៣ ១១២:១០ ១៤០:១១ សភ ១៤:៣២

២៤:១៦ **៣៤:២២** ច នក ៦:៦ ១៥:១៣ លក ១:៦៨ វវ ១៤:៣ ឆ ទដ ២:១២ **៣៥:១** ក នក ១៤:១៤ **៣៥:១** ខ ១សយ ២៤:១៥ **៣៥:២** គ ទដ ៣:៣ ឃ ទដ ៣:៧ ង លប ៥០:២៤ យប ១៧:៣ **៣៥:៣** ច ជន ២៥:៧ ឆ យស ៨:១៨

**៣៤:១៧–១៨** សូមមើលក្នុង ៥១: ១៧ ។

**៣៤:១៩–២២** នៅក្នុងខ.ទាំងនេះបានធានារ៉ាប់រងថា ព្រះអម្ចាស់ទ្រង់នឹងជួយដល់ពួកមនុស្សសុចរិតជានិច្ចនិរន្តន៍ ហើយព្រះយេហូវ៉ាទ្រង់នឹងដាក់ទោសមនុស្សអាក្រក់ទៅតាមការដែលគេប្រព្រឹត្ត ចំពោះពួកមនុស្សសុចរិត (សូមមើលក្នុង ខ.២១) ។

**៣៤:២០** *អស់ទាំងឆ្អឹង* ឃ្លានេះគឺនិយាយសំដៅលើរូបកាយទាំងមូល (សូមមើលការពន្យល់ក្នុង ៦:២) ។ *មិនឱ្យឆ្អឹងណាមួយត្រូវបាក់ឡើយ* ពាក្យនេះប្រហែលជាចង់និយាយសំដៅលើព្រះយេស៊ូវ ដែលមាននិយាយនៅក្នុងដំណឹងល្អតាមលោកយ៉ូហាន (សូមមើលការពន្យល់ក្នុង យហ ១៩:៣៦) ដែលទ្រង់គឺជាមនុស្សម្នាក់ដែលហៅថា "សុចរិត"(ខ.១៩) ជាងគេ ។

**៣៤:២១–២២** *ត្រូវទោស* គឺមានទំនាក់ទំនងនឹងការមានកំហុស (សូមធៀបជាមួយ យរ ២:៣ ហស ១០:២) ។

**៣៤:២២** *លោះ* សូមមើលការពន្យល់ក្នុង ២៥:២២ ។ *អ្នកដែលពឹងជ្រកក្នុងទ្រង់* សូមមើលក្នុង ២:១២ ។

**ទដ ៣៥** នៅក្នុងជំពូកនេះស្ដេចដាវីឌទ្រង់បាន អំពាវនាវដង្ហោយហៅដល់ស្ដេចនៃស្ថានសួគ៌ដែលទ្រង់ជាមេទ័ពចម្បាំង និងជាចៅក្រមដ៏សុចរិត សូមព្រះអម្ចាស់ទ្រង់យាងមកដើម្បីការពារពួក "អ្នកបំរើទ្រង់" (សូមមើលក្នុង ខ.២៧) ដែលកំពុងជួបការបៀតបៀន និយាយពាក្យបង្ខូចបង្កាច់ពីសំណាក់ពួកដែលគាត់ចង់បង្កើតមិត្រភាពជាមួយ ។ ការបៀតបៀន និងការវាយប្រហារនេះមើលទៅហាក់បីដូចជាបង្ករឡើង ក្នុងអំឡុងពេលដែលស្ដេចដាវីឌទ្រង់កំពុងប្រឈរមុខនឹង"សេចក្ដីអន្តរាយ" (សូមមើលក្នុង ខ.២៦) ដែលកំពុងតែជោរជន់មកលើជីវិតរស់នៅរបស់ទ្រង់ (សូមមើលក្នុង ខ.១៥, ១៩,២១,២៥) ហើយសេចក្ដីអន្តរាយនោះប្រហែលជាជំងឺ (សូមមើលក្នុង ខ.១៣ និងសេចក្ដីផ្ដើមទំនុកដំកើង ជំពូក ៦) ។ នៅក្នុងព្រះគម្ពីរទំនុកដំកើង ជំពូក ៣៥ នេះមានគំរូនៃការ"អំពាវនាវ"ហៅព្រះអម្ចាស់ដោយការរងចាំដោយមានសេចក្ដីជំនឿជឿជាក់ថា ព្រះអម្ចាស់ទ្រង់នឹងឆ្លើយតប ហើយនិងសម្រេចក្ដីពួកគេដូចជាបាននិយាយនៅក្នុង ទដ ៣៤:១៥–២២ ដែរ ។ ប៉ុន្តែនៅក្នុងជំពូកនេះមានករណីលើកលែងមួយត្រង់ថា នៅទីនេះអ្នកនិពន្ធគាត់មិនបានណែនាំ ឬបង្ហាញពីខ្លួនគាត់ថា ជា"មនុស្សសុចរិត"នោះឡើយ (សូមមើលក្នុង ៣៤:២១) ។ នៅទីនេះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បានអំពាវនាវរកទ្រង់ដោយនិយាយថា គាត់គឺជាជនរងគ្រោះម្នាក់ដែលគ្មានទោសនោះឡើយ ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺជាគូនឹងទំនុកដំកើងជំពូក ៣៦ ដែលមានទីតាំងស្ថិតនៅចន្លោះកណ្ដប្រាជ្ញា២នៃព្រះគម្ពីរទំនុកដំកើង (ជំពូក ៣៤ និង ៣៧ ហើយសូមមើលសេចក្ដីផ្ដើមព្រះគម្ពីរទំនុកដំកើងជំពូក ៣៤–៣៧) ។ ព្រះគម្ពីរទំនុកដំកើងទាំង២ជំពូកនេះ (៣៥–៣៦) បានរំឭកពីភាពភ័យខ្លាចនិងអន្តរាយនៃជីវិត ដែលស្ថិតនៅកណ្ដាលពួកបណ្ដាជនទាំងឡាយណា ដែលភ្នែករបស់ពួកគេគ្មានសេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់(មើល ទដ ៣៦:១) ប៉ុន្តែផ្ទុយមកវិញព្រះគម្ពីរនេះបានធ្វើបន្ទាល់ពីភាពសុខសាន្តរបស់ព្រះអ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ា (ធៀបនឹង ៣៤:៧) និងពួកមនុស្សសុចរិត (មើលក្នុង ៣៥:២៤,២៨ ៣៦:៦,១០) ។

គេបានគិតថា នៅដើមល្បះ២ដំបូងនៃប្រយោគក្នុងជំពូកនេះ ដែលមានកំណាព្យហេព្រើរ៤ក្នុងល្បះនិមួយៗ (មើល ខ.១–៣ និង ៤–៦) គឺមានតុល្យភាពជាមួយគ្នានឹងល្បះ២ ដែលមាន៤ឃ្លាចុងក្រោយ (ខ.២២–២៥,២៦–២៧) ។ នៅចំណុចកណ្ដាលនៃជំពូកនេះដែលមាន៧ឃ្លាក្នុង១ល្បះ (មើល ខ.១១–១៦) បានលេចចេញការប្រឆាំងទាស់របស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង ចំពោះគូសត្រូវរបស់គាត់ ។ នៅបន្ទាត់ចុងក្រោយ (ខ.២៨) ពណ៌នាពីការសរសើរដំកើង (មើលការពន្យល់ ៧:១៧) ។

**៣៥:១–៣** នៅក្នុងខទាំងនេះ គឺជាការអំពាវនាវសុំជំនួយមកពីព្រះអម្ចាស់ ដែលទ្រង់ជាមេទ័ពនិងជាស្ដេច (សូមមើលក្នុង នក ១៥:១២–១៨) ដែលជាព្រះរបស់ស្ដេចដាវីឌ ។ សូមមើលទំនាក់ទំនងនៃ ខ.២២–២៥ ក្នុងការពន្យល់របស់ខ.ទាំងអស់នោះ ។

**៣៥:២** *ខែលតូចធំ* គេប្រើវត្ថុទាំងនោះដើម្បីការពារខ្លួន ។ សូមមើលឃ្លាដែលនិយាយថាព្រះយេហូវ៉ាទ្រង់ជា "ខែល" របស់អ្នកនិពន្ធក្នុង ៣:៣ ៧:១០ ១៨:២,៣០ ២៨:៧ ៣៣:២០ ៥៩:១១ ៨៤:៩,១១ ៨៩:១៨ ១១៥:៩–១១ ១១៩:១១៤ ១៤៤:២ ។ *ក្រោកឡើង* សូមមើលការពន្យល់ក្នុង ៣:៧ ។

**៣៥:៣** *ងាលំពែង* គឺងាលំពែងដើម្បីវាយប្រហារ ។ សូមមើលក្នុង ហប

សូមមានបន្ទូលមកព្រលឹងទូលបង្គំថា
ព្រះអង្គជាសេចក្ដីសង្គ្រោះនៃទូលបង្គំ[ជ]
[4]សូមឱ្យអស់អ្នកដែលប៉ងអាក្រក់ដល់ព្រលឹងទូលបង្គំ[ឈ]បាន
ទៅជាមានសេចក្ដីខ្មាស[ញ] ហើយអាប់យសទៅ[ដ]
សូមឱ្យអស់អ្នកដែលគិតប្រទូសរ៉ាយដល់ទូលបង្គំបានត្រូវ
ថយចេញ[ឋ] ដោយខ្មាសវិញ
[5]សូមឱ្យគេបានដូចជាចំបើង[ឌ]ដែលខ្យល់ផាត់ទៅ
ហើយឱ្យទេវតានៃព្រះយេហូវ៉ា[ឍ]ដេញតាមគេផង
[6]សូមឱ្យផ្លូវគេបានងងឹត ហើយរអិល
ព្រមទាំងមានទេវតានៃព្រះយេហូវ៉ាដេញតាមគេដែរ
[7]ដ្បិតគេបានលាក់អន្ទាក់[ណ]នៅក្នុងរណ្ដៅដើម្បីចាប់ទូលបង្គំ
ដោយឥតហេតុ[ត] គេបានជីករណ្ដៅ[ថ]ទាក់ព្រលឹងទូលបង្គំ
ដោយឥតហេតុ
[8]សូមឱ្យសេចក្ដីហិនវិនាសលោមកលើគេ
ដោយឥតដឹងខ្លួន[ទ] ហើយឱ្យអន្ទាក់ដែលគេបានលាក់នោះ
ជាប់ខ្លួនគេវិញ សូមឱ្យគេធ្លាក់ទៅជាប់អន្ទាក់[ធ]នោះ
ហើយវិនាសទៅផង
[9]នោះព្រលឹងទូលបង្គំនឹងមានសេចក្ដីអំណរ[ន]ក្នុងព្រះយេហូវ៉ា
ហើយនិងមានសេចក្ដីរីករាយ
ដោយសេចក្ដីសង្គ្រោះរបស់ទ្រង់[ប]
[10]អស់ទាំងឆ្អឹងនៃទូលបង្គំនឹងពោលថា
ឱព្រះយេហូវ៉ាអើយ តើមានអ្នកណាដូចទ្រង់[ផ]
ដែលទ្រង់ជួយមនុស្សក្រីក្រឱ្យរួចពីអ្នកដែលខ្លាំងជាង[ព]ខ្លួន
អើ ទាំងពួកក្រីក្រនិងមនុស្សកំសត់[ភ]ឱ្យរួចពីអ្នករឹបជាន់ខ្លួន

**៣៥:៣** ជ ទដ ២៧:១
**៣៥:៤** ឈ ទដ ៣៨:១២ ៤០:១៤ យរ ៤:៣០ ញ ទដ ៦៩:៦,១៩ ៧០:២ ៨៣:១៧ អស ៤៥:១៦ មឡ ១២:៩ ដ ទដ ២៥:៣ ឋ ទដ ១២៩:៥
**៣៥:៥** ឌ យប ១៣:២៥ ទដ ១:៤ ឍ ទដ ៣៤:៧
**៣៥:៧** ណ យប ១៨:៨ ត ទដ ៧:៤ ថ យប ៩:៣១ ទដ ៧:១៥ ៥៥:២៣
**៣៥:៨** ទ អស ៤៧:១១ ១ថន ៥:៣ ធ ទដ ៧:១៥
**៣៥:៩** ន ទដ ២:១១ លក ១:៤៧ ប ទដ ៩:១៤ ១៣:៥ ២៧:១
**៣៥:១០** ផ នក ៩:១៤ ទដ ១៨:៣១ ១១៣:៥ ព ទដ ១៨:១៧ ភ ទដ ១២:៥ ៣៧:១៤ ៧៤:២១ ៨៦:១ ១០៩:១៦ ១៤០:១២ អស ៤១:១៧
**៣៥:១១** ម នក ២៣:១ មថ ២៦:៦០

[11]មានសាក្សី[ម]កោងលើកគ្នាឡើង
គេចោទសួរពីរឿងដែលទូលបង្គំមិនដឹង
[12]គេប្រព្រឹត្តការអាក្រក់ដល់ទូលបង្គំ ស្នងនឹងការល្អ[យ]
ដើម្បីឱ្យព្រលឹងទូលបង្គំត្រូវនៅតែឯង
[13]តែឯទូលបង្គំ កាលគេបានឈឺ
នោះទូលបង្គំបានស្លៀកពាក់ សំពត់ធ្មៃ[រ]
ទូលបង្គំបានសំដែងសេចក្ដីទុក្ខ ដោយតមអត់អាហារ[ល]
ហើយសេចក្ដីអធិស្ឋានរបស់ទូលបង្គំបានត្រឡប់ចូលមក
ក្នុងទ្រូងខ្លួនវិញ
[14]ទូលបង្គំបានប្រព្រឹត្ត បែបដូចជាអ្នកនោះជាសំឡាញ់ឬជា
បងប្អូន ទូលបង្គំបានឱនខ្លួនដោយសេចក្ដីសោក
ដូចជាអ្នកដែលកាន់ទុក្ខ[វ]ចំពោះម្ដាយ
[15]តែក្នុងគ្រាដែលទូលបង្គំកើតមានសេចក្ដីទំនាស់ចិត្ត[ស]
នោះគេបានអរសប្បាយវិញ ព្រមទាំងប្រជុំគ្នាផង
មនុស្សចង្រៃនោះ គេប្រជុំគ្នាទាស់នឹងទូលបង្គំ
តែទូលបង្គំមិនបានដឹងខ្លួនសោះ
គេបានហែក[ហ]ទូលបង្គំឥតឈប់ឈរ
[16]គេបានសំញែងធ្មេញ[ឡ]ដាក់ទូលបង្គំ ដូចជាពួកអ្នកមាន
ពុត ដែលប្រមាថក្នុងពេលលៀងលោមគ្នា[អ]
[17]ឱព្រះអម្ចាស់អើយ តើទ្រង់នឹងព្រងើយចំពោះគេដល់

**៣៥:១២** យ ទដ ៣៨:២០ ១០៩:៥ សភ ១៧:១៣ យរ ១៨:២០ **៣៥:១៣** រ ២សយ ៣:៣១ ១ពរ ២០:៣១ ទដ ៣០:១១ ៦៩:១១ ល យប ៣០:២៥ ទដ ៦៩:១០ ១០៩:២៤ **៣៥:១៤** វ ទដ ៣៨:៦ ៤២:៩ ៤៣:២ **៣៥:១៥** ស យប ៣១:២៩ ហ យប ១៦:១០ **៣៥:១៦** ឡ ទដ ២២:៧ មក ១០:៣៤ អ យប ១៦:៩ មក ៩:១៨ កច ៧:៥៤

៣:១១ ដែលនិយាយថា ព្រះអម្ចាស់ទ្រង់បានងាលំពែង ។ *ព្រលឹង* សូមមើលការពន្យល់ក្នុង ៦:៣ ។

**៣៥:៤–៦** នៅក្នុងខទាំងនេះ អ្នកនិពន្ធគាត់បានអំពាវនាវសូមឱ្យព្រះអង្គទ្រង់ដោះស្រាយចំពោះអ្នកដែលបៀតបៀនគាត់ ដោយការបំផ្លាញអស់ទាំងការដែលគេប្រព្រឹត្តហើយធ្វើឱ្យគេអសមត្ថភាព ។ សូមមើលទំនាក់ទំនងជាមួយ ខ.២៦-២៧ ក្នុងការពន្យល់ក្នុងខនោះ ។

**៣៥:៤** *អ្នកដែលគិតប្រទូសប្រ៉ាយដល់ទូលបង្គំ* មើលការពន្យល់ ៥:៩ ។

**៣៥:៥–៦** *ទេវតានៃព្រះយេហូវ៉ា* សូមមើលក្នុង ៣៤:៧ និងការពន្យល់ ។

**៣៥:៥** *ដូចជាចំបើង* សូមមើលការពន្យល់ក្នុង ១:៤ ។

**៣៥:៧–១០** នៅក្នុងខនេះ គឺជាការអំពាវនាវសូមឱ្យព្រះអង្គប្រឆាំងទាស់ចំពោះអ្នកដែលប្រឆាំងទាស់ចំពោះសេចក្ដីសង្គ្រោះរបស់ទ្រង់ (សូមមើលការពន្យល់ក្នុង ៥:១០) ដែលការនោះនឹងធ្វើឱ្យអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងសរសើរដំកើងចំពោះព្រះអម្ចាស់ (សូមមើលការពន្យល់ក្នុង ៧:១៧) ។

**៣៥:៧–៨** *បានដាក់អន្ទាក់ . . . រណ្ដៅ . . . ជីករណ្ដៅ . . . ធ្លាក់ទៅជាប់អន្ទាក់* សូមមើលក្នុង ៩:១៥ និងការពន្យល់ ។

**៣៥:៩** *ព្រលឹង* សូមមើលការពន្យល់ក្នុង ៦:៣ ។

**៣៥:១០** *មនុស្សក្រីក្រនិងមនុស្សកំសត់* សូមមើល ៣៤:៦ និងការពន្យល់ ។

**៣៥:១១–១៦** នៅក្នុងខទាំងនេះ គឺជាការចោទប្រកាន់មួយ គេបង់ថ្លៃនៃមិត្តភាពរបស់ទូលបង្គំដោយការនិយាយបង្កាច់បង្ខូច ។ ការចោទប្រកាន់នេះ គឺស្ថិតនៅក្នុងចំណុចកណ្ដាលនៃព្រះគម្ពីរជំពូកនេះ (សូមមើលការពន្យល់ក្នុង ៦:៦) ។

**៣៥:១២** *ព្រលឹង* សូមមើលការពន្យល់ក្នុង ៦:៣ ។

**៣៥:១៣** *សំពត់ធ្មៃ* សូមមើលការពន្យល់ក្នុង ៣០:១១ ។ *តមអត់* បង្ហាញពីការឈឺចាប់និងទុក្ខព្រួយ (សូមមើលក្នុង ៦៩:១០) ។

**៣៥:១៥** *សេចក្ដីទំនាស់ចិត្ត* សេចក្ដីទំនាស់ចិត្តនោះមិនមែនជារឿងខុសនោះឡើយ ។ ដោយសារកាលៈទេសៈពេលនោះបានធ្វើឱ្យគាត់ធ្លាក់ចុះ (សូមមើលក្នុង ៩:៣ ២៧:២ ៣៧:២៤ ៥៦:១៣ ១១៩:១៦៥) ។

**៣៥:១៦** *សំញែងធ្មេញ* ការនេះចង់និយាយសំដៅលើការព្យាបាទ (សូមមើលក្នុង ៣៧:១២ បទ ២:១៦) ។

**៣៥:១៧–២១** ជាថ្មីម្ដងទៀត នៅក្នុងខទាំងនេះបាននិយាយពីការអំពាវនាវសូមសេចក្ដីសង្គ្រោះមកពីព្រះយេហូវ៉ា ដោយភ្ជាប់មកជាមួយការសរសើរដំកើង (សូមមើលក្នុង ខ.១៨) ។

កាលណាទៀត[ក] សូមដោះព្រលឹងទូលបង្គំឱ្យរួចពីការ
បំផ្លាញរបស់គេ ហើយដួងជីវិត[ខ]នៃទូលបង្គំឱ្យរួចពីសិង្ហ[គ]
១៨ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ នៅក្នុងពួកជំនុំធំ[ឃ]
ទូលបង្គំនឹងសរសើរដល់ទ្រង់[ង] នៅកណ្ដាល[ច]មហាជន
១៩ សូមកុំឱ្យពួកខ្មាំងសត្រូវ[ឆ]របស់ទូលបង្គំមានសេចក្ដីអំណរ
ដោយឈ្នះទូលបង្គំឡើយ ក៏កុំឱ្យពួកអ្នកដែលស្អប់ទូលបង្គំ
ដោយឥតហេតុ[ជ]បានមិចភ្នែកដាក់គ្នាដែរ[ឈ]
២០ ដ្បិតគេមិននិយាយដោយសេចក្ដីមេត្រីទេ
គឺគេគិតតែបង្កើតសេចក្ដីភូតភរ[ញ]ចំពោះមនុស្សស្ងប់រំងាប់
នៅក្នុងស្រុកវិញ
២១ អើ គេហាមាត់ធំ[ដ]ទាស់នឹងទូលបង្គំ ដោយថា ន៏ ន៏[ឋ]
ភ្នែកយើងបានឃើញច្បាស់ហើយ
២២ ឱព្រះយេហូវ៉ាអើយ ទ្រង់បានឃើញ[ឌ]ដែរ
សូមកុំនៅស្ងៀមឡើយ ឱព្រះអម្ចាស់អើយ
សូមទ្រង់កុំគង់ឆ្ងាយ[ឍ]ពីទូលបង្គំឱ្យសោះ
២៣ សូមទ្រង់រំពូកឡើង[ណ] ហើយតើន[ត]មកវិនិច្ឆ័យទូលបង្គំ
ដោយយុត្តិធម៌ ឱព្រះដ៏ជាព្រះអម្ចាស់នៃទូលបង្គំអើយ
សូមវិនិច្ឆ័យរឿងក្ដី[ថ]នៃទូលបង្គំផង
២៤ ឱព្រះយេហូវ៉ាដ៏ជាព្រះនៃទូលបង្គំអើយ
សូមវិនិច្ឆ័យទូលបង្គំតាមសេចក្ដីសុចរិតរបស់ទ្រង់
សូមកុំឱ្យគេមានសេចក្ដីអំណរដោយឈ្នះ[ទ]ទូលបង្គំឡើយ
២៥ កុំឱ្យគេគិតក្នុងចិត្តថា ន៏[ធ] សមដូចយើងប្រាថ្នា
ហើយកុំឱ្យគេថា យើងបានលេបវាបាត់ហើយ[ន]
២៦ ឯអស់អ្នកដែលអរសប្បាយ[ប]ដោយសេចក្ដីអន្តរាយ[ផ]របស់
ទូលបង្គំ នោះសូមឱ្យគេទៅជាមានសេចក្ដីខ្មាស[ព] ហើយ
ជ្រប់មុខចុះ ឯអស់អ្នកដែលលើកគ្នាទាស់នឹងទូលបង្គំ[ភ]
នោះសូមឱ្យគេហ៊ុំមហា ដោយសេចក្ដីខ្មាសនឹងអាប់យសទៅ
២៧ តែអស់អ្នកដែលកាន់ខាងសេចក្ដីសុចរិត[ម]របស់ទូលបង្គំ
សូមឱ្យគេបានស្រែកហ៊ោឡើងដោយអំណរ[យ] ហើយ
សប្បាយវិញ អើ សូមឱ្យគេបានពោលជានិច្ចថា
សូមឱ្យព្រះយេហូវ៉ាបានថ្កើងរុងរឿងឡើង
ដែលទ្រង់សព្វព្រះហឫទ័យ[រ]ចំពោះសេចក្ដីចំរើននៃអ្នក
បំរើទ្រង់[ល]
២៨ យ៉ាងនោះ អណ្ដាទូលបង្គំនឹងថ្លែងប្រាប់ពីសេចក្ដី
សុចរិត[វ]របស់ទ្រង់
ហើយពីសេចក្ដីសរសើរនៃទ្រង់ជាដរាបរាល់ថ្ងៃ[ស]។

**៣៥:១៧** ក ទដ ៦:៣ ខ ទដ ២២:២០ គ ទដ ២២:២១ ៥៧:៤ ៥៨:៦ **៣៥:១៨** ឃ ទដ ២២:២៥ ង ទដ ២២:២២ ច ទដ ៤២:៤ ១០៩:៣០ **៣៥:១៩** ឆ ទដ ៩:១៣ ជ ខ.៧ ទដ ៣៨:១៩ ៦៩:៤ យហ ១៥:២៥ ឈ សភ ៦:១៣ ១០:១០ **៣៥:២០** ញ ទដ ៣៨:១២ ៥៥:២១ យរ ៩:៨ មីក ៦:១២ **៣៥:២១** ដ យប ១៦:១០ ឋ ទដ ៤០:១៥ ៧០:៣ អគ ២៥:៣ **៣៥:២២** ឌ នក ៣:៧ ទដ ១០:១៤ ឍ ទដ ១០:១ **៣៥:២៣** ណ ទដ ៧:៦ ៨០:២ ត ទដ ១៧:១៣ ថ ១សយ ២៤:១៥ **៣៥:២៤** ទ ទដ ២២:១៧ **៣៥:២៥** ធ ខ.២១ ន ទដ ១២៤:៣ សភ ១:១២ បទ ២:១៦ **៣៥:២៦** ប ទដ ២២:១៧ ផ ទដ ៤:១ ព យប ៨:២២ ទដ ១០៩:២៩ មីក ៧:១០ ភ យប ១៩:៥ ទដ ៣៨:១៦ **៣៥:២៧** ម ទដ ៩:៤ យ ទដ ២០:៥ ៣៣:៣ រ ទដ ១៤៧:១១ ១៤៩:៤ ល យប ១៧:៣ **៣៥:២៨** វ ទដ ៥:៨ ៥១:១៤ ស ទដ ៧១:១៥,២៤ ៧២:១៥

**៣៥:១៧** *ដល់កាលណាទៀត* សូមមើលការពន្យល់ក្នុង ៦:៣ ។ *សិង្ហ* សូមមើលការពន្យល់ក្នុង ៧:២ ។
**៣៥:១៨** *ពួកជំនុំ* សូមមើលការពន្យល់ក្នុង ១:៥ ។
**៣៥:១៩** *ឥតហេតុ* សូមមើលក្នុង ខ.១១–១៧ ។ ជាញឹកញាប់ពាក្យនេះក៏មានប្រើនៅក្នុងកន្លែងផ្សេងៗទៀតដែរក្នុងព្រះគម្ពីរទំនុកដំកើង (សូមមើល ក្នុង ៣៨:១៩ ៦៩:៤ ១០៩:៣ ១១៩:៧៨,៨៦,១៦១ ក៏សូមមើលក្នុង បទ ៣:៥២) ។ *ពួកអ្នកដែលស្អប់ទូលបង្គំ ដោយឥតហេតុ* សូមមើលក្នុង ៦៩:៤ គេមិនបានដឹងថា តើអត្ថបទមួយណាក្នុងចំណោមអត្ថបទទាំងនេះដែលនឹងនិយាយនៅក្នុង យហ ១៥:២៥ នោះទេ ។ អត្ថបទទាំង២នេះ (ទដ ៣៥:១៩, ៦៩:៤) គឺនិយាយសំដៅលើពេលវេលានិងបទពិសោធរបស់ព្រះយេស៊ូវ (ប៉ុន្តែសូមមើលក្នុងសេចក្ដីផ្ដើម ទដ ៦៩) ។
**៣៥:២១** *ន៏ ន៏* សូមមើលក្នុង ខ.២៥ និងការពន្យល់ក្នុង ៣:២ ។
**៣៥:២២–២៥** នៅក្នុងខនេះ គឺត្រឡប់មកនិយាយពីការអំពាវនាវដល់ព្រះយេហូវ៉ាកាលពីដើមឃ្លា (មើលក្នុង ខ.១–៣) ដើម្បីសូមឱ្យទ្រង់បានក្រោកឡើងដើម្បីសងសឹកចំពោះហេតុរបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង ហើយ "វិនិច្ឆ័យ" ដល់អ្នកណាដែលព្យាបាទនិងបៀតបៀនពួកគេ ។
**៣៥:២២** *សូមកុំនៅស្ងៀមឡើយ* គឺចង់មានន័យថា កុំខ្ជិលឡើយ (សូមមើលក្នុង ២៨:១ និងការពន្យល់ ៨៣:១ ១០៩:១) ។
**៣៥:២៣** *សូមទ្រង់រំពូកឡើង* មើលការពន្យល់ ៧:៦ ។ *តើន* មើលការពន្យល់ក្នុង ៣:៧ ។
**៣៥:២៤** *សេចក្ដីសុចរិត* សូមមើលការពន្យល់ក្នុង ៤:១ ។
**៣៥:២៥** *លេប* សូមមើលក្នុង ១២៤:៣ ។
**៣៥:២៦–២៧** ជាថ្មីម្ដងទៀត (សូមមើលក្នុង ខ.៤–៦) នៅក្នុងខនេះអ្នកនិពន្ធបានអំពាវនាវសូមឱ្យព្រះអម្ចាស់ទ្រង់នាំ "សេចក្ដីខ្មាស" និង "អាប់យស" មកលើពួកខ្មាំងសត្រូវដែលជាគូវិវាទរបស់គាត់ ។ សំរាប់ទំរង់ទាំង២នេះ និងសាច់រឿងនេះ សូមធៀបជាមួយ ៤០:១៤–១៦ ។
**៣៥:២៦** *អស់អ្នកដែលអរសប្បាយ ដោយសេចក្ដីអន្តរាយរបស់ទូលបង្គំ* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ឃ្លានេះគឺជាការនិយាយដែលមានន័យដូចគ្នានឹងឃ្លា "អស់អ្នកដែលប៉ងអាក្រក់" (សូមមើលក្នុង ខ.៤) ។ *ហ៊ុំមហា* សូមមើលការពន្យល់ក្នុង ១០៩:២៩ ។
**៣៥:២៧** នៅក្នុងខនេះចង់និយាយថា សូមឱ្យអស់អ្នកដែលស្មោះត្រង់ចំពោះ "អ្នកបំរើ" របស់ព្រះយេហូវ៉ា (នៅទីនេះពាក្យនេះមានន័យដូចគ្នា និងពាក្យថា "អ្នកដែលព្រះចាក់ប្រេងតាំងឱ្យ" សូមមើលការពន្យល់ក្នុង ២:២) ចូរឱ្យបានអរសប្បាយឡើង និងសរសើរតម្កើងចំពោះព្រះអម្ចាស់ព្រះយេហូវ៉ាជាព្រះនៃយើង ។
**៣៥:២៨** នៅក្នុងខនេះ គឺជាសេចក្ដីបញ្ចប់មួយដោយមានការប្ដេជ្ញាចិត្ត ក្នុងការសរសើរតម្កើងដល់ព្រះយេហូវ៉ា (សូមមើលការពន្យល់ក្នុង ៧:១៧) ។ *សេចក្ដីសុចរិត* សូមមើលការពន្យល់ក្នុង ៤:១ ។

ទំនុកនៃស្ដេចដាវីឌ ជាអ្នកបំរើនៃព្រះយេហូវ៉ា
ដែលទ្រង់លើកសំរាប់មេភ្លេង ។

**៣៦** ការរំលងច្បាប់របស់មនុស្សអាក្រក់[ក] នោះសំដែងក្នុង
ចិត្តខ្ញុំថា នៅភ្នែកគេ[ខ] គ្មានសេចក្ដីកោតខ្លាច[គ] ដល់ព្រះទេ
២ ដ្បិតនៅភ្នែកគេក៏មើលខ្លួនជាគួរបញ្ចើចបញ្ចើវិញដោយ
ថា សេចក្ដីទុច្ចរិតរបស់ខ្លួន មិនដែលមានអ្នកណាឃើញ
ឬស្អប់ឡើយ[ឃ]
៣ អស់ទាំងពាក្យដែលចេញពីមាត់គេ[ង]
សុទ្ធតែជាសេចក្ដីទុច្ចរិត ហើយភូតភរទទេ[ច]
គេបានលែងមានប្រាជ្ញា[ឆ] ក៏មិនប្រព្រឹត្តល្អដែរ[ជ]
៤ គេដេកគិតបង្កើតការទុច្ចរិតនៅលើដំណេកខ្លួន[ឈ]
ក៏តាំងខ្លួនដើរ តាមផ្លូវដែលមិនល្អ[ញ]
គេមិនចេះខ្ពើមការអាក្រក់ឡើយ[ដ] ។
៥ ឱព្រះយេហូវ៉ាអើយ
សេចក្ដីសប្បុរសនៃទ្រង់ខ្ពស់ដល់ផ្ទៃមេឃ
សេចក្ដីស្មោះត្រង់[ឋ] នៃទ្រង់ក៏ដល់ពពកផង[ឌ]
៦ សេចក្ដីសុចរិត[ឍ] របស់ទ្រង់ដូចជាភ្នំនៃព្រះសេចក្ដីវិនិច្ឆ័យ
របស់ទ្រង់[ណ] ដូចមហាសមុទ្រដ៏ជ្រៅ[ត] ឱព្រះយេហូវ៉ាអើយ
ទ្រង់ទំនុកបំរុងទាំងមនុស្សនឹងសត្វផង[ថ]
៧ ឱព្រះអង្គអើយ សេចក្ដីសប្បុរសនៃទ្រង់ថ្លៃវិសេសយ៉ាង
ណាហ្ន៎[ទ] ពួកមនុស្សលោកក៏ជ្រកនៅម្លប់នៃស្លាបទ្រង់[ធ]
៨ គេនឹងបានឆ្អែត ដោយរបស់ដ៏បរិបូរក្នុងដំណាក់ទ្រង់[ន]

**៣៦:១** ក យប ២១:១៦ ខ យប ២៣:១៥ រម ៣:១៨ គ យរ ២:១៩ ៣៦:១៦,២៤ **៣៦:២** ឃ ចទ ២៩:១៩ **៣៦:៣** ង ទដ ១០:៧ ច យប ៥:១៣ ទដ ៥:៦,៩ ៤៣:១ ១៤៤:៨,១១ អស ៤៤:២០ **៣៦:៣** ឆ ទដ ៩៤:៨ ជ យរ ៤:២២ ១៣:២៣ អម ៣:១០ **៣៦:៤** ឈ សភ ៤:១៦ ញ អស ៦៥:២ ដ ទដ ៥២:៣ រម ១២:៩ **៣៦:៥** ឋ ទដ ៨៩:១ ១១៩:៩០ ឌ ទដ ៥៧:១០ ៧១:១៩ ៨៩:២ ១០៣:១១ ១០៨:៤ **៣៦:៦** ឍ ទដ ៥:៨ ណ ទដ ៦៨:១៥ ត លប ១:២ ៧:១១ ថ នហ ៩:៦ ទដ ១០៤:១៤ ១៤៥:១៦ **៣៦:៧** ទ ទដ ៦:៤ ធ រម ២:១២ ទដ ១៧:៨ ៥៧:១ ៩១:៤ **៣៦:៨** ន ទដ ៦៥:៤ អស ២៥:៦ យរ ៣១:១២,១៤ ប យប ២០:១៧ វវ ២២:១

**ទំនុកកំកើងជំពូក៣៦** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអំពាវនាវទូលសូមឱ្យព្រះយេហូវ៉ាទ្រង់បានការពារគាត់ជានិច្ច ។ អ្នកនិពន្ធក៏បានផ្ដោតលើពីការគ្មានព្រះរបស់ពួកមនុស្សអាក្រក់ ហើយក៏បាននិយាយពីសេចក្ដីមេត្តាករុណានៃព្រះយេហូវ៉ាដែរ ។ សូមមើលទំនាក់ទំនងព្រះគម្ពីរទំនុកដំកើងជំពូកនេះ ជាមួយ ទដ ៣៥ ក្នុងសេចក្ដីផ្ដើម ទដ ៣៤–៣៧ ។ នៅក្នុងជំពូកនេះមានសំណង់ប្រយោគខ្លី ដែលមានឃ្លា២មានចំណាប់ចុងចួន(ខ.១) បានបង្ហាញ ឬណែនាំពីលំដាប់ល្បះ៤ នៃកំណាព្យហេព្រើរ៣(ខ.២–៤,៥–៧ក,៧ខ–៩,១០–១២) ។ នៅសម័យកាលក្រោយមកទៀត ពួកយូដាមានការនិយមប្រើប្រាស់ ខ.៧–១០ ក្នុងការអធិស្ឋាននៅពេលព្រឹកព្រលឹម ។

**៣៦ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ក្នុង ទដ ៤ត្រង់ចំណងជើង ។ *ជាអ្នកបំរើនៃព្រះយេហូវ៉ា* គឺមានន័យថា យើងគឺជាអ្នកបម្រើហ្លួងរបស់ទ្រង់ (សូមមើលការពន្យល់ ទដ ១៨ ត្រង់ចំណងជើង) ៣៥:២៧ និង ២សយ ៧:២០) ។

**៣៦:១** *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។ *គ្មានសេចក្ដីកោតខ្លាចដល់ព្រះ* ក្រុមមនុស្សនេះ គឺមានចរិតដូចគ្នានឹងក្រុមមនុស្សដែលអ្នកនិពន្ធបាននិយាយនៅក្នុង ជំពូក ៣៤ និង ៣៧ ដែរ ។ សូមមើលក្នុង ៥៥:១៩ លប ២០:១១ ។ ពួកគេមិនបានដឹង ឬមានគំនិតយកព្រះអង្គទុកក្នុងភ្នែករបស់ពួកគេឡើយ ដូច្នេះហើយទើបការជំនុំជម្រះដ៏សុចរិត និងអំណាចរបស់ព្រះនឹងតាមជាប់ពួកគេ ដ្បិតទ្រង់នឹងជំនុំជម្រះគេដោយសុចរិតបំផុត (សូមមើលការពន្យល់ក្នុង ១០:១) ។ លោកសាវកប៉ូលក៏បានប្រើខនេះដែរ (សូមមើលក្នុង រម ៣:១៨) ។

**៣៦:២–៤** នៅក្នុងខទាំងនេះ ពណ៌នាពីអត្តចរិតរបស់ពួកមនុស្សអាក្រក់ (សូមមើលក្នុង ១០:២–១១) ។

**៣៦:៣** *អស់ទាំងពាក្យដែលចេញពីមាត់គេ* សូមមើលការពន្យល់ ៥:៩ ។ *សុទ្ធតែ . . . ហើយភូតភរ* សូមមើលក្នុង ៣៥:២០ ។ *លែងមានប្រាជ្ញា* សូមមើលក្នុង ៩៤:៨–១១ សភ ២:៩–១១ ។ *មិនប្រព្រឹត្តល្អ* ការប្រព្រឹត្តរបស់មនុស្សអាក្រក់ផ្ទុយពីការប្រព្រឹត្តរបស់ដែលមានប្រាជ្ញា និងអ្នកដែលស្រឡាញ់ព្រះអម្ចាស់(មើលក្នុង ៣៤:១៤ ៣៧:៣,២៧ និងការពន្យល់ ៣៤:៨–១៤) ។

**៣៦:៤** *នៅលើដំណេកខ្លួន* ការចូលដំណេកនេះ គឺនៅពេលអ្នកណាម្នាក់គិតថាខ្លួនមានសេរីភាពគ្រប់គ្រាន់ ហើយគេបង្កើតគំរោងការណ៍សម្រាប់ពេលថ្ងៃទៀត ។ ពួកមនុស្សអាក្រក់ គេមិនបានសញ្ជឹងគិតពីក្រិត្យវិន័យរបស់ព្រះយេហូវ៉ា "ទាំងយប់ទាំងថ្ងៃនោះឡើយ" (សូមមើលក្នុង ១:២ និង ១១៩:៥៥) ហើយក៏មិនអនុញ្ញាត្តឱ្យពួកអ្នកដែលស្រឡាញ់ព្រះអង្គបង្ហាត់បង្រៀនគេនៅពេលយប់ដែរ (មើល ១៦:៧) ឬនៅជាមួយព្រះអង្គនៅពេលយប់ឡើយ (មើល ៤២:៨) គិតពីទ្រង់ (មើល ៦៣:៦) រំពឹងគិតលើសេចក្ដីសន្យារបស់ទ្រង់នោះឡើយ (មើល ១១៩:១៤៨) ។ *បង្កើតការទុច្ចរិត* មើល ៣៤:១៤ ៣៧:២៧ ហើយធៀបនឹង មីក ២:១ ។

**៣៦:៥–៧ក** នៅក្នុងខ.ទាំងនេះ គឺជាការពណ៌នាពីការទុកចិត្តចំពោះព្រះអម្ចាស់ ។

**៣៦:៥** *សេចក្ដីសប្បុរស . . . សេចក្ដីស្មោះត្រង់* ឃ្លានេះចង់និយាយសំដៅលើសេចក្ដីស្រឡាញ់ និងភាពស្មោះត្រង់របស់ទ្រង់ (ដូចជាមាននិយាយនៅក្នុង ៥៧:៣ ៦១:៧ ៨៥:១០ ៨៦:១៥ ៨៩:១៤ ១១៥:១ ១៣៨:២ សភ ៣:៣ ១៤:២២ ១៦:៦ ២០:២៨ និងការពន្យល់ក្នុង ៣:៧) ។ *ខ្ពស់ដល់ផ្ទៃមេឃ . . . ក៏ដល់ពពកផង* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់ផ្ដល់សេចក្ដីសប្បុរស និងសេចក្ដីស្មោះត្រង់របស់ទ្រង់ដល់គ្រប់ទាំងអស់ នៃការបង្កើតរបស់ទ្រង់គ្រប់ទីកន្លែងទាំងអស់ (សូមមើលក្នុង ៥៧:១០ ១០៨:៤) ។

**៣៦:៦** *សេចក្ដីសុចរិត . . . សេចក្ដីវិនិច្ឆ័យ* មើល ៣៣:៥ ៣៧:៦ ៨៩:១៤ ៩៧:២ ហស ២:១៩ និង អស ៩:៧ ៣៣:៥ យរ ៩:២៤ និងការពន្យល់ក្នុង ទដ ៤:១ ។ *ភ្នំនៃព្រះ . . . មហាសមុទ្រដ៏ជ្រៅ* ចង់និយាយថា សេចក្ដីសុចរិត និងសេចក្ដីវិនិច្ឆ័យនៃទ្រង់ខ្ពស់ភ្នំ ហើយជ្រៅដូចជាមហាសមុទ្រ ។

**៣៦:៧ក** *សេចក្ដីសប្បុរសនៃទ្រង់ថ្លៃវិសេស* សូមមើលក្នុង ខ.៥ និងការពន្យល់ក្នុង ៦:៤ ។

**៣៦:៧ខ–៩** នៅក្នុងខទាំងនេះចង់និយាយថា ព្រះអម្ចាស់ទ្រង់នឹងប្រទានពរដល់គ្រប់ទាំងអស់នៃស្នាព្រះហស្តរបស់ទ្រង់ ដែលទ្រង់បានបង្កើតមក (មើល ៣៣:៤–៥) ។ *ម្លប់នៃស្លាបទ្រង់* មើល ១៧:៨ និងការពន្យល់ ។

**៣៦:៨** *បានឆ្អែត . . . ផឹក* គឺមានន័យថា ព្រះអង្គទ្រង់នឹងប្រទានអាហារ និងទឹកប្រចាំដើម្បីឱ្យយើងបរិភោគ ។ *ដំណាក់* ដំណាក់នៅទីនេះគឺសំដៅលើដំណាក់ ឬនគររបស់ព្រះ ឧ.ដូចជានៅលើលោកិយនេះ ព្រះអង្គទ្រង់នឹង

ហើយទ្រង់នឹងឱ្យគេផឹកពីទន្លេ[ប]នៃសេចក្តីអំណររបស់ទ្រង់[ផ]
៩ ដ្បិតជ្រោះនៃជីវិត[ព] នោះនៅជាមួយនឹងទ្រង់
នៅក្នុងពន្លឺ[ភ]នៃទ្រង់ នោះយើងខ្ញុំនឹងបានភ្លឺ
១០ ឱសូមទ្រង់ចេះតែផ្តល់សេចក្តីសប្បុរស[ម]ដល់អ្នកដែល
ស្គាល់ទ្រង់តទៅ[យ] ហើយសេចក្តីសុចរិតរបស់ទ្រង់
ដល់អស់អ្នកដែលមានចិត្តទៀងត្រង់ផង[រ]
១១ សូមកុំឱ្យជើងរបស់មនុស្សឆ្មើងឆ្មៃ[ល] មកទាស់នឹងទូលបង្គំ
ឬដៃនៃមនុស្សអាក្រក់មកបណ្តេញទូលបង្គំឡើយ
១២ សូមឱ្យពួកអ្នកដែលប្រព្រឹត្តអាក្រក់នោះបានដួលចុះ
ឱ្យគេត្រូវទំលាក់ទៅឥតក្រោកឡើងវិញបានឡើយ[វ] ។

ទំនុកនៃស្តេចដាវីឌ

**៣៧** កុំឱ្យក្តៅចិត្ត ដោយព្រោះមនុស្សដែលប្រព្រឹត្ត
អាក្រក់ឡើយ ក៏កុំឱ្យច្រណែន[ក]នឹងពួកអ្នកដែលធ្វើការ

**៣៦:៨** ផ ទដ ២៣:២ ៦៣:៥ **៣៦:៩** ព ទដ ៨៧:៧ សភ ១០:១១ ១៦:២២ យរ ២:១៣ ភ ទដ ៤:៦ ២៧:១ ៧៦:៤ ១០៤:២ អស ២:៥ ៩:២ ៦០:១,១៩ យហ ១:៤ ១ពត ២:៩ **៣៦:១០** យ យរ ៩:២៤ ២២:១៦ រ ទដ ៧:១០ ១១:២ ៩៤:១៥ ១២៥:៤ **៣៦:១១** ល ទដ ៧១:៤ ១៤០:៤ **៣៧:១** ក សភ ៣:៣១ ២៣:១៧–១៨ **៣៦:១០** ម យរ ៣១:៣

ប្រទានអាហារគ្រប់គ្រាន់ដល់ជីវិតទាំងឡាយ (សូមមើលការពន្យល់ក្នុង ២៤:២) ។ *ទន្លេ* គឺសំដៅលើ "ផ្លូវទឹក" (សូមមើល យប ៣៨:២៥) ដែលទ្រង់នាំយកទឹកភ្លៀងចេញពី "ឃ្លាំង" របស់ទ្រង់ (សូមមើលក្នុង ៣៣:៧ យប ៣៨:៨–១១,២២,៣៧ យរ ១០:១៣) ។ សម្រាប់ការស្រោចពី "ដំណាក់ទ្រង់មក" (សូមមើល ១០៤:១៣ ៦៥:៩ អស ៣០:២៥ ហើយការស្រោចនោះតំណាងឱ្យព្រះពររបស់ព្រះអម្ចាស់មកពីស្ថានសួគ៌ មើល លប ៤៩:២៥ ចទ ៣៣:២៣) ។ រូបភាពជាឧទាហរណ៍ដ៏រស់រវើកនេះ គឺជាការពណ៌នាពីការគ្រប់គ្រងរបស់ព្រះអម្ចាស់ និងអំណោយទានជាទឹកពីលើស្ថានសួគ៌មកដើម្បីបំពេញទន្លេ និងស្ទឹងដែលមាននៅផែនដីនេះសម្រាប់ផ្តល់ជាជីវិត និងការរស់នៅរបស់ទាំងឡាយដែលទ្រង់បង្កើតមក នៅកន្លែងណាដែលទឹកនោះដល់ហើយទឹកទន្លេនោះ គឺជានិមិត្តរូបនៃ "ទឹកទន្លេនៃជីវិត" ដែលហូរចេញពីដំណាក់នៃទ្រង់ (មើល វវ ២២:១–២ និង អក ៤៧:១–១២) ។ *នៃសេចក្តីអំណរ* មានន័យថា នៅក្នុងដំណាក់នៃទ្រង់គឺពោរពេញដោយសេចក្តីអំណរអរសប្បាយ ។

**៣៦:៩** នៅក្នុងខនេះជាចំណុចសំខាន់បំផុត និងជាសេចក្តីសង្ខេបពី ខ.៥–៩ ផងដែរ ។ *ជ្រោះនៃជីវិត* សូមមើល យរ ២:១៣ ១៧:១៣ ។ សម្រាប់អ្នកមានបាបនោះ ព្រះអម្ចាស់ទ្រង់ប្រទានទឹករស់តាមរយៈព្រះយេស៊ូវគ្រីស្ទ (សូមមើល យហ ៤:១០,១៤) ។ *ពន្លឺនៃទ្រង់* សូមមើលក្នុង ២៧:១ និងការពន្យល់ ។ *ភ្លឺ* សំដៅការធ្លាប់ដឹង និងអំណរ ដូចជាមាននិយាយនៅក្នុង ១៦:១០ ២៧:១៣ ៣៤:៨,១២ ៤៩:៩,១៩ ៨៩:៤៨ ៩០:១៥ ១០៦:៥ ត្រង់ឃ្លាថា ("សេចក្តីអំណរ") យប ៩:២៥ ត្រង់ឃ្លា ("ឥតដែលឃើញ") ៤២:៥ សស ១:១៦ ("ធ្លាប់ដឹង") សស ៣:១៣ ("រីករាយ") សស ៦:៦ ("សេចក្តីរីករាយ") សស ៨:១៦ អស ៥៣:១០ បទ ៣:១ ។ *ពន្លឺ* មានន័យថា គ្រប់ទាំងអស់អាចរស់នៅបានក៏ដោយសារមានពន្លឺដែរ ។ សូមមើលទំណាក់ទំនងពន្លឺនិងជីវិតក្នុង ៤៩:១៩ ៥៦:១៣ យប ៣:២០ ៣៣:២៨,៣០ អស ៥៣:១១ ។

**៣៦:១០–១២** នៅក្នុងខទាំងនេះបានអធិស្ឋានថាៈ "សេចក្តីសប្បុរស" នៃទ្រង់ (ខ.៥) ហើយនិង"សេចក្តីសុចរិត"របស់ទ្រង់ (ខ.៦) ដែលបានបង្ហាញដល់គ្រប់ទាំងអស់នៃស្នាព្រះហស្តរបស់ទ្រង់ នោះគឺដើម្បីឱ្យគ្រប់ទាំងអស់នោះបានដឹង(ទទួលស្គាល់)ពីទ្រង់ ។ ប៉ុន្តែសូមកុំឱ្យ "ជើង" និង "ដៃ"របស់មនុស្សអាក្រក់មានជ័យជម្នះលើទូលបង្គំឡើយ (ទូលបង្គំគឺសំដៅលើស្តេចដាវីឌ សូមមើលការពន្យល់ក្នុង ៣៣:១៦) ។

**៣៦:១០** *សេចក្តីសប្បុរស* សូមមើលការពន្យល់ក្នុង ៦:៤ ។ *អស់អ្នកដែលស្គាល់ទ្រង់* សូមមើលក្នុង ៩:១០ និងការពន្យល់ ។ *សេចក្តីសុចរិត* សូមមើលការពន្យល់ក្នុង ៤:១ ។

**៣៦:១១** *មនុស្សឆ្មើងឆ្មៃ* សូមមើលការពន្យល់ក្នុង ៣១:២៣ ។

**៣៦:១២** នៅក្នុងខនេះ អ្នកនិពន្ធបានអធិស្ឋានដោយមានទំនុកចិត្តចំពោះព្រះអម្ចាស់ (សូមមើលការពន្យល់ក្នុង ៣:៨) ។ *បណ្តេញ* ប្រហែលនាំឱ្យស្លាប់ (សូមមើលការពន្យល់ក្នុង ១៣:៤) ។

**ទំនុកដំកើង ៣៧** នៅក្នុងជំពូកនេះគឺជាសេចក្តីបង្រៀនមួយដែលប្រកបដោយគតិបណ្ឌិតរបស់អ្នកដែលស្រឡាញ់ព្រះ (សូមមើល "ប្រាជ្ញា" ផ្សេងៗទៀតដែលមាននិយាយនៅក្នុងព្រះគម្ពីរ ក្នុង ទដ ៣៤:៨–២២ ជំពូក ៤៩,១១២ និងបទគម្ពីរទំនុកដំកើង១ចំនួនទៀតដូចជា ជំពូក ១,៧៣,៩១ ៩២:៦–៩,១២–១៥ ជំពូក ១១១,១១៩,១២៧–១២៨,១៣៣) ។ ផ្ទៃរឿងព្រះគម្ពីរទំនុកដំកើងជំពូកនេះបានសង្កត់ធ្ងន់ទៅលើភាពខុសគ្នា រវាងពួកមនុស្សអាក្រក់ និងមនុស្សសុចរិត ដែលមាននិយាយនៅក្នុង ទដ ជំពូក ៣៦ ។ សេចក្តីថ្លែងការណ៍នៅកណ្តាលជំពូកនេះគឺ "នោះនឹងបានផែនដីជាមរដក" (មើលក្នុង ខ.៩,១១,២២,២៩) ។ តើអ្នកណានឹងរស់នៅដោយអំណរមកពីព្រះអម្ចាស់ក្នុងទឹកដីសន្យា ? ជាមនុស្សអាក្រក់ (ខ.១២) មនុស្សដែលបង្កើតការអាក្រក់ (៧,៣២) ជាអ្នកដែលខ្ចីគេឥតសងវិញ (ខ.២១) ជាអ្នកប្រើអំណាចដើម្បីបានប្រយោជន៍ផ្ទាល់ខ្លួន (ខ.១៤) ជាអ្នកដែលមើលទៅផ្លូវរបស់គេហាក់បីដូចជាចម្រើន (ខ.៧,១៦,៣៥) ឬជាមួយជាមនុស្សសុចរិត ជាអ្នកដែលមានការទុកចិត្តចំពោះព្រះអម្ចាស់ (ខ.៣,៥,៧,៣៤) ជាមនុស្សរាបសារ (ខ.១១) ជាមនុស្សទៀតត្រង់ (ខ.១៨,៣៧) ជាមនុស្សដែលមានគុណ (ខ.២១,២៦) ជាមនុស្សគ្រប់លក្ខណ (ខ.៣៧) ជាមនុស្សដែលមានសេចក្តីសុខសាន្តត្រាណ (ខ.៣៧) និងជាមនុស្សដែលមាត់គេពោលចេញសុទ្ធតែប្រាជ្ញា ហើយរំពឹងគិតពីក្រឹត្យវិន័យរបស់ព្រះអម្ចាស់ទាំងយប់ទាំងថ្ងៃ (ខ.៣០–៣១) ។ សូមមើលអតចរិត្តរបស់ពួកមនុស្សអាក្រក់ ដែលប្រហាក់ប្រហែលគ្នានេះក្នុង ១០:២–១១ ៧៣:៤–១២ ហើយអតចរិត្តរបស់មនុស្សសុចរិតក្នុង ទដ ជំពូក ៤៩ ៧៣:១៨–២០ ។

លក្ខណៈសំណង់ប្រយោគនៅក្នុងទំនុកដំកើងជំពូកនេះ គឺមានចំណាប់ចុងចួន ដោយមាន២២មានភាពស៊ីគ្នាទៅនឹងតួរអក្សរនិមួយៗនៃរបស់ក្រមអក្សរ ទោះបីជាមានការប្រែប្រួលខ្លះ១ក៏ដោយ ។ ផ្ទៃរឿងសំខាន់គឺមាននិយាយនៅក្នុង ខ.១–១១ ហើយក៏បានពណ៌នាយ៉ាងល្អិតល្អន់ពី ខ.១២ រហូតដល់ចុងបញ្ចប់នៃជំពូកនេះតែម្តង ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះទាំងមូលត្រូវបានកាត់ផ្តាច់ដោយពាក្យសំដីដ៏ខ្លីរបស់ពួកមនុស្សអាក្រក់ (សូមមើលក្នុង ខ.១–២) និងការទំនុកបំរុងរបស់ព្រះអម្ចាស់ដល់ពួកមនុស្សសុចរិត (ខ.៣៩–៤០) ។ សូមមើលទំនាក់ទំនងព្រះគម្ពីរ ទដ ជំពូកនេះទៅនិង ទដ ៣៤–៣៦ ក្នុងសេចក្តីផ្តើម ទដ ៣៤–៣៧ ។

ទុច្ចរិតដែរ[ខ]
២ដ្បិតនៅបន្តិចទៀត គេនឹងត្រូវច្រូតកាត់ដូចជាស្មៅ[គ]
ហើយនិងក្រៀមស្វិតទៅ ដូចជាស្មៅខ្ចីដែរ[ឃ]។
៣ចូរទុកចិត្តនឹងព្រះយេហូវ៉ា
ហើយប្រព្រឹត្តការល្អចុះយ៉ាងនោះ
អ្នកនឹងបាននៅក្នុងស្រុក[ង]
ហើយចំអែតខ្លួនដោយសេចក្ដីពិត[ច]
៤ចូរយកព្រះយេហូវ៉ាជាសេចក្ដីអំណរ[ឆ]របស់អ្នក
នោះទ្រង់នឹងប្រទានឱ្យអ្នកបានដូចបំណងចិត្ត[ជ]
៥ចូរទុកដាក់ផ្លូវអ្នកនឹងព្រះយេហូវ៉ាចុះ
ថែមទាំងទុកចិត្ត[ឈ]ដល់ទ្រង់ផង នោះទ្រង់នឹងប្រោសឱ្យ
បានសំរេច
៦ទ្រង់នឹងឱ្យសេចក្ដីសុចរិត[ញ]របស់អ្នកបានផ្សាយចេញដូចជា
ពន្លឺ[ដ] ហើយសេចក្ដីយុត្តិធម៌របស់អ្នក
ដូចជាវេលាថ្ងៃត្រង់ផង
៧ចូរស្ងៀម[ឋ]នៅចំពោះព្រះយេហូវ៉ា ហើយរង់ចាំ[ឌ]ទ្រង់ចុះ
កុំឱ្យក្ដៅចិត្ត[ឍ] ដោយព្រោះអ្នកដែលចំរើនក្នុងផ្លូវគេ[ណ]
ឬមនុស្សដែលបង្កើតការអាក្រក់សំរេចបាននោះឡើយ[ត]។
៨ចូរឈប់ពីសេចក្ដីកំហឹង[ថ]ហើយបោះបង់សេចក្ដីឃោរ
ឃៅចោលចេញ កុំឱ្យក្ដៅចិត្តឡើយ[ទ]
ដ្បិតនោះនឹងនាំឱ្យប្រព្រឹត្តអាក្រក់វិញ
៩ពីព្រោះពួកអ្នកដែលធ្វើអាក្រក់
នឹងត្រូវកាត់ចេញ[ធ] តែអស់អ្នកដែលរង់ចាំ[ន]ព្រះយេហូវ៉ា
នោះនឹងបានផែនដីជាមរដក[ប]
១០ដល់បន្តិចទៀត មនុស្សអាក្រក់នឹងមិនមានទៀតទេ[ផ] អើ
អ្នកនឹងខំមើលកន្លែងគេ តែគេមិននៅទេ
១១ឯមនុស្សរាបសា គេនឹងបានផែនដីជាមរដក[ព]
ហើយនិងបានចិត្តរីករាយដោយសេចក្ដីក្សេមក្សាន្តដ៏
បរិបូរ[ភ]

**៣៧:១** ខ ទដ ៧៣:៣ សភ ២៤:១៩ **៣៧:២** គ ២ពវ ១៩:២៦ យប ១៤:២ ទដ ១០២:៤ អស ៤០:៧ ឃ ខ.៣៨ ទដ ៩០:៦ ៩២:៧ យក ១:១០ **៣៧:៣** ង ចទ ៣០:២០ ច អគ ៣៤:១៤ យហ ១០:៩ **៣៧:៤** ឆ យប ២៧:១០ ជ យប ៧:៦ ទដ ២១:២ ១៤៥:១៩ មថ ៦:៣៣ **៣៧:៥** ឈ ទដ ៤:៥ **៣៧:៦** ញ ទដ ១៨:២៤ ១០៣:១៧ ១១២:៣ ដ យប ១១:១៧ **៣៧:៧** ឋ នក ១៤:១៤ អស ៤១:១

ឌ ទដ ២៧:១៤ ៤០:១ ១៣០:៤ អស ៣៨:១៣ ហាព ៣:១៦ រម ៨:២៥ ឍ ខ.១ ណ យរ ១២:១ ត ទដ ២១:១១ ២៦:១០ ១១៩:១៥០ **៣៧:៨** ថ អភ ៤:៣១ កល ៣:៨ ទ ខ.១ **៣៧:៩** ធ ទដ ៣១:២២ ១០១:៨ ១១៨:១០ សភ ២:២២ ន អស ២៥:៩ ២៦:៨ ៤០:៣១ ៤៩:២៣ ៥១:៥ ប ខ.២២ ទដ ២៥:១៣ អស ៤៩:៨ ៥៧:១៣ មថ ៥:៥ **៣៧:១០** ផ យប ៧:១០ អគ ២៧:៣៦ **៣៧:១១** ព ជន ១៤:២៤ មថ ៥:៥ ភ លវ ២៦:៦ ជន ៦:២៦

**៣៧:១–២** សូមមើលក្នុង ខ.៧ និង ទដ ជំពូក ៧៣ ។

**៣៧:១** នៅក្នុងខ.នេះគឺស្ទើរតែដូចគ្នានឹង សភ ២៤:១៩ ដែរ ។

**៣៧:២** សូមមើលការពន្យល់ក្នុង ខ.២០។

**៣៧:៣** សូមមើលក្នុង ៣៤:៨–១៤ និងការពន្យល់ ។

**៣៧:៤** *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។

**៣៧:៥** *ចូរទុកដាក់* សូមមើលក្នុង ១ពត ៥:៧ ។

**៣៧:៦** *សេចក្ដីសុចរិតរបស់អ្នក* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់នឹងប្រទានភាពចម្រុងចម្រើននិងសុខសុវត្ថិភាពមកដល់យើង គឺអាស្រ័យលើសេចក្ដីស្មោះត្រង់របស់ "អ្នក"ចំពោះទ្រង់(សូមធៀបជាមួយ ខ.៩ ហើយមើលក្នុង សភ ៨:១៨ ២១:២១ ត្រង់ពាក្យថា "សេចក្ដីសុចរិត" ហើយក៏សូមមើលក្នុង អស ៤៨:១៨) ។ *សេចក្ដីសុចរិត... សេចក្ដីយុត្តធម៌* គឺមានន័យថា ព្រះទ្រង់នឹងប្រទានសេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌មកលើរាស្ត្រទ្រង់ (សូមមើលការពន្យល់ក្នុង ៣៦:៦) ។ *សេចក្ដីយុត្តិធម៌របស់អ្នក* អាចនិយាយម្យ៉ាងទៀតថា "សេចក្ដីសុចរិត"(ដូចជាមាននិយាយនៅក្នុង ទដ ៣៥:២៧ និងការពន្យល់) ។ សទិសន័យនៃពាក្យហេព្រើរ ដែលប្រើនៅទីនេះទោះទាំង "សេចក្ដីសុចរិត" និង "សេចក្ដីយុត្តធម៌" គឺសុទ្ធតែសំដៅលើសេចក្ដីមេត្តាករុណានៃព្រះ ដែលបានបើកសម្ដែងយ៉ាងច្បាស់ ចំពោះអ្នកណាដែលទ្រង់សព្វព្រះទ័យប្រទានពរ និងរំដោះដូចជាមាននិយាយនៅក្នុង អស ៥៩:៩ (ពាក្យទាំង២ដែលនិយាយនៅកន្លែងនេះ វាទាក់ទងនឹងពាក្យថា"ពន្លឺ") ហើយក្នុង អស ៥៩:១១ (ពាក្យថា "យុត្តិធម៌" វាទាក់ទងទៅនឹងពាក្យ "សេចក្ដីសង្គ្រោះ") ។ យោងទៅតាមពាក្យថា "សេចក្ដីសុចរិតរបស់អ្នក" ហើយនិងពាក្យ"សេចក្ដីយុត្តិធម៌/សេចក្ដីសុចរិត" ដែលនិយាយនៅក្នុងខនេះ គឺមានវាមានទំនាក់ទំនងជាមួយពាក្យ "សេចក្ដីសុចរិតរបស់អ្នក(របស់ព្រះ)" និងពាក្យ "សេចក្ដីយុត្តិធម៌របស់អ្នក(របស់ព្រះ)" ដែលមាននិយាយនៅក្នុង ៣៦:៦ ដែរ ។ វាគឺជា"សេចក្ដីសុចរិតរបស់ព្រះ" និងសេចក្ដី "យុត្តិធម៌របស់ព្រះ" ដែលបានធានារាប់រងចំពោះ "សេចក្ដីសុរិត" និង "សេចក្ដីយុត្តធម៌"របស់ពួកអ្នកដែល "ទុកចិត្តចំពោះទ្រង់" ។

**៣៧:៨** *សេចក្ដីកំហឹង . . . សេចក្ដីឃោរឃៅ* សេចក្ដីកំហឹងនិងសេចក្ដីឃោរឃៅ គឺជាតំរុយនៃការដែលព្រះអម្ចាស់ទ្រង់នឹងធ្វើទុក្ខបៀតបៀនចំពោះភាពចំរើនលូតលាស់ លើពួកមនុស្សអាក្រក់ដោយព្រោះតែពួកគេយកផលចំណេញលើពួកមនុស្សសុចរិត ។

**៣៧:៩** *អ្នកដែលរងចាំ* សូមមើលក្នុង ខ.៣៤ ។ *នោះនឹងបានផែនដីជាមរដក* នៅក្នុងឃ្លានេះមានន័យថា ពួកគេបានទទួលសិទ្ធិអំណាចមកពីព្រះ (ទាំងពួកគេ និងកូនចៅគេ) ដើម្បីឈានជើងចូលមកក្នុងទឹកដីសន្យាដែលជាប្រភពនៃធនធានជាច្រើន និងដើម្បីផ្គត់ផ្គង់ដល់ការរស់នៅរបស់រាស្ត្រទ្រង់ ហើយពួកអ្នកដែលរងចាំព្រះអម្ចាស់ដោយមានទំនុកចិត្តចំពោះទ្រង់នោះនឹងបានផែនដីជាមរដរ ហើយពួកមនុស្សដែលបែរចេញពីទ្រង់នោះនឹងគ្មានចំណែកឡើយ (សូមមើល ខ.១១,២២,២៩ ហើយធៀបជាមួយ យសជំពូក ៧) ។

**៣៧:១០** *ដល់បន្តិចទៀត* រយះពេលដ៏ខ្លីដែលបាននិយាយនៅកន្លែងនេះ គឺជានិមិត្តរូបមួយចង់បង្ហាញថា ការនោះវានឹងកើតឡើងមានជាពិតប្រាកដ(សូមមើលក្នុង ៥៨:៩ យប ២០:៥–១១ ហក ២:៦) ។

**៣៧:១១** សូមមើលក្នុង មថ ៥:៥ ។ *មនុស្សរាបសារ* មនុស្សរាបសារដែលនិយាយនៅទីនេះ គឺសំដៅលើមនុស្សដែលមានការបន្ទាបខ្លួនហើយទទួលស្គាល់ថា ពួកគេរស់នៅគឺដោយសារពឹងអាស្រ័យលើសេចក្ដីសប្បុរស និងព្រះគុណនៃព្រះអម្ចាស់ ហើយបដិសេធន៍មិនព្រមប្រព្រឹត្តអាក្រក់ទាស់នឹងអ្នកដទៃ ។ *សេចក្ដីក្សេមក្សាន្តដ៏បរិបូរ* នៅក្នុងឃ្លានេះនិយាយសំដៅលើព្រះពរដ៏ពិតមិនក្លែងបន្លំ ។

១២ ចំណែកមនុស្សអាក្រក់គេគិតគូរ[ម]ការទាស់នឹងមនុស្ស
សុចរិត ក៏សំញែងធ្មេញ[យ]ដាក់អ្នកនោះ
១៣ តែព្រះអម្ចាស់ទ្រង់នឹងសើចនឹងគេ ដ្បិតទ្រង់ជ្រាបថា
ថ្ងៃកំណត់របស់គេកាន់តែជិតដល់[រ]
១៤ ពួកមនុស្សអាក្រក់បានហូតដាវ[ល]ជាស្រេចហើយដំឡើង
ធ្នូ[វ]ទុក ដើម្បីនឹងទំលាក់មនុស្សទ័លក្រ[ស] ហើយនិងមនុស្ស
កំសត់ទុគតិ
ព្រមទាំងសំឡាប់អស់អ្នកដែលកាន់តាមផ្លូវទៀងត្រង់
១៥ តែដាវគេនឹងចាក់ចូលក្នុងចិត្តខ្លួនគេវិញ[ហ] ហើយធ្នូគេនឹង
ត្រូវបាក់[ឡ]
១៦ ឯរបស់បន្តិចបន្តួចនៃមនុស្សសុចរិត
នោះវិសេសជាជាងរបស់បរិបូរ[អ]នៃមនុស្សអាក្រក់ជា
ច្រើននាក់ទៅទៀត
១៧ ដ្បិតដៃនៃមនុស្សអាក្រក់នឹងត្រូវបាក់[ក]
តែព្រះយេហូវ៉ាទ្រង់ទប់ទល់[ខ]មនុស្សសុចរិត ។
១៨ ព្រះយេហូវ៉ាទ្រង់ជ្រាបនូវអស់ទាំងថ្ងៃរបស់មនុស្សទៀង
ត្រង់[គ] ហើយមរដករបស់គេនឹងនៅជាប់ជាដរាប[ឃ]
១៩ គេនឹងមិនត្រូវខ្មាសក្នុងគ្រាអាក្រក់ឡើយ
ហើយនៅវេលាអំណត់ នោះគេនឹងបានឆ្អែត ។
២០ តែមនុស្សអាក្រក់នឹងត្រូវវិនាសទៅ[ង]
ហើយពួកខ្មាំងនៃព្រះយេហូវ៉ា និងដូចជាខ្លាញ់កូនចៀម
គេនឹងត្រូវសូន្យបាត់ទៅ
គេនឹងឆេះទៅជាផ្សែងអស់រលីង[ច]
២១ ឯមនុស្សអាក្រក់គេខ្ចីឥតសងវិញឡើយ
តែមនុស្សសុចរិតគេមានគុណ ហើយក៏ឱ្យទានវិញ[ឆ]
២២ ដ្បិតអស់អ្នកដែលទទួលព្រះពរពីទ្រង់ នោះនឹងបានផែន
ដីជាមរដក តែអស់អ្នកដែលទ្រង់ដាក់បណ្តាសា[ជ]វិញនោះ
នឹងត្រូវកាត់ចោលចេញ[ឈ] ។
២៣ គឺព្រះយេហូវ៉ាដែលដំរូវ[ញ]អស់ទាំងដំហាននៃមនុស្សល្អ
ហើយទ្រង់សព្វព្រះហឫទ័យនឹងផ្លូវដែលគេដើរដែរ[ដ]
២៤ ទោះបើគេភ្លាត់ដួលគង់តែមិនត្រូវដួលទាំងស្រុងទេ[ឋ]
ដ្បិតព្រះយេហូវ៉ាទ្រង់ទ្រ[ឌ]អ្នកនោះដោយព្រះហស្ត
២៥ យើងពីដើមនៅក្មេង ឥឡូវនេះចាស់ហើយ
តែមិនដែលឃើញមនុស្សសុចរិតត្រូវលះបង់ចោល[ឍ]
ឬពូជពង្សគេសូមទាន[ណ]អាហារឡើយ
២៦ គេរមែងមានគុណជាដរាបរាល់ថ្ងៃ ព្រមទាំងឱ្យគេខ្ចី[ត]
ហើយពូជពង្សគេបានពរដែរ[ថ] ។
២៧ ចូរគេចចេញពីការអាក្រក់ ហើយប្រព្រឹត្តការល្អចុះ[ទ]
នោះអ្នកនឹងបាននៅជារៀងរាបដរាប[ធ]
២៨ ដ្បិតព្រះយេហូវ៉ាទ្រង់សព្វព្រះទ័យនឹងសេចក្តីយុត្តិធម៌

**៣៧:១២** ម ទដ ២:១ ៣១:១៣ យ យប ១៦:៩ ទដ ៣៥:១៦ ១១២:១០ **៣៧:១៣** រ ១សយ ២៦:១០ អគ ១២:២៣ **៣៧:១៤** ល ទដ ២២:២០ វ ទដ ១១:២ ស ទដ ៣៥:១០ **៣៧:១៥** ហ ទដ ៩:១៦ ឡ ១សយ ២:៤ ទដ ៤៦:៩ យរ ៤៩:៣៥ **៣៧:១៦** អ សភ ១៥:១៦ ១៦:៨ **៣៧:១៧** ក យប ៣៨:១៥ ទដ ១០:១៥ ខ ទដ ៤១:១២ ១៤០:១២ ១៤៥:១៤ ១៤៦:៧ **៣៧:១៨** គ យប ២៣:១០ ទដ ៤៤:២១ ឃ ខ.២៧,២៩ **៣៧:២០** ង ទដ ៣៤:២១ ច ទដ ៦៨:២ ១០២:៣ អស ៥១:៦ **៣៧:២១** ឆ លវ ២៥:៣៥ ទដ ១១២:៥ **៣៧:២២** ជ យប ៥:៣ ឈ ខ.៩ **៣៧:២៣** ញ ជន ១៤:៨ ទដ ១៤៧:១១ ដ យប ១១:១៥ ទដ ៧:៩ ៦៦:៩ **៣៧:២៤** ឋ ទដ ១៣:៤ ២៧:២ ៣៨:១៧ ៥៥:២២ ១១៩:១៦៥ សភ ៣:២៣ ១០:៩ ឌ ២របា ៩:៨ ទដ ៤១:១២ ១៤៥:១៤ **៣៧:២៥** ឍ ខ.២៨ លប ១៥:១ ហព ១៣:៥ ណ ទដ ១១១:៥ ១៤៥:១៥ មក ១០:៤៦ **៣៧:២៦** ត លវ ២៥:៣៥ ថ ចទ ២៨:៤ ទដ ១១២:២ **៣៧:២៧** ទ ទដ ៣៤:១៤ ២យហ ១:១១ ធ ជន ២៤:២១

**៣៧:១២** *មនុស្សសុចរិត* សូមមើលការពន្យល់ក្នុង ១:៥ ។ *សំញែ៉ងធ្មេញ* សូមមើលក្នុង ៣៥:១៦ និងការពន្យល់ ។

**៣៧:១៣** *ព្រះអម្ចាស់ទ្រង់នឹងសើច* សូមមើលក្នុង ២:៤ ។ *ដ្បិតទ្រង់ជ្រាបថា ថ្ងៃកំណត់របស់គេកាន់តែជិតដល់* នៅក្នុងឃ្លានេះមានការគួរឱ្យគត់សម្គាល់មួយគឺ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់មិនបាននិយាយនៅកន្លែងផ្សេងណាទៀតពីការដែលទ្រង់បំផ្លាញមនុស្សអាក្រក់នោះឡើយ ទោះបីជាគាត់បាននិយាយជាប្រយោលនៅក្នុង ខ.២២ ក៏ដោយ ។ អ្វីដែលពិតនោះគឺពួកមនុស្សអាក្រក់ "នឹងត្រូវកាត់ចេញ" ដែលពាក្យនេះតែងតែអះអាងនៅក្នុងគម្ពីរទំនុកដំកើង(សូមមើលក្នុង ខ.៩,២២,២៨,៣៤,៣៨ ហើយធៀបជាមួយ ខ.២,៨,១០,១៥,១៧,២០,៣៦,៣៨) ហើយព្រះអម្ចាស់ទ្រង់ក៏ជ្រាបពីការនេះដែរ ប៉ុន្តែ ចំណុចវិជ្ជមានរបស់ទ្រង់នៅទីនេះគឺទ្រង់ការពារ និងថែរក្សាដល់ពួកមនុស្សសុចរិត ។ *ថ្ងៃកំណត់របស់គេ* ឃ្លានេះចង់និយាយសំដៅលើថ្ងៃដែលទ្រង់នឹង"កាត់ពួកគេចេញ" ដូចជាមាននិយាយនៅក្នុង ១សយ ២៦:១០ ("ថ្ងៃកំណត់" តាមលក្ខណៈអក្សរសាស្ត្រគឺ "ពេលកំណត់" យប ១៨:២០ "ប្រវត្តិ" ។

**៣៧:១៤–១៥** *ដាវ . . . ធ្នូ . . . ដាវ . . . ធ្នូ* សូមមើល ៦៤:៣–៤,៧–៨ សភ ៣០:១៤ និងការពន្យល់ក្នុង ទដ ៥:៩ ។

**៣៧:១៤** *មនុស្សទាល់ក្រ ហើយនិងមនុស្សកំសត់ទុរគត* សូមមើល ៣៤:៦ និងការពន្យល់ ។

**៣៧:១៥** *ចាក់ចូលក្នុងចិត្ត* សូមមើលក្នុង ៤៥:៥ ។

**៣៧:១៦–១៧** *មនុស្សសុចរិត* សូមមើលការពន្យល់ក្នុង ១:៥ ។

**៣៧:១៨** *មនុស្សទៀងត្រង់* សូមមើល ខ.៣៧ និង ១៥:២ និងការពន្យល់ ។ *ជ្រាបនូវ* សូមមើលក្នុង ១:៦ ។

**៣៧:២០** *សូន្យបាត់ទៅ* គឺត្រូវសូន្យបាត់ទៅដូចជាស្មៅនិងផ្កាដែរ (សូមធៀបជាមួយ ខ.២ ៩០:៥–៦ ៩២:៧ ១០២:១១ ១០៣:១៥–១៦ យប ១៤:២ និងការពន្យល់ អស ៤០:៦–៧ យក ១:១០–១១) ។

**៣៧:២១** នៅក្នុងច.នេះគេអាចនិយាយម្យ៉ាងទៀតថា "ពួកមនុស្សអាក្រក់ខ្ចីគេ ហើយមិនសងគេវិញឡើយ ប៉ុន្តែពួកមនុស្សសុចរិតគេនឹងសងវិញ "(សូមមើលក្នុង ចទ ១៥:៦ ២៨:១២,៤៤)។

**៣៧:២៤** សូមមើលក្នុង សភ ២៤:១៦ ។

**៣៧:២៦** សូមមើលការពន្យល់ក្នុង ខ.២១ ។

**៣៧:២៧** *ចូរចេញពីការអាក្រក់ ហើយប្រព្រឹត្តការល្អចុះ* សូមមើលក្នុង ៣៤:១៤ និងការពន្យល់ ។

**៣៧:២៨** *ថែរក្សាគេអស់កល្បជានិច្ច* សូមមើលការពន្យល់ក្នុង ៤:៣ ។

ក៏មិនដែលបោះបង់ចោលពួកបរិសុទ្ធរបស់ទ្រង់ឡើយ[ន]
ទ្រង់ថែរក្សាគេអស់កល្បជានិច្ច
តែពូជរបស់មនុស្សអាក្រក់នឹងត្រូវកាត់ចេញវិញ[ប]
២៩ ពួកអ្នកសុចរិតនឹងបានស្រុកទុកជាមរដក[ផ]
ហើយនិងនៅក្នុងស្រុកនោះជានិច្ច[ព] ។
៣០ មាត់របស់មនុស្សសុចរិតពោលចេញសុទ្ធតែប្រាជ្ញា[ភ]
ហើយអណ្តាតគេក៏សំដែងជាសេចក្តីយុត្តិធម៌
៣១ ក្រិត្យវិន័យរបស់ព្រះនៃគេ នោះនៅក្នុងចិត្តឯជិហាននៃ
គេ[ម] ក៏នឹងមិនភ្លាំងភ្លាត់ឡើយ[យ]
៣២ មនុស្សអាក្រក់ឃ្លាំមើល[រ] មនុស្សសុចរិត[ល]
ហើយក៏រកសំឡាប់គេ
៣៣ ព្រះយេហូវ៉ាទ្រង់មិនទុកគេ ឱ្យនៅក្នុងកណ្តាប់ដៃមនុស្ស
អាក្រក់ឡើយ ក៏មិនឱ្យគេមានទោស[វ]ក្នុងកាលដែលត្រូវជំនុំ
ជំរះដែរ[ស] ។
៣៤ ចូររង់ចាំព្រះយេហូវ៉ា[ហ] ហើយកាន់តាមផ្លូវទ្រង់ចុះ[ឡ]
នោះទ្រង់នឹង ដំកើងអ្នក ឱ្យបានផែនដីជាមរដក
នៅគ្រាដែលមនុស្សអាក្រក់ត្រូវ
កាត់ចេញ[អ]នោះអ្នកនឹងបានឃើញ[ក]ហើយ
៣៥ យើងបានឃើញមនុស្សអាក្រក់មានអំណាចយ៉ាងសន្ធឹក
ហើយកំពុងតែពង្រីកធំឡើង[ខ]
ដូចជាដើមឈើខ្ចីដែលចំរើននៅទីកំណើតវា

**៣៧:២៨** ន ចទ ៧:៦ ទដ ១៨:២៥ ៩៧:១០ ប លប ១៧:១៤ ចទ ៣២:២៦ សភ ២:២២
**៣៧:២៩** ផ ខ.៩ សភ ២:២១ ព អស ៣៤:១៧
**៣៧:៣០** ភ ទដ ៤៩:៣ សភ ១០:១៣
**៣៧:៣១** ម ចទ ៦:៦ យប ២២:២២ យ ចទ ៣២:៣៥
**៣៧:៣២** រ ទដ ១០:៨ ល ទដ ១១:៥
**៣៧:៣៣** វ យប ៣២:៣ ទដ ៣៤:២២ ៧៩:១១ ស ២ពត ២:៩
**៣៧:៣៤** ហ ទដ ២៧:១៤ ឡ ទដ ១៨:២១
**៣៧:៣៤** អ ខ.៩ ក ទដ ៥២:៦
**៣៧:៣៥** ខ យប ៥:៣
**៣៧:៣៦** គ ខ.១០

៣៦ តែគេបាត់ទៅ ហើយមើល មិនមានគេទៀតឡើយ អើ
យើងបានស្វែងរកគេ តែមិនប្រទះសោះ[គ] ។
៣៧ ចូរចំណាំមើលមនុស្សគ្រប់លក្ខណ៍វិញ[ឃ]
ហើយពិចារណាមើល មនុស្សទៀងត្រង់ចុះ[ង]
ដ្បិតចុងបំផុតនៃមនុស្សនោះមានសេចក្តីសាន្តត្រាណ[ច]
៣៨ ឯពួកមនុស្សរំលងច្បាប់[ឆ]នឹងត្រូវវិនាសទៅជាមួយគ្នា[ជ]
ឯចុងបំផុតនៃមនុស្សអាក្រក់នោះនឹងត្រូវកាត់ចេញវិញ[ឈ]
៣៩ ឯសេចក្តីសង្គ្រោះ[ញ]នៃមនុស្សសុចរិតនោះមកពី
ព្រះយេហូវ៉ាក្នុងគ្រាដែលមានសេចក្តីលំបាកនោះទ្រង់
ជាទីអាងដល់គេ[ដ]
៤០ ព្រះយេហូវ៉ាទ្រង់ជួយ[ឋ]គេ ក៏ប្រោស[ឌ]ឱ្យរួច ទ្រង់ប្រោស
គេឱ្យរួចពីមនុស្សអាក្រក់ ព្រមទាំងជួយសង្គ្រោះ[ឍ]គេផង
ពីព្រោះគេបានពឹងជ្រក[ណ]ក្នុងទ្រង់ ។

ទំនុកនៃស្តេចដាវីឌ ដែលទ្រង់លើកទុកសំរាប់ជាសេចក្តីរំឭក ។

**៣៨** ឱព្រះយេហូវ៉ាអើយ
សូមកុំបន្ទោសទូលបង្គំក្នុងកាលដែលទ្រង់ខ្ញាល់

សភ ១២:៧ អស ៤១:១២ ដយ ១១:១៩ **៣៧:៣៧** ឃ ខ.១៨ លប ៦:៩ ទដ ១៨:២៥ ង ទដ ១១:៧ ច អស ៥៧:១–២ **៣៧:៣៨** ឆ ទដ ១:១ ជ ខ.២ ទដ ៧៣:១៩ ឈ ខ.៩ **៣៧:៣៩** ញ ទដ ៣:៨ ដ ទដ ៩:៩ **៣៧:៤០** ឋ ១រប ៥:២០ ទដ ២០:២ ឌ ទដ ៣៤:៧ ឍ ទដ ១៨:៤៨ ណ ទដ ២:១២

**៣៧:២៩** *ជានិច្ច* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអង្គទ្រង់នឹងឱ្យពួកគេ កូនចៅគេ និងចៅរបស់គេជំនាន់ក្រោយទៀតរស់នៅក្នុងទឹកដីនោះជារៀងរហូត ដែលការនេះផ្ទុយពីមនុស្សអាក្រក់ដែលមិនបានអ្វីសោះ (សូមមើលក្នុង ខ.២៨) ។

**៣៧:៣០** *ប្រាជ្ញា* សូមមើលក្នុង ១១៩:៩៨,១៣០ ចទ ៤:៦ ។

**៣៧:៣១** *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។ *មិនភ្លាំងភ្លាត់* មានន័យថា គេដើរក្នុងផ្លូវដ៏ត្រឹមត្រូវ (សូមមើលក្នុង ១៧:៥) ។

**៣៧:៣២** *ឃ្លាំមើល* សូមមើលក្នុង ១០:៨–៩ និងការពន្យល់ក្នុង ៧:២ ។ *រកសំលាប់គេ* ពួកមនុស្សអាក្រក់គេព្យាយាមរឹបអូសនិងវាយប្រហារ តាមរយៈសាក្សីក្លែងក្លាយក្នុងទីលានជំនុំជម្រះ (សូមមើលក្នុង ខ.៣៣) ។

**៣៧:៣៤** សូមមើលក្នុង ខ.៩ ។

**៣៧:៣៥–៣៦** សូមធៀបជាមួយ ខ.២៥–២៦ ។

**៣៧:៣៩–៤០** *មនុស្សសុចរិត . . . គេ* នៅក្នុងឃ្លានេះចង់និយាយថាសេចក្តីសង្គ្រោះរបស់ពួកមនុស្សសុចរិត មិនមែនបានមកពីមនុស្សអាក្រក់នោះឡើយ គឺមកពីព្រះអម្ចាស់វិញ ដ្បិតអីព្រះអម្ចាស់ទ្រង់ជាទីអាងដល់គេ ហើយជំនួសនឹងអ្វីដែលពួកមនុស្សអាក្រក់គេធ្វើ នោះព្រះអម្ចាស់ទ្រង់នឹងប្រទានទឹកដីសន្យាជាមរដកដល់ពួកមនុស្សសុចរិតថែមទៀតផង ។

**ទំនុកដំកើងជំពូក ៣៨–៤១** នេះគឺជាជំពូកទាំង៤ចុងក្រោយនៃទំនុកដំកើងវគ្គទី១ ដែលនៅក្នុងជំពូកទាំង៤នេះបានភ្ជាប់មកជាមួយនឹងផ្ទៃរឿងដ៏សាមញ្ញ (មើលសេចក្តីផ្តើមនៃទំនុកដំកើងទាំងនោះ) ។ នៅក្នុងចំណោមទំនុកដំកើងទាំង៤ជំពូកនេះ មាន១ជំពូកដែលនិយាយពីការលន់តួអំពើបាប ដែលទង្វើរបែបនេះមាននៅកន្លែងផ្សេងទៀតនៃព្រះគម្ពីរទំនុកដំកើងវគ្គទី១គឺមានតែនៅក្នុង ទដជំពូក ២៥ និង ៣២ ប៉ុណ្ណោះ (សូមមើលសេចក្តីផ្តើមព្រះគម្ពីរទំនុកដំកើងទាំង ២ជំពូកនោះ) ។ មានការគួរឱ្យកត់សម្គាល់១ ដែលមាននៅក្នុងកណ្ឌនៃប្រាជ្ញា (ជំពូក ៣៧) គឺអំពើបាបដែលនិយាយនៅទីនេះគឺសំដៅលើ "អំពើឆោតល្ងង់" (សូមមើលក្នុង ៣៨:៥) ។

**ទដ ៣៨** នៅក្នុងជំពូកនេះអ្នកនិពន្ធគាត់បានអំពាវនាវសូមឱ្យព្រះអង្គទ្រង់រំដោះ និងជួយឱ្យរួចពីការឈឺចាប់ដោយព្រោះជម្ងឺ ហើយការដែលនាំឱ្យព្រះអម្ចាស់ទ្រង់បន្ទោសនោះ គឺដោយអំពើបាបដែលស្តេចដាវីឌទ្រង់បានប្រព្រឹត្ត ។ គេមិនបានដឹងពីឱកាសឬហេតុផលនៃការច្រៀងបទនេះ និងជម្ងឺអ្វីឱ្យបានច្បាស់លាស់នោះឡើយ ។ ការរងទុក្ខរបស់ស្តេចដាវីឌគឺកាន់តែធ្ងន់ទៅៗដោយព្រោះពួកភឿនមិត្តសំឡាញ់របស់ទ្រង់បានបោះបង់និងរត់ចេញពីទ្រង់ (សូមមើលក្នុង ខ.១១) ហើយពួកខ្មាំងសត្រូវរបស់ទ្រង់បានយកឱកាសនេះដើម្បីបំផ្លាញដល់ទ្រង់ (សូមមើលក្នុង ខ.១២,១៦,១៩–២០) ។ តាមទំនៀមទំលាប់របស់គ្រីស្ទបរិស័ទ គេបានដឹងថាជំពូកនេះគឺជាជំពូក១ក្នុងចំណោមសៀវភៅច្បាប់ទាំង៧ដែលគេពេញនិយមប្រើ (សូមមើលសេចក្តីផ្តើមទំនុកដំកើងជំពូក ៦) ។ ដូចគ្នានឹងជំពូក ៣៣ដែរ នៅក្នុងគម្ពីរជំពូកនេះមានរហូតដល់ទៅ ២២ខ គឺដោយសារវាអាស្រ័យលើអក្សរក្រមភាសា

កំកុំវាយផ្ចាល់ទូលបង្គំ ដោយព្រះហឫទ័យក្ដៅឡើយ[ក]
២ដ្បិតព្រួញ[ខ]របស់ទ្រង់ជាប់គាំងនៅក្នុងខ្លួនទូលបង្គំ
ហើយព្រះហស្ដទ្រង់ក៏សង្កត់ទូលបង្គំខ្លាំងណាស់ផង
៣គ្មានកន្លែងណាក្នុងរូបសាច់ទូលបង្គំ ដែលមិនឈឺ[គ]នោះទេ
ដោយព្រោះសេចក្ដីខ្ញាល់របស់ទ្រង់
ក៏គ្មានសេចក្ដីសុខនៅក្នុងឆ្អឹង[ឃ]ទូលបង្គំដែរ
ដោយព្រោះបាបរបស់ទូលបង្គំ
៤ដ្បិតអំពើទុច្ចរិតរបស់ទូលបង្គំបានឡើងលិចក្បាល[ង]
ទូលបង្គំហើយ
ក៏ដូចជាបន្ទុកយ៉ាងធ្ងន់ ដែលទូលបង្គំទ្រាំមិនបាន[ច]
៥អ្នកទាំងរបួសនៃទូលបង្គំ សុទ្ធតែរលួយ
ហើយស្អុយដោយព្រោះអំពើឆោតខ្លៅរបស់ទូលបង្គំ
៦ទូលបង្គំឈឺ[ឆ] ហើយកោងខ្លួនចុះជាខ្លាំង
ទូលបង្គំដើរទាំងមានទុក្ខក្រាំជាដរាបរាល់ថ្ងៃ[ជ]
៧ដ្បិតទូលបង្គំមានសេចក្ដីរោលរាលពេញនៅក្នុងពោះ[ឈ]
ហើយគ្មានកន្លែងណាក្នុងរូបសាច់ទូលបង្គំដែលមិនឈឺ[ញ]
នោះឡើយ
៨ទូលបង្គំហេវ ហើយត្រូវជាំជាខ្លាំង[ដ] ទូលបង្គំបានថ្ងូរ[ឋ]
ដោយព្រោះសេចក្ដីថែថប់ក្នុងចិត្ត[ឌ] ។
៩ឱព្រះអម្ចាស់អើយ អស់ទាំងសេចក្ដីប៉ងប្រាថ្នា[ឍ]របស់
ទូលបង្គំ នៅចំពោះទ្រង់ ហើយដំងូរ[ណ]របស់ទូលបង្គំក៏មិន
លាក់នឹងទ្រង់ដែរ
១០ចិត្តទូលបង្គំកំរើកជាខ្លាំង[ត]ហើយកំឡាំងនៃទូលបង្គំក៏អន់
ថយ[ថ] ឯពន្លឺនៃភ្នែកទូលបង្គំ នោះក៏ងងឹតទៅ[ទ]
១១ពួកមិត្រសំឡាញ់ និងពួកដែលធ្លាប់ភប់ប្រសព្វនឹង
ទូលបង្គំ គេឈរឃ្លាតពីសេចក្ដីវេទនារបស់ទូលបង្គំ[ធ]
ហើយទាំងបងប្អូននៃទូលបង្គំក៏ឈរនៅឆ្ងាយដែរ
១២ឯពួកអ្នកដែលស្វែងរកជីវិតទូលបង្គំ គេដាក់អន្ទាក់[ន]
ហើយពួកអ្នកដែលប៉ងប្រទូសរ៉ាយនឹងទូលបង្គំ
គេពោលទំលាក់សេចក្ដីអាក្រក់[ប]
ហើយគិតតែឧបាយជាដរាបរាល់ថ្ងៃ[ផ]
១៣តែទូលបង្គំមិនឮទេ[ព] ដូចជាមនុស្សថ្លង់
ក៏មិនហាមាត់ស្ដីដែរ ដូចជាមនុស្សគ
១៤អើ ទូលបង្គំដូចជាមនុស្សដែលមិនឮសោះ
ហើយដែលគ្មានពាក្យសបនៅក្នុងមាត់ឡើយ ។
១៥ដ្បិត ឱព្រះយេហូវ៉ាអើយ ទូលបង្គំសង្ឃឹម[ភ]ដល់ទ្រង់
ឱព្រះអម្ចាស់ ជាព្រះនៃទូលបង្គំអើយទ្រង់នឹងឆ្លើយតប[ម]
ចំពោះគេ
១៦ពីព្រោះទូលបង្គំបាននឹកថា ក្រែងគេមានសេចក្ដីអំណរ

**៣៨:១** ក ទដ ៦:១
**៣៨:២** ខ យប ៦:៤
**៣៨:៣** គ សភ ៣:៨ ៤:២២ ឃ យប ៣៣:១៩
**៣៨:៤** ង ទដ ៤០:១២ ៦៥:៣ ច ជន ១១:១៤ អរ ៩:៦ លក ១១:៤៦
**៣៨:៦** ឆ ទដ ៥៧:៦ ១៤៥:១៤ ១៤៦:៨ ជ ទដ ៣៥:១៤
**៣៨:៧** ឈ យប ១៤:២២ ញ ខ.៣
**៣៨:៨** ដ ទដ ៣៤:១៨ សភ ១៧:២២ ឋ ទដ ៦:៦ ២២:១ សភ ៥:១១ ឌ ទដ ៦:៣
**៣៨:៩** ឍ ទដ ១១៩:២០ ១៤៣:៧ ណ យប ៣:២៤
**៣៨:១០** ត យប ៣៧:១ ថ ទដ ៣១:១០ ទ ទដ ៦:៧ ១៩:៨ ៨៨:៩
**៣៨:១១** ធ ខ.៥
**៣៨:១២** ន ទដ ៣១:៤ ១៤០:៥ ១៤១:៩ ប ទដ ៣៥:៤ ៤១:៥ ផ ទដ ៣៥:២០
**៣៨:១៣** ព ទដ ១១៥:៦ ១៣៥:១៧ អស ៤៣:៨ មក ៧:៣៧ **៣៨:១៥** ភ ទដ ២៧:១៤ ម ទដ ១៧:៦

ហេព្រើរ ។ នៅក្នុងជំពូកនេះមាន៥ល្បះហើយក្នុង១ល្បះមាន៤ខស្មើៗគ្នា ហើយមាន២ខចុងក្រោយជាខបញ្ចប់ ។

**ជំពូក៣៨ត្រង់ចំណងជើង** *សេចក្ដីរំឭក* ពាក្យនេះមានប្រើនៅក្នុងចំណងជើងនៃទដ ៧0 ប៉ុណ្ណោះ ។

**៣៨:១–៤** នៅក្នុងខ.ទាំងនេះគឺជាការអង្វរសូមកុំឱ្យព្រះអម្ចាស់ទ្រង់បន្ទោសក្នុងកាលដែលទ្រង់ខ្ញាល់នោះឡើយ ។

**៣៨:១** *បន្ទោស . . . វាយផ្ចាល* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់នឹងបន្ទោស និងវាយផ្ចាលគេ(សូមមើលក្នុង ៣៩:១១ និងការពន្យល់ក្នុង ៣:៧) ។ *ខ្ញាល់ . . . ព្រះហឫទ័យក្ដៅ* សូមមើលការពន្យល់ក្នុង ២:៥ ។

**៣៨:២** *ព្រួញ* នេះគឺជាពាក្យប្រៀបធៀបដែលចង់និយាយសំដៅលើការវាយបំផ្លាញរបស់ព្រះអម្ចាស់ (សូមមើលក្នុង យប ៦:៤) ៣៤:៦ បទ ៣:១២ អគ ៥:១៦ និងការពន្យល់ក្នុង ៩:១៣) ។ *ព្រះហត្ថទ្រង់ក៏សង្កត់ទូលបង្គំខ្លាំងណាស់ផង* សូមមើលក្នុង ៣២:៤ និងការពន្យល់ក្នុង ៣២:៣–៥ ។

**៣៨:៣** *ឆ្អឹង* សូមមើលការពន្យល់ក្នុង ៦:២ ។

**៣៨:៤** *បន្ទុក* នៅក្នុងឃ្លានេះមិនត្រឹមតែនិយាយសំដៅលើ "បន្ទុកដោយព្រោះការរំលង"ដែលមាននៅក្នុងចិត្តប៉ុណ្ណោះនោះទេ ប៉ុន្តែក៏និយាយសំដៅលើបន្ទុកនៃការឈឺចាប់ជាពន់ប្រមាណដែលមាននិយាយនៅក្នុង ខ.៥–៨ ផងដែរ ។

**៣៨:៥–៨** នៅក្នុងខនេះ អ្នកនិពន្ធបាននិយាយរាយរ៉ាប់ពីជម្ងឺនៅក្នុងរាងកាយនិងក្នុងវិញ្ញាណរបស់គាត់ ។

**៣៨:៨** *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។

**៣៨:៩–១២** នៅក្នុងខ.ទាំងនេះអ្នកនិពន្ធគាត់នៅតែបន្តអធិស្ឋានអំពាវនាវដល់ព្រះអម្ចាស់ ហើយមិនត្រឹមតែប៉ុណ្ណោះគាត់ក៏បានរ៉ាយរ៉ាប់ពីបញ្ហាទាំងនេះយ៉ាងល្អិតល្អន់ដូចជា ជម្ងឺរបស់គាត់ (សូមមើលក្នុង ខ.១០) ពួកភឿនមិត្តបានបោះបង់ហើយឃ្លាតឆ្ងាយពីគាត់ (សូមមើលក្នុង ខ.១២) ។

**៣៨:១០** *ពន្លឺនៃភ្នែកទូលបង្គំ នោះក៏ងងឹតទៅ* មើលការពន្យល់ ១៣:៣ ។

**៣៨:១១** សូមមើលការពន្យល់ក្នុង ៣១:១១–១២ ។

**៣៨:១២** សូមមើលការពន្យល់ក្នុង ៥:៩ ។ *ដាក់អន្ទាក់* សូមមើលការពន្យល់ក្នុង ៩:១៥ ។

**៣៨:១៣–១៦** នៅក្នុងខទាំងនេះចង់និយាយថា សូមឱ្យព្រះអម្ចាស់ទ្រង់មានបន្ទូលតបឆ្លើយមកដល់ពួកខ្មាំងសត្រូវនៃទូលបង្គំ (សូមមើលក្នុង ខ.១៥) ។ ពេលនេះស្ដេចដាវីឌគាត់ប្រៀបបាននឹងមនុស្សថ្លង់ហើយគ គាត់មិនអាចឆ្លើយតបដល់ពួកខ្មាំងសត្រូវរបស់គាត់បានឡើយ (សូមមើលក្នុង ខ.១៣–១៤) ដូច្នេះហើយគាត់បានរង់ចាំសូមឱ្យព្រះអម្ចាស់ទ្រង់ធ្វើការនោះជំនួសគាត់វិញ (សូមមើលក្នុង ខ.១៥–១៦ និង ១សយ ២៥:៣២–៣៩ ២សយ ១៦:១០,១២) ។

**៣៨:១៦** *ដោយទូលបង្គំភ្លាត់ជើង* នៅក្នុងឃ្លានេះចង់និយាយសំដៅលើគ្រាដែលសុខភាពគាត់អន់ថយ ឬក៏កាលៈទេសៈផ្សេងៗទៀតដែលស្រដៀងនឹង

ដោយ[យ]ទូលបង្គំភ្លាត់ជើង[រ] ហើយគេអួតខ្លួនទាស់នឹងទូល
បង្គំ
១៧ ដ្បិតទូលបង្គំជិតដួលហើយ[ល] សេចក្តីទុក្ខព្រួយ[វ] របស់ទូល
បង្គំនៅមុខទូលបង្គំជានិច្ច
១៨ ទូលបង្គំនឹងលន់តួអំពើទុច្ចរិតរបស់ទូលបង្គំ[ស] ហើយនិង
ឈឺចិត្ត ដោយព្រោះអំពើបាបរបស់ទូលបង្គំដែរ
១៩ ប៉ុន្តែពួកខ្មាំងសត្រូវនៃទូលបង្គំគេស្ទិតស្វាញ[ហ]
ហើយមានកំឡាំង ឯពួកអ្នកដែលស្អប់ទូលបង្គំ[ឡ]
ដោយឥតហេតុ[អ]ក៏ចំរើនជាច្រើនឡើង
២០ ពួកអ្នកដែលប្រព្រឹត្តការអាក្រក់[ក]ស្នងនឹងគុណ
គេតតាំង[ខ]នឹងទូលបង្គំ
ដោយព្រោះតែទូលបង្គំប្រព្រឹត្តតាមការល្អ
២១ ឱព្រះយេហូវ៉ាអើយ សូមកុំលះចោលទូលបង្គំឡើយ[គ]

**៣៨:១៦** យ ទដ ២២:១៧ រ ចទ ៣២:៣៥ **៣៨:១៧** ល ទដ ៣៧:២៤ វ ខ.៧ យប ៦:១០ **៣៨:១៨** ស លវ ២៦:៤០ **៣៨:១៩** ហ ទដ ១៨:១៧ ឡ ទដ ២៥:១៩ អ ទដ ៣៥:១៩ **៣៨:២០** ក លប ៤៤:៤ ១យហ ៣:១២ ខ ទដ ៥៤:៥ ៥៩:១០ ១១៩:២៣ **៣៨:២១** គ ទដ

ឱព្រះនៃទូលបង្គំអើយ សូមកុំគង់ឆ្ងាយ[ឃ]ពីទូលបង្គំឱ្យសោះ
២២ ឱព្រះអម្ចាស់ ជាសេចក្តីសង្គ្រោះនៃទូលបង្គំអើយ[ង]
សូមប្រញាប់[ច]នឹងជួយ[ឆ]ទូលបង្គំផង ។

ទំនុកនៃស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង
ជូនដល់លោកយេឌូថិន ។

**៣៩** ខ្ញុំបាននឹកថា ខ្ញុំនឹងប្រយ័ត្នផ្លូវខ្លួន[ក]
ដើម្បីមិនឱ្យអណ្តាតខ្ញុំធ្វើបាបឡើយ[ខ]
ខ្ញុំនឹងដាក់បង្ខាំងទប់មាត់ខ្ញុំ[គ]
ក្នុងកាលដែលពួកអាក្រក់នៅចំពោះមុខ

២៧:៩ ៧១:១៨ ១១៩:៨ ឃ ទដ ១០:១ ២២:១១ ៣៥:២២ ៧១:១២ **៨:២២** ង ១របា ១៦:៣៥ ច ទដ ៤០:១៣ ឆ ទដ ២២:១៩ **៣៩:១** ក ១ពវ ២:៤ ទដ ១១៩:៩,៥៩ សភ ២០:១១ ខ យប ១:២២ ទដ ៣៤:១៣ យក ៣:២ គ យប ៦:២៤ យក ១:២៦

ការនេះ ហើយនៅទីនេះឃ្លានេះគឺនិយាយសំដៅលើគ្រាដែលគាត់មានជម្ងឺ (សូមមើលក្នុង ៦៦:៩ ៩៤:១៨ ១២១:៣) ។

**៣៨:១៧–២០** នៅក្នុងខ.នេះចង់និយាយថា ក្នុងគ្រាដែលសុខភាពរបស់គាត់ចុះខ្សោយ នោះពួកខ្មាំងសត្រូវរបស់គាត់កាន់តែមានគ្នាច្រើនឡើង ។

**៣៨:១៧** *ដ្បិតទូលបង្គំជិតដួលហើយ* នៅក្នុងឃ្លានេះចង់និយាយថា ពេលនេះសេចក្តីស្លាប់ហាក់បីដូចជាជិតដល់ហើយ (សូមមើលការពន្យល់ក្នុង ១៣:៤) ។ *ដួល* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ពាក្យនេះមានទំនាក់ទំនងនឹង ៣៥:១៥ "សេចក្តីទំនាស់ចិត្ត" ។

**៣៨:១៨** សូមមើលក្នុង ខ.៣–៤ ទដ ជំពូក ៣២ ។

**៣៨:១៩–២០** នៅក្នុងខនេះចង់និយាយថា អ្នកនិពន្ធមានអំពើបាបដោយព្រោះប្រឆាំងទាស់នឹងព្រះ ប៉ុន្តែគាត់គ្មានអំពើបាបដោយព្រោះធ្វើអ្វី ខុសទាស់ប្រឆាំងចំពោះអ្នកដែលទាស់ប្រឆាំងចំពោះគាត់ឡើយ (សូមមើលការពន្យល់ក្នុង ៣៥:១៩) ។

**៣៨:២០** *ការអាក្រក់ស្នងនឹងគុណ* សូមមើលក្នុង ៣៥:១២–១៤ ។ *ការអាក្រក់* គឺចង់និយាយសំដៅលើការចោទប្រកាន់ផ្សេងៗ (សូមមើលក្នុង ៧១:១៣ ១០៩:៤,២០,២៩ សក ៣:១) ។ *ការល្អ* គឺសំដៅលើសិលធម៌ត្រឹមត្រូវ (សូមមើលក្នុង ៣៤:១៤) ។

**៣៨:២១–២២** នៅក្នុងខទាំងនេះគឺជាសេចក្តីបញ្ចប់មួយ ដែលអ្នកនិពន្ធនៅតែបន្តការអំពាវនាវដល់ព្រះអម្ចាស់ថែមទៀត ។

**ទំនុកដំកើងជំពូក៣៩** នៅក្នុងជំពូកនេះ ពណ៌នាពីសេចក្តីអធិស្ឋានប្រកបដោយទុក្ខព្រួយរបស់ស្តេចដាវីឌ ក្នុងគ្រាដែលទ្រង់មានបញ្ហាដ៏ធ្ងន់ដែលបណ្តាលមកពីជីវិតមិនស្ថិតស្ថេររបស់មនុស្ស ។ ស្តេចដាវីឌ ទ្រង់បានរំឭកពីបញ្ហាទាំងអស់នេះដោយនិយាយពីបញ្ហានៃជម្ងឺដែលទ្រង់មាន ដោយព្រោះព្រះអម្ចាស់ទ្រង់បានបោះបង់ចោលទ្រង់ (ខ.១០–១១) ដោយព្រោះ"អំពើរំលងរបស់ទ្រង់"(ខ.៨) ។ នៅក្នុងជំពូក៣៨ ស្តេចដាវីឌទ្រង់មានបន្ទូលដោយស្ងៀមស្ងាត់នៅចំពោះមុខខ្មាំងសត្រូវរបស់ទ្រង់ ហើយនៅក្នុងជំពូក៣៩វិញ ទ្រង់មានបន្ទូលដោយស្ងៀមស្ងាត់នៅចំពោះព្រះអម្ចាស់ ។ ទាំងក្នុងជំពូក ៣៨ និងក្នុងជំពូក ៣៩ ស្តេចដាវីឌទ្រង់បានអធិស្ឋានក្នុងគ្រាដែលទ្រង់មាន"ជំងឺ" (ការបោះបង់ចោលរបស់ព្រះអម្ចាស់ ខ.១១ ៣៨:១) ហើយនៅក្នុងជំពូកទាំងនេះ ក៏បានពណ៌នាពីការទទួលស្គាល់នូវអំពើបាបដែលខ្លួនបានប្រព្រឹត្តផងដែរ មិនត្រឹមតែប៉ុណ្ណោះសោតវាក៏និយាយពីការទុកចិត្តចំពោះព្រះអម្ចាស់ថែមទៀត។សូមមើលសេចក្តីផ្តើម ក្នុងជំពូក ៤០ ។ បន្ថែមពីនេះទៀតព្រះគម្ពីរជំពូកនេះមានទំនាក់ទំនងជាច្រើនជាមួយនឹងគម្ពីរ ទំនុកដំកើងជំពូក ៩០ (សូមមើលក្នុងសេចក្តីផ្តើមជំពូក ៤៩) ។ ទម្រង់សំណង់ប្រយោគក្នុងជំពូកនេះ គឺមានភាពសមមូលជាមួយគ្នាទៅវិញទៅមក: នៅក្នុង២ល្បះដំបូងនៃល្បះទាំង៥ ដែលមានកំណាព្យនៃព្រះគម្ពីរភាសាហេព្រើរ៣បន្ទាត់គឺមានតុល្យភាពនឹងល្បះ២ចុងក្រោយនៃល្បះទាំង៥ដែលមាន៣បន្ទាត់ ។ នៅក្នុងចំណុចកណ្តាលនៃជំពូកនេះ(សូមមើលក្នុង ខ.៦ និងការពន្យល់ក្នុង ៦:៦) មាននិយាយពីប្រាជ្ញា ដែលជាការជំនួសឱ្យស្ថានភាពរបស់ស្តេចដាវីឌ ដែលមាននិយាយនៅក្នុងបរិបទទាំងមូល(មើលការពន្យល់ ខ.៦) ។

**ទដ៣៩ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ក្នុង ជំពូក ៤ ត្រង់ចំណងជើង ។ *លោកយេឌូថិន* គាត់គឺជាអ្នកដឹកនាំចំរៀងម្នាក់ក្នុងចំណោមអ្នកចំរៀងទាំង៣របស់ស្តេចដាវីឌ (សូមមើល ១របា ១៦:៤១–៤២ ២៥:១,៦ ២របា ៥:១២ ហើយនៅក្នុង ២របា ៣៥:១៥ ហៅថា "អ្នកមើលឆុត") ។ លោកយេឌូថិន ប្រហែលជាមនុស្សតែម្នាក់ជាមួយលោកអេថានដែលមាននិយាយនៅក្នុង ១របា ៦:៤៤ ១៥:១៩ ហើយបើសិនគាត់ជាមនុស្សតែ១មែន នោះគាត់គឺជាម្នាក់ដែលតំណាងឱ្យគ្រួសាររបស់ម្រ៉ារី ទោះបីជាអេសាបគាត់ជាមនុស្សរបស់ក្រុមគ្រួសារគើសុន ហើយហាមានជាមនុស្សរបស់គ្រួសារកេហាត់ ដែលអ្នកទាំង៣ (គឺសុន កេហាត់ និងម្រ៉ារី) គឺសុទ្ធតែជាកូនរបស់លេវី(សូមមើលក្នុង ១របា ៦:១៦,៣៣,៣៩,៤៣–៤៤ និងមើលក្នុងចំណងជើង ទដ ជំពូក ៦២ ៧៧ និង ៨៩ ។

**៣៩:១–៣** សេចក្តីផ្តើមៈដោយសារការស្ងៀមស្ងាត់ក្នុងចិត្ត នោះនៅចុងបញ្ចប់ ការចាប់បារម្ភណ៍មិនអាចនៅជាប់ក្នុងគាត់ទៀតឡើយ ។

**៣៩:១** នៅក្នុងជំពូកនេះស្តេចដាវីឌ ទ្រង់បានដាក់បង្ខាំងក្នុងមាត់របស់ទ្រង់ដោយព្រោះទ្រង់ខ្លាចថា ពាក្យសំដីដែលទ្រង់បាននិយាយនឹងឮដល់ពួកមនុស្សអាក្រក់ (សូមមើលក្នុង ទដ ជំពូក ៧៣) ។

[២]ខ្ញុំបាននៅជាគ ឥតនិយាយអ្វីសោះ[ឃ]គឺបាននៅសៀម
ចំពោះទាំងសេចក្ដីល្អផង
នោះសេចក្ដីទុក្ខព្រួយ[ង]របស់ខ្ញុំក៏ជ្រួលឡើង
[៣]ចិត្តខ្ញុំបានក្ដៅ[ច]នៅក្នុងខ្លួន កំពុងដែលខ្ញុំគិតរំពឹង[ឆ]
នោះភ្លើង[ជ]ក៏ឆួលឡើង ហើយអណ្ដាតខ្ញុំបាននិយាយថា
[៤]ឱព្រះយេហូវ៉ាអើយ សូមឱ្យទូលបង្គំដឹងពីចុងបំផុតនៃទូល
បង្គំ[ឈ] ហើយពីចំនួនថ្ងៃអាយុនៃទូលបង្គំផង
ដើម្បីឱ្យទូលបង្គំបានដឹងជាមានជីវិត[ញ]ស្រួយអម្បាលម៉ាន[ដ]
ទៅ
[៥]មើលទ្រង់បានធ្វើឱ្យថ្ងៃ[ឋ]អាយុនៃទូលបង្គំបានខ្លី
ប្រវែង១ចំអាមដៃ ហើយជន្មរជីវិតរបស់ទូលបង្គំ
ដូចជាឥតមានសោះនៅចំពោះទ្រង់ មែនហើយ
គ្រប់មនុស្ស ទោះទាំងមនុស្សនៅក្នុងសណ្ឋានពេញវ័យ
នោះក៏ឥតប្រយោជន៍ទទេដែរ[ឌ]។ –បង្អង់
[៦]ប្រាកដមែន គ្រប់មនុស្សទាំងឡាយដើរប្រៀបដូចជា
ស្រមោលទទេ[ឍ] គេជ្រួលជ្រើមឡើង[ណ]ជាឥតប្រយោជន៍[ត]
គេបង្គរទ្រព្យសម្បត្តិឡើង[ថ] ឥតដឹងជាអ្នកណានឹងទទួលទេ[ទ]
[៧]ឥឡូវនេះ ឱព្រះអម្ចាស់អើយ តើទូលបង្គំនៅរង់ចាំអ្វីទៀត
ដ្បិតទូលបង្គំសង្ឃឹមដល់ទ្រង់តែ១ប៉ុណ្ណោះ[ធ]
[៨]សូមជួយទូលបង្គំ[ន]ឱ្យរួចពីគ្រប់អំពើរំលងរបស់ទូលបង្គំ[ប]
សូមកុំឱ្យទូលបង្គំបានជាទីដៀលត្មះរបស់ពួកមនុស្ស
ឆោត[ផ]ល្ងង់ឡើយ
[៩]ទូលបង្គំបាននៅជាគ[ព] ឥតហើបមាត់សោះ[ភ]
ដ្បិតគឺជាទ្រង់ដែលបានធ្វើការនោះ[ម]
[១០]សូមដករំពាត់របស់ទ្រង់ចេញពីទូលបង្គំ
ទូលបង្គំត្រូវវិនាសហើយ[យ] ដោយសារព្រះហស្តទ្រង់វាយ[រ]
[១១]កាលណាទ្រង់វាយប្រដៅ[ល]ផ្ចាញ់ផ្ចាល[វ]មនុស្សដោយ
ព្រោះអំពើទុច្ចរិតរបស់គេ នោះទ្រង់ធ្វើឱ្យសេចក្ដីលំអ
របស់គេបាត់ទៅ[ស]ដូចជាមេអំបៅ[ហ]
ពិតប្រាកដជាមនុស្សទាំងអស់សុទ្ធតែឥតប្រយោជន៍ទទេ[ឡ]។
[១២]ឱព្រះយេហូវ៉ាអើយ
សូមស្ដាប់ពាក្យដែលទូលបង្គំអធិស្ឋាន[អ]
សូមផ្ទៀងព្រះកាណ៌[ក]ស្ដាប់សំរែកទូលបង្គំផង[ខ]
សូមទ្រង់កុំនៅធ្មឹងនឹងទឹកភ្នែកនៃទូលបង្គំឡើយ
ដ្បិតទូលបង្គំជាអ្នកដទៃ[គ]នៅចំពោះទ្រង់
ជាអ្នកស្នាក់នៅ[ឃ]ដូចជាពួកឰយុកោទូលបង្គំទាំងអស់គ្នា
ដែរ[ង]
[១៣]ឱសូមប្រណីដល់ទូលបង្គំ
ដើម្បីឱ្យទូលបង្គំបានមានកំឡាំងឡើង
មុនដែលទូលបង្គំចេញបាត់ទៅហើយមិនមានទៀត[ច]។

*៤០:១៣–១៧ – ទដ ៧០:១–៥*

ទំនុកនៃស្ដេចដាវីឌ ជាសេចក្ដីបង្រៀន ។

**៤០** ខ្ញុំបានរង់ចាំព្រះយេហូវ៉ា ដោយអំណត់[ក]
ទ្រង់ក៏បានផ្ទៀងព្រះកាណ៌មកស្ដាប់

**៣៩:២** ឃ ខ.៩ យប ៣១:៣៤ ទដ ៧៧:៤ ង ទដ ៦:៣ ២៥:១៧ ៣១:១០ **៣៩:៣** ច លក ២៤:៣២ ឆ ទដ ១:២ ៤៨:៩ ៧៧:១២ ១១៩:១៥ ជ យរ ៥:១៤ ២០:៩ ២៣:២៩ **៣៩:៤** ឈ យប ១៤:៥ ញ យប ១៤:២ ដ លប ៤៧:៩ យប ៧:៧ **៣៩:៥** ឋ យប ១០:២០ ទដ ៨៩:៤៥ ១០២:២៣ ឌ យប ៧:៧ ទដ ៦៣:៩ **៣៩:៦** ឍ យប ៨:៩ ទដ ១០២:១១ សស ៦:១២ យក ៤:១៤ ណ យក ១:១១ ត ទដ ១២៧:២ ថ យប ២៧:១៧ ទ លក ១២:២០ **៣៩:៧** ធ ទដ ៩:១៨ ២៥:៥ **៣៩:៨** ន ទដ ៦:៤ ៥១:១៤ ប ទដ ៣២:១ ៥១:១ អស ៥៣:៥,៨,១០ ផ ចទ ២៨:៣៧ ទដ ៦៩:៧ ៧៩:៤ អស ៤៣:២៨ ដយ ៩:១៦ **៣៩:៩** ព ខ.២ ភ ទដ ៣៨:១៣ ម អស ៣៨:១៥ **៣៩:១០** យ ២រប ២១:១៤ អគ ៧:៩ ២៤:១៦ រ នក ៩:៣ **៣៩:១១** ល ចទ ២៨:២០ អស ៦៦:១៥ អគ ៥:១៥ ២ពត ២:១៦ វ ទដ ៩៤:១០ អស ២៦:១៦ ស ទដ ៩០:៧ ហ យប ១៣:២៨ អស ៥១:៨ លក ១២:៣៣ យក ៥:២ ឡ យប ៧:៧ **៣៩:១២** អ ទដ ១៧:១ ក ចទ ១:៤៥ ខ ២ពវ ២០:៥ គ លវ ២៥:២៣ ឃ លប ២៣:៤ ហព ១១:១៣ ង លប ៤៧:៩ ១រប ២៩:១៥ **៣៩:១៣** ច យប ១០:២១ **៤០:១** ក ទដ ៣៧:៧

**៣៩:២–៣** នៅក្នុងខទាំងនេះចង់ពិណពីនាថា អ្វីដែលធ្វើឱ្យគាត់មានការថប់បារម្មណ៍នោះគឺការឈឺចាប់របស់គាត់កាន់តែធ្ងន់ទៅៗ (សូមមើលក្នុង យរ ២០:៩) ។

**៣៩:៤–៥** នៅក្នុងខទាំងនេះស្ដេចដាវីឌ ទ្រង់បានអធិស្ឋានសូមឱ្យព្រះអង្គជួយឱ្យទ្រង់បានយល់ និងមានការអត់ធ្មត់ក្នុងការទទួលយកនូវជីវិតដ៏ផុយស្រួយរបស់មនុស្ស ។

**៣៩:៤** *ជីវិតស្រួយអម្បាលម៉ានទៅ* សូមមើល ៧៨:៣៩ និងការពន្យល់ក្នុង ៣៧:២០ ។

**៣៩:៥** *ដូចជាឥតមានសោះនៅចំពោះទ្រង់* សូមមើលក្នុង ៩០:៤ ។ *មនុស្សនៅក្នុងសណ្ឋានពេញវ័យ* សូមមើលក្នុង ខ.១១ ៦២:៩ ១៤៤:៤ ។

**៣៩:៦** នៅក្នុងខនេះ គឺដូចជាសង្ខេបចេញពីព្រះគម្ពីរសាស្ដាទាំងស្រុង ។

**៣៩:៧–៩** នៅក្នុងខទាំងនេះ គឺជាសេចក្ដីអធិស្ឋានមួយដែលមានលក្ខណៈសុភាពរម្យទម ដោយស្ដេចដាវីឌទ្រង់សូមឱ្យព្រះអង្គជួយគាត់ឱ្យរួចពីការបោះបង់របស់ព្រះអម្ចាស់ ។

**៣៩:៨** *សូមជួយទូលបង្គំ* គឺជួយឱ្យរួចពីខ្មាំងសត្រូវ ។ *ជាទីដៀលត្មះរបស់ពួកមនុស្សឆោតល្ងង់* នៅក្នុងឃ្លានេះចង់និយាយថា បើសិនជាព្រះអម្ចាស់ទ្រង់មិនបានជួយស្រោចស្រង់ជាថ្មីម្ដងទៀតទេ នោះស្ដេចដាវីឌទ្រង់នឹងត្រូវពួកមនុស្សឆោតល្ងង់ (សូមមើលក្នុង ១៤:១) មើលងាយជាមិនខាន (សូមមើលក្នុង ២២:៧–៨ ៦៩:៦–១២) ។

**៣៩:១០** *ដោយសារព្រះហស្តទ្រង់វាយ* សូមមើលក្នុង ៣២:៤ ៣៨:២ ។

**៣៩:១១** *វាយប្រដៅផ្ចាញ់ផ្ចាល* សូមមើលក្នុង ៦:១ ៣៨:១ ។ *មនុស្សទាំងអស់* សូមមើលការពន្យល់ក្នុង ខ.៥ ។

**៣៩:១២–១៣** នៅក្នុងខទាំងនេះ គឺជាសេចក្ដីអធិស្ឋានមួយដែលកាន់តែរមទម្យទៅៗ ។

**៣៩:១២** *អ្នកដទៃ* នៅក្នុងឃ្លានេះស្ដេចដាវីឌទ្រង់ចង់មានបន្ទូលថាកាលដែលទ្រង់រស់នៅចំពោះព្រះ នោះទ្រង់ធៀបដូចជាអ្នកហែរហមព្រះ ។

**៣៩:១៣** *សូមប្រណីដល់ទូលបង្គំ* សូមមើល យប ៧:១៧–១៩ ១០:២០–២១ ១៤:៦ ។

**ទដ ជំពូក៤០–៤១** នៅក្នុងវគ្គទី១នៃព្រះគម្ពីរទំនុកដំកើង គេឃើញថាមាន២ជំពូកបានភ្ជាប់នឹងឃ្លាដែលនិយាយថា "មានពរហើយ អ្នកណាដែល" (មើល

ហើយទទួលតាមសំរែករបស់ខ្ញុំ[ខ]
២ ទ្រង់បានស្រង់ខ្ញុំចេញពីអន្លង់គួរស្បើម[គ]
ឱ្យរួចពីភក់[ឃ]ស្អិត[ង] ក៏ដាក់ជើង[ច]ខ្ញុំលើថ្មដា[ឆ]
ព្រមទាំងតាំងជំហានខ្ញុំឱ្យខ្ជាប់ខ្ជួន
៣ ទ្រង់បានបណ្ដាលឱ្យមានទំនុកថ្មី[ជ] នៅក្នុងមាត់ខ្ញុំ
គឺជាសេចក្ដីសរសើរដល់ព្រះនៃយើងខ្ញុំ
មនុស្សជាច្រើននឹងឃើញ ព្រមទាំងមានសេចក្ដីកោត
ខ្លាច[ឈ] ហើយនិងទុកចិត្ត[ញ]ដល់ព្រះយេហូវ៉ាផង
៤ មានពរហើយ អ្នកណា[ដ]ដែលយកព្រះយេហូវ៉ាជាទីពឹង[ឋ]
ឥតយល់ដល់មនុស្សឆ្មើងឆ្មៃ[ឌ]ឬពួកអ្នកដែលបែរទៅឯ
សេចក្ដីភូតភរឡើយ[ឍ] ។
៥ ឱព្រះយេហូវ៉ាដ៏ជាព្រះនៃទូលបង្គំអើយ
ការអស្ចារ្យ[ណ]ដែលទ្រង់បានធ្វើ នោះមានច្រើនណាស់
ព្រមទាំងគំនិតដែលទ្រង់នឹកដល់យើងខ្ញុំផង
គ្មានអ្នកណាអាចនឹងរៀបរាប់[ត]ដោយលំដាប់ពីការទាំង
នោះ នៅចំពោះទ្រង់បានឡើយ
បើទូលបង្គំនឹងចង់និទានប្រាប់
នោះមានច្រើនហួសកំណត់[ថ]នឹងរាប់បាន
៦ ឯយញ្ញបូជា ហើយនិងដង្វាយ
នោះទ្រង់មិនសព្វព្រះហឫទ័យទេ[ទ]
ទ្រង់បានបើកត្រចៀកឱ្យទូលបង្គំស្ដាប់តាម[ធ]
ទ្រង់មិនចង់បានដង្វាយដុត[ន]ឬយញ្ញបូជាលោះបាបនោះទេ

**៤០:១** ខ ទដ ៦:៩ ៣១:២២ ៣៤:១៥ ១១៦:១ ១៤៥:១៩ **៤០:២** គ យប ៩:៣១ ទដ ៧:១៥ ឃ យប ៣០:១៩ ង ទដ ៦៩:១៤ ច ទដ ៣១:៨ ឆ ទដ ២៧:៥ **៤០:៣** ជ ទដ ២៨:៧ ៩៦:១ វវ ៥:៩ ឈ ទដ ៥២:៦ ៦៤:៩ ញ នក ១៤:៣១ **៤០:៤** ដ ទដ ៣៤:៨ ឋ ទដ ៨៤:១២ ឌ ទដ ១០១:៥ ១៣៨:៦ សភ ៣:៣៤ ១៦:៥ អស ៦៥:៥ ១ពត ៥:៥ ឍ ចទ ៣១:២០ ទដ ៤:២ ២៦:១ **៤០:៥** ណ ចទ ៤:៣៤ ទដ ៧៥:១ ១០៥:៥ ១៣៦:៤ ត ទដ ១៣៩:១៨ ថ ទដ ៧១:១៥ ១៣៩:១៧ **៤០:៦** ទ ១សយ ១៥:២២ យរ ៦:២០ អម ៥:២២ ធ នក ២១:៦ ន ទដ ៥០:៨ ៥១:១៦ អស ១:១១ ហស ៦:៦

៤០:៤ ៤១:១) ដូចគ្នានឹងបទនៃទំនុកដំកើង២ជំពូកដំបូងដែរ (មើល ១:១ ២:១២) ។ ដូច្នេះបទនៃទំនុកដំកើងទាំងមូលដែលមាននៅក្នុងវគ្គទី១ គឺបានធ្វើឱ្យយើងមានការចាប់អារម្មណ៍ដោយឃ្លាមួយ ដែលបាននិយាយថា មានពរហើយអ្នកណាដែល "ត្រេកអរនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា" (មើល ១:២) អ្នកណាដែល "យកទ្រង់ជាទីពឹងជ្រក" (មើល ២:១២) អ្នកណាដែល "មិនបែរទៅឯសេចក្ដីភូតភរ" ប៉ុន្តែជា "អ្នកដែលទុកចិត្តចំពោះទ្រង់" (មើល ៤០:៤) ហើយជាអ្នកដែល "មានអធ្យាស្រ័យដល់ពួកមនុស្សក្រីក្រ" (មើល ៤១:១) នេះគឺជាសេចក្ដីសង្ខេបពីអត្តចរិតដ៏ខ្លីមួយរបស់ពួកអ្នកស្រឡាញ់ព្រះ (មើលសេចក្ដីផ្ដើម ទដ ជំពូក ១–២) ។

**ទដ ៤០** នៅក្នុងជំពូកនេះ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបានអធិស្ឋានសូមសេចក្ដីជំនួយមកពីព្រះ ក្នុងកាលដែលគាត់មានទុកលំបាកជាច្រើន ។ មូលហេតុពិតប្រាកដ ដែលបណ្ដាលឱ្យគាត់ជួបប្រទះនូវការទុក្ខលំបាកនេះ គេមិនបានដឹងប្រាកដឡើយ ប៉ុន្តែស្ដេចដាវីឌទ្រង់បានទទួលស្គាល់ថា ពួកគេជួបប្រទះបញ្ហាទាំងនេះ គឺបណ្ដាលមកពីអំពើបាបរបស់ទ្រង់ (មើល ខ.១២) ដូចជាមាននិយាយនៅក្នុង ទដ ៣៨–៣៩ និង ៤១ ដែរ (មើលសេចក្ដីផ្ដើម ទដ ៣៩ និង ៤១) ។ ពួកខ្មាំងសត្រូវកាន់តែមើលងាយពួកគេកាន់តែខ្លាំងឡើងៗ ហើយផ្ទៃរឿងបែបនេះក៏មាននិយាយនៅក្នុង ទដ ៣៨–៣៩ និង ៤១ ផងដែរ (មើល ទដ ៣៨) ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងចាប់ផ្ដើមអធិស្ឋានដោយការនិយាយពីព្រះគុណ និងសេចក្ដីមេត្តាករុណារបស់ព្រះនាពេលកន្លងមក (មើល ខ.១–៥)។ ខ.ទាំងនេះមាន២ល្បះដែលមានកំណាព្យហេព្រើរ៥ក្នុងល្បះនិមួយ) និងទីបន្ទាល់សេចក្ដីស្មោះត្រង់របស់ស្ដេចដាវីឌចំពោះព្រះអម្ចាស់ (ស.៦–១០ នៅក្នុងខ ទាំងនេះមាន២ល្បះដែលមាន៣បន្ទាត់ក្នុង២ភាសាហេព្រើរ) ។ ទាំអស់នេះហើយ គឺជាទម្រង់នៃមូលដ្ឋានគ្រឹះក្នុងការសូមជំនួយមកពីព្រះអម្ចាស់ (មើល ខ.១១–១៧) ។

**ទដ ៤០ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ក្នុង ទដ ជំពូក ៤ ត្រង់ចំណងជើង ។

**៤០:១–៥** នៅក្នុងខទាំងនេះ គឺពណ៌នាពីបទពិសោធន៍របស់ស្ដេចដាវីឌដែលទ្រង់ធ្លាប់ទទួលបានសេចក្ដីជំនួយ នាពេលមុនក្នុងពេលដែលទ្រង់មានសេចក្ដីទុក្ខព្រួយ ដែលការទាំងនេះហើយបានធ្វើឱ្យស្ដេចដាវីឌបានសរសើរតម្កើង និងទុកចិត្តចំពោះព្រះអម្ចាស់ (មើលការពន្យល់ ៧:១៧ ៩:១) ។

**៤០:២** សូមមើលក្នុង ៣០:១ និងការពន្យល់ ។

**៤០:៣** *ទំនុកថ្មី* មើលការពន្យល់ ៣៣:៣ ។ *មនុស្សជាច្រើននឹងឃើញ* នេះគឺជាលទ្ធផលនៃការសរសើរតម្កើងរបស់ស្ដេចដាវីឌ (សូមមើល ១៨:៤៩ ២២:២២–៣១ និងការពន្យល់ ៩:១) ។ *កោតខ្លាច* សូមមើលការពន្យល់ ៣៤:៨–១៤ ។

**៤០:៤–៥** នៅក្នុងខទាំងនេះ ពណ៌នាពីការប្រទានពររបស់ព្រះអម្ចាស់ចំពោះមនុស្សផ្សេងៗទៀតដែលទុកចិត្តចំពោះព្រះអម្ចាស់ (មើល ខ.៤) និងពួកអ៊ីស្រាអែលដែលជារាស្ត្ររបស់ទ្រង់ (មើល ខ.៥) ។

**៤០:៤** សូមមើល យរ ១៧:៧ ។ នៅក្នុងខនេះ អ្នកនិពន្ធបានសរសើរតម្កើងចំពោះព្រះអម្ចាស់ ដោយព្រោះទ្រង់ប្រទានពរជាច្រើនដល់អ្នកណាដែលទុកចិត្តចំពោះទ្រង់ (មើល ៣២:១–២ ១៤៦:៥) ។ *មានពរហើយ* មើលការពន្យល់ ១:១ ។ *មនុស្សឆ្មើងឆ្មៃ* មើលការពន្យល់ ៣១:២៣ ។

**៤០:៥** *ការអស្ចារ្យ* មើលការពន្យល់ ៩:១ ។ *គំនិតដែលទ្រង់នឹកគិត* នៅក្នុងឃ្លានេះគឺចង់និយាយថា ការងាររបស់ព្រះអម្ចាស់ដែលទ្រង់បានធ្វើចំពោះអ៊ីស្រាអែល គឺអាស្រ័យលើគោលបំណងដ៏ច្បាស់លាស់របស់ព្រះអម្ចាស់ (មើល អស ២៥:១ ៤៦:១០–១១) ។

**៤០:៦–៨** នៅក្នុងខនេះ ស្ដេចដាវីឌទ្រង់បានប្ដេជ្ញាចិត្តថា នឹងធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ ។ អ្វីដែលមាននិយាយនៅក្នុងខទាំងនេះ គឺជាការនិយាយសំដៅលើព្រះយេស៊ូវគ្រីស្ទដែលមាននិយាយនៅ ហេព ១០:៥–១០ (សូមមើលការពន្យល់ទីនោះ) ។

**៤០:៦** *មិនសព្វព្រះហឫទ័យ . . . មិនចង់បាន* ពីព្រោះព្រះអម្ចាស់ទ្រង់រាប់ការស្ដាប់បង្គាប់ជាការសំខាន់ជាង (មើល ១សយ ១៥:២២) ជាពិសេសចំពោះក្រិត្យវិន័យរបស់ព្រះអម្ចាស់ (មើល អស ១:១០–១៧ អម ៥:២១–២៤ មីក ៦:៦–៨) រួមទាំងក្រឹត្យវិន័យគ្រឹះទាំងដប់នៃការតាំងសញ្ញា (មើល នក ២០:៣–១៧ ចទ ៥:៧–២១) ។ *បើក* តាមភាសាអក្សរសាស្ត្រពាក្យនេះគឺ "ជីក" ។ ការបកប្រែថា "បើក" ប្រហែលសំដៅលើសញ្ញាមួយដែល

៧ បានជាទូលបង្គំទូលថា មើល ទូលបង្គំមកហើយ
សេចក្តីនេះបានកត់ទុកពីទូលបង្គំ នៅក្នុងគម្ពីរហើយ[ប]
៨ គឺថា ឱព្រះនៃទូលបង្គំអើយ[ផ] ទូលបង្គំមានសេចក្តីអំណរ
នឹងធ្វើតាមព្រះហឫទ័យទ្រង់[ព]
អើ ក្រឹត្យវិន័យរបស់ទ្រង់ក៏នៅក្នុងចិត្តទូលបង្គំ[ភ]
៩ ទូលបង្គំបានប្រកាសដំណឹងល្អ ពីសេចក្តីសុចរិត[ម] នៅក្នុង
ជំនុំធំ[យ] មើល ឱព្រះយេហូវ៉ាអើយ ទ្រង់ជ្រាប[រ] ហើយថា
ទូលបង្គំនឹងមិនទប់មាត់ឡើយ
១០ ទូលបង្គំមិនបានលាក់សេចក្តីសុចរិតរបស់ទ្រង់នៅក្នុង
ចិត្តទេ
គឺបានថ្លែងប្រាប់ពីសេចក្តីស្មោះត្រង់[ល] នឹងសេចក្តីសង្គ្រោះ
របស់ទ្រង់វិញ ក៏មិនបានបំបិទសេចក្តីសប្បុរស
និងសេចក្តីពិតរបស់ទ្រង់ នៅក្នុងជំនុំធំដែរ[វ]
១១ ឱព្រះយេហូវ៉ាអើយ សូមកុំបង្ខាំងសេចក្តីមេត្តាករុណា[ស]
របស់ទ្រង់ចំពោះទូលបង្គំឡើយ សូមឱ្យសេចក្តី
សប្បុរស[ហ] និងសេចក្តីពិតត្រង់[ឡ] របស់ទ្រង់បានថែរក្សា[អ]
ទូលបង្គំជានិច្ច
១២ ដ្បិតមានសេចក្តីអាក្រក់[ក] ឥតគណនាព័ទ្ធទូលបង្គំជុំវិញ
អំពើទុច្ចរិតរបស់ទូលបង្គំ បានតាមទូលបង្គំទាន់ហើយ[ខ]
បានជាទូលបង្គំមិនអាចនឹងងើបឡើងមើលបានឡើយ
អំពើទាំងនោះច្រើនជាងសរសៃសក់លើក្បាលទូលបង្គំ[គ]
ចិត្តទូលបង្គំក៏អស់សង្ឃឹម[ឃ] ទៅ
១៣ ឱព្រះយេហូវ៉ាអើយ
សូមទ្រង់សព្វព្រះហឫទ័យនឹងជួយទូលបង្គំឱ្យរួច
ឱព្រះយេហូវ៉ាអើយ សូមប្រញាប់នឹងជួយទូលបង្គំផង[ង]
១៤ ឯអស់អ្នកដែលរកបំផ្លាញព្រលឹងទូលបង្គំ[ច]
នោះសូមឱ្យគេត្រូវមានសេចក្តីខ្មាស
ហើយលាក់មុខទាំងអស់គ្នា[ឆ]
ឯពួកអ្នកដែលប៉ងប្រទូស្តនឹងទូលបង្គំ
នោះសូមឱ្យគេត្រូវថយចេញ[ជ]

**៤០:៧** ប យប ១៩:២៣ យរ ៣៦:២ ៤៥:១ អគ ២:៩ សក ៥:១ **៤០:៨** ផ ហព ១០:៥–៧ ព មថ ២៦:៣៩ ភ ចទ ៦:៦ យប ២២:២២ រម ៧:២២ **៤០:៩** ម ទដ ២២:៣១ យ ទដ ២២:២៥ រ យស ២២:២២ **៤០:១០** ល ទដ ៨៩:១ វ ទដ ២២:២២ **៤០:១១** ស សក ១:១២ ហ សភ ២០:២៨ ឡ ទដ ២៦:៣ អ ទដ ៦១:៧ **៤០:១២** ក ទដ ២៥:១៧ ខ ទដ ៣៨:៤ ៦៥:៣ គ ទដ ៦៩:៤ ឃ ទដ ៧៣:២៦ **៤០:១៣** ង ទដ ២២:១៩ ៣៨:២២ **៤០:១៤** ច ១សយ ២០:១ ឆ នក ៩:២ ទដ ៣៥:២៦ ជ ទដ ៣៥:៤

អ្នកបម្រើបានឱ្យពរ ជាអាយុយឺនយូរដល់ចៅហ្វាយ (មើល ២១:៦ ចទ ១៥:១៧) ។ ទោះបីជាយ៉ាងណាក៏ដោយវាក៏ប្រែថា "បើក" គឺសំដៅលើការបើកត្រចៀកស្តាប់ក្រឹត្យវិន័យរបស់ព្រះអម្ចាស់ (មើល សភ ២៨:៩ អស ៤៨:៨ ៥០:៤–៥) ។

**៤០:៧** *មើលទូលបង្គំមកហើយ* ឃ្លានេះប្រហែលនិយាយសំដៅលើការប្តេជ្ញាចិត្តរបស់ស្តេចដាវីឌចំពោះព្រះអម្ចាស់ ក្នុងគ្រាដែលស្តេចដាវីឌទទួលការអភិសេកជាស្តេច ។ *សេចក្តីនេះបានកត់ពីទូលបង្គំ នៅក្នុងគម្ពីរហើយ* អ្នកខ្លះគិតថាឃ្លានេះ គឺសំដៅលើការថ្លែងទំនាយប្រហែលនិយាយនៅក្នុង ចទ ១៧:១៤–១៥ ។ ទោះបីជាយ៉ាងណាក៏ដោយតាមរយៈបរិបទនេះបង្ហាញថា "គម្ពីរ" នេះក៏និយាយសំដៅលើការចម្លងក្រឹត្យវិន័យផ្ទាល់ខ្លួនមួយ ក្នុងអំឡុងពេលដែល ស្តេចដាវីឌទ្រង់ទទួលការអភិសេកដើម្បីបម្រើការងារជាអ្នកសម្តែង និងរ៉ាយរ៉ាប់ពីការតាំងសញ្ញាក្នុងរាជការរបស់ទ្រង់ (មើល ចទ ១៧:១៨–២០ ២ពវ ១១:១២ ហើយធៀបជាមួយ ១ពវ ២:៣) ។

**៤០:៨** *ទូលបង្គំមានសេចក្តីអំណរ* នៅក្នុងឃ្លានេះគឺដូចគ្នានឹងបំណងព្រះហឫទ័យនៃព្រះដែរ (មើល ខ.៦) ។

**៤០:៩–១០** នៅក្នុងខទាំងនេះចង់និយាយថា នៅក្នុងជីវិតរស់នៅរបស់ស្តេចដាវីឌគឺមានពេញទៅដោយការសរសើរតម្កើង និងការប្រកាសប្រាប់ពីសេចក្តីស្មោះត្រង់ និងសេចក្តីស្រឡាញ់របស់ទ្រង់ ដែលព្រះអង្គបានធ្វើចំពោះរាស្ត្ររបស់ទ្រង់ (ធៀបជាមួយ ៨៥:១០–១១) ។ ការទាំងអស់នោះហើយដែលព្រះអម្ចាស់ទ្រង់សព្វព្រះទ័យជាងយញ្ញបូជា ដង្វាយសត្វទៅទៀត (មើល ៥០:៧–១៥,២៣) ។

**៤០:៩** *ទូលបង្គំបានប្រកាស* មើល ៦៨:១១ ៩៦:២ ។ ឃ្លានេះគឺនិយាយសំដៅលើការប្រកាសដំណឹងល្អ (មើល ១ពវ ១:៤២ អស ៤០:៩ ៤១:២៧ ៥២:៧ ៦១:១) ។ *សេចក្តីសុចរិត* មើលការពន្យល់ ៤:១ ។ *នៅក្នុងជំនុំធំ* មើលការពន្យល់ ១:៥ ៩:១ ។ *ទូលបង្គំនឹងមិនទប់មាត់ឡើយ* នៅក្នុងឃ្លានេះចង់និយាយថា ស្តេចដាវីឌទ្រង់មិននៅស្ងៀមក្នុងការសរសើរតម្កើងដល់ព្រះអម្ចាស់នោះឡើយ (មើល ៣៨:១៣–១៦ ៣៩:១ និងការពន្យល់) ។

**៤០:១០** *ចិត្ត* មើលការពន្យល់ ៤:៧ ។ *សេចក្តីសប្បុរស និងសេចក្តីពិត* មើលការពន្យល់ ២៦:៣ ។

**៤០:១១–១៧** នៅក្នុងខទាំងនេះ និយាយពីការអធិស្ឋានទូលសូមសេចក្តីជំនួយមកពីព្រះយេហូវ៉ា ។

**៤០:១១–១៣** នៅក្នុងខទាំងនេះ គឺនិយាយពីការអង្វររបស់ស្តេចដាវីឌសូមឱ្យព្រះអម្ចាស់ទ្រង់ជួយសង្គ្រោះឱ្យរួចពីបញ្ហាទាំងឡាយ ដែលទ្រង់មាន។

**៤០:១១** *សេចក្តីសប្បុរស និងសេចក្តីពិតត្រង់របស់ទ្រង់* គឺជាការមួយដែលស្តេចដាវីឌបានប្រកាសដល់មនុស្សទាំងអស់នៅក្នុងពួកជំនុំ (មើល ខ.១០ និងការពន្យល់) ។

**៤០:១២** *អំពើទុច្ចរិតរបស់ទូលបង្គំ បានតាមទូលបង្គំទាន់ហើយ* នៅក្នុងឃ្លានេះចង់និយាយថាបន្ទុកដ៏ធ្ងន់របស់គាត់នោះគឺជា "សេចក្តីអាក្រក់ឥតគណនា" (មើល ទដ ៣៨–៣៩ និងសេចក្តីផ្តើមនៃទំនុកដំកើងទាំងនេះ) ។ *ទូលបង្គំមិនអាចអាចនឹងងើបឡើងមើលបានឡើយ* មើលការពន្យល់ ១៣:៣ ។ *ច្រើនជាងសរសៃសក់លើក្បាលទូលបង្គំ* មើល មថ ១០:៣០ លក ១២:៧ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៤០:១៤–១៦** នៅក្នុងខទាំងនេះ គឺជាសេចក្តីអធិស្ឋានសូមសេចក្តីជំនួយមកពីព្រះអម្ចាស់ ដើម្បីឱ្យពួកខ្មាំងសត្រូវរបស់ស្តេចដាវីឌមានការអៀនខ្មាស់ និងលើកតម្កើងដល់ពួកអ្នកដែលស្រឡាញ់ព្រះអម្ចាស់ ។ ការវិខានរបស់ពួកខ្មាំងសត្រូវក្នុងគ្រាដែលមានបញ្ហា មើល ៣៨:១២ ៣៩:៨ ៤១:៥,៧ និងទំនុកដំកើងផ្សេងៗទៀត (មើលការពន្យល់ ៥:៩) ។ មើលការទាំង២នេះ និងការផ្តត់ផ្តង់ក្នុង ៣៥:២៦–២៧ ។

**៤០:១៤** *សេចក្តីខ្មាស ហើយលាក់មុខ . . . សេចក្តីអាប់យស* នៅក្នុងខនេះស្តេចដាវីឌទ្រង់ចង់ឱ្យពួកអ្នកដែលរកបំផ្លាញព្រលឹងទ្រង់ និងចង់ឱ្យទ្រង់មាន

ព្រមទាំងមានសេចក្ដីអាប់យសផង
១៥ ឯអស់អ្នកដែលនិយាយមកទូលបង្គំថា ន៍ ន៍[ឈ]
នោះសូមឱ្យគេត្រូវស្រឡាំងកាំង
ដោយសេចក្ដីខ្មាសរបស់គេទៅ
១៦ ចំណែកពួកអស់អ្នកដែលស្វែងរកទ្រង់[ញ]
នោះសូមឱ្យគេបានរីករាយសប្បាយ[ដ]ក្នុងទ្រង់ចុះ
សូមឱ្យអស់អ្នកដែលស្រឡាញ់សេចក្ដីសង្គ្រោះនៃទ្រង់បាន
ពោលជានិច្ចថា សូមឱ្យព្រះយេហូវ៉ាបានថ្កើងឡើង[ឋ]
១៧ ឯទូលបង្គំៗក្រីក្រ ហើយទុគ៌ត[ឌ] ប៉ុន្តែព្រះអម្ចាស់ទ្រង់នឹក[ឍ]
ដល់ទូលបង្គំដែរ ទ្រង់ជាជំនួយ[ណ]
ហើយជាអ្នកប្រោសឱ្យទូលបង្គំរួចផង[ត]
ឱព្រះនៃទូលបង្គំអើយ សូមកុំបង្អង់ឡើយ[ថ] ។

ទំនុកនៃស្ដេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**៤១** មានពរហើយ[ក] អ្នកណាដែលមានអធ្យាស្រ័យ
ដល់ពួកមនុស្សក្រីក្រ[ខ]
ព្រះយេហូវ៉ាទ្រង់នឹងជួយអ្នកនោះ ឱ្យរួចក្នុងថ្ងៃអាក្រក់[គ]
២ ព្រះយេហូវ៉ាទ្រង់នឹងជួយទំនុកបំរុង[ឃ] ហើយថែរក្សាជីវិត
អ្នកនោះ[ង] គេនឹងបានពរនៅផែនដីនេះ[ច]
ហើយទ្រង់នឹងមិនប្រគល់គេទៅក្នុងបំណងចិត្តនៃពួកខ្មាំង
សត្រូវឡើយ[ឆ]
៣ ព្រះយេហូវ៉ានឹងទ្រទ្រាំចំពោះគេនៅគ្រាដេកឈឺនៅគ្រែ[ជ]
ទ្រង់ក៏រៀបគ្រែឱ្យ នៅគ្រប់វេលាមានធុរៈ[ឈ] ។
៤ ខ្ញុំបានទូលថា ឱព្រះយេហូវ៉ាអើយសូមអាណិតមេត្តា[ញ]
ដល់ទូលបង្គំផង សូមប្រោស[ដ]ព្រលឹងទូលបង្គំឱ្យបានជា
ដ្បិតទូលបង្គំបានធ្វើបាប[ឋ]នឹងទ្រង់ហើយ
៥ ពួកខ្មាំងសត្រូវនៃទូលបង្គំ គេនិយាយសេចក្ដីអាក្រក់ពី
ទូលបង្គំថា តើវេលាណាវានឹងស្លាប់
ហើយឈ្មោះវាវិនាសបាត់ទៅ[ឌ]
៦ បើកាលណាគេមកសួរទូលបង្គំនោះក៏ពោលតែសេចក្ដី
ភូតភរទទេ[ឍ] ចិត្តគេប្រមូលសេចក្ដីទុច្ចរិតទុក[ណ]
លុះចេញទៅក្រៅហើយនោះក៏ផ្សាយប្រាប់[ត]សេចក្ដីនោះ
៧ ពួកអ្នកដែលស្អប់ទូលបង្គំ
គេខ្សឹបខ្សៀវគ្នា[ថ]ទាស់នឹងទូលបង្គំ
គេបង្កើតការប្រទូសរ៉ាយនឹងទូលបង្គំ ។
៨ គេថា មានរោគអាក្រក់ជាប់នៅខ្លួនវា ឥឡូវនេះ
ដែលវាដេកចុះហើយ

**៤០:១៥** ឈ ទដ ៣៥:២១ **៤០:១៦** ញ ចទ ៤:២៩ ១រប ២៨:៩ ទដ ៩:១០ ១១៩:២ ដ ទដ ៩:២ ឋ ទដ ៣៥:២៧ **៤០:១៧** ឌ ទដ ៨៦:១ ១០៩:២២ ឍ ទដ ១៤៤:៣ ណ ទដ ២០:២ ត ទដ ១៨:២ ថ ទដ ១១៩:៦០ **៤១:១** ក ចទ ១៤:២៩ ខ យប ២៤:៤ គ ទដ ២៥:១៧ **៤១:២** ឃ ទដ ១២:៥ ៣២:៧ ង អរ ៩:៩ ទដ ៧១:២០ ១១៩:៨៨,១៥៩ ១៣៨:៧ ១៤៣:១១ ច ទដ ៣៧:២២ ឆ ចទ ៦:២៤ **៤១:៣** ជ ទដ ៦:៦ ឈ ២សយ ១៣:៥ ២ពវ ១:៤

**៤១:៤** ញ ទដ ៦:២ ៩:១៣ ដ ចទ ៣២:៣៩ ឋ ទដ ៥១:៤ **៤១:៥** ឌ ទដ ៣៨:១២ **៤១:៦** ឍ ទដ ១២:២ ១០១:៧ មថ ៥:១១ ណ សភ ២៦:២៤ ត លវ ១៩:១៦ **៤១:៧** ថ ទដ ៧១:១០

សេចក្ដីខ្មាស បានមានសេចក្ដីខ្មាសដល់ខ្លួនវិញ (មើលការពន្យល់ ៥:១០) ។

**៤០:១៥** *ន៍ ន៍* សូមមើលការពន្យល់ ៣:២ ។

**៤០:១៧** *ក្រីក្រ ហើយទុគ៌ត* ឃ្លានេះគឺនិយាយសំដៅលើពួកអ្នកដែលត្រូវការសេចក្ដីជំនួយមកពីព្រះ (មើលការពន្យល់ ៣៤:៦) ។

**ទំនុកដំកើង៤១** នៅក្នុងជំពូកនេះ និយាយពីការអធិស្ឋានរបស់ស្ដេចដាវីឌ សូមសេចក្ដីមេត្តាករុណាមកពីព្រះអម្ចាស់ក្នុងគ្រាដែលទ្រង់កំពុងប្រឈរមុខនឹងព្រះឈួនដ៏ធ្ងន់ធ្ងរមួយ ។ ស្ដេចដាវីឌទ្រង់បានទទួលស្គាល់ថា ព្រះឈួនរបស់ទ្រង់គឺមានការទាក់ទងទៅនឹងអំពើបាបដែលទ្រង់បានប្រព្រឹត្ត (សូមមើលក្នុង ខ.៤ ហើយសូមមើលសេចក្ដីផ្ដើម ទដ ៣៨-៤០) ។ ពួកខ្មាំងសត្រូវរបស់ទ្រង់សង្ឃឹមចង់បានឱ្យព្រះអង្គសោយទីវង្គត់ (មើលការពន្យល់ ៥:៩) ហើយពេលនេះសូម្បីតែពួក"មិត្តសំឡាញ់ស្និទ្ធស្នាល"របស់ទ្រង់(ខ.៩) ក៏បានបោះបង់ និងត្រឡប់ទៅជាក្បត់នឹងព្រះអង្គដែរ (មើលការពន្យល់ ៣១:១១-១២) ។ នៅក្នុងបទគម្ពីរទំនុកដំកើងជំពូកនេះបានបញ្ចប់ដោយដាក់បញ្ចូលទំនុកដំកើង៤ចូលគ្នា ដែលភ្ជាប់ជាមួយនឹងផ្ទៃរឿងដ៏សាមញ្ញមួយ ។ មិនតែប៉ុណ្ណោះសោតព្រះគម្ពីរជំពូកនេះ និងជំពូក ៤០ គឺជាសេចក្ដីបញ្ចប់នៃទំនុកដំកើងវគ្គទី១ (មើលសេចក្ដីផ្ដើម ទដ ៤០-៤១) ។ ជាការពិតណាស់ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះគឺមានលក្ខណៈ សមប្បមាណនឹងគ្នាដែលមាន៤ល្បះហើយក្នុង១ល្បះមាន៣ខ ។ នៅក្នុងល្បះទី១និងល្បះទី៤គឺបានបរិយាយយ៉ាងល្អិតល្អន់ពីសេចក្ដីអធិស្ឋាន ។ នៅក្នុង ខ.១៣ វាមិនមែនជាចំណែករបស់បទគម្ពីរទំនុកដំកើងឡើយ ប៉ុន្តែវាជាការសរសើរដំកើងដល់ព្រះដែលបានភ្ជាប់មកក្នុងព្រះគម្ពីរទំនុកដំកើងវគ្គទី១នេះ (សូមមើលការពន្យល់ ខ.១៣) ។

**ទដ ៤១ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ៤ ត្រង់ចំណងជើង ។

**៤១:១-៣** នៅក្នុងខទាំងនេះអ្នកនិពន្ធមានទំនុកចិត្តថា ព្រះយេហូវ៉ាទ្រង់នឹងរៀបចំជីវិតគាត់ឡើងវិញ ។

**៤១:១** *មានពរហើយ អ្នកណាដែលមានអធ្យាស្រ័យដល់ពួកមនុស្សក្រីក្រ* ជាការពិតណាស់ ព្រះអម្ចាស់ទ្រង់នឹងប្រទានពរដល់មនុស្សទាំងអស់ដែលមានអធ្យាស្រ័យដល់ពួកក្រីក្រ ប៉ុន្តែជាពិសេសគឺដល់ស្ដេចដែលទ្រង់មានភារៈកិច្ចក្នុងការ ការពារដល់ពួកអ្នកដែលគ្មានអំណាច (មើល ៧២:២,៤, ១២-១៤ ៨២:៣-៤ សភ ២៩:១៤ ៣១:៨-៩ អស ១១:៤ យរ ២២:១៦) ។ *មានពរហើយ* មើលការពន្យល់ក្នុង ១:១ ។

**៤១:៤-៦** នៅក្នុងខទាំងនេះ ស្ដេចដាវីឌទ្រង់បានអធិស្ឋានសូមឱ្យព្រះអង្គទ្រង់ផ្ដល់សេចក្ដីមេត្តាករុណា និងប្រោសព្រះរោគរបស់ទ្រង់ ។

**៤១:៤** *ធ្វើបាប* សូមមើលការពន្យល់ ៣២:៣-៥ ។

**៤១:៥** *តើវេលាណាវានឹងស្លាប់* មើលការពន្យល់ ៣:២ ។ *ឈ្មោះវាវិនាសបាត់ទៅ* មើលការពន្យល់ ៩:៥ ។

**៤១:៦** *មកសួរទូលបង្គំ* គឺជាពួកអ្នកដែលមកសួរសុខទុក្ខទ្រង់ ក្នុងពេលដែលទ្រង់ព្រះឈួន ។ *ពោលតែសេចក្ដីភូតភរ* នៅកន្លែងនេះពួកគេនិយាយនៅកាន់ស្ដេចដាវីឌដូចជាមិត្តនឹងគ្នា ។ *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។

**៤១:៧-៩** ពួកមនុស្សដែលនិយាយនៅក្នុងខ.ទាំងនេះ គឺជាពួកខ្មាំងសត្រូវ និងមិត្តសំឡាញ់របស់ស្ដេចដាវីឌ ។

មុខជានឹងក្រោកឡើង[ទ]វិញមិនបានឡើយ
៩ អើ ទាំងមិត្រសំឡាញ់ស្និទ្ធស្នាលរបស់ទូលបង្គំ[ធ]
ជាអ្នកដែលទូលបង្គំបានទុកចិត្តហើយក៏បានបរិភោគបាយ
របស់ទូលបង្គំផង នោះបានលើកកែងជើងចង់ជាន់ឈ្លី
ទូលបង្គំដែរ[ន]
១០ តែ ឱព្រះយេហូវ៉ាអើយ សូមទ្រង់អាណិតមេត្តា[ប]លើទូល
បង្គំឡើងវិញ[ផ] ដើម្បីឱ្យទូលបង្គំបានសង[ព]តបដល់គេ ។
១១ យ៉ាងនោះ ទូលបង្គំនឹងដឹងថាទ្រង់សព្វព្រះហឫទ័យនឹង
ទូលបង្គំពិត[ភ]
ដោយពួកសត្រូវមិនមានជ័យជំនះឈ្នះទូលបង្គំឡើយ[ម]
១២ ឯទូលបង្គំ ទ្រង់ទប់ទល់ដោយសេចក្ដីសុចរិត[យ]របស់
ទូលបង្គំ[រ]
ហើយក៏តាំងទូលបង្គំឱ្យនៅចំពោះទ្រង់ជាដរាបទៅ[ល] ។
១៣ សូមលើកសរសើរ[វ]ដល់ព្រះយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែល[ស] ចាប់តាំងពីអតីត
ទៅដល់អនាគត អស់កល្បជានិច្ច អាម៉ែន
ហើយអាម៉ែន[ហ] ។

ប៉ែកទី២

ទំនុករបស់កូនចៅកូរេ
ដែលលើកសំរាប់មេភ្លេង ជាសេចក្ដីបង្រៀន ។

**៤២** ឱព្រះអង្គអើយ ព្រលឹងទូលបង្គំដង្ហក់[ក]រកទ្រង់ដូចជា

**៤១:៨** ទ ២ពវ ១:៤ **៤១:៩** ធ ២សយ ១៥:១២ យប ១៩:១៤ ន ជន ៣០:២ យប ១៩:១៩ ទដ ៥៥:២០ ៨៩:៣៤ មថ ២៥:២៣ លក ២២:២១ យហ ១៣:១៨ **៤១:១០** ប ខ.៤ ផ ទដ ៣:៣ ៩:១៣ ព ២សយ ៨:៨៩ **៤១:១១** ភ ជន ១៤:៨ ម ទដ ២៥:២ **៤១:១២** យ ទដ ២៥:២១ រ ទដ ១៨:៣៥ ៣៧:១៧ ៦៣:៨ ល យប ៤:៧ ទដ ២១:៦ ៦១:៧ **៤១:១៣** វ លប ២៤:២៧ ស ទដ ៧២:១៨ ហ ទដ ៧២:១៩ ៨៩:៥២ ១០៦:៤៨ **៤២:១** ក យប ១៩:២៧ ទដ ១១៩:១៣១ យអ ១:២០

**៤១:៩** *មិត្រសំឡាញ់ស្និទ្ធស្នាល . . . ក៏បានបរិភោគបាយរបស់ទូលបង្គំ* នៅក្នុងឃ្លានេះនិយាយសំដៅលើម្នាក់ ដែលបានចូលរួមទទួលទានអាហាររួមតុជាមួយនឹងស្ដេចដាវីឌ ដូចជាអ្នកដែលមានកិត្តិយស រួមទាំងពួកសំណប់របស់ស្ដេច និងពួកមិត្រសំឡាញ់ (មើលការពន្យល់ ៣១:១១–១២) ។ ពួកអ្នកដែលបាននិយាយនៅកន្លែងនេះប្រហែលសំដៅលើពួកអ្នក ដែលបោះត្រានៃសេចក្ដីសញ្ញាជាមិត្តភាពជាមួយនឹងស្ដេចដាវីឌ(មើលការពន្យល់ ២៣:៥)។ ព្រះយេស៊ូវគ្រីស្ទទ្រង់ក៏បានដកស្រង់ ខនេះមកនិយាយអំពីព្រះអង្គទ្រង់ដែរ(មើល យហ ១៣:១៨) ដើម្បីឱ្យបានសំរេចពីការគ្រប់គ្រងរបស់ទ្រង់ ដែលព្រះយេហូវ៉ាបានចាក់ប្រេងតាំងឱ្យគ្រប់គ្រងលើពួកអ៊ីស្រា–អែលនោះព្រះបុត្រដ៏ឆ្នើមរបស់ស្ដេច ដាវីឌទ្រង់ក៏ធ្លាប់ជួបប្រទះនូវការប្រឆាំងបះបោរពីសំណាក់អ្នកដទៃ ហើយមនុស្សក្នុងជំនាន់របស់ទ្រង់ ក៏បាត់បង់ការទុកចិត្តដែរ ហើយការទាំងនោះ គឺដើម្បីឱ្យបានសម្រេចពីការទុក្ខព្រួយរបស់ពួកព្ឋយុកោទ្រង់ ។

**៤១:១០–១២** នៅក្នុងកន្លែងនេះអ្នកនិពន្ធគាត់បានអធិស្ឋានដោយមានទំនុកចិត្តចំពោះព្រះអម្ចាស់ ។

**៤១:១០** *ដើម្បីឱ្យទូលបង្គំបានសងតបដល់គេ* នៅក្នុងឃ្លានេះចង់និយាយថាដើម្បីឱ្យទូលបង្គំ(ស្ដេចដាវីឌ)បានតវ៉ាជាមួយពួកគេ ។

**៤១:១២** *សេចក្ដីសុចរិតរបស់ទូលបង្គំ* មើលការពន្យល់ ១៥:២ ។ *តាំង* គឺនិយាយសំដៅទៅលើការតែងតាំង ឬការស្ដាបនាជីវិតឡើងវិញ ។ *នៅចំពោះទ្រង់* នៅក្នុងឃ្លានេះស្ដេចដាវីឌទ្រង់ចង់មានបន្ទូលថា ព្រះយេហូវ៉ាទ្រង់បានតែងតាំង ព្រះអង្គឱ្យធ្វើជាអ្នកបម្រើរបស់ទ្រង់ ដោយប្រទានអំណាចឱ្យក្លាយជាស្ដេចរបស់ពួកអ៊ីស្រាអែល ។ មើលសំនួនវោហាស់នេះក្នុង ១០១:៧ ១សយ ១៦:២២ "បំរើនៅមុខយើងចុះ" ១ពវ ១០:៨ "ចំពោះទ្រង់" ១៧:១ "ឈរនៅចំពោះ") ។ *អស់កល្បជានិច្ច* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់មិនដែលបដិសេធន៏ចំពោះស្ដេច ដាវីឌនោះឡើយ (សូមមើល ២សយ ៧:១៥–១៦) ។

**៤១:១៣** នៅក្នុងខនេះគឺជាបទនៃការសរសើរតម្កើង ដែលពួកអ្នកថ្វាយបង្គំដល់ព្រះអម្ចាស់ទាំងឡាយបានបញ្ចូលមក ដើម្បីតបឆ្លើយមាតិកានៃព្រះគម្ពីរទំនុកដំកើងវគ្គទី១ ។

**ទំនុកដំកើង ៤២–៤៥** ជំពូកទាំងនេះគឺជាប៉ែកទី២នៃព្រះគម្ពីរទំនុកដំកើង ដែលចាប់ផ្ដើមដោយមានសេចក្ដីអធិស្ឋានចំនួន៣បានភ្ជាប់មកជាមួយ (ប៉ុន្តែសូមមើលក្នុងសេចក្ដីផ្ដើម ទដ ៤២–៤៣) ហើយមិនត្រឹមតែប៉ុណ្ណោះសោតនៅក្នុងអារម្មណ៍កថា នៃចុងបញ្ចប់នៃគម្ពីរទំនុកដំកើងវគ្គទី២នេះបានភ្ជាប់មកជាមួយនូវទំនុកដំកើងនៃព្រះមហាក្សត្រថែមទៀតផង (សូមមើលសេចក្ដីផ្ដើម ទដ ៦៩–៧២) ។ សេចក្ដីអធិស្ឋានទាំងនោះបានភ្ជាប់មកដោយពាក្យគន្លឹះសំខាន់ៗ ដែលពាក្យទាំងនោះគេរកឃើញនៅក្នុងព្រះគម្ពីរទំនុកដំកើងវគ្គទី២ មានតែក្នុង ទដ ៦៩–៧២ ប៉ុណ្ណោះ ហើយក្នុងចំណោមចង្កោមទាំង៧នោះវាស្ថិតនៅចំណុចកណ្ដាលនៃព្រះគម្ពីរជំពូកនេះ (សូមមើលសេចក្ដីផ្ដើមព្រះគម្ពីរ ទដ ៥៤–៦០) ។ ទោះបីជាព្រះគម្ពីរទំនុកដំកើង ៤២–៤៣ ពណ៌នាពីសេចក្ដីអធិស្ឋានសម្រាប់លក្ខណៈបុគ្គល ហើយក្នុង ទដ ៤៤ និយាយពីការអធិស្ឋានសម្រាប់សហគមន៍ក៏ដោយ ក៏ទំនុកដំកើងទាំង២នេះវាមានផ្ទៃរឿងយ៉ាងសាមញ្ញជាច្រើនដូចគ្នា ។ ចំណុចស្នូលក្នុងទដទាំង២នេះគឺនិយាយពីការអំពាវនាវមួយដែលសួរថា "ហេតុអ្វីបានជាទ្រង់?" (សូមមើលក្នុង ៤២:៩ ៤៣:២ ៤៤:២៣–២៤) ហេតុអ្វីបានជាទ្រង់ភ្លេចទូលបង្គំ (សូមមើលក្នុង ៤២:៩ ៤៤:២៤) ហើយហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ (សូមមើលក្នុង ៤៣:២ ៤៤:២៣) នៅចំពោះមុខពួកខ្មាំងសត្រូវដែលសង្កត់សង្កិនទូលបង្គំដូច្នេះ (សូមមើល ក្នុង ៤២:៩ ៤៤:២៤) ប៉ុន្តែពាក្យថា "ហេតុអ្វី?" គឺសម្ដែង ប្រាប់ពីភាពតានតឹងនៃសេចក្ដីជំនឿ ដែលធ្លាប់ជួបប្រទះក្នុងស្ថានភាពមួយ ដូចជាអ្នកនិពន្ធបានពណ៌នា នាពេលនេះ ។ នៅទីនេះគឺជាសេចក្ដីផ្ដើមទាំង២ដំបូងនៃព្រះគម្ពីរទំនុកដំកើង ដែលនិយាយពីសេចក្ដីជំនឿ ដែលតបឆ្លើយចំពោះការធានាអះអាងនៃការខំទប់ "ចូរសង្ឃឹមដល់ព្រះចុះ" (សូមមើលក្នុង ៤២:៥,១១ ៤៣:៥) ពីព្រោះ "សេចក្ដីសប្បុរស"នៃទ្រង់មិនដែលកន្លងបាត់ឡើយ(សូមមើលក្នុង ៤២:៨ ៤៤:២៦) ។ តាមរយៈការជួបជុំគ្នាអំពាវនាវរបស់ពួកអ្នកដែលមានការថប់បារម្ភ នៅចំពោះព្រះអម្ចាស់ដែលទ្រង់ មិនបានប្រកាន់ចំពោះរាស្ត្រទ្រង់ ។ នៅក្នុងបទចម្រៀងនេះមានផ្ទៃរឿង២ដែលមានទំនាក់ទំនងជាមួយគ្នាយ៉ាងទូលំទូលាយនៃផ្ទៃរឿង (១).និយាយពីទំនួលខុសត្រូវរបស់ស្ដេចដាវីឌដោយប្រកាន់ភ្ជាប់យកសេចក្ដីយុត្តិធម៌ និងការពារប្រជានុរាស្ត្ររបស់ទ្រង់ឱ្យរួចពី

ក្តាន់ញី[ខ]ដង្ហក់រកជ្រោះទឹក[គ]
២ព្រលឹងទូលបង្គំស្រេក[ឃ]រកព្រះ
គឺព្រះដ៏មានព្រះជន្មរស់នៅ[ង]
តើដល់កាលណាបានទូលបង្គំនឹងមក[ច]ឈរចំពោះទ្រង់
៣ទឹកភ្នែក[ឆ]របស់ទូលបង្គំជាអាហារទូលបង្គំទាំងថ្ងៃទាំង
យប់ កំពុងដែលគេសួរមកទូលបង្គំជានិច្ចថា
តើព្រះឯងនៅឯណា[ជ]។
៤ឯដំណើរដែលទូលបង្គំបានទៅជាមួយនឹងហ្វូងមនុស្សព្រម
ទាំងនាំមុខគេទៅដល់ដំណាក់នៃព្រះ[ឈ]

**៤២:១** ខ ចទ ១០:៧ ក ចទ ១០:៧ **៤២:២** ឃ ទដ ៦៣:១ ១៤៣:៦ ង យស ៣:១០ ១សយ ១៤:៣៩ មថ ១៦:១៦ រម ៩:២៦ ច ទដ ៤៣:៤ ៨៤:៧ **៤២:៣** ឆ យប ៣:២៤ ជ ខ.១០ ទដ ៧៩:១០ ១១៥:២ យអ ២:១៧ មីក ៧:១០ **៤២:៤** ឈ ទដ ៥៥:១៤ ១២២:១ អស ២:២ ៣០:២៩

ពួកខ្មាំងសត្រូវជារៀងរហូត (២).ការធានារ៉ាប់រ៉ងពីសេចក្តីប្រោសលោះរបស់ព្រះ ដែលធ្វើឱ្យនគររបស់ទ្រង់ (ស្តេចដាវីឌ) រីកចម្រើនក្នុងអំឡុងពេលដែលទ្រង់គ្រប់គ្រង ហើយជំនួរវង្សរបស់ទ្រង់នឹងបានស្ថិតស្ថេរជានិច្ចនិរន្តរ៍ ហើយកិត្តិនាមនៃពីធីអភិសេករបស់ទ្រង់ជាមួយម្ចាស់ក្សត្រីសាសន៍ដទៃគឺជានិមិត្តរូបនៃការនេះ ។

**ទដ ៤២–៤៣** នៅក្នុងជំពូកទាំងនេះស្តេចដាវីឌទ្រង់បានអធិស្ឋានសូមឱ្យព្រះអម្ចាស់ទ្រង់រំដោះគាត់ចេញពីការ "សង្កត់សង្កិនរបស់ពួកខ្មាំងសត្រូវ" (សូមមើលក្នុង ៤២:៩ ៤៣:២) ហើយមិនត្រឹមតែប៉ុណ្ណោះសោត ស្តេចដាវីឌទ្រង់ក៏បានសូមឱ្យព្រះអម្ចាស់រៀបចំជីវិតរបស់ព្រះអង្គឡើងវិញ នៅចំពោះព្រះវត្តមានព្រះយេហូវ៉ាក្នុងព្រះវិហាររបស់ទ្រង់ ។ ដូច្នេះដែលព្រះគម្ពីរទំនុកដំកើងទាំង២ជំពូកនេះមានទម្រង់សេចក្តីអធិស្ឋានតែ១ (ទោះបីព្រះគម្ពីរនេះមាន២ជំពូកក៏ដោយ និងក្នុងសិបធ្យូជីនក៏បានគិតបែបនេះដែរ "សិបធ្យូជីនគឺជាការបកប្រែព្រះគម្ពីរសញ្ញាចាស់ ទៅភាសាក្រិចរបស់ពួកគ្រីស្ទបរិស័ទជំនាន់មុន") នោះវាគឺជាភស្តុតាងបញ្ជាក់ថាព្រះគម្ពីរទាំង២ជំពូកនេះមានលក្ខណៈតែ១ (សូមមើលខាងក្រោមនេះ) ហើយក៏បានវិវត្តន៍ប្រែក្លាយមកជាផ្ទៃរឿងសាមញ្ញមួយ ។ ការបែងចែកព្រះគម្ពីរទដ ៤៣ និង ទដ ៤២ ពីគ្នាប្រហែលដោយព្រោះគោលបំណងពិសេសក្នុងការសរសើរតម្កើងដល់ព្រះ (សូមមើលក្នុងសេចក្តីផ្តើម ទដ ៨) ។ អ្នកនិពន្ធនៅក្នុងកន្លែងនេះប្រហែលជាអ្នកដឹកនាំរបស់ពួកកូនចៅកូរេ ដែលពួកគេមានតួនាទីជាប់ទាក់ទងនឹងការច្រៀងថ្វាយព្រះនៅក្នុងព្រះវិហារ (សូមមើលក្នុង ៤២:៤ និងការពន្យល់ក្នុង ៤២ ត្រង់ចំណងជើង) ។ ប្រហែលពួក"បណ្តាជន ដែលមិនកោតខ្លាចព្រះ"ដែលនិយាយនៅកន្លែងនេះ សំដៅលើពួកសាសន៍ស៊ីរី មកពីក្រុងដាម៉ាស ហើយបន្ទាប់ពីនោះមក អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គាត់ត្រូវបានពួកស៊ីរីចាប់ជាឈ្លើយ ក្នុងអំឡុងពេលមានការលុកលុយមួយ ក្នុងចំណោមការលុកឯទៀតនៅក្នុងស្រុកយូដា ដូចជាក្នុងសម័យកាលស្តេចហាសែល (សូមមើលក្នុង ២ពវ ១២:១៧–១៨) ។ (ការវាយប្រហារពីសំណាក់ស្តេចហាសែលនេះ អាចមានឥទ្ធិពលប៉ះពាល់ដល់តំបន់ដែលពួកកូនចៅកូរេ ដែលជាកូនចៅរបស់ពួកគេហាត់រស់នៅ មើល យស ២១:៤,៩–១៩) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះគឺជាការចាប់ផ្តើមប៉ែកទី២នៃកណ្ឌទំនុកដំកើង (មើលសេចក្តីផ្តើម ទដ ៤២–៤៥) ដែលមានលក្ខណៈខុសគ្នាពីប៉ែកទី១ ដោយសារភាសាហេព្រើរនៃពាក្យថា "ព្រះ" (ភាសាហេព្រើរ អេឡូហ៊ីម) ដែលមានចំនួនច្រើនលើសលប់ចំណែកឯក្នុងប៉ែកទី១ ព្រះគម្ពីរភាសាហេព្រើរប្រើពាក្យថា "ព្រះយេហូវ៉ា"(យ៉ាវ៉េ) ក៏ច្រើនណាស់ដែរ ។

សំណង់ប្រយោគក្នុងព្រះគម្ពីរទំនុកដំកើងនេះ មាន៣ល្បះដែលសមមូលគ្នា (ក្នុង១ល្បះមាន ៤ខ) ហើយល្បះនិមួយៗមានបទបន្ទរ (មើល ៤២:៥,១១ ៤៣:៥) ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងល្បះកណ្តាល គឺវាមានចំណុចស្នូលសំខាន់របស់វា (មើលការពន្យល់ ៦:៦) ហើយក៏មានខបន្ថែមទៀត (មើល ៤២:៨) ដែលកាត់ផ្តាច់គំនិតរីកចម្រើនមួយ ហើយបញ្ចូលមកវិញ គឺបង្ហាញពីទំនុកចិត្តចំពោះព្រះអម្ចាស់ ។ ចាប់តាំងពីផ្នែកដែលមានសេចក្តីបន្ទរមក នោះសេចក្តីអធិស្ឋានបាននិយាយពីការចង់បានវត្តមានរបស់ព្រះអម្ចាស់ (មើល ៤២:១) និងការប្តេជ្ញាចិត្តក្នុងការសរសើរតម្កើងចំពោះព្រះនៅអាសនានៃព្រះ (មើល ៤៣:៤) ។ សូមមើលទំនុកដំកើងឯទៀតដែលមានបទបន្ទរ ទដ ៤៦,៤៩,៥៩,៨០,១០៧ ។

**ទដ ៤២ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ៤ត្រង់ចំណងជើង ។ *សេចក្តីបង្រៀន* មីលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។ *ទំនុករបស់កូនចៅកូរេ* គេអាចនិយាយម៉្យាងទៀថា "សម្រាប់កូនចៅពួកកូរេ" សូមមើល "ជូនដល់លោកយេឌូថិន" (ទដ ៣៩ ត្រង់ចំណងជើង) ។ ឃ្លាដែលថា "កូនចៅកូរេ" នៅទីនេះគឺសំដៅលើពួកចម្រៀងលេវី ដែលជាពួកព្ទយុកោរបស់ពួកកូរេ ដែលដាវីឌបានតែងតាំងឡើងដើម្បីបម្រើការងារជាអ្នកច្រៀងថ្វាយព្រះក្នុងព្រះវិហារ ។ ពួកកូនចៅកូនកូរេ គឺតំណាងឱ្យក្រុមគ្រួសារលេវី ដែលកេហាត់ជាកូនរបស់លេវី ។ អ្នកដឹកនាំរបស់ពួកគេក្នុងយុគ្គសម័យកាលស្តេចដាវីឌគឺហេម៉ាន (មើល ទដ ៨៨ ត្រង់ចំណងជើង) ។ ដូចគ្នានឹងអេសាបដែលជាអ្នកដឹកនាំក្រុមចម្រៀង ចេញពីគ្រួសារគើសុន ហើយយេឌូថិន (អេថាន) ដែលជាអ្នកដឹកនាំក្រុមចម្រៀង ក្នុងក្រុមគ្រួសារម្រ៉ារី (មើល ១រប ៦:៣១–៤៧ និងការពន្យល ទដ ៣៩ ត្រង់ចំណងជើង) ។ នេះគឺជាវគ្គដំបូង នៃវគ្គទាំង៧ក្នុងគម្ពីរទំនុកដំកើងដែលជាសេចក្តីបង្រៀនរបស់ពួកកូនចៅកូរេ (មើល ទដ ៤២–៤៩) ដែលមាន៣បាននិយាយនៅក្នុងប៉ែកទី៣នៃគម្ពីរទំនុកដំកើង (ទដ ៨៤–៨៥,៨៧–៨៨) ។

**៤២:១–៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់មានបំណងប្រាថ្នាចង់រស់នៅក្នុងដំណាក់នៃទ្រង់ ។

**៤២:១** *ដូចជាក្តាន់ . . . ដង្ហក់រកជ្រោះទឹក* នៅក្នុងឃ្លានេះចង់និយាយថាជីវិតរបស់សត្វក្តាន់គឺអាចរស់បានអាស្រ័យដោយមានទឹក ជាពិសេសនៅពេលជួបការបៀតបៀនចង់បានជីវិតពីសំណាក់នាយព្រាន វាក៏ដូចគ្នានឹងអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងដែរ ពេលនេះគាត់ក៏ត្រូវជួបប្រទះការជិះជាន់សង្កត់សង្កិនពីសំណាក់ពួកខ្មាំងសត្រូវរបស់គាត់ដែរ ។ *ព្រលឹង* សូមមើលការពន្យល់ក្នុង ៦:៣ ។

**៤២:២** *ព្រះដ៏មានព្រះជន្មរស់នៅ* មើល ចទ ៥:២៦ ។ *តើដល់កាលណា* ពេលវេលានេះ (មើល ខ.៩ ៤៣:១–២) ព្រះអម្ចាស់ទ្រង់បានថែរក្សាការពារជីវិតរបស់អ្នកនិពន្ធនៅឯព្រះវិហារ ។ *ឈរចំពោះទ្រង់* ឃ្លានេះចង់មានន័យថា ចូលទៅចំពោះព្រះវត្តមាននៃព្រះដើម្បីសន្ទនាជាមួយគ្នា (មើល នក ១៩:១៧ ២៩:៤២–៤៣ ៣០:៦,៣៦) ។

**៤២:៣** *ទាំងយប់ទាំងថ្ងៃ* សូមមើល ខ.៨ ។ *តើព្រះឯងនៅឯណា* សូមមើលការពន្យល់ ១០:១១ ។

**៤២:៤** *ព្រលឹង* មើលការពន្យល់ ៦:៣ ។ *ទៅជាមួយនឹងហ្វូងមនុស្សព្រម*

ដោយសំឡេងអរសប្បាយ[ញ] និងសេចក្ដីសរសើរ[ដ]
គឺជាពួកកកុញ ដែលកំពុងតែកាន់ថ្ងៃបរិសុទ្ធ[ឋ]
កាលណាទូលបង្គំនឹកចាំពីសេចក្ដីនេះនោះទូលបង្គំក៏ប្លុង
ព្រលឹងចេញ[ឌ]
៥ ឱព្រលឹងអញអើយ[ឍ] ហេតុអ្វីបានជាត្រូវបង្អោនចុះ
ហើយមានសេចក្ដីរសាប់រសល់[ណ] នៅក្នុងខ្លួនដូច្នេះ
ចូរសង្ឃឹមដល់ព្រះចុះ[ត]
ដ្បិតអញនឹងបានសរសើរ[ថ]ដល់ទ្រង់ទៀត
ដោយព្រោះព្រះភក្ត្រទ្រង់ដែលតែងតែជួយ[ទ] ។
៦ ឱព្រះនៃទូលបង្គំអើយ[ធ]
ព្រលឹងទូលបង្គំត្រូវបង្អោននៅក្នុងខ្លួន
ហេតុនោះបានជាទូលបង្គំនឹកចាំ[ន]ពីទ្រង់
នៅក្នុងស្រុកក្បែរទន្លេយ័រដាន់[ប] ភ្នំហើម៉ូន[ផ] និងភ្នំមីតសារ
៧ ទីជ្រៅហៅរកទីជ្រៅ[ព]ផងគ្នា
ដោយសូរឈូឆរនៃរមូររលក អស់ទាំងរលក
នឹងរំកាញ់ទឹកនៃទ្រង់បានហូរមកគ្របទូលបង្គំហើយ[ភ]
៨ ប៉ុន្តែព្រះយេហូវ៉ានឹងចាត់សេចក្ដីសប្បុរសទ្រង់[ម]មកនៅ
វេលាថ្ងៃ ហើយនៅវេលាយប់[យ]
បទចំរៀង[រ]នៃទ្រង់នឹងនៅជាមួយនឹងទូលបង្គំផង
គឺជាសេចក្ដីអធិស្ឋានដល់ព្រះនៃជីវិតទូលបង្គំ[ល] ។
៩ ទូលបង្គំនឹងទូលដល់ព្រះដ៏ជាថ្មដា[វ]នៃទូលបង្គំថា
ហេតុអ្វីបានជាទ្រង់ភ្លេច[ស]ទូលបង្គំ
ហេតុអ្វីបានជាទូលបង្គំត្រូវដើរទាំងទុក្ខព្រួយ[ហ]

**៤២:២** ញ អរ ៣:១៣ ដ យស ៦:៥ ទដ ៩៥:២ ១០០:៤ ១៤៧:៧ យហ ២:៩ ឋ ទដ ៣៥:១៨ ១០៩:៣០ ឌ ១សយ ១:១៥ **៤២:៥** ឍ ទដ ៣៨:៦ ៧៧:៣ បទ ៣:២០ មថ ២៦:៣៨ ណ យប ២០:២ ត ទដ ២៥:៥ ៧១:១៤ ថ ទដ ៩:១ ទ ទដ ១៨:៤៦ **៤២:៦** ធ ខ.១១ ទដ ៤៣:៥ ន ទដ ៦៣:៦ ៧៧:១១ ប លប ១៣:១០ ជន ១៣:២៩ ផ ចទ ៣:៨ ៤:៤៨ **៤២:៧** ព លប ១:២ ៧:១១ ភ ទដ ៦៩:២ យហ ២:៣ **៤២:៨** ម ទដ ៥៧:៣ យ ទដ ១៦:៧ រ ទដ ៧៧:៦ ល ទដ ១៣៣:៣ សស ៥:១៨ ៨:១៥ **៤២:៩** វ ទដ ១៨:៣១ ស ទដ ១០:១១ ហ ទដ ៣៥:១៤ ឡ យប ២០:១៩ ទដ ៤៣:២ ១០៦:៤២

*ទាំងនាំមុខគេ* នៅក្នុងឃ្លានេះចង់និយាយថា បើសិនជាការនិយាយនេះជាការពិតនោះបង្ហាញថា ជានិច្ចកាលអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់តែងតែដឹកនាំក្រុមចម្រៀងក្នុងការច្រៀងថ្វាយព្រះក្នុងព្រះវិហារ ។

**៤២:៥** ក្នុងខនេះនិយាយពីបន្ទរ សេចក្ដីជំនឿបានជំរុញចិត្តឱ្យកាន់តែមានជំនឿខ្លាំងឡើង (មើល ២៧:១៣–១៤ និងសេចក្ដីផ្ដើម ទដ ២៧) ។ *នឹងបានសរសើរ* សរសើរដោយព្រោះសេចក្ដីសង្គ្រោះរបស់ព្រះអង្គក្នុងកាលដែលទ្រង់បានជួយដល់គាត់ (មើលការពន្យល់ ៧:១៧ ៩:១ និង ៤៣:៤) ។

**៤២:៦–១០** នៅក្នុងខទាំងនេះនិយាយពីមូលហេតុ ដែលបណ្ដាលឱ្យអ្នកនិពន្ធមានបញ្ហាដ៏ធ្ងន់ធ្ងរក្នុងព្រលឹងរបស់គាត់ ។

**៤២:៦** *ឱព្រលឹងអញអើយ ហេតុអ្វីបានជាត្រូវបង្អោនចុះ* មើល ខ.៥,១១ ៤៣:៥ ។ *ហេតុនោះបានជាទូលបង្គំនឹកចាំពីទ្រង់* គឺគាត់បាននឹកចាំ (មើល ខ.៤) ពីគ្រានិរទេស និងគ្រាអំណររីករាយកាលពីអតីតកាល ហើយឥឡូវនេះក្នុងគ្រាដែលគាត់និរទេស គាត់បាននឹកចាំពីព្រះអម្ចាស់ និងការអស្ចារ្យរបស់ទ្រង់ (មើល ខ.៧,៩–១០) ប៉ុន្តែមិនមែនដោយគ្មានសេចក្ដីសង្ឃឹមឡើយ (មើល ខ.៨) ។ *នៅក្នុងស្រុក . . . ភ្នំមីតសារ* ប្រហែលចង់និយាយថា អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងនិយាយ នៅពេលដែលគាត់បានរួចពីសណ្ឋានជាឈ្លើយ នៅក្រៅព្រំប្រទល់អ៊ីស្រាអែលនិងយូដា ។ អ្នកខ្លះទៀតគិតថា អ្នកនិពន្ធចង់និយាយថាគាត់រស់នៅមីតសា (មីតសារគឺជាភ្នំឬជាភូមិមួយដ៏តូចមួយ ហើយគេមិនបានដឹងច្បាស់អំពីវាឡើយ) តាមចង្កេះភ្នំហើម៉ូនដែលនៅជិតក្បាលទឹកនៃទន្លេយ័រដាន់ ។ ការកាត់ស្រាយផ្សេងទៀតគឺនៅក្នុងភាសាហេព្រើរពាក្យថា "នៅក្នុង" និង "តាំងពី"និង"ស្រុកក្បែរទន្លេយ័រដាន់"គឺសំដៅលើទឹកដីសន្យា ។ ការនិយាយពី "ភ្នំហើម៉ូន" ប្រហែលចង់និយាយសំដៅទៅលើកំពូលដ៏ខ្ពស់មួយ នៅភាគខាងជើងនៃព្រំប្រទល់ទឹកដីនេះ (មើល ចទ ៣:៨ យស ១១:១៧ ១៣:១១ ១របស ៥:២៣) ហើយហូរធ្លាក់មកក្រោម (មើល ១៣៣:៣ បស ៤:៨) ។ អ្នកខ្លះទៀតនិយាយថា "ភ្នំមីតសារ"គឺសំដៅលើ "ភ្នំហើម៉ូន" ។

**៤២:៧** *ទីជ្រៅហៅរក . . . រំកាញ់ទឹកនៃទ្រង់* ជាញឹកញាប់ ឃ្លានេះគឺជាការនិយាយបញ្ចៀងលើទឹក ដែលធ្លាក់ពីភាគខាងលើនៃទន្លេយ័រដាន់ដូចដែលធ្លាក់មកពីលើកំពូលភ្នំហើម៉ូនដែរ ។ ទោះបីជាយ៉ាងនេះក៏ដោយ ការនេះគឺគ្រាន់តែភាសារបញ្ចៀង "រំកាញ់នៃទឹក" ដែលទឹកនោះបានធ្លាក់មកពីឃ្លាំងរបស់ទ្រង់ (មើលការពន្យល់ ៣៦:៨) ។ "ទីជ្រៅ" ដែលនៅខាងលើ បានហូរធ្លាក់ចូលក្នុងជ្រោះ និងទន្លេដែលគ្មានទឹក ហើយក៏បានហូរចូលសមុទ្រគឺមកដល់ទីជ្រៅនៅខាងក្រោម ។ រូបភាពនេះបង្ហាញពីទុក្ខលំបាកដ៏ធំរបស់អ្នកនិពន្ធព្រះគម្ពីរ ទដ ហើយរូបនេះក៏សំដៅលើ "រលកនិងការវាយបំបែក" របស់ព្រះអម្ចាស់ ដែលទ្រង់វាយគាត់ (អ្នកនិពន្ធ) (មើល ៦៩:១–២ ៨៨:៧ យហ ២:៣,៥ និងការពន្យល់ ៣២:៦) ។ ព្រះហស្ដនៃព្រះយេហូវ៉ាគឺមានការជាប់ទាក់ទងនឹងការឈឺចាប់របស់អ្នកនេះពន្ធ ដោយព្រោះព្រះអម្ចាស់ទ្រង់បានវាយផ្ទាល់ ហើយយ៉ាងហោចណាស់ព្រះអម្ចាស់ទ្រង់ជាអ្នកបណ្ដាលឱ្យមហន្តរាយនេះកើតឡើង ។ ព្រះអម្ចាស់ទ្រង់ហាក់បីដូចជា "ភ្លេច"(ខ.៩) និងបោះបង់ចោលអ្នកនិពន្ធ (៤៣:២) ។

**៤២:៨** នៅក្នុងខនេះ ជាចំណុចកណ្ដាលនៃជំពូកនេះដែលនិយាយពីការទុកចិត្ត និងសង្ឃឹមដល់ព្រះអម្ចាស់ ។ អ្នកនិពន្ធគាត់បាននិយាយថាព្រះយេហូវ៉ាទ្រង់នឹងចាត់"សេចក្ដីសប្បុរសរបស់ទ្រង់មកនៅវេលាថ្ងៃ (សូមធៀបជាមួយ ខ.៣) ហើយនៅវេលាយប់ បទចម្រៀងនៃទ្រង់នឹងនៅជាមួយនឹងទូលបង្គំ (មើលការពន្យល់ ៣:៧) ។ *ព្រះយេហូវ៉ា* នៅក្នុងជំពូកនេះពាក្យនេះមានប្រើតែនៅក្នុងចំណុចកណ្ដាលនៃជំពូកនេះប៉ុណ្ណោះ (មើលក្នុងសេចក្ដីផ្ដើម) ។ *ចាត់សេចក្ដីសប្បុរសទ្រង់មក* នៅក្នុងឃ្លានេះចង់និយាយថាព្រះអម្ចាស់ទ្រង់ផ្សាយសេចក្ដីសប្បុរសនៃទ្រង់មក ដូចជាអ្នកនាំសារដែលបានផ្សាយពីបំណងព្រះហឫទ័យរបស់ព្រះអង្គដែ (មើល ៤៣:៣) ។ *សេចក្ដីសប្បុរស* មើលការពន្យល់ ៦:៤ ។ *បទចំរៀងនៃទ្រង់* គឺជាបទចំរៀងដែលទាក់ទងនឹងព្រះអម្ចាស់ ។ *សេចក្ដីអធិស្ឋាន* នៅក្នុងឃ្លានេះចង់និយាយថាទាំងសេចក្ដីអធិស្ឋាននិងបទចម្រៀងតែង តែមាននៅក្នុងគំនិតរបស់អ្នកនិពន្ធជានិច្ច ។

**៤២:៩** ខនេះនឹងលើកមកនិយាយម្ដងទៀតក្នុង ៤៣:២ ។ *ថ្មដា* សូមមើលការពន្យល់ក្នុង ១៨:២ ។ *ហេតុអ្វី . . . ហេតុអ្វី . . .* សូមមើលការពន្យល់ក្នុង ៦:៣ និងសេចក្ដីផ្ដើម ទដ ៤២–៤៥ ។

ដោយព្រោះការសង្កត់សង្កិន[ឡ] របស់ខ្មាំងសត្រូវដូច្នេះ[អ]
១០ ពួកខ្មាំងសត្រូវ គេចំអក[ក] ឱ្យទូលបង្គំ
ប្រៀបដូចជាដាវចាក់[ខ] ក្នុងឆ្អឹងទូលបង្គំ
ដោយគេសួរជានិច្ចថា តើព្រះឯងនៅឯណា[គ]
១១ ឱព្រលឹងអញអើយ
ហេតុអ្វីបានជាឯងត្រូវបង្អោនចុះហើយ
មានសេចក្តីរសាប់រសល់នៅក្នុងខ្លួនដូច្នេះ
ចូរសង្ឃឹមដល់ព្រះចុះ
ដ្បិតអញនឹងបានសរសើរដល់ទ្រង់ទៀត
ដែលទ្រង់ជាសេចក្តីជំនួយ ហើយជាព្រះនៃអញ[ឃ] ។

**៤៣** ឱព្រះអង្គអើយ សូមវិនិច្ឆ័យទូលបង្គំ
ហើយកាន់ក្តី[ក] របស់ទូលបង្គំ ទាស់នឹងបណ្តាជន
ដែលមិនកោតខ្លាចដល់ព្រះ
ឱសូមជួយទូលបង្គំ[ខ] ឱ្យរួចពីមនុស្សកំភូត ហើយទុច្ចរិតផង[គ]
២ ដ្បិតទ្រង់ជាព្រះដ៏ប្រទានកំឡាំងដល់ទូលបង្គំ
ហេតុអ្វីបានជាទ្រង់ចោល[ឃ] ទូលបង្គំ
ហេតុអ្វីបានជាទូលបង្គំ ត្រូវទៅទាំងទុក្ខ ព្រួយ[ង] ដោយ
ព្រោះការសង្កត់សង្កិននៃពួកខ្មាំងសត្រូវដូច្នេះ[ច]
៣ ឱសូមផ្សាយពន្លឺ[ឆ] និងសេចក្តីពិត[ជ]
ចេញមកនាំមុខទូលបង្គំ[ឈ]
ដើម្បីឱ្យបាននាំទូលបង្គំទៅឯភ្នំបរិសុទ្ធ[ញ]
ហើយក្នុងព្រះវិហារនៃទ្រង់[ដ]
៤ នោះទូលបង្គំនឹងទៅ[ឋ] ឯអាសនា[ឌ] នៃព្រះ
គឺដល់ព្រះដ៏ជាសេចក្តីអំណរ[ឍ]
នឹងជាសេចក្តីរីករាយ[ណ] របស់ទូលបង្គំ ឱព្រះអង្គដ៏ជាព្រះ
នៃទូលបង្គំអើយ ទូលបង្គំនឹងសរសើរដល់ទ្រង់ដោយ
ចាប់ស៊ុង[ត]
៥ ឱព្រលឹងអញអើយ ហេតុអ្វីបានជាត្រូវបង្អោន ហើយ
រសាប់រសល់នៅក្នុងខ្លួនដូច្នេះ ចូរសង្ឃឹមដល់ព្រះចុះ
ដ្បិតអញនឹងបានសរសើរដល់ទ្រង់ទៀត
ដែលទ្រង់ជាសេចក្តីជំនួយ ហើយជាព្រះនៃអញ[ថ] ។

ទំនុករបស់កូនចៅកូរេ
ដែលលើកសំរាប់មេភ្លេង ជាសេចក្តីបង្រៀន ។
**៤៤** ឱព្រះអង្គអើយ យើងខ្ញុំបានឮដោយត្រចៀក
ពួកឰយុកោយើងខ្ញុំ[ក] បានថ្លែងប្រាប់មកយើងខ្ញុំ[ខ]

**៤២:៩** អ ទដ ៩:១៣ ៤៣:២ **៤២:១០** ក ទដ ៦:២ ខ ចទ ៣២:២៧ ទដ ៤៤:១៦ ៨៩:៥១ ១០២:៨ ១១៩:៤២ គ ខ.៣ **៤២:១១** ឃ ខ.៥ ទដ ៤៣:៥ **៤៣:១** ក ពច ៦:៣១ ខ ទដ ២៥:២០ គ ទដ ៣៦:៣ ១០៩:២ **៤៣:២** ឃ ទដ ៤៤:៩ ៧៤:១ ៨៨:១៤ ៨៩:៣៨ ង ទដ ៣៥:១៤ ច ទដ ៤២:៩ **៤៣:៣** ឆ ទដ ២៧:១ ជ ទដ ២៦:៣ ឈ ទដ ២៥:៥ ញ ទដ ២:៦ ដ ២សយ ១៥:២៥ **៤៣:៤** ឋ ទដ ៤២:២ ឌ ទដ ២៦:៦ ៨៤:៣ ឍ ទដ ២១:៦ ណ ទដ ១៦:៣ ត លប ៤:២១ **៤៣:៥** ថ ទដ ៤២:៦ **៤៤:១** ក ២សយ ៧:២២ ១របា ១៧:២០ យរ ២៦:១១ ខ ពច ៦:១៣

**៤២:១០** សូមមើលក្នុង ខ.៣ ។ *ឆ្អឹង* សូមមើលការពន្យល់ក្នុង ៦:២ ។
**៤៣:១-៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធគាត់បានអធិស្ឋានសូមឱ្យព្រះអម្ចាស់ទ្រង់រំដោះគាត់ឱ្យរួចពីពួកខ្មាំងសត្រូវ និងសូមឱ្យព្រះវត្តមាននៃទ្រង់ បានគង់នៅជាមួយគាត់ឡើងវិញ ។
**៤៣:១** នៅក្នុងខនេះ គឺជាការអង្វរករនៅក្នុងដំណាក់នៃព្រះ (សូមមើលសេចក្តីផ្តើម ទដ ៧១) ។
**៤៣:២** ខនេះគឺជាការដកស្រង់ចេញពី ៤២:៩ ។
**៤៣:៣** *ពន្លឺ និងសេចក្តីពិត* ទាំងនេះគឺជាអ្នកនាំសាររបស់ព្រះអង្គដែលបម្រើនៅខាងក្រៅដូច្នេះដែរ ដែល(១).សំដៅលើសេចក្តីសង្គ្រោះរបស់ទ្រង់ (ពន្លឺ មើលការពន្យល់ ២៧:១) ហើយ (២).សំដៅលើសេចក្តីស្មោះត្រង់ដែលទ្រង់ការពារគេ (សេចក្តីពិត ២៦:៣ ៣០:៩ ៤០:១០) ។ នៅក្នុងឃ្លានេះក៏មានន័យដែរថា សូមឱ្យការទាំងនោះបាននាំទូលបង្គំមកកាន់ព្រះវិហារនៃទ្រង់សារជាថ្មី ។ *ភ្នំបរិសុទ្ធ* មើលការពន្យល់ ២:៦ ។
**៤៣:៤** សូមមើលការពន្យល់ ៧:១៧ ។ *អាសនានៃព្រះ* សូមមើល ២៦:៦ និងការពន្យល់ ។
**ទដ ៤៤ ត្រង់ចំណងជើង** នៅក្នុងជំពូកនេះពួកអ៊ីស្រាអែលគេបានទូលសូមសេចក្តីជំនួយមកពីព្រះអម្ចាស់បន្ទាប់ពីពួកគេរងទុក្ខវេទនា និងវិនាសកម្មដ៏ធំធេងដែលបង្កឡើងដោយពួកខ្មាំងសត្រូវ ។ នៅក្នុង ខ.១៧-២២ វាមានការពិបាកក្នុងការបញ្ចូលព្រះគម្ពីរទំនុកដំកើងជំពូកនេះ ទៅនឹងពួកមនុស្សដែលបរាជ័យដែលប្រកាសឡើងដោយពួកហោរា ដែលពួកហោរាទាំងនោះជាចៅក្រមកាត់ក្តីលើសេចក្តីសញ្ញារបស់ពួកអ៊ីស្រាអែល ដោយព្រោះគេមិនបានស្មោះត្រង់ចំពោះសេចក្តីសញ្ញានេះ ។ ទំនុកដំកើងជំពូកនេះប្រហែលមានទំនាក់ទំនងទៅនឹងអាណាចក្រយូដា (ជាប្រជាជាតិដែលស្មោះត្រង់ចំពោះសេចក្តីសញ្ញានៃព្រះ ប៉ុន្តែនៅសម័យកាលក្រោយមកទៀតគេក៏បានបោះបង់សេចក្តីសញ្ញារបស់ព្រះ) ក្នុងសម័យកាលរាជស្តេចយេហូសាផាត ឬហេសេគា ។ សំណង់ប្រយោគ នៅក្នុងជំពូកនេះមានផ្ទៃរឿង៣ដែលមានការវិវឌ្ឍន៍លេចធ្លោដូចជាទំនុកដំកើងផ្សេងទៀត ដែលនិយាយពីការអធិស្ឋាននៅខបញ្ចប់ ។ ផ្ទៃរឿងទី១គឺនិយាយ ពីការសរសើរតម្កើងដល់ព្រះអម្ចាស់ដែលទ្រង់បានប្រទានជ័យជម្នះនា ពេលកន្លងមក (មើល ខ.១-៨) (២).ទៀតគឺនិយាយរ៉ាយរ៉ាប់ពីជ័យជម្នះ សង្គ្រាមនាពេលបច្ចុប្បន្ន និងចម្បាំងដណ្តើមទឹកដី (មើល ខ.៩-១៦) (៣). ពណ៌នាឬបញ្ជាក់ពីភាពគ្មានទោស(មើល ១៧-២២) ហើយនៅចុងបញ្ចប់ គឺជាសេចក្តីអធិស្ឋាន(មើល ខ.២៣-២៦) ។ ផ្ទៃរឿងនិមួយៗ (រំឭកពីការអស្ចារ្យកាលពីគ្រាមុនពណ៌នាពីបញ្ហាទុក្ខលំបាកនាពេលបច្ចុប្បន្ន និងការប្រកាសពីការស្មោះត្រង់ចំពោះសេចក្តីសញ្ញា) គឺជាគ្រឹះដើម្បីអធិស្ឋានសូមជំនួយមកពីព្រះអម្ចាស់ (មើល ទដ ៤០ និងសេចក្តីផ្តើម និងសេចក្តីអធិស្ឋានដ៏វែងមួយក្នុង ទដ ៤០,៨៩) ។ ទំនាក់ទំនងផ្ទៃរឿងរវាងជំពូក ៤៤ និង ៤២-៤៣ និងតួនាទីនៃទំនុកដំកើង ទាំងនោះដែលមាននៅក្នុងប៉ែកទី២ នៃទំនុកដំកើង សូមមើលក្នុងសេចក្តីផ្តើម ទដ ៤២-៤៥ ។
**ទដ ៤៤ត្រង់ចំណងជើង** សូមមើលក្នុង ទដ ៤២ ត្រង់ចំណងជើង ។
**៤៤:១-៨** នៅក្នុងខទាំងនេះ គឺជាការសរសើរដំកើងដល់ព្រះអម្ចាស់ចំពោះជ័យជម្នះដែលពួកគេធ្លាប់ទទួលបានកាលពីគ្រាមុនដូចជា (១).ពួកគេបាន

ពីការទាំងប៉ុន្មានដែលទ្រង់បាន
ធ្វើនៅសម័យចាស់បុរាណក្នុងជំនាន់គេ[គ]
២គឺពីទ្រង់បណ្តេញ[ឃ]អស់ទាំងសាសន៍ដទៃចេញដោយព្រះ
ហស្តទ្រង់ ហើយបានបណ្តុះ[ង]ពួកអ៊ីស្រាអែលវិញ
ទ្រង់បានប្រហារ[ច]អស់ទាំងសាសន៍ដទៃតែបានឱ្យ
អ៊ីស្រាអែលវាតទីចេញទៅ[ឆ]
៣ដ្បិតគេមិនបានចាប់យកស្រុកនោះ ដោយដាវ[ជ]ខ្លួនទេ
ក៏មិនមែនជាដៃខ្លួនគេ ដែលបានជួយសង្គ្រោះគេដែរ
គឺជាព្រះហស្តស្តាំ[ឈ] នឹងព្រះពាហុទ្រង់[ញ]
ព្រមទាំងពន្លឺ[ដ]នៃព្រះភក្ត្រទ្រង់វិញ
ដ្បិតទ្រង់បានប្រោស[ឋ]ដល់គេ ។
៤ឱព្រះអង្គអើយ ទ្រង់ជាមហាក្សត្រ[ឌ]នៃទូលបង្គំ[ឍ]
សូមបង្គាប់ឱ្យមានសេចក្តីសង្គ្រោះ[ណ]ដល់ពួកយ៉ាកុប
៥យើងខ្ញុំនឹងច្រានផ្តួល[ត]ពួកខ្មាំងសត្រូវ ដោយសារទ្រង់
ហើយនិងជាន់ឈ្លី[ថ] ពួកអ្នកដែលលើកគ្នាទាស់នឹងយើងខ្ញុំ
ដោយនូវព្រះនាមទ្រង់
៦ដ្បិតទូលបង្គំនឹងមិនពឹងធ្នូរបស់ទូលបង្គំទេ[ទ]
ហើយដាវទូលបង្គំក៏មិនជួយសង្គ្រោះទូលបង្គំដែរ
៧គឺទ្រង់ដែលជួយសង្គ្រោះ[ធ]យើងខ្ញុំ ឱ្យរួចពីពួកសត្រូវវិញ
ព្រមទាំងធ្វើឱ្យពួកអ្នកដែលស្អប់យើងខ្ញុំត្រូវខ្មាសផង[ន]
៨យើងខ្ញុំបានអួត[ប]ពីព្រះ ជាដរាបរាល់ថ្ងៃ[ផ]
ហើយនិងសរសើរដល់ព្រះនាមទ្រង់ ជាដរាបតទៅ[ព] ។
–បង្អង់
៩ប៉ុន្តែ ឥឡូវនេះ ទ្រង់បានបោះបង់ចោល[ភ]យើងខ្ញុំ
ហើយបានធ្វើឱ្យយើងខ្ញុំអាប់យសផង[ម]
ក៏មិនយាងចេញទៅជាមួយនឹងពលទ័ពយើងខ្ញុំទៀតដែរ[យ]

**៤៤:១** គ ចទ ៣២:៧ យប ៣៧:២៣ **៤៤:២** ឃ យស ៣:១០ កច ៧:៤៥ ង នក ១៥:១៧ អស ៦០:២១ ច ពច ៤:២៣ ២របា ១៤:១៣ ឆ ទដ ៨០:៩ យរ ៣២:២៣ **៤៤:៣** ជ យស ២៤:១២ ឈ ទដ ៧៨:៥៤ ញ នក ១៥:១៦ ទដ ៧៧:១៥ ៧៩:១១ ៨៩:១០ ៩៨:១ អស ៤០:១០ ៥២:១០ ៦៣:៥ ដ ទដ ៨៩:១៥ ឋ ចទ ៤:៣៧ **៤៤:៤** ឌ ទដ ២៤:៧ ឍ ទដ ៥:២ ណ ទដ ២១:៥ **៤៤:៥** ត យស ២៣:៥ ថ ទដ ៦០:១២ ១០៨:១៣ **៤៤:៦** ទ លប ៤៨:២២ ហស ១:៧ **៤៤:៧** ធ ចទ ២០:៤ ន យប ៨:២២ **៤៤:៨** ប ទដ ៣៤:២ ១កថ ១:៣១ ២កថ ១០:១៧ ផ ទដ ៥២:១ ព ទដ ៣០:១២ **៤៤:៩** ភ ទដ ៤៣:២

១០ទ្រង់បណ្តាលឱ្យពួកយើងខ្ញុំបែរខ្នង[រ]ចំពោះពួកខ្មាំង
សត្រូវ ហើយពួកអ្នកដែលស្អប់យើងខ្ញុំ
គេរឹបជាន់យករបឹប[ល]ទៅសំរាប់ខ្លួនគេ
១១ទ្រង់ធ្វើឱ្យយើងខ្ញុំបានដូចជាចៀម[វ]ដែលសំរាប់ធ្វើសាច់
ក៏បានកំចាត់កំចាយយើងខ្ញុំទៅនៅគ្រប់ទាំងសាសន៍ដទៃ[ស]
១២ទ្រង់លក់រាស្ត្រទ្រង់ឥតយកថ្លៃ[ហ]
ហើយមិនបានចំរើនទ្រព្យដោយសារដំឡៃរបស់គេទេ ។
១៣ទ្រង់ធ្វើឱ្យយើងខ្ញុំត្រឡប់ដោយសេចក្តីដំនៀល[ឡ]
ចំពោះពួកអ្នកជិតខាង[អ] ជាទីឡកឡើយ[ក]
ហើយជាទីសំណើច[ខ]ដល់អស់អ្នកដែលនៅជុំវិញ
១៤ក៏ឱ្យយើងខ្ញុំទៅជាសេចក្តីប្រៀបធៀប[គ]នៅគ្រប់ទាំង
នគរ ហើយជាទីគ្រវីក្បាល[ឃ]នៅគ្រប់សាសន៍ដទៃផង
១៥សេចក្តីអាប់យស[ង]របស់ទូលបង្គំនៅមុខទូលបង្គំជានិច្ច
ហើយភាពខ្មាស[ច]នៃមុខទូលបង្គំ ក៏គ្របទូលបង្គំដែរ
១៦ដោយព្រោះសំឡេង[ឆ]នៃពួកអ្នកដែលប្រមាថមើលងាយ[ជ]
ហើយពួកខ្មាំងសត្រូវ នឹងពួកអ្នកដែលសងសឹក[ឈ]ផង ។
១៧ការទាំងនោះបានកើតដល់យើងខ្ញុំហើយ
ប៉ុន្តែ យើងខ្ញុំមិនបានភ្លេចទ្រង់ឡើយ[ញ]

ម ចទ ៨:៣ ៣១:១៧ ទដ ១០៧:៣៩ អស ៥:១៥ យ យស ៧:១២ ទដ ១០៨:១១ **៤៤:១០** រ លវ ២៦:១៧ ល ពច ២:១៤ **៤៤:១១** វ ខ.២២ យរ ១២:៣ ស លវ ២៦:៣៣ ទដ ៩:១១ អគ ៦:៨ សក ២:៦ **៤៤:១២** ហ ចទ ៣២:៣០ អស ៥២:៣ យរ ១៥:១៣ ៥០:១ ៥២:៣ យរ ១៥:១៣ **៤៤:១៣** ឡ ២របា ២៩:៨ អស ៣០:៣ យរ ២៥:៩ ៨០:៦ ៤២:១៨ ៤៤:៨ អ ទដ ៧៩:៤ ៨៩:៤១ ក ចទ ២៨:៣៧ មីក ២:៦ ខ អគ ២៣:៣២ **៤៤:១៤** គ ១ពវ ៩:៧ ឃ ២ពវ ១៩:២១ **៤៤:១៥** ង លប ៣០:២៣ ២របា ៣២:២១ ទដ ៣៥:២៦ ច ទដ ៣៤:៥ **៤៤:១៦** ឆ ទដ ៤២:១០ ជ ទដ ១០:១៣ ៥៥:៣ ៧៤:១០ ឈ ១សយ ១៨:២៥ យរ ១១:១៩ រម ១២:១៩ **៤៤:១៧** ញ ចទ ៦:១២ ៣២:១៨ ទដ ១១៩:១៦,៦១,១៥៣,១៧៦ សភ ៣:១

ចូលរស់នៅក្នុងទឹកដីសន្យា(មើល ខ.១–៣) (២).សេចក្តីសុខសាន្តដែលគេបានក្នុងទឹកដីសន្យា (ខ.៤–៨) ។

**៤៤:១** សូមមើលក្នុង ៧៨:៣ ។

**៤៤:៣** *ពន្លឺនៃព្រះភក្ត្រទ្រង់* សូមមើលការពន្យល់ក្នុង ៤:៦ ១៣:១ ។

**៤៤:៤** *នៃ* ពាក្យនេះប្រើនៅកន្លែងនេះ និងកន្លែងផ្សេងៗទៀតក្នុងព្រះគម្ពីរទំនុកដំកើង វាជាបុរសទី១ឯកវចនៈដែលសំដៅលើប្រជាជាតិទាំងមូល (មើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង) ។ *យ៉ាកុប* មើលការពន្យល់ ១៤:៧ ។

**៤៤:៥,៨** *ព្រះនាមទ្រង់* សូមមើល ខ.២០ និងការពន្យល់ ៥:១១ ។

**៤៤:៨** *យើងខ្ញុំបានអួតពីព្រះ* នៅក្នុងឃ្លានេះចង់មានន័យថា យើងនឹងថ្វាយការសរសើរដល់ព្រះរាល់តែថ្ងៃ ។

**៤៤:៩–១៦** ប៉ុន្តែ ឥឡូវនេះទ្រង់បានបោះបង់ចោលយើងខ្ញុំ មានន័យថា (១).ទ្រង់ជាអ្នកបណ្តាលឱ្យមានការឈឺចាប់កើតមានដល់យើងខ្ញុំ (មើល ខ.៩–១២) (២).ព្រះអម្ចាស់ទ្រង់បានធ្វើឱ្យយើងខ្ញុំខ្មាសនៅចំពោះមុខខ្មាំងសត្រូវនៃទូលបង្គំ (ខ.១៣–១៦) ។

**៤៤:១១** *ទ្រង់ធ្វើឱ្យយើងខ្ញុំបានដូចជាចៀមដែលសំរាប់ធ្វើសាច់* នៅក្នុងឃ្លានេះចង់មានន័យថា ព្រះអម្ចាស់ទ្រង់មិនបានធ្វើជាអ្នកគង្វាលនៃយើងខ្ញុំ (សូមមើលក្នុង ខ.៤ និងការពន្យល់ក្នុង ២៣:១) ។

**៤៤:១២** *ទ្រង់លក់រាស្ត្រទ្រង់* គឺលក់ដូចជាទ្រព្យដែលគ្មានតំលៃ (មើល ចទ ៣២:៣០ ពច ២:១៤) ។ *ឥតយកថ្លៃ* នៅក្នុងឃ្លានេះចង់មានន័យថា ពួកគេគ្មានតម្លៃអ្វីទាល់តែសោះ (សូមមើល អស ៥២:៣ យរ ១៥:១៣ ធៀបនឹង អស ៤៣:៣–៤) ។

**៤៤:១៤** *ជាទីគួរគ្រវីក្បាល* គឺមាននន័យថា ជាទីមើលងាយដល់សាសន៍ដទៃ (សូមមើល ៦៤:៨) ។

**៤៤:១៦** *ពួកអ្នកដែលសងសឹក* សូមមើល ៨:២ និងការពន្យល់ ។

**៤៤:១៧–២២** ពួកយើងខ្ញុំស្មោះត្រង់នឹងទ្រង់មានន័យថា (១).យើងខ្ញុំមិនបានក្បត់សេចក្តីសញ្ញាទ្រង់ដែរ (មើល ខ.១៧–១៩) (២).មានន័យថាទ្រង់គឺជាទីបន្ទាល់អំពីយើងខ្ញុំថា យើងខ្ញុំមិនបានបែរទៅព្រះណាផ្សេងៗទៀត

កំមិនបានក្បត់សេចក្ដីសញ្ញាទ្រង់ដែរ
១៨ ចិត្តយើងខ្ញុំមិនបានថយត្រឡប់[ដ] ទេ
ជំហាននៃយើងខ្ញុំក៏មិនបានទាសចេញពីផ្លូវទ្រង់ដែរ
១៩ ទោះបើទ្រង់បានបំបាក់បំបែក[ឋ] យើងខ្ញុំនៅទីរបស់ឆ្កែព្រៃ[ឌ] ហើយគ្របយើងខ្ញុំ ដោយម្លប់នៃសេចក្ដីស្លាប់ក៏ដោយ[ឍ] ។
២០ បើយើងខ្ញុំបានភ្លេច[ណ] ព្រះនាមនៃព្រះរបស់យើងខ្ញុំ
ឬប្រទូលដៃទៅឯព្រះដទៃណាមួយ[ត]
២១ នោះតើព្រះមិនស៊ើបរកឱ្យឃើញទេឬអី
ដ្បិតទ្រង់ជ្រាបទាំងសេចក្ដីលាក់កំបាំងនៅក្នុងចិត្តផង[ថ]
២២ យើងខ្ញុំត្រូវគេសំឡាប់
ជាដរាបរាល់ថ្ងៃដោយព្រោះទ្រង់
ហើយក៏រាប់ទុកដូចជាចៀម[ទ] ដែលសំរាប់សំឡាប់[ធ] ។
២៣ ឱព្រះអម្ចាស់អើយ[ន] សូមទ្រង់តើនឡើង
ហេតុអ្វីបានជាទ្រង់នៅផ្ទំលក់[ប] សូមទ្រង់តើនឡើង[ផ]
កុំបោះបង់ចោលយើងខ្ញុំជាដរាបឡើយ[ព]
២៤ ហេតុអ្វីបានជាទ្រង់លាក់ព្រះភក្ត្រ[ភ]
ហើយភ្លេច[ម] សេចក្ដីវេទនា
និងសេចក្ដីទុក្ខលំបាករបស់យើងខ្ញុំ[យ]
២៥ ដ្បិតព្រលឹងនៃយើងខ្ញុំបានត្រូវឱនដល់ធូលីដីហើយ[រ]
ខ្លួនប្រាណនៃយើងខ្ញុំក៏ជាប់នៅដីដែរ
២៦ សូមទ្រង់តើនឡើង[ល] ជួយយើងខ្ញុំ ហើយលោះ[វ] យើងខ្ញុំ
ដោយយល់ដល់សេចក្ដីសប្បុរសរបស់ទ្រង់ផង[ស] ។

ទំនុករបស់កូនចៅកូរេ ដែលលើកតាមបទ "ផ្កាឈូក"
សំរាប់មេភ្លេង ជាចំរៀងពីសេចក្ដីស្រឡាញ់[ក] ។

**៤៥** ចិត្តរបស់ខ្ញុំពេញហៀរដោយសេចក្ដីដ៏ល្អ

**៤៤:១៨** ដ ទដ ១១៩:៥១,១៥៧ **៤៤:១៩** ឋ ២រប ១៤:១៣ ទដ ៥១:៨ ឌ យប ៣០:២៩ អស ៣៤:១៣ ឍ យប ៣:៥ **៤៤:២០** ណ ចទ ៣២:១៨ ពច ៣:៧ ត នក ២០:៣ អស ៤៣:១២ យរ ៥:១៩ **៤៤:២១** ថ ១សយ ១៦:៧ ១ពវ ៨:៣៩ សភ ១៥:១១ យរ ១២:៣ ១៧:១០ **៤៤:២២** ទ ខ.១១ ធ អស ៥៣:៧ យរ ១១:១៩ ១២:៣ រម ៨:៣៦

**៤៤:២៣** ន ទដ ៧:៦ ប ទដ ៧៨:៦៥ ផ ទដ ៥៩:៥ ព ទដ ៧៤:១ ៧៧:៧ **៤៤:២៤** ភ ចទ ៣២:២០ ទដ ១៣:១ ម បទ ៥:២០ យ ចទ ២៦:៧ **៤៤:២៥** រ ទដ ១១៩:២៥ **៤៤:២៦** ល ជន ១០:៣៥ ទដ ១២:៥ ១០២:១៣ វ ទដ ២៦:១១ ស ទដ ៦:៤ **៤៥:ចំណងជើង** ក បស ១:១

ឡើយ (មើល ខ.២០–២២) ។

**៤៤:១៧** *សេចក្ដីសញ្ញាទ្រង់* សូមមើលក្នុង នក ជំពូក ១៩–២៤ ។

**៤៤:១៨** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ *ផ្លូវទ្រង់* គឺមានន័យថា ផ្លូវដែលបំពេញសេចក្ដីសញ្ញានៃទ្រង់ (សូមមើលការពន្យល់ ៥:៨) ។

**៤៤:១៩** *ទ្រង់បានបំបែកយើងខ្ញុំ* ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ការនោះមិនមែនជាទីបន្ទាល់ថា យើងខ្ញុំមិនស្មោះត្រង់នឹងទ្រង់ឡើយ ។ *នៅទីរបស់ឆ្កែ* គឺមានន័យថាទ្រង់បានយកយើងខ្ញុំទៅកន្លែងដែលសោះកក្រោះ ហើយគ្មានមនុស្សរស់នៅ (សូមមើល អស ១៣:២២ យរ ៩:១១) ។ *ម្លប់នៃសេចក្ដីស្លាប់* គឺជាទីដែលគ្មានពន្លឺ (សូមមើលការពន្យល់ ៣០:១ ៣៦:៩) ។

**៤៤:២០** *ប្រទូលដៃ* គឺមានន័យថា អធិស្ឋាន (សូមមើល នក ៩:២៩ និងការពន្យល់) ។

**៤៤:២២** *ដោយព្រោះ* គេអាចនិយាយម្យ៉ាងទៀតថា "ដោយរឿងរ៉ាវនេះ" ឬ "ឱព្រះអង្គអើយ គឺទ្រង់ដែលជ្រាប" ។ ចាប់តាំងពីពួកអ៊ីស្រាអែលរស់នៅក្នុងស្រុកអេស៊ីព្ទ ពួកអ៊ីស្រាអែលបានរងទុក្ខលំបាកជាច្រើន ដោយព្រោះទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះអម្ចាស់ (មើល មថ ១០:៣៤) ។ លោកសាវកប៉ូល ក៏បានយកខនេះមកនិយាយសំដៅលើគ្រីស្ទបរិស័ទដែលរស់នៅក្នុងពន្លឺនៃសេចក្ដីស្លាប់ និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ (សូមមើលក្នុង រម ៨:៣៦) ។

**៤៤:២៣–២៦** នៅក្នុងខទាំងនេះ គឺជាការអធិស្ឋានអំពាវនាវសូមសេចក្ដីជំនួយមកពីព្រះយេហូវ៉ា ។ អ្នកនិពន្ធបានអធិស្ឋានសូម (១).ឱព្រះអង្គអើយ សូមតើនឡើងហើយបំពេញសេចក្ដីត្រូវការរបស់យើងខ្ញុំ (មើល ខ.២៣–២៤) (២).សូមតើនឡើង ហើយជួយយើងខ្ញុំ (ខ.២៥–២៦ និងសេចក្ដីផ្ដើម ទដ ១៦) ។

**៤៤:២៣** *សូមតើនឡើង* មើលការពន្យល់ ៧:៦ ។ *ហេតុអ្វី* មើលការពន្យល់ ៦:៣ និងសេចក្ដីផ្ដើម ទដ ៤២–៤៥ ។

**៤៤:២៥** *ដ្បិតព្រលឹងនៃយើងខ្ញុំបានត្រូវឱនដល់ធូលីដីហើយ* នៅក្នុងឃ្លានេះប្រហែលជាចង់និយាយថា ប្រហែលជាអាចនឹងស្លាប់ (មើល ២២:២៩ និងការពន្យល់ ៣០:១) ។ នៅក្នុងព្រះគម្ពីរភាសារហេព្រើរឃ្លានេះវាមានទំនាក់ទំនងនឹងឃ្លាបន្ទរត្រង់កន្លែង "ឱព្រលឹងអញអើយហេតុអ្វីបានត្រូវបង្អោនចុះ" ដែលមាននិយាយនៅ ទដ ៤២–៤៣ ។

**៤៤:២៦** *សូមតើនឡើងជួយយើងខ្ញុំ* មើល ៤៦:១,៥ និងការពន្យល់ត្រង់ ៣:៧ ។ *លោះ* មើលការពន្យល់ ២៥:២២ ។ *សេចក្ដីសប្បុរសរបស់ទ្រង់* មើលការពន្យល់ ៦:៤ និង ៤២:៨ និងការពន្យល់ ។

**ទំនុកដំកើងជំពូក៤៥** នៅក្នុងជំពូកនេះ គឺជាចម្រៀងនៃការសរសើរដល់ព្រះមហាក្សត្រក្នុងថ្ងៃរៀបអភិសេករបស់ទ្រង់ (សូមមើលចំណងជើងនិងសេចក្ដីផ្ដើម ទដ ៤២–៤៥) ។ អ្នកនិពន្ធគាត់បានឧទ្ទិសបទចម្រៀងនេះដល់ជំនួរវង្សរបស់ស្ដេចដាវីឌ ហើយបទចម្រៀងនេះផងដែរប្រហែលមិនមែនប្រើតែក្នុងពិធីរៀបអភិសេករបស់ស្ដេចតែម្ដងនោះទេ ។ ដោយព្រោះតែកូនក្រមុំជាម្ចាស់ក្សត្រីសាសន៍ដទៃ (មើល ខ.១០,១២) នោះការរៀបអភិសេកនេះបានបង្ហាញថា ព្រះមហាក្សត្រទ្រង់គឺជាភ្ញៀវអន្តរជាតិម្នាក់ដែលមានសារៈសំខាន់បំផុត (មើលការពន្យល់ ខ.៩) ។ ដោយហេតុនោះហើយបានជាគាត់អះអាងថា ក្នុងរជ្ជកាលរបស់ទ្រង់ ទ្រង់បានទទួលជ័យជម្នះលើនគរជាច្រើន (មើល ៣–៥ ហើយធៀបជាមួយ ទដ ២,១១០) ។ ក្នុងនាមព្រះអង្គជាបុត្រារបស់ស្ដេចដាវីឌ នោះទ្រង់គឺជាគំរូ (ស្រមោល) អំពីព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់ពីគ្រានិរទេសវិញ បទទំនុកដំកើងនេះ គឺនិយាយសំដៅលើព្រះមែស៊ី ជាកូននៃសេចក្ដីសន្យារបស់ស្ដេចដាវីឌ ជាអ្នកដែលអង្គុយលើបល្ល័ង្ករបស់ស្ដេចដាវីឌ (នៅក្នុង ខ.៦–៧ និយាយសំដៅលើព្រះយេស៊ូវគ្រីស្ទ សូមមើល ហព ១:៨–៩) ។ តាមចំណងជើងនៃព្រះគម្ពីរទំនុកដំកើងជំពូកនេះ បានបង្ហាញថាបទនៃទំនុកនេះបានតែងឡើង និងច្រៀងដោយពួកកូនចៅលេវីដែលច្រៀងក្នុងព្រះវិហារ ហើយហេតុការណ៍នេះវាមិនមែនអ្វីគួរឱ្យភ្ញាក់ផ្អើលពីទំនាក់ទំនងរវាងព្រះវិហារ (បល្ល័ង្កផែនដីនៃដំណាក់របស់ស្ដេចនៃពួកអ៊ីស្រាអែល) និងជំនួរវង្សរបស់ស្ដេចដាវីឌ

គឺខ្ញុំនិយាយពីសេចក្តីដែលខ្ញុំបាននិពន្ធពីដំណើរមហាក្សត្រ
អណ្តាតខ្ញុំជាស្លាបប្រកានៃអ្នកតែងរឿងយ៉ាងជំនាញ ។
២ ទ្រង់ព្រះករុណាល្អវិសេសជាងអស់ទាំងពួកមនុស្ស
ព្រះរឹមទ្រង់ប្រកបដោយព្រះគុណ[ខ]
ហេតុនោះបានជាព្រះបានប្រទានពរដល់ទ្រង់ជាដរាប
តទៅ[គ]
៣ ឱព្រះករុណាដ៏មានឥទ្ធិឫទ្ធិអើយ[ឃ]
សូមក្រវាត់ដាវ[ង]ជាប់នៅត្រគាកទ្រង់ ទុកជាគ្រឿងលំអ
និងសក្តិយសនៃទ្រង់ផង[ច]
៤ រួចជិះទៅ ដោយឥទ្ធិឫទ្ធិរបស់ទ្រង់មានទាំងជ័យជំនះផង[ឆ]
ដើម្បីការពារសេចក្តីពិត សេចក្តីសុភាព នូវសេចក្តី
សុចរិត[ជ] នោះព្រះហស្តស្តាំ[ឈ]នៃទ្រង់នឹងបង្រៀនទ្រង់ពីការ
ដែលគួរកោតខ្លាច[ញ]
៥ ព្រួញ[ដ]ទ្រង់មុតធៀបដល់បេះដូង[ឋ]របស់ពួកខ្មាំងសត្រូវនៃ
ព្រះករុណា[ឌ] សាសន៍ទាំងប៉ុន្មាននឹងដួលចុះនៅក្រោមទ្រង់
៦ ឱព្រះអង្គអើយ បល្ល័ង្កទ្រង់ស្ថិតស្ថេរនៅអស់កល្ប
ជានិច្ចរៀងរាបតទៅ[ឍ]
ឯព្រះដំបងពេជ្ររបស់រាជ្យទ្រង់ នោះជាដំបងសុចរិត
៧ ទ្រង់បានស្រឡាញ់សេចក្តីសុចរិត[ណ]
ហើយស្អប់ការទុច្ចរិត[ត] ហេតុនោះបានជាព្រះ

**៤៥:២** ខ លក ៤:២២ គ ទដ ២១:៦ **៤៥:៣** ឃ ២សយ ១:១៩ ង ចទ ៣២:៤១ ទដ ១៤៩:៦ វវ ១:១៦ ច យប ៤០:១០ ទដ ២១:៥ **៤៥:៤** ឆ វវ ៦:២ ជ សផ ២:៣ ឈ ទដ ២១:៨ ញ ចទ ៤:៣៤ ទដ ៦៥:៥ ៦៦:៣ **៤៥:៥** ដ ចទ ៣២:២៣ ឋ ជន ២៤:៨ ឌ ទដ ៩:១៣ ៩២:៩ **៤៥:៦** ឍ លប ២១:៣៣ បទ ៥:១៩ **៤៥:៧** ណ ទដ ៣៣:៥ ត ទដ ១១:៥ ថ ទដ ២:២ អស ៤៥:១ ៦១:១ សក ៤:១៤

(ជាអ្នកដែលព្រះអម្ចាស់តាំងឱ្យគ្រប់គ្រងលើប្រជារាស្ត្រទ្រង់ ដែលបានពណ៌នានៅក្នុងព្រះគម្ពីរសាំយូអែល ពង្សាវតារក្សត្រ និងរបាក្សត្រ) ។

លក្ខណៈសំណង់ប្រយោគវិញ បទនៃទំនុកនេះបានកាត់ផ្តាច់ដោយ ខ.១,១៧ ក្នុងខណៈពេលដែល ខ.២,១៦ ជាគ្រឹះទី២ ហើយទាំងអស់នេះ គឺសុទ្ធតែពណ៌នាអំពីស្តេច ។ បទចម្រៀងនេះមាន២ផ្នែក ដែលផ្នែក (១).ច្រៀងអំពីស្តេច (ខ.៣–៩) ហើយ (២).និយាយពីកូនក្រមុំ (ខ.១០–១៥) ។ នៅក្នុងផ្នែកនិមួយៗមាន២ផ្នែក ដែលទី១ (ក) ឧបទេសពីស្តេច (ខ.៣–៥) (ខ) សិរីល្អរបស់ស្តេច (ខ.៦–៩) ទី២ (ក) ឧបទេសពីកូនក្រមុំ (ខ.១០–១២) (ខ) សិរីល្អរបស់កូនក្រមុំ (ខ.១៣–១៥) ។

**ទដ ៤៥ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ជាសេចក្តីបង្រៀន* មើលការពន្យល់ ទដ ៩ ត្រង់ចំណងជើង ។ *ផ្កាឈូក* មើល ទដ ៦៩ ត្រង់ចំណងជើង ។ ពាក្យថា ផ្កាឈូកនៅកន្លែងនេះប្រហែលជាទម្រង់កាត់នៃពាក្យ "ត្រែ" នៃសេចក្តីបន្ទាល់ដែលមាននៅក្នុងចំណងជើង ទដ ៦០,៨០ ។ *ទំនុករបស់ពួកកូនចៅកូរេ* មើលការពន្យល់ ទដ ៤២ ត្រង់ចំណងជើង ។ *ចំរៀង* មើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង ។

**៤៥:១** សូមមើលក្នុង ខ.១៧ នៅត្រង់កន្លែងដែលមានការសច្ចាប្រណិធាន (ប្រហែលពួកមនុស្សដែលច្រៀងចម្រៀងនេះជាអ្នកសច្ចា) ថានឹងធ្វើឱ្យមានសេចក្តីនឹករឭកពីស្តេចជារៀងរហូតគ្រប់ទាំងតំណរ និងសេចក្តីសរសើរពីទ្រង់ដល់គ្រប់ទាំងសាសន៍ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៤៥:២** *ទ្រង់ព្រះករុណាល្អវិសេសជាងអស់ទាំងពួកមនុស្ស* នៅក្នុងឃ្លានេះចង់និយាយថាព្រះមហាក្សត្រអង្គនោះ គឺជាម្នាក់ដែលមានរូបឆោមសម្បត្តិល្អប្រពៃ(មើល ១សយ ៩:២ ១៦:១៨) ប៉ុន្តែទ្រង់គឺជាមនុស្សម្នាក់ដែលហួសពីមនុស្សធម្មតាទៅទៀត ហើយស្ទើរតែដូចជាព្រះ(មើលការពន្យល់ ខ.៦)។ *ព្រះរឹមទ្រង់ប្រកបដោយព្រះគុណ* មើល សភ ២២:១១ សស ១០:១២ ធៀបនឹង អស ៥០:៤ លក ៤:២២ និង ខ.១៦ នៅត្រង់កន្លែងដែលបង្ហាញថាព្រះមហាក្សត្រទ្រង់នឹងបានតំណាល ពីព្រះបុត្រទ្រង់ជារៀងរហូត ។ *ជាដរាប* មើលការពន្យល់ ខ.៦ ។

**៤៥:៣–៥** នៅក្នុងខទាំងនេះចង់និយាយថា សូមឱ្យព្រះករុណាបានចេញទៅទាំងមានដាវនៃជ័យជម្នះទៅជាមួយ ហើយនិងបំពាក់អាវនៃកិត្តិយសរបស់ទ្រង់ផង ។ ការទាំងនោះនឹងធ្វើឱ្យរាជរបស់ទ្រង់បានពិតត្រង់ជាងសម្លៀកបំពាក់ថ្ងៃរៀបអភិសេក ដែលតែងនៅពេលនេះទៅទៀត (សូមមើល ខ.៨) ។

**៤៥:៣** *ទុកជាគ្រឿង* មើលការពន្យល់ ១០៩:២៩ ។ *គ្រឿងលំអ និងកិត្តិយស* មើល ២១:៥ និងការពន្យល់ ។

**៤៥:៤** *សេចក្តីសុចរិត* មើលការពន្យល់ ១:៥ ។ *ពីការដែលគួរឱ្យកោតខ្លាច* មើល ៦៦:៥ ១០៦:២២ ១៤៥:៦ ។

**៤៥:៥** *សាសន៍ទាំងប៉ុន្មាន និងដួលចុះនៅក្រោមទ្រង់* សូមមើលក្នុង ២:៨–៩ ១១០:១–២,៥–៦ ។

**៤៥:៦–៩** នៅក្នុងខទាំងនេះ និយាយពីព្រះកិត្តិយសរបស់ស្តេចក្នុងសម័យកាលដែលទ្រង់គ្រប់គ្រង ដែលនៅក្នុងសម័យកាលនោះប្រទេសជាតិមានពេញដោយសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិត (មើល ទដ ៧២) ។

**៤៥:៦** *ឱព្រះអង្គអើយ* បល្ល័ង្ករបស់ស្តេចក៏ជាបល្ល័ង្ករបស់ព្រះយេហូវ៉ាដែរ ពីព្រោះព្រះមហាក្សត្រ ទ្រង់គឺជាអ្នកដែលព្រះបានតែងតាំងឱ្យក្លាយជាអ្នកសម្រេចកិច្ចការសម្រាប់ព្រះអង្គ ។ ជាមួយគ្នានោះផងដែរឃ្លានេះក៏អាចជាការអះអាងរបស់ស្តេចដែលបានណែនាំខ្លួនព្រះអង្គថា ទ្រង់គឺជាព្រះ ។ ជំនួវង្សរបស់ស្តេចដាវីឌ (ការ"ចាក់តាំង"របស់ព្រះ មើល ២សយ ១៩:២១) គឺជាអ្នកដែលមានទំនាក់ទំនងពិសេសជាមួយព្រះអម្ចាស់ នោះព្រះអម្ចាស់បានហៅទ្រង់ថា "ជាបុត្រ" របស់ព្រះអម្ចាស់ (មើល ២:៧ ២សយ ៧:១៤ ១របា ២៨:៦ ធៀបនឹង ៨៩:២៧) ។ នៅក្នុង ទដ ជំពូកនេះដែលបាននិយាយពីស្តេច ជាពិសេសសរសើរពី "គ្រឿងលំអ និងកិត្តិយសនៃទ្រង់" (មើល ខ.៣) ការនេះហើយដែលអាចឱ្យគិតបានថា គេហៅព្រះអង្គថាជាព្រះនោះ គឺជាងារនៃព្រះកិត្តិយសរបស់ទ្រង់ (មើលធៀបនឹង អស ៩:៦) ។ ដូច្នេះការពិណ៌នាពីជំនួវង្សនៃស្តេចដាវីឌ ដែលមានន័យគ្រប់គ្រាន់ គឺនៅពេលដែលព្រះគ្រីស្ទយាងមក ដូចដែលអ្នកនិពន្ធព្រះគម្ពីរហេព្រើរបានពណ៌នាស្រាប់ (ហេព ១:៨–៩) ។ (ពេលខ្លះស្តេចផារ៉ោនត្រូវបានស្តេចនៃស្រុកកាណានហៅថា "ព្រះនៃទូលបង្គំ") ។ *ជានិច្ចរៀងដរាបតទៅ* មើល ខ.២,១៧ ។ ដូច្នេះឃ្លានេះ គឺជាភាសារដែលប្រើជាសេចក្តីគោរពចំពោះស្តេច(មើលការពន្យល់ ២១:៤) ។ នៅទីនេះគឺចង់និយាយពីសារៈសំខាន់ក្នុងការតាំងសញ្ញារវាងព្រះអម្ចាស់និងស្តេចដាវីឌ(មើល ៨៩:៤,២៩,៣៦ ១៣២:១២ ២សយ ៧៣:១៦) បុត្ររបស់ស្តេចដាវីឌបានសម្រេចនៅពេលដែលព្រះគ្រីស្ទយាងមក ។

គឺជាព្រះនៃទ្រង់បានចាក់ប្រេង[ថ]ថ្វាយទ្រង់
ជាប្រេងនៃសេចក្ដីត្រេកអរសាទរ[ទ] លើសជាងពួក
សំឡាញ់នៃទ្រង់
[៨]ព្រះពស្ត្រទ្រង់ផ្សាយក្លិនក្រអូប[ធ]
ដោយជ័រល្វីងទេស[ន] ក្រឹស្នា[ប] និងកំញាន[ផ] មានពួសរភ្លេង[ព]
ចេញពីដំណាក់ភ្លុក[ភ] បណ្ដាលឱ្យទ្រង់សប្បាយឡើង
[៩]មានបុត្រីស្ដេច[ម] នៅក្នុងពួកស្ត្រីជាន់ខ្ពស់របស់ទ្រង់
ឯអគ្គមហេសី[យ]ព្រះនាងគង់នៅខាងស្ដាំ[រ] ទ្រង់ប្រដាប់ដោយ
គ្រឿងមាសពីស្រុកអូភារ[ល]។
[១០]កូនស្រីអើយ[វ] ចូរស្ដាប់ ហើយពិចារណា[ស]
ចូរផ្ទៀងត្រចៀកស្ដាប់ចុះ ចូរភ្លេចសាសន៍[ហ]ឯង
នឹងផ្ទះឪពុកឯងទៅ
[១១]នោះស្ដេចទ្រង់នឹងគាប់ព្រះទ័យ ដោយសេចក្ដីលំអរ
របស់ឯង[ឡ] ដ្បិតទ្រង់ជាចៅហ្វាយឯង[អ]
ដូច្នេះត្រូវកោតខ្លាច[ក]ដល់ទ្រង់
[១២]ឯបុត្រីក្រុងទីរ៉ុស[ខ]នាងនឹងនៅទីនោះ ទាំងថ្វាយជង្វាយ
ផង[គ] ពួកអ្នកមានក្នុងបណ្ដាជន និងមករកពឹងគុណនៃឯង
ដែរ
[១៣]ឯបុត្រីនៃស្ដេច ដែលនៅក្នុងដំណាក់នាងមានសេចក្ដីរុង
រឿង[ឃ] ព្រះភូសារបស់នាងចិរុះដោយមាស[ង]។
[១៤]គេនឹងនាំនាងមកថ្វាយព្រះករុណា[ច] ប្រដាប់ដោយព្រះ
ភូសាប៉ាក់[ឆ] ឯពួកព្រហ្មចារី ជាភឿន[ជ] ដែលដង្ហែនាងមក
នោះនឹងមកឯទ្រង់ដែរ
[១៥]នឹងមានអ្នកនាំគេចូលមកក្នុងព្រះរាជដំណាក់
ដោយមានសេចក្ដីរីករាយសប្បាយ[ឈ]។
[១៦]នោះនាងនឹងបានព្រះរាជបុត្រជំនួសឪពុក
ហើយនាងនឹងតាំងព្រះរាជបុត្រទាំងនោះឱ្យធ្វើជា
ចៅហ្វាយ[ញ]នៅគ្រប់លើផែនដី
[១៧]អញនឹងធ្វើឱ្យមានសេចក្ដីរឭកនឹកចាំពីឈ្មោះឯងនៅ
គ្រប់ទាំងដំណមនុស្សតទៅ[ដ] ហេតុនោះអស់ទាំងសាសន៍
នឹងសរសើរដល់ឯង[ឋ]
នៅអស់កល្បជានិច្ចរៀងរាបតទៅ[ឌ]។

**៤៥:៧** ទ ទដ ២៣:៥ ហព ១:៨-៩ **៤៥:៨** ធ សក ២៧:៩ ១:៣ ៤:១០ ន លប ៣៧:២៥ ប ជន ២៤:៦ យហ ១៩:៣៩ ផ នក ៣០:២៤ ព ទដ ១៤៤:៩ ១៥០:៤ អស ៣៨:២០ ភ ១ពវ ២២:៣៩ **៤៥:៩** ម បស ៦:៨ យ អស ៦២:៥ រ ១ពវ ២:១៩ ល លប ១០:២៨ **៤៥:១០** វ នរ ១:១១ ស យរ ៥:១ ហ នរ ១:១៦ **៤៥:១១** ឡ នអ ១:១១ បទ ២:១៥ អ ១ពត ៣:៦ ក អក ៥:៣៣ **៤៥:១២** ខ យស ១៩:២៩ គ ១ពវ ៩:១៦ ២របា ៩:២៤ **៤៥:១៣** ឃ អស ៦១:១០ ង នក ៣៩:៣ **៤៥:១៤** ច នអ ២:១៥ ឆ ពច ៥:៣០ ជ បស ១:៣ **៤៥:១៥** ឈ នអ ៨:១៧ **៤៥:១៦** ញ ១សយ ២:៨ ទដ ៦៨:២៧ ១១៣:៨ **៤៥:១៧** ដ នអ ៣:១៥ ទដ ៣៣:១១ ១១៩:៩០ ១៣៥:១៣ ឋ ទដ ១៣៨:៤ ឌ ទដ ២១:៤ វវ ២២:៥

**៤៥:៧** *ពួកសំឡាញ់* គឺជាពួកភ្ញៀវអភិជនរបស់ស្ដេច ហើយប្រហែលមកពីបណ្ដាប្រទេសផ្សេងៗ ។ *ប្រេងនៃសេចក្ដីអំណរ* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់បានចាក់ប្រេងតាំងដល់ទ្រង់ដោយប្រេងនៃអំណរដ៏ហូរហៀរជាងប្រេងក្រអូប ដែលចាក់លាបលើសិរិសារ និងរូបកាយទ្រង់ ក្នុងថ្ងៃអភិសេករបស់ទ្រង់ទៅទៀត (មើល ២៣:៥ អស ៦១:៣) ។

**៤៥:៨-៩** នៅក្នុងខទាំងនេះ គឺពិពណ៌នាពីសិរីល្អរបស់ព្រះមហាក្សត្រក្នុងថ្ងៃអភិសេករបស់ទ្រង់ ។

**៤៥:៨** *ជ័រល្វីងទេស* មើលការពន្យល់ លប ៣៧:២៥ បស ១:១៣ ។ *ក្រឹស្នា* មើលការពន្យល់ បស ៤:១៤ ។ *កំញាន* មើលការពន្យល់ នក ២៥:៦ ។ *ដំណាក់ភ្លុក* សូមមើល ១ពវ ២២:៣៩ អម ៣:១៥ ៦:៤ ។

**៤៥:៩** *បុត្រីស្ដេច* ស្ត្រីនោះរាប់ទាំងស្ត្រីស្នំរបស់ស្ដេច (មើល ១ពវ ១១:១-៣) ឬក៏ពួកភ្ញៀវដែលចូលរួមពិធីបង្គលការរបស់ទ្រង់ដែលពួកគេ គឺជាអ្នកដែលតំណាងឱ្យពួកភ្ញៀវជាតិសាសន៍ដទៃរបស់ព្រះអង្គ (ស្ដេច) ។ *ប្រដាប់ដោយគ្រឿងមាសពីស្រុកអូភារ* គឺការតាក់តែងកាយដោយគ្រឿងមាសយ៉ាងល្អប្រណិត (មើលការពន្យល់ លប ១០:២៩ ១ពវ ៩:២៨) និងសម្លៀកបំពាក់ដ៏ល្អប្រណិត ។

**៤៥:១០-១២** នៅក្នុងខទាំងនេះ គឺជាពាក្យសម្ដីដល់កូនក្រមុំ ។

**៤៥:១០-១១** នៅក្នុងខទាំងនេះចង់និយាយថា សូមឱ្យស្មោះត្រង់ចំពោះស្ដេចនៃអ្នក ។

**៤៥:១២** *បុត្រីក្រុងទីរ៉ុស* ឃ្លានេះចង់និយាយពីភាពល្អឥតខ្ចោះរបស់ក្រុងទីរ៉ុស (មើលការពន្យល់ ២ពវ ១៩:២១) ។ ស្ដេចនៃក្រុងទីរ៉ុស គឺជាជាតិសាសន៍ដទៃដំបូង ដែលបានទទួលស្គាល់ជំនួរវង្សរបស់ស្ដេចដាវីឌ (មើល ២សយ ៥:១១) ហើយស្ដេចសាឡូម៉ូនទ្រង់បានផ្សារទំនាក់ទំនងដ៏ជិតស្និទជាមួយមនុស្សក្នុងក្រុងនេះ (មើល ១ពវ ជំពូក ៥ ៩:១០-១៤,២៦-២៨) ។ ទីក្រុងទីរ៉ុសមានឈ្មោះល្បីល្បាញ និងមានសារៈសំខាន់ពីព្រោះទីក្រុងនេះជាមជ្ឈមណ្ឌលពាណិជកម្មដ៏សំខាន់ តាមឆ្នេរសមុទ្រមេឌីទែរ៉ានេ (មើលការពន្យល់ អស ជំពូក ២៣ អក ២៦:១-២៨:១៩) ។ *ពួកអ្នកមានក្នុងបណ្ដាជន* គឺអ្នកទាំងនេះមានដូចជាមនុស្សដែលមកពីស្រុករបស់ទ្រង់ដែរ ។ *មករកពឹង* គឺពួកគេមានបំណងប្រាថ្នាចង់ក្លាយជាអ្នកមានគុណ ដែលដូចជាអគ្គមហេសីរបស់ស្ដេច ។ ដូច្នេះពួកអ្នកមានទាំងនោះនឹងក្លាយជារបស់អ្នក បើសិនជាអ្នកស្មោះត្រង់ចំពោះស្វាមីរបស់អ្នក ។

**៤៥:១៣-១៥** នៅក្នុងខទាំងនេះ គឺនិយាយពីកិត្តិយសរបស់កូនស្រីៗដែលនៅក្រមុំ ។

**៤៥:១៤** *ពួកព្រហ្មចារី* ពួកនាងក៏ជា"ពួកសម្លាញ់"របស់ទ្រង់ផងដែរ (មើល ខ.៧) ប្រហែលពួកនាងទាំងនោះ បានមកឯព្រះមហាក្សត្រជារៀងរហូត ។ *មកឯទ្រង់ដែរ* គឺមកចំពោះស្ដេច ។

**៤៥:១៦** *ជំនួសឪពុក* គឺមានន័យថា ជាអ្នកបន្តវង្សត្រកូល (បន្តរាជ) ។ នៅក្នុងឃ្លានេះប្រហែលចង់និយាយថា ពួកគេនឹងអាចទទួលបានកិត្តិយសជាងព្រះបិតាទ្រង់ទៅទៀត (មើលការពន្យល់ ខ.២) ។ *ផែនដី* គេអាចនិយាយម្យ៉ាងទៀតថា"លោកិយ" ។

**៤៥:១៧** មើលការពន្យល់ ខ.១ ។ *ជានិច្ចរៀងរាបតទៅ* មើលការពន្យល់ ខ.៦ ។

ទំនុករបស់កូនចៅកូរេ ដែលលើកសំរាប់មេភ្លេង
ត្រូវច្រៀងដោយសំឡេងស្រួច ។
**៤៦** ព្រះទ្រង់ជាទីពឹងជ្រក[ក] ក៏ជាកំឡាំងនៃយើងខ្ញុំ[ខ]
ជាជំនួយ[គ]ដែលនៅជាប់ជាមួយ[ឃ]ក្នុងគ្រាអាសន្ន[ង]
២ ហេតុនោះ
យើងខ្ញុំនឹងមិនខ្លាចឡើយ[ច] ទោះបើផែនដីប្រែប្រួលទៅ[ឆ]
ហើយភ្នំទាំងប៉ុន្មានត្រូវរើធ្លាក់ចុះ[ជ] នៅកណ្តាលសមុទ្រ
ក៏ដោយ[ឈ]
៣ ទោះបើទឹកសមុទ្របញ្ចេញសូរគឹកកង[ញ] ហើយរំជួល
ឡើង[ដ] ឬភ្នំទាំងឡាយត្រូវកក្រើកញ័រ[ឋ] ដោយរលកលោត
ចុះឡើងក្តី ។ –បង្អង់

**៤៦:១** ក ទដ ៩:៩ ៣៧:៣៩ ៦១:៣ ៧៣:២៦ ៩១:២,៩ ១៤២:៥ អស ៣៣:១៦ យរ ១៦:១៩ ១៧:១៧ យអ ៣:១៦ ណហ ១:៧ ខ ទដ ១៨:១ គ ទដ ១៨:៦ លក ១:៥៤ ឃ ទដ ៣៤:១៨ បទ ៣:៥៧ ង ចទ ៤:៣០ ទដ ២៥:១៧ **៤៦:២** ច លប ៤:៧ ទដ ៣:៦ ឆ ទដ

៤ មានទន្លេ១[ឌ]ដែលព្រែក[ឍ]ទាំងប៉ុន្មាននាំឱ្យក្រុងនៃព្រះ[ណ]
មានសេចក្តីអំណរគឺជាទីបរិសុទ្ធនៃពន្លា[ត]របស់ព្រះដ៏ខ្ពស់
បំផុត[ថ]
៥ ព្រះទ្រង់គង់នៅកណ្តាល ហើយទីក្រុងនោះ[ទ]មិនត្រូវរង្គើ
ឡើយ[ធ] ព្រះទ្រង់នឹងជួយ[ន]ចាប់តាំងពីព្រលឹមផង

៨២:៥ អស ១៣:១៣ ២៤:១,១៩,២០ យរ ៤:២៣ ដយ ១១:១៩ អម ៨:១៤ វវ ៦:១៤ ជ ខ.៦ ទដ ១៨:៧ ៩៧:៥ អស ៥៤:១០ អម ៩:៥ មីក ១:៤ ណហ ១:៥ ហព ៣:៦ ឈ នក ១៥:៨ **៤៦:៣** ញ ទដ ៩៣:៣ អស ១៧:១៣ យរ ៥:២២ អគ ១:២៤ វវ ១៩:៦ ដ យប ៩:២៦ ឋ ពច ៥:៥ **៤៦:៤** ឌ លប ២:១០ វវ ២២:១ ឍ ទដ ១:៣ ណ ទដ ៤៨:១,៨ ៨៧:៣ ១០១:៨ វវ ៣:១២ ត ២សយ ១៥:២៥ ថ លប ១៤:១៨ **៤៦:៥** ទ ចទ ២៣:១៤ ទដ ២៦:៨ អស ១២:៦ សក ២:៥ ធ ទដ ១២៥:១ ន ១រប ៥:២០

**ទំនុកដំកើង ៤៦–៤៨** ទំនុកដំកើងទាំងនេះ គឺជាចង្កោមនៃទំនុកដំកើងដែលជាសេចក្តីផ្តើមរបស់ទំនុកដំកើងប៉ែកទី២ (មើលក្នុងសេចក្តីផ្តើម ទដ ៤២–៤៥) ។ ផ្ទៃរឿងបន្ទាប់ទៀតដែលមានទំនាក់ទំនងជាមួយនឹងចង្កោមនៃទំនុកដំកើងទាំងនេះ គឺពណ៌នាពីទំនុកចិត្តរាស្ត្ររបស់ព្រះ ។ ក្នុង ទដ ៤៦ និង ទដ ៤៨ ផ្តោតសំខាន់លើសេចក្តីសុខនៃក្រុងយេរូសាឡិម "ក្រុងនៃព្រះ" (មើល ៤៦:៤ ៤៨:១) ហើយក្នុង ទដ ៤៧ បានផ្តោតសំខាន់លើអំណាចដ៏ធំនៅលើផែនដីរបស់"ព្រះមហាក្សត្រដ៏ធំ" ដែលគង់នៅក្រុងយេរូសាឡិម (សូមមើល ៤៨:២) ។

**ទដ ៤៦** នៅក្នុងជំពូកនេះ និយាយពីសុខសុវត្ថិភាពក្រុងយេរូសាឡិមដែលជាក្រុងរបស់ព្រះអម្ចាស់ (ចម្រៀងនៃការទូន្មានដ៏ល្អរបស់ម៉ាធីន លូធ័របានច្រៀងថា "ព្រះនៃយើងទ្រង់ជាទីពឹងជ្រក"មើល ខ.៧,១១) ។ ផ្ទៃរឿងទំនុកដំកើងជំពូកនេះមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយ ទដ ៤៨ (មើល ៧៦,៨៧) ដោយក្នុងនោះ ទដ ៤៧ និយាយពីជ័យជម្នះរបស់ព្រះអម្ចាស់លើផែនដីទាំងមូល (មើលក្នុងសេចក្តីផ្តើម ទដ ៤៦–៤៨) ។ ទំនុកដំកើងនេះប្រហែលសរសេរឡើងមុនពេលនិរទេស ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារបទចម្រៀងនេះមានទំនាក់ទំនងជាមួយ "ក្រុងនៃព្រះ" (ខ.៤) ដែលជាទីក្រុងរបស់អង្គលើផែនដី (មើល ទដ ៤៨) នោះបទចម្រៀងនេះបានបន្សល់ទុកដល់ពួកអ៊ីស្រាអែល ដើម្បីច្រៀងអបអរក្នុងថ្ងៃបុណ្យផ្ចិតថ្ងៃត្រៃ ដែលនិយាយពីនគររបស់ព្រះអម្ចាស់ ។ ប្រភពដើមនៃបទចម្រៀងនេះគឺគេច្រៀងក្នុងព្រះវិហារ ដែលរៀបរាប់ពីក្រុងយេរូសាឡិម (ឬពួកកូនចៅលេវីច្រៀងនៅទីកន្លែងដែលគេរស់នៅ) ដែលប្រហែលជាច្រៀងជាកិច្ចចាប់ផ្តើមនៃល្បះនេះ (ខ.១–៣) ហើយពួកបណ្តាជនក៏ឆ្លើយតប (មើល ខ.៧,១១) ក្នុងខណៈពេលដែលពួកអ្នកដឹកនាំចម្រៀងនៃពួកកូនចៅលេវីបានច្រៀងនៅក្នុងល្បះទី២ និងទី៣ (មើល ខ.៤–៦,៨–១០) ។ លក្ខណៈសំណង់ប្រយោគក្នុងជំពូកនេះ បានដាច់ចេញពីឃ្លាបន្ទរ (ខ.៧,១១) ដោយព្រះគម្ពីរទំនុកដំកើងជំពូកនេះ បានតែងឡើងជាល្បះ ដែលមានចំណាប់ចុងចួននៅក្នុងល្បះនិមួយមាន៣ខ ។ មើលទដផ្សេងៗទៀត ដែលមានបទបន្ទរស្តួនគ្នាក្នុងសេចក្តីផ្តើម ទដ ៤២–៤៣ ។

**ទដ ៤៦ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ទំនុករបស់កូនចៅកូរេ* មើលការពន្យល់ ទដ ៤២ ចំណងជើង ។ *ត្រូវច្រៀងដោយ* មើលការពន្យល់ ទដ ៦ ត្រង់ចំណងជើង ។ *សំលេងស្រួច* នៅក្នុងព្រះគម្ពីរភាសារហេព្រើរពាក្យនេះមានន័យថា "ស្រីក្រមុំ" ហើយឃ្លាដែលថា ត្រូវច្រៀងដោយសំលេងស្រួចប្រហែលចង់និយាយសំដៅ "ស្រីក្រមុំដែលវាយក្រាប់" ដែលបានមកជាមួយនឹងពួកចម្រៀងដែលបានច្រៀងនៅតាមផ្លូវឆ្ពោះមកកាន់ព្រះវិហារ (មើល ៦៨:២៥) ។ *ច្រៀង* មើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង ។

**៤៦:១–៣** នៅក្នុងខទាំងនេះចង់និយាយថា ដោយការទុកចិត្តចំពោះព្រះអម្ចាស់នោះយើងខ្ញុំនឹងមិនភ័យខ្លាចអ្វីឡើយ ទោះបីជាទីបលោកនេះរលាយបាត់ ហើយទឹកសមុទ្របញ្ចេញសូរគឹកកង ឬកក្រើកញ័រក៏ដោយ ឬក៏អ្វីៗដែលទ្រង់បានបង្កើតមកហាក់បីដូចជាត្រឡប់ទៅជារបស់ដែលទ្រង់មិនបានបង្កើតមកក៏ដោយ (មើល ១០៤:៦–៩ លប ១:៩–១០) ហើយអ្វីៗទាំងអស់អាចនិងត្រូវធ្លាក់ទៅទីជ្រៅក៏ដោយ ។ ការពណ៌នាយ៉ាងក្បោះក្បាយនេះប្រហែលជានិមិត្តរូបមួយ ដែលចង់សម្តែងពីការឈ្លានពានដ៏ធំចំពោះពួកកូនចៅអ៊ីស្រាអែល (មើលការពន្យល់ ៣២:៦) ជាពិសេសការឈ្លានពានពីសំណាក់ពួកខ្មាំងសត្រូវពួកគេ (មើល ខ.៦,៨–១០ ៦៥:៥–៨) ។

**៤៦:៤–៦** នៅក្នុងខទាំងនេះ គឺពណ៌នាពីព្រះពរដល់ក្រុងស៊ីយ៉ូន ហើយក៏បាននិយាយពីការកំសាន្តចិត្តរបស់ព្រះដ៏មានគ្រប់ព្រះចេស្តា ដែលទ្រង់បានមានវត្តនៅក្នុងទីក្រុងនៃព្រះ ។

**៤៦:៤** *ទន្លេ* តាមធម្មតានៅក្នុងក្រុងយេរូសាឡិមគ្មានទន្លេនោះទេ មិនដូចជានៅនរ–ហាម៉ូន (ណហ ៣:៨) ដាម៉ាស (២ពវ ៥:១២) ស្រុកត្បូង (ណហ ២:២៦,៨) ឬបាប៊ីឡូនឡើយ (១៣៧:១) តែនៅទីនេះគេបាននិយាយថា មាន "ទន្លេមួយ" ។ "ទន្លេ"ដែលបាននិយាយនៅក្នុង ៣៦:៨ (មើលការពន្យល់ទីនោះ) គឺជាការប្រៀបធៀបមួយដែលអ្នកនិពន្ធចង់ប្រៀបធៀប ពីព្រះពរនិងការផ្គត់ផ្គង់ ដែលហូរមិនចេះដាច់របស់ព្រះអម្ចាស់មកលើក្រុងនៃព្រះ ដែលដូចគ្នានឹងសួនឡុច្បាអេដែនដែរ (មើល ខ.៥ លប ២:១០ អស ៣៣:២១ ៥១:៣ ធៀបនឹង អគ ៣១:៤–៩) ។ *ក្រុងនៃព្រះ* មើល ខ.៥ ជាពិសេសនោះគឺក្នុង ទដ ៤៨ ។ *ព្រះដ៏ខ្ពស់បំផុត* នៅក្នុងឃ្លានេះចង់និយាយថាព្រះអម្ចាស់ទ្រង់ខ្ពស់បំផុត (មើល ៥៧:២ និងការពន្យល់ ៣:៧) ។ *ខ្ពស់បំផុត* មើលការពន្យល់ លប ១៤:១៩ ។ *នៃ* មើលការពន្យល់ ៩:១១ ។

**៤៦:៥** *ចាប់តាំងពីព្រលឹម* គេអាចនិយាយម្យ៉ាងទៀតថា "ពេលថ្ងៃរះ"។ នៅក្នុងឃ្លាហាក់បីដូចជាចង់និយាយថា ការវាយប្រហារទីក្រុងគឺបានចាប់ផ្តើមតាំងពីពេលព្រឹកព្រលឹមមកម្ល៉េះ ។ សេចក្តីជំនួយរបស់ទ្រង់នឹងនាំឱ្យមាន

៦ អស់ទាំងសាសន៍ដទៃ[ប]បានជ្រួលជ្រើម[ផ] ហើយនគរទាំង
ប៉ុន្មាន[ព]ពពាក់ពពូនឡើង តែទ្រង់បញ្ចេញព្រះសូរសៀង[ភ]
នោះផែនដីក៏រលាយទៅ[ម]
៧ ព្រះយេហូវ៉ានៃពួកពលបរិវារ[យ] ទ្រង់គង់នៅជាមួយនឹង
យើងខ្ញុំ[រ]គឺព្រះនៃយ៉ាកុប[ល] ទ្រង់ជាទីពឹងជ្រករបស់យើងខ្ញុំ[វ] ។
–បង្អង់
៨ ចូរមកពិចារណាមើលអស់ទាំងការនៃព្រះយេហូវ៉ា[ស]
ជាការហិនវិនាស[ហ] ដែលទ្រង់បានធ្វើនៅផែនដី
៩ ទ្រង់បណ្ដាលឱ្យការសង្គ្រាម[ឡ]ស្ងប់រំងាប់រហូតដល់ចុង
ផែនដី ទ្រង់បំបាក់ធ្នូ[អ]
ហើយកាច់លំពែងក៏ដុតអស់ទាំងរទេះចំបាំងនៅក្នុងភ្លើង[ក]
១០ ចូរបង្អង់សិន ឱ្យបានដឹងថា អញជាព្រះ[ខ]
អញនឹងបានថ្កើងឡើង[គ] នៅកណ្ដាលពួកសាសន៍ដទៃ
អញនឹងបានថ្កើងឡើងនៅផែនដី
១១ ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់គង់នៅជាមួយនឹង
យើងខ្ញុំ ព្រះនៃយ៉ាកុប[ឃ]ជាទីពឹងជ្រកនៃយើងខ្ញុំ[ង] ។–បង្អង់

ទំនុករបស់កូនចៅកូរេ ដែលលើកសំរាប់មេភ្លេង ។

**៤៧** ម្នាល ជនទាំងឡាយអើយ ចូរទះដៃ[ក]ទាំងអស់គ្នាចុះ
ចូរស្រែកហ៊ោថ្វាយព្រះ ដោយសំឡេងជាជ័យជំនះ[ខ]

**៤៦:៦** ប យបប ១២:២៣ ផ ទដ ៧៤:២៣ អស ៥:៣០ ១៧:១២ ព ទដ ៦៨:៣២ ១០២:២២ អស ១៣:៤,១៣ ២៣:១១ អគ ២៦:១៨ មថ ៤:៨ ភ ទដ ២៩:៣ អស ៣៣:៣ ម ខ.២ **៤៦:៧** យ ១សយ ១:១១ **៤៦:៧** រ លប ២១:២២ ល ទដ ២០:១ វ ខ.១១ទដ ១៨:២

**៤៦:៨** ស ទដ ៦៦:៥ ហ អស ១៧:៩ ៦៤:១០ ដយ ៩:២៦ លក ២១:២០ **៤៦:៩** ឡ អស ២:៤ អ ទដ ៣៧:១៥ អស ២២:៦ ក អស ៩:៥ អក ៣៩:៩ ហស ២:១៨ **៤៦:១០** ខ ចទ ៤:៣៥ ១ពវ ១៨:៣៦,៣៩ ទដ ១០០:៣ អស ៣៧:១៦,២០ ៤៣:២១ អគ ៣៦:២៣ គ ទដ ១៨:៤៦ អស ២:១១ **៤៦:១១** ឃ ទដ ២០:១ ង ខ.៧ **៤៧:១** ក ២ពវ ១១:១២ ខ ទដ ៣៣:៣

សេចក្ដីសង្គ្រោះនៅពេលព្រឹកព្រលឹម បំបាក់គ្រោះថ្នាក់នៅពេលយប់ (មើល ៤៤:១៩ និងការពន្យល់ ហើយធៀបនឹង អស ៣៧:៣៦ ) ។

**៤៦:៦** *អស់ទាំងសាសន៍ . . . ពពាក់ពពូន* គឺដោយសារជ័យជម្នះរបស់ព្រះអម្ចាស់ដែលទ្រង់បានឈ្នះលើលោកិយ (មើល ខ.៨–៩ ៤៨:៤–៧) ។ *បានជ្រួលជ្រើម* មើល ខ.៣ និងការពន្យល់ ខ.១–៣ និងមើល ២:១–៣ វវ ១១:១៨ ។ *បញ្ចេញព្រះសូរសៀង* មើល ២:៥ ៩:៥ យរ ២៥:៣០ អម ១:២ និង ១០៤:៧ ។ នៅក្នុងឃ្លានេះ គឺចង់និយាយពីផ្គរនៃសេចក្ដីក្រោធរបស់ព្រះអម្ចាស់ (មើលក្នុងសេចក្ដីផ្ដើម ទដ ២៩ និង ១៨:១៣ អស ២:១០) ។ *នោះផែនដីក៏រលាយទៅ* គឺដូចគ្នានឹងពេលដែលផែនដីញាប់ញ័រនៅពេលឃើញផ្លេកបន្ទោរដែរ (មើល ទដ ៩៧:៤–៥) ។

**៤៦:៧** នៅក្នុងខនេះ ចង់និយាយពីការឆ្លើយតបដោយមានអំណរខ្លាំងក្រៃរបស់ពួកបណ្ដាជន ។ *ព្រះយេហូវ៉ានៃពួកពលបរិវារ* មើលការពន្យល់ក្នុង ១សយ ១:៣ ។ *យ៉ាកុប* មើលការពន្យល់ ១៤:៧ ។

**៤៦:៨–១០** នៅក្នុងខទាំងនេះ គឺជាការប្រកាសពីព្រះពរនៃការទទួលបានជ័យជម្នះរបស់ព្រះអម្ចាស់លើផែនដីទាំងមូល ។

**៤៦:៨** *ចូរមកពិចារណាមើល* នៅក្នុងឃ្លានេះគឺជាការអញ្ជើញហៅឱ្យមកមើលពីជ័យជម្នះរបស់ព្រះអម្ចាស់លើផែនដីទាំងមូល (មើល ៤៨:៨ និងការពន្យល់) ។ *ព្រះយេហូវ៉ា* ឃ្លានេះគឺជាឃ្លាមួយដែលសង្កត់ធ្ងន់ពីអំណាចរបស់ព្រះ ពីព្រោះពាក្យនេះកំរមានប្រើណាស់នៅក្នុងប៉ែកទី២នៃព្រះគម្ពីរទំនុកដំកើង ។ *នៅផែនដី* គឺចង់និយាយសំដៅក្នុងចំណោមប្រជាតិដែលជាពួកខ្មាំងសត្រូវ ។

**៤៦:៩** នៅក្នុងខនេះចង់និយាយថា ពេលនេះនៅក្នុងក្រុងនៃព្រះគ្មានការវាយប្រហារ ឬឈ្លានពានទៀតឡើយ ។ នៅក្នុងខនេះប្រហែលជាការនិយាយអះអាងអំពីសន្តិភាពនៃពិភពលោក (មើលការពន្យល់ ៦៥:៦–៧) ។ *បំបាក់ . . . កាច់ . . . ដុត* មើល ៧៦:៣ និងក្នុង ១សយ ២:៤ ។ ជ័យជម្នះរបស់ព្រះមែស៊ីលើពួកខ្មាំងសត្រូវអ៊ីស្រាអែល មើល អស ៩:២–៧ ។

**៤៦:១០** នៅក្នុងខនេះចង់និយាយថា ព្រះសូរសៀងនៃព្រះយេហូវ៉ាមានអំណាច ដូចដែលទ្រង់បាននិយាយពីពួកបណ្ដាជន (មើល ខ.៦) ដូច្នេះតាមរយៈការនេះបានបង្ហាញថា ព្រះសូរសៀងនៃព្រះគឺមានអំណាចបំផុត ។ *ចូរបង្អង់សិន* ក្នុងព្រះគម្ពីរភាសារហេព្រើរ ប្រហែលមានន័យថា "ឈប់សិន" ដូចដែលបាននិយាយនៅ ១សយ ១៥:១៦ ។ *ឱ្យបានដឹងថា* គឺចង់និយាយពីចំណេះដឹង ។ *អញនឹងបានថ្កើងឡើង . . . ផែនដី* អំណាចចេស្ដារបស់ព្រះអម្ចាស់ដែលទ្រង់ធ្វើចំពោះរាស្ត្រទ្រង់ និងធ្វើឱ្យលោកិយទាំងមូលទទួលស្គាល់ ហើយការទាំងនោះ គឺជាផ្ទៃរឿងដ៏សំខាន់នៅក្នុងព្រះគម្ពីរទំនុកដំកើង (មើល ២២:២៧ ៤៧:៩ ៥៧:៥,១១ ៦៤:៩ ៦៥:៨ ៦៦:១–៧ ៦៧:២–៥,៧ ៧៧:១៤ ៨៦:៩ ៩៨:២–៣ ៩៩:២–៣ ១០២:១៥) ហើយក្នុងព្រះគម្ពីរសញ្ញាចាស់ មើល នក ៧:៥ ១៤:៤,១៨ លវ ២៦:៤៥ ជន ១៤:១៥ ១សយ ១៧:៤៦ ១ពវ ៨:៤១–៤៣ ២ពវ ១៩:១៩ អស ២:២–៣ ១១:១០ ២៥:៣ ៤៩:៦–៧ ៥១:៥ ៥២:១០ ៦០:១–១៤ ៦២:១–២ យរ ១៦:១៩ អគ ២០:៤១ ២៨:២៥ ៣៦:២៣ ហប ២:១៤) ។ នេះគឺជាភស្តុតាងបញ្ជាក់ពីសេចក្ដីពិតនៃអំណាចរបស់ព្រះ ដែលទ្រង់បានជួយគេទាំងពីកំណើតស្លាប់និងរស់ឡើងវិញ និងសិរីល្អរបស់ព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែការសំរេចពេញលេញនោះ គឺនៅពេលដែលទ្រង់យាងមកឯផែនដីជាលើកទី២ ។

**៤៦:១១** សូមមើលការពន្យល់ក្នុង ខ.៧ ។

**ទដ ៤៧** នៅក្នុងជំពូកនេះ គឺជាការប្រកាសពីការគ្រប់គ្រងផែនដីរបស់ព្រះនៃពួកសាសន៍អ៊ីស្រាអែល ធ្វើបន្ទាល់ដល់ម្នាលជនទាំងឡាយ ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺជាការតែងឡើងដោយក្រុមចម្រៀង ដែលពួកគេបានតែងឡើងជូនដល់ស្ដេចដ៏ឆ្នើម ដែលផ្ទៃរឿងនេះមាននិយាយនៅកន្លែងផ្សេងទៀតគឺក្នុង ទដ ៩២–១០០ ។ ទំនុកដំកើងក្នុងជំពូកនេះមានទំនាក់ទំនងជាប់ជាមួយ ទដ ៤៦ និង ទដ ៤៨ ដែលបានបង្ហាញពីសញ្ញាណនៃការគ្រប់គ្រងរបស់ព្រះអម្ចាស់លើក្រុងស៊ីយ៉ូន ដែលទ្រង់ជា "មហាក្សត្រយ៉ាងធំនៅលើផែនដីទាំងមូល"(មើល ខ.២,៧ និង ៤៨:២ និងសេចក្ដីផ្ដើម ទដ ៤៦–៤៨) ព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺតែងឡើងចាប់តាំងពីគ្រា ដែលមានស្ដេចគ្រប់គ្រង ហើយតែងឡើងដើម្បីច្រៀងក្នុងព្រះវិហារក្នុងថ្ងៃឈប់សម្រាក ហើយបុណ្យ នោះប្រហែលជាពិធីបុណ្យបារាំ (មើល លវ ២៣:៣៤) និងពិធីបុណ្យឆ្លងព្រះវិហារដែលសាឡូម៉ូនបានរៀបចំធ្វើ (មើល ១ពវ ៨:២) ។ ការច្រៀងសរសើរដំកើងនេះ ដោយការដង្ហែនេះ គឺជាគិតទុកជាមុន (មើល ខ.៥) ដែលមានការប្រហាក់ប្រហែលគ្នានឹង ទដ ២៤ និង ៦៨ ដែរ ។ នៅសម័យកាលក្រោយមកទៀត ពួកយូដាគេប្រើជំពូកនេះសូត្រក្នុងសាលាប្រជុំក្នុងថ្ងៃចូលឆ្នាំថ្មី ។ នៅក្នុងពួកជំនុំគ្រីស្ទបរិស័ទវិញគេបាន

២ ដ្បិតព្រះយេហូវ៉ាដ៏ខ្ពស់បំផុត[គ] ទ្រង់គួរស្ញែងខ្លាច[ឃ]
ទ្រង់ជាមហាក្សត្រ[ង]យ៉ាងធំលើផែនដីទាំងមូល
៣ ទ្រង់បង្ក្រាប[ច]ជនទាំងឡាយនៅក្រោមអំណាចយើងខ្ញុំ
ព្រមទាំងនគរផ្សេងៗ ឱ្យនៅក្រោមជើងយើងខ្ញុំផង
៤ គឺទ្រង់ដែលរើសមរដក[ឆ]ឱ្យយើងខ្ញុំ
គឺជាសិរីល្អរបស់យ៉ាកុប[ជ] ជាអ្នកដែលទ្រង់ស្រឡាញ់ ។
–បង្អង់

៥ ព្រះទ្រង់បានយាងឡើង[ឈ]ដោយសំឡេងហ៊ោ[ញ]
គឺព្រះយេហូវ៉ាបានឡើងទៅដោយសូរផ្លុំត្រែ[ដ]
៦ ចូរច្រៀងសរសើរ[ឋ]ដល់ព្រះ ចូរច្រៀងសរសើរចុះ
ចូរច្រៀងសរសើរដល់មហាក្សត្រនៃយើងខ្ញុំ
ចូរច្រៀងសរសើរចុះ
៧ ដ្បិតព្រះទ្រង់ជាមហាក្សត្រលើផែនដីទាំងមូល[ឌ]
ចូរច្រៀងសរសើរ[ឍ]យ៉ាងពីរោះចុះ ។
៨ ព្រះទ្រង់គ្រប់គ្រង[ណ]លើអស់ទាំងសាសន៍
ព្រះទ្រង់គង់លើបល្ល័ង្កបរិសុទ្ធនៃទ្រង់[ត]
៩ ពួកអស់អ្នកធំនៃសាសន៍ទាំងឡាយបានប្រជុំគ្នាមកឯរាស្ត្រ
របស់ព្រះនៃអ័ប្រាហាំ
ដ្បិតអស់ទាំងខែលនៅផែនដីជារបស់ផងព្រះ[ថ]
ទ្រង់បានថ្កើងឡើងយ៉ាងក្រៃលែង[ទ] ។

ទំនុកចំរៀងជារបស់កូនចៅកូរេ ។

## ៤៨ ព្រះយេហូវ៉ាទ្រង់ធំប្រសើរ[ក]

**៤៧:២** គ ចទ ៧:២១ ឃ លប ១៤:១៨ ង ទដ ២:៦ ៤៨:២ ៩៥:៣ មថ ៥:៣៥ **៤៧:៣** ច ទដ ១៨:៣៩,៤៧ អស ១៤:៦ **៤៧:៤** ឆ ទដ ២:៨ ១៦:៦ ៧៨:៥៥ ១ពត ១:៤ ជ អម ៦:៨ ៨:៧ **៤៧:៥** ឈ ទដ ៦៨:១៨ អភ ៤:៨ ញ យប ៨:២១ ទដ ១០៦:៥ ដ ជន ១០:២ ២សយ ៦:១៥ **៤៧:៦** ឋ ២សយ ២២:៥០

**៤៧:៧** ឌ សក ១៤:៩ ឍ ១របា ១៦:៧ កល ៣:១៦ **៤៧:៨** ណ ១របា ១៦:៣១ ត ១ពវ ២២:១៩ ទដ ៩:៤ វវ ៤:៩ **៤៧:៩** ថ យប ២៥:២ ទ ទដ ៤៦:១០ ៩៧:៩ **៤៨:១** ក ទដ ៨៦:១០ ៩៦:៤ ៩៩:២ ១៣៥:៥ ១៤៧:៥ យរ ១០:៦

យកបទនៃទដជំពូកនេះប្រើ ដើម្បីអបអរសាទរក្នុងពេលដែលព្រះគ្រីស្ទទ្រង់យាងទៅស្ថានសួគ៌ វិញក្រោយដែលទ្រង់មានព្រះជន្មរស់ (ខ.៥) ។ លក្ខណៈសំណង់ប្រយោគនៅក្នុងសេចក្តីផ្តើម និយាយពីការហៅឱ្យចូលមកសរសើរដំកើងដល់ព្រះអម្ចាស់ (មើល ខ.១) ដែលមាន៣ល្បះ ហើយក្នុង១ល្បះមានកំណាព្យហេព្រើរ៣ (ខ.២–៤,៥–៧,៨–៩) ដែលនិយាយពីការសរសើរដំកើងចំពោះព្រះដែលទ្រង់ជា "មហាក្សត្រលើផែនដី" (មើល ខ.៧) ។

**៤៧ ត្រង់ចំណងជើង** សូមមើលការពន្យល់ក្នុង ៤២ ត្រង់ចំណងជើង ។

**៤៧:១–៤** នៅក្នុងខទាំងនេះ គឺជាការហៅឱ្យម្នាលជនទាំងឡាយឱ្យមកដោយមានអំណរនៅចំពោះព្រះនៃពួកអ៊ីស្រាអែល ដែលជាព្រះនៃផែនដីទាំងមូល ។ ការនេះគឺជាការផ្សាយដំណឹងល្អក្នុងសញ្ញាចាស់ដល់ពួកជនទាំងឡាយ (មើលការពន្យល់ ខ.៩ ៩:១) ។

**៤៧:១** *ចូរទះដៃទាំងអស់គ្នាចុះ* នៅក្នុងឃ្លានេះ គឺចង់និយាយថា ចូរទះដៃដើម្បីសរសើរ និងអភិសេកទ្រង់ជាមហាក្សត្រនៅលើផែនដី (មើល ២ពវ ១១:១២ និង ទដ ៩៨:៨) ឬក៏ទះដៃបង្ហាញពីអំណរក្នុងឱកាសផ្សេងៗទៀត (មើល អស ៥៥:១២) ។ *ស្រែកហ៊ោ* មើល ១ពវ ១:៤០ ២ពវ ១១:១៤ ។

**៤៧:២–៣** នៅក្នុងខទាំងនេះចង់និយាយថា ព្រះអម្ចាស់ជាព្រះនៃផែនដីទ្រង់បានរៀបចំវាសនាសម្រាប់ពួកអ៊ីស្រាអែល ដែលជារាស្ត្ររបស់ទ្រង់ (សូមមើលក្នុង ១០៥:៦ ១៣៥:៤ នក ៩:២៩ ១៥:១–១៨ ១៩:៥–៦ ចទ ៧:៦ ១៤:២ អស ៤១:៨) ។

**៤៧:២** *ទ្រង់គួរស្ញែងខ្លាច* មើល ៦៨:៣៥ ៨៩:៧ ១១១:៩ និងការពន្យល់ ៤៥:៤ ។ *ដ៏ខ្ពស់បំផុត* មើលការពន្យល់ លប ១៤:១៩ ។ *ទ្រង់ជាមហាក្សត្រយ៉ាងធំ* ជាញឹកញាប់ងារនេះគឺជាការដាក់ដោយអធិរាជ្យ នៃប្រទេសស៊ីរី (មើលការពន្យល់ ២ពវ ១៨:១៩) ។

**៤៧:៣** សូមមើល ២សយ ៥:១៧–២៥ ៨:១–១៤ និងជំពូក ១០ ។

**៤៧:៤** *មរដក* មរដកដែលនិយាយនៅកន្លែងនេះ គឺសំដៅលើទឹកដីសន្យា (មើល លប ១២:៧ ១៧:៨ នក ៣:៨ ចទ ១:៨ យរ ៣:១៨) ។ *សិរីល្អ* សិរីល្អដែលបានធ្វើឱ្យយ៉ាកុបមានអំណររីករាយយ៉ាងខ្លាំង ។ *យ៉ាកុប* មើលការពន្យល់ ១៤:៧ ។

**៤៧:៥–៦** នៅក្នុងខទាំងនេះ គឺជាចំណុចស្នូលនៃកំណាព្យក្នុងជំពូកនេះ (មើលការពន្យល់ ៦:៦) ។ ខទាំងនោះបានពណ៌នាពីការច្រៀងលើកតម្កើងព្រះអម្ចាស់នៅក្នុងព្រះវិហារ ប្រហែលច្រៀងដោយអ្នកតំណាងក្រុមដែលបាននាំយកហឹបនៃសេចក្តីសញ្ញាមកក្នុងព្រះវិហារ ។ ហឹបនៃសេចក្តីសញ្ញាគឺជានិមិត្តរូបនៃបល្ល័ង្ករបស់ព្រះ ហើយផែនដីគឺជានិមិត្តរូបនៃស្ថានសួគ៌លោកិយ (មើល ទដ ជំពូក ២៤ និង ៦៨) ។

**៤៧:៥** *ដោយសំលេងហ៊ោ . . . ដោយផ្លុំត្រែ* មើលការពន្យល់ ខ.១ ។ *ត្រែ* គឺជាស្នែង ហើយនៅទីនេះផ្លុំត្រែដើម្បីអបអរសាទរ ឬប្រកាសថាទ្រង់ជាស្តេច (មើល ៩៨:៦ នក ១៩:១៦,១៩ យស ៦:៤) ។

**៤៧:៧–៩** នៅក្នុងខទាំងនេះ គឺជាការច្រៀងអភិសេកព្រះអង្គឱ្យធ្វើជាមហាក្សត្រនៃផែនដី ។

**៤៧:៧** *ត្បិតព្រះទ្រង់ជាមហាក្សត្រលើផែនដីទាំងមូល* មើល ២សយ ១៥:១០ ២ពវ ៩:១៣ អស ៥២:៧ ។ *ចូរច្រៀងសរសើរ* មើលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។

**៤៧:៨** *គង់លើបល្ល័ង្កបរិសុទ្ធនៃទ្រង់* គឺគង់នៅក្នុងទីបរិសុទ្ធបំផុត ក្នុងព្រះវិហារ ជាកន្លែងដែលទ្រង់ទទួលអំណាចនៃការគ្រងលើផែនដី (មើល យរ ១៧:១២) ។ ខនេះជាញឹកញាប់មាននិយាយ នៅក្នុងព្រះគម្ពីរវិវរណៈ (មើល វវ ៤:៩,១០ ៥:១,៧,១៣ ៦:១៦ ៧:១០,១៥ ១៩:៤) ។

**៤៧:៩** នៅក្នុងខនេះ ពួកបណ្តាជនបានទទួលស្គាល់ព្រះនៃពួកអ៊ីស្រាអែលថា ទ្រង់គឺជាមហាក្សត្រដ៏ធំហើយ គឺជាការប្រមើលទុកជាមុនថា ទ្រង់គឺជាអ្នកគ្រប់គ្រងក្រោយបង្អស់នៅលើផែនដី (មើលការពន្យល់ ៤៦:១០) ។ *រាស្ត្ររបស់ព្រះនៃអ័ប្រាហាំ* នៅក្នុងឃ្លានេះចង់និយាយថា គ្រប់ទាំងសេចក្តីសន្យាដែលព្រះយេហូវ៉ាបានសន្យាជាមួយលោកអ័ប្រាហាំ នោះទ្រង់នឹងសម្រេចឱ្យ (មើល លប ១២:២–៣ ១៧:៤–៦ ២២:១៧–១៨) ។ *អស់ទាំងខែល* មើលការពន្យល់ ៣:៣ ហើយធៀបនឹង អស ២:២ ៥៦:៧ ។

**ទដ ៤៨** នៅក្នុងជំពូកនេះ គឺជាការអបអរសាទរចំពោះសេចក្តីសុខសាន្តក្នុងក្រុងស៊ីយ៉ូន (ដូចដែលបានឃើញសេចក្តីជំនឿនឹងភ្នែក) ដែលជាទីក្រុងរបស់មហាក្សត្រដ៏ធំ (មើលក្នុងសេចក្តីផ្តើម ទដ ៤៦–៤៧ និងសេចក្តីផ្តើម ទដ ៤៦–៤៨) ។ បទចម្រៀងក្នុងជំពូកនេះប្រហែលច្រៀងដោយពួកលេវី ហើយប្រហែលច្រៀងនៅខាងក្រោយពួកអ្នកចូលរួមថ្វាយបង្គំទាំងអស់ ក្នុងព្រះ

ហើយគួរសរសើរណាស់[ខ] ក្នុងទីក្រុងរបស់ព្រះនៃយើងខ្ញុំ[គ]
គឺនៅលើភ្នំបរិសុទ្ធនៃទ្រង់[ឃ]
២ ឯភ្នំស៊ីយ៉ូន[ង] នៅទិសខាងជើង[ច]
នោះមានលំអ[ឆ] ដោយនៅលើទីខ្ពស់
ជាទីរីករាយចិត្តដល់ផែនដីទាំងមូល[ជ]
គឺជាទីក្រុងនៃមហាក្សត្រដ៏ធំ
៣ ព្រះទ្រង់បានសំដែងថា
ទ្រង់ជាទីពឹង[ឈ] នៅក្នុងព្រះរាជវាំងនៃក្រុងនោះ[ញ] ។
៤ ដ្បិតមើល ពួកមហាក្សត្រទាំងប៉ុន្មានបានប្រជុំគ្នាក៏នាំគ្នា
យាងទៅតាមទីនោះ[ដ]
៥ គ្រាឃើញទីក្រុង នោះក៏អស្ចារ្យក្នុងចិត្ត
គេមានសេចក្តីតក់ស្លុត រួចរត់ចេញបាត់ទៅ[ឋ]
៦ នៅទីនោះគេកើតមាន[ឌ] សេចក្តីភ័យញ័រគ្រប់គ្នា

**៤៨:១** ខ ២សយ ២២:៤ ១របា ១៦:២៥ ទដ ១៨:៣ គ ទដ ៤៦:៤ ឃ ចទ ៣៣:១៩ ទដ ២:៦ ៨៧:១ អស ១១:៩ ៣២:១៦ យរ ៣១:២៣ ដយ ៩:១៦ មីក ៤:១ សក ៨:៣ **៤៨:២** ង ទដ ២:៦ ច យស ១៣:២៧ ឆ ទដ ៥០:២ បទ ២:១៥ អគ ១៦:១៤ ជ មថ ៥:៣៥ **៤៨:៣** ឈ ខ.១៣ ទដ ១២២:៧ ញ ទដ ១៨:២

ក៏ឈឺចាប់ដូចជាស្ត្រីដែលសំរាលកូន[ឍ]
៧ ទ្រង់បានបំបាក់បំបែកនាវាតើស៊ីស[ណ] ដោយខ្យល់ពីទិស
ខាងកើត[ត]
៨ នៅក្នុងទីក្រុងរបស់ព្រះនៃពួកពលបរិវារគឺជាក្រុងរបស់
ព្រះនៃយើងខ្ញុំ នោះយើងខ្ញុំបានឃើញមាន
ដូចជាបានឮរៀងមកហើយ
ព្រះទ្រង់នឹងតាំងទីក្រុងនោះឱ្យនៅជាប់ជារៀងរាបដរាប
ទៅ[ថ] ។ –បង្គង់
៩ ឱព្រះអង្គអើយ នៅកណ្តាលព្រះវិហារនៃទ្រង់
នោះយើងខ្ញុំបាននឹករំពឹង[ទ] ពីសេចក្តីសប្បុរសរបស់ទ្រង់[ធ]

**៤៨:៤** ដ ២សយ ១០:១–១៩ **៤៨:៥** ឋ នក ១៥:១៦ អស ១៣:៨ យរ ៤៦:៥ ដយ ៥:៩ **៤៨:៦** ឌ យប ៤:១៤ ឍ លប ៣:១៦ **៤៨:៧** ណ លប ១០:៤ ១ពវ ១០:២២ ២២:៤៨ ត លប ៤១:៦ **៤៨:៨** ថ យរ ២៣:៦ សក ៨:១៣ ១៤:១១ **៤៨:៩** ទ ទដ ៣៩:៣ ធ ទដ ៦:៤

វិហារ ។ ផ្ទៃរឿងនិងសំណង់ប្រយោគមានលក្ខណៈល្អប្រណិត ។ ខដំបូង និងខចុងក្រោយ បានភ្ជាប់ទំនាក់ទំនងដោយការលើកទឹកចិត្ត និងទំនាក់ទំនងក្រុងស៊ីយ៉ូនជាក្រុងរបស់ព្រះ ។ ខ.៨ គឺជាចំណុចស្នូល (មើលការពន្យល់ ៦:៦) ហើយជាសេចក្តីសង្ខេបផ្ទៃរឿងទាំងមូលក្នុងជំពូកនេះ ។ ជំពូកនេះមាន៤ល្បះ (មានកំណាព្យហេព្រើរ៣ ដែលមានចំណាប់ចុងចួន ហើយកំណាព្យនិមួយៗមាន៤បន្ទាត់ (១).លំអរនៃក្រុងស៊ីយ៉ូនជាក្រុងរបស់ព្រះ ដែលមិនអាចមានអ្នកណាវាយយកបាន (ខ.២–៣) (២).បរាជ័យរបស់ពួកខ្មាំងសត្រូវ(ខ.៤–៧) (៣).អំណររបស់អ្នកក្រុងស៊ីយ៉ូនចំពោះសេចក្តីសង្គ្រោះរបស់ព្រះ(ខ.៩–១១) ហើយចំណុចទី៣នេះ មានទំនាក់ទំនងជាមួយនឹងល្បះទី២ (៤).ស៊ីយ៉ូនគឺជាទីក្រុងដ៏មាំមួនមួយ(ខ.១២–១៣) ដែលទាក់ទងទៅនឹងល្បះទី១ ។

**៤៨ ត្រង់ចំណងជើង** *ទំនុក* មើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង ។ *របស់ពួកកូនចៅកូរេ* មើលការពន្យល់ ទដ ៤២ ត្រង់ចំណងជើង ។

**៤៨:១** *ក្នុងទីក្រុងរបស់ព្រះនៃយើងខ្ញុំ គឺនៅលើភ្នំបរិសុទ្ធនៃទ្រង់* មើល ៤៦:៤ ។ *ព្រះនៃយើងខ្ញុំ* នៅក្នុងជំពូកនេះ ពាក្យនេះមានប្រើតែនៅកន្លែងនេះក្នុង ខ.៨ និង ខ.១៤ ។ *ភ្នំបរិសុទ្ធ* មើល ៤៣:៣ និងការពន្យល់ ២:៦ ។

**៤៨:២–៣** នៅកក្នុងខទាំងនេះ គឺជាការពណ៌នាពីទីខ្ពស់នៃភ្នំស៊ីយ៉ូន ។

**៤៨:២** *លំអរ* ត្រង់កន្លែងនេះ គឺសំដៅលើភាពខ្ពស់ និងសុខសុវត្ថិភាពដែលមាននៅក្នុងក្រុងស៊ីយ៉ូន (មើលការពន្យល់ ២៧:៤) ។ *ទីខ្ពស់* ទោះបីវាមិនមែនជាទីដែលខ្ពស់ដាច់គេក៏ដោយ ប៉ុន្តែវាជានិមិត្តរូបនៃភ្នំរបស់ព្រះដែលជាភ្នំមួយខ្ពស់បំផុតនៅលើលោកិយនេះ (មើល ៦៨:១៥–១៦ និងការពន្យល់ អស ២:២) ។ *ជាទីរីករាយចិត្តដល់ផែនដីទាំងមូល* នៅក្នុងឃ្លានេះប្រហែលជានិយាយសំដៅលើការកោតសរសើរ និងការត្រេកអរពីសំណាក់បណ្តាជនទាំងឡាយដែលនៅផែនដី ដូចដែលព្រះនាងសេបាបានពណ៌នារួចមកហើយ (មើល ១ពវ ១០:១–១៣) ។ *មហាក្សត្រដ៏ធំ* មើលការពន្យល់ ៤៧:២ ។

**៤៨:៣** នៅល្បះបន្តទៀតបាននិយាយថា ព្រះយេហូវ៉ាផ្ទាល់ទ្រង់គឺជាពំនឹងរបស់អ្នកក្រុងស៊ីយ៉ូន មិនមែនកំផែងនោះឡើយ (មើលការពន្យល់ ខ.១២–១៣) ។ *ព្រះរាជវាំងនៃក្រុងនោះ* សូមមើល ខ.១៣ ។

**៤៨:៤–៧** នៅក្នុងខទាំងនេះចង់និយាយថា ការប៉ុនប៉ងព្យាយាមរបស់ពួកខ្មាំងសត្រូវ ត្រូវបានត្រឡប់ជាអសារឥតការ គ្មានប្រយោជន៍អ្វីឡើយ ។ ពួកខ្មាំងសត្រូវទាំងនោះ បានរត់ចេញបាត់ទៅនៅពេលដែលគេបានឃើញមហាក្សត្រដ៏ធំបានគង់នៅក្រុងស៊ីយ៉ូន ។ ការនេះក៏ដូចគ្នានឹងព្រឹត្តិការណ៍នៃការវិនាសកម្មរបស់សម្ព័ន្ធមិត្តក្នុងគ្រាយ៉ូសាផាតដែរ (មើល ២របា ជំពូក ២០) ឬការសម្លាប់រង្គាលពួកអាសស៊ើរ ក្នុងសម័យកាលស្តេចហេសេគា (មើល ២ពវ ១៩:៣៥–៣៦) ។ កត្តាទាំងនេះប្រហែលជាបានដក់ជាប់ក្នុងអារម្មណ៍របស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង ។

**៤៨:៧** *នាវាតើស៊ីស* វាជានាវាជំនួញសំខាន់នៅសមុទ្រមេឌីទែរ៉ាណេ (មើល ១ពវ ១០:២២ និងការពន្យល់) ។ *បំបាក់បំបែក . . . ដោយខ្យល់ពីទិកខាងកើត* មើល កច ២៧:១៤ និង ១ពវ ២២:៤៨ ។ *ខាងកើត* សូមមើលសេចក្តីផ្តើមខាងលើ ។

**៤៨:៨** នៅក្នុងខនេះ គឺជាចំណុចកណ្តាល ហើយក៏ជាផ្ទៃរឿងក្នុងព្រះគម្ពីរទំនុកដំកើងជំពូកនេះផងដែរ (មើលការពន្យល់ ៦:៦) ។ *ដូចឃើញមានដូចជាបានឮ* ពាក្យថា "ឃើញ" គឺជាការឃើញដោយផ្ទាល់ភ្នែក ដូចដែលបាននិយាយនៅក្នុង យប ៤២:៥ ។ យើងបានឮពីព្រោះ "ពួកឰយុកោរបស់យើងបានថ្លែងមកយើងខ្ញុំ ពីការទាំងប៉ុន្មានដែលទ្រង់បានធ្វើនៅសម័យចាស់បុរាណក្នុងជំនាន់គេ" (មើល ៤៤:១ និង ៧៨:៣) ប៉ុន្តែ ឥឡូវនេះក្នុងបទចម្រៀងអំពីការគង់នៅរបស់ព្រះអម្ចាស់នៅក្នុងព្រះវិហារ ពួកគេបាន "ឃើញ" ពីសេចក្តីសុខសាន្តដែលព្រះបានប្រទានមកក្រុងរបស់ទ្រង់ ។ *ព្រះយេហូវ៉ានៃពួកពលបរិវារ* មើលការពន្យល់ ១សយ ជំពូក ១៣ ។ *ព្រះនៃយើងខ្ញុំ* មើលការពន្យល់ ខ.១ ។

**៤៨:៩–១១** នៅក្នុងខទាំងនេះពួកអ្នកដែលចូលរួមថ្វាយបង្គំ គេបានផ្ចង់ចិត្តនៅក្នុងព្រះវិហារដោយអំណរ ដោយព្រោះតែសេចក្តីជំនួយរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ ដែលទ្រង់បានធ្វើដល់ក្រុងស៊ីយ៉ូន ។

**៤៨:៩** *កណ្តាលវិហារនៃទ្រង់* គឺនៅក្នុងទីធ្លានៃព្រះវិហារ ។ *សេចក្តីសប្បុរស* មើលការពន្យល់ ៦:៤ ។ អ្វីដែលមាននិយាយពី ខ.១០–១១ គឺជា

១០ឱព្រះអង្គអើយ ដែលល្បីព្រះនាមទ្រង់បានឮសុសសាយ
យ៉ាងណា[ន]
នោះសេចក្តីសរសើរនៃទ្រង់ក៏បានដល់ចុងផែនដីបំផុត
យ៉ាងនោះដែរ[ប]
ព្រះហស្តស្តាំនៃទ្រង់មានពេញដោយសេចក្តីសុចរិត
១១គួរឱ្យក្រុងស៊ីយ៉ូនមានសេចក្តីអំណរ
គួរឱ្យពួកកូនស្រីសាសន៍យូដាបានរីករាយឡើង
ដោយព្រោះសេចក្តីយុត្តិធម៌របស់ទ្រង់[ផ]
១២ចូរដើរសព្វគ្រប់ក្នុងក្រុងស៊ីយ៉ូន ចូរដើរព័ទ្ធជុំវិញផង
ហើយរាប់អស់ទាំងប៉មនៃទីក្រុង[ព]
១៣ចូរសង្កេតមើលកំផែងទាំងប៉ុន្មានឱ្យមែនទែន[ភ]
ហើយពិចារណាព្រះរាជវាំងនោះផង[ម]
ដើម្បីនឹងថ្លែងប្រាប់ដល់កូនចៅតទៅ[យ]
១៤ដ្បិតព្រះនេះ ទ្រង់ជាព្រះនៃយើងខ្ញុំនៅអស់កល្បជានិច្ច
ទ្រង់នឹងធ្វើជាអ្នកនាំមុខ[រ] យើងខ្ញុំដរាបដល់អស់ជីវិតផង ។

ទំនុករបស់កូនចៅកូរេ ដែលលើកសំរាប់មេភ្លេង ។

**៤៩** អស់ទាំងសាសន៍អើយ[ក] ចូរស្តាប់[ខ] សេចក្តីនេះ

**៤៨:១០** ន នក ៦:៣ យស ៧:៩ ប ១សយ ២:១០ ទដ ២២:២៧ ៦៥:៥ ៩៨:៣ ១០០:១ អស ១១:១២ ២៤:១៦ ៤២:១០ ៤៩:៦ **៤៨:១១** ផ ទដ ៩៧:៨ **៤៨:១២** ព នហ ៣:១ **៤៨:១៣** ភ ២សយ ២០:១៥ អស ២៦:១ បទ ២:៨ ហព ២:១ ម ខ.៣ យ ទដ ៧១:១៨ ៧៨:៦ ១០៩:១៣ **៤៨:១៤** រ ទដ ២៥:៥ ៧៣:២៤ សភ ៦:២២ អស ៤៩:១០ ៥៧:១៨ ៥៨:១១ **៤៩:១** ក ទដ ៧៨:១ ខ អស ១:២

ការនិយាយបញ្ជាក់ពីសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ក្នុងខនេះ (ខ.៩) តាមរយៈការប្រកាសសេចក្តីសញ្ញាពីសេចក្តីស្រឡាញ់របស់ទ្រង់ ចំពោះរាស្ត្រព្រះអម្ចាស់ (មើល ៣១:២១ ៤០:៩–១០) ។

**៤៨:១០** *ព្រះនាម* មើលការពន្យល់ ៥:១១ ។ *បានដល់* នៅក្នុងឃ្លានេះចង់និយាយថា ព្រះនាមទ្រង់ល្បីចាប់តាំងពីព្រះវិហាររហូតដល់ចុងបំផុតនៃផែនដី (មើល ៩:១១ ២២:២៧) ។ *ព្រះហស្តស្តាំ* នៅក្នុងសំនួនវោហារហេព្រើរពាក្យនេះគឺនិយាយសំដៅលើទិសខាងត្បូង ។ *សេចក្តីសុចរិត* គឺនិយាយសំដៅលើការងារសុចរិត (មើល ៤០:៩–១០ និងការពន្យល់ព្រមទាំងការពន្យល់ក្នុង ៤:១) ។

**៤៨:១១** *សេចក្តីយុត្តិធម៌* គឺចង់និយាយសំដៅលើការជំនុំជម្រះដោយសេចក្តីសុចរិតរបស់ព្រះអម្ចាស់ តាមរយៈការដែលទ្រង់បានការពារក្រុងស៊ីយ៉ូន ។

**៤៨:១២–១៣** នៅក្នុងខទាំងនេះ ពួកបណ្តាជនគេបានសញ្ជឹងគិតពីពំនឹងនៃក្រុងស៊ីយ៉ូនតាមរយៈទស្សនៈវិស័យដែលគេបាន "ឃើញ" (ខ.៨) នៅត្រង់ព្រះវិហារ ។ ចំណុចខ្លាំងរបស់"ប៉ម"ក្រុងស៊ីយ៉ូន និង "កំផែង" ហើយនិង "ព្រះរាជវាំង"គឺជាព្រះវត្តមានរបស់ព្រះអម្ចាស់ ។

**៤៨:១៣** *កូនចៅ* តាមភាសារអក្សរសាស្ត្រគឺ "ជំនាន់ក្រោយ"ហើយនៅក្នុងសំនួនវោហារហេព្រើរពាក្យថា "ក្រោយ" គឺសំដៅលើទិសខាងលិច ។

**៤៨:១៤** *ព្រះនៃយើងខ្ញុំ* មើលការពន្យល់ ខ.១ ។ *នាំមុខ* គឺនាំមុខក្នុងនាមជាអ្នកគង្វាលដ៏ល្អ (មើល ២៣:១,៣) ។ *ដល់អស់ជីវិត* តាមភាសាអក្សរសាស្ត្រគឺរហូតដល់ស្លាប់ ។

**ទំនុកដំកើង ៤៩–៥៣** នេះគឺជាចង្កោមទំនុកដំកើងមួយ ដែលបានបង្ហាញឱ្យឃើញពីភាពផ្ទុយគ្នា និងបាននិយាយពីការដង្ហោយហៅរបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងចំពោះពួកអ្នកដែលស្រឡាញ់ព្រះ ។ មួយវិញទៀតយើងបានជួបប្រទះនូវបទគម្ពីរទំនុកដំកើង២ ដែលមានទម្រង់ដូចគ្នាបេះបិទ (១).ការត្រាស់ហៅរបស់ព្រះអម្ចាស់ដល់ប្រជារាស្ត្រទ្រង់ ឱ្យចូលមកចំពោះទ្រង់និងស្តាប់សាលក្រមរបស់ព្រះអង្គ ដែលមានទំនាក់ទំនងនឹងការរស់នៅរបស់ពួកគេ(ទដ ជំពូក ៥០) ហើយ (២).ការអធិស្ឋានដោយការបន្ទាបខ្លួនសូមឱ្យព្រះអម្ចាស់ប្រោសអភ័យទោស និងសំអាតគ្រប់ទាំងអំពើបាប(ទដ ៥១) ។ ម៉្យាងវិញទៀត មានបទគម្ពីរទំនុកដំកើង២ (ជំពូក ៤៩,៥២) ដែលបានពណ៌នាពីអ្នក ដែលទុកចិត្តចំពោះទ្រព្យសម្បត្តិរបស់ពួកគេ (៤៩:៦ និង ៥២:៧) ហើយបាន"អួតអាង"ពីទ្រព្យសម្បត្តិនោះ (មើល ទដ ៤៩:៦) និងធ្វើ "អាក្រក់" ពីអ្វីដែលគេអាចធ្វើបាន (មើល ៥២:១) ។ នៅក្នុងព្រះគម្ពីរទំនុកដំកើង គេមិនបានឃើញព្រះគម្ពីរទំនុកដំកើងណាទៀត ដែលពណ៌នាពីមនុស្សដែលគ្មានព្រះដូចជាក្នុងជំពូកនេះឡើយ ។ នៅក្នុងផ្នែកទី១នៃទំនុកដំកើងជំពូកនេះបានពណ៌នាពី "មនុស្សខ្លៅល្ងង់" និង "មនុស្សកំរោល" (៤៩:១០) ។ ដូច្នេះ ព្រះគម្ពីរទំនុកដំកើងទាំង៤ជំពូកនេះ ដែលអ្នកនិពន្ធបានចែកជាផ្នែកតូចៗ គឺដើម្បីបន្ថែមនិងរំឭកខ្លះឡើងវិញពីអ្វី ដែលមាននិយាយនៅក្នុង ទដ ១៤ ដែលពួកមនុស្សខ្លៅល្ងង់គេគិតថាគ្មានព្រះបន្ទាប់ពីទំនុកដំកើង ៤៦–៤៨ មានទំនុកដំកើង៥ទៀតដែលមានតួនាទីជាការរំឭកថា មានតែអ្នកដែលទុកចិត្តចំពោះអម្ចាស់ប៉ុណ្ណោះ ដែលមានហេតុ និងអបអរសាទរចំពោះសេចក្តីសុខសាន្តនៅក្នុង "ទីក្រុងរបស់ព្រះនៃ យើងខ្ញុំ" (មើល ៤៨:១,៨ និងសេចក្តីផ្តើម ទដ ៤៦–៤៨) ។

**ទដ ៤៩** នៅក្នុងជំពូកនេះ ពណ៌នាពីសេចក្តីបង្រៀនដែលប្រកបដោយគតិបណ្ឌិតដែលទាក់ទងជាមួយនឹងមនុស្សខ្លៅល្ងង់ដែលទុកចិត្ត និងអួតអាងពីទ្រព្យសម្បត្តិរបស់ពួកគេ និងទុកចិត្តចំពោះខ្លួនឯងលើការរស់នៅ និងសុវត្ថិភាពរបស់ពួកគេលើលោកិយនេះ (មើល ទដ ៥២ និង សេចក្តីផ្តើម ទដ ៤៩–៥៣) ។ ពួកអ្នកនិព្វលេវីបានដឹងថា គឺជាអ្នកដែលគ្មានទ្រព្យសម្បត្តិ (ជន ១៨:២១–២៤ ចទ ១៤:២៧–២៩) ហើយជាអ្នកសង្កេតមើលដល់អ្នកមានជាច្រើននាក់ទៀតផង (ខ.៥–៦) ។ ពួកគេបានឃើញពីការចំកួតលីលាតាមរយៈជីវិតរស់នៅរបស់គេហើយទោះបីជាបែបនេះក៏ដោយ ក៏ពួកគេបានផ្តល់ប្រាជ្ញារបស់ពួកគេ ដើម្បីឱ្យមនុស្សគ្រប់គ្នាបានស្តាប់ដែរ (មើល ខ.១–២) ធ្វើដូច្នេះពួកអ្នកដែលភ័យខ្លាច ដោយសារពួកអ្នកមាននោះអាចនឹងរួចផុតមានសេរីភាពពីការប្រព្រឹត្តរបស់មនុស្សអាក្រក់នោះ ។ ការមិនអាចគេចចេញពីសេចក្តីស្លាប់គឺជាវាសនា និងសេចក្តីវិនាសអន្តរាយរបស់ពួកមនុស្ស"ខ្លៅល្ងង់ និងសេចក្តីកំរោល"(៤៩:១០) តែចុងបញ្ចប់របស់"មនុស្សទៀងត្រង់នឹងជាន់ឈ្លីគេ"វិញ(ខ.១៤) ។ នៅកន្លែងផ្សេងទៀត (មើលការពន្យល់ក្នុងសេចក្តីផ្តើម ទដ ៣៣) អ្នកនិពន្ធគាត់បានតែងឡើងដោយមានកំណាព្យហេព្រើរ ២២ បន្ទាត់ដោយអាស្រ័យលើចំនួនអក្សរហេព្រើរ ។ សំណង់ប្រយោគក្នុងផ្ទៃរឿងនេះ គឺមានចំណាប់ចុងចួនដោយមាន៤បន្ទាត់ជាសេចក្តីផ្តើម (ខ.១–៤) ហើយក្នុងតួរសេចក្តីបានបែងចែកជា២ល្បះដោយក្នុង១ល្បះមាន៨បន្ទាត់ (ខ.៥–១១,១៣–១៩) ហើយក៏មានបន្ថែមនូវឃ្លាបន្ទរថែមទៀតដែរ (ខ.១២,២០) ។ បទគម្ពីរទដផ្សេងៗទៀតដែលមានបទបន្ទរ មើលសេចក្តីផ្តើម ទដ ៤២–៤៣ ។ កាលបរិច្ឆេទនៃការតែងបទគម្ពីជំពូកនេះប្រហែលជាបាន និយាយនៅដើមជំពូកនេះ ។ មើល

មនុស្សទាំងឡាយនៅលោកីយអើយ ចូរផ្ទៀងត្រចៀក
ស្តាប់ចុះ[គ]
២ គឺទាំងធំទាំងតូច[ឃ] ទាំងមានទាំងក្រគ្រប់គ្នា
៣ មាត់ខ្ញុំនឹងបញ្ចេញប្រាជ្ញា[ង] ហើយចិត្តខ្ញុំនឹងរំពឹងគិតតែពី
សេចក្តីត្រឹមត្រូវ[ច]
៤ ខ្ញុំនឹងផ្ទៀងត្រចៀកស្តាប់ពាក្យឧបមា[ឆ]
ខ្ញុំនឹងផ្តើមច្រៀងសេចក្តីអាថ៌កំបាំងរបស់ខ្ញុំ[ជ]តាមស្នូរស៊ីង[ឈ]
៥ ហេតុអ្វីបានជាខ្ញុំត្រូវមានចិត្តភ័យខ្លាច[ញ]ក្នុងគ្រាអាក្រក់
គឺកាលណាសេចក្តីទុច្ចរិត
ដែលតាមជាប់កែងជើងបានព័ទ្ធខ្ញុំជុំវិញហើយ
៦ ឯក្នុងពួកអស់អ្នកដែលទុកចិត្តនឹងរបស់ទ្រព្យខ្លួន[ដ]
ហើយអួតអាង[ឋ]ពីទ្រព្យសម្បត្តិដ៏មានជាបរិបូរ[ឌ]
៧ នោះគ្មានអ្នកណាមួយនឹងអាចលោះបងប្អូនខ្លួន
ឬយកដំឡៃសំរាប់លោះគេទៅថ្វាយដល់ព្រះបានឡើយ
៨ ដ្បិតដំឡៃលោះ[ឍ]ព្រលឹងគេ
នោះថ្លៃពេកណាស់ឥតដែលអាចនឹងលោះបានឡើយ[ណ]
៩ នឹងឱ្យគេរស់នៅ[ត]ជាដរាប
ឥតឃើញសេចក្តីពុករលួយមិនបានទេ[ថ] ។
១០ អើ គេនឹងឃើញពិតថា ពួកមនុស្សប្រាជ្ញក៏ស្លាប់ដែរ[ទ]
ហើយមនុស្សខ្លៅល្ងង់ និងមនុស្សកំរោល[ធ]
គេវិនាសទៅដូចគ្នា
ព្រមទាំងចោលរបស់ខ្លួន[ន]ទុកឱ្យអ្នកដទៃផង[ប]
១១ អ្នកទាំងនោះគិតស្មានក្នុងចិត្តថា ពូជពង្សរបស់គេនឹងនៅ
ជាប់ជានិច្ច[ផ]ហើយថា ទីលំនៅ[ព]គេនឹងធន់នៅគ្រប់ទាំងដំណ
តទៅ គេក៏ដាក់ឈ្មោះស្រុក តាមឈ្មោះ[ភ]របស់ខ្លួនដែរ
១២ ប៉ុន្តែមនុស្សមិនស្ថិតស្ថេរនៅ[ម] ដោយមានកេរ្តិ៍ឈ្មោះទេ
គឺគេដូចជាសត្វតិរច្ឆានដែលត្រូវវិនាសវិញ[យ] ។
១៣ ឯផ្លូវគេ នោះសុទ្ធតែផ្តេសផ្តាសទទេ
ប៉ុន្តែមនុស្សដែលកើតមក

**៤៩:១** គ ទដ ៣៣:៨ **៤៩:២** ឃ ទដ ៦២:៩ **៤៩:៣** ង ទដ ៣៧:៣០ ច ទដ ១១៩:១៣០ **៤៩:៤** ឆ ទដ ៧៨:២ សភ ១:៦ អគ ១២:២២ ១៦:៤៤ ១៨:២–៣ លក ៤:២៣ ជ ជន ១២:៨ ឈ ១សយ ១៦:១៦ ទដ ៣៣:២ **៤៩:៥** ញ ទដ ២៣:៤ ២៧:១ **៤៩:៦** ដ យប ២២:២៥ ទដ ៧៣:១២ យរ ៤៨:៧ ឋ ទដ ១០:៣ ឌ យប ៣៦:១៩ **៤៩:៨** ឍ ជន ៣៥:៣១ ណ មថ ១៦:២៦ **៤៩:៩** ត ទដ ២២:២៩ ៨៩:៤៨ ថ ទដ ១៦:១០ **៤៩:១០** ទ សស ២:១៦ ធ ទដ ៩២:៦ ៩៤:៨ ន យប ២៧:១៧ ប សស ២:១៨,២១ លក ១២:២០ **៤៩:១១** ផ ទដ ១០៦:៣១ ព មក ៥:៣ លក ៨:២៧ ភ ចទ ៣:១៤ **៤៩:១២** ម យប ១៤:២ យ ខ.២០ ២ពត ២:១២

សេចក្តីផ្តើម ទដ ៣៧ ។

**ទដ ៤៩ត្រង់ចំណងជើង** សូមមើលការពន្យល់ ទដ ៤២ ត្រង់ចំណងជើង ។

**៤៩:១–៤** នៅក្នុងខទាំងនេះគឺជាសេចក្តីផ្តើម ។

**៤៩:១–២** នៅក្នុងខ.ទាំងនេះវាមានលក្ខណៈទៅនឹងការថ្លែង ទំនាយរបស់ពួកហោរា (មើល ១ពវ ២២:២៨ អស ៣៤:១ មីក ១:២) ជាសេចក្តីបង្រៀនរបស់គ្រូប្រាជ្ញាជាង (មើល ៣៤:១១ សភ ១:៨,១០ ២:១) ។

**៤៩:៣** មើល មថ ១២:៣៤ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៤៩:៤** *ផ្ទៀងត្រចៀក* ប្រាជ្ញាដែលគ្រូប្រដៅគាត់នឹងនិយាយដំបូងនោះគឺ ឱ្យ "ស្តាប់"គាត់ ពីព្រោះប្រាជ្ញានោះគឺសុទ្ធតែមកអំពីព្រះ (មើល យប ជំពូក ២៨) ។ *ពាក្យឧបមា . . . សេចក្តីអាថ៌កំបាំង* ថ្នាក់ពាក្យជានាមរបស់ភាសាហេព្រើរទាំង២នេះ ប្រើសំដៅលើសេចក្តីបង្រៀនដ៏ជ្រាលជ្រៅ ដែលពោរពេញទៅដោយសិល្បៈ (មើល ៧៨:២ "សេចក្តីប្រៀបធៀប" "សេចក្តីអាថ៌កំបាំង" សភ ១:៦ "ពាក្យសុភាសិត" "ប្រស្នា" អគ ១៧:២ "ប្រស្នា" "សេចក្តីប្រៀបធៀប") ។ *តាមស្នូរស៊ីង* នេះគឺជាពាក្យប្រលយផ្សេងៗទៀតដែលជាសេចក្តីបង្រៀនរបស់អ្នកនិពន្ធ (មើល ១សយ ១០:៥–៦ ២ពវ ៣:១៥) ។

**៤៩:៥–១១** នៅក្នុងខនេះចង់និយាយថា នៅពេលដែលពួកមនុស្សខ្លៅល្ងង់បានហ៊ុំព័ទ្ធគេ នោះពួកមនុស្សកំណាច និងពួកមនុស្សដែលមានអំណាចមិនអាចស្ថិតស្ថេរឡើយ ហើយទីបញ្ចប់សេចក្តីស្លាប់គឺជាវាសនារបស់គេ ។

**៤៩:៦** *អស់អ្នកដែលទុកចិត្តនឹងរបស់ទ្រព្យខ្លួន* មើល ៥២:៧ ។ *អួតពី* គេអាចនិយាយម្យ៉ាងទៀតថា "អួតតែ" ។ ពួកគេអួតអាងលើទ្រព្យសម្បត្តិរបស់គេ ដើម្បីការពារពួកគេ និងផ្តល់សេចក្តីសុខរបស់ពួកគេ (មើល ៥២:១ និងការពន្យល់) ។

**៤៩:៧–៩** នៅក្នុងឃ្លានេះចង់និយាយថា ទ្រព្យសម្បត្តិមិនអាចទិញជីវិតបានឡើយ ហើយក៏មិនអាចបំពេញការ"ប្រោសលោះ"នៅក្នុងគ្រួសារអ្នកណាម្នាក់ឡើយ (សូមធៀបជាមួយ នក ២១:៣០ លវ ២៥:៤៧–៤៩) ។ មានតែព្រះអម្ចាស់១ប៉ុណ្ណោះ ដែលអាចលោះជីវិតយើងពីស្ថានឃុំព្រលឹងមនុស្សស្លាប់បាន (សូមមើលក្នុង ខ.១៥ និងការពន្យល់) ។

**៤៩:១០** នៅក្នុងឃ្លានេះចង់និយាយថា "អ្នកដែលមានភ្នែកនៅត្រង់ក្បាលរបស់គេ" (សូមមើល សស ២:១៤) គេនឹងបានឃើញថា សូម្បីតែមនុស្សដែលមានប្រាជ្ញាក៏ស្លាប់ដែរ (មើល សស ៧:២ ៩:៥) ហើយបានទុកទ្រព្យរបស់គេនៅនឹងដៃអ្នកដទៃវិញ (មើល សស ២:១៨,២១) ។ បើការនេះកើតដល់មនុស្សមានប្រាជ្ញទៅហើយ ចុះទំរាំមនុស្សខ្លៅល្ងង់តើវានឹងកើតឡើងច្រើនជាងនេះអម្បាលម៉ានទៅទៀត (មើល ៧៣:១៨–២០ ៩២:៦–៧ និង ៥២:៥ ៨៩:៤៨ យប ៣០:២៣ សស ២:១៤–១៦) ។ *មនុស្សប្រាជ្ញ . . . មនុស្សខ្លៅល្ងង់ . . . មនុស្សកំរោល* វាគឺជាសេចក្តីដំរូវការចាំបាច់សម្រាប់មនុស្ស "សុចរិត" និង "មនុស្សកំណាច" ដែលមាននិយាយនៅ ទដ ៣៧ ។ *ទ្រព្យសម្បត្តិ* ជាញឹកញាប់បានធ្វើឱ្យមនុស្សវង្វេង នោះហើយជាប្រាជ្ញានៃសេចក្តីខ្លៅល្ងង់របស់ពួកគេ (មើល ខ.៥,១២ និង ៥២:១–៤,៧) ។ *ឱ្យអ្នកដទៃ* មិនមែនឱ្យទៅកូនរបស់ពួកគេឡើយ (មើលការពន្យល់ ៣៧:២៩ និង ៣៩:៦ លក ១២:២០–២១) ។

**៤៩:១១** នៅក្នុងខនេះចង់និយាយថា ទោះបីជាពួកគេបានចំណាយទ្រព្យសម្បត្តិរបស់ពួកគេជាច្រើនមកលើផ្នូររបស់គេ និងព្យាយាមឱ្យមានការចងចាំពួកគេដោយដាក់ឈ្មោះរបស់ពួកគេនៅលើទឹកដីដ៏ធំរបស់គេ (មើល ជន ៣២:៤១) ទីបញ្ចប់ពួកគេទទួលការរងទុក្ខ ហើយស្ថានឃុំព្រលឹងមនុស្សស្លាប់ជា "ផ្ទះដ៏អស់កល្បជានិច្ច"របស់ពួកគេ (មើល សស ១២:៥ ហើយសូមធៀបជាមួយ និងសេចក្តីសង្ឃឹមរបស់អ្នកនិពន្ធ ខ.១៥) ។

**៤៩:១២** នៅក្នុងខនេះ គឺចង់និយាយសំដៅលើពាក្យសិលាចារិកនៅមុខផ្នូររបស់គេ (មើលការពន្យល់ ១០:១៨ និង សស ៣:១៩ ៧:២) និងបទបន្ទររបស់អ្នកនិពន្ធ ។

ខាងក្រោយក៏ចូលចិត្តនឹងពាក្យសំដីរបស់គេដែរ[រ] –បង្អង់

១៤ គេដូចជាហ្វូងសត្វដែលដំរង់[ល] ទៅឯទីស្លាប់[វ] សេចក្ដីស្លាប់
និងស៊ីគេ ហើយមនុស្សទៀងត្រង់នឹងជាន់ឈ្លី[ស] គេតាំង
ពីព្រលឹម រូបល្អរបស់គេនឹងត្រូវសូន្យទៅនៅស្ថានឃុំ
ព្រលឹងមនុស្សស្លាប់ ឥតមានទីអាស្រ័យឡើយ

១៥ ប៉ុន្ដែព្រះទ្រង់នឹងលោះព្រលឹងខ្ញុំ
ឱ្យរួចពីអំណាចនៃស្ថានឃុំព្រលឹងមនុស្សស្លាប់នោះវិញ[ហ]
ដ្បិតទ្រង់នឹងទទួលខ្ញុំទុក[ឡ]។ –បង្អង់

១៦ កុំឱ្យភ័យខ្លាច ដោយអ្នក១បានមានឡើង ក្នុងកាលដែល
សេចក្ដីរុងរឿងនៅផ្ទះបានបរិបូរនោះឡើយ

១៧ ដ្បិតកាលណាគេស្លាប់ទៅ
នោះនឹងយកអ្វីៗទៅផងមិនបាន[អ]
ហើយសេចក្ដីរុងរឿងរបស់គេនឹងមិនចុះទៅតាមឡើយ[ក]

១៨ ទោះបើអ្នកនោះបានរាប់ខ្លួនជាមានពរ[ខ] ក្នុងកាលដែល
នៅរស់នៅឡើយ ហើយបាននាំឱ្យមនុស្សសរសើរខ្លួន
ដោយបានលៀងជីវិតយ៉ាងល្អក៏ដោយ

១៩ គង់តែនឹងត្រូវទៅតាមពួកព្ធយុកោខ្លួន[គ] ដែលមិនឃើញ
ពន្លឺទៀត[ឃ]

២០ មនុស្សណាដែលមានកេរ្តិ៍ឈ្មោះ
តែឥតមានយោបល់នោះ[ង] ធៀបដូចជាសត្វតិរច្ឆាន
ដែលវិនាសទៅនោះឯង[ច]។

ទំនុករបស់អេសាភ ។

**៥០** ព្រះ គឺជាព្រះដ៏មានឥទ្ធិឫទ្ធិ ព្រះនាមជាព្រះយេហូវ៉ា[ក]
ទ្រង់បានមានបន្ទូលហើយ

**៤៩:១៣** រ លក ១២:២០
**៤៩:១៤** ល យរ ៤៣:១១ អគ ៣១:១៤ វ ជន ១៦:៣០ យប ២១:១៣ ទដ ៩:១៧ ៥៥:១៥ ស អស ១៤:២ ដយ ៧:១៨ ១កថ ៦:២
**៤៩:១៥** ហ ទដ ៥៦:១៣ ហស ១៣:១៤ ឡ លប ៥:២៤
**៤៩:១៧** អ ១ធថ ៦:៧ ក ទដ ១៧:១៤
**៤៩:១៨** ខ ទដ ១០:៦ លក ១២:១៩
**៤៩:១៩** គ លប ១៥:១៥ ឃ យប ៣៣:៣០ **៤៩:២០** ង ទដ ១៦:១៦ ច ខ.១២
**៥០:១** ក យស ២២:២២

**៤៩:១៣–១៩** នៅក្នុងខទាំងនេះ គឺនិយាយពីចុងបញ្ចប់របស់មនុស្សខ្លៅល្ងង់ និងពួកមនុស្សសុចរិត ដូច្នេះតើហេតុអ្វីបានជាមនុស្សនៅស្ញើចសរសើរចំពោះពួកអ្នកមានទៀត ។

**៤៩:១៣** *គេ* គឺជាពួកអ្នកដែលបានទទួល "ជ័យជម្នះ" (មើល ខ.៦) ។

**៤៩:១៤** *ដូចជាហ្វូងសត្វ* ដោយសារសេចក្ដីស្លាប់បានឆក់យកជីវិតអ្នកគង្វាលគេរួចទៅហើយ ដូច្នេះទើបពួកគេ "ដំរង់" ទៅឯទីស្លាប់ ។ *សេចក្ដីស្លាប់និងស៊ីគេ* រូបភាពនៃសេចក្ដីស្លាប់ (ឬស្ថានឃុំព្រលឹងមនុស្សស្លាប់ ដែលប្រៀបបានទៅនឹងអសុរកាយស៊ីជនរងគ្រោះមិនចេះឆ្អែតមិនចេះឆ្អន់នោះ មើល ៦៩:១៥ ១៤១:៧ សភ ១:១២ ២៧:២០ ៣០:១៥–១៦ អស ៥:១៤ យហ ២:២ (ពាក្យថា "រណ្ដៅ" បើតាមភាសាអក្សរសាស្ត្រគឺ "ក្បាលពោះ ឬប៉ោង" ហប ២:៥ ។ រូបភាពនៃពាក្យប្រៀបប្រដូចនេះ គឺយកចេញពីរឿងព្រេងរបស់ពួកកាណានដែលពណ៌នាអំពីព្រះម៉ូឌ (មានន័យថា សេចក្ដីស្លាប់) ។ តាមឯកសាររបស់ពួកកាណានមួយបានសម្ដែងថា "កុំឱ្យយើងប្រព្រឹតបែបមិនគួរនឹងព្រះម៉ូឌឡើយ បើមិនដូច្នោះទេព្រះម៉ូឌនឹងចាប់យើងមករំពារដូចជាចាប់សត្វចៀមដែរ" ។ *ជាន់ឈ្លី* មើល លវ ២៦:១៧ អស ១៤:២ ។ ប្រហែលពាក្យថា "ឈ្នះលើ" មានអត្ថន័យផ្ទុយនឹងស្ថានការណ៍ដែលបាននិយាយនៅ ខ.៥ ។ *តាំងពីព្រលឹម* មើល ខ.១៥,១៩ និងការពន្យល់ ៦:៥ ១១:៧ ១៦:៩–១១ ១៧:១៥ ។ ប៉ុន្ដែ មើលសេចក្ដីផ្ដើម ទដ ៥៧ ។

**៤៩:១៥** សូមមើលការពន្យល់ ខ.៧–៩ ។ *លោះ . . . ស្ថានឃុំព្រលឹងមនុស្សស្លាប់* ធៀបនឹង ខ.១១ ។ នៅទីនេះប្រហែលជាអ្នកនិពន្ធចង់និយាយសំដៅលើការជួយសង្គ្រោះឱ្យរួចពីសេចក្ដីស្លាប់ (ដូចមាននិយាយនៅក្នុង យប ៥:២០ និង ទដ ១១៦:៨) នោះបរិបទនេះបានសង្កត់ធ្ងន់ដូច្នេះថាឃ្លានេះគឺជាការនិយាយពីវាសនាចុងក្រោយរបស់មនុស្សទៀងត្រង់ ។ ប្រហែលគំនិតនេះគឺនាំឱ្យយើងបានទៅដល់ព្រះវត្តមានរបស់ព្រះអម្ចាស់ នៅឯក្រុងស្ថានសួគ៌ ដែលស្រដៀងគ្នានឹងអាសនារបស់ពួកយូដា ដែលគេគិតថាជាស្ពានឆ្លងទៅដល់"ដើមទ្រូងលោកអ័ប្រាហាំ"(លក ១៦:២២ និងការពន្យល់ ៦:៥ ១១:៧ ១៦:៩–១១ ១៧:១៥) ។ *ព្រលឹងខ្ញុំ* មើលការពន្យល់ ៦:៣ ។ *ដ្បិតទ្រង់នឹងទទួលខ្ញុំទុក* មើល ៧៣:២៤ លប ៥:២៤ និងការពន្យល់។

**៤៩:១៦** *នៅផ្ទះ* គឺនិយាយសំដៅលើគ្រឿងសង្ហារិមក្នុងផ្ទះទាំងមូល (មើល នក ២០:១៧) ។

**៤៩:១៩** *ពន្លឺ* សូមមើលការពន្យល់ ២៧:១ ៣៦:៩ និង អស ៥៣:១១ ។

**៤៩:២០** សូមមើលការពន្យល់ក្នុង ខ.១២ ។

**ទដ ៥០** នៅក្នុងជំពូកនេះព្រះយេហូវ៉ា ទ្រង់បានហៅរាស្ត្រនៃសេចក្ដីសញ្ញារបស់ទ្រង់មកឱ្យស្ដាប់ពីការអស្ចារ្យរបស់ទ្រង់ ។ សូមមើលប្រភេទរបស់ទំនុកដំកើងក្នុងចំណោមទំនុកដំកើងផ្សេងទៀតក្នុងសេចក្ដីផ្ដើម ទដ ៤៩–៥៣ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ តែងឡើងដើម្បីច្រៀងសរសើរតម្កើងដល់ព្រះអម្ចាស់នៅក្នុងព្រះវិហារ ដែលពួកអ៊ីស្រាអែលបានច្រៀងបង្ហាញពីការប្ដេជ្ញាតាមសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ ។ ពួកអ្នកដឹកនាំចម្រៀងដែលចេញពីពួកលេវីបានណែនាំ ឬនិយាយពីពួកកូនចៅអ៊ីស្រាអែលដោយនូវនាមព្រះយេហូវ៉ា (មើល ទដ ១៥,២៤) ។ បទចម្រៀងក្នុងជំពូកនេះវាក៏អាចមានទំនាក់ទំនងជាមួយនឹងបុណ្យបាវាំផងដែរ (មើល ចទ ៣១:៩–១៣ និងសេចក្ដីផ្ដើម ទដ ៤៧) ។ នៅក្នុងការបន្ទោសចំពោះការយល់ខុសពីការថ្វាយយញ្ញបូជា នោះគេសង្កេតឃើញថាព្រះគម្ពីរទំនុកដំកើងមានទំនាក់ទំនងជាមួយនឹងការថ្លែងទំនាយរបស់ហោរាអេម៉ុស ហោរាមីការ និង ហោរាអេសាយ ហើយកាលបរិច្ឆេទនៃការសរសេរប្រហែលជានៅក្រោយ ឬដើមសតវត្សរ៍ទី៨ មុន គ.ស ។ មិនតែប៉ុណ្ណោះសោតព្រះគម្ពីរជំពូកនេះក៏មានទំនាក់ទំនងយ៉ាងស្និត ទៅនឹងការកែរទម្រង់របស់ស្ដេចយ៉ូសៀសដែរ (មើល ២ពវ ២២:១–២៣:២៥) និងការងារបម្រើរបស់ហោរាយេរេមាផងដែរ ។ ចំណែកឯលក្ខណៈសំណង់ប្រយោគវិញព្រះគម្ពីរទំនុកដំកើងជំពូកនេះបែងចែកជា៣ផ្នែកដែរ (១).និយាយពីសេចក្ដីប្រកាសពីការ "យាងមក" របស់ព្រះនៃសេចក្ដីញ្ញារបស់ពួកអ៊ីស្រាអែលដែលទ្រង់បានកោះហៅរាស្ត្រទ្រង់ឱ្យចូលមក (មើល ខ.១–៦) (២).ព្រះបន្ទូលដ៏ត្រឹមត្រូវរបស់ព្រះយេហូវ៉ា ចំពោះអ្នកណាដែលស្មោះត្រង់ (ខ.៧–១៥) ហើយ (៣).សេចក្ដីបន្ទោសរបស់ទ្រង់ចំពោះពួក "មនុស្សអាក្រក់" នៅក្នុងណោមមនុស្សជាច្រើន (ខ.១៦–២៣) ។

**ទដ ៥០ត្រង់ចំណងជើង** តាមទម្លាប់ដែលតែងតែអះអាងគេគិតថា នេះជា

ទ្រង់បានកោះហៅទាំងអស់ដែលនៅ
លើផែនដីចាប់តាំងពីទិសខាងថ្ងៃរះទៅដល់ទិសថ្ងៃលិច[ខ]
២ ព្រះទ្រង់បានភ្លឺមកពីក្រុងស៊ីយ៉ូន[គ]
ដែលជាទីក្រុងមានលំអ[ឃ]ដ៏គ្រប់លក្ខណ៍[ង]
៣ ព្រះនៃយើងខ្ញុំទ្រង់យាងមក[ច] ហើយមិននៅស្ងៀមទេ[ឆ]
មានភ្លើងឆេះ[ជ]នៅចំពោះទ្រង់[ឈ]
ហើយនៅព័ទ្ធជុំវិញទ្រង់មានព្យុះសង្ឃរា[ញ]
៤ ទ្រង់បង្គាប់ដល់ស្ថានសួគ៌នៅខាងលើ
និងដល់ផែនដី[ដ]ដើម្បីជំនុំជំរះរាស្ត្ររបស់ទ្រង់ថា[ឋ]
៥ ចូរប្រមូលពួកអ្នកបរិសុទ្ធរបស់អញ ឱ្យមកឯណេះ[ឌ]
គឺជាពួកដែលបានតាំងសញ្ញា[ឍ]នឹងអញដោយថ្វាយយញ្ញ
បូជា
៦ នោះផ្ទៃមេឃនឹងសំដែង[ណ]ពីសេចក្តីសុចរិតរបស់ទ្រង់
ដ្បិតគឺព្រះហើយ ដែលជាចៅក្រម[ត]។ –បង្អង់
៧ ម្នាលរាស្ត្រអញអើយ ចូរស្តាប់ចុះ អញនឹងពោល
ឱអ៊ីស្រាអែលអើយ អញនឹងធ្វើបន្ទាល់[ថ]ទាស់នឹងឯងអញ
ជាព្រះ គឺជាព្រះនៃឯងហើយ[ទ]
៨ អញនឹងមិនបន្ទោស[ធ]ឯង
ដោយព្រោះយញ្ញបូជា[ន]ដែលឯងថ្វាយ នោះទេ

**៥០:១** ខ ទដ ១១៣:៣ **៥០:២** គ ទដ ២:៦ ឃ ទដ ៤៨:២ បទ ២:១៥ ង ចទ ៣៣:២ **៥០:៣** ច ទដ ៩៦:១៣ ឆ ខ.២១ អស ៤២:១៤ ៦៤:១២ ៦៥:៦ ជ លវ ១០:២ ឈ ទដ ១៨:៨ ញ យប ៣៧:៩ ទដ ៨៣:១៥ ១០៧:២៥ ១៤៧:១៨ អស ២៩:៦ ៣០:២៨ យហ ១:៤ ណាហ ១:៣
**៥០:៤** ដ ចទ ៤:២៦ ៣១:២៨ អស ១:២ ឋ ហាព ១០:៣០ **៥០:៥** ឌ ចទ ៧:៦ ទដ ១៨:២៥ ឍ នក ២៤:៧ ២របា ៦:១១ **៥០:៦** ណ ទដ ១៩:១ ត លប ១៦:៥ យប ៩:១៥ **៥០:៧** ថ ហាព ២:៤ ទ នក ២០:២ ទដ ៤៨:១៤ **៥០:៨** ធ ២សយ ២២:១៦ ន ទដ ៤០:៦

ទំនុករបស់អេសាភ ឬក៏"ជូនដល់អេសាភ"(ការនិយាយថា ជូនដល់យេថូឌិន នោះសូមមើល ទដ ៣៩ ត្រង់ចំណងជើង) ឬសម្រាប់ពួកកូនចៅអេសាភ ដែលពួកគេមានតួនាទីជាអ្នកជំនួសតួនាទីរបស់អេសាភ ។ ទំនុកដំកើងជំពូកនេះប្រហែលចែកដាច់ពីគ្នារវាងទំនុករបស់អេសាភក្នុង ទដ ផ្សេងៗទៀត (ទដ ៧៨–៨៣) គឺដើម្បីឱ្យជំពូកនេះជាគូនឹង ទដ ៥១ ដែលជាចង្កោមនៃទំនុកដំកើង ៤៩–៥៣ ។ អេសាភគឺជាអ្នកចម្រៀងម្នាក់ក្នុងចំណោមអ្នកចម្រៀងទាំង៣របស់ស្តេចដាវីឌ (មើលការពន្យល់ ទដ ៣៩ ត្រង់ចំណងជើង) ។

**៥០:១–៦** នៅក្នុងខទាំងនេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់បានយាងមក (ខ.៣) នៅក្នុងព្រះវិហារ ដើម្បីកែរដំរង់ និងស្តីបន្ទោសចំពោះរាស្ត្រទ្រង់ ។ ពួកអ៊ីស្រាអែលត្រូវតែដឹងថា ព្រះយេហូវ៉ាជាព្រះដែលគង់នៅក្រុងស៊ីយ៉ូន ក៏ជាព្រះដែលបានគង់នៅភ្នំស៊ីណាយដែរ (សូមមើល នក ១៩:១៦–២០) ។

**៥០:១** *ព្រះគឺជាព្រះដ៏មានឥទ្ធិឫទ្ធិ* ឃ្លានេះនៅកន្លែងផ្សេងទៀតមាននិយាយតែនៅក្នុង យស ២២:២២ ប៉ុណ្ណោះ (សូមមើលការពន្យល់ទីនោះ) ។ ទំនុកដំកើងជំពូក ៥០ គឺមានការគួឱ្យកត់សម្គាល់ ពីព្រះនាមរបស់ព្រះជាច្រើនត្រូវបានប្រើក្នុងជំពូកនេះ (ទាំងអស់មាន ៧ ដោយក្នុងនោះនៅក្នុង ខ.១ មាន ៣ ហើយមានចំនួន៤ ដែលមាននិយាយនៅក្នុងពេញជំពូកនេះតែម្តង មើលការពន្យល់ ខ.៦,១៤,២១–២២) ។ *ផែនដី* មើលពាក្យថា"ស្ថានសួគ៌ . . . ផែនដី"(មើល ខ.៤) និងពាក្យថា"ផ្ទៃមេឃ" (មើល ខ.៦) នៅពេលដែលលោកម៉ូសេកែប្រែសេចក្តីសញ្ញារវាងព្រះ និងអ៊ីស្រាអែលនៅវាលទំនាបស្រុកម៉ូអាប់ ហើយព្រះអម្ចាស់ទ្រង់បានអាងដល់ស្ថានសួគ៌ និងផែនដីដើម្បីនឹងធ្វើបន្ទាល់ដល់ពួកគេ (មើល ចទ ៣០:១៩ និង ៣១:២៨) ។ ពេលនេះព្រះអម្ចាស់ទ្រង់បានកោះហៅអ្នកទាំងនោះមក ដើម្បីធ្វើសេចក្តីបន្ទាល់ថាព្រះវត្តមាននៃព្រះបន្ទូលរបស់ទ្រង់ ចំពោះប្រជារាស្ត្ររបស់ទ្រង់ គឺមានតាំងពីពេលដែលពួកគេបានតាំងសញ្ញាមកម្ល៉េះ (មើល អស ១:២) ។ ទំនាក់ទំនងរបស់ព្រះអម្ចាស់ចំពោះរាស្ត្រទ្រង់ គឺជាអ្វីៗទាំងអស់ដែលព្រះអម្ចាស់ទ្រង់បង្កើតមក ហើយដោយសារតែមូលហេតុនោះបានជាគ្រប់របស់ទាំងអស់ ដែលទ្រង់បង្កើតមកគឺជាក្រុមដែលមានការចាប់អារម្មណ៍ចំពោះទំនាក់ទំនងនោះ (មើល លប ជំពូក ១–៣ និង យរ ១២:៤ រម ៨:២២ និងការពន្យល់) ។

**៥០:២** *លំអដ៏គ្រប់លក្ខណ៍* នៅក្នុងឃ្លានេះចង់និយាយថា មូលហេតុដែលបណ្តាលឱ្យក្រុងស៊ីយ៉ូនមានលំអដ៏គ្រប់លក្ខណ៍ ពីព្រោះព្រះយេហូវ៉ាទ្រង់បានគង់នៅទីនោះ (ធៀបនឹង អគ ២៧:៣–៤,១១ ២៨:១២) ។ *ភ្លឺមកពី* នៅក្នុងឃ្លានេះគឺចង់និយាយថា សិរីល្អនៃព្រះបានយាងមកធ្វើការនៅលើផែនដីនេះ គឺមានលក្ខណៈភ្លឺច្បាស់ (មើល ៨០:១ ៩៤:១ ចទ ៣៣:២ ហើយធៀបជាមួយ អគ ២៨:៧,១៧) ។ ឥឡូវនេះព្រះអម្ចាស់ទ្រង់បានហៅរាស្ត្ររបស់ព្រះឱ្យមកស្តាប់ពីការដែលទ្រង់បានធ្វើ ប៉ុន្តែមិនទាន់និយាយពីការជំនុំជម្រះដូចបាននិយាយនៅក្នុង អស ជំពូក១ និង មីក ជំពូក១ នោះឡើយ ។

**៥០:៣** *យាងមក* គឺបានយាងចេញពីបល្ល័ង្ករបស់ទ្រង់ចន្លោះចេរូប៊ីន (មើល ៨០:១ ៩៩:១ និង ១សយ ៤:៤ ២សយ ៦:២ ២ពវ ១៩:១៥) ដែលជាកន្លែងបរិសុទ្ធបំផុតនៅក្នុងព្រះវិហារ (មើលការពន្យល់ ២៨:២ និង អស ២៦:២១ មីក ១:៣) ។ *មិននៅស្ងៀមទេ* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់នឹងមិនលើកលែងអំពើបាបរបស់គេទៀតឡើយ (មើល ខ.២១) ។ *ភ្លើង* សូមមើល នក ១៩:១៦,១៨ ។

**៥០:៤** *ជំនុំជំរះ* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់នឹងហៅគេមកជំនុំជំរះទៅតាមសេចក្តីសេចក្តីសញ្ញានៃទ្រង់ ។

**៥០:៥** *ពួកអ្នកបរិសុទ្ធរបស់អញ* មើលការពន្យល់ ៤:៣ ។ *ដោយថ្វាយយញ្ញបូជា* យញ្ញបូជាគឺជាត្រានៃសេចក្តីសញ្ញា (មើល នក ២៤:៤–៨) ហើយនៅបន្តអនុវត្តទាំងស្រុងចំពោះពួកអ៊ីស្រាអែលក្នុងការ ប្តេជ្ញាចិត្តចំពោះសេចក្តីសញ្ញានៃព្រះ ។

**៥០:៦** *សំដែង* មើល ខ.១ ។ *សេចក្តីសុចរិត* មើលការពន្យល់ ៤:១ ។ *ចៅក្រម* មានន័យថាព្រះយេហូវ៉ាទ្រង់គ្រប់គ្រងលើរាស្ត្ររបស់ទ្រង់ (ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យថា "ចៅក្រម" និង "ស្តេច" ពេលខ្លះ គឺជាសទិសន័យ មើល អស ៣៣:២២ "ចៅក្រម" ដែលពន្យថាចៅក្រមគឺជាងាររបស់ ព្រះអម្ចាស់ (មើលការពន្យល់ ខ.១) និងក្នុង ទដ ៩៤:២ លប ១៨:២៥ ពច ១១:២៧ ។

**៥០:៧–១៥** នៅក្នុងខទាំងនេះ និយាយពីការដែលព្រះយេហូវ៉ាទ្រង់កែតម្រង់រាស្ត្រទ្រង់ ។

**៥០:៧** *រាស្ត្រអញ* ពាក្យថា"ព្រះនៃយើងខ្ញុំ"(ខ.៣) និង "ព្រះនៃឯង" (ទីនេះ) គឺជាពាក្យចំណងនៃសេចក្តីសញ្ញា ។ *អញជាព្រះ គឺជាព្រះនៃឯងហើយ* មើល នក ១៩:៣–៦ លវ ១៩:២–៤,១០,២៥,៣១,៣៤,៣៦ ២០:៧,២៤ ២២:៣៣ ២៣:២២ ។

ឯដង្វាយដុតរបស់ឯង នោះក៏នៅចំពោះអញជានិច្ច
៩ តែអញមិនយកគោឈ្មោល[ប]ពីផ្ទះឯង
ឬពពែឈ្មោល[ផ]ពីក្រោលឯងឡើយ[ព]
១០ ដ្បិតអស់ទាំងសត្វនៅព្រៃ[ភ]សុទ្ធតែរបស់អញ
ព្រមទាំងហ្វូងសត្វទាំងប៉ុន្មាននៅលើភ្នំទាំងពាន់ផង[ម]
១១ អញស្គាល់អស់ទាំងសត្វស្លាប[យ]នៅលើភ្នំ
ហើយសត្វព្រៃ[រ]ទាំងឡាយជារបស់ផងអញដែរ ។
១២ បើកាលណាអញឃ្លាន នោះអញមិនប្រាប់ដល់ឯង
ពីព្រោះលោកីយ[ល] និងរបស់សព្វសារពើក្នុងលោកជា
របស់ផងអញ[វ]
១៣ តើអញនឹងស៊ីសាច់គោឈ្មោល
ឬផឹកឈាមពពែឈ្មោលឬអី
១៤ ចូរថ្វាយដង្វាយ[ស]ជាសេចក្ដីអរព្រះគុណដល់ព្រះវិញ
ហើយលាបំណន់[ហ]ដែលបានបន់ដល់ព្រះដ៏ខ្ពស់បំផុតផង[ឡ]
១៥ ចូរអំពាវនាវ[អ]ដល់អញនៅថ្ងៃមានសេចក្ដីទុក្ខលំបាក[ក]
នោះអញនឹងជួយឱ្យរួច[ខ] ឯងនឹងលើកដំកើង[គ]ដល់អញ ។
១៦ តែព្រះទ្រង់មានបន្ទូលចំពោះមនុស្សអាក្រក់ថា
ឯងត្រូវការអ្វីនឹងថ្លែងប្រាប់[ឃ]ពីបញ្ញត្តិ[ង]អញ
ហើយយកសញ្ញាអញមកនៅក្នុងមាត់ឯង

**៥០:៩** ប លវ ១:៥ ផ លវ ១៦:៥ ព ជន ៣២:១៦ **៥០:១០** ភ ទដ ១០៤:២០ អស ៥៦:៩ មីក ៥:៨ ម ទដ ១០៤:២៤ **៥០:១១** យ មថ ៦:២៦ រ ទដ ៨:៧ ៨០:១៣ **៥០:១២** ល នក ១៩:៥ វ ចទ ១០:១៤ យស ៣:១១ ទដ ២៤:១ ១កថ ១០:២៦ **៥០:១៤** ស អរ ១:៤ ទដ ២៧:៦ ហ ជន ៣០:២ ទដ ៦៦:១៣ ៧៦:១១ ឡ ទដ ៧:៨ **៥០:១៥** អ ទដ ៤:១ ៨១:៧ អស ៥៥:៦ ៥៨:៩ សក ១៣:៩ ក ទដ ៦៩:១៧ ៨៦:៧ ១០៧:៦ ១៤២:២ យក ៥:១៣ ខ ទដ ៣:៧ គ ទដ ២២:២៣ **៥០:១៦** ឃ អស ២៩:១៣ ង ទដ ២៥:១០ **៥០:១៧** ច សភ ១:២២ ឆ ១ពវ ១៤:៩ **៥០:១៨** ជ រម ១:៣២ ១ធថ ៥:២២ ឈ យប ២២:១៥ **៥០:១៩** ញ ទដ ១០:៧ ៣៦:៣ ៥២:២ ១០១:៧ **៥០:២០** ដ មថ ១០:២១ **៥០:២១** ឋ អស ៤២:១៤ ៥៧:១១ ៦២:១ ៦៤:១២ ឌ ទដ ៦:១ ១៨:១៥ ៧៦:៦ ១០៤:៧ អស ៥០:២ ឍ ទដ ៨៥:៥ អស ៥៧:១៦ **៥០:២២** ណ យប ៨:១៣ អស ១៧:១០ ត ចទ ៣២:៣៩ មីក ៥:៨

១៧ ដែលឯងជាអ្នកស្អប់[ច]សេចក្ដីប្រដៅ
ហើយក៏បោះបង់ចោលពាក្យអញទៅក្រោយខ្នង[ឆ]ដូច្នេះ
១៨ កាលឯងបានឃើញចោរ នោះកំចូលគំនិត[ជ]នឹងគេ
ហើយមានចំណែកជាមួយនឹងពួកសំផឹងផង[ឈ]
១៩ ឯងបានប្រគល់មាត់ឯងទៅសេចក្ដីអាក្រក់
ហើយអណ្ដាតឯងបង្កើតកលមាយា[ញ]
២០ ឯងអង្គុយនិយាយដើមពីបងប្អូន[ដ]
ឯងនិយាយបង្កាច់ឈ្មោះទាំងកូនពោះ១នឹងឯងផង
២១ អំពើនោះឯងបានធ្វើហើយ តែអញបាននៅស្ងៀមវិញ[ឋ]
ឯងបានគិតស្មានថា អញដូចឯងតែប៉ុណ្ណោះ
អញនឹងបន្ទោស[ឌ]ដោយរៀបរាប់[ឍ]អំពើឯង នៅចំពោះមុខ
២២ ដូច្នេះ ឯងរាល់គ្នាដែលភ្លេចព្រះអើយ[ណ]
ចូរពិចារណាសេចក្ដីនេះចុះ
ក្រែងអញហែកឯងខ្ទេចខ្ទីទ័លបើជួយផង[ត]

**៥០:៨–១៣** នៅក្នុងខនេះចង់និយាយថា ពួកអ៊ីស្រាអែលគេមិនខុសឡើយក្នុងការថ្វាយយញ្ញបូជា (ខ.៨) ប៉ុន្តែអ្វីដែលខុសនោះគឺពួកគេបានគិតថា យញ្ញបូជាគឺមានសារៈសំខាន់បំផុតនៅចំពោះព្រះ ធ្វើឱ្យគេពឹងលើយញ្ញបូជាដើម្បីឱ្យបានទទួលការប្រោសលោះ ។ គំនិតនៃញាណអារម្មណ៍នេះ គឺកើតចេញពីពួកអ្នកជិតខាងរបស់ពួកអ៊ីស្រាអែល ដែលអ្នកជិតខាងរបស់គេមិនបានគោរពថ្វាយបង្គំព្រះនោះឡើយ ។ មើលការពន្យល់ ៤០:៦ ។

**៥០:១០** *ទាំងពាន់* នៅទីនេះគឺនិយាយសំដៅលើចំនួនដ៏ច្រើនលើសលប់ ។

**៥០:១២** *លោកិយនិងរបស់សព្វសារពើ* មើល ២៤:១ និងការពន្យល់ ។

**៥០:១៤–១៥** នៅក្នុងខនេះ ព្រះយេហូវ៉ាទ្រង់ចង់ឱ្យពួកអ៊ីស្រាអែលទាំងអស់ពឹងពាក់អាស្រ័យលើទ្រង់ ដោយថ្វាយដង្វាយនៃការអរព្រះគុណចំពោះសេចក្តីសេចក្តីសប្បុរសរបស់ទ្រង់ (ខ.១៤) ហើយដោយការអធិស្ឋានទៅចំពោះព្រះអង្គគ្រប់ពេលដែលគេត្រូវការ (សូមមើល ខ.១៥ និង ១១៦:១៧–១៩) ។ ពួកអ្នកដែលធ្វើការបែបនេះ និងទទួលបានព្រះគុណមកពីព្រះអម្ចាស់ ដោយការទ្រង់បានឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់គេ (មើលការថ្លែងក្នុង ខ.២៣) ។ មិនតែប៉ុណ្ណោះសោត ព្រះអម្ចាស់ទ្រង់ចង់ឱ្យគេស្តាប់បង្គាប់ក្រឹត្យវិន័យរបស់ព្រះដែរ (សូមមើល ខ.១៦–២១ និងការពន្យល់ ៤០:៦) ។

**៥០:១៤** *ដង្វាយជាសេចក្តីអរព្រះគុណ* មើល លវ ៧:១២–១៣ ។ *ព្រះដ៏ខ្ពស់បំផុត* គឺចង់និយាយថាព្រះយេហូវ៉ាទ្រង់ខ្ពស់បំផុត (សូមមើល ៥៧:២ និងការពន្យល់ ៣:៧) ។ *បំណន់* គឺជាបំណន់ដែលមានក្នុងសេចក្តីអធិស្ឋាន ហើយជាញឹកញាប់ គឺទាក់ទងនឹងដង្វាយនៃការអរព្រះគុណ (សូមមើលក្នុង ៦៦:១៣–១៥) ហើយក៏ទាក់ទងចំពោះការឆ្លើយតបរបស់ព្រះក្នុងសេចក្តីអធិស្ឋានរបស់គេដែរ (សូមមើលការពន្យល់ ៧:១៧ និង ហព ១៣:១៥) ។ *ព្រះដ៏ខ្ពស់បំផុត* សូមមើលការពន្យល់ ខ.១ និងការពន្យល់ លប ១៤:១៩ ។

**៥០:១៥** *លើកដំកើងដល់អញ* គឺតាមរយៈការសរសើរតម្កើងនៅពេលបានលាបំណន់ (សូមមើល ខ.២៣) និងតាមរយៈការស្តាប់បង្គាប់សេចក្តីសញ្ញារបស់ទ្រង់ ។

**៥០:១៦–២៣** នៅក្នុងខទាំងនេះ និយាយពីការដែលព្រះយេហូវ៉ាទ្រង់បន្ទោសដល់ពួកមនុស្សអាក្រក់ ។

**៥០:១៦** *ថ្លែងប្រាប់ពីបញ្ញត្តិអញ* គឺជាផ្នែកនៃចម្រៀងដែលស្តីពីការប្តេជ្ញាក្នុងសេចក្តីសញ្ញា ។

**៥០:១៧** *ឯងជាអ្នកស្អប់សេចក្តីប្រដៅ* ជានិច្ចកាលគេតែងតែធ្វើតាមច្បាប់ដ៏បរិសុទ្ធ ប៉ុន្តែគេបានបដិសេធន៍ចំពោះក្រឹត្យវិន័យរបស់ព្រះ ដែលជាអ្នកដឹកនាំជីវិតរបស់ពួកគេ ។

**៥០:១៩** *ប្រគល់មាត់ឯងទៅសេចក្តីអាក្រក់* សូមមើលការពន្យល់ ៥:៩ ។

**៥០:២១** នៅក្នុងខ.នេះចង់និយាយថា ដោយសារសេចក្តីសប្បុរសរបស់ទ្រង់ និងការស្ងៀមរបស់ព្រះអង្គបានធ្វើឱ្យមនុស្សអាក្រក់ទៅជាខូច (សូមមើល សស ៨:១១ អស ៤២:១៤ ៥៧:១១) ។ *គិតស្មានថា អញដូចជាឯង* សូមមើល នក ៣:១៤ និងការពន្យល់ ហើយការពន្យល់ ខ.១ នៃជំពូកនេះ ។ *ដោយរៀបរាប់អំពើឯង នៅចំពោះមុខឯង* ព្រះអម្ចាស់ទ្រង់នឹងសួរចម្លើយគេដោយចៅក្រមវិសេសរបស់ព្រះអង្គ ។

**៥០:២២** *ព្រះអើយ* នេះគឺជាពាក្យដែលកម្រមាននិយាយអំពីព្រះ (ភាសាហេព្រើរគឺ អេឡូហ៊ីម) តែនៅក្នុងយ៉ូបវិញគឺប្រើយ៉ាងសាមញ្ញ (សូមមើលការពន្យល់ ខ.១) ។

២៣ អ្នកណាដែលថ្វាយដង្វាយជាសេចក្តីអរព្រះគុណនោះក៏
លើកដំកើងអញដែរ
ហើយអញនឹងសំដែងសេចក្តីសង្គ្រោះរបស់
ព្រះ[ថ]ដល់អ្នកណាដែលរៀបផ្លូវ[ទ]របស់ខ្លួនឱ្យត្រង់ ។

ទំនុករបស់ស្តេចដាវីឌ ដែលទ្រង់
លើកសំរាប់មេភ្លេង នៅពេលដែលហោរាណាថាន់បានមកឯទ្រង់
ក្រោយដែលទ្រង់បានចូលទៅឯនាងបាតសេបា[ក] ។

**៥១** ឱព្រះអង្គអើយ សូមអណិតមេត្តា[ខ]ដល់ទូលបង្គំ
តាមសេចក្តីសប្បុរសរបស់ទ្រង់[គ]
ហើយសូមលុប[ឃ]សេចក្តីរំលងរបស់[ង]
ទូលបង្គំចេញដោយសេចក្តីមេត្តាករុណា[ច]ដ៏បរិបូររបស់
ទ្រង់
២ សូមលាងទូលបង្គំឱ្យយ៉ាងស្អាត[ឆ]ពីអំពើទុច្ចរិតរបស់ទូល
បង្គំ សូមសំអាត[ជ]អំពើបាបរបស់ទូលបង្គំផង
៣ ដ្បិតទូលបង្គំទទួលស្គាល់អំពើរំលងរបស់ទូលបង្គំហើយ
ឯអំពើបាបរបស់ទូលបង្គំនោះក៏នៅចំពោះមុខទូលបង្គំ
ជានិច្ច[ឈ]
៤ ទូលបង្គំបានធ្វើបាប[ញ]នឹងទ្រង់ហើយគឺនឹងទ្រង់តែ១ព្រះអង្គ
ព្រមទាំងប្រព្រឹត្តសេចក្តីដែលអាក្រក់នៅព្រះនេត្រទ្រង់
ផង[ដ] ទូលបង្គំទទួលស្គាល់អំពើទាំងនោះដើម្បីឱ្យទ្រង់បាន
រាប់ជាសុចរិតក្នុងកាលដែលទ្រង់មានបន្ទូល
ហើយឱ្យបានឥតសៅហ្មង ក្នុងកាលដែលទ្រង់ជំនុំជំរះ[ឋ]
៥ មើល ទូលបង្គំបានកើតមក[ឌ]ក្នុងសេចក្តីទុច្ចរិត[ឍ]

**៥០:២៣** ថ ទដ ៩:១៤ ៩១:១៦ ៩៨:៣ អស ៥២:១០ ទ ទដ ៨៥:១៣ **៥១:ចំណងជើង** ក ២សយ ១១:៤ ១២:១ **៥១:១** ខ ២សយ ២៤:១៤ ទដ ៩:១៣ គ ទដ ២៥:៧ ១១៩:៨៨ ឃ ២សយ ១២:១៣ ២រប ៦:២១ នហ ៤:៥ កច ៣:១៩ ង ទដ ៣៩:៨ ច នហ ៩:២៧ ទដ ៨៦:១៥ អស ៦៣:៧ **៥១:២** ឆ នរ ៣:៣ យរ ២:២២ ១៣:២៧ កច ២២:១៦ ១យហ ១:៩ ជ សភ ២០:៣០ អស ៤:៤ អគ ៣៦:២៥ សក ១៣:១ មថ ២៣:២៥–២៦ ហព ៩:១៤ **៥១:៣** ឈ អស ៥៩:១២ **៥១:៤** ញ ១សយ ១៥:២៤ ដ លប ២០:៦ លក ១៥:២១ ឋ រម ៣:៤ **៥១:៥** ឌ យប ៥:៧ ឍ លវ ៥:២

**៥០:២៣** សូមមើលការពន្យល់ ខ.១៤–១៥ ។

**ទដ ៥១** នៅក្នុងជំពូកនេះ ស្តេចដាវីឌបានអធិស្ឋានដោយការបន្ទាបខ្លួន សូមឱ្យព្រះអង្គទ្រង់បានអត់ទោស និងលាងជម្រះអំពើរបាបរបស់ទ្រង់ ។ ដោយជំពូកនេះនិយាយពីការសោកស្តាយនូវអំពើបាប ដែលបានប្រព្រឹត្ត នោះជំពូកនេះបានតំណាងឱ្យ ការទទួលខុសត្រូវរបស់ប្រជារាស្ត្រនៃទ្រង់ ចំពោះការកោះហៅរបស់ព្រះអម្ចាស់ ដែលមាននិយាយនៅក្នុង ទដ ៥០ (សូមធៀប ខ.១៦ ជាមួយ ទដ ៥០:៨–១៥ និងសេចក្តីផ្តើម ទដ ៤៩–៥៣) ។ ព្រះគម្ពីរ ទដ ក្នុងជំពូកនេះមានចំណុចជាច្រើនដែលខុសគ្នាជាមួយ ទដ ២៥ តាមទម្លាប់របស់គ្រីស្ទបរិស័ទគេចាត់ទុកថា ជំពូកនេះគឺជាសៀវភៅច្បាប មួយក្នុងចំណោមសៀវភៅច្បាប់ទាំង៧ ដែលមាននៅក្នុងទំនុកដំកើង (សូមមើលក្នុងសេចក្តីផ្តើម ទដ ៦) ។ ទំនុកដំកើងក្នុងជំពូកនេះ បានតែងឡើង ដោយមានចំណាប់ចុងចួន ។ ២ខដំបូងដែលជាសេចក្តីផ្តើម បានណែនាំ ដល់២ខចុងក្រោយដែលជាសេចក្តីបញ្ចប់ ហើយបានភ្ជាប់មកជាមួយនូវ ល្បះចំនួន៤ ដែលមាន៥បន្ទាត់ ៣បន្ទាត់ និង ៤បន្ទាត់ ។ នៅក្នុងជំពូកនេះ ទាំងមូលនិយាយពីការ ដែលស្តេចដាវីឌអធិស្ឋានសម្រាប់លោកផ្ទាល់ (ខ.១–២) និងសម្រាប់ក្រុងស៊ីយ៉ូន (ខ.១៨–១៩) ។ ផាសុខភាពរបស់ស្តេច និងអ្នកក្នុងក្រុងងើបឡើង ហើយក៏ដួលចុះជាមួយគ្នា (សូមមើល ២៨:៨ ការពន្យល់ ៣:៨) ។

**៥១ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *នៅពេល* នៅពេលណានោះ សូមមើល ២សយ ១១:១–១២:២៥ និងការពន្យល់ក្នុង ដទ ៣ ត្រង់ចំណងជើង ។

**៥១:១–២** នៅក្នុងខនេះ អ្នកនិពន្ធសូមឱ្យព្រះយេហូវ៉ាទ្រង់បានផ្តល់សេចក្តីសប្បុរសរបស់ទ្រង់មកដល់គាត់ (សូមមើល លក ១៨:១៣) ។ មានការគួរឱ្យកត់សម្គាល់ថា នៅក្នុងព្រះគម្ពីរមានសទីសន័យជាច្រើន ដូចជាពាក្យថា សេចក្តីសប្បុរស សេចក្តីស្មោះត្រង់ សេចក្តីមេត្តាករុណា ។ ពាក្យថាលុបលាងសម្អាត គឺជាសទីសន័យនឹងគ្នា ហើយពាក្យថា សេចក្តីរំលង កំហុសនិងអំពើបាបក៏ជាសទីសន័យនឹងគ្នាផងដែរ ។

**៥១:១** *សេចក្តីសប្បុរស* មើលការពន្យល់ ៦:៤ ។ *លុប* សូមមើល ខ.៩ ។ អត្ថន័យ និងរូបភាពនៅក្នុងឃ្លានេះ គឺបានដកស្រង់ចេញពីសិលា ប៉ាពីរ៉ាស់ (មើលការពន្យល់ ៩:៥) ដែលក្នុងនោះបាននិយាយពីការដែលព្រះយេហូវ៉ាទ្រង់បានកត់ចុះទង្វើរជាច្រើន ដែលស្តេចដាវីឌបានធ្វើ ។ ឃ្លាដែលអ្នកនិពន្ធនិយាយថា សូម"លុបសេចក្តីរំលង" នោះគឺចង់បង្ហាញថា ព្រះនៃយើងទ្រង់គឺជាព្រះនៃការអត់ទោស (មើល យរ ១៨:២៣ អស ៤៣:២៥) ។ សម្រាប់ការដែលព្រះអង្គទ្រង់បានកត់ចុះ គឺព្រឹត្តិការណ៍ផ្សេងៗនៅក្នុងនគររបស់ទ្រង់នៅអ្វីដែលស្តេចផែនដីបានធ្វើ មើល ៥៦:៨ និងការពន្យល់ ៨៧:៦ ១៣០:៣ ១៣៩:១៦ និងការពន្យល់ នហ ១៣:១៤ ដយ ៧:១០ នក ៣២:៣២–៣៣ ។

**៥១:២** សូមមើល ខ.៧ ។ *លាង* គឺដូចជាលាងសម្លៀកបំពាក់ដែលប្រឡាក់ដែរ ។ *សំអាត* នៅក្នុងឃ្លានេះគឺចង់មានន័យថា សូមឱ្យទូលបង្គំបានស្អាតនៅក្នុងព្រះនេត្ររបស់ទ្រង់ (សូមមើល លវ ១១:៣២) ។

**៥១:៣–៦** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានសារភាពពីកំហុសឆ្គងគាត់ទាំងប៉ុន្មានទៅចំពោះព្រះអម្ចាស់ (សូមធៀបនឹង សភ ២៨:១៣ ១យហ ១:៩) ។

**៥១:៣** *នៅចំពោះមុខទូលបង្គំ* នៅក្នុងឃ្លានេះចង់និយាយថា អំពើបាបរបស់ទូលបង្គំគឺមាននៅក្នុងចិត្តទូលបង្គំជានិច្ច ។

**៥១:៤** *ទូលបង្គំបានធ្វើបាបនឹងទ្រង់ហើយ . . . ១ព្រះអង្គ* នៅក្នុងឃ្លានេះ ស្តេចដាវីឌទ្រង់បានទទួលស្គាល់ថា គ្រប់ទាំងអំពើបាបដែលទ្រង់បានធ្វើនោះ គឺសុទ្ធតែទាស់នឹងបំណងព្រះហឫទ័យរបស់ព្រះអង្គ (មើល ២សយ ១២:១៣ ហើយធៀបនឹង លប ២០:៦ ៣៩:៩ លក ១៥:១៨) ។ ស្តេចដាវីឌទ្រង់បានប្រព្រឹត្តល្មើសនឹងសេចក្តីសញ្ញាដ៏ពិសេស ដែលបានតាំងសញ្ញាជាមួយព្រះអម្ចាស់ (មើល នក ២០:១៣–១៤,១៧) ។ *ក្នុងកាលដែលទ្រង់មានបន្ទូល . . . ក្នុងកាលដែលទ្រង់ជំនុំជំរះ* ព្រះអម្ចាស់ព្រះយេហូវ៉ាទ្រង់បានធ្វើការទាំងអស់នេះតាមរយៈហោរាណាថាន (មើល ២សយ ១២:៧–១២) ។ សូមមើលការនេះក្នុងសញ្ញាថ្មី គឺក្នុង រម ៣:៤ ។

**៥១:៥** នៅក្នុងខនេះ អ្នកនិពន្ធមិនអាចនឹងនិយាយថា ក្នុងជីវិតរបស់គាត់កម្រ

ហើយម្តាយទូលបង្គំបានមានទំងន់បង្កើតទូលបង្គំនៅក្នុង
អំពើបាបដែរ
៦ មើល ទ្រង់ប្រាថ្នាចង់បានសេចក្តីពិតនៅចំណែកខាងក្នុង
ហើយគឺនៅទីលាក់កំបាំងខាងក្នុង[ណ]
ដែលទ្រង់នឹងធ្វើឱ្យទូលបង្គំស្គាល់ប្រាជ្ញា[ត]ដែរ
៧ សូមជិរះ[ថ]ទូលបង្គំដោយមែកហ៊ីសុប[ទ] នោះទូលបង្គំនឹងបាន
ជ្រះស្អាត សូមដុសលាងទូលបង្គំ
នោះនឹងបានសជាងហិមៈ[ធ]
៨ សូមឱ្យទូលបង្គំបានឮសេចក្តីអំណរ និងសេចក្តីរីករាយ[ន]
នោះអស់ទាំងឆ្អឹង[ប]ដែលទ្រង់បានបំបាក់បំបែកនឹងបាន
អរសប្បាយវិញ

**៥១:៦** ណ យប ៩:៤ ៣៤:៣២ ត ទដ ១១៩:៦៦ ១៤៣:១០ **៥១:៧** ថ អស ៤:៤ អគ ៣៦:២៥ សក ១៣:១ ទ នក ១២:២២ ជន ១៩:៦ ហព ៩:១៩ ធ អស ១:១៨ ៤៣:២៥ ៤៤:២២ **៥១:៨** ន អស ៣៥:១០ យរ ៣៣:១១ យអ ១:១៦ ប នក ១២:៤៦

៩ សូមបាំងព្រះភក្ត្រទ្រង់ចេញពីអំពើបាប[ផ]របស់ទូលបង្គំ
ហើយលុប[ព]គ្រប់ទាំងអំពើទុច្ចរិតរបស់ទូលបង្គំចេញ
១០ ឱព្រះអង្គអើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ[ភ]
ហើយកែវិញ្ញាណក្នុងទូលបង្គំឱ្យត្រឹមត្រូវឡើង[ម]
១១ សូមកុំចោលទូលបង្គំ[យ]ចេញពីចំពោះ[រ]ទ្រង់
ហើយកុំដកយកព្រះវិញ្ញាណបរិសុទ្ធ[ល]របស់ទ្រង់ចេញពី
ទូលបង្គំឡើយ

**៥១:៩** ផ យរ ១៦:១៧ សក ៤:១០ ព ២សយ ១២:១៣ **៥១:១០** ភ ទដ ២៤:៤ ៧៨:៧ មថ ៥:៨ កច ១៥:៩ ម អគ ១៨:៣១ ៣៦:២៦ **៥១:១១** យ ទដ ២៧:៩ ៧១:៩ ១៣៨:៨ រ លប ៤:១៤ នក ៣៣:១៥ ល ទដ ១០៦:៣៣ អស ៦៣:១០ អភ ៤:៣០

នឹងប្រព្រឹត្តបាបនោះឡើយ ។ អំពើបាបទាំងនោះគឺបានកើតចេញតាំង "ចំណែកខាងក្នុង"(មើល ខ.៦) របស់គាត់តាំងពីកំណើតមកម៉្លេះ (មើល ៥៨:៣ លប ៨:២១ ធៀបនឹង យហ ៩:៣៤ អភ ២:៣) ។ សកម្មភាពប្រហាក់ប្រហែលគ្នានេះ មាននិយាយនៅក្នុង យប ១៤:៤ ១៥:១៤ ២៥:៤–៦ តែមានហេតុផលនៃជីវិតខុសគ្នា ។

**៥១:៦** នៅក្នុងខនេះ មានការផ្ទុយគ្នាយ៉ាងខ្លាំងបំផុតពីអ្វីដែលព្រះចង់បានពីស្តេចដាវីឌ និងអ្វីដែលស្តេចដាវីឌទ្រង់បានធ្វើ ។ អ្វីដែលស្តេចដាវីឌបានធ្វើគឺជាការផ្ទុយទាំងស្រុងពីអ្វីដែលព្រះចង់បានពីគាត់ អ្វីដែលព្រះអម្ចាស់ទ្រង់បង្រៀនគាត់នៅក្នុង "ទីលាក់កំបាំង" ប៉ុន្តែគាត់គ្រាន់តែដឹងថា សេចក្តី "ប្រាថ្នា" និងសេចក្តី "បង្រៀន"របស់ព្រះអម្ចាស់នោះ គឺជាសេចក្តីសង្ឃឹមរបស់គាត់ នេះហើយគឺជាអ្វីដែលគាត់បាននិយាយនៅក្នុង ខ.៧,១០ ។ *សេចក្តីពិត* គឺចង់និយាយសំដៅលើអំពើសិលធម៌ត្រឹមត្រូវ ។ *ចំណែកខាងក្នុង* មើល ១៣៩:១៣–១៦ យប ៣៨:៣៦ ។ *ប្រាជ្ញា* ពួកអ្នកដែលបណ្តោយខ្លួនប្រព្រឹត្តបាបម្តងហើយម្តងទៀត នោះជាពួកមនុស្សខ្លៅល្ងង់ ហើយពួកអ្នកដែលយកចិត្តទុកដាក់នឹងក្រឹត្យវិន័យរបស់ព្រះនោះ គឺជាអ្នកដែលមានប្រាជ្ញា (មើល ៣៧:៣០–៣១) ។ *ទីលាក់កំបាំង* គឺជាអាថ៌កំបាំងបំផុត ។

**៥១:៧–៩** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអធិស្ឋានសារជាថ្មីម្តងទៀតក្នុងការទូលសូមសេចក្តីប្រោសលោះមកពីព្រះអម្ចាស់ ។

**៥១:៧** *សូមជិរះទូលបង្គំ* តាមភាសារអក្សរសាស្ត្រគឺ "សូមកុំរាប់ទូលបង្គំជាអ្នកមានបាបឡើយ" ។ *ហ៊ីសុប* គេប្រើមែកហ៊ីសុបដើម្បីសំអាតអ្វីមួយ(សូមមើលការពន្យល់ នក ១២:២២) ។ *នោះទូលបង្គំនឹងបានស្អាត* នៅក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះ គឺមានន័យដូចគ្នានឹងពាក្យថា "លាង"ដែលនិយាយ ខ.២ ។ *សជាងហិមៈ* ស្តេចដាវីឌទ្រង់ត្រូវការឱ្យព្រះអង្គលាងសម្អាតបាបរបស់ទ្រង់ឱ្យដូចគ្នានឹងលាងសម្លៀកបំពាក់ដែលកខ្វក់ដែរ (មើលការពន្យល់ ខ.២) ប៉ុន្តែបើសិនជាព្រះ នោះគាត់នឹងបានទទួលការបន្សុទ្ធដែលមិនអាចនឹងថ្លែងបាន (មើល អស ១:១៨ ដយ ៧:៩ វវ ៧:១៤ ១៩:១៤) ។

**៥១:៨** *សូមឱ្យទូលបង្គំបានឮសេចក្តីអំណរ* នៅក្នុងឃ្លានេះចង់និយាយថា សូមហ៊ុំព័ទ្ធទូលបង្គំដោយសេចក្តីអំណរ (មើល ៣២:៧ និងការពន្យល់ និងមើល ៣៥:២៧) ឬថា សូមឱ្យទូលបង្គំបានស្តាប់ឮការថ្លែងទំនាយរបស់ពួកហោរាពីការអត់ទោស ដែលនឹងធ្វើឱ្យទូលបង្គំមានអំណរ (សូមមើល ២សយ ១២:១៣) ។ *អស់ទាំងឆ្អឹង* សូមមើលការពន្យល់ ៦:២ ។

**៥១:៩** *សូមបាំងព្រះភក្ត្រទ្រង់* គឺមានន័យថា សូមបាំងអំពើបាបដែល "នៅចំពោះមុខទូលបង្គំជានិច្ច"(ខ.៣) ។ *លុប* សូមមើលការពន្យល់ ខ.១ ។

**៥១:១០–១២** នៅក្នុងខទាំងនេះ ស្តេចដាវីឌទ្រង់បានអធិស្ឋានសូមឱ្យព្រះអង្គទ្រង់បានបង្កើតចិត្តឱ្យបានបរិសុទ្ធ សូមឱ្យវិញ្ញាណបានស្មោះត្រង់ និងឱ្យមានចិត្តក្នុងការបម្រើរដល់ព្រះអម្ចាស់ ។ ការនេះអាចនឹងកើតឡើងចំពោះគាត់បាន ដរាបណាព្រះអម្ចាស់ទ្រង់មិនបដិសេធន៍គាត់ ហើយអនុញ្ញាតឱ្យព្រះអង្គទ្រង់បានដកព្រះវិញ្ញាណបរិសុទ្ធចេញពីគាត់ ។ បើសិនជាស្តេចដាវីឌព្រមអនុញ្ញាត នោះព្រះទ្រង់នឹងប្រទានសេចក្តីអំណរ ធ្វើឱ្យវិញ្ញាណរបស់គាត់បានអំណរឡើង ។

**៥១:១០** *សូមបង្កើត* ស្តេចដាវីឌសូមឱ្យព្រះអម្ចាស់បានបង្កើតចិត្តរបស់ទ្រង់ជាថ្មីឡើងដែលមិនអាចមើលឃើញ ដូចជាអ្វីដែលមាននៅពេលនេះឡើយ (ខ.៥) ហើយមានតែព្រះអម្ចាស់ប៉ុណ្ណោះដែលអាចរចនា ឬបង្កើតការនេះបាន (សូមមើល លប ១:១ និងការពន្យល់ អស ៦៥:១៧ យរ ៣១:២២) ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**៥១:១១** នៅក្នុងខនេះ មានសេចក្តីសំណូម២ដែលសំខាន់ (សូមមើល ១៣៩:៧ អគ ៣៩:២៩) ។ សេចក្តីអធិស្ឋានរបស់ស្តេចដាវីឌ បានធ្វើឱ្យយើងនឹកឃើញពីការដែលព្រះអម្ចាស់ទ្រង់បានបដិសេធន៍ចំពោះស្តេចសូល (សូមមើល ១សយ ១៦:១,១៤ ២សយ ៧:១៤) ហើយទ្រង់ក៏បានសូមកុំឱ្យព្រះអម្ចាស់ទ្រង់ បានដកវិញ្ញាណចេញពីទ្រង់ដែរ ពីព្រោះទ្រង់គឺជាអ្នកដែលបានតែងតាំងដល់គាត់ឱ្យធ្វើជាមន្ត្រីរបស់ទ្រង់ (សូមមើល ១សយ ១៦:១៣ ហើយធៀបជាមួយ ២សយ ២៣:១–២) ។ *ព្រះវិញ្ញាបរិសុទ្ធ* ពាក្យនេះនៅក្នុងសញ្ញាចាស់មានតែកន្លែងនេះ និងក្នុង អស ៦៣:១០–១១ ។ តាមរយៈព្រះវិញ្ញាណនៃទ្រង់ នោះធ្វើឱ្យព្រះអង្គទ្រង់ទទួលជោគជ័យក្នុងការបង្កើតរបស់ទ្រង់ (សូមមើល ១០៤:៣០ លប ១៣២ យប ៣៣:៤) និងសេចក្តីប្រោសលោះ (សូមមើល អស ៣២:១៥ ៤៤:៣ ៦៣:១១,១៤ ហក ២:៥) ផ្តល់ការងារដល់អ្នកបម្រើរបស់ទ្រង់ (សូមមើល នក ៣១:៣ ជន ១១:២៩ ពច ៣:១០ ១សយ ១០:៦ ១៦:១៣ អស ១១:២ ៤២:១) បង្រៀនដល់ពួកហោរារបស់ទ្រង់ (ជន ២៤:២–៣ ២សយ ២៣:២ នហ ៩:៣០ អស ៥៩:២១

១២ សូមឱ្យទូលបង្គំមានចិត្តរីករាយចំពោះសេចក្ដីសង្គ្រោះ
នៃទ្រង់ឡើងវិញ[វ] ហើយទប់ទល់ទូលបង្គំ[ស] ដោយព្រះ
វិញ្ញាណដ៏សន្ធានៃទ្រង់[ហ]
១៣ នោះទូលបង្គំនឹងបង្រៀនពីអស់ទាំងផ្លូវ[ឡ]នៃទ្រង់ដល់
មនុស្សដែលប្រព្រឹត្តអំពើរំលងដូច្នេះ
និងមានមនុស្សបាប[អ]ប្រែចិត្តត្រឡប់មកឯទ្រង់[ក]
១៤ ឱព្រះអង្គ ជាព្រះដ៏ជួយសង្គ្រោះទូលបង្គំ[ខ]អើយ
សូមដោះទូលបង្គំ[គ] ឱ្យរួចពីទោសកំចាយឈាម[ឃ]
នោះអណ្ដាតទូលបង្គំនឹងបន្លឺសំឡេង
ច្រៀងពីសេចក្ដីសុចរិតរបស់ទ្រង់[ង]
១៥ ឱព្រះអម្ចាស់អើយ សូមបើកបបូរមាត់[ច]ទូលបង្គំ
នោះមាត់ទូលបង្គំនឹងបានប្រកាសប្រាប់ពីសេចក្ដីសរសើរ
របស់ទ្រង់
១៦ ដ្បិតទ្រង់មិនសព្វព្រះហឫទ័យនឹងយញ្ញបូជាទេ[ឆ]
បើសព្វព្រះហឫទ័យវិញនោះទូលបង្គំនឹងបានថ្វាយហើយ
ទ្រង់ក៏មិនពេញព្រះហឫទ័យនឹងដង្វាយដុតដែរ
១៧ ឯដង្វាយ[ជ]ដែលគួរថ្វាយដល់ព្រះនោះគឺជាវិញ្ញាណខ្ទេច
ខ្ទាំ ឱព្រះអង្គអើយ ទ្រង់មិនមើលងាយចំពោះចិត្តខ្ទេច
ខ្ទាំ[ឈ] ហើយទន់ទាបឡើយ ។
១៨ សូមទ្រង់ប្រព្រឹត្តដោយសប្បុរស ដល់ក្រុងស៊ីយ៉ូន[ញ]
តាមបំណងព្រះហឫទ័យដ៏ល្អរបស់ទ្រង់
សូមសង់កំផែងក្រុងយេរូសាឡិមឡើង[ដ]
១៩ នោះទ្រង់នឹងសព្វព្រះហឫទ័យដោយដង្វាយនៃសេចក្ដី
សុចរិត[ឋ] គឺជាដង្វាយដុតនឹងយញ្ញបូជា[ឌ]ថ្វាយទាំងមូលផង
ដូច្នេះគេនឹងថ្វាយគោឈ្មោល[ឍ]នៅលើអាសនានៃទ្រង់ ។

ទំនុករបស់ស្ដេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង
នៅវេលាដែលដូអេក ជាសាសន៍អេដំ[ក] មកទូលស្ដេចសូលថា
ដាវីឌបានចូរទៅក្នុងផ្ទះអ័ហ៊ីម៉ាលេក ជាសេចក្ដីបង្រៀន ។

**៥២** ឱមនុស្សខ្លាំងពូកែអើយ
ហេតុអ្វីបានជាអួតខ្លួន[ខ]ពីអំពើអាក្រក់ដូច្នេះ[គ]

**៥១:១២** វ យប ៣៣:២៦ ស ទដ ១៥:៣៥ ហ ទដ ១១០:៣ **៥១:១៣** ឡ នក ៣៣:១៣ កច ៩:២១–២២ អ ទដ ១:១ ក យប ៣៣:២៧ **៥១:១៤** ខ ទដ ៣៩:៦ គ ២សយ ១២:៩ ឃ ទដ ២៥:៥ ៦៨:២០ ៨៨:១ ង ទដ ៥:៨ ៣៥:២៨ ៧១:១៥ **៥១:១៥** ច នក ៤:១៥ **៥១:១៦** ឆ ១សយ ១៥:២២ **៥១:១៧** ជ សភ ១៥:៨ ហក ២:១៤ ឈ មថ ១១:២៩ **៥១:១៨** ញ ទដ ១០២:១៦ ១៤៧:២ អស ១៤:៣២ ៥១:៣ សក ១:១៦–១៧ ដ ទដ ៦៩:៣៥ អស ៤៤:២៦ **៥១:១៩** ឋ ចទ ៣៣:១៩ ឌ ទដ ៦៦:១៣ ៩៦:៨ យរ ១៧:២៦ ឍ ៦៦:១៥ **៥២:ចំណងជើង** ក ១សយ ២១:៧ ២២:៩ **៥២:១** ខ ទដ ១០:៣ ៩៤:៤ គ ទដ ៤៤:៨

៦១:១ អគ ១១:៥ មីក ៣:៨ សក ៧:១២) និងដឹកនាំការងាររបស់ពួកគេ (១ពវ ១៨:១២ ២ពវ ២:១៦ អស ៤៨:១៦ អគ ២:២ ៣:១៤) ។ ព្រះវិញ្ញាណនៃព្រះ គឺជាអ្នកដែលបាន "បង្កើតចិត្ត . . . កែវិញ្ញាណ"ដល់រាស្ត្ររបស់ទ្រង់ ដើម្បីឱ្យពួកគេរស់នៅតាម "បំណងព្រះហឫទ័យរបស់ទ្រង់" (សូមមើល អគ ៣៦:២៦–២៧ និង យរ ២៤:៧ ៣២:៣៩ អគ ១១:១៩ ១៨:៣១) ។

**៥១:១៣–១៧** នៅក្នុងខទាំងនេះ និយាយពីការប្ដេជ្ញាចិត្ត និងសច្ចាថានឹងលើកតម្កើងព្រះនាមទ្រង់ (សូមមើលការពន្យល់ ៧:១៧) ។

**៥១:១៣** នៅក្នុងខនេះចង់និយាយថា ការអធិស្ឋានរបស់គាត់ក្នុងការសូមការអត់ទោស និងសូមការលាងជម្រះមកពីព្រះអម្ចាស់ ត្រូវតែមានសេចក្ដីបង្រៀនពីផ្លូវរបស់ព្រះដល់ពួកអ្នកដែល "ប្រព្រឹត្តរំលង" និងពួកដែលបានធ្វើ"បាប"(សូមមើល ខ.៣) ។ អ្នកនិពន្ធគាត់ប្ដេជ្ញាថា នឹងបង្រៀនមនុស្សឯទៀតឱ្យចេះសរសើរតម្កើងព្រះអម្ចាស់ឱ្យដូចគ្នានឹង ការប្ដេជ្ញាចិត្តរបស់អ្នកនិពន្ធ ទដ ៣៤ ដែរ(សូមមើលការពន្យល់ ៣២:៨–១០) ។ *ផ្លូវរបស់ទ្រង់* សូមមើល ២៥:៤ និងការពន្យល់ ។

**៥១:១៤** នៅក្នុងខ.នេះចង់និយាយថា បើសិនជាព្រះអម្ចាស់ទ្រង់អត់ទោសដល់គាត់ នោះព្រះអង្គក៏ទទួលបានការសរសើរដំកើងដែរ ។ *សេចក្ដីសុចរិត* សូមមើលការពន្យល់ ៤:១ ។

**៥១:១៥** *សូមបើកបបូរមាត់ទូលបង្គំ* គឺមានន័យថា សូមឱ្យព្រះអង្គទ្រង់អត់ទោស និងលាងសំអាតទូលបង្គំ ។

**៥១:១៦** សូមមើលការពន្យល់ ៤០:៦ ។

**៥១:១៧** *វិញ្ញាណខ្ទេចខ្ទាំ* នៅក្នុងឃ្លានេះចង់និយាយថា អ្វីដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យជាងយញ្ញាបូជានោះគឺជាការបន្ទាបខ្លួន ហើយចេះអំពាវនាវរកព្រះអង្គនៅពេលកើតមានបញ្ហា និងចេះអធិស្ឋានសូមសេចក្ដីមេត្តាករុណាមកពីព្រះ ដើម្បីឱ្យព្រះអង្គអត់ទោសនូវអំពើបាបដែលបានប្រព្រឹត្ត (សូមមើល ៥០:៧–១៥ និងការពន្យល់ និងក្នុង ៣៤:១៧–១៨) ។

**៥១:១៨–១៩** នៅក្នុងខនេះ អ្នកនិពន្ធបានអធិស្ឋានសម្រាប់ក្រុងស៊ីយ៉ូន (សូមមើលការពន្យល់ ៣:៨) ។

**៥១:១៩** *ដង្វាយនៃសេចក្ដីសុចរិត* ដង្វាយនៃសេចក្ដីសុចរិត គឺជាដង្វាយដែលព្រះទ្រង់សព្វព្រះហឫទ័យ ។ ដង្វាយដែលនិយាយនៅទីនេះ គឺរាប់ទាំងការសរសើរតម្កើង ចំពោះសេចក្ដីមេត្តាករុណារបស់ព្រះអង្គថែមទៀត (សូមមើល ៥០:១៤–១៥ និងការពន្យល់) ។

**ទំនុកដំកើងជំពូក ៥២** នៅក្នុងជំពូកនេះចង់និយាយថា នៅពេលអ្នកនិពន្ធគាត់ជួបប្រទះការវាយប្រហារពួកមនុស្សអាក្រក់ ដែលជាខ្មាំងសត្រូវរបស់គាត់ បានធ្វើឱ្យគាត់មានការកោតខ្លាចចំពោះព្រះអម្ចាស់ព្រះយេហូវ៉ា ។ ស្ដេចដាវីឌទ្រង់បានឈរចំពោះវត្តមានរបស់ព្រះអម្ចាស់ និងនៅលើប៉មដ៏ខ្ពស់ដែលទ្រង់យកជាទីពំនាក់ ហើយបានមានព្រះបន្ទូល (ដូចគ្នានឹងការថ្លែងទំនាយរបស់ពួកហោរាដែលនិយាយនៅក្នុង អស ២២:១៥–១៩ ដែរ) ទៅកាន់ពួកខ្មាំងសត្រូវទាំងប៉ុន្មាន ដែលធ្វើការបៀតបៀននគររបស់ទ្រង់ ។ ទោះបីជំពូកនេះមិនមែនជាទំនុកដំកើង បែបប្រាជ្ញាក៏ដោយ ក៏វាមានលក្ខណៈដូចគ្នានឹងទំនុកដំកើងជំពូក ៤៩ ដែរ (សូមមើលសេចក្ដីផ្ដើម ទដ ៤៩–៥៣ និងសេចក្ដីផ្ដើម ទដ ៤៩) ។ នៅក្នុងជំពូកនេះបាន ការពិពណ៌នាដ៏វែងអន្លាយ នៃទម្រង់ខ្មាំងសត្រូវរបស់ស្ដេចដាវីឌ ដែលផ្ទុយនឹងជំពូក៥១ ដែលនិយាយពីព្រលឹងវិញ្ញាណ ។ សូមមើលការនិយាយរបស់ដាវីឌចំពោះកូលីយ៉ាតក្នុង ១សយ ២២:៩–១០ ។

**៥២:២ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ជាសេចក្ដីបង្រៀន* សូមមើលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។ *វេលា* សូមមើលការពន្យល់ ទដ ៣ ត្រង់ចំណងជើង

សេចក្ដីសប្បុរសនៃព្រះស្ថិតស្ថេរនៅជាដរាប

២ ឯអណ្ដាតឯង នោះបង្កើតសេចក្ដីអាក្រក់[ឃ]

ទាំងប្រព្រឹត្តឧបាយឆបោក[ង] ដូចជាកាំបិតកោរយ៉ាងមុត[ច]

៣ ឯងស្រឡាញ់សេចក្ដីអាក្រក់[ឆ]ជាជាងសេចក្ដីល្អ

និងការភូតភរ[ជ]ជាជាងការសុចរិត ។ –បង្អង់

៤ ឱអណ្ដាតកំភូតអើយ[ឈ]

ឯងស្រឡាញ់គ្រប់អស់ទាំងពាក្យដែលនាំឱ្យវិនាសបង់

៥ ព្រះទ្រង់នឹងបំផ្លាញឯងអស់កល្បជានិច្ច

គឺទ្រង់នឹងចាប់យកឯងទៅ និងកន្ត្រាក់[ញ]ឯងចេញពីទីលំនៅ

ហើយរំលើង[ដ]ឯងផុតពីស្ថានរបស់មនុស្សរស់ចេញ[ឋ] ។

–បង្អង់

៦ មនុស្សសុចរិតនឹងឃើញដែរ

ហើយនិងកោតខ្លាចគេនឹងសើចឡក[ឌ]ឱ្យ ដោយពាក្យថា

៧ មើល នេះនែបុរសដែលមិនបានយកព្រះជាទីពឹង[ឍ]

គឺបានទុកចិត្តនឹងទ្រព្យសម្បត្តិខ្លួនដ៏មានជាបរិបូរ[ណ]

ហើយបានចំរើនកំឡាំង ដោយការអាក្រក់របស់ខ្លួន

៨ ឯខ្ញុំវិញ ខ្ញុំដូចជាដើមអូលីវខៀវខ្ចី[ត] នៅក្នុងដំណាក់ព្រះ

ខ្ញុំទុកចិត្ត[ថ]នឹងសេចក្ដីសប្បុរសនៃព្រះជានិច្ច

៩ ទូលបង្គំនឹងសរសើរដល់ទ្រង់ជាដរាប[ទ] ដោយព្រោះទ្រង់

បានសំរេចការនោះ

ហើយទូលបង្គំនឹងសង្ឃឹម[ធ]ដល់ព្រះនាមទ្រង់

ដ្បិតព្រះនាមទ្រង់ល្អវិសេស[ន]

នៅចំពោះពួកអ្នកបរិសុទ្ធរបស់ទ្រង់[ប] ។

*៥៣:១–៦ – ទដ ១៤:១–៧*

ទំនុកជាសេចក្ដីបង្រៀនរបស់ស្ដេចដាវីឌ

ដែលទ្រង់លើកសំរាប់មេភ្លេង ត្រូវលេងដោយខ្លុយ ។

**៥៣** មនុស្សល្ងង់ខ្លៅ[ក]បានគិតក្នុងចិត្តថា គ្មានព្រះឡើយ[ខ]

គេសុទ្ធតែជាមនុស្សខូចអាក្រក់

**៥២:២** ឃ ទដ ៥:៩ ង ទដ ៥០:១៩ ច ជន ៦:៥ **៥២:៣** ឆ នក ១០:១០ ១សយ ១២:២៥ អម ៥:១៤–១៥ យហ ៣:២០ ជ ទដ ៥៨:៣ យរ ៩:៥ វវ ២១:៨ **៥២:៤** ឈ ទដ ៥:៩ ១០:៧ ១០៩:២ ១២០:២,៣ សភ ១០:៣១ ១២:១៩ **៥២:៥** ញ ចទ ២៩:២៨ យប ៤០:១២ អស ២២:១៩ អគ ១៧:២៤ ដ ចទ ២៨:៦៤ ឋ យប ២៨:១៣ **៥២:៦** ឌ យប ២២:១៩ **៥២:៧** ឍ ២សយ ២២:៣ ណ ទដ ៤៩:៦ សភ ១១:២៨ មក ១០:២៣ **៥២:៨** ត ទដ ១:៣ វវ ១១:៤ ថ ទដ ៦:៤ ១៣:៥ **៥២:៩** ទ ទដ ៣០:១២ ធ យប ៧:៦ ទដ ២៥:៣ ន ទដ ៥៤:៦ ប ចទ ៧:៦ ទដ ១៦:៣ **៥៣:១** ក ទដ ៧៤:២២ ១០៧:១៧ សភ ១០:២៣ ខ ទដ ១០:៤

សូមមើលហេតុការនេះក្នុង ១ សយ ២២:៩–១០ ។

**៥២:១–៤** នៅក្នុងខទាំងនេះ គឺនិយាយពីការដាក់ផ្ដន់ទារទោសចំពោះពួកខ្មាំងសត្រូវ ។

**៥២:១** *ហេតុអ្វី* មើល ៥០:១៦ អស ៣:១៥ ។ *អួត* គឺអួតដោយពីការប្រព្រឹត្ត និងដោយពាក្យសម្ដី (មើល ៧៥:៤–៥) ។ *មនុស្សខ្លាំងពូកែ* មនុស្សនេះគេគិតថា គេជាអ្នកខ្លាំងពូកែដោយខ្លួនឯង (សូមមើល អស ២២:១៧) ។

**៥២:២** *អណ្ដាតឯង* សូមមើល ខ.៤ និងការពន្យល់ ៥:៩ ។

**៥២:៣** នៅក្នុងខនេះចង់និយាយថា ការប្រព្រឹត្តរបស់អ្នកទាំងអស់ គឺសុទ្ធតែអាក្រក់ ។ *ស្រឡាញ់* មានន័យថា ចូលចិត្ត ។

**៥២:៤** *អណ្ដាត* សូមមើលការពន្យល់ ខ.២ ។

**៥២:៥–៧** នៅក្នុងខនេះ និយាយពីចុងបញ្ចប់របស់ពួកខ្មាំងសត្រូវ ។ នោះព្រះអម្ចាស់ទ្រង់នឹងសម្លាប់ឯង ហើយមនុស្សសុចរិតនឹងមើលងាយដល់ឯង ។

**៥២:៥** នៅក្នុងខនេះមានរូបភាព៣គឺ "បំផ្លាញឯង" "ចាប់យកឯងទៅ" និង "កន្ត្រាក់" ។ ចុងបញ្ចប់របស់ពួកខ្មាំងសត្រូវនឹងដូចគ្នាចុងបញ្ចប់របស់ពួកមនុស្សខ្លៅល្ងង់ដែលនិយាយនៅក្នុង ទដ ៤៩ ។ *ចេញពីលំនៅ* សូមមើល យប ១៨:១៤ ។ *ចាប់យកឯង* ផ្ទុយពីធ្វីដែលនិយាយ ខ.៨ ។

**៥២:៦** *មនុស្សសុចរិត* សូមមើលការពន្យល់ ១:៥ ។ *កោតខ្លាច* គឺដោយព្រោះគេបានឃើញពីការដួលចុះរបស់ឯង (សូមមើល ៤០:៣ និង ការពន្យល់ ៣៤:៨–១៤) ។

**៥២:៧** សូមមើល ទដ ៤៩ ។

**៥២:៨–៩** នៅក្នុងខទាំងនេះចង់និយាយថា អ្នកដែលផ្ដល់សេចក្ដីសុខដល់ស្ដេចដាវីឌ គឺជាព្រះ ។

**៥២:៨** *ខ្ញុំដូចជាដើមអូលីវ* ដូច្នេះឃ្លានេះចង់មានន័យថា គាត់អាចរស់នៅបានរាប់រយឆ្នាំដែលដូចនឹងដើមអូលីវដែលអាចរស់បានជាងរយឆ្នាំដែរ ។ *ខៀវខ្ចី* សូមមើល ១:៣ ។ ឃ្លានេះគឺចង់និយាយថា គាត់នឹងមិនត្រូវចាប់យកចេញឡើយ (ខ.៥) ។ *នៅក្នុងដំណាក់ព្រះ* ដើមអូលីវមិនដែលដាំក្នុងទីធ្លានៃព្រះវិហារនោះទេ ប៉ុន្តែឃ្លានេះគឺចង់និយាយថា ស្ដេចដាវីឌទ្រង់បានចូលមកដល់វិហារនៃព្រះ ហើយយកព្រះវិហារនោះធ្វើជាទីពំនាក់របស់គាត់ (មើល ១៥:១ ២៣:៦ ២៧:៤ ៦១:៤ និងការពន្យល់) ហើយជាកន្លែងដែលធ្វើឱ្យគាត់មានសុវត្ថិភាពដែរ (សូមមើល ២៧:៥ និងការពន្យល់) ។ *សេចក្ដីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**៥២:៩** នៅក្នុងខនេះអ្នកនិពន្ធគាត់បានសន្យាថា និងសរសើរតម្កើងដល់ព្រះអម្ចាស់ (សូមមើលការពន្យល់ ៧:១៧) ។ *ព្រះនាម* សូមមើលការពន្យល់ក្នុង ៥:១១ ។ *អ្នកបរិសុទ្ធ* សូមមើលការពន្យល់ ៤:៣ ។

**ទដ ៥៣** នៅក្នុងជំពូកនេះ គឺជាបន្ទាល់ដែលទាក់ទងទៅនឹងភាពល្ងង់ខ្លៅរបស់មនុស្សអាក្រក់ ។ ក្នុងជំពូកនេះវាមានលក្ខណៈដូចគ្នាខ្លះៗទៅនិង ទដ ១៤(សូមមើលសេចក្ដីផ្ដើមនៅទីនោះ) ។ ចំណុចចំបងដែលខុសគ្នារវាងព្រះគម្ពីរទំនុកដំកើងទាំង២នេះ គឺនៅទីនេះពាក្យថា "ព្រះ"ជំនួសឱ្យពាក្យថា "ព្រះយេហូវ៉ា"(សូមមើលការពន្យល់ ខ.៥) ។ បទនៃទំនុកដំកើងដើមប្រហែលមានការកែប្រែព្រឹត្តិការណ៍ដូចដែលមាននិយាយនៅក្នុង ២របា ២០ ព្រះគម្ពីរ ទដ ក្នុងជំពូកនេះមានតួនាទីជាអ្នកអធិប្បាយពីប្រភេទរបស់មនុស្សអាក្រក់ ដែលមាននិយាយនៅក្នុង ទដ ៤៩,៥២ (សូមមើលសេចក្ដី ផ្ដើម ទដ ៤៩–៥៣) ។

**៥៣ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ត្រង់ចំណងជើង ។ *ត្រូវលេងដោយ* មើលការពន្យល់ ទដ ៦ ត្រង់ចំណងជើង ។ *ខ្លុយ* វាជាឈ្មោះឧបករណ៍ភ្លេងមួយប្រភេទ (មើលការពន្យល់ ទដ ៩ ត្រង់ចំណងជើង) ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរ គេប្រើពាក្យនេះសំដៅលើ "ទុក្ខព្រួយ" ឬ "ជំងឺ"(មើល ទដ ៨៨ ត្រង់ចំណងជើង និងការពន្យល់នៅទីនេះ) ។ ប្រហែលឃ្លានៃភាសាហេព្រើរដែលប្រើនៅទីនេះចង់និយាយបង្ហាញថា អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង បានសរសេរជំពូក

ហើយបានប្រព្រឹត្តការទុច្ចរិតគួរស្អប់ខ្ពើម
ឥតមានអ្នកណាមួយដែលប្រព្រឹត្តល្អសោះ
២ព្រះទ្រង់បានទតមើលពីលើស្ថានសួគ៌[គ] ចំពោះពួកកូន
មនុស្ស ដើម្បីឱ្យបានជ្រាបថា មានអ្នកណាខ្លះដែលមាន
គំនិត[ឃ] គឺដែលស្វែងរកព្រះឬទេ[ង]
៣គ្រប់គ្នាបានវង្វេងចេញ
បានត្រឡប់ទៅជាស្មោកគ្រោកទាំងអស់
គ្មានអ្នកណាមួយដែលប្រព្រឹត្តល្អឡើយសូម្បីតែម្នាក់ក៏គ្មាន
ផង[ច]
៤ឯអស់អ្នកដែលប្រព្រឹត្តទុច្ចរិតដូច្នេះ តើគ្មានប្រាជ្ញាទេឬ
ជាពួកអ្នកដែលស៊ីរាស្ត្រអញ ដូចជាស៊ីអាហារ
ហើយមិនដែលអំពាវនាវដល់ព្រះឡើយ
៥យ៉ាងនោះ គេមានសេចក្ដីភ័យជាខ្លាំង
នៅកន្លែងដែលឥតមាន ហេតុគួរឱ្យភ័យផង[ឆ]
ដ្បិតព្រះទ្រង់បានកំចាត់កំចាយឆ្អឹង[ជ]
របស់ពួកអ្នកដែលបោះទ័ពទាស់នឹងឯង[ឈ]
ឯងបានធ្វើឱ្យគេអៀនខ្មាស[ញ]
ដោយព្រោះព្រះបានលះចោលគេហើយ[ដ]
៦ឱបើសិនជាសេចក្ដីសង្គ្រោះនៃសាសន៍អ៊ីស្រាអែលបាន
ចេញពីស៊ីយ៉ូនមកទៅអេះ
កាលណាព្រះទ្រង់នាំពួកឈ្លើយនៃរាស្ត្រទ្រង់មកវិញ
នោះយ៉ាកុបនឹងអរសប្បាយឡើងហើយអ៊ីស្រាអែលនឹងរីក
រាយសាទរ ។

**៥៣:២** គ ទដ ៣៣:១៣ ឃ ទដ ៨២:៥ យរ ៤:២២ ៨:៨ ង ២រប ១៥:២
**៥៣:៣** ច រម ៣:១០–១២
**៥៣:៥** ឆ លវ ២៦:១៧ ជ ២ពវ ២៣:១៤ ទដ ១៤១:៧ យរ ៨:១ អគ ៦:៥ ឈ ២ពវ ១៧:២០ ញ យប ៨:២២ ដ យរ ៦:៣០ ១៤:១៩ បទ ៥:២២
**៥៤:ចំណងជើង** ក ១សយ ២៣:១៩ ២៦:១
**៥៤:១** ខ ១សយ ២៤:១៥ គ ទដ ២០:១

ទំនុកជាសេចក្ដីបង្រៀន
របស់ស្ដេចដាវីឌ ដែលទ្រង់លើកនៅវេលាដែលពួក
ស៊ីភ[ក] បានមកទូលស្ដេចសូលថា ដាវីឌពួននៅជាមួយនឹងយើងខ្ញុំ
សំរាប់ឱ្យមេភ្លេងលេងដោយប្រដាប់មានខ្សែ ។

**៥៤** ឱព្រះអង្គអើយ សូមជួយសង្គ្រោះទូលបង្គំ[ខ]
ដោយសារព្រះនាមទ្រង់[គ] ហើយវិនិច្ឆ័យទូលបង្គំ

នេះឡើងក្នុងពេលដែលគាត់មានសេចក្ដីវេទនា គឺក្នុងគ្រាដែលពួកមនុស្សអាក្រក់គេមើលងាយដល់គាត់ (មើល ទដ ១០២ និងការពន្យល់ ៥:៩) ។ *ជាសេចក្ដីបង្រៀន* សូមមើលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។

**៥៣:១–៤** សូមមើលការពន្យល់ ១៤:១–៤ ។

**៥៣:៥** នៅក្នុងខនេះ វាមានសណ្ឋានខុសគ្នាជាមួយ ទដ ១៤:៥–៦ ទោះបីជាជាមូលដ្ឋានគ្រឹះនៃគម្ពីរនេះមានគំនិតខ្លះដូចគ្នាទៅនឹង ទដ ១៤:៥–៦ ក៏ដោយ គំនិតដែលដូចគ្នារវាងព្រះគម្ពីរទាំង២នេះ គឺព្រះអម្ចាស់ទ្រង់នឹងសង្កត់សង្កិនលើពួកអ្នកដែលគិតថា គ្មានព្រះដែលគេបានធ្វើទុក្ខដល់ប្រជារាស្ត្ររបស់ទ្រង់ ។ ទម្រង់កិរិយាស័ព្ទដែលប្រើនៅក្នុងជំពូកនេះ គឺជាកាលអតីកាល (ប្រហែលប្រើពណ៌នាពីការហិនវិនាសរបស់ពួកគេ) ។ *នៅកន្លែងដែលឥតមានហេតុគួរឱ្យភ័យ* នៅក្នុងកន្លែងនេះចង់និយាយថា គេមានអារម្មណ៍ថាពួកគេព្យាយាមផ្ដួលជនរងគ្រោះឱ្យភ័យខ្លាច នៅពេលណាពួកមនុស្សជាតិទាំងនោះនិយាយថាពួកគេមិនមានការបៀតបៀនអ្វីឡើយ ។ បណ្ដាសាររបស់ព្រះបានធ្លាក់ទៅលើពួកគេ ជាងទៅលើពួកអ៊ីស្រាអែលទៅទៀត (សូមមើលក្នុង លវ ២៦:៣៦–៣៧ ពច ៧:២១ ២ពវ ៣:២២–២៣ ៧:៦–៧ សភ ២៨:១) ។ *កំចាត់កំចាយឆ្អឹង* ព្រះអម្ចាស់ទ្រង់បានកំចាត់កំចាយឆ្អឹងគេនៅទីចម្បាំងដែលគេច្បាំងគ្នា ។ សាកសពរបស់គេនឹងនៅពាសពេញដីដូចជាអ្វីដែលគួឱ្យស្អប់ខ្ពើម (សូមមើលក្នុង អស ១៤:១៨–២០ យរ ៨:២ និងការពន្យល់) ។ *ព្រះបានលះចោលគេ* ព្រះនិងបោះបង់គេ ដូចគ្នានឹងអ្វីដែលពួកគេបានបោះបង់ចោលព្រះ ។

**៥៣:៦** សូមមើលការពន្យល់ក្នុង ១៤:៧ ។

**ទដ ៥៤–៦០** នៅក្នុងជំពូកទាំងនេះគឺជាចង្កោមនៃបទគម្ពីរទំនុកដំកើងទាំង៧ដែលអ្នកនិយាយពីការអធិស្ឋានជាលក្ខណៈបុគ្គល (ទដ ៥៤) និងអធិស្ឋានសម្រាប់សហគមន៍ (ទដ ៦០ និងសេចក្ដីផ្ដើម ទដ ៤២–៤៥) ។ ព្រះគម្ពីរទំនុកដំកើងដែលនិយាយនៅក្នុងចង្កោមនេះ (ទដ ៥៤) គឺមានកំណាព្យ៧ខ. ដែលជាគំរូក្នុងសំណង់ប្រយោគនេះ (សូមមើលសេចក្ដីផ្ដើមក្នុងជំពូកនេះ) ទំនុកដំកើងដែលបានបញ្ចប់ដោយ ដកស្រង់ពីការរអ៊ូរទាំដែលមាននៅក្នុង ទដ ៤៤ ដែលបាននិយាយថា ព្រះយេហូវ៉ាទ្រង់នឹង "បោះបង់" រាស្ត្ររបស់ទ្រង់មិនបានយាងទៅជាមួយ "ពួកពលទ័ព" របស់យើងខ្ញុំឡើយ (សូមមើល ៤៤:៩ ៦០:១០) ។ នៅពាក់កណ្ដាលនៃចង្កោមទំនុកដំកើង ៥៤–៦០ គឺជំពូក ៥៧ ដែលនិយាយពីសេចក្ដីអធិស្ឋាន ដែលមានកំណាព្យហេព្រើរ ១៤ ឃ្លាបែងចែកជា២ផ្នែកហើយក្នុង១ផ្នែកមាន៧ឃ្លា ហើយមានបន្ទរដែលនិយាយការចូលចំពោះព្រះដើម្បី "លើកដំកើងព្រះអម្ចាស់" ឡើង (សូមមើល ខ.៥,១១) ខ្ពស់លើអស់ទាំងរបស់ដែលទ្រង់បង្កើតមក តាមរយៈសេចក្ដីសង្គ្រោះរបស់ទ្រង់ ។ ទំនាក់ទំនងរវាងព្រះគម្ពីរ ទដ ៥៥ និង ៥៩ សូមមើលក្នុងសេចក្ដីផ្ដើមទំនុកដំកើងទាំង២នេះ ។ សូមមើលពីការផ្ទុយគ្នារវាងជំពូក ៥៦ និង ៥៨ សូមមើលសេចក្ដីផ្ដើម ទំនុកដំកើងទាំង២ជំពូកនោះ ។

**ទដ ៥៤** នៅក្នុងជំពូកនេះស្ដេចដាវីឌ ទ្រង់បានអធិស្ឋានសូមឱ្យព្រះអម្ចាស់ជួយរំដោះទ្រង់ឱ្យរួចពីខ្មាំងសត្រូវដែលចង់សម្លាប់ទ្រង់ ។ សេចក្ដីអធិស្ឋានក្នុងជំពូកនេះខ្លីដូចគ្នានឹង ទដ ជំពូក ៣,៤,១៣ ដែរ ប៉ុន្តែវាជាសេចក្ដីអធិស្ឋានដែលមានប្រជាប្រិយបំផុត ក្នុងទំនុកដំកើងដែលបានភ្ជាប់មកជាមួយនឹងមុខងារនៃសេចក្ដីអធិស្ឋានទាំងនេះ (សូមមើលក្នុងសេចក្ដីផ្ដើមត្រង់ប្រភេទនៃទំនុកដំកើង) ។ ចំណាប់ចុងចួនក្នុងសេចក្ដីអធិស្ឋាន គឺនិយាយពីសំរែកនៃសេចក្ដីអធិស្ឋានរបស់ស្ដេចដាវីឌ សូមឱ្យព្រះអង្គទ្រង់វិនិច្ឆ័យដល់ទ្រង់ (ខ.១) ហើយនិងការធានាអះអាងរបស់គាត់ថា គាត់នឹងមានជ័យជម្នះលើខ្មាំងសត្រូវរបស់ (ខ.៧) ។ ការនិយាយពីការទុកចិត្តចំពោះព្រះ (ខ.៤) នោះគឺជាចំណុចសំខាន់នៃសេចក្ដីអធិស្ឋាន (សូមមើល ៤២:៨ និងការពន្យល់ ៦:៦) ។ នៅដើមល្បះដំបូង និងចុងបញ្ចប់គឺមាន២ខដូចគ្នា (ហើយចំណុចទាំង២នេះនិយាយសំដៅលើ "ព្រះនាមរបស់ទ្រង់") ហើយ ខ.៣,៥ បានចែកដាច់ពីសេចក្ដីអធិស្ឋានត្រង់នេះ ។

**៥៤ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ៤ត្រង់ចំណងជើង ។ *ដោយប្រដាប់មានខ្សែ* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *សេចក្ដី*

ដោយឥទ្ធិឫទ្ធិរបស់ទ្រង់[ឃ]
២ ឱព្រះអង្គអើយ[ង] សូមស្តាប់សេចក្ដីដែលទូលបង្គំអធិស្ឋាន
សូមផ្ទៀងព្រះកាណ៌ស្តាប់វាចារបស់ទូលបង្គំផង
៣ ដ្បិតមានមនុស្សដទៃលើកគ្នាឡើងទាស់នឹងទូលបង្គំ[ច]
ហើយពួកមនុស្សច្រឡោត[ឆ]ស្វែងរកជីវិតទូលបង្គំ[ជ]
គេមិនបានតាំងព្រះនៅមុខគេឡើយ[ឈ] ។ –បង្អង់
៤ មើល ព្រះទ្រង់ជាជំនួយនៃទូលបង្គំ[ញ]
ព្រះអម្ចាស់ទ្រង់គង់ជាមួយនឹងពួកអ្នកដែលទប់ទល់ព្រលឹង
នៃទូលបង្គំ[ដ]
៥ ទ្រង់នឹងសង[ឋ]សេចក្ដីអាក្រក់របស់ពួកខ្មាំងសត្រូវទូលបង្គំ
ទៅលើគេវិញ
សូមបំផ្លាញគេដោយនូវសេចក្ដីស្មោះត្រង់[ឌ]របស់ទ្រង់
៦ ទូលបង្គំនឹងយកដង្វាយស្ម័គ្រពីចិត្ត[ឍ]មកបូជាថ្វាយដល់ទ្រង់
ឱព្រះយេហូវ៉ាអើយ
ទូលបង្គំនឹងសរសើរ[ណ]ដល់ព្រះនាមទ្រង់ ដ្បិត
ព្រះនាមទ្រង់ល្អវិសេស[ត]
៧ ពីព្រោះទ្រង់បានជួយទូលបង្គំ[ថ]ឱ្យរួចពីគ្រប់សេចក្ដីវេទនា
ភ្នែកទូលបង្គំបានឃើញបំណងចិត្តកើតដល់ពួកខ្មាំងសត្រូវ
របស់ទូលបង្គំហើយ[ទ] ។

ទំនុកជាសេចក្ដីបង្រៀនរបស់ស្តេចដាវីឌ
ដែលទ្រង់លើកសំរាប់មេភ្លេង ត្រូវលេងដោយប្រដាប់មានខ្សែ ។
**៥៥** ឱព្រះអង្គអើយ សូមផ្ទៀងព្រះកាណ៌
ស្តាប់សេចក្ដីដែលទូលបង្គំអធិស្ឋាន
សូមកុំលាក់ព្រះអង្គនឹងពាក្យដែលទូលបង្គំទូលអង្វរឡើយ[ក]
២ សូមសំកាំងស្តាប់ ហើយឆ្លើយមកទូលបង្គំផង[ខ]
ទូលបង្គំអន្ទះអន្ទែង
ហើយថ្ងូរដោយសេចក្ដីទុក្ខព្រួយរបស់ទូលបង្គំ[គ]
៣ គឺដោយព្រោះសំឡេងរបស់ខ្មាំងសត្រូវនឹងសេចក្ដីសង្កត់ញ
សង្កិនរបស់មនុស្សអាក្រក់
ដ្បិតគេទំលាក់ការទុច្ចរិតមកលើទូលបង្គំ[ឃ]
ព្រមទាំងបៀតបៀន[ង]ទូលបង្គំដោយសេចក្ដីកំហឹង[ច]

**៥៤:១** ឃ ២របា ២០:៦
**៥៤:២** ង ទដ ៤:១ ៥:១ ៥៥:១
**៥៤:៣** ច ទដ ៨៦:១៤ ឆ ទដ ១៨:៤៨ ១៤០:១,៤,១១ ជ ១សយ ២០:១ ឈ ទដ ៣៦:១
**៥៤:៤** ញ ១របា ៥:២០ ទដ ២០:២ ដ ទដ ១៨:៣៥
**៥៤:៥** ឋ ចទ ៣២:៣៥ ទដ ៩៤:២៣ សភ ២៤:១២ ឌ ទដ ៨៩:៤៩ អស ៤២:៣
**៥៤:៦** ឍ លវ ៧:១២,១៦ អរ ១:៤ ទដ ២៧:៦ ណ ទដ ៤៤:៨ ៦៩:៣០ ១៣៨:២ ១៤២:៧ ១៤៥:១ ត ទដ ៥២:៩
**៥៤:៧** ថ ទដ ៣៤:៦ ទ ទដ ៥៩:១០ ៩២:១១ ១១២:៨ ១១៨:៧ **៥៥:១** ក ទដ ២៧:៩ បទ ៣:៥៦ **៥៥:២** ខ ទដ ៤:១ គ ១សយ ១:១៥–១៦ ទដ ៧៧:៣ ៨៦:៦–៧ ១៤២:២ **៥៥:៣** ឃ ២សយ ១៦:៦–៨ ទដ ១៧:៩ ១៤៣:៣ ង ទដ ៤៤:១៦ ច ទដ ៧១:១១

*បង្រៀន* មើលការពន្យល់ ៣២ ត្រង់ចំណងជើង ។ *នៅវេលា* ឯពេលវេលាណានោះ មើល ១សយ ២៣:១៩ និងការពន្យល់ ដទ ៣ ត្រង់ចំណងជើង ។

**៥៤:១–២** នៅក្នុងខនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះអម្ចាស់វិនិច្ឆ័យចំពោះរឿងក្ដីរបស់គាត់ (មើល ទដ ១៧) ។

**៥៤:១** *ព្រះនាមទ្រង់* សូមមើល ខ.៦ និងការពន្យល់ ៥:១១ ។

**៥៤:៣** នៅក្នុងខនេះ គឺនិយាយពីមូលហេតុ ដែលនាំឱ្យគាត់ទាស់ប្រឆាំងចំពោះពួកខ្មាំងសត្រូវរបស់គាត់ ។ *គេមិនបានតាំងព្រះនៅមុខគេឡើយ* គឺដូចគ្នានឹងពួកមនុស្សដែលនិយាយនៅក្នុង ទដ ៥៣ ដែរ ។

**៥៤:៤** នៅកណ្ដាលនៃសេចក្ដីអធិស្ឋានក្នុងខនេះ និយាយពីការទុកចិត្តចំពោះព្រះ (មើល ៤២:៨ និងការពន្យល់) ។

**៥៤:៥** នៅក្នុងខនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះអម្ចាស់ទ្រង់បានដាក់ទោសដល់ពួកខ្មាំងសត្រូវរបស់គាត់ (មើលការពន្យល់ ៥:១០) ។

**៥៤:៦** នៅក្នុងខនេះ និយាយពីការប្ដេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះអម្ចាស់ព្រះយេហូវ៉ា (មើលការពន្យល់ ៧:១៧) ។ *ព្រះនាម* មើល ខ.១ និងការពន្យល់ ៥:១១ ។

**៥៤:៧** នៅក្នុងខនេះ និយាយពីការធានារ៉ាប់រងចំពោះអ្នកដែលបានស្តាប់ឮ (សូមមើលការពន្យល់ ៣:៨) ។

**ទដ ៥៥** នៅក្នុងជំពូកនេះ អ្នកនិព្វបានអធិស្ឋានសូមសេចក្ដីជំនួយមកពីព្រះ នៅពេលដែលគាត់ជួបការបៀតបៀន ពីសំណាក់ភឿនមិត្តកម្បត់របស់គាត់ដែលមានអំណាចរស់នៅក្រុងយេរូសាឡិម ។ (នៅក្នុង ទដ ៥៩ និយាយពីការអធិស្ឋានសូមសេចក្ដីជំនួយមកពីព្រះ ដើម្បីទាស់ប្រឆាំងចំពោះអំណាចរបស់ពួកខ្មាំងសត្រូវ ដែល "ដើរក្រវែល" (៥៥:១០ ៥៩:៦,១៤) ទីក្រុងដើម្បីសម្រេចតាមបំណងប្រាថ្នាដ៏អាក្រក់របស់ពួកគេ ដ្បិតមាត់គឺជាវុធរបស់ពួកគេ (សូមមើលសេចក្ដីផ្ដើម ទដ ៥៤–៦០) ។ មានស្ថានការណ៍មួយដែលស្រដៀងនឹងស្ថានការណ៍នេះដែរ គឺការក្បត់របស់អាប់សាឡំមចំពោះស្តេច (សូមមើល ២សយ ជំពូក ១៥–១៧) ។ ស្ថានភាពទីក្រុងពេលនេះមានការជ្រួលច្របល់ ហើយគ្រោះថ្នាក់នៅគ្រប់ទីកន្លែងទាំងអស់ គ្មានអ្នកណាអាចនឹងទុកចិត្តបានឡើយ គេនិយាយពាក្យចចាមរ៉ាម ធ្វើបន្ទាល់ក្លែងនិងនិយាយតែពាក្យបង្ខូចបង្កាច់ ។ ក្នុងស្ថានការណ៍បែបនេះស្តេចដាវីឌទ្រង់ចង់បានឱ្យការនោះបានស្ងប់ស្ងាត់និងកន្លងផុតទៅ (ខ.៦–៨) ។ ដោយសារការអស់សំណួរក្នុងការសួរដល់ព្រះ បានធ្វើឱ្យគាត់បោះបង់ការងាររបស់គាត់ក្នុងការបម្រើរដល់ព្រះ ដែលកាលពីមុនមានតែព្រះប៉ុណ្ណោះ ដែលគាត់អាចទុកចិត្តបាន ។ សំណង់ប្រយោគក្នុងជំពូកនេះ សេចក្ដីអធិស្ឋានត្រូវបានបង្ហាញច្បាស់ គឺការសូមសេចក្ដីជំនួយ (ខ.១) និងការពណ៌នាពីសេចក្ដីជំនឿ ("តែទូលបង្គំ នឹងទុកចិត្តដល់ទ្រង់វិញ" ខ.២៣) ។ នៅចំណុចកណ្ដាលនៃជំពូកនេះ (ខ.១៥) គឺជាចំណុចស្នូលនៃសេចក្ដីអធិស្ឋាន ។ មួយវិញទៀតនៅចំណុចនេះផងដែរ មានភាសាហេព្រើ១២បន្ទាត់ដែលបានភ្ជាប់ជាមួយសេចក្ដីផ្ដើម និងសេចក្ដីបញ្ចប់ ហើយក្នុងចំណោមបន្ទាត់ទាំង១២នោះ បានបែងចែកជាល្បះតូចៗជាច្រើន ដូចជា មាន៥បន្ទាត់ ៣បន្ទាត់ ៤បន្ទាត់ ។

**៥៥ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ត្រូវលេងដោយប្រដាប់មានខ្សែ* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *សេចក្ដីបង្រៀន* មើលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។

**៥៥:១–៣** គោលបំណងនៃសេចក្ដីអធិស្ឋានក្នុងខទាំងនេះ គឺសូមឱ្យព្រះទ្រង់បានស្តាប់ឮសំរែកដែលគាត់បានស្រែករកព្រះអង្គ ។

៤ ចិត្តទូលបង្គំអន្ទះសា[ឆ] នៅក្នុងខ្លួន
ហើយសេចក្ដីស្ញែងខ្លាច[ជ] ចំពោះសេចក្ដីស្លាប់
បានគ្របសង្កត់លើទូលបង្គំ
៥ ទូលបង្គំបានកើតមានសេចក្ដីភ័យខ្លាច[ឈ] ហើយញាប់ញ័រ
សេចក្ដីតក់ស្លុត[ញ] បានបង្គ្របទូលបង្គំហើយ
៦ នោះទូលបង្គំបានពោលថា
ឱបើសិនណាជាមានស្លាបដូចជាព្រាបទៅវ៉ា
នោះអញនឹងហើរចេញទៅ ឱ្យបានសេចក្ដីសុខ
៧ អើ យ៉ាងនោះទូលបង្គំនឹងបានទៅឆ្ងាយស្នាក់នៅឯទី
រហោស្ថានវិញ[ដ] ។ –បង្អង់
៨ ទូលបង្គំនឹងបានរត់ជាប្រញាប់ទៅឯទីជ្រក[ឋ]
ឱ្យបានរួចពីខ្យល់គំហុក នឹងព្យុះសង្ឃរា[ឌ]
៩ ឱព្រះអម្ចាស់អើយ
សូមបំផ្លាញគំនិតគេ ឱ្យគេនិយាយសុទ្ធតែខុសគ្នា[ឍ]
ដ្បិតទូលបង្គំបានឃើញសេចក្ដីច្រឡោតនឹងសេចក្ដីទាស់
ទែងគ្នា[ណ] នៅក្នុងទីក្រុង[ត]
១០ ទាំងយប់ទាំងថ្ងៃ គេប្រព្រឹត្តយ៉ាងនោះ[ថ] នៅលើកំផែង
ជុំវិញទីក្រុង នៅខាងក្នុង មានសុទ្ធតែសេចក្ដីនឿយហត់
ហើយព្រួយចិត្ត
១១ មានការអាក្រក់[ទ] នៅកណ្ដាលទីក្រុង សេចក្ដីសង្កត់សង្កិន
ហើយឆបោក[ធ] មិនចេះបាត់ពីផ្លូវក្រុងឡើយ ។
១២ មិនមែនជាខ្មាំងសត្រូវដែលបកកេរខ្ញុំ
យ៉ាងនោះខ្ញុំនឹងធន់ទ្រាំបាន
ក៏មិនមែនជាអ្នកស្អប់ខ្ញុំដែលលើកខ្លួនទាស់នឹងខ្ញុំនោះខ្ញុំនឹង
បានពួនខ្លួនឱ្យរួចពីគេ
១៣ គឺជាអ្នកឯងវិញ ជាមនុស្សស្មើគ្នានឹងខ្ញុំ ជាភឿន
ហើយជាសំឡាញ់ស្និទ្ធស្នាលនឹងខ្ញុំ[ន]
១៤ យើងបានធ្លាប់ប្រឹក្សាគ្នាយ៉ាងផ្អែមល្ហែម[ប]
ក៏ដើរជាមួយគ្នា នៅកណ្ដាលហ្វូងមនុស្សក្នុងដំណាក់ព្រះ[ផ]
១៥ សូមឱ្យសេចក្ដីស្លាប់លោមកគ្របលើគេ[ព]
ឱ្យគេចុះទាំងរស់ទៅក្នុង ស្ថានឃុំព្រលឹងមនុស្សស្លាប់[ភ]
ដ្បិតមានអំពើអាក្រក់នៅក្នុងទីលំនៅរបស់គេ
ហើយនៅខាងក្នុងគេផង
១៦ ចំណែកខ្ញុំនឹងអំពាវនាវដល់ព្រះ
ហើយព្រះយេហូវ៉ាទ្រង់នឹងជួយសង្គ្រោះខ្ញុំ
១៧ ខ្ញុំនឹងអធិស្ឋាន ហើយស្រែកថ្ងូរ ទាំងពេលល្ងាច[ម]
ពេលព្រឹក[យ] និងថ្ងៃត្រង់ផង[រ]
ហើយទ្រង់នឹងស្ដាប់សំឡេងខ្ញុំជាមិនខាន

**៥៥:៤** ឆ ទដ ៦:៣ ជ យប ១៨:១១ **៥៥:៥** ឈ យប ៤:១៤ ២កថ ៧:១៥ ញ ចទ ២៨:៦៧ អស ២១:៤ យរ ៤៦:៥ ៤៩:៥ អគ ៧:១៨ **៥៥:៧** ដ ១សយ ២៣:១៤ **៥៥:៨** ឋ ទដ ៣១:២០ ឌ ទដ ៧៧:១៨ អស ៤:៦ ២៥:៤ ២៨:២ ២៩:៦ ៣២:២ **៥៥:៩** ឍ លប ១១:៩ កច ២:៤ ណ ទដ ១១:៥ អស ៥៩:៦ យរ ៦:៧ អគ ៧:១១ ហព ១:៣ ត លប ៤:១៧ **៥៥:១០** ថ ១ពត ៥:៨ **៥៥:១១** ទ ទដ ៥:៩ ធ ទដ ១០:៧ **៥៥:១៣** ន ២សយ ១៥:១២ **៥៥:១៤** ប កច ១:១៦–១៧ ផ ទដ ៤២:៤ **៥៥:១៥** ព ទដ ៦៤:៧ សភ ៦:១៥ អស ២៩:៥ ៤៧:៩,១១ ១ថន ៥:៣ ភ ទដ ៤៩:១៤ **៥៥:១៧** ម ទដ ១៤១:២ កច ៣:១ ១០:៣,៣០ យ ទដ ៥:៣ ៨៨:១៣ ៩២:២ រ កច ១០:៩

**៥៥:៤–៨** នៅក្នុងខទាំងនេះ និយាយពីចិត្តទុកព្រួយរបស់ស្ដេចដាវីឌ ។

**៥៥:៤–៥** នៅក្នុងខទាំងនេះចង់និយាយថា ស្ថានភាពនៃគ្រោះថ្នាក់គឺមាននៅគ្រប់ទីកន្លែងទាំងអស់ (មើល ៣១:១៣) ហើយគ្រោះថ្នាក់នោះ គឺធំបំផុតដែលអាចនឹងធ្វើឱ្យស្លាប់បាន (មើល ១៨:៤–៥ ១១៦:៣) ។

**៥៥:៤** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ *ស្ញែងខ្លាចចំពោះសេចក្ដីស្លាប់* មើល ១សយ ៥:១១ ១៥:៣២ ២៨:៥ យប ១៨:១៤ ។

**៥៥:៦–៨** នៅក្នុងខទាំងនេះ ស្ដេចដាវីឌសូមឱ្យការបៀតបៀនទាំងនោះបានកន្លងផុតបាត់ គឺទាំងការទុរសយី និងពួកអ្នកដែលរួមគំនិតប្រព្រឹត្តការអាក្រក់ (មើលស្ថានភាពប្រហាក់ប្រហែលគ្នាក្នុង យរ ៩:២–៦) ។

**៥៥:៩–១១** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានសូមឱ្យព្រះអម្ចាស់ទ្រង់បានបំផ្លាញគំនិតរបស់ពួកខ្មាំងសត្រូវរបស់គាត់ ។

**៥៥:៩** *បំផ្លាញ . . . ឱ្យគេនិយាយសុទ្ធតែខុស* នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យព្រះទ្រង់បានបង្ខាំងគំនិតពួកអ្នកដែលក្បត់នឹងគាត់ ដោយការទាស់ប្រឆាំងនឹងគេ ដូចជានៅត្រង់បាបិលជាដើម (មើល លប ១១:៥–៩ និង ២សយ ១៧:១–១៤) ។ *ទីក្រុង* មើល ខ.១១ ។ ទីក្រុងនេះគឺសំដៅលើទីក្រុងយេរូសាឡិម ។

**៥៥:១០** *សេចក្ដីនឿយហត់ និងព្រួយចិត្ត* គឺពួកគេមានសេចក្ដីនឿយហត់ដូចជាពួកអ្នកដែលចាំយាមកំផែងក្រុងដែរ (មើល ១២៧:១ ១៣០:៦ បស ៥:៧) ។

**៥៥:១១** *សេចក្ដីសង្កត់សង្កិន ហើយឆបោក* ដូចជាពួកឆ្មាំក្រុងដែលដើររាតត្បាតទីក្រុងដែរ (សូមមើល បស ៣:៣) ។

**៥៥:១២–១៤** នៅក្នុងខទាំងនេះចង់និយាយថា ការមើលងាយ និងគំនិតអាក្រក់របស់ពួកខ្មាំងសត្រូវអាចនឹងនៅជាប់ជានិច្ច ប៉ុន្តែតើពួកអ្នកកម្សត់ទាំងប៉ុន្មានអាចនឹងជាប់នៅដែរឬទេ? ។

**៥៥:១៣** *ជាមនុស្សស្មើគ្នានឹងខ្ញុំ ជាភឿន* សូមមើល ខ.២០ និង ៤១:៩ និងការពន្យល់ ។

**៥៥:១៤** *ក្នុងដំណាក់ព្រះ* នៅក្នុងឃ្លានេះចង់និយាយថា ចំណងមិត្តភាពរបស់ពួកគេត្រូវបានចងដោយការចូលមកឧទ្ទិសថ្វាយនៅចំពោះព្រះ ហើយបោះត្រាដៅចំណាំនៅចំពោះវត្តមាននៃព្រះ និងចំពោះមុខអ្នកដែលចូលរួមថ្វាយបង្គំព្រះក្នុងព្រះវិហារ ។

**៥៥:១៥** នៅក្នុងខនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះអង្គទ្រង់បានសងសឹកនៅចំពោះគេ (សូមមើលការពន្យល់ ៥:១០) ។ *សូមឱ្យសេចក្ដីស្លាប់លោមកគ្របលើគេ* ពួកមនុស្សក្បត់ទាំងនេះបាននិយាយពីសេចក្ដីស្លាប់របស់អ្នកនិពន្ធ ។ *ឱ្យគេចុះទាំងរស់ទៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់* នៅក្នុងឃ្លានេះប្រហែលចង់និយាយថា សូមឱ្យគេបានទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់មុនដែលគេបានស្លាប់ទៅ (សូមមើល ខ.២៣ ជន ១៦:២៩–៣៣ សភ ១:១២ អស ៥:១៤) ។

**៥៥:១៦–១៩** នៅក្នុងខទាំងនេះ និយាយពីការធានាអះអាងរបស់ពួកអ្នកដែលស្ដាប់ឮ (មើលការពន្យល់ ៣:៨) ។

**៥៥:១៧** *ហើយស្រែកថ្ងូរ ទាំងពេលល្ងាច ពេលព្រឹក និងថ្ងៃត្រង់ផង* សូម

១៨ ទ្រង់បានដោះព្រលឹងខ្ញុំ ឱ្យរួចពីសឹកសង្គ្រាមដោយសុខ
សាន្ត ដ្បិតមានគេទាស់ទទឹងនឹងខ្ញុំជាច្រើន
១៩ ព្រះទ្រង់នឹងឮ[ល] ហើយនឹងធ្វើសបដល់គេ
គឺជាព្រះដែលគង់នៅទាំងពីអស់កល្បរៀង[វ] មកនោះ
ហើយ ។ –បង្អង់
គេមិនព្រមប្រែចិត្តសោះ ក៏មិនកោតខ្លាចដល់ព្រះដែរ[ស]
២០ គេបានលូកដៃទៅទាស់នឹងមិត្រ[ហ] ដែលជាមេត្រីនឹងគេ
គេបានក្បត់ចំពោះសញ្ញារបស់ខ្លួនហើយ[ឡ]
២១ មាត់គេរឥលជាងខ្លាញ់[អ] តែចិត្តគេមានពេញដោយការ
ចំបាំងវិញ វាចាគេទន់ល្វន់ជាងប្រេង[ក]
ប៉ុន្តែពាក្យទាំងនោះសុទ្ធតែជាដាវហូតស្រាប់[ខ]
២២ ចូរផ្ទេរបន្ទុករបស់អ្នកទៅលើព្រះយេហូវ៉ា
នោះទ្រង់នឹងជួយទប់ទល់អ្នក[គ]
ទ្រង់មិនព្រមឱ្យមនុស្សសុចរិតត្រូវរង្គើឡើយ[ឃ]
២៣ តែឱព្រះអង្គអើយ ទ្រង់នឹងឱ្យគេចុះទៅឯរណ្តៅ[ង] នៃ
សេចក្តីហិនវិនាស ពួកមនុស្សកំចាយឈាម
ហើយមនុស្សឧបាយកល[ច] នឹងរស់នៅមិនដល់ត្រឹមពាក់
កណ្តាលអាយុផង[ឆ] តែទូលបង្គំនឹងទុកចិត្តដល់ទ្រង់វិញ[ជ] ។

ពាក្យកាព្យរបស់ស្តេចដាវីឌ ដែលទ្រង់លើកតាមបទ
"សត្វព្រាបគនៅស្រុកឆ្ងាយ" ក្នុងកាលដែល
សាសន៍ភីលីស្ទីនចាប់ទ្រង់នៅក្រុងកាថ សំរាប់មេភ្លេង ។

**៥៦** ឱព្រះអង្គអើយ សូមទ្រង់អាណិតមេត្តាដល់ទូលបង្គំ[ក]
ដ្បិតមនុស្សចង់លេបបំបាត់ទូលបង្គំហើយ[ខ] គេសង្កត់សង្កិន
ដោយតស៊ូនឹងទូលបង្គំជាដរាបរាល់ថ្ងៃ[គ]
២ គឺពួកខ្មាំងសត្រូវចង់តែលេបបំបាត់ទូលបង្គំជាដរាប
រាល់ថ្ងៃ[ឃ]
ដ្បិតមានគ្នាច្រើនដែលតស៊ូនឹងទូលបង្គំដោយចិត្តឆ្មើងឆ្មៃ[ង]
៣ តែវេលាណាដែលទូលបង្គំភ័យ[ច]

**៥៥:១៩** ល នក ១៥:១៨ ចទ ៣៣:២៧ ទដ ២៩:១០ វ ទដ ៧៨:៥៩ ស ទដ ៣៦:១ ៦៤:៤ **៥៥:២០** ហ ទដ ៧:៤ ឡ ទដ ៤១:៩ **៥៥:២១** អ ទដ ១២:២ ក សភ ៥:៣ ៦:២៤ ខ ទដ ៥៧:៤ ៥៩:៧ ៦៤:៣ សភ ១២:១៨ វវ ១:១៦ **៥៥:២២** គ ទដ ១៨:៣៥ មថ ៦:២៥–៣៤ ១ពត ៥:៧ ឃ ទដ ១៥:៥ ២១:៧ ៣៧:២៤ ១១២:៦ **៥៥:២៣** ង ទដ ៩:១៥ ៣០:៣ ៧៣:១៨ ៩៤:១៣

អស ១៤:១៥ អគ ២៨:៨ លក ៨:៣១ ច ទដ ៥:៦ ឆ យប ១៥:៣២ ជ ទដ ១១:១ ២៥:២ ៥៦:៣ **៥៦:១** ក ទដ ៦:២ ខ ទដ ៥៧:១–៣ គ ទដ ១៧:៩ **៥៦:២** ឃ ទដ ៣៥:២៥ ១២៤:៣ ង ទដ ៣៥:១ **៥៦:៣** ច ទដ ៥៥:៤–៥

---

ធៀបជាមួយ ដយ ៦:១០ ។

**៥៥:១៨** *ដោះ* នៅកន្លែងនេះមានន័យដូចគ្នានឹងពាក្យ"ជួយលោះ" (សូមមើល អស ៥០:២ យរ ៣១:១១) ។

**៥៥:១៩** នៅក្នុងខ.នេះចង់និយាយថា ស្តេចដែលគង់នៅអស់កល្បគឺនឹងប្រាស្រ័យទាក់ទងជាមួយអ្នកណា ដែល"មិនព្រមប្រែផ្លាស់"ការប្រព្រឹត្តិ និងអ្នកដែល"គ្មានសេចក្តីកោតខ្លាចដល់ព្រះ" (សូមមើល ៣៦:១ និងការពន្យល់ ទដ ជំពូក ១៤,៥៣) ។

**៥៥:២០–២១** នៅក្នុងខទាំងនេះ ចង់និយាយអំពីការឈឺចាប់ (ឬកំហឹង) ដែលបានដះត្រឡប់មកលើពួកភឿនមិត្តកម្សត់របស់គាត់ ។

**៥៥:២០** *មិត្រ ដែលជាមេត្រី* តាមភាសាអក្សរសាស្ត្រគឺ "អ្នកដែលស្រឡាញ់សន្តិភាពជាមួយគាត់" (៧:៤) ។

**៥៥:២១** សូមមើលក្នុង ២៨:៣ សភ ៥:៣–៤ និងការពន្យល់ ៥:៩ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៥៥:២២–២៣** នៅក្នុងខទាំងនេះ និយាយពីការធានាអះអាងចំពោះពួកអ្នកដែលបានស្តាប់ឮព្រះបន្ទូលរបស់ព្រះ ។

**៥៥:២២** អ្វីដែលមាននិយាយនៅក្នុងខនេះ គឺជាទីបន្ទាល់ចំពោះពួកមនុស្សដែលបានចូលរួមប្រជុំនៅត្រង់ព្រះវិហារ ។ នៅក្នុង ១ពត ៥:៧ បានដកស្រង់ការធានាអះអាងនៅក្នុងខនេះ ។ *មនុស្សសុចរិត* សូមមើលការពន្យល់ ១:៥ ។

**៥៥:២៣** *រណ្តៅនៃសេចក្តីហិនវិនាស* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើស្ថានឃុំព្រលឹងមនុស្សស្លាប់ (មើលការពន្យល់ ៣០:១) ។ *រស់នៅមិនដល់ត្រឹមពាក់កណ្តាលអាយុផង* មើលការពន្យល់ ខ.១៥ ។

**ទដ ៥៦** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានសូមសេចក្តីជំនួយមកពីព្រះក្នុងគ្រាដែលគាត់ជួបប្រទះការបៀតបៀន និងវាយប្រហារពីសំណាក់ពួកខ្មាំងសត្រូវរបស់គាត់ ។ ការនេះវាបានបង្ហាញច្បាស់តាមរយៈកំសាន្តចិត្តពីការទុកចិត្តចំពោះព្រះក្នុងគ្រាដែលមានសេចក្តីភ័យខ្លាច ។ លក្ខណៈសំណង់ប្រយោគវិញ សេចក្តីអធិស្ឋានក្នុងជំពូកនេះបានបែងចែកជា ២ផ្នែក ដោយក្នុង១ផ្នែក មានសរសេរជាភាសាហេព្រើរ៧បន្ទាត់ ដូចគ្នានិង ទដ ៥៧ ដែរ (សូមមើលសេចក្តីផ្តើម ទដ ជំពូក ៥៧) ។ ពាក់បណ្តូល សំណង់ប្រយោគនៃផ្នែកនិមួយៗគឺបែងចែកស្មើគ្នា (មាន២បន្ទាត់ ៣បន្ទាត់) ដែលមានបទបន្ទរនៅកណ្តាលផ្នែកនិមួយៗ (គេប្រើបទបន្ទរនៅពេលណានោះ សូមមើលសេចក្តីផ្តើម ទដ ៤២–៤៣) ។ បទគម្ពីរទំនុកដំកើងក្នុងជំពូកនេះទាំងមូល ត្រូវបានបង្ហាញច្បាស់តាមរយៈការអធិស្ឋានជាបន្ទាន់ទៅចំពោះព្រះ (សូមមើ ខ.១–២) និងការទុកចិត្តចំពោះព្រះ (ខ.១២–១៣) ។ ការទុកចិត្តចំពោះទីពំនឹងរបស់ព្រះ និងសេចក្តីសង្គ្រោះ របស់ទ្រង់ក្នុងជំពូកនេះ គឺមានលក្ខណៈផ្ទុយគ្នាជាមួយពួកមនុស្សអាក្រក់ ដែលគ្រប់គ្រងនៅលើលោកិយដែលមាននិយាយនៅក្នុង ទដ ៥៨ ។

**៥៦ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ដែលទ្រង់លើកតាមបទ* មើលការពន្យល់ ទដ ៩ ត្រង់ចំណងជើង ។ *ពាក្យកាព្យ* សូមមើលការពន្យល់ ទដ ១៦ ត្រង់ចំណងជើង ។ *ក្នុងកាល* មើលការពន្យល់ ទដ ៣ ត្រង់ចំណងជើង ។ ព្រឹត្តិការណ៍ដែលទាក់ទងក្នុងជំពូកនេះ មើល ១សយ ២១:១០–១៥ និង ទដ ៣៤ ត្រង់ចំណងជើង និងការពន្យល់ ។ *ចាប់ទ្រង់* ឬប្រហែលជាចាប់ ទ្រង់ ។

**៥៦:១–២** នៅក្នុងខនេះ អ្នកនិពន្ធបានអធិស្ឋានសូមសេចក្តីជំនួយមកពី ព្រះ ។

**៥៦:២** *ពួកខ្មាំងសត្រូវ* អាវុធដ៏សំខាន់របស់ពួកខ្មាំងសត្រូវទាំងនោះគឺជាអណ្តាត (សូមមើលការពន្យល់ក្នុង ៥:៩) ។ *ចិត្តឆ្មើងឆ្មៃ* នៅក្នុងឃ្លានេះចង់និយាយថា ពួកគេបានទុកចិត្តចំពោះកម្លាំងរបស់ពួកគេ ហើយគេមិនបានស្គាល់ពីព្រះរបស់ដាវីឌនោះឡើយ (មើលការពន្យល់ ៣:២ ៥:៩ ១០:១១) ។

**៥៦:៣–៤** សូមមើល ខ.១០–១១ ។ នៅក្នុងខនេះ ចង់និយាយថាអ្នកនិពន្ធ

នោះទូលបង្គំនឹងទុកចិត្តដល់ទ្រង់[ឆ]
៤ នៅក្នុងព្រះ (ទូលបង្គំនឹងសរសើរព្រះបន្ទូលទ្រង់)[ជ]
គឺសេចក្ដីពឹងពាក់របស់ទូលបង្គំ នោះបានទុកនៅក្នុងព្រះ
ទូលបង្គំនឹងមិនខ្លាចឡើយ[ឈ]
តើសាច់ឈាមនឹងអាចធ្វើអ្វីដល់ទូលបង្គំបាន[ញ]
៥ គេមួលបង្កាច់ពាក្យទូលបង្គំវាល់ព្រឹកវាល់ល្ងាច[ដ]
អស់ទាំងគំនិតរបស់គេសុទ្ធតែប៉ងអាក្រក់ដល់ទូលបង្គំ
៦ គេប្រជុំគ្នា[ឋ] គេបំពួនខ្លួន
គេឃ្លាំមើលអស់ទាំងជំហានរបស់
ទូលបង្គំ[ឌ] ដោយចាំសង្គ្រុបចាប់ជីវិតទូលបង្គំ[ឍ]
៧ តើគេនឹងគេចរួច[ណ] ដោយអំពើអាក្រក់យ៉ាងនោះឬ
ឱព្រះអង្គអើយ
សូមទ្រង់បោះទំលាក់ពួកទាំងនេះចុះ ដោយសេចក្ដីខ្ញាល់
របស់ទ្រង់[ត]
៨ ទ្រង់រាប់អស់ទាំងការសាត់អណ្តែតរបស់ទូលបង្គំ
សូមទ្រង់ដាក់អស់ទាំងទឹកភ្នែករបស់ទូលបង្គំទុកនៅក្នុងដប
នៃទ្រង់[ថ] ទឹកភ្នែកទាំងនោះ
តើមិនកត់ទុកក្នុងបញ្ជីទ្រង់ទេឬអី[ទ]
៩ យ៉ាងនោះ នៅថ្ងៃដែលទូលបង្គំអំពាវនាវ[ធ]
នោះពួកខ្មាំងសត្រូវនឹងថយចេញទៅ[ន] ទូលបង្គំដឹងហើយ

**៥៦:៣** ឆ ទដ ៥៥:២៣
**៥៦:៤** ជ ខ.១០ ឈ ទដ ២៧:១ ញ ទដ ១១៨:៦ មថ ១០:២៨ ហព ១៣:៦
**៥៦:៥** ដ ទដ ៤១:៧ ២ពត ៣:១៦
**៥៦:៦** ឋ ទដ ៥៩:៣ ៩៤:២១ មក ៣:៦ ឌ ទដ ១៧:១១ ឍ ទដ ៧១:១០
**៥៦:៧** ណ សភ ១៩:៥ អគ ១៧:១៥ រម ២:៣ ហព ១២:២៥ ត ទដ ៣៦:១២ ៥៥:២៣
**៥៦:៨** ថ ២ពវ ២០:៥ ទ អស ៤:៣ ដយ ៧:១០ ១២:១ មឡ ៣:១៦
**៥៦:៩** ធ ទដ ១០២:២ ន ទដ ៩:៣ ប ជន ១៤:៨ ចទ ៣១:៦ រម ៨:៣១

ដ្បិតព្រះទ្រង់គង់នៅខាងទូលបង្គំ[ប]
១០ នៅក្នុងព្រះ ទូលបង្គំនឹងសរសើរព្រះបន្ទូលទ្រង់នៅក្នុង
ព្រះយេហូវ៉ា ទូលបង្គំនឹងសរសើរព្រះបន្ទូលទ្រង់
១១ សេចក្ដីពឹងពាក់របស់ទូលបង្គំ នោះបានទុកនៅក្នុងព្រះ
ទូលបង្គំនឹងមិនខ្លាចឡើយ
តើមនុស្សនឹងអាចធ្វើអ្វីដល់ទូលបង្គំបាន
១២ ឱព្រះអង្គអើយ ទូលបង្គំនៅជាប់បំណន់[ផ]នឹងទ្រង់
ទូលបង្គំនឹងថ្វាយដង្វាយអរព្រះគុណដល់ទ្រង់
១៣ ដ្បិតទ្រង់បានជួយជីវិតទូលបង្គំឱ្យរួចពីស្លាប់[ព]
ក៏បានជួយជើងទូលបង្គំឱ្យរួចពីជំពប់ដួលដែរ
ដើម្បីឱ្យទូលបង្គំបានដើរនៅចំពោះព្រះក្នុងពន្លឺនៃមនុស្ស
រស់វិញ[ភ] ។

*៥៧:៧–១១ – ទដ ១០៨:១–៥*

ពាក្យកាព្យរបស់ស្ដេចដាវីឌ ដែលទ្រង់លើកតាមបទ
"សូមកុំបំផ្លាញ" ក្នុងកាលដែលទ្រង់
រត់ពីស្ដេចសូលទៅនៅក្នុងរូងថ្ម សំរាប់មេភ្លេង[ក] ។

# ៥៧

សូមអាណិតមេត្តាដល់ទូលបង្គំ ឱព្រះអង្គអើយ
សូមអាណិតមេត្តាទូលបង្គំផង

**៥៦:១២** ផ ទដ ៥០:១៤ **៥៦:១៣** ព ទដ ៣០:៣ ៣៣:១៩ ៤៩:១៥ ៨៦:១៣ ១០៧:២០ ១១៦:៨ ភ យប ៣៣:៣០ **៥៧:ចំណងជើង** ក ១សយ ២២:១ ២៤:៣ ទដ ១៤២ចំណងជើង

មានទំនុកចិត្តចំពោះព្រះ ក្នុងគ្រាដែលគាត់ជួបប្រទះសេចក្ដីភ័យខ្លាច ។

**៥៦:៤** *ព្រះបន្ទូល* ព្រះបានសន្យាថាទ្រង់នឹងធ្វើជាព្រះដល់រាស្ត្ររបស់ទ្រង់ ហើយទ្រង់នឹងយាងមក ធ្វើជាអ្នកជំនួយដល់គេក្នុងគ្រាដែលគេអំពាវនាវរកទ្រង់ (សូមមើល ទដ ៥០:១៥ ៩១:១៥ និង ១១៩:៧៤,៨១ ១៣០:៥) ។

**៥៦:៦–៧** នៅក្នុងទាំងនេះ អ្នកនិពន្ធបានចោទប្រកាន់ពីអ្វីដែល ពួកខ្មាំងសត្រូវគាត់បានធ្វើចំពោះគាត់ និងសូមឱ្យព្រះទ្រង់បានកាត់ទោសដល់ពួកគេ (មើលការពន្យល់ ៥:៩–១០) ។

**៥៦:៥** *គេមួលបង្កាច់ពាក្យទូលបង្គំ* សូមមើល ខ.២ ។

**៥៦:៧** មើលការពន្យល់ ៥:១០ ។ *សេចក្ដីខ្ញាល់* មើលការពន្យល់ ២:៥ ។

**៥៦:៨–៩** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានទូលសូមឱ្យព្រះទ្រង់បានកត់ទុក និងដៅចំណាំពិសេសពីសេចក្ដីទុក្ខលំបាកដែលគាត់មាន ។

**៥៦:៨** *រាប់ . . . កត់ទុកក្នុងបញ្ជីទ្រង់* នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យទ្រង់បានកត់ចុះពីសេចក្ដីទុក្ខលំបាក របស់ទូលបង្គំទុកក្នុងបញ្ជីរជីវិតរបស់ទ្រង់ដើម្បីនឹងប្រាប់ពីទង្វើរ និងការងាររបស់យើង (សូមមើលការពន្យល់ ៥១:១) ។

**៥៦:៩** នៅក្នុងខនេះចង់និយាយថា បើសិនព្រះអម្ចាស់ទ្រង់បានដាក់អស់ទាំងទឹកភ្នែករបស់គាត់នៅក្នុងសៀវភៅរបស់ទ្រង់ នោះគឺមានន័យថា ទ្រង់នឹងស្ដាប់ឮ ហើយនិងឆ្លើយតបការអំពាវនាវរបស់ស្ដេចដាវីឌ ។

**៥៦:១០–១១** ជាថ្មីម្ដងទៀតនៅក្នុងខអ្នកនេះ អ្នកនិពន្ធបានបង្ហាញពីការទុកចិត្តចំពោះព្រះក្នុងកាលដែលគាត់ជួបការទុក្ខលំបាក (សូមមើលក្នុង ខ.៣–៤) ។

**៥៦:១២–១៣** នៅក្នុងខទាំងនេះ គឺជាការធានាអះអាងចំពោះអ្នកណាដែលបានស្ដាប់ឮព្រះបន្ទូលរបស់ទ្រង់ (មើលការពន្យល់ ៣:៨) ។

**៥៦:១២** *ទូលបង្គំជាប់បំណន់នឹងទ្រង់* នៅក្នុងឃ្លានេះស្ដេចដាវីឌទ្រង់ចង់មានបន្ទូលថា បើសិនជាព្រះទ្រង់បានសណ្ដាប់ឮសេចក្ដីអធិស្ឋានរបស់ទ្រង់ និងបានតបឆ្លើយហើយនោះ នោះទ្រង់ត្រូវតែរក្សាបំណន់ដែលទ្រង់បានបន់ទៅចំពោះព្រះក្នុងគ្រាដែលព្រះអង្គកើតមានសេចក្ដីវេទនា (សូមមើល ៦៦:១៤ និងការពន្យល់ ៧:១៧) ។

**៥៦:១៣** *ទូលបង្គំ* មើលការពន្យល់ ៦:៣ ។ *ជំពប់ដួល* មើលការពន្យល់ ៣៥:១៥ ។ *នៅចំពោះព្រះ* មើលការពន្យល់ ១១:៧ ។ *ពន្លឺនៃមនុស្សរស់នៅ* ក្នុងឃ្លានេះ គឺចង់និយាយពីជីវិតរស់នៅ ដែលពោរពេញដោយព្រះពរ (សូមមើលការពន្យល់ ៣៦:៩) ។

**ទដ ៥៧** នៅក្នុងជំពូកនេះ ស្ដេចដាវីឌទ្រង់បានអធិស្ឋានសូមឱ្យព្រះយេហូវ៉ាទ្រង់រំដោះគាត់ ក្នុងគ្រាដែលគាត់ជួបប្រទះការវាយប្រហារពីសំណាក់ពួកខ្មាំងសត្រូវ (ព្រះគម្ពីរទំនុកដំកើងជំពូកនេះ មានទំនាក់ទំនងជាមួយ ទដ ៥៦) អ្នកនិពន្ធបានរំឭកឱ្យឃើញ នៅរូបភាពនៃការគ្រោះថ្នាក់នៅពេលយប់ (មើល ខ.៤ "ទូលបង្គំដេក") ចាំដល់សេចក្ដីសង្គ្រោះនៅពេលព្រឹក (មើល ខ.៨ "ឯអញក៏នឹងភ្ញាក់ឡើង") ។ សម្រាប់ហេតុការ ដែលទាក់ទងនឹងហេតុការណ៍នេះ មើល ៣០:៥ ៤៦:៥ ៥៩:៦,១៤, ១៦ ៦៣:១,៦ ៩០:១៤ ។ នៅក្នុង ខ.៧–១១ នឹងលើកមកនិយាយម្ដងទៀតនៅ ទដ ១០៨:១–៥ ។ ឯលក្ខណៈ

ពីព្រោះព្រលឹងទូលបង្គំពឹងនៅក្នុងទ្រង់[ខ] អើ
ទូលបង្គំជ្រកនៅក្រោមម្លប់នៃស្លាបទ្រង់[គ]
ដរាបដល់សេចក្ដីអន្តរាយទាំងនេះបានបាត់ទៅ[ឃ]
២ ទូលបង្គំនឹងអំពាវនាវដល់ព្រះដ៏ខ្ពស់បំផុត
គឺដល់ព្រះដែលទ្រង់សំរេចគ្រប់ការឱ្យទូលបង្គំ[ង]
៣ កាលណាមនុស្សដែលចង់លេបបំបាត់ទូលបង្គំ[ច] គេត្មះតិះដៀល[ឆ]
នោះទ្រង់នឹងចាត់មកពីស្ថានសួគ៌ ដើម្បីជួយសង្គ្រោះទូលបង្គំវិញ[ជ] ។
–បង្អង់
គឺព្រះទ្រង់នឹងចាត់សេចក្ដីសប្បុរសនឹងសេចក្ដីពិតរបស់ទ្រង់មក
៤ ព្រលឹងទូលបង្គំនៅកណ្ដាលហ្វូងសិង្ហ[ឈ]
ទូលបង្គំដេកនៅកណ្ដាលពួកដែលឆួលឡើងហើយ
គឺជាមនុស្សដែលមានធ្មេញទុកជាលំពែង
នឹងព្រួញក៏មានអណ្ដាតទុកជាដាវយ៉ាងមុតដែរ[ញ]
៥ ឱព្រះអង្គអើយ
សូមឱ្យទ្រង់បានថ្កើងឡើងខ្ពស់ជាងផ្ទៃមេឃ
សូមឱ្យសិរីល្អនៃទ្រង់បាននៅពីលើផែនដីទាំងមូល[ដ] ។
៦ គេបានត្រៀមអន្ទាក់សំរាប់ទាក់ជើងទូលបង្គំ[ឋ]
ព្រលឹងនៃទូលបង្គំបានត្រូវឱនចុះ[ឌ]
គេបានជីករណ្ដៅ[ឍ] នៅមុខទូលបង្គំ
តែខ្លួនគេបានធ្លាក់ទៅក្នុងរណ្ដៅនោះវិញ[ណ] ។ –បង្អង់
៧ ទូលបង្គំបានតាំងចិត្តជាស្រេច ឱព្រះអង្គអើយ

**៥៧:១** ខ ទដ ២:១២ ៩:៩ ៣៤:២២ គ រម ២:១២ មថ ២៣:៣៧ ឃ អស ២៦:២០ **៥៧:២** ង ទដ ១៣៨:៨ **៥៧:៣** ច ទដ ៥៦:១ ឆ ទដ ១៨:៩,១៦ ៦៩:១៤ ១៤២:៦ ១៤៤:៥,៧ ជ ទដ ២៥:១០ ៤០:១១ ១១៥:១ **៥៧:៤** ឈ ទដ ៣៥:១៧ ញ ទដ ៥៥:២១ សភ ៣០:១៤ **៥៧:៥** ដ ខ.១១ ទដ ១០៨:៥ **៥៧:៦** ឋ ទដ ១០:៩ ៣១:៤ ១៤០:៥ ឌ ទដ ៣៨:៦ ១៤៥:១៤ ឍ ទដ ៩:១៥ ណ នអ ៦:១៣ ទដ ៧:១៥ សភ ២៨:១០ សស ១០:៨

សំណាង់ប្រយោគវិញ ព្រះគម្ពីរទំនុកដំកើងជំពូកនេះបានចែកជា២ចំណែកស្មើៗគ្នាហើយ១ចំណែកៗ មានអក្សរសាស្ត្រហេព្រើរ៧បន្ទាត់ ហើយក្នុងចំណែកនិមួយៗត្រូវបានតាក់តែងឡើងជា៣គូ និងមានបទបន្ទរថែមទៀត (មើលសេចក្ដីផ្ដើម ទដ ៥៦ និងសេចក្ដីផ្ដើម ទដ ៥៤) ។ សម្រាប់ការជំនួសព្រះគម្ពីរទំនុកដំកើងជំពូកនេះ ក្នុងចំណោមព្រះគម្ពីរទំនុកដំកើងក្នុងប៉ែកទី២ សូមមើលសេចក្ដីផ្ដើម ទដ ៤២–៤៥ និងសេចក្ដីផ្ដើម ទដ ៥៤–៦០ ។

**៥៧ ត្រង់ចំណាងជើង** សូមមើលការពន្យល ទដ ៥៦ ត្រង់ចំណាងជើង ។ *សូមកុំបំផ្លាញ* សូមមើល ទដ ៥៨ ៥៩ ៧៥ ត្រង់ចំណាងជើង ។ *ក្នុងកាល* សូមមើលហេតុការណ៍នេះ កើតឡើងនៅពេលណាក្នុង ១សយ ២៤:១–៣ និង ទដ ១៤២ ត្រង់ចំណាងជើង ។

**៥៧:១–៥** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអធិស្ឋានអំពាវនាវដល់ព្រះយេហូវ៉ា ។

**៥៧:១** នៅក្នុងខនេះ អ្នកនិពន្ធបានអធិស្ឋានសូមសេចក្ដីជំនួយមកពីព្រះ ។ *ព្រលឹងទូលបង្គំ* គេអាចនិយាយម្យ៉ាងទៀតថា "ទូលបង្គំ" ដូចជាមាននិយាយនៅក្នុង ខ.៤ ដែលនៅក្នុងកន្លែងនោះពាក្យថា "ទូលបង្គំ" គឺជាពាក្យអក្សរសាស្ត្រនៃពាក្យថា "ព្រលឹងទូលបង្គំ" (មើលការពន្យល់ ៦:៣) ។ *ម្លប់នៃស្លាបទ្រង់* សូមមើលការពន្យល់ ១៧:៨ ។

**៥៧:២–៣** នៅក្នុងខនេះចង់និយាយថា អ្នកនិពន្ធមានទំនុកចិត្តថាព្រះទ្រង់នឹងស្តាប់ឮសំរែកដែលគាត់បានអំពាវនាវរកទ្រង់ ។

**៥៧:២** *ខ្ពស់បំផុត* មើលការពន្យល់ លប ១៤:១៩ ។ *ដែលទ្រង់សំរេចគ្រប់ការឱ្យទូលបង្គំ* មើល ទដ ១៣៨:៨ ។ ព្រះយេហូវ៉ាទ្រង់មិនបានទុកឱ្យពួកខ្មាំងសត្រូវរបស់ស្ដេចដាវីឌយកឈ្នះ ឬធ្វើឱ្យខកខានពីបំណងព្រះហឫទ័យរបស់ទ្រង់ ក្នុងការចាក់ប្រេងតាំងដល់ដាវីឌនោះឡើយ (មើល ១សយ ១៦:១,១២ ២សយ ជំពូក ៧) ។ នៅក្នុងភាសាហេព្រើរឃ្លានេះក៏អាចបកថា "ជាអ្នកដែលធ្វើឱ្យការអាក្រក់របស់មនុស្ស ល្មើសបានកន្លងផុតទៅ" (មើល ៧:៩) ។

**៥៧:៣** *ទ្រង់នឹងចាត់* ព្រះទ្រង់នឹងចាត់បញ្ជូនសេចក្ដីស្រឡាញ់ និងសេចក្ដីសប្បុរសរបស់ទ្រង់មកដល់រាស្ត្ររបស់ទ្រង់ (នៅទីនេះ គឺគ្រាន់តែរូបបារម្មណ៍ប៉ុណ្ណោះ មើលការពន្យល់ ២៣:៦) មកពីស្ថានសួគ៌ដើម្បីជួយសង្គ្រោះដល់រាស្ត្ររបស់ទ្រង់ (មើលការពន្យល់ ៤៣:៣) ។ *សេចក្ដីសប្បុរស និងសេចក្ដីពិត* មើលការពន្យល់ ២៦:៣ ។ *សេចក្ដីសប្បុរស* មើលការពន្យល់ ៦:៤ ។

**៥៧:៤** នៅក្នុងខនេះ និយាយពីស្ថានការណ៍ដែលអ្នកនិពន្ធបានជួបប្រទះនឹងការបៀតបៀន ។ *ដេក* គឺដូចជាសត្វចៀមដែលដេកនៅក្នុងចំណោមសត្វសិង្ហដែរ ។ *ហ្វូងសិង្ហ* ជាញឹកញាប់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងតែងតែធ្វើការប្រៀបធៀបពួកខ្មាំងសត្រូវរបស់គាត់ ទៅនឹងសត្វព្រៃដែលសាហាវ (មើលការពន្យល់ ៧:២) ។ (ពាក្យប្រៀបធៀបនៅទីនេះ មិនមានទំនាក់ទំនងអ្វីជាមួយស្ដេចសូល និងយូណាថានដែលមាននិយាយនៅ ២សយ ១:២៣ នោះឡើយ) ។ *អណ្ដាត* មើលការពន្យល់ ៥:៩ ។

**៥៧:៥** នៅក្នុងខនេះអ្នកនិពន្ធគាត់បានអធិស្ឋាន សូមឱ្យព្រះទ្រង់បង្ហាញពីអំណាចចេស្ដា និងសិរីល្អរបស់ទ្រង់ដែលមាននៅក្នុងស្ថានសួគ៌ទាំងឡាយដែលទ្រង់បានបង្កើតមក តាមរយៈការយាងមកជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ ។ (មើល ៧:៦–៧ ២១:១៣ ៤៦:១០ ៥៩:៥,៨ ១១៣:៤–៩ ហើយធៀបនឹង នក ១៤:៤ អស ២៦:១៥ ៤៤:២៣ ៥៩:១៩ និងការពន្យល់ ទដ ៤៦:១០) ។

**៥៧:៦–១១** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានសរសើរតម្កើងចំពោះសេចក្ដីសង្គ្រោះរបស់ព្រះអម្ចាស់ ទ្រង់បានជួយសង្គ្រោះដល់គាត់តាមការចង់បាន ។ សម្រាប់ការភ្ជាប់សេចក្ដីអធិស្ឋានឆ្លង ទៅនិយាយពីការធានាអះអាងរបស់ព្រះ មើលការពន្យល់ ៣:៨ ។

**៥៧:៦** នៅក្នុងខនេះនិយាយពីពួកអ្នកដែលបៀតបៀន និងលទ្ធផលរបស់គេគឺបានធ្វើឱ្យត្រឡប់ជាមានទុក្ខលំបាកដោយព្រោះគម្រោងការណ៍របស់គេវិញ ។ *អន្ទាក់ . . . រណ្ដៅ* ពួកគេនឹងធ្វើការប្រមាញ់ដល់គាត់ដូចជាប្រមាញ់សត្វព្រៃដែរ ប៉ុន្តែ"សិង្ហ"ខ្លួនឯងនឹងត្រូវចាប់នោះ (មើល ៧:១៥ ៩:១៥ និងការពន្យល់) ។

**៥៧:៧** នៅក្នុងខនេះចង់និយាយថា ពេលគ្រប់ទាំងសេចក្ដីភ័យខ្លាចបានកន្លងបាត់ពីអ្នកនិពន្ធហើយ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។ *បានតាំងចិត្ត* មានន័យ

ចិត្តទូលបង្គំបានតាំងស្រេចហើយ[ត] ទូលបង្គំនឹងច្រៀង
អើ ទូលបង្គំនឹងច្រៀងសរសើរ
៨ឱកិត្តិយសអញអើយ ចូរភ្ញាក់ឡើង ឱពិណ
ហើយនិងស៊ុងអញ[ថ] អើយ ចូរភ្ញាក់ឡើង
ឯអញក៏នឹងភ្ញាក់ពីព្រលឹមស្រាងដែរ
៩ឱព្រះអម្ចាស់អើយ
ទូលបង្គំនឹងប្រទូលដៃដល់ទ្រង់នៅកណ្ដាលពួកជន
ទូលបង្គំនឹងច្រៀងសរសើរទ្រង់នៅកណ្ដាលពួកសាសន៍ដទៃ
១០ដ្បិតសេចក្ដីសប្បុរសនៃទ្រង់ខ្ពស់ដល់ស្ថានសួគ៌
ហើយសេចក្ដីពិតរបស់ទ្រង់ក៏ខ្ពស់ដល់ផ្ទៃមេឃ
១១ឱព្រះអង្គអើយ[ទ]
សូមឱ្យទ្រង់បានថ្កើងឡើងខ្ពស់ជាងស្ថានសួគ៌[ធ]
ហើយឱ្យសិរីល្អទ្រង់បាននៅពីលើផែនដីទាំងមូលផង[ន] ។

ពាក្យកាព្យរបស់ស្ដេចដាវីឌ ដែលទ្រង់លើកតាមបទ "សូមកុំបំផ្លាញ" សំរាប់មេភ្លេង ។

**៥៨** តើពិតជាអ្នករាល់គ្នាពោលសេចក្ដីសុចរិត[ក]
ដោយនូវតែស្ងៀមដូច្នេះឬ នែ មនុស្សជាតិអើយ
តើអ្នករាល់គ្នាវិនិច្ឆ័យដោយទៀតត្រង់ពិតឬ
២មិនមែនទេ គឺនៅក្នុងចិត្តអ្នករាល់គ្នាប្រព្រឹត្តតែសេចក្ដីអាក្រក់ទទេ[ខ] ហើយនៅក្នុងស្រុក នោះក៏ថ្លឹងឱ្យមានការច្រឡោតដែល ដៃអ្នករាល់គ្នាធ្វើវិញ[គ]
៣ឯពួកមនុស្សអាក្រក់ គេជាអ្នកដទៃតាំងតែពីពោះម្ដាយមក

**៥៧:៧** ត ទដ ១១២:៧
**៥៧:៨** ថ ទដ ៣៣:២ ១៤៩:៣ ១៥០:៣
**៥៧:១០** ទ ទដ ៣៦:៥
**៥៧:១១** ធ ទដ ៨:១ ១១៣:៤ ន ខ.៥
**៥៨:១** ក ទដ ៨២:២
**៥៨:២** ខ មថ ១៥:១៩ គ ទដ ៩៤:២០ អស ១០:១ លក ៦:៣៨

ថា គាត់មានអារម្មណ៍ទទួលបានក្ដីសុខសាន្ត (មើល ១១២:៧) ។

**៥៧:៨** *ចូរភ្ញាក់ឡើង . . . ចូរភ្ញាក់ឡើង* នៅក្នុងឃ្លានេះគឺជាពាក្យគំនាបសួរដោយអំណរចំពោះថ្ងៃដែលព្រះបានជួយសង្គ្រោះពួកគេនាពេលព្រឹកព្រលឹម (មើល អស ៥១:៩,១៧ ៥២:១) ។ *កិត្តិយស* ពាក្យនេះគឺជាភាសាអក្សរសាស្ត្រ (មើលការពន្យល់ ៧:៥) ។ *ពិណ ហើយនិងស៊ុង* វត្ថុទាំងនេះគឺជាឧបករណ៍ភ្លេងដើម្បីលេងក្នុងពេលសរសើរតម្កើងចំពោះព្រះអម្ចាស់នៅក្នុងព្រះវិហារនាពេលដែលទ្រង់បានរំដោះ និងជួយសង្គ្រោះពួកគេឱ្យរួចពីពួកខ្មាំងសត្រូវ (មើល ៧១:២២ ៨១:២ និងការពន្យល់ក្នុង ៤ ត្រង់ចំណងជើង) ។ *ភ្ញាក់ពីព្រលឹមស្រាង* គឺដើម្បីស្រែកដោយអំណរចំពោះសេចក្ដីសង្គ្រោះរបស់ព្រះ ។

**៥៧:៩–១០** នៅក្នុងខទាំងនេះ គឺជាបំណន់នៃការសរសើរដំកើងចំពោះព្រះយេហូវ៉ានៃពួកពលបរិវ៉ា (មើលការពន្យល់ ៧:១៧ និង ៩:១) ។

**៥៧:១០** *សេចក្ដីសប្បុរស* មើលការពន្យល់ ៦:៤ ។ *សេចក្ដីសប្បុរស . . . សេចក្ដីពិត* គឺមានន័យថា ព្រះអង្គជាព្រះនៃសេចក្ដីសប្បុរស និងសេចក្ដីពិត (មើល ខ.៣ និងការពន្យល់ ៣៦:៥ ហើយនិងការពន្យល់ ៣:៧) ។ *ខ្ពស់ដល់ផ្ទៃមេឃ* មើលការពន្យល់ ៣៦:៥ ។

**៥៧:១១** នៅក្នុងខនេះ គឺជាបទបន្ទរ (មើល ខ.៥) ប៉ុន្តែនៅទីនេះ គឺចង់និយាយពីការសរសើរដំកើងវិញ (មើល ១៨:៤៦ ៣០:១ ៣៤:៣ ៣៥:២៧ ៤០:១៦ ៧០:៤ ៩២:៨ ៩៧:៩ ៩៩:២ ១១៣:៤ ១៤៨:១៣) ។

**ទដ ៥៨** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអំពាវនាវដល់ព្រះអម្ចាស់ ដែលទ្រង់ជាចៅក្រម សូមឱ្យព្រះអង្គទ្រង់ផ្ដល់ភាពយុត្តិធម៌ដល់មនុស្សជាតិ ដោយសូមឱ្យព្រះអង្គទ្រង់ជំនុំជម្រះដល់អ្នកដឹកនាំទាំងឡាយណា ដែលពុករលួយ អយុត្តិធម៌ និងបង្ករហេតុទាស់នឹងពួកសុចរិត ។ (ក្រុមជំនុំជំនាន់មុន បានយកព្រះគម្ពីរទដក្នុងជំពូកនេះ និយាយសំដៅលើការកាត់ទោសព្រះយេស៊ូវគ្រីស្ទនៅចំពោះមុខពួកមេដឹកនាំសាសនាយូដា មើល មថ ២៦:៥៧–៦៨) ។ ការជំនុំជម្រះដោយយុត្តិធម៌ គឺមាននិយាយជាច្រើនក្នុងសញ្ញាចាស់ទាំងមូល ។ ការនេះ គឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធរដ្ឋបាលសម្រាប់ពួកអ្នកដែលរស់នៅក្នុងតំបន់មជ្ឈឹមបូព៌ានាសម័យបុរាណ ក្នុងការការពារជនដែលស្មោះត្រង់ជាពិសេសគឺពួកអ្នកក្រីក្រ និងជនដែលគ្មានអំណាច ។ ពួកអ្នកដែលរំលោភបំពានទាំងនោះជានិច្ចកាល គឺជាពួកអ្នកមានទ្រព្យសម្បត្តិមានអំណាច ។ ពួកប្រជាជនអ៊ីស្រាអែលគេកំពុងតែជួបប្រទះនឹងបញ្ហាពុករលួយ ពីសំណាក់ពួកចៅក្រម ដែលមានអំណាចចាប់តាំងពីគ្រាហោរាសាំយូអែលរហូតដល់គ្រាចុងក្រោយនៃរបបរាជានិយម (មើល ១សយ ៨:៣ អស ១:២៣ ៥:២៣ ១០:១–២ អក ២២:៦,១២ អម ៥:៧,១០–១៣ មីក ៣:១–៣,៩–១១ ៧:២) ។ ទោះបីជាក្នុងសម័យកាលដែលដែលស្ដេចដាវីឌ ទ្រង់គ្រប់គ្រងក៏ដោយក៏ស្ថានភាពក្នុងប្រទេសមិនល្អទាំងស្រុងនោះឡើយ (មើល ២សយ ១៥:១–៤) ។ ចំណុចស្នូលនៃទំនាក់ទំនងនេះក្នុងព្រះគម្ពីរ ទដ ត្រង់នេះ មើល ទដ ៨២ ។ ទដ ៥៨ នេះជាដៃគូនឹង ទដ ៥៦ មើលសេចក្ដីផ្ដើម ទដ នោះ) ។

លក្ខណះសំណង់ប្រយោគក្នុង ទដ ជំពូកនេះមាននិយាយបំភ្លៃដល់ពួកចៅក្រមអាក្រក់ (មើល ខ.១–២) និងការធានាចំពោះ "មនុស្សសុចរិត" (ខ.៩–១១) ។ នៅក្នុងជំពូកនេះ បានសង្កត់ធ្ងន់ថា អ្នកណាដែលកាត់ក្ដីដោយអយុត្តិធម៌ (ខ.១) នោះព្រះអម្ចាស់ទ្រង់នឹងជំនុំជម្រះដល់អ្នកនោះ (ខ.១១) ។ ចន្លោះពីខមួយទៅខមួយមាន២ ឬ៣ខដែលឈរនៅក្រៅផ្ទៃរឿង ដោយក្នុងនោះ ខ.៣–៥ និយាយពីផ្លូវរបស់ពួកមនុស្សអាក្រក់និង ខ.៦–៨ និយាយពីអសមត្ថភាពរបស់ពួកគេ ។

**ទដ ៥៨ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ៤ ត្រង់ចំណងជើង ។ *លើកតាមបទ* មើលការពន្យល់ ទដ ៩ ត្រង់ចំណងជើង ។ *សូមកុំបំផ្លាញ* មើល ទដ ៥៧ ៥៩ ៧៥ ត្រង់ចំណងជើង ។ *សេចក្ដីបង្រៀន* មើលការពន្យល់ ទដ ១៦ ត្រង់ចំណងជើង ។

**៥៨:២–៥** នៅក្នុងខទាំងនេះ គឺជាពាក្យសម្ដីទាស់ប្រឆាំងចំពោះពួកចៅក្រមអាក្រក់ ។

**៥៨:១–២** នៅក្នុងខទាំងនេះ គឺជាការទាស់ប្រឆាំងចំពោះការដឹកនាំរបស់ពួកមនុស្សអាក្រក់ ដោយព្រោះ មាត់ ចិត្ត ដៃរបស់គេរួមគ្នា ដើម្បីបង្កើតអំពើអយុត្តិធម៌ ។

**៥៨:២** *ចិត្ត* មើលការពន្យល់ ៤:៧ ។ *ថ្លឹងឱ្យមានការច្រឡោត* នេះគឺជាសម្រេចចិត្តក្នុងការកាត់ក្ដីបែបអយុត្តិធម៌ ។

**៥៨:៣–៥** នៅក្នុងខនេះ គឺចង់និយាយពីភាពរឹងចចេសនិងភាពកាចសាហាវរបស់ពួកមនុស្សអាក្រក់ ។

គេវង្វេង ហើយពោលសេចក្ដីកំភូតតាំងតែពីកើតមក
៤ពិសរបស់គេ ដូចជាពិសនៃពស់[ឃ] ដូចជាពស់វែកដីឡង់
ដែលបិទត្រចៀក
៥ដែលមិនព្រមស្ដាប់[ង]សំឡេងរបស់គ្រូអាយលម្ដាយ[ច]
ទោះបើចេះសូត្របៀនប្រសប់យ៉ាងណាក៏ដោយ
៦ឱព្រះអង្គអើយ[ឆ] សូមបំបាក់ធ្មេញនៅក្នុងមាត់គេ
ឱព្រះយេហូវ៉ាអើយ សូមបំបាក់ចង្កូមនៃពួកសិង្ហស្ទាវ[ជ]
៧សូមឱ្យគេរលាយហូរទៅដូចជាទឹក[ឈ]
កាលណាគេដំរង់ព្រួញគេ នោះ
សូមឱ្យព្រួញទាំងនោះ បានដូចជាបាក់វិញ[ញ]
៨សូមឱ្យគេបានដូចជាខ្យងដែលរលាយបាត់ទៅ[ដ]
ដូចជាកូនរលូត[ឋ]ដែលមិនឃើញពន្លឺថ្ងៃឡើយ
៩ឯមុនដែលរំកាច់ឱស[ឌ]បានប៉ះនឹងឆ្នាំង
នោះខ្យល់កួចនឹងផាត់យកទៅ[ឍ]
ដោយទាំងឱសស្រស់នឹងឱសដែលឆេះផង
១០ឯមនុស្សសុចរិត គេនឹងមានសេចក្ដីអំណរ[ណ]ដោយឃើញ
សេចក្ដីសងសឹក[ត] គេនឹងលាងជើងក្នុងឈាមនៃមនុស្ស
អាក្រក់[ថ]
១១បានជាមនុស្សនឹងថា ពិតប្រាកដជាមានរង្វាន់ដល់មនុស្ស
សុចរិត[ទ]ពិតប្រាកដជាមានព្រះ១អង្គដែលវិនិច្ឆ័យនៅផែន
ដីដែរ[ធ]។

ពាក្យកាព្យរបស់ស្ដេចដាវីឌ ដែលទ្រង់លើកតាមបទ
"សូមកុំបំផ្លាញ" ក្នុងកាលដែលស្ដេចសូលចាត់គេទៅឈ្លបលប
នៅឯផ្ទះ[ក] ដើម្បីនឹងសំឡាប់ទ្រង់ សំរាប់មេភ្លេង ។

**៥៩** ឱព្រះនៃទូលបង្គំអើយ[ខ] សូមទ្រង់ជួយឱ្យទូលបង្គំរួច

**៥៨:៤** ឃ ជន ២១:៦ **៥៨:៥** ង ទដ ៨១:១១ ច សស ១០:១១ យរ ៨:១៧ **៥៨:៦** ឆ ទដ ៣:៧ ជ យប ៤:១០ **៥៨:៧** ឈ លវ ២៦:៣៦ យប ១១:១៦ ញ ទដ ១១:២ ៥៧:៤ ៦៤:៣ **៥៨:៨** ដ អស ១៣:៧ ឋ យប ៣:១៦ **៥៨:៩** ឌ ទដ ១១៨:១២ សស ៧:៦ ឍ យប ៧:១០ ២១:១៨ **៥៨:១០** ណ យប ២២:១៩ ត ចទ ៣២:៣៥ ទដ ៧:៩ ៩១:៨ យរ ១១:២០ រម ១២:១៧–២១ ថ ទដ ៦៨:២៣ **៥៨:១១** ទ លប ១៥:១ ទដ ១២៨:២ លក ៦:២៣ ធ លប ១៨:២៥ **៥៩:ចំណងជើង** ក ១សយ ១៩:១១ **៥៩:១** ខ ទដ ១៤៣:៩

**៥៨:៣** *តាំងពីពោះម្ដាយ . . . តាំងតែពីកើតមក* នៅក្នុងឃ្លានេះចង់និយាយថា ពួកគេបានប្រព្រឹត្តអំពើបែបអយុត្តិធម៌ជារៀងរហូតមកតាំងពីកំណើតមកម្ល៉េះ (មើល ៥១:៥) ។ នៅទីនេះអ្នកនិពន្ធនិយាយចំពោះតែពួកមនុស្ស "អាក្រក់"ប៉ុណ្ណោះ ។ គាត់មិនបាននិយាយពីគ្រប់មនុស្សទាំងអស់ នោះឡើយ ហើយករណីនេះក៏ដូចគ្នានឹងករណីដែលនិយាយនៅក្នុង លប ៦:៥ ៨:២១ យប ១៤:៤ ១៥:១៤–១៦ ២៥:៤–៦ ដែរ ។ *មនុសអាក្រក់* ភាគច្រើននៃពួកមនុស្សអាក្រក់ទាំងនោះ គឺជាពួកអ្នកដែលមានអំណាចគ្រប់គ្រង ឬដឹកនាំប្រទេស ។ សូមមើលការពណ៌នាពីចរិតលក្ខណៈទូទៅរបស់មនុស្សអាក្រក់ ទដ ជំពូក ១០ ។ *ពោលសេចក្ដីកំភូត* មានន័យថាពួកគេមិនដែលខ្វល់នឹងការនិយាយពាក្យពិតនោះឡើយ (មើល យហ ៨:៤៤) ។

**៥៨:៤** *ពិស* នៅក្នុងឃ្លានេះចង់និយាយថា អ្វីដែលចេញពីមាត់គេគឺមានភាពកាចសាហាវព្រៃផ្សៃដូចជាពិសពស់ដែរ (មើល ១៤០:៣ មថ ២៣:៣៣ យក ៣:៨) ។ *បិទត្រចៀក* មានន័យថាពួកគេក្បាលរឹង ។

**៥៨:៦–៨** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះយេហូវ៉ាទ្រង់បានកំចាត់កំចាយដល់ពួកមនុស្សអាក្រក់ ។ អ្នកនិពន្ធប្រើរូបភាពនេះដោយដកស្រង់ចេញពីពួកមនុស្សដែលរស់នៅក្នុងតំបន់មជ្ឈឹមបុព៌ា កាលពីសម័យបុរាណ (សូមមើលការពន្យល់ ៥:១០) ។

**៥៨:៦** នៅក្នុងខនេះចង់និយាយថា សូមឱ្យអាវុធនៃមាត់របស់គេ (មើល ៥៧:៤) បានបែកបាក់ និងកំចាត់កំចាយ ។ *សិង្ហ* មើលការពន្យល់ ៧:២ ។

**៥៨:៧** *ហូរទៅដូចជាទឹក* នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យគេបានហូរទៅដូចជាទឹកដែលជ្រាបដោយសារដី ។ *ព្រួញ* មានន័យថា ការអាក្រក់របស់គេអាក្រក់ហួសពីការថ្លែងទៅទៀត (មើល ៥៧:៤) ។

**៥៨:៨** *ខ្យង* គឺជាខ្យងនៅក្នុងទីហួតហែង ហើយផ្លាស់ប្ដូរដោយការលូនលើថ្មក្រោមកំដៅថ្ងៃ ។

**៥៨:៩–១១** នៅក្នុងខនេះអ្នកនិពន្ធមានទំនុកចិត្តថា ព្រះទ្រង់នឹងជំនុំជម្រះដល់ពួកមនុស្សអាក្រក់ទាំងនោះ (សូមមើលការពន្យល់ ៣:៨) ។

**៥៨:៩** នៅក្នុងខនេះប្រហែលនិយាយថា ព្រះទ្រង់នឹងជំរុំជម្រះដល់ពួកគេក្នុងពេលឆាប់ៗ ។ *រំកាច់ឱស* គឺជាមែកឈើតូចៗដែលគេយកពីព្រៃមកប្រើដើម្បីកំដៅនិងចំអិនម្ហូបអាហារបានយ៉ាងឆាប់រហ័ស (សូមមើល ១១៨:១២ សស ៧:៦) ។ *ផាត់យកទៅ* គឺផាត់ទៅដោយសារព្យុះរបស់ព្រះ (មើល យប ២៧:២១) ។

**៥៨:១០** *មនុស្សសុចរិត* នៅទីនេះពួកចៅក្រមបានកាត់ទោសដ៏ត្រឹមត្រូវដល់ពួកអ្នកដែលសុចរិត ប៉ុន្តែអយុត្តិធម៌ដល់អ្នកណាដែលប្រព្រឹត្តិខុសវិញ (មើលការពន្យល់ ១:៥) ។ *ដោយឃើញសេចក្ដីសងសឹក* គឺនៅពេលដែលព្រះអម្ចាស់បានដាក់ទោសដល់ពួកអ្នកដែលទាស់ប្រឆាំងនឹងទ្រង់ ។ *គេនឹងលាងជើងក្នុងឈាមនៃមនុស្សអាក្រក់* រូបភាពដែលយកមកនិយាយនេះ គឺដកស្រង់ចេញពីអក្សរសាស្ត្ររបស់ពួកមនុស្ស ដែលរស់នៅក្នុងតំបន់មជ្ឈឹមបុព៌ា កាលពីសម័យបុរាណ (មើល ៦៨:២៣) ។ នេះគឺជាភាសារបំភ្លើសរបស់ពួកអ្នកដែលធ្វើសង្គ្រាមឈ្នះ នៅពេលគេរាយការណ៍ពីជ័យជម្នះរបស់ពួកគេ ។

**៥៨:១១** នៅក្នុងខនេះចង់និយាយថា នៅពេលដែលព្រះទ្រង់ជំនុំជម្រះដល់ "ចៅក្រម"ដែលអយុត្តិធម៌ (មើលការពន្យល់ ខ.១) នោះមនុស្សទាំងអស់គេនឹងបានឃើញថា ទីបំផុតពួកមនុស្សល្អនឹងបានឈ្នះដោយសារការជំនុំជម្រះរបស់ព្រះ (មើលការពន្យល់ ៤៦:១០ និង ទដ ៩៣,៩៦–៩៩) ។ គ្មានអ្វីទៀតដែលធ្វើឱ្យបណ្ដារាស្ត្រទាំងអស់នោះអស់សង្ឃឹមឡើយ ការនេះក៏ដូចគ្នានឹងមនុស្សដែលបាននិយាយនៅក្នុង មឡ ៣:១៥ ដែរ ។

**ទដ ៥៩** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះយេហូវ៉ាទ្រង់បានរំដោះ និងជួយសង្គ្រោះគាត់ក្នុងពេលដែលគាត់ជួបគ្រោះថ្នាក់ដោយការវាយប្រហារពីសំណាក់ពួកខ្មាំងសត្រូវរបស់គាត់ (ទំនាក់ទំនងព្រះគម្ពីរជំពូកនេះជាមួយ ទដ ៥៥ សូមមើលក្នុងសេចក្ដីផ្ដើមព្រះគម្ពីរនោះ និងសេចក្ដីផ្ដើម ទដ ៥៤–៦០) ។ បើសិនជាបទគម្ពីរទំនុកដំកើងត្រង់ជំពូកនេះ ជាការតែងឡើងដោយស្ដេចដាវីឌ ក្នុងពេលដូចដែលបាននិយាយពីខាងដើមមែននោះព្រះគម្ពីរនេះត្រូវបានសរសេរនិងកែប្រែជាថ្មី ដើម្បីឱ្យក្រុមចម្រៀងណាមួយរបស់ស្ដេចដាវីឌ ច្រៀងក្នុងពេលដែលក្រុងយេរូសាឡិមកំពុងជួប

ពីពួកខ្មាំងសត្រូវ សូមការពារឱ្យរួចពីពួកអ្នកដែលលើក
គ្នាទាស់នឹងទូលបង្គំ[ក]
២សូមជួយទូលបង្គំឱ្យរួចពីពួកអ្នកដែលប្រព្រឹត្តអាក្រក់[ឃ]
ហើយសង្គ្រោះទូលបង្គំឱ្យរួចពីមនុស្សដែលកំចាយឈាម[ង]
៣ដ្បិតមើល ឱព្រះយេហូវ៉ាអើយ គេលបចាំប់ជីវិតទូលបង្គំ
ពួកមនុស្សខ្លាំងពូកែគេប្រជុំគ្នា[ច]ទាស់នឹងទូលបង្គំ
មិនមែនដោយព្រោះអំពើរំលង
ឬអំពើបាបរបស់ទូលបង្គំឡើយ
៤គេរត់មកត្រៀមខ្លួន[ឆ] ឥតទូលបង្គំធ្វើខុសអ្វីផង[ជ]
សូមទ្រង់តើនឡើងមកជួយទូលបង្គំ
ហើយពិចារណាមើល[ឈ]
៥ឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារគឺជាព្រះនៃ
សាសន៍អ៊ីស្រាអែលអើយ[ញ]
សូមទ្រង់តើនឡើង[ដ]មកដាក់ទោសដល់ពួកសាសន៍ដទៃ[ឋ]
សូមកុំអាណិតមេត្តាដល់អ្នកណាមួយ ដែលរំលងដោយ
កាចអាក្រក់ឡើយ[ឌ] ។ –បង្អង់
៦គេត្រឡប់មកវិញរាល់តែល្ងាច គេលូដូចជាឆ្កែ[ឍ]
ព្រមទាំងដើរក្រវែលទីក្រុង
៧មើល គេភើចេញមកពីមាត់គេ[ណ]
ក៏មានដាវ[ត]នៅបបូរមាត់ ដ្បិតគេថា តើមានអ្នកណានឹងឮ[ថ]
៨តែឱព្រះយេហូវ៉ាអើយ ទ្រង់នឹងសើចឡកឱ្យគេ[ទ]
ទ្រង់នឹងចំអកឱ្យពួកសាសន៍ដទៃទាំងអស់ផង[ធ]
៩ហេតុដោយព្រោះគេមានកំឡាំងខ្លាំង[ន]បានជាទូលបង្គំ

**៥៩:១** ក ទដ ២០:១ **៥៩:២** ឃ ទដ ១៤:៤ ៣៦:១២ ៥៣:៤ ៩២:៧ ៩៤:១៦ ង ទដ ២៦:៩ ១៣៩:១៩ សភ ២៩:១០ **៥៩:៣** ច ទដ ១១៩:៣ **៥៩:៤** ឆ មថ ៥:១១ ជ ទដ ១១៩:៣ ឈ ទដ ១៣:៣ **៥៩:៥** ញ ទដ ៦៩:៦ ៨០:៤ ៨៤:៨ ដ ទដ ៤៤:២៣ ឋ ទដ ៩:៥ អស ១០:៣ ឌ យរ ១៨:២៣ **៥៩:៦** ឍ ខ.១៤ ទដ ២២:១៦ **៥៩:៧** ណ ទដ ៩៤:៤ សភ ១០:៣២ ១២:២៣ ១៥:២,២៨ ត ទដ ៥៥:២១ ថ យប ២២:១៣ **៥៩:៨** ទ ទដ ៣៧:១៣ សភ ១:២៦ ធ ទដ ២:៤ **៥៩:៩** ន ទដ ១៨:១

ការឡោមព័ទ្ធពីសំណាក់ពួកខ្មាំងសត្រូវដែលមកពីគ្រប់ទិសទី និងមកពីគ្រប់ប្រជាជាតិ ។ ជាក់ស្តែង ដូចជាស្តេចស្រុកអាសស៊ើរឡោមព័ទ្ធទីក្រុងក្នុងអំឡុងពេលដែលស្តេចហេសេគាគ្រប់គ្រង (សូមមើល ២ពវ ១៨:១៩) ។ ភាគច្រើននៃអាវុធយុទ្ធភ័ណ្ឌ របស់ខ្មាំងសត្រូវទាំងនោះគឺជាអណ្តាតដែលអាចនាំឱ្យសម្លាប់ និងដាក់បណ្តាសា (មើលការពន្យល់ ៥:៩) ។ នៅក្នុងព្រះគម្ពីរទំនុកដំកើងជំពូកនេះដែរ ក៏បាននិយាយពីរូបភាពដែលនិយាយពីគ្រោះថ្នាក់ ក្នុងពេលយប់ (មើល ខ.៦,១៤) នោះនឹងបានដោះលែងនៅពេលព្រឹកព្រលឹម (មើល ខ.១៦) ។

លក្ខណៈសំណង់ប្រយោគវិញ ព្រះគម្ពីរនោះបានបែងចែកជា ២ផ្នែកដែលមានតុល្យភាពនឹងគ្នា (ខ.១–៩,១០–១៧) ហើយផ្នែកនិមួយៗបានបញ្ចប់ដោយមានបទបន្ទរ (មើល ខ.៩,១៧) ហើយនៅដើមល្បះក៏បានចាប់ផ្តើមនិយាយពីចរិតលក្ខណៈរបស់ពួកខ្មាំងសត្រូវ (ខ.៦,១៤) នៅពាក់កណ្តាលនៃផ្នែកទី១នៃព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺមាននិយាយពីសេចក្តីអធិស្ឋានជាច្រើន ហើយនៅពាក់កណ្តាលនៃផ្នែកទី២វិញ បាននិយាយពីការធានាចំពោះការរំដោះ និងការជួយសង្គ្រោះ ។ នៅក្នុងបទគម្ពីរជំពូកនេះទាំងមូល មាននិយាយពីការអធិស្ឋានសូមឱ្យព្រះទ្រង់បានការពារ (ខ.១) និងការនិយាយដោយអំណររបស់អ្នកនិពន្ធថា ព្រះយេហូវ៉ាទ្រង់ "ប៉មយ៉ាងខ្ពស់"របស់ទូលបង្គំ (ខ.១៧) ។ នៅក្នុងភាសាហេព្រើរ ពាក្យថា"ប៉មយ៉ាងខ្ពស់"ដែលនិយាយក្នុងខនេះ គឺជាការដកស្រង់ចេញពីពាក្យថា "ការពារ"ដែលមាននិយាយនៅក្នុង ខ.១ ។

**៥៩ ត្រង់ចំណងជើង** សូមមើលការពន្យល់ក្នុង ទដ ៥៦ ត្រង់ចំណងជើង ។ *សូមកុំបំផ្លាញ* មើល ទដ ៥៧,៥៨,៧៥ ត្រង់ចំណងជើង ។ *ក្នុងកាល* សម្រាប់ព្រឹត្តិការណ៍ដែលនិយាយនៅក្នុងពេលនេះ មើល ១សយ ១៩:១១ ។

**៥៩:១–២** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះទ្រង់ជួយសង្គ្រោះគាត់ពីពួកខ្មាំងសត្រូវ ។

**៥៩:១** *ការពារ* ពាក្យនេះបើតាមភាសារអក្សរសាស្ត្រគេនិយាយថា"សូមលើកទូលបង្គំឱ្យបានខ្ពស់ឡើង ហើយដាក់នៅកន្លែងណា ដែលមានសុខសន្តិភាព" ។

**៥៩:២** *អ្នកដែលប្រព្រឹត្តអាក្រក់ . . . មនុស្សដែលកំចាយឈាម* នេះជាឃ្លាដ៏សាមញ្ញមួយដែលនិយាយពីចរិតលក្ខណៈដ៏អាក្រក់រកថ្លែងពុំបាននៃពួកខ្មាំងសត្រូវរបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង ។

**៥៩:៣** *លបចាំប់* មើល ១០:៨–៩ និងការពន្យល់ ៧:២ ។

**៥៩:៤** *សូមទ្រង់តើនឡើង* មើលការពន្យល់ ៣:៧ ។

**៥៩:៥** *ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវ៉ា* សូមមើលការពន្យល់ ១សយ ១:៣ ។ *ព្រះនៃសាសន៍អ៊ីស្រាអែល* នៅក្នុងឃ្លានេះចង់និយាយថា ការដែលសូមឱ្យព្រះយេហូវ៉ាទ្រង់ជាព្រះនៃសាសន៍អ៊ីស្រាអែល ដាក់ទោសដល់សាសន៍ដទៃ នោះគឺដើម្បីឱ្យគេបានដឹងថា ការដែលពួកសាសន៍ដទៃបៀតបៀនដល់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង នោះក៏ទាក់ទងនឹងការបៀតបៀនដល់ពួកអ៊ីស្រាអែលដែរ ។ *សូមទ្រង់តើនឡើង* មើលការពន្យល់ ៧:៦ ។ *ដាក់ទោស . . . អាណិតមេត្តា* មើលការពន្យល់ ៥:១០ ។ *អ្នកណាមួយដែលរំលងដោយកាចអាក្រក់* ទោះបីជាមិនដឹងពីពេលដែលពួកអ៊ីស្រាអែលត្រូវទទួលរងការវាយប្រហារពីអ្នកណាខ្លះក៏ដោយ ក៏ប៉ុន្តែបើតាមភាសាហេព្រើរដែលប្រើនៅទីនេះវិញបានបង្ហាញថា គឺមានតែពួកអ្នកដែលក្បត់ប៉ុណ្ណោះ ។

**៥៩:៦–៨** នៅក្នុងខទាំងនេះអ្នកនិពន្ធមានទំនុកចិត្តថា ព្រះយេហូវ៉ាទ្រង់នឹងសើចឡកដល់ក្រុមឆ្កែទាំងនោះ (មើល ២២:១៦–១៧) ។

**៥៩:៦** *ទីក្រុង* ពួកខ្មាំងសត្រូវទាំងនោះគេដើរក្រវែលទីក្រុងដូចជាសត្វដើរស្វែងរកចំណីនៅពេលយប់ដែរ (មើល ខ.១៤–១៥) ។

**៥៩:៧** *មានដាវនៅបបូរមាត់* នៅក្នុងឃ្លានេះគឺចង់និយាយសំដៅលើ "សេចក្តីបណ្តាសារ និងសេចក្តីកំភូត"របស់ពួកគេ (សូមមើល ខ.១២) ។ សូមមើលរូបភាពនៃការប្រៀបប្រដូចនេះក្នុង ៥៧:៤ និងការពន្យល់ ៥:៩ ។ *គេថា* សូមមើលការពន្យល់ ៣:២ ។

**៥៩:៩** *សំឡឹងមើល* នៅក្នុងភាសាហេព្រើរពាក្យនេះគឺ "សាម៉ា"(Shamar) ការពន្យល់ ខ.១៧ ។ ថ្នាក់ពាក្យជាកិរិយាស័ព្ទដែលប្រើនៅទីនេះ គឺមានការប្រហាក់ប្រហែលគ្នានឹងកិរិយាដែលគេប្រើ ៣១:៦ និង យហ ២:៩ ដែរ ("មើលទៅ") ។ ពាក្យនេះវាជាគ្រឹះនៃពាក្យដែលថា សូមសេចក្តីជំនួយ

សំឡឹងមើលដល់ទ្រង់ ដ្បិតព្រះទ្រង់ជាប៉មយ៉ាងខ្ពស់[ប]នៃ
ទូលបង្គំ
១០ព្រះនៃទូលបង្គំ ទ្រង់នឹងយាងមកប្រោសដោយសេចក្ដី
សប្បុរសនៃទ្រង់ ទ្រង់នឹងឱ្យទូលបង្គំឃើញបំណងចិត្តធ្លាក់
លើពួកខ្មាំងសត្រូវរបស់ទូលបង្គំ
១១សូមកុំសំឡាប់គេ ក្រែងរាស្ត្រទូលបង្គំភ្លេច[ផ]តែ
ឱព្រះអម្ចាស់ដ៏ជាខែលនៃយើងខ្ញុំ[ព] អើយសូមកំចាត់កំចាយ
គេ ដោយព្រះចេស្តាទ្រង់ ហើយទំលាក់គេចុះវិញ[ភ]
១២សូមឱ្យគេជាប់ទោស ដោយសេចក្ដីអំនួតរបស់គេ[ម]
ដោយព្រោះបាបរបស់មាត់គេ[យ] និងពាក្យដែលចេញ
ពីបបូរមាត់[រ] ព្រមទាំងសេចក្ដីបណ្ដាសា
និងសេចក្ដីភូតភរដែលគេពោលនោះផង
១៣សូមបំផ្លាញគេ ដោយសេចក្ដីក្រោធរបស់ទ្រង់
សូមបំផ្លាញគេ ដើម្បីកុំឱ្យមានទៀតឡើយ[ល]
ហើយឱ្យគេដឹងថា ព្រះទ្រង់គ្រប់គ្រង
នៅលើពួកយ៉ាកុបរហូតដល់ចុងផែនដីបំផុត[វ] ។ –បង្អង់
១៤នោះឱ្យគេត្រឡប់មកលូវរាល់តែល្ងាចដូចជាឆ្កែ
ឱ្យគេដើរក្រវែលទីក្រុងចុះ
១៥គេនឹងដើរចុះឡើងរកអាហារ[ស]
ហើយបើគេមិនបានឆ្អែតនោះឱ្យគេអាស្រ័យដរាបដល់ភ្លឺ
ទៀត
១៦តែទូលបង្គំនឹងច្រៀង[ហ]ពីព្រះចេស្តានៃទ្រង់[ឡ] អើ
ចាប់តាំងពីព្រលឹងស្រាង[អ]នោះទូលបង្គំនឹងបន្លឺសំឡេង
ច្រៀងពីសេចក្ដីសប្បុរសរបស់ទ្រង់[ក]
ដ្បិតទ្រង់ជាប៉មយ៉ាងខ្ពស់នៃទូលបង្គំ[ខ] ហើយជាទីជ្រក
នៅថ្ងៃដែលទូលបង្គំមានសេចក្ដីវេទនា[គ]
១៧ឱព្រះដ៏ជាកំឡាំងនៃទូឡបង្គំអើយ ទូលបង្គំនឹងច្រៀង
សរសើរដល់ទ្រង់ ដ្បិតព្រះទ្រង់ជាប៉មយ៉ាងខ្ពស់នៃទូលបង្គំ
ក៏ប្រកបដោយមេត្តាករុណាចំពោះទូលបង្គំផង[ឃ] ។

*៦០:៥–១២ – ទដ ១០៨:៦០–១៣*

ពាក្យកាព្យរបស់ស្តេចដាវីឌ

ដែលទ្រង់លើកតាមបទឈ្មោះ "ត្រែនៃសេចក្ដីបន្ទាល់" ក្នុងកាលដែលទ្រង់ច្បាំងនឹងសាសន៍អើរ៉ាម–ន៉ាហារេម ហើយនិងសាសន៍អើរ៉ាម–សេបា រួចយ៉ូអាប់ត្រឡប់មកវាយសាសន៍អេដំមទាំង១ម៉ឺន ២ពាន់នាក់នៅច្រកភ្នំអំបិល សំរាប់មេភ្លេង ។

**៦០** ឱព្រះអង្គអើយ ទ្រង់បានបោះបង់ចោលយើងខ្ញុំ[ក]
ទ្រង់បានទំលាយទំលុះយើងខ្ញុំហើយ[ខ] ទ្រង់បានមានសេចក្ដី

**៥៩:៩** ប ទដ ៩:៩ ១៨:២ ៦២:២ ៧១:៣
**៥៩:១១** ផ ចទ ៤:៩ ៦:១២ ប ទដ ៣:៣ ៨៤:៩ ភ ទដ ៨៩:១០ ១០៦:២៧ ១៤៤:៦ អស ៣៣:៣
**៥៩:១២** ម ទដ ១០:៧ យ ទដ ៦៤:៨ សភ ១០:១៤ ១២:១៣ រ អស ២:១២ ៥:១៥ សផ ៣:១១
**៥៩:១៣** ល ទដ ១០៤:៣៥ វ ទដ ៨៣:១៨
**៥៩:១៥** ស យប ១៥:២៣
**៥៩:១៦** ហ ទដ ១០៨:១ ឡ ១សយ ២:១០ អ ទដ ៥:៣ ៨៨:១៣ ក ទដ ១០១:១ ខ ២សយ ២២:៣ គ ចទ ៤:៣០
**៥៩:១៧** ឃ ខ.១០

**៦០:១** ក ២សយ ៥:២០ ទដ ៤៤:៩ ខ ទដ ៧៩:៥

ដោយ "មើលទៅទាំងមានសេចក្ដីសង្ឃឹម" មកពីព្រះអម្ចាស់ ។ ការសំឡឹងមើលរបស់អ្នកនិពន្ធ គឺដូចគ្នានឹងអ្នកដែលរងចាំសេចក្ដីសង្គ្រោះនៅពេលព្រឹកព្រលឹមដែរ (មើល ១៣០:៦) ។

**៥៩:១០–១៣** មកដល់ខនេះ អ្នកនិពន្ធអធិស្ឋានជាថ្មីទៅចំពោះព្រះអម្ចាស់ ដោយមានសង្ឃឹមថា ព្រះយេហូវ៉ាទ្រង់នឹងស្ដាប់ឮពាក្យដែលគាត់បានអំពាវនាវរកទ្រង់ (មើល ខ.១០) ហើយទ្រង់នឹងដាក់ទោសដល់ជាតិសាសន៍ដទៃ (ខ.៥) ។ អ្នកនិពន្ធបានអធិស្ឋានថា សូមកុំឱ្យព្រះអង្គសម្លាប់គេក្នុងពេលឥឡូវនេះឡើយ តែសូមឱ្យព្រះអង្គទ្រង់បានដាក់ទោសដល់គេយ៉ាងយូរវិញ ដើម្បីឱ្យពួកអ៊ីស្រាអែល ("រាស្ត្រទូលបង្គំ") មិភ្លេចពីសេចក្ដីសង្គ្រោះរបស់ព្រះអង្គដូចដែលគេធ្លាប់បានធ្វើកន្លងមក (មើល ៧៨:១១ ១០៦:១៣) ។ តែទោះបីជាយ៉ាងណាក៏ដោយ អ្នកនិពន្ធគាត់បានអធិស្ឋានសូមឱ្យព្រះយេហូវ៉ាទ្រង់បានដាក់ទោសដល់ពួកគេទាំងអស់គ្នា កុំឱ្យអ្នកណាម្នាក់រួចជីវិតនោះឡើយ (មើល ខ.១២–១៣) ។

**៥៩:១០** *សេចក្ដីសប្បុរស* មើលការពន្យល់ ៦:៤ ។

**៥៩:១១** *ខែល* មើលការពន្យល់ ៣:៣ ។ *កំចាត់កំចាយ* គឺដូចគ្នានឹងពួកមនុស្សអនាថា ដែលគ្មានទីលំនៅស្នាក់អាស្រ័យដែរ (មើល លប ៤:១២ ២សយ ១៥:២០ បទ ៤:១៥) ហើយមានតែការបរបាញ់ ឬចាប់សត្វប៉ុណ្ណោះ ដើម្បីឱ្យបានអាហារបរិភោគ (ដូចជាសត្វឆ្កែ ខ.១៥ ១០៨:១០ អម ៤:៨) ។

**៥៩:១២** សូមមើលការពន្យល់ក្នុង ខ.៧ ។ *សូមឱ្យគេជាប់ទោស ដោយសេចក្ដីអំនួតរបស់គេ* នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យសេចក្ដីអំណួតនិងការក្បត់របស់ពួកគេដែលធ្វើទុក្ខ និងវាយប្រហារដល់អ្នកបម្រើរបស់ព្រះនិងរាស្ត្រទ្រង់ក្លាយជាអន្ទាក់ដាក់ដល់គេវិញ ។ *សេចក្ដីបណ្ដាសា និង សេចក្ដីកំភូត* សូមមើល ១០:៧ និងការពន្យល់ ។

**៥៩:១៣** *ដើម្បីឱ្យគេដឹងថា* នៅពេលដែលព្រះអង្គទ្រង់បានធ្វើការទាំងនោះដល់ពួកអ៊ីស្រាអែលហើយ នោះពួកមនុស្សទាំងអស់នៅក្នុងលោកិយគេនឹងទទួលស្គាល់ថា ជាចៅក្រមដ៏ពិតប្រាកដនៅលើលោកិយនេះ (មើល ៥៨:១១) គឺជាព្រះនៃពួកអ៊ីស្រាអែល ។ *យ៉ាកុប* មើលការពន្យល់ ១៤:៧ ។

**៥៩:១៤–១៦** នៅក្នុងខនេះ គឺជាការធានាចំពោះអ្នកដែលស្ដាប់ឮ (មើលការពន្យល់ ៣:៨) ។ ដោយសារព្រះយេហូវ៉ាទ្រង់បានសើចចំអកមើលងាយដល់ពួកឆ្កែទាំងនោះ (ខ.៦–៨) នោះបានធ្វើឱ្យអ្នកនិពន្ធបានច្រៀងពីព្រះដោយអំណរនៅមុខពួកគេ ។

**៥៩:១៦** *សេចក្ដីសប្បុរស . . . ប៉ម . . . ជាទីពឹងជ្រក* សូមមើលបទបន្ទរ (ខ.៩,១៧) ។ *ពេលព្រឹក* សូមមើលក្នុងសេចក្ដីផ្ដើម ។

**៥៩:១៧** នៅក្នុងជំពូកនេះ គឺជាសេចក្ដីសន្យានៃការសរសើរតម្កើងដល់ព្រះ (មើលការពន្យល់ ៧:១៧) ។ *ច្រៀង* នៅក្នុងព្រះគម្ពីរភាសាហេព្រើរគឺហ្សាម៉ា (មើលការពន្យល់ ខ.៩) ។ ការលេងពាក្យនៅក្នុងបទបន្ទរនេះ គឺបានធ្វើឱ្យយើងទន្ទឹងរងចាំសេចក្ដីជំនួយមកពីព្រះយេហូវ៉ា ក្នុងយប់នៃគ្រោះថ្នាក់ ហើយក៏បានច្រៀងពីសេចក្ដីសង្គ្រោះនោះពេលព្រឹកផងដែរ (ធៀបជាមួយ ៥៧:៨ និងការពន្យល់ ៣០:៥) ។

**ទដ ៦០** នៅក្នុងជំពូកនេះពួកប្រជាជាតិអ៊ីស្រាអែល គេបានអំពាវនាវដល់ព្រះយេហូវ៉ាដើម្បីសូមសេចក្ដីជំនួយមកពីព្រះអង្គ បន្ទាប់ពីពួកគេរងទុក្ខវេទនាជាច្រើន ដែលពួកសាសន៍ដទៃបានបក់មកលើពួកគេ ហើយគេគិតថាពួកសាសន៍ដទៃទាំងនេះគឺជាពួកអេដំម (មើល ខ.៩) ។ អ្នកដឹកនាំការ

ខ្វាល់ ឱសូមឱ្យយើងខ្ញុំបានដូចដើមវិញ[គ]
២ ទ្រង់បានធ្វើឱ្យស្រុក[ឃ]ញាប់ញ័រ ព្រមទាំងបំបែកចេញផង
សូមកែទីធ្លុះធ្លាយឡើងវិញ[ង] ដ្បិតកំពុងតែទ្រេតទ្រោតទៅ
៣ ទ្រង់បានធ្វើឱ្យរាស្ត្រទ្រង់ឃើញការពិបាកណាស់[ច]
ទ្រង់បានធ្វើឱ្យយើងខ្ញុំផឹកស្រាជាសេចក្ដីងេងងោង[ឆ]
៤ តែទ្រង់បានប្រទានទង់ជ័យ[ជ]១ដល់ពួកអ្នកដែលកោតខ្លាច
ទ្រង់ ដើម្បីឱ្យបានលើកឡើងឱ្យឃើញដោយព្រោះសេចក្ដី
ពិត ។ –បង្អង់

៥ សូមជួយសង្គ្រោះយើងខ្ញុំដោយសារព្រះហស្តស្តាំនៃទ្រង់[ឈ]
ហើយស្តាប់ យើងផង
ដើម្បីឱ្យស្ងួនភ្ងា[ញ]របស់ទ្រង់បានសេចក្ដីប្រោសឱ្យរួច
៦ ព្រះទ្រង់បានមានបន្ទូលដោយសេចក្ដីបរិសុទ្ធ របស់ទ្រង់
ហើយយើងនឹងត្រេកអរឡើង យើងនឹងបែងចែងក្រុង
ស៊ីគែម[ដ] ហើយនិងវាស់ច្រកភ្នំសិកូត[ឋ]

**៦០:១** គ ទដ ៨០:៣ **៦០:២** ឃ ទដ ១៨:៧ ង ២របា ៧:១៤ **៦០:៣** ច ទដ ៧១:២០ ឆ ទដ ៧៥:៨ អស ២៩:៩ ៥១:១៧ ៦៣:៦ យរ ២៥:១៦ សក ១២:២ វវ ១៤:១០ **៦០:៤** ជ អស ៥:២៦ ១១:១០,១២ ១៨:៣ **៦០:៥** ឈ យប ៤០:១៤ ញ ចទ ៣៣:១២ **៦០:៦** ដ លប ១២:៦ ឋ លប ៣៣:១៧

អធិស្ឋាននេះប្រហែលជាស្តេច (មើលពាក្យថា "ទូលបង្គំ" ខ.៩) ដូចគ្នានឹងការអធិស្ឋានក្នុង ២របា ជំពូក ២០ ដែរ ។ ការនិយាយពីសំណោកដែលបណ្ដាលឱ្យព្រះអង្គ"បោះបង់ចោល"(ខ.១,១០) ប្រជារាស្ត្ររបស់ទ្រង់ និងការដែលទ្រង់មិនបានយាងទៅជាមួយនឹង"ពលទ័ព"របស់យើង (ខ.១០) នោះបានធ្វើឱ្យព្រះគម្ពីរទំនុកដំកើងជំពូកនេះ មានទំនាក់ទំនងជាមួយ ទដ ៤៤ (មើល ៤៤:៩ និងសេចក្ដីផ្ដើម ទដ ៥៤–៦០) ។ ខ.៥–១២ ដែលមាននិយាយក្នុងជំពូកនេះ និងលើកមកនិយាយម្ដងទៀត ទដ ១០៨:៦–១៣ ។ លក្ខណៈសំណង់ប្រយោគក្នុងជំពូកនេះវិញ នោះសេចក្ដីអធិស្ឋានដែលមាននៅក្នុងជំពូកនេះបានបង្ហាញឱ្យឃើញច្បាស់ ដោយមាន៣ខនិយាយពីសំណោកនៃរាស្ត្រព្រះក្នុងកាលដែលទ្រង់បានបោះបង់គេចោល (មើលក្នុង ខ.១–៣) ហើយ៣ខទៀតបានពណ៌នាពីទំនុកចិត្តថា ព្រះយេហូវ៉ាដែលទ្រង់ជាអ្នកដែលបោះបង់ពួកគេចោល នោះព្រះអង្គទ្រង់ក៏នឹងធ្វើឱ្យគេទទួលជ័យជម្នះឡើងវិញដែរ (ខ.១០–១២) ។ ផ្នែកនេះបានចាប់ផ្ដើមនិយាយពីទំនួញសោក មកការទុកចិត្តបានបង្កើតជាចលនាវិលចុះឡើងក្នុងការអធិស្ឋាន ។ នៅក្នុង ខ.៤–៨ គឺជាការអំពាវនាវសូមសេចក្ដីជំនួយ (ខ.៥) និងការទុកចិត្តចំពោះព្រះ (ខ.៤,៦–៨) ។

**៦០ត្រង់ចំណងជើង** សូមមើលការពន្យល់ ទដ ៥៦ ត្រង់ចំណងជើង ។ *ក្រៃនៃសេចក្ដីបន្ទាល់* មើល ទដ ៨០ត្រង់ចំណងជើង និងការពន្យល់ ទដ ៤៥ ត្រង់ចំណងជើង ។ *ក្នុងកាល* ព្រឹត្តិការណ៍ដែលកើតឡើងក្នុង ជំពូកនេះ មើល ២សាម ជំពូក ៨ ១របា ជំពូក ១៨ (ប្រហែលជាមាន និយាយនៅក្នុង ២សាម ជំពូក ១០ ផងដែរ) ។ បើសិនជាការអធិស្ឋាននេះ គឺជាការអធិស្ឋានចំពោះហេតុការណ៍នោះពិតប្រាកដមែន នោះការយល់ដឹងរបស់យើងអំពីហេតុការណ៍នោះ គឺជាការដែលមិនត្រឹមត្រូវឡើយ ព្រោះហេតុការណ៍នោះមិនបាននិយាយពីពួកសាសន៍អេដំមឡើយ ។ ពួកអ៊ីស្រាអែលបានធ្វើសង្គ្រាមទាស់ប្រឆាំងចំពោះពួកអេដំម ក្នុងពេលដែលទីលានចម្បាំងនៅភាគខាងជើងត្រួតត្រាដោយពួកអេដំមមួយចំនួន ដែលគេបានព្យាយាមកាន់កាប់ចំណែករបស់ពួកអ៊ីស្រាអែល ក្នុងកាលដែលពួកអ៊ីស្រាអែល ជាអ្នកកាន់កាប់មុនហើយពួកអេដំមបានឈ្នះក្នុងសង្គ្រាម ដោយបានត្រួតត្រាមូលដ្ឋានសឹកនៅភាគខាងត្បូងនៃព្រំប្រទល់យូដា ។

**៦០:១–៣** នៅក្នុងខទាំងនេះ និយាយពីសំណោកដោយព្រោះការដែលព្រះអង្គទ្រង់បានបោះបង់ចោលរាស្ត្រទ្រង់ (មើល ៤៤:៩–១៦ ៨៩:៣៨–៤៥) ហើយអ្នកនិពន្ធក៏បានសូមឱ្យព្រះអង្គទ្រង់សាងសង់ពួកគេឡើងវិញ ។

**៦០:១** *បោះបង់ចោលយើងខ្ញុំ* យ៉ាងហោចណាស់ក៏ព្រះអម្ចាស់ទ្រង់បានបោះបង់ចោលពួកគេអស់១រយៈពេលដែរ (មើល ៣០:៥) ។ ការដែលពួកគេបរាជ័យចំពោះពួកខ្មាំងសត្រូវ គឺជាទីបន្ទាល់មួយដែលសម្ដែងពីចេសក្ដីក្រោធរបស់ព្រះចំពោះពួកគេ (ទោះបីជាទីនេះមិនបាន និយាយពីមូលហេតុដែលបណ្ដាលឱ្យព្រះអង្គក្រោធចំពោះគេក៏ដោយ ហើយចំណងនៃមេត្រីភាពរវាងព្រះអម្ចាស់ និងពួកអ៊ីស្រាអែលមិនដែលកន្លងបាត់ឡើយ) ។ *ទំលាយទំលុះ* ដូចគ្នានឹងទឹកជំនន់ដែរ (មើលការពន្យល់ ២សាម ៥:២០) ។

**៦០:២** *ធ្វើស្រុកញាប់ញ័រ* ដូចគ្នានឹងមហន្តរាយដែលបង្ករឡើងដោយការរញ្ជួយផែនដីដែរ ហើយក៏ដូចគ្នានឹងការហិនវិនាសដែលពួកកាណានសម័យមុនបានជួបប្រទះដែរ ។

**៦០:៣** *ស្រាជាសេចក្ដីងេងងោង* នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់បានឱ្យពួកគេផឹកពីពែងនៃសេចក្ដីក្រោធរបស់ទ្រង់ ជាជាងឱ្យគេផឹកពែងនៃព្រះពរ និងសេចក្ដីសង្គ្រោះ (មើលការពន្យល់ ទដ ១៦:៥) ។

**៦០:៤–៨** នៅក្នុងខទាំងនេះ គឺជាការអធិស្ឋានសូមសេចក្ដីជំនួយមកពីព្រះយេហូវ៉ា និងការទុកចិត្តចំពោះព្រះ ។

**៦០:៤** *ពួកអ្នកដែលកោតខ្លាចទ្រង់* គឺជារាស្ត្រទ្រង់ដែលទទួលបានការគោរពស្រឡាញ់ពីប្រជាជាតិផ្សេងៗទៀត (មើល ៦១:៥ និងការពន្យល់ លប ២០:១១) ។ *ទង់ជ័យ* អាចជាព្រះបន្ទូលនៃការធានារ៉ាប់រងរបស់ព្រះអម្ចាស់ដែលមាននិយាយនៅក្នុង ខ.៦–៨ (មើល និក ១៧:១៥) ។

**៦០:៥–៨** នៅក្នុងខនេះ គឺជាការអធិស្ឋាន (ខ.៥) ដែលមានការធានារ៉ាប់រងមកពីព្រះយេហូវ៉ា (ខ.៦–៨) ។ ប្រហែលពាក្យទាំងនេះ អ្នកនិពន្ធគាត់បាន និយាយអធិស្ឋានម្ដងរួចមកហើយ ក្នុងគ្រាដែលមានចម្បាំងដណ្ដើមទឹកដី ។ បើសិនដូច្នេះមែន នោះប្រហែលជាមានកត់ទុកក្នុង "សៀវភៅដែលនិទានពីចំបាំងផងព្រះយេហូវ៉ា" (សូមមើលក្នុង ជន ២១:១៤) ។ នៅក្នុងហេតុការណ៍ផ្សេងៗទៀត ព្រះយេហូវ៉ាទ្រង់គឺជាមេទ័ពរបស់ពួកអ៊ីស្រាអែល (មមើល និក ១៥:៣,១៣–១៨) ។

**៦០:៥** *ពួកស្ងួនភ្ងា* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ឃ្លាដែលនិយាយានៅទីនេះ គឺជាពាក្យដ៏វិសេសមួយ ដែលបង្ហាញពីសេចក្ដីស្រឡាញ់ ឬជាការពេញចិត្តយ៉ាង ខ្លាំង ដូចជាមាននិយាយនៅក្នុង ១២៧:២ ២សាម ១២:២៥ យរ ១១:១៥ ។

**៦០:៦** *យើងនឹងបែងចែក . . . វាល់* ស្តេចដាវីឌទ្រង់បានបែងចែកព្រំប្រទល់នេះដល់ពួកអ្នកបម្រើរបស់ទ្រង់ ដែលបានធ្វើដំណើរមកជាមួយទ្រង់ក្នុងទីលានចម្បាំង ។ *ក្រុងស៊ីគែម . . . សិកូត* តំបន់ទាំងនេះជាកន្លែងដែលតំណាងឱ្យព្រំប្រទល់នៅភាគខាងលិច និងខាងកើតនៃទន្លេរយ័រដាន់ ដែលគ្រប់គ្រងដោយព្រះយេហូវ៉ា និងពួកអ៊ីស្រាអែល (មើល លប ៣៣:១៧–១៨ ១ពវ ១២:២៥) ។

៧ឯស្រុកកាឡាត[ឌ]ជារបស់ផងយើង ហើយខេត្តម៉ានាសេផង
ខេត្តអេប្រាអិម[ឍ]ជាទីមាំមួនដែលការពារក្បាលយើង
ហើយស្រុកយូដា[ណ]ជាអ្នកតែងច្បាប់របស់យើង[ត]
៨ស្រុកម៉ូអាប់ជាអាងសំរាប់ឱ្យយើងងូតទឹក
ហើយយើងនឹងបោះស្បែកជើងទៅលើស្រុកអេដំម នែ
ស្រុកភីលីស្ទីន ចូរស្រែកហ៊ោឡើងដោយព្រោះយើង[ថ] ។
៩តើអ្នកណានឹងនាំទូលបង្គំចូលក្នុងទីក្រុងមាំមួនបាន
តើអ្នកណានឹងនាំទូលបង្គំទៅឯស្រុកអេដំម
១០ឱព្រះអង្គអើយ តើមិនមែនទ្រង់ទេឬអីដែលទ្រង់បាន
ចោល យើងខ្ញុំហើយ ឱព្រះអង្គអើយ ទ្រង់ក៏មិនយាងចេញ
ទៅជាមួយនឹងពលទ័ពរបស់យើងខ្ញុំទៀតដែរ[ទ]
១១សូមទ្រង់ប្រោសមេត្តាជួយយើងខ្ញុំទាស់នឹងពួកសត្រូវដ្បិត
សេចក្តីជំនួយរបស់មនុស្ស នោះឥតប្រយោជន៍ទេ[ធ]
១២ដោយពឹងដល់ព្រះនោះយើងខ្ញុំនឹងតស៊ូយ៉ាងរឹងប៉ឹងវិញ
ដ្បិតគឺទ្រង់ហើយ ដែលនឹងជាន់ឈ្លីពួកសត្រូវរបស់យើងខ្ញុំ
បង់[ន] ។

ទំនុករបស់ស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង
ត្រូវលេងដោយប្រដាប់មានខ្សែ ។

**៦១** ឱព្រះអង្គអើយ[ក]
សូមស្តាប់សេចក្តីអំពាវនាវរបស់ទូលបង្គំ

**៦០:៧** ឌ យស ១៣:៣១ ឍ លប ៤១:៥២ ណ ជន ៣៤:១៩ ត លប ៤៩:១០ **៦០:៨** ថ ២សយ ៨:១ **៦០:១០** ទ យស ៧:១២ **៦០:១១** ធ ទដ ១៤៦:៣ សភ ៣:៥ **៦០:១២** ន យប ៤០:១២ ទដ ៤៤:៥ **៦១:១** ក ទដ ៦៤:១

**៦០:៧** នៅក្នុងឃ្លានេះចង់និយាយថា ដោយសារប្រទេសអ៊ីស្រាអែលជាណាចក្ររបស់ព្រះយេហូវ៉ា នោះទឹកដីនេះត្រូវតែជារបស់ផងព្រះអង្គ ហើយជាកន្លែងដែលប្រជារាស្ត្ររបស់ទ្រង់បានស្ថាបនាឡើងដែរ ។ *ស្រុកកាឡាត. . . ខេត្តម៉ានាសេ* ពាក់កណ្តាលនៃពូជអំបូរម៉ានាសេបានរស់នៅក្នុងស្រុកកាឡាតដែលមានទីតាំងនៅភាគខាងកើតនៃទន្លេយ័រដាន់ ហើយពាក់កណ្តាលនៃពួកគេទៀតរស់នៅភាគខាងលិចទន្លេយ័រដាន់ ភាគខាងជើងស្រុកភ្នំអេប្រាអិម (មើល យស ១៣:២៩–៣១ ១៧:៥–១១) ។ ការនេះបានបង្ហាញថា នគររបស់ព្រះអម្ចាស់ គឺមានទាំងនៅភាគខាងកើតនិងខាងលិចនៃទន្លេយ័រដាន់ ។ *ខេត្តអេប្រាអិម... ស្រុកយូដា* អេប្រាអិម និងយូដា គឺជាអ្នកដឹកនាំទាំង២ ក្នុងចំណោមអ្នកដឹកនាំផ្សេងទៀតរបស់អំបូរអ៊ីស្រាអែល ។ ម្នាក់គឺជាអ្នកតំណាងឱ្យពូជអំបូរដែលកើតចេញពីរ៉ាដែល (អេប្រាអិម) ដែលបានមករស់នៅភាគខាងជើង ហើយម្នាក់ទៀតជាអ្នកតំណាងឱ្យលេអា (យូដា) ដែលនៅភាគខាងត្បូង (មើល លប ៤៨:១៣–២០ ៤៩:៨–១២ ជន ២:៣,១៨ យស ជំពូក ១៥–១៦) ។ ពួកគេទាំង២នាក់គឺជាអ្នកតំណាងឱ្យពួកអ៊ីស្រាអែលទាំងមូល (មើកល អស ១១:១៣ អត ៩:១៣) ។ *ទីមាំមួន* នៅក្នុងឃ្លានេះចង់និយាយថា ដោយសារអេប្រាអិមគឺជាអ្នកដែលមានអំណាចនិងជាអ្នកឈ្លានពានគេឯង (មើល ចទ ៣៣:១៧ ពច ៧:២៤–៨:៣ ១២:១) នោះអេប្រាអិម គឺជាអ្នកតំណាងឱ្យភាពមាំមួនរបស់ព្រះអម្ចាស់ ។ *អ្នកតែងច្បាប់* ហេតុដែលហៅយូដាថា ជាអ្នកតែងច្បាប់ពីព្រោះយូដាដែលអាចនឹងមកដល់ (មើល លប ៤៩:១០) ឥឡូវនេះបានមកដល់ហើយ (មើល ១សយ ១៦:១–១៣) ហើយគាត់ជាអ្នកដែលព្រះបានជ្រើសរើសឱ្យគ្រប់គ្រងរាស្ត្ររបស់ទ្រង់ (មើល ២សយ ជំពូក ៧) ។

**៦០:៨** *ម៉ូអាប់ . . . អេដំម . . . ភីលីស្ទីន* ពួកអ្នកទាំងនេះគឺជាខ្មាំងសត្រូវស៊ីសាច់ហុតឈាមរបស់ពួកអ៊ីស្រាអែលជាយូរមកហើយ ។ ពួកគេជាអ្នកដែលរស់នៅភាគខាងកើត ខាងត្បូង និងភាគខាងលិចនៃព្រំប្រទល់ដែលអ៊ីស្រាអែលរស់នៅ (មើល នក ១៥:១៤–១៥ នក ១៣:១៧ ជន ២០:១៤–២១,២២–២៤) ។ *ជាអាងសំរាប់ឱ្យយើងងូតទឹក* នៅក្នុងឃ្លានេះចង់និយាយថា ស្រុកម៉ូអាប់នឹងបានបង្រួមមកឱ្យនៅតូចដូចជាអណ្តូងនៅក្នុងផ្ទះដែលអាចឱ្យព្រះអង្គលាងជើងបាន (មើល លប ១៨:៤) ។ ពាក្យបំរៀបន័យនេះប្រហែលបង្ហាញថា ស្រុកម៉ូអាប់គឺលាតសន្ធឹងពីទិសខាងកើតនៃច្រាំងសមុទ្រស្លាប់ ។ *បោះស្បែកជើង* ប្រហែលចង់និយាយសំដៅលើជម្លោះប្តឹងផ្តល់ដីធ្លី (សូមផ្ទៀបជាមួយ នរ ៤:៧) ។

**៦០:៩–១២** នៅក្នុងខទាំងនេះ គឺជាល្បះចុងក្រោយ ហើយនៅខទាំងនេះនិយាយពីការទុកចិត្តចំពោះព្រះអម្ចាស់ថា ទ្រង់នឹងប្រទានជ័យជម្នះដល់គេ (មើលការពន្យល់ ៣:៨) ។

**៦០:៩** *ទូលបង្គំ . . . ទូលបង្គំ* ទោះបីក្នុងជំពូកនេះគឺជាសេចក្តីធីស្ពានរបស់ពួកបណ្តាជនជាច្រើនក៏ដោយ (មើលការពន្យល់ ទដ ៣០ត្រង់ចំណងជើង) ក៏ពាក្យនេះ (ទូលបង្គំ) ប្រហែលនិយាយសំដៅលើឃ្លារបស់ព្រះមហាក្សត្រដែលទ្រង់ប្រើក្នុងពេលអធិស្ឋាន (មើលក្នុងសេចក្តីផ្តើម) ។ *នាំទូលបង្គំ* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយសំដៅលើការនាំដូចជា កាលដែលព្រះអម្ចាស់ទ្រង់យាងនាំមុខរាស្ត្ររបស់ទ្រង់ធ្វើសង្គ្រាម ក្នុងទីរហោស្ថាន (មើល នក ១៣:២១) និងក្នុងអំឡុងពេលច្បាំងដណ្តើមទឹកដី (មើល នក ២៣:២៧–២៨ ៣៣:២ ចទ ៩:៣ ៣១:៨) ។

**៦០:១០** *ចោល* មើល ៦.១) ។

**៦០:១១** *ជួយ* តាមភាសាអក្សរសាស្ត្រគេនិយាយថា "សង្គ្រោះ" (មើល ៦.៥ ត្រង់ពាក្យថា "ជួយសង្គ្រោះ") ។ *របស់មនុស្ស* មើល ៣៣:១៧ ។

**៦០:១២** *តស៊ូយ៉ាងរឹងប៉ឹង* តាមភាសាអក្សរសាស្ត្រគេនិយាយថា "នឹងធ្វើការយ៉ាងអស្ចារ្យ" ។ ដោយសារមានសេចក្តីជំនួយមកពីព្រះយេហូវ៉ា នោះពួកប្រជាជនអ៊ីស្រាអែល និងទទួលបានជ័យជម្នះតាមបំណងដោយសារព្រះអម្ចាស់ទ្រង់ផ្ទាល់ (មើល ទដ ១១៨:១៥–១៦) ហើយគេនឹងឈ្នះលើពួកអេដំម (មើល ជន ២៤:១៨ "នឹងមានជ័យជំនះ") ។ *ជាន់ឈ្លី* គឺឱ្យក្លាយជាមេទ័ពដែលមានជ័យជម្នះ (មើល អស ១៤:១៩,២៥ យរ ១២:១០ អត ១០:៥) ។

**ទដ ៦១–៦៤** នៅក្នុងជំពូកទាំងនេះ គឺជាលំដាប់នៃទំនុកដំកើងទាំង៤ដែលមានទំនាក់ទំនងជាមួយគ្នា ដោយបានភ្ជាប់នឹងផ្ទៃរឿងសាមញ្ញមួយដែលនិយាយពីការទុកចិត្តចំពោះព្រះអម្ចាស់ថា ព្រះអម្ចាស់ទ្រង់នឹងជួយសង្គ្រោះឱ្យរួចពីសេចក្តីស្លាប់ ឬគ្រោះថ្នាក់ ។ មានឧបកថាចំនួន២ដែលនិយាយអំពីស្តេច (ជំពូក ៦១,៦៣) ហើយឧបកថា២ទៀត (ជំពូក ៦២,៦៤) ប្រហែលនិយាយអំពីអ្នកតំណាងរបស់ស្តេច ។

**ទដ ៦១** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះអង្គទ្រង់បានស្ថាបនាជីវិតគាត់ឡើងវិញ នៅចំពោះព្រះវត្តមានរបស់ទ្រង់ ។ ស្ថានភាពដែលបានកើតឡើងនាពេលនេះ គឺប្រហាក់ប្រហែលគ្នានឹងស្ថានភាពដែល

សូមទ្រង់សំកាំងស្តាប់ពាក្យទូលបង្គំអធិស្ឋានផង[ខ]
២ កាលណាចិត្តទូលបង្គំត្រូវបង្រ្កប[គ] នោះទូលបង្គំនឹងអំពាវ
នាវដល់ទ្រង់ពីចុងផែនដីផង
សូមនាំទូលបង្គំទៅឯថ្មដា[ឃ] ដែលខ្ពស់ជាងទូលបង្គំ
៣ ដ្បិតទ្រង់បានធ្វើទីជ្រកឱ្យទូលបង្គំ គឺជាប៉មយ៉ាងមាំ[ង]
ឱ្យរួចពីខ្មាំងសត្រូវ[ច]
៤ ទូលបង្គំនឹងអាស្រ័យនៅ[ឆ]ក្នុងពន្លារបស់ទ្រង់ជានិច្ច
ទូលបង្គំនឹងជ្រកនៅទីកំបាំង ក្រោមស្លាបទ្រង់[ជ] ។ –បង្អង់
៥ ដ្បិត ឱព្រះអង្គអើយ
ទ្រង់បានឮសេចក្តីដែលទូលបង្គំបន់ហើយ[ឈ]
ទ្រង់បានប្រោសប្រទានឱ្យទូលបង្គំបានមរដក
ដែលត្រូវខាងពួកអ្នកដែលកោតខ្លាចដល់ព្រះនាមទ្រង់[ញ]
៦ ទ្រង់នឹងចំរើនជីវិតទូលបង្គំដ៏ជាស្តេចឱ្យវែង[ដ]
អស់ទាំងឆ្នាំនៃជីវិតទូលបង្គំ និងបានដូចជាអាយុរបស់
មនុស្សជាច្រើនដំណតទៅ[ឋ]
៧ ទូលបង្គំនឹងអាស្រ័យនៅចំពោះព្រះជាដរាបតទៅ[ឌ]
ឱសូមរៀបសេចក្តីសប្បុរស
និងសេចក្តីពិតឱ្យបានរក្សាទូលបង្គំផង[ឍ]
៨ យ៉ាងនោះ ទូលបង្គំនឹងច្រៀងសរសើរដល់ព្រះនាម[ណ] ទ្រង់

**៦១:១** ខ ទដ ៤:១ ៨៦:៦ **៦១:២** គ ទដ ៦:២ ឃ ទដ ១៨:២ ៣១:២ ៩៤:២២ **៦១:៣** ង ទដ ៩:៩ ៤៦:១ ៦២:៧ ច ទដ ៥៩:៩ សភ ១៨:១០ **៦១:៤** ឆ ទដ ១៥:១ ជ ចទ ៣២:១១ មថ ២៣:៣៧ **៦១:៥** ឈ ជន ៣០:២ ទដ ៥៦:១២ ញ នក ៦:៣ ចទ ៣៣:៩ នហ ១:១១ ទដ ១០២:១៥ អស ៥៩:១៩ មថ ៦:៩ **៦១:៦** ដ ១ពវ ៣:១៤ ឋ ទដ ២១:៤ **៦១:៧** ឌ ទដ ៤១:១២ លក ២២:៦៩ អភ ១:២០ កល ៣:១ ឍ ទដ ៤០:១១ **៦១:៨** ណ នក ១៥:១ ទដ ៧:១៧ ៣០:៤

បានកើតឡើងក្នុង ទដ ៤២–៤៣ ដែរ ។ ទោះបីជាបែបនេះក៏ដោយ ក៏នៅទីនេះមាននិយាយទាក់ទងពីព្រះមហាក្សត្រដែរ (មើល ខ.៦) ហើយបើសិនអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងត្រង់ជំពូកនេះជាស្តេចដាវីឌ នោះទ្រង់បានតែងបទទំនុកនៃសេចក្តីអធិស្ឋានក្នុងជំពូកនេះនៅគ្រាដែលព្រះអង្គរត់គេចពីអាប់សាឡុម (មើល ២សយ ១៧:២១–២៩) ។ សូមមើលព្រឹត្តិការណ៍ផ្សេងៗទៀតក្នុងការពន្យល់ត្រង់ ខ.២ ។ លក្ខណៈសំណង់ប្រយោគវិញជំពូកនេះ បាននិយាយពីការអធិស្ឋានទៅចំពោះព្រះ (ខ.១) និងការច្រៀងសរសើរតម្កើងដល់ព្រះអម្ចាស់ (ខ.៨) ។ បទកម្ពីរជំពូកនេះទាំងមូលត្រូវបានសរសេរឡើងជា៣ផ្នែកគឺ ខ.២–៣,៤–៥,៦–៧ ។

**៦១ ត្រង់ចំណងជើង** សូមមើលការពន្យល់ក្នុង ទដ ៤ត្រង់ចំណងជើង ។

**៦១:១** នៅក្នុងខនេះ អ្នកនិពន្ធមានបំណងចិត្តសូមឱ្យព្រះអង្គទ្រង់ស្តាប់ ឮ ហើយតបឆ្លើយចំពោះសេចក្តីអធិស្ឋានរបស់គាត់ ។

**៦១:២–៣** នៅក្នុងខទាំងនេះ គឺចង់និយាយពីសេចក្តីអធិស្ឋាន ។

**៦១:២** *ចុងផែនដី* មើល ៤២:៦ ។ ឃ្លានេះប្រហែលចង់និយាយសំដៅកន្លែងជិតជ្រុំជម្រៅក្រោយពេលដែលមនុស្សស្លាប់ទៅ ដែលគេតែងតែហៅថាស្ថានឃុំព្រលឹងមនុស្សស្លាប់ (មើល ៦៣:៩) ។ នៅពេលនេះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងមានអារម្មណ៍ថា សេចក្តីស្លាប់កាន់តែខិតជិតមកដល់រូបគាត់ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។ *សូមនាំទូលបង្គំ* មើល ២៣:២ ។ *ថ្មដា* អ្នកនិពន្ធចង់មានន័យសំដៅលើកន្លែង ដែលមានសុវត្ថិភាព (មើល ២៧:៥ ៤០:២) ។ *ខ្ពស់ជាងទូលបង្គំ* ទីកន្លែងគាត់ស្វែងរក នោះវាឆ្ងាយដែលគាត់មិនអាចទៅដល់មានតែ ព្រះអម្ចាស់ព្រះយេហូវ៉ាមួយព្រះអង្គប៉ុណ្ណោះដែលអាចនាំគាត់ទៅដល់ ។ ដោយព្រោះជានិច្ចកាលអ្នកនិពន្ធតែងតែគិតថា ព្រះយេហូវ៉ាទ្រង់គឺជា"ថ្មដាមាំមួន" (មើល ទដ ៣១:២ ៧១:៣ និង ១៨:២ ៦២:២,៦–៧ ៩៤:២២) នោះព្រះអម្ចាស់ទ្រង់ក៏ជា"ថ្មដាដែលខ្ពស់" (ជាទីពឹងមាំមួន) ដែលអ្នកនិពន្ធមានបំណងជ្រកកោនក្នុងដែរ (មើល ខ.៣) ឯទីបរិសុទ្ធរបស់ទ្រង់ ក៏ជាទីកន្លែងពឹងជ្រកដែលប្រកបដោយសុវត្ថិភាពដែរ (សូមមើល ខ.៤ និង ២៧:៥) ។

**៦១:៣** មូលហេតុដែលអ្នកនិពន្ធអំពាវនាវដល់ព្រះអម្ចាស់ គឺដោយព្រោះព្រះអម្ចាស់ទ្រង់មិនដែលខាននឹងធ្វើជាទីពឹងជ្រករបស់គាត់នោះឡើយ ។ *ខ្មាំងសត្រូវ* បើសិនអ្នកនិពន្ធអធិស្ឋានក្នុងពេលដែលគាត់កំពុងប្រឈមមុខនឹងសេចក្តីស្លាប់ នោះខ្មាំងសត្រូវរបស់គាត់នាពេលនេះគឺជាសេចក្តីស្លាប់ (មើល ៦៨:២០ ១៤១:៨ យប ៣៣:២២ អស ២៥:៨ ២៨:១៥ យរ ៩:២១ ហស ១៣:១៤ និង ១រប ១៥:២៦ និងការពន្យល់ ៤៩:១៤) ។

**៦១:៤–៥** នៅក្នុងខទាំងនេះ អ្នកនិពន្ធមានបំណងចង់ជ្រកកោននៅក្នុងទីបរិសុទ្ធរបស់ទ្រង់ គឺជាកន្លែងមួយដែលមានសុវត្ថិភាពបំផុត (មើល ២៧:៥ និងការពន្យល់) ។

**៦១:៤** *អាស្រ័យនៅក្នុង* មើលការពន្យល់ ១៥:១ ។ *ពន្លា* គឺជាទីកន្លែងដែលពួកបរិសុទ្ធរបស់ទ្រង់ស្នាក់អាស្រ័យនៅ (មើល ២សយ ៦:១៧ ៧:២ ១ពវ ១:៣៩ ២:២៨–៣០) ។ *ទូលបង្គំនឹងជ្រកនៅទីកំបាំង ក្រោមស្លាបទ្រង់* មើលការពន្យល់ ១៧:៨ ។

**៦១:៥** មូលហេតុដែលអ្នកនិពន្ធមានបំណងចិត្តពឹងជ្រកក្នុងទ្រង់គឺ (១).ពីព្រោះព្រះអម្ចាស់ទ្រង់បានគិតគូរដល់គាត់កាលពីអតីតកាល (២).ព្រះអម្ចាស់ទ្រង់អាចធ្វើឱ្យគាត់ស្កប់ចិត្ត ពីគោលបំណងរបស់គាត់ ។ *សេចក្តីដែលទូលបង្គំបន់* គឺជាបំណន់ដែលលាយជាមួយនឹងសេចក្តីអធិស្ឋាន (មើល ៥០:១៤ ៦៦:១៤ និងការពន្យល់ ៧:១៧) ។ *មរដក* គឺជាទឹកដីសន្យាដែលប្រជារាស្ត្ររបស់ទ្រង់បានរស់នៅក្នុង តាមការសន្យារបស់ព្រះអម្ចាស់ (មើល ១៦:៦ ៣៧:១៨ ១៣៥:១២ ១៣៦:២១–២២) ។ *ពួកអ្នកដែលកោត ខ្លាច* សូមមើល ៦០:៤ និងការពន្យល់ ។ *ព្រះនាមទ្រង់* មើលការពន្យល់ ៥:១១ ។

**៦១:៦–៧** នៅក្នុងជំពូកនេះ ប្រហែលជាព្រះមហាក្សត្រផ្ទាល់ទ្រង់បានអធិស្ឋានសូមឱ្យព្រះយេហូវ៉ាប្រទានពរ ឱ្យព្រះអង្គមានព្រះជន្មយឺនយូរពីព្រោះដោយសំអាងលើលក្ខណៈអក្សរសាស្ត្រ របស់ពួកអ្នកដែលរស់នៅក្នុងតំបន់មជ្ឈឹមបូព៌ាកាលពីសម័យបុរាណគេបានប្រើទម្រង់បុរសទី៣ បែបនេះឬអាចជាសេចក្តីអធិស្ឋានរបស់ពួកបណ្តាជន ដែលបានអធិស្ឋានសម្រាប់ស្តេច (ប្រហែលជាពួកសង្ឃ ឬពួកលេវី) ។ នៅសម័យក្រោយមកទៀតពួកយូដាគេបានយកខទាំងនេះ ដើម្បីនិយាយអំពីព្រះមែស៊ីដែលត្រូវយាងមក ។ អត្ថន័យ និងអត្ថរស់ក្នុងខទាំងនេះបានសម្រេចពេញលេញ នៅពេលដែលព្រះគ្រីស្ទទ្រង់បានយាងមក ។

**៦១:៦** នៅក្នុងខនេះចង់និយាយថា សូមឱ្យមហាក្សត្រទ្រង់មានព្រះជន្មយឺនយូរ (មើលការពន្យល់ ៤៥:៦) ។

**៦១:៧** *ទូលបង្គំនឹងអាស្រ័យនៅចំពោះព្រះជាដរាបតទៅ* មើលការពន្យល់ ៤១:១២ ។ *សេចក្តីសប្បុរស និងសេចក្តីពិត* ទាំងនេះគឺជាលក្ខណៈសម្បត្តិរបស់ព្រះ (មើលការពន្យល់ ២៣:៦ ៤៣:៣ និងការពន្យល់ ២៦:៣) ។

ជាដរាបដើម្បីឱ្យបានលាបំណន់របស់ទូលបង្គំរាល់តែ
ថ្ងៃ[ត] ។

ទំនុករបស់ស្តេចដាវីឌ ដែលទ្រង់លើកឱ្យមេភ្លេង
សំរាប់លោកយេឌូថិន ។

**៦២** ព្រលឹងខ្ញុំរង់ចាំព្រះអង្គតែមួយ[ក] ដោយស្ងៀមស្ងាត់[ខ]
សេចក្តីសង្គ្រោះរបស់ខ្ញុំក៏មកតែពីទ្រង់ដែរ
២ គឺទ្រង់តែមួយព្រះអង្គដែលជាថ្មដា[គ]
ហើយជាសេចក្តីសង្គ្រោះនៃខ្ញុំ[ឃ]
គឺជាប៉មយ៉ាងខ្ពស់[ង] របស់ខ្ញុំៗមិនត្រូវរង្កើជាខ្លាំងឡើយ[ច]
៣ តើអ្នករាល់គ្នានឹងសង្កុញចូលទៅលើមនុស្សទាំងចង់
សំឡាប់គេដល់កាលណាទៀត ប្រៀបដូចជាកំផែងដែល
ទ្រេត[ឆ] ដូចជារបងដែលចង់រលំហើយ
៤ គេប្រឹក្សាគ្នា ដើម្បីតែនឹងទំលាក់អ្នកនោះចុះពីយសរបស់
ខ្លួន គេចូលចិត្តនឹងសេចក្តីភូតភរ មាត់គេឱ្យពរ
តែនៅក្នុងចិត្ត គេប្រទេចផ្តាសាវិញ[ជ] ។ –បង្អង់
៥ ព្រលឹងខ្ញុំអើយ ចូរនៅស្ងៀមចាំតែព្រះចុះ[ឈ]
ដ្បិតសេចក្តីសង្ឃឹមរបស់ខ្ញុំ នោះមកតែពីទ្រង់ទេ
៦ គឺទ្រង់តែ១ព្រះអង្គដែលជាថ្មដា ហើយជាសេចក្តីសង្គ្រោះ
នៃខ្ញុំ ក៏ជាប៉មយ៉ាងខ្ពស់របស់ខ្ញុំៗ មិនត្រូវរង្កើឡើយ
៧ សេចក្តីសង្គ្រោះ នឹងសិរីល្អរបស់ខ្ញុំ នោះនៅនឹងព្រះ
ឯថ្មដានៃកំឡាំងខ្ញុំ នឹងទីពឹងជ្រករបស់ខ្ញុំ
ក៏នៅក្នុងព្រះដែរ[ញ]
៨ ជនទាំងឡាយអើយ[ដ] ចូរទុកចិត្តនឹងទ្រង់ជានិច្ច
ចូរអ្នករាល់គ្នាប្តូងចិត្តនៅចំពោះទ្រង់[ឋ] ព្រះទ្រង់ជាទីពឹង
ជ្រកសំរាប់យើង ។ –បង្អង់
៩ ប្រាកដមែន មនុស្សធម្មតា[ឌ] ជាអសារឥតការ
ហើយមនុស្សមាំទាំជាសេចក្តីបោកប្រាស
បើនឹងថ្លឹងគេនៅជញ្ជីង[ឍ]
នោះទាំងអស់រួមគ្នាស្រាលជាងខ្យល់ដង្ហើមទៅទៀត[ណ]
១០ កុំឱ្យទុកចិត្តនឹងសេចក្តីសង្កត់សង្កិនឡើយ[ត]
ក៏កុំឱ្យអួតខ្លួនក្នុងការលួចប្លន់ដែរ[ថ]

**៦១:៨** ត ជន ៣០:២ ចទ ២៣:២១ **៦២:១** ក ខ.៥ ខ ទដ ៥:៣ **៦២:២** គ ទដ ១៨:៣១ ៨៩:២៦ ឃ នក ១៥:២ ង ទដ ៥៩:៩ ច យប ២៩:១៨ **៦២:៣** ឆ អស ៣០:១៣ **៦២:៤** ជ ទដ ២៨:៣ ៥៥:២១ **៦២:៥** ឈ ខ.១ **៦២:៧** ញ ទដ ៦១:៣ **៦២:៨** ដ ទដ ៣៧:៥ អស ២៦:៤ ឋ ១សយ ១:១៥ ទដ ៤២:៤ មថ ២៦:៣៦–៤៦ **៦២:៩** ឌ ទដ ៤៩:២ ឍ អស ៤០:១៥ ណ យប ៧:៧ **៦២:១០** ត ទដ ១២:៥ ១ធថ ៦:១៧ ថ អស ៦១:៨ អគ ២២:២៩ ណហ ៣:១

**៦១:១៨** នៅក្នុងខនេះគឺជាការបំណន់ នៃការសរសើរតម្កើងចំពោះព្រះ (មើលការពន្យល់ ៤៥:៦) ។

**ទដ ៦២** នៅក្នុងជំពូកនេះអ្នកនិពន្ធបានប្តេជ្ញាចិត្តចំពោះព្រះ ក្នុងគ្រាដែលគាត់ជួបការបៀតបៀន និងធ្វើទុក្ខពីសំណាក់ពួកអ្នកក្បត់គាត់ទាំងប៉ុន្មានដែលគេមានបំណង "ទំលាក់អ្នកនោះពីយសរបស់ខ្លួន" (សូមមើល ខ.៤) ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺប្រហែលជាស្តេចដាវីឌ បើសិនជាស្តេចដាវីឌមែន នោះមានន័យថា ក្រុមគ្រួសាររបស់ស្តេចសូល គឺជាអ្នកដែលព្យាយាមទម្លាក់យសដល់គាត់ ។ នៅក្នុង ខ.៣ និយាយពីពេលវេលារបស់ពួកមនុស្សអាក្រក់ ហើយប្រហែលជាចង់ចង្អុលបង្ហាញអំពីការរីកចម្រើននៃដំណើរជីវិត ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងជំពូកនេះ គាត់បានអធិស្ឋានសូមឱ្យព្រះអម្ចាស់ទ្រង់ជួយដល់គាត់ ។ គ្មានបទគម្ពីរទំនុកដំកើងណាទៀត ដែលនិយាយពីការទុកចិត្តដល់ព្រះ លើសពីនេះឡើយ (មើល ទដ ៣១ និងសេចក្តីផ្តើម ទដ ៦១) ។ នៅក្នុងព្រះគម្ពីរទំនុកដំកើងជំពូកនេះបានតាក់តែងឡើងជា៣ផ្នែកគឺ ខ.៣–៤,៥–៨,៩–១០) ដែលបានបង្ហាញការសម្រាកដ៏ស្ងប់ស្ងាត់ក្នុងព្រះអម្ចាស់ (មើល ខ.១–២) និងនិយាយពីមូលហេតុដែលបណ្តាលឱ្យអ្នកនិពន្ធទុកចិត្តចំពោះព្រះ (មើល ខ.១១–១២) ។ នៅពាក់កណ្តាលល្បះ បានបង្កើតជាផ្ទៃរឿងមួយសម្រាប់ឈានដល់ផ្ទៃរឿងផ្សេងទៀតដោយមាន២ខ (មើល ខ.៥–៦) ជាការដកស្រង់ចេញពីខដើមឃ្លា ហើយនៅក្នុងខចុងក្រោយ (មើល ខ.៧–៨) គឺជាសេចក្តីបញ្ចប់ដ៏វិសេសមួយ ។ នៅមានល្បះ២ទៀត (មើល ខ.៣–៤,៩–១០) គឺបាននិយាយពីពួកអ្នកដែលបៀតបៀនដល់ស្តេចដាវីឌ ។

**៦២ ត្រង់ចំណងជើង** សូមមើលការពន្យល់ ១០:៦ ។

**៦២:១–២** នៅក្នុងខទាំងនេះ គឺនិយាយពីការទុកចិត្តទាំងស្រុងចំពោះការការពាររបស់ព្រះអម្ចាស់ ។

**៦២:២,៦** *រង្កើឡើយ* មើលការពន្យល់ ១០:៦ ។

**៦២:៣–៤** នៅក្នុងខទាំងនេះ និយាយពីសកម្មភាពបៀតបៀនរបស់ពួកខ្មាំងសត្រូវ ។

**៦២:៣** មានសំណួរមួយ សួរដល់មេទ័ពទាំងនោះថា តើអ្នកពិតជាមិនដែលបោះបង់ចោលការប្រកួតមែនឬ ។ *ដូចជាកំផែងទ្រេត ដូចជារបងដែលចង់រលំ* ពាក្យទាំងនេះគឺជាពាក្យប្រៀបប្រដូចអំពីការធ្លាក់ចុះរបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងដូចជា (១).អ្នកនិពន្ធបានសារភាពថា គាត់គ្មានកម្លាំងនៅក្នុងខ្លួន (២).អ្នកនិពន្ធទទួលស្គាល់ថា ខ្លួនជាមនុស្សខ្សោយ (៣).ផ្តោតអំពីរបៀបដែលពួកខ្មាំងសត្រូវលបវាយគាត់ ។

**៦២:៤** *យស* ពាក្យនេះគឺនិយាយសំដៅលើបល្ល័ង្ក ។ *សេចក្តីភូតភរ . . . ប្រទេចផ្តាសា* មើលការពន្យល់ ១០:៧ ។ *ឱ្យពរ* ជាឧទាហរណ៍ដូចជាពាក្យថា "ជ័យយោព្រះករុណា" (មើល ១សយ ១០:២៤ ២សយ ១៦:១៦ និង ១ពវ ១:២៥,៣៤,៣៩) ។

**៦២:៥–៨** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានជម្រុញចិត្តខ្លួនឯង (ខ.៥) និងពួកបណ្តាជន (ខ.៨) ឱ្យទុកចិត្តចំពោះព្រះអម្ចាស់ ។

**៦២:៥** *ចូរនៅស្ងៀម* មើលការពន្យល់ ខ.១ ។

**៦២:៨** នៅក្នុងខនេះ អ្នកនិពន្ធបានដាក់តឿនដល់ប្រជារាស្ត្ររបស់ព្រះ (មើល ៣១:២៣–២៤) ។ *ប្តូងចិត្ត* មានន័យថា អធិស្ឋានឱ្យអស់ពីចិត្ត (មើល បទ២:១៩) ។ *ចិត្ត* មើលការពន្យល់ ៧:៤ ។

**៦២:៩–១០** នៅក្នុងខនេះចង់និយាយថា មនុស្សទាំងអស់គឺសុទ្ធតែជាអសារឥតការទាំងមនុស្សធម្មតា និងអ្នកសង្កត់សង្កិនគេ ។

**៦២:៩** *ធម្មតា . . .មនុស្សមាំទាំ* គឺនិយាយសំដៅលើមនុស្សគ្រប់ស្រទាប់ ។ *បោកប្រាស់ . . . ខ្យល់ដង្ហើម* ចង់មានន័យថា មនុស្សនឹងកាន់តែមានគ្នាច្រើនជាងពេលនេះទៅទៀត (មើល ៣៧:២,២០ ៣៩:៥ និងការពន្យល់) ជាពិសេសពួកអ្នកមាន និងអ្នកមានអំណាច ។

**៦២:១០** នៅក្នុងខនេះ គឺជាសេចក្តីព្រមានដល់ពួកអ្នក (រាប់ទាំងអស់អ្នក

បើកាលណាមានទ្រព្យសម្បត្តិចំរើនឡើង
នោះកុំឱ្យទុកចិត្តនឹងរបស់ទាំងនោះឱ្យសោះ[ទ]
១១ ព្រះទ្រង់បានមានបន្ទូលម្តងហើយ
ខ្ញុំបានឮសេចក្តីនេះ២ដងផង គឺថា
ឫទ្ធានុភាពសំរេចនៅលើព្រះ[ធ]
១២ ឱព្រះអម្ចាស់អើយ សេចក្តីសប្បុរសក៏ជារបស់ផងទ្រង់
ដែរ[ន] ដ្បិតទ្រង់សងដល់គ្រប់មនុស្សទាំងអស់តាមការ
ប្រព្រឹត្តរបស់គេ[ប] ។

ទំនុករបស់ស្តេចដាវីឌ
ដែលទ្រង់លើកក្នុងកាលដែលទ្រង់នៅទីរហោស្ថានស្រុកយូដា ។

**៦៣** ឱព្រះអង្គអើយ ទ្រង់ជាព្រះនៃទូលបង្គំ
ទូលបង្គំនឹងស្វែងរកទ្រង់អស់ពីចិត្ត
ព្រលឹងទូលបង្គំស្រេករកទ្រង់[ក] រូបសាច់ទូលបង្គំរឭកចង់
បានទ្រង់ នៅក្នុងស្រុករីងស្ងួត
ហើយហួតហែងដែលគ្មានទឹកសោះ[ខ]
២ ដើម្បីឱ្យបានឃើញឥទ្ធិឫទ្ធិ និងសិរីល្អរបស់ទ្រង់[គ]
ដូចជាទូលបង្គំបានឃើញនៅក្នុងទីបរិសុទ្ធដែរ[ឃ]
៣ ដ្បិតសេចក្តីសប្បុរសនៃទ្រង់ នោះវិសេសជាងជីវិត[ង]
បបូរមាត់ទូលបង្គំនឹងសរសើរដល់ទ្រង់
៤ គឺយ៉ាងនោះ ដែលទូលបង្គំនឹងលើកដំកើងទ្រង់ក្នុងកាល
ដែលនៅរស់ឡើយ[ច] ទូលបង្គំនឹងប្រទូលដៃឡើង
ដោយនូវព្រះនាមទ្រង់[ឆ]

**៦២:១០** ទ យប ៣១:២៥ មថ ១៩:២៣–២៤ ១ធថ ៦:៦–១០ **៦២:១១** ធ ១រប ២៩:១១ វវ ១៩:១ **៦២:១២** ន ទដ ៨៦:៥ ១០៣:៨ ១៣០:៧ ប យប ២១:៣១ ទដ ២៨:៤ មថ ១៦:២៧ រម ២:៦ ១កថ ៣:៨ កឡ ៣:២៥ **៦៣:១** ក ទដ ៤២:២ ៨៤:២ ខ ទដ ១៤៦:៦ **៦៣:២** គ នក ១៦:៧ ឃ ទដ ១៥:១ ២៧:៤ ៦៨:២៤ **៦៣:៣** ង ទដ ៣៦:៧ ៦៩:១៦ ១០៦:៤៥ ១០៩:២១ **៦៣:៤** ច ទដ ១០៤:៣៣ ១៤៦:២ អស ៣៨:២០ ឆ ទដ ២៨:២ ១ធថ ២:៨

ដែលរួមគំនិតក្បត់ប្រឆាំងនឹងអ្នកនិពន្ធ) ដែលបានទុកចិត្តចំពោះពាក្យកំភូតរបស់ខ្លួន ដើម្បីចង់បាននូវអ្វីដែលគេចង់បាន (តាមរូបភាពត្រឹមត្រូវ និងមិនត្រឹមត្រូវ) ជាជាងទុកចិត្តដល់ព្រះ ។ អ្វីដែលបាននិយាយនៅក្នុងជំពូកនេះ វាស្ទើរតែដូចគ្នានឹងជំពូក ៤៩ ដែរ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៦២:១១–១២** នៅក្នុងខនេះនិយាយពីការរំឭកឱ្យឃើញ ពីព្រះបន្ទូលការធានារ៉ាប់រងរបស់ព្រះអម្ចាស់ចំពោះរាស្ត្រទ្រង់ ។ *ឫទ្ធានុភាព . . . សេចក្តីសប្បុរស* សេចក្តីទាំងនេះ គឺជាសមត្ថភាពដែលព្រះអម្ចាស់ទ្រង់អាចធ្វើបានចំពោះរាស្ត្រដែលបានទទួលសេចក្តីសង្គ្រោះ និងព្រះពររបស់ទ្រង់មកពីព្រះយេហូវ៉ា ។

**៦២:១១** *ម្តងហើយ . . . សេចក្តីទាំង២* មើលការពន្យល់ អម ១:៣ ។

**៦២:១២** *សេចក្តីសប្បុរស* មើលការពន្យល់ ៦:៤ ។ *ដ្បិត* នៅក្នុងឃ្លានេះចង់និយាយថា ទីបំផុតមនុស្សទាំងអស់គេនឹងឃើញសេចក្តីសុចរិតរបសព្រះអម្ចាស់ (មើលការពន្យល់ ៤:១) ។ *សង . . . តាមការប្រព្រឹត្តរបស់គេ* មើលការពន្យល់ យរ ១៧:១០ ៣២:១៩ ។

**ទដ ៦៣** នៅក្នុងជំពូកនេះ អ្នកនិពន្ធមានបំណងប្រាថ្នាចង់បានព្រះអម្ចាស់ និងសូមឱ្យព្រះវត្តមានរបស់ព្រះបានគង់នៅជាមួយ ជួយគាត់ឱ្យរួចពីគ្រោះថ្នាក់ ក្នុងពេលដែលមានការបៀតបៀនពីខ្មាំងសត្រូវ ។ គេអាចដឹងពីបំណងចិត្ត នៃការចង់បានព្រះរបស់អ្នកនិពន្ធ តាមរយៈការប្រើពាក្យប្រៀបប្រដូចដូចជាស្រេករកទ្រង់ (ខ.១) និងការស្រេកឃ្លានព្រះ (ខ.៥ និង ៤២:១–២) ទំនុកដំកើងជំពូកនេះ ក៏ដូចជាទំនុកដំកើងជំពូក ៦២ ដែរ គឺសុទ្ធតែបានពណ៌នាពីសេចក្តីអធិស្ឋានដែលមិនអាចថ្លែងបាន ។ មិនតែប៉ុណ្ណោះសោតព្រះគម្ពីរទាំង២ជំពូកនេះមានទំនាក់ទំនងគ្នាតាមរយៈ ការស្តាប់ឮ (មើល ៦២:១១) បែមកឃើញដោយផ្ទាល់វិញ (ខ.២ ទដ ៤៨:៨ និងការពន្យល់) ។ រូបភាពនៃការគ្រោះថ្នាក់នាពេលយប់ (ខ.៦) និងសេចក្តីសង្គ្រោះនាពេលព្រឹកព្រលឹម (មើលការពន្យល់ ខ.១) ត្រូវបានលើកមកនិយាយម្តងទៀត (មើលក្នុងសេចក្តីផ្តើម ទដ ៥៧) ។ ពួកជំនុំជំនាន់ដើមគេតែងតែប្រើសេចក្តីអធិស្ឋានក្នុងជំពូកនេះ ជាប្រចាំក្នុងពេលថ្វាយបង្គំព្រះអម្ចាស់ ។ លក្ខណៈសំណង់ប្រយោគក្នុងជំពូកនេះគេឃើញថា នៅដើមឃ្លានិយាយពីការចង់បានព្រះ (ខ.១) ហើយនៅចុងបញ្ចប់និយាយពីការអំណរ (ខ.១១) នេះគឺជាលក្ខណៈអក្សរសាស្ត្រក្នុងជំពូកនេះ ។ នៅក្នុង ខ.៦ វិញគឺជាផ្នែករឿងគ្រឹះមួយដែលមានទំនាក់ទំនងជាមួយ ខ.១ និង ខ.១១ ហើយ ខ.៦ នេះទៀតសោតវាបានឈរនៅចន្លោះល្បះ២ដែលមានតុល្យភាពជាមួយគ្នា (ខ.២–៥, ៧–១០) ដែលល្បះនិមួយមាន ៤ខ ហើយមានភាសាហេព្រើរចំនួន ២៧ ។ នៅក្នុងជំពូកនេះនិយាយពីការសញ្ជឹងគិត ពីព្រះបន្ទូលព្រះក្នុងពេលរាត្រីរបស់អ្នកនិពន្ធ (មើល ខ.៦) ការដែលគាត់ចង់បានព្រះ (មើល ខ.១ ហើយធៀបជាមួយ ១៤៣:៥–៦) និងការរងចាំដោយសង្ឃឹម (ខ.១១) ។ មើលទំនាក់ទំនងផ្នែគ្រឹះក្នុងល្បះទាំង២នេះ ក្នុងសេចក្តីពន្យល់ខាងក្រោមនេះ ។

**៦៣ ត្រង់ចំណងជើង** សូមមើលការពន្យល់ ទដ ៣ ត្រង់ចំណងជើង ។ *ក្នុងកាល* ប្រហែលនិយាយសំដៅលើព្រឹត្តិការណ៍ដែលបានកើតឡើងក្នុង ២សយ ១៥:២៣–២៨ ១៦:២,១៤ ១៧:១៦,២៩ ពីព្រោះអ្នកនិពន្ធបាននិយាយថាក្នុងជំពូកនេះថា ខ្លួនគាត់គឺជាស្តេច (មើល ខ.១១) ។

**៦៣:១** នៅក្នុងខនេះ អ្នកនិពន្ធមានបំណងចិត្តចង់បានព្រះ ក្នុងពេលដែលត្រូវការ ។ *អស់ពីចិត្ត* តាមភាសារអក្សរសាស្ត្រគឺ "ជិតភ្លឺ" ។ *ព្រលឹងទូលបង្គំ . . . រូបសាច់ទូលបង្គំ* គឺនិយាយសំដៅលើរូបកាយទាំងមូល (មើលការពន្យល់ ៦:៣) ។ *នៅក្នុងស្រុករីងស្ងួត ហើយហួតហែង* ពាក្យប្រៀបប្រដូច (មើល ទដ ១៤៣:៦ អស ៦:៣) ពីស្រុកដែលអ្នកនិពន្ធមានបំណងប្រាថ្នាចង់រស់នៅ គឺជាស្រុកមួយដែលមានដោយ "ទន្លេ១ដែលមានព្រែកទាំងប៉ុន្មាន នាំឱ្យទីក្រុងនៃព្រះមានសេចក្តីអំណរ" (មើល ៤៦:៤ និងការពន្យល់) ពីព្រោះនៅស្រុកនេះគាត់មិនដែល "បានឆ្អែត" ឡើយ (មើល ខ.៥) ។

**៦៣:២–៥** នៅក្នុងខទាំងនេះ គឺជាការបញ្ជាក់បន្ថែមពីដែលអ្នកនិពន្ធបានឃើញក្នុងទីបរិសុទ្ធ ហើយការនេះបានឱ្យអ្នកនិពន្ធភ្ញាក់ដឹងខ្លួនដើម្បីទទួលយកសេចក្តីអំណរដែលគាត់បានរងចាំ ។

**៦៣:២** មើល ២៧:៤ ៤៨:៨ និងការពន្យល់ ។

**៦៣:៣** *សេចក្តីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**៦៣:៤** *ព្រះនាម* មើលការពន្យល់ ៥:១១ ។ *ទូលបង្គំនឹងប្រទូលដៃឡើង* ជាញឹកញាប់នៅពេលប្រទូលដៃឡើងទៅចំពោះព្រះ គឺនៅពេលអធិស្ឋាន

៥ នោះព្រលឹងទូលបង្គំនឹងបានឆ្អែត ដូចជាបានបរិភោគខួរ
ឆ្អឹង ហើយនិងខ្លាញ់ផង[ជ] មាត់ទូលបង្គំក៏នឹងសរសើរទ្រង់
ដោយបបូរមាត់រីករាយ
៦ ដោយទូលបង្គំនឹកដល់ទ្រង់ នៅលើដំណេក
ហើយរំពឹងគិតពីទ្រង់ នៅអស់ទាំងយាមយប់[ឈ]
៧ ដ្បិតទ្រង់បានធ្វើជាជំនួយដល់ទូលបង្គំ[ញ]
ទូលបង្គំនឹងមានចិត្តរីករាយនៅក្រោមម្លប់ស្លាបទ្រង់[ដ]
៨ ព្រលឹងទូលបង្គំតាមទ្រង់ប្រកិត[ឋ]
ព្រះហស្តស្តាំនៃទ្រង់ក៏ទប់ទល់ទូលបង្គំ[ឌ]
៩ តែអស់អ្នកដែលរកបំផ្លាញព្រលឹងនៃទូលបង្គំ[ឍ]
នោះនឹងចុះទៅក្នុងជំរៅនៃផែនដី[ណ]
១០ គេនឹងត្រូវប្រគល់ទៅក្នុងអំណាចដាវ[ត]
គេនឹងបានជាអាហារដល់ឆ្កែព្រៃ[ថ]
១១ តែទូលបង្គំ ជាក្សត្រ នឹងរីករាយក្នុងព្រះវិញ
អស់អ្នកណាដែលស្បថដោយនូវទ្រង់នោះនឹងបាន
សរសើរដោយអរសាទរ[ទ]
ពីព្រោះមាត់នៃពួកមនុស្សកំភូតនឹងត្រូវបិទ[ធ]។

ទំនុករបស់ស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**៦៤** ឱព្រះអង្គអើយ សូមស្តាប់សំឡេងទូលបង្គំ
ដែលទូលបង្គំពោលដំអូញ[ក] សូមការពារជីវិតទូលបង្គំ

**៦៣:៥** ជ ទដ ៣៦:៨ មថ ៥:៦ **៦៣:៦** ឈ ចទ ៦:៤–៩ ទដ ១៦:៧ ១១៩:១៤៨ មថ ១៤:២៥ **៦៣:៧** ញ ទដ ២៧:៩ ១១៨:៧ ដ នរ ២:១២ **៦៣:៨** ឋ ជន ៣២:១២ ហស ៦:៣ ឌ ទដ ៤១:១២ **៦៣:៩** ឍ ទដ ៤០:១៤ ណ ទដ ៥៥:១៥ ៧១:២០ ៩៥:៤ ១៣៩:១៥

**៦៣:១០** ត យរ ១៨:២១ អគ ៣៥:៥ អម ១:១១ ថ បទ ៥:១៨ **៦៣:១១** ទ ទដ ២១:១ អស ១៩:១៨ ៤៥:២៣ ៦៥:១៦ ធ យប ៥:១៦ រម ៣:១៩ **៦៤:១** ក ទដ ១៤២:២

ហើយនិងការសរសើរដំកើង (មើល ១៣៤:២) ។ គំនិតនេះកម្រនឹងមានឃើញក្នុងព្រះគម្ពីរណាស់ ។

**៦៣:៥** *ព្រលឹង* មើលការពន្យល់ ៦:៣ ។ *បានឆ្អែតដូចជា បានបរិភោគខួរឆ្អឹង* នេះគឺជាភាសារអក្សរសាស្ត្រ (មើលគំនិតដែលប្រហាក់ប្រហែលគ្នានេះក្នុង អស ២៥:៦) ។

**៦៣:៦** នៅក្នុងខនេះ គឺជាចំណុចស្នូលដែលបាននិយាយអំពី (មើលសេចក្តីផ្តើមទំនុកដំកើងជំពូកនេះ) ការសញ្ជឹងគិតនៅលើដំណេក និងការចងចាំពីអ្វីដែលគាត់ (អ្នកនិពន្ធ) បានឃើញនៅក្នុង "ទីបរិសុទ្ធ" (ខ.២) ។ *នៅលើដំណេក* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា នៅពេលយប់គាត់បានរង់ចាំដោយសង្ឃឹម ក្នុងការរង់ចាំសេចក្តីសង្គ្រោះនៅពេលព្រឹក ។ *នៅអស់ទាំងយាមយប់* មើលការពន្យល់ ពច ៧:១៩ និង ១១៩:១៤៨ បទ ២:១៩ ។

**៦៣:៧–១០** នៅក្នុងខទាំងនេះមានការខុសគ្នាច្រើន រវាងពាក្យថាទ្រង់ជា "ជ័យជម្នះ" របស់ទូលបង្គំ និងជាជ័យជម្នះរបស់ពួកគេ ។ នៅក្នុងខនិមួយៗក្នុងចំណោមខទាំង៤ គឺមានផ្ទៃរឿងមួយចំនួនដែលមានទំនាក់ទំនងជាមួយគ្នា ដែលមានតុល្យភាពជាមួយគ្នា(សូមមើលសេចក្តីផ្តើម ទដជំពូកនេះ) ។

**៦៣:៧** *ម្លប់ស្លាបទ្រង់* មើលការពន្យល់ ១៧:៨ ។ ដោយសារសេចក្តីជំនួយរបស់របស់ព្រះយេហូវ៉ា បានធ្វើឱ្យអ្នកនិពន្ធបានមកក្នុងទីបរិសុទ្ធរបស់ព្រះជាថ្មី (មើល ខ.២) ហើយនាំមកជាមួយនឹងបទចម្រៀងនៃការសរសើរតម្កើងដល់ព្រះអម្ចាស់សួគ៌ ។

**៦៣:៨** នៅក្នុងខនេះ អ្នកនិពន្ធធ្លាប់ទទួលបាន"សេចក្តីសប្បុរស" របស់ព្រះដែលវិសេសជាងជីវិតទៅទៀត (ខ.៣) ។

**៦៣:៩** នៅក្នុងខនេះចង់និយាយថា ពួកខ្មាំងសត្រូវទាំងប៉ុន្មានរបស់គាត់ នឹងទទួលលទ្ធផលយ៉ាងសក្តិសមតាមអ្វីដែលគេប្រព្រឹត្តិ ។ ពួកគេស្វែងរកជីវិតរបស់គាត់ដើម្បីបំផ្លាញ ប៉ុន្តែពួកគេត្រូវបានបាត់បង់ជីវិតរបស់គេវិញ(មើល លប ៩:៥ នក ២១:២៣ ចទ ១៩:២១ និងការពន្យល់ ទដ ៥:១០) ។ ចុងបញ្ចប់របស់ពួកខ្មាំងសត្រូវទាំងនោះ គឺមានការខុសគ្នាពីសេចក្តីសង្ឃឹមរបស់អ្នកនិពន្ធដូចដែលបានប្រមើលទុកជាមុននៅក្នុង ខ.៧–៨ (មើល ខ.៤) ហើយអ្នកនិពន្ធនឹងពោលថា "ទូលបង្គំនឹងលើកដំកើងទ្រង់" ហើយ "ខ្មាំងសត្រូវរបស់ទូលបង្គំនឹងត្រូវដួលចុះ" ទៅកន្លែងដែល "ត្រូវបិទ" (មើល ខ.១១) ។ *ជំរៅ* មើលការពន្យល់ ៣០:១ ។ *ផែនដី* ឃ្លានេះគឺចង់និយាយសំដៅលើស្ថានឃុំព្រលឹងមនុស្សស្លាប់ ឬការជំនុំជម្រះលើកទី២ (មើលការពន្យល់ ៦:១២) ។

**៦៣:១០** *អាហារដល់ឆ្កែព្រៃ* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា អ្នកណាដែលរកបំផ្លាញជីវិតគាត់ នោះនឹងបានដូចគ្នានឹងសាកសពរបស់ពួកខ្មាំងសត្រូវឯទៀត ដែលមិនបានកប់នៅក្នុងវាលចម្បាំងដ៏គួរឱ្យអាម៉ាស់មុខបំផុត (មើលការពន្យល់ ៥៣:៥) ។ សូមធ្វើការកត់សំគាល់ថា នៅទីនេះមានការខុសគ្នា២គឺ "ទូលបង្គំនឹងបានឆ្អែត ដូចជាបានបរិភោគខួរឆ្អឹង" (ខ.៥) និង "គេនឹងបានជាអាហារដល់ឆ្កែព្រៃ" ។

**៦៣:១១** នៅក្នុងខនេះ គឺជាសេចក្តីបញ្ចប់នៃជំពូកនេះ (សូមមើលសេចក្តីផ្តើមទំនុកដំកើងជំពូកនេះ) ។ នៅក្នុងសេចក្តីបញ្ចប់នេះអ្នកនិពន្ធបានបង្ហាញពីអត្តសញ្ញាណរបស់គាត់ថា គាត់គឺក្សត្រមួយអង្គ ។ *អស់អ្នកណាដែលស្បថដោយនូវទ្រង់* គឺជាអស់អ្នកណាដែលស្រឡាញ់ និងទុកចិត្តចំពោះព្រះ (មើល ចទ ៦:១៣) ។ *មាត់នៃមនុស្សកំភូត* គឺជាពួកអ្នកដែលរស់នៅដោយការនិយាយតែពាក្យមិនពិត (មើល ៥:៦ ៥៨:៣ ១០១:៧ និងការពន្យល់ ទដ ៥:៩) ។

**ទដ ៦៤** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានទៅចំពោះព្រះ ដោយសូមឱ្យព្រះអង្គបានការពារដល់គាត់ ក្នុងពេលជួបការបៀតបៀនពីពួកមនុស្សអាក្រក់ (សូមមើលក្នុងសេចក្តីផ្តើម ទដ ៦១–៦៤) ។ ស្ថានភាពរបស់អ្នកនិពន្ធពេលនេះ ប្រហែលដូចគ្នានឹងស្ថានភាពរបស់ពួកអ្នកដែលមាននិយាយនៅក្នុង ទដ ៦២ដែរ (សូមមើលក្នុងសេចក្តីផ្តើម ទដ ៦២) ប៉ុន្តែ នៅក្នុងជំពូកនេះ មិនបានពណ៌នាពីភាពកំសោយរបស់ស្តេចនោះឡើយ ហើយនៅក្នុងជំពូកនេះ ក៏មិនបាននិយាយច្បាស់ថា តើពួកមនុស្សអាក្រក់ទាំងនោះគេចេញមកពីណាឡើយ មិនដឹងថាតើមកពីក្នុងពួកអ៊ីស្រាអែល ឬជាតិសាសន៍ដទៃនោះទេ (មើលការពន្យល់ ខ.២) ។ ជាញឹកញាប់ក្នុងសេចក្តីអធិស្ឋានអ្នកនិពន្ធតែងតែនិយាយថា អណ្តាតរបស់ពួកខ្មាំងសត្រូវ គឺជាអាវុធដ៏ចម្បង (ការពន្យល់ ទដ ៥:៩) ។ គោលបំណងសំខាន់នៃសេចក្តីអធិស្ឋាននៅក្នុងជំពូកនេះ គឺសូមឱ្យព្រះអម្ចាស់ទ្រង់ជួយការពារ ពីពួកខ្មាំងសត្រូវ (មើល ខ.១) ហើយបានបញ្ចប់វិញ ដោយការហៅឱ្យចូលមកលើកដំកើងព្រះអម្ចាស់ទាំងអស់គ្នា (ខ.១០) ហើយប្រស្រ័យទាក់ទងគ្នា ដោយការលេងពាក្យ (មើលការពន្យល់ខទាំងនោះ) ។ មានល្បះ២ ដែលមានតុល្យភាពចំពោះគ្នា

ឱ្យរួចពីការភ័យខ្លាចចំពោះពួកខ្មាំងសត្រូវ[ខ]
២ សូមលាក់ទូលបង្គំ ឱ្យកំបាំងពីសេចក្ដី[គ]ដែលពួកប្រព្រឹត្ត
អាក្រក់[ឃ] ប្រឹក្សាដោយសំងាត់
និងពីការចលាចលរបស់មនុស្ស ដែលប្រព្រឹត្តអំពើទុច្ចរិត
៣ ជាពួកអ្នកដែលបានសំលៀងអណ្ដាតដូចជាសំលៀងដាវ[ង]
ព្រមទាំងដំរង់ព្រួញគេ គឺជាពាក្យជូរចត់[ច]
៤ ដើម្បីនឹងបាញ់ពីទីកំបាំង ឱ្យត្រូវមនុស្សគ្រប់លក្ខណ៍[ឆ]
គេស្រាប់តែបាញ់អ្នកនោះ ឥតខ្លាចអ្វីសោះ[ជ]
៥ គេជំរុញចិត្តគ្នាក្នុងការអាក្រក់ ក៏ពិគ្រោះគ្នាអំពីការដាក់
អន្ទាក់[ឈ] ដោយស្ងាត់កំបាំង គេថា តើអ្នកណានឹងឃើញ[ញ]
៦ គេស្វែងរកអំពើទុច្ចរិត គេថា
យើងបានស្វែងរកអស់ពីចិត្ត ជាស្រេចហើយ
ឯគំនិតខាងក្នុង នឹងចិត្តរបស់គេ សុទ្ធតែមានជំរៅណាស់
៧ ប៉ុន្តែព្រះទ្រង់នឹងបាញ់ចំគេ
លោតែគេនឹងត្រូវរបួសដោយព្រួញណាមួយ
៨ គឺអណ្ដាតខ្លួនគេនឹងនាំឱ្យគេដួល[ដ]
ហើយអស់អ្នកណាដែលឃើញនឹងគ្រវីក្បាល[ឋ,ឌ]
៩ នោះមនុស្សទាំងអស់នឹងភ័យខ្លាច[ឍ]
ហើយនិងប្រកាសប្រាប់ពីកិច្ចការរបស់ព្រះ
ព្រមទាំងពិចារណាដោយប្រាជ្ញាពីការដែលទ្រង់ធ្វើ[ណ]
១០ ពួកមនុស្សសុចរិតនឹងអរសប្បាយ
ដោយនូវព្រះយេហូវ៉ា[ត] គេនឹងពឹងជ្រកក្នុងទ្រង់[ថ]
អស់អ្នកណាដែលមានចិត្តទៀងត្រង់
គេនឹងអួតសរសើរ[ទ] ។

ទំនុកជាបទចំរៀងរបស់
ស្ដេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។
**៦៥** ឱព្រះអង្គអើយ សេចក្ដីសរសើរចាំតែទ្រង់នៅ

**៦៤:១** ខ ទដ ១៤០:១ **៦៤:២** គ នក ១:១០ ឃ ទដ ៥៦:៦ ៥៩:២ **៦៤:៣** ង ទដ ៥៥:២១ អស ៤៩:២ ច ទដ ៧:១៣ ៥៨:៧ **៦៤:៤** ឆ យប ៩:២៣ ទដ ១០:៨ ១១:២ ជ ទដ ៥៥:១៩ **៦៤:៥** ឈ ទដ ៩១:៣ ១១៩:១១០ ១៤០:៥ ១៤១:៩ ញ យប ២២:១៣ **៦៤:៨** ដ ទដ ៥៩:១២ សភ ១៨:៧ ឋ ២ពវ ១៩:២១ ទដ ១០៩:២៥ ឌ ចទ ២៨:៣៧ **៦៤:៩** ឍ ទដ ៤០:៣ **៦៤:៩** ណ យរ ៥១:១០ **៦៤:១០** ត យប ២២:១៩ ថ ទដ ១១:១ ២៥:២០ ៣១:២ ទ ទដ ៣២:១១

បានពន្យល់យ៉ាងក្បោះក្បាយពីសេចក្ដីអធិស្ឋានរបស់ស្ដេចដាវីឌ និងការបៀតបៀនរបស់ពួកអ្នកក្បត់ (មើល ខ.២–៤) និងការជំទាស់របស់ព្រះអម្ចាស់ និងផលប៉ះពាល់ដល់អ្នកដែលស្ដាប់ឮ (មើល ខ.៧–៩) ។ ទំនាក់ទំនងរវាងល្បះដែលមានតុល្យភាពចំពោះគ្នានេះ គឺបានបង្ហាញច្បាស់តាមរយៈការប្រើពាក្យគន្លឹះ ដែលបានឃើញនៅក្នុងកំណាព្យហេព្រើរយ៉ាងស៊ីចង្វាក់គ្នា តាមលំដាប់នៃពាក្យ "ប្រព្រឹត្ត" (ខ.២) "អណ្ដាត" (ខ.៣) "ស្រាប់តែបាញ់" (ខ.៤) "នឹងបាញ់" (ខ.៧) "អណ្ដាត" (ខ.៨) "កិច្ចការ" (ខ.៩ នៅក្នុងភាសាហេព្រើរពាក្យនេះ មានន័យដូចគ្នានឹងពាក្យប្រព្រឹត្ត ដែលមាននិយាយនៅក្នុង ខ.២ ដែរ" ។ នៅចំណុចកណ្ដាលនៃជំពូកនេះ (ខ.៥–៦) បានពណ៌នាពីការមើលងាយរបស់ពួកអ្នកដែលក្បត់គាត់ ។

**៦៤ត្រង់ចំណងជើង** សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។

**៦៤:១** គោលបំណងចម្បងរបស់អ្នកនិពន្ធក្នុងខនេះ គឺចង់ឱ្យព្រះអម្ចាស់ទ្រង់ស្ដាប់ឮពាក្យដែលគាត់បានអំពាវនាវរកព្រះ ។ *សូមស្ដាប់* នៅក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះ គឺជាការលេងពាក្យមួយនៃពាក្យ "អរសប្បាយ" (ខ.១០) (មើលការពន្យល់ក្នុងខនោះ) ។

**៦៤:២–៤** នៅក្នុងខនេះ គឺនិយាយពីការដែលអ្នកនិពន្ធបានរ៉ាយរ៉ាប់រឿងរបស់គាត់ទៅចំពោះព្រះ និងការបៀតបៀន ។

**៦៤:២** *ការចលាចលរបស់មនុស្ស* នៅក្នុងព្រះគម្ពីរភាសាហេព្រើរឃ្លានេះមានន័យដូចគ្នានឹងឃ្លា "ជ្រួលជ្រើម" ដែលនិយាយនៅក្នុង ២:១ ។

**៦៤:៣** *អណ្ដាត* សូមមើលការពន្យល់ ៥:៩ ។ *ដាវ ព្រមទាំងដំរង់ព្រួញ* សូមមើលការពន្យល់ ៥៩:៧ ។

**៦៤:៤** *ឥតខ្លាចអ្វីសោះ* ដោយព្រោះពួកគេមានអារម្មណ៍ថា ខ្លួនគេបានទទួលនូវសេចក្ដីសុខសាន្តត្រាន្ត ពីពួកអ្នកដែលតតាំង និងពួកអ្នកដែលសងសឹក (មើល ទដ ១០ និងការពន្យល់ ១០:៦,១១) ប៉ុន្តែ មើល ខ.៧–៨ ។

**៦៤:៥–៦** នៅក្នុងខនេះ គឺនិយាយអំពីការដែលពួកខ្មាំងសត្រូវគេមានទំនុកអំពីខ្លួនគេ ។

**៦៤:៥** *ដាក់អន្ទាក់ដោយស្ងាត់កំបាំង* មើលការពន្យល់ ៩:១៥ ។

**៦៤:៦** *ចិត្ត* មើលការពន្យល់ ៤:៧ ។ *ជំរៅ* ពាក្យនេះគឺជាភាសាអក្សរសាស្ត្រ (មើលល សភ ១៨:៤ ២០:៥) ។

**៦៤:៧–៩** នៅក្នុងខនេះចង់និយាយថា ដោយសារអ្នកនិពន្ធគាត់មានទំនុកចំពោះការជំនុំជម្រះដ៏យុត្តិធម៌របស់ព្រះ នោះគាត់នឹងធ្វើឱ្យពួកខ្មាំងសត្រូវទាំងប៉ុន្មាន ដែលព្យាយាមដោយចេតនាក្នុងការព្យាបាទដល់ស្ដេចដាវីឌ (មើល ខ.៣–៤) និងទទួលផលតាមអ្វីដែលគេធ្វើ ។ សូមមើលទំនាក់ទំនងរវាងល្បះនេះ និង ខ.២–៤ មើលក្នុងសេចក្ដីផ្ដើម ទំនុកដំកើង ជំពូកនេះ ។

**៦៤:៧** *បាញ់... ព្រួញ* សូមមើលការពន្យល់ លប ៩:១៣ ។

**៦៤:៨** *គ្រវីក្បាល* សូមមើល ៤៤:១៤ ។

**៦៤:៩** នៅក្នុងខ.នេះចង់និយាយថា គ្រប់ទាំងមនុស្សនឹងកោតខ្លាច ថ្លែងប្រាប់ និងសញ្ជឹងគិតពី "ការងារ" របស់ព្រះអម្ចាស់ដែលទ្រង់បានធ្វើចំពោះ "មនុស្សអាក្រក់" (ខ.២ សូមមើលការពន្យល់ក្នុង ៤៦:១០ និង ៤០:៣ ៥៨:១១ ៦៥:៨) ។

**៦៤:១០** នៅក្នុងខនេះ គឺជាសេចក្ដីបញ្ចប់នៃ ទដ ៦៤ (មើល ខ.១) ដែលនិយាយថា ពួកមនុស្សសុចរិតនឹងអរសប្បាយ ដោយនូវព្រះយេហូវ៉ា គេនឹងពឹងជ្រកក្នុងទ្រង់ ។ *ពួកមនុស្សសុចរិត* មើលការពន្យល់ ១:៥ ។ *អរសប្បាយ* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ នេះគឺជាពាក្យដំបូងនៅក្នុងចង្កោមនៃទំនុកដំកើងនេះ ហើយពាក្យនេះក៏ជាការលេងពាក្យនៃពាក្យ "សូមស្ដាប់" ដែលមាននិយាយនៅដើមខដំបូង ។

**ទដ ៦៥–៦៨** នៅក្នុងជំពូកទាំងនេះ គឺជាបទនៃទំនុកដំកើង៤ដែលផ្ទៃរឿងរបស់វាបានសង្កត់ធ្ងន់លើការសរសើរតម្កើង និងភ្ជាប់ដោយឃ្លាដែលទទួលស្គាល់ថា ព្រះអម្ចាស់ "គួរឱ្យភ័យខ្លាច" ដែលបានរំពូកពីការមន្ទិលសង្ស័យរបស់មនុស្ស "ចុងបំផុតនៃផែនដីទាំងមូល" ហើយបានធ្វើគ្រប់ទាំងអស់នៃមនុស្សដែលនៅផែនដីនោះ បានចូលរួមជាមួយពួកអ៊ីស្រាអែលដើម្បីច្រៀងសរសើរតម្កើងដល់ព្រះនៃសាសន៍អ៊ីស្រាអែល (មើលការពន្យល់

ក្រុងស៊ីយ៉ូន[ក] នោះគេនឹងលាបំណន់ចំពោះទ្រង់[ខ]
២ឱព្រះដែលស្តាប់សេចក្តីអធិស្ឋានអើយ
អស់ទាំងមនុស្សនឹងមូលមកឯទ្រង់[គ]
៣អស់ទាំងសេចក្តីទុច្ចរិតតែងតែឈ្នះទូលបង្គំ
ឯការរំលងរបស់យើងខ្ញុំ[ឃ] នោះទ្រង់នឹងជំរះចោលចេញ[ង]
៤មានពរហើយ អ្នកណាដែលទ្រង់រើស[ច] ហើយនាំមកនៅ[ឆ]
ចំពោះទ្រង់ ដើម្បីឱ្យបានអាស្រ័យនៅក្នុងព្រះលានទ្រង់
យើងខ្ញុំនឹងបានស្កប់ចិត្តដោយសេចក្តីល្អនៃដំណាក់ទ្រង់[ជ]
គឺជាព្រះវិហារដ៏បរិសុទ្ធរបស់ទ្រង់
៥ឱព្រះដ៏ជួយសង្គ្រោះយើងខ្ញុំអើយ[ឈ] ទ្រង់នឹងឆ្លើយមកយើង
ខ្ញុំ ដោយការគួរស្ញែងខ្លាចតាមសេចក្តីសុចរិត[ញ]
ទ្រង់ជាទីទុកចិត្តសង្ឃឹមស្មោះ នៃគ្រប់ទាំងចុងផែនដី

**៦៥:១** ក ទដ ២:៦ ខ ចទ ២៣:២១ ទដ ១១៦:១៨ **៦៥:២** គ ទដ ៨៦:៩ អស ៦៦:២៣ **៦៥:៣** ឃ ទដ ៤០:១២ ង ទដ ៧៩:៩ រម ៣:២៥ ហប ៩:១៤ **៦៥:៤** ច ទដ ៣៣:១២ ឆ ជន ១៦:៥ ជ ទដ ៣៦:៨ **៦៥:៥** ឈ ចទ ៤:៣៤ ទដ ៤៥:៤ ១០៦:២២ អស ៦៤:៣ ញ ទដ ១៨:៤៦ ៦៨:១៩ ៨៥:៤

៤៦:១០) ។ នៅក្នុងបទទំនុកដំកើងទាំង ៤ ជំពូកនេះបានប្រាប់ពីឱកាស និងមូលហេតុដែលពិភពលោកទាំងមូល ត្រូវសរសើរតម្កើងចំពោះព្រះយេហូវ៉ាដូចជា (១).អំណាចចេស្តារបស់ព្រះយេហូវ៉ា ដែលទ្រង់បានធ្វើការអះអាងតាមរយៈការបង្កើតរបស់ទ្រង់ និងបានធ្វើឱ្យរបស់ទាំងអស់ដែលទ្រង់បានបង្កើតនោះបង្កើតផលផ្លែ ហើយការទាំងអស់នោះបានធ្វើឱ្យមនុស្សទទួលបានព្រះពរដ៏បរិបូរមកពីព្រះអម្ចាស់ (២).សេចក្តីសង្គ្រោះដែលព្រះយេហូវ៉ាទ្រង់បានជួយរាស្ត្ររបស់ទ្រង់ ។ ផ្នែកដែលមានសារៈសំខាន់ទាំងអស់ដែលបាននិយាយនៅទីនេះ គឺសុទ្ធតែបានផ្លាស់វេនគ្នាក្នុងការសញ្ជឹងគិត និងផ្តោតលើ ។ ទំនុកដំកើង ៦៥ និង ទដ ៦៧ គឺជាសេចក្តីអធិស្ឋានរំឭកពីគ្រាអតីតកាលហើយក្នុង ទដ ៦៦ និង ទដ ៦៨ និយាយពីសេចក្តីអធិស្ឋានពីការដែលព្រះអម្ចាស់ទ្រង់នឹងធ្វើទៀត ។

**ទដ ៦៥** នៅក្នុងជំពូកនេះ គឺជាបទចម្រៀងនៃការសរសើរតម្កើងដល់ព្រះចំពោះសេចក្តីសប្បុរសរបស់ទ្រង់ ដែលទ្រង់បានធ្វើចំពោះប្រជារាស្ត្ររបស់ទ្រង់ ។ ដើម្បីឆ្លើយតបចំពោះការអំពាវនាវរបស់ពួកគេនោះ (១).ព្រះអម្ចាស់ទ្រង់បានអត់ទោសអំពើបាបរបស់ពួកគេ ដើម្បីឱ្យគេអាចបន្ត "ធ្វើការល្អ" ដោយអំណរក្នុងការប្រកបជាមួយព្រះអម្ចាស់ក្នុងព្រះវិហារ (មើល ខ.១-៤) (២).ក្នុងនាមព្រះអង្គ ជាម្នាក់ដែលបានប្រទានសុខសន្តិភាពគ្រប់បែបយ៉ាង ចំពោះស្នាព្រះហស្តទាំងឡាយ ដែលព្រះបានបង្កើតមកនោះព្រះអម្ចាស់ទ្រង់ក៏បានរៀបចំផ្តល់ការងារដល់លោកិយនេះដែរ ដូច្នេះពួកសាសន៍ដទៃដែលចលាចលទាំងនោះបានសាបសូន្យ ហើយពួកអ៊ីស្រាអែលគេនឹងបានរស់នៅដោយសុខសាន្តត្រាន ក្នុងទឹកដីរបស់ពួកគេ (ខ.៥-៨) (៣).ព្រះអង្គបានបង្វែទឹកដីសព្វា ឱ្យទៅជាសួនច្បារអេដែនដ៏ពិត (មើល ខ.៩-១៣) ។ គ្រប់ការទាំងអស់នេះ ព្រះអម្ចាស់ទ្រង់ត្រូវបានហៅថា "ទ្រង់ជាទីសង្ឃឹម" របស់មនុស្សជាតិ ។ ការល្អរបស់ព្រះអម្ចាស់បានធ្វើឱ្យសេចក្តី "ភ័យខ្លាច" របស់ពួកគេប្រែក្លាយទៅជា "ច្រៀងដោយអំណរ" ពីព្រះ ។

**៦៥ ត្រង់ចំណងជើង** សូមមើលការពន្យល់ក្នុង ទដ ៤ និង ទដ ៣០ ត្រង់ចំណងជើង ។

**៦៥:១-២** នៅក្នុងខទាំងនេះគឺជាសេចក្តីផ្តើម ពីការប្តេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះអម្ចាស់ ។

**៦៥:១** *ចាំតែ* គេអាចនិយាយ "ដោយស្ងៀមស្ងាត់" (មើលការពន្យល់ ៦២:១) ។ ឃ្លានេះប្រហែលជាចង់បញ្ជាក់ពីរូបភាព នៃការសរសើរតម្កើងដល់ព្រះអម្ចាស់ជាអចិន្ត្រៃយ៍ក្នុងព្រះវិហារ របស់ពួកអ្នកដែលត្រូវក្រោកឡើងសរសើរតម្កើងនៅពេលដែលគេមកបន់ ក្នុងការសរសើរតម្កើង (មើល ៥៧:៨) ។ *បំណន់* ឃ្លានេះគឺជា ឧទានស័ព្ទនៃការសរសើរតម្កើងរបស់ពួកគេនៅក្នុងគ្រាដែលគេត្រូវការព្រះ (មើល ៦៦:១៤ និងការពន្យល់ ៧:១៧) ។

**៦៥:២** *អស់ទាំងមនុស្ស* តាមភាសាអក្សរសាស្ត្រគឺ "អស់ទាំងសាច់ឈាម" ហើយពាក្យនេះដែរ ប្រហែលនិយាយសំដៅលើរាស្ត្ររបស់ព្រះទាំងអស់ដូចដែលបាននិយាយនៅក្នុង យអ ២:២៨ ("គ្រប់ទាំងមនុស្ស") ។ តាមការកាត់ស្រាយជាច្រើន គេបានជឿថា (មើល ខ.៥,៨) ឃ្លានេះគឺនិយាយសំដៅលើមនុស្សជាច្រើនដែលនៅលើលោកិយនេះ ដូចដែលបាននិយាយនៅក្នុង ៦៤:៩ ៦៦:១,៤,៨ ៦៧:៣-៥ និងកន្លែងផ្សេងៗទៀតក្នុងព្រះគម្ពីរ ។ *នឹងមូលមក* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា គេនឹងមកសរសើរតម្កើងចំពោះព្រះអម្ចាស់តែ១ ក្នុងកាលដែលទ្រង់បានស្តាប់ឮ និងបានឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ពួកគេ ។

**៦៥:៣-៤** នៅក្នុងខទាំងនេះ បានបង្ហាញអំពីសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ ដែលបានបើកផ្លូវនៃព្រះពរដល់រាស្ត្រទ្រង់ ដែលបានពណ៌នានៅក្នុងល្បះ២នេះ ។

**៦៥:៣** *ឯការរំលងរបស់យើងខ្ញុំ នោះទ្រង់នឹងជំរះចោលចេញ* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា នៅពេលដែលគាត់បានថ្វាយដង្វាយឱ្យធួននឹងបាបតាមដែលព្រះអម្ចាស់ទ្រង់បានកំណត់មក នោះទ្រង់បានអត់ទោសសេចក្តីកំហុសរបស់គាត់(សូមមើល ៣២:១-២ ៧៨:៣៨ ៧៩:៩ និងការពន្យល់ លវ ១៦:២០-២២ ១៧:១១ ហប ២:១៧ ៩:៥-៧) ។

**៦៥:៤** *មានពរហើយ* មើលការពន្យល់ ១:១ ។ *អ្នកណាដែលទ្រង់រើស* នៅក្នុងឃ្លានេះនិយាយសំដៅលើអស់អ្នកដែលជារបស់ព្រះ នៃពួកសាសន៍អ៊ីស្រាអែល (មើល ៣៣:១២ ចទ ៤:៣៧) និងជាអ្នកដែលព្រះអម្ចាស់ទទួលស្គាល់នៅក្នុងព្រះវិហាររបស់ទ្រង់ ។ *អាស្រ័យនៅក្នុងព្រះលានទ្រង់* មើលការពន្យល់ ១៥:១ និង ២៣:៦ ។ *សេចក្តីល្អនៃដំណាក់ទ្រង់* គឺចង់និយាយសំដៅលើព្រះពរ ដែលបានហូរចេញពីព្រះវត្តមានរបស់ព្រះអម្ចាស់ (មើល ៣៦:៨ និងការពន្យល់) ។

**៦៥:៥-៨** នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ដែលទ្រង់នៅតែលើកដំកើងចំពោះស្នាព្រះហស្តទាំងប៉ុន្មាន ដែលទ្រង់បង្កើតមក នោះទ្រង់បានធ្វើឱ្យពួកសាសន៍ដទៃគ្រឡប់ជាស្ងាត់ស្ងៀម ហើយបានធ្វើឱ្យពួកអ៊ីស្រាអែលមានសេចក្តីសុខសាន្តត្រាណវិញ ដោយព្រះអម្ចាស់ទ្រង់បានតបឆ្លើយចំពោះពាក្យដែលគេបានអធិស្ឋានដល់ព្រះអង្គ ។

**៦៥:៥** *ដោយការគួរស្ញែងខ្លាច* គឺជាការស្ញែងខ្លាចចំពោះការដែលព្រះអម្ចាស់ទ្រង់បានធ្វើចំពោះអ៊ីស្រាអែលជារាស្ត្ររបស់ទ្រង់ ក្នុងកាលដែលទ្រង់បានរំដោះគេចេញពីស្រុកអេស៊ីព្ទ និងជួយពួកគេក្នុងពេលមានចម្បាំងជាមួយពួកកាណាន និងការដែលទ្រង់បានធ្វើឱ្យពួកខ្មាំងសត្រូវរបស់ពួកអ៊ីស្រាអែលត្រូវដួលចុះ (មើល ៦៦:៣ ១០៦:២២ ១៤៥:៦ ចទ ១០:២១ ២សយ ៧:២៣ អស ៦៤:៣) ។ *សេចក្តីសុចរិត* គឺជាសេចក្តីសង្គ្រោះដែល

បំផុត[ឌ] ហើយនិងចុងសមុទ្រនៅទីឆ្ងាយផង[ឋ]
៦ ទ្រង់បានតាំងអស់ទាំងភ្នំ[ឱ]ឱ្យមាំមួន ដោយឥទ្ធិឫទ្ធិនៃទ្រង់
ទ្រង់ក្រវាត់ដោយឫទ្ធានុភាព[ឍ]
៧ ទ្រង់ធ្វើឱ្យសូរសន្ធឹកនៃសមុទ្របានស្ងប់ឈឹង[ណ]
ព្រមទាំងសូរសន្ធឹកនៃរលក
និងការជ្រួលជ្រើមនៃបណ្តាជនទាំងឡាយផង[ត]
៨ ឯពួកអ្នកដែលនៅទីឆ្ងាយបំផុតគេក៏ខ្លាចដោយការអស្ចារ្យរបស់ទ្រង់
ទ្រង់បណ្តាលឱ្យពេលព្រលឹមស្រាងនឹងពេលល្ងាចព្រលប់
បានអរសប្បាយផងគ្នា[ថ]
៩ ទ្រង់ក៏ថែរក្សា ហើយស្រោចស្រប់ផែនដី[ទ]
ព្រមទាំងធ្វើឱ្យមានផលកាន់តែច្រើនឡើង[ធ]ដោយទន្លេនៃ
ព្រះមានទឹកពេញ រួចទ្រង់ផ្គត់ផ្គង់ឱ្យមានស្រូវ[ន]
ដោយរៀបចំផែនដីយ៉ាងនោះ
១០ ទ្រង់ស្រោចគន្លងទាំងប៉ុន្មានជាបរិបូរ
ក៏ពង្រាបអាចម៍បំណះ ហើយធ្វើឱ្យដីទន់ ដោយទឹកភ្លៀង[ប]
ក៏ប្រទានពរដល់ពន្លក
១១ ទ្រង់ប្រោសប្រទានឱ្យឆ្នាំបានប្រកបដោយសេចក្តី
សប្បុរសនៃទ្រង់ រីឯឈ្លប[ផ]
ហើយអស់ទាំងផ្លូវទ្រង់ក៏ស្រក់ជាសេចក្តីបរិបូរ[ព]
១២ នោះក៏ស្រក់មកលើដីឃ្វាលសត្វនៅទីរហោស្ថាន[ភ]
ហើយអស់ទាំងទួលក៏ព័ទ្ធដោយសេចក្តីអំណរដែរ[ម]
១៣ អស់ទាំងដីឃ្វាលសត្វបានប្រដាប់ដោយហ្វូងចៀម[យ]
ឯច្រកភ្នំទាំងប៉ុន្មាន នោះក៏មានស្រូវដាសពាសពេញ[រ]
ទីទាំងនោះបន្លឺឡើង ដោយអំណរ ហើយក៏ច្រៀងផង[ល] ។

ទំនុកជាបទចំរៀង ដែលបានលើកសំរាប់មេភ្លេង ។
**៦៦** នែ ផែនដីទាំងមូលអើយ[ក] ចូរបន្លឺឡើង

**៦៥:៥** ឌ ទដ ៤៨:១០ ឋ ទដ ១០៧:២៣ **៦៥:៦** ឱ អម ៤:១៣ ឍ ទដ ១៨:១ ៩៣:១ អស ៥១:៩ **៦៥:៧** ណ ទដ ៨៩:៩ ៩៣:៣–៤ ១០៧:២៩ មថ ៨:២៦ ត ចទ ៣២:៤១ ទដ ២:១ ៧៤:២៣ ១៣៩:២០ អស ១៧:១២–១៣ **៦៥:៨** ថ ទដ ១០០:២ ១០៧:២២ ១២៦:២ អស ២៤:១៦ ៥២:៩ **៦៥:៩** ទ លវ ២៦:៤ ធ ទដ ១០៤:២៤ ន លប ២៧:២៨ ចទ ៣២:១៤ ទដ ១០៤:១៤ **៦៥:១០** ប ចទ ៣២:២

២សយ ១:២១ យប ៣៦:២៨ កច ១៤:១៧ **៦៥:១១** ផ ចទ ២៨:១២ ទដ ១០៤:២៨ យហ ១០:១០ ព យប ៣៦:២៨ ទដ ១៤៧:១៤ លក ៦:៣៨ **៦៥:១២** ភ យប ២៨:២៦ យអ ២:២២ ម ទដ ៩៨:៨ **៦៥:១៣** យ ទដ ១៤៤:១៣ អស ៣០:២៣ សក ៨:១២ រ ទដ ៧២:១៦ ល ទដ ៩៨:៨ អស ១៤:៨ ៤៤:២៣ ៤៩:១៣ ៥៥:១២ **៦៦:១** ក ទដ ៨១:១ ៨៤:៨ ៩៥:១ ៩៨:៤ ១០០:១

ព្រះអម្ចាស់ ទ្រង់ធ្វើតាមការតាំងសញ្ញាជាមួយពួកអ៊ីស្រាអែល (មើលការពន្យល់ ៤:១) ។ *ជាទីទុកចិត្តសង្ឃឹមស្មោះ* ពួកគេមានសង្ឃឹម ទោះបីជាប្រជាជាតិទាំងអស់ ដែលនៅលើពិភពលោកមិនទានមានសេចក្តីសង្ឃឹមពេញលេញក៏ដោយ ។

**៦៥:៦–៧** នៅក្នុងខទាំងនេះចង់និយាយថា ព្រះអម្ចាស់នៃការបង្កើត ហើយដោយសារអំណាចចេស្តារបស់ព្រះអម្ចាស់ ទ្រង់បានធ្វើឱ្យលោកិយទាំងមូលបានរួចផុតពីភាពច្របូកច្របល់ ដែលមានកាលពីដើម (មើល លប ជំពូក ១) ប៉ុន្តែ ឱ្យមានពេញដោយសណ្តាប់ធ្នាប់វិញ ។ ការនេះវាមានភាពប្រហាក់ប្រហែលគ្នា ក្នុងការដែលទ្រង់បានជួយសង្គ្រោះដល់រាស្ត្ររបស់ទ្រង់ និងសាងសន្តិភាពដល់ពួកគេ ក្នុងចំណោមជាតិសាសន៍ដទៃ (មើល អស ២:៤ ១១:៦–៩ មីក ៤:៣–៤) ដូច្នេះហើយទើបធ្វើឱ្យពួកអ៊ីស្រាអែលគេបានសម្រាកក្នុងទឹកដីសន្យា (មើល ទដ ជំពូក ៣៣,៤៦) ។ ជាញឹកញាប់កវីនិពន្ធក្នុងសញ្ញាចាស់ តែងតែប្រៀបធៀបពីអំណាចចេស្តារបស់ព្រះអម្ចាស់នៅពេលដែលទ្រង់សង្គ្រោះពួកគេ ទៅនឹងអំណាចក្នុងការបង្កើត (មើល ៧៤:១២–១៧ ៨៩:៩–១៨ អស ២៧:១ ៤០:៦–១៤,២១–៣១ ៥១:៩–១១) ពីព្រោះអំណាចចេស្តារបស់ទ្រង់ក្នុងការបង្កើត គឺជាអ្នកធានារ៉ាប់រងចំពោះអំណាចចេស្តារបស់ទ្រង់ក្នុងការសង្គ្រោះ ។ *តាំងអស់ទាំងភ្នំ . . . សមុទ្រ* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់គឺជាអ្នកដែលតាំងឱ្យមានសណ្តាប់ធ្នាប់ ចំពោះស្នាព្រះហស្តទាំងឡាយ ដែលទ្រង់បានបង្កើតមក (មើល ៩៥:៤–៥) ។

**៦៥:៧** *ការជ្រួលជ្រើមនៃបណ្តាជន* ចង់និយាយថា ព្រះអម្ចាស់ទ្រង់នៅតែបន្តធ្វើឱ្យសាសន៍ដទៃជ្រួលជ្រើម ពីព្រោះពួកគេតែងតែព្យាបាទដល់ពួកអ៊ីស្រាអែល ។ សូមមើលការប្រៀបធៀបពីការដែលព្រះអម្ចាស់ទ្រង់បង្ករទឹកសមុទ្រឡើងក្នុងការពន្យល់ក្នុង ៣២:៦ និង ៣៣:៧ ។

**៦៥:៨** នៅក្នុងខនេះចង់និយាយថា គ្រប់មនុស្សទាំងអស់គេនឹងឃើញពីសេចក្តីសង្គ្រោះរបស់ទ្រង់ ក្នុងកាលដែលទ្រង់បានជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ ហើយព្រះអម្ចាស់ទ្រង់បានធ្វើឱ្យពួកគេមានសេចក្តីស្ញែងខ្លាចចំពោះព្រះអង្គ (មើលការពន្យល់ ៤៦:១០) ហើយគ្រប់ទាំងអស់នៃស្នាព្រះហស្តរបស់ទ្រង់បែរជាមានអំណរវិញ (មើល ខ.១៣) ។ *ការអស្ចារ្យ* គេអាចនិយាយទៀតថា "ទីសំគាល់" ។ ពាក្យនេះគេនិយាយសំដៅលើសេចក្តីសង្គ្រោះដ៏ធំរបស់ព្រះអម្ចាស់ ជាក់ស្តែងដូចជាក្នុងពេលដែលព្រះអម្ចាស់ទ្រង់បានរំដោះពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទមក (ចទ ៤:៣៤ ទដ ៧៨:៤៣ ១០៥:២៧ ១០៥:២៧ ១៣៥:៩) ។ ដូច្នេះ "ទីសំគាល់" គឺពួកគេនិយាយសំដៅលើការងាររបស់ព្រះអម្ចាស់ (មើល យហ ២:១១ និងការពន្យល់) ។

**៦៥:៩–១៣** នៅក្នុងខទាំងនេះ ចង់និយាយពីការដែលទ្រង់បានឆ្លើយតបចំពោះពាក្យអធិស្ឋានរបស់ពួកអ៊ីស្រាអែល ដោយប្រទានពរដល់ទឹកដីសន្យាឱ្យបានកើតផលល្អគ្រប់ជំពូក ។

**៦៥:៩** *ទន្លេនៃព្រះ* មើលការពន្យល់ ៣៦:៨ ។

**៦៥:១១** *សេចក្តីសប្បុរស* តាមភាសាអក្សរសាស្ត្រពាក្យនេះគឺ "ការល្អ" (មើល ៦៨:១០ និង ៣១:១៩ និងការពន្យល់) ។

**៦៥:១៣** *ទីទាំងនោះបន្លឺឡើង ដោយអំណរ ហើយក៏ច្រៀងផង* ឃ្លានេះគឺជាភាសាមួយ ដែលអ្នកនិពន្ធបានប្រើដើម្បីពណ៌នាពីគ្រប់ទាំងអស់ នៃស្នាព្រះហស្តរបស់ព្រះ និងបានចូលរួមសរសើរតម្កើងដល់ព្រះជាមួយនឹងមនុស្សចំពោះសេចក្តីសប្បុរសរបស់ព្រះ ក្នុងការបង្កើតព្រះពរ និងការប្រោសលោះ (មើល ៨៩:១២ ៩៦:១១–១៣ ៩៨:៨–៩ ១០៣:២២ ១៤៥:១០ ១៤៨:២–៤,៧–១០ យប ៣៨:៧ អស ៤៤:២៣ ៤៩:១៣ ៥៥:១២) ។

**ទដ ៦៦** នៅក្នុងជំពូកនេះ គឺជាបទចម្រៀងនៃការសរសើរតម្កើងចំពោះព្រះអម្ចាស់ ក្នុងកាលដែលទ្រង់បានឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ពួកគេប្រហែលអ្នកនិពន្ធបានសរសើរតម្កើង ដោយព្រោះព្រះអង្គបានរំដោះគាត់ពីពួកខ្មាំងសត្រូវ ។ អ្នកនិពន្ធក៏បានបង្ហាញថា បទនៃជំពូកនេះបាននិយាយា

ដោយអំណរថ្វាយព្រះចុះ
2 ចូរច្រៀងពីកិត្តិយសនៃព្រះនាមទ្រង់[ខ]
ឱ្យសេចក្ដីសរសើរទ្រង់បានរុងរឿងឡើង[គ]
3 ចូរទូលដល់ព្រះថា អស់ទាំងកិច្ចការរបស់ទ្រង់គួរស្ញែង
ខ្លាចយ៉ាងណាទៅ[ឃ] ពួកខ្មាំងសត្រូវនឹងចុះចូល[ង]ចំពោះ
ទ្រង់ ដោយព្រោះឥទ្ធិឫទ្ធិដ៏ជាធំរបស់ទ្រង់
4 ផែនដីទាំងមូលនឹងថ្វាយបង្គំ[ច]
ហើយនិងច្រៀងថ្វាយ[ឆ]ទ្រង់ផង
គេនឹងច្រៀងសរសើរដល់ព្រះនាមទ្រង់ ។ –បង្អង់
5 មកនេះ ចូរមកមើលការ[ជ]ទាំងប៉ុន្មានរបស់ព្រះទ្រង់គួរ
ស្ញែងខ្លាច ក្នុងការដែលទ្រង់ធ្វើដល់ពួកមនុស្សជាតិ
6 ទ្រង់បំផ្លាស់បំប្រែសមុទ្រឱ្យទៅជាដីគោក[ឈ]
គេក៏បានដើរកាត់[ញ]ទន្លេទៅ
នៅទីនោះយើងខ្ញុំបានរីករាយ[ដ]ដោយសារទ្រង់
7 ទ្រង់សោយរាជ្យជារៀងរាបតទៅ[ឋ]ដោយសារព្រះចេស្ដា
នៃទ្រង់ ព្រះនេត្រទ្រង់រំពៃមើល[ឌ]អស់ទាំងសាសន៍
មិនត្រូវឱ្យពួកបះបោរ[ឍ]លើកគ្នាឡើងឡើយ ។ –បង្អង់
8 ម្នាលជនទាំងឡាយអើយចូរលើកដំកើង[ណ]ព្រះនៃយើង
រាល់គ្នា ហើយបន្លឺឡើឱ្យបានឮសេចក្ដីសរសើរទ្រង់ទូទៅ
9 គឺព្រះដែលរក្សាជីវិតយើងឱ្យរស់នៅ[ត]
ក៏មិនឱ្យជើងយើងត្រូវរឥលឡើយ[ថ]
10 ដ្បិត ឱព្រះអង្គអើយ ទ្រង់បានល្បងល[ទ]យើងខ្ញុំហើយ
ក៏បានសាកយើងខ្ញុំដូចជាគេសាកប្រាក់ដែរ[ធ]

**៦៦:២** ខ ទដ ៧៩:៩ ៨៦:៩ គ អស ៤២:៨,១២ ៤២:២១ **៦៦:៣** ឃ ចទ ៧:២១ ១០:២១ ទដ ៦៥:៥ ១០៦:២២ ១១១:៦ ១៤៥:៦ ង ២សយ ២២:៤៥ **៦៦:៤** ច ទដ ២២:២៧ ឆ ទដ ៧:១៧ ៦៧:៣ **៦៦:៥** ជ ខ.៣ ទដ ១០៦:២២ **៦៦:៦** ឈ លប ៨:១ នក ១៤:២២ ញ ១កថ ១០:១ ដ លវ ២៣:៤០

**៦៦:៧** ឋ នក ១៥:១៨ ទដ ១៤៥:១៣ ឌ នក ៣:១៦ ទដ ១១:៤ ឍ ជន ៧:១០ ទដ ១១២:១០ ១៤០:៨ **៦៦:៨** ណ ទដ ២២:២៣ **៦៦:៩** ត ទដ ៣០:៣ ថ ចទ ៣២:៣៥ យប ១២:៥ **៦៦:១០** ទ នក ១៥:២៦ ធ យប ៦:២៩ ២៨:១ ទដ ១២:៦

ពីការដ៏អស្ចារ្យ របស់ពួកយូដានៅពេលដែលព្រះអម្ចាស់ទ្រង់បានរំដោះគេឱ្យរួចពីពួកស៊ីរី (មើល ២ពវ ជំពូក ១៩) ។ ប៉ុន្តែ ឱកាសនៃការច្រៀងបទចម្រៀងនេះ គឺមានការជជែកគ្នាជាច្រើន ហើយបានពណ៌នាយ៉ាងលំអិតនៅ ខ.១៣–២០ ។ បើសិនការនោះជាមូលហេតុពិតប្រាកដមែននោះ អ្វីដែលបាននិយាយនៅក្នុងជំពូកនេះ គឺអ្នកនិពន្ធនិយាយពីបទពិសោធន៍របស់គាត់ ជាមួយព្រះ ក្នុងកាលដែលព្រះអង្គបានជួយសង្គ្រោះដល់រូបគាត់ ដែលជារាស្ត្ររបស់ទ្រង់ម្នាក់ និងមាននិយាយនៅក្នុងបរិបទនៃការជួយសង្គ្រោះរបស់ព្រះ ចំពោះពួកអ៊ីស្រាអែលដែលមាននិយាយនៅក្នុងព្រះគម្ពីរនិកម្ខនំ ។ បទចម្រៀងនេះគឺធ្វើឡើងនៅត្រង់ព្រះវិហារ (មើល ខ.១៣–១៤ និងការពន្យល់ ៧:១៧) ។ ជាញឹកញាប់នៅក្នុងការសរសើរតម្កើងអ្នកនិពន្ធតែងតែហៅឱ្យគ្រប់ទាំងជីវិត បានចូលមកលើកតម្កើងដល់ព្រះអម្ចាស់ដែរ (មើលការពន្យល់ ៩:១) ។ នៅទីនេះក៏ដូចជានៅកន្លែងផ្សេងៗទៀតដែរ (មើល ៦៧:៣–៥ ៦៨:៣២ ៩៨:៤ ៩៩:១–៣ ១០០:១ ១១៧:១) អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គាត់បានចាប់ផ្ដើមហៅដល់ផែនដីទាំងមូលឱ្យមកសរសើរដំកើងដល់ព្រះ ទោះបីជាមនុស្សទាំងនោះ គេនៅចុងបំផុតនៃផែនដីក៏ដោយ ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ គឺជាបទទី២ ក្នុងចំណោមទំនុកដំកើងទាំង៤បទ (មើលក្នុងសេចក្ដីផ្ដើម ទដ ៦៥–៦៨) ។ នៅក្នុងជំពូកនេះបានបង្ហាញច្បាស់ ដោយការហៅឱ្យផែនដីទាំងមូលចូលមកសរសើរតម្កើង (មើល ខ.១–២) និងមូលហេតុនៃការសរសើរតម្កើងដល់ព្រះ (មើល ខ.១៩–២០ នៅក្នុងភាសាហេព្រើរពាក្យថា "សរសើរដំកើង" និងពាក្យថា "អធិស្ឋាន" គឺមានន័យប្រហាក់ប្រហែលគ្នា) ។ ខ.១–៤ គឺជាល្បះដំបូង ដោយមានផ្ទៃរឿង២ទៀត ដែលមានសំណង់ប្រយោគដូចគ្នា ដោយមាន៣ខក្នុង១ល្បះ (ខ.៥–៧,១៣–១៥) ហើយក៏មានល្បះផ្សេងទៀតដែលក្នុង១ល្បះមាន ៥ខដែរ (ខ.៨–១២,១៦–២០) ។ នៅក្នុងល្បះទី១ នៃកថាទី១ (ខ.៥) បានចាប់ផ្ដើមនិយាយថា "មកនេះ ចូរមកមើល" ហើយនៅក្នុងល្បះទី១នៃកថាទី២ (ខ.១៦) បាននិយាយថា "មកនេះ ចូរស្ដាប់ចុះ" ។

**៦៦ ត្រង់ចំណងជើង** សូមមើលការពន្យល់ ទដ ៤,៣០ ត្រង់ចំណងជើង ។

**៦៦:១–៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានហៅដល់ផែនដីទាំងមូល ឱ្យចូលមកសរសើរតម្កើងព្រះអម្ចាស់ដោយអំណរ ។

**៦៦:១** *នៃដីទាំងមូល* មើលការពន្យល់ ៦៥:២ ។

**៦៦:២** *ព្រះនាម* មើលការពន្យល់ ៥:១១ ។

**៦៦:៣** *ស្ញែងខ្លាច* មើល ខ.៥ និងការពន្យល់ ៦៥:៥ ។ *ចុះចូល* មើល ១៨:៤៤ ហើយធៀបជាមួយ យស ៥:១ ២រប ២០:២៩ ។

**៦៦:៤** សូមមើលការពន្យល់ ៤៦:១០ ។

**៦៦:៥–៧** នៅក្នុងខទាំងនេះចង់និយាយថា អ្នកនិពន្ធបាននឹកចាំពីសេចក្ដីសង្គ្រោះរបស់ព្រះចំពោះពួកអ៊ីស្រាអែល នៅឯសមុទ្រក្រហម ដែលជាទីសម្គាល់ពីអំណាចចេស្ដារបស់ព្រះអង្គ ក្នុងការគ្រប់គ្រងលើប្រជាជាតិ ។ អ្នកនិពន្ធបានពណ៌នាពីសេចក្ដីសង្គ្រោះ ដែលគាត់ទទួលបាន (មើលក្នុងសេចក្ដីផ្ដើមខាងលើ) ដែលដូចគ្នានឹងសេចក្ដីសង្គ្រោះដែលគេទទួលបាននៅឯសមុទ្រក្រហមដែរ ក្នុងកាលដែលព្រះអង្គទ្រង់បានជួយគេដោយអំណាចចេស្ដារបស់ព្រះអម្ចាស់ (មើល ៦៥:៥–៧) ។

**៦៦:៥** *មកនេះ ចូរមកមើល* មើលក្នុងសេចក្ដីផ្ដើមទំនុកដំកើងជំពូកនេះ ។ សេចក្ដីសង្គ្រោះរបស់ព្រះដែលមានកាលពីអតីតកាល គឺនៅតែបន្តហើយអាចមើលឃើញនៅក្នុង "ព្រះវិហារ" ជាកន្លែងដែលគេនៅតែបន្តការសរសើរតម្កើងដល់ទ្រង់ (មើល ៤៦:៨ ៤៨:៨–៩ និងការពន្យល់) ។ *ក្នុងការដែលត្រង់ធ្វើដល់មនុស្សជាតិ* គឺទ្រង់បានធ្វើការអស្ចារ្យចំពោះរាស្ត្ររបស់ទ្រង់ ។

**៦៦:៦** *ទន្លេ* នៅក្នុងឃ្លានេះ ប្រហែលអ្នកនិពន្ធនិយាយសំដៅលើទន្លេយ័រដាន់ ប៉ុន្តែភាគច្រើនប្រហែលជាសមុទ្រស្លាប់ ។

**៦៦:៧** *ពួកបះបោរ* គឺជាពួកសាសន៍ដទៃ ដែលបះបោរប្រឆាំងនឹងការគ្រប់គ្រងរបស់ព្រះអម្ចាស់ (មើល ៦៨:៦) ។

**៦៦:៨–១២** នៅក្នុងខទាំងនេះ គឺជាការសរសើរដំកើងពីសេចក្ដីសង្គ្រោះរបស់ព្រះចំពោះរាស្ត្ររបស់ទ្រង់ ។

**៦៦:៨** *ម្នាល ជនទាំងឡាយ* នៅទីនេះប្រហែលនិយាយសំដៅលើហ្វូងមនុស្សដែលបានចូលរួមថ្វាយបង្គំ (មើល ២រប ២០:២៧–២៨) ។

**៦៦:៩** *មិនឱ្យជើងយើងត្រូវរឥលឡើយ* មើលការពន្យល់ ៣៨:១៦ ។

**៦៦:១០** *ល្បងយើងខ្ញុំហើយក៏បានសាក* តាមទស្សនៈវិស័យមួយបានបង្ហាញ

១១ ទ្រង់បាននាំយើងខ្ញុំឱ្យជាប់មង[ន]
ហើយបានផ្ទុកបន្ទុកយ៉ាងធ្ងន់[ប] នៅលើចង្កេះយើងខ្ញុំ
១២ ទ្រង់បានឱ្យមនុស្សជិះក្បាលយើងខ្ញុំ[ផ] យើងខ្ញុំបានដើរលុយ
ភ្លើង និងទឹកទៅ ប៉ុន្តែទ្រង់បាននាំយើងខ្ញុំចេញមកនៅទី
ដ៏មានជាបរិបូរវិញ[ព]
១៣ ទូលបង្គំនឹងយកដង្វាយដុត[ភ] ចូលទៅក្នុងដំណាក់ទ្រង់
ហើយនិងលាបំណន់[ម] របស់ទូលបង្គំ
១៤ ជាបំណន់ដែលបបូរមាត់ទូលបង្គំបានបន់ទុក
ហើយដែលមាត់ទូលបង្គំបានមានវាចាក្នុងកាលដែល
មានសេចក្តីវេទនា
១៥ ទូលបង្គំនឹងថ្វាយចៀមយ៉ាងធាត់ជាដង្វាយដុតដល់ទ្រង់
ព្រមទាំងក្លិនឈ្ងុយរបស់ចៀមឈ្មោលផង
ទូលបង្គំនឹងថ្វាយទាំងកូនគោ និងពពែឈ្មោលដែរ[យ] ។
–បង្អង់
១៦ មកនេះ ចូរស្តាប់ចុះ[រ] អស់អ្នកដែលកោតខ្លាចដល់ព្រះ
អើយ ខ្ញុំនឹងថ្លែងប្រាប់[ល] ពីការដែលទ្រង់
បានប្រោសដល់ព្រលឹងខ្ញុំ
១៧ មាត់ខ្ញុំបានអំពាវនាវដល់ទ្រង់
ហើយអណ្តាតខ្ញុំបានសរសើរដំកើងទ្រង់
១៨ បើប្រសិនជាខ្ញុំឃើញមានសេចក្តីទុច្ចរិតនៅក្នុងចិត្ត
នោះព្រះអម្ចាស់ទ្រង់មិនព្រមស្តាប់ខ្ញុំទេ[វ]
១៩ ប៉ុន្តែព្រះទ្រង់បានស្តាប់ពាក្យ[ស] ខ្ញុំអធិស្ឋាន
២០ សូមសរសើរព្រះអង្គ
ដែលទ្រង់មិនបានបែរចេញ[ហ] ពីសេចក្តីអធិស្ឋានរបស់ខ្ញុំ
ក៏មិនបានបង្វែរសេចក្តីសប្បុរសទ្រង់ពីខ្ញុំចេញដែរ ។

ទំនុកជាបទចំរៀង ដែលបានលើកសំរាប់មេភ្លេង
ត្រូវលេងដោយប្រដាប់មានខ្សែ ។

**៦៧** សូមព្រះអង្គអាណិតមេត្តាដល់យើងខ្ញុំហើយប្រទាន
ពរផង សូមឱ្យព្រះភក្រ្តទ្រង់ភ្លឺមកដល់យើងខ្ញុំ[ក] ។ –បង្អង់

**៦៦:១១** ន ទដ ១៤២:៧ ១៤៦:៧ អស ៤២:៧,២២ ៦១:១ ប លប ៣:១៧ នក ១:១៤ ទដ ៣៨:៤ អស ១៨:១៩ **៦៦:១២** ផ អស ៥១:២៣ ប ទដ ១៨:១៩ **៦៦:១៣** ភ ទដ ៥១:១៩ ម ទដ ២២:២៥ ៥០:១៤ ១១៦:១៤ សស ៥:៤ យហ ២:៩ **៦៦:១៥** យ លវ ១៦:១៥ ទដ ៥១:១៩ រ ទដ ៣៤:១១ ល ទដ ៧១:១៥,២៤ **៦៦:១៨** វ ចទ ១:៤៥ ១សយ ៨:១៨ យក ៤:៣ **៦៦:១៩** ស ទដ ២២:២៤ **៦៦:២០** ហ ទដ ២២:២៤ **៦៧:១** ក ជន ៦:២៤–២៦

ថា ពេលវេលានៃការទុក្ខលំបាកដែលកំពុងតែមាន គឺជាការល្បងលរបស់ព្រះអម្ចាស់ចំពោះរាស្ត្រដែលទុកចិត្ត និងស្មោះត្រង់ចំពោះព្រះ ។

**៦៦:១១–១២** *ទ្រង់ . . . ទ្រង់* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអង្គទ្រង់គ្រប់គ្រងលើហេតុការណ៍ទាំងអស់ ទោះបីជាក្នុងពេលដែលពួកខ្មាំងសត្រូវគេគៀបសង្កត់រាស្ត្ររបស់ទ្រង់ក៏ដោយក៏ព្រះអង្គទ្រង់គ្រប់គ្រងដែរ ។ ព្រះអម្ចាស់ទ្រង់មិនគ្រាន់តែមើលសង្កេតពីគេប៉ុណ្ណោះនោះទេ តែព្រះអម្ចាស់ទ្រង់បានជួយគេ ដោយបំណងព្រះហឫទ័យដ៏បរិសុទ្ធរបស់ព្រះអម្ចាស់ (មើល អស ៤៥:៧ អម ៣:៦) ។ *មង . . . បន្ទុក . . . ជិះ* ប្រហែលនិយាយសំដៅពីគ្រាដែលគេបានចាកចេញពីស្រុកអេស៊ីព្ទ ។

**៦៦:១២** *ភ្លើង និងទឹក* ឃ្លានេះគឺជាពាក្យប្រៀបប្រដូចមួយដែលចង់និយាយពីការកាត់ក្តី (មើល អស ៤៣:២) ។ *ទីដ៏មានបរិបូរ* តាមភាសាអក្សរសាស្ត្រគឺ "កន្លែងដែលពេញហៀរ" (មើល ២៣:៥) ។ ពួកគេនឹងត្រូវនាំចេញពីកន្លែងដែលមានទុក្ខព្រួយ ទៅកន្លែងមួយដែលមានពរដ៏ហូរហៀរ គឺនៅក្នុងទឹកដីសន្យា ។

**៦៦:១៣–១៥** នៅក្នុងខនេះ អ្នកនិពន្ធបានប្រកាសពីការបំពេញបំណន់របស់គាត់ ហើយគាត់បាននិយាយពីការនេះទៅចំពោះព្រះអម្ចាស់ (មើលការពន្យល់ ៧:១៧ និង ៥០:១៤ ១១៦:១៧–១៩) ។

**៦៦:១៣** *ទូលបង្គំ* ពាក្យថា ទូលបង្គំដែលប្រើនៅកន្លែងនេះគឺសំដៅលើស្តេច ។

**៦៦:១៦–២០** នៅក្នុងខនេះ អ្នកនិពន្ធគាត់បានអះអាងពីអ្វីដែលព្រះអម្ចាស់ទ្រង់បានធ្វើដល់រូបគាត់ ហើយការនេះបានធ្វើឱ្យគាត់សរសើរដល់ព្រះអម្ចាស់ និងណែនាំដល់ប្រជាជាតិឯទៀតចូលរួមសរសើរដំកើងដល់ព្រះ (សូមធៀបជាមួយ ៣៤:១–៧) ។

**៦៦:១៦** *មកនេះ ចូរស្តាប់ចុះ* សូមមើលក្នុងសេចក្តីផ្តើម ។ *កោតខ្លាចដល់ព្រះ* សូមមើលការពន្យល់ លប ២០:១១ ។

**៦៦:១៧** *សរសើរដំកើងទ្រង់* នៅក្នុងឃ្លានេះ គឺនិយាយសំដៅលើការអធិស្ឋាន និងការសរសើរដំកើងដែលមាននិយាយនៅក្នុងសញ្ញាចាស់ (រួមទាំងក្នុង អភ ៤:៦ ១ធថ ២:១) ។

**៦៦:២០** *សូមសរសើរព្រះអង្គ* មើល ខ.៨ ។ *សេចក្តីសប្បុរស* មើលការពន្យល់ ៦:៤ ។

**ទដ ៦៧** នៅក្នុងជំពូកនេះ ពួកបណ្តាជនគេនាំគ្នាមកអធិស្ឋានសូមព្រះពរមកពីព្រះអម្ចាស់ ។ យោងតាមមាតិការឿង ទម្រង់ និងសេចក្តីសង្ខេបដែលមាននៅក្នុងជំពូកនេះបានបង្ហាញថា បទទំនុកដំកើង ក្នុងជំពូកនេះគឺជាសេចក្តីអធិស្ឋានរបស់ពួកបណ្តាជន សម្រាប់សូត្រនៅពេលថ្វាយបង្គំចប់ ហើយប្រហែលជាសូត្រតែពួកសង្ឃប៉ុណ្ណោះ ដើម្បីជាការប្រទានពរ (មើលការពន្យល់ ខ.១) ។ ព្រះពររបស់ព្រះចំពោះរាស្ត្ររបស់ទ្រង់ (រួមទាំងសេចក្តីសង្គ្រោះរបស់ព្រះចំពោះពួកគេ) និងធ្វើប្រជាជាតិសាសន៍ដទៃបានសរសើរតម្កើងដល់ព្រះអង្គដែរ (មើល ៦៥:២) ។ ទំនុកដំកើងជំពូកនេះគឺជាបទទី៣ក្នុងចំណោមទំនុកដំកើងទាំង៤បទ ដែលផ្ទៃរឿងពិសេសរបស់វា មានទំនាក់ទំនងជាមួយទដ ៦៥ (មើលក្នុងសេចក្តីផ្តើម ទដ ៦៥–៦៨) ។ លក្ខណៈសំណង់ប្រយោគក្នុងជំពូកនេះ តែងឡើងដោយភាពសមមូលគ្នា ដោយក្នុងនោះមានៈ២ខដំបូងនិយាយពីសេចក្តីអធិស្ឋាន ហើយនៅ២ខចុងក្រោយនិយាយពីការ ដែលព្រះអង្គទ្រង់បានតបឆ្លើយចំពោះពាក្យអំពាវនាវរបស់គេ ។ ល្បះកណ្តាលមានបទបន្ទរ (ខ.៣,៥) ពួកបណ្តាជនគេបានស្វែងរកការឆ្លើយតបរបស់ព្រះ ដោយបាននិយាយថា ចូរឱ្យជនទាំងឡាយចូលមកសរសើរដំកើងដល់ព្រះអម្ចាស់ ដែលការនេះនឹងធ្វើរាស្ត្ររបស់ទ្រង់ភ្ញាក់ខ្លួនឡើង ។

**៦៧ ត្រង់ចំណងជើង** មើលការពន្យល់ ទដ ៤,៣០ ត្រង់ចំណងជើង ។

**៦៧:១–២** នៅខទាំងនេះ និយាយពីសេចក្តីអធិស្ឋានរបស់ពួកបណ្តាជន ។

**៦៧:១** នៅក្នុងខនេះ គឺជាចំណុចស្នូលនៃសេចក្តីអធិស្ឋានហើយបើតាមការ

២ ដើម្បីឱ្យមនុស្សលោកបានស្គាល់ផ្លូវរបស់ទ្រង់
ហើយឱ្យអស់ទាំងសាសន៍ដទៃ[ខ]បានស្គាល់សេចក្តីសង្គ្រោះ[គ]
របស់ទ្រង់ដែរ
៣ ឱព្រះអង្គអើយ សូមឱ្យជនទាំងឡាយសសើរដល់ទ្រង់
ឱ្យជនទាំងអស់សរសើរដល់ទ្រង់[ឃ]
៤ ឱសូមឱ្យអស់ទាំងនគរបានអរសប្បាយហើយច្រៀង
ដោយអំណរចុះ[ង]
ដ្បិតទ្រង់នឹងជំនុំជំរះអស់ទាំងសាសន៍ដោយទៀងត្រង់[ច]
ហើយគ្រប់គ្រងអស់ទាំងនគរដែលនៅផែនដី[ឆ] ។ –បង្អង់
៥ ឱព្រះអង្គអើយ សូមឱ្យជនទាំងឡាយសរសើរដល់ទ្រង់ ឱ្យ
ជនទាំងអស់សរសើរទ្រង់ចុះ

**៦៧:២** ខ ទដ ៩៨:២ អស ៦២:២ កច ១០:៣៥ ទត ២:១១ គ អស ៤០:៥ ៥២:១០ ៦២:១ **៦៧:៣** ឃ ខ.៥ **៦៧:៤** ង ទដ ១០០:១–២ ច ទដ ៩:៤ ៩៦:១០–១៣ ឆ ទដ ៦៨:៣២ **៦៧:៦** ជ លប ៨:២២ លវ ២៦:៤ ទដ ៨៥:១២ អស ៥៥:១០ អគ ៣៤:២៧ សក ៨:១២ ឈ

៦ នោះដីនឹងបង្កើតផលឡើង[ជ]
ហើយព្រះដ៏ជាព្រះនៃយើងខ្ញុំ ទ្រង់នឹងប្រទានពរមក
យើងខ្ញុំ[ឈ]
៧ ព្រះទ្រង់នឹងប្រទានពរមកយើងខ្ញុំជាពិត
ហើយអស់ទាំងចុងផែនដីបំផុត[ញ]នឹងកោតខ្លាចដល់ទ្រង់[ដ] ។

ទំនុកជាបទចំរៀងរបស់
ស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។
**៦៨** សូមព្រះអង្គទ្រង់ឈរឡើង[ក]
ឱ្យពួកខ្មាំងសត្រូវទ្រង់ត្រូវខ្ចាត់ខ្ចាយទៅ[ខ]

លប ១២:២ **៦៧:៧** ញ ទដ ២:៨ ដ ទដ ៣៣:៨ **៦៨:១** ក ទដ ១២:៥ ១៣២:៨ ខ ទដ ១៨:១៤ ៨៩:១០ ៩២:៩ ១៤៤:៦

គិត គេបានដឹងថា គឺជាការប្រទានពររបស់ពួកសង្ឃ (មើល ជន ៦:២៤–២៦) ។ *សូមឱ្យព្រះភក្ត្រទ្រង់ភ្លឺមក* មើលការពន្យល់ ៤:៦ ១៣:១ ។

**៦៧:២** នៅក្នុងខនេះ ចង់និយាយថា សូមឱ្យសេចក្តីសប្បុរសរបស់ទ្រង់ដែលមានចំពោះរាស្ត្រព្រះអង្គ បានសម្តែងយ៉ាងច្បាស់ដល់ប្រជាជាតិផ្សេងៗ ហើយសូមឱ្យប្រជាជាតិទាំងនោះ គេបានឃើញការអស្ចារ្យនោះ (មើលការពន្យល់ ៤៦:១០) ។

**៦៧:៣–៥** នៅក្នុងខទាំងនេះ គឺចង់និយាយពីមូលហេតុដែលត្រូវសរសើរតម្កើងដល់ព្រះអម្ចាស់ ។ ការពណ៌នាយ៉ាងល្អិតល្អន់អំពីព្រះអម្ចាស់នៅក្នុង ខ.២ បានធ្វើឱ្យបណ្តាជននៅផែនដីទាំងមូល សរសើរតម្កើងដល់ព្រះ ហើយសម្លេងនោះបានជាទីពេញចិត្តដល់ព្រះ នៅពេលដែលទ្រង់ប្រទានពរដល់ប្រជារាស្ត្ររបស់ទ្រង់ ។ បំណងចិត្តរបស់ពួកបណ្តាជនមាន២គឺ (១).សូមឱ្យព្រះពររបស់ព្រះ ជាព្រះពរដ៏បរិបូរដើម្បីឱ្យរាស្ត្ររបស់ទ្រង់ គេបានសរសើរតម្កើងដល់ព្រះនាមទ្រង់ (២).ពួកសាសន៍ដទៃគេអាចនឹងសរសើរតម្កើងដល់ព្រះអម្ចាស់ដូចជាពួកអ៊ីស្រាអែល ។

**៦៧:៤** នៅក្នុងខនេះចង់និយាយថា សូមឱ្យពួកសាសន៍ដទៃបានរីករាយក្នុងព្រះអម្ចាស់ នៅពេលដែលគេឃើញការគ្រប់គ្រងដ៏ល្អរបស់ទ្រង់ (មើល ៦៥:៧–៨ ៩៨:៤–៦ ១០០:១) ។

**៦៧:៦–៧** នៅក្នុងខទាំងនេះ គឺចង់និយាយពីព្រះពរដ៏ល្អរបស់ព្រះចំពោះរាស្ត្ររបស់ទ្រង់ ។

**៦៧:៦** នៅក្នុងខនេះចង់និយាយថា ទឹកដីសន្យានឹងបង្កើតផលជាច្រើន (មើល ៦៥:៩–១៣) ។

**៦៧:៧** *អស់ទាំងចុងផែនដីបំផុតនឹងកោតខ្លាចដល់ទ្រង់* មើល ៦៥:៨ ។

**ទដ ៦៨** នៅក្នុងជំពូកនេះ គឺបទនៃការសរសើរចំពោះជ័យជម្នះរបស់ព្រះនៃពួកអ៊ីស្រាអែល ចាប់តាំងពីភ្នំស៊ីណាយដល់ភ្នំស៊ីយ៉ូន ។ ពួកបណ្តាជនបានរួមគ្នាចូលមកអធិស្ឋាន សូមឱ្យអំណាចចេស្តារបស់ព្រះអម្ចាស់នៅតែបន្តរហូតដល់គ្រាដែលរាស្ត្ររបស់ទ្រង់ គេទទួលបានសេចក្តីសុខសាន្តត្រាណហើយសូមឱ្យគ្រប់ទាំងនគរនៅលើផែនដី និងបាននាំយកដង្វាយមកថ្វាយទ្រង់ដើម្បីបង្ហាញពីបន្ទាល់ ពីការសរសើរដំកើងដល់ព្រះនៃពួកអ៊ីស្រាអែល ។ សម្លេងដែលបន្លឺឡើងនៅទីនេះ គឺជាសម្លេងរបស់មនុស្សជាច្រើនដែលចូលរួមថ្វាយបង្គំជាលក្ខណៈសហគមន៍ ហើយប្រហែលព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ គេសូត្រនៅពេលដែលគេធ្វើដំណើរតាមផ្លូវឆ្ពោះទៅកាន់ក្រុងយេរូសាឡិម (មើលក្នុងសេចក្តីផ្តើម ទដ ២៤,៤៧,១១៨,១៣២) ។ នៅពាក់កណ្តាលផ្នែកទី១នៃជំពូកនេះ (មើល ខ.១–១៨ មានកំណាព្យហេព្រើរចំនួន១៩) បានភ្ជាប់មកជាមួយការបញ្ជាក់ពីជ័យជម្នះរបស់ព្រះអម្ចាស់ ចាប់តាំងពីភ្នំស៊ីណាយ (ជំនាន់លោកម៉ូសេ) ដល់ភ្នំស៊ីយ៉ូន (សម័យកាលស្តេចដាវីឌ) ។ ព្រឹត្តិការណ៍ដែលបានកើតឡើងនៅភ្នំស៊ីណាយ បានបង្ហាញពីកំណើតនៃនគរព្រះក្នុងចំណោមពួកអ៊ីស្រាអែល ដែលជារាស្ត្ររបស់ទ្រង់ ។ វត្តមាននៃហឹបសេចក្តីសញ្ញា (និមិត្តរូបពីការសោយរាជរបស់ព្រះអម្ចាស់) នៅក្នុងក្រុងយេរូសាឡិម បានបង្ហាញពីការប្រោសលោះរបស់ព្រះអម្ចាស់ដល់ប្រជាជាតិផ្សេងៗទៀត នៅលើផែនដីនេះដោយចាប់ផ្តើចេញពីក្រុងយេរូសាឡិម ។ នៅពាក់កណ្តាលផ្នែកទី២នៃទំនុកដំកើងក្នុងជំពូកនេះ (ខ.១៩–៣៥ មានកំណាព្យហេព្រើរចំនួន ១៩) គឺបាននិយាយពីសំរែកនៃការសរសើរតម្កើងថា "សូមឱ្យព្រះអម្ចាស់បានប្រកបដោយព្រះពរ" និងនិយាយពីការទន្ទឹងរងចាំពីជ័យជម្នះរបស់ព្រះអម្ចាស់ រហូតទាល់តែសេចក្តីប្រោសលោះរាស្ត្ររបស់ទ្រង់បានសម្រេចគ្រប់លក្ខណ៍ ហើយមនុស្សនៅលើពិភពលោកទទួលស្គាល់ការគ្រប់គ្រងរបស់ព្រះអម្ចាស់ ដោយបន្លឺសម្លេងច្រៀងសរសើរតម្កើង ។ ពួកជំនុំសម័យដើមបានដកស្រង់ពាក្យនេះមកនិយាយនៅក្នុង អភ ៤:៨–១៣ ហើយគេបានដឹងថា ទំនុកំកើងជំពូកនេះ គឺជាតំរុយពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ការលើកឡើងទៅលើ (ហោះឡើងលើអាកាស) និងការគ្រប់គ្រងរួមទាំងជ័យជម្នះចុងក្រោយរបស់ពួកជំនុំទ្រង់លើពួកខ្មាំងសត្រូវផ្សេងៗ ។ ទំនុកដំកើងជំពូក៦៨ គឺជាជំពូកចុងក្រោយក្នុងចំណោមបទទំនុកដំកកើងទាំង៤ជំពូក (មើលក្នុងសេចក្តីផ្តើម ទដ ៦៥–៦៨) ។

ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ បានតែងឡើងជា៩ល្បះ (ខ.១៩ –២០ ប្រហែលអាចដាក់បញ្ចូលគ្នាជាមួយ ខ.២១–២៣) ដោយបានបញ្ចប់ដោយបទនៃការសរសើរ ។ នៅក្នុងល្បះទី១ (ខ.១–៣) គេចាប់ផ្តើមសូត្របទចម្រៀងនេះ ក្នុងខណៈពេលចេញក្បួនដង្ហែរហើយក្នុងល្បះចុង ក្រោយ (ខ.៣២–៣៥) គឺជាសេចក្តីបញ្ចប់នៃជំពូកនេះ ដែលបាននិយាយពីការអភិសេកទ្រង់ ឱ្យគង់នៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ។ ល្បះទី៧ (ខ.២៤–២៧) បានពណ៌នាពីក្បួនដង្ហែររបស់បណ្តាជន ចូលមកក្នុងទីបរិសុទ្ធ ។ នៅក្នុងល្បះទី៣ (ខ.៧–១០) បានបង្ហាញពីដំណាក់កាលនៃក្បួនដង្ហែរ ហើយបានរំឭកឱ្យឃើញពីការដែលទ្រង់យាងនាំមុខក្នុងដំណើរដ៏វែងអន្លាយ របស់

ហើយឱ្យអស់អ្នកដែលស្អប់ទ្រង់ រត់[គ]ពីចំពោះទ្រង់ចេញ
២ សូមទ្រង់បណ្តេញគេចេញ ដូចជាផ្សែង[ឃ]ត្រូវផាត់បាត់ទៅ
ដែរ សូមឱ្យពួកមនុស្សអាក្រក់វិនាសបាត់[ង]ពីចំពោះព្រះ
ទៅដូចជាក្រមួនដែលរលាយទៅ[ច]នៅចំពោះភ្លើង
៣ តែសូមឱ្យមនុស្សសុចរិតបានរីករាយសប្បាយវិញ
ឱ្យគេបានត្រេកអរ[ឆ]នៅចំពោះព្រះចុះ អើ
សូមឱ្យគេបានរីករាយឡើងដោយសេចក្តីអំណរផង
៤ ចូរច្រៀងថ្វាយព្រះ ចូរច្រៀងសរសើរដល់ព្រះនាមទ្រង់[ជ]
ចូរលើកថ្កល់ឡើងថ្វាយព្រះ ដែលទ្រង់ជិះយាងកាត់
ទីរហោស្ថានមក[ឈ] ទ្រង់ព្រះនាមជាព្រះយេហូវ៉ា[ញ]
ចូរលោកកញ្ឆោងនៅចំពោះទ្រង់ចុះ
៥ ឯព្រះដែលគង់នៅក្នុងទីលំនៅបរិសុទ្ធ[ដ]ទ្រង់ជាឪពុកដល់
ពួកកំព្រា[ឋ] និងជាចៅក្រមដល់ពួកមេម៉ាយ[ឌ]
៦ ព្រះទ្រង់ប្រោសមនុស្សត្រមោច[ឍ]ឱ្យបែកជាគ្រួសារឡើង[ណ]
ទ្រង់នាំពួកឈ្លើយ[ត]ឱ្យចេញមកឯសេចក្តីចំរើន
តែពួករឹងចចេសត្រូវអាស្រ័យនៅស្រុកហួតហែងវិញ[ថ]។

៧ ឱព្រះអង្គអើយ កាលទ្រង់បានយាងចេញ[ទ]នាំមុខរាស្ត្រ
ទ្រង់ទៅ នៅវេលាដែលទ្រង់បានយាងកាត់ទីរហោស្ថាន[ធ]
–បង្អង់
៨ នោះផែនដីក៏ញ័រ[ន]
ហើយមេឃក៏ធ្លាក់មកជាភ្លៀងនៅចំពោះទ្រង់[ប]
ភ្នំស៊ីណាយ[ផ]ក៏កក្រើកញ័រ នៅចំពោះព្រះ
គឺជាព្រះនៃសាសន៍អ៊ីស្រាអែល[ព]
៩ ឱព្រះអង្គអើយ ទ្រង់បានបង្អុរភ្លៀងជាបរិបូរ[ភ]
ក៏បានតាំងមរដកទ្រង់ដែលហេវនោះ ឱ្យជាប់មាំមួនឡើង
១០ ពួកកងរបស់ទ្រង់បានអាស្រ័យនៅស្រុកនោះ[ម]
ឱព្រះអង្គអើយ ទ្រង់បានផ្គត់ផ្គង់[យ]ដល់ពួកមនុស្សក្រីក្រ

**៦៨:១** គ ជន ១០:៣៥ អស ១៧:១៣ ២១:១៥ ៣៣:៣ **៦៨:២** ឃ ទដ ៣៧:២០ ង ជន ១០:៣៥ ទដ ៩:៣ ៨០:១៦ ច ទដ ២២:១៤ **៦៨:៣** ឆ ទដ ៦៤:១០ ៩៧:១២ **៦៨:៤** ជ ២សយ ២២:៥០ ទដ ៧:១៧ ៣០:៤ ៦៦:២ ៩៦:២ ១០០:៤ ១៣៥:៣ ឈ ខ.៣៣ នក ២០:២១ ចទ ៣៣:២៦ ញ នក ៦:៣ ទដ ៨៣:១៨ **៦៨:៥** ដ ចទ ២៦:១៥ យរ ២៥:៣០ ឋ ទដ ១០:១៤ ឌ នក ២២:២២ ចទ ១០:១៨ **៦៨:៦** ឍ ទដ ២៥:១៦ ណ ទដ ១១៣:៩ ត ទដ ៧៩:១១ ១០២:២០ ១៤៦:៧ អស ៦១:១ លក ៤:១៨ ថ អស ៣៥:៧ ៤៩:១០ ៥៨:១១ **៦៨:៧** ទ នក ១៣:២១ ធ ទដ ៧៨:៤០ ១០៦:១៤ **៦៨:៨** ន ២សយ ២២:៨ ប ពច ៥:៤ ២សយ ២១:១០ សស ១១:៣ ផ ចទ ៣៣:២ ព ពច ៥:៥ **៦៨:៩** ភ ចទ ៣២:២ យប ៣៦:២៨ អគ ៣៤:៦ **៦៨:១០** ម ចទ ២៨:១២ យ ទដ ៦៥:៩

គេក្នុងទីរហោស្ថាន ដែលចាប់ផ្តើមចេញពីភ្នំស៊ីណាយ ឆ្ពោះទៅកាន់ទឹកដីសន្យា ហើយក្នុងល្បះទី៥ (ខ.១៥–១៨) បានបង្ហាញពីដំណាក់កាលដែលយាងឡើងកំពូលភ្នំស៊ីយ៉ូន ។ មួយវិញទៀតល្បះទី២ (ខ.៤–៦) បានឆ្លុះបញ្ចាំងពីការដឹកនាំ ប្រកបដោយសេចក្តីសប្បុរសរបស់ព្រះអម្ចាស់ឯក្នុងល្បះទី៤វិញ (ខ.១១–១៤) បានរំឭកពីជ័យជម្នះរបស់ទ្រង់លើស្តេចកាណាន ។ នៅក្នុងល្បះទី៦ (ខ.១៩–២៣) និយាយពីការរ៉ាប់រងពីជ័យជម្នះនៅថ្ងៃក្រោយ ហើយនៅក្នុងល្បះទី៨ (ខ.២៨–៣១) និយាយពីអធិស្ឋានដែលនិយាយថា ព្រះអម្ចាស់ទ្រង់នឹងផ្តល់កម្លាំងរបស់ទ្រង់ ដើម្បីវាយពួកខ្មាំងសត្រូវដូចដែលទ្រង់បានធ្វើកាលពីគ្រាមុន ។

**៦៨ ត្រង់ចំណងជើង** មើលការពន្យល់ ទដ ជំពូក ៤,៣០ ត្រង់ចំណងជើង ។

**៦៨:១–៣** នៅក្នុងខ.នេះ គឺជាការចាប់ផ្តើមចេញក្បួនដង្ហែរដោយមានសូត្របទចម្រៀងនេះ ។ បទចម្រៀងនេះបានរំឭកពីការយាងនាំមុខរបស់ព្រះអង្គជាមួយរាស្ត្រទ្រង់ក្នុងពេលមានសង្គ្រាមចាប់តាំងពីភ្នំស៊ីណាយ (សូមមើល ជន ១០:៣៣–៣៥) ។

**៦៨:១** *ពួកខ្មាំងសត្រូវទ្រង់ត្រូវខ្ចាត់ខ្ចាយ* សូមមើលការពន្យល់ ខ.៣០ ។

**៦៨:៣** *មនុស្សសុចរិត* ពួកអ៊ីស្រាអែល គឺជារាស្ត្ររើសតាំងរបស់ព្រះ ហើយជាប់ទាក់ទងនឹងការយាងមកនៃនគរព្រះ ("ពួកមនុស្សអាក្រក់" ខ.២) ។

**៦៨:៤–៦** នៅក្នុងខនេះ អ្នកនិពន្ធបានហៅមនុស្សទាំងអស់ ឱ្យមកសរសើរតម្កើងដល់ព្រះ ចំពោះការគ្រប់គ្រងប្រកបដោយសេចក្តីមេត្តាករុណា ។

**៦៨:៤** *ព្រះនាម* មើលការពន្យល់ ៥:១១ ។ *ជិះកាត់ទីរហោស្ថាន* នៅមុខខ្ទមព្រះបាលនៅស្រុកកាណាន គេបានរកឃើញអក្សរសាស្ត្របែបនេះ បានប្រើដើម្បីពណ៌នាពីព្រះយេហូវ៉ា (ព្រះយេហូវ៉ា មិនមែនព្រះបាលទេ) ថា ព្រះអង្គ គឺជាព្រះដែលគួរនឹងលើកតម្កើង ដែលទ្រង់គឺជាអ្នកដែលបានបង្កើតឱ្យមានព្យុះពពក ដែលជារទេះចម្បាំងរបស់ព្រះ (មើល ខ.៣៣ ១៨:៩ ១០៤:៣ ចទ ៣៣:២៦ អស ១៩:១ មថ ២៦:៦៤) ។

**៦៨:៥–៦** នៅក្នុងខនេះចង់និយាយថា ព្រះអម្ចាស់ព្រះយេហូវ៉ាទ្រង់គឺជាទីពុំនឹងដល់អ្នកណាដែលគ្មានអំណាច (មើល ១០:១៤ ១៤៥:៧–៩ ១៤៧:៦ ចទ ១០:១៨) ។

**៦៨:៦** *ប្រោសមនុស្សត្រមោចឱ្យបែកជាគ្រួសារឡើង* មើល នក ១:២១ នរ ៤:១៤–១៧ ១សយ ២:៥ ។ *នាំពួកឈ្លើយឱ្យចេញមកឯសេចក្តីចំរើន* ព្រះទ្រង់នឹងនាំពួកគេដូចគ្នា និងកាលដែលព្រះអង្គទ្រង់នាំពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទដែរ (មើល ៦៩:៣៣ ១០៧:១០,១៤) ។ *ពួករឹងចចេស* មើលការពន្យល់ ខ.១៨ ៦៦:៧ ។ *ហួតហែង* គឺជាទីកន្លែងសោះកក្រោះគ្មានដីជាតិសម្រាប់ដំណាំផ្សេងៗ (មើល អគ ២៦:៤,១៤) ។

**៦៨:៧–១០** នៅក្នុងខនេះ គឺជាការរំឭកពីគ្រាដែលព្រះអង្គទ្រង់បានដឹកនាំពួកគេឆ្លងកាត់ទីរហោស្ថានស៊ីណាយ ឆ្ពោះទៅកាន់ទឹកដីសន្យា (មើល ពច ៥:៤–៥ ហប ៣:៣–៦) ។

**៦៨:៨** *នោះផែនដីក៏ញ័រ* ឃ្លានេះគឺនិយាយសំដៅលើការញ័ររញ្ជួយភ្នំស៊ីណាយ (មើល នក ១៩:១៨) ។ *មេឃក៏ធ្លាក់ភ្លៀង* នៅក្នុងកណ្ឌគម្ពីរបញ្ចកណ្ឌមិនបាននិយាយថា មានភ្លៀងធ្លាក់នៅក្នុងទីរហោស្ថានឡើយ ប៉ុន្តែនៅទីនេះ (ពច ៥:៤) បាននិយាយថា ភ្លៀងធ្លាក់គឺមានទំនាក់ទំនងជាមួយនឹងការញ័ររញ្ជួយផែនដី ហើយការនេះបានបើកសម្តែងយ៉ាងច្បាស់ពីអំណាចចេស្តារបស់ព្រះ ។ ប្រហែល "រន្ទះ ផ្លេកបន្ទោរ និងពពកដ៏សែនក្រាស" មាននៅលើភ្នំស៊ីណាយ (មើល នក ១៩:១៦) គឺមាននៅពេលដែលមានភ្លៀងធ្លាក់ ។ ប៉ុន្តែ មើល ខ.៩ ពីព្រោះបាននិយាយថា ព្រះបានបញ្ជូនភ្លៀងមកដើម្បីឱ្យពួកគេងាយស្រួលក្នុងការធ្វើដំណើររបស់ពួកគេ ។

**៦៨:៩** *ឱព្រះអង្គអើយ . . . មរដក* គឺជាពួកអ៊ីស្រាអែលដែលត្រូវទទួលកេរដកនេះ (មើល ចទ ៩:២៩) ។

**៦៨:១០** *ស្រុកនោះ* ពាក្យនេះប្រហែលសំដៅលើទឹកដីសន្យា ។ *សេចក្តីសប្បុរស* នេះគឺជាភាសាអក្សរសាស្ត្រ (មើល ៦៥:១១ និងការពន្យល់) ។

ដោយសេចក្ដីសប្បុរសនៃទ្រង់
១១ ព្រះអម្ចាស់ទ្រង់ប្រទានព្រះបន្ទូល
ហើយពួកអ្នកដែលប្រកាសប្រាប់ដំណឹង
នោះមានគ្នា[រ] ច្រើនណាស់
១២ ពួកស្ដេចនៃកងទ័ពក៏រត់[ល] គេរត់ទៅ
ហើយពួកស្រីៗដែលនៅផ្ទះក៏ចែករបឹបគ្នា[វ]
១៣ ទោះបើអ្នករាល់គ្នាបានដេកនៅកណ្ដាលក្រោលសត្វ[ស]
គង់តែនឹងមានស្លាបដូចជាព្រាបដែលស្រោបដោយប្រាក់
ហើយរោមក៏ស្រោបដោយមាសល្មឿង
១៤ នៅវេលាដែលព្រះដ៏មានព្រះចេស្ដាបំផុត
ទ្រង់កំចាត់[ហ] ពួកស្ដេចនៅក្នុងស្រុក
នោះបានដូចជាវេលាដែលហិមៈធ្លាក់នៅលើភ្នំសាលម៉ូន[ឡ]
១៥ ភ្នំបាសានជាភ្នំនៃព្រះ ភ្នំបាសាន[អ] ក៏មានកំពូលខ្ពស់[ក]
១៦ ឱភ្នំដ៏មានកំពូលខ្ពស់អើយ
ហេតុអ្វីបានជាមើលដោយច្រណែន
ដល់ភ្នំដែលព្រះសព្វព្រះហឫទ័យយក[ខ] ជាទីលំនៅដូច្នេះ
អើ ព្រះយេហូវ៉ាទ្រង់នឹងគង់នៅភ្នំនោះអស់កល្បជានិច្ច[គ]
១៧ អស់ទាំងរាជរថ[ឃ] របស់ព្រះ
នោះមានចំនួន២ម៉ឺនគឺទាំងពាន់ៗ[ង]
ព្រះអម្ចាស់ទ្រង់ក៏គង់នៅកណ្ដាល
ដូចក្នុងទីបរិសុទ្ធនៅភ្នំស៊ីណាយ
១៨ ទ្រង់បានយាងឡើង[ច] ទៅឯស្ថានខ្ពស់[ឆ]
ទ្រង់បានចាប់ពួកឈ្លើយ[ជ] នាំទៅជាឈ្លើយ
ព្រមទាំងទទួលអំណោយទានសំរាប់ចែកឱ្យ ដល់មនុស្ស[ឈ]
គឺដល់ទាំងមនុស្សបះបោរផង[ញ]
ដើម្បីឱ្យព្រះដ៏ជាព្រះយេហូវ៉ាបានគង់នៅជាមួយនឹងគេ
១៩ សូមឱ្យព្រះអម្ចាស់បានប្រកបដោយព្រះពរ
ដែលទ្រង់ទទួលយកបន្ទុកយើងខ្ញុំរាល់ៗថ្ងៃ[ដ]

**៦៨:១១** រ លក ២:១៣ **៦៨:១២** ល យស ១០:១៦ វ ពច ៥:៣០ **៦៨:១៣** ស លប ៤៩:១៤ **៦៨:១៤** ហ ២សយ ២២:១៥ ឡ ពច ៩:៤៨ **៦៨:១៥** អ ឧ.២២ ជន ២១:៣៣ យរ ២២:២០ ក ទដ ៣៦:៦ **៦៨:១៦** ខ ចទ ១២:៥ ទដ ២:៦ ១៣២:១៣ គ ទដ ១៣២:១៤ **៦៨:១៧** ឃ ២ពវ ២:១១ អស ៦៦:១៥ ហព ៣:៨ ង ដយ ៧:១០ **៦៨:១៨** ច ទដ ៤៧:៥ ឆ ទដ ៧:៧ ជ ពច ៥:១២ ឈ អភ ៤:៨ ញ ជន ១៧:១០ **៦៨:១៩** ដ ទដ ៨១:៦

*មនុស្សក្រីក្រ* គឺសំដៅលើពួកអ៊ីស្រាអែលពីព្រោះពួកគេរស់នៅអាស្រ័យលើព្រះ ។

**៦៨:១១–១៤** នៅក្នុងខនេះ រំឭកពីជ័យជម្នះរបស់ព្រះអម្ចាស់លើស្ដេចស្រុកកាណាន ។

**៦៨:១១** *ប្រទានព្រះបន្ទូល* ព្រះអម្ចាស់ទ្រង់បានប្រកាសជាមុនពីជ័យជម្នះជាមុនថា ទ្រង់យកឈ្នះលើស្ដេចពួកសាសន៍កាណាន (មើល នក ២៣:២២–២៣,២៧–២៨,៣១ ចទ ៧:១០–២៤ ១១:២៣–២៥ យស ១:២–៦) ។ *ប្រកាសប្រាប់* នៅក្នុងឃ្លានេះ គឺចង់និយាយសំដៅលើការប្រកាសប្រាប់ពីជ័យជម្នះរបស់ព្រះអម្ចាស់ (មើល នក ១៥:១–២១ ១សយ ១៨:៦–៧ ២របា ២០:២៦–២៨) ។ *ប្រកាស* មើល ៤០:៩ និងការពន្យល់ ។

**៦៨:១៣** *ដេកនៅកណ្ដាលក្រោលសត្វ* ចង់និយាយថា ពួកគេស្នាក់ក្នុងត្រសាល (មើល ពច ៥:១៦ និងការពន្យល់ លប ៤៩:១៤) ។ *ស្លាបដូចជាព្រាប ដែលស្រោបដោយប្រាក់* នៅក្នុងឃ្លានេះ គឺចង់និយាយថា ពួកអ៊ីស្រាអែលដែលជា "ព្រាប" របស់ព្រះអម្ចាស់ (មើល ៧៤:១៩ និងការពន្យល់ ហើយធៀបនឹង ហស ៧:១១) គឺមានទ្រព្យសម្បត្តិជាបរិបូរ គឺមានប្រាក់និងមាសដែលចាប់បានពីស្ដេចស្រុកកាណាន ទោះបីជាពួកគេស្នាក់នៅក្នុងត្រសាលក៏ដោយ ។ ការនិយាយបែបបំភ្លើសនេះ បានទទួលស្គាល់និងប្រកាសពីព្រះអម្ចាស់ថា ព្រះយេហូវ៉ាទ្រង់បានធ្វើឱ្យស្ដេចជាច្រើនទទួលបរាជ័យយ៉ាងជូរចត់ ទោះបីជាពួកអ៊ីស្រាអែលមិនទាន់ទៅច្បាំងជាមួយគេក៏ដោយ (មើល យស ២:៨–១១ ៥:១ ៦:១៦ និង ២សយ ៥:២៤ ២ពវ ៧:៥–៧ ១៩:៣៥ ២របា ២០:២២–៣០) ។

**៦៨:១៤** *ព្រះចេស្ដា* មើលការពន្យល់ លប ១៧:១ ។ *ហិមៈធ្លាក់នៅលើភ្នំសាលម៉ូន* ភ្នំសាលម៉ូន គឺស្ថិតនៅក្បែរតំបន់ស៊ីគែម (មើល ពច ៩:៤៦–៤៨) ប៉ុន្តែក៏មានអ្នកខ្លះទៀតនិយាយថា យេបែលឌ្រូ ដែលជាភ្នំភ្លើងដែលមានសភាពងងឹតស្ថិតនៅខាងកើតពីស្រុកបាសាន ។ ពាក្យថា សាលម៉ូនមានន័យថា "ងងឹត" ហើយតាមការជជែកវែកញែកពីពួកដែលនៅល្បាណូន គឺមានន័យថាជួរភ្នំ "ស" ហើយពាក្យនេះសំដៅលើថ្មកំបោរ ។ ពាក្យនេះផងដែរប្រហែលជាមានភាពផ្ទុយគ្នារវាងហិមៈសដែលធ្លាក់នៅលើ "ភ្នំងងឹត" ។ ពាក្យនេះក៏ប្រហែលជាភាសា ដែលនិយាយសំដៅលើអាវុធ ដែលស្ដេចបានបោះបង់ចោលនៅវាលចម្បាំង ហើយរត់គេចខ្លួន (មើល ២ពវ ៧:១៥) ។

**៦៨:១៥–១៨** នៅក្នុងខនេះ ចង់និយាយពីការអបអរសាទរចំពោះការដែលព្រះអម្ចាស់យាងឡើងភ្នំស៊ីយ៉ូន ។

**៦៨:១៥–១៦** នៅក្នុងខទាំងនេះ ចង់និយាយថា ភ្នំផ្សេងៗទៀតដែលនៅជុំវិញភ្នំបាសានរាប់ទាំងភ្នំហ៊ីម៉ូន គឺច្រណែននឹងភ្នំនេះ ពីព្រោះព្រះបានរើសយកភ្នំស៊ីយ៉ូនជាកន្លែងដែលទ្រង់គង់នៅ ជាហេតុធ្វើឱ្យភ្នំស៊ីយ៉ូនមាន "កំពូលខ្ពស់" ជាងគេ (មើល ៤៨:២ និងការពន្យល់) ។

**៦៨:១៧** *រាជរថរបស់ព្រះ* គឺសំដៅលើទ័ពស្ថានសួគ៌របស់ព្រះ ។ ឃ្លាដែលនិយាយនៅទីនេះ គឺចង់មានន័យពីមេទ័ពចម្បាំងដ៏ច្រើន (មើល ២ពវ ៦:១៧ ហប ៣:៨,១៥) ។ នៅក្នុងសម័យកាលចក្រភពរ៉ូមគ្រប់គ្រង គេគិតថា ព្រះយេស៊ូវទ្រង់សម្ដែងព្រះអង្គទ្រង់ថា ជាទ័ពរបស់ព្រះក្នុងនាមជា "កង" (មើល មថ ២៦:២៥) ។

**៦៨:១៨** *យាងឡើងទៅឯស្ថានខ្ពស់* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើការយាងឡើងរបស់ព្រះអម្ចាស់ ទៅលើកលំពូលភ្នំស៊ីយ៉ូន ដើម្បីទទួលការអភិសេក (មើល ៤៧:៥–៦ និងការពន្យល់ និងមើល ៧:៧) ។ *ទ្រង់បានចាប់នាំពួកឈ្លើយ . . . អំណោយទាន* នៅក្នុងឃ្លានេះចង់និយាយថា ពួកគេបានទទួលអំណោយដូចគ្នា និងអ្នកដែលទទួលបានអំណោយពីស្ដេចក្រោយពេលមានជ័យជម្នះដែរ ។ *មនុស្សបះបោរ* គឺជាពួកអ្នកដែលបដិសេធចំពោះនគរព្រះ (មើល ឧ.៦ និងការពន្យល់ ៦៦:៧) ដែលបានបង្ខំឱ្យពួកគេចុះចូលចំពោះព្រះអង្គ ។ *ព្រះយេហូវ៉ាបានគង់នៅជាមួយនឹងគេ* លោកសាវកប៉ុលបានយកឃ្លានេះ និយាយសំដៅលើការយាងឡើងរបស់ព្រះគ្រីស្ទ (មើល អភ ៤:៨–១៣ និងការពន្យល់ អភ ៤:៨–៩,១១) ។

**៦៨:១៩–២៣** នៅក្នុងខទាំងនេះ គឺនិយាយពីការមានអំណរដោយសង្ឃឹម

គឺជាព្រះដ៏ជាទីសង្គ្រោះដល់យើងខ្ញុំ[ឋ] ។ –បង្អង់
២០ ព្រះទ្រង់ជាព្រះដែលប្រោសឱ្យយើងខ្ញុំរួច[ឌ]
ហើយសេចក្ដីរួចពីស្លាប់ក៏ស្រេចនៅព្រះយេហូវ៉ាជាព្រះ
អម្ចាស់ដែរ[ឍ]
២១ តែព្រះទ្រង់នឹងវាយបំបែកក្បាល[ណ]ពួកខ្មាំងសត្រូវទ្រង់
និងស្បែកក្បាលរបស់អស់អ្នកដែលចេះតែដើរក្នុងសេចក្ដី
កំហុសរបស់ខ្លួនដែរ
២២ ព្រះអម្ចាស់ទ្រង់មានបន្ទូលថា
អញនឹងនាំគេត្រឡប់មកពីស្រុក បាសាន
អញនឹងនាំគេឱ្យវិលពីបាតសមុទ្រវិញ[ត]
២៣ ដើម្បីឱ្យឯងបានជាន់ឈ្លីគេព្រមទាំងជ្រលក់ជើងឯងក្នុង
ឈាមផង[ថ] ប្រយោជន៍ឱ្យអណ្ដាតឆ្កែ[ទ]បានចំណែកនៃខ្មាំង
សត្រូវរបស់ទ្រង់ដែរ
២៤ ឱព្រះអង្គអើយ គេបានឃើញការយាងយាសនៃទ្រង់ជា
ដំណើររបស់ព្រះនៃទូលបង្គំ គឺជាស្ដេចនៃទូលបង្គំ
ដែលទ្រង់យាងចូលទៅក្នុងទីបរិសុទ្ធ[ធ]
២៥ ពួកចំរៀង[ន]បានដើរនាំមុខ
ពួកភ្លេង[ប]បានដើរតាមក្រោយ
នៅកណ្ដាលពួកស្រីក្រមុំដែលវាយក្រាប់[ផ]
២៦ ឱអស់អ្នកដែលកើតពីទីកំណើតនៃអ៊ីស្រាអែលអើយ[ព]
ចូរលើកដំកើងព្រះ គឺជាព្រះអម្ចាស់ នៅក្នុងពួកជំនុំ[ភ]
២៧ នៅទីនោះមានបេនយ៉ាមីន[ម]
ជាពៅបង្អស់[យ]ដែលគ្រប់គ្រងលើគេ ពួកចៅហ្វាយនៃយូដា
និងក្រុងជំនុំរបស់គេ ព្រមទាំងពួកចៅហ្វាយ
នៃសាប់យូល៉ូនហើយពួកចៅហ្វាយនៃណែបថាលីផង[រ]
២៨ ព្រះនៃឯង ទ្រង់បានបង្គាប់ឱ្យផ្ដល់កំឡាំង[ល]ដល់ឯង
ឱព្រះអង្គអើយ សូមចំរើនកំឡាំង[វ]
ចំពោះអស់ទាំងការដែលទ្រង់បានប្រោសដល់យើងខ្ញុំផង[ស]
២៩ ឯពួកស្ដេច គេនឹងនាំយកដង្វាយមកថ្វាយទ្រង់ ដោយ
យល់ដល់ព្រះវិហារនៃទ្រង់ ដែលនៅក្រុងយេរូសាឡិម[ហ]
៣០ សូមស្ដីបន្ទោសដល់សត្វ[ឡ] ដែលនៅកណ្ដាលដើមត្រែង[អ]
និងហ្វូងគោឈ្មោល[ក]ព្រមទាំងកូនគោនៃសាសន៍ទាំង
ឡាយផង ឱ្យគ្រប់គ្នាមកក្រាបចុះ ថ្វាយប្រាក់ទាំងដុំៗ

**៦៨:១៩** ឋ ទដ ៦៥:៥ **៦៨:២០** ឌ ១សយ ១០:១៩ ឍ ទដ ៥៦:១៣ យរ ៤៥:៥ អគ ៦:៨ **៦៨:២១** ណ ទដ ៧៤:១៤ ១១០:៥ ហាព ៣:១៣ **៦៨:២២** ត យប ៣៦:៣០ មថ ១៨:៦ **៦៨:២៣** ថ ទដ ៥៨:១០ ទ ១ពវ ២១:១៩ ២ពវ ៩:៣៦ **៦៨:២៤** ធ ទដ ៦៣:២ **៦៨:២៥** ន ១របា ១៥:១៦ ប ១របា ៦:៣១ ២របា ៥:១២ វវ ១៨:២២ ផ លប ៣១:២៧ អស ៥:១២ **៦៨:២៦** ប លវ ១៩:២ ភ ទដ ២២:២២ ហាព ២:១២ **៦៨:២៧** ម ជន ៣៤:២១ យ ១សយ ៩:២១ រ ពច ៥:១៨ **៦៨:២៨** ល នក ៩:១៦ វ ទដ ២៩:១១ ស អស ២៦:១២ ២៩:២៣ ៤៥:១១ ៦០:២១ ៦៤:៨ **៦៨:២៩** ហ ២របា ៩:២៤ ៣២:២៣ **៦៨:៣០** ឡ អស ២៧:១ ៥១:៩ អគ ២៩:៣ អ យប ៤០:២១ ក ទដ ២២:១២ អស ៣៤:៧ យរ ៥០:២៧

ចំពោះជ័យជម្នះរបស់ព្រះអម្ចាស់ និងនៅតែមានរហូតទាល់តែរាស្ត្ររបស់ទ្រង់ទទួលសេចក្ដីសង្គ្រោះពេញលេញ ។

**៦៨:១៩** *ទ្រង់ទទួលយកបន្ទុកយើងខ្ញុំរាល់ថ្ងៃ* នៅក្នុងឃ្លានេះចង់និយាយថា ព្រះអម្ចាស់ទ្រង់ទទួលបន្ទុករបស់យើងទាំងអស់គ្នា ឱ្យរួចពីភាពជាទាសករ ហើយការនេះបានធ្វើឱ្យខ្មាំងសត្រូវទាំងនោះ ស្ញែងខ្លាចចំពោះពួកយើង (មើលការពន្យល់ ៦:៥ ១១:៧ ១៦:៩–១១ ១៧:១៥ ៤៩:១៤–១៥) ។

**៦៨:២១** នៅក្នុងខនេះ ចង់និយាយថាដោយសារតែព្រះយេហូវ៉ាទ្រង់ជាអ្នកផ្ដល់សេចក្ដីសុខសាន្ត និងជីវិតដល់រាស្ត្រទ្រង់ (មើល ខ.២០) ដូច្នេះហើយទើបព្រះអម្ចាស់ទ្រង់អាចវាយបំបែក ចំពោះពួកអ្នកដែលប្រឆាំងតបតនឹងព្រះអង្គ ។ *វាយបំបែកក្បាល* មើល ២៤:១៧ យរ ៤៨:៤៥–៤៦ និងការពន្យល់ ។

**៦៨:២២** *គេ* ពាក្យថា "គេ" ដែលនិយាយនៅកន្លែងនេះ គឺសំដៅលើពួកខ្មាំងសត្រូវដែលបានរត់គេចខ្លួនពីព្រះអម្ចាស់ និងពួកទ័ពសេះរបស់ទ្រង់ (សូមមើល ខ.១២,១៧) ។ *ស្រុកបាសាន . . . បាតសមុទ្រ* ពីមុនដំបូង (មើល ខ.១៥) ព្រះអម្ចាស់ទ្រង់ធ្វើការ ដោយប្រមូលគេពីទីខ្ពស់នៅភាគ ខាងកើតនៃទន្លេយ័រដាន់ (មើល ខ.១៥) ហើយបន្ទាប់មកទៀត គឺពីសមុទ្រមេឌីទែរ៉ានេ ដ្បិតគ្មានកន្លែងណាមួយដែលពួកខ្មាំងសត្រូវអាចនឹងរត់គេចខ្លួនពីព្រះអម្ចាស់បាននោះឡើយ (មើល អម ៩:១–៤) ។

**៦៨:២៣** សូមមើលការពន្យល់ ៥៨:១០ ។

**៦៨:២៤–២៧** នៅក្នុងខទាំងនេះបានបង្ហាញថា ចម្រៀងនៃក្បួនដង្ហែរគឺកាន់តែខិតជិតដល់ព្រះវិហារហើយ (មើល ទដជំពូក ២៤,៤៧) ។

**៦៨:២៥** *ពួកស្រីក្រមុំដែលវាយក្រាប* មើលការពន្យល់ យរ ៣១:៤ ។

**៦៨:២៧** នៅក្នុងខនេះចង់និយាយថា គ្រប់ទាំងអំបូរនៃពួកអ៊ីស្រាអែលគឺសុទ្ធតែមានអ្នកតំណាងចូលរួម ដោយរាប់តាំងពីអំបូរបេនយ៉ាមីនជាពៅគេបង្អស់ រហូតដល់ពួកចៅហ្វាយនៃពួកយូដា រួមទាំងអំបូរទាំងប៉ុន្មានដែលនៅភាគខាងជើង និងខាងត្បូងផងដែរ ។ *បេនយ៉ាមីន ជាពៅបង្អស់ដែលគ្រប់គ្រងលើគេ* នៅក្នុងឃ្លានេះប្រហែលជាចង់បង្ហាញការពិតមួយថា ស្ដេចទី១នៃស្រុកអ៊ីស្រាអែល គឺកើតចេញពីអំបូរយូដា (ស្ដេចសូល) ជាអ្នកដែលបានបង្ក្រាបខ្មាំងសត្រូវរបស់ពួកអ៊ីស្រាអែល (មើល ១សយ ១១:១១ ១៤:២០–២៣) ។

**៦៨:២៨–៣១** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះអម្ចាស់ទ្រង់នៅតែបន្តចម្បាំងទាស់ចំពោះអ្នកដែលបៀតបៀនរាស្ត្រទ្រង់ ។

**៦៨:២៨** *បង្គាប់ឱ្យផ្ដល់កំឡាំង* នៅក្នុងឃ្លានេះគេអាចនិយាយបានម្យ៉ាងទៀតថា "បញ្ជាឱ្យផ្ដល់កំឡាំងជំនួយ" ។

**៦៨:២៩** *ដោយយល់ដល់ព្រះវិហារនៃទ្រង់* គឺដោយសារតំណាក់នៅលើផែនដីរបស់ព្រះអម្ចាស់ គឺបានស្ថាបនាឡើងនៅក្នុងក្រុងយេរូសាឡិម ។ *នាំយកដង្វាយ* នៅក្នុងឃ្លានេះចង់និយាយថា គេបានបង្ហាញពីការទទួលស្គាល់ទ្រង់ដោយការនាំយកដង្វាយមកថ្វាយចំពោះទ្រង់ គឺដូចគ្នានឹងស្ដេចជាច្រើនបាននាំយកសួយសារអាករទៅថ្វាយដល់ស្ដេច ដែលមានជ័យជម្នះក្នុងសង្គ្រាមដែរ (មើល ២សយ ៨:២,៦,១០ ២ពវ ៣:៤) ។

**៦៨:៣០** *ស្ដីបន្ទោស* មើលការពន្យល់ ៧៦:៦ ។ *សត្វដែលនៅកណ្ដាលដើមត្រែង* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើស្ដេចផារ៉ោន (មើល អគ ២៩:៣) ។ *ហ្វូងគោឈ្មោល ព្រមទាំងកូនគោ* នៅក្នុងឃ្លានេះ គឺចង់និយាយសំដៅលើស្ដេច ដែលមានអំណាចខ្លាំងក្លានិងស្ដេចដែលគ្មានអំណាច ឬអំណាចតូចតាចដែលជាពលបរិវាររបស់ស្ដេចផារ៉ោន ។ ពួកអេស៊ីព្ទគឺជាសាសន៍តែ១ ដែលបាននិយាយនៅទីនេះ ជាអ្នកតំណាងឱ្យនគរទាំងអស់

ទ្រង់បានកំចាត់កំចាយអស់ទាំងសាសន៍[ខ] ដែលពេញចិត្ត
នឹងការសឹកសង្គ្រាម[គ]
៣១ ពួកអ្នកធំនឹងចេញពីស្រុកអេស៊ីព្ទ[ឃ]មកឯស្រុកអេធីយ៉ូពី[ង]
និងប្រញាប់ប្រវាដៃទៅឯព្រះដែរ ។
៣២ អស់ទាំងនគរនៅផែនដីអើយ[ច] ចូរច្រៀងថ្វាយព្រះ
ឱចូរច្រៀងសរសើរ[ឆ]ដល់ព្រះអម្ចាស់ចុះ –បង្អង់
៣៣ គឺដល់ព្រះដែលទ្រង់យាង[ជ]លើផ្ទៃមេឃនៃអស់ទាំងជាន់
ផ្ទៃមេឃ ដ៏នៅតាំងពីបូរាណមក ន៍
ទ្រង់បញ្ចេញព្រះសូរសៀង[ឈ]គឺជាសំនៀងដ៏ខ្លាំងក្រៃលែង[ញ]
៣៤ ចូរសរសើរថា ព្រះទ្រង់មានព្រះចេស្តា[ដ]
ឫទ្ធានុភាព[ឋ]នៃទ្រង់គ្របលើសាសន៍អ៊ីស្រាអែល
ហើយព្រះចេស្តាទ្រង់ក៏នៅលើផ្ទៃមេឃ
៣៥ ឱព្រះអង្គ ទ្រង់គួរស្ញែងខ្លាច[ឌ]នៅក្នុងទីបរិសុទ្ធរបស់
ទ្រង់[ឍ] ព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់ប្រទានកំឡាំងនឹងអំណាច[ណ]ដល់រាស្ត្រទ្រង់[ត]
សូមឱ្យព្រះបានប្រកបដោយព្រះពរចុះ[ថ] ។

**៦៨:៣០** ខ ទដ ១៨:១៤ ៨៩:១០ គ ទដ ១២០:៧ ១៤០:២ **៦៨:៣១** ឃ អស ១៩:១៩ ៤៣:៣ ៤៥:១៤ ង អស ១១:១១ ១៨:១ សផ ៣:១០ **៦៨:៣២** ច ទដ ៤៦:៦ ៦៧:៤ ឆ ទដ ៧:១៧ **៦៨:៣៣** ជ ចទ ៣៣:២៦ ឈ នក ៩:២៣ ទដ ២៩:៣ ញ ទដ ២៩:៤

ទំនុកស្តេចដាវីឌ ដែលទ្រង់លើក
សំរាប់ឱ្យមេភ្លេងលេងតាមបទ "ផ្កាឈូក"។

**៦៩** ឱព្រះអង្គអើយ សូមជួយសង្គ្រោះទូលបង្គំ

អស ៣០:៣០ ៣៣:៣ ៦៦:៦ **៦៨:៣៤** ដ ខ.២៨ ឋ ទដ ៤៥:៣ **៦៨:៣៥** ឌ ចទ ៧:២១ ឍ លប ២៨:១៧ ណ ទដ ១៨:១ អស ៤០:២៩ ៤១:១០ ៥០:២ ត ទដ ២៩:១១ ថ ទដ ២៨:៦ ៦៦:២០ ២របា ១:៣

ដែលបានទាស់ប្រឆាំងចំពោះពួកអ៊ីស្រាអែល ដែលធ្លាប់ធ្វើឱ្យពួកអ៊ីស្រាអែលទទួលបទពិសោធន៍ នៃអំណាចក្នុងលោកិយនេះ ។ ការនេះក៏អាចនិយាយថា នៅក្នុងសម័យកាលនោះអ្នកនិពន្ធបានតែងអំពីសាសន៍អេស៊ីព្ទ គឺចង់បង្ហាញថា អេស៊ីព្ទគឺជាចក្រភពដ៏ល្បីល្បាញមួយ ដែលមានអំណាចលើពួកអ៊ីស្រាអែល ។ *កំចាត់កំចាយអស់ទាំងសាសន៍* មើល ខ.១ ។ ដោយសារការទាំងនេះហើយ ទើបពួកអ៊ីស្រាអែលគេអាចនឹងទទួលបានសន្តិភាពដ៏ពិតប្រាកដ (មើល ៤៦:៩ ៤៨:៤–៧ ៦៥:៧ ៧៦:៣) ។

**៦៨:៣២–៣៥** នៅក្នុងខទាំងនេះ គឺនិយាយពីបទចម្រៀងនៃក្បួនដង្ហែរ ដោយបានហៅឱ្យអស់ទាំងនគរទាំងប៉ុន្មាន ដែលនៅផែនដីចូលមកសរសើរតម្កើងដល់ព្រះនៃសាសន៍អ៊ីស្រាអែល គឺជាព្រះដែលបានគង់នៅស្ថានសួគ៌ និងបានតាំងនគរផែនដីរបស់ទ្រង់ នៅក្នុងព្រះវិហារក្រុងយេរូសាឡិម (សូមមើល ទដ ៤៧) ។

**៦៨:៣៣** សូមមើល ខ.៤ និងការពន្យល់ ។ *ព្រះសូរសៀង គឺជាសំនៀងដ៏ខ្លាំងក្រៃលែង* មើលការពន្យល់ ទដ ២៩:៣–៩ ។

**៦៨:៣៥** *គួរស្ញែងខ្លាច* មើល ទដ ៤៥:៤ និងការពន្យល់ ។ *ទ្រង់ប្រទានកំឡាំង និងអំណាចដល់រាស្ត្រទ្រង់* នៅក្នុងឃ្លានេះចង់បង្ហាញថាព្រះយេហូវ៉ាជាព្រះលើទាំងអស់ ជាបង្កើតពួកអ៊ីស្រាអែលឡើងទុកជា ("នគរ"របស់ទ្រង់ មើល នក ១៩:៥–៦) ហើយព្រះអម្ចាស់ទ្រង់ជាអ្នកគ្រប់គ្រងលើគេ ហើយបានប្រទានជ័យជម្នះដល់ពួកគេ (មើល ២៩:១០–១១) ។

**ទដ ៦៩–៧២** នៅក្នុងផ្នែកប៉ែកទី២ នៃបទគម្ពីរទំនុកដំកើងបានភ្ជាប់មកជាមួយនឹងសេចក្តីអធិស្ឋាន៣ រួមទាំងភ្ជាប់មកជាមួយនឹងទំនុករបស់ស្តេចដោយមានតុល្យភាពជាមួយនឹងបទគម្ពីរទំនុកដំកើងវគ្គទី១ នៃប៉ែកទី២ (មើលការពន្យល់ ទដ ៤២–៤៥) ។ សេចក្តីអធិស្ឋានទាំង៣នោះ គឺជាការអធិស្ឋានទាំងទូលអង្វររបស់ព្រះមហាក្សត្រ នៅក្នុងប្រទេសអ៊ីស្រាអែល ដើម្បីឱ្យព្រះអម្ចាស់ទ្រង់បានរំដោះទ្រង់ និងរាស្ត្ររបស់ទ្រង់ឱ្យរួចពីពួកខ្មាំងសត្រូវទាំងឡាយ ។ ពួកគេទាំងអស់ បានអធិស្ឋានដោយប្រើពាក្យគន្លឹះ ហើយពាក្យទាំងនេះ អាចរកឃើញនៅក្នុងប៉ែកទី២ នៃទំនុកដំកើងគឺនៅក្នុងជំពូក ៤២–៤៤ និងបទនៃទំនុកទាំង៧ជំពូកទៀត (ជំពូក ៥៤–៦០) ដែលស្ថិតនៅចំណុចកណ្តាលនៃព្រះគម្ពីរទំនុកដំកើង ។ ទំនាក់ទំនងផ្សេងៗទៀតចំពោះទំនុកដំកើងជំពូក ៦៩–៧១ និង ទដ ៤២–៤៤ គឺគ្រាន់តែជាការជំនួសឱ្យនៃទំនុកដ៏ខ្លីនៅក្នុងចំណុចកណ្តាលនៃបណ្តុំទំនុកដំកើងទាំង៣ប៉ុណ្ណោះ ។ ការជំនួសឱ្យទាំងនោះទំនងជាមាន មិនបានពិគ្រោះក្នុងការបោះពុម្ពផ្សាយណ្ណោះ ។ នៅក្នុង ទដ ជំពូក ៤៣ បានបំបែកខ្លួនចេញពី ទដ ៤២ ដោយសារសិល្បវិទ្យារបស់អ្នកនិពន្ធ (មើលក្នុងសេចក្តីផ្តើម ទដ ៤២–៤៣) ក្នុងពេលដែលទំនុកដំកើងជំពូក៧០ បានលើកអ្វីដែលមាននិយាយនៅក្នុង ទដ ៤០:១៣–១៧ មកនិយាយម្តងទៀត (ដោយមានការកែប្រែខ្លះៗ) ហើយការលើកយកមកនិយាយម្តងទៀតនេះ ប្រហែលដើម្បីយកមកធ្វើជាសេចក្តីផ្តើមនៃព្រះគម្ពីរទំនុកដំកើង ៧១ ។ ការភ្ជាប់មកជាមួយនឹងសេចក្តីអធិស្ឋានសម្រាប់ស្តេច (ទដ ៧២) គឺវាមានលក្ខណៈដូចគ្នានឹង ទដ ៦៩–៧១ ហើយក៏ដូចគ្នានឹង ទដ ៤៥ ជាមួយ ទដ ៤២–៤៤ ហើយអ្វីដែលបានពណ៌នានៅក្នុង ជំពូកទាំងនេះក៏មាននៅក្នុងសេចក្តីបញ្ចប់ក្នុងប៉ែកទី២ នៃបទគម្ពីរទំនុកដំកើងដែរ ។ មានការគួរឱ្យកត់សម្គាល់មួយកើតចេញពី ទដ ៦៥–៦៨ គឺមនុស្សទាំងអស់នៅលើលោកិយនេះ បានប្រមូលគ្នាមកដើម្បីនឹងលើកតម្កើងចំពោះព្រះយេហូវ៉ា (មើលការពន្យល់ ទដ ៦៥–៦៨) ហើយនៅទីនេះវិញ យើងឃើញថា អ្នកនិពន្ធបានហៅឱ្យគ្រប់ទាំងអស់ដែល ព្រះអម្ចាស់បានបង្កើតឡើងចូលមកសរសើរដល់ព្រះអម្ចាស់វិញ (មើល ខ.៣៤) ចំណែកឯក្នុង ទដ ៧២ វិញបាននិយាយថា គ្រប់ទាំងអស់នៃប្រជារាស្ត្រ និងស្តេចទាំងប៉ុន្មាននឹងចុះចូលចំពោះបុត្ររបស់ស្តេចដាវីឌ (ខ.៨–១១) ហើយអ្នកទាំងនោះនឹងបានពរដោយសាររាជរបស់ទ្រង់ ។

**ទដ ៦៩** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានដោយអង្វរទៅចំពោះព្រះ ដើម្បីឱ្យព្រះអម្ចាស់ទ្រង់បានជួយសង្គ្រោះ ដល់គាត់ឱ្យរួចពីពួកខ្មាំងសត្រូវ ។ សេចក្តីអធិស្ឋានរបស់អ្នក ដែលព្រះមហាក្សត្រនៅពេលនេះ គឺក្នុងពេលដែលទ្រង់ជួបប្រទះការវាយប្រហារ ដ៏កាចសាហាវពីសំណាក់ពួកក្បត់ក្នុងគ្រាដែលព្រះយេហូវ៉ាទ្រង់ធ្វើឱ្យគាត់ "មានរបួស" (មើល ខ.២៦) ដោយព្រោះអំពើបាបខ្លះដែលព្រះអង្គបានប្រព្រឹត្ត (មើល ខ.៥) ។ បើសិនជាការអះអាងនេះជាការពិត នោះដាវីឌគឺជាអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងនេះ (សូមមើលចំណងជើង) ហើយឱកាសនៃការសរសេរ គឺមិនដឹងច្បាស់នោះឡើយ ។ តាមរយៈទំរង់សេចក្តីអធិស្ឋាន ដែលប្រើក្នុងទំនុកដំកើងជំពូកនេះ បានបង្ហាញថាបុត្ររបស់ទ្រង់ និងក្លាយជាអ្នកគ្រប់ គ្រងលើនគរខាងត្បូង (មើល ខ.៣៥) ។ ស្តេចនោះប្រហែលជា ស្តេចហេសេគា (មើល ២ពវ

ដ្បិតទឹក[ក]បានហូរចូលដល់ព្រលឹងនៃទូលបង្គំហើយ[ខ]
២ទូលបង្គំផុងចុះក្នុងល្បាប់ដ៏ជ្រៅជាកន្លែងដែលគ្មាន
ទីឈរសោះ
ទូលបង្គំបានមកដល់ក្នុងទីទឹកជ្រៅហើយរលកក៏បោក
គ្របលើទូលបង្គំ[គ]
៣ទូលបង្គំល្វើយ ដោយការអំពាវនាវរបស់ទូលបង្គំ[ឃ]
បំពង់កនៃទូលបង្គំខ្លះហើយ
ភ្នែកទូលបង្គំស្រវាំងទៅ[ង]ដោយរង់ចាំមើលផ្លូវព្រះនៃ
ទូលបង្គំ ។
៤ពួកអ្នកដែលស្អប់ទូលបង្គំ[ច]ដោយឥតហេតុនោះ[ឆ]មានច្រើន
ជាងសក់ក្បាលនៃទូលបង្គំទៅទៀត
អស់អ្នកដែលចង់បំផ្លាញទូលបង្គំ[ជ]
គឺជាពួកខ្មាំងសត្រូវនឹងទូលបង្គំដោយឥតរឿង[ឈ]
គេមានកំឡាំងណាស់ គេចាប់ឱ្យទូលបង្គំសងរបស់ដែល
ទូលបង្គំមិនបានយកសោះ
៥ឱព្រះអង្គអើយ ទ្រង់ជ្រាបសេចក្ដីចំកួតរបស់ទូលបង្គំ[ញ]
ឯអំពើបាបនៃទូលបង្គំក៏មិនបិទបាំងនឹងទ្រង់ដែរ[ដ] ។
៦ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់នៃពួកពលបរិវារអើយ
សូមកុំឱ្យពួកអ្នកដែលពឹងពាក់ដល់ទ្រង់ត្រូវខ្មាសដោយ
ព្រោះទូលបង្គំឡើយ ឱព្រះនៃសាសន៍អ៊ីស្រាអែលអើយ
សូមកុំឱ្យពួកអ្នកដែលស្វែងរកទ្រង់បានត្រូវអាប់យស
ដោយព្រោះទូលបង្គំឱ្យសោះ
៧ដ្បិតគឺដោយយល់ដល់ទ្រង់[ឋ]ហើយ បានជាទូលបង្គំធន់ទ្រាំ
នឹងសេចក្ដីត្មះតិះដៀល[ឌ]
ហើយសេចក្ដីអៀនខ្មាសបានគ្របមុខទូលបង្គំផង[ឍ]
៨ទូលបង្គំបានត្រឡប់ដូចជាអ្នកដទៃចំពោះបងប្អូនទូលបង្គំ
គឺដូចជាសាសន៍ក្រៅដល់ពួកអ្នកពោះ១នឹងទូលបង្គំ[ណ] ។
៩ដ្បិតសេចក្ដីឧស្សាហ៍ដល់ដំណាក់ទ្រង់
បានស៊ីបង្ហិនទូលបង្គំ[ត]

**៦៩:១** ក ទដ ៤២:៧ ខ ទដ ៣២:៦ យហ ២:៥ **៦៩:២** គ យប ៣០:១៩ **៦៩:៣** ឃ ទដ ៦:៦ ង ទដ ១១៩:៨២ **៦៩:៤** ច ទដ ២៥:១៩ ឆ យប ១៥:២៥ ជ ទដ ៤០:១៤ ១១៩:៩៥ អស ៣២:៧ ឈ ទដ ៣៥:១៩ ៣៨:១៩ **៦៩:៥** ញ ទដ ៣៨:៥ ដ ទដ ៤៤:២១ **៦៩:៧** ឋ យរ ១៥:១៥ ឌ ទដ ៣៩:៨ ឍ ទដ ៤៤:១៥ **៦៩:៨** ណ យប ១៩:១៣–១៥ ទដ ៣១:១១ ៣៨:១១ អស ៥៣:៣ យហ ៧:៥ **៦៩:៩** ត យហ ២:១៧

១៨–២០ ២រប ២៩–៣២) ។ ក្នុងជំពូកនេះមានសេចក្ដីអធិស្ឋាន៣ ដើម្បីសូមឱ្យព្រះអម្ចាស់ទ្រង់បានរំដោះគាត់ ក្នុងគ្រាដែលគាត់ប្រឈមមុខនិងការឈ្លានពានពីសំណាក់ពួកខ្មាំងសត្រូវ (មើលក្នុងសេចក្ដីផ្ដើម ទដ ៦៩–៧២) ។ ចំណែកឯលក្ខណៈសំណង់ប្រយោគនេះវិញ ព្រះគម្ពីរទំនុកដំកើងជំពូកនេះបានតែងឡើងជា២ផ្នែកស្មើគ្នា ដែលមាន២២បន្ទាត់ក្នុងផ្នែកនិមួយៗ ។ ពាក់កណ្ដាលផ្នែកទី១ (ខ.១–១៥) បានបញ្ចប់ដោយពណ៌នាពីការឈឺចាប់ ដែលដូចគ្នានឹងឃ្លាចាប់ផ្ដើមដែរ ។ មានការគួរឱ្យកត់សម្គាល់មួយបង្ហាញថា ខ.៥ គឺជាចំណុចស្នូលនៃ ខ.១–១៥ ហើយ ខ.២៩ ក៏ជាចំណុចស្នូលនៃ ខ.២២–៣៦ ។ ចំណុចស្នូលរបស់ខទាំង២នេះ គឺដើម្បីបង្ហាញថា ហេតុអ្វីបានជាខទាំងនេះជាផ្ទៃរឿងមួយដែលបានដាច់ចេញពីបរិបទទាំងមូល នៅក្នុងជំពូកនេះ (ការបែងចែកតាមអក្សរសាស្ត្រ មើលការពន្យល់ ៦:៦ ហើយទំនាក់ទំនងផ្ទៃរឿងនៃខទាំង២នេះ សូមមើលការពន្យល់ខាងក្រោម) ។ អ្នកនិពន្ធព្រះគម្ពីរក្នុងសញ្ញាថ្មីបានរំឭកពីសំរែកឈឺចាប់ របស់អ្នកគោរពថ្វាយបង្គំព្រះថាការឈឺចាប់ទាំងនោះ គឺជាតំរុយនៃការឈឺចាប់របស់ព្រះគ្រីស្ទយេស៊ូវ ។ គ្មានបទគម្ពីរទំនុកដំកើងណា ទៀតក្រៅពីទំនុកដំកើង ជំពូក ២២ ដែលនឹងលើកយកមកនិយាយនៅក្នុងសញ្ញាថ្មីនោះឡើយ ។

**៦៩ ត្រង់ចំណងជើង** *សំរាប់ឱ្យមេភ្លេង* មើលការពន្យល់ ទដ ជំពូក ៤ ត្រង់ចំណងជើង ។ *ត្រូវលេងតាមបទ* មើលការពន្យល់ ទដ ៩ ត្រង់ចំណងជើង ។ *ផ្កាឈូក* មើលការពន្យល់ ទដ ៤៥ ត្រង់ចំណងជើង ។

**៦៩:១–៤** ទុក្ខជាទម្ងន់ដែលបានពណ៌នានៅក្នុងខទាំងនេះ បានរំឭកឱ្យឃើញពីសេចក្ដីអធិស្ឋានរបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង ។

**៦៩:១–២** *ទឹក . . . ល្បាប់ដ៏ជ្រៅ . . . ទីទឹកជ្រៅ . . . រលក* ពាក្យទាំងនេះគឺជាពាក្យបំភៀបន័យ ដែលចង់និយាយសំដៅលើទុក្ខយ៉ាងធ្ងន់ (មើលការពន្យល់ ៣០:១ ៣២:៦) ហើយនៅពេលនេះ គឺនិយាយសំដៅលើការដែលព្រះអម្ចាស់បានធ្វើឱ្យ "របួស" (មើល ខ.២៦) ប៉ុន្តែជាញឹកញាប់ គឺសំដៅលើការឈ្លានពានរបស់ពួកខ្មាំងសត្រូវ (មើល ខ.១៤–១៥,២៩) ។

**៦៩:៣** *បំពង់កនៃទូលបង្គំខ្លះហើយ* មើល ២២:១៥ ។ *ភ្នែកទូលបង្គំស្រវាំងទៅ* មើល ៦:៧ និងការពន្យល់ ។

**៦៩:៤** *ដោយឥតហេតុ . . . ដោយឥតរឿង* អ្នកនិពន្ធមិនបានធ្វើអ្វីខុសចំពោះពួកគេឡើយ ប៉ុន្តែគេបែជាជីករណ្ដៅដើម្បីដាក់ដល់គាត់វិញ (មើល ទដ ៣៥:១៩) ។ *មានច្រើនជាងសក់ក្បាលនៃទូលបង្គំ* មើលការពន្យល់ ៤០:១២ ។ *គេចាប់ឱ្យទូលបង្គំ* ឃ្លានេះគឺចង់និយាយថា ពួកខ្មាំងសត្រូវរបស់គាត់ គឺកាន់តែចោទប្រកាន់គាត់ខ្លាំងឡើងៗ (មើល ៥:៩ និងការពន្យល់) ។

**៦៩:៥** នៅក្នុងខនេះ អ្នកនិពន្ធបានសារភាពពីកំហុសរបស់គាត់ ដែលកំហុសទាំងនោះ គឺជាមូលហេតុដែលបណ្ដាលឱ្យព្រះអម្ចាស់ទ្រង់ធ្វើឱ្យគាត់មាន "របួស" (មើល ខ.២៦) និងមូលហេតុដែលនាំឱ្យគាត់ "មានសេចក្ដីវេទនា និងឈឺចាប់" (មើល ខ.២៩) ។ *សេចក្ដីចំកួត* មើលការពន្យល់ ១៤:១ ។

**៦៩:៦–១២** អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបានទទួលស្គាល់ថា "របួស" ដែលព្រះបានធ្វើដល់គាត់ គឺដោយព្រោះតែអំពើបាបនៅក្នុងជីវិតរបស់គាត់ (ប៉ុន្តែមិនមែនដោយអំពើបាប ដែលទាស់ប្រឆាំងនឹងអ្នកដែលធ្វើខុសនឹងគាត់ឡើយ) ។ ដោយព្រោះសេចក្ដីទុក្ខលំបាក ដែលគាត់មាននាពេលបច្ចុប្បន្ននេះ នោះបានធ្វើឱ្យពួកខ្មាំងសត្រូវរបស់គាត់សើចចំអកមើលងាយចំពោះការប្ដេជ្ញាដើរតាមព្រះអម្ចាស់របស់គាត់ (មើល ២២:៦–៨ ៤២:៣ ៧៩:១០ ១១៥:២ យប ២:៩) ។ អ្នកនិពន្ធបានបង្ហាញពីការទុកចិត្តចំពោះព្រះថា ព្រះអម្ចាស់ទ្រង់នឹងលើកគាត់ឡើងជាថ្មី ។

**៦៩:៨** នៅក្នុងខនេះបានពណ៌នាថា សូម្បីតែអ្នកដែលនៅជិតគាត់បំផុតក៏គេឈប់មានទំនាក់ទំនងជាមួយគាត់ដែរ (មើល ៣១:១១–១២ និងការពន្យល់) ។

**៦៩:៩** *សេចក្ដីឧស្សាហ៍ដល់ដំណាក់ទ្រង់* អ្វីដែលបានកើតឡើងចំពោះអ្នកនិពន្ធ ក៏រឹតតែកើតឡើងចំពោះព្រះយេស៊ូវដែរ (មើល យហ ២:១៧) ។ *សេចក្ដីត្មះដៀលទាំងប៉ុន្មានដែលគេដៀលដល់ទ្រង់* អ្នកដែលមើលងាយ

ឯសេចក្ដីត្មះតិះដៀលទាំងប៉ុន្មានដែលគេដៀលដល់ទ្រង់
នោះបានធ្លាក់មកលើទូលបង្គំវិញ[ថ]
១០កាលទូលបង្គំបានយំ ហើយបញ្ឈឺចិត្ត ដោយតមអត់[ទ]
នោះហើយជាហេតុឱ្យគេត្មះតិះដៀលដល់ទូលបង្គំ
១១កាលណាទូលបង្គំយកសំពត់ធ្មៃ[ធ]ទុកជាសំលៀកបំពាក់
នោះក៏ត្រឡប់ជាពាក្យប្រៀបផ្ទឹមរបស់គេវិញ
១២ពួកអ្នកដែលអង្គុយនៅទីទ្វារក្រុង[ន]គេនិយាយដើមពីទូល
បង្គំ ហើយទូលបង្គំជាទំនុកច្រៀងដល់ពួកប្រមឹកស្រា[ប] ។
១៣ប៉ុន្តែឯទូលបង្គំ ឱព្រះយេហូវ៉ាអើយ
សេចក្ដីអធិស្ឋានរបស់ទូលបង្គំដំរង់ទៅឯទ្រង់ក្នុងវេលា
ដែលទ្រង់សព្វព្រះហឫទ័យ[ផ,ព] ឱព្រះអង្គអើយ
សូមឆ្លើយតបមកទូលបង្គំដោយសេចក្ដីសង្គ្រោះដ៏ពិតរបស់
ទ្រង់
១៤សូមស្រង់ទូលបង្គំឡើងចេញពីល្បាប់
កុំឱ្យទូលបង្គំផុងចុះទៅឡើយ
សូមប្រោសឱ្យទូលបង្គំបានរួចពីពួកដែលស្អប់ទូលបង្គំ
ហើយពីទឹកជ្រៅផង[ភ]
១៥សូមកុំឱ្យទឹកជន់[ម]មកពន្លិចទូលបង្គំ
ឬឱ្យទីជំរៅលេបទូលបង្គំបាត់[យ]
ឬឱ្យរណ្ដៅបិទមាត់ពីលើទូលបង្គំឡើយ[រ] ។
១៦ឱព្រះយេហូវ៉ាអើយ សូមឆ្លើយតបមកទូលបង្គំផង
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ល្អណាស់ហើយ[ល]
សូមបែរមកឯទូលបង្គំ
តាមសេចក្ដីមេត្តាករុណាដ៏បរិបូររបស់ទ្រង់
១៧សូមកុំលាក់ព្រះភក្ត្រ[វ]នឹងអ្នកបំរើរបស់ទ្រង់ឡើយ
សូមឆ្លើយមកទូលបង្គំជាប្រញាប់ផង[ស]
ដ្បិតទូលបង្គំមានសេចក្ដីវេទនាហើយ[ហ] ។
១៨សូមទ្រង់ចូលមកជិត លោះព្រលឹងនៃទូលបង្គំ
សូមដោះទូលបង្គំឱ្យរួច[ឡ] ដោយព្រោះពួកខ្មាំងសត្រូវ
១៩ទ្រង់ជ្រាបសេចក្ដីដំនៀល
សេចក្ដីខ្មាសនឹងសេចក្ដីអាប់យស[អ]របស់ទូលបង្គំហើយ
ពួកអ្នកដែលតតាំងនឹងទូលបង្គំសុទ្ធតែនៅចំពោះទ្រង់គ្រប់
ទាំងអស់
២០សេចក្ដីត្មះតិះដៀលបានញាំញីចិត្តទូលបង្គំ
ក៏មានសេចក្ដីទំងន់សង្កត់នៅពេញក្នុងខ្លួនហើយ
ទូលបង្គំបានគន់រកអ្នកណាដែលនឹងអាណិតមេត្តាតែឥត
មាន១សោះ ក៏ស្វែងរកអ្នកណាដែលនឹងកំសាន្តចិត្ត[ក]
តែមិនឃើញ១ទេ[ខ]
២១គេបានឱ្យថ្នាំស្ពឹកមកទូលបង្គំសំរាប់ជាអាហារ
ហើយកាលទូលបង្គំស្រេក[គ]នោះគេយកទឹកខ្មេះមកឱ្យផឹក[ឃ]

**៦៩:៩** ថ ទដ ៨៩:៥០-៥១ រម ១៥:៣ **៦៩:១០** ទ ទដ ៣៥:១៣ **៦៩:១១** ធ ២សយ ៣:៣១ ទដ ៣៥:១៣ **៦៩:១២** ន លប ១៨:១ ២៣:១០ ប យប ៣០:៩ **៦៩:១៣** ផ អស ៤៩:៨ ២កថ ៦:២ ប ទដ ១៧:៧ ៥១:១ **៦៩:១៤** ភ ខ.២ ទដ ១៤៤:៧ **៦៩:១៥** ម ទដ ១២៤:៤-៥ យ ជន ១៦:៣៣ រ ទដ ២៨:១ **៦៩:១៦** ល ទដ ៦៣:៣ **៦៩:១៧** វ ទដ ២២:២៤ ស ទដ ១៤៣:៧ ហ ទដ ៥០:១៥ ៦៦:១៤ **៦៩:១៨** ឡ ទដ ៤៩:១៥ **៦៩:១៩** អ ទដ ២២:៦ **៦៩:២០** ក យប ១៦:២ ខ ទដ ១៤២:៤ អស ៦៣:៥ **៦៩:២១** គ មថ ២៧:៣៤ មក ១៥:២៣ យហ ១៩:២៨-៣០ ឃ ជន ៦:៣ មថ ២៧:៤៨ មក ១៥:៣៦ លក ២៣:៣៦

ដល់ព្រះយេហូវ៉ា ក៏មើលងាយដល់អ្នកបម្រើរបស់ទ្រង់ដែរ (មើល ៧៤:១៨, ២២-២៣ ២ពវ ១៨:៣១-៣៥) ហើយការនេះក៏ដូចគ្នានឹងព្រះយេស៊ូវដែរ (សូមមើល រម ១៥:៣) ។

**៦៩:១០-១១** *យំ . . . បញ្ឈឺចិត្ត . . . យកសំពត់ធ្មៃទុកជាសំលៀកបំពាក់* គាត់ធ្វើដូច្នេះ គឺដើម្បីបង្ហាញពីការបន្ទាបខ្លួននៅចំពោះព្រះ ដោយការ ស្ដាយក្រោយនូវអ្វីដែលខ្លួនបានប្រព្រឹត្ត និងការអធិស្ឋានសូមឱ្យព្រះអង្គជួយស្រោចស្រង់ឡើងវិញ (មើល ៣៥:១៣ និងការពន្យល់ និង លប ៣៧:៣៤ ២សយ ១២:១៦-១៧ យអ ១:១៣-១៤ ២:១៥-១៧ យណ ៣:៥)។

**៦៩:១២** *ពួកអ្នកដែលអង្គុយនៅទ្វារទីក្រុង . . . ពួកប្រមឹកស្រា* នៅក្នុងឃ្លានេះគឺចង់និយាយថា គ្រប់ទាំងអស់នៃពួកមនុស្សចាស់ៗទោះទាំងមកពីក្រុងធំក្ដី តូចក្ដី គឺសុទ្ធតែប្រមឹក ។

**៦៩:១៣-១៥** នៅក្នុងខនេះ អ្នកនិពន្ធចង់និយាយថា ទោះជាពួកខ្មាំងសត្រូវមើលងាយគាត់យ៉ាងណាក៏ដោយ ក៏គាត់នៅតែអធិស្ឋានទៅចំពោះព្រះអម្ចាស់ដែរ ។

**៦៩:១៣** *ក្នុងវេលាដែលទ្រង់សព្វព្រះហឫទ័យ* គឺសំដៅលើពេលវេលាដែលព្រះយេហូវ៉ាទ្រង់ជិតយាងមកជួយសង្គ្រោះ (មើក ៣២:៦ និងការពន្យល់ ហើយក៏សូមមើល អស ៤៩:៨ ៦១:២ ២កថ ៦:២) ។ *សេចក្ដីសប្បុរសដ៏បរិបូរ* មើលការពន្យល់ ៦:៤ ។

**៦៩:១៤-១៥** *ល្បាប់ . . . ទឹកជ្រៅ . . . ទឹកជន់ . . .ទីជំរៅ* សូមមើលការពន្យល់ ខ.១-២ ។ សេចក្ដីអធិស្ឋានរបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងជានិច្ចកាលតែងនិយាយត្រឡប់ពីអ្វី ដែលគាត់បាននិយាយពីខាងដើមពីសេចក្ដីទុក្ខលំបាករបស់គាត់ ។ នៅទីនេះអ្នកនិពន្ធបានត្រឡប់ទៅនិយាយពីចុងបញ្ចប់នៃពាក់កណ្ដាលផ្នែកទី១ ដែលគាត់បានអធិស្ឋានទៅចំពោះព្រះ ។

**៦៩:១៥** *លេបទូលបង្គំ* មើលការពន្យល់ ៤៩:១៤ ។ *រណ្ដៅ* មើលការពន្យល់ ៣០:១ ។

**៦៩:១៦-១៨** នៅក្នុងឃ្លានេះ អ្នកនិពន្ធបានសូមឱ្យព្រះអម្ចាស់ទ្រង់មេត្តាស្ដាប់ពាក្យដែលគាត់បានអធិស្ឋានទៅរកព្រះអម្ចាស់ ។

**៦៩:១៦** *សេចក្ដីសប្បុរស* មើលការពន្យល់ ៦:៤ ។

**៦៩:១៧** *លាក់ព្រះភក្ត្រ* មើលការពន្យល់ ១៣:១ ។

**៦៩:១៨** *លោះ* មើលការពន្យល់ ២៥:២២ ។

**៦៩:១៩-២១** នៅក្នុងខទាំងនេះ ចង់និយាយថា មានសេចក្ដីទុក្ខលំបាកជាច្រើនដែលជាសេចក្ដីដំនៀល គឺត្រូវបានជំនួសមកវិញនូវការកំសាន្តចិត្ត (មើល ៣៥:១១-១៦ និង ១៤២:៤ យប ១៣:៤ ១៦:២ ២១:៣៤) ។

**៦៩:២០** *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៦៩:២១** *ដាក់ថ្នាំស្ពឹកមកទូលបង្គំជាអាហារ ហើយកាលទូលបង្គំស្រេក នោះគេយកទឹកខ្មេះមកឱ្យផឹក* ពាក្យទាំងនេះគឺជាពាក្យប្រៀបប្រដូច ដែលចង់និយាយសំដៅលើសេចក្ដីដំនៀលដ៏ធ្ងន់មួយ ដែលគេបានយកមកឱ្យគាត់

២២ សូមឱ្យតុរបស់គេត្រឡប់ជាអន្ទាក់ដល់គេ
ហើយកាលណាគេមាន
សេចក្ដីសុខ នោះសូមឱ្យប្រែជាអង្គប់ដល់គេវិញ[ង]
២៣ សូមឱ្យភ្នែកគេងងឹតទៅ រហូតដល់មើលមិនឃើញ
ហើយឱ្យចង្កេះគេញ័រជានិច្ច[ច]
២៤ សូមចាក់សេចក្ដីក្ដៅក្រហាយ[ឆ]របស់ទ្រង់ទៅលើគេ
ហើយឱ្យសេចក្ដីក្រោធដ៏សហ័សនៃទ្រង់តាមគេទាន់
២៥ សូមឱ្យលំនៅរបស់គេត្រូវចោលស្ងាត់[ជ]
ឥតមានអ្នកណាអាស្រ័យនៅក្នុងត្រសាលគេឡើយ[ឈ]
២៦ ដ្បិតគេធ្វើទុក្ខបៀតបៀនអ្នកដែលទ្រង់បានវាយហើយ
ក៏ថ្លែងពីសេចក្ដីឈឺចាប់របស់ពួកអ្នកដែលទ្រង់បានធ្វើឱ្យ
មានរបួសផង[ញ]
២៧ សូមបន្ថែមទោសទៅលើទោសរបស់គេ[ដ]
ហើយកុំឱ្យគេចូលមកក្នុងសេចក្ដីសុចរិតរបស់ទ្រង់ឡើយ[ឋ]
២៨ សូមឱ្យគេបានលុបចេញពីបញ្ជីជីវិតទៅ[ឌ]
កុំឱ្យកត់នៅជាមួយនឹងពួកមនុស្សសុចរិតឡើយ[ឍ] ។
២៩ ចំណែកទូលបង្គំមានសេចក្ដីវេទនា ហើយឈឺចាប់
ឱ្យព្រះអង្គអើយ
សូមឱ្យសេចក្ដីសង្គ្រោះរបស់ទ្រង់មកលើទូលបង្គំឡើង
ដាក់នៅទីខ្ពស់វិញ[ណ] ។
៣០ ទូលបង្គំនឹងច្រៀងទំនុកសរសើរដល់ព្រះនាមរបស់ព្រះ[ត]
ហើយនិងលើកដំកើងទ្រង់[ថ] ដោយអរព្រះគុណ
៣១ យ៉ាងនោះ នឹងបានជាទីសព្វព្រះហឫទ័យដល់ព្រះ
យេហូវ៉ា ជាជាងថ្វាយគោឈ្មោល១

**៦៩:២២** ង ១សយ ២៨:៩ យហ ១៨:១០ **៦៩:២៣** ច រម ១១:៩–១០ **៦៩:២៤** ឆ ទដ ៧៩:៦ យរ ១០:២៥ **៦៩:២៥** ជ លវ ២៦:៤៣ មថ ២៣:៣៨ ឈ កច ១:២០ **៦៩:២៦** ញ យប ១៩:២២ សក ១:១៥ **៦៩:២៧** ដ នហ ៤:៥ ឋ ទដ ១០៩:១៤ **៦៩:២៨** ឌ នក ៣២:៣២–៣៣ លក ១០:២០ ឍ អគ ១៣:៩ **៦៩:២៩** ណ ទដ ២០:១ **៦៩:៣០** ត ទដ ២៨:៧ ថ ទដ ៣៤:៣

បានជីវជាតិចិញ្ចឹមជីវិត និងការកំសាន្តចិត្ត ។ អ្នកនិពន្ធក្នុងកណ្ឌគម្ពីរដំណឹងល្អ ជាពិសេសក្នុងព្រះគម្ពីរម៉ាថាយ បានបង្ហាញថាការរងទុក្ខទាំងនេះ គឺជាតំរុយនៃការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទនៅលើឈើឆ្កាង (មើល មថ ២៧:៣៤,៤៨ មក ១៥:២៣,៣៦ លក ២៣:៣៦ យហ ១៩:២៩) ។

**៦៩:២២–២៨** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះអង្គទ្រង់បានកាត់ក្ដីជិនួសដល់ពួកអ្នកដែលប្រព្រឹត្តិខុស (មើលការពន្យល់ ៥:១០) ។

**៦៩:២២–២៣** លោកសាវកប៉ុលក៏បានដកស្រង់ខទាំងនេះ នៅពេលដែលគាត់និយាយសំដៅលើការបដិសេធរបស់ពួកយូដា ក្នុងពេលដែលពួកគេបានបដិសេធចំពោះព្រះយេស៊ូវដែរ (មើល រម ១១:៩–១០) ។

**៦៩:២២** ពួកគេបានយកតុរបស់គាត់ដាក់ដោយ "ថ្នាំស្លឹក" និង "ទឹកខ្មេះ" (មើល ខ.២១) ។ *សូមឱ្យតុរបស់គេត្រឡប់ជា* ឃ្លានេះប្រហែលជានិយាយសំដៅលើអាហារនៃសេចក្ដីសញ្ញា ដែលបានបោះត្រា (មើលការពន្យល់ ២៣:៥) ។ នៅក្នុងដំណើររឿងនេះខនេះចង់និយាយសំដៅលើសញ្ញានៃការរួបរួមរបស់ពួកខ្មាំងសត្រូវ ហើយអ្នកនិពន្ធបានអំពាវនាវដល់ព្រះអម្ចាស់សូមឱ្យព្រះអង្គបង្វែរការនោះ ទាស់ប្រឆាំងដល់ពួកគេវិញ ។ *សូមឱ្យប្រែជាអង្គប់ដល់គេវិញ* ឃ្លាដែលប្រើនៅទីខុសប្លែកពីធម្មតា (មើលការពន្យល់ ៩:១៥) ។

**៦៩:២៣** នៅក្នុងខនេះចង់និយាយថា ពួកខ្មាំងសត្រូវទាំងនោះគេមើលងាយដល់អ្នកនិពន្ធដោយព្រោះ "របួស" ដែលព្រះបានធ្វើដល់គាត់ (មើល ខ.២៦) ។ ពេលនេះប្រហែលជាពួកគេនឹងទទួលបទពិសោធន៍ នៃការខ្សោយភ្នែកដូចគ្នាដែរ (មើល ខ.៣ និងការពន្យល់ ៦:៧) និងត្រូវបង្អោន (ពីភាពទន់ខ្សោយ និងការឈឺចាប់ មើល ៣៨:៥–៨) ។ *ហើយឱ្យចង្កេះគេញ័រ* តាមភាសាអក្សរសាស្ត្រគឺ "សូមឱ្យសិង្ហរបស់គេបានរត់អស់ទៅ" ។ "សិង្ហ គឺសំដៅលើក្បាលពោះ និងផ្នែកផ្សេងៗទៀត នៃ ចង្កេះ" ហើយសិង្ហក៏បង្ហាញពីចំណុចស្នូលនៃកម្លាំង (មើល ៦៦:១១ និង យប ៤០:១៦) ។

**៦៩:២៤** *សេចក្ដីក្ដៅក្រហាយ... សេចក្ដីក្រោធ* មើលការពន្យល់ ២:៥ ។ *តាមគេទាន់* ដូចជាទឹកជំនន់ដែរ ។

**៦៩:២៥** នៅក្នុងខនេះ ពួកគេគិតនឹងបណ្ដេញគាត់ចេញពីលំនៅស្ថានរបស់គាត់ ប៉ុន្តែពួកគេទេដែលនឹងត្រូវបណ្ដេញចេញវិញ (ធៀបនឹងការជំនុំជំនុំជំនុំ... (ធៀបនឹងការជំនុំជំនរៈដល់ពួកយូដា ដែលលោកពេត្រុសបាននិយាយក្នុង កច ១:២០) ។

**៦៩:២៦** នៅក្នុងខនេះ ចង់និយាយសំដៅលើកំហុសដ៏ធ្ងន់ដែលពួកខ្មាំងសត្រូវបានប្រព្រឹត្តិទាស់ប្រឆាំងចំពោះគាត់ ។

**៦៩:២៧** នៅក្នុងខនេះ ចង់និយាយថា ពួកគេបានចោទប្រកាន់ខុសទំនងដល់គាត់ដើម្បីបំផ្លាញគាត់ (មើល ខ.៤) ហើយរាល់ទាំងអស់នៃការចោទប្រកាន់ទាំងខុសទំនងទាំងនោះ និងចោទប្រកាន់ដល់គេវិញ ។

**៦៩:២៨** ពួកខ្មាំងសត្រូវទាំងនោះ បាននិទានពីដំណើររឿងនៃសេចក្ដីស្លាប់គាត់ តែតាមពិតសេចក្ដីស្លាប់នឹងអាចជាជោគវាសនារបស់ពួកគេវិញ ។ *បញ្ជីជីវិត* គឺសំដៅលើបញ្ជីឈ្មោះពួកមនុស្សសុចរិតដែលព្រះបានកត់ទុក ក៏ជាអ្នកដែលព្រះបានប្រទានពរជាជីវិតដល់គេដែរ (មើល ១:៣ ៧:៩ ១១:៧ ៣៤:១២ ៣៧:១៧,២៩ ៥៥:២២ ៧៥:១០ ៩២:១២–១៤ ១៤០:១៣) ។ សូមមើលបទគម្ពីរផ្សេងៗទៀត ដែលនិយាយសំដៅលើបញ្ជីរជីវិតដែលព្រះបានកត់ចុះ ដូចជាការពន្យល់ ៩:៥ ៥១:១ ។ នៅក្នុងសញ្ញាថ្មី "បញ្ជីជីវិត" គឺសំដៅលើបញ្ជីរឈ្មោះ ដែលព្រះបានកត់ទុកចំពោះអ្នកណាដែលមានជីវិតអស់កល្បជានិច្ច (មើល ភល ៤:៣ វវ ៣:៥ និងការពន្យល់ ១៣:៨ ១៧:៨ ២០:១២,១៥ ២១:២៧ ធៀបនឹង លក ១០:២០ ហព ១២:២៣ និងការពន្យល់) ។

**៦៩:២៩** នៅក្នុងខនេះ គឺជាសេចក្ដីសង្ខេបសេចក្ដីអធិស្ឋានជាថ្មីឡើងវិញ ដែលកាលពីដើមជាសេចក្ដីអធិស្ឋានបែបបំណន់ ហើយពេលនេះជាសេចក្ដីអធិស្ឋានបែបសរសើរតម្កើងវិញ (មើលការពន្យល់ ខ.៥) ។ *ឈឺចាប់* ពាក្យនេះគឺជាការដកស្រង់ចេញពី ខ.២៥ ។ *សេចក្ដីសង្គ្រោះរបស់ទ្រង់* សូមធៀបជាមួយ ខ.១៣,១៧ ។ *មកលើទូលបង្គំ* តាមភាសាអក្សរសាស្ត្រគឺ "សូមលើកទូលបង្គំទៅឯទីខ្ពស់ ជាកន្លែងដែលមានសុខសន្តិភាព" ។

**៦៩:៣០–៣៣** នៅក្នុងខនេះ គឺចង់និយាយពីការប្ដេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះ (មើលការពន្យល់ ៧:១៧) ដោយសង្ឃឹមថា ព្រះទ្រង់នឹងស្ដាប់ឮពាក្យអំពាវនាវ (មើលការពន្យល់ ៣:៨) ។

**៦៩:៣០** *ព្រះនាមរបស់ព្រះ* មើល ខ.៣៦ និងការពន្យល់ ៥:១១ ។

គឺជាជាងគោឈ្មោលដែលថ្វាយ ទាំងស្នែងនឹងក្រចកផង[ទ]
៣២ ពួកមនុស្សមានចិត្តរាបទាបបានឃើញ ហើយក៏មាន
សេចក្តីអំណរ[ធ] អ្នករាល់គ្នាដែលស្វែងរកព្រះអើយ
ចូរឱ្យចិត្តអ្នករាល់គ្នាបានភ្ញារ ឡើង[ន]
៣៣ ពីព្រោះព្រះយេហូវ៉ាទ្រង់ប្រោសស្តាប់មនុស្សកំសត់
ទុគ៌ត[ប] ហើយមិនដែលមើលងាយដល់ពួកអ្នករបស់ទ្រង់
ដែលត្រូវគេចាប់ចងឡើយ ។
៣៤ ចូរឱ្យផ្ទៃមេឃនឹងផែនដី ព្រមទាំងសមុទ្រ
ហើយសត្វទាំងប៉ុន្មាន ដែលរវើកនៅក្នុងនោះបាន
សរសើរដល់ទ្រង់ចុះ[ផ]
៣៥ ពីព្រោះ ព្រះទ្រង់នឹងជួយសង្គ្រោះក្រុងស៊ីយ៉ូន[ព]
ហើយនិងសង់អស់ទាំងទីក្រុងយូដាឡើង[ភ] ដូច្នេះ
គេនឹងអាស្រ័យនៅស្រុកនោះ
ហើយនិងបានទុកជាកេរ្តិ៍អាកររបស់គេ
៣៦ ពូជពង្សនៃពួកអ្នកបំរើទ្រង់ នឹងគ្រងបានទុកជាមរដក[ម]
ហើយអស់អ្នកដែលស្រឡាញ់ដល់ព្រះនាមទ្រង់
នឹងបានអាស្រ័យនៅក្នុងស្រុកនោះ[យ] ។

*៧០:១–៥ – ទដ ៤០:១៣–១៧*

ទំនុកដែលស្តេចដាវីឌ បានលើកឱ្យមេភ្លេង សំរាប់នឹងរំឭក ។

**៧០** ឱព្រះអង្គអើយ សូមទ្រង់ប្រោសឱ្យទូលបង្គំរួច
ឱព្រះយេហូវ៉ាអើយ សូមប្រញាប់នឹងជួយទូលបង្គំផង[ក]
២ សូមឱ្យពួកអ្នកដែលប្រាថ្នាជីវិតទូលបង្គំ[ខ]បានត្រូវអៀន
ខ្មាស ហើយទុញទាល់នៅ
សូមឱ្យពួកអ្នកដែលរីករាយក្នុងហេតុអាក្រក់ដែលកើត
ដល់ទូលបង្គំ បានត្រូវថយចេញហើយអាប់យសទៅ[គ]
៣ ឯពួកអ្នកដែលសើចឡកថា ហាស ហាៗ[ឃ]
នោះសូមឱ្យគេត្រូវថយចេញ
ដោយកើតមានសេចក្តីខ្មាសវិញ
៤ សូមឱ្យអស់អ្នកដែលស្វែងរកទ្រង់[ង]បានរីករាយហើយមាន
សេចក្តី អំណរ[ច]ចំពោះទ្រង់
ហើយឱ្យពួកអ្នកដែលស្រឡាញ់សេចក្តីសង្គ្រោះនៃទ្រង់
បានពោលជានិច្ចថា សូមឱ្យព្រះបានលើកដំកើតងឡើង[ឆ]
៥ ចំណែកទូលបង្គំ មានសេចក្តីវេទនាហើយកំសត់ទុគ៌ត[ជ]
ឱព្រះអង្គអើយ សូមទ្រង់ប្រញាប់នឹងមកឯទូលបង្គំ[ឈ]
គឺទ្រង់ជាជំនួយ[ញ] ហើយជាអ្នកប្រោសឱ្យទូលបង្គំរួច[ដ]
ឱព្រះយេហូវ៉ាអើយ សូមកុំបង្អង់ឡើយ[ឋ] ។

*៧១:១–៣ – ទដ ៣១:១–៤*

**៧១** ឱព្រះយេហូវ៉ាអើយ ទូលបង្គំពឹងជ្រកនៅក្នុងទ្រង់[ក]

**៦៩:៣១** ទ ទដ ៥០:៩–១៣ ៥១:១៦ **៦៩:៣២** ធ ទដ ៣៤:២ ន ទដ ២២:២៦ **៦៩:៣៣** ប ទដ ១២:៥ **៦៩:៣៤** ផ ទដ ៩៦:១១ ៩៨:៧ អស ៤៤:២៣ **៦៩:៣៥** ប អប ១:១៧ ភ អរ ៩:៩ ទដ ៥១:១៨ **៦៩:៣៦** ម ទដ ២៥:១៣ យ ទដ ៣៧:២៩ **៧០:១** ក ទដ ២២:១៩ ៧១:១២ **៧០:២** ខ ទដ ៣៥:៤ គ ទដ ៦:១០ ៣៥:២៦ ៧១:១៣ ១០៩:២៩ ១២៩:៥ **៧០:៣** ឃ ទដ ៣៥:២១ **៧០:៤** ង ទដ ៩:១០ ច ទដ ៣១:៦–៧ ៣២:១១ ១១៨:២៤ ឆ ទដ ៣៥:២៧ **៧០:៥** ជ ទដ ៨៦:១ ១០៩:២២ ឈ ទដ ១៤១:១ ញ ទដ ៣០:១០ ៣៣:២០ ដ ទដ ១៨:២ ឋ ទដ ១១៩:៦០ **៧១:១** ក ចទ ២៣:១៥ នរ ២:១២

**៦៩:៣២** *មនុស្សមានចិត្តរាបទាប* មើលការពន្យល ៣៤:៦ ។ *បានឃើញ ហើយក៏មានសេចក្តីអំណរ* មើល ២២:២៦ និងការពន្យល់ ។ *ចិត្ត* មើលការពន្យល់ ។ *ភ្ញារឡើង* គឺពោះចេញដោយសេចក្តីអំណរក្នុងជីវិត ដោយព្រោះព្រះអម្ចាស់ទ្រង់បានស្តាប់ឮសេចក្តីអធិស្ឋានរបស់គាត់ ។

**៦៩:៣៤–៣៦** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអំពាវនាវដល់គ្រប់ទាំងអស់ដែលមានជីវិតឱ្យចូលមកសរសើរតម្កើងដល់ព្រះ (មើលការពន្យល់ ៩:១) ។ ដោយការហៅបែបនេះ អ្នកនិពន្ធមានទំនុកចិត្តថា ព្រះទ្រង់នឹងជួយស្រោចស្រង់ពួកយូដាឡើងវិញ ហើយនិងផ្តល់កេមរដកជាទឹកដីសន្យាដល់រាស្ត្រទ្រង់ ។

**៦៩:៣៤** សូមមើល ១៤៨:១–១៣ អស ៤៩:១៣ ។

**៦៩:៣៥–៣៦** *គេ… ពូជពង្ស* គឺសំដៅលើរាស្ត្ររបស់ព្រះ និងកូនចៅរបស់គេគ្រប់ទាំងតំណរជាពិសេស ពួកអ្នកដែលស្រឡាញ់ដល់ព្រះនាមទ្រង់ ។

**៦៩:៣៥** *ក្រុងស៊ីយ៉ូន* សូមមើលការពន្យល់ ៩:១១ ។

**ទដ ៧០** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអំពាវនាវដល់ព្រះអម្ចាស់ ដោយសូមសេចក្តីជំនួយមកពីទ្រង់ក្នុងគ្រាដែលពួកខ្មាំងសត្រូវបៀតបៀន ។ អ្វីដែលមាននិយាយនៅក្នុងជំពូកនេះ មានលក្ខណៈដូចគ្នាខ្លះទៅនឹង ទដ ៤០:១៣–១៧ (មើលការពន្យល់ទីនោះ) ។ នៅក្នុងជំពូកនេះ គឺជាជំពូកទី២ក្នុងចំណោមចង្កោមទាំង៣ នៃទំនុកដំកើងនៅចុងបញ្ចប់ប៉ែកទី២ ដែលនិយាយពីការអធិស្ឋាន ។ ភាសាដែលប្រើក្នុងជំពូកនេះ គឺមានលក្ខណៈដូចគ្នាច្រើនជាមួយ ទដ ៧១ ។ មើលពីតួនាទីទំនុកដំកើងជំពូកនេះ ក្នុងចំណោមចង្កោមទំនុកដំកើងក្នុងសេចក្តីផ្តើម ទដ ៦៩–៧២ និងទំនាក់ទំនងពិសេសជាមួយ ទដ ៧១ មើកក្នុងសេចក្តីផ្តើមទំនុកដំកើងជំពូកនេះ ។ សេចក្តីអធិស្ឋានក្នុងជំពូកនេះបានបង្ហាញឱ្យឃើញច្បាស់ ដោយអ្នកនិពន្ធសូមឱ្យព្រះអង្គ "ឆាប់យាងមក" ដើម្បីជួយដល់គាត់ (មើល ខ.១,៥) ។ នៅទីបញ្ចប់នៃសេចក្តីអធិស្ឋានក្នុងជំពូកនេះ បានផ្តោតលើលទ្ធផល នៃការយាងមកជួយរបស់ព្រះអម្ចាស់ដោយ (១).មានជ័យជម្នះលើ "ពួកអ្នកដែលប្រាថ្នា" ជីវិតទូលបង្គំ (មើល ខ.២–៣) (២).មានជ័យជម្នះលើពួកអ្នក ដែលស្វែងរកទ្រង់ (មើល ខ.៤) ។

**៧០ ត្រង់ចំណងជើង** សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *រំឭក* សូមមើលការពន្យល់ ទដ ៣៨ ត្រង់ចំណងជើង ។

**៧០:៤** នៅក្នុងឃ្លានេះគឺចង់ខ្ញុំនិយាយថា ដោយសារការដែលព្រះអម្ចាស់បានយាងមកជួយសង្គ្រោះអ្នកបម្រើទ្រង់ និងធ្វើឱ្យពួកអ្នកដែលទុកចិត្តលើព្រះអង្គគេមានអំណរ ពីព្រោះគេបានឃើញការធានាពីសេចក្តីសង្គ្រោះដល់ពួកគេ ។ *សូមឱ្យព្រះបានលើកដំកើងឡើង* ពីព្រោះដោយសារសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ គឺពិតត្រង់ និងមានប្រសិទ្ធិភាព (ផ្ទុយពី ខ.៣) ។

**៧០:៥** ពាក្យទាំងប៉ុន្មានដែលនិយាយនៅក្នុងខនេះ គឺបានដកស្រង់ចេញពី ខ.១ ដូចជាពាក្យថា "ឱព្រះអង្គអើយ" និងពាក្យថា "ឱព្រះយេហូវ៉ាអើយ" សូមទ្រង់យាងមកប្រញាប់ ។

**ទដ ៧១** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានទូលសូមសេចក្តីជំនួយមកពីព្រះ នៅគ្រាដែលគាត់មានវ័យចំណាស់ ពេលដែលគាត់ជួបការឈ្លានពានពីសំណាក់ពួកខ្មាំងសត្រូវ ពីព្រោះគេបានដឹងថាកម្លាំងរបស់គាត់កាន់

សូមកុំឱ្យទូលបង្គំត្រូវខ្មាសឡើយ[ខ]
២សូមទ្រង់ដោះទូលបង្គំឱ្យរួច
ហើយស្រោចស្រង់ដោយសេចក្ដីសុចរិតរបស់ទ្រង់
សូមផ្ទៀងព្រះកាណ៌[គ] មកស្ដាប់
ហើយជួយសង្គ្រោះទូលបង្គំផង
៣សូមឱ្យទ្រង់ធ្វើជាថ្មដា សំរាប់ជាទីលំនៅដល់ទូលបង្គំ
ជាកន្លែងដែលទូលបង្គំទៅមកជានិច្ចបាន
ទ្រង់បានចេញបង្គាប់ឱ្យជួយសង្គ្រោះទូលបង្គំហើយ
ដ្បិតទ្រង់ជាថ្មដា ហើយជាបន្ទាយរបស់ទូលបង្គំ[ឃ] ។
៤ឱព្រះនៃទូលបង្គំអើយ សូមស្រោចស្រង់[ង]ទូលបង្គំឱ្យរួចពី
កណ្ដាប់ដៃនៃមនុស្សអាក្រក់[ច]
គឺឱ្យចេញរួចពីកណ្ដាប់ដៃនៃមនុស្សទុច្ចរិតដ៏សាហាវផង[ឆ]
៥ដ្បិតឱព្រះអម្ចាស់យេហូវ៉ាអើយទ្រង់ជាទីសង្ឃឹមនៃទូល
បង្គំ[ជ] ទ្រង់ជាទីទុកចិត្ត[ឈ]ដល់ទូលបង្គំតាំងតែពីក្មេងមក
៦គឺទ្រង់ហើយដែលថែរក្សាទូលបង្គំ តាំងតែពីផ្ទៃម្ដាយមក[ញ]
ទ្រង់បានគាំទូលបង្គំឱ្យចេញចាកពីពោះម្ដាយ[ដ]
ទូលបង្គំនឹងសរសើរ[ឋ]ពីទ្រង់ជានិច្ច ។
៧ទូលបង្គំជាទីអស្ចារ្យដល់មនុស្សជាច្រើន[ឌ]
តែគឺទ្រង់ជាទីពឹងមាំមួនរបស់ទូលបង្គំទេ[ឍ]
៨មាត់[ណ]ទូលបង្គំនឹងពេញដោយសេចក្ដីសរសើរដល់ទ្រង់
ហើយនិងពោលពីកិត្តិសព្ទ[ត]នៃព្រះនាមទ្រង់ដរាបរាល់ថ្ងៃ
៩សូមកុំបោះបង់ចោល[ថ]ទូលបង្គំក្នុងកាលដែលចាស់ជរា
ឡើយ[ទ] ហើយកុំលះបង់[ធ]ទូលបង្គំ
ក្នុងកាលដែលមានកំឡាំងអន់ថយនោះដែរ
១០ដ្បិតពួកខ្មាំងសត្រូវ[ន] គេនិយាយដើមពីទូលបង្គំ
ហើយពួកអ្នកដែលចាំមើល[ប]ជីវិតទូលបង្គំ គេជំនុំគ្នា[ផ]ថា
១១ព្រះបានបោះបង់ចោល[ព]វាហើយ
ចូរយើងដេញតាមចាប់វាចុះដ្បិតគ្មានអ្នកណានឹងជួយ[ភ]វា
សោះ ។
១២ឱព្រះអង្គអើយ សូមកុំគង់ឆ្ងាយ[ម]ពីទូលបង្គំឡើយ

**៧១:១** ខ ទដ ២២:៥ **៧១:២** គ ២ពវ ១៩:១៦ **៧១:៣** ឃ ទដ ១៨:២ **៧១:៤** ង ២ពវ ១៩:១៩ ច ទដ ១៤០:៤ ឆ លប ៤៨:១៦ **៧១:៥** ជ ទដ ៩:១៨ ២៥:៥ ឈ យប ៤:៦ យរ ១៧:៧ **៧១:៦** ញ ទដ ២២:១០ ដ យប ៣:១៦ ទដ ២២:៩ ឋ ទដ ៩:១ ៣៤:១ ៥២:៩ ១១៩:១៦៤ ១៤៥:២ **៧១:៧** ឌ ចទ ២៨:៤៦ អស ៨:១៨ ១កថ ៤:៩ ឍ ២សយ ២២:៣ ទដ ៦១:៣

**៧១:៨** ណ ខ.១៥ ទដ ៥១:១៥ ៦៣:៥ ត ទដ ៩៦:៦ ១០៤:១ **៧១:៩** ថ ទដ ១៥:១១ ទ ទដ ៩២:១៤ អស ៤៦:៤ ធ ចទ ៤:៣១ ៣១:៦ **៧១:១០** ន ទដ ៣:៧ ប ទដ ១០:៨ ៥៩:៣ សភ ១:១៨ ផ នក ១:១០ ទដ ៣១:១៣ មថ ១២:១៤ **៧១:១១** ព ទដ ៩:១០ អស ៤០:២៧ ៥៤:៧ បទ ៥:២០ មថ ២៧:៤៦ ភ ទដ ៧:២

តែខ្សោយទៅៗ (មើលការពន្យល់ ៥:៩) ។ នៅក្នុងជំពូកនេះគ្មានចំណង ជើងឡើយ ប៉ុន្តែដែលមាននោះប្រហែលជានៅក្នុង ទដ ៧០ អ្នកនិពន្ធបាន យកមកបង្ហាញជាសេចក្ដីផ្ដើម ទដ ៧១ វិញ (សូមប្រៀបធៀបជាមួយ ខ.១, ១២–១៣ ជាមួយ ៧០:១–២,៥) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺពណ៌នា ពីស្ដេចដាវីឌ(ក្នុងគ្រាដែលត្រង់មានវ័យចាស់ជរា មើល ខ.៩,១៨) ។ ចាប់ ពី ទដ ជំពូក ៧២ គឺជាសេចក្ដីអធិស្ឋានសម្រាប់ស្ដេចសាឡូម៉ូន (មើលក្នុង សេចក្ដីផ្ដើមត្រង់នោះ) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺជាសេចក្ដី អធិស្ឋានលំដាប់ទី៣ ក្នុងចំណោមសេចក្ដីអធិស្ឋានទាំង៣ដែលមាននៅក្នុង វគ្គចុងក្រោយនៃប៉ែកទី២ (មើលកក្នុងសេចក្ដីផ្ដើម ទដ ៦៩–៧២) ។ ផ្ទៃ រឿងសំខាន់នៅក្នុងជំពូកនេះ គឺនិយាយពីសេចក្ដីសង្ឃឹម (មើល ខ.១៤) ។ ទម្រង់សំណង់ប្រយោគក្នុងជំពូក នេះបានតែងឡើងជា៦ល្បះ ដែលមាន ៥ខ,៤ខ,៥ខ,៥ខ,៤ខ,៥ខ (នៅក្នុងភាសាហេព្រើរ) ។ ជំនាក់ទំនងនៃខ និមួយៗគឺ ខ.១–៤ (មាន៥បន្ទាត់) ខ.៤–៨ (៤បន្ទាត់) ខ.៩–១៣ (៥បន្ទាត់) ខ.១៥–១៨ (៥បន្ទាត់) ខ.១៩–២១ (៤បន្ទាត់) ខ.២២–២៤ (៥បន្ទាប់) ។ នៅចំណុចកណ្ដាល (ខ.១៤ មើលការពន្យល់ ៦:៦) បានបង្ហាញឱ្យឃើញ ច្បាស់ពីទំនុកចិត្ត ចំពោះព្រះរបស់អ្នកនិពន្ធ ។ បទគម្ពីរក្នុងជំពូកនេះទាំង មូល គឺនិយាយពីការដង្ហោយរកសេចក្ដីជំនួយមកពីព្រះអម្ចាស់ (មើល ខ.១–៤) និងការច្រៀងសរសើរតម្កើងដល់ទ្រង់ ចំពោះការប្រោសលោះរបស់ ព្រះអម្ចាស់ ។ ល្បះទី២ និងទី៥មានទំនាក់ទំនងជាមួយគ្នាដោយព្រោះបាន និយាយពីបញ្ហា នៃសេចក្ដីទុក្ខព្រួយបស់ស្ដេចដែលធ្លាប់ជួបប្រទះ ។ នៅក្នុង ល្បះទី៣ និងទី៤ បានិយាយពីតំណាក់កាលចុងក្រោយនៃជីវិតរបស់ ។

**៧១:១–៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអធិស្ឋានសូមសេចក្ដីជំនួយមកពី ព្រះយេហូវ៉ា ។ ក្នុង ខ.១–៣ មានភាពខុសគ្នាបន្តិចបន្តួចពី ទដ ៣១:១–៣ ។

**៧១:២** *សេចក្ដីសុចរិតរបស់ទ្រង់* សូមមើល ខ.១៥–១៦,១៩,២៤ និង ការពន្យល់ ៤:១ ។

**៧១:៣** *ទ្រង់បានចេញបង្គាប់ឱ្យជួយសង្គ្រោះទូលបង្គំហើយ* នៅក្នុងព្រះ គម្ពីរភាសាហេព្រើរ គឺមានការគួឱ្យកត់សំគាល់ពីសំនួនវោហាស៍ នៃទំនាក់ ទំនងជាមួយ ទដ ៤៤:៤ ត្រង់ឃ្លា "សូមបង្គាប់ឱ្យមានសេចក្ដីសង្គ្រោះ" ។ ប្រយោគបែបនេះនៅក្នុងព្រះគម្ពីរភាសាហេព្រើរ គឺមានតែ២កន្លែងនេះ ប៉ុណ្ណោះនៅក្នុងសញ្ញាចាស់ ។

**៧១:៥–៨** នៅក្នុងខទាំងនេះ អ្នកនិពន្ធចង់និយាយថា ជានិច្ចកាលព្រះ យេហូវ៉ាទ្រង់ជាក្ដីសង្ឃឹមដល់គាត់ (មើល ខ.១៤,១៩–២០) ។

**៧១:៥–៦** សូមធៀបជាមួយ ២២:១០–១១ ។

**៧១:៧** *ទូលបង្គំជាទីអស្ចារ្យ* នៅក្នុងឃ្លានេះគឺនិយាយថា សេចក្ដីទុក្ខលំបាក ដែលគាត់មាននៅក្នុងជីវិតរបស់គាត់ (មើល ខ.២០) ត្រូវបានបង្ហាញឱ្យ ឃើញច្បាស់ពីសេចក្ដីសង្គ្រោះ ជាពិសេសក្នុងពេលដែលព្រះអម្ចាស់ទ្រង់ជា "ទីពឹងដ៏មាំមួន" របស់ពួកគេ ។

**៧១:៨** *មាត់ទូលបង្គំនឹងពេញដោយសេចក្ដីសរសើរ . . . ព្រះនាមទ្រង់* គឺដោយសារភាពស្មោះត្រង់របស់ព្រះយេហូវ៉ា នោះបានធ្វើឱ្យអ្នកនិពន្ធ ព្រះគម្ពីរទំនុកដំកើងគាត់បានបំពេញជីវិតរបស់គាត់ ដែលជាគោលបំណង ដ៏ខ្ពស់របស់ព្រះអម្ចាស់ក្នុងកិច្ចការសង្គ្រោះ និងការប្រទានពរដល់រាស្ត្រទ្រង់ (សូមមើល យរ ១៣:១១ ៣៣:៩) ។

**៧១:៩–១៣** នៅក្នុងខទាំងនេះ គឺជាសេចក្ដីអធិស្ឋានសូមសេចក្ដីជំនួយមកពី ព្រះក្នុងគ្រាដែលជីវិតគាត់ជួមប្រទះនូវភាពសោះកក្រោះ ។

**៧១:១០** *ដ្បិតពួកខ្មាំងសត្រូវ គេនិយាយដើមទូលបង្គំ* សូមមើលការពន្យល់ ៣:២ ៥:៩ ។

**៧១:១២** *សូមកុំគង់ឆ្ងាយពីទូលបង្គំ* សូមធៀបជាមួយ ២២:១១,១៩ ៣៥:២២ ៣៨:២១ ។ *សូមប្រញាប់មកជួយទូលបង្គំ* សូមធៀបជាមួយ ២២:១៩

ឱព្រះនៃទូលបង្គំអើយ សូមប្រញាប់មកជួយ[យ]ទូលបង្គំផង
១៣ សូមឱ្យពួកអ្នកដែលទាស់ទទឹង[រ]នឹងជីវិតទូលបង្គំបានត្រូវអៀនខ្មាស[ល] ហើយវិនាសសូន្យទៅ
ឯពួកអ្នកដែលរកប្រទូស្តនឹងទូលបង្គំនោះ
សូមឱ្យគេបានគ្របពេញដោយសេចក្តីដំនៀលនឹងអាប់យសវិញ[វ]
១៤ ឯទូលបង្គំនឹងមានសង្ឃឹមជានិច្ច[ស]
ហើយនិងសរសើរដល់ទ្រង់កាន់តែច្រើនឡើង
១៥ មាត់ទូលបង្គំនឹងថ្លែងប្រាប់[ហ]ពីសេចក្តីសុចរិត[ឡ]
និងពីសេចក្តីសង្គ្រោះ របស់ទ្រង់ជាដរាបរាល់ថ្ងៃ
ពីព្រោះទូលបង្គំមិនដឹងជាមានចំនួនប៉ុន្មានទេ
១៦ ទូលបង្គំនឹងទៅដោយព្រះចេស្តារបស់ព្រះអម្ចាស់យេហូវ៉ា[អ]
ហើយនិងដំណាលពីសេចក្តីសុចរិតរបស់ទ្រង់គឺរបស់ទ្រង់តែ១ប៉ុណ្ណោះ ។
១៧ ឱព្រះអង្គអើយ
ទ្រង់បានបង្ហាត់បង្រៀន[ក]ទូលបង្គំតាំងតែពីក្មេងមក
ហើយដរាបដល់ឥឡូវនេះ
ទូលបង្គំបានសំដែងពីអស់ទាំងការអស្ចារ្យរបស់ទ្រង់[ខ]
១៨ ឱព្រះអង្គអើយ សូមកុំលះបង់ចោលទូលបង្គំឡើយ
ទោះទាំងវេលាដែលទូលបង្គំចាស់សក់ស្កូវហើយផង[គ]
ដរាបដល់ទូលបង្គំបានថ្លែងប្រាប់ពីព្រះចេស្តា[ឃ]ទ្រង់
ដល់ដំណមនុស្សជាន់ក្រោយ
និងពីឥទ្ធានុភាពទ្រង់ដល់ពួកអ្នកដែលត្រូវកើតខាងមុខ[ង]
១៩ ឯសេចក្តីសុចរិតរបស់ទ្រង់
ឱព្រះអង្គអើយនោះខ្ពស់ណាស់[ច]
ចំណែកឯទ្រង់ដែលបានធ្វើការយ៉ាងធំ[ឆ] ឱព្រះអង្គអើយ
តើមានអ្នកណាដូចទ្រង់[ជ] ។
២០ ទ្រង់បានឱ្យយើងខ្ញុំឃើញសេចក្តីវេទនាដ៏លំបាកជាច្រើនហើយ[ឈ] តែទ្រង់នឹងប្រោស[ញ]ឱ្យមានជីវិតចំរើនឡើងវិញ
ទ្រង់នឹងនាំយើងខ្ញុំឡើងចេញពីទីជំរៅនៃផែនដី[ដ]
២១ សូមលើកសេចក្តីខ្ពង់ខ្ពស់[ឋ]នៃទូលបង្គំឡើង
ហើយវិលមកជួយកំសាន្ត[ឌ]ទូលបង្គំវិញ ។
២២ ឱព្រះនៃទូលបង្គំអើយ
ទូលបង្គំនឹងសរសើរទ្រង់ដោយពិណដែរ[ឍ]
គឺនឹងសរសើរពីសេចក្តីពិតរបស់ទ្រង់
ឱព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលអើយ[ណ]
ទូលបង្គំនឹងច្រៀងសរសើរថ្វាយទ្រង់តាមស៊ុង[ត]

**៧១:១២** ម ទដ ៣៨:២១ យ ទដ ២២:១៩ ៣៨:២២ **៧១:១៣** រ យរ ១៨:១៩ ល យប ៨:២២ ទដ ២៥:៣ វ ទដ ៧០:២ **៧១:១៤** ស ទដ ២៥:៣ ៤២:៥ ១៣០:៧ ១៣១:៣ **៧១:១៥** ហ ខ.៨ ទដ ៦៦:១៦ ឡ ទដ ៥១:១៤ **៧១:១៦** អ ទដ ៩:១ ៧៧:១២ ១០៦:២ ១១៨:១៥ ១៤៥:៤ **៧១:១៧** ក ចទ ៤:៥ យរ ៧:១៣ ខ យប ៥:៩ ទដ ២៦:៧ ៨៦:១០ ៩៦:៣ **៧១:១៨** គ អស ៤៦:៤ ឃ នក ៩:១៦ ង យប ៨:៨ ទដ ២២:៣០,៣១ ៧៨:៤ ១៤៥:៤ យអ ១:៣ **៧១:១៩** ច ទដ ៣៦:៥ ឆ ទដ ១២៦:២ លក ១:៤៩ ជ ទដ ៣៥:១០ ៧៧:១៣ ៨៩:៨ **៧១:២០** ឈ ទដ ២៥:១៧ ញ ទដ ៨០:៣,១៩ ៨៥:៤ ហស ៦:២ ដ ទដ ៦៣:៩ **៧១:២១** ឋ ទដ ១៨:៣៥ ឌ ទដ ២៣:៤ ៨៦:១៧ អស ១២:១ ៤០:១-២ ៤៩:១៣ ៥៤:១០ **៧១:២២** ឍ ទដ ៣៣:២ ណ ២ពវ ១៩:២២ ត យប ២១:១២ ទដ ៩២:៣ ១៤៤:៩

៣៨:២២ ៤០:១៣ ៧០:១ ៧០:៥ ១៤១:១ ។

**៧១:១៣** នៅក្នុងខនេះ គឺនិយាយពីការសូមឱ្យព្រះទ្រង់ជំនុំជម្រះដល់ពួកគេជំនួសគាត់ (មើលការពន្យល់ ៥:១០) ។ ពាក្យគន្លឹះក្នុងខចុងក្រោយនៃពាក់កណ្តាលផ្នែកទី១នេះ គឺដូចគ្នានឹងចុងបញ្ចប់នៃខចុងក្រោយពាក់កណ្តាលផ្នែកទី២ដែរ ។ ភាសាដែលប្រហាក់ប្រហែលគ្នានេះ អាចរកឃើញនៅក្នុង ៣៥:៤,២៦ ៤០:១៤-១៥ ៧០:២-៣ ៨៣:១៧ ១០៩:២៨-២៩ ។

**៧១:១៤** នៅក្នុងខនេះគឺចង់និយាយពីការទុកចិត្តព្រះទាំងស្រុង ហើយការនេះមានទំនាក់ទំនងជាមួយ ទដ ៤២-៤៣ (មើល ទដ ៤២:៨ និងការពន្យល់ ៦:៦) ។

**៧១:១៥-១៨** នៅក្នុងខនេះ គឺនិយាយពីការប្តេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះយេហូវ៉ា ដោយភ្ជាប់នឹងការរំឭកពីសេចក្តីអធិស្ឋានកាលពីគ្រាមុន (ខ.១៨) មើលការពន្យល់ ៧:១៧ ។

**៧១:១៥** *ថ្លែងប្រាប់ . . . សេចក្តីសុចរិត . . . សេចក្តីសង្គ្រោះ* នៅទីនេះ "សេចក្តីសុចរិត"ដែលអ្នកនិពន្ធប្តេជ្ញាថា និងថ្លែងប្រាប់ គឺនិយាយសំដៅលើសេចក្តីសង្គ្រោះរបស់ព្រះ ដែលទ្រង់បានឆ្លើយតាមការអធិស្ឋាន (មើលការពន្យល់ ខ.១៦-១៧ ៤:១) ។

**៧១:១៦-១៧** *ព្រះចេស្តា . . . សេចក្តីសុចរិត . . . ការអស្ចារ្យ* គឺនិយាយសំដៅលើការអស្ចារ្យ ដែលព្រះបានធ្វើចំពោះរាស្ត្ររបស់ទ្រង់ ដោយព្រោះសេចក្តីសុចរិតរបស់ទ្រង់ ដូចច្នេះហើយទើបគេហៅថា ជាអ្នកសុចរិតរបស់ទ្រង់ (សូមមើល ខ.២) ។

**៧១:១៦** *ទៅ* គឺនិយាយសំដៅលើការទៅព្រះវិហារ ជាកន្លែងដែលរាស្ត្រទ្រង់ប្រជុំគ្នាថ្វាយបង្គំ ។

**៧១:១៩-២១** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានសម្តែងថា ព្រះយេហូវ៉ាទ្រង់នៅតែផ្តល់សេចក្តីសង្ឃឹមដល់គាត់ ទោះបីជាគាត់ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ឬសេចក្តីទុក្ខព្រួយក៏ដោយ (មើល ខ.៥-៨, ១៤) ។

**៧១:១៩** *ខ្ពស់ណាស់* នៅក្នុងឃ្លានេះចង់និយាយថា សេចក្តីសប្បុរសរបស់ទ្រង់គឺខ្ពស់កប់ពពក ហើយទូលាយ (មើល ៣៦:៥ និងការពន្យល់) ។ *ឱព្រះអង្គអើយ តើមានអ្នកណាដូចទ្រង់* សូមមើល មីក ៧:១៨ ។

**៧១:២០** *ទ្រង់បានឱ្យយើងខ្ញុំឃើញសេចក្តីវេទនាដ៏លំបាកជាច្រើនហើយ* សេចក្តីទុក្ខលំបាកដែលនិយាយនៅទីនេះមិនច្បាស់លាស់ឡើយ ។ *ទ្រង់នឹងប្រោសឱ្យមានជីវិតចំរើនឡើង* ពីព្រោះព្រះយេហូវ៉ាទ្រង់គឺជាអ្នកប្រទានជីវិតដល់គាត់ (សូមមើល ខ.៦) នោះទ្រង់នឹងចំរើនគាត់ឡើងវិញ ។ *ទីជំរៅនៃផែនដី* គឺនិយាយសំដៅលើទីជំរៅនៃសេចក្តីស្លាប់ ដែលប្រៀបដូចជាខ្លោងទ្វារនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ (សូមមើលការពន្យល់ ៣០:១) ។

**៧១:២២-២៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានប្តេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះ ដោយមានទំនុកចិត្តលើសេចក្តីជំនួយមកពីព្រះ (មើលការពន្យល់ ៣:៨ ៧:១៧) ។

**៧១:២២** *ពិណ. . . ស៊ុង* មើលការពន្យល់ ៥៧:៨ ។ *ព្រះដ៏បរិសុទ្ធរបស់*

២៣កាលណាទូលបង្គំច្រៀងសរសើរដល់ទ្រង់
នោះបបូរមាត់នៃទូលបង្គំនឹងបន្លឺឡើងដោយអំណរ
ព្រមទាំងព្រលឹងនៃទូលបង្គំដែលទ្រង់បានលោះនោះផង[ថ]
២៤ឯអណ្ដាតរបស់ទូលបង្គំ
និងនិទានពីសេចក្ដីសុចរិតរបស់ទ្រង់ ជាដរាបរាល់ថ្ងៃ[ទ]
ដ្បិតពួកអ្នកដែលរកប្រទូស្តនឹងទូលបង្គំគេបាន[ធ]
ត្រូវអៀនខ្មាសមួរមុខចុះហើយ[ន] ។

ទំនុករបស់ស្ដេចសាឡូម៉ូន ។

**៧២** ឱព្រះអង្គអើយ សូមទ្រង់ប្រទានបញ្ញត្តច្បាប់[ក]
នៃទ្រង់មកទូលបង្គំជាស្ដេច
ហើយសេចក្ដីសុចរិតនៃទ្រង់ដល់ព្រះរាជបុត្រាផង
២ឱ្យព្រះរាជបុត្រាបានគ្រប់គ្រងលើរាស្ត្ររបស់ព្រះដោយ
សុចរិត[ខ] ហើយលើពួកក្រីក្រដោយទៀងត្រង់
៣នោះអស់ទាំងភ្នំធំតូច នឹងចំរើនសេចក្ដីសុខដល់បណ្ដាជន
ដោយសេចក្ដីសុចរិត
៤សូមឱ្យទ្រង់បានសំរេចក្ដី ដល់ពួកកំសត់[គ]ក្នុងបណ្ដាជន
ហើយជួយសង្គ្រោះដល់ពួកកូនរបស់មនុស្សក្រីក្រ[ឃ]
ព្រមទាំងវាយពួកអ្នកសង្កត់សង្កិនឱ្យខ្ទេចខ្ទីទៅ[ង] ។
៥យ៉ាងនោះ គេនឹងកោតខ្លាច[ច]ដល់ទ្រង់ដ៏ជាព្រះ
អស់អំឡុងដែលនៅមានព្រះអាទិត្យភ្លឺតទៅ
ព្រមទាំងព្រះច័ន្ទផង ដរាបដល់អស់ទាំងដំណតរៀងទៅ[ឆ]
៦សូមឱ្យទ្រង់បានដូចជាភ្លៀង[ជ]ធ្លាក់ចុះមកលើវាលដែល
ច្រូតស្មៅហើយ គឺដូចជាភ្លៀង១មេៗដែលស្រោចដី
៧នៅក្នុងគ្រាព្រះរាជបុត្រា
នោះមនុស្សសុចរិតនឹងមានសេចក្ដីចំរើនឡើង[ឈ]
ហើយនិងមានសេចក្ដីសុខជាបរិបូរដរាបដល់ព្រះច័ន្ទ
រលត់សូន្យទៅ ។
៨ទ្រង់នឹងមានអំណាចចាប់តាំងពីសមុទ្រម្ខាងទៅដល់

**៧១:២៣** ថ ទដ ២០:៥ ទ នក ១៥:១៣ **៧១:២៤** ធ ទដ ៣៥:២៨ ន ខ.១៣ ប នក ៩:២ **៧២:១** ក ចទ ១:១៦ ទដ ៩:៨ **៧២:២** ខ អស ៩:៧ ១១:៤–៥ ១៦:៥ ៣២:១ ៥៩:១៧ ៦៣:១ យរ ២៣:៥ ៣៣:១៥ **៧២:៤** គ ទដ ៩:១២ ៧៦:៩ អស ៤៩:១៤ ឃ ខ.១៣ អស ១១:៤ ២៩:១៩ ៣២:៧ ង ទដ ២៧:១១ **៧២:៥** ច ១សយ ១៣:១៣ ឆ ទដ ៣៣:១១ **៧២:៦** ជ ចទ ៣២:២ **៧២:៧** ឈ ទដ ៩២:១២ សភ ១៤:១១

*អ៊ីស្រាអែល* មើល ៧៨:៤១ ៨៩:១៨ ២ពវ ១៩:២២ និងការពន្យល់ ។

**៧១:២៣** *លោះ* នៅទីនេះមានន័យដូចគ្នានឹងពាក្យថា "ដោះលែង"ដែរ ។

**៧១:២៤** *សេចក្ដីសុរិត* នៅទីនេះគឺនិយាយសំដៅលើសេចក្ដីសុរិត ដែលព្រះបានជួយសង្គ្រោះរាស្ត្ររបស់ព្រះ តាមសេចក្ដីសន្យា (មើល ៨៨:១២ ៧ច ៥:១១ ១សយ ១២:៧ និងការពន្យល់ ដយ ៩:១៦ មីក ៦:៥ វវ ១៥:៤) ។

**ទដ ៧២** នៅក្នុងជំពូកនេះ គឺនិយាយពីការអធិស្ឋានសម្រាប់ព្រះរាជបុត្រារបស់ស្ដេចដាវីឌ ដែលបានគង់ចុះលើបល្ល័ង្ករបស់ដាវីឌជាបិតា ក្នុងនាមជារាជានុសិទ្ធរបស់ព្រះយេហូវ៉ានៅលើផែនដី លើរាស្ត្ររបស់ព្រះអម្ចាស់ ។ បទចម្រៀងនេះ ប្រហែលប្រើក្នុងពិធីអភិសេកព្រះអង្គឱ្យឡើងគ្រងរាជ្យ (ដូចជាក្នុង ទដ ជំពូក ២,១១០) ។ នៅក្នុង ខ.២–១១,១៧ បានពណ៌នាពីការសរសើរតម្កើងដល់ព្រះ (មើលការពន្យល់ ខ.២) ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ខទាំងនេះគឺពណ៌នាពីការអធិស្ឋានវិញ ។ នៅក្នុងជំពូកនេះ ក៏បានពណ៌នាពីបំណងប្រាថ្នារបស់បណ្ដាជន ដែលទន្ទឹងចាំរាជរបស់ទ្រង់ ដែលជាទាយជ្ជទានរបស់ស្ដេចចំពោះរាស្ត្រទ្រង់ តាមរយៈសេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិត និងគុណធម៌របស់ព្រះមហាក្សត្រ ។ សេចក្ដីអធិស្ឋានក្នុងជំពូកនេះបានឆ្លុះបញ្ចាំងពីទំនាក់ទំនងរបស់ព្រះមហាក្សត្រ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ក្នុងជំនាន់ដែលព្រះអង្គទ្រង់គ្រប់គ្រង ។ សូមមើលពីការពណ៌នារបស់ហោរាយេរេមាពីជំនួរវង្សចុងក្រោយក្នុង យរ ២២:២–៣ និងការថ្លែងទំនាយពីសេចក្ដីសុចរិតរបស់ព្រះមែស៊ីក្នុង អស ៩:៧ ១១:៤–៥ យរ ២៣:៥–៦ ៣៣:១៥–១៦ សក ៩:៩ ។ នៅក្នុងសម័យកាលក្រោយមកទៀតពួកយូដាបានប្រើបទគម្ពីរក្នុងជំពូកនេះ ដើម្បីថ្លែងពីព្រះមែស៊ី ហើយពួកជំនុំជំនាន់ដើមក៏ធ្វើការនេះដែរ ។ ៣ខចុងក្រោយនៃជំពូកនេះ មិនមែនជាសេចក្ដីអធិស្ឋានឡើយ (សូមមើលការពន្យល់ទីនេះ) ។

**៧២ត្រង់ចំណងជើង** *ទំនុករបស់សាឡូម៉ូន* នៅក្នុងឃ្លានេះចង់និយាយថា បទគម្ពីរទំនុកដំកើងក្នុងជំពូកនេះ គឺតែងឡើងដោយ សាឡូម៉ូន ឬក៏សម្រាប់ស្ដេចសាឡូម៉ូន ។ ពួកអ៊ីស្រាអែល (យូដា) ក៏បានប្រើទំនុកនេះក្នុងការអធិស្ឋានឱ្យជំនួរវង្សជំនាន់ក្រោយរបស់ដាវីឌផងដែរ ។

**៧២:១** នៅក្នុងខនេះ គឺជាគ្រឹះនៃសេចក្ដីអធិស្ឋាន ។ *បញ្ញាច្បាប់ . . . សេចក្ដីសុចរិត* នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យព្រះអម្ចាស់ទ្រង់បានផ្ដល់អំណោយទាន និងសេចក្ដីសប្បុរសរបស់ទ្រង់ និងសេចក្ដីស្មោះត្រង់របស់ទ្រង់ មកដល់រាស្ត្រទ្រង់ ដើម្បីឱ្យគេបានដឹងថា សម័យកាលនៃការគ្រប់គ្រងរបស់ទ្រង់គឺមកពីព្រះ ។ ស្ដេចសាឡូម៉ូនបានសូមប្រាជ្ញាមកពីព្រះអម្ចាស់ដូច្នេះហើយ ទើបធ្វើឱ្យទ្រង់អាចគ្រប់គ្រងលើរាស្ត្ររបស់ទ្រង់ដោយយុត្តិធម៌ (សូមមើល ១ពវ ៣:៩,១១–១២ សភ ១៦:១២) ។ *សេចក្ដីសុចរិត* សូមមើលការពន្យល់ ៤:១ ។

**៧២:២–៧** នៅក្នុងខទាំងនេះ គឺនិយាយពីកល្ពណៈសម្បត្តិនៃរាជរបស់ទ្រង់ សូមឱ្យទ្រង់បានគ្រប់គ្រងដោយសេចក្ដីសុចរិត ចម្រុងចម្រើន រុងរឿង និងគង់វង្ស ។

**៧២:៣** នៅក្នុងខនេះចង់និយាយថា សេចក្ដីសុចរិតរបស់ទ្រង់គឺដូចជាភ្លៀងដែលបានបង្អុរមកលើផែនដី ហើយព្រះយេហូវ៉ាទ្រង់នឹងប្រទានពរដល់រាស្ត្ររបស់ទ្រង់យ៉ាងច្រើនបរិបូរ (មើល ខ.៦–៧ ៥:១២ ៦៥:៩–១៣ ១៣៣:៣ លវ ២៥:១៩ ចទ ២៨:៨) ។

**៧២:៥** *អស់អំឡុងដែលនៅមានព្រះអាទិត្យភ្លឺតទៅ* សូមមើល ២១:៤ និងការពន្យល់ ។

**៧២:៦** សូមមើល ខ.៣ និងការពន្យល់ និងមើល ខ.៧ ។

**៧២:៧** *មនុស្សសុរិត* មីលការពន្យល់ ១:៥ ។ *សេចក្ដីចំរើន* គឺពីព្រះព្រះមហាក្សត្របានគាំទ្រ និងការពារពួកគេ ប៉ុន្តែព្រះអង្គបានប្រើអំណាចរបស់ទ្រង់ដើម្បីសង្កត់សង្កិនពួកមនុស្សអាក្រក់ (សូមមើល ទដ ១០១) ។

**៧២:៨–១៤** នៅក្នុងខនេះចង់និយាយថា អំណាចរបស់ទ្រង់ដែលមានពេញពាសផែនដី (ខ.៨–១៤) គឺជាលទ្ធផលនៃការគ្រប់គ្រងដែលប្រកបសុចរិត (សូមមើល ខ.១២–១៤) ។

**៧២:៨** នៅក្នុងខនេះចង់និយាយថា នគរនិងសិទ្ធអំណាចរបស់ទ្រង់ នឹងត្រូវ

សមុទ្រម្ខាង ហើយពីទន្លេ[ញ] រហូតដល់ទីបំផុតផែនដី[ដ]
៩ ឯពួកមនុស្សដែលអាស្រ័យនៅទីរហោស្ថាន
គេនឹងក្រាបចុះនៅចំពោះទ្រង់
ហើយពួកខ្មាំងសត្រូវរបស់ទ្រង់ នឹងក្រាបលិទ្ធធូលីដី
១០ ពួកក្សត្រនៃស្រុកតើស៊ីស[ឋ]
និងកោះទាំងប៉ុន្មាន[ឌ]នឹងថ្វាយសួយអាករ
ពួកក្សត្រនៃស្រុកសេបា[ឍ]
និងស្រុកសាបានឹងថ្វាយគ្រឿងបណ្ណាការដែរ[ណ]
១១ អើ ពួកក្សត្រទាំងអស់
នឹងផ្តួលខ្លួនក្រាបចុះ[ត]នៅចំពោះទ្រង់
ហើយអស់ទាំងនគរនឹងចំណុះ[ថ]ទ្រង់ដែរ
១២ ដ្បិតទ្រង់នឹងជួយពួកក្រីក្រឱ្យរួចក្នុងកាលដែលថ្លែងទុក្ខ
ព្រមទាំងពួកកំសត់ ដែលឥតមានអ្នកណាជួយនោះផង
១៣ ទ្រង់នឹងមានសេចក្តីអាណិតមេត្តា[ទ]ដល់មនុស្ស
រហេមរហាមនិងមនុស្សទុគ៌ត
ក៏នឹងជួយសង្គ្រោះជីវិតនៃមនុស្សក្រីក្រផង
១៤ ទ្រង់នឹងលោះ[ធ]ជីវិតគេ
ឱ្យរួចពីការសង្កត់សង្កិននឹងការច្រឡោត
ឯឈាមគេនឹងបានវិសេស[ន]នៅព្រះនេត្រទ្រង់ដែរ ។
១៥ ដូច្នេះ គេនឹងរស់នៅ
ហើយនិងមានដង្វាយជាមាសពីស្រុកសេបា[ប]
ឱ្យបានថ្វាយដល់ទ្រង់
មនុស្សទាំងឡាយនឹងអធិស្ឋានឱ្យទ្រង់ជានិច្ច
ហើយនិងថ្វាយពរដល់ទ្រង់ជាដរាបរាល់ថ្ងៃ[ផ]
១៦ ដូច្នេះ នឹងមានស្រូវ[ព]ជាបរិបូរនៅក្នុងស្រុករហូតដល់
កំពូលភ្នំ ឯគួរស្រូវ នោះនឹងទ្រេតចុះឡើង[ភ]
ដូចជាដើមឈើនៅភ្នំល្បាណូន[ម]
ហើយមនុស្សនឹងចំរើនឡើងនៅក្នុងទីក្រុង
ដូចជាស្មៅនៅដីដែរ[យ]
១៧ នាមទ្រង់នឹងស្ថិតស្ថេរនៅជាដរាប[រ]
គឺនឹងមាននៅអស់អំឡុងដែលនៅមានព្រះអាទិត្យភ្លឺតទៅ[ល]
ហើយមនុស្សទាំងឡាយនឹងបានពរដោយសារទ្រង់
អស់ទាំងសាសន៍នឹងហៅទ្រង់ថា ជាអ្នកមានពរ[វ] ។
១៨ សូមក្រាបថ្វាយបង្គំដល់ព្រះយេហូវ៉ាដ៏ជាព្រះ
គឺជាព្រះនៃសាសន៍អ៊ីស្រាអែល[ស]
ជាព្រះតែ១អង្គដែលធ្វើការអស្ចារ្យ[ហ]
១៩ សូមឱ្យព្រះនាម[ឡ]ដ៏រុងរឿងរបស់ទ្រង់បានប្រកបដោយ
ព្រះពរនៅអស់កល្បជានិច្ច
សូមឱ្យផែនដីទាំងស្រុងបានពេញដោយសិរីល្អ[អ]នៃទ្រង់
អាម៉ែន[ក] ។
២០ ពាក្យអធិស្ឋានរបស់ដាវីឌ
ជាបុត្រអ៊ីសាយ[ខ] ចប់តែប៉ុណ្ណេះ ។

**៧២:៨** ញ នក ២៣:៣១ ១ពវ ៤:២១ ដ សក ៩:១០ **៧២:១០** ឋ លប ១០:៤ ឌ នអ ១០:១ ឍ លប ១០:៧ ណ ១ពវ ៩:១៦ ២របា ៩:២៤ **៧២:១១** ត លប ២៧:២៩ ថ អរ ១:២ **៧២:១៣** ទ អស ៦០:១០ យអ ២:១៨ លក ១០:៣៣ **៧២:១៤** ធ ទដ ៦៩:១៨ អគ ១៣:២៣ ៣៤:១០ ន ១សយ ២៦:២១ **៧២:១១** ត លប ២៧:២៩ ថ អរ ១:២ **៧២:១៣** ទ អស ៦០:១០ យអ ២:១៨ លក ១០:៣៣ **៧២:១៤** ធ ទដ ៦៩:១៨ អគ ១៣:២៣ ៣៤:១០ ន ១សយ ២៦:២១ **៧២:១៥** ប លប ១០:៧ ផ ទដ ៣៥:២៨ **៧២:១៦** ប លប ២៧:២៨ ទដ ៤:៧ ភ អស ៤:២ ២៧:៦ អគ ៣៤:២៧ ម ទដ ៩២:១២ ១០៤:១៦ យ ជន ២២:៤ អស ៤៤:៤ ៥៨:១១ ៦៦:១៤ **៧២:១៧** រ នក ៣:១៥ ល ទដ ៨៩:៣៦ វ លប ១២:៣ លក ១:៤៨ **៧២:១៨** ស ១របា ២៩:១០ ទដ ៤១:១៣ ១០៦:៤៨ លក ១:៦៨ ហ យប ៥:៩ **៧២:១៩** ឡ ២សយ ៧:២៦ អ ជន ១៤:២១ ក ទដ ៤១:១៣ **៧២:២០** ខ នរ ៤:១៧

ប៉ែកទី៣

ទំនុករបស់អេសាភ ។

## ៧៣ ប្រាកដមែន ព្រះទ្រង់ប្រព្រឹត្តល្អដល់សាសន៍

បានផ្សព្វផ្សាយពេញពាសផែនដីទាំងមូល (សូមមើល ខ.៩–១១ ហើយផ្ទៀបជាមួយ ១១០:២ និងការពន្យល់) ។ គំនិត និងសក្តានុភាពនៃអំណាចគ្រប់គ្រងរបស់ព្រះនៅលើផែនដី ។

**៧២:៩** *លិទ្ធធូលីដី* សូមមើល មីក ៧:១៧ និងការពន្យល់ ។

**៧២:១០** នៅក្នុងខនេះចង់និយាយថា បណ្តាក្សត្រទាំងប៉ុន្មានដែលនៅជាប់ព្រំប្រទល់នៃសមុទ្រមេឌីទែរ៉ាណេ រហូតដល់ភាគខាងលិចគេនឹងទទួលស្គាល់ព្រះអង្គ (បុត្រដាវីឌ) ថាជាអធិរាជដែលនឹងគ្រប់គ្រងនៅភាគខាងត្បូង រហូតដល់ភាគខាងជើងនៃកោះនៅប្រទេសអាហ្វ្រិច ។ *ស្រុកតើស៊ីស* ស្រុកនេះមានចម្ងាយយ៉ាងឆ្ងាយ ពីកំពង់ផែសមុទ្រមេឌីទែរ៉ាណេ គឺមានចម្ងាយឆ្ងាយដូចគ្នានឹងពីប្រទេសអេស្ប៉ាញដែរ ។ *ស្រុកសេបា* មើលការពន្យល់ លប ១០:២៨ ១ពវ ១០:១ យអ ៣:៨ ។ *ស្រុកសេបា* ពាក្យនេះនៅក្នុងសញ្ញាចាស់គឺមានទំនាក់ទំនងជាមួយគូស (សូមមើល លប ១០:៧ អស ៤៣:៣) ហើយពាក្យប្រហែលនិយាយសំដៅលើតំបន់ស៊ូដង់សម័យទំនើប នៅភាគខាងត្បូងនៃប្រទេសអេស៊ីព្ទ ។

**៧២:១៥–១៧** នៅក្នុងខទាំងនេះគឺជាសេចក្តីបញ្ចប់ : សូមឱ្យព្រះមហាក្សត្រទ្រង់មានអាយុយឺនយូរ ចុំចំរើង ដើម្បីឱ្យប្រជាជាតិទាំងប៉ុន្មានបានព្រះពរ ។

**៧២:១៧** *មនុស្សទាំងឡាយ* ភាសាដែលប្រើនៅកន្លែងនេះ បានរំឭកឱ្យឃើញពីសេចក្តីសញ្ញាដែលបានសន្យាជាមួយលោកអ័ប្រាហាំ (សូមមើល លប ១២:៣ ២២:១៨) ហើយការនេះត្រូវបានសំរេចតាមរយៈរាជដាវីឌ ។

**៧២:១៨–១៩** នៅក្នុងខទាំងនេះ គឺជាបទចម្រៀងនៃសេចក្តីបញ្ចប់ក្នុងប៉ែកទី២នៃបទគម្ពីរទំនុកដំកើង (សូមមើល ទដ ៤១:១៣ និងការពន្យល់) ។ ទំនួលខុសត្រូវរបស់ពួកបណ្តាត្រូវនិយាយថា "អាម៉ែន" ហើយពាក្យនេះផងដែរគឺជាបរិបទទាំងមូលនៅក្នុងប៉ែកទី២ (សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង) ។

**៧២:១៩** *ពេញដោយសិរីល្អនៃទ្រង់* សូមមើលការពន្យល់ ទដ ៨៥:៩ ។

**៧២:២០** *ពាក្យអធិស្ឋានរបស់ដាវីឌ* សូមមើលក្នុង ទដ ៨៦,១៤២ ត្រង់ចំណងជើង ។

**ទដ ៧៣–៧៨** នៅក្នុងបទគម្ពីរទំនុកដំកើងប៉ែកទី៣នេះ គឺបានកើតឡើងដោយការបណ្តុំគ្នារវាងទំនុកដំកើង៣ក្រុម ហើយសមប្បមាណទាំងមូល (ទាំង៣ក្រុម) ចែកចេញជា : ៦ជំពូក (៧៣–៧៨) ៥ជំពូក (៧៩–៨៣)

អ៊ីស្រាអែល គឺដល់អស់អ្នកដែលមានចិត្តត្រចះ[ក]
២ តែឯជើងទូលបង្គំ បានកន្ទ្រែកចេញហៀបនឹងផុតទីហើយ[ខ]
ជំហាននៃទូលបង្គំបានហៀបនឹងរឥលភ្លាត់ទៅ[គ]
៣ ដ្បិតទូលបង្គំមានសេចក្តីច្រណែន[ឃ] ចំពោះមនុស្សអំនួត
ដោយឃើញសេចក្តីចំរើនរបស់មនុស្សអាក្រក់នោះ[ង]
៤ ពីព្រោះកាលគេស្លាប់ នោះគ្មានឈឺចាប់អ្វីសោះ
គឺកំឡាំងគេនៅតែមាំមួនដដែល
៥ គេមិនមានទុក្ខ[ច] ដូចជាមនុស្សធម្មតាឡើយ
ក៏មិនត្រូវវេទនា ដូចមនុស្សដទៃដែរ

**៧៣:១** ក ទដ ២៤:៤ មថ ៥:៨ **៧៣:២** ខ ទដ ៦៩:២ អភ ៤:២៧ គ ចទ ៣២:៣៥ **៧៣:៣** ឃ សភ ៣:៣១ ២៣:១៧ ២៤:១–២ ង យប ៩:២៤ ២១:៧ យរ ១២:១ មឡ ៣:១៥ **៧៣:៥** ច ខ.១២ អគ ២៣:៤២

៦ជំពូក (៨៤–៨៩) ហើយក្នុងនោះជំពូក ៨១ គឺជាជំពូកស្នូលនៃគម្ពីរទំនុកដំកើងក្នុងប៉ែកទី៣ ដែលបាននិយាយពីការដាស់តឿនទូន្មានសំខាន់ៗដែលមាននៅក្នុងសេចក្តីសញ្ញាចំពោះព្រះយេហូវ៉ា (សូមមើលសេចក្តីផ្តើម ទដ ៧៩–៨៣ សេចក្តីផ្តើម ទដ ៨៤–៨៩ និងសេចក្តីផ្តើម ទដ ៨១) ។ ក្នុងវគ្គទី១នៃប៉ែកទី៣នេះបានបង្ហាញច្បាស់ តាមរយៈសេចក្តីផ្តើមដែលមាននៅក្នុងទំនុកដំកើងទាំងនោះ ។ ជំពូក៧៣ គឺជាពាក្យសម្តីប្រកបដោយគតិបណ្ឌិតរបស់អ្នកសំណប់ព្រះ ផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន ហើយទដ ជំពូក ៧៨ គឺជាទំនុកដំកើង នៃសេចក្តីបង្រៀនដោយផ្អែកលើការរួបរួមរបស់អ៊ីស្រាអែល ដែលមាននៅក្នុងប្រវត្តិសាស្ត្រ ។ នៅក្នុង ទដ ៧៤ (សេចក្តីអធិស្ឋានរបស់បណ្តាជន) គឺមានទំនាក់ទំនងជាមួយ ទដ ៧៧ (អធិស្ឋានផ្ទាល់ខ្លួន) ដោយសារបទ គម្ពីរទាំង២ជំពូកនេះនិយាយពីបទពិសោធន៍ ដ៏សាមញ្ញមួយដែលហាក់ដូចជាចង់និយាយថា ព្រះបានបោះបង់ចោលពួកគេ (សូមមើល ៧៤:១ ៧៧:៧) និងតាមរយៈការរំឭកពីសេចក្តីសង្គ្រោះ របស់ព្រះអម្ចាស់ចំពោះអ៊ីស្រាអែលឱ្យចេញពីស្រុកអេស៊ីព្ទ (សូមមើល ៧៤:១៣–១៥ ៧៧:១៦–១៩) ។ ចំណុចកណ្តាលវគ្គទី១ប៉ែកទី៣នេះ គេសង្កេតឃើញថា មានទំនុកដំកើង២ជំពូក (៧៥,៧៦) បានពណ៌នាពីសេចក្តីអំណរ ដោយព្រោះព្រះនៃពួកអ៊ីស្រាអែល (ព្រះនាមរបស់ទ្រង់) "ស្ថិតនៅជិត ៧៥:១" ព្រះនាមទ្រង់ក៏ធំនៅក្នុងសាសន៍អ៊ីស្រាអែល ៧៦:១ បានហៅមនុស្សអាក្រក់មកដើម្បីជំនុំជំរះ ហើយព្រះអម្ចាស់ ទ្រង់នឹងកាត់ "ស្នែង" របស់ពួកមនុស្សអាក្រក់ចេញ (សូមមើល ទដ ៧៥:១០) និងកាត់ "វិញ្ញាណអ្នកត្រកូលខ្ពស់" ចេញ (សូមមើល ៧៦:១២)។

**ទដ ៧៣** នេះគឺជាពាក្យសម្តី ដែលប្រកបដោយគតិបណ្ឌិតរបស់អ្នកសំណប់ព្រះ ដែលនិយាយទាក់ទងទៅនឹងជោគវាសនារបស់មនុស្សសុចរិត និងមនុស្សកំណាច (សូមមើលសេចក្តីផ្តើម ទដ ៧៣–៧៨) ។ បទគម្ពីរជំពូកនេះជាកិច្ច ចាប់ផ្តើមប៉ែកទី៣នៃគម្ពីរទំនុកដំកើង ដែលនិយាយពីសេចក្តីជំនឿ (សារភាពនៅ ខ.១ សាកល្បង ខ.២–២៦ និងការអះអាងឡើងវិញ ខ.២៧–២៨) ។ បទគម្ពីរទដ ៧៣ ដែលស្ថិតនៅក្នុងប៉ែកទី៣នេះ គឺមានលក្ខណៈដូចគ្នានឹង ទដ ១–២ ដែលស្ថិតនៅក្នុងប៉ែកទី១ដែរ (មើលក្នុងសេចក្តីផ្តើម ទដ ១–២) ។ នៅទីនេះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបានពណ៌នាពីបញ្ហាដ៏រំខានមួយ ក្នុងចំណោមបញ្ហាជាច្រើន ដែលមាននៅក្នុងសញ្ញាចាស់ : តើពួកមនុស្សអាក្រក់គេបានរីកចំរើនប៉ុន្មាននៅគ្រាដែលអ្នកសំណប់ព្រះជួបបញ្ហា ។ ផ្ទៃរឿងក្នុងជំពូកនេះ គឺមានទំនាក់ទំនងច្រើនជាមួយ ទដ ៤៩ (មើលក្នុងសេចក្តីផ្តើមទំនុកដំកើង និង ទដ ៣៧) ។ ផ្ទៃរឿងក្នុងជំពូកនេះបានបែងចែកជា២ផ្នែកស្មើៗគ្នា មានផ្នែកនិមួយៗមាន ១៤ខ ។

**៧៣ ត្រង់ចំណងជើង** ក្នុងជំពូកនេះគឺជាទំនុករបស់អេសាភ ជាអ្នកដឹកនាំចម្រៀងម្នាក់ ក្នុងចំណោមអ្នកដឹកនាំចម្រៀងទាំង៣ដែលចេញពីលេវី (២នាក់ទៀតគឺ ហេម៉ាន យេឌូថិន ពួកគេទាំង៣នាក់ គឺជាអ្នកដែលតំណាងឱ្យគ្រួសារពួកលេវី មើលការពន្យល់ ទដ ៣៩,៤២,៥០ ត្រង់ចំណងជើង) ។ នៅក្នុងប៉ែកទី៣នេះ បានចាប់ផ្តើមដោយការជ្រើសបទចម្រៀង ដែលជាការតែងឡើងដោយអេសាភចំនួន១១ (ទដ ៧៣–៨៣) ហើយ ទដ ៥0 ក៏ប្រហែលជាការតែងឡើងដោយអេសាភដែរ ។ ការជ្រើសរើសនេះបានបង្ហាញយ៉ាងច្បាស់ ដោយបានភ្ជាប់មកជាមួយនឹងសេចក្តីអធិស្ឋាននៅក្នុងជំពូកបន្ទាប់ទៀត (ដូចជា ទដ ៧៤ ៧៩ ៨៣) ដែលបានបង្ហាញនៅចំណងជើងថា ជាការតែងឡើងដោយអេសាភ ហើយពេលខ្លះទៀតជាកូនចៅរបស់អេសាភ ដែលជាអ្នកធ្វើការជំនួសអេសាភជាឪពុក (មើលការពន្យល់ ទដ ៥0 ត្រង់ចំណងជើង) ។ ទំនុកដំកើងដែលសរសេរឡើង ដោយកូនចៅអេសាភ គឺសង្កត់ធ្ងន់លើការគ្រប់គ្រងរបស់ព្រះ លើប្រជារាស្ត្ររបស់ទ្រង់ និងលើប្រជាជាតិទាំងមូល ។ ក្រៅពីសេចក្តីបង្រៀនដែលមាននៅក្នុងសេចក្តីផ្តើម (ទដ ៧៣) នោះគេបានឃើញថា សេចក្តីអធិស្ឋានសូមឱ្យព្រះអម្ចាស់ ទ្រង់បានជួយសង្គ្រោះរាស្ត្រទ្រង់ឱ្យរួចពីសាសន៍ដទៃ (មើល ទដ ៧៤,៨៣) បានកាត់ផ្តាច់ទំនុកដំកើងក្នុងប៉ែកទី៣នេះចេញពីក្រុម ។ ចុងបញ្ចប់នៃក្រុមទំនុកដំកើងក្នុងប៉ែកទី៣នេះ (ទដ ៧៥–៨២) បានឆ្លុះបញ្ចាំងពីផ្ទៃរឿងចំនួន២គូគឺ (១).ព្រះដែលបានបំផ្លាញការរបស់ពួកមនុស្សអាក្រក់ និងជាអ្នកដែលលើកតាំងពួកអ្នកសុចរិត (ទដ ៧៥) គឺជាព្រះដែលបានសង្គ្រោះ និងជាព្រះអម្ចាស់របស់ពួកអ៊ីស្រាអែល (មើល ទដ ៧៦) (២).រំឭកឱ្យឃើញពីសេចក្តីសង្គ្រោះរបស់ព្រះ ចំពោះរាស្ត្ររបស់ទ្រង់ (មើល ទដ ៧៧–៧៨) (៣).អ្នកនិពន្ធបានអំពាវនាវដល់ព្រះយេហូវ៉ា សូមឱ្យព្រះអង្គបានទាស់ប្រឆាំងដល់ពួកខ្មាំងសត្រូវរបស់ពួកអ៊ីស្រាអែល (៤).ព្រះអម្ចាស់ទ្រង់ជាចៅហ្វាយលើចៅក្រម ក្នុងការជំនុំជម្រះរាស្ត្រទ្រង់ (ទដ ៨១) និងលើអំណាចនៅក្នុងលោកិយ (ទដ ៨២) ។ ភាពជាគូ នៃទំនុកដំកើងនេះគឺជាការពិតដែលមាននៅក្នុងទំនុកដំកើងដែលអេសាភ បានតែងឡើង (សូមមើលក្នុងសេចក្តីផ្តើម ទដ ៧៣– ៧៨) ។

**៧៣:១–១៤** នៅក្នុងខទាំងនេះ គឺនិយាយពីការពិសោធមើលពីសេចក្តីជំនឿ ។ នៅក្នុងចំណោមរាល់ទាំងអស់នៃសេចក្តីទុក្ខលំបាកនោះ ពួកអ៊ីស្រាអែលបានបណ្តាលឱ្យភ្នែករបស់ពួកគេ សម្លឹងមើលភាពរុងរឿងរបស់ពួកមនុស្សអាក្រក់វិញ ។

**៧៣:១** *ចិត្តត្រចះ* មើល ខ.១៣ និងការពន្យល់ ២៤:៤ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៧៣:២** *តែឯជើងទូលបង្គំ បានកន្ទ្រែកចេញហៀបនឹងផុតហើយ* នៅក្នុងឃ្លានេះ គឺចង់និយាយសំដៅលើការហៀបនឹងចេញផុតពីផ្លូវនៃសេចក្តីពិត និងងាកចេញពីការស្រឡាញ់ដល់ព្រះ (មើល ៣៧:៣១ និងការពន្យល់) ។

**៧៣:៤–១២** នៅក្នុងខទាំងនេះ គឺពណ៌នាពីភាពរីកចម្រើនរបស់ពួកមនុស្សអាក្រក់ និងភាពក្រអឺតក្រទម ដោយការពឹងលើខ្លួនឯង ដូចជាពឹងលើការរីកចម្រើនរបស់ខ្លួន ។

៦ហេតុនោះបានជាសេចក្ដីអំនួត[ឆ]របស់គេប្រៀបដូចជាខ្សែ
ច្រវាក់[ជ]ពាក់នៅក ហើយគេប្រដាប់ខ្លួន
ដោយសេចក្ដីច្រឡោត[ឈ]
៧ភ្នែកគេលៀនចេញ ដោយមានសាច់ច្រើន
គេមានច្រើនលើសជាងចិត្ត[ញ]ប្រាថ្នាទៅទៀត
៨គេចំអកឡកឡឺយ[ដ] ហើយពោលជាការគំហកកំហែង[ឋ]
ដោយចិត្តអាក្រក់ ក៏និយាយដោយពាក្យធំខ្ពស់[ឌ]
៩គេតាំងមាត់ពោលទាស់នឹងស្ថានសួគ៌
ហើយអណ្ដាតគេបង្ហិលទៅមកពេញលើផែនដី ។
១០ហេតុនោះបានជារាស្ត្ររបស់ទ្រង់វិលមកឯណេះ
ក៏ផឹកសំរេងទឹកដែលពេញពែងផង
១១គេសួរថា ធ្វើដូចម្ដេចឱ្យព្រះជ្រាបបាន
តើព្រះដ៏ខ្ពស់បំផុតទ្រង់ប្រកបដោយដំរិះដែរឬ
១២នេះហើយដែលហៅថាមនុស្សអាក្រក់
ហើយដោយព្រោះ គេចេះតែនៅដោយសុខស្រួល[ឍ]
បានជាទ្រព្យសម្បត្តិគេចំរើនឡើង[ណ]
១៣យ៉ាងនោះ ការដែលទូលបង្គំបានជំរះចិត្ត
ហើយលាងដៃឱ្យឥតមានសៅហ្មង[ត]នោះឥតប្រយោជន៍
ទទេ[ថ]
១៤ដ្បិតទូលបង្គំត្រូវរងវិពាត់ជាដរាបរាល់ថ្ងៃ[ទ]
ហើយត្រូវវាយផ្ចាលរាល់តែព្រឹកជានិច្ច ។
១៥បើសិនជាទូលបង្គំបានពោលថា
អញនឹងនិយាយដូច្នេះដែរ
នោះឈ្មោះថាបានក្បត់ពូជពង្សនៃកូនចៅទ្រង់ហើយ
១៦កាលទូលបង្គំបានពិចារណាដើម្បីចង់ដឹង[ធ]ច្បាស់ពី
សេចក្ដីនេះ នោះក៏ពិបាកដល់ទូលបង្គំណាស់
១៧ទាល់តែទូលបង្គំបានចូលទៅក្នុងទីបរិសុទ្ធ[ន]របស់ព្រះ
ហើយបានពិចារណាពីចុងបំផុតរបស់គេ[ប]
១៨ពិតប្រាកដជាទ្រង់ឱ្យគេឈរនៅកន្លែងដ៏រអិល[ផ]
ទ្រង់ក៏បោះគេចុះទៅឱ្យត្រូវហិនវិនាស[ព]
១៩យីអើ គេត្រូវអន្តរធានទៅជាឆាប់អីម្ល៉េះ[ភ]
គេត្រូវសាបសូន្យទៅ[ម] ដោយហេតុគួរស្ញែងខ្លាច
២០នេះបែបដូចជាកាលណាយល់សប្តិ[យ]រួចភ្ញាក់ឡើង[រ]
ឱព្រះអម្ចាស់អើយ
កាលណាទ្រង់តើនឡើង នោះទ្រង់នឹងតោះតើយ
ចំពោះរូបគេដែរ[ល] ។
២១ដូច្នេះ កាលទូលបង្គំមានសេចក្ដីកំរើកក្នុងចិត្ត
ហើយមានសេចក្ដីចាក់ចុចក្នុងថ្លើម
២២នោះទូលបង្គំជាមនុស្សឆោត[វ] ហើយល្ងង់ខ្លៅ
គឺទូលបង្គំដូចជាសត្វតិរច្ឆាន[ស]នៅចំពោះទ្រង់

**៧៣:៦** ឆ លវ ២៦:១៩ ជ លប ៤១:៤២ ៤:៩ អគ ១៦:១១ ឈ លប ៦:១១ សភ ៤:១៧ **៧៣:៧** ញ ទដ ១៧:១០ **៧៣:៨** ដ ទដ ៤១:៥ អគ ២៥:១៥ កល ៣:៨ ឋ ទដ ១០:៧ ១២:៥ ឌ ទដ ១៧:១០ **៧៣:១២** ឍ ខ.៥ ណ ទដ ៤៩:៦ **៧៣:១៣** ត លប ៤៤:១៦ ថ យប ៩:២៩-៣១ ២១:១៥ **៧៣:១៤** ទ ខ.៥ **៧៣:១៦** ធ សស ៨:១៧ **៧៣:១៧** ន នក ១៥:១៧ ទដ ១៥:១ ប យប ៨:១៣ ភល ៣:១៩ **៧៣:១៨** ផ ចទ ៣២:៣៥ សភ ៣៥:៦ ព ទដ ១៧:១៣ **៧៣:១៩** ភ ចទ ២៨:២០ សភ ២៤:២២ អស ៤៧:១១ ម លប ១៩:១៥ **៧៣:២០** យ យប ២០:៨ រ ទដ ៧៨:៦៥ អស ២៩:៨ ល សភ ១២:១១ ២៨:១៩ **៧៣:២២** វ ទដ ៤៩:១០ ៩២:៦ ៩៤:៨ ស ទដ ៤៩:១២,២០ សស ៣:១៨ ៩:១២

**៧៣:៦** *សេចក្ដីអំណួតរបស់គេប្រៀបដូចជាខ្សែច្រវាក់ពាក់នៅក* នៅក្នុងឃ្លានេះវាផ្ទុយគ្នានឹងអ្វីដែលបានពណ៌នានៅក្នុង សភ ១:៩ ៣:៣,២២ ។ *ប្រដាប់ខ្លួនដោយ* មើលការពន្យល់ ១០៩:២៩ ។

**៧៣:១១** *គេសួរថា* ពួកគេមិនត្រឹមតែនិយាយប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងប្រព្រឹត្តទៀតផង ដោយបង្ហាញពីការដែលពួកគេ "រស់នៅឆ្ងាយពីទ្រង់" (សូមមើល ខ.២៧) ។ *ព្រះដ៏ខ្ពស់បំផុត* គឺចង់និយាយថា ព្រះយេហូវ៉ាគឺជាព្រះដ៏ខ្ពស់បំផុត (សូមមើល ៥៧:២ និងការពន្យល់ ៣:៧) ។ *ខ្ពស់បំផុត* សូមមើលការពន្យល់ លប ១៤:១៩ ។

**៧៣:១៣-១៤** នៅក្នុងឃ្លានេះចង់និយាយថា គំនិតដែលបំពុលដល់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង ក្នុងគ្រាដែលគាត់ប្រៀបធៀបពីការរីកចម្រើនរបស់ពួកមនុស្សអាក្រក់ ជាមួយបញ្ហាដែលគាត់មាន ។

**៧៣:១៣** *ជំរះចិត្ត* សូមមើលការពន្យល់ ខ.១ ។

**៧៣:១៤** *វាយផ្ចាល* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា ព្រះយេហូវ៉ាទ្រង់បានវាយផ្ចាលគាត់ ដូចគ្នានឹងឪពុកម្ដាយដែលវាយផ្ចាលកូនដើម្បីឱ្យកូនដើរតាមគន្លងផ្លូវល្អត្រឹមត្រូវ (មើល សភ ៣:១២ ២៣:១៣-១៤) ។

**៧៣:១៥-២៨** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអះអាងជាថ្មីពីសេចក្ដីជំនឿរបស់គាត់ ។ នៅក្នុងព្រះវិហារជាកន្លែងដែលគេតែងតែបង្រៀនពីព្រះនោះបានធ្វើឱ្យអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គាត់បានឃើញពីការដែលព្រះយេហូវ៉ាបានកំណត់វាសនាដល់ពួកមនុស្សកំណាចអាក្រក់ ។

**៧៣:១៥** *បើសិនជាទូលបង្គំបានពោលថា* នៅក្នុងឃ្លានេះគឺចង់និយាយថា បើសិនជាអ្នកនិពន្ធបានពណ៌នាជាសាធារណៈ ពីបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ឱ្យគេកាន់តែយល់ច្បាស់ ។ *កូនចៅ* គឺជាអ្នកដែលមានការបន្ទាបខ្លួន និងប្ដេជ្ញាដើរតាមព្រះយេហូវ៉ា ។

**៧៣:១៨-២០** នៅក្នុងឃ្លានេះចង់និយាយថា ទោះបីជាពួកមនុស្សអាក្រក់មើលទៅហាក់បីដូចជាចម្រើនរុងរឿងក៏ដោយ តែព្រះយេហូវ៉ាទ្រង់នឹងដកហូតតួនាទី និងអ្វីដែលពួកគេមាន ។ ព្រះអម្ចាស់ទ្រង់មិនបានតាស់តឿនពួកគេឡើយ គឺធ្វើឱ្យពួកគេត្រូវបក់ផាត់ទៅឆ្ងាយ ។ នៅទីនេះអ្នកនិពន្ធមិនបានផ្ដោត ឬឆ្លុះបញ្ចាំងពីទីកន្លែងដែលគេត្រូវទៅបន្ទាប់ពីស្លាប់នោះឡើយ ប៉ុន្តែគាត់ចង់និយាយថា ព្រះយេហូវ៉ាទ្រង់នឹងបោះពួកមនុស្សអាក្រក់ចោលចេញពីអំណួតនៃការរីកចម្រើនរបស់ពួកគេ (មើល ទដ ៤៩ ហើយធៀបជាមួយ ទីកន្លែងចុងក្រោយរបស់ពួកមនុស្សសុចរិតនៅក្នុង ខ.២៤) ។

**៧៣:២០** នៅពេលដែលព្រះអង្គទ្រង់ក្រោពីដំណេក (មើលការពន្យល់ ៧:៦) នោះព្រះអម្ចាស់ ទ្រង់ក៏ចាប់ផ្ដើមមានទំនាក់ទំនងជាមួយមនុស្សអាក្រក់ពួកគេនឹងរលាយបាត់ ដូចគ្នានឹងស្រមោលក្នុងសុបិន្តនិមិត្តដែរ ។

**៧៣:២១** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**៧៣:២២** *ទូលបង្គំដូចជាសត្វតិរច្ឆាននៅចំពោះទ្រង់* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា នៅចំពោះព្រះអង្គនោះគាត់គ្រាន់តែជាមនុស្សម្នាក់ដែលល្ងីល្ងើរដូចនឹងតិរច្ឆានដែរ (មើល យប ១៨:៣) ។

២៣ ប៉ុន្តែទូលបង្គំនៅជាប់នឹងទ្រង់ជានិច្ច
ទ្រង់បានកាន់ដៃស្តាំនៃទូលបង្គំ[ហ]
២៤ ទ្រង់នឹងនាំ[ឡ]ទូលបង្គំ ដោយដំបូន្មានរបស់ទ្រង់[អ]
រួចនឹងទទួលទូលបង្គំចូលក្នុងសិរីល្អ
២៥ ឯនៅស្ថានសួគ៌ តើទូលបង្គំមានអ្នកឯណាក្រៅពីទ្រង់[ក]
ហើយនៅផែនដីទូលបង្គំប្រាថ្នាចង់បានតែទ្រង់ទេ[ខ]
២៦ ឯសាច់ និងចិត្ត[គ]ទូលបង្គំ នោះនឹងសាបសូន្យទៅបាន[ឃ]
ប៉ុន្តែ ព្រះទ្រង់ជាទីពឹង[ង]នៃចិត្ត
ហើយជាចំណែកមរដក[ច]នៃទូលបង្គំជាដរាបដែរ ។
២៧ ដ្បិតមើល អស់អ្នកដែលនៅឆ្ងាយពីទ្រង់
គេនឹងត្រូវវិនាស[ឆ]
ទ្រង់បំផ្លាញអស់អ្នកដែលផិត[ជ]ចេញពីទ្រង់
២៨ ឯទូលបង្គំ ដែលទូលបង្គំចូលទៅជិតព្រះនោះជាការល្អ
ដល់ទូលបង្គំ[ឈ]ទូលបង្គំបានយកព្រះអម្ចាស់យេហូវ៉ាទុក
ជាទីពឹង[ញ]ហើយ ដើម្បីឱ្យបានថ្លែងប្រាប់ពីអស់ទាំងការ
របស់ទ្រង់[ដ] ។

**៧៣:២៣** ហ លប ៤២:១៣ **៧៣:២៤** ឡ ទដ ៤៣:១៤ អ ១ពវ ២២:៥ **៧៣:២៥** ក ទដ ១៦:២ ខ ភល ៣:៨ **៧៣:២៦** គ ទដ ៨៤:២ ឃ ទដ ៣១:១០ ៤០:១២ ង ទដ ១៨:១ ច ចទ ៣២:៩ **៧៣:២៧** ឆ ទដ ៣៤:២១ ជ លវ ៦:២ យរ ៥:១១ ហស ៤:១២ ៩:១
**៧៣:២៨** ឈ សផ ៣:២ ហព ១០:២២ យក ៤:៨ ញ ទដ ៩:៩ ដ ទដ ២៦:៧ ៤០:៥ **៧៤:១** ក ទដ ៤២:២ ខ ទដ ៤៤:២៣ គ ទដ ៧៩:១៣ ៩៥:៧ ១០០:៣

ទំនុកជាសេចក្តីបង្រៀនរបស់អេសាភ ។

**៧៤** ឱព្រះអង្គអើយ ហេតុអ្វីបានជាទ្រង់បោះបង់ចោល[ក]
យើងខ្ញុំជាដរាប[ខ]
ហេតុអ្វីបានជាសេចក្តីខ្ញាល់របស់ទ្រង់ហុយផ្សែងឡើង
ទាស់នឹងហ្វូងចៀមដែលនៅទីវាលរបស់ទ្រង់ដូច្នេះ[គ]

**៧៣:២៣–២៦** នៅក្នុងខនេះចង់និយាយថា ទោះបីជាអ្នកនិពន្ធស្ទើរតែធ្លាក់ខ្លួនជាអ្នកខ្លៅល្ងង់យ៉ាងណាក៏ដោយ ក៏ព្រះអម្ចាស់ទ្រង់មិនបណ្តោយឱ្យគាត់មានបញ្ហាបែបនេះរហូតឡើយ ។

**៧៣:២៤** នៅក្នុងខនេះចង់និយាយថា ដោយសារដំបូន្មានរបស់ព្រះដែលឈ្នះលើសេចក្តីល្ងង់ខ្លៅរបស់គេ នោះនឹងនាំឱ្យផុតពីអន្លង់នៃគ្រោះថ្នាក់ទាំងឡាយដែលមាននៅក្នុងជីវិត (មើល ១៦:៧ ៣២:៨ ១០៧:១១) ។ *ទូលបង្គំនឹងចូលក្នុងសិរីល្អ* សិរីល្អនឹងនៅជាប់មួយជីវិតនៃអ្នកជឿគ្រប់រូប (មើល ៤៩:១៥ និងការពន្យល់) ។

**៧៣:២៥** នៅក្នុងខនេះអ្នកនិពន្ធចង់និយាយថា ទោះជាគាត់ធ្លាប់ច្រណែននឹងមនុស្សអាក្រក់ក៏ដោយ តែពេលនេះគាត់ទទួលស្គាល់ថា គ្មានអ្វីដែលប្រសើរជាងមានព្រះឡើយ ។

**៧៣:២៦** *ឯសាច់ និងចិត្តទូលបង្គំ* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយសំដៅលើរូបកាយទាំងមូល (មើល ៨៤:២) ។ *ចិត្ត* មើលការពន្យល់ក្នុង ៤:៧ ។ *ចំណែកមរដក* ដោយព្រោះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងជាពួកលេវី ហើយព្រះយេហូវ៉ាគឺជាចំណែកមរដកនៅក្នុងទឹកដីសន្យា ការនេះចង់មានន័យថា គាត់រស់នៅគឺដោយពឹងផ្អែកលើដង្វាយ១០ហូត១របស់ពួកបណ្តាជន ដែលគេថ្វាយទៅចំពោះព្រះយេហូវ៉ា (មើល ជន ១៨:២១–២៤ ចទ ១០:៩ ១៨:១–២) ។ នៅទីនេះអ្នកនិពន្ធបានសារភាពទៅចំពោះព្រះពីការដែលគាត់ស្រឡាញ់ព្រះលើសពីពួកអ៊ីស្រាអែល ធ្វើទៅទៀតដ្បិតគាត់បាននិយាយថា ព្រះយេហូវ៉ាទ្រង់បានរ៉ាប់រ៉ង និងការពារជីវិតដល់ពួកអ្នកដែលទុកចិត្តទ្រង់ (មើលការពន្យល់ ១៦:៥–៦) ។

**៧៣:២៧–២៨** សូមមើល ៣៤:២១–២២ ៣៧:១៨–២០ សភ ២៤:១៦ ។

**៣៧:២៧** *អស់អ្នកដែលនៅឆ្ងាយពីទ្រង់* តាមភាសាអក្សរសាស្ត្រគឺ "ពួកអ្នកដែលប្រព្រឹត្តសេចក្តីកំផិត/សាហាយស្មន់" ។ នៅកន្លែងផ្សេងទៀតអ្នកនិពន្ធបាននិយាយសំដៅលើសេចក្តីកំផិត ដែលបើកចំហរ (ដូចជានិយាយនៅ ចទ ៣១:១៦ យរ ២:២០ ហស ២:៥ និងមើលការពន្យល់ទីនោះ) ឬនិយាយសំដៅលើសម្ព័ន្ធមិត្ត នៃគោលនយោបាយនៃអំណាចលោកិយជាជាងការដែលពឹងពាក់ស្នាក់អាស្រ័យលើព្រះ (មើល អគ ១៦:២៦–២៩) ។ ទីនេះអ្នកនិពន្ធបាននិយាយពីការ ដែលពួកមនុស្សអាក្រក់គេពឹងពាក់លើទ្រព្យសម្បត្តិរបស់គេ ដែលបានមកដោយសារការជញ្ជក់ឈាមគេ (មើល ខ.៦–១១ ១សយ ១:២១ និងការពន្យល់) ។

**៧៣:២៨** *ដើម្បីឱ្យបានថ្លែងប្រាប់ពីអស់ទាំងការរបស់ទ្រង់* នៅក្នុងឃ្លានេះគឺជាសេចក្តីបញ្ចប់ នៃការហៅឱ្យមនុស្សទាំងអស់ចូលមកសរសើរតម្កើងដល់ព្រះអម្ចាស់ (សូមមើលការពន្យល់ ៧:១៧) ។

**ទដ ៧៤** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះអង្គទ្រង់បានមកជួយដល់រាស្ត្ររបស់ទ្រង់ និងជួយដោះស្រាយអស់ទាំងបញ្ហាដែលពួកខ្មាំងសត្រូវទាំងឡាយមើលងាយដល់គាត់ ពីព្រោះគាត់បានដឹងថា ទំនាក់ទំនងរបស់ព្រះអម្ចាស់ជាមួយរាស្ត្រទ្រង់ គឺដូចគ្នានឹងទំនាក់ទំនងរបស់ស្តេចជាមួយប្រជារាស្ត្រដែរ ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺបានតែងឡើងក្នុងគ្រានិរទេស ជាគ្រាដែលអ៊ីស្រាអែល ត្រូវបានគេវាយឱ្យដួលរលំ ទឹកដីសន្យាត្រូវគេចាប់បាន ហើយព្រះវិហារត្រូវបំផ្លាញ (មើល ទដ ៧៩ បទ ជំពូក ២) ។ គេមិនបានដឹងច្បាស់ថា តើជំពូកនេះវាមានទំនាក់ទំនងជាមួយកិច្ចការងាររបស់ហោរាយេរេមា និងអេសេគាល ដែរឬអត់ (មើលការពន្យល់ ខ.៩) ។ ឯផ្ទៃរឿងវិញ ព្រះគម្ពីរទំនុកដំកើងជំពូកនេះបានចែកជា២ល្បះស្មើគ្នាដែលមាន ១១ខ ក្នុង១ល្បះ ។ ខ.១២ (ចំណុចកណ្តាលនៃជំពូកនេះ មើលការពន្យល់នៅទីនោះ) គឺជាផ្ទៃរឿងគ្រឹះនៃក្តីអធិស្ឋាន ។ នៅក្នុង ខ.១–១១ គឺបានបង្ហាញថា "ហេតុអ្វីបានជារាស្ត្ររបស់ព្រះរអ៊ូរទាំ" (មើល ខ.១,១១) ហើយនៅក្នុងជំពូកនេះទាំងមូលបានពណ៌នាអំពីការ អំពាវនាវដល់ព្រះ "សូមឱ្យព្រះអង្គទ្រង់នឹកចាំ" (មើល ខ.២,២២) ។

**៧៤ ត្រង់ចំណងជើង** *សេចក្តីបង្រៀន* មើលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។ *អេសាភ* មើលការពន្យល់ ទដ ៧៣ត្រង់ចំណងជើង ។

**៧៤:១–២** នៅក្នុងខទាំងនេះ បានប្រាប់ពីមូលហេតុដែលបណ្តាលពួកបណ្តាជនរអ៊ូរទាំ និងអំពាវនាវសូមឱ្យព្រះនឹកចាំពីពួកគេ ។

**៧៤:១** *ហេតុអ្វី . . . ហេតុអ្វី . . .* សូមផ្ទៀបជាមួយនឹងឃ្លា "ដល់កាលណា" ដែលមាននិយាយនៅ ខ.១០ និងពាក្យថា "ហេតុអ្វី"ដែលនិយាយនៅ ខ.១១ ហើយសូមមើលការពន្យល់ ៦:៣ ។ *ជាដរាប* គេមើលទៅហាក់បីដូចជាឃើញថា ទ្រង់បានបោះបង់ចោលពួកគេរហូត ពីព្រោះគេមិនបានឃើញសេចក្តីដែលប្រសើរឡើយ ។ *សេចក្តីខ្ញាល់* សូមមើលការពន្យល់ ២:៥ ។ *ហ្វូងចាមនៅទីវាល* នៅក្នុងឃ្លានេះគឺជាពាក្យធៀបមួយ ដែលអ្នកនិពន្ធចង់និយាយសំដៅថា ព្រះមហាក្សត្រគឺប្រៀបដូចជាអ្នកគង្វាល លើរាស្ត្ររបស់

២សូមនឹកចាំពីពួកជំនុំដែលទ្រង់រើស[យ]បានពីកាលចាស់
បុរាណ[ង]
ជាពួកដែលទ្រង់បានលោះ[ច]សំរាប់ជាពូជអំបូរដែលទ្រង់
នឹងគ្រងជាមរដក[ឆ] គឺភ្នំស៊ីយ៉ូន[ជ]
ជាកន្លែងដែលទ្រង់បានគង់នៅ[ឈ]
៣សូមទ្រង់លើកព្រះបាទយាងមកឯកន្លែងដែលនៅបាក់
បែកជានិច្ច[ញ] គឺមកឯការអាក្រក់ទាំងប៉ុន្មាន
ដែលពួកខ្មាំងសត្រូវបានធ្វើនៅក្នុងទីបរិសុទ្ធ ។
៤ពួកដែលតតាំងនឹងទ្រង់ បានស្រែកហ៊ោ[ដ]នៅកណ្តាលជំនុំ
របស់ទ្រង់ គេបានលើកទង់[ឋ]របស់គេឡើងជាទីសំគាល់
៥គេមើលទៅដូចជាមនុស្សដែលលើកពូថៅឡើងប្រុងនឹង
កាប់ព្រៃញឹក[ឌ]
៦ឥឡូវនេះគេបំបាក់បំបែកអស់ទាំងក្បាច់ចំឡាក់[ឍ] ដោយ
ពូថៅ និងញញួរ
៧ក៏បានយកភ្លើងទៅដុតទីបរិសុទ្ធរបស់ទ្រង់ ព្រមទាំង
បង្អាប់[ណ]ទីលំនៅ[ត]នៃព្រះនាមទ្រង់ឱ្យរាបចុះដល់ដី[ថ]
៨ដោយនឹកក្នុងចិត្តថា ចូរយើងកំទេច[ទ] ចេញឱ្យអស់
គេក៏ដុតបំផ្លាញ[ធ]អស់ទាំងសាលាប្រជុំនៃព្រះដែលនៅក្នុង
ស្រុកដែរ ។
៩យើងខ្ញុំមិនឃើញទង់របស់យើងខ្ញុំទៀតទេ[ន]
ក៏គ្មានហោរាណាទៀតឡើយ[ប]
ហើយឥតមានអ្នកណាក្នុងពួកយើងខ្ញុំដែលដឹងជាការនេះ
នឹងបានដល់យូរប៉ុណ្ណាដែរ
១០ឱព្រះអង្គអើយ
ពួកទាស់ទទឹងនឹងដៀលត្មះ[ផ]ដល់កាលណា[ព]
តើពួកខ្មាំងសត្រូវនឹងប្រមាថ[ភ]ដល់ព្រះនាមទ្រង់ជាដរាបឬ
១១ហេតុអ្វីបានជាទ្រង់ដកព្រះហស្ត គឺព្រះហស្តស្តាំនៃទ្រង់
ចេញដូច្នេះ[ម] សូមទ្រង់ដកព្រះហស្តចេញពីព្រះឱរា[យ]មក
ហើយបំផ្លាញគេចុះ ។
១២ប៉ុន្តែព្រះទ្រង់ជាមហាក្សត្រ[រ]នៃទូលបង្គំតាំងតែពីបុរាណ
មកទ្រង់ក៏ប្រោសប្រទានសេចក្តីសង្គ្រោះ[ល]នៅកណ្តាល
ផែនដី

**៧៤:២** យ នក ១៥:១៦ ១កថ ៦:២០ ង ចទ ៣២:៧ ច នក ១៥:១៣ អស ៤៨:២០ ឆ នក ៣៤:៩ ជ ទដ ២:៦ ឈ ទដ ៤៣:៣ ៦៨:១៦ អស ៤៦:១៣ យអ ៣:១៧,២១ អប ១:១៧ **៧៤:៣** ញ អស ៤៤:២៦ ៥២:៩ **៧៤:៤** ដ បទ ២:៧ ឋ ជន ២:២ យរ ៤:៦ **៧៤:៥** ឌ យរ ៤៦:២២ **៧៤:៦** ឍ ១ពវ ៦:១៨ **៧៤:៧** ណ លវ ២០:៣ កច ២១:២៨ ត លវ ១៥:៣១ ថ ទដ ៧៥:១ **៧៤:៨** ទ ទដ ៩៤:៥ ធ ២ពវ ២៥:៩ ២របា ៣៦:១៩ យរ ២១:១០ ៣៤:២២ ៥២:១៣ **៧៤:៩** ន នក ៤:១៧ ១០:១ ប ១សយ ៣:១ **៧៤:១០** ផ ខ.២២ ប ទដ ៦:៣ ៧៩:៥ ៨០:៤ ភ ទដ ៤៤:១៦ **៧៤:១១** ម នក ១៥:៦ យ នហ ៥:១៣ អគ ៥:៣ **៧៤:១២** រ ទដ ២:៦ ២៤:៧ ៦៨:២៤ ល ទដ ២៧:១

ទ្រង់ (សូមមើលការពន្យល់ ២៣:១ ៩៥:៧ និង ៧៩:១៣ ១០០:៣) ។

**៧៤:២** *រើស* ពាក្យនេះអាចនិយាយបានម្យ៉ាងទៀតថាបាន "ទទួល" ឬ បាន "បង្កើត" ។ *ពូជអំបូរ* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើពួកអ៊ីស្រាអែលទាំងមូលតែម្តង ។ *មរដក* សូមមើលក្នុង ចទ ៩:២៩ ។ *សូមនឹកចាំ* នៅទីនេះពាក្យនេះមានន័យដូចគ្នានឹងពាក្យ "ប្រោសលោះ" ។ *ភ្នំស៊ីយ៉ូន* សូមមើលការពន្យល់ក្នុង ខ.១៣–១៧ ហើយធ្វើការប្រៀបធៀប ខ.១២ ជាចំណុចស្នូលនៃជំពូកនេះជាមួយបទចម្រៀងចុងក្រោយ ដែលមាននិយាយនៅក្នុង នក ១៥:១៨ ។ ពួកបាប៊ីឡូនបានវាយបំផ្លាញភ្នំនៃក្រុងស៊ីយ៉ូន គឺដូចនឹងសេចក្តីហិនវិនាសដែលព្រះបានវាយពួកអេស៊ីព្ទដើម្បីរំដោះរាស្ត្រទ្រង់ដែរ ។

**៧៤:៣–៨** នៅក្នុងខទាំងនេះពណ៌នាពីការវាយបំផ្លាញព្រះវិហារ នៃព្រះយេហូវ៉ា ។

**៧៤:៣** *សូមលើកព្រះបាទ* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថាសូមព្រះអង្គប្រញាប់យាងមកស្រោចស្រង់រាស្ត្រទ្រង់ឡើងវិញ ។

**៧៤:៤** *ទង់* ប្រហែលជាទង់តាមពួកកងរបស់គេ (មើល ជន ១:៥២ អស ៣១:៩ យរ ៤:២១) ។ *ទីសំគាល់* គឺជាទីសម្គាល់ពីជ័យជំនះរបស់ពួកគេ ។

**៧៤:៦** *ក្បាច់ចំលាក់* សូមមើល ១ពវ ៦:១៥ ។

**៧៤:៧** *ព្រះនាមទ្រង់* មើលការពន្យល់ ៥:១១ ។ នៅក្នុងព្រះគម្ពីរ "ព្រះនាម" គឺនិយាយសំដៅលើវត្តមានរបស់ព្រះ ក្នុងទីបរិសុទ្ធ (មើល ចទ ១២:៥) ។

**៧៤:៨** *នឹកក្នុងចិត្ត* មើលការពន្យល់ ១០:១១ ។ *អស់ទាំងសាលាប្រជុំនៃព្រះ* ពាក្យនេះតាមភាសាអក្សរសាស្ត្រគឺ "ជំនុំរបស់ទ្រង់" (មើល ខ.៤) ។ គេមិនបានដឹងថា ពាក្យនេះតើអ្នកនិពន្ធចង់និយាយសំដៅលើទីកន្លែងណាមួយនោះឡើយ ។ នៅក្នុងគ្រាដែលពួកបាប៊ីឡូនឈ្លានពាន ប្រហែលជាមានទីកន្លែង (មិនស្របច្បាប់) ជាច្រើនដែលរាស្ត្ររបស់ព្រះ តែងតែមកជួបជុំគ្នាដើម្បីថ្វាយបង្គំដល់ព្រះ (សូមមើលការពន្យល់ ១ពវ ៣:២ ២ពវ ១៨:៤) ។

**៧៤:៩–១១** ជាថ្មម្តងទៀត ពួកគេបានអធិស្ឋាននិងរអ៊ូរទាំជាមួយព្រះម្តងទៀត (សូមមើល ខ.១–២) ។

**៧៤:៩** *យើងខ្ញុំមិនឃើញទង់របស់យើងខ្ញុំទៀតទេ* ហេតុការណ៍នេះគឺដូចគ្នានឹងហេតុការណ៍ ដែលបានកើតឡើងក្នុងគ្រានិកម្ខនំដែរ (មើល ខ.១៣–១៥ ៧៨:៤៣) ។ *គ្មានហោរា* ពីព្រោះហោរាយេរេមាត្រូវបាននាំទៅប្រទេសអេស៊ីព្ទ (យរ ៤៣:៦–៧) ហើយគេក៏មិនដឹងថាតើអេសេគាលនៅបន្តធ្វើជាហោរាដែរឬអត់នោះទេ ។ ប្រហែលទំនុកដំកើងជំពូកនេះ គឺជា ការតែងឡើងដោយពួកកូនចៅអេសាភ ដែលជាពួកអ្នកសំណល់របស់ពួកអ៊ីស្រាអែល ។ ពួកគេជាក្រុមមួយដ៏តូចបំផុតដែលស្ថិតនៅក្រោមការថែរក្សាដោយយ៉ូហាណាន (សូមមើល យរ ៤៣:៤–៧) ។

**៧៤:១០** *ដៀលត្មះ . . . ប្រមាថដល់ព្រះនាមទ្រង់* សូមមើល ខ.១៨ និង ខ.២២ ២ពវ ១៨:៣២–៣៥ អស ៣៧:៦,២៣ ។

**៧៤:១២** ខនេះ គឺជាចំណុចស្នូលនៃបទគម្ពីរទំនុកដំកើងជំពូកនេះ ។ ព្រះគម្ពីរជំពូកនេះទាំងមូល គឺបានពណ៌នាពីការពិតថា ព្រះអម្ចាស់ទ្រង់គឺជាស្តេចនៃពួកអ៊ីស្រាអែល ជាសេចក្តីសង្ឃឹម និងជាអ្នកសង្គ្រោះរបស់ពួកគេ ហើយពួកអ៊ីស្រាអែលគេជារាស្ត្ររបស់ព្រះ ។ ដំណើររឿងដែលនិយាយនៅក្នុងព្រះគម្ពីរទំនុកដំកើងនេះ គឺបង្ហាញទាំងការរអ៊ូរទាំ និងការអធិស្ឋានទៅចំពោះព្រះ ហើយហេតុអ្វីបានជាពួកអ្នកដែលមើលងាយដល់ព្រះនាមព្រះគេបានបំផ្លាញដល់ពួកអ៊ីស្រាអែលដូច្នេះ ។ *នៃទូលបង្គំ* ពាក្យនេះតែងតែប្រើក្នុងទម្រង់ជាសព្វនាមកម្មសិទ្ធ (មើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង) ។ *តាំងតែពីបុរាណ* គឺចាប់តាំងពីគ្រាចាកចេញពីស្រុកអេស៊ីព្ទ ដែល

១៣ ទ្រង់បានញែកទឹកសមុទ្រ[វ] ដោយឫទ្ធិរបស់ទ្រង់
ក៏បានបំបែកក្បាលអស់ទាំងសត្វសំបើម[ស] នៅក្នុងទឹក
១៤ ទ្រង់បានកិនកំទេចក្បាលរបស់ក្រពើ[ហ] ព្រមទាំងប្រទាន
សាច់វាទុកជាអាហារដល់ពួកមនុស្សដែលនៅទីរហោ
ស្ថាន[ឡ]
១៥ ទ្រង់បានវាយបំប្រេះថ្ម
ឱ្យមានក្បាលទឹក[អ]និងទឹកជ្រោះចេញមក
ក៏ធ្វើឱ្យទន្លេដែលហូរជានិច្ច បានរីងស្ងួតទៅ[ក]ផង
១៦ ពេលថ្ងៃជារបស់ផងទ្រង់ ហើយពេលយប់ក៏ដែរ
ទ្រង់បានបង្កើតពន្លឺ និងដួងព្រះអាទិត្យ[ខ]
១៧ ទ្រង់បានតាំងព្រំខណ្ឌ[គ]ទាំងប៉ុន្មាននៃផែនដី
ហើយកំណត់ឱ្យមានរដូវក្ដៅ និងរដូវត្រជាក់[ឃ] ។
១៨ ឱព្រះយេហូវ៉ាអើយ សូមទ្រង់នឹកចាំថាពួកខ្មាំងសត្រូវ[ង]
បានត្មះតិះដៀល ហើយថា
សាសន៍១ដែលល្ងីល្ងើបានប្រមាថដល់ព្រះនាមទ្រង់ហើយ
១៩ ឱសូមកុំប្រគល់ជីវិតនៃលលក[ច]ទ្រង់ដល់សត្វព្រៃ
សូមកុំភ្លេចពួកមនុស្សកំសត់[ឆ]របស់ទ្រង់ជាដរាបឡើយ

**៧៤:១៣** វ នក ១៤:២១ ស អស ២៧:១ ៥១:៩ អគ ២៩:៣ ៣២:២ **៧៤:១៤** ហ យប ៣:៨ ឡ អស ១៣:២១ ២៣:១៣ ៣៤:១៤ យរ ៥០:៣៩ **៧៤:១៥** អ នក ១៧:៦ ជន ២០:១១ ក នក ១៤:២៩ យស ២:១០ **៧៤:១៦** ខ លប ១:១៦ ទដ ១៣៦:៧–៩ **៧៤:១៧** គ ចទ ៣២:៨ កច ១៧:២៦ ឃ លប ៨:២២ **៧៤:១៨** ង ចទ ៣២:៦ **៧៤:១៩** ច លប ៨:៨ អស ៥៩:១១ ឆ ទដ ៩:១៨

២០ សូមទ្រង់យល់ដល់សេចក្ដីសញ្ញា[ជ]
ដ្បិតអស់ទាំងទីងងឹត[ឈ] នៅផែនដីបានពេញដោយទី
អាស្រ័យនៃសេចក្ដីច្រឡោតហើយ
២១ ឱសូមកុំឱ្យពួកអ្នកដែលត្រូវគេសង្កត់សង្កិន[ញ]បានមកវិញ
ទាំងមានសេចក្ដីខ្មាសនោះឡើយ សូមឱ្យមនុស្សក្រីក្រ
ហើយកំសត់ទុគ៌ត[ដ]បានសរសើរដល់ព្រះនាមទ្រង់វិញ ។
២២ ឱព្រះអង្គអើយ សូមឈរឡើង[ឋ]ផ្ចាញ់គេពីដំណើរទ្រង់
សូមនឹកចាំពីបែបយ៉ាងណាដែលមនុស្សល្ងីល្ងើ[ឌ]បានត្មះតិះ
ដៀលដល់ទ្រង់រាល់ថ្ងៃជានិច្ច
២៣ សូមកុំភ្លេចពីសូរសំរែក[ឍ]របស់ពួកតតាំងនឹងទ្រង់[ណ]
ឬសូរទ្រហឹងអឹងកង[ត]របស់ពួកអ្នកដែលលើកគ្នាមកទាស់
នឹងទ្រង់[ថ] ដែលចេះតែពូឡើងជានិច្ចនោះឡើយ ។

**៧៤:២០** ជ លប ៦:១៨ ឈ យប ៣៤:២២ **៧៤:២១** ញ ទដ ៩:៩ ១០:១៨ ១០៣:៦ អស ៥៨:១០ ដ ទដ ៣៥:១០ **៧៤:២២** ឋ ទដ ១៧:១៣ ឌ ទដ ៥៣:១ **៧៤:២៣** ឍ អស ៣១:៤ ណ ទដ ៦៥:៧ ត ទដ ៤៦:៦ ថ ជន ២៥:១៧

មាននិយាយនៅក្នុង គម្ពីរនិក្ខមនំ (នក ៣:៧ ១៩:៥–៦) ។

**៧៤:១៣–១៧** នៅក្នុងខនេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់គឺជាព្រះដ៏មានគ្រប់ទាំងព្រះចេស្ដា ជាព្រះអង្គសង្គ្រោះ និងការបង្កើត (មើល ៦៥:៦–៧ និងការពន្យល់) ។

**៧៤:១៣–១៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានរំឭកឱ្យឃើញពីអំណាចចេស្ដារបស់ព្រះយេហូវ៉ា ក្នុងគ្រាដែលទ្រង់បានរំដោះរាស្ត្រទ្រង់ចេញពីស្រុកអេស៊ីព្ទ ។ រូបភាពនៃការប្រៀបប្រដូចនេះបានយកចេញពីរឿងនិទានស្ដីពីការបង្កើត របស់ពួកអ្នកដែលរស់នៅក្នុងតំបន់មជ្ឈិមបូព៌ាកាលពីសម័យបុរាណ ដែលរឿងនោះស្ដីពីការរំពើងនៃទឹក ដែលប្រៀបបានទៅនឹងសត្វសំបើមៗយ៉ាងចំលែកជាច្រើន ដែលជាស្នាព្រះហស្តដែលព្រះបានបង្កើតឡើង (រូបព្រះ) បន្ទាប់ពីទ្រង់បានសាងពិភពលោកនេះឡើង (មើលការពន្យល់ ៣២:៦) ។ នៅទីនេះកវីនិពន្ធបានបញ្ចូលនូវផ្ទៃរឿង ដែលនិយាយពិការបង្កើត និងសេចក្ដីសង្គ្រោះដែលមានលក្ខណៈរួមគ្នា ដើម្បីបង្ហាញថា ព្រះនៃពួកអ៊ីស្រាអែលបានបង្ហាញឱ្យមនុស្សបានស្គាល់ពីកិច្ចការសង្គ្រោះរបស់ទ្រង់ (តាមរយៈការដែលទ្រង់បានញែកទឹកសមុទ្រក្រហមដើម្បីឱ្យរាស្ត្រទ្រង់បានដើរ និងការដែលទ្រង់បំផ្លាញពួកអេស៊ីព្ទ) ឱ្យគេបានដឹងថាទ្រង់មានអំណាចដ៏ខ្លាំងពូកែ អាចយកឈ្នះលើពួកខ្មាំងសត្រូវបាន និងមានអំណាចចេស្ដាជួយសង្គ្រោះរាស្ត្ររបស់ទ្រង់ ។ អ្នកនិពន្ធបានប្រើរូបភាពនេះដើម្បី (១).សរសើរតម្កើងចំពោះស្នាព្រះហស្តរបស់ទ្រង់ (មើល ៨៩:១០ យប ៩:១៣ ២៦:១២–១៣) (២).ដើម្បីអបអរសាទរចំពោះសេចក្ដីសង្គ្រោះ ដែលទ្រង់បានជួយដល់រាស្ត្រទ្រង់ចេញពីស្រុកអេស៊ីព្ទ (មើល អស ៥១:៩) (៣).ដើម្បីប្រកាសពីសេចក្ដីសង្គ្រោះដល់ពួកអ៊ីស្រា–អែលនៅថ្ងៃអនាគត (មើល អស ២៧:១) ។ មិនតែប៉ុណ្ណោះរូបភាពនៃការប្រៀបប្រដូចនេះ ក៏និយាយពីវត្តមានរបស់ ព្រះក្នុងការជំនុំជម្រះរបស់ព្រះទាស់ប្រឆាំងជាមួយពួកអេស៊ីព្ទដែរ (មើល អគ ២៩:៣–៥ ៣២:២–៦) ។

**៧៤:១៥** ខនេះបានរំឭកឱ្យឃើញពីការអស្ចារ្យ ដែលព្រះបានញែកទឹកសមុទ្រក្រហម និងក្នុងទីរហោស្ថាន ព្រមទាំងទន្លេយ័រដាន់ ។

**៧៤:១៦–១៧** នៅក្នុងខទាំងនេះចង់និយាយថា ព្រះអម្ចាស់ព្រះយេហូវ៉ាទ្រង់ជាព្រះដែលគ្រប់គ្រងលើការបង្កើត ហើយមានតែព្រះអង្គមួយប៉ុណ្ណោះដែលអាចជួយសង្គ្រោះ និងស្អាងនគររបស់ទ្រង់នៅក្នុងលោកិយនេះ ដើម្បីទាស់ប្រឆាំងលើការបង្កើតទាំងឡាយណា ដែលប្រឆាំងទាស់នឹងព្រះអង្គ ។

**៧៤:១៨–២៣** នៅក្នុងខនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះជួយរំដោះគាត់ និងជួយស្រោចស្រង់គាត់ឡើងវិញ ។

**៧៤:១៨** សូមមើល ខ.២,១០ ។ *សាសន៍១ដែលល្ងីល្ងើ* គឺនិយាយសំដៅលើពួក "ខ្មាំងសត្រូវ" (សូមមើល ខ.១០) ពីព្រោះពួកគេបានមើលងាយដល់ព្រះយេហូវ៉ា (សូមមើល ខ.២២ និងការពន្យល់ ១៤:១) ។

**៧៤:១៩** *លលកនៃទ្រង់* ពួកអ៊ីស្រាអែលគេជាលលកនៃទ្រង់ ។ ពាក្យនេះគឺជាពាក្យសម្ដីយ៉ាងផ្អែមល្ហែម ដែលព្រះនិយាយទៅកាន់ពួកអ៊ីស្រាអែល (សូមមើល បស ២:១៤ ៥:២ ៦:៩ ទដ ៦៨:១៣ និងការពន្យល់) ។ *សត្វព្រៃ* សូមមើលការពន្យល់ ៧:២ ។

**៧៤:២០** *សេចក្ដីសញ្ញា* គឺជាសេចក្ដីសញ្ញាដែលព្រះបានតាំងថានឹងធ្វើជាព្រះនៃអ៊ីស្រាអែល ជាអ្នកដែលធ្វើឱ្យពួកគេទទួលបានព្រះពរ និងបង្កើតផលនៅក្នុងទឹកដីសន្យា (មើល នក ១៩:៥–៦ ២៣:២៧–៣១ ៣៤:១០–១១ លវ ២៦:១១–១២ ៤២, ៤៤–៤៥ ចទ ២៨:១–១៤ និង ទដ ១០៥:៨–១១ ១០៦:៤៥ ១១៥:៥,៩ អស ៥៤:១០ យរ ១៤:២១ អគ ១៦:៦០) ។

**៧៤:២១** *មនុស្សក្រីក្រ និងមនុស្សទុរគ៌ត* សូមមើលការពន្យល់ ៣៤:៦ ។

**៧៤:២២** *សូមឈរឡើង* សូមមើលការពន្យល់ ៣:៧ ។

**៧៤:២៣** *សូរសំរែក... សូរទ្រហឹង* សូមមើល ៦៤:២ ។

ទំនុកជាបទចំរៀងរបស់អេសាភ ដែលលោកលើក
សំរាប់មេភ្លេង ឱ្យលេងតាមបទ "សូមកុំបំផ្លាញ" ។

**៧៥** ឱព្រះអង្គអើយ យើងខ្ញុំអរព្រះគុណដល់ទ្រង់
យើងខ្ញុំអរព្រះគុណដោយព្រោះព្រះនាមទ្រង់ស្ថិតនៅជិត[ក]
មនុស្សទាំងឡាយប្រកាសប្រាប់ពីការអស្ចារ្យរបស់ទ្រង់[ខ] ។
២ កាលណាដល់វេលាដែលកំណត់ទុកហើយ[គ]
នោះអញនឹងជំនុំជំរះដោយសុចរិត[ឃ]
៣ ផែនដីនឹងអស់ទាំងមនុស្សនៅផែនដីត្រូវរលាយទៅ[ង]
គឺអញដែលបានតាំងសសរ[ច]ផែនដីឡើង ។ –បង្អង់
៤ ទូលបង្គំបាននិយាយទៅពួកអំនួត[ឆ]ថាកុំឱ្យអួតខ្លួនឡើយ[ជ]
ហើយទៅមនុស្សអាក្រក់ថា កុំឱ្យដំកើងខ្លួនឱ្យសោះ[ឈ]
៥ មិនត្រូវលើកខ្លួនឡើងឱ្យខ្ពស់
ឬនិយាយដោយព្រហើនឡើយ[ញ]
៦ ដ្បិតឯការដំកើតឡើង
នោះមិនមែនមកពីទិសខាងកើតឬខាងលិច
ក៏មិនមកពីទីរហោស្ថាននោះទេ ។
៧ គឺព្រះដែលជាចៅក្រម[ដ] ទ្រង់បន្ទាបម្នាក់ចុះ
ហើយលើកម្នាក់ទៀតឡើង[ឋ]
៨ ពីព្រោះព្រះយេហូវ៉ាទ្រង់កាន់ពែង១នៅព្រះហស្តដែល
មានស្រា[ឌ]កំពុងតែពពុះឡើង ពែងនោះពេញដោយស្រា
លាយ ហើយទ្រង់ក៏ចាក់ចេញឯមនុស្សអាក្រក់ទាំងប៉ុន្មាន
ដែលនៅផែនដីគេនឹងផឹកសំរេងកាកក្នុងពែងនោះជាមិន
ខាន[ឍ] ។
៩ តែទូលបង្គំនឹងប្រកាសប្រាប់[ណ]ការទាំងនេះជាដរាប
ទូលបង្គំនឹងច្រៀងសរសើរ[ត]ថ្វាយព្រះនៃយ៉ាកុប[ថ]

**៧៥:១** ក ទដ ១៤៥:១៨ ខ យស ៣:៥ ទដ ៤៤:១ ៧១:១៦ ៧៧:១២ ១០៥:២ ១០៧:៨,១៥ ១៤៥:៥,១២ **៧៥:២** គ នក ១៣:១០ ឃ ទដ ៧:១១ **៧៥:៣** ង អស ២៤:១៩ ច ១សយ ២:៨ ២សយ ២២:៨ **៧៥:៤** ឆ ទដ ៥:៥ ជ ១សយ ២:៣ ឈ សក ១:២១ **៧៥:៥** ញ យប ១៥:២៥ **៧៥:៧** ដ លប ១៦:៥ ទដ ៥០:៦ ៥៨:១១ វវ ១៨:៨ ឋ ១សយ ២:៧ យប ៥:១១ ទដ ១៤៧:៦ អគ ២១:២៦ ដយ ២:២១ **៧៥:៨** ឌ សភ ២៣:៣០ ឍ អស ៥១:១៧ យរ ២៥:១៥ សក ១២:២ **៧៥:៩** ណ ទដ ៤០:១០ ត ទដ ១០៨:១ ថ លប ២៤:១២ ទដ ៧៦:៦

**ទដ ៧៥** នៅក្នុងជំពូកនេះ គឺជាបទចម្រៀងមួយដែលស្ដីពីបំណងប្រាថ្នាចង់បានព្រះក្នុងគ្រាដែលពួកមនុស្សអាក្រក់គេបានឈ្លានពាន ដល់សុវត្ថិភាពរបស់ប្រជាជនអ៊ីស្រាអែល ។ បទគម្ពីរទំនុកដំកើងនេះ ប្រហែលតែងឡើងក្នុងគ្រា ដែលពួកអ៊ីស្រាអែលជួបការគម្រាមកំហែងពីពួកអាសស៊ើរ (មើល ២ពវ ១៨:១៣–១៩:៣៧ និង ទដ ជំពូក ១១ និងជំពូក ៧៦) ។ ផ្ទៃរឿងដែលនិយាយនៅក្នុងជំពូកនេះ គឺមានលក្ខណៈ ប្រហាក់ប្រហែលគ្នានឹងបទចម្រៀងរបស់នាងហាណាដែរ (មើល ១សយ ២:១–១០) ។ សេចក្ដីថ្លែងការណ៍របស់ក្រុមដែលបានចូលរួមថ្វាយបង្គំព្រះ (មើល ខ.១) ហើយប្រហែលមានម្នាក់ដែលចេញពីអំបូរអេសាភ ជាអ្នកនាំការសរសើរ (មើល ខ.៩) ។ អ្វីដែលលេចធ្លោនៅក្នុងជំពូកនេះ គឺការអរព្រះគុណ (មើល ខ.១) និងការសរសើរដំកើង (មើល ខ.៩–១០) ។

**៧៥ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ត្រូវលេងតាមបទ* មើលការពន្យល់ ទដ៩ ត្រង់ចំណងជើង ។ *សូមកុំបំផ្លាញ* សូមមើល ទដ ៥៧ ៥៨ ៥៩ ត្រង់ចំណងជើង ។ *អេសាភ* មើលការពន្យល់ ទដ ៧៣ ត្រង់ចំណងជើង ។ *ទំនុកចម្រៀង* មើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង ។

**៧៥:១** នៅក្នុងខនេះ ក្រុមពួកអ្នកដែលបានចូលមកសរសើរតម្កើង បានចាប់ផ្ដើមពោលពាក្យអរព្រះគុណចំពោះព្រះអម្ចាស់ ដែលមានលក្ខណៈបែបសរសើរ (មើល ៧:១៧ ២៨:៧ ៣០:១២ ៣៥:១៨) ។ *ព្រះនាម* មើលការពន្យល់ ៥:១១ ៧៤:៧ ។ *ការអស្ចារ្យរបស់ទ្រង់* មើលការពន្យល់ ៩:១ ។

**៧៥:២–៥** នៅក្នុងខទាំងនេះ គឺជាការធានាអះអាងរបស់ព្រះនៅស្ថានលើ ដែលទ្រង់បានសន្យាថា ទ្រង់នឹងមិនដែលភ្លេចហៅមនុស្សអាក្រក់មកជំនុំជម្រះនោះឡើយ ។ យើងមិនបានដឹងឡើយថា តើនេះជាព្រះបន្ទូលថ្មីរបស់ព្រះអម្ចាស់ ឬក៏ជាព្រះបន្ទូលដែលព្រះធ្លាប់សន្យាកាលពីគ្រាមុន ឬជាការសង្ខេបទំនាយរបស់ហោរា (ដូចជាលោកអ៊ីសាយ ដែលមាននិយាយនៅក្នុង ២ពវ ១៩:២១–៣៤) ។

**៧៥:២** នៅក្នុងខនេះ ចង់និយាយថា ព្រះអម្ចាស់ទ្រង់ជាចៅក្រមដ៏សុចរិត (សូមមើលក្នុង ទដ ៩៦,៩៨) ប៉ុន្តែត្រូវរងចាំដល់ពេលវេលាដែលទ្រង់គាប់ព្រះហឫទ័យ ។

**៧៥:៣** នៅក្នុងខនេះចង់និយាយថា នៅពេលនោះ ដោយព្រោះពួកមនុស្សអាក្រក់កាន់តែមានគ្នាច្រើន ហើយអំណាចពួកគេកាន់តែពុះកញ្ជ្រោលទៅ នោះនឹងធ្វើឱ្យលោកិយទាំងមូល មើលទៅហាក់បីដូចជាបាក់បែក ប៉ុន្តែឯព្រះទ្រង់នៅតែស្ថិតស្ថេរជានិច្ច (មើលការពន្យល់ ១១:៣) ។ *សសរ* មើលការពន្យល់ ២៤:២) ។

**៧៥:៤** *ពួកអំនួត . . . ពួកមនុស្សអាក្រក់* នៅក្នុងព្រះគម្ពីរទំនុកដំកើងកាលណានិយាយពីមនុស្សអាក្រក់ គឺសំដៅលើមនុស្សអំណួត (សូមមើល ទដ ១០ ៧៣:៤–១២ ៩៤:៤ និងការពន្យល់ ៣១:២៣) និងមនុស្សល្ងង់ខ្លៅ (សូមមើល ១៤:១ ៧៤:១៨,២២ ៩២:៦ ៩៤:៨) ។ *ដំកើងខ្លួន* ពាក្យនេះ គឺចង់និយាយសំដៅលើការគាបសង្កត់ (សូមមើល ខ.១០) ។

**៧៥:៥** *និយាយដោយព្រហើន* គឺសំដៅលើការមានះ ។

**៧៥:៦–៨** នៅក្នុងខទាំងនេះ គឺជាការអបអរចំពោះជ័យជម្នះដែលពួកគេទទួលបាន ដោយស្រែកប្រកាសពីផែនដី ។ ប្រហែលពួកកូនចៅលេវីដែលមាននាទីជាអ្នកនាំចម្រៀងជាអ្នកប្រកាសប្រាប់ពីជ័យជម្នះនេះ ប្រៀបបានទៅនឹងព្រះបន្ទូលនៃការកំសាន្តចិត្តដែលមកពីព្រះអម្ចាស់ ។

**៧៥:៨** *ពែង* មើលការពន្យល់ ១៦:៥ ។ *ស្រាលាយ* គឺជាស្រាដែលបានលាយជាមួយជាតិពុល (មើល សភ ៩:២,៥ ២៣:២៩–៣–បស ៨:២ អស ៦៥:១១) ។ *ផឹកសំរេងកាក* ពីព្រោះព្រះអម្ចាស់ទ្រង់បានចាក់ស្រា នោះទើបធ្វើឱ្យពួកគេបង្ខំចិត្តផឹកដោយគ្មានជំរើស ។

**៧៥:៩** នៅក្នុងខនេះ អ្នកនិពន្ធបានសម្រេចចិត្តក្នុងការសរសើរតម្កើងដល់ព្រះជារៀងរហូត (មើលការពន្យល់ ៧:១៧) ដោយព្រោះព្រះអង្គទ្រង់ជាចៅក្រមដ៏សុចរិត ។ *ទូលបង្គំ* ពាក្យនេះប្រហែលនិយាយសំដៅលើពួកអ្នកនាំចម្រៀងដែលចេញពីពួកលេវី ជាអ្នកតំណាងឱ្យពួកបណ្ដាជនទាំងមូល ប៉ុន្តែបើតាមទម្រង់សព្វនាមកម្មសិទ្ធិដែលប្រើនៅទីនេះ ប្រហែលប្រើសំដៅលើក្រុមសហគន៍ ដូចដែលមាននិយាយនៅក្នុង ៧៤:១២ (សូមមើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង) ។ *យ៉ាកុប* ពាក្យនេះមានន័យស្មើគ្នានឹងពាក្យអ៊ីស្រាអែល (សូមមើល លប ៣២:២៨) ។

១០ទូលបង្គំនឹងកាត់អំណាចទាំងប៉ុន្មាននៃមនុស្សអាក្រក់
ចេញ តែអំណាចរបស់មនុស្សសុចរិតនឹងបានដំកើងឡើង
វិញ[ទ] ។

ទំនុកជាបទចំរៀងរបស់អេសាភ ដែលលោកលើកសម្រាប់មេភ្លេង ត្រូវលេងដោយប្រដាប់មានខ្សែ ។

**៧៦** នៅស្រុកយូដាគេស្គាល់ព្រះហើយ ព្រះនាមទ្រង់ក៏ធំ[ក]
នៅក្នុងសាសន៍អ៊ីស្រាអែល
២រោងឧបោសថរបស់ទ្រង់នៅក្រុងសាឡិម[ខ]
ហើយទីលំនៅទ្រង់នៅភ្នំស៊ីយ៉ូន[គ]
៣នៅទីនោះ ទ្រង់បានបំបាក់ព្រួញ ធ្នូ[ឃ] ខែល និងដាវ
ហើយអស់ទាំងគ្រឿងចំបាំងបង់[ង] ។ –បង្អង់
៤ទ្រង់រុងរឿងឧត្តម[ច]
ហើយមានលំអប្រសើរជាងភ្នំរំពាទាំងប៉ុន្មាន
៥ពួកអ្នកដែលមានចិត្តក្លាហាន[ឆ] គេបានត្រូវប្លន់ជារំពាវិញ
គេបានដេកអស់ពេលដេករបស់គេហើយ[ជ]
ក្នុងពួកអ្នកខ្លាំងពូកែ ទាំងប៉ុន្មាន
គ្មានអ្នកណាមួយអាចលើកដៃឡើងបានឡើយ
៦ឱព្រះនៃយ៉ាកុបអើយ កាលណាទ្រង់បន្ទោស[ឈ]
នោះទាំងរទេះចំបាំង[ញ] និងសេះផងក៏ត្រូវលក់ស៊ប់ទាំង
អស់គ្នា
៧គឺទ្រង់ ទ្រង់តែ១ប៉ុណ្ណោះ
ដែលគួរស្ញែងខ្លាច[ដ]កាលណាទ្រង់
មានសេចក្តីខ្ញាល់[ឋ] នោះតើអ្នកណាអាចនឹងឈរ[ឌ]នៅ
ចំពោះទ្រង់បាន
៨ទ្រង់បានឱ្យឮពាក្យកាត់ទោសពីលើស្ថានសួគ៌មក
ផែនដីក៏ភ័យខ្លាច[ឍ] ហើយស្ងៀមឈឹងនៅ

**៧៥:១០** ទ ទដ ៨៩:១៧ ៩២:១០ ១១២:៩ ១៤៨:១៤
**៧៦:១** ក ទដ ៩៩:៣
**៧៦:២** ខ លប ១៤:១៨ ហាព ៧:១ គ ២សយ ៥:៧ ទដ ២:៦
**៧៦:៣** ឃ អគ ៣៩:៩ ង ទដ ៤៦:៩
**៧៦:៤** ច ទដ ៣៦:៩
**៧៦:៥** ឆ ពច ២០:៤៤ ជ ទដ ១៣:៣ មថ ៩:២៤
**៧៦:៦** ឈ ទដ ៥០:២១ ញ នក ១៥:១
**៧៦:៧** ដ ១របស ១៦:២៥ ឋ អរ ៩:១៥ វវ ៦:១៧ ឌ ទដ ២:៥ ណហ ១:៦
**៧៦:៨** ឍ ១របស ១៦:៣០ អគ ៣៨:២០

**៧៥:១០** នៅក្នុងខនេះគេមិនបានដឹងថា នរណាម្នាក់ជាអ្នកនិយាយនោះឡើយ ។ គ្រប់ទាំងពាក្យសច្ចាប្រណិធាននៅទីនេះ មើលទៅវាមិនមែនជាពួកបណ្ដាជនឡើយ ប៉ុន្តែប្រហែលជាការសច្ចាប្រណិធានរបស់ព្រះមហាក្សត្រវិញ (សូមមើល ទដ ១០១) ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏បទនៃទំនុកដំកើងក្នុងជំពូកនេះ វាមិនជាការការតែងឡើងដោយស្តេចនោះឡើយ ។ *មនុស្សសុចរិត* មើលការពន្យល់ ១:៥ ។ *ដំកើងឡើង* សូមមើល ខ.៧ និងការពន្យល់ ខ.៤ ។

**ទដ ៧៦** នៅក្នុងជំពូកនេះ គឺជាការអបអរសាទរចំពោះជ័យជម្នះរបស់ព្រះយេហូវ៉ា គឺទ្រង់មានអំណាចការពារក្រុងយេរូសាឡិម ដែលជាទីក្រុងរបស់ព្រះអង្គ ។ ផ្ទៃរឿងក្នុងជំពូកនេះមានទំនាក់ទំនងជាមួយនឹង ទដ ៤៦,៤៨,៨៧ (មើលសេចក្តីផ្តើម ទដ ៤៦) ។ តាមទំនៀមទំលាប់ពីសម័យបុរាណ ប្រហែលបទគម្ពីរទំនុកដំកើងនេះ ត្រូវបានតែងឡើងបន្ទាប់ពីព្រះយេហូវ៉ាទ្រង់បានវាយបំផ្លាញពលទ័ពសានហេរិប នៅពេលដែលពួកគេឈ្លានពានក្រុងយេរូសាឡិម (សូមមើល ២ពវ ១៩:៣៥) ។ លក្ខណៈសំណង់ប្រយោគវិញឃើញថា នៅកិច្ចចាប់ផ្តើម (សូមមើល ខ.១–៣) និងកិច្ចបញ្ចប់ (ខ.១១–១២) បានភ្ជាប់មកជាមួយនឹងផ្ទៃរឿងគ្រឹះ ។

**៧៦ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ដោយប្រដាប់មានខ្សែ* សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *អេសាភ* សូមមើលការពន្យល់ ទដ ៧៣ ត្រង់ចំណងជើង ។ *បទចម្រៀង* សូមមើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង ។

**៧៦:១–៣** នៅក្នុងខទាំងនេះ បានពណ៌នាពីការដែលព្រះយេហូវ៉ាទ្រង់វាយកំទេចដល់ពួកខ្មាំងសត្រូវ ដើម្បីបង្ហាញថាទ្រង់ការពារដល់ក្រុងស៊ីយ៉ូន ។

**៧៦:១** *គេស្គាល់* ពាក្យនេះចង់និយាយថា ពេលនេះជាពេលដ៏វិសេសដែលទ្រង់អាចសម្តែងការអស្ចារ្យដើម្បីឱ្យគេបានស្គាល់ពីព្រះអម្ចាស់ ។ *អ៊ីស្រា–អែល* នៅទីនេះអ្នកនិពន្ធមិនបាននិយាយឱ្យច្បាស់រវាងនគរទាំង២នោះឡើយ (ជាយូដា ឬអ៊ីស្រាអែល) ប៉ុន្តែគាត់និយាយតែ១ប៉ុណ្ណោះ ដែលជាការនិយាយសំដៅលើរាស្ត្រ នៃសេចក្តីសញ្ញារបស់ព្រះទាំងមូល ។ មួយវិញទៀតក្នុងពេលដែលពួកអាសស៊ើរ បានវាយលុកហើយបានផ្លាសលំនៅស្ថានពួកអ៊ីស្រាអែល ចេញពីនគរខាងជើង តែឥឡូវនេះពួកអ៊ីស្រាអែលបានតាំងលំនៅស្ថាននៅជុំវិញក្រុងយេរូសាឡិមវិញ ។

**៧៦:២** *រោងឧបោស . . . ទីលំនៅ* ដោយព្រោះពាក្យទាំង២នេះជាភាសាហេព្រើរដែលជានាម នោះជានិច្ចកាលពាក្យនេះ និយាយសំដៅលើរូងរបស់សិង្ហ ជាកន្លែងពួន ឬជាជម្រកសត្វព្រៃ (សូមមើល ១០:៩ ១០៤:២២ យប ៣៨:៤០ យរ ២៥:៣៨ អម ៣:៤) ។ ឃ្លានេះផងដែរអាចមានន័យថា អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបានពណ៌នាពីព្រះនៃពួកអ៊ីស្រាអែលថា ជាសិង្ហដែលមានអំណាចខ្លាំងពូកែ ។ *ស៊ីយ៉ូន* សូមមើលការពន្យល់ ៩:១១ ។

**៧៦:៤–១០** នៅក្នុងខ.ទាំងនេះ គឺជាការសរសើរដំកើងចំពោះអំណាចឥទ្ធិឫទ្ធិរបស់ព្រះអម្ចាស់ ដែលគួរឱ្យស្ញែងខ្លាច(សូមមើលសេចក្តីផ្តើម) ។

**៧៦:៤** *មានលំអរ . . . រំពារ* បើសិនជាថ្នាក់ពាក្យជានាមដែលបាននិយាយនៅក្នុង ខ.២ សំដៅលើរូងសិង្ហ (សូមមើលការពន្យល់នៅទីនោះ) នោះការនេះវាអាចនឹងនិយាយបានថាវាជា "លំអរប្រសើរជាងភ្នំរំពាទាំងប៉ុន្មាន" ។

**៧៦:៥–៦** នៅក្នុងខទាំងនេះ ប្រហែលជាការនិយាយឡើងវិញ ពីជ័យជម្នះរបស់ព្រះអម្ចាស់លើពួកអេស៊ីព្ទនៅត្រង់សមុទ្រក្រហម (សូមមើល នក ១៤:២៨, ៣០ ១៥:៤–៥,១០) ។

**៧៦:៦** *បន្ទោស* ពាក្យនេះកាលណានិយាយពណ៌នាពីព្រះអម្ចាស់ជានិច្ចកាលគឺនិយាយសំដៅលើ (១).គឺជាផ្គរលាន់នៃឥទ្ធិឫទ្ធិនៃព្រះ ដែលទ្រង់បង្ហាញឱ្យឃើញពីអធិបតេយ្យភាពរបស់ទ្រង់ ដែលគ្រប់គ្រងលើអំណាចទាំងឡាយ (មើល ១៨:១៥ ១០៤:៧ ១០៦:៩ យប ២៦:១១ អស ៥០:២ ណហ ១:៤) ឬការស្អប់ខ្ពើមដល់ខ្មាំងសត្រូវរបស់ព្រះអង្គ (មើល ៩:៥ ៦៨:៣០ អស ១៧:១៣) (២).និយាយសំដៅលើផ្គរលាន់ នៃសេចក្តីក្រោធរបស់ទ្រង់ (មើល ទដ ៨០:១៦ អស ៥១:២០ ៥៤:៩ ៦៦:១៥ មីក ២:៣) ។ *ព្រះនៃយ៉ាកុប* ឃ្លានេះមានទំនាក់ទំនងជាមួយទដ ៧៥ (មើល ៧៥:៩ និងការពន្យល់) ។

**៧៦:៨** *ពីលើស្ថានសួគ៌* ទោះជាពេលនេះព្រះវត្តមានរបស់ព្រះអម្ចាស់គង់

៩ គឺក្នុងកាលដែលព្រះទ្រង់ឈរឡើង ដើម្បីជំនុំជំរះ[ណ]
ប្រយោជន៍នឹងជួយសង្គ្រោះដល់ពួកមនុស្សរាបសា[ត] នៅ
ផែនដី ។ –បង្អង់
១០ ពិតប្រាកដជាសេចក្តីឃោរឃៅរបស់មនុស្សនឹង
សរសើរ[ថ] ទ្រង់ ឯសំណល់សេចក្តីឃោរឃៅ
នោះទ្រង់នឹងរួបរឹតទុកវិញ[ទ]
១១ ចូរបន់ព្រះយេហូវ៉ា
ជាព្រះនៃឯងរាល់គ្នា ហើយលាបំណន់នោះចុះ[ធ]
ចូរឱ្យអស់អ្នកដែលនៅជុំវិញទ្រង់យកដង្វាយ[ន] មកថ្វាយដល់
ព្រះដ៏គួរស្ញែងខ្លាច
១២ ទ្រង់នឹងកាត់វិញ្ញាណនៃពួកត្រកូលខ្ពស់ចេញ
ទ្រង់ជាទីគួរតក់ស្លុត ដល់ពួកក្សត្រនៅផែនដី ។

ទំនុករបស់អេសាភ ដែលលោកលើកសំរាប់មេភ្លេង
ជូនដល់លោកយេឌូថិន ។
**៧៧** ខ្ញុំបន្លឺសំឡេង អំពាវនាវដល់ព្រះ[ក]
ខ្ញុំបន្លឺសំឡេងឡើងដល់ព្រះហើយទ្រង់ក៏ស្តាប់ខ្ញុំ
២ នៅថ្ងៃដែលខ្ញុំមានសេចក្តីវេទនា[ខ] នោះខ្ញុំបានស្វែងរក
ព្រះអម្ចាស់ នៅពេលយប់[គ]
នោះខ្ញុំបានប្រទូលដៃ[ឃ] ឡើងឥតឈប់ឈរ
ព្រលឹងខ្ញុំមិនព្រមក្សាន្តទុក្ខទេ[ង]
៣ ខ្ញុំនឹក[ច] ពីព្រះ នោះក៏មានចិត្តទុរនទុរា ខ្ញុំនឹកជញ្ជឹង[ឆ]
នោះវិញ្ញាណខ្ញុំក៏ល្វើយទៅ[ជ] ។ –បង្អង់
៤ ទ្រង់ទល់ភ្នែកទូលបង្គំមិនឱ្យលក់ ទូលបង្គំមានសេចក្តីទុក្ខ
ប្រដេញ ទាល់តែរកនិយាយមិនចេញ[ឈ]
៥ ទូលបង្គំបានពិចារណាពីអស់ទាំងថ្ងៃកន្លងទៅហើយ[ញ]
នឹងអស់ទាំងឆ្នាំពីកាលមុន
៦ ទូលបង្គំនឹកឃើញទំនុកដែលធ្លាប់ច្រៀងនៅពេលយប់
នោះទូលបង្គំបានត្រិះរិះក្នុងចិត្ត
ហើយវិញ្ញាណទូលបង្គំក៏ស្វែងរកសេចក្តីចំឡើយដែរ
៧ តើព្រះអម្ចាស់ទ្រង់នឹងបោះបង់ចោលជាដរាបឬ[ដ]
តើទ្រង់មិនព្រមប្រោសប្រាណ[ឋ] ទៀតទេឬ
៨ តើសេចក្តីសប្បុរស[ឌ] នៃទ្រង់អស់រលីងជាដរាបទៅឬ
តើសេចក្តីសន្យា[ឍ] ទ្រង់អាក់ខានទៅជានិច្ចឬ
៩ តើព្រះទ្រង់ភ្លេចប្រព្រឹត្តដោយករុណា[ណ] របស់ទ្រង់ហើយឬ

**៧៦:៩** ណ ទដ ៩:៨ ៥៨:១១ ៧៤:២២ ៨២:៨ ៩៦:១៣ ត ទដ ៧២:៤ **៧៦:១០** ថ នក ៩:១៦ រម ៩:១៧ **៧៦:១១** ទ លវ ២២:១៨ ទដ ៥០:១៤ សស ៥:៤–៥ ធ ២សយ ៣២:២៣ **៧៧:១** ក ១ពវ ៨:៥២ **៧៧:២** ខ លប ៣២:៧ ២សយ ២២:៧ ទដ ១១៨:៥ គ ទដ ៦:៦ ២២:២ ៨៨:១ ឃ នក ៩:២៩ យប ១១:១៣ ង លប ៣៧:៣៥ មថ ២:១៨ **៧៧:៣** ច ទដ ៧៨:៣៥ ឆ នក ២:២៣ ទដ ៦:៦ យរ ៤៥:៣ ជ ទដ ៦:២ **៧៧:៤** ឈ ទដ ៣៩:២

**៧៧:៥** ញ ចទ ៣២:៧ ទដ ៤៤:១ ១៤៣:៥ សស ៧:១០ **៧៧:៧** ដ ១របា ២៨:៩ ឋ ទដ ៨៥:១ ១០២:១៣ ១០៦:៤ **៧៧:៨** ឌ ទដ ៦:៤ ៩០:១៤ ឍ ២ពត ៣:៩ **៧៧:៩** ណ ទដ ២៥:៦ ៤០:១១ ៥១:១

នៅក្រុងស៊ីយ៉ូនក៏ដោយ (មើល ខ.២) ក៏អំណាចជាអធិបតេយ្យភាពរបស់ទ្រង់អាចនឹងគ្រប់គ្រងមកពីស្ថានសួគ៌បានដែរ ។

**៧៦:១០** *សេចក្តីឃោរឃៅ* សូមមើលការពន្យល់ ២:៥ ។ *សរសើរ* នៅពេលដែលព្រះអម្ចាស់ទ្រង់បានដោះលែងគេ នោះពួកអ្នកដែលបានសង្គ្រោះគេនឹងបានសរសើរតម្កើងដល់ព្រះអម្ចាស់ ។ ជាញឹកញាប់នៅក្នុងព្រះគម្ពីរពាក្យនេះមានន័យថា នៅពេលដែលមនុស្សក្រោកឡើងទាស់ប្រឆាំងចំពោះនគររបស់ទ្រង់ នោះព្រះអម្ចាស់ទ្រង់បានវាយបំបាក់គេដោយសេចក្តីឃោរឃៅដើម្បីឱ្យគេបានសរសើរដំកើងដល់ទ្រង់ ដែលទ្រង់ជាព្រះនៃជ័យជម្នះនិងជាអ្នកដោះលែង ហើយនិង "សំណល់នៃសេចក្តីឃោរឃៅរបស់ព្រះ" បានបង្ហាញថា ចៅក្រមទ្រង់មិនបានបង្អង់ចំពោះសេចក្តីឃោរឃៅរបស់ទ្រង់ឡើយ ។

**៧៦:១១–១២** នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យពួកអ៊ីស្រាអែលបានទទួលស្គាល់ពីសេចក្តីជំនួយរបស់ព្រះយេហូវ៉ា ដោយការសរសើរ ការអរគុណ ហើយសូមឱ្យប្រជាជាតិទាំងឡាយបានទទួលស្គាល់ពីអធិបតេយ្យភាពរបស់ព្រះអង្គដែលទ្រង់បានគ្រប់គ្រងលើពិភពលោកទាំងមូល ។

**៧៦:១១** *ចូរបន់* សូមមើលការពន្យល់ ៥០:១៤ ។

**៧៦:១២** *វិញ្ញានៃពួកអ្នកត្រកូលខ្ពស់* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើវិញ្ញាណ និងឈាមនៃអ្នកបះបោរ ។

**ទដ ៧៧** នៅក្នុងជំពូកនេះ បានរំឭកឱ្យឃើញពីការកំសាន្តចិត្តក្នុងគ្រាដែលមានទុក្ខវេទនា ។ សម្រាប់ទំនាក់ទំនងរវាងព្រះគម្ពីរទំនុកដំកើងជំពូកនេះនិង ទដ ៧៤ មើលកសេចក្តីផ្តើម ទដ ៧៣–៧៨ ។ ដោយសារកិរិយាស័ព្ទដែលប្រើមិនច្បាស់លាស់ដែលប្រើនៅក្នុង ខ.១–៦ នោះគេមិនបានដឹងថាតើនេះជាសេចក្តីអធិស្ឋានរបស់អ្នកនិពន្ធ ឬមួយជាការអធិស្ឋានរបស់ពួកបណ្តាជននោះឡើយ ។ សេចក្តីទុក្ខលំបាកដែលនិយាយនៅទីនេះ ប្រហែលជាសេចក្តីទុក្ខលំបាកផ្ទាល់ខ្លួន ជាងសេចក្តីទុក្ខលំបាករបស់សហគមន៍ ។

**៧៧ត្រង់ចំណងជើង** *សំរាប់មេភ្លេង* មើលការពន្យល់ ទដ៤ ត្រង់ចំណងជើង ។ *យេឌូថិន* សូមមើលការពន្យល់ ទដ ៣៩ ត្រង់ចំណងជើង ។ *អេសាភ* សូមមើលការពន្យល់ ទដ ៧៣ ត្រង់ចំណងជើង ។

**៧៧:១–៩** នៅក្នុងខនេះ ពណ៌នាពីការថប់បារម្ភ ក្នុងការទន្ទឹងរងចាំដល់ព្រះអម្ចាស់ក្នុងគ្រា ដែលមើលទៅឯព្រះអង្គទ្រង់ហាក់បីដូចជាមិនបានតបឆ្លើយមកពួកគេ ។

**៧៧:២** *ព្រលឹង* សូមមើលការពន្យល់ ៦:៣ ។

**៧៧:៣–៦** នៅក្នុងខ.នេះ បានរំឭកឱ្យឃើញពីសេចក្តីសប្បុរសរបស់ព្រះយេហូវ៉ាដែលទ្រង់បានធ្វើកាលពីគ្រាមុន ដូចជាបាននិយាយនៅក្នុង ២២:១–១១) ។ ពេលនេះប្រហែលជាអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គាត់មិនបានដេកលួនឡើយ ដោយព្រោះសេចក្តីវេទនាដែលគាត់មាន ដ្បិតព្រះអម្ចាស់ទ្រង់មិនបានយាងមកជួយដល់គាត់ទេ (សូមធៀបជាមួយ ៣:៥ ៤:៨) និងមិនបានមានបន្ទូលមកកាន់គាត់ដែរ (ប៉ុន្តែសូមមើល ខ.១០–២០) ។

**៧៧:៦** *ចិត្ត* សូមមើលការពន្យល់ក្នុង ៤:៧ ។

**៧៧:៧–៩** នៅក្នុងខទាំងនេះចង់និយាយថា ទោះបើជាអ្នកនិពន្ធគាត់រកនិយាយមិនចេញក៏ដោយ (សូមមើល ខ.៤) ក៏សេចក្តីទុក្ខលំបាកទាំងឡាយនៅតែតាមជាប់គាត់ដដែល ។

**៧៧:៨** *សេចក្តីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**៧៧:៩** *សេចក្តីខ្វាល់* សូមមើលការពន្យល់ ២:៥ ។

តើទ្រង់បានបិទបាំងសេចក្ដីអាណិតមេត្តារបស់ទ្រង់ទុក
ដោយសេចក្ដីខ្ញាល់ដែរឬអី[ត] ។ –បង្អង់
១០ នោះទូលបង្គំបាននឹកថា
នេះហើយជាសេចក្ដីទុក្ខរបស់ទូលបង្គំ
តែទូលបង្គំនឹងនឹកចាំពីគ្រាដែលព្រះហស្តស្តាំ[ថ]នៃព្រះដ៏
ខ្ពស់បំផុត បានប្រោសវិញ
១១ ទូលបង្គំនឹងរឭកពីអស់ទាំងការនៃព្រះយេហូវ៉ា
ដ្បិតទូលបង្គំនឹកឃើញអស់ទាំងការអស្ចារ្យ[ទ]ដែលទ្រង់បាន
ធ្វើកាលពីដើម
១២ ទូលបង្គំនឹងរំពឹងគិត[ធ]ពីគ្រប់ទាំងការរបស់ទ្រង់
ហើយពិចារណាពីកិច្ចដែលទ្រង់ធ្វើទាំងប៉ុន្មាន[ន]
១៣ ឱព្រះអង្គអើយ ផ្លូវទ្រង់ជាផ្លូវបរិសុទ្ធ
តើមានព្រះឯណាដែលធំដូចជាទ្រង់[ប]
១៤ ទ្រង់ជាព្រះដែលធ្វើការយ៉ាងអស្ចារ្យ[ផ]
ទ្រង់បានសំដែងឱ្យស្គាល់ឥទ្ធានុភាពនៃទ្រង់
នៅកណ្ដាលអស់ទាំងសាសន៍
១៥ ទ្រង់បានប្រោសបណ្ដារាស្ត្រឱ្យរួចដោយព្រះហស្តរបស់
ទ្រង់[ព] គឺជាពួកកូនចៅយ៉ាកុប នឹងយ៉ូសែបផង ។ –បង្អង់
១៦ ឱព្រះអង្គអើយ ទឹក[ភ]ទាំងប៉ុន្មានបានឃើញទ្រង់
គឺទឹកទាំងប៉ុន្មានបានឃើញទ្រង់ហើយមានសេចក្ដីភិតភ័យ[ម]
អស់ទាំងទីជំរៅក៏ញ័រដែរ
១៧ អស់ទាំងពពកបានចាក់ទឹក[យ]ចេញផ្ទៃមេឃក៏បញ្ចេញសូរ
រំពង[រ] ហើយព្រួញ[ល]របស់ទ្រង់បានហើរទៅគ្រប់អន្លើដែរ
១៨ សូរសៀងនៃផ្គររបស់ទ្រង់ក៏នៅក្នុងខ្យល់កួច[វ]
ផ្លេកបន្ទោរ[ស]បានបំភ្លឺលោកីយ ឯផែនដីក៏ញ័រកក្រើក[ហ]
១៩ ផ្លូវ[ឡ]ដែលទ្រង់យាង នោះនៅក្នុងសមុទ្រ[អ]
ហើយផ្លូវច្រករបស់ទ្រង់ ក៏នៅទីមានទឹកច្រើន
ឥតមានអ្នកណាឃើញដានព្រះបាទទ្រង់ឡើយ
២០ ទ្រង់បាននាំរាស្ត្រទ្រង់[ក] ដូចជាហ្វូងចៀម[ខ]
គឺដោយដៃរបស់ម៉ូសេ និងអើរ៉ុន[គ] ។

**៧៧:៩** ត អស ៤៩:១៥ **៧៧:១០** ថ នក ១៥:៦ **៧៧:១១** ទ នហ ៩:១៧ **៧៧:១២** ធ លប ២៤:៦៣ ន ទដ ១៤៣:៥ **៧៧:១៣** ប នក ១៥:១១ ទដ ៧១:១៩ ៨៦:៨ **៧៧:១៤** ផ នក ៣:២០ ៣៤:១០ **៧៧:១៥** ព នក ៦:៦ **៧៧:១៦** ភ នក ១៤:២១,២៨ អស ៥០:២ ហព ៣:៨ ម ទដ ១១៤:៤ ហព ៣:១០ **៧៧:១៧** យ ពច ៥:៤ រ នក ៩:២៣ ទដ ២៩:៣ ល ចទ ៣២:២៣ **៧៧:១៨** វ ទដ ៥៥:៨ ស ២សយ ២២:១៣ ហ ពច ៥:៤ **៧៧:១៩** ឡ នក ១៤:២២ អ យប ៩:៨ **៧៧:២០** ក នក ១៣:២១ ខ ទដ ៧៨:៥២ អស ៦៣:១១ គ នក ៤:១៦ ជន ៣៣:១

**៧៧:១០–២០** នៅក្នុងខទាំងនេះ បានរំឭកឱ្យឃើញពីឫទ្ធិបារមីរបស់ព្រះ ដែលទ្រង់បានធ្វើដល់ពួកអ៊ីស្រាអែលក្នុងគ្រានិក្ខមនំ ។

**៧៧:១០–១២** នៅក្នុងខនេះគឺចង់និយាយថា ដោយសារសេចក្ដីជំនឿបានធ្វើឱ្យមនុស្សម្នាក់ហ៊ានសម្រេចចិត្ត ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលមានក្នុងពេលបច្ចុប្បន្ន ហើយការឆ្លើយតបរបស់ព្រះអម្ចាស់ដែលមើលទៅហាក់បីដូចជានៅស្ងៀម ធ្វើឱ្យគាត់ព្យាយាមរំឭកពីសេចក្ដីសង្គ្រោះដែលព្រះធ្លាប់ធ្វើកាលពីគ្រាមុន។

**៧៧:១០** *ដ៏ខ្ពស់បំផុត* សូមមើលការពន្យល់ ១៤:១៩ ។

**៧៧:១១,១៤** *ការអស្ចារ្យ* សូមមើលការពន្យល់ ៩:១ ត្រង់ពាក្យ "ការអស្ចារ្យ" ។

**៧៧:១៣–២០** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានរំឭកឱ្យឃើញការអស្ចារ្យរបស់ព្រះដែលទ្រង់ធ្វើក្នុងគ្រានិក្ខមនំ ។

**៧៧:១៣** នៅក្នុងខនេះ បានរំឭកឱ្យឃើញពីព្រះគម្ពីរ នក ១៥:១១ ។ *បរិសុទ្ធ* គេអាចនិយាយបានម្យ៉ាងទៀតថា "មានតែទ្រង់ទេដែលឃើញនៅក្នុងទីបរិសុទ្ធ"(សូមមើល ៦៣:២) ។

**៧៧:១៥** *ប្រោស* ពាក្យនេះជាញឹកញាប់មានន័យដូចគ្នានឹងពាក្យថា "លោះ" (មើល ៧៤:២) ។ *យ៉ូសែប* ជានិច្ចកាលអ្នកនិពន្ធនៅក្នុងសញ្ញាចាស់តែងតែនិយាយអំពីនគរខាងជើងថាជា "យ៉ូសែប" (ឬ "អេប្រាអិម" ជាកូនរបស់យ៉ូសែប) ដែលមានចម្ងាយដ៏ឆ្ងាយពីពួកយូដានគរខាងត្បូង (មើល ៧៨:៦៧ ២សយ ១៩:២០ ១ពវ ១១:២៨ អគ ៣៧:១៦,១៩ អម ៥:៦,១៥ ៦:៦ សក ១០:៦) ។ ទោះបីជាបែបនេះក៏ដោយ នៅទីនេះ និងកន្លែងផ្សេងៗទៀត (មើល ៨០:១ ៨១:៥ អប ខ.១៨) ពាក្យថា "យ៉ូសែប" គឺជាកូនច្បងដែលមានមុខដំណែងដ៏ខ្ពស់ (មើល លប ៤៨:៥ និងការពន្យល់ យប ១៦:១–៤ ១រប ៥:២ អគ ៤៧:១៣) ដែលតំណាងឱ្យកូនចៅជំនាន់ក្រោយទាំងតំណររបស់គាត់ និងកូនចៅរបស់យ៉ាកុប ។

**៧៧:១៦–១៩** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានបំផុសគំនិតយ៉ាងល្អដើម្បីពណ៌នាការអស្ចារ្យរបស់ព្រះ ដែលបានបើកសម្ដែងឱ្យឃើញក្នុងគ្រាដែលទ្រង់បានញែកទឹកសមុទ្រក្រហម (មើល ៧៤:១៣–១៥) ។ នៅក្នុង ខ.១៦, ១៩ បានពណ៌នាពីព្រឹត្តិការណ៍នៃការអស្ចារ្យ ដែលទ្រង់បានធ្វើនៅត្រង់សមុទ្រក្រហមហើយខដែលស្ថិតនៅចន្លោះ (ខ.១៧–១៨) បានរំឭកឱ្យឃើញពីអំណាចឫទ្ធិរបស់ព្រះអង្គ ដែលទ្រង់បានបង្ហាញតាមរយៈផ្គរលាន់ ខ្យល់កួច និងផែនដីញ័រកក្រើក ។ នៅក្នុង នក ១៤:៩ គឺគ្រាន់តែពណ៌នាពីពពករបស់ព្រះអម្ចាស់ប៉ុណ្ណោះ ដោយមិនបាននិយាយពីផ្គរលាន់ ខ្យល់ព្យុះ ឬការញ័ររញ្ជួយនៃផែនដីឡើយ ប៉ុន្តែនៅក្នុងពាក្យឃ្លោងរបស់ភាសាហេព្រើរជាញឹកញាប់តែងតែភ្ជាប់មកជាមួយឃ្លាទាំងនេះ ដើម្បីពណ៌នាពីការយាងមករបស់ព្រះយេហូវ៉ា ដើម្បីជួយសង្គ្រោះរាស្ត្រទ្រង់ ឬក៏ជំនុំជំរះ ។ គ្មានអ្វីដែលគួរឱ្យសង្ស័យឡើយ ពីព្រោះពាក្យទាំង២នេះគឺជាពាក្យដែលគួរឱ្យភ័យខ្លាចបំផុត ដែលបានបង្ហាញពីអំណាចចេស្ដារបស់ព្រះអង្គ (សូមមើលក្នុង ១៨:១២–១៤ ៦៨:៨ ពច ៥:៤–៥ ហប ៣:៦,១០) ។ នៅនេះអ្នកនិពន្ធគាត់បានប្រកាសថា គឺជាព្រះនៃផ្គរលាន់ ខ្យល់ព្យុះ និងជាអ្នកដែលធ្វើឱ្យដែលមានការញ័ររញ្ជួយនៃផែនដី ជាអ្នកដែលបង្ហាញអំណាចចេស្ដារបស់ទ្រង់តាមរយៈការញែកទឹកសមុទ្រឱ្យរាស្ត្រទ្រង់ឆ្លងផុតពីភាពជាទាសករ ។

**៧៧:១៧** *ធ្នូ* ធ្នូដែលនិយាយនៅទីនេះគឺសំដៅលើផ្លេកបន្ទោរ (មើលការពន្យល់ លប ៩:១៣) ។

**៧៧:២០** អ្វីដែលបាននិយាយនៅក្នុង ខ.១៥ ត្រូវបានសម្រេចក្នុងខនេះ (មើលសេចក្ដីផ្ដើម)។ *ទ្រង់បាននាំរាស្ត្រទ្រង់* គឺសំដៅលើការនាំឆ្លងទីរហោស្ថានស៊ីណាយ ។ *ដូចជាហ្វូងចៀម* សូមមើល ២៣:១ ៧៤:១ និងការពន្យល់ ។

សេចក្ដីបង្រៀនរបស់អេសាភ ។
**៧៨** ឱសាសន៍របស់ខ្ញុំអើយ
ចូរប្រុងត្រចៀកស្ដាប់សេចក្ដីបង្រៀនរបស់ខ្ញុំ[ក]
ហើយផ្ទៀងត្រចៀកស្ដាប់អស់ទាំងពាក្យដែលចេញពីមាត់
ខ្ញុំចុះ
២ ខ្ញុំនឹងបើកមាត់បញ្ចេញជាសេចក្ដីប្រៀបធៀប[ខ]
ហើយនិងពោលជាសេចក្ដីអាថ៌កំបាំងពីចាស់បូរាណ
៣ ជាសេចក្ដីដែលពួកយើងធ្លាប់បានឮបានដឹងហើយ
ដែលឪពុកយើងបានប្រាប់តៗមក[គ]
៤ យើងក៏មិនលាក់សេចក្ដីទាំងនោះទុកចំពោះកូនចៅរបស់
គាត់ដែរ[ឃ] គឺនឹងប្រកាសពីអស់ទាំងសេចក្ដីសរសើរនៃ
ព្រះយេហូវ៉ា ដល់ដំណមនុស្សជាន់ក្រោយឱ្យបានស្ដាប់[ង]
ព្រមទាំងឥទ្ធានុភាព[ច]និងការអស្ចារ្យ[ឆ]ដែលទ្រង់បានធ្វើផង
៥ ដ្បិតទ្រង់បានតាំងឱ្យមានទីបន្ទាល់[ជ] នៅក្នុងពួកយ៉ាកុប[ឈ]
ក៏បានដំរូវឱ្យមានក្រិត្យវិន័យនៅក្នុងពួកអ៊ីស្រាអែល
ជាច្បាប់ដែលទ្រង់បានបង្គាប់ដល់ពួកឰយុកោរបស់យើង
ប្រយោជន៍នឹងបង្រៀនឱ្យពួកកូនចៅបានដឹងតរៀងទៅ
៦ ដើម្បីឱ្យដំណមនុស្សជាន់ក្រោយបានស្គាល់
គឺទាំងកូនចៅដែលត្រូវកើតតទៅ[ញ]
ជាពួកអ្នកដែលនឹងកើតឡើង
ហើយប្រាប់ដល់កូនចៅគេតទៅទៀត
៧ សំរាប់ឱ្យគេបានតាំងចិត្តសង្ឃឹមដល់ព្រះ
ឥតភ្លេច[ដ]អស់ទាំងការនៃទ្រង់ឡើយ

**៧៨:១** ក អស ៥១:៤ ៥៥:៣
**៧៨:២** ខ ទដ ៤៩:៤ មថ ១៣:៣៥
**៧៨:៣** គ ពច ៦:១៣
**៧៨:៤** ឃ ចទ ១១:១៩ ង ចទ ៣២:៧ ទដ ៧១:១៨ ច ទដ ២៦:៧ ៧១:១៧ ឆ យប ៥:៩
**៧៨:៥** ជ ទដ ១៩:៧ ៨១:៥ ឈ ទដ ១៤៧:១៩
**៧៨:៦** ញ ទដ ២២:៣១
**៧៨:៧** ដ ចទ ៦:១២ ឋ ចទ ៥:២៩

**ទដ ៧៨** នៅក្នុងបទគម្ពីរទំនុកដំកើងជំពូកនេះ មិនបានរំឭកឱ្យឃើញពីអំពើបាបរបស់ពួកអ៊ីស្រាអែលដែលពួកគេបានប្រព្រឹត្តកន្លងមកនោះឡើយ ប៉ុន្តែវាប្រភេទទំនុកដំកើងបែបបង្រៀននិងប្រមានវិញ ។ មិនតែប៉ុណ្ណោះបទគម្ពីរនេះបានរំឭកឱ្យឃើញពីសេចក្ដីសង្គ្រោះរបស់ព្រះ ដែលទ្រង់បានជួយដល់ពួកគេដោយព្រះគុណ និងរំឭកឱ្យពួកគេបានរក្សាជំនឿក្នុងព្រះអង្គ និងសេចក្ដីសញ្ញា ។ នៅទីនេះក៏ដូចជានៅកន្លែងផ្សេងៗដែរ កាលណានិយាយពីពាក្យថា ទុកចិត្ត និងស្មោះត្រង់ចំពោះព្រះរបស់រាស្ត្រទ្រង់ គឺនិយាយដោយផ្អែកលើសេចក្ដីសញ្ញា ។ ពួកគេមិនបានងាកចេញពីជំនឿលើអរូបបិយនោះឡើយ (ដូចជាទំនាក់ទំនងរវាងព្រះនិងមនុស្ស) ឬស្មារតីរបស់មនុស្សឡើយ (ដូចជាអារម្មណ៍ដែលពឹងលើ"ព្រះ") ប៉ុន្តែពួកគេមិនបានចងចាំពីការដែលព្រះបានសង្គ្រោះពួកគេវិញ ។ ការគ្មានសេចក្ដីជំនឿ គឺត្រូវបានបន្ទោសយ៉ាងខ្លាំង ពីព្រោះគេបានមើលងាយចំពោះការអស្ចារ្យរបស់ព្រះ (សូមមើល ទដ ១០៥–១០៦) ។

បទគម្ពីរទំនុកដំកើងនេះប្រហែលតែងឡើង ក្នុងគ្រាដែលមានស្ដេចហើយប្រហែលក្នុងគ្រាហោរាហូសេ (ជាញឹកញាប់ហោរាហូសេ និងអេសាយតែងតែនិយាយពីនគរខាងជើងថា អេប្រាអិម ពីព្រោះជាអំបូរដែលមានអំណាច) ។ ការមិនស្មោះត្រង់របស់ពួកអ៊ីស្រាអែលដែលនិយាយនៅទីនេះ គឺជាការសង្ខេបពីអំពើបាបរបស់ពួកអេប្រាអិម (មើល ខ.៩) ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ បានបញ្ចប់ដោយការរំឭកពីការដែលព្រះ "បដិសេធ" ដល់ពួកអ៊ីស្រាអែល (មើល ខ.៥៩) និងការបោះបង់ស៊ីឡូ (មើល ខ.៦០) ប៉ុន្តែព្រះអង្គរើសយូដា និងភ្នំស៊ីយ៉ូនវិញ (មើល ខ.៦៨) ។

ដោយសារបទគម្ពីរទំនុកដំកើងជំពូកនេះស្ថិតនៅបន្ទាប់ពី ទដ ៧៧ នោះអ្នកត្រួតពិនិត្យព្រះគម្ពីរទំនុកដំកើង គាត់បានឱ្យតម្លៃដាវីឌប្រហាក់ប្រហែលគ្នានិងលោកម៉ូសេ (ហើយអើរ៉ុន) ក្នុងនាមជាអ្នកគង្វាលរបស់ព្រះយេហូវ៉ា ដែលមានតួរនាទីជាអ្នកឃ្វាលរាស្ត្ររបស់ព្រះអង្គ (មើល ខ.៧០–៧២ ៧៧:២០) ជាអ្នកដែលបាននាំរាស្ត្ររបស់ព្រះចាកចេញ (បណ្ដោះអាសន្ន) និងបង្កើតផលដោយការច្បាំងដណ្ដើមបានទឹកដីសន្យាដែលការនោះ ជាទស្សនៈអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបានមើលឃើញ ។

ព្រះគម្ពីរទំនុកដំកើងជំពូកនេះ បានតែងឡើងមាន៧៧បន្ទាត់ (ក្នុងភាសាហេព្រើរ) ដែលមាន ៧២ខ និង៧ល្បះ ដែលក្នុង១ល្បះមាន១១បន្ទាត់ដែលនិយាយពីសេចក្ដីបង្រៀន ។ បន្ទាប់ពីសេចក្ដីបង្រៀន លក្ខណៈសំណង់ប្រយោគក្នុងល្បះនិមួយៗ គឺមានភាពសមាមាត្រជាមួយគ្នា ដោយមាន៨បន្ទាត់ ១៦បន្ទាត់ ៩បន្ទាត់ ១៦បន្ទាត់ ៩បន្ទាត់ និង៨បន្ទាត់ ។

**៧៨ ត្រង់ចំណងជើង** *សេចក្ដីបង្រៀន* សូមមើលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។ *អេសាភ* មើលការពន្យល់ ទដ ៧៣ ត្រង់ចំណងជើង ។

**៧៨:១–៨** នៅក្នុងខទាំងនេះចង់និយាយថា ដើម្បីឱ្យបានដឹងថាពួកគេស្មោះត្រង់ចំពោះព្រះយេហូវ៉ា នោះពួកគេត្រូវតែថ្លែងប្រាប់ពីព្រះអង្គដល់កូនចៅរបស់ពួកគេ "កូនចៅរបស់យើងត្រូវតែឮពីអ្វីដែលឪពុករបស់យើងបានប្រាប់យើង" ។

**៧៨:១–២** នៅក្នុងខទាំងនេះគឺជាសេក្ដីផ្ដើម ដែលអ្នកនិពន្ធបានសរសេរឡើងតាមបែបគតិបណ្ឌិត (សូមមើល ទដ ៤៩:១–៤) ។

**៧៨:២** *សេចក្ដីប្រៀបធៀប . . . សេចក្ដីអាថ៌កំបាំង* ពាក្យទាំង២នេះគឺត្រូវបានគេប្រើក្នុងទម្រង់វិសេស ហើយពាក្យទាំង២នេះក៏ជាពាក្យយ៉ាងសាមញ្ញាមួយដែលគេនិយមប្រើ ដើម្បីជាសេចក្ដីបង្រៀនក្នុងទម្រង់ផ្សេងៗគ្នា (មើលការពន្យល់ ៤៩:១៤) ។ *សេចក្ដីអាថ៌កំបាំងពីចាស់បុរាណ* នៅក្នុងឃ្លានេះចង់និយាយសំដៅលើសេចក្ដីបង្រៀន ដែលមានតាំងពីសម័យកាលមុន ។ នៅក្នុង មថ ១៣:៣៥ ព្រះយេស៊ូវបានប្រើទំនាយនៅក្នុងខនេះជាសេចក្ដីបង្រៀនបែបប្រៀបប្រដូច ។ តែទោះបីជាយ៉ាងណាក៏ដោយការប្រើពាក្យប្រៀបប្រដូចក្នុងទំនុកដំកើងជំពូកនេះ គឺភាគច្រើនដូចគ្នានឹងសេចក្ដីបង្រៀនរបស់ស្ទេផាន(កច ៧)ជាសេចក្ដីប្រៀបប្រដូចអំពីព្រះយេស៊ូវគ្រីស្ទ ។

**៧៨:៤–៥** នៅក្នុងខនេះគឺនិយាយពីសេចក្ដីសង្គ្រោះរបស់ព្រះ និងសេចក្ដីសញ្ញារបស់ទ្រង់ ។ សេចក្ដីសង្គ្រោះ និងសេចក្ដីសញ្ញាគឺត្រូវតែលើកយកមកបង្រៀន ហើយត្រូវតែមានទំនាក់ទំនងជាមួយគ្នា ពីព្រោះពាក្យនេះគឺជាចំណុចប្រសព្វនៃសេចក្ដីជំនឿ និងការស្ដាប់បង្គាប់គ្រប់ទាំងតំណរតទៅ (សូមមើល ខ.៧–៨) ។

**៧៨:៤** *មិនលាក់* សូមមើល យប ១៥:១៨ ។

**៧៨:៥** *បង្រៀនឱ្យពួកកូនចៅ* មើល នក ១០:២ ១២:២៦–២៧ ១៣:៨,១៤ ចទ ៤:៩ ៦:២០–២១ ។

គឺកាន់តាមអស់ទាំងសេចក្ដីបង្គាប់របស់ទ្រង់វិញ[ឋ]
៨ ដើម្បីកុំឱ្យគេបានដូចជាពួកឰយុកោ[ឌ]ជាដំណមនុស្សរឹងរូស[ឍ] ហើយបះបោរ[ណ]ជាដំណមនុស្សដែលមិនបានតាំងចិត្តឱ្យទៀងត្រង់ ហើយវិញ្ញាណគេក៏មិនស្មោះចំពោះព្រះនោះឡើយ ។
៩ ឯពួកកូនចៅអេប្រាអិមដែលមានគ្រឿងធ្នូ[ត]
ហើយក៏ប្រសប់បាញ់ គេបានបែរខ្នងនៅថ្ងៃសឹកសង្គ្រាម[ថ]
១០ គេមិនបានកាន់តាមសេចក្ដីសញ្ញារបស់ព្រះ[ទ]
ក៏មិនព្រមប្រព្រឹត្តតាមក្រិត្យវិន័យទ្រង់សោះ[ធ]
១១ គេបានភ្លេចអស់ទាំងកិច្ចដែលទ្រង់ធ្វើ[ន]
ព្រមទាំងការអស្ចារ្យ
ដែលទ្រង់បានសំដែងឱ្យគេឃើញដែរ
១២ ទ្រង់បានធ្វើការចំឡែក[ប] នៅភ្នែកពួកឰយុកោគេ
នៅស្រុកអេស៊ីព្ទ[ផ] ត្រង់វាលសូអាន[ព]
១៣ ទ្រង់បានវែកសមុទ្រ[ភ] បើកជាផ្លូវឱ្យគេដើរឆ្លងទៅ
ក៏បានធ្វើឱ្យទឹកឈរឡើងដូចជាកំផែង[ម]
១៤ នៅវេលាថ្ងៃទ្រង់បាននាំគេ ដោយពពក
ហើយវេលាយប់ទាល់ព្រឹក បាននាំដោយពន្លឺនៃភ្លើងវិញ[យ]
១៥ ទ្រង់បំប្រេះថ្មដា[រ] នៅទីរហោស្ថាន
ឱ្យគេបានផឹកទឹកជាបរិបូរ ដូចជាហូរចេញពីទីជំរៅមក
១៦ ទ្រង់បានធ្វើឱ្យមានទឹកចេញពីថ្មហូរចុះមកដូចជាទន្លេ ។
១៧ ទោះបីយ៉ាងនោះ គង់តែគេនៅតែធ្វើបាប[ល]នឹងទ្រង់ទៀត
ជាការបះបោរនឹងព្រះដ៏ខ្ពស់បំផុតត្រង់ទីរហោស្ថាន
១៨ គេបានល្បងលព្រះនៅក្នុងចិត្តគេ[វ]
ដោយសូមអាហារតាមគេប្រាថ្នា[ស]
១៩ អើ គេបាននិយាយទំនាស់នឹងព្រះ[ហ] ដោយពាក្យថា
តើព្រះទ្រង់អាចនឹងចាត់ចែងឱ្យមានអាហារបរិភោគនៅទីរហោស្ថាននេះបានឬ
២០ មើល ទ្រង់បានវាយថ្មដា ឱ្យមានទឹកផុលចេញ[ឡ]
ហើយឱ្យជ្រោះមានទឹកជន់លិចច្រាំង ដូច្នេះ
តើទ្រង់អាចនឹងប្រទានឱ្យមាននំបុ័ងដែរឬ
តើទ្រង់នឹងផ្គត់ផ្គង់ ឱ្យរាស្ត្រទ្រង់មានសាច់[អ]បរិភោគឬអី
២១ ហេតុនោះ ព្រះយេហូវ៉ាទ្រង់ក៏ឮ
ហើយមានសេចក្ដីក្រោធ រួចមានភ្លើងឆួលឡើង[ក]
បញ្ឆេះពួកយ៉ាកុប មានសេចក្ដីខ្ញាល់ចេញទៅទាស់នឹង

**៧៨:៨** ឌ ២របា ៣០:៧ ឍ នក ៣២:៩ ណ នក ២៣:២១ ចទ ២១:១៨ អស ៣០:៩ ៦៥:២ **៧៨:៩** ត ខ.៥៧ ១របា ១២:២ ហស ៧:១៦ ថ ពច ២០:៣៩ **៧៨:១០** ទ យស ៧:១១ ២ពវ ១៧:១៥ ធ នក ១៦:២៨ យរ ១១:៨ **៧៨:១១** ន ទដ ១០៦:១៣ **៧៨:១២** ប នហ ៩:១៧ ទដ ១០៦:២២ ផ នក ១១:៩ ប ជន ១៣:២២ **៧៨:១៣** ភ នក ១៤:២១ ទដ ៦៦:៦ ១៣៦:១៣ ម នក ១៤:២២ ១៥:៨ **៧៨:១៤** យ នក ១៣:២១ ទដ ១០៥:៣៩ **៧៨:១៥** រ ជន ២០:១១ ១កថ ១០:៤ **៧៨:១៧** ល ខ.៣២,៤០ ចទ ៩:២២ អស ៣០:១ ៦៣:១០ ហព ៣:១៦ **៧៨:១៨** វ នក ១៧:២ ១កថ ១០:៩ ស នក ១៥:២៤ ជន ១១:៤ **៧៨:១៩** ហ ជន ២១:៥ **៧៨:២០** ឡ ជន ២០:១១ អស ៣៥:៦ អ ជន ១១:១៨ **៧៨:២១** ក ជន ១១:១

**៧៨:៨** *រឹងរូស ហើយបះបោរ* ពួកគេបានបះបោរជាមួយព្រះដូចគ្នា និងកូនដែលបះបោរនឹងឪពុកដែរ (មើល ចទ ៩:៦–៧,២៤ ៣១:២៧) ។ *កូនចៅ* នៅទីនេះគឺនិយាយសំដៅលើមនុស្សដែលមានសណ្ដានចិត្តល្អ (មើល ២៤:៦ ចទ ៣២:៥,២០) ដែលមិនដែលមានពេលកំណត់ឡើយ ចាប់តាំងពីពេលក្នុងគ្រានិក្ខមនំ (មើល ខ.៩–១១,៥៦–៦៤) ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៧៨:៩–១៦** នគរខាងជើងបានប្រព្រឹត្តល្មើសនឹងក្រឹត្យវិន័យរបស់ព្រះ ដោយពួកគេមិនបាននឹកចាំពីសេចក្ដីសង្គ្រោះរបស់ទ្រង់ (ព្រះរាជសារនេះបានប្រកាសដោយហោរា អេម៉ុស និងហូសេ) ។ ប្រវត្តិសាស្ត្ររបស់ពួកអ៊ីស្រាអែល គឺបានប្រព្រឹត្តល្មើសនឹងក្រឹត្យវិន័យរបស់ព្រះជាយូរមកហើយ (មើល ខ.៩–១៦,៣២–៣៩,៥៦–៦៤) ជាក់ស្តែងដូចជាក្នុងទីរហោស្ថាន (មើល ខ.១៧–៣១,៤០–៥៥) ។

**៧៨:៩** *ពួកកូនចៅអេប្រាអិម* គឺជាពួកនគរខាងជើងដែលត្រួតត្រាលើអំបូរអេប្រាអិម (មើលក្នុងសេចក្ដីផ្ដើម) ។ នៅក្នុងខ.នេះមិនបាននិយាយថា ពួកអេប្រាអិមហើយ និងអ្នកដែលរស់នៅក្នុងនគរខាងជើង ខ្លាចបរាជ័យក្នុងការធ្វើសង្គ្រាមនោះឡើយ (មើល ចទ ៣៣:១៧) ។ អ្វីដែលនិយាយនៅក្នុងខទាំងនេះ គឺជាពាក្យប្រៀបប្រដូចទៅនឹងការដែលពួកអ៊ីស្រាអែលគេបានក្បត់នឹងសេចក្ដីសញ្ញារបស់ព្រះ (មើល ខ.១០) ហើយមានទំនាក់ទំនងទៅនឹងពាក្យប្រៀបប្រដូចទៀតគឺ "ធ្នូមិនត្រង់" (មើល ខ.៥៧) ។

**៧៨:១២–១៦** នៅក្នុងខនេះ គឺជាសេចក្ដីសង្ខេបពីគ្រោះចង្រៃដែលមាននៅក្នុងស្រុកអេស៊ីព្ទ និងការអស្ចារ្យនៅត្រង់សមុទ្រក្រហម ព្រមទាំងក្នុងទីរហោស្ថាន ។

**៧៨:១២** សូមមើល នក ជំពូក ៧–១២។ *វាលសូអាន* មានទីតាំងនៅភាគខាងជើងទន្លេនីល (មើល ខ.៤៣ ជន ១៣:២២ និងការពន្យល់) ។

**៧៨:១៣** សូមមើល នក ១៤:១–១៥:២១ ។

**៧៨:១៥–១៦** សូមមើល ខ.២០ នក ១៧:៦ ជន ២០:៨,១០–១១ ។

**៧៨:១៧–៣១** នៅក្នុងខទាំងនេះ និយាយពីការបះបោររបស់អ៊ីស្រាអែល និងការដែលព្រះបានផ្គត់ផ្គង់អាហារដល់ពួកគេ ព្រមទាំងនិយាយពីសេចក្ដីក្រោធរបស់ទ្រង់ ។

**៧៨:១៧** *នៅធ្វើ* នៅក្នុងឃ្លានេះចង់និយាយថា ទោះបីជាមិនបានដឹងថាតើអំពើបាបណាមួយ ដែលគេប្រព្រិត្តនៅត្រង់ទីរហោស្ថានក៏ដោយ ក៏ប្រហែលអ្នកនិពន្ធគាត់បានសង្ឃឹមលើពួកអ្នកអានថា ពួកគេនឹងនឹកទៅដល់គ្រាដែលពួកបណ្ដាជននេះគេបះបោរ ត្អូញត្អែរនឹងព្រះនៅត្រង់ម៉ារាដោយព្រោះគេខ្វះទឹក (មើល នក ១៥:២៤) ។ *ដ៏ខ្ពស់បំផុត* មើល ខ.៣៥,៥៦ និងការពន្យល់ក្នុង លប ១៤:១៩ ។

**៧៨:១៨** សូមមើល នក ១៦:២–៣ ។ *គេបានល្បងលព្រះ* សូមមើល ខ.៤១,៥៦ និងការពន្យល់ នក ១៧:២ ។

**៧៨:១៩** *តើព្រះទ្រង់អាចនឹងចាត់ចែងឱ្យមានអាហារបរិភោគនៅទីរហោស្ថាន* សូមមើលការប្រើរូបភាពផ្សេងពីនេះទៀតនៅក្នុង ២៣:៥ ។

**៧៨:២០** *នំបុ័ង . . . សាច់* នៅពេលនេះប្រហែលអ្នកនិពន្ធគាត់ដាក់បញ្ចូលគ្នារវាងឧបកថា២ (សូមមើល នក ១៦:២–៣ ជន ១១:៤) ។

**៧៨:២១** *សេចក្ដីក្រោធ* សូមមើល ខ.៣១,៤៩–៥០,៥៨–៥៩,៦២ និងការពន្យល់ ២:៥ ។

អ៊ីស្រាអែល
២២ ដោយព្រោះគេមិនបានជឿដល់ព្រះ
ក៏មិនបានទុកចិត្ត[ខ]នឹងសេចក្ដីសង្គ្រោះរបស់ទ្រង់ផង
២៣ ទ្រង់បានបង្គាប់ដល់ផ្ទៃមេឃនៅខាងលើក៏បានបើកទ្វារ
នៃស្ថានសួគ៌[គ]
២៤ ហើយបង្អុរនំម៉ាន៉ា[ឃ] ឱ្យធ្លាក់មកលើគេ
ដូចជាភ្លៀងសំរាប់គេបរិភោគ
គឺទ្រង់ប្រទានអាហារពីស្ថានសួគ៌ដល់គេ
២៥ គេបានបរិភោគនំរបស់ពួកទេវតាទាំងអស់គ្នា
ទ្រង់បានផ្ញើអាហារមកគេឱ្យបានឆ្អែត ។
២៦ ទ្រង់បានធ្វើឱ្យខ្យល់[ង]ពីទិសខាងកើតបក់នៅលើមេឃ
ហើយបាននាំខ្យល់ពីទិសខាងត្បូងដោយព្រះចេស្ដារបស់
ទ្រង់
២៧ ក៏ទំលាក់សាច់មកលើគេដូចជាធូលីដី
គឺជាសត្វស្លាប[ច]ជាច្រើន ដូចជាខ្សាច់នៅសមុទ្រ
២៨ ទ្រង់ឱ្យធ្លាក់នៅព័ទ្ធជុំវិញលំនៅរបស់គេ
គឺនៅកណ្ដាលទីដំឡើងត្រសាល
២៩ ដូច្នេះ គេក៏បរិភោគទៅ ហើយបានឆ្អែត[ឆ] ពេញបន្ទុក
ទ្រង់បានប្រទានឱ្យ តាមបំណងចិត្តគេ
៣០ គឺគេមិនទាន់អស់អាល័យក្នុងចិត្ត
ហើយកាលអាហារនោះនៅក្នុងមាត់គេនៅឡើយ[ជ]
៣១ នោះសេចក្ដីខ្ញាល់របស់ព្រះ បានឆួលឡើងទាស់នឹងគេ
ព្រមទាំងសំឡាប់អស់អ្នកដែលធាត់ៗ[ឈ]ក្នុងពួកគេ
ហើយវាយផ្ដួលពួកកំឡោះៗនៃសាសន៍អ៊ីស្រាអែលផង ។
៣២ ទោះបើយ៉ាងនោះក៏ដោយ
គង់តែគេនៅតែធ្វើបាបទៀត[ញ]
គេមិនព្រមជឿ[ដ]ការអស្ចារ្យ[ឋ]របស់ទ្រង់ឡើយ
៣៣ ហេតុនោះ ទ្រង់បានធ្វើឱ្យអស់ទាំងថ្ងៃរបស់គេកន្លង
ទៅជាឥតប្រយោជន៍[ឌ] ហើយអស់ទាំងឆ្នាំគេ
ដោយសេចក្ដីស្ញែងខ្លាច
៣៤ វេលាណាដែលទ្រង់ប្រហារពួកគេ ទើបគេសួររក[ឍ]ទ្រង់
ហើយត្រឡប់មកស្វែងរកព្រះអស់ពីចិត្ត
៣៥ គេក៏នឹកចាំថា ព្រះទ្រង់ជាថ្មដារបស់ខ្លួនគេ[ណ]
គឺព្រះដ៏ខ្ពស់បំផុត ទ្រង់ជាអ្នកប្រោសលោះដល់គេ[ត] ។
៣៦ គេបានលើកបញ្ចើចទ្រង់ដោយមាត់គេ[ថ]
តែអណ្ដាតរបស់គេបានកុហកទ្រង់ទេ
៣៧ ដ្បិតចិត្តគេមិនបានទៀងត្រង់[ទ] នៅចំពោះទ្រង់
ក៏មិនស្មោះចំពោះនឹងសេចក្ដីសញ្ញាទ្រង់ដែរ
៣៨ ប៉ុន្តែចំណែកទ្រង់មានសេចក្ដីមេត្តាករុណា[ធ]
បានជាទ្រង់អត់ទោស[ន] ចំពោះសេចក្ដីទុច្ចរិត[ប] របស់គេ
ហើយមិនបានបំផ្លាញគេទេ អើ
ទ្រង់បានបង្វែរសេចក្ដីខ្ញាល់[ផ]ទ្រង់ចេញជាញយៗ

**៧៨:១៧** ល ខ.៣២,៤០ ចទ ៩:២២ អស ៣០:១ ៦៣:១០ ហាព ៣:១៦ **៧៨:១៨** វ នក ១៧:២ ១កថ ១០:៩ ស នក ១៥:២៤ ជន ១១:៤ **៧៨:១៩** ហ ជន ២១:៥ **៧៨:២០** ឡ ជន ២០:១១ អស ៣៥:៦ អ ជន ១១:១៨ **៧៨:២១** ក ជន ១១:១

**៧៨:២២** ខ ចទ ១:៣២ ហាព ៣:១៩ **៧៨:២៣** គ លប ៧:១១ ២ពវ ៧:២ **៧៨:២៤** ឃ នក ១៦:៤ យហ ៦:៣១ **៧៨:២៦** ង ជន ១១:៣១ **៧៨:២៧** ច នក ១៦:១៣ ជន ១១:៣១ **៧៨:២៩** ឆ ជន ១១:២០ **៧៨:៣០** ជ ជន ១១:៣៣ **៧៨:៣១** ឈ អស ១០:១៦ **៧៨:៣២** ញ ខ.១៧ ដ ខ.២២ ឋ ខ.១១ **៧៨:៣៣** ឌ ជន ១៤:២៩ **៧៨:៣៤** ឍ ចទ ៤:២៩,៣៥ **៧៨:៣៥** ណ លប ៤៩:២៤ ត ចទ ៩:២៦ **៧៨:៣៦** ថ អគ ៣៣:៣១ **៧៨:៣៧** ទ ខ.៨ កថ ៩:២១ **៧៨:៣៨** ធ នក ៣៤:៦ ន អស ១:២៥ ២៧:៩ ៤៨:១០ ដយ ១១:៣៥ ប ទដ ២៥:១១ ៨៥:២ ផ យប ៩:១៣ អស ៣០:១៨

**៧៨:២៣** *បើកទ្វារនៃស្ថានសួគ៌* សូមមើល លប ៧:១១ ២ពវ ៧:២ មឡ ៣:១០ ។

**៧៨:២៥** *នំរបស់ពួកទេវតា* គេហៅដូច្នេះដោយព្រោះនំនោះគឺត្រូវបានប្រទានមកពីស្ថានសួគ៌ ។*ទេវតា* តាមភាសាអក្សរសាស្ត្រគឺ "អ្នកដែលមានអំណាច" ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះមានប្រើតែក្នុងកន្លែងនេះប៉ុណ្ណោះ ប៉ុន្តែគឺបានបញ្ជាក់ដែលជាការនិយាយសំដៅលើពួកអ្នកដែលរស់នៅស្ថានសួគ៌ (មើល ១០៣:២០) ។

**៧៨:២៦-២៨** សូមមើល នក ១៦:១៣ ជន ១១:៣១ ។

**៧៨:២៦** *ខ្យល់ពីទីសខាងកើត . . . នាំខ្យល់ពីទីសខាងត្បូង* ខ្យល់ពីទីសទាំង២នេះ គឺបក់មកពីអេស៊ីព្ទហើយមានកម្លាំងខ្លាំងដូចគ្នា ។ ខ្យល់ដែលបក់មកពីទីសខាងត្បូងប្រហែលគឺបក់នាំទៅទីសខាងជើង ហើយខ្យល់ដែលបក់ពីទីសខាងកើតប្រហែលបក់បង្វែរទៅទីរហោស្ថាន ចំកន្លែងដែលពួកអ៊ីស្រាអែលរស់នៅ (នៅក្នុងព្រះគម្ពីរនេហេមាមិនបាននិយាយពីខ្យល់ឡើយ) ។

**៧៨:២៧** *ដូចជាធូលីដី . . . ដូចជាខ្សាច់* ឃ្លានេះគឺជាការប្រៀបប្រដូចដែលចង់និយាយសំដៅលើចំនួនដ៏ច្រើន (មើលការពន្យល់ លប ១៣:១៦)។

**៧៨:៣០-៣១** សូមមើល នក ១១:៣៣ ។

**៧៨:៣២-៣៩** នៅក្នុងខទាំងនេះ ចង់និយាយអំពីការបះបោរដែលនាំឱ្យអ៊ីស្រាអែលមានផ្លូវនៃជីវិត ដែលមានតាំងពីគ្រាមុននៅក្នុងទីរហោស្ថាន (មើល ខ.១៧-៣១) និងបន្តរហូតក្នុងដំណើររបស់ពួកគេ ។

**៧៨:៣២** *មិនព្រមជឿ* គឺគេមិនជឿថាព្រះជាអ្នកប្រទានឱ្យគេមានជ័យជម្នះលើពួកកាណានឡើយ (សូមមើល ជន ១៤:១១) ។

**៧៨:៣៣** នៅក្នុងខ.នេះចង់បញ្ជាក់ថា ពួកកូនចៅដែលនិយាយនៅក្នុងគ្រាដែលបានចាកចេញពីស្រុកអេស៊ីព្ទ គឺត្រូវទទួលទណ្ឌកម្មរហូតដល់ស្លាប់នៅក្នុងទីរហោស្ថាន (សូមមើល ជន ១៤:២២-២៣,២៨-៣៥) ។

**៧៨:៣៤-៣៧** ហេតុការណ៍ដែលបាននិយាយនៅក្នុងខ.ទាំងនេះ គឺតែងតែកើតឡើងម្ដងហើយម្ដងទៀតក្នុងគ្រាដែលទ្រង់ជំនុំជម្រះ ។

**៧៨:៣៥** *ថ្មដា* សូមមើលការពន្យល់ ១៨:២ ។ *ប្រោសលោះ* គឺដោះលែង (សូមមើលការពន្យល់ នក ៦:៦)។

**៧៨:៣៦** សូមមើល អស ២៩:១៣ ។

**៧៨:៣៧** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**៧៨:៣៨** សូមមើលក្នុង នក ៣២:១៤ ជន ១៤:២០ ។ *អត់ទោស* សូមមើលការពន្យល់ ៦៥:៣ ។

ឥតឱ្យសេចក្តីក្រោធរបស់ទ្រង់ផុលឡើងទាំងអស់ឡើយ
៣៩ ទ្រង់បាននឹកចាំថា គេគ្រាន់តែជាសាច់ឈាមប៉ុណ្ណោះ[ព]
គឺជាខ្យល់[ភ]ដែលបក់កន្លងហួសទៅ ឥតមកវិញឡើយ ។
៤០ ប៉ុន្មានដងហើយ
ដែលគេបះបោរ[ម]នឹងទ្រង់ នៅទីរហោស្ថាន[យ]
ហើយនាំឱ្យព្រួយ[រ]ព្រះហឫទ័យនៅទីល្ហល្ហេវ
៤១ គឺគេបានបែរជាល្បងលព្រះវិញទៀត[ល]
ហើយគេបិទផ្លូវព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល[វ]
៤២ គេមិនបាននឹកចាំ[ស]ពីព្រះហស្តទ្រង់
ឬពីថ្ងៃដែលទ្រង់បានដោះគេចេញពីខ្មាំងសត្រូវ[ហ]
៤៣ ឬពីបែបយ៉ាងណាដែលទ្រង់បានសំដែងទីសំគាល់[ឡ]របស់
ទ្រង់នៅស្រុកអេស៊ីព្ទ និងការអស្ចារ្យ[អ]នៅទីវាលសូអាន
ឡើយ
៤៤ ទ្រង់បានធ្វើឱ្យទន្លេ នឹងព្រែករបស់សាសន៍
អេស៊ីព្ទត្រឡប់ទៅជាឈាម[ក] ឱ្យគេផឹកទឹកនោះមិនបាន
៤៥ ទ្រង់បានចាត់ហ្វូងរុយ[ខ]មកបង្ខិននៅកណ្តាលគេ
និងកង្កែប[គ]មកបំផ្លាញគេផង
៤៦ ទ្រង់បានប្រគល់ផលរបស់គេ ឱ្យចង្រិតកាត់[ឃ]
ហើយការរបស់គេដល់កណ្តូប[ង]
៤៧ ទ្រង់បានបំផ្លាញដើមទំពាំងបាយជូរគេដោយព្រឹល[ច]
ហើយដើមឧទុម្ពរដោយសន្សើមកក
៤៨ ទ្រង់ក៏ប្រគល់ហ្វូងគោគេឱ្យត្រូវព្រឹល
ហើយហ្វូងចៀម[ឆ]គេឱ្យត្រូវរន្ទះបាញ់ដែរ
៤៩ ទ្រង់បានបោះសេចក្តីខ្ញាល់ដ៏សហ័សទៅលើគេ[ជ]
ព្រមទាំងសេចក្តីក្រោធ
សេចក្តីគ្នាន់ក្នាញ់នឹងសេចក្តីវេទនាផង
គឺជាសេចក្តីអាក្រក់ទាំងហ្វូង ដែលទ្រង់ចាត់មក[ឈ]
៥០ ទ្រង់បានពង្រាបផ្លូវ សំរាប់សេចក្តីខ្ញាល់របស់ទ្រង់
ទ្រង់មិនបានប្រណីព្រលឹងគេឱ្យរួចពីស្លាប់ទេ
គឺបានប្រគល់ជីវិតគេដល់ជំងឺអាសន្នរោគ
៥១ ក៏បានប្រហារអស់ទាំងកូនច្បងនៅស្រុកអេស៊ីព្ទ[ញ]
គឺជាដើមកំឡាំងរបស់ហាំនៅក្នុងត្រសាលគេ[ដ] ។
៥២ ប៉ុន្តែ ទ្រង់បានកៀងនាំរាស្ត្រទ្រង់ចេញដូចជាចៀម[ឋ]
ហើយដឹកនាំគេនៅក្នុងទីរហោស្ថាន ដូចជាហ្វូងសត្វ
៥៣ ទ្រង់ក៏នាំគេទៅដោយសុខសាន្ត មិនឱ្យភ័យខ្លាចឡើយ
តែសមុទ្របានគ្រប[ឌ]លើពួកខ្មាំងសត្រូវគេវិញ[ឍ]
៥៤ ទ្រង់បាននាំគេទៅដល់ព្រំស្រុកបរិសុទ្ធរបស់ទ្រង់
គឺដល់ភ្នំនេះដែលព្រះហស្តស្តាំ[ណ]ទ្រង់បានវាយយក
៥៥ ទ្រង់បានបណ្តេញអស់ទាំងសាសន៍ដទៃ[ត]ពីមុខគេចេញ
ក៏វាស់ស្រុកនេះ ចែកដល់គេទុកជាមរដក[ថ]
ព្រមទាំងឱ្យពូជអំបូរសាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន
អាស្រ័យនៅក្នុងលំនៅរបស់សាសន៍ទាំងនោះ
៥៦ ប៉ុន្តែគេបានល្បងលព្រះដ៏ខ្ពស់បំផុតហើយបះបោរនឹង
ទ្រង់វិញ ឥតកាន់តាមសេចក្តីបញ្ញត្តទ្រង់ឡើយ
៥៧ គឺបានថយចេញ ហើយប្រព្រឹត្តដោយក្បត់

**៧៨:៣៩** ប លប ៦:៣ អស ២៩:៥ ភ យបប ៧:៧ យក ៤:១៤ **៧៨:៤០** ម នក ២៣:២១ យ ទដ ៩៥:៨ ១០៦:១៤ រ អភ ៤:៣០ **៧៨:៤១** ល នក ១៧:២ វ ២ពវ ១៩:២២ ទដ ៧១:២២ ៨៩:១៨ **៧៨:៤២** ស ពច ៣:៧ នហ ៩:១៧ ហ ទដ ២៧:១១ **៧៨:៤៣** ឡ នក ១០:១ អ នក ៣:២០ **៧៨:៤៤** ក នក ៧:២០,២១ ទដ ១០៥:២៩ **៧៨:៤៥** ខ នក ៨:២៤ ទដ ១០៥:៣១ គ នក ៨:២,៦ **៧៨:៤៦** ឃ ណហ ៣:១៥ ង នក ១០:១៣ **៧៨:៤៧** ច នក ៩:២៣ ទដ ១០៥:៣២ ១៤៧:១៧ **៧៨:៤៨** ឆ នក ៩:២៥ **៧៨:៤៩** ជ នក ១៥:៧ ឈ លប ១៩:១៣ ១កថ ១០:១០ **៧៨:៥១** ញ នក ១២:១២ ទដ ១៣៥:៨ ដ ទដ ១០៥:២៣ ១០៦:២២ **៧៨:៥២** ឋ យប ២១:១១ ទដ ២៨:៩ ៧៧:២០ **៧៨:៥៣** ឌ នក ១៤:២៨ ឍ នក ១៥:៧ ទដ ១០៦:១០ **៧៨:៥៤** ណ ទដ ៤៤:៣ **៧៨:៥៥** ត ទដ ៤៤:២ ថ ចទ ១:៣៨ យស ១៣:៧ កច ១៣:១៩

**៧៨:៣៩** សូមមើល ១០៣:១៤ និង ៣៩:៥ ៦២:៩ ១៤៤:៤ និងការពន្យល់ ។

**៧៨:៤០–៦៤** នៅក្នុងខទាំងនេះ គឺជាជុំទី២ (ជុំទី១គឺនៅក្នុង ខ.១៧–៣៩) ។

**៧៨:៤០–៥៥** នៅក្នុងខនេះ ចង់បង្ហាញពីការបះបោររបស់ពួកអ៊ីស្រាអែលដែលចាប់ផ្តើមឡើងនៅត្រង់ទីរហោស្ថាន ដោយព្រោះគេមិនបាននឹកចាំពីការដែលព្រះជួយដោះលែងពួកគេពីការគាបសង្កត់ និងភាពជាទាសករតាមរយៈការដែលព្រះអង្គបានវាយប្រហារពួកអេស៊ីព្ទ (មើល ខ.២) ។ ព្រះអង្គទ្រង់បាននាំគេឆ្លងកាត់សមុទ្រ និងទីរហោស្ថាន រួមទាំងបានសង់ពួកគេឡើងក្នុងទឹកដីសន្យា ។

**៧៨:៤១** *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើល ៧១:២២,៨៩:១៨ ២ពវ ១៩:២២ និងការពន្យល់ ។

**៧៨:៤៤–៥១** នៅក្នុងខទាំងនេះ បានពណ៌នាពីគ្រោះកាចដែលមាននៅក្នុងស្រុកអេស៊ីព្ទ (មើល នក ជំពូក ៧–១២) ។ ក្នុងចំណោមគ្រោះកាចដែលនិយាយនៅក្នុងគម្ពីរនិក្ខមនំមានតែគ្រោះកាចទី១ និងគ្រោះកាចចុងក្រោយប៉ុណ្ណោះ ដែលបានលើកយកនិយាយ ហើយគ្រោះកាចទី ៣ ទី៥ ទី៩ មិនបានលើកមកនិយាយឡើយ ។

**៧៨:៤៧** *ដើមឧទុម្ពរ* សូមមើលការពន្យល់ អម ៧:១៤ ។

**៤៨:៤៩** *សេចក្តីអាក្រក់ទាំងហ្វូង* នៅក្នុងឃ្លានេះអ្នកនិពន្ធបានពណ៌នាពីសេចក្តីកំហឹងរបស់ព្រះ ដែលទ្រង់បានខ្ញាល់យ៉ាងខ្លាំងប្រៀបដូចជាហ្វូងនៃទេវតារបស់ទ្រង់ដែលមានគ្នាដ៏ច្រើន ។

**៧៨:៥១** *ត្រសាល* គឺជាកន្លែងដែលគេស្នាក់អាស្រ័យ ។ *ហាំ* សូមមើលពីទំនាក់ទំនងរបស់ហាំ ជាមួយពួកអេស៊ីព្ទក្នុង ១០៥:២៣,២៧ ១០៦:២១–២២ លប ១០:៦ និងការពន្យល់ ។

**៧៨:៥២** *ដូចជាចៀម* សូមមើល ៧៧:២០ និងការពន្យល់ ។

**៧៨:៥៣** *សមុទ្រ* គឺចង់និយាយសំដៅលើសមុទ្រក្រហម ។

**៧៨:៥៥** នៅក្នុងខនេះ គឺជាសេចក្តីសង្ខេបសាច់រឿងដែលចេញពីព្រះគម្ពីរយ៉ូស្វេ ។

**៧៨:៥៦–៦៤** នៅក្នុងខទាំងនេះ ចង់និយាយពីការបន្តការបះបោររបស់ពួកអ៊ីស្រាអែល ក៏ជារបៀបដែលគេបានជីវិតក្នុងទឹកដីសន្យាដែរ (បានធ្វើឱ្យនឹកឃើញផ្ទៃរឿងស្តីពីការជំនុំជំរះ ហើយក៏សូមមើលក្នុង ១សយ ២:១២–៧:២) ដោយការនេះហើយទើបព្រះទ្រង់បានបោះបង់ចោលពួកគេ (សូមមើល ខ.៥៩ យរ ៧:១៥) ។

**៧៨:៥៧** *ធ្នូមិនត្រង់* សូមមើលការពន្យល់ក្នុង ខ.៩ ។

ដូចជាពួកព្យុះកោគេដែរ[ទ] គេក្រឡាច់រមួលដូចជាធ្នូមិនទ្រង់[ធ]
៥៨ គេបានធ្វើឱ្យព្រះហឫទ័យទ្រង់[ន]ថ្នាំងថ្នាក់ដោយទីខ្ពស់[ប]
របស់គេ ព្រមទាំងបណ្ដាលឱ្យទ្រង់ប្រចណ្ឌដោយរូបឆ្លាក់
របស់គេផង[ផ] ។
៥៩ កាលព្រះទ្រង់បានជ្រាប[ព] ហើយនោះទ្រង់មានសេចក្ដី
ក្រោធ[ភ] ហើយបានស្អប់ខ្ពើមដល់សាសន៍អ៊ីស្រាអែល[ម]ជា
ខ្លាំង
៦០ ដល់ម្ល៉េះបានជាទ្រង់លះបង់រោងឧបោសថដែលនៅត្រង់
ស៊ីឡូរ[យ]គឺជាត្រសាលដែលទ្រង់បានតាំងឱ្យនៅកណ្ដាល
ពួកមនុស្សលោក[រ]
៦១ ទ្រង់ក៏ប្រគល់ឥទ្ធិឫទ្ធិ[ល] របស់ទ្រង់ឱ្យទៅជាឈ្លើយ[វ]
ហើយសិរីល្អទ្រង់ទៅក្នុងកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ
៦២ ទ្រង់បានប្រគល់រាស្ត្រទ្រង់ដល់អំណាចដាវដែរ[ស]
ហើយមានសេចក្ដីក្រោធចំពោះមរដកទ្រង់[ហ]
៦៣ មានភ្លើងឆេះបំផ្លាញ[ឡ]ពួកកំលោះគេ ឯពួកក្រមុំរបស់គេ
ឥតមានអ្នកណាដណ្ដឹងឡើយ[អ]
៦៤ ពួកសង្ឃរបស់គេក៏ដួលស្លាប់ដោយដាវ[ក]
តែប្រពន្ធរបស់គេមិនបានយំសោកសោះ ។
៦៥ គ្រានោះ ព្រះអម្ចាស់ទ្រង់តើនឡើង[ខ]
ដូចជាមនុស្សដែលភ្ញាក់ពីដេកលក់
គឺដូចជាមនុស្សខ្លាំងពូកែដែលស្រែកហ៊ោដោយ
អំណាចស្រាទំពាំងបាយជូរ
៦៦ រួចទ្រង់វាយពួកដែលតតាំងនឹងទ្រង់ ឱ្យថយក្រោយ
ទ្រង់ឱ្យគេមានសេចក្ដីខ្មាសនៅជានិច្ច[គ]
៦៧ មួយទៀត
ទ្រង់មិនបានទទួលត្រសាលរបស់ ពួកយ៉ូសែបឡើយ
ក៏មិនបានរើសពូជអំបូរអេប្រាអិមដែរ[ឃ]

**៧៨:៥៧** ទ ២រប ៣០:៧ អគ ២០:២៧ ធ ខ.៩ **៧៨:៥៨** ន ពច ២:១២ ប លវ ២៦:៣០ ផ នក ២០:៤ ចទ ៥:៨ ៣២:២១ **៧៨:៥៩** ប ទដ ៥៥:១៩ ភ លវ ២៦:២៨ ជន ៣២:១៤ ម ចទ ៣២:១៩ **៧៨:៦០** យ យស ១៨:១ រ អគ ៨:៦ **៧៨:៦១** ល ទដ ១៣២:៨ វ ១សយ ១០:១ **៧៨:៦២** ស ចទ ២៨:២៥ ហ ១សយ ១០:១ **៧៨:៦៣** ឡ ជន ១១:១ អ ១ពវ ៤:៣២ យរ ៧:៣៤ ១៦:៩ ២៥:១០ **៧៨:៦៤** ក ១សយ ៤:១៧ **៧៨:៦៥** ខ ទដ ៤៤:២៣ **៧៨:៦៦** គ ១សយ ៥:៦ **៧៨:៦៧** ឃ យរ ៧:១៥ ហស ៩:១៣ ១២:១

**៧៨:៥៨** *ទីខ្ពស់* សូមមើលការពន្យល់ ១សយ ៩:១២ ។ *ប្រចណ្ឌ* នៅក្នុងឃ្លានេះ អ្នកនិពន្ធចង់និយាយពីបំណងព្រះហឫទ័យរបស់ព្រះ ដែលចង់បំផ្លាញដល់គាត់ (សូមមើលការពន្យល់ នក ២០:៥) ។

**៧៨:៥៩** *ស្អប់ខ្ពើមដល់ពួកអ៊ីស្រាអែលជាខ្លាំង* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា ព្រះបានប្រគល់ពួកអ៊ីស្រាអែលទៅឱ្យពួកខ្មាំងសត្រូវគេ ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គាត់មិនបាននិយាយពីការដែលព្រះគ្រល់ពួកអ៊ីស្រាអែល ទៅពួកខ្មាំងសត្រូវរហូតនោះឡើយសូម្បីតែអំបូរទាំង១០ ដែលនៅក្នុងនគរខាងជើងក៏ដោយ ។

**៧៨:៦០** *ស៊ីឡូរ* វាគឺជាមជ្ឈមណ្ឌលសម្រាប់ថ្វាយបង្គំដ៏សំខាន់មួយក្នុងសម័យកាលលោកយ៉ូស្វេ (សូមមើល យស ១៨:១,:១–២ ពច ១៨:៣១ ១សយ ១:៣ យរ ៧:១២) ។ ស៊ីឡូរមានទីតាំងស្ថិតនៅក្នុងតំបន់អេប្រាអិម ចន្លោះបេតអែលនិងស៊ីគែម (សូមមើល ពច២ ១:១៩) ។ ស៊ីឡូប្រហែលត្រូវបានពួកភីលីស្ទីនវាយបំផ្លាញ ក្នុងអំឡុងពេលដែលពួកគេចាប់បានហឹបនៃសេចក្ដីសញ្ញា ឬក្រោយគ្រាចាប់បានហឹបនៃសេចក្ដីសញ្ញាដ៏ខ្លីមួយ (សូមមើលការពន្យល់ យរ ៧:១២) ។

**៧៨:៦១** *ឥទ្ធិឫទ្ធិរបស់ទ្រង់ . . . សិរីល្អរបស់ទ្រង់* អ្នកនិពន្ធចង់និយាយថា ឥឡូវនេះហឹបនៃសេចក្ដីសញ្ញានៅទីនេះ ហើយដែលត្រូវបានគេហៅបែបដូច្នេះពីព្រោះហឹបនៃសេចក្ដីសញ្ញា គឺជានិមិត្តរូបនៃភាពជាស្ដេចរបស់ព្រះអង្គនៅលក្នុងពួកអ៊ីស្រាអែល និងជាចំណុចប្រសព្វគ្នាដើម្បីបង្ហាញពីអំណាច និងសិរីល្អរបស់ព្រះអម្ចាស់ (សូមមើលក្នុង ២៦:៨ ៦៣:២ ១សយ ៤:៣,២១–២២) ។

**៧៨:៦២,៧១** *មរដកទ្រង់* សូមមើល ចទ ៩:២៩ ។

**៧៨:៦៣** *ភ្លើង* ជានិច្ចកាលពាក្យនេះតែងតែមានទំនាក់ទំនងជាមួយដាវ (សូមមើល ខ.៦២,៦៤) ព្រោះវាមូលដ្ឋានគ្រឹះឧបករណ៍នៃការបំផ្លាញទាំង២ នៅក្នុងសម័យកាលបុរាណ ។ *ឯកូនក្រមុំរបស់គេ ឥតមានអ្នកដណ្ដឹងឡើយ* នៅក្នុងឃ្លានេះអ្នកនិពន្ធនិយាយសំដៅលើមហន្តរាយដ៏សង្វេកដែលសូម្បីតែបទចម្រៀងថ្ងៃមង្គលការ សម្រែករបស់ស្ត្រីមេម៉ាយ (សូម មើលក្នុង ខ.៦៤) ក៏មិនបានឮនៅក្នុងស្រុកនោះដែរ ។

**៧៨:៦៤** *ពួកសង្ឃរបស់គេក៏ដួលស្លាប់ដោយដាវ* មើលក ១សយ ៤:១១ ។

**៧៨:៦៥–៧២** នៅក្នុងខនេះ ចង់និយាយពីការដែលព្រះជ្រើសរើសអំបូរយូដា (ជំនួសឱ្យអំបូរអេប្រាអិម) ឱ្យធ្វើជាអ្នកដឹកនាំក្នុងអ៊ីស្រាអែល (បានសម្រេចតាមការប្រទានពររបស់យាកុបមុនពេលស្លាប់ លប ៤៩:៨–១២) នៅត្រង់ភ្នំស៊ីយ៉ូន (ជំនួសឱ្យស៊ីឡូរ) ជាទីបរិសុទ្ធ (ដំណាក់ស្ដេច) និងតាំងរាជរបស់ដាវីឌជាអ្នកគង្វាលឱ្យឃ្វាលលើហ្វូងរាស្ត្រទ្រង់ ។ ដោយការទាំងអស់នេះ ព្រះអម្ចាស់ទ្រង់បានស្ថាបនារាស្ត្រទ្រង់ឡើងក្នុងទឹកដីសន្យា ដែលមានពេញដោយសុវត្ថិភាព ចាប់តាំងពីគ្រាដែលអ៊ីស្រាអែលមានបញ្ហាជាយូរមកហើយគឺចាប់តាំងពីគ្រាយ៉ូស្វេស្លាប់ រហូតដល់គ្រាដែលស្ដេចសូលចូលទីវង្គត់ ហើយនិងសេចក្ដីសង្គ្រោះរបស់ព្រះដែលមានតាំងពីគ្រាដែលគេបានចាកចេញពីស្រុកអេស៊ីព្ទមក ក៏ត្រូវបានសម្រេចនៅពេលនេះ (សូមមើលសេចក្ដីផ្ដើម ទដ ៦៨) ។

**៧៨:៦៥** *ភ្ញាក់ពីដេក* នៅក្នុងឃ្លានេះ គឺសិល្បវិធីរបស់អ្នកនិពន្ធដើម្បីឱ្យអ្នកអានមានការចាប់អារម្មណ៍ ដើម្បីបង្ហាញពីការផ្ទុយគ្នាពីកិច្ចការងាររបស់ព្រះ ដែលទ្រង់បានបើកសម្ដែងក្នុងយុគសម័យកាលស្ដេចដាវីឌ និងក្នុងគ្រាដែលពួកអ៊ីស្រាអែលមានសេចក្ដីវេទនា (សូមមើលការពន្យល់ ៧:៦) ។

**៧៨:៦៦–៧២** សេចក្ដីសង្គ្រោះរបស់ព្រះ ត្រូវបានង្ហាញនូវចំណុច២ (១).ព្រះទ្រង់បានប្ដេជ្ញាថា នឹងយកជ័យជម្នះលើខ្មាំងសត្រូវឱ្យទាល់តែបាន និងសាងក្រុងស៊ីយ៉ូនជាក្រុងរបស់ព្រះ (២).តាំងដាវីឌជាអ្នកគង្វាលលើរាស្ត្ររបស់ព្រះ ។

**៧៨:៦៧** *ត្រសាលរបស់ពួកយ៉ូសែប* គឺនិយាយសំដៅលើអំបូរបេនយ៉ាមីន (សូមមើលអត្ថន័យ នៃពាក្យ "ត្រសាល" (ក្នុង ខ.៥១ ៦៩:២៥ ៨៣:៦ ៨៤:១០ ១២០:៥ លប ៩:២៧ ចទ ៣៣: ១៨ ១ពវ ១២:១៦ យប ៨:២២ ១២:៦ ហប ៣:៧ មឡ ២:១២) ។

៦៨ គឺទ្រង់បានរើសពូជអំបូរយូដា[ង] និងភ្នំស៊ីយ៉ូន[ច]
ដែលទ្រង់ស្រឡាញ់នោះវិញ
៦៩ ទ្រង់ក៏ស្អាងទីបរិសុទ្ធ[ឆ]នៃទ្រង់ ដូចជាអស់ទាំងកំពូលខ្ពស់
គឺដូចជាផែនដីដែលទ្រង់បានតាំងឱ្យជាប់ជាដរាបនោះផង
៧០ ទ្រង់ក៏រើសដាវីឌ[ជ] ជាអ្នកបំរើទ្រង់
ហើយនាំយកលោកចេញពីក្រោលចៀមមក
៧១ គឺទ្រង់នាំយកលោកពីការឃ្វាលមេចៀម[ឈ]ដែលមានកូន
ដើម្បីឱ្យធ្វើជាអ្នកគង្វាល[ញ]ដល់ពួកយ៉ាកុប ជារាស្ត្រទ្រង់
គឺពួកអ៊ីស្រាអែលដែលជាមរដករបស់ទ្រង់វិញ
៧២ ដូច្នេះ លោកក៏ធ្វើជាអ្នកគង្វាលឃ្វាលគេដោយចិត្ត
ទៀងត្រង់[ដ] ព្រមទាំងនាំផ្លូវគេ ដោយថ្វីដៃជំនាញ ។

**៧៨:៦៨** ង ជន ១:៧ ទដ ១០៨:៨ ច នក ១៥:១៧ ទដ ៦៨:១៦ **៧៨:៦៩** ឆ ទដ ១៥:១ **៧៨:៧០** ជ ១សយ ១៦:១ **៧៨:៧១** ឈ លប ៣៧:២ ញ ទដ ២៨:៩ **៧៨:៧២** ដ លប ១៧:១ **៧៩:១** ក នក ៣៤:៩

ទំនុករបស់អេសាភ ។

**៧៩** ឱព្រះអង្គអើយ ពួកសាសន៍ដទៃ
បានចូលរុករានក្នុងមរដកទ្រង់ហើយ[ក]
គេបានបង្អាប់[ខ]ព្រះវិហារ បរិសុទ្ធនទ្រង់

**៧៨:៦៨, ៧០** *ទ្រង់បានរើស . . . ភ្នំស៊ីយ៉ូន . . . ទ្រង់ក៏រើសដាវីឌ* សូមមើល ទដ ១៣២ ។

**៧៨:៦៩** *អស់ទាំងកំពូលខ្ពស់ . . . ដូចជាផែនដី* នៅក្នុងខនេះមានការកាត់ស្រាយ២គឺ (១).ព្រះយេហូវ៉ាទ្រង់នឹងសាងតំណាក់ដ៏រឹងមាំរបស់ទ្រង់ ដែលគ្មាននរណាអាចវាយដណ្តើមបានឡើយ ប្រៀបដូចជាភ្នំ ជាបន្ទាយ ដែលស្ថិតស្ថេរជានិច្ច គឺជាផែនដីចាស់ (២).ព្រះយេហូវ៉ាទ្រង់នឹងសង់ដំណាក់បរិសុទ្ធរបស់ទ្រង់ ដែលមានពេញដោយសេចក្តីសុខសាន្ត និងស្ថិតស្ថេរជានិច្ច គឺជាផ្ទៃមេឃនិងផែនដី (មើលការពន្យល់ ២៤:២) ហើយបានបង្ហាញសិរីល្អរបស់ទ្រង់នៅទីនោះ (មើល ២៤:៧–១០ ២៦:៨ ៦៣:២ ៩៦:៦) ក៏ដូចជាបង្ហាញតាមរយៈស្នាបង្កើតផ្សេងៗទៀតរបស់ព្រះ (សូមមើល ១៩:១ ២៩:៩ ៩៧:៦) ។

**៧៨:៧០–៧១** សូមមើល ១សយ ១៦:១១–១៣ ២សយ ៧:៨ ។

**៧៨:៧០** *អ្នកបំរើទ្រង់* នៅទីនេះគឺជាងារផ្លូវការរបស់ស្តេចដាវីឌ ក្នុងនាមជាមន្ត្រីដ៏ស្មោះត្រង់របស់ព្រះ (សូមមើលការពន្យល់ នក ១៤:៣១ ទដ ១៨ ត្រង់ចំណងជើង អស ៤១:៨–៩ ៤២:១) ។ សូមមើល ៨៩:៣,២០,៣៩ ១៣២:១០ ១៤៤: ២០ ដែលនិយាយថាស្តេចដាវីឌជា "អ្នកបម្រើ"ព្រះ ។

**៧៨:៧១** *អ្នកគង្វាល* សូមមើល ខ.៧២ និងការពន្យល់ ២៣:១ ។

**៧៨:៧២** នៅក្នុងខនេះ ចង់និយាយថាពួកអ៊ីស្រាអែលស្ថិតនៅក្រោមការថែរក្សារបស់ព្រះអម្ចាស់តាមរយៈរាជ្យវង្សរបស់ស្តេចដាវីឌ គឺឱ្យធ្វើជាហោរាសម្រាប់ផ្តល់ស្តេចក្តីសង្ឃឹមដល់រាស្ត្ររបស់ព្រះ (មើល អគ ៣៤:២៣ ៣៧:២៤ មីក ៥:៤ ហើយបទគម្ពីរដែលនិយាយក្នុង មីក ៥:៤ ត្រូវបានសម្រេចនៅពេលដែលព្រះយេស៊ូវទ្រង់បានយាងមកផែនដី មថ ២:៦ យហ ១០:១១ វវ ៧:១៧) ។ *អ្នកគង្វាល* សូមមើលការពន្យល់ ២៣:១ ។

**ទដ ៧៩–៨៣** នៅក្នុងជំពូកទាំងនេះ គឺជាក្រុមទំនុកដំកើងទាំង៥ជំពូក ដែលស្ថិតក្នុងប៉ែកទី៣នៃទំនុកដំកើង ដែលបាននិយាយពីសេចក្តីអធិស្ឋានចំនួន២របស់ពួកបណ្តាជន ក្នុងពេលដែលប្រទេសជាតិរបស់ពួកគេជួបការឈ្លានពានពីសំណាក់ខ្មាំងសត្រូវដែលមានអំណាច (សូមមើលពីហេតុការណ៍ផ្សេងៗទៀតក្នុងសេចក្តីផ្តើម ទដ ៧៩ និង ៨៣) ។ សេចក្តីអធិស្ឋានទាំង២នេះមានផ្ទៃរឿងចំនួន៤គឺ (១).នៅក្នុង ៧៩:៤ ពួកអ៊ីស្រាអែលគេបានរអ៊ូរទាំថា ពួកគេគឺជាទីដៀលត្មះដល់អ្នកជិតខាង ហើយជាទីស្អប់ខ្ពើម និងជាទីសើចឡកដល់ពួកអស់ដែលនៅជុំវិញ គឺដល់ពួកខ្មាំងសត្រូវរបស់ពួកគេ ។ នៅ ៨៣:១៧ ពួកគេបានអធិស្ឋានទូលព្រះថា ពួកខ្មាំងសត្រូវរបស់ពួកគេអាចនឹង "ត្រូវខ្មាស ហើយភ័យស្លុតជាដរាប . . . គេត្រូវស្រឡាំងកាំងហើយវិនាសទៅ" (២).នៅក្នុង ៧៩:១១ ពួកគេបានអំពាវនាវទៅចំពោះព្រះដើម្បីសូមឱ្យព្រះទ្រង់បានរំដោះពួកគេ ដោយ"ព្រះហស្ត"ដ៏ពូកែរបស់ទ្រង់ ហើយនៅក្នុង ៨៣:៨ ពួកគេបាននិយាយថា ពួកអាសើគេបានពួតដៃគ្នាដើម្បីឈ្លានពានពួកអ៊ីស្រាអែល (៣).នៅក្នុង ៧៩:៥ ពួកគេបានពណ៌នាពីការថប់បារម្ភក្នុងខណៈពេលដែលគេបានដឹងថា ព្រះអម្ចាស់ទ្រង់នៅតែខ្ញាល់ចំពោះពួកគេដែលនឹង"ឆេះដូចជាភ្លើង" ហើយក្នុង ៨៣:១៤ ពួកគេបានអធិស្ឋានថា ព្រះយេហូវ៉ាទ្រង់នឹងកាត់ទោសដល់ពួកខ្មាំងសត្រូវរបស់ពួកគេប្រៀបដូចជា "ភ្លើង" ដែលឆេះព្រៃ (៤).នៅក្នុង ៧៩:៦ គេបានអធិស្ឋានថាព្រះទ្រង់នឹងចាក់បង្ហូរសេចក្តីក្រោធរបស់ទ្រង់មកលើប្រជាជាតិណា ដែលមិនព្រម"ទទួលស្គាល់ទ្រង់" មិនបានអំពាវនាវដល់ព្រះនាមទ្រង់ ហើយនេះជាផ្ទៃរឿងដែលសំខាន់បំផុត ។ ដោយឡែកក្នុង ៨៣:១៦,១៨ ពួកគេបានអធិស្ឋានថា សូមឱ្យព្រះយេហូវ៉ាទ្រង់បានសង្កត់មកលើពួកសាសន៍ដទៃ ដើម្បីឱ្យគេបាន "ស្វែងរកព្រះនាមទ្រង់" និងទទួលស្គាល់ថា ទ្រង់ខ្ពស់បំផុតនៅលើផែនដី ។

នៅចំកណ្តាលនៃក្រុមទំនុកដំកើងក្នុងជំពូកទាំង៥នេះ (ទដ ៨១) និងជាចំណុចស្នូលនៃទំនុកដំកើងក្នុងប៉ែកទី៣ បានដាស់តឿនក្រើនរំឭកពីការរឹងចចេសរបស់ពួកអ៊ីស្រាអែល ហើយក៏បានរំឭកទៀតថា កាលដើមឡើយពួកគេល្អណាស់នៅចំពោះព្រះ ដែលបាននាំគេចេញពីស្រុកអេស៊ីព្ទក្នុងពេលដែលព្រះការពារពួកគេ នាំគេចេញពីពួកខ្មាំងសត្រូវ ។

នៅចំណុចកណ្តាលនៃក្រុមទំនុកដំកើង គឺជាផ្នែកមួយនៃសេចក្តីអធិស្ឋានរបស់ពួកបណ្តាជន សូមឱ្យព្រះទ្រង់បានជួយកសាងពួកគេឡើងវិញ ដែលពួកគេប្រៀបបានទៅហ្វូងចៀមរបស់ព្រះអង្គ និងសូមឱ្យព្រះអង្គបានជំនុំជំរះដល់ពួកស្តេចទាំងឡាយនៅក្នុងលោកិយនេះ (មើល ទដ ៨២) ។

**ទដ ៧៩** នៅក្នុងជំពូកនេះ ចង់និយាយពីការដែលពួកអ៊ីស្រាអែលបានអធិស្ឋានសូមការអត់ទោសមកពីព្រះ និងសេចក្តីជំនួយមកពីទ្រង់ព្រមទាំងសូមឱ្យព្រះទ្រង់បានកាត់ទោស ដល់ប្រជាជាតិសាសន៍ដទៃទាំងឡាយណាដែលសាហាវព្រៃផ្សៃក្នុងការបំផ្លាញ ព្រមទាំងការមើលងាយចំពោះព្រះ និងរាស្ត្ររបស់ទ្រង់ ។ សម្រាប់ទំនាក់ទំនងរវាងព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះជាមួយ ទដ ៨០–៨៣ សូមមើលក្នុងសេចក្តីផ្តើម ទដ ៧៩–៨៣ ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះគឺមានផ្ទៃរឿងច្រើនដូចគ្នានឹង ទដ ៧៤ ដែរ ។ ព្រះគម្ពីរទំនុកដំកើងជំពូក ៧៩ បានតែងឡើងក្នុងអំឡុងគ្រា ដែលពួកគេបានរួចពីសណ្ឋានជាឈ្លើយ ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ មានផ្ទៃរឿងស្ទួនគ្នានឹង ទដ ៧៧ (រំឭកពីសេចក្តីសង្គ្រោះរបស់ព្រះក្នុងគ្រាលោកម៉ូសេ) ហើយ ទដ ៧៨ (រំឭកពីសេចក្តីង្គ្រោះរបស់ព្រះក្នុងសម័យកាលស្តេចដាវីឌ) ព្រះគម្ពីរទំនុកដំកើងទាំង២នេះ មានទំនាក់ទំនងជាមួយគ្នាដោយបានលើក

ហើយបានបំផ្លាញក្រុងយេរូសាឡិម ឱ្យទៅជាគំនរថ្ម[គ]
២ គេបានប្រគល់ខ្មោចនៃពួកអ្នកបំរើទ្រង់ទុកជាអាហារដល់
សត្វហើរ[ឃ] លើអាកាស និងសាច់នៃពួកអ្នកបរិសុទ្ធរបស់
ទ្រង់ដល់សត្វនៅផែនដី[ង]
៣ គេបានកំចាយឈាមរបស់អ្នកទាំងនោះដូចជាទឹកនៅ
ជុំវិញក្រុងយេរូសាឡិម ឥតមានអ្នកណាកប់[ច] ខ្មោចឡើយ[ឆ]
៤ យើងខ្ញុំបានត្រឡប់ជាទីដៀលត្មះដល់ពួកអ្នកជិតខាងហើយ
ជាទីស្អប់ខ្ពើម[ជ]
និងជាទីសើចឡកដល់ពួកអស់អ្នកដែលនៅជុំវិញផង[ឈ]
៥ ឱព្រះយេហូវ៉ាអើយ តើដល់កាលណាទៀត[ញ]
តើទ្រង់នឹងមានសេចក្តីខ្ញាល់[ដ] ជានិច្ចឬអី
តើសេចក្តីប្រចណ្ឌនៃទ្រង់នឹងឆេះដូចជាភ្លើងឬ[ឋ]
៦ សូមចាក់សេចក្តីក្រោធ[ឌ] របស់ទ្រង់ទៅលើសាសន៍ដទៃ
ដែលមិនស្គាល់[ឍ] ទ្រង់ ហើយលើអស់ទាំងនគរដែលមិន
អំពាវនាវដល់ព្រះនាមទ្រង់វិញ[ណ]
៧ ដ្បិតគេបានស៊ីបង្ហិន[ត] ពួកយ៉ាកុប
ព្រមទាំងបំផ្លាញទីលំនៅរបស់គេហើយ
៨ សូមកុំនឹកចាំពីការទុច្ចរិតដែលយើងខ្ញុំធ្វើពីដើមឡើយ[ថ]
សូមឱ្យសេចក្តីសប្បុរសទ្រង់
មកប្រោសយើងខ្ញុំជាប្រញាប់វិញ
ដ្បិតយើងខ្ញុំបានត្រឡប់ជាទាបថោកណាស់[ទ]
៩ ឱព្រះដ៏ជួយសង្គ្រោះយើងខ្ញុំអើយ[ធ]
សូមជួយយើងខ្ញុំដោយយល់ដល់សិរីល្អនៃព្រះនាមទ្រង់

**៧៩:១** ខ លវ ២០:៣ គ ២ពវ ២៥:៩ នហ ៤:២ អស ៦:១១ **៧៩:២** ឃ វវ ១៩:១៧–១៨ ង ចទ ២៨:២៦ យរ ៧:៣៣ **៧៩:៣** ច យរ ២៥:៣៣ វវ ១១:៩ ឆ យរ ១៦:៤ **៧៩:៤** ជ ទដ ៣៩:៨ អគ ៥:១៤ ឈ ទដ ៤៤:១៣ ៨០:៦ **៧៩:៥** ញ ទដ ៧៤:១០ ដ ទដ ៧៤:១ ៨៥:៥ ឋ ចទ ២៩:២០ ទដ ៨៩:៤៦ សផ ៣:៨

**៧៩:៦** ឌ ទដ ២:៥ ៦៩:២៤ ១១០:៥ វវ ១៦:១ ឍ ទដ ១៤៧:២០ យរ ១០:២៥ ណ ទដ ១៤:៤ **៧៩:៧** ត អស ៩:១២ យរ ១០:២៥ **៧៩:៨** ថ លប ៩:២៥ យរ ៤៤:២១ ទ ទដ ១១៦:៦ ១៤២:៦ **៧៩:៩** ធ ២របា ១៤:១១

យកពីរូបភាពនៃអ្នកគង្វាល រួមទាំងផ្ទៃរឿងគ្រឹះមួយចំនួនទៀតមកនិយាយ ។ ពួកអ៊ីស្រាអែលគេទទួលស្គាល់ថា ព្រះយេហូវ៉ាទ្រង់បានប្រើជាតិសាសន៍ដទៃឱ្យមកធ្វើទុក្ខដល់ពួកគេដោយព្រោះអំពើបាបដែលគេបានប្រព្រឹត្ត ដូច្នេះហើយទើបពួកគេសុំការអត់ទោសមកពីព្រះ ។ ប៉ុន្តែពួកគេក៏បានដឹងដែរថា ពួកសាសន៍ដទៃនោះបានធ្វើការហួសពីការងារដែលព្រះឱ្យគេធ្វើ គឺគេបែជាមើលងាយដល់ព្រះ និងរាស្ត្ររបស់ទ្រង់វិញ ។ ដោយសារការទាំងអស់នេះហើយ ទើបពួកគេបានអំពាវនាវដោយសូមឱ្យព្រះអម្ចាស់ទ្រង់ជំនុំជម្រះដល់ពួកទាំងនោះ (សូមមើល អស ១០:៥–១១ ៤៧:៦–៧) ។ សេចក្តីអធិស្ឋានរបស់លោកដានីយ៉ែល (ដយ ៩:៤–១៩) គឺមានការប្រហាកប្រហែលគ្នានេះដែរ ។

**៧៩ ត្រង់ចំណងជើង** *អេសាភ* សូមមើលការពន្យល់ ទដ ៧៣ ត្រង់ចំណងជើង ។

**៧៩:១–៤** នៅក្នុងខទាំងនេះ បានពណ៌នាប្រាប់យើងពីអ្វីដែលពួកសាសន៍ដទៃបានធ្វើ ដោយពួកគេហ៊ានរំលោភបំពានលើមរដករបស់ទ្រង់ បំពានលើព្រះវិហាររបស់ទ្រង់ និងបំផ្លាញទីក្រុងរបស់ព្រះអង្គ ហើយបានសម្លាប់រាស្ត្រទ្រង់ និងបង្ហូចយសរហូតដល់ស្លាប់ (សូមមើលការពន្យល់ ៥៣:៥ និងទុកសាកសពឱ្យនៅពាសវាល ដើម្បីជាចំណីដល់សត្វ) រួមទាំងការធ្វើឱ្យពួកគេវិនាសផងដែរ ។

**៧៩:១** *ករដកទ្រង់* ធៀបជាមួយ ៧៨:៦២,៧១ ។ នៅទីនេះគឺចង់និយាយសំដៅលើទឹកដីរបស់ពួកអ៊ីស្រាអែល ដែលជាមរដករបស់ព្រះយេហូវ៉ា (មើលការពន្យល់ ២:៨) ។ *ព្រះវិហារបរិសុទ្ធ* សូមមើលការពន្យល់ ៧៨:៦៩ ។

**៧៩:២** *អ្នកបំរើទ្រង់* ទោះបីជាពួកគេត្រូវបានបណ្តេញចេញពីទឹកដីរបស់ព្រះ ដោយព្រោះតែអំពើបាបដែលមិនអាចប្រកែកបានក៏ដោយ ក៏ការនិរទេសនោះតែការពារពីទំនាក់ទំនងពិសេសរវាងព្រះអម្ចាស់ និងពួកគេដែរ សូមមើលក្នុងឃ្លា "ពួកបរិសុទ្ធរបស់ទ្រង់" នៅទីនេះ និងពាក្យថា "រាស្ត្ររបស់ទ្រង់ ហើយជាហ្វូងចៀមនៅទីគង្វាលទ្រង់ ដែលនិយាយនៅ ខ.១៣" ។ *បរិសុទ្ធ* សូមមើលការពន្យល់ ៤:៣ ។

**៧៩:៣** *កំចាយឈាម . . . ជុំវិញក្រុងយេរូសាឡិម* សូមធៀបជាមួយ ២ពវ ២១:១៦ ។

**៧៩:៥–៨** នៅក្នុងខនេះ គឺជាសេចក្តីអធិស្ឋានសូមឱ្យព្រះទ្រង់ផ្តល់សេចក្តីមេត្តាករុណា និងសូមឱ្យព្រះទ្រង់ដាក់ទោសដល់សាសន៍ដទៃដែលមិនទទួលស្គាល់ទ្រង់ ។

**៧៩:៥** *តើដល់កាលណា* មើលការពន្យល់ ៦:៣ ។ *សេចក្តីខ្ញាល់* មើល ខ.៦ និងការពន្យល់ ២:៥ ។ *ប្រចណ្ឌ* សូមមើលការពន្យល់ ៧៨:៥៨ ។

**៧៩:៦–៧** សូមមើល យរ ១០:២៥ និងការពន្យល់ ។ ប្រហែលអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បានដកស្រង់ចេញពីព្រះគម្ពីរយេរេមា ។

**៧៩:៦** *ចាក់សេចក្តីក្រោធ* ព្រះទ្រង់នឹងចាក់សេចក្តីក្រោធរបស់ទ្រង់មកលើពួកគេ ដូចគ្នានឹងពួកគេបាន"កំចាយឈាម"ចំពោះរាស្ត្ររបស់ព្រះដែរ ។ ពួកគេបានអធិស្ឋានសូមឱ្យព្រះទ្រង់បានជំនុំជម្រះ ដល់ពួកអ្នកដែលប្រព្រឹត្តិខុសនឹងពួកគេ (មើលការពន្យល់ ៥:១០) ។

**៧៩:៧** *ស៊ីបង្ហិន* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា ពួកខ្មាំងសត្រូវទាំងនោះគេសាហាវដូចជាសត្វតិរិច្ឆាន (មើល ៤៤:១១ ៧៤:១៩ និង ការពន្យល់ ៧:២) ។ *យ៉ាកុប* ពាក្យនេះគឺចង់និយាយសំដៅលើពួកអ៊ីស្រាអែល (មើល លប ៣២:២៨) ។

**៧៩:៨** *ការទុច្ចរិតដែលយើងខ្ញុំបានធ្វើពីដើម* ពួកអ៊ីស្រាអែលគេបានរងទុក្ខលំបាកក្នុងគ្រានិរទេស ដោយព្រោះអំពើបាបដ៏ច្រើនរបស់ពួកសាសន៍ដទៃ (សូមមើល ២ពវ១៧:៧–២៣ ២៣:២៦–២៧ ២៤:៣–៤ ដយ ៩:៤–១៤) និងដោយការដែលគេមិនព្រមប្រែចិត្ត រហូតដល់គ្រាដែលព្រះជំនុំជម្រះលើពួកគេ ។ នៅទីនេះពួកអ្នកដែលមានសណ្ឋានជាឈ្លើយ គេបានអធិស្ឋានសូមឱ្យព្រះអង្គទ្រង់ទតមើលសេចក្តីទុក្ខលំបាករបស់ពួកគេ និងសូមកុំឱ្យដាក់ទោសពួកគេដោយព្រោះតែបាបរបស់ឰយុកោរបស់ពួកគេឡើយ ។ *សេចក្តីសប្បុរស* នៅទីនេះគឺចង់និយាយសំដៅលើភ្នាក់ងាររបស់ព្រះអម្ចាស់ ដែលទ្រង់នឹងបញ្ជូនមក ដើម្បីឱ្យរាស្ត្ររបស់ព្រះបានការកំសាន្តចិត្ត (មើលការពន្យល់ ២៣:៦ ៤៣:៣) ។

**៧៩:៩–១១** នៅក្នុងខទាំងនេះ ពួកបណ្តាជនបានអធិស្ឋានសូមសេចក្តីជំនួយពីព្រះ ដើម្បីឱ្យទ្រង់អត់ទោសដល់ពួកគេ និងកាត់ទោសដល់ពួកខ្មាំងសត្រូវ ។

**៧៩:៩** *ដោយយល់ដល់សិរីល្អនៃព្រះនាមទ្រង់* ពីព្រោះការហិនវិនាសរបស់

សូមប្រោសឱ្យយើងខ្ញុំរួច
ហើយអត់ទោសអំពើបាបរបស់យើងខ្ញុំផង
ដោយយល់ដល់ព្រះនាមទ្រង់[ន]
១០ តើគួរគប្បីឱ្យពួកសាសន៍ដទៃប្រមាថសួរថា
ព្រះរបស់គេនៅឯណាឬអី[ប]
សូមឱ្យការសងសឹក[ផ]ចំពោះឈាម[ព]នៃពួកអ្នកបំរើទ្រង់
ដែលត្រូវកំចាយនោះ បានស្គាល់ច្បាស់ នៅកណ្តាលពួក
សាសន៍ដទៃ ឱ្យយើងខ្ញុំបានឃើញផង
១១ សូមឱ្យដំងូររបស់ពួកឈ្លើយបានឮមកដល់ទ្រង់
ហើយដោយព្រះហស្តដ៏មានព្រះចេស្តារបស់ទ្រង់នោះ
សូមជួយទំនុកបំរុងដល់អស់អ្នកដែលបានដំរូវឱ្យត្រូវស្លាប់
ផង
១២ ឱព្រះអង្គអើយ ឯការ[ភ]ដែលពួកអ្នកជិតខាងយើងខ្ញុំបាន
ត្មះតិះដៀលដល់ទ្រង់
នោះសូមសងទៅលើទ្រូងគេ១ជា៧[ម]វិញ
១៣ យ៉ាងនោះ យើងខ្ញុំជារាស្ត្ររបស់ទ្រង់ហើយជាហ្វូង
ចៀមនៅទីគង្វាលទ្រង់[យ] យើងខ្ញុំនឹងអរព្រះគុណដល់ទ្រង់
ជាដរាបតទៅ[រ] យើងខ្ញុំនឹងសំដែងសេចក្តីសរសើររបស់
ទ្រង់នៅអស់ទាំងដំណតរៀងទៅ ។

ទំនុករបស់អេសាភ ដែលលោកលើកឱ្យ
មេភ្លេងសំរាប់លេងតាមបទ "ផ្កាឈូកនៃសេចក្តីបន្ទាល់" ។

**៨០** ឱព្រះដ៏ឃ្វាលសាសន៍អ៊ីស្រាអែល
ជាព្រះដែលនាំមុខពួកយ៉ូសែប ដូចជានាំហ្វូងចៀមអើយ[ក]

**៧៩:៩** ន ទដ ២៥:១១ ៣១:៣ យរ ១៤:៧
**៧៩:១០** ប ទដ ៤២:៣ ផ ទដ ៩៤:១ វវ ៦:១០ ប ខ.៣
**៧៩:១២** ភ អស ៦៥:៦ យរ ៣២:១៨ ម លប ៤:១៥
**៧៩:១៣** យ ទដ ៧៤:១ រ ទដ ៤៤:៨
**៨០:១** ក ទដ ៧៧:២០

រាស្ត្រទ្រង់ គឺធ្វើឱ្យប៉ះពាល់ដល់ព្រះនាមរបស់ព្រះ (មើល ខ.១០) ដូច្នេះ នៅពេលដែលព្រះអង្គទ្រង់ផ្តល់សេចក្តីសង្គ្រោះនិងទ្រព្យធនដល់ពួកគេ នឹងធ្វើឱ្យសិរីល្អរបស់ព្រះអង្គបានថ្កើងឡើង (មើលការពន្យល់ ២៣:៣) ។ *សិរីល្អ* សូមមើលការពន្យល់ ៦៥:៣ ។

**៧៩:១០** *ព្រះរបស់គេនៅឯណា* សូមមើលការពន្យល់ ៣:២ ។ *សងសឹក* សូមមើល ចទ ៣២:២៥,៤៣ ។

**៧៩:១១** *ពួកឈ្លើយ . . . អស់អ្នកដែលបានតំរូវឱ្យត្រូវស្លាប់* គឺព្រះចៅអធិរាជចក្រភពបាប៊ីឡូនសម្លាប់ពួកគេក្នុងគ្រានិរទេស (សូមមើល ១០២:២០) មិនមែនស្លាប់ដោយព្រោះការឃុំឃាំងឡើយ គឺស្លាប់ក្នុងពេលគេព្យាយាមវិលត្រឡប់មកកាន់លំនៅស្ថានគេវិញ ។

**៧៩:១២–១៣** នៅក្នុងខនេះ គឺជាសេចក្តីបញ្ចប់នៃសេចក្តីអធិស្ឋាន ហើយក៏ជាការប្តេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះ ។

**៧៩:១២** *សូមសងទៅលើទ្រូងគេ១ជា៧វិញ* សូមមើលការពន្យល់ យរ ៣២:១៨ ។ *៧* តាមទំនៀមទំលាប់របស់ពួកអ៊ីស្រាអែល លេខ៧គឺតំណាងឱ្យលេខដែលគ្រប់លក្ខណ៍ ។ *ត្មះតិះដៀលដល់ទ្រង់* គ្រប់ទាំងអស់នៃជម្លោះដែលពួកខ្មាំងសត្រូវបានបង្ករដល់ពួកអ៊ីស្រាអែល គឺជាការប្រមាថមើលងាយដល់ព្រះយេហូវ៉ា (សូមមើល ខ.១,១០ ២ពវ ១៩:១០–១២,២២–២៣ អស ៥២:៥) ។

**៧៩:១៣** *ជាហ្វូងចៀមនៅទីគង្វាលទ្រង់* មើល ២៣:២ ៧៤:១ និងការពន្យល់ ហើយសូមមើល ៧៧:២០ ៧៨:៧២ ៨០:១ ។ *យើងខ្ញុំនឹងសំដែងសេចក្តីសរសើររបស់ទ្រង់* មើលការពន្យល់ ៧:១៧ ។ *នៅអស់ទាំងតំណតរៀងទៅ* សូមមើល ៧៨:៤ ។

**ទដ ៨០** នៅក្នុងជំពូកនេះពួកអ៊ីស្រាអែល គេបានអធិស្ឋានសូមឱ្យព្រះយេហូវ៉ាទ្រង់ស្តាបនាពួកគេឡើងវិញ ក្នុងពេលដែលគេជួបការបៀតបៀននិងការបំផ្លិចបំផ្លាញពីសំណាក់ពួកខ្មាំងសត្រូវ ដែលមានអំណាចទាំងឡាយ។ សម្រាប់ទំនាក់ទំនងរវាងព្រះគម្ពីរទំនុកដំកើងជំពូកនេះ ជាមួយបទគម្ពីរផ្សេងៗទៀតក្នុងក្រុមនៃទំនុកដំកើងក្នុងប៉ែកទី៣ សូមមើលសេចក្តីផ្តើម ទដ ៧៩–៨៣ ។ នៅក្នុងជំពូកនេះ "អេប្រាអិម បេនយ៉ាមីន និងម៉ាន៉ាសេ" (មើល ខ.២) ជាអ្នកដែលតំណាងឱ្យពួកអ្នកដែលរស់នៅក្នុងនគរខាងជើង ។ បើសិនជា យេរ៉ូបោមពិតជាត្រួតលើអំបូរចំនួន១០ (មើល ១ពវ ១១:២៩–៣៦) តាមការដែលព្រះយេហូវ៉ាទ្រង់ឱ្យគាត់ ហើយឱ្យអំបូរ១ដល់យេហូបោម គឺជាអំបូរពួកយូដា (មើល ១ពវ ១២:២០) ដែលតាមការពិត គឺមានអំបូរចំនួន២ ពីព្រោះអំបូរស៊ីម្មានគេបានរស់នៅជាមួយអំបូរយូដា (មើល យស ១៩:១–៩) នោះបញ្ជាក់ថាបេនយ៉ាមីន គឺពិតជារស់នៅក្នុងនគរខាងជើងមែន ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅមានអំបូរបេនយ៉ាមីនខ្លះបានស្នាក់អាស្រ័យនៅលើទឹកដីនៃនគរខាងត្បូងមួយចំនួនដែរ ពីព្រោះមរដកទឹកដីរបស់ពួកគេមានព្រំប្រទល់ជាប់ក្រុងយេរូសាឡិម ហើយពួកអ្នកដែលនៅនគរខាងត្បូងគេមានបំណងចិត្តគ្រប់គ្រងលើពួកអ្នក ដែលនៅជុំវិញក្រុងយេរូសាឡិម (មើល ២ពវ ១២:២១) ។ ការនេះបានបញ្ជាក់ថា មូលហេតុនៃសេចក្តីទុកលំបាករបស់នគរខាងជើង គឺបណ្តាលមកពីការវាយលុកពីសំណាក់របស់ពួកអាសស៊ើរ (មើល ២ពវ ១៧:១–៦) ។ ការកំណាយរកថ្មីៗនេះនៅលើទឹកដីបរិសុទ្ធបានបង្ហាញថា ក្រុងយេរូសាឡិម និងបណ្តាខេត្តផ្សេងៗទៀតដែលនៅជុំវិញ គឺធ្លាប់ទទួលរងនូវមហាវិនាសកម្ម ដោយព្រោះការកើនឡើងនៃចំនួនប្រជាជនក្នុងសម័យកាលនោះ ។

**៨០ ត្រង់ចំណងជើង** *លើកឱ្យមេភ្លេង* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ត្រូវលេងតាមបទ* សូមមើលការពន្យល់ ទដ ៩ ត្រង់ ចំណងជើង ។ *ផ្កាឈូកនៃសេចក្តីបន្ទាល់* មើលការពន្យល់ ទដ ៤៥ ត្រង់ចំណងជើង ។ *អេសាភ* សូមមើលការពន្យល់ ទដ ៧៣ ត្រង់ចំណងជើង ។

**៨០:១–៣** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអធិស្ឋានសូមឱ្យព្រះទ្រង់តើនឡើង ដើម្បីនាំមុខរាស្ត្រទ្រង់ជាថ្មីម្តងទៀត ដូចកាលដែលព្រះអង្គទ្រង់បានធ្វើចំពោះពួកគេនៅក្នុងទីរហោស្ថាន ។

**៨០:១** សូមមើលសេចក្តីពន្យល់អំពីចៀមនៅទីគង្វាល ដែលនិយាយនៅក្នុង ៧៤:១ ៧៧:២០ ៧៨:៥២,៧១–៧២ ៩៧:១៣ ២៣:១–២ និងការពន្យល់ ។ *យ៉ូសែប* សូមមើលការពន្យល់ ៧៧:១៥ ។ *គង់នៅកណ្តាលចេរូប៊ីន* សូមមើលការពន្យល់ នក ២៥:១៨ ។ *សូមភ្លឺមក* នៅក្នុងឃ្លានេះ អ្នកនិពន្ធចង់និយាយថា សូមសម្តែងសិរីល្អរបស់ទ្រង់ឱ្យទូលបង្គំបានឃើញម្តងទៀត ដូចជាពេលធ្វើដំណើរក្នុងទីរហោស្ថានដែរ (សូមមើល នក ២៤:១៦–១៧ ៤០:៣៤–៣៥) ហើយជាពិសេសសូមសម្តែងតាមរយៈសេចក្តីសង្គ្រោះរបស់ទ្រង់ជាថ្មីឡើង (សូមមើល ១០២:១៥–១៦ នក ១៤:៤,១៧–១៨ ជន ១៤:២២ អស ៤០:៥ ៤៤:២៣ ៦០:១–២) ។

សូមផ្ទៀងព្រះកាណ៌ស្ដាប់
ឱព្រះដែលគង់នៅកណ្ដាលចេរូប៊ីនអើយ[ខ] សូមភ្លឺមក
២ សូមបណ្ដាលឥទ្ធិឫទ្ធិរបស់ទ្រង់ឡើង[គ]
នៅចំពោះពួកអេប្រាអិម បេនយ៉ាមីន និងម៉ាន៉ាសេ[ឃ]
ហើយយាងមកជួយសង្គ្រោះយើងខ្ញុំផង[ង]
៣ ឱព្រះអង្គអើយ សូមបង្វិល[ច] យើងខ្ញុំមកវិញ[ឆ]
សូមឱ្យព្រះភក្ត្រទ្រង់ភ្លឺមក នោះយើងខ្ញុំនឹងបានរួចហើយ[ជ]
៤ ឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារអើយ
តើទ្រង់នឹងខ្ញាល់ទាស់[ឈ] នឹងសេចក្ដីអធិស្ឋានរបស់រាស្ត្រ
ទ្រង់ដល់កាលណា[ញ]
៥ ទ្រង់បានឱ្យគេបរិភោគនំបុ័ងដែលនាំឱ្យស្រក់ទឹកភ្នែក[ដ]
ព្រមទាំងឱ្យគេផឹកទឹកភ្នែកពេញរង្វាល់ហើយ[ឋ]
៦ ទ្រង់បានធ្វើឱ្យយើងខ្ញុំត្រឡប់ជាសេចក្ដីទាស់ទែងគ្នាដល់
ពួកអ្នកជិតខាង
ពួកខ្មាំងសត្រូវរបស់យើងខ្ញុំក៏សើចឡកក្នុងពួកគេ[ឌ]
៧ ឱព្រះនៃពួកពលបរិវារអើយ សូមបង្វិលយើងខ្ញុំមកវិញ
សូមឱ្យព្រះភក្ត្រទ្រង់ភ្លឺមកនោះយើងខ្ញុំនឹងបានរួចហើយ[ឍ] ។
៨ ទ្រង់បានយកដើមទំពាំងបាយជូរ[ណ] ១ពីស្រុកអេស៊ីព្ទមក
ក៏បណ្ដេញ[ត] អស់ទាំងសាសន៍ដទៃចេញហើយបានដាំ[ថ] ដើម
នោះវិញ
៩ ទ្រង់បានរៀបកន្លែងនៅជុំវិញ
ហើយដើមនោះក៏ចាក់ឫសបែកសាយទៅពេញក្នុងស្រុក
១០ ម្លប់ដើមនោះបានគ្របពេញលើអស់ទាំងភ្នំ
ហើយខ្នែងក៏បានដូចជាដើមតាត្រៅនៃព្រះ
១១ បានបោះខ្នែងរហូតដល់សមុទ្រ ហើយលំពង់ដល់ទន្លេ[ទ]
១២ ហេតុអ្វីបានជាទ្រង់រំលំរបងចេញ[ធ]
ឱ្យអស់អ្នកដើរតាមនោះ បានបោចបំផ្លាញដូច្នេះ
១៣ ជ្រូកក៏ចេញពីព្រៃមកឈ្លូស[ន]
ហើយសត្វនៅវាលក៏ស៊ីបំផ្លាញដែរ
១៤ ឱព្រះនៃពួកពលបរិវារអើយ យើងខ្ញុំអង្វរដល់ទ្រង់
សូមបែរមកវិញ ហើយទតពីលើស្ថានសួគ៌មកមើល[ប]
ព្រមទាំងប្រោសដើមទំពាំងបាយជូរនេះផង
១៥ ក៏ជាដើមដែលព្រះហស្តស្ដាំទ្រង់បានដាំ

**៨០:១** ខ នក ២៥:២២ **៨០:២** គ ជន ២:១៨–២៤ ឃ ទដ ៣៥:២៣ ង ទដ ៥៤:១ ៦៩:១ ៧១:២ ១០៩:២៦ ១១៦:៤ ១១៩:៩៤ **៨០:៣** ច ទដ ៧១:២០ ៨៥:៤ យរ ៣១:១៨ បទ ៥:២១ ឆ ជន ៦:២៥ ជ ខ.៧,១៩ **៨០:៤** ឈ ចទ ២៩:២០ ញ ទដ ៧៤:១០ **៨០:៥** ដ យប ៣:២៤ ឋ អស ៣០:២០ **៨០:៦** ឌ ទដ ៧៩:៤ **៨០:៧** ឍ ខ.៣ **៨០:៨** ណ អស ៥:១–២ យរ ២:២១ មថ ២១:៣៣–៤១

ត នក ២៣:២៨–៣០ យស ១៣:៦ កច ៧:៤៥ ថ នក ១៥:១៧ **៨០:១១** ទ ទដ ៧២:៨ **៨០:១២** ធ ទដ ៨៩:៤០ អស ៥:៥ ៣០:១៣ យរ ៣៩:៨ **៨០:១៣** ន យរ ៥:៦ **៨០:១៤** ប ចទ ២៦:១៥

**៨០:២** *នៅចំពោះពួកអេប្រាអិម បេនយ៉ាមីន និងម៉ាន៉ាសេ* នៅក្នុងឃ្លានេះ អ្នកនិពន្ធចង់និយាយថា សូមឱ្យព្រះអម្ចាស់ទ្រង់បានទាស់ប្រឆាំងជាមួយពួកសាសន៍ដទៃ ដូចជាកាលដែលទ្រង់បានគង់នៅចំណោមពួកពលទ័ពក្នុងពេលចេញពីទីរហោស្ថានសីណាយចូលក្នុងទឹកដីសន្យាដែរ (នៅក្នុងដំណើរនោះ ហឹបនៃសេចក្ដីសញ្ញាបាននាំមុខអំបូរ៣ មើល ជន ១០:២១–២៤ ហើយមើលក្នុងសេចក្ដីផ្ដើម ទដ ៦៨) ។ *សូមសម្ដែង* មើលការពន្យល់ ៧:៦ ។
**៨០:៣** *សូមឱ្យព្រះភក្ត្រទ្រង់ភ្លឺមក* សូមមើល ខ.៧,១៩ និងការប្រទានពររបស់ពួកសង្ឃ (សូមមើល ជន ៦:២៥ និងការពន្យល់ ៤:៦ ១៣:១) ។
**៨០:៤–៧** នៅក្នុងខទាំងនេះ និយាយពីសំណោករាស្ត្ររបស់ទ្រង់ ក្នុងការដែលទ្រង់បានព្រមានដល់ពួកគេ ។
**៨០:៤** *ឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវ៉ា* សូមមើល ខ.៧,១៤,១៩ និងការពន្យល់ ១សយ ១:៣ ។ *ដល់កាលណា* សូមមើលការពន្យល់ ៦:៣ ។ *សេចក្ដីខ្ញាល់* សូមមើលការពន្យល់ ២:៥ ។
**៨០:៥** នៅក្នុងខនេះបានបង្ហាញថា ពេលនេះព្រះអម្ចាស់ទ្រង់បានឱ្យគេបរិភោគ និងផឹក មិនមែន"នំបុ័ងរបស់ពួកទេវតា" ហើយឱ្យ"ទឹកដែលចេញពីថ្មដា"ដូចជាគ្រាមុននោះឡើយ (មើល ៧៨:២០,២៥) ។
**៨០:៨–១៦** ដើមទំពាំងបាយជូរដែលនិយាយនៅទីនេះ (គឺជាការប្រៀបដែលអ្នកនិពន្ធ គាត់ចង់និយាយសំដៅលើការប្រែប្រួលពីតម្លៃរបស់ពួកអ៊ីស្រាអែល) ក៏មាននិយាយក្នុងកណ្ឌហោរាផងដែរ (សូមមើល អស ៣:១៤ ៥:១–៧ ២៧:២ យរ ២:២១ ១២:១០ អគ ១៧:៦–៨ ១៩:១០–១៤ ហស ១០:១ ១៤:៧ មីក ៧:១ លប ៤៩:២២ មថ ២០:១–១៦ មក ១២:១–៩ លក ២០:៩–១៦ យហ ១៥:១–៥) ។
**៨០:៨–១១** នៅក្នុងខនេះចង់និយាយថា ពួកអ៊ីស្រាអែលគឺជាដើមទំពាំងបាយជូរដែលព្រះបានដាំ ។
**៨០:៨** *បានយក* មើល ៧៨:៥២ ។ ទម្រង់កិរិយាសព្ទដែលប្រើនៅទីនេះ គឺនិយាយសំដៅលើ ទាំងឫសតែម្ដងដូចជាមាននិយាយនៅក្នុង យប ១៩:១០ ។ *បណ្ដេញអស់ទាំងសាសន៍នោះចេញ ហើយបានដាំដើមនោះវិញ* មើល ៤៤:២ ។
**៨០:៩** *រៀបចំកន្លែង* សូមមើល អស ៥:២ ។
**៨០:១០** *ដើមតាត្រៅនៃព្រះ* នេះភាសាអក្សរសាស្ត្រ ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរកាលណានិយាយថា "ព្រះ" គឺសំដៅលើអ្នកដែលមានអំណាច (មើលការពន្យល់ ២៩:១) ។
**៨០:១១** *សមុទ្រ . . . ទន្លេ* សូមមើល នក ២៣:៣១ និងការពន្យល់ ។
**៨០:១២** *ហេតុអ្វី* ក្ដីព្រួយរបស់ពួកអ៊ីស្រាអែល បានធ្វើឱ្យគេអល់អែកចំពោះការដែលព្រះបានបោះបង់ចោលពួកគេ (សូមមើលការពន្យល់ ៦:៣) ។ *រំលងរបងចេញ* គឺចង់និយាយសំដៅលើការឈប់ជួយ ។
**៨០:១៤** *ទតពីលើ* សូមមើល នក ៣:១៦ ។ ឃ្លាភាសាហេព្រើរដែលប្រើនៅទីនេះ ប្រហែលមានន័យដូច នរ ១:៦ "យាងមកប្រទាន" ។
**៨០:១៥** *ខ្នែង* គឺសំដៅលើពួកអ៊ីស្រាអែល (សូមមើល នក ៤:២២–២៣ ហស ១១:១) ។ ប៉ុន្តែពេលខ្លះ"ខ្នែង" ក៏និយាយសំដៅលើខ្នែងទំពាំងបាយជូរដែរ (មើលការពន្យល់ លប ៤៩:២២) ។ នៅទីនេះប្រហែលនិយាយសំដៅលើផលផ្លែដ៏ល្អនៃ "ឫស និងមែក" របស់ទំពាំងបាយជូរទាំងមូល (សូមមើល យប ១៨:១៦ ២៩:១៩ អគ ១៧:៧ មឡ ៤:១ អស ៥:២៤ ២៧:៦ ៣៧:៣១ អគ ១៧:៩ ៣១:៧ ហស ៩:១៦ អម ២:៩ រម ១១:១៦) ។ *ធ្វើឱ្យមានកំឡាំងសំរាប់ព្រះអង្គ* មើល ខ.១៧ ។ ពាក្យនេះបើតាមព្រះគម្ពីរភាសាអក្សរសាស្ត្រគឺ "ធ្វើឱ្យរឹងមាំ" ។

ជាខ្នែងដែលទ្រង់បានធ្វើឱ្យមានកំឡាំងសំរាប់អង្គទ្រង់
១៦ដើមនេះត្រូវភ្លើងឆេះ[ផ] ហើយត្រូវកាប់ចេញ
គេត្រូវវិនាសដោយព្រះភក្ត្រទ្រង់ទតបន្ទោស[ព]
១៧សូមឱ្យព្រះហស្តទ្រង់ថែរក្សាដល់អ្នក
ដែលព្រះហស្តស្តាំទ្រង់បានតាំងឡើង
គឺជាកូនមនុស្ស[ភ] ដែលទ្រង់បានធ្វើឱ្យមានកំឡាំងសំរាប់អង្គទ្រង់
១៨យ៉ាងនោះ យើងខ្ញុំនឹងមិនថយចេញពីទ្រង់ឡើយ
សូមប្រោសឱ្យយើងខ្ញុំមានជីវិតឡើងវិញ[ម]
នោះយើងខ្ញុំនឹងអំពាវនាវដល់ព្រះនាមទ្រង់
១៩ឱព្រះយេហូវ៉ា
ជាព្រះនៃពួកពលបរិវារអើយ សូមបង្វិលយើងខ្ញុំមកវិញ
សូមឱ្យព្រះភក្ត្រទ្រង់ភ្លឺមក នោះយើងខ្ញុំនឹងបានរួចហើយ។

ទំនុករបស់អេសាភ ដែលលោកលើកសំរាប់មេភ្លេង
ត្រូវលេងដោយប្រដាប់ភ្លេងគីធីត ។

**៨១** ចូរបន្លឺសំឡេងឡើង
ច្រៀងថ្វាយព្រះដ៏ជាកំឡាំងនៃយើងខ្ញុំ
ចូរបញ្ចេញសំឡេងអំណរថ្វាយព្រះនៃយ៉ាកុបចុះ[ក]
២ចូរច្រៀងទំនុក ហើយវាយក្រាប់ចុះ[ខ]
ព្រមទាំងចាប់ស៊ុង[គ]ដ៏ពីរោះ និងដេញពិណផង[ឃ]
៣ចូរផ្លុំត្រែ[ង]ក្នុងថ្ងៃដើមខែ[ច] ថ្ងៃពេញបូណ៌
និងថ្ងៃបុណ្យរបស់យើងខ្ញុំផង

**៨០:១៦** ផ ទដ ៧៩:១ ប ចទ ២៨:២០
**៨០:១៧** ភ យប ២៥:៦
**៨០:១៨** ម ទដ ៨៥:៦ អស ៥៧:១៥ ហស ៦:២
**៨១:១** ក ទដ ៦៦:១
**៨១:២** ខ នក ១៥:២០ គ ទដ ៩២:៣ ឃ យប ២១:១២
**៨១:៣** ង នក ១៩:១៣ ច នហ ១០:៣៣

**៨០:១៦–១៩** នៅក្នុងខទាំអនេះ គឺជាសេចក្ដីបញ្ចប់នៃការអធិស្ឋានសូមឱ្យព្រះអម្ចាស់ទ្រង់បានស្រោចស្រង់ពួកគេឡើងវិញ ។

**៨០:១៦** *បន្ទោស* សូមមើល ៩:៥ និងការពន្យល់ ៧៦:៦ ។

**៨០:១៧** *សូមឱ្យព្រះហស្តទ្រង់បានថែរក្សាដល់អ្នក* នៅក្នុងឃ្លានេះអ្នកនិពន្ធគាត់ចង់និយាយថា សូមឱ្យព្រះអង្គទ្រង់ផ្ដល់សេចក្ដីប្រោសមេត្តាមកដល់យើងខ្ញុំ (មើល អរ ៧:៦,៩,២៨ ៨:១៨,២២,៣១ នហ ២:៨,១៨) ។ *ព្រះហស្តស្តាំ* នៅទីនេះប្រហែលនិយាយសំដៅលើជំនួរវង្សរបស់ស្ដេចដាវីឌ ដែលព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំង ឱ្យគង់លើបល្ល័ង្កកិត្តិយសរបស់ព្រះ (មើល ១១០:១) និងជាម្នាក់ដែលជាសេចក្ដីសង្ឃឹមរបស់ពួកបណ្ដាជន (មើល ២:៧–៩ ៧២:៨–១១ ៨៩:២១–២៥) ។ ប៉ុន្តែនៅក្នុង ខ.១៥ បាននិយាយសំដៅលើមនុស្សផ្សេងទៅវិញ គឺជាយ៉ាកុប អ៊ីស្រាអែលដែលជា "ព្រះហស្តស្តាំរបស់ព្រះ" ដែលព្រះបាន "ដាំ" និងលើកឡើងសម្រាប់ព្រះអង្គ ។

**៨០:១៨** នៅក្នុងខអ្នកនិពន្ធបានប្ដេជ្ញាចិត្តថា និងស្មោះត្រង់ចំពោះព្រះ និងទុកចិត្តចំពោះទ្រង់តែ១អង្គប៉ុណ្ណោះ ។

**ទដ ៨១** នៅក្នុងជំពូកនេះ គឺជាបទចម្រៀងសម្រាប់ច្រៀងក្នុងពិធីបុណ្យ ប៉ុន្តែគេមិនប្រាកដឡើយថាតើសម្រាប់ពិធីបុណ្យអ្វី ជាបុណ្យរំលង/បុណ្យនំបុ័ងឥតដំបែរ (សូមមើល ខ.៥ នក ១២:១៤–១៧) ឬមួយបុណ្យផ្លុំត្រែក្នុងដើមខែ (សូមមើល ខ.៣ លវ ២៣:២៤ ជន ២៩:១) ឬជាបុណ្យបារាំ (សូមមើល ខ.៣ លវ ២៣:៣៤ ជន ២៩:១២) នោះឡើយ ។ ទំនុកដំកើងនេះ ប្រហែលជាប្រើក្នុងឱកាសនៃពិធីបុណ្យទាំង៣នេះតែម្ដង ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទំនុកដំកើងក្នុងជំពូកនេះប្រហែលតែងឡើងសម្រាប់ប្រើក្នុងពិធីបុណ្យ២គឺបុណ្យផ្លុំត្រែ និងបុណ្យបារាំ (មើលការពន្យល់ខាងក្រោមនេះ) ។ ទោះបីជាបែបនេះក៏ដោយ កាលបរិច្ឆេទនៃការតែងព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះក្នុងពេលនិរទេស ឬក្រោយពេលនិរទេសមិនបានដឹងឡើយ គ្រាន់តែដឹងថា តែងឡើងសម្រាប់បុណ្យប្រចាំឆ្នាំរបស់ពួកអ៊ីស្រាអែល ។ ពួកគេបាននាំចាំពីសេចក្ដីសង្គ្រោះរបស់ព្រះ ដូច្នេះគេក៏បានហៅពួកអ៊ីស្រា–អែលទាំងមូល ឱ្យចូលមកសរសើរតម្កើងដល់ព្រះយេហូវ៉ា ដើម្បីរំឭកពីព្រះអង្គ និងការប្ដេជ្ញាចិត្តជាថ្មីក្នុងការដើរតាមព្រះអម្ចាស់ (មើល ទដ ៩៥)។ សូមមើលពីសារៈសំខាន់នៃទំនុកដំកើង ជំពូកនេះក្នុងចំណោមទំនុកដំកើងក្នុងប៉ែកទី៣ ក្នុងសេចក្ដីផ្ដើម ទដ ៧៣–៧៨ និងសេចក្ដីផ្ដើម ទដ ៧៩–៨៣) ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះបានចែកជា២ផ្នែក (ខ.១–៥ ខ.៦–១៦) ។

**៨១ ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ត្រង់ចំណងជើង ។ *ត្រូវលេងដោយ* សូមមើលការពន្យល់ ទដ ត្រង់ចំណងជើង ។ *គីធីត* សូមមើលការពន្យល់ ទដ ៨ត្រង់ចំណងជើង ។ *អេសាភ* សូមមើលការពន្យល់ ទដ ៧៣ ត្រង់ចំណងជើង ។

**៨១:១–៥** នៅក្នុងខទាំងនេះ គឺជាការកោះហៅដល់មនុស្សទាំងអស់ឱ្យចូលមកអបអរសាទរក្នុងពិធិបុណ្យដ៏ពិសិទ្ធិមួយ ។

**៨១:១** *យ៉ាកុប* ពាក្យនេះគឺនិយាយសំដៅលើអ៊ីស្រាអែល (សូមមើល លប ៣២:២៨) ។

**៨១:២** *ក្រាប់* សូមមើលការពន្យល់ យរ ៣១:៤ ។ *ស៊ុងនិងពិណ* សូមមើលការពន្យល់ ៥៧:៨ ។

**៨១:៣** *ត្រែ* គឺជាត្រែដែលធ្វើពីស្នែងចៀមឈ្មោល (សូមមើល នក ១៩:១៣) ។ *បុណ្យរបស់យើងខ្ញុំ* បុណ្យនេះប្រហែលជាបុណ្យបារាំដែលជាញឹកញាប់គេគ្រាន់តែនិយាយថា "បុណ្យ"ប៉ុណ្ណោះ (មើល ១ពវ ៨:២,៦៥ ១២:៣២ ២របា ៥:៣ ៧:៨ នហ ៨:១៤,១៨ អគ ៤៥:២៥ ចទ ១៦:១៤) ។ ពិធីបុណ្យដ៏យូរដែលមានរយៈពេល៧ថ្ងៃនេះ គឺបានចាប់ផ្ដើមឡើងនៅថ្ងៃទី១៥នៃខែពេញបូរមី ដែលពិធីបុណ្យនេះគេប្រព្រឹត្តិឡើងបន្ទាប់ពីថ្ងៃបុណ្យធួននឹងបាប (នៅខែអស្សុជ សូមមើល លវ ១៦:២៩) ដើម្បីរំលឹកដល់ការថែរក្សារបស់ព្រះអម្ចាស់ចំពោះរាស្ត្ររបស់ទ្រង់ ក្នុងអំឡុងពេលដែលទ្រង់បាននាំគេក្នុងដំណើរក្នុងទីរហោស្ថាន (សូមមើល លវ ២៣:៤៣) និងក៏ជាពិធី បុណ្យអរគុណចំពោះផលចំរូតដែរ (សូមមើល លវ ២៣:៣៩–៤០ ចទ ១៦:១៣–១៥) រួមទាំងពិធីបុណ្យប្រមូលផលចុងឆ្នាំដោយមានទាំងបុណ្យរំលង និងបុណ្យនំបុ័ងឥតដំបែរដែលគេធ្វើឡើងកាលពី៦ ខែមុន (សូមមើល នក ២៣:១៤–១៧ លវ ជំពូក ២៣ ចទ ១៦:១៦ និងការពន្យល់ សក ១៤:១៦) ។ នៅរាល់ឆ្នាំទី៧ក្នុងពិធីបុណ្យបែបនេះ នោះត្រូវបានអានច្បាប់នៃការតាំងសញ្ញានៅចំពោះមុខបណ្ដាជនទាំងអស់ (សូមមើល ចទ ៣១:៩–១៣ នហ ៨:២,១៥) ។ ថ្ងៃទី១នៃខែនេះ (ខែពេញបូរមី) គឺជាថ្ងៃ

៤ដ្បិតនោះហើយជាច្បាប់សំរាប់សាសន៍អ៊ីស្រាអែល
គឺជាបញ្ញត្តិរបស់ព្រះនៃយ៉ាកុប[ឆ]
៥ទ្រង់តាំងច្បាប់នោះ ទុកជាទីបន្ទាល់នៅក្នុងពួកយ៉ូសែប
ក្នុងកាលដែលទ្រង់ចេញទៅទាស់នឹងស្រុកអេស៊ីព្ទ[ជ]
វេលានោះ ខ្ញុំបានឮសំឡេង១ដែលខ្ញុំមិនស្គាល់ទេ[ឈ]
៦សំឡេងនោះក៏ថា អញបានដាក់បន្ទុក[ញ]ចុះពីស្មាវា[ដ]
ហើយឱ្យដៃវារួចពីការកាន់កញ្ជ្រែង
៧នៅគ្រាដែលមានសេចក្តីវេទនា នោះឯងបានអំពាវនាវ[ឋ]
ហើយអញបានជួយឯងឱ្យរួច
អញបានតប[ឌ]ដល់ឯងពីទីសំងាត់នៃផ្គរ
អញបានល្បងលឯងនៅត្រង់ទឹកមេរីបា[ឍ] ។ –បង្អង់
៨ឱរាស្ត្រអញអើយ[ណ] ចូរស្តាប់ចុះអញនឹងធ្វើបន្ទាល់ដល់ឯង
ឱអ៊ីស្រាអែលអើយ នេះបើឯងនឹងព្រមស្តាប់អញ
៩មិនត្រូវឱ្យមានព្រះដទៃណា[ត]នៅក្នុងពួកឯងឡើយ
ក៏មិនត្រូវឱ្យឯងថ្វាយបង្គំដល់ព្រះនៃសាសន៍ដទៃណាមួយ
ដែរ

១០អញនេះ គឺព្រះយេហូវ៉ា ជាព្រះនៃឯងដែលបាននាំឯង
ឡើងចេញពីស្រុកអេស៊ីព្ទមក[ថ] ចូរឯងហាមាត់[ទ]ឱ្យធំចុះ
នោះអញនឹងបំពេញ[ធ]ឱ្យ
១១ប៉ុន្តែរាស្ត្រអញមិនបានស្តាប់តាមអញឡើយ
សាសន៍អ៊ីស្រាអែលមិនព្រមតាមអញសោះ[ន]
១២ដូច្នេះ អញបានបណ្តោយឱ្យគេទៅតាម[ប]ចិត្តរឹងចចេស
របស់គេទៅ ឱ្យគេបានប្រព្រឹត្តតាមសេចក្តីដំបូន្មានរបស់
ខ្លួនគេ
១៣ឱបើប្រសិនណាជារាស្ត្រអញនឹងស្តាប់តាមអញ[ផ]
ឱបើអ៊ីស្រាអែលនឹងដើរតាមផ្លូវអញទៅអេះ
១៤នោះអញនឹងបង្ក្រាបខ្មាំងសត្រូវគេជាយ៉ាងឆាប់[ព]
ព្រមទាំងបែរដៃទៅទាស់នឹងពួកដែលតតាំងនឹង[ភ]គេវិញ
១៥គួរឱ្យអស់អ្នកដែលស្អប់ដល់ព្រះយេហូវ៉ាបានចុះចូល[ម]
ចំពោះទ្រង់ ប៉ុន្តែពេលវេលារបស់អ៊ីស្រាអែលនឹងស្ថិត
ស្ថេរនៅជាដរាបតទៅ

**៨១:៤** ឆ ខ.១
**៨១:៥** ជ នក ១១:៤ ឈ ទដ ១១៤:១
**៨១:៦** ញ នក ១:១៤ ដ អស ៩:៤ ៥២:២
**៨១:៧** ឋ នក ២:២៣ ឌ នក ១៩:១៩ ឍ នក ១៧:៧ ចទ ៣៣:៨
**៨១:៨** ណ ទដ ៥០:៧ ៧៨:១
**៨១:៩** ត នក ២០:៣
**៨១:១០** ថ នក ៦:៦ ១៣:៣ ២៩:៤៦ ទ នក ២:៨ ធ ទដ ១០៧:៩
**៨១:១១** ន នក ៣២:១–៦
**៨១:១២** ប អគ ២០:២៥ កច ៧:៤២ រម ១:២៤
**៨១:១៣** ផ ចទ ៥:២៩ **៨១:១៤** ប ទដ ៤៧:៣ ភ អម ១:៨ **៨១:១៥** ម ២សយ ២២:៤៥

បុណ្យផ្លុំត្រែរំពូក (សូមមើល លវ ២៣:២៤) ។

**៨១:៤–៥** *ច្បាប់ . . . បញ្ញត្តិ . . . តាំង* សូមមើលការពន្យល់ ខ.៣ ។

**៨១:៥** *យ៉ូសែប* សូមមើលការពន្យល់ ៧៧:១៥ ។ *ក្នុងកាលដែលទ្រង់ចេញទៅទាស់ប្រឆាំងនឹងស្រុកអេស៊ីព្ទ* ឃ្លាដែលនិយាយនៅទីនេះបានធ្វើឱ្យអ្នកខ្លះគាត់ជឿថា ពិធីបុណ្យដែលនិយាយនៅក្នុងជំពូកនេះ គឺសំដៅលើបុណ្យរំលង និងបុណ្យនំបុ័ងឥតដំបែ (សូមមើល នក ១២:១៤,៤៤) ។ អ្វីដែលបានពណ៌នានៅក្នុងជំពូកនេះ ហាក់បីដូចជានិយាយសំដៅលើហេតុការណ៍ ដែលបានកើតឡើងនៅក្នុងគ្រាដែលចាកចេញពីស្រុកអេស៊ីព្ទជាពិសេស ដោយនិយាយពីការ ដែលព្រះយេហូវ៉ាទ្រង់ទាស់ប្រឆាំងនឹងស្រុកអេស៊ីព្ទហើយជួយរំដោះរាស្ត្រទ្រង់ (សូមមើល ខ.៦–៧) ។ *ខ្ញុំបានឮសំឡេង១ ដែលខ្ញុំមិនស្គាល់* សំលេងនោះគឺជាសម្លេងដ៏ចម្លែក១ដែលកើតឡើងនៅក្នុងទឹកដីសាសន៍ដទៃ (សូមមើល ១១៤:១ ចទ ២៨:៤៩ អស ១៩:១៨ ៣៣:១៩ យរ ៥:១៥ អគ ៣:៥–៦) ។ បើសិនជានៅក្នុងការពន្យល់នៅក្នុងព្រះគម្ពីរ បានកាត់ស្រាយពាក្យថា "ព្រះសូរសៀង" របស់ព្រះគឺជា "ផ្គរ" ដែលព្រះយេហូវ៉ាទ្រង់បញ្ជូនមកដើម្បីជំនុំជំម្រះពួកអេស៊ីព្ទ (មើល ខ.៧) នោះវាគឺជាហេតុមួយ ដែលបណ្តាលឱ្យពួកកូនចៅលេវីបានធ្វើពិធីអធិស្ឋានទៅចំពោះព្រះអម្ចាស់ (សូមមើល ខ.៦–១៦) ។

**៨១:៦–១០** នៅក្នុងខនេះ ព្រះអម្ចាស់ទ្រង់បានស្តាប់ឮសម្រែកដែលពួកគេបានស្រែកអំពាវនាវរកព្រះអង្គ ហើយទ្រង់ក៏បានដោះឱ្យពួកគេមានសេរីភាព មិនតែប៉ុណ្ណោះឥឡូវនេះព្រះអម្ចាស់ ទ្រង់ក៏បានកោះហៅរាស្ត្ររបស់ទ្រង់ដើម្បីឱ្យគេនៅរក្សាភក្តីភាពជាមួយព្រះ ។

**៨១:៦** *ស្មា . . . កញ្ជ្រែង* នៅក្នុងឃ្លានេះគឺសំដៅលើកម្លាំងពលកម្មរបស់ពួកអ៊ីស្រាអែល ក្នុងអំឡុងពេលដែលគេរស់នៅក្នុងស្រុកអេស៊ីព្ទ (សូមមើល នក ១:១១–១៤) ។

**៨១:៧** *ឯងបានអំពាវនាវ ហើយអញបានជួយឯង* មើល នក ៣:៧–១០ ។ *ផ្គរ* មើល ១០៦:៩ នក ១៤:២១,២៤ ១៥:៨,១០ និងការពន្យល់ ៧៦:៦ ។ *អញបានល្បងលឯង* សូមមើល នក ១៧:១–៧ ។

**៨១:៨–១០** នៅក្នុងខនេះ ព្រះអម្ចាស់ទ្រង់បានស្តាប់ឮសម្រែកអំពាវនាវរបស់រាស្ត្រទ្រង់ក្នុងកាលដែលគេមានទុក្ខវេទនា (សូមមើល ខ.៦–៧) ដូច្នេះ ហើយពួកគេត្រូវតែស្តាប់បង្គាប់ព្រះអង្គ ។

**៨១:៩–១០** សូមមើល នក១៩:៤–៥ ២០:២–៤ ចទ ៤:១៥–២០ ។

**៨១:១០** *ចូរឯងបើកមាត់ឱ្យធំចុះ* នៅក្នុងខនេះអ្នកនិពន្ធចង់មានន័យថា ចូរទុកចិត្តលើព្រះអម្ចាស់តែ១ព្រះអង្គប៉ុណ្ណោះ ថាទ្រង់គឺជាអ្នកផ្គត់ផ្គង់អស់ទាំងសេចក្តីតម្រូវការរបស់ឯង ។ *អញនឹងបំពេញឱ្យ* សូមមើល ខ.១៦ ។ នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់នឹងបំពេញសេចក្តីត្រូវការរបស់ពួកគេ ឱ្យដូចគ្នានឹងពេលដែលព្រះអង្គបានបំពេញគេនៅក្នុងទីរហោស្ថានដែរ (សូមមើល ៧៨:២៣–២៩ ៣៧:៣–៤ ចទ ១១:១៣–១៥ ២៨:១–៤) ។

**៨១:១១–១៦** នៅក្នុងខនេះចង់និយាយពីការដែលពួកអ៊ីស្រាអែល គេមិនព្រមស្តាប់ព្រះអម្ចាស់(សូមមើល អគ ១៨:២៣,៣២ ៣៣:១១) ។

**៨១:១១** មើល ៧៨:១០,១៧,៣២,៤០,៥៦ ចទ ៩:៧,២៤ យរ ៧:២៤–២៦។

**៨១:១២** នៅក្នុងខនេះចង់និយាយថា ព្រះអម្ចាស់ទ្រង់គឺជាអ្នកដែល "កាត់ស្បែក" ចិត្តរបស់យើងរាល់គ្នា (សូមមើល ចទ ៣០:៦ ១ពវ ៨:៥៨ យរ ៣១:៣៣ អគ ១១:១៩ ៣៦:២៦) ។ ដូច្នេះ នៅពេលដែលព្រះយេហូវ៉ាទ្រង់បានបណ្តោយរាស្ត្ររបស់ទ្រង់ ឱ្យប្រព្រឹត្តតាមអំពើបាបរបស់ពួកគេ នោះគឺបង្ហាញពីការជំនុំជម្រះដ៏គួរឱ្យព្រឺព្រួច និងភ័យខ្លាចដែលព្រះទ្រង់នឹងជំនុំជម្រះដល់រាស្ត្រទ្រង់(សូមមើល ៧៨:២៩ អស ៦:៩–១០ ២៩:១០ ៦៣:១៧ ហើយធៀបជាមួយ រម ១:២៤,២៦,២៨)។

**៨១:១៣–១៦** សូមមើលពីសេចក្តីសន្យាពីព្រះពរ ដែលមាននិយាយក្នុងព្រះគម្ពីរ នក ២៣:២២–២៧ លវ ២៦:៣–១៣ ចទ ៧:១២–២៦ ២៨:១–១៤ ។

**៨១:១៣** *ផ្លូវអញ* សូមមើល ២៥:៤ និងការពន្យល់ ។

១៦ ទ្រង់នឹងចិញ្ចឹមគេដោយស្រូវសាលីល្អបំផុត[យ]
ហើយនិងចំអែតគេដោយទឹកឃ្មុំពីថ្មដា ។

ទំនុករបស់អេសាភ ។

**៨២** ព្រះទ្រង់ឈរនៅក្នុងពួកជំនុំដ៏ខ្លាំងពូកែ
គឺទ្រង់ដែលវិនិច្ឆ័យ[ក] នៅកណ្តាលពួកអ្នកមានអំណាច[ខ]
២ តើឯងរាល់គ្នានឹងជំនុំជំរះដោយទុច្ចរិត
ហើយយល់មុខ[គ]មនុស្សអាក្រក់ដល់កាលណា[ឃ]។ –បង្អង់
៣ ចូរការពារដល់មនុស្សក្រីក្រ និងមនុស្សកំព្រា[ង]
ហើយកាត់ក្តីដល់មនុស្សវេទនា
និងមនុស្សកំសត់[ច]ដោយយុត្តិធម៌ចុះ
៤ ចូរជួយសង្គ្រោះមនុស្សក្រីក្រ និងមនុស្សកំសត់ទុគ៌តដែរ
ត្រូវជួយគេឱ្យរួចពីកណ្តាប់ដៃនៃមនុស្សអាក្រក់
៥ គេមិនដឹង ក៏មិនយល់សោះ[ឆ]
គេតែងដើរទៅមកក្នុងសេចក្តីងងឹត[ជ]
អស់ទាំងឫសផែនដី[ឈ]ក៏ត្រូវកក្រើករំពើក
៦ អញបានពោលថា ឯងរាល់គ្នាសុទ្ធតែជាអ្នកមានអំណាច[ញ]
ហើយជាកូននៃព្រះដ៏ខ្ពស់បំផុតទាំងអស់គ្នា
៧ ប៉ុន្តែឯងនឹងស្លាប់ទៅ[ដ] ដូចជាមនុស្សធម្មតាដែរ
គឺនឹងត្រូវដួលដូចជាមេណាមួយ

**៨១:១៦** យ ចទ ៣២:១៤ **៨២:១** ក ទដ ៧:៨ ៥៨:១១ អស ៣:១៣ ៦៦:១៦ យអ ៣:១២ ខ យប ២១:២២ **៨២:២** គ ចទ ១:១៧ ឃ ទដ ៥៨:១-២ សភ ១៨:៥ **៨២:៣** ង ចទ ២៤:១៧ ច ទដ ១៤០:១២ យរ ៥:២៨ ២២:១៦ **៨២:៥** ឆ ទដ ១៤:៤ ៥៣:២ ជ យប ៣០:២៦ អស ៥:៣០ ៨:២១-២២ ៩:២ ៥៩:៩ ៦០:២ យរ ១៣:១៦ ២៣:១២ បទ ៣:២ ឈ ពច ៥:៤ ទដ ១១:៣ **៨២:៦** ញ យប ១០:៣៤ **៨២:៧** ដ ទដ ៤៩:១២ អក ៣១:១៤

**៨១:១៦** *ទឹកឃ្មុំពីថ្មដា* សូមមើលការពន្យល់ ចទ ៣២:១៣ ។

**ទដ ៨២** នៅក្នុងជំពូកនេះ គឺជាព្រះបន្ទូលរបស់ព្រះដែលទ្រង់នឹងជំនុំជម្រះដល់ពួកអ្នកគ្រប់គ្រង និងពួកចៅក្រមដែលអយុត្តធម៌ ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ គាត់គឺជាម្នាក់ដែលចេញពីអំបូរលេវី បានរំឭកពីទស្សនៈរបស់ព្រះអម្ចាស់ ដែលទ្រង់នឹងធ្វើជាអធិបតេយ្យភាពក្នុងសាលក្រមនៃការជំនុំជម្រះដល់ពួកបរិសុទ្ធរបស់ទ្រង់ ដោយបានប្រៀបពីកិច្ចការនេះទៅនឹងអ្វីដែលពួកហោរាបានឆ្លងកាត់កន្លងមក (មើល ១ពវ ២២:១៩-២២ អស ៦:១-៧ យរ ២៣:១៨,២២ និងក្នុង យប ១៥:៨) ។ ក្នុងនាមព្រះ អម្ចាស់ដែលជាព្រះមហាក្សត្រដ៏ឧត្តម (សូមមើលក្នុងសេចក្តីផ្តើម ទដ ជំពូក ៤៧) ជាចៅក្រមនៃផែនដី (មើល ទដ ៩៤:២ លប ១៨:២៥ ១សយ ២:១០) ដែល "ស្រឡាញ់" សេចក្តីយុត្តិធម៌ (មើល ៩៩:៤) ព្រមទាំងជំនុំជម្រះប្រជាជាតិដោយសេចក្តីយុត្តិធម៌ (មើល ៩:៨ ៩៦:១៣) នោះទ្រង់បានហៅដល់មនុស្សទាំងអស់ ដែលមានទំនួលខុសត្រូវក្នុងការកាត់ក្តីសូមឱ្យគេបានជួយការពារដល់ពួកមនុស្ស ដែលទន់ខ្សោយ និងជនដែលគេសង្កត់សង្កិន ។ តាមការកាត់ស្រាយរបស់ពួកគ្រូប្រដៅ (សូមមើល យហ ១០:៣៤-៣៥) បានបង្ហាញថា "ពួកមានអំណាច" (សូមមើល ខ.១,៦) គឺជាអ្នកកាត់ក្តីដ៏អយុត្តិធម៌ ហើយជាអ្នកដែលត្រួតត្រាក្នុងពួកអ៊ីស្រាអែល (សូមមើល ១សយ ៨:៣ អស ១:១៦-១៧ ៣:១៣-១៥ យរ ២១:១២ ២២:៣ អក ៣៤:៤,២១ មីក ៣:៣ ៧:៣) ។ មនុស្សជាច្រើន ដែលមានអត្ថសញ្ញាណជា "ពួកមានអំណាច" គឺជាពួកមហាក្សត្រទាំងឡាយដែលនៅក្នុងពួកសាសន៍ដទៃ ជាអ្នកដែលមានអំណួតថា ពួកគេគឺជាព្រះដ៏ពិត ប៉ុន្តែ ពួកគេបែរជាដឹកនាំដោយធ្វើឫកខុស និងកាត់ក្តីដោយអយុត្តិធម៌ទៅវិញ ។ មួយវិញទៀត "ពួកមានអំណាច" គឺនិយាយសំដៅលើព្រះអម្ចាស់ ដែលស្តេចទាំងឡាយបានអភិសេកឱ្យធ្វើជាអ្នកគ្រប់គ្រង (សូមមើល ៩៥:៣) ។

**៨២ ត្រង់ចំណងជើង** សូមមើលការពន្យល់ក្នុង ទដ ៧៣ ត្រង់ចំណងជើង ។

**៨២:១** *ជំនុំដ៏ខ្លាំងពូកែ* គឺជាពួកជំនុំដែលបានប្រជុំគ្នានៅក្នុងព្រះទីនាំនៃការវិនិច្ឆ័យ (សូមធៀបជាមួយ ១ពវ ៣:៧) ក្នុងនគរស្ថានសួគ៌ (សូមមើល ៨៩:៥ ១ពវ ២២:១៩ យប ១:៦ ២:១ អស ៦:១-៤) ។ បើសិននេះជាទស្សនៈមួយនោះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បានឃើញពួកអ្នកគ្រប់គ្រង និងពួកចៅក្រមបានប្រមូលគ្នានៅចំពោះព្រះភ័ក្ត្រស្តេចដ៏ឧត្តម ដើម្បីរ៉ាយរ៉ាប់ទូលថ្វាយពីការគ្រប់គ្រងរបស់ខ្លួនក្នុងការកាត់ក្តីរបស់ខ្លួន ។ *ពួកមានអំណាច* សូមមើល ខ.៦ ។ នៅក្នុងសញ្ញាចាស់ និងភាសារបស់ពួកអ្នកដែលនៅតំបន់មជ្ឈឹមបូព៌ាកាលពីសម័យបុរាណ កាលណានិយាយពីពួកអ្នកគ្រប់គ្រងពួកចៅក្រម ជាឧបរដ្ឋមន្ត្រីរបស់មហាក្សត្រ គឺត្រូវបានផ្តល់កិត្តយស ក្នុងនាមជា "អ្នកដែលមានអំណាច" (សូមមើលការពន្យល់ ៤៥:៦ និងការពន្យល់ នក ២១:៦ ២២:៨) ឬក៏ត្រូវបានហៅថា "កូនព្រះ" (សូមមើល ២:៧ និងការពន្យល់) ។

**៨២:៣-៤** នៅក្នុងសញ្ញាចាស់ កិច្ចការសំខាន់របស់ព្រះមហាក្សត្រ និងពួកចៅក្រមគឺត្រូវតែការពារដល់ប្រជាជន ដែលគ្មានអំណាចទាស់ប្រឆាំងចំពោះពួកអ្នកដែលអាចនឹងសង្កត់សង្កិនពួកគេ (សូមមើល ៧២:២,៤,១២-១៤ សភ ៣១:៨-៩ អស ១១:៤ យរ ២២:៣,១៦) ។

**៨២:៥** *គេមិនដឹង ក៏មិនយល់សោះ* ឃ្លានេះគឺជាចំណុចស្នូលនៃបទគម្ពីរនេះ (សូមមើល ៦:៦) ។ ពួកគេម្នាក់ៗត្រូវតែមានចំណែកជាមួយនឹងប្រាជ្ញារបស់ព្រះ (សូមមើល ១ពវ ៣:៩ សភ ៨:១៤-១៦ អស ១១:២) ប៉ុន្តែពួកគេបែរជាគ្មានអ្វីសោះក្នុងយល់ដឹងពីសេចក្តីពិតនៃសិលធម៌ ឬយល់ដឹងពីការគ្រប់គ្រងរបស់ព្រះ (សូមមើល អស ៤៤:១៨ យរ ៣:១៥ ៩:២៤) ។ *ឫស . . . កក្រើករំពើក* នៅពេលដែលមនុស្សទាំងអស់ឃើញសេចក្តីយុត្តិធម៌ នោះពិភពលោកទាំងមូលក៏ត្រូវកក្រើករំពើកដែរ (មើល ១១:៣ ៧៥:៣ និងការពន្យល់) ។

**៨២:៦** *អញបានពោលថា* នៅក្នុងឃ្លានេះចង់និយាយថា ពួកអ្នកគ្រប់គ្រង ឬពួកចៅក្រមទាំងនោះ គឺកើតឡើងតាមការតែងតាំងរបស់ព្រះអម្ចាស់(សូមមើល ២:៧ អស ៤៤:២៨) ដូច្នេះពួកគេគឺជាអ្នកតំណាងរបស់ព្រះអម្ចាស់ ទោះបីជាគេបានទទួលស្គាល់ ឬ មិនទទួលស្គាល់ទ្រង់ក៏ដោយ(សូមមើលក្នុង នក ៩:១៦ យរ ២៧:៦ ដយ ២:២១ ៤:១៧,៣២ ៥:១៨ យហ ១៩:១១ រម ១៣:១) ។ *អ្នកមានអំណាច* សូមមើលការពន្យល់ ខ.១ ។ *ជាកូន* សូមមើលការពន្យល់ ខ.១ ។ *ដ៏ខ្ពស់បំផុត* សូមមើលការពន្យល់ ១៤:១៩ ។

**៨២:៧** នៅក្នុងខនេះចង់និយាយថា ការលើកតម្កើង អួតអាងពីកិត្តិយស និងតំណែងរបស់ខ្លួន នោះពួក "មានអំណាច" ដែលពុករលួយគេនឹងត្រូវដួលចុះដោយព្រោះតែការជំនុំជម្រះរបស់ព្រះមានចំពោះពួកគេ ។ *ដួល* សូមមើលការពន្យល់ ១៣:៤ ។

៨ឱព្រះអង្គអើយ សូមទ្រង់ឈរឡើង[ឋ] ជំនុំជំរះ[ឌ] ផែនដីចុះ
ដ្បិតទ្រង់នឹងបានអស់ទាំងនគរទុកជាមរដក[ឍ] ។

ទំនុកជាបទចំរៀងរបស់អេសាភ ។

**៨៣** ឱព្រះអង្គអើយ សូមកុំឱ្យទ្រង់នៅស្ងៀមឡើយ[ក]
ឱព្រះអង្គអើយ សូមកុំឱ្យសិំងំ ឬព្រងើយនៅឱ្យសោះ
២ដ្បិតមើល ពួកខ្មាំងសត្រូវទ្រង់ គេកំពុងតែអ៊ូអែ[ខ]
ហើយពួកអ្នកដែលស្អប់ទ្រង់ គេធ្វើក្រអឺតក្រអោង[គ]
៣គេប្រឹក្សាគ្នាបង្កើតឧបាយទាស់[ឃ] នឹងរាស្ត្រទ្រង់
ហើយគិតគូរគ្នា ទាស់នឹងអស់អ្នកដែលទ្រង់ខាខាំង[ង]
៤គេបានថា ចូរយើងកាត់គេចេញ[ច] មិនឱ្យធ្វើជានគរទៀត
បាន[ឆ] ហើយកុំឱ្យមានសេចក្តីនឹកចាំ[ជ] ពីឈ្មោះអ៊ីស្រាអែល
ទៀតឡើយ
៥ដ្បិតគេបានពិគ្រោះព្រមព្រៀងគ្នាហើយ[ឈ]
គេបានតាំងសញ្ញាទាស់នឹងទ្រង់
៦គឺអស់ទាំងពួកសាសន៍អេដំម[ញ] សាសន៍អ៊ីសម៉ាអែល
សាសន៍ម៉ូអាប់[ដ] និងសាសន៍ហាការេន[ឋ]
៧សាសន៍កេបាល[ឌ] សាសន៍អាំម៉ូន[ឍ] សាសន៍អាម៉ាលេក[ណ]
សាសន៍ភីលីស្ទីន[ត] ព្រមទាំងពួកអ្នកនៅស្រុកទីរ៉ុសផង[ថ]
៨ឯស្រុកអាសស៊ើរ[ទ] បានពួតដៃជាមួយនឹងគេដែរ
សាសន៍ទាំងនោះក៏ចូលដៃជួយពួកកូនចៅឡុត[ធ] ។ –បង្អង់
៩សូមទ្រង់ធ្វើដល់គេ ដូចបានធ្វើដល់សាសន៍ម៉ាឌាន[ន]
គឺដូចជាបានធ្វើដល់ស៊ីសេរ៉ា[ប]

**៨២:៨** ឋ ទដ ១២:៥ ឌ ទដ ៧៦:៩ ឍ ទដ ២:៨
**៨៣:១** ក ទដ ២៨:១ ៣៥:២២ អស ៤២:១៤ ៥៧:១១ ៦២:១ ៦៤:១២
**៨៣:២** ខ ទដ ២:១ អស ១៧:២ គ ពច ៨:២៨
**៨៣:៣** ឃ នក ១:១០ ទដ ៣១:១៣ ង ទដ ១៧:១៤
**៨៣:៤** ច នអ ៣:៦ ឆ យរ ៣៣:២៤ ជ យរ ១១:១៩
**៨៣:៥** ឈ ទដ ២:២
**៨៣:៦** ញ ទដ ១៣៧:៧ អស ៣៤:៥ យរ ៤៩:៧ អម ១:១១ ដ ២រប ២០:១ ឋ លប ២៥:១៦ **៨៣:៧** ឌ យប ១៣:៥ ឍ លប ១៩:៣៨ ណ លប ១៤:៧ នក ១៧:១៤ ត នក ១៥:១៤ ថ អស ២៣:៣ អគ ២៧:៣ **៨៣:៨** ទ លប ១០:១១ ធ ចទ ២:៩ **៨៣:៩** ន លប ២៥:២ ពច ៧:១–២៣ ប ពច ៤:២

**៨២:៨** នៅក្នុងខ.នេះចង់និយាយថា ដោយសារបានមើលឃើញ ពីជ័យជម្នះនោះអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង បានអធិស្ឋានសូមឱ្យព្រះប្រទានការវិនិច្ឆ័យរបស់ទ្រង់ដោយយុត្តិធម៌ជាបន្ទាន់មកដល់លោកិយទាំងមូល ។ *តើនឡើង* សូមមើលការពន្យល់ ៣:៧ ។ *មរដក* គឺសំដៅលើកម្មសិទ្ធិ (សូមមើលការពន្យល់ ៧៩:១) ។

**ទដ ៨៣** នៅក្នុងជំពូកនេះ ពួកអ៊ីស្រាអែលគេបានអធិស្ឋានទៅចំពោះព្រះអម្ចាស់ សូមឱ្យទ្រង់បានបំផ្លាញពួកខ្មាំងសត្រូវរបស់ពួកគេ នៅក្នុងគ្រាដែលផែនដីទាំងមូល បានទាស់ប្រឆាំងចំពោះរាស្ត្រទ្រង់ ។ ទំនាក់ទំនងព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ ជាមួយទំនុកដំកើងផ្សេងៗទៀតសូមមើលក្នុងសេចក្តីផ្តើម ទដ ៧៩–៨៣ ។ នៅក្នុងព្រះគម្ពីរ ពង្សាវតារក្សត្រ និងគម្ពីររបាក្សត្រមិនបានប្រាប់យើងពីការរួបរួម ដូចដែលបានពណ៌នាក្នុងជំពូកនេះឡើយ ។ ប្រហែលមានតែប្រជាជាតិមួយចំនួនតិចដែលបានពណ៌នានៅទីនេះប៉ុណ្ណោះ ដែលជាអ្នកដែលវាយប្រហារ ឬឈ្នានីសពិតប្រាកដ ក្នុងខណៈពេល ដែលប្រវត្តិសាស្ត្រនៃខ្មាំងសត្រូវរបស់ពួកអ៊ីស្រាអែលបានគាំទ្រចំពោះពួកអ្នកដែលបញ្ចុះបញ្ចូល ។ បើសិនជាដូច្នេះមែន នោះប្រហែលហេតុការណ៍នេះ គឺជារបាយការណ៍ពី ២រប ជំពូក ២០ ក្នុងពេលដែលពួកម៉ូអាប់ អាំម៉ូន និងពួកគេអេដំម រួមទាំងពួកសម្ព័ន្ធមិត្តរបស់គេបានឈ្លានពានដល់ពួកយូដា ។ នៅក្នុងហេតុការណ៍ផ្សេងៗទៀត ព្រះគម្ពីរនេះបានសរសេរឡើងក្រោយរាជ្យស្តេចសាឡូម៉ូន និងមុនពេលការឈ្លានពានពីសំណាក់ពួកអាសស៊ើរក្នុងរាជស្តេចមហាណិម (សូមមើល ២ពវ ១៥:១៩) ។

**៨៣ ចំណងជើង** *បទចំរៀង* មើលការពន្យល់ ទដ៣០ ត្រង់ចំណងជើង ។ *អេសាភ* សូមមើលការពន្យល ទដ ៧៣ ត្រង់ចំណងជើង ។

**៨៣:១–៤** នៅក្នុងខនេះ គឺជាសេចក្តីអធិស្ឋានសូមឱ្យព្រះបានធ្វើការនៅចំពោះមុខពួកអ៊ីស្រាអែល ក្នុងគ្រាដែលគេជួបគ្រោះថ្នាក់ ។

**៨៣:១** *សូមកុំឱ្យទ្រង់នៅស្ងៀមឡើយ* នៅក្នុងឃ្លានេះចង់និយាយថា សូមកុំនៅព្រងើយកន្តើយឡើយ (សូមមើល ៣៥:២២ ១០៩:១) ។

**៨៣:២** *អ៊ូអែ* នៅក្នុងកិរិយាស័ព្ទភាសារហេព្រើរ មានពាក្យ១ទៀតដែលមានន័យដូចគ្នានេះដែរគឺ "ជ្រួលជ្រើម" (៤៦:៦) និង "ដើរក្រវែល" (៥៩:៦,១៤ ។

**៨៣:៤** *គេបានថា* សូមមើលការពន្យល់ ៣:២ ។ *ចូរយើងកាត់គេចេញ* ពួកអ៊ីស្រាអែលគេជួបការបៀតបៀនខ្លាំងបំផុត (សូមមើល ខ.១២) ។

**៨៣:៥–៨** នៅក្នុងខទាំងនេះ ពណ៌នាពីយុទ្ធសាស្ត្រ នៃការវាយលុករបស់ពួកខ្មាំងសត្រូវនៃសាសន៍អ៊ីស្រាអែល ដោយពួកគេបានចាប់ផ្តើមវាយប្រហារចេញពីទិសទាំង៤ ។

**៨៣:៦** *សាសន៍ហាការេន* ពួកគេអាចជាអំបូររបស់សាសសន៍អ៊ីសម៉ាអែល (កូនចៅរបស់នាងហាកាយ) ឬជាក្រុមសម្ព័ន្ធមិត្តសាសន៍អើរ៉ាមដែលមាននិយាយនៅក្នុងសិលាចារិករបស់ពួកអាសស៊ើរ (សូមមើល ១រប ៥:១០, ១៨–២២ ២៧:៣១) ។

**៨៣:៧** *សាសន៍កេបាល* សូមមើល ១ពវ ៥:១៨ អគ ២៧:៩ ។ បើនិយាយពីទីក្រុងកេបាលវិញ វាគឺជាទីក្រុង១ដែលមានសារៈសំខាន់នៅក្នុងស្រុកភេនិច ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានការកាត់ស្រាយអ្នកបានយល់ថា "កេបាស" ដែលនិយាយនៅទីនេះគឺសំដៅលើទីកន្លែង ឬជាតំបន់មួយនៅក្នុងស្រុកអេដំម ភាគខាងត្បូងសមុទ្រស្លាប់ ក្បែរក្រុងប៉េត្រា។

**៨៣:៨** *ស្រុកអាសស៊ើរ* ដោយព្រោះស្រុកនេះមានទំនាក់ទំនងតែជាមួយពួកម៉ូអាប់ និងពួកកូនចៅអាំម៉ូន (កូនចៅរបស់ឡុត មើលការពន្យល់ លប ១៩:៣៦–៣៨) នោះពួកអ្នកស្រុកអាសស៊ើរដែលទោះជាមានសកម្មភាពយ៉ាងណាក៏ដោយ ក៏មិនទាន់ក្លាយជាអ្នកដែលបៀតបៀនយ៉ាងខ្លាំងដែរ ។

**៨៣:៩–១២** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានទូលអង្វរដល់ព្រះសូមឱ្យព្រះអម្ចាស់ទ្រង់បានបំផ្លាញដល់ពួកខ្មាំងសត្រូវរបស់គាត់ ដូចកាលដែលព្រះអង្គធ្លាប់ធ្វើក្នុងគ្រាពួកចៅហ្វាយដែរ ។ ដូច្នេះពួកអ្នកដែលបានតាំងខ្លួនទាស់ប្រឆាំងចំពោះនគររបស់ព្រះ ត្រូវតែបំផ្លាញគេចេញពីផែនដីដ៏អប្បលក្ខណ៍នេះចេញ ហើយដោយការទាំងអស់នេះហើយ ពួកអ្នកដែលមិនជឿ នោះអំណាចរបស់គេនឹងត្រូវដកក្រវែងចោលដូចជាដកដើមឱ្មម បើសិនជានគរដ៏សុចរិតរបស់ព្រះ និងសេចក្តីសុខសាន្តមកដល់(មើលការពន្យល់ ៥:១០)។

**៨៣:៩** *ដូចបានធ្វើដល់សាសន៍ម៉ាឌាន* គឺនិយាយសំដៅលើគ្រាដែលព្រះយេហូវ៉ាប្រទានជ័យជំនះដ៏ធំដល់គេឌាន (សូមមើល ពច ជំពូក ៧) ។ *ដូច*

និងយ៉ាប៊ីន[ផ]នៅត្រង់ស្ទឹងគីសុន[ព]
១០ជាអ្នកដែលវិនាសទៅ នៅត្រង់អេន-ដោរ[ភ]
ហើយបានត្រឡប់[ម]ដូចជាលាមកនៅដី
១១សូមធ្វើឱ្យពួកមានត្រកូលខ្ពស់របស់គេ បានដូចជាអូរិប
និងសៀប[យ] អើ សូមឱ្យអស់ពួកចៅហ្វាយក្នុងសាសន៍ទាំង
នោះបានដូចជាសេបា ហើយនិងសាលម៉ូន៉ា[រ]
១២ជាអ្នកដែលនិយាយថា ចូរយើងចាប់យក[ល] អស់ទាំងទី
លំនៅរបស់ព្រះ ទុកជាកេរ្តិ៍អាកររបស់យើងចុះ
១៣ឱព្រះនៃទូលបង្គំអើយ សូមធ្វើឱ្យគេបានដូចជាធូលីកួច
ដូចជាកំទេចចំបើង[វ]ដែលផាត់ទៅដោយខ្យល់
១៤ដូចភ្លើងដែលឆេះព្រៃ
ហើយដូចជាអណ្តាតភ្លើងដែលរាលឡើងឆេះភ្នំផង[ស]
១៥សូមដេញតាមគេដោយខ្យល់គំហុក[ហ]របស់ទ្រង់
ហើយធ្វើឱ្យគេភ័យញ័រដោយព្យុះសង្ឃរារបស់ទ្រង់យ៉ាង
នោះឯង[ឡ]
១៦សូមគ្របមុខគេដោយសេចក្តីអៀនខ្មាស[អ]
ដើម្បីឱ្យគេបានស្វែងរកព្រះនាមទ្រង់ ឱព្រះយេហូវ៉ាអើយ
១៧សូមឱ្យគេត្រូវខ្មាស ហើយភ័យស្លុតជាដរាប[ក] អើ
សូមឱ្យគេត្រូវស្រឡាំងកាំង ហើយវិនាសទៅ[ខ]
១៨ដើម្បីឱ្យគេបានដឹងថា
គឺទ្រង់តែ១អង្គព្រះនាមជាយេហូវ៉ា[គ]
ដែលជាព្រះដ៏ខ្ពស់បំផុត[ឃ]លើផែនដីទាំងមូល[ង]។

ទំនុករបស់កូនចៅកូរេ ដែលលើកសំរាប់មេភ្លេង
ត្រូវលេងដោយប្រដាប់ភ្លេងគីធីត ។

# ៨៤

ឱព្រះយេហូវ៉ានៃពួកពលបរិវារអើយ

**៨៣:៩** ផ យស ១១:១ ប ពច ៤:២៣-២៤ **៨៣:១០** ភ ១សយ ២៨:៧ ម ២ពវ ៩:៣៧ អស ៥:២៥ យរ ៨:២ ៩:២២ ១៦:៤ ២៥:៣៣ សផ ១:១៧ **៨៣:១១** យ ពច ៧:២៥ រ ពច ៨:៥ **៨៣:១២** ល ២របា ២០:១១ អគ ៣៥:១០ **៨៣:១៣** វ យប ១៣:២៥ **៨៣:១៤** ស ចទ ៣២:២២ អស ៩:១៨ **៨៣:១៥** ហ ទដ ៥០:៣ ឡ យប ៩:១៧ **៨៣:១៦** អ ទដ ៣៤:៥ ១០៩:២៩ ១៣២:១៨ **៨៣:១៧** ក ២ពវ ១៩:២៦ ខ ទដ ៣៥:៤ **៨៣:១៨** គ ទដ ៦៨:៤ ឃ ទដ ៧:៨ ១៨:១៣ ង យប ៣៤:២៩

*បានធ្វើដល់ស៊ីសេរ៉ា* គឺនិយាយសំដៅលើគ្រាដែលបារ៉ាកបានច្បាំងឈ្នះការឈ្លានពានរបស់ពួកសាសន៍កាណាន (សូមមើល ពច ជំពូក ៤) ។
**៨៣:១០** *អេន-ដោរ* មើល យស ១៧:១១ និងការពន្យល់ ។ អេន-ដោរមានទីតាំងស្ថិតនៅភាគខាងជើង ជាកន្លែងចម្បាំងដ៏សំខាន់ ។
**៨៣:១១** *អូរិប និងសៀប . . . សេបា . . . សាលមូន៉ា* ពួកអ្នកទាំងនេះគឺជាមេដឹកនាំរបស់សាសន៍ម៉ាឌាន ហើយក៏ជាអ្នកដែលគេឌានបានបំផ្លាញដែរ ។
**៨៣:១២** សូមមើល ខ.៤ ។
**៨៣:១៣-១៦** នៅក្នុងខទាំងនេះ គឺជាការទូលអង្វរជាថ្មី ដោយបានភ្ជាប់មកជាមួយអារម្មណ៍របស់ពួកពលទ័ព និងអំណាចដ៏គួរឱ្យភ័យខ្លាចរបស់ព្រះ ។
**៨៣:១៥** នៅក្នុងខនេះបានពណ៌នា ពីពួកពលទ័ពនៃស្ថានសួគ៌ច្បាំងចំពោះពួកខ្មាំងសត្រូវ ដោយប្រើព្យុះរន្ទះជាអាវុធ (សូមមើល ១៨:៧-១៥ ៦៨:៣៣ ៧៧:១៧-១៨ នក ១៥:៧-១០ យស ១០:១១ ពច ៥:៤,២០-២១ ១សយ ២:១០ ៧:១០ អស ២៩:៥-៦ ៣៣:៣)។ សូមមើល ៦៨:៤ និងការពន្យល់ដែលនិយាយពីព្យុះពពកដែលព្រះបញ្ជូនមក ។
**៨៣:១៦** *ស្វែងរក* សូមមើលការពន្យល់ ខ.១៨ ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។
**៨៣:១៧-១៨** នៅក្នុងខទាំងនេះ គឺជាសេចក្តីបញ្ចប់នៃសេចក្តីអធិស្ឋាន ។
**៨៣:១៨** នៅក្នុងខនេះនិយាយថា គោលបំណងនៃចម្បាំងរបស់ព្រះមិនគ្រាន់តែដើម្បីការពារពួកអ៊ីស្រាអែល និងបំផ្លាញខ្មាំងសត្រូវរបស់គេ ព្រមទាំងខ្មាំងសត្រូវរបស់ព្រះប៉ុណ្ណោះនោះឡើយ ប៉ុន្តែក៏ដើម្បីឱ្យលោកិយទាំងមូលបានដឹង និងទទួលស្គាល់ពីសេចក្តីពិតរបស់ព្រះ និងការគ្រប់គ្រងរបស់ទ្រង់(សូមមើល ខ.១៦ ៤០:៩ ៤៧:៩ ៥៨:១១ ៥៩:១៣ និងការពន្យល់) ។ *ខ្ពស់បំផុត* សូមមើលការពន្យល់ ១៤:១៩ ។
**ទដ ៨៤-៨៩** នៅព្រះគម្ពីរទំនុកដំកើងទាំង៦ជំពូកដំបូង បានជំនួសឱ្យបទគម្ពីរទំនុកដំកើងជំពូកចុងក្រោយក្នុងប៉ែកទី៣ (សូមមើលក្នុងសេចក្តីផ្តើមជំពូក ៧៣-៧៨) បានពណ៌នាពីការបំណងប្រាថ្នាក្នុងការប្រកបស្និទ្ធិជាមួយនឹងព្រះអម្ចាស់ ដែលទ្រង់បានគង់ក្នុងព្រះវិហាររបស់ទ្រង់ក្នុងក្រុងស៊ីយ៉ូន ហើយដែលមានតែទ្រង់ប៉ុណ្ណោះដែលអាចនាំសេចក្តីសុខសាន្ត និងព្រះពរដល់ពួកគេបាន ។ ការដែលនិយាយថា ព្រះអម្ចាស់ជា"ព្រះដ៏មានគ្រប់ព្រះចេស្តា" និងសេចក្តីអធិស្ឋានសូមឱ្យព្រះអម្ចាស់ធ្វើជា"ខែលនៃយើងខ្ញុំ" និង "ការចាក់ប្រេងតាំង" របស់ព្រះយេហូវ៉ា នោះគឺជាទីសំគាល់មួយដើម្បីបង្ហាញថា ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកទាំងនោះមានទំនាក់ទំនងជាមួយព្រះគម្ពីរទំនុកដំកើងក្នុងចុងបញ្ចប់ក្នុងប៉ែកទី៣នេះ (សូមមើលលក្ខណៈទម្រង់ ៨៤:១,៣,៨,១២ និង ៨៩:៨ ៨៤:៩ ៨៩:១៨,៣៨,៥១) ។ ព្រះគម្ពីរទំនុកដំកើង៥ជំពូកដែលបាននិយាយដោយក្នុងនោះមាន៤ បាននិយាយពីការដង្ហោយរកព្រះក្នុងគ្រាដែលមានសេចក្តីវេទនា វាគឺជាចំណុចស្នូលនៃបទចម្រៀង (ជំពូក ៨៧) ដែលបានសរសើរចំពោះសេចក្តីស្រឡាញ់ដ៏ពិសេសរបស់ព្រះចំពោះក្រុងស៊ីយ៉ូន និងការថែរក្សានិងយកចិត្តទុកដាក់ចំពោះរាស្ត្រនៃក្រុងនេះ ។ នៅក្នុងចំណោមទំនុកដំកើងទាំង៤ជំពូកនោះដំបូង (៨៥) និងជំពូកចុងក្រោយ (៨៩) គឺជាសេចក្តីអធិស្ឋានរបស់ពួកបណ្តាជនដែលគេបានមូលមកឯព្រះ ចំណែកឯ២ជំពូកទៀត (ទដ ៨៦,៨៨) គឺជាសេចក្តីអធិស្ឋានជាលក្ខណៈបុគ្គល ។ នៅក្នុងជំពូកទាំងនេះបានពណ៌នាពី "សេចក្តីសប្បុរស និងសេចក្តីពិតត្រង់" (មើល ៨៥:៧,១០-១១ ៨៦:៥,១៣,១៥ ៨៨:១១ ៨៩:១-២,៨,១៤,២៨,៣៣,៤៩) និង "សេចក្តីសង្គ្រោះ" របស់ទ្រង់(សូមមើល ៨៥:៤-៧,៩, ៨៦:២,១៦ ៨៨:១ ៨៩:២៦) ។ នៅក្នុងវគ្គចុងក្រោយក្នុងប៉ែកទី៣នេះមាន៣ជំពូកទៀត ដែលមានចំណែកក្នុងផ្ទៃរឿងនេះដោយនិយាយពី "សេចក្តីសុចរិត" (មើល ៨៥:១០-១១,១៣ ៨៨:១២ ៨៩:១៤) ។ ២ជំពូកចុងក្រោយដែលនិយាយពីសេចក្តីអធិស្ឋាន (ទដ ៨៨, ៨៩) បានបញ្ចប់ដោយការពណ៌នាពីទំនុកចិត្តថា ព្រះទ្រង់នឹងស្តាប់ពាក្យដែលគេបានអធិស្ឋាន ហើយនិងតបឆ្លើយ (មើលការពន្យល់ ៣:៨)។
**ទដ ៨៤** នៅក្នុងជំពូកនេះ គឺជាសេចក្តីអធិស្ឋានចង់បានដំណាក់នៃព្រះយេហូវ៉ា ។ តាមរយៈទស្សនៈវិស័យដែលបានពណ៌នា បានបង្ហាញថា ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះមានទំនាក់ទំនងជាមួយ ទដ ៤២ ហើយប្រហែលជាបានឆ្លុះបញ្ចាំងពីកាលៈទេសៈដូចគ្នាទៀតផង ។ បើសិនជាដូច្នេះមែន (ប្រ

អស់ទាំងទី[ក]ដែលទ្រង់ស្ថិតនៅនោះគួរស្រឡាញ់ណាស់ហ្ន៎
២ព្រលឹងទូលបង្គំរឭក[ខ] អើ ក៏កន្លេងចិត្ត ដោយនឹកដល់
ទីលាននៃព្រះយេហូវ៉ា ចិត្តនិងសាច់ឈាមទូលបង្គំស្រែក
អាល័យដល់ព្រះដ៏មានព្រះជន្មរស់នៅ[គ]
៣ឱព្រះយេហូវ៉ានៃពួកពលបរិវារ[ឃ]
ដែលមានមហាក្សត្រ[ង]ហើយជាព្រះនៃទូលបង្គំអើយ[ច]
ទោះទាំងចាបក៏រកទីនៅបានហើយសត្វត្រចៀកកាំ
ក៏បានសំបុក សំរាប់ខ្លួនដាក់កន្លែងដែលដាក់កូនបានដែរ
គឺជាអាសនានៃទ្រង់[ឆ]
៤មានពរហើយ អស់អ្នកណាដែលអាស្រ័យនៅក្នុងដំណាក់
ទ្រង់ គេនឹងចេះតែសរសើរដល់ទ្រង់ជានិច្ច ។ –បង្អង់
៥មានពរហើយ មនុស្សណាដែលយកទ្រង់ជាកំឡាំង[ជ]
របស់ខ្លួន ជាអ្នកដែលមានគ្រប់ទាំងផ្លូវរៀបចំក្នុងចិត្ត
ហើយ[ឈ]
៦កាលណាអ្នកនោះដើរកាត់ច្រកនៃសេចក្តីយំសោក
ក៏ធ្វើឱ្យច្រកនោះត្រឡប់ទៅជាទីមានក្បាលទឹកហូរ[ញ]
អើ ទឹកភ្លៀង[ដ]ក៏គ្របដោយពរដែរ
៧ពួកនោះដើរទៅទាំងមានកំឡាំងខ្លាំងឡើងបណ្តើរ[ឋ]
គ្រប់គ្នាក៏លេចមក[ឌ]នៅចំពោះព្រះ ត្រង់ស៊ីយ៉ូន[ឍ]
៨ឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារអើយ
សូមស្តាប់សេចក្តីអធិស្ឋានរបស់ទូលបង្គំ[ណ]
ឱព្រះនៃយ៉ាកុបអើយ សូមផ្ទៀងព្រះកាណ៌ផង ។ –បង្អង់
៩ឱព្រះដ៏ជាខែលនៃយើងខ្ញុំអើយ[ត] សូមទ្រង់ទតមក

**៨៤:១** ក ចទ ៣៣:២៧ ទដ ២៧:៤ ៤៣:៣ ៩០:១ ១៣២:៥ **៨៤:២** ខ យប ១៩:២៧ គ យស ៣:១០ **៨៤:៣** ឃ ទដ ៤៣:៤ ង យរ ៤៤:១១ ច ទដ ២:៦ ឆ ទដ ៥:២ **៨៤:៥** ជ ទដ ៨១:១ ឈ យរ ៣១:៦ **៨៤:៦** ញ យប ៣៨:២៦ ដ យអ ២:២៣ **៨៤:៧** ឋ យប ១៧:៩ ឌ ចទ ១៦:១៦ ឍ ១ពវ ៨:១ **៨៤:៨** ណ ទដ ៤:១ **៨៤:៩** ត ទដ ៥៩:១១

ហែលពួកលេវីកំពុងតែបម្រើក្នុងព្រះវិហារ) នោះអ្នកនិពន្ធមានបំណងចិត្តចង់ចូលទៅចំពោះដំណាក់នៃព្រះ (ប្រហែលជានៅពេលដែលសានហេរីបចូលវាយលុកស្រុកយូដា សូមមើល ២ពវ ១៨:១៣–១៦) ដើម្បីចូលឱ្យបានជិតបំផុតជាមួយព្រះក្នុងព្រះវិហារ នៃទ្រង់ដែលគាត់បានស្គាល់កាលពីការមុន ។ ការដែលនិយាយពីការដែលព្រះបាទគង់នៅក្នុងវិហារទ្រង់ និង"ព្រះពរ" (សូមមើល ខ.៤–៥,១២) របស់ពួកអ្នកដែលបានចូលទៅឯព្រះនោះ គឺជាចំនុចស្នូលក្នុងផ្ទៃរឿងនេះ ។

**៨៤ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ត្រូវលេងដោយ* សូមមើលការពន្យល់ ទដ ៦ ត្រង់ចំណងជើង ។ *ប្រដាប់មានខ្សែ* មើលការពន្យល់ ទដ ជិពូក៨ត្រង់ចំណងជើង ។ *ទំនុកកូនចៅកូរេ* សូមមើល ទដ ៤២ ត្រង់ចំណងជើង ។

**៨៤:១–៤** នៅក្នុងខទាំងនេះ គឺនិយាយពីបំណងចិត្តចង់បានព្រះ ។

**៨៤:១** *គួរស្រឡាញ់* ពាក្យនេះទំនងជាកើតចេញពីភាសាហេព្រើរ ។ *ព្រះយេហូវ៉ានៃពួកពលបរិវ៉ា* មើល ខ.៣,៨,១២ និងការពន្យល់ ១សយ ១:៣ ។

**៨៤:២** *ព្រលឹងទូលបង្គំ* គឺនិយាយសំដៅលើទូលបង្គំព្រះករុណា (សូមមើលការពន្យល់ ៦:៣) ។ *ទីលាន* គឺទីលាននៃព្រះវិហារ (សូមមើលការពន្យល់ ខ.១០ ២ពវ ២១:៥ ២៣:១១–១២) ។ *ចិត្ត និងសាច់ឈាមទូលបង្គំ* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយសំដៅលើរូបកាយទាំងមូល(មើល ៧៣:២៦) ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។ *ព្រះដ៏មានព្រះជន្មរស់នៅ* សូមមើល ចទ ៥:២៦ ។

**៨៤:៣** នៅក្នុងខនេះ អ្នកនិពន្ធបានប្រៀណនឹងបក្សាបក្សីដ៏តូចដែលមានសិទ្ធិចូលទៅដល់ព្រះវិហារ និងទីអាសនារបស់ព្រះបាន ។ បក្សាបក្សីទាំងនេះ គេមានសមត្ថភាពក្នុងការសង់សំបុកសម្រាប់កូនរបស់ពួកគេ នៅកន្លែងដែលពួកអ៊ីស្រាអែលគួរតែជួបជុំប្រកបជាមួយព្រះ ។

**៨៤:៤–៥,១២** *មានពរហើយ* សូមមើលការពន្យល់ ១:១ ។

**៨៤:៤** *អស់អ្នកណាដែលស្នាក់នៅក្នុងដំណាក់ទ្រង់* មើលការពន្យល់ ១៥:១។

**៨៤:៥–៧** នៅក្នុងខទាំងនេះ គឺនិយាយពីព្រះពរនៃសេចក្តីអំណររបស់ពួកអ្នកដង្ហែរក្បួនចម្រៀងឆ្ពោះទៅកាន់ក្រុងស៊ីយ៉ូន ។

**៨៤:៥** *មនុស្សណាដែលយកទ្រង់ជាកំឡាំងរបស់ខ្លួន* គឺជាពួកអ្នកដែលបានទទួលស្គាល់ថា ព្រះអម្ចាស់គឺជាអ្នកដែលបានសង្គ្រោះពួកគេ និងជាអ្នកដែលទ្រទ្រង់ជីវិតពួកគេ ។ *ជាអ្នកដែលមានគ្រប់ទាំងផ្លូវរៀបចំក្នុងចិត្តហើយ* តាមភាសាអក្សរសាស្ត្រឃ្លានេះគឺ "នៅក្នុងចិត្តរបស់គេមានផ្លូវដ៏ធំ" ។ ផ្លូវដ៏ធំគឺជាផ្លូវ ដែលពួកអ៊ីស្រាអែលនឹងធ្វើពិធីបុណ្យនៅឯកក្រុងយេរូសាឡិម (ស៊ីយ៉ូន ខ.៧) ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**៨៤:៦** *កាលណាអ្នកនោះដើរកាត់* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើការធ្វើដំណើរដើរកាត់ផ្លូវទៅឯព្រះវិហារ ។ *ច្រកនៃសេចក្តីយំសោក* ច្រកនោះមានន័យថា "យំសោក" ។ ទីកន្លែងពិតប្រាកដនៃច្រកនេះគេមិនស្គាល់ឡើយហើយប្រហែលនិយាយសំដៅ (សូមមើល ២៣:៤) លើទីកន្លែងដែលសោះកក្រោះដែលពេលហែរធម្មយាត្រាបានឆ្លងកាត់ ។ *ក៏ធ្វើឱ្យច្រកនោះត្រឡប់ទៅជាមានក្បាលទឹកហូរ* នៅក្នុងឃ្លានេះគឺចង់និយាយសំដៅលើសេចក្តីអំណរដែលគេសង្ឃឹមថានឹងបាន របស់ក្រុមអ្នកហែរក្បួនធម្មយាត្រាក្នុងការបំផ្លាស់បំប្រែពីសេចក្តីទុក្ខលំបាក ឬជអំណរ និងភាពស្រស់ថ្លា ។ *ទឹកភ្លៀងក៏គ្របដោយពរ* គឺសំដៅលើការភ្លៀងធ្លាក់យ៉ាងខ្លាំងនៅមុនរដូវកាលដែលជាតំរុយបង្ហាញថា ភ្លៀងក្នុងរដូវវស្សាដែលនឹងមានពេញលើទីហួតហែងក្នុងប្រទេសអ៊ីស្រាអែល (សូមមើល ១០៤:១៣–១៥) ហើយគ្របដណ្តប់ពាសពេញជ្រលងភ្នំ (សូមមើល ៦៥:៩–១៣ យអ ២:២៣–២៤) ។

**៨៤:៧** *មានកំឡាំងកាន់តែខ្លាំងឡើង* នៅក្នុងឃ្លានេះចង់និយាយថា ទោះបីជាគេធ្វើដំណើរយ៉ាងពិបាកក៏ដោយ ក៏គេមានកម្លាំងដែរ (សូមមើល អស ៤០:៣១) ។ *ស៊ីយ៉ូន* សូមមើល ៩:១១ និងការពន្យល់ ។ ព្រះអម្ចាស់ទ្រង់បានប្រទានពរដល់ព្រះមហាក្សត្រនៃក្រុងស៊ីយ៉ូន ជាម្នាក់ដែលអ្នកនិពន្ធបាននិយាយថា គាត់មានបំណងចិត្តក្នុងការចូលមកបម្រើក្នុងព្រះវិហារ (សូមមើលក្នុងសេចក្តីផ្តើម) ។

**៨៤:៨** *ព្រះនៃពួកពលបរិវ៉ា . . . ព្រះនៃយ៉ាកុប* នៅក្នុងឃ្លានេះចង់និយាយថាព្រះយេហូវ៉ានៃពួកពលបរិវ៉ាគឺជាព្រះនៃយ៉ាកុប (សូមមើល ៥៩:៥ និងការពន្យល់ ៣:៧) ។ *យ៉ាកុប* ពាក្យនេះគឺមានន័យដូចគ្នានឹងពាក្យថា អ៊ីស្រាអែល (សូមមើល លប ៣២:២៨) ។

**៨៤:៩** *ខែលនៃយើងខ្ញុំ* គឺនិយាយសំដៅលើស្តេចនៃក្រុងយេរូសាឡិម (សូមមើលការពន្យល់ ៣:៣) ។ *ចាក់ប្រេងតាំងឱ្យ* គឺជាអ្នកដែលព្រះបានចាក់ប្រេងតាំងឱ្យធ្វើជាអ្នកដឹកនាំលើរាស្ត្ររបស់ទ្រង់ (ជិន្នូរវង្សនៃស្តេចដាវីឌប្រហែលជាស្តេចហេសេគាល មើលសេចក្តីផ្តើម និងការពន្យល់ ២:២) ។

សូមមើលចំមុខរបស់អ្នកដែលទ្រង់បានចាក់ប្រេងតាំងឱ្យ[ឋ]
១០ដ្បិត១ថ្ងៃនៅក្នុងព្រះលាននៃទ្រង់នោះវិសេសជាង១ពាន់
ថ្ងៃណាទៀត ទូលបង្គំស៊ូធ្វើជាអ្នកឆ្មាំទ្វារ[ទ] នៅក្នុងដំណាក់
របស់ព្រះនៃទូលបង្គំ ជាជាងនៅក្នុងលំនៅនៃសេចក្តី
អាក្រក់
១១ពីព្រោះព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់ជាព្រះអាទិត្យ[ធ] ហើយ
ជាខែល[ន] ព្រះយេហូវ៉ាទ្រង់នឹងផ្តល់ព្រះគុណ
ព្រមទាំងកិត្តិយស ទ្រង់នឹងមិនសំចៃទុក[ប] របស់ល្អអ្វីដល់ពួក
អ្នកដែលដើរដោយទៀងត្រង់ឡើយ
១២ឱព្រះយេហូវ៉ានៃពួកពលបរិវារអើយ
មនុស្សណាដែលទុកចិត្តនឹងទ្រង់ នោះមានពរ[ផ] ហើយ ។

ទំនុករបស់កូនចៅកូរេ ដែលលើកសំរាប់មេភ្លេង ។

**៨៥** ឱព្រះយេហូវ៉ាអើយ
ទ្រង់បានមេត្តាប្រោសដល់ស្រុកទ្រង់
ហើយបាននាំពួកយ៉ាកុបដែលជាឈ្លើយមកវិញ[ក]
២ទ្រង់បានអត់ទោស[ខ] ចំពោះការទុច្ចរិត[គ] របស់រាស្ត្រទ្រង់
ក៏បានគ្របបាំងអស់ទាំងបាបរបស់គេហើយ ។ –បង្អង់
៣ទ្រង់បានដកសេចក្តីក្រោធ[ឃ] នៃទ្រង់ចេញអស់ហើយ
ទ្រង់បានបែរចេញពីសេចក្តីខ្ញាល់ដ៏សហ័សរបស់ទ្រង់[ង]
៤ឱព្រះដ៏ជួយសង្គ្រោះយើងខ្ញុំអើយ[ច] សូមបង្វិល[ឆ] យើងខ្ញុំមក
វិញ សូមទ្រង់លែងមានសេចក្តីគ្នាន់ក្នាញ់ចំពោះយើងខ្ញុំ
ផង
៥តើទ្រង់នឹងខ្ញាល់ចំពោះយើងខ្ញុំជាដរាបឬ[ជ]
តើនឹងបន្លាយសេចក្តីខ្ញាល់ទ្រង់ដរាបដល់គ្រប់ទាំងដំណ
តទៅឬអី
៦តើទ្រង់មិនប្រោស[ឈ] ឱ្យយើងខ្ញុំមានជីវិតឡើងវិញ
ដើម្បីឱ្យរាស្ត្ររបស់ទ្រង់បានរីករាយ[ញ] ក្នុងទ្រង់ទេឬអី
៧ឱព្រះយេហូវ៉ាអើយ សូមសំដែងសេចក្តីសប្បុរសរបស់
ទ្រង់[ដ] ឱ្យយើង ខ្ញុំឃើញ ហើយប្រោសសេចក្តីសង្គ្រោះនៃ
ទ្រង់ដល់យើងខ្ញុំផង[ឋ] ។
៨ខ្ញុំនឹងស្តាប់សេចក្តីដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់នឹង

**៨៤:៩** ឋ ១សយ ១៦:៦ ទដ ២:២ ១៨:៥០ ១៣២:១៧ **៨៤:១០** ទ ១រប ២៣:៥ **៨៤:១១** ធ អស ៦០:១៩ យរ ៤៣:១៣ វវ ២១:២៣ ន លប ១៥:១ ប ទដ ៣៤:១០ **៨៤:១២** ផ ទដ ២:១២ **៨៥:១** ក ចទ ៣០:៣ ទដ ១៤:៧ **៨៥:២** ខ ជន ១៤:១៩ គ នក ៣២:៣០ ទដ ៧៨:៣៨ **៨៥:៣** ឃ ទដ ១០៦:២៣ ដយ ៩:១៦ ង នក ៣២:១២ ចទ ១៣:១៧ ទដ ៧៨:៣៨ យហ ៣:៩

**៨៥:៤** ច ទដ ៧១:២០ ឆ ទដ ៦៥:៥ **៨៥:៥** ជ ទដ ៥០:២១ **៨៥:៦** ឈ ទដ ៨០:១៨ ញ ភល ៣:១ **៨៥:៧** ដ ទដ ៦:៤ ឋ ទដ ២៧:១

**៨៤:១០** *ឆ្មាំទ្វារ* ប្រហែលអ្នកនិពន្ធចង់និយាយសំដៅលើមនុស្សសាមញ្ញ ដែលបម្រើការនៅក្នុងព្រះវិហារ (ជាអ្នកដែលបន្ទាបខ្លួន) (មើល ២ពវ ២២:៤) ។ *លំអរនៃសេចក្តីអាក្រក់* នៅក្នុងឃ្លានេះចង់និយាយថា ពួកគេមានចំណែកជាមួយនឹងពួកអ្នកដែលមិនជឿ និងមិនគោរពស្រឡាញ់ព្រះនៃក្រុងស៊ីយ៉ូន ។ មិនតែប៉ុណ្ណោះសោត ឃ្លានេះប្រហែលនិយាយសំដៅលើពួកអ្នកដែលស្តេចសើកុនទី២បញ្ជូនមក (មើល ២ពវ ១៧:២៤–៣៣) ទៅដាក់ឱ្យមករស់ក្នុងពេលដែលអ្នកនិពន្ធបានរស់នៅ ។

**៨៤:១១** *ព្រះអាទិត្យ* គឺជាសិរីល្អដែលធ្វើឱ្យជីវិតមានពន្លឺ (សូមមើលការពន្យល់ ២៧:១) ។ *ខែល* សូមមើលការពន្យល់ ៣:៣ ។ *អ្នកដែលដើរដោយទៀងត្រង់* សូមមើល ១៥:២ លប ១៧:១ និងការពន្យល់ ។

**៨៤:១២** នៅក្នុងខនេះគឺសេចក្តីបញ្ចប់នៃជំពូក៨៤នេះ (មើល ៤០:៤) ។

**ទដ ៨៥** នៅក្នុងជំពូកនេះ ពួកបណ្តាជនគេបានរួមគ្នាមកអធិស្ឋានសូមសេចក្តីមេត្តាករុណាជាថ្មីមកពីព្រះអម្ចាស់ ក្នុងគ្រាដែលពួកគេកើតមានទុក្ខវេទនាខ្លាំងឡើងៗ ។ មនុស្សជាច្រើនបានជឿថានៅក្នុង ខ.១–៣ គឺនិយាយសំដៅលើពួកអ្នកដែលបានវិលត្រឡប់ពីការនិរទេសវិញ ហើយពួកអ្នកដែលកើតមានសេចក្តីទុក្ខព្រួយ គឺពណ៌នាពីអ្នកដែលរស់នៅក្នុងជំនាន់នេហេមា និងម៉ាឡាគី ។ នៅក្នុង ខ.១២ បង្ហាញថាគ្រោះរាំងស្ងួតបានបំផ្លាញទឹកដីដែលជាស្រុករបស់ពួកគេ ហើយប្រហែលនិយាយសំដៅលើគ្រោះរាំងស្ងួតដែលព្រះអម្ចាស់ទ្រង់បញ្ជូនមក ជាការព្រមានដល់រាស្ត្រទ្រង់ក្នុងជំនាន់ហោរាហាកាយ (មើល ហាក ១:៥–១១) ។ សេចក្តីអធិស្ឋានក្នុងជំពូកនេះ និងទំនាក់ទំនងព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ ជាមួយទំនុកកើងផ្សេងៗទៀតដែលនៅក្នុងក្រុមជាមួយគ្នានេះ មើលក្នុងសេចក្តីផ្តើម ទដ ៨៤–៨៩ ។

ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ បានបែងចែកជា២ចំណែកធំៗដែលមាន៧ខ (នៅក្នុងភាសារហេព្រើរ) ក្នុង១ផ្នែក ។ ផ្នែកទី១ (ខ.១–៧) និយាយពីសេចក្តីអធិស្ឋាន ហើយនៅក្នុងផ្នែកទី២ (៨–១៣) និយាយពីការធានារាប់រងរបស់ព្រះអម្ចាស់ ។

**៨០ត្រង់ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ទំនុករបស់កូនចៅកូរេ* សូមមើលការពន្យល់ ទដ ៤២ ត្រង់ចំណងជើង ។

**៨៥:១–៧** នៅក្នុងខទាំងនេះ គឺជាសេចក្តីអធិស្ឋានរបស់ពួកបណ្តាជនដែលគេអធិស្ឋានសូមសេចក្តីមេត្តាករុណាជាថ្មីមកពីព្រះអង្គ ។

**៨៥:១–៣** ពួកកូនចៅកូរេ គេបានយកលំនាំពួកអ៊ីស្រាអែលមកអធិស្ឋាន ដោយពួកគេបានរំឭកពីសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ កាលពីគ្រាមុន ក៏រំឭកពីការអត់ទោស និងការស្រោចស្រង់ពួកគេឡើង (ប្រហែលការស្រោចស្រង់ពួកគេបន្ទាប់ពីគ្រានិរទេស) ។

**៨៥:១** *បាននាំពួកយ៉ាកុបដែលជាឈ្លើយមកវិញ* សូមមើល យរ ២៩:១៤ និងការពន្យល់) ។ *យ៉ាកុប* ពាក្យនេះមានន័យដូចគ្នានឹងពាក្យថា អ៊ីស្រាអែល (សូមមើល លប ៣២:២៨) ។

**៨៥:៣** *សេចក្តីក្រោធ . . . សេចក្តីខ្ញាល់* សូមមើល ខ.៥ និងការពន្យល់ ២:៥ ។

**៨៥:៤–៧** នៅក្នុងសេចក្តីអធិស្ឋាននេះ ពួកគេបានទទួលស្គាល់ថា សេចក្តីទុក្ខលំបាកដែលពួកគេមាននៅពេលនេះ គឺជាសញ្ញាណនៃការដែលព្រះបានបោះបង់ចោលពួកគេ ។ នៅទីនេះមិនបាននិយាយពីការលន់តួរបាបឡើយ ប៉ុន្តែដោយយោងទៅតាម ខ.៣ និង ខ.៨ ប្រហែលប្រាប់ដែរតែលមានលក្ខណៈមិនច្បាស់ ។

**៨៥:៧** *សេចក្តីសប្បុរស* សូមមើល ខ.១០ និងការពន្យល់ ៦:៤ ។

**៨៥:៨–១៣** នៅក្នុងខទាំងនេះ គឺជាចម្លើយរបស់ព្រះដែលទ្រង់បានតបឆ្លើយចំពោះសេចក្តីអធិស្ឋានរបស់ពួកគេ ហើយអ្នកដែលអធិស្ឋាន ប្រហែលជា

មានបន្ទូលមក ដ្បិតទ្រង់នឹងមានបន្ទូលពីសេចក្តីសុខ[ឱ]ដល់
រាស្ត្រទ្រង់និងពួកអ្នកបរិសុទ្ធរបស់ទ្រង់
កុំឱ្យតែគេវិលត្រឡប់ទៅឯសេចក្តីចំកួតទៀតឡើយ[ល]
៩ ពិតប្រាកដជាសេចក្តីសង្គ្រោះ[ណ]របស់ទ្រង់
នៅជិតនឹងអស់អ្នកដែលកោតខ្លាចដល់ទ្រង់
ដើម្បីឱ្យមានសេចក្តីរុងរឿង[ត]នៅក្នុងស្រុករបស់យើង
១០ សេចក្តីសប្បុរស និងសេចក្តីពិតត្រង់[ថ]បានជួបគ្នា
សេចក្តីសុចរិត[ទ] និងសេចក្តីមេត្រី បានថើបគ្នា
១១ សេចក្តីពិតត្រង់ពន្លកចេញពីដីមក
ហើយសេចក្តីសុចរិត[ធ]ក៏មើលពីលើស្ថានសួគ៌ដែរ
១២ អើ ព្រះយេហូវ៉ាទ្រង់នឹងប្រោសប្រទានសេចក្តីដ៏ល្អ[ន]
ហើយស្រុកយើងនឹងបង្កើត[ប]ផលចំរើន
១៣ សេចក្តីសុចរិតនឹងដើរនៅចំពោះទ្រង់
ហើយនិងដាក់យើងនៅក្នុងផ្លូវ តាមដានព្រះបាទទ្រង់ ។

សេចក្តីអធិស្ឋានរបស់ដាវីឌ ។
**៨៦** ឱព្រះយេហូវ៉ាអើយ សូមផ្ទៀងព្រះកាណ៌មកស្តាប់

**៨៥:៨** ឱ លវ ២៦:៦ អស ៦០:១៧ យហ ១៤:២៧ ២ថន ៣:១៦ ល សភ ២៦:១១ ២៧:២២ **៨៥:៩** ណ ទដ ២៧:១ អស ៤៣:៣ ៤៥:៨ ៤៦:១៣ ៥១:៥ ៥៦:១ ៦២:១១ ត នក ២៩:៤៣ អស ៦០:១៩ ហាក ២:៩ សក ២:៥ **៨៥:១០** ថ ទដ ៨៩:១៤ ១១៥:១ សភ ៣:៣ ទ ទដ ៧២:២–៣ **៨៥:១១** ធ អស ៤៥:៨ **៨៥:១២** ន ទដ ៨៤:១១ យក ១:១៧ ប លវ ២៦:៤ ទដ ៦៧:៦ សក ៨:១២

ម្នាក់ដែលចេញពីពួកកូនចៅកូរេ មិនមែនជាពួកសង្ឃ ឬពួកលេវីឡើយ (សូមមើលការពន្យល់ ១២:៥–៦ និង ២របា ២០:១៩) ។

**៨៥:៨–៩** នៅក្នុងខទាំងនេះចង់និយាយថា ព្រះអម្ចាស់ទ្រង់នឹងជួយដល់រាស្ត្ររបស់ទ្រង់ជាថ្មីម្តងទៀត ។

**៨៥:៨** *ខ្ញុំនឹងស្តាប់* មានន័យថា អ្នកនោះគាត់បានរងចាំព្រះបន្ទូលមកពីព្រះយេហូវ៉ា ។ *មានបន្ទូលពីសេចក្តីសុខសាន្ត* នេះជាព្រះបន្ទូលដែលមកពីព្រះយេហូវ៉ា ហើយប្រហែលជាសង្ឃជាអ្នកប្រទានពរ (សូមមើល ជន ៦:២២–២៦) ។ *ពួកបរិសុទ្ធ* សូមមើលការពន្យល់ ៤:៣ ។ *កុំឱ្យតែគេវិលត្រឡប់ទៅឯសេចក្តីចំកួតទៀតឡើយ* នៅក្នុងឃ្លានេះចង់និយាយថាបើមិនដូច្នេះទេ ព្រះអម្ចាស់ទ្រង់នឹងបោះបង់ពួកគេចោលម្តងទៀត ។ ឃ្លានេះគេក៏អាចនិយាយថា "ពួកអ្នកដែលគេចចេញពីសេចក្តីចំកួត" ។ *សេចក្តីចំកួត* សូមមើលការពន្យល់ ១៤:១ ។

**៨៥:៩** *សេចក្តីរុងរឿង* នៅពេលណាដែលព្រះបានបង្ហាញអំណាចចេស្តារបស់ទ្រង់ នោះសេចក្តីរុងរឿងរបស់ព្រះក៏បង្ហាញនៅពេលនោះដែរ (សូមមើល ៥៧:៥ និងការពន្យល់ ៧២:១៨–១៩ នក ១៤:៤,១៧–១៨ ជន ១៤:២២ អស ៦:៣ និងការពន្យល់ ៤០:៥ និងការពន្យល់ ៤៤:២៣ ៦៦:១៩ អគ ៣៩:២១) ។

**៨៥:១០–១៣** នៅក្នុងខនេះចង់និយាយថា ព្រះអម្ចាស់ទ្រង់ផ្តល់សេចក្តីសម្បុរសដល់រាស្ត្ររបស់ទ្រង់ គឺធ្វើឡើងដោយផ្អែកលើសេចក្តីសញ្ញាដែលបានតាំងឡើង គឺនឹងផ្តល់ចំពោះអ្នកណាដែលស្មោះត្រង់ចំពោះព្រះអម្ចាស់ និងពួកសុចរិត (សូមធៀបជាមួយ ៤០:៩–១០) ។

**៨៥:១០** *សេចក្តីសប្បុរស . . . សេចក្តីមេត្រី* សេចក្តីទាំងនេះគឺចង់បង្ហាញពីការប្រោសមេត្តារបស់ទ្រង់ព្រះអម្ចាស់ចំពោះរាស្ត្រទ្រង់ (សូមមើលការពន្យល់ ២៣:៦) និងចង់បង្ហាញពីជួបជុំរបស់ពួកគេ និងព្រះគុណរបស់ព្រះអម្ចាស់ជាមួយនឹងរាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ (សូមមើល ខ.១១, ១៣ និងការពន្យល់ ៤:១) ។ *សេចក្តីមេត្រី* មើលការពន្យល់ ជន ៦:២៦ ។

**៨៥:១១** *សេចក្តីពិតត្រង់ពន្លកចេញពីដី* គឺប្រៀបបានទៅនឹងរុក្ខជាតិទាំងឡាយដែលដុះចេញពីដី ដើម្បីជាពរដ៏បរិបូរដល់បណ្តាសត្វនិករទាំងឡាយដែលរស់នៅលើចក្រវាលនេះ ។ *មនុស្សសុចរិតក៏មើលពីលើ* គឺមើលមកថែមទាំងចាក់ព្រះពរ និងសេចក្តីមេត្តា ("រួមទាំងគ្រោះធម្មជាតិ") ។ នៅក្នុងភាសាហេព្រើរ "មើលពី" គឺចង់ចង្អុលប្រាប់ពីលក្ខណៈផ្ទុយ ពីពាក្យ "សេចក្តីអាក្រក់" យរ ៦:១ ។ ព្រះអម្ចាស់ទ្រង់នឹងចាក់ព្រះពររបស់ទ្រង់ពីលើស្ថានសួគ៌មកលើផែនដី ទាល់តែពែងនៃពួកអ៊ីស្រាអែលពេញឡើង ។

**៨៥:១២** *សេចក្តីដ៏ល្អ* មើល ៤:៦ និងការពន្យល់ ។ *នឹងបង្កើតផល ចំរើន* សូមមើលការពន្យល់ ៦៧:៦ ។

**៨៥:១៣** *សេចក្តីសុចរិតនឹងដើរនៅចំពោះទ្រង់* ពាក្យនេះគឺជាសិល្បវិធីនៃការតែងរបស់អ្នកនិពន្ធប៉ុណ្ណោះ ។ សេចក្តី សុចរិតបាននាំមុខ ព្រមទាំងបានបង្ហាញពីសេចក្តីសន្យារបស់ទ្រង់ចំពោះរាស្ត្រព្រះអង្គ ។ មិនតែប៉ុណ្ណោះ សេចក្តីសុចរិតគឺជាសេចក្តីស្មោះត្រង់របស់ព្រះ ចំពោះរាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ និងចំពោះពួកអ្នកដែលបានប្តេជ្ញាចិត្តចំពោះព្រះអង្គ (សូមមើល ការពន្យល់ ៤:១) ។

**ទដ ៨៦** នៅក្នុងជំពូកនេះគឺជាសេចក្តីអធិស្ឋានជាលក្ខណៈផ្ទាល់ខ្លួនដែលគេបានសូមជំនួយមកពីព្រះក្នុងគ្រាដែលពួកខ្មាំងសត្រូវចូលឈ្លានពាន ជាអ្នកដែលកាចសាហាវ ជាអ្នកមើលងាយចំពោះព្រះ ។ អ្នកនិពន្ធក្នុងជំពូកនេះមិនមែនជាស្តេចដាវីឌឡើយ(សូមមើលសេចក្តីផ្តើមក្នុង ត្រង់ចំណុចអ្នកនិពន្ធ និងចំណងជើង) ។ អ្នកនិពន្ធបានបង្ហាញពីសញ្ញាណរបស់ខ្លួនជា "អ្នកបំរើ" របស់ព្រះ (សូមមើល ខ.២) ហើយតាមរយៈការនេះក៏បានបង្ហាញថាគាត់ជាអ្នកដែលមានទំនាក់ទំនងវិសេសជាមួយព្រះ(សូមមើលក្នុង ២សយ ៧:៥,៨ និងការពន្យល់ ទដ ១៨ ត្រង់ចំណងជើង) ។ ពួកខ្មាំងសត្រូវទាំងនោះប្រហែលជាអ្នកដែលរស់នៅក្នុងអាណាចក្រជាមួយនឹងគាត់ ប៉ុន្តែគេមិនបានទទួលស្គាល់គាត់ថា ជាអ្នកដែលព្រះចាក់ប្រេងតាំងនោះឡើយ ឬក៏ជាអ្នកប្រទេសក្រៅដែលមានអំណាចក្នុងការបំលាស់ប្តូរគាត់បាន ។ ការផ្លាស់ប្តូរបទគម្ពីរទំនុកដំកើងត្រង់ជំពូកនេះ ជាមួយបទគម្ពីរទំនុកដំកើងផ្សេងៗ ទៀតក្នុងក្រុមសូមមើលក្នុង សេចក្តីផ្តើម ទដ ៨៤–៨៩ ។

បទកំណាព្យនៃសេចក្តីអធិស្ឋានក្នុងជំពូកនេះបានបែងចែកជា៥ល្បះដែលក្នុងល្បះនិមួយៗសុទ្ធតែមានចំណាប់ចុងចួន (៤ខ,៣ខ,៣ខ,៣ខ, និង ៤ខ) ។ នៅក្នុងល្បះដំបូង និងល្បះចុងក្រោយអ្នកនិពន្ធបានបង្ហាញសញ្ញាណរបស់ខ្លួនថាជាអ្នកបម្រើរបស់ព្រះអម្ចាស់ ហើយនៅក្នុងសេចក្តីអធិស្ឋាននោះ ក៏បានភ្ជាប់មកជាមួយនឹងការទូលអង្វរសូមសេចក្តីមេត្តាករុណាមកពីព្រះ និងជួយរំដោះឱ្យចេញផុតពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ ។ ល្បះទី២ (ខ.៥–៧) បាននិយាយបន្ថែមពីលក្ខណៈសម្បត្តិរបស់ព្រះ ក្នុងការធានារ៉ាប់រង ហើយក្នុងល្បះទី៤ (ខ.១១–១៣) បាននិយាយពីការប្តេជ្ញាចិត្តក្នុងការសរសើរដំកើងដល់ព្រះ ។ ក្នុងល្បះនិមួយៗមានទំនាក់ទំនងជាមួយគ្នាដោយព្រោះបានពណ៌នាពី"សេចក្តីសប្បុរស"របស់ព្រះ (សូមមើលការ

ហើយតប[ក]មកទូលបង្គំផង
ពីព្រោះទូលបង្គំទាល់ក្រហើយខ្វះខាត
២សូមការពារព្រលឹងទូលបង្គំ ដ្បិតទូលបង្គំជាអ្នកជ្រះថ្លា
ឱព្រះនៃទូលបង្គំអើយ
សូមជួយសង្គ្រោះអ្នកបំរើដែលទុកចិត្តដល់ទ្រង់[ខ]
៣ឱព្រះអម្ចាស់អើយ សូមអាណិតមេត្តា[គ]ដល់ទូលបង្គំផង
ដ្បិតទូលបង្គំអំពាវនាវ[ឃ]ដល់ទ្រង់ជាដរាបរាល់ថ្ងៃ
៤សូមបណ្ដាលឱ្យព្រលឹងនៃអ្នកបំរើទ្រង់ បានរីករាយឡើង
ពីព្រោះ ឱព្រះអម្ចាស់អើយ ទូលបង្គំលើក[ង]ព្រលឹងថ្វាយ
ដល់ទ្រង់
៥ដ្បិតឱព្រះអម្ចាស់អើយ ទ្រង់ល្អទ្រង់បំរុងតែនឹងអត់ទោស
ក៏មានសេចក្ដីសប្បុរស[ច]ជាបរិបូរចំពោះអស់អ្នកណា
ដែលអំពាវនាវដល់ទ្រង់
៦ឱព្រះយេហូវ៉ាអើយ សូមផ្ទៀងព្រះកាណ៌មកចំពោះ
សេចក្ដីអធិស្ឋានរបស់ទូលបង្គំ ហើយស្ដាប់សំឡេងដែល
ទូលបង្គំអង្វរ[ឆ]ផង
៧នៅថ្ងៃវេទនា[ជ] នោះទូលបង្គំនឹងអំពាវនាវ[ឈ]ដល់ទ្រង់
ពីព្រោះទ្រង់នឹងឆ្លើយតប[ញ]មក
៨ឱព្រះអម្ចាស់អើយ នៅក្នុងអស់ទាំងពួកព្រះ[ដ]គ្មានណាមួយ
ឱ្យដូចជាទ្រង់ឡើយ[ឋ] ក៏គ្មានការអ្វីឱ្យដូចជាការរបស់
ទ្រង់ដែរ
៩ឱព្រះអម្ចាស់អើយអស់ទាំងសាសន៍ដែលទ្រង់បានបង្កើត
គេនឹងមក[ឌ] ក្រាបថ្វាយបង្គំ[ឍ]នៅចំពោះទ្រង់
ហើយគេនឹងលើកដំកើង[ណ]ព្រះនាមទ្រង់
១០ដ្បិតទ្រង់ធំប្រសើរ[ត] ហើយក៏ធ្វើការយ៉ាងអស្ចារ្យ[ថ]
ទ្រង់ជាព្រះតែមួយ[ទ]អង្គឯង
១១ឱព្រះយេហូវ៉ាអើយសូមបង្រៀនទូលបង្គំឱ្យស្គាល់ផ្លូវ[ធ]

**៨៦:១** ក ទដ ១៧:៦ **៨៦:២** ខ ទដ ២៥:២ ៣១:១៤ **៨៦:៣** គ ទដ ៤:១ ៩:១៣ ៥៧:១ ឃ ទដ ៨៨:៩ **៨៦:៤** ង ទដ ៤៦:៥ ១៤៣:៨ **៨៦:៥** ច នក ៣៤:៦ នហ ៩:១៧ ទដ ១០៣:៨ ១៤៥:៨ យអ ២:១៤ យហ ៤:២ **៨៦:៦** ឆ ទដ ៥:២ ១៧:១ **៨៦:៧** ជ ទដ ២៧:៥ ៥០:១៥ ៩៤:១៣ ហព ៣:១៦ ឈ យប ២២:២៧ ទដ ៤:៣ ៨០:១៨ ៩១:១៥ អស ៣០:១៩ ៥៨:៩ ៦៥:២៤ សក ១៣:៩ ញ ទដ ៣:៤ **៨៦:៨** ដ នក ៨:១០ យប ២១:២២ ឋ ទដ ១៨:៣១ **៨៦:៩** ឌ ទដ ៦៥:២ ឍ ទដ ៦៦:៤ អស ១៩:២១ ២៧:១៣ ៤៩:៧ សក ៨:២០–២២ ១៤:១៦ វវ ១៥:៤ ណ អស ៤៣:៧ ៤៤:២៣ **៨៦:១០** ត ២សយ ៧:២២ ទដ ៤៨:១ ថ នក ៣:២០ ទដ ៧១:១៧ ៧២:១៨ ទ ចទ ៦:៤ អស ៤៣:១០ មក ១២:២៩ ១កថ ៨:៤ **៨៦:១១** ធ នក ៣៣:១៣ ១សយ ១២:២៣ ទដ ២៥:៥

ពន្យល់ ៦:៤) ដូចជាមាននិយាយនៅ ខ.៥,១៣ ។ ល្បះកណ្ដាល (ខ.៨–១០) បានពណ៌នាថា ព្រះយេហូវ៉ាទ្រង់គឺជាព្រះដែលរកគូផ្ទឹមគ្មាន ជាព្រះតែ១ ដែលប្រជាជាតិទាំងមុលនឹងថ្វាយបង្គំនៅថ្ងៃណាមួយមិនខាន ។ ខ.៩ គឺជាចំណុចស្នូលក្នុងបទគម្ពីរទំនុកដំកើងជំពូកនេះ (មើលការពន្យល់ ៦:៦) ។ នៅក្នុងជំពូកនេះមានពាក្យថា "ព្រះយេហូវ៉ា"ចំនួន៤ដង (ក្នុងល្បះទី១,២,៤,៥) ហើយឯពាក្យថា "ព្រះអម្ចាស់"ក៏មាន៤ដងដែរ ចំណែកឯពាក្យថា "ព្រះអង្គ" មាន៧ដង ។

**៨៦ត្រង់ចំណងជើង** *សេចក្ដីអធិស្ឋាន* មើលការពន្យល់ ទដ ១៧ ត្រង់ចំណងជើង និងការពន្យល់ ទដ ៧២:២០ ។ *របស់ស្ដេចដាវីឌ* នៅក្នុងឃ្លានេះគឺជាឃ្លាទី១ហើយដែលបាននិយាយពីស្ដេចដាវីឌ ក្នុងប៉ែកទី៣នេះ ។ ជំពូកនេះប្រហែលជំនួសឱ្យទំនុករបស់ពួកកូនចៅកូរេ ពីព្រោះផ្ទៃរឿងវាមានទំណាក់ទំនងរវាង ខ.៩ និង ទដ ៨៧:៤ ។

**៨៦:១–៤** នៅក្នុងខទាំងនេះ គឺជាសេចក្ដីអធិស្ឋានសូមសេចក្ដីសប្បុរសមកពីព្រះអម្ចាស់ និងសូមឱ្យទ្រង់បានការពារដល់អ្នកបម្រើរបស់ទ្រង់ ។

**៨៦:១** *ទាល់ក្រ ហើយខ្វះខាត* សូមមើល ៣៥:១០ និង ៣៤:៦ និងការពន្យល់ ។

**៨៦:២** *ជាអ្នកជ្រះថ្លា* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ឃ្លានេះមានន័យថា ហាសុីត (មើលការពន្យល់ ៤:៣) ។ *ទុកចិត្តដល់ទ្រង់* នៅក្នុងឃ្លានេះចង់និយាយថាស្ដេចដាវីឌមិនមែនជាអ្នកដែលជិតស្និតជាមួយទ្រង់ឡើយ ប៉ុន្តែព្រះទ្រង់ជាអ្នកដែលបានជ្រើសរើសដាវីឌជាអ្នកបម្រើទ្រង់ (សូមមើល ១សយ ១៣:១៤ ១៥:២៨ ១៦:១២ ២សយ ៧:៨) ។ ការដែលដាវីឌបានថ្វាយចិត្តនិងការស្មោះស្ម័គ្រទៅចំពោះព្រះ និងការតាំងសញ្ញារបស់ព្រះចំពោះព្រះអង្គ(ស្ដេចដាវីឌ) គឺបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និត ។ *ជាអ្នកបំរើ* សូមមើល ខ.៤,១៦ និងសេចក្ដីផ្ដើម ។

**៨៦:៤** *ព្រលឹងនៃអ្នកបំរើទ្រង់* សូមមើលការពន្យល់ ៦:៣ ។

**៨៦:៥–៧** នៅក្នុងខ.ទាំងនេះចង់និយាយថា នៅគ្រាចាំបាច់ក្នុងគ្រោះអាសន្ន ស្ដេចដាវីឌទ្រង់បានអធិស្ឋានទៅចំពោះព្រះយេហូវ៉ា ពីព្រោះទ្រង់មានទំនុកចិត្តថាព្រះទ្រង់នឹងមានបន្ទូលតបឆ្លើយមកដល់ទ្រង់ ។

**៨៦:៥** *សេចក្ដីសប្បុរស* សូមមើល ខ.១៣,១៥ និងការពន្យល់ ៦:៤ ។

**៨៦:៧** *នោះទូលបង្គំនឹងអំពាវនាវដល់ទ្រង់ . . . ទ្រង់នឹងឆ្លើយតបមក* សូមមើលការពន្យល់ ១១៨:៥ ។

**៨៦:៨–១០** នៅពាក់កណ្ដាលនៃសេចក្ដីអធិស្ឋាននេះ ស្ដេចដាវីឌទ្រង់បានពណ៌នាពីមូលដ្ឋានគ្រឹះនៃសេចក្ដីជំនឿរបស់ទ្រង់ (សូមមើល ១១៥:៣–៧ ១៣៥:១៣–១៧ និងការពន្យល់) ហើយទ្រង់បានពន្យល់ថែមទៀតថា ហេតុអ្វីបានជាទ្រង់អំពាវនាវដល់ព្រះយេហូវ៉ានៅពេលនេះ ។

**៨៦:៩** *អស់ទាំងសាសន៍* សូមមើលការពន្យល់ក្នុង ៤៦:១០ ។ ខ.៩ នេះគឺជាខគន្លឹះក្នុងទំនុកដំកើងជំពូក៨៦នេះ (សូមមើលការពន្យល់ក្នុង ៦:៦) ហើយក៏បានភ្ជាប់មកជាមួយនឹងគោលនៃសេចក្ដីជំនឿ ដែលមានទំនាក់ទំនងជាមួយអធិបតេយ្យភាពរបស់ព្រះ និងអំណាចនៃការគ្រប់គ្រងរបស់ទ្រង់លើពិភពលោក ។ *គេនឹងលើកដំកើងព្រះនាមទ្រង់* ពួកគេនឹងធ្វើដូចជាអ្វីដែលស្ដេចដាវីឌបានធ្វើដែរ (សូមមើល ខ.១២) ។ *ព្រះនាមទ្រង់* សូមមើល ខ.១១–១២ និងការពន្យល់ ៥:១១ ។

**៨៦:១០** *ការយ៉ាងអស្ចារ្យ* សូមមើលការពន្យល់ ៩:១ ។

**៨៦:១១–១៣** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអំពាវនាវដល់ទ្រង់ សូមឱ្យព្រះបានជួយគាត់ឱ្យបានស្គាល់ទ្រង់ ហើយមិនត្រឹមតែប៉ុណ្ណោះគាត់ក៏បានប្ដេជ្ញាចិត្តក្នុងការសរសើរតម្កើងដល់ព្រះថែមទៀត ។

**៨៦:១១** *សូមបង្រៀនទូលបង្គំ . . . សូមបំព្រួម* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា តើមានប្រយោជន៍អ្វីបើព្រះគ្រាន់តែរំដោះគាត់ឱ្យរួចពីពួកខ្មាំងសត្រូវ ប៉ុន្តែ បណ្ដោយឱ្យគាត់ប្រព្រឹត្តិតាមការចចេសរបស់គាត់នោះ ។ អ្វីដែលស្ដេចដាវីឌបានពឹង និងទុកចិត្តចំពោះព្រះអង្គនោះ ពេលនេះព្រះ

នៃទ្រង់ ទូលបង្គំនឹងដើរក្នុងសេចក្ដីពិតរបស់ទ្រង់[ន]
សូមបំព្រួម[ប]ចិត្តទូលបង្គំមកឱ្យកោតខ្លាច[ផ]ដល់ព្រះនាមទ្រង់
១២ឱព្រះអម្ចាស់ ជាព្រះនៃទូលបង្គំអើយ
ទូលបង្គំនឹងសរសើរទ្រង់ឱ្យអស់ពីចិត្ត[ព]
ហើយនិងលើកដំកើងព្រះនាមទ្រង់ជាដរាបតទៅ
១៣ដ្បិតទ្រង់មានសេចក្ដីសប្បុរសយ៉ាងខ្លាំង ចំពោះទូលបង្គំ
ទ្រង់បានប្រោសព្រលឹងទូលបង្គំឱ្យរួច[ភ]ពីស្ថានឃុំព្រលឹង
មនុស្សស្លាប់ដ៏ជ្រៅបំផុត[ម]
១៤ឱព្រះអង្គអើយ មនុស្សឆ្មើងឆ្មៃបានលើកគ្នាឡើងទាស់
នឹងទូលបង្គំហើយ មានពួកមនុស្សច្រឡោតស្វែងរកជីវិត
ទូលបង្គំ គេមិនបានតាំងទ្រង់នៅមុខគេទេ[យ]
១៥តែឱព្រះអម្ចាស់អើយ ទ្រង់ជាព្រះដ៏ប្រកបដោយមេត្តា
ករុណា និងអាណិតអាសូរ[រ] ក៏ទ្រង់យឺតនឹងខ្ញាល់[ល]
ហើយមាន[វ]សេចក្ដីសប្បុរសនិងសេចក្ដីពិតត្រង់ជាបរិបូរ[ស]
១៦ឱសូមវិលមកឯទូលបង្គំ[ហ]វិញហើយអាណិតមេត្តា[ឡ]
ដល់ទូលបង្គំផង សូមប្រទានកំឡាំង[អ]របស់ទ្រង់
មកទូលបង្គំជាអ្នកបំរើទ្រង់
ហើយជួយសង្គ្រោះកូនរបស់ស្ត្រីជាអ្នកបំរើទ្រង់ដែរ[ក]
១៧សូមសំដែងទីសំគាល់[ខ]១ពីសេចក្ដីល្អដែលនឹងប្រោសដល់
ទូលបង្គំ ដើម្បីឱ្យពួកអ្នកដែលស្អប់ទូលបង្គំបានឃើញ
ហើយមានសេចក្ដីខ្មាសវិញ ដោយព្រោះទ្រង់
ឱព្រះយេហូវ៉ាអើយ ទ្រង់បានជួយហើយកំសាន្តចិត្តនៃទូល
បង្គំហើយ ។

ទំនុកជាបទចំរៀងរបស់កូនចៅកូរេ ។

**៨៧** ព្រះយេហូវ៉ាបានតាំងទីលំនៅរបស់ទ្រង់នៅលើភ្នំ
បរិសុទ្ធ[ក]
២ទ្រង់ស្រឡាញ់អស់ទាំងទ្វារក្រុងស៊ីយ៉ូន[ខ]

**៨៦:១១** ន ទដ ២៦:៣ ប យរ ២៤:៧ ៣២:៣៩ អគ ១១:១៩ ១កថ ៧:៣៥ ផ ចទ ៦:២៤ **៨៦:១២** ប ទដ ៩:១ **៨៦:១៣** ភ ទដ ៣៤:៤ ៤៩:១៥ ១១៦:៨ ម ទដ ១៦:១០ ៥៦:១៣ **៨៦:១៤** យ ទដ ៥៤:៣ **៨៦:១៥** រ ទដ ៥១:១ ១០៣:៨ ១១១:៤ ១១៦:៥ ១៤៥:៨ ល ជន ១៤:១៨ វ ខ.៥ ស នក ៣៤:៦ នហ ៩:១៧ យអ ២:១៣ **៨៦:១៦** ហ ទដ ៦:៤ ឡ ទដ ៩:១៤ អ ទដ ១៨:១ ក ទដ ១១៦:១៦ **៨៦:១៧** ខ នក ៣:១២ មថ ២៤:៣ យហ ២:១១ **៨៧:១** ក ទដ ៤៨:១ **៨៧:២** ខ ទដ ២:៦

អម្ចាស់ទ្រង់បានឱ្យសម្រេចហើយ ដូច្នេះហើយអ្វីដែលព្រះអង្គ (ស្ដេចដាវីឌ) ទ្រង់ចង់បានពីព្រះអម្ចាស់នោះ គឺសូមឱ្យព្រះទ្រង់បានជួយសង្គ្រោះគាត់រួចពីខ្មាំងសត្រូវថែមទាំងបង្រៀនឱ្យដើរក្នុងផ្លូវទ្រង់ កុំឱ្យតាមផ្លូវដ៏ចំកួតរបស់គាត់អី (សូមមើល ២៥:៥ ៥១:៧,១០ និងការពន្យល់) ។ មានតែអ្នកដែលថ្វាយខ្លួនទៅចំពោះព្រះប៉ុណ្ណោះ ដែលអាចនឹងទទួលសេចក្ដីជំនួយមកពីព្រះ (មើល ខ.១២) ។ *បំព្រួមចិត្ត* សូមមើល អគ ១១:១៩ និងការពន្យល់ ហើយមើល ១របា ១២:៣៣ ១កថ ៧:៣៥ ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។

**៨៦:១២** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានប្ដេជ្ញាចិត្ត ក្នុងការសរសើរតម្កើងដល់ព្រះយេហូវ៉ា(សូមមើលការពន្យល់ ៧:១៧) ។

**៨៦:១៣** នៅក្នុងខនេះ ស្ដេចដាវីឌទ្រង់បានសង្ឃឹមទុកជាមុនថា ព្រះអម្ចាស់ទ្រង់នឹងតបឆ្លើយចំពោះសេចក្ដីអធិស្ឋានរបស់ទ្រង់ (សូមមើល ៣:៨) ។ *ជ្រៅបំផុត* សូមមើលការពន្យល់ ៣០:១ ។

**៨៦:១៤–១៧** នៅក្នុងខទាំងនេះ គឺជាសេចក្ដីសារជាថ្មី ហើយក៏ជាចុងបញ្ចប់នៃជំពូកនេះផងដែរ ។

**៨៦:១៤** *មនុស្សច្រឡោត* នៅក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះក៏មានន័យដូចនឹងពាក្យថា មនុស្សគ្មានសីលធម៌ ។ *មិនបានតាំងទ្រង់នៅមុខគេ* មានន័យថា ពួកគេបានបណ្ដេញស្ដេចដាវីឌ ដែលជាមេទ័ពរបស់ទ្រង់ចេញពីមុខពួកគេ (មើលការពន្យល់ ១០:១១ និង យរ ២០:១១) ។

**៨៦:១៥** ខនេះបានដកស្រង់ចេញពី ខ.៥ ប៉ុន្តែភាគច្រើនខនេះដូចគ្នានឹង នក ៣៤:៦–៧) ។

**៨៦:១៦** *សូមប្រទានកំឡាំងទ្រង់* នៅក្នុងឃ្លានេះ អ្នកនិពន្ធចង់និយាយថា សូមទ្រង់ចំរើនកំឡាំង និងអំណាចរបស់ទ្រង់បន្ថែមទៀតដល់គាត់ ។ *កូនស្ត្រីជាអ្នកបំរើទ្រង់* គឺនិយាយសំដៅលើម្នាក់ដែលបានកើតមកក្នុងផ្ទះនៃគ្រួរគេ ហើយនិងអ្នកបម្រើដែលកើតមកក្នុងភាពក្មេង (សូមមើល ១១៦:១៦ និងការពន្យល់) ។

**៨៦:១៧** *សេចក្ដីល្អ* គឺនិយាយសំដៅលើសេចក្ដីសញ្ញាដែលព្រះបានតាំងថានឹងពេញចិត្តចំពោះគាត់ (សូមមើល ២៧:១៣ និងការពន្យល់) ។ *ដើម្បី . . . បានឃើញ* គឺនឹងបានឃើញថា ព្រះអង្គទ្រង់គង់នៅជាមួយនឹងទូលបង្គំ ដើម្បីនឹងជួយទូលបង្គំ (សូមមើល ៣១:១៩ និងការពន្យល់) ។

**ទដ ៨៧** នៅក្នុងជំពូកនេះគេបានរាប់ក្រុងស៊ីយ៉ូនថា ជា"ទីក្រុងរបស់ព្រះ" (សូមមើល ខ.៣) ។ ក្រុងនេះគឺជាក្រុង១ដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ និងជាក្រុងហ្លួងនៃនគររបស់ទ្រង់ (សូមមើលក្នុងសេចក្ដីផ្ដើម ទដ ៤៦ ៤៨ ៧៦) ។ យោងទៅតាមទំនៀមទំលាប់ពីបុរាណ និងការកាត់ស្រាយដ៏ជាប់លាប់មួយរបស់ពួកយូដា និងគ្រីស្ទបរិស័ទ ក៏ដូចនឹងអ្វីដែលព្រះគម្ពីរទំនុកដំកើងនេះបានដាច់ចេញពីគេ (ប៉ុន្តែសូមមើល ៤៧:៩) បានបង្ហាញថា ការប្រមូលមនុស្សមកជួបជុំគ្នានៅក្រុងស៊ីយ៉ូន ក៏ដូចជាពួកអ៊ីស្រាអែលដែលរស់នៅក្នុងនគរនៃព្រះ (សូមមើល អស ២:២–៤ ១៩:១៩–២៥ ២៥:៦ ៤៥:១៤,២២–២៤ ៥៦:៦–៨ ៦០:៣ ៦៦:២៣ ជយ ៧:១៤ មីក ៤:១–៣ សក ៨:២៣ ១៤:១៦) ។ អ្នកខ្លះបានកាត់ស្រាយថា ក្រុងស៊ីយ៉ូនដែលនិយាយនៅក្នុងព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ ផ្ទុយពីបទចម្រៀងរបស់ពួកក្រុងស៊ីយ៉ូនដែលនិយាយនៅក្នុងជំពូកផ្សេងៗទៀត (សូមមើល ទដ ៤៦, ៤៨,៧៦,១២៥,១២៩,១៣៧) ។

**៨៧ ត្រង់ចំណងជើង** *កូនចៅកូរេ* សូមមើលការពន្យល់ ទដ ៤២ ត្រង់ចំណងជើង ។ *ទំនុកជាបទចំរៀង* សូមមើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង ។

**៨៧:១** *លំនៅ* ព្រះអម្ចាស់ទ្រង់បានតាំងលំនៅ នៅក្រុងស៊ីយ៉ូន (សូមមើល អស ១៤:៣២) ហើយក្នុងព្រះវិហារដែលជាដំណាក់ហ្លួងរបស់ទ្រង់ ។ *ភ្នំ* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះគឺពហុវចនៈ ដែលគេចង់និយាយសំដៅលើអំណាចចេស្ដានៃភ្នំបរិសុទ្ធរបស់ទ្រង់ ដែលព្រះអម្ចាស់ទ្រង់បានដាក់បល្ល័ង្កទ្រង់នៅទីនេះ (សូមមើល ៤៨:២ និងការពន្យល់) ។

**៨៧:២** *ស្រឡាញ់ . . . ជាជាង* ដោយសារទីក្រុងនេះគឺជាក្រុងដែលទ្រង់បានតាំងលំនៅដើម្បីគ្រប់គ្រងលើរាស្ត្រទ្រង់ទាំងអស់ នោះក្រុងស៊ីយ៉ូនគឺជាទី

ជាជាងអស់ទាំងទីអាស្រ័យរបស់យ៉ាកុប
៣ឱទីក្រុងរបស់ព្រះអង្គអើយ
គេថ្លែងប្រាប់សេចក្ដីឧត្តុង្គឧត្តមពីឯង[គ] ។ –បង្អង់
៤អញនឹងដំណាលពីរ៉ាហាប[ឃ]
ហើយពីបាប៊ីឡូនទុកជាពួកដែលស្គាល់អញ នុ៎ះន៍
សាសន៍ភីលីស្ទីន[ង] សាសន៍ទីរ៉ុស[ច] និងសាសន៍អេធីយ៉ូពី
ដែរ គឺនៅក្នុងក្រុងស៊ីយ៉ូនដែលគេបានកើតមក[ឆ]
៥អើ គេនឹងនិយាយពីក្រុងស៊ីយ៉ូនថា អ្នកនេះ១
អ្នកនោះ១បានកើត នៅក្រុងនោះ
ហើយគឺព្រះដ៏ខ្ពស់បំផុតដែលនឹងតាំងឱ្យមាំមួនដែរ
៦កាលណាព្រះយេហូវ៉ាទ្រង់ចុះបញ្ជី[ជ]អស់ទាំងសាសន៍
នោះទ្រង់នឹងរាប់ថា អ្នកនេះបានកើតនៅក្រុងនោះឯង ។
–បង្អង់
៧ហើយពួកអ្នកចំរៀង[ឈ] និងពួកអ្នកលេងភ្លេង គេនឹងថា
អស់ទាំងដើមហេតុ[ញ]នៃខ្ញុំនៅក្នុងឯងដែរ ។

**៨៧:៣** គ ទដ ៤៦:៤
**៨៧:៤** ឃ យប ៩:១៣ ង ២សយ ៨:១ ទដ ៨៣:៧ ច ទដ ៤៥:១២ យអ ៣:៤ ឆ អស ១៩:២៥
**៨៧:៦** ជ នក ៣២:៣២ ទដ ៦៩:២៨ អស ៤:៣ មឡ ៣:១៦
**៨៧:៧** ឈ ទដ ១៤៩:៣ ញ ទដ ៣៦:៩

ទំនុកជាបទចំរៀងរបស់កូនចៅកូរេ ដែលលើកសំរាប់មេភ្លេង ត្រូវលេងដោយខ្លុយ ជាសេចក្ដីបង្រៀនរបស់ហេម៉ាន ពូជអេសរ៉ាគីត ។

# ៨៨

១ឱព្រះយេហូវ៉ា ជាព្រះដ៏ជួយសង្គ្រោះទូលបង្គំអើយ[ក]

**៨៨:១** ក ទដ ៥១:១៤

ក្រុងដែលព្រះយេហូវ៉ាទ្រង់ស្រឡាញ់បំផុតក្នុងចំណោមទីក្រុងនៅប្រទេសអ៊ីស្រាអែល (សូមមើល ៩:១១ និងការពន្យល់ ៧៨:៦៨ ១៣១:១៣–១៤) ។ *យ៉ាកុប* ពាក្យនេះជាសទីសន័យនឹងពាក្យថា អ៊ីស្រាអែល (សូមមើល លប ៣២:២៨) ។

**៨៧:៤** *អញនឹងដំណាល . . . នៅក្នុងក្រុងស៊ីយ៉ូនដែលគេបានកើតមក* នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់នឹងកត់ឈ្មោះពួកគេទុកនៅក្នុងបញ្ជីជីវិត (សូមមើលការពន្យល់ ៩:៥ ៥១:១ ៦៩:២៨) ដូចគ្នានឹងពួកអ្នកដែលមានដើមកំណើត(កើត)ដែលកើតមកក្នុងទីក្រុងហ្លួងនេះដែរ ហើយពួកគេមានឯកសិទ្ធិគ្រប់បែបយ៉ាងក្នុងកាទទួលយកគុណតម្លៃ និងសេចក្ដីសុខសាន្តដូចគ្នានឹងប្រជាពលរដ្ឋក្នុងក្រុងនេះដែរ ។ *រ៉ាហាប* នៅកន្លែងខ្លះឈ្មោះនេះគឺនិយាយសំដៅលើរឿងព្រេងស្ដីពីសត្វចំឡែកៗ ដែលនៅក្នុងសមុទ្រដ៏ជ្រៅ (សូមមើល ៨៩:១០ និងការពន្យល់ ៣២:៦ យប ៩:១៣) ។ រ៉ាហាបដែលនិយាយនៅទីនេះគឺសំដៅលើពួកអេស៊ីព្ទ ដូចជាមាននិយាយនៅក្នុង អស ៣០:៧ (មើលការពន្យល់នៅទីនោះ) និង ៥១:៩ ។ ឈ្មោះរបស់ពួកបណ្ដាជនដែលបានកត់ចុះ គឺជាការតំណាងឱ្យសាសន៍ដទៃទាំងអស់ ។ ជានិច្ចកាលតាមការកាត់ស្រាយបានបង្ហាញថា ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ គឺជាតំរុយនៃការប្រែចិត្តរបស់បណ្ដាជនទៅចំពោះព្រះយេហូវ៉ា (សូមមើល អស ១៩:២១ ២៦:១៨ និងការពន្យល់) ។ ប៉ុន្តែ បើសិនជាការពន្យល់នេះជាការត្រឹមត្រូវ (មើល ខ.៥) នោះព្រះយេហូវ៉ា ដែលនិយាយនៅទីនេះ គឺជាម្នាក់ដែលបានកត់ឈ្មោះរាស្ត្រទ្រង់ទុកទាំងមានការប្រុងប្រយ័ត្នបំផុត ជាពិសេសគឺចំពោះអ្នកដែលទទួលស្គាល់ទ្រង់ថា ព្រះអម្ចាស់នៃសេចក្ដីសញ្ញា (សូមមើល ហស ៦:៣) ហើយព្រះអង្គក៏បានថែរក្សាពួកគេដូចជាព្រះអង្គបានថែរក្សារាស្ត្រក្នុងក្រុងហ្លួងដែរ ។ មានការគំរាមកំហែងមួយ គឺព្រះអង្គទ្រង់ព្រមានប្រជាជាតិទាំងនោះ (សូមមើល អស ១៤:២៨–៣២) ដោយការប្រុងប្រយ័ត្នទាំងអស់ហើយជំនុំជម្រះពួកគេតាមការដែលគេប្រព្រឹត្តិចំពោះពួកអ្នកទាំងនោះ (សូមមើល ១០៥:១៥) ។

**៨៧:៥** *អ្នកនេះ១ អ្នកនោះ១* ប្រហែលពួកគេបានផ្ដាច់ខ្លួនចេញពីពួកសាសន៍ដទៃទាំងនោះ ។ *ខ្ពស់បំផុត* សូមមើលការពន្យល់ លប ១៤:១៩ ។

**៨៧:៧** *អស់ទាំងដើមហេតុនៃខ្ញុំ* ពួកគេម្នាក់អាចរកឃើញជីវិតបែបស្រស់ប្រិមប្រិយបាន គឺដោយសាររស់នៅក្នុងទីក្រុងនៃព្រះដែលប្រៀបបានទៅនឹង "ទន្លេនៃសេចក្ដីអំណរ"របស់ទ្រង់ (សូមមើល ៣៦:៨) ដែល"នាំឱ្យក្រុងនៃព្រះមានសេចក្ដីអំណរ"(មើល ៤៦:៤) ។ ពាក្យថា "ដើមហេតុ" ប្រហែលជាពាក្យប្រៀបប្រដូចនៃពាក្យថា ធនធានឬប្រភព ហើយពាក្យនេះអាចមានន័យថា ពួកយើងទាំងអស់គ្នានឹងរីកចម្រើនដោយសារទ្រង់ ។ *នៃខ្ញុំ* នេះគឺជាពាក្យដែលបណ្ដាជនទាំងអស់ប្រើបែបពហុវចនៈ (សូមមើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង) ។

**ទដ ៨៨** នៅក្នុងជំពូកនេះ គឺជាការអំពាវនាវរបស់អ្នកដែលធ្លាក់ក្នុងអន្លង់ជ្រៅ ជាសេចក្ដីអធិស្ឋានរបស់ពួកអ្នកដែលឈរនៅលើច្រាំងនៃសេចក្ដីស្លាប់ ដែលសេចក្ដីទាំងនេះបានតាមជាប់ពេញមួយជីវិតរបស់គាត់ ធ្វើឱ្យគាត់ស្ទើរតែជិតទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ទៅហើយ (សូមមើល ទដ ៩០) ។ សេចក្ដីទុកលំបាកដែលគាត់មានគាត់បានគិតថា គឺកើតឡើងដោយសារតែព្រះហស្តរបស់ព្រះប៉ុណ្ណោះ("សេចក្ដីក្រោធរបស់ព្រះ" ខ.៧) ហើយសូម្បីតែម្នាក់ដែលនៅក្បែរនឹងគាត់បំផុត ក៏គេបានដកខ្លួនចេញពីគាត់ ថែមទាំងជាទីមើលងាយទៀតផង (សូមមើល ខ.៨) ។ នៅក្នុងជំពូកនេះ អ្នកនិពន្ធមិនបាននិយាយពីសេចក្ដីសង្ឃឹម (ស្ទើរតែទាំងអស់នៃសេចក្ដី អធិស្ឋានរបស់អ្នកនិពន្ធ ប៉ុន្តែ សូមមើល ទដ ៤៤ និង ៨៩) ត្រូវបានថ្លែងចេញពីមាត់នោះឡើយ ប៉ុន្តែទីបញ្ចប់នៃសេចក្ដីអធិស្ឋាននោះគាត់បែជា និយាយថា "ពួកមិត្រភក្តិ"របស់ទូលបង្គំក៏បាត់ទៅក្នុងសេចក្ដីងងឹតហើយ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកនិពន្ធចាប់ផ្ដើមអធិស្ឋានដោយប្រើពាក្យថា "ឱព្រះយេហូវ៉ាជាព្រះដ៏ជួយសង្គ្រោះទូលបង្គំអើយ" ដែរ ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះបានរំឭកយើងឱ្យនឹកឃើញពីការពិតមួយ គឺទោះបីជាពេលខ្លះ អ្នកសំណប់ព្រះបានរស់នៅក្នុងសេចក្ដីទុក្ខលំបាកវេទនា ជារៀងរហូត (មើល ទដ ៧៣:១៤) ក៏ពួកគេនៅបន្តសង្ឃឹមថាព្រះ អម្ចាស់ទ្រង់គឺជាអ្នកសង្គ្រោះពួកគេដែរ(សូមមើល ទដ ៨៧ និងសេចក្ដីផ្ដើម ទដ ៨៤–៨៩) ។ ពួកជំនុំសម័យដើមជាច្រើនបានកាត់ស្រាយថា បទគម្ពីរទំនុកដំកើងក្នុងជំពូកនេះគឺនិយាយសំដៅលើសេចក្ដីទុក្ខលំបាករបស់ព្រះយេស៊ូវគ្រីស្ទ (ដូចជា ទដ ២២ ដែរ) ហើយដោយសារមូលហេតុនេះហើយ ទើបគេយកបទគម្ពីរទំនុកដំកើងក្នុងជំពូកនេះ មកសូត្រក្នុងថ្ងៃសុក្រល្អ (មុនថ្ងៃបុណ្យព្រះជន្មរស់ឡើងវិញ) ។

លក្ខណៈសំណង់ប្រយោគក្នុងជំពូកនេះគេសង្កេតឃើញថា នៅចុងបញ្ចប់នៃសេចក្ដីអធិស្ឋាន (ខ.១៣–១៨) គឺមានសណ្ឋានដូចគ្នានឹងការចាប់អធិស្ឋានដែរ (ខ.១–៥) ដោយក្នុងផ្នែកនិមួយៗមានកំណាព្យហេព្រើរចំនួន២ (ខ.១–២, ១៣–១៤) ហើយមាន៤ខទៀតដែលបន្តរពីនេះដែលបាននិយាយពីសេចក្ដីទុក្ខលំបាករបស់អ្នកនិពន្ធ ។

ទូលបង្គំបានអំពាវនាវ[ខ] នៅចំពោះទ្រង់ ទាំងយប់ទាំងថ្ងៃ
២សូមឱ្យសេចក្ដីអធិស្ឋានរបស់ទូលបង្គំបានចូលមកនៅចំ
ពោះទ្រង់ សូមផ្ទៀងព្រះកាណ៌ស្ដាប់ពាក្យទូលបង្គំទូល
អង្វរផង
៣ដ្បិតព្រលឹងនៃទូលបង្គំមានពេញដោយសេចក្ដីវេទនា[គ]
ជីវិតនៃទូលបង្គំក៏កាន់តែជិតស្ថានឃុំព្រលឹងមនុស្សស្លាប់[ឃ]
៤គេរាប់ទូលបង្គំជាមួយនឹងពួកអ្នកដែលកំពុងតែចុះទៅក្នុង
រណ្ដៅ[ង] ទូលបង្គំក៏ដូចជាមនុស្សដែលគ្មានកំឡាំង[ច]
៥ត្រូវបោះបង់ចោលនៅកណ្ដាលពួកមនុស្សស្លាប់ហើយ
ដូចជាអ្នក១ដែលត្រូវគេកាប់សំឡាប់ដែលដេកនៅក្នុងផ្នូរ
ជាអ្នកដែលទ្រង់មិននឹកចាំទៀតសោះ
ហើយត្រូវកាត់ចេញ[ឆ]ពីព្រះហស្តទ្រង់ទៅ
៦ទ្រង់បានផ្ដេកទូលបង្គំនៅក្នុងរណ្ដៅជ្រៅបំផុត
គឺក្នុងទីងងឹត នៅទីជំរៅ[ជ]
៧សេចក្ដីក្រោធ[ឈ] របស់ទ្រង់កំពុងតែសង្កត់លើទូលបង្គំជា
ធ្ងន់ ទ្រង់បានធ្វើទុក្ខទូលបង្គំ ដោយអស់ទាំងរលកទ្រង់[ញ] ។
–បង្អង់
៨ទ្រង់បានធ្វើឱ្យពួកមិត្រភក្ដិ[ដ] របស់ទូលបង្គំឃ្លាតឆ្ងាយទៅ
ក៏បានធ្វើឱ្យទូលបង្គំត្រឡប់ជាទីខ្ពើមឆ្អើម[ឋ]ដល់គេ
ទូលបង្គំត្រូវបង្ខាំងនៅ និងចេញមកមិនរួច[ឌ]
៩ភ្នែក[ឍ]ទូលបង្គំស្រវាំងទៅ ដោយសេចក្ដីទុក្ខព្រួយ
ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានទូលអង្វរ[ណ]ដល់ទ្រង់រាល់
តែថ្ងៃជានិច្ច ទូលបង្គំបានប្រទូលដៃ[ត]ចំពោះទ្រង់
១០តើទ្រង់នឹងសំដែងការអស្ចារ្យដល់មនុស្សដែលស្លាប់
ហើយឬ តើអ្នកដែលស្លាប់នឹងងើបឡើងសរសើរដល់ទ្រង់
ដែរឬ[ថ] ។ –បង្អង់
១១តើនឹងមានគេថ្លែងពីសេចក្ដីសប្បុរសទ្រង់នៅក្នុងផ្នូរ
ឬពីសេចក្ដីស្មោះត្រង់[ទ] របស់ទ្រង់ នៅទីហិនវិនាសដែរឬអី

**៨៨:១** ខ ទដ ៣:៤ ២២:២ លក ១៨:៧ **៨៨:៣** គ ទដ ៦:៣ ២៥:១៧ ឃ យប ៣៣:២២ **៨៨:៤** ង ទដ ៣១:១២ ច ទដ ១៨:១ **៨៨:៥** ឆ ទដ ៣១:២២ **៨៨:៦** ជ ទដ ៣០:១ ៦៩:១៥ បទ ៣:៥៥ យហ ២:៣ **៨៨:៧** ឈ ទដ ៧:១១ ញ ទដ ៤២:៧ **៨៨:៨** ដ យប ១៩:១៣ ទដ ៣១:១១ ឋ យប ៣០:២ ៣៣:១ ឌ យប ៣:២៣ **៨៨:៩** ឍ ទដ ៣៨:១០ ណ ទដ ៥:២ ត យប ១១:១៣ ទដ ១៤៣:៦ **៨៨:១០** ថ ទដ ៦:៥ **៨៨:១១** ទ ទដ ៣០:៩

**៨៨ត្រង់ចំណងជើង** នៅក្នុងបទគម្ពីរនេះមាននិយាយពីថា មានអ្នកនិពន្ធ២ប្រហែលចង់និយាយថា បទគម្ពីរក្នុងជំពូកនេះ មានវប្បធម៌២ដែលខុសគ្នា ។ *ចំរៀង* មើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង ។ *របស់កូនចៅកូរេ* មើលការពន្យល់ ទដ ៤២ ត្រង់ចំណងជើង ។ *សំរាប់មេភ្លេង* មើលការពន្យល់ ទដ ៤ ត្រង់ចំណងជើង ។ *ត្រូវលេងដោយ* មើលការពន្យល់ ទដ ៦ ត្រង់ចំណងជើង ។ *សេចក្ដីបង្រៀន* មើលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។ *ហេម៉ាន* មើលការពន្យល់ ទដ ៣៩ ត្រង់ចំណងជើង ។ *អេសរ៉ាគីត* គឺនិយាយសំដៅលើអែសរ៉ាជា ម្នាក់ក្នុងចំណោមកូនជាច្រើនទៀតរបស់យូដា (សូមមើល ១របា ២:៦) ដែលគេបានកត់ចុះថា ជាហេម៉ាន និងអេថាន (សូមមើល ទដ ៨៩ ត្រង់ ចំណងជើង) ។ បើជាសិនវាជាការពិតមែននោះ នោះចំណងជើងនៃព្រះ គម្ពីរទំនុកដំកើងដែលនិយាយនៅទីនេះគឺបង្ហាញថា វប្បធម៌របស់ពួកគេមានភាពមិនច្បាស់លាស់ ហើយបានកើតឡើង ដោយសារឈ្មោះពួកយូដា២នាក់ ដែលមានឈ្មោះប្រហាក់ប្រហែលគ្នា ដែលពួកគេទាំង២នាក់នោះជាអ្នក ចម្រៀងដ៏ល្បីរបស់កូនចៅកូរេ ។

**៨៨:១–២** នៅក្នុងខទាំងនេះ អ្នកនិពន្ធចាប់ផ្ដើមអធិស្ឋានដោយប្រើពាក្យថា"ព្រះដ៏ជួយសង្គ្រោះទូលបង្គំ" ។

**៨៨:៣–៥** នៅក្នុងខទាំងនេះ អ្នកនិពន្ធបាននិយាយថា គាត់បានរស់នៅលើច្រាំងនៃសេចក្ដីស្លាប់ ។

**៨៨:៣** *ព្រលឹងនៃទូលបង្គំ* សូមមើលការពន្យល់ ៦:៣ ។

**៨៨:៤** *រណ្ដៅ* សូមមើល ២៨:១ ៣០:៣,៩ ១៤៣:៧ ។

**៨៨:៥** *ជាអ្នកដែលទ្រង់មិននឹកចាំទៀតសោះ* ដោយសារការដែលគាត់មិនបានមើលឃើញពីទស្សនះវិស័យដែលមាននៅក្នុងជីវិតគាត់ ធ្វើឱ្យសេចក្ដីស្លាប់បានកាត់គាត់ចេញពីការថែរក្សារបស់ព្រះអម្ចាស់ ។ ព្រះអម្ចាស់ទ្រង់មិនបាននឹកចាំពីការរងទុក្ខរបស់ពួកកំសត់ទុរគត ក្នុងការស្ដាបនាពួកគេឡើងវិញឡើយ (សូមមើល ២៥:៧ ៧៤:២ ១០៦:៤) ។ អ្នកនិពន្ធបានពណ៌នាពីស្ថានភាពជីវិតគាត់ពេលនោះថា គាត់រស់នៅក្នុងភាពងងឹតនៃស្បែអន្ធការ (សូមមើលការពន្យល់ ៦:៥) ។

**៨៨:៦–៩** នៅក្នុងខទាំងនេះ អ្នកនិពន្ធចង់និយាយថា ឱព្រះអម្ចាស់ព្រះយេហូវ៉ាអើយ គឺទ្រង់ហើយដែលធ្វើឱ្យការទាំងនេះកើតឡើងដល់ទូលបង្គំ ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ គាត់មិនបានដឹងពីមូលហេតុនៃការរងទុក្ខរបស់គាត់ឡើយ (សូមមើល ខ.១៤ ហើយធៀបជាមួយ ទដ ៤៤) ប៉ុន្តែផ្ទុយមកវិញគាត់គ្រាន់តែដឹងថា គឺព្រះហស្តរបស់ព្រះដែលធ្វើការនេះ (សូមមើល បរ ១:២០–២១ អម ៣:៦) ។ ព្រះដ៏ជួយសង្គ្រោះរបស់គាត់បានបង្ហាញគាត់ឱ្យឃើញពីសេចក្ដីក្រោធដ៏ខ្លាំង ធ្វើឱ្យគាត់មានអារម្មណ៍តានតឹង និងអស់សង្ឃឹម ។ អ្នកនិពន្ធមិនបានព្យាយាមរកវិធីយ៉ាងណាដើម្បីគេចចេញពីភាពងងឹតអន្ធការនោះឡើយ ។ ប៉ុន្តែមើលទៅ គឺគាត់បានសារភាពពីកំហុសរបស់ខ្លួន ដូច្នេះហើយទើបព្រះដ៏ជួយសង្គ្រោះរបស់គាត់អាចនឹងលេចមក (សូមមើល ខ.១) ។

**៨៨:៦** *រណ្ដៅជ្រៅបំផុត គឺក្នុងទីងងឹតនៅទីជំរៅ* មើលការពន្យល់ ៣០:១ ។

**៨៨:៧** *សេចក្ដីក្រោធ* សូមមើល ខ.១៦ និងការពន្យល់ ២:៥ ។ *អស់ទាំងរលកទ្រង់* សូមមើលការពន្យល់ ៣២:៦ ។

**៨៨:៨** *ពួកមិត្រភក្ដិ* សូមមើល ខ.១៨ និងការពន្យល់ ៣១:១១–១២ ។

**៨៨:៩** *ភ្នែកទូលបង្គំស្រវាំងទៅ* សូមមើលការពន្យល់ ៦:៧ ។

**៨៨:៩–១២** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានអំពាវនាវសុំឱ្យព្រះអង្គជួយដល់គាត់ មុនពេលដែលគាត់បានធ្លាក់ទៅក្នុង"ស្ថានភ្លេចភ្លាំង" (សូមមើលការពន្យល់ ខ.៥) ។

**៨៨:១០,១២** *ការអស្ចារ្យ* គឺសំដៅលើសេចក្ដីសង្គ្រោះរបស់ព្រះដែលទ្រង់បានជួយដល់រាស្ត្រទ្រង់(សូមមើលការពន្យល់ ៩:១) ។

**៨៨:១០** *ងើបឡើង* គឺងើបចេញពីស្ថានឃុំព្រលឹងមនុស្សស្លាប់ (មិនមែនរស់ពីស្លាប់ឡើងវិញឡើយ) សូមមើល អស ១៤:៩ ។ *សរសើរដល់ទ្រង់* សូមមើល ៦:៥ ៣០:៩ ១១៥:១៧ និងការពន្យល់ ។

**៨៨:១១** *សេចក្ដីសប្បុរស . . . សេចក្ដីស្មោះត្រង់* មានន័យថា ព្រះអង្គជាព្រះដែលមានសេចក្ដីសប្បុរស និងស្មោះត្រង់ (សូមមើលការពន្យល់ ៣៦:៥

១២ តើនឹងមានអ្នកណាស្គាល់ការអស្ចារ្យរបស់ទ្រង់នៅក្នុងទី
ងងឹត ឬសេចក្ដីសុចរិតទ្រង់នៅស្ថានភ្លេចភ្លាំងបានឬទេ
១៣ ប៉ុន្តែ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់
ទ្រង់[ធ] នៅពេលព្រឹក[ន] សេចក្ដីអធិស្ឋានរបស់ទូលបង្គំនឹងមក
ចំពោះទ្រង់[ប]
១៤ ឱព្រះយេហូវ៉ាអើយ ហេតុអ្វីបានជាទ្រង់បោះបង់[ផ] ព្រលឹង
នៃទូលបង្គំចោល ម្ដេចក៏ទ្រង់លាក់ព្រះភក្ត្រ[ព] នឹងទូលបង្គំ
ដូច្នេះ
១៥ ទូលបង្គំមានទុក្ខវេទនា[ភ] ហើយប្រុងប្រៀបនឹងស្លាប់តាំង
តែពីក្មេងមក[ម] កាលទូលបង្គំកំពុងតែរងទ្រាំអស់ទាំង
សេចក្ដីស្ញែងខ្លាច[យ] របស់ទ្រង់
នោះទូលបង្គំមានចិត្តស្លឹកស្រពន់[រ]
១៦ សេចក្ដីក្រោធដ៏សហ័ស[ល] របស់ទ្រង់បានហូរគ្របលើទូល
បង្គំហើយ សេចក្ដីស្ញែងខ្លាច[វ] របស់ទ្រង់បានកាត់ទូលបង្គំ
ចេញ
១៧ សេចក្ដីទាំងនោះបានឡោមព័ទ្ធទូលបង្គំជុំវិញដូចជាទឹក[ស]
ជាដរាបរាល់ថ្ងៃ ក៏នាំគ្នារឹតរួតទូលបង្គំទាំងអស់
១៨ ទ្រង់បានធ្វើឱ្យទាំងអ្នកដែលស្រឡាញ់ទូលបង្គំ[ហ]
និងពួកភឿនឃ្លាតឆ្ងាយពីទូលបង្គំទៅ
ពួកមិត្រភក្តិរបស់ទូលបង្គំក៏បាត់ទៅក្នុងសេចក្ដីងងឹត
ហើយ ។

**៨៨:១៣** ធ ទដ ៣០:២ ន ទដ ៥:៣ ៥៥:១៧ ប ទដ ១១៩:១៤៧ **៨៨:១៤** ផ ទដ ៤៣:២ ប ទដ ១៣:១ **៨៨:១៥** ភ ទដ ១២៩:១ យរ ២២:២១ អគ ១៦:២២ ហស ២:១៥ ម ទដ ៩:១២ យ យប ៦:៤ ១៨:១១ រ ២កថ ៤:៨ **៨៨:១៦** ល ទដ ៧:១១ វ យប ៦:៤ **៨៨:១៧** ស ទដ ១២៤:៤

សេចក្ដីបង្រៀនរបស់អេថាន ជាពួកអេសរ៉ាគីត ។

**៨៩** ទូលបង្គំនឹងច្រៀង[ក] ពីព្រះគុណនៃព្រះយេហូវ៉ាជា
ដរាប មាត់ទូលបង្គំនឹងសំដែងឱ្យស្គាល់[ខ] សេចក្ដីស្មោះត្រង់

**៨៨:១៨** ហ ខ.៨ ទដ ៣៨:១១ **៨៩:១** ក ទដ ៥៩:១៦ ខ ទដ ៣៦:៥ ៤០:១០

និងការពន្យល់ ៣:៧) ។ *សេចក្ដីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**៨៨:១២** *សេចក្ដីសុចរិត* សូមមើល ៧១:២៤ និងការពន្យល់ ។

**៨៨:១៣–១៤** នៅក្នុងខទាំងនេះ គឺជាសេចក្ដីបញ្ចប់នៃសេចក្ដីអធិស្ឋាន ដែលខទាំងនេះក៏មាននិយាយនៅក្នុង ខ.១–២ដែរ ។

**៨៨:១៣** *ពេលព្រឹក* សូមមើក ១០១:៨ និងការពន្យល់ ។

**៨៨:១៤** *ហេតុអ្វី* សូមមើលការពន្យល់ ៦:៣ ។ *លាក់ព្រះភក្ត្រ* សូមមើលការពន្យល់ ១៣:១ ។

**៨៨:១៥–១៨** នៅក្នុងខទាំងនេះចង់និយាយថា សេចក្ដីទុក្ខលំបាកដែលអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងមាន វាមិនមែនជារឿងចំឡែកនោះឡើយ ដ្បិត អីនៅក្នុង១ជីវិតគាត់ជួបតែសេចក្ដីទុក្ខលំបាក ដែលជាសេចក្ដីខ្លាចមកពីព្រះ (សូមធៀបជាមួយ ទដ ៩០) ។

**៨៨:១៧** *ដូចជាទឹក* សូមមើល ខ.៧ និងការពន្យល់ ៣២:៦ ។

**ទដ ៨៩** នៅក្នុងជំពូកនេះគឺជាសេចក្ដីអធិស្ឋានរំលែកទុក្ខ ចំពោះការធ្លាក់ចុះនៃជំនួវង្សរបស់ស្ដេចដាវីឌ និងសូមឱ្យព្រះអង្គបានស្ដាបនាពួកគេឡើងវិញ ។ ភាពតក់ស្លុតដែលបង្ករឱ្យមានភាពជូរល្វីងដោយសារហេតុការណ៍ទាំងនេះ(សូមមើល ខ.៣៨) គឺស្ទើរតែមិនអាចទ្រាំទ្របាន ។ ព្រះអម្ចាស់ជាព្រះនៃសេចក្ដីសប្បុរស និងជាព្រះដែលមានគ្រប់ទាំងព្រះចេស្ដាបានបោះបង់ចោលអ្នកដែលព្រះបានចាក់ប្រេងតាំង ហើយបានធ្វើឱ្យពួកគេក្លាយជាទីមើលងាយរបស់ពួកសាសន៍ដទៃ ។ ការនេះមើលទៅហាក់បីដូចជាទ្រង់បានបំពានល្មើសចំពោះសេចក្ដីសញ្ញាដែលទ្រង់បានតាំងជាមួយ ដាវីឌ ហើយក៏បានរំឭកពីសេចក្ដីតំងូររបស់អ្នកនិពន្ធដែរ (មើល ខ.៣៨–៤៥) ។ ហេតុការណ៍ដ៏អាក្រក់នេះ ប្រហែលនិយាយសំដៅលើការវាយបំផ្លាញក្រុងយេរូសាឡិមពីសំណាក់ស្ដេចនេប៊ូក្នេសា និងការនិរទេសស្ដេចយ៉ូយ៉ាគីនក្នុងឆ្នាំ ៥៩៧ មុន គ.ស (មើល ២ពវ ២៤:៨–១៧) ។ ទោះបីជាព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ ដូចគ្នានឹងព្រះគម្ពីរទំនុកដំកើង ជំពូក ៤៤ និងជំពូក ៨៨ ក៏ដោយ ក៏អ្នកនិពន្ធក្នុងជំពូកនេះបានបញ្ចប់សេចក្ដីអធិស្ឋាន ដោយការនិយាយពីការមិនបានធូរស្បើយពីភាពវេទនា និងសេចក្ដីត្អូញត្អែរពីការដែលព្រះយេហូវ៉ាទ្រង់បាន "បោះបង់ចោល" (សូមមើល ខ.៣៨ ហើយធៀបជាមួយ ៤៤:៩ ៨៨:១៤) ។ ក្នុងជួរលំដាប់នៃទំនុកដំកើងក្នុងជំពូកនេះជាមួយបទគម្ពីរទំនុកដំកើងផ្សេងៗទៀត ក្នុងក្រុមជាមួយ គឺបទគម្ពីរជំពូកនេះមានទំនាក់ទំនងជាមួយផ្ទៃរឿងដែលនិយាយនៅក្នុង ទដ ៨៤ និង ៨៧ (មើលសេចក្ដីផ្ដើម ទដ ៨៤–៨៩) ។

ព្រះគម្ពីរទំនុកដំកើងជំពូកនេះក៏ដូចគ្នានឹង ទដ ៤៤ដែរ (សូមមើលសេចក្ដីផ្ដើមក្នុងទំនុកដំកើងជំពូកនោះ) គឺមានគ្រឹះនៃសេចក្ដីអធិស្ឋានជាច្រើន ដែលអ្នកនិពន្ធគាត់ប្រើក្នុងសេចក្ដីបញ្ចប់នៃសេចក្ដីអធិស្ឋាន ។

នៅក្នុងសេចក្ដីផ្ដើមនៃជំពូកនេះ (ខ.១–៤) អ្នកនិពន្ធបានច្រៀងពីសេចក្ដីសប្បុរស និងសេចក្ដីស្មោះត្រង់របស់ព្រះអម្ចាស់(សូមមើល ខ.១–២) ព្រមទាំងសេចក្ដីសញ្ញា ដែលទ្រង់បានតាំងជាមួយស្ដេចដាវីឌ (សូមមើល ខ.៣–៤) ។ នៅក្នុងជំពូកនេះមានផ្ទៃរឿង២ដែលនិយាយពីសេចក្ដីអំណរអរយ៉ាងក្រៃលែងគឺនៅ ខ.៥–១៨ និយាយពីសេចក្ដីសប្បុរស និងសេចក្ដីស្មោះត្រង់របស់ព្រះយេហូវ៉ា ហើយនៅក្នុង ខ.១៩–៣៧ និយាយពីសេចក្ដីសញ្ញាដែលព្រះបានតាំងជាមួយស្ដេចដាវីឌ ។ ប៉ុន្តែសេចក្ដីអំណរទាំងនោះក៏ប្រែក្លាយជាសំណោកទៅវិញ ហើយអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងក៏បានពណ៌នាយ៉ាងលំអិតពីរបៀបណាដែលព្រះអម្ចាស់ទ្រង់បានបោះចោលអ្នក ដែលព្រះបានចាក់ប្រេងតាំង (សូមមើល ខ.៣៨–៤៥) ។ ដូច្នេះអ្នកនិពន្ធក៏បានអធិស្ឋាន ដោយការអន្ទះអន្ទែងគ្មានការអត់ធ្មត់ដោយចង់ឱ្យព្រះអម្ចាស់ទ្រង់បាននឹកចាំពីសេចក្ដីសញ្ញារបស់ទ្រង់ ដែលទ្រង់បានតាំងជាមួយស្ដេចដាវីឌ (សូមមើល ខ.៤៦–៥១) (ខ.៥២ បានរាប់ថាមិន មែនជាបទចម្រៀងនៃទំនុកដំកើងក្នុងជំពូកនេះឡើយ ប៉ុន្តែគ្រាន់តែជាផ្នែក ដែលមាននៅក្នុងប៉ែកទី៣ប៉ុណ្ណោះ) ។

**៨៩ត្រង់ចំណងជើង** *សេចក្ដីបង្រៀន* សូមមើលការពន្យល់ ទដ ៣២ ត្រង់ចំណងជើង ។ *អេថាន* គឺជាយេឌូថិន (សូមមើលការពន្យល់ ៣៩ ត្រង់ចំណងជើង) ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ គឺជាពួកលេវី (ប្រហែលជាកូនរបស់យេឌូថិន) ដែលគាត់មានតួរនាទីជាអ្នកនាំពាក្យដល់បណ្ដាជននិងអធិស្ឋានដោយការថប់ព្រួយ ។ *អេរ៉ាគីត* សូមមើលការពន្យល់ ៨៨ ត្រង់ចំណងជើង ។

**៨៩:១–២** នៅក្នុងខទាំងនេះ អ្នកនិពន្ធពណ៌នាពីសេចក្ដីសប្បុរស និងសេចក្ដីស្មោះត្រង់របស់ទ្រង់ ។

របស់ទ្រង់ រហូតដល់អស់ទាំងដំណតទៅ
២ ដ្បិតទូលបង្គំបានពោលហើយថា ព្រះគុណនឹងបានតាំង
ឡើង ឱ្យនៅអស់កល្បជានិច្ច ទ្រង់ក៏នឹងតាំងសេចក្ដីស្មោះ
ត្រង់របស់ទ្រង់នៅលើស្ថានសួគ៌ផង[គ] ។
៣ អញបានតាំងសញ្ញានឹងអ្នកដែលអញបានរើសតាំង
អញបានស្បថនឹងដាវីឌជាអ្នកបំរើអញថា
៤ អញនឹងតាំងពូជពង្សឯង ឱ្យនៅអស់កល្បជានិច្ច
ក៏នឹងដំកល់រាជ្យឯង ឱ្យនៅគ្រប់ទាំងដំណតទៅ[ឃ] ។ –បង្អង់
៥ ឱព្រះយេហូវ៉ាអើយ ផ្ទៃមេឃ[ង]និងសរសើរការអស្ចារ្យ
របស់ទ្រង់ ព្រមទាំងសេចក្ដីស្មោះត្រង់ទ្រង់ផង
នៅក្នុងពួកជំនុំ[ច]នៃអស់អ្នកបរិសុទ្ធ
៦ ដ្បិតតើមានអ្នកណានៅលើមេឃដែលផ្ទឹមនឹងព្រះយេហូវ៉ា
បាន ក្នុងអស់ពួកខ្លាំងពូកែ
តើមានអ្នកណាឱ្យដូចព្រះយេហូវ៉ា[ឆ]
៧ ជាព្រះដែលគួរស្ញែងខ្លាចណាស់
នៅក្នុងទីប្រជុំ[ជ]នៃអស់អ្នកបរិសុទ្ធ[ឈ] ក៏គួរកោតខ្លាច
លើសជាងអស់អ្នកនៅជុំវិញទ្រង់ផង[ញ]

៨ ឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារអើយ
តើមានអ្នកណាខ្លាំងពូកែ[ដ]ដូចជាទ្រង់[ឋ] ឱព្រះយេហូវ៉ា
អើយ សេចក្ដីស្មោះត្រង់របស់ទ្រង់ក៏នៅព័ទ្ធជុំវិញទ្រង់
៩ ទ្រង់បង្ក្រាបការលើកកំពស់នៃសមុទ្រ
កាលណារលកកំរើកឡើងនោះទ្រង់បន្ទ្រោមចុះ ឱ្យស្ងប់
វិញ[ឌ]
១០ ទ្រង់បានកំទេចកំទីពួករ៉ាហាប[ឍ]
ដូចជាមនុស្សដែលគេវាយសំឡាប់
ទ្រង់បានកំចាត់កំចាយ[ណ]ពួកខ្មាំងសត្រូវទៅដោយព្រះ
ពាហុដ៏មានឫទ្ធិ
១១ ផ្ទៃមេឃជារបស់ផងទ្រង់[ត] ព្រមទាំងផែនដីផង[ថ]
ឯលោកីយ និងសព្វសារពើ ដែលនៅក្នុងលោកីយ
នោះគឺទ្រង់បានសង់ឡើងដែរ[ទ]
១២ ទ្រង់បានបង្កើតទិសខាងជើង នឹងទិសខាងត្បូង
ឯភ្នំតាបោរ[ធ] និងភ្នំហើម៉ូន[ន]នោះក៏បានរីករាយ[ប]

**៨៩:២** គ ទដ ៣៦:៥ **៨៩:៤** ឃ ២សយ ៧:១២–១៦ ១ពវ ៨:១៦ ទដ ១៣២:១១–១២ អស ៩:៧ អគ ៣៧:២៤–២៥ មថ ១:១ លក ១:៣៣ **៨៩:៥** ង ទដ ១៩:១ ច ទដ ១:៥ **៨៩:៦** ឆ លប ១:២៦ នក ៩:១៤ ទដ ១៨:៣១ ១១៣:៥ **៨៩:៧** ជ ទដ ១១១:១ ឈ យប ៥:១ ញ ទដ ៤៧:២ **៨៩:៨** ដ អស ៦:៣ ឋ ទដ ៧១:១៩ **៨៩:៩** ឌ ទដ ៦៥:៧ **៨៩:១០** ឍ យប ៩:១៣ ណ ទដ ៥៩:១១ ៦៨:១ ៩២:៩ **៨៩:១១** ត ចទ ១០:១៤ ទដ ១១៥:១៦ ថ ១រប ២៩:១១ ទដ ២៤:១ ទ លប ១:១ **៨៩:១២** ធ យស ១៩:២២ ន ចទ ៣:៨ ៤:៤៨ ប ទដ ៩៨:៨

**៨៩:១** *ព្រះគុណ . . . សេចក្ដីស្មោះត្រង់* សូមមើល ខ.២,៣៣,៤៩ ។ នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់ជាព្រះនៃព្រះគុណ និងជាព្រះដែលស្មោះត្រង់ (មើល ខ.១៤ និងការពន្យល់ ៣៦:៥) ។ *ព្រះគុណ* សូមមើល ខ.២,១៤,២៤,២៨,៣៣,៤៩ និងការពន្យល់ ៦:៤ ។ នៅគ្រាដែលព្រះបានបោះបង់ចោលពួកគេ ព្រះអង្គមិនបានផ្ដល់ព្រះគុណនិងសេចក្ដីស្មោះត្រង់របស់ទ្រង់ មកដល់ជំនួរវង្សរបស់ដាវីឌឡើយ (សូមមើល ខ.៣៨–៤៥) ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបាន និយាយឃ្លាបែបនេះចំនួន៧ដង (នៅក្នុង ខ.១៤ នៅក្នុងព្រះគម្ពីរភាសាហេព្រើរប្រើខុសពីនេះប៉ុន្តែមានការទាក់ទងជាមួយពាក្យថា "ស្មោះត្រង់") ។

**៨៩:២** *នៅលើស្ថានសួគ៌ផង* នៅក្នុងឃ្លានេះចង់និយាយថា ព្រះគុណនិងសេចក្ដីសប្បុរសនៃព្រះ គឺបានបង្ហាញយ៉ាងច្បាស់នៅទីដ៏ខ្ពស់បំផុតនៃបល្ល័ង្គដ៏មានអំណាចចេស្ដារបស់ទ្រង់ (សូមមើល ខ.៥–៨) ។

**៨៩:៣–៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធបាននិយាយពីសេចក្ដីសញ្ញា ដែលព្រះបានតាំងជាមួយស្ដេចដាវីឌ (សូមមើល ២សយ ៧:៨–១៦) ។

**៨៩:៣** *អ្នកបំរើ* សូមមើល ខ.២០,៣៩,៥០ ។ អ្នកបម្រើដែលនិយាយនៅទីនេះគឺសំដៅលើមន្ត្រីជាផ្លូវការណ៍ (សូមមើលការពន្យល់ ៧៨:៧០) ។

**៨៩:៥–៨** នៅក្នុងខទាំងនេះ អ្នកនិពន្ធចង់និយាយថាសេចក្ដីសប្បុរស និងសេចក្ដីស្ញែងខ្លាចរបស់ព្រះយេហូវ៉ា គឺស្ថិតក្នុងចំណោមស្នាព្រះហស្ដទាំងឡាយដែលមានអំណាចនៅលើស្ថានសួគ៌ ហើយស្នាព្រះហស្ដទាំងឡាយដែលព្រះបានបង្កើតមក ពួកគេបានទទួលពីអំណាចរបស់ព្រះដោយការសរសើរដំកើង និងការចុះចូល ។

**៨៩:៥** *ផ្ទៃមេឃ* នៅក្នុងឃ្លានេះចង់និយាយសំដៅលើគ្រប់ទាំងអស់ដែលជាស្នាព្រះហស្ដរបស់ព្រះដែលមាននៅលើផ្ទៃមេឃ ។ *ការអស្ចារ្យ* គឺនិយាយសំដៅលើអំណាចចេស្ដារបស់ព្រះក្នុងការបង្កើត និងប្រោសលោះ (សូមមើលការពន្យល់ ៩:១) ។ *នៅក្នុងពួកជំនុំនៃអស់អ្នកបរិសុទ្ធ* គឺប្រជុំក្នុងដំណាក់របស់ព្រះនៅលើស្ថានសួគ៌ (មើល ខ.៧ និងការពន្យល់ ៨២:១) ។

**៨៩:៦** *អស់ទាំងពួកខ្លាំងពូកែ* នៅក្នុងភាសាអក្សរសាស្ត្រគឺ "អស់ទាំងកូនរបស់ពួកព្រះ" (សូមមើល ២៩:១ និងការពន្យល់) ។

**៨៩:៨** *ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវ៉ា* សូមមើលការពន្យល់ ១សយ ១:៣ ។

**៨៩:៩–១៣** នៅក្នុងឃ្លានេះ ចង់និយាយអំពីអំណាចចេស្ដារបស់ព្រះអទិករ និងសេចក្ដីអំណរនៃការបង្កើតទាំងឡាយនៅក្នុងទ្រង់ ។

**៨៩:៩–១០** នៅក្នុងរឿងដែលបានពណ៌នានៅក្នុងខទាំងនេះ អ្នកនិពន្ធបានដកស្រង់គំនិតនៃរូបនេះ ពីរឿងព្រេងរបស់ពួកអ្នកដែលនៅតំបន់មជ្ឈឹមបូព៌ា ដើម្បីពណ៌នាពីអំណាចចេស្ដារបស់ព្រះអម្ចាស់ដែលបានធ្វើឱ្យរលកទឹកកក្រើករំពើង ដើម្បីឱ្យស្នាព្រះហស្ដផ្សេងៗទៀតដែលព្រះបង្កើតមកបានតាំងជាប់នៅ និងកើតឡើង (សូមមើល លប ១:៦–១០ និងការពន្យល់ ៦៥:៦–៧ ៧៤:១៣–១៤) ។

**៨៩:១០** *រ៉ាហាប* ឃ្លានេះគឺជាពាក្យប្រៀបប្រដូចដែលអ្នកនិពន្ធគាត់ចង់និយាយសំដៅលើសត្វចំឡែកៗដែលនៅក្នុងទឹកដ៏ជ្រៅ (សូមមើលការពន្យល់ ៣២:៦ ៨៧:៤) ។ ពាក្យនេះផងដែរប្រហែលជាឈ្មោះ១ទៀតរបស់សត្វដ៏ចម្លែកៗដែលមាននិយាយនៅក្នុង ៧៤:១៤ និង ១០៤:២៦) ។ ពាក់កណ្ដាលឃ្លាចុងក្រោយក្នុងជំពូកនេះ ប្រហែលជានឹងនិយាយម្ដងទៀតក្នុង លក ១:៥១ ។

**៨៩:១២** *ទិសខាងជើង និងទិសខាងត្បូង* ឃ្លានេះប្រហែលជានិយាយសំដៅលើភ្នំ២ ហើយនៅទីនេះពាក្យនេះគឺជាការប្រៀបធៀបទៅនឹងភ្នំតាបោរ និងភ្នំហើម៉ូន៖"ភ្នំនៅទិសខាងជើង"(ភ្នំហ្សាហ្វូន "វាជាឈ្មោះភ្នំដ៏អាថ៌កំបាំងមួយនៅភាគខាងជើង" ដែលភាគច្រើនគេស្គាល់ថា ភ្នំស៊ីយ៉ូន

ចំពោះព្រះនាមទ្រង់
១៣ ទ្រង់មានព្រះពាហុខ្លាំងពូកែ ព្រះហស្តទ្រង់មានឫទ្ធិខ្លាំង
ព្រះហស្តស្តាំទ្រង់ក៏ខ្ពស់ណាស់[ផ]
១៤ សេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌ជាជើងថ្កល់នៃបល្ល័ង្ក
ទ្រង់[ព] សេចក្ដីសប្បុរស និងសេចក្ដីពិតត្រង់ដើរនាំមុខទ្រង់[ភ]
១៥ មានពរហើយ សាសន៍ណាដែលស្គាល់សំឡេងរីករាយ
នោះ ឱព្រះយេហូវ៉ាអើយ
គេដើរ[ម] នៅក្នុងពន្លឺ[យ] នៃព្រះភក្ត្រទ្រង់
១៦ គេមានចិត្តរីករាយ ដោយព្រះនាម[រ] ទ្រង់ជាដរាបរាល់
ថ្ងៃ ហើយគេបានដំកើងឡើងដោយសេចក្ដីសុចរិតរបស់
ទ្រង់
១៧ ដ្បិតទ្រង់ជាសិរីល្អនៃកំឡាំងគេ[ល]
ហើយទ្រង់នឹងលើកអំណាចយើងខ្ញុំឡើងដោយព្រះគុណ[វ]
១៨ ដ្បិតព្រះយេហូវ៉ាទ្រង់ជាខែល[ស] របស់យើងខ្ញុំ ហើយព្រះ
ដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ទ្រង់ជាមហាក្សត្រ[ហ] នៃ
យើងខ្ញុំ ។
១៩ គ្រានោះ ទ្រង់មានបន្ទូលដល់អ្នកបរិសុទ្ធទ្រង់ដោយការ
ជាក់ស្ដែងថា អញបានបន្ថែមសេចក្ដីជំនួយដល់អ្នក១ដែល
ខ្លាំងពូកែ
អញបានរើសយកអ្នកមួយចេញពីរាស្ត្រតាំងឡើងហើយ
២០ គឺអញបានរកឃើញដាវីឌ[ឡ] ជាអ្នកបំរើអញ[អ] ក៏បានចាក់
ប្រេងតាំង[ក] ឡើង ដោយប្រេងបរិសុទ្ធ[ខ] របស់អញ
២១ ដៃអញនឹងទប់ទល់ ឯដើមដៃអញ នឹងចំរើនកំឡាំងឱ្យ[គ]
២២ ពួកខ្មាំងសត្រូវនឹងមិនដែលទារអាករ[ឃ]
ហើយពួកមនុស្សអាក្រក់ក៏មិនដែលសង្កត់សង្កិន[ង] ឡើយ
២៣ អញនឹងវាយពួកតតាំងនឹងដាវីឌ ឱ្យដួលនៅចំពោះមុខ[ច]
ហើយនិងវាយអស់អ្នកដែលស្អប់ផងដែរ[ឆ]
២៤ សេចក្ដីស្មោះត្រង់ និងសេចក្ដីសប្បុរសរបស់អញនឹងនៅ
ជាមួយ[ជ] ហើយអំណាចរបស់ដាវីឌនឹងបានដំកើងឡើង
ដោយឈ្មោះអញ
២៥ អញនឹងតាំងឱ្យមានអំណាចនៅលើសមុទ្រ
ហើយឱ្យដៃស្តាំបានគ្រប់គ្រងលើអស់ទាំងទន្លេ[ឈ]
២៦ ដាវីឌនឹងអំពាវនាវដល់អញថាទ្រង់ជាព្រះវរបិតានៃទូល
បង្គំ[ញ] គឺជាព្រះនៃទូលបង្គំ
ហើយជាថ្មដា[ដ] ដ៏ជួយសង្គ្រោះទូលបង្គំផង[ឋ]
២៧ ឯអញៗនឹងតាំងឡើង ឱ្យធ្វើជាកូនច្បងរបស់អញ[ឌ]
គឺជាមហាក្សត្រ[ឍ] យ៉ាងខ្ពស់បំផុត[ណ] នៅផែនដី
២៨ អញនឹងបំរុងទុកសេចក្ដីសប្បុរសរបស់អញ
សំរាប់ដាវីឌនៅអស់កល្បជានិច្ច
ហើយសេចក្ដីសញ្ញារបស់អញនឹងនៅជាប់ជាមួយ[ត]
២៩ អញនឹងធ្វើឱ្យពូជពង្សដាវីឌនៅជាប់ជាដរាប
ហើយឱ្យរាជ្យបាននៅអស់កាលដែលផ្ទៃមេឃមាននៅ
ផង[ថ]
៣០ បើកូនចៅរបស់ដាវីឌបោះបង់ចោលច្បាប់អញ

**៨៩:១៣** ផ យស ៤:២៤ **៨៩:១៤** ព ទដ ៩៧:២ ភ ទដ ៨៥:១០–១១ **៨៩:១៥** ម ទដ ១:១ យ ទដ ៤៤:៣ **៨៩:១៦** រ ទដ ៣០:៤ ១០៥:៣ **៨៩:១៧** ល ទដ ១៨:១ វ ខ.២៤ ទដ ៧៥:១០ ៩២:១០ ១១២:៩ ១៤៨:១៤ **៨៩:១៨** ស ទដ ១៨:២ ហ ទដ ៤៧:៩ អស ១៦:៥ ៣៣:១៧,២២ **៨៩:២០** ឡ កច ១៣:២២ អ ទដ ៧៨:៧០ ក ១សយ ២:៣៥ ២សយ ២២:៥១ ខ នក ២៩:៧ ១ពវ ១:៣៩ **៨៩:២១** គ ខ.១៣ ទដ ១៨:៣៥ **៨៩:២២** ឃ ពច ៣:១៥ ង ២សយ ៧:១០ **៨៩:២៣** ច ទដ ១៨:៤០ ឆ ២សយ ៧:៩ **៨៩:២៤** ជ ២សយ ៧:១៥ **៨៩:២៥** ឈ ទដ ៧២:៨ **៨៩:២៦** ញ ២សយ ៧:១៤ យរ ៣:៤ ហព ១:៥ ដ ទដ ៦២:២ ឋ ២សយ ២២:៤៧ **៨៩:២៧** ឌ កល ១:១៨ ឍ ជន ២៤:៧ ណ ទដ ២:៦ វវ ១:៥ ១៩:១៦ **៨៩:២៨** ត ខ.៣៣–៣៤ អស ៥៥:៣ **៨៩:២៩** ថ ខ.៤,៣៦

សូមមើល ៤៨:២ និងការពន្យល់) និងភ្នំអាម៉ាណា (មើល សស ៤:៨) ។ *តាបោរ* សូមមើលការពន្យល់ ពច ៤:៦ ។ *ហើម៉ូន* សូមមើលការពន្យល់ ចទ ៣:៨ ។ *រីករាយ* សូមមើលការពន្យល់ ៦៥:១៣ ។ *ព្រះនាមទ្រង់* សូមមើល ខ.១៦,២៤ និងការពន្យល់ ៥:១១ ។

**៨៩:១៤–១៨** នៅក្នុងខទាំងនេះនិយាយពីសេចក្ដីសុចរិត និងសេចក្ដីស្មោះត្រង់របស់ព្រះយេហូវ៉ា ក្នុងការដឹកនាំនិងគ្រប់គ្រងលើប្រជារាស្ត្ររបស់ទ្រង់ និងសេចក្ដីសញ្ញាដ៏នៅអស់កល្បដែលព្រះអម្ចាស់ទ្រង់បានតាំង ។ គំនិតប្រាជ្ញាក្នុងជំពូកនេះត្រូវបានបែងចែកដូចតទៅ (១).និយាយពីសេចក្ដីផ្ដើម (ខ.១៩) (២).ស្ដេចដាវីឌគឺជាអ្នកដែលអញបានចាក់ប្រេងតាំងឱ្យធ្វើជាអ្នកបម្រើអញ ហើយអញនឹងផ្គត់ផ្គង់ដល់គេ (៣).អញនឹងបណ្ដេញអស់ទាំងខ្មាំងសត្រូវឱ្យចេញអស់ពីមុខឯង (ខ.២២–២៣) (៤).អញនឹងពង្រីងនគររបស់អញ(ខ.២៤–២៥) (៥).អញនឹងតាំងវាជាស្ដេចដំបូងលើអស់ទាំងស្ដេច (ខ.២៦–២៧) (៦).អញនឹងតាំងជំនួវង្សដាវីឌឱ្យសោយរាជជារៀងរហូត (ខ.២៨–២៩) ហើយសេចក្ដីសញ្ញានេះត្រូវបានសម្រេចក្នុងគ្រាដែលព្រះគ្រីស្ទយាងមកលើផែនដីនេះ (សូមមើល យហ ១២:៣៤) ។

**៨៩:១៩** *ការជាក់ស្ដែង* គឺសំដៅលើការដែលព្រះបានបើកសម្ដែងដល់សាំយ៉ូអែល (សូមមើល ១សយ ១៦:១២) និងណាថាន (សូមមើល ២សយ ៧:៤–១៦) ។

**៨៩:២៥** *សមុទ្រ . . . ទន្លេ* នៅក្នុងឃ្លានេះចង់និយាយថា ការគ្រប់គ្រងរបស់ដាវីឌនឹងរាលដាលពីសមុទ្រមេឌីទែរ៉ានេ រហូតដល់ទន្លេអ៊ើប្រាត (សូមមើល ៧២:៨ ៨០:១១ និងការពន្យល់ នក ២៣:៣១) ។ ប៉ុន្តែនៅទីនេះអ្នកនិពន្ធបានប្រើរូបភាពនេះដើម្បីពណ៌នាថា "បុត្រា"ដ៏ស្មោះត្រង់របស់ទ្រង់(សូមមើល ខ.២៦) និងរាជទ្រង់ (រាជ្យរបស់បុត្រា) និងការគ្រប់គ្រងរបស់ស្ដេចដាវីឌ និងបានឆ្លុះបញ្ចាំងពីការគ្រប់គ្រងរបស់ព្រះ (សូមមើល ខ.៩–១០ និងការពន្យល់និងធៀប ខ.២៣ ជាមួយ ខ.១០) ។

**៨៩:២៧** *កូនច្បង* គឺជាឯកសិទ្ធដ៏ខ្ពស់បំផុតដែលគាត់នឹងទទួលបានក្នុងនគរព្រះ (សូមមើល ២:៧–១២ ៤៥:៦–៦–៩ ៧២:៨–១១ ជំពូក ១១០) ដូច្នេះហើយទើបស្ដេចជាច្រើននៅលើផែនដីទទួលបានព្រះកិត្តិយស (មើល វវ ១:៥) ។

**៨៩:២៩** *ហើយឱ្យរាជ្យបាននៅអស់កាល ដែលផ្ទៃមេឃមាននៅផង* សូមមើល ខ.៣៦–៣៧ ។

**៨៩:៣០–៣៧** នៅក្នុងខនេះនិយាយថា សេចក្ដីសញ្ញារបស់ព្រះដែលទ្រង់

ឥតប្រតិបត្តិតាមបញ្ញត្តអញ
៣១ បើគេក្បត់ក្រិត្យក្រមរបស់អញ
ឥតរក្សាសេចក្ដីបង្គាប់ឡើយ
៣២ នោះអញនឹងធ្វើទោសចំពោះការរំលងរបស់គេដោយ
ដំបង ហើយចំពោះការទុច្ចរិតរបស់គេដោយស្នាម
រំពាត់[ទ] ។
៣៣ ប៉ុន្តែអញនឹងមិនដកសេចក្ដីសប្បុរសរបស់អញចេញពី
ដាវីឌឡើយ[ធ] ក៏មិនឱ្យសេចក្ដីស្មោះត្រង់របស់អញខាតខាន
ដែរ
៣៤ អញនឹងមិនក្បត់សេចក្ដីសញ្ញារបស់អញ ឬបំផ្លាស់បំប្រែ
សេចក្ដីដែលបានចេញពីបបូរមាត់អញឡើយ[ន]
៣៥ អញបានស្បថម្ដងហើយ ដោយនូវសេចក្ដីបរិសុទ្ធរបស់
អញថា អញមិនព្រមពោលកុហកដល់ដាវីឌឡើយ
៣៦ ពូជពង្សដាវីឌនឹងស្ថិតស្ថេរនៅជារៀងរាបដរាប
ហើយរាជ្យនឹងជាប់នៅចំពោះអញដូចជាព្រះអាទិត្យដែរ[ប]
៣៧ រាជ្យនោះនឹងបានតាំងនៅជាប់អស់កល្បជានិច្ចដូចជា
ព្រះចន្ទ គឺដូចជាទីសំគាល់ស្មោះត្រង់ដែលនៅលើមេឃ[ផ] ។
–បង្អង់
៣៨ ប៉ុន្តែទ្រង់បានបោះបង់ចោល[ព]
ហើយបណ្តេញទៅទ្រង់មាន
សេចក្ដីក្រោធនឹងអ្នកដែលទ្រង់ចាក់ប្រេងតាំងឱ្យ
៣៩ ទ្រង់បានលើកចោលសេចក្ដីសញ្ញានៃអ្នកបំរើទ្រង់
ក៏បានបង្អាប់មកុដ ដោយបោះចុះទៅដី[ភ]
៤០ ទ្រង់បានរំលំរបងចេញ[ម]
ហើយបានបំផ្លាញទីមាំមួនអស់រលីង[យ]
៤១ អស់អ្នកដែលដើរតាមផ្លូវក៏ប្លន់[រ] អ្នកបំរើទ្រង់បានត្រឡប់

**៨៩:៣២** ទ ២សយ ៧:១៤
**៨៩:៣៣** ធ ២សយ ៧:១៥
**៨៩:៣៤** ន ជន ២៣:១៩
**៨៩:៣៦** ប ខ.៤
**៨៩:៣៧** ផ យរ ៣៣:២០–២១
**៨៩:៣៨** ព ១រប ២៩:៩ ទដ ៤៤:៩ ៧៨:៥៩
**៨៩:៣៩** ភ បទ ៥:១៦
**៨៩:៤០** ម ទដ ៨០:១២ យ អស ២២:៥ បទ ២:២
**៨៩:៤១** រ ពច ២:១៤
ល ទដ ៤៤:១៣
**៨៩:៤២** វ ទដ ១៣:២ ៨០:៦
**៨៩:៤៣** ស ទដ ៤៤:១០
**៨៩:៤៥** ហ ទដ ៣៩:៥ ឡ ទដ ៤៤:១៥ ១០៩:២៩
**៨៩:៤៦** អ ទដ ៧៩:៥
**៨៩:៤៧** ក លប ៤៧:៩ យប ៧:៧ ទដ ៣៩:៥ ១ពត ១:២៤
**៨៩:៤៨** ខ លប ៥:២៤ ទដ ២២:២៩
**៨៩:៥០** គ ទដ ៦៩:១៩

ជាទីត្មះតិះដៀលដល់ពួកអ្នកជិតខាង[ល]
៤២ ទ្រង់បានលើកដៃស្តាំនៃពួកតតាំងឡើង
ក៏បានឱ្យពួកខ្មាំងសត្រូវមានសេចក្ដីរីករាយសាទរ[វ]
៤៣ ទ្រង់បានធ្វើឱ្យមុខដាវត្រឡប់មកវិញ
ហើយមិនបានឱ្យអ្នកបំរើទ្រង់ឈរមាំនៅក្នុងទីចំបាំង
ឡើយ[ស]
៤៤ ទ្រង់បានផ្តាច់សេចក្ដីរុងរឿងចេញ
ព្រមទាំងទំលាក់បល្ល័ង្កទៅដី
៤៥ ទ្រង់បានបំព្រួញ[ហ]វ័យក្មេងរបស់អ្នកបំរើទ្រង់ឱ្យរួចជាខ្លី
ហើយបានបង្គ្រប ដោយសេចក្ដីខ្មាសផង[ឡ] ។ –បង្អង់
៤៦ ឱព្រះយេហូវ៉ាអើយ តើដល់កាលណាទៅ
តើទ្រង់នឹងពួនអង្គទ្រង់នៅជានិច្ចឬ
សេចក្ដីក្រោធរបស់ទ្រង់នឹងឆួលឆេះដូចជាភ្លើងដល់
កាលណាទៀត[អ]
៤៧ ឱសូមទ្រង់នឹកចាំពីអាយុទូលបង្គំ ដែលខ្លីម្ល៉េះនេះ[ក]
ហើយពីជីវិតនៃអស់ទាំងមនុស្សជាតិដែលឥតប្រយោជន៍
ជាយ៉ាងណា
៤៨ តើមានមនុស្សឯណាដែលនឹងរស់នៅឥតឃើញសេចក្ដី
ស្លាប់ឡើយ ឬដែលដោះព្រលឹងខ្លួន ឱ្យរួចពីអំណាចនៃ
ស្ថានឃុំព្រលឹងមនុស្សស្លាប់ទៅបាន[ខ] ។ –បង្អង់
៤៩ ឱព្រះអម្ចាស់អើយ អស់ទាំងសេចក្ដីសប្បុរសដែលទ្រង់
ប្រោស កាលពីដើម ជាសេចក្ដីដែលទ្រង់បានស្បថដល់
ដាវីឌដោយសេចក្ដីស្មោះត្រង់របស់ទ្រង់នោះ
ឥឡូវនេះតើនៅឯណា
៥០ ឱព្រះអម្ចាស់អើយ សូមទ្រង់នឹកចាំពីសេចក្ដីដែលគេត្មះ
តិះដៀល[គ] ដល់ពួកអ្នកបំរើទ្រង់

បាន តាំងជាមួយស្តេចដាវីឌនិងជំនួរវង្សរបស់ទ្រង់ (សូមមើលការពន្យល់ ២សយ ៧:១–២៩) គឺស្ថិតស្ថេរជាដរាប (សូមមើល ខ.២៨–២៩) និងគ្មានលក្ខខណ្ឌអ្វីទាំងអស់ ទោះបីជាកូនចៅនៃជំនួរវង្សរបស់ទ្រង់មិនស្មោះត្រង់ចំពោះព្រះអម្ចាស់ក៏ដោយ ក៏ព្រះអម្ចាស់ដាក់ទោសតែគេម្នាក់ប៉ុណ្ណោះ ។

**៨៩:៣៨–៤៥** នៅក្នុងខទាំងនេះ ពណ៌នាពីការដែលព្រះអម្ចាស់ទ្រង់បានបោះបង់ចោលបុត្រានៃស្តេចដាវីឌជាបណ្តោះអាសន្ន និងផលវិបាកដ៏គួរឱ្យភ័យខ្លាច ជាហេតុធ្វើឱ្យរាល់ទាំងអស់នៃសេចក្ដីសញ្ញាត្រូវខូចប្រយោជន៍ (សូមមើល ខ.១៩–២៩) ។ សូមធ្វើការប្រៀបធៀបទំនុកដំកើងក្នុងជំពូកនេះជាមួយ ទដ ១៨ ដែលនិយាយពីការលើកដំកើងនិងបំពេញសេចក្ដីអំណរដល់អ្នកដែលយំសោក ។

**៨៩:៤៦–៥១** នៅក្នុងខទាំងនេះ គឺជាសេចក្ដីអធិស្ឋានដែលអ្នកនិពន្ធបានអំពាវនាវដល់ព្រះ ជំនួសឱ្យការនិយាយពីសេចក្ដីស្មោះត្រង់របស់ព្រះយេហូវ៉ាចំពោះសេចក្ដីសញ្ញា ដែលទ្រង់បានតាំងជាមួយស្តេចដាវីឌ ។ ការនេះបង្ហាញ សូម្បីតែនៅក្នុងយុគសម័យកាលដ៏ខ្មៅងងឹតនាពេលដែលរស់នៅ ក៏គាត់នៅមានសេចក្ដីសង្ឃឹមលើព្រះយេហូវ៉ាដែរ ។

**៨៩:៤៦** *តើដល់កាលណា...* សូមមើលការពន្យល់ ៦:៣ ។ *សេចក្ដីក្រោធ* សូមមើលការពន្យល់ ២:៥ ។

**៨៩:៤៧** *អាយុទូលបង្គំ ដែលខ្លីម្ល៉េះ* សូមមើល ៣៧:២០ ៣៩:៤–៦ និងការពន្យល់ ។ ដោយសារអ្នកនិពន្ធបានយល់ថា ជីវិតរបស់មនុស្សគឺខ្លីណាស់ ដូច្នេះហើយ ទើបធ្វើឱ្យគាត់បានអំពាវនាវដល់ព្រះអម្ចាស់ជាបន្ទាន់ ។ *ឥតប្រយោជន៍* នៅក្នុងឃ្លានេះចង់និយាយថា ដោយសារតែអំណាច និងកម្លាំងរបស់មនុស្សមានដែនកំណត់ហើយត្រូវតែស្លាប់ នោះពួកគេបានពឹងលើព្រះអម្ចាស់ ក្នុងគ្រាដែលគេរស់នៅលើផែនដីនេះ (មើល ៦០:១១ ៩០:៥–៦ និងការពន្យល់ ១០៨:១២ ១២៧:១–២ និងយប ៧:១–៣ សស ១:២ និងការពន្យល់) ។

**៨៩:៤៩** *អស់ទាំងសេចក្ដីសប្បុរស ដែលទ្រង់ប្រោសកាលពីដើម* នៅឃ្លានេះ គឺនិយាយសំដៅលើព្រះគុណដែលនិយាយនៅក្នុង ខ.១ ។

**៨៩:៥០** *នឹកចាំ* សូមមើល ខ.៤៧ ។

ហើយពីទូលបង្គំទ្រាំរងសេចក្តីដំនៀលរបស់បណ្តាជន
ទាំងឡាយនៅក្នុងទ្រូងផង
៥១ឱព្រះយេហូវ៉ាអើយពួកខ្មាំងបានយកសេចក្តីដំនៀលនោះ
ឯងមកត្មះតិះដៀលដល់ទូលបង្គំដែរ
គឺគេបានត្មះតិះដៀលដល់អស់ទាំងជំហាននៃអ្នកដែលទ្រង់
បានចាក់ប្រេងតាំងឱ្យ[យ] ។
៥២សូមឱ្យព្រះយេហូវ៉ាបានប្រកបដោយព្រះពរ
នៅអស់កល្បជានិច្ច អាម៉ែន ហើយអាម៉ែន[ង] ។

**៨៩:៥១** យ ទដ ៧៤:១០
**៨៩:៥២** ង ទដ ៤១:១៣ ៧២:១៩
**៩០:១** ក ចទ ៣៣:២៧ អភ ២:២២ វវ ២១:៣

ប៉ែកទី៤
សេចក្តីអធិស្ឋានរបស់ម៉ូសេ ជាអ្នកសំណប់របស់ព្រះ ។
**៩០** ឱព្រះអម្ចាស់អើយ ទ្រង់បានធ្វើជាទីអាស្រ័យនៅ[ក]នៃ
យើងខ្ញុំនៅអស់ទាំងដំណាតមក
២គឺមុនដែលអស់ទាំងភ្នំបានកើតឡើង[ខ] ក្នុងកាលដែលទ្រង់
មិនទាន់បង្កើតផែនដីនឹងមនុស្សលោកនៅឡើយ
ចាប់តាំងពីអស់កល្ប រៀងទៅដល់អស់កល្បជានិច្ច[គ]

**៩០:២** ខ យប ១៥:៧ គ អស ៩:៦ ៥៧:១៥

**៨៩:៥២** នៅក្នុងខនេះ គឺជាបទចម្រៀងសរសើរដំកើងដ៏ខ្លី ដែលអ្នកនិពន្ធបានបញ្ចប់សេចក្តីនៅក្នុងប៉ែកទី៣នៃបទគម្ពីរទំនុកដំកើង (សូមមើលការពន្យល់ ៤១:១៣) ។

**ទដ ៩០–១០០** នៅក្នុងជំពូកទាំងនេះ គឺជាលំដាប់នៃទំនុកតម្កើងដែលមាន ១១ ជំពូក ដែលសេចក្តីអធិស្ឋានបានចាប់ផ្តើម និងបញ្ចប់ដោយឃ្លា"ទ្រង់បានធ្វើជាទីអាស្រ័យនៅនៃយើងខ្ញុំនៅអស់ទាំងដំណរតមក" (សូមមើល ៩០:១) និង"សេចក្តីស្មោះត្រង់របស់ទ្រង់ក៏នៅអស់ទាំងដំណមនុស្សតទៅ" (មើល ១០០:៥) ។ ផ្ទៃរឿងទាំងឡាយដែលបានពណ៌នាក្នុងទំនុកដំកើង ២ជំពូកដំបូងក្នុងប៉ែកនេះ(៩០–៩១) គឺមានទំនាក់ទំនងជាមួយគ្នា ។ ៣ជំពូកក្រោយមកទៀត(ជំពូក ៩២–៩៤) មានទម្រង់ជាត្រីវិនាដសាស្ត្រ ដែលមានតួរនាទីជាស្ពានចម្លងទៅឯផ្ទៃរឿងចុងក្រោយក្នុងប៉ែកនេះ (៩៥–៩៩) ។ ទំនុកដំកើង ជំពូក ៩៥ គឺជាជំពូក១ដែលស្ថិតនៅកណ្តាល ដែលបានធ្វើការពណ៌នាជាមុនពីទំនុកដំកើង៤បន្ទាប់ទៀត និងបានបន្ថែមពីការដាស់តឿនឱ្យអបអរសាទរចំពោះរាជរបស់ព្រះយេហូវ៉ា ដែលរំឭកឱ្យឃើញពីការទូន្មានរបស់លោកម៉ូសេក្នុងបទគម្ពីរ ចទ ៦:១៣–១៨ ។ ជាភស្តុតាងគឺអ្នកត្រួតពិនិត្យព្រះគម្ពីរគាត់មានបំណងចង់ឱ្យអ្នកអានទំនុកដំកើងក្នុងប៉ែកនេះ បានដឹងពីសម្លេងដែលម៉ូសេបានទូលអង្វរជំនួសពួកគេ (ទំនុកដំកើង ជំពូក ៩០) និងតាស់តឿនក្រើនរំឭក (ទដ ៩៥:៨–១១) ។ តាមរយៈការងារ (អ្នកដែលមានចំណែកគឺរាប់ទាំង អើរ៉ុន និង សាំយូអែល)ដែលពួកគេធ្វើឱ្យអ៊ីស្រាអែលទទួលបានពរមកពីព្រះ តាមរយៈព្រះយេហូវ៉ាដែលជាស្តេចដ៏ឆ្នើមរបស់ពួកគេ (សូមមើល ៩៩:៦–៨) ។

**ទដ៩០** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអធិស្ឋានទៅចំពោះព្រះអម្ចាស់ សូមឱ្យព្រះអង្គបានប្រោសមេត្តាដល់អ្នកបម្រើរបស់ទ្រង់ ដ្បិតអីគេបានស្គាល់ទ្រង់តាំងពីកំណើតមកថា ជាទីអាស្រ័យដ៏សុខសាន្តរបស់ពួកគេជារៀងរហូតមក(សូមមើល ខ.១ និង ៩១:៩) ហើយក៏ជាអ្នកដែលធ្លាប់ការឈឺចាប់ដោយព្រោះសេចក្តីក្រោធរបស់ទ្រង់ ដោយព្រោះតែអំពើបាបដែលគេបានប្រព្រឹត្ត និងកាត់ទោសដោយបណ្តាលឱ្យសេចក្តីស្លាប់បានកាត់បន្ថយអាយុជីវិតគាត់ក្នុងការរស់នៅ ។ អ្នកនិពន្ធក៏បានអំពាវនាវ និងអះអាងថា តាមរយៈការឈឺដែលគាត់មានរាល់យប់ នោះព្រះអង្គទ្រង់នឹងបង្រៀនពួកគេដោយគតិបណ្ឌិតដ៏ពិត(សូមមើល ខ.១២ និងការពន្យល់) ហើយកាលព្រឹកឡើងព្រះអម្ចាស់ទ្រង់ក៏បានប្រទានពរដល់ពួកគេស្មើៗគ្នា ដោយសេចក្តីសប្បុរសរបស់ទ្រង់ ដូច្នេះហើយសេចក្តីអំណរប្រហែលជានឹងបានប្រទានដល់គេ និងពួកកូនចៅរបស់គេ ហើយព្រះអង្គទ្រង់ក៏ប្រទានពរ និងចំរើនការងាររបស់ពួកគេដែរ ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ មានទំនាក់ទំនងជាច្រើនជាមួយ ទដ ៣៩ ។

ដូច្នេះជីវិតមនុស្សដែលពណ៌នានៅទីនេះ ប្រហែលមិនមែនមានតែភាពស្រងេះស្រងោចប៉ុណ្ណោះនោះទេ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បាននិយាយពីសេចក្តីអំណរ ដែលមានលក្ខខណ្ឌមួយគឺសេចក្តីអំណរនោះនឹងបានឱ្យដល់អ្នកណាដែល"នៅជាប់ក្នុងទីកំបាំង"នៃព្រះដ៏ខ្ពស់បំផុត (សូមមើលក្នុង ៩១:១) និងអ្នកដែល"យកព្រះដ៏ខ្ពស់បំផុតជាទីលំនៅ"(សូមមើលក្នុង ៩១:៩ និង ៩២:១៣) ។ ដើម្បីបំបែកព្រះគម្ពីរទំនុកដំកើងជំពូក៩០ឱ្យចេញពីបរិបទនេះគឺបំបែកមុខងារវាចេញពីចង្កោមនៃទំនុកដំកើងដែលមាននៅក្នុងប៉ែកនេះ ។ សូមមើលក្នុង ទដ ១០៣ ។

នៅក្នុងជំពូកនេះមានល្បះ២ដែលបានពណ៌នាពីស្ថានភាពរបស់ មនុស្សជាតិនៅគ្រាដែលព្រះយេហូវ៉ាទ្រង់មានសេចក្តីក្រោធចំពោះពួកគេ (សូមមើលក្នុងខ.៣–៦,៧–១០)ដោយបែងចែកជាគូៗ(ខ.១–២,១១–១២)ដែលដោយសារការជាប់ទាក់ទងទៅនឹងភាពផ្ទុយគ្នារបស់ពួកគេបានធ្វើឱ្យល្បះនេះដាច់ពីគ្នា (១).ព្រះយេហូវ៉ាទ្រង់គឺជាទីអាស្រ័យនៃយើងខ្ញុំនៅអស់ទាំងដំណរតមក (ខ.១) ពេលនេះទ្រង់បានបណ្តាលឱ្យយើងឃើញពីអំណាចរបស់ទ្រង់ក្នុងគ្រាដែលព្រះអង្គទ្រង់កើតមានសេចក្តីខ្ញាល់ (ខ.៧) (២).ព្រះយេហូវ៉ាទ្រង់ជាព្រះដែលគង់នៅមុនអ្វីៗទាំងអស់ (ខ.២) ក្នុងពេលដែលមនុស្សមានជីវិតដ៏ខ្លីប៉ុណ្ណោះ(ខ.១២) ។

**៩០ ត្រង់ចំណងជើង** *សេចក្តីអធិស្ឋាន* សូមមើលការពន្យល់ ១៧ ត្រង់ចំណងជើង ។ *ម៉ូសេ* តាមទំនៀមទំលាប់គេគិតថា ម៉ូសេជាអ្នកសរសេរបទគម្ពីរទំនុកដំកើងក្នុងជំពូកនេះ ពីព្រោះ (១).នៅក្នុងជំពូកនេះមានប្រើភាសាដែលប្រើក្នុង ចទ ៣២–៣៣ (២).ការទូលអង្វរនៅទីនេះ ដូចគ្នានឹងការទូលអង្វរនេះចេញពីបបូរមាត់របស់លោកម៉ូសេ ដែលជាអ្នកអង្វរ ដ៏ឆ្នើមរបស់ពួកអ៊ីស្រាអែល (សូមមើល នក ៣២:១១–១៣ ៣៤:៩ ជន ១៤:១៣–១៩ ចទ ៩:២៥–២៩ ទដ ១០៦:២៣ យរ ១៥:១ និង ទដ ៩៩:៦) (៣).នៅកន្លែងផ្សេងទៀត មានលោកម៉ូសេម្នាក់ប៉ុណ្ណោះ ដែលសុំព្រះអម្ចាស់ដោយផ្ទាល់ដែលអាច"បន្ទន់ចិត្ត"ព្រះអម្ចាស់ក្នុងគ្រាដែលទ្រង់ខ្ញាល់ចំពោះពួកអ៊ីស្រាអែល (សូមមើល ខ.១៣ និង នក ៣២:១២) ។ *អ្នកសំណប់របស់ព្រះ* ឃ្លានេះនៅក្នុងសញ្ញាចាស់គឺនិយាយសំដៅលើហោរា (សូមមើលការពន្យល់ ១សយ ២:២៧) ហើយនិងលោកម៉ូសេផងដែរ (សូមមើល យស ១៤:៦) ។

**៩០:១** *ទីអាស្រ័យ* សូមមើល ៩១:៩ ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរឃ្លានេះមានន័យថា "ជាទីលំនៅ"(សូមមើល ៧១:៣) ។ ឃ្លាដែលប្រើនៅទីនេះ និងក្នុង ៩១:៩ គឺមានន័យខុសពី "ផ្ទះ"ឬ "ទីជំរកដ៏សុខសាន្ត" ។

នោះគឺទ្រង់ហើយជាព្រះ[ឃ]
[៣]ទ្រង់ធ្វើឱ្យមនុស្សត្រឡប់ទៅជាធូលីដីវិញ ដោយបន្ទូលថា
អស់ទាំងមនុស្សជាតិអើយចូរត្រឡប់វិលទៅវិញចុះ[ង]
[៤]ដ្បិតនៅព្រះនេត្រទ្រង់ នោះ១ពាន់ឆ្នាំរាប់ដូចជាថ្ងៃម្សិល
ដែលកន្លងហួសទៅហើយ ក៏ដូចជាយាម១ក្នុងវេលាយប់
ប៉ុណ្ណោះ[ច]
[៥]ទ្រង់កៀរយកគេទៅ[ឆ] ដូចជាទឹកជន់ ដូចជាដេកលក់មួយ
ស្របក់ប៉ុណ្ណោះ
នៅពេលព្រឹកគេធៀបដូចជាស្មៅដែលលាស់ឡើង
[៦]គឺនៅពេលព្រឹកវារីកផ្កា
ហើយលាស់ឡើងដល់ល្ងាចគេត្រូវច្រូត កាត់ទៅ
ហើយក៏ក្រៀមស្វិតវិញ[ជ]
[៧]ដ្បិតយើងខ្ញុំត្រូវវិនាសទៅដោយសេចក្តីខ្ញាល់របស់ទ្រង់
ហើយសេចក្តីក្រោធរបស់ទ្រង់ក៏បំភ័យយើងខ្ញុំ
[៨]ទ្រង់បានដាក់អស់ទាំងអំពើទុច្ចរិតរបស់យើងខ្ញុំនៅចំពោះ
ទ្រង់ ព្រមទាំងអំពើបាប[ឈ]ដែលយើងខ្ញុំប្រព្រឹត្តដោយលាក់
កំបាំងឱ្យនៅក្នុងពន្លឺនៃព្រះភក្ត្រទ្រង់ផង[ញ]
[៩]ដ្បិតអស់ទាំងថ្ងៃអាយុរបស់យើងខ្ញុំបានកន្លងបាត់ទៅដោយ
សេចក្តីក្រោធនៃទ្រង់ យើងខ្ញុំបង្ហើយអាយុយើងខ្ញុំដូចជា
សូរថ្ងូរ[ដ]
[១០]កំណត់អាយុនៃយើងខ្ញុំ គឺបានត្រឹម៧០ឆ្នាំទេ[ឋ]
ឬបើមានកំឡាំងច្រើននោះបានដល់៨០ឆ្នាំប៉ុណ្ណោះ[ឌ]
គង់តែអ្វីៗដែលជាទីអួតក្នុងឆ្នាំទាំងនោះសុទ្ធតែជាការ
នឿយលំបាក និងសេចក្តីទុក្ខព្រួយទទេ[ឍ]
ដ្បិតអាយុយើងខ្ញុំឆាប់កន្លងទៅហើយ
យើងខ្ញុំហើរទៅបាត់[ណ]
[១១]តើមានអ្នកណាដែលស្គាល់អំណាចនៃសេចក្តីខ្ញាល់នឹង
សេចក្តីក្រោធ[ត]របស់ទ្រង់ តាមដែលគួរកោតខ្លាចដល់ទ្រង់
នោះ[ថ]
[១២]ដូច្នេះ សូមបង្រៀនឱ្យយើងខ្ញុំចេះកំណត់រាប់ថ្ងៃ[ទ]អាយុនៃ
យើងខ្ញុំ ដើម្បីឱ្យយើងខ្ញុំមានចិត្តខ្មីឃ្មាត ឱ្យបានសតិបញ្ញា[ធ]
[១៣]ឱព្រះយេហូវ៉ាអើយ សូមវិលមកវិញ តើដល់កាលណា[ន]
ទៅ សូមសំរាលព្រះហឫទ័យ ចំពោះពួកអ្នកបំរើទ្រង់ផង[ប]
[១៤]ឱសូមចំអែត[ផ]យើងខ្ញុំ ដោយសេចក្តីសប្បុរស[ព]នៃទ្រង់នៅ
ពេលព្រឹកដើម្បីឱ្យយើងខ្ញុំបានរីករាយ[ភ]ឡើងហើយមាន

**៩០:២** ឃ លប ២១:៣៣ យប ១០:៥ ទដ ១០២:២៤-២៧ សភ ៨:២៣-២៦ **៩០:៣** ង លប ២:៧ យប ៧:២១ ៣៤:១៥ ១កថ ១៥:៤៧ **៩០:៤** ច យប ១០:៥ ២ពត ៣:៨ **៩០:៥** ឆ លប ១៩:១៥ **៩០:៦** ជ អស ៤០:៦-៨ មថ ៦:៣០ យក ១:១០ **៩០:៨** ឈ ទដ ១៩:១២ ២កថ ៤:២ អភ ៥:១២ ញ ហព ៤:១៣ **៩០:៩** ដ ទដ ៧៨:៣៣ **៩០:១០** ឋ អស ២៣:១៥,១៧ យរ ២៥:១១ ឌ ២សយ ១៩:៣៥ ឍ យប ៥:៧ ណ យប ២០:៨ ៣៤:១៥ ត ទដ ៧:១១ ថ ទដ ៧៦:៧ **៩០:១២** ទ ទដ ៣៩:៤ ១៣៩:១៦ សភ ១៦:៩ ២០:២៤ ធ ចទ ៣២:២៩ **៩០:១៣** ន ទដ ៦:៣ ប ចទ ៣២:៣៦ **៩០:១៤** ផ ទដ ១០៣:៥ ១០៧:៩ ១៤៥:១៦,១៩ ព ទដ ៧៧:៨ ១៤៣:៨ ភ ទដ ៥:១១

**៩០:៣-៦** នៅក្នុងខទាំងនេះចង់និយាយថា ជីវិតរបស់មនុស្ស គឺកើតមកក៏ត្រូវតែស្លាប់វិញដែរ ពីព្រោះវាគឺជាការជំនុំជម្រះរបស់ព្រះ "ជាធូលីដី . . . ជាធូលីដីវិញ" (សូមមើល លប ៣:១៩) ។

**៩០:៤-៥** *ដ្បិត . . . ទ្រង់* ឃ្លានេះជូនកាលគេប្រើ "សូម្បីតែ . . . ទ្រង់" ។ នៅក្នុងឃ្លានេះចង់និយាយថា សូម្បីតែ១០០០ឆ្នាំមែន តែវាខ្លីដូចជាមួយយាមយប់អញ្ចឹង ។ ព្រះអម្ចាស់ទ្រង់បានកាត់ជីវិតមនុស្សយ៉ាងនោះដែរ ការនេះធៀបបានទៅផ្កាស្មៅដែលទើបនឹងដុះឡើងមុនព្រឹកព្រលឹម ក៏ត្រូវរុះរោយទៅវិញមុនថ្ងៃលិចដូច្នោះដែរ ។

**៩០:៤** *យាម១ក្នុងវេលាយប់* សូមមើលការពន្យល់ ពច ៧:១៩ ។

**៩០:៥-៦** ខ្សែជីវិតដ៏ខ្លីរបស់មនុស្ស ជាញឹកញាប់តែងតែមានក្នុងគំនិតអ្នកនិពន្ធ (សូមមើល ៣៧:២,២០,៣៦ ៣៩:៥,១១ ៦២:៩ ៧៨:៣៩ ៨៩:៤៧ ១០២:៣,១១ ១០៣:១៥-១៦ ១០៩:២៣ ១៤៤:៤ យប ៨:៩ ១៤:១-២ សស ៦:១២ អស ៤០:៦-៨ យក ១:១០-១១ ១ពត ១:២៤-២៥) ។

**៩០:៧-១០** នៅក្នុងខទាំងនេះចង់និយាយថា ទោះបីជាជីវិតមនុស្សខ្លី និងមានទុក្ខព្រួយកង្វល់ក៏ដោយ ក៏ព្រះអម្ចាស់ទ្រង់បានហៅអស់ទាំងអ្នកមានបាបមក ដើម្បីឱ្យគេបានដឹងពីកំហឹងដ៏សុចរិតរបស់ទ្រង់ ។

**៩០:៧** *សេចក្តីខ្ញាល់ . . . បំភ័យយើងខ្ញុំ* សូមមើល ខ.៩,១១ និងការពន្យល់ ២:៥ ។

**៩០:៨** *ពន្លឺនៃព្រះភក្ត្រទ្រង់* គឺជាពន្លឺបរិសុទ្ធរបស់ព្រះដែលសម្រាប់បំភ្លឺសេចក្តីងងឹតនៃចិត្ត និងសម្តែងឱ្យឃើញអស់ទាំងការអាថ៌កំបាំង ។

**៩០:១០** *៨០ឆ្នាំ* សូមមើលការពន្យល់ អម ១:៣) ។ *ជាទីអួតអាង* នៅក្នុងភាសាហេព្រើរពាក្យនេះមានការខុសគ្នា ។ បើសិនជាអាននៅសេចក្តីពន្យល់ក្នុងព្រះគម្ពីរគេឃើញថាមានន័យ២យ៉ាងគឺ (១).និយាយសំដៅលើសម័យកាលដ៏ល្អបំផុតរបស់ពួកគេ (២).និយាយសំដៅលើអ្វីដែលគេមានហើយគិតថាល្អបំផុតក្នុងសម័យកាលរបស់ពួកគេ ប៉ុន្តែការទាំងអស់ ដែលគេមានសុទ្ធតែជាមូលហេតុដែលបណ្តាលឱ្យមានទុក្ខលំបាក និងសោយសោក ។

**៩០:១១-១២** *តើមានអ្នកណាដែលស្គាល់ . . . សូមបង្រៀនឱ្យយើងខ្ញុំ* គ្មាននរណាម្នាក់អាចដឹង និងវាស់ពីសេចក្តីកំហឹងរបស់ព្រះបានឡើយ ប៉ុន្តែមនុស្សគ្រប់គ្នាត្រូវតែរង្វាស់នៃជីវិតដ៏ខ្លីរបស់គេ ឬប្រព្រឹត្តការអាក្រក់ដោយមិនបានគិតពីសិលធម៌ ឬគុណនេយ្យភាពរបស់ពួកគេចំពោះព្រះ (សូមមើល ទដ ជំពូក ១០ ៣០:៦ ៤៩ ៧៣:៤-១២ និង ចទ ចំពូក៨) ។

**៩០:១១** *តាមដែលគួរកោតខ្លាច* សូមមើលការពន្យល់ លប ២០:១១ ។

**៩០:១២** *ដើម្បីឱ្យយើងខ្ញុំមានចិត្តខ្មីឃ្មាត ឱ្យបានសតិបញ្ញា* ព្រះយេហូវ៉ា ទ្រង់នឹងវាយផ្ចាលអ្នកអួតអាង និងអ្នកមានបាបដើម្បីឱ្យគេបានបន្ទាបខ្លួន ហើយព្រះអម្ចាស់ទ្រង់ក៏បង្រៀនគេដោយសតិបញ្ញាដ៏ពិតរបស់ទ្រង់ (សូមមើល ទដ ជំពូក ៣៩ ៩៤:១២ សភ ៣:១-១២ ហព ១២:៧-១១ ហើយធៀបជា មួយ គដ ៩២:៦-៧ ៩៤:៨-១០) ។

**៩០:១៣** *សូមវិលមកវិញ* នៅភាសាអក្សរសាស្ត្រគឺ "សូមត្រឡប់មក" (សូមធៀបជាមួយ ខ.៣) ។ *តើដល់កាលណា* សូមមើលការពន្យល់ ៦:៣ (សូមមើលសេចក្តីផ្តើម ត្រង់ចំណុច វិជ្ជាព្រះ) ។

**៩០:១៤** *នៅពេលព្រឹក* នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យសេចក្តីសប្បុរសរបស់ទ្រង់នៅព្រឹកព្រលឹមបានចំអែកចំណង់របស់យើង ពីព្រោះពេលយប់ គឺជាសេចក្តីកំហឹងរបស់ទ្រង់ (សូមមើលសេចក្តីផ្តើម ទដ ៥៧) ។ ចម្លើយចុងក្រោយចំពោះសេចក្តីអធិស្ឋាននេះគឺធ្វើឱ្យពួកគេរស់ឡើងវិញ (សូមមើល

សេចក្ដីអំណររហូតដល់អស់១ជីវិត[ម]
១៥សូមឱ្យយើងខ្ញុំបានថ្ងៃអរសប្បាយ
ឱ្យស្មើនឹងថ្ងៃដែលទ្រង់បានធ្វើទុក្ខដល់យើងខ្ញុំហើយ
គឺឱ្យស្មើនឹងអស់ទាំងឆ្នាំ
ដែលយើងខ្ញុំទ្រាំរងសេចក្ដីអាក្រក់នោះ
១៦សូមឱ្យកិច្ចការរបស់ទ្រង់សំដែងមកច្បាស់ដល់ពួកអ្នក
បំរើទ្រង់ ហើយឱ្យឃើញសិរីល្អនៃទ្រង់ស្ថិតលើកូនចៅគេ
ផង[យ]
១៧សូមឱ្យព្រះគុណនៃព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំបាន
សណ្ឋិតលើយើងខ្ញុំ ហើយតាំងការនៃដៃយើងខ្ញុំ ឱ្យខ្ជាប់
ខ្ជួនឡើង អើ សូមតាំងការនៃដៃយើងខ្ញុំឱ្យស្ថិតស្ថេរចុះ[រ] ។

**៩១** អ្នកណាដែលនៅជាប់ក្នុងទីកំបាំង[ក]នៃព្រះដ៏ខ្ពស់បំផុត
នោះនឹងបានជ្រកនៅក្រោមម្លប់[ខ]នៃព្រះដ៏មានគ្រប់ព្រះ
ចេស្ដា ។
២ឯទូលបង្គំ នឹងពោលពីព្រះយេហូវ៉ាថា ទ្រង់ជាទីពឹង
ពំនាក់[គ] ជាបន្ទាយនៃទូលបង្គំ[ឃ]គឺជាព្រះនៃទូលបង្គំហើយ
ទូលបង្គំទុកចិត្តនឹងទ្រង់ ។
៣ពិតប្រាកដជាទ្រង់នឹងជួយឱ្យឯងរួចពីលប់របស់នាយ
ព្រាន[ង] ហើយពីសេចក្ដីវេទនាដែលនាំឱ្យអន្តរាយ[ច]
៤ទ្រង់នឹងក្រុងឯងដោយស្លាបទ្រង់ ហើយឯងនឹងជ្រកនៅ
ក្រោមចំអែងស្លាបរបស់ទ្រង់[ឆ] សេចក្ដីពិតរបស់ទ្រង់ជា
ខែល[ជ] ហើយជាអាវក្រោះ
៥ឯងនឹងមិនភ័យខ្លាច[ឈ]អ្វីឡើយ ទោះទាំងសេចក្ដីខ្មែងខ្លាច
នៅពេលយប់ ឬព្រួយដែលហើរនៅពេលថ្ងៃ
៦ឬសេចក្ដីវេទនាដែលតែងមាននៅក្នុងទីងងឹត
ឬសេចក្ដីហិនវិនាសដែលបំផ្លាញនៅពេលថ្ងៃត្រង់ផង
៧នឹងមានមនុស្ស១ពាន់នាក់ដួលស្លាប់នៅក្បែរឯង
ហើយ១ម៉ឺននាក់នៅខាងដៃស្ដាំឯងដែរ

**៩០:១៤** ម ទដ ៣១:៧ **៩០:១៦** យ ទដ ៤៤:១ ហាព ៣:២ **៩០:១៧** រ អស ២៦:១២ **៩១:១** ក នក ៣៣:២២ ខ ទដ ៦៣:៧ អស ៤៩:២ បទ ៤:២០ **៩១:២** គ ខ.៩ ២សយ ២២:៣ ទដ ៩:៩ ឃ ២សយ ២២:២ **៩១:៣** ង ទដ ១២៤:៧ សភ ៦:៥ ច ១ពវ ៨:៣៧ **៩១:៤** ឆ នរ ២:១២ ទដ ១៧:៨ ជ ចទ ៣២:១០ ទដ ៣៥:២ អស ២៧:៣ ៣១:៥ សក ១២:៨ **៩១:៥** ឈ យប ៥:២១

រម ៥:២-៥ ៨:១៨ ២កថ ៤:១៦-១៨) ។ *សេចក្ដីអំណររហូត* សូមមើលការពន្យល់ ៦:៤ ។

**៩០:១៦** *កិច្ចការ . . . សិរីល្អ* នៅក្នុងឃ្លានេះគឺចង់និយាយថា កិច្ចការរបស់ទ្រង់គឺល្អប្រពៃ (សូមមើល ១១១:៣ និងការពន្យល់ ៣:៧) ។ សូមមើលពីការល្អនៃកិច្ចការរបស់ទ្រង់ក្នុង ទដ ជំពូក ១១១ ។ *កូនចៅ គេ* នៅក្នុងឃ្លានេះអ្នកនិពន្ធសូមឱ្យព្រះអង្គសម្ដែងសិរីល្អនៃទ្រង់ ដល់កូនចៅគេ ដូចគ្នានឹងទ្រង់សម្ដែងដល់ពួកកូនចៅគេកាលពីគ្រាមុន (សូមមើល ខ.១) ។

**៩០:១៧** *ព្រះគុណ* សូមមើល ២៧:៤ និងការពន្យល់ ។ *តាំង* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់មានន័យថា គឺមានតែទ្រង់ម្នាក់ប៉ុណ្ណោះដែលជាអ្នកផ្ដល់សេចក្ដីសុខសាន្តដល់យើងទាំងអស់គ្នានៅលើផែនដីនេះ (មើល ខ.១) ដូច្នេះហើយព្រះអម្ចាស់ទ្រង់ ក៏បានធ្វើឱ្យការងាររបស់យើងចម្រើនឡើងស្ថិតស្ថេរជាដរាប ទោះបីជាយើងគ្រាន់តែរស់នៅជាបណ្ដោះអាសន្នក៏ដោយ ។

**ទដ ៩១** នៅក្នុងជំពូកនេះ គឺជាទីបន្ទាល់នៃសេចក្ដីសុខសាន្តនៃអ្នកដែលទុកចិត្តចំពោះទ្រង់។ជំពូកនេះមានទីតាំងស្ថិតនៅក្បែរទំនុកដំកើងជំពូក៩០ ដែលបានពណ៌នាពីសេចក្ដីសង្វៃករបស់មនុស្សជាតិ (សូមមើលក្នុង សេចក្ដីផ្ដើមជំពូកនោះ) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះប្រហែលសរសេរឡើងដោយម្នាក់ដែលបម្រើការងារក្នុងព្រះវិហារ (ជាសង្ឃ ឬជាលេវី) ក្នុងនាមជាអ្នកនាំព្រះបន្ទូលពីព្រះដល់បណ្ដាជនដែលមកថ្វាយបង្គំ ។ ពាក្យថា "ឯង" ដែលនិយាយនៅក្នុង ខ.១-១៣ គឺសំដៅលើអ្នកដែល"យកព្រះដ៏ខ្ពស់បំផុតជាទីលំនៅ" (ខ.៩ ៩០:១) ហើយវិញ្ញាអាក្រក់បានយក ខ.១១-១២ និយាយទៅកាន់ព្រះយេស៊ូវ (សូមមើល មថ ៤:៦ លក ៤:១០-១១) ។

លក្ខណៈសំណង់ប្រយោគក្នុងជំពូកនេះ អ្នកនិពន្ធបានបែងចែកជា២ផ្នែកស្មើៗគ្នាដែលក្នុង១ផ្នែកមាន៨ខ ហើយនៅពាក់កណ្ដាលផ្នែកទី២មានចំណាប់ចុងចួន (សូមមើល ខ.៩-១០)ដែលដូចគ្នានឹងផ្ទៃរឿងដែលនិយាយនៅក្នុ ង១-២ ។ ពាក់កណ្ដាលផ្នែកទី១ និយាយពីសេចក្ដីសុខសាន្តរបស់អ្នកដែលស្រឡាញ់ព្រះ ដោយឱ្យគេរួចពីការឈ្លានពានទាំង៤ (មើល ខ.៥-៦) ទោះបីជាមនុស្ស១ពាន់នាក់ដួលចុះក៏ដោយ (ខ.៧) ។ នៅក្នុងផ្នែកទី២និយាយពីការធានាជ័យជម្នះ ដោយព្រះអង្គទ្រង់នឹងឱ្យគេទទួលជ័យជម្នះលើខ្មាំងសត្រូវ៤ប្រភេទ (ច.១៣) ។

**៩១:១** *ទីកំបាំង* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើព្រះវិហារ (ដូចនិយាយនៅក្នុង ២៧:៥ ៣១:២០ និងក្នុង ២៣:៦ ២៧:៤) ដ្បិតអីព្រះវិហារគឺជាដ៏មានសេចក្ដីសុខសាន្តដែលអ្នកស្រឡាញ់ទ្រង់បានស្វែងរកដើម្បីជ្រកក្រោមចំអែងស្លាបរបស់ទ្រង់ (សូមមើល ខ.៤ ៦១:៤) ។ *ដ៏ខ្ពស់បំផុត* សូមមើលក្នុងខ.៩ និងការពន្យល់ លប ១៤:១៩ ។ *ម្លប់* សូមមើលការពន្យល់ក្នុង ១៧:៨ ។ *ដ៏មានគ្រប់ព្រះចេស្ដា* សូមមើលការពន្យល់ លប ១៧:១ ។

**៩១:៣** *លប់របស់នាយព្រាន* នៅក្នុងឃ្លានេះគឺជាពាក្យប្រៀបប្រដូចដែលអ្នកនិពន្ធនិយាយពីគ្រោះថ្នាក់ដែលបង្ករឡើងដោយពួកខ្មាំងសត្រូវ (មើល ១២៤:៧ និងការពន្យល់ ៩:១៥) ។ *អន្តរាយ* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើគ្រោះថ្នាក់ដែលបណ្ដាលមកពីជម្ងឺ ។ ការបៀតបៀន ២ ប្រភេទទៀតមាននិយាយនៅក្នុង ខ.៥-៦ ។

**៩១:៤** *ដោយស្លាបទ្រង់* សូមមើលការពន្យល់ ១៧:៨ ។

**៩១:៥** *ភ័យខ្លាច* គឺដូចមាននិយាយនៅ ៦៤:១ ។ នៅកន្លែងនេះគឺនិយាយសំដៅលើការបៀតបៀនរបស់ពួកខ្មាំងសត្រូវ ។ ពាក្យនេះមានន័យដូចគ្នានឹងពាក្យថា"ធ្នូ" ។ ឃ្លាទាំងនេះនិយាយសំដៅលើការបៀតបៀនឈ្លានពានក្នុងពេលសង្គ្រាម ដែលអ្នកនិពន្ធចង់ពណ៌នាពីសេចក្ដី "ភ័យខ្លាច" និងសេចក្ដី"វេទនា"(សូមមើល ខ.៦) ក៏ជាការពពណ៌នាដែលនិយាយសំដៅលើជំងឺដែលតែងតែព្យាបាទមនុស្ស ។ *នៅពេលយប់ . . . នៅពេលថ្ងៃ* នៅក្នុងឃ្លានេះចង់និយាយថា ទោះបីជាមានការបៀតបៀនដែលនឹងមក នៅវេលាណាមួយទោះបីជាយប់ឬថ្ងៃ នោះព្រះទ្រង់នឹងការពារឯងជានិច្ច ។ ពេលវេលានៃការបៀតបៀន មិនច្បាស់លាស់ឡើយ(សូមមើល ខ.៦) ។

**៩១:៧** *១ពាន់នាក់* នៅក្នុងកំណាព្យហេព្រើរចំនួន១0000 និង ១000 គឺជា

តែសេចក្ដីនោះនឹងមិនមកជិតឯងឡើយ
៨ ឯងនឹងបានក្រឡេកឃើញការតបស្នងដល់ពួកមនុស្ស
អាក្រក់ ដោយភ្នែកតែប៉ុណ្ណោះទេ[ញ]
៩ ពីព្រោះឯងបានថា ព្រះយេហូវ៉ាជាទីពឹងជ្រកនៃឯង
គឺបានយកព្រះដ៏ខ្ពស់បំផុតជាទីលំនៅរបស់ឯង
១០ យ៉ាងនោះ នឹងគ្មានសេចក្ដីអាក្រក់[ដ]ណាកើតឡើងដល់ឯង
ឡើយ ក៏គ្មានវេទនាណាមកជិតទីលំនៅរបស់ឯងដែរ
១១ ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតា[ឋ]របស់ទ្រង់ពីដំណើរ
ឯង ឱ្យបានថែរក្សាឯង ក្នុងគ្រប់ទាំងផ្លូវរបស់ឯង[ឌ]
១២ ទេវតាទាំងនោះនឹងទ្រឯងដោយដៃក្រែងជើងឯងទង្គិច
នឹងថ្ម[ឍ]
១៣ ឯងនឹងជាន់លើទាំងសត្វសិង្ហ និងពស់ហនុមានផង
ឯសិង្ហស្ទាវ និងនាគនោះឯងនឹងអាចជាន់ឈ្លីដោយជើង
បាន[ណ] ។
១៤ ដោយព្រោះវាបានយកអញជាទីស្រឡាញ់
នោះអញនឹងជួយឱ្យរួច អញនឹងតាំងឡើងយ៉ាងខ្ពស់
ពីព្រោះវាបានស្គាល់ឈ្មោះអញ
១៥ វានឹងអំពាវនាវដល់អញ ហើយអញនឹងឆ្លើយតប
អញនឹងនៅជាមួយនឹងវាក្នុងគ្រាទុក្ខលំបាក
ក៏នឹងដោះឱ្យរួចចេញ ហើយនិងលើកមុខឱ្យ[ត]
១៦ អញនឹងឱ្យវាស្កប់ចិត្តដោយអាយុយឺនវែង[ថ]
ហើយនិងបង្ហាញឱ្យឃើញសេចក្ដីសង្គ្រោះរបស់អញ[ទ] ។

ទំនុកជាបទចំរៀងសំរាប់ថ្ងៃឈប់សំរាក ។
**៩២** នេះជាការល្អហើយ គឺដែលនឹងអរព្រះគុណដល់
ព្រះយេហូវ៉ា ហើយច្រៀងសរសើរ[ក]ដល់ព្រះនាម[ខ]នៃទ្រង់
ជាព្រះដ៏ខ្ពស់បំផុត[គ]
២ ព្រមទាំងសំដែងពីសេចក្ដីសប្បុរសនៃទ្រង់នៅពេលព្រឹក[ឃ]

**៩១:៨** ញ ទដ ៣៧:៣៤ ៥៨:១០ **៩១:១០** ដ សភ ១២:២១ **៩១:១១** ឋ លប ៣២:១ ហព ១:១៤ ឌ ទដ ៣៤:៧ **៩១:១២** ឍ មថ ៤:៦ លក ៤:១០–១១ **៩១:១៣** ណ ដយ ៦:២២ លក ១០:១៩ **៩១:១៥** ត ១សយ ២:៣០ យហ ១២:២៦ **៩១:១៦** ថ ចទ ៦:២ ទដ ២១:៤ ទ ទដ ៥០:២៣

**៩២:១** ក ទដ ២៧:៦ ខ ទដ ៩:២ ១៤៧:១ គ ទដ ១៣៥:៣ **៩២:២** ឃ ទដ ៥៥:១៧

ចំនួនដែលមានការប្រហាក់ប្រហែលគ្នា (សូមមើលការពន្យល់ ៩០:១០ ១សយ ១៨:៧ អម ១:៣) ។

**៩១:៩** *ទីលំនៅ* សូមមើល ៩០:១ និងការពន្យល់ ។

**៩១:១១–១២** នៅក្នុងបទគម្ពីរ មថ ៤:៦ លក ៤:១០–១១ សាតាំងបានដកស្រង់ព្រះបន្ទូលកន្លែងនេះដើម្បីល្បងព្រះយេស៊ូវគ្រីស្ទ ។

**៩១:១១** *ពួកទេវតារបស់ទ្រង់* សូមមើលការពន្យល់ ៣៤:៧ ។

**៩១:១២** *ទង្គិចនឹងថ្ម* គឺទង្គិចនឹងថ្មដែលនៅក្នុងស្រុកកាណាន (សូមមើល សភ ៣:២៣) ។

**៩១:១៣** *សត្វសិង្ហ . . . ពស់ស៊ីហុន . . . សិង្ហស្ទាវ. . . នាគ* ការនិយាយស្ទួនគ្នារវាង សិង្ហ និងពស់នៅក្នុងឃ្លានេះ គឺដូចគ្នានឹងការនិយាយស្ទួននៅក្នុង ខ.៥–៦ ដែរ ហើយឃ្លានេះគឺនិយាយសំដៅលើការព្យាបាទដ៏ពេញលេញនៅក្នុងថ្ងៃចុងក្រោយ (សូមមើល អម ៥:១៨) ។

**៩១:១៤–១៦** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានលើកពីទំនាយរបស់ហោរាមកថ្លែង (សូមមើលក្នុងសេចក្ដីផ្ដើម) ជាការគាំទ្រដល់បន្ទាល់របស់គាត់ ដោយគាត់បានធានាថា ពួកអ្នកដែលស្រឡាញ់ដល់ព្រះនឹងទទួលបានការស្អាងចិត្តដោយសេចក្ដីសន្យារបស់ទ្រង់ ចំពោះអ្នកណាដែលទុកចិត្តចំពោះព្រះអម្ចាស់ និងអ្នកណាដែលស្រឡាញ់ទ្រង់ដោយពិតត្រង់ ។

**៩១:១៤** *អញនឹងតាំង* ពាក្យនេះតាមភាសាអក្សរសាស្ត្រគឺ "អញនឹងលើកឡើងទៅឯទីខ្ពស់" ។ *ស្គាល់ឈ្មោះអញ* សូមមើល ៩:១០ "ស្គាល់ព្រះនាមទ្រង់" និងការពន្យល់ ។ *ឈ្មោះអញ* សូមមើលការពន្យល់ ៥:១១ ។

**៩១:១៥** *វានឹងអំពាវនាវដល់អញ ហើយអញនឹងឆ្លើយតប* សូមមើលការពន្យល់ ១១៨:៥ ។

**៩១:១៦** *អាយុយឺនយូរ* ឃ្លានេះបានឆ្លើយតបចំពោះ ទដ ៩០ ។

**ទដ៩២** នៅក្នុងជំពូកនេះ គឺជាការពណនាពីច្រៀងដោយអំណរចំពោះសេចក្ដីសុចរិតរបស់ព្រះ ។ នៅក្នុងជំពូកនេះ គឺជាទីបន្ទាល់នៃសេចក្ដីចំរើនរបស់មនុស្សសុចរិតដែលបាន "ដាំក្នុងដំណាក់នៃព្រះយេហូវ៉ា" (សូមមើល ខ.១៣) ។ ផ្ទៃរឿងក្នុងជំពូកនេះមានទំនាក់ទំនងយ៉ាងស្និទ្ធជាមួយផ្ទៃរឿងក្នុង ជំពូក ៩១ (សូមមើលសេចក្ដីផ្ដើមទំនុកដំកើងជំពូកនោះ)។ មានហេតុផលដែលគួរឱ្យជឿជាក់បាន គឺថាអ្នកត្រួតពិនិត្យព្រះគម្ពីរទំនុកដំកើងបានដាក់បញ្ចូលគ្នាជាមួយ ទដ ៩២–៩៤ ជាត្រីវនាដសាស្ត្រ ដែលមានតួរនាទីជាស្ពានចម្លងរវាងព្រះគម្ពីរទំនុកដំកើង ៩០–៩១ ហើយនិង ៩៥–៩៩ (សូមមើលសេចក្ដីផ្ដើម ទដ ៩៣,៩៤) ។ ជាពិសេសព្រះអម្ចាស់មានលេចឡើង៧ដងនៅក្នុងទំនុកដំកើងជំពូកនេះ ។ នៅក្នុង ខ.១០–១១ បានបង្ហាញថាអ្នកនិពន្ធប្រហែលជាស្ដេចម្នាក់របស់ពួកអ៊ីស្រាអែល ។

នៅក្នុង ខ.១–៣ និយាយពីការសរសើរដំកើង ហើយក្នុង ខ.៤–៥ និយាយពីមូលហេតុដែលត្រូវសរសើរតម្កើង ហើយពាក្យថា ("ទូលបង្គំ" "ទូលបង្គំ") នឹងមាននិយាយម្ដងទៀតនៅក្នុង ខ.១០–១១ ("ទូលបង្គំ" "ទូលបង្គំ" "ទូលបង្គំ" "ទូលបង្គំ") ។ នៅក្នុង ខ.១២–១៥ បានពណ៌នាពីសេចក្ដីសុខចម្រើនរបស់ពួកមនុស្សសុចរិត ។ នៅក្នុង ខ.៧ និង ខ.១៣ ក៏មានទំនាក់ទំនងជាមួយគ្នាដែរ ។

**៩២ ត្រង់ចំណងជើង** *បទចម្រៀង* សូមមើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង ។ *សំរាប់ថ្ងៃឈប់សំរាក* ពួកគេបានច្រៀងបទចម្រៀងនេះក្នុងពេលដែលពួកគេបានថ្វាយយញ្ញបូជា នៅពេលព្រឹកព្រលឹមក្នុងថ្ងៃឈប់សំរាក (ថ្ងៃធ្វើការក្នុង១សប្ដាហ៍មាន ថ្ងៃទី១ "ទដ ២៤" ថ្ងៃទី២"ទដ ៤៨" ថ្ងៃទី៣ "ទដ ៨២" ថ្ងៃទី៤ "ទដ ៩៤" ថ្ងៃទី៥ "ទដ ៨១" និងថ្ងៃទី៦"ទដ ៩៣") ។

**៩២:១–៣** នេះគឺជាសេចក្ដីផ្ដើមនៃបទចម្រៀងសរសើរតម្កើងដល់ព្រះ ។

**៩២:១** *ព្រះយេហូវ៉ា . . . ជាព្រះដ៏ខ្ពស់បំផុត* នៅក្នុងឃ្លានេះចង់បញ្ជាក់ថា ព្រះយេហូវ៉ា គឺជាព្រះដ៏ខ្ពស់បំផុត(មើល ៧:១៧ និងការពន្យល់ ៣:៧) ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។ *ខ្ពស់បំផុត* ឃ្លានេះមានទំនាក់ទំនងជាមួយ ទដ ៩១ (សូមមើល ទដ ៩១:១,៩) ។ សូមមើលការពន្យល់ លប ១៤:១៩ ដែលនិយាយពីព្រះនាមរបស់ព្រះ ។

**៩២:២** *សេចក្ដីសប្បុរស . . . សេចក្ដីស្មោះត្រង់* នៅក្នុងឃ្លានេះចង់បង្ហាញ

ហើយពីសេចក្តីស្មោះត្រង់របស់ទ្រង់រាល់តែយប់
៣ដោយប្រដាប់ភ្លេងមានខ្សែ១០ និងពិណ[ង]
ហើយដោយសូរចាប់ស៊ុងយ៉ាងរងំ[ច]
៤ដ្បិត ឱព្រះយេហូវ៉ាអើយ ទ្រង់បានឱ្យទូលបង្គំមានសេចក្តី
អំណរ ដោយកិច្ចការរបស់ទ្រង់ ទូលបង្គំនឹងបន្លឺឡើង
ដោយអំណរ[ឆ]ចំពោះការនៃព្រះហស្តទ្រង់[ជ]
៥ឱព្រះយេហូវ៉ាអើយ អស់ទាំងកិច្ចការរបស់ទ្រង់ធំណាស់
ហ្ន៎[ឈ] ឯអស់ទាំងព្រះដំរិះទ្រង់ក៏ជ្រៅណាស់ផង[ញ]
៦មនុស្សកំរោល[ដ]មិនដឹងទេ ហើយមនុស្សឥតបើគិតក៏មិន
យល់សេចក្តីនេះដែរ
៧វេលាណាដែលមនុស្សអាក្រក់ដុះដាលឡើងដូចជាស្មៅ
ហើយអស់អ្នកដែលប្រព្រឹត្តអំពើទុច្ចរិតលូតលាស់ឡើង
នោះគឺសំរាប់តែឱ្យគេត្រូវវិនាសទៅអស់កល្បជានិច្ច
ប៉ុណ្ណោះ[ឋ]
៨ប៉ុន្តែឯទ្រង់ ឱព្រះយេហូវ៉ាអើយទ្រង់ជាព្រះដ៏ខ្ពស់បំផុត
ដរាបដល់អស់កល្បរៀងទៅ
៩ដ្បិត ឱព្រះយេហូវ៉ាអើយ សូមទតមើលពួកខ្មាំងសត្រូវ
ទ្រង់[ឌ] មើល ពួកខ្មាំងសត្រូវទ្រង់ គេត្រូវវិនាសហើយ
អស់ពួកអ្នកដែលប្រព្រឹត្តអំពើទុច្ចរិតគេនឹងត្រូវខ្ចាត់ខ្ចាយ
ទៅ[ឍ]
១០តែទ្រង់បានដំកើងស្នែង[ណ]របស់ទូលបង្គំឡើង
ដូចជាស្នែងនៃគោព្រៃ[ត] ទូលបង្គំមានប្រេងថ្មី[ថ]ចាក់លាប
លើខ្លួនហើយ
១១ភ្នែកទូលបង្គំនឹងឃើញបំណងចិត្តកើតដល់ពួកខ្មាំង
ហើយត្រចៀកទូលបង្គំនឹងឮនិយាយពីការដែលកើតដល់
ពួកមនុស្សអាក្រក់ជាពួកអ្នកដែលលើកគ្នាឡើងទាស់នឹង
ទូលបង្គំ[ទ]
១២ឯមនុស្សសុចរិត គេនឹងលូតលាស់ឡើង[ធ]ដូចជាដើម
លម៉ើ ក៏នឹងធំឡើង ដូចជាដើមតាត្រៅនៅលើភ្នំល្បាណូន
ដែរ[ន]
១៣គេត្រូវដាំនៅក្នុងដំណាក់នៃព្រះយេហូវ៉ា
គេដុះដាលឡើងនៅក្នុងទីលានរបស់ព្រះនៃយើងខ្ញុំ[ប]
១៤កាលណាចាស់ហើយ នោះគេនឹងនៅតែកើតផល[ផ]
គេនឹងមានជ័រជាបរិបូរ ហើយនៅតែខៀវស្រស់
១៥ដើម្បីនឹងសំដែងឱ្យឃើញថា ព្រះយេហូវ៉ាទ្រង់ទៀង
ត្រង់ទ្រង់ជាថ្មដានៃខ្ញុំ

**៩២:៣** ង ទដ ៧១:២២ ច ១សយ ១០:៥ នហ ១២:២៧ ទដ ៣៣:២ ៨១:២ **៩២:៤** ឆ ទដ ៥:១១ ២៧:៦ ជ ទដ ៨:៦ ១១១:៧ ១៤៣:៥ **៩២:៥** ឈ យប ៣៦:២៤ វវ ១៥:៣ ញ ទដ ៤០:៥ ១៣៩:១៧ អស ២៨:២៩ ៣១:២ រម ១១:៣៣ **៩២:៦** ដ ទដ ៧៣:២២ **៩២:៧** ឋ ទដ ៣៧:២ **៩២:៩** ឌ ទដ ៤៥:៥ ឍ ទដ ៦៨:១ ៨៩:១០ **៩២:១០** ណ ទដ ៨៩:១៧ ត ទដ ២៩:៦ ថ ទដ ២៣:៥ **៩២:១១** ទ ទដ ៥៤:៧ ៩១:៨ **៩២:១២** ធ ទដ ៧២:៧ ន ទដ ១:៣ ៥២:៨ យរ ១៧:៨ ហព ១៤:៦ **៩២:១៣** ប ទដ ១៣៥:២ **៩២:១៤** ផ ទដ ១:៣ យហ ១៥:២

ថាព្រះយេហូវ៉ាទ្រង់សប្បុរស ហើយក៏ស្មោះត្រង់ (សូមមើលការពន្យល់ ៣៦:៥ និងការពន្យល់ ៣:៧) ។ *សេចក្តីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។ *នៅពេលព្រឹក . . . ពេលយប់* មានន័យថាព្រះយេហូវ៉ាទ្រង់នៅតែបន្តផ្តល់សេចក្តីសប្បុរស និងសេចក្តីស្មោះត្រង់របស់ទ្រង់ជានិច្ចដល់ពួកគេ ។

**៩២:៣** *ពិណ . . . ស៊ុង* សូមមើលការពន្យល់ ៥៧:៨ ។ *ស៊ុង* សូមមើលការពន្យល់ លប ៣១:២៧ ។

**៩២:៤–៥** នៅក្នុងឃ្លានេះ និយាយពីអំណរចំពោះសេចក្តីសង្គ្រោះរបស់ព្រះ (សូមមើល ខ.១០–១១) ។

**៩២:៥** *ជ្រៅ* ពាក្យនេះគឺនិយាយតាមភាសាអក្សរសាស្ត្រ ។ *ព្រះដំរិះ* ព្រះដំរិះរបស់ទ្រង់បានបង្ហាញឱ្យឃើញច្បាស់តាមរយៈការដែលទ្រង់ធ្វើ ។

**៩២:៦–៩** នៅក្នុងខទាំងនេះ ចង់និយាយពីគ្រោះមហន្តរាយរបស់មនុស្សអាក្រក់ (ខុសពី ខ.១២–១៥) ។

**៩២:៦** *មនុស្សកំរោលមិនដឹងអី . . . មនុស្សឥតបើគិត* សូមមើលការពន្យល់ ១៤:១ និងក្នុង ៤០:១០ និងជាពិសេសការពន្យល់ក្នុង ៩៤:៨–១១ ។ មនុស្សទាំង២ប្រភេទនេះគេមិនបានទទួលស្គាល់ថា ព្រះអង្គទ្រង់សុចរិតនោះទេ ។ ពួកគេឃើញ តែការរីកចំរើនរបស់មនុស្សអាក្រក់ ប៉ុន្តែមិនបានឃើញព្រះយេហូវ៉ា ឬមិនបានឃើញសេចក្តីអន្តរាយដែលនៅពីមុខគេឡើយ ។ អ្នកនិពន្ធគាត់បាននិយាយពីចរិតលក្ខណៈមនុស្ស"ទុចរិត" (ខ.១១) ដែលព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យគេខ្ចាត់ខ្ចាយទៅ ។

**៩២:៧** នៅក្នុងខនេះ គឺជាសេចក្តីសង្ខេបពីអ្វីដែលបាននិយាយយ៉ាងក្បោះក្បាយនៅក្នុង ទដ ៧៣ (ក៏សូមមើល ទដ ៣៧:២ ៦២:៩ ៩០:៥–៦ និងការពន្យល់) ។

**៩២:៨** *ទ្រង់ជាព្រះដ៏ខ្ពស់បំផុតដរាបដល់អស់កល្បរៀងទៅ* នៅក្នុងឃ្លានេះគឺចង់និយាយពីការលើកដំកើងដ៏នៅអស់កល្បរបស់ព្រះអម្ចាស់ ដែលទ្រង់អះអាងថា នឹងបំផ្លាញពួកខ្មាំងសត្រូវរបស់ទ្រង់ ។

**៩២:៩** *ខ្មាំងសត្រូវ* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើពួកមនុស្សអាក្រក់ដូចជានិយាយនៅក្នុង ខ.៧ ដែរ ។

**៩២:១០–១១** នៅក្នុងខទាំងនេះ អ្នកនិពន្ធចង់និយាយពីសេចក្តីអំណរចំពោះការដែលព្រះអង្គទ្រង់សព្វព្រះទ័យចំពោះគាត់ (សូមមើល ខ.៤–៥) ក្នុងកាលដែលព្រះអង្គទ្រង់បានធ្វើឱ្យគាត់មានជ័យជម្នះ (សូមមើល ៨៩:២៤) និងការដែលទ្រង់បានចាក់ប្រេងតាំងគាត់ដោយ "ប្រេងនៃសេចក្តីត្រេកអរសាទរ" (៤៥:៧ ២៣:៥) ដោយព្រះប្រទានឱ្យគាត់មានជ័យជម្នះលើខ្មាំងសត្រូវទាំងអស់ ។

**៩២:១២–១៥** នៅក្នុងខទាំងនេះ គឺនិយាយពីសេចក្តីសុខសាន្តរបស់មនុស្សសុចរិត (ខុសពី ខ.៦–៩) ។

**៩២:១៣** *គេត្រូវដាំនៅក្នុងដំណាក់នៃព្រះយេហូវ៉ា* នៅក្នុងឃ្លានេះចង់និយាយថា ទោះបីជាមនុស្សអាក្រក់អាច"ដុះដាលដូចជាស្មៅ"ក៏ដោយក៏គេត្រូវតែវិនាសទៅវិញអស់កល្បជានិច្ចដែរ (សូមមើល ខ.៧) តែឯមនុស្សសុចរិតនឹងត្រូវដាំក្នុងកន្លែងដែលមានសុខសន្តិភាព (សូមមើល ទដ ជំពូក ៩១) និងមានកម្លាំងតាំងពីពេលក្មេងរហូតដល់ចាស់ ដោយមានអំណរក្នុងសេចក្តីយុត្តិធម៌របស់ព្រះអង្គ (សូមមើល ខ.១៥) ។ *ទីលាន* គឺជាទីលាននៃព្រះវិហារ (សូមមើល ៨៤:២,១០ ២ពវ ២១:៥ ២៣:១១–១២) ។

**៩២:១៥** *ទៀងត្រង់ . . . ថ្មដា . . . គ្មានសេចក្តីទុច្ចរិតណានៅក្នុងទ្រង់ឡើយ* សូមមើល ចទ ៣២:៤ ។

គ្មានសេចក្ដីទុច្ចរិតណានៅក្នុងទ្រង់ឡើយ[ព] ។

**៩៣** ព្រះយេហូវ៉ាទ្រង់ជាអ្នកគ្រប់គ្រង[ក]
ទ្រង់ប្រដាប់អង្គដោយភាពដ៏រុងរឿងឧត្ដម[ខ]
ព្រះយេហូវ៉ាទ្រង់ប្រដាប់អង្គ ដោយតេជានុភាព[គ]
ព្រមទាំងក្រវាត់អង្គ ដោយសេចក្ដីនោះដែរ
ឯលោកីយនោះបានតាំងមាំមួន[ឃ] និងរង្គើមិនបានឡើយ[ង]
២ បល្ល័ង្កទ្រង់បានតាំងនៅ[ច] ចាប់តាំងពីចាស់បូរាណ
គឺមានទ្រង់តាំងតែពីអស់កល្បរៀងមក[ឆ]
៣ ឱព្រះយេហូវ៉ាអើយ អស់ទាំងជំនន់[ជ]បានជន់ឡើងជាធំ
ជំនន់ទាំងប៉ុន្មានបានបន្លឺសំឡេងឡើង[ឈ]
ជំនន់ទាំងនោះបានកំរើកឡើងជារលកផ្ទប់ច្រាំង[ញ]
៤ ព្រះយេហូវ៉ាដ៏គង់នៅស្ថានខ្ពស់[ដ]
ទ្រង់មានឫទ្ធិជាជាងសូរគ្រាំគ្រេង[ឋ]
នៃទឹកធំគឺជាងរលកគំហុក[ឌ]នៃសមុទ្រផង
៥ ឱព្រះយេហូវ៉ាអើយ អស់ទាំងសេចក្ដីបន្ទាល់របស់ទ្រង់
សុទ្ធតែពិតប្រាកដ សេចក្ដីបរិសុទ្ធ[ឍ]សំណាំនៅដំណាក់
ទ្រង់[ណ]នៅអស់កល្បតទៅផង ។

**៩៤** ឱព្រះយេហូវ៉ា ជាព្រះនៃសេចក្ដីសងសឹក[ក]អើយ

**៩២:១៥** ព យប ៣៤:១០ **៩៣:១** ក ១របា ១៦:៣១ ទដ ៩៧:១ ខ យប ៤០:១០ ទដ ២១:៥ គ ទដ ៦៥:៦ ឃ ទដ ២៤:២ ៧៨:៦៩ ១១៩:៩០ ង ១របា ១៦:៣០ ទដ ៩៦:១០ **៩៣:២** ច ២សយ ៧:១៦ ឆ លប ២១:៣៣ **៩៣:៣** ជ ទដ ៩៦:១១ ៩៨:៧ អស ៥:៣០ ១៧:១២–១៣ យរ ៦:២៣ ឈ ទដ ៤៦:៣ ញ យប ៩:៨ ទដ ១០៧:២៥, ២៩ អស ៥១:១៥ យរ ៣១:៣៥ ហព ៣:១០ **៩៣:៤** ដ នហ ៩:៣២ យប ៩:៤ ឋ ទដ ៦៥:៧ យរ ៦:២៣ **៩៣:៤** ឌ ទដ ១៨:៤ យហ ១:១៥ **៩៣:៥** ឍ ទដ ២៩:២ ៩៦:៩ ណ ទដ ៥:៧ ២៣:៦ **៩៤:១** ក លប ៤:២៤ រម ១២:១៩

**ទដ ៩៣** នៅក្នុងជំពូកនេះ គឺជាបទចម្រៀងសរសើរតម្កើងចំពោះការគ្រប់គ្រងដ៏នៅអស់កល្ប លើពិភពលោកទាំងមូលរបស់ព្រះអម្ចាស់ ។ ផ្ទៃរឿងក្នុងជំពូកនេះមានទំនាក់ទំនងជាមួយ ទដ ៤៧,៩៥–៩៩ ។ បទគម្ពីរទំនុកដំកើងទាំងនោះ បាននិយាយពីចម្រៀងសរសើរតម្កើងដល់ព្រះអម្ចាស់ចំពោះអំណាចឫទ្ធានុភាពរបស់ទ្រង់ និងនិយាយពីសេចក្ដីជំនឿ និងសេចក្ដីសង្ឃឹមនឹងការរស់នៅក្នុងនគររបស់ព្រះ ក្នុងកាលដែលរស់នៅលើផែនដី ។ បទគម្ពីរទំនុកដំកើងនេះ ប្រហែលនិពន្ធឡើងក្នុងគោលបំណងដើម្បីច្រៀងក្នុងពិធីបុណ្យដ៏សំខាន់ ក្នុងការអភិសេកភាពជាស្ដេចរបស់ព្រះអម្ចាស់ដែលទ្រង់គ្រប់គ្រងលើទាំងអស់ គឺលើទាំងធម្មជាតិ គ្រប់ទាំងប្រជាជាតិ ហើយជាពិសេសនោះ គឺលើពួកអ៊ីស្រាអែលទាំងមូល ដូច្នេះហើយទើបគេច្រៀងចម្រៀងនេះជារៀងរាល់ឆ្នាំ (សូមមើលក្នុងសេចក្ដីផ្ដើម ទដ ៤៧) បទចម្រៀងនេះ ប្រហែលតែងឡើងដោយក្រុមអ្នកដែលបម្រើការងារក្នុងព្រះវិហារ ហើយច្រៀងដោយពួកគេផ្ទាល់តែម្ដង ។ ព្រះគម្ពីរទំនុកដំកើង ៩៣ បានកាច់ផ្ដាច់ចេញពីក្រុមទំនុកដំកើង ៩៥–៩៩ ព្រោះ ទដ ៩៣ មាននាទីជាផ្ទៃរឿងស្នូលរវាង ទដ ៩២ និង ទដ ៩៤ (ដូចគ្នានឹង ទដ ៤៧ ជាផ្ទៃរឿងស្នូលរវាង ទដ ៤៨) ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ បាននិយាយពីការអបអរចំពោះសេចក្ដីសុខសាន្តរបស់ព្រះយេហូវ៉ា ក្នុងការគ្រប់គ្រងដែលប្រកបដោយសេចក្ដីសុចរិត និងការគ្រប់គ្រងលើការងាររបស់មនុស្សដោយព្រោះព្រះអង្គប្រទានឱ្យគេនូវសេចក្ដីអំណរ (ទដ ៩២) និងសេចក្ដីសង្ឃឹម (ទដ ៩៤) ចំពោះអ្នកណាដែលជឿលើព្រះអម្ចាស់ក្នុងការការពារពួកគេឱ្យរួចពីពួកខ្មាំងសត្រូវ ដែលគ្មានព្រះក្នុងខ្លួនរស់នៅដោយការបង្ករជម្លោះ ។

**៩៣:១–២** នៅក្នុងខនេះ ចង់និយាយពីការគ្រប់គ្រងរបស់ព្រះអម្ចាស់ ដែលបានធ្វើឱ្យគ្រប់ទាំងអស់នៃស្នាព្រះហស្តទ្រង់ នឹងប្រទានឱ្យគេមានសេចក្ដីសុខសាន្តអស់១ជីវិត (លប ១:១) ។ ទោះបីជាពួកអ៊ីស្រាអែលគេគឺជាប្រជាជាតិមួយដែលទើបតែនឹងកើតមានឡើងក៏ដោយ ក៏ព្រះនៃពួកគេបានស្ដេចមុនអ្វីៗទាំងអស់នៅក្នុងលោកិយនេះបានកើតឡើងទៅទៀត ។

**៩៣:១** *ព្រះយេហូវ៉ាទ្រង់ជាអ្នកគ្រប់គ្រង* នេះគឺជាការពិតដែលនឹងកើតឡើងនៅក្នុងគ្រាចុងក្រោយ។ ឃ្លានេះក៏ជាគ្រឹះនិងជាសេចក្ដីជំនឿចំបងរបស់ពួកអ៊ីស្រាអែលដែរ (សូមមើល ៩៦:១០ ៩៧:១ ៩៩:១ និង សក ១៤:៩ និងការពន្យល់) ។

**៩៣:៣–៤** នៅក្នុងខទាំងនេះចង់និយាយថា នៅគ្រាដែលមានទឹកជំនន់ធំនៅលើផែនដី នោះព្រះយេហូវ៉ាទ្រង់នឹងសំដែងឱ្យឃើញអនុភាពដ៏ខ្លាំងពូកែរបស់ទ្រង់ថា អំណាចរបស់ទ្រង់គឺខ្លាំងជាងអំណាចណាៗទាំងអស់ដែលតែងតែ វាយលុក និងបៀតបៀនដល់នគររបស់ទ្រង់ ។

**៩៣:៤** *សមុទ្រ* ពាក្យនេះគឺនិយាយសំដៅលើការរំពើង ឬកក្រើកនៃទឹកដែលកើតមានដោយសារព្រះបន្ទូលរបស់ទ្រង់ ដោយការបង្គាប់បញ្ជា (សូមមើល ទដ ៣៣:៧ ១០៤:៧–៩ លប ១:៦–៧ យប ៣៨:៨–១១) ។ ពាក្យប្រៀបប្រដូចនេះគឺចង់និយាយសំដៅលើគ្រប់ទាំងអស់ ដែលបានបដិសេធចំពោះការយាងមករបស់ព្រះយេហូវ៉ា និងនគររបស់ទ្រង់ (សូមមើល ៦៥:៦–៧ ៧៤:១៣–១៤ និងការពន្យល់) ។

**៩៣:៤** នៅក្នុងខនេះចង់និយាយថា រលកគំហុកនៃសមុទ្រ មិនបានទាស់ប្រឆាំង ចំពោះអំណាចចេស្ដារបស់ទ្រង់និងព្រះបន្ទូលរបស់ទ្រង់នោះឡើយ (សូមមើល ១០៤:៧) ។

**៩៣:៥** *សេចក្ដីបន្ទាល់* អំណាចនៃការគ្រប់គ្រងរបស់ព្រះអង្គបានធ្វើឱ្យពិភពលោកមានការភ័យខ្លាច ក៏ប៉ុន្តែបានធ្វើឱ្យរាស្ត្រទ្រង់មានជីវិតដោយស្វ័យប្រវត្តិដែលស្ថិតស្ថេរ និងជឿជាក់ (សូមមើល ១៩:៧) ដូច្នេះហើយពួកគេត្រូវតែគោរពថ្វាយបង្គំព្រះអម្ចាស់ (សូមមើល ៩៥:៨–១១) ។ *ដំណាក់ទ្រង់* នៅក្នុងឃ្លានេះ គឺនិយាយសំដៅលើព្រះវិហាររបស់ទ្រង់ដែលនៅលើផែនដី ប៉ុន្តែក៏និយាយសំដៅលើដំណាក់នៅស្ថានសួគ៌ផងដែរ ។ *នៅអស់កល្បតទៅ* ឃ្លានេះបានបង្ហាញពីលក្ខណៈសម្បត្តិនៃសេចក្ដីបន្ទាល់ និងសេចក្ដីបរិសុទ្ធរបស់ទ្រង់ ។

**ទដ ៩៤** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានអំពាវនាវដល់ព្រះអម្ចាស់ដែលទ្រង់ជា "ចៅក្រមនៃផែនដី" សូមឱ្យព្រះអង្គបានកាត់ក្ដីចំពោះអ្នកលៃប្រព្រឹត្តការអាក្រក់ដោយការដកយកអំណាច និងដំណែងរបស់ពួកគេ ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះ មានទំនាក់ទំនងជាមួយ ទដ ៩២ (សូមមើលសេចក្ដីផ្ដើម ទដ ៩២ និង ទដ ៩៣) ។ ប៉ុន្តែនេះគឺជាសំលេងនៃពួកអ៊ីស្រាអែល ដែលត្រូវគេសង្កត់សង្កិនក្នុងកាលដែលពួកគេបានស្វែងរកការសងសឹកនៅត្រង់បល្ល័ង្ករបស់ទ្រង់ ដោយព្រោះសេចក្ដីអយុត្តិធម៌ដែលបង្ករឡើងដោយ "មនុស្សចំកួត" ដែលបានតាំងអំណាចរបស់ពួកគេឡើង ។ នេះគឺជា

ឱព្រះនៃសេចក្ដីសងសឹកអើយ សូមភ្លឺមក[ខ]
២ ឱចៅក្រម[គ]នៃផែនដីអើយ សូមទ្រង់ក្រោកឡើង[ឃ]
សូមសង[ង]ដល់ពួកឆ្មើងឆ្មៃតាមសមគួរ
៣ មនុស្សអាក្រក់នឹងនៅមានជ័យជំនះដល់កាលណាទៀត
ឱព្រះយេហូវ៉ាអើយ តើដល់កាលណាទៅ[ច]
៤ គេបង្ហូរចេញជាពាក្យព្រហើន[ឆ]
ហើយពោលតែពាក្យឆ្មើងឆ្មៃប៉ុណ្ណោះ[ជ]
គឺអស់អ្នកដែលប្រព្រឹត្តអំពើអាក្រក់ គេរមែងអួតខ្លួន
៥ ឱព្រះយេហូវ៉ាអើយ គេញាំញីរាស្ត្ររបស់ទ្រង់[ឈ]
ហើយធ្វើទុក្ខដល់មរដកទ្រង់[ញ]
៦ គេសំឡាប់ស្រីមេម៉ាយ[ដ] និងពួកអ្នកស្នាក់នៅ
ព្រមទាំងប្រហារជីវិតនៃពួកកំព្រាផង[ឋ]
៧ ហើយពោលថា ព្រះយេហូវ៉ាមិនឃើញទេ[ឌ]
ព្រះនៃយ៉ាកុប[ឍ] ទ្រង់មិនពិចារណាឡើយ
៨ ឱពួកអ្នកកំរោលក្នុងបណ្ដាជនអើយ[ណ] ចូរពិចារណាចុះ
ឱមនុស្សឥតបើគិតអើយ តើកាលណានឹងមានប្រាជ្ញាឡើង
៩ ឯព្រះដែលទ្រង់បង្កើតត្រចៀក តើទ្រង់មិនឮទេឬ
ព្រះដែលសូនធ្វើភ្នែក តើទ្រង់មិនឃើញទេឬ[ត]
១០ ព្រះដែលវាយប្រដៅ[ថ]ដល់អស់ទាំងសាសន៍
តើទ្រង់មិនផ្ចាលឯងទេឬអី គឺព្រះនោះឯង
ដែលបង្រៀន[ទ]ឱ្យមនុស្សមានចំណេះ
១១ ព្រះយេហូវ៉ាទ្រង់ជ្រាបអស់ទាំងគំនិត[ធ]របស់មនុស្សថា
សុទ្ធតែឥតប្រយោជន៍ទទេ[ន]
១២ ឱព្រះយេហូវ៉ាអើយ មានពរហើយ
មនុស្សណាដែលទ្រង់វាយផ្ចាល[ប] ហើយបង្ហាត់បង្រៀន[ផ]
តាមក្រិត្យវិន័យទ្រង់ផង
១៣ គឺដើម្បីឱ្យទ្រង់បានប្រោស ឱ្យអ្នកនោះមានសេចក្ដីសំរាក
នៅថ្ងៃអាក្រក់[ព] ទំរាំតែគេជីករណ្ដៅ[ភ]សំរាប់មនុស្ស
ប្រព្រឹត្តទំនាស់
១៤ ដ្បិតព្រះយេហូវ៉ាទ្រង់នឹងមិនចោលរាស្ត្រទ្រង់ឡើយ[ម]
ក៏មិនលះបង់មរដកទ្រង់ដែរ
១៥ ពីព្រោះសេចក្ដីវិនិច្ឆ័យនឹងត្រឡប់តាមសុចរិតវិញ[យ]
ហើយអស់អ្នកដែលមានចិត្ត[រ]ទៀងត្រង់គេនឹងប្រព្រឹត្តតាម
ដែរ

**៩៤:១** ខ ចទ ៣៣:២ ទដ ៨០:១ **៩៤:២** គ លប ១៨:២៥ ហព ១២:២៣ ឃក ៥:៩ ឃ ជន ១០:៣៥ ង ទដ ៣១:២៣ **៩៤:៣** ច ទដ ១៣:២ **៩៤:៤** ឆ យរ ៤៣:២ ជ ទដ ៥២:១ **៩៤:៥** ឈ ទដ ៤៤:២ ៧៤:៨ អស ៣:១៥ យរ ៨:២១ ញ ទដ ២៨:៩ **៩៤:៦** ដ ចទ ១០:១៨ អស ១:១៧ ឋ ចទ ២៤:១៩ **៩៤:៧** ឌ យប ២២:១៤ ឍ លប ២៤:១២ **៩៤:៨** ណ ចទ ៣២:៦ ទដ ៧៣:២២ **៩៤:៩** ត នក ៤:១១ សភ ២០:១២ **៩៤:១០** ថ ទដ ៣៩:១១ ទ នក ៣៥:៣៤ យប ៣៥:១១ អស ២៨:២៦ **៩៤:១១** ធ ទដ ១៣៩:២ សភ ១៥:២៦ មថ ៩:៤ **៩៤:១១** ន ១កថ ៣:២០ **៩៤:១២** ប យប ៥:១៧ ១កថ ១១:៣២ ហព ១២:៥ ផ ចទ ៨:៣ ១សយ ១២:២៣ **៩៤:១៣** ព ទដ ៨៦:៧ ភ ទដ ៧:១៥ ៥៥:២៣ **៩៤:១៤** ម ចទ ៣១:៦ ទដ ៣៧:២៨ រម ១១:២ **៩៤:១៥** យ ទដ ៩៧:២ រ ទដ ៧:១០ ១១:២ ៣៦:១០

បទគម្ពីរតែ១គត់ក្នុងចំណោម ទដ ៩០–១០០ ហើយមានងារជាអ្នកដំណាងឱ្យសម្រេកនៃពួកអ្នកដែលត្រូវសង្កិនសង្កត់ជាច្រើន ដែលមាននិយាយនៅក្នុងប៉ែកទី ១–៣ នៃព្រះគម្ពីរទំនុកដំកើង ។

**៩៤:១–៣** នៅក្នុងខនេះ អ្នកនិពន្ធបានអំពាវនាវដល់ព្រះអម្ចាស់ ដែលទ្រង់ជាចៅក្រមនៃផែនដី ។

**៩៤:១** *សងសឹក* គឺសងសឹកចំពោះការអាក្រក់ (មើល ចទ ៣២:៣៥,៤១ និងការពន្យល់ ៣២:៣៥) ។ ការសងសឹកគឺជាតួនាទីរបស់ស្ដេចក្នុងគ្រាដែលទ្រង់គ្រប់គ្រងលើផែនដីនេះ ។ បរិបទក្នុងជំពូកនេះ មានទំនាក់ទំនងជាមួយ ទដ ៤៧,៩៣,៩៥–៩៩ ។

**៩៤:២** *ពួកឆ្មើងឆ្មៃ* សូមមើល ខ.៤–៧ ដែលបាននិយាយពីចរិតលក្ខណៈរបស់ពួកគេ ។

**៩៤:៣** *តើដល់កាលណាទៅ* សូមមើលការពន្យល់ ៦:៣ ។

**៩៤:៤–៧** នៅក្នុងខទាំងនេះ គឺជាការពណ៌នាពីចរិតរបស់មនុស្សអាក្រក់ ។

**៩៤:៤** *ពាក្យព្រហើន . . . គេរមែងអួតខ្លួន* សម្រាប់ចរិតលក្ខណៈប្រហែលគ្នានេះទៀតរបស់មនុស្សអាក្រក់ សូមមើល ១០:២–១១ និងការពន្យល់ ។

**៩៤:៥** *រាស្ត្ររបស់ទ្រង់ . . . មករដកទ្រង់* ងារទាំងនេះនឹងបានដល់អ្នកណាដែលគ្មានទីពឹង (សូមមើល ខ.៦) ។

**៩៤:៧** *ហើយពោលថា* សូមមើលការពន្យល់ ៣:២ ។ *យ៉ាកុប* ពាក្យនេះ គឺជាសទីសន័យនៃពួកអ៊ីស្រាអែលទាំងមូល (សូមមើល លប ៣២:២៨) ។

**៩៤:៨–១១** នៅក្នុងឃ្លានេះ គឺជាការព្រមានដល់ពួកមនុស្សអាក្រក់ គឺដល់ពួក "មនុស្សកំរោល . . . មនុស្សឥតបើគិត" (សូមមើល ៩២:៦–៩ និងការពន្យល់ ១៤:១) ។

**៩៤:១០** *វាយប្រដៅ* គឺព្រះអម្ចាស់ទ្រង់បានទុកពួកគេក្នុងផ្លូវទ្រង់ ដោយការវាយផ្ចាល (មើល លវ ២៦:១៨ យរ ៣១:១៨) ។ *បង្រៀន* គឺព្រះអម្ចាស់ទ្រង់នឹងផ្ដល់ចំណេះដឹងពីការបង្កើតដល់គេ (សូមមើល អស ២៨:២៦) ។

**៩៤:១១** *ព្រះយេហូវ៉ាទ្រង់ជ្រាប* នៅក្នុងឃ្លានេះចង់បង្ហាញថា ព្រះដំរិះរបស់ទ្រង់ គឺផ្ទុយពីគំនិតរបស់មនុស្សអាក្រក់ (សូមមើល ខ.៧) ។

**៩៤:១២–១៥** នៅទីនេះមានការប្រែប្រួលមួយបានកើតឡើង គឺពីការអួតអាងនិងចំណាចអាក្រក់របស់ពួកមនុស្សអាក្រក់ បានត្រឡប់ជាសេចក្ដីអំណររីករាយដល់ពួកអ្នក ដែលរាប់បញ្ចូលខ្លួនគេក្នុងចំណោមរាស្ត្រទ្រង់ និងអ្នកដែលត្រូវព្រះអង្គវាយផ្ចាល និងជឿលើការថែរក្សាមកពីព្រះ ។

**៩៤:១២** *មានពរហើយ* សូមមើលការពន្យល់ ១:១ ។ *វាយផ្ចាល . . . បង្ហាត់បង្រៀន* មើល ខ.១០ ។ នៅទីនេះអ្នកនិពន្ធគាត់និយាយពីសេចក្ដីបង្រៀនដ៏ត្រឹមត្រូវតាមក្រឹត្យវិន័យ ដែលព្រះអង្គបង្រៀនដល់រាស្ត្រទ្រង់ ។

**៩៤:១៤** *រាស្ត្រទ្រង់ . . . មរដកទ្រង់* សូមមើល ខ.៥ ។ ព្រះយេហូវ៉ាទ្រង់មិនព្រមបោះបង់ចោលអ្នកទន់ខ្សោយ នៃរាស្ត្រទ្រង់ដោយអយុត្តិធម៌ឡើយ នៅចំពោះមុខអ្នកដែលសង្កត់សង្កិនគេឡើយ ។ លោកប៉ូលបានយកខនេះទៅ និយាយ រម ១១:១–២ ។

**៩៤:១៥** នៅក្នុងខនេះមានការពិបាកក្នុងកាត់ស្រាយបន្តិច ។ អ្នកនិពន្ធបាននិយាយថា ការគ្រប់គ្រងដែលប្រកបដោយសុចរិតរបស់ព្រះអម្ចាស់នឹងនាំឱ្យមានសេចក្ដីយុត្តិធម៌ឡើងវិញ ចំពោះអ្នកណាដែលធ្លាប់ប្រព្រឹត្តិខុស ដែលបានកែខ្លួនជាថ្មីដែលត្រូវរាប់ថា "ចិត្តទៀងត្រង់" (មើល ខ.២១) ។ *ចិត្ត*

១៦ តើអ្នកណានឹងក្រោកឡើង[ល]ជំនួសខ្ញុំ
ដើម្បីទាស់នឹងពួកអ្នកដែលប្រព្រឹត្តការអាក្រក់
តើអ្នកណានឹងឈរឡើងជំនួសខ្ញុំ
ដើម្បីទប់ទល់នឹងពួកដែលប្រព្រឹត្តការទុច្ចរិត[វ]
១៧ បើប្រសិនជាព្រះយេហូវ៉ាទ្រង់មិនបានជួយខ្ញុំទេ[ស]
នោះព្រលឹងខ្ញុំនឹងបានទៅនៅក្នុងទីស្ងាត់ឈឹងដោយឆាប់
ហើយ[ហ]
១៨ កាលទូលបង្គំបានពោលថា ជើងទូលបង្គំរឥលភ្លាត់ហើយ
នោះ[ឡ] ឱព្រះយេហូវ៉ាអើយ សេចក្ដីសប្បុរសនៃទ្រង់បាន
ទប់ទល់ទូលបង្គំ
១៩ គ្រាដែលទូលបង្គំមានគំនិតសាន់វ័ណ្ឌ[អ]ក្នុងចិត្តជាច្រើន
នោះសេចក្ដីកំសាន្តចិត្ត[ក]នៃទ្រង់ក៏ជាទីរីករាយដល់ព្រលឹង
ទូលបង្គំវិញ
២០ តើបល្ល័ង្កនៃសេចក្ដីអាក្រក់[ខ] នឹងអាចមានសេចក្ដីប្រកប
នឹងទ្រង់បានដែរឬ គឺជាពួកអ្នកដែលបង្កើតការប្រទូស
រ៉ាយដោយអាងមាត្រាច្បាប់[គ]
២១ គេលើកគ្នា[ឃ]ទាស់នឹងជីវិតនៃមនុស្សសុចរិត
ហើយក៏កាត់ទោសដល់ឈាម[ង]ដែលឥតមានទោស[ច]ផង
២២ ប៉ុន្តែព្រះយេហូវ៉ាទ្រង់ជាទីពឹងយ៉ាងខ្ពស់នៃទូលបង្គំ
គឺព្រះនៃទូលបង្គំ ទ្រង់ជាថ្មដា[ឆ]ដែលទូលបង្គំពឹងពាក់បាន[ជ]
២៣ ទ្រង់បានទំលាក់[ឈ]ការទុច្ចរិតរបស់គេទៅលើគេវិញ
ហើយនិងកាត់គេចេញ[ញ]ដោយអំពើអាក្រក់របស់ខ្លួនគេ
គឺព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំទ្រង់នឹងកាត់កាប់គេចេញ

**៩៥** មកចុះ[ក] យើងនឹងច្រៀងថ្វាយព្រះយេហូវ៉ា ចូរយើង
ឡើងសំឡេង[ខ]ដោយអំណរ[គ]ដល់ថ្មដា[ឃ]នៃសេចក្ដីសង្គ្រោះ
របស់យើង
២ ចូរយើងចូលទៅចំពោះទ្រង់[ង] ដោយអរព្រះគុណ[ច]
ចូរយើងឡើងសំឡេងថ្វាយទ្រង់ ដោយទំនុកដំកើង[ឆ]ចុះ
៣ ដ្បិតព្រះយេហូវ៉ាទ្រង់ជាព្រះយ៉ាងធំ[ជ] ហើយជា
មហាក្សត្រ[ឈ] យ៉ាងខ្ពស់លើអស់ទាំងព្រះ[ញ]

**៩៤:១៦** ល ជន ១០:៣៥ ទដ ១៧:១៣ អស ១៤:២២ វ ទដ ៥៩:២ **៩៤:១៧** ស ទដ ១២៤:២ ហ ទដ ៣១:១៧ **៩៤:១៨** ឡ ចទ ៣២:៣៥ យប ១២:៥ **៩៤:១៩** អ សស ១១:១០ ក យប ៦:១០ **៩៤:២០** ខ យរ ២២:៣០ ៣៦:៣០ គ ទដ ៥៨:២ **៩៤:២១** ឃ ទដ ៥៦:៦ ង លប ១៨:២៣ ច ទដ ១០៦:៣៨ សភ ១៧:១៥,២៦ ២៨:២១ អស ៥:២០,២៣ មថ ២៧:៤

**៩៤:២២** ឆ ទដ ៦១:២ ជ ២សយ ២២:៣ ទដ ១៨:២ **៩៤:២៣** ឈ នក ៣២:៣៤ ទដ ៥៤:៥ ញ ទដ ៩:៥ ៣៧:៣៨ ១៤៥:២០ **៩៥:១** ក ទដ ៥:១១ ៨០:២ **៩៥:១** ខ ទដ ៨១:១ អស ៤៤:២៣ សផ ៣:១៤ គ ទដ ៥:១១ ឃ ២សយ ២២:៤៧ **៩៥:២** ង ទដ ១០០:២ មីក ៦:៦ ច ទដ ៤២:៤ ឆ ទដ ៨១:២ អភ ៥:១៩ **៩៥:៣** ជ ទដ ៤៨:១ ៨៦:១០ ១៤៥:៣ ១៤៧:៥ ឈ ទដ ៤៧:២ ញ ទដ ៩៦:៤ ៩៧:៩

សូមមើលការពន្យល់ ៤:៧ ។

**៩៤:១៦–១៩** នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់គឺជាទីលានដ៏ពិតក្នុងការជំនុំជម្រះ ។

**៩៤:១៧** *ទីស្ងាត់ឈឹង* សូមមើលការពន្យល់ ៣០:១ ។ នៅក្នុងឃ្លានេះចង់និយាយថា បើសិនជាគ្មានសេចក្ដីជំនួយមកពីព្រះទេ នោះមនុស្សអាក្រក់នឹងធ្វើឱ្យអ្នកនិពន្ធបទគម្ពីរទំនុកដំកើងបានទៅឯទីស្ងាត់ឈឹងក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ទៅហើយ ប៉ុន្តែអ្នកដែលជីករណ្ដៅបានត្រូវធ្លាក់ទៅវិញ (សូមមើល ខ.១៣) ។

**៩៤:១៨** *កាលទូលបង្គំបានពោលថា* នៅក្នុងពេលដែលមានអារម្មណ៍រំជួលក្នុងពេលមានការសង្កិតសង្កត់ពីសំណាក់មនុស្សអាក្រក់ (សូមមើលការពន្យល់ ៣៨:១៦) ។ *សេចក្ដីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**៩៤:១៩** *ព្រលឹង* សូមមើលការពន្យល់ ៦:៣ ។

**៩៤:២០–២៣** នៅក្នុងខទាំងនេះ អ្នកនិពន្ធមានទំនុកចិត្តថា សេចក្ដីសុចរិតរបស់ព្រះនឹងនាំឱ្យមានជ័យជម្នះ ។

**៩៤:២០** *បល្ល័ង្កនៃសេចក្ដីអាក្រក់* គឺជាបល្ល័ង្កនៃសេចក្ដីពុករលួយ ។

**៩៤:២១** *មនុស្សសុចរិត* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើអ្នកដែលមិនបានប្រព្រិត្តិខុសចំពោះអ្នកណាម្នាក់នោះឡើយ ។ ពាក្យនេះមានន័យដូចគ្នានឹងពាក្យថា "គ្មានទោស" (សូមមើលការពន្យល់ ខ.១៥) ។

**ទដ ៩៥** នៅក្នុងជំពូកនេះ និយាយពីការហៅដល់មនុស្សឱ្យចូលមកសរសើរតម្កើង និងថ្វាយបង្គំចំពោះព្រះអម្ចាស់ ។ ប្រហែលជាពួកសង្ឃ ឬពួកលេវីជាអ្នកថ្លែងសន្ទកថានេះទៅកាន់ពួកជំនុំនៃសាសន៍អ៊ីស្រាអែល ដែលបានមកឯព្រះវិហារ (សូមមើលសេចក្ដីផ្ដើម ទដ ៩៣) ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះស្ថិតនៅចំណុចកណ្ដាល នៃក្រុមទំនុកដំកើងក្នុងប៉ែកទី៤នេះ (មើល ទដ ៩០–១០០) ក៏ជាទំនុកដំកើងដំបូងដែលនិយាយពីការសរសើរតម្កើងចំពោះរាជ្យ នៃការគ្រប់គ្រងរបស់ព្រះអម្ចាស់លើលោកិយនេះក្នុងចំណោមទំនុកដំកើង ដែលនិយាយពីការសរសើរតម្កើង (ទដ ៩៥–៩៩) ។ ព្រះគម្ពីរទំនុកដំកើង ជំពូក ៩៥ នេះបានរំឭកឱ្យឃើញពីសេចក្ដីសុខសាន្តរបស់ពួកអ៊ីស្រាអែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះយេហូវ៉ា តាមរយៈការអធិស្ឋាន (សូមមើល ទដ ៩០,៩៤) និងសេចក្ដីសរសើរដំកើងរបស់ពួកគេ (សូមមើល ទដ ៩១–៩៣,៩៥–១០០) តែការទាំងនោះនឹងបានដរាបណាគេគោរពស្រឡាញ់ និងធ្វើជាអ្នកបំរើដែលស្ដាប់បង្គាប់តាមព្រះអម្ចាស់ប៉ុណ្ណោះ ។ តួរនាទីនៃទំនុកដំកើងក្នុងទំកើងជំពូកនេះប្រហាក់ប្រហែលគ្នាជាមួយ ទដ ៨១ ដែរ (មើលក្នុងសេចក្ដីផ្ដើម ទដ ៧៩–៨៣) ។

បទគម្ពីរទំនុកដំកើងក្នុងជំពូកនេះបានចែកជា២ផ្នែក ។ ផ្នែកទី១និយាយពីការហៅមនុស្សទាំងអស់នៅលើផែនដីឱ្យចូលមកសរសើរតម្កើងដល់ព្រះ (ខ.១–៥) ដោយឡែកផ្នែកទី២ និយាយពីការហៅដល់មនុស្សទាំងអស់ឱ្យបានទទួលស្គាល់ព្រះអម្ចាស់ ដោយការស្ដាប់បង្គាប់ចំពោះភាពជាស្ដេចរបស់ព្រះដែលគ្រប់គ្រងលើរាស្ត្ររបស់ទ្រង់ (ខ.៦–១១) ។

**៩៥:១–២** នៅក្នុងជំពូកនេះ និយាយពីការហៅឱ្យមកសរសើរតម្កើង ។

**៩៥:១** *ថ្មដានៃសេចក្ដីសង្គ្រោះរបស់យើង* មើលការពន្យល់ ១៨:២ ។

**៩៥:៣–៥** នៅក្នុងខទាំងនេះ បានបង្ហាញប្រាប់ពីមូលហេតុ ដែលពួកអ៊ីស្រាអែលសរសើរតម្កើងដល់ព្រះអម្ចាស់ ។ មូលហេតុនោះគឺថា ពីព្រោះទ្រង់គឺជាព្រះលើអស់ទាំងព្រះ ហើយគ្មានអ្វីមួយដែលនៅក្នុងលោកិយនេះមិនបានកើតឡើងពីព្រះហស្តព្រះនោះឡើយ ។ កាលពីសម័យចាស់បុរាណ គេគោរពថ្វាយបង្គំរូបព្រះខុសៗគ្នាទៅតាមសម័យកាលនិមួយ និងទៅតាមមនុស្ស និង តាមតំបន់និមួយៗ គឺអ្វីទាំងអស់ខុសគ្នាទាំងអស់ ។

៤អស់ទាំងទីជិវៅនៃផែនដី[ដ] នៅក្នុងព្រះហស្តទ្រង់
ហើយកំពូលភ្នំទាំងប៉ុន្មាន សុទ្ធតែជារបស់ផងទ្រង់ដែរ
៥សមុទ្រជារបស់ផងទ្រង់ គឺទ្រង់ដែលបានបង្កើតមក
ហើយគឺព្រះហស្តទ្រង់ដែលបានសូនធ្វើដីគោក[ឋ]
៦មកចុះ ចូរយើងឱនកាយ[ឌ]ថ្វាយបង្គំទាំងអស់គ្នា[ឍ]
ចូរយើងលុតជង្គង់[ណ]នៅចំពោះព្រះយេហូវ៉ាជាព្រះដ៏បង្កើតយើងខ្ញុំ[ត]
៧ដ្បិតទ្រង់ជាព្រះនៃយើងខ្ញុំហើយ
យើងខ្ញុំក៏ជាហ្វូងចៀមនៅ
ទីគង្វាល[ថ]របស់ទ្រង់ គឺជារាស្ត្រដែលនៅក្នុងព្រះហស្តទ្រង់
នៅថ្ងៃនេះ បើឯងរាល់គ្នាឮសំឡេងទ្រង់
៨នោះកុំឱ្យតាំងចិត្ត[ទ]រឹងរូស ដូចកាលនៅត្រង់មេរីបា[ធ]
ឬដូចកាលថ្ងៃនៅត្រង់ម៉ាសា ក្នុងទីរហោស្ថាននោះឡើយ[ន]
៩ជាគ្រាដែលពួកឰយុកោឯងរាល់គ្នាបានល្បង[ប]អញ
ព្រមទាំងលអញមើល ហើយបានឃើញការរបស់អញ
១០អញមានចិត្តជិនទ្រាន់នឹងមនុស្សដំណនោះអស់៤០ឆ្នាំ[ផ]
ហើយក៏ថា នេះជាបណ្តាមនុស្សដែលតែងតែមានចិត្តវង្វេង[ព] ឥតដែលស្គាល់ផ្លូវរបស់អញឡើយ[ភ]
១១ដូច្នេះ អញបានស្បថ[ម] ដោយសេចក្តីក្រោធរបស់អញថា
វារាល់គ្នានិងមិនដែលចូលមកក្នុងសេចក្តីសំរាករបស់អញឡើយ[យ] ។

**៩៥:៤** ដ ទដ ៦៣:៩ **៩៥:៥** ឋ លប ១:៩ ទដ ១៤៦:៦ **៩៥:៦** ឌ ២សយ ១២:១៦ ភល ២:១០ ឍ ទដ ២២:២៩ ណ ២របា ៦:១៣ ត ទដ ១០០:៣ ១៤៩:២ អស ១៧:៧ ៥៤:៥ ដយ ៦:១០–១១ ហស ៨:១៤ **៩៥:៧** ថ ទដ ៧៤:១ **៩៥:៨** ទ មក ១០:៥ ហព ៣:៨ ធ នក ១៧:៧ ចទ ៣៣:៨ ហព ៣:១៥ ៤:៧ ន ទដ ៧៨:៤០ **៩៥:៩** ប ជន ១៤:២២ ១កថ ១០:៩

*៩៦:១–១៣ – ១របា ១៦:២៣–៣៣*

**៩៦** ចូរច្រៀងបទថ្មី[ក]ថ្វាយព្រះយេហូវ៉ា[ខ] ចូរឱ្យជនទាំង

**៩៥:១០** ផ នក ១៦:៣៥ ជន ១៤:៣៤ កច ៧:៣៦ ហព ៣:១៧ ព ទដ ៥៨:៣ ១១៩:៦៧,១៧៦ សភ ១២:២៦ ១៦:២៩ អស ៥៣:៦ យរ ៤១:១៩ ៥០:៦ អគ ៣៤:៦ ភ ចទ ៨:៦ **៩៥:១១** ម ជន ១៤:២៣ យ ចទ ១:៣៥ ហព ៣:៧–១១ ៤:៣ **៩៦:១** ក ទដ ៣៣:៣ ៤០:៣ ៩៨:១ ១៤៤:៩ ១៤៩:១ អស ៤២:១០ វវ ៥:៩ ខ ទដ ៣០:៤

**៩៥:៤–៥** *ទីជិវៅ . . . កំពូលភ្នំ . . . សមុទ្រ . . . ដីគោក* នៅក្នុងឃ្លានេះចង់និយាយសំដៅលើពិភពលោកទាំងមូល និងគ្រប់ទាំងរបស់ដែលមាននៅក្នុងលោកនេះ ។

**៩៥:៦–១១** នៅក្នុងខនេះ គឺជាការជំរុញទឹកចិត្តឱ្យចុះចូលទៅចំពោះព្រះយេហូវ៉ាដោយការស្តាប់បង្គាប់នៅក្នុងចិត្ត ដ្បិតអីការឱនសំពះមិនគ្រប់គ្រាន់នោះឡើយ ។ ទំនាក់ទំនងរវាងខនេះជាមួយសញ្ញាថ្មីដែលនិយាយពីព្រះគ្រីស្ទ សូមមើល ហប ៣:៧–៤:១៣ ។

**៩៥:៦–៧** នៅក្នុងខនេះអ្នកនិពន្ធ បានហៅមនុស្សទាំងអស់ឱ្យចូលមកឱនកាយថ្វាយបង្គំនៅចំពោះព្រះយេហូវ៉ា ។

**៩៥:៦** *ព្រះដ៏បង្កើតយើងខ្ញុំ* គឺនិយាយសំដៅលើព្រះអាទិករដែលបង្កើតអ្វីៗទាំងអស់ (លប ជំពូក១) និងព្រះដ៏ប្រោសលោះនៃពួកអ៊ីស្រាអែល ដែលបាន"បង្កើត"គេឱ្យក្លាយជារាស្ត្ររបស់ព្រះនៅលើផែនដី (សូមមើល អស ៤៥:៩–១៣ ៥១:១២–១៦) ។

**៩៥:៧** *ចៀមក្នុងទីគង្វាល* សូមមើល ១០០:៣ យរ ២៣:១ អគ ៣៤:១៧–២៣ ។ ដោយព្រោះស្តេចជានិច្ចកាលគេហៅថា "អ្នកគង្វាល" នៃរាស្ត្រទ្រង់ (សូមមើលការពន្យល់ ២៣:១ ៧៤:១) នោះនគររបស់ពួកគេប្រៀបបានទៅនឹង"ទីគង្វាល"(សូមមើល យរ ២៥:៣៦ ៤៩:២០ ៥០:៤៥) ។ *នៅថ្ងៃនេះ បើឯងរាល់គ្នាឮសំលេងទ្រង់* គឺជាសំលេងនៃការសរសើរក្នុងពិធីបុណ្យមួយចំនួនដូចដែលបាននិយាយនៅក្នុង ទដ ៥០ ឬ ទដ ៧៨ ។

**៩៥:៨** *មេរីបា . . . ម៉ាសេ* នៅក្នុងខ.នេះអ្នកដឹកនាំចម្រៀងគាត់បានរំឭកដល់ពួកអ៊ីស្រាអែលក្នុងគ្រាដែលគេបះបោរនឹងព្រះក្នុងទីរហោស្ថាន (សូមមើល នក ១៧:៧ ជន ២០:១៣) ។

**៩៥:៩** *អញ* ពាក្យនេះគឺជានាមផ្លូវការណ៍របស់ព្រះយេហូវ៉ា ។ នៅពេលដែលនិយាយពីព្រះអង្គគឺប្រែក្លាយជាបុរសទី១ (សូមមើល ៥០:៥,៧–១៥ និងការពន្យល់ លប ១៦:៧) ។ *បានឃើញការរបស់អញ* គឺគេឃើញនៅស្រុកអេស៊ីព្ទ និងត្រង់សមុទ្រក្រហម និងការផ្តល់អាហារនៅត្រង់ទីរហោស្ថាន (សូមមើល នក ១៦ និង ជន ១៤:១១) ។

**៩៥:១០** *៤០ឆ្នាំ* ពួកអ៊ីស្រាអែលបានបះបោរនឹងព្រះនៅពេលដែលពួកគេគ្មានជំនឿ និងបដិសេធមិនព្រមចូលច្បាំងយកទឹកលដីសន្យា និងចង់ត្រឡប់ទៅស្រុកអេស៊ីព្ទវិញ (សូមមើល ជន ១៤:១–៤) ។ នៅពេលនោះព្រះយេហូវ៉ាទ្រង់បានវាយផ្ចាល និងដាក់ទោសពួកគេឱ្យគេវង្វេងក្នុង ទីរហោស្ថាន (សូមមើល ជន ១៤:៣៤) ។ *ជិនទ្រាន់* សូមមើលការពន្យល់ ២:៥ ។ *មនុស្សដំណរនេះ* នៅក្នុងឃ្លានេះ គឺនិយាយសំដៅលើពួកអ៊ីស្រាអែល (មនុស្សចាស់)ដែលបានចេញពីស្រុកអេស៊ីព្ទ ហើយបានតាំងសញ្ញាជាមួយព្រះនៅត្រង់ភ្នំស៊ីណាយ (សូមមើល ជន ៣២:១៣) ។ *ជាបណ្តាជន . . . ឥតស្គាល់ផ្លូវរបស់អញឡើយ* នៅក្នុងឃ្លានេះគឺជាការនិយាយឡើងវិញពីអ្វីដែលព្រះយេហូវ៉ាទ្រង់បានមានបន្ទូលក្នុង ជន ១៤:១១ ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ *ផ្លូវរបស់អញ* សូមមើល ២៥:៤ និងការពន្យល់ ។

**៩៥:១១** *ស្បថ* សូមមើល ជន ១៤:២៨ ចទ ១:៣៤–៣៥ ។ *មិនដែលបានចូលមកក្នុងសេចក្តីសំរាករបស់អញឡើយ* ភាសាដែលប្រើក្នុង ជន ១៤:៣០ គឺ "ពិតប្រាកដជាឯងរាល់គ្នានឹងមិនបានចូលទៅក្នុងស្រុកនោះ" ប៉ុន្តែ ដោយព្រោះទឹកដីសន្យា គឺជាកន្លែងដែលឱ្យរាស្ត្ររបស់ទ្រង់បាន "សំរាក" (សូមមើល យស ១:១៣,១៥ នក ៣៣:១៤ ចទ ១២:១០ ២៥:១៩) នោះគេឃើញថា មានសេចក្តីថ្លែងការ២ដែលសមមូលគ្នា ។ *សំរាក* មានបរិបទជាច្រើន បាននិយាយពីភោគទ្រព្យរបស់ពួកអ៊ីស្រាអែលជាមួយព្រះអម្ចាស់នៅលើផែនដីនេះ ហើយក៏ជាកន្លែងដែលធ្វើឱ្យគេបានគេចរួចពីពួកខ្មាំងសត្រូវ ឬការឈ្លានពានផ្សេងៗទាំងក្នុង និងខាងក្រៅ (សូមមើល ទច ៣:២០ ១ពវ ៥:៤ និងការពន្យល់) ។

**ទដ ៩៦** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានហៅដល់ប្រជាជាតិទាំងឡាយ ឱ្យចូលមកសរសើរតម្កើងដល់ព្រះអម្ចាស់តែ១អង្គគត់ និងអភិសេកព្រះចេស្តានៃរាជ្យទ្រង់នៅលើសកលលោកទាំងមូល ហើយកិច្ចការងារដែលមាននៅក្នុងសញ្ញាចាស់ គឺជាការតម្រូវទុកជាមុនពីការងាររបស់មនុស្សក្នុងគ្រាសញ្ញាថ្មី (សូមមើល មថ ២៨:១៦–២០) ។ (សូមមើលក្នុងសេចក្តីផ្តើម ទដ ៩៣,៩៥) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះមានលក្ខណៈដូចគ្នាខ្លះទៅនឹង

ឡាយនៅផែនដីច្រៀងថ្វាយព្រះយេហូវ៉ាចុះ
២ចូរច្រៀងថ្វាយព្រះយេហូវ៉ា
ហើយក្រាបថ្វាយបង្គំដល់ព្រះនាមទ្រង់[គ]
ចូរសំដែងចេញនូវសេចក្ដីសង្គ្រោះ[ឃ]របស់ទ្រង់រាល់តែថ្ងៃតទៅ
៣ចូរថ្លែងប្រាប់ពីសិរីល្អ[ង]ទ្រង់ នៅកណ្ដាលអស់ទាំងសាសន៍
ហើយពីការអស្ចារ្យ[ច]របស់ទ្រង់ នៅកណ្ដាលបណ្ដាជនទាំងឡាយ
៤ដ្បិតព្រះយេហូវ៉ាទ្រង់ធំប្រសើរ ហើយក៏គួរសរសើរ
ណាស់[ឆ] ទ្រង់ជាទីគួរកោតខ្លាច[ជ]លើសជាងអស់ទាំងព្រះ[ឈ]
៥ពីព្រោះអស់ទាំងព្រះរបស់សាសន៍ដទៃសុទ្ធតែជារបស់
ឥតប្រយោជន៍[ញ] តែព្រះយេហូវ៉ាវិញ ទ្រង់បានបង្កើតផ្ទៃមេឃ[ដ]
៦កិត្តិយស និងតេជានុភាព[ឋ]នៅចំពោះទ្រង់ ឥទ្ធិឫទ្ធិ
និងភាពលំអ[ឌ]នៅក្នុងទីបរិសុទ្ធរបស់ទ្រង់
៧ចូរថ្លែងប្រាប់ពីព្រះយេហូវ៉ា[ឍ]អស់ទាំងពូជពង្សនៃសាសន៍
ទាំងឡាយ[ណ]អើយ ចូរថ្លែងប្រាប់ពីព្រះយេហូវ៉ាថា
ទ្រង់មានសិរីល្អនឹងព្រះចេស្ដា
៨ចូរថ្លែងប្រាប់ពីព្រះយេហូវ៉ាថា ព្រះនាមទ្រង់មានសិរីល្អ
ចូរនាំយកដង្វាយ[ត]ចូលមកក្នុងទីលានរបស់ទ្រង់[ថ]
៩ចូរថ្វាយបង្គំដល់ព្រះយេហូវ៉ា[ទ]ដោយពាក់គ្រឿងដ៏បរិសុទ្ធ[ធ]
ឱផែនដីទាំងមូលអើយចូរញាប់ញ័រ[ន]នៅចំពោះទ្រង់ចុះ[ប]
១០ចូរពោលនៅកណ្ដាលអស់ទាំងសាសន៍ថាព្រះយេហូវ៉ា

**៩៦:២** គ ទដ ៦៨:៤ ឃ ទដ ២៧:១ ៧១:១៥ **៩៦:៣** ង ទដ ៨:១ ច ទដ ៧១:១៧ វវ ១៥:៣ **៩៦:៤** ឆ ទដ ៤៨:១ ជ ចទ ២៨:៥៨ ១រប ១៦:២៥ ទដ ៨៩:៧ឈ ទដ ៩៥:៣ **៩៦:៥** ញ លវ ១៩:៤ ដ លប ១:១ ២រប ២:១២ **៩៦:៦** ឋ ទដ ២១:៥ ឌ ទដ ២៩:១ ៨៩:១៧ **៩៦:៧** ឍ ទដ ២៩:១ ណ ទដ ២២:២៧ **៩៦:៨** ត ទដ ៤៥:១២ ៥១:១៩ ៧២:១០ ថ ទដ ៦៥:៤ ៨៤:១០ ៩២:១៣ ១០០:៤ **៩៦:៩** ទ នក ២៣:២៥ យហ ១:៩ ធ ទដ ៩៣:៥ ន នក ១៥:១៤ ទដ ១១៤:៧ ប ទដ ៣៣:៨

ព្រះគម្ពីរ១របាក្សត្រ ១៦:២៣–៣៣ ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺជាគូនឹងព្រះគម្ពីរទំនុកដំកើង ជំពូក ៩៨ គឺដូចទាំងទម្រង់នៃការសរសេរភាសា ហើយនិងផ្ទៃរឿង (សូមប្រៀបធៀបដើមល្បះ និងឃ្លាចុងបញ្ចប់នៃល្បះ) ។ នៅក្នុងល្បះនិមួយៗ និយាយពីការអបអរចំពោះរាជ្យនៃការគ្រប់គ្រងរបស់ព្រះអម្ចាស់ (សូមធៀបជាមួយ ៩៧:៨–១២ ៩៩:៤–៩) ។ ព្រះគម្ពីរទំនុកជំពូក ៩៦ មានទំនាក់ទំនងជាមួយ ទដ ៩៧ ហើយ ទដ ៩៩ មានទំនាក់ទំនងជាមួយ ទដ ៩៨ ។

ព្រះគម្ពីរទំនុកដំកើងជំពូកនេះ បានតែងឡើងជា២ផ្នែក ។ ផ្នែកទី១ នៅដើមឃ្លាបានចាប់ផ្ដើមដោយហៅមនុស្សឱ្យមក "ច្រៀងថ្វាយព្រះអម្ចាស់" ហើយ "ថ្វាយបង្គំដល់ព្រះនាមទ្រង់"(សូមមើល ខ.១–៦) ។ ផ្នែកទី២ ចាប់ផ្ដើមដោយនិយាយពីការហៅដល់ប្រជាជាតិឱ្យ "ថ្លែងប្រាប់ពីព្រះយេហូវ៉ា . . . ព្រះនាមទ្រង់មានសិរីល្អ"(សូមមើល ខ.៧–១៣) ។

**៩៦:១–៣** នៅក្នុងខនេះ អ្នកនិពន្ធបានហៅដល់មនុស្សទាំងអស់នៅលើផែនដីឱ្យចូលមកសរសើរតម្កើងព្រះនាមទ្រង់ នៅក្នុងចំណោមសាសន៍ទទៃ ។ នៅក្នុងខនេះមានឃ្លាស្ទួនគ្នាចំនួន៣ដង ("ច្រៀង . . . ច្រៀង . . . ច្រៀង") ដែលជាទ្រង់ទ្រាយយ៉ាងសាមញ្ញក្នុងសញ្ញាចាស់នៅពេលដែលគេហៅឱ្យចូលមកសរសើរតម្កើងដល់ព្រះនាមទ្រង់ (សូមមើល ខ.៧–៩ និងការពន្យល់ ១០៣:២០–២២ ១១៨:២–៤ ១៣៥:១ ១៣៦:១–៣) ។

**៩៦:១** *ចូរច្រៀងបទថ្មី* សូមមើលការពន្យល់ ៣៣:៣ ។ *ជនទាំងឡាយ* មើល ខ.៩ ។ ឃ្លានេះអាចនិយាយបានម្យ៉ាងទៀតថា "ផែនដី" ដែលនិយាយសំដៅលើពួកអ៊ីស្រាអែល ។ ទោះបីជាយ៉ាងណាក៏ដោយ បើតាមទស្សនៈវិស័យដ៏ធំទូលាយនៃព្រះគម្ពីរទំនុកដំកើងជំពូកនេះ (ជាពិសេស សូមមើល ខ.៧) បានបង្ហាញថា ព្រះគម្ពីរទំនុកដំកើងជំពូកនេះបាននិយាយពីអនាគតដែលនឹងកើតមកដល់ (មើល ខ.៧–៩ ១១៧:១ ៩:១ និងការពន្យល់) ។

**៩៦:២** *ព្រះនាម* មើល ខ.៨ និងការពន្យល់ ៥:១១ ។ *ចូរសំដែងចេញសេចក្ដីសប្បុរស* នៅក្នុងឃ្លានេះគឺចង់និយាយសំដៅលើការប្រកាសដំណឹងល្អ (សូមមើល ៤០:៩ និងការពន្យល់) ពីសេចក្ដីសង្គ្រោះដែលព្រះបានធ្វើចំពោះពួកអ៊ីស្រាអែល(សូមមើល ៣:៨ និង ៨៥:៩) ។

**៩៦:៣** *សិរីល្អ* សូមមើលការពន្យល់ ៨៥:៩ ។ *ការអស្ចារ្យរបស់ទ្រង់* សូមមើលការពន្យល់ ៧១:១៦–១៧ ។

**៩៦:៤–៦** នៅក្នុងឃ្លានេះបានបង្ហាញហេតុផលថា ហេតុអ្វីបានជាផែនដីទាំងមូលត្រូវសរសើរតម្កើងដល់ព្រះយេហូវ៉ា គឺដោយព្រោះព្រះយេហូវ៉ាគឺជាព្រះដ៏ធំបំផុត (សូមមើល ទដ ១១៥) ។

**៩៦:៤** *ជាទីកោតខ្លាច* សូមមើលការពន្យល់ លប ២០:១១ ។

**៩៦:៥** *ទ្រង់បានបង្កើតផ្ទៃមេឃ* នៅក្នុងឃ្លានេះចង់និយាយថា ដោយសារព្រះអង្គទ្រង់ជាអ្នកដែលបានបង្កើតផ្ទៃមេឃឡើង នោះព្រះយេហូវ៉ាទ្រង់ជាព្រះ ដែលធំប្រសើរជាងអស់ទាំងរូបព្រះដែលពួកមនុស្សជាច្រើនគោរពថ្វាយបង្គំ (សូមមើល ៩៧:៧) ។

**៩៦:៦** *កិត្តិយស និងតេជានុភាព . . . ទ្រង់មានសិរីល្អនិងព្រះចេស្ដា* នៅក្នុងឃ្លានេះគឺជាងាររបស់ព្រះយេហូវ៉ា ដែលបានគង់នៅលើបល្ល័ង្កដែលតំណាងឱ្យព្រះវត្តមានរបស់ព្រះយេហូវ៉ា និងការលើកតម្កើងដល់ព្រះអម្ចាស់ឱ្យធ្វើជាស្ដេចលើពិភពលោកទាំងមូល ។ សម្រាប់ងារដែលប្រហាក់ប្រហែលគ្នានេះ សូមមើល ២៣:៦ និងការពន្យល់ ។ *កិត្តិយស* នៅក្នុងភាសាហេព្រើរ ពាក្យនេះមិនមែនដូចគ្នា ឬជាឫសគល់នៃពាក្យថា លំអរនោះឡើយ ។

**៩៦:៧–៩** នៅក្នុងខទាំងនេះ និយាយពីការហៅដល់ប្រជាជាតិទាំងឡាយ ឱ្យចូលមកសរសើរ និងថ្វាយបង្គំព្រះយេហូវ៉ា (សូមមើល ២៩:១–២ និងការពន្យល់) ។

**៩៦:៨** *ទីលាន* គឺជាទីធ្លានៃព្រះវិហារ (សូមមើល ៨៤:២,១០ ២ពវ ២១:៥ ២៣:១១–១២) ។

**៩៦:៩** *ពាក់គ្រឿងដ៏បរិសុទ្ធ* មើលការពន្យល់ ២៩:២ ។ *ញាប់ញ័រ* គឺសំដៅលើការស្ញែងខ្លាច ហើយមានន័យដូចគ្នានឹងពាក្យថា "គួរកោតខ្លាច" (សូមមើល ខ.៤) ។

**៩៦:១០–១៣** នៅក្នុងខនេះ អ្នកនិពន្ធបានហៅគ្រប់ប្រជាជាតិទាំងអស់ឱ្យមកប្រកាស និងថ្លែងប្រាប់ពីសេចក្ដីសុចរិតរបស់ព្រះអម្ចាស់នៅកណ្ដាលទាំងសាសន៍ផ្សេងៗទៀត ។

**៩៦:១០** *ព្រះយេហូវ៉ាទ្រង់គ្រប់គ្រង* សូមមើល ៩៣:១ និងការពន្យល់ ។ *ឯលោកិយ . . . ដោយទៀងត្រង់* ជាទូរទៅទស្សនៈវិស័យនៅក្នុងសញ្ញា

ទ្រង់គ្រប់គ្រង[ផ] ឯលោកីយ ក៏បានតាំង[ព]មាំមួននៅ
និងរង្គើមិនបានឡើយ[ភ] ទ្រង់នឹងជំនុំជំរះ[ម]គ្រប់ទាំងសាសន៍
ដោយទៀតត្រង់[យ]
១១ចូរឱ្យផ្ទៃមេឃមានសេចក្ដីអំណរ[រ] ហើយឱ្យផែនដីបានរីក
រាយឡើង[ល]ឱ្យសមុទ្រលាន់ឮរំពងឡើងព្រមទាំងរបស់
សព្វសារពើនៅក្នុងនោះដែរ
១២ចូរឱ្យស្រែចំការ នឹងរបស់ទាំងប៉ុន្មាន ដែលមាននៅទី
នោះ បានសប្បាយឡើងយ៉ាងក្រៃលែង នោះអស់ទាំង
ដើមឈើ[វ] នៅព្រៃនឹងច្រៀងដោយអំណរដែរ[ស]
១៣គឺនៅចំពោះព្រះយេហូវ៉ា ដ្បិតទ្រង់យាងមក
គឺទ្រង់យាងមក ដើម្បីជំនុំជំរះផែនដី
ទ្រង់នឹងជំនុំជំរះ[ហ]លោកីយ ដោយសេចក្ដីសុចរិត[ឡ]
ព្រមទាំងសាសន៍ទាំងប៉ុន្មាន ដោយសេចក្ដីពិតត្រង់របស់
ទ្រង់[អ] ។

**៩៧** ព្រះយេហូវ៉ាទ្រង់គ្រប់គ្រង[ក] គួរឱ្យផែនដីអរសប្បាយ
ឡើង[ខ] គួរឱ្យពួកកោះ[គ]ដ៏មានជាច្រើន មានសេចក្ដីអំណរ
ដែរ
២មានពពក[ឃ] និងសេចក្ដីងងឹត[ង]បាំងជុំវិញទ្រង់ សេចក្ដី
សុចរិត និងសេចក្ដីយុត្តិធម៌ជាជើងថ្កល់បល្ល័ង្កទ្រង់[ច]

**៩៦:១០** ផ ទដ ៩១:១ ប ទដ ២៤:២ ៧៨:៦៩ ១១៩:៩០ ភ ទដ ៩៣:១ ម ទដ ៥៨:១១ យ ទដ ៦៧:៤ ៩៨:៩ **៩៦:១១** រ វវ ១២:១២ ល ទដ ៩៧:១ អស ៤៩:១៣ **៩៦:១២** វ អស ៤៤:២៣ ៥៥:១២ អក ១៧:២៤ ស ទដ ៦៥:១៣ **៩៦:១៣** ហ វវ ១៩:១១ ឡ ទដ ៧:១១ កច ១៧:៣១ អ ទដ ៨៦:១១ **៩៧:១** ក នក ១៥:១៨ ទដ ៩៣:១ ៩៦:១០ ៩៩:១ អស ២៤:២៣ ៥២:៧ ខ ទដ ៩៦:១១ គ នអ ១០:១ **៩៧:២** ឃ យប ២២:១៤ ង នក ១៩:៩ ច ទដ ៨៩:១៤

ចាស់ កាលណានិយាយពីលោកិយ គឺគេនិយាយសំដៅទៅលើទិដ្ឋភាពទូរទៅរបស់វា និងសីលធម៌ពីព្រោះទាំង២នេះ (ទិដ្ឋភាពទូរទៅ និងសីលធម៌) គឺព្រះអម្ចាស់ទ្រង់ជាអ្នកស្ថាបនាឡើង ដើម្បីឱ្យក្លាយជានគររបស់ទ្រង់ ។ ដូច្នេះការគ្រប់គ្រងរបស់ព្រះអម្ចាស់លើការបង្កើត និងលើការងាររបស់មនុស្ស គឺជានិច្ចកាល គឺនិយាយតាមរបៀបប្លែកៗពីគ្នា ហើយ"សេចក្ដីសុចរិត" "សេចក្ដីស្មោះត្រង់" និង"សេចក្ដីសប្បុរស"គឺមានតម្លៃស្មើគ្នា ។ ដោយព្រោះតែគ្រប់ទាំងអស់នៃការបង្កើតគឺសុទ្ធតែ "ល្អ" (សូមមើល លប ជំពូក ១) នោះជាញឹកញាប់ត្រូវបានកវីកំណាព្យក្នុងសញ្ញាចាស់ យកមកតាក់តែងកំណាព្យឡើង (ដូចជានៅទីនេះជាដើម) ដើម្បីបញ្ជាក់ពីការធានា ការគ្រប់គ្រងរបស់ព្រះអម្ចាស់លើមនុស្សជាតិ និងការងាររបស់គេ ស្មើៗគ្នា ដោយ"សេចក្ដីសុចរិត" និង "សេចក្ដីពិតត្រង់"(សូមមើល ខ.១៣ និង ៩:៧–៨ ១១:៣ ៣៣:៤–១១ ៣៦:៥–៩ ៥៧:១០ ៥៨:១១–៦៥:៦–៧ ៧១:១៩ ៧៤:១៣–១៤,១៦–១៧ ៧៥:២ ៨២:៥ ៩៣:៣–៤ ៩៨:៩ ៩៩:៤ ១១៩:៨៩–៩១ និងការពន្យល់) ។ *នឹងជំនុំជំរះ* សូមមើល ខ.១៣ និងការពន្យល់ ។

**៩៦:១១–១២** នៅក្នុងខទាំងនេះ ចង់និយាយថា ដោយព្រោះតែការគ្រប់គ្រងរបស់ព្រះអម្ចាស់ (សូមមើល ខ.១០ និងការពន្យល់) បានធ្វើឱ្យគ្រប់ទាំងអស់ដែលទ្រង់បង្កើតមកមានអំណរ នៅពេលដែលព្រះអម្ចាស់គ្រប់គ្រងលើមនុស្សជាតិប្រកបដោយសេចក្ដីសុចរិត ដើម្បីបំពេញលើនគររបស់ទ្រង់ (សូមមើលការពន្យល់ ៦៥:១៣ និង ៩៧:៧–៩) ។

**៩៦:១៣** *យាងមក . . . យាងមកដើម្បីជំនុំជំរះ* នៅក្នុងឃ្លានេះចង់និយាយថាដោយព្រោះតែព្រះអង្គជាអ្នកគ្រប់គ្រងលើទាំងអស់ និងការដែលទ្រង់ផ្ដល់សេចក្ដីសង្ឃឹមដើម្បីឱ្យពួកអ៊ីស្រាអែល (ដូចអ្វីដែលពួកហោរាបាននិយាយ) ក្នុងគ្រា"យាងមក"របស់ព្រះអង្គ នោះការងាររបស់ព្រះអង្គនាថ្ងៃអនាគតគឺទ្រង់នឹងយាងមកដើម្បីជំនុំជម្រះដល់ពួកមនុស្សអាក្រក់ ហើយនិងលើកមនុស្សសុចរិតឡើង ។ *សេចក្ដីសុចរិត* សូមមើលការពន្យល់ ៤:១ ។

**ទដ ៩៧** នៅក្នុងជំពូកនេះ និយាយពីការអបអរដោយអំណរចំពោះសេចក្ដីសុចរិតនៃព្រះដែលគ្រប់គ្រងលើពិភពលោកទាំងមូល (សូមមើលក្នុងសេចក្ដីផ្ដើម ទដ ៩៣,៩៥) និងបញ្ញាស្មារតីពិសេសនៃការគ្រប់គ្រងរបស់ទ្រង់ដែលធ្វើឱ្យពួកអ៊ីស្រាអែលមានអំណរយ៉ាងខ្លាំង (សូមមើលក្នុងសេចក្ដីផ្ដើម ទដ ៩៦) ។ ព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះបានចែកជា២វគ្គស្មើគ្នា (ខ.១–៦, ៨–១២ ក្នុងវគ្គនិមួយស្មើរតែដូចគ្នា គឺមានភាសាហេព្រើរ ៤២ និង ៤៣ ពាក្យ) ដែលមានខស្នូល (ខ.៧ និងការពន្យល់ ៦:៦) ដែលមានតួរនាទីជាផ្ទៃរឿងស្នូល ។ នៅខដំបូងនៃការចាប់ផ្ដើមក្នុងវគ្គទាំង២ គឺមានទំនាក់ទំនងជាមួយគ្នា ។ ខ១ បាននិយាយថា "ចូរឱ្យផែនដីបានអរសប្បាយឡើង . . . អំណរ"ហើយក្នុង ខ.៨ បាននិយាយថា "សេចក្ដីអំណរ . . . រីករាយ" ។ នៅក្នុងវគ្គទី ១និយាយពី "ផែនដី"(ខ.១) និងបញ្ចប់ដោយ"ផ្ទៃមេឃ"(ខ.៦) ហើយនៅ ក្នុងវគ្គទី២ ចាប់ផ្ដើម "ក្រុងស៊ីយ៉ូន . . . សាសន៍យូដា" (ខ.៨) ហើយចប់ដោយពាក្យថា "មនុស្សសុចរិត"(ខ.១២) ។

**៩៧:១–៦** នៅក្នុងខទាំងនេះ គឺជាសេចក្ដីបន្ទាល់ចំពោះពួកសាសន៍ដទៃ ក្នុងកាលដែលគេបានឃើញការអស្ចារ្យរបស់ព្រះ (ខ.២–៦) ហើយមានអំណររីករាយជាមួយពួកអ៊ីស្រាអែល ក្នុងការអបអរចំពោះរាជ្យនៃព្រះយេហូវ៉ា ។

**៩៧:១** *ព្រះយេហូវ៉ាទ្រង់គ្រប់គ្រង* សូមមើល ៩៣:១ និងការពន្យល់ ។ *ផែនដី* សូមមើល ៩៦:១ ៩៩:១ ១១៧:១ និងការពន្យល់ ៩:១ ។ *ពួកកោះ* នៅក្នុងឃ្លានេះចង់និយាយសំដៅលើផែនដីឯនាយ ដែលនៅឆ្ងាយសន្លឹម អាចទៅបានតែកប៉ាល់ប៉ុណ្ណោះ (សូមមើល ១ពវ ៩:២៦–២៨ ១០:២២ អស ៦០:៩ យហ ១:៣) ។

**៩៧:២–៦** នៅក្នុងខទាំងនេះ គឺនិយាយពីអំណាចចេស្ដារបស់ព្រះអម្ចាស់ ដ៏គួរឱ្យភ័យខ្លាច ដែលបានបង្ហាញនៅលើផ្ទៃមេឃ ជាពិសេសគឺផ្គរលាន់ (សូមមើល ១៨:៧–១៥ និងការពន្យល់ និងសេចក្ដីផ្ដើម ទដ ២៩) ។

**៩៧:២** *ពពក និងសេចក្ដីងងឹត* នៅក្នុងឃ្លានេះគឺនិយាយថា ពពកខ្មៅដែលបាំងចាំងព្រះអាទិត្យ ហើយវាយបំបែកវិញ្ញាណអាក្រក់ឱ្យខ្ចាត់ខ្ចាយនៅលើផ្ទៃមេឃ គឺជាវិនាសកម្មមួយដែលមើលឃើញនឹងភ្នែកបានរំឭកយើងពីភាពកាចសាហាវនៃកំដៅ និងពន្លឺចាំងចែងនៃសិរីល្អរបស់ព្រះ គឺបានបាំងពីភ្នែកជីវិតទាំងឡាយដែលព្រះអង្គបង្កើតមក (សូមមើល នក ១៩:៩ ១ពវ ៨:១២) ។ ដូច្នេះហើយបានវាំងននដែលបាំងនៅក្នុងទីបរិសុទ្ធបំផុតក្នុងរោងឧបោសថ និងក្នុងព្រះវិហារ (សូមមើល នក ២៦:៣៣ ២របា ៣:១៤) បានបាំងក្នុងទីងងឹត ។ *សេចក្ដីសុចរិត* សូមមើល ខ.៦ និងការពន្យល់ ៤:១ ។ *ជាជើងថ្កល់បល្ល័ង្កទ្រង់* គឺព្រះអម្ចាស់ទ្រង់គ្រប់គ្រងដោយអំណាចចេស្ដារបស់ទ្រង់ (សូមមើល ៦៦:៧) ប៉ុន្តែរាជ្យរបស់ទ្រង់វិញបានថ្កល់លើសេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌ ដែលផ្ទៃមេឃបានសម្តែងនិងប្រកាសប្រាប់

៣មានភ្លើង[ឆ]ចេញទៅនៅចំពោះ[ជ]ទ្រង់ ឆេះបំផ្លាញ[ឈ]ពួក
ដែលតតាំងនឹងទ្រង់នៅជុំវិញ
៤ផ្លេកបន្ទោរ[ញ]របស់ទ្រង់ក៏បំភ្លឺលោកីយ ផែនដី[ដ]បានឃើញ
ហើយញាប់ញ័រ[ឋ]
៥អស់ទាំងភ្នំបានរលាយទៅ[ឌ] ដូចជាក្រមួន[ឍ]នៅចំពោះព្រះ
យេហូវ៉ា គឺនៅចំពោះព្រះអម្ចាស់នៃផែនដីទាំងមូល[ណ]
៦ផ្ទៃមេឃប្រកាសប្រាប់ពីសេចក្ដីសុចរិតរបស់ទ្រង់[ត]
ហើយគ្រប់ទាំងសាសន៍បានឃើញសិរីល្អនៃទ្រង់[ថ]
៧សូមឱ្យអស់អ្នកដែលគោរពប្រតិបត្តិដល់រូបឆ្លាក់[ទ]មាន
សេចក្ដីខ្មាស[ធ] គឺជាពួកអ្នកដែលអួតពីរូបព្រះ[ន]ទាំងប៉ុន្មាន
នៃ ព្រះទាំងឡាយ[ប] ចូរថ្វាយបង្គំដល់ទ្រង់ចុះ[ផ]
៨ឱព្រះយេហូវ៉ាអើយ ក្រុងស៊ីយ៉ូនបានឮហើយ ក៏មាន
សេចក្ដីអំណរ[ព]ពួកកូនស្រីនៃសាសន៍យូដាបានរីករាយ
ឡើង ដោយព្រោះបញ្ញត្តិ[ភ]ទាំងប៉ុន្មានរបស់ទ្រង់
៩ដ្បិត ឱព្រះយេហូវ៉ាអើយ ទ្រង់ជាព្រះខ្ពស់បំផុត[ម]
នៅលើផែនដីទាំងមូល[យ]ទ្រង់ថ្កើងឡើង[រ]យ៉ាងពិសេស
ជាងអស់ទាំងព្រះ

**៩៧:៣** ឆ អស ៩:១៩ ដយ ៧:១០ យអ ១:១៩ ២:៣ ជ ហព ៣:៥ ឈ ២សយ ២២:៩ **៩៧:៤** ញ យប ៣៦:៣០ ដ ២សយ ២២:៨ ឋ ទដ ១៩:៧ ១០៤:៣២ វវ ៦:១២ **៩៧:៥** ឌ ទដ ៤៦:២,៦ ឍ ទដ ២២:១៤ ណ យស ៣:១១ **៩៧:៦** ត ទដ ៥០:៦ ៩៨:២ ថ ទដ ១៩:១ **៩៧:៧** ទ លវ ២៦:១ ធ អស ៤២:១៧ យរ ១០:១៤ ន ទដ ៥:៨ ប នក ១២:១២ ទដ ១៦:៤ ផ ហព ១:៦ **៩៧:៨** ប ទដ ៩:២ ភ ទដ ៤៨:១១

១០ឱពួកអ្នកស្រឡាញ់ដល់ព្រះយេហូវ៉ាអើយ ចូរស្អប់ការ
អាក្រក់ចុះ[ល] ទ្រង់ទំនុកបំរុង[វ]ព្រលឹងនៃពួកអ្នកបរិសុទ្ធ[ស]
របស់ទ្រង់ក៏ជួយគេឱ្យរួច[ហ]ពីកណ្ដាប់ដៃនៃពួកមនុស្ស
អាក្រក់[ឡ]
១១មានពន្លឺ បានសាបព្រោះ[អ]ទៅ សំរាប់មនុស្សសុចរិត[ក]
និងសេចក្ដីអំណរ សំរាប់មនុស្សដែលមានចិត្តទៀងត្រង់[ខ]
១២ឱមនុស្សសុចរិតអើយ[គ] ចូរមានសេចក្ដីរីករាយក្នុងព្រះ
យេហូវ៉ា ហើយអរព្រះគុណ ឱ្យជាទីរឭកដល់សេចក្ដី
បរិសុទ្ធរបស់ទ្រង់ចុះ[ឃ] ។

ទំនុក ។

**៩៨** ចូរច្រៀងបទថ្មី[ក]ថ្វាយព្រះយេហូវ៉ា[ខ]ពីព្រោះទ្រង់បាន

**៩៧:៩** ម ទដ ៧:៨ យ យប ៣៤:២៩ រ ទដ ៤៧:៩ **៩៧:១០** ល យប ២៨:២៨ អម ៥:១៥ រម ១២:៩ វ ទដ ១៤៥:២០ ស ទដ ៣១:២៣ ៣៧:២៨ សភ ២:៨ ហ ទដ ៣៤:៧ ដយ ៣:២៨ ៦:១៦ ឡ ទដ ៣៧:៤០ យរ ១៥:២១ ២០:១៣ **៩៧:១១** អ យប ២២:២៨ ក ទដ ១១:៥ ខ ទដ ៧:១០ **៩៧:១២** គ យប ២២:១៩ ទដ ១០៤:៣៤ អស ៤១:១៦ ភល ៤:៤ ឃ នក ៣:១៥ ទដ ៩៩:៣ **៩៨:១** ក ទដ ៩៦:១ ខ ទដ ៣០:៤

(សូមមើល ខ.៦ និងការពន្យល់) ។ ដូច្នេះ បល្ល័ង្ករបស់ទ្រង់គឺបានស្ថាបនាឡើងដោយសេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌បានក្លាយជាសុភាសិតមួយនៅក្នុងប្រទេសអ៊ីស្រាអែល (សូមមើល សភ ១៦:៣២ ២៥:៥ ២៩:១៤ ហើយផ្ទៀបជាមួយ ទដ ៩:៧–៨ ១០៣:៦–១៩ និងការពន្យល់) ។

**៩៧:៣** *ភ្លើង* ភ្លើងនេះជាពន្លឺស្រាលៗដែលមាននៅក្នុងពពកដែលបង្ហាញឱ្យជាក់ស្តែង (សូមមើល ខ.៤) ។ ជានិច្ចកាលភ្លើងគឺពណ៌នាពីការជំនុំជម្រះរបស់ព្រះអង្គដោយសេចក្ដីក្រោធ (សូមមើល ២១:៩ ៥០:៣ ៨៣:១៤ ចទ ៤:២៤ ៩:៣ ៣២:២២ ១ពវ ១៩:១២ អស ១០:១៧ ៣០:២៧,៣០ និងការពន្យល់ បទ ១:១៣) ។

**៩៧:៤** *ផែនដី* នៅទីនេះគឺនិយាយសំដៅលើផ្ទៃដី ។

**៩៧:៦** *ប្រកាសប្រាប់ពីសេចក្ដីសុចរិតរបស់ទ្រង់* នៅទីនេះគឺភាពធំល្វឹងល្វើយនៃផ្ទៃមេឃជាអ្នកសម្តែងពីសិរីល្អរបស់ព្រះ (សូមមើល ១៩:១–៤) គេបានប្រកាសថា ការគ្រប់គ្រងរបស់ព្រះគឺពោរពេញដោយសេចក្ដីទៀងត្រង់ និងខ្ពស់ (សូមមើលការពន្យល់ ៩៦:១០) ។ *គ្រប់ទាំងសាសន៍បានឃើញ* សូមមើល ខ.២–៦ ។

**៩៧:៧** នៅក្នុងខនេះ គឺជាចំណុចស្នូលក្នុងជំពូកនេះ (សូមមើលការពន្យល់ ៦:៦) ហើយក៏ជាចំណុចស្នូននៃទំនុកដំកើងជំពូកនេះដែរ ដែលបាននិយាយពីសេចក្ដីអំណររបស់ពួកអ្នកដែលគោរព និងថ្វាយបង្គំព្រះអម្ចាស់និងសេចក្ដីអៀនខ្មាសពីភាពអាម៉ាស់របស់ពួកអ្នកទុកចិត្តចំពោះរូបព្រះ ។ *ថ្វាយបង្គំដល់ទ្រង់* នៅក្នុងឃ្លានេះ អ្នកនិពន្ធបានចំអកឡកឡឺយដល់រូបព្រះដែលមនុស្សថ្វាយបង្គំដោយភាពល្ងង់ខ្លៅ ឱ្យមកថ្វាយបង្គំដល់ព្រះយេហូវ៉ាវិញ (សូមមើល ខ.៩ និង ២៩:១ និងការពន្យល់) ។

**៩៧:៨–១២** នៅក្នុងខទាំងនេះ គឺជាការប្រកាសពីសេចក្ដីអំណររបស់ក្រុងស៊ីយ៉ូនក្នុងកាលដែលទ្រង់យាងមកគ្រប់គ្រង (សូមមើល ខ.៨–៩) ហើយបានរំឭកថា មានតែអ្នកដែលស្អប់ខ្ពើមចំពោះការអាក្រក់ទេ ដែលមានអំណរចំពោះការគ្រប់គ្រងរបស់ព្រះយេហូវ៉ាដោយសុចរិត (សូមមើល ខ.១០–១២) ។

**៩៧:៨** *ក្រុងស៊ីយ៉ូនបានឮ* គឺបានឮពីការ "គ្រប់គ្រង" របស់ព្រះយេហូវ៉ា (សូមមើល ខ.១) ប្រកបដោយសេចក្ដីសុចរិត (ខ.៦) ។

**៩៧:៩** *ខ្ពស់បំផុត* សូមមើលការពន្យល់ លប ១៤:១៩ ។

**៩៧:១០** *ពួកអ្នកសុចរិត* សូមមើលការពន្យល់ ៤:៣ ។

**៩៧:១១** *ពន្លឺ* សូមមើល ២៧:១ និងការពន្យល់ និងក្នុង ៣៦:៩ ។ *មនុស្សសុចរិត* សូមមើល ខ.៩ និងការពន្យល់ ១:៥ ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**៩៧:១២** *ព្រះនាម* សូមមើលការពន្យល់ ៣០:៤ ។

**ទដ ៩៨** នៅក្នុងព្រះគម្ពីរទំនុកដំកើងជំពូកនេះ បាននិយាយពីការត្រាស់ហៅដល់មនុស្សទាំងអស់ ឱ្យចូលមកអបអរសាទរចំពោះរាជ្យដ៏សុចរិតរបស់ព្រះយេហូវ៉ា (សូមមើលក្នុងសេចក្ដីផ្ដើម ទដ ៩៣,៩៥) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ បានចាប់ផ្ដើម និងបញ្ចប់ដោយនិយាយពីការសរសើរតម្កើងដែលបានដកស្រង់ឃ្លាចេញពីទំនុកដំកើង ជំពូក ៩៦ ដល់ព្រះយេហូវ៉ា (សូមមើលក្នុងសេចក្ដីផ្ដើម ទដ ៩៦) ។ នៅក្នុងជំពូកនេះមាន៣ល្បះធំគឺ (១).ការថ្វាយបង្គំរបស់ពួកសហធម្មចារីនៅត្រង់ព្រះវិហារ (២).ការថ្វាយបង្គំរបស់មនុស្សទាំងអស់នៅលើផែនដី (៣).និយាយពីរបស់សព្វសារពើទាំងអស់ដែលព្រះអង្គបានបង្កើតមក ។ នៅក្នុងល្បះទី១បានរំឭកឱ្យឃើញពីសេចក្ដីសុចរិតរបស់ព្រះយេហូវ៉ា (ខ.២) តាំងពីគ្រាមុន ហើយនៅក្នុងល្បះចុងក្រោយអ្នកនិពន្ធបាននិយាយដោយទំនុកចិត្តថា នៅពេលដែលព្រះយេហូវ៉ាយាងមកទ្រង់នឹងគ្រប់គ្រងដោយ "សុចរិត" (ខ.៩) ហើយចំណែកឯល្បះកណ្ដាលវិញបាននិយាយពីសម្រែកដ៏មានអំណរ "ចូរឡើងសម្លេងដោយ

ធ្វើការយ៉ាងអស្ចារ្យ[គ] ព្រះហស្តស្តាំ[ឃ]និងព្រះពាហុដ៏
បរិសុទ្ធ[ង]របស់ទ្រង់បាននាំឱ្យទ្រង់មានជ័យជំនះ[ច]
២ ព្រះយេហូវ៉ាទ្រង់បានសំដែងឱ្យស្គាល់[ឆ]សេចក្តីសង្គ្រោះ
របស់ទ្រង់ធ្វើឱ្យសេចក្តីសុចរិត[ជ]របស់ទ្រង់ប្រាកដ
ច្បាស់នៅចំពោះភ្នែកនៃអស់ទាំងសាសន៍[ឈ]
៣ ទ្រង់បាននឹកចាំ[ញ]ពីសេចក្តីសប្បុរស និងសេចក្តីស្មោះត្រង់
របស់ទ្រង់ ចំពោះវង្សអ៊ីស្រាអែលហើយ អស់ទាំងចុង
ផែនដី[ដ]បានឃើញសេចក្តីសង្គ្រោះរបស់ព្រះនៃយើងខ្ញុំ[ឋ]
៤ ចូរឡើងសំឡេងដោយអំណរ[ឌ]ថ្វាយព្រះយេហូវ៉ា
ឱផែនដីទាំងមូលអើយចូរទំលាយ ច្រៀងដោយអំណរ
អើ ចូរច្រៀងសរសើរចុះ
៥ ចូរច្រៀងបទសរសើរថ្វាយព្រះយេហូវ៉ាតាមស៊ុង[ឍ]
គឺដោយចាប់ស៊ុង ហើយដោយសំឡេងដ៏ពីរោះ[ណ]
៦ ដោយត្រែ[ត]និងស្នូរស្នែង[ថ]ផង ចូរឡើងសំឡេង
ដោយអំណរ[ទ]នៅចំពោះព្រះយេហូវ៉ាដ៏ជាមហាក្សត្រ[ធ]
៧ ចូរឱ្យសមុទ្រ[ន]លាន់ឮរំពងព្រមទាំងរបស់សព្វសារពើ
ដែលនៅក្នុងនោះ ហើយលោកីយ និងអស់អ្នកដែលនៅ
លោកីយផង[ប]
៨ ចូឱ្យអស់ទាំងទន្លេទះដៃ[ផ] ហើយឱ្យភ្នំ[ព]ទាំងប៉ុន្មានច្រៀង
ជាមួយគ្នាដោយអំណរ ៩ គឺនៅចំពោះព្រះយេហូវ៉ា
ដ្បិតទ្រង់យាងមកដើម្បីជំនុំជំរះផែនដី
ទ្រង់នឹងជំនុំជំរះលោកីយ ដោយសេចក្តីសុចរិត
ហើយអស់ទាំងសាសន៍ ដោយសេចក្តីទៀងត្រង់[ភ] ។

## ៩៩ ព្រះយេហូវ៉ាទ្រង់គ្រប់គ្រង[ក] ត្រូវឱ្យអស់សាសន៍ញាប់

**៩៨:១** គ នក ១៥:១ ទដ ៩៦:៣ អស ១២:៥ លក ១:៥១ ឃ នក ១៥:៦ ង យស ៤:២៤ យប ៤០:៩ អស ៥១:៩ ៥២:១០ ៥៣:១ ៦៣:៥ ច ទដ ៤៤:៣ អស ៥៩:១៦ **៩៨:២** ឆ អស ៥២:១០ លក ៣:៦ ជ ទដ ៩៧:៦ ឈ ទដ ៦៧:២ **៩៨:៣** ញ ១រប ១៦:១៥ ដ លប ៤៩:១០ ទដ ៤៨:១០ ឋ ទដ ៥០:២៣ **៩៨:៤** ឌ ទដ ២០:៥ អស ១២:៦ ៤៤:២៣ ៥២:៩ ៥៤:១ ៥៥:១២ **៩៨:៥** ឍ ទដ ៣៣:២ ៩២:៣ ១៤៧:៧ ណ អស ៥១:៣ **៩៨:៦** ត ជន ១០:២ ២សយ ៦:១៥ ថ នក ១៩:១៣ ទ ទដ ២០:៥ ១០០:១ អស ១២:៦ ធ ទដ ២:៦ ៤៧:៧ **៩៨:៧** ន ទដ ៩៣:៣ ប ទដ ២៤:១ **៩៨:៨** ផ ២ពវ ១១:១២ ព ទដ ១៤៨:៩ អស ៤៤:២៣ ៥៥:១២ **៩៨:៩** ភ ទដ ៩៦:១០ **៩៩:១** ក ១រប ១៦:៣១ ទដ ៩៧:១

អំណរ"(ខ.៤,៦) ។

**៩៨:១–៣** នៅក្នុងខទាំងនេះ និយាយពីការហៅដល់មនុស្សទាំងអស់ឱ្យចូលមកអបអរសាទរដោយច្រៀងចម្រៀងពីសេចក្តីសង្គ្រោះរបស់ព្រះ ដែលទ្រង់បានឱ្យចំពោះរាស្ត្រព្រះអង្គ ។

**៩៨:១** *បទថ្មី* សូមមើលការពន្យល់ ៣៣:៣ ។ *ការអស្ចារ្យ* សូមមើលការពន្យល់ ៩:១ ។

**៩៨:២** *សំដែង . . . ស្គាល់ . . . ប្រាកដកច្បាស់ . . . អស់ទាំងសាសន៍* នៅក្នុងឃ្លានេះគឺចង់និយាយថា សេចក្តីសង្គ្រោះរបស់ព្រះយេហូវ៉ាដែលទ្រង់បានធ្វើចំពោះរាស្ត្ររបស់ទ្រង់ គឺជាការបើកសម្តែងពីព្រះអង្គទ្រង់ដល់បណ្តាប្រជាជាតិផ្សេងៗ ។ នៅក្នុងហេតុការណ៍គឺចង់និយាយថា ព្រះយេហូវ៉ាទ្រង់ជាអ្នកដែលបានប្រកាសដំណឹងល្អដោយផ្ទាល់ (សូមមើល ៧៧:១៤ និងការពន្យល់ ៤៦:១០ និង អស ៥២:១០) ។ *សេចក្តីសង្គ្រោះ . . . សេចក្តីសុចរិត* នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាគឺជាព្រះនៃសេចក្តីសង្គ្រោះ និងសុចរិត (សូមមើល ៣៦:៥ និងការពន្យល់ ៣:៧) ។ ចង្កោមនៃឃ្លានេះជាញឹកញាប់គឺជាសេចក្តីសង្ខេបពីសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ដែលទ្រង់បានតាំងសញ្ញាជាមួយរាស្ត្រទ្រង់ (សូមមើលការពន្យល់ ៦:៤) ។

**៩៨:៤–៦** នៅក្នុងខនេះ អ្នកនិពន្ធបានហៅមនុស្សទាំងអស់ឱ្យមកអបអរសាទរចំពោះព្រះអម្ចាស់ ។

**៩៨:៤** សូមមើល ១០០:១ ។ *ផែនដីទាំងមូល* គឺនិយាយសំដៅលើបណ្តាជនដែលនៅលើផែនដី (សូមមើល ៩៦:១ និងការពន្យល់ និងមើល ៩៩:១) ។

**៩៨:៥** *ស៊ុង* សូមមើលការពន្យល់ លប ៣១:២៧ ។

**៩៨:៦** *ស្នែង* គឺជាវែងពិសេស ដែលគេផ្លុំនៅក្នុងទីបរិសុទ្ធ (ពាក្យនេះមាននិយាយតែកន្លែងនេះប៉ុណ្ណោះ សូមមើលការពន្យល់ ជន ១០:២–៣,១០) ។ *ស្នូរស្នែង* គឺជាស្នែងដែលខុសពីធម្មតា (ពាក្យនេះក៏មាននិយាយនៅក្នុង ៤៧:៥ ៨១:៣ ១៥០:៣ និងការពន្យល់ យអ ២:១) ។

**៩៨:៧–៩** នៅក្នុងខនេះ គឺជាការហៅដល់របស់សព្វសារពើ ទាំងអស់ឱ្យមកសរសើរដល់ព្រះអម្ចាស់ (សូមមើលការពន្យល់ ៩៦:១១–១២) ។

**៩៨:៧** *សមុទ្រ . . . លោកិយ* នៅក្នុងឃ្លាទាំង២នេះគឺជាតំបន់ដ៏សំខាន់សម្រាប់ជីវិតទាំងឡាយដែលព្រះអម្ចាស់បង្កើតមក ។

**៩៨:៨** *សមុទ្រ . . . ភ្នំ* នៅក្នុងឃ្លានេះ គឺចង់និយាយថា ចាប់តាំងពីសមុទ្ររហូតដល់ភ្នំ នោះសូមឱ្យគ្រប់ទាំងអស់ដែលមានដង្ហើមបានទះដៃ និងច្រៀងសរសើរតម្កើងដល់ព្រះ(សូមមើលការពន្យល់ ៦៥:១៣) ។

**៩៨:៩** *យាងមកដើម្បីជំនំជំរះ:* សូមមើល ៩៦:១៣ និងការពន្យល់ ។ នៅក្នុងឃ្លានេះ ចង់និយាយសំដៅលើសេចក្តីជំនឿរបស់ពួកអ៊ីស្រាអែលកាលពីមុន (ខ.១–៣) សេចក្តីសុចរិតរបស់ព្រះក្នុងថ្ងៃអនាគត ។ *សេចក្តីសុរិត . . . ទៀងត្រង់* សូមមើល ៩៦:១០ និងការពន្យល់ ។

**ទដ៩៩** នៅក្នុងជំពូកនេះ គឺជាបទចម្រៀងនៃការសរសើរតម្កើងដល់ព្រះយេហូវ៉ា ក្នុងនាមទ្រង់ជាស្តេចដ៏ធំហើយបរិសុទ្ធដែលបានគង់នៅក្នុងក្រុងស៊ីយ៉ូនពិសេសចំពោះគុណប្រយោជន៍នៃរាជ្យទ្រង់សម្រាប់ពួកអ៊ីស្រាអែល ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះមានទំនាក់ទំនងជាមួយទដ ៩៧ (សូមមើលសេចក្តីផ្តើមទដ ៩៦) ។ ដើម្បីវិវឌ្ឍន៍ផ្ទៃរឿងក្នុងជំពូកនេះ អ្នកនិព្វបានប្រើនិមិត្តរូបនៃចំនួនដ៏គ្រប់លក្ខណ៍មួយគឺលេខ ៧ ។ នៅក្នុងជំពូកនេះ អ្នកនិពន្ធបាននិយាយពីព្រះយេហូវ៉ាចំនួន៧ដង ហើយមាន៧ដងទៀតដែលគាត់បាននិយាយពីព្រះយេហូវ៉ា ដោយចង្អុលបង្ហាញតាមរយៈការប្រើទម្រង់វេយ្យាករណ៍ ជាសព្វនាមកម្មសិទ្ធឯករាជ្យ (តាមវេយ្យាករណ៍ហេព្រើរ) (សូមមើលក្នុងសេចក្តីផ្តើមទដ ៩៣) ។

ទម្រង់នៃការសរសេរក្នុងជំពូកនេះ មានភាពសមមាត្រនឹងគ្នាដោយបានបែងចែកជា៤ល្បះ ដែលមានកំណាព្យហេព្រើរ៣ ហើយបែងចែកជា២វគ្គធំៗ (ដោយមានបទបន្ទរ) ដែលមានតុល្យភាពជាមួយគ្នាដោយក្នុងវគ្គនិមួយៗមានភាសាហេព្រើរចំនួន ៤២ និង ៤១ ពាក្យ ។ ទម្រង់នៃការសរសេរមានលក្ខណៈសាមញ្ញ ដែលមានទំនាក់ទំនងជាមួយ ទដ ៩៧ (សូមមើលសេចក្តីផ្តើមទំនុកដំកើងជំពូកនោះ) ។ បទបន្ទរមួយចំនួនតិចតួច

ញ័រ[ខ] ទ្រង់គង់[គ]ពីលើចេរូប៊ីន[ឃ] ត្រូវឱ្យផែនដីកក្រើករំពើក
ចុះ
២ ព្រះយេហូវ៉ា[ង] ទ្រង់ធំប្រសើរក្នុងក្រុងស៊ីយ៉ូន[ច] ទ្រង់ខ្ពស់
លើស[ឆ]ទាំងបណ្ដាជន
៣ ចូរឱ្យគេសរសើរ[ជ]ដល់ព្រះនាមដ៏ធំហើយ[ឈ]
គួរស្ញែងខ្លាចរបស់ទ្រង់ចុះ ដ្បិតទ្រង់បរិសុទ្ធ[ញ] ។
៤ ឯកំលាំងនៃមហាក្សត្រ[ដ] នោះគឺដោយស្រឡាញ់ សេចក្ដី
យុត្តធម៌[ឋ]គឺទ្រង់ដែលតាំងឱ្យមានសេចក្ដីទៀងត្រង់[ឌ]
ទ្រង់ក៏សំរេចតាមសេចក្ដីយុត្តធម៌ និងសេចក្ដីសុចរិតនៅ
ក្នុងពួកយ៉ាកុប[ឍ]
៥ ចូរលើកដំកើង[ណ] ព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំ
ហើយថ្វាយបង្គំនៅទៀបកំណល់កល់ព្រះបាទទ្រង់
ដ្បិតទ្រង់បរិសុទ្ធ ។
៦ ឯម៉ូសេ[ត] និងអើរ៉ុន[ថ] ក្នុងពួកសង្ឃ ហើយសាំយូអែល[ទ]
ក្នុងពួកអ្នកដែលអំពាវនាវដល់ព្រះនាមទ្រង់គេបានអំពាវ
នាវដល់ព្រះនាមយេហូវ៉ា ហើយទ្រង់ក៏ទទួលព្រម[ធ]
៧ ទ្រង់មានបន្ទូលនឹងអ្នកទាំងនោះ នៅក្នុងបង្គោលពពក[ន]
គេបានរក្សាសេចក្ដីបន្ទាល់របស់ទ្រង់ព្រមទាំងក្រិត្យក្រម
ដែលទ្រង់ប្រទានឱ្យផង

**៩៩:១** ខ នក ១៥:១៤ ១រប ១៦:៣០ គ ២សយ ៦:២ ឃ នក ២៥:២២ **៩៩:២** ង ទដ ៤៨:១ ច ទដ ២:៦ ឆ នក ១៥:១ ទដ ៤៦:១០ ៩៧:៩ ១១៣:៤ ១៤៨:១៣ **៩៩:៣** ជ ទដ ៣០:៤ ៣៣:២១ ៩៧:១២ ១០៣:១ ១០៦:៤៧ ១១១:៩ ១៤៥:២១ ១៤៨:៥ ឈ ទដ ៧៦:១ ញ នក ១៥:១១ លវ ១១:៤៤ វវ ៤:៨ **៩៩:៤** ដ ទដ ២:៦ ឋ ១ពវ ១០:៩ ឌ ទដ ៩៨:៩ ឍ លប ១៨:១៩ វវ ១៥:៣ **៩៩:៥** ណ នក ១៥:២ **៩៩:៦** ត នក ២៤:៦ ថ នក ២៨:១ ទ ១សយ ៧:៥ **៩៩:៦** ធ ទដ ៤:៣ ៩១:១៥ **៩៩:៧** ន នក ១៣:២១ ១៩:៩ ជន ១១:២៥

ទៀតដែលនិយាយថា "ទ្រង់បរិសុទ្ធ" (សូមមើល ខ.៣,៥ និង ខ.៩) ប្រហែលគេប្រើ ជានិទ្ទេសបទ (សូមមើល អស ៦:៣ វវ៤:៨ និងក្នុង ទដ ៩៦:១–៣,៧–៩ និងការពន្យល់) ។

**៩៩:១–៣** នៅក្នុងខទាំងនេះបង្ហាញថា ព្រះយេហូវ៉ាទ្រង់បានគង់នៅក្នុងក្រុងស៊ីយ៉ូន ដើម្បីគ្រប់គ្រងលើអស់ទាំងបណ្ដាជន ដូច្នេះសូមឱ្យគេបានទទួលស្គាល់ព្រះអង្គ ។

**៩៩:១** *ព្រះយេហូវ៉ាទ្រង់គ្រប់គ្រង* សូមមើល ៩៣:១ និងការពន្យល់ ។ *ញាប់ញ័រ . . . កក្រើក* នៅក្នុងឃ្លានេះគឺនិយាយសំដៅលើការកោតខ្លាចដល់ព្រះយេហូវ៉ាយ៉ាងអស់ពីចិត្ត ។ *ចេរូប៊ីន* សូមមើល ៨០:១ និងការពន្យល់ នក ២៥:១៨ ។

**៩៩:៣** *ចូរឱ្យគេសរសើរ* ដោយព្រោះក្នុងនាមព្រះអង្គជាស្ដេចធំ នោះព្រះគួរនឹងទទួលបានការកោតខ្លាច (សូមមើល ខ.១) និងគោរពថ្វាយបង្គំ ។ *ព្រះនាម* សូមមើល ខ.៦ និងការពន្យល់ ៥:១១ ។ *បរិសុទ្ធ* សូមមើល ខ.៥,៩ និងសេចក្ដីផ្ដើមព្រះគម្ពីរលេវី ត្រង់ចំណុចទិវង្គានៃព្រះ ផ្ទៃរឿង និងការពន្យល់ លវ ១១:៤៤ ។

**៩៩:៤–៥** នៅក្នុងខទាំងនេះ ព្រះយេហូវ៉ាទ្រង់បានសម្ដែងសមត្ថភាពនៃការគ្រប់គ្រងរបស់ទ្រង់តាមរយៈការដែលទ្រង់បានធ្វើចំពោះពួកអ៊ីស្រាអែល ។

**៩៩:៤** *នោះគឺដោយស្រឡាញ់ សេចក្ដីយុត្តិធម៌* សេចក្ដីទាំង២នេះគឺជាចរិតលក្ខណៈចម្បងនៃរាជ្យរបស់ទ្រង់ ។ *តាំងឱ្យមានសេចក្ដីទៀងត្រង់* នៅក្នុងឃ្លានេះចង់មានន័យថា ព្រះអង្គទ្រង់បានផ្ដល់សេចក្ដីទៀងត្រង់ដល់លោកិយទាំងមូល ដោយមានលក្ខណ៍ជាពិសេសសម្រាប់ពួកអ៊ីស្រាអែល (សូមមើល ៩៦:១០ និងការពន្យល់) ។ *យ៉ាកុប* ពាក្យនេះគឺចង់សំដៅលើអ៊ីស្រាអែលទាំងមូល(សូមមើល លប ៣២:២៨) ។ *សេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិត* ក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់យុត្តិធម៌ និងសុចរិត (ដូចដែលមាននិយាយនៅក្នុង ៩៧:២ ។ ទោះបីជាផ្ទៃមេឃសំដែងពីសេចក្ដីសុចរិតនៃព្រះ (សូមមើល ៩៦:៧ និងការពន្យល់) ក៏ដោយ ក៏សេចក្ដីសុចរិតនៃព្រះបានសម្ដែងតាមរយៈសេចក្ដីសង្គ្រោះ ដែលទ្រង់ផ្ដល់ពួកអ៊ីស្រាអែលដែរ (សូមមើល ទដ ៩៨:២ និងការពន្យល់) ។

**៩៩:៥** សូមមើល ខ.៩ ។ សូមមើលបទបន្ទរផ្សេងៗទៀតក្នុងទំនុកដំកើងនៅក្នុងសេចក្ដីផ្ដើម ទដ ៤២–៤៣ ។ *កំណល់កល់ព្រះបាទ* កំណល់កល់ព្រះបាទ (សូមមើល ២រប ៩:១៨) ដែលនិយាយនៅទីនេះគឺជាពាក្យប្រៀបប្រដូចដែលទាក់ទងនៅនឹងរាជ្យបល្ល័ង្កនៅស្ថានសួគ៌ជាមួយនិងផែនដី ។ នៅពេលដែលព្រះអម្ចាស់ ទ្រង់បានគង់ប្រថាប់នៅលើបល្ល័ង្កនៅស្ថានសួគ៌ នោះផែនដីបានក្លាយជាកំណល់កល់ព្រះបាទទ្រង់ (នៅទីនេះគឺ"ភ្នំបរិសុទ្ធ" ខ.៩ និងក្នុង ១៣២:៧ ១រប ២៨:២ បទ២:១) ។

**៩៩:៦–៧** នៅក្នុងខនេះចង់មានន័យថា ព្រះយេហូវ៉ាទ្រង់បានធ្វើឱ្យមានសង្ឃក្នុងពួកអ៊ីស្រាអែលដើម្បីឱ្យធ្វើជា (១).អ្នកទូលអង្វរ ឬអំពាវនាវដល់ព្រះនាមទ្រង់ជំនួសរាស្ត្រទ្រង់ដែលបានប្រព្រឹត្តខុស ឬទន់ខ្សោយ (ខ.៦) (២).ពួកសង្ឃ គឺជាអ្នកទទួលចំណេះដឹងពីបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ ដូច្នេះហើយ ទើបពួកគេអាចបង្ហាត់បង្រៀនដល់ពួកអ៊ីស្រាអែល ។

**៩៩:៦** *ម៉ូសេ និងអើរ៉ុន . . . សាំយូអែល* ពួកគេទាំង៣នាក់ដែលនិយាយនៅទីនេះមានតួរនាទីជាអ្នកតំណាងឱ្យអ្នកទូលអង្វរជំនួសរាស្ត្រទ្រង់ ក្នុងគ្រាដែលពួកគេមានពិលាបយ៉ាងខ្លាំងក្រៃ ។ *ក្នុងពួកសង្ឃ . . . អំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា* នៅក្នុងឃ្លានេះចង់និយាយថា តួរនាទីរបស់ពួកសង្ឃក្នុងការទូលអង្វរឬអំពាវនាវជំនួសរាស្ត្រទ្រង់ គឺជាផ្នែកដ៏មានសារៈសំខាន់មួយ (សូមមើល នក ១៧:១១ និងការពន្យល់ ៣២:១១–១៣,៣១–៣២ ជន ១៤:១៣–១៩ ២១:៧ ១សយ ៧:៥,៨–៩ ១២:១៩,២៣ យរ ១៥:១) ។ *គេបានអំពាវនាវ . . . ទ្រង់ក៏ទទួលព្រម* សូមមើលការពន្យល់ ១១៨:៥ ។ *ទទួលព្រម* សូមមើល ខ.៨ ហើយសូមមើលការទទួលខុសត្រូវរបស់ព្រះអង្គចំពោះអ្នកដែលបានទូលអង្វរ ដែលមាននិយាយ ក្នុងការពន្យល់ ខ.៦–៧ ។

**៩៩:៧** *ទ្រង់មានបន្ទូលនឹងអ្នកទាំងនោះ នៅក្នុងបង្គោលពពក* នៅក្នុងឃ្លានេះប្រហែលនិយាយសំដៅលើពួកអ៊ីស្រាអែលទាំងអស់ (អ្នកទាំងនោះ) ជាជាងនិយាយសំដៅលើការដែលព្រះអម្ចាស់មានបន្ទូលមកកាន់ម៉ូសេ តែម្នាក់គាត់ (សូមមើល នក ៣៣:៩) និងលោកអើរ៉ុន (សូមមើល ជន ១២:៥–៦) ។ ប៉ុន្តែ ការបើកសម្ដែងពិសេសក្នុងទីរហោស្ថានដែលនិយាយនៅកន្លែងនេះប្រហែលបានរាប់បញ្ចូលជាមួយនឹងការបើកសម្ដែងរបស់ព្រះ ចំពោះហោរាសាំយូអែល ក្នុងគ្រាដែលព្រះអម្ចាស់ត្រាស់ហៅឱ្យធ្វើជាហោរារបស់ទ្រង់នៅក្នុងទីបរិសុទ្ធ ដែលហឹបនៃសេចក្ដីសញ្ញារបស់ព្រះស្ថិតនៅ (សូមមើល ១សយ ៣:៣ និង ១សយ ១២:២៣) ។ *គេបានរក្សា* ទោះបីជាយ៉ាងណាពាក្យនេះប្រហែលមិនពិតទាំងស្រុងឡើយ ។ មានតែក្នុងពួកអ៊ីស្រាអែលប៉ុណ្ណោះដែលបានស្គាល់ពីព្រះ ដូច្នេះហើយបានជាសេចក្ដីបន្ទាល់ពីសេចក្ដីសុចរិត និងក្រិតក្រមរបស់ព្រះបានរក្សាទុក (សូមមើល

៨ ឱព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំអើយ ទ្រង់បានមានបន្ទូល
តបនឹងអ្នកទាំងនោះ ទ្រង់ជាព្រះដែលអត់ទោសឱ្យគេ[ប]
ទោះបើទ្រង់បានធ្វើទោស[ផ] ចំពោះអំពើរបស់គេក៏ដោយ
៩ ចូរលើកដំកើងព្រះយេហូវ៉ា ជាព្រះនៃយើងហើយថ្វាយ
បង្គំនៅត្រង់ភ្នំបរិសុទ្ធរបស់ទ្រង់ចុះ ដ្បិតព្រះយេហូវ៉ា ជា
ព្រះនៃយើងខ្ញុំ ទ្រង់បរិសុទ្ធ ។

ទំនុកសំរាប់អរព្រះគុណ

**១០០** ម្នាល បណ្ដាជននៅផែនដីអើយ ចូរឡើងសំឡេង
ដោយអំណរ[ក] ថ្វាយព្រះយេហូវ៉ា
២ ចូរគោរពប្រតិបត្តិដល់ព្រះយេហូវ៉ា[ខ]
ដោយអរសប្បាយឱ្យចូលមកនៅចំពោះទ្រង់[គ]
ដោយច្រៀងចំរៀងចុះ
៣ ត្រូវឱ្យដឹងថា ព្រះយេហូវ៉ាទ្រង់ជាព្រះ[ឃ] គឺទ្រង់ដែលបាន
បង្កើតយើងខ្ញុំ[ង] យើងខ្ញុំជារបស់ផងទ្រង់ យើងខ្ញុំជារាស្ត្រ
របស់ទ្រង់[ច] ហើយជាហ្វូងចៀមនៅទីគង្វាលរបស់ទ្រង់[ឆ]
៤ ចូរនាំគ្នាចូលតាម ទ្វារទ្រង់ដោយពោលពាក្យអរព្រះ
គុណ[ជ] ហើយចូលនៅក្នុងទីលានទ្រង់[ឈ] ដោយបទសរសើរ
ចូរអរព្រះគុណដល់ទ្រង់ ហើយសរសើរព្រះនាមទ្រង់ចុះ[ញ]
៥ ពីព្រោះព្រះយេហូវ៉ាទ្រង់ល្អ[ដ] សេចក្ដីសប្បុរសនៃទ្រង់ស្ថិត
ស្ថេរនៅជានិច្ច[ឋ] ហើយសេចក្ដីស្មោះត្រង់[ឌ] របស់ទ្រង់ក៏នូវ
នៅអស់ទាំងដំណមនុស្សតទៅ ។

ទំនុកនៃស្ដេចដាវីឌ ។

**១០១** ទូលបង្គំនឹងច្រៀងពីសេចក្ដីសប្បុរស[ក] និងសេចក្ដី
យុត្តិធម៌ ឱព្រះយេហូវ៉ាអើយ

**៩៩:៨** ប នក ២២:២៧ ជន ១៤:២០ ផ លវ ២៦:១៨
**១០០:១** ក ទដ ៩៨:៦
**១០០:២** ខ ចទ ១០:១២ គ ទដ ៩៥:២
**១០០:៣** ឃ ១ពវ ១៨:២១ ទដ ៤៦:១០ ង យប ១០:៣ ច ទដ ៧៩:១៣ អស ១៩:២៥ ៦៣:៨, ១៧–១៩ ៦៤:៩ ឆ ២សយ ២៤:១៧ ទដ ៧៤:១
**១០០:៤** ជ ទដ ៤២:៤ ឈ ទដ ៩៦:៨ ញ ទដ ១១៦:១៧
**១០០:៥** ដ ១របា ១៦:៣៤ ឋ អរ ៣:១១ ទដ ១០៦:១ ឌ ទដ ១០៨:៤ ១១៩:៩០
**១០១:១** ក ទដ ៣៣:១ ៥១:១៤ ៨៩:១ ១៤៥:៧

១៤៧:១៩–២០ ចទ ៤:៥–៨) ។

**៩៩:៨–៩** នៅក្នុងឃ្លានេះចង់និយាយថា សេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិតនៃការគ្រប់គ្រងរបស់ព្រះចំពោះពួកអ៊ីស្រាអែល (សូមមើល ខ.៤) បានបង្ហាញតាមរយៈការឆ្លើយ តបចំពោះអំពើបាបរបស់ពួកគេ (សូមមើល នក ៣៤:៦–៧ និងការពន្យល់ ៤:១) ។

**៩៩:៩** *ភ្នំបរិសុទ្ធ* សូមមើល ខ.៥ និងការពន្យល់ ។

**ទដ ១០០** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានហៅដល់ម្នាល់ជនដែលនៅផែនដីឱ្យចូលមកសរសើរតម្កើងដល់ព្រះយេហូវ៉ា ។ ទោះបីជាបទគម្ពីរជំពូកនេះបានតែងឡើងក្នុងគោលបំណងបែបនេះមែន ឬក៏មិនមែនក៏ដោយ ក៏នៅចុងបញ្ចប់អ្នកនិពន្ធបានប្រើទម្រង់ប្រយោគ ដែលមានការទាក់ទងនឹងចង្កោមទំនុកដំកើងក្នុងប៉ែកនេះ ដែលចាប់ផ្ដើមតាំងពី ទដ ៩០ មកម្លេះ ។ លក្ខណៈពិសេសនៃព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺមានសណ្ឋានដូចគ្នានឹង ទដ ៩៥:១–២,៦–៧ និង ទដ ១១៧ ហើយសូមមើលក្នុងសេចក្ដីផ្ដើម ទដ ៩៣ ។ នៅផ្នែកទី២នៃបទគម្ពីរទំនុកដំកើងជំពូកនេះ (ខ.៤–៥) មានសណ្ឋានដូចគ្នានឹងសំណង់ប្រយោគដែលនិយាយនៅក្នុងផ្នែកទី១ដែរ (ខ.១–៣) គឺនិយាយពីការហៅឱ្យមនុស្សមកសរសើរតម្កើង និងមូលហេតុនៃការសរសើរតម្កើង ដូច្នេះ ទំនាក់ទំនងនៃផ្នែកទាំង២នេះគឺមានលក្ខណៈពេញបរិបូរ ។

**១០០ ត្រង់ចំណងជើង** *អរព្រះគុណ* គឺនិយាយសំដៅលើចម្រៀងអរព្រះគុណ (សូមមើល ខ.៤ និងការពន្យល់ ៧៥:១) ។ បទចម្រៀងបែបអរព្រះគុណនេះប្រហែលភ្ជាប់មកជាមួយនឹងដង្វាយ នៃការអរព្រះគុណផងដែរ (សូមមើល លវ ៧:១២) ។

**១០០:១** *ម្នាលជននៅផែនដី* ទោះបីជានៅក្នុង ខ.៣,៥ និយាយសំដៅលើទំនាក់ទំនងពិសេសរវាងព្រះនិងពួកអ៊ីស្រាអែលក៏ដោយ ក៏នៅក្នុងខនេះអ្នកនិពន្ធហៅដល់មនុស្សទាំងអស់ នៅលើផែនដីឱ្យចូលមកសរសើរតម្កើងដល់ព្រះអម្ចាស់ព្រះយេហូវ៉ា និងគោរពថ្វាយបង្គំដល់ព្រះនាមទ្រង់ ឱ្យទទួលស្គាល់ទ្រង់ក្នុងគ្រប់ការទាំងអស់ ដែលទ្រង់បានធ្វើចំពោះរាស្ត្រទ្រង់ (សូមមើល ទដ ៩៨–៩៩,១១៧) ។

**១០០:៣** *ដឹង* គឺសំដៅលើការទទួលស្គាល់ ។ *បង្កើតយើងខ្ញុំ* សូមមើល ៩៥:៦ និងការពន្យល់ ។ *ជាហ្វូងចៀមនៅទីគង្វាលទ្រង់* សូមមើល ៩៥:៧ និងការពន្យល់ ២៣:១ ។

**១០០:៤** *ទ្វារទ្រង់* គឺទ្វារនៃព្រះវិហារ (មើល ២៤:៧ និងការពន្យល់) ។ *ទីលាន* គឺទីលានព្រះវិហារ (មើល ៨៤:២,១០ ២ពវ ២១:៥ ២៣:១១–១២) ។

**១០០:៥** *ព្រះយេហូវ៉ាទ្រង់ល្អ* ពីព្រោះសេចក្ដីសប្បុរស និងសេចក្ដីស្មោះត្រង់របស់ទ្រង់ (សូមមើលការពន្យល់ ៣៦:៥) ស្ថិតស្ថេរជាដរាប (មើល ៨៨:៣ និងការពន្យល់) ។ *សេចក្ដីសប្បុរស* មើលការពន្យល់ ៦:៤) ។

**ទដ ១០១–១១០** នៅក្នុងជំពូកទាំងនេះ គឺជាបទទាំង១០ដែលស្ថិតនៅចន្លោះក្រុម២ទៀតនៃព្រះគម្ពីរទំនុកដំកើង (សូមមើលសេចក្ដីផ្ដើម ទដ ៩០–១០០, ១១១–១១៨) ហើយមាន២ជំពូកដែលនិយាយទាក់ទងទៅនឹងស្ដេច (ដំបូងគឺនិយាយពីព្រះរាជសម្បថរបស់ព្រះករុណា ដែលទាក់ទងទៅនឹងរាជ្យរបស់ទ្រង់ បន្ទាប់ពីមានការគ្រប់គ្រងប្រកបដោយសុចរិតរបស់ព្រះយេហូវ៉ា ហើយបន្ទាប់ទៀត និយាយពីសេចក្ដីសន្យារបស់ព្រះយេហូវ៉ាថា និងការពារព្រះករុណាដែលទ្រង់បានចាក់ប្រេងតាំងឱ្យ និងឱ្យមានជ័យជម្នះលើពួកខ្មាំងសត្រូវទាំងពួង) ។ ចង្កោមនៃព្រះគម្ពីរទំនុកដំកើងដ៏ខ្លីនេះ គឺបានប្រមូលផ្ដុំនិងចងក្រងទុកជាមុន ។ ព្រះគម្ពីរទំនុកដំកើង ១០២ និង ១០៩ និយាយពីសេចក្ដីអធិស្ឋានផ្ទាល់ខ្លួនក្នុងគ្រាដែលសេចក្ដីទុក្ខលំបាកយ៉ាងខ្លាំង ។ ចំណែកឯព្រះគម្ពីរទំនុកដំកើងជំពូក ១០៣ និង ១០៨ គឺជាបទនៃការសរសើរដល់ព្រះយេហូវ៉ាដ្បិត "សេចក្ដីសប្បុរសរបស់ទ្រង់ក៏ធំច្រើន" ក៏ខ្ពស់ដល់ពពកដែរ (សូមមើល ១០៣:១១ និង ១០៨:៤) ។ ជំពូក ១០៤ និង ១០៧ គឺជាចំណែកបន្ថែមទៀត ដ្បិតនៅក្នុង ជំពូក ១០៤ និយាយពីការអបអរសាទរចំពោះព្រះប្រាជ្ញាញាណដ៏ធំឧត្តមរបស់ព្រះយេហូវ៉ា និងសេចក្ដីមេត្តាករុណាក្នុងការបង្កើតជីវិតទាំងឡាយ ហើយ ជំពូក ១០៧ និយាយពីការអបអរចំពោះ "ការអស្ចារ្យរបស់ទ្រង់" (សូមមើល ខ.៨,១៥,២១,២៤,៣១) ដែលទ្រង់បានធ្វើចំពោះមនុស្សជាតិតាមរយៈការបង្ហាញថា ទ្រង់ជាម្ចាស់នឹងជាអ្នកគ្រប់គ្រងលើការបង្កើត ។ ចំណែកឯ២ជំពូកទៀតក៏ជាបទបន្ថែមដែរ ដោយនៅក្នុង

ទូលបង្គំនឹងច្រៀងសរសើរទ្រង់
២ទូលបង្គំនឹងប្រព្រឹត្តតាមផ្លូវគ្រប់លក្ខណ៍[ខ] ដោយប្រាជ្ញា
ឱកាលណាបានទ្រង់យាងមកឯទូលបង្គំទូលបង្គំនឹង
ប្រព្រឹត្ត[គ] ដោយចិត្តទៀតត្រង់នៅក្នុងផ្ទះទូលបង្គំ
៣ទូលបង្គំនឹងមិនតាំងរបស់អាក្រក់អ្វី[ឃ] នៅចំពោះភ្នែកទូល
បង្គំឡើយទូលបង្គំខ្ពើម[ង]កិច្ចការរបស់ពួកអ្នកដែលមិន
ទៀងកិច្ចការទាំងនោះនឹងមិនជាប់នៅខ្លួនទូលបង្គំឡើយ
៤ចិត្ត[ច] វៀចកោងនឹងត្រូវថយចេញពីទូលបង្គំទៅទូលបង្គំមិន
ព្រមស្គាល់សេចក្តីអាក្រក់ទេ

**១០១:២** ខ លប ១៧:១ ភល ១:១០ គ ១ពវ ៣:១៤ **១០១:៣** ឃ យរ ១៦:១៨ អគ ១១:២១ ហស ៩:១០ ង ទដ ៥:៥ **១០១:៤** ច សភ ៣:៣២ ៦:១៦–១៩ ១១:២០

នោះ ជំពូក ១០៥ បានពណ៌នាពីដំណើររឿងពីពួកអ៊ីស្រាអែលទទួលបានការប្រោសលោះហើយក្នុងជំពូក ១០៦ បានពណ៌នាពីដំណើររឿងនៃការបះបោររបស់អ៊ីស្រាអែល ។ ចង្កោមនៃព្រះគម្ពីរទំនុកដំកើងដ៏តិចតួចនេះដែរមានទម្រង់បែបបទជាច្រើន និងផ្ទៃរឿងគឺបានរកឃើញនៅក្នុងចង្កោមនៃទំនុកដំកើងនេះ ។ ផ្ទៃរឿងក្រៅពីនេះទៀតគឺជាការឧទ្ទិសថ្វាយដល់ទំនុករបស់ព្រះករុណាជីវិតដ៏កល់លើត្បូង ហើយចំណុចស្នូល២ទៀតបានរំឭកនិទានពីប្រវត្តិពួកអ៊ីស្រាអែលជាមួយព្រះអម្ចាស់ ។ នៅគ្រានោះផ្ទៃរឿងរបស់វាបានលាតត្រដាងតាំងពីការបង្កើតរបស់ព្រះ និងសេចក្តីសញ្ញាដ៏នៅអស់កល្បរបស់ព្រះ ក្នុងការដែលទ្រង់បានតាំងសញ្ញាជាមួយលោកអ័ប្រាហាំ អ៊ីសាក យ៉ាកុប និងការចាកចេញរបស់ពួកអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ ការចូលទឹកដីកាណាន ការនិរទេស ការស្ដាបនាឡើងវិញ ហើយនៅចុងក្រោយនិយាយពីជ័យជម្នះ ដ៏ធំលើពួកសាសន៍ដទៃក្រោមការចាក់ប្រេងតាំងមកពីព្រះ ។

**ទដ ១០១** នៅក្នុងជំពូកនេះ ពណ៌នាពីការតាំងព្រះទ័យរបស់ព្រះករុណាជីវិតដ៏កល់លើត្បូងក្នុងការគ្រប់គ្រងដោយសុចរិត (សូមមើល ២ពវ ២៣:៣) បន្ទាប់ពីការដែលព្រះអម្ចាស់ផ្ដល់គំរូនៃការគ្រប់គ្រង ។ សម្រាប់ទំនាក់ទំនងព្រះគម្ពីរជំពូកនេះ ទៅនឹង ជំពូក ១១០ សូមមើលក្នុងសេចក្តីផ្តើម ទដ ១០១–១១០ ។ បើសិនជាអ្នកជានិពន្ធជាស្តេចដាវីឌ (សូមមើលចំណងជើង) នោះប្រហែលបទគម្ពីរជំពូកនេះត្រូវបានតែងឡើង មុនគ្រាដែលហឹបនៃសេចក្តីសញ្ញារបស់ព្រះនាំយកមកកាន់ក្រុងយេរូសាឡិម (សូមមើលការពន្យល់ ខ.២ ២សយ ជំពូក ៦) ។ មានតែព្រះយេស៊ូវគ្រីស្ទជាវង្សហ្លួង របស់ព្រះបាទដាវីឌប៉ុណ្ណោះ ដែលជាអ្នកសម្រេចគ្រប់លក្ខណ៍លើការនេះ ។

នៅក្នុងជំពូកនេះបានតែងឡើងមាន៧វគ្គ (លេខ៧ជាចំនួនគ្រប់លក្ខណ៍) ។ ព្រះគម្ពីរជំពូកនេះបានចាប់ផ្តើមឡើងដោយមានសេចក្តីផ្តើម ២ស (សូមមើល ខ.១–៣ និងការពន្យល់ខាងក្រោម) ដែលមាន៥ល្បះ (ខ.៣–៨) ហើយបានពណ៌នាយ៉ាងល្អិតល្អន់ដល់ផ្ទៃរឿងក្នុងល្បះទី២ ។ ក្នុងចំណោមល្បះទាំង៥នោះមានល្បះកណ្តាល១ (ខ.៦) ដែលបានពណ៌នាពីការប្តេជ្ញារបស់ព្រះករុណាថា "ស្មោះត្រង់" និងប្រព្រឹត្តដោយ "ទៀងត្រង់" ហើយ៤ល្បះទៀត (ខ.៣–៤,៥,៧,៨) ប្រកាសប្រាប់ពីការបដិសេធន៍របស់ព្រះករុណាចំពោះ "ភាពមិនស្មោះត្រង់ " និង "ការអាក្រក់" នៅក្នុងទឹកដី (សម្រាប់ល្បះដែលប្រហាក់ប្រហែលគ្នាទាក់ទងទៅនឹងល្បះ ទី៦និង៧ជាមួយល្បះទី៣ និងទី៤ សូមមើលការពន្យល់ខាងក្រោម) ។ ល្បះកណ្តាលនេះមានទំនាក់ទំនងជាមួយល្បះទី១ និងទី២ដោយនិយាយពី "ទៀងត្រង់" (សម្រាប់ចំណុចស្នូល ព្រះគម្ពីរទំនុកដំកើងជំពូកនេះ សូមមើលការពន្យល់ក្នុង ៦:៦) ។ លក្ខណៈពិសេសនៃព្រះគម្ពីរទំនុកដំកើងជំពូកនេះទាំងមូលគឺដោយពណ៌នាពី "ព្រះយេហូវ៉ា" ដែលមាននៅក្នុងល្បះទី១ និងល្បះចុងក្រោយ (ខ.១,៨) ។ ចាប់តាំងពីល្បះទី២រហូតដល់ល្បះចុងក្រោយមានពាក្យស្ទួន២ដូចគ្នានឹងពាក្យស្ទួននៅដើមល្បះទី២ដែរ ("ក្នុងផ្ទះទូលបង្គំ"ខ.២,៧ និង "ចំពោះមុខទូលបង្គំ" ខ.៧) ហើយនៅក្នុងភាសាហេព្រើរពាក្យនេះមានន័យដូចគ្នានឹងឃ្លា "នៅចំពោះភ្នែកទូលបង្គំ" (ខ.៣) ។

**១០១:១–២** នៅក្នុងខនេះ គឺពណ៌នាពីគំរូភាពនៃរាជ្យរបស់ព្រះអម្ចាស់ដែលព្រះករុណាទ្រង់បានយកមកអនុវត្ត និងគំរូតាមក្នុងជីវិតរបស់ទ្រង់ ។

**១០១:១** *សេចក្តីសប្បុរស និងសេចក្តីយុត្តិធម៌* សេចក្តីទាំង២នេះគឺជាលក្ខណៈសម្បត្តិគ្រឹះនៃការគ្រប់គ្រងរបស់ព្រះយេហូវ៉ា (សូមមើល ៦:៤ ៩៩:៤ និងការពន្យល់) ។ សម្រាប់សារៈសំខាន់ពិសេសនៃការបញ្ចូលគ្នានៃឃ្លានេះ សូមមើល ហស ១២:៦ មីក ៦:៨ ហើយធៀបជាមួយ សក ៧:៩ ។ ឃ្លាបច្ចុប្បន្នកាលនេះប្រហែលកើតឡើងដោយទម្រង់ខ្លីនៃពាក្យ "សប្បុរស" និង "ស្មោះត្រង់" បញ្ចូលគ្នាជាមួយពាក្យថា "សេចក្តីសុចរិត និងសេចក្តីយុត្តិធម៌" (ដូចដែលមាននិយាយនៅក្នុង ៨៩:១៤ ហើយធៀបជាមួយ ៣៣:៥ ៣៦:៥–៦ ៤៨:៩–១១ អស ១៦:៥ ហស ២:១៩) ។

**១០១:២ក** *គ្រប់លក្ខណ៍* សូមមើល ខ.២,៦ និងការពន្យល់ លប ១៧:១ ។ *កាលណា* តាមរយៈឃ្លានេះប្រហែលអ្នកនិពន្ធចង់បង្ហាញពីបំណងប្រាថ្នារបស់ស្តេចដាវីឌ ដែលទ្រង់ព្រះករុណាចង់បានហឹបនៃព្រះ ក្នុងក្រុងរបស់ទ្រង់ ដើម្បីបង្ហាញពីសញ្ញាថា ព្រះវត្តមានរបស់ព្រះយេហូវ៉ា បានគង់នៅជាមួយទ្រង់ និងគាំទ្រចំពោះការគ្រប់គ្រង (សូមមើល ២សយ ជំពូក ៦ និងការពន្យល់ ២សយ ៦:២) ។ សម្រាប់ព្រះករុណាក្រោយៗទៀតអាចនឹងអង្វរដល់ព្រះអម្ចាស់ សូមឱ្យមានសមត្ថភាពក្នុងការគ្រប់គ្រងដែលមានទំនាក់ទំនងជាមួយ ខ.១–២ (សូមធៀបជាមួយ ទដ ៧២ ១ពវ ៣:៧–៩) ។

**១០១:២ខ–៣ក** នៅក្នុងខនេះនិយាយពីសារៈសំខាន់នៃការប្តេជ្ញាចិត្ត ។ *ចិត្ត . . . ភ្នែក* នៅក្នុងសញ្ញាចាស់ មនុស្សតែងតែមានការប្តេជ្ញាចិត្តក្នុងការធ្វើអ្វីមួយ ហើយការនេះ គឺចង់និយាយសំដៅលើអ្វីដែលស្ថិតនៅខាងក្នុង (សូមមើលការពន្យល់ ៤:៧)។ សេចក្តីបោកបញ្ឆោតនៃភ្នែកគឺជាភ្នែកដែលនៅខាងក្រៅ (មើល ១១៩:៣៧ ពច ១៤:១–២ ២សយ ១១:២ ២ពវ ១៦:១០ យប ៣១:១ សភ ៤:២៥ ១៧:២៤)។ សម្រាប់ការប្រើពាក្យថា ភ្នែក និងចិត្តចូលគ្នា សូមមើល ខ.៥ ជន ១៥:៣៩ យប ៣១:៧ សភ ២១:៤ សស ២:១០ យរ ២២:១៧ ។

**១០១:២ខ** *ផ្ទះ* គឺនិយាយសំដៅលើកិច្ចការងាររដ្ឋបាលរបស់ព្រះករុណា (សូមមើល ខ.៧) ។

**១០៣:៣ក** *ការអាក្រក់* ពាក្យនេះនៅក្នុងព្រះគម្ពីរភាសាហេព្រើរគឺ "អារក្សបេលាល" (មើល ២កថ ៦:១៥) និងមើលការពន្យល់ ចទ ១៣:១៣ ។

**១០១:៣ខ–៤** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានបដិសេធក្នុងការប្រព្រឹត្តិអាក្រក់ និងអ្នកដែលប្រព្រិត្តិ (សូមមើល ខ.៧) ។

**១០១:៣ខ** *មិនទៀង* គឺនិយាយសំដៅលើពួកអ្នកដែលបះបោរប្រឆាំងនឹងសេចក្តីដែលត្រឹមត្រូវ (សូមមើល ហស ៥:២) ។

**១០១:៤** *ចិត្តវៀចកោង* អត្តចរិតគេផ្ទុយពីពួក "ដែលប្រព្រឹត្តិតាមផ្លូវគ្រប់លក្ខណ៍"(សូមមើល ១៨:២៦ ត្រង់ពាក្យថា "ក្រវិចក្រវៀន" និងសូម មើល

៥ឯអ្នកណាដែលបង្កាច់អ្នកជិតខាងខ្លួន[ឆ]ដោយសំងាត់នោះ
ទូលបង្គំនឹងបំផ្លាញចេញ ហើយអ្នកណាដែលមានឫកខ្ពស់[ជ]
និងចិត្តឆ្មើងឆ្មៃ នោះទូលបង្គំនឹងទ្រាំមិនបានឡើយ
៦ឯភ្នែកទូលបង្គំ និងនៅលើពួកអ្នកស្មោះត្រង់ក្នុងស្រុក
ដើម្បីឱ្យគេបាននៅជាមួយនឹងទូលបង្គំវិញអ្នកណាដែល
ប្រព្រឹត្តតាមផ្លូវទៀងត្រង់[ឈ]អ្នកនោះឯងនឹងបំរើទូលបង្គំ
៧ឯអ្នកណាដែលប្រព្រឹត្តដោយភូតភរ នោះនឹងនៅក្នុងផ្ទះ
ទូលបង្គំមិនបានអ្នកណាដែលពោលកុហកក៏មិនធន់នៅ
ចំពោះមុខទូលបង្គំដែរ
៨រាល់តែព្រឹក[ញ]ទូលបង្គំនឹងបំផ្លាញ អស់ពួកមនុស្សអាក្រក់[ដ]
ចេញពីស្រុកទៅដើម្បីនឹងកាត់កាល់អស់ទាំងមនុស្សដែល
ប្រព្រឹត្តសេចក្ដីទុច្ចរិត[ឋ]ចេញពីទីក្រុងនៃព្រះយេហូវ៉ាបង់[ឌ]។

**១០១:៥** ឆ នក ២០:១៦ លវ ១៩:១៦ ជ ទដ ១០:៥
**១០១:៦** ឈ ខ.២ ទដ ១១៩:១
**១០១:៨** ញ ទដ ៥:៣ យរ ២១:១២ ដ ទដ ៧៥:១០ ឋ ២សយ ៣:៣៩ ទដ ១១៨:១០–១២ ឌ

សេចក្ដីអធិស្ឋានរបស់មនុស្សវេទនា
ក្នុងកាលដែលមានទុក្ខមកគ្របសង្កត់ ហើយបង្ហូរសេចក្ដីទំនួញ
របស់ខ្លួន នៅចំពោះព្រះយេហូវ៉ា ។

**១០២** ឱព្រះយេហូវ៉ាអើយ សូមស្ដាប់ សេចក្ដីអធិស្ឋាន[ក]

ទដ ៤៦:៤ **១០២:១** ក ទដ ៤:១

សភ ១១:២០ ១៩:១ ២៨:៦) ។ ចិត្តកោងកាច និងអណ្ដាត ភូតភរ (ខ.៧) គឺជាឫស និងផលផ្លែរបស់មនុស្សអាក្រក់ (សូមមើល សភ ១៧:២០) ។

**១០១:៥** នៅកក្នុងខនេះអ្នកនិពន្ធបានអះអាងថា គាត់នឹងបំផ្លាញចេញពីមុខគាត់ ចំពោះអ្នកណាដែលនិយាយបង្កាច់អ្នកជិតខាង និងមនុស្សប្រព្រឹត្តការអាក្រក់ (សូមមើល ខ.៨) ។ *បំផ្លាញ* គឺនិយាយសំដៅលើការបំផ្លាញបង់ (មើល ៥៤:៥ ៩៤:២៣ និងក្នុង ខ.៨) ។ *ឫកខ្ពស់ និងចិត្តឆ្មើងឆ្មៃ* មើល ខ.២ខ–៣ក និងការពន្យល់ ។ សេចក្ដីទាំងនេះគឺជា "ចង្កៀងរបស់មនុស្សអាក្រក់" (សូមមើល សភ ២១:១ ហើយធៀបជាមួយ ទដ ១៣១:១ អស ១០:១២ ។ មនុស្សកំណាចគេគ្មានមេត្តា (សូមមើល អស ១០:១២) ហើយច្បាប់ស្ថិតក្នុងមាត់ពួកគេ (មើលការពន្យល់ ៣១:២៣) ។

**១០១:៦** នៅក្នុងខនេះព្រះករុណាទ្រង់សន្យាថា នឹងហ៊ុំព័ទ្ធរាជ្យទ្រង់ដោយសេចក្ដីស្មោះត្រង់និងប្រព្រឹត្តិតាមផ្លូវទៀងត្រង់ ។ *ភ្នែកទូលបង្គំ នឹងនៅលើ* នៅក្នុងឃ្លានេះព្រះករុណាទ្រង់ចង់មានព្រះបន្ទូលថា ទ្រង់នឹងទតមើលពួកគេដោយសេចក្ដីមេត្តាករុណា (សូមមើល ៣៣:១៨ ៣៤:១៥) ។ *ពួកអ្នកស្មោះត្រង់* គឺជាពួកអ្នកដែលប្រកាន់ខ្ជាប់នឹងសីលធម៌ត្រឹមត្រូវ ។ *បំរើទូលបង្គំ* គឺមានន័យថា ជាអង្គរក្ស ឬអ្នកជិនិត (សូមមើល នក២៤:១៣ ជាអ្នកដែលត្រូវបានយកចិត្តទុកដាក់ (លប ៣៩:៤ ១ពវ ១៩:២១) និងជាអ្នកបម្រើផ្ទាល់ខ្លួន (សូមមើល ២ពវ ៤:៤៣) ជាមេទ័ព (សូមមើល ១បរ ២៧:១ ២របា ១៧:១៩ សភ ២៩:១២) ។

**១០១:៧** នៅក្នុងខនេះ អ្នកនិពន្ធបានបដិសេធន៍ចំពោះអ្នកដែលដើរតាមផ្លូវ២ (សូមមើល ខ.៣–៤) ។

**១០១:៨** នៅក្នុងចនេះអ្នកនិពន្ធបានអះអាងថា និងបំផ្លាញអ្នកដែលប្រព្រឹត្តិអាក្រក់ឱ្យបង់ពីនគរព្រះ (មើល ខ.៥) ។ *រាល់តែព្រឹក* គឺ និយាយសំដៅលើការព្យាយាមតស៊ូរ (សូមមើល យរ ២១:១២ សផ ៣:៥) ។ វាជាវប្បធម៌យ៉ាងសាមញ្ញ ដែលស្ដេចទ្រង់ចង់ឮសេចក្ដីយុត្តិធម៌នៅពេលព្រឹកក្នុងពេលកណ្ដាលយប់ពោរពេញទៅដោយខ្យល់ត្រជាក់ ។ នៅពេលនោះហើយ ជាគ្រាដែលអ្នករងគ្រោះ សុំឱ្យព្រះអង្គរំដោះគាត់ចេញពីការសង្កត់សង្កិន (ធៀបជាមួយ ៨៨:១៣ ១៤៣:៨ អស ៣៣:២) ។ *ក្រុងនៃព្រះ យេហូវ៉ា* សូមមើល ទដ ៤៦,៤៨,៨៧ និងការពន្យល់ ៣:៤ ។

**ទដ ១០២** នៅក្នុងជំពូកនេះ គឺជាសេចក្ដីអធិស្ឋានផ្ទាល់ខ្លួន នៅក្នុងគ្រាដែលមានសេចក្ដីទុក្ខវេទនា ។ សម្រាប់ទំនាក់ទំនងព្រះគម្ពីរទំនុកដំកើងជំពូកនេះជាមួយទំនុកដំកើង ជំពូក ១០៩ សូមមើលក្នុងសេចក្ដីផ្ដើម ទដ ១០១–១១០ ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងជំពូកនេះ ប្រហែលជាម្នាក់ដែលបានរស់នៅក្នុងស្ថានភាពដែលប្រជាជាតិកើតមានវិបត្តិភ័យ (សូមមើលការពន្យល់ត្រង់ចំណងជើង) ។ បើសិននេះជាមូលហេតុពិតមែន នោះសម្លេងសូរសៀងដែលបានឮនៅទីនេះ គឺអាចដូចគ្នានឹងសូរសៀងដែលប្រើពាក្យថា "យើងខ្ញុំ" ដែលមាននិយាយនៅក្នុង ទដ ៩០ ដែលអ្នកនិពន្ធក្នុងជំពូកនោះនិយាយពីខ្លួនគាត់ផ្ទាល់ (សម្រាប់ទំនាក់ទំនងផ្ទៃរឿងទំនុកដំកើងទាំង២ជំពូកនោះ សូមមើលការពន្យល់ខាងក្រោម) ។ ពួកអ្នកកាត់ស្រាយមួយចំនួនបានជឿថាពាក្យថា "ទូលបង្គំ" ដែលឃើញមាននៅក្នុង ខ.១–១១,២៣–២៤ គឺជាសម្លេងនៃមនុស្សជាច្រើនដែលគេប្រើថា "ទូលបង្គំ" (សូមមើលការពន្យល់ ទដ ៣០ ត្រង់ចំណងជើង) ប៉ុន្តែការនេះវាមិនសូវជាសំខាន់ប៉ុន្មានឡើយ ។ ពួកជំនុំសម័យដើម ពេលថ្វាយបង្គំគេបានប្រើទំនុកដំកើងជំពូកនេះ ដើម្បីបង្ហាញពីការប្រែចិត្ត ឬស្ដាយពីកំហុសដែលខ្លួនប្រព្រឹត្តិ (សូមមើលសេចក្ដីផ្ដើម ទដ ជំពូក ៦) ទោះបីជាមិនបានភ្ជាប់មកពីការលន់តួរបាបក៏ដោយ ។

តួរសេចក្ដីនៃព្រះគម្ពីរទំនុកដំកើងជំពូកនេះ (ខ.១–២២) បានបែងចែកជា៤ល្បះ (ល្បះទី១ គឺសូមឱ្យព្រះអម្ចាស់ទ្រង់បានស្ដាប់ឮសេចក្ដីអធិស្ឋានរបស់គាត់ ខ.១–២ ល្បះទី២ ពណ៌នាពីសេចក្ដីទុក្ខវេទនា ខ.៣–១១ ល្បះទី៣បង្ហាញពីការទំនុកចិត្តថា ព្រះអម្ចាស់ទ្រង់នឹងស្ដាប់ឬសេចក្ដីអធិស្ឋាន ខ.១២–១៧ ហើយល្បះចុងក្រោយគឺសូមឱ្យព្រះអម្ចាស់ទ្រង់បានរំដោះគាត់ដើម្បីឱ្យបានជាទីសរសើរជារៀងរហូត ខ.១៨–២២) និងបញ្ចប់ដោយការនិយាយសារដើមវិញ (ខ.២៣–២៨) ។

**១០២ ត្រង់ចំណងជើង** ព្រះគម្ពីរទំនុកដំកើងជំពូកនេះ គឺជាជំពូកតែ១គត់ក្នុងចង្កោមគម្ពីរទំនុកដំកើងក្នុងវគ្គនេះ (មិនប្រាប់ពីអ្នកនិពន្ធ ប្រភេទនៃបទចម្រៀង) ដែលចំណងជើងគ្រាន់តែនិយាយពីស្ថានភាពជីវិតរស់នៅក្នុងសម័យកាលនោះប៉ុណ្ណោះ ។ បើយោងទៅតាម ខ.១–១១,២៣–២៤ បង្ហាញថាសេចក្ដីអធិស្ឋានក្នុងជំពូកនេះគឺជាសេចក្ដីអធិស្ឋានបែបបុគ្គល ប៉ុន្តែ ខ.១២–២២,២៨ បានបង្ហាញពីសេចក្ដីទុក្ខវេទនារបស់ប្រជាជាតិ ។ ប្រហែលសេចក្ដីទុក្ខលំបាកនេះ គឺជាសេចក្ដីទុក្ខលំបាករបស់បុគ្គលផ្ទាល់ខ្លួនណាម្នាក់ ព្រោះបានពណ៌នាពីជំងឺថា វាជាលទ្ធផល១ដែលគាត់មានចំណែកក្នុងវិបត្តិភ័យដែលមាននៅក្នុងប្រទេសជាតិ ដូចជាការនិរទេសជាដើម ។ គំនិតបែបនេះ គឺដោយយោងទៅតាមការនិយាយពីការសង់ក្រុងស៊ីយ៉ូនឡើងវិញ ពីព្រោះតែព្រះគម្ពីរនេះ មានការទាក់ទងនៅនឹងភ័ព្វវាសនារបស់ព្រះករុណាជីវិតដំកល់លើត្បូងនិងប្រជាជាតិ ហើយដោយព្រោះផ្ទៃរឿងជាច្រើនមានចំណែកក្នុងហេតុការណ៍នេះ នោះវាគួឱ្យជឿបានថាសេចក្ដីអធិស្ឋានក្នុងជំពូកនេះគឺជាសេចក្ដីអធិស្ឋានរបស់ពួកកូនចៅស្ដេចដាវីឌ ឬជាសមាជិកនៃ

របស់ទូលបង្គំសូមឱ្យពាក្យដែលទូលបង្គំអំពាវនាវ[ខ]បានឮ
ដល់ទ្រង់
២ សូមកុំលាក់ព្រះភក្ត្រទ្រង់[គ]នឹងទូលបង្គំ ក្នុងថ្ងៃដែលទូល
បង្គំមានសេចក្តីទុក្ខលំបាកឡើយ
សូមផ្ទៀងព្រះកាណ៌[ឃ]ទ្រង់មក
ឯទូលបង្គំក្នុងថ្ងៃដែលទូលបង្គំស្រែកទូល
នោះសូមឆ្លើយមកទូលបង្គំជាប្រញាប់
៣ ត្បិតអស់ទាំងថ្ងៃនៃទូលបង្គំ រសាត់ទៅដូចជាផ្សែង[ង]
ហើយអស់ទាំងឆ្អឹង[ច]របស់ទូលបង្គំក៏ឆេះក្តៅដូចជាកន្ទុយ
ឧស
៤ ចិត្តទូលបង្គំត្រូវកាត់ចុះដូចជាស្មៅ[ឆ] ហើយ
ក៏ស្រពោនទៅដរាបដល់ទូលបង្គំភ្លេចទាំងទទួលទាន
អាហារផង[ជ]
៥ អស់ទាំងឆ្អឹងរបស់ទូលបង្គំជាប់ជិតនឹងសាច់
ដោយព្រះដំងូរ[ឈ]ដែលទូលបង្គំថ្ងូរជានិច្ច
៦ ទូលបង្គំប្រៀបដូចជាសត្វទុង[ញ]នៅទីរហោស្ថានក៏បាន
ត្រឡប់ដូចជាមៀម នៅទីសូន្យស្ងាត់
៧ ទូលបង្គំចាំយាម[ដ] ក៏ដូចជាចាបឥតគូ[ឋ]នៅលើដំបូលផ្ទះ

**១០២:១** ខ នក ២:២៣
**១០២:២** គ ទដ ២២:២៤ ឃ ២ពវ ១៩:១៦ ទដ ៣១:២ ៨៨:២
**១០២:៣** ង ទដ ៣៧:២០ យក ៤:១៤ ច បទ ១:១៣
**១០២:៤** ឆ ទដ ៣៧:២ ៩០:៥-៦ ជ ១សយ ១:៧ អរ ១០:៦ យប ៣៣:២០
**១០២:៥** ឈ ទដ ៦:៦
**១០២:៦** ញ ចទ ១៤:១៥-១៧ យប ៣០:២៩ អស ៣៤:១១ សផ ២:១៤
**១០២:៧** ដ ទដ ៧៧:៤ ឋ ទដ ៣៨:១១
**១០២:៨** ឌ ទដ ៣១:១១

៨ ពួកខ្មាំងសត្រូវ[ឌ]ពោលប្រទេចចំពោះទូលបង្គំ[ឍ]ជាដរាប
រាល់ថ្ងៃហើយពួកអ្នកដែលស្អប់ទូលបង្គំគេយកឈ្មោះទូល
បង្គំជាសេចក្តីផ្តាសា[ណ]
៩ ទូលបង្គំបានទទួលទានផេះ[ត]ទុកជាអាហារ ហើយបាន
លាយគ្រឿងផឹករបស់ទូលបង្គំដោយទឹកភ្នែក[ថ]
១០ ដោយព្រោះសេចក្តីថ្នាំងថ្នាក់ និងសេចក្តីក្រោធ[ទ]របស់
ទ្រង់ដ្បិតទ្រង់បានលើកទូលបង្គំឡើង
ហើយបោះចោលវិញ
១១ អស់ទាំងថ្ងៃអាយុនៃទូលបង្គំ ដូចជាស្រមោលដែលជ្រេ
ទៅ[ធ]ហើយទូលបង្គំក្រៀមទៅ[ន]ដូចជាស្មៅ ។
១២ ប៉ុន្តែ ឱព្រះយេហូវ៉ាអើយ ទ្រង់នឹងគង់សោយរាជ្យ
នៅអស់កល្បជានិច្ច[ប] ហើយនិងមានសេចក្តីនឹកចាំ[ផ]ពីទ្រង់
នៅអស់ទាំងដំណមនុស្សតទៅ[ព]

ឍ ទដ ៤២:១០ លក ២២:៦៣-៦៥ ២៣:៣៥-៣៧ ណ នក ២២:២៨ អស ៦៥:១៥ យរ ២៤:៩ ២៥:១៨ ៤២:១៨ ៤៤:១២ អគ ១៤:៨ សក ៨:១៣ **១០២:៩** ត អស ៤៤:២០ ថ ទដ ៦:៦ ៤២:៣ ៨០:៥ **១០២:១០** ទ ទដ ៧:១១ ៣៨:៣ **១០២:១១** ធ ១របា ២៩:១៥ យប ១៤:២ ទដ ៣៩:៦ ន យប ៨:១២ យក ១:១០ **១០២:១២** ប នក ១៥:១៨ ផ ទដ ១៣៥:១៣ អស ៥៥:១៣ ៦៣:១២ ប នក ៣:១៥

ពួកផ្ទះរបស់ទ្រង់ ក្នុងអំឡុងពេលនិរទេសទៅបាប៊ីឡូន ។ *សេចក្តីអធិស្ឋាន* មើល ខ.១,១៧ ។ *គ្របសង្កត់* មើល ៦១:២ ៧៧:៣ ១៤២:៣ ១៤៣:៤ និងក្នុង ១០៧:៥ យហ ២:៧ ។ *ទំនួញ* នៅក្នុងភាសាហេព្រើរ ពាក្យនេះមានន័យថា "រអ៊ូរទាំ" ដូចក្នុង ៦៤:១ ១៤២:២ យប ៧:១៣ ៩:២៧ ១០:១ ២១:៤ ។

**១០២:១-២** នៅក្នុងជំពូកនេះ អ្នកនិពន្ធសូមឱ្យព្រះអង្គបានស្តាប់ឮសម្រែកដែលគាត់បានអធិស្ឋាន ។

**១០២:២** *លាក់ព្រះភក្ត្រ* សូមមើលការពន្យល់ ១៣:១ ។ *ទូលបង្គំស្រែកទូល នោះសូមឆ្លើយ* សូមមើលការពន្យល់ ១១៨:៥ ។

**១០២:៣-១១** នៅក្នុងខទាំងនេះ គឺពណ៌នាពីសេចក្តីទុក្ខលំបាក និងការរងទុក្ខដែលធ្វើឱ្យរូបកាយ និងវិញ្ញាណត្រូវស្វិតដោយព្រោះតែសេចក្តីក្រោធរបស់ទ្រង់ (ខ.១០) ហើយធ្វើឱ្យខ្មាំងសត្រូវមើលងាយចំពោះគាត់ (ខ.៨) ។

**១០២:៣** *ដ្បិតអស់ទាំងថ្ងៃនៃទូលបង្គំ រសាត់ទៅដូចជាផ្សែង* សូមមើល ខ.១១,២៣ ។ *ឆ្អឹង . . . ឆេះ* សូមមើល ៣១:១០ ៣២:៣ ៤២:១០) ។

**១០២:៤** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ ចិត្តដែលនិយាយនៅទីនេះ គឺប្រើបញ្ចូលគ្នាជាមួយពាក្យថា "ឆ្អឹង" (ខ.៣) ហើយនិយាយសំដៅលើរូបកាយទាំងមូល(រូបកាយ និងវិញ្ញាណ) សូមមើល ២២:១៤ សភ ១៤:៣០ ១៥:៣០ អស ៦៦:១៤ ("ឯងរាល់គ្នា" ដែលនៅក្នុងភាសាហេព្រើរគឺ "ឆ្អឹងឯងរាល់គ្នា") យរ ២០:៩ ២៣:៩ ។ *កាត់* ឬ "ក្រៀមស្វិត" (ដោយព្រោះកំដៅថ្ងៃ) សូមមើល ១២៦:១ ។ *ស្រពោនទៅ* សូមមើល ខ.១១ ។

**១០២:៦** *សត្វទុង . . . មៀម* ពាក្យទាំង២នេះបានបកប្រែចេញពីភាសារ២ខុសគ្នា(សូមផ្ទៀបជាមួយ លវ ១១:១៦-១៨) ។ សត្វទុង ឬមៀមគឺរស់នៅក្នុងទីរហោស្ថាន ហើយនិងទីបាក់បែក(សូមមើល អស ៣៤:១១,១៥ យរ ៥០:៣៩ សផ ២:១៤) ។

**១០២:៨** *ពួកខ្មាំងសត្រូវពោលប្រទេចចំពោះទូលបង្គំ* មើល ១០៩:២៥ និងការពន្យល់ ៥:៩ ៣៩:៨ ។ *គេយកឈ្មោះទូលបង្គំជាសេចក្តីផ្តាសា* គេបាននិយាយថា "សូមឱ្យវាត្រឡប់ដូចជាអ្នកនោះដែរ" (ឈ្មោះអ្នកណាម្នាក់) ។

**១០២:៩** *គ្រឿងផឹក . . . ទឹកភ្នែក* សូមមើល ៤២:៣ ៨០:៥ ដែលនិយាយពីទឹកភ្នែកជាគ្រឿងផឹក ។

**១០២:១០** *សេចក្តីក្រោធ* សូមមើលការពន្យល់ ២:៥ ។

**១០២:១១** នៅក្នុងខនេះបានដកស្រង់ចេញពី ខ.៣-៤ ។ *ស្រមោល* សូមមើល ១០៩:២៣ ១៤៤:៤ យប ៨:៩ ១៤:២ សស ៦:១២ ។ *ស្មៅ* សូម មើល ៣៧:២០ ៩០:៥-៦ និងការពន្យល់ ។

**១០២:១២-១៧** នៅក្នុងខទាំងនេះ គឺជាការធានាអះអាងមួយថា ព្រះមហាក្សត្រដែលគង់នៅស្ថានសួគ៌ដ៏នៅអស់កល្ប ទ្រង់នឹងស្តាប់ឮសម្រែកសេចក្តីអធិស្ឋានរបស់មនុស្សវេទនា (ខ.១៧) ហើយនិងសង់ក្រុងស៊ីយ៉ូនឡើងវិញ ។ សូមមើលពីការធានាអះអាងបែបនេះ ដែលមាននៅក្នុងសេចក្តីអធិស្ឋាន ក្នុងចង្កោមព្រះគម្ពីរទំនុកដំកើង ក្នុងការពន្យល់ ៣:៨ ។

**១០២:១២** *ទ្រង់នឹងគង់សោយរាជ្យនៅអស់កល្បជានិច្ច* ឃ្លានេះគឺជាផ្ទៃរឿងគ្រឹះនៃជំពូកមុនៗ (ទដ ៩០-១០០) ។ ដោយព្រោះព្រះអម្ចាស់ទ្រង់បានសោយរាជ្យជារៀងរហូត និងនៅតែដដែលៗ (សូមមើល ខ.២៧) នោះទ្រង់នឹងមិនដែលខាននឹងប្រទានសេចក្តីសប្បុរសនៃទ្រង់ ដល់អ្នកដែលទន្ទឹងរងចាំសេចក្តីសង្គ្រោះពីទ្រង់នោះឡើយ ។ *នឹកចាំ* សូមមើលការពន្យល់ ៣០:៤ ("ព្រះនាម") ។ សូមមើលពត៌មានលំអិតស្តីពីការអរសប្បាយចំពោះការនឹកចាំរបស់ព្រះយេហូវ៉ាក្នុង ទដ ជំពូក ១១១ ១៣៥ ១៤៥ ។

១៣ទ្រង់នឹងក្រោកឡើង[ភ] ហើយមានសេចក្ដីមេត្តាករុណា[ម]
ដល់ក្រុងស៊ីយ៉ូន ដ្បិតដល់វេលា[យ]ហើយ ដែលគួរប្រោស
មេត្តា[រ]ដល់ទីក្រុង អើ ពេលកំណត់[ល]បានមកដល់ហើយ
១៤ពីព្រោះពួកអ្នកបំរើទ្រង់ គេអាល័យដល់អស់ទាំងថ្ម
ហើយក៏ស្ដាយស្រណោះដល់ ធូលីដីនៃទីក្រុង
១៥យ៉ាងនោះពួកសាសន៍ដទៃនឹងកោតខ្លាច[វ]
ដល់ព្រះនាមព្រះយេហូវ៉ា ហើយអស់ទាំងស្ដេច[ស]នៅផែន
ដីនឹងក្រែងខ្លាច ដល់សិរីល្អនៃទ្រង់
១៦ដ្បិតព្រះយេហូវ៉ាទ្រង់ នឹងសង់ក្រុងស៊ីយ៉ូន[ហ]ឡើងវិញ
ហើយនិងលេចមកក្នុងសិរីល្អនៃទ្រង់[ឡ]
១៧ទ្រង់តែងតែទទួលសេចក្ដីអធិស្ឋាន[អ]របស់មនុស្ស
វេទនាឥតដែលមើលងាយចំពោះពាក្យសូមអង្វររបស់គេ
ឡើយ
១៨សេចក្ដីនេះនឹងបានកត់ទុក[ក]សំរាប់ដំណមនុស្សជាន់
ក្រោយឱ្យបណ្ដាមនុស្សដែលនឹងកើតឡើង[ខ]បានសរសើរ
ដំកើងដល់ព្រះយេហូវ៉ា
១៩ដ្បិតទ្រង់បានក្រឡេកទតពី[គ]ជាន់ ខ្ពស់នៃទីបរិសុទ្ធទ្រង់
គឺព្រះយេហូវ៉ាបានទតពីស្ថានសួគ៌
មកពិចារណាមើលផែនដី
២០ដើម្បីនឹងស្ដាប់ដំងូររបស់ពួកឈ្លើយ[ឃ]ហើយនិងស្រាយ
លែងអស់អ្នកដែលបានដំរូវឱ្យត្រូវស្លាប់
២១ប្រយោជន៍ឱ្យមនុស្សទាំងឡាយបានប្រកាស[ង]ព្រះនាមនៃ
ព្រះយេហូវ៉ានៅក្រុងស៊ីយ៉ូន និងសេចក្ដីសរសើរ[ច]ទ្រង់នៅ
ក្រុងយេរូសាលឹម
២២ក្នុងកាលដែលអស់ទាំងសាសន៍បានប្រជុំមូលគ្នាព្រមទាំង
នគរទាំងប៉ុន្មានផង ដើម្បីនឹងគោរពប្រតិបត្តិ[ឆ]ដល់ព្រះ
យេហូវ៉ា ។
២៣ទ្រង់បានធ្វើឱ្យកំឡាំងរបស់ទូលបង្គំអន់ថយទៅ នៅ

**១០២:១៣** ភ ទដ ៤៤:២៦ ម ចទ ៣២:៣៦ ១៣វ ៣:២៦ អស ៥៤:៨ ៦០:១០ សក ១០:៦ យ ទដ ១១៩:១២៦ រ ទដ ៧៧:៧ ល នក ១៣:១០ ដយ ៨:១៩ កច ១:៧ **១០២:១៥** វ ១ពវ ៨:៤៣ ទដ ៦៧:៧ អស ២:២ ស ទដ ៧៦:១២ ១៣៨:៤ ១៤៨:១១ **១០២:១៦** ហ ទដ ៥១:១៨ ឡ ទដ ៨:១ អស ៦០:១-២ **១០២:១៧** អ ១ពវ ៨:២៩ ទដ ៤:១ ៦:៩ **១០២:១៨** ក រម ៤:២៤ ខ ទដ ២២:៣១ **១០២:១៩** គ ទដ ៥៣:២ **១០២:២០** ឃ ទដ ៦៨:៦ លក ៤:១៩ **១០២:២១** ង ទដ ២២:២២ ច ទដ ៩:១៤ **១០២:២២** ឆ ទដ ២២:២៧ អស ៤៩:២២-២៣ សក ៨:២០-២៣

**១០២:១៣** នៅក្នុងខនេះ និង ខ.១៦ (ហើយក៏មើល ខ.១៤) បានបង្ហាញថា សេចក្ដីទុក្ខលំបាករបស់អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង គឺស្ថិតក្នុងគ្រានិរទេសទៅបាប៊ីឡូន ។ *ក្រោកឡើង* សូមមើលការពន្យល់ ៣:៧ ។ *ដល់វេលាហើយ* គឺដល់ពេលដែលព្រះយេហូវ៉ាទ្រង់ជំនុំជម្រះ និងរំដោះ (សូមមើល ៧៥:២ នក ៩:២ ២សយ ២៤:១៥ ដយ ១១: ២៧,៣៥) ។ ប្រហែលអ្នកនិពន្ធនិយាយសំដៅលើពេលវេលាដែលហោរាបានថ្លែងប្រាប់ ។

**១០២:១៤** *អ្នកបំរើទ្រង់គេអាល័យ* នៅក្នុងឃ្លានេះចង់និយាយថា បើក្រុងស៊ីយ៉ូនជាក្រុងនៃព្រះយេហូវ៉ា (សូមមើល ៤៦:៤ ៤៨:១-២,៨ ៨៧:៣ ១០១:៨ ១៣២:១៣) ហើយជាទីស្រឡាញ់ដល់អ្នកបម្រើទ្រង់ទៅហើយ ចុះទំរាំព្រះយេហូវ៉ាវិញ តើទ្រង់ស្រឡាញ់ក្រុងនេះជាងអំបាលម៉ានទៅទៀត ។

**១០២:១៥** *ពួកសាសន៍ដទៃនឹងកោតខ្លាច* សូមមើលការពន្យល់ ៤៦:១០ ។ *ព្រះនាមព្រះយេហូវ៉ា* ឃ្លានេះនិយាយសំដៅលើការនឹកចាំរបស់ព្រះយេហូវ៉ា (សូមមើលការពន្យល់ ៣០:៥) "ព្រះនាម" ។ ការនឹកចាំរបស់ព្រះយេហូវ៉ា ដ៏នៅអស់កល្បអស់ទាំងដំណរនឹងបានជាទីពឹកដល់អ្នកដែលមានអំណាចនៅលើលោកិយឱ្យកោតខ្លាចដល់ព្រះនាមទ្រង់ ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**១០២:១៦** *នឹងសង់ក្រុងស៊ីយ៉ូនឡើងវិញ* នៅក្នុងឃ្លានេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់នឹងបង្ហាញ "សេចក្ដីមេត្តាករុណា" ដល់ក្រុងស៊ីយ៉ូន (ខ.១៣) ដោយការសាងសង់ឡើងវិញ ។ *ហើយនឹងលេចមកក្នុងសិរីល្អនៃទ្រង់* (សូមមើល ខ.១៥ និងការពន្យល់ក្នុង ៤៦:១០ និងក្នុង អស ៤០:១-៥) ។ សេចក្ដីសង្ឃឹមនេះនឹងបានសម្រេចពេញបរិបូរនៅក្នុង "ក្រុងយេរូសាឡិមថ្មី" (សូមមើល វវ ជំពូក ២១) ។

**១០២:១៧** *មនុស្សវេទនា* នៅក្នុងឃ្លានេះនិយាយសំដៅលើ "អ្នកបំរើទ្រង់" (សូមមើល ខ.១៤) ។ *ពាក្យសូមអង្វរ* នៅក្នុងឃ្លានេះនិយាយសំដៅលើពាក្យទូលអង្វរក្នុងគ្រាដែលគេស្ដាយស្រណោះ ឬស្រឡាញ់ដល់ក្រុងស៊ីយ៉ូនក្នុងគ្រាដែលក្រុងនេះបានបាក់បែក (សូមមើល ខ.១៤) ។

**១០២:១៨-២២** នៅក្នុងឃ្លានេះចង់និយាយថា សូមឱ្យគេបានកត់ចុះពីសេចក្ដីសង្គ្រោះ និងការរំដោះដ៏ពិតដែលទ្រង់បានធ្វើចំពោះរាស្ត្រទ្រង់ ដើម្បីឱ្យគេបានសរសើរពីទ្រង់ (សូមមើល ខ.៨) រហូតដល់ថ្ងៃដែលពួកអ្នកថ្វាយបង្គំព្រះយេហូវ៉ា បានអបអរសាទរចំពោះការប្រោសលោះនៃក្រុងស៊ីយូន បានរីកសាយដល់ "គ្រប់ទាំងមនុស្ស" និង "គ្រប់ទាំងនគរ"នៅលើផែនដីនេះ (សូមមើល ខ.២២) ។ សូមមើលក្នុងសេចក្ដីផ្ដើម ទដ ១១៧ និងក្នុង វវ ១៥:៤ ២១:២៤,២៦ ។

**១០២:១៨** *កត់ទុក* មានតែនៅទីនេះប៉ុណ្ណោះដែលអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់បានហៅដល់មនុស្សទាំងអស់ឱ្យនឹកចាំពីការអស្ចារ្យ និងសេចក្ដីសង្គ្រោះរបស់ព្រះអង្គតាមរយៈការកត់ចុះ ក្នុងសៀវភៅដែលជានិច្ចកាល គឺគ្រាន់តែនិយាយផ្ទាល់មាត់ប៉ុណ្ណោះ (មើល ២២:៣០ ៤៤:១ ៧៨:១-៤) ។ *កើតឡើង* គឺកើតឡើងដោយសារអំណាចរបស់ព្រះអង្គ (សូមមើល ៥១:១០ ១០៤:៣០ ១៣៩:១៣) ។

**១០២:២០** *ពួកឈ្លើយ . . . អស់អ្នកដែលបានតំរូវឱ្យសត្រូវស្លាប់* នៅក្នុងឃ្លានេះប្រហែលនិយាយសំដៅលើពួកឈ្លើយក្នុងសង្គ្រាម ប៉ុន្តែភាគច្រើនគេជឿថាជាឈ្លើយក្នុងពេលនិរទេសទៅបាប៊ីឡូន (សូមមើល ៧៩:១១ និងការពន្យល់) ។

**១០២:២១** *សេចក្ដីសរសើរ* សូមមើលការពន្យល់ ៩:១ ។

**១០២:២២** សូមមើលការពន្យល់ ៤៦:១០ និងក្នុង ៤៧:៩ និងការពន្យល់ ៨៦,៩៨,១០០ ។ ការរង់ចាំដោយសេចក្ដីសង្ឃឹមនៅទីនេះ ប្រហែលក៏មាននៅក្នុងការថ្លែងទំនាយរបស់ពួកហោរាដែរ (សូមមើល អស ២:២-៤ មីក ៤:១-៣) ។

**១០២:២៣-២៨** នៅក្នុងខទាំងនេះ គឺជាសេចក្ដីបញ្ចប់នៃសេចក្ដីអធិស្ឋាន ។ នៅក្នុងល្បះនេះបានបង្ហាញពីភាពខុសគ្នារវាង ខ.២៣,២៨ ។ ជីវិតមនុស្សត្រូវបានបន្ថយឱ្យនៅខ្លី (ខ.២៣) ដោយសារអ្នកដែលអាយុកាលតាំងពីដើមរៀងមក (សូមមើល ខ.២៥-២៧) បានធ្វើឱ្យអ្នកនិពន្ធគាត់បានគិតថា និង

កណ្ដាលផ្លូវ ទ្រង់បានពង្រួញថ្ងៃអាយុរបស់ទូលបង្គំហើយ[ជ]
[២៤]ទូលបង្គំបានទូលថា ឱព្រះនៃទូលបង្គំអើយ ទ្រង់មាន
ព្រះជន្មស្ថិតស្ថេរនៅ ដរាបដល់អស់ទាំងដំណមនុស្សតទៅ
សូមកុំដកទូលបង្គំចេញ នៅ[ឈ]វេលាកណ្ដាលអាយុទូលបង្គំ
ឡើយ
[២៥]កាលដើមដំបូង[ញ]ទ្រង់បានតាំងឫសផែនដី ហើយផ្ទៃ
មេឃ[ដ] ក៏ជាស្នាដៃរបស់ព្រះហស្តទ្រង់ដែរ[ឋ]
[២៦]របស់ទាំងនោះនឹងវិនាសសូន្យទៅ[ឌ]ពិតតែទ្រង់នឹងស្ថិត
ស្ថេរនៅវិញ អើ របស់ទាំងនោះនឹងចាស់ទៅ ដូចជា
សំលៀកបំពាក់ ហើយទ្រង់នឹងផ្លាស់ចេញដូចជាផ្លាស់អាវ
ដូច្នេះនឹងបានផ្លាស់ចេញជាពិត
[២៧]ប៉ុន្តែ ឯទ្រង់ៗនៅដដែល[ឍ] ហើយព្រះជន្មទ្រង់មិនចេះ
ផុតឡើយ[ណ]
[២៨]ចំណែកកូនចៅរបស់ពួកអ្នកបំរើ[ត]ទ្រង់គេនឹងចេះតែមាន
នៅ ហើយពូជពង្ស[ថ]របស់គេនឹងបានតាំងនៅចំពោះទ្រង់

**១០២:២៣** ជ ទដ ៣៩:៥ **១០២:២៤** ឈ លប ២១:៣៣ យប ៣៦:២៦ ទដ ៩០:២ **១០២:២៥** ញ លប ១:១ ហព ១:១០–១២ ដ ២រប ២:១២ ឋ ទដ ៨:៣ **១០២:២៦** ឌ អស ១៣:១០,១៣ ៣៤:៤ ៥១:៦ អក ៣២:៨ យអ ២:១០ មថ ២៤:៣៥ ២ពត ៣:៧–១០ វវ ២០:១១ **១០២:២៧** ឍ ជន ២៣:១៩ ហព ១៣:៨ យក ១:១៧ ណ ទដ ៩:៧

ទំនុកនៃស្ដេចដាវីឌ ។

**១០៣** ឱព្រលឹងអញអើយ[ក]ចូរសរសើរដល់ព្រះយេហូវ៉ា[ខ]
ហើយគ្រប់ទាំងអស់ ដែលរួមនៅក្នុងខ្លួនអញចូរសរសើរ
ដល់ព្រះនាមបរិសុទ្ធនៃទ្រង់ដែរ[គ]
[២]ព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ[ឃ]
ហើយកុំឱ្យភ្លេច[ង]បណ្ដាព្រះគុណណាមួយរបស់ទ្រង់ឡើយ
[៣]ដែលទ្រង់អត់ទោសចំពោះអស់ទាំងការទុច្ចរិត[ច]របស់ឯង
ទ្រង់ប្រោស[ឆ]ជំងឺទាំងប៉ុន្មានរបស់ឯងឱ្យជា
[៤]ក៏ជួយជីវិត[ជ]ឯងឱ្យរួចពីរណ្ដៅ
ហើយយកសេចក្ដីសប្បុរស
និងសេចក្ដីមេត្តាករុណាបំពាក់ជាមកុដឱ្យឯងវិញ[ឈ]

**១០២:២៨** ត ទដ ៦៩:៣៦ ថ ទដ ២៥:១៣ ៨៩:៤ **១០៣:១** ក ទដ ១០៤:១ ខ ទដ ២៨:៦ គ ទដ ៣០:៤ **១០៣:២** ឃ ទដ ១០៦:១ ១១៧:១ ង ចទ ៦:១២ ទដ ៧៧:១១ **១០៣:៣** ច នក ៣៤:៧ ឆ នក ១៥:២៦ កល ៣:១៣ ១ពត ២:២៤ ១យហ ១:៩ **១០៣:៤** ជ ទដ ៣៤:២២ ៥៦:១៣ អស ៤៣:១ ឈ ទដ ៨:៥ ២៣:៦

បាត់បង់ដល់អ្នក១ ប៉ុន្តែព្រះអង្គក៏បានបន្ថែមសេចក្ដីសង្ឃឹមដល់អ្នក១ទៀតដែរ (សូមមើល ខ.២៨) ដូច្នេះហើយ ទើបគាត់អធិស្ឋានដល់ព្រះអម្ចាស់ជាបន្ទាន់ដើម្បីឱ្យទ្រង់ជួយ ដូចគ្នានឹង ទដ ៩០:១–៦ ដែរ (សូមមើលការពន្យល់ ៩០:៤–៥) ។

**១០២:២២–២៤** សូមមើល ខ.៣–១១ ។

**១០២:២៤–២៧** សូមមើល ខ.១២ និងការពន្យល់ ។ សម្រាប់ព្រះគម្ពីរសញ្ញាថ្មី ដែលបានយក ខ.២៥–២៧ និយាយសំដៅលើព្រះគ្រីស្ទយេស៊ូវ សូមមើល ហព ១:១០–១២ និងការពន្យល់ ១:១០ ។

**១០២:២៦** *ដូចជាសំលៀកបំពាក់* នៅក្នុងឃ្លានេះ អ្នកនិពន្ធចង់និយាយថា នៅពេលដែលព្រះអម្ចាស់ទ្រង់បង្កើតពិភពលោកលើកដំបូង ព្រះអម្ចាស់ទ្រង់បានហ៊ុំព្រះអង្គទ្រង់ ដោយសិរីល្អយ៉ាងប្រដាក់ច្បាស់ (សូមមើល ទដ ៨:១,៣–៤ ១៩:១ ២៩:៣–៩ ១០៤:១,៣១ អស ៦:៣ និង យប ៣៨–៤១ ជាពិសេសនៅ អស ៤០:១០) ។ ប៉ុន្តែព្រះអម្ចាស់ទ្រង់ស្ថិតស្ថេរជាងអ្វីៗដែលទ្រង់បានបង្កើតមកទៅទៀត ហើយការបង្កើតដំបូងនឹងត្រូវកន្លងផុតទៅ ដើម្បីឱ្យការបង្កើតថ្មីបានមកដល់ (សូមមើល អស ៦៥:១៧ ៦៦:២២) ។

**១០២:២៨** នៅក្នុងឃ្លានេះចង់និយាយថា ដោយព្រោះយេហូវ៉ាទ្រង់នៅតែដដែល (សូមមើល ខ.២៧) នោះអនាគតនៃពួកអ៊ីស្រាអែលគឺនឹងមានសេចក្ដីសុខសាន្ត (សូមមើល មឡ ៣:៦) ។ *នឹងបានតាំងនៅចំពោះទ្រង់* សូមមើល ២សយ ៧:២៤ ។

**ទដ ១០៣** នៅក្នុងខនេះ គឺជាបទចម្រៀងនៃការសរសើរតម្កើងចំពោះសេចក្ដីសប្បុរសនៃព្រះ និងសេចក្ដីអាណិតអាសូរចំពោះរាស្ត្រទ្រង់ ។ សម្រាប់ទំនាក់ទំនងជាមួយ ទដ ១០៨ សូមមើលក្នុងសេចក្ដីផ្ដើម ទដ ១០១–១១០ ។ ឫសគល់នៃការសរសើរដំកើងដល់ព្រះយេហូវ៉ា ត្រូវបានបែងចែកជា២ផ្នែកមិនស្មើគ្នា ដោយនៅក្នុងផ្នែកទី១ មាន៣ខ (៣–៥) និយាយពីផលកំរៃផ្ទាល់ខ្លួន ដែលបុគ្គលនោះទទួលបាន ហើយនៅក្នុងផ្នែកទី២វិញមាន ១៤ខ (ខ.៦–១៩) ដែលនិយាយពីសេចក្ដីសប្បុរសរបស់ព្រះ ចំពោះពួកអ៊ីស្រាអែល ។ នៅក្នុងផ្នែកក្រោយនេះ (ខ.៦–១៩) ត្រូវបានតែងឡើងជា៦ចំណុចហើយចំណុចនេះបានផ្ដាច់ចេញពីចំណុចទី៧ (ខ.៦,១៩) ដែលបានពណ៌នាពីអត្ថចរិតទូរទៅ នៃរាជ្យរបស់ព្រះយេហូវ៉ា ។ ផ្ទៃរឿងក្នុងជំពូកនេះបានចែកជា២ផ្នែក ដែល១ផ្នែកមាន៦ខស្មើៗគ្នា(ខ.៧–១២,១៣–១៨) នៅក្នុងផ្នែកទី១និយាយពីការអបអរចំពោះសេចក្ដីមេត្តារបស់ទ្រង់ ចំពោះរាស្ត្រទ្រង់ដែលជាមនុស្សមានបាប ហើយនៅក្នុងផ្នែកទី២ គឺជាបទចម្រៀងពីក្ដីមេត្តា របស់ទ្រង់ចំពោះពួកគេក្នុងគ្រាដែលគេទន់ខ្សោយ (សូមមើល ទដ ៧៨:៣៨–៣៩) ។ នៅក្នុងសេចក្ដីបញ្ចប់នៃផ្នែកទាំង២នេះ បានប្រកាសពីសេចក្ដីស្រឡាញ់ដ៏រកថ្លៃងពុំបានរបស់ព្រះយេហូវ៉ា (ខ.១១–១២) និងភាពស្ថិតស្ថេរនៃសេចក្ដីស្រឡាញ់របស់ទ្រង់ (ខ.១៧–១៨) ។

**១០៣:១–២** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានបង្គាប់បញ្ជាដល់ព្រលឹងរបស់គាត់ដែលស្ថិតនៅខាងក្នុងនៃរូបកាយឱ្យសរសើរតម្កើងដល់ព្រះយេហូវ៉ា (សូមធៀបជាមួយ ខ.២០–២២) ។

**១០៣:១–២,២២** *ឱព្រលឹងអញអើយ* ពាក្យនេះនៅក្នុងព្រះគម្ពីរភាសាហេព្រើរ គឺជាឃ្លាសាមញ្ញក្នុងការណែនាំខ្លួនរណាម្នាក់ (សូមមើល ១០៤:១,៣៥ ១១៦:៧) ។ *ព្រលឹង* សូមមើលការពន្យល់ ៦:៣ ។

**១០៣:៣–៥** ក្នុងខទាំងនេះ អ្នកនិពន្ធបានរ៉ាយរាប់រឿងផ្ទាល់ខ្លួនរបស់គាត់ក្នុងកាលដែលគាត់ធ្លាប់ទទួលព្រះពរមកពីព្រះ ។

**១០៣:៣** *អត់ទោស . . . ប្រោសជំងឺ* សូមមើល មថ ៩:២,៥ និងរឿងខប្រហាក់ប្រហែលទៀត ។

**១០៣:៤** *ជួយជីវិតឱ្យរួច* ឃ្លានេះមានន័យដូចគ្នានឹងពាក្យថា "ប្រោសលោះ" ។ *រណ្ដៅ* នៅក្នុងឃ្លានេះគឺជាពាក្យប្រៀបប្រដូចដែលអ្នកនិពន្ធចង់និយាយសំដៅលើស្ថានឃុំព្រលឹងមនុស្សស្លាប់ (សូមមើលការពន្យល់ ៣០:១) ។ *សេចក្ដីសប្បុរស និងសេចក្ដីមេត្តា* នេះគឺពាក្យគន្លឹះក្នុងចម្រៀងសរសើរតម្កើងដល់ព្រះនាមទ្រង់ (សូមមើល ខ.៨,១១,១៣,១៧) ។ *សេចក្ដីសប្បុរស* សូមមើល ខ.៨,១១,១៧ និងការពន្យល់ក្នុង ៦:៤ ។

៥ព្រមទាំងប្រោសប្រទាន ឱ្យសំបកកាយនៃឯងបានស្កប់
ស្កល់[ញ]ដោយរបស់ល្អប្រយោជន៍ឱ្យវ័យក្មេងឯង បានកែ
ឡើងជាថ្មី[ដ] ដូចជាឥន្ទ្រី[ឋ]
៦ព្រះយេហូវ៉ា ទ្រង់សំរេចកិច្ចការដ៏សុចរិត[ឌ]
ហើយនិងសេចក្ដីយុត្តិធម៌ ចំពោះអស់អ្នកណាដែលត្រូវគេ
សង្កត់សង្កិន[ឍ]
៧ទ្រង់បានសំដែង ឱ្យម៉ូសេស្គាល់[ណ]អស់ទាំងផ្លូវ[ត]របស់ទ្រង់
ហើយឱ្យពួកកូនចៅអ៊ីស្រាអែលស្គាល់អស់ទាំងកិច្ចការ[ថ]
របស់ទ្រង់ដែរ
៨ព្រះយេហូវ៉ាទ្រង់មានសេចក្ដីមេត្តាករុណា ហើយនិង
សេចក្ដីអាណិតអាសូរ[ទ]ទ្រង់យឺតនឹងខ្ញាល់ ហើយមាន
សេចក្ដីសប្បុរសដ៏បរិបូរ
៩ទ្រង់នឹងមិនបន្ទោសជាដរាប ក៏មិនប្រកាន់ជារៀងរាប
ទៅដែរ[ធ]
១០ទ្រង់មិនបានប្រព្រឹត្តនឹងយើងតាមអំពើបាបរបស់យើង
ទេ[ន] ក៏មិនបានសងតាមអំពើទុច្ចរិតរបស់យើងដែរ
១១ដ្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីច្រើនប៉ុណ្ណា
សេចក្ដីសប្បុរស[ប]របស់ទ្រង់ក៏ធំច្រើនប៉ុណ្ណោះចំពោះអស់
អ្នកដែលកោតខ្លាចដល់ទ្រង់[ផ]
១២ឯទិសខាងកើតនៅឆ្ងាយពីទិសខាងលិចយ៉ាងណាទ្រង់
បានដកយកអស់ទាំងការល្មើស[ព] នៃយើងឱ្យឃ្លាតឆ្ងាយពី
យើងយ៉ាងនោះដែរ
១៣ព្រះយេហូវ៉ាទ្រង់មានព្រះហឫទ័យអាណិត[ភ]ដល់អ្នកដែល
កោតខ្លាចទ្រង់ដូចជាឪពុកមានចិត្តអាសូរដល់កូនរបស់ខ្លួន
ដែរ
១៤ដ្បិតទ្រង់ស្គាល់រាងកាយរបស់យើង[ម] ក៏នឹកចាំថា យើង
គ្រាន់តែជាធូលីដីប៉ុណ្ណោះ[យ]
១៥ចំណែកឯមនុស្ស ថ្ងៃអាយុរបស់គេធៀបដូចជាស្មៅ[រ]
គេរីកឡើងដូចជាផ្កា[ល]នៅទីវាល
១៦ដ្បិតកាលណាខ្យល់បក់[វ]មកត្រូវ នោះក៏សូន្យបាត់ទៅ
ហើយកន្លែងនោះ[ស]មិនស្គាល់វាទៀត
១៧តែសេចក្ដីសប្បុរសនៃព្រះយេហូវ៉ាស្ថិតស្ថេរនៅតាំងពី
អស់កល្បដរាបដល់អស់កល្បជានិច្ច ចំពោះអស់អ្នកដែល
កោតខ្លាចដល់ទ្រង់ សេចក្ដីសុចរិតរបស់ទ្រង់ ក៏នៅរហូត
ដល់កូនចៅគេតទៅ[ហ]

**១០៣:៥** ញ ទដ ៩០:១៤ ១០៤:២៨ ដ យប ៣៣:២៥ ទដ ១១៩:២៥,៩៣ ២កថ ៤:១៦ ឋ នក ១៩:៤ **១០៣:៦** ឌ ទដ ៩:៨ ៦៥:៥ អស ៩:៧ ឍ ទដ ៧៤:២១ លក ៤:១៩ **១០៣:៧** ណ ទដ ៩៩:៧ ១៤៧:១៩ ត នក ៣៣:១៣ ថ ទដ ១០៦:២២ **១០៣:៨** ទ នក ២២:២៧ ទដ ៨៦:១៥ មីក ៧:១៨–១៩ យក ៥:១១ **១០៣:៩** ធ ទដ ៣០:៥ ៧៩:៥ អស ៥៧:១៦ យរ ៣:៥,១២ មីក ៧:១៨ **១០៣:១០** ន អរ ៩:១៣ រម ៦:២៣ **១០៣:១១** ប ទដ ១៣:៥ ៥៧:១០ ១០០:៥ ១០៦:៤៥ ១១៧:២ បទ ៣:២២ អភ ៣:១៨ ផ ២របា ៦:៣១ **១០៣:១២** ព ២សយ ១២:១៣ រម ៤:៧ អភ ២:៥ **១០៣:១៣** ភ មឡ ៣:១៧ ១យហ ៣:១ **១០៣:១៤** ម ទដ ១១៩:៧៣ ១៣៩:១៣–១៥ អស ២៩:១៦ យ លប ២:៧ ទដ ១៤៦:៤ **១០៣:១៥** រ ទដ ៣៧:២ ៩០:៥ ១០២:១១ អស ៤០:៦ ល យប ១៤:២ យក ១:១០ **១០៣:១៦** វ អស ៤០:៧ ហក ១:៩ ស យប ៧:៨ **១០៣:១៧** ហ លប ៤៨:១១ អរ ៩:១២

**១០៣:៥** *ដូចជាឥន្ទ្រី* នៅក្នុងឃ្លានេះអ្នកនិពន្ធចង់និយាយថា កម្លាំងរបស់មនុស្សវ័យក្មេង បានកែជាថ្មីឡើងដែលប្រៀបបានទៅនឹងកម្លាំងរបស់ឥន្ទ្រី (សូមមើល អស ៤០:៣០–៣១) ។

**១០៣:៦–១៩** នៅក្នុងខទាំងនេះ និយាយពីសេចក្ដីសប្បុរសនិងសេចក្ដីមេត្តារបស់ព្រះអម្ចាស់ចំពោះរាស្ត្រទ្រង់ ។

**១០៣:៦** នៅក្នុងខនេះ ក៏ដូចគ្នានឹង ខ.១៩ ដែរ គឺបានពណ៌នាពីអត្តចរិតលក្ខណៈនៃរាជ្យរបស់ព្រះយេហូវ៉ា ដែលជាគ្រាមួយដែលពួកអ៊ីស្រាអែលបានទទួលព្រះគុណ និងព្រះពរដ៏បរិបូរមកពីព្រះយេហូវ៉ា ។ *សេចក្ដីសុចរិត* សូមមើល ខ.១៧ និងការពន្យល់ ៤:១ ។

**១០៣:៧–១២** នៅក្នុងខទាំងនេះ ពណ៌នាពីសេចក្ដីមេត្តាករុណារបស់ព្រះយេហូវ៉ាចំពោះរាស្ត្ររបស់ទ្រង់ ក្នុងកាលដែលពួកគេបានធ្វើបាបទាស់នឹងទ្រង់ ។

**១០៣:៧–៨** សូមមើល នក ៣៣:១៣ និងការពន្យល់ នក ៣៤:៦–៧ ។

**១០៣:៧** *ផ្លូវរបស់ទ្រង់* សូមមើល ២៥:១០ និងការពន្យល់ ។

**១០៣:៩** *ប្រកាន់* សូមមើលការពន្យល់ ២:៥ ។

**១០៣:១០,១២** *អំពើបាប . . . អំពើទុច្ចរិត . . . ការល្មើស* សូមមើល ៣២:៥ និងការពន្យល់ ។

**១០៣:១១–១២** នៅក្នុងខទាំងនេះ និយាយពីសេចក្ដីស្រឡាញ់ដ៏រកថ្លែងពុំបានរបស់ព្រះយេហូវ៉ា ហើយសេចក្ដីស្រឡាញ់នេះគឺបានបង្ហាញតាមរយៈការដែលទ្រង់បានអត់ទោសចំពោះពួកអ៊ីស្រាអែល ។

**១០៣:១១** សូមមើល ៣៦:៥–៩ ។ *ក៏ធំច្រើនប៉ុណ្ណោះ* គឺរកថ្លែងពុំបាន ។ *អស់អ្នកណាដែលកោតខ្លាចទ្រង់* សូមមើល ខ.១៣,១៧–១៨ ៣៤:៨–១៤ និងការពន្យល់ ។

**១០៣:១២** សូមមើល អស ១:១៨ ៣៨:១៧ ៤៣:២៥ យរ ៣១:៣៤ ៥០:២០ មីក ៧:១៨–១៩ ។

**១០៣:១៣–១៨** នៅក្នុងខទាំងនេះ និយាយពីសេចក្ដីមេត្តាករុណារបស់ព្រះយេហូវ៉ាចំពោះរាស្ត្ររបស់ទ្រង់ក្នុងកាលដែលគេទន់ខ្សោយ (សូមមើល ៧៨:៣៩) ។

**១០៣:១៣–១៤** នៅដើមឃ្លាក្នុងព្រះគម្ពីរភាសាហេព្រើរ នៃពាក្យទាំង២ខនេះ គឺមានសូរស្ពនដូចគ្នាក្នុង ខ.១១–១២ ដោយហេតុនោះវាគឺជាចំណងរវាង ខ.១៣–១៨ និង ខ.៧,១២ ។

**១០៣:១៤** *យើងគ្រាន់តែជាធូលីដីប៉ុណ្ណោះ* សូមមើលក្នុង លប ២:៧ ៣:១៩ ។

**១០៣:១៥–១៦** សូមមើលការពន្យល់ ៩០:៥–៦ ។

**១០៣:១៧–១៨** នៅក្នុងខនេះ និយាយពីភាពស្ថិតស្ថេរនៅនៃសេចក្ដីសប្បុរសនៃព្រះ (សូមធៀបធៀបជាមួយ ខ.១១–១២) ។

**១០៣:១៧** *តាំងពីអស់កល្បដរាបដល់អស់កល្បជានិច្ច . . . នៅរហូតដល់កូនចៅគេតទៅ* នៅក្នុងឃ្លានេះចង់និយាយថា សេចក្ដីសប្បុរសនៃព្រះគឺស្ថិតស្ថេរនៅគ្រប់ទាំងតំណរមនុស្ស ទោះបីជាមនុស្សមានអាយុកាលដ៏ខ្លីក៏ដោយ (សូមធៀបជាមួយការពន្យល់ ១០៩:១២) ។

១៨គឺដល់អស់អ្នកដែលកាន់តាមសេចក្ដីសញ្ញា[ឡ]ទ្រង់ នឹងពួក
អ្នកដែលនឹកចាំ[អ]ពីអស់ទាំងសេចក្ដីបញ្ញត្តទ្រង់ ដើម្បីនឹង
ប្រព្រឹត្តតាម[ក]
១៩ព្រះយេហូវ៉ាទ្រង់បានតាំងបល្ល័ង្ក[ខ]ទ្រង់នៅ
លើស្ថានសួគ៌ហើយរាជ្យទ្រង់ក៏គ្រប់គ្រង[គ]លើទាំងអស់
២០ចូរសរសើរដល់ព្រះយេហូវ៉ា[ឃ] អស់ពួកទេវតា[ង]
របស់ទ្រង់អើយ ជាអ្នកដែលមានឥទ្ធិឫទ្ធិខ្លាំង[ច]
ហើយក៏ប្រតិបត្តិតាមបង្គាប់ទ្រង់ ដោយស្តាប់តាម[ឆ]ព្រះសូរ
សៀងនៃព្រះបន្ទូលទ្រង់
២១ចូរសរសើរដល់ព្រះយេហូវ៉ា អស់ពួកពលបរិវាររបស់
ទ្រង់អើយ[ជ] ជាពួកអ្នកបំរើ[ឈ]ទ្រង់ដែលធ្វើតាមព្រះហឫទ័យ
២២អស់ទាំងស្នាដៃ[ញ]របស់ទ្រង់អើយ ចូរសរសើរដល់ព្រះ
យេហូវ៉ានៅគ្រប់ទីកន្លែងដែលទ្រង់មានអំណាចព្រលឹង
អញអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ[ដ] ។

# ១០៤

ឱព្រលឹងអញអើយ[ក] ចូរសរសើរដល់ព្រះយេហូវ៉ា
ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ ទ្រង់ធំក្រៃលែង
ទ្រង់ប្រដាប់អង្គដោយសសក្តិនឹងតេជានុភាព[ខ]
២ក៏ហ៊ុម[គ]អង្គដោយពន្លឺ[ឃ] ដូចជាទ្រង់ព្រះភូសា គឺទ្រង់ដែល

**១០៣:១៨** ឡ ចទ ២៩:៩ អ ទដ ១១៩:៥២ ក ជន ១៥:៤០ យហ ១៤:១៥ **១០៣:១៩** ខ ទដ ៤៧:៨ ៨០:១ ១១៣:៥ គ ទដ ២២:២៨ ៦៦:៧ ដយ ៤:១៧ **១០៣:២០** ឃ ទដ ២៨:៦ ង នហ ៩:៦ លក ២:១៣ ហព ១:១៤ ច ទដ ២៩:១ ឆ ទដ ១០៧:២៥ ១៣៥:៧ ១៤៨:៨ **១០៣:២១** ជ ១ពរ ២២:១៩ ឈ នហ ៧:៧៣ **១០៣:២២** ញ ទដ ១៩:១ ៦៧:៣ ១៤៥:១០ ១៥០:៦ ដ ខ.១ ទដ ៤:១ **១០៤:១** ក ទដ ១០៣:២២ ខ យប ៤០:១០ **១០៤:២** គ អស ៤៩:១៨ យរ ៤៣:១២ ឃ ទដ ១៨:១២ ១ធថ ៦:១៦

**១០៣:១៨** *ដល់អស់អ្នកណាដែលកាន់តាមសេចក្ដីសញ្ញាទ្រង់ . . . បញ្ញត្តិទ្រង់* សូមមើល ២៥:១០ នក១៩:៥ និងការពន្យល់ ២៦:៦ និងការពន្យល់ ចទ ៤:៤០ ២៩:៩ ។

**១០៣:១៩** សូមមើល ខ.៦ និងការពន្យល់ និង ៩:៤,៧ ១១:៤ ៤៧:២,៧–៨ ១២៣:១ ។

**១០៣:២០–២២** នៅក្នុងខទាំងនេះ គឺជាសេចក្ដីបញ្ចប់នៃសេចក្ដីអធិស្ឋាន ។ អ្នកនិពន្ធបានបង្គាប់ដល់គ្រប់អស់ទាំងស្នាព្រះហស្តទ្រង់ ចាប់តាំងពីខាងក្នុងខ្លួននៃអ្នកនិពន្ធ (ខ.១–២) រហូតដល់គ្រប់ទាំងអស់នៃស្នាដៃដែលបម្រើព្រះនៅស្ថានសួគ៌ ។ ការហៅដល់គ្រប់ទាំងអស់នៃស្នាព្រះហស្តទ្រង់ឱ្យមកសរសើរតម្កើងដល់ព្រះ គឺតែងតែមាននៅក្នុងព្រះគម្ពីរទំនុកដំកើង (ដូចជានៅ ទដ ១៤៨–១៥០) ។ សូមមើលការពន្យល់ ៩:១ ។ *ចូរសរសើរ . . . ចូរសរសើរ . . . ចូរសរសើរ* សូមមើលការពន្យល់ ៩៦:១–៣ ។

**១០៣:២០** *ពួកអ្នកដែលមានឥទ្ធិឫទ្ធិខ្លាំង* មើល ៩១:១១ ហព ១:១៤ ។

**១០៣:២១** *ពួកពលបរិវារ* នៅទីនេះ និងក្នុង ១៤៨:២ ពាក្យថា ពួកពលបរិវារ គឺមានទំនាក់ទំនងជាមួយពួកទេវតា ។ *ពួកអ្នកបំរើទ្រង់* នៅទីនេះក្នុងព្រះគម្ពីរភាសាហេព្រើរគឺ "អ្នកបំរើ" ដូចជាមាននិយាយនៅក្នុង ទដ ១០១:៦ (មើលការពន្យល់នៅទីនោះ, និងការពន្យល់ ១០៤:៤) ។

**១០៣:២២** *អស់ទាំងស្នាដៃរបស់ទ្រង់* សូមមើល ៦៥:១៣ ៩៦:១១–១២ និងការពន្យល់ ។

**ទដ ១០៤** នៅក្នុងជំពូកនេះ គឺជាបទចម្រៀងនៃការសរសើរដំកើងដល់ព្រះអទិករ ។ សម្រាប់ទំនាក់ទំនងព្រះគម្ពីរទំនុកដំកើងជំពូកនេះជាមួយ ទដ ១០៨ នៅក្នុងក្រុមនៃទំនុកដំកើងនេះ សូមមើលសេចក្ដីផ្ដើម ទដ ១០១–១១០ ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ បានតែងឡើងមុនគ្រានិរទេសទៅបាប៊ីឡូន ហើយបានយកលំនាំតាមព្រះគម្ពីរ លប ជំពូក ១ ដើម្បីបង្ហាញពីគោលបំណងផ្ទាល់ខ្លួនរបស់គាត់ និងផ្ទៃរឿងបន្ទាប់បន្សំមួយចំនួនទៀត(សូមមើលអត្ថបទខាងក្រោយ) ។ នៅក្នុងព្រះគម្ពីរ លប ជំពូក ១ បានរ៉ាយរាប់ពីសកម្មភាពនៃការបង្កើតរបស់ព្រះ ដែលការងារដំបូងរបស់ព្រះអង្គតាំងពីដើមដំបូងមកម្ល៉េះ ប៉ុន្តែកវីនិពន្ធក្នុងជំពូកនេះ គាត់បានរំឭកឱ្យឃើញពីការបង្កើតរបស់ទាំងអស់នៅលោកិយដែលមាននៅចំពោះភ្នែករបស់គាត់ និងបទចម្រៀងសរសើរពីសិរីល្អនៃព្រះអទិករដែលបានបង្កើតឡើង និងជាអ្នកគ្រប់គ្រង ។ ដើម្បីធ្វើឱ្យអ្នកអានមានការភ្ញាក់ផ្អើល អ្នកនិពន្ធគ្រាន់តែនិយាយប្រលយពាក្យដ៏ល្អមួយតាមបែបនៃពួកទេវតា (ខ.៤) ហើយឯមនុស្សវិញគ្រាន់តែនិយាយពីការកន្លងហួសរបស់ពួកគេប៉ុណ្ណោះ (ខ.១៤,២៣) ។ ផ្ទៃរឿងរបស់គាត់ គឺនិយាយពីការបង្កើតទាំងឡាយដែលមនុស្សមើលឃើញផ្ទាល់ភ្នែក ដែលជាពិភពលោកធំក្រៃ ដែលព្រះអាទិករទ្រង់បានបំពាក់សិរីល្អនៃទ្រង់នៅលើរបស់ទាំងនោះ ។

នៅក្នុងព្រះគម្ពីរទំនុកដំកើងជំពូកនេះមាន១ខដែលជាសេចក្ដីផ្ដើម ហើយអ្នកនិពន្ធបានតាក់តែងសេចក្ដីផ្ដើមនៃកណ្ឌកំណាព្យរបស់គាត់ដែលនៅក្នុងចំណុចកណ្ដាលនេះ ដោយលល្បះតូចៗជាច្រើនដែលមាន ៣ខ,៩ខ,៥ខ, ហើយនិង ៣ខ ។ នៅក្នុងល្បះទី១និយាយពីស្ថានសួគ៌ខាងលើ (សូមមើល ខ.២–៤) ហើយនៅក្នុងល្បះទី៥ និយាយពីរបស់ដែលនៅសមុទ្រខាងក្រោម(ខ.២៤–២៦) ហើយស្ថានទាំង២នេះហើយបានស្ថិតនៅសងខាងនៃ"ផែនដី" ។ បទចម្រៀងទី២ បាននិយាយពីគ្រឹះដ៏រឹងមាំរបស់ផែនដី និងព្រំប្រទល់ (ខ.៥–៩) ហើយនៅបទទី៤ និយាយពីដំណើរនៃជីវិតសត្វទាំងឡាយដែលមាននៅក្នុងលោកិយនេះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយព្រះអាទិត្យ ព្រះច័ន្ទ (ខ.១៩–២៣) ។ នៅចំណុចកណ្ដាលមាន៩ខ (បានតែងឡើងជា៣ក្រុម) បាននិយាយពីការអបអរសាទរចំពោះភាពត្រសំត្រសាយនៃជីវិតទាំងឡាយដែលនៅលើលោកិយនេះ (ខ.១០–១៩) ។ ក្នុងតួរសេចក្ដីនៃជំពូកនេះ អ្នកនិពន្ធគាត់បានបន្ថែម៤ខទៀតបានពណ៌នាពីរបៀបដែលព្រះអាទិករទ្រង់ផ្គត់ផ្គង់ថែរក្សាជីវិតនៅលើផែនដី (ខ.២៧–៣៩) ហើយមាន២ខទៀតដែលជាសេចក្ដីបញ្ចប់ (ខ.៣២–៣៣ ដែលមានលក្ខណៈដូចគ្នានឹង ខ.១ ទាំងស្រុងដែរ) ហើយ៣ខទៀតជាអវសាន្តកថា (ខ.៣៣–៣៥) ។ គ្រោងកាយខាងក្រៅ ("ឱព្រលឹងអញអើយចូរសរសើរដល់ព្រះយេហូវ៉ា" ប្រហែលជាអ្នកនិពន្ធគាត់បានបន្ថែមចូលមក ក្នុងពេលដែលបែងចែកព្រះគម្ពីរនេះ បន្ទាប់ពីជំពូក១០៦ ដែលជាសេចក្ដីបញ្ចប់ក្នុងប៉ែកទី៤ ហើយបានភ្ជាប់ជាមួយបទចម្រៀងសរសើរ (សូមមើលគ្រោងអក្សរសាស្ត្រលើ ទដ ១០៥–១០៦ និងសេចក្ដីបញ្ចប់ប្រហាក់ប្រហែលគ្នាក្នុងប៉ែកទី៥ ទដ ១៤៦–១៥០) ។

**១០៤:១–២** *ប្រដាប់អង្គ . . . ហ៊ុំអង្គ* សូមមើលការពន្យល់ ១០៩:២៩ ។

**១០៤:១** ក្នុងខនេះគឺជាសេចក្ដីផ្ដើម ហើយក៏ជាផ្ទៃរឿងនៃការសរសើរដំកើងតម្កើងដល់ព្រះ ។

**១០៤:២–៤** នៅក្នុងខនេះនិយាយពីស្ថានសួគ៌ខាងលើ ។

លាត[ង]ផ្ទៃមេឃ[ច] ដូចជាលាតបារាំ[ឆ]
៣ទ្រង់ដាក់ឫស[ជ]ដំណាក់ទ្រង់នៅក្នុងទឹក[ឈ] ក៏យកពពក[ញ]ធ្វើជា
រថ[ដ]របស់ទ្រង់ ហើយទ្រង់យាងលើស្លាបខ្យល់[ឋ]
៤ទ្រង់យកខ្យល់ធ្វើជាអ្នកជូនដំណឹង[ឌ]របស់ទ្រង់ ហើយយក
អណ្ដាតភ្លើង[ឍ]ធ្វើជាពួកបំរើទ្រង់
៥ទ្រង់បានតាំងឫស[ណ]ផែនដី[ត] ដើម្បីឱ្យបានមាំមិនឱ្យត្រូវ
រញ្ជួយនៅអស់កល្ប
៦ទ្រង់បានគ្រប[ថ]ផែនដីដោយទឹកជ្រៅ[ទ] ដូចជាគ្របដោយ
អាវទឹកនោះក៏គ្រប[ធ]អស់ទាំងភ្នំផង ។
៧កាលទ្រង់បង្គាប់[ន]នោះទឹកបានហូរទៅ ក៏ប្រញាប់ទៅ
ដោយសូរផ្គរ[ប]របស់ទ្រង់
៨អស់ទាំងភ្នំបានដុះឡើង ហើយច្រកទាំងប៉ុន្មានក៏ស្រុតទៅ
គឺនៅត្រង់កន្លែងដែលទ្រង់បានកំណត់[ផ]ឱ្យ
៩ទ្រង់បានដាក់ព្រំខណ្ឌ[ព] មិនឱ្យទឹកហូររំលងឡើយ
ដើម្បីកុំឱ្យឡើងលិចផែនដីទៀត
១០ទ្រង់ធ្វើឱ្យមានក្បាលទឹក[ភ]ផុះឡើងនៅក្នុងច្រកភ្នំទឹកនោះ
ហូរនៅកណ្ដាលភ្នំ
១១ក៏ឱ្យគ្រប់ទាំងសត្វនៅវាលមានទឹក[ម]ផឹកឯលា[យ]ព្រៃក៏ផឹក
ឆ្អែតដែរ
១២អស់ទាំងសត្វហើរលើអាកាស[រ]ធ្វើសំបុកតាមផ្លូវទឹកទាំង
នោះហើយកញ្ជ្រៀវលេងនៅលើមែកឈើ[ល]
១៣ទ្រង់ស្រោចអស់តាំងភ្នំ[វ]ពីដំណាក់ទ្រង់[ស] ហើយផែនដី
បានពេញដោយផលនៃស្នាដៃទ្រង់[ហ]
១៤ទ្រង់ធ្វើឱ្យស្មៅដុះឡើង[ឡ] សំរាប់សត្វ ហើយបន្លែសំរាប់
មនុស្សដើម្បីឱ្យទាំង២បានអាហារ[អ]ពីផែនដីមក
១៥ព្រមទាំងស្រាទំពាំងបាយជូរ[ក] ដែលនាំឱ្យចិត្តមនុស្សបាន
សប្បាយនឹងប្រេង[ខ] សំរាប់ឱ្យមុខគេបានរលើបភ្លឺ
ហើយអាហារផង សំរាប់ចំរើន[គ]កំឡាំងចិត្តមនុស្ស
១៦អស់ទាំងដើមឈើរបស់ព្រះយេហូវ៉ា[ឃ]បានឆ្អែតគឺដើម
តាត្រៅនៅភ្នំល្បាណូន[ង] ជាដើមដែលទ្រង់បានដាំ

**១០៤:២** ង យប ៩:៨ យរ ៥១:១៥ ច យប ៣៧:១៨ អស ៤០:២២ ៤២:៥ ៤៤:២៤ សក ១២:១ ឆ ទដ ១៩:៤ **១០៤:៣** ជ អម ៩:៦ ឈ ទដ ២៤:២ ញ ចទ ៣៣:២៦ អស ១៩:១ ណហ ១:៣ ដ ២ពវ ២:១១ ឋ ទដ ១៨:១០ **១០៤:៤** ឌ ទដ ១៤៨:៨ ហព ១:៧ ឍ លប ៣:២៤ ២ពវ ២:១១ **១០៤:៥** ណ នក ៣១:១៧ យប ២៦:៧ ទដ ២៤:១–២ ១០២:២៥ ១២១:២ ត ១សយ ២:៨ **១០៤:៦** ថ លប ៧:១៩ ទ លប ១:២ ធ ២ពត ៣:៦ **១០៤:៧** ន ទដ ១៨:១៥ ប នក ៩:២៣ ទដ ២៩:៣ **១០៤:៨** ផ ទដ ៣៣:៧ **១០៤:៩** ព លប ១:៩ ទដ ១៦:៦ **១០៤:១០** ភ ទដ ១០៧:៣៣ អស ៤១:១៨ **១០៤:១១** ម ខ.១៣ យ លប ១៦:១២ អស ១២:១៤ យរ ១៤:៦ **១០៤:១២** រ ខ.១៧ មថ ៨:២០ ល មថ ១៣:៣២ **១០៤:១៣** វ ទដ ១៣៥:៧ ១៤៧:៨ យរ ១០:១៣ សក ១០:១ ស លវ ២៦:៤ ហ អម ៩:៦ **១០៤:១៤** ឡ យប ៣៨:២៧ ទដ ១៤៧:៨ អ លប ១:៣០ យប ២៨:៥ **១០៤:១៥** ក លប ១៤:១៨ ពច ៩:១៣ ខ ទដ ២៣:៥ ៩២:១០ លក ៧:៤៦ គ ចទ ៨:៣ មថ ៦:១១ **១០៤:១៦** ឃ លប ១:១១ ង ទដ ៧២:១៦

**១០៤:២** *ពន្លឺ* ធៀបជាមួយថ្ងៃដំបូងនៃការបង្កើតក្នុង លប ១ ។ *ផ្ទៃមេឃ* សូមធៀបថ្ងៃទី២នៃការបង្កើតក្នុង លប ១ ។ *ដូចជាលាតបារាំ* គឺបានលាតនៅលើផែនដី ហើយបានផ្ដល់ជារស្មីពន្លឺ ។

**១០៤:៣** *យកពពកធ្វើជារថ* នៅក្នុងឃ្លានេះគឺជាពាក្យប្រៀបប្រដូចមួយដែលអ្នកនិពន្ធចង់និយាយសំដៅលើទីលំនៅលើស្ថានសួគ៌ ដែលព្រះបានគង់នៅ(សូមមើល ខ.១៣) ។ នៅក្នុងភាសាហេព្រើរ ជាឯកវចនៈឃ្លានេះតែងតែនិយាយសំដៅលើបន្ទប់ដែលនៅខាងលើ (១ពវ ១៧:១៩ ២ពវ ១:២) ។ *ទឹក* ទឹកដែលនៅពីលើ "បារាំ" (ខ.២ លប ១:៧) ដែលមាននៅក្នុងសញ្ញាចាស់ គឺចង់និយាយសំដៅលើការដែលទ្រង់ប្រទានឱ្យមាន ទឹកភ្លៀង (មើល ខ.១៣ និងក្នុង ៣៦:៨ និងការពន្យល់) ។ *ពពកធ្វើជារថ* មើល ១៨:៧–១៥ ៦៨:៤ ៧៧:១៦–១៩ និងការពន្យល់ ។

**១០៤:៤** *ខ្យល់ . . . អណ្ដាតភ្លើង* គឺនិយាយសំដៅលើខ្យល់ និងផ្លេកបន្ទោរដែលចាំងភ្លឺ ។ នៅទីនេះគឺនិយាយសំដៅលើភ្នាក់ងារបំរើរបស់ព្រះ (សូមមើល ១៤៨:៨ ហើយធៀបជាមួយ ១០៣:២១ និងក្នុង ហព ១:៧ និងការពន្យល់) ។

**១០៤:៥–៩** នៅក្នុងខ.នេះគឺចង់និយាយពីភាពមាំមួននៃផែនដី ។ នៅក្នុង ខ.៥,៩ គឺជាគ្រោងកាយនៃផ្ទៃរឿសំខាន់ទាំង២ ។

**១០៤:៥** *ផែនដី* គឺជាដីដែលមានចម្ងាយដ៏សែនឆ្ងាយពីផ្ទៃមេឃ និងសមុទ្រ មិនមែនជាផែនដីនៅក្នុងភពព្រះគ្រោះនោះឡើយ (មើល លប ១:១០) ។ *ឫស* សូមមើល ២៤:២ និងការពន្យល់ ។ *មិនត្រូវឱ្យរញ្ជួយនៅអស់កល្ប* មានន័យថា គ្រឹះដ៏រឹងមាំ (សូមមើល ៩៣:១ ៩៦:១០) នេះនឹងមិនត្រូវរញ្ជួយឡើយ (សូមធៀបជាមួយ ខ.៩) ។

**១០៤:៧** *បង្គាប់* សូមមើលការពន្យល់ ៧៦:៦ ។ *ទឹកបានហូរទៅ* សូមធៀបជាមួយថ្ងៃទី៣នៃការបង្កើតក្នុង លប ជំពូក ១ ។

**១០៤:៩** *ដាក់ព្រំខណ្ឌ* ដោយការនេះ នោះផែនដីនឹងត្រូវគ្របដោយទឹកសមុទ្រឡើង (សូមធៀបជាមួយ ខ.៥ និងក្នុង ៣៣:៧ និងការពន្យល់ ហើយសូមមើល លប ៩:១៥) ។

**១០៤:១០–១៨** នៅក្នុងខទាំងនេះ និយាយពីភាពល្អត្រកាលនៃសួនច្បារជីវិត ។ ខទាំងនេះក៏ជាចំណុចស្នូលនៃជំពូកនេះផងដែរ ហើយក៏ជាចំណុចប្រសព្វនៃគំនិតរបស់អ្នកនិពន្ធស្ដីពីការបង្កើតថែមទៀតផង (ផែនដីដែលព្រំខណ្ឌដោយលំហរអាកាស ខ.២–៤ ហើយនិងសមុទ្រ ខ.២៤–២៦) ។ សូមធៀបជាមួយថ្ងៃទី៣ និងថ្ងៃទី៦នៃការបង្កើតនៅក្នុង លប ជំពូក ១ ។

**១០៤:១០–១២** នៅក្នុងខទាំងនេះ និយាយពីអំណោយទានជាទឹកដែលមកពីក្រោម គឺមកពីស្រុកត្បូង ។

**១០៤:១៣–១៥** នៅក្នុងខទាំងនេះ និយាយពីអំណោយទានជាទឹកមកពីលើដែលជាប្រភពនៃកសិកម្មរបស់អ៊ីស្រាអែល ។

**១០៤:១៣** *ពីដំណាក់ទ្រង់* សូមមើល ខ.៣ និងការពន្យល់ ។

**១០៤:១៥** *ចិត្ត . . . ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ *ប្រេង* គឺជាប្រេងអូលីវ ។ *សំរាប់ឱ្យមុខគេបានរលើបភ្លឺ* គឺដូចជាអាហារ (សូមមើល ១ពវ ១៧:១២) ដែលបានធ្វើឱ្យមុខមនុស្សបានរលើបដោយមានសុខភាពល្អ (សូមមើល នអ ២:១២) ។

**១០៤:១៦–១៨** នៅក្នុងខទាំងនេះចង់និយាយថា ក្បាលទឹកល្បានណូន (ស្ថិតនៅភាគខាងជើងនៃស្រុកអ៊ីស្រាអែល) និងដើមឈើដ៏ល្អ ដែលអាចឱ្យសត្វធ្វើសំបុក្រ ជាទីអាស្រ័យដល់សត្វ គឺបានបង្ហាញពីគំរូនៃចំណាតរបស់ព្រះលើផែនដី (សូមមើល ៧២:១៦ ២ពវ ១៤:៩ ១៩:២៣ អស ១០:៣៤ ៣៥:២ ៤០:១៦ ៦០:១៣ យរ ២២:៦ ហស ១៤:៧) ។

¹⁷ ជាកន្លែងដែលសត្វស្លាប[ច]ធ្វើសំបុកនៅឯសត្វកុកវាបាន
ដើមកកោះជាទីអាស្រ័យ
¹⁸ អស់ទាំងភ្នំខ្ពស់ជាទីសំរាប់ពពែព្រៃ[ឆ] ហើយអស់ទាំងថ្ម
ជាទីពឹងជ្រកនៃទន្សាយថ្ម[ជ]
¹⁹ ទ្រង់បានដំរូវព្រះចន្ទទុកសំរាប់ជាទីកំណត់រដូវ[ឈ] ចំណែក
ព្រះអាទិត្យ[ញ]ក៏ដឹងពេលដែលត្រូវលិចដែរ
²⁰ ទ្រង់ធ្វើឱ្យងងឹត[ដ] នោះគឺជាយប់ហើយ[ឋ]
ជាពេលដែលគ្រប់ទាំងសត្វនៅព្រៃ[ឌ]រមែងចេញមក
²¹ អស់ទាំងសិង្ហស្ទាវគ្រហឹមរកចាប់រំពា[ឍ] ក៏សូមអាហារ
ពីព្រះមក[ណ]
²² លុះថ្ងៃរះឡើងកាលណា វាក៏បាត់ទៅចូលទៅដេកក្នុង
រូងវាវិញ[ត]
²³ ឯមនុស្សគេចេញមកឯកិច្ចធុរៈ[ថ] របស់ខ្លួន
ហើយក៏ធ្វើការដរាបដល់ល្ងាច[ទ]
²⁴ ឱព្រះយេហូវ៉ាអើយ អស់ទាំងស្នាដៃរបស់ទ្រង់មានច្រើន
ប្រការ[ធ]ណាស់ហ្ន៎ទ្រង់បានធ្វើ[ន]ទាំងអស់ដោយប្រាជ្ញា ផែន
ដីបានពេញដោយរបស់ដែលទ្រង់បង្កើត[ប]
²⁵ នុ៎ះន៍ សមុទ្រដ៏ធំ[ផ] ហើយទូលាយនៅក្នុងទឹក
នោះមានរបស់រវើកឥតគណនាជាសត្វទាំងតូចទាំងធំ[ព]
²⁶ ក៏មាននាវា[ភ]បើកទៅមកហើយមានសត្វធំសំបើម[ម]ដែល
ទ្រង់បានបង្កើតឱ្យលេង[យ]ក្នុងទឹក[រ]
²⁷ គ្រប់សត្វទាំងនោះសង្ឃឹមចាំតែទ្រង់ ឱ្យទ្រង់បាន
ប្រទានចំណី[ល]ដល់វាតាមត្រូវពេល
²⁸ ទ្រង់ក៏ប្រទានឱ្យ ហើយវាទទួលយកកាលទ្រង់លា
ព្រះហស្តទៅ នោះវាបានឆ្អែត[វ]ដោយរបស់ល្អ
²⁹ កាលទ្រង់លាក់ព្រះភក្ត្រ[ស] នោះវាបានថប់ព្រួយវិញកាល
ទ្រង់ដកយកដង្ហើមចេញ នោះវាក៏ស្លាប់ ហើយត្រឡប់ទៅ
ជាធូលីដីវិញ[ហ]។
³⁰ ទ្រង់បាត់ព្រះវិញ្ញាណ[ឡ]របស់ទ្រង់ទៅ នោះវាកើតឡើង
ទ្រង់កែប្រែផែនដីឡើងជាថ្មី
³¹ សូមឱ្យសិរីល្អនៃព្រះយេហូវ៉ា[អ]នៅជាប់ជានិច្ច សូមឱ្យព្រះ
យេហូវ៉ាបានរីករាយឡើង ដោយសារស្នាដៃទ្រង់[ក]
³² កាលណាទ្រង់ក្រឡេកទតមកផែនដី នោះផែនដីក៏ញ័រ[ខ]
កាលណាទ្រង់ពាល់ភ្នំ[គ] នោះភ្នំក៏ហុយផ្សែងឡើង[ឃ]
³³ កាលនៅមានជីវិតនៅឡើយ នោះទូលបង្គំនឹងច្រៀង[ង]
ថ្វាយព្រះយេហូវ៉ាជាដរាបកាលទូលបង្គំមាននៅៗឡើយ
នោះនឹងច្រៀងសរសើរដល់ព្រះនៃទូលបង្គំ
³⁴ សូមឱ្យសេចក្ដីនឹកដញ្ញឹងរបស់ទូលបង្គំបានផ្អែមត្រចៀក
ដល់ទ្រង់ទូលបង្គំនឹងរីករាយ[ច]ក្នុងព្រះយេហូវ៉ា

**១០៤:១៧** ច ខ.១២
**១០៤:១៨** ឆ ចទ ១៤:៥ ជ សភ ៣០:២៦
**១០៤:១៩** ឈ លប ១:១៤ ញ ទដ ១៩:៦
**១០៤:២០** ដ អស ៤៥:៧ អម ៥:៨ ឋ ទដ ៧៤:១៦ ឌ ទដ ៥០:១០
**១០៤:២១** ឍ អម ៣:៤ ណ ទដ ១៤៥:១៥ យអ ១:២០ មថ ៦:២៦
**១០៤:២២** ត យប ៣៧:៨
**១០៤:២៣** ថ លប ៣:១៩ ទ ពច ១៩:១៦
**១០៤:២៤** ធ ទដ ៤០:៥ ន លប ១:៣១ ប ទដ ២៤:១ ៥០:១០-១១
**១០៤:២៥** ផ ទដ ៦៩:៣៤ ព អគ ៤៧:១០
**១០៤:២៦** ភ ទដ ១០៧:២៣ អគ ២៧:៩ យហ ១:៣ ម យប ៣:៨ ៤១:១
យ យប ៤០:២០ រ លប ១:២១ **១០៤:២៧** ល យប ៣៦:៣១ ទដ ១៤៥:១៥ ១៤៧:៩ **១០៤:២៨** វ ទដ ១០៣:៥ ១៤៥:១៦ អស ៥៨:១១ **១០៤:២៩** ស ចទ ៣១:១៧ ហ យប ៧:២១ **១០៤:៣០** ឡ លប ១:២ **១០៤:៣១** អ នក ៤០:៣៥ ទដ ៨:១ រម ១១:៣៦ ក លប ១:៤ **១០៤:៣២** ខ ទដ ៩៧:៤ គ នក ១៩:១៨ ឃ ទដ ១៤៤:៥ **១០៤:៣៣** ង នក ១៥:១ ទដ ១០៨:១ **១០៤:៣៤** ច ទដ ២:១១ ៩:២ ៣២:១១

**១០៤:១៩-២៣** នៅក្នុងខទាំងនេះ និយាយពីដំណើរជីវិតទាំងឡាយរបស់ជីវិតទាំងឡាយនៅលើផែនដីដែលគ្រប់គ្រងដោយព្រះច័ន្ទ និងព្រះអាទិត្យ ។ សូមធៀបជាមួយថ្ងៃទី៤ នៃការបង្កើតដែលនិយាយនៅក្នុង លប ជំពូក ១ ។

**១០៤:២១,២៣** *សិង្ហ . . . មនុស្ស* នៅក្នុងចំណោមសត្វ២ប្រភេទនេះមាន១ប្រភេទជា (តំណាងឱ្យសត្វទាំងអស់នៅលើលោកិយ) ម្ចាស់នៃពេលយប់ ហើយ១ប្រភេទទៀតជាម្ចាស់ពេលថ្ងៃ ។

**១០៤:២៤-២៦** នៅក្នុងខទាំងនេះ និយាយពីអាណាចក្រនៃសមុទ្រខាងក្រោម (សូមមើលការពន្យល់ ខ.១៩-២៣) ។ សូមធៀបជាមួយការបង្កើតក្នុងថ្ងៃទី៥ដែលមាននិយាយនៅក្នុង លប ជំពូក ១ ។ សមុទ្រគឺមានទំហំស្មើគ្នានឹងផ្ទៃមេឃដែរ (សូមមើល ខ.២-៤) ដើម្បីធ្វើព្រំខណ្ឌនៃផែនដី ។

**១០៤:២៤** នៅក្នុងខនេះ អ្នកនិពន្ធបានផ្អាកពណ៌នាពីមុនមក ដើម្បីពណ៌នាពីសមុទ្រ ។

**១០៤:២៥** *ឥតគណនា* សូមមើល លប ១:២០-២១ ។

**១០៤:២៦** *សត្វសំបើមៗ* នៅក្នុងឃ្លានេះអ្នកនិពន្ធបានលើកពីរឿងនិទានដ៏គួរឱ្យភ័យខ្លាចដែលនិយាយពីសត្វចំឡែកៗ ដែលនៅក្នុងសមុទ្រខាងក្រោម (សូមមើល យប ៣:៨ និងការពន្យល់) ។ នៅទីនេះអ្នកនិពន្ធចង់បង្ហាញថាគ្មានអ្វីមួយដែលមានសេចក្ដីសុខជាងសត្វសមុទ្រ ដែលព្រះបង្កើតមកឱ្យលេងក្នុងសមុទ្រនោះឡើយ ។

**១០៤:២៧-៣០** នៅក្នុងខទាំងនេះចង់និយាយថា ដោយសារតែសេចក្ដីមេត្តាករុណារបស់ព្រះ ក្នុងការដែលទ្រង់បានថែរក្សាហ្វូងសត្វរបស់ទ្រង់ក្នុងឧទ្យានដ៏ល្អរបស់ព្រះ ។ ធៀបជាមួយការបង្កើតក្នុងថ្ងៃទី៦ លប ជំពូក ១ ។

**១០៤:២៩** *លាក់ព្រះភក្ត្រ* សូមមើលការពន្យល់ ១៣:១ ។

**១០៤:៣០** *ព្រះវិញ្ញាណរបស់ទ្រង់* សូមមើលការពន្យល់ ៥១:១១ ។ *កើតឡើង* សូមមើលការពន្យល់ ១០២:១៨ ។

**១០៤:៣១** *សិរីល្អនៃព្រះយេហូវ៉ា* គឺជាសិរីល្អដែលបានបង្ហាញឱ្យឃើញតាមរយៈការបង្កើតរបស់ទ្រង់ ។

**១០៤:៣២** នៅក្នុងឃ្លានេះចង់និយាយថា ព្រះអង្គទ្រង់ធំអស្ចារ្យជាងរបស់ទាំងឡាយដែលជាស្នាព្រះហស្តរបស់ទ្រង់ ដែលគ្រាន់តែទតមើល ឬបះពាល់ក៏ព្រះអាចទំលាយចោលបានដែរ ។

**១០៤:៣៣-៣៥** នៅក្នុងខទាំងនេះ គឺជាសេចក្ដីបញ្ចប់នៃការសញ្ជឹងគិតរបស់អ្នកនិពន្ធទៅចំពោះព្រះយេហូវ៉ា (ធៀបជាមួយការពន្យល់ ខ.៣៥) ។

**១០៤:៣៣** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានប្ដេជ្ញាចិត្តសរសើរតម្កើងព្រះយេហូវ៉ា ហើយបានភ្ជាប់មកជាមួយនឹងបទចម្រៀងនៃការសរសើរតម្កើង (សូមមើលការពន្យល់ ៧:១៧) ។

**១០៤:៣៤** *សេចក្ដីសញ្ជឹងគិតរបស់ទូលបង្គំ* គឺសំដៅលើបទចម្រៀងពីពេលមុន (សូមមើល ១៩:១៤ និងការពន្យល់) ។

៣៥សូមឱ្យពួកអ្នកមានបាបសូន្យ[ឆ]ចេញពីផែនដីទៅ
ហើយកុំឱ្យមានមនុស្សអាក្រក់នៅសល់ឡើយ[ជ] ចូរសរសើរ
ដល់ព្រះយេហូវ៉ាព្រលឹង
អញអើយចូរសរសើរដល់ព្រះយេហូវ៉ាចុះ[ឈ] ។

*១០៥:១-១៥ – ១របា ១៦:៨-២២*

**១០៥** ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា[ក] ហើយអំពាវ
នាវដល់ព្រះនាមទ្រង់[ខ] ចូរសំដែងពីអស់ទាំងការរបស់ទ្រង់
នៅកណ្តាលសាសន៍ទាំងប៉ុន្មាន
២ចូរច្រៀងថ្វាយទ្រង់[គ] ចូរច្រៀងសរសើរ[ឃ]ដល់ទ្រង់ចុះឱ្យ
គិតរំពឹងពីអស់ទាំងការអស្ចារ្យរបស់ទ្រង់[ង]
៣ចូរយកព្រះនាមបរិសុទ្ធ[ច]របស់ទ្រង់ជាទីអំណរព្រើព្រួចចុះ
ត្រូវឱ្យអស់អ្នកដែលស្វែងរកព្រះយេហូវ៉ាមានចិត្តរីករាយ
ឡើង
៤ចូររកព្រះយេហូវ៉ា និងព្រះចេស្តារបស់ទ្រង់
ចូររកព្រះភក្ត្រទ្រង់ជានិច្ច[ឆ]
៥ត្រូវឱ្យនឹកចាំពីការអស្ចារ្យ[ជ]ដែលទ្រង់បានធ្វើ
ហើយពីការចំឡែក និងបញ្ញត្តិទាំងប៉ុន្មាន ដែលចេញ
ពីព្រះឱស្ឋទ្រង់មក[ឈ]
៦ឱពូជពង្សនៃអ័ប្រាហាំ ជាអ្នកបំរើទ្រង់[ញ]
គឺអស់ទាំងកូនចៅរបស់យ៉ាកុបជាពួកអ្នករើសតាំង[ដ]របស់
ទ្រង់អើយ

**១០៤:៣៥** ឆ ទដ ៣៧:៣៨ ជ យប ៧:១០ ឈ ទដ ២៨:៦ ១០៥:៤៥ ១០៦:៤៨ **១០៥:១** ក ១របា ១៦:៣៤ ខ ទដ ៨០:១៨ ៩៩:៦ ១១៦:១៣ យអ ២:៣២ កច ២:២១ **១០៥:២** គ ទដ ៣០:៤ ៣៣:៣ ៩៦:១ ឃ ទដ ៧:១៧ ១៨:៤៩ ២៧:៦ ៥៩:១៧ ៧១:២២ ១៤៦:២ ង ទដ ៧៥:១

**១០៥:៣** ច ទដ ៨៩:១៦ **១០៥:៤** ឆ ទដ ២៤:៦ **១០៥:៥** ជ ទដ ៤០:៥ ឈ ចទ ៧:១៨ **១០៥:៦** ញ ខ.៤២ ដ ចទ ១០:១៥ ទដ ១០៦:៥

**ទដ ១០៤:៣៥** នៅក្នុងខនេះចង់និយាយថា សូមឱ្យផែនដីសម្អាតអស់ទាំងសង្គ្រាមដែលមាន (សូមធៀបជាមួយ *វវ* ២១:២៧) ។ *ចូរសរសើរដល់ព្រះយេហូវ៉ា* ឃ្លានេះប្រហែលដកស្រង់ចេញពី ទដ ១០៥ (សូមមើលការពន្យល់ ១០៥:៤៥ ១០៦:១,៤៨) ។

**ទដ ១០៥** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានលើកទឹកចិត្តដល់ពួកអ៊ីស្រាអែលឱ្យថ្វាយបង្គំ និងទុកចិត្តចំពោះព្រះយេហូវ៉ា ពីព្រោះព្រះយេហូវ៉ាទ្រង់តែងតែសម្រេចសេចក្តីសន្យា ដែលទ្រង់បានតាំងជាមួយលោកអ័ប្រាហាំថា នឹងឱ្យទឹកដីសន្យាដល់កូនចៅរបស់លោកអ័ប្រាហាំ ។ នៅក្នុងជំពូកនេះបានតែងឡើង ដើម្បីណែនាំបង្ហាញពីពួកអ៊ីស្រាអែលពីសំណាក់ពួកលេវី (សូមមើល ១របា ១៦:៧ ហើយធៀប ខ.១-១៥ ជាមួយ ១របា ១៦:៨-២២) រៀងរាល់ពិធីពីបុណ្យប្រចាំឆ្នាំរបស់ពួកគេ ។ ការណែនាំនេះប្រហែលធ្វើឡើងក្នុងពិធីបុណ្យបារាំ (សូមមើល លវ ២៣:៣៤) ប៉ុន្តែភាគច្រើនប្រហែលក្នុងពិធីបុណ្យអាទិត្យទី៧ ឬបុណ្យថ្ងៃទី៥០ (សូមមើល នក ២៣:១៦ លវ ២៣:១៥-២១ ជន ២៨:២៦ ចទ ១៦:៩-១២ និង ចទ ២៦:១-១១) ។ សម្រាប់រឿងដូចគ្នានេះទៀត (ប៉ុន្តែគោលបំណងផ្សេងគ្នា) សូមមើល ទដ ៧៨ ១០៦ យស ២៤:២-១៣ នហ ៩:៧-២៥ ។ សម្រាប់ការទំនាក់ទំនងនៃព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះជាមួយនឹង ទដ ១០៦ សូមមើលក្នុងសេចក្តីផ្តើម ទដ ១០១-១១០ ។

នៅក្នុងសេចក្តីផ្តើមមាន៧ខហើយចែកជា២ផ្នែក ។ ផ្នែកទី១ និយាយពីការលើកទឹកចិត្ត (ដោយមានបទបញ្ជាចំនួន១០) ឱ្យថ្វាយបង្គំព្រះយេហូវ៉ា (ខ.១-៤) ផ្នែកទី២ អ្នកនិពន្ធបានរំឭកពួកអ៊ីស្រាអែលឱ្យនឹកចាំពីការដែលព្រះយេហូវ៉ាបានធ្វើកន្លងមក (សូមមើល ខ.៥-៧) ។ នៅក្នុងតួរសេចក្តីមានគ្រោងល្បះ២ ហើយក្នុងល្បះនីមួយៗមាន៤ខ (ខ.៨-១១,៤២-៤៥) ។ ផ្ទៃរឿងក្នុងជំពូកនេះគឺចង់និយាយថា ព្រះយេហូវ៉ាទ្រង់ជាព្រះ ដែលបាននឹកចាំពីសេចក្តីសញ្ញាជាមួយលោកអ័ប្រាហាំ ។ អ្នកនិពន្ធក៏បានបន្ថែមឃ្លាមួយទៀតគឺ "ហាលេលូយ៉ា" (សូមមើលសេចក្តីផ្តើម ទដ ១០៤ និងការពន្យល់ ១០៤:៣៥) ។

**១០៥:១-៤** នៅក្នុងខទាំងនេះ គឺជាការលើកទឹកចិត្តដល់មនុស្សឱ្យថ្វាយបង្គំចំពោះព្រះយេហូវ៉ា ។

**១០៥:១** *ឱសូមអរព្រះគុណ* គឺអរព្រះគុណតាមរយៈការសរសើរតម្កើងដល់ព្រះនាមព្រះយេហូវ៉ា (សូមមើលការពន្យល់ ទដ ១០០ ត្រង់ចំណងជើង) ។ *អំពាវនាវ* គឺជាការអំពាវនាវក្នុងពេលអធិស្ឋាន (សូមមើល ខ.៤) ។ នៅទីនេះមានសេចក្តីបង្គាប់ចំនួន២ ក្នុងចំណោមសេចក្តីបង្គាប់ទាំង១០ដែលជាផ្ទៃរឿង២ ដ៏សំខាន់និយាយពីការលើកទឹកចិត្តឱ្យមនុស្សថ្វាយបង្គំដល់ព្រះយេហូវ៉ា : ការសរសើរតម្កើង និងអធិស្ឋាន គឺបានសម្តែងពីការសញ្ជឹងគិតទៅចំពោះព្រះយេហូវ៉ា (សរសើរចំពោះសេចក្តីសង្គ្រោះដែលទ្រង់ធ្វើការពីគ្រាកន្លងមក ដូច្នេះចូរឱ្យយើងទុកចិត្តចំពោះសេចក្តីសង្គ្រោះ និងព្រះពររបស់ព្រះនៅថ្ងៃអនាគតទៀត) ។ *ព្រះនាមទ្រង់* សូមមើល ខ.៣ និងការពន្យល់ ៥:១១ ។ *នៅកណ្តាលអស់ទាំងសាសន៍* មានន័យថា សរសើរព្រះអង្គនៅគ្រប់ទីកន្លែង (សូមមើល ខ.១) ។

**១០៥:២** *ការអស្ចារ្យ* សូមមើល ខ.៥ និងការពន្យល់ ៩:១ ។

**១០៥:៣,២៥** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**១០៥:៥-៧** នៅក្នុងខទាំងនេះ អ្នកនិពន្ធបានជំរុញទឹកចិត្តបណ្តាជនឱ្យនឹកចាំពីសេចក្តីសង្គ្រោះរបស់ទ្រង់ ។

**១០៥:៥** *នឹកចាំ* ការនឹកចាំគឺជាហេតុផលដែលនាំឱ្យមនុស្សថ្វាយបង្គំ និងទុកចិត្តចំពោះព្រះយេហូវ៉ា ។ នៅទីនេះអ្នកនិព្វបានប្រាប់ឱ្យគេនឹកចាំ ពីការនឹកចាំរបស់ទ្រង់ចំពោះសេចក្តីសញ្ញា (សូមមើល ខ.៨-១១) ។ *បញ្ញត្តិ* សូមមើល ខ.៧ និងការពន្យល់ ៤៨:១១ ៩៧:៨ ។ *ចេញពីព្រះឱស្ឋ* ដោយព្រោះព្រះយេហូវ៉ាទ្រង់ជាព្រះ នោះអ្វីដែលទ្រង់បង្គាប់នឹងសម្រេចជាមិនខានឡើយ (សូមមើល ៧:៦) "សេចក្តីយុត្តិធម៌ដែលទ្រង់បង្គាប់" ៣៣:៩ ៧១:៣ ៧៨:២៣ ១៤៧:១៥,១៨ ១៤៨:៥ អស ៥:៦ ៥៥:១១ យរ ១:១២ អម ៩:៣-៤ ។

**១០៥:៦,៩** *អ័ប្រាហាំ . . . យ៉ាកុប . . . អ៊ីសាក* នៅក្នុងចង្កោមនៃទំនុកដំកើងនេះ ពាក្យថា "យ៉ាកុប" មានចំនួន៣៣ ដង ហើយអ័ប្រាហាំ មាននិយាយតែក្នុងកន្លែងនេះប៉ុណ្ណោះ ។

**១០៥:៥-១១** នៅក្នុងខទាំងនេះចង់និយាយថា ព្រះយេហូវ៉ាទ្រង់បាននឹកចាំពីសេចក្តីសន្យាដែលទ្រង់សន្យាជាមួយលោកអ័ប្រាហាំ (សូមមើលក្នុង ខ.៤២-៤៥) ។

៧ ទ្រង់ជាព្រះនៃយើងខ្ញុំ ព្រះនាមជាព្រះយេហូវ៉ា
ឯបញ្ញត្តិទាំងប៉ុន្មានរបស់ទ្រង់ក៏នៅពេញពាសលើផែនដី
៨ ទ្រង់បាននឹកចាំពីសេចក្ដីសញ្ញា[ឋ] ទ្រង់ជានិច្ច គឺជាព្រះបន្ទូល
ដែលទ្រង់បានបង្គាប់ដល់មនុស្សទាំងពាន់ដំណ
៩ ជាសេចក្ដីសញ្ញាដែលទ្រង់បានតាំងនឹងអ័ប្រាហាំ[ឌ] និង
សម្បថដែលទ្រង់ បានស្បថនឹងអ៊ីសាកផង
១០ ក៏បានតាំងសេចក្ដីនោះ[ឍ]ដល់យ៉ាកុបទុកជាច្បាប់
គឺដល់អ៊ីស្រាអែល សំរាប់ជាសេចក្ដីសញ្ញា ដ៏នៅអស់កល្ប
ជានិច្ច[ណ]
១១ ដោយបន្ទូលថាអញនឹង ឱ្យស្រុកកាណាន[ត]ដល់ឯង ទុកជា
ចំណែកមរដករបស់ឯង[ថ]
១២ គ្រានោះ គេមានគ្នាចំនួនតិច អើ មានតិចណាស់[ទ]
ហើយក៏គ្រាន់តែស្នាក់នៅក្នុងស្រុកនោះផង[ធ]
១៣ គេជាអ្នកដើរចុះឡើង ពីនគរ១ទៅនគរ១[ន]
ហើយពីស្រុក១ទៅដល់សាសន៍១ទៀត
១៤ តែទ្រង់មិនបើកឱ្យអ្នកណាសង្កត់សង្កិន[ប] គេឡើង
អើទ្រង់បានផ្ចាលទាំងពួកស្តេចដោយយល់ដល់គេ[ផ]
១៥ ដោយថា កុំឱ្យប៉ះពាល់[ព]នឹងអ្នកដែលអញបានចាក់ប្រេង
តាំងឱ្យ ហើយកុំឱ្យប្រទូសរ៉ាយដល់ពួកហោរា[ភ]របស់អញ
ឡើយ
១៦ ទ្រង់បានបង្គាប់ឱ្យមានអំណត់[ម] កើតឡើងក្នុងស្រុក
ក៏បានផ្តាច់អស់ទាំងអាហារផង
១៧ ទ្រង់បានចាត់មនុស្សម្នាក់ឱ្យទៅមុនគេ គឺយ៉ូសែបដែល
ត្រូវលក់ទៅធ្វើជាខ្ញុំបំរើ[យ]
១៨ ជើងគាត់ត្រូវរឹតរួតជាប់ដោយចំណង[រ]
ហើយមានច្រវាក់ដែកជាប់នៅប្រាណ
១៩ ព្រះបន្ទូលនៃព្រះយេហូវ៉ាបានល្បងល[ល]គាត់ដរាបដល់
កំណត់ដែលពាក្យ[វ]គាត់បានសំរេច
២០ ទើបស្តេចបានចាត់គេទៅដោះលែងគាត់ចេញ គឺជាអ្នក
ដែលគ្រប់គ្រងលើសាសន៍ផ្សេងៗបានស្រាយគាត់ឱ្យរួច[ស]
២១ ក៏បានតាំងគាត់ឡើង ឱ្យធ្វើជាម្ចាស់លើដំណាក់ ហើយ
ជាអ្នកគ្រប់គ្រងលើព្រះរាជទ្រព្យទាំងអស់
២២ ឱ្យមានអំណាចនឹងចាប់ចងពួកវង្ស[ហ]នៃស្តេចតាមចិត្ត
បានហើយនិងបង្ហាត់បង្រៀនឱ្យពួកចាស់ទុំនៃស្តេចមាន
ប្រាជ្ញា[ឡ]
២៣ ឯអ៊ីស្រាអែលក៏ចូលមកក្នុងស្រុកអេស៊ីព្ទដែរ[អ]គឺយ៉ាកុប
បានស្នាក់នៅ[ក] ក្នុងស្រុករបស់ហាំ[ខ]
២៤ ព្រះទ្រង់ក៏ចំរើនរាស្ត្រទ្រង់ឱ្យច្រើនឡើងក្រៃលែង[គ]
ព្រមទាំងឱ្យមានកំឡាំងលើសជាងពួកដែលតតាំងនឹងគេ
ផង
២៥ ទ្រង់បានបំផ្លាស់បំប្រែ[ឃ]ចិត្តសាសន៍នោះ ឱ្យស្អប់ដល់
រាស្ត្រទ្រង់វិញ ឱ្យគេបានប្រព្រឹត្តដោយកិច្ចកល[ង]ចំពោះ
ពួកបំរើទ្រង់

**១០៥:៨** ឋ លប ៩:១៥ ទដ ១០៦:៤៥ ១១១:៥ អគ ១៦:៦០ លក ១:៧២ **១០៥:៩** ឌ លប ១២:៧ ១៥:១៨ ២២:១៦–១៨ លក ១:៧៣ កទ ៣:១៥–១៨ **១០៥:១០** ឍ លប ២៨:១៣–១៥ ណ អស ៥៥:៣ **១០៥:១១** ត លប ១២:៧ ថ ជន ៣៤:២ **១០៥:១២** ទ ចទ ៧:៧ ធ លប ២៣:៤ ហព ១១:៩ **១០៥:១៣** ន លប ១៥:១៣–១៦ ជន ៣២:១៣ ៣៣:៣–៤៩ **១០៥:១៤** ប លប ៣៥:៥ ផ លប ១២:១៧–២០ ២០:៣ ទដ ៩:៥ **១០៥:១៥** ប លប ២៦:១១ ១សយ ១២:៣ ភ លប ២០:៧ **១០៥:១៦** ម លប ១២:១០ លវ ២៦:២៦ អស ៣:១ អគ ៤:១៦ **១០៥:១៧** យ លប ៣៧:២៨ កច ៧:៩ **១០៥:១៨** រ លប ៤០:១៥ **១០៥:១៩** ល លប ១២:១០ ៤០:២០–២២ វ លប ៤១:៤០ **១០៥:២០** ស លប ៤១:១៤ **១០៥:២២** ហ លប ៤១:៤៣–៤៤ ឡ លប ៤១:៤០ **១០៥:២៣** អ លប ៤៦:៦ កច ៧:១៥ ១៣:១៧ ក លប ៤៧:២៨ ខ ទដ ៧៨:៥១ **១០៥:២៤** គ នក ១:៧,៩ កច ៧:១៧ **១០៥:២៥** ឃ នក ៤:២១ ង នក ១:៦–១០ កច ៧:១៩

**១០៥:៨** *សេចក្ដីសញ្ញា* គឺជាសេចក្ដីសញ្ញាដែលបានសន្យា សូមមើល លប ១៥:៩–២១) ។ ខ.នេះ និង ខ.៩ ប្រហែលជាមាននិយាយម្ដងទៀតនៅក្នុង លក ១:៧២–៧៣ ។ *ទាំងពាន់ដំណរ* សូមមើល នក ២០:៦ ចទ ៧:៩ ១របា ១៦:១៥ ។

**១០៥:១០** *ទុកជាច្បាប់* វាគឺជាច្បាប់នៃការគ្រប់គ្រងដែលមិនអាចកែប្រែបានក្នុងថ្ងៃអនាគត (សូមមើលការពន្យល់ ខ.៤៥) ។

**១០៥:១២–៤១** នៅក្នុងខទាំងនេះ និយាយពីសេចក្ដីសង្គ្រោះរបស់ព្រះដែលទ្រង់បានធ្វើចំពោះពួកអ៊ីស្រាអែល ចាប់តាំងពីគ្រាដែលទ្រង់បានតាំងសញ្ញា (សូមមើល ខ.១១ លប ១៥:៩–២១) រហូតដល់គ្រាដែលបានសម្រេចពេញលេញ (សូមមើល ខ.៤៤ យស ២១:៤៣) ។ សូមផ្ទៀបជាមួយសេចក្ដីបង្គាប់របស់លោកម៉ូសេ ឱ្យនាំយកដង្វាយផលដំបូងមកថ្វាយចំពោះព្រះយេហូវ៉ា (សូមមើល ចទ ២៦:១១–១១) ។

**១០៥:១៤–១៥** សូមមើល លប ២០:២–៧ និងការពន្យល់ ២០:៧ ។

**១០៥:១៨** *ច្រវាក់ដែក* គឺជាច្រវាក់ដែលធ្វើឡើងពីដែក (សូមមើល ១៤៩:៨ និងការពន្យល់ ៣:៧) ។ នៅក្នុងខនេះអ្នក និពន្ធបានដកសេរីភាព ដើម្បីពណ៌នាបង្ហាញពីពួកឈ្លើយនៅពេលក្រោយ (សូមមើល យប ១៣:២៧ ៣៣:១១) ។ នៅក្នុង លប ៣៩:២០–២៣ នោះទេ ហើយសម័យក្រោយមកទៀត ច្រវ៉ាក់ក៏បានក្លាយជាឧបករណ៍ប្រើ ដែលពេញនិយមរបស់ពួកគេ ហើយកាលពីសម័យកាលបុរាណ ច្រវ៉ាក់ធ្វើឡើងពីទង់ដែង សូមមើល ពច ១៦:២១) ។

**១០៥:២២** *ចាប់ចង* នេះជាភាសាអក្សរសាស្ត្រ ។ "ជើង"របស់គាត់ (សូមមើល ខ.១៨ នៅក្នុង ភាសាហេព្រើរគឺ "*នីហ្វឹស* " (*nephesh*) ដែលបានដាក់ច្រវ៉ាក់ ឥឡូវនេះត្រូវបានដោះលែងឱ្យមានអំណាច ដើម្បី"ចង"ដល់ពួកពង្សនៃស្តេចផារ៉ោន តាមបំណងព្រះហឫទ័យទ្រង់ ។ *ពួកចាស់ទុំ* គឺជាពួកចាស់ទុំនៃពួកផារ៉ោន ដែលមានបទពិសោធន៍ និងកំពុងរៀនសូត្រ (សូមមើលការពន្យល់ នក ៣:១៦) ។

**១០៥:២៣,២៧** *ស្រុករបស់ហាំ* សូមមើល ៧៨:៥១ និងការពន្យល់ ។

**១០៥:២៥** *បំផ្លាស់បំប្រែ* ពាក្យនេះ នៅក្នុងសញ្ញាចាស់គឺនិយាយសំដៅលើការទទួលយក ការគ្រប់គ្រងរបស់ព្រះយេហូវ៉ាលើជីនួវង្សនៃពួកអ៊ីស្រាអែលជាការគ្រប់គ្រងដោយពេញលេញ អាថ៌កំបាំង ទោះបីជាមានមនុស្សអាក្រក់ខ្លះរឹងទទឹងនឹងទ្រង់ក៏ដោយ (សូមមើល នក ៤:២១ ៧:៣ យស ១១:២០ ២សយ ២៤:១ អស ១០:៥–៧ ៣៧:២៦–២៧ យរ ៣៤:២២ ។

២៦ រួចទ្រង់ចាត់ប្រើម៉ូសេ[ច] ជាអ្នកបំរើទ្រង់និងអើរ៉ុន[ឆ]
ដែលទ្រង់បានរើសយក[ជ]
២៧ លោកទាំង២នោះក៏សំដែង[ឈ]ទីសំគាល់[ញ]របស់ទ្រង់នៅ
កណ្តាលសាសន៍នោះ នឹងការយ៉ាងអស្ចារ្យ[ដ] នៅក្នុងស្រុក
របស់ហាំ
២៨ ទ្រង់ចាត់ប្រើសេចក្តីងងឹត[ឋ]មកបណ្តាលឱ្យស្រុកងងឹត
ទៅលោកមិនបានទទឹងនឹង[ឌ]ព្រះបន្ទូលរបស់ទ្រង់ទេ
២៩ ទ្រង់ក៏ធ្វើឱ្យទឹកនៅស្រុកគេត្រឡប់ទៅជាឈាម[ឍ] ហើយ
ឱ្យត្រីទាំងអស់ស្លាប់ទៅ[ណ]
៣០ ស្រុកគេមានដេរដាសទៅដោយកង្កែប[ត] រហូតដល់ទៅ
ក្នុងបន្ទប់នៃស្តេចផង
៣១ ទ្រង់មានបន្ទូល[ថ] នោះក៏មានរុយទាំងហ្វូងៗមក[ទ]
ក៏មានចៃ[ធ] នៅគ្រប់ក្នុងព្រំស្រុកគេ
៣២ ទ្រង់ប្រទានឱ្យគេមានព្រឹល[ន]ជំនួសភ្លៀង ហើយភ្លើង
ក៏ឆេះនៅក្នុងស្រុកគេ
៣៣ ទ្រង់បានវាយអស់ទាំងដើមទំពាំងបាយជូរ[ប] និងដើម
ល្វា[ផ]របស់គេក៏បំបាក់អស់ទាំងដើមឈើនៅព្រំទីរបស់គេ
៣៤ ទ្រង់មានបន្ទូល[ព] នោះក៏មានកណ្តូបមក[ភ]
ព្រមទាំងចង្រិត[ម] ឥតគណនា[យ]
៣៥ សត្វទាំងនោះបានស៊ីអស់ទាំងដំណាំក្នុងស្រុកក៏ស៊ីទាំង
ផលកើតពីដីរបស់គេដែរ
៣៦ ទ្រង់បានប្រហារអស់ទាំងកូនច្បង[រ]នៅក្នុងស្រុកគេ
គឺជាដើមកំឡាំងរបស់គេទាំងប៉ុន្មាន
៣៧ ត្រង់បាននាំរាស្ត្រទ្រង់ចេញមកមានជាប់ទាំងប្រាក់នឹង
មាសផង[ល] ឯក្នុងអស់ទាំងពូជអំបូរនោះ គ្មានអ្នកណាមួយ
គ្រាកចិត្តឡើយ
៣៨ កាលគេបានចេញទៅផុតហើយ នោះពួកសាសន៍អេស៊ីព្ទ
ក៏អរសប្បាយ ដ្បិតមានសេចក្តីស្ញែងខ្លាចចំពោះពួក
អ៊ីស្រាអែល[វ]ជាខ្លាំង
៣៩ ទ្រង់បានលាតពពក[ស] សំរាប់គ្របបាំងគេព្រមទាំងភ្លើង
សំរាប់បំភ្លឺនៅពេលយប់[ហ]
៤០ គេទូលសូម[ឡ] នោះទ្រង់ក៏នាំហ្វូងក្រួចមក[អ]
ហើយបានចំអែតគេ ដោយអាហារនៃស្ថានសួគ៌[ក]
៤១ ទ្រង់បំប្រេះថ្មដា[ខ] នោះមានទឹកផុសចេញមក ហូរសាយ
តាមកន្លែងហួតហែងដូចជាទន្លេ
៤២ ដ្បិតទ្រង់បាននឹកចាំពីព្រះបន្ទូល[គ]ដ៏បរិសុទ្ធរបស់ទ្រង់
ហើយពីអ័ប្រាហាំ ជាអ្នកបំរើទ្រង់ដែរ
៤៣ ទ្រង់បាននាំរាស្ត្រទ្រង់ចេញមក ដោយសេចក្តីរីករាយ[ឃ]
គឺជាពួកអ្នករើសតាំងរបស់ទ្រង់ ដោយច្រៀងបណ្តើរ

**១០៥:២៦** ច នក ៣:១០ ឆ នក ៤:១៦ ជន ៣៣:១ ជ ជន ១៦:៥ ១៧:៥–៨ **១០៥:២៧** ឈ ខ.២៨–៣៧ នក ៧:៨–១២:៥១ ញ នក ៤:១៧ ១០:១ ដ នក ៣:២០ ដយ ៤:៣ **១០៥:២៨** ឋ លប ១:៤ នក ១០:២២ ឌ នក ៧:២២ **១០៥:២៩** ឍ ទដ ៧៨:៤៤ ណ នក ៧:២១ **១០៥:៣០** ត នក ៨:២,៦ **១០៥:៣១** ថ ទដ ១០៧:២៥ ១៤៨:៨ ទ នក ៨:២១–២៤ ទដ ៧៨:៤៥ ធ នក ៨:១៦–១៨ **១០៥:៣២** ន នក ៩:២២–២៥ យប ៣៨:២២ ទដ ៧៨:៤៧ **១០៥:៣៣** ប ទដ ៧៨:៤៧ ផ នក ១០:៥,១២ **១០៥:៣៤** ព ទដ ១០៧:២៥ ភ នក ១០:៤,១២–១៥ ម ១ពវ ៨:៣៧ យ យអ ១:៦ **១០៥:៣៦** រ នក ៤:២៣ ១២:១២ **១០៥:៣៧** ល នក ៣:២១,២២ **១០៥:៣៨** វ នក ១៥:១៦ **១០៥:៣៩** ស នក ១៣:២១ ១កថ ១០:១ **១០៥:៣៩** ហ ទដ ៧៨:១៤ **១០៥:៤០** ឡ ទដ ៧៨:១៨,២៤ អ នក ១៦:១៣ ក នក ១៦:៤ យហ ៦:៣១ **១០៥:៤១** ខ ជន ២០:១១ ១កថ ១០:៤ **១០៥:៤២** គ លប ១២:១–៣ ១៣:១៤–១៧ ១៥:១៣–១៦ **១០៥:៤៣** ឃ នក ១៥:១–១៨ ទដ ១០៦:១២

**១០៥:២៦, ៤២** *អ្នកបំរើ* សូមមើល ៧៨:៧០ និងការពន្យល់ ។

**១០៥:២៨–៣៦** នៅក្នុងខនេះ បានរំឭកឱ្យឃើញពីគ្រោះកាចដែលព្រះបានវាយប្រហារ នៅក្នុងស្រុកអេស៊ីព្ទ ។ នៅក្នុងជំពូកនេះអ្នកនិពន្ធបានលើកយកគ្រោះកាចចំនួន៧ (ជាចំនួនបង្គ្រប់) ក្នុងចំណោមគ្រោះកាចទាំង១០ (សូមមើល នក ជំពូក ៧–១១) មកពណ៌នា ។ ក្រៅពីចំណុចដែលបាត់ (គ្រោះកាចដែលកើតដល់ហ្វូងសត្វនិងបូស) នេះអ្នកនិពន្ធយកទាំងអស់ ដែលមាននៅក្នុងគម្ពីរនិក្ខមនំ ប៉ុន្តែគាត់បានបញ្ចូលគ្រោះកាចទី៣ និងទី៤ (ចៃនិងកណ្តូប) បញ្ចូលគ្នាបញ្ច្រាសមកវិញ ដោយដាក់ក្នុងគ្រោះកាចទី៧វិញ ។ អ្នកនិពន្ធក៏បានជំនួសគ្រោះកាចទី៩ (គ្រោះងងឹត) ដើម្បីធ្វើជាគ្រោងរំឭកពីគ្រោះកាចចំនួន២ ។

**១០៥:៣៧** *មានជាប់ទាំងប្រាក់ និងមាសផង* សូមមើល នក ៣:២២ និងការពន្យល់ ១២:៣៥–៣៦ ។

**១០៥:៣៩** *សំរាប់គ្របបាំង* នៅក្នុងកន្លែងផ្សេងៗទៀតអ្នកនិពន្ធគាត់បាននិយាយដូច្នេះវិញថាពពក (ជានិមិត្តរូបនៃព្រះវត្តមានរបស់ព្រះអម្ចាស់) គឺជា (១).ជាអ្នកនាំផ្លូវពួកអ៊ីស្រាអែលក្នុងដំណើរក្នុងទីរហោស្ថាន (សូមមើល ៧៨:១៤ នក ១៣:២១ ជន ៩:១៧ នហ ៩:១២,១៩) (២).ពពកគឺជាខែលនៃសេចក្តីងងឹតដែលបានការពារពួកអ៊ីស្រាអែល នៅពេលដែលពួកអេស៊ីព្ទដេញតាម(សូមមើល នក ១៤:១៩–២០) (៣).ពពកគឺជាទីគ្របបាំងដ៏ក្រហាមឆ្អៅ ដែលបង្ហាញពីការលេចមកនៃសិរីល្អរបស់ព្រះ (សូមមើល នក ១៦:១០ ២៤:១៦ ៣៤:៥ ៤០:៣៤–៣៥,៣៨ ជន ១១:២៥ ១២:៥ ១៦:៤២ ចទ ៣១:១៥ ១ពវ ៨:១១) ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងគាត់ចង់បង្ហាញថា ព្រះយេហូវ៉ាទ្រង់ការពារដល់ពួកអ៊ីស្រាអែលដែលជារាស្ត្ររបស់ទ្រង់នៅក្នុងទីរហោស្ថាន ដោយម្លប់នៃ "ស្លាប"របស់ទ្រង់ (សូមមើល ១៧:៨ និងការពន្យល់នៅទីនោះ) ដូច្នេះព្រះអាទិត្យមិនអាចនឹងធ្វើទុក្ខគេនៅពេលថ្ងៃបានឡើយ (សូមមើល ១២១:៥–៦) ។

**១០៥:៤០** *អាហារនៃស្ថានសួគ៌* សូមមើល ៧៨:២៤–២៥ និងការពន្យល់ ៧៨:២៥ ។

**១០៥:៤១** *ដូចជាទន្លេ* នៅក្នុងឃ្លានេះគឺជាគំនិតដ៏ល្អឯករបស់កវីនិពន្ធ ដែលចង់បង្ហាញ ឬរំឭកពីការអស្ចារ្យរបស់ព្រះ ។ ការអស្ចារ្យដែលព្រះយេហូវ៉ាទ្រង់បានធ្វើនៅទីរហោស្ថាន បានពណ៌នា និងជំនួសការងារមួយក្នុងចំណោមការងារដែលស្តីពីការប្រោសលោះរបស់ព្រះ និងសេចក្តីមេត្តាករុណារបស់ព្រះអង្គ (សូមមើល ១១៤:៨ អស ៤៣:១៩–២០ ហើយធៀបជាមួយ អស ៥០:២) ។

**១០៥:៤២–៤៥** នៅក្នុងខទាំងនេះ គឺជាសេចក្តីបញ្ចប់ដោយសង្ខេបនៃព្រះគម្ពីរទំនុកដំកើងជំពូកនេះ(មានតុល្យភាពជាមួយសេចក្តីផ្តើម ដែលបានពណ៌នានៅ ខ.៨–១១ ដែរ) ។

៤៤ ទ្រង់ក៏ប្រទានស្រុករបស់នគរដទៃទាំងប៉ុន្មាន[ង]ឱ្យដល់គេ
គេបានចាប់យក[ច]ផលនៃស្នាដៃរបស់សាសន៍ទាំងនោះ ទុក
ជារបស់ផងខ្លួន
៤៥ ដើម្បីឱ្យបានកាន់តាមសេចក្ដី បញ្ញត្តិទ្រង់
ហើយប្រព្រឹត្តតាមក្រិត្យវិន័យ[ឆ]របស់ទ្រង់ផង
ចូរសរសើរដល់ព្រះយេហូវ៉ា[ជ]ចុះ។

*១០៦:១,៤៧–៤៨ – ១របា ១៦:៣៤–៣៦*

**១០៦** ចូរសរសើរដល់ព្រះយេហូវ៉ា[ក]ឱសូមអរព្រះគុណ
ដល់ព្រះយេហូវ៉ាដ្បិតទ្រង់ល្អ[ខ] សេចក្ដីសប្បុរសនៃទ្រង់ស្ថិត
ស្ថេរនៅជានិច្ច[គ]
២ តើមានអ្នកណាអាចនឹងពណ៌នាពីការ[ឃ]ខ្លាំងពូកែរបស់
ព្រះយេហូវ៉ាឬសំដែងពីសេចក្ដីសរសើររបស់ទ្រង់ទាំង
អស់បាន
៣ មានពរហើយអស់អ្នកដែលរក្សាសេចក្ដីយុត្តិធម៌[ង] ហើយ
អ្នកដែលប្រព្រឹត្តតាមសេចក្ដីសុចរិតគ្រប់ពេលគ្រប់វេលា[ច]
៤ ឱព្រះយេហូវ៉ាអើយ សូមទ្រង់នឹកចាំ[ឆ]នឹងប្រោសទូលបង្គំ
ដោយសេចក្ដីសប្បុរស[ជ] ដែលទ្រង់ផ្ដល់ដល់រាស្ត្រទ្រង់
ឱសូមប្រោសទូលបង្គំ ដោយសេចក្ដីសង្គ្រោះ[ឈ]នៃទ្រង់ផង
៥ ដើម្បីឱ្យទូលបង្គំបានឃើញសេចក្ដីចំរើន[ញ]នៃពួករើសតាំង
របស់ទ្រង់[ដ]ឱ្យទូលបង្គំបានរីករាយ ដោយសេចក្ដីអំណរ[ឋ]នៃ
រាស្ត្រទ្រង់ ហើយឱ្យបានអរព្រឺព្រួច ជាមួយនឹងមរដក[ឌ]
របស់ទ្រង់ ។

**១០៥:៤៤** ង នក ៣២:១៣ យស ១១:១៦–២៣ ១២:៨ ១៣:៦–៧ ទដ ១១:៦ ច ចទ ៦:១០–១១ ទដ ៧៨:៥៥ **១០៥:៤៥** ឆ ចទ ៤:៤០ ៦:២១–២៤ ទដ ៧៨:៥–៧ ជ ទដ ១០៤:៣៥ **១០៦:១** ក ទដ ២២:២៣ ១០៣:២ ខ ទដ ១១៩:៦៨ គ អរ ៣:១១ ទដ ១៣៦:១–២៦ យរ ៣៣:១១ **១០៦:២** ឃ ទដ ៧១:១៦

**១០៦:៣** ង ទដ ១១២:៥ ហស ១២:៦ ច ទដ ១៥:២ **១០៦:៤** ឆ ទដ ២៥:៦,៧ ជ ទដ ៧៧:៧ ឈ លប ៥០:២៤ **១០៦:៥** ញ ចទ ៣០:១៥ ទដ ១:៣ ដ ទដ ១០៥:៦ ឋ ទដ ២០:៥ ២៧:៦ ៤៧:៥ ១១៨:១៥ ឌ នក ៣៤:៩

**១០៥:៤៤** *ប្រទានស្រុករបស់នគរដទៃទាំងប៉ុន្មានឱ្យដល់គេ* មើល ខ.១១ ។

**១០៥:៤៥** *សេចក្ដីបញ្ញត្តិទ្រង់* ដោយព្រះយេហូវ៉ាទ្រង់បានរក្សា"សេចក្ដីសញ្ញា"របស់ទ្រង់ (ខ.១០) ដូច្នេះពួកអ៊ីស្រាអែលត្រូវរក្សាទុក "សេចក្ដីបញ្ញត្តិ"របស់ទ្រង់ ។ នៅក្នុងភាសាហេព្រើរ ពាក្យនេះមានន័យដូចគ្នានឹងពាក្យថា នឹកចាំដែលមាននិយាយនៅក្នុង ខ.៥ ដែរ ។ ការប្រោសលោះរបស់ព្រះយេហូវ៉ាដែលទ្រង់បានសម្រេចតាមសេចក្ដីសន្យា គឺនឹងបានផ្ដល់ដល់រាស្ត្ររបស់ទ្រង់ដែលបានថ្វាយជីវិតរបស់គេ ទៅតាមបំណងព្រះហឫទ័យដ៏បរិសុទ្ធរបស់ទ្រង់ (សូមមើល អស ៥:១–៧) ។ ដូច្នេះទំនួលខុសត្រូវដែលនិយាយពី ខ.១ មកដែលនិយាយពីការសរសើរតម្កើង និងអធិស្ឋាន (ការទុកចិត្ត) គឺបានសម្រេចក្នុងទំនួលខុសត្រូវទី៣ ដែលនិយាយពីការស្ដាប់បង្គាប់ (សូមមើល លប ១៨:១៩) ។

**ទដ ១០៦** នៅក្នុងជំពូកនេះ គឺជាការពណ៌នាប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់ពួកអ៊ីស្រាអែលក្នុងការបះបោរជាមួយព្រះ និងការអធិស្ឋានសូមឱ្យព្រះអង្គទ្រង់បានជួយសង្គ្រោះដល់រាស្ត្ររបស់ទ្រង់ជាថ្មី ។ ថិរវេលា រចនាបទនៃការសរសេរ និងផ្ទៃរឿងនៅក្នុងជំពូកនេះគឺមានលក្ខណៈដូចគ្នាបេះបិទនៅនឹង ទដ ១០៥ បេះបិទ ទោះបីជាមានចំណុចដែលផ្ទុយគ្នាត្រង់កន្លែងដែលនិយាយ ពីការបះបោរកាលពីគ្រាមុនរបស់ពួកអ៊ីស្រាអែលក៏ដោយ (សូមមើល ទដ ៧៨ នហ ៩:៥–៣៧) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះ ប្រហែលសរសេរនៅក្នុងក្រុងយេរូសាឡិមដោយពួកលេវី បន្ទាប់ពីបានរួចសណ្ឋានជាឈ្លើយ ។ តាមរយៈ៥ខដំបូង និង២ខចុងក្រោយ ហាក់បីដូចជាបានដកស្រង់យកពីការនិពន្ធកាលពីគ្រាមុន (មើល ១របា ១៦:៣៤–៣៦) ។ ដូច្នេះប្រហែលជាអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងបានបន្ថែមចំណុចខ្លះ (ដូចជាពាក្យថា "ហាលេលូយ៉ា") (ដែលជាការយកគំនិតតាម ទំនុករបស់ពួកកូនចៅរបស់ដាវីឌ) នៅពេលដែលគេចែករវាង ជំពូក ១០៦ និង ១០៧ ។ សូមមើលសេចក្ដីផ្ដើម ទដ ១០១–១១០ ។

ដោយព្រះគម្ពីរទំនុកដំកើងជំពូកនេះជាជំពូកចុងក្រោយក្នុងវគ្គនេះ (វគ្គទី៤) នោះព្រះគម្ពីរជំពូកនេះបានស្ថិតនៅចន្លោះបទចម្រៀង២ដែលនិយាយពីការហៅឱ្យចូលមកសរសើរដំកើងដល់ព្រះ ដោយមានពាក្យ "ហាលេលូយ៉ា" ។ ក្នុងពេលដែលគ្រោងព្រះគម្ពីរនេះបានស្ថិតនៅខាងក្រៅ និងយកទម្រង់ភាសាបែបការសរសើរដំកើង (សូមមើល ខ.១,៤៨ ហើយសូមមើលការពន្យល់នៅទីនោះ) ។

**១០៦:១–៥** នៅក្នុងខទាំងនេះគឺជាសេចក្ដីផ្ដើម ។

**១០៦:១** *អរព្រះគុណ* គឺជាអរព្រះគុណជាមួយការសរសើរដំកើង (សូមមើលការពន្យល់ ទដ ១០០ ត្រង់ចំណងជើង) ។ ព្រះគម្ពីរទំនុកដំកើងនេះគឺទាក់ទងទៅនឹងការហៅមនុស្សឱ្យមកសរសើរដតម្កើងដល់ព្រះអម្ចាស់ (សូមមើល ១០៧:១ ១១៨:១,២៩ ១៣៦:១) ។ *សេចក្ដីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**១០៦:២–៣** នៅក្នុងខទាំងនេះ គឺជាស្ពានចម្លងទៅឯតួរទំនុកដំកើងនេះដោយមានទាំងសំណួរ និងចម្លើយ ។

**១០៦:២** *តើមានអ្នកណាអាច* គឺពណ៌នាដោយសេចក្ដីសុចរិត ។ *សេចក្ដីសរសើរ* គឺសរសើរពីការអស្ចារ្យរបស់ទ្រង់ (សូមមើល ខ.៤៧ និងការពន្យល់ ៩:១) ។

**១០៦:៣** *មានពរហើយ* សូមមើលការពន្យល់ ១:១ ។ *សេចក្ដីយុត្តិធម៌ . . . សេចក្ដីសុចរិត* គឺចង់មានន័យថា យុត្តិធម៌ និងសុចរិត (សូមមើល ៣៦:៦ និងការពន្យល់ ៣:៧ ១១៩:១២១) ។ ខ.នេះគឺជាចម្លើយដែលបានចោទសួរនៅក្នុង ខ.២ ។

**១០៦:៤** *សូមទ្រង់នឹកចាំនិងប្រោសទូលបង្គំ* នៅក្នុងឃ្លានេះគឺជាពាក្យសំដីរបស់ម្នាក់ដែលបានប្ដេជ្ញាចិត្ត ថ្វាយជីវិតរស់នៅទៅព្រះដែលបានពណ៌នានៅក្នុង ខ.៣ ។ *ដោយសេចក្ដីសប្បុរស ដែលទ្រង់បានផ្ដល់រាស្ត្រទ្រង់* ឃ្លានេះអាចនិយាយបានម្យ៉ាងទៀតគឺ "សេចក្ដីសប្បុរសដែលទ្រង់ផ្ដល់ឱ្យ"(សូមមើល ខ.៤៤–៤៦) ។ *ដោយសេចក្ដីសង្គ្រោះ* ឬដោយសេចក្ដីសង្គ្រោះរបស់ទ្រង់ ។ អ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងនេះគាត់បានអធិស្ឋានថា ព្រះអង្គទ្រង់នឹងផ្ដល់ដល់គាត់សេចក្ដីសប្បុរសរបស់ទ្រង់ (ខ.៤៥) ដែលទ្រង់បានផ្ដល់ដល់រាស្ត្រទ្រង់ ។

**១០៦:៥** *សេចក្ដីចំរើន . . . រីករាយ . . . សេចក្ដីអំណរ* សេចក្ដីទាំងនេះគឺជាកម្មផលដែលបន្តនៅក្នុងជីវិតមនុស្ស ។ *មរដកនៃទ្រង់* មើល ខ.៤០ ។

[៦] យើងខ្ញុំរាល់គ្នាបានធ្វើបាប[ឈ]ដូចជាពួកពួយុកោ[ណ] យើងខ្ញុំ
ដែរក៏បានប្រព្រឹត្តអំពើទុច្ចរិត ហើយធ្វើការអាក្រក់ផង[ត]
[៧] ពួកព្ធយុកោយើងខ្ញុំមិនបានពិចារណាយល់[ថ]ពីការអស្ចារ្យ
របស់ទ្រង់នៅស្រុកអេស៊ីព្ទទេក៏មិនបាននឹកចាំ[ទ]ពីសេចក្តី
សប្បុរសដ៏បរិបូររបស់ទ្រង់ដែរ គេបានបះបោរនៅត្រង់
មាត់សមុទ្រវិញ[ធ]គឺជាសមុទ្រក្រហម
[៨] ទោះបីយ៉ាងនោះគង់តែទ្រង់បានជួយសង្គ្រោះគេ[ន]ដែរ
ដោយយល់ដល់ព្រះនាមទ្រង់[ប] ដើម្បីនឹងធ្វើឱ្យព្រះហស្តដ៏
ខ្លាំងពូកែ[ផ]របស់ទ្រង់បានប្រាកដច្បាស់
[៩] ទ្រង់បានបង្គាប់[ព]ដល់សមុទ្រក្រហម សមុទ្រនោះក៏រីងទៅ[ភ]
យ៉ាងនោះទ្រង់បាននាំគេដើរ[ម]កាត់ទីជំរៅ ដូចជាដើរនៅ
ទីគោក
[១០] ទ្រង់បានជួយ[យ]ឱ្យរួចពីកណ្តាប់ដៃ នៃពួកអ្នកដែលស្អប់
គេ[រ] ក៏លោះគេឱ្យរួចពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ[ល]
[១១] ទឹកសមុទ្របានហូរគ្រប[វ]លើពួកតតាំងនឹងគេ
ឥតមាននៅសល់ដល់មួយឡើយ
[១២] នោះទើបគេបានជឿ ព្រះបន្ទូលទ្រង់ ហើយច្រៀង
សរសើរដល់ទ្រង់[ស] ។
[១៣] តែមិនយូរប៉ុន្មាន ក៏ភ្លេច[ហ]កិច្ចការរបស់ទ្រង់ទៅ
ហើយមិនបានរង់ចាំស្តាប់សេចក្តីដំបូន្មានរបស់ទ្រង់ទេ[ឡ]
[១៤] គឺគេមានចិត្តខ្ជួលខ្នាញ់នៅទីរហោស្ថាន[អ] ក៏ល្បងល[ក]ព្រះ
នៅទីហួតហែង[ខ]វិញ
[១៥] ទ្រង់ក៏ព្រមប្រទានតាមសេចក្តីសំណូមរបស់គេ[គ]
តែទ្រង់ឱ្យមានសេចក្តីក្រៀមស្ងួត[ឃ]នៅក្នុងចិត្តគេវិញ
[១៦] គេក៏មានសេចក្តីច្រណែន[ង]នឹងម៉ូសេនៅក្នុងទីដំឡើង
ត្រសាលហើយនិងអើរ៉ុន ដែលជាអ្នកបរិសុទ្ធរបស់ព្រះ
យេហូវ៉ាដែរ
[១៧] នោះផែនដីក៏ប្រេះហា[ច]ស្រូបយកដាថានទៅ[ឆ] ហើយគ្រប
លើអ័ប៊ីរ៉ាម[ជ] និងពួកគាត់
[១៨] មានភ្លើងឆេះឡើង[ឈ]ក្នុងពួកគេ អណ្តាតភ្លើងនោះក៏
បញ្ឆេះមនុស្ស អាក្រក់ទៅ ។
[១៩] គេបានធ្វើរូបកូនគោ[ញ]នៅត្រង់ភ្នំហោរែប ហើយបាន
ក្រាបថ្វាយបង្គំចំពោះរូបសិតនោះ
[២០] គឺយ៉ាងនោះដែលគេបានប្តូរព្រះដ៏ជាសិរីល្អ[ដ]នៃគេឱ្យបាន
ជារូបដូចគោដែលស៊ីស្មៅវិញ
[២១] គេបានភ្លេចព្រះ[ឋ]ដែលជួយសង្គ្រោះគេជា ព្រះដែលបាន
ធ្វើការយ៉ាងធំសំបើម[ឌ]នៅស្រុកអេស៊ីព្ទ
[២២] គឺជាការយ៉ាងអស្ចារ្យនៅស្រុកហាំ[ឍ] និងការគួរស្ញែង
ខ្លាច[ណ]នៅត្រង់សមុទ្រក្រហម
[២៣] ដូច្នេះ ទ្រង់បានមានបន្ទូល ថានឹងបំផ្លាញ[ត]គេបង់
ប៉ុន្តែម៉ូសេ ជាអ្នករើសតាំងរបស់ទ្រង់
លោកបានឈរនៅចំពោះទ្រង់ ក្នុងដំណើររំលងនោះ[ថ]
ដើម្បីនឹងបង្វែរសេចក្តីក្រោធរបស់ទ្រង់ចេញក្រែងទ្រង់
បំផ្លាញគេមែន ។

**១០៦:៦** ឈ ១ពវ ៨:៤៧ រម ៣:៩ ណ ២រប ៣០:៧ ត នហ ១:៧ **១០៦:៧** ថ ពច ៣:៧ ទ ទដ ៧៨:១១,៤២ ធ នក ១៤:១១–១២ **១០៦:៨** ន នក ១៤:៣០ ទដ ៨០:៣ ១០៧:១៣ អស ២៥:៩ យអ ២:៣២ ប នក ៩:១៦ ទដ ២៣:៣ ផ នក ១៤:៣១ **១០៦:៩** ប ទដ ១៨:១៥ អស ៥០:២ ភ នក ១៤:២១ ណហ ១:៤ ម ទដ ៧៨:១៣ អស ៦៣:១១–១៤ **១០៦:១០** យ នក ១៤:៣០ ទដ ១០៧:១៣ រ ទដ ៧៨:៥៣ ល ទដ ៧៨:៤២ ១០៧:២ អស ៣៥:៩ ៦២:១២ **១០៦:១១** វ នក ១៤:២៨ **១០៦:១២** ស នក ១៥:១–២១ ទដ ១០៥:៤៣ **១០៦:១៣** ហ នក ១៥:២៤ ឡ នក ១៦:២៨ ជន ២៧:២១ **១០៦:១៤** អ ទដ ៧៨:៤០ ក នក ១៧:២ ១កថ ១០:៩ ខ ទដ ៦៨:៧ **១០៦:១៥** គ នក ១៦:១៣ ទដ ៧៨:២៩ ឃ ជន ១១:៣៣ **១០៦:១៦** ង ជន ១៦:១–៣ **១០៦:១៧** ច ចទ ១១:៦ ឆ នក ១៥:១២ ជ ជន ១៦:១ **១០៦:១៨** ឈ លវ ១០:២ **១០៦:១៩** ញ នក ៣២:៤ កថ ៧:៤១ **១០៦:២០** ដ យរ ២:១១ រម ១:២៣ **១០៦:២១** ឋ ទដ ៧៨:១១ ឌ ចទ ១០:២១ ទដ ៧៥:១ **១០៦:២២** ឍ ទដ ៧៨:៥១ ណ នក ៣:២០ ចទ ៤:៣៤ **១០៦:២៣** ត នក ៣២:១០ ថ នក ៣២:១១–១៤ ជន ១១:២ ចទ ៩:១៩

**១០៦:៦–១២** នៅក្នុងខទាំងនេះ និយាយពីការបះបោររបស់ពួកអ៊ីស្រាអែល និងសេចក្តីមេត្តាករុណារបស់ព្រះអង្គ នៅក្នុងគ្រាដែលគេបានចាកចេញពីអេស៊ីព្ទ ។

**១០៦:៦** នៅក្នុងខនេះគឺជាការលន់តួរអំពើបាបទូរទៅ ។ *យើង* នៅទីនេះ អ្នកនិពន្ធបាននិយាយថា ខ្លួនគាត់បានបះបោរនឹងព្រះជាមួយពួកអ៊ីស្រាអែល ហើយសូម្បីតែក្នុងសេចក្តីអធិស្ឋានក៏គាត់ បានសូមឱ្យព្រះបានផ្តល់សេចក្តីមេត្តាករុណាដល់រាស្ត្រទ្រង់ដែរ (សូមមើល អរ ៩:៦–៧) ។

**១០៦:៧,២២** *ការអស្ចារ្យ* ឧទាហរណ៍ដូចជា គ្រោះកាចដែលកើតមានដល់ពួកអេស៊ីព្ទជាដើម (មើលការពន្យល់ ៩:១ ត្រង់ពាក្យថា "ការ អស្ចារ្យ") ។

**១០៦:១០** *ជួយឱ្យរួច* នៅទីនេះពាក្យនេះជាសទីសន័យនឹងពាក្យថា "ប្រោសលោះ" ។

**១០៦:១២** *ច្រៀងសរសើរទ្រង់* សូមមើល នក ១៥:១–២១ ។

**១០៦:១៣–១៨** នៅក្នុងខទាំងនេះ និយាយពីការខ្ជួលខ្នាញ់របស់ពួកអ៊ីស្រាអែលនិងការជំនុំជម្រះរបស់ព្រះយេហូវ៉ា ។

**១០៦:១៣–១៥** នៅក្នុងខទាំងនេះនិយាយ ពីការដែលពួកអ៊ីស្រាអែលមិនពេញចិត្តចំពោះការផ្គត់ផ្គង់របស់ព្រះយេហូវ៉ា (សូមមើល នក ជំពូក ១៦ ជន ជំពូក ១១) ។

**១៦:១៣** *សេចក្តីដំបូន្មានរបស់ទ្រង់* គឺជារបៀបដំណោះស្រាយរបស់ព្រះ ។

**១០៦:១៦–១៨** នៅក្នុងខទាំងនេះ និយាយពីការដែលពួកអ៊ីស្រាអែលមិនពេញចិត្តចំពោះអ្នកដឹកនាំដែលព្រះបានរើសតាំង (មើល ជន ១៦:១–៣៥) ។

**១០៦:១៩–២៣** នៅក្នុងខទាំងនេះ និយាយពីសេចក្តីកំផិតនៅត្រង់ភ្នំហោរែប និងការទូលអង្វររបស់លោកម៉ូសេ ។

**១០៦:១៩** *ភ្នំហោរែប* សូមមើលការពន្យល់ នក ៣:១ ។

**១០៦:២០** *សិរីល្អ* គឺជាសិរីល្អរបស់ព្រះយេហូវ៉ា (សូមមើល ១សយ ១៥:២៩ យរ ២:១១) ។

**១០៦:២២** *ស្រុកហាំ* សូមមើល ៧៨:៥១ និងការពន្យល់ ។

**១០៦:២៣** *ឈរនៅចំពោះទ្រង់* សូមមើល នក ៣២:១១–១៤,៣១–៣២ *សេចក្តីក្រោធ* សូមមើលការពន្យល់ ២:៥ ។

២៤អើ គេបានមើលងាយ[ទ]ស្រុកដ៏សប្បាយនោះ[ធ] គេមិន
បានជឿ[ន]ព្រះបន្ទូលទ្រង់ទេ
២៥គឺបានរទូររទាំ[ប]នៅក្នុងត្រសាលគេវិញ ឥតស្តាប់តាម
ព្រះសូរសៀងនៃព្រះយេហូវ៉ាឡើយ
២៦ដូច្នេះ ទ្រង់ក៏លើកព្រះហស្តឡើងស្បថ[ផ]នឹងគេថា ទ្រង់នឹង
ឱ្យគេដួលនៅក្នុងទីរហោស្ថាន[ព]
២៧ហើយថា នឹងឱ្យពូជពង្សគេដួលនៅកណ្តាលអស់ទាំង
សាសន៍ ព្រមទាំងកំចាត់កំចាយ[ភ]គេ ឱ្យទៅនៅពេញ
ពាសក្នុងប្រទេសដទៃទាំងប៉ុន្មាន ។
២៨គេក៏បានទៅភ្ជាប់ខ្លួននឹងព្រះបាល-ពេអរ[ម] ហើយបាន
បរិភោគអស់ទាំងគ្រឿងបូជា ដែលថ្វាយដល់រូបព្រះ
ឥតជីវិត
២៩គឺយ៉ាងនោះដែលគេបានបណ្តាលឱ្យទ្រង់ខ្ញាល់[យ]
ដោយសារអំពើ[រ]របស់គេ ហើយមានការប្រហារជីវិត[ល]
កើតឡើងនៅក្នុងពួកគេ
៣០គ្រានោះភីនេហាស[វ]ក៏ក្រោកឡើង សំរេចទោសដល់គេ
រួចការប្រហារជីវិតនោះក៏អាក់ខានទៅ[ស]
៣១ការនោះបានរាប់ជាសេចក្តីសុចរិតដល់ភីនេហាស[ហ]
ដរាបដល់គ្រប់ទាំងដំណមនុស្ស[ឡ]ជារៀងរាបតទៅ ។
៣២គេក៏បណ្តាលឱ្យទ្រង់ខ្ញាល់ នៅត្រង់ទឹកមេរីបា[អ]
ទៀតការនោះជាហេតុនាំឱ្យម៉ូសេកើតមានទោសដែរ
ដោយព្រោះគេ
៣៣ដ្បិតគេបានរំអុក[ក]ដល់ចិត្ត[ខ]លោក ហើយបបូរមាត់លោក
បាននិយាយឥតបើគិត[គ] ។
៣៤គេក៏មិនបានបំផ្លាញ[ឃ]សាសន៍ដទៃទាំងប៉ុន្មាន ដូចជា
ព្រះយេហូវ៉ាបានបង្គាប់[ង]ដែរ
៣៥គឺគេបានទៅប្រព្រឹត្តច្របូកច្របល់[ច]ជាមួយព្រមទាំង
រៀនតាមកិរិយារបស់សាសន៍ដទៃទាំងនោះវិញ
៣៦ក៏គោរពប្រតិបត្តិដល់រូបព្រះរបស់សាសន៍ទាំងនោះ[ឆ]
ដែរជាការដែលត្រឡប់ជាអន្ទាក់[ជ]ដល់គេ
៣៧អើ គេបានទាំងបូជាថ្វាយនូវកូនប្រុស[ឈ]កូនស្រីគេ ដល់
អារក្សផង[ញ]
៣៨ក៏កំចាយឈាមដែលគ្មានទោសគឺជាឈាម របស់កូន
ប្រុស[ដ]កូនស្រីគេដែលគេបូជាថ្វាយដល់អស់ទាំងរូបព្រះ
នៅស្រុកកាណាន ដូច្នេះស្រុកក៏ត្រឡប់ជាស្មោកគ្រោក

**១០៦:២៤** ទ ជន ១៤:៣០-៣១ ធ ចទ ន ជន ១៤:១១ ហេព ៣:១៨-១៩ **១០៦:២៥** ប នក ១៥:២៤ ចទ ១:២៧ ១កថ ១០:១០ **១០៦:២៦** ផ ជន ១៤:២៣ ហេព ៤:៣ ព ចទ ២:១៤ ហេព ៣:១៧ ៨:៧ យរ ៣:១៩ **១០៦:២៧** ភ លវ ២៦:៣៣ **១០៦:២៨** ម ជន ២៣:២៨ **១០៦:២៩** យ ជន ២៥:៣ រ ទដ ៦៤:២ ១៤១:៤ **១០៦:២៩** ល ជន ១៦:៤៦ ២៥:៨ **១០៦:៣០** វ នក ៦:២៥ ស ជន ២៥:៨ **១០៦:៣១** ហ លប ១៥:៦ ជន ២៥:១១-១៣ ឡ ទដ ៤៩:១១

**១០៦:៣២** អ នក ១៧:៧ ជន ២០:២-១៣ **១០៦:៣៣** ក នក ២៣:២១ ទដ ១០៧:១១ ខ ទដ ៥១:១១ អស ៦៣:១១ គ នក ១៧:៤-៤ ជន ២០:៨-១២ **១០៦:៣៤** ឃ យស ៩:១៥ ពច ១:២៧-៣៦ **១០៦:៣៤** ង នក ២៣:២៤ ចទ ២:៣៤ ៧:១៦ ២០:១៧ **១០៦:៣៥** ច ពច ៣:៥-៦ អរ ៩:១-២ **១០៦:៣៦** ឆ ចទ ៧:១៦ ជ នក ១០:៧ **១០៦:៣៧** ឈ លវ ១៨:២១ ចទ ១២:៣១ អគ ១៦:២០-២១ ញ នក ២២:២០ ចទ ៣២:១៧ ១កថ ១០:២០ **១០៦:៣៨** ដ លវ ១៨:២១ ចទ ១៨:១០ ២ពវ ៣:២៧

**១០៦:២៤-២៧** នៅក្នុងខទាំងនេះ និយាយាពីការដែលពួកអ៊ីស្រាអែលគេខ្វះសេចក្តីជំនឿនៅត្រង់ព្រំប្រទល់ទឹកដីសន្យា និងការជំនុំជម្រះរបស់ព្រះយេហូវ៉ា(សូមមើល ជន ១៤:១-២៣) ។

**១០៦:២៤** *ស្រុកដ៏សប្បាយ* គឺបានពណ៌នានៅក្នុង យរ ៣:១៩ ១២:១០ សក ៧:១៤ និងក្នុង ចទ ៨:៧-៩ អគ ២០:៦ ។

**១០៦:២៦-២៧** *ដួល* សូមមើលការពន្យល់ ១៣:៤ ។

**១០៦:២៧** *ព្រមទាំងកំចាត់កំចាយគេ* សូមមើល លវ ២៦:៣៣ ចទ ២៨:៣៦-៣៧,៦៤ និងការពន្យល់ អគ ២០:២៣ ។

**១០៦:២៨-៣៣** នៅក្នុងខទាំងនេះ និយាយពីសេចក្តីកំផិតនៅត្រង់ពេអរ និងការបាត់បង់លោកម៉ូសេ ។

**១០៦:២៨** *ភ្ជាប់ខ្លួន* សូមមើល ជន ២៥:៣,៥ ("ចូលខាង") ។

**១០៦:៣១** *ការនោះបានរាប់ជាសេចក្តីសុចរិត* ដូចគ្នានឹងលោកអ័ប្រាហាំដែរ លោកបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿ (សូមមើល លប ១៥:៦) ដូច្នេះអ្វីដែលអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើងនិយាយគឺ ភាពជាសង្ឃរបស់ភីនីហាសគឺសម្រាប់ព្រះយេហូវ៉ា (សូមមើល ជន ២៥:៧-៨) ។ *ដរាបដល់គ្រប់ទាំងដំណមនុស្ស ជារៀងដរាប* នៅក្នុងឃ្លានេះអ្នកនិពន្ធនិយាយសំដៅលើ "សេចក្តីសញ្ញា ឱ្យបានការងារជាសង្ឃ នៅជាដរាបតទៅ" (សូមមើល ជន ២៥:១៣) ដែលព្រះយេហូវ៉ាទ្រង់បានផ្តល់ឱ្យភីនេហាសជាអំណោយទាននៃព្រះគុណ ដោយព្រោះជំនឿដ៏ល្អរបស់គាត់ ។ គឺជាសេចក្តីសញ្ញាដែលបានធានាថា ព្រះអង្គទ្រង់នឹងរាប់គាត់ជាសុចរិត ដ្បិតសេចក្តីសន្យាដែលព្រះបានតាំងសញ្ញាជាមួយលោកអ័ប្រាហាំ នោះព្រះបានរាប់គាត់ជាសុចិតដោយពោះសេចក្តីជំនឿដែលគាត់មាន (សូមមើល លប ១៥:៩-១២) ។ សេចក្តីសញ្ញានៃការអនុញ្ញាត្តប្រហាក់ប្រហែលគ្នានេះគឺបានតាំងជាមួយលោកណូអេ (សូមមើល លប ៩:៩-១៧) ហើយនឹងដាវីឌ (សូមមើល ២សយ ៧:៥-១៦) គឺយោងទៅតាមទីបន្ទាល់របស់ព្រះអម្ចាស់ ដោយព្រោះសេចក្តីសុចរិតរបស់ពួកគេ (សូមមើល លប ៧:១ ១សយ ១៣:១៤) ។

**១០៦:៣២** *មេរីបា* សូមមើលការពន្យល់ នក ១៧:៧ ។

**១០៦:៣៤-៣៩** នៅក្នុងខទាំងនេះ ពណ៌នាពីការបះបោររបស់ពួកអ៊ីស្រាអែលនៅក្នុងទឹកដីសន្យា ចាប់តាំងពីគ្រាពួកចៅហ្វាយ រហូតដល់គ្រានិរទេសទៅបាប៊ីឡូន ។

**១០៦:៣៦** *ត្រឡប់ជាអន្ទាក់ដល់គេ* សូមមើល នក ២៣:៣៣ ចទ ៧:១៦ ពច ២:៣ ៨:២៧ ហើយធៀបជាមួយ នក១០:៧ ៣៤:១២ ១សយ ១៨:២១ និងការពន្យល់ ៩:១៥ ។

**១០៦:៣៧** *គេបានទាំងបូជា* ភាសាហេព្រើរពាក្យនេះ មានប្រើក្នុងសញ្ញាចាស់គឺមានតែក្នុង ចទ ៣២:១៧ ប៉ុណ្ណោះ ដែលនិយាយសំដៅលើពួកព្រះក្លែងក្លាយ ។ ពាក្យនេះមានទំនាក់ទំនងទៅនឹងភាសាពួកបាប៊ីឡូនដែលនិយាយសំដៅលើវិញ្ញាណការពារ (ពួកអ្នកមិនជឿ) ។

**១០៦:៣៨** សូមធៀបជាមួយ យរ ១៩:៤-៥ ។ *ឈាមគ្មានទោស* គឺជាឈាមនៃអ្នកដែលគ្មានទោសពីបទឧក្រិដ្ឋឡើយ ។ *ស្មោគគ្រោក* នៅក្នុងឃ្លានេះ

ដោយសារឈាម
៣៩គឺយ៉ាងនោះដែលគេបានធ្វើឱ្យខ្លួន[ឋ] មានសៅហ្មង
ដោយសារកិរិយារបស់គេ ព្រមទាំងប្រព្រឹត្តសេចក្ដីកំផិត[ឌ]
ដោយអំពើរបស់គេផង ។
៤០ហេតុនោះបានជាសេចក្ដីក្រោធរបស់ព្រះយេហូវ៉ា
បានឆួលឡើង[ឍ]ទាស់នឹងរាស្ត្រទ្រង់ហើយទ្រង់ក៏ស្អប់ខ្ពើម
ពួកដែលជាមរដករបស់ទ្រង់វិញ[ណ]
៤១ទ្រង់ប្រគល់គេទៅក្នុង[ត]កណ្ដាប់ដៃនៃសាសន៍ដទៃ
ហើយពួកអ្នកដែលស្អប់គេ បានគ្រប់គ្រងលើគេវិញ
៤២ពួកខ្មាំងសត្រូវបានសង្កត់សង្កិន[ថ] ហើយគេត្រូវចុះចាញ់
នៅក្រោមកណ្ដាប់ដៃពួកសត្រូវនោះ
៤៣ទ្រង់បានប្រោសគេឱ្យរួចជាច្រើនដងច្រើនគ្រា[ទ] ប៉ុន្តែ
សេចក្ដីដំបូន្មានរបស់គេបានទាស់ទទឹង[ធ]នឹងទ្រង់ ហើយគេ
ត្រូវធ្លាក់ទៅជាទាបថោកក្នុងអំពើទុច្ចរិតរបស់គេ
៤៤ទោះបីយ៉ាងនោះ គង់តែទ្រង់បានទតមើលសេចក្ដីវេទនា
របស់គេក្នុងកាលដែលគេអំពាវនាវរកទ្រង់ដែរ[ន]
៤៥ទ្រង់ក៏នឹកចាំពីសេចក្ដីសញ្ញា[ប]របស់ទ្រង់ចំពោះគេ
ហើយបានប្រែគំនិត[ផ] ទៅដោយសេចក្ដីសប្បុរស[ព]ដ៏បរិបូរ
របស់ទ្រង់
៤៦ទ្រង់បណ្ដាលឱ្យពួកអ្នកដែលដឹកនាំគេទៅជាឈ្លើយ[ភ]
ត្រឡប់ជាមានសេចក្ដីអាណិតមេត្តាដល់គេវិញ ។
៤៧ឱព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំអើយ សូមជួយ
សង្គ្រោះយើងខ្ញុំ[ម]ផងសូមប្រមូលយើងខ្ញុំ[យ]ពីកណ្ដាលពួក
សាសន៍ដទៃមកដើម្បីឱ្យយើងខ្ញុំបានលើកដំកើង[រ]ព្រះ
នាម[ល]បរិសុទ្ធនៃទ្រង់ព្រមទាំងយកការសរសើរដល់ទ្រង់
ទុកជាសេចក្ដីអំណររបស់យើងខ្ញុំផង ។
៤៨ឱ សូមសរសើរដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែលចាប់តាំងពីអស់កល្បរៀងទៅដល់អស់កល្ប
ជានិច្ចត្រូវឱ្យបណ្ដាជនទាំងឡាយពោលថា អាម៉ែន
ចូរលើក ដំកើងព្រះយេហូវ៉ាចុះ ។

ប៉ែកទី៥

**១០៧** ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា[ក]ដ្បិតទ្រង់ល្អ[ខ]

**១០៦:៣៩** ឋ លប ៣:១៧ លវ ១៨:២៤ អគ ២០:១៨ ឌ ជន ១៥:៣៩ **១០៦:៤០** ឍ លវ ២៦:២៨ ណ នក ៣៤:៩ ចទ ៩:២៩ **១០៦:៤១** ត ពច ២:១៤ **១០៦:៤២** ថ ពច ៤:៣ **១០៦:៤៣** ទ យស ១០:១៤ ពច ៧:១-២៥ នហ ៩:២៨ ទដ ៨១:១៣-១៤ ធ ពច ២:១៦-១៩ ៦:១-៧ **១០៦:៤៤** ន ពច ៣:៩ **១០៦:៤៥** ប លប ៩:១៥ ទដ ១០៥:៨ លក ១:៧២ ផ នក ៣២:១៤ ព ទដ ១៧:៧ ១០៣:១១ **១០៦:៤៦** ភ នក ៣:២១ ១ពវ ៨:៥០ **១០៦:៤៧** ម ទដ ២៨:៩ យ ទដ ១០៧:៣ ១៤៧:២ អស ១១:១២ ២៧:១៣ ៥៦:៨ ៦៦:២០ យរ ៣១:៨ អគ ២០:៣៤ មីក ៤:៦ រ ទដ ១០៥:១ ល ទដ ៣០:៤ ៩៩:៣ **១០៧:១** ក ១រប ១៦:៨ ២រប ៥:១៣ ខ ២រប ៧:៣

ចង់និយាយថា នៅគ្រប់ទាំងស្រុកគឺបង្ករឱ្យមានភាពស្មោកគ្រោកដោយការសម្លាប់អ្នកដែលគ្មានទោស (សូមមើល ជន ៣៥:៣៣ យរ៣:២,៩) ។

**១០៦:៣៩** *ធ្វើឱ្យខ្លួន* មើល លវ ១៨:២៤ យរ ២:២៣ អគ ២០:៣០-៣១ ២២:៣-៤ ។ *ប្រព្រឹត្តិសេចក្ដីកំផិត* មើល នក ៣៤:១៥ និងការពន្យល់ ។

**១០៦:៤០-៤៦** នៅក្នុងខទាំងនេះ និយាយពីការតឹងរឹងរបស់ព្រះអម្ចាស់ ក្នុងការទាស់ប្រឆាំងចំពោះអ្នកដែលបះបោរនឹងព្រះអង្គ (មើល ខ.៤០-៤៣) ប៉ុន្តែព្រះអង្គទ្រង់ក៏ផ្ដល់ព្រះគុណមកដែរ ដោយព្រោះទ្រង់បាននឹកចាំពីសេចក្ដីសញ្ញា (ខ.៤៤-៤៦) ។ ការជំនុំជម្រះនៅទីនេះបានផ្ដោតសំខាន់លើការបញ្ជាក់ពីសេចក្ដីសញ្ញារបស់ទ្រង់ (មើល លវ ២៦:២៥-២៦,៣៣, ៣៨-៣៩ ចទ ២៨:២៥ ៣៦-៣៧ ៤៨-៥៧ ៦៤-៦៨) ។

**១០៦:៤០** *សេចក្ដីក្រោធ* មើលការពន្យល់ ២:៥ ។ *ស្អប់ខ្ពើម* មើល ៥:៦ ។

**១០៦:៤៤** *ទតមើលសេចក្ដីវេទនារបស់គេ ក្នុងកាលដែលគេអំពាវនាវរកទ្រង់* សូមមើល នក២:២៣ ៣:៧-៩ ជន ២០:១៦ ពច ៣:៩,១៥ ៤:៣ ៦:៦-៧ ១០:១០ ១សយ ៩:១៦ ២រប ២០:៦-១២ នហ៩: ២៧-២៨ ។

**១០៦:៤៥** *នឹកចាំពីសេចក្ដីសញ្ញា* សូមមើល ១០៥:៨,៤២ នក ២:២៤ លវ ២៦:៤២,៤៥ ។ *សេចក្ដីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**១០៦:៤៦** *ពួកអ្នកដែលដឹកនាំគេទៅជាឈ្លើយ ត្រឡប់ជាមានសេចក្ដីអាណិតមេត្តាដល់គេវិញ* ការពណ៌នារបស់អ្នកនិពន្ធគឺគាត់បានរាប់បញ្ចូលទាំងការនាំទៅជាឈ្លើយនៅបាប៊ីឡូន (សូមមើល ១ពវ ៨:៥០ ២រប ៣០:៩ អស ៩:៩ យរ ៤២:១២) ។

**១០៦:៤៧** នៅក្នុងខនេះ គឺជាសេចក្ដីអធិស្ឋានរបស់ពួកបណ្ដាជន សូមឱ្យព្រះអង្គទ្រង់រំដោះពួកគេ និងស្ដារបនាជីវិតពួកគេឡើងវិញ ក្នុងគ្រាដែលគេត្រូវកំចាត់កំចាយ(សូមមើលសេចក្ដីផ្ដើម និងការពន្យល់ ខ.៤)។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។ *សរសើរដំកើង* គឺសរសើរតម្កើងចំពោះជ័យជម្នះ ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរឃ្លានេះមានតែក្នុងការប្រៀបធៀប ១៦:៣៥ ។ *ការសរសើរ* សូមមើលការពន្យល់ ៩:១ ។

**១០៦:៤៨ក** នៅក្នុងខនេះទាក់ទងទៅនឹងការសរសើរតម្កើង ដែលមានតួនាទីជាបទសរសើរតម្កើងបញ្ចប់ព្រះគម្ពីរទំនុកដំកើងប៉ែកទី៤ (សូមមើល ៤១:១៣ និងការពន្យល់, សេចក្ដីផ្ដើមព្រះគម្ពីរទំនុកដំកើងជំពូកនេះ និងការពន្យល់ ខ.១ ។

**១០៦:៤៨ខ** *ត្រូវឱ្យបណ្ដាជនទាំងឡាយបានពោលថា* មើល ១រប ១៦:៣៦ គឺជាឧទានស័ព្ទមួយផ្សេងទៀត ។ *អាម៉ែន* សូមមើល ចទ ២៧:១៥ និងការពន្យល់ ១រប ១៦:៣៦ នហ ៥:១៣ យរ ១១:៥ រម ១:២៥ និងការពន្យល់ ១កថ ១៤:១៦ ។

**ទដ ១០៧** នៅក្នុងជំពូកនេះ អ្នកនិពន្ធបានជំរុញចិត្តដល់បណ្ដាជនឱ្យចូលមកសរសើរតម្កើងចំពោះព្រះយេហូវ៉ា ដោយព្រោះសេចក្ដីសប្បុរសនៃទ្រង់ស្ថិតស្ថេរជានិច្ច ដែលបានតបឆ្លើយចំពោះសេចក្ដីអធិស្ឋានរបស់អ្នកកំសត់ទុរគត៌ និងសង្គ្រោះគេ (សូមមើលអត្ថបទក្រោយទៀត) ។ ព្រះគម្ពីរទំនុកដំកើងជំពូកនេះត្រូវបាននិពន្ធឡើង ដើម្បីច្រៀងសរសើរតម្កើងដល់ព្រះយេហូវ៉ាក្នុងពិធីបុណ្យប្រចាំឆ្នាំរបស់ពួកអ៊ីស្រាអែល ។ ការកាត់ស្រាយព្រះគម្ពីរទំនុកដំកើងក្នុងជំពូកនេះមានលក្ខណៈប្រែប្រួល និងខុសគ្នាជាច្រើន ប៉ុន្តែការកាត់ស្រាយខាងក្រោមនេះគឺមានលក្ខណៈច្បាស់ជាង គឺនិយាយថា ដោយការទទួលបានសេចក្ដីសប្បុរសនៃព្រះ ក្នុងពេលដែលពួកគេត្រឡប់ពីនិរទេសវិញ (សូមមើល ខ.៣ យរ ៣៣:១១) នោះពួកអ៊ីស្រាអែលដែលដឹកនាំដោយពួកលេវី គេអបអរសាទរចំពោះសេចក្ដីសប្បុរសដ៏នៅអស់កល្បជានិច្ច ក្នុងកាលដែលទ្រង់ប្រទានពរដល់អ្នកណាដែលអំពាវនាវដល់ព្រះនាម

សេចក្ដីសប្បុរសនៃទ្រង់ស្ថិតស្ថេរ នៅជានិច្ច
២ គួរឱ្យពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះ[ក] បានថា
ដូច្នេះដែរគឺអស់អ្នកដែលទ្រង់បានលោះឱ្យរួចពីកណ្ដាប់
ដៃនៃពួកខ្មាំងសត្រូវនោះ
៣ ហើយប្រមូល[ឃ] មកពីគ្រប់ទាំងស្រុក គឺពីទិសខាងកើត
ទិសខាងលិច ទិសខាងជើង ហើយទិសខាងត្បូងផង ។
៤ គេបានដើរសាត់អណ្ដែត តាមផ្លូវស្ងាត់ឈឹង ក្នុង
ទីរហោស្ថាន[ង] គេរកទីក្រុង[ច] ណាដែលល្មមអាស្រ័យនៅមិន
បានឡើយ
៥ ព្រលឹងគេក៏ហេវ[ឆ] ទៅ ដោយស្រេកឃ្លាន[ជ]
៦ គ្រានោះ គេបានអំពាវនាវ[ឈ] ដល់ព្រះយេហូវ៉ា
ដោយសេចក្ដីវេទនារបស់គេហើយទ្រង់ក៏ប្រោសឱ្យរួចពី
សេចក្ដីលំបាកនោះ
៧ ទ្រង់បាននាំគេតាមផ្លូវត្រង់[ញ] វិញដើម្បីឱ្យគេចូលដល់
ទីក្រុង[ដ] ដែលអាស្រ័យនៅបាន
៨ ឱសូមឱ្យមនុស្សទាំងឡាយសរសើរ[ឋ] ដល់ព្រះយេហូវ៉ា
ដោយព្រោះសេចក្ដីសប្បុរស[ឌ] របស់ទ្រង់ ហើយដោយ
ព្រោះ អស់ទាំងការអស្ចារ្យ[ឍ] ដែលទ្រង់បានប្រោសដល់
មនុស្សជាតិ
៩ ដ្បិតទ្រង់ប្រោសព្រលឹងដែលសង្វាតឱ្យបានស្កប់ស្កល់[ណ]
ហើយទ្រង់ចំអែតព្រលឹង ដែលស្រេកឃ្លានដោយសេចក្ដី
ល្អ[ត]

**១០៧:២** ក ទដ ១០៦:១០ អស ៣៥:៩
**១០៧:៣** ឃ នហ ១:៩
**១០៧:៤** ង យស ៥:៦ ច ខ.៣៦
**១០៧:៥** ឆ នក ១៦:៣ ជ នក ១៥:២២ ១៧:២
**១០៧:៦** ឈ នក ១៤:១០
**១០៧:៧** ញ អរ ៨:២១ ដ ខ.៣៦
**១០៧:៨** ឋ ទដ ១០៥:១ ឌ ទដ ៦:៤ ឍ ទដ ៧៥:១
**១០៧:៩** ណ ទដ ២២:២៦ ៦៣:៥ អស ៥៨:១១ មថ ៥:៦ លក ១:៥៣ ត ទដ ២៣:១ យរ ៣១:២៥

ទ្រង់ ។ របៀប ឬរចនាបទនៃការច្រៀងបទចម្រៀងព្រះគម្ពីរទំនុកដំកើងជិពូកនេះ គឺមានទំនាក់ទំនងជាមួយព្រះគម្ពីរ ទដ ១០៤–១០៦ ហើយភាសាដែលប្រើក្នុងជិពូកនេះមានទំនាក់ទំនងជាមួយ ទដ ១០៥–១០៦ ។ ដោយព្រោះតែមូលហេតុនេះ ធ្វើឱ្យមានគោលបំណងប្រាកដប្រជាច្បាស់លាស់ជាមួយព្រះគម្ពីរទំនុកដំកើង២ជិពូកចុងក្រោយ ដែលមានទម្រង់ជាត្រីវិនាដសាស្ត្រ ដែលសរសេរឡើងដោយអ្នកនិពន្ធតែមួយ ។ ទោះបីជាបែបនេះ ឬមិនមែនបែបនេះ ក៏ដោយការដែលព្រះគម្ពីរទំនុកដំកើងជិពូកនេះមានភាពស្របគ្នា ជាមួយព្រះគម្ពីរជិពូកមុនៗបានបង្ហាញថា គឺវាមានទំនាក់ទំនងជាមួយផ្ទៃរឿង មុនដែលមានការបែងចែកព្រះគម្ពីរវាង ជិពូក ១០៦ និង ១០៧ ដែលមានបំណងបញ្ចប់ព្រះគម្ពីរទំនុកដំកើងដ៏ខ្លីមួយ ពីជិពូក ១០៤, ១០៧ ។ ព្រះគម្ពីរទំនុកដំកើងនេះបានពណ៌នាពី "ការអស្ចារ្យដែលទ្រង់បានប្រោសដល់មនុស្សជាតិ" (ខ.៨) ដែលជាចំណុចប្រសើរបំផុតជាមួយ ទដ ១០៥–១០៦ ដែលពណ៌នាពីការបង្កើតរបស់ទ្រង់ (មើល ១០៤:២–២៦) និងការប្រទានពរដល់ជីវិតសត្វទាំងឡាយនៅលើផែនដី (មើល ១០៤:២៧–៣០) ។

**១០៧:១–៣** នៅក្នុងខទាំងនេះ គឺជាសេចក្ដីផ្ដើម ។

**១០៧:១** នៅក្នុងខនេះ និយាយពីការហៅឱ្យចូលមកសរសើរតម្កើងដល់ព្រះអម្ចាស់(សូមមើល ១០៦:១ ១១៨:១, ២៩ ១៣៦:១ យរ ៣៣:១១) ។ *ឱសូមអរព្រះគុណ* សូមមើល ខ.៨,១៥,២១,៣១ និង ការពន្យល់ ទដ ១០០ ត្រង់ចំណងជើង ។ *សេចក្ដីសប្បុរស* សូមមើល ខ.៨,១៥,២១,៣១,៤៥ និងការពន្យល់ ៦:៤ ។

**១០៧:២** *ប្រោសលោះ* នៅទីនេះក៏ដូចនៅកន្លែងផ្សេងៗទៀតដែរ ពាក្យនេះមានន័យដូចគ្នានឹងពាក្យថា "ជួយឱ្យរួច"។

**១០៧:៣** *ប្រមូលមកពីគ្រប់ទាំងស្រុក* គឺនិយាយសំដៅលើការប្រមូលពីការខ្ចាត់ខ្ចាយដែលពួកសាសន៍អាសស៊ើ (សូមមើល ២ពវ ១៧:៦) និងពួកបាប៊ីឡូនចាប់ទៅជាឈ្លើយ (សូមមើល ២ពវ ២៤:១៤,១៦ ២៥:១១,២៦ យរ ៥២:២៨–៣០ និង នហ ១:៨ នអ ៨:៥,៩,១៣ អស ១១:១២ ៤៣:៥–៦ អគ ១១:១៧ ២០:៣៤) ។ *ទិសខាងត្បូង* តាមភាសាអក្សរសាស្ត្រ ពាក្យនេះគឺនិយាយសំដៅលើ "សមុទ្រ" (សូមមើលការពន្យល់) ហើយពាក្យនេះ មានន័យដូចគ្នានឹងពាក្យថា ទិសខាងលិច ដូចជាមាននិយាយនៅក្នុង អស ៤៩:១២ ។ ប៉ុន្តែប្រហែលពីព្រោះភាសាហេព្រើរមានការបាត់នៅពាក្យចុងក្រោយ ទើបនៅសល់តែពាក្យ "ទិសខាងត្បូង "។

**១០៧:៤–៩** នៅក្នុងខទាំងនេះ ចង់និយាយពីការប្រោសលោះដល់អ្នកដែលបានដើរសាត់អណ្ដែតក្នុងទីរហោស្ថាន ។ នៅក្នុងខទាំងនេះមិនបាននិយាយពីការបះបោររបស់ពួកគេនោះឡើយ (ដូចជានៅក្នុងល្បះទី៣ និងល្បះទី៤) ប៉ុន្តែក្នុងអំឡុងពេលដែលពួកអ៊ីស្រាអែលគេធ្វើដំណើរឆ្លងកាត់ទីរហោស្ថាន ឆ្ពោះទៅកាន់ទឹកដីសន្យា ពួកគេបានជួបប្រទះនូវបទពិសោធដែលគួរឱ្យតក់ស្លុតយ៉ាងខ្លាំងនៅក្នុងទីរហោស្ថាន ។ ពួកគេបានមកដល់ព្រំប្រទល់ខាងកើត ដោយបានធ្វើដំណើរកាត់ទីរហោស្ថានអារ៉ាប់ (ស្ថិតនៅខាងលិចសមុទ្រមេឌីទែរ៉ាណេ សូមមើល ខ.២៣–៣២) ដោយរួមទាំងមានពួកឈ្មួញទៅជាមួយដែរ ។

**១០៧:៤,៧,៣៦** *ទីក្រុងណាដែលល្មមអាស្រ័យ* នៅក្នុងឃ្លានេះបើតាមលក្ខណៈអក្សរសាស្ត្រ គឺ "ទីក្រុងស្នាក់អាស្រ័យ" ដូចជា កន្លែងដែលគេរស់នៅ ឬកន្លែងដែលមានអាហារ និងទឹកដែលអាចរស់នៅបានយ៉ាងស្រួល ។

**១០៧:៦** *គេអំពាវនាវ* នៅក្នុងខនេះ អ្នកនិពន្ធបានប្រើកិរិយាស័ព្ទនៃភាសាហេព្រើរដូចគ្នាក្នុង ខ.២៨ ។ ដោយសារការនេះ បានបញ្ជាក់ថានៅក្នុងល្បះទី៥ វាមានទំនាក់ទំនងជាមួយល្បះទី២ ។ នៅក្នុង ខ.១៣,១៩ អ្នកនិពន្ធបានប្រើកិរិយាស័ព្ទជាភាសាហេព្រើរខុសគ្នា (ប៉ុន្តែ សម្លេងប្រហាក់ប្រហែលគ្នា) ហើយការនេះវាមានទំនាក់ទំនងរវាងល្បះទី៣និងល្បះទី៤ ។ ប្រវត្តិសាស្ត្រនៃពួកអ៊ីស្រាអែល គឺជាប្រវត្តិសាស្ត្រមួយដែលពួកគេបានទទួលការរំដោះដោយព្រះអម្ចាស់ (សូមមើល ទដ ១០៥) ហើយក៏មានប្រវត្តិសាស្ត្រនៃការបះបោរផងដែរ (សូមមើល ទដ ១០៦) ហើយមិនត្រឹមតែប៉ុណ្ណោះសោត ពួកគេក៏មានប្រវត្តិសាស្ត្រ ក្នុងនាមជាអ្នកអំពាវនាវដល់ព្រះយេហូវ៉ាក្នុងគ្រាដែលពួកគេជួបសេចក្ដីទុក្ខលំបាកដែរ (សូមមើលការពន្យល់ ១០៦:៤៤) ។

**១០៧:៧** *តាមផ្លូវត្រង់* ផ្លូវត្រង់គឺជាផ្លូវដែលមានគ្រោះថ្នាក់និងឧបស័គ្គ ។

**១០៧:៨** សូមមើលបទបន្ទរផ្សេងៗទៀតក្នុង សេចក្ដីផ្ដើម ទដ ៤២–៤៣ ។ *ការអស្ចារ្យ* សូមមើល ខ.១៥,២១,២៤,៣១ និងការពន្យល់ ៩:១ ។

**១០៧:៩** *ប្រោសព្រលឹងដែលសង្វាត ឱ្យបានស្កប់ស្កល់ . . . ស្រេកឃ្លាន* សូមមើល ខ.៥ និងក្នុង ១០៥:៤០–៤១ ។

[១០] ឯអស់អ្នកដែលអង្គុយនៅទីងងឹត[ថ] ហើយក្នុងម្លប់នៃ
សេចក្ដីស្លាប់ជាពួកអ្នកដែលជាប់មានសេចក្ដីវេទនា[ទ]
ហើយនិងចំណងច្រវាក់[ធ]
[១១] ដោយព្រោះគេបានបះបោរ[ន]នឹងព្រះបន្ទូលនៃព្រះ
ហើយបានមើលងាយ[ប]ដល់សេចក្ដីដំបូន្មាន[ផ]របស់ព្រះដ៏
ខ្ពស់បំផុត
[១២] បានជាទ្រង់បន្ទាបចិត្តគេ ដោយការនឿយហត់ គេបាន
ដួលចុះ ឥតមានអ្នកណាជួយឡើយ[ព]
[១៣] គ្រានោះ គេបានអំពាវនាវ ដល់ព្រះយេហូវ៉ាដោយ
សេចក្ដីវេទនារបស់គេ[ភ] ហើយទ្រង់ក៏ប្រោសឱ្យរួចពីសេច
ក្ដីលំបាកនោះ
[១៤] ទ្រង់បាននាំគេចេញ ពីទីងងឹត[ម] និងម្លប់នៃសេចក្ដី
ស្លាប់[យ] ព្រមទាំងបណ្ដាច់ចំណងគេផង[រ]
[១៥] ឱសូមឱ្យមនុស្សទាំងឡាយសរសើរ[ល]ដល់ព្រះយេហូវ៉ា
ដោយព្រោះសេចក្ដីសប្បុរស[វ]របស់ទ្រង់ហើយដោយ
ព្រោះអស់ទាំងការអស្ចារ្យ[ស]ដែលទ្រង់បានប្រោសដល់
មនុស្សជាតិ
[១៦] ដ្បិតទ្រង់បានទំលាយអស់ទាំងទ្វារលង្ហិន ហើយបំបាក់
រនុកដែកដែរ ។

[១៧] ឯពួកមនុស្សមោហោ[ហ] គេរមែងមានទុក្ខ[ឡ]ដោយព្រោះ
ការរំលងច្បាប់[អ] និងអំពើទុច្ចរិតរបស់គេ
[១៨] ព្រលឹងគេតែងតែខ្ពើមអាហារ[ក] គ្រប់មុខហើយគេចូល
ទៅជិតទ្វារនៃសេចក្ដីស្លាប់[ខ]
[១៩] គ្រានោះគេអំពាវនាវ[គ]ដល់ព្រះយេហូវ៉ាដោយសេចក្ដី
វេទនារបស់គេ[ឃ] ហើយទ្រង់ក៏ប្រោសឱ្យរួចពីសេចក្ដី
លំបាកនោះ
[២០] ទ្រង់ចាត់ព្រះបន្ទូល[ង]ទៅប្រោសគេឱ្យជា[ច] ក៏ដោះ[ឆ]ឱ្យគេ
រួចពីសេចក្ដីវិនាស[ជ]
[២១] ឱសូមឱ្យមនុស្សទាំងឡាយសរសើរ[ឈ]ដល់ព្រះយេហូវ៉ា
ដោយព្រោះសេចក្ដីសប្បុរសរបស់ទ្រង់[ញ] ហើយដោយ
ព្រោះ អស់ទាំងការអស្ចារ្យ[ដ]ដែលទ្រង់ប្រោសដល់មនុស្ស
ជាតិ
[២២] ដូច្នេះគួរឱ្យគេថ្វាយដង្វាយ[ឋ] នៃសេចក្ដីអរព្រះគុណ

**១០៧:១០** ថ ខ.១៤ ទដ ៨៨:៦ ១៤៣:៣ អស ៩:២ ៤២:៧,១៦ ៤៩:៩ មីក ៧:៩ ទ ទដ ១០២:២០ អស ៦១:១ ធ យប ៣៦:៨ **១០៧:១១** ន ទដ ៥:១០ ប ជន ១៤:១១ ផ ១ពវ ២២:៥ ២របា ៣៦:១៦ **១០៧:១២** ព ២ពវ ១៤:២៦ ទដ ៧២:១២ **១០៧:១៣** ភ ទដ ១០៦:៨ **១០៧:១៤** ម ខ.១០ អស ៩:២ ៤២:៧ ៥០:១០ ៥៩:៩ ៦០:២ លក ១:៧៩ យ ទដ ៨៦:១៣ អស ២៩:១៨ រ យប ៣៦:៨ ទដ ១១៦:១៦ កច ១២:៧ **១០៧:១៥** ល ខ.៨, ២១,៣១ ១០៥:១ វ ទដ ៦:៤ ស ទដ ៧៥:១ **១០៧:១៧** ហ ទដ ៥៣:១ ឡ ទដ ២៥:៧ អ លវ ២៦:១៦ អស ៦៥:៦–៧ យរ ៣០:១៤–១៥ កទ ៦:៧–៨ **១០៧:១៨** ក យប ៣:២៤ ៦:៦ ខ យប ១៧:១៦ ៣៣:២២ **១០៧:១៩** គ ខ.២៨ ទដ ៥:២ ឃ ខ.១៣ ទដ ៣៤:៤ **១០៧:២០** ង ចទ ៣២:២ ទដ ១៤៧:១៥ មថ ៨:៨ លក ៧:៧ ច នក ១៥:២៦ ឆ យប ៣៣:២៨ ជ ទដ ១៦:១០ ៣០:៣ ៥៦:១៣ **១០៧:២១** ឈ ខ.១៥ ញ ទដ ៦:៤ ដ ទដ ៧៥:១ **១០៧:២២** ឋ លវ ៧:១២

**១០៧:១០–១៦** នៅក្នុងខទាំងនេះ គឺចង់និយាយពីការដែលព្រះយេហូវ៉ាទ្រង់បានរំដោះពួកគេឱ្យរួចពីទណ្ឌកម្ម នៃភាពជាទាសកររបស់ពួកសាសន៍ដទៃ ព្រះអម្ចាស់ទ្រង់ក៏បានរំដោះអស់អ្នកដែលអំពាវនាវដល់ព្រះនាមទ្រង់ ក្នុងគ្រាដែលគេមានសេចក្ដីទុក្ខលំបាក (សូមមើល ខ.១៧– ២០,៣៣ –៤១) ។

**១០៧:១០** *អង្គុយនៅទីងងឹត ហើយបានមើលងាយដល់សេចក្ដីដំបូន្មាន* នៅទីនេះគឺជារូបភាពមួយ ដែលចង់និយាយសំដៅលើសេចក្ដីទុក្ខលំបាកដ៏ខ្លាំងក្រៃ (សូមមើល ១៨:២៨ អស ៥:៣០ ៨:២២ ៥៩:៩ និងការពន្យល់ ៤៤:១៩) ។ *អ្នកដែលជាប់មានសេចក្ដីវេទនា ហើយនិងចំណងច្រវ៉ាក់* គឺនិយាយសំដៅលើភាពជាទាសកររបស់ពួកសាសន៍ដទៃ ។ អ្នកនិពន្ធនៅក្នុងសញ្ញាចាស់តែងតែប្រើពាក្យនេះ និយាយសំដៅលើអ្នកដែលកើតមានសេចក្ដីទុក្ខលំបាក (សូមមើល យប ៣៦:៨ អស ២៨:២២ បទ ៣:៧) ។

**១០៧:១១** *ព្រះដ៏ខ្ពស់បំផុត* នៅក្នុងឃ្លានេះគឺចង់បញ្ជាក់ថា ព្រះយេហូវ៉ាទ្រង់ខ្ពស់បំផុត (សូមមើល លប ១៤:១៩ និងការពន្យល់ ហើយនិងការពន្យល់ ៤៤:១៩) ។ *សេចក្ដីដំបូន្មាន* សេចក្ដីដំបូន្មានដែលប្រកបដោយព្រះប្រាជ្ញាញាណរបស់ទ្រង់ គឺតំណាងឱ្យព្រះបន្ទូលរបស់ទ្រង់ (សូមមើល ៧៣:២៤ និងការពន្យល់) ។

**១០៧:១២** *ទ្រង់បានបន្ទាបចិត្តគេដោយការនឿយហត់* ឃ្លានេះគឺជាភាសាអក្សរសាស្ត្រ ។ *ដួល* មានន័យថា កម្លាំងគេថយចុះ (សូមមើល ៣១:១០ ១០៩:២៤ នហ ៤:១០ អស ៤០:៣០ សក ១២:៨) ។

**១០៧:១៣** *អំពាវនាវ* សូមមើលការពន្យល់ ខ.៦ ។

**១០៧:១៦** នៅក្នុងខនេះគឺបានដកស្រង់ចេញពី អស ៤៥:២ ឬមួយខគម្ពីរទាំង២នេះ បានស្រង់ចេញពីការនិយាយផ្ទាល់ពីព្រះអង្គ ។ *ទ្វារលង្ហិន* ជាទ្វារទីក្រុងដែលជាទូទៅគេធ្វើពីឈើតែទ្វារក្នុងខនេះ គឺជាទ្វាធ្វើពីលង្ហិន ។ ដែលជាទ្វារទីក្រុងមួយយ៉ាងរឹងមាំង (១ពវ ៤:១៣ ធៀបនិង យរ១:១៨) ។ *រនុកដែក* គឺជារនុកដែលសំរាប់ការពារទ្វារទីក្រុង (ចទ ៣:៥ យរ ៥១:៣០) ។ នៅពេលនោះក៏មានសុភាសិត១ពោលថា តើមនុស្សអាចវាយបំបែកដែកនិងលង្ហិនបានទេ? (សូមមើល យរ ១៥:១២) ។

**១០៧:១៧–២២** ជាការដោះលោះឱ្យរួចផុតពីការកើតជម្ងឺផ្សេង។ (សូមមើលការពន្យល់ ខ.១០–១៦) ។

**១០៧:១៧** *មនុស្សមោហោ* សូមមើល យរ ៤:២២ និងការពន្យល់ ១៤:១ "មនុស្សមោហោស្អប់ ប្រាជ្ញានិងការប្រដៅ" (សភ ១:៧ សូមមើល ខ.៤៣) *នឹងអំពើទុច្ចរិតរបស់គេ* សូមមើល លវ ២៦:១៦,២៥ ចទ ២៨:២០–២២, ៣៥,៥៨–៦១ ។

**១០៧:១៨** *ទ្វារនៃសេចក្ដីស្លាប់* គឺជាទីស្ថាននៃសេចក្ដីស្លាប់ ក៏បានគេពណ៌នាថាជាទីក្រុងនៃស្ថាននរកដែលមានកំផែងនៅកណ្ដាលនិងមានទ្វារផងដែរ ។ (មាន៧ ទ្វារនៃជ្រុងនិមួយ។ គឺតាមការបកស្រាយរបស់ទេវកថាវិទ្យា (តាមរឿងអាទិទេព និង វរៈបុរសសម័យបុរាណ) សូមមើល ៩:១៣ និងការពន្យល់ត្រង់ យប ៣៨:១៧ ក៏សូមមើល មថ ១៦:១៨ ផងដែរ) ។

**១០៧:១៩** *អំពាវនាវដល់* សូមមើលការពន្យល់ ខ.៦ ។ *ប្រោសឱ្យរួច* សូមមើលការពន្យល់ ខ.១៣ (ក៏មានឃ្លាបន្ទាត់ជាអត្ថបទកំណាព្យសំខាន់។នៅចន្លោះវគ្គទី២ និងទី៣) ធៀបនិង ខ.៦,២៨ ។

**១០៧:២០** *ព្រះបន្ទូល* ជាសេក្ដីបញ្ញត្តិរបស់ផងទ្រង់ ក៏បង្ហាញអំពីព្រះទ័យរបស់ទ្រង់ជាគោលដៅមួយ (សូមមើល ១៤៧:១៥,១៨ និងការពន្យល់ ២៣:៦) ។

ហើយប្រកាសពីស្នាដៃ[ឱ]នៃទ្រង់ដោយចំរៀងអរសប្បាយ
ចុះ[ឲ] ។
២៣ឯពួកអ្នកដែលចុះនាវា[ណ]ដើរផ្លូវសមុទ្រ[ត]ជាអ្នកដែល
រកស៊ីទទួលការតាមផ្លូវទឹកធំ
២៤ពួកនោះគេឃើញអស់ទាំងការនៃព្រះយេហូវ៉ា[ថ] និងការ
អស្ចារ្យរបស់ទ្រង់នៅទីជំរៅ
២៥ដ្បិតទ្រង់បង្គាប់[ទ]ទៅ នោះក៏កើតមានខ្យល់ព្យុះ[ធ]
ដែលបណ្តាលឱ្យរលកកំរើកឡើង[ន]
២៦រលកទាំងនោះផាត់ឡើងដល់ផ្ទៃមេឃក៏ធ្លាក់ទៅវិញដល់
ទីជំរៅ[ប]នោះព្រលឹងគេក៏រលាយទៅ[ផ] ដោយសេចក្តីអន្ត
រាយ
២៧គេឃ្លេងឃ្លោង[ព] ចុះឡើង ហើយដើរទទ្រេតទទ្រោតដូច
ជាមនុស្សស្រវឹង គេក៏ទាល់ប្រាជ្ញាទៅ
២៨គ្រានោះ គេអំពាវនាវ[ភ]ដល់ព្រះយេហូវ៉ាដោយសេចក្តី
វេទនារបស់គេហើយទ្រង់ក៏ប្រោសឱ្យរួចពីសេចក្តីលំបាក
នោះ[ម]
២៩ទ្រង់ធ្វើឱ្យព្យុះសង្ឃរា[យ]បាន ស្ងាត់ឈឹងទៅវិញ ហើយឱ្យ
រលក[រ]ស្ងប់ស្ងៀមដែរ[ល]
៣០នោះគេមានសេចក្តីអំណរដោយព្រោះស្ងប់ច្រៀប
ហើយ
ទ្រង់ក៏នាំគេ[វ]ទៅដល់ទ្វារសមុទ្រ ដែលគេប្រាថ្នាចង់ទៅ
៣១ឱសូមឱ្យមនុស្សទាំងឡាយសរសើរ[ស]ដល់ព្រះយេហូវ៉ា
ដោយព្រោះសេចក្តីសប្បុរស[ហ]របស់ទ្រង់ ហើយដោយ
ព្រោះអស់ទាំងការអស្ចារ្យ[ឡ] ដែលទ្រង់ប្រោសដល់មនុស្ស
ជាតិ
៣២គួរឱ្យគេលើកដំកើង[អ]ទ្រង់នៅក្នុងជំនុំ[ក]នៃជនទាំងឡាយ
ហើយសរសើរទ្រង់នៅទីអង្គុយរបស់ពួកចាស់ទុំដែរ ។
៣៣ទ្រង់ធ្វើឱ្យទន្លេត្រឡប់ទៅជាទីហួតហែង[ខ] ហើយឱ្យ
ក្បាលទឹក[គ]ប្រែទៅជាដីខ្សោះទៅវិញ
៣៤ក៏ឱ្យស្រុកដុះដាល ទៅជាមានដីប្រៃ[ឃ]ដោយព្រោះអំពើ
អាក្រក់របស់ពួកអ្នកដែលនៅស្រុកនោះ
៣៥ទ្រង់ក៏បំផ្លាស់ទីហួតហែងឱ្យទៅជាត្រពាំង[ង] ហើយដីស្ងួត
ធេងឱ្យមានក្បាលទឹកវិញ[ច]
៣៦ទ្រង់តាំងមនុស្សអត់ឃ្លានឱ្យនៅទីនោះ ដើម្បីឱ្យគេបាន
សង់ទីក្រុង សំរាប់អាស្រ័យនៅ
៣៧ព្រមទាំងធ្វើស្រែ ហើយធ្វើចំការ[ឆ] ទំពាំងបាយជូរឱ្យ
បានមានផលចំរើនឡើង
៣៨ទ្រង់ក៏ប្រទាន ពរដល់គេដែរ ដើម្បីឱ្យគេបានចំរើនជា
ច្រើនឡើង[ជ] ហើយទ្រង់មិនឱ្យហ្វូងសត្វរបស់គេថយចុះ
ឡើយ[ឈ]
៣៩បើជាគេត្រូវថយចុះវិញ[ញ] ហើយត្រូវអាប់ឱន ដោយមាន
គេសង្កត់សង្កិន ធ្វើទុក្ខបុកម្នេញហើយឱ្យមានសេចក្តីព្រួយ
លំបាក[ដ]
៤០នោះទ្រង់ចាក់សេចក្តីមើលងាយទៅលើពួកអ្នកធំ[ឋ]ហើយ
បណ្តាលឱ្យគេដើរសាត់ព្រាត់នៅទីស្ងាត់ឈឹងដែលឥត

**១០៧:២២** ឱ ទដ ៩:១១ ៧៣:២៨ ១១៨:១៧ ឲ យប ៨:២១ ទដ ៦៥:៨ **១០៧:២៣** ណ អស ៤២:១០ ត ទដ ១០៤:២៦ **១០៧:២៤** ថ ទដ ៦៤:៩ ១១:២ ១៤៣:៥ **១០៧:២៥** ទ ទដ ១០៥:៣១ ធ ទដ ៥០:៣ ន ទដ ៩៣:៣ **១០៧:២៦** ប លក ៨:២៣ ផ យស ២:១១ **១០៧:២៧** ព អស ១៩:១៤ ២៤:២០ ២៨:៧ **១០៧:២៨** ភ ខ.១៩ ម ទដ ៤:១ យហ ១:៦ **១០៧:២៩** យ លក ៨:២៤ រ ទដ ៩៣:៣ ល ទដ ៦៥:៧ យហ ១:១៥ **១០៧:៣០** វ ខ.៧ **១០៧:៣១** ស ខ.១៥ ហ ទដ ៦:៤ ឡ ទដ ៧៥:១ ១០៦:២ **១០៧:៣២** អ ទដ ៣០:១ ៣៤:៣ ៩៩:៥ ក ទដ ១:៥ ២២:២២,២៥ ២៦:១២ ៣៥:១៨ **១០៧:៣៣** ខ ១ពវ ១៧:១ ទដ ៧៤:១៥ អស ៤១:១៥ ៤២:១៥ ៥០:២ គ ទដ ១០៤:១០ **១០៧:៣៤** ឃ លប ១៣:១០ **១០៧:៣៥** ង ២ពវ ៣:១៧ ទដ ០១៥:៤១ ១២៦:៤ អស ៤៣:១៩ ៥១:៣ ច យប ៣៨:២៦ អស ៣៥:៧ **១០៧:៣៧** ឆ ២ពវ ១៩:២៩ អស ៣៧:៣០ **១០៧:៣៨** ជ លប ១២:២ ចទ ៧:១៣ ឈ លប ៤៩:២៥ **១០៧:៣៩** ញ ២ពវ ១០:៣២ អគ ៥:១២ ដ ទដ ៤៤:៩ **១០៧:៤០** ឋ យប ១២:១៨

**១០៧:២២** *ដង្វាយនៃសេចក្តីអរព្រះគុណ* សូមមើល លវ ៧:១២–១៥ ២២:២៩–៣០ ។ *ប្រកាសពីស្នាដៃនៃទ្រង់* សូមើលការពន្យល់ លវ ៧:១៧ នៅក្នុងវគ្គដែលជាន័យរួមនិងវគ្គបញ្ចប់ចុងក្រោយបង្អស់ ចំពោះវគ្គកំណាព្យ ៤ ឬ ៥ ឃ្លានេះ ។ *ដោយចំរៀងអរសប្បាយចុះ* សូមមើល ទដ ១១៦ ។

**១០៧:២៣–៣២** គឺជាការសង្គ្រោះឱ្យរួចពីគ្រោះថ្នាក់នៅឯសមុទ្រ (សូមមើលការពន្យល់ ខ.៤–៥) ដោយសាររាស្ត្របានធ្វើជំនួញដែលតំរូវឱ្យហ៊ានប្រថុយជីវិតក្នុងការធ្វើដំណើរតាមសមុទ្រដែគួរធ្វើជំនួញ ។ (សូមមើល លប ៤៩:១៣ ពច ៥:១៧ ១ពវ ៩:២៦–២៨ ១០:២២) ។

**១០៧:២៣** *ទឹកធំ* សូមើល ២៩:៣ ។

**១០៧:២៤** *ការអស្ចារ្យរបស់ទ្រង់នៅទីជំរៅ* គឺខណៈពេលដែលប្រជាជនប្រទេសជាច្រើននៅតំបន់សមុទ្រមេឌីទែរ៉ាណេ ដែលមានទំនាក់ទំនងទឹកដ៏ធំនេះ (ខ.២៣) ដែលជាផ្ទៃទឹកដែលនាំឱ្យមានភាពរឹករវតាំងពីបុរាណមកម្លេះ (មើលការពន្យល់ ៣២:៦) ជាការដែលព្រះបានធ្វើការអស្ចារ្យ និងការពាររាស្ត្រអ៊ីស្រាអែលគ្រប់ទីកន្លែង ។ គឺមានព្យុះកំណាចដែលបោះបោកមនុស្សនៅតំបន់នោះ (សូមមើល យហ ១ កច ២៧) ។

**១០៧:៣០–៤២** គឺជាការពីរបែប ដែលព្រះបានធ្វើការដល់រាស្ត្ររបស់ទ្រង់ គឺទី១ ព្រះយេហូវ៉ាបានប្រដៅតម្រង់ដល់រាស្ត្រទ្រង់តាមរយៈបង្វិលស្រុកដែលមានភោគផល ទៅជាវាលរហោស្ថានហួតហែង (មើល ខ.៣៤ ១ពវ ២ពវ ១៧:១–៧,២ពវ ៨:១) ។ តែក្រោយមកព្រះបានរៀបចំឱ្យមានដីល្អឡើងវិញ (សូមមើល យរ១:៦ ១ពវ ១៨:៤៤–៤៥) ដូចច្នេះមនុស្សអត់ឃ្លានក៏មានរស់នៅទីនោះ (ខ.៣៦) ហើយបានទទួលព្រះពរដ៏ពេញបរិបូរណ៍ ។ តែក្រោយមកព្រះបានបញ្ជូនពួកទ័ពអាសើរ ឱ្យទៅវាយប្រឆាំងនិងពួកគេនោះ ២ពវ ១៧:៣–៦ និងហើយក៏មានពួកបាប៊ីឡូនមកវាយប្រឆាំងផងដែរ (២ពវ ២៤:១០–១៧ ២៥:១–២៦) ក៏បានឱ្យដីនោះហិនហោចម្តងទៀត និងបាននិរទេសប្រជាជននៅក្នុងស្រុកដីនោះឱ្យចាកចេញពីស្រុក ។ រួចក្រោយមកព្រះក៏បានតាំងមនុស្សកំសត់ទុរគតឹឱ្យបានរួចពីសេចក្តីវេទនា (ខ.៤១ ។

**១០៧:៣៣–៣៥** ខទាំងនេះមានលក្ខណៈដូចក្នុង អស ៣៥:៦–៧ ៤១:១៨ ៤២:១៩–២០ ៥០:២ ហើយក៏បានបញ្ជាក់ពីឥទ្ធិពលរបស់អ្នកនិពន្ធតាមរយៈលោកអេសាយ ។

**១០៧:៤០** ជាសេចក្តីដកស្រង់ចេញពី យប ១២:២១,២៤ ។ ក្នុងការដែលគេ

មានផ្លូវវិញ[ឌ]
[៤១] ទ្រង់ក៏តាំងមនុស្សកំសត់ទុគ៌ត[ឍ] ឡើងឱ្យរួចពីសេចក្តី
វេទនា ព្រមទាំងឱ្យគ្រួសារគេសាយក្រោយឡើង
ដូចជាហ្វូងសត្វ[ណ]
[៤២] ពួកមនុស្សទៀងត្រង់ក៏ឃើញ ហើយមានសេចក្តីអំណរ[ត]
ឡើងឯសេចក្តីទុច្ចរិត និងត្រូវបាត់មាត់ទៅ[ថ]
[៤៣] បើអ្នកណាមានប្រាជ្ញា[ទ] នោះនឹងរក្សាទុកនូវសេចក្តីទាំង
នេះ ហើយនឹងពិចារណាពីសេចក្តីសប្បុរស[ធ]របស់ព្រះ
យេហូវ៉ា ។

*១០៨:១-៥ – ទដ ៥៧:៧-១១*

*១០៨:៦-១៣ – ទដ ៦០:៥-១២*

បទចំរៀងជាទំនុករបស់ស្តេចដាវីឌ ។

**១០៨** ឱព្រះអង្គអើយ
ចិត្តទូលបង្គំបានតាំងនៅមាំ[ក]ហើយ
ទូលបង្គំនឹងច្រៀង[ខ] អើ និងច្រៀងសរសើរដោយសារ
កិត្តិយសរបស់ទូលបង្គំដែរ
[២] ឱពិណ ហើយនិងស៊ុងអើយ[គ] ចូរភ្ញាក់ឡើង ឯទូលបង្គំនឹង
ភ្ញាក់ពីព្រលឹមដែរ
[៣] ឱព្រះយេហូវ៉ាអើយ ទូលបង្គំអរព្រះគុណដល់ទ្រង់នៅ
កណ្តាលជនទាំងឡាយទូលបង្គំនឹងច្រៀងសរសើរទ្រង់នៅ
កណ្តាលសាសន៍ដទៃទាំងប៉ុន្មាន
[៤] ដ្បិតសេចក្តីសប្បុរស[ឃ]របស់ទ្រង់ធំខ្ពស់ជាងផ្ទៃមេឃ
ហើយសេចក្តីពិត[ង]របស់ទ្រង់ក៏ខ្ពស់ដល់ពពកដែរ[ច]
[៥] ឱព្រះអង្គអើយ សូមឱ្យទ្រង់បានថ្កើងឡើងខ្ពស់ជាងផ្ទៃ
មេឃ[ឆ] ហើយឱ្យសិរីល្អនៃទ្រង់ផ្សាយទៅពេញលើផែនដី[ជ]
[៦] ដើម្បីឱ្យអស់អ្នកស្ងួនភ្ងារបស់ទ្រង់ បានប្រោសឱ្យរួចសូម
ជួយសង្គ្រោះ ដោយព្រះហស្តស្តាំនៃទ្រង់[ឈ] ហើយឆ្លើយ
មកយើងខ្ញុំផង
[៧] ព្រះទ្រង់បានមានបន្ទូល[ញ] ដោយសេចក្តីបរិសុទ្ធរបស់ទ្រង់
ថា[ដ] យើងនឹងត្រេកអរឡើង ក៏នឹងបែងចែកស្រុកស៊ីគែម[ឋ]
ហើយនិងវាស់ច្រកភ្នំសិកូត[ឌ]
[៨] ឯស្រុកកាឡាត ជាស្រុករបស់ផងយើងហើយ
ខេត្តម៉ាន៉ាសេផងខេត្តអេប្រាអិមជាទីមាំមួនការពារក្បាល
យើង ហើយស្រុកយូដា[ឍ]ជាអ្នកតែងច្បាប់របស់យើង
[៩] ស្រុកម៉ូអាប់[ណ] ជាអាងសំរាប់ឱ្យយើងងូតទឹក ហើយយើង
បោះស្បែកជើងទៅលើស្រុកអេដំម[ត]យើងនឹងស្រែកឡើង
ពីលើស្រុកភីលីស្ទីន[ថ]
[១០] តើអ្នកណានឹងនាំទូលបង្គំចូលទៅក្នុងទីក្រុងមាំមួនបាន
តើអ្នកណានឹងនាំទូលបង្គំទៅឯស្រុកអេដំម
[១១] ឱព្រះអង្គអើយ តើមិនមែនទ្រង់ទេឬអី ជាព្រះដែលបាន
ចោលយើងខ្ញុំហើយផង ឱព្រះអង្គអើយ ទ្រង់ក៏មិនយាង
ចេញទៅជាមួយនឹងពលទ័ពរបស់យើងខ្ញុំទៀតដែរ[ទ]
[១២] សូមទ្រង់ប្រោសមេត្តាជួយយើងខ្ញុំទាស់នឹងពួកសត្រូវដ្បិត
សេចក្តីជំនួយរបស់មនុស្ស នោះឥតប្រយោជន៍ទេ[ធ]
[១៣] ដោយពឹងដល់ព្រះ នោះយើងខ្ញុំនឹងតស៊ូយ៉ាងរឹងប៉ឹងវិញ
ដ្បិតគឺទ្រង់ហើយ ដែលនឹងជាន់ឈ្លី[ន]ពួកសត្រូវ របស់យើង
ខ្ញុំបង់ ។

**១០៧:៤០** ឌ ចទ ៣២:១០ **១០៧:៤១** ឍ ១សយ ២:៨ ទដ ១១៣:៧-៩ ណ យប ២១:១១ **១០៧:៤២** ត យប ២២:១៩ ទដ ៩៧:១០-១២ ថ យប ៥:១៦ រម ៣:១៩ **១០៧:៤៣** ទ យរ ៩:១២ ហស ១៤:៩ ធ ទដ ១០៣:១១ **១០៨:១** ក ទដ ១១២:៧ ១១៩:៣០, ១១២ ខ ទដ ១៨:៤៩ **១០៨:២** គ យប ២១:១២ **១០៨:៤** ឃ ជន ១៤:១៨ ទដ ១០៦:៤៥ ង នក ៣៤:៦ ច ទដ ៣៦:៥ **១០៨:៥** ឆ ទដ ៨:១ ជ ទដ ៥៧:៥ **១០៨:៦** ឈ យប ៤០:១៤ **១០៨:៧** ញ ទដ ៨៩:៣៥ ដ ទដ ៦៨:៣៥ ១០២:១៩ ឋ លប ១២:៦ ឌ លប ៣៣:១៧ **១០៨:៨** ឍ ទដ ៧៨:៦៨ **១០៨:៩** ណ លប ១៩:៣៧ ត ២សយ ៨:១៣-១៤ ថ ២សយ ៨:១ **១០៨:១១** ទ ទដ ៤៤:៩ **១០៨:១២** ធ ទដ ១១៨:៨ ១៤៦:៣ អស ១០:៣ ៣០:៥ ៣១:៣ យរ ២:៣៦ ១៧:៥ **១០៨:១៣** ន ទដ ៤៤:៥ អស ២២:៥ ៦៣:៣,៦

បាននាំភាពសុខសាន្តដល់ប្រជាជន គឺជាការងាររបស់អ្នកសុចរិតដែលនាំមកនូវភាពរីករាយ ដែលបានងាកខ្នងរបស់គេទៅរកព្រះដែលបានប្រទានពរអោយគេនោះ ។ (សូមមើល ចទ ៣១:២០ ៣២:១៥) ទ្រង់ក៏បានបង្វែរគេទៅឯទីរហោស្ថានវិញ (សូមមើល ចទ ៣២:២០,៣២,១៤) ។

**១០៧:៤១** *មនុស្សកំសត់* គឺជាអ្នកដែលត្រូវការជំនួយ (មើល ខ.៣៩ និង ៩:១៨ និងការពន្យល់) ។

**១០៧:៤២** ជាផ្នែកបញ្ចប់នៃសេចក្តីផ្តើម (ខ.៣៣-៤១) ក៏ជាការបញ្ចាក់ឡើងវិញពីគម្ពីរ យ៉ូប ៥:១៦ ។ *ពួកមនុស្សទៀងត្រង់ . . . . សេចក្តីទុច្ចរិត* គឺវាមានលក្ខណៈផ្ទុយនិងគ្រាសញ្ញាចាស់ (សូមមើល សភ ២:២១-២២ ១១:៦-៧ ១២:៦ ១៤:១១ ១៥:៨ ២១:១៨,២៩ ២៩:២៧ ។

**១០៧:៤៣** ខនេះគឺជាការបញ្ចប់របស់គម្ពីរទំនុកដំកើង ។ *បើអ្នកណាមានប្រាជ្ញា* សូមមើល ចទ ៣២:២៩ ហស ១៤:៩ ។ *សេចក្តីទាំងនេះ* ជាឃ្លានៃសេចក្តីណែនាំមានក្នុង ខ.៣៣-៤២ ។ *ពិចារណាពីសេក្តីសប្បុរស* ជាសេចក្តីដែលបង្ហាញពីផ្ទៃរឿងទាំងមូលឡើងវិញគឺមានក្នុង ខ. ៤-៣២ ។

**ទដ ១០៨** គឺការសរសើរចំពោះសេចក្តីស្រឡាញ់របស់ព្រះ និងការអធិស្ឋានសូមជំនួយពីព្រះ ដើម្បីប្រឆាំងនឹងសត្រូវ ក៏មានការរៀបចំប្រកបដោយការកែសម្រួលខ្លះៗនៃ ៥៧:៧-១១ និង ៦០:៥-១២ ។ ឯចំពោះការតែងនិពន្ធនៃបទគម្ពីរទំនុកដំកើងថ្មី គឺបានមកដោយការដកស្រង់បញ្ចូលផ្នែកៗនៃគម្ពីរទំនុកដំកើងមួយចំនួន សូមមើល ១រប ១៦:៨-៣៦ ។ ក៏មានការសម្តែងនៃសេចក្តីសប្បុរសរបស់ទ្រង់ធំខ្ពស់ជាឧត្តម (ខ.៤) ។

**១០៨ ចំណងជើង** *បទចំរៀងជាទំនុក* សូមមើលការពន្យល់ ទដ ជំពូក ៣០ ជាទំនុករបស់ស្តេចដាវីដ ។ តាមរយៈប្រភពពីរ (ទដ ៥៧,៦០) ដែលជាការសសើរដល់ព្រះយេហូវ៉ា ។

**១០៨:១-៥** ជាបទសសើរចំពោះសេក្តីសប្បុរសទ្រង់ដែលធំខ្ពស់ជាង់ផ្ទៃមេឃ (ជាសេចក្តីស្រឡាញ) ជាសេចក្តីពិតរបស់ព្រះ (គឺព្រះជាព្រះនៃ . . . ខ.៧-៩,១១) ក៏ចំពោះអ្នកស្ងួនភ្ងារបស់ទ្រង់ដែលទ្រង់ប្រោសឱ្យរួច (ខ.៦,១២) ។

**១០៨:១** *កិត្តិយស* តាមបែបអក្សរសាស្ត្រ គឺ (ព្រលឹង) (មើលការពន្យល់ ៧:៥) ។

**១០៨:៦-១៣** ជាសេក្តីអធិស្ឋានសូមជំនួយពីព្រះប្រឆាំងនិងសត្រូវ (សូមមើលការពន្យល់ ៦០:១២) ។

ទំនុកនៃស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**១០៩** ឱព្រះនៃសេចក្តីសរសើរ[ក]របស់ទូលបង្គំអើយ
សូមទ្រង់កុំគង់ស្ងៀមស្ងាត់ឡើយ[ខ]
២ដ្បិតមាត់របស់មនុស្សអាក្រក់[គ] និងមាត់មាយាបានហា
ឡើងទាស់នឹងទូលបង្គំហើយគេបាននិយាយនឹងទូលបង្គំ
ដោយអណ្តាកំភូត[ឃ]
៣គេបានឡោមព័ទ្ធទូលបង្គំជុំវិញ ដោយពាក្យ សំអប់[ង]
ក៏តយុទ្ធនឹងទូលបង្គំ ដោយឥតហេតុ[ច]
៤គេជាសត្រូវស្នងនឹងសេចក្តីស្រឡាញ់របស់ទូលបង្គំ
ប៉ុន្តែទូលបង្គំផ្ចង់ចិត្ត និងអធិស្ឋានវិញ[ឆ]
៥គេបានសងការអាក្រក់ដល់ទូលបង្គំ ស្នងនឹងការល្អហើយ[ជ]
ស្នងសេចក្តីសំអប់ ចំពោះសេចក្តីស្រឡាញ់របស់ទូលបង្គំ
៦សូមទ្រង់តាំងអ្នកអាក្រក់ឱ្យគ្រប់គ្រងលើវា ហើយឱ្យ
សាតាំង[ឈ]ឈរនៅខាងស្តាំវា
៧កាលណាវាត្រូវជំនុំជំរះ នោះសូមឱ្យវាមានទោស[ញ]
ហើយឱ្យសេចក្តីអធិស្ឋានរបស់វាត្រឡប់ជាអំពើបាប[ដ]វិញ
៨សូមឱ្យថ្ងៃអាយុរបស់វាបានខ្លីចុះ[ឋ] ហើយឱ្យមានម្នាក់ទៀត
ទទួលយកការងារ[ឌ]របស់វា
៩សូមឱ្យកូនចៅវានៅជាកំព្រាឪពុក ហើយឱ្យប្រពន្ធនៅ
មេម៉ាយ[ឍ]
១០សូមឱ្យកូនចៅវាធ្វើជាមនុស្សអារ៉ាសែ[ណ]
ទាំងដើរសុំទានឱ្យគេរកស៊ីតាមទីច្រកល្ហករបស់គេ
១១សូមឱ្យម្ចាស់បំណុល[ត]រឹបយករបស់វាទាំងអស់ទៅហើយ
ឱ្យមនុស្សដទៃដណ្តើមយកផល[ថ]នៃការរបស់វា[ទ]
១២សូមកុំឱ្យ មានអ្នកណាអាណិតមេត្តាដល់វាឡើយ
ក៏កុំឱ្យមានអ្នកណាអាសូរ[ធ]ដល់កូនកំព្រារបស់វាដែរ
១៣សូមឱ្យពូជវាត្រូវផុតចេញ[ន]លុះដល់ដំណជាន់ក្រោយ

**១០៩:១** ក នក ១៥:២ យរ ១៧:១៤ ខ យប ៣៤:២៩ **១០៩:២** គ ទដ ៤៣:១ ឃ ទដ ៥២:៤ **១០៩:៣** ង ទដ ៦៩:៤ ច ទដ ៣៥:៧ យហ ១៥:២៥ **១០៩:៤** ឆ ទដ ៦៩:១៣ ១៤១:៥ **១០៩:៥** ជ លប ៤៤:៤ **១០៩:៦** ឈ ១រប ២១:១ យប ១:៦ សក ៣:១ **១០៩:៧** ញ ទដ ១:៥ ដ សភ ២៨:៩ អស ៤១:២៤ **១០៩:៨** ឋ យប ១៥:៣២ ឌ កច ១:២០ **១០៩:៩** ឍ នក ២២:២៤ យរ ១៨:២១ **១០៩:១០** ណ លប ៤:១២ **១០៩:១១** ត នហ ៥:៣ ថ ជន ១៤:៣ អស ១:៧ ៦:១១ ៣៦:១ បទ ៥:២ ទ យប ២០:១៨ **១០៩:១២** ធ យប ៥:៤ **១០៩:១៣** ន យប ១៨:១៩ ទដ ២១:១០

**ទដ ១០៩** ជាការអធិស្ឋានសូមព្រះជួយឱ្យរួចពីមនុស្សមានអណ្តាតកំភូត ។ អ្នកនិពន្ធបាននិយាយពីសត្រូវរបស់គាត់ជាលក្ខណៈផ្ទាល់ខ្លួន គឺមានក្នុង ខ.៦–១៩ ក៏ប៉ុន្តែមានលក្ខណៈសម្រាប់គ្រប់គ្នាផងដែរ ។ មានពាក្យបណ្តាសាររបស់សត្រូវដល់អ្នកនិពន្ធ ខ.៦–១៩ មើលការពន្យល់ ខ.៦) ។ អត្ថបទមានលក្ខណៈ (១).និពន្ធតាមបែបផ្សេងៗឬក៏ (២).និយាយពីសត្រូវដែលមានគ្នាដឹកនាំប្រឆាំងចំពោះអ្នកនិពន្ធបទទំនុកដំកើង ដែលអ្នកនិពន្ធការពារដល់អ្នកស្លូតត្រង់ ។ មានការព្យាយាមដើម្បីកំទេចកំរងបទចំរៀងទំនុកដំកើងដែលគេហៅថា (សេចក្តីបណ្តាសារ) (និងបន្ទាប់មកក៏មានបង្ហាញអំពីជំពូក ១០៩ នៃគម្ពីរ ទដ ដែលជាឈុតមួយពិសេស) ក៏មានកំហុស (សូមមើលការពន្យល់ ខ.៦–១៥) ។ តាមរយៈគោលរឿងនៃវិទ្យានិពន្ធបញ្ជាក់ថាការអធិស្ឋាននេះ មានលក្ខណៈទាក់ទងគ្នាដែលស្រដៀងគ្នាទៅនិង ទដ ៣៥ ទដ ១០២ ។ (សូមមើលសេចក្តីណែនាំនៃ ទដ ១០១–១១០) ហើយមានតែមួយបន្ទាត់គត់ដែលវែងជាងបទទំនុកធម្មតា (ខ.១–៥,២៦–២៩) ក៏មានពីរបន្ទាត់ពីខាងក្រោមជាឃ្លាសរុបសេចក្តី (ខ.៣០–៣១) ។ ឯបន្ទាត់២០ដែលនៅសល់នោះ ក៏ចែកជាពីរចំណែកសំខាន់ៗ ។ (ខ.៦–១៥, ១៦–២៥) ។

**១០៩:១–៥** ជាពាក្យអំពាវនាវដល់ព្រះ ដើម្បីរំដោះស្តេចដាវីឌពីមនុស្សមានអណ្តាតកំភូតដែលប៉ះពារដល់ទ្រង់ ។

**១០៩:១** *ព្រះនៃសេចក្តីសរសើររបស់ទូលបង្គំអើយ* គឺជាអង្គមួយដែលទ្រង់សរសើរតម្កើង ដែលទុកដូចជាព្រះអង្គសង្គ្រោះដែលគួរជាទីទុកចិត្តបំផុតនៃទ្រង់និងជាអ្នកការពារ (សូមមើល ២២:៣ និងការពន្យល់ ក៏សូមមើល ៣៥:១៨ ៧៤:២១ ៧៦:១០ ៧៩:១៣ ១០២:១៨) ។ *ស្ងៀមស្ងាត់* (សូមមើល ២៨:១ ៣៥:២២ ៥០:៣,២១ ៨៣:១) ។

**១០៩:២–៥** ជាវគ្គពិសេសមួយរបស់ស្តេចដាវីឌ ដែលទ្រង់មានវត្តមាននៅពីខាងមុខព្រះយេហូវ៉ា (សូមមើល ៣៥:១១–១៦) ។

**១០៩:២** *ហាឡើងទាស់នឹងទូលបង្គំហើយ* សូមមើលការពន្យល់ ៥:៩ ។

**១០៩:៤** *ប៉ុន្តែទូលបង្គំផ្ចង់ចិត្តនឹងអធិស្ឋានវិញ* គឺមានលក្ខណៈផ្ទុយនិងពួកសត្រូវដែលព្យាយាមទាស់ទទឹងវិញ តែទូលបង្គំបានអធិស្ឋានឱ្យពួកគេនោះវិញ (សូមមើល ខ.១៦–១៨) (ក៏ដូចជាមានក្នុង ៣៥:១៣–១៤) ។

**១០៩:៦–១៥** បង្ហាញពីភាពយុត្តិធម៌ ដែលព្រះបានធ្វើចំពោះពួកគេអាស្រ័យទៅលើទង្វើរបស់ពួកគេ ដែលព្យាយាមប្រឆាំងនិងទ្រង់រួមទាំងអ្នកប្រព្រឹត្តបទឧក្រិដ្ឋផងដែរ (សូមមើលការពន្យល់ ៥:១០ ៣៥:៤–១០) ។

**១០៩:៦** *អ្នកអាក្រក់ឱ្យគ្រប់គ្រងលើវា* (គឺមានលក្ខណៈដូចជាក្នុងការពន្យល់ យប ១:៦) គឺជាសត្រូវរបស់អ្នកនិពន្ធគម្ពីរទំនុកដំកើង ដែលជាមនុស្សមានអណ្តាតកំភូតនិយាយបង្ខូចទ្រង់ដើម្បីឱ្យទ្រង់ដួលចុះ តែឥឡូវនេះបានឱ្យពួកសត្រូវនោះបានទល់មុខជាមួយនិងមនុស្សមានអណ្តាតកំភូតចុះ ។

**១០៩:៨** *ថ្ងៃអាយុវាបានខ្លីចុះ* គឺពួកមានអណ្តាយកំភូតក៏មានឥទ្ធិពលលើសេចក្តីស្លាប់របស់ស្តេចដាវីឌ (សូមមើល ១ពវ ២១:៨–១៥) ។ *ម្នាក់ទៀតទទួលយកការងាររបស់វា* គឺពួកសត្រូវក៏មានតួនាទីក្នុងស្រុកយូដាតាមរយៈការផ្តួលរំលំអ្នកដទៃយកដំណែង សូមមើល កច ១:២០ ។

**១០៩:១០–១១** គឺជាការរារាំងកុំឱ្យទ្រព្យសម្បត្តិបានទៅដល់អ្នកទទួលមរតកឬក៏ទៅឱ្យកូនចៅណាឡើយ ។

**១០៩:១២** *សូមកុំឱ្យមានអ្នកណាអាណិតមេត្តា* សូមមើល ខ.១៦ ។ *កូនកំព្រារបស់វាដែរ* គឺមានអត្តសញ្ញាណស្រដៀងគ្នាទៅនឹងមនុស្សដែលមានកូនហើយកូននិងឪពុក គឺជាការរួបរួមជាចំណងយ៉ាងរឹងមាំតាំងពី៤ជំនាន់កន្លងមកនាសម័យសង្គមបុរាណ ។ តែវាស៊ីជម្រៅទៅនឹងរឿងរ៉ាវទាក់ទងនឹងមនុស្ស ចំពោះគោលការណ៍ស្របច្បាប់នាសម័យបុរាណកាល "សម្រាប់កាត់ទោស "ដល់កូនជំនាន់ក្រោយ ដោយសារតែអំពើបាបរបស់ពួកព្ធយុកោ (ឪពុក) របស់ពួកកូនទាំងនោះតាំងពីបី ឬ បួនជំនាន់មកម្លេះ" (សូមមើល នក ២០:៥ ១០៣:១៧ លប ១៨:១៩) ។

**១០៩:១៣** គឺចាប់តាំងពីមនុស្ស បានរសពឹងផ្អែកទៅលើកូនរបស់គេមក គឺផ្តោតទៅលើការជំនុំជម្រះដែលនៅតែមាន ចំពោះមនុស្សដែលមានអណ្តាត

សូមឱ្យឈ្មោះវាត្រូវសូន្យបាត់ទៅ[ប]
១៤សូមឱ្យព្រះយេហូវ៉ានឹកចាំពីសេចក្តីទុច្ចរិតរបស់ពួក
ព្ធយុកោវា[ផ] ហើយកុំឱ្យបាបរបស់ម្តាយវាត្រូវលុបចេញ
ឡើយ
១៥សូមឱ្យសេចក្តីទាំងនោះនៅចំពោះ[ព] ព្រះយេហូវ៉ាជានិច្ច
ដើម្បីឱ្យទ្រង់បានផ្តាច់សេចក្តីនឹកចាំ[ភ] ពីគេចេញពីផែនដី
ទៅ
១៦ពីព្រោះវាមិនបាននឹកចាំនឹងសំដែងសេចក្តីមេត្តាទេ គឺ
បានសង្កត់សង្កិនមនុស្សក្រលំបាក និងមនុស្សកំសត់ទុគ៌ត[ម]
ព្រមទាំងមនុស្សដែលមានចិត្តសង្រេងវិញ[យ] ដើម្បីនឹង
សំឡាប់គេបង់
១៧អើ វាបានចូលចិត្តនឹងការដេរប្រទេច ហើយការនោះ
ក៏កើតមកដល់ខ្លួនវា[រ] វាមិនចូលចិត្តនឹងការឱ្យពរទេ
ហើយការនោះក៏នៅឆ្ងាយពីវា
១៨វាបានប្រដាប់ខ្លួន ដោយការដេរប្រទេច[ល] ដូចជាពាក់
អាវ ហើយការនោះក៏ចូលទៅដល់ខាងក្នុងវាដូចជាទឹក
ហើយបានជ្រាប[វ] ទៅក្នុងឆ្អឹងវាដូចជាប្រេង
១៩សូមឱ្យការនោះបានសំរាប់វា ដូចជាសំលៀកបំពាក់
ដែលវាតែងស្លៀកពាក់[ស] ហើយជាខ្សែក្រវាត់ដែលវារឹត
នៅចង្កេះជានិច្ចដែរ
២០នេះហើយជារង្វាន់[ហ] ដែលព្រះយេហូវ៉ាទ្រង់ប្រទានដល់
ពួកខ្មាំងសត្រូវនៃទូលបង្គំ ហើយដល់អ្នកដែលនិយាយ
បង្កាច់[ឡ] ដល់ព្រលឹងនៃទូលបង្គំដែរ
២១តែឱព្រះយេហូវ៉ា ជាព្រះអម្ចាស់អើយ សូមទ្រង់ប្រោស
ទូលបង្គំដោយយល់ដល់ព្រះនាម[អ] ទ្រង់សូមប្រោសឱ្យទូល
បង្គំបានរួច[ក] ដោយព្រោះសេចក្តីសប្បុរសដ៏ប្រសើររបស់
ទ្រង់[ខ]
២២ដ្បិតទូលបង្គំជាអ្នកក្រលំបាក ហើយ កំសត់ទុគ៌ត ហើយ
ចិត្តនៅក្នុងខ្លួនទូលបង្គំមានរបួសផង
២៣ទូលបង្គំទៅបាត់ ដូចជាស្រមោលដែលជ្រេទៅ[គ] ទូលបង្គំ
ត្រូវគេដេញចុះឡើងដូចជាកណ្តូប
២៤ក្បាលជង្គង់នៃទូលបង្គំញ័រ[ឃ] ដោយតមអាហារ[ង] ហើយ
រូបសាច់ទូលបង្គំក៏ស្គមស្គាំងទៅ[ច]
២៥ទូលបង្គំបានត្រឡប់ជាទីត្មះតិះដៀល[ឆ] ដល់គេ កាលណា
គេប្រទះឃើញទូលបង្គំ នោះគេគ្រវីក្បាល[ជ]
២៦ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ សូមជួយទូលបង្គំ
ផងឱសូម[ឈ] ជួយសង្គ្រោះទូលបង្គំ តាមសេចក្តីសប្បុរសនៃ
ទ្រង់
២៧ដើម្បីឱ្យគេបានដឹងថា[ញ] ការនេះគឺជាព្រះហស្តទ្រង់ធ្វើទេ
គឺជាទ្រង់ ឱព្រះយេហូវ៉ាអើយ ដែលបានធ្វើការនេះ
២៨ឱ្យគេដេរប្រទេចចុះ[ដ] តែសូមទ្រង់ប្រទានពរវិញកាល

**១០៩:១៣** ប ជន ១៤:១២ ទដ ៩:៥ សភ ១០:៧ **១០៩:១៤** ផ នក ២០:៥ ជន ១៤:១៨ អស ៦៥:៦–៧ យរ ៣២:១៨ **១០៩:១៥** ព ទដ ៩០:៨ ភ នក ១៧:១៤ ចទ ៣២:២៦ **១០៩:១៦** ម យប ២០:១៩ ទដ ៣៥:១០ យ ទដ ៣៤:១៨ **១០៩:១៧** រ សភ ២៨:២៧ មថ ៧:២ **១០៩:១៨** ល ទដ ១០:៧ វ ជន ៥:២២ **១០៩:១៩** ស ខ.២៩ ទដ ៧៣:៦ អគ ៧:២៧ **១០៩:២០** ហ នក ៣២:៣៤ ទដ ៥៤:៥ ៩៤:២៣ អស ៣:១១ ២ធថ ៤:១៤ ឡ ទដ ៧១:១០ **១០៩:២១** អ នក ៩:១៦ ទដ ២៣:៣ **១០៩:២១** ក ទដ ៣:៧ ខ ទដ ៦៩:១៦

**១០៩:២៣** គ យប ១៤:២ **១០៩:២៤** ឃ ហព ១២:១២ ង ទដ ៣៥:១៣ ច ប ១៦:៨ **១០៩:២៥** ឆ ទដ ២២:៦ ជ យប ១៦:៤ មថ ២៧:៣៩ មក ១៥:២៩ **១០៩:២៦** ឈ ទដ ១២:១ ១១៩:៨៦ **១០៩:២៧** ញ យប ៣៧:៧ **១០៩:២៨** ដ ២សយ ១៦:១២

កំភូត (សូមមើល ២១:១០ ៣៧:២៨) ។

**១០៩:១៤–១៥** *សេចក្តីទុច្ចរិតរបស់ពួកព្ធយុកោវា . . . បាបរបស់ម្តាយវា* ខទាំងនេះ គឺវាទាក់ទងនិងសាច់រឿងក្នុង ខ.៧–៨ (គឺជាផ្នែកកំណាព្យសំខាន់ៗ) : ជាសេក្តីចោទប្រកាន់ ដែលអ្នកមានអណ្តាតកំភូតប្តឹងតបវិញ មានទាំងអំពើបាបរបស់ពួកព្ធយុកោពួកគេ (មើលការពន្យល់ ខ.១២) ។

**១០៩:១៥** *បានផ្តាច់សេចក្តីនឹកចាំពីពួកគេចេញ* គឺឱ្យសេចក្តីជាពាក្យនិយាយបង្ខូចឱ្យបាត់ជាមួយនឹងគ្រួសារចុងក្រោយរបស់គេទៅ ។

**១០៩:១៦–២០** ជាសេចក្តីដែលគ្មានមេត្តាករុណារបស់ពួកសត្រូវ អាចឱ្យពួកគេទទួលបាននូវការឈឺចាប់ ដោយព្រោះផលអាក្រក់របស់គេ(សូមមើល ១០:២–១៥ ៥៩:១២–១៣) ។ ឯការចោទប្រកាន់របស់ពួកសត្រូវគឺជារឿងធម្មតានៅក្នុងគម្ពីរទំនុកដំកើង ក៏បង្ហាញពីការកាត់ទោសពីស្ថានសួគ៌ (មើល ៥:៩–១០ ១០:២–១១ ១៧:១០–១២) ។

**១០៩:១៧** *វាបានចូលចិត្តនឹងការដេរប្រទេច* មើលការពន្យល់ ១០:៧ ។

**១០៩:១៨–១៩** *ពាក់អាវ . . . ដែលវាតែងស្លៀកពាក់* មើលការពន្យល់ ខ.២៩ ។

**១០៩:១៨** *ខាងក្នុងដូចជាទឹក ហើយបានជ្រាបទៅក្នុងឆ្អឹងវាដូចជាប្រេង* បើថាការប្រទេជផ្តាសាទៅលើអ្វីមួយនោះ វាគឺជាអាហារ ហើយនិងទឹកដែលជាការល្អចំពោះសំលៀកបំពាក់ ហើយគាត់រស់នៅក្នុងសេចក្តីប្រទេជផ្តាសារ (មើល សភ ៤:១៧ និងការពន្យល់) ។

**១០៩:២០** *ព្រះយេហូវ៉ាទ្រង់ប្រទានដល់* សូមមើល ៥៤:៥ ៩៤:២៣ អស ៣:១១ ២ធម ៤:១៤ ។

**១០៩:២១–២៥** ជាក្តីប្រាថ្នាចេញពីការឈឺចាប់របស់ទូលបង្គំ គឺសូមឱ្យព្រះយេហូវ៉ាដោះឱ្យបានរួច ។

**១០៩:២១** *ដោយយល់ដល់ព្រះនាមទ្រង់* មើលការពន្យល់ ៥:១១ ២៣:៣ ។ *សេចក្តីសប្បុរស* សូមមើល ខ.២៦ ក៏សូមមើលការពន្យល់ ៦:៤ ។

**១០៩:២២** គឺជាការពណ៌នារបស់អ្នកនិពន្ធគម្ពីរទំនុកដំកើង បាននិយាយពីស្ថានភាពនៃជីវិតរបស់គាត់ ដែលមានក្នុង ខ.១៦ ។ ពាក្យថា *ជាអ្នកក្រលំបាកហើយកំសត់ទុរគតិ* ហើយពឹងផ្អែកលើព្រះយេហូវ៉ា (មើលការពន្យល់ ២៦:៦) ។ *ចិត្ត* មើលការពន្យល់ ៤:៧ ។ មានរបួសបើជាភាសាហេព្រើរចំពោះឃ្លានេះគឺស្មើនិង "ការដេរប្រទេច" មានក្នុង ខ.១៧,១៨ ។

**១០៩:២៣** *ទូលបង្គំទៅបាត់ដូចជាស្រមោល* ជាការបង្ហាញពីភាពឈឺចាប់របស់អ្នកនិពន្ធគម្ពីរទំនុកដំកើង ដែលកាលៈទេសៈបានតម្រូវឱ្យសត្រូវមានប្រៀបជាង (សូមមើល ខ.២៤–២៥ មើលការពន្យល់ ៥:៩) ។ *ដូចជាស្រមោលដែលជ្រេទៅ* សូមមើល ១០២:១១ ។ *ត្រូវគេដេញចុះ* សូមមើល នហ ៥:១៣ យប ៣៨:១៣ ។

**១០៩:២៨** *អ្នកបំរើ* គឺជាការនិយាយរៀបរាប់ពីអ្នកនិពន្ធគម្ពីរទំនុកដំកើងនេះ

ណាគេលើកគ្នាឡើងនោះ គេនឹងត្រូវមានសេចក្ដីខ្មាសតែ
អ្នកបំរើទ្រង់នឹងអរសប្បាយវិញ[ឋ]
២៩សូមឱ្យពួកសត្រូវនៃទូលបង្គំ បានត្រូវប្រដាប់ខ្លួនដោយ
សេចក្ដីអាប់យស ឱ្យគេគ្រលុំខ្លួន ដោយសេចក្ដីអាម៉ាស់
ខ្មាស[ឌ]ដូចជាពាក់អាវ
៣០មាត់ទូលបង្គំនឹងអរព្រះគុណដល់ព្រះយេហូវ៉ាយ៉ាងក្រៃ
លែង[ឍ] អើ ទូលបង្គំនឹង សរសើរដល់ទ្រង់នៅកណ្ដាល
ជនទាំងឡាយ
៣១ដ្បិតទ្រង់ឈរនៅខាងស្តាំ[ណ]នៃមនុស្សកំសត់ទុគ៌ត ដើម្បី
នឹងជួយឱ្យរួចពីពួកអ្នកដែលប្រកាន់ទោស ចំពោះព្រលឹង
គេ ។

**១០៩:២៨** ឋ ទដ ៦៦:៤ អស ៣៥:១០ ៥១:១១ ៥៤:១ ៦៥:១៤ **១០៩:២៩** ឌ ទដ ៣៥:២៦ **១០៩:៣០** ឍ ទដ ៣៥:១៨ **១០៩:៣១** ណ ទដ ១៦:៨ ១០៨:៦ **១១០:១** ក មថ ២២:៤៤ មក ១២:៣៦ លក ២០:៤២ កច ២:៣៤

ទំនុកនៃស្ដេចដាវីឌ ។

**១១០** ព្រះយេហូវ៉ាទ្រង់មានបន្ទូល[ក] ដល់ព្រះអម្ចាស់នៃ
ទូលបង្គំថាចូលឱ្យឯងអង្គុយនៅខាងស្តាំ[ខ]អញ ទាល់តែអញ
ដាក់ពួកខ្មាំងសត្រូវឯងឱ្យធ្វើជាកំណល់កល់ជើងឯង[គ]
២ព្រះយេហូវ៉ាទ្រង់នឹងសន្ធឹងដំបង[ឃ]នៃព្រះចេស្ដាឯងចេញ
ពីក្រុងស៊ីយ៉ូន[ង]ឱ្យឯងគ្រប់គ្រង[ច]នៅកណ្ដាលខ្មាំងសត្រូវផង
៣រាស្ត្ររបស់ឯងគេថ្វាយខ្លួនស្ម័គ្រពីចិត្តនៅថ្ងៃដែលឯង
ដំរៀបក្បួនទ័ពដ៏ប្រដាប់ដោយគ្រឿងបរិសុទ្ធ[ឆ] ពួកកំឡោះ

ខ មក ១៦:១៩ ហត ១:១៣ ១២:២ គ យស ១០:២៤ ១ពរ ៥:៣ ១កថ ១៥:២៥ **១១០:២** ឃ លប ៤៩:១០ ទដ ៤៥:៦ អស ១៤:៥ យរ ៤៨:១៧ ង ទដ ២:៦ ច ទដ ៧២:៨ **១១០:៣** ឆ នក ១៥:១១

តែម្ដង ដែលព្រះយេហូវ៉ាបានចាក់ប្រេងតាំងឡើង (សូមមើលចំណងជើង ក៏សូមមើល ៧៨:៧០ និងការពន្យល់) ។

**១០៩:២៩** *ត្រូវប្រដាប់ខ្លួនដោយសេចក្ដីអាប់យស* ឃ្លានេះមានការប្រើសម្រាប់ធ្វើការប្រដូចទៅនិងសកម្មភាពផ្សេងៗ សូមមើល ខ.១៨–១៩ ៣៥:២៥ ៤៥:៣ ៧៣:៦ ១០៤:១–២ ១៣២:៩,១៦,១៨ ២៦:១៦ ៣១:១៥ សក ៦:១៣ លក ២៤:១៩ រម ១៣:១៤ ។

**១០៩:៣០–៣១** គឺជាការស្រែកសរសើរចំពោះព្រះយេហូវ៉ា ដើម្បីដោះលោះ (សូមមើលការពន្យល់ ៧:១៧) ។

**ទដ ១១០** ជាបទទំនាញ ដែលទាក់ទងនឹងសង្ឃហ្លួង ជាព្រះម៉ែស៊ី ។ បទគម្ពីរទំនុកដំកើង (ក៏ជាបទទំនាយពីរជាលក្ខណៈសង្ខេប ខ.១,៤) គឺជារឿយៗបង្ហាញពីព្រះគ្រីស្ទជាបន្ទាល់ដូចជា ទដ ជំពូក ២ គឺជាសញ្ញានៃការបង្ហាញពីស្ដេចអង្គថ្មីពីជួរហ្លួងដាវីឌ ។ ដូចពីមុនគ្រីស្ទបរិស័ទពួកយូដាបានប្រកាស់ថានិងមានព្រះមួយអង្គត្រូវយាងមក គឺព្រះម៉ែស៊ី ។ សូមមើលការបកស្រាយតាមរយៈ (មថ ២២:៤៣–៤៥ មក ១២:៣៦–៣៧ លក ២០:៤២–៤៤) ក៏មានស្រាយតាមរយៈលោកពេត្រុសនិងអ្នកនិពន្ធសាសន៍ហេព្រើរ (មើល កច ២:៣៤–៣៦ ហត ១:១៣ ៥:៦–១០ ៧:១១–២៨) ។ ជាទូទៅគ្រីស្ទបរិស័ទនាសម័យនោះមានជំនឿថា វាជាសេចក្ដីទំនាយដោយផ្ទាល់តាមរយៈបទគម្ពីរទំនុកដំកើង ។ ដូចជាស្ដេចដាវីឌទ្រង់បានថ្លែងពីសេចក្ដីទំនាយ (សូមមើល ២សយ ២៣:២) ។ ការនិពន្ធបទទំនុកដំកើងពីការទទួលអភិសេក នៃព្រះរាជបុត្រាសម្រាប់ជាថ្ងៃអនាគត ដែលពួកហោរាពុំបានថ្លែងទំនាយនៅឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ស្ដេចដាវីឌបាននិពន្ធបទទំនុកដំកើងពីការគ្រងរាជ្យរបស់ព្រះបុត្រាព្រះអង្គ គឺជាស្ដេចសាឡូម៉ូន (ខ.១) ដែលព្រះរាជបុត្រានេះនិងមានអំណាចគ្រប់ព្រះចេស្ដា ជាស្ដេចប្រកបដោយប្រាជ្ញាញាណ ។ សូមមើលសេចក្ដីផ្ដើម ទដ ១០១–១១០ ។ បទគម្ពីរទំនុកដំកើងបានចែកដាច់ជាពីរផ្នែក (ខ.១–៣,៤–៧) ។ ផ្នែកនិមួយៗក្នុងពីចំណែកនេះជាការសង្ខេបខ្លីៗនៃបទទំនាយ (ខ.១,៤) ដែលមានបែបផែននៃវិទ្យានិពន្ធ និងការសំអិតសំអាងជាឃ្លាប្រយោគស្រដៀងៗគ្នា ដូចជា ខ.៤ ខ.១ ខ.៥ ខ.២ និង ខ.៦–៧ គឺទាក់ទងនិង ខ.៣ ។

**១១០:១–៣** ជាព្រះរាជក្រិតរបស់ព្រះយេហូវ៉ា បានតែងតាំងនិងផ្ដល់សិទ្ធពិសេសដើម្បីគ្រប់គ្រង (សូមមើល ២:៧–១២) ។

**១១០:១** ជាបទទំនាញទី១ (សូមមើលការពន្យល់នៅ ខ.៤) *ព្រះអម្ចាស់នៃទូលបង្គំ* គឺជាព្រះមហាក្សត្រនៃទូលបង្គំ ដែលមានភាពឧត្តម្ភដល់ស្ដេចដាវីឌ (សូមមើល ធថ ២២:៤៤–៤៥ មក ១២:៣៦–៣៧ លក ២០:៤២–៤៤ កច ២:៣៤–៣៥ ហត ១:១៣ ។ *អង្គុយ* គឺជាការអង្គុយនៅលើបល័ង្ក ។ *នៅខាងស្តាំអញ* គឺជាទីកន្លែងដែលមានកិត្តិយឧត្តម្ភនៅជាប់ព្រះមហាក្សត្រ (សូមមើល ៤៥:៩ ១ពវ ២:១៩) គឺទ្រង់បានឱ្យអ្នកសំណប់របស់ទ្រង់មានអំណាចព្រះចេស្ដាបន្ទាប់ពីទ្រង់ (សូមមើល មថ ២៦:៦៤ មក ១៤:៦២ ១៦:១៩ លក ២២:៦៩ កច ២:២៣ ៥:៣១ ៧:៥៥–៥៦ រម ៨:៣៤ អភ ១:២០ កល ៣:១ ហត ១:៣ ៨:១ ១០:១២ ១២:២) ។ *ពួកខ្មាំសត្រូវ* សូមមើលការពន្យល់ ២:១–៣ ។ *ជាកំណល់កល់ជើងឯង* សូមមើល ហត ១០:១២–១៣ ។ ស្ដេចនាសម័យបូរាណតែងតែមានទម្រជាកន្លែងទ្រនាប់ជើង ដើម្បីពាក់និងជើងរបស់ពួកគេដើម្បីយកជ័យជម្នះលើពួកសត្រូវទាំងអស់នោះ (សូមមើល យស ១០:២៤) ។ ក៏ជាប្រដាប់ពាក់ជើងរបស់ស្ដេចដែលជាប់នៅរាជបល្ល័ង្ក សូមមើល ២រប ៩:១៨ ៥:៣ ។ សាវកប៉ុលក៏យកព្រះបន្ទូលក្នុងខនេះមកអនុវត្តក្នុងការបម្រើព្រះផងដែរ ១កថ ១៥:២៥ អភ ១:២២ ។

**១១០:២** *សន្ធឹងដំបងនៃព្រះចេស្ដា* មានន័យថា ពង្រីករាជអំណាចគ្រប់ទាំងទិសទី និងរហូតដល់អស់មាសត្រូវដែលព្យាយាមប្រឆាំងនឹការដឹកនាំរបស់ទ្រង់ ។ ពាក្យថា *ក្រុងស៊ីយ៉ូន* គឺជាទីក្រុងរាជារបស់ស្ដេចដាវីឌ (សូមមើល ២សយ ៥:៧,៩) វាក៏ជារាជធានីរបស់ព្រះអម្ចាស់ដែលមានគ្រប់ទិសទី (សូមមើល ទដ ៤៦:៤៨ ១៣២:១៣–១៨) ។ ព្រះក៏បានចាក់ប្រេងតាំងឱ្យគាត់មានសិទ្ធលើនគរផែនដីទាំងមូល ។

**១១០:៣** *ស្ម័គ្រពីចិត្ត* ជាពាក្យមានន័យថា "ការថ្វាយទាំងស្រុងនូវចិត្តកាយ" ពោលគឺពួកគេបានថ្វាយខ្លួនធ្វើជាអ្នកចំបាំង ដើម្បីជួយដល់អ្នកក្នុងការធ្វើសង្គ្រាម (សូមមើល ពច ៥:២) ដូចជារាស្ត្រអ៊ីស្រាអែលបានថ្វាយទ្រព្យសម្បត្តិគេ ដើម្បីសាងសង់រោងឧបោសថនៅក្នុងទីរហោស្ថាន (សូមមើល នក ៣៥:២៩ ៣៦:៣ ក៏សូមមើល អគ ១:៤ ២:៦៨) ។ តាមពាក្យសម្ដីរបស់លោកសាវកប៉ុល អ្នកដែលដើរតាមព្រះ គឺត្រូវថ្វាយរូបកាយគេជាយញ្ញបូជារស់ (រម ១២:១) ឬសម្រាប់ជាដង្វាយផឹក (ភល ២:១៧ ២កថ ៨:៥) ។ *ដំរៀបក្បួន* ពណ៌នាពីការចាក់ប្រេងតាំងពីព្រះអម្ចាស់ ក៏បានពណ៌នាពីទ្រង់មានលក្ខណៈផ្ទាំងស្បែសំពត់មានតេជះ សេរីល្អ និងភាពស្រស់ស្រទន់ក៏មានលក្ខណៈដូចជា "ប្រភពផ្ដល់ជីវិត" ដែលនាំឱ្យមានពេលវេលាព្រឹកដែលបន្សល់ទុកទឹកសន្សើម (ឯចំពោះការប្រើតាមរបៀបផ្សេងៗរបស់និមិត្ត

របស់ឯង នឹងបានដូចជាទឹកសន្សើម ដែលចេញពីផ្ទៃនៃ
បច្ចូសកាលមក[ជ]
៤ព្រះយេហូវ៉ាទ្រង់បានស្បថហើយ ថាឯងជាសង្ឃនៅអស់
កល្បជានិច្ច[ឈ] តាមរបៀបលោកម៉ិលគីស្សាដែក[ញ]ទ្រង់នឹង
មិនប្រែព្រះហឫទ័យឡើយ[ដ]
៥ព្រះអម្ចាស់ដែលគង់នៅខាងស្តាំ[ឋ]ឯងទ្រង់នឹងវាយលំអិត
ស្តេច[ឌ]ទាំងប៉ុន្មាននៅថ្ងៃនៃសេចក្តីក្រោធរបស់ទ្រង់[ឍ]
៦ទ្រង់នឹងជំនុំជំរះនៅកណ្តាលអស់ទាំងសាសន៍[ណ]ឲ្យមាន
ពេញដោយសាកសព[ត]ទ្រង់នឹងវាយបំបែកក្បាលនៃនគរ[ថ]
ជាច្រើន

៧ទ្រង់នឹងសោយទឹកជ្រោះតាមផ្លូវដូច្នេះទ្រង់នឹងបានងើប
ព្រះសិរឡើង[ទ] ។

**១១១** ចូរសរសើរដល់ព្រះយេហូវ៉ា ខ្ញុំនឹងអរព្រះគុណ
ដល់ព្រះយេហូវ៉ា[ក]ដោយអស់ពីចិត្ត[ខ]នៅក្នុងចំណោមនៃ
មនុស្ស[គ]ទៀងត្រង់ហើយក្នុងពួកជំនុំជន[ឃ]
២អស់ទាំងស្នាដៃ[ង]នៃព្រះយេហូវ៉ាសុទ្ធតែធំវិសេសគួរឲ្យ

**១១០:៣** ជ មីក ៥:៧ **១១០:៤** ឈ សក ៦:១៣ ហាព ៥:៦ ៧:២១ ញ លប ១៤:១៨ ហាព ៥:១០ ៧:១៥–១៧ ដ ជន ២៣:១៩ **១១០:៥** ឋ ទដ ១៦:៨ ឌ ចទ ៧:២៤ ទដ ២:១២ ៦៨:២១ ៧៦:១២ អស ៦០:១២ ដយ ២:៤៤ ឍ ទដ ២:៥ រម ២:៥ វវ ៦:១៧ ១១:១៨ **១១០:៦** ណ ទដ ៩:១៩ ត អស ៥:២៥ ៣៤:៣ ៦៦:២៤ ថ ទដ ១៨:៣៨ **១១០:៧** ទ ទដ ៣:៣ ២៧:៦ **១១១:១** ក ទដ ៣៤:១ ១០៩:៣០ ១១៥:១៨ ១៤៥:១០ ខ ទដ ៩:១ គ ទដ ៨៩:៧ ឃ ទដ ១:៥ **១១១:២** ង យប ៣៦:២៤ ទដ ១៤៣:៥ វវ ១៥:៣

សញ្ញានេះ សូមមើល អស ២៦:១៩) ។ ដូចជាការនិយាយពីកងទ័ពវ័យក្មេង ដែលប្រមូលផ្តុំគ្នាជាកងទ័ព ដែលមានឯកសណ្ឋានជាគំរូពីព្រះអម្ចាស់ ដែលត្រៀបខ្លួនចូលរួមប្រយុទ្ធក្នុងសង្គ្រាមសាសនា (សូមមើល ១សយ ២១:៤–៥ ២៥:២៨ ២រប ១៣:៨,១២ ២០:១៥,២១ អស ១៣:៣–៤ យរ ៦:៤ ៥១:២៧) ។ *គ្រឿងបរិសុទ្ធ* សូមមើលការពន្យល់ ២៩:២ ។

**១១០:៤–៧** ជាពាក្យសម្បថរបស់ព្រះយេហូវ៉ា បានបណ្តុះដល់ពួកសង្ឃដែលរស់នៅក្នុងក្រុងយេរូសាឡឹមហើយបានបញ្ជាក់ថា សង្ឃនោះនឹងមានអំណាចលើអស់ទាំងអំណាចដែលប្រឆាំងនឹងទ្រង់ ។

**១១០:៤** ជាសេចក្តីទំនាយទី២ (សូមមើល ខ.១) ។ *ទ្រង់បានស្បថហើយ* ដោយយោងទៅលើសេចក្តីសម្បថតាមរយៈសេចក្តីសញ្ញា ដែលទ្រង់និងរក្សារាជវង្សស្តេចដាវីឌឲ្យមានជានិរន្ត (សូមមើល ៨៩:៣៥–៣៧) ។ អ្នកនិពន្ធជាភាសាហេព្រើរបានបញ្ជាក់ផងដែរ (ហាព ៦:១៦–១៨ ៧:២០–២២) ។ *ជាសង្ឃនៅអស់កល្បជានិច្ច តាមរបៀបលោកម៉ិលគីស្សាដែក* គឺមានស្តេចដាវីឌនិងរាជបុត្ររបស់ទ្រង់ ដែលដំណាងនៃអំណាចរបស់ព្រះដើម្បីថ្វាយបង្គំព្រះ និងមើលខុសត្រូវនូវហឹបសេចក្តីសញ្ញា (សូមមើល ២សយ ៦:១–១៥ ជាពិសេស ខ.១៤ ១ពវ ៨:១) មើលការសាងសង់និងមើលការខុសត្រូវដល់ទីថ្វាយបង្គំព្រះ (សូមមើល ១ពវ ជំពូក ៥–៦ ២ពវ ១២:៤–៧ ២២:៣–៧ ២៣:៤–៧ ២រប ១៥:៨ មើលការងារពួកសង្ឃ និងពួកលេវីក៏ដូចជាសេចក្តីអធិប្បាយក្នុងព្រះវិហារ (សូមមើល ១រប ៦:៣១ ១៥:១១–១៦ ១៦:៤–៤២ ២៣:៣–៣១ ២៥:១ ២រប ១៧:៧–៩ ១៩:៨–១១ ២៩:២៥,៣០ ៣១:២ ៣៥:១៥–១៦ អក ៣:១០ ៨:២០ នហ ១២:២៤,៣៦, ៤៥) ។ តែក្នុងកិច្ចការទាំងអស់នេះគ្រប់ទាំងអំណាច គឺស្ថិតនៅលើសង្ឃ ។ តែពេលខ្លះពួកគេពុំអាចលូកដៃក្នុងកិច្ចការ ដែលព្រះបានចាត់តាំងដ៏ពិសេសនោះទេ ព្រោះជាកិច្ចការរបស់ពួកសង្ឃ គឺជាកូនចៅរបស់លោកអើរ៉ុន (មើល ២រប ២៦:១៦–១៨) ។ ដោយបានសម្តែងបទទំនាយពីព្រះរាជបុត្រានៃស្តេចដាវីឌ ដែលព្រះរៀបចំជាសង្ឃនៅក្រុងស៊ីយ៉ូន បន្ទាប់ពីស្តេចម៉ិលគីស្សាដែកជាស្តេចក្រុងយេរូសាឡិម គឺទ្រង់ជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុតនៅឯក្រុងយេរូសាឡិមក្នុងជន្មាលោកអ័ប្រាហាំ (មើល ១៤:១៨) ។ ក៏ដូចជាសង្ឃ ដែលបានចាត់ធ្វើជាសង្ឃដ៏ខ្ពស់បំផុតជាងអើរ៉ុន និងកូនរបស់គាត់ផង ។ (គឺដើម្បីបញ្ចូលបង្រួមពួកស្តេចនិងពួកសង្ឃឲ្យជាមនុស្សតែមួយ សូមមើល សក ៦:១៣ និងការពន្យល់) ។

**១១០:៥** *ព្រះអម្ចាស់ដែលគង់នៅខាងស្តាំឯង* គឺព្រះអម្ចាស់ទ្រង់គង់នៅជិតបង្កើយនៃអ្នក គឺដើម្បីជាជំនួយដល់ការធ្វើសង្គ្រាមរបស់អ្នក (សូមមើល ខ.២ ប្រៀបធៀប ១០៩:៣១) ។

**១១០:៦** *ទ្រង់* ក៏មានការចាក់ប្រេងតាំងពីព្រះយេហូវ៉ា ជាការបង្ហាញសញ្ញានៃសង្គ្រាម គឺស្តែងចេញពីភាពមានជ័យជម្នះនៃស្តេចដាវីឌ ដែលព្រះយេហូវ៉ាបានប្រទានឲ្យមានជោគជ័យលើគ្រប់អស់អ្នកដែលទាស់ទទឹងនិងនគរព្រះ (សូមមើល ២:៩ វវ ១៩:១១–២១) ។

**១១០:៧** *សោយទឹកពីជ្រោះ* ដូចជាក្នុងពេលមានសង្គ្រាម គឺទ្រង់បានងើបព្រះសិរឡើង (សូមមើលការពន្យល់ ខ.៣) ។

**ទដ ១១១** គឺជាការសរសើរព្រះចំពោះភាពសុចរិត និងការមិនប្រែប្រួលរបស់ទ្រង់ ។ កណ្ឌគម្ពីរទំនុកដំកើងរួមបញ្ចូលទាំងការសរសើរព្រះជាបទទំនុកជាមួយនឹងការណែនាំឲ្យមានប្រាជ្ញា គឺដូចជាមាននៅក្នុងខដំបូងនិងខចុងក្រោយមួយចំនួនបានបញ្ជាក់យ៉ាងដូច្នេះដែរ ។ ការប្រៀបធៀបយ៉ាងច្បាស់លាស់ពី ទដ ១១២ ក៏បង្ហាញថា ជំពូកទាំងពីរមានលក្ខណៈដូចជាកូនភ្លោះក៏ចេញពីប្រភពអ្នកនិពន្ធតែ១ ។ សូមមើលសេចក្តីផ្តើម ទដ ១១១–១១៩ ។ ការសរសេរឃ្លាទាំងពីរ ទដ ១១១ និង ទដ ១១២ គឺមានលក្ខណៈតាមលំដាប់អក្ខរៈក្រមជាកំណាព្យ ប៉ុន្តែវាមានលក្ខណៈដូចគ្នាតែមួយ ។ កណ្ឌគម្ពីរទំនុកដំកើងទាំងពីរក៏បានគេរៀបជាគ្រោងគឺមានខដំបូង និងខក្រោយបង្អស់ ជាខសំខាន់ដែលបញ្ជាក់ពីផ្ទៃរឿងសំខាន់ៗ ក្នុងបទទំនុក ឯក្នុងកណ្ឌទំនុកដំកើងទាំងពីរជំពូកនេះ គួសេចក្តីសំខាន់គឺជាផ្ទៃរឿងដែលបង្ហាញនៅក្នុងខទីមួយ ។ នៅក្នុងគម្ពីរទំនុកដំកើងទាំពីរឯគួសេចក្តីសំខាន់នៃខទាំង៨ ក៏បានចែកជាពីផ្នែកក្នុង៤ខ ដែលខគម្ពីរយោង (ប្រៀបធៀបនឹង ១១១:២ និង ១១១:៦ ក៏សូមមើល ខ.៥,៩) ។ ឯខទាំងនោះក្នុងកណ្ឌគម្ពីរ ទដ ទាំពីរនោះក៏បានបង្ហាញពីផ្ទៃរឿងដូចៗគ្នាដែរ (ធៀបនឹង ១១១:២–៥ និង ១១២:៣–៥) ។ គម្ពីរទំនុកដំកើងទាំងពីរដែលមានលក្ខណៈស្រដៀងគ្នានេះ គឺចេញពីស្នាដៃអ្នកនិពន្ធតែមួយ ក៏តាមលំដាប់ព្យញ្ជនៈភាសាហេព្រើរដូចគ្នា ។

**១១១:១** *ចូរសរសើរ* ជាពាក្យសេចក្តីផ្តើម ដើម្បីសរសើរព្រះដែលមានបន្តក្នុង ខ.២–៩ ។ *ដោយអស់ពីចិត្ត* មើល ទដ ជំពូក ១១៩ (ខ.១០,៣៤,៥៨,៦៩, ១៤៥) ។ *ក្នុងចំណោមនៃមនុស្សទៀងត្រង់* គឺបង្ហាញពីលក្ខណៈស្និទ្ធស្នាលជាការរួបរួមមុនៗ (សូមមើល ១០៧:៣២) គឺមានលក្ខណៈផ្ទុយគ្នាដោយឡែក និងបើមើលទៅអ្នកដែលនាំដោយព្រះវិញ្ញាណដូចជា"មនុស្សទៀងត្រង់" មើល ១១២:២,៤ (សូមមើល ១១:៧ ៣៣:១ ៩៧:១១ ១០៧:៤២ ១៤០:១៣) ។ *ក្នុងពួកជំនុំជន* សូមមើលការពន្យល់ ៩:១ ។

អស់អ្នកណាដែលចូលចិត្តនឹងការទាំងនោះ[ច]បានស្វែង
រកតាម
៣ឯស្នាដៃនៃទ្រង់ នោះល្អប្រពៃ ហើយរុងរឿងឧត្តម
សេចក្ដីសុចរិតរបស់ទ្រង់ ក៏ស្ថិតស្ថេរ[ឆ]នៅជាដរាប
៤ទ្រង់បានធ្វើឱ្យមានសេចក្ដីនឹកចាំពីការអស្ចារ្យរបស់ទ្រង់
ព្រះយេហូវ៉ាទ្រង់ប្រកបដោយមេត្តាករុណា នឹងអាណិត
អាសូរ[ជ]
៥ទ្រង់បានប្រទានអាហារ[ឈ]ដល់អស់អ្នកដែលកោតខ្លាច
ទ្រង់[ញ] ក៏នឹងនឹកចាំពីសេចក្ដីសញ្ញា[ដ]ទ្រង់ជានិច្ចដែរ
៦ទ្រង់បានសំដែងព្រះចេស្ដានៃការ[ឋ]ទ្រង់ឱ្យរាស្ត្រទ្រង់
ឃើញដោយប្រទានឱ្យគេគ្រងបានមរដកនៃអស់ទាំង
សាសន៍[ឌ]
៧អស់ទាំងស្នាដៃ[ឍ]នៃព្រះហស្តទ្រង់សុទ្ធតែពិតត្រង់
ហើយសុចរិតបញ្ញត្តទាំងប៉ុន្មាននៃទ្រង់សុទ្ធតែម៉ត់ចត់[ណ]
៨ក៏បានតាំងឱ្យនៅអស់កល្បជានិច្ច[ត]ហើយបានសំរេចដោយ
សេចក្ដីពិត និងសេចក្ដីទៀងត្រង់
៩ទ្រង់បានចាត់ប្រើសេចក្ដីប្រោសលោះ[ថ]ដល់រាស្ត្រទ្រង់
ទ្រង់បានសំរេចសេចក្ដីសញ្ញាទ្រង់ ឱ្យនៅជាដរាបព្រះនាម
ទ្រង់បរិសុទ្ធ ហើយគួរគោរព[ទ]
១០ឯសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា[ធ]នោះជាដើមចមនៃ
ប្រាជ្ញា[ន] អស់អ្នកដែលកាន់តាម នោះមានយោបល់[ប]ល្អ
សេចក្ដីសរសើរនៃទ្រង់ជាប់នៅអស់កល្បជានិច្ច[ផ]។

**១១២** ចូរសរសើរដល់ព្រះយេហូវ៉ា[ក] មានពរហើយ
អ្នកណា[ខ]ដែលកោតខ្លាចដល់ព្រះយេហូវ៉ា[គ]ហើយមាន
សេចក្ដីអំណរ[ឃ]ជាខ្លាំងចំពោះសេចក្ដីបង្គាប់របស់ទ្រង់
២ពូជពង្ស[ង]របស់អ្នកនោះ នឹងបានពូកែនៅផែនដីឯដំណ

**១១១:១** ច ទដ ៦៤:៩ **១១១:៣** ឆ ទដ ១១២:៣,៩ ១១៩:១៤២ **១១១:៤** ជ ចទ ៤:៣១ ទដ ៨៦:១៥ **១១១:៥** ឈ លប ១:៣០ ទដ ៣៧:២៥ មថ ៦:២៦,៣១–៣៣ ញ ទដ ១០៣:១១ ដ ១របា ១៦:១៥ ទដ ១០៥:៨ **១១១:៦** ឋ ទដ ៦៤:៩ ៦៦:៣,៥ ឌ ទដ ១០៥:៤៤ **១១១:៧** ឍ ទដ ៩២:៤ ណ ទដ ១៩:៧ ១១៩:១២៨ **១១១:៨** ត ទដ ១១៩:៨៩,១៥២,១៦០

អស ៤០:៨ មថ ៥:១៨ **១១១:៩** ថ ទដ ៣៤:២២ ១០៣:៤ ១៣០:៧ លក ១:៦៨ ទ ទដ ៣០:៤ ៩៩:៣ លក ១:៤៩ **១១១:១០** ធ យប ២៣:១៥ ទដ ១៩:៩ ន ចទ ៤:៦ ប ចទ ៤:៦ ទដ ១១៩:៩៨,១០៤,១៣០ ផ ទដ ២៨:៦ ៨៩:៥២ **១១២:១** ក ទដ ៣៣:២ ១០៣:១ ១៥០:១ ខ ទដ ១:១–២ គ យប ១:៨ ទដ ១០៣:១១ ១១៥:១៣ ១២៨:១ ឃ ទដ ១:២ ១១៩:១៤,១៦,៤៧,៩២ **១១២:២** ង ទដ ២៥:១៣ ៣៧:២៦ ១២៨:២–៤

**១១១:២–៥** វគ្គនេះគឺសំដៅលើព្រះរាជកិច្ច និងសេចក្ដីសញ្ញារបស់ផងទ្រង់ (សូមមើល ខ.៦–៩ និងការពន្យល់) ។

**១១១:២** *ស្នាដៃនៃព្រះយេហូវ៉ា* ជាឃ្លានៃបទទំនុកដែលមានលក្ខណៈពិសេស ផ្ដោតទៅលើអ្វីដែលព្រះបានធ្វើក្នុងចំណោមរាស្ត្ររបស់ផងទ្រង់ ។ មាន ខ.៥,៩ (សូមមើល អគ ១០:១៦ "ជាសេចក្ដីអង្កេតមួយ" សស ១:១៣ ជាការសិក្សា" ។

**១១១:៣** *សេចក្ដីសុចរិត* គឺជាការសម្ដែងតាមរយៈអំពើរបស់ទ្រង់ (សូមមើលការពន្យល់ ៤:១) ។

**១១១:៤** *ពីការអស្ចារ្យ* សូមមើលការពន្យល់ ៩:១ ។ *មេត្តាករុណានិងអាណិតអាសូរ* សូមមើល នក ៣៤:៦–៧ និងការពន្យល់ ។

**១១១:៥** *ប្រទានអាហារ* ជាការបង្ហាញពីការជួយឧត្ដម្ភជាបរិបូរ សម្រាប់សេចក្ដីត្រូវការប្រចាំថ្ងៃចំពោះរាស្ត្ររបស់ផងទ្រង់ (ដូចជាសេចក្ដីអធិស្ឋានរបស់ព្រះយេហូវ៉ា ដែលផ្ដល់ឱ្យយើងមានអាហាប្រចាំថ្ងៃ មថ ៦:១១) ។ *កោតខ្លាច* សូមមើល ខ.១០ និងការពន្យល់ ។ *សេចក្ដីសញ្ញាទ្រង់* ដោយទ្រង់ចង់ចាំ"ជារៀងរហូត" នូវសេចក្ដីសញ្ញា គឺជាសេចក្ដីសញ្ញា "ទ្រង់ប្រទានមកជារៀងរហូត" (ខ.៩ សូមមើល ១០៥:៨–១១) ។

**១១១:៦–៩** គឺជាវគ្គដែលទាក់ទងនិងការដែលព្រះយេហូវ៉ាបានធ្វើការ" និងសេចក្ដីសញ្ញារបស់ទ្រង់" (សូមមើល ខ.២–៥ និងការពន្យល់) ។

**១១១:៧** *ពិតត្រង់ហើយសុចរិត* សូមប្រៀបធៀប"សេចក្ដីរុងរឿង ឧត្តមសេចក្ដីសុចរិតរបស់ទ្រង់" (ខ.៣) ។ សូមមើលការពន្យល់ ៩៣:៥ ។

**១១១:៨** "ជាកិច្ចការដោយព្រះហស្តទ្រង់" (ខ.៧) ។ *សេចក្ដីពិតនិងសេចក្ដីទៀងត្រង់* ប្រៀបធៀបនិង "ប្រកបដោយមេត្តាករុណា និងអាណិតអាសូរ" (ខ.៤) ។

**១១១:៩** *ចាត់ប្រើសេចក្ដីប្រោសលោះ* គឺជាផលកំរៃមួយដ៏អស្ចារ្យនៃការងាររបស់ព្រះអង្គក្នុងនាមទ្រង់ជាអង្គដែលតំណាងឱ្យប្រជាជន (ប្រៀបធៀប "ការផ្ដល់អាហារ" ខ.៥) ។ *ព្រះនាមទ្រង់បរិសុទ្ធ ហើយគួរគោរព* គឺជាការបង្ហាញតាមរយៈការងាររបស់ទ្រង់ ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**១១១:១០** ជាពាក្យបញ្ជាក់ពីប្រាជ្ញាដែលនិងទទួលបានពីព្រះ ។ *ឯសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ានោះជាដើមចមនៃប្រាជ្ញា* ជាផ្នែកគម្ពីរសញ្ញាចាស់ បង្ហាញពីអក្សរសាស្ត្រដែលទាក់ទង់និងមូលដ្ឋានគ្រឹះ នៃគម្ពីរសាសនាដែលជាប្រភពនាំឱ្យមនុស្សមានប្រាជ្ញា (សូមមើល យប ២៨:២៨ សភ ១:៧ ៩:១០ សូមមើលការពន្យល់ លប ២០:១១) ។ *អស់អ្នកដែលកាន់តាម* គឺអស់អ្នកដែលធ្វើតាមឬស្ដាប់នូវសេចក្ដីបញ្ញត្តិទាំងអស់របស់ព្រះយេហូវ៉ា មើល ខ.៧ (សូមមើល ១៩:៧–៩ ទីណាដែលមានការកោតខ្លាចដល់ព្រះយេហូវ៉ា គឺអ្នកដែលមានការត្រាស់ហៅ រួមទាំអ្នកដែលឈរនៅក្នុង "ស្ថានភាពដូចគ្នា" "មានសិក្ខាបទដូចគ្នា" "សេចក្ដីបញ្ញត្តិពីព្រះដូចគ្នា" "ការចាក់ប្រេងតាំងដូចគ្នា" សូមមើល ១១២:១) ។

**ទដ ១១២** ជាពាក្យសរសើរចំពោះមនុស្សល្អសុចរិតដោយវិញ្ញាណនៃ ទដ ជំពូក ១ ប៉ុន្តែ សូមមើល ទដ ជំពូក ១១១ តែសេចក្ដីនិងសកម្មភាពទាំងស្រុង (គឺសូមមើលសេចក្ដីផ្ដើម ទដ ១១១) ។

**១១២:១** គឺការបង្ហាញផ្ទេរឿងជាមូលដ្ឋានគ្រឹះ ក៏បង្ហាញឱ្យឃើញច្បាស់នៅក្នុង ខ.២–៩ ។ ឯ ខ.១០ បញ្ជាក់ពីភាពប្រច្រាស់គ្នាក្នុងព្រះបន្ទូល សូមមើល ១:១–២ ១២៨:១ ។ ពាក្យថា *មានពរហើយ* សូមមើលការពន្យល់ ១:២១ ។ *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើល ៣៤:៨–១៤ និងការពន្យល់ ។ *មានសេចក្ដីអំណរជាខ្លាំង . . . សេចក្ដីបង្គាប់របស់ទ្រង់* ជាឃ្លាពាក្យពេជ្រ ដែលភ្ជាប់ទៅនឹង ជំពូក ១១៩ (សូមមើល ១១៩:៣៥) ។

**១១២:២–៥** ជាវគ្គដែលបានប្រមូល ដែលបង្ហាញពីកូនមនុស្សមានបែបផែនជាព្រះ ។

**១១២:២** *ពូជពង្សរបស់អ្នកនោះ* គឺការដែលពឹងដោយព្រះវិញ្ញាណ ក៏បាននាំ

មនុស្សទៀងត្រង់គេនឹងបានពរ
៣ ចំណែកធនធាន និងទ្រព្យសម្បត្តិ[ច] រមែងមាននៅក្នុងផ្ទះ
គេ ហើយសេចក្ដីសុចរិតរបស់អ្នកនោះក៏គង់នៅ[ឆ]ជាដរាប
៤ មានពន្លឺភ្លឺឡើង[ជ] ក្នុងទីងងឹត សំរាប់មនុស្សទៀងត្រង់គេជា
អ្នកមានចិត្តប្រកបដោយមេត្តាករុណាអាណិតអាសូរ
ហើយសុចរិត[ឈ]
៥ អ្នកណាដែលមានចិត្តមេត្តា ឱ្យគេខ្ចីនោះបានសប្បាយ[ញ]
ហើយអ្នកនោះនឹងរក្សានូវកិច្ចការខ្លួន តាមសេចក្ដីយុត្តិធម៌
៦ ដ្បិតគេមិនត្រូវរង្គើឡើយ[ដ] និងចេះតែមានសេចក្ដីនឹកចាំ[ឋ]
ពីមនុស្សសុចរិតនៅជារៀងរាបដរាប
៧ អ្នកនោះនឹងមិនខ្លាចដំណឹងអាក្រក់ឡើយ ចិត្តគេបានមាំ
មួនហើយ[ឌ] ដោយទុកចិត្តនឹងព្រះយេហូវ៉ា[ឍ]
៨ ចិត្តគេបានតាំងខ្ជាប់ខ្ជួន គេនឹងមិនភ័យខ្លាចឡើយ[ណ]
ដរាបដល់បានឃើញបំណងចិត្តកើតដល់ពួកសត្រូវខ្លួន[ត]
៩ គេបានចែកចាយ គឺបានចែកឱ្យដល់មនុស្សកំសត់[ថ]
សេចក្ដីសុចរិតរបស់គេគង់នៅ[ទ]ជាដរាបមនុស្សទាំងឡាយ
នឹងលើកមុខ[ធ]អ្នកនោះ ឱ្យមានកិត្តិសព្ទ
១០ ពួកមនុស្សអាក្រក់នឹងមើលឃើញ[ន] ហើយនិងមានចិត្ត
ក្នាញ់គេនឹងសង្កៀតធ្មេញ[ប] ហើយរលាយបាត់ទៅ[ផ]
បំណងចិត្តនៃមនុស្សអាក្រក់នោះនឹងវិនាសសូន្យទៅវិញ[ព] ។

**១១៣** ចូរសរសើរដល់ព្រះយេហូវ៉ា[ក] ឱពួកអ្នកបំរើនៃ
ព្រះយេហូវ៉ាអើយ[ខ] ចូរសរសើរចុះ ចូរសរសើរដល់ព្រះ
នាមព្រះយេហូវ៉ា

**១១២:៣** ច ចទ ៨:១៨ ឆ ទដ ៣៧:៦ ១១១:៣ **១១២:៤** ជ ទដ ១៨:២៨ ឈ ទដ ៥:១២ **១១២:៥** ញ ទដ ៣៧:២១,២៦ លក ៦:៣៥ **១១២:៦** ដ ទដ ១៥:៥ ៥៥:២២ ឋ សភ ១០:៧ សស ២:១៦ **១១២:៧** ឌ ទដ ៥៧:៧ ១០៨:១ ឍ ទដ ២៨:៧ ៥៦:៣–៤ អស ១២:២ **១១២:៨** ណ ទដ ៣:៦ ២៧:១ ៥៦:១១ សភ ១:៣៣ អស ១២:២ ត ទដ ៥៤:៧ **១១២:៩** ថ លក ១៩:៨ កច ៩:៣៦ ២កថ ៩:៩ ទ ទដ ១១១:៣ **១១២:៩** ធ ទដ ៧៥:១០ **១១២:១០** ន ទដ ៨៦:១៧ ប ទដ ៣៧:១២ មថ ៨:១២ ផ ទដ ៣៤:២១ ព យប ៨:១៣ **១១៣:១** ក ទដ ២២:២៣ ខ ទដ ៣៤:២២ ១០៣:២១ ១៣៤:១

ជាព្រះពរដល់កូនចៅពួកគេ ក៏ដូចជាខ្លួនរបស់ពួកគេផងដែរ មិនតែប៉ុណ្ណោះ សោធតាមរយៈកូនរបស់ពួកគេ ក៏នាំមកនៅការចងចាំរំឭកដល់មនុស្សសុចរិតនៅក្នុងសហគមន៍គេ (សូមមើល ខ.៦ និង ចទ ២៥:៦ នរ ៤:១០ និងសូមមើលបន្ថែមទៀតក្នុង ទដ ៣៧:២៦ ។ *និងបានពូកែ* គឺជាមនុស្សដែលមានឥទ្ធិពលនិងទទួលបានកិត្តិយសល្អបំផុត ។

**១១២:៣** សូមប្រៀបធៀបនិង *ចំណែកធនធាននិងទ្រព្យសម្បត្តិ* សូមមើល ១:៣ ១២៨:២ ។ *សេចក្ដីសុចរិត* សូមមើល ខ.៦ ក៏សូមមើលការពន្យល់ ១:៥ ផងដែរ ។ *ក៏គង់នៅ* គឺមិនមែនជាលក្ខណៈសម្បត្តិមួយដែលកើតឡើងដោយចៃដន្យ តាមរយៈសកម្មបាននោះទេ (សូមមើល "បានមាំមួន" ខ.៧) ។

**១១២:៤** *ក្នុងទីងងឹត* គឺជាន័យធៀបមួយដែលសំដៅទៅលើកាលៈទេសៈទុក្ខលំបាកវេទនា (សូមមើល ១០៧:១០ និងការពន្យល់) ។ *ពន្លឺភ្លឺ* សូមមើលការពន្យល់ ២៧:១ ។ *ប្រកបដោយមេត្តាករុណា អាណិតអាសូរ* សូមមើល ១១១:៤ ប្រៀបធៀប នក ៣៤:៦–៧ និងការពន្យល់ ។ *សុចរិត* ប្រៀបធៀបពីការនិយាយអំពីព្រះយេហូវ៉ា ១១៦:៥ ១៤៥:៨,១៧ ។

**១១២:៥** *សប្បាយហើយ* គឺជាភាពសុខសាន្ត និងវិបុលសុខចំរើនឡើង(សូមមើល ៣៤:៨–១៤ និងការពន្យល់) ដូចជាអ្នកដែលមានចិត្តសុភាព ស្លូតត្រង់ហើយកោតខ្លាចដល់ទ្រង់ សូមមើល ១១១:៥ និង ខ.៩ ។

**១១២:៦–៩** គឺជាវគ្គដែលរៀបចំឡើងដើម្បីបង្ហាញពីមនុស្សសុចរិត ដែលធ្វើឱ្យគេ"នឹកចាំជានិច្ច" (សូមមើល ការពន្យល់ ខ.២) និងភាពសប្បុរសរបស់គេ (សូមមើលការពន្យល់ ខ.២–៥) ។

**១១២:៦** *ត្រូវរង្គើឡើយ* សូមមើលការពន្យល់ ១០:៦ ។

**១១២:៧** គឺជាផ្ទៃរឿងតពី ១១១:៧ ដែលជាផ្ទៃរឿងសំខាន់បានបញ្ជាក់ច្បាស់ ។ *ចិត្ត* សូមមើល ២.៨ ក៏សូមមើលការពន្យល់ ៤:៧ ។ *ទុកចិត្តនិង* ការទុកចិត្តដល់ព្រះអម្ចាស់ និងមានភាពមាំមួនដូចជាភាពសុចរិតរបស់ផងទ្រង់ដែលស្ថិតស្ថេរជានិច្ច (សូមមើល ខ.៣) ។ ការមានសេចក្ដីទៀងត្រង់និងការស្ដាប់បង្គាប់ព្រះ គឺជាការកោតខ្លាចដល់ព្រះយេហូវ៉ា គឺនិងមិនខ្វះអ្វីឡើយ ។ សូមមើល ៣៤:៨–១៤ និងការពន្យល់ ។

**១១២:៨** *បានតាំងខ្ជាប់ខ្ជួន* គឺបើក្នុងភាសាហេព្រើរ គឺជាពាក្យស័ព្ទសម្ដែងអំពី"ភាពបានមាំមួន" មើលក្នុង ១១១:៨ ។ *ដរាបបានឃើញបំណងចិត្ត* គឺដូចជា"ការចាប់មានពន្លឺនៅក្នុងទីងងឹត" (ខ.៤) ។

**១១២:៩** សូមមើល ២កថ ៩:៩ និងការពន្យល់ ។ *គឺការចែកដល់មនុស្សកំសត់* សូមមើល ខ.៥ ។ *សេចក្ដីសុចរិតរបស់គេ* ក៏ដូចជាព្រះយេហូវ៉ាបានចង់ចាំពីសេចក្ដីសញ្ញារបស់ផងទ្រង់ (១១១:៥,៩) ដូច្នេះមនុស្សសុចរិតគេប្រព្រឹត្តទៅតាមសេចក្ដី "យុត្តិធម៌" (ខ.៥)"សេចក្ដីសុចរិតវិញ" (ខ.៩) គឺជាគុណធម៌ ឬគុណសម្បត្តិដែលជាសីលធម៌ចំបងពីរផ្នែកដែលព្រះយេហូវ៉ាទៀមទាឱ្យបាវបម្រើសេចក្ដីសញ្ញារបស់ផងទ្រង់មានជានិច្ច (សូមមើល លប ១៨:១៩ ទដ ១០៦:៣ អស ៥:៧ ៥៦:១ អគ ១៨:៥,២១ ៣៣:១៤,១៦,១៩ ៤៥:៩ អម ៥:២៤ ៦:១២ ។ សូមមើល ២ សយ ៨:១៥ សភ ១:៣ ២១:៣ យរ ២២:១៥ ៣២:១៥ ។ *លើកមុខអ្នកនោះឱ្យមានកិត្តិសព្ទ* ក៏ដូចជានាមទ្រង់ដែលទទួលការកោតសរសើរយ៉ាងអស្ចារ្យ (សូមេមើល ១១១:៩) ។

**១១២:១០** ក៏មានលក្ខណៈបញ្ច្រាស់គ្នាដូចជា ១១១:១០ ។ *និងមើលឃើញហើយនិងមានចិត្តក្នាញ់* ឯភាពស្រឡាញ់ព្រះគឺជាការវៃកផ្លូវដើម្បីទទួលព្រះពរ តែឯផ្លូវរបស់មនុស្សអាក្រក់ ដែលពួកគេបានជ្រើសយកនោះក៏នាំពួកគេទៅឯសេចក្ដីស្លាប់នៅចុងបញ្ចប់ (សូមមើល ១០:២–១១ ១០៧:៤២) ។ *និងវិនាសសូន្យទៅវិញ* សូមមើល ១:៤–៦ ទដ ជំពូក ៣៧ សភ ១០:២៨ ។

**ទដ ១១៣–១១៨** "ជាបទទំនុក អេស៊ីព្ទ" ក៏បានប្រើក្នុងផ្នែកអក្សរសាស្ត្រនៃពួកយូដាសម្រាប់ពីធីបុណ្យសាសនាធំៗ មានដូចជា : បុណ្យរំលង បុណ្យចំរូតបុណ្យប្រមូលផល បុណ្យចូលខែ សូមមើល លវ ជំពូក ២៣ ជន ១០:១០ យហ ១០:២២ ។ ឯបុណ្យរំលងមានក្នុង ទដ ១១៣ និង ១១៤ គេតែងតែច្រៀងបទទំនុកមុនពេលទទួលទានអាហារ ។

**ទដ ១១៣** ជាបទទំនុក សម្រាប់ពិធីបុណ្យដល់ព្រះយេហូវ៉ា ដើម្បីសរសើរពីភាពឧត្ដមរបស់ផងទ្រង់ (សូមមើល ១៣៨:៦) ។ គេបានតែងនិពន្ធទំនុកនេះដំបូងមកជាប្រភពដើមនៃបទសរសើរដតម្កើង គឺដើម្បីច្រៀងនៅព្រះវិហារ ។ ដូចជាមានចម្រៀងរបស់ហាណា (១សយ ២:១–១៥) ក៏ដូចជា

២ សូមឱ្យព្រះនាមព្រះយេហូវ៉ាបានព្រះពរ[គ] ចាប់តាំងពីឥឡូវ
នេះ ដរាបដល់អស់កល្បតទៅ[ឃ]
៣ ចាប់តាំងពីទីថ្ងៃរះ[ង] រហូតដល់ទីថ្ងៃលិចនោះព្រះនាមព្រះ
យេហូវ៉ាគួរសរសើរ
៤ ព្រះយេហូវ៉ាទ្រង់ស្ថិតនៅទីខ្ពស់[ច] លើគ្រប់ទាំងសាសន៍
ហើយសិរីល្អនៃទ្រង់ក៏ខ្ពស់ជាងផ្ទៃមេឃ[ឆ]
៥ តើមានអ្នកឯណាឱ្យដូចជាព្រះយេហូវ៉ា[ជ]
ជាព្រះនៃយើងខ្ញុំ ជាព្រះដែលគង់នៅ[ឈ] ស្ថានដ៏ខ្ពស់នោះ[ញ]
៦ ទ្រង់ឱនព្រះនេត្រ ដើម្បីទតមើល[ដ] ផ្ទៃមេឃ នឹងផែនដី
៧ ទ្រង់លើកមនុស្សក្រីក្រ[ឋ] ឡើងចេញពីធូលីដី
ហើយមនុស្សកំសត់ទុគ៌ត[ឌ] ចេញពីគំនរសំរាម
៨ ដើម្បីនឹងតាំងឱ្យគេ[ឍ] អង្គុយជាមួយនឹងពួកអ្នកធំគឺជាមួយនឹង
ពួកអ្នកធំនៃរាស្ត្រទ្រង់
៩ ទ្រង់ក៏ប្រោសឱ្យស្រីអារ[ណ] បានផ្ទះសំបែង ហើយឱ្យមានកូន
ដោយរីករាយវិញចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។

**១១៣:២** គ ទដ ៣០:៤ ៤៨:១០ ១៤៥:២១ ១៤៨:១៣ ១៤៩:៣ អស ១២:៤ ឃ ទដ ១១៥:១៨ ១៣១:៣ ដយ ២:២០ **១១៣:៣** ង អស ២៤:១៥ ៤៥:៦ ៥៩:១៩ មឡ ១:១១ **១១៣:៤** ច ទដ ៩៩:២ ឆ ទដ ៨:១ ៥៧:១១ **១១៣:៥** ជ នក ៨:១០ ទដ ៣៥:១០ ឈ ទដ ១០៣:១៩ ញ យប ១៦:១៩ **១១៣:៦** ដ ទដ ១១:៤ ១៣៨:៦ អស ៥៧:១៥ **១១៣:៧** ឋ ១សយ ២:៨ ទដ ៣៥:១០ ៦៨:១០ ១៤០:១២ ឌ ទដ ១០៧:៤១ **១១៣:៨** ឍ ២សយ ៩:១១ **១១៣:៩** ណ ១សយ ២:៥ **១១៤:១** ក នក ១៣:៣ ២៩:៤៦

## ១១៤ កាលសាសន៍អ៊ីស្រាអែល បានចេញពីស្រុក អេស៊ីព្ទ[ក] គឺកាលពូជពង្សនៃយ៉ាកុប បានចេញពីសាសន៍

ចម្រៀងនាងម៉ារា (លក ១:៤៦–៥៥) ។ ក៏មានវគ្គប្រហែលៗគ្នាបី (វគ្គនិមួយៗមានបីខ) ដែលធ្វើឱ្យបទទំនុកច្រៀងស៊ីគ្នារណ្តំចិត្ត ។ ក៏មាន៧ខរួមទាំងអស់ដែលអ្នកនិពន្ធតែងសម្រាប់សរសើរព្រះមានក្នុងវគ្គទី២ និងទី៣ (មានដូចជាពាក្យ "ទ្រង់ស្ថិតនៅទីខ្ពស់" "ដែលគង់នៅ . . . ស្ថានដ៏ខ្ពស់" "ឱនព្រះនេត្រ" "ទ្រង់លើក" "តាំងឱ្យគេអង្គុយ" "ប្រោសឱ្យស្រីអារមានផ្ទះសំបែង") ក៏សូមចំណាំពីការសរសើរបួនបែបនៅក្នុងវគ្គដំបូង ។ នៅចំកណ្តាលវគ្គ (ខ.៥ មើលការពន្យល់ ៦:៦) ។

**១១៣:១** *ព្រះនាមព្រះយេហូវ៉ា* សូមមើល ខ.២–៣ ។ គឺជាការសរសើរដដែលៗបីដងដែលជាទំនៀមទម្លាប់ជាទូទៅ គឺពួកគេតែងតែនិយាយពីព្រះនាមព្រះយេហូវ៉ាច្រើនដង (សូមមើលការពន្យល់ ៩៦:១–៣) ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**១១៣:២** *ចាប់តាំងពីឥឡូវនេះ ដរាបដល់អស់កល្បតទៅ* គឺជាការសរសើររបស់អ្នកណាដែលបានផ្ញើចិត្តសរសើរដល់ព្រះ ដោយពុំមានការរអាក់រអួល រហូតដល់ពេលកំណត់ សូមមើល ខ.៣ ។

**១១៣:៣** ជាស្នាដៃរបស់អ្នកនិពន្ធបទទំនុក ដែលមានបែបផែនជាលក្ខណៈបូរាណដែលបង្ហាញពីបរិយាកាស ឬទំនៀបទម្លាប់ទូទៅនាសម័យនោះ ។ ដូចជាសិបុត្ររបស់ពួកកាណាន ដែលអានដូចខាងក្រោម អ៊ូ ព្រះមហាក្សត្រជាព្រះយេហូវ៉ានៃទូលបង្គំអើយ ដោយទ្រង់បានតាំនាមទ្រង់នៅឯទិលថ្ងៃរះ ហើយរហូតដល់ទិសដែលថ្ងៃលិចដែរ (ទដ ១៣៩:៩ និងការពន្យល់)។

**១១៣:៤** សូមមើល សេចក្តីសម្អាងនៅក្នុង ៥៧:៥,១១ ។ *ស្ថិតនៅលើទីខ្ពស់លើគ្រប់ទាំងសាសន៍* ដោយវាទព្រះចេស្តាលើអស់ទាំងរូបព្រះ (សូមមើល ៩៥:៣ ៩៦:៤–៥ ៩៧:៩ សូមមើល ៤៧:២,៧–៨) ។ ដោយព្រោះមានមនុស្សជាច្រើនបានទទួលសេចក្តីសង្គ្រោះពីទ្រង់ (១១៨:២៨) ដោយបទភ្លេងទំនុកដំកើង"បទទំនុក" ។ *នៃទ្រង់ក៏ខ្ពស់ជាងផ្ទៃមេឃ* គឺលើអស់ទាំងអ្វីៗដែលព្រះបានបង្កើតមក (សូមមើល ខ.៦ ១៤៨:១៣) ។

**១១៣:៥** គឺជាផ្នែកកណ្តាលនៃសាច់រឿង (សូមមើល ៦:៦) ។ *ព្រះយេហូវ៉ាជាព្រះនៃយើង* គឺអ្វីៗដែលជាព្រះគុណដែលមានចែងក្នុងសេចក្តីសញ្ញាគឺជាព្រះ"នៃយើង" (សូមមើល លប ១៧:៧ នក ១៩:៥–៦ ២០:២) ។

**១១៣:៧–៩** គឺព្រះយេហូវ៉ាបានលើកមនុស្សទាល់ក្រ និងមនុស្សកំសត់ឡើងខ្ពស់ ។ ដោយព្រះមានគ្រប់តេជះ ដ៏ខ្ពង់ខ្ពស់មិនចងសម្ព័ន្ធជាមួយអ្នកមានអំណាចខ្ពង់ខ្ពស់ក្នុងលោកីយទេ តែទ្រង់បានឈរជាមួយមនុស្សកំសត់ខ្វះខាត និងលើកពួកគេឱ្យឡើងខ្ពស់វិញ (មើល ១សយ ២:៣–៨ លក ១:៤៦–៥៥) មើល ទដ ១១៨ ។

**១១៣:៧–៨** គឺជាការបង្ហាញឱ្យឃើញភាពត្រង់ៗចេញពី ១សយ ២:៨ ។

**១១៣:៧** *មនុស្សក្រីក្រ . . . មនុស្សកំសត់ទុគ៌ត* សូមមើល ៩:១៨ ៣៤:៦ និងការពន្យល់ ។ *ពីធូលីដី . . . ពីគំនរសំរាម* ក៏បង្ហាញពីស្ថានភាពបន្ទាបខ្លួន (សូមមើល ១៨:២៧ ១ពវ ១៦:២) ប៉ុន្តែក៏ជាការបង្ហាញពីភាពទុក្ខព្រួយក្រៀមក្រំយ៉ាងខ្លាំង និងមានភាពកំសត់ (សូមមើល យប ៣០:១៦ ៤២:៦ អស ៤៧:១ យរ ២៥:៣៤) ។

**១១៣:៩** *ស្រីអារ* នៅក្នុងសង្គមបុរាណ ភាពជាស្រីអារគឺមានការឈឺចាប់យ៉ាងខ្លាំង និងមានភាពសោកនាដកម្មយ៉ាងសំបើម ។ ចំពោះស្ត្រីមានវ័យចំណាស់ក៏រសក្នុងស្ថានភាពឯកកោដូចជានាងន៉ាអូមី ដែលពុំមាននណាម្នាក់ទទួលនាង (សូមមើល នរ ១:១១–១៣ ២ពវ ៤:១៤) ។ *ផ្ទះសំបែង* គឺទាក់ទងក្នុងរង្វង់គ្រួសារបងប្អូន ។ *រីករាយ* ជាសេចក្តីអំណរដែលព្រះបានប្រទានឱ្យស្ត្រីអារអាចមានកូន ដោយអំណាចព្រះចេស្តាទ្រង់ ដូចជាករណីជីវិតរបស់នាងសារ៉ាជាឈ្មោះថ្មីរបស់ប្រពន្ធលោកអ័ប្រាហាំ (មើល លប ២១:២) នាងរេបិកា (សូមមើល លប ២៥:២១) នាងរ៉ាជែល (សូមមើល លប ៣០:២៣) នាងហាណា (សូមមើល ១សយ ១:២០ និង ២ពវ ៤:១៧)។

**ទដ ១១៤** គឺជាផ្នែកនៃបទទំនុកចំរៀងដើម្បីធ្វើពិធីចេញដំណើរ ក៏ជាបទទំនុកទី២នៅក្នុង"បទចំរៀងជាតិសាសន៍អេស៊ីព្ទ" (សូមមើលសេចក្តីផ្តើម ទដ ១១៣–១១៨) ។ គឺជាបទទំនុកល្អដាច់គេ ឯបទទំនុកនេះគឺបាននិពន្ធឡើងតាំងពីសម័យរាជាដែលនគរបានបែកបាក់គ្នា (មើល ខ.២) បទទំនុកនេះបានតែងឡើងគឺសម្រាប់ប្រើក្នុងព្រះវិហារ ដើម្បីទុកច្រៀងក្នុងបុណ្យសាសនាប្រចាំឆ្នាំនិមួយៗ (សូមមើល សេចក្តីផ្តើម ទដ ១១៣) ។ គឺវាបង្ហាញពីផ្ទៃរឿងដែលដំណើរការទៅ ដោយឆ្លងកាត់វគ្គប្រហែលៗគ្នាបួនដែលជាផ្គុំអត្ថន័យរួមក្នុងផ្នែកទាំងបួននោះ ។ ឯវគ្គពីរដំបូង (ខ.១–៤) បង្ហាញពីព្រឹត្តិការដ៏អស្ចារ្យ នៃការបានចេញដំណើរ ឯវគ្គពីចុងក្រោយ (ខ.៥–៨) ក៏បង្ហាញពីផ្ទៃរឿងសំខាន់ៗតាមលំដាប់លំដោយរបស់វា ។

**១១៤:១–២** ជាគ្រាសញ្ញាចាស់ដ៏អស្ចារ្យមួយដែលបង្ហាញ ពីព្រឹត្តិការនៃការលោះបាប ។

**១១៤:១** *សាសន៍អ៊ីស្រាអែល . . . ពូជពង្សយ៉ាកុប* ជាការប្រើពាក្យ ដែលមានទិសន័យ(ន័យស្មើ) (សូមមើលក្នុង នក ១៩:៣) ។ *បានចេញពីស្រុកអេស៊ីព្ទ*

ដែលមានភាសាទីទៃ
២នោះពួកយូដា[ខ]បានត្រឡប់ជាទីបរិសុទ្ធ[គ]របស់ទ្រង់
ហើយពួកអ៊ីស្រាអែលបានធ្វើជាអាណាខេត្តរបស់ទ្រង់
៣សមុទ្របានឃើញ ហើយក៏រត់បាត់ទៅ[ឃ]
ទន្លេយ័រដាន់ក៏ហូរថយច្រាសវិញ[ង]
៤អស់ទាំងភ្នំធំៗ ក៏លោត[ច]ដូចជាចៀមឈ្មោល
ហើយភ្នំតូចៗដូចជាកូនចៀម
៥ឱសមុទ្រអើយ តើវាថ្វី បានជារត់ទៅដូច្នេះ[ឆ]
ហើយទន្លេយ័រដាន់ឯងដែរបានជាហូរថយច្រាសទៅ
៦នឹងអស់ទាំងភ្នំធំៗអើយ បានជាលោតដូចជាចៀមឈ្មោល
ហើយឯងដែរ ភ្នំតូចៗអើយ បានជាលោតដូចជាកូនចៀម
ដូច្នេះ
៧ឱផែនដីអើយ[ជ]ចូររញ្ជួររន្ធត់នៅ ចំពោះព្រះអម្ចាស់
គឺនៅចំពោះព្រះនៃយ៉ាកុបចុះ
៨ជាព្រះដែលធ្វើឱ្យថ្មដាប្រែទៅជាត្រពាំងទឹក
គឺថ្មរឹងឱ្យទៅជាក្បាលទឹកហូរ[ឈ] ។

*១១៥:៤–១១ – ទដ ១៣៥:១៥–២០*

**១១៥** មិនមែនយើងខ្ញុំ ឱព្រះយេហូវ៉ាអើយមិនមែនយើង
ខ្ញុំដែលគួរលើកដំកើងទេ សូមទ្រង់លើកដំកើងព្រះនាមនៃ
ទ្រង់វិញ[ក] ដោយយល់ដល់សេចក្ដីសប្បុរសនិងសេចក្ដីពិត
ត្រង់របស់ទ្រង់[ខ]
២តើមានទំនងអ្វីឱ្យពួកសាសន៍ដទៃសួរថាតើព្រះគេនៅឯ
ណា[គ]
៣ចំណែកព្រះនៃយើងខ្ញុំ ទ្រង់គង់នៅស្ថានសួគ៌[ឃ]ទ្រង់បាន

**១១៤:២** ខ ទដ ៧៦:១ គ នក ១៥:១៧ ទដ ៧៨:៦៨–៦៩ **១១៤:៣** ឃ នក ១៤:២១ ទដ ៧៧:១៦ ង នក ១៥:៨ យស ៣:១៦ **១១៤:៤** ច ពច ៥:៥ **១១៤:៥** ឆ នក ១៤:២១ **១១៤:៧** ជ នក ១៥:១៤ ១រប ១៦:៣០ **១១៤:៨** ឈ នក ១៧:៦ ជន ២០:១១ **១១៥:១** ក ទដ ២៩:២ ៦៦:២ ៩៦:៨ ខ នក ៣៤:៦ **១១៥:២** គ ទដ ៤២:៣ **១១៥:៣** ឃ អរ ៥:១១ នហ ១:៤ ទដ ១០៣:១៩ ១៣៦:២៦ មថ ៦:៩

គឺគេថាការចេញដំណើរ និងព្រឹត្តការដ៏អស្ចារ្យនៃការធ្វើដំណើរនៅឯវាលរហោស្ថាន ។

**១១៤:២** *ពួកយូដា . . . ពួកអ៊ីស្រាអែល* គឺជាប្រជាជននៅឯនគរខាងត្បូងនិងខាងជើងដែលបង្ហាញនៅក្នុងខនេះគឺជារាស្ត្ររបស់ព្រះតែមួយ ។ *បានត្រឡប់ជា* គឺសំដៅទៅលើព្រឹត្តិការដ៏ចាំបាច់ដែលបានតាំងជាសេចក្ដីសញ្ញាឡើងនៅឯភ្នំស៊ីណាយ ដែលជាទីកន្លែងពួករាស្ត្រអ៊ីស្រាអែលបានភ្ជាប់ទំនាក់ទំនងជាមួយព្រះយេហូវ៉ា ដែលមានលក្ខណៈនគរនៃពួកសង្ឃ និងជាជាតិសាសន៍ដ៏បរិសុទ្ធ (នក ១៩:៣–៦) ។ ពាក្យថា *ព្រះនៃ* គឺ(របស់ផងទ្រង់) "គឺអ្វីៗមានពីមុនមក" (ខ.៧) ។ *ទីបរិសុទ្ធ* គឺជាព្រះវិហារទ្រង់ ដែលទ្រង់ប្រើជាព្រះរាជដំណាក់នៅនាលោកីយនេះ ក៏មាននៅរោងឧបោសថតែក្រោមមកមានលក្ខណៈជាព្រះវិហារវិញ ។ មានក្នុង នក ១៥:១៧ ។ ក៏មានទឹកដីសន្យាក៏បានហៅថា ជាទីបរិសុទ្ធរបស់ទ្រង់ដែរ ។ *អាណាខេត្ត* គឺព្រះរាជាណាចក្រដ៏ពិសេសទាំងមូល ដែលទ្រង់គ្រងរាជជាស្តេច ។ គឺធំជាងស្រុក ដែលពួកគេកំពុងធ្វើដំណើរទៅ គឺដោយសារតែភាពគួរឱ្យស្ញែងនៃព្រះគុណទ្រង់ ។

**១១៤:៣–៤** អ្នកនិពន្ធក៏បានប្រកាសប្រកូកពីឈុតឆាក ដែលគួរឱ្យរន្ធតខ្លាចពីព្រះចេស្ដារបស់ទ្រង់ដូចជាក្នុងវគ្គកំពាព្យខ្លះទៀត (សូមមើល ១៨:៧–១៥ ៦៨:៧–៨ ៧៧:១៦–១៩ ពច ៥:៤–៥) ។

**១១៤:៣** *សមុទ្រ . . . ទន្លេយ័រដាន់* ក៏មានទន្លេក្រហមនិងទន្លេយ័រដាន់ ដែលព្រះយេហូវ៉ាបាននាំរាស្ត្ររបស់ទ្រង់ដើរឆ្លងកាត់ទន្លេទាំងនោះ ។ *បានឃើញហើយក៏រត់បាត់ទៅ* គឺបានឃើញព្រះអម្ចាស់ដែលមានគ្រប់ព្រះចេស្ដាបានបង្ហាឱ្យឃើញនៅក្នុងសរសរពពកដែលគួរឱ្យរន្ធត់ហើយបាត់ទៅ ។

**១១៤:៤** *លោត* ឬ"ជាការលោតជើងមួយ" គឺដូចជាតូចឬធំក៏ញ័ររន្ធត់យ៉ាងខ្លាំងចំពោះវត្តមានទ្រង់ (២៩:៦) ។

**១១៤:៧–៨** ព្រះយេហូវ៉ាក៏ជាព្រះនៃថ្ងៃស្អែក (ខ.៥–៦) ព្រះនៃយ៉ាកុបក៏គង់សណ្ឋិតជាមួយយើងទាំងអស់គ្នា ។

**១១៤:៨** *គឺថ្មរឹងឱ្យទៅជាក្បាលទឹកហូរ* គឺឱ្យមានគ្រប់ទាំធាតុ និងមានជីវិតរស់ដោយស្រស់ថ្លា (សូមមើល នក ១៧:៦ ជន ២០:១១) ។

**១១៥** គឺជាបទទំនុកទី៣ក្នុង"ទំនុកបទចម្រៀងពួកអេស៊ីព្ទ" (សូមមើលសេចក្ដីផ្ដើម ទដ ១១៣–១១៨) គឺជាការសរសើរដល់ព្រះយេហូវ៉ា គឺជាព្រះក៏ពិតដោយព្រោះសេចក្ដីស្រឡាញ់របស់ផងទ្រង់ និងសេចក្ដីសប្បុរសរបស់ទ្រង់ចំពោះរាស្ត្រទ្រង់ ។ គឺបទទំនុកនោះហើយ ដែលបានរៀបចំឡើងមានលក្ខណៈជាបទទំនុកសរសើរ សម្រាប់ថ្វាយបង្គំក្នុងព្រះវិហារ ។ ជាពិសេសបទទំនុកនេះក៏បាននិពន្ធដើម្បីប្រើក្នុងការថ្វាយព្រះវិហារទីពីរដល់ព្រះដើម្បីសម្រាប់ថ្វាយបង្គំ (សូមមើល អគ ៦:១៦) គឺក្នុងខណៈពេលដែលរាស្ត្រអ៊ីស្រាអែលមានជីវិតរស់ឡើងវិញបន្ទាប់ពីពេលត្រូវគេបំបោះបំបង់ ។ សូមមើលសេចក្ដីផ្ដើម ទដ ១១៣ សូមមើល (១).ខ.១–៨ ពីប្រជាជន (២).ខ.៩–១១ ពីថ្នាក់ដឹកនាំ (៣).ខ.១២–១៣ ពីប្រជាជន (៤).ខ.១៤–១៥ ពីពួកសង្ឃ (៥).ខ.១៦–១៨ ពីប្រជាជន ។

**១១៥:១–៨** ជាឃ្លាពីការសរសើរដល់ព្រះពីសេចក្ដីស្រឡាញ់របស់ទ្រង់ និងសេចក្ដីសប្បុរសដែរទ្រង់មានចំពោះរាស្ត្រទ្រង់ ដែលកំពុងស្ថិតក្នុងភាពស្ងាត់ស្ងៀម ។

**១១៥:១** *មិនមែនយើងខ្ញុំ . . . មិនមែនយើងខ្ញុំ* គឺជាការផ្ដើមពីការអធិស្ឋានលន់តួអំពើបាប ។ ដោយព្រោះរាស្ត្រអ៊ីស្រាអែលនៅរស់ ក៏មានជីវិតងើបឡើងវិញមិនមែនពីការបានដោយសារពួកគេខំប្រឹងប្រែងនោះទេ ។ *ព្រះនាមទ្រង់* សូមមើលការពន្យល់ ៥:១១ ។ *ដល់សេចក្ដីសប្បុរស និងសេចក្ដីពិតត្រង់របស់ទ្រង់* គឺជាសេចក្ដីអធិប្បាយនៃគ្រាសញ្ញាចាស់ ដែលជាលក្ខណៈទូទៅចំពោះអត្ថប្រយោជន៍ពីសេចក្ដីសញ្ញារបស់ព្រះ (សូមមើលការពន្យល់ ២៦:៣) ។ *សេចក្ដីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**១១៥:២** *តើព្រះគេនៅឯណា* គឺជាពាក្យសម្ដីនិយាយឡកឡឺយខណៈពេលដែលរាស្ត្រអ៊ីស្រាអែលទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ដោយសារគ្រោះធម្មជាតិ (សូមមើល យអ ២:១៧) ឬក៏បំផ្លាញដោយសត្រូវ ជាពិសេសក្នុងគ្រាពួកយ៉ូដាត្រូវគេបំផ្លាញ ហើយវិហាររបស់ព្រះក៏ត្រូវគេរុះចោល ។ (សូមមើល ៧៩:១០ មីក ៧:១០) ។

**១១៥:៣** *ទ្រង់គង់នៅស្ថានសួគ៌* គឺគង់ក្នុងបល្ល័ង្ក (សូមមើល ១១២:៥) "គឺក្នុងស្ថានសួគ៌ដ៏ខ្ពស់បំផុត" (ខ.៦) ។ *ការដែលគាប់ដល់ព្រះហឫទ័យទ្រង់* គឺ

ធ្វើការដែលគាប់ដល់ព្រះហឫទ័យទ្រង់ហើយ[ង]
៤ឯព្រះរបស់គេ នោះសុទ្ធតែជារូប ធ្វើពីប្រាក់នឹងមាស[ច]
ជាស្នាដៃដែលមនុស្សធ្វើ[ឆ] ៥រូបទាំងនោះមានមាត់
តែមិនចេះនិយាយ[ជ] មានភ្នែកតែមើលមិនឃើញ
៦មានត្រចៀក តែស្តាប់មិនឮ មានច្រមុះ តែធុំក្លិនមិនបាន
៧មានដៃ តែចាប់កាន់មិនបាន
មានជើងតែមិនចេះដើរឡើយ
ក៏មិនចេះបញ្ចេញសំឡេងតាមបំពង់កផង
៨ជាងដែលធ្វើ អើ អស់អ្នកដែលទុកចិត្តនឹងរូបទាំងនោះ
គេនឹងបានដូចជារូបនោះដែរ
៩ឱអ៊ីស្រាអែលអើយ ចូរទុកចិត្ត[ឈ]នឹងព្រះយេហូវ៉ាចុះ
ទ្រង់ជាអ្នកជួយ និងជាខែលរបស់ឯង
១០ឱពួកវង្សអ៊ើរ៉ុនអើយ[ញ] ចូរទុកចិត្តនឹងព្រះយេហូវ៉ាចុះ
ទ្រង់
ជាអ្នកជួយ និងជាខែលរបស់ឯង
១១ឱពួកអ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ាអើយ[ដ] ចូរទុក
ចិត្តនឹងព្រះយេហូវ៉ាចុះទ្រង់ជាអ្នកជួយនឹងជាខែលរបស់
ឯង
១២ព្រះយេហូវ៉ាទ្រង់បាននឹកចាំ[ឋ]ពីយើងខ្ញុំទ្រង់នឹងប្រទាន
ពរពិត ទ្រង់នឹងប្រទានពរដល់ពួកវង្សអ៊ីស្រាអែល[ឌ] ទ្រង់
នឹងប្រទានពរដល់ពួកវង្សអ៊ើរ៉ុន
១៣ទ្រង់នឹងប្រទានពរដល់អស់អ្នក ទាំងតូចទាំងធំ ដែល
កោតខ្លាច[ឍ]ព្រះយេហូវ៉ា
១៤សូមព្រះយេហូវ៉ាចំរើនឯងរាល់គ្នា ឱ្យកាន់តែច្រើន
ឡើង[ណ]គឺឯងរាល់គ្នា ហើយនិងកូនចៅរបស់ឯងរាល់
គ្នាផង
១៥ឯងរាល់គ្នាបានពរពីព្រះយេហូវ៉ា ជាព្រះដែលបាន
បង្កើតផ្ទៃមេឃ[ត] និងផែនដី
១៦ឯស្ថានសួគ៌ គឺជាស្ថានរបស់ព្រះយេហូវ៉ា[ថ] ចំណែក
ផែនដីវិញ នោះទ្រង់បានប្រគល់[ទ]ដល់មនុស្សជាតិ
១៧មនុស្សស្លាប់[ធ]រមែងមិនសរសើរដល់ព្រះយេហូវ៉ាទេព្រម
ទាំងមនុស្សដែលចុះទៅនៅឯស្ថានស្ងាត់ឈឹងផង
១៨តែចំណែកយើងខ្ញុំ នឹងសូមឱ្យព្រះយេហូវ៉ា[ន]បានប្រកប
ដោយព្រះពរ ចាប់តាំងពីឥឡូវនេះ ដរាបដល់អស់កល្ប
តទៅ[ប]ចូរសរសើរដល់ព្រះយេហូវ៉ាចុះ[ផ]។

**១១៦** ខ្ញុំស្រឡាញ់ព្រះយេហូវ៉ា[ក] ដ្បិតទ្រង់តែងស្តាប់
សំឡេង[ខ]ខ្ញុំ និងពាក្យដែលខ្ញុំទូលអង្វរ[គ]

**១១៥:៣** ង ទដ ១៣៥:៦ **១១៥:៤** ច វវ ៩:២០ ឆ ២ពវ ១៩:១៨ ២រប ៣២:១៩ យរ ១០:៣–៥ កច ១៩:២៦ **១១៥:៥** ជ យរ ១០:៥ **១១៥:៩** ឈ ទដ ៣៧:៣ ៦២:៨ **១១៥:១០** ញ នក ៣០:៣០ ទដ ១១៨:៣ **១១៥:១១** ដ ទដ ២២:២៣ ១០៣:១១ ១១៨:៤ **១១៥:១២** ឋ ១រប ១៦:១៥ ឌ លប ១២:២ **១១៥:១៣** ឍ ទដ ១១២:១ **១១៥:១៤** ណ ចទ ១:១១ **១១៥:១៥** ត លប ១:១ កច ១៤:១៥ វវ ១០:៦ **១១៥:១៦** ថ ទដ ៨៩:១១ ទ លប ១:២៨ ទដ ៨:៦–៨ **១១៥:១៧** ធ ទដ ៨៨:១០–១២ **១១៥:១៨** ន ទដ ១១១:១ ប ទដ ១១៣:២ ផ ទដ ២៨:៦ ៣៣:២ ១០៣:១ **១១៦:១** ក ទដ ១៨:១ ខ ទដ ៣១:២២ ៤០:១ គ ទដ ៦:៩ ២៨:២

បើសិនជារាស្ត្រអ៊ីស្រាអែលត្រូវបានវិនាសនោះ ក៏ជាទង្វើនៃព្រះរបស់យើងដើម្បីបំផ្លាញដល់អ្នកដែលថ្វាយបង្គំរូបព្រះ ហើយគ្មានអំណាចរូបព្រះណាមួយអាចប្រឆាំងនិងព្រះអម្ចាស់បានឡើយ ។

**១១៥:៤–៧** គឺជាអំណាចនៃរូបព្រះទាំនោះដែលជាព្រះក្លែងក្លាយ (គ្រាន់តែជានិមិត្តរូបមួយក្នុងលក្ខណៈជារូបភាពដែលជាដំណាងឱ្យវិញ្ញាណអាក្រក់ឯពួករូបព្រះទាំងនោះ គឺជាវិញ្ញាណអាក្រក់ដែលគ្រាន់តែជាសេចក្តីស្រម៉ៃរបស់មនុស្សដែលបង្កើតឡើងដើម្បីពួកគេគោរពវត្ថុគ្មានប្រយោជន៍ទទេ សូមមើល ១៣៥:១៥–១៨ អស ៤៦:១–៧) ។

**១១៥:៨** *ជាងដែលធ្វើ* គឺជាពូជសាសន៍ដែលធ្វើរូបព្រះទាំងនោះគេតែងតែនិយាយឡកឡឺយដល់ព្រះនាមព្រះនិងរាស្ត្ររបស់ទ្រង់ ។ (ធៀបនិង ខ.២) *គេនិងបានដូចជារូបនោះដែរ* សូមមើល អស ៤៤:៩–២០ ។

**១១៥:៩–១១** គឺការត្រាស់ហៅដើម្បីទុកចិត្តដល់ព្រះយេហូវ៉ា មិនមែនទុកចិត្តលើរូបព្រះទេ (សូមមើល ខ.៨) ។ គឺជាការនិយាយឡើងវិញចំនួនបីដងជាសេចក្តីសន្ទត់បែបផែនអក្សរសាស្ត្រ សូមមើលការពន្យល់ ៩៦:១–៣ ។

**១១៥:១១** *អ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ា* (សូមមើល ១ពវ ៨:៤១–៤៣ អក ៦:២ នហ ១០:២៨) ។

**១១៥:១២–១៣** ការលន់តួបាបរបស់ប្រជាជនចំពោះសេចក្តីពិត ។

**១១៥:១៤–១៥** ជាព្រះពរដល់កូនចៅទ្រង់ ។

**១១៥:១៤** *ចំរើន* គឺឱ្យមានកាន់តែច្រើនឡើងទាំងទ្រព្យសម្បត្តិនិងកម្លាំង (ធៀបនិង សស ២:៩) ។

**១១៥:១៦–១៨** ជាសេចក្តីបទទំនុកច្រៀងសរសើរ ។

**១១៥:១៦** *ឯស្ថានសួគ៌ . . . ផែងដី* គឺជាទីមួយដែលមានវត្តមានព្រះអម្ចាស់សម្រាប់មនុស្ស ដែលជារាស្ត្រទ្រង់រស់ក្រោមក្រឹត្យច្បាប់របស់ព្រះគេសប្បាយនិងព្រះពរដ៏ហៀរបរិបូរ (ខ.១២–១៣,១៨) ។

**១១៥:១៧** *មនុស្សស្លាប់រមែងមិនសរសើរ* គឺមនុស្សស្លាប់ក៏លែងមានក្នុង "លោកកីយនេះហើយ" (ខ.១៦) តែពួកគេបានចុះទៅស្ថានស្ងាត់ជ្រងំនៅខាងក្រោមវិញលែងទាំងមានសេចក្តីអំណរ ហើយការសរសើរក៏លែងមាន (សូមមើលការពន្យល់ ៦:៥ ៣០:១) ។

**ទដ ១១៦** ជាការសរសើរដល់ព្រះយេហូវ៉ា ដើម្បីសុំការលោះចេញពីសេចក្តីស្លាប់ ។ ជាឃ្លាដែលបានកត់ត្រាដោយព្រះមហាក្សត្រ (សូមមើល ខ.១៦ និងការពន្យល់ ធៀបនិងការអរព្រះគុណរបស់ស្តេចអេសេគាល អស ៣៨:១០–២០) ។ សេចក្តីសរសើរនេះក៏បានប៉ះទៅនិងបទទំនុករបស់ស្តេចដាវីឌផងដែរ គឺតាមបែបអក្សរសាស្ត្រនៃពួកយូដា (សូមមើល សេចក្តីផ្តើម ទដ ១១៣–១១៨) ការសរសេរឃ្លានេះមានលក្ខណៈសព្វនាមជាបុគ្គលឯកវចនៈត្រូវគេប្រើជាលក្ខណៈរួម សូមមើលការពន្យល់ ទដ ដែលមានចំណងជើង ៣០ ។ ឯអ្វីដែលទាក់ទងនិង "សេចក្តីស្លាប់" ប្រៀបដូចជាការជាប់ចំណងនៅស្រុកអេស៊ីព្ទ ឬការដែលគេបានបោះបង់ចេញទៅ ។

ឯសំណង់ឃ្លាពីគម្ពីរទំនុកដំកើង គឺរៀបចំឡើងដែលមានពាក់កណ្តាលជាផ្នែកទី២ (ខ.១០–១៩) បានឆ្លុះបង្ហាញពីភាគពាក់កណ្តាលដំបូង (ខ.១–៩) នៃគ្រីស្ទបរិស័ទនាសម័យដើម ដែលបកប្រែពីភាសាក្រិចនៃគ្រាសញ្ញាចាស់ ក៏បានចែកបទទំនុកនេះជាពីផ្នែក ។ ឯផ្ទៃរឿងជាមូលដ្ឋានគ្រិះគឺបានអភិវឌ្ឍន៍ទៅជាសេរី (ខ.១–២,៣–៤,៥–៦,៨–៩,១០–១១,១៣–១៤,

២ហេតុព្រោះទ្រង់បានផ្ទៀងព្រះកាណ៌[ឃ]មកស្តាប់ខ្ញុំ បានជា
ខ្ញុំនឹងអំពាវនាវដល់ទ្រង់អស់១ជីវិត
៣ចំណងនៃសេចក្តីស្លាប់[ង] បានរុំព័ទ្ធខ្ញុំ
ហើយសេចក្តីឈឺចាប់ នៃស្ថានឃុំព្រលឹងមនុស្សស្លាប់បាន
ចាប់ខ្ញុំ ខ្ញុំក៏កើតមានទុក្ខវេទនា និងព្រួយបារម្ភ
៤នោះខ្ញុំបានអំពាវនាវដល់ព្រះនាម[ច]ព្រះយេហូវ៉ាថា
ឱព្រះយេហូវ៉ាអើយ ទូលបង្គំសូមអង្វរដល់ទ្រង់
សូមប្រោសព្រលឹងទូលបង្គំឱ្យរួចផង[ឆ]
៥ព្រះយេហូវ៉ាទ្រង់ប្រកប ដោយសេចក្តីមេត្តាករុណា
និងសេចក្តីសុចរិត[ជ] អើ ព្រះនៃយើងខ្ញុំ
ទ្រង់មានសេចក្តីអាណិតអាសូរ[ឈ]
៦ព្រះយេហូវ៉ាទ្រង់ជួយទំនុកបំរុងមនុស្សឆោតល្ងង់
ឯខ្ញុំក៏បានត្រូវគេបន្ទាបន្ថោកម្តង[ញ]ហើយទ្រង់បានជួយ
សង្គ្រោះខ្ញុំ[ដ]
៧ឱព្រលឹងខ្ញុំអើយ ចូរត្រឡប់ទៅឯទីសំរាក[ឋ]របស់ខ្លួនវិញ

**១១៦:២** ឃ ទដ ៥:១
**១១៦:៣** ង ២សយ ២២:៦ ទដ ១៨:៤–៥
**១១៦:៤** ច ទដ ៨០:១៨ ១១៨:៥ ឆ ទដ ៨០:២
**១១៦:៥** ជ នក ៩:២៧ ២រប ១២:៦ អរ ៩:១៥ ឈ នក ២២:២៧ ទដ ៨៦:១៥
**១១៦:៦** ញ ទដ ៧៩:៨ ដ ទដ ១៨:៣ ២២:៥ ១០៧:១៣
**១១៦:៧** ឋ ទដ ៨៦:១០ ៦២:១ ១៣១:២ មថ ១១:២៩ ឌ ទដ ១៣:៦ ១០៦:១ ១៤២:៧

ដ្បិតព្រះយេហូវ៉ា ទ្រង់បានប្រព្រឹត្ត ដោយគុណដ៏ប្រសើរ[ឌ]
៨គឺទ្រង់បានប្រោសជីវិតខ្ញុំ[ឍ]ឱ្យរួចពីស្លាប់ និងឱ្យខ្ញុំរួចពីការ
ស្រក់ទឹកភ្នែក ហើយឱ្យជើងខ្ញុំរួចពីការចំពប់ដួលផង
៩ខ្ញុំនឹងដើរនៅចំពោះព្រះយេហូវ៉ា[ណ]នៅក្នុងស្ថាននៃមនុស្ស
រស់[ត]
១០ខ្ញុំបានជឿ[ថ]ហើយ បានជាខ្ញុំថា ខ្ញុំមានទុក្ខខ្លាំងណាស់[ទ]
១១ក្នុងការរួសរាន់របស់ខ្ញុំ នោះខ្ញុំបានថាមនុស្សទាំងអស់
សុទ្ធតែភូតកុហក[ធ]
១២តើត្រូវឱ្យខ្ញុំយកអ្វីតបស្នងព្រះយេហូវ៉ា ចំពោះព្រះគុណ[ន]
ដែលទ្រង់បានផ្តល់មកខ្ញុំទាំងប៉ុន្មាន
១៣គឺខ្ញុំនឹងទទួលយកពែង នៃសេចក្តីសង្គ្រោះ
ហើយនិងអំពាវនាវដល់ព្រះនាម[ប]ព្រះយេហូវ៉ា

**១១៦:៨** ឍ ទដ ៨៦:១៣ **១១៦:៩** ណ លប ៥:២២ ទដ ៥៦:១៣ ៨៩:១៥ ត យប ២៨:១៣ ទដ ២៧:១៣ អស ៣៨:១១ យរ ១១:១៩ **១១៦:១០** ថ ២កថ ៤:១៣ ទ ទដ ៩:១៨ ៧២:២ ១០៧:១៧ ១១៩:៦៧,៧១,៧៥ **១១៦:១១** ធ ទដ ១០៣:២ ១០៦:១ **១១៦:១៣** ន ទដ ១០៥:១

១៥–១៦,១៧–១៩ ឯចុងក្រោយបង្អស់ក៏ភ្ជាប់ទៅជាបីៗឃ្លា) ។ (ខ.៧ មានចន្លោះរវាងវគ្គភ្ជាប់គ្នា ពីរចុងក្រោយនៃផ្នែកពាក់កណ្តាលវគ្គដំបូង) ។ ហើយ ខ.១២ (ចន្លោះរវាងវគ្គបន្តជាប់គ្នាពីរដំបូងនៃវគ្គពាក់កណ្តាលជួរទី២) គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ក្រោយមកទៀត ព្រះនាមព្រះដ៏បរិសុទ្ធគឺព្រះយ៉ាវេ ឬព្រះយេហូវ៉ា ក៏ប្រែសម្រួលមក ។

**១១៦:១–២** ខ្ញុំស្រឡាញ់ព្រះយេហូវ៉ា ពីព្រោះទ្រង់មានព្រះទ័យសង្គ្រោះខ្ញុំ ។

**១១៦:២** *ខ្ញុំនិងអំពាវនាវដល់ទ្រង់* ខ្ញុំទុកចិត្តនិងទ្រង់និងអធិស្ឋានជារៀងរហូតចំពោះទ្រង់ ។ "ខ្ញុំអំពាវនាវ" គឺជាពាក្យគន្លឹះ (ក្នុងភាសាហេព្រើរក៏មានទំរង់ដូចគ្នាក្នុងឃ្លានេះដែរ) ក៏មានលេចឱ្យឃើញពីដងក្នុងកណ្តាលនៃបទទំនុកនិមួយៗ (ខ.២,៤,១៣,១៧) ។

**១១៦:៣–៤** ជាការគំរាមកំហែងពីសេចក្តីស្លាប់ (សូមមើល ១៨:៤–៦) ។

**១១៦:៣** *ចំណែកនៃសេចក្តីស្លាប់* សូមមើលការពន្យល់ ១៨:៥ ។

**១១៦:៥** *សេចក្តីមេត្តាករុណា . . . សេចក្តីសុចរិត សេចក្តីអាណិតអាសូរ* សូមមើល ១៤៥:៨,១៧ ប្រៀបធៀប ១១២:៤ ។ *ព្រះនៃយើងខ្ញុំ* អ្នកនិពន្ធបាននិយាយផ្តោតសំខាន់លើពាក្យសំដីអ្នកដែលសរសើរ ឬអធិស្ឋានទៅរកព្រះក្នុងពេលមានវត្តមានដែលមានរាស្ត្ររបស់ទ្រង់ច្រើន (មើល ខ.១៤,១៨) ។

**១១៦:៦** *មនុស្សឆោតល្ងង់* គឺអ្នកដែលមានសណ្ឋានជាទារកក្នុងព្រះអម្ចាស់ដែលគេមានវិញ្ញាណពឹងផ្អែកលើតែសេចក្តីពិត ក្នុងព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ (សូមមើលការពន្យល់ ១៩:៧) ។

**១១៦:៧** *ឱព្រលឹងខ្ញុំអើយ ចូរត្រឡប់ទៅឯទីសំរាក់របស់ខ្លួនវិញ* "គឺបង្វែព្រលឹងរបស់ខ្ញុំទៅទីសម្រាកក្នុងទ្រង់" ។ គឺជាស្ថានភាពដែលឃ្លាតឆ្ងាយពីការគំរាមកំហែងដែលស្ថិតក្នុងភាពសុខសាន្ត (ប្រៀបធៀប យរ ៦:១៦ មើល ១ពរ ៥:៤ ក៏សូមមើលការពន្យល់ ១០៣:១–២–២២ ។ *ទ្រង់បានប្រព្រឹត្តដោយគុណដ៏ប្រសើរ* សូមមើល ខ.១២ និងការពន្យល់ ។

**១១៦:៨–៩** ពួកគេទទលបាននូវការប្រោសឱ្យរួចពីសេចក្តីស្លាប់ ដែលជាសេចក្តីល្អបានវិលមកពួកគេ មើល ខ.៣–៤ ។

**១១៦:៨** *ជីវិតខ្ញុំ* ពាក្យថាខ្ញុំ (សូមមើល ៦:៣) ។

**១១៦:១០** *ខ្ញុំបានជឿហើយ* អ្នកនិពន្ធបានផ្តើមនិយាយពីសេចក្តីជំនឿរបស់គាត់ បានប្តូរឱ្យគាត់បានបែររកព្រះយេហូវ៉ា ក៏អំពាវនាវរកទ្រង់ គឺខណៈដែលទ្រង់បានទទួលការគំរាមកំហែង ។ *ខ្ញុំមានទុកខ្លាំងណាស់* នេះជាសេចក្តីដកស្រង់ចេញខ្លះៗក្នុង ខ.១១ ក៏អាចយករួមក្នុង ខ.៤ បានជាការប្រមូលសង្ខេបពីការអធិស្ឋានខណៈពេលអ្នកនិពន្ធបទទំនុកជួបប្រទះសេចក្តីទុក្ខព្រួយយ៉ាងខ្លាំង ។ គឺពីការគំរាមកំហែងដល់ជីវិត ដោយសារតែការចោទប្រកាន់ខុសរបស់ពួកខ្មាំងសត្រូវ ដូចជាក្នុងគម្ពីរទំនុកដំកើង ១០៩ (សូមមើលការពន្យល់ ៥:៩ ១០:៩ ១០:៧) ។ ចំពោះសេចក្តីបកស្រាយមួយទៀត សូមមើលការពន្យល់ ដូចខាងក្រោម ។

**១១៦:១១** *មនុស្សទាំងអស់សុទ្ធតែភូតកុហក* គឺពួកគេមានចិត្តមានគំនិតចោទប្រកាន់រករឿង ហើយគេតែងតែមានលេខ ដើម្បីគ្របបាំងកំហុសគេ (ឧទាហារណ៌ សេចក្តីចោទប្រកាន់មានលក្ខណៈស្រដៀងនឹង ៥:៩–១០ ៣៥:១១,១៥ ១០៩:២–៣) ។ ក៏មានសេចក្តីបកស្រាយខ្លះទៀតដែលបកស្រាយពាក្យទាំងនេះ (សូមមើល ៦០:១១ ១១៨:៨–៩) ។

**១១៦:១២** *តើត្រូវឱ្យខ្ញុំយកអ្វីតបស្នងព្រះយេហូវ៉ា* តាមបែបអក្សរសាស្ត្រគឺ "តើខ្ញុំត្រូវប្រព្រឹត្តយ៉ាងដូចម្តេចចំពោះព្រះ " ។ *ព្រះគុណដែលទ្រង់បានផ្តល់* ជាភាសាហេព្រើរចំពោះពាក្យនេះ គឺមានឃើញតែក្នុងគ្រាសញ្ញាចាស់ទេតែវាជាពាក្យដែលតំណាងជាឫសគល់ជាមូលដ្ឋានគ្រឹះដូចគ្នា "គឺជាសេចក្តីល្អទាំងឡាយ" មានក្នុង ខ.៧ មាន ខ.៧,១២ ដែលជាអត្ថន័យរួមឬជាសកម្មភាពជាគន្លឹះក្នុងផ្ទៃរឿងគម្ពីរទំនុកដំកើងមូល ។

**១១៦:១៣–១៤** ចំលើយក្នុងសំណួរនេះគឺមានក្នុង ខ.១២ គឺដោយការថ្វាយដាច់ដល់ព្រះយេហូវ៉ា តាមរយៈពីការបង្ហាញនូវភក្តីភាពតស៊ូពុះពារ (ប្រៀបធៀបនឹង ខ.១៣–១៤,១៧,១៨ និង ៥០:១៤–១៥,២៣) ។

**១១៦:១៣** *ពែងនៃសេចក្តីសង្គ្រោះ* ជាទូទៅគឺទាក់ទងនឹងពិធីបុណ្យរំលងតាមសេចក្តីសំអាងលើ មថ ២៦:២៧ និងហេតុការណ៍ដូចគ្នាមួយចំនួនជា

១៤ ខ្ញុំនឹងលាបំណន់[ផ] របស់ខ្ញុំចំពោះព្រះយេហូវ៉ា
អើ នៅមុខបណ្ដាជនទាំងប៉ុន្មានរបស់ទ្រង់ផង
១៥ ការស្លាប់របស់ពួកអ្នកបរិសុទ្ធ[ព] នៃព្រះយេហូវ៉ា
ជាការវិសេសដល់ព្រះនេត្រ[ភ] ទ្រង់
១៦ ឱព្រះយេហូវ៉ាអើយ ទូលបង្គំជាទាសារបស់ទ្រង់ពិត[ម]
គឺជាទាសារបស់ទ្រង់ ហើយជាកូននៃទាសី[យ] របស់ទ្រង់តែ
ទ្រង់បានស្រាយចំណងរបស់ទូលបង្គំចេញហើយ[រ]
១៧ ទូលបង្គំនឹងថ្វាយដង្វាយ[ល] ជាសេចក្ដីអរព្រះគុណ
ដល់ព្រះយេហូវ៉ា ហើយនិងអំពាវនាវដល់ព្រះនាមទ្រង់
១៨ ខ្ញុំនឹងលាបំណន់[វ] របស់ខ្ញុំចំពោះព្រះយេហូវ៉ា អើ នៅមុខ
បណ្ដាជនទាំងប៉ុន្មានរបស់ទ្រង់ផង
១៩ គឺនៅក្នុងព្រះលាននៃដំណាក់[ស] ព្រះយេហូវ៉ា
គឺនៅកណ្ដាលឯង ឱក្រុងយេរូសាឡិម[ហ] អើយ
ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។

**១១៧** ឱសាសន៍ទាំងឡាយអើយ ចូរសរសើរដល់ព្រះ
យេហូវ៉ា[ក] ឱជនរាល់គ្នាអើយ[ខ] ចូរដំកើងទ្រង់ចុះ
២ ដ្បិតសេចក្ដីសប្បុរស[គ] នៃទ្រង់ចំពោះយើងរាល់គ្នានោះ
ធំក្រៃលែងហើយសេចក្ដីពិតនៃព្រះយេហូវ៉ា[ឃ] ក៏ស្ថិតស្ថេរ
នៅជាដរាបចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។

**១១៨** ចូរអរព្រះគុណដល់ព្រះយេហូវ៉ា[ង] ដ្បិតទ្រង់ល្អ[ច]

**១១៦:១៤** ប ជន ៣០:២ ទដ ៦៦:១៣ **១១៦:១៥** ផ ជន ២៣:១០ ព ទដ ៧២:១៤ **១១៦:១៦** ភ ទដ ១១៩:១២៥ ១៤៣:១២ ម ទដ ៨៦:១៦ យ យប ១២:១៨ **១១៦:១៧** រ លវ ៧:១២ អរ ១:៤ **១១៦:១៨** ល ខ.១៤ លវ ២២:១៨ **១១៦:១៩** វ ទដ ៩២:១៣ ៩៦:៨
១០០:៤ ១៣៥:២ ស ទដ ១០២:២១ **១១៧:១** ក ទដ ២២:២៣ ១០៣:២ ខ រម ១៥:១១ **១១៧:២** គ ទដ ១៧:៧ ១០៣:១១ ឃ ទដ ១១៩:៩០ ១៤៦:៦ **១១៨:១** ង ១របា ១៦:៨ ច ២របា ៥:១៣ ៧:៣

ពិសេសវាមានលក្ខណៈដូចជាស្រាមួយពែងដែលគេទទួលទៀន នាពេលបុណ្យអរព្រះគុណ (ប្រៀបធៀប ២២:២៦,២៩ លវ ៧:១១–២១) នោះហើយគេហៅថា "ពែងនៃសេចក្ដីសង្គ្រោះ" ពីព្រោះដង្វាយអរព្រះគុណ និងពិធីបុណ្យពីសេចក្ដីសង្គ្រោះដែលព្រះយេហូវ៉ា បានប្រទានមក ។ មើលហេតុការណ៍ដូចគ្នាជាមួយនិង "យញ្ញបូជាជាដង្វាយអរព្រះគុណ" ខ.១៧–១៨ ។

**១១៦:១៤** *បំណន់* គឺជាការសរសើរដល់ព្រះយេហូវ៉ា (សូមមើលការពន្យល់ ៧:១៧) ។

**១១៦:១៥–១៦** គឺជាសេចក្ដីបរិយាយមានក្នុង ខ.៣–៤ ក៏មានការពន្យល់ដែលទាក់ទងនឹង"សេចក្ដីស្លាប់"មានក្នុង ខ.៣,១៥ ប្រៀបធៀប ខ.៨–៩ ។

**១១៦:១៥** *ការស្លាប់របស់ . . . ជាការវិសេស* ជាអត្ថន័យមួយយ៉ាងខ្លង់ខ្លស់ដែលត្រូវពិនិត្យដោយប្រុងប្រយ័ត្ន សូមប្រៀបធៀបសេចក្ដីវោហាស័ព្ទដែលស្រដៀងគ្នា "ជាការវិសេសនោះគឺឈាមរបស់ពួកគេដែលនៅព្រះនេត្រទ្រង់ដែរ"(៧២:១៤) ។ *ពួកអ្នកបរិសុទ្ធ* សូមមើលការពន្យល់ ៤:៣ ។

**១១៦:១៦** *គឺជាទាសារបស់ទ្រង់* ពាក្យនេះក៏ចងបញ្ជាក់ពីអ្នកនិពន្ធទំនុក ដែលពួកគេបានចាក់ប្រេងតាំងពីព្រះយេហូវ៉ា (សូមមើល ៧៨:៧០) ប៉ុន្តែ ក៏ជាព្រឹត្តិការណ៍បង្ហាញពីការលះបង់ដោយបន្ទាបខ្លួនជាអ្នកបម្រើ ជាទាសកររបស់ព្រះយេហូវ៉ា (សូមមើល ១៩:១១,១៣) ។ *ជាកូននៃទាសីរបស់ទ្រង់* សូមមើល ៨៦:១៦ និងការពន្យល់ ។

**១១៦:១៧** *ថ្វាយដង្វាយជាសេចក្ដីអរព្រះគុណ* មើលការពន្យល់ ខ.១៣ ។

**១១៦:១៩** *នៅក្នុងព្រះលាននៃ* (សូមមើល ៨៤:២,២០ ២ពវ ២១:៥ ២៣:១១–១២) ។

**ទដ ១១៧** គឺជាបទទំនុកដំកើងដ៏ខ្លីជាងគេក្នុងបទចម្រៀងសរសើរ ហើយក៏ជាជំពូកខ្លីជាងគេដែរក្នុងព្រះគម្ពីរទាំងមូល បទគម្ពីរ ទដ ១១៧ បានលាតត្រដាងបញ្ចេញពាក្យថា ហាលេលូយ៉ា (ក៏មានភ្ជាប់និងជំពូក ១១៨ ដែរ) ។ ពាក្យនេះជាលក្ខណៈលំនាំដើមដែលជាការប្រជុំ សេចក្ដីសរសើរ អរព្រះគុណ ការទុកចិត្ត (ទដ ១១១–១១៦) ។

គឺគ្រប់អស់ទាំងសាសន៍ និងរាស្ត្រទាំងអស់ដែលព្រះបានហៅមកដើម្បីសរសើរព្រះយេហូវ៉ា (ដូចមានក្នុង ៤៧:១ ៦៧:៣–៥ ៩៦:៧ ៩៨:៤ ១០០:១ មើលការពន្យល់ ៩:១) ដោយព្រោះសេចក្ដីស្រឡាញ់ និងផ្ដល់នូវភាពសប្បុរសចំពោះរាស្ត្រអ៊ីស្រាអែល(សូមមើល អស ១២:៤–៦) ។ ពាក្យថា ហាលេលូយ៉ា នៃបទទំនុកគ្រាសញ្ញាចាស់ក៏បានបរិយាយយ៉ាងច្បាស់ដែលបង្ហាញពីសេចក្ដីទុកចិត្តយ៉ាងពិតប្រាកដ ជារឿយៗបានសង្កត់ធ្ងន់ទៅលើគ្រាសញ្ញាចាស់ គឺគ្រប់ទាំងវាសនាជីវិតរបស់មនុស្សទាំងអស់ទាក់ទងនិងព្រះរាជកិច្ចជាអ្នកសម្រេច គឺសម្រាប់រាស្ត្រអ៊ីស្រាអែលរបស់ផងទ្រង់ (មើល ២:៨–១២ ៤៧:៩ ៦៧:២ ៧២:១៧ ១០២:១៥,១១០ លប ១២:៣ ចទ ៣២:៤៣ ១ពវ ៨:៤១–៤៣ អស ២:២–៤ ១១:១០ ១៤:២ ២៥:៦–៧ ៥២:១៥ ៥៦:៧ ៦០:៣ ៦៦:១៨–២៤ យរ ៣:១៧ ១៦:១៦–២១ ៣៣:៩ អម ៩:១១–១២ មីក ៥:៧–៩ សផ ៣:៨–៩ ហក ២:៧ សក ២:១០–១១ ៨:២០–២៣ ៩:៩–១០ ១៤:២–៣ មឡ ៣:១២) សូមមើលសេចក្ដីផ្ដើម ទដ ១១៣–១១៨ ។

**១១៧:១** ជាសេចក្ដីស្រង់ពីគម្ពីរ រម ១៥:១១ គឺជាសេចក្ដីបង្ហាញថា សេចក្ដីសង្គ្រោះរបស់សាសន៍ដទៃ និងការថ្វាយសេរីល្អដល់ព្រះតាមរយៈសាសន៍ដទៃគឺមិនប្រកបដោយព្រះវិញ្ញាណទេ ។

**១១៧:២** ជាហេតុផលនៃការសរសើរតម្កើង ។ *សេចក្ដីសប្បុរសនៃទ្រង់* គឺទ្រង់មានសេចក្ដីស្រឡាញ់និងសេចក្ដីពិតត្រង់ (សូមមើល ៣៦:៥ និងការពន្យល់ ក៏សូមមើលការពន្យល់ ៣:៧) ។ សូមមើលការពន្យល់ ៦:៤ ។

**ទដ ១១៨** ក្នុងជំពូកនេះបង្ហាញពីបទទំនុកចំរៀងសរសើរតម្កើង ដែលបញ្ជាក់ពីការអរព្រះគុណដល់ព្រះកាល ដែលទ្រង់បានរំដោះលោះលែងពួកគេឱ្យរួចពីពួកសត្រូវ ។

ក៏មានសេចក្ដីបកស្រាយមួយចំនួនពីបទទំនុក គឺពួកគេប្រកាន់យកបីចំណុចសំខាន់ៗ (គឺបង្ហាញជាលក្ខណៈលំអិត)។

១. គឺបង្ហាញពីស្ដេចដាវីឌ ដែលដឹកនាំជាតិសាសន៍ ដែលរក្សានូវការទូលដល់ព្រះពីការអរព្រះគុណ ចំពោះការលោះឬដោះលេងឱ្យមានសេរីភាព មានជ័យជម្នះ បន្ទាប់ពីបាន ច្បាំងជាមួយនិងជាតិសាសន៍មួយចំនួន ដែលគេរួមគ្នាជាសហព័ន្ធ ដែលជា ជាតិមួយគួរឱ្យស្ញែញខ្លាច (ប្រៀបធៀបនិង ២របា ២០:២៧–២៧ សូមមើល ការពន្យល់ ខ.១៩) ។

២. បង្ហាញពីរាស្ត្រអ៊ីស្រាអែល ដែលពួកយូដាធ្វើពិធីរំលឹកនូវការដោះលែងពួកគេឱ្យរួចពីពួកអេស៊ីព្ទ និងការយកជ័យជម្នះលើពួកកាណាន ។

៣. បង្ហាញពីប្រវត្តិសាស្ត្រ ដែលពួកយូដាបានធ្វើពិធីរំឭកនូវាការដោះលែងឱ្យរួចពីពួកសត្រូវរបស់ពួកគេក៏ដូចជាការប្រគល់ថ្វាយ ព្រះវិហារទីពីរដល់

សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប[ឆ]
២ ឥឡូវនេះ គួរឱ្យសាសន៍អ៊ីស្រាអែលពោលថា[ជ]
សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប[ឈ]
៣ ឥឡូវនេះ គួរឱ្យពូជពង្សនៃអើរ៉ុនពោលថា[ញ] សេចក្តី
សប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
៤ ឥឡូវនេះ គួរឱ្យអស់អ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ា[ដ]
បានពោលថា សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជា
ដរាប
៥ ខ្ញុំបានអំពាវនាវដល់ព្រះយេហូវ៉ា ដោយសេចក្តីវេទនា[ឋ]
របស់ខ្ញុំព្រះយេហូវ៉ាទ្រង់ក៏ទទួលស្តាប់[ឌ]
ហើយបានដាក់ខ្ញុំទុកនៅទីធំទូលាយ
៦ ព្រះយេហូវ៉ាទ្រង់កាន់ខាងខ្ញុំ[ឍ] ៗនឹងមិនខ្លាចអ្វីឡើយ
តើមនុស្សអាចនឹងធ្វើអ្វីដល់ខ្ញុំបាន[ណ]
៧ ព្រះយេហូវ៉ាទ្រង់កាន់ខាងខ្ញុំ ជាមួយនឹងពួកអ្នកដែលជួយខ្ញុំ
ដែរ[ត] ដូច្នេះខ្ញុំនឹងឃើញការកើតដល់ពួកអ្នក ដែលស្អប់ខ្ញុំ
តាមបំណងចិត្តខ្ញុំ[ថ]
៨ ស៊ូពឹងជ្រកនៅព្រះយេហូវ៉ា[ទ] ជាជាងទុកចិត្តនឹងមនុស្ស[ធ]
៩ ស៊ូពឹងជ្រកនៅព្រះយេហូវ៉ា ជាជាងទុកចិត្តនឹងពួកអ្នកធំ[ន] ។
១០ ឱសាសន៍ទាំងប៉ុន្មានបានឡោមព័ទ្ធខ្ញុំ តែដោយនូវព្រះ
នាមព្រះយេហូវ៉ា ខ្ញុំនឹងបំផ្លាញគេចេញ[ប]
១១ គេបានឡោមព័ទ្ធខ្ញុំ[ផ] អើ បានឡោមព័ទ្ធខ្ញុំពិត[ព]
តែដោយនូវព្រះនាមព្រះយេហូវ៉ា ខ្ញុំនឹងបំផ្លាញគេចេញ
១២ គេបានឡោមព័ទ្ធ ខ្ញុំជុំវិញ ដូចជាហ្វូងឃ្មុំ[ភ]
តែគេត្រូវរលត់ទៅ ដូចជាភ្លើង
ដែលឆេះបន្លា[ម] ដោយនូវព្រះនាមព្រះយេហូវ៉ា
ខ្ញុំនឹងបំផ្លាញគេចេញ[យ]
១៣ គេបានច្រានយ៉ាងខ្លាំង ចង់ឱ្យខ្ញុំដួល ប៉ុន្តែព្រះយេហូវ៉ា
ទ្រង់បានជួយខ្ញុំ[រ]
១៤ ព្រះយេហូវ៉ាទ្រង់ជាកំឡាំង[ល] ហើយជាទំនុកច្រៀង
របស់ខ្ញុំក៏បានត្រឡប់ជាសេចក្តីសង្គ្រោះរបស់ខ្ញុំដែរ[វ] ។

**១១៨:១** ឆ អរ ៣:១១ **១១៨:២** ជ ទដ ១១៥:៩ ឈ ទដ ១០៦:១ ១៣៦:១–២៦ **១១៨:៣** ញ នក ៣០:៣០ ទដ ១១៥:១០ **១១៨:៤** ដ ទដ ១១៥:១១ **១១៨:៥** ឋ ទដ ១៨:៦ ៣១:៧ ៧៧:២ ១២០:១ ឌ ខ.២១ ទដ ៣៤:៤ ៨៦:៧ ១១៦:១ ១៣៨:៣ **១១៨:៦** ឍ ចទ ៣១:៦ ហព ១៣:៦ ណ ទដ ៥៦:៤ **១១៨:៧** ត ចទ ៣៣:២៩ ថ ទដ ៥៤:៧

**១១៨:៨** ទ ទដ ២:១២ ៥:១១ ៩:៩ ៣៧:៣ ៤០:៤ អស ២៥:៤ ៥៧:១៣ ធ ២របា ៣២:៧–៨ ទដ ១០៨:១២ អស ២:២២ **១១៨:៩** ន ទដ ១៤៦:៣ **១១៨:១០** ប ទដ ៣៧:៩ **១១៨:១១** ផ ទដ ៨៨:១៧ ព ទដ ៣:៦ **១១៨:១២** ភ ចទ ១:៤៤ ម ទដ ៥៨:៩ យ ទដ ៣៧:៩ **១១៨:១៣** រ ខ.៧ ២របា ១៨:៣១ ទដ ៨៦:១៧ **១១៨:១៤** ល នក ១៥:២ វ ទដ ៦២:២

ព្រះ (សូមមើល អគ ៦:១៦) ឬក៏បង្ហាញពីការថ្វាយកំផែងក្រុងយេរូសាឡឹមដែលបានសង់ឡើងវិញ ទៅព្រះយេហូវ៉ា (មើល នហ ១២:៣៧–៤៣) ។ យោងតាមការបកស្រាយដែលបានសសរសេក្នុង ខ.៥–២១ គឺជាស្តេចនាសម័យនោះបើយោងតាមអ្នកពណ៌នាទីពីរ និងទីបី ដែលជាអ្នកដំណាងឱ្យប្រជាជន ។ តាមការសន្មតពីអ្នកបកស្រាយលើកទី១ ពីប្រវត្តិសាស្ត្រពួកយូដាដែលប្រារពពិធីបុណ្យ (សូមមើលសេចក្តីផ្តើម ទដ ១១៣) ជាបទចម្រៀងដែលបានគេប្រើសម្រាប់អរព្រះគុណ ក្នុងការដែលព្រះបានប្រោសរាស្ត្រអស់ទាំងស្រុកឱ្យបានរួច ។ ក៏ជាបទចម្រៀងសម្រាប់ទន្នេញ ដែលនាសម័យព្រះយេស៊ូវ និងសាវ័កទ្រង់បានច្រៀងនៅពេលបញ្ចប់ ពិធីលៀងព្រះអម្ចាស់ (សូមមើល មថ ២៦:៣០) ។ ដែលមានបទទន្នេញដើម្បីសរសើរ (ខ.១–៤) ដែលជាស្នាព្រះហស្តទ្រង់បានថ្វាយឱ្យ ដើម្បីច្រៀងអរព្រះគុណពីការដោះលែងនិងឱ្យមានជ័យជម្នះក្នុងសង្គ្រាម (ខ.៥–៣១) ។ ក៏មានខគម្ពីរបរិវគ្គ (ខ.៥–៧) ដែលសង្ខេបផ្តែរឿងសំខាន់ៗ ហើយក៏មានវគ្គថាមានប្រាំពីរខពីវគ្គ (ខ.៨–១៤,១៥–២១) បរិយាយពណ៌នាការដែលនាំឱ្យទទួលបានសេចក្តីសង្គ្រោះក្នុង ខ.២២–២៧ នាំឱ្យរាស្ត្រមានសេចក្តីអំណរនូវអ្វីដែលព្រះបានធ្វើ ។ ឯព្រះមហាក្សត្រក៏បានពោលសរសើរនូវព្រះបន្ទូលចុងក្រោយ (ខ.២៨) ។ មានសេចក្តីបញ្ចប់ (ខ.២៩) គឺជាការបើកការអធិស្ឋានមានទ្រង់ទ្រាយធំក្នុងវគ្គមានប្រាំពីរខដល់ (ខ.៨–៤,១៥–២១) ។ បានបង្ហាញពីនាមបរិសុទ្ធ គឺព្រះនាម "យ៉ាវេ"(Yahweh)(ឯពាក្យខ្លីវិញគឺបរិសុទ្ធវិញគឺ "យ៉ា" (Yah) គឺបានសរសេឱ្យឃើញមានប្រាំពីរដងក្នុងវគ្គនោះមានប្រាំមួយ ខ (ខ.២២–២៧) វាក៏ឃើញប្រាំពីរដងដែរ និងនៅក្នុងខដែលនៅមានរហូតតមក (១–៧,២៨–២៩) គឺឃើញប្រាំពីរដង ។

**១១៨:១–៤** គឺជាការអំពាវនាវ ដើម្បីសរសើរតម្កើង ។

**១១៨:១** គឺជាការអំពាវនាវដោយសរសើរតម្កើង (មានក្នុង ទដ ១០៥–១០៧,១៣៦ ១របា ១៦:៨,៣៤ ២របា ២០:២១) ។ *ចូរអរព្រះគុណ* សូមមើលការពន្យល់ ទដ ១០០ ក៏សូមមើល ខ.២–៤ គឺជាបទទន្នេញ និង ២៩ ឬ ៥–២១ ។ *សេចក្តីសប្បុរស* សូមមើល ខ.២–៤,២៩ ។

**១១៨:២–៤** *អ៊ីស្រាអែល . . . ពូជពង្សនៃអើរ៉ុន . . . កោតខ្លាចដល់ព្រះយេហូវ៉ា* មើល ១១៥:៩–១១ និងការពន្យល់ (មើលការពន្យល់ ៩៦:១–៣) ។

**១១៨:៥–២១** គឺជាបទចម្រៀងរបស់ស្តេច ពីការអរព្រះគុណដោយការជួយសង្គ្រោះ និងជ័យជម្នះ ។

**១១៨:៥–៧** សេចក្តីផ្តើម : ខ្ញុំបានអំពាវនាវដល់ព្រះយេហូវ៉ាទ្រង់ក៏ឆ្លើយជាបន្ទូលមិនឱ្យទូលបង្គំភ័យខ្លាចឡើយ ។

**១១៨:៥** *ខ្ញុំបានអំពាវនាវដល់ព្រះយេហូវ៉ា . . . ទ្រង់ក៏ទទួលស្តាប់* ឃ្លានេះមានទំនាក់ទំនងនិងខគម្ពីរ ៣:៤ ៤:១ ១៧:៦ ២២:២ ២៧:៧ ៨៦:៧ ៩១:១៥ ៩៩:៦ ១០២:២ ១២០:១ ១៣៨:៣ ១ពង្ស ១៨:២៤ សភ ២១:១៣ អស ៦៥:២៤ យរ ៣៣:៣ គ្រប់ទាំងពាក្យអត្ថបទទាំងនេះ គឺមានលក្ខណៈពាក្យជាភាសាហេព្រើរដែរ ។ *ធំទូលាយ* "គឺក្នុងលក្ខណៈធំទូលាយ" សូមមើល ១៨:១៩ និងការពន្យល់ ។

**១១៨:៧** *ខ្ញុំនិងឃើញការ* "មើល" ។

**១១៨:៨–១៤** គឺជាការឆ្លុះបញ្ចាំងពីសេចក្តីសង្គ្រោះរបស់ព្រះយេហូវ៉ា មានក្នុង ខ.៨–៩ និង ខ.១៤ ។

**១១៨:១០** *នូវព្រះនាមព្រះយេហូវ៉ា* សូមមើល ១សយ ១៧:៤៥ ។ *ព្រះនាម* សូមមើល ខ.១១–១២,២៦ មើល ៥:១១ ។

**១១៨:១២** *ភ្លើងដែលឆេះបន្លា* សូមមើល ៥៨:៩ និងការពន្យល់ ។

**១១៨:១៣** *ដួល* គឺជាការស្លាប់ដោយគេសម្លាប់ (សូមមើល ខ.១៧–១៨ សូមមើលការពន្យល់ ១៣:៤) ។

**១១៨:១៤** ប្រហែលជាការអំពាវនាវជាបទចម្រៀងជ័យជម្នះ មានក្នុង នក

១៥ នៅក្នុងលំនៅរបស់មនុស្សសុចរិត នោះមានឮ
សំឡេងច្រៀងដោយអំណរ[ស]ពីសេចក្តីសង្គ្រោះ ព្រះហស្ត
ស្តាំ[ហ]នៃព្រះយេហូវ៉ាសំដែងឥទ្ធិឫទ្ធិ[ឡ]
១៦ ព្រះហស្តស្តាំនៃព្រះយេហូវ៉ាបានថ្កើងឡើងព្រះហស្តស្តាំ
នៃព្រះយេហូវ៉ាសំដែងឥទ្ធិឫទ្ធិ ។
១៧ ខ្ញុំនឹងមិនស្លាប់ទេ[អ] គឺនឹងរស់នៅវិញ ហើយខ្ញុំនឹង
ប្រកាស[ក]ពីអស់ទាំងស្នាដៃនៃព្រះយេហូវ៉ា
១៨ ព្រះយេហូវ៉ា បានវាយផ្ចាល[ខ]ខ្ញុំយ៉ាងខ្លាំង
តែមិនបានបណ្តាលឱ្យខ្ញុំស្លាប់ទេ[គ]
១៩ សូមបើកទ្វារ[ឃ]នៃសេចក្តីសុចរិតឱ្យខ្ញុំ នោះខ្ញុំនឹងចូល[ង]ទៅ
ហើយនិងអរព្រះគុណដល់ព្រះយេហូវ៉ា
២០ នេះហើយជាទ្វារនៃព្រះយេហូវ៉ា[ច]ពួកមនុស្សសុចរិត
នឹងចូលតាមទ្វារនេះ[ឆ]
២១ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានឆ្លើយ
មកទូលបង្គំ[ជ] ហើយបានត្រឡប់ជាសេចក្តីសង្គ្រោះដល់ទូល
បង្គំ[ឈ] ។

**១១៨:១៥** ស យប ៨:២១ ទដ ១០៦:៥ ហ នក ១៥:៦ ទដ ៨៩:១៣ ១០៨:៦ ឡ លក ១:៥១ **១១៨:១៧** អ ហព ១:១២ ក ចទ ៣២:៣ ទដ ៦៤:៩ ៧១:១៦ ៧៣:២៨ **១១៨:១៨** ខ យរ ៣១:១៨ ១កថ ១១:៣២ ហព ១២:៥ គ ទដ ៨៦:១៣ **១១៨:១៩** ឃ ទដ ២៤:៧ ង ទដ ១០០:៤ **១១៨:២០** ច ទដ ១២២:១-២ ឆ ទដ ១៥:១-២ ២៤:៣-៤ វវ ២២:១៤ **១១៨:២១** ជ ខ.៥ ឈ

២២ ឯថ្ម[ញ]ដែលពួកជាងសង់ផ្ទះបានចោលចេញ នោះបាន
ត្រឡប់ជាថ្មជ្រុងយ៉ាងឯកហើយ[ដ]
២៣ នេះគឺជាការដែលព្រះយេហូវ៉ាទ្រង់ធ្វើ
ហើយក៏អស្ចារ្យ[ឋ] នៅភ្នែកនៃយើងខ្ញុំ
២៤ ថ្ងៃនេះជាថ្ងៃដែលព្រះយេហូវ៉ាបានកំណត់ទុកនៅ
ថ្ងៃនេះ យើងរាល់គ្នានឹងរីករាយសប្បាយ[ឌ]ឡើង ។
២៥ ឱព្រះយេហូវ៉ាអើយ យើងខ្ញុំទូលអង្វរដល់ទ្រង់សូម
ជួយសង្គ្រោះឥឡូវ[ឍ] ឱព្រះយេហូវ៉ាអើយ យើងខ្ញុំទូលអង្វរ
ដល់ទ្រង់សូមចាត់សេចក្តីចំរើនមកឥឡូវ
២៦ សូមឱ្យព្រះអង្គ ដែលយាងមក[ណ]ដោយនូវព្រះនាមព្រះ
យេហូវ៉ា បានប្រកបដោយព្រះពរ អំពីដំណាក់នៃព្រះ
យេហូវ៉ា[ត]

ទដ ២៧:១ **១១៨:២២** ញ អស ៨:១៤ ដ អស ១៧:១០ ១៩:១៣ ២៨:១៦ សក ៤:៧ ១០:៤ មថ ២១:៤២ មក ១២:១០ លក ២០:១៧ កច ៤:១១ ១ពត ២:៧ **១១៨:២៣** ឋ មថ ២១:៤២ មក ១២:១១ **១១៨:២៤** ឌ ទដ ៧០:៤ **១១៨:២៥** ឍ ទដ ២៨:៩ ១១៦:៤ **១១៨:២៦** ណ មថ ១១:៣ ២១:៩ ២៣:៣៩ មក ១១:៩ លក ១៣:៣៥ ១៩:៣៨ យហ ១២:១៣ ត ទដ ១២៩:៨

ជំពូក ១៥ (សូមមើល អស ១២:២) ។

**១១៨:១៥–២១** ជាពិធីរំលឹកពីការដែលព្រះបានប្រោសលោស សូមមើល ខ.១៥–១៦ និង ខ.២១ ។

**១១៨:១៥** *លំនៅ* គឺជាទីជ្រកកោនរបស់អ្នកដែលជារាស្ត្រផងទ្រង់ ដូចជារាស្ត្រអ៊ីស្រាអែលដែលពួកគេលះបង់ចិត្តនិងកាយ ដើម្បីព្រះយេហូវ៉ា (សូមមើល ខ.២០ ក៏សូមមើល ៦៨:៣ និងការពន្យល់ដែរ) ។

**១១៨:១៧** *រស់នៅ . . . និងប្រកាស* សូមមើល ១១៥:១៧–១៨ សូមមើលការពន្យល់ ៦:៥ ។

**១១៨:១៨** *វាយផ្ចាលខ្ញុំយ៉ាងខ្លាំង* គឺក្នុងភាពជាព្រះមហាក្សត្រក៏ទទួលស្គាល់ថា ស្ថានឃុំព្រលឹងកំពុងបានគំរាមកំហែងទ្រង់តាមរយៈខណៈពេលទ្រង់បានបម្រើព្រះ ឬខណៈពេលទ្រង់ព្យាយាមដើរតាមផ្លូវព្រះ (សូមមើល ៦:១ ៣៨:១ ៩៤:១២ ចទ ៤:៣៦ ៨:៥) ។

**១១៨:១៩** *បើទ្វារនៃសេចក្តីសុចរិតឱ្យខ្ញុំ* គឺជាដំណើរការបើកនូវសេចក្តីសរសើរតម្កើងដូចជាការអធិប្បាយក្នុងព្រះវិហារ ដូចជាអ្នកនាំនូវការថ្វាយបង្គំព្រះ (សូមមើល ទដ ២៤,៦៨) ។ *ទ្វារ* ជាកន្លែងច្រកផ្លូវសម្រាប់ដើរចូលទៅឯទីក្នុងព្រះវិហារ ។ *នៃសេចក្តីសុចរិត* គឺជាទូទៅ គឺសំដៅទៅលើឈ្មោះរបស់ច្រកចូលណាមួយ ។ តែពាក្យពណ៌នាក្នុងខនេះគឺជាទ្វារចូលសម្រាប់អ្នកសុចរិតចូលទៅ (ខ.២០) ។ ក៏ជាទ្វារដែលព័ទ្ធជុំវិញទីក្រុង គឺជាទ្វារ "នៃសេចក្តីសុចរិត" គឺជាទ្វារក្រុងយេរូសាឡឹមនោះឯង គឺជាទីក្រុងរបស់ព្រះ (សូមមើលការពន្យល់ ២៤:៧ សូមមើល អស ២៦:២) ។

**១១៨:២១** ក្នុងខបញ្ចប់នេះគឺជាចម្រៀងអរព្រះគុណដែលបង្ហាញពីការថ្លែងអំណរគុណដូចជា ខ.១ ផងដែរ "ឯចំលើយ . . . ទូលបង្គំ" ក្នុង ខ.៥ និងជាបន្ទាល់ក្នុង ខ.១៤ ។

**១១៨:២២–២៧** គឺជាការលើកសរសើរតម្កើងរបស់ប្រជាជន ។

**១១៨:២២** *ថ្មដែលពួកជាងសង់ផ្ទះបានចោលចេញ* គឺបាននិយាយពីស្តេច (ដែលគេបានជួយសង្គ្រោះ និងមានជ័យជម្នះ) ឬជាពួកអ្នកដែលស្តេចមាកងាយលើពួកគេ ឬជាទីដែលស្តេចបានលុកលុយហើយបានសង់ទីក្រុងនៃចក្រក្រភពនៃទីនោះ ។ ក៏មានអ្នកខ្លះសន្មត់យ៉ាងពេញទំហឹងថា ឃ្លាខាងលើនេះគឺសំដៅលើរាស្ត្រអ៊ីស្រាអែល គឺជារាស្ត្រដែលមានអំណាចលើលោក ។ *ថ្មជ្រុងយ៉ាងឯក* គឺមានដាំលើកំពូលកាច់ជ្រុងទ្វារនិមួយៗ (ក៏មានថ្មធំៗគេប្រើធ្វើជាឆ្អឹង) (មើល សក ៤:៧ ១០:៤) ។ មើល អស ១៩:១៣ ពច ២០:២ ១សយ ១៤:៣៨) ។ ថ្មនេះក៏បានធ្វើឡើងដោយមានអំណាចព្រះចេស្តា ដែលបណ្តាលឱ្យក្លាយជាថ្មដែលមានសារៈសំខាន់នៅក្នុងព្រះវិហារនៃពីភពលោក ថ្មមួយគឺតាមរយៈ ខ.២៣ គឺសំដៅទៅលើអង្គទ្រង់ផ្ទាល់ (សូមមើល ២១:៤២ មក ១២:១០–១១ លក ២០:១៧ កច ៤:១១ អក ២:២០ ១ពត ២:៧) ។

**១១៨:២៤** *ថ្ងៃនេះជាថ្ងៃដែលព្រះយេហូវ៉ាបានកំណត់ទុក . . . រីករាយសប្បាយឡើង* គឺជាថ្ងៃដែលព្រះបង្កើតឱ្យមានការដោះលោះ គឺជាភាពជោគជ័យដែលគេបានរមញកឡើង ។ ក៏មានអ្នកខ្លះគិតថាវាជាថ្ងៃបុណ្យរំលង ឬបុណ្យបារាំង ។ *បានកំណត់* "គឺជាការបង្កើតឱ្យមានថ្ងៃនោះឯង" (សូមមើល ខ.១៥–១៧,២៣) ក៏បានធ្វើ "ថ្ម" "ថ្មជ្រុងឯក" (ខ.២២) ។

**១១៨:២៥** ជាការអធិស្ឋានដល់ព្រះយេហូវ៉ា ឱ្យទ្រង់បន្តការជួយសង្គ្រោះទ្រទ្រង់ដល់រាស្ត្ររបស់ទ្រង់ ។

**១១៨:២៦** *ដែលយាងមកដោយនូវព្រះនាមព្រះយេហូវ៉ា* គឺអស់អ្នកដែលមានជំនួយពីព្រះអម្ចាស់បានធ្វើឱ្យសត្រូវបានដួលចុះ "ក្នុងព្រះនាមព្រះយេហូវ៉ា" (សូមមើល ខ.១០–១២) ។ *អំពីដំណាក់នៃព្រះយេហូវ៉ា* គឺចេញពីវត្តមានទ្រង់ (សូមមើល ១៣៤:៣) ។ *យើងខ្ញុំ* គឺជាទម្រង់ពហុវចនៈ ប្រើសម្រាប់សរសើរតម្កើងដល់ព្រះមហាក្សត្រនៃយើង (ពហុវចនៈ ជារឿយៗប្រើសំដៅលើព្រះអម្ចាស់) ឯព្រះអម្ចាស់ក៏ប្រទានពរចំពោះយើងម្នាក់ៗ (មើល ១ពរ ៩:៦) ។ ដែលទ្រង់ប្រទានពរឱ្យមានជ័យជម្នះ ហើយវិលត្រឡប់មកពីសមរភូមិវិញ ។

២៧ ព្រះយេហូវ៉ា[ថ] ទ្រង់ជាព្រះ ទ្រង់បានប្រទានពន្លឺ[ទ] មកយើង
ខ្ញុំចូរចង[ធ] យញ្ញបូជាភ្ជាប់នឹងស្នែងអាសនា[ន] ដោយខ្សែចុះ
២៨ ទ្រង់ជាព្រះនៃទូលបង្គំ ហើយទូលបង្គំនឹងអរព្រះគុណ
ដល់ទ្រង់ ទ្រង់ជាព្រះនៃទូលបង្គំ[ប] ៗនឹងដំកើង[ផ] ទ្រង់ឡើង ។
២៩ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ដ្បិតទ្រង់ល្អសេចក្តី
សប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប ។

**១១៩** មានពរ ហើយ អស់អ្នកដែលផ្លូវប្រព្រឹត្តរបស់ខ្លួន
បានគ្រប់លក្ខណ៍[ក] គឺជាអ្នកដែលដើរ[ខ] តាមក្រិត្យវិន័យរបស់
ព្រះយេហូវ៉ា[គ]
២ មានពរ ហើយ[ឃ] អស់អ្នកដែលរក្សាទុកនូវសេចក្តីបន្ទាល់[ង]
របស់ទ្រង់ជាអ្នកដែលស្វែងរកទ្រង់[ច] ឱ្យអស់ពីចិត្ត[ឆ]
៣ អើ ពួកនោះមិនដែលប្រព្រឹត្តអំពើទុច្ចរិតឡើយ[ជ]

**១១៨:២៧** ថ ១ពវ ១៨:២១ ទ ទដ ២៧:១ អស ៥៨:១០ ៦០:១,១៩,២០ មឡ ៤:២ ១ពត ២:៩ធ លវ ២៣:៤០ ន នក ២៧:២ **១១៨:២៨** ប លប ២៨:២១ ទដ ១៦:២ ៦៣:១ អស ២៥:១ ផ នក ១៥:២ **១១៩:១** ក លប ១៧:១ ចទ ១៨:១៣ សភ ១១:២០ ខ ទដ ១២៨:១ គ ទដ ១:២ **១១៩:២** ឃ ទដ ១១២:១ អស ៥៦:២ ង ខ.១៤៦ ទដ ៩៩:៧ ច ១រប ១៦:១១ ទដ ៤០:១៦ ឆ ចទ ១០:១២ **១១៩:៣** ជ ទដ ៥៩:៤ ១យហ ៣:៩ ៥:១៨

**១១៨:២៧** *ទ្រង់ប្រទានពន្លឺមកយើងខ្ញុំ* គឺជាព្រះពរដែលទ្រង់ប្រទានមកឱ្យយើង (មើល ជន ៦:២៥ និងមើល លវ ៧:១១–២១) ។

**១១៨:២៨** សេចក្តីបញ្ចប់របស់ស្តេច ដែលមានបន្ទូលឡើងវិញពីពាក្យសន្យារបស់ទ្រង់ មានក្នុង ខ.២១ ។

**១១៨:២៩** គឺជាការអំពាវដោយការសរសើរ (មើល ខ.១ និងការពន្យល់) ។

**ទដ ១១៩** ជាការពុះពារដើរតាមព្រះបន្ទូលព្រះ ។ ឯអ្នកនិពន្ធជាជនជាតិអ៊ីស្រាអែល ។ (១).ស៊ូពុះពារប្តូរផ្តាច់ដើរតាមផ្លូវព្រះ ក៏ចាត់ទុកព្រះបន្ទូលជាព្រះបន្ទូលនៃជីវិត (២).បន្ទាបខ្លួនហើយទទួលស្គាល់កំហុសក្នុងចិត្ត ក្នុងជីវិត ។ (៣).ស្គាល់នូវការឈឺចាប់ តែជាផលផ្លែពីវិន័យនៃការកែតម្រង់របស់ព្រះ និងទី(៤).ទទួលការឈឺចាប់យ៉ាងច្រើនដោយដៃរបស់មនុស្សច្រឡោងខាង គឺពួកមាកងាយដល់ព្រះបន្ទូលរបស់ព្រះអម្ចាស់ (មើលការពន្យល់ ខ.២៣,៥៧) ឯបទទំនុកដំកើងក៏អាចជាគ្រឿងដឹកឆ្លងសម្រាប់ជាសេចក្តីតម្រង់ដល់ពួកសង្ឃឱ្យស្ថិតក្នុងភាពបរិសុទ្ធនៃព្រះ ។ តែអ្នកនិពន្ធបានពណ៌នាយ៉ាងល្អិតនូវផ្ទៃរឿង ១៩:៧–១៣ គឺបញ្ចូលទាំងសេចក្តីតម្រូវឱ្យមានការសូទ្រាំអត់ធ្មត់ ។ ឯសេចក្តីសរសេរនិពន្ធនោះសោធ ក៏តម្រូវឱ្យមានច្រៀងនូវសេចក្តីទំនុកចម្រៀង ឬក៏ទន្ទេញនោះទេ ស្ទើរតែគ្រប់ជួរបន្ទាត់នៃសេចក្តីទំនុក គឺជាការទូលទៅរកព្រះអម្ចាស់ ជាការអធិស្ឋានដោយព្រលឹងវិញ្ញាណស្ទាត់ជំនាញពីបញ្ញត្តិរបស់ទ្រង់ ។ សូមមើល ទដ ១១១–១១៩ ១១១:១ ១១២:១ ។ ស្ទើរតែគ្រប់វគ្គឃ្លារឃ្លោងអ្នកនិពន្ធបានផ្តោតទៅលើចំណុចសំខាន់មួយគឺព្រះ ដែលមានគ្រប់ព្រះចេស្តា អាមបានបង្កើតនូវអ្វីៗទាំងអស់ និងជាព្រះដ៏ប្រោសលោះដែលទ្រង់គ្រប់គ្រងលើអស់ទាំងពីភពលោកទាំងមូល អ្នកនិពន្ធក៏បានកត់ចំណាំនូវទស្សនៈពីរ ។ (១).ជាសេចក្តីបង្គាប់បញ្ជាពីព្រះសម្រាប់ជីវិតមនុស្ស ។ (២).មានព្រះបន្ទូលសន្យា ចំពោះអ្នកដែលស្តាប់បង្គាប់ដល់ទ្រង់ ចំពោះសេចក្តីជំនឿ (គឺមានចំណុចសំខាន់ពីរនៃភាពបរិសុទ្ធ សូមមើល ៣៤:៨–១៤ និងការពន្យល់) ។ ចំពោះករណីនេះក៏មានការជ្រើសរើសជាភាសាហេព្រើរប្រាំបីពាក្យ ដែលគេបានប្រើក្នុងគម្ពីរសញ្ញាចាស់មានដូចជាពាក្យ តូរ៉ាហ មានន័យថា "សេចក្តីបញ្ញត្តិ" ពាក្យថា អ៊ីដូត មានន័យថា "ស្ថានភាព" ពីហ្គុដៀម មានន័យថា បញ្ញត្តិ ឬសិក្ខាបទពាក្យសិក្ខាបទគេប្រើក្នុងព្រះពុទ្ធសាសនា ពាក្យថា មីស្ប៊ីត មានន័យថា ក្រឹត្យវិន័យ ឬបញ្ញត្តិ ពាក្យថា មីសប៉ាទីម មានន័យថា"ច្បាប់" (ដូចជាមាននៅក្នុង ១៩:៧–៩ តែពាក្យមីសប៉ាទីមគេបានបកប្រែថា "សេចក្តីបង្គាប់ឬបញ្ញត្តិ" មានក្នុង ១៩:៩ ពាក្យថា ហាគហ្គីម មានន័យថា "ច្បាប់" ពាក្យថា ដាបា មានន័យថា"ពាក្យឬព្រះបន្ទូល" (តែជួនកាលវាបង្កប់ន័យថា"ព្រះបន្ទូលសន្យា") ពាក្យថាអ៊ីមរ៉ាហ គឺមានន័យថា "ពាក្យឬព្រះបន្ទូល" ពេកខ្លះមានន័យថា "ព្រះបន្ទូលសន្យា" ។ ឯពាក្យទាំងនេះមានប្រើឬសរសេរនៅក្នុងគ្រប់ទាំង ២២វគ្គ (ក៏ប្រើពាក្យទាំង៨នោះជាមួយនិងពាក្យទ្រង់ ពាក្យ waw ពាក្យ Heth ពាក្យ Yodth ពាក្យ Kaph ឬពាក្យ Pe គឺប្រើមិនតិចជាង៦ដងឡើយ) ។ ដែលជាកិច្ចការបានធ្វើមិនតាមលំដាប់ដូចក្នុងវគ្គគាថានិមួយៗ នោះទេ ។ ឯពាក្យទាំងប្រាំនោះក៏បានកំណត់ (ក្នុងផ្នែកមួយយ៉ាងធំ) ។ ឯចំពោះអ្នកនិពន្ធ ក៏បានសម្រេចរៀបពាក្យទៅតាមលំដាប់អក្សរ ។ ជាពិសេសក៏មានវគ្គមួយបាននិយាយលំអិត សម្របទៅតាមអ្នកអាននាសម័យថ្មី (ដូចជាប្រើអ្នកនិពន្ធបានជ្រើសរើសបែបបទតាមទំនៀមទម្លាប់ តាទម្រង់កំណាព្យ) ។ អ្នកនិពន្ធបង្កើតជាផ្ទៃរឿងដើម្បីបំពេញផ្នែកខាងវិញ្ញាណ ឯសាច់រឿងគឺមានលក្ខណៈធំធេងដូចជាតម្លៃជីវិត ។ ដែលផ្តោតលើប្រវែង បណ្តោយ ទទឹង កំពស់ និងសេចក្តីស្លាប់របស់ដំណើរជីវិតមនុស្សម្នាក់ៗជាមួយព្រះអម្ចាស់ ។ ក្រៅពីទម្រង់ដែលបានប្រើប្រាស់ចងក្រងឡើង ដោយទម្រងជាកំណាព្យដែលបានជ្រើសរើសដូចជាឃ្លា ៣ខ ដំបូងនិង ៣ខ ចុងក្រោយ គឺគេសរសេរបែបលក្ខណៈជាសេចក្តីផ្តើម និងសេចក្តីបញ្ចប់ដែលទាក់ទងនឹងផ្ទៃរឿងតាំងពីដំបូង គឺជាសេចក្តីណែនាំពីប្រាជ្ញាក៏ជាសេចក្តីសង្ខេបផ្ទៃរឿងសំខាន់ៗ ។ ក៏មានការកត់សម្គាល់ដែរថា ក្នុងកណ្តាលកណ្ឌគម្ពីរទដ គឺបានបង្ហាញ (សូមមើលការពន្យល់ ខ.៨៩–៩១) ។

**១១៩:១–៣** គឺជាសេចក្តីផ្តើមទូទៅ ។

**១១៩:១–២** *មានពរ ហើយ* សូមមើលការពន្យល់ ១:១ ។

**១១៩:១** *អ្នកដែលមានផ្លូវប្រព្រឹត្ត . . . តាមក្រិត្យវិន័យ* គឺជាការបើកនូវការពណ៌នាយ៉ាងល្អិតល្អន់ ផ្នែកផ្សេងពីផ្នែកមុនៗ ទាក់ទងនិងការបង្ហាញពីដំណើររបស់ពួកគេក្នុងផ្លូវរបស់ផងទ្រង់ (ខ.៣) សូមមើល លប ១៧:១ ប្រៀបធៀប លប ២៦:៥ និងការពន្យល់ ។ *ក្រិត្យវិន័យ* ជាភាសាហេព្រើរមានន័យថា ថូរ៉ា គឺជាការប្រមូលផ្តុំពាក្យពេជ្រដើម្បីជាសេចក្តីសញ្ញាពីព្រះគឺសំដៅលើរាស្ត្ររបស់ទ្រង់ (សូមមើល ចទ ៤:៤៤ និងការពន្យល់) ។ "ក្រឹត្យវិន័យ" គឺជារឿយៗបានឃើញបន្តបន្ទាប់ដើម្បីបង្ហាញពីអត្ថន័យរួម ឬទាំងមូលដែលជាគម្ពីរបញ្ចកណ្ឌទាំមូល (សូមមើល លក ២៤:៤៤ និងការពន្យល់) ។ ក៏ដូចជាគម្ពីរសញ្ញាចាស់ទាំងមូល (សូមមើល យហ ១០:៣៤ ១២:៣៤ ១៥:២៥ ១កថ ១៤:២១ និងការពន្យល់) ។

**១១៩:២** *នូវសេចក្តីបន្ទាល់* ជាភាសាហេព្រើរបញ្ចេញ សម្លេងថា អ៊ីដត់ ជាពិសេសជាពាក្យនៃសេចក្តីសញ្ញា ដែលសំដៅលើការដាក់លក្ខខណ្ឌពិសេសដោយសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា (សូមមើល ២៥:១០ "សេចក្តីតម្រូវ" ចទ ៤:៤៥ "លក្ខខណ្ឌពិសេស") ។ *ដែលស្វែងរកទ្រង់ដោយអស់ពីចិត្ត* សូមមើល ចទ ៤:២៩ និងការពន្យល់ ។ ពីចិត្ត សូមមើល ខ.៧ និងមើល ៤:៧ ។

គឺគេដើរតាមផ្លូវរបស់ទ្រង់វិញ[ឈ]
៤ ទ្រង់បានប្រកាសសេចក្តីបញ្ញត្តិរបស់ទ្រង់មក[ញ]
ដើម្បីឱ្យយើងខ្ញុំបានកាន់តាមដោយម៉ត់ចត់[ដ]
៥ ឱបើសិនណាជាផ្លូវទាំងប៉ុន្មានរបស់ទូលបង្គំបានរៀបចំ
ទៅអេះ ដើម្បីឱ្យបានកាន់តាមច្បាប់ទ្រង់[ឋ]
៦ កាលណាទូលបង្គំរាប់អានអស់ទាំងសេចក្តីបង្គាប់របស់
ទ្រង់[ឌ] នោះទូលបង្គំនឹងមិនត្រូវខ្មាសឡើយ[ឍ]
៧ កាលណាទូលបង្គំបានរៀនអស់ទាំងខច្បាប់ដ៏សុចរិត
របស់ទ្រង់នោះទូលបង្គំនឹងអរព្រះគុណដល់ទ្រង់
ដោយចិត្តទៀងត្រង់
៨ ទូលបង្គំនឹងកាន់តាមច្បាប់ របស់ទ្រង់ ឱសូមកុំលះចោល
ទូលបង្គំឱ្យអស់រលីងឡើយ[ណ] ។
៩ មនុស្សកំឡោះនឹងសំអាតផ្លូវដែលខ្លួន[ត] ប្រព្រឹត្តដោយ
សារអ្វីគឺដោយប្រយ័ត្ននឹងប្រព្រឹត្តតាមព្រះបន្ទូលនៃទ្រង់[ថ]
១០ ទូលបង្គំបានស្វែងរកទ្រង់អស់ពីចិត្ត[ទ] ឱសូមកុំឱ្យទូលបង្គំ
វង្វេងចេញពីសេចក្តីបង្គាប់របស់ទ្រង់ឡើយ[ធ]
១១ ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត[ន]
ប្រយោជន៍កុំឱ្យទូលបង្គំធ្វើបាប[ប] នឹងទ្រង់ឡើយ
១២ ឱព្រះយេហូវ៉ាអើយទ្រង់មានពរ[ផ] ហើយ
សូមបង្រៀនអស់ទាំងបញ្ញត្តិ[ព] របស់ទ្រង់ដល់ទូលបង្គំ[ភ]
១៣ បបូរមាត់ទូលបង្គំបានសំដែងពីគ្រប់ទាំងច្បាប់
ដែលចេញពីព្រះឱស្ឋទ្រង់មក[ម]
១៤ ទូលបង្គំបានត្រេកអរក្នុងផ្លូវប្រព្រឹត្តតាមសេចក្តីបន្ទាល់[យ]
របស់ទ្រង់ឱ្យស្មើនឹងសេចក្តីអំណរចំពោះទ្រព្យសម្បត្តិ
គ្រប់យ៉ាង
១៥ ទូលបង្គំនឹងរំពឹងគិតពីសេចក្តីបញ្ញត្តិ[រ] របស់ទ្រង់
ហើយនិងស្រឡាញ់រាប់អានអស់ទាំងផ្លូវរបស់ទ្រង់
១៦ ទូលបង្គំនឹងមានចិត្តរីករាយ[ល] ចំពោះបញ្ញត្តិទ្រង់ទាំង
ប៉ុន្មានឥតភ្លេចព្រះបន្ទូលទ្រង់ឡើយ ។

**១១៩:៣** ឈ ទដ ១២៨:១ យរ ៦:១៦ ៧:២៣ **១១៩:៤** ញ ទដ ១០៣:១៨ ដ ខ.៥៦ ចទ ៦:១៧ **១១៩:៥** ឋ លវ ១៩:៣៧ **១១៩:៦** ឌ ខ.៤៦,៨០ ឍ ខ.១១៧ **១១៩:៨** ណ ទដ ៣៨:២១ **១១៩:៩** ត ទដ ៣៩:១ ថ ខ.៦៥,១៦៩ **១១៩:១០** ទ ទដ ៩:១ ធ ខ.២១,១១៨ **១១៩:១១** ន ចទ ៦:៦ យប ២២:២២ ប ខ.១៣៣,១៦៥ ទដ ១៨:២២–២៣ ១៩:១៣ សភ ៣:២៣ អស ៦៣:១៣ **១១៩:១២** ផ ទដ ២៨:៦ ព នក ១៨:២០ ភ ទដ ១៤៣:៨,១០ **១១៩:១៣** ម ខ.៧២ **១១៩:១៤** យ ខ.១១១ **១១៩:១៥** រ ខ.៩៧,១៤៨ ទដ ១:២ **១១៩:១៦** ល ទដ ១១២:១

**១១៩:៣** *ផ្លូវ* ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យនេះ មានលេចមកតែនៅក្នុងបទទំនុកនេះតែវាមានសរសេរច្រើនក្នុង ចទ និងមានកន្លែងខ្លះទៀតដូចជា ។

**១១៩:៤–៨** គឺអស់អ្នកដែលស្តាប់បង្គាប់នូវច្បាប់របស់ព្រះ (សូមមើល ខ.៤–៥,៨) គឺមានសេចក្តីសង្ឃឹមចំពោះចំនួនរបស់ព្រះ (សូមមើល ២–៨) ។

**១១៩:៤** *សេចក្តីបញ្ញត្តិ* ក្នុងព្រះគម្ពីរភាសាហេព្រើរថា គឺហ្គឌាម គឺជាសេចក្តីបញ្ញត្តិដែលបានដាក់មក តាមរយៈព្រះយេហូវ៉ា (សូមមើលក្នុង ១៩:៨ ១១១:១៣) ។

**១១៩:៥** *ច្បាប់* ក្នុងព្រះគម្ពីរភាសាហេព្រើរគឺអាហ្គីន គឺជាសេចក្តីសញ្ញា (សូមមើល ចទ ៦:២ ២៨:១៥ ៣០:១០,១៦ ១ពវ ១១:១១) ។ ក៏បង្ហាញពីលក្ខណៈសម្បត្តិច្បាស់លាស់ ។

**១១៩:៦** *និងមិនត្រូវខ្មាសឡើយ* អ្នកតែងនិពន្ធបទទំនុក ក៏បានទទួលការឈឺចាប់ ឬក៏មានជម្ងឺ ឬក៏ភាពទទួលការអាម៉ាសឈឺផ្សារក្នុងដៃសត្រូវ ។ ក៏ត្រូវជាប្រធានបទ ឬមុខសញ្ញាដែលត្រូវទទួការមើលងាយ (មើល ខ.៣១,៤៦,៨០ ២៥:២–៣,២០ ក៏សូមមើលសេចក្តីផ្តើម ទដ) តែគេមានហេតុផលដើម្បីសរសើរព្រះយេហូវ៉ា (សូមមើល ខ.៧) ។ មានព្រះពរបានទទួលនិងការប្រោសលោះដោយព្រះបានធ្វើការក្នុងជីវិតគាត់ (សូមមើល ខ.៨) ។ *រាប់អានអស់* គឺជាការគោរពកោតខ្លាច ហើយដើរតាមនូវរាល់សេចក្តីបញ្ញត្តិ (សូមមើល ខ.១៥ ៧៤:២០) ។ *សេចក្តីបង្គាប់* ជាសេចក្តីបង្គាប់មានន័យថា *មីសស្វក់* ជាចេសក្តីណែនាំពីក្រឹត្យច្បាប់ (សូមមើល នក ២០:៦ ២៤:១២ ចទ ៤:២) ជាការរៀបចំ ឬតែងតាំងយ៉ាងជាក់លាក់ នូវអ្វីៗដែលព្រះអម្ចាស់បានបញ្ជាមក ។

**១១៩:៧** *សុចរិត* គឺជាផ្នែកមួយនៃលក្ខណៈសម្បត្តិដ៏ស្មោះសររបស់អ្នកនិពន្ធតាមច្បាប់បញ្ញត្តិរបស់ព្រះអម្ចាស់ (សូមមើល ខ.៦,៧៥,១០៦,១២៣,១៣៨,១៤៤,១៦០,១៦៤,១៧២ និង ១៩:៩) ។ *ខច្បាប់* ក្នុងព្រះគម្ពីរភាសាហេព្រើរនិយាយថា មីសប៉ាទីម គឺជាសេចក្តីណែនាំប្រៀនប្រដៅពីសេចក្តីសញ្ញា (សូមមើល នក ២១:១ ២៤:៣ ចទ ៤:១) ។ គឺជាក្រឹតច្បាប់បានចារកំណត់ដោយអ្នកដឹកនាំជា (ព្រះមហាក្សត្រ) ។

**១១៩:៨** *កុំលះចោលពីទូលបង្គំ* គឺជាការទូលអង្វររបស់រាស្ត្ររបស់ព្រះដែលអធិស្ឋានសុំកុំឱ្យជួបប្រទះជម្ងឺ ភាពអត់ឃ្លាន ឬដោយការវាយប្រហារពីសត្រូវ (ធៀបនិង ៩:១០ ២២:១ ២៧:៩–១០ ៣៨:២១ ៧១:១៩,១១,១៨) ។

**១១៩:៩** *មនុស្សកំឡោះ* មានអ្នកខ្លះយល់ថា នេះជាលក្ខណៈរបស់អ្នកនិពន្ធប៉ុន្តែវាទំនងជាសេចក្តីណែនាំដល់យុវ័យក្មេងៗ ឱ្យធ្លាប់យល់ពីប្រាជ្ញារបស់គ្រូ (សូមមើល ៣៤:១១ សភ ១:៤ សស ១១:៩ ១២:១ សូមមើល កថាខណ្ឌទី១ ក្នុងសេចក្តីផ្តើមរបស់គម្ពីរសុភាសិតជាគោលបំណង និងសេចក្តីបង្រៀន) ។ *សំអាតផ្លូវ* គឺត្រូវឱ្យគេចេញពីផ្លូវនៃសេចក្តីសៅហ្មងផ្លូវពុករលួយ (សូមមើល ៧៣:១៣) ។ *ព្រះបន្ទូល* ក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យថា ដាប៉ា ជាទូទៅគឺសំដៅលើ (ព្រះបន្ទូល) ពីព្រះអម្ចាស់ផ្ទាល់ដែលទ្រង់បានបើកសម្តែងមកយើងផ្ទាល់ ។ តែពាក្យថា ព្រះបន្ទូលនៅក្នុងខនេះ គឺសំដៅលើសេចក្តីបញ្ញត្តិរបស់ផងទ្រង់ ដែលទ្រង់(បានមានជាព្រះបន្ទូលសន្យា) ។

**១១៩:១១** *ព្រះបន្ទូល* ក្នុងព្រះគម្ពីរភាសាហេព្រើរបញ្ចេញសំឡេងថា អុីមរ៉ាហ ដែលមានន័យស្មើ (សទិសន័យ) និងភាសាហេព្រើរមួយទៀតគឺ ។ *ដាប៉ា* ជា(ព្រះបន្ទូល) សូមើលការពន្យល់ ខ.៩ ក៏សូមមើល ចទ ៣៣:៩ ទដ ៣០:៥ ។ ពេលខ្លះក៏មានន័យប្រែថា "ព្រះបន្ទូលសន្យា" ។

**១១៩:១៣** *បានសំដែង* គឺជាការសញ្ជឹងគិត ឬក៏បទទន្ទេញពីសេចក្តីសញ្ញាក្នុងការលះបង់ដើម្បីព្រះយេហូវ៉ា (សូមមើល ៥០:១៦ "បទទន្ទេញ") ។

**១១៩:១៤** *ដែលចេញពីព្រះឱស្ឋទ្រង់* សូមមើល ខ.៧២,១១១ ១៦:២ ។

**១១៩:១៥** *ទាំងផ្លូវ* បើក្នុងភាសាហេព្រើរដែលមានសទិសន័យដូចក្នុង ខ.៣ (សូមមើល ២៥:៤ និងការពន្យល់) ។

១៧សូមប្រោសអ្នកបំរើរបស់ទ្រង់ ដោយគុណដ៏ប្រសើរ
ប្រយោជន៍ឱ្យទូលបង្គំបានរស់នៅ ហើយកាន់តាមព្រះ
បន្ទូលទ្រង់[ស]
១៨សូមបំភ្លឺភ្នែកទូលបង្គំ
ឱ្យបានឃើញសេចក្ដីអស្ចារ្យនៅក្នុង
ក្រិត្យវិន័យរបស់ទ្រង់
១៩ទូលបង្គំជាមនុស្សគ្រាន់តែស្នាក់នៅផែនដីប៉ុណ្ណោះ[ហ]
សូមកុំលាក់សេចក្ដីបង្គាប់របស់ទ្រង់នឹងទូលបង្គំឡើយ
២០ព្រលឹងទូលបង្គំសង្រេង[ឡ] ដោយនឹករឭកដល់ច្បាប់[អ]ទ្រង់
គ្រប់ពេលវេលា
២១ទ្រង់បានបន្ទោសមនុស្សឆ្មើងឆ្មៃ[ក] ដែលត្រូវបណ្ដាសា[ខ]
ហើយជាពួកអ្នកដែលវង្វេងចេញ[គ]ពីសេចក្ដីបង្គាប់របស់
ទ្រង់
២២សូមដកយកការដំនៀល[ឃ] និងការមើលងាយពីទូលបង្គំ
ចេញ ដ្បិត ទូលបង្គំបានរក្សាសេចក្ដីបន្ទាល់របស់ទ្រង់ទុក[ង]
២៣មានទាំងពួកអ្នកធំបានអង្គុយប្រឹក្សាគ្នាទាស់នឹងទូលបង្គំ
ដែរ អ្នកបំរើរបស់ទ្រង់បាននឹករំពឹងតែពីសេចក្ដីបញ្ញត្តិ
របស់ទ្រង់វិញ
២៤ទូលបង្គំយកសេចក្ដីបន្ទាល់ទ្រង់ ទុកជាសេចក្ដីអំណរ
របស់ខ្លួនហើយជាសេចក្ដីដំបូន្មានផង ។
២៥ព្រលឹងទូលបង្គំឈ្លក់នៅនឹងធូលីដី[ច] សូមប្រោសទូល
បង្គំ[ឆ]ឱ្យភ្ញារឡើង តាមព្រះបន្ទូលទ្រង់[ជ]
២៦ទូលបង្គំបានទូលសំដែងពីផ្លូវប្រព្រឹត្តរបស់ទូលបង្គំ
ហើយទ្រង់បានឆ្លើយមកសូមបង្រៀនអស់ទាំងបញ្ញត្តិទ្រង់
មកទូលបង្គំផង[ឈ]
២៧សូមឱ្យទូលបង្គំបានយល់ក្នុងផ្លូវឱវាទរបស់ទ្រង់យ៉ាង
នោះទូលបង្គំនឹងនឹករំពឹងពីការអស្ចារ្យទ្រង់[ញ]
២៨ព្រលឹងទូលបង្គំរលាយទៅ ដោយសេចក្ដីធ្ងន់ចិត្ត[ដ]សូម
ចំរើនកំឡាំងដល់ទូលបង្គំ[ឋ] តាមព្រះបន្ទូលនៃទ្រង់[ឌ]
២៩សូមដកការប្រព្រឹត្តដោយភូតភរពីទូលបង្គំចេញ[ឍ]
ហើយអនុញ្ញាតប្រទានក្រិត្យវិន័យរបស់ទ្រង់មកទូលបង្គំ[ណ]
ដោយព្រះគុណ
៣០ទូលបង្គំបានរើសយក[ត]ផ្លូវស្មោះត្រង់[ថ] ហើយទូលបង្គំបាន

**១១៩:១៧** វ ទដ ១៣:៦ ១១៦:៧ ស ខ.៦៧ ទដ ១០៣:២០ **១១៩:១៩** ហ លប ២៣:៤ ហព ១១:១៣ **១១៩:២០** ឡ ទដ ៤២:២ ៨៤:២ អ ខ.១៣១ ទដ ៦៣:១ អស ២៦:៩ **១១៩:២១** ក ខ.៥១ យប ៣០:១ ទដ ៥:៥ យរ ២០:៧ ៥០:៣២ ដយ ៤:៣៧ មឡ ៣:១៥ ខ ចទ ២៧:២៦ គ ខ.១០ **១១៩:២២** ឃ ទដ ៣៩:៨ ង ខ.២ **១១៩:២៥** ច ទដ ៤៤:២៥ ឆ ខ.៥០, ១០៧ ទដ ១៤៣:១១ ជ ខ.៩ **១១៩:២៦** ឈ ទដ ២៥:៤ ២៧:១១ ៨៦:១១ **១១៩:២៧** ញ ទដ ១០៥:២ ១៤៥:៥ **១១៩:២៨** ដ ទដ ៦:៧ ១១៦:៣ អស ៥១:១១ យរ ៤៥:៣ ឋ ទដ ១៨:១ អស ៤០:២៩ ៤១:១០ ឌ ខ.៩ **១១៩:២៩** ឍ ទដ ២៦:៤ ណ ជន ៦:២៥ **១១៩:៣០** ត យស ២៤:២២ ថ ទដ ២៦:៣

**១១៩:១៧–២៤** ការពុះពារដើម្បីច្បាប់បញ្ញត្តិរបស់ព្រះ គឺមានចំពោះអ្នកបម្រើព្រះយេហូវ៉ា រួចព្រះយេហូវ៉ាបានទាញគេចេញពីសេចក្ដីចចេសរឹងរូសវិញ (ខ.២១) ។

**១១៩:១៧** *កាន់តាមព្រះបន្ទូលទ្រង់* គឺជាការដឹងពីព្រះគុណករុណា ការថែរក្សាពីព្រះអម្ចាស់ និងព្រះពររបស់ទ្រង់ ។

**១១៩:១៨** *សេចក្ដីអស្ចារ្យ* គឺជាការពណ៌នាពីការប្រោសលោះ (សូមមើល ៩:១ និងការពន្យល់) តែសេចក្ដីបញ្ញត្តិរបស់ព្រះក៏មានភាពអស្ចារ្យ (សូមមើល ខ.២៧) គឺមានតែព្រះដែលបើកភ្នែករបស់មនុស្ស ។

**១១៩:១៩** *ទូលបង្គំជាមនុស្សគ្រាន់តែស្នាក់នៅផែនដីប៉ុណ្ណោះ* គឺដូចជាអ្នកបម្រើព្រះយេហូវ៉ា ដែលជាប្រជារាស្ត្ររបស់ទ្រង់ ដូចជាអ្នកនិពន្ធទំនុកដំកើងជាទីលំនៅរបស់យើង ក្នុងនគរនៃទឹកដីលោកីយទេ សូមមើល ៣៩:១២ និងការពន្យល់ ខ.៥៤) ។

**១១៩:២០** *ព្រលឹងទូលបង្គំ* (សូមមើល ខ.២៨,៨១ និងការពន្យល់ ៦:៣) ។

**១១៩:២១** *មនុស្សឆ្មើងឆ្មៃ* គឺជាមនុស្សអាក្រក់ ដែលប្រកាន់ ឬឆ្មើងឆ្មៃ ហើយធ្វើបាបដល់មនុស្សក្រីក្រ មើល ១០:២–១១ (សូមមើល ខ.៥១,៦៩, ៧៨,៨៥,១២២ មើលការពន្យល់ ៣១:២៣) ។ ឯអ្នកនិពន្ធក៏ទទួលការឈឺចាប់ជាច្រើនពីការប្រទូស្តភាពការធ្វើទុក្ខរបស់ពួកគេ ដោយអ្នកនិពន្ធបានស្វែងរកព្រះនិងផ្លូវរបស់ផងទ្រង់ ឯពីរខបន្ទាប់ទៀតក៏បញ្ជាក់ពីសកម្មភាពនោះ ។ *ត្រូវបណ្ដាសា* គឺជាការកាត់ទោសពីព្រះ ។

**១១៩:២២** *ការដំនៀល និងការមើលងាយ* គឺពីពួកមនុស្សឆ្មើងឆ្មៃ ។

**១១៩:២៣** *ទាំងពួកអ្នកធំ* ពីព្រោះអ្នកនិពន្ធក៏បង្ហាញ និងនិយាយ "មុខស្ដេច" (ខ.៤៦) ។ អ្នកនិពន្ធក៏បានពួកអ្នកធំបៀតបៀនផងដែរ (ខ.១៦១) ។ ឯអ្នកនិពន្ធ ក៏មានចំណែកក្នុងតួនាទីផ្លូវការខ្លះក្នុងពួកគេនោះ ដូចជាពួកសង្ឃ (គឺអ្នកដែលមានតួនាទីបង្រៀនបញ្ញត្តិរបស់ព្រះអម្ចាស់ មើល ១០:១១ អគ ៧:៦ នហ ៨:២–៨ យរ ២:៨ ១៨:១៨ មឡ ២:៧ និងការពន្យល់ ខ.៥៧) ។ មានព្រះមហាក្សត្រនិងអ្នកធំ គឺសំដៅលើអ្នកដែលជាជនជាតិអ៊ីស្រាអែល ក្នុងសម័យពួកយូដាមានប្រព័ន្ធដឹកនាំដូច ពេទ្យ ឬអ៊ុំរ៉ង និងបែបរាជាធិរាជ ។ *អង្គុយ* គឺមានលក្ខណៈដូចអ្នកដែលបោះជំរុំជីវិតនៅក្នុងលោកិយ ក៏មិនមានលក្ខណៈដូចមនុស្សចំឡែកនោះទេ (ធៀបនឹង ខ.១៩) ។ *ប្រឹក្សាគ្នាទាស់នឹងទូលបង្គំ* គឺដូចជាពួកគេចែកចាយពីលោកិយរបស់ពួកគេ (ខ.២៤) ។

**១១៩:២៥** *ឈ្លក់នៅនឹង* គឺអ្នកនិពន្ធបានពណ៌នាយ៉ាងច្រើន ពីទុក្ខព្រួយរបស់ពួកគេ និងការឈឺចាប់របស់ពួកគេ (សូមមើល ខ.២៨,៥០,៦៧,៧១,៧៥, ៨៣,៩២,១០៧,១៤៣,១៥៣) ។ វាមានលក្ខណៈដូចជាការចំអកមើលងាយ និងការបៀតបៀនពីសត្រូវ ជារឿយៗមានចំពោះអ្នកដែលលះបង់ក្នុងការបម្រើព្រះអម្ចាស់ គឺអ្នកដែលបង្កើត ឬទទួលព្រះបន្ទូល (ជាច្បាប់បញ្ញត្តិនិងជាព្រះបន្ទូលសន្យារបស់ផងទ្រង់) ជាសេចក្ដីសង្ឃឹងរបស់ជីវិតរបស់ពួកគេ (មើល ខ.៤២,៥១,៦៥,៦៩,៧៨,៨៥,១១០,១៣៤,១៤១,១៥០,១៥៧,១៦១ មើលការពន្យល់ ខ.៦ ៥:៩ ៣១:១១–១២) ។ *ធូលីដី* សូមមើល ៤៤:២៥ និងការពន្យល់ ។ *ព្រះបន្ទូល* គឺសំដៅលើព្រះបន្ទូលសន្យា មើល ២៨:៣៧ ។

**១១៩:២៧** *ការអស្ចារ្យ* សូមមើលការពន្យ់ ខ.១៨ ។

**១១៩:២៩** *ដោយភូតភរ* គឺជាផ្លូវមួយដែលមើលទៅហាក់ដូចជាល្អត្រឹមត្រូវ តែការពិតវាជាផ្លូវដែលនាំទៅរកសេចក្ដីស្លាប់ (សូមមើល ទដ ១៤:១២ និងការពន្យល់) គឺមានលក្ខណៈផ្ទុយនិងផ្លូវជាច្បាប់បញ្ញត្តិព្រះ ដែលជាការអាចទុកចិត្តបាន (មើល ជំពូក ខ.៨៦,១៣៨) និងសេចក្ដីពិត (មើល ខ.១៤២, ១៥១,១៦០) ។ *ប្រទានក្រិត្យវិន័យ* ដើម្បីឱ្យទូលបង្គំរក្សាបាននូវបញ្ញត្តិរបស់ផងទ្រង់ក៏សូមឱ្យទូលបង្គំទទួលបានព្រះពរ ដោយសេចក្ដីអំណរពីទ្រង់ ។

តាំងច្បាប់របស់ទ្រង់[ទ] នៅចំពោះភ្នែកដែរ
៣១ ទូលបង្គំកាន់ខ្ជាប់តាម[ធ] សេចក្ដីបន្ទាល់របស់ទ្រង់ឱ
ព្រះយេហូវ៉ាអើយ សូមកុំឱ្យទូលបង្គំត្រូវខ្មាសឡើយ
៣២ ទូលបង្គំនឹងរត់ទៅតាមផ្លូវនៃសេចក្ដីបង្គាប់
ទ្រង់ដ្បិតទ្រង់បានពង្រីកចិត្តទូលបង្គំឡើងហើយ ។
៣៣ ឱព្រះយេហូវ៉ាអើយ សូមបង្រៀនផ្លូវនៃអស់ទាំង
បញ្ញត្តិទ្រង់មកទូលបង្គំ[ន] នោះទូលបង្គំនឹងកាន់តាមដរាប
ដល់ចុងបំផុត
៣៤ សូមប្រទានឱ្យទូលបង្គំមានយោបល់[ប] នោះទូលបង្គំនឹង
កាន់តាមក្រឹត្យវិន័យទ្រង់[ផ] អើ ទូលបង្គំនឹងរក្សាទុកអស់ពី
ចិត្តផង[ព]
៣៥ សូមបណ្ដាលឱ្យទូលបង្គំ[ភ] ដើរទៅ តាមផ្លូវច្រកនៃសេចក្ដី
បង្គាប់របស់ទ្រង់[ម] ដ្បិតទូលបង្គំមានសេចក្ដីរីករាយក្នុងផ្លូវ
នោះ[យ]
៣៦ សូមធ្វើឱ្យចិត្ត[រ] ទូលបង្គំល្អៀងទៅខាងសេចក្ដីបន្ទាល់
របស់ទ្រង់កុំឱ្យល្អៀងទៅខាងសេចក្ដីលោភឡើយ[ល]
៣៧ សូមបង្វែរភ្នែកទូលបង្គំមិនឱ្យមើលការឥតប្រយោជន៍
ហើយប្រោសឱ្យទូលបង្គំ[វ] មានកំឡាំងឡើងក្នុងផ្លូវទ្រង់[ស]
៣៨ សូមសំរេចដល់អ្នកបំរើទ្រង់តាមព្រះបន្ទូល[ហ]
ជាសេចក្ដីដែលទុកសំរាប់ពួកអ្នកកោតខ្លាចដល់ទ្រង់
៣៩ សូមបង្វែរសេចក្ដីដំនៀល[ឡ] ដែលទូលបង្គំខ្លាចនោះចេញ
ពីទូលបង្គំទៅ ដ្បិតច្បាប់នៃទ្រង់សុទ្ធតែល្អ
៤០ មើល ទូលបង្គំបាននឹកអាល័យ[អ] ដល់បញ្ញត្តិទាំងប៉ុន្មាន
របស់ទ្រង់សូមប្រោសឱ្យទូលបង្គំ[ក] មានកំឡាំងឡើង
ដោយសេចក្ដីសុចរិតរបស់ទ្រង់ ។
៤១ ឱព្រះយេហូវ៉ាអើយ សូមឱ្យសេចក្ដីសប្បុរស[ខ] ទ្រង់
ផ្សាយមកដល់ទូលបង្គំគឺជាសេចក្ដីសង្គ្រោះរបស់ទ្រង់តាម
ព្រះបន្ទូលទ្រង់[គ]
៤២ យ៉ាងនោះ ទូលបង្គំនឹងមានពាក្យចំឡើយ[ឃ] ដល់អ្នកណា
ដែលត្មះតិះដៀលទូលបង្គំ[ង] ដ្បិតទូលបង្គំទុកចិត្តនឹងព្រះ
បន្ទូលទ្រង់
៤៣ សូមកុំដកព្រះបន្ទូលដ៏ពិតចេញ ពីមាត់ទូលបង្គំអស់រលីង
ឡើយ[ច] ដ្បិតទូលបង្គំបានសង្ឃឹម[ឆ] ដល់ច្បាប់នៃទ្រង់
៤៤ យ៉ាងនោះ ទូលបង្គំនឹងកាន់តាមក្រិត្យវិន័យ[ជ] ទ្រង់ជានិច្ច
នៅអស់កល្បជានិច្ចរៀងតទៅ
៤៥ ទូលបង្គំនឹងដើរទៅដោយសេរីភាពដ្បិតទូលបង្គំបាន
ស្វែងរកអស់ទាំងបញ្ញត្តនៃទ្រង់[ឈ]
៤៦ ទូលបង្គំនឹងពោលពីសេចក្ដីបន្ទាល់របស់ទ្រង់នៅចំពោះ
ពួកស្តេច[ញ] ឥតដែលត្រូវខ្មាសឡើយ[ដ]
៤៧ ទូលបង្គំនឹងមានចិត្តរីករាយ[ឋ] ដោយសារសេចក្ដីបង្គាប់
របស់ទ្រង់ជាសេចក្ដីដែលទូលបង្គំបានស្រឡាញ់[ឌ]
៤៨ ទូលបង្គំនឹងលើកដៃប្រណម្យចំពោះសេចក្ដីបង្គាប់របស់
ទ្រង់ ដែលទូលបង្គំបានស្រឡាញ់ហើយនិងរំពឹងគិត[ឍ] ពី
បញ្ញត្តិទ្រង់ ។

**១១៩:៣០** ទ ទដ ១០៨:១
**១១៩:៣១** ធ ចទ ១០:២០
**១១៩:៣៣** ន ខ.១២
**១១៩:៣៤** ប ខ.២៧,៧៣,១៤៤,១៦៩ យប ៣២:៨ សភ ២:៦ ដយ ២:២១ យក ១:៥ ផ ចទ ៦:២៥ ព ខ.៦៩
**១១៩:៣៥** ភ ទដ ២៥:៤–៥ ម ខ.៣២ យ ទដ ១:២
**១១៩:៣៦** រ យស ២៤:២៣ ល អគ ៣៣:៣១
**១១៩:៣៧** វ ខ.២៥ ទដ ៧១:២០ ស ខ.៩
**១១៩:៣៨** ហ ជន ២៣:១៩
**១១៩:៣៩** ឡ ខ.២២ ទដ ៦៩:៩ ៨៩:៥១ អស ២៥:៨ ៥១:៧ ៥៤:៤
**១១៩:៤០** អ ខ.២០ ក ខ.២៥,១៤៩,១៥៤
**១១៩:៤១** ខ ទដ ៦:៤ គ ខ.៧៦,១៦,១៥៤,១៧០

**១១៩:៤២** ឃ សភ ២៧:១១ ង ទដ ៤២:១០ **១១៩:៤៣** ច ១ពវ ១៧:២៤ ឆ ខ.៧៤,៨១,១១៤,១៤៧ **១១៩:៤៤** ជ ខ.៣៣,៣៤,៥៥ ចទ ៦:២៥ **១១៩:៤៥** ឈ ខ.៩៤,១៥៥ **១១៩:៤៦** ញ មថ ១០:១៨ កច ២៦:១–២ ដ ខ.៦ **១១៩:៤៧** ឋ ខ.៧៧,១៤៣ ទដ ១១២:១ ឌ ខ.៩៧,១២៧,១៥៩,១៦៣,១៦៥ **១១៩:៤៨** ឍ លប ២៤:៦៣

**១១៩:៣០** *ផ្លូវស្មោះត្រង់* សូមមើលការពន្យល់ ខ.២៩ ។
**១១៩:៣១** *ទូលបង្គំត្រូវខ្មាស* សូមមើលការពន្យល់ ខ.៦ ។
**១១៩:៣២** *បានពង្រីកចិត្តទូលបង្គំឡើងហើយ* "ការពង្រីកដួងចិត្ត" គឺឱ្យមានសេចក្ដីអំណរ (សូមមើល អស ៦០:៥ "មានសេចក្ដីអំណរយ៉ាងត្រជាក់ត្រជុំ") ។ ក៏មានអ្នកបកស្រាយខ្លះទៀតបានបកស្រាយថា "បង្កើនការយល់ដឹងរបស់ទូលបង្គំ" (សូមមើល ១ពវ ៤:២៩ "កំរិតនៃការយល់ដឹង") ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។
**១១៩:៣៣–៤០** ជាការអធិស្ឋានសូមនូវការបង្ហាញផ្លូវពីព្រះតាមព្រះហឫទ័យ ដូចជាពួកគេខំស្វែងរកច្បាប់បញ្ញត្តិរបស់ទ្រង់ ។
**១១៩:៣៤** *ចិត្ត* សូមមើល ខ.៣៦ ក៏សូមមើលការពន្យល់ ៤:៧ ។
**១១៩:៣៨** *សំរាប់ពួកអ្នកកោតខ្លាច* ព្រះយេហូវ៉ាបានបើកសម្ដែងក្នុងការសម្រេចតាមព្រះបន្ទូលរបស់ទ្រង់ ដល់អស់អ្នកដែលទុកចិត្តដល់ទ្រង់ ថាទ្រង់ជាព្រះពិតប្រាកដ (សូមមើល ១៣០:៤ ២សយ ៧:២៥–២៦ ១ពវ ៨:៣៩–៤០ យរ ៣៣:៨–៩) ។
**១១៩:៣៩** *សេចក្ដីដំនៀលដែលទូលបង្គំខ្លាចនោះ* សូមមើលការពន្យល់ ។
**១១៩:៤០** *សេចក្ដីសុចរិត* សូមមើលការពន្យល់ ៤:១ ។
**១១៩:៤១–៤៨** សូមឱ្យព្រះយេហូវ៉ាប្រោសលោះខ្ញុំ ចេញពីការអាក្រក់ ក៏សូមកុំឱ្យសេចក្ដីពិតរបស់ទ្រង់ឃ្លាតឆ្ងាយចេញពីទូលបង្គំឡើយ ឬចេញពីមាត់ទូលបង្គំឡើយ ។ ដ្បិតទូលបង្គំគោរពសេចក្ដីបញ្ញត្តិរបស់ទ្រង់ និងនិយាយទៅកាន់ទ្រង់ដោយស្រឡាញ់សេចក្ដីបញ្ញត្តិទ្រង់ ។
**១១៩:៤១** *សេចក្ដីសប្បុរស* សូមមើល ខ.៦៤,៧៦,៨៨,១២៤,១៤៩,១៥៩ សូមមើលការពន្យល់ ៦:៤ ។
**១១៩:៤២** *អ្នកណាដែលត្មះតិះដៀលទូលបង្គំ* សូមមើលការពន្យល់ ខ.២៥ ("ការបន្ទាបបន្ថោក") ។ *ព្រះបន្ទូល* សូមមើលការពន្យល់ ខ.២៥ ។
**១១៩:៤៣** *ព្រះបន្ទូលដ៏ពិតចេញពីមាត់ទូលបង្គំ* សូមមើល ខ.១៣ និងការពន្យល់ ខ.៤៦ ។
**១១៩:៤៥** *សេរីភាព* "គឺមានភាពទូលំទូលាយ" មិនទទួលការធ្វើទុក្ខបុកម្នេញ (សូមើល ១៨:១៩ និងការពន្យល់) ។
**១១៩:៤៦** *នៅចំពោះមុខស្តេច* គឺជាមោទនៈភាពមួយរបស់គេ (សូមមើល ខ.២៣) ។
**១១៩:៤៨** *ទូលបង្គំនឹងលើកដៃប្រណម្យចំពោះ* គឺជាសកម្មភាពសរសើរ (សូមមើល ៦៣:៤ ១៣៤:២) តែអត្ថន័យពិតគឺ ទូលបង្គំសូមសរសើរ ។

៤៩សូមទ្រង់នឹកចាំពីសេចក្ដី[ណ]ដែលទ្រង់មានបន្ទូល ដល់
អ្នកបំរើទ្រង់ ជាសេចក្ដីដែលនាំឱ្យទូលបង្គំមានសេចក្ដី
សង្ឃឹម[ត]
៥០នេះហើយជាសេចក្ដីសំរាន្តចិត្តដល់ទូលបង្គំក្នុងវេលា
ដែលទូលបង្គំកើតទុក្ខព្រួយ គឺព្រះបន្ទូលទ្រង់បានប្រោសឱ្យ
ទូលបង្គំមានកំឡាំងឡើង[ថ]
៥១ពួកអ្នកឆ្មើងឆ្មៃបាន មើលងាយ[ទ]ទូលបង្គំពន់ពេក
ប៉ុន្តែទូលបង្គំមិនបានបែរចេញ[ធ]ពីក្រិត្យវិន័យទ្រង់ឡើយ
៥២ឱព្រះយេហូវ៉ាអើយ ទូលបង្គំបាននឹកចាំ[ន]ពីបញ្ញត្តិទ្រង់
ដ៏មានពីបុរាណមក ជាការនាំឱ្យទូលបង្គំបានក្សាន្តចិត្ត
៥៣ទូលបង្គំមានសេចក្ដីគ្នាន់ក្នាញ់មកគ្រប់សង្កត់ចិត្ត[ប]
ដោយព្រោះមនុស្សអាក្រក់ ដែលបោះបង់ចោលក្រិត្យ
វិន័យរបស់ទ្រង់[ផ]
៥៤អស់ទាំងបញ្ញត្តិរបស់ទ្រង់ ជាបទចំរៀង[ព]របស់ទូលបង្គំ
នៅក្នុងផ្ទះដែលទូលបង្គំអាស្រ័យនៅ
៥៥ឱព្រះយេហូវ៉ាអើយ ទូលបង្គំបាននឹកចាំ[ភ]ពី ព្រះនាមទ្រង់
នៅវេលាយប់ ហើយបានកាន់តាមក្រិត្យវិន័យទ្រង់[ម]
៥៦សេចក្ដីនេះបានកើតដល់ទូលបង្គំ ដោយព្រោះបាន
រក្សាទុកនូវបញ្ញត្តិរបស់ទ្រង់[យ] ។
៥៧ឯចំណែកនៃទូលបង្គំ[រ] ឱព្រះយេហូវ៉ាអើយ ទូលបង្គំ
បានពោលថា
ត្រូវឱ្យទូលបង្គំរក្សាអស់ទាំងព្រះបន្ទូលនៃទ្រង់[ល]
៥៨ទូលបង្គំបានទូលអង្វរ[វ]ដល់ទ្រង់អស់ពីចិត្ត សូមទ្រង់មេត្តា
ប្រោសដល់ទូលបង្គំ[ស] តាមព្រះបន្ទូលទ្រង់[ហ]
៥៩ទូលបង្គំបាននឹក ពីផ្លូវប្រព្រឹត្តរបស់ខ្លួន[ឡ] នោះបានបំបែរ
ជើងទៅតាមសេចក្ដីបន្ទាល់របស់ទ្រង់វិញ
៦០ទូលបង្គំមិនបានបង្អែបង្អង់ឡើយ គឺបានប្រញាប់នឹងរក្សា
អស់ទាំងសេចក្ដីបង្គាប់របស់ទ្រង់[អ]
៦១ចំណងរបស់មនុស្សអាក្រក់បានរុំព័ទ្ធទូលបង្គំជុំវិញ
តែទូលបង្គំមិនបានភ្លេច[ក]ក្រិត្យវិន័យរបស់ទ្រង់ឡើយ
៦២នៅកណ្ដាលអធ្រាត្រ[ខ]ទូលបង្គំនឹងក្រោកឡើង ដើម្បីអរ
ព្រះគុណដល់ទ្រង់ ដោយព្រោះអស់ទាំងច្បាប់ដ៏សុចរិត
របស់ទ្រង់[គ]
៦៣ទូលបង្គំជាមិត្រភក្ដិនឹងអស់អ្នកដែលកោតខ្លាចដល់ទ្រង់[ឃ]
ហើយនិងអស់អ្នកដែលរក្សាបញ្ញត្តិទ្រង់ដែរ[ង]
៦៤ឱព្រះយេហូវ៉ាអើយ ផែនដីមានពេញដោយសេចក្ដី
សប្បុរស[ច]របស់ទ្រង់សូមបង្រៀនសេចក្ដីបញ្ញត្តទ្រង់ដល់
ទូលបង្គំផង[ឆ] ។
៦៥ឱព្រះយេហូវ៉ាអើយ ទ្រង់បានប្រោសអ្នកបំរើទ្រង់
ដោយល្អ[ជ]តាមព្រះបន្ទូលនៃទ្រង់[ឈ]
៦៦សូមបង្រៀនឱ្យទូលបង្គំ មានប្រាជ្ញា[ញ]ឆ្លុះយល់

**១១៩:៤៩** ណ ខ.៩ ត ខ.៤៣ **១១៩:៥០** ថ ខ.២៥ **១១៩:៥១** ទ ខ.២១ យប ១៦:១០ ១៧:២ ធ យប ២៣:១១ **១១៩:៥២** ន ទដ ១០៣:១៨ **១១៩:៥៣** ប នក ៣២:១៩ ៣៣:៤ ផ ទដ ៨៩:៣០ **១១៩:៥៤** ព ខ.១៧២ ទដ ១០១:១ ១៣៨:៥ **១១៩:៥៥** ភ ខ.៦២, ៧២ ទដ ១:២ ៤២:៨ ៦៣:៦ ៧៧:២ អស ២៦:៩ កច ១៦:២៥ ម ខ.៤៤ **១១៩:៥៦** យ ខ.៤, ១០០,១៣៤,១៦៨ ជន ១៥:៤០ **១១៩:៥៧** រ ចទ ៣២:៩ យរ ៥១:១៩ បទ ៣:២៤ ល ខ.១៧, ៦៧,១០១ **១១៩:៥៨** វ ចទ ៤:២៩ ១រប ១៦:១១ ទដ ៣៤:៤ ស លប ៤៣:២៩ អរ ៩:៨ ហ ខ.៤១

**១១៩:៥៩** ឡ យស ២៤:១៤–១៥ ទដ ៣៩:១ **១១៩:៦០** អ ខ.១១៥ **១១៩:៦១** ក ខ.៨៣,១០៩,១៥៣,១៧៦ **១១៩:៦២** ខ ខ.៥៥ កច ១៦:២៥ គ ខ.៧ **១១៩:៦៣** ឃ ទដ ១៥:៤ ១០១:៦–៧ ១០៣:១១ ង ខ.៥៦ ទដ ១១១:១០ **១១៩:៦៤** ច ទដ ៣៣:៥ ឆ ខ.១២,១០៨ **១១៩:៦៥** ជ ខ.១៧ ទដ ១២៥:៤ អស ៥០:២ ៥៩:១ មីក ២:៧ ឈ ខ.៩ **១១៩:៦៦** ញ ទដ ៥១:៦

**១១៩:៤៩–៥៦** ព្រះបន្ទូលរបស់ព្រះ គឺជាការកំសាន្តចិត្តដល់ខ្ញុំ និងកានាំផ្លូវរបស់ខ្ញុំទោះក្នុងកាលៈទេសៈបែបណាក៏ដោយ ។

**១១៩:៤៩** *បន្ទូល* សូមមើលការពន្យល់ ខ.២៥ ។

**១១៩:៥០–៥១** *ទូលបង្គំកើតទុក្ខព្រួយ... ពួកអ្នកឆ្មើងឆ្មៃបានមើលងាយទូលបង្គំពន់ពេក* សូមមើលការពន្យល់ ខ.២៥ ("ការបន្ទាបបន្ថោក") ។

**១១៩:៥១** *ពួកអ្នកឆ្មើងឆ្មៃ* សូមមើលការពន្យល់ ខ.២១ ។

**១១៩:៥២** *ពីបុរាណ* គឺបញ្ញត្តិរបស់ព្រះអម្ចាស់មិនផ្លាស់ប្ដូរ ឬប្រែប្រួលឡើយ តែកាន់តែមានភាពខ្លាំជានិច្ច នេះគឺជាប្រភពនៃការលើកទឹកចិត្តមួយ (សូមមើល ខ.៨៩,១៤៤,១៥២,១៦០) ។

**១១៩:៥៣** *មានសេចក្ដីគ្នាន់ក្នាញ់មកគ្របសង្កត់ចិត្ត* គឺជាការស្រែកអំពាវនាវរកសេចក្ដីបញ្ញត្តិព្រះ (សូមមើល ខ.១៣៦,១៣៩) ជាការដាស់តឿនក្រេនរំឭកឱ្យអ្នកបានបរិសុទ្ធ ហើយទាស់នឹងមនុស្សដែលទាស់និងបដិសេធន៍នៅសេចក្ដីបញ្ញត្តិនោះ (មើល ខ.១១៣,១១៥,១៥៨) ក៏បាននាំឱ្យមានភាពខ្លះជាអរិជ្ជមានដែលផ្ទុយនឹងការនោះ (មើល ១០៤,១២៨,១៦៣ ក៏មើល ខ.៣៦) ។

**១១៩:៥៤** *នៅក្នុងផ្ទះដែលទូលបង្គំអាស្រ័យនៅ* តាមន័យធម្មតាគឺ "ជាផ្ទះបណ្ដោះអាសន្នរបស់ទូលបង្គំ" គឺអាចមានអត្ថន័យនៅក្នុង ខ.១៩ និងការពន្យល់ ។

**១១៩:៥៥** *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**១១៩:៥៧–៦៤** ព្រះយេហូវ៉ាគឺជាទីលំនៅនឹងកំណើតដ៏ពិតប្រាកដរបស់អ្នកនិពន្ធ ពីព្រោះគឺជាសេចក្ដីបញ្ញត្តិដែលបំពេញឱ្យផែនដីទទួលបាននៅភាពសុខសាន្ត និងសេចក្ដីអំណរ ។ ដូច្នេះព្រះបន្ទូលសន្យាគឺផ្ដល់ឱ្យមានសេចក្ដីសង្ឃឹមពីទ្រង់ និងច្បាប់បញ្ញត្តិរបស់ទ្រង់ ។

**១១៩:៤៧** *ចំណែក* អាចមានអត្ថសញ្ញាណជាអ្នកនិពន្ធដែលជាពួកសង្ឃ ឬក៏ពួកលេវី (សូមមើល ៧៣:២៦ និងការពន្យល់) ។

**១១៩:៥៨** *ពីចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**១១៩:៦១** *បានរុំព័ទ្ធទូលបង្គំជុំវិញ* គឺការធ្វើទុក្ខដល់ទូលបង្គំ ។

**១១៩:៦២** *អរព្រះគុណដល់ទ្រង់* សូមមើលការពន្យល់ ទដ ១០០ ។ *ដ៏សុចរិតរបស់ទ្រង់* សូមមើលការពន្យល់ ខ.៧ ។

**១១៩:៦៣** *មិត្រភក្ដិ* សូមមើលការពន្យល់ ខ.៥៣ ។

**១១៩:៦៥–៧២** ជាសេចក្ដីដែលទ្រង់មានចំពោះរាស្ត្ររបស់ផងទ្រង់ ហើយនិងផ្ដល់នូវអំណាចចេស្ដាដល់រាស្ត្រទ្រង់ ឱ្យមានការវិនិច្ឆ័យនិងកាត់ទោសបានត្រឹមត្រូវ ។

**១១៩:៦៥** *ដោយល្អ* ប្រៀបធៀប ខ.៦៨ សូមមើល ៣១:១៩ ៨៦:១៧ និងការពន្យល់ ។ *ព្រះបន្ទូល* សូមមើលការពន្យល់ ខ.២៥ ។

ហើយចេះដឹងយ៉ាងល្អ ដ្បិតទូលបង្គំបានជឿចំពោះសេចក្ដី
បង្គាប់នៃទ្រង់ហើយ
៦៧ កាលមុនដែលទូលបង្គំកើតទុក្ខព្រួយ[ដ] នោះទូលបង្គំបាន
វង្វេងទៅ[ឋ] តែឥឡូវនេះទូលបង្គំកាន់តាមព្រះបន្ទូលទ្រង់
វិញ[ឌ]
៦៨ ទ្រង់ល្អប្រសើរ ហើយក៏ធ្វើការល្អ[ឍ]ដែរសូមបង្រៀន
បញ្ញត្តិទ្រង់ដល់ទូលបង្គំ[ណ]
៦៩ ពួកមនុស្សឆ្មើងឆ្មៃបានបង្កើតសេចក្ដីភូតភរ[ត]ទាស់នឹង
ទូលបង្គំតែទូលបង្គំនឹករក្សាទុកនូវបញ្ញត្តិទ្រង់យ៉ាងអស់ពី
ចិត្ត
៧០ ចិត្តគេស្លឹក[ថ]ដូចជាមនុស្សមានខ្លាញ់ខន់តែទូលបង្គំមាន
ចិត្តអំណរចំពោះក្រិត្យវិន័យទ្រង់វិញ
៧១ ការដែលទូលបង្គំកើតមានទុក្ខព្រួយ[ទ]នោះគឺជា
ប្រយោជន៍ដល់ទូលបង្គំហើយ ដើម្បីឱ្យទូលបង្គំបានរៀន
យកបញ្ញត្តិរបស់ទ្រង់
៧២ ក្រិត្យវិន័យដែលចេញពីព្រះឱស្ឋទ្រង់មកនោះវិសេសដល់
ទូលបង្គំ ជាជាងមាសប្រាក់ទាំងពាន់ផង[ធ]។
៧៣ ព្រះហស្តនៃទ្រង់បានបង្កើតហើយតាំងទូលបង្គំ[ន]ឡើង
សូមប្រោសឱ្យទូលបង្គំមានយោបល់ដើម្បីនឹងរៀនឱ្យបាន
ស្គាល់សេចក្ដីបង្គាប់របស់ទ្រង់
៧៤ ពួកអ្នកដែលកោតខ្លាចដល់ទ្រង់ គេនឹងឃើញទូលបង្គំ
ហើយមានសេចក្ដីអំណរ[ប] ដោយព្រោះទូលបង្គំបាន
សង្ឃឹមព្រះបន្ទូលនៃទ្រង់[ផ]
៧៥ ឱព្រះយេហូវ៉ាអើយ ទូលបង្គំដឹងហើយថាអស់ទាំងខ
ច្បាប់របស់ទ្រង់សុទ្ធតែសុចរិត[ព] ហើយថា ទ្រង់បានធ្វើឱ្យ
ទូលបង្គំកើតមានទុក្ខដោយសេចក្ដីស្មោះត្រង់[ភ]របស់ទ្រង់
ទេ
៧៦ ទូលបង្គំទូលអង្វរដល់ទ្រង់ សូមឱ្យសេចក្ដីសប្បុរស[ម]
របស់ទ្រង់ផ្សាយមកជួយដោះទុក្ខទូលបង្គំតាមសេចក្ដីដែល
ទ្រង់មានបន្ទូល[យ]ដល់អ្នកបំរើទ្រង់ហើយ
៧៧ សូមប្រទានសេចក្ដីមេត្តាករុណា[រ]របស់ទ្រង់មកទូលបង្គំ
ដើម្បីឱ្យទូលបង្គំមានជីវិតស្ថិតស្ថេរនៅ ដ្បិតទូលបង្គំយក
ក្រិត្យវិន័យទ្រង់ជាសេចក្ដីអំណរដល់ខ្លួន[ល]
៧៨ សូមឱ្យពួកមនុស្សឆ្មើងឆ្មៃ[វ]ត្រូវមានសេចក្ដីខ្មាសវិញ
ដ្បិតគេបានប្រព្រឹត្តក្រវិចក្រវៀននឹងទូលបង្គំដោយឥត
ហេតុ[ស]តែទូលបង្គំនឹងរំពឹងគិតពីបញ្ញត្តិទ្រង់
៧៩ សូមឱ្យអស់អ្នកដែលកោតខ្លាចដល់ទ្រង់បានបែរមក
ឯទូលបង្គំនោះគេនឹងស្គាល់សេចក្ដីបន្ទាល់របស់ទ្រង់ផង[ហ]
៨០ សូមឱ្យចិត្តទូលបង្គំបានជាប់ស៊ប់[ឡ]នឹងបញ្ញត្តិទ្រង់[អ]ដើម្បីកុំ
ឱ្យទូលបង្គំត្រូវខ្មាសឡើយ[ក]។
៨១ ព្រលឹងនៃទូលបង្គំភ្លឹកទៅ[ខ] ដោយប្រាថ្នាចង់បាន

**១១៩:៦៧** ដ ទដ ១១៦:១០ ឋ ទដ ៩៥:១០ យរ ៨:៤ ឌ ខ.១៧ **១១៩:៦៨** ឍ ទដ ១០០:៥ ១០៦:១ ១០៧:១ ១៣៥:៣ ណ នក ១៨:២០ **១១៩:៦៩** ត យប ១៣:៤ ទដ ១០៩:២ **១១៩:៧០** ថ ទដ ១៧:១០ អស ២៩:១៣ កច ២៨:២៧ **១១៩:៧១** ទ ខ.៦៧,៧៥ **១១៩:៧២** ធ យប ២៨:៧១ ទដ ១៩:១០ **១១៩:៧៣** ន លប ១:២៧ យប ៤:១៧ ១០:៨ ទដ ១៣៨:៨ ១៣៩:១៣–១៦ **១១៩:៧៤** ប ទដ ៣៤:២ ផ ខ.៩ ទដ ១៣០:៥ **១១៩:៧៥** ព ខ.៧, ១៣៨,១៧២ ភ ហព ១២:៥–១១ **១១៩:៧៦** ម ទដ ៦:៤ យ ខ.៤១ **១១៩:៧៧** រ ទដ ៩០:១៣ ១០៣:១៣ ល ខ.៤៧ **១១៩:៧៨** វ ខ.៥១ យរ ៥០:៣២ ស ខ.៨៦,១៦១ ទដ ៣៥:១៩ **១១៩:៧៩** ហ ខ.២៧,១២៥ **១១៩:៨០** ឡ ខ.១ ១ពវ ៨:៦១ អ លប ២៦:៥ ក ខ.៦ **១១៩:៨១** ខ ខ.២០ ទដ ៨៤:២

**១១៩:៦៦** *ជឿចំពោះ* គឺជាការទុកចិត្តក្នុងព្រះរាជបញ្ជា គឺពុំមានការបោកប្រាស់ (សូមមើលការពន្យល់ ខ.២៩) ឬមានភាពមិនស្មោះត្រង់ (សូមមើលការពន្យល់ ខ.៥២) ។

**១១៩:៦៧** *កើតទុក្ខព្រួយ* ក៏ទ្រង់ជាអ្នកគ្រប់គ្រងហើយស្ថិតនៅក្នុងព្រះហស្ត របស់ទ្រង់ដែរ (មើល ខ.៧១ និងការពន្យល់ ខ.២៥ "បន្ទាបបន្ថោក") ។ *ព្រះបន្ទូល* សូមមើលការពន្យល់ ខ.១១ ។

**១១៩:៦៩** *ពួកមនុស្សឆ្មើងឆ្មៃ* សូមមើលកាពន្យល់ ខ.២១ ។

**១១៩:៧០** ក្នុងខនេះក៏មានលក្ខណៈស្រដៀងនិង អស ៦:១០ យរ ៥:២៨ (សូមមើល ១៧:១០) ។

**១១៩:៧២** *ជាជាងមាសប្រាក់ទាំងពាន់ផង* សូមមើលក្នុង ខ.១៤,៥៧,១១១, ១៦២ ។

**១១៩:៧៣–៨០** សូមបំពេញពីបញ្ញើរបស់ទ្រង់ពីខ្ញុំ ក៏ជួយយើងខ្ញុំឱ្យដើរតាមច្បាប់ដ៏សុចរិតរបស់ទ្រង់ ដើម្បីពួកមនុស្សឆ្មើងឆ្មៃនិងខ្មាស់អៀន ឯអ្នកដែលកោតខ្លាចដល់ទ្រង់ និងមានសេចក្ដីអំណរជាមួយគ្នា ។ (វគ្គគាថាមានទម្រងប្រយោគប្រៀបធៀបនិង ខ.៧៣ និង ៨០ និង ៧៤ និង ៧៩ ៨៤ និង ៧៨,៧៦ និង ៧៧) ។

**១១៩:៧៣** *សូមប្រោសឱ្យទូលបង្គំមានយោបល់* គឺអ្វីៗដែលតម្រូវឱ្យរាស្ត្រទ្រង់បំពេញកិច្ចការបានល្អ គឺចាប់តាំពីព្រះបានបង្កើតមនុស្សមកម្លេះ ។

**១១៩:៧៤** *កោតខ្លាចដល់ទ្រង់* សូមមើល ខ.៧៩ និងមើលការពន្យល់ ៣៤:៨–១៤ ។ *គេនឹងឃើញទូលបង្គំ* គឺខណៈពេលទូលបង្គំបានព្រះផ្ដុំបានពេញរូបរាង្គនិងបានទទួលសេចក្ដីអំណរព្រះពរនៃសិរីល្អ ។ *ព្រះបន្ទូល* សូមមើលការពន្យល់ ខ.២៥ ។

**១១៩:៧៥** *ខច្បាប់* ក្នុងពាក្យនេះ បើជាភាសាហេព្រើរនិយាយថា មីសប៉ាទីម (Mishpatim) គឺអាចមានន័យថា ការសម្រេចពីព្រះអម្ចាស់ក្នុងការទំនាក់ទំនងជាមួយរាស្ត្ររបស់ទ្រង់ (សូមមើល ខ.៨៤ និងការពន្យល់) ។ *ទ្រង់បានធ្វើឱ្យទូលបង្គំកើតមានទុក្ខ* សូមើល ខ.៦៧,៧១ ។

**១១៩:៧៦** *សេចក្ដីសប្បុរស* (សូមមើលការបន្យល់ ៦:៤) ។

**១១៩:៧៧** *ដើម្បីឱ្យទូលបង្គំមានជីវិតស្ថិតស្ថេរ* គឺមិនឱ្យវិនាសបង់ជីវិតសូន្យទៅឡើយ ។

**១១៩:៧៨** *ពួកមនុស្សឆ្មើងឆ្មៃ* សូមមើលការពន្យល់ ខ.២១ ។ *មានសេចក្ដីខ្មាសវិញ* ដូចជាពួកមានបំណងដាក់ឱ្យទូលបង្គំទទួលការអៀនខ្មាស (សូមមើលការពន្យល់ ៥:១០) ។ *ដ្បិតគេបានប្រព្រឹត្តក្រវិចក្រវៀននឹងទូលបង្គំ* សូមមើលការពន្យល់ ខ.២៥ ("ជាការបន្ទាបបន្ថោក") ។

**១១៩:៧៩** *បែរមកឯទូលបង្គំ* សូមមើល ខ.៦៣ និងការពន្យល់ ខ.៥៣ ។

**១១៩:៨០** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ *មានសេចក្ដីខ្មាសវិញ* សូមមើលការពន្យល់ ខ.៦ ។

សេចក្តីសង្គ្រោះរបស់ទ្រង់[គ]ទូលបង្គំក៏សង្ឃឹម[ឃ]ដល់ព្រះ
បន្ទូលទ្រង់
៨២ភ្នែកទូលបង្គំស្រវាំងទៅ[ង] ដោយចង់បានព្រះបន្ទូលនៃ
ទ្រង់[ច] ហើយទូលបង្គំនិយាយថា តើកាលណាបានទ្រង់
ដោះទុក្ខទូលបង្គំទៅ
៨៣ដ្បិតទូលបង្គំបានត្រឡប់ដូចជាថង់ស្បែកដែលត្រូវផ្សែង
តែទូលបង្គំមិនភ្លេច[ឆ]បញ្ញត្តិទ្រង់ឡើយ
៨៤តើថ្ងៃអាយុនៃអ្នកបំរើទ្រង់បានប៉ុន្មានទៅតើដល់កាល
ណា[ជ]បានទ្រង់សំរេចទោសដល់ពួកអ្នកដែលបៀតបៀន
ទូលបង្គំ[ឈ]
៨៥ពួកមនុស្សឆ្មើងឆ្មៃ[ញ]បានជីករណ្តៅ[ដ]សំរាប់ចាប់ទូលបង្គំ
ជាការប្រព្រឹត្តល្មើសចំពោះក្រិត្យវិន័យទ្រង់
៨៦អស់ទាំងសេចក្តីបង្គាប់របស់ទ្រង់សុទ្ធតែស្មោះត្រង់[ឋ] ឯគេ
ៗបៀតបៀនទូលបង្គំ[ឌ]ដោយឥតហេតុ[ឍ]សូមជួយទូលបង្គំ
ផង[ណ]
៨៧គេបានធ្វើឱ្យទូលបង្គំហៀបតែនឹងសូន្យបាត់ពីផែនដីទៅ
ប៉ុន្តែទូលបង្គំមិនបានបោះបង់ចោល[ត]បញ្ញត្តិទ្រង់ទេ
៨៨សូម ចំរើនកំឡាំងនៃទូលបង្គំ[ថ] តាមសេចក្តីសប្បុរស
របស់ទ្រង់[ទ] យ៉ាងនោះទូលបង្គំនឹងបានរក្សាសេចក្តី
បន្ទាល់[ធ]ដែលចេញពីព្រះឱស្ឋទ្រង់មក ។

៨៩ឱព្រះយេហូវ៉ាអើយ ព្រះបន្ទូលទ្រង់បានតាំងនៅស្ថាន
សួគ៌ដរាបដល់អស់កល្បជានិច្ច[ន]
៩០សេចក្តីស្មោះត្រង់[ប]របស់ទ្រង់ក៏ស្ថិតស្ថេរនៅគ្រប់ដំណ[ផ]
មនុស្សតទៅ ទ្រង់បានប្រតិស្ឋានផែនដី
ហើយផែនដីក៏តាំងនៅជាប់[ព]
៩១ទាំងអស់ស្ថិតស្ថេរនៅ[ភ]ដរាបដល់សព្វថ្ងៃនេះតាមច្បាប់
ទ្រង់ ដ្បិតទាំងអស់សំរាប់បំរើទ្រង់[ម]
៩២បើទូលបង្គំមិនបានរីករាយក្នុងក្រិត្យវិន័យរបស់ទ្រង់[យ]
នោះទូលបង្គំនឹងបានវិនាសទៅក្នុងសេចក្តីទុក្ខព្រួយរបស់
ទូលបង្គំហើយ[រ]
៩៣ទូលបង្គំនឹងមិនដែលភ្លេច[ល]បញ្ញត្តិទ្រង់ឡើយ ដ្បិតទ្រង់
បានប្រោសឱ្យទូលបង្គំមានកំឡាំង ឡើងដោយសារបញ្ញត្តិ
ទាំងនោះឯង[វ]
៩៤ទូលបង្គំជារបស់ផងទ្រង់ហើយសូមជួយសង្គ្រោះទូលបង្គំ
ផង[ស] ដ្បិតទូលបង្គំបានស្វែងរកបញ្ញត្តិទ្រង់[ហ]
៩៥ពួកមនុស្សអាក្រក់គេបានរង់ចាំនឹងធ្វើឱ្យទូលបង្គំវិនាស[ឡ]

**១១៩:៨១** គ ខ.១២៣ ឃ ខ.៤៣ **១១៩:៨២** ង ទដ ៦:៧ ៦៩:៣ បទ ២:១១ ច ខ.៤១,១២៣ **១១៩:៨៣** ឆ ខ.៦១ **១១៩:៨៤** ជ ទដ ៦:៣ វវ ៦:១០ ឈ ខ.៥១ យរ ១២:៣ ១៥:១៥ ២០:១១ **១១៩:៨៥** ញ ខ.៥១ ដ ទដ ៣៥:៧ ៥៧:៦ យរ ១៨:២០,២២ **១១៩:៨៦** ឋ ខ.១៣៨ ឌ ទដ ៧:១ ឍ ខ.៧៨ ណ ទដ ១០៩:២៦ **១១៩:៨៧** ត ខ.១៥០ អស ១:៤,២៨ ៥៨:២ ៥៩:១៣ **១១៩:៨៨** ថ ទដ ៤១:២ ទ ខ.១២៤ ទដ ៥១:១ ១០៩:២៦ ធ ខ.២,១០០,១២៩, ១៣៤,១៦៨ **១១៩:៨៩** ន ខ.១១១, ១៤៤ ទដ ១១១:៨ អស ៥១:៦ មថ ៥:១៨ ១ពត ១:២៥ **១១៩:៩០** ប ទដ ៣៦:៥ ផ ទដ ៤៥:១៧ ព យប ៨:១៩ ទដ ១៤៨:៦ **១១៩:៩១** ភ យរ ៣៣:២៥ ម ទដ ១០៣:២–៤ យរ ៣១:៣៥ **១១៩:៩២** យ ទដ ៣៧:៤ ១១២:១ រ ខ.៥០,៦៧ **១១៩:៩៣** ល ខ.៨៣ វ ទដ ១០៣:៥ **១១៩:៩៤** ស ខ.១៤៦ ទដ ៥៤:១ ១១៦:៤ យរ ១៧:១៤ ៣១:១៨ ៤២:១១ ហ ខ.៤៥ **១១៩:៩៥** ឡ ទដ ៦៩:៤

**១១៩:៨១–៨៨** សូមជួយសង្គ្រោះទូលបង្គំពីការធ្វើទុក្ខ ឬការរងទុក្ខនិងមនុស្សបៀតបៀន គឺដោយនឹកចាំពីព្រះបន្ទូលសន្យា ហើយទូលបង្គំនឹងស្តាប់តាម ។ ចំណែកឯវគ្គចុងក្រោយរបស់ទំនុកនៃវគ្គអក្ខខណ្ឌទីមួយ ផ្នែកពាក់កណ្តាលខាងលើ ។

**១១៩:៨១** *ព្រលឹង* សូមមើលការពន្យល់ ៦:៣ ។

**១១៩:៨២** *ភ្នែកទូលបង្គំស្រវាំង* សូមមើលការពន្យល់ ៦:៧ ។

**១១៩:៨៣** *ត្រឡប់ដូចជាថង់ស្បែកដែលត្រូវផ្សែង* ដូចជាថង់ស្បែកដែលគេព្យួរនៅទីមានផ្សែង ។

**១១៩:៨៤** *តើដល់កាលណាបានទ្រង់សំរេចទោស* គឺជាការរាប់ចំនួនថ្ងៃដែលត្រូវកាត់ទោសពីព្រះដោយជីវិតទូលបង្គំខ្លីណាស់ ។ *សំរេចទោស* "គឺជាការជំនុំជម្រះ" ជាភាសាហេព្រើរក្នុងពាក្យ"សម្រេចទោស"គេនិយាយថា ។ *មីសផែក* មើលការពន្យល់ ខ.៧ "បញ្ញត្តិ" មើលការពន្យល់ ៥:១០) ។

**១១៩:៨៥** *ពួកមនុស្សឆ្មើងឆ្មៃ* សូមមើលការពន្យល់ ខ.២១ ។ *ជីករណ្តៅ* គឺអាចសំដៅទៅលើអ្នកដែលនិយាយបង្ខូច ឬជាការបៀតបៀនជាសាធារណៈដែលអ្នកនិពន្ធបទទំនុកដំកើង អាចមានកំហុសជាអំពើបាបដោយប្រការណាមួយ បើមិនដូច្នេះទេអ្នកនិពន្ធក៏មិនទទួលការឈឺចាប់ដែរ (សូមមើលការពន្យល់ ៥:៩ ៩:១៥) ។ *ល្មើសចំពោះក្រិត្យវិន័យទ្រង់* មើល នក ២០:១៦ ។

**១១៩:៨៦** *សុទ្ធតែស្មោះត្រង់* សូមមើលការពន្យល់ ខ.២៩ ("ដោយនយោបាយបោកប្រាស់") ។

**១១៩:៨៨** *សេចក្តីសប្បុរស* សូមមើលកាពន្យល់ ៤:៦ ។

**១១៩:៨៩–៩១** ភាពជាក្សត្ររបស់ព្រះអម្ចាស់ និងព្រះបន្ទូលឥតប្រែប្រួលដែលគ្រប់គ្រងនឹងថែរក្សាគ្រប់ទាំងស្នាព្រះហស្ត ។ (មានខបីដំបូងក្នុងកណ្តាលកណ្ឌគម្ពីរទំនុកដំកើង វគ្គទី២ គឺបង្រៀនពីសេចក្តីពិតទូទៅ ប្រៀបធៀប ខ.១–៣) ។

**១១៩:៨៩** *ព្រះបន្ទូលទ្រង់* ជាអត្ថន័យពីព្រះបន្ទូលដែលបង្កើតរបស់សព្វសារពើទ្រង់ក៏ថែរក្សានឹងគ្រប់គ្រងលើទាំងអស់ (សូមមើល ៣៣:៤,៦ ១០៧:២០ ១៤៧:១៥,១៨) ។ *បានតាំងនៅឯស្ថានសួគ៌ដរាបដល់អស់កល្បជានិច្ច* ព្រះបង្កើតឱ្យមានភាពសុខសាន្តល្អ ទាំងស្ថានសួគ៌និងផែនដី (ខ.៩០) ការប្រកាស (១៩:១–៤) ក៏នាំឱ្យជឿទុកចិត្តព្រះបន្ទូលរបស់ទ្រង់ (គឺជាបញ្ញត្តិទ្រង់ ខ.៩១) ។ ដោយទ្រង់គ្រប់គ្រងលើអ្វីៗទាំងអស់ ("តាមសេចក្តីសប្បុរសរបស់ទ្រង់" ខ.៩០) ដែលជាសេចក្តីបរិសុទ្ធនៃព្រះ (ជាបញ្ញត្តិនឹងសេចក្តីសន្យា) ដែលទ្រង់បានបើកសម្តែង (សូមមើលការពន្យល់ ៩៣:៥ ៩៦:១០ និងការពន្យល់ ខ.២៩ "ផ្លូវនៃការបោកប្រាស់") ។

**១១៩:៩០** *សេចក្តីស្មោះត្រង់របស់ទ្រង់* គឺជាពាក្យមិនផ្ទាល់ តែន័យពិតគឺជាព្រះបន្ទូលរបស់ទ្រង់ (សូមមើល ខ.៨៩ និងការពន្យល់) ។

**១១៩:៩២** *និងបានវិនាសទៅក្នុងសេចក្តីទុក្ខព្រួយ* គឺមិនបានរៀនសូត្រទទួលនៅផ្លូវជីវិតដែលពិតប្រាកដ (សូមមើល ខ.៩៣) គឺពុំបានរៀនពីបញ្ញត្តិរបស់ទ្រង់ (សូមមើល ខ.៦៧,៧១ និងកាពន្យល់ ខ.៦៥,៧២) ។

**១១៩:៩៥** *មនុស្សអាក្រក់* មើលការពន្យល់ ខ.២១ (មនុស្សឆ្មើងឆ្មៃ) ដែលកំពុងរង់ចាំបំផ្លាញខ្ញុំ មើលការពន្យល់ ខ.២៥ (គឺជាការបន្ទាបបន្ថោក) ។

តែទូលបង្គំនឹងពិចារណាសេចក្ដីបន្ទាល់របស់ទ្រង់[អ]
៩៦ទូលបង្គំបានឃើញចុងនៃសេចក្ដីគ្រប់លក្ខណ៍ហើយ តែ
សេចក្ដីបង្គាប់របស់ទ្រង់ធំទូលាយលើសទៅទៀត[ក] ។
៩៧ឱទូលបង្គំស្រឡាញ់ក្រឹត្យវិន័យរបស់ទ្រង់[ខ]ណាស់ហ្ន៎
ទូលបង្គំរំពឹងគិត[គ]ពីក្រឹត្យវិន័យនោះជាដរាបរាល់ថ្ងៃ
៩៨សេចក្ដីបង្គាប់របស់ទ្រង់ ក៏ធ្វើឱ្យទូលបង្គំមានប្រាជ្ញា
លើស[ឃ]ជាងខ្មាំងសត្រូវ ដ្បិតបាននៅជាប់ជាមួយនឹងទូល
បង្គំ ជាដរាប
៩៩ទូលបង្គំមានយោបល់ជាងអស់ទាំងគ្រូ របស់ទូលបង្គំទៅ
ទៀត ដ្បិតសេចក្ដីបន្ទាល់ទ្រង់ជាទីនឹករំពឹងរបស់ទូលបង្គំ[ង]
១០០ទូលបង្គំយល់បានច្រើនជាងពួកចាស់ៗ ពីព្រោះទូលបង្គំ
បានរក្សាអស់ទាំងបញ្ញត្តិរបស់ទ្រង់[ច]
១០១ទូលបង្គំបានបង្ខាំងជើង[ឆ]ឱ្យវៀរចាកពីផ្លូវអាក្រក់ដើម្បី
ឱ្យទូលបង្គំបានកាន់តាមព្រះបន្ទូលនៃទ្រង់[ជ]
១០២ទូលបង្គំមិនបានបែរចេញពីច្បាប់ទ្រង់[ឈ]ឡើយ
ដ្បិតទ្រង់បានបង្រៀន[ញ]ទូលបង្គំ
១០៣ព្រះបន្ទូលនៃទ្រង់ផ្អែមនៅអណ្ដាតទូលបង្គំណាស់
ហ្ន៎អើ ក៏ផ្អែមជាងទឹកឃ្មុំ[ដ]ដល់មាត់ទូលបង្គំទៅទៀត[ឋ]
១០៤ទូលបង្គំបានមានយោបល់[ឌ]ដោយសារបញ្ញត្តិទ្រង់ហេតុ
នោះបានជាទូលបង្គំស្អប់ដល់អស់ទាំងផ្លូវកំភូត[ឍ] ។
១០៥ព្រះបន្ទូលនៃទ្រង់ជាចង្កៀង[ណ]ដល់ជើងទូលបង្គំ
ហើយជាពន្លឺ[ត]បំភ្លឺផ្លូវរបស់ទូលបង្គំផង
១០៦ទូលបង្គំបានស្បថ[ថ] ហើយក៏នឹងសំរេចតាមថា
ទូលបង្គំនឹងកាន់តាមបញ្ញត្តិដ៏សុចរិតរបស់ទ្រង់[ទ]
១០៧ទូលបង្គំមានទុក្ខព្រួយជាច្រើនណាស់
ឱព្រះយេហូវ៉ាអើយ សូមប្រោសឱ្យទូលបង្គំមានកំឡាំង
ឡើង[ធ] តាមព្រះបន្ទូលទ្រង់
១០៨ឱព្រះយេហូវ៉ាអើយ ទូលបង្គំសូមអង្វរឱ្យទ្រង់ទទួល
ដង្វាយនៃមាត់ទូលបង្គំ[ន]ដែលថ្វាយដោយស្ម័គ្រពីចិត្តហើយ
សូមបង្រៀនអស់ទាំងច្បាប់ទ្រង់ដល់ទូលបង្គំផង[ប]
១០៩ជីវិតនៃទូលបង្គំមានអន្តរាយឥតឈប់ឈរ[ផ]
តែទូលបង្គំមិនភ្លេច[ព]ក្រឹត្យវិន័យរបស់ទ្រង់ឡើយ
១១០ពួកមនុស្ស អាក្រក់បានដាក់អន្ទាក់[ភ]ចង់ចាប់ទូលបង្គំ
ប៉ុន្តែទូលបង្គំមិនបានវង្វេងចេញ[ម]ពីបញ្ញត្តិទ្រង់ទេ
១១១ទូលបង្គំបានទទួលយក សេចក្ដីបន្ទាល់ទ្រង់ទុកជាមរដក
នៅជាដរាប ដ្បិតសេចក្ដីទាំងនោះនាំឱ្យចិត្តទូលបង្គំបាន
រីករាយ[យ]
១១២ទូលបង្គំបានលំអៀងចិត្តទៅឱ្យសំរេច[រ]តាមបញ្ញត្តិទ្រង់
នៅជាដរាប រហូតដល់ចុងបំផុត[ល] ។
១១៣ទូលបង្គំស្អប់ចំពោះអស់អ្នកដែលមានចិត្ត២តែ[វ]
ទូលបង្គំស្រឡាញ់ដល់ក្រឹត្យវិន័យទ្រង់វិញ[ស]
១១៤ទ្រង់ជាទីពឹងជ្រក ហើយជាខែលរបស់ទូលបង្គំ[ហ]
ទូលបង្គំសង្ឃឹម[ឡ]ដល់ព្រះបន្ទូលនៃទ្រង់

**១១៩:៩៥** អ ខ.៩៩ **១១៩:៩៦** ក ទដ ១៩:៧ **១១៩:៩៧** ខ ខ.៤៧ គ ខ.១៥ **១១៩:៩៨** ឃ ខ.១៣០ ចទ ៤:៦ ទដ ១៩:៧ ២ធថ ៣:១៥ **១១៩:៩៩** ង ខ.១៥ **១១៩:១០០** ច ខ.៥៦ ចទ ៦:១៧ **១១៩:១០១** ឆ សភ ១:១៥ ជ ខ.៥៧ **១១៩:១០២** ឈ ចទ ១៧:២០ ញ ចទ ៤:៥ **១១៩:១០៣** ដ ទដ ១៩:១០ ឋ សភ ២៤:១៣–១៤ **១១៩:១០៤** ឌ ទដ ១១១:១០ ឍ ខ.១២៨ **១១៩:១០៥** ណ សភ ២០:២៧ ២ពត ១:១៩ ត ខ.១៣០ សភ ៦:២៣ **១១៩:១០៦** ថ នហ ១០:២៩ ទ ខ.៧ **១១៩:១០៧** ធ ខ.២៥ **១១៩:១០៨** ន ទដ ៥១:១៥ ៦៣:៥ ៧១:៨ ១០៩:៣០ ប ខ.៦៤ **១១៩:១០៩** ផ ពច ១២:៣ ព ខ.៦១ **១១៩:១១០** ភ ទដ ២៥:១៥ ៦៤:៥ អស ៨:១៤ អម ៣:៥ ម ខ.១០ **១១៩:១១១** យ ខ.១៤,១៦២ **១១៩:១១២** រ ទដ ១០៨:១ ល ខ.៣៣ **១១៩:១១៣** វ ១ពវ ១៨:២១ យក ១:៨ ៤:៨ ស ខ.៤៧ **១១៩:១១៤** ហ លប ១៥:១ ទដ ១៨:២ ឡ ខ.៤៣

**១១៩:៩៦** *សេចក្ដីគ្រប់លក្ខណ៍* គឺជាសេចក្ដីពេញខ្នាតខាងឯព្រលឹងវិញ្ញាណ ដោយបានដាក់គ្រប់ទាំងដំណើរជីវិត នៅលើផ្លូវសុចរិតរបស់ព្រះ ។ *ធំទូលាយលើសទៅទៀត* គឺគ្រប់អស់ដែលចេញពីព្រះបន្ទូលរបស់ទ្រង់លើសពីភាពគ្រប់លក្ខណ៍ទាំងនោះ ហើយសេចក្ដីទាំងនោះហើយ ដែលជាប្រភពជីវិតដល់មនុស្សក្នុងលោកិយ (មើល ខ.៩៧–១០០) ។
**១១៩:៩៧–១០៤** គឺជាការសញ្ជឹងគិតទៅលើសេចក្ដីបញ្ញត្តិរបស់ទ្រង់ដែលនាំឱ្យមានភោគផលជីវិត គឺជាប្រាជ្ញាដ៏ឧត្តមក្រៃលែង ។
**១១៩:៩៨** *ខ្មាំងសត្រូវ* គឺជាពួកមនុស្សឆ្មើងឆ្មៃ (សូមមើលការពន្យល់ ខ.២១) គឺអ្នកដែលផ្ទេរការទុកចិត្តលើអំណាចលោកិយ ។
**១១៩:៩៩** *គ្រូ* គឺជាគ្រូរបស់លោក ។
**១១៩:១០០** *ពួកចាស់ៗ* អាចជាមនុស្សចាស់ៗ មនុស្សមានបទពិសោធន៍ច្រើនទាំងការបម្រើនិងការសិក្សា (សូមមើលការពន្យល់ នក ៣:១៦) ។
**១១៩:១០២** *ដ្បិតទ្រង់បានបង្រៀនទូលបង្គំ* តាមរយៈបញ្ញត្តិរបស់ទ្រង់ ។
**១១៩:១០៣** *ព្រះបន្ទូល* គឺអាចជា"បញ្ញត្តិ"របស់ព្រះអម្ចាស់(សូមមើល ខ.៦៧,១៣៣,១៥៨,១៧២ និងការពន្យល់ ខ.៧១) ។
**១១៩:១០៤** *ស្អប់ដល់អស់ទាំងផ្លូវកំភូត* សូមមើលការពន្យល់ ខ.៥២ ។
**១១៩:១០៥** *ចង្កៀង . . . ពន្លឺ* នៅឯទីងងឹតយើងអាចឃើញពន្លឺនោះយ៉ាងច្បាស់លាស់ដោយមិនកំបាំង ។
**១១៩:១០៦** *បានស្បថហើយក៏នឹងសំរេចតាម* ដូចជាមានក្នុងសេចក្ដីសញ្ញា (សូមមើល នហ ១០:២៩) ។
**១១៩:១០៧** សូមមើល ខ.២៥ និងការពន្យល់ ។
**១១៩:១០៩** *ជីវិតទូលបង្គំមានអន្តរាយឥតឈប់ឈរ* ដោយការបញ្ជោតរបស់ព្រះអម្ចាស់ដ៏សុចរិតទោះជាក្នុងកាលៈទេសៈណា ដែលប្រឈមមុខនិងការគម្រាមកំហែង ឬក៏ភាពមហន្តរាយក៏ដោយ (សូមមើល ខ.២៣,៤៦,១៦១) ។
**១១៩:១១០** *បានដាក់អន្ទាក់* សូមមើល ខ.៨៥ និងការពន្យល់ ។
**១១៩:១១១–១១២** *ចិត្ត* មើលការពន្យល់ ៤:៧ ។
**១១៩:១១១** *ទុកជាមរដក* គឺជាកម្មសិទ្ធិបានទទួលពីព្រះអម្ចាស់ទុកដូចជាផ្ទះកំណើតរបស់ទូលបង្គំ គឺអ្វីដែលបានទទួលផលនៃជីវិត (សូមមើលការពន្យល់ ខ.៥៧–៦៤) ។
**១១៩:១១៣** *ស្អប់ចំពោះអស់អ្នកដែលមានចិត្ត២* សូមមើល ខ.១១៥ និងការពន្យល់ ខ.៥៣ ។ មនុស្សដែលមានចិត្ត២ គឺពុំអាចសម្រេចនូវអ្វីដែលគេបានប្រព្រឹត្តនោះទេ (យក ១:៨) ។
**១១៩:១១៤** *ព្រះបន្ទូល* សូមមើលការពន្យល់ ខ.២៥ ។

១១៥ នែ អ្នករាល់គ្នាដែលប្រព្រឹត្តអាក្រក់ អើយ ចូលថយពីអញចេញ[អ] ដើម្បីឱ្យអញបានរក្សាសេចក្ដីបង្គាប់របស់ព្រះនៃអញ
១១៦ សូមទប់ទល់ទូលបង្គំ[ក] តាមព្រះបន្ទូលនៃទ្រង់[ខ] ឱ្យទូលបង្គំបានរស់នៅសូមកុំឱ្យទូលបង្គំត្រូវខ្មាស ដោយព្រោះសេចក្ដីសង្ឃឹមរបស់ទូលបង្គំឡើយ[គ]
១១៧ សូមទ្រង់ធ្វើជាបង្អែកនៃទូលបង្គំ[ឃ] ឱ្យទូលបង្គំបានសេចក្ដីសុខ[ង] នោះទូលបង្គំនឹងគោរពរាប់អានចំពោះបញ្ញត្តិទ្រង់ជានិច្ច[ច]
១១៨ ទ្រង់បានលើកថ្លឹងនូវអស់អ្នកដែលវង្វេងចេញ[ឆ] ពីបញ្ញត្តិទ្រង់ ដ្បិតសេចក្ដីឆបោករបស់គេជាសេចក្ដីកំភូតទទេ
១១៩ ទ្រង់ធ្វើឱ្យពួកមនុស្សអាក្រក់បាត់ចេញពីផែនដី ដូចជាគេដួសពពុះចេញពីឆ្នាំង[ជ] ហេតុនោះបានជាទូលបង្គំស្រឡាញ់ដល់សេចក្ដីបន្ទាល់របស់ទ្រង់[ឈ]
១២០ រូបសាច់ទូលបង្គំញ័ររញ្ជាក់[ញ] ដោយភ័យខ្លាចដល់ទ្រង់[ដ] ទូលបង្គំក៏ខ្លាច[ឋ] ចំពោះសេចក្ដីវិនិច្ឆ័យរបស់ទ្រង់ដែរ ។
១២១ ទូលបង្គំបានសំរេចតាមសេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិត[ឌ] សូមកុំបោះបង់ចោលទូលបង្គំទៅក្នុងអំណាចនៃពួកអ្នកដែលសង្កត់សង្កិនឡើយ
១២២ សូមទ្រង់ធានាឱ្យអ្នកបំរើទ្រង់បានសេចក្ដីល្អ[ឍ] សូមកុំឱ្យពួកមនុស្សឆ្មើងឆ្មៃសង្កត់សង្កិនទូលបង្គំឡើយ[ណ]
១២៣ ភ្នែកទូលបង្គំស្រវាំងទៅ[ត] ដោយទន្ទឹងចាំឱ្យបានសេចក្ដីសង្គ្រោះ[ថ] និងព្រះបន្ទូល ដ៏សុចរិតរបស់ទ្រង់[ទ]
១២៤ សូមប្រព្រឹត្តនឹងអ្នកបំរើទ្រង់ តាមសេចក្ដីសប្បុរស[ធ] របស់ទ្រង់ហើយបង្រៀនអស់ទាំងបញ្ញត្តិរបស់ទ្រង់ដល់ទូលបង្គំ[ន]
១២៥ ទូលបង្គំជាអ្នកបំរើទ្រង់ហើយ[ប] សូមប្រទានឱ្យទូលបង្គំមានយោបល់ ដើម្បីឱ្យបានស្គាល់សេចក្ដីបន្ទាល់របស់ទ្រង់[ផ]
១២៦ នេះជាវេលាដែលគួរឱ្យព្រះយេហូវ៉ាសំរេចការហើយ ដ្បិតគេបានរំលងល្មើសចំពោះក្រិត្យវិន័យរបស់ទ្រង់[ព]
១២៧ ហេតុនោះបានជាទូលបង្គំ ស្រឡាញ់ដល់សេចក្ដីបង្គាប់[ភ] របស់ទ្រង់ច្រើនជាងមាស[ម] អើ ក៏ស្រឡាញ់ច្រើនជាងមាសសុទ្ធផង[យ]
១២៨ ដូច្នេះ ទូលបង្គំរាប់អស់ទាំងបញ្ញត្តិទ្រង់ថាជាត្រឹមត្រូវ[រ] គ្រប់ប្រការ តែទូលបង្គំ ស្អប់ដល់គ្រប់ទាំងផ្លូវកំភូតវិញ[ល] ។
១២៩ សេចក្ដីបន្ទាល់របស់ទ្រង់សុទ្ធតែអស្ចារ្យ[វ] ហេតុនោះបានជាព្រលឹងនៃទូលបង្គំគោរពកាន់តាម[ស]
១៣០ ការបើកសំដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញ[ហ] ក៏ធ្វើឱ្យមនុស្សឆោតល្ងង់មានយោបល់[ឡ]
១៣១ ទូលបង្គំបានហាមាត់ដកដង្ហើមធំ[អ] ដោយនឹករឭកដល់សេចក្ដីបង្គាប់របស់ទ្រង់[ក]
១៣២ សូមទ្រង់បែរមក[ខ] មានសេចក្ដីអាណិតមេត្តា[គ] ដល់ទូលបង្គំ ដូចជាទ្រង់តែងធ្លាប់ធ្វើដល់អស់អ្នកដែលស្រឡាញ់ព្រះនាមទ្រង់[ឃ]

**១១៩:១១៥** អ ទដ ៦:៨
**១១៩:១១៦** ក ទដ ១៨:៣៥ ៤១:៣ ៥៥:២២ អស ៤៦:៤ ខ ខ.៤១ គ រម ៥:៥
**១១៩:១១៧** ឃ អស ៤១:១០ ៤៦:៤ ង ទដ ៣៤:៤ ច ខ.៦
**១១៩:១១៨** ឆ ខ.១០
**១១៩:១១៩** ជ អស ១:២២,២៥ អក ២២:១៨,១៩ ឈ ខ.៤៧
**១១៩:១២១** ញ យប ៤:១៤ អស ៦៤:២ ដ យស ២៤:១៤ ឋ យរ ១០:៧ ហព ៣:២
**១១៩:១២១** ឌ ២សយ ៨:១៥ យប ២៧:៦
**១១៩:១២២** ឍ យប ១៧:៣ ណ ខ.២១,១២១,១៣៤ ទដ ១០៦:៤២
**១១៩:១២៣** ត អស ៣៨:១៤ ថ ខ.៨១ ទ ខ.៨២
**១១៩:១២៤** ធ ខ.៨៨ ទដ ២៥:៧ ន ខ.១២
**១១៩:១២៥** ប ទដ ១១៦:១៦ ផ ខ.៧៩

**១១៩:១២៦** ព ជន ១៥:៣១ **១១៩:១២៧** ភ ខ.៤៧ ម ទដ ១៩:១០ យ យប ៣:២១ **១១៩:១២៨** រ ទដ ១៩:៨ ល ខ.១០៤,១៦៣ ទដ ៣១:៦ សភ ១៣:៥ **១១៩:១២៩** វ ខ.១៨ ស ខ.២២,៨៨ **១១៩:១៣០** ហ ខ.១០៥ ឡ ទដ ១៩:៧ **១១៩:១៣១** អ ទដ ៤២:១ ក ខ.២០ **១១៩:១៣២** ខ ទដ ៦:៤ គ ២សយ ២៤:១៤ ទដ ៩:១៣ ឃ ទដ ៥:១១

**១១៩:១១៨** ទ្រង់បានកំចាត់ពួកអ្នកដែលវង្វេងផ្លូវនៃសេចក្ដីបោកបញ្ឆោតទទេ (សូមមើលការពន្យល់ ខ.២៩) ។

**១១៩:១១៩** *ពពុះចេញពីឆ្នាំង* គឺជាការជ្រើសសម្រាំងនូវភាពខ្ជិលច្រអូស ឬភាពអាក្រក់របស់មនុស្សជាពិសេសអ្នកដែលរស់នៅមានសណ្ឋានជីវិត ដូចពពុះទឹកដែលតែងតែរលាយបាត់ទៅ ខ.១១៨ ។

**១១៩:១២០** *រូបសាច់ទូលបង្គំញ័ររញ្ជាក់* គឺជាការភ័យខ្លាចចំពោះព្រះចេស្ដារបស់ទ្រង់ ។

**១១៩:១២១–១២៨** ក្នុងនាមជាអ្នកបម្រើដ៏ស្មោះត្រង់ ដែលបានអធិស្ឋានដើម្បីដោះលែងពីភាពជិះជាន់ ក៏មានវគ្គទៀតដែលអ្នករងគ្រោះបានអធិស្ឋានសុំឱ្យរួចផុតពីការគ្រប់គ្រងជិះជាន់ (មើល ខ.៨១–៨៨ និងការពន្យល់ ខ.២៥) ។

**១១៩:១២២** គឺជាខតែមួយគត់ ដែលនៅក្នុងព្រះគម្ពីរទំនុកដំកើងដែលមិនបង្ហាញធំៗទេ (ដូចជាមានក្នុង ខ.៩០,១២១,១៣២ ក៏សូមមើលការពន្យល់ ខ.២១) ។

**១១៩:១២៣** *ភ្នែកទូលបង្គំស្រវាំងទៅ* សូមមើលការពន្យល់ ៦:៧ ។

**១១៩:១២៤** *សេចក្ដីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**១១៩:១២៦** *សំរេចការ* គឺជាការដែលព្រះយេហូវ៉ាបានការពារដល់អ្នកបម្រើទ្រង់ ហើយក៏ជាពេលដែលព្រះបានសម្រេចការជំនុំជម្រះដល់ពួកអ្នកដែលដើររំលងបញ្ញត្តិទ្រង់ ។

**១១៩:១២៧** *ច្រើនជាងមាស* សូមមើល ខ.១៤,៥៧,៧២,១១១ ។

**១១៩:១២៩** *សុទ្ធតែអស្ចារ្យ* សូមមើល ខ.១៨ និងការពន្យល់ ។

**១១៩:១៣០** *ការបើកសំដែង* តាមលក្ខណៈអក្សរសាស្ត្រគឺស្មើនិង"បង្ហាញឱ្យឃើញ"ក៏មានន័យថា: (១).ការសម្ដែងព្រះបន្ទូល (២).ការបកស្រាយ (មើលពាក្យថា"អធិប្បាយ ពណ៌នា" នៅក្នុង ៤៩:៤) ពីព្រះបន្ទូលរបស់ទ្រង់ ឬក៏ (៣).បញ្ចូលព្រះបន្ទូលទៅក្នុងចិត្ត ។ ពាក្យថា *ឆោតល្ងង់* សូមមើល ១៩:៧ និងកាពន្យល់ ។

**១១៩:១៣២** *ដូចជាទ្រង់តែងធ្លាប់ធ្វើ* តាមបែបអក្សរសាស្ត្រមានន័យថា"ដូចជាព្រះទ័យដែលមាននោះ" ។

១៣៣សូមតាំងជំហាននៃទូលបង្គំឱ្យដើរតាមព្រះបន្ទូលទ្រង់[ង]
សូមកុំឱ្យសេចក្តីទុច្ចរិតណាមានអំណាច[ច] លើទូលបង្គំ
ឡើយ
១៣៤សូមលោះទូលបង្គំឱ្យរួចពីការសង្កត់សង្កិនរបស់
មនុស្ស[ឆ] នោះទូលបង្គំនឹងកាន់តាមបញ្ញត្តិទ្រង់[ជ]
១៣៥សូមឱ្យព្រះភក្ត្រទ្រង់ភ្លឺ[ឈ] មកលើអ្នកបំរើទ្រង់
ហើយបង្រៀនអស់ទាំងបញ្ញត្តិទ្រង់ដល់ទូលបង្គំផង[ញ]
១៣៦ទឹកភ្នែក[ដ] ទូលបង្គំហូរហាម ពីព្រោះគេមិនកាន់តាម
ក្រិត្យវិន័យរបស់ទ្រង់[ឋ] ។
១៣៧ឱព្រះយេហូវ៉ាអើយ ទ្រង់សុចរិត[ឌ] ហើយសេចក្តី
វិនិច្ឆ័យរបស់ទ្រង់ក៏សុទ្ធតែទៀងត្រង់[ឍ]
១៣៨ទ្រង់បានតាំងសេចក្តីបន្ទាល់របស់ទ្រង់នៅលើសេចក្តី
យុត្តិធម៌[ណ] ហើយលើសេចក្តីស្មោះត្រង់ដ៏ពិតផង[ត]
១៣៩សេចក្តីឧស្សាហ៍របស់ទូលបង្គំបានស៊ីបង្ហិនទូលបង្គំ[ថ]
ពីព្រោះពួកអ្នកតតាំងនឹងទូលបង្គំ គេបានភ្លេចព្រះបន្ទូល
ទ្រង់
១៤០ព្រះបន្ទូលទ្រង់[ទ] បានត្រូវសំរងយ៉ាងបរិសុទ្ធ[ធ] ជាទីបំផុត
ហើយហេតុនោះអ្នកបំរើរបស់ទ្រង់ក៏ស្រឡាញ់ណាស់[ន]
១៤១ឯទូលបង្គំជាអ្នកតូច ហើយត្រូវគេមើលងាយ[ប] ប៉ុន្តែ
ទូលបង្គំមិនភ្លេចបញ្ញត្តិរបស់ទ្រង់ឡើយ[ផ]
១៤២សេចក្តីសុចរិតរបស់ទ្រង់ជាសេចក្តីសុចរិត ដ៏នៅអស់
កល្បជានិច្ច ហើយក្រិត្យវិន័យទ្រង់ជាសេចក្តីពិត[ព]
១៤៣សេចក្តីទុក្ខ នឹងសេចក្តីលំបាក បានមកគ្របសង្កត់លើ
ទូលបង្គំហើយ
ទោះបើយ៉ាងនោះ គង់តែសេចក្តីបង្គាប់របស់ទ្រង់ជាទី
រីករាយដល់ទូលបង្គំដែរ[ភ]
១៤៤សេចក្តីបន្ទាល់របស់ទ្រង់សុទ្ធ តែសុចរិតនៅជាដរាប
សូមប្រោសឱ្យទូលបង្គំមានយោបល់[ម] នោះទូលបង្គំនឹង
បានរស់នៅ ។
១៤៥ទូលបង្គំបានអំពាវនាវដល់ទ្រង់អស់ពីចិត្ត[យ]
ឱព្រះយេហូវ៉ាអើយ សូមឆ្លើយមកទូលបង្គំផង ទូលបង្គំ
នឹងរក្សាអស់ទាំងបញ្ញត្តិរបស់ទ្រង់[រ]
១៤៦ទូលបង្គំបានអំពាវនាវដល់ទ្រង់ ហើយសូមជួយសង្គ្រោះ
ទូលបង្គំផង[ល] នោះទូលបង្គំនឹងកាន់តាមសេចក្តីបន្ទាល់
របស់ទ្រង់
១៤៧ទូលបង្គំបានភ្ញាក់មុនពេលព្រលឹមស្រាង[វ] ហើយបាន
បន្លឺឡើងថា ទូលបង្គំបានសង្ឃឹមដល់ព្រះបន្ទូលទ្រង់
១៤៨ទូលបង្គំភ្ញាក់មុនអស់ទាំងយាមយប់[ស] ហើយបើកភ្នែក
ដើម្បីរំពឹងគិតពីព្រះបន្ទូលទ្រង់
១៤៩សូមស្តាប់សំឡេងទូលបង្គំ[ហ] តាមសេចក្តីសប្បុរស[ឡ]
របស់ទ្រង់ ឱព្រះយេហូវ៉ាអើយ សូមប្រោសឱ្យទូលបង្គំ[អ]
មានកំឡាំងឡើង តាមច្បាប់របស់ទ្រង់
១៥០ពួកអ្នកដែល រត់តាមសេចក្តីអាក្រក់[ក] គេមកកាន់តែជិត
គេនៅឆ្ងាយពីក្រិត្យវិន័យទ្រង់ទេ
១៥១ឯទ្រង់ ឱព្រះយេហូវ៉ាអើយ ទ្រង់គង់នៅជិតដែរ[ខ]
ហើយគ្រប់ទាំងសេចក្តីបង្គាប់របស់ទ្រង់សុទ្ធតែពិតត្រង់[គ]
១៥២តាំងពីយូរមកហើយ ទូលបង្គំបានដឹងដោយសារ
សេចក្តីបន្ទាល់[ឃ] របស់ទ្រង់ថា ទ្រង់បានតាំងសេចក្តីទាំង
នោះឱ្យនៅអស់កល្បជានិច្ច[ង] ។
១៥៣សូមទតមើលសេចក្តីទុក្ខព្រួយ[ច] របស់ទូលបង្គំ
ហើយជួយឱ្យរួចផង[ឆ] ដ្បិតទូលបង្គំមិនភ្លេច[ជ]

**១១៩:១៣៣** ង ខ.៩ ច ខ.១១ រម ៦:១៦ **១១៩:១៣៤** ឆ ខ.១២២ ជ ខ.៥៦,៨៨ **១១៩:១៣៥** ឈ ជន ៦:២៥ ទដ ៤:៦ ៦៧:១ ៨០:៣ ញ ខ.១២ **១១៩:១៣៦** ដ ទដ ៦:៦ អស ២២:៤ យរ ៩:១,១៨ ១៣:១៧ ១៤:១៧ បទ ១:១៦ ៣:៤៨ ឋ ខ.១៥៨ ទដ ១០៦:២៥ អស ៤២:២៤ អគ ៩:៤ **១១៩:១៣៧** ឌ នក ៩:២៧ អរ ៩:១៥ ឍ នហ ៩:១៣ **១១៩:១៣៨** ណ ខ.៧៥ ទដ ១៩:៧ ត ខ.៨៦ **១១៩:១៣៩** ថ ទដ ៦៩:៩ យហ ២:១៧ **១១៩:១៤០** ទ យស ២៣:១៤ ធ ទដ ១២:៦ ន ខ.៤៧ **១១៩:១៤១** ប ទដ ២២:៦ ផ ខ.៦១, ១៣៤ **១១៩:១៤២** ព ខ.១៥១,១៦០ ទដ ១៩:៧ **១១៩:១៤៣** ភ ខ.២៤,៤៧ **១១៩:១៤៤** ម ខ.៣៤ **១១៩:១៤៥** យ ខ.១០ **១១៩:១៤៥** រ ខ.២២, ៥៥ **១១៩:១៤៦** ល ខ.៩៤ **១១៩:១៤៧** វ ទដ ៥:៣ ៥៧:៨ ១០៨:២ **១១៩:១៤៨** ស ទដ ៦៣:៦ **១១៩:១៤៩** ហ ទដ ២៧:៧ ឡ ខ.១២៤ អ ខ.៤០ **១១៩:១៥០** ក ទដ ៣៧:៧ **១១៩:១៥១** ខ ទដ ៣៤:១៨ ភល ៤:៥ គ ខ.១៤២ **១១៩:១៥២** ឃ ខ.៧,៧៣ ង ខ.៨៩ ទដ ១១១:៨ លក ២១:៣៣ **១១៩:១៥៣** ច ទដ ១៣:៣ ឆ ទដ ៣:៧ ជ ទដ ៤៤:១៧

**១១៩:១៣៤** *ការសង្កត់សង្កិន* សូមមើលការពន្យល់ ខ.២៥ ។

**១១៩:១៣៥** *ព្រះភក្ត្រទ្រង់ភ្លឺមក* សូមមើលការពន្យល់ ១៣:១ ដែលទ្រង់បាន ("លាក់ព្រះភក្ត្រទ្រង់") ។

**១១៩:១៣៦** សូមមើល ខ.៥៣ និងការពន្យល់ ។

**១១៩:១៣៧–១៤៤** ព្រះយេហូវ៉ានឹងបញ្ញត្តិរបស់ផងទ្រង់គឺសុចរិត ។

**១១៩:១៣៧** *សុចរិត* សូមមើលការពន្យល់ ៤:១ ។

**១១៩:១៣៨** *សុទ្ធតែទៀងត្រង់* សូមមើល ខ.១៤២ ក៏សូមមើលការពន្យល់ ខ.២៩ ដែលបង្ហាញភាពផ្ទុយគឺ(ដោយភូតភរ) ។

**១១៩:១៤០** *ព្រះបន្ទូលទ្រង់* គឺសំដៅលើព្រះបន្ទូលសន្យាជាភាសាហេព្រើរ មានន័យថា អ៊ីមរ៉ា ពេលខ្លះគេថាជាព្រះបន្ទូលសន្យា (សូមមើលការពន្យល់ ខ.១១) ។ ទ្រង់ក៏មានព្រះបន្ទូលជាការល្បងលដល់រាស្ត្រទ្រង់ ។

**១១៩:១៤១** *ជាអ្នកតូច ហើយត្រូវគេមើលងាយ* ធៀបនឹង ខ.២៥,១៤៣ ។

**១១៩:១៤៥–១៥២** សូមជួយទូលបង្គំផងព្រះយេហូវ៉ាអើយ ទូលបង្គំនឹងរក្សាបញ្ញត្តិច្បាប់ទ្រង់ដូចជាក្នុងទំនុកដំកើង ដោយទូលបង្គំមានពួកសត្រូវមកគ្របដណ្តប់ជិះជាន់លើ សូមទ្រង់ជួយទូលបង្គំផង(មើលការពន្យល់ ខ.២៥) ។

**១១៩:១៤៨** *អស់ទាំងយាមយប់* មើលការពន្យល់ ពច ៧:១៩ ទដ ២:១៩ ។

**១១៩:១៤៩** *សេចក្តីសប្បុរស* មើលការពន្យល់ ៦:៤ ។ *តាមច្បាប់របស់ទ្រង់* ឬក៏ "សេចក្តីយុត្តិធម៌របស់ទ្រង់" (ការសម្តែងនូវ "សេចក្តីស្រឡាញ់របស់ទ្រង់")ជាភាសាហេព្រើរនិយាយថា ។ *ម៉ុសផែត* មើលការពន្យល់ ខ.៧៥ ។

**១១៩:១៥០** *គេនៅឆ្ងាយពីក្រិត្យវិន័យទ្រង់ទេ* សូមមើល ខ.២១,៥៣,១១៨, ១២៦,១៣៩,១៥៥,១៥៨ ។

**១១៩:១៥២** *នៅអស់កល្បជានិច្ច* សូមមើលការពន្យល់ ខ.៥២ ។

ក្រិត្យវិន័យរបស់ទ្រង់ឡើយ
១៥៤សូមការពាររឿងក្តី[ឈ] របស់ទូលបង្គំ ហើយលោះទូល
បង្គំផង[ញ] សូមប្រោសឱ្យទូលបង្គំ[ដ]មានកំឡាំង តាមព្រះ
បន្ទូលទ្រង់[ឋ]
១៥៥សេចក្តីសង្គ្រោះរមែងនៅឆ្ងាយពីពួកមនុស្សអាក្រក់
ពីព្រោះគេមិនស្វែងរក[ឌ]បញ្ញត្តិរបស់ទ្រង់
១៥៦ឱព្រះយេហូវ៉ាអើយ សេចក្តីមេត្តាករុណាដ៏ទន់សន្តោស
របស់ទ្រង់ នោះលើសលប់[ឍ] សូមប្រោសឱ្យទូលបង្គំ[ណ]
មានកំឡាំងតាមច្បាប់របស់ទ្រង់[ត]
១៥៧ឯពួកអ្នកដែលបៀតបៀន ហើយតតាំងនឹងទូលបង្គំ[ថ]
គេមានគ្នាច្រើន ប៉ុន្តែ ទូលបង្គំមិនបានបែរចេញ[ទ]ពីសេច
ក្តីបន្ទាល់របស់ទ្រង់ឡើយ
១៥៨ទូលបង្គំបានពិចារណាមើលមនុស្សក្បត់ហើយក៏ស្អប់
ខ្ពើមគេ[ធ] ដោយព្រោះមិនកាន់តាមព្រះបន្ទូលទ្រង់សោះ[ន]
១៥៩សូមទ្រង់ពិចារណាដែលទូលបង្គំស្រឡាញ់ដល់អស់ទាំង
បញ្ញត្តិរបស់ទ្រង់ជាយ៉ាងណាឱព្រះយេហូវ៉ាអើយ សូម
ប្រោសឱ្យទូលបង្គំ[ប]មានកំឡាំងឡើង តាមសេចក្តី
សប្បុរសរបស់ទ្រង់
១៦០បូករួម អស់ទាំងព្រះបន្ទូលនៃទ្រង់ទៅឃើញថា ពិត
ត្រង់ទាំងអស់ ហើយគ្រប់ទាំងច្បាប់ដ៏សុចរិតរបស់ទ្រង់
ក៏ស្ថិតស្ថេរនៅអស់កល្បជានិច្ចដែរ[ផ] ។
១៦១ពួកអ្នកធំបានបៀតបៀនទូលបង្គំ[ព]ដោយឥតហេតុ
ប៉ុន្តែចិត្តទូលបង្គំនៅតែភ័យញ័រ[ភ]ចំពោះព្រះបន្ទូលទ្រង់
១៦២ទូលបង្គំមានសេចក្តីរីករាយ[ម]ចំពោះព្រះបន្ទូលទ្រង់
ប្រៀបដូចជាមនុស្សណាដែលប្រទះនឹងរឹបជាច្រើន[យ]
១៦៣ទូលបង្គំជិនណាយ ហើយក៏ស្អប់ខ្ពើម[រ] សេចក្តីកំភូតតែ
ស្រឡាញ់ដល់ក្រិត្យវិន័យទ្រង់វិញ[ល]
១៦៤ទូលបង្គំសរសើរដល់ទ្រង់ក្នុង១ថ្ងៃ៧ដងដោយព្រោះ
ច្បាប់ដ៏សុចរិតរបស់ទ្រង់[វ]

**១១៩:១៥៤** ឈ ទដ ៣៥:១ យរ ៥០:៣៤ មីក ៧:៩ ញ ១សយ ២៤:១៥ ដ ខ.២៥ ឋ ខ.៤១
**១១៩:១៥៥** ឌ ខ.៩៤, ១១៨
**១១៩:១៥៦** ឍ នហ ៩:២៧ យក ៥:១១ ណ ខ.២៥ ត ខ.១៤៩
**១១៩:១៥៧** ថ ទដ ៧:១ ទ ទដ ៤៤:១៨
**១១៩:១៥៨** ធ ខ.១០៤ នក ៣២:១៩ ន ខ.១៣៦
**១១៩:១៥៩** ប ខ.២៥ ទដ ៤១:២
**១១៩:១៦០** ផ ខ.៨៩ ទដ ១១១:៨
**១១៩:១៦១** ព ខ.២៣, ១២២,១៥៧ ១សយ ២៤:១៤–១៥ ភ ខ.១២០
**១១៩:១៦២** ម ខ.១១១ យ ១សយ ៣០:១៦ អស ៩:៣ ៥៣:១២
**១១៩:១៦៣** រ ខ.១២៨ ល ខ.៤៧
**១១៩:១៦៤** វ ខ.៧,១៦០
**១១៩:១៦៥** ស ទដ ៣៧:១១ អស ២៦:៣,១២ ២៧:៥ ៣២:១៧ ៥៧:១៩ ៦៦:១២ ហ ខ.១១ ទដ ៣៧:២៤ ១យហ ២:១០

១៦៥ពួកអ្នកដែលស្រឡាញ់ក្រិត្យវិន័យទ្រង់
នោះមានសេចក្តីសុខ[ស]ដ៏លើសលប់ ហើយគ្មានហេតុនឹង
ចំពប់ដួលឡើយ[ហ]
១៦៦ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានសង្ឃឹមដល់សេចក្តី
សង្គ្រោះរបស់ទ្រង់[ឡ] ក៏បានប្រព្រឹត្តតាមបង្គាប់របស់ទ្រង់
ដែរ
១៦៧ព្រលឹងទូលបង្គំបានកាន់តាមសេចក្តីបន្ទាល់របស់ទ្រង់
ទូលបង្គំក៏ស្រឡាញ់សេចក្តីបន្ទាល់[អ]នោះយ៉ាងក្រៃលែង
១៦៨ទូលបង្គំបានកាន់តាមអស់ទាំងបញ្ញត្តិ[ក] និងសេចក្តី
បន្ទាល់[ខ]របស់ទ្រង់ ពីព្រោះអស់ទាំងផ្លូវដែលទូលបង្គំ
ប្រព្រឹត្ត នោះសុទ្ធតែនៅ[គ]ចំពោះទ្រង់ហើយ ។
១៦៩ឱព្រះយេហូវ៉ាអើយ សូមឱ្យសំរែករបស់ទូលបង្គំ
បានចូលមក[ឃ]ជិតនៅចំពោះទ្រង់សូមប្រទានទូលបង្គំមាន
យោបល់[ង]តាមព្រះបន្ទូលទ្រង់[ច]
១៧០សូមឱ្យពាក្យអង្វររបស់ទូលបង្គំបានមក[ឆ]នៅចំពោះទ្រង់
សូមប្រោសទូលបង្គំឱ្យបានរួច[ជ]តាមព្រះបន្ទូលទ្រង់ផង[ឈ]
១៧១សូមអនុញ្ញាតឱ្យបបូរមាត់ទូលបង្គំបានពោលពាក្យ
សរសើរ[ញ] ដ្បិតទ្រង់បង្រៀនអស់ទាំងបញ្ញត្តិរបស់ទ្រង់
ដល់ទូលបង្គំ[ដ]
១៧២សូមឱ្យអណ្តាតទូលបង្គំបានច្រៀង[ឋ]ពីព្រះបន្ទូលទ្រង់
ពីព្រោះគ្រប់ទាំងសេចក្តីបង្គាប់របស់ទ្រង់សុទ្ធតែសុចរិត
ទាំងអស់[ឌ]
១៧៣សូមឱ្យព្រះហស្តទ្រង់បានប្រុងប្រៀបនឹងជួយ[ឍ]ទូលបង្គំ
ព្រោះទូលបង្គំបានរើសយក[ណ]បញ្ញត្តិរបស់ទ្រង់

**១១៩:១៦៦** ឡ ខ.៨១ **១១៩:១៦៧** អ ខ.៤៧ **១១៩:១៦៨** ក ខ.៥៦,៨៨ ខ ខ.២,២២ គ យប ១០:៤ ២៣:១០ ទដ ១៣៩:៣ សភ ៥:២១ **១១៩:១៦៩** ឃ យប ១៦:១៨ ង ខ.៣៤ ច ខ.៩ **១១៩:១៧០** ឆ ១ពវ ៨:៣០ ២របៈ ៦:២៤ ទដ ២៨:២ ១៤០:៦ ១៤៣:១ ជ ទដ ៣:៧ ២២:២០ ៥៩:១ ឈ ខ.៤១ **១១៩:១៧១** ញ ទដ ៥១:១៥ ៦៣:៦ ដ ទដ ៩៤:១២ អស ២:៣ មីក ៤:២ **១១៩:១៧២** ឋ ទដ ៥១:១៤ ឌ ខ.៧,៧៥ **១១៩:១៧៣** ឍ ទដ ៣៧:២៤ ៧៣:២៣ អស ៤១:១០ ណ យស ២៤:២២

**១១៩:១៥៣–១៦០** សូមមើលការពន្យល់ ខ.១៤៥–១៥២ ។
**១១៩:១៥៥** *ពួកមនុស្សអាក្រក់* សូមមើលការពន្យល់ ខ.២១ ("ឬពួកមនុស្សឆ្មើងឆ្មៃ") ។
**១១៩:១៥៦** *តាមច្បាប់របស់ទ្រង់* សូមមើល ខ.១៤៩ និងការពន្យល់ ។
**១១៩:១៥៨** *ព្រះបន្ទូលទ្រង់* ពាក្យភាសាហេព្រើរ គឺអ៊ីមរ៉ាហ (សូមមើលការពន្យល់ ខ.១១) ។
**១១៩:១៦០** *បូករួមទាំងអស់* តាមន័យអក្សរសាស្ត្រ "គឺចំនួនសរុប" (ដូចជាក្នុង ១៣៩:១៧) ។ *ពិតត្រង់* សូមមើលការពន្យល់ ខ.២៩ (ដោយភូតភរ) ។ *ស្ថិតស្ថេរនៅអស់កល្បជានិច្ច* សូមមើលការពន្យល់ ខ.៥២ ។
**១១៩:១៦១–១៦៨** សូមមើលការពន្យល់ ខ.១៤៥–១៥២ ។
**១១៩:១៦១** *ពួកអ្នកធំ* សូមមើលការពន្យល់ ខ.២៣ ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។
**១១៩:១៦២** *ប្រទះនឹងរឹបជាច្រើន* សូមមើល ខ.១៤,៧២,១១១ ។
**១១៩:១៦៣** *ស្អប់* សូមមើលការពន្យល់ ខ.៥៣ ។ *សេចក្តីកំភូត* ដែលជា (ផ្លូវ) សេចក្តីបោកប្រាស (សូមមើល ខ.២៩ និងការពន្យល់) ។
**១១៩:១៦៤** *៧ដង* គឺជាចំនួនបញ្ជាក់ច្បាស់ពីការសរសើរព្រះពេញមួយថ្ងៃ ។
**១១៩:១៦៩–១៧៦** សូមមើលការពន្យល់ ខ.១៤៥–១៥២ ។
**១១៩:១៧១** *បានពោលពាក្យសរសើរ* ដោយទ្រង់បានលោះទូលបង្គំពីអំពើបាប ។
**១១៩:១៧២** *សុចរិត* សូមមើលការពន្យល់ ខ.៧ ។

១៧៤ឱព្រះយេហូវ៉ាអើយ ទូលបង្គំបាននឹករឭកដល់សេចក្ដី
សង្គ្រោះរបស់ទ្រង់[ត] ហើយក្រិត្យវិន័យរបស់ទ្រង់ជាទីរីក
រាយដល់ទូលបង្គំ[ថ]
១៧៥សូមអនុញ្ញាតឱ្យព្រលឹងទូលបង្គំរស់នៅ[ទ] នោះនឹងបាន
សរសើរដល់ទ្រង់ ហើយសូមឱ្យច្បាប់របស់ទ្រង់ជួយទូល
បង្គំផង
១៧៦ទូលបង្គំបានវង្វេងទៅ ដូចជាចៀមបាត់បង់[ធ] សូមដេញ
រកអ្នកបំរើទ្រង់ផង ដ្បិតទូលបង្គំមិនភ្លេច[ន]សេចក្ដីបង្គាប់
របស់ទ្រង់ឡើយ ។

ទំនុកច្រៀងតាមថ្នាក់ ។

**១២០** កាលខ្ញុំមានសេចក្ដីវេទនា[ក]នោះបានអំពាវនាវ
ដល់ព្រះយេហូវ៉ា[ខ] ហើយទ្រង់បានតបមកខ្ញុំ
២ឱព្រះយេហូវ៉ាអើយ សូមជួយព្រលឹងទូលបង្គំ ឱ្យរួចពី
បបូរមាត់[គ]ដ៏កំភូតហើយពីអណ្ដាតដែលបញ្ឆោត[ឃ]
៣ឱអណ្ដាត ដែលបញ្ឆោតអើយ តើត្រូវឱ្យអ្វីដល់ឯង
តើត្រូវធ្វើអ្វីទៀតដល់ឯង
៤គឺព្រួញមុត[ង]របស់មនុស្សខ្លាំងពូកែ និងរងើកភ្លើង
ឈើដង្កោផង
៥វេទនាដល់ខ្ញុំ ព្រោះអាស្រ័យនៅស្រុកមែសេកគឺដែល
ខ្ញុំនៅកណ្ដាលត្រសាលនៃសាសន៍កេដារ[ច]

**១១៩:១៧៤** ត ខ.១៦៦ ថ ខ.១៦,២៤ **១១៩:១៧៥** ទ ខ.១១៦,១៥៩ អស ៥៥:៣ **១១៩:១៧៦** ធ ខ.១០ ទដ ៩៥:១០ យរ ៥០:១៧ អគ ៣៤:១១ លក ១៥:៤ ន ទដ ៤៤:១៧ **១២០:១** ក ទដ ១៨:៦ ខ ២សយ ២២:៧ ទដ ១១៨:៥ **១២០:២** គ ទដ ៣១:១៨ ឃ ទដ ៥២:៤ **១២០:៤** ង ចទ ៣២:២៣ **១២០:៥** ច លប ២៥:១៣ យរ ២:១០

**១១៩:១៧៤–១៧៦** គឺជាសេចក្ដីបញ្ចប់បទទំនុក ។

**១១៩:១៧៦** *ទូលបង្គំបានវង្វេងទៅ* សូមមើល អស ៥៣:៦ គឺជាសេចក្ដីបញ្ជាក់យ៉ាងច្បាស់ពីការទទួលស្គាល់របស់អ្នកនិពន្ធ ដែលគេបានលះបង់គ្រប់ការទាំងអស់ចំពោះច្បាប់បញ្ញត្តិព្រះ ។ ជួនពេលខ្លះអ្នកនិពន្ធក៏បានវង្វេងឃ្លាតទៅឆ្ងាយ ដោយសចក្ដីបោកបញ្ឆោតពីការអាក្រក់ ដែលមានលក្ខណៈដូចជាចៀមដែលបាប់បង់ តែត្រូវបានអ្នកគង្វាលពីស្ថានសួគ៌នាំយកមកវិញ ។ តែក្រោយមកពួកគេជាអ្នករៀបចំទទួលបញ្ញត្តិច្បាប់ពីព្រះដើម្បីជាសេចក្ដីលំនាំឱ្យពួកស្នួនភា្ជរបានទទួលកំណាប់ជីវិត ។

**ទដ ១២០–១៣៧** ក្នុងជំពូកទាំងនេះគឺជាការចងក្រងបទគម្ពីរ ជំពូក ១៥ (១២០–១៣៤) ក្នុងជំពូកនិមួយៗគឺមានសរសេរចំណងជើង"បទចំរៀងសរសើរដំកើង"ក៏លើកដំកើងក៏មានក្នុង ទដ ១៣៥–១៣៧ ទដ ១២០–១៣៦ គឺសំអាងទៅលើប្រពៃណីពួកសាសន៍យូដាខ្លះៗ ដែលពួកគេបានរក្សាទុកនិងកាន់ខ្ជាប់ខ្ជួន ។ "គឺជាបទទំនុកចំរៀង"(ក៏មានភាពខុសប្លែកគ្នាខ្លះពីបទទំនុកចម្រៀងរបស់"ជនជាតិអេស៊ីព្ទ"សូមមើលសេចក្ដីផ្ដើម ទដ ១១៣–១១៨) ។ ទដ ១៣៧ ក៏បង្ហាញពីការលះបង់ ឬតុះពារចំពោះក្រុងស៊ីយូន (ក្រុងយេរូសាឡិម)ជាទីក្រុងដែលបានបង្ហាញវត្តមានព្រះយេហូវ៉ាជាមួយនិងរាស្ត្ររបស់ទ្រង់ ដែលនាំមកនូវការរួបរួម ។ ក៏មានអ្នកខ្លះយល់ថា"ការឡើង" គឺសំដៅលើជណ្ដើរ១៥កាំ ដែលដឹកនាំឆ្ពោះទៅព្រះវិហារដូច្នេះ ហើយទើបចំណងជើងមានន័យថា"ចម្រៀងនៃជណ្ដើរ" ។ ឯចម្រៀងនោះប្រើសម្រាប់ច្រៀងក្នុងពិធីបុណ្យបារាំនៅឯព្រះវិហារ ។ ក៏គេថាជាបុណ្យប្រចាំឆ្នាំ គឺបុណ្យធម្មយាត្រាសាសនា ដែលតម្រង់ឆ្ពោះទៅក្រុងយេរូសាឡិម (សូមមើល ៨៤:៥–៧ នក ២៣:១៤–១៧ ចទ ១៦:១៦ មីក ៤:២ សក ១៤:១៦ និងការពន្យល់) ដែលនាំឱ្យអ្នកថ្វាយបង្គំច្រៀងសរសើរចំពោះភ្នំក្រុងស៊ីយ៉ូន (អស ៣០:២៩) គឺជាទស្សនៈដែលមិនអាចខានបានក្នុងការបញ្ចូលទៅនិងកិច្ចការព្រះវិហារ ។ ចំណងជើងក៏ឆ្លុះបញ្ចាំងពីវគ្គប្រវត្តិកាលនាសម័យបាប៊ីឡូន ជាជាងបង្ហាញពីគោលបំណងដើម នៃការតែងនិពន្ធគ្រប់ទាំងបទទំនុកទាំងអស់ ។ ដូងព្រលឹងក្នុងគម្ពីរទំនុកដំកើងជំពូក ៨៤ បានលាតត្រដាងពីការចងក្រងបទគម្ពីរនេះ (សូមមើល ទដ ៤២:–៤៣) ។

ម្យ៉ាងវិញទៀតផ្ទៃរឿងទាំងមូល(ក៏មានរឿងខ្លះទៀត)ក៏ជាការគ្រប់គ្រងរៀបចំ"ផ្លូវទៅលើ"ដែលកើតមានឡើដោយការចូលរួមអធិស្ឋានឬដោយការបំផុស ឬការត្រាស់ហៅ ដើម្បីសរសើរតម្កើងក្នុងទីបរិសុទ្ធ ។ គឺមានក្នុងចំណុចសំខាន់នៃគម្ពីរជាភាសាហេព្រើរ នៅក្នុង ទដ ១២៧ ក្នុងកណ្ដាលអត្ថបទ ក៏មានដកស្រង់ពីអត្ថបទស្ដេចសាឡូម៉ូន ដែលមានបួនជំពូកដូចជា:(១២២,១២៤,១៣១,១៣៣) ហើយក៏បានពណ៌នាពីស្ដេចដាវីឌ ។ (ជាទំនៀមទម្លាប់របស់ជនជាតិក្រិកក្នុងសម័យដើម ឬសម័យសញ្ញាចាស់) ។

**ទដ ១២០** គឺជាសេចក្ដីអធិស្ឋានរបស់អ្នកជឿព្រះគ្រីស្ទនាសម័យនោះ ដើម្បីឱ្យរំដោះពួកគេចេញពីពួកមានបបូរមាត់ដ៏កំភូត (សូមមើល ៥:៩ និងការពន្យល់) ។ គឺសំដៅទៅលើ"សង្គ្រាម"(ខ.៧) គឺជាពាក្យប្រៀបប្រដូច ។ ក៏មានវគ្គគាថាបី: មានដូចជាការបន្លឺស្រែកអធិស្ឋាន (ខ.១–២) សចក្ដីប្រកាសថ្លែងពីសត្រូវចំពោះមុខ (ខ.៣–៤) ជាបទទំនុកសោកសៅ(ខ.៥–៧)។

**១២០** *ជាចំណងជើង* សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣០ ។

**១២០:១–២** ខទាំងនេះគឺជាសេចក្ដីអធិស្ឋាន ។

**១២០:១** *បានអំពាវនាវ . . . ទ្រង់* សូមមើលការពន្យល់ ១១៨:៥ ។

**១២០:២,៦** *ទូលបង្គំ . . . ខ្ញុំបាន* "ព្រលឹងរបស់ទូលបង្គំ"(សូមមើលការពន្យល់ ៥:៩ ។

**១២០:២** *បបូរមាត់ដ៏កំភូត . . . អណ្ដាតដែលបញ្ឆោត* សូមមើលការពន្យល់ ៥:៩ ។

**១២០:៣–៤** គឺជាការធានារ៉ាប់រង ដែលព្រះនិងធ្វើការដល់រាស្ត្រទ្រង់ (សូមមើល ៦:៨–១០ និងការពន្យល់ ៣:៨) ។

**១២០:៣** ព្រះអម្ចាស់ទ្រង់នឹងកាត់ទោសជំនុំជម្រះ ដល់សត្រូវទាំងអស់ គឺមានអណ្ដាតកំភូតទាំងឡាយ (សូមមើល ១សយ ៣:១៧ និងការពន្យល់) ។

**១២០:៤** *ព្រួញមុត . . . រងើកភ្លើងឈើដង្កោ* គឺមានសណ្ឋានជាអាវុធគ្រឿងសឹកសង្គ្រាមដែលព្រួញដ៏មុតស្រួច គឺប្រៀបដូចជាអណ្ដាតរបស់មនុស្សកំភូតមនុស្សឆ្មើងឆ្មៃ (សូមមើល សក ២៥:១៨ យរ ៩:៨ ៥៧:៤ ៦៤:៣) និងភ្លើងឆេះខ្លោច (សូមមើល សភ ១៦:២៧ យក ៣:៦) ហើងសេចក្ដីជំនុំជម្រះរបស់ព្រះអម្ចាស់នឹងផ្ដល់ជាចំលើយ តាមប្រភេទអំពើបាបរបស់ពួកគេ (សូមមើល ៦៣:៩–១០ ៦៤:៧–៨ និងការពន្យល់) ។

**១២០:៥** *ស្រុកមែសេក . . . នៃសាសន៍កេដារ* គឺជាឈ្មោះអតីតកាលរបស់ស្រុកអាស៊ីមីណរ (សូមមើលការពន្យល់ លប ១០:២)ក្រោយមកទៀតជាប្រទេសអារ៉ាប៊ី(សូមមើលការពន្យល់ អស ២១:១៦) ។ ពួកមនុស្សមានមាត់

៦ជាយូរមកហើយ ព្រលឹងនៃខ្ញុំបាននៅជាមួយនឹងពួកអ្នក
ដែលស្អប់សេចក្តីសុខ
៧ខ្ញុំចូលចិត្តខាងសេចក្តីសុខ តែកាលណាខ្ញុំថាទៅនោះ
គេចូលចិត្តតែចង់ច្បាំងវិញ ។

ទំនុកច្រៀងតាមថ្នាក់ ។

**១២១** ខ្ញុំនឹងងើបភ្នែកមើលទៅឯភ្នំតែសេចក្តីជំនួយជួ
យដល់ខ្ញុំមកពីណា
២សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះ
ដែលបង្កើតផ្ទៃមេឃ[ឆ] និងផែនដី[ជ] ។
៣ទ្រង់នឹងមិនឱ្យជើងអ្នករឥលភ្លាត់ឡើយព្រះអង្គ ដែល
រក្សាអ្នក ទ្រង់នឹងមិនផ្ទំរលីវឡើយ
៤មើលព្រះអង្គដែលរក្សា[ឈ]អ៊ីស្រាអែល
ទ្រង់នឹងមិនដែលងោកងុយ ក៏មិនដែលផ្ទំលក់ឡើយ
៥ព្រះយេហូវ៉ាទ្រង់ជាព្រះដែលថែរក្សា[ញ] អ្នក
ព្រះយេហូវ៉ាទ្រង់ជាម្លប់នៅខាងស្តាំអ្នក ។
៦នៅពេលថ្ងៃអ្នកនឹងមិនត្រូវព្រះអាទិត្យ[ដ] ធ្វើទុក្ខឡើយ
ហើយនៅពេលយប់ក៏មិនត្រូវព្រះចន្ទធ្វើទុក្ខដែរ
៧ព្រះយេហូវ៉ានឹងរក្សាអ្នក ឱ្យរួចពីគ្រប់ទាំងសេចក្តីអាក្រក់[ឋ]
ទ្រង់នឹងថែរក្សាព្រលឹងរបស់អ្នក ឯដំណើរដែលអ្នកចេញ
ចូលទៅមកនោះព្រះយេហូវ៉ាទ្រង់នឹងរក្សាចាប់តាំងពី
ឥឡូវនេះរៀងតទៅ[ឌ] ។

ទំនុកច្រៀងតាមថ្នាក់ ជាបទរបស់ស្តេចដាវីឌ ។

**១២២** កាលគេនិយាយមកខ្ញុំថា ចូរយើងចូលទៅក្នុង
ដំណាក់នៃព្រះយេហូវ៉ា នោះខ្ញុំមានសេចក្តីអំណរអរ
ណាស់
២ឱ ក្រុងយេរូសាឡិមអើយ ជើងយើងឈរនៅខាងក្នុងទ្វារ
របស់ឯងហើយ
៣យេរូសាឡិមអើយ ឯងបានសង់ឡើង

**១២១:២** ឆ លប ១:១ ជ ទដ ១០៤:៥ ទដ ១១៥:១៥
**១២១:៤** ឈ ទដ ១២៧:១
**១២១:៥** ញ ទដ ១:៦
**១២១:៦** ដ អស ៤៩:១០
**១២១:៧** ឋ ទដ ៩:៩ ឌ ចទ ២៨:៦

វៀចឡោមព័ទ្ធហើយយកស្រុកនោះទៅ ក៏មានពួកសាហាវជាច្រើនបានហ៊ុំព័ទ្ធយកផងដែរ ។

**ទដ ១២១** ពាក្យដែលនិយាយទាក់ទងគ្នាពីការលន់តួបាប និងការធានារ៉ាប់រងការប្រើរបស់វាដូចជាបទទំនុកដែលជាដំណើរការសម្រាប់ជាគន្លឹះ ដើម្បីស្វែងយល់សេចក្តីពិត ។ គឺខណៈពេលវគ្គគាថាមានទំរង់ឯកវចនៈ(ប្រៀបធៀបនិងបទបន្ទ មើលក្នុង ទដ ៤២–៤៣)ឬចន្លោះនិមួយៗក្នុងលក្ខណៈដូចជាការធ្វើដំណើរតាមផ្លូវជីវិតនៃការ ដែលមិនបានទទួលរងនូវគ្រោះមហន្តរាយទាំងឡាយទេ ដោយព្រះយេហូវ៉ាជាអ្នកជួយថែរក្សា គឺទ្រង់គង់នៅជិតពួកគេបង្កើយ ។ ដំណើរធម្មយាត្រានៃជីវិត គឺសម្រាប់ជាសិរីល្អនៃជីវិតដោយព្រោះអ្នកដែលស្មោះត្រង់សុចរិត និងទទួលនូវពរជ័យ(សូមមើលការពន្យល់ ៤៩:១៥ ៧៣:២៤) ឯកណ្ឌគម្ពីរទំនុកដំកើងបាននិពន្ធឡើងដោយចែកជាបួនផ្នែក ក៏មានសេចក្តីផ្តើមរៀងៗខ្លួន ។ ឯពាក្យគន្លឹះមានដូចជាពាក្យ"ព្រះយេហូវ៉ា"និង"រក្សា" ពាក្យនេះបានលេចឱ្យឃើញប្រាំដងក្នុងអត្ថបទនេះ ។

**១២១** *ជាចំណងជើង* សូមមើលសេចក្តីផ្តើម ទដ ១២០–១៣៧ ។

**១២១:១–២** គឺជាការលន់តួបាបនៃសេចក្តីពិតក្នុងព្រះយេហូវ៉ា ។

**១២១:១** *ភ្នំ* គឺជាប្រភេទកូនភ្នំច្រើនដែលមានទីតាំងក្បែរក្រុងយេរូសាឡឹម ដូចជាភ្នំស៊ីយ៉ូន (១២៥:២ ឬក៏បើមានសណ្ឋានជាទម្រង់ពហុវចនៈ គឺបញ្ជាក់ពីភាពឧត្តម (ដូចជាក្នុងភាសាហេព្រើរ ៨៧:១,១៣៣:៣) ដូចជាភ្នំស៊ីយ៉ូន ។

**១២១:២** *បង្កើផ្ទៃមេឃនិងផែនដី* គឺជាព្រះមួយអង្គជាព្រះដ៏ពិត គឺជាព្រះមហាក្សត្រនៃគ្រប់ទាំងស្នាព្រះហស្តទ្រង់ (សូមមើល ១២៤:៨ ១៣៤:២–៩ ១៣៦:៤–៩) ។

**១២១:៣** *មិនឱ្យជើងអ្នករឥលភ្លាត់ឡើយ* មិនថាផ្លូវរបស់ពួកគេប្រកបដោយគ្រោះថ្នាក់នោះទេ ។ *មិនផ្ទំរលីវឡើយ* គឺព្រះនៃយើងមិនផ្ទំដូចជាព្រះបាល–ពេអរ របស់ពួកសាសន៍ដទៃ (សូមមើល ១ពវ ១៨:២៧) ។

**១២១:៤** *ព្រះអង្គដែលរក្សាអ៊ីស្រាអែល* ដោយព្រះអង្គជាព្រះយេហូវ៉ាលើគ្រប់ទាំងរបស់ដែលទ្រង់បង្កើត ក៏ជាអ្នកថែរក្សាលើពួកអ៊ីស្រាអែល ។ ដែលព្រះពេញដោយសេចក្តីសុចរិត ។

**១២១:៥** *ជាម្លប់* សូមមើល ៩១:១ ("ម្លប់សម្រាប់ជ្រក")មើលការពន្យល់ ១៧:៨ ។ *នៅខាងស្តាំអ្នក* សូមមើល ១៦:៨ និងកាពន្យល់ ។

**១២១:៦** *ព្រះអាទិត្យ . . . ព្រះបន្ទូល* នៅក្នុងឃ្លានេះគឺជាសេចក្តីព្រមព្រៀង "ម្លប់" គឺជាពាក្យប្រៀបប្រដូចគ្នានឹងពាក្យថា ឬក៏ជាការគំរាមកំហែងទាំងថ្ងៃទាំងយប់ (សូមមើល អស ២:៦ ២៥:៤–៥ ៤៩:១០ យហ ៤:៨) ។

**១២១:៨** *អ្នកចេញចូលទៅមក* គឺសំដៅពលទ័ព គឺជាទាហាដែលមានដំណើរយាមល្បាតទៅមកដូចជានៅក្នុង ១សយ ២៩:៦ ២សយ ៣:២៥ (សកម្មភាពរបស់គេ)អត្ថន័យនៅទីកន្លែងនេះមានលក្ខណៈស្រដៀងគ្នានឹង ចទ ២៨:៦ ។

**ទដ ១២២** គឺជាបទទំនុកនៃសេចក្តីអំណរពេញទាំងក្រុងយេរូសាឡិម (សូមមើល ទដ ៤២–៤៦,៤៨,៨៤,៨៧,១៣៧ ក៏មានសេចក្តីផ្តើមឱ្យឃើញពីបទចម្រៀងទាំងនោះដែរ) ។ គឺគេបានច្រៀងចម្រៀងនេះក្នុងពេលធ្វើធម្មយាត្រាក្នុងក្រុងយេរូសាឡិម (គឺទំនងជាប្រើសម្រាប់ពិធីបុណ្យប្រចាំឆ្នាំ ចទ ១៦:១៦) បានបង្ហាញពីសេចក្តីអំណរជ្រាវជ្រៅពេញទីក្រុងទាំងមូល ហើយក៏ជាការជួបជុំអធិស្ឋានសុំឱ្យមានសុខភាព ឬសន្តិសុខក្នុងសង្គមនោះ ។ វគ្គទីបីគឺជារៀបចំបែបបទឱ្យមានភាពរីកចម្រើន ក្នុងវគ្គគាថាពីវគ្គហើយវគ្គនិមួយៗមាន៤ខ ក្នុងព្យាង្គនិមួយៗ (ក្នុងភាសាហេព្រើរវគ្គទី១មានព្យាង្គសរុបចំនួន ៥៧ ឯវគ្គទីពីរមានព្យាង្គសរុប ៦០ ។ ក៏មានក្នុងសេចក្តីផ្តើម ទដ ១២៧,១២៨,១២៩) គឺចង់បង្ហាញពីដំណាក់របស់ព្រះយេហូវ៉ា(ខ.១,៩) ។

**១២២:១** *ក្នុងដំណាក់នៃព្រះយេហូវ៉ា* គឺជាព្រះវិហារ (២សយ ៥:៣,៥ ៧:៥,១៣ "ព្រះវិហារ" ៨:១០) ។ គឺជាទីក្រុងយេរូសាឡិមនោះហើយ ដែលជាទីធម្មយាត្រាមុនពេលប្រគល់ថ្វាយដង្វាយ នៃទីព្រះវិហារ ១ពវ ៣:៤ ៨:១–១១ ។

**១២២:២** *ទ្វារ* គឺទ្វារមានក្លោងទ្វារចូលបាន ។

**១២២:៣–៥** បានបង្ហាញពីសក្ខីភាពរបស់ក្រុងយេរូសាឡិមចំពោះភាពស្មោះត្រង់សុចរិត ។

**១២២:៣** *ដែលណែនណាន់ជាប់គ្នា* គឺគេនិយាយសំដៅសំណង់អាគាដ៏រឹងមាំ

ដូចជាទីក្រុងដែលណែនណាន់ជាប់គ្នា
៤ ជាកន្លែងដែលអស់ទាំងពូជអំបូរគឺពូជអំបូរនៃព្រះ
យេហូវ៉ាគេឡើងទៅតាម ទំលាប់នៃសាសន៍អ៊ីស្រាអែល
ដើម្បីនឹងអរព្រះគុណដល់ព្រះនាមព្រះយេហូវ៉ា
៥ ដ្បិតនៅទីនោះមានបល្ល័ង្កតាំងឡើង សំរាប់ការវិនិច្ឆ័យ
គឺជាបល្ល័ង្កទាំងប៉ុន្មាននៃរាជវង្សដាវីឌ
៦ ចូរអធិស្ឋានឱ្យក្រុងយេរូសាឡិមបានសេចក្ដីសុខចុះសូមឱ្យ
អស់អ្នកដែលស្រឡាញ់[ក]ឯង បានសេចក្ដីចំរើន
៧ សូមឱ្យមានសេចក្ដីសុខ[ខ]នៅខាងក្នុងកំផែងឯង
ហើយសេចក្ដីចំរើននៅ ក្នុងព្រះរាជវាំងរបស់ឯង[គ]
៨ ព្រោះយល់ដល់ពួកបងប្អូន និងពួកមិត្រសំឡាញ់របស់អញ
បានជានឹងពោលឥឡូវថា សូមឱ្យមានសេចក្ដីសុខនៅខាង
ក្នុងឯងចុះ
៩ ដោយយល់ ដល់ដំណាក់នៃព្រះយេហូវ៉ា ជាព្រះនៃយើង
រាល់គ្នានោះ អញនឹងស្វែងរកសេចក្ដីល្អដល់ឯង[ឃ] ។

ទំនុកច្រៀងតាមថ្នាក់ ។
**១២៣** ឱព្រះដែលគង់នៅ[ក]ស្ថានសួគ៌អើយទូលបង្គំងើប
ភ្នែកមើលដល់ទ្រង់ដោយសង្ឃឹម
២ មើល ភ្នែកពួកទាសាក្រឡេកមើលទៅដៃចៅហ្វាយខ្លួន
ហើយភ្នែកនៃទាសីក្រឡេកមើលទៅដៃចៅហ្វាយស្រី
របស់ខ្លួនយ៉ាងណានោះភ្នែកយើងខ្ញុំក៏ក្រឡេកមើលទៅ
ព្រះយេហូវ៉ា[ខ]ជាព្រះនៃយើងខ្ញុំយ៉ាងនោះដែរ
ទំរាំតែទ្រង់ផ្ដល់សេចក្ដីមេត្តាករុណាដល់យើងខ្ញុំ
៣ ឱព្រះយេហូវ៉ាអើយ សូមទ្រង់មេត្តាប្រោសដល់យើងខ្ញុំ
សូមមេត្តាប្រោសយើងខ្ញុំផង ដ្បិតយើងខ្ញុំឆ្អែតចំពោះ
សេចក្ដីមើលងាយយ៉ាងក្រៃលែង
៤ ព្រលឹងនៃយើងខ្ញុំឆ្អែតចំពោះសេចក្ដីចំអករបស់មនុស្ស
ដែលនៅដោយឥតកង្វល់នឹងសេចក្ដីមើលងាយរបស់
មនុស្សឆ្មើងឆ្មៃ ។

**១២២:៦** ក ទដ ២៦:៨
**១២២:៧** ខ ១សយ ២៥:៦ គ ទដ ៤៨:៣
**១២២:៩** ឃ ទដ ១២៨:៥
**១២៣:១** ក ទដ ៦៨:៥ អស ៦:១ ៦៣:១៥
**១២៣:២** ខ ទដ ២៥:១៥

របស់ទីក្រុងមួយ (សូមមើល ទដ ៤៨)ក៏អាចជាការនិយាយសំដៅលើការសាងសង់រោងឧបោសថ (ប្រៀបធៀបនឹង នក ២៦:១១ ដែលតំរៀបបញ្ចូលគ្នាជាទ្រង់ទ្រាយមួយ) ។ ក៏មានលក្ខណៈរបៀបដូចជាក្រុងយេរូសាឡិមក៏មានប្រារព្ធពីធីថ្វាយដំណាក់ដំបូងបង្អស់របស់ព្រះអម្ចាស់ (សូមមើលការពន្យល់ ៩:១១ និង អស ៤:៥) ។

**១២២:៤** *អរព្រះគុណដល់* ជាការសរសើរតម្កើងព្រះអម្ចាស់ក្នុងការទ្រង់បានជួយដល់រាស្ត្រអ៊ីស្រាអែលនឹងប្រទានពរដល់ពួកគេ ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។ *តាមទំលាប់នៃសាសន៍អ៊ីស្រាអែល* សូមមើល ៨១:៣៥ ចទ ១៦:១–១៧ ។

**១២២:៥** *បល្ល័ង្កទាំងប៉ុន្មាននៃរាជវង្សដាវីឌ* គឺជាក្រុងយេរូសាឡិម ដែលជារាជធានីរបស់ព្រះយេហូវ៉ា និងជាខ្សែរាជវង្សដែលព្រះបានរើសតាំងឡើង ដែលទ្រង់ការពារ ហើយដឹកនាំលើរាស្ត្ររបស់ទ្រង់ (សូមមើល ខ.២,៦–៧ ៨៩:៣–៤,១៩–៣៧,១១០ ២សត ៧:៨–១៦ និងការពន្យល់) ។ តាមកាលប្បវត្តនាសម័យពួកអេស៊ីព្ទ និងបាប៊ីឡូនក៏បានចាថា ព្រះម៉ែស៊ីដែលយាងមកក៏តាមរយៈវង្សដាវីឌដែរ ។

**១២២:៦–៩** ជាការអធិស្ឋាន ដើម្បីសន្តិភាពដល់ក្រុងយេរូសាឡិម ។

**១២២:៦** ក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យថា ផ្សារភ្ជាប់យ៉ាងស៊ីតរមួតនូវ "ការអធិស្ឋាន""សន្តិភាព""ក្រុងយេរូសាឡិម"និង"មានសន្តិសុខ" ។ *សេចក្ដីសុខ* សូមមើល ខ.៧–៨ មានទាំងសន្តិសុខ និងវិបុលសុខ ។ *អស់អ្នកដែលស្រឡាញ់ឯង* អ្នកនិពន្ធបទទំនុកទាក់ទងនឹង ខ.១,៨ ដែលស្រឡាញ់ក្រុងយេរូសាឡិម ដោយពួកគេបានលះបង់ចំពោះព្រះយេហូវ៉ា និងព្រះមហាក្សត្រ ដែលទ្រង់បានជ្រើសរើស ។ គឺជាការរួមនៃសេចក្ដីស្រឡាញ់ប្រកបគ្នា ថ្វាយបង្គំរួមគ្នា និងស្វែងរកសុខមាលភាពឱ្យគ្នាទៅវិញទៅមកក្នុងនាមជារាស្ត្ររបស់ព្រះអម្ចាស់ (សូមមើល ទដ ១៣៣) ។

**១២២:៧** *កំផែង . . . ព្រះរាជវាំង* មើល ៤៨:១៣ (កំផែងព្រះរាជវាំង) ។

**១២២:៨–៩** *ព្រោះយល់ដល់ពួកបងប្អូន . . . ដោយព្រោះយល់ដល់ដំណាក់នៃព្រះយេហូវ៉ា* ដោយព្រោះអម្ចាស់និងរាស្ត្ររបស់ទ្រង់ បានជួបគ្នាក្នុងពេលធ្វើពិធីលៀងព្រះអម្ចាស់ ក៏ជាទីដែលអ្នកនិពន្ធបទទំនុកសូមឱ្យមានភាពសុខសាន្តក្នុងទីក្រុង ។

**១២២:៩** *ដំណាក់នៃព្រះយេហូវ៉ា* សូមមើល ខ.១ និងការពន្យល់ ។

**ទដ ១២៣** ជាការអធិស្ឋានរបស់រាស្ត្រ ដែលបន្ទាបខ្លួននៅចំពោះព្រះភ័ក្ត្រ ។ សូមមើលសេចក្ដីផ្ដើមចំពោះ ទដ ១២៤ ដូចជាការតែងឃ្លារបស់បទទំនុកនោះ គឺសេចក្ដីផ្ដើមទៅតាមវគ្គគាថាពីរវគ្គ ឯវគ្គនិមួយៗបង្កើតបានជាផ្ទៃរឿងផ្ទាល់ៗខ្លួន ។

**១២៣** *ចំណងជើង* សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣៧ ។

**១២៣:១** *ទូលបង្គំងើបភ្នែកមើល* អ្នកនិពន្ធបទទំនុកនិយាយក្នុងនាមជាតំណាង ឬជាអ្នកនាំពាក្យសម្រាប់សហគមន៍ ។ *ដែលគង់នៅស្ថានសួគ៌អើយ* ក៏ដូចជាព្រះតែមួយដែលគង់នៅព្រះវិហារនៅលើភ្នំស៊ីយ៉ូន (សូមមើល ១២២:៥ និងការពន្យល់ ២:៤ ៩:១១ ១១:៤ ៨០:១ ៩៩:១ ១១៣:៥ ១៣២:១៤) ។

**១២៣:២** គឺបង្ហាញពីលក្ខណៈស្រដៀងគ្នាពីរដែលជីវិតមនុស្សក្នុងស្រុកត្រូវទទួលសម្ពាតពីមនុស្សខ្លាំជាងគេ ហើយគេជាអ្នកពឹងផ្អែកលើព្រះអម្ចាស់ ។

**១២៣:៤** *សេចក្ដីចំអក . . . មនុស្សឆ្មើងឆ្មៃ* គឺប្រភេទមនុស្សដែលតែងតែពឹងផ្អែកការរស់នៅដោយសារភាពប៉ិនប្រសព ឬតាមកម្លាំងរស់ពួកគេដែលពួកគេមិនបានពឹងផ្អែកលើផ្លូវរបស់ព្រះទេ (សូមមើលការពន្យល់ ១០:២–១១ ៣១:២៣) នេះជាការមើលងាយដល់អស់អ្នកដែលបន្ទាបខ្លួនពឹងផ្អែកលើព្រះយេហូវ៉ា ។ ដូចជាពួកដែលនៅជាប់ជាមួយស្ដេចហេសេគា (២ពវ ១៨:១៧–១៩:១៩) ឬក៏អ្នកដឹកនាំគឺលោកនេហេមា (នហ ៤,៦:១–៤) ។

ទំនុកច្រៀងតាមថ្នាក់ ជាបទរបស់ស្តេចដាវីឌ ។

**១២៤** បើមិនមែនជាព្រះយេហូវ៉ាដែលកាន់ខាងពួកយើងនោះគួរឱ្យអ៊ីស្រាអែលនិយាយឥឡូវថា[ក]
២ បើមិនមែនជាព្រះយេហូវ៉ាដែលកាន់ខាងពួកយើងទេក្នុងកាលដែលមនុស្សបានលើកគ្នាទាស់នឹងយើង
៣ នោះប្រាកដជាគេបានលេបយើងទាំងរស់ហើយគឺក្នុងកាលដែលសេចក្តីក្រោធរបស់គេបានក្តៅឡើងទាស់នឹងពួកយើង
៤ យ៉ាងនោះ ប្រាកដជាទឹកជំនន់[ខ]បានលិចយើង គឺទឹកជ្រោះ[គ]បានហូរមកគ្របលើព្រលឹងយើងហើយ
៥ អើ ទឹកវល់ច្របល់បានហូរមកគ្របលើព្រលឹងយើង
៦ សូមឱ្យព្រះយេហូវ៉ាបានប្រកបដោយព្រះពរ ដែលទ្រង់មិនបានប្រគល់ពួកយើងឱ្យជារំពាដល់ធ្មេញគេ
៧ ព្រលឹងយើងបានរួចដូចជាសត្វស្លាបដែលហើររួចពីអន្ទាក់របស់នាយព្រាន[ឃ] អន្ទាក់គេបានដាច់ ហើយ[ង]យើងបានរួចចេញ
៨ ឯសេចក្តីជំនួយរបស់យើង គឺដោយពឹងដល់ព្រះនាម[ច]ព្រះយេហូវ៉ា ដែលទ្រង់បានបង្កើតផ្ទៃមេឃ[ឆ] និងផែនដី ។

ទំនុកច្រៀងតាមថ្នាក់ ។

**១២៥** ពួកអ្នកដែលទុកចិត្តនឹងព្រះយេហូវ៉ាគេដូចជាភ្នំស៊ីយ៉ូន[ក] ដែលនឹងរង្គើមិនបាន[ខ] គឺបានជាប់នៅជាដរាប
២ មានភ្នំនៅព័ទ្ធជុំវិញក្រុងយេរូសាឡិម[គ] យ៉ាងណានោះព្រះយេហូវ៉ាក៏គង់នៅជុំវិញ[ឃ]រាស្ត្រទ្រង់យ៉ាងនោះដែរ ចាប់តាំងពីឥឡូវនេះ ដរាបដល់អស់កល្បជានិច្ច
៣ ពីព្រោះដំបង[ង]នៃសេចក្តីអាក្រក់នឹងមិនគ្រប[ច]លើចំណែកនៃមនុស្សសុចរិតឡើយប្រយោជន៍កុំឱ្យមនុស្សសុចរិតលូកដៃទៅចាប់សេចក្តីទុច្ចរិតឱ្យសោះ[ឆ]
៤ ឱព្រះយេហូវ៉ាអើយ[ជ] សូមប្រោសសេចក្តីល្អ ដល់មនុស្សល្អ

**១២៤:១** ក ទដ ១២៩:១
**១២៤:៤** ខ ទដ ៨៨:១៧ គ ទដ ១៨:៤
**១២៤:៧** ឃ ទដ ៩១:៣ ង ទដ ២៥:១៥
**១២៤:៨** ច ១សយ ១៧:៤៥ ឆ លប ១:១ ទដ ១១៥:១៥ ១២១:២ ១៣៤:៣
**១២៥:១** ក ទដ ៤៨:១២ អស ៣៣:២០ ខ ទដ ៤៦:៥ ៤៨:២–៥
**១២៥:២** គ ១រប ២១:១៥ ឃ ទដ ៣២:១០ សក ២:៤–៥
**១២៥:៣** ង នរអ ៤:១១ ច ទដ ៨៩:២២ សភ ២២:៨ អស ១៣:១១ ១៤:៥ ឆ ១សយ ២៤:១០
**១២៥:៤** ជ ទដ ១១៩:៦៥

**ទដ ១២៤** ជាការសរសើររបស់រាស្ត្រអ៊ីស្រាអែល ចំពោះការរំដោះលែង ឬសង្គ្រោះពួកគេពីពួកសត្រូវដ៏មានអំណាច ក្នុងគ្រាដែលពួកគេកំពុងមានវិប័ត្ត ទដ ១២៣ ។ ដូចជាពេលពួកលេវីនិយាយក្នុង ខ.១–៥ ខណៈពេលថ្វាយបង្គំ ហើយក្នុងសេចក្តីផ្តើមដែលផ្ទៃរឿងបានផ្តោតលើការរំដោះលោះក្រុងស៊ីយ៉ូនចេញពីសត្រូវដ៏មានអំណាច(សូមមើលការពន្យល់ ១២៥:៥) ។

**១២៤** *ចំណងជើង ទំនុកច្រៀងតាមថ្នាក់* សូមមើលសេចក្តីផ្តើមក្នុង ទដ ១២០–១៣៧ ។ គឺជាបទទំនុករបស់ស្តេចដាវីឌ ។ ក៏មិនមែនជាបន្ទាល់ពីបុរាណកាលទាំងអស់នោះទេបើតាមអត្ថបទមានទាំងភាសា និងផ្ទៃរឿង ហើយនិងការសន្និដ្ឋានពីការបរិច្ឆេទនៃផ្ទៃរឿង (សូមមើលការពន្យល់ ទដ ១២២ ជាផ្នែកនៃចំណងជើង) ។ ក៏សូមមើល ទដ ១៨,៦៩ ។

**១២៤:១–៥** គឺជាការចង់ឱ្យរាស្ត្រអ៊ីស្រាអែលទទួលស្គាល់ថា គឺជាព្រះយេហូវ៉ាតែមួយគត់ ដែលបានជួយសង្គ្រោះពួកគេចេញពីការហិនវិនាស (សូមមើល ២០:៧ ៩៤:១៧) ។

**១២៤:២** *មនុស្សបានលើកគ្នាទាស់* ជាសេចក្តីអំណួត និងមនុស្សមានសេចក្តីឆ្មើងឆ្មៃ(១២៣:៤) ។ ទោះមានការទាស់ទែងតែព្រះយេហូវ៉ាទ្រង់នៅខាង ឬទ្រង់ជួយរាស្ត្រអ៊ីស្រាអែល (ខ.៨) ។

**១២៤:៣** *បានលេបយើង* មានលក្ខណៈដូចសេចក្តីស្លាប់(សូមមើលការពន្យល់ ៤៩:១៤) ក៏សូមមើល ៦៩:១៥ ។

**១២៤:៤–៥** *ទឹកជំនន់ . . . ទឹកវល់ច្របល់* សូមមើល ១៨:១៦ ៣២:៦ ៦៩:១–២ និងការពន្យល់ ។

**១២៤:៦** *រំពាដល់ធ្មេញគេ* គឺមានលក្ខណៈដូចជាសត្វចតុបាតសាហាវ (សូមមើលការពន្យល់ ៧:២) ។

**១២៤:៧** *ដូចជាសត្វស្លាបដែលហើររួចពីអន្ទាក់របស់នាយព្រាន* គឺប្រៀបដូចជាការរំដោះរាស្ត្រអ៊ីស្រាអែល ពីការជាប់ជាឈ្លើយរបស់ពួកបាប៊ីឡូន (ប្រៀបធៀប ៩:១៥) ។

**១២៤:៨** ក្នុងសាច់រឿងមានលក្ខណៈជាការលន់តួបាប (សូមមើល ១២១:២ និងការពន្យល់) ។

**ទដ ១២៥** ជាសេចក្តីសុខសាន្តមានដល់ពួកអ៊ីស្រាអែល ដោយពួកគេយកការអធិស្ឋានជាធំ និងការទាំងឡាយ (ការសរសើរតម្កើង) ។ បទទំនុកគឺជាទម្រង់មានលក្ខណៈជាសណ្ឋានបែបប្រវត្តិសាស្ត្រនៃពួកបាប៊ីឡូន គេក៏អាចយកមកសម្តែង អធិប្បាយនៅព្រះវិហារបានដោយពួកលេវី ។ ទដ ១២៥ និង ១២៦ ក៏និពន្ធជាភាសាហេព្រើរ ដែលមាន ១១៦ ព្យាង្គ ។

**១២៥ ចំណងជើង** សូមមើលសេចក្តីផ្តើម ទដ ១២០–១៣៧ ។

**១២៥:១** *ពួកអ្នកដែលទុកចិត្តនឹងព្រះយេហូវ៉ា* គឺជាព្រះហើយមនុស្សជារបស់ផងព្រះ (ខ.២) ក៏ជាអ្នកមានលក្ខណៈសម្បត្តិជាអ្នកមានភាព"សុចរិត" (ខ.៣)និងត្រូវមានលក្ខណៈស្រដៀងគ្នានេះទៀត ទៅនិងមនុស្ស"សុចរិត" សូមមើល ៣៤:៨–១៤ និងការពន្យល់ ។ *ដូចជាភ្នំស៊ីយ៉ូន* គឺព្រះយេហូវ៉ាទ្រង់មានព្រះទ័យផ្តល់សេចក្តីចំរើនសុខដល់ពួកគេ (សូមមើល ទដ ៤៦:៤៨)។

**១២៥:២** *ភ្នំនៅព័ទ្ធជុំវិញក្រុងយេរូសាឡិម* មានន័យថា បើភាពជាក់ស្តែងក្រុងយេរូសាឡិមមិនមែនមានភ្នំព័ទ្ធជុំវិញក៏ដោយ ឬនៅក្នុងតំបន់មានភ្នំក៏ដោយ ក៏ក្នុងគម្ពីរសញ្ញាចាស់បានសរសេរថា ក្រុងយេរូសាឡិមមានថ្មព័ទ្ធជុំវិញ ជាការពិតមានប្រវត្តិមានព្រះយេហូវ៉ានៅទីនោះ គឺទ្រង់គង់នៅជុំវិញក្រុងយេរូសាឡិម ហើយនិងការពារក្រុងនោះ ដូច្នេះ ទ្រង់ក៏ការពាររាស្ត្ររបស់ទ្រង់ដែរ (សូមមើល ២ពវ ៦:១៧ សក ២:៥) ។

**១២៥:៣** បង្ហាញពីអ្នកដឹកនាំនៃមនុស្សអាក្រក់ ដែលព្យាយាមសង្កត់សង្កិនដល់ពួកមនុស្សសុចរិត តែជានិច្ចកាលព្រះយេហូវ៉ាទ្រង់តែងតែការពាររាស្ត្ររបស់ទ្រង់ ឱ្យពួកគេបានរួចផុតពីកណ្តាប់ដៃនៃមនុស្សអាក្រក់ទាំងនោះ ។ *ដំបងនៃសេចក្តីអាក្រក់* គឺសំដៅទៅលើការដឹកនាំរបស់ពួកស្តេចពើស៊ី (សូមមើល នហ ៩:២៦–៣៧) ក៏ដូចជាពួកអ្នកដែលត្រូវស្តេចនេហេមាបានគាបសង្កត់ដែរ (សូមើល នហ ២:១៩ ៤:១–៣,៧–៨ ៦:១–១៩ ១៣:៧–៨ឬ២៨) ។ តែទីបញ្ចប់ព្រះយេហូវ៉ាបានប្រគល់ស្រុកឱ្យដល់រាស្ត្ររបស់ផងទ្រង់ដើម្បីកាន់កាប់វិញ គឺជាទឹកដីសន្យាដែលទ្រង់ឱ្យនោះ ។

ហើយដល់ពួកអ្នកដែលមានចិត្តទៀងត្រង់ផង[ឈ]
៥ តែចំណែកមនុស្សដែលបែរ[ញ]ទៅតាមផ្លូវ[ដ]ខ្វិចខ្វៀនរបស់
ខ្លួនវិញនោះព្រះយេហូវ៉ាទ្រង់នឹងនាំគេចេញទៅ[ឋ]ជាមួយ
នឹងពួកអ្នកដែលប្រព្រឹត្តអំពើទុច្ចរិតសូមឱ្យសេចក្ដីសុខគ្រប
លើសាសន៍អ៊ីស្រាអែលផង[ឌ] ។

ទំនុកច្រៀងតាមថ្នាក់ ។

**១២៦** កាលព្រះយេហូវ៉ាទ្រង់បាននាំពួកឈ្លើយមក[ក]
ឯក្រុងស៊ីយ៉ូនវិញនោះយើងរាល់គ្នាបានដូចជាមនុស្ស
ដែលយល់សប្តិទេ
២ គ្រានោះ មាត់យើងបានពេញដោយការសើចសប្បាយ[ខ]
ហើយអណ្ដាតក៏ពេញដោយបទចំរៀង[គ] នោះនៅគ្រប់ទាំង
សាសន៍មានគេថា ព្រះយេហូវ៉ាទ្រង់បានធ្វើការយ៉ាងធំ[ឃ]
សំរាប់ពួកនោះពិត
៣ ព្រះយេហូវ៉ាបានធ្វើការយ៉ាងធំ[ង]
សំរាប់យើងមែនយើងក៏អរណាស់ដែរ[ច]
៤ ឱព្រះយេហូវ៉ាអើយ សូមនាំពួកយើងខ្ញុំដែលជាឈ្លើយ
ឱ្យត្រឡប់មកវិញ[ឆ] ដូចជាទឹកជ្រោះនៅស្រុកខាងត្បូង[ជ]
៥ អស់អ្នកដែលសាបព្រោះ ដោយស្រក់ទឹកភ្នែក[ឈ] នោះនឹង
បានច្រូតវិញ[ញ] ដោយច្រៀងអរសប្បាយ[ដ]
៦ ឯអ្នកដែលកណ្ដៀតពូជ សំរាប់សាបព្រោះចេញទៅទាំង
យំ[ឋ] នោះប្រាកដជានឹងចូលមកវិញដោយអំណរព្រមទាំង
យកកណ្ដាប់មកផង ។

ទំនុកច្រៀងតាមថ្នាក់ ជាបទរបស់ស្ដេចសាឡូម៉ូន ។

**១២៧** បើគ្មានព្រះយេហូវ៉ាសង់ផ្ទះឡើង[ក] នោះពួកជាង
ដែលសង់គេធ្វើការជាឥតប្រយោជន៍ទេ បើគ្មានព្រះ

**១២៥:៤** ឈ ទដ ៣៦:១០ **១២៥:៥** ញ យប ២៣:១១ ដ សភ ២:១៥ អស ៥៩:៨ ឋ ទដ ៩២:៧ ឌ ទដ ១២៨:៦ កទ ៦:១៦ **១២៦:១** ក អរ ១:១–៣ ទដ ៨៥:១ ហស ៦:១១ **១២៦:២** ខ លប ២១:៦ គ យប ៨:២១ ទដ ៦៥:៨ ឃ ចទ ១០:២១ ទដ ៧១:១៩ លក ១:៤៩ **១២៦:៣** ង ទដ ១០៦:២១ យអ ២:២១,២៦ ច ទដ ៩:២ ១៦:១១

**១២៦:៤** ឆ ចទ ៣០:៣ ជ ទដ ១០៧:៣៥ អស ៤៣:១៩ ៥១:៣ **១២៦:៥** ឈ ទដ ៦:៦ ៨០:៥ យរ ៥០:៤ ញ កទ ៦:៩ ដ ទដ ១៦:១១ ២០:៥ ២៣:៦ អស ៣៥:១០ ៥១:១១ ៦០:១៥ ៦១:៧ យរ ៣១:៦–៧,១២ **១២៦:៦** ឋ ជន ២៥:៦ ទដ ៣០:៥ **១២៧:១** ក ទដ ៧៨:៦៩

**១២៥:៤–៥** គឺចំពោះអស់អ្នក ដែលបានប្រព្រឹត្តតាមបែបផ្លូវសុចរិតរបស់ព្រះ (សូមមើលសេចក្ដីអធិស្ឋាន ខ.៤–៥) ។

**១២៥:៤** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**១២៥:៥** *សូមឱ្យសេចក្ដីសុខគ្របលើសាសន៍អ៊ីស្រាអែល* គឺអាចជាការជូនពរជាលក្ខណៈសង្ខេបខ្លីៗ (ជន ៦:២៤–២៦) ការជូនពរនេះក៏មានក្នុងការអធិស្ឋានផងដែរ មើល ១២៦:៤–៦ ។ (ដែលធ្វើឡើងសម្រាប់ពីគួរ ១២៥–១២៦ ១២៧–១២៨) ។

**ទដ ១២៦** គឺជាវគ្គនៃបទចម្រៀងទំនុកដំកើង បង្ហាញពីសេចក្ដីអំណរចំពោះការដែលព្រះជួយសង្គ្រោះក្រុងស៊ីយ៉ូន ឱ្យវិលមករកភាពសុខសាន្តឡើងវិញ (សូមមើល អរ និង នហ) (ប្រៀបធៀប ទដ ៤២–៤៣,៨៤,១៣៧) ។ ឯបទទំនុកចម្រៀងចែកចេញជាពីរវគ្គក្នុងចំណោមបួនជួរ ដែលជា (ភាសាហេព្រើរ) សេចក្ដីផ្ដើមនិមួយៗបានបង្ហាញផ្ទៃរឿងទូទៅ ។ ឯឃ្លាប្រយោគនោះក៏បានបង្ហាញពីការនិយាយដដែលៗទៀត (គឺ"ព្រះយេហូវ៉ា""ច្រៀងនៃក្ដីអំណរ"ទាំងយក) ។ គឺសំដៅទៅលើសកម្មភាពរបស់ព្រះអម្ចាស់ (ខ.១,៣) ជាគម្រោងសំណោពីវគ្គដំបូង គឺខណៈខទី២បានពណ៌នា ។ ឯចំពោះការទំនាក់ទំនងរបស់កណ្ឌគម្ពីរបទទំនុក ដែលមានទំនាក់ទំនងនឹង ទដ ១២៥ សូមមីលសេចក្ដីផ្ដើមនៃគម្ពីរទំនុកដំកើង ។

**១២៦ ចំណងជើង** សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣៧ ។

**១២៦:១** *នាំពួកឈ្លើយមកឯក្រុងស៊ីយ៉ូនវិញ* ការបកប្រែនេះបានបង្ហាញឱ្យឃើញលទ្ធផលដូចៗគ្នា ។ *យល់សប្តិ* គឺជាភាពសង្ស័យ និងសេចក្ដីអំណរដែលមានភាពអស្ចារ្យ ដែលមិនគួរឱ្យជឿ ។ តែរឿងពិតខ្លះដែលកើតឡើងគឺដោយកម្រនិងធ្វើឱ្យមនុស្សគេជឿបានណាស់ ។

**១២៦:២** គឺមានឥទ្ធិពលពីរបែបៈ គឺជាសេចក្ដីអំណរចំពោះអ្នកដែលបានវិលមកវិញ និងការគោរពកោតខ្លាចដល់ព្រះយេហូវ៉ា (សូមមើលការពន្យល់ ៤៦:១០) ។

**១២៦:៤–៦** ជាការអធិស្ឋានសូមព្រះអម្ចាស់ ឱ្យនាំមកនូវភាពសុខសាន្តសាជាថ្មីឡើងវិញ ។

**១២៦:៤** *នាំពួកយើងដែលជាឈ្លើយឱ្យត្រឡប់មកវិញ* ជាការវិលត្រឡប់ចេញស្ថានភាពទេសករមកជារាស្ត្រដែលទទួលភាពសុខសាន្តវិបុលសុខដូចពេលគ្រាដើម ។ *ដូចជាទឹកជ្រោះនៅស្រុកខាងត្បូង* ដែលក្នុងរដូវប្រាំងប្រែក្លាយជាស្ងួតកក្រោះរហូតដល់ដើមរដូវភ្លៀងខ្យល់ ទើបមានទឹកហូរមកបំពេញវិញ ។

**១២៦:៥–៦** ជាផ្នែក ឬវគ្គប្រៀបធៀបពីសេចក្ដីអំណរសេចក្ដីសុខ ដែលគេបានឆ្លងកាត់ជាបទពិសោធន៍ក្នុងជីវិត និងសេចក្ដីអំណរ ដែលសង្ឃឹមទុកជាមុន ។ *ស្រក់ទឹកភ្នែក . . . ទាំងយំ* គឺទោះជាពេលដែលទទួលពួកគេក៏ដោយគឺទទួលបាននៅភាពកង្វល់ ឬសេចក្ដីសោកស្ដាយ និងការប្រមូលផលចុងក្រោយក៏នាំមកនូវសេចក្ដីអំណរ គឺមានខខ្លះបានបង្ហាញ មើល ២០:៥ ។

**ទដ ១២៧** ប្រាជ្ញាដែលព្រះប្រទានឱ្យ ទាក់ទងនិងការសាងសង់ផ្ទះ និងទីធ្លា ។ ឯសាច់រឿងនេះក៏មានកិច្ចការច្រើនទៀត ដែលបានរំឭកឱ្យអ្នកធ្វើដំណើរធម្មាត្រាឆ្ពោះទៅក្រុងយេរូសាឡិម គឺព្រះអម្ចាស់បានប្រទានឱ្យពួកគេមានជីវិតសុខសាន្ត និងព្រះពរដែលជាអំណោយទានរបស់ព្រះ គឺមិនមែនមកពីសមត្ថិភាពរបស់គេទេ (សូមមើល ចទ ២៨:១–១៤) ។ ក៏មានវគ្គ ឬឃ្លាបង្ហាញច្បាស់ (ជាភាសាហេព្រើរ វគ្គនិមួយៗមាន ៤៧ព្យាង្គ) ដែលមានការបែងចែកជាពីរផ្នែក តែមានទំនាក់ទំនង និងផ្ទៃរឿងទាំអស់ ។

**១២៧ ចំណងជើង** *ទំនុកច្រៀងតាមថ្នាក់* សូមមើល សេចក្ដីផ្ដើម ទដ ១២០–១៣៧ ។ *របស់ស្ដេចសាឡូម៉ូន* បើសិនជាស្ដេចសាឡូម៉ូនមិនមែនជាអ្នកនិពន្ធ (នោះក៏គ្មានការអះអាងក្នុងអត្ថបទបង្ហាញពីស្ដេចសាឡូម៉ូនដែរ) ។ យើងអាចសម្គាល់តាមរយៈអ្នកផ្សេង ដែលគេជាអ្នកនិពន្ធក្នុងជំពូកនេះ ។

**១២៧:១** *ផ្ទះ* គឺជាទីជម្រកក្នុងភូមិស្រុកមួយ ។ *ពួកជាងដែលសង់* ក្នុងព្រះគម្ពីរភាសាហេព្រើរពាក្យនេះ គឺជាការប្រើវោហាលេងពាក្យចំពោះ "បទទំនុកច្រៀង"ក្នុង ខ.៣ ។ *ព្រះយេហូវ៉ាថែរក្សា* សូមមើល ១២១:៣–៨ ។ *ទីក្រុង* គឺជាមជ្ឈមណ្ឌលរបស់អ្នកមានអំណាចក៏មានការភៀសខ្លួន នៅពេលសត្រូវឈ្លានពានដល់ស្រុក ។ *ពួកយាមល្បាត* សូមមើល ៣៤ ១៨:២៤–២៧ បស ៣:៣ ៥:៧ ។

យេហូវ៉ាថែរក្សា[ខ]ទីក្រុង នោះពួកយាមល្បាតគេចាំយាម
ជាឥតប្រយោជន៍ដែរ
២ការដែលឯងក្រោកឡើងមុនកំណត់ ហើយក្រចូលដេក
ពេលយប់ព្រមទាំងបរិភោគ[គ]ដោយធ្វើការនឿយហត់ផង
នោះជាការឥតប្រយោជន៍ទៀត ដ្បិតទ្រង់ប្រោសប្រទានឱ្យ
ពួកស្ងួនភ្ងា[ឃ]របស់ទ្រង់បានដេកលក់[ង]សប្បាយ
៣មើល កូនចៅជាមរដកមកពីព្រះយេហូវ៉ា
ហើយផលកើតពីផ្ទៃ ក៏ជារង្វាន់[ច]ដែលទ្រង់ប្រទានដែរ
៤កូនដែលឯងបង្កើតពីកាលនៅក្មេងនោះធៀបដូចជា
ព្រួញ[ឆ]នៅដៃនៃមនុស្សខ្លាំងពូកែ
៥សប្បាយហើយ អ្នកណាដែលមានបំពង់ព្រួញពេញ[ជ]
ដោយព្រួញយ៉ាងនោះកាលណាត្រូវការនិយាយនឹងខ្មាំង
សត្រូវ[ឈ] នៅមាត់ទ្វារក្រុង[ញ]នោះឯងមិនត្រូវខ្មាសឡើយ ។

ទំនុកច្រៀងតាមថ្នាក់ ។

**១២៨** មានពរ ហើយអស់អ្នកដែលកោតខ្លាចដល់ព្រះ
យេហូវ៉ា[ក]ជាពួកអ្នកដែលដើរតាមផ្លូវរបស់ទ្រង់[ខ]
២ដ្បិតឯងនឹងបានបរិភោគផលនៃកំឡាំងដៃឯង[គ]
ឯងនឹងបានសប្បាយ[ឃ] ហើយនិងមានសេចក្ដីសុខផង
៣ប្រពន្ធឯងនឹងបានដូចជាដើមទំពាំងបាយជូរមានផ្លែ[ង]
ដែលដាំនៅក្នុងទីធ្លានៃផ្ទះឯង កូនឯងទាំងប៉ុន្មាន[ច]នឹងបាន
ដូចជាដើមអូលីវ[ឆ]នៅជុំវិញតុរបស់ឯង
៤មើល មនុស្សដែលកោតខ្លាចដល់ព្រះយេហូវ៉ា[ជ]
នឹងបានពរយ៉ាងនោះហើយ[ឈ]
៥ព្រះយេហូវ៉ាទ្រង់នឹងប្រទានពរដល់ឯងពីក្រុងស៊ីយ៉ូន[ញ]មក
ហើយឯងនឹងបានឃើញសេចក្ដីល្អដែលផ្សាយមកលើក្រុង
យេរូសាឡិមដរាបដល់អស់មួយជីវិតឯង[ដ]
៦អើ ឯងនឹងបានឃើញចៅរបស់ឯង[ឋ]ដែរ
សូមឱ្យមានសេចក្ដីសុខគ្របលើសាសន៍អ៊ីស្រាអែលផង[ឌ] ។

**១២៧:១** ខ ទដ ១២១:៤ **១២៧:២** គ លប ៣:១៧ ឃ ចទ ៣៣:១២ សស ២:២៥ ង ជន ៦:២៦ យប ១១:១៨ **១២៧:៣** ច លប ១:២៨ **១២៧:៤** ឆ ទដ ១១២:២ **១២៧:៥** ច ទដ ១២៨:២–៣ ឈ លប ២៤:៦០ ញ លប ២៣:១០ **១២៨:១** ក ទដ ១០៣:១១ ១១២:១ ខ ទដ ១១៩:១–៣ **១២៨:២** គ ទដ ៥៨:១១ ១០៩:១១ អស ៣:១០ ឃ លប ៣៩:៣ សភ ១០:២២ **១២៨:៣** ង លប ៤៩:២២ ច យប ២៩:៥ ឆ ទដ ៥២:៨ ១៤៤:១២ **១២៨:៤** ជ ទដ ១១២:១ ឈ ទដ ១:១ **១២៨:៥** ញ ទដ ២០:២ ដ ទដ ១២២:៩ **១២៨:៦** ឋ លប ៤៨:១១ ឌ ទដ ១២៥:៥

**១២៧:២** *បានដេកលក់សប្បាយ* ដោយការប្រមូលផលមិនបានសម្រេចទាំងស្រុងទេ ការងារលំបាកៗក៏គ្មានទីបញ្ចប់ដែរ ក៏ប៉ុន្តែការទទួលផលដោយព្រះពរដែលព្រះប្រទានឱ្យ (សូមមើល សភ ១០:២២ មថ ៦:២៥–៣៤ ១ពត ៥:៧) ។ *ពួកស្ងួនភ្ងារបស់ទ្រង់* ជាពិសេសសូមមើល ចទ ៣៣:១២ យរ ១១:១៥ ។

**១២៧:៣–៥** កូនក្មេងគឺជាអំណោយទានដែលព្រះអម្ចាស់ប្រទានមក ក៏ជាសញ្ញានៃភាពសប្បុរសរបស់ទ្រង់ ។

**១២៧:៣** *កូនចៅ* សូមមើលការពន្យល់ ខ.១ ។ គឺមិនមែនបានមកដោយសមត្ថភាពរបស់ឪពុកម្ដាយទេ (សូមមើល ១១៣:៩ និងការពន្យល់ លប ៣០:២) ។ *ជាមរដក* ពាក្យថាមរដកដែលបានបង្ហាញនៅទីនេះ គឺចង់សំដៅលើអំណោយទាន មិនមែនសំដៅទៅលើទ្រព្យសម្បត្តិទេ ។ តែវាបានឃើញនៅក្នុងគម្ពីរសញ្ញាចាស់ ។ ក្នុងគ្រាសញ្ញាចាស់ ក៏មានសេដ្ឋកិច្ចដែលជា "មរដក" របស់រាស្ត្រអ៊ីស្រាអែល ដែលព្រះយេហូវ៉ាជាអ្នកផ្ដល់ឱ្យ ។ មរដកដំបូងបង្អស់គឺទឹកដីសន្យា (ជន ២៦:៥៣ យស ១១:២៣ ពច ២:៦) ដែលជាស្រុកមានភាពសុខសាន្តនិង "បានសម្រាក" (យស ១:៣) គឺជានគររបស់ព្រះយេហូវ៉ា តែបើគ្មានកូនចៅដែលជាមរដកមកពីព្រះទេ ទឹកដីដែលជាស្រុកនិងបាត់បង់ទៅវិញ (ជន ២៧:៨–១១) ដូចច្នេះ ការបន្តពូជ គឺជាមរដក ។

**១២៧:៥** *កាលណាត្រូវការនិយាយនឹងខ្មាំងសត្រូវ* ឪពុកដែលមានកូនច្រើនក៏មានអ្នកការពារច្រើនដែរ ជាពិសេសក្នុងគ្រាមានការចោទប្រកាន់ក្នុងតុលាការ ហើយជាការពិតបើយើងមានកូនច្រើនក៏ជារង្វាន់របស់ព្រះ (ខ.៣) ជាការបញ្ជាក់ភាពសប្បុរសរបស់ទ្រង់ចំពោះរាស្ត្រទ្រង់ ហើយពួកគេបានផ្ដល់ឱ្យនូវសម្បត្តិលក្ខណៈទីបន្ទាល់ (សូមមើល ១២៨:៣–៤) ។ *នៅក្នុងមាត់ទ្វារក្រុង* គឺសំដៅ "(ទីក្រុង) ក្លោងទ្វារ" ដូចជាក្លោងទ្វារតុលាការ សូមមើល ចទ ១៧:៥ ២១:១៩ ២២:១៥,២៤ ២៥:៧ នរ ៤:១ អស ២៩:២១ អម ៥:១២ ។

**ទដ ១២៨** ជាភាពដែលមានពរពិតរបស់មនុស្ស ដែលមានព្រះគង់សណ្ឋិត ។ ឯអត្ថន័យផ្សេងទៀតរបស់ពាក្យថាប្រាជ្ញា គឺទាក់ទង់ទៅនិងជម្រក ឬផ្ទះកំណើត (សូមមើលសេចក្ដីផ្ដើម ទដ ១២៧) ។ សេចក្ដីបញ្ចប់ពីភាពសេរីភាពដែលបទទំនុកដំកើងបានផ្ដល់ជាសេចក្ដីណែនាំ ដើម្បីជាការរួបរួមពីផ្ទះនិមួយៗ ដើម្បីរួមគ្នាថ្វាយបង្គំនៅក្នុងក្រុងយេរូសាឡិម ។

**១២៨:១–៤** សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣៧ ។

**១២៨:១** *មានពរ* សូមមើលការពន្យល់ ១:១ ។ *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមើល ខ.៤ និងមើលការពន្យល់ ៣៤:៨–១៤ ។ *តាមផ្លូវរបស់ទ្រង់* សូមមើលការពន្យល់ ២៥:៤ ។

**១២៨:៣** គឺជាកិរយាស្មោះត្រង់និងមានផលផ្លែ ។ *ដើមទំពាំងបាយជូរ* ជានិមិត្តិពីផលផ្លែបានកើត (លប ៤៩:២២ បស ៧:៨–១២ ចព ៩:១៣) ។ *នៅក្នុងទីធ្លានៃផ្ទះឯង* មិនមានលក្ខណៈជាប្រពន្ធដែលមានចិត្តមិនស្មោះ ឬជាអ្នក "មិនដែលស្នាក់នៅផ្ទះទេ" (សភ ៧:១១) ។ *ដើមអូរលីវ* គឺមានភាពស្រស់ដែលជាព្រះបន្ទូលសន្យាឱ្យមានជីវិតយូរអង្វែងនិងបង្កើតផលផ្លែ (ពីភាពសំខាន់ជាដើមឈើ ផ្លែឈើ ប្រេង) ។ ដើមទំពាំងបាជូរ និងដើមប្រេងអូលីវ គឺបានបង្ហាញទាំងពីរក្នុងគម្ពីរសញ្ញាចាស់ដូចជាឧទាហរណ៍ក្នុង នក ២៣:១១) ។ ជាពិសេសដើមទាំងនេះមានជីវិតយូរអង្វែង និងបង្កើតផលផ្លែទំពាំបាយជូរនិងប្រេង គឺជាតួនាទីចំបងមួយក្នុងការរស់នៅរបស់ប្រជាជន ។ *នៅជុំវិញតុរបស់ឯង* គឺជាការជួបជុំគ្នាជប់លៀងជាលក្ខណៈគ្រួសារនាំមកនៅសេចក្ដីអំណរមកដល់ស្រុករបស់ពួកគេ ។

**១២៨:៥–៦** ជាវគ្គអធិស្ឋានសរសើរតម្កើង និងការទទួលព្រះពរ គឺជាពរដែលមិនអាចបាត់បង់បាន ហើយជាការមានទំនាក់ទនងសេចក្ដីសុខសាន្តជាមួយព្រះជាភាពមានជីវិតរបស់ពូជសាសន៍ (គឺជាព្រះពរសុខសាន្តដល់ក្រុងយេរូសាឡិម និងជីវិតយូរអង្វែង) ។

**១២៨:៥** *ពីក្រុងស៊ីយូន* សូមមើល ៩:១១ និងការពន្យល់ ២០:២ ១៣៥:២១ ។

**១២៨:៦** *មានសេចក្ដីសុខគ្របលើសាសន៍អ៊ីស្រាអែល* សូមមើល ១២៥:៥ និងការពន្យល់ ។

ទំនុកច្រៀងតាមថ្នាក់ ។

**១២៩** គួរឱ្យសាសន៍អ៊ីស្រាអែលនិយាយ[ក]ឥឡូវថាតាំងពី
ខ្ញុំនៅក្មេង[ខ]គេបានធ្វើទុក្ខខ្ញុំ[គ]ជាច្រើនដងហើយ
២ គឺតាំងពីខ្ញុំនៅក្មេង គេបានធ្វើទុក្ខខ្ញុំជាច្រើនដងមែន
តែគេមិនបានឈ្នះ[ឃ]ខ្ញុំឡើយ
៣ ពួកអ្នកភ្ជួរបានភ្ជួរខ្នងខ្ញុំ គេបានធ្វើគន្លងគេឱ្យវែង
៤ តែព្រះយេហូវ៉ាទ្រង់សុចរិត[ង] ទ្រង់បានកាត់បណ្ដាច់អស់
ទាំងចំណង[ច]របស់ពួកមនុស្សអាក្រក់ចេញ[ឆ]
៥ សូមឱ្យអស់អ្នកដែលស្អប់ក្រុងស៊ីយ៉ូន[ជ] បានត្រូវខ្មាស
ហើយត្រឡប់ថយក្រោយទៅ[ឈ]
៦ សូមឱ្យគេបានដូចជាស្មៅដែលដុះនៅលើដំបូលផ្ទះ[ញ]
ដែលស្វិតក្រៀម[ដ]ទៅមុនដែលដុះធំឡើងផង
៧ ជាស្មៅដែលមិនបានបំពេញដល់ដៃ[ឋ]នៃអ្នកច្រូតឡើយ
ក៏មិនបានបំពេញឱបនៃអ្នកដែលចងបាច់ដែរ
៨ ហើយពួកអ្នកដែលដើរតាមទីនោះ ក៏មិនថាសូមឱ្យព្រះពរ
នៃព្រះយេហូវ៉ានៅលើឯងចុះយើងឱ្យពរដល់ឯង[ឌ]ដោយ
នូវព្រះនាមព្រះយេហូវ៉ានោះឡើយ ។

**១២៩:១** ក ទដ ១២៤:១ ខ ទដ ៨៨:១៥ គ នក ១:១៣ **១២៩:២** ឃ យរ ១:១៩ ១៥:២០ ២០:១១ មថ ១៦:១៨ **១២៩:៤** ង នក ៩:២៧ ច ទដ ៣៧:៩ ឆ ទដ ១៤០:៥ **១២៩:៥** ជ មីក ៤:១១ ឈ ទដ ៧០:២ **១២៩:៦** ញ អស ៣៧:២៧ ដ ២ពវ ១៩:២៦ ទដ ១០២:១១ **១២៩:៧** ឋ ចទ ២៨:៣៨ ទដ ៧៩:១២ **១២៩:៨** ឌ ទដ ១១៨:២៦ **១៣០:១** ក យប ៣០:១៩ ទដ ៤២:៧

ទំនុកច្រៀងតាមថ្នាក់ ។

**១៣០** ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់
ទ្រង់[ក]ពីទីជំរៅមក[ខ]
២ ឱព្រះអម្ចាស់អើយ សូមស្ដាប់សំឡេងទូលបង្គំ[គ]
សូមឱ្យព្រះកាណ៌ទ្រង់ប្រុងស្ដាប់[ឃ]ពាក្យទូលបង្គំទូលអង្វរ[ង]
៣ ឱព្រះយេហូវ៉ាអើយ បើសិនជាទ្រង់កត់ចំណាំអស់ទាំង
អំពើទុច្ចរិតនោះ ឱព្រះអម្ចាស់អើយ
តើអ្នកណានឹងធន់នៅបាន[ច]
៤ ប៉ុន្តែ ទ្រង់មានព្រះហឫទ័យអត់ទោសវិញ[ឆ]
ដើម្បីឱ្យគេបានកោតខ្លាចដល់ទ្រង់[ជ]
៥ ទូលបង្គំរង់ចាំព្រះយេហូវ៉ា[ឈ] គឺព្រលឹងទូលបង្គំរង់ចាំ
ទ្រង់[ញ] ទូលបង្គំសង្ឃឹមដល់ព្រះបន្ទូល[ដ]នៃទ្រង់
៦ ព្រលឹងនៃទូលបង្គំរង់ចាំព្រះអម្ចាស់ជាជាងពួកយាម

បទ ៣:៥៥ ខ ទដ ២២:២ ៥៥:១៧ ១៤២:៥ **១៣០:២** គ ទដ ២៧:៧ ២៨:២ ឃ ២របា ៦:៤០ ង ទដ ២៨:៦ ៣១:២២ ៨៦:៦ ១៤០:៦ **១៣០:៣** ច ១សយ ៦:២០ អរ ៩:១៥ ទដ ១៤៣:២ នហ ១:៦ វវ ៦:១៧ **១៣០:៤** ឆ នក ៣៤:៧ ២សយ ២៤:១៤ យរ ៣១:៣៤ ជ ១ពវ ៨:៤០ **១៣០:៥** ឈ ទដ ២៧:១៤ អស ៨:១៧ ២៦:៨ ៣០:១៨ ៤៩:២៣ ញ ទដ ៥:៣ ដ ទដ ១១៩:៧៤

**ទដ ១២៩** រាស្ត្រអ៊ីស្រាអែលបានអធិស្ឋានសូមឱ្យព្រះយេហូវ៉ាជួយដល់ពូកគេឱ្យរួចឫមានជ័យជម្នះលើសត្រូវដែលមានអំណាច គឺការរំឭកពីការដែលបានចេញផុតស្រុក (ខ.៤) ការអធិស្ឋានក៏ទទួលបានព្រះពរមកពីព្រះ (ទដ ១២៤–១២៨ ខ.៨) ក៏មាននៅក្នុង ទដ ១២៧ ហើយនិងវគ្គទាំងពីផ្នែក (ខ.១–៤៥) ។ មានព្យាង្គបទទំនុកជាភាសាព្រើរ ៥៩ តែសរុបទាំងអស់មាន (១២៧) វាស្មើតែមានចំនួនស្មើនិង ទដ ១៣០ (មាន ១២៣ ព្យាង្គ) ចំពោះការដែលមានទំនាក់ទំនងគ្នានិង ទដ ជំពូក ១២៤ សូមមើល សេចក្ដីផ្ដើមក្នុងជំពូកនោះ ។

**១២៩:១** *តាំងពីខ្ញុំនៅក្មេង* គឺតាំងពីជនជាតិអ៊ីស្រាអែលត្រូវបានពួកអេស៊ីព្ទចាប់យកទៅធ្វើជាទាសករ ក៏ត្រូវទទួលការឈឺចាប់យ៉ាងខ្លាំង ដោយព្រោះជីវិតសាសន៍អ៊ីស្រាអែលទាំងអស់ ស្ថិតក្នុងកណ្ដាប់ដៃនៃពួកសត្រូវដ៏មានអំណាចនោះ ។

**១២៩:២** *តែគេមិនបានឈ្នះខ្ញុំឡើយ* គឺគេពុំបានជោគជ័យពីការប្រឹងប្រែងរបស់ពួកគេទេ ក្នុងការបំផ្លាញរាស្ត្រអ៊ីស្រាអែល ឬគេពុំអាចរក្សាចំណងរបស់ដែលចងរាស្ត្រអ៊ីស្រាអែលបានឡើយ ។

**១២៩:៤** *សុចរិត* សូមមើលការពន្យល់ ៤:១ ។

**១២៩:៥–៨** គឺជាការអធិស្ឋានសូមឱ្យពួកសាសន៍ដែលបៀតបៀន ឬពួកដែលស្អប់ប្រជាជនអ៊ីស្រាអែលជារាសាស្ត្រក្នុងក្រុងស៊ីយ៉ូនឱ្យវិនាសទៅឆ្ងាយ (សូមមើល ទដ ១៣៧) ។

**១២៩:៥** សូមមើលការពន្យល់ ៥:១០ ។

**១២៩:៦** *ដូចជាស្មៅដែលដុះនៅលើដំបូលផ្ទះ* ដូចជាអ្នក"ភ្ជួរ"លើខ្នងរបស់រាស្ត្រអ៊ីស្រាអែល (សូមមើល ខ.៣) គឺមានលក្ខណៈដូចជាស្មៅដែលដុះពន្លកនៅលើវាលរាបស្មើ នៅលើដំបូលផ្ទះដែលមានកំដៅព្រះអាទិត្យ ដូច្នេះការទទួលផលចម្រូតក៏គ្មានដែរ (ខ.៧) ។

**១២៩:៨** *ពួកអ្នកដែលដើរតាម* គឺអ្នកដែលដើរឆ្លងកាត់ពួកអ្នកចម្រូតក្នុងវាលចម្រូតពុំបានទទួលការស្វាគមន៍ដែលចេញពីសេចក្ដីអំណរពិតនោះទេ ។ ទដ គឺជាទីបន្ទាល់ពីសេចក្ដីពិតក្នុងព្រះយេហូវ៉ាដោយគេម្នាក់នោះស្គាល់ពីអ្វីៗដែលគេធ្វើបាប គឺជាអ្នកមានបាបឯព្រះយេហូវ៉ាក៏ឲ្យពួកគេឃំសោក ដោយអស់ពីចិត្តផងដែរ ។ នេះគឺជាបទទំនុកដំកើងពីភាពរងទុក្ខទី៦ ក្នុងចំណោមបទទំនុកទាំង ៧វគ្គ (សូមមើល សេចក្ដីផ្ដើម ទដ ៦)។

**១៣០ ចំណងជើង** សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣៧ ។

**១៣០:១–៤** ជាការអធិស្ឋានសុំនូវការមេត្តាករុណា ។

**១៣០:១** *ពីទីជំរៅមក* ដូចជាក្នុង ៦៩:២ (សូមមើលការពន្យល់ ៣០:១ ៣២:៦ ប្រៀបធៀប ១២១:១ ១២៣:១) ។

**១៣០:៤** *មានព្រះហឫទ័យអត់ទោសវិញ* គឺពាក្យដែលអាចទុកចិត្តបាន នក ៣៤:៦–៧ ។ *កោតខ្លាចព្រះ* គឺជាការថ្វាយបង្គំដោយការកោតខ្លាច និងបម្រើទ្រង់ដែលជាព្រះដ៏ពិត (សូមមើល ទដ ៣៤:៨–១៤ និងការពន្យល់) ។ បើសិនជាព្រះមិនបានលើកលែងទោសដល់រាស្ត្រ នោះមនុស្សនិងមិនបានរួចផុតពីការទុក្ខលំបានឡើយ ។

**១៣០:៥–៨** ការទុកចិត្តលើព្រះយេហូវ៉ា : គឺជាទីបន្ទាល់ (សូមមើល ១៣១:៣) ។

**១៣០:៥** *ទូលបង្គំរងចាំ* គឺជាការសង្ឃឹម ទាំងមានសង្ឃឹម ។ *ព្រលឹងទូលបង្គំ* សូមមើល ៦:៣ ។ *ព្រះបន្ទូលនៃទ្រង់* ជាពិសេសព្រះបន្ទូលសន្យានៃសេចក្ដីសញ្ញា (សូមមើល ១១៩:២៥,២៨,៣៧,៤២,៤៩,៦៥,៧៤,៨១,១០៧,១១៤,ថ ១៤៧) ។

**១៣០:៦** *ពួកយាមល្បាត* សូមមើល ១២៧:១ ២សយ ១៣:៣៤ ១៨:២៤–២៧ បស ៣:៣ ៥:៧ ។ *ភ្លឺ* សូមមើលសេចក្ដីផ្ដើមក្នុង ទដ ៥៧ ៥៩:៩ និងការពន្យល់ ។

ល្បាត[ប] រង់ចាំភ្លឺឡើងអើ ជាជាងពួកយាមល្បាតរង់ចាំភ្លឺ
ឡើងទៅទៀត[ឌ]
៧ឱអ៊ីស្រាអែលអើយ ចូរសង្ឃឹម[ឍ]ដល់ព្រះយេហូវ៉ាចុះ
ដ្បិតមានសេចក្ដីសប្បុរស[ណ]នៅនឹងព្រះយេហូវ៉ា
ហើយមានសេចក្ដីប្រោសលោះជាបរិបូរ នៅនឹងទ្រង់ដែរ[ត]
៨ទ្រង់នឹងលោះ[ថ]សាសន៍អ៊ីស្រាអែលឱ្យរួចពីគ្រប់សេចក្ដី
ទុច្ចរិតរបស់ខ្លួន[ទ] ។

ទំនុកច្រៀងតាមថ្នាក់ ជាបទរបស់ស្ដេចដាវីឌ ។

**១៣១** ឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំមិនមែន
ឆ្មើងឆ្មៃ[ក] ហើយភ្នែកទូលបង្គំក៏មិនប្រកាន់យស[ខ]ទូលបង្គំ
មិនយកចិត្តទុកដាក់ក្នុងការដ៏ធំ[គ]ឬក្នុងដំណើរដែល
អស្ចារ្យហួសល្បត់ទូលបង្គំឡើយ[ឃ]
២ទូលបង្គំបានរំងាប់ហើយព្រលួងព្រលឹងទូលបង្គំជាស្រេច[ង]
ដូចជាក្មេងដែលម្ដាយបានផ្ដាច់ដោះឱ្យ គឺដូចជាក្មេងដែល
លែងដោះនៅជាមួយនឹងម្ដាយអើ ព្រលឹង[ច]នៅក្នុងខ្លួនទូល
បង្គំប្រៀបដូចជាកូនដែលលែងដោះហើយ
៣អ៊ីស្រាអែល អើយ ចូរសង្ឃឹម[ឆ]ដល់ព្រះយេហូវ៉ាចាប់តាំង
ពីឥឡូវនេះ ដរាបដល់អស់កល្បជានិច្ចចុះ[ជ] ។

*១៣២:៨–១០ – ២របា ៦:៤១–៤២*

ទំនុកច្រៀងតាមថ្នាក់ ។

**១៣២** ឱព្រះយេហូវ៉ាអើយ សូមទ្រង់នឹកចាំពីដាវីឌ
ហើយពីគ្រប់ទាំងសេចក្ដីទុក្ខព្រួយរបស់លោក[ក]

**១៣០:៦** ឋ ទដ ៦៣:៦ ឌ ២សយ ២៣:៤ **១៣០:៧** ឍ ទដ ២៥:៥ ៧១:១៤ ណ ១របា ២១:១៣ ត ទដ ១១១:៩ រម ៣:២៤ **១៣០:៨** ថ លក ១:៦៨ ទ នក ៣៤:៧ មថ ១:២១ **១៣១:១** ក ទដ ១០១:៥ អស ២:១២ រម ១២:១៦ ខ ២សយ ២២:២៨ យប ៤១:៣៤ គ យរ ៤៥:៥ ឃ យប ៥:៩

ទដ ១៣៩:៦ **១៣១:២** ង ទដ ១១៦:៧ ច មថ ១៨:៣ ១កថ ១៣:១១ ១៤:២០ **១៣១:៣** ឆ ទដ ២៥:៥ ១១៩:៤៣ ១៣០:៧ ជ ទដ ១១៣:២ **១៣២:១** ក ១សយ ១៨:១១ ២សយ ១៥:១៤

**១៣០:៧** សូមមើល ១៣១:៣ ។ *សេចក្ដីសប្បុរស* មើលការពន្យល់ ៦:៤ ។

**១៣០:៨** *គ្រប់សេចក្ដីទុច្ចរិតរបស់ខ្លួន* គឺចេញពីឫសគល់នៃការអាក្រក់គ្រប់យ៉ាង ឬចេញពីផលវិបាកផ្សេងៗ ។ គឺគ្រប់ការទាំងអស់នេះមានព្រះគ្រីស្ទជាអ្នកសម្រេច ។

**ទដ ១៣១** គឺជាផ្នែកនៃការលន់តួបាបនៃពួកអ្នកបន្ទាបខ្លួន ដែលទុកចិត្តលើព្រះយេហូវ៉ាជាការទាក់ទងនិង ជំពូក ១៣០ ។

**១៣១ ជាផ្នែកចំណងជើង** *ទំនុកច្រៀងតាមថ្នាក់* សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣៧ ។ *របស់ស្ដេចដាវីឌ* គឺឯកសារនាសម័យដើមក៏ពុំមាននិយាយទាំងស្រុងពីអត្ថបទនេះទេ (សូមមើលការពន្យល់ត្រង់ផ្នែកចំណងជើងនៃ ទដ ១២២,១៣២,១២៧,១៣៣) ។ វាជាអត្ថបទ បទទំនុកដែលស្ដេចដាវីឌបានរៀបចំឡើងដោយព្រោះវាសម ឬស៊ីនឹងទសនៈរបស់ដាវីឌ ក្នុងបទទំនុកទាំងនេះ ។

**១៣១:១** *ចិត្តទូលបង្គំ* សូមមើលការពន្យល់ ៤:៧ ។ *ឆ្មើងឆ្មៃ... មិនប្រកាន់យស* សេចក្ដីតម្កើងខ្លួនតាមដែលពួកគេមាន គឺជាធម្មជាតិរបស់មនុស្សចំពោះចៅហ្វាយរបស់ពួកគេ ដែលជាព្រះអាទិករទ្រង់បានបង្កើតធម្មជាតិសព្វយ៉ាងនោះ ។ ដោយសារពួកមនុស្សខំព្យាយាមគ្រប់គ្រងវាសនាជីវិតរបស់ពួកគេ តាមតែសមត្ថិភាពរបស់ពួកគេ(ដូចជាពួកគេបានសាងសង់ទីក្រុងបាបិលនិងប៉មដូចជាមានគំរូក្នុងព្រះគម្ពីរស្រាប មើល លប ១១:១–៩) (សូមមើលការពន្យល់ ៣១:២៣) ។ *ដំណើរដែលអស្ចារ្យហួសល្បត់ទូលបង្គំឡើយ* គឺពួកគេមានសភាពជាវីរៈបុរសដែលមានភាពអង្គអាចដែលទទួលសម្រេចបានក្នុងការប្រកួតប្រជែង បើគ្មានជំនួយពីព្រះដ៏មានព្រះចេស្ដានោះទេ ក៏មិនអាចទៅរួចឡើយ ។ តែក្នុងនេះអត្ថន័យ គឺផ្ដោតទៅលើអំណាចចេស្ដានៃព្រះ ជាជាងផ្ដោតលើព្រះទ័យរបស់ព្រះក្នុងការដែលព្រះប្រទានពរ ឬតាមរយៈការប្រោះលោះដោះឱ្យរួចពីគ្រោះថ្នាក់ ឬបញ្ហាទាំងឡាយ ។

**១៣១:២** *ព្រលឹង* សូមមើលការពន្យល់ ៦:៣ ។ *កូនក្មេងដែលម្ដាយបានផ្ដាច់ដោះ* គឺជាកូនមានអាយុ៤ ឬ៥ឆ្នាំ ដែលនៅក្បែរម្ដាយជាប់ជានិច្ច ។

**១៣១:៣** ក៏ដូចជាអ្នកនិពន្ធបទទំនុកដំកើង និងរាស្ត្រអ៊ីស្រាអែលទាំងអស់ផង (សូមមើល ១៣០:៧) គឺសម្រាប់គ្រប់ពេលវេលាទាំងអស់ ដែលពួកគេសង្ឃឹមលើព្រះយេហូវ៉ា ។

**ទដ ១៣២** គឺជាសេចក្ដីអធិស្ឋានចំពោះភាពសប្បុរសរបស់ទ្រង់ ក្នុងការលើកព្រះរាជបុត្រានៃស្ដេចដាវីឌឡើង និងនាសម័យដែលស្ដេចដាវីឌបានបង្កើតឡើងដូចជារចនាសម្ព័នដែលបង្កើតឡើង (និងការពន្យល់ ខ.១០) ។ តាមរយៈភាសាបកស្រាយបង្ហាញថា វាកើតឡើងក្នុងសម័យរាជានិយមដំបូងបង្អស់ ។ វាជាគោលជំនឿដែលគួរឱ្យគោរពតាមវាក៏បាននិពន្ធឡើងសម្រាប់ប្រើក្នុងពេលមានវិធីថ្វាយព្រះវិហារទៅដល់ព្រះ (ប្រៀបធៀប ៨–១០ និង ២របា ៦:៤១–៤២) ប៉ុន្តែបទទំនុកដំកើងនេះគេមិនយកទៅប្រើសម្រាប់កិច្ចការខាងក្រៅទេ តែគេប្រើសម្រាប់ធ្វើពិធីអភិសេក បះរៀបចំពិធីសោយរាជ្យដែលជាទម្លាប់វិញ (ប្រៀបធៀប ទដ ២,៧២,១១០) ។ អ្នកនិពន្ធនៃផ្នែកពង្សាវតារតាមរៀបជាសេចក្ដីអធិស្ឋាន (ឬជាវគ្គនៃការអធិស្ឋាន) នៅនឹងបបូរមាត់របស់ព្រះមហាក្សត្រផ្ទាល់ ។ ដូចជាបានប្រើក្នុងបទទន្ទេញពីកាលប្រវត្តិដែលបានទាក់ទងនិងព្រះម៉ែស៊ី ។

មានពីរខជាការទាមទារ (ខ.១,១០) ខមួយយកតាមលំនាំ (ភាសាហេព្រើរ) ដែលមានវគ្គគាថាពីរវគ្គចែកជាបួន ។ វគ្គទាំងអស់ក៏មានទម្រងបង្ហាញបញ្ជាក់ច្បាស់លាស់មានបន្ទាត់បង្ហាញពីសេចក្ដីផ្ដើម ឯបន្ទាត់ខាងក្រោមមានឃ្លាដែលបង្កប់ន័យពីបន្ទាត់ (សូមមើលសំណង់ឃ្លានៃសេចក្ដីដកស្រង់) ។ ទីបញ្ចប់ក៏មានសេចក្ដីអធិស្ឋាននិងបញ្ចប់វគ្គ ។ មានឃ្លាពីជាប់គ្នាក៏មានចុងជួនដូចគ្នា ជាវគ្គនៃសេចក្ដីអធិស្ឋានចំពោះវគ្គសេចក្ដីបញ្ចប់ ។ ឯវគ្គគាថាទាំងបួននេះដែលរួមបានជាពីរប្រយោគមានចុងជួនដូចគ្នា ក៏ជាសេចក្ដីអធិស្ឋានដែលមានក្នុង ខ.១,១០ ។ មាន ខ.២–៩ បង្ហាញឱ្យឃើញពីពាក្យស្បថសច្ចាប្រណិធានរបស់ស្ដេចដាវីឌ ចំពោះព្រះយេហូវ៉ាដើម្បីរក "កន្លែង" សម្រាប់ព្រះយេហូវ៉ា និងនាំហឹបសញ្ញាទៅកាន់ "ទីកន្លែងតម្កល់ទុក" គឺខណៈពេល ខ.១១–១៨ បង្ហាញឱ្យឃើញពីពាក្យសច្ចាស្បថរបស់ព្រះយេហូវ៉ាជាព្រះបន្ទូលសន្យាចំពោះស្ដេចដាវីឌ រើសរបស់ទ្រង់នៃក្រុងស៊ីយ៉ូនទុកដូចជាកន្លែង "សម្រាករបស់ផងទ្រង់" (ប៉ុន្តែសូមមើលការពន្យល់ ខ.១០) ។

**១៣២ ជាចំណងជើង** សូមមើល សេចក្ដីផ្ដើម ទដ ១២០–១៣៧ ។

**១៣២:១** ជាសេចក្ដីទទួច ឬទូលអង្វរដំបូង (សូមមើល ខ.១០) ។ *សូមទ្រង់*

²ដែលលោកបានស្បថនឹងព្រះយេហូវ៉ា ហើយបន់ដល់ព្រះ
ដ៏ខ្លាំងពូកែនៃយ៉ាកុបថា[ខ]
³ពិតប្រាកដជាទូលបង្គំនឹងមិនចូលទៅក្នុងផ្ទះជាទីលំនៅ[គ]
របស់ទូលបង្គំ ឬឡើងទៅដេកនៅលើគ្រែឡើយ
⁴ក៏មិនព្រមឱ្យភ្នែកទូលបង្គំដេកលក់ ឬឱ្យត្របកភ្នែក
ធ្មេចឡើយ
⁵ដរាបដល់ទូលបង្គំរកបានទីកន្លែង[ឃ]សំរាប់ព្រះយេហូវ៉ា
គឺជាពន្លាសំរាប់ព្រះដ៏ខ្លាំងពូកែនៃយ៉ាកុប
⁶មើលយើងខ្ញុំបានឮនិយាយនៅភូមិអេប្រាតា[ង]ក៏ប្រទះឃើញ
នៅវាលយ៉ាអើរ[ច]
⁷យើងខ្ញុំនឹងចូលទៅក្នុងពន្លារបស់ទ្រង់ យើងខ្ញុំ[ឆ]
នឹងក្រាបថ្វាយបង្គំ នៅមុខទីកំណល់កល់ព្រះបាទទ្រង់[ជ]

**១៣២:២** ខ លប ៤៩:២៤ អស ៤៩:២៦ ៦០:១៦
**១៣២:៣** គ ២សយ ៧:២,២៧
**១៣២:៥** ឃ ១ពវ ៨:១៧ កច ៧:៤៦
**១៣២:៦** ង ១សយ ១៧:១២ ច យស ៩:១៧ ១សយ ៧:២
**១៣២:៧** ឆ ២សយ ១៥:២៥ ទដ ៥:៧ ១២២:១ ជ ១របា ២៨:២
**១៣២:៨** ឈ ជន

⁸សូម ក្រោកឡើង ឱព្រះយេហូវ៉ាអើយ[ឈ] សូមយាងចូល
ទៅក្នុងទីសំរាករបស់ទ្រង់គឺ ទ្រង់ ព្រមទាំងហឹបដ៏ជាព្រះ
ចេស្តានៃទ្រង់ផង
⁹សូមឱ្យពួកសង្ឃរបស់ទ្រង់បានប្រដាប់ខ្លួន ដោយសេចក្តី
សុចរិត[ញ] ហើយឱ្យពួកអ្នកបរិសុទ្ធទាំងប៉ុន្មានរបស់ទ្រង់
ស្រែកឡើងដោយអំណរ
¹⁰សូមកុំបំបែរមុខនៃអ្នក ដែលទ្រង់បានចាក់ប្រេងតាំង
ចេញឡើយគឺដោយយល់ដល់ដាវីឌ ជាអ្នកបំរើទ្រង់
¹¹ព្រះយេហូវ៉ាទ្រង់បានស្បថនឹងដាវីឌ[ឋ] ដោយសេចក្តីពិត
ទ្រង់ ក៏មិនព្រមប្រែចេញវិញឡើយ គឺថា អញនឹងយកម្នាក់

១០:៣៥ **១៣២:៩** ញ យប ២៧:៦ អស ៦១:៣,១០ សក ៣:៤ មទ្យ ៣:៣ អភ ៦:១៤ ដ ទដ ១៦:៣ ៣០:៤ ១៤៩:៥ **១៣២:១១** ឋ ទដ ៨៩:៣-៤,៣៥

*នឹងចាំ* សូមមើល ២០:៣ ១ពវ ១១:១២-១៣ ១៥:៤-៥ ។ *គ្រប់ទាំងសេចក្តីទុក្ខព្រួយ* គឺជាសេចក្តីទូលសូមរបស់អ្នកដែលបានសច្ចាចំពោះទ្រង់ (ខ.២-៥ មើល ជន ៣០:១៣ គឺជាពាក្យបច្ចេកទេសដូចៗគ្នា គឺជាសេចក្តីសម្បថ) ។

**១៣២:២-៥** ពាក្យសម្បថរបស់ស្តេចដាវីឌ គឺទាក់ទងនឹងព្រះវិហារសម្រាប់ព្រះយេហូវ៉ា រួចព្រះយេហូវ៉ាបានត្រាស់ហៅទ្រង់ជាថ្មី ។

**១៣២:២** *លោកបានស្បថ* ជាពាក្យអធិស្ឋានចំពោះព្រះរាជបុត្ររបស់ស្តេចដាវីឌ ក៏ជាការបង្កើតទំនាក់ទំនងពិសេសរវាងស្តេចដាវីឌនិងព្រះយេហូវ៉ា ដូចជាសេចក្តីដែលបានបង្ហាញខ្លះក្នុងពាក្យសម្បថរបស់ពួកគេ (សូមមើល ខ.១១-១២) ។ នៅក្នុង ២សយ ៦-៧ ជាការធ្វើការអធិប្បាយនូវព្រឹត្តិការណ៍ដែលទ្រង់ត្រាស់ហៅមក ។ *ព្រះដ៏ខ្លាំងពូកែនៃយ៉ាកុប* សូមមើល ខ.៥ អស ១:២៤ សូមមើលការពន្យល់ ៣:៧ ។ *យ៉ាកុប* គឺជាពាក្យស្មើនិងពាក្យអ៊ីស្រាអែល (សូមមើល លប ៣២:២៨) ។

**១៣២:៦-៩** គឺបង្ហាញពីស្ថានភាពក្នុងដំណើរការរបស់ប្រជាជនចំពោះកិច្ចការព្រះវិហារក្នុងការថ្វាយបង្គំ ។

**១៣២:៦** *នៅភូមិ... នៅវាល* តាមអត្ថន័យនេះគឺចង់សំដៅទៅលើហឹប ឬជាសេចក្តីសញ្ញា ដែលជាការទំនាក់ទំនងនិងការត្រាស់ហៅរបស់ព្រះ ដើម្បីមកថ្វាយបង្គំ ។ *ភូមិអេប្រាតា* គឺជាភូមិនៅតំបន់ឯស្រុកបេថ្លេហិម គឺជាក្រុងស្រុកកំណើតរបស់ស្តេចដាវីឌ (សូមមើល រន ៤:១១ មីក ៥:២) ។ *នៅវាលយ៉ាអើរ* សូមមើល ២សយ ៦:២ និងការពន្យល់ ។ ជាទីដែលព្រះត្រាស់ហៅមកថ្វាយបង្គំ ដោយមានការពណ៌នាលំអិតពីក្រុងដាវីឌ រាជកាលហោរាសាំយូអែល (សូមមើល ១សយ ៧:១) ។ ការត្រាស់ហៅគឺក្នុងពេលបន្ទាប់ពីព្រះវិហារបានសាងសង់ ។ អ្នកនិពន្ធបទទំនុកព្យាយាមបង្រួមព្រឹត្តិការណ៍ឱ្យខ្លីងាយយល់ ។

**១៣២:៧** *កំណល់កល់ព្រះបាទទ្រង់* សូមមើល ៩៩:៥ និងការពន្យល់ ។

**១៣២:៨** *សូមក្រោកឡើង* ទោះបីជា (តាមទស្សនៈករីកំណាព្យជាភាសាហេព្រើរ)ភាសាហេព្រើក៏បានលប់ពាក្យសម្រាប់ប្រើជាសេចក្តីផ្តើម ដូចជាពាក្យ"មានបន្ទូល"ក្នុង ខ.៨-៩ គឺជាពាក្យចេញពីបបូរមាត់របស់អ្នកថ្វាយបង្គំ ។ សូមមើលសេចក្តីផ្តើម ទដ ២៤ ។ *ទីសម្រាករបស់ផងទ្រង់* គឺជាទីកដីសន្យា ដែលជាទីកន្លែងសម្រាប់រាស្ត្រអ៊ីស្រាអែល បានសម្រាកបន្ទាប់ពីការដើរទៅលើទីវាលរហោស្ថានដ៏វែងឆ្ងាយ (សូមមើល ជន ១០:៣៣ យស ១:១៣ មីក ២:១០) ។ ដូច្នេះព្រះបានសម្រាកនៅក្នុងត្រសាល (សូមមើល ២សយ ៧:៦ ១របា ២៨:២) មានការបញ្ជាក់ថា ព្រះវិហារក៏ជាទីដែលទ្រង់តាំងរាជបល្ល័ង្ក (ខ.១៤) ។ *ហឹបក៏ជាព្រះចេស្តានៃទ្រង់ផង* សូមមើលការពន្យល់ ៧៨:៦១ ។

**១៣២:៩** *បានប្រដាប់ខ្លួនដោយ* គឺមានលក្ខណៈខុសសំលៀកបំពាក់របស់ពួកសង្ឃធម្មតារបស់គេ គឺប្រហែលជាសំលៀកបំពាក់ផ្សេងៗគ្នានេះក៏បង្ហាញពីមុខងារផ្សេងៗគ្នាដែរ សូមមើលការពន្យល់ ១០៩:២៩ ។ *សេចក្តីសុចរិត* គឺជាពាក្យដែលមានទំនាក់ទំនងនិង ខ.១៦ ជាពាក្យ"សេចក្តីសង្គ្រោះ"គឺដូចគ្នានិងពាក្យដែលអ្នកនិពន្ធរបស់កណ្ឌគម្ពីរបាក្យត្រដែរ ។ គឺខណៈពេលគេស្រង់ខនេះមក (២របា ៦:៦១) ខណៈនោះពាក្យ "សេចក្តីសុចរិត" និងពាក្យ "សេចក្តីសង្គ្រោះ" គឺជារឿយៗមានលក្ខណៈស្រដៀងគ្នាស៊ីគ្នា (៤០:១០ ៥១:១៤ ៧១:១៥ ៩៨:២ អស ៤៥:៨ ៤៦:១៣ ៥១:៥-៦ ៥៦:១ ៥៩:១៧ ៦០:១៧-១៨ ៦១:១០ ៦២:១) ពោលគឺអត្ថន័យទាំងអស់សំដៅយ៉ាងច្បាស់ទៅលើភាពសុចរិតរបស់ព្រះ ដែលនាំឱ្យមានសេចក្តីសង្គ្រោះដល់រាស្ត្ររបស់ទ្រង់ (សូមមើលការពន្យល់ ៤:១) ។ *ពួកអ្នកបរិសុទ្ធ* សូមមើលការពន្យល់ ៤:៣ ។

**១២៣:១០** គឺជាការបញ្ជូនសំបុត្រលើកទី២ (សូមមើល ខ.១) ។ *ជាអ្នកបំរើទ្រង់* សូមមើលការពន្យល់ ទដ ១៨ ត្រង់ចំណងជើង ។ *សូមកុំបំបែរមុខ* គឺកុំបង្វែរចេញពីសេចក្តីរបស់ទ្រង់ (មើល ១ពវ ២:១៦-១៧,២០ សូមមើល ១ពវ ៨:៥៨ ២របា ៦:៤១-៤២) ។ បើមានការស្នើរតែសុំនៅការទូលអង្វរមានក្នុង ខ.១,១០ គឺជាទម្រង់បទទំនុកដំកើងពាក់កណ្តាលនូវវគ្គដំបូង ឬផ្នែកពាក់កណ្តាលវគ្គទី២ គឺជាការអធិស្ឋានបាន(ប្រហែលជាការនិយាយដោយពួកសង្ឃ ឬពួកលេវី) ។ ខណៈពេលខ្លះស្តេចដាវីឌបានស្បថថា និងថ្វាយព្រះយេហូវ៉ានូវទីកន្លែងសណ្ឋិតក៏ជាកន្លែងរបស់ព្រះរាជបុត្ររបស់ទ្រង់ និងសម្រាប់រាស្ត្រអ៊ីស្រាអែល គឺជាដំណាក់នៃការអធិស្ឋាន (សូមមើល ១ពវ ៨:២៧-៥៣ ៩:៣ ២របា ៧:១៥-១៦ អស ៥៦:៧) ។ ដើម្បីជាការឱ្យព្រះឮនូវសេចក្តីអធិស្ឋានរបស់អ្នកអធិស្ឋាន សូមមើលការពន្យល់ ២:២ ។

**១៣២:១១-១២** គឺជាការតាំងសញ្ញារបស់ព្រះយេហូវ៉ា ជាមួយស្តេចដាវីឌ ដែលគេហៅ ថាកន្លែងអធិស្ឋាន ។ ខទាំងនេះមាន ខ.១៣-១៨ គឺជាបទកំណាព្យ ដែលប្រមូលផ្តុំវិញ ១ពវ ៩:១-៥ (មើល ២របា ៧:១១-១៨) ។

ជាផល[ឌ]ដែលកើតពីខ្លួនឯងតាំងឡើងឱ្យអង្គុយលើបល្ល័ង្ក
របស់ឯង
១២ បើសិនជាកូនចៅរបស់ឯងរក្សាសេចក្ដីសញ្ញា[ឍ]របស់
អញនឹងសេចក្ដីបន្ទាល់ដែលអញនឹងបង្រៀនដល់គេ
នោះកូនចៅគេនឹងអង្គុយលើបល្ល័ង្ក[ណ] ឯងជាដរាបតរៀង
ទៅ
១៣ ដ្បិតព្រះយេហូវ៉ាទ្រង់បានរើសក្រុងស៊ីយ៉ូន[ត] ទ្រង់សព្វព្រះ
ហឫទ័យចង់បានសំរាប់ជាលំនៅរបស់ទ្រង់[ថ]
១៤ នេះជាទីសំរាករបស់អញនៅអស់កល្បជានិច្ច[ទ] អញនឹង
អាស្រ័យនៅទីនេះ[ធ] ដ្បិតអញមានចិត្តចង់បានហើយ
១៥ អញនឹងឱ្យពរជាបរិបូរដល់ស្បៀងអាហាររបស់ក្រុង
នេះហើយនិងចំអែតមនុស្សក្រនៅក្រុងនេះដោយអាហារ
ដ៏គ្រប់គ្រាន់[ន]
១៦ ឯពួកសង្ឃ[ប]អញនឹងតាក់តែង ដោយសេចក្ដីសង្គ្រោះ
ហើយពួកបរិសុទ្ធនឹងស្រែកហ៊ោដោយអំណរ[ផ]
១៧ នៅទីនេះអញនឹងធ្វើឱ្យស្នែងរបស់ដាវីឌប៊ុចឡើង[ព]អញ
បានចាត់ចែងចង្កៀង[ភ]១ សំរាប់អ្នកដែលអញបានចាក់
ប្រេងតាំងឱ្យ[ម]
១៨ អញនឹងយកសេចក្ដីខ្មាស[យ]តាក់តែងឱ្យពួកខ្មាំងសត្រូវ
របស់លោក តែនៅលើក្បាល[រ]លោកវិញនោះនឹងមាន
មកុដដ៏រុងរឿង ។

ទំនុកច្រៀងតាមថ្នាក់ ជាបទរបស់ស្ដេចដាវីឌ ។

**១៣៣** មើល ដែលបងប្អូននៅមូលជាមួយគ្នា[ក]ដោយ
ចិត្តព្រមព្រៀង[ខ]នោះជាការល្អ ហើយសមគួរយ៉ាងណា
ទៅ
២ នោះធៀបដូចជាប្រេងដ៏វិសេសដែលចាក់លើក្បាល[គ]ក៏
ហូរចុះមកដល់ពុកចង្កា គឺជាពុកចង្ការបស់អើរ៉ុន
រួចស្រក់ទៅ ដល់ជាយអាវរបស់លោកផង

**១៣២:១១** ឌ ១របា ១៧:១១–១៤ មថ ១:១ លក ៣:៣១ **១៣២:១២** ឍ ២របា ៦:១៦ ទដ ២៥:១០ ណ លក ១:៣២ កច ២:៣០ **១៣២:១៣** ត នក ១៥:១៧ ទដ ៤៨:១–២ ៦៨:១៦ ថ ១ពវ ៨:១៣ **១៣២:១៤** ទ ខ.៨ ទដ ៦៨:១៦ ធ ២សយ ៦:២ ទដ ៨០:១ **១៣២:១៥** ន ទដ ១០៧:៩ ១៤៧:១៤ **១៣២:១៦** ប ២របា ៦:៤១ ផ យប ៨:២១ ទដ ១៤៩:៥ **១៣២:១៧** ព ១សយ ២:១០ ទដ ៩២:១០ អគ ២៩:២១ លក ១:៦៩ ភ ១ពវ ១១:៣៦ ២ពវ ៨:១៩ ២របា ២១:៧ ទដ ១៨:២៨ ម ទដ ៨៤:៩ **១៣២:១៨** យ យប ៨:២២ រ ២សយ ១២:៣០ **១៣៣:១** ក លប ១៣:៨ រម ១២:១០ ខ យហ ១៧:១១ **១៣៣:២** គ នក ២៩:៧

**១៣២:១១** *បានស្បថនឹង* សូមមើល ខ.២ និងការពន្យល់ ។ ២សយ ៧ ក៏ពុំបានបង្ហាញជាពាក្យសម្បថ ប៉ុន្តែមានកន្លែងខ្លះព្រះក៏មានព្រះបន្ទូលសន្យាចំពោះស្ដេចដាវីឌ ដែលជាសេចក្ដីសញ្ញា (មើល ៨៩:៣,២៨,៣៤,៣៩ ២សយ ២៣:៥ អស ៥៥:៣) ឬមានសេចក្ដីសញ្ញាដែលជាសម្បថ មើល ១១០:៤ ។

**១៣២:១២** *សេចក្ដីសញ្ញា . . . សេចក្ដីបន្ទាល់* គឺជាលក្ខខ័ណ្ឌនៅលើភ្នំស៊ីណាយ ជាសេចក្ដីសញ្ញាដែលរាស្ត្រអ៊ីស្រាអែលទាំងអស់កាន់តាម (សូមមើល ១សយ ១០:២៥ និងការពន្យល់ និងមើល ១ពវ ២:៣–៤) ។

**១៣២:១៣–១៦** គឺការជ្រើសរើសរបស់ព្រះយេហូវ៉ា ចំពោះក្រុងស៊ីយ៉ូនដែលគេហៅថាទីអធិស្ឋាន ។

**១៣២:១៣** *ទ្រង់សព្វព្រះហឫទ័យចង់បាន សំរាប់ជាលំនៅរបស់របស់ទ្រង់* គឺជាដំណាក់របស់ដាវីឌ ដែលព្រះយេហូវ៉ាចង់បានជាទីសុខសាន្ត (សូមមើល ចទ ១២:៥–១៤) ។

**១៣២:១៥** ព្រះយេហូវ៉ាបានគង់ប្រថាប់នៅទីលានម្រាករបស់ផងទ្រង់ (សូមមើល ខ.៨,១៤) ដែលទ្រង់ប្រទានពរដល់ស្រុកដែលជាទឹកដីមួយសម្រាប់ទ្រង់ធ្វើជាទីគង់សម្រាក ក៏ជាកន្លែងដល់រាស្ត្រទ្រង់សម្រាប់រស់សុខសាន្ត (សូមមើល ចទ ១២:៩ យស ១:១៣ ១ពវ ៥:៤) ។

**១៣២:១៦** សូមមើលការពន្យល់ ខ.៩ ។

**១៣២:១៧–១៨** គឺជាពាក្យបញ្ចប់សេចក្ដី ដោយមានភាពច្បាស់លាស់ដែលបង្ហាញយ៉ាងទទូច (ខ.១,១០) ដោយផ្ទាល់និងតាមបរិយកាសជាក់ស្ដែង ។

**១៣២:១៧** *ស្នែង* គឺសំដៅលើអំណាចចេស្ដាដែលព្រះបានប្រទានឱ្យមានក៏ជាការចាក់ប្រេងតាំងពីព្រះយេហូវ៉ា ។ *ប៊ុចឡើង* គឺសំដៅលើរុក្ខជាតិទាំងឡាយដែលមានពន្លកចេញជាមែកធាងជាច្រើន ។ *បានចាត់ចែងចង្កៀង១ សំរាប់* សូមមើលការពន្យល់ ១ពវ ១១:៣៦ ។

**១៣២:១៨** *យកសេចក្ដីខ្មាសតាក់តែងឱ្យពួកខ្មាំងសត្រូវ* គឺមានលក្ខណៈផ្ទុយនឹខ.១៦ ។ មានមកុដដ៏រុងរឿង "គឺការមានផលផ្លែ" ។

**ទដ ១៣៣** គឺជាបទចំរៀងសរសើរតម្កើង ដើម្បីសុំឱ្យមានការរួបរួមនៅក្នុងចំណោមរាស្ត្ររបស់ផងទ្រង់ ។ បើអ្នកនិពន្ធជាស្ដេចដាវីឌ (សូមមើលការពន្យល់ត្រង់ចំណងជើង) ការនិពន្ធក្នុងជំពូកនេះបាននិពន្ធឡើង គឺបន្ទាប់ពីរសង្គ្រាម ឯប្រជាជនអ៊ីស្រាអែលទាំងអស់ក៏មកឯក្រុងហេប្រុន ដើម្បីជួបជុំគ្នា ក៏បានចាក់ប្រេងតាំងឱ្យស្ដេចដាវីឌធ្វើជាស្ដេចនៅទីនោះ គឺដើម្បីឱ្យទ្រង់ដឹកនាំប្រជាជនអ៊ីស្រាអែលនៅពេលនោះ (២សយ ៥:១–៣) ។ ក៏មានចលនាទៅមុខមួយទៀតបានបង្ហាញពីប្រវត្តិសាស្ត្រ ពីរការហូរចូលនៅជនភៀសខ្លួនជាច្រើនពីពូជអំបូរនៃនគរខាងជើង ចូលទៅអាណាចក្រយ៉ូដាគឺក្នុងកំឡុងពេលនៃការលុកលុយឈ្លានពានរបស់ពួកអាសើរ (សូមមើលសេចក្ដីផ្ដើម ទដ ៨០) ឬក៏មានការទាក់ទងនឹងពង្សាវតាប្រវត្តតាំងពីសម័យបាប៊ីឡូន គឺជាតំណាងឱ្យគ្រប់រាស្ត្រអ៊ីស្រាអែលទាំងអស់ ក៏បានឆ្លុះបញ្ចាំងក្នុងកណ្ឌគម្ពីរអែសរ៉ានិងកណ្ឌគម្ពីរនេហេមា (មើល អរ ៨:២៥ នង ១២:១៤) មានបន្ទាត់ទី១ និងបន្ទាត់ចុងក្រោម (ជាភាសាហេព្រើរ) (ខ.១,៣) ។ បានរៀបបទទំនុកទាំងមូល ជាវគ្គៗតាំផ្ទៃរឿងសំខាន់ៗនៃបទចម្រៀង ។

**១៣៣** *ចំណងជើងទំនុកច្រៀងតាមថ្នាក់* សូមមើល ទដ ១២០–១៣៧ ។ *របស់ស្ដេចដាវីឌ* ក៏ពុំមានប្រភពទំនុកចំរៀងច្បាស់លាស់ពីសម័យបុរាណ បានពណ៌នាពីស្ដេចដាវីឌបានគ្រប់ទាំងអស់ទេ តែមានមួយចំនួនប៉ុណ្ណោះ (សូមមើលការពន្យល់ ទដ ១២២,១២៧,១៣១) ។

**១៣៣:១** *ការល្អហើយសមគួរ* សូមមើល ១៣៥:៣ ១៤៧:១ ។

**១៣៣:២** *ជាប្រេងដ៏វិសេស . . . ហូរមកដល់ពុកចង្កា គឺជាពុកចង្ការបស់អើរ៉ុន* គឺជាការដែលចាក់ប្រេងតាំងចំពោះអើរ៉ុន (នក ២៩:៧ លវ ២១:១០) ការធ្វើកិច្ចនេះ គឺបញ្ជាក់ពីការឱទ្ទិសថ្វាយចំពោះព្រះដើម្បីញែកជាបរិសុទ្ធ គឺមានលក្ខណៈស្រដៀងទៅនិងការឧទ្ទិសថ្វាយ សូមសេចក្ដីសុខរូបរួមពីប្រជារាស្ត្ររបស់ព្រះ ។

៣ក៏ធៀបដូចជាទឹកសន្សើម[ឃ] នៅលើភ្នំហើម៉ូន[ង]
ដែលធ្លាក់មកលើភ្នំនៃក្រុងស៊ីយ៉ូន[ច] ដ្បិត នៅទីនោះព្រះ
យេហូវ៉ាបានប្រទានព្រះពរ[ឆ] គឺជាជីវិតដ៏នៅអស់កល្ប
ជានិច្ច[ជ] ។

ទំនុកច្រៀងតាមថ្នាក់ ។
**១៣៤** នៃ អស់អ្នកបំរើ[ក] របស់ព្រះយេហូវ៉ាដែលឈរ
នៅ[ខ]ក្នុងដំណាក់ទ្រង់នៅពេលយប់[គ] អើយចូរថ្វាយពរដល់
ព្រះយេហូវ៉ាចុះ
២ចូរប្រណម្យដៃ[ឃ]ទៅឯទីបរិសុទ្ធ[ង] ហើយសូមឱ្យព្រះ
យេហូវ៉ា[ច] បានព្រះពរចុះ
៣សូមឱ្យព្រះយេហូវ៉ា ដែលទ្រង់បង្កើតផ្ទៃមេឃ[ឆ] និងផែន
ដី ទ្រង់ប្រទានពរដល់អ្នករាល់គ្នាពីក្រុងស៊ីយ៉ូនមកផង[ជ] ។

*១៣៥:១៥–២០ – ទដ ១១៥:៤–១១*
**១៣៥** ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់
ព្រះនាមព្រះយេហូវ៉ា ឱពួកអ្នកបំរើ[ក] របស់ព្រះយេហូវ៉ា
អើយ ចូរសរសើរទ្រង់ចុះ
២ពួកអ្នករាល់គ្នាដែលឈរនៅក្នុងដំណាក់[ខ]នៃព្រះយេហូវ៉ា
គឺក្នុងទីព្រះលាន[គ]នៃដំណាក់របស់ព្រះនៃយើងខ្ញុំអើយ
៣ចូរសរសើរដល់ព្រះយេហូវ៉ា ដ្បិតព្រះយេហូវ៉ាទ្រង់ល្អ[ឃ]
ចូរច្រៀងសរសើរដល់ព្រះនាមទ្រង់[ង] ដ្បិតនោះពីរោះ
ហើយ[ច]
៤ព្រោះព្រះយេហូវ៉ាបានរើសយ៉ាកុប[ឆ]ទុកសំរាប់ទ្រង់
គឺអ៊ីស្រាអែល ឱ្យបានដាច់ជារបស់ផងទ្រង់[ជ]
៥ពីព្រោះខ្ញុំដឹងថា ព្រះយេហូវ៉ាទ្រង់ធំ[ឈ] ហើយថា ព្រះ
អម្ចាស់នៃយើងខ្ញុំ ទ្រង់ខ្ពស់លើសជាងអស់ទាំងព្រះ[ញ]
៦ការអ្វីក៏ដោយ ដែលព្រះយេហូវ៉ា សព្វព្រះហឫទ័យចង់

**១៣៣:៣** ឃ យប ២៩:១៩ សភ ១៩:១២ អស ១៨:៤ ២៦:១៩ ៤៥:៨ ហស ១៤:៥ មីក ៥:៧ ង ចទ ៣:៨ ៤:៤៨ ច នក ១៥:១៧ ទដ ២:៦ ៧៤:២ ឆ លវ ២៥:២១ ជ ទដ ២១:៤ **១៣៤:១** ក ទដ ១១៣:១ ១៣៥:១–២ វវ ១៩:៥ ខ ជន ១៦:៩ ១រប ១៥:២ គ ១រប ២៣:៣០ **១៣៤:២** ឃ ទដ ២៨:២ ១ធថ ២:៨ ង ទដ ១៥:១ ច ទដ ៣៣:២ ១០៣:១ **១៣៤:៣** ឆ ទដ ១២៤:៨ ជ លវ ២៥:២១ ទដ ២០:២ **១៣៥:១** ក នហ ៧:៧៣ **១៣៥:២** ខ ១រប ១៥:២ លក ២:៣៧ គ ទដ ១១៦:១៩ **១៣៥:៣** ឃ ១រប ១៦:៣៤ ទដ ១១៩:៦៨ ង ទដ ៦៨:៤ ច ទដ ៩២:១ ១៤៧:១ **១៣៥:៤** ឆ ចទ ១០:១៥ ជ នក ១៩:៥ ចទ ៧:៦ មទ្ស ៣:១៧ ទត ៧:៦ **១៣៥:៥** ឈ ទដ ៤៨:១ ១៤៥:៣ ញ នក ១២:១២ ១រប ១៦:២៥ យប ២១:២២

**១៣៣:៣** *ទឹកសន្សើមនៅលើភ្នំហើម៉ូន . . . ធ្លាក់មកលើភ្នំនៃក្រុងស៊ីយ៉ូន* ជាទឹកសន្សើមភ្នំស៊ីយ៉ូន (ឬក៏នៅឯភ្នំស៊ីយ៉ូន) ដែលបញ្ជាក់ពីភោគផលក៏សំបូរ (សូមមើល លប ២៧:២៨ បក ១:១០ សក ៨:១២) ។ ដូច្នេះការទូលអង្វររបស់រាស្ត្រអ៊ីស្រាអែល ទទួលបានភោគផលល្អក្នុងស្រុកគេ ។ ក៏មានខសិរីតសំរាំងពីរទៀតគឺ (ខ.២–៣) គឺបង្ហាញពីព្រះពរបានបង្ហូរមករាស្ត្រអ៊ីស្រាអែលតាមរយៈការជួយផ្គត់ផ្គង់ដល់ពួកសង្ឃនៅឯទីបរិសុទ្ធ (សូមមើល នក ២៩:៤៤–៤៦ លវ ៩:២២–២៤ នៅឯទីបរិសុទ្ធ (នក ២៩:៤៤–៤៦ លវ ៩:២២–២៤ ជន ៦:២៤–២៦) ជាផ្នែកសង្ខេបបទពីព្រះមេត្តាករុណាដ៏ប្រោសលោះរបស់ព្រះនឹងតាមរយៈទឹកសន្សើម ដែលជាអង្គធាតុសម្រាប់ជីវិតនៃការរស់នៅរបស់មនុស្ស សត្វ ដែលជាស្នាព្រះហស្តរបស់ទ្រង់ ។ *ជាជីវិត* ជាព្រះពរដែលជាសេចក្ដីសញ្ញាដ៏ធំឧត្តម្ភ (សូមមើល ចទ ៣០:១៥, ១៩–២០ ៣២:៤៧) ។

**ទដ ១៣៤** ជាបទសម្រាប់សូត្រ ឬច្រៀងសរសើរព្រះដើម្បីជាការផ្លាស់ប្តូរខ្លះដែលជាលក្ខណៈសង្ខេបខ្លីៗ ក្នុងលក្ខណៈអ្នកថ្វាយបង្គំរៀបចាកចេញពីព្រះវិហារបន្ទាប់ពីកម្មវិធីថ្វាយបង្គំពេលល្ងាច ឬសម្រាប់ពួកលេវីដែលនៅចាំយាមក្នុងព្រះវិហារពេញមួយយប់ ។ គឺក្នុងអត្ថបទរបស់អ្នកនិពន្ធបទទំនុកនេះបានបញ្ចប់សេចក្ដីដោយ "ទំនុកច្រៀងតាមថ្នាក់" ដូចជា ទដ ១១៧ ដែលមានឃ្លាបញ្ចប់ដោយច្រៀងថា ហាលេលូយ៉ា (ទដ ១១១–១១៧ ឯការបរិច្ឆេទគឺប្រហែលជាសម័យបាប៊ីឡូន ។

**១៣៤ ចំណងជើង** សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣៧ ។

**១៣៤:១–២** គឺជាចាប់ផ្ដើមឱ្យអ្នកថ្វាយបង្គំអំពាវនាវដល់ពួកលេវី ដើម្បីបន្តសរសើរដល់ព្រះយេហូវ៉ារហូតអស់រយៈពេលពេញមួយយប់ (សូមមើល ១រប ៩:៣៣) ។

**១៣៤:២** *ចូរប្រណម្យដៃទៅឯទីបរិសុទ្ធ* សូមមើល ៦៣:៤ ។

**១៣៤:៣** ជាវគ្គដែលពួកលេវីឆ្លើតតបតាមរយៈការប្រើពាក្យថ្វាយព្រះពរ ឬប្រសិទ្ធិពរជ័យចំពោះអ្នកដែលថ្វាយបង្គំព្រះ (មើលការពន្យល់ ១២១:២ ១២៤:៨ ១២៨:៥) ។

**ទដ ១៣៥** ជាការអំពាវនាវឱ្យសរសើរតម្កើងដល់ព្រះយេហូវ៉ា គឺជាព្រះអម្ចាស់ជីវិតមនុស្ស សត្វទាំងអស់ ក៏ជាព្រះលើគ្រប់ទាំងពូជសាសន៍ រួចទ្រង់ជាអង្គដែលជួយសង្គ្រោះ ។ ការនេះក៏បង្ហាញយ៉ាងច្បាស់ក៏តាមរយៈគម្ពីរសញ្ញាចាស់ជាច្រើនទៀត ។ ឃ្លាក្នុងខនេះគេនិពន្ធឡើងសម្រាប់ការសរសើរតម្កើងក្នុងព្រះវិហារ ។ គឺសំដៅលើការច្រៀងទំនុកមានលក្ខណៈពិសេស សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣៧ ។ បទទំនុកនេះក៏ច្រៀងភ្ជាប់ជាមួយពាក្យ "ហាលេលូយ៉ា" (ដូចជា ទដ ១៤៦–១៥០) ឯវគ្គការថាដំបូងនិងចុងក្រោយក៏បង្កប់ន័យការសរសើរ ។ ក៏ជាបទទំនុកច្រៀងទោលពីសេចក្ដីសង្គ្រោះដែលទ្រង់សង្គ្រោះរាស្ត្រអ៊ីស្រាអែល ដែលជាប់នៅស្រុកអេស៊ីព្ទ និងស្រុកការណាន (ខ.៨–១២) (ខ.៣–៤,១៣–១៤ ខ.៥–៧,១៥–១៨) ។

**១៣៥:១–២** ជាការត្រាស់ហៅដំបូងដើម្បីសរសើរតម្កើង ហើយក៏បង្ហាញឱ្យពួកសង្ឃនឹងពួកលេវីដឹងពីការបម្រើព្រះ (សូមមើល ១៣៤:១–២) ។

**១៣៥:១,៣,១៣** *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។

**១៣៥:៣–៤** ហេតុផលចំបងចំពោះរាស្ត្រអ៊ីស្រាអែល ដើម្បីសរសើរតម្កើងព្រះយេហូវ៉ា (សូមមើល ខ.១៣–១៤) ។

**១៣៥:៣** *ដ្បិតនោះពីរោះហើយ* សូមមើល ១៣៣:១ ។ តែមានពាក្យមួយទៀងថា "ទ្រង់ជាព្រះ គឺទ្រង់ល្អស្អាតស្អំ" (មើល ២៧:៤ និងការពន្យល់) ។

**១៣៥:៤** *យ៉ាកុប* ដែលមានសទិសន័យ (ន័យស្មើនិង) អ៊ីស្រាអែល (សូមមើល លប ៣២:២៨) ។ *ឱ្យបានដាច់របស់ផងទ្រង់* សូមមើល នក ១៩:៥ និងការពន្យល់ ។

**១៣៥:៥–៧** ព្រះយេហូវ៉ាមានភាពឧត្តម្ភដូចជាភាពគ្មានបាប (ខ.៣) គឺទ្រង់ជាព្រះយេហូវ៉ាលើគ្រប់ទាំងការបង្កើត ដែលជាស្នាព្រះហស្តរបស់ទ្រង់ទាំងអស់ (ប្រៀបធៀប និងពាក្យថារូបព្រះមានក្នុង ខ.១៥–១៨ សូមមើល យរ ១០:១១–១៦ សូមមើល ១១៥:៣ និង ៩៦:៥ ៩៧:៧ និងការពន្យល់) ។

ធ្វើ[ដ] នោះក៏បានធ្វើទៅ ទាំងនៅលើមេឃ នៅលើផែនដី[ឋ]
នៅក្នុងសមុទ្រ ហើយនៅទីជំរៅទាំងប៉ុន្មានផង
៧ទ្រង់បណ្ដាលឱ្យចំហាយទឹកឡើងពីចុងផែនដី
មកទ្រង់ធ្វើឱ្យមានផ្លេកបន្ទោរសំរាប់ភ្លៀង[ឌ]ក៏បញ្ចេញ
ខ្យល់[ឍ] ពីឃ្លាំងទ្រង់មកដែរ[ណ]
៨គឺទ្រង់ដែលបានប្រហារអស់ទាំងកូនច្បង[ត]របស់សាសន៍
អេស៊ីព្ទទាំងមនុស្ស ហើយនិងសត្វផង ។
៩ឱស្រុកអេស៊ីព្ទអើយ ទ្រង់បានចាត់ប្រើទីសំគាល់[ថ]
និងការអស្ចារ្យ ទៅកណ្ដាលឯង ហើយគឺឱ្យកើតដល់
ផារ៉ោន និងពួកមហាតលិកទាំងអស់គ្នា[ទ]
១០ទ្រង់ក៏បានប្រហារសាសន៍ដទៃជាច្រើន[ធ]ព្រមទាំងសំឡាប់
ស្ដេចជាច្រើនអង្គ ដែលមានអានុភាពខ្លាំងផង
១១គឺស៊ីហុន[ន] ជាស្តេចសាសន៍ អាម៉ូរី[ប] និងអុក
ជាស្ដេចស្រុកបាសាន[ផ] ហើយអស់ទាំងនគរ នៅស្រុក
កាណានទៀត[ព]
១២ទ្រង់ក៏ប្រទានស្រុករបស់គេ ទុកជាមរដក[ភ]
គឺជាមរដកដល់អ៊ីស្រាអែល ជារាស្ត្ររបស់ទ្រង់។
១៣ឱព្រះយេហូវ៉ាអើយ ព្រះនាមទ្រង់ស្ថិតស្ថេរ នៅ
ជាដរាប[ម]ឱព្រះយេហូវ៉ាអើយ សេចក្ដីនឹកចាំពីទ្រង់[យ]
ក៏ស្ថិតស្ថេរ នៅដរាបដល់អស់ទាំងដំណមនុស្សតទៅ
១៤ដ្បិតព្រះយេហូវ៉ាទ្រង់នឹងវិនិច្ឆ័យរាស្ត្រទ្រង់[រ]
ហើយនិងប្រែព្រះហឫទ័យ ចំពោះពួកអ្នកបំរើទ្រង់[ល]។
១៥អស់ទាំងព្រះរបស់សាសន៍ដទៃ[វ]សុទ្ធតែជារូបធ្វើពីប្រាក់
នឹងមាសប៉ុណ្ណោះជារបស់ដែលដៃមនុស្សបានធ្វើមក[ស]
១៦រូបទាំងនោះមានមាត់ តែមិនចេះនិយាយ[ហ] មានភ្នែក
តែមើលមិនឃើញ
១៧មានត្រចៀក តែស្តាប់មិនឮ ក៏គ្មានខ្យល់ដង្ហើម[ឡ]នៅក្នុង
មាត់ផង
១៨ពួកជាងដែលធ្វើរូបទាំងនោះក៏ដូចជារូបនោះឯងព្រម
ទាំងពួកអ្នកដែលទុកចិត្តនឹងរូបនោះផង ។
១៩ឱពូជពង្សអ៊ីស្រាអែលអើយ ចូរសូមឱ្យព្រះយេហូវ៉ា[អ]
បានប្រកបដោយព្រះពរ ឱវង្សអើរ៉ុនអើយ ចូរសូមឱ្យព្រះ
យេហូវ៉ាបានប្រកបដោយព្រះពរ
២០ឱវង្សលេវីអើយ ចូរសូមឱ្យព្រះយេហូវ៉ាបានប្រកប
ដោយព្រះពរ ហើយអស់អ្នកដែលកោតខ្លាចដល់ព្រះ
យេហូវ៉ាអើយ ចូរសូមឱ្យព្រះយេហូវ៉ាបានប្រកបដោយ
ព្រះពរចុះ
២១សូមឱ្យព្រះយេហូវ៉ាបានប្រកបដោយព្រះពរពីក្រុង
ស៊ីយ៉ូន[ក]មកជាព្រះដែលទ្រង់គង់ នៅក្រុងយេរូសាឡិម[ខ]
ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។

**១៣៥:៦** ដ ទដ ១១៥:៣ ដយ ៤:៣៥ ឋ មថ ៦:១០ **១៣៥:៧** ឌ យប ៥:១០ ទដ ៦៨:៩ អស ៣០:២៣ យរ ១០:១៣ ៥១:១៦ យអ ២:២៣ សក ១០:១ ឍ អម ៤:១៣ ណ ចទ ២៨:១២ **១៣៥:៨** ត នក ៤:២៣ ១២:១២ **១៣៥:៩** ថ នក ៧:៩ ទ ទដ ១៣៦:១០–១៥ **១៣៥:១០** ធ ជន ២១:២១–២៥ យស ២៤:៨–១១ ទដ ៤៤:២ ៧៨:៥៥ ១៣៦:១៧–២១ **១៣៥:១១** ន ជន ២១:២១ ប ជន ២១:២៦ ផ ជន ២១:៣៣ ព យស ១២:៧–២៤ ២៤:១២ **១៣៥:១២** ភ ចទ ២៩:៨ **១៣៥:១៣** ម នក ៣:១៥ យ ទដ ១០២:១២

**១៣៥:១៤** រ ១សយ ២៤:១៥ ហព ១០:៣០ **១៣៥:១៤** ល ចទ ៣២:៣៦ **១៣៥:១៥** វ ទដ ៩៦:៥ វវ ៩:២០ ស អស ២:៨ ៣១:៧ ៣៧:១៩ ៤០:១៩ យរ ១:១៦ ១០:៥ **១៣៥:១៦** ហ ១ពវ ១៨:២៦ **១៣៥:១៧** ឡ យរ ១០:១៤ ហព ២:១៩ **១៣៥:១៩** អ ទដ ២២:២៣ **១៣៥:២១** ក ទដ ១២៨:៥ ១៣៤:៣ ខ ១ពវ ៨:១៣ ២របា ៦:២

**១៣៥:៦** *ការអ្វីក៏ដោយ ដែលព្រះយេហូវ៉ាសព្វព្រះហឫទ័យចង់ធ្វើ នោះក៏ធ្វើបានទៅ* ឯរូបព្រះពុំអាចធ្វើបានទាំងអស់ (ខ.១៦–១៧) រូបព្រះទាំងនោះបង្កើតឡើងដោយពួកអ្នកដែលថ្វាយបង្គំរូបព្រះទាំងនោះ (ខ.១៨) ។ *នៅលើមេឃ . . . នៅផែនដី . . . ក្នុងសមុទ្រ* ក៏មានផ្នែកសំខាន់ៗបីផ្នែកនៃការបង្កើតដែលជាស្នាព្រះហស្តពីទ្រង់ ដូចជាទស្សនៈនាសម័យបុរាណ (សូមមើល លប ១:៨–១០ និងសេចក្ដីផ្ដើម ទដ ១០៤) ។

**១៣៥:៧** *ទ្រង់បណ្ដាលឱ្យចំហាយទឹកឡើងពី* ព្រះយេហូវ៉ាទ្រង់មិនមែនជាព្រះបាល ហើយក៏មិនមែនជារូបព្រះដ៏ទៃណាឡើយ ។ ឯរូបព្រះទាំងនោះពុំអាចនាំឱ្យមានភ្លៀងធ្លាក់ឡើយ មានតែព្រះយេហូវ៉ាដែលអាចនាំឱ្យមានភ្លៀងធ្លាក់បាន (សូមមើល ទដ ២៩ និងសេចក្ដីផ្ដើម និងសូមមើល យរ ១៤:២២ សក ១០:១ និងការពន្យល់) ។ *ខ្យល់* សូមមើល ១០៤:៤ ១៤៨:៨ ។ ឯចំណែករូបព្រះ ក៏ពុំមានអំណាចធ្វើឱ្យមាន"ខ្យល់ញ" (ដង្ហើម) នៅក្នុងដង្ហើមរបស់ពួកគេឡើង (ខ.១៧) ។ សូមមើល ៣៣:៧ និងការពន្យល់ យប ៣៣:៧ និងការពន្យល់ យប ៣៨:២២ ។

**១៣៥:៨–១២** គឺជាភាពជោគជ័យលើពួកអេស៊ីព្ទ និងពួកស្ដេចតែស្រុកទាំងនោះប្រែក្លាយជាមរដករបស់រាស្ត្រអ៊ីស្រាអែល ឯស្ដេចសង្ខេបរួមមានក្នុង នក ៧–១៤ ជន ២១:២១–៣៥ ។

**១៣៥:១៣–១៤** សូមមើល ៣–៤ និងការពន្យល់ ។

**១៣៥:១៤** *វិនិច្ឆ័យ* គឺព្រះគ្រីស្ទទ្រង់វាយកំទេចពួកប្រឆាំងទាំងឡាយ គឺដោយសារអំណាចលោកិយ សូម្បីតែប្រជាជនអ៊ីស្រាអែលក៏បានប្រកាសថា មានតែព្រះយេហូវ៉ាប៉ុណ្ណោះដែលជាព្រះពិត ។ *ប្រែព្រះហឫទ័យចំពោះ* សូមមើល នក ៣៤:៦–៧ ។ *អ្នកបំរើទ្រង់* គឺជាប្រជាជនដែលមានសេចក្ដីសញ្ញានឹងទ្រង់ ។

**១៣៥:១៥–១៨** ជាភាពគ្មានអំណាចចេស្ដាចំពោះព្រះក្លែងក្លាយ និងពួកអ្នកដែលថ្វាយបង្គំរូបព្រះទាំងនោះ (សូមមើល ខ.៥–៧ ១១៥:៤–៨ និងការពន្យល់) ។

**១៣៥:១៩–២១** គឺជាការអធិស្ឋាន ដើម្បីសរសើរតម្កើងដល់ព្រះយេហូវ៉ា គឺគេបានជួបជុំគ្នាក្នុងព្រះវិហារ ដើម្បីអធិស្ឋានសរសើរ (មើល ១១៥:៩–១១ ១១៨:២–៤) ។

**១៣៥:២០** *ឱវង្សលេវីអើយ* ពាក្យនេះបានបង្ហាញតែនៅទីកន្លែងនេះទេ (ប្រៀបធៀប ១របា ២៣:៤,៣០–៣១ ២៥:១ ២របា ២០:១៩,២១) ។

**១៣៥:២១** *ពីក្រុងស៊ីយ៉ូន* គឺចង់បង្ហាញថាមិនត្រឹមតែនៅក្រុងស៊ីយ៉ូនប៉ុណ្ណោះទេក៏មានរហូតដល់ពាសពេញទាំងផែនដីផងដែរ (សូមមើលការពន្យល់ ៩:១ ២២:២២–៣១) ។

**១៣៦** ឱសូមអរព្រះគុណ[ក]ដល់ព្រះយេហូវ៉ាដ្បិតទ្រង់ល្អ[ខ]
សេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប[គ]
២ឱសូមអរព្រះគុណ[ឃ]ដល់ព្រះដ៏ធំលើអស់ទាំងព្រះ[ង]
ដ្បិត សេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
៣ឱសូមអរព្រះគុណ[ច]ដល់ព្រះអម្ចាស់ដ៏ធំលើអស់ទាំងព្រះ
អម្ចាស់[ឆ] ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជា
ដរាប
៤គឺដល់ទ្រង់ដែលធ្វើការអស្ចារ្យយ៉ាងធំ[ជ]តែ១អង្គទ្រង់
ដ្បិត សេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
៥គឺដល់ទ្រង់ដែលបានបង្កើតផ្ទៃមេឃ[ឈ]ដោយប្រាជ្ញា[ញ]
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
៦គឺដល់ទ្រង់ដែលបានក្រាលផែនដី[ដ]នៅលើទឹក[ឋ]
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
៧គឺដល់ទ្រង់ដែលបានបង្កើតតួពន្លឺយ៉ាងធំ[ឌ]ទាំងប៉ុន្មាន
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
៨គឺព្រះអាទិត្យ សំរាប់បំភ្លឺនៅ[ឍ]ពេលថ្ងៃ
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
៩នឹងព្រះចន្ទ ហើយផ្កាយទាំងប៉ុន្មាន សំរាប់បំភ្លឺ
នៅពេលយប់ ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ
នៅជាដរាប
១០គឺដល់ទ្រង់ដែលបានប្រហារស្រុកអេស៊ីព្ទ ចំលើអស់ទាំង
កូនច្បង[ណ]របស់គេដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិត
ស្ថេរ នៅជាដរាប
១១ ព្រមទាំងនាំសាសន៍អ៊ីស្រាអែលចេញ[ត]ពីកណ្ដាលគេមក
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
១២ ដោយព្រះហស្ត[ថ]ខ្លាំងពូកែ និងព្រះពាហុលើកសំរេច[ទ]
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
១៣គឺដល់ទ្រង់ដែលបានវែកសមុទ្រក្រហម[ធ]ចេញជា២
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
១៤ក៏ឱ្យសាសន៍អ៊ីស្រាអែលដើរកាត់[ន]កណ្ដាលសមុទ្រនោះ
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
១៥តែបានរលាស់ទំលាក់ផារ៉ោន ព្រមទាំងពលទ័ពនៅក្នុង
សមុទ្រក្រហម[ប] ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ
នៅជាដរាប
១៦គឺដល់ទ្រង់ដែលបាននាំរាស្ត្រទ្រង់ដើរកាត់ទីរហោស្ថាន[ផ]
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
១៧គឺដល់ទ្រង់ដែលបានប្រហារស្ដេចដ៏ធំទាំងប៉ុន្មាន[ព]
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
១៨ ហើយបានសំឡាប់ពួកស្ដេច ដែលមានល្បីឈ្មោះផង[ភ]
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ ស្ថិតស្ថេរ នៅជាដរាប
១៩គឺស៊ីហុន ជាស្ដេចនៃសាសន៍អាម៉ូរី[ម] ដ្បិតសេចក្ដី
សប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
២០ ហើយនិងអុក ជាស្ដេចស្រុកបាសាន[យ]
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
២១ ព្រមទាំងប្រទានស្រុក[រ]គេ ទុកជាមរដក[ល]
ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប
២២គឺជាមរដក[វ]ដល់អ៊ីស្រាអែល ជាអ្នកបំរើ[ស]
ទ្រង់ដ្បិតសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរ នៅជាដរាប

**១៣៦:១** ក ទដ ១០៥:១ ខ ទដ ១០០:៥ ១០៦:១ ១៤៥:៩ យរ ៣៣:១១ ណាហ ១:៧ គ ខ.២–២៦ ២របា ៥:១៣ អរ ៣:១១ ទដ ១១៨:១–៤ **១៣៦:២** ឃ ទដ ១០៥:១ ង ចទ ១០:១៧ **១៣៦:៣** ច ទដ ១០៥:១ ឆ ចទ ១០:១៧ ១ធថ ៦:១៥ **១៣៦:៤** ជ នក ៣:២០ យប ៩:១០ **១៣៦:៥** ឈ សភ ៣:១៩ យរ ៥១:១៥ ញ លប ១:១ **១៣៦:៦** ដ លប ១:១ អស ៤២:៥ យរ ១០:១២ ៣៣:២ ឋ លប ១:៦ **១៣៦:៧** ឌ លប ១:១៤,១៦ ទដ ៧៤:១៦ យក ១:១៧ **១៣៦:៨** ឍ លប ១:១៦ **១៣៦:១០** ណ នក ៤:២៣ ១២:១២ **១៣៦:១១** ត នក ៦:៦ ១៣:៣ ទដ ១០៥:៤៣ **១៣៦:១២** ថ នក ៣:២០ ចទ ៥:១៥ ទ ចទ ៩:២៩

**១៣៦:១៣** ធ នក ៧៨:១៣ **១៣៦:១៤** ន នក ១៤:២២ ទដ ១០៦:៩ **១៣៦:១៥** ប នក ១៤:២៧ **១៣៦:១៦** ផ នក ១៣:១៨ ទដ ៧៨:៥២ **១៣៦:១៧** ព ជន ២១:២៣–២៥ យស ២៣:៨–១១ ទដ ៧៨:៥៥ ១៣៥:៩–១២ **១៣៦:១៨** ភ ចទ ២៩:៧ យស ១២:៧–២៤ **១៣៦:១៩** ម ជន ២១:២១–២៥ **១៣៦:២០** យ ជន ២១:៣៣–៣៥ **១៣៦:២១** រ យស ១២:១ ល ចទ ១:៣៨ យស ១៤:១ **១៣៦:២២** វ ចទ ២៩:៨ ទដ ៧៨:៥៥ ស អស ២០:៣ ៤១:៨ ៤២:១៩ ៤៣:១០ ៤៤:១,២១ ៤៥:៤ ៤៩:៥–៧

**ទដ ១៣៦** គឺជាបទទន្នេញសម្រាប់សរសើរតម្កើងដល់ព្រះយេហូវ៉ា ជាព្រះអាទិករ និងជាព្រះអង្គសង្គ្រោះដល់រាស្ត្រអ៊ីស្រាអែល ។ ឯផ្ទៃរឿងគឺមានលក្ខណៈស្រដៀងគ្នានិងខគម្ពីរ ទដ ១៣៥ ។ គឺទំនងដូចជាចម្រៀងពួកសង្ឃលេវីដែលពួកគេលើកជាបទទំនុក (១របា ១៦:៤១ ២របា ៥:១៣ ៣:១១) ឬក៏សម្រាប់អ្នកថ្វាយបង្គំទូទៅ (២របា ៧:៣,៦ ២០:២១) វាទាក់ទងនិងបទបន្ទរ (សូមមើល ១០៦:១ ១០៧:១–៤,២៩) ។ ជាបទទន្នេញសម្រាប់សូត្រសរសើរព្រះ (សូមមើលសេចក្ដីផ្ដើម ទដ ១២០–១៣៧) ។ បន្ទាប់ពីការអំពាវនាវឱ្យសរសើរ (ខ.១–៣) ដែលពណ៌នាពីស្នាព្រះហស្តទ្រង់ដែលទ្រង់បានបង្កើត (ខ.៤–៩) គឺទាក់ទងនិងការរំដោះរាស្ត្រអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ (ខ.១០–១៥) គឺជាផ្នែកដែលគេធ្វើដំណើរនៅវាលរហោស្ថាន (ខ.១៦) គឺមាន៦ខ ដែលនិយាយពីការធ្វើដំណើរនោះ ។ ចំណែកឯ៦ខបន្ទាប់ទៀត ជាការពណ៌នាពីសេចក្ដីបញ្ចប់ដែលបញ្ជាក់ពីផ្ទៃរឿងដូចៗគ្នាក៏មានសកម្មភាពផ្ទុយគ្នាខ្លះ ដែលទ្រង់បានបង្ហាញជាប្រវត្តិសាស្ត្រក្នុងនាមជាអ្នកដំណាងឱ្យរាស្ត្ររបស់ផងទ្រង់ (ខ.២៣–២៤) ។ សកម្មភាពរបស់ព្រះក្នុងលំដាប់លំដោយពីការបង្កើត (ខ.២៥) ក៏មានវគ្គបញ្ចប់នៃសេចក្ដីអំពាវនាវនៃការអធិស្ឋាន (ខ.២៦) ។ *សេចក្ដីសប្បុរសរបស់ទ្រង់ស្ថិតសេរ នៅជាដរាប* ពាក្យនេះលេចជាសំណេរមានចំនួន២៦ដង គឺទាក់ទងនិងព្រះនាមព្រះ "យ៉ាវេ" (Yaweh) គឺជាភាសាហេព្រើរមានន័យថាព្រះយេហូវ៉ា ។

**១៣៦:១–៣,២៦** *ឱសូមអរព្រះគុណដល់* ឬក៏មានន័យថា "សរសើរដំកើង" (សូមមើល ៧:១៧ និងការពន្យល់) ។

**១៣៦:២** *ព្រះដ៏ធំលើអស់ទាំងព្រះ* សូមមើល ចទ ១០:១៧ និង ១៣៥:៥ ។

**១៣៦:៥** *ដោយប្រាជ្ញា* សូមមើល សភ ៣:១៩ យរ ១០:១២ ។

**១៣៦:៦** *នៅលើទឹក* សូមមើល ២៤:២ និងការពន្យល់ ។

**១៣៦:៧–៩** បង្ហាញពីគម្ពីរ លប ១:១៦ ។

២៣ជាព្រះដែលបាននឹកចាំពីយើងខ្ញុំ[ហ]ក្នុងកាលដែលនៅក្នុង
សណ្ឋានទាបថោកនៅឡើយដ្បិតសេចក្តីសប្បុរសរបស់
ទ្រង់ស្ថិតស្ថេរនៅជាដរាប
២៤ហើយបានប្រោសយើងខ្ញុំ[ឡ]ឱ្យរួចពីពួកខ្មាំងសត្រូវ[អ]
ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប
២៥ជាព្រះដែលប្រទានឱ្យគ្រប់ទាំងសាច់មានអាហារ[ក]
ដ្បិតសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប
២៦ឱសូមអរព្រះគុណ[ខ]ដល់ព្រះនៃស្ថានសួគ៌ចុះ[គ]
ដ្បិត សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប[ឃ] ។

**១៣៧** យើងបានអង្គុយចុះនៅមាត់ទន្លេស្រុកបាប៊ីឡូន[ក]
អើ យើងបានយំ[ខ] ដោយនឹករឭកដល់ក្រុងស៊ីយ៉ូន[គ]
២យើងបានពាក់ព្យួរស៊ុង[ឃ]របស់យើងនៅដើមចាក[ង]
នាកណ្តាលស្រុកនោះ
៣ដ្បិតនៅទីនោះ ពួកអ្នកដែលនាំយើងទៅជាឈ្លើយ[ច]គេ
បង្ខំ[ឆ]ឱ្យយើងច្រៀងបទគឺពួកអ្នកដែលបំផ្លាញយើង គេឱ្យ
យើងលេង ឱ្យគេបានអរសប្បាយ ដោយពាក្យថា
ចូរច្រៀងបទ១របស់ក្រុងស៊ីយ៉ូនមកឱ្យយើងស្តាប់មើល[ជ]
៤តែយើងនឹងច្រៀងបទនៃព្រះយេហូវ៉ា[ឈ] នៅក្នុងប្រទេស
ដទៃដូចម្តេចបាន
៥ឱក្រុងយេរូសាឡិមអើយ បើសិនជាខ្ញុំភ្លេចឯង[ញ]នោះសូម
ឱ្យដៃស្តាំខ្ញុំភ្លេចថ្វីដៃទៅផង
៦បើសិនជាខ្ញុំមិនរឭក[ដ]ដល់ឯងគឺបើខ្ញុំមិនចូលចិត្តនឹងក្រុង
យេរូសាឡិម[ឋ]ជាជាងសេចក្តីអំណរយ៉ាងសំខាន់របស់ខ្ញុំ
នោះសូមឱ្យអណ្តាតខ្ញុំជាប់នៅក្រអូមមាត់[ឌ]ចុះ
៧ឱព្រះយេហូវ៉ាអើយ សូមទ្រង់នឹកចាំពីពួកជនជាតិអេដិម[ឍ]
ថានៅថ្ងៃលំបាកនៃក្រុងយេរូសាឡិម នោះគេបានស្រែក
ថាចូររំលំ[ណ]វា ចូររំលំវាទៅ រហូតដល់ឫសជញ្ជាំងផង[ត]
៨ឱកូនស្រីនៃបាប៊ីឡូនអើយ ឯងនឹងត្រូវបំផ្លាញ[ថ]
ហើយ សប្បាយហើយ អ្នកណាដែលសងដល់ឯងតាមការ
ដែលឯងបានប្រព្រឹត្តនឹងយើង

**១៣៦:២៣** ហ ទដ ៧៨:៣៩ ១០៣:១៤ ១១៥:១២ **១៣៦:២៤** ឡ យស ១០:១៤ នហ ៩:២៨ អ ចទ ៦:២៦ **១៣៦:២៦** ក ទដ ១០៥:១ ខ ទដ ១១៥:៣ គ អរ ៣:១១ **១៣៧:១** ក អគ ១:១,៣ ៣:១៥ ១០:១៥ ខ នហ ១:៤ គ អស ៣:២៦ បទ ១:៤ **១៣៧:២** ឃ យប ៣០:៣១ អស ២៤:៨ អគ ២៦:១៣ អម ៦:៥ ង លវ ២៣:៤០ **១៣៧:៣** ច ទដ ៧៩:១–៤ បទ ១:៥ ឆ យប ៣០:៩ ទដ ៨០:៦ ជ អគ ១៦:៥៧ ២២:៤ ៣២:២៩ **១៣៧:៤** ឈ នហ ១២:៤៦ **១៣៧:៥** ញ អស ២:៣ ៥៦:៧ ៦៥:១១ ៦៦:២០ **១៣៧:៦** ដ នហ ២:៣ ឋ ចទ ៤:២៩ យរ ៥១:៥០ អគ ៦:៩ ឌ ទដ ២២:១៥ **១៣៧:៧** ឍ លប ២៥:៣០ ២របា ២៨:១៧ ទដ ៨៣:៦ បទ ៤:២១–២២ ណ ២ពវ ២៥:១–១០ អប ១:១១ ត ទដ ៧៤:៨ **១៣៧:៨** ថ អស ១៣:១,១៩ ៤៧:១–១៥ យរ ២៥:១២,២៦ ៥០:១ ៥០:២–៥១:៥៨

**១៣៦:២៣–២៤** គឺអាចជាការបញ្ចប់វគ្គសង្ខេបពីការប្រោសលោះ ដែលគេនឹងចាំមិនភ្លេច ក៏ជាការនិយាយធៀបទៅនិងការសង្គ្រោះក្នុងគ្រាជំនុំជម្រះ និងក្នុងរាជ្យកាលនាស្តេចដាវីឌ ។

**១៣៦:២៦** *ព្រះនៃស្ថានសួគ៌* គឺជាចំណងជើងរបស់ភាសា "ភើសៀន" (Persian) មានន័យស្មើ "ព្រះអម្ចាស់"(សូមមើលការពន្យល់ អគ ១:២) ជាពិសេសមានច្រើនក្នុងគម្ពីរអេសរ៉ា នេហេមា និងដានីយ៉ែល ។ គោលបំណងក្នុងវគ្គនេះគឺស្រដៀងទៅនឹងភាសានិយាយក្នុង ខ.២–៣ ។

**ទដ ១៣៧** គឺជាចម្រៀងដែលត្អូញត្អែ អំពីការដែលបាននិរទេសចេញក្រៅស្រុកក៏ដូចជាខណៈពេល ដែលបានវិលត្រឡប់មកពីស្រុក ហើយជាប់ក្នុងអារម្មណ៍ពួកគេ ក្នុងខណៈដែលពួកគេស្ថិតនៅក្នុងទឹកដីនៃប្រទេសក្រៅ ដូចជាព្រឹត្តិការណ៍ដ៏ឃោឃៅ ។ ក្នុងវគ្គនេះនិយាយពីសេចក្តីស្រឡាញ់ក៏ស៊ីជម្រៅរបស់ក្រុងស៊ីយ៉ូន ដូចដែលបានឃើញនៅក្នុង ទដ ៤២–៤៣,៤៦,៤៨, ១២២,១២៦ ។ អ្នកពិនិត្យចំពោះបទទំនុកចម្រៀង បានរៀបរាប់ពីបទទំនុកចម្រៀងនេះបង្ហាញពីភាពពុះពា ឬថ្វាយទីក្រុងសម្រាប់ជាទីថ្វាយបង្គំរាស្ត្រអ៊ីស្រាអែលដល់ព្រះយេហូវ៉ា (សូមមើលសេចក្តីផ្តើម ទដ ១២០–១៣៧) ។

បន្ទាត់កំណាព្យទាំង១២បន្ទាត់ចំពោះបទចម្រៀងជាភាសាហេព្រើរក៏ចែកជាបីវគ្គការថាក្នុងបួនបន្ទាត់ : គឺជាភាពសោកសៅដែលគួរឱ្យចងចាំ និងការធ្វើទារុណកម្មផ្សេងៗ (ខ.១–៣) ក៏ដូចជាសេចក្តីសម្បថចំពោះការពុះពារចំពោះក្រុងយេរូសាឡិម (ខ.៤–៦) គឺជាការអំពាវនាវដើម្បីដាក់ទោសលើក្រុងអេដំ និងក្រុងបាប៊ីឡូន (ខ.៧–៩) ។

**១៣៧:១** *ទន្លេ* គឺជាទន្លេហើដេកែល និងទន្លេអើប្រាតដែលមានព្រែកតូចៗជាច្រើនជាប់ខ្វាត់ខ្វែងនឹងទន្លេនោះ ។ *យើងបានអង្គុយចុះ* គិតហើយគិតទៀតចំពោះកម្លាំងរបស់ពួកគេដែលបានផ្តាចចេញពីក្រុងស៊ីយ៉ូន ដែលនាំឱ្យធ្លាក់ចុះក្នុងទីមរណៈ និងការកាន់ទុក្ខ (មើល យប ២:៨,១៣ បទ ២:១០) ។

**១៣៧:២** *យើងបានពាក់ព្យួរស៊ុងរបស់យើង* "ឯស៊ុងពោរពេញដោយក្តីអំណរគឺភាពស្ងាត់ស្ងៀម"(អស ២៤:៨) ដោយសារតែពួកបាប៊ីឡូនដែលឥតមានភាពមេត្តា បានតម្រូវឱ្យពួកអ្នកទទួលរងទុកបានច្រៀងជាបទទំនុកជាសេចក្តីអំណរចំពោះក្រុងស៊ីយ៉ូន ដែលនៅឆ្ងាយគឺជាការដែលពួកគេបាននិរទេសដែលនាំឱ្យមានភាព "សោកសៅនិងការកាន់ទុក្ខ" (សូមមើល យប ៣០:៣១) ។

**១៣៧:៤–៦** គឺចងពោលចំពោះអ្នកដែលមានចិត្តពុំទទួលព្រះយេហូវ៉ា និងទីក្រុងយេរូសាឡិមជាទីក្រុងបរិសុទ្ធរបស់គេ គឺអាចកើតមាននៅក្នុងពួកសាសន៍បាប៊ីឡូន ។

**១៣៧:៧** *ពួកជនជាតិអេដំម* គឺជាការសំអប់អស់មួយជីវិតរបស់ពូជអេដំមចំពោះពូជអេសាវ គឺជាបងប្រុសរបស់យ៉ាកុប ដែលបង្ហាញនូវភាពកំសាករបស់គេក្នុងការប្រឈរមុខ និងរយៈពេលងងឹតរបស់ក្រុងយេរូសាឡិម ។ ក៏កុំបាច់ឆ្ងល់ឡើយ ដោយអ្នកនិពន្ធស្គាល់ពីការកាត់ទោសជំនុំជម្រះរបស់ព្រះយេហូវ៉ាប្រឆាំងនិងជាតិសាសន៍នោះ ដែលប្រកាសប្រាប់តាមរយៈពួកហោរា (អស ៦៣:១–៤ យរ ៤៩:៧–២២ អគ ២៥:៨,១២–១៤,៣៥) ។ *ចូររំលំវា* សូមមើល បទ ៤:២១ ។

**១៣៧:៨** *ឱកូននៃបាប៊ីឡូន* គឺចង់បង្ហាញពីលក្ខណៈសម្បត្តិនៃទីក្រុងបាប៊ីឡូន (សូមមើលការពន្យល់ ២ពវ ១៩:២១) ។ ត្រូវបំផ្លាញហើយ គឺអ្នកនិពន្ធនិងអ្នកដែលបានលើកទំនុកបទចម្រៀងនេះមកច្រៀង គឺដឹងច្បាស់ថាព្រះយេហូវ៉ាបានប្រកាសពីការជំនុំជម្រះទៅលើពួក ដែលជាអ្នកបំផ្លាញដ៏សាហាវនេះ (អស ១៣,៤៧ យរ ៥០–៥១) ។ ក្នុងថ្ងៃដែលព្រះយេហូវ៉ាបានជំនុំជម្រះក្រុងបាប៊ីឡូន គឺគេនិងទទួលនៅអ្វីដែលគេបានធ្វើចំពោះអ្នកដទៃ

៩សប្បាយហើយ អ្នកណាដែលនឹងចាប់កូនតូច[ទ] របស់ឯង
ទៅបោកនឹងថ្មផង ។

ទំនុកនៃស្តេចដាវីឌ ។

**១៣៨** ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់អស់អំពីចិត្តទូល
បង្គំនឹងច្រៀង[ក]សរសើរទ្រង់នៅចំពោះមុខនៃអស់ទាំង
ព្រះ[ខ]
២ទូលបង្គំនឹងក្រាបថ្វាយបង្គំដំរង់ទៅឯព្រះវិហារបរិសុទ្ធ[គ]
នៃទ្រង់ព្រមទាំងអរព្រះគុណដល់ព្រះនាម[ឃ] ទ្រង់ផងដោយ
ព្រោះសេចក្តីសប្បុរស និងសេចក្តីពិត[ង] របស់ទ្រង់
ដ្បិតទ្រង់បានដំកើងព្រះបន្ទូលទ្រង់ឱ្យធំលើព្រះនាមទ្រង់
ទៅទៀត[ច]
៣នៅថ្ងៃដែលទូលបង្គំបានអំពាវនាវ[ឆ]
នោះទ្រង់បានឆ្លើតប មកទូលបង្គំ[ជ] ទ្រង់បានកំឡាចិត្ត[ឈ]
ទូលបង្គំ ដោយចំរើនកំឡាំងនៃព្រលឹងទូលបង្គំ[ញ]
៤ឱព្រះយេហូវ៉ាអើយអស់ទាំងស្តេចនៅលើផែនដី[ដ]
និងអរព្រះគុណដល់ទ្រង់ ដ្បិតគេបានឮព្រះបន្ទូលដែល
ចេញពីព្រះឱស្ឋទ្រង់មកហើយ
៥អើ គេនឹងច្រៀង[ឋ]ពីអស់ទាំងផ្លូវនៃព្រះយេហូវ៉ា

**១៣៧:៩** ទ ២ពវ ៨:១២ អស ១៣:១៦ លក ១៩:៤៤ **១៣៨:១** ក ទដ ៩៥:៣ ៩៦:៤ ខ ទដ ២៧:៦ ១០៨:១ **១៣៨:២** គ ១ពវ ៨:២៩ ទដ ៥:៧ ឃ ទដ ៧៤:២១ ៩៧:១២ ១៤០:១៣ ង ទដ ១០៨:៤ ១១៥:១ ច ទដ ១១៩:៩

**១៣៨:៣** ឆ ទដ ១៨:៦ ៣០:២ ៩៩:៦ ១១៦:៤ ជ ទដ ១១៨:៥ ឈ សភ ២៨:១ កច ៤:២៩ ញ ទដ ២៨:៧ **១៣៨:៤** ដ ទដ ៧២:១១ ១០២:១៥ **១៣៨:៥** ឋ ទដ ៥១:១៤ ៧១:១៦ ១៤៥:៧

(មើល យរ ៥០:១៥,២៩ ៥១:២៤,៣៥,៤៩ ប្រៀបធៀប វវ ១៨:៥–៦) ។ ចំពោះគោលការណ៍ខ្លះមានក្នុង សេចក្តីពន្យល់ អគ ១៦:៤៣ ។ *សប្បាយហើយ* គឺជាការអបអរចំពោះអ្នកដែលកំចាយឈាម និងត្រូវបំបាត់ឱ្យអស់ពីផែនដី (សូមមើល អស ១៤:៣–៨ និងការពន្យល់,ប្រៀបធៀប យរ ៥១:៤៧–៤៨ វវ ១៩:១–៣) ។

**១៣៧:៩** *កូនតូចរបស់ឯង* សង្គ្រាមនាសម័យនោះឃោរឃៅជាងសម័យឥឡូវនេះ គឺពួកស្រីៗនិងកូរក្មេងក៏ពុំទុកជីវិតឱ្យឡើយ (សូមមើល ២ពវ ៨:១២ ១៥:១៦ អស ១៣:១៦,១៨ ហស ១០:១៤ ១៣:១៦ អម ១:១៣ ណហ ៣:១០) ។ ចំពោះការប្រកាសចុងក្រោយពីភាពមហន្តរាយនៃ "ក្រុងបាប៊ីឡូន" ដែលមានជាយូរមកហើយក៏បានប្រឆាំង និងទីក្រុងរបស់ព្រះអម្ចាស់ សូមមើល វវ ១៨:១–១៩:៤ ។

**ទដ ១៣៨–១៤៥** គឺជាការប្រមូលបទចំរៀងទំនុកតម្កើងរបស់ស្តេចដាវីឌទាំងប្រាំបី គឺជាបទទំនុកចុងក្រោយ ។ បទទាំងនេះមួយចំនួនធំ បានចង្អុលបង្ហាញពីព្រឹត្តិកាលសម័យបាប៊ីឡូន កាលបរិច្ឆេទគេក៏បញ្ជាក់ពីទំនៀមទម្លាប់នាសម័យស្តេចដាវីឌដែលមានកិត្តិស័ព្ទ និងអំណាចចេស្តាបំផុត ។ គឺជាការប្រមូលផ្តុំនូវបទចម្រៀងសរសើរ (ទដ ១៣៨,១៤៥) ។ គឺផ្តើមឡើងដោយការសរសើរពីសិរីល្អរបស់ព្រះ ក្នុងខណៈពេលព្រះបានឆ្លើយតបនូវការអធិស្ឋានក៏សម្តែងពីការ "អំពាវនាវ" របស់ពួកកំសត់ "ទន់ខ្សោយ" ខណៈពេលត្រូវទទួលការឈឺចាប់ក្នុងដៃរបស់មនុស្ស "ចិត្តធំអួតអាង" ។ ក្នុងបទទំនុកការដែលសំខាន់គឺការសរសើរដល់ព្រះដ៏មានព្រះចេស្តា ក៏មានវគ្គជាឃ្លាអធិស្ឋានចំនួន ៦វគ្គ ដែលបង្ហាញបញ្ជាក់ពីគោលបំណងជាក់លាក់ ។

ឯបទទំនុកចម្រៀងរបស់ស្តេចដាវីឌ ក៏មានការបង្ហាញពីអត្តសញ្ញាណសំខាន់ធំៗពីរផ្នែកចំពោះភាពល្អសុចរិតរបស់ទ្រង់ ។ ចំពោះផ្នែកទី១ គឺផ្តោតទៅលើការចងមេត្រីរបស់ផងទ្រង់ជាមួយមនុស្សទាំងអស់ (ទដ ១៣៩) ឯផ្នែកមួយទៀតគឺ (ទដ ១៤៥) ការចងចំណងទាក់ទងជាមួយការបង្កើតរបស់ទ្រង់ ដែលជាស្នាព្រះហស្ត ។

**ទដ ១៣៨** គឺជាឃ្លាបទចម្រៀងសរសើរចំពោះការសង្គ្រោះរបស់ព្រះអម្ចាស់ដែលទ្រង់បានជួយប្រឆាំងតបនិងពួកមច្ចាមិត្តជាសត្រូវ ។ ក្នុងគំនិតខ្លះក្នុង ទដ ១៨ ក៏ជាសេចក្តីសង្ខេប គឺជាវគ្គការថាបួនផ្នែនចែកជាពីរផ្នែកធំៗ (ខ.១–៣,៦–៨) គឺវាបង្កើតបានជាផ្ទៃរឿងទាំងមូល ចំណែកឯចំណុចកណ្តាលនៃវគ្គការថាពីរបន្ទាត់ (ខ.៤–៥) បានពង្រីកនូវក្រុមអ្នកដែលសរសើរតម្កើងដល់ព្រះយេហូវ៉ាដែលជាព្រះអម្ចាស់ "មើលគ្រប់ទាំងស្តេចក្នុងលោកិយនេះ" ។

**១៣៨ ចំណងជើង** សូមមើលសេចក្តីផ្តើម ទដ ១៣៨–១៤៥ ។

**១៣៨:១–៣** ឃ្លានេះ គឺជាការសរសើរតម្កើងចំពោះសេចក្តីសប្បុរសរបស់ទ្រង់ដែលបង្ហាញដោយការអធិស្ឋាន ។

**១៣៨:១** *អំពីចិត្ត* មើលការពន្យល់ ៤:៧ ។ *អស់ទាំងព្រះ* មានពួកស្តេចនៃពួកថ្វាយបង្គំរូបព្រះ (មើល ខ.៤–៥) ឬក៏ពួកអ្នកដែលគេប្រកាស់ថា ខ្លួនគេជាតំណាងមកពីព្រះ(មើលសេចក្តីផ្តើម ទដ ៨២ និងការពន្យល់ ៨២:១) ។

**១៣៨:២** *ព្រះវិហារបរិសុទ្ធនៃទ្រង់* បើតាមការបង្ហាញឃើញថាស្តេចដាវីឌគឺជាអ្នកនិពន្ធដោយមានសេចក្តីសំអាង ដែលមានត្រសាលបានរៀបចំឡើងសម្រាប់ហឹបនៃសេចក្តីសញ្ញា (២យស ៦:១៧) ក៏មានចម្រៀងទំនុកតម្កើងជាច្រើនបានផ្តល់នូវអំណះអំណាងពីស្តេចដាវីឌ ជាពិសេសកិច្ចការដែលទាក់ទងនឹង "ព្រះវិហារ" (សូមមើល ៥:៧ ១១:៤ ១៨:៦ ២៧:៤ និង ទដ ៣០ បង្ហាញពីចំណងជើង) ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។ *សេចក្តីសប្បុរស និងសេចក្តីពិតរបស់ទ្រង់* សូមមើលការពន្យល់ ៣៦:៥ ។ *សេចក្តីសប្បុរស* សូមមើល ខ.៨ និងការពន្យល់ ៦:៤ ។ *ព្រះបន្ទូលទ្រង់* ជាបន្ទូលពីសេចក្តីបញ្ញត្តិក្នុងទិសដៅរៀបចំលោកិយ (មើល ១៤៧:១៥) ក៏មានព្រះបន្ទូលមួយចំនួនធំគឺជាព្រះបន្ទូលសន្យា (មើល ខ.៤ និងការពន្យល់) ។ ការតាំងសញ្ញារបស់ផងព្រះបង្ហាញពីសេចក្តីស្រឡាញ់ និងភាពសុចរិត ដែលជាចម្លើយតាមរយៈការអធិស្ឋាន (ខ.៣) ក៏បង្ហាញព្រះនាមទ្រង់ និងសេចក្តីសន្យា បានសម្តែងឱ្យឃើញតាមរយៈរាស្ត្ររបស់ទ្រង់ ដូចជាពួកស្តេចមួយចំនួន ។

**១៣៨:៣** *ទូលបង្គំបានអំពាវនាវ នោះទ្រង់បានឆ្លើយតបមកទូលបង្គំ* សូមមើលការពន្យល់ ១១៨:៥ ។

**១៣៨:៤–៥** គឺជាក្រអៅក្នុងបទកំណាព្យ (សូមមើលការពន្យល់ ៦:៦) គឺជាផ្នែកនៃការបួងសួងប៉ងប្រាថ្នារបស់ស្តេចមួយចំនួន បានមកចូលរួមក្នុងការសរសើរតម្កើងដល់ព្រះយេហូវ៉ា (សូមមើលការពន្យល់ ៩:១) ។

**១៣៨:៤** *ព្រះបន្ទូលដែលចេញពីព្រះឱស្ឋ* គឺជាព្រះបន្ទូលសន្យាដ៏ធំរបស់ទ្រង់ចំពោះរាស្ត្ររបស់ទ្រង់ក៏ដូចជាចំពោះរាជវង្សដាវីឌ (សូមមើល ១៨:៣០ និងការពន្យល់) ។

**១៣៨:៥** *ទាំងផ្លូវនៃព្រះយេហូវ៉ា* មើល ២៥:១០ និងការពន្យល់ ។ ព្រះបន្ទូលទ្រង់នឹងផ្លូវទ្រង់ គឺមានភាពសុខដុម ហើយផ្លូវទាំងនោះក៏សម្តែងឱ្យឃើញពីសិរីរុងរឿងរបស់ព្រះតាមរយៈរាស្ត្រទ្រង់ (ប្រៀបធៀប ទដ ១៤៥) ។

ពីព្រោះសិរីល្អនៃព្រះយេហូវ៉ា[ឱ] នោះធំក្រៃលែង
៦ ដ្បិតទោះបើព្រះយេហូវ៉ាទ្រង់ខ្ពស់ គង់តែទ្រង់យល់ដល់
ពួកអ្នករាបសាដែរ[ឍ] តែឯមនុស្សឆ្មើងឆ្មៃ[ណ]
ទ្រង់ស្គាល់គេពីចំងាយហើយ
៧ ទោះបើទូលបង្គំដើរ[ត]នៅកណ្តាលសេចក្តីទុក្ខវេទនា
គង់តែទ្រង់នឹងចំរើនកំឡាំងដល់ទូលបង្គំផង[ថ] ទ្រង់នឹងលើក
ព្រះហស្ត[ទ]ឡើងទាស់នឹងសេចក្តីក្រេវក្រោធរបស់ពួក
ខ្មាំងសត្រូវ[ធ]ទូលបង្គំ ហើយព្រះហស្ត[ន]ស្តាំនៃទ្រង់នឹងជួយ
សង្គ្រោះទូលបង្គំដែរ[ប]
៨ ព្រះយេហូវ៉ាទ្រង់នឹងធ្វើឱ្យជំនឿ[ផ]របស់ទូលបង្គំបានពេញ
ខ្នាតឡើង ឱព្រះយេហូវ៉ាអើយ សេចក្តីសប្បុរសរបស់ទ្រង់
ស្ថិតស្ថេរនៅជាដរាប[ព] សូមទ្រង់កុំបោះបង់ចោល[ភ]អស់
ទាំងស្នាដៃនៃព្រះហស្តទ្រង់ឡើយ[ម] ។

ទំនុកនៃស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**១៣៩** ឱព្រះយេហូវ៉ាអើយ ទ្រង់បានពិនិត្យមើល[ក] ហើយ
បានស្គាល់[ខ]ទូលបង្គំផង
២ ទ្រង់ជ្រាបការដែលទូលបង្គំអង្គុយចុះនឹងការដែលទូល
បង្គំក្រោកឡើង[គ] ផងទ្រង់ក៏យល់គំនិត[ឃ] របស់ទូលបង្គំពី
ចំងាយដែរ
៣ ទ្រង់ពិនិត្យពិចារណាផ្លូវច្រក[ង] និងទីដេករបស់ទូលបង្គំក៏
ស្គាល់អស់ទាំងផ្លូវប្រព្រឹត្តរបស់ទូលបង្គំដែរ[ច]
៤ ដ្បិត ឱព្រះយេហូវ៉ាអើយពាក្យសំដីមិនទាន់មាននៅ
អណ្តាតទូលបង្គំនៅឡើយនោះទ្រង់ក៏ជ្រាបគ្រប់ជំពូក
ហើយ[ឆ]
៥ ទ្រង់បានព័ទ្ធទូលបង្គំជិត[ជ]ពីមុខពីក្រោយ
ហើយបានដាក់ព្រះហស្តលើទូលបង្គំ
៦ ការដឹងច្បាស់យ៉ាងនេះ ក៏អស្ចារ្យហួសល្បត់[ឈ] ទូលបង្គំ
ហើយខ្ពស់ដល់ម្ល៉េះ[ញ] បានជាទូលបង្គំ ឈោងមិនដល់
សោះ
៧ តើទូលបង្គំនឹងទៅឯណា ឱ្យរួចពីព្រះវិញ្ញាណ
ទ្រង់តើនឹងរត់ទៅ[ដ]ឯណា ឱ្យរួចពីព្រះភក្ត្រទ្រង់
៨ ទោះបីទូលបង្គំនឹងទៅឯស្ថានសួគ៌[ឋ] ក៏មានទ្រង់សណ្ឋិត
នៅទីនោះ ទោះបើទូលបង្គំនឹងរៀបដំណេក[ឌ]នៅស្ថាន
ឃុំព្រលឹងមនុស្សស្លាប់នោះក៏ឃើញមានទ្រង់សណ្ឋិតនៅ
ដែរ

**១៣៨:៥** ឱ ទដ ២១:៥ **១៣៨:៦** ឍ ទដ ១១៣:៦ ណ ទដ ៤០:៤ មថ ២៣:១២ **១៣៨:៧** ត ទដ ២៣:៤ ថ ទដ ៤១:២ ទ នក ៧:៥ ធ ទដ ៧:៦ ន ទដ ២០:៦ ៦០:៥ ១០៨:៦ ប ទដ ១៧:៧,១៤ **១៣៨:៨** ផ ភល ១:៦ ព អរ ៣:១១ ទដ ១០០:៥ ភ ទដ ៥១:១១ ម យប ១០:៣,៨ **១៣៩:១** ក ទដ ១៧:៣ រម ៨:២៧ ខ ទដ ៤៤:២១ **១៣៩:២** គ ២ពវ ១៩:២៧ ឃ ទដ ៩៤:១១ សភ ២៤:១២ យរ ១២:៣ **១៣៩:៣** ង ២ពវ ១៩:២៧ ច យប ៣១:៤ **១៣៩:៤** ឆ ហព ៤:១៣ **១៣៩:៥** ជ ២សយ ២៥:១៦ ទដ ៣២:១០ ៣៤:៧ ១២៥:២ **១៣៩:៦** ឈ ទដ ១៣១:១ ញ រម ១១:៣៣ **១៣៩:៧** ដ យរ ២៣:២៤ យហ ១:៣ **១៣៩:៨** ឋ ចទ ៣០:១២–១៥ អម ៩:២–៣ ឌ យប ១៧:១៣

**១៣៨:៦–៨** គឺជាសេចក្តីបន្ទាល់ចំពោះអង្គព្រះអម្ចាស់ផ្ទាល់ និងសេចក្តីសប្បុរសដ៏ពិតត្រង់ចំពោះអ្នកអធិស្ឋាន ។

**១៣៨:៦** សូមមើល ១១៣:៤–៩ និងការពន្យល់ ។ *យល់* គឺជាព្រះតម្រះស្គាល់ពីសណ្ឋានមនុស្សអាក្រក់ ។ *មនុស្សឆ្មើងឆ្មៃ* សូមមើលការពន្យល់ ៣១:២៣ ១០១:៥ ១៣១:១ ។ *ទ្រង់ស្គាល់ពីចម្ងាយ* ព្រោះទ្រង់បានឃើញហើយស្គាល់គ្រប់ទាំងសណ្ឋានមនុស្សអាក្រក់ពីចម្ងាយ ដោយមនុស្សលោកពុំស្គាល់ពីអាថ៌កំបាំងទ្រង់ឡើយ ទ្រង់ពុំឱ្យអ្នកណាម្នាក់ឃើញព្រះភ័ក្ត្រទ្រង់ឡើយ (សូមមើលការពន្យល់ ១១:៧) ។ ប្រៀបធៀប ១៣៩:២ ។

**១៣៨:៨** *ធ្វើឱ្យជំនឿរបស់ទូលបង្គំបានពេញខ្នាត* សូមមើល ៥៧:២ និងការពន្យល់ ។ *សូមទ្រង់កុំបោះបង់ចោលអស់ទាំងស្នាដៃនៃព្រះហស្តទ្រង់ឡើយ* ដោយសារតែសេចក្តីអធិស្ឋានចំពោះព្រះដ៏សប្បុរស នោះទ្រង់និងផ្តល់ឱ្យទទួលបាននូវភាពអស់កល្បក្នុងជីវិត ។

**ទដ ១៣៩** គឺជាវគ្គអធិស្ឋានចំពោះព្រះអម្ចាស់ ដែលទ្រង់ល្បងលដល់ចិត្តរបស់មនុស្ស និងការដែលទ្រង់ជ្រាបពីការលះបង់របស់ពួកគេយ៉ាងពិតប្រាកដ ។ ដូចជាករណីលោកយ៉ូប ដែលអ្នកនិពន្ធបានប្រកាសបង្ហាញពីភាពស្មោះត្រង់របស់គាត់ចំពោះព្រះយេហូវ៉ា ។ ក៏គ្មានអ្នកណាមួយ(ក្រៅពីលោកយ៉ូប) បង្ហាញពីសម្បជញ្ញៈចំពោះការទូលសូមឱ្យព្រះអម្ចាស់នូវការល្បងលមិនត្រឹមជីវិតទេ ក៏ប៉ុន្តែទាំងព្រលឹងផងដែរ ។ ដោយទ្រង់បានស្គាល់ពីគ្រប់ទាំងគំនិតពាក្យសម្តី ទង្វើ ឬពីទីលាក់កំបាំង ឬពីក្នុងផ្ទៃម្តាយរបស់មនុស្សគ្រប់គ្នា ។ (ខ.១–៦,៧–១២,១៣–១៨,១៩–២៤) ក្នុងបទចម្រៀងនេះបានផ្តើមនិងបញ្ចប់ដោយសេចក្តីអធិស្ឋាន ។

**១៣៩:៣១–៦** ព្រះអម្ចាស់ទ្រង់ស្គាល់ទូលបង្គំយ៉ាយច្បាស់ ដែលហួសពីសមត្ថភាពរបស់ទូលបង្គំ និងគ្រប់ទាំងសកម្មភាពទាំងឡាយរបស់ទូលបង្គំ ។

**១៣៩:២** *ទ្រង់ក៏យល់គំនិតរបស់ទូលបង្គំពីចំងាយ* សូមមើល ភាពផ្ទុយគ្នាក្នុង ១៣៨:៨ និងការពន្យល់ ។ *គំនិតរបស់ទូលបង្គំ* គឺជាការប៉ងប្រាថ្នារបស់ទូលបង្គំ ឬផែនការផ្សេងៗរបស់ទូលបង្គំ ។

**១៣៩:៥–៦** គឺជាការឆ្លើយតបរបស់អ្នកនិពន្ធបទទំនុក ចំពោះសេចក្តីដែលព្រះស្គាល់ពួកគេយ៉ាងច្បាស់ ។

**១៣៩:៥** *ទ្រង់បានព័ទ្ធទូលបង្គំជិត* ធ្វើឱ្យទូលបង្គំមានសុវត្ថិភាព ។ *បានដាក់ព្រះហស្តលើទូលបង្គំ* ដើម្បីកុំឱ្យទូលបង្គំគេចឆ្ងាយចេញពីទ្រង់ ។ អត្ថន័យនេះបង្ហាញពីភាពប្លែកពីគម្ពីរយ៉ូប ១៣:២៧ ប៉ុន្តែផ្នត់គំនិតមានលក្ខណៈស្រដៀងគ្នាច្រើន ។ *ព្រះហស្ត* ជាពាក្យមានសណ្ឋានជាលក្ខណៈឯកវចនៈ ឬ "ពហុវចនៈ" ។

**១៣៩:៦** *ក៏អស្ចារ្យហួសល្បត់ទូលបង្គំ* គឺអ្វីៗដែលចេញពីស្នាព្រះហស្ត គឺមានភាព"អស្ចារ្យ"ឯប្រាជ្ញារបស់ទ្រង់ មានអំណាចហួសពីសមត្ថភាពរបស់ទូលបង្គំ (សូមមើល ៧៧:១១,១៤ "ជាការអស្ចារ្យ" នក ១៥:១១) ។

**១៣៩:៧–១២** គ្មានអ្វីមួយដែលលាក់កំបាំងពីទ្រង់សោះក្នុងវគ្គនេះ ក៏គ្មានគោលទិទ្ធិណាដែលនៅទីងងឹតឡើយចំពោះវត្តមាន(ដែលគេគង់នៅគ្រប់ទីកន្លែងរបស់ទ្រង់) តែការទាំងនោះពេញដោយភាពកោតក្រែងញាប់ញ័រ (សូមមើល យរ ២៣:២៣–២៤) ។

**១៣៩:៧** *ពីព្រះវិញ្ញាណទ្រង់ . . . ឱ្យរួចពីព្រះភក្ត្រទ្រង់* សូមមើល ៥១:១១ និងការពន្យល់ អស ៦៣:៩–១០ អគ ៣៩:២៩ (ព្រះភក្ត្រនិងព្រះវិញ្ញាណ) ។

**១៣៩:៨** *ស្ថានសួគ៌ . . . នៅស្ថានឃុំព្រលឹងមនុស្សស្លាប់* គឺជាសណ្ឋានផ្ទុយគ្នាដាច់ស្រឡះ ។

៩ ទោះបើទូលបង្គំនឹងយកស្លាបនៃបច្ចូសកាលហោះទៅ
នៅឯទីបំផុតនៃសមុទ្រ
១០ គង់តែព្រះហស្តទ្រង់នឹងនាំទូលបង្គំនៅទីនោះ[ឍ] ហើយ
ព្រះហស្តស្តាំ[ណ]ទ្រង់នឹងក្តាប់ទូលបង្គំដែរ
១១ បើទូលបង្គំថា សេចក្តីងងឹតនឹងគ្របបាំងទូលបង្គំជា
ប្រាកដ ហើយពន្លឺដែលភ្លឺនៅជុំវិញទូលបង្គំនឹងត្រឡប់ជា
យប់វិញ
១២ ដូច្នេះ ទាំងសេចក្តីងងឹត[ត]នោះឯងមិនលាក់ពីទ្រង់ឡើយ
ទោះទាំងយប់ក៏ភ្លឺដូចជាពេលថ្ងៃដែរ ឯសេចក្តីងងឹត
និងពន្លឺភ្លឺ នោះស្មើគ្នានៅចំពោះទ្រង់
១៣ ដ្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ[ថ]
ហើយបានផ្សំគ្រឿងនៃទូលបង្គំ[ទ]នៅក្នុងផ្ទៃម្តាយ[ធ]
១៤ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់[ន] ដ្បិតទ្រង់បានបង្កើត
ទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់
ក៏សុទ្ធតែអស្ចារ្យទាំងអស់[ប] ព្រលឹងទូលបង្គំក៏ដឹងច្បាស់
ហើយ

**១៣៩:១០** ឍ ទដ ២៣:៣ ណ ទដ ១០៨:៦ អស ៤១:១០ **១៣៩:១២** ត យប ៣៤:២២ ដយ ២:២២ **១៣៩:១៣** ថ ទដ ១១៩:៧៣ ទ យប ១០:១១ ធ អស ៤៤:២,២៤ ៤៦:៣ ៤៩:៥ យរ ១:៥ **១៣៩:១៤** ន ទដ ១១៩:១៦៤ ១៤៥:១០ ប យប ៤០:១៩ **១៣៩:១៥** ផ សស ១១:៥ ព យប ១០:១១ ភ ទដ ៦៣:៩ **១៣៩:១៦** ម យប ៣៣:២៩ ទដ ៩០:១២ **១៣៩:១៧** យ យប ៥:៩ រ ទដ ៩២:៥ **១៣៩:១៨** ល ទដ ៤០:៥ វ យប ២៩:១៨ ស ទដ ៣:៥

១៥ កាលទូលបង្គំកើតមាន[ផ]នៅទីកំបាំង ហើយបានសួនធ្វើ
បែបចំឡែកៗ[ព]នៅទីទាបនៃផែនដី[ភ] នោះគ្រោងកាយ
របស់ទូលបង្គំមិនកំបាំងនឹងទ្រង់ទេ
១៦ ព្រះនេត្រទ្រង់បានឃើញធាតុនៃទូលបង្គំក្នុងកាលដែល
មិនទាន់មានរូបរាងនៅឡើយទាំងអស់បានកត់ទុក[ម]ក្នុង
បញ្ជីរបស់ទ្រង់ គឺអស់ទាំងថ្ងៃអាយុ ដែលបានដំរូវឱ្យទូល
បង្គំរស់នៅក្នុងកាលដែលមិនទាន់មានថ្ងៃណាមួយនោះ
នៅឡើយ
១៧ ឱព្រះអង្គអើយ[យ] ព្រះដំរិះរបស់ទ្រង់[រ]មានដំឡៃវិសេស
ដល់ទូលបង្គំណាស់ហ្ន៎ ក៏មានចំនួនច្រើនណាស់ផង
១៨ បើសិនជា ទូលបង្គំនឹងខំរាប់ចំនួន[ល]
នោះមានច្រើនជាងគ្រាប់ខ្សាច់ទៅទៀត[វ]
កាលណាទូលបង្គំភ្ញាក់ឡើង[ស]នោះទូលបង្គំនៅជាមួយ
នឹងទ្រង់នៅឡើយ

**១៣៩:៩** *យកស្លាបនៃបច្ចូសកាល . . . ទីបំផុតនៃសមុទ្រ* គឺសំដៅលើជើងមេឃពីម្ខាងទៅជើងមេឃម្ខាងទៀត ដែលជាទិសខាងកើត និងទិសខាងលិច (ជាសមុទ្រមេឌីទែរ៉ាណេ) ក៏ជាការបង្ហាញពីការញែកដាច់ពីគ្នានូវការបង្កើតដោយស្នាព្រះហស្តជាពីផ្នែកធំៗ (មើល ខ.៨–៩) ។

**១៣៩:១០** *នាំទូលបង្គំ . . . ក្តាប់ទូលបង្គំ* តាមរយៈភាសាសរសេរនេះ ក៏បានឃើញក្នុង ៧៣:២៣–២៤ ដែលបង្ហាញពីព្រះទ័យរបស់ទ្រង់ ក្នុងការខ្វាយខ្វល់ចំពោះរាស្ត្ររបស់ទ្រង់ ដោយព្រោះទ្រង់មានអំណាចចេស្តាលើគ្រប់ទាំងអស់ ហើយវាជាលក្ខណៈមួយដែលគ្មានលក្ខណៈណាដូចជាគំនិតក្នុង ខ.៥ នេះឡើយ ។

**១៣៩:១១–១២** បង្ហាញពីការបង្កើតរបស់ទ្រង់ ក៏ពុំមានទីលាក់កំបាំងសោះឡើយ (ខ.៨–៩) ទោះក្នុងគ្រាងងឹតយប់ ឬថ្ងៃក្តី (មើល យប ៣៤:២២) ។

**១៣៩:១៣–១៨** អង្គទ្រង់ផ្ទាល់បានដាក់ទូលបង្គំក្នុងផ្ទៃ និងចាក់ប្រេងតាំងជីវិតទូលបង្គំតាំងពីទូលបង្គំមុនពេលចាប់កំណើតមកម្លេះ ។ ដោយទ្រង់ស្គាល់គ្រប់ទាំងសណ្ឋានរបស់ទូលបង្គំយ៉ាងច្បាស់ ព្រោះទ្រង់បានបង្កើតទូលបង្គំ ។

**១៣៩:១៣** *បានបង្កើត* ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះកិរិយាស័ព្ទនេះគឺមានន័យស្រដៀងក្នុងគម្ពីរ លប ១៤:១៩,២២ សភ ៨:២២ តែមិនដូចនៅក្នុង លប ១:១,២១,២៧ ។ *ចិត្តថ្លើម* តាមបែបអក្សរសាស្ត្រមានដូចជា "ក្រលៀន" ឯតាមបែបភាសាហេព្រើរអាចមានន័យថា អារម្មណ៍ ចិត្ត ឬព្រលឹង និងសីលធម៌ដឹងខុសត្រូវ ដែលព្រះអម្ចាស់បានល្បងលនោះ គឺខណៈពេលដែលទ្រង់ចង់ដឹងពីជីវិតអ្នកណាម្នាក់ (សូមមើលការពន្យល់ ៧:៩) ។

**១៣៩:១៤** *មកយ៉ាងគួរកោត គួរអស្ចារ្យ . . . សុទ្ធតែអស្ចារ្យ* ដោយទ្រង់ស្គាល់ទូលបង្គំដូចជាអ្នកដែលបង្កើតទ្រង់ទ្រាយជារូបទូលបង្គំ (សូមមើល ខ.១៥–១៦) ប៉ុន្តែ ឯរូបទូលបង្គំពុំអាចយល់បាន ឬបាននូវគ្រប់អស់ទាំងធម្មជាតិរបស់ផងទ្រង់ ដូចជាគ្រប់អ្វីៗដែលទ្រង់បង្កើត ។ ទូលបង្គំក្រឡេកមើលទ្រង់ប្រកបដោយភាពញាប់ញ័រកោតក្រែង (សូមមើលការពន្យល់ ខ.៦) និងការសរសើរដល់ទ្រង់ (សូមមើល សស ១១:៥) ។

**១៣៩:១៥** *នៅទីកំបាំង . . . នៅទីទាបនៃផែនដី* គឺសំដៅលើតាំងពីការបង្កដំនើតពីក្នុងផ្ទៃម្តាយដែលគេហៅថា "នៅទីកំបាំង" ក៏មនុស្សគ្រប់គ្នាពុំអាចយល់ឱ្យស៊ីជម្រៅបានដែរ (សូមមើល ២សយ ១២:១២) ហើយវាជានិស្ស័យរបស់ទូលបង្គំដែលត្រូវស្លាប់នៅផែនដីគឺជា "ទីទាបនៃផែនដី" (សូមមើលការពន្យល់ ៣០:១) គឺទាក់ទងនិងភាពងងឹត ភាពសើម និងមានភាពដាច់ស្រលះពីបទទំនុកតម្កើងពីជីវិត ។ លើសពីនេះទៅទៀតគឺឃ្លាទាំងពីរនេះក៏ចង់សំដៅទៅលើទីនៃសេចក្តីស្លាប់ (៦៣:៩ យប ១៤:១៣ អស ៤៤:២៣ ៤៥:១៩) ដោយការបង្កឱ្យមានកំណើតជីវិតក្នុងផ្ទៃ នាំឱ្យមានជីវិតក្នុងសង្គមនុស្សដែលអាចមកពីធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលីដីវិញដែរ (៦៣:៩ យប ១៤:១៣ អស ៤៤:២៣ ៤៥:១៩) ឯស្បូនកំណើតនោះ គឺជាសេចក្តីស្លាប់ (៩០:៣ លប ៣:១៩ សស ៣:២០ ១២:៧) គេស្លាប់ដែលមានលក្ខណៈដូចទីកន្លែងដែលគេចាប់កំណើតមកដែរ (សូមមើល អស ៤៤:២,២៤ ៤៩:៥ យរ ១:៥) ។

**១៣៩:១៦** *គឺអស់ទាំងថ្ងៃអាយុ* គឺជាចំណែកជីវិតដែលទ្រង់ផ្តល់ឱ្យមានអំណាចក្នុងកាលដែលនៅរស់ ។ *ក្នុងបញ្ជីរបស់ទ្រង់* គឺជាការដែលទ្រង់បានចុះក្នុងសៀវភៅជីវិតនៅស្ថានសួគ៌ (សូមមើលការពន្យល់ ៥៦:៨) ។

**១៣៩:១៧–១៨** គឺជាការឆ្លើយតបរបស់អ្នកនិពន្ធបទទំនុកតម្កើង ៖ ព្រះទ័យទ្រង់ចំពោះអ្នកនិពន្ធមានភាពធំធេង និងសេចក្តីស្រឡាញ់ (សូមមើលការពន្យល់ ៥៦:៨) ។

**១៣៩:១៧** *ព្រះដំរិះ* បានសម្តែងចេញក្នុងគ្រប់ទាំងព្រះបន្ទូល ក៏ខុសពីគំនិតប្រាជ្ញារបស់ទូលបង្គំ (ខ.២ និងការពន្យល់) ។

**១៣៩:១៨** *កាលណាទូលបង្គំភ្ញាក់ឡើង* ដោយសារការដេកលក់ ឬដោយការអស់កម្លាំងពីខ្លួន ក៏ធ្វើឱ្យទូលបង្គំពុំមានជម្រើសឯណាដើម្បីប្រឆាំងនឹងដំរិះ ឬប្រឆាំងនឹងរាជកិច្ចទេ (សូមមើល ៦៣:៦ ១១៩:១៤៨) ហើយនិងបាន

១៩ឱព្រះអង្គអើយ ទ្រង់នឹងប្រហារពួកមនុស្សអាក្រក់[ហ]ជាមិន
ខាន នែ ពួកមនុស្សដែលកំចាយឈាម[ឡ]អើយ
ចូរថយចេញពីអញទៅ[អ]
២០ដ្បិតគេពោលយ៉ាងអាក្រក់ទាស់នឹងទ្រង់ហើយពួកខ្មាំង
សត្រូវ[ក]របស់ទ្រង់ គេចេញព្រះនាមទ្រង់ជាអសារឥតការ[ខ]
២១ឱព្រះយេហូវ៉ាអើយ ទូលបង្គំស្អប់ដល់ពួកអ្នក[គ]
ដែលស្អប់ទ្រង់ ក៏ខ្ពើម[ឃ]ដល់ពួកអ្នកដែលលើកគ្នាទាស់នឹង
ទ្រង់ដែរទេតើ
២២គឺទូលបង្គំស្អប់គេពេញទីហើយ គេបានត្រឡប់ជាខ្មាំង
សត្រូវដល់ទូលបង្គំដែរ[ង]
២៣ឱព្រះអង្គអើយ សូមពិនិត្យមើល[ច] ឱ្យបានស្គាល់ចិត្ត[ឆ]
ទូលបង្គំផងសូមល្បងលឱ្យបានជ្រាបអស់ទាំងគំនិតនៃទូល
បង្គំចុះ
២៤សូមទតមើលបើមានអំពើអាក្រក់ណា[ឋ] នៅក្នុងទូលបង្គំ
ហើយនាំទូលបង្គំ[ឈ]តាមផ្លូវដ៏នៅអស់កល្បជានិច្ច ។

ទំនុករបស់ស្តេចដាវីឌ ដែលទ្រង់លើកសំរាប់មេភ្លេង ។

**១៣៩:១៩** ហ ទដ ៥:៦ អស ១១:៤ ឡ ទដ ៥៩:២ អ ទដ ៦:៨ **១៣៩:២០** ក ទដ ៦៥:៧ ខ ចទ ៥:១១ **១៣៩:២១** គ ២រប ១៩:២ ទដ ៣១:៦ ១១៩:១១៣ ឃ ទដ ២៦:៥ **១៣៩:២២** ង មថ ៥:៤៣ **១៣៩:២៣** ច យប ៣១:៦ ឆ ១សយ ១៦:៧ ១រប ២៨:១៧ ទដ ៧:៩ សភ ១៧:៣ យរ ១១:២០ វវ ២:២៣ **១៣៩:២៤** ជ យរ ២៥:៥ ៣៦:៣ ឈ ទដ ៥:៨ ២៣:២

**១៤០** ឱព្រះយេហូវ៉ាអើយ សូមប្រោសទូលបង្គំ[ក] ឱ្យរួច
ពីមនុស្សអាក្រក់ សូមការពារខ្លួនទូលបង្គំឱ្យរួចពីមនុស្ស
ច្រឡោត[ខ]
២ជាអ្នកដែលតែងមានចិត្តគិតគូរការអាក្រក់[គ]
ហើយចេះតែលើកគ្នាចង់ធ្វើចំបាំង[ឃ]ជានិច្ច
៣គេបានសំលៀងអណ្តាតគេ ឱ្យស្រួច[ង]ដូចជាអណ្តាតពស់ក៏
មានពិសពស់ហនុមាន[ច]នៅក្រោមបបូរមាត់គេ ។ -បង្អង់
៤ឱព្រះយេហូវ៉ាអើយសូមថែរក្សាទូលបង្គំ[ឆ]ឱ្យរួចពីដៃ
នៃមនុស្សអាក្រក់[ជ]សូមការពារទូលបង្គំឱ្យរួចពីមនុស្ស
ច្រឡោតជាអ្នកដែលបានសំរេចចិត្តនឹងធ្វើឱ្យទូលបង្គំភ្លាត់
ក្នុងផ្លូវប្រព្រឹត្ត
៥ពួកឆ្មើងឆ្មៃបានដាក់អន្ទាក់[ឈ]ចង់ចាប់ទូលបង្គំ

១៤៣:១០ **១៤០:១** ក ទដ ១៧:១៣ ២៥:២០ ៥៩:២ ៧១:៤ ១៤២:៦ ១៤៣:៩ ខ ខ.១១ ទដ ៨៦:១៤ **១៤០:២** គ ទដ ៣៦:៤ ៥២:២ សភ ៦:១៤ ១៦:២៧ អស ៥៩:៤ ហស ៧:១៥ ឃ ទដ ៦៨:៣០ **១៤០:៣** ង ទដ ៥៧:៤ ច ទដ ៥៨:៤ រម ៣:១៣ យក ៣:៨ **១៤០:៤** ឆ ទដ ១៤១:៩ ជ ទដ ៣៦:១១ **១៤០:៥** ឈ យប ៣៤:៣០ ទដ ១១៩:១១០

ដាស់ព្រលឹងទូលបង្គំដែលលិចលង់ឱ្យបានងើបឡើងសាជាថ្មី ដោយបានឃើញវត្តមានទ្រង់ ។ ម្យ៉ាងវិញទៀតទ្រង់បានដាស់ទូលបង្គំឱ្យបានភ្ញាក់ពីដំណេកនៃសេចក្តីស្លាប់របស់លោកិយ ដូចជានៅក្នុងគម្ពីរ ទដ ១៧:១៥ (សូមមើល ២ពវ ៤:៣១ យប ១៤:១២ អស ២៦:៩ យរ ៥១:៣៩,៥៧ ដយ ១២:២) ។ ដូច្នេះ អ្នកនិពន្ធបទទំនុកចម្រៀងបានពង្រីកគោលចារឹកនៃវត្តមានទ្រង់ឱ្យផុតពី"ទ្វារនៃស្ថានឃុំព្រលឹង" ។

**១៣៩:១៩-២៤** ភាពស្លូតខ្ពះខ្មែង គឺជាសេចក្តីជំនឿរបស់ទូលបង្គំចំពោះទ្រង់ និងភាពស្មោះត្រង់ចំពោះទ្រង់ ហើយសូមដាក់ជីវិតទូលបង្គំឱ្យប្រឆាំងនិងសត្រូវរបស់ទ្រង់ទាំងអស់ ។

**១៣៩:១៩** ការខ្វះខាតសេចក្តីអត់ធ្មត់ និងការច្រណែន ហើយនិងភាពអត់ធ្មត់របស់ព្រះអម្ចាស់ ហើយមនុស្សអាក្រក់ដែលជីវិតគេនិងត្រូវផុតរលត់ (អស ១១:៤) ។ តែចំពោះអ្នកនិពន្ធបទទំនុកតម្កើងថ្វាយការកាត់ទោស ទៅឱ្យព្រះអម្ចាស់ជាអ្នកជំនុំជម្រះវិញ (ប្រៀបធៀបការពន្យល់ ៥:១០) ។

**១៣៩:២០** *គេចេញព្រះនាមទ្រង់ជាអសារឥតការ* ប្រហែលជាពួកគេព្យាយាមប្រើពាក្យពុំសមរម្យ ឬដេរប្រមាថចំពោះអ្នកដែលមានចិត្តស្មោះត្រង់ចំពោះព្រះ គឺជាអ្នកបម្រើព្រះដ៏ពិតត្រង់ ។

**១៣៩:២១-២២** គឺជាការប្រកាសពីភាពស្មោះត្រង់ ដោយបានស្បថសន្យាដោយពួកស្តេចនាសម័យមួយនៅមជ្ឈឹមបូព៌ានាសម័យបុរាណ ដែលគ្រប់គ្រងនៅលើប្រទេសចំណុះមួយចំនួន (ចំពោះមិត្តរបស់ខ្ញុំ អ្នកគួរជាមិត្តនិងគេដែរ ចំពោះសត្រូវរបស់ខ្ញុំ អ្នកគួរតែជាសត្រូវរបស់គេដែរ គឺចាប់តាំងពីសម័យស្តេចមើស៊ីលីសទី២ ស្តេចហេត និងស្តេចនូហាស៊ី សតវត្សទី១៤ មុន គ.ស) ។

**១៣៩:២៣-២៤** ជាសេចក្តីល្បងលលើភាពសុចរិតរបស់អ្នកបម្រើព្រះ ដែលពុះពារក្នុងការនាំដំណឹងល្អ និងរក្សាសេចក្តីពិតនៅក្នុងខ្លួន (សូមមើល ១៧:៣-៥ និងការពន្យល់) ។ ប្រៀបធៀប ខ.១-២ ។

**១៣៩:២៣** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ *ទាំងគំនិត* សូមមើល ៩៤:១៩ គឺជារឿងតូចតាចទេដែលព្រះល្បងលបែបនេះ ។

**១៣៩:២៤** *តាមផ្លូវដ៏នៅអស់កល្បជានិច្ច* សូមមើលការពន្យល់ ១៦:៩-១១ ។

**ទដ ១៤០** ជាវគ្គនៃការអធិដ្ឋានសូមព្រះអម្ចាស់ ដើម្បីដោះឱ្យរួចពីគម្រោងការអាក្រក់ និងការនិយាយបង្ខូចពីសត្រូវដែលពុំមានចិត្តមេត្តា ។ ក៏និងឃើញបទទំនុក ទដ ៥៨ និង ៦៤ តែអត្ថន័យនេះក៏ពុំបានបង្ហាញពីនៅក្នុងខណាផ្សេងទៀតឡើយនៅក្នុងគម្ពីរសញ្ញាចាស់ ។ ឯវគ្គការថាពិសេសៗទាំងបួនក៏មានពីរខ ជាសេចក្តីបញ្ចប់ ។ ជាសេចក្តីអធិស្ឋានដែលមានយ៉ាងច្រើនសន្ធឹក ដែលទាក់ទងនឹងពាក្យសម្តីបញ្ចិតបញ្ចៀងដូចជាពាក្យ ចិត្ត ក្បាល អណ្តាត បបូរមាត់ ដៃ ជើង និងត្រចៀក (បែបអក្សរសាស្ត្រពាក្យថា "ព្រះការណ៍ ឬត្រចៀកមានក្នុង" ខ.៦) និងធ្មេញ (តាមរយៈការលេងពាក្យនៅក្នុងភាសាហេព្រើរ ដូចជាពាក្យ "សំលៀងឱ្យស្រួច" ខ.៣) ។ សូមមើលសេចក្តីផ្តើម ទដ ១៤១ និងសេចក្តីផ្តើម ទដ ១៣៨-១៤៥ ។

**ទដ ចំណងជើង** *សំរាប់មេភ្លេង* សូមមើលការបន្យល់ ទដ ៤ ជាចំណងជើង *របស់ស្តេចដាវីឌ* សូមមើលការពន្យល់ ទដ ១២៨ ត្រង់ចំណងជើង ។

**១៤០:១** *ព្រះយេហូវ៉ា* បើក្នុងព្រះគម្ពីរជាភាសាហេព្រើរមានន័យថា "យ៉ាវេ" (Yahweh) គឺជាព្រះនាមដ៏បរិសុទ្ធដែលមានលេចមក៧ដងក្នុងជំពូកនេះ ។

**១៤០:២** *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**១៤០:៣** *អណ្តាត* សូមមើលការពន្យល់ ៥:៩ ។ *ពិសពស់* សូមមើល ៥៨:៤ និងការពន្យល់ ។

**១៤០:៤-៥** សូមការពារទូលបង្គំឱ្យផុតពីសេចក្តីអួតអាងទាំងឡាយ និងផុតពីមនុស្សតាមកំចាយឈាមទាំងឡាយ (មើល ១០:២-១២ និងការពន្យល់) ។

**១៤០:៥** *ពួកឆ្មើងឆ្មៃ* សូមមើលការពន្យល់ ៣១:២៣ ។ *អន្ទាក់ចង់ចាប់ . . . លាតមក . . . អង្គប់* សូមមើល ១៤១:៩-១០ ។

ព្រមទាំងខ្សែរូតផងគេបានលាតមង[ញ]តាមផ្លូវ
និងអន្ទាក់[ដ]ផង ដើម្បីចាប់ទូលបង្គំ ។
៦ខ្ញុំបានទទួលដល់ព្រះយេហូវ៉ាថា ទ្រង់ជាព្រះនៃទូល
បង្គំ[ឋ] ឱព្រះយេហូវ៉ាអើយ សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យ
ដែលទូលបង្គំទូលអង្វរ[ឌ]
៧ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់[ឍ] ដែលទ្រង់ជាកំឡាំង
នៃសេចក្តីសង្គ្រោះរបស់ទូលបង្គំអើយ
ទ្រង់បានគ្របក្បាលទូលបង្គំនៅថ្ងៃសង្គ្រាម
៨ឱព្រះយេហូវ៉ាអើយ សូមទ្រង់កុំអនុញ្ញាតដល់ពួកមនុស្ស
អាក្រក់[ណ] តាមអំពើចិត្តគេឡើយ ក៏កុំឱ្យកិច្ចកលរបស់គេ
បានជឿនទៅដែរ ក្រែងគេអួតខ្លួន ។ –បង្អង់
៩ឯក្បាលនៃពួកអ្នកដែលព័ទ្ធទូលបង្គំជុំវិញ
នោះសូមឱ្យអំពើអាក្រក់របស់បបូរមាត់គេបានធ្លាក់ទៅ
លើគេវិញ[ត]
១០សូមឱ្យមានរងើកភ្លើងឆេះធ្លាក់ទៅលើ ហើយឱ្យគេត្រូវ
បោះទៅក្នុងភ្លើង[ថ] គឺទៅក្នុងរណ្តៅយ៉ាងជ្រៅ
នឹងឡើងមកមិនរួចឡើយ
១១មនុស្សដែលមានអណ្តាតអាក្រក់ នោះមិនដែលបានតាំង
ឡើងឱ្យមាំមួននៅផែនដីឡើយ ឯមនុស្សច្រឡោតនឹងមាន
សេចក្តីអាក្រក់ដេញតាមបំផ្លាញគេ[ទ]
១២ទូលបង្គំដឹងថា ព្រះយេហូវ៉ានឹងកាន់ក្តីរបស់មនុស្សមាន
ទុក្ខវេទនា[ធ] ព្រមទាំងសំរេចសេចក្តីយុត្តិធម៌[ន]ដល់មនុស្ស
កំសត់ទុគ៌តផង[ប]
១៣ពួកមនុស្សសុចរិតនឹងអរព្រះគុណដល់ព្រះនាមទ្រង់[ផ]
ហើយមនុស្សទៀងត្រង់នឹងនៅ[ព]ចំពោះទ្រង់ជាមិនខាន[ភ] ។

ទំនុកនៃស្តេចដាវីឌ ។

**១៤១** ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់
ទ្រង់ហើយសូមប្រញាប់[ក]នឹងយាងមកឯទូលបង្គំសូមផ្ទៀង
ព្រះកាណ៌ស្តាប់សំឡេង[ខ]ទូលបង្គំក្នុងកាលដែលទូលបង្គំ
អំពាវនាវផង
២សូមឱ្យសេចក្តីអធិស្ឋានរបស់ទូលបង្គំបានផ្សាយឡើង
ដូចជាគ្រឿងក្រអូប[គ]នៅចំពោះទ្រង់នឹងការលើកដៃ[ឃ]
ប្រណម្យរបស់ទូលបង្គំបានដូចជាយញ្ញបូជាពេលល្ងាច[ង]
៣ឱព្រះយេហូវ៉ាអើយ សូមទ្រង់ដាក់ការយាមនៅមាត់ទូល
បង្គំ[ច] ហើយថែរក្សាទ្វារបបូរមាត់របស់ទូលបង្គំផង[ឆ]

**១៤០:៥** ញ យប ១៨:៨ ដ យប ១៨:៩ ទដ ៣១:៤ ៣៨:១២ **១៤០:៦** ឋ ទដ ១៦:២ ឌ ទដ ២៨:២,៦ **១៤០:៧** ឍ ទដ ៦៨:២០ **១៤០:៨** ណ ទដ ១០:២–៣ ៦៦:៧ **១៤០:៩** ត សភ ១៨:៧ **១៤០:១០** ថ ទដ ១១:៦ ២១:៩ មថ ៣:១០ លក ១២:៤៩ វវ ២០:១៥ **១៤០:១១** ទ ទដ ៣៤:២១ **១៤០:១២** ធ ទដ ៨២:៣ ន ១ពវ ៨:៤៥ ប ទដ ៣៥:១០ **១៤០:១៣** ផ ទដ ១៣៨:២ ព ទដ ១១:៧ ភ ទដ ១៦:១១ **១៤១:១** ក ទដ ២២:១៩ ខ ទដ ៤:១ ៥:១–២ ២៧:៧ ១៤៣:១ **១៤១:២** គ លក ១:៩ វវ ៥:៨ ៨:៣ ឃ ទដ ២៨:២ ៦៣:៤ ១ធថ ២:៨ ង នក ២៩:៣៩,៤១ ៣០:៨ **១៤១:៣** ច ទដ ៣៤:១៣ យក ១:២៦ ៣:៨ ឆ ទដ ១២:២

**១៤០:៦–៨** កុំឱ្យពួកមនុស្សអាក្រក់សម្រេចបាននូវសេចក្តីប៉ងប្រាថ្នារបស់ពួកគេប្រឆាំងនិងទូលបង្គំឡើយ ។

**១៤០:៦** *ព្រះយេហូវ៉ាអើយ សូមផ្ទៀងព្រះការណ៌ស្តាប់ពាក្យដែលទូលបង្គំទូលអង្វរ* ជាពាក្យបង្ហាញពីផ្ទៃរឿង និងទំនាក់ទំនងជាពាក្យសម្តីវាចាផ្ទាល់ មើល ១៤១:១ ១៤២:១ ១៤៣:១ ។

**១៤០:៩–១១** សូមឱ្យភាពមានគ្រោះថ្នាក់ ដែលពួកសត្រូវព្យាយាមដាក់មកលើទូលបង្គំបានត្រឡប់ទៅលើក្បាលពួកគេវិញ(មើលការពន្យល់ ៥:១០) ។

**១៤០:៩** *ឯក្បាលនៃ . . . បានធ្លាក់ទៅលើគេវិញ* ប្រៀបធៀប ១៤១:៥ ។

**១៤០:១០** *រងើកភ្លើងឆេះ* សូមើលសេចក្តីយោងបញ្ជាក់ លវ ១៦:១២ យប ៤១:២១ សភ ៦:២៨ អស ៤៧:១៤ អគ ២៤:១១ ។ ក៏មានឧទាហរណ៍ផ្សេងទៀតចំពោះរូបភាពទាំងឡាយ ដែលបង្ហាញពីការជំនុំជម្រះពីព្រះអម្ចាស់ក៏អាចឃើញក្នុង ទដ ១៨:៨ ១២០:៤ អគ ១០:២ ។ *ក្នុងភ្លើង . . . ក្នុងរណ្តៅយ៉ាងជ្រៅ* រឿងរ៉ាវដែលមានភ្ជាប់គ្នាក្នុង យប ១៥:៣០ ២០:២៦ គឺជាសេចក្តីសន្មតថា វាគឺជាភ្លើងនៃការជំនុំជម្រះពីព្រះ (សូមមើល ២១:៩ ៩៧:៣ អស ១:៣១ ២៦:១១ ៣៣:១៤) គឺវាឆ្ពោះទៅរកអាណាចក្រនៃសេចក្តីស្លាប់ និងភាពងងឹតសូន្យសុង (សូមមើល យប ៣១:១២ និងការពន្យល់ ទដ ៣០:១) ។ ពាក្យថា *និងឡើងមកមិនរួចឡើយ* សូមមើល ៣៦:១២ អស ២៦:១៤ ។

**១៤០:១១** *ចេញតាមបំផ្លាញគេ* គឺជាសេចក្តីមហន្តរាយមានចំពោះអ្នកកំចាយឈាមទាំនោះវិញ (ឧ.៤–៥) ដោយព្រោះការដែលពួកគេតាមប្រមាញ ។

**១៤០:១២–១៣** សេចក្តីទុកចិត្តក្នុងការជំនុំជម្រះរបស់ព្រះអម្ចាស់(សូមមើលការពន្យល់ ៣:៨) ។

**១៤០:១២** *មនុស្សមានទុក្ខវេទនា . . . មនុស្សកំសត់ទុក៏តផង* សូមមើលការពន្យល់ ៩:១៨ ៣៤:៦ ។

**១៤០:១៣** *មនុស្សសុចរិត* សូមមើលការពន្យល់ ១:៥ ។ *និងអរព្រះគុណដល់* គឺចំពោះអ្នកមានបទពិសោធន៍ទទួលបានជំនួយពីទ្រង់ (សូមមើលការពន្យល់ ៧:១៧ ៩:១) ។ *និងនៅចំពោះទ្រង់ជាប់មិនខាន* គឺមានលក្ខណៈផ្ទុយនិងមនុស្សអាក្រក់ (ឧ.១០ សូមមើលការពន្យល់ ១១:៧ ១៦:៩–១១) ។

**ទដ ១៤១** ជំពូកនេះ គឺជាវគ្គអធិស្ឋានសូមការដោះលែងឱ្យរួចចេញពីពួកមនុស្សអាក្រក់ និងផ្លូវដ៏អាក្រក់របស់ពួកគេ ។ នៅគ្គខ្លះក្នុងជំពូកនេះក៏បង្ហាញពីផ្ទៃរឿង (សូមមើលការពន្យល់ ឧ.៥) ។ ដូចជា ទដ ១៤០ សេចក្តីអធិស្ឋានមានលក្ខណៈច្រើនបែបច្រើនយ៉ាង ដែលពាក្យប្រៀបប្រដូច ឬពាក្យបញ្ញិតដូចជាពាក្យ : ព្រះហស្ត ព្រះការណ៌ មាត់ បបូរមាត់ ចិត្ត ក្បាល ឆ្អឹង ភ្នែក (សូមមើលសេចក្តីផ្តើម ទដ) ។

**១៤១ ចំណងជើង** សូមមើលសេចក្តីផ្តើម ទដ ១៣៨–១៤៥ ។

**១៤១–២** គឺជាវគ្គទូលអង្វសូមការជំនួយពីព្រះ ។

**១៤១:១** *សូមផ្ទៀងព្រះកាណ៏ស្តាប់សំឡេងទូលបង្គំ ក្នុងកាលដែលទូលបង្គំអំពាវនាវផង* សូមមើល ១៤០:៦ និងការពន្យល់ ។

**១៤១:២** *សេចក្តីអធិស្ឋានរបស់ទូលបង្គំបានផ្សាយឡើង ដូចជាគ្រឿងក្រអូប* សូមមើលការពន្យល់ នក ៣០:១ លក ១:៩ វវ ៥:៨ ។ *បានដូចជាយញ្ញបូជាពេលល្ងាច* សូមមើល នក ២៩:៣៨–៤១ ជន ២៨:៣–៨ ។ ការមានជាយញ្ញបូជាដូចនេះជារឿយៗបានបញ្ជាក់ (សូមមើល ១ពវ ១៨:២៩ ២ពវ ១៦:១៥ ១រប ១៦:៤០ ២រប ១៣:១១ ៣១:៣ អគ ៣:៣ ៩:៤–៥ ដយ ៩:២១) ។

**១៤១:៣–៤** គឺជាវគ្គដែលមានការទទួលដោយគេធ្វើទុក្ខបៀតបៀន នៅក្នុងអំណាចលោកិយ ហើយពួកគេបានទូលសូមឱ្យព្រះជួយពួកគេឱ្យផុតពីសេចក្តី

៤ សូមកុំឱ្យចិត្ត[ង]ទូលបង្គំល្អៀងទៅខាងសេចក្ដីអាក្រក់ណា
ដើម្បីប្រព្រឹត្តការអាក្រក់[ឈ]ជាមួយនឹងមនុស្សដែលតែងតែ
ធ្វើការទុច្ចរិតឡើយ ហើយកុំឱ្យទូលបង្គំទទួលទានចំណី
ឆ្ងាញ់របស់គេឱ្យសោះ[ញ]
៥ សូមឱ្យមនុស្សសុចរិតវាយទូលបង្គំចុះ នោះនឹងបានជា
គុណ ហើយឱ្យគេប្រដៅទូលបង្គំផង[ដ] នោះនឹងបានដូចជា
ប្រេងចាក់លាបលើក្បាល[ឋ] ឯក្បាលរបស់ទូលបង្គំនឹងមិន
ប្រកែកទេ ដ្បិតទូលបង្គំនឹងនៅតែអធិស្ឋានក្នុងកាលដែល
កើតមានសេចក្ដីអាក្រក់ផង
៦ ពួកចៅក្រមរបស់គេបានត្រូវបោះចុះទៅដល់ជើងថ្ម[ឌ]ដា
ហើយគេនឹងឮពាក្យសំដីរបស់ទូលបង្គំ ដ្បិតពាក្យទាំងនោះ
ផ្អែមល្ហែម
៧ អស់ទាំងឆ្អឹងរបស់យើងរាល់គ្នាបានខ្ចាត់ខ្ចាយ[ឍ]នៅមាត់[ណ]
ទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់ដូចជាកាលគេកាប់ ហើយ
ពុះឧសនៅលើដី[ត]

៨ ដ្បិត ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់អើយ ភ្នែកទូលបង្គំ
មើលចំ[ថ]ទៅឯទ្រង់ទូលបង្គំពឹងជ្រក[ទ]នៅក្នុងទ្រង់សូមកុំ
បោះបង់
ចោលព្រលឹងនៃទូលបង្គំឡើយ
៩ សូមរក្សាទូលបង្គំ[ធ]ឱ្យរួចពីអន្ទាក់ដែលគេបានដាក់[ន]សំរាប់
ចាប់ទូលបង្គំ ហើយពីអស់ទាំងអង្គប់របស់[ប]ពួកអ្នកដែល
ប្រព្រឹត្តអំពើទុច្ចរិតផង
១០ សូមឱ្យមនុស្សអាក្រក់ធ្លាក់[ផ]ទៅក្នុងមងរបស់ខ្លួនគេតែ
ឱ្យទូលបង្គំបានរួចវិញ[ព] ។

ទំនុករបស់ស្ដេចដាវីឌ ដែលទ្រង់លើ
ក្នុងកាលដែលទ្រង់នៅរអាងថ្ម[ក] ជាសេចក្ដីអធិស្ឋាន ។

**១៤២** ទូលបង្គំស្រែក[ខ]ទូលដល់ព្រះយេហូវ៉ាដោយ
សំឡេងនៃទូលបង្គំគឺដោយសំឡេងរបស់ទូលបង្គំដែល

**១៤១:៤** ង យស ២៤:២៣ ឈ ទដ ១០៦:២៩ ញ សភ ២៣:១–៣ **១៤១:៥** ដ សភ ៩:៨ ១៩:២៥ ២៥:១២ សស ៧:៥ ឋ នក ២៩:៧ ទដ ២៣:៥ **១៤១:៦** ឌ ២រប ២៥:១២ **១៤១:៧** ឍ ទដ ១២៩:៣ ណ ជន ១៦:៣០ ត ជន ១៦:៣២–៣៣ **១៤១:៨** ថ ទដ ១២៣:២ ទ ទដ ២:១២ ១១:១ **១៤១:៩** ធ ទដ ១៤០:៤ ន ទដ ៦៤:៥ ប ទដ ៣៨:១២ **១៤១:១០** ផ ទដ ៧:១៥ ៣៥:៨ ៥៧:៦ ព ទដ ១២៤:៧ **១៤២:ចំណងជើង** ក ១សយ ២២:១ ២៤:៣ ទដ ៥៧ ចំណងជើង **១៤២:១** ខ ១ពវ ៨:៥២ ទដ ៣:៤

ប៉ងប្រាថ្នាដ៏អាក្រក់ ឬឱ្យផុតពីការប្រព្រឹត្តការអាក្រក់ទាំងឡាយ ។

**១៤១:៤** *សូមកុំឱ្យចិត្តទូលបង្គំ* រក្សាទូលបង្គំកុំឱ្យចង់ប្រាថ្នាលើការអាក្រក់ទាំងឡាយ (សូមមើល សភ ១:១០–១៦) ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។ *ចំណីឆ្ងាញ់របស់គេ* គឺចង់សំដៅលើតុអាហារដ៏មានឱជារស់ឆ្ងាញ់ ដែលជាផលរបស់មនុស្សអាក្រក់ទទួលបានពីការមិនបរិសុទ្ធ ស្អាតស្អំ ជាអធិស្ឋានដែលអ្នកនិពន្ធទូលសូមឱ្យដោះគេចេញ ពីសេចក្ដីស្រេកឃ្លានម្ហូបអាហារឆ្ងាញ់វិសេសដែលចេញពីភាពមិនស្អាតស្អំ ។ ឃ្លាជានាមបានឃើញសរសេរតែក្នុងទីនេះទេ ឃ្លានេះក៏ចង់សំដៅទៅលើពាក្យសម្ដីដ៏ផ្អែមពិរោះ តែវាជាគ្រឿងបញ្ឆោត និងជាការអាក្រក់ទាំងអស់ ។ វាក៏ជាសេចក្ដីអធិស្ឋានដែលអ្នកនិពន្ធបទទំនុកទូលសូមកុំឱ្យពួកគេជួបប្រទះនៅរឿងរ៉ាវអាស្រូវ ឬមានមាត់មិនល្អដែលជាសេចក្ដីងងឹត សម្រាប់ជីវិត (សូមមើល សភ ១៥:២៦ ១៦:២១ ២៣:៨) ។

**១៤១:៥** គឺជាចំណុចសំខាន់នៃបទទំនុកដំកើង (សូមមើលការពន្យល់ ៦:៦) ។ *សូមឱ្យមនុស្សសុចរិតវាយទូលបង្គំចុះ* ការដែលមនុស្សសុចរិតដាក់វិន័យធ្វើបាបដោយផ្អែកលើសេចក្ដីសុចរិត គឺជាសេចក្ដីពិត "ភាពសប្បុរស" (ជាភាសាហេព្រើរបច្ចេកសម្លេងថា ហែស មានន័យថា "សេចក្ដីស្រឡាញ់" ឬមានន័យថា "សម្លេងពីមិត្តិភាពដ៏យូរអង្វែង" សូមមើល សភ ២៧:៦ និងការពន្យល់ ទដ ៦:៤) ។ ពាក្យថា *ជាប្រេងលើក្បាលទូលបង្គំ* សូមមើលការពន្យល់ ២៣:៥ ។ ពាក្យថា *ឯក្បាល . . . ដែលកើតមានសេចក្ដីអាក្រក់ផង* ក៏អាចមានន័យថា "សូមកុំឱ្យក្បាលទូលបង្គំបដិសេធន៍វា (គឺបដិសេធដែលចេញពីការសុចរិតនោះ) ដោយសេចក្ដីអធិស្ឋានរបស់ទូលបង្គំនៅតែប្រឆាំងនឹងទង្វើអាក្រក់របស់អារក្សអាសោច" ។

**១៤១:៦–៧** វគ្គនេះបង្ហាញពីវាសនាអាក្រក់របស់មនុស្សអាក្រក់ ។ *ពួកចៅក្រមរបស់គេបានត្រូវចុះទៅដល់ជើងថ្មដាហើយ* ក៏មានន័យថា អំពើអាក្រក់របស់មេដែលបានទទួលលទ្ធផលអាក្រក គឺការជំនុំជម្រះពីព្រះនាំឱ្យពួកកូនចៅគេឃើញហើយនិយាយពីការនោះ ។

**១៤១:៦** *ពាក្យសំដីរបស់ទូលបង្គំ* គឺជាការប្រកាន់យកនូវភាពសុចរិតដូចមានក្នុង ខ.៣–៥ ។ *ពាក្យទាំងនោះពិរោះ* គឺជាទង្វើត្រឹមត្រូវ ។

**១៤១:៨–១០** ជាការទូលសូមឱ្យព្រះប្រោសឱ្យរួចផុតពីសេចក្ដីប៉ងប្រាថ្នាទៅលើការអាក្រក់ទាំងឡាយ ។

**១៤១:៨** *សូមកុំបោះបង់ចោលព្រលឹងនៃទូលបង្គំឡើយ* គឺខណៈពេលពួកគេបានប្រព្រឹត្តការអាក្រក់រួចហើយនោះ ក៏បានបែរមករកការលនតួបាប (សូមមើល ខ.៧ ៧៣:១៨–២០,២៣–២៦ និងការពន្យល់) ។

**១៤១:៩** *អន្ទាក់ . . . អង្គប់* ក៏ជាអំពើអាក្រក់របស់មនុស្សដែលនាំឱ្យពួកគេត្រូវដួលចុះហិនវិនាស (មើល ៣៨:១២ ៦៤:៥ ៩១:៣ ១៤០:៥ ១៤២:៣ និងការពន្យល់ ៩:១៥) និង ទដ ១៤០,១៤២ ។

**១៤១:១០** *សូមឱ្យមនុស្សអាក្រក់ធ្លាក់ទៅ* សូមមើលការពន្យល់ ៥:១០ ។ *ធ្លាក់ទៅក្នុងមងរបស់ខ្លួនគេ* មើល ១៤០:១០ ជាភាសាហេព្រើរមានន័យថា (ការបោះទៅក្នុងរណ្ដៅជ្រៅ) ។

**ទដ ១៤២** ជាការអធិស្ឋានតាមបែប ឬរបៀបតម្អូញតូញត្អែរ គឺដើម្បីឱ្យមានការប្រោសលោះចេញពីកណ្ដាប់ដៃពួខ្មាំងសត្រូវដ៏មានអំណាច គឺគ្រាដែលពុំមានកម្លាំង មានភាពឯកកោរ និងគ្មានទីជម្រក ។ ក៏មានបទទំនុកដំកើងខ្លះទៀតមានភាពស្រដៀងគ្នាពីការអធិស្ឋាន (សូមមើលសេចក្ដីពន្យល់ខាងក្រោម) ក្រៅពីសេចក្ដីផ្ដើម (ខ.១–២) និងសេចក្ដីបញ្ចប់ ឯការអធិស្ឋានតាមបែបជាភាសាហេព្រើរ ក៏បាននិពន្ធឡើងមានបួនវគ្គគាថា ហើយចែកជាពីផ្នែកធំៗ ។

**១៤២ ចំណងជើង** *ទំនុក* សូមមើលការពន្យល់ ៣២ ជាចំណងជើង ។ *របស់ស្ដេចដាវីឌ* សូមមើលសេចក្ដីផ្ដើមក្នុងជំពូក ទដ ១៣៨–១៤៥ ។ *កាល . . . រវល់* សូមមើលការពន្យល់ ទដ ៥៧ ត្រង់ចំណងជើង ។

**១៤២:១–២** គឺជាការចាប់ផ្ដើម នូវសេចក្ដីដំបូងដោយប្រើសព្វនាមបុគ្គលទី៣ គឺគេប្រើសម្រាប់និយាយពីព្រះមហាក្សត្រ ជាស្ដេចគ្រប់គ្រងលើអស់ទាំងមនុស្ស ។

ទូលបង្គំទូលអង្វរដល់ព្រះយេហូវ៉ា[គ]
២ទូលបង្គំបង្ហូរសេចក្តីទំនួញ[ឃ] របស់ទូលបង្គំចេញនៅ
ចំពោះទ្រង់ ហើយក្រាបទូលពីសេចក្តីទុក្ខលំបាករបស់
ទូលបង្គំនៅចំពោះទ្រង់ដែរ[ង]
៣កាលវិញ្ញាណទូលបង្គំបានអន់ថយ[ច] នៅក្នុងខ្លួន
នោះទ្រង់បានស្គាល់ផ្លូវច្រករបស់ទូលបង្គំគេបានដាក់
អន្ទាក់លាក់កំបាំងក្នុងផ្លូវដែលទូលបង្គំដើរ
៤សូមទតទៅខាងស្តាំមើល
ដ្បិតគ្មានអ្នកណាស្គាល់ទូលបង្គំសោះ
គ្រប់ទាំងទីពឹងបានបាត់ពីទូលបង្គំចេញ[ឆ]
ហើយឥតមានអ្នកណារវល់[ជ]នឹងព្រលឹងទូលបង្គំឡើយ
៥ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់ទ្រង់
ទូលបង្គំបានពោថា ទ្រង់ជាទីពឹង[ឈ] របស់ទូលបង្គំ គឺជា
ចំណែក[ញ]នៃទូលបង្គំនៅក្នុងស្ថានរបស់មនុស្សរស់នេះ[ដ]
៦សូមប្រុងស្តាប់ពាក្យអំពាវនាវ[ឋ] របស់ទូលបង្គំ
ដ្បិតទូលបង្គំត្រូវទាបថោកណាស់[ឌ] ហើយសូមប្រោស[ឍ]ឱ្យ
រួចពីពួកអ្នកបៀតបៀនទូលបង្គំ ដ្បិតគេខ្លាំង[ណ]ជាងទូលបង្គំ
៧សូមនាំព្រលឹងទូលបង្គំចេញពីគុកទៅ[ត] ដើម្បីឱ្យបានអរព្រះ
គុណដល់ព្រះនាម[ថ] ទ្រង់ពួកមនុស្សសុចរិតនឹងព័ទ្ធទូលបង្គំ
ជុំវិញ ពីព្រោះទ្រង់នឹងប្រោសទូលបង្គំយ៉ាងល្អជាបរិបូរ[ទ]

ទំនុកនៃស្តេចដាវីឌ ។

**១៤៣** ឱព្រះយេហូវ៉ាអើយ សូមស្តាប់ពាក្យអធិស្ឋាន
របស់ទូលបង្គំ[ក] សូមផ្ទៀងព្រះកាណ៌ស្តាប់នៃសេចក្តីទូល
អង្វររបស់ទូលបង្គំ[ខ] សូមឆ្លើយតបមកទូលបង្គំផង
ដោយសេចក្តីស្មោះត្រង់[គ] និងសេចក្តីសុចរិត[ឃ] របស់ទ្រង់
២សូមកុំឱ្យកើតក្តីនឹងអ្នកបំរើទ្រង់ឡើយដ្បិតនៅព្រះនេត្រ

**១៤២:១** គ ទដ ៣០:៨
**១៤២:២** ឃ ទដ ៦៤:១ ង ទដ ៥០:១៥
**១៤២:៣** ច ទដ ៦:២ ៧៧:៣ ៨៤:២ ៨៨:៤ ១៤៣:៤,៧ យរ ៨:១៨ បទ ១:២២
**១៤២:៤** ឆ យរ ២៥:៣៥ ជ យរ ៣០:១៧
**១៤២:៥** ឈ ទដ ៤៦:១ ញ ចទ ៣២:៩ ទដ ១៦:៥ ដ យប ២៨:១៣ ទដ ២៧:១៣
**១៤២:៦** ឋ ទដ ១៧:១
ឌ ទដ ៧៩:៨ ឍ ទដ ២៥:២០ ណ យរ ៣១:១១ **១៤២:៧** ត ទដ ៦៦:១១ ថ ទដ ៧:១៧ ៩:២ ទ ២របា ៦:៤១
**១៤៣:១** ក ទដ ១៤១:១ ខ ទដ ២៨:២ ១៣០:២ គ នក ៣៤:៦ ទដ ៨៩:១–២ ឃ ទដ ៧១:២

**១៤២:១** ជាឃ្លាមានភាពស្រដៀងគ្នាទៅនិង ជំពូក ៧៧:១ ។ *សំឡេងរបស់ទូលបង្គំដែលទូលបង្គំទូលអង្វរដល់ព្រះយេហូវ៉ា* សូមមើល ១៤០:៦ និងការពន្យល់ ។

**១៤២:២** *ទូលបង្គំបង្ហូរសេចក្តីទំនួញរបស់ទូលបង្គំនៅចំពោះទ្រង់* ឃ្លានេះមានលក្ខណៈស្រដៀងគ្នាចំពោះសេចក្តីសំណេរក្នុង ទដ ១០២ ។

**១៤២:៣–៤** ការពណ៌នាពីភាពអស់សង្ឃឹមរបស់គាត់ (ខ.៦) ។

**១៤២:៣** *កាលវិញ្ញាណទូលបង្គំបានអន់ថយ* ព្រោះស្ថានភាពជីវិតរបស់គាត់បានមានឥទ្ធិពលលើគាត់ ក៏គ្របសង្កត់លើគាត់ (សូមមើល ២២:១៤–១៥) មានវគ្គផ្ទៃរឿង និងវគ្គពោលវាចាទៅតាមស្ថានភាពផ្ទាល់របស់គាត់ទាក់ទងនឹង ១៤៣:៦ (មើល ៧៧:៣ ទដ ១០២ ជាចំណងជើង យហ ២:៧) ។ *ទ្រង់បានស្គាល់ផ្លូវច្រករបស់ទូលបង្គំ* ឃ្លានេះទាក់ទងនឹង (ការប្រៀបធៀប ខ.៤) ។ *គេបានដាក់អន្ទាក់លាក់កំបាំងក្នុងផ្លូវដែលទូលបង្គំដើរ* អត្ថន័យនេះមានទំនាក់ទំនងនឹង ១៤០:៥ ១៤១:៩–១០ (សូមើលការពន្យល់ ៩:១៥) ។

**១៤២:៤** *ខាងស្តាំមើល* គឺជាផ្នែកខាងស្តាំដៃក៏មានអ្នកជំនួយនៅក្បែរនោះដែរ (សូមមើល ១៦:៨ និងការពន្យល់) ។ *ស្គាល់ទូលបង្គំសោះ* "ស្គាល់" (ខ.៣) សូមមើល នរ ២:១០,១៩ ("ការកត់ចំណាំ") ។ *រវល់នឹង* សូមមើល ចទ ១១:១២ ។

**១៤២:៥–៧** ជាវគ្គអធិស្ឋានដើម្បីសូមការជួយសង្គ្រោះ ។

**១៤២:៥** *ទ្រង់ជាទីពឹងរបស់ទូលបង្គំ* សូមមើល ៧១:៧ យរ ១៧:១៧ ។ *គឺជាចំណែក* ពាក្យនេះបង្ហាញន័យពីរថា ទ្រង់ជាប្រភពទ្រទ្រង់ និងជារបាំងការពារនៃជីវិតរបស់ស្តេចដាវីឌ (សូមមើល ៧៣:២៦ និងការពន្យល់) ។ *នៅក្នុងស្ថានរបស់មនុស្សរស់នេះ* សូមមើល ២៧:១៣ និងការពន្យល់ ៥២:៥ ១១៦:៩ ។

**១៤២:៦** *ស្តាប់ពាក្យអំពាវនាវរបស់ទូលបង្គំ* សូមមើល ១៧:១ ។ *សូមប្រោសឱ្យរួចពី* សូមមើល ១៤៣:៩ ១៤៤:៧ ។

**១៤២:៧** *គុក* ជាពាក្យប្រៀបធៀបដែលមានន័យថា បានជាប់គំនាប ឬការជិះជាន់នាំឱ្យមានភាពវេទនាលំបាក ។ (សូមមើលការពន្យល់ ១៨:១៩ សូមមើល យប ៣៦:៨) ។ *ដើម្បីឱ្យបានអរព្រះគុណដល់ព្រះនាមទ្រង់* គឺជាពិធីរំលឹកដល់សេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ដែលបានជួយ (សូមមើលការពន្យល់ ៧:១៧) ។ *ព្រះនាម* សូមមើលការពន្យល់ ៥:១១ ។ *មនុស្សសុចរិត* មើល ១:៥ ។ *និងព័ទ្ធទូលបង្គំជុំវិញ* គឺស្តេចដាវីឌលែងរស់នៅតែឯងទៀតហើយ ។ ឯវគ្គបញ្ចប់របស់បទទំនុកតម្កើងនេះ គឺបានបញ្ចប់ដោយប្រើពាក្យពេជ្រនៃការទុកចិត្តនិងផ្ញើរសេចក្តីសង្ឃឹមទៅលើព្រះ (មើលការពន្យល់ ៣:៨) ។ *ទ្រង់នឹងប្រោសទូលបង្គំយ៉ាងល្អជាបរិបូរ* មើល ១៣:៦ ១១៦:៧ ។

**ទដ ១៤៣** ជាវគ្គសេចក្តីអធិស្ឋានទូលសូមការជួយសង្គ្រោះ ឱ្យបានរួចផុតពីកណ្តាប់ដៃនៃខ្មាំងសត្រូវ និងសូមឱ្យមានការនាំផ្លូវពីព្រះ ។ នេះគឺជាវគ្គទី៧ ហើយជាបទទំនុកចម្រៀងសោកសៅចុងក្រោយ (សូមមើលសេចក្តីផ្តើម ទដ ៦) ។ បទទំនុកម្រៀងនៃទំនុកតម្កើងបាននេះបាននិពន្ធឡើងមានជាវគ្គធំៗពីរ បើក្នុងភាសាហេព្រើរវគ្គនិមួយៗមាន៧បន្ទាត់ ខ.១–៦,៧–១០) ។ ចំណែកឯបន្ទាត់ពីរចាប់បញ្ចូលគ្នាបង្ហាញពីរមូលដ្ឋានគ្រិះ នៃសេចក្តីអធិស្ឋាន (ខ.៣–៤) ក្នុងវគ្គធំទី១ក៏បានពណ៌នាពីភាពសៅហ្មងទុក្ខព្រួយ ខណៈនោះមានបន្ទាត់បីនៅកណ្តាលវគ្គ (ខ.៨–៩) នៅក្នុងវគ្គទី២ធំបានបង្ហាញពីទំនុកចិត្តរបស់អ្នកនិពន្ធចំពោះព្រះយេហូវ៉ា ដើម្បីដោះលែងពួកគេចេញពីភាពសៅហ្មងទុក្ខព្រួយទាំងឡាយ ។ ឯខ.១,១១ បង្ហាញឱ្យឃើញសេចក្តីសុចរិតរបស់ផងព្រះនិងបានបង្ហាញពីអត្តសញ្ញាណរបស់អ្នកនិពន្ធផ្ទាល់ ដែលពួកគេចាត់ខ្លួន"ជាអ្នកបម្រើព្រះ"(ខ.២,២២)ដែលពឹងផ្អែកទៅលើការអធិស្ឋាន ។ សូមមើល ខ.១ បង្ហាញពីភាពសប្បុរសរបស់ផងព្រះ និងសេចក្តីស្រឡាញ់ឥតមានពុតមាយារបស់ផងទ្រង់ (ខ.១២) សូមមើលសេចក្តីពន្យល់ ៣៦:៥ ។

**១៤៣ ជាចំណងជើង** សូមមើលសេចក្តីផ្តើម ទដ ១៣៨–១៤៥ ។

**១៤៣:១** *សេចក្តីទូលអង្វររបស់ទូលបង្គំ* សូមមើល ១៤០:៦ និងការពន្យល់ ។ *សេចក្តីសុចរិត* សូមមើលការពន្យល់ ៤:១ ។

**១៤៣:២** ខណៈពេលដែលស្តេចដាវីឌអធិស្ឋានសូមកុំឱ្យព្រះអម្ចាស់ជំនុំជម្រះ

ទ្រង់គ្មានមនុស្សរស់ណាមួយ ដែលសុចរិត[ង]ទេ
[៣]ដ្បិត ខ្មាំងសត្រូវបានបៀតបៀនព្រលឹងនៃទូលបង្គំគេបាន
វាយជីវិតទូលបង្គំចុះដល់ដីហើយ ក៏ធ្វើឱ្យទូលបង្គំអាស្រ័យ
នៅក្នុងទីងងឹត[ច] ដូចជាពួកអ្នកដែលបានស្លាប់ជាយូរមក
ហើយ[ឆ]
[៤]ហេតុនោះបានជាវិញ្ញាណនៅក្នុងខ្លួន ទូលបង្គំត្រូវ
អន់ថយទៅ ហើយចិត្តនៅក្នុងទូលបង្គំក៏នៅតែលតោល[ជ]
[៥]ទូលបង្គំនឹកចាំ[ឈ]ពីអស់ទាំងថ្ងៃដែលកន្លងទៅហើយក៏រំពឹង
គិត[ញ]ពីអស់ទាំងកិច្ចការរបស់ទ្រង់ហើយនឹកជញ្ជឹងពីអស់
ទាំងស្នាដៃនៃព្រះហស្តទ្រង់ដែរ
[៦]ទូលបង្គំលើកដៃ[ដ]ប្រណម្យដល់ទ្រង់ព្រលឹងទូលបង្គំស្រែក
រកទ្រង់ ដូចជាដីហួតហែងស្រែករកទឹក ។ –បង្អង់
[៧]ឱព្រះយេហូវ៉ាអើយ សូមប្រញាប់[ឋ]នឹងឆ្លើយមក
ទូលបង្គំដ្បិតវិញ្ញាណទូលបង្គំអន់ថយ[ឌ] ហើយសូមកុំលាក់
ព្រះភក្ត្រ[ឍ]នឹងទូលបង្គំឡើយ ក្រែងទូលបង្គំនឹងត្រឡប់ដូច
ជាពួកអ្នកដែលចុះទៅក្នុងរណ្តៅ
[៨]សូមឱ្យទូលបង្គំបានឮសេចក្តីសប្បុរសរបស់ទ្រង់
នៅពេលព្រឹក[ណ] ដ្បិតទូលបង្គំទុកចិត្តនឹងទ្រង់ សូមឱ្យទូល
បង្គំបានស្គាល់ផ្លូវ[ត]ដែលគួរ ដើរ ពីព្រោះ ទូលបង្គំបាន
លើកព្រលឹងទៅរកទ្រង់[ថ]
[៩]ឱព្រះយេហូវ៉ាអើយ សូមប្រោសទូលបង្គំ[ទ]ឱ្យរួចពីពួកខ្មាំង
សត្រូវ[ធ]ទូលបង្គំរត់មកពឹងជ្រកនៅទ្រង់
[១០]សូមបង្ហាត់បង្រៀនឱ្យទូលបង្គំ[ន]បានប្រព្រឹត្តតាមព្រះ
ហឫទ័យទ្រង់ ដ្បិតទ្រង់ជាព្រះនៃទូលបង្គំ[ប]ពិត សូមឱ្យព្រះ
វិញ្ញាណដ៏ល្អរបស់ទ្រង់នាំ[ផ]ទូលបង្គំ ចូលទៅក្នុងស្រុក
ដែលប្រកបដោយសេចក្តីទៀងត្រង់[ព]
[១១]ឱព្រះយេហូវ៉ាអើយ សូមចំរើនកំឡាំងដល់ទូលបង្គំ[ភ]
ដោយយល់ដល់ព្រះនាមទ្រង់[ម]សូមនាំព្រលឹងទូលបង្គំ
ចេញពីសេចក្តីវេទនា ដោយសេចក្តីសុចរិត[យ]របស់ទ្រង់
[១២]ហើយសូមកាត់ពួកខ្មាំងសត្រូវទូលបង្គំចេញ[រ]
ដោយសេចក្តីសប្បុរសរបស់ទ្រង់ ព្រមទាំងបំផ្លាញអស់អ្នក
ដែលសង្កត់សង្កិនព្រលឹងទូលបង្គំផង[ល] ដ្បិតទូលបង្គំជាអ្នក
បំរើទ្រង់ហើយ[វ] ។

**១៤៣:២** ង ទដ ១៤:៣ រម ៣:១០ **១៤៣:៣** ច ទដ ១០៧:១០ ឆ បទ ៣:៦ **១៤៣:៤** ជ ទដ ៣០:៧ **១៤៣:៥** ឈ ទដ ៧៧:៦ ញ លប ២៤:៦៣ **១៤៣:៦** ដ នក ៩:២៩ យប ១១:១៣ **១៤៣:៧** ឋ ទដ ៦៩:១៧ ឌ ទដ ១៤២:៣ ឍ ទដ ២២:២៤ ២៧:៩ ៣០:៧ **១៤៣:៨** ណ ទដ ៦:៤ ៩០:១៤ ត នក ៣៣:១៣ យប ៣៤:៣២ ទដ ២៧:១១ ៣២:៨ ថ ទដ ២៥:១-២ ៨៦:៤ **១៤៣:៩** ទ ទដ ១៤០:១ ធ ទដ ១៨:១៧ ៣១:១៥ **១៤៣:១០** ន ទដ ១១៩:១២ ប ទដ ៣១:១៤ ផ នហ ៩:២០ ទដ ២៥:៤-៥ ព ទដ ២៦:១២ **១៤៣:១១** ភ ទដ ២៥:១១ ម ទដ ៤១:២ យ ទដ ៣១:១ ៧១:២ **១៤៣:១២** រ ទដ ៨:២ ល ទដ ៥៤:៥ វ ទដ ១១៦:១៦

ដល់អ្នកបម្រើទ្រង់ ស្តេចដាវីឌស្គាល់ពីភាពបរាជ័យរបស់ទ្រង់ (សូមមើល ខ.១០) តែគាត់បានផ្តោតលើការចាប់អារម្មណ៍ ដែលមានការវិនិច្ឆ័យល្អចំពោះភាពឃោរឃៅរបស់ខ្មាំងសត្រូវ និងការប្រយុទ្ធលុកលុយរបស់ខ្មាំងសត្រូវដែលអាចឈ្នះគាត់បាន ។ *អ្នកបំរើទ្រង់* វាមានលក្ខណៈផ្ទុយនិង ១៤៤:១០ ដោយគេបានពោលថា ហេតុអ្វីបានជាបទទំនុកដំកើងបានរាយរាប់ពណ៌នាចំណុចសំខាន់តែលើស្តេចដាវីឌដូច្នេះ (មើល ៧៨:៧០ ១៣២:១០ និងការពន្យល់) ។

**១៤៣:៣-៤** ជាវគ្គពណ៌នាពីសេចក្តីទុក្ខព្រួយកង្វល់ និងការឈឺចាប់ ។

**១៤៣:៣** ឯវគ្គពាក់កណ្តាលចុះក្រោយនៃខនេះ បានបង្ហាញចំៗតែម្តងក្នុង បទ ៣:៦ ។ *ក្នុងទីងងឹត* គឺមានលក្ខណៈដូចជាអ្នកណាម្នាក់បានផ្តាច់ទំនាក់ទំនងពីការបម្រើការងាររបស់មនុស្ស (សូមមើល ខ.៧ និងការពន្យល់ ២៧:១ ៣០:១) ។

**១៤៣:៤** *វិញ្ញាណនៅក្នុងខ្លួនទូលបង្គំត្រូវអន់ថយទៅ* សូមមើលការពន្យល់ ១៤២:៣ ។ *ចិត្ត* សូមមើលការពន្យល់ ៤:៧ ។

**១៤៣:៥-៦** ការនឹកចាំពីរឿងអតីតកាលរបស់ព្រះអម្ចាស់ ដែលបានជួយសង្គ្រោះ និងដោះលែងរាស្ត្រទ្រង់ដូចជាស្តេចដាវីឌជាពិសេសក្នុងការដែលអំពាវនាវ ។

**១៤៣:៦** *ទូលបង្គំលើកដៃប្រណម្យដល់ទ្រង់* គឺក្នុងការអធិស្ឋាន (សូមមើល ៤៤:២០ ៨៨:៩ នក ៩:២៩) ។ *ព្រលឹង* មើល ខ.៨ និងការពន្យល់ ៦:៣ ។ *ស្រែករកទ្រង់* សូមមើលការពន្យល់ ៦៣:១ ។

**១៤៣:៧-១០** ជាការអធិស្ឋាន ។

**១៤៣:៧** *វិញ្ញាណទូលបង្គំអន់ថយហើយ* គឺអាចជាវិញ្ញារបស់ទូលបង្គំអន់ថយដោយសារការស៊ីទ្រាំ ឬរងចាំមានហេតុការណ៍ ១១៩:៨១ ក៏មានសេចក្តីនៅបន្ទាត់ក្រោយទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាយ៉ាងខ្លាំងក្នុង ១០៤:២៩ (ដែលក្នុងនោះពាក្យថា"ដង្ហើម"ដែលបានបកប្រែថាដូចក្នុងភាពក្នុងភាសាហេព្រើរគឺសំដៅលើ"ព្រលឹង") ។ តែជាទីបញ្ចប់"ព្រលឹងរបស់ទូលបង្គំ"ដែលបានធ្លាក់ចុះនោះក៏បានប្រោសឱ្យងើបឡើងវិញ និងដឹកនាំដោយ"ព្រះវិញ្ញាណដ៏សប្បុរសរបស់ទ្រង់"(ខ.១០) ក៏មានការបង្ហាញពីរបែបទាក់ទងនិងការអធិស្ឋាន ។ *លាក់ព្រះភក្ត្រ* មើលការពន្យល់ ១៣:១ ។ *រណ្តៅ* សូមមើល ខ.៣ និងការពន្យល់ ៣០:១ ។

**១៤៣:៨** *នៅពេលព្រឹក* គឺជាការសង្គ្រោះឱ្យផុតពី"ភាពងងឹត"ដែលកើតមានថ្មី (ខ.៣ សូមមើលសេចក្តីផ្តើម ទដ ៥៧ និងការពន្យល់ ១០១:៨) ។ *សេចក្តីសប្បុរសរបស់ទ្រង់* សូមមើល ខ.១២ និងការពន្យល់ ៦:៤ ។ *ដ្បិតទូលបង្គំបានទុកចិត្តនឹងទ្រង់ . . . ពីព្រោះទូលបង្គំបានលើកព្រលឹងទៅរកទ្រង់* សូមមើលការពន្យល់ ២៥:១-២ ២៤:៤ ។ *សូមឱ្យទូលបង្គំបានស្គាល់ផ្លូវដែលគួរដើរ* សូមមើល ខ.១០ គឺការដែលទ្រង់បានជួយឱ្យរួចពីកណ្តាប់ដៃពួកសត្រូវនោះមិនទាន់គ្រប់ល្មមទេ គឺត្រូវឱ្យយើងមានចំណែកជា "អ្នកបម្រើព្រះ"ព្រះអម្ចាស់ (សូមមើល ខ.២,១២) គឺជាច្រកសម្រាប់ទទួលបានជីវិត ។

**១៤៣:១០** *ស្រុកដែលប្រកបដោយសេចក្តីទៀងត្រង់* សូមមើល ២៦:១២ ។

**១៤៣:១១-១២** ជាការរួមសរុបឡើងវិញនូវសេចក្តីអធិស្ឋាន (សូមមើលសេចក្តីផ្តើម) ។ សូមចំណាំតើ "ភាពសុចរិតរបស់ទ្រង់" "អ្នកបម្រើរបស់ទ្រង់" ហើយនិង "ភាពសប្បុរសរបស់ទ្រង់" បានបង្កើតឡើងមានទំនាក់ទំនងនិង ខ.១-២ ដោយវិធីណាដែរ ។

**១៤៣:១១** *ដោយយល់ដល់ព្រះនាមទ្រង់* សូមមើលការពន្យល់ ២៣:៣ ។

**១៤៣:១២** *បំផ្លាញអស់អ្នកដែលសង្កត់សង្កិនព្រលឹងទូលបង្គំ* សូមមើលការពន្យល់ ៥:១០ ។

ទំនុកនៃស្តេចដាវីឌ ។
**១៤៤** សូមឱ្យព្រះយេហូវ៉ា ជាថ្មដា[ក]នៃទូលបង្គំបាន
ប្រកបដោយព្រះពរជាព្រះដែលបង្ហាត់បង្វឹកដៃទូលបង្គំឱ្យ
ចេះច្បាំង ហើយម្រាមដៃរបស់ទូលបង្គំឱ្យធ្វើសង្គ្រាម
២ទ្រង់ជាសេចក្តីសប្បុរស ហើយជាបន្ទាយ[ខ]នៃទូលបង្គំជា
ប៉មយ៉ាងខ្ពស់[គ] ហើយជាអ្នកដែលប្រោសឱ្យទូលបង្គំរួចក៏ជា
ខែល[ឃ]នៃទូលបង្គំ ហើយទូលបង្គំពឹងជ្រកនៅក្នុងទ្រង់
គឺទ្រង់ ដែលបង្ក្រាបរាស្ត្រ[ង]នៅក្រោមអំណាចទូលបង្គំ
៣ឱព្រះយេហូវ៉ាអើយ តើមនុស្ស[ច]ជាអ្វីបានជាទ្រង់យកចិត្ត
ទុកដាក់នឹងគេ ឬកូនមនុស្ស បានជាទ្រង់រាប់អានដូច្នេះ
៤មនុស្សធៀបដូចជាខ្យល់ដង្ហើមទេ[ឆ] អស់ទាំងថ្ងៃអាយុរបស់
គេដូចជាស្រមោលដែលតែងបាត់ទៅ[ជ]
៥ឱព្រះយេហូវ៉ាអើយ សូមទ្រង់បង្អោនស្ថានសួគ៌[ឈ]
ហើយយាងចុះមក[ញ] សូមពាល់ភ្នំទាំងប៉ុន្មាន នោះ
នឹងមានផ្សែងហុយឡើង[ដ]
៦សូមចាត់ប្រើផ្លេកបន្ទោរ[ឋ]ចុះមកកំចាត់កំចាយ[ឌ]គេសូម
បាញ់អស់ទាំងព្រួញ[ឍ]របស់ទ្រង់ចេញ ទៅបំបាក់ទ័ពគេ
៧សូមទ្រង់លូកព្រះហស្តចុះមកពីលើ[ណ] កន្ទ្រាក់ជួយឱ្យទូល
បង្គំរួច ហើយប្រោសទូលបង្គំ[ត]ឱ្យរួចពីទឹក[ថ]ធំ គឺពីកណ្តាប់
ដៃនៃពួកសាសន៍ដទៃ[ទ]
៨ដែលមាត់គេពោលតែពាក្យកលឧបាយ[ធ] ហើយដៃស្តាំ[ន]
របស់គេក៏ប្រព្រឹត្តតែសេចក្តីភូតភរទទេ[ប]
៩ឱព្រះអង្គអើយ ទូលបង្គំនឹងច្រៀងបទ[ផ]ថ្មីថ្វាយទ្រង់ទូលបង្គំ
នឹងច្រៀងសរសើរដល់ទ្រង់ដោយដេញពិណខ្សែ១០[ព]
១០គឺទ្រង់ដែលប្រោសសេចក្តីសង្គ្រោះដល់ពួកស្តេច[ភ]ក៏
ប្រោសដាវីឌ[ម]ជាអ្នកបំរើទ្រង់ ឱ្យរួចពីដាវដ៏អាក្រក់[យ]
១១សូមកន្ទ្រាក់ជួយទូលបង្គំ[រ] ហើយប្រោសឱ្យរួចពីកណ្តាប់
ដៃនៃពួកសាសន៍ដទៃ[ល] ដែលមាត់គេពោលតែពាក្យកល
ឧបាយ[វ] ហើយដៃស្តាំរបស់គេប្រព្រឹត្តតែសេចក្តីភូតភរ
ទទេ[ស] ។
១២កូនប្រុសៗរបស់យើងខ្ញុំ នឹងបានដូចជាដើមណាដែល

**១៤៤:១** ក លប ៤៩:២៤ **១៤៤:២** ខ ទដ ៥៩:៩ ៩១:២ គ ទដ ២៧:១ ៣៧:៣៩ ៤៣:២ ឃ លប ១៥:១ ទដ ១៨:២ ង ពច ៤:២៣ ទដ ១៨:៣៩ **១៤៤:៣** ច ហព ២:៦ **១៤៤:៤** ឆ យប ៧:៧ ២៧:៣ អស ២:២២ ជ ១រប ២៩:១៥ យប ១៤:២ យក ៤:១៤ **១៤៤:៥** ឈ ទដ ១៨:៩ អស ៦៤:១ ញ លប ១១:៥ ទដ ៥៧:៣ ដ ទដ ១០៤:៣២ **១៤៤:៦** ឋ ហព ៣:១១ សក ៩:១៤ ឌ ទដ ៥៩:១១ ៦៨:១ ឍ ទដ ៧:១២–១៣ ១៨:១៤ **១៤៤:៧** ណ ២សយ ២២:១៧ ត ទដ ៣:៧ ៥៧:៣ ថ ទដ ៦៩:២ ទ ទដ ១៨:៤៤ **១៤៤:៨** ធ ទដ ១២:២ ៤១:៦ ន លប ១៤:២២ ចទ ៣២:៤០ ប ទដ ៣៦:៣ **១៤៤:៩** ផ ទដ ២៨:៧ ៩៦:១ ព ទដ ៣៣:២–៣ ៧១:២២ **១៤៤:១០** ភ ២សយ ៨:១៤ ម ទដ ១៨:៥០ យ យប ៥:២០ **១៤៤:១១** រ ទដ ៣:៧ ២៥:២០ ល ទដ ១៨:៤៤ វ ទដ ៤១:៦–៧ ស ទដ ១២:២ ៣៦:៣ ១០៦:២៦ អស ៤៤:២០

**ទដ ១៤៤** ជាការអធិស្ឋានសូមការដោះលែងពីសត្រូវ ដែលជាគ្រូខុសឆ្គងការនិពន្ធនេះទំនងជារបៀបពួកស្តេចអធិស្ឋាន ។ ក្នុង ខ.១–១០ ក៏បង្ហាញពីដំណើរដែលមានការទាក់ទងគ្នាជាច្រើនចំពោះ ទដ ១៨ និងជាមួយ ខ.៥–៧ ដែលផ្នែកទាំងអស់បានបង្ហាញឱ្យឃើញពីភាពខុសគ្នាខ្លះៗ ដែលនៅផ្នែកនៃសេចក្តីពន្យល់ខាងក្រោម (សូមមើលការពន្យល់ បន្ទាត់ខាងក្រោមឯទៀត) ឯបន្ទាត់ដែលក្រៅពីនេះក៏មានសំណេរស្រដៀងទៅនិងបទទំនុកដំកើងផ្សេងទៀត ហើយអ្នកនិពន្ធក៏បានតែងឡើងពីសណ្ឋានផ្សេងៗពីការអធិស្ឋានរបស់អ្នកនិពន្ធបទទំនុកនេះផ្ទាល់ ។ ឯផ្នែកផ្សេងបន្ទាប់ទៀតបានបង្ហាញយ៉ាងច្បាស់ដូចជា : ខ.១១ គឺជាខដែលសរុបបញ្ចូលពីការអធិស្ឋានចេញពី ខ.៥–៨,១២–១៤ បានពណ៌នាពីប្រជាជនបានមានក្តីអំណរដែលទទួលឧត្តមគតិដ៏ល្អពីស្នាដៃអ្នកនិពន្ធ ខ.១៥ ជាឃ្លាពណ៌នាពីសេចក្តីបញ្ចប់នៃបទទំនុក ៣៣:១២ ចំពោះវគ្គបន្តក៏មានក្នុងការពន្យល់ខាងក្រោម ។

**១៤៤:១–២** ជាការសរសើរចំពោះព្រះយេហូវ៉ា ក៏ជាឃ្លាផ្តើមនៃការអធិស្ឋាន វាផ្អែកទៅលើការអធិស្ឋានពីរផ្នែក គឺមួយជាសេចក្តីផ្តើម និងមួយទៀតជាផ្នែកលន់តួបាប (សូមមើល ១៨:២) ។

**១៤៤:២** *ទ្រង់ជាសេចក្តីសប្បុរស ហើយជាបន្ទាយនៃទូលបង្គំ* ឯសំណេរតាមបែបអក្សរសាស្ត្របានសរសេរថា "ទ្រង់ជាសេចក្តីសប្បុរសនៃទូលបង្គំ" (សូមមើលការពន្យល់ ៦:៤) ។ គឺដោយព្រះអម្ចាស់ជាប្រភពនៃសេចក្តីមេត្តាករុណានឹងសេចក្តីសប្បុរស ដែលស្តេចដាវីឌបានពឹងផ្អែកចំពោះទ្រង់ ដោយយើងអាចហៅទ្រង់ថាជា "ព្រះអង្គសង្គ្រោះរបស់ទូលបង្គំ" ដោយសារទ្រង់ជាប្រភពនៃសេចក្តីសង្គ្រោះ (សូមមើល ២៧:១ ៣៥:៣ ៦២:២) ។

**១៤៤:៣–៤** ជាការទទួលស្គាល់រវាងមនុស្សដែលគ្មានអំណាចចេស្តា និងភាពមានព្រះចេស្តា នៃអំណាចរបស់ព្រះដែលទ្រង់បានយកព្រះទ្រង់ទ័យទុកដាក់ចំពោះពួកមនុស្សលោក ។

**១៤៤:៣** បង្ហាញភាពខុសប្លែកគ្នារវាងមនុស្សនឹងព្រះ ៨:៤ ។

**១៤៤:៤** *ខ្យល់ដង្ហើម* សូមមើល ៣៩:៤–៦ និងការពន្យល់ ។ *ស្រមោល* សូមមើល ១០២:១១ និងការពន្យល់ ។

**១៤៤:៥–៨** ជាការអធិស្ឋានដើម្បីសុំការប្រោះលោះ ។

**១៤៤:៥** សូមមើល ១៨:៩ និងការពន្យល់ ១៨:៧–១៥ អស ៦៤:១ ។

**១៤៤:៦** សូមមើល ១៨:១៤ និងការពន្យល់ ។

**១៤៤:៧** សូមមើល ១៨:១៦–១៧ និងការពន្យល់ ៣២:៦ ។

**១៤៤:៨** *មាត់* សូមមើលការពន្យល់ ៥:៩ ។ *ដៃស្តាំ* គឺសំដៅលើដៃដែលលើកសច្ចាប្រណិស្បថចំពោះសេចក្តីសញ្ញា ដែលគេបានពោលថា និងទទួលព្រមយកដើរតាម(សូមមើល ១០៦:២៦ នក ៦:៨ ចទ ៣២:៤០) ។

**១៤៤:៩–១០** ជាពាក្យសរសើរដោយសច្ចា (មើលការពន្យល់ ៧:១៧) ។

**១៤៤:៩** *ច្រៀងបទថ្មី* សូមមើលការពន្យល់ ៣៣:៣ ។

**១៤៤:១០** *ដាវីឌជាអ្នកបំរើទ្រង់* សូមមើល ១៤៣:២ និងការពន្យល់ ។

**១៤៤:១១** ខនេះគឺជាការបង្ហាញឡើងវិញពីការអធិស្ឋានមានក្នុង ខ.៧–៨ ក៏មានទំនាក់ទំនងទៅនឹងអត្ថន័យខាងក្រោម : គឺបើព្រះអម្ចាស់ប្រោសលោះដាវីឌជាអ្នកបម្រើទ្រង់នោះអាណាចក្រទាំងមូលនឹងបានទទួលនូវសេចក្តីសុខសាន្ត ។

**១៤៤:១២–១៥** មានសេចក្តីជំនឿជាច្រើនយល់ថា វាជាការអធិស្ឋានដាច់ៗពីគ្នា (សូមឱ្យកូនប្រុសៗរបស់យើង) ក៏ពុំមានទំនាក់ទំនងដូច ខ.១–១១ ទេ ប៉ុន្តែ វាជាការប្តូរពីផ្នែកមួយទៅផ្នែកមួយទៀត ។

**១៤៤:១២** *ហើយកូនស្រីៗរបស់យើងខ្ញុំនឹងបានដូចជាថ្មសីមា* គឺជាសរសរទម្រដក់ព្រះវិហារក្នុងលក្ខណៈជាស្ត្រីមួយមានលក្ខណៈពិសេស (ដូចជាទីក្រុង

ចំរើនធំឡើងពីកាលនៅក្មេង[ហ] ហើយកូនស្រីៗរបស់យើង
ខ្ញុំនឹងបានដូចជាថ្មសីមា[ឡ]ដែលដាប់ធ្វើតាមរបៀបព្រះរាជ
វាំង
១៣ជង្រុករបស់យើងខ្ញុំនឹងបានពេញ[អ]ដោយស្បៀងអាហារ
គ្រប់មុខហ្វូងចៀមរបស់យើងខ្ញុំនឹងកើតកូនទាំងពាន់ទាំង
ម៉ឺន ចំរើនឡើងនៅឯវាល
១៤គោ[ក]របស់យើងខ្ញុំនឹងមានកំឡាំងធ្វើការយ៉ាងធ្ងន់ និង
គ្មានខ្មាំងរុករានចូល[ខ] ឬនាំយើងខ្ញុំចេញទៅជាឈ្លើយ
ឡើយ ក៏នឹងគ្មានឮសំរែកដោយភ័យនៅក្នុងផ្លូវយើងខ្ញុំ
ដែរ[គ]
១៥សប្បាយហើយសាសន៍[ឃ]ណាដែល មានសណ្ឋានដូច្នេះ
អើ សាសន៍ណាដែលយកព្រះយេហូវ៉ា
ទុកជាព្រះរបស់ខ្លួន
នោះសប្បាយហើយ ។

ទំនុកជាបទសរសើររបស់ស្តេចដាវីឌ ។

**១៤៥** ឱព្រះដ៏ជាមហាក្សត្រនៃទូលបង្គំអើយ[ក]
ទូលបង្គំនឹងលើកដំកើងទ្រង់[ខ] ហើយនិងសូមឱ្យព្រះនាម[គ]
ទ្រង់បានពរអស់កល្បជានិច្ច
២ទូលបង្គំនឹងសូមឱ្យទ្រង់បានប្រកបដោយព្រះពររាល់ៗថ្ងៃ
ព្រមទាំងសរសើរ[ឃ]ដល់ព្រះនាម[ង]ទ្រង់អស់កល្បជានិច្ច
៣ព្រះយេហូវ៉ាទ្រង់ធំប្រសើរ[ច] គឺគួរសរសើរយ៉ាងក្រៃ
លែង[ឆ] ឯសណ្ឋានធំប្រសើររបស់ទ្រង់ នោះនឹងរកយល់
មិនបាន[ជ]
៤មនុស្សដំណ១[ឈ]នឹងសរសើរស្នាដៃរបស់ទ្រង់ ដល់ដំណ១
ទៀតព្រមទាំងប្រកាសប្រាប់[ញ]ពីការឥទ្ធិឫទ្ធិរបស់ទ្រង់ផង[ដ]
៥ទូលបង្គំនឹងរំពឹងគិតពីឫទ្ធានុភាពដ៏រុងរឿងឧត្តម[ឋ] ហើយពី
ការអស្ចារ្យរបស់ទ្រង់ដែរ[ឌ]
៦មនុស្សទាំងឡាយនឹងថ្លែង[ឍ]ពីឫទ្ធិនៃការដ៏គួរស្ញែងខ្លាច
របស់ទ្រង់[ណ] ឯទូលបង្គំនឹងប្រកាស[ត]ពីសណ្ឋានដ៏ធំវិសេស
នៃទ្រង់ដែរ[ថ]
៧គេនឹងបញ្ចេញសេចក្តី ដែលនឹកចាំពីព្រះហឫទ័យដ៏ល្អ
ប្រសើរ[ទ] ហើយច្រៀង[ធ]ពីសេចក្តីសុចរិតរបស់ទ្រង់[ន]
៨ព្រះយេហូវ៉ាទ្រង់ប្រកបដោយមេត្តាករុណា និងអាណិត
អាសូរ[ប] ទ្រង់យឺតនឹងខ្ញាល់ ក៏មានសេចក្តីសប្បុរសដ៏ធំ
ទូលាយ[ផ]

**១៤៤:១២** ហ ទដ ៩២:១២–១៤ ១២៨:៣ ឡ បស ៤:៤ ៧:៤ **១៤៤:១៣** អ សភ ៣:១០ **១៤៤:១៤** ក សភ ១៤:៤ ខ ២ពវ ២៥:១១ គ អស ២៤:១១ យរ ១៤:២–៣ **១៤៤:១៥** ឃ ចទ ២៨:៣ **១៤៥:១** ក ទដ ៣០:១ ៣៤:១ **១៤៥:១** ខ ទដ ២:៦ ៥:២ គ ទដ ៥៤:៦ **១៤៥:២** ឃ ទដ ៧១:៦ ង ទដ ៣៤:១ អស ២៥:១ ២៦:៨ **១៤៥:៣** ច ទដ ៩៥:៣ ឆ ២សយ ២២:៤ ទដ ៩៦:៤ ជ យប ៥:៩ **១៤៥:៤** ឈ ទដ ២២:៣០ ញ ចទ ១១:១៩ ដ ទដ ៧១:១៦ **១៤៥:៥** ឋ ទដ ៩៦:៦ ១៤៨:១៣ ឌ ទដ ៧៥:១ **១៤៥:៦** ឍ ទដ ៧៨:៤ ណ ទដ ៦៦:៣ ត ចទ ៣២:៣ ថ ទដ ៧៥:១ ១០៦:២២ **១៤៥:៧** ទ នក ១៨:៩ ទដ ២៧:១៣ ធ ទដ ៥:១១ ១០១:១ ន ទដ ១៣៨:៥ **១៤៥:៨** ប ទដ ៨៦:១៥ ១០៣:៨ ផ ទដ ៨៦:៥

កំផែងដ៏រឹងមាំនៅក្នុងរាជធានីប្រទេសក្រិកនាសម័យដើម) ។

**១៤៤:១៤** *គោរបស់យើងខ្ញុំនឹងមានកំឡាំងធ្វើការ* ឬក៏ "គោរបស់យើងនឹងមានសាច់ឈាមធំធាត់" ឬក៏មានន័យថា "គោរបស់យើងនៅស្ទាវពេញកម្លាំង" ។

**១៤៤:១៥** *សប្បាយហើយ* មានន័យជាមានពរហើយ សូមមើលការពន្យល់ ១:១ ។ *សាសន៍ណាដែលមានសណ្ឋានដូច្នេះអើ* ប្រៀបធៀបនឹង ៣៣:១២ សូមមើល ចទ ២៨:៣–៨ ១ពវ ៥:៤ និងការពន្យល់ ។

**ទដ ១៤៥** ជាបទទំនុកដំកើងសរសើរពីភាពឧត្តមដល់ព្រះយេហូវ៉ា ដែលទ្រង់ជាព្រះមហាក្សត្រដ៏មានគុណធម៌ (ព្រះគុណ) ប្រកដដោយភាពមេត្តាករុណាដល់រាស្ត្រទ្រង់ទាំងអស់ដោយទ្រង់បានគ្រប់គ្រង ដោយមានភាពសប្បុរសវាជាផលនៃភាសាដែលជាទំនៀមទម្លាប់ពីការសរសើរតម្កើង និងបែបជាកំណាព្យតាមលំដាប់អក្សរ ។ ក៏បានបង្ហាញត្រឡប់មកវិញនូវការយកចិត្តទុកដាក់នៃការនិពន្ធបែបសិក្សាលំអិត ។ ការយកចិត្តទុកដាក់នេះក៏ឃើញមាននៅក្នុងផ្ទៃរឿងទាំងមូល ។ ឯរវាងសេចក្តីផ្តើមដែលមានពីបន្ទាត់ (ខ.១–២) និងមួយបន្ទាប់ជាសេចក្តីបញ្ចប់ (ខ.២១) ។

មានវគ្គគាថាសំខាន់ៗបួន (ខ.៣៧,៩១៣,១៣–១៦,១៧–២០) ក៏បង្កើតបានជាផ្ទៃរឿងជាច្រើន ។ សេចក្តីផ្តើមនិមួយៗមានជួរឃ្លាតាមបែបផែនវិទ្យានិពន្ធ ។ វគ្គគាថាពីរដំបូងបាននិពន្ធជាបែបបន្ទាត់ជួរៗ ជាកំណាព្យតាមលំនាំ៥បែបក៏មានវគ្គពីរចុងក្រោយក្នុងចំណោមបួនបន្ទាត់ ។ ឯចំណុចកណ្តាលរវាងបន្ទាត់ពីរដំបូង គឺជាបន្ទាត់តែងតាមបែបកំណាព្យបន្ថែមទៀត (ខ.៨) ។ នក ៣៤:៦–៧ បញ្ជាក់ពីផ្ទៃរឿងគឺជាចំណុចសំខាន់ (សូមមើលការពន្យល់ ៦:៦) ហើយក៏ពុំបានបញ្ជាក់ច្បាប់ពិស្តារទេ (តែសូមមើល ៨៦:១៥ ១០៣:៨–១២ ១១១:៤–៥ ១១៦:៥–៦) វគ្គនេះអ្នកនិពន្ធបានរក្សារធាតុដើមពីភាសាហេព្រើរជាច្រើន ។ ម្យ៉ាងវិញទៀតគាថាពីរដំបូង (ខ.៣–១៣) ក៏បង្ហាញពីការបើកការច្រៀងសរសើរពីសិរីល្អ ដ៏មានព្រះចេស្តានៃរាជបល្ល័ង្ករបស់ព្រះយេហូវ៉ា បន្ទាប់មកមានវគ្គពីរចុងក្រោយ (ខ.១៣–២០) បានផ្តោយសំខាន់លើកិច្ចការដែលស្តេចដាវីឌបានធ្វើ គឺជាការសរសើរតម្កើងដល់ព្រះ ។

**១៤៥ ជាផ្នែកចំណងជើង** *លើកដំកើងទ្រង់* ឯភាសាហេព្រើរសរសេរថា "ថៃហីឡា" (Tehillah) ពាក្យនេះឃើញមានតែនៅក្នុងជំពូកនេះតែប៉ុណ្ណោះ គឺក្នុងចំណងជើងនៃបទទំនុកតម្កើងនេះ ។ តែបើជាទម្រងពហុវចនៈវិញគេសរសេរថា "ថៃហីលីម" (Tehillim) ដែលគេតែងតែប្រើជាទម្លាប់ក្នុងភាសាហេព្រើរ ។ *របស់ស្តេចដាវីឌ* មើលសេចក្តីផ្តើម ទដ ១៣៨–១៤៥ ។

**១៤៥:១–២** នេះជាវគ្គសរសើរតម្កើងដំបូង ។ *ព្រះនាម* សូមមើល ខ.២១ ៥:១១ ។

**១៤៥:៣–៧** ការសរសើរដល់ព្រះអម្ចាស់ពីសណ្ឋានទ្រង់ដ៏ធំប្រសើររបស់ទ្រង់ (ខ.៣) និងភាពធំឧត្តម្ភរបស់ព្រះ (ខ.៧) គឺអ្នកនិពន្ធបានបង្ហាញធ្ងន់ទៅលើវគ្គគាថាខ័ណ្ឌដែលមានឃ្លាយោងពីរឃ្លា ។ ចំពោះការដែលមានឃ្លានូវប្រយោគ សូមមើល ៨៦:១០,១៧ ១៣៥:៣,៥ ។

**១៤៥:៤** *នឹងសរសើរ . . . ប្រកាសប្រាប់* សូមមើល ខ.៥–៧,១០–១២,២១ និងការពន្យល់ ៩:១ ។ *ស្នាដៃរបស់ទ្រង់* ការបង្កើតនិងការប្រោសលោះ ។

**១៤៥:៧** *សេចក្តីសុចរិតរបស់ទ្រង់* សូមមើលការពន្យល់ ៤:១ ។

៩ ព្រះយេហូវ៉ាទ្រង់ល្អ[ព] ដល់មនុស្សទាំងអស់
ហើយព្រះហឫទ័យទន់សន្តោស[ភ] របស់ទ្រង់ ក៏គ្របលើ
កិច្ចការ របស់ទ្រង់ទាំងប៉ុន្មាន
១០ ឱព្រះយេហូវ៉ាអើយ អស់ទាំងស្នាដៃរបស់ទ្រង់នឹងអរព្រះ
គុណដល់ទ្រង់[ម]
ហើយពួកអ្នកបរិសុទ្ធរបស់ទ្រង់នឹងសូមឱ្យ[យ] ទ្រង់បានប្រកប
ដោយព្រះពរ[រ]
១១ គេនឹងថ្លែងពីសិរីល្អនៃនគរ[ល] ទ្រង់ និងពីតេជានុភាព
របស់ទ្រង់[វ]
១២ ប្រយោជន៍ឱ្យពួកមនុស្សជាតិបានស្គាល់អស់ទាំងការ
ឥទ្ធិឫទ្ធិរបស់ទ្រង់[ស] ហើយនិងសិរីល្អនៃឫទ្ធានុភាពរបស់
រាជ្យទ្រង់[ហ]
១៣ រាជ្យទ្រង់ស្ថិតស្ថេរ នៅអស់កល្បជានិច្ច[ឡ] ហើយអំណាច
ទ្រង់ក៏នៅ ដរាបដល់អស់ទាំងដំណតទៅ
១៤ ព្រះយេហូវ៉ាទ្រង់គាំទ្រ[អ]ដល់អស់អ្នកដែលដួលក៏លើកពួក
អ្នក[ក]ដែលត្រូវឱនឡើងវិញ[ខ]
១៥ ភ្នែករបស់មនុស្សទាំងអស់រង់ចាំតែទ្រង់ ហើយទ្រង់ក៏
ប្រទានអាហារ[គ]ដល់គេតាមត្រូវពេល
១៦ ទ្រង់លាព្រះហស្ត
ក៏បំពេញចិត្តប្រាថ្នា[ឃ]នៃជីវិតទាំងឡាយ
១៧ ព្រះយេហូវ៉ាទ្រង់សុចរិត[ង]ក្នុងគ្រប់ទាំងផ្លូវទ្រង់ក៏សប្បុរស
ក្នុងគ្រប់ទាំងកិច្ចការរបស់ទ្រង់ដែរ[ច]
១៨ ព្រះយេហូវ៉ាទ្រង់គង់នៅជិត[ឆ]នឹងអស់អ្នកដែលអំពាវនាវ
ដល់ទ្រង់[ជ] គឺអស់អ្នកដែលអំពាវនាវដល់ទ្រង់ដោយពិតត្រង់
១៩ ទ្រង់នឹងបំពេញបំណងចិត្ត[ឈ]នៃអស់អ្នកដែលកោតខ្លាច
ដល់ទ្រង់[ញ]ក៏នឹងឮពាក្យអំពាវនាវ[ដ] របស់គេព្រមទាំងជួយ
សង្គ្រោះគេផង[ឋ]
២០ ព្រះយេហូវ៉ាទ្រង់រមែងការពារ[ឌ]អស់អ្នក ដែល
ស្រឡាញ់ទ្រង់[ឍ] តែនឹងបំផ្លាញពួកមនុស្សអាក្រក់វិញ[ណ]
២១ មាត់ទូលបង្គំនឹងពោលពាក្យ[ត]សរសើរពីព្រះយេហូវ៉ា
គួរឱ្យមនុស្សទាំងឡាយ[ថ] បានសូមឱ្យព្រះនាមបរិសុទ្ធ[ទ]
របស់ទ្រង់បានពរ នៅអស់កល្បជានិច្ចដែរ ។

**១៤៦** ចូរសរសើរដល់ព្រះយេហូវ៉ា[ក]នៃព្រលឹងអញ
អើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ

**១៤៥:៩** ព ១របា ១៦:៣៤ ទដ ១៣៦:១ មថ ១៩:១៧ មក ១០:១៨ ភ ទដ ១០៣:១៣–១៤ **១៤៥:១០** ម ទដ ៨:៦ ១០៣:២២ ១៣៩:១៤ យ ទដ ៣០:៤ ១៤៨:១៤ ១៤៩:៩ រ ទដ ១១៥:១៧–១៨ **១៤៥:១១** ល ឧ.១២–១៣ នក ១៥:២ មថ ៦:៣៣ វ ទដ ២១:១៣ **១៤៥:១២** ស ទដ ៧៥:១ ១០៥:១ ហ ឧ.១១ ទដ ១០៣:១៩ អស ២:១០,១៩,២១ **១៤៥:១៣** ឡ នក ១៥:១៨ ១ធថ ១:១៧ ២ពត ១:១១ វវ ១១:១៥ **១៤៥:១៤** អ ទដ ៣៧:១៧ ក ១សយ ២:៨ ទដ ១៤៦:៨ ខ ទដ ៣៨:៦

**១៤៥:១៥** គ លប ១:៣០ យប ២៨:៥ ទដ ៣៧:២៥ មថ ៦:២៦ **១៤៥:១៦** ឃ ទដ ៩០:១៤ ១០៤:២៨ **១៤៥:១៧** ង នក ៩:២៧ អរ ៩:១៥ ច ឧ.១៣ **១៤៥:១៨** ឆ ជន ២៣:២១ ទដ ៤៦:១ ភល ៤:៥ ជ ទដ ១៨:៦ ៨០:១៨ **១៤៥:១៩** ឈ ទដ ២០:៤ ញ យប ២២:២៨ ដ ទដ ៣១:២២ ៤០:១ ឋ ១សយ ១០:១៩ ទដ ៧:១០ ៣៤:១៨ **១៤៥:២០** ឌ ទដ ១:៦ ឍ ទដ ៣១:២៣ ៩១:១៤ ៩៧:១០ ណ ទដ ៩៤:២៣ **១៤៥:២១** ត ទដ ៧១:៨ ថ ទដ ៦៥:២ ១៥០:៦ ទ នក ៣:១៥ ទដ ៣០:៤ ៩៩:៣ **១៤៦:១** ក ទដ ១០៣:១ ១០៤:១

**១៤៥:៩–១៣ក** គឺជាការសរសើរចំពោះប្រះអម្ចាស់ នូវព្រះគុណប្រកបដោយភាពមេត្តាករុណាដែលមានជីវិត ដែលជាស្នាព្រះហស្តបានធ្វើការសរសើរតម្កើងសិរីល្អដល់នគររបស់ទ្រង់ ។

**១៤៥:១០** *អស់ទាំងស្នាដៃរបស់ទ្រង់នឹងអរព្រះគុណដល់ទ្រង់* សូមើល ឧ.២១ និងការពន្យល់ ៦៥:១៣ ។ *ពួកអ្នកបរិសុទ្ធ* សូមមើលការពន្យល់ ៤:៣ ។

**១៤៥:១៣ខ–១៦** ការសរសើរចំពោះសេចក្ដីពិតត្រង់របស់ទ្រង់ ។

**១៤៥:១៣ខ,១៧** *សប្បុរស* សូមមើលការពន្យល់ ៦:៤ ឯការបូកបញ្ចូលពាក្យ "សេចក្ដីពិតត្រង់" និងសេចក្ដី "សប្បុរស" សូមមើលការពន្យល់ ៣៦:៥ ។

**១៤៥:១៧–២០** ការសរសើរតម្កើង ចំពោះភាពសុចរិតរបស់ទ្រង់ ។

**១៤៥:១៨** *ដោយពិតត្រង់* ប្រកបដោយសេចក្ដីសុចរិតរបស់ទ្រង់ ។

**១៤៥:២១** ការសរសើរតម្កើងព្រះអម្ចាស់ត្រូវតែបន្ត ហើយគ្រប់មនុស្សទាំងឡាយត្រូវសរសើរតម្កើងព្រះជារៀងរហូតអស់កល្បជានិច្ច ។ *មនុស្សទាំងឡាយ* ឬក៏មានន័យស្មើនឹង "គ្រប់ជាតិសាសន៍ទាំងអស់) ឬគ្រប់ ("ជីវិត" សូមមើល "មនុស្សទាំងអស់" តែសូមមើល ១៥០:៦ ដែរ) ។

**ទដ ១៤៦–១៥០** ជាការចងក្រងចុងក្រោយបង្អស់របស់ទំនុកជាបទដែលមានប្រាំវគ្គគ្រប់ទាំវគ្គបានដាក់ក្នុងវង់ដង្កៀបដោយមានពាក្យស្រែកថា ហាលេលូយ៉ា! (សរសើរដល់ព្រះយ៉ាវេ) សូមមើលសេចក្ដីផ្ដើម ទដ ១០៥–១០៦ ទដ ១១១–១១៧) ។ អ្នកនិពន្ធបទទំនុកបានប្រមូលបទទំនុកពីរដែលបង្ហាញពីអ្នកអាន និងអ្នកដែលមានតួនាទី ឬជាអ្នកសំខាន់ (សូមមើលសេចក្ដីផ្ដើម ទដ ១–២) ។ ឯនៅក្នុវគ្គចុងក្រោយនេះ គឺជាវគ្គសរុប ឬប្រមូលផ្ដុំអត្ថន័យបទទំនុកដំកើងដែលជាផ្ទៃរឿងចុងក្រោយ ។ គឺជាគោលរឿងពីការសរសើរនិងអំពាវនាវដល់ព្រះមហាក្សត្រនៃស្ថានសួគ៌របស់ក្រុងស៊ីយ៉ូន (សូមមើល ១៤៦:១០ ១៤៧:១២ ១៤៩:២) ដល់អ្នកបង្កើតអ្វីៗទាំងអស់អ្នកដែលទ្រទ្រង់គឺជាព្រះយេហូវ៉ាលើគ្រប់អស់ទាំងការដែលទ្រង់បង្កើត (សូមមើល ១៤៦:៦ ១៤៧:៤,៨–៩,១៥–១៨ ១៤៨:៥–៦) គឺជាអង្គដែលមានអំណាចចេស្ដាដែលគ្រប់ទាំងអស់ ហើយទ្រង់ក៏ជាអង្គដែលជួយដល់មនុស្សរងគ្រោះ គឺចំពោះអស់អ្នកដែលពឹងទ្រង់ឱ្យជួយ (សូមមើល ១៤៦:៥–៩ ១៤៧:២–៣,៦,១១, ១៣–១៤ ១៤៩:៤) ទ្រង់ជាព្រះយេហូវ៉ាជាម្ចាស់លើគ្រប់ប្រវត្តិសាស្ត្រទាំងអស់ហើយទ្រង់ក៏ពុះពារដើម្បីរាស្ត្រទ្រង់ និងសម្រាប់សុវត្ថិភាពរបស់រាស្ត្រទ្រង់ក៏ធានាថាពួកគេគឺជារាស្ត្រស្ថានសួគ៌ (សូមមើល ១៤៧:១៩–២០) ឯរាស្ត្រស្ថានសួគ៌ពួកគេនិងមានជ័យជម្នះនាគ្រាចុងក្រោយ ទៅលើកម្លាំងឬអំណាចលោកិយ ជាពិសេសពួកប្រឆាំងនិងរាស្ត្ររបស់ផងទ្រង់ ក៏ត្រូវវិនាសទាំងស្រុង(មើល ១៤៦:៣,១០ ១៤៧:២,៦,១០,១៣–១៤ ១៤៨:១៤ ១៤៩:៤–៩) ។

**ទដ ១៤៦** ជាចម្រៀងទំនុកដំកើង ដើម្បីច្រៀងសរសើរតម្កើងដល់ព្រះមហាក្សត្រនៃស្ថានសួគ៌របស់ក្រុងស៊ីយ៉ូន ដែលផ្ដោតទៅលើចំណុចពិសេសគឺការដែលទ្រង់ថែរក្សាដល់ប្រជារាស្ត្ររបស់ផងទ្រង់ គឺប្រជាជនក្រុងស៊ីយ៉ូនដែលកំពុងស្វែងរកទ្រង់នៅពេលពួកគេជួបប្រទេះការសង្កត់សង្កិន ឧបសគ្គផ្សេងៗការខ្ទេចខ្ទាំ ឬក៏ក្នុងពេលដែលពួកគេរងនូវការឈឺចាប់យ៉ាងច្រើននោះ ។ បទទំនុកនេះក៏មានឃ្លារឃ្លោងជាច្រើនបង្ហាញពីគោលរឿងសំខាន់ៗមានក្នុង ទដ ៣៣,៦២,១៤៥ ។ មើលសេចក្ដីផ្ដើម ទដ ១៤៦–១៥០ ។

**១៤៦:១–២** ជាការសច្ចាស្បថប្រើក្នុងសេចក្ដីផ្ដើម ចំពោះការសរសើរ

២ កាលខ្ញុំកំពុងរស់នៅឡើយនោះខ្ញុំនឹងសរសើរដល់ព្រះ
យេហូវ៉ា[ខ] ខ្ញុំនឹងច្រៀងសរសើរ[គ]ដល់ព្រះនៃខ្ញុំក្នុងកាល
ដែលនៅមានជីវិតតទៅ[ឃ]
៣ កុំឱ្យទុកចិត្តនឹងអ្នកធំ[ង] ឬនឹងពូជពង្សនៃមនុស្សណាឡើយ[ច]
គេនឹងជួយឯងមិនបានទេ
៤ គេផុតដង្ហើមទៅ ហើយត្រឡប់ទៅជាដីវិញ[ឆ]
នៅថ្ងៃនោះឯង អស់ទាំងគំនិតរបស់គេក៏សូន្យបាត់ទៅ[ជ]
៥ សប្បាយហើយ អ្នកណា[ឈ]ដែលមានព្រះនៃយ៉ាកុបជា
ជំនួយ[ញ]របស់ខ្លួន ជាអ្នកដែលសង្ឃឹមដល់ព្រះយេហូវ៉ា
ជាព្រះនៃខ្លួន
៦ ជាព្រះដែលបង្កើតផ្ទៃមេឃ[ដ] និងផែនដី ព្រមទាំងសមុទ្រ
និងរបស់សព្វសារពើ ដែលនៅស្ថានទាំងនោះផង ទ្រង់
ក៏រក្សាសេចក្តីពិតត្រង់[ឋ]ជាដរាប
៧ ទ្រង់សំរេច[ឌ]សេចក្តីសុចរិតដល់ពួកអ្នក ដែលត្រូវគេ
សង្កត់សង្កិន[ឍ] ក៏ប្រទានអាហារដល់អស់អ្នកដែលឃ្លាន[ណ]
ដែរ ព្រះយេហូវ៉ាទ្រង់ស្រាយពួកអ្នក ដែលជាប់ចំណងឱ្យ
រួចចេញ[ត]
៨ ព្រះយេហូវ៉ាទ្រង់បំភ្លឺ[ថ]ភ្នែករបស់មនុស្សខ្វាក់[ទ]
ព្រះយេហូវ៉ាទ្រង់លើកអស់អ្នកដែលត្រូវឱនឱ្យត្រង់ឡើង
វិញ[ធ] ព្រះយេហូវ៉ាទ្រង់ស្រឡាញ់ពួកមនុស្សសុចរិត[ន]
៩ ព្រះយេហូវ៉ាទ្រង់ការពារពួកអ្នកប្រទេសដទៃ[ប]
ទ្រង់ទប់ទល់ពួកកូនកំព្រា[ផ] និងស្រីមេម៉ាយ[ព]
តែឯផ្លូវរបសមនុស្សអាក្រក់នោះទ្រង់បំបត់បំបែនវិញ
១០ ព្រះយេហូវ៉ាទ្រង់នឹងសោយរាជ្យ[ភ]នៅអស់កល្បជានិច្ច
គឺព្រះនៃឯង ឱក្រុងស៊ីយ៉ូនអើយទ្រង់នឹងសោយរាជ្យដរាប
ដល់អស់ទាំងដំណតទៅចូរសរសើរដល់ព្រះយេហូវ៉ាចុះ។

**១៤៧** ចូរសរសើរដល់ព្រះយេហូវ៉ា ដ្បិតការដែល
ច្រៀងសរសើរដល់ព្រះនៃយើងខ្ញុំ នោះជាការសំណំ
ហើយ[ក] ក៏ពីរោះផងសេចក្តីសរសើរជាការគួរគប្បី[ខ]
២ ព្រះយេហូវ៉ាទ្រង់កំពុងតែសង់ក្រុងយេរូសាឡិមឡើង[គ]

**១៤៦:២** ខ ទដ ១០៤:៣៣ គ ទដ ១០៥:២ ឃ ទដ ៦៣:៤ **១៤៦:៣** ង ទដ ១១៨:៩ ច ទដ ៦០:១១ ១០៨:១២ អស ២:២២ **១៤៦:៤** ឆ លប ៣:១៩ យប ៧:២១ ទដ ១០៣:១៤ សស ១២:៧ ជ ទដ ៣៣:១០ ១រប ២:៦ **១៤៦:៥** ឈ ទដ ៣៣:១៨ ៣៧:៩ ១១៩:៤៣ ១៤៤:១៥ យរ ១៧:៧ ញ ទដ ៧០:៥ ៧១:៥ ១២១:២ **១៤៦:៦** ដ ២រប ២:១២ ទដ ១១៥:១៥ កច ១៤:១៥ វវ ១០:៦

ឋ ចទ ៧:៩ ទដ ១៨:២៥ ១០៨:៤ ១១៧:២ **១៤៦:៧** ឌ ទដ ៣៧:១៧ ឍ ទដ ១០៣:៦ ណ ទដ ១០៧:៩ ១៤៥:១៥ ត ទដ ៦៦:១១ ៦៨:៦ **១៤៦:៨** ថ សភ ២០:១២ អស ២៩:១៨ ៣២:៣ ៣៥:៥ ៤២:៧,១៨–១៩ ៤៣:៨ មថ ១១:៥ ទ នក ៤:១១ធ ទដ ៣៨:៦ ន ចទ ៧:១៣ យប ២៣:១០ **១៤៦:៩** ប លវ ១៩:៣៤ **១៤៦:៩** ផ ទដ ១០:១៨ ព នក ២២:២២ យក ១:២៧ **១៤៦:១០** ភ លប ២១:៣៣ ១រប ១៦:៣១ ទដ ៩៣:១ ៩៩:១ វវ ១១:១៥ **១៤៧:១** ក ទដ ១៣៥:៣ ខ ទដ ៣៣:១ **១៤៧:២** គ ទដ ៥១:១៨

តម្កើងអស់មួយជីវិត (សូមមើល ១៤៥:២១) ។
**១៤៦:១** *ចូរសរសើរដល់ព្រះយេហូវ៉ា នៃព្រលឹងអញអើយ* សូមមើលវគ្គចងក្រង ទដ ១០៣–១០៤ ។ ព្រលឹង សូមមើលការពន្យល់ ៦:៣ ។
**១៤៦:៣–៤** គឺជាការអំពាវនាវចុងក្រោយ ដល់ព្រះយេហូវ៉ាជាជាងស្វែងរកជំនួយពីពួកមនុស្សក្នុងនាលោកិយ (សូមមើល ១១៨:១០–១១ និងការពន្យល់ ១៤៧:១០–១១) ។
**១៤៦:៥–៩** បានលើកទឹកចិត្តចំពោះសេចក្តីពិតក្នុងសេចក្តីសញ្ញានៃព្រះរបស់យ៉ាកុប (សូមមើល ១៤:៧) គឺជាព្រះអាទិករ ដែលជាព្រះយេហូវ៉ាលើគ្រប់ទាំងអស់ក៏ជាអង្គដែលមានសេចក្តីពិតត្រង់ ក៏គាំទ្រថែរក្សាដល់មនុស្សស្លូតត្រង់ ពិតត្រង់ តែទ្រង់កាត់ទោសមនុស្សអាក្រក់វិញ ។
**១៤៦:៦** *បង្កើតផ្ទៃមេឃនឹងផែនដី* សូមមើលការពន្យល់ ១២១:២ ។
**១៤៦:៧** *សំរេចសេចក្តីសុចរិតដល់ពួកអ្នកដែលត្រូវគេសង្កត់សង្កិន* សូមមើល ៩:៩ ១០:១៨ ១០៣:៦ ។ *ប្រទានអាហារដល់អស់អ្នកដែលឃ្លានដែរ* មើល ១៧:១៤ ៣៤:១០ ១០៧:៩ ប្រៀបធៀប អស ៤៩:១០ ។ *ស្រាយពួកអ្នកជាប់ចំណងឱ្យរួចចេញ* សូមមើល ៦៨:៦ ៧៩:១១ ១០២:២០ ១០៧:១០,១៤ ប្រៀបធៀប អស ៤២:៧ និងការពន្យល់ ៦១:១ ។
**១៤៦:៨** *បំភ្លឺភ្នែករបស់មនុស្សខ្វាក់* សូមមើល អស ២៩:១៨ ៣៥:៥ ប្រៀបធៀប អស ៤២:៧ ៤៨:៨ ។ *លើកអស់អ្នកដែលត្រូវឱន* មើល ១៤៥:១៤ ។ *ពួកមនុស្សសុចរិត* សូមមើលការពន្យល់ ១:៥ ។
**១៤៦:៩** *ការពារពួកអ្នកប្រទេសក្រៅ . . . ពួកកំព្រា . . . ស្រីមេម៉ាយ* សូមមើល ចទ ១០:១៨ ប្រៀបធៀប ១:១៧ ៩:១៧ និងការពន្យល់ ប្រៀបធៀប យរ ២២:១៦ យក ១:១៧ ។ *តែឯផ្លូវរបស់មនុស្សអាក្រក់នោះទ្រង់បំបត់បំបែនវិញ* ប្រៀបធៀប ១០៤:៣៥ ១៤៥:២០ ។

**១៤៦:១០** ការបញ្ចប់ដោយបង្ហាញពីកោតសរសើរ ចំពោះភាពជារាស្ត្ររបស់ទីក្រុងនៃរាជាណាចក្រព្រះ ។ *ព្រះយេហូវ៉ាទ្រង់នឹងសោយរាជ្យនៅអស់កល្បជានិច្ច* សូមមើល ៩៣:១ និងការពន្យល់ ។ *ក្រុងស៊ីយ៉ូន* សូមមើលការពន្យល់ ៩:១១ ។
**ទដ ១៤៧** ជាការសរសើរដល់ព្រះអម្ចាស់ គឺជាព្រះអាទិករ និងជាព្រះយេហូវ៉ាលើគ្រប់ទាំងអស់ ដោយទ្រង់មានសេចក្តីមេត្តាករុណាដ៏ពិសេសមួយចំពោះរាស្ត្រអ៊ីស្រាអែល ។ គម្ពីរទដនេះក៏ជាការតែងនិពន្ធសម្រាប់ជាបទចម្រៀងលេវីវិន័យនាឱកាសនៃភាពអំណរពីសេចក្តីពុះពារ ចំពោះការសាងសង់កំផែងក្រុងយេរូសាឡិម (សូមមើល នហ ១២:២៧–៤៣) ។ ក៏ជាវគ្គកណ្ឌគម្ពីរសញ្ញាចាស់ជាភាសាក្រិក ក្នុងគ្រាគ្រីស្ទបរិស័ទសម័យដើមដំបូងមកគេអាចញែកកិច្ចការនិពន្ធនេះទៅជាបទទំនុកដាច់ៗពីគ្នាក្នុងវគ្គ (ខ.១–១១,១២–២០) ។ ទោះជាយ៉ាងណាវគ្គគម្ពីរទំនុកដំកើងនេះបានចងក្រងជាភាសាហេព្រើរជាមរតកវិញក៏មានឃើញក្នុងសេចក្តីផ្តើម (ខ.១) ដែលបង្ហាញពីភាពសប្បុរសរបស់ព្រះយេហូវ៉ា ចំពោះរាស្ត្រអ៊ីស្រាអែល ហើយគេបានរំឭកពីទ្រង់ (ខ.២–៣,១៩–២០) ជាផ្នែកតួសេចក្តីនៃផ្ទៃរឿងសំខាន់នៅតួរឿង(ខ.១០–១១)មានសេចក្តីបញ្ជាក់ពីសេចក្តីមេត្តាករុណាដ៏ពិសេសវិសាលរបស់ព្រះយេហូវ៉ា ចំពោះអស់អ្នកណាដែលពឹងផ្អែកផ្លូវជីវិតទៅលើព្រះអង្គទ្រង់ ជាជាងពឹងផ្អែកលើនិស្ស័យធម្មជាតិរបស់ពួកគេ ។ នៅក្នុងវគ្គគាថាដែលបង្កើតបានជាអត្ថន័យរួម (ខ.៤–៩,១២–១៨) ឯវគ្គកណ្តាលផ្ទៃរឿងក្នុងអត្ថបទដ៏ធំនេះចំពោះព្រះរាជកិច្ចរបស់ព្រះអម្ចាស់ និងផ្លូវរបស់ផងទ្រង់ សូមមើលសេចក្តីផ្តើម ទដ ១៤៦–១៥០ ។
**១៤៧:១** សូមមើលការពន្យល់ ១៣៥:៣ ។
**១៤៧:២** *សង់* ដោយយោងតាមការកត់ត្រាពីប្រវត្តិសាស្ត្រនាសម័យពួកយូដា

ទ្រង់កំពុងតែប្រមូលពួកសាសន៍អ៊ីស្រាអែលដែលត្រូវបំបរ
ទៅជាឈ្លើយ[យ]មកវិញ
៣ទ្រង់ប្រោសអស់អ្នកដែលមានចិត្តសង្រេង[ង]
ឱ្យបានជា ក៏រុំរបួសឱ្យគេផង[ច]
៤ទ្រង់រាប់ចំនួននៃអស់ទាំងផ្កាយ[ឆ]
ក៏ហៅបានតាមឈ្មោះទាំងអស់
៥ព្រះអម្ចាស់[ជ]នៃយើងខ្ញុំទ្រង់ធំប្រសើរ
ហើយមានឫទ្ធានុភាពក្រៃលែង[ឈ]
ឯប្រាជ្ញាញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់[ញ]
៦ព្រះយេហូវ៉ាទ្រង់ទប់ទល់មនុស្សរាបសា[ដ]
តែបង្រ្កាបពួកមនុស្សអាក្រក់[ឋ]ចុះដល់ដីវិញ
៧ចូរច្រៀងថ្វាយព្រះយេហូវ៉ា[ឌ] ដោយពាក្យអរព្រះគុណ[ឍ]
ចូរច្រៀងបទ[ណ]សរសើរដល់ព្រះនៃយើងខ្ញុំ
ដោយចាប់ស៊ុង[ត]
៨ទ្រង់បាំងមេឃដោយពពក[ថ] ក៏ចាត់ចែងភ្លៀង[ទ]សំរាប់
ផែនដី ហើយធ្វើឱ្យមានស្មៅដុះឡើង[ធ]នៅលើភ្នំ
៩ទ្រង់ប្រទានអាហារ[ន]ដល់សត្វទាំងប៉ុន្មានព្រមទាំងដល់កូន
ក្អែក[ប]ដែលយំផង
១០ទ្រង់មិនសព្វព្រះហឫទ័យនឹងកំឡាំង[ផ]នៃសេះទេ[ព]
ក៏មិនត្រូវការនឹងជើងមនុស្សដែរ
១១គឺព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ[ភ]តែនឹងអស់អ្នក
ដែលកោតខ្លាចទ្រង់[ម] ហើយនិងអស់អ្នកដែលសង្ឃឹម[យ]
ដល់សេចក្ដីសប្បុរសរបស់ទ្រង់ប៉ុណ្ណោះ[រ]
១២ឱក្រុងយេរូសាឡិមអើយ[ល] ចូរសរសើរដល់ព្រះយេហូវ៉ា
ឱក្រុងស៊ីយ៉ូនអើយ ចូរសរសើរដល់ព្រះនៃឯងចុះ
១៣ដ្បិតទ្រង់បានធ្វើឱ្យរនុកទ្វារ[វ]ឯងបានមាំមួនឡើង
ក៏បានប្រទានពរដល់កូនចៅ[ស]នៅកណ្ដាលឯងដែរ
១៤ទ្រង់ធ្វើឱ្យមានសេចក្ដីសុខ[ហ] នៅក្នុងដែនខេត្តរបស់ឯង
ទ្រង់ចំអែតឯង[ឡ] ដោយស្រូវសាលីយ៉ាងល្អបំផុត[អ]
១៥ទ្រង់ចាត់ព្រះរាជបញ្ជា[ក]មកលើផែនដី
ព្រះបន្ទូលទ្រង់ក៏រត់[ខ]លឿនណាស់ផង
១៦ទ្រង់ប្រទានហិមៈ[គ]មកឱ្យដូចជារោមចៀម

**១៤៧:២** យ ទដ ១០៦:៤៧ **១៤៧:៣** ង ទដ ៣៤:១៨ ច ជន ១២:១៣ យប ៥:១៨ អស ១:៦ អគ ៣៤:១៦ **១៤៧:៤** ឆ លប ១៥:៥ **១៤៧:៥** ជ ទដ ៤៨:១ ឈ នក ១៤:៣១ ញ ទដ ១៤៥:៣ អស ៤០:២៨ **១៤៧:៦** ដ ២រប ៣៣:២៣ ទដ ១៤៦:៨–៩ ឋ ទដ ៣៧:៩–១០ ១៤៥:២០ **១៤៧:៧** ឌ ទដ ៣០:៤ ៣៣:៣ ឍ ទដ ៤២:៤ ណ ទដ ២៧:៦ ត ទដ ៩៨:៥ **១៤៧:៨** ថ យប ២៦:៨ ទ ចទ ១១:១៤ ៣២:២ ២សយ ១:២១ យប ៥:១០ ធ យប ២៨:២៦ ទដ ១០៤:១៤ **១៤៧:៩** ន លប ១:៣០ ទដ ១០៤:២៧–២៨ មថ ៦:២៦ ប លប ៨:៧ **១៤៧:១០** ផ ១សយ ១៦:៧ ព យប ៣៩:១១ ទដ ៣៣:១៦–១៧ **១៤៧:១១** ភ ទដ ៣៥:២៧ ម ទដ ៣៣:១៨ ១០៣:១១ យ ទដ ១១៩:៤៣ រ ទដ ៦:៤ **១៤៧:១២** ល ទដ ៤៨:១ **១៤៧:១៣** វ ចទ ៣៣:២៥ ស លវ ២៥:២១ ទដ ១២៨:៥ ១៣៤:៣ **១៤៧:១៤** ហ លវ ២៦:៦ ២សយ ៧:១០ អស ៤៨:១៨ ឡ ទដ ១៣២:១៥ អ ចទ ៣២:១៤ **១៤៧:១៥** ក យប ៣៧:១២ ទដ ៣៣:៩ ១៤៨:៥ ខ អស ៥៥:១១ **១៤៧:១៦** គ ទដ ១៤៨:៨

និងបាប៊ីឡូន គឺជាការរបស់ក្រុងយេរូសាឡិមឡើងវិញ ។ *ត្រូវបំបរទៅជាឈ្លើយ* បានប្រែជាពាក្យភាសាហេព្រើរដែលមានន័យបង្កប់ គឺយើងឃើញក្នុង អស ១១:១០ ៥៦:៨ គឺជាគ្រប់សកម្មភាពនិយាយពីការប្រម៉ែប្រមូលពួកអ៊ីស្រាអែលឱ្យទទួលជីវិតថ្មី និងមានសេរីភាពឡើងវិញ ។

**១៤៧:៣** *មានចិត្តសង្រេង* គឺដូចជាពួកដែលត្រូវគេបំបរទៅជាឈ្លើយ (សូមមើល ទដ ១៣៧ ប្រៀបធៀប ទដ ១២៦) ហើយដូចជាអ្នកដែលបានពុះពារឧបស័គ្គដោយប្រឈរមុខនិងការធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង ក្នុងការសាងសង់កំផែងក្រុងយេរូសាឡិម (នហ ២:១៧–២០ ៤:១–២៣) ។

**១៤៧:៤–៦** ជាព្រះអង្គសង្រ្គោះដែលទ្រង់មានអំណាចចេស្ដា និងមានប្រាជ្ញាញាណ ។ ព្រះអម្ចាស់ទ្រង់អាចរាប់អស់ទាំងផ្កាយ ដែលមានទាំងអស់ហើយ ហើយដាក់ឈ្មោះឱ្យផ្កាយទាំងអស់ ហើយទ្រង់ក៏អាចជួយសង្រ្គោះ ឬទ្រទ្រង់មនុស្សអាក្រក់ឱ្យធ្លាក់ចុះបាក់ស្បាត (សូមមើល ២០:៨ ១៤៦:៩ អស ៤០:២៦–២៩) ។

**១៤៧:៦** *មនុស្សរាបសា* គឺអស់អ្នកដែលទទួលស្គាល់ពីសម្ពភាពខ្លួន និងពួកអ្នកដែលដឹងថាគេគ្មានប្រភពជំនួយឯណាដើម្បីដោះលែងពួកគេ ឬថែរក្សារពួកគេ គឺអ្នកដែលជារាស្ដ្ររបស់ទ្រង់ ដែលតែងតែពឹងផ្អែកលើទ្រង់១ប៉ុណ្ណោះ ហើយជាអ្នកដាក់សេចក្ដីទុកចិត្តក្នុងទ្រង់ជាព្រះយេហូវ៉ា (សូមមើល ១៤៩:៤ និងការពន្យល់ ២២:២៦ "មនុស្សទាល់ក្រ" ៣៧:១១ "ភាពញើបៗ" សូមមើលការពន្យល់ ៦៩:៣២ "មនុស្សទាល់ក្រ") ។ *ដី* គឺអាចសំដៅទៅលើផ្នូរខ្មោច (សូមមើលការពន្យល់ ៦១:២) ។

**១៤៧:៧–៩** ព្រះអម្ចាស់របស់រាស្ដ្រអ៊ីស្រាអែល គឺព្រះយេហូវ៉ាលើគ្រប់អស់ទាំងការបង្កើតទាំងអស់ទ្រង់ជាអង្គមួយ ដែលប្រទានឱ្យមានគ្រប់ទាំងរបស់របរសម្រាប់រស់នៅ ។

**១៤៧:១០–១១** ជាវគ្គមានពីរខមានអត្ថន័យដូចគ្នា (សូមមើល ៦:៦) ដែលស៊ីគ្នានឹង ខ.២–៣ និង ខ.១៩–២០ (សូមមើលសេចក្ដីផ្ដើមខាងលើ) ។ ព្រោះពួកមានអំណាចបុណ្យស័ក្តិនៅក្នុងនគរលោកិយនេះ គេពុំបានចាប់អារម្មណ៍ចំពោះព្រះអម្ចាស់របស់រាស្ដ្រអ៊ីស្រាអែលឡើយ (សូមធៀបនឹង ១៤៦:៣–៤ និងការពន្យល់) ។ ដែលជាហេតុនាំឱ្យព្រះអម្ចាស់ពុំសព្វព្រះហឫទ័យនឹងពួកគេទាំងនោះ ។ តែទ្រង់សព្វព្រះហឫទ័យខណៈណាពួកគេបានពឹងផ្អែកលើទ្រង់ លើគ្រប់ទាំងផ្លូវជីវិតរបស់ពួកគេ គឺគេនិងក្លាយជារាស្ដ្ររបស់ផងទ្រង់ (ប្រៀបធៀប ១៤៦:៥–៩) ។

**១៤៧:១១** *កោតខ្លាច* សូមមើលការពន្យល់ ៣៤:៨–១៤ ។ *សេចក្ដីសប្បុរស* សូមមើលការពន្យល់ ៦:៤ ។

**១៤៧:១២–១៨** ព្រះយេហូវ៉ាជាព្រះលើគ្រប់ទាំងអស់ ក៏ជាព្រះអម្ចាស់នៃក្រុងស៊ីយ៉ូនទ្រង់ផ្ដល់សន្តិសុខជូនរាស្ដ្រទ្រង់ ការពារឱ្យរាស្ដ្រទ្រង់មានសន្តិភាព និងមានពេញជាបរិបូរ ។ ឯខគម្ពីរទាំងនោះបង្ហាញពីពពក និងភ្លៀង (ខ.៨) ក៏មានព្រឹល ទឹកសន្សើម (ខ.១៦–១៧) ក៏មានខ្យល់នាំមកទឹកកក និងអាកាសធាតុក្ដៅល្មមដែរ គឺខ្យល់ត្រជាក់ល្មម (ខ.១៧–១៨) ។

**១៤៧:១៥** *ព្រះរាជបញ្ជា . . . ព្រះបន្ទូលទ្រង់* បង្ហាញពីលក្ខណៈអង្គទ្រង់ដែលទទួលព្រះរាជកិច្ចជាអ្នកនាំសារ ជាព្រះបន្ទូលមកពីស្ថានសួគ៌ ជាព្រះរាជបេសកកម្មដើម្បីអនុវត្តន៍នូវច្បាប់ស្ថានសួគ៌ (សូមមើល ខ.១៨ និងការពន្យល់ ២៣:៦ ៣៣:៤ ១០៤:៤) ។

កំបាចសាចសន្សើម[ឃ] មកដូចជាផេះ
១៧ ទ្រង់បោះទឹកកក[ង] របស់ទ្រង់មកជាដុំៗ
តើមានអ្នកណានឹងទ្រាំចំពោះពេលរងាររបស់ទ្រង់បាន
១៨ ទ្រង់បញ្ចេញព្រះបន្ទូល[ច] ទៅរំលាយទាំងអស់វិញ
ទ្រង់ធ្វើឱ្យខ្យល់របស់ទ្រង់បក់មក[ឆ] នោះទឹកក៏ហូរ
១៩ ទ្រង់សំដែងព្រះបន្ទូល[ជ] ដល់យ៉ាកុប[ឈ] ហើយបញ្ញត្តិ
និងច្បាប់[ញ] របស់ទ្រង់ ដល់អ៊ីស្រាអែល
២០ ទ្រង់មិនដែលប្រព្រឹត្តនឹងសាសន៍ណាទៀតយ៉ាងនោះ
ឡើយ[ដ] ឯច្បាប់ទាំងប៉ុន្មានរបស់ទ្រង់ គេមិនបានស្គាល់[ឋ]
ទេចូរសរសើរដល់ព្រះយេហូវ៉ាចុះ[ឌ] ។

**១៤៨** ចូរសរសើរដល់ព្រះយេហូវ៉ា[ក] ចូរសរសើរដល់
ព្រះយេហូវ៉ាពីលើស្ថានសួគ៌[ខ] ចូរសរសើរដល់ទ្រង់នៅ
អស់ទាំងទីដ៏ខ្ពស់
២ អស់ទាំងទេវតានៃទ្រង់អើយ ចូរសរសើរដល់ទ្រង់[គ] អស់
ទាំងពួកពលបរិវារទ្រង់អើយ[ឃ] ចូរសរសើរដល់ទ្រង់ចុះ
៣ ព្រះអាទិត្យ[ង] និងព្រះចន្ទអើយ ចូរសរសើរដល់ទ្រង់
អស់ទាំងផ្កាយដែលភ្លឺអើយ ចូរសរសើរដល់ទ្រង់
៤ ផ្ទៃមេឃ នៃអស់ទាំងជាន់ផ្ទៃមេឃ[ច] អើយ
ចូរសរសើរដល់ទ្រង់ចុះ ហើយឯងដែរ អស់ទាំងទឹកដែល
នៅពីលើមេឃទៅទៀតនោះ[ឆ]
៥ គួរឱ្យគ្រប់គ្នាសរសើរដល់ព្រះនាម[ជ] ព្រះយេហូវ៉ា
ដ្បិតទ្រង់បានចេញបង្គាប់[ឈ] ហើយរបស់ទាំងនោះបាន
កើតមក
៦ ទ្រង់បានតាំងរបស់ទាំងនោះឱ្យនៅអស់កល្បជានិច្ចទ្រង់
បានដាក់ច្បាប់ហើយ ជាច្បាប់[ញ] ដែលរបស់ទាំងនោះ
និងមិនប្រព្រឹត្តរំលងឡើយ
៧ ចូរសរសើរដល់ព្រះយេហូវ៉ា[ដ] ពីផែនដីដែរ នែ អស់ទាំង
សត្វសំបើម[ឋ] នៅក្នុងសមុទ្រ និងទីជំរៅទាំងប៉ុន្មាន[ឌ]
៨ អស់ទាំងភ្លើង និងព្រឹល[ឍ] ហិមៈ និងចំហាយទឹក
ទាំងខ្យល់ព្យុះ ដែលសំរេចតាមព្រះបន្ទូលទ្រង់[ណ]
៩ ព្រមទាំង ភ្នំធំតូចទាំងអស់[ត] ដើមឈើដែលមានផ្លែ
និងដើមតាត្រៅទាំងប៉ុន្មាន
១០ គ្រប់ទាំងសត្វព្រៃ[ថ] សត្វស្រុក សត្វលូនវារ និងសត្វស្លាប
១១ អស់ទាំងស្តេច[ទ] នៅលើផែនដី និងបណ្តាជន
ទាំងឡាយពួកអ្នកធំៗ និងពួកចៅក្រមនៅផែនដី
១២ ទាំងមនុស្សកំឡោះ និងស្រីក្រមុំ ទាំងចាស់ទាំងក្មេង
អើយ
១៣ ត្រូវឱ្យទាំងអស់សរសើរដល់ព្រះនាមព្រះយេហូវ៉ាចុះ[ធ]
ដ្បិត មានតែព្រះនាមទ្រង់១ដែលខ្ពស់ប្រសើរសិរីល្អ[ន]

**១៤៧:១៦** ឃ យប ៣៧:១២ ៣៨:២៩ **១៤៧:១៧** ង នក ៩:២២–២៣ យប ៣៨:២២ ទដ ៧៨:៤៧ **១៤៧:១៨** ច ខ.១៥ ទដ ៣៣:៩ ១០៧:២០ ឆ ទដ ៥០:៣ **១៤៧:១៩** ជ នក ២០:១ រម ៣:២ ឈ ទដ ៧៨:៥ ញ ចទ ៣៣:៤ យស ១:៨ ២ពវ ២២:៨ មឡ ៤:៤ រម ៩:៤ **១៤៧:២០** ដ ចទ ៤:៧–៨,៣២–៣៤ ឋ ទដ ៧៩:៦ ឌ ទដ ៣៣:២ ១០៣:១ **១៤៨:១** ក ទដ ៣៣:២ ១០៣:១ ខ ទដ ១៩:១ ៦៩:៣៤ ១៥០:១ **១៤៨:២** គ ទដ ១០៣:២០ ឃ ១ពវ ២២:១៩ **១៤៨:៣** ង ទដ ១៩:១ **១៤៨:៤** ច ចទ ១០:១៤ ឆ លប ១:៧ **១៤៨:៥** ជ ទដ ១៤៥:២១ ឈ ទដ ១៤៧:១៥ **១៤៨:៦** ញ យរ ៣១:៣៥–៣៦ ៣៣:២៥ **១៤៨:៧** ដ ទដ ៣៣:២ ឋ លប ១:២១ ទដ ៧៤:១៣–១៤ ឌ ចទ ៣៣:១៣ **១៤៨:៨** ឍ នក ៩:១៨ យស ១០:១១ ណ យប ៣៧:១១–១២ ទដ ១០៣:២០ ១៤៧:១៥–១៨ **១៤៨:៩** ត អស ៤៤:២៣ ៤៩:១៣ ៥៥:១២ **១៤៨:១០** ថ អស ៤៣:២០ ហស ២:១៨ **១៤៨:១១** ទ ទដ ១០២:១៥ **១៤៨:១៣** ធ ទដ ១១៣:២ ១៣៨:៤ ន ទដ ១៤៥:៥

**១៤៧:១៩–២០** គឺជាអំណោយទានគ្មានពីរពិសេសបំផុត ដែលមនុស្សលោកអាចមានមកពីព្រះអម្ចាស់សម្រាប់រាស្ត្រអ៊ីស្រាអែល គឺជាព្រះបន្ទូលដ៏មានសណ្តាបធ្នាប់ ជាព្រះបន្ទូលដ៏ប្រោសលោះរបស់ទ្រង់ ដែលទ្រង់បំណងផែនការណ៍ក្នុងការសង្គ្រោះមនុស្សលោក គឺជាព្រះទ័យដ៏បរិសុទ្ធរបស់ទ្រង់ ។ ឯខគម្ពីរទាំងនេះបានផ្តល់ជាសាច់រឿងពេញ ដូចជា ខ.២–៣,១០–១១ (សូមមើលសេចក្តីផ្តើម ផ្នែកខាងលើនិងការពន្យល់ត្រង់ ខ.១០–១១) ។

**ទដ ១៤៨** គឺជាវគ្គអំពាវនាវដល់គ្រប់អ្វីៗទាំងអស់ និងសត្វមានជីវិតទាំងអស់ក្នុងការដែលទ្រង់បានបង្កើតដើម្បីសរសើរតម្កើងដល់ព្រះយេហូវ៉ា ។ ក៏ដូចជាទិសដៅក្នុងការសម្តែង ការសញ្ជឹងទៅរកព្រះជាការអធិស្ឋាន ជាបទទំនុកដំកើងការបង្ហាញឱ្យឃើញនូវបទចំរៀង គឺក្នុងវគ្គពាក់កណ្តាល ដើម្បីបញ្ចប់ពីការអំពាវនាវសរសើរតម្កើង ដែលអ្នកនិពន្ធបានបញ្ចប់ (សូមមើលសេចក្តីផ្តើម ទដ ១៤៦–១៥០) ។ ក៏មានវគ្គគាថាពីរដែលបានសរសេរឡើងមានលក្ខណៈស្រដៀងគ្នា ដែលអំពាវនាវដល់អស់ទាំងធម្មជាតិនៅឯស្ថានសួគ៌ និងជីវិតសត្វដែលនៅក្រោមស្ថានសួគ៌ឱ្យចូលរួមលើកជាបទទំនុកចម្រៀងដើម្បីសរសើរតម្កើងដល់ព្រះយេហូវ៉ា ដែលជាព្រះអាទិករលើគ្រប់ទាំងអស់ (ខ.១–៦,៧–១៤ ១០៣:២០–២២ និងការពន្យល់) ។

**១៤៨:១–៦** ជាការកំណត់ឱ្យជីវិតទាំងអស់នៅស្ថានសួគ៌សរសើរតម្កើងដល់ព្រះយេហូវ៉ា ។

**១៤៨:២** ជាការអំពាវនាវដល់ពួកពលបរិវានៅឯស្ថានសួគ៌ ឱ្យសរសើរតម្កើងដល់ព្រះយេហូវ៉ា សូមមើល ១០៣:២១ និងការពន្យល់ ។

**១៤៨:៣** *ព្រះអាទិត្យ និងព្រះចន្ទអើយ . . . ផ្កាយដែលភ្លឺអើយ* សូមមើលការពន្យល់ ៦៥:១៣ ។

**១៤៨:៤** *ទឹកដែលនៅពីលើមេឃ* (សូមមើល លប ១:៧ ធៀបនឹង"ជម្រៅទឹកសមុទ្រ" ខ.៧ និងការពន្យល់ ៤២:៧) ។

**១៤៨:៥–៦** ជាការជម្រុញឱ្យគ្រប់ទាំងជីវិតនៅឯស្ថានសួគ៌ សរសើរដល់ព្រះយេហូវ៉ា (ធៀប ខ.១៣–១៤) ។

**១៤៨:៥,១៣** *ព្រះនាមព្រះយេហូវ៉ា* សូមមើលការពន្យល់ ៥:១១ ។ ពួកគេទាំងអស់បានសរសើរតម្កើងដល់ព្រះយេហូវ៉ា ពីព្រោះទ្រង់បានបង្កើតពួកគេ និងធ្វើឱ្យពួកគេមានសុវត្ថិភាព និងមានជីវិតរស់នៅ ។

**១៤៨:៧** *អស់ទាំងសត្វសំបើមនៅក្នុងសមុទ្រ និងទីជំរៅទាំងប៉ុន្មាន* មានដូជា លប ជំពូក ១ (សូមមើល លប ១:៧,១០,២១) គឺគ្រប់ទាំងសត្វលូនវារលើគោក សត្វក្នុងទឹក និងសត្វហើលើអាកាស គឺសុទ្ធតែទ្រង់បង្កើតរួមទាំងមនុស្សផង ។

**១៤៨:៨** (សូមមើល ១៤៧:១៥ និងកាពន្យល់) គឺគ្រប់ទាំងធម្មជាតិត្រូវសម្រេចតាមព្រះបន្ទូលរបស់ទ្រង់ជាអ្នកកំណត់ ។

**១៤៨:១៣–១៤** គឺជាសេចក្តីបញ្ចប់ដែលប្រកបឧត្តមគតិ ដែលផ្តោតទៅលើ

នៃទ្រង់ខ្ពស់ជាងផែនដី និងផ្ទៃមេឃទៅទៀត[ប]
១៤ ទ្រង់បានលើកស្នែងរបស់រាស្ត្រទ្រង់ឡើង[ផ]
ទ្រង់ជាទីសរសើរ[ព]នៃអស់ទាំងពួកអ្នកបរិសុទ្ធ[ភ]របស់ទ្រង់
គឺរបស់ជនជាតិអ៊ីស្រាអែលជាសាសន៍ដែលនៅជិតដិតនឹង
ទ្រង់ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ[ម] ។

**១៤៩** ចូរសរសើដល់ព្រះយេហូវ៉ា[ក]ចូរច្រៀងបទ១ថ្មី[ខ]
ថ្វាយព្រះយេហូវ៉ាព្រមទាំងសេចក្តីសរសើរពីទ្រង់នៅក្នុង
ជំនុំ[គ]នៃពួកបរិសុទ្ធផង
២ គួរឱ្យពួកអ៊ីស្រាអែលរីករាយ[ឃ]ឡើងក្នុងព្រះដែលបង្កើត[ង]
ខ្លួន គួរឱ្យពួកកូនចៅនៃក្រុងស៊ីយ៉ូនបានត្រេកអរក្នុង
មហាក្សត្ររបស់ខ្លួន[ច]
៣ គួរឱ្យគេសរសើរព្រះនាមទ្រង់ ដោយលោតកញ្ឆេង[ឆ]
គួរឱ្យគេច្រៀងសរសើរទ្រង់ ដោយក្រាប់នឹងស៊ុង[ជ]
៤ ដ្បិតព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ[ឈ]នឹងរាស្ត្រទ្រង់
ទ្រង់តាក់តែងមនុស្សរាបសា ដោយសេចក្តីសង្គ្រោះ[ញ]
៥ គួរឱ្យពួកអ្នកបរិសុទ្ធរីករាយឡើង[ដ]ក្នុងសិរីល្អ គួរឱ្យគេ
ច្រៀងដោយអំណរកំពុងដែលដេកនៅក្នុងដំណេកខ្លួន[ឋ]
៦ គួរឱ្យមានសេចក្តីសរសើរយ៉ាងប្រសើរពីព្រះនៅក្នុង
មាត់គេ[ឌ] និងដាវមានមុខ២[ឍ] នៅដៃគេដែរ[ណ]
៧ ដើម្បីនឹងសំរេចការសងសឹក[ត]ដល់សាសន៍ដទៃទាំងប៉ុន្មាន
និងការវាយផ្ចាល[ថ] ដល់បណ្តាជនទាំងឡាយ
៨ ប្រយោជន៍នឹងដាក់ច្រវាក់[ទ]ដល់ពួកស្តេចគេ និងខ្នោះដែក

**១៤៨:១៣** ប ទដ ៨:១ **១៤៨:១៤** ផ ១សយ ២:១ ព នក ១៥:២ ទដ ២២:៣ ភ ទដ ១៤៥:១០ ម ចទ ២៦:១៩ **១៤៩:១** ក ទដ ៣៣:២ ១០៣:១ ខ ទដ ២៨:៧ ៩៦:១ វវ ៥:៩ គ ទដ ១:៥ **១៤៩:២** ឃ អស ១៣:៣ យរ ៥១:៤៨ ង យប ១០:៣ ទដ ៩៥:៦ អស ៤៤:២ ៤៥:១១ ៥៤:៥ ច ទដ ១០:១៦ ៤៧:៦ អស ៣២:១ សក ៩:៩ **១៤៩:៣** ឆ នក ១៥:២០ ជ ទដ ៥៧:៨ **១៤៩:៤** ឈ ទដ ៣៥:២៧ ១៤៧:១១ ញ ទដ ១៣២:១៦ **១៤៩:៥** ដ ទដ ១៣២:១៦ ឋ យប ៣៥:១០ ទដ ៤២:៨ **១៤៩:៦** ឌ ទដ ៦៦:១៧ ឍ ហព ៤:១២ វវ ១:១៦ ណ នហ ៤:១៧ **១៤៩:៧** ត ជន ៣១:៣ ចទ ៣២:៤១ ថ ទដ ៨១:១៥ **១៤៩:៨** ទ ២សយ ៣:៣៤ អស ១៤:១–២

ការសរសើរតម្កើងសាជាថ្មីម្តងទៀត (ប្រៀបធៀប ខ.៥–៦) ។

**១៤៨:១៣** *ព្រះនាមព្រះយេហូវ៉ា . . . ខ្ពស់ប្រសើរ* ដូចជាការដែលបានបង្ហាញក្នុងសេរីល្អពីការបង្កើតរបស់ទ្រង់ ។ *ខ្ពស់ជាង* ដោយសិរីល្អនៃព្រះអាទិករមានភាពអស្ចារ្យជាងសិរីល្អនៃការបង្កើត ។

**១៤៨:១៤** *ស្នែង* គឺព្រះបានចាត់ប្រេងតាំង (សូមមើលការពន្យល់ ២:២ ទដ ១៨ ជាចំណងជើង) ពាក្យថាស្នែងដែលបង្ហាញនៅទីនេះ គឺសំដៅលើកម្លាំង និងអំណាចចេស្តារបស់រាស្ត្រទ្រង់ (សូមមើល ៩២:១០ ១សយ ២:១ យរ ៤៨:២៥ បទ ២:១៧) ។ ក្នុងព្រឹត្តិការណ៍ខ្លះពាក្យថា "ស្នែង" នេះគឺសំដៅទៅលើព្រះរាជកិច្ចដែលទ្រង់ត្រៀមសម្រាប់រាស្ត្រអ៊ីស្រាអែល ។ ដោយព្រះអម្ចាស់ត្រូវបានគេសរសើរចំពោះព្រះរាជកិច្ចរបស់ទ្រង់ ក្នុងការបង្កើតអ្វីៗទាំងអស់ និងការប្រោសលោះ (សូមមើលការពន្យល់ ៦៥:៦–៧) ។ *ជាទីសរសើរ* សូមមើល ២២:៣ និងការពន្យល់ ។

**ទដ ១៤៩** ខនេះជាវគ្គសរសើរតម្កើងដល់ព្រះអម្ចាស់ ដោយសេចក្តីគោរពកោតខ្លាច ដោយព្រោះទ្រង់មានសេចក្តីសប្បុរសចំពោះរាស្ត្រអ៊ីស្រាអែល ។ ភាពសុចរិតទៀងត្រង់របស់រាស្ត្រអ៊ីស្រាអែលមានពីផ្នែក : គឺរាស្ត្រអ៊ីស្រាអែល ទទួលបានសេចក្តីសង្គ្រោះ (ដូចមានក្នុងព្រះបន្ទូលសន្យា) និងមួយទៀត គឺស្ថិតក្រោមការគ្រប់គ្រងដ៏សុខសាន្តរបស់ព្រះអម្ចាស់ គឺជាសេចក្តីសញ្ញានៅលើភ្នំស៊ីណាយ ដែលព្រះយេហូវ៉ាប្រគលមកយើងរាលគ្នា (សូមមើល ជំពូក ១៨) ហើយជាពេលដែលព្រះបានមកជំនុំជម្រះចំពោះអំណាចរបស់លោកកិយ ដែលពួកគេមានអំណាចនៅលោកិយនោះក៏កំពុងទាស់ប្រឆាំងនឹងនគររបស់ព្រះ ។ ដោយសាររាស្ត្រអ៊ីស្រាអែលបានបម្រើព្រះ គឺមានតួនាទីជាទាហានរបស់នគរស្ថានសួគ៌ មើល ៦៨:១៧ និងការពន្យល់ ។ (យស ៥:១៤ ២យស ៥:២៣–២៤ ២រប ២០:១៥–១៧,២២) ។ ឯបទទំនុកដំកើងចុងក្រោយ គឺក្នុង ទដ ជំពូក ២ និងសេចក្តីផ្តើម ទដ ១៤៦–១៥០ ។ ឯវគ្គបន្តទៀតមានខដែលជាពាក្យផ្តើមចំពោះផ្ទៃរឿងសំខាន់ៗពីរ ដែលសរសេរតាមបែបគាថាស្រដៀងគ្នាពីរវវាងចន្លោះ ៤ខម្តង គឺសំដៅលើពួកអ្នក "ជាសង្ឃ" របស់ព្រះអម្ចាស់ (សូមមើល ខ.៥) ។ ពាក្យថា "សេចក្តីសុចរិត" និងពាក្យ "សិរីល្អ" (ខ.៩) ក៏មានទំនាក់ទំនងវគ្គគាថាពីរ (សូមមើល ៨:៥ ២១:៥,១១ សរីល្អ ព្រះតេជះ ១០៤:១,៣១ ១៤៥:៥,១២ អស ៣៥:២) ។

**១៤៩:១** *បទ១ថ្មី* សូមមើលការពន្យល់ ៣៣:៣ ។ *សេចក្តីសរសើរពីទ្រង់* សូមមើលការពន្យល់ ៩:១ ។ *អ្នកបរិសុទ្ធ* មើល ខ.៥,៩ និងការពន្យល់ ៤:៣ ។

**១៤៩:២–៥** ជាការសរសើរចំពោះអ៊ីស្រាអែលចំពោះព្រះមហាក្សត្ររបស់ពួកគេដែលពួកគេបានបំពាក់មកុដរាជ្យ ឱ្យសោយរាជប្រកបដោយសេចក្តីសុចរិតនៃការសង្គ្រោះ ។

**១៤៩:៣** *ព្រះនាមទ្រង់* សូមមើលការពន្យល់ ៥:១១ ។

**១៤៩:៤** *ទ្រង់តាក់តែងមនុស្សរាបសា* ជាអំណោយប្រកបដោយភាពរុងរឿង (សូមមើល អស ៥៥:៥ ៦០:៩ ៦១:៣) ។ *មនុស្សរាបសា* គឺជាមនុស្សព្រមទទួលស្គាល់ថា ពួកគេជាមនុស្សដែលគ្មានទីពឹង (សូមមើល ១៤៧:៦) ។

**១៤៩:៥** *ដេកនៅដំណេកខ្លួន* គឺជាសេចក្តីសង្គ្រោះ (ខ.៤) ដោយមានលក្ខណៈជាក់ស្តែងក្នុងបទចំរៀងពីការអំពាវនាវនាពេលថ្ងៃរះ តែត្រូវគេសរសើរនាពេលយប់ (សូមមមើល ៤២:៨ ៦៣:៦ ៧៧:៦) ។

**១៤៩:៦–៩** ជាការអំពាវនាវឱ្យពួកអ៊ីស្រាអែលសរសើរព្រះអម្ចាស់របស់ពួកគេជាអង្គដែលបានប្រទានឱ្យពួកគេនូវិសរីល្អជាដាវទុកដូចជាទាហានរបស់ទ្រង់ (ប្រៀបធៀប ទដ ១៣៧ ១៣៩:១៩–២២ អម ៩:១២ អគ ៣៨–៣៩ ដយ ២:៤៤ ៧:២២,២៦–២៧) ។

**១៤៩:៧** *ការសងសឹក* គឺជាព្រះរាជកិច្ចដែលតម្រូវឱ្យសងសឹកដល់អស់អ្នកដែលប្រឆាំងនិងនគររបស់ទ្រង់ ។ គឺជាការកាត់ទោសពីព្រះ ដែលបានឃើញជាច្រើននៅក្នុងព្រះគម្ពីរសញ្ញាចាស់ ៥៨:១០ ៧៩:១០ ៩៤:១ ជន ៣១:២ ចទ ៣២:៣៥,៤១,៤៣ ២ពវ ៩:៧ អស ៣៤:៨ ៣៥:៤ ៤៧:៣ ៥៩:១៧ ៦១:២ ៦៣:៤ យរ ៤៦:១០ ៥០:១៥,២៨ ៥១:៦,១១,៣៦ អគ ២៥:១៤,១៧ មីក ៥:១៥ ណាហ ១:២ ។ ឯក្នុងគ្រាសញ្ញាថ្មីរាស្ត្ររបស់ទ្រង់បានបំពាក់ដោយដាវនៃព្រះវិញ្ញាណដើម្បីយកជ័យជម្នះលើពួកវិញ្ញាណមានអំណាចលើលោកិយ ដែលបានប្រឆាំងនិងនគរព្រះ (សូមមើល ២កថ ៦:៧ ១០:៤ អភ ៦:១២,១៧ ហព ៤:១២) ។ ជាការចូលរួមរបស់ពួកគេពីការកាត់ទោសរបស់ព្រះអម្ចាស់ទៅលើលោកិយទាំងមូល ក៏រងចាំរហូតដល់ការជំនុំជម្រះជាចុងក្រោយ (សូមមើល ១កថ ៦:២–៣) ។

ដល់ពួកអ្នកមានត្រកូលខ្ពស់របស់គេដែរ[ធ]
៩ដើម្បីនឹងសំរេចការវិនិច្ឆ័យដល់គេ[ន] ដូចជាបានកត់ទុក
ហើយការនេះជាកិត្តិយសដល់ពួកអ្នកដែលបរិសុទ្ធ[ប]របស់
ទ្រង់ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។

**១៥០** ចូរសរសើរដល់ព្រះយេហូវ៉ា[ក]
ចូរសរសើដល់ព្រះ នៅក្នុងទីបរិសុទ្ធរបស់ទ្រង់[ខ]
ចូរសរសើរដល់ទ្រង់ នៅចន្លោះអាកាសជាទីសំដែង
ព្រះចេស្តាទ្រង់[គ]
២ចូរសរសើរដល់ទ្រង់ ដោយព្រោះការឥទ្ធិឫទ្ធិរបស់ទ្រង់[ឃ]
ចូរសរសើរដល់ទ្រង់ ឱ្យសមនឹងសណ្ឋានដ៏ធំប្រសើររបស់
ទ្រង់[ង]
៣ចូរសរសើរទ្រង់ដោយសូរត្រែ[ច] ចូរសរសើរដល់ទ្រង់
ដោយដេញពិណ និងចាប់ស៊ុង[ឆ]
៤ចូរសរសើរដល់ទ្រង់ដោយវាយក្រាប់
ហើយលោតកញ្ឆេង[ជ] ចូរសរសើរទ្រង់ដោយប្រដាប់មាន
ខ្សែ[ឈ] ហើយនិងខ្លុយ[ញ]
៥ចូរសរសើរដល់ទ្រង់ដោយវាយឈឹងឱ្យឮរងំ[ដ]
ចូរសរសើរទ្រង់ដោយវាយឈឹងឮសូររំពង
៦គួរឱ្យជីវិតទាំងឡាយ[ឋ]ដែលមានដង្ហើមបានសរសើរដល់
ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។

**១៤៩:៨** ធ ២រប ៣៣:១១
**១៤៩:៩** ន ចទ ៧:១ អគ ២៨:២៦ ប ទដ ១៤៥:១០
**១៥០:១** ក ទដ ១១២:១ ខ ទដ ៦៨:២៤–២៦ ៧៣:១៧ ១០២:១៩ គ ទដ ១៤៨:១
**១៥០:២** ឃ ចទ ៣:២៤ ង នក ១៥:៧
**១៥០:៣** ច ជន ១០:២ ឆ ទដ ៥៧:៨
**១៥០:៤** ជ នក ១៥:២០ ឈ ទដ ៤៥:៨ ញ លប ៤:២១ **១៥០:៥** ដ ២សយ ៦:៥
**១៥០:៦** ឋ ទដ ១០៣:២២

**១៤៩:៩** *សំរេចការវិនិច្ឆ័យដល់គេដូចជាបានកត់ទុកហើយ* គឺជាការជំនុំជម្រះកាត់ទោសយ៉ាងតឹងរឹងរបស់ព្រះអម្ចាស់ (មើល ១៣៩:១៦ និងការពន្យល់) ។
**ទដ ១៥០** គឺជាវគ្គសរសើរដល់ព្រះយេហូវ៉ាចុងក្រោយបង្អស់ ដែលប្រែពីភាសាហេព្រើរមានន័យថា ហាលេលូយ៉ា អ្នកនិពន្ធបទទំនុកដំកើងបាននិពន្ធឃ្លាសរសើដំកើងដល់ព្រះយេហូវ៉ា គឺដើម្បីបញ្ចប់ការសរសើរដំកើង ។ សូមមើលវគ្គបញ្ចប់តាមរយៈកណ្ឌគម្ពីរ៤ដំបូង ៤១:១៣ ៧២:១៨–១៩ ៨៩:៥២ ១០៦:៤៨ ។ វគ្គអំពាវនាវចុងក្រោយដើម្បីសរសើរតម្កើងសូមឱ្យព្រះយេហូវ៉ាធ្វើការក្នុងចិត្តដោយពឹងផ្អែលើអំណាចចេស្តារបស់ទ្រង់ តាមរយៈរកភ្លេងនៃទំនុក និងការសរសើរដល់ព្រះយេហូវ៉ាដោយស្រែកថា ហាលេលូយ៉ា ។ សូមមើលសេចក្តីផ្តើម ទដ ១៤៦–១៥០ ។
**១៥០:១** ជាវគ្គបង្ហាញពីទីកន្លែងដែលយើងជ្រើសរើសមកសរសើរតម្កើងដល់ព្រះ ។ *នៅក្នុងទីបរិសុទ្ធរបស់ផងទ្រង់* គឺនៅឯក្រុងយេរូសាឡិម ។ *ចន្លោះអាកាសជាទីសំដែងព្រះចេស្តាទ្រង់* តាមបែបអក្សរសាស្ត្រមានន័យថា "ជាទីដែលទ្រង់ពង្រីកអំណាចព្រះចេស្តា" (សូមមើល ១៩:១ "អាកាស" លប ១:៦) ពោលគឺទ្រង់ពង្រីកនូវការបើកសម្តែង ឬបង្ហាញពីនិមិត្តរូបពីអំណាចព្រះចេស្តារបស់ទ្រង់ មានតាំងនៅស្ថិតថេរជានិច្ច ជាពិសេសតាមរយៈព្រះវិហារ នៅឯស្ថានសួគ៌របស់ព្រះអម្ចាស់ (សូមមើល ១១:៤) ។
**១៥០:២** ហេតុដែលយើងត្រូវសរសើរដល់ព្រះអម្ចាស់ ។ *ដោយព្រោះការឥទ្ធិឫទ្ធិរបស់ទ្រង់* ដោយអ្វីៗដែលទ្រង់បានធ្វើនោះ (មានក្នុងការបង្កើត និងការប្រោសលោះ) ។ *សណ្ឋានដ៏ធំប្រសើរបស់ទ្រង់* តើទ្រង់ជាអង្គណា ។
**១៥០:៣–៥** តើយើងត្រូវសរសើរតម្កើតព្រះដោយរបៀបណា ឬក៏សរសើរដោយលើកជាបទភ្លេងឡើង (ឧបករណ៍ទាំងបី : ខ្យល់ ខ្សែ ការគោះ) ដោយលោតរាំនៅកណ្តាលទីបរិសុទ្ធ ។
**១៥០:៦** តើអ្នកណាដែលត្រូវតែសរសើរដល់ព្រះ ។ ជាក្រុមគ្រីស្ទបរិស័ទដែលបញ្ចេញវោហារស្រែកយ៉ាងខ្លាំង ដើម្បីផ្លែងពីការដែលព្រះមានគ្រប់ទាំងព្រះចេស្តា និងភាពសុចរិតរបស់ទ្រង់ ។

# ព្រះគម្ពីរសុភាសិត

## សេចក្តីផ្តើម

### អ្នកនិពន្ធ

ទោះជាកណ្ឌគម្ពីរនេះ បានចាប់ផ្តើមដោយឈ្មោះស្តេចសាឡូម៉ូនដែលនាំឱ្យយើងសន្មតថា គឺជាសុភាពសិតរបស់ស្តេចសាឡូម៉ូន ក៏ដោយ ក៏វាបានបង្ហាញកាន់តែច្បាស់ថែមទៀតតាមរយៈជំពូកក្រោយៗ ដែលបង្ហាញថា ទ្រង់មិនមែនជាអ្នកនិពន្ធតែម្នាក់ឯងនោះទេ ។ សភ ២២:១៧ "ដោយយោងទៅតាមពាក្យពំនោលរបស់អ្នកប្រាជ្ញ" និងមើល ២៤:២៣ ក៏បានបញ្ជាក់បន្ថែម "នូវពាក្យពោលទុក (ពាក្យពំនោល) របស់អ្នកប្រាជ្ញ" ។ ចំពោះសេចក្តីផ្តើមក្នុង ២២:១៧-២១ បានបង្ហាញបញ្ជាក់បន្ថែមទៀតថា វគ្គទាំងនេះមានប្រភព ឬមកពីអ្នកប្រាជ្ញ មិនមែនជាស្តេចសាឡូម៉ូនទេ ។ ជំពូក ៣០ ក៏បានសន្មត់ចំពោះពាក្យរបស់អេគើរជាកូនយ៉ាកេ និង ៣១:១៩ គឺចំពោះស្តេចលេមយួលក៏មានបង្ហាញនៅកន្លែងផ្សេងៗទៀតដែរ ។ ឯពាក្យពោលទុករបស់ស្តេចលេមយួល ដែលបានសរសេរឡើងជាភាសាអេរ៉ាមជាច្រើនឃ្លានោះ គឺបង្ហាញថាអ្នកនិពន្ធមិនមែនមានប្រវត្តិ ឬប្រភពចេញពីប្រជាជនអ៊ីស្រាអែលទេ ។

ម្យ៉ាងវិញទៀយកណ្ឌគម្ពីរភាគច្រើនបង្ហាញពីភាពមានទំនាក់ទំនងច្រើនជាមួយស្តេចសាឡូម៉ូន ។ សារបាន (ក្បាលរឿង) នៅក្នុង ១០:១ និង ២៥:១ ក្នុងនោះក៏បានបញ្ចូលព្រះនាមទ្រង់ដែរ ២៥:១ ថ្លែងបញ្ជាក់ថា ពាក្យសុភាសិត ឬគម្ពីរសុភាសិត "ត្រូវបានគេចងក្រងឡើងវិញ ដោយមនុស្សជាច្រើនរបស់ស្តេចហេសេគាលនៃស្រុកយូដា" ការនេះបង្ហាញបញ្ជាក់ថា មានក្រុមអ្នកប្រាជ្ញមួយក្រុម ឬអ្នកនិពន្ធបានប្រមូលផ្តុំចងក្រងនូវពាក្យសុភាសិតទាំងនេះ ទាំងការធ្វើឡើងនិងការបន្ថែមជំពូក ២៥-២៩ បញ្ចូលទៅជាមួយការប្រមូលចងក្រងពីមុនៗមក ។ សមត្ថភាពរបស់ស្តេចសាឡូម៉ូន គឺបានបង្កើតឱ្យមានគម្ពីរសុភាសិតឡើង ក៏បញ្ជាក់ក្នុង ១ពវ ៤:៣២ ក្នុងនោះក៏មានពាក្យសុភាសិត៣០០០ ពាក្យដែលកំណត់ ឬបញ្ជាក់ច្បាស់ពីទ្រង់ផងដែរ ។ មានការសរសេរពីរឃ្លាអំពីប្រាជ្ញា ដែលមានលក្ខណៈខុសគ្នារបស់ទ្រង់ (១ពវ ៤:២៩-៣១,៣៤) ប្រហែលជាព្រះគម្ពីរសុភាសិតស្ទើទាំងអស់ គឺមានប្រភពចេញពីទ្រង់មក ។ កណ្ឌគម្ពីរនេះសរសេរឡើងដែលមានវគ្គបុរេកថា (ការបង្ហាញឱ្យឃើញពីសាច់រឿងខ្លីៗ) (១:១-៧) និងមានសេចក្តីបញ្ចប់វែងៗ (៣១:១០-៣១) ដែលបន្ថែមទៅនិងឯកសាផ្សេងទៀត ។ វាក៏ជាលទ្ធិភាពមួយ ដែលមានការបង្ហាញបញ្ជាក់ជាច្រើន នៅក្នុងផ្នែកទូទៅ (៣១:១០-៣១) ដែលបន្ថែម ឬបញ្ចូលទៅក្នុងវគ្គផ្សេងទៀត ។ (១:៨-៩:១៨) គឺជាការងាររបស់អ្នកចងក្រង ឬអ្នកប្រម៉ែប្រមូល ប៉ុន្តែ មានភាពស្រដៀងគ្នាខ្លះក្នុងជំពូក ៦ ក្នុងវគ្គនេះជាមួយនឹងជំពូកផ្សេងទៀត (ប្រៀបធៀប ៦:១ ជាមួយនឹង ១១:១៥ ១៧:១៨ ២០:១៦ ២៧:១៣ ឬធៀប ៦:១៤,១៩ និង ១០:១២ ១៥:១៨ ១៦:២៨ ២៨:២៥ ២៩:២២ ប្រៀបធៀប ៦:១៩ និង ១០:១២ ១៥:១៨ ១៦:២៨ ១៦:២៨ ២៨:២៥) គឺស៊ីគ្នានឹងកិច្ចការរបស់ស្តេចសាឡូម៉ូនយ៉ាងខ្លាំង ។ ការសង្កត់ធ្ងន់គឺសំដៅទៅលើ "ការកោតខ្លាចដល់ព្រះយេហូវ៉ា (១:៧) គ្រប់ទាំងកណ្ឌគម្ពីរទាំងអស់មានទំនាក់ទំនងជាមួយវគ្គផ្សេងៗរួមគ្នា ។

### កាលបរិច្ឆេទ

បើសិនជាស្តេចសាឡូម៉ូនបានទទួលកេរ្តិ៍ឈ្មោះ ក្នុងការដែលទ្រង់មានតួនាទីដ៏ល្បីល្បាញនៅក្នុងកណ្ឌគម្ពីរ គឺមានបទគម្ពីរភាគច្រើនដែលមានប្រវត្តិមកពីចេញពីសតវត្សទី១០ មុន គ.ស ក្នុងអំឡុងពេលនាសម័យមានចក្រក្រភពអ៊ីស្រាអែល ។ សន្តិភាពនិងភាពរុងរឿងដែលបង្ហាញពីលក្ខណៈសម្បត្តិនៃយុគសម័យ ដែលបង្ហាញនូវការអភិវឌ្ឍន៍នៃគតិបណ្ឌិត ប្រាជ្ញា និងបង្កើតឱ្យមានកិច្ចការផ្នែកខាងអក្សរសាស្ត្រជាច្រើន ។ ក៏មានអ្នកបកស្រាយជាច្រើនទៀត បានកត់សម្គាល់ឃើញថា មានពាក្យពំនោល (ពាក្យពោលទុក) របស់អ្នកប្រាជ្ញ ៣០ ពាក្យក្នុង ២២:១៧-២៤:២២ (ជាពិសេសពាក្យ ១០ដំបូង) មានលក្ខណៈស្រដៀងគ្នានឹងវគ្គទាំង៣០របស់ស្រុកអេស៊ីព្ទ ក៏មានផ្នែកជាសេចក្តីណែនាំខ្លះ គឺមានការទាក់ទងនឹងសម័យស្តេចសាឡូម៉ូន ។ ក៏ដូចជាការកើតមានប្រាជ្ញា ដែលជាប្រភពនៃភាពល្បីសុះសាយមានក្នុងជំពូក ១-៩ (សូមមើល ១:២០ និងការពន្យល់ ៣:១៥-១៨ ៨:១-៣៦ ៩:១-២០) ក៏អាចប្រៀបប្រដូចទៅនឹងលក្ខណៈលម្បត្តិនៃយោបល់ដ៏ពិសេសនៅក្នុងការតែងនិពន្ធរបស់ស្រុកមេសូប៉ូតាមា និងស្រុកអេស៊ីព្ទនៃសហស្សវត្សរ៍ទី២ មុន ស.គ ។

ឯតួនាទីនៃមនុស្សរបស់ស្តេចហេសេគា (សូមមើល ២៥:១) បានបញ្ជាក់ ឬចង្អុលបង្ហាញពីផ្នែកសំខាន់ៗ របស់កណ្ឌគម្ពីរសុភាសិតក៏បានចងក្រងនឹងត្រួតពិនិត្យឡើងវិញតាំពីឆ្នាំ ៧១៥ រហូតដល់ ៦៨៦ មុន ស.គ ។ ខណៈនោះជាពេលដែលលេចបង្ហាញឱ្យឃើញនៅព្រះវិញ្ញាណបរិសុទ្ធដែលដឹកនាំដោយព្រះមហាក្សត្រ ដែលជាអង្គដែលបង្ហាញនូវការចាប់អារម្មណ៍ដ៏អស្ចារ្យ ក្នុងការនិពន្ធរបស់ស្តេចដាវីឌនិងលោកអេសាភ (សូមមើល ២រប ២៩:៣០) ។ វាក៏ជាពេលដែលពាក្យពំនោលរបស់អេគើរជំពូក ៣០ និងស្តេចលេមយួល (៣១:១-៩) និងពាក្យពោលទុក (ពាក្យពំនោល) របស់អ្នកប្រាជ្ញផ្សេងៗទៀត (២២:១៧-២៤:២២ ២៤:២៣-៣៤) ដែលបានបន្ថែម

ចូលក្នុងកណ្ឌគម្ពីរដែលបានចងក្រងទុករបស់ស្តេចសាឡូម៉ូន ទោះជាកិច្ចការចងក្រងប្រមូផ្តុំបានចប់សព្វគ្រប់រហូតដល់រាជ្ជកាលរបស់ស្តេចហេសេគាក៏ដោយ ។

### លក្ខណៈទូទៅរបស់គម្ពីរសុភាសិត

ព្រះបន្ទូលសុភាសិតដែលបានរៀបចំឡើងនៅក្នុងកណ្ឌគម្ពីរនេះ គឺមិនមែនបកស្រាយជាលក្ខណៈសេចក្តីទំនាយទាំងស្រុង ឬក៏អ្វីដែលគេថ្លែងអំពីឥទ្ធិពល និងលទ្ធផលនៃព្រះបន្ទូលសន្យាទេ ។ ឧទាហរណ៍ ១០:២៧ ឆ្នាំនៃអាយុរបស់មនុស្សអាក្រក់នឹងត្រូវរួញខ្លីវិញ ។ គឺជាលក្ខណៈមនុស្សសុចរិតវិញបានរស់យូរអង្វែង និងទទួលបានវិបុសុខគ្រប់យ៉ាងក្នុងជីវិត (មើល ៣:២ និងការពន្យល់) ។ មនុស្សសុចរិតមានអាហារបរិបូរ (១០:៣) ប៉ុន្តែមនុស្សអាក្រក់នឹងត្រូវស្រេចឃ្លានវិញ(១៣:២៥) ។ គឺជាសេចក្តីបញ្ជាក់ដែលជាសេចក្តីពិតទូទៅ ក៏មានករណីលើកលែងមួយចំនួនដែលបង្ហាញថា ជួនកាលមនុស្សសុចរិតត្រូវទទួលការឈឺចាប់ ឯមនុស្សអាក្រក់បានទទួលភាពសុខវិញ (សូមមើលការពន្យល់ ៣:២) ។ តាមធម្មតាមនុស្សសុចរិតនិងមនុស្សអាក្រក់ បានទទួលលទ្ធផលទៅតាមទង្វើដែលគេធ្វើនៅលោកិយ (១១:៣១) ប៉ុន្តែ ការទទួលរង្វាន់និងការទទួលទណ្ឌកម្មតម្រូវឱ្យឆ្លងកាត់ស្ថានឃុំព្រលឹងជាមុន ។

នៅក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យ ថា "សុភាសិត" ហើយបានបកប្រែថា "សេចក្តីទំនាយ" (ជន ២៣:៧,១៨) ឬជា "ពាក្យសម្តីចំអកឡកឡឺយ"(អស ១៤:៤) និង "ពាក្យ ប្រស្នា" (អគ ១៧:២) ដូច្នេះ អត្ថន័យទាំងនេះត្រូវបានគេពិនិត្យពិចារណាថា វាមានលក្ខណៈធំទូលាយជាងពាក្យនៃភាសាអង់គ្លេស ។ កិច្ចការនេះហើយដែលអាចជួយពន្យល់ផ្នែកនៃព្រះគម្ពីរ ដែលមានឃ្លាវែងៗក្នុងព្រះបន្ទូលនាពេលបច្ចុប្បន្នដូចជាក្នុងជំពូក ១–៩ ។ ព្រះបន្ទូលសុភាសិតភាគច្រើនមានលក្ខណៈខ្លីៗ ក៏ជាអត្ថបទបង្រួមដែលបង្ហាញពីសេចក្តីពិតអំពីតួយ៉ាងនៃចរិតលក្ខណៈ និងការប្រព្រឹត្តរបស់មនុស្ស ។ ជារឿយៗក៏មានព្រះបន្ទូលដែលបង្ហាញឱ្យឃើញជាច្រើនសា ដើម្បីជួយឱ្យយើងងាយចងចាំ ។ ក្នុង ៣០:៣៣ ឧទាហរណ៍ ដូចជាកិរិយាស័ព្ទគម្ពីរភាសាហេព្រើរខ្លះ ត្រូវបានគេបកប្រែថា "កកាយ" "មួល" និង "កូឱ្យសព្ទ" ។

វគ្គដែលវែងបំផុតក្នុងកណ្ឌគម្ពីរនេះ (១០:១–២២:១៦) វគ្គសុភាសិតភាគច្រើន គឺមានប្រវែងពីរបន្ទាត់ហើយផ្នែកទាំងនោះមានក្នុងជំពូក ១០–១៥ ស្ទើរតែបញ្ជាក់ពីភាពខុសគ្នាទាំងស្រុង ។ ពេលខ្លះអ្នកនិពន្ធបានបង្កើត ឱ្យមានភាពតាមដានខ្លះៗ ដូចជាពាក្យថា "សំណូករាប់ជាត្បូងមានតម្លៃដល់អ្នកណាដែលមាន" (១៧:៨ ធៀបនិង ១៤:២០) ប៉ុន្តែជាទូទៅទ្រង់វាយតម្លៃពីការប្រព្រឹត្ត "តែអ្នកណាដែលស្អប់សំណូកនោះនឹងរស់នៅវិញ" (១៥:២៧) ។ ជាការពិតណាស់ពាក្យសុភាសិតជាច្រើន ដែលពណ៌នាពីកាលៈទេសៈពីសកម្មភាពដ៏ជាក់លាក់ ឬក៏លក្ខណៈជាតួអង្គ : "កូនប្រុសដ៏មានភាពវៃឆ្លាតបាននាំសេចក្តីអំណរទៅឱ្យឪពុករបស់ផងខ្លួន" (១០:១) ។ ចាប់តាំងពីគម្ពីរសុភាសិតបានសរសេរឡើង ដើម្បីជាសេចក្តីណែនាំ ជារឿយៗមានលក្ខណៈជាសេចក្តីបង្គាប់: "កុំឱ្យល្មោភដេកក្រែងលោត្រឡប់ជាទាល់ក្រ" (២០:១៣) ។ ទោះជាមានទម្រង់ខ្លះមានលក្ខណៈបង្គាប់បញ្ជាដែលមិនពិតប្រាកដក៏ដោយ ក៏មានមានសកម្មភាពជាលក្ខណៈច្បាស់លាស់ដែរ (សូមមើល ១៤:៥) ។

លក្ខណៈពិសេសរួមនៃគម្ពីរសុភាសិតគឺការប្រើភាសាប្រៀបប្រដូច : ទឹកបានត្រជាក់ដល់ព្រលឹងមនុស្សល្វឹងល្វើយជាយ៉ាណានោះក៏ជាដំណឹងល្អដែលមកពីស្រុកឆ្ងាយ" (២៥:២៥) ។ ក្នុងជំពូក ២៥ តែមួយគត់អាចមាន ១១ខ ដែលផ្តើមដោយពាក្យ "ដូចជា" ឬក៏ពាក្យ "ដូច" ។ ពាក្យប្រៀបប្រដូចទាំងនេះធ្វើឱ្យគម្ពីរសុភាសិតកាន់តែមានភាពរណ្តំ និងមានអំណាច ។ ដោយពេលខ្លះពាក្យប្រៀបធៀបត្រូវបានគេប្រើក្នុងរបៀបគួរឱ្យចង់សើច ឬជាលក្ខណៈចំអកបញ្ឈឺចិត្ត "គឺមានលក្ខណៈដូចជាចិញ្ចៀនក្នុងល័ក្ខ ដោយពោលពាក្យពុំមានភាពប្រុងប្រយ័ត្ន" (១១:២២ ប្រៀបធៀប ២៦:៩) ឬក៏ "ដូចជាទ្វារដែលមានត្រចៀកបើកបិតទៅមក ដូច្នេះមនុស្សខ្ជិលច្រអូសចេះតែបំរាស់ននៀលនៅលើគ្រែដូចទ្វារដែលបិតបើកទៅមកផងដែរ" (២៦:១៤) ។ ក៏មានផលប្រយោជន៍ចំពោះពាក្យប្រៀបប្រដូច : "ការបង្រៀនរបស់អ្នកប្រាជ្ញ គឺជាប្រភពទឹកនៃជីវិត" (១៣:១៤) ចំណែកឯ "អណ្តាតដែលនាំមកនូវការប្រោសលោះដល់ជីវិត គឺជាដើមឈើជីវិត" (១៥:៤) ។ យោងតាម ១៦:២៤ "ជាព្រះបន្ទូលដែលជាទីរីករាយ គឺសំណុំទឹកឃ្មុំ" ។ សេចក្តីបង្ហាញនឹងការលើកយកមកនេះត្រូវបានគេប្រើទាំងលក្ខណៈវិជ្ជមាន និងលក្ខណៈអវិជ្ជមាន (ផ្លូវស្រប ឬផ្លូវមិនស្រប) (ប្រៀបធៀប ១១:១៨ ២២:៨) ។ ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ ឬការកំណត់តម្លៃពីចំនួននៃព្រះបន្ទូលសុភាសិត ក្នុងការប្រើជាលក្ខណៈប្រៀបធៀបផ្ទាល់ "មនុស្សក្រីក្រដែលប្រព្រឹត្តតាមផ្លូវទៀងត្រង់របស់ខ្លួន នោះវិសេសជាងមនុស្សក្រវិកក្រវៀនក្នុងគ្រប់ទាំងផ្លូវរបស់គេទោះបើជាអ្នកមានក៏ដោយ" (២៨:៦) ។ ពាក្យថា "វិសេសជាង" គឺមានគំរូដែលយើងអាចឃើញក្នុង ១៥:១៦–១៧ ១៦:១៩,៣២ ១៧:១,១២ ជាទម្រង់មានលក្ខណៈបង្ហាញបញ្ជាក់ ដែលមានឃើញក្នុង ២២:១ ។ ក៏មានគំរូមួយទៀតដែលបានឃើញ ឬជួបក្នុងកណ្ឌគម្ពីរដែលគេហៅថា សុភាសិតដែលទាក់ទងពីចំនួនលេខ ។ ដែលបានប្រើលើកទី១ នៅក្នុង ៦:១៦ (សូមមើលការពន្យល់ ៦:១៦) គឺជាប្រភេទនៃពាក្យពោលទុកដែលមានលេខទី៣ក្នុងបន្ទាត់ទី១ និងទី៤ក្នុង

បន្ទាត់ទី២ (ធៀប ៣០:១៥,១៨,២១,២៩) ។

ជាការបង្ហាញឱ្យឃើញឡើងវិញនៃគម្ពីរសុភាសិតទាំងមូល (ធៀប ៦:១០-១១ និង ២៤:៣៣-៣៤ ១៤:១២ និង ១៦:២៥ ១៨៣៨ និង ២៦:២២ ២០:១៦ និង ២៧:១៣ ២១:១៩ និង ២៥:២៤) ឬក៏ជាវគ្គនៃគម្ពីរសុភាសិតដែលចូលរួមបម្រើផ្នែកខាងបំផុសឱ្យមានគំនិតប្រាជ្ញា ។ ក៏មានភាពផ្សេងៗពីគ្នាតិចតួចដែលបានបណ្តាលឱ្យអ្នកនិពន្ធប្រើរូបភាពដូចៗគ្នា ដើម្បីឱ្យមានចំណុចទាក់ទងគ្នាទៅវិញទៅមក (ដូចជានៅក្នុង ១៧:៣ ២៧:២១) ឬក៏ដើម្បីជំនួសពាក្យមួយ ឬពាក្យដើម្បីសម្រេចនូវការចង្អុលបង្ហាញឱ្យកាន់តែភ្លឺច្បាស់ (ធៀប ១៩:១ ២៨:៦) ។ ក្នុង ២៦:៤-៥ គឺបន្ទាត់ដូចគ្នាដែលបានគេរំឭកដដែលៗ ក្នុងរបៀបខុសៗគ្នាតែចំណុចនេះអ្នកនិពន្ធលើកឡើងដើម្បីធ្វើឱ្យមានចំណុចផ្ទុយគ្នាពីរ (មើលការពន្យល់នៅទីនោះ) ។

ក្នុងសម័យនោះកណ្ឌគម្ពីរសុភាសិត គឺមានលក្ខណៈផ្ទាល់ៗ ឬចំៗ និងដែលទាក់ទងនឹងលោកិយ (ប្រៀបធៀប ៦:៦ ២១:៩ ២៥:១៦ ២៦:៣) ។ នេះគឺជានិស្ស័យនៃអក្សរសាស្ត្រដែលផ្តល់ឱ្យមានគរុកោសល្យ ដ៏មានប្រសិទ្ធភាពដើម្បីបំភ្លឺគំនិតប្រាជ្ញា ដល់ស្ថានជីវិតគ្រប់ស្រទាប់ និងជាការយកព្រះទ័យទុកដាក់ពីព្រះវិញ្ញាណបរិសុទ្ធ ។

## គោលបំណងនិងសេចក្តីបង្រៀន

ដោយយោងទៅលើវគ្គជាសេចក្តីផ្តើម (បុរេកថា) (១:១-៧) គឺគម្ពីរសុភាសិត ត្រូវបានគេនិពន្ធឡើងដើម្បីផ្តល់ "សម្រាប់មនុស្សឆោតល្ងង់មានសេចក្តីឆ្លៀវឆ្លាត និងមនុស្សកម្លោះមានតំរិះ ហើយនិងបញ្ញានឹងធឹង" (១:៤) និងមនុស្សប្រាជ្ញបានស្តាប់ ហើយចម្រើនឡើង (១:៥) ។ តាមធម្មតាព្រះបន្ទូលនៅក្នុងសុភាសិត មានបញ្ចូលមនុស្សទូទៅដោយពាក្យ *"នែកូនអើយ"* (១:៨,១០ ២:១ ៣:១ ៤:១ ៥:១) គឺបង្ហាញពីការសង្កត់ន័យទៅលើសេចក្តីណែនាំចំពោះយុវវ័យ និងនាំផ្លូវរបស់ពួកគេទៅរកការចម្រើនរហូតដល់ទីបញ្ចប់ ។ ការដែលទទួលបាននូវប្រាជ្ញា និងការដឹងពីហេតុការណ៍ដែលត្រូវជៀសវាងឱ្យផុតពីរណ្តៅនៃភាពល្ងង់ខ្លៅ ឬអំពើអាក្រក់ផ្សេងៗ ដើម្បីនាំខ្លួនគេឱ្យទទួលភាពប្រសើរមានការទំនាក់ទំនងនិងគ្រួសារ ដោយសេចក្តីសប្បាយរីករាយកិច្ចការជាពលកម្ម ដែលទទួលបានភោគផលល្អ និងឈរនៅក្នុងការរួបរួមជាសហគមន៍ ។ ដោយគម្ពីរសុភាសិត គឺជាកណ្ឌគម្ពីរសម្តែងពីការអនុវត្តទាក់ទងនឹងរបៀប ឬច្បាប់នៃការរស់នៅ ដែលផ្អែកលើប្រាជ្ញាឆ្លាតវ័យពីព្រះបន្ទូលយ៉ាងតឹងរឹង ដោយឈរលើការកោតខ្លាចដល់ព្រះយេហូវ៉ា (១:៧ សូមមើល ទដ ៣៤:៨-១៤ និងការពន្យល់) ។ តាមរយៈកណ្ឌគម្ពីរនេះបង្ហាញពីរការកោតខ្លាច និងគោរពយ៉ាងជ្រាលជ្រៅដល់ព្រះអម្ចាស់ ហើយទុកចិត្តទៅលើទ្រង់ដោយពឹងផ្អែកផ្លូវឆ្ពោះទៅមុខជាផ្លូវរបស់ទ្រង់ក្នុងជីវិត ដែលមានសេចក្តីសុខស្រួលដល់ជីវិត (ប្រៀបធៀប ៣:៥-១០ ៩:១០១២ ១៤:២៦-២៧ ១៦:៣,៦-៧ ១៨:១០ ១៩:២៣ ២០:២២ ២២:៤ ២៨:២៥ ២៩:២៥) ។ ជាប្រាជ្ញាពីព្រះវិញ្ញាណបរិសុទ្ធ ដែលជាភាពពិតត្រង់ "ជាដើមនៃជីវិត" (៣:១៨ ១១:៣០ ១៣:១២ ១៥:៤) បានឱ្យផលជាជីវិតរីករាយ ដែលព្រះអម្ចាស់បានបំពេញលក្ខណៈឱ្យអ្វីដែលទ្រង់បង្កើតឱ្យមានឡើងនោះ ។

ជាការចាប់ផ្តើមនៃព្រះបន្ទូលតម្រង់ប្រដៅ (១:៨-៩:១៨) គឺអ្នកនិពន្ធបានបង្ខំឱ្យមនុស្សកម្លោះជ្រើសរើសផ្លូវនៃសេចក្តីចម្រើនប្រាជ្ញា (ដែលនាំឱ្យមានជីវិត) និងគេចចេញពីផ្លូវនៃសេចក្តីឆោតល្ងង់ (ដែលមានសេចក្តីល្បួង និងនាំឱ្យពួកគេឆ្ពោះទៅរកសេចក្តីស្លាប់) ។ អ្នកនិពន្ធជ្រើសរើសលើកយកឧទាហរណ៍សំខាន់ៗពីនៃសេចក្តីឆោតល្ងង់ មកបង្ហាញពីការរំលឹកដាស់តឿន : (១).គឺដើម្បីនាំមុខលោកិយ និងចាប់យកអ្នកដទៃទៀតជាជាងដោយការដែលខំប្រឹងប្រែងលើកិច្ចការឥតប្រយោជន៍ ចំណែកឯករណីទី (២).គឺជាការស្វែងរកសេចក្តីស្រើបស្រាលសប្បាយ ។ សេចក្តីល្បួងបានមកដល់អ្នកដែលមានឋានៈខ្ពង់ខ្ពស់ និងវ័យកម្លោះ (១:១០-១៩) សេចក្តីល្បួងក៏មកដល់ មនុស្សផ្សេងទៀត គឺមកពីស្រីកំផិត (ជំពូក ៥, ៦:២០-៣៥ ជំពូក ៧) ។ ការបង្ហាញបញ្ជាក់ពីសេចក្តីល្បួងពីរទាំងនេះ គឺជាការបង្ហាញនូវភាពជ្រួតជ្រាប និងអំណាចនៃភាពស្រើបស្រាលចំពោះភាពឆោតល្ងង់ ដែលមនុស្សកម្លោះបានប្រឈមមុខក្នុងជីវិត និងត្រៀមខ្លួនដើម្បីទប់ទល់នឹងហេតុការណ៍ផ្សេងៗ (សូមមើលខាងក្រោម) ។

ការចងក្រងផ្នែកសំខាន់នៃព្រះគម្ពីរសុភាសិត ដែលតាមលំអាននៃផ្នែកលំដាប់ឆ្លងកាត់នូវវគ្គស្រដៀងៗគ្នា ពីស្ថានភាពជីវិតមនុស្សលោក គឺជាប្រាជ្ញាតម្រិះ ដែលផ្តល់ឱ្យមានទំនាក់ទំនងនឹងទទួលខុសត្រូវចំពោះសេចក្តីប្រមាថ សេចក្តីណែនាំ និងការផ្តល់ដំបូន្មានក៏បានជំរុញឱ្យយកចិត្តទុកដាក់ ឬរក្សាព្រះបន្ទូលសុភាសិត ។ វគ្គនឹងការសរុបរួមពីវគ្គផ្សេងៗ ក៏ជាការបង្ហាញបញ្ជាក់ពីផ្នែកដែលអាចនាំឆ្ពោះទៅរកលក្ខណៈរួមទូទៅ គឺជាសួរស័ព្ទក្រមសីលធម៌ និងការប្រមូលចងក្រងទាំងមូល ។ ក្នុងស្ថានភាពផ្សែកៗ និងការមានទំនាក់ទំនងដែលអ្នកអានបានផ្លែងពីភាពស្មោះត្រង់មានការយកចិត្តទុកដាក់ ចិត្តល្អស្អាត សប្បុរស យល់ពីការលើកលែងទោស មានសេចក្តីពិត អត់ធ្មត់បន្ទាបខ្លួន មានភាពរីករាយ ភក្តីភាព ចេះទប់ចិត្ត និងមានពិចារណាយ៉ាងត្រឹមត្រូវពីការអាក្រក់ទាំងឡាយ ដែលចេញពីចរិតលក្ខណៈពីការ

ជ្រើសរើស និងសកម្មភាពផ្សេៗ ។ ឯកំហឹងគួរតែតម្រូវឱ្យពិនិត្យមើលក្នុងខ្លួនឡើង ភាពឃោរឃៅទាំងឡាយ ការឈ្លោះប្រកែកក៏ត្រូវគេចឱ្យឆ្ងាយ ការជៀសវាងពីការនិយាយរអេចរអូច ការបដិសេធន៍ភាពក្រអឺតក្រអាង ។ ភាពស្រវឹង ការបរិភោគច្រើនហួសប្រមាណ សេចក្តីច្រណែន និងសេចក្តីលោភគឺរឿងទាំងអស់នោះគួរតែបោះបង់ចោល ។ ឯអ្នកក្រមិនត្រូវគាបសង្កត់គេឡើយចៅក្រមមិនត្រូវសម្រេចសម្រួលទៅលើភាពអយុត្តិធម៌ទេ ឬការប្រើអំណាចមិនស្របតាមច្បាប់ ក្នុងការស្វែងរកកិត្តិយសឡើយ ។ ឯមាតាបិតាគួរតែផ្តល់ដំបូន្មាន និងដាក់វិន័យអប់រំដល់កូនចៅរបស់ពួកគេ ចំណែកឯកូនចៅត្រូវតែស្តាប់បង្គាប់ ឬគោរពដល់មាតាបិតា និងមិនត្រូវនាំមកនូវភាពអាប់យសដល់ពួកលោកឡើយ ។ តាមការអង្កេតនៃមនុស្ស និងតាមរយៈបទពិសោធន៍បានបង្រៀនដល់អ្នកប្រាជ្ញថា សេចក្តីត្រឹមត្រូវ សេចក្តីរៀបរយដ៏ពិតប្រាកដគឺនៅទីដែលជាការបង្កើតរបស់ផងទ្រង់ ។

ទោះជាយ៉ាណាក៏ដោយ គម្ពីរសុភាសិតគឺជាគម្ពីរដែលសម្តែងការអនុវត្ត ឬការប្រព្រឹត្តរបស់មនុស្សជាជាងទៅលើការសិក្សាពីវិជ្ជានៃព្រះ គឺព្រះរាជកិច្ចជាអង្គនៃព្រះអាទិករ គឺទ្រង់ជាអ្នកបង្កើតគ្រប់ទាំងអស់ ជាពិសេសក៏បានគូសបញ្ជាក់ផងដែរ ។ ឯមុខងារនៃប្រាជ្ញាក្នុងការបង្កើតគឺជាប្រធានបទ ៨:២២-៣១ និងការពន្យល់ ក្នុងនោះប្រាជ្ញាមានលក្ខណៈជាការកំណត់របស់ព្រះអម្ចាស់ ក៏បានកំណត់ច្បាស់ផងដែរ ។ ព្រះអម្ចាស់ត្រូវបានគេឱ្យព្រះនាមទ្រង់ថា ជាអ្នកបង្កើតអ្នកក្រ (១៤:៣១ ១៧:៥ ២២:២) ។ ទ្រង់ជាមហាក្សត្រដឹកនាំគ្រប់ទាំងជិហានរាស្ត្រទ្រង់ (ធៀប ១៦:៩ ២០:២៤) សូម្បីតែគ្រប់សកម្មភាពរបស់ព្រះមហាក្សត្រ (២១:១) ចំណែកឯព្រះនេត្រទ្រង់ទតអង្កេតមើលរាល់ទង្វើមនុស្សលោកបានធ្វើ (ធៀប ៥:២១ ១៥:៣) ។ គ្រប់អស់ទាំងប្រវត្តិសាស្ត្រដែលបានវិវឌ្ឍន៍ទៅមុខក៏បានគ្រប់គ្រងដោយទ្រង់ដែរ (សូមមើល ១៦:៤,៣៣ និងការពន្យល់) ។

ក្នុងសេចក្តីសង្ខេបរបស់គម្ពីរសុភាសិត បានផ្តលនូវការណែនាំតម្រង់ប្រដៅ ឱ្យរស់នៅដោយមានភាពវ៉ៃឆ្លាត និងជោគជ័យក្នុងការដែល "កោតខ្លាចដល់ព្រះយេហូវ៉ា" (១:៧ ៩:១០) ។ ការកោតខ្លាចដល់ព្រះយេហូវ៉ា គឺទាំងការមានសេចក្តីពិតក្នុងការពុះពារ ឬប្រព្រឹត្តចំពោះព្រះ និងចំពោះព្រះទ័យទ្រង់ដែលបានបើកសម្តែងតាមរយៈព្រះបន្ទូលទ្រង់ ។ ឯប្រាជ្ញាដែលបង្ហាញនៅក្នុងព្រះបន្ទូលនេះគឺចិត្តមេត្តាប្រណី ក៏ឈរទៅលើចិត្តមេត្តាប្រណីដែលសម្តែងចេញពីព្រះមហាក្សត្រ ដើម្បីឱ្យបានសេចក្តីអំណរសប្បាយដល់មនុស្សនៅក្នុងការរៀបរយនៃការបង្កើតរបស់ផងទ្រង់ មានជាលទ្ធផលនៅក្នុងអារម្មណ៍ (១:២) និងជាគុណភាពនៃជីវិត (១:៣) ។

**ទម្រង់បែបអក្សរសាស្ត្រ**

ចំណុចសំខាន់នៃរឿង ឬជាការសរសេរដែលមានក្នុងអត្ថបទ បានចែកចេញជាវគ្គៗ ។ មានសេចក្តីផ្តើមខ្លីៗ (បុរេកថា) (សេចក្តីបង្ហាញបញ្ជាក់ពីគោលដៅ និងផ្ទៃរឿង ១:១-៧) ការចាប់ផ្តើមនូវកណ្ឌគម្ពីរ និងសេចក្តីបញ្ចប់ជាលក្ខណៈវែងៗ (ដែលបង្ហាញពីអត្តសញ្ញាណដោយរឿងរ៉ាវជាប្រធាន និងទម្រង់តាមលំដាប់អក្ខរៈក្រមរបស់កណ្ឌគម្ពីរ ៣១:១០-៣១) គឺជាការបញ្ចប់ ។ ឯជំពូក៩បាននិពន្ធឡើងជាលក្ខណៈតជាភាគៗនៃការថ្លែងបញ្ជាក់ ដែលផ្ទុយនឹងផ្លូវ និងផលប្រយោជន៍របស់ប្រាជ្ញា ដែលផ្លូវរបស់ពួកអាក្រក់ ។ លើកលែងតែសម្រាប់វគ្គមួយចំនួន ដែលបង្ហាញពីលក្ខណៈនៃប្រភពប្រាជ្ញា (១:២០ ៨:១ ៩:១) ឯការថ្លែងបញ្ជាក់និមួយៗនៃព្រះបន្ទូល គឺមានបន្ទូលដោយពាក្យ "នែកូនអើយ" ឬក៏ពាក្យ "នែកូនទាំងឡាយអើយ" ។

លក្ខណៈពិសេសជាគន្លឹះក្នុងវគ្គជាសេចក្តីផ្តើមនៃគម្ពីរសុភាសិត គឺជាការបង្ហាញបញ្ជាក់ទាំងប្រាជ្ញា និងភាពល្ងង់ខ្លៅដូចជាពួកស្រីៗដែលពួកគេ(បានអំពាវនាវ និងសេចក្តីប្រាប់ពីផ្នែកស្ត្រីដោយប្រើសេចក្តីល្បួងលួងឡោម គឺជាការនៃសេចក្តីអាក្រក់) បានស្វែងរកសេចក្តីលួងលោមឱ្យពួកកម្លោះយុវវ័យឱ្យដើរតាមផ្លូវរបស់នាង ។ ចំពោះអត្ថបទទាំងនេះគឺបានរៀបចំចងក្រងយ៉ាងច្បាស់លាស់ ។ សេចក្តីផ្តើម (១:៨-៣៣) និងការបញ្ចប់ (ជំពូក ៨-៩) ដែលទាក់ទងនឹងការល្បួងលួងលោមដោយផ្ទាល់ និងការអំពាវនាវនឹងវគ្គជាការថ្លែងរៀបរាប់ជាផ្នែកសំខាន់បានមានជាទ្រង់ទ្រាយដោយមានវគ្គស៊ីគ្នាពីរ ឯផ្នែកទីមួយគឺជាការសរសើរពីប្រាជ្ញា (ជំពូក ២-៤) និងផ្នែកផ្សេងទៀតជាការប្រមានដាស់តឿនដល់មនុស្សអាក្រក់ (ជំពូក ៥-៧) ។ ក្នុងសេចក្តីរៀបរាប់ទាំងនេះពីមនុស្សកម្លោះ ក៏ត្រូវបានគេពិពណ៌នាពីសេចក្តីល្បួង ឬការបបួលនាំឱ្យពួកគេធ្វើការអាក្រក់ក្និងលោកិយ (១:១០-១៩) ឬក៏ដោយសារពួកស្រីៗណាដែលបានស្វែងរកសេចក្តីស្រើបស្រាលកំជិតក្បត់នៅឯខាងក្រៅ ដែលបានរៀបការ (ជំពូក ៥ ៦:២០-៣៥ ជំពូក ៧) ។ ក្នុងបែបបទសង្គមនាសម័យនោះ ឃើញថាមានសេចក្តីល្បួងពីរធំៗចំពោះយុវវ័យក្មេងៗ ។ ឯតួនាទីពិសេសទីពីរ នៅទីនេះ ក៏បានបង្ហាញនិងបញ្ជាក់នៃភាពល្ងង់ខ្លៅរបស់ស្ត្រី ។

ឯការប្រមែប្រមូលចងក្រងនូវអត្ថបទសំខាន់ៗនូវគម្ពីរសុភាសិតរបស់ស្តេចសាឡូម៉ូនក្នុង ១០:១-២ ២:១៦ ដែលសរសេរឡើងដោយភាពចុងចួនផ្សេងៗមានមួយចំនួន ក៏បញ្ជាក់ពីភាពផ្សេងគ្នា ។

ការប្រមែប្រមូលចងក្រងលើទីពីររបស់ស្តេចសាឡូម៉ូន (ជំពូក ២៥-២៩) ឃើញខគំរូពីរបន្ទាត់ក៏មាន ឧទាហរណ៍នៃពាក្យ

សុភាសិតដែលមានបីបន្ទាត់ (២៥:១៣ ២៧:១០,២២,២៧) ឬបួនបន្ទាត់ (២៥:៤-៥,២១-២២ ២៦:១៨-១៩) ។ ប្រាំខចុងក្រោយនៃជំពូក ២៧ មាន (ខ.២៣-២៧) បង្ហាញឱ្យឃើញវគ្គអធិប្បាយខ្លីៗស្ដីអំពីផលប្រយោជន៍នៃការចិញ្ចឹមហ្វូងចៀម និងពពែ ។ ក្នុង "ឯពាក្យពោលទុក" ចំនួន ៣០ របស់អ្នកប្រាជ្ញមាន (២២:១៧-២៤:២២) និងមាន "ពាក្យពោលទុកបន្តទៀត" នៃជំពូក ២៤:២៣-៣៤ ដែលមានលក្ខណៈទូទៅនៃវគ្គមានពីរ ឬបីខនឹងពេលខ្លះក៏មានលក្ខណៈដូចជំពូក ១-៩ (ជាពិសេសសូមមើល ២៣:២៩-៣៥) ។ វគ្គទាំងនេះបានបញ្ចូលបន្ថែមទៅអត្ថបទសំណេរ ដើមនឹងមានប្រយោគគម្ពីរសុភាសិតខ្លះ មានលក្ខណៈស្រដៀងនឹងវគ្គដែលមានក្នុងការប្រមែប្រមូលចងក្រងក្នុងវគ្គដំបូងគេ (ប្រៀបធៀប ២៤:៦ និង ១១:១៤ ២៤:១៦ និង ១១:៥) ឬជំពូក ១-៩ (ប្រៀបធៀប ២៣:២៧ ២:១៦ ២៤:៣៣-៣៤ និង ៦:១០-១១) ។

ក្នុងវគ្គបញ្ចប់របស់កណ្ឌគម្ពីរនេះ អ្នកពិនិត្យផ្ទៀងផ្ទាត់បានភ្ជាប់បញ្ចូលផ្នែកបន្ថែមបីវគ្គក្នុងទម្រង់ជាលក្ខណៈផ្សេងគ្នាខ្លះៗ និងមាតិកាបញ្ជីរឿង "ជាពាក្យពោលទុករបស់អេគើរ" "ពាក្យពោលទុករបស់ស្ដេចលេមយួល" និងការពណ៌នារបស់ "ស្ត្រីគ្រប់លក្ខណ" ។ វគ្គដំបូងនៃកិច្ចការទាំងនេះ (ជំពូក ៣០) បានគេរៀបចំដោយជាលេខ ឬចំនួនក្នុងគម្ពីរសុភាសិត (៣០:១៥,១៨,២១,២៤,២៩ សូមមើលការពន្យល់ ៦:១៦) ។ វគ្គទីពីរ (៣១:១-៩) បង្ហាញច្រើនពីការដែលមានទំនោរយ៉ាងស្មោះចំពោះការណែនាំរបស់ព្រះមហាក្សត្រ ។ វគ្គទីបី (៣១:១០-៣១) គឺជាសេចក្ដីបញ្ចប់នូវគ្រប់កិច្ចការទាំងអស់ គឺបានបង្ហាញពីភាពសុចរិតទៀងត្រង់ ដូចជាស្ត្រីគ្រប់លក្ខណ (ប្រៀបធៀប នរ ៣:១១ និងការពន្យល់) ។ នាងបានសំដែងពីភាពគ្រប់លក្ខណតាមរយៈកិច្ចការផ្សេងៗ ដែលមានប្រាជ្ញាក៏បង្ហាញតាមរយៈកណ្ឌគម្ពីរសុភាសិតបានបង្ហាញសង្កត់ខ្លាំងនោះ គឺចំពោះយុវវ័យ ឬពួកកម្លោះគឺបង្ហាញពីទិស្ស័យជីវិតរបស់ពួកគេ ក៏ផ្ដោតទៅលើស្ត្រីជាប្រពន្ធដែលមានលក្ខណៈអស្ចារ្យរបស់នាង ។ ប៉ុន្តែគោលបំណងនៃគម្ពីរនេះបានរៀបចំឡើងជាពីផ្នែក : (១).បានផ្ដល់នូវដំបូន្មាន ឬប្រឹក្សាឱ្យរក ឬធ្វើជាប្រពន្ធ ឬកម្លោះដែលមានចិត្តស្លូតបូតមានចិត្តមេត្តា ចំណែកទី (២).គឺផ្លូវនៃភាពប៉ិនប្រសប់ក្នុងការឱ្យជាដំបូន្មានមនុស្សកម្លោះឱ្យរៀបការនឹងស្ត្រីមានប្រាជ្ញា ដែលនៅក្នុងសាច់រឿងនៃជំពូក ១-៩ (ដូចជាព្រឹត្តការក្នុងជំពូក ៩ ធៀបនឹងការពិពណ៌នានៃប្រាជ្ញារបស់ស្ត្រីក្នុង ៩:១-២ ដែលមានភាពសុចរិតនៃភរិយាក្នុង ៣០:១០-៣១) ។ ក្នុងព្រឹត្តិការណ៍ខ្លះមានសេចក្ដីសង្ខេបរួមនៃប្រាជ្ញានៅក្នុងប្រពន្ធ គឺជាការគ្រប់លក្ខ ។ តាមការបែបអក្សរសាស្ត្រដែលមានវគ្គរ៉ាយរាប់ជាលក្ខណៈចំហាពីប្រាជ្ញា ក៏បង្ហាញពីលក្ខណៈតួយ៉ាងដូចជាស្ត្រីម្នាក់ ។

**គម្រោងសង្ខេប**

I. ការផ្ដើមសេចក្ដី : គោលបំណង និងផ្ទៃរឿង (១:១-៧)

II. លក្ខណៈប្រសើរចម្រុងចម្រើននៃផ្លូវរបស់ប្រាជ្ញា (១:២០-៣៣)

ក. ការអំពាវនាវ ឬប្រមានខណៈពេលប្រឈមមុខក្នុងភាពយុវវ័យ (១:៨-៣៣)

១. សេចក្ដីអំពាវនាវឱ្យគេចេញពីភាពសប្បាយដោយសារការរំលោភបំពាន (១:៨-១៩)

២. សេចក្ដីដាសតឿនជាការដែលជំទាស់នឹងប្រាជ្ញា (១:២០-៣៣)

ខ. ការកោតសរសើរពីប្រាជ្ញា (ជំពូក ២-៤)

១. ផលប្រយោជន៍នៃការទទួលយកសេចក្ដីណែនាំពីប្រាជ្ញា (ជំពូក ២)

២. ប្រាជ្ញាគឺជាអំណោយទានដ៏ល្អប្រសើរ (៣:១-២០)

៣. សេចក្ដីណែនាំពីប្រាជ្ញានឹងផលប្រយោជន៍របស់ប្រាជ្ញា (៣:២១-៣៥)

៤. ការលើកទឹកចិត្តឱ្យទទួលយកប្រាជ្ញា (ជំពូក ៤)

គ. ការព្រមានប្រឆាំងនឹងអំពើអាក្រក់ផ្សេងៗ (ជំពូក ៥-៧)

១. ការទូន្មានដល់ការកុំឱ្យផឹកក្បត់ (ជំពូក ៥)

២. ការទូន្មានចំពោះការប្រព្រឹត្តរបស់មនុស្សចចេស ឆ្មើងឆ្មៃ (៦:១-១៩)

៣. ការជំនុំជម្រះពីការប្រព្រឹត្តអំពើកំផឹត (៦:២០-៣៥)

៤. ការប្រមានប្រដៅចំពោះការល្បួងទាក់ទាញចិត្តរបស់ពួកស្ត្រីកំផឹតប្ដី (ជំពូក ៧)

ឃ. ការអំពាវនាវដល់យុវវ័យ (ជំពូក ៨-៩)

១. ការអំពាវនាវរកប្រាជ្ញា (ជំពូក ៨)

២. ការអញ្ជើញអស់អ្នកមានយោបល់ និងអស់អ្នកណាដែលឆោតល្ងង់ (ជំពូក ៩)

III. គឺជាវគ្គប្រមូលផ្ដុំសំខាន់ៗ នៃគម្ពីរសុភាសិតរបស់ស្ដេចសាឡូម៉ូន (១០:១-២២:១៦)

IV. ពាក្យពោលទុកទាំង៣០ពាក្យរបស់អ្នកប្រាជ្ញ (២២:១៧–២៤:២២)
V. ពាក្យពោលទុកបន្ថែមទៀតរបស់អ្នកប្រាជ្ញ (ជំពូក ២៤:២៣–៣៤)
VI. ការប្រមូលចងក្រងរបស់ស្ដេចហេសេគា នៃគម្ពីរសុភាសិតរបស់ស្ដេចសាឡូម៉ូន (ជំពូក ២៥–២៩)
VII. ពាក្យពោលទុករបស់លោកអេគើរ (ជំពូក ៣០)
VIII. ពាក្យពោលទុករបស់ស្ដេចលេមយួល (៣១:១–៩)
IX. សេចក្ដីបញ្ចប់ : ពីស្ត្រីគ្រប់លក្ខណ (៣១:១០–៣១)

## អ្នកប្រាជ្ញនៅក្នុងគម្ពីរសុភាសិត : គម្រោងសង្ខេប

**I. ចរិតលក្ខណៈ**

ក. ជាអ្នកបង្រៀនបាន មិនពិបាកកែប្រដៅ
១. គេជាអ្នកចុះចូល និងស្រឡាញ់ការណែនាំ (១៨:១៥ ១៩:២០)
២. គេជាអ្នកលូតលាស់ខាងឯប្រាជ្ញា (១៥:៥ ៩:៩ ១០:១៤)
ខ. គេជាមនុស្សសុចរិត មិនមែនមនុស្សអាក្រក់
១. ជាអ្នកកោតខ្លាចព្រះ (១:៧ ១៤:១៦ សូមមើលអត្ថបទខាងក្រោមពីការទំនាក់ទំនងជាមួយព្រះយេហូវ៉ា)
២. គេស្អប់នូវអ្វីៗដែលមិនពិត (១៣:៥)
៣. ជាអ្នកគេចចេញពីការអាក្រក់ (៣:៧ ១៤:១៦ ១៦:៦) ។
៤. គេធ្វើអ្វីដែលជាសេចក្ដីសុចរិត (២:២០)
៥. គេនិយាយតែពីសេចក្ដីពិត (២២:២១)
គ. ជាអ្នកបន្ទាបខ្លួន មិនមែនជាអ្នកមានចិត្តអំនួត (១៥:៣៣)
ឃ. ជាអ្នកអាចគ្រប់គ្រងអារម្មណ៍បានមិនច្រឡោត
១. ចរិតលក្ខណៈ
ក. ជាអ្នកចេះទប់ចិត្ត (២៩:១១)
ខ. គេជាអ្នកមានចិត្តត្រជាក់ (១៧:២៧)
គ. ពួកល្ងីល្ងើសំដែងកំហឹងរបស់ខ្លួនចេញ (២៩:៨,១១)
២. សកម្មភាព
ក. គេជាអ្នកប្រយ័ត្ន មិនឆេវឆាវ (១៩:២)
ខ. គេគិតមុនពេលធ្វើអ្វីមួយ (១៣:១៦ ១៤:៨)
គ. គេគិតមុនពេលនិយាយ (១២:២៣ ១៥:២)
ឃ. ជាអ្នកលើកលែងទោសឱ្យគេ មិនមែនសងសឹក ឬគុំគួន
១. គេជាមនុស្សយឺតនឹងខឹង (១៩:១១)
២. គេមានមេត្រីភាព ចិត្តស្រុះស្រួល (១៤:៩)
៣. គេលើកលែងកំហុសចំពោះអស់អ្នកដែលទាស់ខុសនឹងគេ (១០:១២ ១៧:៩)
៤. គេមិនព្យាបាទសងសឹក (២០:២២ ២៤:២៩)

**II. ការទំនាក់ទំនង**

ក. ចំពោះព្រះយេហូវ៉ា
១. គេកោតខ្លាចដល់ព្រះយេហូវ៉ា (៩:១០ ១៤:១៦ ១៥:៣៣)
២. គេទុកចិត្តលើព្រះយេហូវ៉ា (៣:៥ ១៦:៣,២០)
៣. គេជាអ្នកកោតខ្លាចព្រះយេហូវ៉ា (៣:៦)

៤. គេជ្រើសរើសផ្លូវប្រាជ្ញារបស់ព្រះយេហូវ៉ា (៨:១០-១១ ១៧:២៤)
៥. គេបានចុះចូលនឹងសេចក្តីប្រៀនប្រដៅរបស់ព្រះយេហូវ៉ា (១:២-៣ ៣:១១)
៦. ជាអ្នកលន់តួបាបរបស់គេ (២៨:១៣)

ខ. ទំនាក់ទំនងចំពោះគ្រួសា :

១. ចំពោះឪពុកម្តាយ

ក. គោរពដល់ពួកគាត់ (១៧:៦ ដែលខុសគ្នានឹង ៣០:១៧)
ខ. ស្តាប់ដល់ពួកគាត់ (២៣:២២ ធៀប ១:៨ ៤:១)
គ. នាំមកនូវឱ្យពួកគាត់ទទួលនូវកិត្តិយស និងសេចក្តីអំណរ
១. ដោយទទួលបានប្រាជ្ញា (១០:១ ១៥:២០ ២៩:៣)
២. ដោយទទួលបានភាពសុចរិត (២៣:២៤)
៣. ខំប្រឹតប្រមូលទុក (១០:៥)

២. ចំពោះប្រពន្ធ

ក. ឱ្យតម្លៃដល់នាង
១. នាងជាអំណោយទានពីព្រះយេហូវ៉ា (១៨:២២ ១៩:១៤)
២. នាងជាមកុដនៃសេរីល្អដល់ប្តី (១២:៤ ៣១:១០-៣១)
ខ. ប្តីត្រូវសរសើរដល់ប្រពន្ធ (៣១:២៨)
គ. ប្តីត្រូវទុកចិត្តលើប្រពន្ធ (៣១:១១)
ឃ. ប្តីត្រូវស្មោះត្រង់និងប្រពន្ធ (៥:១៥-២០)

៣. ចំពោះកូនរបស់គេ

ក. ត្រូវស្រឡាញ់កូន (៣:១២ ១៣:២៤)
ខ. ខ្វល់ខ្វាយពីកូនទាំនោះ (១:៨-៩:១៨)
គ. បង្ហាត់បង្រៀនពួកគេ (២២:៦)
១. ហេតុផលដែលត្រូវបង្ហាត់ពួកគេ
ក. ឱ្យមានសន្តិភាពផ្លូវចិត្ត និងមានសេចក្តីអំណរ (២៩:១៧)
ខ. គ្រឿងវិសេសលើក្បាលកូននឹងសុខមាលភាព(១:៨-៩ ៤:៩ ១៩:១៣-១៤)
២. ដោយបង្រៀន តម្រងប្រដៅពួកគេ (១:១០ ជំពូក ៥-៧ ២៨:៧ ធៀបនឹង ៤:១៩)
៣. ដោយប្រដៅពួកគេ
ក.ដោយការកែតម្រង់ដោយវាចារចិត្ត (១៣:១)
ខ. ដោយការវាយប្រើរំពាត់ (១៣:២៤ ២៣:១៣-១៤)
គ. ត្រូវផ្តល់ឱ្យកូនៗនូវ :
១. តម្រូវការផ្នែកខាងសាច់ឈាម (២១:២០ ធៀបនឹង ២៧:៣-២៧)
២. ផ្តល់នូវទ្រព្យខាងឯព្រលឹងវិញ្ញាណ (១៤:២៦ ២០:៧)

៣. ការទំនាក់ទំនងចំពោះមិត្ត និងអ្នកជិតខាង

១. ចំពោះមិត្តភ័ក្ររបស់គេ

ក. ត្រូវឱ្យតម្លៃគេទាំងនោះ (២៧:១០)
ខ. គេត្រូវមានភាពស្និទ្ធស្នាល (១៧:១៧ ១៨:២៤)
គ. ត្រូវផ្តល់ជាប្រឹក្សាចំពោះពួកគេ (២៧:៩,១៧ ធៀបនឹង ២៧:៦ ២៨:២៣)

២. ចំពោះអ្នកជិតខាង

ក. គេត្រូវបំពេញកាតព្វកិច្ច (៣:២៧-២៨)
ខ. តស៊ូដើម្បីសន្តិភាព (៣:២៩-៣០)
គ. គេមិនត្រូវបំពានការ ដែលគេរាក់ទាក់រកឡើយ (២៥:១៧)
ឃ. មិនត្រូវបញ្ឆោត ឬក៏បន្ទឹពួកគេឡើយ (១៦:២៩ ២៦:១៨-១៩)

**III. ពាក្យសំដីរបស់អ្នកមានប្រាជ្ញា**

ក. អំណាចនៃពាក្យសំដីរបស់គេ
១. អំណាចរបស់ពួកគេ
ក. អំណាចជីវិតនឹងសេចក្តីស្លាប់ (១២:៦ ១៣:១៤ ១៥:៤ ១៨:២១)
ខ. អំណាចនៃការប្រោសលោះ ឬការឈឺចាប់ (១១:៩,១១ ១២:១៨ ១៥:៤,៣០ ១៦:២៤)
២. ការកំណត់របស់ពួកគេ
ក. គ្មានអ្វីមួយដែលអាចជំនួសទង្វើគេបានឡើយ (១៤:២៣)
ខ. គឺមិនអាចបំផ្លែងការពិតបានទេ (២៦:២៣-២៦)
គ. មិនអាចបដិសេធនៅអ្វីបានមកដល់ (២៩:១៩)
ខ. លក្ខណៈសម្បត្តិនៃពាក្យសម្តីរបស់គេ
១. ពួកគេមានចិត្តស្មោះមិនក្លែងក្លាយ (១២:២២ ១៦:១៣) ។
២. ពួកគេនិយាយតិច មិនច្រើនទេ (១០:១៩)
ក. ឥតមានចិត្តអំនួត (២៧:២)
ខ. មិនចូលចិត្តប្រកែក (១៧:១៤)
គ. មិនចូលចិត្តប្រឈ្លោះ (២៩:៩)
ឃ. មិននិយាយដើមគេ
១. មិននិយាយបកកេរ (១១:១៣ ២០:១៩)
២. មិនបើកកកាយរឿងអាស្រូវ (១០:១៨ ២៦:២០-២២) ។
៣. គេមានចិត្តស្ងាត់ស្ងៀម មិនឆេវឆាវ
ក. ប្រកបដោយវិចារណញ្ញាណ (១៥:២៨ ១៧:២៧)
ខ. ចិត្តសុភាព និងមានភាពស្ងាត់ស្ងៀម (១៥:១,១៨)
គ. ជាអ្នកដែលបញ្ចុះបញ្ចូល(២៥:១៥)
៤. គេជាអ្នកមានភាពវៃឆ្លាត មិនមែនប្រើពាក្យសម្តីខុសពេល (១៥:២៣ ២៥:១១)
គ.. ប្រភពនៃពាក្យសម្តី
១. ទឹកចិត្ត ចរិតលក្ខណៈ (ធៀប ៤:២៣ និង មថ ១២:៣៣-៣៥)
ក. និយាយពីការល្អ គេក៏សុចរិត (ធៀប ១០:១១) ១៣:១៤)
ខ. ពុំមាន ឬគេអត់មាន
១. មានក្តីអំនួត (១៣:១០ ធៀប ៦:១៦-១៩)
២. ឬពុំមានសម្អប់ (២៦:២៤,២៨)
២. គេដើរជាមួយ (១៣:២០ ២៧:១៧)
៣. ប្រាជ្ញាឆ្លើយតប (១៥:២៨)

## សេចក្ដីផ្ដើមៈ គោលបំណង និងខ្លឹមសារ

**១** ១នេះជាសុភាសិត[ក]របស់សាឡូម៉ូន[ខ] ជាព្រះរាជបុត្រនៃ
ដាវីឌ ស្ដេចសាសន៍អ៊ីស្រាអែល[គ] ២សំរាប់ឱ្យបានស្គាល់
ប្រាជ្ញា និងសេចក្ដីប្រៀនប្រដៅ ហើយឱ្យបានយល់អស់ទាំង
សេចក្ដីដែលត្រូវខាងយោបល់ ៣ក៏សំរាប់ឱ្យទទួលសេចក្ដី
បង្រៀននៃគំនិតត្រឹមត្រូវនៃសេចក្ដីសុចរិត សេចក្ដីយុត្តិធម៌
និងសេចក្ដីទៀងត្រង់ ៤ហើយសំរាប់ឱ្យមនុស្សឆោតល្ងង់[ឃ]
មានសេចក្ដីឆ្លៀវឆ្លាត និងឱ្យមនុស្សកំឡោះមានដំរិះ ហើយ
និងសតិបញ្ញានឹងធឹង[ង] ៥ប្រយោជន៍ឱ្យមនុស្សប្រាជ្ញបានស្ដាប់
ហើយចំរើនចំណេះឡើង[ច] ឱ្យអ្នកណាដែលមានយោបល់
បានដឹងដល់សេចក្ដីទូន្មានមាំទាំ ៦ព្រមទាំងឱ្យបានយល់
ពាក្យសុភាសិត និងប្រស្នា[ឆ] អស់ទាំងពាក្យរបស់អ្នកប្រាជ្ញ
និងពាក្យអាថ៌កំបាំង[ជ]ទាំងប៉ុន្មានផង[ឈ]។
៧សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា[ញ] នោះជាដើមចម
នៃដំរិះ តែមនុស្សឥតបើគិត គេមើលងាយប្រាជ្ញា[ដ] និង
សេចក្ដីប្រៀនប្រដៅវិញ[ឋ]។

## ការលើកទឹកចិត្តឱ្យទទួលប្រាជ្ញា

## ការព្រមានអំពីការប៉ងប្រាថ្នា

៨នែ កូនអើយ[ឌ] ចូរស្ដាប់ពាក្យ ប្រៀនប្រដៅរបស់
ឪពុក[ឍ]ចុះ កុំឱ្យកូនបោះបង់ចោលសេចក្ដីដំបូន្មានរបស់ម្ដាយ
ឯងឡើយ[ណ] ៩ដ្បិតសេចក្ដីនោះនឹងបានជាគុណពាក់លើ
ក្បាលឯង ទុកជាគ្រឿងលំអ ហើយជាខ្សែប្រដាប់ពាក់នៅក
ឯង[ត] ១០កូនអើយ បើមនុស្សមានបាបបបួលនាំ[ថ]ឯង នោះកុំ
ព្រមតាម[ទ]គេឡើយ[ធ] ១១បើគេថាចូរមកជាមួយនឹងយើងចុះ
យើងនឹងរង់ចាំ[ន]ឱកាសកំចាយឈាម យើងនឹងអែបលប

**១:១** ក មថ ១៣:៣ ខ ១ពវ ៤:២៩–៣៤ គ សភ ១០:១ ២៥:១ សស ១:១ **១:៤** ឃ សភ ៨:៥ ង សភ ៨:១២ **១:៥** ច សភ ៩:៩ **១:៦** ឆ ទដ ៤៩:៤ មថ ១៣:១០–១៧ ជ ជន ១២:៨ ពច ១៤:១២ ឈ សភ ២២:១៧ ២៤:២៣ **១:៧** ញ នក ២០:២០ យប ២៣:១៥ ទដ ៣៤:៤–២២ ១១២:១ សភ ៩:១០ ១៥:៣៣ អស ៣៣:៦ ៥០:១០ ៥៩:១៩ ដ ចទ ៤:៦ យរ ៨:៩ ឋ សភ ៨:៣៣–៣៦ ៩:៧–៩ ១២:១ ១៣:១៨ ១៥:៣២ **១:៨** ឌ ខ.៨–៩ សភ ២:១ ៣:១ ៤:១ ៥:១ ៦:១ ៧:១ ១៩:២៧ ២២:១៧ ២៣:២៦–២៨ ឍ យរ ៣៥:៨ ណ ចទ ២១:១៨ សភ ៦:២០ **១:៩** ត សភ ៣:២១–២២ ៤:១–៩ **១:១០** ថ យប ២៤:១៥ ទ ចទ ១៣:៨ ធ ខ.១៥ ទដ ១:១ សភ ១៦:២៩ **១:១១** ន ទដ ១០:៨

**១:១** *សាឡូម៉ូន* នេះជាសុភាសិត និងទំនុកចម្រៀង បានសរសេរឡើង ដោយប្រាជ្ញា និងស្មារព្រះហស្តរបស់ស្ដេចសាឡូម៉ូន បានបញ្ជាក់នៅក្នុង ១ពវ ៤:២៩–៣៤ (មើលការពន្យល់នៅក្នុងខនោះ) ។ ឈ្មោះរបស់គាត់ឃើញមានម្ដងទៀត នៅក្នុងជំពូក ១០:១ និង ២៥:១ ។ ធៀបនឹង ៥៥:១ ។

**១:២–៤** នៅក្នុង ខ.២–៣ ឆ្លើយតបចំពោះកូនប្រុស (ឬសិស្ស) ខ.៤ និយាយសំដៅលើឪពុក (ឬគ្រូបង្រៀន) ។

**១:២** *ប្រាជ្ញា និងសេចក្ដីប្រៀនប្រដៅ* គុណធម៌២យ៉ាង គឺឃើញយ៉ាងវែងក្នុងបញ្ជីមួយយ៉ាងច្បាស់ អំពីគោលបំណងនៃព្រះគម្ពីរនេះ (ខ.២–៦) ។ រំឭកនៅចុងបញ្ចប់ក្នុង ខ.៧ វគ្គនៃឃ្លានេះនៅក្នុង (ខ.២–៧) ។ *ប្រាជ្ញា* នេះជាពាក្យដ៏សំខាន់ដែលឃើញមានជាង៤០ដង នៅក្នុងព្រះគម្ពីរនេះ ។ រួមទាំងជំនាញនៅក្នុងការរស់នៅ ដោយដើរតាមផែនការរបស់ព្រះ និងដើម្បីចៀសរួចផុតពីការធ្លាក់ទៅក្នុងរណ្ដៅ ។ សិប្បករ (ជាងហត្ថករ) ត្រូវបានគេឱ្យឈ្មោះថា ជាមនុស្សឆ្លាត (ប៉ិនប្រសប់) ((នក ៣១:១) ។ សុភាសិតបានផ្ដល់ឱ្យមនុស្សនូវប្រាជ្ញា (៤:៥ ធៀបនឹង យក ១:៥ និងការពន្យល់) គឺវាមានតម្លៃជាងប្រាក់ និងមាសទៅទៀត (៣:១៣–១៤) ។ ព្រះគម្ពីរសញ្ញាថ្មីនិយាយសំដៅទៅលើព្រះគ្រីស្ទថា "ជាព្រះដែលមានប្រាជ្ញាមកពីព្រះ" (១កថ ១:៣០ ធៀបនឹង កល ២:៣) ។

**១:៣** *សេចក្ដីសុចរិត សេចក្ដីយុតិធម៌ និងសេចក្ដីទៀតត្រង់* មើល ២:៩ ទដ ១១៩:១២១ និងការពន្យល់ ភល ៤:៨ ។

**១:៤** *សេចក្ដីឆ្លៀវឆ្លាត* នេះជាការជំនុំជម្រះដ៏ល្អរបស់ព្រះ ឬទ្រង់ជាព្រះវិញ្ញាណដ៏ល្អ (មើល ១៥:៣ ១៩:២៥) ។ ក្រៅពីព្រះគម្ពីរសុភាសិត ព្រះគម្ពីរភាសាហេព្រើរ បានប្រើនៅក្នុងន័យអវិជ្ជមានថា "ការមានល្បិចកល" (លប ៣:១ យប ៥:១៣) ។ *ឆោតល្ងង់* នេះជាពាក្យដ៏សំខាន់មួយផ្សេងទៀតនៅក្នុងព្រះគម្ពីរសុភាសិត ឃើញមានប្រហែលជា១៥ដង ។ វានិយាយសំដៅទៅលើអ្នកដែលងាយស្រួល ក្នុងការដែលបញ្ចុះបញ្ចូល អស់អ្នកដែលទទួលនូវការជំនុំជម្រះ (៩:៤,១៦) អស់អ្នកដែលមិនទាន់រីកចម្រើនពេញវ័យនៅក្នុងព្រះ និងអ្នកដែលគ្មានបទពិសោធន៍ ហើយនិងអ្នកដែលឆោតល្ងង់ផងដែរ (ធៀបនឹង ទដ ១៩:៧ និងការពន្យល់) ។

**១:៦** *ប្រស្នា* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ ជួនអាចនិយាយសំដៅទៅលើពាក្យប្រៀបប្រដូច (ធៀបនឹង អគ ១៧:២) ។

**១:៧** សាច់រឿងនៃព្រះគម្ពីរនេះ (មើល ៩:១០ ៣១:៣០ ធៀបនឹង យប ២៨:២៨ ទដ ១១១:១០ និងការពន្យល់) ។ *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* គឺស្រឡាញ់ដល់ព្រះ ចុះចូលចំពោះទ្រង់ និងធ្វើតាមបទបញ្ញត្តិរបស់ទ្រង់ (មើល សស ១២:១៣ និងការពន្យល់ ហើយនិងមើលសេចក្ដីផ្ដើមផងដែរ គោលបំណង និងសេចក្ដីបង្រៀន) មើលការពន្យល់ លប ២០:១១ ។ *មនុស្សឥតបើគិត* ជាមនុស្សដែល "ស្អប់ដល់ចំណេះដឹង" (ខ.២២) និងរាល់ការកែតម្រង់ (១២:១) អស់អ្នកដែល "ឆាប់នឹងបង្ករជម្លោះ" អស់អ្នកដែលសំដែងចេញ "នូវកំហឹងរបស់គេ" (២៩:១១) អស់អ្នកដែលស្អប់ចិត្ត (១:៣២) និងអស់អ្នកដែលទុកចិត្តលើខ្លួន (២៨:២៦) ជាជាងទុកចិត្តលើព្រះ (ទដ ១៤:១) ។ គេមើលងាយប្រាជ្ញា និងសេចក្ដីប្រៀនប្រដៅ មើល ៥:១២ និងការពន្យល់ ។

**១:៨** នេះជាប្រភេទនៃសេចក្ដីផ្ដើមមួយ ចំពោះសេចក្ដីណែនាំពាក្យសុភាសិត ការរំឭកអំពីស្ថានភាពនៅក្នុងគ្រួសារ ដែលឪពុករៀបចំជីវិតរបស់កូនខ្លួននៅលើលោកីយនេះ ។ នៅក្នុងខនេះ និងនៅក្នុង ៦:២១ ម្ដាយគឺត្រូវបានលើកមកពណ៌នាថា ដូចជាគ្រូបង្រៀនផងដែរ ។

**១:៩** *ជាគុណ . . . ទុកជាគ្រឿងលំអរ* មើល ៦:២១ អស់អ្នកដែលដើរតាមប្រាជ្ញា នោះនឹងមានកិត្តិយស និងជីវិតស្រស់ភ្លឺថ្លា ។

**១:១០** *បបួលនាំឯង* ពាក្យនៅក្នុងព្រះគម្ពីរភាសាហេព្រើរ គឺទាក់ទងគ្នាទៅនឹងនាមនៃភាសាហេព្រើរ ដែលគេបានបកប្រែថា "សាមញ្ញ" (មើល ខ.៤ និងការពន្យល់) ។ មនុស្សម្នាក់ដែល "សាមញ្ញ" គឺងាយស្រួលនឹងបញ្ចុះបញ្ចូល មើល ទដ ១៩:៧ និងការពន្យល់ ។

**១:១១** ចូរមកជាមួយ ប៉ុន្តែឪពុកបានផ្ដល់ដំបូន្មានថា "កុំឱ្យទៅជាមួយគេឡើយ" (ខ.១៥) ។ ធៀបនឹង ប្រាជ្ញារបស់ស្ត្រី នៅក្នុង៩:៤–៦ ។ *យើងរង់ចាំឱកាសកំចាយឈាម* គោលដៅរបស់គេ គឺរកទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដោយ

ដោយសិងាត់ ដើម្បីចាប់មនុស្សដែលឥតទោសដោយឥត
ហេតុ ១២ យើងនឹងលេប[ប]គេទាំងរស់ ដូចជាស្ថានឃុំព្រលឹង
មនុស្សស្លាប់ ហើយទាំងមូលផង ដូចជាពួកអ្នកដែលចុះទៅ
ក្នុងរណ្តៅ[ផ] ១៣ យើងនឹងបានប្រទះរបស់មានដំឡៃគ្រប់យ៉ាង
ក៏នឹងបំពេញលំនៅ យើងដោយរបឹប ១៤ ចូរឯងចូលមកក្នុង
ពួកយើងចុះ យើងនឹងមានថង់ប្រាក់តែ១ប៉ុណ្ណោះ[ព] ១៥ កូន
អើយ កុំឱ្យឯងដើរក្នុងផ្លូវជាមួយនឹងគេឡើយ ត្រូវឱ្យឃាត់
ខាំងជើង[ភ]ឯង មិនឱ្យចូលទៅក្នុងផ្លូវច្រករបស់គេវិញ[ម]
១៦ ដ្បិតជើងគេរត់តាមតែសេចក្តីអាក្រក់ទេ[យ] គេក៏រហ័សនឹង
កំចាយឈាមផង[រ] ១៧ ពីព្រោះការដែលដាក់លប់ នៅ
ចំពោះសត្វហើរឱ្យវាឃើញនោះឥតប្រយោជន៍ទេ ១៨ ឯពួក
នេះគេរង់ចាំ[ល]តែនឹងកំចាយឈាមរបស់ខ្លួនគេ ហើយក៏
អែបលបដោយសិងាត់ ដើម្បីតែនឹងបំផ្លាញជីវិតខ្លួនគេវិញ[វ]
១៩ ចំណែកអស់អ្នកដែលលោភចង់បានកំរៃ ក៏យ៉ាងនោះ
ដែរ សេចក្តីនោះនឹងដកយកជីវិតចេញពីអស់អ្នកដែល
បណ្តោយតាមផង[ស]។

## ការព្រមានអំពីការបដិសេធន៍ប្រាជ្ញា

២០ ប្រាជ្ញាតែងបន្លឺឡើងនៅក្នុងផ្លូវ ក៏បញ្ចេញសំឡេង[ហ]នៅ
ទីធ្លា ២១ ប្រាជ្ញាស្រែកប្រកាសនៅទីផ្លូវប្រសព្វទ្រហឹងអឹងកង
នឹងនៅមាត់ទ្វារក្រុង ឯនៅខាងក្នុងទីក្រុង នោះក៏បញ្ចេញ
ពាក្យថា ២២ ឱមនុស្សឆោតល្ងង់[ឡ]អើយ តើនឹងស្រឡាញ់
សេចក្តីឆោតល្ងង់នោះដល់កាលណាទៀត ឯពួកមនុស្ស
ចំអក គេនឹងចូលចិត្តខាងសេចក្តីឡកឡឺយ ហើយមនុស្ស
កំឡៅនឹងចេះតែស្អប់[អ] ដល់ការចេះដឹងដល់កាលណា
២៣ កាលណាអញបន្ទោស នោះចូរឱ្យឯងរាល់គ្នាបែរខ្លួន
ស្តាប់តាមចុះ នែ អញនឹងចាក់វិញ្ញាណអញទៅលើឯងរាល់

**១:១២** ប ទដ ៣៥:២៥ ផ ខ.១៦–១៨ យប ៣៣:១៨ ទដ ៣០:៣ **១:១៤** ព ខ.១៩ **១:១៥** ភ ទដ ១១៩:១០១ ម លប ៤៩:៦ សភ ៤:១៤ **១:១៦** យ យប ១៥:៣១ រ សភ ៦:១៨ អស ៥៩:៧ **១:១៨** ល ទដ ៧១:១០ វ ខ.១១–១២ **១:១៩** ស ខ.១៣–១៤ សភ ៤:១៤–១៧ ១១:១៩

**១:២០** ហ យប ២៨:១២ សភ ៧:១០–១៣ ៩:១–៣,១៣–១៥ **១:២២** ឡ សភ ៦:៣២ ៧:៧ ៨:៥ ៩:៤,១៦ អ ទដ ៥០:១៧

ការលួចឆក់ប្លន់ ឬដោយសារការជិះជាន់ (ខ.១៣,១៩) ហើយគេបានក្លាយទៅជាឃាតក ។ អ្នកនិពន្ធនិយាយអំពីការរកទ្រព្យសម្បត្តិមាន២ចំណុចធំៗ ដែលគេជួបប្រទះកាលពីនៅក្មេង (នៅក្នុងវប្បធម៌មួយ) ជាឧទាហរណ៍មួយអំពីការដើរក្នុងផ្លូវល្ងីល្ងើ ដូចជា (១).មានបានមកពីការកេងចំណេញពីអ្នកដទៃ (២). បានមកពីការសប្បាយ អសីលធម៌ផ្លូវភេទ ជាមួយនឹងស្ត្រីផិតក្បត់ប្តីរបស់គេ ( ១៥:១–៦ ៦:២៤ ៧:៥ ធៀបនឹង ២:១២–១៩) ។

**១:១២** *លេបគេទាំងរស់ ដូចជាស្ថានឃុំមនុស្សស្លាប់* នេះជាការប្រៀបធៀបអំពីកំណាព្យមួយដ៏រស់រវើក ដែលជាសេចក្តីអាម៉ាស់ចំពោះអ្នកដទៃនោះ (ធៀបនឹង ទដ ៤៩:១៤ និងការពន្យល់) ។

**១:១៣** *របស់មានដំឡៃ* ខុសគ្នានៅក្នុងព្រះគម្ពីរសុភាសិតបង្រៀនថា ប្រាជ្ញានាំឱ្យអ្នកមានទ្រព្យសម្បត្តិជាច្រើន (៣:១៣–១៦ ១៦:១៦ មើលផងដែរ យប ២៨:១២–១៩) ។

**១:១៥** *ក្នុងផ្លូវ* ធៀបនឹង ផ្លូវនៃសេចក្តីហិនវិនាសរបស់ស្រីកំផិត នៅក្នុង ២:១៨ (មើលការពន្យល់ក្នុងខនោះ និង ៧:២៥) ។

**១:១៦** ដូចគ្នានឹងបន្ទាត់២ដំបូង នៅក្នុង អស ៥៩:៧ និងខ្លះទៀតបានដកស្រង់នៅក្នុង រម ៣:១៥ ធៀបនឹង សភ ៦:១៧–១៨ ។

**១:១៧** *ដាក់លប់* គេប្រើលប់សម្រាប់ចាប់សត្វហើរ និងសត្វផ្សេងទៀត (មើល ៦:៥ ៧:២៣ សស ៩:១២ អស ៥១:២០ យរ ៥:២៦) ។

**១:១៨** *ដើម្បីតែនឹងបំផ្លាញជីវិតខ្លួនគេវិញ* មើល ខ.១១ ។ មនុស្សអាក្រក់មិនដាក់លប់ឱ្យជើងរបស់ខ្លួនជិពប់ដួលនោះឡើយ (២៩:៦ ទដ ៣៥:៨) ហើយគេឆ្លាតតិចជាងសត្វហើរទៅទៀត (មើល ៧:២២–២៣) ។

**១:១៩** ដោយយោងតាម អស ១៧:១៤ ការបំផ្លិចបំផ្លាញគឺជាទណ្ឌកម្មចំពោះអស់អ្នកដែលលួចឆក់ប្លន់ពីរាស្ត្ររបស់ព្រះ ខុសគ្នាទៅនឹងអស់អ្នកដែលស្អប់សេចក្តីលោភ នោះនឹងចំរើនអាយុយឺនយូរវិញ (២៨:១៦) ។

**១:២០** *ប្រាជ្ញាតែងបន្លឺឡើង* ប្រាជ្ញាផ្ទាល់ខ្លួនតែងបន្លឺជាធម្មតា នៅក្នុង ៨:១–៥ ៩:៤–៦ (មើលការពន្យល់ក្នុង ៨:១–៣៦) ។ *នៅទីធ្លា* នៅក្នុងផ្លូវច្រកប្រសព្វគ្នាក្នុងទីក្រុង (មើល ៨:៣) ។

**១:២១** *មាត់ទ្វារក្រុង* ជាទីកន្លែងដែលអ្នកដឹកនាំនៃទីក្រុងនេះ មកជួបជុំគ្នានៅទីធ្លានេះ (មើល ៣១:២៣ មើលផងដែរ លប ១៩:១) ។ នរ ៤:១ យប ២៩:៧ និងការពន្យល់) និងនៅកន្លែងទីផ្សារ (២ពវ ៧:១) ។ ដូចជាមនុស្សកំលោះប្រឈមមុខជីវិតរបស់ខ្លួនចំពោះសង្គម មានសំឡេងពីរល្បួងជីវិតរបស់គេ គឺ (១). សំឡេងនៃប្រាជ្ញា (បង្ហាញអំពីសេចក្តីបង្រៀនរបស់គ្រូដែលមានប្រាជ្ញា (២). សំឡេងនៃសេចក្តីល្ងង់ខ្លៅ (បង្ហាញអំពីមនុស្សមានបាបនៅក្នុង ខ.១០–១១ និងស្រីក្បត់ចិត្តស្វាមី ៥:៣ ៦:២៤ ៧:៥) នៅក្នុងជីវិតយុវវ័យត្រូវរៀន ដើម្បីឱ្យចេះប្រុងប្រយ័ត្ន នៅក្នុងខនេះ និងនៅក្នុងជំពូក ៨–៩ ប្រាជ្ញានាំឱ្យមានលក្ខណៈគុណសម្បត្តិល្អ ប្រាជ្ញាបន្លឺសំឡេងចេញពីស្ថានសួគ៌មក (ដោយការបើកសម្តែងយ៉ាងពិសេស ដូចជាការបើកសម្តែងដល់ពួកហោរាផងដែរ) មិនមែនសម្លេងចេញពីផែនដី (ដោយសម្លេងមកពីខ្មោច គ្រូខាប មើល ១៩:៣១ ចទ ១៨:១១ ១សយ ២៨:៧–១៩) ប៉ុន្តែចេញពីចំណុចកណ្តាលនៃជីវិតរស់នៅទីក្រុង ដែលជាបទពិសោធន៍នៃការបង្កើតរបស់ព្រះ (គ្រប់របស់ទាំងអស់បានបង្កើតឡើង ដោយសារប្រាជ្ញារបស់ទ្រង់ ៨:២២–៣១) គឺបានសង្កត់ទៅលើ (មើលឧទាហរណ៍ ១១:១០ និងការពន្យល់) ។ និងការគោរពកោតខ្លាចដល់ព្រះ ជាប្រាជ្ញាដ៏ ពិតប្រាកដ ដែលមនុស្សមានបទពិសោធន៍ ក្នុងការសាកល្បងនៃសេចក្តីជំនឿ និងបន្ទាប់មកទ្រង់ប្រទានប្រាជ្ញាដល់គេ ដើម្បីបង្រៀនដល់គេ ដូចជានៅក្នុងព្រះគម្ពីរសុភាសិត ។

**១:២២** *ឯពួកមនុស្សចំអក* អស់អ្នកដែល "មានសេចក្តីអំនួត និងវាយឫកធំ" (២១:២៤) គេចូលចិត្តមើលងាយអ្នកដទៃ មានសេចក្តីសំអប់ និងសង្កត់សង្កិនគេ (៩:៧–៨ ២២:១០ ២៩:៨) គេមិនព្រមទទួលការកែតម្រង់ពីអ្នកណាឡើយ (១៣:១ ១៥:១២) ដែលគេសមនឹងទទួលការវាយផ្ចាល (១៩:២៥ ២១:១១) ។

**១:២៣** *នែ អញនឹងចាក់វិញ្ញាណអញទៅលើឯងរាល់គ្នា* ប្រាជ្ញាគឺដូចជាប្រភពទឹក ប្រាជ្ញានាំឱ្យមានភាពស្រស់ស្រាយជានិច្ច និងជាកំឡាំងដល់យើង (មើល ១:៤ និងការពន្យល់) ។ *វិញ្ញាណអញ* មើល ២:២ ៣:១ ៤:៤ ៥:១២

គ្នា ហើយឱ្យឯងរាល់គ្នាបានយល់ពាក្យអញ ២៤ពីព្រោះអញ
បានស្រែកហៅ[ក] តែឯងរាល់គ្នាមិនព្រមស្ដាប់ទេ[ខ] អញបាន
ហុចដៃទៅ តែឥតមានអ្នកណារវល់សោះ[គ] ២៥ឯងរាល់គ្នា
ក៏បោះបង់ចោលអស់ទាំងដំបូន្មានរបស់អញចេញហើយមិន
ព្រមទទួលពាក្យបន្ទោសរបស់អញដែរ ២៦ដូច្នេះអញនឹង
សើច[ឃ]ដែរ ក្នុងថ្ងៃដែលឯងរាល់គ្នាត្រូវអន្តរាយ[ង] អញនឹង
ចំអកឱ្យ[ច] ក្នុងកាលដែលឯងរាល់គ្នាកើតមានសេចក្ដីភិត
ភ័យផង[ឆ] ២៧គឺក្នុងកាលដែលសេចក្ដីភិតភ័យមកលើឯង
រាល់គ្នា ដូចជាព្យុះសង្ឃរា ហើយសេចក្ដីអន្តរាយ[ជ]របស់
ឯងរាល់គ្នាមក ដូចជាខ្យល់កួច ក្នុងកាលដែលសេចក្ដី
លំបាក និងសេចក្ដីទុក្ខព្រួយមកគ្របសង្កត់លើឯងរាល់គ្នា
២៨ខណនោះ គេនឹងអំពាវនាវដល់អញ តែអញមិនព្រម
ឆ្លើយសោះ[ឈ] គេនឹងស្វែងរកអញអស់ពីចិត្ត តែគេនឹងរក
អញមិនឃើញឡើយ[ញ] ២៩ពីព្រោះគេបានស្អប់ការចេះដឹង
ហើយមិនបានរើសយកសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា
ទេ[ដ] ៣០គេមិនបានយកចិត្តទុកដាក់នឹងបំបូន្មានរបស់អញ
ឡើយ ក៏បានមើលងាយសេចក្ដីបន្ទោសរបស់អញដែរ[ឋ]
៣១ហេតុនោះបានជាត្រូវឱ្យគេស៊ីផលនៃផ្លូវរបស់ខ្លួនគេវិញ
ហើយគេនឹងបានឆ្អែតដោយកិច្ចការរបស់ខ្លួន[ឌ] ៣២ដ្បិតឯ
ពួកឆោតល្ងង់នោះ ការថយទៅវិញរបស់គេនឹងសំឡាប់គេ
ទៅ ហើយចំណែកមនុស្សកំឡៅ នោះសេចក្ដីសុខស្រួល
របស់គេនឹងឱ្យគេវិនាសដែរ[ឍ] ៣៣តែអ្នកណាដែលស្ដាប់
តាមអញ នោះនឹងនៅដោយសេចក្ដីសុខពិត[ណ] ហើយនិង
មានសេចក្ដីសំរាក ឥតភ័យខ្លាចចំពោះការអាក្រក់ឡើយ[ត]។

## ប្រយោជន៍នៃការមានប្រាជ្ញា

**២** ១កូនអើយ[ក] បើឯងនឹងទទួលពាក្យអញ ហើយនិង
ប្រមូលពាក្យបណ្ដាំរបស់អញ ទុកនៅជាប់នឹងឯង ២ដើម្បីឱ្យ
បានប្រុងត្រចៀកស្ដាប់តាមប្រាជ្ញា ហើយផ្ចង់ចិត្តឱ្យបាន
យោបល់[ខ] ៣អើ បើឯងស្រែកហៅរកដំរិះ[គ] ព្រមទាំងបន្លឺ
សំឡេងឡើង សូមឱ្យបានយោបល់ ៤បើឯងខំរកដូចជា
រកប្រាក់ ហើយស្វែងរកដូចជារកកំណប់ទ្រព្យ[ឃ] ៥នោះឯង
នឹងបានយល់សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា ហើយប៉ះ

**១:២៤** ក អស ៦៥:១២ ៦៦:៤ យរ ៧:១៣ ខ យរ ២៦:៥ ៣៥:១៧ ៣៦:៣១ គ ១សយ ៨:១៩ **១:២៦** ឃ ទដ ២:៤ ង ខ.៣៣ ទដ ៥៩:៨ ច ២ពវ ១៩:២១ ឆ ចទ ២៨:៦៣ **១:២៧** ជ ទដ ១៨:១៨ សភ ៥:១២–១៤ **១:២៨** ឈ ចទ ១:៤៥ ១សយ ៨:១៨ យរ ១១:១១ ញ យប ២៧:៩ សភ ៨:១៧ អគ ៨:១៨ ហស ៥:៦ សក ៧:១៣ **១:២៩** ដ យប ២១:១៤ **១:៣០** ឋ ខ.២៥ **១:៣១** ឌ ២របា ៣៦:១៦ សភ ១៤:១៤ យរ ៦:១៩ ១៤:១៦ ២១:១៤ ៣០:១៥ **១:៣២** ឍ សភ ៥:២២ ១៥:១០ អស ៦៦:៤ **១:៣៣** ណ ជន ២៤:២១ ចទ ៣៣:២៨ សភ ៣:២៣ ត ខ.២១–២៦ ទដ ១១២:៨ **២:១** ក សភ ១:៨ **២:២** ខ សភ ២២:១៧ ២៣:១២ **២:៣** គ យក ១:៥ **២:៤** ឃ យប ៣:២១ មថ ១៣:៤៤

៦:១៤ មើលផងដែរ ទដ ៤:៧ និងការពន្យល់ ។

**១:២៤** *មិនព្រមស្ដាប់ទេ* ដូចជាពួកអ៊ីស្រាអែលមិនព្រមស្ដាប់ព្រះអម្ចាស់ (មើល អស ១:៤ ៥:២៤ ហស ២:១៣ ១១:២) ដែលគេស្វែងរកប្រាជ្ញា "ដូចជាការងារទី១របស់គេ" (៨:២២) និងដូចជាបណ្ដាជននៃក្រុងយេរូសាឡិម បានបដិសេធន៍មិនព្រមស្ដាប់ព្រះយេស៊ូវផងដែរ (មើល មថ ២៣:៣៧) នេះគឺសម្ដែងយ៉ាងច្បាស់អំពីប្រាជ្ញារបស់ព្រះ (មើល យហ ១:១–១៤ ១កល ១:១៥–១៧ ២:៣ ហព ១:១–៤ និងការពន្យល់) ។ *អញបានហុចដៃទៅ* ធៀបនឹង អស ៦៥:២ ព្រះបានលូកព្រះហស្ដទៅលើ "មនុស្សរឹងចចេស "ចំពោះមនុស្សរឹងចចេស" ។

**១:២៥** *បោះបង់ចោល . . . ដំបូន្មាន* ធៀបនឹង ៨:៣៣ ។

**១:២៦** *ក្នុងថ្ងៃដែលឯងរាល់គ្នាត្រូវអន្តរាយ* បញ្ជាក់អំពីចិត្តគ្មានក្ដីមេត្តាករុណា និងជាប្រត្តិកម្មមួយដែលមិនសមទំនងរបស់មនុស្សល្ងីល្ងើ ដែលសើចចំពោះប្រាជ្ញា ជ្រើសរើសសេចក្ដីល្ងីល្ងើ និងនាំឱ្យមានសេចក្ដីហិនវិនាសដល់ខ្លួនគេ ធៀបនឹងព្រះអម្ចាស់ទ្រង់ឆ្លើយតបចំពោះស្ដេច ដែលគិតថាទ្រង់អាចបះបោរទាស់នឹងព្រះបាននោះ (ទដ ២:៤) ។ ក្នុងកាលដែលឯងរាល់គ្នាកើតមានសេចក្ដីភិតភ័យផង នេះជាលទ្ធផលអាក្រក់នៃ "កិរិយាអាក្រក់របស់មនុស្សអាក្រក់" (៦:១២–១៥) ។

**១:២៧** *ដូចជាព្យុះសង្ឃរា* មើល ១០:២៥) និងការពន្យល់ ។ ក្នុងកាលដែលសេចក្ដីលំបាក និងសេចក្ដីទុក្ខព្រួយ មើល អស ៨:២២ ។

**១:២៨** តែអញមិនព្រមឆ្លើយសោះ នេះជាការដែលព្រះមិនព្រមឆ្លើយចំពោះអ៊ីស្រាអែល នៅពេលដែលពួកគេធ្វើបាបនឹងព្រះនោះ (មើល ចទ ១:៤៥) អស ១:១៦ និងការពន្យល់) ។ តែគេនឹងរកអញ អស់អ្នកដែលស្វែងរកទ្រង់នោះនឹងស្វែងរកជីវិត និងស្វែងរកព្រះពរ (មើល ខ.៣៣ ៣:១៣) និងមើល ៨:១៧,៣៥) ។

**១:២៩** *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* មើល ខ.៧ និងការពន្យល់ ។

**១:៣១** *ឱ្យគេស៊ីផលនៃផ្លូវរបស់ខ្លួន* នេះគឺវាអាស្រ័យទៅសកម្មភាពរបស់គេ (មើល ១២:១៤ និងការពន្យល់ ១៨:២០ ៣១:៣១ អស ៣:១០) ។ មនុស្សត្រូវកាត់នូវអ្វីដែលគេសាបព្រោះចុះ (លប ៦:៧) ។ *កិច្ចការ* ការដែលបដិសេធន៍ចំពោះដំបូន្មានរបស់ប្រាជ្ញា (ខ.៣០) គឺជាការរងទុក្ខមួយរបស់មនុស្សល្ងីល្ងើ ដែលជា "កិច្ចការមួយ" (ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យ "ដំបូន្មាន" និង "កិច្ចការ" គឺដូចគ្នា) ។

**១:៣២** *សេចក្ដីសុខស្រួល* នេះជាអត្ថន័យនៃសេចក្ដីសុខស្រួលក្លែងក្លាយ (មើល អស ៣២:៩ អម ៦:១ និងការពន្យល់ សជ ១:១២) ។

**១:៣៣** *នោះនឹងនៅដោយសេចក្ដីសុខពិត* ពាក្យនេះបានប្រើអំពីទីកន្លែងមួយដែលមានអំណរចំពោះការការពាររបស់ផងព្រះ (មើល អស ៣២:១៨ អគ ៣៤:២៧) ។

**២:១** *ទុកនៅជាប់នឹងឯង* នេះជាបទទំនុកដម្កើង អំពីការយកព្រះបន្ទូលទៅទុកដាក់ក្នុងចិត្ត ដើម្បីចៀសចេញពីអំពើបាប (ទដ ១១៩:១១) ។

**២:២** *ប្រុងត្រចៀកស្ដាប់* គឺជាការស្ដាប់ដោយយកចិត្តទុកដាក់ជាទីបំផុត និងស្ដាប់បង្គាប់ (អស ៥៥:៣ យរ ១៣:១៥) ។ *ចិត្ត* មើលការពន្យល់ ១:២៣ ។

**២:៣** *ប្រាក់ . . . កំណប់ទ្រព្យ* យប ២៨:១–១១ ពណ៌នាអំពីបច្ចេកទេស ក្នុងការជីកត្បូងរ៉ែនៅសម័យបុរាណ ដោយប្រៀបទៅនឹងការខំរកត្បូងរ៉ែ ឱ្យដូចជាការខំរកប្រាជ្ញា (មើល យប ២៨:១២,២០) ។

**២:៥** *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* មើលការពន្យល់ ១:៧ ។ *សេចក្ដីស្គាល់ដល់ព្រះអង្គ* ការមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះ (ធៀបនឹង ភល ៣:១០ និងការពន្យល់) និងស្គាល់នូវអ្វីដែលទ្រង់បាន បង្រៀនដល់យើង

ប្រទះនឹងសេចក្ដីស្គាល់ដល់ព្រះអង្គ[ង] ៦ដ្បិតព្រះយេហូវ៉ាទ្រង់
ប្រទានឱ្យមានប្រាជ្ញា[ច] ឯដំរិះនឹងយោបល់ នោះចេញពីព្រះ
ឱស្ឋរបស់ទ្រង់មក[ឆ] ៧ទ្រង់បំរុងទុកសេចក្ដីដែលមាន
ប្រយោជន៍ សំរាប់មនុស្សសុចរិត ក៏ជាខែល[ជ]ដល់អស់អ្នក
ដែលដើរក្នុងសេចក្ដីទៀងត្រង់[ឈ] ៨ដើម្បីឱ្យបានរក្សាអស់
ទាំងផ្លូវច្រកនៃសេចក្ដីយុត្តិធម៌ ហើយការពារផ្លូវរបស់ពួក
បរិសុទ្ធរបស់ទ្រង់[ញ] ៩យ៉ាងនោះឯងនឹងបានយល់[ដ]សេចក្ដី
សុចរិត សេចក្ដីយុត្តិធម៌ និងសេចក្ដីទៀងត្រង់ គឺគ្រប់ទាំង
ផ្លូវល្អ ១០ដ្បិត ប្រាជ្ញានឹងចូលមកស្ថិតនៅក្នុងចិត្តឯង[ឋ] ហើយ
ការចេះដឹងនឹងគាប់ចិត្តដល់ឯង ១១គំនិតវាងវៃនឹងការពារ
ឯង ហើយយោបល់នឹងថែរក្សាឯង[ឌ] ១២ដើម្បីនឹងជួយ[ឍ]
ឱ្យឯងរួចពីផ្លូវអាក្រក់ ហើយពីពួកមនុស្សដែលតែងតែ
និយាយពាក្យវៀច ១៣ជាអ្នកដែលបោះបង់ចោលផ្លូវទៀង
ត្រង់ ដើម្បីនឹងដើរតាមផ្លូវងងឹតវិញ[ណ] ១៤ក៏មានចិត្តរីករាយ
ដោយប្រព្រឹត្តការអាក្រក់ ហើយត្រេកអរដោយចិត្តវៀច

**២:៥** ង ចទ ៤:៦
**២:៦** ច យប ១២:១៣ ទដ ១១៩:៣៤ ឆ យប ៩:៤ ២២:២២
**២:៧** ជ លប ១៥:១ សភ ៣០:៥–៦ ឈ លប ៦:៩ ទដ ៨៤:១១
**២:៨** ញ ១សយ ២:៩ ទដ ១៨:២៥ ៩៧:១០
**២:៩** ដ ចទ ១:១៦
**២:១០** ឋ សភ ១៤:៣៣
**២:១១** ឌ សភ ៤:៦
**២:១២** ឍ ខ.១៦ សភ ៣:១៣–១៨ ៤:៥
**២:១៣** ណ សភ ៤:១៩

របស់មនុស្សអាក្រក់[ត] ១៥ផ្លូវគេសុទ្ធតែក្ងិកក្ងក់[ថ] ហើយផ្លូវ
ច្រករបស់គេក៏ទាសចេញ[ទ] ១៦ហើយដើម្បីនឹងជួយឱ្យឯង
រួចពីស្រីអាវ៉ាសែ[ធ] គឺឱ្យរួចពីមនុស្សស្រីដទៃ ដែលនិយាយ
ប្រលោមដោយពាក្យផ្អែមល្ហែម ១៧ជាអ្នកដែលលះចោល
គូសំឡាញ់ ដែលបានគ្នាពីក្រមុំកំឡោះ ក៏ភ្លេចសេចក្ដីសញ្ញា
នៃព្រះរបស់ខ្លួន[ន] ១៨ដ្បិតផ្ទះរបស់ស្ត្រីនោះ ទ្រេតទៅខាង
សេចក្ដីស្លាប់[ប] ហើយផ្លូវច្រករបស់វា នាំទៅឯពួកមនុស្ស
ស្លាប់ ១៩ឯពួកអ្នកដែលទៅឯវា នោះគ្មានអ្នកណាត្រឡប់
មកវិញឡើយ ក៏មិនចាប់កាន់ផ្លូវច្រកនៃជីវិតដែរ[ផ] ២០ហើយ
មានប្រយោជន៍ឱ្យឯងបានដើរក្នុងផ្លូវរបស់មនុស្សល្អ ព្រម
ទាំងរក្សាផ្លូវច្រកនៃពួកសុចរិត ២១ដ្បិតមនុស្ស ទៀងត្រង់
នឹងអាស្រ័យនៅផែនដី[ព] ហើយមនុស្សគ្រប់លក្ខណ៍នឹងបាន

**២:១៤** ត សភ ១០:២៣ ១៥:២១ **២:១៥** ថ ទដ ១២៥:៥ ទ សភ ២១:៨ **២:១៦** ធ សភ ៥:១–៦ ៦:២០–២៩ ៧:៥–២៧ **២:១៧** ន មឡ ២:១៤ **២:១៨** ប សភ ៥:៥ ៧:២៧ ៩:១៨ **២:១៩** ផ សភ ៣:១៦–១៨ ៥:៨ សស ៧:២៦ **២:២១** ព ទដ ៣៧:២៩

(មើល ខ.៦) ។

**២:៧** *ទ្រង់បំរុងទុក* សម្រាប់អស់អ្នក "កាន់តាម"បទបញ្ញត្តិរបស់ទ្រង់ (ខ.១ ) ។ *ខែល* ជួយឱ្យមានជ័យជំនះ នៅក្នុង ទដ ១៨:២,៣៥ ធៀបនឹង សភ ៣០:៥ មើល ទដ ៣:៣ និងការពន្យល់ ។ *សេចក្ដីទៀងត្រង់* ដែលមានសេចក្ដីសុចរិតខាងផ្នែកសីលធម៌ និងខាងផ្នែកព្រលឹងវិញ្ញាណ គឺគ្មានអំពើបាប (មើល ១៩:១) មើល ខ.២១ មើលផងដែរ ទដ ១៥:២ និងការពន្យល់ ។

**២:៨** *បានរក្សា . . . ហើយការពារ* មើល ទដ ៩១:៣–៧,១១–១២ ។

**២:៩–១១** អស់អ្នកដែលបានស្គាល់ដល់ព្រះអម្ចាស់ និងប្រាជ្ញាដែលទ្រង់ប្រទានឱ្យគេនឹងស្គាល់ ហើយដើរតាម (ធៀបនឹង ហព ៥:១១–១៤) ។

**២:៩** *សេចក្ដីសុចរិត សេចក្ដីយុតិធម៌ និងសេចក្ដីទៀងត្រង់* មើល ១:៣ និងការពន្យល់ ។ ផ្លូវល្អ ធៀបនឹង "ផ្លូវនៃសេចក្ដីសុចរិត" នៅក្នុង ទដ ២៣:៣ (និងមើលការពន្យល់នៅក្នុងខនោះ) ។

**២:១០** *នឹងគាប់ចិត្តដល់ឯង* នេះជាពាក្យរបស់មនុស្សដែលមានប្រាជ្ញា "គឺផ្អែមដល់ព្រលឹង" ដល់អ្នកផ្សេងទៀត (មើល ១៦:២៤ និងការពន្យល់ ធៀបនឹង ៣:១៧) ។

**២:១១** *ការពារឯង ហើយយោបល់នឹងថែរក្សាឯង* ដូចជាព្រះអម្ចាស់ថែរក្សាមនុស្សសុចរិត (ខ.៨) ។

**២:១២–១៩** ប្រាជ្ញានឹងសង្គ្រោះគេ ពីសេចក្ដីល្បួងរបស់មនុស្ស ឱ្យដើរតាមផ្លូវរបស់ព្រះ (ខ.១២–១៥) និង "ពីពាក្យល្បួងលួងលោម" នៃសេចក្ដីកំផិត (ខ.១៦–១៩) មើលការពន្យល់ ១:១១ ។

**២:១២** *ពាក្យវៀច* ធៀបនឹង ខ.១៤ នេះជាពាក្យនៃការបោកមនុស្ស ដែលបានបញ្ជាក់នៅក្នុង ៦:១២,១៧ ៨:១៣ ១០:៣១–៣២ ១៧:២០ ១៩:២៨ ។

**២:១៣** *ផ្លូវទៀតត្រង់* មើល ៣:៦ និងការពន្យល់ ៩:១៥ ។ *ផ្លូវងងឹតវិញ* មនុស្សគេស្រឡាញ់សេចក្ដីងងឹត ជាជាងពន្លឺ (មើល យហ ៣:១៩–២១ មើលផងដែរ យក ២៤:១៤–១៧ អស ២៩:១៥ រម ១៣:១២) ។

**២:១៤** *ក៏មានចិត្តរីករាយ . . . ហើយត្រេកអរ . . . មនុស្សអាក្រក់* ដូចជាមនុស្សមានបាបនៅក្នុង ១:១០–១៩ ។

**២:១៥** *ផ្លូវគេសុទ្ធតែក្ងិកក្ងក់* មើល អស ៥៩:៧–៨ ។

**២:១៦** *លះចោលគូសំឡាញ់ ដែលបានគ្នាពីក្រមុំកំឡោះ* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ កើតមានម្តងទៀតនៅក្នុង ៥:២០ និង ៧:៥ កន្សោមពាក្យនេះមានន័យត្រង់ថា "ចម្លែក" និង "ជនបរទេស" (ធៀបនឹង ៥:១០) ពីព្រោះចិត្តរបស់គេមានប្រពន្ធលើសពីមួយ ហើយដូចជាជនបរទេសបានគោរពថ្វាយបង្គំដល់រូបព្រះ (ធៀប ១ពវ ១១:១–២) ។ "ប្រពន្ធមានចិត្តមានះ" គឺដូចគ្នាទៅនឹងពាក្យ "ស្ត្រីដែលគ្មានសីលធម៌" នៅក្នុង ៦:២៤ និង "ជាស្រីសំផឹង" នៅក្នុង ២៣:២៧ ។ *ដែលនិយាយប្រលោម* ដូចគ្នាទៅនឹងពាក្យ "អណ្តាតភ្លើង" នៅក្នុង ៦:២៤ និង " និយាយដោយក្តៅក្រហាយ" នៅក្នុង ៧:២១ ធៀបនឹង ៥:៣ និងការពន្យល់ ។

**២:១៧** *គូសំឡាញ់ ដែលបានគ្នាពីក្រមុំកំឡោះ* ជាប្តីរបស់នាងដែលនាងបានរៀបការ កាលពីនៅវ័យក្រមុំ (ធៀបទៅនឹង អស ៥៤:៦) ក៏ភ្លេចសេចក្ដីសញ្ញានៃព្រះរបស់ខ្លួន នោះគឺជាសេចក្ដីសញ្ញាអំពីអាពាហ៍ពិពាហ៍ ដែលបានប្រកាសនៅចំពោះវត្តមានរបស់ព្រះ (មើល អគ ១៦:៨ មក ២:១៤) ។ ការធ្វើរំលងទៅនឹងក្រិត្យវិន័យទី៧ (នក ២០:១៤) ។

**២:១៨** *ទ្រេតទៅខាងសេចក្ដីស្លាប់* ដោយយោងនៅក្នុង ៧:២៧ "ផ្ទះរបស់នាង គឺជាផ្លូវមួយទៅកាន់សេចក្ដីស្លាប់" ជីវិតដែលគ្មានសីលធម៌ នាំទៅរកសេចក្ដីហិនវិនាស និងសេចក្ដីស្លាប់ សម្រាប់មនុស្សណាដែលដើរតាមផ្លូវនោះ ។ (ធៀបនឹង ៥:៥ ៩:១៨) ។ *នាំទៅឯពួកមនុស្សស្លាប់* មើល យប ២៦:៥ និងការពន្យល់ ត្រូវបញ្ចុះក្នុងថ្នូរ (ស្ថានឃុំព្រលឹងមនុស្សស្លាប់ "ថ្នូរខ្មោច" (៧:២៧) ។

**២:២១** *អាស្រ័យនៅផែនដី* ពូជពង្សរបស់លោកអ័ប្រាហាំ បានទទួលទឹកដីសន្យា គឺស្រុកកាណាន (មើល ១២:៧ ១៧:៨ ចទ ៤:១) និង ទដ ៣៧:២៩ និយាយថា "មនុស្សសុចរិតនឹងទទួលទឹកដីជាកេរ្ត៍មរតក" (មើល ទដ ៣៧:៩, ១១ មថ ៥:៥) ។ *គ្រប់លក្ខណ៍* មើលការពន្យល់ ខ.៧ ។

នៅជាប់ [២២]តែមនុស្សអាក្រក់[ភ]នឹងត្រូវកាត់ឱ្យសូន្យចេញពី
ផែនដីវិញ[ម] ហើយមនុស្សប្រទូសរ៉ាយនឹងត្រូវរំលើងចេញ
ពីស្រុកទៅ[យ]។

## ប្រយោជន៍ផ្សេងទៀតនៃការមានប្រាជ្ញា

**៣** [១]កូនអើយ[ក] កុំភ្លេចឱវាទអញឡើយ[ខ] គួរឱ្យចិត្តឯង កាន់
តាមបណ្តាំរបស់អញទាំងប៉ុន្មាន [២]ដ្បិតសេចក្តីទាំងនោះ
នឹងបន្ថែមឱ្យឯងបានថ្ងៃវែង[គ] និងអាយុយឺនយូរ ព្រមទាំង
សេចក្តីសុខផង[ឃ] [៣]កុំឱ្យសេចក្តីមេត្តា និងសេចក្តីពិត[ង] ចេញ
ពីឯងបាត់ឡើយ ចូរចងសេចក្តីទាំង២នោះនៅកឯងចុះ
ហើយចារិកទុកនៅដួងចិត្តឯងដែរ[ច] [៤]យ៉ាងនោះឯងនឹង
បានប្រកបដោយគុណ និងបំណាងល្អចំពោះព្រះ ហើយ
នឹងមនុស្សផង[ឆ] [៥]ចូរទីពឹងដល់ព្រះយេហូវ៉ា[ជ]ឱ្យអស់អំពីចិត្ត
កុំឱ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ [៦]ត្រូវឱ្យទទួល
ស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់
ទាំងផ្លូវច្រក[ឈ]របស់ឯង[ញ] [៧]កុំឱ្យមើលខ្លួនថាមានប្រាជ្ញា
ឡើយ[ដ] ចូរកោតខ្លាចដល់ព្រះយេហូវ៉ា[ឋ]វិញ ហើយចៀស
ចេញពីសេចក្តីអាក្រក់ទៅ[ឌ] [៨]នោះនឹងបានជាសេចក្តីសុខ
ស្រួលដល់សរសៃឯង[ឍ] ហើយជាធាតុសើមដល់ឆ្អឹងឯង[ណ]
[៩]ចូរថ្វាយកិត្តនាមដល់ព្រះយេហូវ៉ា ដោយទ្រព្យសម្បត្តិ
ហើយនឹងផលដំបូង[ត] ពីសេចក្តីចំរើនរបស់ឯងទាំងអំបាល
ម៉ានចុះ [១០]យ៉ាងនោះ អស់ទាំងជង្រុកឯងនឹងបានពេញ
បរិបូរ[ថ] ឯអស់ទាំងធុងឯង នឹងបានទឹកទំពាំងបាយជូរហូរ
ហៀរផង[ទ] [១១]កូនអើយ[ធ] កុំឱ្យមើលងាយសេចក្តីប្រៀនរបស់
ព្រះយេហូវ៉ាឡើយ[ន] ក៏កុំឱ្យណាយចិត្តនឹងសេចក្តីបន្ទោស
របស់ទ្រង់ដែរ [១២]ដ្បិតអ្នកណាដែលព្រះយេហូវ៉ាទ្រង់

**២:២២** ភ ទដ ៥:៤៥ ម យប ១៨:១៧ យ ចទ ២៨:៦៣ ២៩:២៨ ទដ ៣៧:៩,២៨–២៩ សភ ១០:៣០ **៣:១** ក សភ ១:៨ ខ ទដ ៤៤:១៧ **៣:២** គ ចទ ១១:២១ ឃ ចទ ៥:១៦ ៣០:១៥,១៦ ១ពវ ៣:១៣,១៤ សភ ៩:៦,១០–១១ **៣:៣** ង ទដ ៨៥:១០ ច នក ១៣:៩ ចទ ៦:៦ សភ ៦:២១ ៧:៣ ២កថ ៣:៣ **៣:៤** ឆ ១សយ ២:២៦ លក ២:៥២ **៣:៥** ជ ទដ ៤:៥ **៣:៦** ឈ យប ៣៣:១១ អស ៣០:១១ ញ ទដ ៥:៨ សភ ១៦:៣ អស ៤០:៣ យរ ៤២:៣ **៣:៧** ដ សភ ២៦:៥,១២ អស ៥:២១ ឋ ទដ ១១១:១០ ឌ នក ២០:២០ ចទ ៤:៦ យប ១:១ **៣:៨** ឍ ទដ ៣៨:៣ សភ ៤:២២ ណ យប ២១:២៤ **៣:៩** ត នក ២២:២៩ ចទ ២៦:១–១៥ **៣:១០** ថ ទដ ១៤៤:១៣ ទ យប ២២:២១ យអ ២:២៤ មឡ ៣:១០–១២ **៣:១១** ធ សភ ១:៨–៩ ន យប ៥:១៧

**២:២២** *នឹងត្រូវកាត់ឱ្យសូនចេញពីផែនដីវិញ . . . ត្រូវរំលើងចេញពីស្រុកទៅ* ចទ ២៨:៦៣ ព្រះបានព្រមានថា បើបណ្តាជនបដិសេធន៍ មិនស្តាប់បង្គាប់ទ្រង់ នោះគេនឹងត្រូវដករំលើងចេញពីទឹកដី "មនុស្សអាក្រក់ និងកូនចៅរបស់គេនឹងត្រូវកាត់ចេញ (ទដ ៣៧:៩,២៨) ។

**៣:២** *នឹងអាយុយឺនយូរ* សេចក្តីកោតខ្លាចដល់ព្រះ (១៩:២៣) នាំឱ្យមានសុខភាពល្អដល់រូបកាយ (ខ.៨) និង "ថែមកម្លាំងដល់ជីវិត"(១០:២៧ មើលផងដែរ ៩:១០–១១) ។ *ព្រមទាំងសេចក្តីសុខផង* នៅពេលដែលស្តេចសាឡូម៉ូនបានអធិស្ឋានសុំប្រាជ្ញាព្រះ (១ពវ ៣:៩) ព្រះបានសន្យាប្រទានទ្រព្យសម្បត្តិ ព្រមទាំងអាយុយឺនយូរដល់ទ្រង់ បើសិនជាទ្រង់ស្តាប់ដល់ព្រះ (១ពវ ៣:១៣–១៤) ជាធម្មតាមនុស្សសុចរិត គឺមានសេចក្តីសុខ និងសប្បាយរីករាយ (១២:២១) ប៉ុន្តែជួនកាល មនុស្សអាក្រក់មានកម្លាំងខ្លាំង និងសេចក្តីសុខ (ទដ ៧៣:៣,១២) ក្នុងរយៈពេលខ្លី (ទដ ៣៧:១០,២០,៣៥–៣៦ ៧៣:១៧–១៩) យប ១–២ បង្ហាញផងដែរពីគ្រោះមហន្តរាយ និងសេចក្តីស្លាប់ អាចបំផ្លាញដល់ជីវិតរបស់មនុស្ស ដែលថ្វាយបង្គំដល់រូបព្រះ ។

**៣:៣** *កុំឱ្យសេចក្តីមេត្តា និងសេចក្តីពិតចេញពីឯងបាត់ឡើយ* មើល ទដ ២៦:៣ និងការពន្យល់ ។ *ចូរចងសេចក្តីទាំងនេះនៅកឯង* ដូចជាការពាក់ខ្សែកយ៉ាងស្រស់ស្អាត (ធៀបនឹង ខ.២២ ១:៩ ៣:២២) ។ *ហើយចរិកទុកនៅដួងចិត្តឯង* មើល ៧:៣ ធៀបនិង យរ ៣១:៣៣ និងការពន្យល់ ។ សេចក្តីបង្រៀនទាំងអស់នេះកុំឱ្យឃ្លាតបាត់ចេញពីឯងឡើយ (មើល នក ១៣:៩ ចទ ៦:៨–៩ និងការពន្យល់) ។

**៣:៤** *បានប្រកបដោយគុណ* មើល ៨:៣៥ ១២:២ លប ៦:៨ ។ *ព្រះ ហើយនិងមនុស្សផង* មើល ១សយ ២:២៦ លក ២:៥២ រម ១២:១៧ និងការពន្យល់ ២កថ ៨:២១ ។

**៣:៥** *ចូរទីពឹងដល់ព្រះយេហូវ៉ា* "ប្តេជ្ញាចិត្តដើរតាមផ្លូវរបស់ព្រះអម្ចាស់" (ទដ ៣៧:៥) ដូចជាពួកកង្សយុកោអ៊ីស្រាអែល ដែលបានទុកចិត្តដល់ព្រះ ហើយទ្រង់បានរំដោះពួកគេ (ទដ ២២:២–៥) ។ *ឱ្យអស់អំពីចិត្ត* ដូចជាលោកកាលែប (ជន ១៤:២៤ ចទ ១:៣៦ យប ១៤:៦–១៤) ឬដូចជាស្តេចសេដេគា (អស ៣៨:៣) ។ ស្តេចដាវីឌបានជំរុញលើទឹកចិត្តស្តេចសាឡូម៉ូនឱ្យបម្រើដល់ព្រះអម្ចាស់ "ដោយអស់ពីចិត្ត" (១របា ២៨:៩) ។

**៣:៦** *ត្រូវឱ្យទទួលស្គាល់ទ្រង់* ស្តាប់បង្គាប់ព្រះ និងបម្រើទ្រង់ដោយស្ម័គ្រចិត្ត និងស្មោះត្រង់ (មើល ១របា ២៨:៩ ហស ៤:១ ៦:៣,៦) ។ *នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង* ទ្រង់នឹងរើអស់ទាំងឧបសគ្គ ពីផ្លូវអ្នក និងនាំអ្នកទៅដល់គោលដៅដែលបានកំណត់ (មើល ១១:៥ អស ៤៥:១៣) ។

**៣:៧** *ចូរកោតខ្លាចដល់ព្រះយេហូវ៉ាវិញ ហើយចៀសចេញពីសេចក្តីអាក្រក់ទៅ* ធៀបនឹង លោកយ៉ូប "ជាមនុស្សគ្រប់លក្ខណ៍" និងទៀងត្រង់ (យក ១:១) មើលការពន្យល់ ១:៧ ។

**៣:៨** *ដល់ឆ្អឹងឯង* រូបកាយទាំងមូល កន្លែងផ្សេងទៀត ដំណឹងល្អ និងពាក្យសប្បាយចិត្តនាំឱ្យខ្លួនមានសុខភាពល្អ ទៅដល់ឆ្អឹង (១៥:៣០ ១៦:២៤ ធៀបនឹង ១២:៤ ១៤:៣០ ១៧:២២) ។

**៣:៩** *ហើយនិងផលដំបូង* អ៊ីស្រាអែលគឺត្រូវបានតម្រូវឱ្យនាំយកអស់ទាំងផលផ្លែដំបូងមួយផ្នែក ដូចជាប្រេងអូលីវ ទំពាំងបាយជូរ និង ភោគផលធញ្ញជាតិជូនដល់សង្ឃជារៀងរាល់ឆ្នាំ (មើល លវ ២៣:១០ ជន ១៨:១២–១៣) ។

**៣:១០** *នឹងបានពេញបរិបូរ* សម្រាប់អស់អ្នកដែលនាំយកដង្វាយទៅថ្វាយដល់ព្រះអម្ចាស់ ព្រះសន្យាប្រទានពរគេជាបរិបូរហូរហៀរ រកកន្លែងដាក់ស្ទើរគ្មាន (មើល មក ៣:១០ មើលផងដែរ ចទ ២៨:៨,១២ ២កថ ៩:៦–១១) ។ *ឯអស់ទាំងធុងឯង* មើលការពន្យល់ ហក ២:១៦ ។

**៣:១១–១២** ការព្រមានមួយថា មនុស្សសុចរិត គឺមិនមានសេចក្តីសុខ (មើល ខ.២ និងការពន្យល់) ។ មានពេលសាកល្បង និងមានពេលសាងសងព្រះបង្រៀនដល់គេ (មើល ១២:១ ទដ ១១៩:៧១) ។ ហេព ១២:៥–៨ ដកស្រង់ខទាំង២នេះ ដើម្បីលើកទឹកចិត្ត ដល់អ្នកជឿឱ្យខ្ជាប់ខ្ជួន និងទ្រាំទ្រចំពោះសេចក្តីលំបាក (ហេព ១២:៧) ។ ព្រះដាក់ពិន័យដល់យើង ប្រយោជន៍ជាការល្អដល់យើង (ហេព ១២:១០) ។

ស្រឡាញ់[ប] នោះទ្រង់ក៏ស្តីប្រដៅផង គឺដូចជាឪពុកធ្វើចំពោះ
កូន ដែលជាទីគាប់ចិត្តដល់ខ្លួនដែរ[ផ]។
១៣សប្បាយហើយ អស់អ្នកណាដែលរកបានប្រាជ្ញា
ហើយអ្នកណាដែលខំប្រឹង ទាល់តែបានយោបល់ ១៤ដ្បិត
ការដែលបាន នោះវិសេសជាងបានប្រាក់ទៅទៀត ហើយ
កំរៃអំពីនោះមកក៏ប្រសើរជាងមាសសុទ្ធផង[ព] ១៥ប្រាជ្ញា
នោះមានដំឡៃជាជាងត្បូងទទឹម[ភ] ឥតមានរបស់ណាដែល
ចិត្តឯងប្រាថ្នាចង់បាន ដែលនឹងយកទៅផ្ទឹមឱ្យស្មើបាន
ឡើយ[ម] ១៦មានអាយុវែងនៅដៃស្តាំ[យ] ព្រមទាំងទ្រព្យសម្បត្តិ
នឹងកិត្តិសព្ទនៅដៃឆ្វេងនៃប្រាជ្ញានោះ[រ] ១៧អស់ទាំងផ្លូវរបស់
ប្រាជ្ញា សុទ្ធតែជាផ្លូវសោមនស្ស ហើយអស់ទាំងផ្លូវច្រក
នោះក៏ជាសេចក្តីសុខដែរ[ល] ១៨ប្រាជ្ញាជាដើមឈើនៃជីវិត[វ]
ដល់អស់អ្នកណាដែលចាប់យកបាន ហើយអស់អ្នកណា
ដែលកាន់ខ្ជាប់ ក៏សប្បាយហើយ[ស] ១៩ព្រះយេហូវ៉ាបាន
ប្រតិស្ឋានផែនដី[ហ] ដោយសារប្រាជ្ញា[ឡ] ក៏បានតាំងផ្ទៃមេឃ[អ]
ដោយសារយោបល់ដែរ ២០ដោយសារព្រះដំរិះទ្រង់ នោះ
អស់ទាំងទីជំរៅបានធ្លាយចេញ ហើយពពកក៏ស្រក់ទឹក
សន្សើមមក ២១កូនអើយ[ក] កុំឱ្យសេចក្តីទាំងនេះចេញបាត់
ពីភ្នែកឯងឡើយ ចូររក្សាសេចក្តីដែលមានប្រយោជន៍ នឹង
គំនិតវាងវៃចុះ[ខ] ២២ដូច្នេះសេចក្តីនោះនឹងបានជាជីវិតដល់
ព្រលឹងឯង[គ] ហើយជាគ្រឿងលំអនៅកឯង[ឃ] ២៣នោះឯងនឹង
បានដើរតាមផ្លូវឯង ដោយសេចក្តីសុខ[ង] ហើយជើងឯង
នឹងមិនចំពប់ឡើយ[ច] ២៤កាលណាឯងដេកទៅ[ឆ] នោះនឹងគ្មាន
ភ័យខ្លាចអ្វីសោះ[ជ] អើ ឯងនឹងដេក[ឈ]ទៅ ហើយលក់ស្រួល
២៥កុំឱ្យនឹកខ្លាចក្រែងលោមានហេតុភ័យកើតមកឆាប់ភ្លាម
នោះឡើយ ក៏កុំឱ្យខ្លាច ការហិនវិនាសរបស់ មនុស្សអាក្រក់
ក្នុងកាលដែលកើតមកនោះដែរ ២៦ដ្បិត ព្រះយេហូវ៉ាទ្រង់
នឹងបានជាទីទុកចិត្ត[ញ]ដល់ឯង ទ្រង់នឹងរក្សាជើងឯង[ដ]មិនឱ្យ
ត្រូវជាប់ឡើយ[ឋ]។

**៣:១២** ប សភ ១៣:២៤ វវ ៣:១៩ ផ ចទ ៨:៥ យប ៥:១៧ ហព ១២:៥–៦ **៣:១៤** ព យប ២៨:១៥ សភ ៨:១៩ ១៦:១៦ **៣:១៥** ភ យប ២៨:១៨ ម យប ២៨:១៧–១៩ **៣:១៦** យ លប ១៥:១៥ រ ១ពវ ៣:១៣,១៤ **៣:១៧** ល មថ ១១:២៨–៣០ **៣:១៨** វ លប ២:៩ សភ ១០:១១ វវ ២:៧ ស សភ ២:១២ ៤:៣–៩,៨ ៨:១៧–២១ **៣:១៩** ហ លប ១:៣១ ទដ ១៣៦:៥–៩ ឡ យប ២៨:២៥–២៧ អ សភ ៨:២៧–២៩ **៣:២១** ក សភ ១:៨–៩ ៦:២០ ខ សភ ៤:២០–២២ **៣:២២** គ ចទ ១:៨–៩ ៦:២០ ឃ សភ ១:៨–៩ **៣:២៣** ង សភ ១:៣៣ ច ទដ ៣៧:២៤ ១១៩:១១ សភ ៤:១២ **៣:២៤** ឆ លវ ២៦:៦ ជ ទដ ៩១:៥ ១១២:៨ ឈ យប ១១:១៨ យរ ៣១:២៦ **៣:២៦** ញ ២ពវ ១៨:៥ យប ៤:៦ ដ ១សយ ២:៩ ឋ យប ៥:១៩

**៣:១២** *គឺដូចជាឪពុក* ព្រះបង្រៀនដល់កូនរបស់ទ្រង់អ៊ីស្រាអែល ដោយសាកល្បងគេនាំគេទៅទីរហោស្ថាន អស់រយៈពេល៤០ឆ្នាំ (ចទ ៨:២–៥) ។

**៣:១៣–១៨** កំណាព្យសរសើរអំពីប្រាជ្ញា ដែលចាប់ផ្តើម និងបញ្ចប់ដោយពាក្យ "ព្រះពរ" (ធៀបនឹង យប ៥:១៧) ។

**៣:១៤** *នោះវិសេសជាងបានប្រាក់ទៅទៀត . . . មាសសុទ្ធផង* ទំនុកដម្កើងដូចគ្នាទៅនឹងបទបញ្ញា និងបទបញ្ញត្តិរបស់ព្រះអម្ចាស់ (ទដ ១១៩:៧២, ១២៧) ។

**៣:១៥–១៨** ប្រាជ្ញាខាងពាក្យសំដី ។

**៣:១៥** *ត្បូងទទឹម* មើល ៨:១១ ២០:២៥ ទោះបីជាត្បូងទទឹមមានតម្លៃបំផុតក្តី នៅជំនាន់សម័យបុរាណ គឺគិតថាវាមានតម្លៃថោកជាងប្រាជ្ញាទៅទៀត នៅក្នុង យប ២៨:១៨ "ប្រពន្ធដែលអត្តចរិកដ៏ថ្លៃថ្នូរ" គឺ "មានតម្លៃជាងត្បូងទទឹមទៅទៀត" (៣១:១០ មើលការពន្យល់ ៣១:១០–៣១) ។

**៣:១៦** *មានអាយុវែង* មើលការពន្យល់ ខ.២ ។ *ព្រមទាំងទ្រព្យសម្បត្តិ និងកិត្តិសព្ទ* មើល ៨:១៨ ២២:៤ ។

**៣:១៧** *ជាសេចក្តីសុខដែរ* ព្រះគម្ពីរហេព្រើរសម្រាប់ពាក្យនេះគឺ សាឡូម (Shalom) បានបកប្រែថា "សេចក្តីសុខសាន្ត" នៅក្នុង ខ.២ (មើល ១៦:៧ ទដ ១១៩:១៦៥) ។

**៣:១៨** *ជាដើមនៃជីវិត* ជាប្រភពនៃជីវិត ន័យប្រៀបអំពីពាក្យសំដី (មើលផងដែរ ១១:៣០ ១៣:១២ ១៥:៤) បានហៅថាជាដើមឈើ នៅក្នុងសួនច្បារអេដែន (មើល លប ២:៩ និងការពន្យល់ មើលផងដែរសេចក្តីផ្តើម គោលបំណង និងសេចក្តីបង្រៀន) ។

**៣:១៩–២០** ការពណ៌នាអំពីប្រាជ្ញា ដែលមានតួនាទីក្នុងការធ្វើអ្វីគ្រប់យ៉ាងដោយពេញលេញនៅក្នុង ៨:២២–៣១ (មើលការពន្យល់នៅក្នុងខនោះ) ។ ព្រះបានបង្កើតគ្រប់របស់ទាំងអស់ ដោយសារប្រាជ្ញារបស់ទ្រង់ ដើម្បីរស់នៅដោយមានប្រាជ្ញា គឺត្រូវធ្វើតាមព្រះអម្ចាស់ និងសម្រេចទៅតាមអ្វីដែលទ្រង់តែងតាំងឱ្យយើងធ្វើ ។

**៣:១៩** *ប្រតិស្ឋានផែនដី* មើល ៨:២៩ ។ កិច្ចការរបស់ព្រះនៅក្នុងការបង្កើតផ្ទៃមេឃ និងផែនដី គឺប្រៀបដូចជាការសាងសង់អាគា (មើល ១ពវ ៥:១៧ ៦:៣៧ មើលផងដែរ យប ៣៨:៤–៦ ទដ ២៤:២ និងការពន្យល់ ១០៤:៥ សក ១២:១) ។ *ក៏តាំងផ្ទៃមេឃដោយសារយោបល់* មើល អស ៤២:៥ ៤៨:១៣ និងការពន្យល់ ៥១:១៦ ។

**៣:២០** *បានធ្លាយចេញ* ឬ "បែកធ្លាយ" ព្រះបានបើកផ្លូវទឹក (មើល លប ៧:១១ ៤៩:២៥ ទដ ៧៤:១៥) ។ នោះប្រហែលជានិយាយសំដៅទៅលើការដែលទ្រង់បានបែងចែករវាងទឹកនៅខាងលើ និងទឹកនៅខាងក្រោម (មើល លប ១:៧ ទដ ៤២:៧ និងការពន្យល់) ។ ទឹកសន្សើម ដែលគេជឿថាមានទាំងទឹកភ្លៀងផង ដែរ (មើល ចទ ៣៣:១៣ ២សយ ១:២១) ។

**៣:២២** ហើយជាគ្រឿងលំអនៅកឯង ដូចជាការពាក់ខ្សែកដ៏ស្រស់ស្អាត (មើល ខ.៣ និងការពន្យល់) ។

៣:២៣ ដោយសេចក្តីសុខ ហើយជើងឯងនឹងមិនជំពប់ឡើយ មើល ខ.២៦ ធៀបនឹង ១០:៩ ។

**៣:២៤** *កាលណាឯងដេកទៅ នោះនឹងមិនភ័យខ្លាចអ្វីសោះ* នេះជាការពេញចិត្តផងដែរនៅក្នុងចំណោមសេចក្តីសញ្ញាអំពីព្រះពររបស់ព្រះ (មើល លវ ២៦:៦ យស ១១:១៨–១៩ មីក ៤:៤ សផ ៣:១៣ និងមើល សភ ១:៣៣) ។ *អើ ឯងនឹងដេកទៅ ហើយលក់ស្រួល* មើល ៥:២២ ដទ ៤:៨ ។

**៣:២៥** *ក្រែងលោមានហេតុភ័យ . . . ការហិនវិនាស* ព្រះអម្ចាស់ជាខែលការពារមនុស្សដែលកោតខ្លាចព្រះ ពីព្រួញនៃសេចក្តីស្លាប់ និងជម្ងឺអាសន្នរោគ (មើល ១០:២៥ ទដ ៩១:៣–៨ យប ៥:២១) ។

**៣:២៦** *ទ្រង់នឹងរក្សាជើងឯងមិនឱ្យត្រូវជាប់ឡើយ* ខុសគ្នាទៅនិងអំពើបាប

២៧កាលណាឯងមានកំឡាំងដៃ អាចធ្វើគុណឱ្យអ្នកណា
ដែលគួរផ្តល់ឱ្យ នោះកុំឱ្យបង្ខាំងទុកឡើយ ២៨បើកាលណា
ឯងមានរបស់អ្វីនៅជិតឯង ដែលអ្នកជិតខាងត្រូវការ នោះ
កុំឱ្យនិយាយឡើយថា ទៅសិនចុះ ស្អែកសឹមមក នោះខ្ញុំនឹង
ឱ្យ[ឌ] ២៩កុំឱ្យបង្កើតការអាក្រក់ទាស់នឹងអ្នកជិតខាងឯង ដែល
អាស្រ័យនៅជិតឯងដោយសុខសាន្តនោះឡើយ[ឍ] ៣០បើ
មនុស្សណាមិនបានធ្វើប្រទូស្តដល់ឯង នោះកុំឱ្យតតាំងនឹង
គេដោយឥតហេតុឱ្យសោះ ៣១កុំឱ្យច្រណែន[ណ]នឹងមនុស្ស
ច្រឡោតឡើយ ក៏កុំឱ្យរើសយកផ្លូវប្រព្រឹត្តណាមួយរបស់
គេដែរ ៣២ដ្បិតមនុស្សវៀចជាទីខ្ពើមឆ្អើម[ត]ដល់ព្រះ
យេហូវ៉ា តែឯមនុស្សទៀងត្រង់ នោះទ្រង់ជាមិត្រនឹងគេ
វិញ[ថ] ៣៣សេចក្តីបណ្តាសា[ទ]របស់ព្រះយេហូវ៉ានោះនៅក្នុង
ផ្ទះនៃមនុស្សអាក្រក់[ធ] តែទ្រង់ប្រទានពរដល់ទីលំនៅរបស់
មនុស្សសុចរិតវិញ[ន] ៣៤ទ្រង់តែងមើលងាយ[ប]ដល់ពួកអ្នក
ដែលមើលងាយ[ផ] តែទ្រង់ផ្តល់ព្រះគុណចំពោះមនុស្ស
រាបសាវិញ[ព] ៣៥មនុស្សប្រាជ្ញនឹងគ្រងបានសិរីល្អទុកជា
មរដក តែសេចក្តីអាម៉ាស់ខ្មាសនឹងបានជារង្វាន់ដល់មនុស្ស
ឆោតល្ងង់វិញ ។

## ប្រាជ្ញាជាសេចក្តីសំខាន់លេខ១

**៤** ១កូនទាំងឡាយអើយ[ក] ចូរស្តាប់ដំបូន្មាន[ខ]របស់ម្នាក់
ដែលជាឪពុកហើយ ចូរផ្ចង់ចិត្តឱ្យបានស្គាល់យោបល់[គ]
២ដ្បិតអញឱ្យលទ្ធិដ៏ល្អដល់ឯងរាល់គ្នា ដូច្នេះកុំឱ្យបោះបង់
ចោលឱវាទអញឡើយ ៣ដ្បិតពីដើមអញជាកូនរបស់ឪពុក
អញដែរ គឺជាកូនទន់ខ្ចី ជាទីស្រឡាញ់បណ្តាច់ដល់ម្តាយអញ
៤ឪពុកបានបង្រៀនអញដោយពាក្យថា ចូរឱ្យចិត្តកូនរក្សា
ទុកអស់ទាំងពាក្យរបស់ឪពុកចុះ ចូររក្សា[ឃ]អស់ទាំងបណ្តាំ
របស់អញ ដើម្បីឱ្យកូនបានរស់នៅ[ង] ៥ចូរខំឱ្យបានប្រាជ្ញា[ច]
ចូរខំឱ្យបានយោបល់ កុំឱ្យភ្លេចឡើយ ក៏កុំឱ្យបែរចេញពី
ពាក្យដែលមាត់អញពោលដែរ ៦កុំឱ្យចោលប្រាជ្ញាឡើយ
នោះនឹងការពារឯង[ឆ] ចូរស្រឡាញ់ប្រាជ្ញាចុះ នោះនឹង
ទំនុកបំរុងឯង[ជ] ៧ប្រាជ្ញាជាសំខាន់លេខ១ ដូច្នេះចូរខំឱ្យ
បានប្រាជ្ញាចុះ អើ កំពុងដែលខំឱ្យបានរបស់ផ្សេងៗ[ឈ] នោះ
ចូរខំឱ្យបានយោបល់ផង[ញ] ៨ចូរដំកើងប្រាជ្ញាឱ្យខ្ពស់ឡើង
នោះនឹងឱ្យឯងខ្ពស់ឡើងដែរ ក៏នឹងនាំឱ្យឯងបានកិត្តិសព្ទ
ដោយឯងឱបក្រសោបជាប់[ដ] ៩ប្រាជ្ញានឹងបំពាក់គ្រឿងដ៏
វិសេសលើក្បាលឯង ហើយនិងឱ្យឯងពាក់សិរីល្អទុកជា
មកុដ[ឋ] ។
១០ចូរស្តាប់ កូនអើយ[ឌ] ហើយទទួលពាក្យរបស់អញចុះ

**៣:២៨** ឌ លវ ១៩:១៣ ចទ ២៤:១៥ លក ១០:២៥-៣៧ **៣:២៩** ឍ សក ៨:១៧ **៣:៣១** ណ ទដ ៣៧:១ សភ ២៤:១-២ **៣:៣២** ត ទដ ១០១:៤ ថ យប ២៩:៤ **៣:៣៣** ទ យប ៥:៣ ធ សក ៥:៤ ន ទដ ៣៧:២២ សភ ១៤:១១ **៣:៣៤** ប ២ពវ ១៩:២១ ផ ទដ ៤០:៤ ព ទដ ១៨:២៥-២៧ មថ ២៣:១២ យក ៤:៦ ១ពត ៥:៥ **៤:១** ក សភ ១:៨ ខ សភ ១៩:២០ គ យប ៨:១០ **៤:៤** ឃ ១ពវ ៩:៤ ង សភ ៧:២ **៤:៥** ច សភ ២:១២ ៣:១៣-១៨ **៤:៦** ឆ ២ថន ២:១០ ជ សភ ២:១១ **៤:៧** ឈ មថ ១៣:៤៤-៤៦ ញ សភ ២៣:២៣ **៤:៨** ដ សភ ១:៨-៩ **៤:៩** ឋ សភ ១:៨-៩ **៤:១០** ឌ ទដ ៣៤:១១-១៦ សភ ១:៨-៩

របស់មនុស្សល្ងីល្ងើ នៅក្នុង ១:១៨ ៧:២២-២៣ ។

**៣:២៧** *អាចធ្វើគុណ* មើល កច ៩:៣៦ កទ ៦:១០ ១យហ ៣:១៧-១៨ ។ *ឱ្យអ្នកណា ដែលគួរផ្តល់ឱ្យ* ជាពិសេសអ្នកក្រីក្រ និងអ្នកដែលខ្វះខាត ។

**៣:២៨** មើល លក ១១:៥-៨ យក ២:១៥-១៦ ។

**៣:៣០** *នោះកុំឱ្យតតាំងនឹងគេដោយឥតហេតុឱ្យសោះ* មើល យប ២:៣ ។

**៣:៣១** *កុំឱ្យច្រណែន* មើល ២៣:១៧ ២៤:១៩ ទដ ៣៧:១,៧ ។ *មនុស្សច្រឡោតឡើយ* ដូចជាមនុស្សមានបាប ១:១០-១៩ (ធៀបនឹង ១៦:២) ។

**៣:៣២** *ជាទីខ្ពើមឆ្អើម* ពាក្យនេះដែលនៅកន្លែងផ្សេងទៀតបញ្ជាក់ថា គួរឱ្យស្អប់ខ្ពើមចំពោះអ្នកដែលមិនព្រមជឿលើព្រះ (ចទ ១៨:៩,១២) និងការរំលោភបំពានផ្នែកសីលធម៌ ។ វាគឺជារឿងសាមញ្ញនៅក្នុង សភ (ឧ. ៦:១៦ ៨:៧ ១១:២០) ។ តែឯមនុស្សទៀតត្រង់ នោះទ្រង់ជាមិត្តនឹងគេវិញ មើល លប ១៨:១៧ និងការពន្យល់ យប ២៩:៤ ទដ ២៥:១៤ អម ៣:៧ យហ ១៥:១៥ ។

**៣:៣៣** ភាពខុសគ្នាគឺឃើញផងដែរនៅក្នុង ចទ ១១:២៦-២៨ ។ *សេចក្តីបណ្តាសារបស់ព្រះយេហូវ៉ានោះនៅក្នុងផ្ទះរបស់មនុស្សអាក្រក់* មើល យស ៧:២៤-២៥ សក ៥:៣-៤ ។ *តែទ្រង់ផ្តល់ប្រទានពរដល់ទីលំនៅរបស់មនុស្សសុចរិតវិញ* មើល យស ៤២:១២-១៤ ។

**៣:៣៤** *ទ្រង់តែងមើលងាយដល់ពួកអ្នកដែលមើលងាយ* មើលការពន្យល់ ១:២៦ ។ *ព្រះគុណ* បង្ហាញពីការពេញចិត្ត(មើល ខ.៤)។ ទាំងលោកយ៉ាកុប និងលោកពេត្រុស បានដកស្រង់នៅក្នុងខនេះ (យក ៤:៦ ១ពត ៥:៥) ។

**៤:៣** *គឺជាកូនទន់ខ្ចី* ធៀបនឹងពាក្យរបស់ស្តេចដាវីឌ ចំពោះសាឡូម៉ូន កាលពី "នៅវ័យក្មេង និងមិនទាន់មានបទពិសោធន៍" (១រប ២២:៥ ២៩:១) ។ នេះគឺជាផ្នែក១នៃសេចក្តីថ្លែងប្រវត្តិរូប ដូចជាជួនកាលគឺបានប្រើដោយ គ្រូដែលមានប្រាជ្ញា (មើល ២៤:៣០-៣៤ មើលព្រះគម្ពីរសាស្តាផងដែរ) ។ *ជាទីស្រឡាញ់* នេះជាសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅ (ធៀបនឹង លប ៣៧:៣ យរ ៦:២៦ និងការពន្យល់ សក ១២:១០) ។

**៤:៤** *ចូរឱ្យចិត្តកូនរក្សាទុក* មើលការពន្យល់ ៣:៥ ។

**៤:៦** *នោះនឹងការពារឯង . . . នោះនឹងទំនុកបំរុងឯង* ព្រះគម្ពីរភាសាហេព្រើរសម្រាប់កិរិយាសព្ទទាំង២នេះ កើតឡើងព្រមគ្នានៅ ២:៨,១១ ។ *ចូរស្រឡាញ់ប្រាជ្ញាចុះ* ស្រឡាញ់ប្រាជ្ញា គឺនាំឱ្យមានភាពសំបូរសប្បាយ (៨:២១) រីឯការដែលស្អប់ដល់ប្រាជ្ញា នោះគឺ "ស្រឡាញ់សេចក្តីស្លាប់" (៨:៣៦) ។

**៤:៧** *លំដាប់លេខ១* ឬ "ចំណាត់ថ្នាក់លេខ១" បានបកប្រែថា "គឺការចាប់ផ្តើមដំបូងគេ" នៅក្នុង ១:៧ ។ *អើ កំពុងដែលខំឱ្យបានរបស់ផ្សេងៗ* ធៀបនឹងនេះជាពាក្យប្រៀបធៀប អំពីការលាក់កំណប់ទ្រព្យទុក និងកែវមុក្តា នៅក្នុង ១៣:៤៤-៤៦ (មើលការពន្យល់នៅក្នុងខនោះ) ។

**៤:៩** *ពាក់សិរីល្អទុកជាមកុដ* កម្រងផ្កា និងមកុត គឺគេបានពាក់នៅក្នុងឱកាសកម្មវិធីសប្បាយរីរាយអ្វីមួយ ដូចជាក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ និងពិធីជប់លៀងណាមួយ (មើល បស ៣:១១ អគ ១៦:១២ ២៣:៤២ ធៀបនឹង ១ពត ៥:៤) ។

នោះឆ្នាំនៃអាយុឯងនឹងបានយឺនយូរ[ល] ១១អញបានបង្រៀន[ណ]
ឯងក្នុងផ្លូវនៃប្រាជ្ញា អញបាននាំឯងទៅក្នុងអស់ទាំងផ្លូវច្រក
នៃសេចក្តីទៀងត្រង់[ត] ១២កាលណាឯងដើរទៅ នោះជំហាន
ឯងនឹងមិនទើសទាល់ ហើយកាលណាឯងរត់ នោះឯងនឹង
មិនចំពប់ឡើយ[ថ] ១៣ចូរតោងជាប់តាមសេចក្តីដំបូន្មាន កុំ
លែងឱ្យសោះ ត្រូវឱ្យរក្សាទុក ដ្បិតសេចក្តីនោះ ជាជីវិត
របស់ឯង[ទ] ១៤កុំឱ្យចូលក្នុងផ្លូវរបស់មនុស្សអាក្រក់ឡើយ
ក៏កុំឱ្យដើរតាមផ្លូវរបស់មនុស្សដែលប្រព្រឹត្តអាក្រក់ដែរ[ធ]
១៥ចូរចៀសចេញ កុំឱ្យដើរជិតផ្លូវនោះឱ្យសោះ ត្រូវឱ្យ
ងាកចេញ ហើយបង្ហួសទៅឱ្យផុត ១៦ដ្បិតពួកនោះ គេមិន
ដេកឡើយ ទាល់តែបានធ្វើអំពើអាក្រក់ជាមុនសិន[ន] ហើយ
បើគេមិនបានធ្វើឱ្យមនុស្សណាដួល នោះគេក៏ដេកមិន
លក់ដែរ ១៧ពីព្រោះគេបរិភោគអាហារ ជាផលនៃការ
អាក្រក់ ហើយផឹកស្រាទំពាំងបាយជូរ ជាផលនៃការ
ច្រឡោត[ប] ១៨តែផ្លូវរបស់មនុស្សសុចរិត[ផ] ធៀបដូចជាពន្លឺ
ដែលកំពុងតែរះឡើង[ព] ដែលភ្លឺកាន់តែខ្លាំងឡើង ដរាប
ដល់ពេញកំឡាំង[ភ] ១៩ឯផ្លូវរបស់មនុស្សអាក្រក់ នោះធៀប
ដូចជាសេចក្តីងងឹតវិញ[ម] គេមិនដឹងជាចំពប់នឹងអ្វីទេ[យ]។
២០កូនអើយ[រ] ចូរប្រុងស្តាប់អស់ទាំងពាក្យរបស់អញ
ហើយផ្ទៀងត្រចៀកស្តាប់សេចក្តី ដែលអញពោលទាំង
អំបាលម៉ាន[ល] ២១កុំឱ្យសេចក្តីទាំងនោះឃ្លាតបាត់ពីភ្នែកឯង
ឡើយ[វ] ត្រូវឱ្យរក្សាទុកនៅកណ្តាលដួងចិត្តឯងវិញ ២២ដ្បិត
សេចក្តីទាំងនោះ ជាជីវិតដល់អស់អ្នកណាដែលស្វែងរក
បាន ក៏ជាសេចក្តីសុខស្រួល ដល់ខ្លួនប្រាណទាំងមូលផង[ស]
២៣ចូររក្សា[ហ]ចិត្ត ដោយអស់ពីព្យាយាម ដ្បិតអស់ទាំងផល
នៃជីវិត សុទ្ធតែចេញពីក្នុងចិត្តមក[ឡ] ២៤ចូរបោះបង់ចោល
មាត់ដែលពោលពាក្យវៀចចេញពីឯងទៅ ព្រមទាំងបបូរ
មាត់ខូចឱ្យនៅឆ្ងាយពីឯងផង ២៥ចូរឱ្យភ្នែកឯង[អ] មើលចំ
ទៅមុខ ហើយត្របកភ្នែកឯងត្រង់ទៅមុខដែរ ២៦ត្រូវឱ្យ
ពិចារណាផ្លូវដែលជើង[ក]ឯងដើរ ហើយចាត់ចែងឱ្យអស់
ទាំងផ្លូវឯងបានត្រឹមត្រូវចុះ ២៧កុំឱ្យងាកបែរទៅខាងស្តាំ
ឬខាងឆ្វេងឡើយ[ខ] ត្រូវឱ្យជើងឯងចៀសចេញពីសេចក្តី
អាក្រក់វិញ ។

## ការព្រមានអំពីការផិតក្បត់

**៥** ១កូនអើយ[ក] ចូរផ្ចង់ចិត្តចំពោះប្រាជ្ញារបស់អញ ហើយ
ផ្ទៀងត្រចៀកចំពោះយោបល់[ខ]អញដែរ ២ដើម្បីឱ្យឯងបាន

**៤:១០** ល ចទ ១១:២១ **៤:១១** ណ ១សយ ១២:២៣ ត ២សយ ២២:៣៧ ទដ ៥:៨ **៤:១២** ថ យប ១៨:៧ សភ ៣:២៣ **៤:១៣** ទ សភ ៣:២២ **៤:១៤** ធ ទដ ១:១ សភ ១:១៥ **៤:១៦** ន ទដ ៣៦:៤ មីក ៧:៣ **៤:១៧** ប លប ៤៩:៥ ទដ ៧៣:៦ សភ ១:១០–១៩ ១៤:២២ អស ៥៩:៦ យរ ២២:៣ ហព ១:២ មឡ ២:១៦ **៤:១៨** ផ យប ១៧:៩ ព យប ២២:២៨ ភ ២សយ ២៣:៤ ដយ ១២:៣ មថ ៥:១៤ យហ ៨:១២ ភល ២:១៥ **៤:១៩** ម សភ ២:១៣

យ ចទ ៣២:៣៥ យប ៣:២៣ សភ ១៣:៩ អស ៨:១៥ **៤:២០** រ ទដ ៣៤:១១–១៦ សភ ១:៨–៩ ល សភ ៥:១ **៤:២១** វ សភ ៣:២១ **៤:២២** ស សភ ៣:៨ **៤:២៣** ហ ២ពវ ១០:៣១ ឡ សភ ១០:១១ លក ៦:៤៥ **៤:២៥** អ យប ៣១:១ **៤:២៦** ក ហព ១២:១៣ **៤:២៧** ខ លវ ១០:១១ ចទ ៥:៣២ **៥:១** ក សភ ១:៨ ខ សភ ៤:២០

**៤:១០** *នោះឆ្នាំនៃអាយុឯងនឹងបានយឺនយូរ* មើលការពន្យល់ ៣:២ ។

**៤:១១** *អស់ទាំងផ្លូវច្រកនៃសេចក្តីទៀងត្រង់* គឺជាផ្លូវដ៏ត្រឹមត្រូវ (មើលការពន្យល់ ៣:៦ ទដ ២៣:៣) ។

**៤:១២** *នោះឯងនឹងមិនជំពប់ឡើយ* ដោយសារបញ្ហាឧបសគ្គ ឬការខ្វះនូវពន្លឺ (មើល ខ.១៩ ៣:២៣ ១០:៩ ទដ ១៨:៣៦ អស ៥:២៧ ៤០:៣០–៣១) ។

**៤:១៤** *ផ្លូវរបស់មនុស្សអាក្រក់ឡើយ* ធៀបនឹងផ្លូវនៃសេចក្តីហិនវិនាសរបស់ស្រីសំផឹង នៅក្នុង ២:១៨ ៧:២៥ មើល ទដ ១:១ ១៧:៤–៥ ។

**៤:១៦** *ដ្បិតពួកនោះគេមិនដេកឡើយ ទាល់តែបានធ្វើអំពើអាក្រក់ជាមុនសិន* មើល ទដ ៣៦:៤ និងការពន្យល់ មីក ២:១ ខុសគ្នាទៅនឹងឥរិយាបថរបស់ស្តេចដាវីឌ ទ្រង់មិនទាន់ផ្ទុំ ទាល់តែទ្រង់បានរកដំណាក់ជាអចិន្ត្រៃរបស់ផងព្រះយេហូវ៉ាជាមុនសិន (ទដ ១៣២:៣–៥) ។

**៤:១៧** *គេបរិភោគអាហារ . . . ហើយផឹកស្រាទំពាំងបាយជូរ* គេប្រព្រឹត្តដោយសេចក្តីច្រឡោត និងការអាក្រក់ (មើល ១៣:២ យស ១៥:១៦ ធៀបនឹង ទដ ១០៩:១៨ និងការពន្យល់) ។

**៤:១៨** *តែផ្លូវរបស់មនុស្សសុចរិត . . . ដែលភ្លឺកាន់តែខ្លាំងឡើង* មនុស្សដែលកោតខ្លាចព្រះ ទ្រង់តែងតែដឹកនាំ និងការពារពួកគេ (មើល ខ.១១–១២) និងអាចដឹកនាំអ្នកដទៃទៀតប្រព្រឹត្តដោយសេចក្តីទៀងត្រង់ផងដែរ (ដយ ១២:៣) ។

**៤:១៩** *ជាសេចក្តីងងឹត* ផ្លូវគួរឱ្យគ្រោះថ្នាក់ នាំទៅរកសេចក្តីហិនវិនាស (មើលការពន្យល់ ២:១៣ មើលផងដែរ អស ៥៩:៩–១០ តរ ២៣:១២ យហ ១១:១០ ១២:៣៥) ។

**៤:២១** *ដួងចិត្ត* មើល ៣:១,៣) ។

**៤:២២** *ជាសេចក្តីសុខស្រួល* ខាងផ្នែករាងកាយ ផ្នែកចិត្តសាស្ត្រ និងខាងផ្នែកព្រលឹងវិញ្ញាណ (មើល ៣:៨ និងការពន្យល់) ។

**៤:២៣** *ដ្បិតអស់ទាំងផលនៃជីវិត* ប្រសិនបើសិនរក្សាទុកនូវគ្រប់ទាំងការល្អ (២:១) នៅក្នុងចិត្ត នោះពាក្យសំដី និងការប្រព្រឹត្តរបស់យើងចេញតែការល្អ "គឺពាក្យសំដីនិយាយហូរចេញពីក្នុងចិត្ត" (មថ ១២:៣៤ ធៀបនឹង មក ៧:២១) ។

**៤:២៤** *ចូរបោះបង់ចោលមាត់ដែលពោលពាក្យវៀចចេញពីឯងទៅ* មើលការពន្យល់ ២:១២ មើលផងដែរ ១៩:១ ។ *បបូរមាត់ខូច* មើល ៦:១២ ១៩:២៨ អក ៤:២៩ និងការពន្យល់ យក ៣:៦ ។

**៤:២៥** *មើលចំទៅមុខ* មិនមែនមើលទៅឯ "សេចក្តីហិនវិនាសនោះឡើយ" (ទដ ១១៩:៣៧) ។

**៤:២៦** *ហើយចាត់ចែងឱ្យអស់ទាំងផ្លូវឯងបានត្រឹមត្រូវចុះ* រើចេញរាល់ឧបសគ្គខាងផ្នែកសីលធម៌ (សូមមើល ខ.១១–១២ អស ២៦:៧ និងការពន្យល់) ។ ហព ១២:១៣ បានដកស្រង់ខនេះពាក់កណ្តាលនៅក្នុងខនេះ (មើលការពន្យល់) ។

**៤:២៧** *កុំឱ្យងាកបែរទៅខាងស្តាំ ឬខាងឆ្វេងឡើយ* នេះជាការព្រមានមួយបានរកឃើញផងដែរនៅក្នុង ចទ ៥:៣២–៣៣ ២៨:១៤ យស ១:៧ ។ *ត្រូវឱ្យជើងឯងចៀសចេញពីសេចក្តីអាក្រក់វិញ* មើល ១:១៥ ។

បំរុងទុកនូវគំនិតវាងវៃ ហើយឱ្យបបូរមាត់ឯងបានរក្សាទុក
នូវដំរិះ ៣ដ្បិតបបូរមាត់របស់ស្ត្រីដទៃ រមែងស្រក់ជាទឹកឃ្មុំ
ហើយមាត់វារឥលជាងប្រេង[គ] ៤ប៉ុន្តែដល់ចុងបំផុតបាន
ល្វីងដូចជាស្លែង[ឃ] ហើយមុតដូចជាដាវមានមុខ២វិញ
៥ជើងវាដើរចុះទៅឯសេចក្ដីស្លាប់ ជំហានវាឈានទៅជាប់
នៅស្ថានឃុំព្រលឹងមនុស្សស្លាប់[ង] ៦អស់ទាំងផ្លូវប្រព្រឹត្តរបស់
វា តែងតែប្រែប្រួល ដើម្បីមិនឱ្យឯងអាចស្គាល់បានក្រែង
ឯងស្ទង់មើលផ្លូវនៃជីវិតឃើញ[ច] ។

៧ដូច្នេះ កូនទាំងឡាយអើយ ចូរស្ដាប់[ឆ]អញឥឡូវចុះ
កុំឱ្យងាកបែរចេញ ពីអស់ទាំងពាក្យ ដែលមាត់អញពោល
ឡើយ ៨ចូរឯងញែកផ្លូវដើររបស់ឯងឱ្យឆ្ងាយពីវាចេញ[ជ] កុំ
ឱ្យចូលទៅជិតទ្វារផ្ទះរបស់វាឱ្យសោះ ៩ក្រែងឯងប្រគល់
កិត្តិសព្ទឯងដល់អ្នកដទៃ ហើយអាយុឯងដល់ពួកសាហាវ
១០ក្រែងមនុស្សដទៃបានឆ្អែតដោយកំឡាំងឯង ហើយការ
នឿយលំបាករបស់ឯង ត្រូវធ្វើនៅក្នុងផ្ទះរបស់មនុស្សក្រៅ
វិញ[ឈ] ១១រួចដល់ចុងបំផុត ឯងនឹងត្រូវថ្ងូរ ក្នុងកាលដែល
សាច់ឈាម ហើយខ្លួនប្រាណឯងរោយរុះទៅ ១២ហើយ
ឯងថា អុញ្ជន់ អញបានស្អប់សេចក្ដីប្រៀនប្រដៅណាស់ ហ្ន៎
ចិត្តអញក៏បានខ្នើមសេចក្ដីបន្ទោស[ញ] ១៣ហើយអញមិន
បានស្ដាប់តាមសំដីនៃគ្រូរបស់អញ ឬផ្ទៀងត្រចៀកចំពោះ
ពួកអ្នកដែលរំឭកអញផងដែរ ១៤អញស្ទើរតែនឹងចូលទៅ
ក្នុងអស់ទាំងអំពើអាក្រក់ហើយ[ដ] គឺនៅកណ្ដាលចំណោម
មនុស្ស និងពួកជំនុំផង[ឋ] ។

១៥ចូរផឹកទឹកពីពាងរបស់ខ្លួនឯង ព្រមទាំងទឹកដែល
ហូរចេញពីអណ្ដូងរបស់ខ្លួនចុះ ១៦តើគួរឱ្យរន្ធទឹកឯងហូរ
សាចចេញទៅក្រៅ ហើយគន្លងទឹកឯងហូរទៅក្នុងផ្លូវឬអី
១៧ត្រូវឱ្យទុកសំរាប់ខ្លួនឯងតែ១ប៉ុណ្ណោះ មិនមែនសំរាប់

**៥:៣** គ ទដ ៥៥:២១ សភ ៧:៥
**៥:៤** ឃ សស ៧:២៦
**៥:៥** ង ទដ ៩:១៧ សភ ២:១៨ ៧:២៦–២៧
**៥:៦** ច សភ ៩:១៣ ៣០:២០
**៥:៧** ឆ សភ ១:៨–៩
**៥:៨** ជ សភ ២:១៦–១៩ ៦:២០–២៩ ៧:១–២៧
**៥:១០** ឈ សភ ២៩:៣
**៥:១២** ញ សភ ១២:១
**៥:១៤** ដ សភ ១:២៤–២៧ ៦:៣៣ ឋ សភ ៣១:៣

**៥:២** *បបូរមាត់ឯងបានរក្សាទុកនូវដំរិះ* គឺជាប្រព្រឹត្តរបស់សង្ឃ មើលនៅក្នុង មឡ ២:៧ ។

**៥:៣** *បបូរមាត់... រមែងស្រក់ជាទឹកឃ្មុំ* គឺជាសេចក្ដីបញ្ជាក់ទៅលើសម្លេងគួរឱ្យរីករាយចិត្ត (ធៀបនឹង ១៦:២៤) នៃការផិតក្បត់ដូចជាការថើប (ធៀបនឹង បស ៤:១១ ៥:១៣ ៧:៩) ។ *ស្ត្រីដទៃ* សូមមើលការពន្យល់នៅក្នុង ២:១៦ ។ *រឥលជាងប្រេង* សូមមើល ២:១៦ សម្ដីរបស់នាងគឺជាការប្រឡោមលួងលោមដែលប្រៀបបីដូចជាប្រេងរឥល (សូមមើល ទដ ៥:២១) ប៉ុន្តែពេញទៅដោយពាក្យបញ្ចើចបញ្ចោរ (សូមមើល សភ ២៦:២៨) និងពោរពេញទៅដោយការលាក់ពុត (សូមមើល ទដ ៥:៩ និងការពន្យល់) ។

**៥:៤** *ស្លែង* គឺជាគ្រាប់រុក្ខជាតិម្យ៉ាងដែលមានរស់ជាតិល្វីង (សូមមើល ចទ ២៩:១៨ បទ ៣:១៥,១៩ អម ៦:១២) ។ *ដាវមានមុខ២* គឺជាអាវុធសម្រាប់សម្លាប់ (សូមមើលផងដែរនៅក្នុង ពច ៣:១៦ សូមមើល ទដ ៥៥:២១ ១៤៩:៦ ហាព ៤:១២ ធៀបនឹង វវ ១:១៦ និងការពន្យល់) ។

**៥:៥** *ចុះទៅឯសេចក្ដីស្លាប់* គឺបង្ហាញពីភាពខ្វះសីលធម៌របស់នាង នៅគ្រាចុងក្រោយ នឹងបានបង្ខំនាងឱ្យធ្លាក់ទៅក្នុងសេចក្ដីស្លាប់ (សូមមើលការពន្យល់នៅក្នុង ២:១៨) ។

**៥:៦** *អស់ទាំងផ្លូវប្រព្រឹត្ត* សូមមើល ២:១៥ ១០:៩ ។ *មិនឱ្យឯងអាចស្គាល់បាន* ឬ "គ្មានអ្នកណាទទួលស្គាល់វាឡើយ" ។

**៥:៧–១៤** *នៅខព្រះគម្ពីរនេះ* គឺនិយាយរៀបរាប់ពីឪពុក មានន័យថា "គ្រូ" ហើយឪពុកជាអ្នកផ្ដល់ដំបូន្មានដល់កូន ហើយកូនជា "សិស្ស" ត្រូវយល់ពីតម្លៃនៃសីលធម៌និងភាពខ្វះសីលធម៌ ។

**៥:៨** *ឆ្ងាយពីវាចេញ* សូមមើល លប ៣៩:១២ ២ធថ ២:២២ ។ *ទ្វារផ្ទះរបស់វា* ធៀបនឹង ៧:២៧ ៩:១៤ ។

**៥:៩** *ពួកសាហាវ* ប្រហែលជាអាចកើតឡើង ដោយការចងគំនុំរបស់ប្ដីនៅពេញមានសេចក្ដីប្រចណ្ឌ (សូមមើល ៦:៣៤–៣៥) ។

**៥:១០** *ដោយកំឡាំងឯង ហើយការនឿយលំបាករបស់ឯង* ខុសគ្នាពីទ្រព្យសម្បត្តិនិងកិត្តសព្ទដែលបានចាប់យកប្រាជ្ញានោះ (៣:១៦–១៨) ។ នៅត្រង់ឃ្លានេះគឺនិយាយពីភាពខ្វះសីលធម៌ជាយថាហេតុ ដើម្បីបញ្ចុះបញ្ចូលមកតែមួយ "ធ្លាក់ខ្លួនទៅជាអ្នកមាននំបុ័ងតែ១ចំណិត" (សូមមើលការពន្យលនៅត្រង់ ៦:២៦) ។

**៥:១១** *សាច់ឈាម ហើយខ្លួនប្រាណឯងរោយចុះទៅ* ប្រហែលជាកើតមានឡើងដោយព្រោះតែសេចក្ដីកំសោយនិងភាពខ្វះសីលធម៌ (សូមមើល ១កូរ ៦:១៨ ធៀបនឹង សភ ៣:៨ ៤:២២) ប៉ុន្តែភាគច្រើនទំនងជាសេចក្ដីបញ្ជាក់ទៅលើការបាត់បង់នៃកម្លាំងដែលចាស់ជរា ។

**៥:១២** *បានស្អប់សេចក្ដីប្រៀនប្រដៅ . . . ក៏បានខ្នើមសេចក្ដីបន្ទោស* នៅពេលចាស់ជរាគាត់បានងាកបែរមើលក្រោយ ហើយទទួលស្គាល់សេចក្ដីទុក្ខព្រួយ ដែលគាត់បានធ្វើការចោលម្សៀតឥតប្រយោជន៍ពីមុនមក សូមមើល ១:៧ និងការពន្យល់ សូមមើលផងដែរ ១:២២,២៩–៣០) ។

**៥:១៣** *មិនបានស្ដាប់តាម* ជាការបោះបង់ចោលនូវសេចក្ដីដំបូន្មាន និងបានរំឭកឡើវិញពីការស្ដាប់ ឬ "ការប្រុងប្រយ័ត្ន" ដើម្បីផ្ដល់ការអប់រំនិងការប្រៀនប្រដៅដល់ពួកគេ (ធៀបនឹង ខ. ៧ ១:៨ ៤:១ ៥:១) ។

**៥:១៤** *អស់ទាំងអំពើអាក្រក់* គឺសំដៅទៅលើការប្រព្រឹត្តអំពើអាក្រក់ នៃរាង្គកាយ ប្រាក់កាស និង សង្គម ។

*នៅកណ្ដាលមនុស្ស នឹងពួកជំនុំ* និយាយពីការប្រមាថ និងសេចក្ដីអាប់យស "សេចក្ដីច្រឡោត និងភាពអាម៉ាស់មុខ" (៦:៣៣) ដែលស្មើនឹងសេចក្ដីស្លាប់ (សូមមើល លវ ២០:១០ ចទ ២២:២២) ។

**៥:១៥** *ពីពាងរបស់ខ្លួនឯង . . . ពីអណ្ដូងរបស់ខ្លួនឯង* គឺប្រៀបធៀបពីប្រពន្ធរបស់ខ្លួនឯង (សូមមើល បស ៤:១២,១៥) ។ ប្រពន្ធរបស់ខ្លួនជាប្រភពនៃសេចក្ដីរីករាយ គឺដូចជាទឹកដែលធ្វើឱ្យមនុស្សស្រេកឃ្លានបានឆ្អែត ។ អណ្ដូងនិងពាងជារបស់ផ្ដាច់មុខផ្ទាល់ខ្លួន (យរ ៣៨:៦) ហើយមានតម្លៃមិនអាចកាត់ថ្លៃបាន (២ពវ ១៨:៣១) ។

**៥:១៦** *រន្ធទឹក . . . គន្លងទឹក* គឺប្រៀបដូច "ពាង" និង "អណ្ដូង" មើលក្នុង ខ.១៥ និងជា "ប្រភពទឹក" មើលក្នុង ខ.១៨ ពាក្យទាំងនេះជាការបញ្ជាក់ទៅលើប្រពន្ធ (សូមមើល បស ៤:១២,១៥) ។ ហូរទៅក្នុងផ្លូវ នៅត្រង់ឃ្លានេះបញ្ជាក់ពី ប្រពន្ធដែលអាចក្លាយទៅជារបស់រួមគ្នា ប្រសិនបើប្ដីមិនស្មោះត្រង់ចំពោះប្រពន្ធ ។

មនុស្សដទៃជាមួយនឹងឯងផងនោះទេ ១៨សូមឱ្យរន្ធទឹកឯង[ឌ]
បានពរ ចូរឱ្យឯងបានរីករាយចំពោះប្រពន្ធដែលបាន
គ្នាពីកាលក្រមុំកំឡោះចុះ[ឍ] ១៩ប្រៀបដូចជាក្តាន់ញី[ណ]ដែល
គួរស្រឡាញ់ និងប្រើសញីសមសួន ត្រូវឱ្យដោះរបស់នាង
បានបំពេញចិត្តឯងជាដរាប ហើយត្រូវឱ្យឯងឈ្លក់ចិត្តនឹង
សេចក្តីស្រឡាញ់របស់នាងជានិច្ចផង ២០ដ្បិតកូនអើយ
តើមានទំនងឱ្យឯងទៅឈ្លក់ចិត្តចំពោះស្ត្រីដទៃ ហើយឱប
ទ្រូងនៃស្ត្រីក្រៅប្តីអី ២១ពីព្រោះអស់ទាំងផ្លូវរបស់មនុស្ស
សុទ្ធតែច្បាស់នៅចំពោះព្រះនេត្រ[ត]ព្រះយេហូវ៉ា ទ្រង់ក៏ស្ទង់
មើល[ថ]អស់ទាំងផ្លូវច្រករបស់គេដែរ[ទ] ២២អស់ទាំងអំពើ
ទុច្ចរិតរបស់មនុស្សអាក្រក់នឹងចាប់យកអ្នកនោះឯង[ធ]
ហើយអ្នកនោះនឹងត្រូវចងជាប់ ដោយចំណងនៃអំពើបាប
របស់ខ្លួន[ន] ២៣អ្នកនោះនឹងត្រូវស្លាប់ទៅ ដោយឥតមាន
អ្នកណានឹងប្រៀនប្រដៅ[ប] ក៏នឹងវង្វេងចេញ ដោយវក់នឹង
ការចំកួត របស់ខ្លួន[ផ] ។

**៥:១៨** ឌ បស ៤:១២–១៥ ឍ ចទ ២០:៧ សភ ២:១៧ សស ៩:៩ មឡ ២:១៤ **៥:១៩** ណ បស ៤:៥ ៨:១៤ **៥:២១** ត ទដ ១១៩:១៦៨ ថ យរ ២៩:២៣ ទ យប ១០:៤ ១៤:១៦ សភ ១៥:៣ យរ ៣២:១៩ ហាព ៤:១៣ **៥:២២** ធ ទដ ៩:១៦ ន ជន ៣២:២៣ យប ១៨:៩ ទដ ៧:១៥–១៦ សភ ១:៣១–៣២ **៥:២៣** ប យប ៤:២១ សភ ១០:២១ ផ យប ៣៤:២១–២៥ សភ ១១:៥ **៦:១** ក សភ ១:៨ ខ យប ១៧:៣ គ សភ ១៧:១៨ ឃ សភ ១១:១៥ ២២:២៦–២៧ **៦:៤** ង ទដ ១៣២:៤ **៦:៥** ច ២សយ ២:១៨ ឆ អស ១៣:១៤ ជ ទដ ៩១:៣ **៦:៦** ឈ ខ.៦–១១ សភ ២០:៤

## ការព្រមានអំពីភាពល្ងង់ខ្លៅ

**៦** ១កូនអើយ[ក] បើឯងបានធានា[ខ]ឱ្យអ្នកជិតខាងឯង[គ] បើ
ឯងបានចាប់ដៃសន្យា[ឃ]ជំនួសអ្នកដទៃ ២នោះឯងបានជាប់
អន្ទាក់ដោយសារពាក្យសន្យារបស់ឯង គឺឯងបានត្រូវចាប់
ហើយ ដោយពាក្យសំដីដែលចេញពីមាត់ឯងមក ៣យ៉ាង
នោះ កូនអើយ ចូរធ្វើដូច្នេះវិញ ហើយដោះខ្លួនឱ្យរួចចុះ
ព្រោះឃើញថា ឯងបានធ្លាក់ទៅក្នុងកណ្តាប់ដៃនៃអ្នកជិត
ខាងឯង ដូច្នេះ ចូរឯងទៅបន្ទាបខ្លួន ហើយអង្វរដល់គេ
៤កុំឱ្យភ្នែកឯងដេកលក់ ឬឱ្យត្របកភ្នែកឯងរលីវឡើយ[ង]
៥ចូរឱ្យដោះខ្លួនចេញ ដូចជាប្រើស[ច]រួចពីកណ្តាប់ដៃនាយ
ព្រាន[ឆ] ហើយដូចសត្វហើររួចពីដៃនៃអ្នកដែលចាប់វា[ជ] ។
៦ឱមនុស្សខ្ជិលច្រអូសអើយ[ឈ] ចូរទៅមើលស្រមោចចុះ
ចូរពិចារណាផ្លូវទាំងប៉ុន្មានរបស់វា ហើយមានប្រាជ្ញា

**៥:១៨** *ប្រពន្ធដែលបានគ្នាពីកាលក្រមុំកំឡោះ* គេអាចជ្រើសរើសប្តីប្រពន្ធដោយសារភាពពេញវ័យរបស់ខ្លួន ។

**៥:១៩** *ក្តាន់ញី . . . ប្រើសញី* នៅត្រង់វគ្គនេះ គឺនិយាយរៀបរាប់ពីរូបសម្ផស្សដ៏ស្រស់ស្អាតរបស់ប្រពន្ធ ដែលប្រៀបធៀបដូចជាដំណើរទន់ភ្លន់នៃក្តាន់ញី (សូមមើល បស ២:៩) ។ *ដោះរបស់នាងបានបំពេញចិត្តឯងជាដរាប* សូមមើល បស ៧:៧–៨ ។ *បានពេញចិត្ត* គឺជា "ភាពសប្បាយរីករាយ" និង "ឈ្លក់វង្វេង" បង្ហាញពីសេចក្តីស្រឡាញ់រវាងប្តីប្រពន្ធ ដែលឆ្ងាញ់ជាងស្រាទំពាំងបាយជូរទៅទៀត មាននៅក្នុង បស ៤:១០ (ធៀបនឹង បស ៧:៩) ។

**៥:២០** *តើមានទំនង . . .* គឺមានពន្លឺលាយនឹងសេចក្តីអំណរ ដែលបានរកឃើញនៅក្នុងចំណងនៃអាពាហ៍ពិពាហ៍ និង "អស់ទាំងអំពើអាក្រក់" (ខ.១៤) នៅផ្នែកខាងក្រៅវា ហេតុអ្វីបានជាប្រព្រឹត្តផិតក្បត់និងស្ត្រីសាសន៍ដទៃយ៉ាងដូច្នេះ ។ *ឈ្លក់ចិត្ត* សូមមើល ខ.៣ ២:១៦ និងការពន្យល់ ។

**៥:២១** *សុទ្ធតែច្បាស់នៅចំពោះព្រះនេត្រព្រះយេហូវ៉ា* សូមមើល ១៥:៣ យប ៣១:៤ ៣៤:២១ យរ ១៦:១៧ ៣២:១៩ ។ *ស្ទង់មើលអស់ទាំងផ្លូវច្រក* សូមមើល យប ៧:១៨ ៣៤:២៣ ទដ ១១:៤ ២៦:២ ១៣៩:២៣ យរ ១១:២០ ១២:៣ ១៧:១០ ។

**៥:២២** *ចាប់យកអ្នកនោះឯង* សូមមើល ១:១៨ និងការពន្យល់ ចទ ៧:២៥ ១២:៣០ ។ នៅក្នុង សស ៧:២៦ មនុស្សមានបាប បានជាប់អន្ទាក់ដោយសារស្ត្រី "ដែលមានចិត្ត ជាអន្ទាក់" ។ *ដោយចំណងនៃអំពើបាបរបស់ឯង* មើល យប ៣៦:៨ សស ៤:១២ អស ៥:១៨ ធៀបនឹង ហស ១១:៤ និងការពន្យល់ ។

**៥:២៣** សេចក្តីស្លាប់នៃមនុស្សល្ងីល្ងើ គឺបាននិយាយរៀបរាប់ស្រដៀងនិងពាក្យនៅក្នុង ១:២៩–៣២ ៧:២១ ធៀបនឹង យប ៣៦:១២ ។ *ប្រៀនប្រដៅ* សូមមើល ខ.១២ និងការពន្យល់ ។

**៦:១** *បានធានា . . . បានចាប់ដៃសន្យា* នៅត្រង់ឃ្លានេះ គឺនិយាយបញ្ជាក់ទៅលើទំនួលខុសត្រូវចំពោះអ្នកណាម្នាក់ ដែលបានជាប់បំណុលជាមួយអ្នកដទៃ (ធៀបនឹង ២២:២៦) ឬសម្រាប់កិច្ចសន្យាដល់អ្នកផ្សេងទៀត ។ វាអាចជាចុងបំផុតនៅក្នុងភាពទ័លក្រ (ធៀបនឹង ២២:២៧) ប្រសិនបើអ្នកមិនបានសងនូវបំណុលទេ នោះអ្នកនិងនៅជាប់ជាទាសករ ។ លោកយូដាបានស្ម័គ្រចិត្តដោយផ្ទាល់ក្នុងការធានារ៉ាប់រងចំពោះសុវត្ថិភាពរបស់លោកបេនយ៉ាមីននៅពេលដែលគាត់ត្រឡប់មកឯលោកយ៉ាកុប (លប ៤៣:៩) ពេលនេះវាហាក់បីដូចជាការដែលមិនអាចធ្វើបានទល់តែសោះ ប៉ុន្តែគាត់បានលក់ខ្លួនរបស់គាត់ទៅឱ្យលោកយ៉ូសែបដូចជាទាសករ (លប ៤៤:៣២–៣៣) ។ គឺបានរៀបចំបោះត្រាដោយ "ដៃ" ដែលមានតម្លៃស្មើគ្នានិងការចាប់ដៃយល់ព្រមរបស់យើង (សូមមើល ១១:១៥ ១៧:១៨ ២០:១៦ ២២:២៦ ធៀបនឹង យប ១៧:៣) ។

**៦:២** *បានជាប់អន្ទាក់ . . . បានត្រូវចាប់ហើយ* ធៀបនឹង ខ.៥ និងសូមមើលផងដែរ ១:១៨ ៥:២២ និងការពន្យល់ ។

**៦:៣** *ដោះខ្លួនឱ្យរួច* គឺជាការដោះលែងឱ្យមានសេរីភាពពីកិច្ចសន្យា ។ *ឯងបានធ្លាក់ទៅក្នុងកណ្តាប់ដៃនៃអ្នកជិតខាង* បានសន្មត់ទុកជាមុននូវការទទួលខុសត្រូវរបស់គាត់ចំពោះកិច្ចសន្យា ។ *ចូរឯងបន្ទាបខ្លួន* គឺជាការស៊ូទ្រាំទូលអង្វររបស់មនុស្សសុចរិតដើម្បីនឹងទទួលជ័យជម្នះ សូមមើល លក ១១:៨ ។

**៦:៤** *កុំឱ្យភ្នែកឯងដេកលក់ ឬឱ្យត្របកភ្នែកឯងរលីវ* នៅត្រង់ឃ្លានេះគឺមានន័យដូចស្តេចដាវីឌ មើលនៅក្នុង ទដ ១៣២:៤ ។

**៦:៥** *រួចពីដៃនៃអ្នកដែលចាប់វា* សូមមើល ទដ ១២៤:៧ ។

**៦:៦** *ស្រមោច* ព្រះអាទិករជាអ្នកបង្កើតវាមក ដែលបានបញ្ជាក់នៅក្នុងព្រះគម្ពីរតែម្តងគត់គឺ ៣០:២៥ សត្វស្រមោចវាតែងតែប្រមូលស្បៀងអាហារទុកនៅក្នុងរដូវក្តៅ (ដូចនៅត្រង់នេះ សូមមើល ខ.៨) ។ *មនុស្សខ្ជិលច្រអូស* នៅត្រង់ឃ្លានេះ គឺបាននិយាយពីមនុស្សខ្ជិលច្រអូស ដែលគេតែងតែបដិសេធចំពោះការងារ ហើយការប្រាថ្នាចង់បានរបស់គេ និងមិនបានអ្វីសោះ (សូមមើល ១០:២៦ ១៣:៤ ១៥:១៩ ១៩:២៤ ២០:៤ ២១:២៥ ២២:១៣ ២៤:៣០ ២៦:១៣–១៦ល) ។

ឡើង [៧]វាគ្មាននាយ គ្មានអ្នកកាន់កាប់ការ ឬអ្នកគ្រប់គ្រងឡើយ [៨]គង់តែវាផ្គត់ផ្គង់អាហារវានៅខែប្រាំង[ញ] ហើយក៏ប្រមូលស្បៀងទុក នៅក្នុងរដូវចំរូតផង[ដ] [៩]ឱមនុស្សខ្ជិលច្រអូសអើយ[ឋ] តើឯងនឹងដេកដល់កាលណា តើដល់កាលណាបានឯងក្រោកពីការដេកលក់ [១០]ដេកបន្តិច ងោកបន្តិច ឱបដៃនឹងដេកបន្តិច[ឌ] [១១]យ៉ាងនោះ សេចក្តីកំសត់ទុគ៌ត[ឍ] របស់ឯង និងលោមមកដល់អ្នកដូចជាចោរប្លន់ ព្រមទាំងសេចក្តីខ្វះខាត ដូចជាអ្នកកាន់គ្រឿងអាវុធ ។

[១២]ឯមនុស្សចោលម្សៀត ជាពួកអ្នកដែលប្រព្រឹត្តអំពើទុច្ចរិត គឺជាមនុស្សដែលប្រើមាត់ពោលពាក្យវៀច [១៣]ជាអ្នកដែលមិចភ្នែក[ណ] ហើយធ្វើទីសំគាល់ដោយជើង និងដៃ[ត] [១៤]ជាអ្នកដែលមានសេចក្តីវៀចនៅក្នុងចិត្ត ក៏តែងតែគិតគួរបង្កើតការអាក្រក់[ថ]ជានិច្ច ព្រមទាំងសាបព្រោះការទាស់តែងគ្នា[ទ] [១៥]ដូច្នេះ សេចក្តីអន្តរាយរបស់វា និងលោមកភ្លាម១រំពេច[ធ]ក្នុងពេលបន្ទាន់[ន]នោះ វានឹងត្រូវបាក់បែកឥតមានអ្វីជួយផង[ប] [១៦]មាន៦មុខ ដែលព្រះយេហូវ៉ាទ្រង់ស្អប់[ផ] អើ មាន៧ផង ដែលទ្រង់ខ្ពើមឆ្អើម [១៧]គឺភ្នែកឆ្មើងឆ្មៃ[ព]១អណ្តាតភូតភរ១[ភ] ដៃដែលកំចាយឈាមមនុស្សឥតទោស១[ម] [១៨]ចិត្តដែលគិតគួរបង្កើតអំពើអាក្រក់១ ជើងដែលរហ័សរត់ទៅប្រព្រឹត្តអាក្រក់១[យ] [១៩]នឹងសាក្សីក្លែងក្លាយ ដែលពោលពាក្យកំភូត១[រ] ហើយមនុស្សដែលសាបព្រោះសេចក្តីទាស់ទែងគ្នាក្នុងពួកបងប្អូន១ដែរ[ល] ។

**៦:៨** ញ សភ ៣០:២៤–២៥ ដ សភ ១០:៤
**៦:៩** ឋ សភ ២៤:៣០–៣៤ ២៦:១៣–១៦
**៦:១០** ឌ សភ ២៤:៣៣ សស ៤:៥
**៦:១១** ឍ ខ.១០–១១ សភ ២០:១៣ ២៤:៣០–៣៤
**៦:១៣** ណ ទដ ៣៥:១៩ សភ ១៦:៣០ ត អស ៥៨:៩
**៦:១៤** ថ ទដ ១៤០:២ ទ ខ.១៦–១៩
**៦:១៥** ធ ទដ ៥៥:១៥ ន យប ៥:៣ ប សភ ១៤:៣២ ២៩:១ **៦:១៦** ផ ខ.១៦–១៩ សភ ៣:៣២ ៨:១៣ ១៥:៨,៩,២៦ ១៦:៥ **៦:១៧** ព យប ៤១:៣៤ ទដ ១០:៥ ភ សភ ១២:២២ ម ចទ ១៩:១០ សភ ១:១៦ អស ១:២១ ៥៩:៧ យរ ២:៣៤ មីក ៧:២ **៦:១៨** យ យប ១៥:៣១ **៦:១៩** រ ចទ ១៩:១៦ ល ទដ ១២:២ វ ខ.១២–១៥ សភ ១៥:១៨ សក ៨:១៧

**៦:៧** *គ្មានអ្នកកាន់កាប់ការ* ធៀបនឹង សត្វកណ្តូប មើលនៅក្នុង ៣០:២៧ ។

**៦:៩** *តើឯងនឹងដេកដល់កាលណា* សេចក្តីស្រឡាញ់ ចំពោះការដេករបស់គាត់គឺបាននិយាយរៀបរាប់នៅក្នុង ២៦:១៤ (សូមមើលការពន្យល់នៅត្រង់ចំណុចនោះ) ។

**៦:១០–១១** បានរំឭកឡើងវិញនៅក្នុង ២៤:៣៣–៣៤ ។

**៦:១១** *សេចក្តីកំសត់ទុគ៌ត... សេចក្តីខ្វះខាត* នៅត្រង់ឃ្លានេះ គឺបានទាក់ទងទៅនិងការដេកយ៉ាងច្រើន មើលក្នុង ១០:៥ ១៩:១៥ ២០:១៣ ។ ធ្វើការងារដោយលំបាក និងការពារ យើងមិនឱ្យធ្លាក់ខ្លួនទៅក្នុងសេចក្តីកំសត់ទុគ៌តឡើយ (សូមមើល ១២:១១ ១៤:២៣ ២៨:១៩) ។ *ដូចជាចោរប្លន់... ដូចជាអ្នកកាន់គ្រឿងអាវុធ* សេចក្តីកំសត់ទុគ៌ត និងចូលមកយ៉ាងឆាប់នៅពេលដែលយើងមិនបានគិតអំពីវា គឺប្រៀបដូចជាចោរប្លន់ (ធៀបនឹង មថ ២៤:៤៣) ។

**៦:១២–១៤** ខព្រះគម្ពីរទាំងនេះ គឺជាការនិយាយរៀបរាប់ពីការប្រើមាត់ពោលពាក្យវៀច ភ្នែក ជើង និងដៃប្រព្រឹត្តការអាក្រក់(ចំណុចទាំងអស់នេះមានការទាក់ទងគ្នា) នៅក្នុងផ្លូវទុច្ចរិតដើម្បីសម្រេចបំណងពីដំណើររឿងដែលជាការបោកបញ្ឆោតរបស់ចិត្តយ៉ាងវិសេស សម្រាប់បង្ហាញនូវពាក្យបង្ខូចដើម្បីនឹងបំផ្លាញអ្នកណាមួយ ។

**៦:១២** *មនុស្សចោលម្សៀត* គឺជាមនុស្សដែលបានប្រព្រឹត្តការយ៉ាងអាក្រក់នឹងអសីលធម៌ (១៦:២៧ ពច ១៩:២២,១សយ ២៥:២៥ យប ៣៤:១៨) សូមមើលការពន្យល់ ចទ ១៣:១៣ ។ *មាត់ពោលពាក្យវៀច* មើល ២:១២ និងការពន្យល់ ១៩:២៨ ។

**៦:១៣** *ជាអ្នកដែលមិចភ្នែក* គឺជាមនុស្សដែលបង្កើតការអាក្រក់ដោយប្រើពាក្យសំដីបញ្ឆិតបញ្ឆៀង (សូមមើល ១០:១០ ១៦:៣០) ។

**៦:១៤** *គិតគួរបង្កើតការអាក្រក់* ខ.១៨ ៣:២៩ មីក ២:១ ។ *សាបព្រោះការទាស់ទែងគ្នា* ដោយសារប្រើពាក្យបង្កាច់បង្ខូច គឺដូចជាមនុស្សមិនមានការទុកចិត្តគ្នាដ៏សម្បើមបំផុត នៅក្នុងការបាក់បែក និងការឈ្លោះប្រកែក (សូមមើល ខ.១៩ ១០:១២ ១៥:១៨ ១៦:២៨ ២៨:២៥ ២៩:២២) ។

**៦:១៥** *សេចក្តីអន្តរាយរបស់វា និងលោមកភ្លាម១រំពេចក្នុងពេលបន្ទាន់* គឺជាទីសម្គាល់ពីការជំនុំជម្រះរបស់ព្រះអម្ចាស់ (សូមមើល ១:២៦ ២៤:២២ និងការពន្យល់ យប ៣៤:២០) ។ *វានឹងត្រូវបាក់បែកឥតមានអ្វីជួយផង* ការប្រព្រឹត្តដ៏អាក្រក់ នឹងធ្វើឱ្យទទួលនូវសេចក្តីហិនវិនាស ដូចជាកម្មអាក្រក់ដែលនិងមកលើពួកគេនូវការទទួលទណ្ឌកម្ម សមនឹងកំហុសរបស់គេ (ធៀបនឹង កទ ៦:៧–៨) ។ *មានអ្វីជួយផង* សូមមើល ២៩:១ និងការពន្យល់ ។

**៦:១៦–១៩** ខគម្ពីរទាំងនេះ គឺជាសេចក្តីពន្យល់លំអិតបន្ថែមទៀត អំពីផ្ទៃរឿងមានក្នុង ខ.១២–១៥ ដែលពន្យល់ពីមូលហេតុ"នៃភាពហិនវិនាសនឹងមកដល់" (ខ.១៥) ឯការប្រព្រឹត្តដ៏អាក្រក់ក៏មានពិពណ៌នានៅទីនេះដែរ ។

**៦:១៦** *មាន៦មុខ... មាន៧ផង* គឺជាវិធីប្រើចំនួនលេខ ដែលមានន័យដូចគ្នាហើយស្របគ្នាទៅនិងកវីនិពន្ធ នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរ (សូមមើលសេចក្តីផ្តើម: និងលក្ខណៈនៃព្រះគម្ពីរសុភាសិត) ។ ដូចជាសៀវភៅរាយនាមនៃរឿងរ៉ាវនិងហេតុការណ៍ដែលកើតឡើងជាញឹកញាប់ នៅក្នុងគតិបណ្ឌិតអក្សរសាស្ត្រនៃព្រះគម្ពីរសញ្ញាចាស់ (សូមមើល ៣០:១៥,១៨,២១,២៩ និងសូមមើលផងដែរនៅក្នុង យប ៥:១៩ ហើយនិងការពន្យល់) ។ មានរឿងហេតុជាច្រើននៅក្នុងព្រះគម្ពីរសុភាសិតទាំងមូល ដែលនិយាយរៀបរាប់ពីចំនួនលេខខ្ពស់ជាង គឺជាផ្នែកនៃប្រតិបត្តិការទៅលើអ្វីមួយ ។ *ស្អប់ខ្ពើម* សូមមើល ៣:៣២ និងការពន្យល់ ។

**៦:១៧** *ភ្នែកឆ្មើងឆ្មៃ* គឺជាការឆ្លុះបញ្ចាំងពីចិត្តអំនួត ហើយព្រះទ្រង់នឹងជំនុំជម្រះដល់ពួកគេ (សូមមើល ២១:៤ ៣០:១៣ ទដ ១៨:២៧ ១០១:៥) ។ *អណ្តាតភូតភរ* សូមមើល ២:១២ និងការពន្យល់ ១២:១៩ ១៧:៧ ២១:៦ ។ *ដៃដែលកំចាយឈាមមនុស្សឥតទោស* សូមមើល ១:១១ និងការពន្យល់ ហើយសូមមើលផងដែរ ១:១៦ ២៨:១៧ ។

**៦:១៨** *ចិត្តដែលគិតគួរបង្កើតអំពើអាក្រក់* សូមមើល ១:៣១ ២៤:២ លប ៦:៥ ។ *ជើងដែលរហ័សរត់ទៅប្រព្រឹត្តអាក្រក់* សូមមើល ១:១៦ និងការពន្យល់ ។

**៦:១៩** *សាក្សីក្លែងក្លាយ* សូមមើល នក ២០:១៦ ចទ ១៩:១៦–១៩ ។ ព្រះគម្ពីរសុភាសិតមានការបញ្ជាក់ពីសេចក្តីអន្តរាយ ដែលប្រព្រឹត្តដោយសារសាក្សីក្លែងក្លាយ(១២:១៧–១៨ ២៥:១៨ សូមមើលការពន្យល់ ទដ ៥:៩) ហើយពួកគេនឹងទទួលនូវទណ្ឌកម្ម(សូមមើលការពន្យល់ ខ.១៥ និងសូមមើលផងដែរ ១៩:៥ ៩ ២១:២៨) ។ *ពោលពាក្យកំភូត* សូមមើល ១៤:៥,២៥ ។ សាបព្រោះសេចក្តីទាស់ទែងគ្នា សូមមើលការពន្យល់ ខ.១៤ ។

### ការព្រមានអំពីការកំផិត

២០កូនអើយ[ស] ចូររក្សាទុកនូវសេចក្ដីបណ្ដាំរបស់ឪពុក
ឯងចុះ ក៏កុំឱ្យបោះបង់ចោលដំបូន្មានរបស់ម្ដាយឯងឡើយ[ហ]
២១ចូរចងក្រៀកនៅនឹងចិត្តឯងជានិច្ច ហើយភ្ជាប់នៅកឯង
ផង[ឡ] ២២កាលណាឯងដើរដំណើរ បណ្ដាំនោះនឹងនាំមុខ
ឯង កាលណាដេកលក់ នោះនឹងចាំយាមរក្សាឯង ហើយ
កាលណាភ្ញាក់ នោះនឹងនិយាយរកឯង ២៣ដ្បិតពាក្យបណ្ដាំ
នោះ ជាចង្កៀង ហើយដំបូន្មាននោះជាពន្លឺ[អ] ឯសេចក្ដី
បន្ទោសនៃពាក្យប្រៀនប្រដៅ នោះជាផ្លូវជីវិតហើយ[ក]
២៤ប្រយោជន៍នឹងរក្សាឯងទុក ឱ្យរួចពីស្ត្រីអាក្រក់ គឺឱ្យរួច
ពីអណ្ដាតបញ្ចើចរបស់ស្រីដទៃ[ខ] ២៥កុំឱ្យឯងមានតណ្ហា
ខ្វល់ខ្វាញ់ចំពោះរូបឆោមឆាយរបស់គេឡើយ ក៏កុំឱ្យគេ
ចាប់ឯងទៅ ដោយសារត្របកភ្នែកគេដែរ ២៦ដ្បិតដោយ
ព្រោះតែស្រីសំផឹង នោះមានមនុស្សដែលនឹងធ្លាក់ខ្លួនទៅ
ជាមាននំបុ័ងតែ១ចំណិតប៉ុណ្ណោះ ហើយស្រីកំផិតតែងតែ
ដេញចាប់ជីវិតដ៏វិសេស[គ] ២៧តើមនុស្សនឹងយកភ្លើងមក
ដាក់នៅនាទ្រូង ឥតឆេះដល់អាវខ្លួនបានឬ ២៨តើនឹងដើរ
លើរងើកភ្លើងឥតរលាកដល់ជើងបានដែរឬ ២៩ដូច្នេះ
អ្នកណាដែលចូលទៅ[ឃ]ឯប្រពន្ធរបស់អ្នកជិតខាង[ង]នោះ
ក៏ដូចគ្នាដែរ អ្នកណាដែលប៉ះពាល់នឹងនាង នោះមិនរួច
ពីមានទោសឡើយ ៣០មនុស្សរមែងមិនស្អប់ដល់ចោរ
គឺបើវាលួច ឱ្យតែបានឆ្អែតពោះប៉ុណ្ណោះ ក្នុងវេលាដែល
ស្រេកឃ្លាននោះទេ ៣១តែបើទាន់ឃើញវា នោះគង់តែ
ត្រូវឱ្យវាសង១ជា៧វិញ[ច]ដែរ វាត្រូវសងដល់ទៅគ្រប់របស់
ដែលនៅក្នុងផ្ទះខ្លួនទាំងអស់ផង ៣២តែឯអ្នកណាដែលលួច
ប្រពន្ធគេ[ឆ] នោះជាអ្នកឥតមានគំនិតឡើយ[ជ] អ្នកណាដែរ
ប្រព្រឹត្តអំពើយ៉ាងនោះ ឈ្មោះថាចង់បំផ្លាញជីវិតខ្លួនហើយ
៣៣អ្នកនោះនឹងត្រូវសៅហ្មង ហើយអាប់យស និងលុបសេច
ក្ដីត្មះតិះដៀលចំពោះអ្នកនោះចេញ មិន[ឈ]បាត់ឡើយ ៣៤ដ្បិត
សេចក្ដីប្រចណ្ឌ[ញ] ជាសេចក្ដីក្ដៅក្រហាយរបស់មនុស្ស[ដ]
ហើយគេនឹងមិនប្រណីក្នុងថ្ងៃសងសឹកទេ ៣៥គេមិនព្រមទាំង
ក្រឡេកមើលដំឡៃលោះណាមួយផង ហើយទោះបើឯងជូន
ជំនូនដល់គេជាច្រើនក៏ដោយ គង់តែមិនបានរំងាប់ចិត្ត
ដែរ[ឋ] ។

### ការព្រមានអំពីស្ត្រីកំផិត

៧ ១កូនអើយ[ក] ចូររក្សាអស់ទាំងពាក្យរបស់អញ ហើយ
ប្រមូលអស់ទាំងបណ្ដាំអញទុកនៅនឹងឯងចុះ ២ត្រូវឱ្យរក្សា
បណ្ដាំអញទាំងប៉ុន្មាន ដើម្បីឱ្យបានរស់នៅ[ខ] ព្រមទាំង
ឱវាទអញ ដូចជារក្សាប្រស្រីភ្នែកឯងដែរ ៣ចូរចងភ្ជាប់
នៅម្រាមដៃ ហើយកំណត់ទុកនៅក្នុងដួងចិត្តឯងផង[គ] ៤ចូរ
និយាយដល់ប្រាជ្ញាថា ឯងជាបងស្រីរបស់អញ ហើយ

**៦:២០** ស សភ ៣:២១ ហ សភ ១:៨ **៦:២១** ឡ ចទ ៦:៨ សភ ៣:៣ ៧:១-៣ **៦:២៣** អ ទដ ១១៩:១០៥ ក សភ ១០:១៧ **៦:២៤** ខ លប ៣៩:៨ ទដ ៥៥:២១ សភ ២:១៦ ៧:៥ **៦:២៦** គ សជ ៧:២២-២៣ **៦:២៩** ឃ នក ២០:១៤ ង សភ ២:១៦-១៩ ៥:៨ **៦:៣១** ច នក ២២:១-១៤ **៦:៣២** ឆ នក ២០:១៤ ជ សភ ៧:៧ ៩:៤,១៦ **៦:៣៣** ឈ សភ ៥:៩-១៤ **៦:៣៤** ញ ជន ៥:១៤ ដ លប ៣៤:៧ **៦:៣៥** ឋ យប ៣១:៩-១១ បស ៨:៧

**៧:១** ក សភ ១:៨ **៧:២** ខ សភ ៤:៤ **៧:៣** គ សភ ៣:៣

**៦:២០** សូមមើល ១:៨ និងការពន្យល់ ។

**៦:២១** សូមមើល ១:៩ និងការពន្យល់ ។

**៦:២២** *ដើរដំណើរ* ធៀបនឹង ៤:១១ ។ *កាលណាដេកលក់* សូមមើលការពន្យល់នៅក្នុង ៣:២៤ ។ *ចាំយាមរក្សាឯង* សូមមើល ៤:៦ ។

**៦:២៣** *ជាចង្កៀង . . . ជាពន្លឺ* នៅត្រង់ចំណុចនេះ និយាយប្រៀបធៀបទៅនឹងព្រះបន្ទូលរបស់ទ្រង់ "គឺជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ" (ទដ ១១៩:១០៥ ធៀបនឹង ១៩:៨) ។ *ជាផ្លូវជីវិត* សូមមើល ៣:២២ ៤:២២ ១០:១៧ គឺខុសគ្នាពីផ្លូវនៃសេចក្ដីស្លាប់ ចំពោះអ្នកណាម្នាក់ដែលបានស្អប់ដល់ការប្រៀនប្រដៅ (សូមមើល ៥:២៣ និងការពន្យល់) ។

**៦:២៤** សូមមើលការពន្យល់នៅក្នុង ២:១៦ ៥:៣ ។

**៦:២៥** *កុំឱ្យឯងមានតណ្ហា* ខព្រះគម្ពីរនៅត្រង់នេះ គឺព្រះយេស៊ូវទ្រង់បានបង្ហាញពីការភ្ជាប់ទំនាក់ទំនងយ៉ាងស្និទ្ធស្នាល រវាងតណ្ហា និងការផិតក្បត់ (មថ ៥:២៨ ធៀបនឹង នក ២០:១៤,១៧ និងការពន្យល់) ។ *រូបឆោមឆាយរបស់គេ* សូមមើល ៥:២០ ។

**៦:២៦** *ធ្លាក់ខ្លួនទៅជាមាននំបុ័ង១ចំណិត* នៅត្រង់ចំណុចនេះ គឺនិយាយពីស្រីសំផឹង និងការផិតក្បត់ (ខ.២ ៩:៣) (សូមមើលការពន្យល់ ៥:១៩) ដែលមនុស្សនឹងធ្លាក់ខ្លួនទៅក្នុងសេចក្ដីកំសត់ទុគ៌ត (សូមមើល ១សយ ២:៣៦) ។

**៦:២៩** *អ្នកណា . . . មិនរួចពីមានទោសឡើយ* សូមមើល ខ.៣៣-៣៤ និងមើលការពន្យល់នៅក្នុង ៥:១៤ ផងដែរ ។

**៦:៣១** *១ជា៧* នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរ គឺជាច្បាប់ពីការសងប្រាក់ដែលមិនច្រើនលើសជាង៥១ជា៥ឡើយ ហើយការសងប្រាក់នេះ ដូចជាចោរលួច (នក ២២:១-៩) ។ ចំនួន៧នៅត្រង់នេះជានិមិត្តសញ្ញាពីចោរលួចដែលនឹងត្រូវសងពេញថ្លៃ ។

**៦:៣២** *បំផ្លាញជីវិតខ្លួន* សូមមើល ៥:១៤ ៧:២២-២៣ និងការពន្យល់ ។

**៦:៣៣** *អាប់យស* គឺដោយព្រោះលោកអាំណូនបានបង្ខូចនាងតាម៉ារ (២សយ ១៣:១៣,២២) ។

**៦:៣៤** *សេចក្ដីប្រចណ្ឌ* វាគឺជាកម្លាំងនៃសេចក្ដីកំហឹងផងដែរ មាននៅក្នុង ២៧:៤ បស ៨:៦ ។

**៧:១** សូមមើល ទដ ១១៩:១១ ។

**៧:២** *រក្សាប្រស្រីភ្នែកឯង* សូមមើល ចទ ៣២:១០ និងការពន្យល់ ។

**៧:៣** *ចូរចងភ្ជាប់នៅម្រាមដៃ* គឺដូចជាការរំឭកឱ្យនឹកឃើញ (សូមមើល ៦:២១ ចទ ៦:៨) ។ *កំណត់ទុកនៅក្នុងដួងចិត្តឯង* សូមមើល ៣:៣ យរ ៣១:៣៣ និងការពន្យល់ ។

**៧:៤** *ប្រាជ្ញា* ដូចជាតំណាងដល់ការអប់រំទាំងឡាយរបស់គ្រូបង្រៀន ដោយប្រាជ្ញា (ខ.១-៣) ។ *ជាបងស្រីរបស់អញ . . . ជាសំឡាញ់* នៅត្រង់ឃ្លានេះនិយាយអំពីប្រាជ្ញាប្រៀបដូចជាបងស្រី និងបងសំឡាញ់ ដែលធ្វើឱ្យបញ្ញារបស់ឯងដូចជាមិត្តស្និទ្ធស្នាល និងជាគូកននៅក្នុងចិត្តអ្នក "បងស្រី" នៅត្រង់នេះប្រហែលជាអាចប្រើនៅក្នុងការតាំងសញ្ញា នៃ"កូនក្រមុំ"(សូមមើល បស

ត្រូវហៅយោបល់ថាជាសំឡាញ់ឯង ៥ដើម្បីឱ្យសេចក្តី
ទាំង២នោះ បានរក្សាឯងឱ្យរួចពីស្ត្រីដទៃ គឺពីស្ត្រីក្រៅ
ដែលនិយាយប្រលោម ដោយពាក្យផ្អែមល្ហែម[ឃ] ៦ដ្បិតអញ
បានមើលពីបង្អួច ហើយតាមតារាងផ្ទះអញទៅ ៧ក៏
ពិចារណា ក្នុងពួកមនុស្សឆោតល្ងង់ ឃើញក្នុងពួកកំឡោះៗ
មានម្នាក់ដែលឥតយោបល់[ង] ៨កំពុងតែដើរទៅតាមជ្រុងផ្លូវ
របស់ស្ត្រីនោះ ក៏ដំរង់ទៅឯផ្ទះនាង ៩គឺនៅពេលព្រលប់
កាលពន្លឺនៅព្រិលៗនៅឡើយ[ច] ឬនៅពេលពាក់កណ្តាល
អធ្រាត្រ កាលងងឹតសូន្យទៅហើយ ១០នោះឃើញមាន
ស្ត្រីម្នាក់មកជួបនឹងវា នាងនោះតែងខ្លួនរបៀបជាស្រីសំផឹង
ហើយមានចិត្តចេះឧបាយ ១១នាងធ្វើសំឡេងឡូៗ[ឆ] ហើយក៏
មានក្បាលរឹង ជាអ្នកដែលនៅក្នុងផ្ទះមិនជាប់ ១២ចួនកាល
នាងនៅឯផ្ទះ ចួនកាលនៅទីផ្សារ ហើយក៏លបចាំនៅគ្រប់
ទាំងជ្រុងផ្លូវផង[ជ] ១៣គឺយ៉ាងនោះដែលនាងចាប់ ហើយ
ថើបវា[ឈ] ក៏និយាយនឹងវាដោយមុខក្រាស់ថា[ញ] ១៤នៅថ្ងៃ
នេះ ខ្ញុំបានត្រូវថ្វាយយញ្ញបូជាជាដង្វាយមេត្រី[ដ] ក៏បាន
លាបំណន់នោះស្រេចហើយ ១៥ហេតុនោះបានជាខ្ញុំចេញ
មកទទួលអ្នក ដើម្បីខំរកឱ្យឃើញមុខអ្នក ក៏បានឃើញ
ហើយ ១៦ខ្ញុំបានក្រាលកំរាលប៉ាក់នៅលើគ្រែខ្ញុំ ព្រមទាំង
សំពត់ពណ៌ ធ្វើពីអំបោះស្រុកអេស៊ីព្ទផង ១៧ខ្ញុំបានប្រោះ
ដំណេក[ឋ] ដោយគ្រឿងក្រអូប គឺដោយជ័រល្វីងទេស[ឌ] ក្រឹស្នា
និងសម្បុរល្វែង ១៨ចូរមក យើងនឹងបានឆ្អែតចិត្តដោយ
សេចក្តីស្នេហាដរាបដល់ភ្លឺ ចូរយើងមានចិត្តត្រេកត្រអាល
ក្នុងសេចក្តីស្រឡាញ់ចុះ[ឍ] ១៩ដ្បិតប្តីខ្ញុំមិននៅផ្ទះទេ គេហ៍
បានធ្វើដំណើរទៅឆ្ងាយហើយ ២០ក៏យកថង់ប្រាក់ជាប់
នឹងខ្លួនទៅដែរ ដល់ពេញបូណ៌ទើបត្រឡប់មកវិញ ២១គឺ
ដោយពាក្យផ្អែមល្ហែមជាច្រើន នាងបានបបួលឱ្យវាព្រម
តាម ហើយដោយពាក្យបញ្ចើចនៃបបូរមាត់នាង ក៏បង្ខំឱ្យ
វាទៅផង[ណ] ២២យ៉ាងនោះ វាក៏តាមជា១រំពេច ប្រៀបដូច
ជាគោដែលទៅឯទីសំឡាប់ ឬដូចជាមនុស្សជាប់ចំណង
ដែលនាំទៅឯទីវាយផ្ចាលមនុស្សចំកួត[ត] ២៣ទាល់តែមាន

**៧:៥** ឃ ខ.២១ យបប ៣១:៩ សភ ២:១៦ ៦:២៤
**៧:៧** ង សភ ១:២២ ៦:៣២
**៧:៩** ច យប ២៤:១៥
**៧:១១** ឆ សភ ៩:១៣
**៧:១២** ជ សភ ៨:១–៣៦ ២៣:២៦–២៨
**៧:១៣** ឈ លប ៣៩:១២ ញ សភ ១:២០
**៧:១៤** ដ លវ ៧:១១–១៨
**៧:១៧** ឋ នអ ១:៦ អស ៥៧:៧ អគ ២៣:៤១ អម ៦:៤ ឌ លប ៣៧:២៥
**៧:១៨** ឍ លប ៣៩:៧
**៧:២១** ណ ខ.៥
**៧:២២** ត យប ១៨:១០

៤:៩–១០,១២ ៥:១–២) ។

**៦:៥** សូមមើលការពន្យល់នៅក្នុង ២:១៦ ៥:៣ ។

**៧:៧** *ឆោតល្ងង់* សូមមើលការពន្យល់នៅក្នុង ១:៤ ។ *ដែលឥតយោបល់* សូមមើល ៦:៣២ ៩:៤,១៦ ។

**៧:៨** *ដំរង់ទៅឯផ្ទះនាង* សូមមើល ៥:៨ ។

**៧:៩** *កាលងងឹតសូន្យ* នៅត្រង់ឃ្លានេះគឺនិយាយពីមនុស្សដែលដើរតាមផ្លូវអាក្រក់ និងមនុស្សដែលតែងតែបោះបង់ចោលផ្លូវទៀងត្រង់ ហើយទ្រង់មានសេចក្តីសង្ឃឹមថា គ្មានអ្នកណាមួយអាចមើលឃើញទ្រង់ឡើយ (សូមមើល ២:១៣ និងការពន្យល់) ។

**៧:១០** *តែងខ្លួនរបៀបជាស្រីសំផឹង* គឺប្រហែលជារបៀបតែងខ្លួនយ៉ាងឆើតឆាយ (សូមមើល អគ ១៦:១៦) និងពាក់ស្បៃបាំងមុខយ៉ាងក្រាស់(សូមមើល លប ៣៨:១៤–១៥) ។

**៧:១១** *សំឡេងឡូៗ* គឺបានអនុវត្តន៍ប្រើចំពោះ"ស្ត្រីដែលល្ងីល្ងើ" មាននៅក្នុង ៩:១៣ (សូមមើលការពន្យល់នៅត្រង់នោះ) ។

**៦:១២** *ក៏លបចាំ* នាងបានរៀបចំខ្លួនជាស្រេច ដើម្បីចាប់នុយមកសម្រាប់ធ្វើជារំពារបស់នាង (សូមមើល ខ. ២២–៣៣) ។

**៧:១៣** *ថើបវា* គឺជាសញ្ញានៃការជម្រាបសួរដោយឥតអៀនខ្មាស(សូមមើល លប ២៩:១១) ។

**៧:១៤** *ថ្វាយយញ្ញបូជាជាដង្វាយមេត្រី* គឺជាចំណែកនៃសាច់ ដែលអាចនឹងបរិភោគបាន ដោយនណាម្នាក់បាននាំយកយញ្ញមកថ្វាយជាដង្វាយមេត្រី ហើយការថ្វាយនោះ គឺតាមរយៈគ្រួសាររបស់គាត់ (លវ ៧:១២–១៥) ។ *បានលាបំណន់នោះស្រេចហើយ* ការថ្វាយយញ្ញបូជា គឺជាលទ្ធផលនៃការលាបំណន់ ដែលជាផ្នែកមួយនៃការថ្វាយយញ្ញបូជា ជាដង្វាយមេត្រី ហើយសាច់ដែលបានបរិភោគនៅថ្ងៃទីមួយ និងថ្ងៃទីពីរ (សូមមើល លវ ៧:១៥–១៦) ។ ដូច្នេះ មនុស្សកម្លោះមានឱកាសដើម្បីសប្បាយ នៅក្នុងពិធីជប់លាងដ៏ប្រសើរនោះជាផ្នែកមួយនៃការចំអកឡកឡឺយ ដែលជាចំណុចសំខាន់នៅក្នុងសាសនា (ធៀបនឹង ១សយ ១:២១ និងការពន្យល់) ។

**៧:១៦** *សំពត់ពណ៌ ធ្វើពីអំបោះស្រុកអេស៊ីព្ទ* សំពត់ខ្លូតទេសគឺជាការទំនាក់ទំនងទៅនឹងអ្នកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ មាននៅក្នុង ៣១:២២ ។ សំពត់ខ្លូតទេសពីស្រុកអេស៊ីព្ទ គឺមានតម្លៃថ្លៃខ្លាំងណាស់ (សូមមើល អស ១៩:៩ និងការពន្យល់ អគ ២៧:៧) ។

**៧:១៧** *ជ័រល្វីងទេស ក្រឹស្នា នឹងសម្បុរល្វែង* គឺជាគ្រឿងក្រអូបដែលដូចជាទឹកអប់ ដែលបានភ្ជាប់ទំនាក់ទំនងជាមួយនឹងការរួមដំណេក (សូមមើល បស ១:៣ ៤:១៤ ៥:៥ និងការពន្យល់ សូមមើល ទដ ៤៥:៨ ផងដែរ) ។

**៧:១៨** *ឆ្អែតចិត្តដោយសេចក្តីស្នេហា* ការរួមដំណេកគឺបានប្រៀបប្រដូចទៅនឹងការបរិភោគអាហារ ហើយនិងការផឹកទឹកផងដែរ មាននៅក្នុង ៩:១៧ ៣០:២០ បស ៤:១៦ ៥:១ ។ *មានចិត្តត្រេកត្រអាល* សូមមើល បស ៤:១០ ។

**៧:១៩** *មិននៅផ្ទះ* ដូច្នេះ គាត់នឹងមិនដែលស្គាល់នៅផ្ទះឡើយ (ធៀបនឹង ៦:៣៤–៣៥) ។ *ធ្វើដំណើរទៅឆ្ងាយ* ប្រហែលជាគាត់ចេញទៅធ្វើជំនួញ ។

**៧:២០** *ប្រាក់* ចំណែកប្រាក់ទាំងនេះគឺមានទម្ងន់ខុសៗគ្នា ជាធម្មតាគឺអាចប្តូរបាន ប៉ុន្តែមិនមានទ្រង់ទ្រាយនៅខាងក្នុង ដូចជារូបិយវត្ថុឡើយ រហូតមកដល់កំឡុងពេលក្រោយមកទៀត ទើបប្រហែលជាមានទ្រង់ទ្រាយដូចរូបិយវត្ថុ ។

**៧:២១** *ពាក្យផ្អែមល្ហែមជាច្រើន . . . ពាក្យបញ្ចើចនៃបបូរមាត់* សូមមើលការពន្យល់នៅក្នុង ២:១៦ ៥:៣ និងសូមមើលផងដែរ ៦:២៤ ៧:៥ ។ *ក៏បង្ខំឱ្យវាទៅ* ធៀបនឹង ៥:២៣ ។

**៧:២២** *ប្រៀបដូចជាគោដែលទៅឯទីសំឡាប់* នៅត្រង់ឃ្លានេះមានន័យថាលទ្ធផលប្រព្រឹត្តអំពើបាបរបស់ពួកគេ នឹងរង់ចាំគេ ប្រៀបដូចជាគោដែលទៅឯទីសម្លាប់ ។ *ជាប់ចំណង* ធៀបនឹង អស ៥១:២០ ។

**៧:២៣** *ទំលុះថ្លើមខ្លួន* ជាលទ្ធផលនៃការប្រព្រឹត្តអាក្រក់ដែលគួរឱ្យភ័យខ្លាចគឺស្រដៀងនិងបាននិយាយរៀបរាប់នៅក្នុង យប ២០:២៤–២៥ ។ *ដំរង់ទៅ*

ព្រួញទិលុះ[ឋ]ថ្លើមខ្លួន ឬដូចសត្វស្លាបហើរដំរង់ទៅជាប់លប់
ឥតដឹងថានឹងចាប់យកជីវិតខ្លួនទេ[ទ] ។
២៤ដូច្នេះ កូនទាំងឡាយអើយ ចូរស្តាប់[ធ]អញឥឡូវ
ហើយផ្ចង់ចិត្តចំពោះពាក្យដែលចេញពីមាត់អញចុះ ២៥កុំឱ្យ
ចិត្តឯងងាកទៅតាមផ្លូវរបស់ស្រីយ៉ាងនោះឡើយ ក៏កុំឱ្យ
វង្វេងទៅតាមផ្លូវច្រករបស់វាដែរ[ន] ២៦ដ្បិតវាបានធ្វើឱ្យ
មនុស្សជាច្រើនត្រូវរបួសដួល អើ ពួកអ្នកដែលវាបាន
សំឡាប់ នោះមានសន្ធឹកណាស់ ២៧ផ្ទះរបស់វា គឺជាផ្លូវ
នាំចុះទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់ គឺនាំចុះទៅដល់
លំនៅរបស់សេចក្តីស្លាប់[ប] ។

## ការបន្លឺសម្លេងនៃប្រាជ្ញា

៨ ១ឯប្រាជ្ញា នោះបន្លឺឡើង[ក] ហើយយោបល់ក៏បញ្ចេញ
សំឡេងទេតើ ២ទាំង២នោះឈរនៅកំពូលនៃអស់ទាំងទី
ខ្ពស់ក្បែរផ្លូវដើរ ហើយនៅកន្លែងដែលផ្លូវច្រកប្រសព្វគ្នា
៣ព្រមទាំងនៅមាត់ទ្វារ ជាផ្លូវចូលទៅក្នុងទីក្រុងផង គឺនៅ
កន្លែងដែលមនុស្សចូលតាមទ្វារក្រុង នោះក៏ស្រែកថា[ខ] ៤ឱ
មនុស្សទាំងឡាយអើយ អញស្រែកហៅឯងរាល់គ្នា[គ] ហើយ
សំឡេងអញក៏ហៅរកដល់អស់មនុស្សជាតិ ៥ឱមនុស្សឆោត
ល្ងង់អើយ[ឃ] ចូររៀនឱ្យដឹងសេចក្តីឆ្លៀវឆ្លាត[ង] ឱមនុស្ស
ចំកួតអើយ ចូរឱ្យចិត្តឯងមានយោបល់ចុះ ៦ចូរស្តាប់ ដ្បិត
អញនឹងពោលសេចក្តីដ៏ប្រសើរវិសេស ហើយដែលអញ
បើកបបូរមាត់ នោះនឹងបញ្ចេញសេចក្តីទៀងត្រង់ ៧ពី

**៧:២៣** ថ យប ១៥:២២ ១៦:១៣ ទ សក ៦:២៦ សស ៧:២៦ **៧:២៤** ធ សក ១:៨–៩ ៨:៣២ **៧:២៥** ន សក ៥:៧–៨ **៧:២៧** ប ពច ១៦:១៩ សក ២:១៨ វវ ២២:១៥ **៨:១** ក យប ២៨:១២ **៨:៣** ខ សក ៧:៦–១៣ **៨:៤** គ អស ៤២:២ **៨:៥** ឃ សក ១:២២ ង សក ១:៤ **៨:៧** ច យប ៨:១៤ **៨:១០** ឆ យប ២៨:១៧ ទដ ១៩:១០ **៨:១១** ជ ខ.១៩ យប ២៨:១៧–១៩ ឈ សក ៣:១៣–១៥ **៨:១២** ញ សក ១:៤ **៨:១៣** ដ លប ២២:១២ ឋ នក ២០:២០ យប

ព្រោះមាត់អញនឹងពោលសេចក្តីពិត[ច] ហើយបបូរមាត់អញ
នឹងខ្ពើមចំពោះសេចក្តីអាក្រក់ ៨អស់ទាំងពាក្យនៃមាត់អញ
សុទ្ធតែសុចរិត ឥតមានអ្វីដែលព័ន្ធពាក់ ឬស្រពិចស្រពិល
ឡើយ ៩គឺសុទ្ធតែប្រច័ក្សច្បាស់ដល់អស់អ្នកដែលយល់ ហើយ
ក៏ទៀងត្រង់ដល់អស់អ្នកដែលរកបានដំរិះដែរ ១០ស៊ូទទួល
យកដំបូន្មានរបស់អញ ជាជាងប្រាក់ ហើយទទួលដំរិះជា
ជាងមាសយ៉ាងវិសេសបំផុត[ឆ] ១១ដ្បិតប្រាជ្ញាប្រសើរជាង[ជ]
ត្បូងទទឹម ហើយរបស់ទាំងប៉ុន្មានដែលមនុស្ស នឹងប្រាថ្នា
ចង់បាន នោះក៏ប្រៀបផ្ទឹមឱ្យស្មើមិនបានផង[ឈ] ។
១២អញនេះជាតួប្រាជ្ញា អញយកគំនិតវាងវៃទុកជា
លំនៅរបស់អញ ក៏មានចំណេះចេះគិតពិចារណា[ញ] ១៣ឯ
ការកោតខ្លាចដល់ព្រះយេហូវ៉ា[ដ] នោះឈ្មោះថា ស្អប់ដល់
សេចក្តីអាក្រក់[ឋ] ចំណែកការលើកខ្លួន ប្រកាន់ខ្លួន ប្រព្រឹត្ត
អាក្រក់ ហើយនិងមាត់ពោលពាក្យវៀច នោះអញក៏ស្អប់[ឌ]
ណាស់ ១៤ការជួយគំនិតជារបស់ផងអញ ព្រមទាំងការ
ទាំងអស់ដែលមានប្រយោជន៍ផង អញជាតួយោបល់ ក៏
មានឥទ្ធិឫទ្ធិដែរ[ឍ] ១៥ពួកមហាក្សត្រសោយរាជ្យ ហើយពួក
មានបណ្តាលសក្តិ[ណ] ក៏សំរេចសេចក្តីយុត្តិធម៌ ដោយសារ
អញ ១៦ពួកអ្នកគ្រប់គ្រង[ត] និងពួកមានត្រកូលខ្ពស់ គឺអស់ទាំង
ចៅហ្វាយដែលនៅផែនដី ក៏គ្រប់គ្រងដោយសារអញដែរ

២៨:២៨ ឌ យរ ៤៤:៤ **៨:១៤** ឍ យប ៩:៤ សក ២១:២២ សស ៧:១៩ **៨:១៥** ណ ទដ ២:១០ **៨:១៦** ត ២របា ១:១០ សក ២៩:៤

*ជាប់លប់* សូមមើលការពន្យល់នៅក្នុង ១:១៧–១៨ ៥:២២ ។

**៧:២៤** សូមមើល ៥:៧ ។

**៧:២៥** *ផ្លូវរបស់ស្រី* សូមមើល ១:១៥ ។

**៧:២៦** *មនុស្សជាច្រើនត្រូវរបួសដួល* សូមមើល ៩:១៨ ២៣:២៨ អស ៥:១៤ និងការពន្យល់ ។

**៧:២៧** *ជាផ្លូវនាំចុះទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់* មើលការពន្យល់ ២:១៨ ៥:៥ និងមើល ១៤:១២ ១៦:២៥ មថ ៧:១៣ ធៀបនឹង ១កថ ៦:៩–១០ ។

**៨:១** *បន្លឺឡើង . . . បញ្ចេញសំឡេង* សូមមើល ១:២០ និងការពន្យល់ ។

**៨:២–៣** សូមមើលការពន្យល់ ១:២០–២១ ។

**៨:៤** *ឱមនុស្សទាំងឡាយអើយ* សូមមើល ខ.៣១ និងការពន្យល់ ។

**៨:៥** *ឱមនុស្សឆោតល្ងង់អើយ . . . ឱមនុស្សចំកួតអើយ* គឺចង់បង្ហាញទាំងពីរបែបក្នុងការថ្លែងរបស់ប្រាជ្ញា មានក្នុង ១:២២,២៣ ។ *ចូររៀនឱ្យដឹងសេចក្តី* សូមមើលការពន្យល់ ១:៤ ។

**៨:៦** *សេចក្តីដ៏ប្រសើរវិសេស . . . សេចក្តីទៀងត្រង់* សូមមើល ភល ៤:៨ ។

**៨:៧** *ហើយបបូរមាត់អញនឹងខ្ពើមចំពោះសេចក្តីអាក្រក់* សូមមើល ៣:៣២ និងការពន្យល់ ១២:២២ ។

**៨:៨** *អ្វីដែលព័ន្ធពាក់ ឬស្រពិច* មើល ៣:៣២ និងការពន្យល់ ១២:២២ ។

**៨:៩** *ដែលប្រច័ក្សច្បាស់* គឺអ្នកដែលឆ្លាតដែលគេស្រឡាញ់ ឬទទួលស្គាល់ពាក្យនៃប្រាជ្ញា ។ *អ្នកដែលរកបានដំរិះដែរ* គឺជាដំរិះនៃព្រះអម្ចាស់ (សូមមើលការពន្យល់ ២:៥) ។

**៨:១០** *ប្រាក់ . . . មាស* សូមមើល ខ.១៩ ២:៤ ៣:១៤ និងការពន្យល់ ។

**៨:១១** គឺមានលក្ខណៈស្រដៀងនឹង ៣:១៥ (មើលការពន្យល់ក្នុងខនោះ) ។

**៨:១២** *អញយកគំនិតវាងវៃទុកជាលំនៅ* ប្រៀបធៀប យប ២៨:២០ ។ *មានចំណេះចេះគិតពិចារណា* សូមមើល ១:៤ និងការពន្យល់ ។

**៨:១៣** *ការកោតខ្លាចដល់ព្រះយេហូវ៉ា . . . ស្អប់ដល់សេចក្តីអាក្រក់* សូមមើល ៣:៧ និងការពន្យល់ ១៦:៦ ។ *ចំណែកការលើកខ្លួន ប្រកាន់ខ្លួន . . . នោះអញក៏ស្អប់ណាស់* សូមមើល ១៦:១៨ ១សយ ២:៣ អស ១៣:១១ និងមើល ទដ ១០:២–១១ និងការពន្យល់ ។ *ប្រព្រឹត្តអាក្រក់ ហើយនិងមាត់ពោលវៀច* មើលការពន្យល់ ២:១២ ក៏សូមមើល ៦:១២–១៩ ផងដែរ ។

**៨:១៤** *ការជួយគំនិតជារបស់ . . .* លក្ខណៈសម្បត្តិរបស់ផងព្រះយេហូវ៉ាទាំងនេះមានក្នុង (២:៦–៧ យប ១២:១៦ អស ៤០:១៣–១៤ រម ១៦:២៧) និងព្រះវិញ្ញាណនៃព្រះយេហូវ៉ា (អស ១១:២) ។ *ជួយគំនិត* សូមមើល ១:២៥ ១៩:២០ ។

**៨:១៥** *ពួកមហាក្សត្រសោយរាជ្យ* សូមមើល ២៩:៤ មានដូចជាស្តេចសាឡូម៉ូនបានអធិស្ឋានសុំប្រាជ្ញា ដើម្បីគ្រប់គ្រងរាស្ត្រអ៊ីស្រាអែល (សូមមើល ១ពវ ៣:៩ ២រប ១:១០) ។

១៧អញស្រឡាញ់ដល់អស់អ្នកដែលស្រឡាញ់អញ[ថ] ហើយ
អស់ពួកអ្នកដែលស្វែងរកអញអស់ពីចិត្ត នោះនឹងបានជួប[ទ]
១៨មានអស់ទាំងទ្រព្យសម្បត្តិ និងកិត្តិយស[ធ]នៅជាមួយនឹង
អញ អើ មានទាំងរបស់ទ្រព្យដ៏ស្ថិតស្ថេរ[ន] និងសេចក្តី
សុចរិតផង ១៩ផលដែលកើតពីអញ នោះវិសេសជាងមាស[ប]
អើ ក៏ប្រសើរជាងមាសយ៉ាងបរិសុទ្ធផង ហើយផលកំរៃ
របស់អញជាជាងប្រាក់យ៉ាងវិសេសបំផុត[ផ] ២០អញដើរក្នុង
ផ្លូវនៃសេចក្តីសុចរិត[ព] គឺនៅកណ្តាលផ្លូវច្រកនៃសេចក្តី
យុត្តិធម៌ ២១ដើម្បីនឹងធ្វើឱ្យអស់អ្នកដែលស្រឡាញ់អញ បាន
ទទួលរបស់ទាំងប៉ុន្មាន ដែលមានទុកជាមរដក ហើយឱ្យ
អញបានបំពេញឃ្លាំងរបស់គេ[ភ] ។
២២ព្រះយេហូវ៉ាទ្រង់បានតាំងអញឡើង ជាដើមការ
នៃទ្រង់ គឺមុនអស់ទាំងកិច្ចការរបស់ទ្រង់ពីបុរាណ ២៣ទ្រង់
បានសិតអញតាំងពីអស់កល្បរៀងមក គឺពីកាលនៅដើម
ឡើយ មុនដែលមានផែនដីផង ២៤ក្នុងគ្រាមុនដែលមាន
ទីជិរៅទឹក នោះអញបានកើតហើយ គឺកាលមិនទាន់មាន
រន្ធទឹកណាដែលហូរចេញជាបរិបូរនៅឡើយ[ម] ២៥មុនដែល
ភ្នំទាំងឡាយបានហាប់មាំមួននៅ[យ] អញបានកើតមកមុន
អស់ទាំងភ្នំតូច[រ] ២៦គឺក្នុងកាលដែលទ្រង់មិនទាន់បង្កើតដី
ឬស្រែចំការ ឬល្អងធូលី មុនដំបូងនៅផែនដីនៅឡើយផង[ល]
២៧ក្នុងកាលដែលទ្រង់ប្រតិស្ឋានផ្ទៃមេឃ[វ] នោះអញបាន
នៅឯណោះហើយ កាលទ្រង់បានគូសវង់[ស]នៅលើទីជិរៅ
ទឹក ២៨កាលទ្រង់បានតាំងឱ្យមានពពកនៅខាងលើ[ហ] និងរន្ធ
ទឹកទាំងប៉ុន្មាននៅទីជិរៅឱ្យបានមានកំឡាំង[ឡ] ២៩កាលទ្រង់
បានកំណត់ព្រំខណ្ឌ[អ]នៃសមុទ្រ ដើម្បីមិនឱ្យទឹកឡើង រំលង
បង្គាប់ទ្រង់[ក] កាលទ្រង់បានកំណត់រាងឫសនៃ ផែនដី[ខ]
៣០នៅគ្រានោះ អញបាននៅជិតទ្រង់[គ] ដូចជាមេជាង ហើយ
អញជាទីគាប់ព្រះហឫទ័យទ្រង់រាល់ៗថ្ងៃ ព្រមទាំងមាន
សេចក្តីរីករាយនៅចំពោះទ្រង់ជានិច្ច ៣១ក៏មានសេចក្តី
រីករាយចំពោះផែនដីទាំងដុំមូលនៃទ្រង់ ហើយបានសេចក្តី

**៨:១៧** ថ ១សយ ២:៣០ យហ ១៤:២១ -២៤ ទ ១រប ១៦:១១ សភ ១:២៨ ៣:១៣–១៨ មថ ៧:៧–១១ **៨:១៨** ធ ១ពវ ៣:១៣ ន ចទ ៨:១៨ **៨:១៩** ប យប ២៨:១៧–១៩ ផ សភ ៣:១៣–១៤ **៨:២០** ព ទដ ៥:៨ **៨:២១** ភ សភ ១៥:៦ ២៤:៤ **៨:២៤** ម លប ៧:១១ **៨:២៥** យ យប ៣៨:៦ រ យប ១៥:៧ **៨:២៦** ល សភ ៩០:២ **៨:២៧** វ យប ២៦:៧ ស យប ២២:១៤ **៨:២៨** ហ យប ៣៦:២៩ ឡ លប ១:៧ យប ៩:៨ ២៦:១០ **៨:២៩** អ លប ១:៩ ទដ ១៦:៦ ក យប ៣៨:៨ ខ ១សយ ២:៨ យប ៣៨:៥ **៨:៣០** គ សភ ៣:១៩–២០ វវ ៣:១៤

**៨:១៧** *អញស្រឡាញ់* គឺអញនឹងចាក់បង្ហូរសេចក្តីប្រយោជន៍មក (សូមមើល ៤:៦ និងការពន្យល់, និងមើល យហ ១៤:២១) ។ *អ្នកដែលស្វែងរកអញអស់ពីចិត្ត នោះនឹងបានជួប* សូមមើល ២:៤–៥ អស ៥៥:៦ យក ១:៥ ។ នៅ ខ.៣៥ បានបង្ហាញគ្រប់សព្វពី “អ្នកដែលស្វែងរកអញអស់ពីចិត្តនឹងបានជីវិតវិញ” ។

**៨:១៨** *ទ្រព្យសម្បិត្តិនិងកិត្តិយល* សូមមើល ខ.២១ ៣:១៦ ២២:៤ ។ *សេចក្តីសុចរិត* សូមមើលការពន្យល់ ៣:២ និងមើល ២១:២១ ។

**៨:១៩** *ផលដែលកើតពីអញ* គឺជាប្រាជ្ញាដែលហៅថា “ដើមនៃជីវិត” មានក្នុង ៣:១៨ (សូមមើលការពន្យល់ ៣:១៨) ។ *ជាងមាស . . . ជាជាងប្រាក់យ៉ាងវិសេសបំផុត* សូមមើល ខ.១០ យប ២៨:១៥ សូមមើល ៣:១៤ និងការពន្យល់ ។

**៨:២០** *ដើរក្នុងផ្លូវ* សូមមើលសេចក្តីផ្តើម ទដ ជំពូក១ និងមើលការពន្យល់ ទដ ១:៦ ។ *ផ្លូវ . . . ផ្លូវច្រក* សូមមើល ៣:១៧ ។ *សេចក្តីយុត្តិធម៌* សូមមើល ខ.១៥ ។

**៨:២១** *ទទួលរបស់ទាំងប៉ុន្មាន* មើល ខ.១៨ សក ៨:១២ និងការពន្យល់ ។ *ទុកជាមរដក ហើយឱ្យអញបានបំពេញឃ្លាំងរបស់គេ* សូមមើល ៣:១០ ២៤:៤ និងការពន្យល់ ។

**៨:២២–៣១** ជាវគ្គចម្រៀងសរសើរតម្កើង អំពីតួនាទីរបស់ប្រាជ្ញាក្នុងការបង្កើតរបស់ផងទ្រង់ ។ ប្រាជ្ញាក្នុងខនេះ គឺបង្ហាញពីលក្ខណៈសម្បត្តិដូចមានក្នុង ១:២០–៣៣ ៣:១៣–១៨ ៩:១–១២ ។ ឯខទាំងនេះក៏មិនបានបកស្រាយឬពណ៌នាចំពោះព្រះគ្រីស្ទដោយផ្ទាល់ទេ ។ ពោលគឺជាការបង្ហាញប្រវត្តិនៃព្រះគម្ពីរសញ្ញាថ្មី ពីព្រះគ្រីស្ទជាព្រះក៏ជាព្រះបន្ទូល (សូមមើល យហ ១:១–៥) ក៏ជាព្រះដំរិះ (សូមមើល ១:២៤) គឺបង្ហាញពីការបង្កើតរបស់ទ្រង់ ។

**៨:២២** *បានតាំងអញឡើង* ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យនេះ ក៏បានគេប្រើក្នុង លប ៤:១ ១៤:១៩,២២ (“ព្រះអាទិករ”) ចទ ៣២:៦ ។ *អញ ប្រាជ្ញា* (សូមមើល ៣:១៩ និងការពន្យល់ ទដ ១០៤:២៤) ។ *ជាដើមការនៃទ្រង់* ប្រៀបធៀបនឹង យប ៤០:១៩ និងការពន្យល់ ។

**៨:២៣** *តាំងពីអស់កល្បរៀងមក* ឃ្លានេះក៏បង្ហាញផងដែរពីព្រះគ្រីស្ទ (សូមមើល យហ ១:១ ធៀបនឹង មីក ៥:២) ។ *មុនដែលមានផែនដីផង* គឺប្រាជ្ញាក៏មានឡើងមុនពេលព្រះអម្ចាស់បានបង្កើតផែនដី (ប្រៀបធៀបសេចក្តីបង្ហាញពីព្រះគ្រីស្ទក្នុង យហ ១៧:៥) ។

**៨:២៤** *អញបានកើតហើយ* គឺគ្រប់ទីកន្លែងសុទ្ធតែទឹកទទេ (យប ៣៨:៨–៩) ហើយនិងអស់ទាំងភ្នំក៏ទទេ (យប ៣៨:៨–៩) ហើយនិងអស់ទាំងភ្នំក៏ពុំបានកើតឡើងនៅឡើយ (ទដ ៩០:២ យប ១៥:៥) ។ *រន្ធទឹកណាដែលហូរចេញជាបរិបូរ* សូមមើល ទដ ១០៤:១០ ។

**៨:២៧** *ទ្រង់ប្រតិស្ឋាននៃមេឃ* សូមមើល ៣:១៩ និងការពន្យល់ ។ *កាលទ្រង់បានគូសវង់នៅលើទីជិរៅទឹក* សូមមើល យប ២៦:១០ ។

**៨:២៨** *រន្ធទឹកទាំងប៉ុន្មាននៅទីជិរៅ* គឺជារន្ធទឹកដែលចេញពីដីមក និងជ្រោះ ឬខ្សែទឹក (សូមមើលការពន្យល់ ៣:២០ ធៀបនឹង លប ៧:១១) ។

**៨:២៩** *បានកំណត់ព្រំខណ្ឌនៃសមុទ្រ* សូមមើល លប ១:៩ និងការពន្យល់ យប ៣៨:១០–១១ ទដ ១០៤:៩ ។ *កំណត់រាងឫសនៃផែនដី* សូមមើលការពន្យល់ ៣:១៩ ។

**៨:៣០** *មេជាង* អស់អ្នកទាំងឡាយណាដែលមានជំនាញក្នុងកិច្ចការសិប្បកម្មផ្សេងៗ ពេលខ្លះហៅថា “អ្នកមានដំរិះប្រាជ្ញា អ្នកប្រាជ” មើលឧទាហរណ៍នៃជីវិតលោកបេតសាលាល គឺជាអ្នកគូសប្លង់ និងសាងសង់រោងឧបោសថ (នក ៣១:៣ សូមមើលការពន្យល់ សភ ១:២) ។ នៅទីនេះជាពាក្យសម្តីបង្ហាញពីជំនាញ នៅក្នុងការបង្កើត ។ *មានសេចក្តីរីករាយ . . . សេចក្តីអំណរ* គឺជាសម្រែករបស់ទេវតា ក្នុងគ្រាដែលទ្រង់បានបង្កើត (យប ៣៨:៧) ។

**៨:៣១** *បានសេចក្តីអំណរដោយនៅជាមួយនិងពួកមនុស្សលោក* សូមប្រៀប

អំណរ ដោយនៅជាមួយនឹងពួកមនុស្សលោក[ឃ] ។
៣២ដូច្នេះ កូនទាំងឡាយអើយ ចូរស្ដាប់[ង]អញឥឡូវ ដ្បិត
អ្នកណាដែលរក្សាអស់ទាំងផ្លូវរបស់អញ នោះមាន[ច]ពរ
ហើយ[ឆ] ៣៣ចូរស្ដាប់ដំបូន្មាន ហើយមានប្រាជ្ញាចុះ កុំឱ្យ
ប្រកែកមិនព្រមទទួលឡើយ ៣៤មានពរហើយ អ្នកណាដែល
ស្ដាប់[ជ]អញ ដោយចាំយាមនៅមាត់ទ្វារអញរាល់ថ្ងៃ គឺដែល
រង់ចាំនៅក្របទ្វារផ្ទះរបស់អញ ៣៥ដ្បិតអ្នកណា ដែល
បាន[ឈ]អញ នោះបានជីវិត[ញ] ក៏នឹងប្រកបដោយព្រះគុណ
នៃព្រះយេហូវ៉ាដែរ[ដ] ៣៦តែឯអ្នកណាដែលធ្វើបាបនឹងអញ
នោះក៏ប្រទូស្តដល់ព្រលឹងខ្លួនឯងដែរ[ឋ] អស់អ្នកណាដែល
ស្អប់អញ នោះឈ្មោះថាស្រឡាញ់សេចក្ដីស្លាប់ហើយ[ឌ] ។

## សេចក្ដីអញ្ជើញនៃប្រាជ្ញា និងសេចក្ដីល្ងង់ខ្លៅ

**៩** ១ប្រាជ្ញាបានសង់[ក]ផ្ទះរបស់ខ្លួនរួចហើយ គឺបានចាំង
សសរទាំង៧ស្រេច ២ក៏បានសំឡាប់សត្វសំរាប់ជប់លៀង
ព្រមទាំងលាយស្រាទំពាំងបាយជូរ[ខ] និងរៀបតុស្រេច
ហើយ[គ] ៣បានទាំងចាត់ពួកស្រីបំរើក្រមុំៗឱ្យចេញទៅ ក៏
ស្រែកប្រកាស[ឃ]នៅលើទីខ្ពស់បំផុតនៃទីក្រុងថា[ង] ៤អ្នកណា
ដែលឆោតល្ងង់[ច] ចូរបែរចូលមកក្នុងទីនេះចុះ ឯចំណែក
អ្នកណាដែលឥតមានយោបល់ នោះក៏ប្រាប់ថា[ឆ] ៥ចូរមក[ជ]
បរិភោគអាហាររបស់អញ ហើយផឹកស្រាទំពាំងបាយជូរ
ដែលអញបានលាយហើយ[ឈ] ៦ចូរលះចោលសេចក្ដីខ្លៅ
ល្ងង់ចេញ នោះនឹងបានរស់នៅ[ញ] រួចឱ្យដើរក្នុងផ្លូវនៃ
យោបល់វិញចុះ[ដ] ។
៧អ្នកណាប្រដៅដំរង់ដល់មនុស្ស ដែលរមែងមើល
ងាយ នោះនឹងបានតែសេចក្ដីត្មះតិះដៀលវិញទេ ហើយ
អ្នកណាដែលបន្ទោសដល់មនុស្សអាក្រក់ នោះនឹងបាន
ប្រឡាក់ជាប់ដល់ខ្លួនហើយ[ឋ] ៨កុំឱ្យបន្ទោសដល់មនុស្ស ដែល
តែងតែមើលងាយ[ឌ]ឡើយ ក្រែងគេស្អប់ឯង ត្រូវឱ្យបន្ទោស
ដល់មនុស្សប្រាជ្ញវិញ គេនឹងស្រឡាញ់ឯង[ឍ] ៩ចូរទូន្មាន
មនុស្សប្រាជ្ញ នោះគេនឹងមានប្រាជ្ញារឹតតែច្រើនឡើង
ហើយបង្រៀនដល់មនុស្សសុចរិត នោះគេនឹងមានចំណេះ
ចំរើនឡើងដែរ[ណ] ១០សេចក្ដីកោតខ្លាចរបស់ព្រះយេហូវ៉ា[ត]

**៨:៣១** ឃ យប ២៨:២៥–២៧ ៣៨:៤–៣៨ ទដ ១០៤:១–៣០ សភ ៣០:៤ យហ ១:១–៤ កល ១:១៥–២០ **៨:៣២** ង សភ ៧:២៤ ច លក ១១:២៨ ឆ ២សយ ២២:២២ ទដ ១៨:២១ **៨:៣៤** ជ ១ពវ ១០:៨ **៨:៣៥** ឈ សភ ៣:១៣–១៨ ញ សភ ៩:៦ យហ ៥:៣៩–៤០ ដ យប ៣៣:២៦ **៨:៣៦** ឋ សភ ១៥:៣២ អស ៣:៩ យរ ៤០:២ ឌ យប ២៨:២២ **៩:១** ក អភ ២:២០–២២ ១ពត ២:៥ **៩:២** ខ អស ២៥:៦ ៦២:៨ គ លក ១៤:១៦–២៣ **៩:៣** ឃ សភ ១:២០ ៨:១–៣ ង ខ.១៤ **៩:៤** ច សភ ១:២២ ឆ ខ.១៦ សភ ៦:៣២ **៩:៥** ជ យហ ៧:៣៧–៣៨ ឈ ទដ ៤២:២ ៦៣:១ ១៤៣:៦ អស ៤៤:៣ ៥៥:១ **៩:៦** ញ សភ ៨:៣៥ ដ សភ ៣:១–២ **៩:៧** ឋ សភ ២៣:៩មថ ៧:៦ **៩:៨** ឌ សភ ១៥:១២ឍ ទដ ១៤១:៥ **៩:៩** ណ សភ ១:៥,៧ ១២:១៥ ១៣:១០ ១៤:៦ ១៥:៣១ ១៩:២ **៩:១០** ត សភ ១:៧

ធៀបនឹង ខ.៤ គឺជាមនុស្សដែលទ្រង់បង្កើតឡើង ឱ្យមានភាពដូចជាទ្រង់ ក៏ជាឧត្តមគតិមួយបង្ហាញពីស្នាព្រះហស្ត (សូមមើល លប ១:២៦–២៨ និងការពន្យល់) ។

**៨:៣២** *មានពរ* គឺជាព្រះពរដែលទាក់ទងនឹងការកើននូវចំណេះ ដែលព្រះទ្រង់បានប្រទានមក ក្នុង ៣:១៣–១៨ មើល ទដ ១:១–៣ និងការពន្យល់ ១១៩:១ ១២៨:១ ។

**៨:៣៤** *ដោយចាំយាមនៅមាត់ទ្វារអញរាល់ថ្ងៃ គឺដែលរង់ចាំនៅក្របទ្វាររបស់អញ* គឺមានលក្ខណៈទៅនឹង (៥:៨) គឺមិនឱ្យទៅជិតទ្វារផ្ទះរបស់ពួកស្រីកំផិតឡើយ ។

**៨:៣៥** *បានជីវិត* មើល ១:២៨ ៣:២ និងការពន្យល់ ប្រៀបធៀបនឹង យហ ១:៤ ។ *ដោយព្រះគុណ* សូមមើល ៣:៤ ១២:២ ១៨:២២ និងការពន្យល់ ។

**៨:៣៦** *អស់អ្នកណាដែលស្អប់អញ នោះឈ្មោះថាស្រឡាញ់សេចក្ដីស្លាប់ហើយ* សូមមើល ១:២៨–៣៣ ៥:១២,២៣ ៧:២៧ និងការពន្យល់ ។

**៩:១** *បានសង់ផ្ទះរបស់ខ្លួន* សូមមើល ១៤:១ និងការពន្យល់ ធៀបនឹង ២៤:៣ និងការពន្យល់ ៣១:១០–២៧ ។ ទាំងប្រាជ្ញានិងភាពល្ងង់ខ្លៅ ក៏មានផ្ទះរបស់គេដែរ ដែលមនុស្សគ្រប់រូបតែងតែបានផ្ទះនោះអញ្ជើញឱ្យចូលទៅ (សូមមើល ខ.៤ ៥:៨ ៨:៣៤) ។ *សសរទាំង៧* ពាក្យថាសសរគឺសំដៅទៅលើ ឬជាតំណាងភាពល្អឥតខ្ចោះខាងឯកិច្ចការប្រាជ្ញា ។

**៩:២** សូមមើល ខ.១៧ និងការពន្យល់ ។ ការជប់លៀងដែលរៀបចំដោយប្រាជ្ញា គឺមានលក្ខណៈផ្ទុយគ្នានឹងការរៀបចំគ្រែដោយគ្រឿងក្រអូប ដែលពួកសំផឹងបានរៀបបំរុងទុក គឺក្នុង ៧:១៧ ។ ពាក្យថា *លាយស្រាទំពាំងបាយជូរ* គឺដើម្បីឱ្យវាមានរសជាតិកាន់តែប្រសើរឡើង ។

**៩:៣** *ក៏ស្រែកប្រកាសនៅលើទីខ្ពស់បំផុតនៃទីក្រុង* សូមមើលការពណ៌នាពីភាពពុំមានឧត្តមគតិ មើលក្នុង ខ.១៤ និងសូមមើល ៨:១–៣ ផងដែរ ។

**៩:៤** ក្នុងខនេះ គឺជាការនិយាយបបួលដោយពុំមានឧត្តមគតិក្នុង ខ.១៦ ក៏សូមមើល ១:៤ ៨:៥ និងការពន្យល់ ។ *ឥតមានយោបល់* មើល ៦:៣២ ៧:៧ ។

**៩:៥** *ចូរមក* ពាក្យនេះគឺជាការបបួលដោយប្រាជ្ញា ដែលលួងចិត្តដល់អ្នកមានបាប មើល ១:១០–១១ (សូមមើលការពន្យល់ ១:១១) ។ ពាក្យថា *បរិភោគ . . . ហើយផឹកស្រា* ដូចក្នុង ខ.២ គឺជាអំណោយទានខាងប្រាជ្ញា បានពណ៌នាពីការស៊ីលៀងដ៏ធំ (សូមមើល អស ៥៥:១–២ និងការពន្យល់ ធៀបនឹង យហ ៦:២៧,៣៥) ។

**៩:៦** *ចូរលះចោលសេចក្ដីខ្លៅល្ងង់ចេញ* សូមមើល ១:២២ ក៏សូមមើល ១:១០–១១ និងការពន្យល់ ។ *បានរស់នៅ* សូមមើល ខ.១១ ៨:៣៥ ក៏សូមមើលការពន្យល់ ៣:២ ធៀបនិង ៣:១៨ និងការពន្យល់ ។

**៩:៧** *អ្នកណាប្រដៅដំរង់ដល់មនុស្ស ដែលរមែងមើលងាយនោះ* មើល ១:២២ និងការពន្យល់ ធៀបនឹង ១:៣០ ។ ពាក្យថា *ប្រឡាក់ជាប់ដល់ខ្លួនហើយ* សូមមើលការពន្យល់ ១ពត ៤:៤ ។

**៩:៨** *ក្រែងគេស្អប់ឯង* សូមមើល ១៥:១២,៣២ ។ ពាក្យថា *បន្ទោសដល់មនុស្សប្រាជ្ញាវិញ គេនិងស្រឡាញ់ឯង* សូមមើល ១០:៨ ១៧:១០ ។

**៩:៩** *គេនឹងមានប្រាជ្ញារឹតតែច្រើនឡើង* សូមមើល ១៨:១៥ ២១:១១ ។

**៩:១០–១២** ពាក្យថាចុងក្រោយរបស់ពាក្យប្រាជ្ញា ក៏បានបំព្រួញមកឱ្យឃើញនិងឮក្នុងជំពូក ១–៩ ។

**៩:១០** *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ាជាដើមចមនៃប្រាជ្ញា* សូមមើល ១:៧ និងការពន្យល់ ។ ក៏សូមមើល ៣០:៣ និងការពន្យល់នៅ ២:៥ ។ ពាក្យថា *ព្រះដ៏បរិសុទ្ធ* ពាក្យនេះក៏លេចឱ្យឃើញនៅក្នុង សុភាសិត ៣០:៣ ។ សូមមើលការពន្យល់ លវ ១១:៤៤ ។

ជាដើមចមនៃប្រាជ្ញ ហើយការដែលស្គាល់ដល់ព្រះដ៏
បរិសុទ្ធ[ថ] នោះគឺជាយោបល់[ទ] ១១ដ្បិតដោយសារអញ នោះ
អស់ទាំងថ្ងៃរបស់ឯងនឹងបានចំរើនជាច្រើនឡើង ហើយ
អស់ទាំងឆ្នាំនៃអាយុឯងនឹងបានយឺនយូរទៅ[ធ] ១២បើឯងមាន
ប្រាជ្ញា នោះគឺមានសិរាប់តែខ្លួនឯងទេ ឬបើឯងចំអក នោះ
មានតែឯង ១នឹងត្រូវរងភារៈនោះ ។
១៣ឯស្ត្រីដែលល្ងីល្ងើ គេតែងស្រែកឡូៗ[ន] ក៏ល្ងង់ខ្លៅ
ឥតដឹងអ្វីសោះ[ប] ១៤គេអង្គុយនៅមាត់ទ្វារផ្ទះរបស់ខ្លួន ឬទី
អង្គុយត្រង់ទីខ្ពស់នៃក្រុង[ផ] ១៥ដើម្បីហៅរក[ព]អស់អ្នក ដែល
ដើរតាមទីនោះ ជាពួកអ្នកដែលដើរដំរង់តាមផ្លូវទៅ
ដោយពាក្យថា ១៦នែ អ្នកណាដែលឆោតល្ងង់ ចូលមកទី
នេះចុះ នាងនិយាយបបួលអស់អ្នកដែលគ្មានយោបល់ថា[ភ]
១៧ទឹកដែលលួចពីគេ នោះរមែងផ្អែម ឯអាហារដែល
បរិភោគដោយលួចលាក់ នោះក៏រមែងឆ្ងាញ់[ម] ១៨តែគេមិន
ដឹងថា ពួកអ្នកស្លាប់មាននៅទីនោះ ឬថាភ្ញៀវរបស់ស្ត្រីនោះ
សុទ្ធ តែនៅក្នុងទីជំរៅនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ[យ] ។

**៩:១០** ថ ទឧ ២២:៣ សជ ៣០:៣ ទ ចទ ៤:៦
**៩:១១** ធ លប ១៥:១៥ ចទ ១១:២១ សភ ៣:១-២ ១០:២៧
**៩:១៣** ន សភ ៧:១១ ប សភ ៥:៦
**៩:១៤** ផ ខ.៣ អក ១៦:២៥
**៩:១៥** ព សភ ១:២០
**៩:១៦** ភ សភ ១:២២
**៩:១៧** ម ២០:១៧
**៩:១៨** យ សភ ២:១៨ ៧:២៦-២៧
**១០:១** ក ១ពវ ៤:៣២ ខ សភ ១:១ គ សភ ១៥:២០ ១៧:២១ ១៩:១៣ ២៣:២២-២៥ ២៧:១១ ២៩:៣

## សុភាសិតនៃស្តេចសាឡូម៉ូន

**១០** ១នេះជាសុភាសិត[ក]របស់សាឡូម៉ូន[ខ] ។ កូនដែលមាន
ប្រាជ្ញា រមែងធ្វើឱ្យឪពុក[គ]មានចិត្តរីករាយ តែកូនដែលល្ងី
ល្ងើ នោះនាំឱ្យម្តាយធុញទ្រូងវិញ ។
២ទ្រព្យសម្បត្តិដែលបានមកដោយអំពើអាក្រក់ នោះ
គ្មានប្រយោជន៍ទេ[ឃ] តែសេចក្តីសុចរិត នោះរមែងជួយឱ្យ
រួចពីស្លាប់[ង]។
៣ព្រះយេហូវ៉ាទ្រង់មិនព្រមឱ្យព្រលឹងនៃមនុស្សសុចរិត
ត្រូវស្រេកឃ្លានទេ[ច] តែទ្រង់ច្រានសេចក្តីលោភរបស់
មនុស្សអាក្រក់ចេញ[ឆ]។
៤អ្នកណាដែលធ្វើការដោយដៃខ្ជិលច្រអូស[ជ] នោះ
រមែងធ្លាក់ខ្លួនជាក្រ តែដៃមនុស្សដែលឧស្សាហ៍ នាំឱ្យមាន
វិញ[ឈ]។
៥ចំណែកអ្នកណាដែលខំប្រឹងប្រមូលទុក នៅក្នុងរដូវ

**១០:២** ឃ សភ ១៣:១១ ២១:៦ ង ខ.១៦ សភ ១១:៤,១៩ ១២:២៨ **១០:៣** ច មថ ៦:២៥-៣៤ ឆ សភ ១៣:២៥ **១០:៤** ជ សភ ៦:៦-៨ ១៩:១៥ ២៤:៣០-៣៤ ឈ សភ ១២:២៤ ២១:៥

**៩:១១** *ទាំងឆ្នាំនៃអាយុឯងនឹងបានយឺនយូរទៅ* សូមមើលការពន្យល់ ៣:២ ក៏សូមមើល ៣:១៦ ១០:២៧ ១៩:២៣ ។

**៩:១២** *បើឯងមានប្រាជ្ញានោះ គឺមានសិរាប់តែខ្លួនឯងទេ* មានប្រាជ្ញាខ្លះបានទទួលជារង្វាន់ សូមមើល ៣:១៦-១៨ ៤:២២ ៨:៣៥ ១៤:១៤ ។ ពាក្យថា *បើឯងចំអក* សូមមើល ខ.៧ ក៏សូមមើលការពន្យល់ ១:២២ ។ *នឹងត្រូវរងភារៈ* សូមមើល ១:២៦ និងការពន្យល់ ១៩:២៩ ។

**៩:១៣** *ស្ត្រីដែលល្ងីល្ងើ* គេតែងស្រែកឡូៗ ពាក្យថា "ឡូៗ" គឺបង្ហាញពីលក្ខណៈ "ល្ងីល្ងើ" ក៏មានភាពកំផិតក្បត់ មើល ២:១៦ ៧:១១ ។ គឺនាងពុំមានយោបល់ឧត្តមគតិ ក៏ពុំមានភាពកោតខ្លាចដល់ព្រះអម្ចាស់ (សូមមើល ១:៣-៤,២២,២៩ ៥:៦) ។

**៩:១៤** *អង្គុយ* សូមប្រៀបធៀបពីការមានប្រាជ្ញាអាចសាងសង់ផ្ទះខ្លួនបាន (ខ.១) ។ *នៅមាត់ទ្វារផ្ទះរបស់ខ្លួន* សូមមើល ខ.១ និងការពន្យល់ ។ ពាក្យថា *ត្រង់ទីខ្ពស់នៃក្រុង* គឺសូមមើលការប្រៀបធៀបមុខងារនៃប្រាជ្ញាក្នុង ខ.៣ ៨:២ ។

**៩:១៥** *ហៅគេ* សូមធៀបនឹង ខ.៣ ៨:១-៤ ។

**៩:១៦** ខនេះការបបួលរបស់នាង បានបញ្ជាក់ពីប្រាជ្ញា (សូមមើល ខ.៤ និងការពន្យល់ ១:២១) ។

**៩:១៧** *ទឹកដែលលួចពីគេ... អាហារដែលបរិភោគដោយលួចលាក់* "គឺជាការស៊ីលៀង"ដែលរៀបចំដោយស្ត្រីល្ងីល្ងើ ដែលមានលក្ខណៈថោកទាបជាងនិងអាហារសាចរបស់ប្រាជ្ញា (ខ.២) ហើយវាជាអាហារដែលបានលួចមក "អាហារនេះ" គឺសំដៅទៅលើសេចក្តីរីករាយដែលបានលួចមក ក៏បានបង្ហាញពីឧទាហរណ៍ ដោយលក្ខណៈផ្លូវភេទខុសច្បាប់ ឬដោយបម្រើដល់មនុស្ស (សូមមើល ៧:១៨ និងការពន្យល់ប្រៀបធៀប ៥:១៥-១៦) ។ *ផ្អែម* សូមមើល យប ២០:១២-១៤ ។

**៩:១៨** *ពួកអ្នកស្លាប់មាននៅទីនោះ . . . ថាភ្ញៀវរបស់ស្ត្រីនោះ សុទ្ធតែនៅក្នុងទីជំរៅនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ* ឃ្លានេះមានលក្ខណៈស្រដៀងគ្នាទៅនិង ២:១៨ ៥:៥ ៧:២៧ និងការពន្យល់ ។

**១០:១** *សុភាសិតរបស់សាឡូម៉ូន* សូមមើលការពន្យល់ ១:១ ចំណងជើងគម្ពីរសុភាសិតនិមួយៗក៏មានក្នុង ២២:១៦ ។ ឯចំណងជើងជាអក្សរព្យញ្ជនៈ ជាតួអក្សរនៅក្នុងភាសាហេព្រើរ ដែលមានក្នុងគម្ពីរសុភាសិតរបស់ស្តេចសាឡូម៉ូនសរុបទាំងអស់មាន ៣៧៥ពាក្យ ក៏សូមមើលការប្រៀបធៀប (១ពវ ៤:៣២) ។ (សូមមើល ១៦:៤ និងការពន្យល់) ។ ពាក្យថា *កូនដែលមានប្រាជ្ញា* សូមមើល ខ.៥ ១៥:២០ ១៧:២១,២៥ ។ ក្នុងការចងក្រងពីការពណ៌នារបស់ស្តេចសាឡូម៉ូនដូចជាពាក្យ "មនុស្សសុចរិត"(២៣:២៤)គឺជា "អ្នកដែលរក្សាច្បាប់បញ្ញត្តិ" (២៨:៧) ។

**១០:២** *ទ្រព្យសម្បត្តិដែលបានមកដោយអំពើអាក្រក់ នោះគ្មានប្រយោជន៍ទេ* ដោយទ្រព្យទាំងនោះនិងបាត់ទៅក្នុងរយៈពេលខ្លី (២១:៦) ឯលទ្ធិផលគឺទទួលការកាត់ទោសពីព្រះ (សូមមើល ខ.១៦ ១:១៩ និងការពន្យល់ អរ ៧:១៩) ។ ពាក្យថា *សេចក្តីសុចរិត នោះរមែងជួយឱ្យរួចពីស្លាប់* យើងឃើញពាក្យនេះក្នុង ១១:៤ ម្តងទៀត (សូមមើល ២:១៦-១៨ ៣:២ ១៣:២១ ប្រៀបនឹង ១២:២៨ ២១:២១ ទដ ១:៥ និងការពន្យល់) ។

**១០:៣** *មិនព្រមឱ្យព្រលឹងមនុស្សសុចរិតត្រូវស្រេកឃ្លាន* សូមមើល ១៣:២៥ ២៨:២៥ និងការពន្យល់ ទដ ៣៤:៩-១០ ៣៧:១៩,២៥-២៦ ។ ប៉ុន្តែ សូមមើលការពន្យល់ សភ ៣:២ ។ *ច្រានសេចក្តីលោភរបស់មនុស្សអាក្រក់ចេញ* សូមមើល ជន ១១:៣៤ ទដ ១១២:១០ និងការពន្យល់ ។

**១០:៤** មានខគម្ពីរសុភាសិតជាច្រើន គឺជាការសរសើតម្កើង ដែលផ្តោតទៅលើការសរសើរព្រះ ដើម្បីឱ្យមនុស្សខ្ជិលច្រអូសបានកាត់ទោស និងឱ្យគេអត់ឃ្លានវេទនា(សូមមើល ៦:៦-១១ និងការពន្យល់ ១២:១១,២៤,២៧ ១៣:៤ ១៤:២៣ ១៨:៩ ២៧:២៣-២៧ ២៧:១៩) ។

**១០:៥** ដេកក្នុងរដូវចំរូតវិញ គឺជាការដែលដេកនៅខណៈពេលមានកិច្ចការ

ក្តៅ នោះឯងជាកូនដែលមានគំនិត តែឯអ្នកណាដែល
រវល់តែដេកនៅរដូវចំរូតវិញ នោះគឺជាកូនដែលនាំឱ្យមាន
សេចក្តីខ្មាស[ញ]។
៦អំណោយពរ រមែងស្ថិតលើក្បាលនៃមនុស្សសុចរិត
តែសេចក្តីច្រឡោត តែងខ្ទប់មាត់របស់មនុស្សអាក្រក់
វិញ[ដ]។
៧សេចក្តីនឹកចាំពីមនុស្សសុចរិត[ឋ] នោះនាំឱ្យមានពរ
តែឈ្មោះរបស់មនុស្សអាក្រក់[ឌ] រមែងពុករលួយទៅ[ឍ]។
៨អ្នកដែលមានចិត្តប្រកបដោយប្រាជ្ញា នោះតែងទទួល
បង្គាប់ តែមនុស្សល្ងីល្ងើដែលមានមាត់រពឹស នោះនឹងត្រូវ
ដួលវិញ[ណ]។
៩អ្នកណាដែលប្រព្រឹត្តដោយទៀងត្រង់[ត] នោះក៏ដើរ
ដោយទុកចិត្ត[ថ] តែអ្នកណាដែលបង្ខូចផ្លូវខ្លួន នោះមនុស្ស
ទាំងឡាយនឹងស្គាល់គេច្បាស់ដែរ[ទ]។
១០អ្នកណាដែលមិចភ្នែក[ធ] នោះរមែងនាំឱ្យកើតទុក្ខ
ហើយមនុស្សល្ងីល្ងើដែលមានមាត់រពឹស នោះក៏នឹងត្រូវ
ដួលចុះ ។
១១មាត់នៃមនុស្សសុចរិត ជាអណ្តូងជីវិត[ន] តែសេចក្តី
ច្រឡោត តែងខ្ទប់មាត់របស់មនុស្សអាក្រក់[ប]។
១២ឯសេចក្តីសំអប់ នោះបណ្តាលឱ្យកើតមានហេតុ
ទាស់ទែងគ្នា តែសេចក្តីស្រឡាញ់ តែងគ្របបាំងអស់ទាំង
អំពើកំហុស[ផ]។
១៣នៅបបូរមាត់របស់មនុស្សមានយោបល់ នោះឃើញ
មានប្រាជ្ញា[ព] តែមានរំពាត់សំរាប់ខ្នងនៃមនុស្សណា ដែល
ឥតមានដំរិះវិញ[ភ]។
១៤មនុស្សប្រាជ្ញ តែងប្រមូលចំណេះទុក តែឯមាត់របស់
មនុស្សល្ងីល្ងើ[ម] នោះជាសេចក្តីហិនវិនាសដែលនៅបង្កើយ
វិញ[យ]។
១៥ទ្រព្យសម្បត្តិរបស់អ្នកមាន ជាទីក្រុងមាំមួនដល់គេ[រ]
សេចក្តីហិនវិនាសរបស់មនុស្សក្រ គឺជាសេចក្តីទាស់ក្រ
របស់គេ[ល]។
១៦កិច្ចការដែលមនុស្សសុចរិតធ្វើ នោះគឺសំរាប់ចិញ្ចឹម
ជីវិត[វ] តែផលរបស់មនុស្សអាក្រក់ សំរាប់តែធ្វើបាបវិញ[ស]។
១៧អ្នកណាដែលស្តាប់តាមសេចក្តីប្រៀនប្រដៅ នោះ
ឈ្មោះថា ដើរក្នុងផ្លូវនៃជីវិតហើយ[ហ] តែអ្នកណាដែលមិន
ព្រមទទួលសេចក្តីបន្ទោស នោះហៅថា វង្វេងវិញ ។

**១០:៥** ញ សភ ២៤:៣០–៣៤ **១០:៦** ដ ខ.៨,១១,១៤ សភ ១២:១៣ ១៣:៣ សស ១០:១២ **១០:៧** ឋ ទដ ១១២:៦ ឌ យប ១៨:១៧ ទដ ១០៩:១៣ ឍ យប ១៨:១៧ ទដ ៩:៦ **១០:៨** ណ ខ.១៤ យប ៣៣:៣៣ មថ ៧:២៤–២៧ **១០:៩** ត ទដ ២៥:២១ ថ ទដ ៣៧:២៤ ទ សភ ២៨:១៨ **១០:១០** ធ ទដ ៣៥:១៩ **១០:១១** ន ខ.២៧ សភ ៣:១៨ ៤:២៣ ១០:៣០ ១៣:១២,១៤,១៩ ១៤:២៧ ១៥:៤ ១៦:២២ ប ខ.៦ **១០:១២** ផ សភ ១៧:៩ ១កថ ១៣:៤–៧ ១ពត ៤:៨ **១០:១៣** ព ខ.៣១ ទដ ៣៧:៣០ សភ ១៥:៧ ភ ចទ ២៤:២ សភ ១៤:៣ ២៦:៣ **១០:១៤** ម សភ ១១:១៣ ១២:២៣ យ ខ.៦ ទដ ៥៩:១២ សភ ១៤:៣ ១៨:៦,៧ មថ ១២:៣៧ **១០:១៥** រ សភ ១៨:១១ ល សភ ១៩:៧ **១០:១៦** វ ចទ ៣០:១៥ ស សភ ១១:១៨–១៩ ១៥:៦ រម ៦:២៣ **១០:១៧** ហ សភ ៦:២៣ ១៥:៥

ធ្វើដើម្បីបង្កើយ ក៏ជាការកាត់ទោសផងដែរ សូមមើលក្នុង ៦:៩–១១ ១៩:១៥ ២០:១៣ ។ ពាក្យថា *កូនដែលនាំឱ្យមានសេចក្តីខ្មាស* សូមមើល ១៧:២ ១៩:២៦ ២៨:៧ ២៩:១៥ ។

**១០:៦** *អំណោយពរ* គឺជាព្រះពរពីព្រះ និងសេចក្តីប្រោសមេត្តារបស់ផងទ្រង់ (សូមមើល ៣:១៣–១៨ ២៨:២០ លប ៤៩:២៦ ចទ ៣៣:១៦) ។ ពាក្យថា *ក្បាល* សូមមើល ១១:២៦ ។ *សេចក្តីច្រឡោតតែងខ្ទប់មាត់របស់មនុស្សអាក្រក់វិញ* គឺរឿងរ៉ាវបណ្តាលមកពីបបូរមាត់របស់ពួកគេ ដែលនាំឱ្យគេទទួលបានគ្រោះមហន្តរាយទៅវិញ ។ (សូមមើល ខ.១១ និងការពន្យល់ ក៏សូមមើល ទដ ១៤០:៩ បហ ២:១៧ ប៉ុន្តែ ប្រៀបធៀប ទដ ២:១១) ។

**១០:៧** *សេចក្តីនឹកចាំពីមនុស្សសុចរិត* (សូមមើល ២២:១ និងការពន្យល់) ។

**១០:៨** *មានចិត្តប្រកបដោយប្រាជ្ញា . . . នោះតែងទទួលបង្គាប់* សូមមើល ៩:៨–៩ ។ *តែមនុស្សល្ងីល្ងើដែលមានមាត់រពឹស នោះនិងត្រូវដួលវិញ* សូមមើល ខ.១០,១៤,១៨,១៩ ។

**១០:៩** *អ្នកដែលប្រព្រឹត្តដោយទៀងត្រង់នោះក៏ដើរដោយទុកចិត្ត* សូមមើល ២:៧ ៣:២៣ ១៣:១៦ ។ *តែអ្នកណាដែលបង្ខូចផ្លូវខ្លួន នោះមនុស្សទាំងឡាយនិងស្គាល់គេច្បាស់ដែរ* សូមមើល ២៦:២៦ លក ៨:១៧ ។

**១០:១០** *មិចភ្នែក* សូមមើលការព្យល់ ៦:១៣ ។ ពាក្យថា *មនុស្សល្ងីល្ងើដែលមានមាត់រពឹស* សូមមើល ខ.៨ ។

**១០:១១** *ជាអណ្តូងជីវិត* គឺជាប្រភពជីវិតដែលទទួលប្រាជ្ញា (សូមមើល ១៣:១៤ ១៤:២៧ ១៦:២ ក៏សូមមើល ទដ ៣៧:៣០) ។ *តែសេចក្តីច្រឡោត* វាប្រហែលជាមានន័យថា សេចក្តីច្រឡោតគ្រប់គ្រងមាត់មនុស្សអាក្រក់ (ប៉ុន្តែ សូមមើល ខ.៦) ។

**១០:១២** *បណ្តាលឱ្យកើតមានហេតុទាស់ទែងគ្នា* មើលការពន្យល់ ៦:១៤ ។ ពាក្យថា *បាំងអស់ទាំងអំពើកំហុស* គឺជាការលើកលែងទោស (សូមមើល ១៧:៩) ។ ឃ្លានេះគឺជាសេចក្តីសំរងក្នុង យក ៥:២០ ១ពត ៤:៨ ។

**១០:១៣** *រំពាត់សំរាប់ខ្នងនៃមនុស្ស* សូមមើល ១៤:៣ ១៩:២៩ ២៦:៣ ។

**១០:១៤** *តែងប្រមូលចំណេះទុក* គឺប្រសើរជាងពួកល្ងីល្ងើ ដូចនេះមនុស្សដែលមានចំណេះបានទទួលភាពសុខសាន្ត សូមមើល ២:១ និងការពន្យល់ ។ ឯមនុស្សល្ងីល្ងើគេមានមាត់ជាសេចក្តីហិនវិនាសវិញ គឺគេបាននាំការហិនវិនាសមកលើខ្លួនគេ (សូមមើល ខ.៨,១០ ១៣:៣) ។

**១០:១៥** *ទ្រព្យសម្បត្តិ . . . ជាទីក្រុងមាំមួន* ក៏បានរំលឹកឡើងវិញក្នុង ១៨:១ ។ ទ្រព្យសម្បត្តិនាំមកឱ្យមានមិត្តសំឡាញ់ (១៤:២០ ១៩:៤) និងអំណាវ (១៨:២៣ ២២:៧) ប៉ុន្តែ ភាពសុខសាន្តបំផុត គឺមានក្នុងព្រះអម្ចាស់ (ទដ ៥២:៧–៨) ។ ភាពអត់ឃ្លាន គឺជាសេចក្តីហិនវិនាសរបស់អ្នកក្រ ។ ភាពអត់ឃ្លានគឺពុំមានភាពសុខសាន្តជាក់លាក់ទេ វាហាក់ដូចជាគ្មានឥទ្ធិពល (១៨:២៣) ឬក៏មិត្តសំឡាញ់ (១៩:៤,៧) សូមមើល ខ.៤ និងការពន្យល់ ។

**១០:១៦** *កិច្ចការដែលមនុស្សសុចរិតធ្វើ នោះគឺសំរាប់ចិញ្ចឹមជីវិត* គឺមិនមែនទ្រព្យ (ខ.១៥) ប៉ុន្តែ ភាពសុចរិតនាំមកនូវជីវិត (សូមមើលការពន្យល់ ៣:២ និងមើល ៣:១៦ ៤:២២) ។ ពាក្យថា *តែផលរបស់មនុស្សអាក្រក់សំរាប់តែធ្វើបាបវិញ* សូមមើល ១៥:៦ ១:១៣,៣១ និងការពន្យល់ ។ "កិច្ចការរបស់អំពើបាប គឺសេចក្តីស្លាប់" (រម ៦:២៣) ។

**១០:១៧** *ផ្លូវនៃជីវិត* សូមមើល ៦:២៣ និងការពន្យល់ ។ *អ្នកណាដែលមិន*

១៨អ្នកណាដែលលាក់សេចក្ដីសំអប់ទុក នោះគឺជាអ្នក
មានបបូរមាត់កុហក[ឡ] ហើយអ្នកណាដែលនិយាយដើមគេ
នោះជាមនុស្សល្ងីល្ងើ ។
១៩អ្នកណាដែលនិយាយច្រើន នោះមិនខាននឹងមាន
បាបឡើយ តែអ្នកណាដែលឃាត់ទប់បបូរមាត់វិញ នោះ
ជាមនុស្សប្រព្រឹត្តដោយប្រាជ្ញា[អ] ។
២០អណ្ដាតរបស់មនុស្សសុចរិត ប្រៀបបីដូចជាប្រាក់
វិសេសបំផុត តែចិត្តរបស់មនុស្សអាក្រក់ រមែងមានដំឡៃ
តិចណាស់ ។
២១បបូរមាត់របស់មនុស្សសុចរិត ឃ្វាលរក្សាមនុស្ស
ជាច្រើន តែមនុស្សល្ងីល្ងើ គេស្លាប់បាត់ទៅ ដោយខ្វះ
យោបល់វិញ[ក] ។
២២អំណោយពរនៃព្រះយេហូវ៉ា[ខ] នោះធ្វើឱ្យទៅជា
មាន[គ] ហើយទ្រង់មិនបន្ថែមសេចក្ដីទុកព្រួយផងទេ[ឃ] ។
២៣ឯការដែលមនុស្សល្ងីល្ងើប្រព្រឹត្តអាក្រក់[ង] នោះដូច
ជាល្បែងលេងសប្បាយដល់គេ តែមនុស្សដែលមានដំរិះ
យោបល់ នោះចូលចិត្តនឹងប្រាជ្ញាវិញ ។
២៤សេចក្ដីដែលមនុស្សអាក្រក់ភ័យខ្លាច[ច] នោះនឹងកើត
ឡើងដល់គេជាពិត[ឆ] ហើយសេចក្ដីដែលមនុស្សសុចរិត
ប្រាថ្នាចង់បាន នោះនឹងបានបើកឱ្យដែរ[ជ] ។
២៥កាលណាខ្យល់កួចហួសបាត់ទៅ នោះមនុស្សអាក្រក់
ឥតមានសល់ឡើយ តែមនុស្សសុចរិត មានឫសដ៏ស្ថិតស្ថេរ[ឈ]
នៅអស់កល្បវិញ[ញ] ។
២៦ទឹកខ្មេះដល់ធ្មេញ ហើយផ្សែង[ដ]ដល់ភ្នែក នោះជា
យ៉ាងណា ឯមនុស្សខ្ជិលច្រអូស ក៏យ៉ាងនោះដល់អ្នកណា
ដែលប្រើវាដែរ[ឋ] ។
២៧សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះចំរើនថ្ងៃ
អាយុ[ឌ] តែអស់ទាំងឆ្នាំនៃអាយុរបស់មនុស្សអាក្រក់ នឹងត្រូវ
រួញខ្លីវិញ[ឍ] ។
២៨ការសង្ឃឹមរបស់មនុស្សសុចរិត នោះនាំឱ្យមានចិត្ត
រីករាយ តែសេចក្ដីទុកចិត្តរបស់មនុស្សអាក្រក់ និងសូន្យ
បាត់ទៅ[ណ] ។
២៩ផ្លូវព្រះយេហូវ៉ា ជាបន្ទាយដល់មនុស្សទៀងត្រង់
តែជាសេចក្ដីវិនាសវិញ ដល់អស់អ្នកណាដែលប្រព្រឹត្តអំពើ
អាក្រក់[ត] ។

**១០:១៨** ឡ ទដ ៣១:១៨
**១០:១៩** អ យប ១:២២ ៦:២៤ សភ ១៧:២៨ ២០:២៥ ២១:២៣ យក ១:១៩ ៣:២–១២
**១០:២១** ក សភ ៥:២២–២៣ អស ៥:១៣ យរ ៥:៤ ហស ៤:១,៦,១៤
**១០:២២** ខ ទដ ១២៨:២ គ លប ១៣:២ ៤៩:២៥ ចទ ៨:១៨ ឃ ២របា ២៥:៩
**១០:២៣** ង សភ ២:១៤
**១០:២៤** ច អស ៦៥:៧ ៦៦:៤ ឆ លប ៤២:៣៦ ជ ទដ ៣៧:៤ ១៤៥:១៧–១៩ អក ១១:៨
**១០:២៥** ឈ ទដ ២០:៨ ញ សភ ១២:៣,៧ មថ ៧:២៤–២៧ **១០:២៦** ដ អស ៦៥:៥ ឋ សភ ១៣:១៧ ២៥:១៣ ២៦:៦
**១០:២៧** ឌ ឧ.១១ ចទ ១១:៩ សភ ៩:១០–១១ ៩:២៣ ២២:៤ ឍ យប ១៥:៣២
**១០:២៨** ណ នអ ៧:១០ យប ៨:១៣ ទដ ១១២:១០ សភ ១១:៧ **១០:២៩** ត សភ ២១:១៥ ហស ១៤:៩

*ព្រមទទួលសេចក្ដីបន្ទោស* សូមមើល ៥:១២ ១៥:១០ ។
**១០:១៨** *អ្នកណាដែលលាក់សេចក្ដីសំអប់ទុក* ដោយធ្វើពុតមានភាពរាក់ទាក់ (សូមមើល ២៦:២៤,២៦,២៨) ។
**១០:១៩** *ឃាត់ទប់បបូរមាត់* សូមមើល ១១:១២ ២១:២៣ និងមើល ១៣:៣ ទដ ៥:៩ ១០:៧ ១២០:៤ និងការពន្យល់ ។
**១០:២០** *ប្រាក់វិសេសបំផុត* គឺអ្វីៗដែលសុចរិត ដែលគេហៅថា ជាវត្ថុមានតម្លៃថ្លៃថ្នូរបំផុត (សូមមើល ៣:១៤ ៨:១០ ២៥:១១) ។ ពាក្យថា *ចិត្តរបស់មនុស្សអាក្រក់* គឺមានទាំងគំនិតនិងគំរោងការអាក្រក់របស់ពួកគេ (សូមមើល ៦:១៤,១៨) ។
**១០:២១** *ឃ្វាលរក្សាមនុស្សជាច្រើន* មើល ឧ.១១ និងការពន្យល់ ។ *ស្លាប់បាត់ទៅដោយខ្វះយោបល់វិញ* មើល ៥:២៣ និងការពន្យល់ ៧:៧ ៩:១៦ ។
**១០:២២** *អំណោយពរនៃព្រះយេហូវ៉ា នោះធ្វើឱ្យទៅជាមាន* មានទ្រព្យសម្បត្តិ គឺជាអំណោយទានមកពីព្រះអម្ចាស់ មិនមែនជាផលតាមរយៈការប្រឹងប្រែងរបស់មនុស្សទេ (សូមមើលការពន្យល់ ឧ.៦ ៣:១០ ៨:២១ លប ២៤:៣៥ ២៦:១២) ។ *មិនបន្ថែមសេចក្ដីទុក្ខព្រួយផង* ព្រះពរទ្រង់មានលក្ខណៈមិនដូច "សម្បត្តិដែលទទួលបានដោយការអាក្រក់" ក្នុង ឧ.២ គឺសូមមើលការពន្យល់ក្នុង ឧ.២ ធៀបនឹង ១៥:៦ ។
**១០:២៣** *ប្រព្រឹត្តអាក្រក់នោះដូចជាល្បែងលេងសប្បាយ* សូមមើល ២:១៤ ១៥:២១ ២៦:១៩ ។
**១០:២៤** *សេចក្ដីដែលមនុស្សអាក្រក់ភ័យខ្លាច* សូមមើល ១:២៦–២៧ និងការពន្យល់ ៣:២៥ យប ១៥:២១ អស ៦៦:៤ ។ *សេចក្ដីដែលមនុស្សសុចរិតប្រាថ្នាចង់បាន* សូមមើល ទដ ៩:១៨ ៣៧:៤ ១៤៥:១៩ មថ ៥:៦ ១យហ ៥:១៤–១៥ ។
**១០:២៥** គឺជាការប្រៀបធៀប ពីមនុស្សមានប្រាជ្ញាដែលសង់ផ្ទះលើថ្មដា ចំណែកឯមនុស្សអាក្រក់គេសង់ផ្ទះលើដីខ្សាច់ (មថ ៧:២៤–២៧) ។ *នោះមនុស្សអាក្រក់ឥតមានសល់ឡើយ* សូមមើល ទដ ៣៧:១០ អស ២៨:១៨ ។ *តែមនុស្សសុចរិតមានឫសដ៏ស្ថិតស្ថេរនៅអស់កល្បវិញ* គឺមានភាពមិនរង្គើ ឬមិនអាចប្រែប្រួលបានទេ (សូមមើល ៣:២៥ និងការពន្យល់ ១២:៣,៧ ១៤:១១ ទដ ១០:៦ និងការពន្យល់ ១កថ ១៥:៥៨) ។
**១០:២៦** *ទឹកខ្មេះ* សូមមើល ទដ ៦៩:២១ ។ *មនុស្សខ្ជិលច្រអូស* សូមមើលការពន្យល់ ៦:៦ ។ *ដល់អស់អ្នកណាដែលប្រើវាដែរ* គឺដូចជាអ្នកនាំសារ (សូមប្រៀបធៀប ១៣:១៧ ២៥:១៣ ២៦:៦ និងការពន្យល់) ។
**១០:២៧** *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើលការពន្យល់ ១:៧ ។ ពាក្យថា *នោះចំរើនថ្ងៃអាយុ* សូមមើលការពន្យល់ ៣:២ ។ *ឆ្នាំ . . . ត្រូវរួញខ្លីវិញ* សូមមើល យប ២២:១៦ ទដ ៣៧:៣៦ សូមមើល យប ២២:១៦ ទដ ៣៧:៣៦ ៥៥:២៣ ។
**១០:២៨** *ការសង្ឃឹមរបស់មនុស្សសុចរិត* សូមមើល ឧ.២៤ និងការពន្យល់ ។ ពាក្យថា *ចិត្តរីករាយ* គឺចំពោះសេចក្ដីសម្រេច (ប្រៀបធៀប ១:៧,២៣) ។ *សេចក្ដីសង្ឃឹមរបស់មនុស្សអាក្រក់ និងសូន្យបាត់ទៅ* មើល ១១:៧,២៣ ។
**១០:២៩** *ផ្លូវនៃព្រះយេហូវ៉ា* គឺជាផ្លូវដែលទ្រង់ពណ៌នាពីជីវិតដែលមានប្រាជ្ញា (សូមមើល ទដ ២៧:១១ ១៤៣:៨ មថ ២២:១៦ កច ១៨:២៥) ។ ពាក្យថា *តែជាសេចក្ដីវិនាសដល់អស់អ្នកណាដែលប្រព្រឹត្តអំពើអាក្រក់* គឺជា

៣០ មនុស្សសុចរិត នឹងមិនត្រូវរង្គើឡើយ តែមនុស្ស
អាក្រក់ នឹងអាស្រ័យនៅផែនដីមិនបាន[ថ] ។
៣១ មាត់របស់មនុស្សសុចរិត តែងបញ្ចេញប្រាជ្ញា[ទ] តែ
អណ្ដាត[ធ]វៀច នឹងត្រូវកាត់ចេញ ។
៣២ បបូរមាត់របស់មនុស្សសុចរិត រមែងដឹងសេចក្ដី
ដែលគួរគប្បី[ន] តែមាត់របស់មនុស្សអាក្រក់ ពោលតែ
សេចក្ដីក្រវិចក្រវៀនវិញ[ប] ។

**១១** ១ ជញ្ជីងមិនត្រឹមត្រូវ ជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា[ក]
តែកូនជញ្ជីងគ្រប់ទំងន់ ជាទីគាប់ដល់ព្រះហឫទ័យទ្រង់
វិញ[ខ] ។
២ កាលណាកើតមានសេចក្ដីអំនួត នោះក៏កើតមាន
សេចក្ដីខ្មាសដែរ[គ] តែប្រាជ្ញា តែងនៅនឹងមនុស្សសុភាព[ឃ] ។
៣ សេចក្ដីសុចរិតរបស់មនុស្សទៀងត្រង់ នឹងនាំផ្លូវគេ
តែសេចក្ដីវៀចរបស់មនុស្សប្រទូស្ដ និងនាំឱ្យវិនាសវិញ[ង] ។
៤ ឯទ្រព្យសម្បត្តិ[ច] គ្មានប្រយោជន៍ក្នុងថ្ងៃពិរោធឡើយ[ឆ]
តែសេចក្ដីសុចរិតនឹងជួយឱ្យរួចពីស្លាប់វិញ[ជ] ។
៥ សេចក្ដីសុចរិតរបស់មនុស្សគ្រប់លក្ខណ៍នឹងដំរង់ផ្លូវ[ឈ]
ខ្លួន តែមនុស្សអាក្រក់នឹងដួលដោយសារអំពើអាក្រក់របស់
ខ្លួនវិញ[ញ] ។
៦ ឯសេចក្ដីសុចរិតរបស់មនុស្សទៀងត្រង់ នឹងជួយឱ្យ
ខ្លួនរួច តែមនុស្សប្រទូស្ដនឹងត្រូវជាប់ក្នុងការទុច្ចរិតរបស់
ខ្លួនវិញ[ដ] ។
៧ កាលណាមនុស្សអាក្រក់ស្លាប់ទៅ នោះសេចក្ដីសង្ឃឹម
របស់គេក៏សូន្យទៅដែរ[ឋ] ហើយសេចក្ដីទុកចិត្តរបស់មនុស្ស
ទុច្ចរិត នឹងត្រូវវិនាសទៅផង[ឌ] ។
៨ មនុស្សសុចរិតរមែងរួចពីសេចក្ដីលំបាក ឯមនុស្ស
អាក្រក់ទទួលរងជំនួសវិញ[ឍ] ។
៩ មនុស្សទមិលល្មើសតែងបំផ្លាញអ្នកជិតខាង ដោយ
សារមាត់ខ្លួន តែដំរិះរបស់មនុស្សសុចរិត នឹងដោះឱ្យខ្លួន
រួចវិញ[ណ] ។
១០ គ្រាដែលមនុស្សសុចរិតមានសេចក្ដីសុខស្រួល នោះ
ទីក្រុងក៏រីករាយសាទរ[ត] ហើយកាលណាមនុស្សអាក្រក់
វិនាសទៅ នោះឮសំឡេងហ៊ោសប្បាយ[ថ] ។
១១ ទីក្រុងបានថ្កុំថ្កើងឡើងដោយសារពររបស់មនុស្ស
ទៀងត្រង់[ទ] តែដោយសារមាត់របស់មនុស្សអាក្រក់ នោះ
ត្រូវរលំវិញ[ធ] ។

**១០:៣០** ថ ទដ ៣៧:៩,២៨–២៩ សភ ២:២០–២២ **១០:៣១** ទ ខ.១៣ សភ ១៥:២ ៣១:២៦ ធ ទដ ៥២:៤ **១០:៣២** ន សស ១០:១២ ប ទដ ៥៩:៧ **១១:១** ក លវ ១៩:៣៦ ចទ ២៥:១៣–១៦ យប ៦:២ សភ ២០:១០,២៣ ខ សភ ១៦:១១ អគ ៤៥:១០ **១១:២** គ សភ ១៦:១៨ ឃ សភ ១៨:១២ ២៩:២៣ **១១:៣** ង ខ.៥ សភ ១៣:៦ **១១:៤** ច អគ ២៧:២៧ ឆ យប ២០:២០ អគ ៧:១៩ ជ សភ ១០:២ **១១:៥** ឈ ១ពវ ៨:៣៦ ញ ខ.៣ សភ ៥:២១–២៣ ១៣:៦
២១:៧ **១១:៦** ដ នអ ៧:៩ **១១:៧** ឋ យប ៨:១៣ ឌ សភ ១០:២៨ **១១:៨** ឍ សភ ២១:១៨ **១១:៩** ណ សភ ១២:៦ យរ ៤៥:៥ **១១:១០** ត ២ពវ ១១:២០ ថ នអ ៨:១៧ **១១:១១** ទ សភ ១៤:៣៤ ធ សភ ២៩:៨

ការជំនុំជម្រះដល់អ្នកដែលបោះបង់ផ្លូវរបស់ព្រះចេញ (សូមមើល ២១:១៥ ១កថ ២:១៥–១៦ ២ពត ២:២១ និងការពន្យល់) ។

**១០:៣០** *នឹងមិនត្រូវរង្គើឡើយ* សូមមើល ខ.២៥ ២:២១ និងការពន្យល់ ១២:៣ ទដ ១២៥:១ ។ *អាស្រ័យនៅផែនដីមិនបាន* សូមមើលការពន្យល់ ២:២២ ។

**១០:៣១** *អណ្ដាតវៀច* សូមមើលការពន្យល់ ២:១២ ។ *កាត់ចេញ* សូមមើល ទដ ១២:៣ ធៀបនឹង មថ ៥:២៩–៣០ និងការពន្យល់ ។

**១១:១** *ជញ្ជីងមិនត្រឹមត្រូវ* គឺជាការប្រកាសប្រឆាំង ដែលមានភាពស្រដៀងគ្នា គឺគេបានឃើញក្នុងគម្ពីរក្រឹត្យវិន័យ (សូមមើល លវ ១៩:៣៥ និងការពន្យល់) ដូចជាកិច្ចការទំនាយ (ហស ១២:៧ អម ៨:៥ មីក ៦:១១) ។ សូមមើល ១៦:១១ ២០:១០,២៣ ។ *ជញ្ជីងគ្រប់ទំងន់* សូមមើលការពន្យល់ ១៦:១១ ។ ដូចជាការថ្លឹងប្រាក់ជាលោហៈ ដែលមានកូនជញ្ជីងជាថ្ម ។ ឯកូនជញ្ជីងមិនគ្រប់ទម្ងន់គេប្រើសម្រាប់បោកប្រាស់ឬបំភាន់ភ្នែក ។

**១១:២** *កាលណាកើតមានសេចក្ដីអំនួត នោះក៏កើតមានសេចក្ដីខ្មាសដែរ* (មើល ១៦:១៨ ធៀបនឹង ១០:១២ អស ១៤:១៣–១៥) ។ *តែប្រាជ្ញាតែងតែនៅជាមួយនឹងមនុស្សសុភាព* (សូមមើលការពន្យល់ ១៥:៣៣) ។

**១១:៣** *សេចក្ដីសុចរិតរបស់មនុស្សទៀងត្រង់និងនាំផ្លូវគេ* សូមប្រៀបធៀបនិងសកម្មភាពរបស់លោកយូសែបក្នុង លប ៣៩:៦–១២ ។ *តែសេចក្ដីវៀករបស់មនុស្សប្រទូស្ដ និងនាំឱ្យវិនាសវិញ* សូមមើល ខ.៦ ២:២២ និងការពន្យល់ ១៩:៣ ។

**១១:៤** *ថ្ងៃពិរោធ* គឺជាថ្ងៃនៃការជំនុំជម្រះ (សូមមើល អស ១០:៣ សផ ១:១៨) ។ ពាក្យថា *តែសេចក្ដីសុចរិត និងជួយឱ្យរួចពីស្លាប់វិញ* សូមមើល ២:១៦–១៨ ៣:២ ១០:២ ១៣:២ ។

**១១:៥** *គ្រប់លក្ខណ៍* សូមមើលការពន្យល់ ២:៧ ។ ពាក្យថា *ដំរង់ផ្លូវខ្លួន* គឺដើម្បីឱ្យពួកគេទៅដល់គោលដៅរបស់ពួកគេ (សូមមើល ខ.៣ ៣:៦ និងការពន្យល់ ១០:៩) ។

**១១:៦** *សេចក្ដីសុចរិត . . . ជួយឱ្យខ្លួនរួច* សូមមើល ខ.៣–៤ ។ *ត្រូវជាប់* សូមមើល ៥:២២ និងការពន្យល់ ។

**១១:៧** *សេចក្ដីសង្ឃឹមរបស់គេក៏សូនទៅដែរ* សូមមើល ខ.២៣ ១០:២៨ ។

**១១:៨** ប្រៀបធៀប នអ ៥:១៤ ៧:១០ ។

**១១:៩** *បំផ្លាញអ្នកជិតខាង* ដោយពង្រីករឿងអាស្រូវ (ប្រៀបធៀប ១០:១៨) *តែដំរិះ* គឺជាចំណេះដឹងនៃការបង្កើតផែនការ ។

**១១:១០** *ទីក្រុងក៏រីករាយសាទរ* សូមមើល ២៨:១២ ២៩:២ ។ គឺជាការរស់នៅក្នុងទីក្រុងផ្ទាល់ ជាគ្រូនៃប្រាជ្ញា (មើល ការពន្យល់ ១:២១) ។ *សំឡេងហ៊ោសប្បាយ* គឺជាការប្រៀបធៀបចំពោះសេចក្ដីសប្បាយ ក្នុងពេលពួកអាសើរបានបរាជ័យ (សូមមើល អស ៣០:៣២ និងការពន្យល់ ណាហ ៣:១៩ ប្រៀបធៀប ២រប ២១:២០) ។

**១១:១១** *ដោយសារពរបស់មនុស្សទៀងត្រង់* គឺជាឥទ្ធិពលដ៏ល្អ និងសេចក្ដីប៉ងប្រាថ្នាខាងឯសេចក្ដីសុចរិត ក៏ដូចជាភាពសុខដុមរបស់គេ (ខ.១០) ក៏នាំឱ្យមានភាពឧដ្ដុងឧត្ដមដល់ទីក្រុង ។ *មាត់របស់មនុស្សអាក្រក់* គឺជាការបោកប្រាស់ភាពមិនស្មោះត្រង់បានបង្ហាញនូវភាពមិនចុះសម្រុង ឬភាពបែកបាក់ (សូមមើល ខ.៩ ៦:១២–១៤ និងការពន្យល់) ។

១២ អ្នកណាដែលមើលងាយ ចំពោះអ្នកជិតខាងខ្លួន[ន] នោះឥតមានប្រាជ្ញាទេ តែអ្នកណាមានយោបល់ រមែងនៅស្ងៀមវិញ[ប]។

១៣ អ្នកណាដែលដើរចុះឡើងនិយាយបកកេរគេ នោះឈ្មោះថាបើកការអាថ៌កំបាំង[ផ] តែអ្នកណាដែលមានចិត្តស្មោះត្រង់ នោះតែងគ្របបាំងរឿងរ៉ាវវិញ[ព]។

១៤ ទីណាដែលឥតមានអ្នកប្រាជ្ញនាំមុខ នោះប្រជាជនរមែងដួលទៅ[ភ] តែបើមានអ្នកប្រឹក្សាជាច្រើន នោះមានសេចក្ដីសុខវិញ[ម]។

១៥ អ្នកណាដែលធានា[យ]ឱ្យអ្នកដទៃ នោះនឹងត្រូវពិបាកណាស់ តែអ្នកណាដែលមិនចូលចិត្តនឹងការធានា នោះនឹងបានសុខវិញ[រ]។

១៦ ស្ត្រីណាដែលមានអធ្យាស្រ័យល្អ នោះតែងរក្សាទុកនូវកិត្តិសព្ទ[ល] ដូចជាមនុស្សប្រិតប្រៀបដែលរក្សាទ្រព្យសម្បត្តិដែរ ។

១៧ មនុស្សដែលមានចិត្តមេត្តា នោះតែងធ្វើល្អដល់ជីវិតខ្លួន តែអ្នកណាដែលសាហាវ នោះធ្វើទុក្ខដល់សាច់ឈាមខ្លួនវិញ ។

១៨ មនុស្សអាក្រក់បានកំរៃដែលតែងតែរលួយ តែអ្នកណាដែលផ្សាយសេចក្ដីសុចរិត នោះបានរង្វាន់យ៉ាងជាប់លាប់[វ]។

**១១:១២** ន សភ ១៤:២១ ប យប ៦:២៤
**១១:១៣** ផ សភ ២០:១៩ ព សភ ១០:១៤
**១១:១៤** ភ សភ ២០:១៨ ម ២សយ ១៥:៣៤ សភ ១៥:២២ ២៤:៦
**១១:១៥** យ សភ ៦:១ រ សភ ១៧:១៨ ២២:២៦-២៧
**១១:១៦** ល សភ ៣១:៣១
**១១:១៨** វ នក ១:២០ យប ៤:៨ ហស ១០:១២-១៣
**១១:១៩** ស ចទ ៣០:១៥ សភ ១០:២ ហ ១សយ ២:៦ ទដ ៨៩:៤៨ សភ ១:១៨-១៩ សស ៧:២ យរ ៤៣:១១
**១១:២០** ឡ សភ ៣:៣២ អ ជន ១៤:៨ ក ១រប ២៩:១៧

១៩ ចំណែកសេចក្ដីសុចរិត តែងនាំឱ្យបានជីវិត[ស] តែអ្នកណា ដែលដេញតាមអំពើអាក្រក់ នោះរមែងធ្វើឱ្យខ្លួនស្លាប់វិញ[ហ]។

២០ អ្នកណាដែលមានចិត្ត[ឡ]វៀច នោះជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា តែអ្នកណាដែលគ្រប់លក្ខណ៍ក្នុងផ្លូវខ្លួនប្រព្រឹត្ត នោះជាទីគាប់[អ]ដល់ព្រះហឫទ័យទ្រង់វិញ[ក]។

២១ ទោះបើព្រួតដៃគ្នា គង់តែមនុស្សអាក្រក់នឹងមិនរួចពីទោសឡើយ តែពូជពង្សរបស់មនុស្សសុចរិតនឹងមានជំនួយជួយឱ្យរួច[ខ]។

២២ ស្ត្រីមានរូបស្រស់ល្អ ដែលឥតមានគំនិតមារយាទ នោះប្រៀបដូចជាក្រវិលមាសដែលពាក់នៅច្រមុះជ្រូក ។

២៣ សេចក្ដីប៉ងប្រាថ្នារបស់មនុស្សសុចរិត នោះសុទ្ធតែល្អ តែសេចក្ដីសង្ឃឹមរបស់មនុស្សអាក្រក់ នោះត្រូវខាងសេចក្ដីក្រេវក្រោធវិញ ។

២៤ មានមនុស្សដែលចែកផ្សាយទ្រព្យ តែចេះតែចំរើនកើនឡើង ក៏មានមនុស្សដែលហួងហែងហួសខ្នាត តែគេចេះតែខ្វះខាតវិញ ។

២៥ មនុស្សដែលមានចិត្តសទ្ធា[គ] និងបានបរិបូរ ហើយអ្នកណាដែលស្រោចទឹកដល់គេ នោះនឹងបានគេស្រោចទឹកដល់ខ្លួនដែរ[ឃ]។

ទដ ១៥:២ ១០១:១-៤ ១១៩:១ សភ ១២:២,២២ ១៥:៩ **១១:២១** ខ សភ ១៦:៥ **១១:២៥** គ ១រប ២៩:១៧ អស ៣២:៨ ឃ សភ ២២:៩ ២កថ ៩:៦-៩

**១១:១២** *មើលងាយ ចំពោះអ្នកជិតខាងខ្លួន* គឺបង្ហាញការមិនពេញចិត្តដោយចំហរ (សូមមើល ១០:១៨ ១៤:២១) ។ *រមែងនៅស្ងៀមវិញ* សូមមើល ១០:១៩ និងការពន្យល់ ។

**១១:១៤** សូមមើលពីហេតុការណ៍ស្រដៀងៗគ្នានៅក្នុង ១៥:២២ ២០:១៨ ២៤:៦ ។ *អ្នកប្រឹក្សា* សូមមើល ២សយ ១៦:២៣ អស ១:២៦ ។

**១១:១៥** សូមមើល ការពន្យល់ ៦:១ ។

**១១:១៦** គឺជាការសន្និដ្ឋានដែលបង្ហាញថានាមឈ្មោះល្អគួររើសយក ដោយវាមានលក្ខណៈប្រសើរជាងមានមាសប្រាក់ដ៏ច្រើនផងដែរ (២២:១) និងបើស្ត្រីមានចិត្តល្អគ្រប់លក្ខណៈក្នុងការប្រព្រឹត្ត បានវិសេសលើសជាងគេទាំងអស់ គឺប្រសើជាងបុរសមានសម្បត្តិដ៏មហាសាល ។ ពាក្យថា *ស្ត្រីណាដែលមានអធ្យាស្រ័យល្អ* សូមមើល ៣១:២៨,៣០ ។

**១១:១៧** *នោះតែងធ្វើល្អដល់ជីវិតខ្លួន* សូមមើល មថ ៥:៧ ។ ពាក្យថា *នោះធ្វើទុក្ខដល់សាច់ឈាមខ្លួនវិញ* សូមមើល លប ៣៤:២៥-៣០ ៤៩:៧ ។

**១១:១៨** *កំរៃដែលតែងតែរលួយ* ពីព្រោះគេពុំមានលក្ខណៈស្ថិតស្ថេរ (សូមមើលការពន្យល់ ១០:២,១៦ សូមមើល ហគ ១:៦) ។ ពាក្យថា *នោះបានរង្វាន់យ៉ាងជាប់លាប់* សូមមើល ១០:២៤ កទ ៦:៨-៩ យក ៣:១៨ ។

**១១:១៩** *តែងនាំឱ្យបានជីវិត* សូមមើល ១០:១៦ និងការពន្យល់ ១២:២៨ ១៩:២៣ ។ ពាក្យថា *នោះរមែងធ្វើឱ្យខ្លួនស្លាប់វិញ* សូមមើល ៥:២៣ ២១:១៦ រម ៦:២៣ យក ១:១៥ ។

**១១:២០** សូមមើល ៣:៣២ និងការពន្យល់ ១៦:៥ ។ *គ្រប់លក្ខណ៍* សូមមើលការពន្យល់ ២:៧ ។

**១១:២១** *មិនរួចពីទោសឡើយ* សូមមើល ៦:២៩ ។ *មិនរួចពីទោសឡើយ* សូមមើល ទដ ១១៨:៥ ។

**១១:២២** *ក្រវិលមាស* តាមទម្លាប់ពួកស្រីៗតែងតែពាក់ក្រវិលនេះនៅលើច្រមុះរបស់ពួកគេ (សូមមើល លប ២៤:៤៧ អក ១៦:១២ និងការពន្យល់) (១សយ ២៥:៣៣) ។

**១១:២៣** សូមមើល ១០:២៤,២៨ ។ *សេចក្ដីក្រេវក្រោធ* គឺជាការជំនុំជម្រះ (សូមមើល ខ.៤ អស ១០:៣ សផ ១:១៨ រម ២:៨-៩) ។

**១១:២៤** ការមានចិត្តសទ្ធា គឺជាផ្លូវទៅរកភោគផលដែលជាព្រះពរ និងភាពចម្រើនរុងរឿង (សូមមើល ៣:៩-១០ និងការពន្យល់ សស ១១:១-២ និងការពន្យល់ ទដ ១១២:៩ ២កថ ៩:៦-៩) ។ ក៏មានភាពផ្ទុយគ្នា គឺជាមនុស្សកំណាញ់ ដែលគេពុំមានមិត្តសម្លាញ់ ហើយគេក៏ជាឧបសគ្គមួយដល់ជីវិតរបស់ពួកគេ ដែលនាំឱ្យជីវិតគេឈឺចាប់អស់រយៈពេលវែង (២១:១៣) ។

**១១:២៥** *មនុស្សដែលមានចិត្តសទ្ធានឹងបានបរិបូរ* ដោយគេបានចែកអាហារពួកគេឱ្យទៅអ្នកទាល់ក្រ (២២:៩) ។ "បើអ្នកណាដែលព្រោះដោយចិត្តសទ្ធា គឺនឹងបានទទួលផលដោយចិត្តសទ្ធា" (២កថ ៩:៦ ធៀបនឹង លក ៦:៣៨) ។ ពាក្យថា *បានស្រោចទឹកដល់ខ្លួន* សូមមើល រម ១:១២ និងការពន្យល់ ១៥:៣២ ។

២៦ឯអ្នកណាដែលបង្ខាំងទុកអង្ករ បណ្ដាជននឹងប្រទេច
ផ្ដាសាអ្នកនោះ តែនឹងមានពរស្ថិតនៅលើក្បាល នៃអ្នកណា
ដែលលក់ឱ្យវិញ ។
២៧អ្នកណាដែលព្យាយាមស្វែងរកសេចក្ដីល្អ នោះ
រមែងបានគេរាប់អានដល់ខ្លួនដែរ តែអ្នកណាដែលស្វែង
រកតាមអាក្រក់ ការអាក្រក់នឹងកើតដល់អ្នកនោះឯង[ង] ។
២៨អ្នកណាដែលទីពឹងចំពោះទ្រព្យសម្បត្តិខ្លួន នោះនឹង
ត្រូវដួលចុះ[ច] តែមនុស្សសុចរិតនឹងចំរើនឡើង ដូចជាស្លឹក
ឈើខៀវខ្ចី[ឆ] ។
២៩អ្នកណាដែលនាំឱ្យកើតវឹកវរក្នុងផ្ទះខ្លួន នោះនឹង
គ្រងបានខ្យល់ជាមរដក ហើយមនុស្សល្ងីល្ងើនឹងធ្វើជាបាវ
បំរើដល់មនុស្សប្រាជ្ញ[ជ] ។
៣០ផលរបស់មនុស្សសុចរិត នោះជាដើមឈើនៃជីវិត[ឈ]
ហើយអ្នកណាដែលមានប្រាជ្ញា នោះរមែងចាប់បានព្រលឹង
របស់មនុស្ស ។
៣១មើល ពួកមនុស្សសុចរិតនឹងទទួលបានរង្វាន់[ញ]នៅ
ផែនដីទៅហើយ ចុះឯមនុស្សអាក្រក់ និងមនុស្សមានបាប
តើនឹងទទួលសំណងលើសជាងអំបាលម៉ានទៅ ។

**១២** ១អ្នកណាដែលចូលចិត្តចំពោះសេចក្ដីប្រៀនប្រដៅ
នោះក៏ស្រឡាញ់ដំរិះ តែអ្នកណាដែលស្អប់ដល់សេចក្ដី
បន្ទោស នោះជាមនុស្សកំរោលវិញ[ក] ។
២មនុស្សល្អនឹងប្រកបដោយព្រះគុណនៃព្រះយេហូវ៉ា[ខ]
តែទ្រង់នឹងកាត់ទោស ដល់មនុស្សណាដែលគិតគួបង្កើត
ការអាក្រក់[គ] ។
៣គ្មានមនុស្សណាបានតាំងមាំមួនឡើង ដោយសារអំពើ
អាក្រក់ទេ តែឫសនៃមនុស្សសុចរិតមិនត្រូវរលើងឡើយ[ឃ] ។
៤ស្ត្រីមានចិត្ត[ង]បរិសុទ្ធ នោះជាមកុដដល់ប្ដី តែស្ត្រីណា
ដែលនាំឱ្យមានសេចក្ដីខ្មាស នោះប្រៀបដូចជាសេចក្ដីពុក
រលួយនៅក្នុងឆ្អឹងរបស់ប្ដីវិញ[ច] ។
៥អស់ទាំងគំនិតរបស់មនុស្សសុចរិត នោះសុទ្ធតែទៀង
ត្រង់ តែគំនិតរបស់មនុស្សអាក្រក់ នោះជាសេចក្ដីឆបោក
វិញ ។
៦ពាក្យសំដីរបស់មនុស្សអាក្រក់ សុទ្ធតែនិយាយពីការ
លបចាំកំចាយឈាម តែមាត់របស់មនុស្សទៀងត្រង់នឹង
ជួយឱ្យគេរួចវិញ[ឆ] ។
៧មនុស្សអាក្រក់ត្រូវដួល ហើយមិននៅទៀតទេ[ជ] តែផ្ទះ
របស់មនុស្សសុចរិតបានស្ថិតស្ថេរនៅវិញ[ឈ] ។
៨មនុស្សនឹងបានគេសរសើរតាមប្រាជ្ញារបស់ខ្លួន តែ
អ្នកណាដែលមានចិត្តវៀច[ញ]នោះគេនឹងស្អប់វិញ ។
៩អ្នកណាដែលគេរាប់អានតិច តែមានបាវបំរើ នោះ

**១១:២៧** ង ទដ ៧:១៥-១៦
**១១:២៨** ច យប ៣១:២៤-២៨ ទដ ៤៩:៦ ៥២:៧ ៦២:១០ យរ ៩:២៣ ៤៨:៧ ឆ ទដ ៥២:៨ ៩២:១២-១៤
**១១:២៩** ជ សភ ១៤:១៩
**១១:៣០** ឈ លប ២:៩ សភ ១០:១១
**១១:៣១** ញ យរ ២៥:២៩ ៤៩:១២ ១ពត ៤:១៨
**១២:១** ក សភ ៥:១១-១៤ ៩:៧-៩ ១៣:១,១៨ ១៥:៥,១០,១២,៣២
**១២:២** ខ យប ៣៣:២៦ ទដ ៨៤:១១ គ ២សយ ១៥:៣ សភ ១១:២០
**១២:៣** ឃ សភ ១០:២៥
**១២:៤** ង នរ ៣:១១ សភ ៣១:១០-១១ ច សភ ១៨:២២ **១២:៦** ឆ សភ ១១:៩ ១៤:៣ **១២:៧** ជ ទដ ៣៧:៣៦ ឈ សភ ១០:២៥ ១៤:១១ ១៥:២៥ **១២:៨** ញ អស ១៩:១៤ ២៩:២៤

**១១:២៦** *បង្ខាំងទុកអង្ករ* គឺជាពិសេសនៅពេលមានភាពក្រខ្សត់ពួកគេក៏តម្លើងថ្លៃ ។ ពាក្យថា *មានពរស្ថិតនៅលើក្បាល* សូមមើល ១០:៦ ។

**១១:២៧** *អ្នកណាដែលព្យាយាមស្វែងរកសេចក្ដីល្អ* ដូចជាបុរសក្នុង ខ.២៥ (ធៀបនឹង មថ ៧:១២) ។ *ស្វែងរកតាមអាក្រក់ ការអាក្រក់នឹងកើតដល់អ្នកនោះឯង* គឺការអាក្រក់របស់គេនឹងឡងមកវិញ (សូមមើល ខ.៨ ១:១៨ និងការពន្យល់) ។

**១១:២៩** *អ្នកណាដែលនាំកើតវឹកវរក្នុងផ្ទះខ្លួន នោះនឹងគ្រងបានខ្យល់ជាមរដក* វាគឺជាមរដករបស់ពួកសាសន៍ លេវីនិងពួកស៊ីម្មាន ដែលត្រូវទទួលរងឥទ្ធិពល ពីព្រោះគេបានប្រឆាំងនិងស្រុកស៊ីគែម (លប ៣៤:២៥-៣០ ៤៩:៥-៧) សូមមើល ១៥:២៧ និងការពន្យល់ ។ *ធ្វើជាបាវបំរើដល់មនុស្សប្រាជ្ញ* គឺដូចជាមនុស្សអាក្រក់ត្រូវបម្រើដល់មនុស្សល្អ (មើល ១៤:១៩ ធៀបនឹង ១៧:២) ។

**១១:៣០** *ផលរបស់មនុស្សសុចរិត* អ្វីៗដែលមនុស្សប្រាជ្ញបង្កើត (៨:១៨-១៩) ។ *ដើមឈើនៃជីវិត* សូមមើលការពន្យល់ ៣:១៨ ។ *ចាប់បានព្រលឹង* (សូមមើល ដយ ១២:៣ ១កថ ៩:១៩-២២ យក ៥:២០) ។

**១១:៣១** *ពួកមនុស្សសុចរិតនិងទទួលបានរង្វាន់* គឺមានដូចជាស្ដេចដាវីឌនិងលោកម៉ូសេគឺបានទទួលទណ្ឌកម្មនៃអំពើបាប (មើល ជន ២០:១១-១២ ២សយ ១២:១០ និងការពន្យល់) ។ *ចុះឯមនុស្សអាក្រក់ និងមនុស្សមានបាប* មើល ១:១៨,៣១ និងការពន្យល់ ទដ ១១:៦ ៧៣:១៨-១៩ ។

**១២:១** *ចូលចិត្តចំពោះសេចក្ដីប្រៀនប្រដៅនោះក៏ស្រឡាញ់ដំរិះ* សូមមើល ១:៧ ១០:១៧ សូមមើល ៦:២៣ និងការពន្យល់ ។ *ស្អប់ដល់សេចក្ដីបន្ទោសនោះជាមនុស្សកំរោលវិញ* សូមមើល ១:២២ ៥:១២ និងការពន្យល់ ។

**១២:២** *ប្រកបដោយព្រះគុណ* មើល ៣:៤ ៨:៣៥ ។ *កាត់ទោសដល់មនុស្សណាដែលគិតគួបង្កើត* ធៀបនឹង ១៤:១៧ យប ៥:១២-១៣ ១កថ ៣:១៩ ។

**១២:៣** *គ្មានមនុស្សណាបានតាំងមាំមួនឡើយ* សូមមើល ១១:៥ ។ *មនុស្សសុចរិតមិនត្រូវរលើងឡើយ* មើល ២:២១ ១០:២៥,៣០ និងការពន្យល់ ។

**១២:៤** *ស្ត្រីមានចិត្តបរិសុទ្ធ* គឺជាលក្ខណៈស្ត្រីដូចជានាងរស់ (នរ ៣:១១) ។ គឺជាប្រភេទស្ត្រីដែលបានពណ៌នាយ៉ាងច្រើនក្នុង ៣១:១០-៣១ ។ *ជាមកុដដល់ប្ដី* គឺនាងបាននាំមកនូវសិរីរុងរឿង និងសេចក្ដីអំណរ (សូមមើល ៤:៩ និងការពន្យល់ ។ *សេចក្ដីពុករលួយ* សូមមើល ហប ៣:១៦ និងការពន្យល់ ។ *ក្នុងឆ្អឹងរបស់ប្ដី* សូមមើលការពន្យល់ ៣:៨ ។

**១២:៥** *គំនិតរបស់មនុស្សអាក្រក់ នោះជាសេចក្ដីឆរបោកវិញ* សូមមើល ១:១០-១៩ និងការពន្យល់ ទដ ១:១ ។

**១២:៦** *ការលបចាំកំចាយឈាម* មើលការពន្យល់ ១:១១ និងមើល ១:១៦ ។ *មនុស្សទៀងត្រង់នឹងជួយឱ្យគេរួចវិញ* សូមមើល ១១:៣-៤,៦,៩ ។

**១២:៧** សូមមើល ១០:២៥ និងការពន្យល់ ។

**១២:៨** *គេសរសើរតាមប្រាជ្ញារបស់ខ្លួន* សូមមើល ៣:៤ និងការពន្យល់ ។ *មានចិត្តវៀចនោះគេនិងស្អប់វិញ* សូមមើល ចទ ៣២:៥ ។

វិសេសជាជាងមនុស្សណាដែលដំកើងខ្លួន ប៉ុន្តែខ្វះខាត
អាហារវិញ ។
១០ មនុស្សសុចរិតរមែងប្រណី ដល់ជីវិតនៃសត្វរបស់
ខ្លួន[ដ] តែចិត្តរបស់មនុស្សអាក្រក់ នោះសាហាវណាស់ ។
១១ អ្នកណាដែលធ្វើស្រែខ្លួន នោះនឹងបានបាយជា
បរិបូរ តែអ្នកណាដែលតាមសេចក្ដីឥតប្រយោជន៍ នោះ
គ្មានយោបល់វិញ[ឋ] ។
១២ ឯមនុស្សអាក្រក់ គេចង់បានរបឹបរបស់មនុស្ស ដែល
ប្រព្រឹត្តអំពើអាក្រក់ តែឫសរបស់មនុស្សសុចរិត នោះ
បង្កើតផលផ្លែវិញ ។
១៣ មានអន្ទាក់អាក្រក់ នៅក្នុងអំពើរំលងរបស់បបូរ
មាត់[ឌ] តែមនុស្សសុចរិតនឹងចេញរួចពីសេចក្ដីលំបាក[ឍ] ។
១៤ មនុស្សនឹងបានស្កប់ចិត្តនឹងសេចក្ដីល្អ ដោយសារ
ផលដែលកើតពីមាត់ខ្លួន[ណ] ហើយកិច្ចការដែលដៃមនុស្ស
ធ្វើ នោះនឹងបានសងដល់អ្នកនោះវិញ[ត] ។
១៥ មនុស្សល្ងីល្ងើ រមែងឃើញផ្លូវរបស់ខ្លួនជាត្រឹមត្រូវ
ហើយ[ថ] តែអ្នកដែលមានប្រាជ្ញា នោះតែងស្ដាប់សេចក្ដី
ដំបូន្មានវិញ[ទ] ។
១៦ សេចក្ដីក្នាន់ក្នាញ់ក្នុងចិត្តមនុស្សល្ងីល្ងើ[ធ] នោះបាន
សំដែងមកឱ្យឃើញភ្លាម[ន] តែមនុស្សឆ្លៀវឆ្លាតគេតែងគ្រប
បាំងសេចក្ដីខ្មាសវិញ[ប] ។
១៧ អ្នកណាដែលពោលពាក្យពិត នោះរមែងសំដែង
ចេញនូវសេចក្ដីសុចរិត តែសាក្សីក្លែងក្លាយ នោះសំដែង
សេចក្ដីកំភូតវិញ[ផ] ។
១៨ មានគេដែលពោលពាក្យឥតបើគិត ដូចជាចាក់ដោយ
ដាវ[ព] តែសំដីរបស់មនុស្សប្រាជ្ញជាថ្នាំផ្សះវិញ[ភ] ។
១៩ បបូរមាត់ដែលបញ្ចេញសេចក្ដីពិត នោះនឹងបាន
តាំងជាប់នៅជានិច្ច តែអណ្ដាតភូតភរ នោះនៅតែ១ភ្លែត
ទេ ។
២០ ការឆបោករមែងនៅក្នុងចិត្តនៃមនុស្សដែលគិត
គួរបង្កើតការអាក្រក់ តែមានសេចក្ដីអំណរសំរាប់មនុស្ស
ដែលប្រឹក្សាឱ្យមានសេចក្ដីសុខ[ម] ។
២១ មនុស្សសុចរិតនឹងមិនត្រូវកើតមានសេចក្ដីភិតភ័យ
អន្តរាយឡើយ[យ] តែមនុស្សដែលប្រព្រឹត្តអាក្រក់នឹងបាន
ឆ្អែត ដោយការអាក្រក់ ។
២២ បបូរមាត់ដែលពោលពាក្យភូតភរ[រ] ជាទីស្អប់ខ្ពើម
ដល់ព្រះយេហូវ៉ា តែពួកអ្នកដែលប្រព្រឹត្តដោយពិតត្រង់
នោះជាទីគាប់[ល]ដល់ព្រះហឫទ័យទ្រង់វិញ[វ] ។

**១២:១០** ដ ជន ២២:២៩ **១២:១១** ឋ សភ ២៨:១៩ **១២:១៣** ឌ ទដ ៥៩:១២ សភ ១០:៦ ១៨:៧ ឍ សភ ២១:២៣ **១២:១៤** ណ សភ ១៣:២ ១៥:២៣ ១៨:២០ ត សភ ១៤:១៤ **១២:១៥** ថ សភ ១៤:១២ ១៦:២,២៥ ទ សភ ៩:៧-៩ ១៩:២០ **១២:១៦** ធ ១សយ ២៥:២៥ ន យប ៥:២ ប សភ ២៩:១១ **១២:១៧** ផ ទដ ១២:២ សភ ១៤:៥,២៥ **១២:១៨** ព ទដ ៥៥:២១ សភ ២៥:១៨ ភ សភ ១៥:៤ **១២:២០** ម រម ១៤:១៩ **១២:២១** យ យប ៤:៧ **១២:២២** រ ១ពវ ១៣:១៨ សភ ៦:១៧ ល ទដ ១៨:១៩ វ សភ ១១:២០

**១២:៩** *តែមានបាវបំរើ* គឺសូម្បីតែមនុស្សធម្មតាដែលមិនជ្រុលនិយម ក៏មានបាវបម្រើដែរ (សូមមើល ពច ៦:១៥,២៧) ។ *នោះវិសេសជាជាងមនុស្សណាដែលដំកើងខ្លួន* ធៀបនឹង ១៣:៧ ។

**១២:១០** *ប្រណីដល់ជីវិតនៃសត្វរបស់ខ្លួន* សូមមើល ២៧:២៣ ចទ ២៥:៤ មថ ១២:១១ ។ *តែចិត្តរបស់មនុស្សអាក្រក់នោះសាហាវណាស់* គឺមានលក្ខណៈដូចគ្នាទាំងមនុស្សទាំងសត្វ ។

**១២:១១** ក្នុងខនេះក៏មានបង្ហាញឡើងវិញក្នុង ២៨:១៩ ។ ពាក្យថា *តាមសេចក្ដីឥតប្រយោជន៍* គឺជាផែនការអាក្រក់ ដើម្បីប្រាក់ចំណូលដោយវិធីសាស្ត្រងាយបំផុត ។

**១២:១២** *គេចង់បានរបឹបរបស់មនុស្ស* សូមមើល ១:១៣ និងការពន្យល់ ២១:១០ ។ *ឫសរបស់មនុស្សសុចរិតនោះបង្កើតផលផ្លែវិញ* គឺពួកគេទទួលបាននូវផលផ្លែជីវិតដែលមានលក្ខណៈឫសរឹងមាំ (មើល ខ.៣,៧ ១១:៣០ ទដ ១:៣ មើល ១០:២៥ និងការពន្យល់) ។

**១២:១៣** *មានអន្ទាក់អាក្រក់នៅក្នុងអំពើរំលងរបស់បបូរមាត់* សូមមើល ១:១៨ និងការពន្យល់ ២៩:៦ ។ *តែមនុស្សសុចរិតនិងចេញរួចពីសេចក្ដីលំបាក* សូមមើល ១១:៨-៩ និងការពន្យល់ ២១:២៣ ២ពត ២:៩ ។

**១២:១៤** គឺជាអ្នកដែលនិយាយដោយប្រាជ្ញា និងច្រូតបានពីផលរបស់ពួកគេក៏ដូចជាកសិករដែលរីករាយក្នុងការច្រូតកាត់ពីផលស្រូវរបស់គេដែរ (សូមមើល ១:៣១ និងការពន្យល់ យប ៣៤:១១) ។

**១២:១៥** *រមែងឃើញផ្លូវរបស់ខ្លួនជាត្រឹមត្រូវ* តែនៅទីបញ្ចប់គឺជាសេចក្ដីស្លាប់ (សូមមើល ១:២៥,៣០ ១៤:១២ ១៦:២៥) ។

**១២:១៦** *តែងគ្របបាំងសេចក្ដីខ្មាសវិញ* គឺសម្ដែងពីការគ្រប់គ្រងជីវិតបានល្អ (សូមមើល ២៩:១១ ២សយ ១៦:១១-១២) ។

**១២:១៧** *សាក្សីក្លែងក្លាយ នោះសំដែងសេចក្ដីកំភូតវិញ* សូមមើលការពន្យល់ ៦:១៩ ។

**១២:១៨** *ពាក្យឥតបើគិត* ធៀបនឹង ទដ ១០៦:៣៣ ។ *ដូចជាចាក់ដោយដាវ* សូមមើលការពន្យល់ ទដ ៥:៩ ។ *តែសំដីរបស់មនុស្សប្រាជ្ញជាថ្នាំផ្សះវិញ* គឺជាពាក្យដែលលើកទឹកចិត្តវិញ (សូមមើល ៤:២០-២២ ១៥:៤) ។

**១២:១៩** *នោះនៅតែ១ភ្លែតទេ* គឺជាពាក្យសំដីភូតភរ ដែលមិនបានទទួលយកឯអ្នកនិយាយភរបានដាក់ទណ្ឌកម្ម (សូមមើល ១៩:៩ ទដ ៥២:៤-៥) ។

**១២:២០** *ការឆរបោករមែងនៅក្នុងចិត្តនៃមនុស្ស* សូមមើលការពន្យល់ ៦:១៤ និងការពន្យល់ ក៏សូមមើល ១:៣១ ផងដែរ ២៤:២ សប ៦:៥ ។ ពាក្យថា *សំរាប់មនុស្សប្រឹក្សាឱ្យមានសេចក្ដីសុខ* "ព្រះពរជាអ្នកដែលបង្កើតឱ្យមានសន្តិភាព" (មថ ៥:៩) ។

**១២:២១** *មិនត្រូវកើតមានសេចក្ដីភិតភ័យ* សូមមើល ១:៣៣ និងការពន្យល់ ២:៨ ទដ ៩១:៩-១៣ ១២:១-៧ ។ *បានឆ្អែតដោយការអាក្រក់* សូមមើល ១:៣១ និងការពន្យល់ ១១:៥,៨ ២២:៨ យប ៤:៨ ។

**១២:២២** សូមប្រៀបធៀប ឃ្លាប្រយោគក្នុង ១១:១,២០ ។ ពាក្យថា *ជាទីស្អប់ខ្ពើម* សូមមើលការពន្យល់ ៣:៣២ ។ *អ្នកដែលប្រព្រឹត្តដោយពិតត្រង់* សូមមើល ១៦:១៣ ។

២៣មនុស្សដែលមានគំនិត គេគ្របបាំងចំណេះរបស់
ខ្លួន[ស] តែចិត្តរបស់មនុស្សល្ងីល្ងើ តែងតែប្រកាសពីសេចក្ដី
ល្ងង់វិញ[ហ]។
២៤ដៃរបស់មនុស្សព្យាយាម នឹងបានឡើងគ្រប់គ្រង
តែមនុស្សខ្ជិលច្រអូសនឹងត្រូវទទួលការបំរើវិញ[ឡ]។
២៥ការទុក្ខដែលគ្របសង្កត់ចិត្ត នោះធ្វើឱ្យរួញថយចុះ[អ]
តែពាក្យល្អ១ម៉ាត់នឹងធ្វើឱ្យរីករាយឡើង ។
២៦មនុស្សសុចរិតជាអ្នកនាំផ្លូវដល់អ្នកជិតខាង តែផ្លូវ
របស់មនុស្សអាក្រក់រមែងនាំឱ្យវង្វេងវិញ[ក]។
២៧មនុស្សខ្ជិលច្រអូស គេមិនអាំងសាច់របស់សត្វ ដែល
ខ្លួនចាប់បានទេ តែអ្វីៗដែលមនុស្សឧស្សាហ៍មាននោះក៏រាប់
ជាវិសេសវិញ ។
២៨ជីវិតស្ថិតនៅក្នុងផ្លូវនៃសេចក្ដីសុចរិត[ខ] ហើយក្នុងផ្លូវ
ច្រកនោះគ្មានសេចក្ដីស្លាប់ឡើយ ។

**១៣** ១កូនដែលមានប្រាជ្ញា រមែងស្ដាប់តាមដំបូន្មាន
របស់ឪពុក តែមនុស្សចំអកមើលងាយ មិនព្រមស្ដាប់តាម
ពាក្យបន្ទោសទេ[ក]។
២មនុស្សនឹងបានសេចក្ដីល្អដោយសារផលដែលកើត
ពីមាត់មក[ខ] តែព្រលឹងរបស់មនុស្សក្បត់នឹងបានតែសេចក្ដី
ច្រឡោតវិញ ។
៣អ្នកណាដែលរវាំងមាត់[គ] នោះរមែងរក្សាជីវិតខ្លួន[ឃ]
តែអ្នកណាដែលហាមាត់ធំ នោះនឹងត្រូវវិនាសទៅ[ង]។
៤ព្រលឹងនៃមនុស្សខ្ជិលច្រអូសប្រាថ្នាចង់បាន តែមិន
បានអ្វីសោះ[ច] ឯព្រលឹងនៃមនុស្សព្យាយាម នោះនឹងបាន
ជាបរិបូរវិញ ។
៥មនុស្សសុចរិតរមែងស្អប់ពាក្យភូតភរ[ឆ] តែមនុស្ស
អាក្រក់គួរខ្ពើម ហើយមានសេចក្ដីខ្មាសផង ។
៦សេចក្ដីសុចរិតតែងតែការពារអ្នកណាដែលប្រព្រឹត្ត
តាមផ្លូវទៀងត្រង់ តែអំពើអាក្រក់រមែងផ្ដួលមនុស្សមាន
បាបវិញ[ជ]។
៧មានគេដែលខំប្រឹងឱ្យបានជាអ្នកស្ដុកស្ដម្ភ តែគេគ្មាន
អ្វីសោះ[ឈ] ក៏មានមនុស្សដែលទៅជាក្រ តែមានទ្រព្យសម្បត្តិ
ច្រើន[ញ]។
៨ឯទ្រព្យសម្បត្តិ នឹងទុកសំរាប់លោះជីវិតមនុស្សបាន

**១២:២៣** ស សភ ១០:១៤ ហ ទដ ៣៨:៥ ៥៩:៧ សភ ១៨:២
**១២:២៤** ឡ សភ ១០:៤
**១២:២៥** អ សភ ១៥:១៣
**១២:២៦** ក ទដ ៩៥:១០
**១២:២៨** ខ ចទ ៣០:១៥ សភ ១០:២
**១៣:១** ក សភ ១២:១ ១៥:៥
**១៣:២** ខ សភ ១២:១៤
**១៣:៣** គ ទដ ១២:២ ៣៤:១៣ ឃ សភ ១០:៦ ២១:២៣ ង យប ១:២២ សភ ១៨:៧,២០–២១
**១៣:៤** ច សភ ២១:២៤–២៦
**១៣:៥** ឆ ទដ ១១៩:១២៨ **១៣:៦** ជ សភ ១១:៣,៥ យរ ៤៤:៥ **១៣:៧** ឈ វវ ៣:១៧ ញ ២កថ ៦:១០

**១២:២៣** *គ្របបាំងចំណេះរបស់ខ្លួន* គឺជាការរក្សាចំណេះដឹង (សូមមើល ១០:១៤ និងការពន្យល់) ។

**១២:២៤** *ដៃរបស់មនុស្សព្យាយាមនិងបានគ្រប់គ្រង . . . មនុស្សខ្ជិលច្រអូស* គឺមានលក្ខណៈផ្ទុយពីអត្ថបទក្នុង ១០:៤ (សូមមើលការពន្យល់) ។ *បានឡើងគ្រប់គ្រង* ប្រៀបធៀប ១៧:២ ។ *ទទួលការបំរើវិញ* សូមមើល ពច ១:២៨ សូមមើលការពន្យល់ ២សយ ២០:២៤ ។

**១២:២៥** *គ្របសង្កត់ចិត្ត* សូមមើល ទដ ៩៤:១៩ ។ *ពាក្យល្អ១ម៉ាត់* សូមមើល ១៥:២៣ ។

**១២:២៦** *មនុស្សសុចរិតជាអ្នកនាំផ្លូវដល់អ្នកជិតខាង* គឺជាការជ្រើសរើសមិត្ត ដោយប្រុងប្រយ័ត្ន (សូមមើល ១៣:២០ ១៨:២៤ ២២:២៤) នាំឱ្យវង្វេងវិញ សូមមើល ៥:២៣ ១៤:២២ ។

**១២:២៧** *គេមិនអាំងសាច់របស់សត្វដែលខ្លួនចាប់បានទេ* គឺគេខ្ជិលច្រអូស សូម្បីតែយកអាហារពីចានមកដាក់ក្នុងមាត់ ក៏ខ្ជិលដែរ (១៩:២៤) ។

**១២:២៨** សូមមើល ១០:២ និងការពន្យល់ ។ *ជីវិត* ធៀបនឹង ៣:២ និងការពន្យល់ ១១:៤ ។ *គ្មានសេចក្ដីស្លាប់* "គឺពុំមានសេចក្ដីស្លាប់" គឺជាផ្លូវ ឬមាគ៌ារបស់ភាពសុចរិត ដែលពុំបណ្ដាលឱ្យស្លាប់ទេ សូមធៀបនឹងអត្ថសញ្ញាណរបស់ប្រាជ្ញាដែលមាន "ដើមឈើជីវិត" (៣:១៨ និងការពន្យល់ ៣:១៨ ធៀបនឹង ១៤:៣២) ។

**១៣:១** *រមែងស្ដាប់តាមដំបូន្មានរបស់ឪពុក* សូមមើល ១:៨ និងការពន្យល់ ៤:១ ។ *មនុស្សចំអកមើលងាយមិនព្រមស្ដាប់តាមពាក្យបន្ទោសទេ* សូមមើល ១:២២ ៩:៧–៨ និងការពន្យល់ ។

**១៣:២** សូមមើល ១២:១៤ និងការពន្យល់ ។ ពាក្យថា *សេចក្ដីច្រឡោតវិញ* សូមមើល ៤:១៧ និងការពន្យល់ ។

**១៣:៣** *អ្នកណាដែលរវាំងមាត់ នោះរមែងរក្សាជីវិតខ្លួន* "គឺអណ្ដាតមានអំណាចឱ្យមានជីវិត ហើយអណ្ដាតក៏មានអំណាចឱ្យមានសេចក្ដីស្លាប់ដែរ" (១៨:២១) ។ ក៏ជាសមត្ថភាពគ្រប់គ្រងដែលជាផ្នែកមួយបង្ហាញពីប្រាជ្ញា ។ សូមមើល ១០:១៩ និងការពន្យល់ ។ ឯអ្នកណាដែលនិយាយដោយពុំបានគិតឱ្យច្បាស់លាស់ នោះនិងត្រូវវិនាសបង់ ។ សូមមើល ១០:១៤ ១២:១៨ និងការពន្យល់ ១៨:៧ ។

**១៣:៤** *មនុស្សខ្ជិលច្រអូស* សូមមើល ៦:៦ និងការពន្យល់ ។ *ប្រាថ្នាចង់បានតែមិនបានអ្វីសោះ* (សូមមើល ២១:២៥–២៦) ។ *ឯព្រលឹងនៃមនុស្សព្យាយាម នោះនឹងបានជាបរិបូរវិញ* គឺមនុស្សសុចរិតទៀងត្រង់ក៏បានទទួលផលកម្រៃ (សូមមើល ៦:៦ ក៏សូមមើលការពន្យល់ ១០:៤,២៤) ។

**១៣:៥** *គេគួរខ្ពើមហើយមានសេចក្ដីខ្មាសផង* ឃ្លានេះមានលក្ខណៈដូចកូនដែលខ្ជិល ដែលទទួលផលនៃសេចក្ដីស្លាប់វិញ (១០:៥ ប្រៀបធៀប និង ១៩:២៦) ។

**១៣:៦** លក្ខណៈផ្ទុយនេះបានបើកឱ្យឃើញនៅក្នុងគម្ពីរ ២:២១–២២ ១០:៩ ១១:៣,៥ (មើលការពន្យល់ក្នុងនោះដែរ) ប្រៀបធៀបនឹង ទដ ២៥:២១ ។

**១៣:៧** ការបង្ហាញទាំងពីរវគ្គ គឺពីកិច្ចការចំកួតរបស់មនុស្សល្ងីល្ងើ ដែលនាំពួកគេកាន់តែល្ងង់ថែមទៀត ។ (សូមមើល ១៤:៨ និងការពន្យល់ ក៏សូមមើល ១១:២៤ និងការពន្យល់ ១២:៩) ។

**១៣:៨** *ទុកសំរាប់លោះជីវិតរបស់មនុស្ស* គឺមានអត្ថន័យថាគេមានប្រាក់សម្រាប់បង់លោះដល់ទង្វើអាក្រក់ (មើល ១០:១៥ និងការពន្យល់ យរ ៤១:៨) ។ ពាក្យថា *មនុស្សក្រគេមិនដែលឮពាក្យកំហែងទេ* គឺវាមានភាព

តែមនុស្សក្រគេមិនដែលឮពាក្យកំហែងទេ[ដ] ។
៩ពន្លឺនៃសុចរិត នោះជាទីសប្បាយហើយ តែចង្កៀង
របស់មនុស្សអាក្រក់នឹងរលត់ទៅ[ឋ] ។
១០ផលនៃសេចក្តីឆ្មើងឆ្មៃ នោះមានតែការទាស់ទែង
គ្នាប៉ុណ្ណោះ តែប្រាជ្ញាស្ថិតនៅនឹងពួកអ្នកដែលស្តាប់តាម
សេចក្តីទូន្មាន[ឌ] ។
១១ទ្រព្យសម្បត្តិដែលបានដោយការមិនគួរគប្បី នោះ
នឹងខ្ជះខ្ជាយទៅ[ឍ] តែអ្នកណាដែលសន្សំដោយប្រឹងប្រែង
នោះនឹងបានចំរើនកើនឡើង ។
១២សេចក្តីសង្ឃឹមដែលចេះតែបន្ថយទៅ នោះនាំឱ្យ
រអាចិត្ត តែកាលណាបានដូចប្រាថ្នា នោះប្រៀបដូចជា
ដើមឈើនៃជីវិតវិញ[ណ] ។
១៣អ្នកណាដែលមើលងាយព្រះបន្ទូល នោះនឹងនាំឱ្យ
ខ្លួនវិនាស[ត] តែអ្នកណាដែលកោតខ្លាច[ថ]ដល់ក្រិត្យវិន័យ
នោះ នឹងបានរង្វាន់វិញ[ទ] ។
១៤ឱវាទរបស់អ្នកប្រាជ្ញជារន្ធទឹកនៃជីវិត[ធ] សំរាប់ឱ្យបាន
រួចពីអន្ទាក់នៃសេចក្តីស្លាប់[ន] ។
១៥គំនិតផ្ចះមុត នោះនាំឱ្យគេរាប់អាន តែផ្លូវរបស់
មនុស្សដែលរំលងច្បាប់ នោះពិបាកវិញ ។
១៦គ្រប់ទាំងមនុស្សដែលមានគំនិតឆ្លៀវឆ្លាត រមែង
ប្រព្រឹត្តដោយដំរិះ តែមនុស្សល្ងីល្ងើគេបង្អួត[ប]សេចក្តីចំកួត
របស់ខ្លួនវិញ[ផ] ។
១៧មនុស្សអាក្រក់ដែលនាំដំណឹង នោះតែងធ្លាក់ទៅ
ក្នុងការអាក្រក់[ព] តែទូតស្មោះត្រង់ នោះចំរើនសេចក្តីសុខ
វិញ[ភ] ។
១៨អ្នកណាដែលមិនព្រមស្តាប់ពាក្យប្រៀនប្រដៅ នឹង
ត្រូវក្រលំបាក ហើយអៀនខ្មាសទៅ[ម] តែអ្នកណាដែលព្រម
ស្តាប់តាមសេចក្តីបន្ទោសវិញ នោះនឹងបានកិត្តិសព្ទ[យ] ។
១៩ការដែលបានសំរេចតាមបំណងចិត្ត នោះមានរស
ផ្អែមដល់ព្រលឹងហើយ[រ] តែដែលលះចេញពីអំពើអាក្រក់
នោះជាសេចក្តីស្អប់ខ្ពើមដល់មនុស្សល្ងីល្ងើវិញ ។
២០អ្នកណាដែលដើរជាមួយនឹងមនុស្សប្រាជ្ញ នោះនឹង
មានប្រាជ្ញាដែរ តែអ្នកណាដែលភប់ប្រសព្វនឹងមនុស្ស
ល្ងីល្ងើ នោះនឹងត្រូវខូចបង់វិញ[ល] ។
២១សេចក្តីអាក្រក់ដេញជាប់តាមមនុស្សបាប[វ] តែមនុស្ស
សុចរិតនឹងបានរង្វាន់ជាសេចក្តីល្អ[ស]វិញ[ហ] ។
២២មនុស្សល្អ គេតែងតែទុកមរដកដល់កូនចៅរបស់
ខ្លួន តែទ្រព្យសម្បត្តិរបស់មនុស្សមានបាប នោះបានប្រមូល

**១៣:៨** ដ សភ ១៥:១៦
**១៣:៩** ឋ យប ១៨:៥ សភ ៤:១៨–១៩
**១៣:១០** ឌ ពច ១៩:៣០ សភ ៩:៩
**១៣:១១** ឍ សភ ១០:២
**១៣:១២** ណ សភ ១០:១១
**១៣:១៣** ត ជន ១៥:៣១ ថ នក ៩:២០ ទ សភ ១៦:២០
**១៣:១៤** ធ សភ ១០:១១ ន សភ ១៤:២៧
**១៣:១៦** ប សស ១០:៣ ផ នអ ៥:១១ ទដ ៣៨:៥
**១៣:១៧** ព សភ ១០:២៦ ភ សភ ២៥:១៣
**១៣:១៨** ម សភ ១:៧ ១២:១ យ ទដ ១៤១:៥ សភ ២៥:១២ សស ៧:៥
**១៣:១៩** រ សភ ១០:១១ **១៣:២០** ល ២រប ១០:៨ **១៣:២១** វ ២សយ ៣:៣៩ យរ ៤០:៣ ៥០:៧ អគ ១៤:១៣ ១៨:៤ ស ទដ ២៥:១៣ ហ ទដ ៣២:១០

កំសត់ជាម្ចាស់ជីវិតរបស់ពួកគេ ។

**១៣:៩** *ពន្លឺ . . . ចង្កៀង* ដែលជានិមិត្តរូបប្រាប់ពីភាពមានជីវិត (ធៀបនឹង យប ៣:២០) គឺមានការបញ្ចោញរស្មីយ៉ាងភ្លឺ គឺជាពន្លឺនៃក្តីអំណរនិងភាពសុខសាន្ត (សូមមើលការពន្យល់ ៤:១៨) ។ *ចង្កៀងរបស់មនុស្សអាក្រក់នឹងរលត់ទៅ* ជីវិតរបស់ពួកគេត្រូវបញ្ចប់ (សូមមើល ២០:២០ ២៤:២០ យប ១៨:៥ ២១:១៧) ។

**១៣:១០** *ផល* សូមមើល ១១:២ និងការពន្យល់ ។

**១៣:១១** *ទ្រព្យសម្បត្តិដែលបានដោយការមិនគួរ . . . និងខ្ជះខ្ជាយទៅ* ដូចជាទ្រព្យសម្បត្តិបានមកដោយការគម្រាមយក (ទដ ៦២:១០) ឬក៏ដោយការបោកបញ្ឆោត (ទដ ២១:៦) សូមមើលការពន្យល់ ១០:២ ក៏សូមមើល យរ ១៧:១១ ។ ពាក្យថា *បានចំរើនកើនឡើង* សូមមើលការពន្យល់ ១០:៤ ។

**១៣:១២** *សេចក្តីសង្ឃឹមដែលចេះតែបន្ថយទៅ នោះនាំឱ្យរអាចិត្ត* ប្រៀបធៀបនឹង លប ៣០:១ ។ *តែកាលណាបានដូចប្រាថ្នានោះប្រៀបដូចជាដើមឈើនៃជីវិតវិញ* គឺជាការចម្រើនរស់ឡើងវិញ និងមានកម្លាំង (សូមមើលការពន្យល់ ៣:១៨ ក៏មើល ១០:២៨ ១៣:១៩) ។

**១៣:១៣** *អ្នកណាដែលមើលងាយព្រះបន្ទូល នោះនិងនាំឱ្យខ្លួនត្រូវវិនាស* សូមមើល ១:២៩–៣១ ៥:១២ និងការពន្យល់ ។ *តែអ្នកណាដែលកោតខ្លាចដល់ក្រិត្យវិន័យនោះនឹងបានរង្វាន់វិញ* គឺជាកំរៃនៃប្រាជ្ញាក៏បានផ្តល់ឱ្យទទួលរង្វាន់ល្អយ៉ាងពិត (សូមមើល ៣:២ និងការពន្យល់ ៣:១៦–១៨ ១៦:២០ ប្រៀបធៀប ១៣:២១) ។

**១៣:១៤** *ជារន្ធទឹកនៃជីវិត* សូមមើលការពន្យល់ ១០:១១ ។ *បានរួចពីអន្ទាក់នៃសេចក្តីស្លាប់* សូមមើលការពន្យល់ ១:១៧ ៥:២២ សូមមើល ៧:២៣ ២២:៥ ផងដែរ ។

**១៣:១៥** សូមមើល ៣:៤ ៨:៣៥ គឺជាគំនិតផ្ចះមុត បានទទួលការគាំទ្រពីមនុស្សដទៃវិញ ។ ពាក្យថា *នោះពិបាក* សូមមើល ឧ.១៣ និងការពន្យល់ ។

**១៣:១៦** សូមមើល ១២:២៣ និងការពន្យល់ ។

**១៣:១៧** *តែធ្លាក់ទៅក្នុងការអាក្រក់* គឺអ្នកដែលតំណាងឱ្យភាពអាក្រក់ ដែលអាកំណាចបញ្ជូនមក ។ ពាក្យថា *ចំរើនសេចក្តីសុខ* គឺសេចក្តីស្មោះត្រង់ដែលនាំឱ្យមានផលកំរៃ (មើល ២៥:១៣ ធៀបនឹង ១២:១៨ ១៥:៤) ។

**១៣:១៨** *និងត្រូវក្រលំបាក ហើយអៀនខ្មាស* សូមមើល ៥:១០–១២ និងការពន្យល់ ។ *អ្នកណាដែលព្រមស្តាប់តាមសេចក្តីបន្ទោសវិញ នោះនិងបានកិត្តសព្ទ* សូមមើល ឧ.១ ៣:១៦–១៨ ៨:៣៥ ១០:១៧ ។

**១៣:១៩** *សំរេចតាមបំណងចិត្ត* សូមមើល ឧ.១២ ។ ពាក្យថា *អំពើអាក្រក់នោះជាសេចក្តីស្អប់ខ្ពើមដល់មនុស្សល្ងីល្ងើវិញ* ប្រៀបធៀបនឹងការស្អប់ចំពោះការប្រៀនប្រដៅ ៥:១២ ។

**១៣:២០** *អ្នកណាដែលដើរជាមួយនិងមនុស្សប្រាជ្ញ នោះនិងមានប្រាជ្ញាដែរ* គឺត្រូវជ្រើសរើសមិត្តរបស់អ្នកដោយប្រុងប្រយ័ត្ន (សូមមើល ២:២០ ១២:២៦) ។ *ភប់ប្រសព្វនិងមនុស្សល្ងីល្ងើ នោះនិងត្រូវខូចបង់វិញ* សូមមើល ១:១០,១៨ ២:១២ ១៦:២៩ ២២:២៤–២៥ ។

**១៣:២១** សូមមើល ឧ.១៣ និងការពន្យល់ ។

**១៣:២២** *ប្រមូលទុកសំរាប់មនុស្សសុចរិតវិញ* លោកយ៉ូបបានយល់ថា បញ្ហានេះតែងតែកើតឡើងដល់សម្បត្តិទ្រព្យរបស់ពួកមនុស្សអាក្រក់ (មើល យប

ទុកសំរាប់មនុស្សសុចរិតវិញ[ឡ] ។
២៣ការភ្ជួររាស់របស់មនុស្សក្រីក្រ នោះរមែងបង្កើត
អាហារជាច្រើន តែមានគេដែលត្រូវបំផ្លាញវិញ ដោយ
ខ្វះសេចក្ដីយុត្តិធម៌ ។
២៤អ្នកណាដែលមិនសូវប្រើរំពាត់[អ] នោះឈ្មោះថា ស្អប់
កូន តែអ្នកណាដែលស្រឡាញ់កូនវិញ នោះឧស្សាហ៍វាយ
ផ្ចាល[ក]វា[ខ] ។
២៥មនុស្សសុចរិតគេបរិភោគទាល់តែស្កប់ស្កល់ តែ
ពោះរបស់មនុស្សអាក្រក់ នឹងត្រូវអត់ឃ្លានវិញ[គ] ។

**១៤** ១គ្រប់ទាំងស្រីៗដែលមានប្រាជ្ញា រមែងសង់ផ្ទះរបស់
ខ្លួនឡើង[ក] តែស្ត្រីល្ងីល្ងើគេរំលំផ្ទះដោយដៃខ្លួនវិញ ។
២អ្នកណាដែលដើរដោយសេចក្ដីទៀងត្រង់របស់ខ្លួន
នោះរមែងកោតខ្លាចដល់ព្រះយេហូវ៉ា តែអ្នកណាដែល
ប្រព្រឹត្តតាមផ្លូវវៀច នោះឈ្មោះថាមើលងាយទ្រង់វិញ ។
៣នៅក្នុងមាត់របស់មនុស្សល្ងីល្ងើ នោះមានរំពាត់
សំរាប់បង្ក្រាបសេចក្ដីអំនួតរបស់វា[ខ] តែបបូរមាត់មនុស្ស
ប្រាជ្ញនឹងការពារខ្លួនគេវិញ[គ] ។
៤ផ្ទះណាគ្មានគោ នោះក្រោលរមែងស្អាតល្អ តែ
គឺដោយកំឡាំងគោ[ឃ]នោះឯង ដែលនឹងចំរើនកើនឡើង
បាន ។
៥សាក្សីស្មោះត្រង់នឹងមិនកុហកឡើយ តែសាក្សីក្លែង
ក្លាយតែងតែពោលពាក្យភូតភរវិញ[ង] ។
៦មនុស្សចំអក គេខំស្វែងរកប្រាជ្ញា តែមិនបានទេ ឯ
ចំណេះវិញ នោះងាយដល់អ្នកណាដែលមានយោបល់[ច] ។
៧ចូរចៀសចេញពីមនុស្សល្ងីល្ងើចុះ ដ្បិតនឹងឃើញមាន
ចំណេះនៅបបូរមាត់វាមិនបាន ។
៨ឯប្រាជ្ញារបស់មនុស្សវាងវៃ នោះគឺឱ្យបានយល់ផ្លូវ
របស់ខ្លួន[ឆ] តែសេចក្ដីចំកួតរបស់មនុស្សល្ងីល្ងើ នោះជា
សេចក្ដីឆបោកទទេ[ជ] ។
៩មនុស្សល្ងីល្ងើរមែងសើចឡកចំពោះអំពើបាប តែនៅ
ក្នុងពួកមនុស្សសុចរិត តែងមានសេចក្ដីរាប់អានគ្នា ។
១០ចិត្តមនុស្សរមែងស្គាល់សេចក្ដីជូរចត់របស់ខ្លួន ឯ
មនុស្សដទៃ នឹងទទួលចំណែកក្នុងសេចក្ដីអំណររបស់ចិត្ត
នោះមិនបាន ។
១១ផ្ទះរបស់មនុស្សអាក្រក់នឹងត្រូវរំលំ[ឈ] តែខ្ទមរបស់
មនុស្សទៀងត្រង់នឹងចំរើនកើនឡើងវិញ[ញ] ។
១២មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អ ដល់
មនុស្ស[ដ] តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្ដីស្លាប់វិញ[ឋ] ។
១៣នៅវេលាកំពុងតែសើចសប្បាយ[ឌ] គង់តែចិត្តមាន

**១៣:២២** ឡ នអ ៨:២ យប ២៧:១៧ នអ ២:២៦ **១៣:២៤** អ ២សយ ៧:១៤ ក សភ ៣:១២ ខ សភ ១៩:១៨ ២២:១៥ ២៣:១៣–១៤ ២៩:១៥,១៧ អភ ៦:៤ ហព ១២:៧ **១៣:២៥** គ សភ ១០:៣ **១៤:១** ក នរ ៣:១១ សភ ២៤:៣ **១៤:៣** ខ សភ ១០:១៤ សស ១០:១២ គ សភ ១០:១៣ ១២:៦ **១៤:៤** ឃ ទដ ១៤៤:១៤ **១៤:៥** ង ទដ ១២:២ សភ ១២:១៧ **១៤:៦** ច សភ ៩:៩ **១៤:៨** ឆ ខ.១៥ សភ ១៥:២៨ ២១:២៩ ជ ខ.២៤ **១៤:១១** ឈ យប ៨:២២ សភ ២១:១២ ញ ទដ ៧២:៧ សភ ៣:៣៣ ១២:៧ **១៤:១២** ដ សភ ១២:១៥ ឋ ភ ១៦:២៥ **១៤:១៣** ឌ សស ២:២ ៧:៣,៦

២៧:១៦–១៧ ប្រៀបធៀប សភ ២៨:៨ សស ២:១៨–២១) ។
**១៣:២៣** *មានគេដែលត្រូវបំផ្លាញវិញដោយខ្វះសេចក្ដីយុត្តិធម៌* គឺប្រហែលជាករណីអ្នកមាននិងការគាបសង្កត់យ៉ាងខ្លាំងដល់អ្នកអាក្រក់ ។ (សូមមើល អម ២:៦–៧ និងការពន្យល់ ប្រៀបធៀបនឹង ទដ ៣៥:១០) ។
**១៣:២៤** *អ្នកណាដែលមិនសូវប្រើរំពាត់ នោះឈ្មោះថាស្អប់កូន* គឺគ្រប់រាល់ឪពុកម្ដាយតម្រូវឱ្យប្រើរំពាត់ក្នុងការដាក់ទណ្ឌកម្ម ដើម្បីកុំឱ្យគេប្រព្រឹត្តខុស (២២:១៥) គឺដើម្បីកុំឱ្យពួកក្មេងដើរក្នុងផ្លូវមហន្តរាយ (១៩:១៨ ២៣:១៣–១៤) រំពាត់វាយប្រដៅ "នាំឱ្យមានប្រាជ្ញា" (២៩:១៥) ក៏នាំឱ្យសុខភាពនឹងសេចក្ដីអំណរនៅក្នុងគ្រួសារ (២៩:១៧) ការប្រដៅតម្រងជាឫសគល់នៃសេចក្ដីស្រឡាញ់ (សូមមើល ៣:១១–១២ និងការពន្យល់) ។ *រំពាត់* គឺអាចជាការផ្ដោតទៅលើពាក្យសំដី អំពីសេចក្ដីស្រឡាញ់ ។
**១៣:២៥** បង្ហាញពីការបង្រៀនយ៉ាងច្បាស់ដែលមានក្នុង ខ.១៣,១៨,២១ សូមមើល ១០:៣ និងការពន្យល់ ។
**១៤:១** *ស្រីៗដែលមានប្រាជ្ញារមែងសង់ផ្ទះរបស់ខ្លួនឡើង* គឺនាងជាប្រភពនៃកម្លាំងហើយក៏ជាគំរូក្នុងការយកចិត្តទុកដាក់ដល់ក្រុមគ្រួសារនាង (មើល ៣១:១០–៣១) ប្រៀបធៀបចំពោះផ្ទះដែលសង់ដោយប្រាជ្ញាក្នុង ៩:១ ។
**១៤:២** *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើលការពន្យល់ ១:៧ ។
**១៤:៣** *រំពាត់សំរាប់បង្ក្រាបសេចក្ដីអំនួត* មើល ១០:១៣ ១៩:២៩ ២៦:៣ ។
**១៤:៤** ក្នុងខនេះ គឺជាគំនិតសម្រាប់ឱ្យប្រជាជនថែរក្សាសត្វពាហនៈរបស់ខ្លួនឱ្យបានត្រឹមត្រូវ (គឺវាមានអត្ថន័យថា វាជាភោគផលរបស់គេ) គឺបើពួកគេចង់បានការប្រមូលផលយ៉ាងច្រើនបរិបូរនោះ (សូមមើល ២:១០ និងការពន្យល់) ។
**១៤:៥** សូមមើលការពន្យល់ ៦:១៩ ។
**១៤:៦** *មនុស្សចំអក* សូមមើល ១:២២ និងការពន្យល់ ។ *គេខំស្វែងរកប្រាជ្ញា តែមិនបានទេ* ព្រោះពួកគេពុំកោតខ្លាចដល់ព្រះយេហូវ៉ា ឬគេពុំព្រមទទួលការកែតម្រង់ ។
**១៤:៨** *សេចក្ដីចំកួតរបស់មនុស្សល្ងីល្ងើនោះជាសេចក្ដីឆបោកទទេ* នេះគឺជាផលផ្លែរបស់មនុស្សអាក្រក់ (គឺជាអំពើអាក្រក់ល្ងីល្ងើរបស់អ្នកទាំងនោះ) ដែលពុំទទួលបានជោគជ័យ តែផ្ទុយទៅវិញត្រូវធ្លាក់ទៅលើសេចក្ដីហិនវិនាសទៅវិញ ។
**១៤:៩** *សើចឡកចំពោះអំពើបាប* ធៀបនឹង ១៩:២៨ ក៏មើល ១១:២៧ ។
**១៤:១០** *ស្គាល់សេចក្ដីជូរចត់របស់ខ្លួន* សូមមើល ១ពរ ៨:៣៨ ប្រៀបធៀបពីបទពិសោធន៍របស់នាងហាណា (១សយ ១:១០) និងលោកពេត្រុស (មថ ២៦:៧៥) ។ *ទទួលចំណែកក្នុងសេចក្ដីអំណររបស់ចិត្ត* សូមធៀបនឹង មថ ១៣:៤៤ ១ពត ១:៨ ។
**១៤:១១** សូមមើល ១០:២៥ និងការពន្យល់ ។
**១៤:១២** ខនេះបានឃើញបង្ហាញឡើងវិញក្នុង ១៦:២៥ ។ *តែចុងបំផុតនៃផ្លូវនោះគឺជាសេចក្ដីស្លាប់វិញ* សូមមើល ៥:៤,២៣ ៧:២១–២៧ មថ ៧:១៣–១៤ ។
**១៤:១៣** *វេលាកំពុងតែសើចសប្បាយ គង់តែចិត្តមានសេចក្ដីសៅសោកដែរ*

សេចក្ដីសៅសោកដែរ ហើយចុងបំផុតនៃសេចក្ដីអំណរ
គឺជាធ្ងន់ទ្រូងវិញ ។
១៤អ្នកណាដែលមានចិត្តរសាយថយទៅវិញ នោះនឹង
បានឆ្អែតក្នុងផ្លូវរបស់ខ្លួន[ឈ] តែមនុស្សល្អនឹងបានស្កប់ស្កល់
អំពីក្នុងចិត្តខ្លួនវិញ[ណ] ។
១៥មនុស្សឆោតល្ងង់ គេជឿគ្រប់ពាក្យទាំងអស់ តែ
មនុស្សមានគំនិតវាងវៃរមែងមើលផ្លូវខ្លួនដោយប្រយ័ត្ន[ត] ។
១៦មនុស្សដែលមានប្រាជ្ញារមែងកោតខ្លាច ហើយ
ក៏ចៀសចេញពីផ្លូវអាក្រក់[ថ] តែមនុស្សល្ងីល្ងើ[ទ] គេមានចិត្ត
ចើងម៉ើង ហើយទុកចិត្តតែនឹងខ្លួនឯងវិញ ។
១៧អ្នកណាដែលរហ័សខឹង[ធ] នោះតែងតែប្រព្រឹត្តឥត
បើគិត[ន] ហើយមនុស្សដែលគិតគូរបង្កើតការអាក្រក់ នោះ
រមែងជាទីស្អប់ដល់អ្នកដទៃ[ប] ។
១៨មនុស្សឆោតល្ងង់ គេគ្រងបានសេចក្ដីចំកួត ទុកជា
មរដក តែមនុស្សឆ្លៀវឆ្លាតបានពាក់ដំរិះជាមកុដវិញ ។
១៩មនុស្សអាក្រក់រមែងឱនចុះ នៅចំពោះមនុស្សល្អ
ហើយមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ ក៏ក្រាបចុះនៅមាត់
ទ្វារនៃមនុស្សសុចរិតដែរ[ផ] ។
២០មនុស្សក្រជាទីខ្ពើម ដល់ទាំងអ្នកជិតខាងខ្លួនផង តែឯ
អ្នកមានវិញ គេមានមិត្រសំឡាញ់ច្រើន[ព] ។

២១អ្នកណាដែលមើលងាយដល់អ្នកជិតខាង[ភ] នោះ
ឈ្មោះថាមានបាបហើយ តែអ្នកណាដែលមានចិត្តមេត្តា
ដល់មនុស្សទាល់ក្រ នោះរមែងសប្បាយវិញ[ម] ។
២២មនុស្សដែលគិតគូរបង្កើតការអាក្រក់ នោះវង្វេង
ហើយទេតើ[យ] ប៉ុន្តែឯមនុស្សដែលគិតគូរបង្កើតការល្អវិញ
នោះនឹងបានសេចក្ដីមេត្តា និងសេចក្ដីពិត ។
២៣អស់ទាំងការដែលខំធ្វើ សុទ្ធតែមានកំរៃ តែសំដី
ទទេៗនាំឱ្យក្រខ្សត់វិញ ។
២៤ទ្រព្យសម្បត្តិជាមកុដដល់មនុស្សប្រាជ្ញា តែសេចក្ដី
ចំកួតរបស់មនុស្សល្ងីល្ងើ នោះជាសេចក្ដីចំកួតសុទ្ធ[រ] ។
២៥សាក្សីទៀងត្រង់ រមែងដោះព្រលឹងមនុស្សឱ្យរួច
តែសាក្សីមិនទៀងត្រង់ នោះពោលពាក្យភូតភរវិញ[ល] ។
២៦មនុស្សដែលកោតខ្លាចដល់ព្រះយេហូវ៉ា នោះមាន
ទីពឹងមាំមួន[វ] ហើយកូនចៅរបស់គេនឹងបានទីពំនាក់ដែរ[ស] ។
២៧សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជារន្ធទឹក
នៃជីវិត[ហ] ប្រយោជន៍ឱ្យបានរួចពីអន្ទាក់នៃសេចក្ដីស្លាប់[ឡ] ។
២៨ដែលស្ដេចមានសិរីល្អ នោះគឺដោយមានរាស្ត្រជា
ច្រើន ឯចៅហ្វាបើគ្មានបណ្ដាជន នោះត្រូវធ្លាក់ចុះវិញ[អ] ។

**១៤:១៤** ឈ សភ ១:៣១ ណ ២រប ១៥:៧ សភ ១២:១៤
**១៤:១៥** ត ខ.៨
**១៤:១៦** ថ នក ២០:២០ សភ ២២:៣ ទ ១សយ ២៥:២៥
**១៤:១៧** ធ ២ពវ ៥:១២ ន ខ.២៩ សភ ១៥:១៨ ១៦:២៨ ២៦:២១ ២៨:២៥ ២៩:២២ ប នអ ៥:៩
**១៤:១៩** ផ សភ ១១:២៩
**១៤:២០** ព សភ ១៩:៤,៧
**១៤:២១** ភ សភ ១១:១២ ម សភ ១៩:១៧
**១៤:២២** យ សភ ៤:១៦-១៧
**១៤:២៤** រ ខ.៨
**១៤:២៥** ល សភ ១២:១៧
**១៤:២៦** វ សភ ១៨:១០ ស ទដ ៩:៩
**១៤:២៧** ហ សភ ១០:១១ ឡ ទដ ១៨:៥ សភ ១៣:១៤ **១៤:២៨** អ ២សយ ១៩:៧

ធៀបនឹង អគ ៣:១១-១២ ។ ពាក្យថា *ចុងបំផុតនៃសេចក្ដីអំណរគឺជាធ្ងន់ទ្រូងវិញ* គឺដូចជាការស្លាប់របស់នាងរ៉ាដែលក្នុងពេលសំរាលកូននោះដែរ (លក ៣៥:១៦-១៨) ។

**១៤:១៤** សូមមើល ១:៣១ ១២:១៤ និងការពន្យល់, សូមមើល ១១:៥ ១៨:២០ ២២:៨ ៤:៨ ។

**១៤:១៥** *មនុស្សឆោតល្ងង់* សូមមើលការពន្យល់ ១:៤ ។ ពាក្យថា *មើលផ្លូវខ្លួនដោយប្រុងប្រយ័ត្ន* សូមមើល ៤:២៦ និងការពន្យល់ ២១:២៩ ។

**១៤:១៦** *មានប្រាជ្ញារមែងកោតខ្លាច . . . ក៏ចៀសចេញពីផ្លូវអាក្រក់* សូមមើលការពន្យល់ ១:៧ ៣:៧ ។ *មានចិត្តចើងម៉ើង* សូមធៀបនឹង ២១:២៤ ។ ក៏សូមមើលក្នុង (១២:១៨ ១៣:៣) និង (ពច ៩:៤) ។

**១៤:១៧** *រហ័សខឹង* សូមមើល ខ.២៩ ទដ ១:៧ ។ ពាក្យថា *គិតគូរបង្កើតការអាក្រក់* ប្រៀបធៀបនឹង ១២:២ យប ៥:១២-១៣ ១កថ ៣:១៩ ។

**១៤:១៨** *បានពាក់ដំរិះជាមកុដ* គឺជាព្រះពរ (សូមមើលការពន្យល់ ៤:៩ ក៏សូមមើល ខ.២ ១២:៤ ទដ ១០៣:៤) ។

**១៤:១៩** *មនុស្សអាក្រក់រមែងឱនចុះ* ប្រៀបធៀបនឹង ១៧:២ ។ *នៅមាត់ទ្វារនៃមនុស្សសុចរិត* គឺប្រហែលជាដើម្បីសុំការអត់ទោសកំហុសឱ្យ (ធៀបនឹង ១សយ ២:៣៦) ។

**១៤:២០** សូមមើល ១៩:៧ ។

**១៤:២១** *អ្នកណាដែលមានចិត្តមេត្តាដល់មនុស្សទាល់ក្រ នោះរមែងសប្បាយវិញ* ដូចជាការចែករំលែកអាហារ (២២:៩) ការឱ្យខ្ចីលុយ (២៨:៨) ការពារសិទ្ធ (៣១:៩) គឺជាការបង្ហាញពីភាពសប្បុរស ។ "គឺក៏ដូចជាមនុស្សមានចិត្តគោរពកោតក្លាចដល់ព្រះ" (ខ.៣១ ធៀបនឹង ១៧:៥) ហើយក៏មិនត្រូវបាត់បង់អ្វីឡើយ (២៨:២៧) ប្រៀបធៀបនឹង ២១:១៣ ទដ ៤១:១ ។

**១៤:២២** គឺជាការងារមនុស្សល្អដែលគិតគូរពីការល្អវិញ សូមមើល ៣:២៩ ៦:១៤,១៨ មីក ២:១ ។ ពាក្យថា *នោះវង្វេងហើយ* សូមមើល ៥:២៣ ១២:២៦ ។ *បានសេចក្ដីមេត្តានឹងសេចក្ដីពិត* គឺជាការទទួលបានការគាំទ្រនិងថែរក្សាពីមិត្តសំឡាញ់ដ៏ស្មោះត្រង់ (ប្រៀបធៀបនឹង ៣:៣ ១៦:៦ ២០:២៨) ក៏ជាការជួយពីព្រះអម្ចាស់ សូមមើល ទដ ២៦:៣ និងការពន្យល់ ។

**១៤:២៣** *អស់ទាំងការដែលខំធ្វើសុទ្ធតែមានកំរៃ* សូមមើលការពន្យល់ ១០:៤ ក៏សូមមើល ២១:៥ ។

**១៤:២៤** *ទ្រព្យសម្បត្តិជាមកុដដល់មនុស្សប្រាជ្ញ* គឺជាមនុស្សទទួលបានទ្រព្យសម្បត្តិជាមកុដដល់ជីវិតឯសម្បត្តិនោះវាគឺជាគ្រឿងលំអរដូចជាមកុដ (សូមមើល ១០:២២ និងការពន្យល់) ឯមនុស្សចំកួតគេពុំទទួលបានអ្វីជាមរតកឡើយ (សូមមើល ខ.១៨ ៣:៣៥) ។

**១៤:២៥** សូមមើល ខ.៥,១២,១៧ សូមមើលការពន្យល់ ៦:១៩ ។

**១៤:២៦** *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើល ១:៧ ៣:៧ និងការពន្យល់ ។ *នោះមានទីពឹងមាំមួន* គឺមានន័យថាការកសាងខ្លួនល្អរបស់ឪពុកម្ដាយ ក៏ជាលិទ្ធផលល្អដល់កូនចៅក្រោយៗរបស់ពួកគេ (សូមមើល ២០:៧) ឬ "ការកោតខ្លាចដល់ព្រះយេហូវ៉ា" (សូមមើល ១៨:១០ ទដ ៧១:៧ អស ៣៣:៦) ។

**១៤:២៧** សូមមើលការពន្យល់ ១០:១១ ១៣:១៤ ។

២៩អ្នកណាដែលមិនឆាប់ខឹង នោះឯងជាអ្នកប្រកប
ដោយយោបល់ច្រើន[ក] តែអ្នកណាដែលមានចិតឆុរឆេវ
នោះសំញែងសេចក្ដីចំកួតរបស់ខ្លួនវិញ[ខ] ។
៣០ឯជីវិតរបស់សាច់ឈាម នោះគឺជាចិត្តដែលស្ងប់
រំងាប់ តែចិត្តច្រណែនជាសេចក្ដីពុករលួយដល់ឆ្អឹងវិញ[គ] ។
៣១អ្នកណាដែលសង្កត់សង្កិនមនុស្សក្រីក្រ នោះឈ្មោះ
ថាប្រកួតនឹងព្រះដ៏បង្កើតខ្លួនមក[ឃ] តែអ្នកណាដែលមេត្តា
ដល់មនុស្សកំសត់ទុគ៌ត នោះជាអ្នកលើកដំកើងទ្រង់វិញ[ង] ។
៣២មនុស្សអាក្រក់ត្រូវធ្លាក់ចុះ[ច] ដោយអំពើខូចអាក្រក់
របស់ខ្លួន តែមនុស្សសុចរិតមានទីពំនាក់ ក្នុងកាលដែល
ស្លាប់វិញ[ឆ] ។
៣៣មានប្រាជ្ញាស្ថិតនៅក្នុងចិត្តមនុស្ស ដែលមានយោបល់[ជ]
តែសេចក្ដីដែលនៅខាងក្នុងមនុស្សល្ងីល្ងើ នោះរមែង
សំដែងចេញមក ។
៣៤សេចក្ដីសុចរិតរមែងលើកដំកើងនគរ[ឈ] តែអំពើ
បាបជាទីគួរខ្មាសដល់សាសន៍ណាៗក៏ដោយ ។
៣៥មហាក្សត្រតែងផ្តល់គុណ ដល់អ្នកបំរើណាដែល
ប្រព្រឹត្តដោយអើពើ តែសេចក្ដីក្រោធរបស់ទ្រង់[ញ] និងទាស់
ចំពោះអ្នកណាដែលបង្កើតហេតុឱ្យខ្មាសវិញ ។

**១៥** ១ពាក្យតបឆ្លើយ[ក]ដោយស្រទន់ នោះរមែងរំងាប់
សេចក្ដីក្រោធទៅ[ខ] តែពាក្យគំរោះគំរើយ នោះបណ្ដាយ
ឱ្យមានសេចក្ដីកំហឹងវិញ ។
២អណ្ដាតរបស់មនុស្សប្រាជ្ញ រមែងធ្វើឱ្យចំណេះបាន
ពីរោះស្ដាប់[គ] តែមាត់របស់មនុស្សល្ងីល្ងើបង្ហូរចេញជា
សេចក្ដីចំកួតវិញ[ឃ] ។
៣ព្រះនេត្រ[ង]នៃព្រះយេហូវ៉ានៅគ្រប់អន្លើ[ច] ក៏យាមមើល
ឃើញទាំងអស់ ទោះទាំងអាក្រក់នឹងល្អផង[ឆ] ។
៤ឯអណ្ដាត[ជ]ដ៏លំហើយ នោះជាដើមឈើនៃជីវិត[ឈ] តែ
បើមានសេចក្ដីវៀចវិញ នោះនាំឱ្យវិញ្ញាណបាក់បែក
ទៅ[ញ] ។
៥មនុស្សល្ងីល្ងើតែងតែស្អប់សេចក្ដីប្រៀនប្រដៅរបស់
ឪពុក តែអ្នកណាដែលស្ដាប់តាមសេចក្ដីបន្ទោស នោះនឹង
បានគំនិតវាងវៃវិញ[ដ] ។
៦នៅក្នុងផ្ទះមនុស្សសុចរិតមានទ្រព្យសម្បត្តិច្រើន[ឋ] តែ
ក្នុងកំរៃនៃមនុស្សអាក្រក់ តែងតែមានសេចក្ដីវេទនាវិញ[ឌ] ។

**១៤:២៩** ក ២ពរ ៥:១២ សភ ១៧:២៧ ខ ឧ.១៧ សស ៧:៨-៩ **១៤:៣០** គ សភ ១៧:២២ **១៤:៣១** ឃ សភ ១៧:៥ ង ចទ ២៤:១៤ យប ២០:១៩ មថ ១០:៤២ **១៤:៣២** ច ទដ ៣៤:២១ សភ ៦:១៥ ឆ យប ១៣:១៥ **១៤:៣៣** ជ សភ ២:៦-១០ **១៤:៣៤** ឈ សភ ១១:១១ **១៤:៣៥** ញ នអ ៨:២ មថ ២៤:៤៥-៥១ ២៥:១៤-៣០ **១៥:១** ក ១ពរ ១២:៧ ២រប ១០:៧ ខ សភ ២៥:១៥ **១៥:២** គ ឧ.៧ សភ ១០:៣១ ឃ ទដ ៥៩:៧ សស ១០:១២ **១៥:៣** ង ២រប ១៦:៩ ច យប ១០:៤ ៣១:៤ ហព ៤:១៣ ឆ យប ៣៤:២១ សភ ៥:២១ យរ ១៦:១៧ **១៥:៤** ជ ទដ ៥:៩ ឈ សភ ១០:១១ ញ សភ ១២:១៨ **១៥:៥** ដ សភ ១០:១៧ ១២:១ ១៣:១ **១៥:៦** ឋ សភ ៨:២១ ឌ សភ ១០:១៦

**១៤:២៩** *អ្នកណាដែលមិនឆាប់ខឹង* សូមមើល ១៥:១៨ ១៦:៣២ ១៩:១១ យក ១:១៩ ។ ពាក្យថា *អ្នកណាដែលមានចិត្តឆុរឆេវ* សូមមើល ឧ.១៧ ប្រៀបធៀបនឹង អភ ៤:២៦ ។

**១៤:៣០** *ឯជីវិតរបស់សាច់ឈាម* ប្រៀបធៀបនឹងឥទ្ធពលដែលនាំឱ្យសុខសប្បាយដោយសារការស្ដាប់បង្គាប់ព្រះយេហូវ៉ា និងការដើរដោយប្រាជ្ញា សូមមើលក្នុង ៣:៧-៨ ។ *ចិត្តច្រណែនជាសេចក្ដីពុករលួយដល់ឆ្អឹងវិញ* សូមមើលការពន្យល់ ៣:៨ និងមើល ១២:៤ ទដ ៣៧:៧-៨ ។

**១៤:៣១** *នោះឈ្មោះថាប្រកួតនិងព្រះដ៏បង្កើតខ្លួនមក* គឺព្រោះតែទ្រង់បានបង្កើតទាំងអ្នកមានហើយនិងអ្នកក្រផងដែរ គឺក្នុងភាពដូចជាអង្គទ្រង់ (មើល ១៧:៥ ២២:២ លប ១:២៦ និងការពន្យល់ យប ៣១:១៥ យក ៣:៩) ។ *មេត្តាដល់មនុស្សកំសត់* សូមមើលការពន្យល់ ឧ.២១ ។ *លើកដំកើងទ្រង់វិញ* គឺជាការធ្វើតាមព្រះហឫទ័យទ្រង់ ក៏ដូចជាការថ្វាយខ្លួន (សូមមើល ១៩:១៧ និងការពន្យល់ មថ ២៥:៤០) ។

**១៤:៣២** *មនុស្សអាក្រក់ត្រូវធ្លាក់ចុះ* សូមមើល ១:២៦ និងការពន្យល់ ១១:៥ ២៤:១៦ ។ *តែមនុស្សសុចរិតមានទីពំនាក់ក្នុងកាលដែលស្លាប់វិញ* ដោយសេចក្ដីជំនឿរបស់ពួកគេក្នុងព្រះអម្ចាស់ ដែលឱ្យពួកគេមានសេចក្ដីសង្ឃឹម (សូមមើល ១២:២៨ ទដ ៤៩:១៥ និងការពន្យល់) ។

**១៤:៣៣** *នៅខាងក្នុងមនុស្សល្ងីល្ងើនោះរមែងសំដែងចេញមក* គឺប្រហែលជាពេលខ្លះមនុស្សល្ងីល្ងើ ក៏សម្ដែងចេញពីប្រាជ្ញា (ប្រៀបធៀបនឹង កច ១៧:២៧-២៨ រម ១:១៩-២០) ។

**១៤:៣៤** *សេចក្ដីសុចរិតរមែងលើដំកើងនគរ* សូមមើលការពន្យល់ ១១:១១ គឺរាស្ត្រអ៊ីស្រាអែល ដែលព្រះមានបន្ទូលសន្យាឱ្យពួកគេទទួលបានភាពសុខសាន្តនិងមានឥទ្ធិពលគ្របសង្កត់លើអស់ទាំងសាសន៍ បើសិនរាស្ត្រអ៊ីស្រាអែលស្ដាប់បង្គាប់បញ្ញត្តិរបស់ទ្រង់ (មើល ចទ ២៨:១-១៤) ។ *បាបជាទីគួរខ្មាសដល់សាសន៍ណាៗក៏ដោយ* គឺក៏ដូចជាពួកសាសន៍កាណាន ដែលត្រូវបានបណ្ដេញចេញ ដោយសារតែអំពើបាបរបស់ពួកគេ ។

**១៤:៣៥** *សេចក្ដីក្រោធរបស់ទ្រង់* សូមមើល ១៦:១៤ និងការពន្យល់ ។

**១៥:១** *ពាក្យឆ្លើយទៅដោយស្រទន់ នោះរមែងរំងាប់សេចក្ដីក្រោធទៅ* ប្រៀបធៀប ពីផ្លូវរបស់លោកគេឌានដែលមានភាពស្ងាត់ស្ងៀម ដែលពុំមានកំហឹងចំពោះពួកអេប្រាអិម ដូចជានៅក្នុង យហ ៨:១-៣ (ប្រៀបធៀបនឹង សភ ១៥:១៨ សស ១០:៤) ។ *ពាក្យគំរោះគំរើយនោះបណ្ដាលឱ្យមានសេចក្ដីកំហឹងវិញ* (១សយ ២៥:១០:១៣) ។

**១៥:២** *បង្ហូរចេញជាសេចក្ដីចំកួតវិញ* មើល ឧ.៧,២៨ ១២:២៣ ១៣:១៦ ។

**១៥:៣** *ព្រះនេត្រនៃព្រះយេហូវ៉ានៅគ្រប់អន្លើ* សូមមើល ៥:២១ យប ៣១:៤ ៣៤:២១ យរ ១៦:១៧ ៣២:១៩ ។

**១៥:៤** *ឯអណ្ដាតដ៏លំហើយ* សូមមើលការពន្យល់ ១២:១៨ ។ *ដើមឈើនៃ* សូមមើលការពន្យល់ ៣:១៨ ។ *បើមានសេចក្ដីវៀចវិញនោះនាំឱ្យវិញ្ញាណបាក់បែកទៅ* ជាពិសេសពួកមានទីបន្ទាល់ក្លែងក្លាយ (សូមមើល ៦:១៩ និងការពន្យល់ ២២:២២) ឬពួកនិយាយបង្ខូចនៅក្នុងសហគមន៍ ។

**១៥:៦** សូមមើល ១០:២ ១៦,២២ និងការពន្យល់ ។ *មានទ្រព្យសម្បត្តិច្រើន* សូមមើល ៨:១៨,២១ ២៤:៤ សក ៨:១២ និងការពន្យល់ សូមមើល ៣:១០ និងការពន្យល់ ។

៧បបូរមាត់របស់មនុស្សប្រាជ្ញ រមែងផ្សាយចេញជា
ចំណេះ[ឍ] តែចិត្តរបស់មនុស្សល្ងីល្ងើមិនមែនដូច្នោះទេ ។
៨យញ្ញបូជា[ណ]របស់មនុស្សអាក្រក់ ជាសេចក្ដីស្អប់ខ្ពើម
ដល់ព្រះយេហូវ៉ា[ត] តែសេចក្ដីអធិស្ឋាននៃមនុស្សទៀងត្រង់
ជាទីគាប់ព្រះហឫទ័យដល់ទ្រង់វិញ[ថ]។
៩ផ្លូវប្រព្រឹត្តរបស់មនុស្សអាក្រក់[ទ] ជាសេចក្ដីស្អប់ខ្ពើម
ដល់ព្រះយេហូវ៉ា តែទ្រង់ស្រឡាញ់ចំពោះអ្នកណាដែល
ដើរតាមសេចក្ដីសុចរិតវិញ[ធ]។
១០មានសេចក្ដីផ្ចាញ់ផ្ចាលយ៉ាងសហ័ស បំរុងទុកសំរាប់
អ្នកណាដែលបោះបង់ចេញពីផ្លូវ ហើយអ្នកណាដែលស្អប់
សេចក្ដីបន្ទោស នោះនឹងត្រូវស្លាប់[ន]។
១១ស្ថានឃុំព្រលឹងមនុស្សស្លាប់ និងទីវិនាស នោះប្រាកដ
ច្បាស់នៅចំពោះព្រះយេហូវ៉ាទៅហើយ[ប] ចំណង់បើចិត្ត
នៃអស់ទាំងមនុស្សជាតិ តើច្បាស់ជាជាងអំបាលម៉ានទៅ
ទៀត[ផ]។
១២មនុស្សដែលចំអកមើលងាយ គេមិនចូលចិត្តឱ្យអ្នក
ណាបន្ទោសខ្លួនឡើយ[ព] ក៏មិនដែលរកអ្នកប្រាជ្ញដែរ ។
១៣ចិត្តរីករាយ តែងតែបណ្ដាលឱ្យមានទឹកមុខផូរផង់[ភ]
តែវិញ្ញាណត្រូវបាក់បែកដោយកើតមានទុក្ខព្រួយក្នុងចិត្ត[ម]។
១៤ចិត្តរបស់អ្នកណាដែលមានយោបល់ហើយ[យ] នោះ
រមែងស្វែងរកចំណេះ តែមាត់របស់មនុស្សល្ងីល្ងើតែងតែ
ចិញ្ចឹមខ្លួន ដោយសេចក្ដីចំកួតវិញ ។
១៥អស់ទាំងថ្ងៃនៃមនុស្សរងទុក្ខវេទនា នោះសុទ្ធតែ
អាក្រក់ទាំងអស់ តែអ្នកណាដែលមានចិត្តជាសុខ នោះ
ប្រៀបដូចជាមានការស៊ីលៀងនៅជានិច្ច[រ]។
១៦មានទ្រព្យសម្បត្តិតិច ហើយមានសេចក្ដីកោតខ្លាច
ដល់ព្រះយេហូវ៉ា នោះវិសេសជាងមានច្រើន ហើយមាន
សេចក្ដីទុក្ខវិញ[ល]។
១៧ស៊ូឱ្យមានតែបន្លែជាម្ហូប នៅកន្លែងណាដែលមាន
សេចក្ដីស្រឡាញ់ ជាជាងមានសាច់គោដែលបំប៉នឱ្យធាត់
ហើយមានសេចក្ដីសំអប់វិញ[វ]។
១៨មនុស្សគំរោះគំរើយ រមែងបណ្ដាលឱ្យមានសេចក្ដី
ទាស់ទែងគ្នា[ស] តែអ្នកណាដែលយឺតនឹងខឹង នោះរំងាប់
សេចក្ដីជំលោះវិញ[ហ]។
១៩ផ្លូវរបស់មនុស្សខ្ជិលច្រអូស ធៀបដូចជារបងបន្លា[ឡ]
តែផ្លូវច្រករបស់មនុស្សទៀងត្រង់ត្រឡប់ជាថ្នល់ធំវិញ ។
២០កូនដែលមានប្រាជ្ញរមែងធ្វើឱ្យឪពុកសប្បាយ[អ] តែ
មនុស្សល្ងីល្ងើ គេមើលងាយម្ដាយខ្លួនវិញ ។
២១ឯការចំកួតជាសេចក្ដីអំណរ ដល់មនុស្សដែលឥត
ប្រាជ្ញា[ក] តែមនុស្សដែលមានយោបល់ គេរមែងដើរតាមផ្លូវ

**១៥:៧** ឍ ខ.២ សភ ១០:១៣ **១៥:៨** ណ ទដ ៥១:១៧ អស ១:១៣ ត សភ ៦:១៦ ២១:២៧ ថ ខ.២៩ យប ៣៥:១៣ សភ ២៨:៩ យហ ៩:៣១ **១៥:៩** ទ សភ ៦:១៦ ធ ចទ ៧:១៣ សភ ១១:២០ **១៥:១០** ន សភ ១:៣១–៣២ ១២:១ **១៥:១១** ប យប ២៦:៦ ផ ១សយ ២:៣ ២របា ៦:៣០ ទដ ៤៤:២១ វវ ២:២៣ **១៥:១២** ព សភ ៩:៨ ១២:១ **១៥:១៣** ភ ខ.១៥ ម សភ ១២:២៥ ១៧:២២ ១៨:១៤ **១៥:១៤** យ សភ ១៨:១៥ **១៥:១៥** រ ខ.១៣ **១៥:១៦** ល ខ.១៧ ទដ ៣៧:១៦–១៧ សភ ១៣:៨ ១៦:៨ ១៧:១ **១៥:១៧** វ ខ.១៦ សភ ១៧:១ សស ៤:៦ **១៥:១៨** ស សភ ៦:១៦–១៩ ១៤:១៧ ហ លប ១៣:៨ **១៥:១៩** ឡ ទដ ២២:៥ **១៥:២០** អ សភ ១០:១ **១៥:២១** ក សភ ២:១៤

**១៥:៨** *យញ្ញបូជារបស់មនុស្សអាក្រក់ ជាសេចក្ដីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា* គឺជាអ្នកដែលមានលក្ខណៈមិនត្រឹមត្រូវចំពោះព្រះនេត្រព្រះ តែទោះជាពួកគេថ្វាយដង្វាយច្រើនយ៉ាងណាក៏ដោយ ក៏នៅតែពុំបានផលប្រយោជន៍អ្វីទាំងអស់ដូចជាដង្វាយ ជាយញ្ញបូជាជាដើម សស ៥:១ (ក៏សូមមើល សភ ២១:៣ អស ១:១១–១៥ យរ ៦:២០ និងការពន្យល់) ។ *សេចក្ដីអធិស្ឋានរបស់មនុស្សទៀងត្រង់* សូមមើល ៣:៣២ ។

**១៥:១០** *ផ្លូវ* គឺជាភាពត្រឹមត្រូវ (បះក៏ត្រង់) ពាក្យថាផ្លូវ (មើល ២:១៣) ។ *អ្នកណាដែលស្អប់សេចក្ដីបន្ទោសនោះនិងត្រូវស្លាប់* សូមមើល ៥:១២,២៣ និងការពន្យល់ ។

**១៥:១១** *ស្លាប់និងទីវិនាស* សូមមើល ២៧:២០ ។ *នោះប្រាកដច្បាស់នៅចំពោះព្រះយេហូវ៉ា* គឺមិនគ្រប់គ្រាន់តែស្ថានឃុំព្រលឹង ឬស្ថាននរកទេ អ្នកដែលហួសពេលនោះនិងគ្មានឱកាសមកឯព្រះឡើយ (មើល យប ២៦:៦ និងការពន្យល់ ទដ ១៣៩:៨) ។ ដោយព្រោះទ្រង់ទតដឹងច្បាស់នូវការសម្ងាត់របស់មនុស្សគ្រប់រូប (ធៀបនឹង ១សយ ១៦:៧ និងការពន្យល់) ។

**១៥:១២** សូមមើល ១:៣០ ១០:៨ ១៣:១ ១៧:១០ ។ *មនុស្សដែលចំអកមើលងាយ* សូមមើលការពន្យល់ ១:២២ ។

**១៥:១៣** *ចិត្តរីករាយតែងតែបណ្ដាលឱ្យមានទឹកមុខផូរផង់* ប្រៀបធៀប ១៤:៣០ ។ *តែវិញ្ញាណត្រូវបាក់បែកដោយកើតមានទុក្ខព្រួយក្នុងចិត្ត* សូមប្រៀបធៀបចំពោះការរងទុក្ខវេទនារបស់លោកយ៉ូប (យប ៣) និងស្ដេចដាវីឌ (ទដ ៥១:៨,១០) ។

**១៥:១៥** *អ្នកណាដែលមានចិត្តជាសុខនោះប្រៀបដូចជាមានការស៊ីលៀងនៅជានិច្ច* គឺជាជីវិតរស់ដែលពេញដោយភាពសុខសាន្ត គឺប្រៀបដូចជាស្ថិតក្នុងពេលកំពុងមានការជប់លៀង ឬពិធីបុណ្យមកដល់ (សូមមើល ខ.១៣ ១៤:៣០ ប្រៀបធៀបនឹង លវ ២៣:៣៩–៤១) ។

**១៥:១៦** *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* មើល ១:៧ និងការពន្យល់ ។ ពាក្យថា *មានច្រើនហើយមានទុក្ខវិញ* ដូចជាទ្រព្យខាងឯការទុក្ខព្រួយឈឺស្កាត់ដូចជាក្នុង ១០:២ (សូមមើលការពន្យល់ក្នុងជំពូកនោះដែរ) ។

**១៥:១៧** *សាច់គោដែលបំប៉នឱ្យធាត់* គឺជាប្រភេទសាច់ល្អប្រណីត សម្រិតសម្រាំងសម្រាប់កម្មវិធីពិសេស (ប្រៀបធៀប ៧:១៤ មថ ២២:៤ លក ១៥:២៣) ។ (ធៀបនឹង ៧:១៤ មថ ២២:៤ លក ១៥:២៣) ។

**១៥:១៨** *មនុស្សគំរោះគំរើយរមែងបណ្ដាលឱ្យមានសេចក្ដីទាស់ទែងគ្នា* សូមមើលការពន្យល់ ៦:១៤ ។ *អ្នកណាដែលយឺតនិងខឹង* សូមមើល ១៤:២៩ ១៦:៣២ ១៩:១១ យក ១:១៩ ។

**១៥:១៩** *មនុស្សខ្ជិលច្រអូស* សូមមើលការពន្យល់ ៦:៦ ។ *ដូចជារបងបន្លា* ពីព្រោះពួកគេខ្ជិលមិនមានលទ្ធភាពយកបន្លាចេញបាន (សូមមើល ២៤:៣០–៣១ ហស ២:៦) ។ *ផ្លូវធំ* គឺអាចធ្វើត្រង់ដល់គោលដៅបាន (មើលការពន្យល់ ៣:៦) ។

**១៥:២០** (សូមមើលការពន្យល់ ៣:៦) ។

ឡើងត្រង់វិញ ។
២២ទីណាគ្មានការប្រឹក្សា នោះមិនបានតាមចិត្តប៉ងទេ[ខ]
តែបើមានអ្នកជួយគំនិត[គ]ជាច្រើន នោះនឹងកើតការវិញ[ឃ]។
២៣មនុស្សរមែងមានសេចក្ដីអំណរ ដោយពាក្យឆ្លើយ
របស់ខ្លួន[ង] ហើយពាក្យ១ម៉ាត់ដែលនឹងពោលត្រូវពេល
នោះល្អណាស់ហ្ន៎[ច]។
២៤ខាងឯមនុស្សមានប្រាជ្ញា នោះផ្លូវនៃជីវិតចេះតែនាំ
ឡើងទៅលើ ដើម្បីឱ្យបានឃ្លាតចេញពីស្ថានឃុំព្រលឹង
មនុស្សស្លាប់ ដែលនៅខាងក្រោម ។
២៥ព្រះយេហូវ៉ានឹងបំផ្លាញផ្ទះរបស់មនុស្សឆ្មើងឆ្មៃ[ឆ] តែ
ទ្រង់នឹងតាំងគោលចារឹកនៃស្រីមេម៉ាយឱ្យមាំមួនវិញ[ជ]។
២៦គំនិត[ឈ]អាក្រក់ជាសេចក្ដីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា[ញ]
តែពាក្យសំដីរបស់មនុស្សបរិសុទ្ធ[ដ] នោះពីរោះវិញ ។
២៧អ្នកណាដែលលោភចង់បានកំរៃ នោះរមែងធ្វើ
ឱ្យផ្ទះខ្លួនកើតទុក្ខ តែអ្នកណាដែលស្អប់សំណូក នោះនឹង
រស់នៅវិញ[ឋ]។
២៨ចិត្តរបស់មនុស្សសុចរិតរំពឹងគិតជាមុន ទើបឆ្លើយ[ឌ]
តែមាត់មនុស្សអាក្រក់បង្ហូរចេញជាសេចក្ដីអាក្រក់វិញ[ឍ]។
២៩ព្រះយេហូវ៉ាទ្រង់គង់នៅឆ្ងាយពីមនុស្សអាក្រក់ តែ
ទ្រង់ស្តាប់សេចក្ដីអធិស្ឋានរបស់មនុស្សសុចរិតវិញ[ណ]។
៣០ពន្លឺនៃភ្នែក នោះនាំឱ្យចិត្តរីករាយ ហើយដំណឹង
ដែលគាប់ចិត្ត នោះរមែងចំរើនកំឡាំងដល់ឆ្អឹង[ត]។
៣១ត្រចៀកណាដែលស្តាប់តាមសេចក្ដីបន្ទោសនៃជីវិត
នោះនឹងអាស្រ័យនៅជាកណ្ដាលពួកអ្នកប្រាជ្ញ[ថ]។
៣២អ្នកណាដែលមិនព្រមទទួលសេចក្ដីប្រៀនប្រដៅ
នោះឈ្មោះថាស្អប់ខ្ពើមដល់ព្រលឹងខ្លួន[ទ] តែអ្នកណាដែល
ស្តាប់តាមសេចក្ដីបន្ទោស នោះបានយោបល់វិញ[ធ]។
៣៣សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា[ន] រមែងបង្រៀន
ឱ្យមានប្រាជ្ញា ហើយសេចក្ដីសុភាពរាបសាតែងតែនាំមុខ
កិត្តិសព្ទ[ប]។

**១៦** ១ គំនិតដែលចាត់ចែងក្នុងចិត្ត នោះស្រេចនៅមនុស្ស
តែគឺព្រះយេហូវ៉ា ដែលឆ្លើយសំរេចការនោះវិញ[ក]។
២គ្រប់ទាំងផ្លូវរបស់មនុស្ស សុទ្ធតែស្អាតនៅភ្នែកខ្លួន[ខ]
តែគឺព្រះយេហូវ៉ាដែលទ្រង់ថ្លឹង[គ]អស់ទាំងទឹកចិត្តវិញ[ឃ]។
៣ចូរទុកដាក់អស់ទាំងការឯង នៅនឹងព្រះយេហូវ៉ាចុះ
នោះអស់ទាំងគំនិតរបស់ឯងនឹងបានសំរេច[ង]។

**១៥:២២** ខ ទដ ១៦:៧ គ ១ពវ ១:១២ សភ ២៤:៦ ឃ សភ ១១:១៤
**១៥:២៣** ង សភ ១២:៤ ច សភ ២៥:១១
**១៥:២៤** ឆ សភ ១២:៧ ជ ចទ ១៩:១៤ សភ ២៣:១០–១១
**១៥:២៦** ឈ ទដ ៩៤:១១ ញ សភ ៦:១៦ ដ ទដ ១៨:២៦
**១៥:២៧** ឋ នក ២៣:៨ ទដ ១៥:៥ អស ១:២៣ ៣៣:១៥
**១៥:២៨** ឌ សភ ១៤:៨ ឍ ទដ ៥៩:៧
**១៥:២៩** ណ ខ.៨ យប ១៥:៣១ ទដ ១៤៥:១៨–១៩ អស ៥៩:២ យហ ៩:៣១
**១៥:៣០** ត សភ ២៥:២៥
**១៥:៣១** ថ សភ ៩:៧–៩ ១២:១
**១៥:៣២** ទ សភ ១:៧ ១២:១ ធ សភ ៩:៧–៩ ១២:១ សស ៧:៥ **១៥:៣៣** ន សភ ១:៧ ប សភ ១៦:១៨ ១៨:១២ ២២:៤ ២៩:២៣ អស ៦៦:២ **១៦:១** ក ខ.៩ សភ ១៩:២១ **១៦:២** ខ សភ ១២:១៥ ៣០:១២ គ ១សយ ២:៣ ឃ ២សយ ៦:៣០ សភ ២០:២៧ ២១:២ លក ១៦:៦ **១៦:៣** ង ២របា ២០:២០ ទដ ២០:៤ ៣៧:៥–៦ សភ ៣:៥–៦

**១៥:២២** សូមមើលហេតុការណ៍ស្រដៀងគ្នាក្នុង ១១:១៤ ២០:១៨ ២៤:៦ ។
**១៥:២៣** *ដោយពាក្យឆ្លើយរបស់ខ្លួន* ធៀបទៅនឹង អស ៥០:៤ ។ *ពោលត្រូវពេលនោះល្អណាស់ហ្ន៎* ប្រៀបធៀបនឹង ២៤:២៦ ។
**១៥:២៤** *នាំឡើងទៅលើ* "គឺទៅកាន់ផ្លូវធំ"(ខ.១៩) "ក៏មានផ្លូវត្រង់" (ខ.២១) ដែលនាំឱ្យមានជីវិត ។ *ដើម្បីឱ្យបានឃ្លាតចេញពីស្ថានឃុំព្រលឹងមនុស្សស្លាប់ ដែលនៅខាងក្រោម* សូមមើលការពន្យល់ ២:១៨ ។
**១៥:២៥** *បំផ្លាញផ្ទះរបស់មនុស្សឆ្មើងឆ្មៃ* សូមមើល ២:២២ ១៤:១១ សូមមើល ១០:២៥ និងការពន្យល់ ។ *ទ្រង់នឹងតាំងគោលចារិតនៃស្ត្រីមេម៉ាយឱ្យមាំមួនវិញ* គឺក្នុងសម័យបូរាណថ្មជាប្រកូលព្រះ ដែលជាទ្រព្យកំណប់របស់មនុស្សម្នាក់ៗ ។ បើអ្នកណាដែលបានរំកិលព្រំ ក៏មានឈ្មោះជាចោលួចទឹកដី (សូមមើល ២២:២៨ យប ២៣:១០ ២៤:២ សូមមើល ចទ ១៩:១៤ និងការពន្យល់) ។
**១៥:២៧** *អ្នកណាដែលលោភចង់បានកំរៃ* នោះរមែងធ្វើឱ្យផ្ទះខ្លួនកើតទុក្ខ សូមមើល ១:៩ ១១:២៩ ២៨:២៥ ដោយក្រុមគ្រួសារអេកានទាំងមូលក៏បានហិនវិនាសដោយសារសេចក្ដីលោភចង់បានកំរៃនៅឯក្រុងយេរីខូ (សូមមើល យស ៧:២៤ និងការពន្យល់) ។ *តែអ្នកណាដែលស្អប់សំណូកនោះនិងបានរស់នៅវិញ* សូមមើល ១៧:៨ និងការពន្យល់ ២៨:១៦ ។
**១៥:២៨** *ទ្រង់ស្តាប់សេចក្ដីអធិស្ឋានរបស់មនុស្សសុចរិតវិញ* សូមធៀបនឹង ១០:៣២ ៣:១៥ ។ *ចេញជាសេចក្ដីអាក្រក់* សូមមើល ខ.២ សូមមើល ខ.៧, ១៧,២៣ ។
**១៥:២៩** *នៅឆ្ងាយពីមនុស្សអាក្រក់* សូមមើល ១:២៨ និងការពន្យល់ ។
**១៥:៣០** *ពន្លឺនៃភ្នែកនោះនាំឱ្យចិត្តរីករាយ* សូមធៀបនឹង ខ.១៣ ១៦:១៥ យប ២៩:២៤ ។ *ហើយដំណឹងដែលគាប់ចិត្តនោះ រមែងចំរើនកំឡាំងដល់ឆ្អឹង* សូមមើល ៣:៨ និងការពន្យល់ សូមមើល ភល ២:១៩ ។
**១៥:៣១** *ដែលស្តាប់តាមសេចក្ដីបន្ទោសនៃជីវិត* សូមមើល ១:២៣ ៦:២៣ និងការពន្យល់ ។
**១៥:៣២** *អ្នកណាដែលមិនព្រមទទួលសេចក្ដីប្រៀនប្រដៅ នោះឈ្មោះថាស្អប់ខ្ពើមដល់ព្រលឹងខ្លួន* សូមប្រៀបធៀប ខ.៥:៣១ ។
**១៥:៣៣** *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើល ១:៧ ។ *សេចក្ដីសុភាពរាបសាតែងតែនាំមុខកិត្តិសព្ទ* សូមមើល ១៨:១២ ២៥:៦–៧ មថ ២៣:១២ លក ១៤:១១ និងការពន្យល់ ១៨:១៤ ១ពត ៥:៦ ។
**១៦:១** *គឺព្រះយេហូវ៉ាដែលឆ្លើតសំរេចការ* គឺព្រះទ្រង់អាចឱ្យយើងសម្រេចបានគ្រប់ការខណៈដែលកិច្ចការទៅតាមព្រះហឫទ័យ (ប្រៀបធៀបនឹង ១៩:២១) ។
**១៦:២** *សុទ្ធតែស្អាត* សូមមើល ១៤:១២ ។ *ព្រះយេហូវ៉ាដែលទ្រង់ថ្លឹងអស់ទាំងទឹកចិត្តវិញ* សូមមើល ២១:២ ២៤:១២ និងការពន្យល់ ទដ ១៣៩:២៣ ១កថ ៤:៤–៥ ហព ៤:១២ ។
**១៦:៣** *ចូរទុកដាក់* សូមមើល ១ពត ៥:៧ ។ *នោះអស់ទាំងគំនិតរបស់ឯងនឹងបានសំរេច* គឺនិងបានទៅដល់ទិសដៅកំណត់របស់យើង (សូមមើល ៣:៥–៦ និងការពន្យល់ ទដ ១:៣ ៥៥:២២ ៩០:១៧) ។

[៤]ព្រះយេហូវ៉ាទ្រង់បានធ្វើគ្រប់របស់ទាំងអស់ ឱ្យសមនឹងប្រយោជន៍នៃរបស់នោះឯង[ច] អើ ទោះទាំងមនុស្សអាក្រក់ក៏បានកើតមកសំរាប់ថ្ងៃនៃសេចក្តីអាក្រក់ដែរ[ឆ]។

[៥]អស់អ្នកណាដែលមានចិត្តឆ្មើងឆ្មៃ[ជ]នោះជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា ទោះបើព្រួតដៃគ្នា គង់តែគេមិនរួចពីទោសឡើយ[ឈ]។

[៦]ឯអំពើកំហុស នោះនឹងបានជ្រះស្អាត ដោយសារសេចក្តីមេត្តា និងសេចក្តីពិត ហើយមនុស្សនឹងរួចពីសេចក្តីអាក្រក់បាន ដោយកោតខ្លាចដល់ព្រះយេហូវ៉ា[ញ,ដ]។

[៧]កាលណាផ្លូវប្រព្រឹត្តរបស់មនុស្សណាជាទីគាប់ដល់ព្រះហឫទ័យនៃព្រះយេហូវ៉ា នោះទ្រង់ក៏បណ្តោយឱ្យទាំងពួកខ្មាំងសត្រូវបានជាមេត្រី[ឋ]នឹងអ្នកនោះដែរ[ឌ]។

[៨]បើមានទ្រព្យតិច ហើយមានសេចក្តីសុចរិត នោះវិសេសជាងមានកំរៃ[ឍ]ច្រើន តែមានសេចក្តីទុច្ចរិតវិញ[ណ]។

[៩]ចិត្តរបស់មនុស្សរមែងគិតសំរេចផ្លូវរបស់ខ្លួន តែគឺព្រះយេហូវ៉ាដែលទ្រង់ដំរង់ជំហានគេវិញ[ត]។

[១០]មានពាក្យទំនាយនៅព្រះរឹមនៃស្តេច ហើយព្រះឱស្ឋទ្រង់នឹងមិនសំរេចខុសក្នុងការវិនិច្ឆ័យឡើយ[ថ]។

[១១]ជញ្ជីង ហើយនិងគ្រាជូត្រឹមត្រូវ នោះជារបស់ផងព្រះយេហូវ៉ា ឯអស់ទាំងកូនជញ្ជីងនៅក្នុងថង់ក៏ជាស្នាដៃរបស់ទ្រង់ដែរ[ទ]។

[១២]បើស្តេចប្រព្រឹត្តអំពើអាក្រក់ នោះជាទីគួរស្អប់ខ្ពើមហើយ ដ្បិតរាជ្យបានតាំងនៅជាប់ ដោយសារតែសេចក្តីសុចរិតទេ[ធ]។

[១៣]ឯបបូរមាត់សុចរិត នោះជាទីគាប់ដល់ព្រះទ័យនៃស្តេចណាស់ ហើយទ្រង់ក៏ស្រឡាញ់ដល់អ្នកណាដែលពោល

**១៦:៤** ច នក ៩:១៦ ឆ ២រប ៣៤:២៤ ទដ ១៨:១៨ រម ៩:២២ **១៦:៥** ជ ទដ ៤០:៤ សភ ៦:១៦ ឈ សភ ១១:២០–២១ **១៦:៦** ញ លប ២០:១១ នក ១:១៧ ដ នក ២០:២០ **១៦:៧** ឋ លប ៣៩:២១ ឌ ទដ ១០៥:១៥ យរ ៣៩:១២ ៤០:១ ៤២:១២ ដយ ១:៩ **១៦:៨** ឍ ទដ ៣៧:១៦ ណ សភ ១៥:១៦ ១៧:១ សស ៤:៦ **១៦:៩** ត ខ.១ យប ៣៣:២៩ ទដ ៩០:១២ **១៦:១០** ថ សភ ១៧:៧ **១៦:១១** ទ សភ ១១:១ អគ ៤៥:១០ **១៦:១២** ធ សភ ២៦:២៨ ២៥:៥ ២៩:១៤ ៣១:៥

**១៦:៤** នៅក្នុងកណ្តាលខរបស់ផ្នែកខ្លះនៃគម្ពីរសុភាសិតមាន (១០:១–២២:១៦) គឺសេចក្តីសង្ខេបពីភាពជាក្សត្ររបស់ព្រះយេហូវ៉ា តាមរយៈគំនិតរបស់មនុស្ស និងសកម្មភាពរបស់មនុស្ស ។ ខគម្ពីរនេះក៏លេចមានក្នុងវគ្គខ្លះៗក្នុងខទាំងប្រាំពីរ (១:៧) គឺនៅដើមជំពូក ១៦ និងមានក្នុងកណ្តាលជំពូកនៃកណ្ឌគម្ពីរសុភាសិត ។ ចំណែកខគម្ពីរទាំងប្រាំពីនោះក៏មានឈ្មោះថា "យ៉ាវេ"(yahweh) គឺបញ្ជាក់ពីតួនាទីដ៏ឧត្តម្ភ គឺជាព្រះយេហូវ៉ា ដែលមានព្រះចេស្តាលើគ្រប់ទាំងអស់ ។ *បានធ្វើគ្រប់ទាំងអស់ឱ្យសមនឹងប្រយោជន៍នៃរបស់នោះឯង* គឺព្រះអម្ចាស់ជាមហាក្សត្រលើគ្រប់ទាំងជីវិតទាំងអស់ នៅក្នុងគ្រប់ទាំងប្រវត្តិសាស្ត្រ (សូមមើល សស ៧:១៤ កច ៣:១៧–១៨ រម ៨:២៨) ។ *មនុស្សអាក្រក់ក៏បានកើតមកសំរាប់ថ្ងៃនៃសេចក្តីអាក្រក់ដែរ* ព្រះរាជកិច្ចក៏សម្រាប់មនុស្សអាក្រក់ គឺអំណាចព្រះចេស្តារបស់ទ្រង់ត្រូវជំនុំជម្រះពួកមនុស្សអាក្រក់នឹងទង្វើអាក្រក់ទាំងអស់ (ប្រៀបធៀប អគ ៣៨:២២–២៣ រម ២:៥–១១) ។

**១៦:៥** សូមមើល ១១:២០–២១ ។

**១៦:៦** *ដោយសារសេចក្តីមេត្តានិងសេចក្តីពិត ហើយមនុស្សនឹងរួចពីសេចក្តីអាក្រក់* គឺជាគុណភាពពីក្រមសីលធម៌ ដែលគេបានប្រព្រឹត្ត ដែលទ្រង់មានព្រះហឫទ័យចង់បាន រួមដូចជា"សេចក្តីស្រឡាញ់ និងសេចក្តីស្មោះត្រង់" (៣:៣ សូមមើល ទដ ២៦:៣ សហ ៤:១ និងការពន្យល់) ។ គឺខណៈពេលដែលរាស្ត្ររបស់ផងទ្រង់បានលន់តួអំពើបាប នឹងនាំឱ្យជីវិតរបស់ពួកគេស្ថិតក្នុងគន្លងនៃព្រះទ័យទ្រង់ គឺព្រះអម្ចាស់ក៏បានលើកលែងទោសហើយក៏ដកចេញពីការជំនុំជម្រះ (សូមមើល ១:១៨–១៩ ៥៥:៧ យរ ៣:២២ ១៨:៧–១០ និងការពន្យល់ អគ ១៨:២៣,៣០–៣២ ៣៣:១១–១២,១៤–១៦ ហស ១៤:១–២,៤ ។ *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើលការពន្យល់ ១:៧ ។ *រួចពីសេចក្តីអាក្រក់* សូមមើល ៣:៧ និងការពន្យល់ ។

**១៦:៧** *នោះទ្រង់ក៏បណ្តាលឱ្យទាំងពួកខ្មាំសត្រូវបានជាមេត្រីនឹងអ្នកនោះដែរ* ដូចជាក្នុងកំឡុងពេលការគ្រងរាជ្យរបស់ស្តេចអេសា ដែលលើកខ្លួនឯងជាព្រះ និងស្តេចយ៉ូសាផាត (២រប ១៤:៦–៧ ១៧:១០) ។ *បានជាមេត្រីនឹង* សូមមើល ៣:១៧ រម ១២:១៨ និងការពន្យល់ ហព ១២:១៤ ។

**១៦:៨** សូមមើល ១០:២ និងការពន្យល់ ។

**១៦:៩** *ព្រះយេហូវ៉ាដែលទ្រង់ដំរង់ជំហានគេវិញ* ខ.១,៣–៤ (សូមមើលការពន្យល់) គឺបង្ហាញពីការគ្រប់គ្រងរបស់ព្រះ ចំពោះការរស់នៅរបស់រាស្ត្ររបស់ទ្រង់ (សូមមើល ១៩:២១ ២០:២៤ ទដ ៣៧:២៣ យរ ១០:២៣) ។

**១៦:១០** *មានពាក្យទំនាយ* ក្នុងករណីជំនុំជម្រះដែលត្រូវនាំមកនៅខាងមុខទ្រង់ គឺព្រះមហាក្សត្រមានតួនាទីដូចជាដំណាងរបស់ព្រះអម្ចាស់ (សូមមើល ចទ ១:១៧) ។ ពោលគឺទ្រង់តម្រូវឱ្យមានអំណោយទានពីព្រះ គឺជាប្រាជ្ញាដើម្បីមើលឱ្យឃើញរវាងត្រូវនិងខុស គឺខុសគោលបំណងប្រគល់ឱ្យព្រះជំនុំជម្រះ ។ គឺនៅពេលទ្រង់កាត់ទោសការជំនុំជម្រះរបស់ទ្រង់ គឺមានលក្ខណៈស្រដៀងនឹងសេចក្តីទំនាយពីព្រះចំពោះរាស្ត្រទ្រង់ (សូមមើល ២សយ ១៤:១៧ ១ពវ ៣:២៨ និងការពន្យល់) ។

**១៦:១១** សូមមើលការពន្យល់ ១១:១ ។ *ជញ្ជីង ហើយនិងគ្រាជូត្រឹមត្រូវ នោះជារបស់ផងព្រះយេហូវ៉ា* ប្រៀបធៀបនឹង ២១:២ ២៤:១២ យប ៦:២ ៣១:៦ ។ *អស់ទាំងកូនជញ្ជីងនៅក្នុងផង* គឺមានអ្នកជំនួញបានកាន់ថ្ម ដែលមានទំហំផ្សេងៗគ្នានៅក្នុងថង់របស់ពួកគេ ដើម្បីថ្លឹងឬវាស់ពីបរិមាណរបស់ប្រាក់ដែលត្រូវបង់ (ប្រៀបធៀបនឹង មីក ៦:១១) ។

**១៦:១២–១៥** ខ្សែកណ្ឌគម្ពីរសុភាសិតទាំងបួនបង្ហាញពីច្បាប់របស់ព្រះមហាក្សត្រ ដូចជាប្រធានប្រត្តិបត្តិក្នុងជីវិតរបស់សហគមន៍ទាំងមូល (ប្រៀបធៀបនឹង ខ.១០) ។

**១៦:១២** *ដ្បិតរាជ្យបានតាំងនៅជាប់ដោយសារតែសេចក្តីសុចរិតទេ* គឺខណៈពេលដែលព្រះមហាក្សត្រជំនុំជម្រះ"អ្នកក្រដោយភាពសមរម្យ"(២៩:១៤) គឺមិនទទួលសំណូក(២៩:៤)ក៏បានយកពួកប្រឹក្សាយោបល់ ដែលមានគំនិតអាក្រក់ចេញ (២៥:៥) ។ ១៤:៣៤ ចទ ១៧:១៩–២០ អស ១៦:៥ រម ១៣:៣–៤ ។

**១៦:១៣** *ឯបបូរមាត់សុចរិត* គឺប្រសើរជាងបបូរមាត់ដែលប្រសព្វយកចិត្ត (មើលការប្រៀបធៀប ២៦:២៨) ។

ដោយត្រឹមត្រូវ[ន]។
[១៤]សេចក្ដីក្រោធរបស់ស្ដេច ប្រៀបដូចជាអ្នកបំរើនៃ
សេចក្ដីស្លាប់[ប] មនុស្សមានប្រាជ្ញានឹងខំរំងាប់សេចក្ដីក្រោធ
នោះទៅ[ផ]។
[១៥]កាលណាស្ដេចមានព្រះភក្ត្ររីករាយ នោះឯងបាន
ជីវិតគង់នៅហើយ[ព] ឯព្រះគុណទ្រង់ក៏ដូចជាពពកនៅចុង
រដូវភ្លៀង[ភ]។
[១៦]ការដែលបានប្រាជ្ញា នោះវិសេសជាងបានមាស
តើអំបាលម៉ានទៅ អើ ការដែលបានយោបល់[ម] នោះគួរ
រើសយកជាជាងប្រាក់ទៅទៀត[យ]។
[១៧]ផ្លូវរបស់មនុស្សទៀងត្រង់ នោះគឺជាការចៀសវាង
ពីអំពើអាក្រក់ អ្នកណាដែលរក្សាទុកនូវផ្លូវប្រព្រឹត្តរបស់ខ្លួន
នោះឈ្មោះថាការពារព្រលឹងខ្លួន[រ]។
[១៨]សេចក្ដីឆ្មើងឆ្មៃ[ល]នាំមុខសេចក្ដីហិនវិនាស ហើយ
ចិត្ត[វ]ព្រហើន ក៏នាំឱ្យដួលចុះដែរ[ស]។
[១៩]ការដែលមានចិត្តសុភាព ជាមួយនឹងពួកមនុស្សរាប
ទាប នោះវិសេសជាងការចែករបឹបជាមួយនឹងមនុស្សអួត
អាង ។
[២០]អ្នកណាដែលរំពឹងគិតពីដំណើរអ្វី នោះនឹងបាន
សេចក្ដីល្អចេញពីនោះមក[ហ] ហើយអ្នកណាដែលទុកចិត្តដល់
ព្រះយេហូវ៉ា នោះសប្បាយហើយ[ឡ]។

**១៦:១៣** ន សភ ២២:១១ **១៦:១៤** ប លប ៤០:២ យប ២៩:២៤ សភ ២០:២ ផ សភ ២៥:១៥ ២៩:៨ សស ១០:៤ **១៦:១៥** ព លប ៤០:២ យប ២៩:២៤ ភ សភ ១៩:១២ ២៥:២-៣ **១៦:១៦** ម ទដ ៨៩:២០ យ យប ២៨:១៥ សភ ៣:១៣-១៤ **១៦:១៧** រ សភ ១៩:១៦ **១៦:១៨** ល ១សយ ១៧:៤២ វ ទដ ១៨:២៧ អស ១៣:១១ យរ ៤៨:២៩ ស នអ ៥:១២ សភ ១១:២ ១៥:៣៣ ១៨:១២ ២៩:២៣ **១៦:២០** ហ សភ ១៣:១៣ ឡ ទដ ៣២:១០ ៤០:៤

[២១]ឯអ្នកណាដែលមានចិត្តប្រកបដោយប្រាជ្ញា នោះ
នឹងបានឈ្មោះថាជាអ្នកឆ្លៀវឆ្លាត ហើយសេចក្ដីផ្អែមល្ហែម
នៃបបូរមាត់ក៏ចំរើនចំណេះកាន់តែច្រើនឡើង[អ]។
[២២]អ្នកណាដែលមានយោបល់ហើយ យោបល់នោះ
ឯងជារន្ធទឹកនៃជីវិតដល់អ្នកនោះ[ក] ហើយការវាយផ្ចាល
របស់មនុស្សល្ងីល្ងើ គឺជាសេចក្ដីចំកួតរបស់ខ្លួនគេ ។
[២៣]ចិត្តរបស់មនុស្សដែលមានប្រាជ្ញា នោះបង្រៀន
មាត់របស់ខ្លួន[ខ] ហើយក៏បង្កើនឱ្យបបូរមាត់មានចំណេះកាន់
តែច្រើនឡើងផង[គ]។
[២៤]ពាក្យសំដីពីរោះ នោះធៀបដូចជាសំណុំឃ្មុំ[ឃ] ក៏ផ្អែម
ដល់ព្រលឹង ហើយជាថ្នាំផ្សះដល់ឆ្អឹងផង[ង]។
[២៥]មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អ ដល់
មនុស្ស[ច] តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្ដីស្លាប់[ឆ]។
[២៦]ការស្រេកឃ្លានរបស់អ្នកណាដែលរកស៊ី នោះខំ
ធ្វើសំរាប់ខ្លួនអ្នកនោះឯង ដ្បិតមាត់ខ្លួនបង្ខំឱ្យធ្វើទៅ ។
[២៧]មនុស្សចោលម្សៀត[ជ] គេគិតគូរបង្កើតការអាក្រក់
ហើយនៅបបូរមាត់គេមានភ្លើងក្ដៅដែរ[ឈ]។

សភ ១៩:៨ ២៩:២៥ យរ ១៧:៧ **១៦:២១** អ ខ.២៣ **១៦:២២** ក សភ ១០:១១ **១៦:២៣** ខ យប ១៥:៥ គ ខ.២១ **១៦:២៤** ឃ ១សយ ១៤:២៧ ង សភ ២៤:១៣-១៤ **១៦:២៥** ច សភ ១២:១៥ ឆ នអ ៣:៦ សភ ១៤:១២ **១៦:២៧** ជ ទដ ១៤០:២ ឈ យក ៣:៦

**១៦:១៤** *ជាអ្នកបំរើនៃសេចក្ដីស្លាប់* គឺដូចជាស្ដេចដែលមានសេចក្ដីក្រោធជាធំ ដែលអាចធ្វើឱ្យមានសេចក្ដីស្លាប់យ៉ាងរហ័ស និងមានប្រសិទ្ធភាព (សូមមើល ១៩:១២ នអ ៧:៧-១០ មថ ២២:៧ លក ១៩:២៧) ។ *មនុស្សមានប្រាជ្ញានឹងខំរំងាប់សេចក្ដីក្រោធនោះទៅ* ប្រៀបធៀបនឹងការឆ្លើយតបរបស់ដានីយ៉ែលចំពោះការផ្ទុះកំហឹងរបស់ស្ដេចនេប៊ូក្នេសា (ដយ ២:១២-១៦) ។

**១៦:១៥** *មានព្រះភក្ត្ររីករាយ* ប្រៀបធៀបនឹង ជន ៦:២៥ និងការពន្យល់ បទ ៤:២០ ។ *ឯព្រះគុណទ្រង់ក៏ដូចជាពពកនៅចុងរដូវភ្លៀង* គឺវាមានសារៈសំខាន់ណាស់សម្រាប់ផលដំណាំ ជាពិសេសដំណាំស្រូវសាលី ក៏មានសញ្ញាពីភ្លៀងនៅក្នុងរដូវផ្ការីកក៏ជាសញ្ញាពីការល្អ និងមរដក សូមប្រៀបធៀប "ទឹកសន្សើម"នៃ ១៩:១២ សូមមើល ទដ ៧២:៦ ។

**១៦:១៦** សូមមើល ១:១៣ ៣:១៤ និងការពន្យល់ ៨:១០,១៩ ។

**១៦:១៧** *ផ្លូវរបស់មនុស្សទៀងត្រង់* សូមមើលការពន្យល់ ៣:៦ ១៥:១៩ ។ *ការចៀសវាងពីអំពើអាក្រក់* សូមប្រៀបធៀបនឹងពាក្យថា បន្លានិងអន្ទាក់ដែលក្នុងផ្លូវរបស់មនុស្សអាក្រក់ (២២:៥) ។

**១៦:១៨** សូមមើល ១១:២ និងការពន្យល់ ធៀបនឹង ១កថ ១០:១២ ។

**១៦:១៩** *នោះវិសេសជាងការចែករបឹបជាមួយនឹងមនុស្សអួតអាង* សូមមើល ៣:៣៤ អស ៥៧:១៥ មថ ៥:៣ និងការពន្យល់ ។ សូមមើល ១:១៣-១៤ ពច ៥:៣០ ។

**១៦:២០** *សេចក្ដីល្អ* សូមមើល ១៣:១៣ ២៨:២៥ និងការពន្យល់ ។ *អ្នកណាដែលទុកចិត្តដល់ព្រះយេហូវ៉ា* សូមមើល ខ.៣ ៣:៥-៦ ទដ ៣៤:៤-៥ ៨៤:១២ ។

**១៦:២១** *សេចក្ដីផ្អែមល្ហែមនៃបបូរមាត់ ក៏ចំរើនចំណេះកាន់តែច្រើនឡើង* សូមប្រៀបធៀប បន្ទាត់ចុងក្រោយ ខ.២៣ "ផ្អែមល្ហែម" (បបូរមាត់"ផ្អែម") ក៏មានក្នុងចុង ខ.២៤ ធៀបនឹងសេចក្ដីបញ្ចុះបញ្ចូលតែវាជាពាក្យរបស់មនុស្សស្រីសំផឹងដែលមានក្នុង ២៧:២១ ។

**១៦:២២** *រន្ធទឹកនៃជីវិត* សូមមើលការពន្យល់ ១០:១១ ការវាយផ្ចាលរបស់មនុស្សល្ងីល្ងើ សូមមើល ១៣:១៣ និងការពន្យល់ ។

**១៦:២៣** *បង្រៀនមាត់របស់ខ្លួន* សូមមើល ២២:១៧-១៨ ។

**១៦:២៤** *ពាក្យសំដីពីរោះ នោះធៀបដូចជាសំណុំឃ្មុំ* គឺជាសំណុំឃ្មុំដែលមានភាពល្អប្រសើរសម្រាប់មនុស្សទូទៅផងដែរ (សូមប្រៀបធៀបនឹង ២:១០ ទដ ១៩:១០) ។ *ជាថ្នាំផ្សះដល់ឆ្អឹងផង* មើលការពន្យល់ ៤:២២ ១២:១៨ ១៥:៣០ ។ *ឆ្អឹង* សូមមើលការពន្យល់ ៣:៨ ។

**១៦:២៥** សូមមើល ១៤:១២ និងការពន្យល់ ។

**១៦:២៦** ធៀបនឹង ២ថស ៣:១០ "គឺបើមនុស្សមិនធ្វើការ មិនខិតខំក្នុងជីវិត នោះគេនឹងមិនបានទទួលអាហារក្នុងជីវិតគេទេ "ក៏សូមមើល សស ៦:៧ អភ ៤:២៨ ។

**១៦:២៧** *មនុស្សចោលម្សៀត* សូមមើល ៦:១២ និងការពន្យល់ ។ *គិតគូរបង្កើតការអាក្រក់* សូមមើល ៣:៣៩ ៦:១៤ មីក ២:១ ។ *មានភ្លើងក្ដៅ* សេចក្ដីថ្លែងបន្ទូលរបស់ស្ដេចសាឡូម៉ូន គឺមានភាពក្ដៅឆេួលខ្លាំងនឹងមានលក្ខណៈគ្រោះថ្នាក់ (សូមមើល យក ៣:៦) ។

២៨ មនុស្សវៀចវេរ គេសាបព្រោះសេចក្ដីទាស់ទែង
គ្នា[ញ] ហើយអ្នកបេះបួយ ក៏នាំឱ្យទាំងមិត្រសំឡាញ់យ៉ាងជិត
ស្និទ្ធបាក់បែកគ្នាដែរ[ដ]។
២៩ មនុស្សច្រឡោតគេល្បួងអ្នកជិតខាង ហើយក៏នាំទៅ
ក្នុងផ្លូវដែលមិនល្អ[ឋ]។
៣០ គេធ្មេច[ឌ]ភ្នែក ដើម្បីគិតគូរបង្កើតការវៀច គេខាំ
មាត់ខ្លួន ដើម្បីនឹងគិតសំរេចការអាក្រក់ ។
៣១ ឯសក់ស្កូវ បើឃើញនៅក្នុងផ្លូវសុចរិត[ឍ] នោះជា
មកុដនៃកិត្តិសព្ទ ។
៣២ អ្នកណាដែលយឺតនឹងខឹង នោះវិសេសជាងអ្នក ដែល
មានកំឡាំងខ្លាំង ហើយអ្នកណាដែលឈ្នះចិត្តខ្លួន ក៏វិសេស
ជាងអ្នកដែលឈ្នះយកបានទីក្រុងទៅទៀត ។
៣៣ មនុស្សតែងបោះ[ណ]ឆ្នោតទៅក្នុងថ្នក់អាវ ប៉ុន្តែដែល
សំរេច[ត]ទៅជាយ៉ាងណា នោះស្រេចនៅព្រះយេហូវ៉ាទេ[ថ]។
**១៧** ១ បើមានតែបាយក្រៀម១ដុំ ដែលនឹងបរិភោគដោយ
សេចក្ដីសុខ នោះវិសេសជាងមានផ្ទះពេញដោយការជប់
លៀង តែមានសេចក្ដីទាស់ទែងគ្នាវិញ[ក]។
២ បាវដែលបំរើដោយប្រាជ្ញា នោះនឹងត្រួតលើកូនដែល
នាំឱ្យឪពុកមានសេចក្ដីខ្មាស ហើយនឹងបានចំណែកមរដក
ជាមួយនឹងបងប្អូនរបស់កូននោះដែរ ។
៣ មនុស្សប្រើបាវដីសំរាប់សំរងប្រាក់ ហើយឡសំរាប់
មាស[ខ] តែគឺព្រះយេហូវ៉ាដែលទ្រង់លមើលចិត្តវិញ[គ]។
៤ មនុស្សដែលប្រព្រឹត្តអាក្រក់ គេតែងស្តាប់តាមបបូរ
មាត់អាក្រក់ ហើយមនុស្សភូតភរក៏ផ្ទៀងត្រចៀក ស្តាប់
អណ្តាតកាច ។
៥ អ្នកណាដែលចំអកឱ្យមនុស្សក្រ[ឃ] នោះក៏មើលងាយ
ដល់ព្រះដែលបង្កើតគេមកដែរ[ង] ឯអ្នកណាដែលត្រេក
អរក្នុងការអន្តរាយ[ច]របស់គេ នោះនឹងមិនរួចពីទោស
ឡើយ[ឆ]។
៦ កូនចៅ[ជ]ជាមកុដដល់មនុស្សចាស់ៗ ហើយឪពុកជាទី
អំនួតរបស់ពួកកូន ។
៧ ពាក្យសំដីខ្ពស់ប្រសើរ មិនសំណំនឹងមនុស្សល្ងីល្ងើ
ទៅហើយ ចំណង់បើបបូរមាត់កំភូត តើមិនសំណំនឹង
មនុស្សត្រកូលខ្ពស់ជាជាងយ៉ាងណាទៅ[ឈ]។
៨ សំណូករាប់ដូចជាត្បូងមានដំឡៃដល់អ្នកណាដែល
មាន ទោះបើជូនទៅខាងណាក៏ដោយ គង់តែសំរេចការ

**១៦:២៨** ញ សភ ១៤:១៧ ដ សភ ១៧:៩
**១៦:២៩** ឋ សភ ១:១០ ១២:២៦
**១៦:៣០** ឌ សភ ៦:១៣
**១៦:៣១** ឍ សភ ២០:២៩
**១៦:៣៣** ណ លវ ១៦:៨ ១សយ ១០:២១ អក ២១:២១ ត ១សយ ១៤:៤១ ថ យក ៧:១៤ សភ ១៨:១៨ ២៩:២៦ យហ ១:៧
**១៧:១** ក សភ ១៥:១៦,១៧ ១៦:៨
**១៧:៣** ខ សភ ២៧:១២ គ ១របា ២៩:១៧ ទដ ២៦:២ ១៣៩:២៣ ១ពត ១:៧
**១៧:៥** ឃ យប ៥:១៦ ង សភ ១៤:៣១ ច យប ៣១:២៩ ឆ អគ ២៥:៣ អប ១:១២ **១៧:៦** ជ ទដ ១២៨:៥–៦ **១៧:៧** ឈ សភ ១៦:១០

**១៦:២៨** *សាបព្រោះសេចក្ដីទាស់ទែងគ្នា* មើលការពន្យល់ ៦:១៤ ។ អ្នកបេះបួយ មើល ១១:១៣ ។

**១៦:២៩** សូមមើល ១:១០–១៩ និងការពន្យល់ ។

**១៦:៣០** *ធ្មេចភ្នែក* មើលការពន្យល់ ៦:១៣ ដើម្បីគិតគូរបង្កើត (សូមមើលការពន្យល់ ៦:១២–១៤) ។

**១៦:៣១** *សក់ស្កូវបើឃើញនៅក្នុងផ្លូវសុចរិត* គឺបង្ហាញឱ្យឃើញពីភាពចាស់ទុំក៏ទទួលបានការគោរពជាច្រើន (មើល លវ ១៩:៣២) ។ *ជាមកុដនៃកិត្តិសព្ទ* សូមមើល ៣:១–២,១៦ ។

**១៦:៣២** *អ្នកណាដែលយឺតនិងខឹង* សូមមើល ១៤:២៩ ១៥:១៨ ១៩:១១ យក ១:១៩ ។ ការមានប្រាជ្ញានោះប្រសើរជាងមានសម្ភារៈសឹកទៅទៀត (សស ៩:១៨) ។ *អ្នកណាដែលឈ្នះចិត្តខ្លួន ក៏វិសេសជាងអ្នកដែលឈ្នះយកបានទីក្រុងទៅទៀត* គឺអ្នកដែលអត់ធ្មត់មិនឱ្យការអាក្រក់មកដឹកនាំគេ នោះជាមនុស្សពិសេសបំផុត ។

**១៦:៣៣** *មនុស្សតែងតែបោះឆ្នោតទៅក្នុងថ្នក់អាវ* គឺជាការសម្រេចដែលបានធ្វើឡើងនាសម័យនោះដែលគេបានដាក់សន្លឹកឆ្នោតសម្រាប់ធ្វើការសម្រេចនៅក្នុងអាវធំ ឯអាវនោះក៏មានដាក់យូរីមនិងធូមីមភ្ជាប់នៅប្រដាប់បាំងទ្រូងនៃការវិនិច្ឆ័ដែរ (សូមមើលការពន្យល់ នក ២៨:៣០ ជន ២៦:៥៣ កច ១:២៦ ក៏សូមមើល ទដ ២២:១៨) តែសេចក្ដីសម្រេច គឺស្រេចនៅលើព្រះអង្គតែប៉ុណ្ណោះ ។ គឺព្រះទ្រង់មិនប្រែប្រួលទ្រង់ជាព្រះអាចគ្រប់គ្រងលើស្ថានភាពទាំងអស់ (សូមមើល ៦.១,៣–៤,៩) ។

**៧:២** *បានដែលបំរើដោយប្រាជ្ញា នោះនឹងត្រួតលើកូន* សូមមើល ១១:២៩ និងការពន្យល់ ។ *កូនដែលនាំឱ្យឪពុកមានសេចក្ដីខ្មាស* សូមមើល ១០:៥ ១៩:២៦ ២៨:៧ ២៩:១៥ ។

**១៧:៣** អត្ថន័យក្នុងបន្ទាត់ទី១ក៏បានបង្ហាញឱ្យឃើញក្នុង ២៧:២១ ។ *មនុស្សប្រើបាវដីសំរាប់សំរងប្រាក់* គឺជាប្រាក់និងមាសដែលគេបានបន្សុត ដើម្បីជម្រះភាពមិនបរិសុទ្ធចេញឱ្យអស់ពីវា (សូមមើល ទដ ១២:៦ និងការពន្យល់) ។ *មើលចិត្ត* ១៥:១១ ១៦:២ និងការពន្យល់ យរ ១៧:១០ ។

**១៧:៥** *អ្នកណាដែលចំអកឱ្យមនុស្សក្រ នោះមើលងាយដល់ព្រះដែលបង្កើតគេមក* មើល ១៤:៣១ និងការពន្យល់ ។ *ឯអ្នកណាដែលត្រេកអរក្នុងការអត្តរាយរបស់គេ នោះនឹងមិនរួចពីទោសឡើយ* គឺដូចជាប្រជារាស្ត្រនៅស្រុកអេដុម ក៏ត្រូវបានគេកាត់ទោស ដោយសារតែការអរសប្បាយចំពោះការធ្លាក់ចុះរបស់"បងប្អូន"មានដូចជាយ៉ាកុប ឬអ៊ីស្រាអែល (សូមមើល ៣៥:១២,១៥ ក៏សូមមើល សភ ២៤:១៧) ។

**១៧:៦** *ជាមកុដដល់មនុស្សចាស់* ប្រៀបធៀបចំពោះ"សក់ស្កូវ"ក្នុង ១៦:៣១ គឺសក់ថ្កូវជាភស្តុតាងមួយបង្ហាញពីភាពពេញខ្នាត ឬចាស់ទុំដែលមានជីវិតដើម្បីមើលការខុសត្រូវដល់ចៅៗទាំងឡាយ ឯសក់ស្កូវនោះក៏គេចាត់ថាជាព្រះពរមួយដ៏ធំធេង (សូមមើល លក ៤:១១ ទដ ១២៨:៥–៦) ។ ឯពួកព្ទយុកោ គឺជារង្វាន់ដល់កូនៗគ្រប់រូប សូមមើល លប ៤:៧ ។

**១៧:៧** ក្នុងឃ្លានៃខគម្ពីរនេះ ក៏បានធៀបនឹង ១៥:១១ ១៩:៧,១០ ២១:២៧ ។ *ពាក្យសំដីខ្ពស់ប្រសើរ* សូមមើលការពន្យល់ក្នុងអត្ថបទគម្ពីរនេះ ។ *បើបបូរមាត់កំភូត តើមិនសំណំនឹងមនុស្សត្រកូលខ្ពស់* តែការដែលជាសេចក្ដីតម្រូវ គឺទាមទាឱ្យមានភាពស្មោះត្រង់និងយុត្តិធម៌ (មើល ១២:២២ ១៦:១២–១៣)។

**១៧:៨** *សំណូករាប់ដូចជាត្បូងមានដំឡៃ* គឺជាសេចក្ដីអធិប្បាយគួរឱ្យសោកស្តាយមួយស្ដីពីនិស្ស័យមនុស្ស (សូមមើល ១៨:១៦ ២១:១៤ សស ១០:១៩)។

បាន[ញ] ។
៩ អ្នកណាដែលគ្របបាំងសេចក្តីកំហុសរបស់អ្នកដទៃ
នោះជាអ្នកស្វែងរកសេចក្តីរាប់អានគ្នា[ដ] តែអ្នកណាដែល
ចេះតែនិយាយសាំពីការនោះ នឹងនាំឱ្យមិត្រសំឡាញ់បាក់
បែកគ្នាវិញ[ឋ] ។
១០ ពាក្យបន្ទោសតែ១ម៉ាត់ តែងមុតចូលទៅក្នុងចិត្ត
របស់មនុស្សមានយោបល់ ជាជាងការវាយមនុស្សល្ងីល្ងើ
១០០រំពាត់ទៅទៀត ។
១១ មនុស្សខូចអាក្រក់ គេរកតែបះបោរម្យ៉ាងប៉ុណ្ណោះ
ដូច្នេះ នឹងត្រូវមានអ្នកបំរើយ៉ាងសាហាវ ចេញមកទាស់
នឹងគេ ។
១២ ស៊ូឱ្យប្រទះនឹងមេខ្លាឃ្មុំដែលបាត់កូន នោះគ្រាន់
បើជាងប្រទះនឹងមនុស្សល្ងីល្ងើ ដែលកំពុងតែប្រព្រឹត្តការ
ចំកួតរបស់ខ្លួន[ឍ] ។
១៣ ឯអ្នកណាដែលសងការអាក្រក់[ឍ]ស្នងនឹងការល្អ[ណ]
សេចក្តីអាក្រក់នឹងមិនឃ្លាតចេញពីផ្ទះអ្នកនោះឡើយ ។
១៤ ការចាប់ផ្តើមប្រកាន់គ្នា នោះប្រៀបដូចជាបើកទំនប់
ទឹក ដូច្នេះ ចូរលើកការទាស់គ្នាចេញ មុនដែលកើតមាន
ការប្រឈ្លោះគ្នាផង[ត] ។
១៥ អ្នកណាដែលរាប់មនុស្សអាក្រក់ជាឥតមានទោស[ថ]
ហើយអ្នកណាដែលកាត់ទោសដល់មនុស្សសុចរិត អ្នកទាំង
២ នោះជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា[ទ] ។
១៦ ការដែលមនុស្សល្ងីល្ងើមានប្រាក់នៅដៃសំរាប់នឹង
រៀនយកប្រាជ្ញា នោះតើមានប្រយោជន៍អ្វី បើឃើញថា វា
គ្មានចិត្តចង់បានទេ[ធ] ។
១៧ មិត្រសំឡាញ់រមែងស្រឡាញ់គ្នានៅគ្រប់វេលា ឯ
បងប្អូនក៏កើតមកសំរាប់គ្រាលំបាកដែរ[ន] ។
១៨ មនុស្សដែលឥតមានប្រាជ្ញាគេទទួលចាប់ដៃ ព្រម
ទាំងធានាពីដំណើរអ្នកជិតខាងខ្លួនផង[ប] ។
១៩ អ្នកណាដែលចូលចិត្តនឹងការឈ្លោះប្រកែក នោះ
ឈ្មោះថាជាអ្នកស្រឡាញ់អំពើបាបហើយ ចំណែកអ្នកណា
ដែលលើកខ្លួនឱ្យខ្ពស់ នោះជាអ្នកស្វែងរកតែសេចក្តីហិន
វិនាស ។
២០ អ្នកណាដែលមានចិត្តវៀច មិនដែលបានសេចក្តីល្អ
ទេ ហើយអ្នកណាដែលមានអណ្តាតចចើង នោះរមែង
ធ្លាក់ទៅក្នុងសេចក្តីអន្តរាយ ។
២១ អ្នកណាដែលបង្កើតបានកូន ជាមនុស្សល្ងីល្ងើ ក៏កើត
មានសេចក្តីទុក្ខព្រួយ ឪពុករបស់មនុស្សល្ងីល្ងើរមែងគ្មាន
សេចក្តីអំណរឡើយ[ផ] ។
២២ ចិត្តដែលសប្បាយជាថ្នាំយ៉ាងវិសេស តែវិញ្ញាណ
បាក់បែក[ព] រមែងឱ្យឆ្អឹងរីងស្ងួតទៅ[ភ] ។
២៣ មនុស្សអាក្រក់ គេតែងតែទទួលសំណូក[ម] ដោយលួច

**១៧:៨** ញ នក ២៣:៨ សភ ១៩:៦ **១៧:៩** ដ សភ ១០:១២ ឋ សភ ១៦:២៨ **១៧:១២** ឌ ១សយ ២៥:២៥ **១៧:១៣** ឍ ១សយ ១៩:៤ ណ លប ៤៤:៤ ទដ ៣៥:១២ **១៧:១៤** ត មថ ៥:២៥-២៦ **១៧:១៥** ថ ទដ ៩៤:២១ សភ ១៨:៥ ទ នក ២៣:៦-៧ អស ៥:២៣ បទ ៣:៣៤-៣៦ **១៧:១៦** ធ សភ ២៣:២៣ **១៧:១៧** ន ២សយ ១៥:២១ សភ ២៧:១០ **១៧:១៨** ប សភ ៦:១-៥ ១១:១៥ ២២:២៦-២៧ **១៧:២១** ផ សភ ១០:១ **១៧:២២** ព ទដ ៣៨:៨ ភ នក ១២:៤៦ សភ ១៤:៣០ ១៥:១៣ ១៨:១៤ **១៧:២៣** ម នក ១៨:២១ ២៣:៨ ១សយ ៨:៣

(១សយ ១២:៨ សស ៧:៧ អស ១:២៣ អម ៥:១២ ១ថធ ៦:១០) ។

**១៧:៩** *អ្នកណាដែលគ្រប់បាំងសេចក្តីកំហុសរបស់អ្នកដទៃនោះជាអ្នកស្វែងរកសេចក្តីរាប់អានគ្នា* សូមមើល ១០:១២ និងការពន្យល់ ។

**១៧:១០** *ពាក្យបន្ទោសតែ១ម៉ាត់ តែងមុតចូលទៅក្នុងចិត្តរបស់មនុស្សមានយោបល់* សូមមើល ៩:៨-៩ ។ *ការវាយមនុស្សល្ងីល្ងើ១០០រំពាត់ទៅទៀត* (ប្រៀបធៀប ១០:១៣ ១៩:២៥,២៩ ២៦:៣ ចទ ២៥:២-៣) ។

**១៧:១១** *អ្នកបំរើយ៉ាងសាហាវ ចេញមកទាស់និងគេ* សូមមើល ១៦:១៤ និងការពន្យល់ ធៀបនឹងការសម្លាប់របស់នាងអ័ប៊ីសាយនិងលោកយ៉ូប ដើម្បីបញ្ចប់ការបះបោររបស់លោកសេបាប្រឆាំងនឹងស្តេចដាវីឌ (២សយ ២០:១-២២ សូមមើល ១ពវ ២:២៥,២៩,៤៦) ។

**១៧:១២** *ប្រទះឃើញមេខ្លាឃ្មុំដែលបាត់កូន* ជាការពិតណាស់និស្ស័យសត្វខ្លាឃ្មុំពេលវាបាត់កូន បើវាជួបនឹងអ្នកណាវានឹងវាយប្រហារហែកហួរ (សូមមើល ២សយ ១៧:១៨ ហស ១៣:៨ ប្រៀបធៀប ២៩:៩) ។

**១៧:១៣** *សងការអាក្រក់ស្នងនឹងការល្អ* គឺដូចជាលោកណាបាលដែលជាមនុស្សកាចសាហាវ ហើយជាអ្នកមិនព្រមស្នងការល្អជាមួយនិងស្តេចដាវីឌទេ (១សយ ២៥:២១ សូមមើល ទដ ១០៩:៥ រម ១២:១៧-២១) ។ ពាក្យថា *សេចក្តីអាក្រក់មិនឃ្លាតចេញពីអ្នកនោះឡើយ* ដូចជាគ្រួសារស្តេចដាវីឌ បន្ទាប់ពីគាត់មានរឿងរ៉ាវស្នេហាជាមួយនឹងនាងបាតសេបា ហើយបានធ្វើឃាតដល់លោកអ៊ូរីទៀត (សូមមើល ២សយ ១២:១០ និងការពន្យល់ ប្រៀបធៀប យរ ១៨:២០-២៣) ។

**១៧:១៥** *អ្នកណាដែលរាប់មនុស្សអាក្រក់ ជាឥតមានទោស* ក៏ព្រោះមកពីការសូកប៉ាន់ (សូមមើល ខ.៨ ២៤:២៤) ។

**១៧:១៦** *មនុស្សល្ងីល្ងើមានប្រាក់នៅដៃ* ជាប្រាក់សម្រាប់សិក្សា ។

**១៧:១៧** *មិត្រសំឡាញ់រមែងស្រឡាញ់គ្នានៅគ្រប់វេលា* ប្រៀបធៀបនឹងមិត្តភាពស្តេចដាវីឌ ជាមួយព្រះអង្គម្ចាស់យ៉ូណាថាន សូមមើល ១៨:២៤ ។

**១៧:១៨** សូមមើល ៦:១ និងការពន្យល់ ។

**១៧:១៩** *អ្នកណាដែលចូលចិត្តការឈ្លោះប្រកែក នោះឈ្មោះថាជាអ្នកស្រឡាញ់អំពើបាបហើយ* គឺអ្នកដែលមានចិត្តឆេវឆាវ តែប្រព្រឹត្តបាបជារឿយៗ (២៩:២២) ។

**១៧:២០** *មិនដែលបានសេចក្តីល្អ* គឺខុសពី ។ ១៦:២០ ពាក្យថា *ហើយអ្នកណាដែលមានអណ្តាតចចើង* សូមមើលការពន្យល់ ២:១២ ។

**១៧:២១** *គ្មានសេចក្តីអំណរឡើយ* សូមមើល ខ.២៥ ១៩:១៣ ។

**១៧:២២** *ចិត្តដែលសប្បាយ* សូមមើល ១៤:៣០ ១៥:១៣,៣០ ១៦:១៥ ។ *តែវិញ្ញាណបាក់បែករមែងឱ្យឆ្អឹងស្ងួតទៅ* មើលការពន្យល់ ៣:៨ ១៤:៣០ សូមមើល ១២:៤ ទដ ៣២:៣ ។

**១៧:២៣** *ទទួលសំណូក* សូមមើលការពន្យល់ ខ.៨ ។

លាក់ ដើម្បីនឹងបង្ខូចផ្លូវយុត្តិធម៌[ឃ] ។
២៤ ឯប្រាជ្ញារមែងនៅចំពោះមុខមនុស្សដែលមានដំរិះ
តែភ្នែក[ង] មនុស្សល្ងីល្ងើមើលទៅឯចុងផែនដីបំផុតវិញ ។
២៥ កូនល្ងីល្ងើជាហេតុឱ្យឪពុកកើតទុក្ខព្រួយ ហើយជាទី
ជូរល្វីងដល់ម្ដាយដែលបង្កើតវាមក[ល] ។
២៦ ការដែលធ្វើទោសដល់មនុស្សសុចរិត[វ] ឬវាយអ្នក
ត្រកូលខ្ពស់ ដោយព្រោះសេចក្ដីទៀងត្រង់របស់គេ នោះ
មិនល្អទេ ។
២៧ អ្នកណាដែលមានដំរិះរមែងសំចៃទុកនូវពាក្យសំដី
ហើយអ្នកណាដែលមានយោបល់[ស] នោះក៏តែងតែមានចិត្ត
ត្រជាក់ដែរ[ហ] ។
២៨ សូម្បីតែមនុស្សឆ្កួត បើវានៅមាត់ស្ងៀម នោះគេ
រាប់ថាជាអ្នកមានប្រាជ្ញាដែរ ឯអ្នកណាដែលបិតបបូរមាត់
ខ្លួនទុក នោះក៏រាប់ជាអ្នកឆ្លៀវឆ្លាតហើយ[ឡ] ។
**១៨** ១ អ្នកណាដែលញែកខ្លួនចេញពីអ្នកដទៃ នោះជាអ្នក
រកបំពេញតែចិត្តខ្លួនឯងទេ ហើយក៏មានចិត្តគ្នាន់ក្នាញ់ទាស់
នឹងអស់ទាំងសេចក្ដីដែលមានទំនង ។
២ ចំណែកមនុស្សល្ងីល្ងើគេឥតមានសេចក្ដីរីករាយក្នុង
យោបល់ទេ គឺចូលចិត្តតែនឹងសំដែងគំនិតក្នុងចិត្តខ្លួនឯង
ចេញវិញ[ក] ។
៣ កាលណាមនុស្សអាក្រក់មកដល់ នោះសេចក្ដីមើល
ងាយមានជាប់តាមមកដែរ ហើយសេចក្ដីត្មះតិះដៀលក៏
រមែងមកជាមួយនឹងសេចក្ដីអាប់យសផង ។
៤ ពាក្យសំដីដែលចេញពីមាត់មនុស្ស ធៀបដូចជាទឹក
ជ្រៅ[ខ] ហើយទីបញ្ចេញប្រាជ្ញាក៏ដូចជាជ្រោះទឹកហូរ ។
៥ ការដែលយោគយល់ដល់មនុស្សអាក្រក់[គ] ហើយការ
បង្វែរសេចក្ដីយុត្តិធម៌ក្នុងការវិនិច្ឆ័យ នោះមិនល្អទេ[ឃ] ។
៦ បបូរមាត់របស់មនុស្សល្ងីល្ងើ តែងតែស៊កចូកក្នុង
សេចក្ដីឈ្លោះប្រកែកគ្នា ហើយមាត់វាតឿនតែរំពាត់ទេ[ង] ។
៧ មាត់របស់មនុស្សល្ងីល្ងើ ជាហេតុនាំឱ្យខ្លួនត្រូវវិនាស
ទៅ ហើយបបូរមាត់ក៏ជាអន្ទាក់[ច]ដល់ព្រលឹងខ្លួនដែរ[ឆ] ។
៨ ពាក្យសំដីរបស់មនុស្សបេះបួយ ធៀបដូចជាម្ហូបយ៉ាង
ឆ្ងាញ់១ម៉ាត ដែលលេបចុះទៅក្នុងពោះ[ជ] ។
៩ អ្នកណាដែលធ្វេសប្រហែសនឹងការរបស់ខ្លួន នោះ
ឈ្មោះថាជាបងប្អូននឹងអ្នកដែលបំផ្លាញ[ឈ] ។
១០ ព្រះនាមព្រះយេហូវ៉ាជាប៉មមាំមួន[ញ] មនុស្សសុចរិត
រត់ចូលទៅពឹងជ្រក ហើយមានសេចក្ដីសុខ[ដ] ។
១១ ឯមនុស្សអ្នកមានវិញ ទ្រព្យសម្បត្តិរបស់គេជាទីក្រុង
មាំមួន[ឋ] ហើយតាមគំនិតរបស់គេ ក៏យល់ថាជាកំផែង
យ៉ាងខ្ពស់ដែរ ។

**១៧:២៣** យ យប ៣៤:៣៣ **១៧:២៤** រ យប ៣១:១ **១៧:២៥** ល សភ ១០:១ **១៧:២៦** វ ទដ ៩៤:២១ **១៧:២៧** ស យប ៦:២៤ ហ សភ ១៤:២៩ **១៧:២៨** ឡ យប ២:១៣ ១៣:៥ សភ ១០:១៩ **១៨:២** ក សភ ១២:២៣ **១៨:៣** ខ ទដ ១៨:១៦ **១៨:៥** គ សភ ២៤:២៣–២៥ ២៨:២១ ឃ ទដ ៨២:២ សភ ១៧:១៥ **១៨:៦** ង សភ ១០:១៤ **១៨:៧** ច ទដ ១៤០:៩ ឆ ទដ ៦៤:៨ សភ ១០:១៤ ១២:១៣ ១៣:៣ សស ១០:១២

**១៨:៨** ជ សភ ២៦:២២ **១៨:៩** ឈ សភ ២៨:២៤ **១៨:១០** ញ ទដ ៦១:៣ ដ ទដ ២០:១ សភ ១៤:២៦ **១៨:១១** ឋ សភ ១០:១៥

**១៧:២៤** *មើលទៅឯចុងផែងដីបំផុតវិញ* (១២:១១) គឺអ្នកណាដែលតាមសេចក្ដីឥតប្រយោជន៍ នោះគ្មានយោបលវិញ (១២:១១) (ប្រៀបធៀប ចទ ៣០:១១–១៤) ។

**១៧:២៥** សូមមើល ខ.២១ ។ *ជាទីជូរល្វីង* មើល ១៤:១០ និងការពន្យល់ ។

**១៧:២៦** *ធ្វើទោសដល់មនុស្សសុចរិត* សូមមើល ខ.១៥ និងការពន្យល់ ។ ពាក្យថា *ឬវាយអ្នកមានត្រកូលខ្ពស់* សូមើល ខ.១០ និងាការពន្យល់ ប្រៀបធៀបនឹង (យរ ២០:២ ៣០:១–៦) ។

**១៧:២៧** *សំចៃនូវពាក្យសំដី* មើល ១០:១៩ ។ *តែងតែមានចិត្ត* សូមមើល ១៦:៣២ និងការពន្យល់ ។

**១៧:២៨** មើល យប ១៣:៥ (សូមមើលការពន្យល់នៅក្នុងគម្ពីរនោះ) ។

**១៨:១** (ប្រៀបធៀប ១៧:១៤) ។

**១៨:២** *ចូលចិត្តតែនឹងសំដែងគំនិតក្នុងចិត្តខ្លួនឯងចេញវិញ* សូមើល សស ១០:៣ ។

**១៨:៣** *សេចក្ដីមើលងាយ . . . សេចក្ដីត្មះតិះដៀល* ប្រៀបធៀប ៣:៣៥ ៦:៣៣ ១០:៥ ១១:២ ទដ ៣១:១៧ ។

**១៨:៤** *ទឹកជ្រៅ* (ប្រៀប ២០:៥) ។ *ទីបញ្ចេញប្រាជ្ញា ក៏ដូចជាជ្រោះទឹកហូរ* គឺមានមនុស្សមានប្រាជ្ញាមានពាក្យសំដីគឺជាប្រភពនៃជីវិត (សូមមើល ១:២៣ ១០:១១ និងការពន្យល់) ។

**១៨:៥** *យោគយល់ដល់មនុស្សអាក្រក់* សូមមើល ១៧:១៥ និងកាពន្យល់ ។ (សូមមើល ១៩:១៥ ចទ ១:១៧ ១៦:១៩) ។ *ការបង្វែសេចក្ដីយុត្តិធម៌ក្នុងការវិនិច្ឆ័យ* សូមមើល ១៧:២៦ ៣១:៥ មឡ ៣:៥ ។

**១៨:៦** *តែងតែស៊កចូលក្នុងសេចក្ដីឈ្លោះប្រកែកគ្នា* គឺជានិស្ស័យចរិករបស់មនុស្សល្ងីល្ងើ ដែលតែងតែរហ័សខឹង និងមានរឿងកើតឡើងបានជារឿងជម្លោះ (សូមមើល ១៧:១៤,១៩ ២០:៣) ។ *វាតឿនតែរំពាត់ទេ* ឯរំពាត់គឺជាការដាក់ទណ្ឌកម្មចំពោះពួកគេ (សូមមើល ១០:១៣ ១៩:២៩) ។

**១៨:៧** សូមមើល ១០:១៤ និងការពន្យល់ ។

**១៨:៨** ខនេះមានបង្ហាញឡើងវិញម្ដងទៀតនៅក្នុង ២៦:២២ ។ *ពាក្យសំដីរបស់មនុស្សបេះបួយ . . . ធៀបដូចជាម្ហូបយ៉ាងឆ្ងាញ់១ម៉ាត់* វាគឺពាក្យសម្ដីដ៏ផ្អែមល្ហែមរបស់ពួកគេដែលតម្រូវឱ្យធ្វើបែបនេះ (ធៀបនឹង ១៦:២១,២៣) ប៉ុន្តែការពិតវានាំឱ្យមានការបែកបាក់គ្នា (មើល ១១:១៣ ២៦:២០) ។

**១៨:៩** *ដែលធ្វេសប្រហែសនិងការងាររបស់ខ្លួន* ន័យនេះសូមមើលក្នុង ១០:៤ និងការពន្យល់ ។

**១៨:១០** *ព្រះនាមព្រះយេហូវ៉ា* ព្រះនាមជារឿយៗគឺមានន័យស្មើនឹងទ្រង់ផ្ទាល់ គឺបង្ហាញពីនិស្ស័យនឹងសមត្ថភាពទ្រង់ផ្ទាល់ (សូមមើល នក ៣:១៤–១៥ និងការពន្យល់ ៩១:២ ១៤៤:២ ។ *សេចក្ដីសុខសាន្ត* សូមមើល ២៩:២៥ ទដ ២៧:៥ ។

**១៨:១១** *ទ្រព្យសម្បត្តិរបស់គេជាទីក្រុងមាំមួន* គឺជាបង្ហាញអត្ថសញ្ញាណមួយប្រភេទដែលបង្ហាញក្នុងបន្ទាត់ទី១ របស់ជំពូក ១០:១៥ (សូមមើលការ

១២មុននឹងត្រូវវិនាស នោះចិត្តរបស់មនុស្សកើតមាន
សេចក្ដីឆ្មើងឆ្មៃ ឯសេចក្ដីរាបសា នោះរមែងតែនាំមុខ
កិត្តិយសវិញ[ឱ]។
១៣អ្នកណាដែលឆ្លើយមុនដែលបានស្ដាប់រឿង នោះ
រាប់ជាការចំកួតហើយ ក៏ជាសេចក្ដីខ្មាសដល់ខ្លួនផង[ឲ]។
១៤វិញ្ញាណនៃមនុស្សនឹងទប់ទល់ខ្លួនក្នុងគ្រាមានធុរៈ
ឈឺ តែឯវិញ្ញាណបាក់បែក តើអ្នកណានឹងទ្រាំបាន[ណ]។
១៥ចិត្តរបស់មនុស្សវាងវៃ តែងតែចំរើនចំណេះឡើង
ហើយត្រចៀករបស់មនុស្សដែលមានប្រាជ្ញា[ត] ក៏ស្វះស្វែង
រកចំណេះដែរ ។
១៦ជំនូន[ថ]របស់មនុស្សរមែងបើកផ្លូវឱ្យដល់ខ្លួន ក៏នាំចូល
ទៅដល់ចំពោះអ្នកធំផង ។
១៧អ្នកណាដែលនិយាយមុនគេក្នុងការក្ដី នោះមើល
ទៅដូចជាត្រឹមត្រូវហើយ តែគូក្ដីរបស់អ្នកនោះមកបើក
សំដែងឱ្យឃើញកំហុសវិញ ។
១៨ការចាប់ឆ្នោត តែងនឹងធ្វើឱ្យសេចក្ដីទាស់ទែង[ទ]គ្នា
បាត់ទៅ ហើយនិងញែកមនុស្សដែលមានអំណាចចេញពី
គ្នាដែរ ។
១៩បងប្អូនណាដែលបានអន់ចិត្ត[ធ]ហើយ នោះពិបាក
ពង្រាបជាជាងទីក្រុងយ៉ាងមាំមួន ហើយសេក្ដីទាស់ទែង
គ្នាយ៉ាងនោះ ធៀបដូចជារនុកទ្វារបន្ទាយ ។
២០មនុស្សនឹងបានឆ្អែតពោះ ដោយផលនៃមាត់ខ្លួនគឺនឹង
បានស្កប់ចិត្ត ដោយផលចំរើននៃបបូរមាត់[ន]។
២១ទោះទាំងសេចក្ដីស្លាប់ ហើយនិងជីវិតក៏នៅក្នុង
អំណាចនៃអណ្ដាតដែរ[ប] អ្នកណាដែលចូលចិត្តប្រើ នោះ
នឹងស៊ីផលនៃអណ្ដាតនោះឯង[ផ]។
២២អ្នកណាដែលរកបានប្រពន្ធ នោះឈ្មោះថាបាន
របស់ល្អ[ព] ហើយបានប្រកបដោយព្រះគុណនៃព្រះយេហូវ៉ា
ដែរ[ភ]។
២៣មនុស្សក្រគេពោលពាក្យអង្វរ តែមនុស្សអ្នកមាន
តបដោយពាក្យគំហកវិញ ។
២៤អ្នកណាដែលមានមិត្រភក្ដិច្រើន នោះនាំឱ្យវិនាស
ខ្លួនទេ ប៉ុន្តែមានមិត្រសំឡាញ់ម្យ៉ាង ដែលនៅជាប់ជាង
បងប្អូនទៅទៀត[ម]។

**១៩** ១ឯមនុស្សទាល់ក្រ ដែលដើរតាមផ្លូវទៀងត្រង់នោះ
វិសេសជាងមនុស្សដែលមានបបូរមាត់ចចើង ហើយចិត្ត
ល្ងីល្ងើ[ក]។
២មួយទៀត ការដែលចិត្តឥតមានចំណេះ នោះមិន
គួរគប្បីទេ ហើយអ្នកណាដែលរហ័សឈានទៅ នោះជ្រួស
ផ្លូវហើយ[ខ]។
៣សេចក្ដីចំកួត[គ]របស់មនុស្ស រមែងបង្ខូចផ្លូវខ្លួនទៅ
ហើយអ្នកនោះក៏អន់ចិត្ត ចំពោះព្រះយេហូវ៉ាដែរ[ឃ]។
៤ការដែលមានទ្រព្យសម្បត្តិ នោះនាំឱ្យមានមិត្រភក្ដិ
កើនឡើង តែមនុស្សក្រត្រូវពង្រាត់ពីពួកមិត្រភក្ដិវិញ[ង]។
៥សាក្សីភូតភរ[ច]នឹងមិនរួចចាកចោលឡើយ[ឆ] ហើយអ្នក

**១៨:១២** ឱ សភ ១១:២ ១៥:៣៣ ១៦:១៨ **១៨:១៣** ឲ សភ ២០:២៥ **១៨:១៤** ណ សភ ១៥:១៣ ១៧:២២ **១៨:១៥** ត សភ ១៥:១៤ **១៨:១៦** ថ លប ៣២:១៣ ១សយ ១០:៤ សភ ១៩:៦ **១៨:១៨** ទ សភ ១៦:៣៣ **១៨:១៩** ធ ១សយ ១៧:២៨ **១៨:២០** ន សភ ១២:១៤ **១៨:២១** ប ទដ ១២:៤ ផ សភ ១៣:២-៣ មថ ១២:៣៧ **១៨:២២** ព សភ ១២:៤ ភ យប ៣៣:២៦ សភ ១៩:១៤ ៣១:១០ **១៨:២៤** ម ១សយ ២០:៤២ យហ ១៥:១៣–១៥ **១៩:១** ក សភ ២៨:៦ **១៩:២** ខ សភ ២៩:២០ **១៩:៣** គ ទដ ១៤:១ សភ ៩:១៣ ២៤:៩ អស ៣២:៦ ឃ យក ១៣–១៥ **១៩:៤** ង ខ.៧ សភ ១៤:២០ **១៩:៥** ច នក ២៣:១ ឆ ទដ ៥៦:៧

ពន្យល់នៅទីនោះ) ។ ពាក្យថា *ជាកំផែងយ៉ាងខ្ពស់* គឺសំដៅពីនិស្ស័យមនុស្សបានដូចជាទ្រព្យសម្បត្តិ ។ល។ តែទ្រង់ជាព្រះអាចផ្ដួលរំលំវាចុះបាន (សូមមើល អស ២៥:១២) ។

**១៨:១២** *ឯសេចក្ដីរាបសា នោះរមែងតែនាំមុខកិត្តិយសវិញ* ក៏បានបង្ហាញនៅក្នុងបន្ទាត់ទី១ក្នុង ១៥:៣៣ (សូមមើលការពន្យល់) ។

**១៨:១៤** សូមមើល ១៥:១៣ ១៧:២២ និងការពន្យល់ ។

**១៨:១៧** ខនេះជាសេចក្ដីប្រមានមួយចំពោះភាគីទាំងពីរក្នុងរឿងក្ដី (ប្រៀបធៀប ចទ ១:១៦) ក្នុងស្ថានភាពមួយចំនួនក៏បានប្រើពាក្យនេះដែរ ។

**១៨:១៨** *ញែកមនុស្សដែលមានអំណាចចេញពីគ្នា* សូមមើល ១៦:៣៣ និងការពន្យល់ ។

**១៨:១៩** *បងប្អូនណាដែលបានអនចិត្តហើយ នោះពិបាកពង្រាបជាជាង* ប្រៀបធៀប កំហឹងរបស់លោកអេសាវចំពោះលោកយ៉ាកុប ដោយសារលោកយ៉ាកុបបានទទួលពរជាច្រើនពីលោកអ៊ីសាក់ (សូមមើល លប ២៧:៤១) ។

**១៨:២០** សូមមើល ១២:១៤ និងការពន្យល់ ។

**១៨:២១** *ទាំងសេចក្ដីស្លាប់ ហើយនិងជីវិតក៏នៅក្នុងអំណាចនៃអណ្ដាតដែរ* មើលការពន្យល់ ១០:១៩ ១៣:៣ ។ *ស៊ីផលនៃអណ្ដាតនោះ* មើល ខ.២០ ។

**១៨:២២** *អ្នកណាដែលរកបានប្រពន្ធ នោះឈ្មោះថាបានរបស់ល្អ* សូមមើល ១២:៤ និងការពន្យល់ ១៩:១៤ ៣១:១០ ។ *បានប្រកប់ដោយព្រះគុណនៃព្រះយេហូវ៉ា* គឺបញ្ជាក់ពីបន្ទាត់ទី៧ក្នុង ៨:៣៥ ។

**១៨:២៤** *អ្នកណាដែលមានមិត្រភក្ដិច្រើននោះនាំឱ្យវិនាសខ្លួនទេ* គឺម្នាក់ៗត្រូវជ្រើសរើសមិត្តភ័ក្ត្រឱ្យបានច្បាស់ (សូមមើល ១២:២៦ និងការពន្យល់ ១៧:១៧) ។

**១៩:១** ខនេះបានបង្ហាញក្នុង ២៨:៦ ។ *ទៀងត្រង់* មើលការពន្យល់ ២:៧ ។ *នោះវិសេសជាង . . . ចិត្តល្ងីល្ងើ* ទោះជាមនុស្សល្ងីល្ងើបានក្លាយជាអ្នកមានក៏ដោយ (សូមមើល ២៨:៦) ។

**១៩:២** *ចិត្តឥតមានចំណេះ* ធៀបនឹង រម ១០:២ ។ *ហើយអ្នកណារហ័សឈានទៅរកនេះជ្រួសផ្លូវហើយ* (២១:៥) ឬក៏ល្ងីល្ងើ (២៩:២០) ។

**១៩:៣** *អ្នកនោះក៏អន់ចិត្តចំពោះព្រះយេហូវ៉ាដែរ* គឺគេបានបន្ទោសព្រះយេហូវ៉ាដោយព្រោះសេចក្ដីអាក្រក់របស់ពួកគេ (សូមមើល លប ៤:៥ អស ៨:២១ ប្រៀបធៀបនឹង បទ ៣:៣៩) ។

**១៩:៤** សូមមើល ៦:១៩ និងការពន្យល់ ។

ណាដែលពោលពាក្យកុហកក៏នឹងគេចមិនរួចដែរ[ជ]។
៦មនុស្សជាច្រើន នឹងខំយកចិត្តរបស់មនុស្សសទ្ធា[ឈ]
ហើយអ្នកណាក៏ដោយ ក៏ជាមិត្រសំឡាញ់នឹងអ្នកដែលចែក
អំណោយទានដែរ[ញ]។
៧អស់ទាំងបងប្អូនរបស់អ្នកទាល់ក្រ ក៏ស្អប់អ្នកនោះ
ចំណង់បើមិត្រភក្តិ តើនឹងឃ្លាតចេញឆ្ងាយ ពីអ្នកនោះជា
ជាងអំបាលម៉ានទៅទៀត[ដ] អ្នកនោះនឹងតាមទៅអង្វរ តែគេ
គេចបាត់ទៅ[ឋ]។
៨អ្នកណាដែលបានប្រាជ្ញា នោះជាអ្នកស្រឡាញ់ដល់
ព្រលឹងខ្លួន អ្នកណាដែលរក្សាយោបល់ទុក នោះនឹងបាន
សេចក្តីល្អ[ឌ]។
៩សាក្សីភូតភរនឹងមិនរួចចាកពីទោសឡើយ ហើយ
អ្នកណាដែលពោលពាក្យកុហក នឹងត្រូវវិនាសទៅ[ឍ]។
១០ការដែលអាស្រ័យនៅដោយរុងរឿង នោះមិនសម
នឹងមនុស្សល្ងីល្ងើ[ណ]ទេ ចំណង់បើខ្ញុំកំដរ ដែលមានអំណាច
លើអ្នកធំ តើមិនសមគួរជាជាអំបាលម៉ានទៅ[ត]។
១១សតិបញ្ញារបស់មនុស្សនឹងនាំឱ្យយឺតនឹងខឹង[ថ] អ្នកនោះ
ក៏តែងមានចិត្តអរ ដោយមិនប្រកាន់ទោសវិញ ។
១២សេចក្តីក្រោធនៃស្តេច ធៀបដូចជាសូរគ្រហឹមនៃ
សិង្ហ[ទ] តែព្រះគុណទ្រង់ ដូចជាទឹកសន្សើម[ធ]នៅលើស្មៅ
វិញ[ន]។
១៣កូនល្ងីល្ងើជាទីអន្តរាយដល់ឪពុក[ប] ហើយការឌុកដាន់
របស់ប្រពន្ធ ក៏ដូចជាទឹកស្រក់តក់ៗមកជានិច្ច[ផ]។
១៤ផ្ទះសំបែង និងទ្រព្យសម្បត្តិ ជាមរដកមកពីឪពុក[ព]
តែប្រពន្ធដែលឆ្លៀវឆ្លាត នោះហើយជាអំណោយទានមក
ពីព្រះយេហូវ៉ា[ភ]។
១៥សេចក្តីខ្ជិលច្រអូស រមែងធ្វើឱ្យមនុស្សលក់ស្និទ្ធទៅ
ហើយអ្នកណាដែលទទេៗ នោះនឹងត្រូវអត់ឃ្លាន[ម]។
១៦អ្នកណាដែលកាន់តាមក្រិត្យវិន័យ នោះឈ្មោះថា
រក្សាព្រលឹងខ្លួន តែអ្នកណាដែលមិនប្រយ័ត្ននឹងផ្លូវប្រព្រឹត្ត
របស់ខ្លួន នោះនឹងត្រូវស្លាប់វិញ[យ]។
១៧អ្នកណាដែលមានចិត្តអាណិត ចែកដល់ពួកទាល់ក្រ
នោះឈ្មោះថាថ្វាយឱ្យព្រះយេហូវ៉ាខ្ចី[រ] ទ្រង់នឹងតបស្នងសង
គុណអ្នកនោះវិញ[ល]។
១៨ចូរវាយផ្ចាលកូន ក្នុងកាលដែលនៅមានសង្ឃឹម
ឱ្យវារាងចាលនៅឡើយ មិនគួរនឹងលើកលែងចោលវាឱ្យ
ត្រូវវិនាសទេ[វ]។
១៩អ្នកណាដែលមានចិត្តក្រោធជាខ្លាំង នោះនឹងត្រូវ
រងទោស ដ្បិតបើឯងជួយវាឱ្យរួច នោះនឹងត្រូវជួយ
តទៅទៀត ។
២០ចូរស្តាប់សេចក្តីដំបូន្មាន ហើយទទួលសេចក្តីប្រៀន
ប្រដៅចុះ[ស] ដើម្បីឱ្យមានប្រាជ្ញាទៅខាងមុខ[ហ]។
២១នៅក្នុងចិត្តមនុស្ស តែងមានគំនិតគិតធ្វើជាច្រើន
យ៉ាង មានតែដំបូន្មាននៃព្រះយេហូវ៉ាប៉ុណ្ណោះ ដែលនឹង
ស្ថិតស្ថេរនៅ[ឡ]។
២២សេចក្តីដែលនាំឱ្យគេរកពឹងដល់មនុស្សណា នោះ

**១៩:៥** ជ ខ.៩ ចទ ១៩:១៩ សភ ២១:២៨ **១៩:៦** ឈ សភ ២៩:៦ ញ សភ ១៧:៨ ១៨:១៦ **១៩:៧** ដ សភ ១០:១៥ ឋ ខ.៤ **១៩:៨** ឌ សភ ១៦:២០ **១៩:៩** ឍ ខ.៥ ចទ ១៩:១៩ **១៩:១០** ណ សភ ២៦:១ ត សភ ៣០:២១–២៣ សស ១០:៥–៧ **១៩:១១** ថ ២ពវ ៥:១២ **១៩:១២** ទ សភ ២០:២ ធ ទដ ១៣៣:៣ ន នអ ១:១២ ៧:៧ ទដ ៧២:៥–៦ សភ ១៦:១៤–១៥ **១៩:១៣** ប សភ ១០:១ ផ នអ ១:១៨ សភ ២១:៩ **១៩:១៤** ព ២កថ ១២:១៤ ភ សភ ១៨:២២ **១៩:១៥** ម សភ ១០:៤ ២០:១៣ **១៩:១៦** យ សភ ១៦:១៧ រម ១០:៥ **១៩:១៧** រ ចទ ២៤:១៤ ល ចទ ២៤:១៩ សភ ១៤:២១ ២២:៩ មថ ១០:៤២ **១៩:១៨** វ សភ ១៣:២៤ ២៣:១៣–១៤ **១៩:២០** ស សភ ៤:១ ហ សភ ១២:១៥ **១៩:២១** ឡ ទដ ៣៣:១១ សភ ១៦:៩ ២០:២៤ អស ៨:១០ ១៤:២៤,២៧ ៣១:២ ៤០:៨ ៤៦:១០ ៤៨:១៤ ៥៥:១១ យរ ៤៤:២៩ បទ ៣:៣៧

**១៩:៦** *ខំយកចិត្តរបស់មនុស្សសទ្ធា* ប្រៀបធៀបនឹង យប ១១:១៩ ។ *ជាមិត្តសំឡាញ់និងអ្នកដែលចែកអំណោយទានដែរ* ជាភាពសប្បុរស (ខ.៤) ឬក៏ជាលក្ខណៈបានសំណូក (១៧:៨) ។
**១៩:៧** *បងប្អូនរបស់អ្នកទាល់ក្រ ក៏ស្អប់អ្នកនោះ* សូមមើល ខ.៤ ១៤:២០ ។
**១៩:៨** *ស្រឡាញ់ដល់ព្រលឹងខ្លួន* ប្រៀបធៀប ៨:៣៥–៣៦ ។ *បានសេចក្តីល្អ* សូមមីល ១៣:១៣ និងការពន្យល់ ។
**១៩:១០** *អាស្រ័យនៅដោយរុងរឿងនោះមិនសមនិងមនុស្សល្ងីល្ងើ* គឺមនុស្សល្ងីល្ងើ មិនសមនឹងទទួលកិត្តិយស ។
**១៩:១១** *យឺតនឹងខឹង* សូមមើល ១៤:២៩ ១៥:១៨ ១៦:៣២ សស ៧:៩ យក ១:១៩ ។ *ដោយមិនប្រកាន់ទោសវិញ* សូមមើល ១២:១៦ ២៩:១១ ២សយ ១៦:១១–១២ ។
**១៩:១២** សូមមើល ១៦:១៤–១៥ និងការពន្យល់ ។ *សេចក្តីក្រោធនៃស្តេចធៀបដូចសូរគ្រហឹមនៃសិង្ហ* គឺជាការបញ្ជាក់ក្នុងបន្ទាត់ទី១នៃជំពូក ២០:២ ។
**១៩:១៣** *កូនល្ងីល្ងើ* សូមមើល ១៧:២១,២៥ ។ *ការឌុកដាន់របស់ប្រពន្ធ* ក៏មានបញ្ជាក់ក្នុង ២១:៩,១៩ ២៥:២៤ ២៧:១៥ (សូមមើល ៦:១៤ និងការពន្យល់) ។
**១៩:១៤** *ប្រពន្ធដែលឆ្លៀវឆ្លាត* សូមមើល ១២:៤ និងការពន្យល់ សូមមើល ១៨:២២ ។
**១៩:១៥** សូមមើល ៦:១១ ១០:៤ និងការពន្យល់ ។
**១៩:១៦** មើល ១៣:១៣ ១៥:១០ ១៦:១៧ និងការពន្យល់ ។
**១៩:១៧** *តើអ្នកណា . . . ចែកដល់ពួកទាល់ក្រ* មើលការពន្យល់ ១៤:២១ ក៏សូមមើល ១៤:១៣ ។ *ព្រះយេហូវ៉ាខ្ចី* ទ្រង់ចាត់ការនោះជាអំណោយទានមួយចំពោះទ្រង់ (ប្រៀបធៀប មថ ២៥:៤០) ។
**១៩:១៨** *ចូរវាយផ្ចាលកូនក្នុងកាលដែលនៅមានសង្ឃឹម* សូមមើលការពន្យល់ ១៣:២៤ ។
**១៩:១៩** *ចិត្តក្រោធជាខ្លាំង* ប្រៀបធៀប ១៤:១៦–១៧,២៩ ១៥:១៨ ។
**១៩:២១** សូមមើល ១៦:១,៤,៩ និងការពន្យល់ ។
**១៩:២២** សេចក្តីស្រឡាញ់គឺពុំសូវឃើញមានឡើយ (ប្រៀបធៀប ១៤:២២ ២០:៦) ។ *ហើយមនុស្សទាល់ក្ររមែងវិសេសជាងមនុស្សភូតភរ* សូមមើល ខ.១,២៨ ៦:១២ ។

គឺជាសេចក្ដីសប្បុរសរបស់អ្នកនោះឯង ហើយមនុស្សទាល់ក្ររមែងវិសេសជាងមនុស្សភូតភរ ។

[២៣]សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះប្រោសឱ្យមានជីវិត ហើយអ្នកណាដែលមានសេចក្ដីនោះនឹងនៅតែមានចិត្តស្កប់ស្កល់ជានិច្ច ឥតមានសេចក្ដីអាក្រក់ណាមកលើខ្លួនឡើយ[អ] ។

[២៤]មនុស្សខ្ជិលច្រអូសគេលូកដៃទៅក្នុងចាន ហើយមិនដកមក សូម្បីតែនឹងបញ្ចុកមាត់ខ្លួនផង[ក] ។

[២៥]ចូរវាយមនុស្សចំអកមើលងាយ នោះមនុស្សខ្លៅល្ងង់នឹងចេះប្រយ័ត្នឡើង ចូរបន្ទោសដល់អ្នកណាដែលមានយោបល់[ខ] អ្នកនោះនឹងស្ដាប់បានតាមលំអាន[គ] ។

[២៦]អ្នកណាដែលបំផ្លាញឪពុកខ្លួន ហើយបណ្ដេញម្ដាយ[ឃ]ចេញ នោះជាកូនដែលនាំឱ្យមានសេចក្ដីខ្មាស និងសេចក្ដីដំនៀល ។

[២៧]កូនអើយ[ង] ចូរលែងស្ដាប់តាមសេចក្ដីដំបូន្មានដែលនាំឱ្យវង្វេងពីផ្លូវនៃដំរិះចេញ ។

[២៨]សាក្សីកោងកាចគេចំអកមើលងាយចំពោះសេចក្ដីយុត្តិធម៌ ហើយមាត់របស់មនុស្សអាក្រក់ក៏ត្របាក់លេបអំពើទុច្ចរិតដែរ[ច] ។

[២៩]សេចក្ដីវិនិច្ឆ័យបានបំរុងជាស្រេច សំរាប់មនុស្សចំអក ហើយការវាយដោយរំពាត់ ក៏សំរាប់ខ្នងនៃមនុស្សល្ងីល្ងើ[ឆ] ។

**២០** [១]ឯស្រាទំពាំងបាយជូរ[ក]ជារបស់បញ្ឆោតមើលងាយ[ខ] ហើយគ្រឿងស្រវឹងបង្កើតការឡូឡា អ្នកណាដែលវង្វេង[គ]ដោយគ្រឿងទាំង២នោះ ឈ្មោះថាគ្មានប្រាជ្ញា[ឃ] ។

[២]សេចក្ដីស្ញែងខ្លាចរបស់ស្ដេច នោះប្រៀបដូចជាសំឡេងគ្រហឹមនៃសិង្ហ[ង] អ្នកណាដែលបណ្ដាលឱ្យទ្រង់ខ្ញាល់ឡើង នោះឈ្មោះថាធ្វើបាបដល់ជីវិតខ្លួនហើយ[ច] ។

[៣]អ្នកណាដែលមិនព្រមបៀតខ្លួន ក្នុងការឈ្លោះប្រកែកគ្នា នោះជាកិត្តិសព្ទដល់ខ្លួនហើយ ប៉ុន្តែគ្រប់ទាំងមនុស្សល្ងីល្ងើ[ឆ]គេចេះតែរករឿងវិញ[ជ] ។

[៤]មនុស្សខ្ជិលច្រអូស[ឈ]មិនព្រមភ្ជួររាស់ ដោយព្រោះនៅរងានៅឡើយ ដូច្នេះ គេនឹងត្រូវសុំទានក្នុងរដូវចំរូត ហើយខ្វះខាតវិញ[ញ] ។

[៥]សេចក្ដីដំបូន្មាននៅក្នុងចិត្តមនុស្ស នោះធៀបដូចជាអណ្ដូងដ៏ជ្រៅ[ដ] តែមនុស្សដែលមានយោបល់ គេនឹងដងឡើងបាន ។

[៦]មនុស្សស្ទើរតែទាំងអស់ សុទ្ធតែជាអ្នកប្រកាសគុណរបស់ខ្លួន តើអ្នកណានឹងរកមនុស្សទៀងត្រង់ សូម្បីតែម្នាក់

**១៩:២៣** អ យប ៤:៧ សភ ១០:២៧
**១៩:២៤** ក សភ ២៦:១៥
**១៩:២៥** ខ ទដ ១៤:១៥ គ សភ ៩:៩ ២១:១១
**១៩:២៦** ឃ សភ ២៨:២៤
**១៩:២៧** ង សភ ១:៨
**១៩:២៨** ច យប ១៥:១៦
**១៩:២៩** ឆ ចទ ២៥:២
**២០:១** ក លវ ១០:៩ ហប ២:៥ ខ ១សយ ២៥:៣៦ គ ១ពវ ២០:១៦ ឃ សភ ៣១:៤
**២០:២** ង សភ ១៩:១២ ច នអ ៧:៧ សភ ១៦:១៤
**២០:៣** ឆ ១សយ ២៥:២៥ ជ លប ១៣:៨
**២០:៤** ឈ សភ ៦:៦ ញ សស ១០:១៨ **២០:៥** ដ ទដ ១៨:១៦

**១៩:២៣** *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើលការពន្យល់ ១:៧ *ឱ្យមានជីវិត* សូមមើលការពន្យល់ ១០:១១ ។ *ឥតមានសេចក្ដីអាក្រក់ណាមកលើខ្លួនឡើយ* សូមមើល ៣:២ ១៤:២៦ និងការពន្យល់ ។

**១៩:២៤** មានបញ្ជាក់ក្នុង ២៦:១៥ ។ *មនុស្សខ្ជិលច្រអូស* សូមមើលការពន្យល់ ៦:៦ ។

**១៩:២៥** *ចូរវាយមនុស្សចំអកមើលងាយ* សូមមើល ឧ.២៩ ១៤:៣ ២១:១១ ក៏សូមមើលការពន្យល់ ១:២៧ ១៧:១០ ២១:២៤ ។ *មនុស្សខ្លៅល្ងង់* សូមកុំច្រឡំនឹងមនុស្សចំអក (សូមមើលការពន្យល់ ១:៤) ។

**១៩:២៦** *បំផ្លាញឪពុកខ្លួន ហើយបណ្ដេញម្ដាយចេញ* គឺគេគ្រប់ប្រាណសង្ឃឹមថានឹងថែរក្សាដល់ឪពុកម្ដាយ នៅពេលដែលពួកគាត់ចាស់ទៅ ឬពេលមានជម្ងឺ ។ (ប្រៀបធៀប អស ៥១:១៨) ។ ឯកូនណាដែលប្រឆាំង ឬធ្វើបាបដល់ឪពុកម្ដាយ គឺត្រូវកំចាត់ព្រាត់ ឬសម្លាប់វិញ (នក ២១:១៥,១៧) ក៏មានឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ (សូមមើលការពន្យល់ នក ២១:១៧)។ *នាំឱ្យមានសេចក្ដីខ្មាស និងសេចក្ដីដំនៀល* សូមមើល ១០:៥ ១៣:៥ ។

**១៩:២៧** សូមមើល ៥:១-២ ។

**១៩:២៨** *សាក្សីកោងកាច* សូមមើល ការពន្យល់ ៦:១៩ ។ *ត្របាក់លេបអំពើទុច្ចរិត* សូមប្រៀបធៀប ចំពោះអ្នកណាម្នាក់បានយកការអាក្រក់មកដាក់ក្នុងខ្លួន ក៏ដូចជាការផឹកការអាក្រក់នោះប្រៀបដូចជាយកទង្វើរបស់អារក្សមកដាក់ក្នុងខ្លួនដែរ ឯការអាក្រក់នោះគឺប្រៀបធៀបនឹងទឹក (យប ១៥:១៦ សូមមើល យប ៣៤:៧) ។

**១៩:២៩** *សេចក្ដីវិនិច្ឆ័យបានបំរុងជាស្រេចសំរាប់មនុស្សចំអក* សូមមើល ឧ.២៥ ។ *ការវាយដោយរំពាត់ក៏សំរាប់ខ្នងនៃមនុស្សល្ងីល្ងើ* សូមមើល ១០:១៣ ១៤:៣ ២៦:៣ ។

**២០:១** *ឯស្រាទំពាំងបាយជូរ ជារបស់បញ្ឆោតមើលងាយ . . . គ្រឿងស្រវឹងបង្កើតការឡូឡា* គឺពួកអ្នកដែលធ្វើអ្វីទៅតាមចិត្តរបស់ខ្លួនហើយក៏ក្លាយជាមនុស្សបញ្ឆោតមើលងាយ និងជាអ្នកបង្កើតការឡូឡា (សូមមើល ហស ៧:៥ និងការពន្យល់) ។ ពាក្យសុភាសិតនេះមានទំនាក់ទំនងនឹងភាពស្រវឹងស្រា ដែលមានភាពក្រីក្រទុរភិក្ស(សូមមើល ២៣:២០-២១ និងការពន្យល់) សេចក្ដីតស៊ូពីភាពវេទនាក្នុងជីវិត (២៣:២៩-៣០) និងពុំមានភាពយុត្តិធម៌ (៣១:៤-៥) ។ *អ្នកណាដែលវង្វេង* សូមមើល លប ៩:២១ និងការពន្យល់ អស ២៨:៧ ។

**២០:២** សូមមើល ១៦:១៤ ១៩:១២ និងការពន្យល់ ។

**២០:៣** *ចេះតែរករឿងវិញ* សូមមើល ៦:១៤ ១៧:១៤,១៩ ១៨:៦ ។

**២០:៤** *មនុស្សខ្ជិលច្រអូស* សូមមើលការពន្យល់ ៦:៦ ។ *ហើយខ្វះខាតវិញ* សូមមើល ១៣:៤ ២១:២៥-២៦ ។

**២០:៥** *សេចក្ដីដំបូន្មាន* ឬជាការ "លើកទឹកចិត្ត" ដែលជិរុញ (ប្រៀបធៀប ១៦:១-២) ។ *អណ្ដូងដ៏ជ្រៅ* ប្រៀបធៀប ១៨:៤ ។ *គេនឹងដងឡើងបាន* គឺដូចជាដងពីអណ្ដូងទឹកអញ្ចឹងដែរ ។

**២០:៦** គឺជាសេចក្ដីស្រឡាញ់ដែលមនុស្សបានប្រកាស តែសេចក្ដីស្រឡាញ់ពិតនោះពិបាកនឹងរកណាស់ ។

បាន[ឋ] ។
៧មនុស្សសុចរិត គេដើរតាមផ្លូវទៀងត្រង់របស់ខ្លួន[ឌ]
កូនចៅរបស់អ្នកនោះ មានពរតរៀងទៅ[ឍ] ។
៨កាលណាស្តេចឡើងគង់នៅទីវិនិច្ឆ័យ[ណ] នោះទ្រង់ក៏
បាត់អស់ទាំងអំពើអាក្រក់ ដោយសារព្រះនេត្រទ្រង់[ត] ។
៩តើអ្នកណាអាចនឹងនិយាយបានថា ខ្ញុំបានជំរះចិត្តខ្ញុំឱ្យ
ស្អាត[ថ] ខ្ញុំបានបរិសុទ្ធរួចពីបាបរបស់ខ្ញុំហើយ[ទ] ។
១០កូនជញ្ជីងឆផ្សេងៗ ហើយរង្វាល់កោងផ្សេងៗទាំង២
យ៉ាងនោះជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា[ធ] ។
១១សូម្បីតែកូនក្មេងក៏សំដែងខ្លួន ដោយសារកិរិយា
ប្រព្រឹត្តរបស់វាដែរ ឱ្យដឹងជាកិរិយានោះបរិសុទ្ធ[ន] ហើយ
ត្រឹមត្រូវឬយ៉ាងណា ។
១២ការស្តាប់ឮដោយត្រចៀក ហើយមើលឃើញដោយ
ភ្នែក នោះគឺព្រះយេហូវ៉ាដែលបង្កើតទាំង២យ៉ាង[ប] ។
១៣កុំឱ្យល្មោភដេក ក្រែងលោត្រឡប់ជាទាល់ក្រ[ផ] ចូរ
បើកភ្នែកឡើង នោះនឹងបានអាហារឆ្អែត ។
១៤អ្នកដែលទិញរមែងថា របស់នោះអាក្រក់ អាក្រក់
ណាស់ តែកាលណាដើរហួសទៅ នោះក៏អួតខ្លួនវិញ ។
១៥មាស ហើយត្បូងទទឹមមានជាបរិបូរ តែបបូរមាត់
ដែលប្រកបដោយចំណេះ នោះជាត្បូងមានដំឡៃយ៉ាង
ប្រសើរវិញ ។
១៦ចូរទទួលបញ្ចាំអាវរបស់អ្នក ដែលធានាឱ្យមនុស្ស
ដទៃ ហើយទាររបស់បញ្ចាំពីអ្នកសន្យា[ព]ជំនួសអ្នកក្រៅ
ចុះ[ភ] ។
១៧អាហារដែលមនុស្សណាបាន ដោយការកំភូតនោះ
រមែងឆ្ងាញ់ដល់ខ្លួន[ម] តែក្រោយមក មាត់មានពេញទៅ
ដោយក្រួសវិញ[យ] ។
១៨អស់ទាំងគំនិតដែលចង់ធ្វើ នោះបានសំរេចមែន
ទែន ដោយសារការប្រឹក្សាគ្នា ហើយបើមានអ្នកជួយគំនិត
ដោយប្រាជ្ញា នោះសឹមធ្វើសង្គ្រាមទៅចុះ[រ] ។
១៩អ្នកណាដែលដើរចុះឡើងនិយាយដើមគេ នោះជា
អ្នកបើកសំដែងការលាក់កំបាំងហើយ[ល] ដូច្នេះ កុំឱ្យភប់
ប្រសព្វនឹងអ្នកណាដែលមានមាត់បាចរហាចឡើយ ។
២០អ្នកណាដែលប្រទេចផ្តាសាឪពុកម្តាយ[វ] ចង្កៀងរបស់
អ្នកនោះនឹងត្រូវពន្លត់នៅក្នុងទីងងឹតសូន្យសុង[ស] ។
២១ឯមរដក ដែលដើមដំបូងបានយ៉ាងរួសរាន់ នោះ
ដល់ចុងក្រោយមិនបានពរទេ ។
២២កុំឱ្យថា អញនឹងសងសឹក នោះឡើយ[ហ] ចូររង់ចាំព្រះ
យេហូវ៉ាចុះ ទ្រង់នឹងជួយសង្គ្រោះឯងវិញ[ឡ] ។

**២០:៦** ឋ ទដ ១២:១
**២០:៧** ឌ ទដ ២៦:១ ឍ ទដ ៣៧:២៥–២៦ ១១២:២
**២០:៨** ណ ១ពវ ៧:៧ ត ខ.២៦ សភ ២៥:៤–៥
**២០:៩** ថ យប ១៥:១៤ ទ ១ពវ ៨:៤៦
**២០:១០** ធ ខ.២៣ សភ ១១:១
**២០:១១** ន ទដ ៣៩:១
**២០:១២** ប ទដ ៩៤:៩
**២០:១៣** ផ សភ ៦:១១ ១៩:១៥
**២០:១៦** ព នក ២២:២៦ ភ សភ ២៧:១៣
**២០:១៧** ម ទដ ៩:១៧ យ យប ២០:១៤ បទ ៣:១៦
**២០:១៨** រ សភ ១១:១៤ ២៤:៦
**២០:១៩** ល សភ ១១:១៣
**២០:២០** វ សភ ៣០:១១ ស នក ២១:១៧ យប ១៨:៥
**២០:២២** ហ សភ ២៤:២៩ ឡ អស ៣៧:២០ យរ ១:១៩ ៤២:១១ រម ១២:១៩

**២០:៧** *មនុស្សសុចរិត* សូមមើលការពន្យល់ ២:៧ ។ *កូនចៅរបស់អ្នកនោះ មានពរតរៀងទៅ* សូមមើល ១៣:២២ ក៏សូមមើលការពន្យល់ ១៤:២៦ ។

**២០:៨** សូមមើល ខ.២៦ និងការពន្យល់ ។ *កំចាត់អស់ទាំងអំពើអាក្រក់* សូមមើល ១៦:១០ ទដ ១១:៤ ។

**២០:៩** *ស្អាតខ្ញុំបានបរិសុទ្ធរួចពីបាប* តែគ្មានអ្នកណាម្នាក់ដែលគ្មានបាបទេ (ប្រៀបធៀប យប ១៤:៤ រម ៣:២៣) តែអ្នកមានបាបនោះក៏លើកលែងទោសឱ្យបាន"សម្អាតដៃនឹងសម្អាតចិត្តជាថ្មី" (ទដ ២៤:៤ មើល ៥១:១–២, ៩–១០) ។

**២០:១០** សូមមើលការពន្យល់ ១១:១ ប្រៀបធៀប ១៦:១១ ។

**២០:១២** សូមមើល នក ៤:១១ ទដ ៩៤:៨–៩ ។

**២០:១៣** *កុំឱ្យល្មោភដេក ក្រែងលោត្រឡប់ជាទាល់ក្រ* សូមមើល ២៤:៣៣–៣៤ ។

**២០:១៤** *របស់នេះអាក្រក់ អាក្រក់ណាស់* គឺតម្លៃនោះវាអាស្រ័យទៅលើការតវ៉ា ឬតថ្លៃទំនិញ គឺអ្នកទិញចង់បានតម្លៃថោក ។

**២០:១៥** *មាសហើយត្បូងទទឹមមានជាបរិបូរ តែបបូរមាត់ដែលប្រកបដោយចំណេះ* គឺចំណេះប្រាជ្ញាប្រសើរជាងមាសពេជ្រ ឬត្បូងមានតម្លៃ (៣:១៤–១៥ ៨:១០–១១) ។

**២០:១៦** ខនេះក៏បានរំឭកក្នុង ២៧:១៣ សូមមើលការពន្យល់ ៦:១ ។ *ចូរទទួលបញ្ចាំអាវរបស់អ្នក* ឯអាវនោះអាចធានាសុវត្ថិភាព ចំពោះសេចក្តីស្លាប់ (ចទ ២៤:១០–១៣) ។

**២០:១៧** *នោះរមែងឆ្ងាញ់ដល់ខ្លួន* ប្រៀបធៀបនឹងអាហារដែលឆ្ងាញ់ដែលរៀបចំដោយអ្នកកំជឹតក្បត់ មើលក្នុង ៩:១៧ ។ ចំណែកនាងសូផាក៏បានសម្គាល់ថា កិច្ចការអាក្រក់វាមានលក្ខណៈផ្អែមល្ហែមនៅក្នុងមនុស្សអាក្រក់ តែវាបែរជាល្វីងជូរវិញនៅក្នុងក្រពះរបស់ពួកគេ (យប ២០:១២–១៨) សូមមើលការពន្យល់ ១០:២ ។

**២០:១៨** *គំនិត . . . ការប្រឹក្សា* សូមមើល ១៥:២២ លក ១៤:៣១ ។

**២០:២០** *ប្រទេចផ្តាសាឪពុកម្តាយ* គឺអស់អ្នកដែលប្រទេចផ្តាសាដល់ឪពុកម្តាយ ក៏ត្រូវទណ្ឌកម្មដល់ជីវិតដែរ គឺសេចក្តីស្លាប់ (សូមមើល នក ២១:១៧ និងការពន្យល់ លវ ២០:៩ ធៀបនឹង សភ ៣០:១១,១៧) ។ *ចង្កៀងរបស់អ្នកនោះនឹងត្រូវពន្លត់ទៅ* គឺជាជីវិតរបស់គេត្រូវស្លាប់ទៅ (សូមមើលការពន្យល់ ១៣:៩) ។

**២០:២១** *ឯមរដកដែលដើមដំបូងបានយ៉ាងរួសរាន់ នោះដល់ចុងក្រោយមិនបានពរទេ* ប្រៀបធៀប ១៩:២៦ សូមមើលរឿងដែលជាបទពិសោធន៍ដ៏ជូរចត់មួយរបស់កូនប្រុសម្នាក់ ដែលបានចាយវាយបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួនអស់ និងទទួលបាននូវភាពវេទនាមកដល់ជីវិតខ្លួនវិញ (សូមមើល លក ១៥:១២–១៣ និងកាពន្យល់) ។

**២០:២២** *អញនឹងសងសឹក* សម្រាប់ការសងសឹកនោះ គឺវាជាបុព្វសិទ្ធរបស់ព្រះ ក៏មិនមែនសិទ្ធនៅលើមនុស្សដែរ ។ ទ្រង់នឹងធ្វើការងារនោះចំពោះ

២៣ កូនជញ្ជីងឆផ្សេងៗ ជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា
ហើយត្រាជូក្លែង នោះមិនល្អទេ[អ]។
២៤ ផ្លូវដើររបស់មនុស្ស នោះស្រេចនៅ[ក]ព្រះយេហូវ៉ា[ខ]
ដូច្នេះ ធ្វើដូចម្តេចឱ្យមនុស្សយល់ផ្លូវខ្លួនបាន[គ]។
២៥ ការដែលនិយាយឥតបើគិតថា នេះជាដង្វាយថ្វាយ
ព្រះហើយ រួចកាលណាបានបន់ព្រះហើយ ទើបស៊ើបសួរ
ជាខាងក្រោយ នោះជាអន្ទាក់ដល់មនុស្សហើយ[ឃ]។
២៦ ស្តេចដែលមានប្រាជ្ញា ទ្រង់កំចាត់មនុស្សអាក្រក់
ចេញ ហើយឱ្យកង់បញ្ជាន់ស្រូវកិនលើគេ[ង]។
២៧ វិញ្ញាណរបស់មនុស្សជាចង្កៀងនៃព្រះយេហូវ៉ា[ច] ក៏
ស្ទង់មើលទៅគ្រប់ក្នុងចំណែកនៃរាងកាយ[ឆ]។
២៨ សេចក្តីមេត្តា និងសេចក្តីទៀងត្រង់ រមែងការពារ
ស្តេច ហើយបល្ល័ង្ករាជ្យទ្រង់ក៏ស្ថិតនៅ ដោយសារសេចក្តី
សប្បុរស[ជ]ដែរ[ឈ]។
២៩ កំឡាំងកាយ ជាសេចក្តីអំនួតរបស់មនុស្សកំឡោះ
ហើយសក់ស្កូវជាគ្រឿងលំអដល់មនុស្សចាស់[ញ]។
៣០ ការវាយដោយរំពាត់ឱ្យត្រូវរបួស នោះនឹងសំអាត[ដ]
អំពើអាក្រក់ចេញ ហើយការវាយ[ឋ]ដោយដំបង ក៏នឹងចូល
ទៅដល់ខាងក្នុងខ្លួនដែរ ។

**២១** ១ ព្រះទ័យនៃស្តេចនោះនៅក្នុងព្រះហស្តព្រះយេហូវ៉ា
ដូចជាផ្លូវនៃទឹកហូរទាំងឡាយ ទ្រង់ឱ្យបែរហូរទៅខាងណា
ក៏តាមតែព្រះហឫទ័យ[ក]។
២ គ្រប់ទាំងផ្លូវរបស់មនុស្ស សុទ្ធតែត្រឹមត្រូវនៅភ្នែក ខ្លួន
តែព្រះយេហូវ៉ាទ្រង់ថ្លឹងចិត្តវិញ[ខ]។
៣ ការដែលប្រព្រឹត្តតាមសេចក្តីសុចរិត និងសេចក្តី
យុត្តិធម៌ នោះជាទីគាប់ព្រះហឫទ័យដល់ព្រះយេហូវ៉ា ជា
ជាងយញ្ញបូជាទៅទៀត[គ]។
៤ ឫក[ឃ]ខ្ពស់នឹងចិត្តអំនួត គឺចង្កៀងរបស់មនុស្សអាក្រក់
នោះហៅថាជាអំពើបាបទាំងអស់ ។
៥ គំនិតរបស់មនុស្សឧស្សាហ៍ នោះនាំឱ្យបានបរិបូរ[ង]
ឡើងតែម្យ៉ាង តែអស់អ្នកណាដែលមានចិត្តរលះរលាំង

**២០:២៣** អ ខ.១០ ចទ ២៥:១៣ **២០:២៤** ក ទដ ៩០:១២ ខ យប ៣៣:២៩ គ សភ ១៩:២១ យរ ១០:២៣ **២០:២៥** ឃ សភ ១០:១៩ ១៨:១៣ សស ៥:២,៤–៥ យរ ៤៤:២៥ **២០:២៦** ង ខ.៨ **២០:២៧** ច ទដ ១១៩:១០៥ ឆ សភ ១៦:២ **២០:២៨** ជ ទដ ៤០:១១ ឈ ១៦:១២ អស ១៦:៥ **២០:២៩** ញ សភ ៤០:១១ **២០:៣០** ដ ទដ ៥១:២ សភ ២២:១៥

ឋ អស ១:៥ **២១:១** ក នអ ៥:១ យរ ៣៩:១១–១២ **២១:២** ខ សភ ១៦:២ **២១:៣** គ ១សយ ១៥:២២ អស ១:១១ **២១:៤** ឃ យប ៤១:៣៤ **២១:៥** ង សភ ១០:៤

មនុស្សអាក្រក់នូវរាល់ទង្វើរបស់គេ (សូមមើល ២៤:១២,២៩ ចទ ៣២:៣៥ ទដ ៩៤:១ និងការពន្យល់) ។ *រង់ចាំព្រះយេហូវ៉ាចុះ* សូមមើល ទដ ២៧:១៤ និងការពន្យល់ ៣៧:៣៤ ។

**២០:២៤** សូមមើល ខ.១០ និងកាពន្យល់ ។

**២០:២៥** ខនេះបង្ហាញពីនិស្ស័យរបស់មនុស្ស ដែលសន្យាជាមួយព្រះដោយថ្វាយដង្វាយ បើសិនជាព្រះប្រទានពរឱ្យពួកគេ (សូមមើល លវ ២៧:១–២៥ ១សយ ១:១១) ។ សូមមើល ចទ ២៣:២១ ចទ ១១:៣០–៣១,៣៤–៤៥ និងការពន្យល់ ។ ខណៈពេលពាក្យសច្ចាស្បថ ប្រញាប់នឹងស្បថពេក នោះពេលខ្លះមិនបានគោរពតាមសេចក្តីសម្បថនោះទេ ។ (ប្រៀបធៀបនឹង សស ៥:៤–៦) ។

**២០:២៦** សូមមើល ខ.៨ ។ *កំចាត់* សូមមើលការពន្យល់ នរ ១:២២ ។ *កង់បញ្ជាន់ស្រូវកិន* គឺដើម្បីញែក ឫសិតអង្កាមចេញពីស្រូវដើម្បីបានអង្ករ (ប្រៀបធៀប អស ២៨:២៧–២៨) ។ ឯការអាក្រក់ក៏ត្រូវញែកចេញពីភាពសុចរិតនឹងត្រូវដាក់ទណ្ឌកម្មជាកំណត់ ។

**២០:២៧** *ចង្កៀងនៃព្រះយេហូវ៉ា* គឺជាព្រះនេត្រនៃទ្រង់ (ប្រៀបធៀប ៥:២១ ១៥:៣ ២១:៤ និងការពន្យល់) ឬក៏ជាព្រះបន្ទូល (សូមមើល ៦:២៣ និងការពន្យល់ ធៀបនឹង ហព ៤:១២–១៣ និងការពន្យល់) ។ សូមមើលការពន្យល់ ១៥:១១ ។

**២០:២៨** *សេចក្តីមេត្តា និងសេចក្តីទៀងត្រង់* សូមមើល ៣:៣ ១៤:២២ ទដ ១៤:២២ ទដ ២៦:៣ និងការពន្យល់ ។ *ការពារស្តេចហើយបល្ល័ង្ករាជ្យទ្រង់ក៏ស្ថិតនៅ* គឺជាភាពមានចិត្ត មេត្តាសប្បុរស មានសេចក្តីស្រឡាញ់ដល់មនុស្សក៏លើកទឹកចិត្តដល់ពួកគេ ឱ្យប្រកាន់នៅភាពស្មោះត្រង់ (ប្រៀបធៀប ១៦:១២ និងការពន្យល់) ។

**២០:២៩** *កំលាំងកាយ* ប្រៀបធៀប យរ ៩:២៣ ។ *សក់ស្កូវជាគ្រឿងលំអដល់មនុស្សចាស់* សូមមើលការពន្យល់ ។

**២០:៣០** *ការវាយដោយរំពាត់ឱ្យត្រូវរបួស នោះក៏សំអាតអំពើអាក្រក់ចេញ* ការដាក់ទណ្ឌកម្មជាការសំខាន់ណាស់ ដើម្បីកំចាត់អំពើអាក្រក់ចេញដូចជាក្នុងព្រះគម្ពីរសុភាសិត គឺមនុស្សល្ងីល្ងើត្រូវបានវាយដោយរំពាត់លើខ្នង (១០:១៣ ១៤:៣ ១៩:១៩ ២៦:៣) គឺដោយគេជាមនុស្សឆ្កួត គេពុំបានផ្លាស់ប្តូរផ្លូវជីវិតរបស់គេទេ (ប្រៀបធៀប ១៧:១០ សូមមើល ២៧:២២ និងការពន្យល់) ។

**២១:១** *ព្រះទ័យនៃស្តេច នោះនៅក្នុងព្រះហស្តព្រះយេហូវ៉ា* ដោយការគ្រប់គ្រងរបស់ទ្រង់ បានគ្រប់គ្រងជីវិតនឹងគ្រប់សកម្មភាពរបស់ស្តេចទាំងនោះ ដូចជាស្តេចនេប៊ូក្នេសា (ដយ ៤:៣១–៣២,៣៥) និងស៊ើរូស (មើល អស ៤៥:១–៧ ធៀបនឹង អគ ៦:២២ រម ១៣:១–៦ និងការពន្យល់) ។ *ទ្រង់ឱ្យបែរហូរទៅ* សូមមើល ១៦:១,៤,៩ និងការពន្យល់ ។

**២១:២** *សុទ្ធតែត្រឹមត្រូវ* សូមមើល ១៤:១២ ១៦:២ ។ *ទ្រង់ថ្លឹងចិត្ត* សូមមើល ១៦:២ ២៤:១២ យប ៣១:៦ និងការពន្យល់ ។ ឯសាសន៍អេស៊ីព្ទពីបូរាណបានគូសពីផ្ទាំងគំនូរបង្ហាញពីការពណ៌នារបស់ព្រះអាទិទេព ដែលបានថ្លឹងចិត្តមនុស្សហើយពីអំពើបាបរបស់ពួកគេ ។

**១២:៣** *តាមសេចក្តីសុចរិត និងសេចក្តីយុត្តិធម៌* សូមមើលការពន្យល់ ទដ ១១៩:១២១ ។ *នោះជាទីគាប់ព្រះហឫទ័យដល់ព្រះយេហូវ៉ាជាជាងយញ្ញបូជាទៅទៀត* អត្ថន័យនេះក៏ឃើញមានក្នុងគម្ពីររបស់ពួកហោរាផងដែរ (សូមមើល អស ១:១១–១៥ និងការពន្យល់) សូមមើល ខ.២៧ ក៏សូមមើលការពន្យល់ ១៥:៨ ។

**២១:៤** *ឫកខ្ពស់* សូមមើលការពន្យល់ ៦:១៧ ។ *ចិត្តអំនួត* មើល ១៦:៥,៨ ។ *ចង្កៀង* គឺជាភ្នែក (សូមមើល ២០:២៧ និងការពន្យល់ លក ១១:៣៤) ។

**២១:៥** *គំនិតរបស់មនុស្សឧស្សាហ៍នោះនាំឱ្យបានបរិបូរ* សូមមើលការ

នោះនឹងបានតែសេចក្ដីខ្វះខាតវិញ ។
៦ការដែលប្រមូលទ្រព្យសម្បត្តិ ដោយសារអណ្ដាត
ភូតភរ នោះជាចំហាយទឹកទទេ ដែលផាត់ទៅមក ដោយ
ពួកអ្នកដែលរកស្លាប់[ច]។
៧សេចក្ដីច្រឡោតរបស់មនុស្សអាក្រក់នឹងបោសខ្លួន
គេចេញទៅ[ឆ] ដោយព្រោះគេមិនព្រមប្រព្រឹត្តតាមសេចក្ដី
យុត្តិធម៌សោះ ។
៨ផ្លូវរបស់មនុស្សណា ដែលផ្ទុកដោយទោសច្រើន នោះ
ជាផ្លូវវៀចណាស់[ជ] តែចំណែកមនុស្សសុចរិតវិញ ការ
ដែលគេប្រព្រឹត្តសុទ្ធតែទៀងត្រង់ ។
៩ស៊ូនៅក្នុងទីកៀន១នៅលើដំបូលផ្ទះ ជាជាងនៅក្នុង
ផ្ទះធំទូលាយ ជាមួយនឹងស្ត្រីដែលចេះតែរករឿងវិញ[ឈ]។
១០ព្រលឹងនៃមនុស្សអាក្រក់ប្រាថ្នាតែការអាក្រក់ ទោះ
ទាំងអ្នកជិតខាងក៏មិនប្រកបដោយគុណអ្នកនោះដែរ ។
១១កាលមនុស្សចំអកមើលងាយ ត្រូវទោសហើយ នោះ
មនុស្សខ្លៅល្ងង់ក៏មានប្រាជ្ញាឡើង ហើយកាលណាមនុស្ស
មានប្រាជ្ញាបានទទួលសេចក្ដីប្រៀនប្រដៅ នោះក៏មាន
ចំណេះឡើងដែរ[ញ]។
១២មនុស្សសុចរិតរមែងពិចារណាមើលវង្សនៃមនុស្ស
អាក្រក់ ឃើញថា គេត្រូវរំលំឱ្យវិនាសបាត់ទៅ[ដ]។
១៣អ្នកណាដែលចុកត្រចៀកមិនស្ដាប់ពាក្យអំពាវនាវ
របស់មនុស្សទាល់ក្រ អ្នកនោះឯងនឹងត្រូវអំពាវនាវ[ឋ]ដែរ
តែមិនមានអ្នកណាស្ដាប់ឡើយ[ឌ]។
១៤អំណោយដែលឱ្យដោយស្ងាត់កំបាំង នោះរមែង
រំងាប់សេចក្ដីកំហឹង ហើយជំនូនដែលជូនដោយលួចលាក់
ក៏បំបាត់សេចក្ដីឃោរឃៅដែរ[ឍ]។
១៥ការដែលប្រព្រឹត្តដោយយុត្តិធម៌ នោះជាសេចក្ដី
អំណរដល់មនុស្សសុចរិត តែនោះជាសេចក្ដីវិនាសដល់
មនុស្សដែលប្រព្រឹត្តទុច្ចរិតវិញ[ណ]។
១៦មនុស្សណាដែលវង្វេងចេញពីផ្លូវនៃប្រាជ្ញា នោះ
នឹងសំរាកនៅក្នុងចំណោមមនុស្សស្លាប់ហើយ[ត]។
១៧ឯអ្នកណា ដែលចូលចិត្តតែនឹងការលេងសប្បាយ
នោះនឹងត្រូវជាមនុស្សទាល់ក្រទៅ អ្នកណាដែលចូលចិត្ត
តែស្រា ហើយនឹងប្រេង នោះមិនដែលទៅជាអ្នកមានទេ[ថ]។
១៨មនុស្សអាក្រក់គេសំរាប់ជាថ្លៃលោះ[ទ] មនុស្សសុចរិត
ហើយមនុស្សក្បត់ក៏ជំនួសមនុស្សទៀងត្រង់ដែរ ។
១៩ស៊ូអាស្រ័យនៅក្នុងទីសូន្យស្ងាត់ ជាជាងនៅជាមួយ
នឹងស្ត្រីដែលចេះតែរករឿង ហើយអុចអាលវិញ[ធ]។

**២១:៦** ច សភ ១០:២
**២១:៧** ឆ សភ ១១:៥
**២១:៨** ជ សភ ២:១៥
**២១:៩** ឈ ខ.១៩ សភ ១៩:១៣ ២៥:២៤
**២១:១១** ញ សភ ១៩:២៥
**២១:១២** ដ សភ ១៤:១១
**២១:១៣** ឋ នក ១១:៦ ឌ យប ២៩:១២
**២១:១៤** ឍ លប ៣២:២០
**២១:១៥** ណ សភ ១០:២៩
**២១:១៦** ត អគ ១៨:២៤
**២១:១៧** ថ សភ ២៣:២០–២១, ២៩–៣៥
**២១:១៨** ទ សភ ១១:៨ អស ៤៣:៣
**២១:១៩** ធ ខ.៩

ពន្យល់ ១០:៤ ។ *ចិត្តរលះរលាំង* ដូចជាទង្វើរលះរលាំង ដែលធ្វើអ្វីទាំងតក់ក្រហល់ (សូមមើល ១៩:២ និងការពន្យល់) ឬជាការប៉ងប្រាថ្នាខាងឯសាច់ឈាម ដើម្បីទទួលកំរៃខ្ពស់ឬក្លាយជាអ្នកមានសម្បត្តិស្ដុកស្ដម្ភយ៉ាងឆាប់ (សូមមើល ១៣:១១ និងការពន្យល់ ២០:២១ ២៨:២០) ។

**២១:៦** *ប្រមូលទ្រព្យសម្បត្តិ ដោយសារអណ្ដាតភូតភរ* សូមមើលការពន្យល់ ១០:២ ប្រៀបធៀប ១៩:១ ។ *នោះជាចំហាយទឹកទទេ* សូមមើល ១៣:១១ សស ១:១៤ និងការពន្យល់ ។ *ពួកអ្នកដែលរកស្លាប់* ប្រៀបធៀប ៥:២២ ៧:២៣ ។

**២១:៧** *សេចក្ដីច្រឡោតរបស់មនុស្សអាក្រក់ នឹងបោកខ្លួនគេចេញទៅ* សូមមើល ១:១៨–១៩ និងការពន្យល់ ។

**២១:៩** ខនេះក៏មានបញ្ជាក់នៅក្នុង ២៥:២៤ ។ *ទីកៀន១នៅលើដំបូលផ្ទះ* គឺជាដំបូលដែលមានរាង្គសំប៉ែត មានរាង្គជាបន្ទប់តូចមួយ ដែលគេអាចរៀបដាក់របស់របរនៅលើនោះ (សូមមើល ២ពវ ៤:១០) ។ *ស្ត្រីដែលចេះតែរករឿងវិញ* សូមមើល ១៩:១៣ និងការពន្យល់ ។

**២១:១០** *ប្រាថ្នាតែការអាក្រក់* សូមមើល ៤:១៦ ១០:២៣ ។ *អ្នកជិតខាងក៏មិនប្រកបដោយគុណ* ប្រៀបធៀបនឹង ១៤:២១ ។

**២១:១១** សូមមើល ១៩:២៥ និងការពន្យល់ ។

**២១:១២** ប្រៀបធៀប យប ៣៤:១៧ ។ *វង្សនៃមនុស្សអាក្រក់ ឃើញថា គេត្រូវរំលំវិនាសបាត់ទៅ* សូមមើល ១០:២៥ និងការពន្យល់ ១៤:១១ ។

**២១:១៣** *ពាក្យអំពាវនាវរបស់មនុស្សទាល់ក្រ* សូមមើល ១៤:២១ សូមមើល ២៨:២៧ ។ *អ្នកនោះឯងនឹងត្រូវអំពាវនាវដែរ តែមិនមានអ្នកណាស្ដាប់ឡើយ* សូមមើលការពន្យល់ ១:២៨ ធៀបនឹងមនុស្សអ្នកមានដ៏ធាត់ម្នាក់ (លក ១៦:១៩–៣១) និងបាវដែលគ្មានចិត្តមេត្តា (មថ ១៨:២៣–៣៥) ដែលផ្ទុយនឹង ទដ ១១៨:៥ (សូមមើលការពន្យល់នៅទីនោះ) ។

**២១:១៤** *អំណោយ . . . ជំនូន* មើលការពន្យល់ ១៧:៨ ១៨:១៦ ១៩:៦ ។ *រំងាប់សេចក្ដីកំហឹង . . . ក៏បំបាត់សេចក្ដីឃោរឃៅដែរ* (មើល ៦:៣៤–៣៥) ។

**២១:១៥** *ជាសេចក្ដីអំណរដល់មនុស្សសុចរិត* សូមមើល ១១:១០ និងការពន្យល់ ។ *សេចក្ដីវិនាសដល់មនុស្សដែលប្រព្រឹត្តទុច្ចរិតវិញ* សូមមើល ១០:២៩ និងការពន្យល់ រម ១៣:៣ ។

**២១:១៦** ខនេះគូសបញ្ជាក់ពីសណ្ឋានមនុស្ស ដែលទោរទន់ទៅរកភាពផឹកក្បត់ (សូមមើល ២:១៨ និងការពន្យល់ ៥:២៣ ៧:២២–២៣ ៩:១៨) ។

**២១:១៧** *ស្រាហើយនិងប្រេង* បង្ហាញបញ្ជាក់ពីពិធីជប់លៀងយ៉ាងធំសំបើម (សូមមើល ២៣:២០–២១ អម ៦:៦) ។ ប្រេងអូលីវគេប្រើដាក់នៅក្នុងថ្នាំលាបគ្រប់ប្រភេទ ឬធ្វើជាទឹកអប់ប្រេងនេះក៏មានតម្លៃថ្លៃ (សូមមើល យហ ១២:៥) ។

**២១:១៨** *មនុស្សអាក្រក់គេសំរាប់ជាថ្លៃលោះមនុស្សសុចរិត* មានលក្ខណៈស្រដៀងនិង ១១:៨ ។ ក្នុង អស ៤៣:៣–៤ ព្រះអម្ចាស់បានប្រទានជាតិសាសន៍ទាំងបីឱ្យទៅស្ដេចពើស៊ី ក្នុងការដោះដូរយកវាលរហោស្ថាន របស់ពើស៊ីដើម្បីរំដោះរាស្ត្ររបស់ទ្រង់ ក៏ឱ្យស្រុកអេស៊ីព្ទទុកជាថ្លៃលោះពួកគេ ។ (សូមមើលការពន្យល់ អស ៤៣:៣) ។

**២១:១៩** សូមមើល ១៩:១៣ និងការពន្យល់ ។

២០មានទ្រព្យវិសេស និងប្រេង នៅក្នុងទីលំនៅរបស់
មនុស្សមានប្រាជ្ញា តែមនុស្សល្ងីល្ងើរមែងលេបបង្ហិនទាំង
អស់ទៅ ។
២១អ្នកណាដែលប្រព្រឹត្តតាមសេចក្ដីសុចរិត និងសេចក្ដី
សប្បុរស នោះរមែងបានជីវិត សេចក្ដីសុចរិត[ន]និងកិត្ត
សព្ទ[ប] ។
២២ឯមនុស្សមានប្រាជ្ញា គេឡើងចូលក្នុងទីក្រុងរបស់
មនុស្សខ្លាំងពូកែ[ផ] ហើយនិងនាំឱ្យកំឡាំងដែលគេពឹងពាក់
ធ្លាក់ចុះវិញ ។
២៣អ្នកណាដែលរក្សាមាត់[ព]នឹងអណ្ដាតខ្លួន នោះក៏រក្សា
ព្រលឹងខ្លួនឱ្យរួចពីទុក្ខព្រួយដែរ[ភ] ។
២៤ឯមនុស្សអំនួត ហើយឆ្មើងឆ្មៃ[ម] មានឈ្មោះជាអ្នក
ចំអក គេតែងតែប្រព្រឹត្តដោយសេចក្ដីប្រមាថមើលងាយ
និងសេចក្ដីអំនួតទទេ ។
២៥បំណងចិត្តរបស់មនុស្សខ្ជិលច្រអូស នោះរមែង
សំឡាប់ខ្លួនវិញ[យ] ដ្បិតដៃគេមិនព្រមធ្វើការសោះ ។
២៦មានគេដែលលោភលន់រាល់តែថ្ងៃជានិច្ច តែឯ
មនុស្សសុចរិត[រ] គេចែកចាយវិញ ឥតសំចៃទុកអ្វីឡើយ[ល] ។
២៧យញ្ញបូជាដែលមនុស្សអាក្រក់ថ្វាយ ជាទីស្អប់ខ្ពើម
ទៅហើយ[វ] ចំណង់បើកាលណាថ្វាយដោយមានគំនិត
អាក្រក់ នោះនឹងគួរខ្ពើមជាជាងអំបាលម៉ានទៅទៀត[ស] ។
២៨សាក្សីក្លែងក្លាយ[ហ]នឹងត្រូវវិនាស[ឡ] តែអ្នកណាដែល
បានឮច្បាស់ នោះនឹងធ្វើទីបន្ទាល់ជាប់នៅជាដរាប ។
២៩មនុស្សដែលប្រព្រឹត្តអាក្រក់ គេធ្វើទឹកមុខរឹង តែ
មនុស្សទៀងត្រង់វិញ គេខំប្រឹងកែឱ្យផ្លូវខ្លួនបានត្រឹមត្រូវ[អ] ។
៣០គ្មានប្រាជ្ញាណា គ្មានយោបល់ណា[ក] ឬការប្រឹក្សាណា
ដែលអាចទាស់នឹងព្រះយេហូវ៉ាបានឡើយ[ខ] ។
៣១គេត្រៀមសេះទុកសំរាប់ថ្ងៃសង្គ្រាម តែការដែល
មានជ័យជំនះ នោះស្រេចនៅព្រះយេហូវ៉ាទេ[គ] ។

# ២២

១នាមឈ្មោះល្អ នោះគួររើសយក ជាជាងទ្រព្យ
សម្បត្តិយ៉ាងច្រើន ហើយចិត្តដែលប្រកបដោយគុណនោះ
វិសេសជាងប្រាក់នឹងមាសផង[ក] ។
២ពួកអ្នកមាន និងពួកក្រតែងតែប្រទះគ្នា គឺព្រះយេហូវ៉ា
ដែលទ្រង់បង្កើតគេគ្រប់គ្នា[ខ] ។
៣មនុស្សដែលមានគំនិតឆ្លៀវឆ្លាត គេឃើញសេចក្ដី
អាក្រក់មក ក៏ពួនខ្លួនទៅ[គ] តែមនុស្សខ្លៅល្ងង់គេចេះតែដើរ
ទៅ ហើយត្រូវមានទុក្ខ[ឃ] ។
៤ផលនៃសេចក្ដីសុភាព និងសេចក្ដីកោតខ្លាចដល់ព្រះ
យេហូវ៉ា នោះគឺជាទ្រព្យសម្បត្តិ កិត្តសព្ទ[ង] និងជីវិត[ច] ។

**២១:២១** ន ទដ ២៥:១៣ ប មថ ៥:៦ **២១:២២** ផ សភ ៨:១៤ **២១:២៣** ព ទដ ១៤:១៣ ភ សភ ១០:១៩ ១២:១៣ ១៣:៣ **២១:២៤** ម យរ ៤៣:២ **២១:២៥** យ សភ ១៣:៤ **២១:២៦** រ ២សយ ១៧:២៧ ល លវ ២៥:៣៥ **២១:២៧** វ ១៣វ ១៤:២៤ ស សភ ១៥:៨ **២១:២៨** ហ អស ២៩:២១ ឡ សភ ១៩:៥ **២១:២៩** អ សភ ១៤:៨ **២១:៣០** ក យប ១២:១៣ ១៥:២៥ ខ ២របា ១៣:១២ យប ៥:១៣ អស ៨:១០ **២១:៣១** គ ទដ ៣៣:១២–១៩ អស ៣១:១ **២២:១** ក សស ៧:១ **២២:២** ខ យប ៣១:១៥ សភ ២៩:១៣ មថ ៥:៤៥ **២២:៣** គ សភ ១៤:៦ ឃ សភ ២៧:១២ **២២:៤** ង សភ ១៥:៣៣ ច សភ ១០:២៧ ដយ ៤:៣៦

**២១:២០** សូមមើល ៣:១០ និងការពន្យល់ ៨:២១ ។ *ប្រេង* សូមមើលការពន្យល់ ឌ.១៧ សូមមើល ចទ ៧:១៣ ។

**២១:២១** *ដែលប្រព្រឹត្តតាមសេចក្ដីសុចរិត* សូមមើល ១៥:៩ និងការពន្យល់ *រមែងបានជីវិត* សូមមើល ១០:២ និងការពន្យល់ ។ *ជីវិតសេចក្ដីសុចរិតនិងកត្តិសព្ទ* គឺជាកំរៃដ៏ប្រសើរដល់អស់អ្នកដែលស្វែងរកប្រាជ្ញា (សូមមើលការពន្យល់ ៣:២ ក៏សូមមើល ៣:១៦ ៨:១៨ ប្រៀបធៀបនឹង ២២:៤) ។

**២១:២២** *ឯមនុស្សមានប្រាជ្ញា គេឡើងចូលក្នុងទីក្រុងរបស់មនុស្សខ្លាំងពូកែ* ក៏មានពាក្យពុំនោលដែលពោលតៗគ្នាថា "ប្រាជ្ញាគឺប្រសើរជាងកម្លាំងដ៏ខ្លាំងក្លា" (សស ៩:១៦) ប្រៀបធៀប ២៤:៥ ២កថ ១០:៤ គឺជាអាវុធខាងឯវិញ្ញាណដែលមានអំណាចពីព្រះអាចកំទេចកំផែងដ៏មាំមួនបាន ។

**២១:២៣** សូមមើល ១៣:៣ និងការពន្យល់ ១៨:២១ ។

**២១:២៤** *មានឈ្មោះជាអ្នកចំអក* សូមើលការពន្យល់ ១:២២ គឺព្រះអម្ចាស់បានចំអកនឹងដាក់ទណ្ឌកម្មដល់គេ ដោយសេចក្ដីអំនួតរបស់គេ (ប្រៀបធៀប ឌ.១១ ៣:៣៤ ១៩:២៥,២៩) ។

**២១:២៥** មើលការពន្យល់ ៦:៦ ១៣:៤ ។

**២១:២៦** *គេចែកចាយវិញ ឥតសំចៃទុកអ្វីឡើយ* គឺមនុស្សសុចរិតបានចែករំលែកដោយឥតមានសំចៃ គឺឱ្យចំពោះអ្នកខ្វះខាតវិញ (មើល ទដ ៣៧:២៥–២៦ ១១២:៩ អក ៤:២៨) ។

**២១:២៧** *យញ្ញបូជាដែលមនុស្សអាក្រក់ថ្វាយជាទីស្អប់ខ្ពើមទៅហើយ* សូមមើលការពន្យល់ ឌ.៣,១៥:៨ ។

**២១:២៨** *សាក្សីក្លែងក្លាយនឹងត្រូវវិនាស* សូមមើល ១៩:៥,៩ សូមមើលការពន្យល់ ៦:១៩ ។

**២១:២៩** *គេធ្វើទឹកមុខរឹង* គឺធៀបដូចជាឥរិយាបទរបស់មនុស្សកំផិតក្បត់មើលក្នុង ៧:១៣ ។

**២១:៣០** *គ្មានយោបល់ណា ឬការប្រឹក្សាណាដែលអាចទាស់នឹងព្រះយេហូវ៉ាបានឡើយ* ពីព្រោះព្រះទ្រង់ជាព្រះដែលគ្រប់គ្រងលើទាំងអស់ គឺទ្រង់មានអំណាចលើគ្រប់ទាំងពូជសាសន៍ទាំងអស់ (សូមមើល ឌ.១ ១៦:៤,៩ និងការពន្យល់ ១៩:២១ ១កថ ៣:១៩–២០) ។

**២១:៣១** *សេះ* ព្រះអម្ចាស់ក៏ទាស់ប្រឆាំងនិងអ្នកដែលទុកចិត្តលើរទេះចម្បាំង (ឧទាហរណ៍ ទដ ២០:៧ ហស ១:៧ ប្រៀបធៀប ចទ ១៧:១៦) ។ *តែការដែលមានជ័យជំនះ នោះស្រេចនៅលើព្រះយេហូវ៉ាទេ* សូមមើល ១សយ ១៧:៤៧ ទដ ៣:៨ និងការពន្យល់ ។

**២២:១** *នាមឈ្មោះល្អ* ក៏ជាតម្លៃមួយ ដែលគេទទួលស្គាល់យក ក៏មានក្នុង ៣:៤ ១០:៧ សស ៧:១ ។ *នោះវិសេសជាងប្រាក់នឹងមាសផង* គឺមានលក្ខណៈដូចទ្រព្យសម្បត្តិនៃប្រាជ្ញា (សូមមើល ៣:១៤ និងការពន្យល់ ១៦:១៦) ។

**២២:២** *ទ្រង់បង្កើតគេគ្រប់គ្នា* សូមមើល ១៤:៣១ និងការពន្យល់ ។

**២២:៣** *មនុស្សដែលមានគំនិតឆ្លៀវឆ្លាត . . . ក៏ពួនខ្លួនទៅ* សូមធៀបនឹង ១៤:៨ ។ មនុស្សខ្លៅល្ងង់ សូមមើលការពន្យល់ ១:៤ ក៏សូមមើល ៩:១៦ ។

**២២:៤** សូមមើល ១៨:១២ ។ *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* ឃ្លានេះមានទំនាក់ទំនងនឹង ១៥:៣៣ (សូមមើលការពន្យល់ ១:៧) ។ *ទ្រព្យសម្បត្តិ*

៥នៅក្នុងផ្លូវរបស់មនុស្សវៀច នោះមានសុទ្ធតែបន្លា
ហើយនិងអន្ទាក់[ឆ] អ្នកដែលរក្សាព្រលឹងខ្លួន និងចៀសឆ្ងាយ
ពីនោះចេញ ។
៦ចូរបង្ហាត់[ជ]កូនក្មេង ឱ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រ-
ព្រឹត្ត[ឈ] នោះវានឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់[ញ]។
៧មនុស្សអ្នកមានគេគ្រប់គ្រងលើពួកអ្នកក្រ ហើយអ្នក
ណាដែលខ្ចីគេ ជាបាវបំរើដល់អ្នកដែលឱ្យខ្ចីនោះ ។
៨អ្នកណាដែលសាបព្រោះសេចក្ដីទុច្ចរិត នោះនឹងច្រូត
បានសេចក្ដីទុក្ខព្រួយ[ដ] ហើយដំបងនៃសេចក្ដីកំហឹងរបស់អ្នក
នោះនឹងសាបសូន្យទៅ[ឋ]។
៩អ្នកណាដែលមើលគេដោយចិត្តល្អ នោះនឹងបានពរ[ឌ]
ដ្បិតអ្នកនោះរមែងចែកអាហារខ្លួនដល់មនុស្សទាល់ក្រ[ឍ]។
១០ចូរបណ្ដេញមនុស្សដែលចំអកមើលងាយ នោះ
សេចក្ដីទាស់ទែងគ្នានឹងបាត់ទៅ អើ សេចក្ដីឈ្លោះប្រកែក
និងសេចក្ដីត្មះតិះដៀលនឹងសប់ទៅដែរ[ណ]។
១១ឯអ្នកណា ដែលស្រឡាញ់សេចក្ដីបរិសុទ្ធខាងចិត្ត
ហើយមានបបូរមាត់ប្រកបដោយគុណដ៏ល្អ នោះស្ដេចនឹង
បានជាមិត្រសំឡាញ់របស់អ្នកនោះ[ត]។
១២ព្រះនេត្រនៃព្រះយេហូវ៉ារក្សាទុកនូវដំរិះ តែទ្រង់
បំផ្លាញពាក្យសំដីរបស់មនុស្សក្បត់វិញ ។
១៣មនុស្សខ្ជិលច្រអូសគេថា មានសិង្ហ១នៅខាងក្រៅ
ហើយ[ថ] បើខ្ញុំចេញទៅ នោះវានឹងសំឡាប់ខ្ញុំនៅនាកណ្ដាល
ផ្លូវ ។
១៤មាត់របស់ស្រីដទៃជារណ្ដៅយ៉ាងជ្រៅ[ទ] អ្នកណា
ដែលជាទីស្អប់ខ្ពើមចំពោះព្រះយេហូវ៉ា នឹងធ្លាក់ទៅក្នុង
រណ្ដៅនោះ[ធ]។
១៥សេចក្ដីចំកួត រមែងនៅជាប់ក្នុងចិត្តរបស់កូនក្មេង
ប៉ុន្តែរំពាត់វាយផ្ចាល និងបណ្ដេញសេចក្ដីនោះ ឱ្យបាត់
ចេញបាន[ន]។
១៦អ្នកសង្កត់សង្កិនមនុស្សទាល់ក្រ ដើម្បីនឹងចំរើនទ្រព្យ
សម្បត្តិខ្លួនឡើង ហើយអ្នកណាដែលជូនជំនូនដល់អ្នកមាន
នោះនឹងត្រឡប់ជាខ្វះខាតវិញ ។

### ពាក្យរបស់មនុស្សមានប្រាជ្ញា

១៧ចូរផ្ទៀងត្រចៀក[ប] ស្ដាប់ពាក្យសំដីនៃមនុស្សដែល

**២២:៥** ឆ សភ ១៥:១៩ **២២:៦** ជ លប ១៤:១៤ ឈ អក ៦:៤ ញ ចទ ៦:៧ **២២:៨** ដ នក ១:២០ យប ៤:៨ កទ ៦:៧–៨ ឋ ហស ៨:៧ **២២:៩** ឌ ចទ ១៤:២៩ ឍ សភ ១១:២៥ ១៩:១៧ ២៨:២៧ **២២:១០** ណ សភ ១៦:១៣ **២២:១១** ត សភ ១៦:១៣ មថ ៥:៨ **២២:១៣** ថ សភ ២៦:១៣ **២២:១៤** ទ សភ ៥:៣–៥ ២៣:២៧ ធ សស ៧:២៦ **២២:១៥** ន សភ ១៣:២៤ ២០:៣០ **២២:១៧** ប សភ ១:១៨

*កិត្តិសព្ទ និងជីវិត* គឺជាផល"ដែលបានទទួល"ចំពោះអស់អ្នកដែលស្វែងរកប្រាជ្ញា (មើលការពន្យល់ ៣:២ ៣:១៦ ៨:១៨ ប្រៀបនឹង ២១:២១) ។

**២២:៥** *បន្លាហើយនិងអន្ទាក់* គឺជាការអាក្រក់ (ធៀបនឹងចៀសឆ្ងាយពីនោះចេញ ព្រោះមនុស្សឆ្លៀវឆ្លាត បានជ្រើសរើសផ្លូវធំខ្ពស់ដើម្បីទៅដល់ទិសដៅនៃភាពសុចរិត (១៦:១៧) ។

**២២:៦** ពាក្យសុភាសិត គឺមិនមែនជាសេចក្ដីទំនាយក៏មិនមែនជាពាក្យសន្យា (សូមមើល សេចក្ដីផ្ដើមត្រង់និស្ស័យរបស់សុភាសិត) ។ ១ពវ ៨:៦៣ ប្រៀបធៀប លប ១៨:១៩ ។ ជាសេចក្ដីណែនាំ (១:៨) និងជាវិន័យច្បាប់ (២២:១៥) គឺទាំងអស់នោះដែលមានទំនាក់ទំនងនិងគ្នា ។ *ផ្លូវដែលគួរប្រព្រឹត្ត* គឺជាផ្លូវត្រឹមត្រូវនៃសេចក្ដីសុចរិត ផ្លូវសេចក្ដីប្រាជ្ញា (សូមមើល ៤:១១ និងការពន្យល់) ។ *ចាស់* "គឺជាការលូតលាស់ដុះដាល" ។

**២២:៧** *មនុស្សអ្នកមាន* សូមមើលការពន្យល់ ១០:១៥ ។ *អ្នកណាដែលខ្ចីគេជាបាវបំរើដល់អ្នកដែលឱ្យខ្ចីនោះ* សូមមើល (ខ.២៦) (ប្រៀបធៀប នហ ៥:៤–៥) ។

**២២:៨** *ច្រូតបានសេចក្ដីទុក្ខព្រួយ* សូមមើល ១២:២១ "គឺមនុស្សទាំងឡាយនិងទទួលបាននៅអ្វីដែលគេបានសាបព្រោះ" (កទ ៦:៧ ក៏សូមមើល ហស ៨:៧ និងការពន្យល់) ។ *ដំបងនៃសេចក្ដីកំហឹង* គឺជាសមត្ថភាព ឬអំណាចដែលគាបសង្កត់មកលើអ្នកដទៃទៀត (សូមមើល ទដ ១២៥:៣ និងការពន្យល់ អស ១៤:៥–៦) ។

**២២:៩** *មើលគេដោយចិត្តល្អ នោះនឹងបានពរ* មើលការពន្យល់ ១១:២៥ ។ *ចែកចាយអាហារខ្លួន* សូមមើល ១:២១ និងការពន្យល់ និងមើល ចទ ១៥:៧–១១ ។

**២២:១០** *ចូរបណ្ដេញមនុស្សដែលចំអកមើលងាយ* សូមមើលការពន្យល់ ១:២២ ប្រៀបធៀប លប ២១:៩–១០ ។ *សេចក្ដីទាស់ទែងគ្នានឹងបាត់ទៅ* ធៀបនឹង ១៧:១៤ ១៨:៣ ២០:៣ ។

**២២:១១** *សេចក្ដីបរិសុទ្ធខាងចិត្ត* ប្រៀបធៀប ទដ ២៤:៤ ។ *បបូរមាត់ប្រកបដោយព្រះគុណដ៏ល្អ* គឺជាលក្ខណៈសម្បត្តិរបស់អ្នកដែលមានប្រាជ្ញា មើលក្នុង សស ១០:១២ ។ *ស្ដេចនិងបានជាមិត្រសំឡាញ់របស់អ្នកនោះ* ធៀបនឹង ខ.២៩ ។

**២២:១២** *ព្រះនេត្រនៃព្រះយេហូវ៉ារក្សាទុកនូវដំរិះ* សូមមើល ៥:២១ ១៥:៣ យប ៣១:៤ ៣៤:២១ ទដ ១២១:៣–៨ យរ ១៦:១៧ ហប ៤:១៣ ។ *រក្សាទុកនូវដំរិះ* ព្រះយេហូវ៉ាទ្រង់ថែរក្សាអ្នកដែលមានដំរិះ (ប្រៀបធៀប ទដ ១:៦ ៣៤:១៥) ។

**២២:១៣** មនុស្សខ្ជិលច្រអូសតែងតែប្រើពាក្យដោះសារ ដើម្បីគេចចេញពីការងារ (សូមមើល ២៦:១៣) ។

**២២:១៤** *មាត់របស់ស្ត្រីដទៃ* គឺជាពាក្យប្រលោមលួងលោមរបស់នាង (សូមមើលការពន្យល់ ៥:៣ ក៏សូមមើល ២:១៦ ៧:៥) ។ *ជារណ្ដៅយ៉ាងជ្រៅ* វាមានលក្ខណៈជាអណ្ដូង ឬជាអន្ទាក់របស់អ្នកដាក់អន្ទាក់ អ្នកប្រម៉ាញ់ (សូមមើល ៥:២២ និងការពន្យល់ ៧:២២ ២៣:២៧) ។

**២២:១៥** *ប៉ុន្តែរំពាត់វាយផ្ចាល* សូមមើលការពន្យល់ ១៣:២៤ ។

**២២:១៦** *អ្នកដែលសង្កត់សង្កិនមនុស្សទាល់ក្រ* គឺជាការកាត់ទោសមួយ ក៏សូមមើលក្នុង ១៤:៣១ ២៨:៣ ។ *អ្នកដែលជូនជំនូនដល់អ្នកមាន* គឺជាអ្នកដែលមានសណ្ដានស៊ីសំណូកសូកប៉ាន់ (សូមមើល ១៧:៨ និងការពន្យល់ ១៨:១៦ ១៩:៦) ខ្វះខាត មើល ខ.២១:៥ ២៨:២២ និងការពន្យល់ ។

**២២:១៧** *ចូរផ្ទៀងត្រចៀកស្ដាប់* សូមមើល ៤:២០ ៥:១ ។ *ពាក្យសំដីនៃមនុស្សដែលមានប្រាជ្ញា* មើល ២៤:២៣ គឺជាចំណងជើងមានលក្ខណៈជា

មានប្រាជ្ញា[ផ] ហើយផ្ចង់ចិត្តចំពោះដំរិះរបស់អញចុះ[ព] ១៨ដ្បិត
បើឯងរក្សាទុកសេចក្តីនោះនៅក្នុងខ្លួន នោះសប្បាយហើយ
គឺបើសេចក្តីនោះស្ថិតនៅជាប់នឹងបបូរមាត់ឯង ១៩អញ
បានសំដែងឲ្យឯងដឹងសេចក្តីនោះនៅថ្ងៃនេះហើយ ដើម្បី
ឲ្យឯងបានទុកចិត្តដល់ព្រះយេហូវ៉ា ២០អញបានកំណត់ទុក
សេចក្តីដ៏វិសេសសំរាប់ឯង គឺជាសេចក្តីទូន្មាន ហើយនិង
ដំរិះមិនមែនឬ ២១ប្រយោជន៍ឲ្យឯងបានដឹងថា ពាក្យដ៏ពិត
ទាំងប៉ុន្មានគួរទុកចិត្តជាប្រាកដហើយ[ភ] ដើម្បីឲ្យឯងបាន
នាំពាក្យដ៏ពិតនោះ ត្រឡប់ទៅជូនពួកអ្នក ដែលចាត់ឯង
មក ។
២២កុំឲ្យកោងយករបស់នៃមនុស្សក្រ[ម] ដោយព្រោះតែ
គេក្រឡើយ ក៏កុំឲ្យសង្កត់សង្កិនមនុស្សវេទនានៅត្រង់ទ្វារ
ក្រុងដែរ[យ] ២៣ដ្បិតព្រះយេហូវ៉ាទ្រង់នឹងជួយកាន់ក្តីជំនួសអ្នក
នោះ[រ] ហើយទ្រង់នឹងរឹបយកជីវិតនៃពួកអ្នកដែលរឹបយក
របស់គេដែរ[ល] ។
២៤កុំឲ្យចងជាមិត្រ នឹងមនុស្សណា ដែលអាសាខឹង
ឡើយ ក៏កុំឲ្យរាប់ប្រសព្វនឹងមនុស្សមួម៉ៅដែរ ២៥ក្រែងឯង
ទំលាប់តាមអំពើរបស់គេ ហើយគេត្រឡប់ជាអន្ទាក់ដល់
ព្រលឹងឯង[វ] ។
២៦កុំឲ្យឯងចូលក្នុងពួកអ្នកដែលចាប់ដៃគ្នា[ស] ឬជាមួយ
នឹងមនុស្សដែលធានាបំណុលឲ្យគេឡើយ ២៧បើឯងគ្មាន
អ្វីនឹងសងគេ នោះចង់ឲ្យគេមកកន្ត្រាក់យកគ្រែពីក្រោមឯង
ទៅធ្វើអី[ហ] ។
២៨កុំឲ្យបន្ថយគោលចារិក[ឡ] ដែលពួកឰយុកោឯងបោះ
ទុកពីបុរាណឡើយ ។
២៩ឯងដែលឃើញមនុស្សខ្នះខ្នែង[អ] ក្នុងការរកស៊ីរបស់
ខ្លួនឬ អ្នកនោះនឹងបានឈរនៅ[ក] ចំពោះស្តេច[ខ] មិនត្រូវឈរ
នៅចំពោះមនុស្សដែលឥតបណ្តាលសក្តិឡើយ ។

**២៣** ១កាលណាឯងអង្គុយបរិភោគភោជនាហារ ជាមួយ
នឹងអ្នកគ្រប់គ្រង នោះត្រូវឲ្យឯងពិចារណាដល់អ្នកដែល
អង្គុយនៅខាងមុខឯងចុះ ២បើឯងជាមនុស្សល្មោភខ្លាំង
នោះចូរផ្ទាប់កាំបិតនៅបំពង់កឯងទៅ ៣កុំឲ្យលោភចង់
បានឱជារសរបស់គេឡើយ[គ] ដ្បិតជារបស់បញ្ឆោតទេ ។
៤កុំឲ្យនឿយហត់ដល់ខ្លួន ដើម្បីឲ្យបានជាអ្នកមានឡើយ
ក៏កុំឲ្យប្រើប្រាជ្ញាឲ្យបានមានឡើងដែរ ៥តើចង់ភ្ជាប់ភ្នែក
តាមរបស់ដែលសោះសូន្យឬ[ឃ] ដ្បិតទ្រព្យសម្បត្តិតែងតែដុះ
ស្លាបជាមិនខាន ក៏នឹងហើរទៅលើមេឃ បែបដូចជា
ឥន្ទ្រី[គ] ។
៦កុំឲ្យបរិភោគភោជនាហាររបស់មនុស្ស ដែលមាន

**២២:១៧** ផ សភ ១:៦ ៣០:១ ៣១:១ ព សភ ២:២
**២២:២១** ភ សស ១២:១០
**២២:២២** ម លវ ២៥:១៧ យប ៥:១៦ យ នក ២៣:៦
**២២:២៣** រ យប ២៩:១៦ ទដ ១៤០:១២ ល នអ ៨:១ ៩:១ សភ ២៣:១០–១១
**២២:២៥** វ ១កថ ១៥:៣៣
**២២:២៦** ស សភ ៦:១–៥
**២២:២៧** ហ សភ ១១:១៥ ១៧:១៨
**២២:២៨** ឡ ចទ ១៩:១៤
**២២:២៩** អ ១ពវ ១១:២៨ ក លប ៤១:៤៦ ខ ៣៩:៤
**២៣:៣** ក ខ.៦–៨ សភ ១៤១:៤
**២៣:៥** ខ មថ ៦:១៩ គ ២៧:២៤

"ពាក្យសុភាសិតរបស់ស្តេចសាឡូម៉ូន" ក្នុង ១០:១ ។ *ហើយផ្ចង់ចិត្តចំពោះ* សូមមើល ២៣:១២ ទដ ៤:៧ និងការពន្យល់ សភ ២៤:៣២ ។

**២២:១៨** *នោះសប្បាយហើយ* សូមមើល ២:១០ ១៦:២៤ និងការពន្យល់ ។

**២២:១៩** *ឲ្យឯងបានទុកចិត្តដល់ព្រះយេហូវ៉ា* សូមមើលការពន្យល់ ៣:៥ ។

**២២:២០** ខនេះគឺមាន៣០ផ្នែក (ដែលបានចែកជា ៣វគ្គ ដែលមួយវគ្គៗមាន ១០អត្ថបទ) គឺក្នុង ២២–២៤:២២ ។ ហើយក្នុងអត្ថបទទាំងអស់នោះក៏មាន ២ខ ឬ ៣ខ ដែលវែងជាងគេ ប៉ុន្តែ សូមមើល ២៣:២៩–៣៥ ។

**២២:២១** ប្រៀបធៀបនឹង ១ពត ៣:១៥ ។

**២២:២២** *កុំឲ្យកោងយករបស់នៃមនុស្សក្រ* សូមមើល ខ.១៦ ១៤:៣១ ។ *ក៏កុំឲ្យសង្កត់សង្កិនមនុស្សវេទនានៅត្រង់ទ្វារក្រុងដែរ* សូមមើល អស ១:១៧ និងការពន្យល់ ។

**២២:២៣** *ព្រះយេហូវ៉ាទ្រង់នឹងជួយកាត់ក្តីជំនួសអ្នកនោះ* មើល ២៣:១១ និងការពន្យល់ ទដ ១២:៥ ១៤០:១២ អស ៣:១៣–១៥ មឡ ៣:៥ ។ *និងរឹបយកជីវិតនៃពួកអ្នកដែលរឹបយករបស់គេ* សូមមើល នក ២២:២១–២៧ និងការពន្យល់ ។

**២២:២៤** *កុំឲ្យចងជាមិត្រ* ប្រៀបធៀប ១២:២៦ ។ *ខឹងឡើយ* ចរិតលក្ខណៈបែបនេះក៏មានក្នុង ១៤:១៦–១៧ ១៥:១៨ ២៩:២២ ។

**២២:២៥** *ក្រែងឯងទំលាប់តាមអំពើរបស់គេ* "មានក្រុមប៉ាក់ពួកមិនល្អបានបំផ្លាញលក្ខណៈល្អរបស់ខ្លួន (១កថ ១៥:៣៣) ។ *ត្រឡប់ជាអន្ទាក់ដល់ព្រលឹងឯង* សូមមើលការពន្យល់ ៥:២២ ១២:១៣–១៤ ២៩:៦ ។

**២២:២៨** *គោលចារិត ដែលពួកឰយុកោឯងបោះទុកពីបុរាណ* សូមមើលការពន្យល់ ១៥:២៥ ២៣:១០ ។

**២២:២៩** *ខ្នះខ្នែងក្នុងការរកស៊ីរបស់ខ្លួន* អ្នកសិប្បករ ក៏គេហៅថាជាមនុស្សឆ្លាត (សូមមើលការពន្យល់ ៨:៣០ ក៏មើល ៣៥:៣០–៣៦:២) ។ *បានឈរនៅចំពោះស្តេច* គឺដូចជាលោកយ៉ូសែប ដែលជាអ្នកដឹកនាំ (លក ៤១:៤៦) មានស្តេចដាវីឌ ដែលជាអ្នកតន្ត្រី (១សយ ១៦:២១–២៣) និងហីរ៉ាមជាអ្នកមានកិច្ចការជាសិប្បករ ជាជាងលង្ហិន (១ពវ ៧:១៣–១៤) ។

**២៣:២** *មនុស្សល្មោភខ្លាំង* ប្រៀបធៀប និងការទូន្មានប្រដៅ ខ.២០–២១ ។

**២៣:៣** *កុំឲ្យលោភចង់ចបានឱជារសរបស់គេឡើយ* ឃ្លានេះតែងតែឃើញក្នុងអត្ថបទផ្សេងៗមានក្នុង ខ.៦ ។ *របស់បញ្ឆោត* វាគឺជាអត្ថន័យដែលអានក្នុង ទដ ១៤:៤ ។

**២៣:៤** *កុំឲ្យនឿយហត់ដល់ខ្លួន ដើម្បីឲ្យបានជាអ្នកមានឡើយ* គឺសេចក្តីប៉ងប្រាថ្នាយ៉ាងខ្លាំង ឯសាច់ឈាមវាគឺជាឫសគល់នៃការអាក្រក់ (១កថ ៦:១០ ប្រៀបធៀបនឹង ១៥:២៧ ២៨:២០ ហព ១៣:៥) ។

**២៣:៥** *តាមរបស់ដែលសោះសូន* គឺអ្វីដែលជារបស់លោកីយបាត់ទៅវិញ ។ តែសេចក្តីទំនុកចិត្តរបស់យើង គឺមានតែនៅក្នុងទ្រង់តែប៉ុណ្ណោះ មិនទុកចិត្តនិងភោគទ្រព្យដែលជាសម្បត្តិត្រូវពុករលួយនោះឡើយ (សូមមើល យរ ១៧:១១ លក ១២:២០–២១ ១ធថ ៦:១៧) ។

**២៣:៦** *មនុស្សដែលមានភ្នែកអាក្រក់* គឺជាមនុស្សដែលមានសេចក្តីប៉ងប្រាថ្នាយ៉ាងខ្លាំង (២៨:២២) ។

ភ្នែកអាក្រក់ឡើយ ក៏កុំឱ្យប្រាថ្នាចង់បានអាហារមានឱជា
រសរបស់គេដែរ[ឃ] ៧ដ្បិតគេគិតក្នុងចិត្តយ៉ាងណាគេក៏យ៉ាង
នោះដែរ គេអញ្ជើញឯងថា ពិសាចុះ តែចិត្តគេមិនមូលនៅ
ជាមួយនឹងឯងទេ ៨អាហារដែលឯងបានបរិភោគចូលទៅ
នោះនឹងក្អួតមកវិញ ហើយនិងបាត់ពាក្យសំដីផ្អែមល្ហែម
របស់ឯងទៅ ។
៩កុំឱ្យនិយាយឱ្យមនុស្សល្ងីល្ងើស្ដាប់ឡើយ ដ្បិតវានឹង
មើលងាយចំពោះប្រាជ្ញានៃពាក្យសំដីឯង[ង] ។
១០កុំឱ្យបន្ថយគោលចារិកពីបុរាណឡើយ[ច] ក៏កុំឱ្យបង្ខិត
ចូលទៅក្នុងដីរបស់កូនកំព្រាដែរ ១១ដ្បិតអ្នកដែលលោះ[ឆ]គេ
នោះមានកំឡាំងខ្លាំង[ជ] ក៏នឹងកាន់ក្ដីគេ ទាស់នឹងឯងដែរ[ឈ] ។
១២ចូរផ្ចង់ចិត្តឯងចំពោះសេចក្ដីប្រៀនប្រដៅ[ញ] ហើយ
ផ្ទៀងត្រចៀកចំពោះពាក្យដែលប្រកបដោយដំរិះចុះ ។
១៣កុំឱ្យខាននឹងវាយប្រដៅកូនឡើយ ដ្បិតបើវាយនឹង
រំពាត់ គង់តែមិនស្លាប់ដែរ ១៤គឺឯងនឹងគ្រាន់តែវាយ ដោយ
រំពាត់ប៉ុណ្ណោះ ហើយយ៉ាងនោះ និងជួយព្រលឹងវាឱ្យរួចពី
ស្ថានឃុំព្រលឹងមនុស្សស្លាប់[ដ] ។
១៥កូនអើយ បើចិត្តឯងប្រកបដោយប្រាជ្ញា នោះចិត្ត
អញនឹងមានសេចក្ដីអំណរ គឺចិត្តរបស់ឪពុកនេះឯង ១៦អើ
ចិត្តថ្លើមអញនឹងរីករាយឡើង ក្នុងកាលដែលបបូរមាត់ឯង
ពោលសេចក្ដីដែលត្រឹមត្រូវ[ឋ] ។
១៧កុំបើកឱ្យចិត្តច្រណែន[ឌ] នឹងមនុស្សមានបាបឡើយ
ចូរឱ្យឯងប្រកបដោយសេចក្ដីកោតខ្លាច ដល់ព្រះយេហូវ៉ា
ជាដរាបរាល់ថ្ងៃ ១៨ដ្បិតនឹងមានរង្វាន់ជាមិនខាន ហើយ
សេចក្ដីសង្ឃឹមរបស់ឯងនឹងមិនកាត់បង់ឡើយ[ឍ] ។
១៩កូនអើយ[ណ] ចូរប្រុងស្ដាប់ ហើយមានប្រាជ្ញាចុះ ត្រូវ
ឱ្យដំរង់ចិត្តទៅតាមផ្លូវ ២០កុំឱ្យនៅកណ្ដាលពួកអ្នកប្រមឹក
ស្រា[ត] ឬក្នុងពួកល្មោភស៊ីឡើយ ២១ដ្បិតមនុស្សប្រមឹក នឹង
មនុស្សល្មោភនឹងទៅជាក្រ[ថ] ហើយសេចក្ដីងុយងោកនឹងនាំ
ឱ្យស្លៀកពាក់កណ្ដាច ។
២២ចូរស្ដាប់តាមឪពុកដែលបង្កើតឯងមក ហើយកុំឱ្យ
មើលងាយម្ដាយឯងក្នុងកាលដែលគាត់ចាស់ឡើយ[ទ] ។
២៣ចូរទិញសេចក្ដីពិតចុះ កុំឱ្យលក់ចេញឡើយ អើ
ទាំងប្រាជ្ញា សេចក្ដីដំបូន្មាន និងយោបល់ផង[ធ] ។
២៤ឪពុកនៃមនុស្សសុចរិត នឹងមានចិត្តរីករាយយ៉ាង
ខ្លាំង ហើយអ្នកណាដែលបង្កើតកូនមានប្រាជ្ញា នោះនឹង
មានសេចក្ដីអំណរដោយសារកូននោះ[ន] ២៥ដូច្នេះ ចូរបើក
ឱកាសឱ្យឪពុកម្ដាយឯងបានរីករាយចុះ ហើយឱ្យអ្នកដែល

**២៣:៦** ឃ ខ.១-៣ ទដ ១៤១:៤ **២៣:៩** ង សភ ៩:៧ **២៣:១០** ច ចទ ១៩:១៤ **២៣:១១** ឆ យប ១៩:២៥ ជ ទដ ២៤:៨ ឈ នក ២២:២២-២៤ សភ ១៥:២៥ ២២:២២-២៣ **២៣:១២** ញ សភ ២:២ **២៣:១៤** ដ សភ ១៣:២៤ ១៩:១៨ **២៣:១៦** ឋ ខ.២៤ សភ ២៧:១១ ២៩:៣ **២៣:១៧** ឌ ទដ ៣៧:១ ៧៣:៣ **២៣:១៨** ឍ ទដ ៩:១៨ ៣៧:១-៤ សភ ២៤:១៤, ១៩-២០ **២៣:១៩** ណ ចទ ៤:៩ សភ ២៨:៧ **២៣:២០** ត អស ៥:១១,២២ ៥៦:១២ ហប ២:១៥ **២៣:២១** ថ សភ ២១:១៧ **២៣:២២** ទ លវ ១៩:៣២ **២៣:២៣** ធ សភ ៤:៧ ១៧:១៦ **២៣:២៤** ន ១៥:១៦

**២៣:៧** *តែចិត្តគេមិននៅជាមួយនឹងឯងទេ* ប្រៀបធៀប ២៦:២៤-២៥ ។ *ចិត្ត* មើល ខ.១២,១៥,១៧,២៦ ទដ ៤:៧ និងការពន្យល់ ។

**២៣:៨** *ក្អួត* ភាពជិនណាយ ឬឆ្អែតឆ្អល់ពីរបស់ដ៏ច្រើនលើសលុប ។

**២៣:៩** *ដ្បិតវានឹងមើលងាយចំពោះប្រាជ្ញានៃពាក្យសំដីឯង* គឺជាសកម្មភាពរបស់មនុស្សល្ងីល្ងើដែលបដិសេធន៍ប្រាជ្ញា (១:៧) នឹងស្អប់ដំរិះវិជ្ជាក៏ដូចជាស្អប់ការប្រៀនប្រដៅដែរ (១:២២ ១២:១) ។ តែពួកគេតែងតែព្យាយាមដាក់បន្ទុកដែលជាកំហុសដល់អ្នកដទៃ (៩:៧) ។

**២៣:១០** *គោលចារិតពីបុរាណ* សូមមើល ១៥:២៥ ២២:២៨ ។ *កូនកំព្រា* គឺការសង្កត់សង្កិនចំពោះស្ត្រីមេម៉ាយ និងកូនកំព្រាក៏គេរិះគន់ដែរ (សូមមើល អស ១០:២ យរ ២២:៣ សក ៧:១០ និងការពន្យល់) ។

**២៣:១១** *អ្នកដែលលោះគេ* គឺជាប់ជាសាច់ឈាមដែលគេបានជួយសង្គ្រោះឱ្យបានវិលមកដល់ស្រុកកំណើតវិញ (សូមមើល លវ ២៥:២៥ និងការពន្យល់) ឬក៏អ្នកដែលសងសឹក ចំពោះសេចក្ដីស្លាប់របស់គេ (សូមមើល ជន ៣៥:១២,១៩) ។ ដ្បិតព្រះអម្ចាស់គឺជាព្រះវបិតាដល់ពួកកំព្រា ឬជាអ្នកសង្គ្រោះដល់ស្ត្រីមេមាយ (ទដ ៦៨:៥) ។ សូមមើលការពន្យល់ នរ ២:២០ យរ ៣១:១១ យរ ៥០:៣៤ ។ *ក៏នឹងកាត់ក្ដីគេ* មើល ទដ ១២:៥ ១៤០:១២ អស ៣:១៣-១៥ មទ្ឋ ៣:៥ ។

**២៣:១២** *ចូរផ្ចង់ចិត្តអ្នកចំពោះ* គឺមានក្នុង ២២:១៧ គឺឃ្លាដែលជាផ្នែកសំខាន់៣មានក្នុងវគ្គទី២ គឺបង្ហាញពីមនុស្សមានប្រាជ្ញា (សូមមើលការពន្យល់ ២២:២០) ។

**២៣:១៣-១៤** មើល ១៣:២៤ និងការពន្យល់ ។

**២៣:១៥** មើល ១០:១ និងការពន្យល់ និងមើល ខ.២,២៤,២៧,១១ ២៩:៣ ។ *កូនអើយ* សូមមើល ១:៨ និងការពន្យល់ ។

**២៣:១៦** *សេចក្ដីដែលត្រឹមត្រូវ* នៅក្នុងភាសាហេព្រើរបានបកប្រែឃ្លានេះយ៉ាងច្បាស់ក្នុង ខ.៣១ ។

**២៣:១៧** *កុំបើកឱ្យចិត្តច្រណែននឹងមនុស្សមានបាបឡើយ* សូមមើល ៣:៣១ ២៤:១,១៩ ។ *សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើលការពន្យល់ ១:៧ ៣:៧ ។

**២៣:១៨** *សេចក្ដីសង្ឃឹម* មើល ២៤:១៤,២០ ទដ ៣៧:៣៧ យរ ២៩:១១ ។

**២៣:១៩** *ដំរង់ចិត្តទៅតាមផ្លូវ* ធៀបនឹង ៤:២៥-២៦ ។

**២៣:២០** *កុំឱ្យនៅកណ្ដាល* មើល ១:១៥ ១២:២៦ និងការពន្យល់ ។ *ពួកអ្នកប្រមឹកស្រា* ភាពញៀនស្រាក៏ត្រូវជិនុំជិរះដែរ មើល ខ.២៩-៣៥ ២០:១ (សូមមើលការពន្យល់នៅទីនោះ) ធៀបនឹង ចទ ២១:២០ មថ ២៤:៤៩ លក ២១:៣៤ រម ១៣:១៣ អភ ៥:១៨ ១ធថ ៣:៣ ។

**២៣:២១** *មនុស្សល្មោភ* សូមមើល ខ.២ ២៨:៧ ប្រៀបធៀប ធថ ១១:១៩ ។ *ទៅជាក្រ* សូមមើល ២១:១៧ ។ *នាំឱ្យស្លៀកពាក់កណ្ដាច* ប្រៀបធៀបនឹងភាពអត់ឃ្លានដែលកំពុងមានឥទ្ធិពលទៅលើមនុស្សល្មោភ ៦:៩-១១ (សូមមើលការពន្យល់) ។

**២៣:២២** *កុំឱ្យមើលងាយម្ដាយ* ប្រៀបធៀប ១:៨ ១០:១ ១៥:២០ ៣០:១៧ ។

**២៣:២៣** *ចូរទិញសេចក្ដីពិតចុះ* សូមមើល ៤:៥ ក៏សូមមើលការពន្យល់ ។

**២៣:២៤-២៥** សូមមើល ខ.១៥ ២៧:១១ សូមមើលការពន្យល់ ១០:១ និងការពន្យល់ ។

សំរាលឯងមកនោះមានចិត្តសប្បាយផង[ប] ។
២៦កូនអើយ[ផ] ចូរប្រគល់ចិត្តឯងមកអញចុះ ហើយឱ្យ
ភ្នែកឯងពេញចិត្តនឹងអស់ទាំងផ្លូវរបស់អញដែរ[ព] ២៧ដ្បិត
ស្រីសំផឹងជារណ្តៅយ៉ាងជ្រៅ[ភ] ហើយស្រីដទៃជារំលុងដ៏
ចង្អៀត ២៨អើ គេលបចាំដូចជាចោរ[ម] ហើយក៏ចំរើនអ្នក
ក្បត់នៅក្នុងពួកមនុស្សលោក ។
២៩តើអ្នកណាមានសេចក្តីពិបាកចិត្ត តើអ្នកណាកើតទុក្ខ
ព្រួយ តើអ្នកណាមានសេចក្តីទាស់ទែងគ្នា តើអ្នកណាត្អូញ
ត្អែរ តើអ្នកណាត្រូវរបួសឥតហេតុ តើអ្នកណាមានភ្នែក
ក្រហម ៣០គឺជាពួកអ្នកដែលអង្គុយផឹកស្រា[យ]ជាយូរ ជាពួក
អ្នកដែលស្វែងរកស្រាលាយនោះឯង ៣១កុំឱ្យមើលស្រា
ទំពាំងបាយជូរ ក្នុងកាលដែលមានពណ៌ក្រហម គឺក្នុងកាល
ដែលព្រួចពពុះនៅក្នុងកែវ ហើយហូរចុះទៅដោយស្រួល
នោះឡើយ ៣២ដ្បិតដល់ចុងបំផុតនឹងចឹកដូចជាពស់វិញ
ហើយអុចដូចជាពស់ហនុមានផង ៣៣ភ្នែកឯងនឹងឃើញស្រី
ដទៃ ហើយចិត្តឯងនឹងពោលសេចក្តីខូចអាក្រក់ដែរ ៣៤អើ
ឯងនឹងបានដូចជាមនុស្សដែលដេកនៅកណ្តាលសមុទ្រ
ឬដូចជាមនុស្ស ដែលដេកនៅលើចុងដងក្តោង ៣៥ឯងនឹង
ថា គេបានវាយអញ តែអញមិនបានឈឺសោះ គេបានសំពង
អញ តែអញមិនដឹងទេ តើអញនឹងភ្ញាក់ឡើងវិញដល់កាល
ណាហ្ន៎ អញនឹងទៅរកផឹកទៀត[រ] ។

**២៣:២៥** ប សភ ១០:១
**២៣:២៦** ផ សភ ៥:១–៦ ព ទដ ១៨:២១
**២៣:២៧** ភ សភ ២២:១៤
**២៣:២៨** ម សភ ៧:១១–១២
**២៣:៣០** យ ឌ.២០–២១ អស ៥:១១
**២៣:៣៥** រ សភ ២០:១

២៤ ១កុំឱ្យមានចិត្តច្រណែន[ក] នឹងមនុស្សអាក្រក់សោះ
ឡើយ ក៏កុំចង់ទៅរួមនៅនឹងគេដែរ ២ដ្បិតចិត្តគេគិតគូរតែ
ការសង្កត់សង្កិនទទេ[ខ] ហើយបបូរមាត់គេពោលតែសេចក្តី
ប្រទូសរ៉ាយ[គ] ។
៣ការដែលសង់ផ្ទះឡើងបាន[ឃ] នោះក៏ដោយសារប្រាជ្ញា
ហើយគឺដោយសារយោបល់ដែលផ្ទះនោះនឹងបានតាំងនៅ
ជាមាំមួន ៤ហើយដោយសារដំរិះ នោះបន្ទប់ទាំងឡាយ
បានពេញដោយគ្រប់ទាំងទ្រព្យសម្បត្តិដ៏វិសេស ជារបស់
ដែលគាប់ចិត្ត[ង] ។
៥មនុស្សមានប្រាជ្ញាក៏មានកំឡាំងច្រើន អើ មនុស្ស
ដែលមានដំរិះក៏ចំរើនអំណាចខ្លួនឡើង ៦ដ្បិតដោយមាន
ការជួយគំនិត ដែលប្រកបដោយប្រាជ្ញា នោះឯងនឹងអាច
ធ្វើសឹកសង្គ្រាមបាន ហើយដោយមានអ្នកប្រឹក្សាជាច្រើន
នោះទើបបានជ័យជំនះ[ច] ។
៧ប្រាជ្ញាជារបស់ខ្ពស់ហួសល្បត់មនុស្សល្ងីល្ងើ គេមិន
បើកមាត់នៅត្រង់ទ្វារក្រុងឡើយ ។
៨អ្នកណាដែលគិតគូរបង្កើតអំពើអាក្រក់ នោះនឹងបាន
ឈ្មោះថាជាមនុស្សកោងកាច ។

**២៤:១** ក សភ ៣:៣១–៣២ ២៣:១៧–១៨
**២៤:២** ខ ទដ ២:១ អស ៣២:៦ ៥៥:៧–៨ ៥៩:៧ ៦៥:២ ៦៦:១៨ ហស ៤:១ គ ទដ ១០:៧ **២៤:៣** ឃ ទដ ១៤:១ **២៤:៤** ង សភ ៨:២១
**២៤:៦** ច សភ ១១:១៤ ២០:១៨ លក ១៤:៣១

**២៣:២៧** *ជារណ្តៅយ៉ាងជ្រៅ . . . ស្រីដទៃជារំលុងដ៏ចង្អៀត* គឺជាប្រភពគ្រោះថ្នាក់ដែលមនុស្សទូទៅពិបាកគេចខ្លួនចេញពីរណ្តៅនោះ ។ ពាក្យថា *រណ្តៅយ៉ាងជ្រៅ* សូមមើលការពន្យល់ ២២:១៤ ។ *ស្រីដទៃ* សូមមើលការពន្យល់ ២:១៦ ក៏សូមមើល ៥:១០ ៧:១៨–២០ ។ *ជារំលុង* ជាពាក្យប្រៀបប្រដូចគ្នា ដែលប្រើចំពោះស្ត្រីទូទៅនៅក្នុង "អាកាដៀន" (akkadian) ។
**២៣:២៨** សូមមើល ៦:២៦ ៧:១២ សស ៧:២៦ ។ *ក៏ចំរើនអ្នកក្បត់នៅក្នុងពួកមនុស្សលោក* មើលការប្រៀបធៀប ៧:២៦ ។
**២៣:២៩** *តើអ្នកណាមានសេចក្តីពិបាកចិត្ត* ពាក្យនេះធៀបទៅនឹងសេចក្តីពិបាកចិត្ត និងពួកប្រមឹកមួយចំនួន គឺមាននៅក្នុង អស ៥:១១,២២ ។ *ទុក្ខព្រួយ* មើល ២០:១ និងការពន្យល់ ។ *ត្រូវរបួស* ប្រៀបធៀបនឹង ១៩:២៩ ។
**២៣:៣០** *ពួកអ្នកអង្គុយផឹកស្រាជាយូរ* សូមមើល ១សយ ២៥:៣៦ ។ *ស្រាលាយ* ជាស្រាដែលលាយជាមួយគ្រឿង ឬធាតុផ្សំផ្សេងៗ (សូមមើល ៩:២ ទដ ៧៥:៨ អស ៥:២២ និងការពន្យល់) ។
**២៣:៣២** *និងចឹកដូចជាពស់វិញ* តែសេចក្តីស្លាប់វាជាលទ្ធផលចុងក្រោយ (ប្រៀបធៀបនឹង ជន ២១:៦) ។
**២៣:៣៤** *ឯងនឹងបានដូចជាមនុស្សដែលដេកនៅកណ្តាលសមុទ្រ* ឯក្បាលរបស់គេនឹងវិលដូចជាដងរហាត់ទឹក ។
**២៣:៣៥** *គេបានសំពងអញ តែអញមិនដឹងទេ* គឺក្នុងលក្ខខ័ណ្ឌ ឬស្ថានភាពក្នុងប្រទេសអ៊ីស្រាអែល មើលក្នុង យរ ៥:៣ ។ *អញនឹងទៅរកផឹកទៀត* សេចក្តីឈឺចាប់ ឬភាពវេទនាពុំអាចទប់ស្កាត់ពួកអ្នកប្រមឹក មិនឱ្យប្រព្រឹត្តនូវភាពល្ងីល្ងើរបស់ពួកគេដែលធ្វើដដែលៗនោះ (ប្រៀបធៀប ២៦:១១ ២៧:២២ អស ៥៦:១២ អម ៤:១) ។
**២៤:១** *កុំឱ្យមានចិត្តច្រណែន* សូមមើល ឌ.១៩ ទដ ៣៧:១ ។ *ក៏កុំឱ្យចង់រួមនឹងគេដែរ* សូមមើល ១:១៥ ១២:២៦ និងការពន្យល់ ២៣:២០ ។
**២៤:២** *គិតគូរតែការសង្កត់សង្កិនទទេ* មើល ១:១១ ៦:១៤ យប ១៥:៣៥ ទដ ៥:៩ និងការពន្យល់ ៣៨:១២ ។
**២៤:៣** *ផ្ទះ* ជានិមិត្តសញ្ញាពីជីវិត ឬពីបុគ្គលម្នាក់ ឬក៏គ្រួសារម្នាក់ៗ ដែលបានភពប្រសព្វគ្នាឡើង ប្រៀបធៀបនឹងការសម្តែងក្នុង ៩:១ ។
**២៤:៤** *ពេញដោយគ្រប់ទាំងទ្រព្យសម្បត្តិដ៏វិសេស* ប្រាជ្ញា ឬអ្នកដែលមានប្រាជ្ញាគឺជាសេចក្តីសន្យាថា និងទទួលបានទ្រព្យសម្បត្តិដោយព្រោះប្រាជ្ញា ក៏ឱ្យដល់អស់អ្នកណាដែលស្រឡាញ់ប្រាជ្ញានោះ (៨:២១) ។
**២៤:៥** *មនុស្សមានប្រាជ្ញា . . . មានដំរិះក៏ចំរើន* បានឮតាមរយៈ ២២:១៧–២១ ដែលផ្តើមដោយផ្នែកសំខាន់បី ដែលបញ្ជូលន័យក្នុងពាក្យពុំនោល "ស្តីអំពីមនុស្សមានប្រាជ្ញា" (មើលការពន្យល់ ២២:២០) ។ *ក៏មានកំឡាំងច្រើន* សូមមើលការពន្យល់ ២១:២២ ។
**២៤:៣៧** *ទ្វាក្រុង* សូមមើលការពន្យល់ ១:២១ ។
**២៤:៨** *បង្កើតអំពើអាក្រក់* សូមមើល ឌ.២ និងការពន្យល់ ។ *មនុស្សកោងកាច* ប្រៀបធៀប"មនុស្សដែលបង្កើតការអាក្រក់" ក្នុង ១២:២ ១៤:១៧ ។

៩គំនិតពីសេចក្ដីចំកួត នោះជាអំពើបាប ហើយអ្នកដែល
ចំអកមើលងាយ ក៏ជាទីស្អប់ខ្ពើមដល់មនុស្សទាំងឡាយ ។
១០បើឯងអន់ថយក្នុងថ្ងៃលំបាក នោះឈ្មោះថាឯងមាន
កំឡាំងតិចទេ[ឆ] ។
១១ចូរជួយសង្គ្រោះពួកអ្នក ដែលគេដឹកនាំទៅឱ្យត្រូវ
ស្លាប់ ហើយរាំងរាពួកអ្នកដែលកំពុងតែទៅឯទីសំឡាប់
ចុះ[ជ] ១២បើឯងថា មើល យើងមិនបានដឹងទេ ឯព្រះដែល
ទ្រង់ថ្លឹងមើល[ឈ,ញ]ចិត្ត តើទ្រង់មិនពិចារណាឃើញ ហើយ
ដែលទ្រង់ថែរក្សាព្រលឹងឯង តើមិនជ្រាបទេឬ តើទ្រង់នឹង
មិន សង[ដ]ដល់មនុស្សទាំងឡាយតាមការដែលគេប្រព្រឹត្ត
ទេឬអី[ឋ] ។
១៣កូនអើយ ចូរបរិភោគទឹកឃ្មុំចុះ ដ្បិតជារបស់ឆ្ងាញ់
ហើយសំណុំឃ្មុំដែលមានរសផ្អែមដល់មាត់ឯងផង។
១៤គឺយ៉ាងនោះដែលឯងនឹងដឹងថាប្រាជ្ញាក៏ល្អដល់
ព្រលឹងឯងដែរ បើឯងរកប្រាជ្ញានោះឃើញ នោះនឹងបាន
រង្វាន់ហើយសេចក្ដីសង្ឃឹមរបស់ឯងនឹងមិនត្រូវកាត់បង់
ឡើយ[ឌ,ឍ] ។
១៥នែ មនុស្សអាក្រក់អើយ កុំឱ្យលបចាំប្រទូស្ដនឹងលំនៅ
របស់មនុស្សសុចរិតឡើយ កុំឱ្យបំផ្លាញទីស្នាក់នៅរបស់គេ
ឱ្យសោះ ១៦ដ្បិតមនុស្សសុចរិត ទោះបើគេដួលដល់៧ដងក៏
ដោយ គង់តែនឹងក្រោកឡើងវិញបាន តែមនុស្សអាក្រក់
ត្រូវទំលាក់ ទៅក្នុងសេចក្ដីអន្តរាយវិញ[ណ] ។
១៧កុំឱ្យមានចិត្តរីករាយ[ត] ក្នុងកាលដែលខ្មាំងសត្រូវឯង
ដួលចុះឡើយ ក៏កុំឱ្យមានចិត្តសប្បាយ[ថ] ក្នុងកាលដែលគេ
ត្រូវទំលាក់ទៅដែរ ១៨ក្រែងព្រះយេហូវ៉ាទ្រង់ទតឃើញ
ហើយការនោះមិនគាប់ដល់ព្រះហឫទ័យ រួចទ្រង់បង្វែរ
សេចក្ដីក្រោធចេញពីអ្នកនោះវិញ[ទ] ។
១៩កុំឱ្យក្ដៅចិត្ត[ធ] ដោយព្រោះមនុស្សដែលប្រព្រឹត្តអំពើ
អាក្រក់ឡើយ ក៏កុំឱ្យច្រណែននឹងមនុស្សកោងកាចដែរ
២០ដ្បិតនឹងគ្មានរង្វាន់ណា ឱ្យដល់មនុស្សដែលប្រព្រឹត្តអំពើ
អាក្រក់ឡើយ ហើយចង្កៀងរបស់មនុស្សកោងកាច នឹង
ត្រូវរលត់ទៅ[ន] ។
២១កូនអើយ ចូរកោតខ្លាចដល់ព្រះយេហូវ៉ា ហើយដល់
ស្ដេចផង[ប] កុំឱ្យឯងសេពគប់នឹងមនុស្សដែលតែងតែសាវ៉ា
ឡើយ ២២ដ្បិតសេចក្ដីអន្តរាយ[ផ]នឹងលោមកលើគេភ្លាម តើ
អ្នកណានឹងអាចស្គាល់ការវិនាស ដែលមកពីព្រះនឹងស្ដេច
នោះបាន ។

**២៤:១០** ឆ យប ៤:៥ **២៤:១១** ជ ទដ ៨២:៤ **២៤:១២** ឈ ទដ ១៣៩:២ ញ ១សយ ២:៣ ដ ទដ ៥៤:៥ ឋ យប ៣៤:១១ ទដ ៦២:១២ មថ ១៦:២៧ រម ២:៦ **២៤:១៤** ឌ ទដ ១១៩:១០៣ សភ ១៦:២៤ ឍ សភ ២៣:១៨ **២៤:១៦** ណ យប ៥:១៩ ទដ ៣៤:២១ **២៤:១៧** ត អប ១:១២ ថ ២សយ ៣:៣២ មីក ៧:៨ **២៤:១៨** ទ យប ៣១:២៩ **២៤:១៩** ធ ទដ ៣៧:១ **២៤:២០** ន យប ១៨:៥ សភ ២៣:១៧–១៨

**២៤:២១** ប រម ១៣:១–៥ **២៤:២២** ផ ទដ ៧៣:១៩

**២៤:៩** *គំនិតពីសេចក្ដីចំកួត នោះជាអំពើបាប* ប្រៀបធៀប ១:១០–១៩ ៩:១៣–១៨ ។ *ហើយអ្នកណាដែលចំអកមើលងាយ* ដោយសាតែគេមានសេចក្ដីអំនួត ។ សេចក្ដីត្មះតិះដៀល (៩:៧) ការឈ្លោះប្រកែក (២២:១០) សូមមើល ១:២២ ។

**២៤:១០** ប្រៀបធៀប យរ ១២:៥ កឡ ៦:៩ ។

**២៤:១១** *គេដឹកនាំឱ្យត្រូវស្លាប់* គឺជាការកាត់ទោសចំពោះអ្នកអត់មានទោសកំហុសរហូតដល់ស្លាប់ (ប្រៀបធៀប ១៧:១៥ អស ៥៨:៦–៧) ។

**២៤:១២** *មើលយើងមិនបានដឹងទេ* សូមមើល យក ៤:១៧ ។ *ទ្រង់ថ្លឹងមើលចិត្តតើទ្រង់មិនពិចារណាឃើញ* គឺព្រះទ្រង់ទប់ស្គាល់ពីចិត្តយើង ។ និងអារម្មណ៍របស់យើង (សូមមើល ១៦:២ ២១:២ និងការពន្យល់ ទដ ៩៤:៩–១១) ។ *សងដល់មនុស្សទាំងឡាយ* សូមមើល ២៩ ២០:២២ ទដ ៥:១០ និងការពន្យល់ ។

**២៤:១៤** *ថាប្រាជ្ញាក៏ល្អដល់ព្រលឹង* នោះគឺជាប្រភពនៃអាហារដែលអាចផ្ដល់ឱ្យរូបរាង្គកាយធំធាត់លូតលាស់បានល្អ (សូមមើល ១៦:២៤ និងការពន្យល់) ។ ហើយសេចក្ដីសង្ឃឹមរបស់ឯង ដែលខុសនឹង ខ.២០ សូមមើល ទដ ៩:១៨ ៣៧:៣៧ យរ ២៩:១១ ។

**២៤:១៥** *កុំឱ្យលបចាំប្រទូស្ដ* សូមមើល ១:១១ និងការពន្យល់ ១២:៦ ទដ ១០:៩–១០ ។

**២៤:១៦** *ដល់៧ដង* គឺបង្ហាញពីលក្ខណៈដែលមានច្រើនដង ច្រើនពេល (សូមមើល ៦:១៦ យប ៥:១៩ និងការពន្យល់ ប្រៀបធៀប សភ ២៦:១៦) ។ *គង់តែនឹងក្រោកឡើងវិញ* គឺជាព្រះបន្ទូលសន្យានឹងជួយដល់អស់អ្នកដែលសុចរិត (ប្រៀបធៀបនឹង ទដស ៣៤:១៩ ៣៧:២៤ មីក ៧:៨) ។ *មនុស្សអាក្រក់ត្រូវទំលាក់* សូមមើល ខ.២២ ៤:១៩ ៦:១៥ និងការពន្យល់ ១១:៣,៥ ។

**២៤:១៧** *កុំឱ្យមានចិត្តរីករាយ* សូមមើល ១៧:៥ និងការពន្យល់ ។

**២៤:១៨** *ទ្រង់បង្វែរសេចក្ដីក្រោធចេញពីអ្នកនោះ* សាសន៍អេដំម ក៏ទទួលរងការទុក្ខព្រួយដោយព្រោះពួកគេសប្បាយលើគំនរទុក្ខរបស់រាស្ត្រអ៊ីស្រាអែល គឺខណៈពេលរាស្ត្រអ៊ីស្រាអែលមានទុក្ខព្រួយ (សូមមើល ទដ ១៣៧:៧ និងការពន្យល់ អរ ៣៥:១៥) ។

**២៤:១៩** ក៏បង្ហាញក្នុង ទដ ៣៧:១ សូមមើល ខ.១ ៣:៣១ ២៣:១៧ ។

**២៤:២០** *និងគ្មានរង្វាន់ណា* ចំពោះមនុស្សអាក្រក់និងមិនបានរង្វាន់ ឬកូនចៅជំនាន់ក្រោយរបស់គេក្ដី (ដែលផ្ទុយនិង ខ.១៤ ២៣:១៨ សូមមើល ទដ ៣៧:២,២៨,៣៨) ។ *ហើយចង្កៀងរបស់មនុស្សកោងកាចនិងត្រូវរលត់ទៅ* សូមមើលការពន្យល់ ១៣:៩ ។

**២៤:២១** *ចូរកោតខ្លាចដល់ព្រះយេហូវ៉ា ហើយដល់ស្ដេចផង* ជាព្រះបន្ទូលឱ្យយើងចុះចូលនិងរដ្ឋអំណាចស៊ីវិលក៏ដូចជាក្នុងសេចក្ដីបញ្ញត្តិនៅក្នុង សស ៨:២–៥ ១ពត ២:១៧ គឺនិយាយពីសេចក្ដី"កោតខ្លាចដល់ព្រះអម្ចាស់ ឬការគោរពដល់ព្រះមហាក្សត្រចំណែកឯគម្ពីរ រម ១៣:១–៧ ក៏បង្គាប់ឱ្យមានការស្ដាប់បង្គាប់ដូចគ្នាដែរ (សូមមើលការពន្យល់ រម ១៣:១–៧) ។

**២៤:២២** *គេភ្លាម* នោះគឺជាសេចក្ដីអន្តរាយ និងការវិនាសដែលតែងតែមានមកលើពួកគេ ។ ឯការជំនុំជម្រះរបស់ព្រះអម្ចាស់មានលក្ខណៈសាមញ្ញបំផុត (សូមមើល ៦:១៥ ១១:៣,៥) ប៉ុន្តែអំណាចចេស្ដារបស់ស្ដេចក៏បានឃើញច្បាស់ក្នុង ២០:៨,២៦ ។

## ពាក្យជាបន្តរបស់ពួកអ្នកប្រាជ្ញ

២៣សេចក្ដីទាំងនេះក៏ជាពាក្យពោលទុក របស់ពួកអ្នក
ប្រាជ្ញដែរ[ព] គឺថា ការដែលយោគយល់[ភ]ខាងអ្នកណាក្នុង
រឿងក្ដី នោះមិនល្អទេ[ម] ២៤អ្នកណាដែលកាត់ឱ្យមនុស្ស
អាក្រក់ថា ឯងសុចរិតទេ[យ] នោះបណ្ដាជននឹងប្រទេចផ្ដាសា
ដល់អ្នកនោះ ហើយអស់ទាំងសាសន៍នឹងស្អប់ខ្ពើមអ្នកនោះ
ដែរ ២៥តែឯអ្នកណាដែលបន្ទោសដល់មនុស្សអាក្រក់វិញ
គេនឹងពេញចិត្តចំពោះអ្នកនោះ ហើយនិងមានពរយ៉ាង
វិសេសមកស្ថិតលើអ្នកនោះដែរ ២៦អ្នកណាដែលតបឆ្លើយ
ដោយពាក្យត្រឹមត្រូវ នោះគេនឹងថើបអ្នកនោះដោយបបូរ
មាត់ ។

២៧ចូរត្រៀមការឯងនៅខាងក្រៅចុះ ហើយរៀបចំ
សំរាប់ខ្លួន នៅឯវាលជាមុនសិន ទើបសង់ផ្ទះឯងឡើងជា
ក្រោយ ។

២៨កុំឱ្យធ្វើបន្ទាល់ទាស់នឹងអ្នកជិតខាង ដោយឥតហេតុ
ឡើយ[រ] ក៏កុំឱ្យបញ្ឆោតដោយបបូរមាត់ឯងដែរ ២៩កុំឱ្យ
ពោលដូច្នេះឡើយ ថា អញនឹងប្រព្រឹត្តដល់គេ ដូចជាគេ
បានប្រព្រឹត្តដល់អញដែរ អញនឹងសងដល់អ្នកនោះតាម
ការដែលគេបានប្រព្រឹត្តរួចហើយ[ល] ។

៣០យើងបានដើរក្បែរចំការរបស់មនុស្សខ្ជិលច្រអូស[វ]
ហើយក្បែរដំណាំទំពាំងបាយជូររបស់មនុស្សដែលឥតមាន
ប្រាជ្ញា ៣១នោះឃើញថា មានបន្លាដុះគ្របពេញហើយ ដី
នោះដេរដាសទៅដោយព្រៃទ្រុបទ្រុល ឯកំផែងថ្មក៏រលំ
ដែរ ៣២នោះយើងបានរំពឹងមើល ហើយពិចារណាដោយ
ល្អិត ក៏យល់ឃើញ ហើយទទួលសេចក្ដីបង្រៀនថា ៣៣ដេក
បន្តិច ងោកបន្តិច ឱបដៃនឹងដេកបន្តិច[ស] ៣៤យ៉ាងនោះ
សេចក្ដីកំសត់ទុគ៌តរបស់ឯង នឹងលោមកដល់ដូចជាចោរ
ប្លន់ ព្រមទាំងសេចក្ដីខ្វះខាត ដូចជាមនុស្សកាន់គ្រឿងអាវុធ
ផង[ហ] ។

## សុភាសិតជាបន្តរបស់ស្ដេចសាឡូម៉ូន

**២៥** ១នេះក៏ជាសុភាសិត[ក]របស់ស្ដេចសាឡូម៉ូនដែរ ជា
សេចក្ដីដែលពួកស្មៀនរបស់ហេសេគា ស្ដេចសាសន៍យូដា
បានចំឡងទុក[ខ] ។

២ការដែលលាក់បំបាំងន័យសេចក្ដី នោះជាទីគាប់
ព្រះហឫទ័យដល់ព្រះ តែពួកស្ដេចវិញ ទ្រង់សព្វព្រះទ័យនឹង
ស្វែងរកឱ្យយល់[គ] ៣ផ្ទៃមេឃខ្ពស់យ៉ាងណា ហើយផែនដី
ជ្រៅយ៉ាងណា ព្រះទ័យនៃស្ដេចក៏ស្ទង់មើលមិនដល់យ៉ាង

**២៤:២៣** ព សភ ១:៦ ភ នក ១៨:១៦ លវ ១៩:៥ ម ទដ ៧២:២ សភ ២៨:២១ ៣១:៨-៩ យរ ២២:១៦
**២៤:២៤** យ សភ ១៧:១៥
**២៤:២៨** រ ទដ ៧:៤
**២៤:២៩** ល ២០:២២ មថ ៥:៣៨-៤១
**២៤:៣០** វ សភ ៦:៦-១១ ២៦:១៣-១៦
**២៤:៣៣** ស សភ ៦:១០
**២៤:៣៤** ហ សភ ១០:៤ សស ១០:១៨
**២៥:១** ក ១ពវ ៤:៣២ ខ សភ ១:១
**២៥:២** គ សភ ១៦:១០-១៥

**២៤:២៣-៣៤** ក្នុងខទាំងនេះក៏បង្ហាញពីមនុស្សមានប្រាជ្ញាដែរ គឺនៅក្នុង ២២:១៧-២៤:២២ ។

**២៤:២៣** *ការដែលយោគយល់ខាងអ្នកណាក្នុងរឿងក្ដីនោះមិនល្អទេ* សូមមើល ១៨:៥ និងការពន្យល់ ។

២៤:២៤ ថាឯងសុចរិតទេ គឺជាពាក្យសំដីមិនពិតរបស់មនុស្សអាក្រក់ សូមមើល ១៧:១៥ និងការពន្យល់ ។ *នោះបណ្ដាជននិងប្រទេចផ្ដាសាដល់អ្នកនោះ* ពាក្យនេះគឺប្រៀបដូចជាប្រជារាស្ដ្រទាំងអស់ "បានប្រទេចផ្ដាសាដល់អស់អ្នកណាដែលបង្ខំទុកស្រូវអង្ករ ដែលពុំបានចែកដល់មនុស្សក្រីក្រ" (សូមមើល ១១:២៦) ។

**២៤:២៥** សូមមើល ១០:៦ និងការពន្យល់ ចទ ១៦:២០ ។

**២៤:២៦** *តបឆ្លើយដោយពាក្យត្រឹមត្រូវ* ប្រៀបធៀប ១៦:១៣ ។ *នឹងថើបអ្នកនោះដោយបបូមាត់* ប្រៀបដូចជាពាក្យផ្អែមល្ហែមដល់ព្រលឹង ១៦:២៤ ។

**២៤:២៨** *កុំឱ្យធ្វើទីបន្ទាល់ . . . ដោយឥតហេតុឡើយ* សូមមើល ៣:៣០ យប ២:៣ ៦:១៩ ។

**២៤:២៩** *អញនឹងសងដល់អ្នកនោះតាមការ . . .* សូមមើល ខ.១២ ។ គឺជាវិញ្ញាណនៃការសងសឹក ២០:២២ (សូមប្រៀបធៀប ២៥:២១-២២ មថ ៥:៤៣-៤៥ រម ១២:១៧) ។

**២៤:៣០** *មនុស្សខ្ជិលច្រអូស* សូមមើលការពន្យល់ ៦:៦ ។

**២៤:៣១** *មានបន្លាដុះ . . . ព្រៃទ្រុបទ្រុល* សូមមើល ១៥:១៩ និងការពន្យល់ ប្រៀបធៀប អស ៣៤:១៣ ។

**២៤:៣២** សូមមើល ២២:១៧ ២៣:១៣ និងការពន្យល់ ទដ ៤:៧ និងការពន្យល់ ។

**២៤:៣៣-៣៤** មើល ៦:១០-១១ និងការពន្យល់ ៦:១១ ។

**២៥:១-២៩:២៧** ក្នុងជំពូកទាំងនេះគឺជាពាក្យអត្ថបទសុភាសិត ដែលមានលក្ខណៈស្រដៀងៗគ្នារបស់ស្ដេចសាឡូម៉ូនដូចជា ១០:១-២២:១៦ ។

**២៥:១** *នេះជាសុភាសិតរបស់ស្ដេចសាឡូម៉ូន* សូមមើលការពន្យល់ ១:១ ១០:១ ដែលបានកត់ត្រាចំលងដោយពួកស្មៀនរបស់ស្ដេចហេសេគា ។ ក៏មានការសម្រួលជាច្រើនក្នុរាជកាលរបស់អង្គស្ដេចហេសេគា ដែលបានរៀបចំបទទំនុកចម្រៀងឱ្យទៅតាមទីកន្លែងសូរសំលេងជាក់លាក់ (២របា ២៩:៣០) ។ ស្ដេចហេសេគាក៏មានចំណាប់អារម្មណ៍ចំពោះពាក្យពេជន៍របស់ស្ដេចដាវីឌ ហើយគាត់ក៏ពេញចិត្តចំពោះការចងក្រងពាក្យសុភាសិតរបស់ស្ដេចសាឡូម៉ូនដែរ ។ ឯស្ដេចសាឡូម៉ូនជាស្ដេចចុងក្រោយបង្អស់របស់ពួកសាសន៍អ៊ីស្រាអែលទ្រង់ក៏បានបង្រួបបង្រួមពួកវង្សក្សត្រទាំងអស់ឱ្យរួមគ្នា ឯស្ដេចហេសេគា ក៏ជាស្ដេចដំបូងក្នុងការដឹកនាំស្រុកអ៊ីស្រាអែលទាំងមូល ។ (ក្រោយមកក៏មានការកំណត់ដាក់ព្រំដែនចំពោះនគរខាងជើង) បន្ទាប់ពីមានការបែកបាក់គ្នា ។

**២៥:២** *ការដែលលាក់កំបាំងន័យសេចក្ដី* ដោយព្រះអម្ចាស់មានគ្រប់ទាំងសេរីល្អ ហើយមនុស្សពុំអាចយល់បានទាំងស្រុងនូវភពចក្រវាលរបស់ទ្រង់ ឫក៏មាគាដែលទ្រង់ដឹកនាំ (សូមមើល ចទ ២៩:២៩ យប ២៦:១៤ និងការពន្យល់ អស ៤០:១២-២៤ រម ១១:៣៦) ។ ពាក្យថា *ស្វែងរកឱ្យយល់* គឺដូចជាព្រះមហាក្សត្រដែលមានពេញដោយសេរីល្អ បើព្រះមហាក្សត្រនោះអាចយល់បាននូវសេចក្ដីពិត និងសេចក្ដីយុត្តិធម៌ គឺមានគ្រប់លក្ខណៈសម្បត្តិហើយ (សូមមើល ១ពវ ៣:៩ ៤:៣៤) ។

**២៥:៣** *ស្ទង់មើលមិនដល់នោះដែរ* ដូចជាការដែលពួកគេពុំយល់ ក៏មានដូច

នោះដែរ ៤ចូរដេញយកអាចម៍ប្រាក់ចេញ នោះនឹងមាន
គ្រឿងចេញពីពុម្ពមកសិរាប់ជាងខាត់ ៥ក៏ដកយកមនុស្ស
អាក្រក់ចេញពីចំពោះស្តេច[ឃ] នោះរាជ្យទ្រង់នឹងបានតាំង
នៅ[ង] ខ្ជាប់ខ្ជួនក្នុងសេចក្តីសុចរិត[ច]។
៦កុំឱ្យឯងបញ្ចើខ្លួននៅចំពោះស្តេចឡើយ ក៏កុំឱ្យឈរ
នៅទីរបស់អ្នកធំដែរ ៧ដ្បិតបើគេមកនិយាយនឹងឯងថា
អញ្ជើញឡើងមកឯណេះ[ឆ] នោះល្អជាជាងត្រូវបន្ទាបនៅ
ចំពោះអ្នកធំ ដែលភ្នែកឯងបានឃើញហើយនោះវិញ ។
៨កុំឱ្យឯងរហ័សនឹងចេញទៅតនឹងគេឡើយ ក្រែងដល់
ចុងបំផុត កាលណាអ្នកជិតខាងបានធ្វើឱ្យឯងខ្មាសហើយ
នោះឯងមិនដឹងធ្វើអ្វីទៀតទេ[ជ] ៩ចូរទៅជជែករឿងរបស់
ឯង ចំពោះអ្នកជិតខាង ដោយមានតែគ្នា២នាក់ប៉ុណ្ណោះ កុំ
ឱ្យបើកការសំងាត់របស់អ្នកដទៃឡើយ ១០ក្រែងអ្នកដែលឮ
គេធ្វើឱ្យឯងខ្មាសវិញ ហើយសេចក្តីអាម៉ាស់របស់ឯងនឹង
មិនចេះបាត់ឡើយ ។
១១ពាក្យសំដីដែលនិយាយចំពេល នោះធៀបដូចជា
ផ្លែសារីមាសធ្លាក់ភ្ជាប់នឹងក្បាច់ប្រាក់[ឈ] ១២អ្នកដែលចេះស្តី
បន្ទោសដោយប្រាជ្ញា នោះក៏ដូចជាក្រវិលមាស និងគ្រឿង
លំអមាសសុទ្ធ ដល់ត្រចៀកដែលព្រមស្តាប់តាមដែរ[ញ]
១៣អ្នកនាំសារដែលស្មោះត្រង់ នោះប្រៀបដូចជាត្រជាក់

**២៥:៥** ឃ សភ ២០:៨ ង ២សយ ៧:១៣ ច សភ ១៦:១២ ២៩:១៤
**២៥:៧** ឆ លក ១៤:៧-១០
**២៥:៨** ជ មថ ៥:២៥-២៦
**២៥:១១** ឈ ខ.១២ សភ ១៥:២៣
**២៥:១២** ញ ខ.១១ ទដ ១៤១:៥ សភ ១៣:១៨
**២៥:១៣** ដ សភ ១០:២៦ ១៣:១៧
**២៥:១៥** ឋ សស ១០:៤ ឌ សភ ១៥:១
**២៥:១៦** ឍ ខ.២៧
**២៥:១៨** ណ សភ ១២:១៨

នៃហិមៈនៅរដូវចំរូត ដល់ពួកអ្នកដែលចាត់ប្រើ ដ្បិតអ្នក
នោះលំហើយព្រលឹងរបស់ចៅហ្វាយខ្លួន[ដ]។
១៤អ្នកណាដែលអួត ដោយពាក្យកំភូត ពីទានដែលខ្លួន
ឱ្យ នោះទុកដូចជាពពក ហើយនិងខ្យល់ដែលឥតមាន
ភ្លៀង ។
១៥ដោយការខំអត់ធ្មត់ នោះទើបនឹងបន្ទន់ចិត្តរបស់
ចៅហ្វាយបាន[ឋ] ហើយអណ្តាតស្រទន់នឹងអាចបំបាក់ឆ្អឹង
បានដែរ[ឌ]។
១៦តើឯងរកបានឃ្មុំហើយឬ ចូរបរិភោគតែល្មមសម
គួរចុះ ក្រែងបរិភោគឆ្អែតទៅនឹងក្អួតចេញមកវិញ[ឍ]។
១៧កុំឱ្យជើងឯងចូលផ្ទះអ្នកជិតខាងជាញឹកញយពេក
ឡើយ ក្រែងគេធុញទ្រាន់ ហើយស្អប់ឯងវិញ ។
១៨អ្នកណាដែលធ្វើបន្ទាល់ក្លែង ទាស់នឹងអ្នកជិតខាង
ខ្លួន នោះធៀបដូចជាញញួរ និងដាវ ហើយនិងព្រួញយ៉ាង
មុត[ណ]។
១៩ការដែលទុកចិត្តពឹងដល់មនុស្សមិនស្មោះ នៅគ្រា
លំបាក នោះធៀបដូចជាធ្មេញបាក់ ហើយជើងដែលថ្លស់
លាសចេញ ។
២០អ្នកណាដែលច្រៀងចំរៀង ជូនដល់មនុស្សដែល
មានចិត្តកើតទុក្ខ ឱ្យគេស្តាប់ នោះធៀបដូចជាគេដោះអាវ

ជារឿងបួនយ៉ាងក្នុង ៣០:១៨-១៩ ។ គឺព្រះអម្ចាស់ដែលជាអ្នកគ្រប់គ្រងលើស្តេចទាំងនោះ (សូមមើលការពន្យល់ ២១:១) ។

**២៥:៤** *ចូរដេញយកអាចម៍ប្រាក់ចេញ* គឺជាការប្រៀបប្រដូចពីការធ្វើឱ្យបរិសុទ្ធដល់សង្គមដែលមានមនុស្សទូទៅ និងអ្នកដឹកនាំឱ្យគេទាំងអស់បានបរិសុទ្ធឡើង មើល អស ១:២២-២៥ អគ ២២:១៨ សក ១៣:៨-៩ មឡ ៣:២-៣ ។

**២៥:៥** *នោះរាជ្យទ្រង់នឹងបានតាំងនៅខ្ជាប់ខ្ជួនក្នុងសេចក្តីសុចរិត* សូមមើលការពន្យល់ ១៦:១២ ឬ ២០:២៦ ។

**២៥:៦** *នៅចំពោះស្តេច* គឺជាពិសេសនៅពេលមានពិធីបុណ្យម្តងៗ (ធៀបនិង ២៣:១) ។ ព្រះយេស៊ូវមានបន្ទូលអំពីទីកន្លែងក្នុងពិធីមង្គលការមួយ (លក ១៤:៧-១១) ។

**២៥:៧** *អញ្ជើញឡើងមកឯណេះ* ធៀបដូចជា"មិត្តដែលបានប្តូរទៅរកទីតាំងល្អ" (លក ១៤:១០) ដែលខុសនឹង អស ២២:១៥-១៩ ។

**២៥:៨** *កុំឱ្យឯងរហ័សនឹងចេញទៅតតាំងនឹងគេ* គឺជាសេចក្តីទូន្មានប្រដៅស្តីអំពីភាពមានជម្លោះដ៏ធំមួយ (សូមមើល ១៧:១៤) ។

**២៥:៩** *កុំឱ្យបើកការសំងាត់របស់អ្នកដទៃឡើយ* តែបើអ្នកប្រព្រឹត្តការនេះគឺអ្នកនឹងក្លាយជាមនុស្សរអេករអូចហើយ (សូមមើល ១១:១៣ ២០:១៩) ។

**២៥:១០** *សេចក្តីអាម៉ាស់* តែកេរ្តិ៍ឈ្មោះល្អគឺជាជីវិតមួយដែលមានទ្រព្យដ៏មានតម្លៃបំផុត (សូមមើល ២២:១ និងការពន្យល់) ។

**២៥:១១** *មាស . . . ប្រាក់* សូមប្រៀបធៀបនឹង ផលផ្លែនិងប្រាជ្ញា សូមមើល ៨:១៩ ។

**២៥:១២** *ក្រវិលមាស* គឺជាពាក្យប្រៀបធៀបទៅនឹងខ្សែកដ៏ស្រស់ស្អាត និងជាតំណាងឱ្យប្រាជ្ញាដ៏ពេញបរិបូរ និងសេចក្តីបង្រៀនដ៏ល្អ (សូមមើល ១:៩ ៣:២២ ៤:៩)។ *អ្នកដែលចេះស្តីបន្ទោសដោយប្រាជ្ញា* សូមមើលការប្រៀបធៀប"សេចក្តីបន្ទោសនៃជីវិត" ដែលមានក្នុង ១៥:៣១ ។

**២៥:១៣** *ត្រជាក់នៃហិមៈ* គឺមានសណ្ឋានដូចជាភេសជៈ ដែលមានភាពត្រជាក់ដោយការធ្លាក់ព្រឹលពីលើភ្នំ វាមិនមែនជាព្រឹលនារដូវច្រូតកាត់ទេ ។ សូមមើល ២៦:១ ដែលខុសនឹង ១០:២៦ ។ ពាក្យថា *អ្នកនាំសារដែលស្មោះត្រង់* សូមមើល ១៣:១៧ និងការពន្យល់ ។

**២៥:១៤** *ពពក . . . ខ្យល់ដែលឥតមានភ្លៀង* គឺជារូបភាពប្រដូចចំពោះការអនុវត្តរបស់ពួកគ្រូក្លែងក្លាយនៅស្រុកយូដា ១២ ។

**២៥:១៥** *ដោយការខំអត់ធ្មត់ នោះទើបនឹងបន្ទន់ចិតរបស់ចៅហ្វាយបាន* ប្រៀបធៀប ១៤:២៩ ។ *អណ្តាតស្រទន់* សូមមើលការពន្យល់ ១៥:១ ។

**២៥:១៦** *ឃ្មុំ* សូមមើល ខ.២៧ ។

**២៥:១៨** *ញញួរ . . . ដាវ . . . ព្រួញ* សូមធៀបនឹង ទដ ៥៧:៤ យរ ៩:៨ ។ ពាក្យថា *បន្ទាល់ក្លែង* សូមមើលការពន្យល់ ៦:១៩ ២៤:២៨ នក ២០:១៦ ។

**២៥:១៩** *ធ្មេញបាក់ . . . ថ្លស់លាស* (សូមមើល អស ៣៦:៦) ។

**២៥:២០** *អំបិលក្បុង* សូមមើល យរ ២៣:២២ ឯអំបិលក្បុងនេះអាចជា សូឌីយ៉ូមកាបូន ។ ឯអំបិលនិងមានប្រត្តិកម្មលេចឡើងនៅពេលដែលទឹកខ្មេះចាក់ទៅលើវា ។ ពាក្យថា *ច្រៀងចំរៀងជូនដល់មនុស្សដែលមានចិត្តកើតទុក្ខ* គឺស្ថានភាពរបស់ពួកដែលគេបាននិរទេស ត្រូវគេបង្ខំឱ្យច្រៀងតែពួកគេមានចិត្តស្ទាក់ស្ទើរពុំចង់ច្រៀងឡើយ គឺចច្រៀងសម្រាប់ទីក្រុងស៊ីយ៉ូន

នៅរដូវរងា ឬដូចជាចាក់ទឹកខ្មេះទៅលើអំបិលក្បុង ។
២១បើសត្រូវឯងឃ្លាន ចូរឱ្យវាស៊ីចុះ បើវាស្រេក ត្រូវ
ឱ្យវាផឹកផង ២២យ៉ាងនោះនឹងបានដូចជាបង្គររងើកភ្លើង[ត]
នៅលើក្បាលវា ហើយព្រះយេហូវ៉ាទ្រង់នឹងប្រទានរង្វាន់
ដល់ឯង[ថ]។
២៣ខ្យល់ពីខាងជើងរមែងនាំភ្លៀងមក ហើយអណ្តាត
ដែលនិយាយដើមគេ ក៏នាំឱ្យគេមានមុខមួម៉ៅដូច្នោះដែរ ។
២៤ស៊ូនៅក្នុងទីកៀន១នៅលើដំបូលផ្ទះ ជាជាងនៅក្នុង
ផ្ទះធំទូលាយ ជាមួយនឹងស្ត្រីដែលចេះតែរករឿង[ទ]។
២៥ទឹកបានត្រជាក់ដល់ព្រលឹងមនុស្សល្វឹងល្វើយជាយ៉ាង
ណា នោះដំណឹងល្អដែលមកពីស្រុកឆ្ងាយក៏យ៉ាងនោះ
ដែរ[ធ]។
២៦មនុស្សសុចរិតដែលចុះចាញ់ចំពោះមនុស្សអាក្រក់
នោះធៀបដូចជារន្ធទឹកល្អក់ ក៏ដូចជាក្បាលទឹកដែលខូច
ហើយដែរ ។
២៧បើបរិភោគទឹកឃ្មុំច្រើនពេក[ន] នោះមិនល្អទេ មួយ
ទៀត ដែលស្វែងរកកិត្តិសព្ទដល់ខ្លួន នោះជាបន្ទុកយ៉ាង
ធ្ងន់ដែរ[ប]។
២៨បើអ្នកណាដែលមិនចេះគ្រប់គ្រងលើចិត្តរបស់ខ្លួន
នោះធៀបដូចជាទីក្រុងដែលរលំ ហើយឥតមានកំផែង ។

**២៦** ១ការដែលហិមៈធ្លាក់នៅរដូវក្តៅ ហើយភ្លៀង[ក]
ធ្លាក់នៅរដូវចំរូតមិនសមយ៉ាងណា កិត្តិយសក៏មិនសមនឹង
មនុស្សល្ងីល្ងើយ៉ាងនោះដែរ[ខ] ២ការដែលចាបហើរទៅ
បាត់ ហើយសត្វត្រចៀកកាំចេះតែហើរទៅមកយ៉ាងណា
នោះ សេចក្តីបណ្តាសាឥតហេតុ មិនទំដាប់ឡើយក៏យ៉ាង
នោះដែរ[គ] ៣មានត្មោងសំរាប់សេះ មានបង្ហៀរសំរាប់លា[ឃ]
ហើយរំពាត់ក៏សំរាប់ខ្នងមនុស្សល្ងីល្ងើដែរ[ង]។
៤កុំឱ្យឆ្លើយតបនឹងមនុស្សល្ងីល្ងើ តាមសេចក្តីចំកួតរបស់
វាឡើយ ក្រែងឯងក៏បានដូចជាវាដែរ[ច] ៥ចូរឆ្លើយតបនឹង
មនុស្សល្ងីល្ងើ ឱ្យចំនឹងសេចក្តីចំកួតរបស់វាចុះ ក្រែងវា
មើលខ្លួនដោយសេចក្តីអំនួតថា ជាអ្នកមានប្រាជ្ញា[ឆ] ៦អ្នក
ណាដែលប្រើមនុស្សល្ងីល្ងើឱ្យនាំដំណឹងទៅ នោះឈ្មោះថា
កាប់ផ្តាច់ជើងរបស់ខ្លួន ហើយក៏ផឹកស្រូបសេចក្តីអន្តរាយ
ដែរ[ជ] ៧ជើងរបស់មនុស្សដែលដើរចាក់ខ្វើច បានខ្សោយ
យ៉ាងណា នោះពាក្យសុភាសិតនៅក្នុងមាត់មនុស្សល្ងីល្ងើ
ក៏យ៉ាងនោះដែរ[ឈ] ៨អ្នកដែលចងក្រួសភ្ជាប់ក្នុងខ្សែដង្ហក់ជា
យ៉ាងណា នោះអ្នកដែលលើកមុខមនុស្សល្ងីល្ងើក៏យ៉ាងនោះ

**២៥:២២** ត ទដ ១៨:៨ ថ ២រប ២៨:១៥ មថ ៥:៤៤ រម ១២:២០
**២៥:២៤** ទ សភ ២១:៩
**២៥:២៥** ធ សភ ១៥:៣០
**២៥:២៧** ន ខ.១៦ ប សភ ២៧:២ មថ ២៣:១២
**២៦:១** ក ១សយ ១២:១៧ ខ ខ.៨ សភ ១៩:១០
**២៦:២** គ ចទ ២៣:៥
**២៦:៣** ឃ ទដ ៣២:៩ ង សភ ១០:១៣
**២៦:៤** ច ខ.៥ អស ២៦:២១
**២៦:៥** ឆ ខ.៤ សភ ៣:៧
**២៦:៦** ជ សភ ១០:២៦ **២៦:៧** ឈ ខ.៩

(សូមមើល ទដ ១៣៧:៣-៤) ។

**២៥:២១-២២** ជាសេចក្តីសម្រង់ក្នុងគម្ពីរ ១២:២០ ។

**២៥:២១** គឺជាការលើកទឹកចិត្តក្នុង ២០:២២ ពីការដែលត្រូវមានសចក្តីល្អដល់សត្រូវ នក ២៣:៤-៥ (សូមមើលការពន្យល់ផងដែរ) ។ *ឱ្យវាស៊ីចុះ . . . ឱ្យវាផឹកផង* គឺខណៈដែលលោកអេលីសេស្នើឡើង ចំពោះកងទ័ពស្រុកអើរ៉ាមដែលចាប់បាននោះ តែផ្ទុយទៅវិញពួកទ័ពទាំងនោះក៏បានទទួលឱ្យស៊ីចុកយ៉ាងច្រើន ហើយក៏ឱ្យគេវិលត្រលប់ទៅឯស្រុកពួកគេវិញ (សូមមើល ២ពាវ ៦:២១-២៣ ធៀបនឹង ២រប ២៨:១៥) ។

**២៥:២២** *ជាបង្គររងើកភ្លើងនៅលើក្បាលវា* គឺជាពាក្យប្រដូចពីការដាក់ទណ្ឌកម្មដល់គូរសត្រូវវិញ គឺចំពោះអ្នកដែលប្រព្រឹត្តអាក្រក់ (សូមមើល ទដ ១៤០:១០) ហើយវាផ្តល់មកជាលទ្ធផលល្អ គឺការនាំឱ្យពួកសត្រូវទាំងនោះលន់តួបាបនិងផ្លាស់ប្តូរជីវិតរបស់ពួកគេ ។ ពាក្យថា *ហើយព្រះយេហូវ៉ាទ្រង់ប្រទានរង្វាន់ដល់ឯង* ទោះជាសត្រូវនៅតែជាសត្រូវក៏ដោយ (សូមធៀបនឹង ១១:១៨ ១៩:១៧) ។

**២៥:២៣** *ពីខាងជើង* ជាចលនាខ្យល់បក់ ក៏អាចជាខ្យល់មកពីទិសខាងជើងឈាងខាងលិច (ធៀបនឹង លក ១២:៤៥) ។ ពាក្យថា *អណ្តាតដែលនិយាយដើមគេ* គឺជាអណ្តាតភូតកុហករបស់អ្នកដែលពង្រីកនូវពាក្យមួលបង្កូច (ប្រៀបធៀប ១០:១៨) ។

**២៥:២៤** មានក្នុង ២:៩ (មើលកាពន្យល់ ២:៩) ។

**២៥:២៥** *នោះដំណឹងល្អដែលមកពីស្រុកឆ្ងាយ* មើល លប ៤៥:២៥-២៨ ។

**២៥:២៦** *ជារន្ធទឹកល្អក់* ប្រៀបធៀប អគ ៣៤:១៨-១៩ ។ *មនុស្សសុចរិតដែលចុះចាញ់ចំពោះមនុស្សអាក្រក់* ដូចជាតាមរយៈធ្វើការសូកប៉ាន់ (ធៀបនឹង ១៧:៨ ២៩:៤ អស ១:២១-២៣) ។

**២៥:២៧** *ទឹកឃ្មុំច្រើនពេក* សូមមើល ខ.១៦ ។ ពាក្យថា *ដែលស្វែងរកកិត្តិសព្ទដល់ខ្លួន* សូមមើល ខ.៦-៧ និងការពន្យល់ ។

**២៦:១** *ភ្លៀងធ្លាក់នៅរដូវចំរូត* គឺវាកំរភ្លៀងធ្លាក់នៅក្នុងទឹកដីបរិសុទ្ធណាក្នុងកំឡុងខែមិថុនា រហូតដល់ខែកញ្ញានោះទេ ប៉ុន្តែ សូមមើល ១សយ ១២:១៧-១៨ ។ ពាក្យថា *កត្តិយសក៏មិនសមនឹងមនុស្សល្ងីល្ងើយ៉ាងនោះ* សូមមើល ខ.៨ ។

**២៦:២** *សេចក្តីបណ្តាសាឥតហេតុ មិនទំដាប់ឡើយ* នៅខណៈពេលស្តេចដាវីឌត្រូវទទួលបណ្តាសារ ដោយសារតែស៊ីម៉ាយ ហើយបណ្តាសារនោះមិនមានឥទ្ធិពលច្រើនមកលើទ្រង់ឡើយ ពីព្រោះទ្រង់ឥតមានកំហុសក្នុងរឿងឃាដកម្មដល់ក្រុមគ្រួសារស្តេចសូលឡើយ (២សយ ១៦:៨,១២) ។

**២៦:៣** *រំពាត់ក៏សំរាប់ខ្នងមនុស្សល្ងីល្ងើដែរ* សូមមើល ១៤:៣ ១៩:២៩ ។

**២៦:៤** *កុំឆ្លើយតបនឹងមនុស្សល្ងីល្ងើតាមសេចក្តីចំកួតរបស់វាឡើយ* (សូមមើល ២៣:៩ មថ ៧:៦ និងការពន្យល់) ។

**២៦:៦** *ក៏ផឹកស្រូបសេចក្តីអន្តរាយ* សូមមើល ៤:១៧ និងការពន្យល់ យប ៣៤:៧ ។ *មនុស្សល្ងីល្ងើឱ្យនាំដំណឹងទៅនោះឈ្មោះថា កាត់ផ្តាច់នឹងរបស់ខ្លួន* គឺគេនោះមានលក្ខណៈមិនដូចជាតំណាងពិតប្រាកដទេ តាមពិតគេធ្វើឱ្យខូចការ ខូចប្រយោជន៍ទទេ (សូមមើល ១៣:១៧ និងការពន្យល់) ។

**២៦:៨** *អ្នកដែលចងក្រួសភ្ជាប់ក្នុងខ្សែដង្ហក់ជាយ៉ាងណា* គឺមនុស្សល្ងីល្ងើដែលមានអំណាច មានគ្រឿងសឹកសាហាវតែវាឥតប្រយោជន៍ទទេ ។ ពាក្យថា

ដែរ[ញ] ៩បន្លាមុតចូលក្នុងដៃរបស់មនុស្សស្រវឹងជាយ៉ាងណា
នោះពាក្យសុភាសិតនៅក្នុងមាត់មនុស្សល្ងីល្ងើក៏យ៉ាងនោះ
ដែរ[ដ] ១០ពលធ្នូម្នាក់ដែលជំនាញបាញ់ឱ្យរបួសទាំងអស់ជា
យ៉ាងណា អ្នកដែលជួលមនុស្សល្ងីល្ងើ និងមនុស្សដែលដើរ
តាមផ្លូវក៏យ៉ាងនោះដែរ ១១មនុស្សល្ងីល្ងើដែលចេះតែធ្វើ
អំពើចំកួតរបស់វាច្រំដែលទៀត[ឋ] នោះធៀបដូចជាឆ្កែ
ដែលត្រឡប់ទៅស៊ីកំអួតវិញ[ឌ] ១២ឯងដែលឃើញមនុស្ស
ដែលប្រកាន់ថាខ្លួនមានប្រាជ្ញាឬទេ[ឍ] មានសង្ឃឹមចំពោះ
មនុស្សល្ងីល្ងើជាជាងអ្នកនោះទៅទៀត[ណ] ។
១៣មនុស្សខ្ជិលច្រអូសតែងតែថា[ត] មានសិង្ហ១នៅ
កណ្ដាលថ្នល់ មានសិង្ហ១នៅត្រង់ផ្លូវ[ថ] ១៤មនុស្សខ្ជិលច្រអូស
ចេះតែបំរាសនទៀលនៅលើគ្រែ បែបដូចទ្វារដែលបិទ
បើកទៅមកជាប់នៅត្រចៀកដែរ[ទ] ១៥មនុស្សខ្ជិលច្រអូសគេ
លូកដៃទៅក្នុងចាន ហើយដែលដកមកបញ្ចុកមាត់វិញ នោះ
ក៏រួយដៃដល់គេណាស់[ធ] ១៦មនុស្សខ្ជិលច្រអូស គេតែង
ប្រកាន់ថា ខ្លួនមានប្រាជ្ញាជាជាងមនុស្ស៧នាក់ដែលតប
ឆ្លើយដោយវាងវៃ ។
១៧អ្នកណាដែលកំពុងតែដើរតាមផ្លូវ ព្រមទុកឱ្យខ្លួន
ក្ដៅក្រហាយ ដោយការឈ្លោះប្រកែករបស់អ្នកដទៃ នោះ
ធៀបដូចជាមនុស្សដែលចាប់ត្រចៀកឆ្កែ ១៨មនុស្សដែល
បញ្ឆោតអ្នកជិតខាង រួចពោលថា អញគ្រាន់តែធ្វើលេង
ទេតើ ១៩នោះប្រៀបដូចជាមនុស្សឆ្កួតដែលបោះកំចាយ
អង្កត់ឧសកំពុងឆេះ ព្រមទាំងព្រួញ និងសេចក្ដីស្លាប់ផង
២០ទីណាដែលឥតមានឧស នោះភ្លើងក៏រលត់ ហើយទីណា
ដែលឥតមានអ្នកបេះបួយ នោះសេចក្ដីទាស់ទែងគ្នាក៏បាត់
អស់ទៅដែរ[ន] ២១មនុស្សដែលចេះតែរករឿង គេរមែងអុច
អាលឱ្យមានសេចក្ដីទាស់ទែងគ្នា ឧបមាដូចជាដាក់ធ្យូងនៅ
លើរងើកភ្លើង ហើយដូចជាដាក់ឧសនៅលើភ្លើងដែរ[ប]
២២ពាក្យសំដីរបស់មនុស្សបេះបួយ ធៀបដូចជាចំណីដែល
ឆ្ងាញ់ពិសា ក៏ចុះទៅដល់ខាងក្នុងរបស់មនុស្ស[ផ] ២៣មាន
បបូរមាត់ហៃនិយាយ ហើយចិត្តអាក្រក់ នោះធៀបដូចជា
ភាជនៈដីស្រោបដោយអាចម៍ប្រាក់ ។
២៤អ្នកណាដែលស្អប់គេ នោះរមែងក្លែងពាក្យដោយ
បបូរមាត់[ព] នោះក៏ប្រមូលទុកសេចក្ដីបញ្ឆោតនៅក្នុងចិត្ត
ដែរ[ភ] ២៥កាលណាអ្នកនោះពោលពាក្យល្អ[ម] នោះកុំឱ្យ
ជឿឱ្យសោះ ដ្បិតនៅក្នុងចិត្តគេមានសេចក្ដីស្អប់ខ្ពើម៧មុខ[យ]
២៦ទោះបើសេចក្ដីសំអប់របស់គេបានគ្របបាំង ដោយពុត
មាយាក៏ដោយ គង់តែសេចក្ដីអាក្រក់របស់គេនឹងសំដែង
ចេញឱ្យច្បាស់ នៅចំពោះមុខនៃពួកជំនុំដែរ ២៧អ្នកណា

**២៦:៨** ញ ឧ.១
**២៦:៩** ដ ឧ.៧
**២៦:១១** ឋ ទដ ៨៥:៨ ឌ ២ពត ២:២២
**២៦:១២** ឍ សភ ៣:៧ ណ សភ ២៩:២០
**២៦:១៣** ត សភ ៦:៦–១១ ២៤:៣០–៣៤ ថ សភ ២២:១៣
**២៦:១៤** ទ សភ ៦:៩
**២៦:១៥** ធ សភ ១៩:២៤
**២៦:២០** ន សភ ២២:១០
**២៦:២១** ប សភ ១៤:១៧
**២៦:២២** ផ សភ ១៨:៨
**២៦:២៤** ព ទដ ៣១:១៨ ភ ទដ ៤១:៦
**២៦:២៥** ម ទដ ២៨:៣ យ យរ ៩:៤–៨

*លើមុខមនុស្សល្ងីល្ងើ* សូមមើល ឧ.១ ។

**២៦:៩** *មនុស្សល្ងីល្ងើ* ជាពាក្យសម្រាប់ទន្ទេញក្នុងគម្ពីរសុភាសិតដែលធ្វើឱ្យឈឺចាប់ដល់អ្នកញៀនស្រាដែលកំពុងតែអោបគុម្ពោតបន្លា ។

**២៦:១០** *អ្នកដែលជួលមនុស្សល្ងីល្ងើ និងមនុស្សដែលដើរតាមផ្លូវក៏យ៉ាងនោះដែរ* គឺដូចជាអ័ប៊ីម៉ាលេកកដ៏ជាសង្ឃបានជួល"ពួកមនុស្សពាលអនាថាដែលមានចរិតព្រហើន"ដើម្បីធ្វើកិច្ចការឱ្យគាត់ ក្នុងការធ្វើឃាដបងប្អូនប្រុសរបស់គាត់ ហើយបង្កើតច្បាប់ព្រៃផ្សៃឡើងដើម្បីអនុវត្តន៍ (សូមមើល ពច ៩:៤–៦) ។

**២៦:១១** *ឆ្កែដែលត្រឡប់ទៅស៊ីកំអួតវាវិញ* ជាពាក្យដក់ស្រង់ក្នុង ២ពត ២:២២ ជាមួយការពោលសំអាងដែលនិយាយពីគ្រូក្លែងក្លាយមួយ (សូមមើលការពន្យល់) ។

**២៦:១២** *ថាខ្លួនមានប្រាជ្ញា* គឺជាគំនិតប្រកាន់ខ្លួនប្រកបដោយក្ដីអំនួត មានដូចជាមនុស្សចំអៀក(មនុស្សមុយៗ)មានក្នុង ឧ.១៦ និងអ្នកមានសម្បត្តិក៏មានក្នុង ២៨:១១ ធៀបនឹង ២៦:៥ ។ *មានសង្ឃឹមចំពោះមនុស្សល្ងីល្ងើ* ក៏មានបង្ហាញឡើងវិញក្នុង ២៩:២០ ។

**២៦:១៣–១៦** គឺជាវគ្គៗរបស់ព្រះគម្ពីរសុភាសិតដែលបានផ្ដោតចំៗ ចំពោះមនុស្សខ្ជិលច្រអូស (មនុស្សចំអៀក) (សូមមើលការពន្យល់ ២៥:២–៧ ២៦:១–១២ ។

**២៦:១៣** សូមមើល ២២:១៣ និងការពន្យល់ ។

**១៦:១៤** មនុស្សខ្ជិលច្រអូសចូលចិត្តគេង ហើយគេចង់ចងភ្ជាប់ខ្លួនរបស់គេទៅនិងគ្រែ ។

**២៦:១៥** សូមមើល ១៩:២៤ និងការពន្យល់ ។

**២៦:១៦** *ប្រកាន់ថាខ្លួនមានប្រាជ្ញាជាជាងមនុស្ស៧នាក់* មើល ឧ.១២ និងការពន្យល់ ។ *៧នាក់* គឺសំដៅលើមនុស្សជាច្រើន(មើលការពន្យល់ ២៤:១៦) ។

**២៦:១៧** *ចាប់ត្រចៀកឆ្កែ* ការធ្វើដូច្នេះ គឺជាការបង្កើតឱ្យមានភាពចលាចលហើយ ។

**២៦:១៨–១៩** *ប្រៀបដូចជាមនុស្សឆ្កួតដែលបោះកំចាយអង្កត់ឧស* ប្រៀបធៀបចំពោះពួកពលធ្នូម្នាក់ក្នុង ឧ.១០ ។

**២៦:២១** *សេចក្ដីទាស់ទែងគ្នា* សូមមើល ៦:១៤ និងការពន្យល់ ។

**២៦:២២** ខនេះបង្ហាញពីសណ្ឋានដូចគ្នានិង ១៨:៨ និងការពន្យល់ ។

**២៦:២៣** *ភាជនៈដីស្រោបដោយអាចម៏ប្រាក់* គឺធៀបដូចជាការលាងពែងនិងចានបានតែសំបកខាងក្រៅ(មើល លក ១១:៣៩ ធៀបនឹង មថ ២៣:២៧) ។ *បបូរមាត់ហៃនិយាយហើយចិត្តអាក្រក់* ដូចជាមនុស្សកំផឹតដែលមានសម្ដីប្រលោម (សូមមើល ២:១៦ ៥:៣ និងការពន្យល់) ។

**២៦:២៤** *ទុកសេចក្ដីបញ្ឆោតនៅក្នុងចិត្ត* សូមមើល ១២:២០ ។

**២៦:២៥** *ពោលពាក្យល្អ* សូមមើល យរ ៩:៨ ។ *៧មុខ* សូមមើលការពន្យល់ ឧ.១៦ គឺជាហេតុការមាន៧ដែលព្រះយេហូវ៉ាបានស្អប់ខ្ពើម សូមមើល ៦:១៦–១៩ ។

**២៦:២៦** *សំដែងចេញឱ្យច្បាស់ចំពោះមុខនៃពួកជំនុំ* មើល ៥:១៤ លក ៨:១៧ ។

ដែលជីករណ្ដៅ អ្នកនោះនឹងធ្លាក់ទៅក្នុងរណ្ដៅនោះឯង[ល]
ហើយអ្នកណាដែលប្រមៀលថ្ម ថ្មនោះនឹងរមៀលត្រឡប់
មកកិនខ្លួនវិញ[វ] ២៨ឯអណ្ដាតភូតភរ នោះរមែងស្អប់ដល់
ពួកអ្នកដែលវាបានធ្វើទុក្ខនោះហើយមាត់[ស]បញ្ចើចតែងតែ
បណ្ដាលឱ្យវិនាស ។

**២៧** ១កុំឱ្យអួត[ក]ខ្លួនពីថ្ងៃស្អែក ដ្បិតឯងមិនដឹងជាថ្ងៃណានឹងកើតមានការអ្វីទេ[ខ] ។

២ទុកឱ្យមនុស្សឯទៀតសរសើរឯងចុះ កុំឱ្យមាត់ឯងសរសើរខ្លួនឡើយ គឺជាអ្នកដទៃ មិនមែនជាបបូរមាត់របស់ឯងឡើយ[គ] ។

៣ដុំថ្មជារបស់ធ្ងន់ ហើយខ្សាច់[ឃ]ក៏មានទំងន់ដែរ តែសេចក្ដីកំហឹងរបស់មនុស្សល្ងីល្ងើ នោះធ្ងន់ជាងទាំង២មុខនោះទៅទៀត ។

៤សេចក្ដីឃោរឃៅ ជាសេចក្ដីដែលសាហាវណាស់ ហើយសេចក្ដីកំហឹងក៏ខ្លាំងក្លាដែរ តែឯសេចក្ដីប្រចណ្ឌ តើអ្នកណានឹងទប់ទល់បាន[ង] ។

៥ការដែលត្រូវបន្ទោសនៅកណ្ដាលជំនុំ នោះវិសេសជាងសេចក្ដីស្រឡាញ់លាក់កំបាំង ។

៦របួសដែលមិត្រសំឡាញ់ធ្វើដល់យើង នោះតែងធ្វើដោយស្មោះត្រង់ទេ តែឯការថើបរបស់ខ្មាំងសត្រូវនោះជា សេចក្ដីបញ្ឆោតវិញ[ច] ។

៧អ្នកណាដែលឆ្អែតហើយ ទោះទាំងសំណុំឃ្មុំក៏ណាយចិត្តដែរ តែឯអ្នកណាដែលឃ្លាន ទោះទាំងរបស់ជូរល្វីងក៏ផ្អែមដល់គេវិញ ។

៨មនុស្សណាដែលវង្វេងឆ្ងាយពីទីលំនៅខ្លួន នោះប្រៀបដូចជាសត្វហើរ ដែលវង្វេងឆ្ងាយពីសំបុក[ឆ]វាដែរ ។

៩ប្រេងលាបនឹងទឹកអប់[ជ] នោះនាំឱ្យចិត្តរីករាយឡើង ឯសេចក្ដីផ្អែមល្ហែមនៃសេចក្ដីដាស់តឿន ដ៏អស់ពីចិត្តរបស់ភឿនមិត្រក៏ដូច្នោះដែរ ។

១០ឯមិត្រភក្តិរបស់ខ្លួន និងមិត្រភក្តិរបស់ឪពុក នោះកុំឱ្យបោះបង់ចោលឡើយ ក៏កុំឱ្យចូលផ្ទះរបស់បងប្អូនឯងក្នុងគ្រាដែលឯងកើតមានសេចក្ដីទុក្ខព្រួយ[ឈ]ដែរ អ្នកមួយដែលនៅជិតខាងខ្លួន នោះវិសេសជាងបងប្អូនដែលនៅឆ្ងាយវិញ ។

១១កូនអើយ ចូរឱ្យឯងមានប្រាជ្ញាឡើង ហើយឱ្យចិត្តអញបានរីករាយចុះ[ញ] ដើម្បីឱ្យអញអាចតបឆ្លើយចំពោះមនុស្សដែលដៀលតិះដល់អញ[ដ] ។

១២មនុស្សដែលមានគំនិតឆ្លៀវឆ្លាត គេឃើញការអាក្រក់មក ក៏ពួនខ្លួន តែមនុស្សល្ងង់ខ្លៅ គេចេះតែដើរទៅ ហើយក៏ត្រូវមានទុក្ខ[ឋ] ។

១៣ចូរទទួលបញ្ចាំអាវរបស់អ្នកដែលធានាឱ្យមនុស្សដទៃ ហើយទទួលរបស់បញ្ចាំពីអ្នកដែលសន្យាជំនួសអ្នកក្រៅចុះ[ឌ] ។

១៤បើអ្នកណាក្រោកពីព្រលឹមស្រាង នឹងឱ្យពរដល់មិត្រ

**២៦:២៧** រ ទដ ៧:១៥ ល នអ ៦:១៣ វ នអ ២:២៣ ៧:៩ ទដ ៣៥:៨ ១៤១:១០ សភ ២៨:១០ ២៩:៦ អស ៥០:១១
**២៦:២៨** ស ទដ ១២:៣ សភ ២៩:៥
**២៧:១** ក ១ពរ ២០:១១ ខ មថ ៦:៣៤ យក ៤:១៣–១៦
**២៧:២** គ សភ ២៥:២៧
**២៧:៣** ឃ យប ៦:៣
**២៧:៤** ង ជន ៥:១៤
**២៧:៦** ច ទដ ១៤១:៥ សភ ២៨:២៣
**២៧:៨** ឆ អស ១៦:២
**២៧:៩** ជ នអ ២:១២ ទដ ៤៥:៨
**២៧:១០** ឈ សភ ១៧:១៧
**២៧:១១** ញ សភ ១០:១ ២៣:១៥–១៦ ដ លប ២៤:៦០ **២៧:១២** ឋ សភ ២២:៣ **២៧:១៣** ឌ សភ ២០:១៦

**២៦:២៧** *អ្នកណាដែលជីករណ្ដៅ អ្នកនោះនឹងធ្លាក់ទៅក្នុងរណ្ដៅនោះ* គឺជាបញ្ហានោះក៏ធ្លាក់មកលើខ្លួនឯងវិញ (ទដ ៧:១៦) សូមមើល ១:១៨ និងការពន្យល់ ២៨:១០ ២៩:៦ ទដ ៧:១៥ សស ១០:៨–៩ ។

**២៦:២៨** *ឯអណ្ដាតភូតភរ នោះរមែងស្អប់ដល់ពួកអ្នកដែលវាបានធ្វើទុក្ខនោះ* សូមមើល ១០:១៨ ។ *មាត់បញ្ចើចតែងតែបណ្ដាលឱ្យវិនាស* សូមមើល ២៩:៥ ប្រៀបធៀប ១៦:១៣ ។

**២៧:១** ប្រៀបធៀបពាក្យរបស់មនុស្សល្ងីល្ងើ និងព្រះបន្ទូលដែលឆ្លើយតបចំពោះពួកគេនៅក្នុង គម្ពីរ លក ១២:១៩–២០ សូមប្រៀបធៀប សភ ១៦:៩ អស ៥៦:១២ យក ៤:១៣–១៦ ។

**២៧:២** *ទុកឱ្យមនុស្សឯទៀតសរសើរឯងចុះ* មើល ២កថ ១០:១២,១៨ ។

**២៧:៤** *តែសេចក្ដីប្រចណ្ឌ តើអ្នកណានឹងទប់ទល់បាន* សូមមើល ៦:៣៤ បស ៨:៦ ។

**២៧:៥** *បន្ទោសនៅកណ្ដាលជំនុំ* គឺជាសេចក្ដីបន្ទាល់នៃជីវិត ឬទទួលយកការបន្ទោស ក៏មាននៅក្នុង ១៥:៣១ ធៀបនឹង កទ ២:១៤ ។

**២៧:៦** សូមមើល ២៨:២៣ ។ *របួសដែលមិត្រសំឡាញ់ធ្វើដល់យើង* មើល ទដ ១៤១:៥ (សូមមើលការពន្យល់ ១៤:៥) ។ *ការថើបរបស់ខ្មាំងសត្រូវ* សូមមើល ៥:៣ និងការពន្យល់ មថ ២៦:៤៩ ។

**២៧:៧** *សំណុំឃ្មុំក៏ណាយចិត្ត* ប្រៀបធៀបនឹង ២៥:១៦,២៧ ។

**២៧:៨** *មនុស្សណាដែលវង្វេងឆ្ងាយពីទីលំនៅខ្លួន* គឺបានបាត់ភាពសុខសាន្តរបស់គេ ហើយក៏ងាយនឹងទទួលការឈឺចាប់ដោយសេចក្ដីល្បួង (ប្រៀបធៀប ៧:២១–២៣) ។

**២៧:៩** *ទឹកអប់* មើលការពន្យល់ ២១:១៧ (បស ៣:៦) ។ *នាំចិត្តរីករាយឡើង* សូមមើល ខ.១១ ។ *សេចក្ដីផ្អែមល្ហែមនៃសេចក្ដីដាស់តឿន . . . ភឿនមិត្រ* សូមមើល ១៦:២១ និងការពន្យល់ ។

**២៧:១០** កុំធ្វើឱ្យមិត្តយើងបរាជ័យ ខណៈពេលគេចង់ពឹងផ្អែកលើមិត្តភាពជាជាងទំនាក់ទំនងជាគ្រួសារ ។ *បងប្អូនដែលនៅឆ្ងាយវិញ* ដូចជាឆ្ងាយទាំងកាយឆ្ងាយទាំងចិត្ត ។

**២៧:១១** *កូនអើយចូរឱ្យឯងមានប្រាជ្ញាឡើង* មើល ១០:១ និងការពន្យល់ ។ *ដើម្បីឱ្យអញអាចតបឆ្លើយ ចំពោះមនុស្សដែលដៀលតិះដល់អញ* ជាកូនដែលមានប្រាជ្ញា (ឬជាសិស្ស) បានធ្វើជាបន្ទាល់ដ៏ល្អដែលឪពុក (គឺជាគ្រូ) ដែលបានធ្វើដើម្បីកូននោះមានតម្លៃឡើង ។

**២៧:១២** *មនុស្សល្ងង់ខ្លៅ* សូមមើលការពន្យល់ ១:៤ ។ *គេចេះតែដើរទៅ ហើយក៏ត្រូវមានទុក្ខ* សូមមើល ៧:២២–២៣ ៩:១៦–១៨ ។

**២៧:១៣** ខនេះក៏បង្ហាញក្នុង ២០:១៦ (សូមមើលការពន្យល់) ។

សំឡាញ់ដោយសំឡេងខ្លាំង នោះនឹងបានរាប់ជាពាក្យជេរ
ដល់គេវិញ ។
១៥ទឹកដែលស្រក់ចុះតក់ៗ[ល]ជានិច្ច នៅថ្ងៃភ្លៀងច្រើន
ហើយស្ត្រីដែលចេះតែរករឿង នោះក៏ដូចគ្នា ១៦អ្នកណា
ដែលចង់ឃាត់នាង នោះឃាត់តែខ្យល់ទេ ហើយដៃអ្នក
នោះចាប់ក្ដាប់ប្រេងប៉ុណ្ណោះ ។
១៧ដែករមែងសំលៀងដែក ឯមនុស្សក៏ធ្វើឱ្យមិត្រសំឡាញ់
ខ្លួនមុតស្រួចយ៉ាងនោះដែរ ។
១៨អ្នកណាដែលថែទាំដើមល្វា អ្នកនោះនឹងបានផ្លែ
បរិភោគ[ណ] ហើយអ្នកណាដែលបំរើចៅហ្វាយខ្លួនដោយល្អ
នោះនឹងបានកិត្តិសព្ទ[ត] ។
១៩មុខផ្ទុះឃើញមុខនៅក្នុងទឹកជាយ៉ាងណា នោះចិត្ត
របស់មនុស្សក៏ច្បាស់ដល់មនុស្សយ៉ាងនោះដែរ ។
២០ស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយនិងទីវិនាស នោះ
មិនចេះស្កប់ស្កល់ឡើយ[ថ] ឯភ្នែកនៃមនុស្សក៏មិនចេះស្កប់
ស្កល់ដូចគ្នាដែរ[ទ] ។
២១មានបាវដីសំរាប់សំរងប្រាក់ ហើយមានឡសំរាប់
មាស[ធ] តែនឹងស្គាល់មនុស្សបានដោយសារតែសេចក្តីដែល
គេសរសើរពីអ្នកនោះទេ ។

**២៧:១៥** ល នរ ១:១៨
**២៧:១៨** ណ ១កថ ៩:៧ ត លក ១៩:១២-២៧
**២៧:២០** ថ សភ ៣០:១៥-១៦ ហប ២:៥ ទ សស ១:៨ ៦:៧
**២៧:២១** ធ សភ ១៧:៣
**២៧:២៣** ន សភ ១២:១០
**២៧:២៤** ប សភ ២៣:៥
**២៨:១** ក ២ពវ ៧:៧ ខ លវ ២៦:១៧ គ ទដ ១៣៨:៣

២២ទោះបីនឹងបុកមនុស្សល្ងីល្ងើនៅក្នុងត្បាល់ជាមួយ
នឹងស្រូវក៏ដោយ គង់តែសេចក្ដីចំកួតរបស់វាមិនព្រមរបក
ចេញពីវាឡើយ ។
២៣ចូរមានចិត្តខ្នះខ្នែងឱ្យស្គាល់សណ្ឋាននៃហ្វូងចៀម
ឯង[ន] ហើយឱ្យថែមើលហ្វូងគោឯងឱ្យល្អចុះ ២៤ដ្បិតទ្រព្យ
សម្បត្តិមិនស្ថិតស្ថេរនៅជាដរាបទេ[ប] តើមកុដស្ដេចនៅជាប់
អស់ទាំងដំណតទៅឬ ២៥ឯស្មៅក្រៀម គេដឹកយកទៅ រួច
ស្មៅខ្ចីលូតលាស់ឡើង ហើយគេប្រមូលស្មៅព្រៅពីភ្នំមក
ដែរ ២៦កូនចៀមទាំងប៉ុន្មាននឹងបានសំរាប់ធ្វើសំលៀក
បំពាក់ដល់ឯង ឯពពែឈ្មោល ក៏សំរាប់សងថ្លៃចំការដែរ
២៧ហើយនិងមានទឹកដោះពពែ ល្មមទុកជាអាហារដល់ឯង
គឺជាអាហារសំរាប់គ្រួសារឯង ហើយសំរាប់ចិញ្ចឹមពួកស្រី
បំរើរបស់ឯងទៀត ។

**២៨** ១មនុស្សអាក្រក់ គេរត់[ក]ក្នុងកាលដែលគ្មានអ្នកណា
ដេញតាមសោះ[ខ] តែមនុស្សសុចរិតមានចិត្តក្លាហានដូច
សិង្ហវិញ[គ] ។
២កាលណាមានការបះបោរកើតឡើងក្នុងស្រុក នោះ
រមែងមានចៅហ្វាយជាច្រើន តែបើមានមនុស្សម្នាក់ដែល
មានយោបល់ ហើយនិងដំរិះ នោះនគរនឹងស្ថិតស្ថេរនៅត

**២៧:១៤** *ឱ្យពរដល់មិត្តសំឡាញ់* ដើម្បីសម្របសម្រួលដល់ពួកគេ (ប្រៀបធៀប ទដ ១២:២) ។

**២៧:១៥** សូមមើល ១៩:១៣ និងការពន្យល់ ។

**២៧:១៧** *ដែករមែងសំលៀងដែក* គឺជាការអភិវឌ្ឍន៍ ឬការស្អាងរូបកាយឱ្យរឹងមាំឡើង ។

**២៧:១៨** *និងបានផ្លែបរិភោគ* ប្រៀបធៀប ២ធថ ២:៦ ។ *និងបានកិត្តិយស* សូមមើល លប ៣៩0:៤ ថម ២៥:២១ លក ១២:៤២-៤៤ យហ ១២:២៦ ។

**២៧:១៩** *នោះចិត្តរបស់មនុស្ស ក៏ច្បាស់ដល់មនុស្ស* គឺជាលក្ខខ័ណ្ឌផ្លូវចិត្តដែលបង្ហាញពីចរិតលក្ខណៈល្អពិតប្រាកដ (សូមមើល មថ ៥:៨) ។

**២៧:២០** *មនុស្សស្លាប់ហើយនិងទីវិនាស* សូមមើលការពន្យល់ យប ២៦:៦ ក៏សូមមើល សភ ១៥:១១ ។ ពាក្យថា *ក៏មិនចេះស្កប់ស្កល់* ជាសេចក្តីស្រេកឃ្លានដែលមិនចេះអស់មិនចេះហើយ (សូមមើល ៣០:១៥-១៦ អស ៥:១៤ ហប ២:៥) ។ *ឯភ្នែកនៃមនុស្ស* សូមមើល សស ៤:៨ ។

**២៧:២១** *មានបាវដីសំរាប់សំរងប្រាក់ . . . ឡសំរាប់មាស* មើល ១៧:៣ ទដ ២:៦ និងការពន្យល់ ។ *ស្គាល់មនុស្សបានដោយសារតែសេចក្តីដែលគេសរសើរពីអ្នកនោះ* តែឯមនុស្សគឺមិនត្រូវមានសេចក្តីអំនួតពេកទេ ។ ហើយពួកគេទាំងនោះក៏ត្រូវប្រយ័ត្នពីសេចក្តីបញ្ជោរលួងលោម (ធៀបនឹង ១២:៨ លក ៦:២៦) ។

**២៧:២២** *ត្បាល់* ជាចានគោម (សូមមើល ជន ១១:៨) ដែលជាត្បាល់បុកដើម្បីស្រិតយកតែអង្ករតែប៉ុណ្ណោះ ។ ពាក្យថា *គង់តែសេចក្តីចំកួតរបស់វាមិនព្រមរបកចេញពីវាឡើយ* គឺផ្ទុយពីការប្រឹងប្រែងដាក់ទណ្ឌកម្មយ៉ាងម៉ឺងម៉ាត់តឹងរឹងដល់មនុស្សល្ងីល្ងើ តែផ្ទុយទៅវិញមនុស្សល្ងីល្ងើបែរជាពុំបានផ្លាស់ប្រែចិត្តគំនិតឡើយតែគេនៅតែបដិសេធមិនទទួលការល្អ (សូមមើល ២០:៣០ ២៦:១១ យរ ៥:៣ និងការពន្យល់) ។

**២៧:២៣-២៧** គឺជាវគ្គបទទំនុកសរសើរដម្កើង ដែលផ្ដែកទៅលើការប្រឹងប្រែងដែលចាប់យកវិស័យកសិកម្ម ដោយសេដ្ឋកិច្ចសម័យបូរាណវិស័យកសិកម្មជាវិស័យចំបង ។

**២៧:២៣** *ចូរមានចិត្តខ្នះខ្នែងឱ្យស្គាល់សណ្ឋាននៃហ្វូងចៀមឯង* គឺដូចជាលោកយ៉ាកុបជាមួយនិងហ្វូងចៀមរបស់លោកឡាបាន់ (សូមមើល លប ៣១:៣៨-៤០) ។

**២៧:២៤** *ដ្បិតទ្រព្យសម្បត្តិមិនស្ថិតស្ថេរនៅជាដរាប* សូមមើលការពន្យល់ ២៣:៥ មថ ៦:១៩ ។ *តើមកុដស្ដេចនៅជាប់អស់ទាំងដំណតទៅឬ* សូមធៀបនឹង ២៩:១៤ ។ គឺសូម្បីតែព្រះមហាក្សត្រក៏អាចបាត់បង់ទ្រព្យសម្បត្តិ និងអំណាចផងដែរ (សូមមើល យប ១៩:៩ បទ ៥:១៦) ។

**២៧:២៧** *ទឹកដោះពពែ* គេបានយកវាមកទទួលទានដូចជាទឹកដោះគោដែរ (សូមមើល អស ៧:២១-២២) ។ *ពួកស្រីបំរើ* សូមមើល ៣១:១៥ ។

**២៨:១** *មនុស្សអាក្រក់គេរត់* សូមមើល លវ ២៦:១៧ ទដ ៥៣:៥ និងការពន្យល់ ។ *មានចិត្តក្លាហានដូចជាសិង្ហវិញ* គឺមានលក្ខណៈដូចស្ដេចដាវីឌផងដែរ ១សយ ១៧:៤៦ ធៀបនឹង ២សយ ២២:៣៣-៣៧ ។

**២៨:២** *មានចៅហ្វាយជាច្រើន* ការបះបោររបស់ពួកអ៊ីស្រាអែលក៏បាននាំមកនូវការផ្លាស់ប្ដូរយ៉ាងរហ័សក្នុងភាពជាអ្នកដឹកនាំ (សូមមើល ១ពវ ១៦:៨-២៨ ២ពវ ១៥:៨-១៤ ២៣:២៩ ២៤:១៧) ។ *មានមនុស្សម្នាក់ដែលមានយោបល់* ដូចជាអ្នកដឹកនាំដែលមានប្រាជ្ញា និងបានជោគជ័យ (សូមមើល ៨:១៥-១៦ ១៦:១២ និងការពន្យល់ ២៤:៥ ២៩:៤) ។

ទៅបាន ។
៣មនុស្សក្រដែលពានលើមនុស្សកំសត់ទុគ៌ត នោះធៀប
ដូចជាភ្លៀងយ៉ាងខ្លាំង ដែលបោសរំលីងមិនឱ្យមានអាហារ
សល់ឡើយ ។
៤ពួកអ្នកដែលបោះបង់ចោលបញ្ញត្តិច្បាប់ គេរមែង
សរសើរមនុស្សអាក្រក់ តែអស់អ្នកដែលប្រព្រឹត្តតាមបញ្ញត្តិ
ច្បាប់វិញ នោះតែងតែតតាំងនឹងគេ ។
៥មនុស្សអាក្រក់មិនយល់សេចក្ដីយុត្តិធម៌ទេ តែពួកអ្នក
ដែលស្វែងរកព្រះយេហូវ៉ា គេយល់គ្រប់ទាំងអស់វិញ ។
៦មនុស្សក្រីក្រដែលប្រព្រឹត្តតាមផ្លូវទៀងត្រង់របស់ខ្លួន
នោះវិសេសជាងមនុស្សក្រវិចក្រវៀន ក្នុងគ្រប់ទាំងផ្លូវ
របស់គេ ទោះបើជាអ្នកមានក៏ដោយ[ឃ] ។
៧អ្នកណាដែលប្រព្រឹត្តតាមបញ្ញត្តិច្បាប់ នោះជាកូន
ដែលមានប្រាជ្ញា តែអ្នកណាដែលភប់ប្រសព្វនឹងមនុស្ស
ល្មោភស៊ីផឹក នោះនាំឱ្យឪពុកមានសេចក្ដីខ្មាសវិញ[ង] ។
៨អ្នកណាដែលចំរើនសម្បត្តិទ្រព្យខ្លួន ដោយយកការ[ច]
ហើយដោយដាក់បុល នោះគឺប្រមូលទុកសំរាប់មនុស្ស[ឆ]
ដែលមានចិត្តមេត្តាដល់មនុស្សទាល់ក្រទេ[ជ] ។
៩អ្នកណាដែលបែរត្រចៀកចេញមិនព្រមស្តាប់បញ្ញត្តិ

**២៨:៦** ឃ សភ ១៩:១
**២៨:៧** ង សភ ២៣:១៩–២១
**២៨:៨** ច នក ១៨:២១ អគ ១៨:៨ ឆ យប ២៧:១៧ ជ យប ៣:១៥ ទដ ១១២:៩ លក ១៤:១២–១៤
**២៨:៩** ឈ ទដ ១០៩:៧ សភ ១៥:៨ អស ១:១៣
**២៨:១០** ញ ទដ ៥៧:៦ សភ ២៦:២៧
**២៨:១២** ដ ២ពវ ១១:២០ ឋ ខ.២៨ យប ២៤:៤ សភ ២៩:២
**២៨:១៣** ឌ ២សយ ១២:១៣ យប ៣១:៣៣ ឍ លវ ៥:៥ ណ ទដ ៣២:១–៥ ដយ ៤:២៧ ១យហ ១:៩

ច្បាប់ នោះទោះទាំងពាក្យអធិស្ឋានរបស់អ្នកនោះ ក៏ជាទី
ស្អប់ខ្ពើមដែរ[ឈ] ។
១០អ្នកណាដែលនាំឱ្យមនុស្សទៀងត្រង់វង្វេងតាមផ្លូវ
អាក្រក់ អ្នកនោះឯងនឹងធ្លាក់ទៅក្នុងរណ្ដៅដែលខ្លួនបាន
ជីកវិញ[ញ] តែមនុស្សទៀងត្រង់នឹងគ្រងបានសេចក្ដីល្អជា
មរដក ។
១១មនុស្សអ្នកមាន គេតែងប្រកាន់ថា ខ្លួនមានប្រាជ្ញា
តែមនុស្សក្រដែលមានយោបល់ និងស្ទង់មើល ឱ្យស្គាល់
គេបាន ។
១២កាលណាមនុស្សសុចរិតមានជ័យជំនះ នោះបណ្ដាជន
មានសេចក្ដីអំណរជាខ្លាំងក្រៃលែង[ដ] តែបើកាលណា
មនុស្សអាក្រក់បានតាំងឡើង នោះជនទាំងឡាយនាំគ្នាពួន
ខ្លួនវិញ[ឋ] ។
១៣អ្នកណាដែលគ្របបាំងការរំលង[ឌ]របស់ខ្លួន នោះ
នឹងមិនចំរើនឡើងទេ តែអ្នកណាដែលលន់តួ[ឍ] ហើយលះ
បង់អំពើនោះ នឹងប្រទះបានសេចក្ដីមេត្តាករុណាវិញ[ណ] ។
១៤សប្បាយហើយ អ្នកណាដែលមានចិត្តកោតខ្លាចជានិច្ច
តែអ្នកណាដែលតាំងចិត្តរឹងទទឹង នោះនឹងធ្លាក់ទៅក្នុង
សេចក្ដីអន្តរាយវិញ ។

**២៨:៣** *ដែលពានលើមនុស្សកំសត់ទុគ៌ត* មើល ១៤:៣១ និងការពន្យល់ ។ *ភ្លៀងយ៉ាងខ្លាំង* ការពណ៌នានេះនិយាយពីអំណាចនៃភាពហិនហោចរបស់ស្តេចអាសស៊ើរ មើលក្នុង អស ២៨:២ (មើលការពន្យល់ អស ២៨:២) ។ ភ្លៀងដែលស្លូតបូត គឺគេប្រៀបដូចស្តេចដែលមានសេចក្ដីសុចរិត មើលក្នុង ទដ ៧២:៦–៧ ។

**២៨:៤** *បញ្ញាច្បាប់* ពាក្យនេះក៏មាននៅក្នុងការបង្រៀនអំពីប្រាជ្ញា (៣:១ ៧:២) ឬក៏ច្បាប់របស់លោកម៉ូសេ (ទដ ១១៩:៥៣) ។ *សរសើរមនុស្សអាក្រក់* ប្រៀបធៀបនឹង រម ១:៣២ និងការពន្យល់ ។ *អ្នកដែលប្រព្រឹត្តតាមបញ្ញត្តិច្បាប់វិញ* សូមមើល ខ.៧ ២៩:១៨ ធៀបនឹង ខ.៩ ។ *តែងតែតតាំងនិងគេ* សូមមើល ៥:៧,១១ ។

**២៨:៥** *អ្នកដែលស្វែងរកព្រះយេហូវ៉ា* គឺអ្នកដែលកោតក្លាចដល់ព្រះ (សូមមើលការពន្យល់ ១:៧) ។ *យល់គ្រប់ទាំងអស់* គឺគេដឹង"នូវអ្វីដែលត្រឹមត្រូវ និងអ្វីដែលសមរម្យ" (២:៩) ។

**២៨:៦** *តាមផ្លូវទៀងត្រង់* មើល ខ.១៨ ២:៧ ទដ ១៥:២ និងការពន្យល់ ។

**២៨:៧** *អ្នកណាដែលប្រព្រឹត្តតាមបញ្ញត្តិច្បាប់* មើលការពន្យល់នៅ ខ.៤ ។ *អ្នកណាដែលភប់ប្រសព្វនិងមនុស្សល្មោភស៊ីផឹក* សូមមើល ២៣:២០–២១ និងការពន្យល់ ។

**២៨:៨** *យកការហើយដោយដាក់បុល* គឺជាការហាមឃាត់ក្នុងគម្ពីរ នក ២២:២៥ (សូមមើលការពន្យល់នៅ នក ២២:២៥–២៧ លវ ២៥:៣៦ អគ ១៨:៨) ។ *ប្រមូលទុកសំរាប់មនុស្ស* សូមមើល ១៣:២២ និងការពន្យល់ ធៀបនឹង លក ១២:២០ ។ *ចិត្តមេត្តាដល់មនុស្សអាក្រក់* សូមមើល ១៤:៣១ និងការពន្យល់ ។

**២៨:៩** *បញ្ញត្តិច្បាប់* សូមមើលការពន្យល់ ខ.៤ ។ *ពាក្យអធិស្ឋានរបស់អ្នកនោះជាទីស្អប់ខ្ពើម* ដូចជាការធ្វើយញ្ញបូជារបស់ពួកមនុស្សអាក្រក់ ១៥:៨ (សូមមើលការពន្យល់ ១៥:៨ សូមមើល ៣:៣២ និងការពន្យល់, ក៏សូមមើល ទដ ៦៦:១៨ អស ១:១៥ ៥៩:១–២ យរ ១១:១៤) ។

**២៨:១០** *អ្នកនោះឯងនឹងធ្លាក់ទៅក្នុងរណ្ដៅដែលខ្លួនបានជីកវិញ* សូមមើលការពន្យល់ ២៦:២៧ ។ *មនុស្សទៀងត្រង់* សូមមើលការពន្យល់ ២:៧ ។ *សេចក្ដីល្អជាមរដក* សូមមើល ៣:៣៥ ហព ៦:១២ ១ពត ៣:៩ ។

**២៨:១១** *មនុស្សអ្នកមានគេតែងប្រកាន់ថា ខ្លួនមានប្រាជ្ញា* ដូចជាមនុស្សល្ងីល្ងើ (២៦:៥) ឬមនុស្សខ្ជិលច្រអូស (២៦:១៦) ។

**២៨:១២** *មានសេចក្ដីអំណរជាខ្លាំងក្រៃលែង* សូមមើល ១១:១០ និងការពន្យល់ ។ *នោះជនទាំងឡាយនាំគ្នាពួនខ្លួនវិញ* សូមមើល ខ.២៨ ។ (១ពវ ១៨:៣–៤) និងយ៉ូអាសក៏បានលាក់ខ្លួនអស់រយៈពេល៦ឆ្នាំខណៈពេលមនុស្សអាក្រក់ឈ្មោះអ័ថាលាដឹកនាំប្រទេស (២ពវ ១១:២–៣) ។

**២៨:១៣** *អ្នកណាដែលគ្របបាំងការរំលងរបស់ខ្លួន នោះមិនចំរើនឡើងទេ* គឺសូមចំណាំពីនិស្ស័យសាច់ឈាម និងផ្នែកចិត្តវិជ្ជាដែលទទួលការឈឺចាប់តាមរយៈ ៣:៧–៨ ទដ ៣២:៣–៥ និងការពន្យល់ ។ *តែអ្នកណាដែលលន់តួហើយលះបង់អំពើនោះ នឹងប្រទះបានសេចក្ដីមេត្តាករុណា* គឺជាសេចក្ដីអំណរនៃការលើកលែងទោសក្នុង ទដ ៣២:៥,១០–១១ ។

**២៨:១៤** *អ្នកណាដែលតាំងចិត្តរឹងទទឹង* គឺមានដូចជាស្តេចផារ៉ោន (នក ៧:១៣) និងដូចជារាស្ត្រអ៊ីស្រាអែល ដែលល្បួងលដល់ព្រះយេហូវ៉ានៅត្រង់មេរីបា ឬកាលនៅឯម៉ាសា (សូមមើល ទដ ៩៥:៨ និងការពន្យល់ រម ២:៥) ។

១៥មនុស្សអាក្រក់ដែលគ្រប់គ្រងលើប្រជាជនទាល់ក្រ
នោះធៀបដូចជាសិង្ហដែលគ្រហឹមគំរាម ហើយដូចខ្លាឃ្មុំ
ដែលកំពុងស្វែងរកអាហារ ។
១៦ចៅហ្វាយណាដែលខ្វះយោបល់ នោះតែងតែសង្កត់
សង្កិនជនជាយ៉ាងខ្លាំង តែអ្នកណាដែលស្អប់សេចក្ដីលោភ
នោះនឹងបានចំរើនអាយុយឺនយូរវិញ ។
១៧ឯមនុស្សដែលមានទោសជាអ្នកកំចាយឈាមគេនោះ
នឹងរត់ចុះ[ត]ទៅក្នុងរណ្ដៅ កុំអោយអ្នកណាឃាត់វាឡើយ ។
១៨អ្នកណាដែលដើរដោយទៀងត្រង់[ថ] នោះនឹងបាន
ប្រោសឱ្យរួច តែអ្នកណាដែលកាន់តាមផ្លូវវៀច នោះនឹង
ត្រូវធ្លាក់ចុះដោយឆាប់រហ័ស[ទ] ។
១៩អ្នកណាដែលធ្វើស្រែខ្លួន នោះនឹងបានអាហារជា
បរិបូរ តែអ្នកណាដែលជាប់តាមមនុស្សចោលម្សៀត នោះ
នឹងបានសេចក្ដីកំសត់យ៉ាងឆ្អែតវិញ[ធ] ។
២០មនុស្សស្មោះត្រង់នឹងបានពរជាបរិបូរ តែអ្នកណា
ដែលប្រញាប់ប្រញាល់ឱ្យបានជាអ្នកមាន នោះនឹងមិនរួច
ចាកពីទោសឡើយ[ន] ។
២១ការដែលយោគយល់[ប]ខាងមនុស្សណា នោះមិនល្អ
ទេ[ផ] ហើយដែលប្រព្រឹត្តរំលងច្បាប់ ឱ្យតែបានអាហារ
បន្តិចបន្តួច នោះក៏មិនល្អដូចគ្នា[ព] ។
២២អ្នកណាដែលមានភ្នែកអាក្រក់ នោះកំពុងតែរួស
រាន់ដេញតាមទ្រព្យសម្បត្តិ ឥតដឹងឡើយថា សេចក្ដីខ្វះខាត
នឹងតាមខ្លួនទាន់[ភ] ។
២៣អ្នកណាដែលបន្ទោសដល់មនុស្ស នោះនៅជាន់ក្រោយ
នឹងមានគេរាប់អានខ្លួន ជាជាងអ្នកដែលបញ្ចើចដោយ
អណ្ដាតទៅទៀត[ម] ។
២៤អ្នកណាដែលលួចយករបស់ឪពុកឬម្ដាយ[យ]ខ្លួន រួច
ពោលថា មិនមែនជាបាបទេ អ្នកនោះឯងជាសំឡាញ់នឹង
ពួកអ្នកបំផ្លាញហើយ[រ] ។
២៥អ្នកណាដែលមានចិត្តធំ នោះបណ្ដាលឱ្យមាន
សេចក្ដីទាស់ទែងគ្នា[ល] ឯអ្នកណាដែលទុកចិត្តដល់ព្រះ
យេហូវ៉ាវិញ[វ] នោះទើបនឹងបានថ្កុំថ្កើងឡើង ។
២៦អ្នកណាដែលទីពឹងតែចិត្តខ្លួនឯង នោះជាអ្នកល្ងីល្ងើ
ហើយ[ស] តែអ្នកណាដែលប្រព្រឹត្តដោយប្រាជ្ញាវិញ នោះនឹង
បានប្រោសឱ្យរួច[ហ] ។
២៧អ្នកណាដែលចែកចាយឱ្យដល់ពួកទាល់ក្រ អ្នកនោះ
នឹងមិនខ្វះខាតឡើយ[ឡ] តែអ្នកណាដែលគេចភ្នែកចេញ
នោះ នឹងត្រូវពាក្យប្រទេចផ្ដាសាជាច្រើន[អ] ។
២៨បើកាលណាពួកមនុស្សអាក្រក់បានតាំងខ្លួនឡើងនោះ

**២៨:១៧** ត ១សយ ៣០:១៧ ១ពវ ២០:២០ យរ ៤១:១៥ ៤៤:១៤ **២៨:១៨** ថ យរ ៣៩:១៨ ទ នអ ៦:១៣ សភ ១០:៩ **២៨:១៩** ធ សភ ១២:១១ **២៨:២០** ន ខ.២២ **២៨:២១** ប លវ ១៩:១៥ ផ ទដ ៩៤:២១ សភ ១៨:៥ ព អគ ១៣:១៩ **២៨:២២** ភ ខ.២០ **២៨:២៣** ម សភ ២៧:៥–៦ **២៨:២៤** យ សភ ១៩:២៦ រ សភ ១៨:៩ **២៨:២៥** ល សភ ១៤:១៧ វ សភ ២៩:២៥ **២៨:២៦** ស ទដ ៤:៥ សភ ៣:៥ ហ ១កថ ៣:១៨ **២៨:២៧** ឡ ចទ ២៤:១៩ សភ ២២:៩ អ ទដ ១០៩:១៧

**២៨:១៥** *សិង្ហដែលគ្រហឹមគំរាម* គឺពេញដោយកំហឹងយ៉ាងខ្លាំង និងមានបំណងសម្លាប់ (ធៀបនឹង ១៩:១២ មថ ២:១៦ ១ពត ៥:៨) ។ *ខ្លាឃ្មុំដែលកំពុងស្វែងរកអាហារ* មើល ១៧:១២ និងការពន្យល់ ។ *មនុស្សអាក្រក់ដែលគ្រប់គ្រង* សូមមើល ខ.១២ ។
**២៨:១៦** *តែអ្នកណាដែលស្អប់សេចក្ដីលោភ នោះនឹងបានចំរើនអាយុយឺនយូរវិញ* គឺមានលក្ខណៈផ្ទុយនឹងមនុស្សដែលលោភចង់បានសេចក្ដីចំណេញ (សូមមើល ១:១៩ និងការពន្យល់) ។
**២៨:១៧** អ្នកកំចាយឈាមនឹងរត់ចុះទៅក្នុងរណ្ដៅ (លប ៤:១៤) អ្នកដែលជាឃាតករត្រូវទទួលរង់ទោសរហូតប្រហារជីវិត (សូមមើល លប ៩:៦ នក ២១:១៤ និងការពន្យល់) ។
**២៨:១៨** *ដើរដោយទៀងត្រង់ . . . ដែលកាន់តាមផ្លូវវៀច* គឺមានលក្ខណៈផ្ទុយគ្នា ក៏មាននៅក្នុង ខ.៦ ១៩:១ ។ *នោះនឹងត្រូវធ្លាក់ចុះដោយឆាប់រហ័ស* ធៀបនឹង ១១:៥ ។
**២៨:១៩** សូមមើល ១២:១១ និងការពន្យល់ ។
**២៨:២០** *ពរជាបរិបូរ* គឺជាអំណោយទានរបស់ព្រះ និងភាពសប្បុរសផងទ្រង់ (សូមមើល ៣:១៣–១៨ ១០:៦ លប ៤៩:២៦ ចទ ៣៣:១៦) ។ ពាក្យថា *តែអ្នកណាដែលប្រញាប់ប្រញាល់ឱ្យបានជាអ្នកមាន នោះនឹងមិនរួចចាកពីទោសឡើយ* ប្រៀបដូចជាការព្រមានដែលមានក្នុង ២០:២១ ២៣:៤ (សូមមើលការពន្យល់ ២៣:៤) ។
**២៨:២១** *ការដែលយោគយល់ខាងមនុស្សណា នោះមិនល្អទេ* សូមមើល ១៨:៥ និងការពន្យល់ ២៤:២៣ ។ ពាក្យថា *ប្រព្រឹត្តរំលងច្បាប់ឱ្យតែបានអាហារបន្តិចបន្តួច* គឺប្រហែលជាសំដៅលើការសូកប៉ាន់ (ប្រៀបធៀប អគ ១៣:១៩ និងការពន្យល់) ។
**២៨:២២** *អ្នកណាដែលមានភ្នែកអាក្រក់* សូមមើល ២៣:៦ ។ *រួសរាន់ដេញតាមទ្រព្យសម្បត្តិ* ក៏ជាសេក្ដីប្រាប់ពីព្រមាននៅក្នុង ខ.២០ ក៏ស្រដៀងនឹង ២០:២១ ២៣:៤ (សូមមើលការពន្យល់ ២៣:៤) ។ *សេចក្ដីខ្វះខាតនឹងតាមខ្លួនទាន់* (សូមមើលការពន្យល់ ១១:២៥) ។
**២៨:២៣** *អ្នកណាដែលបន្ទោសដល់មនុស្ស* សូមមើល កឡ ២:១៤ ធៀបនឹង ១៥:៣១ ២៥:១២ ។ *អ្នកដែលបញ្ចើតដោយអណ្ដាត* សូមមើល ២៦:២៨ ២៩:៥ ធៀបនឹង ១៦:១៣ ។
**២៨:២៤** *អ្នកដែលលួចយករបស់ឪពុកឬម្ដាយខ្លួន* សូមមើលការពន្យល់ ១៩:២៦ ប្រៀបធៀបនឹង មថ ១៥:៤–៦ មក ៧:១០–១២ ។
**២៨:២៥** *បណ្ដាលឱ្យមានសេចក្ដីទាស់ទែងគ្នា* មើលការពន្យល់ ៦:១៤ ។ ពាក្យថា *និងបានថ្កុំថ្កើងឡើង* ក៏កើតមានឡើងនៅក្នុងជីវិតមនុស្សសប្បុរស (សូមមើល ១១:២៥ និងការពន្យល់) ឬអ្នកដែលពុះពារប្ដូរផ្ដាច់(១៣:៤) ។
**២៨:២៦** *អ្នកណាដែលប្រព្រឹត្តដោយប្រាជ្ញា* គឺស្មើនឹងអ្នកដែលទុកចិត្តដល់ព្រះយេហូវ៉ាមានក្នុង ២៩:២៥ ប្រៀបធៀប ៣:៥–៦ ។
**២៨:២៧** *ចែកចាយឱ្យដល់ពួកទាល់ក្រ* សូមមើលការពន្យល់ ១៤:២១ ។ *និងមិនខ្វះខាត់ឡើយ* គឺបានមកពីភាពសប្បុរសជាចំណែកនៃព្រះពរ (សូមមើល ១១:២៤ ១៤:២១ និងការពន្យល់ ១៩:១៧) ។ *គេចភ្នែកចេញ* សូមមើល ២១:១៣ ។
**២៨:២៨** *នោះមនុស្សទាំងឡាយក៏នាំគ្នាពួនខ្លួនអស់* សូមមើល ខ.១២ និងការ

មនុស្សទាំងឡាយនាំគ្នាពួនខ្លួនអស់[ក] តែកាលណាពួកនោះ
វិនាសបាត់ទៅវិញ នោះមនុស្សសុចរិតរមែងចំរើន
ឡើងវិញ ។

**២៩** ១ អ្នកណាដែលត្រូវបន្ទោសជាញយៗ តែតាំងចិត្ត
រឹងវិញ[ក] នោះត្រូវវិនាស[ខ]ក្នុង១រំពេច ទាល់បើជួយផង[គ]។
២ កាលណាមនុស្សសុចរិតមានអំណាចឡើង នោះជន
ទាំងឡាយរមែងមានចិត្តរីករាយ[ឃ] តែកាលណាមនុស្ស
អាក្រក់គ្រប់គ្រងវិញ[ង] នោះបណ្តាជនស្រែកថ្ងូរឡើង[ច]។
៣ អ្នកណាដែលស្រឡាញ់ដល់ប្រាជ្ញា នោះរមែងនាំឱ្យ
ឪពុករីករាយសប្បាយ[ឆ] តែអ្នកណាដែលគប់រកស្រីសំផឹង
នោះស៊ីបង្ហិនទ្រព្យសម្បត្តិគាត់វិញ[ជ]។
៤ ស្តេចរមែងតាំងនគរឱ្យមាំមួន[ឈ] ដោយសារសេចក្តី
យុត្តិធម៌ តែស្តេចណាដែលសង្កត់សង្កិនយកដង្វាយ នោះធ្វើ
ឱ្យស្រុកវិនាសវិញ ។
៥ អ្នកណាដែលបញ្ចើចដល់អ្នកជិតខាង នោះឈ្មោះថា
ដាក់លប់សំរាប់ចាប់ជើងគេទេ[ញ]។
៦ មានអន្ទាក់ នៅក្នុងអំពើរំលងរបស់មនុស្សអាក្រក់[ដ] តែ
មនុស្សសុចរិតគេច្រៀងដោយអរសប្បាយវិញ ។
៧ មនុស្សសុចរិតរមែងពិចារណាយល់ហេតុនៃមនុស្ស
ទាល់ក្រ[ឋ] តែមនុស្សអាក្រក់គ្មានយោបល់យល់បានទេ ។

**២៨:២៨** ក ខ.១២
**២៩:១** ក នក ៣២:៩ ចទ ៩:២៧ ខ យរ ១៩:១៥ ៣៦:៣១ ហប ២:៧ គ ២របា ៣៦:១៦ សភ ៦:១៥
**២៩:២** ឃ ២ពវ ១១:២០ ង សភ ៣០:២ សស ១០:៦ ច សភ ២៨:១២
**២៩:៣** ឆ សភ ១០:១ ២៣:១៥–១៦ ជ សភ ៥:៨–១០ លក ១៥:១១–៣២
**២៩:៤** ឈ ខ.១៤ សភ ៨:១៥–១៦
**២៩:៥** ញ យប ៣២:២១ សភ ២៦:២៨
**២៩:៦** ដ យប ៥:១៣ សភ ២៦:២៧
**២៩:៧** ឋ សភ ៣១:៨–៩
**២៩:៨** ឌ សភ ១១:១១ ១៦:១៤

៨ មនុស្សចំអកមើលងាយ គេអុចអាលឱ្យទីក្រុងឆេះ
ឡើង តែមនុស្សមានប្រាជ្ញា គេបង្វែរបណ្តេញសេចក្តី
ក្រោធចេញវិញ[ឌ]។
៩ បើអ្នកមានប្រាជ្ញា គេកើតមានរឿងនឹងមនុស្សចំកួត
ទោះបើអ្នកនោះខឹង ឬសើចក្តីគង់តែឥតមានសេចក្តីសុខ
វិញឡើយ ។
១០ ពួកមនុស្សដែលកំចាយឈាម នោះរមែងតែស្អប់ដល់
មនុស្សត្រឹមត្រូវ តែមនុស្សទៀងត្រង់រកជួយសង្គ្រោះព្រលឹង
អ្នកនោះវិញ[ឍ]។
១១ ពួកល្ងីល្ងើ សំដែងចេញអស់ទាំងកំហឹងរបស់ខ្លួន[ណ]
តែមនុស្សមានប្រាជ្ញាគេទប់ចិត្ត ហើយរំងាប់ចេញវិញ[ត]។
១២ បើអ្នកគ្រប់គ្រង[ថ]តែងស្តាប់តាមពាក្យភូតភរ នោះ
ពួកអ្នកបំរើរបស់គេក៏ជាមនុស្សអាក្រក់ដែរ[ទ]។
១៣ មនុស្សទាល់ក្រ និងមនុស្សដែលសង្កត់សង្កិន គេតែង
តែប្រទះគ្នា តែគឺព្រះយេហូវ៉ា ដែលបំភ្លឺភ្នែករបស់អ្នកទាំង
២នោះ[ធ]។
១៤ ឯស្តេចណាដែលវិនិច្ឆ័យក្តីរបស់មនុស្សទាល់ក្រ
ដោយឥតមន្ទិល បល្ល័ង្ករាជ្យរបស់ស្តេចនោះនឹងអញបាន

**២៩:១០** ឍ ខ.២៧ ១យហ ៣:១២ **២៩:១១** ណ យប ១៥:១៣ ត សភ ១២:១៦
**២៩:១២** ថ ២ពវ ២១:៩ ទ យប ៣៤:៣០ **២៩:១៣** ធ យប ២២:២ មថ ៥:៤៥

ពន្យល់ ។ *មនុស្សសុចរិតរមែងចំរើនឡើង* សូមមើល ១១:១០ ២៩:២ ។
**២៩:១** *អ្នកណាដែលត្រូវបន្ទោសជាញយៗ តែងតាំងចិត្តរឹងវិញ* សូមមើលការពន្យល់ នក ៣២:៩ មានកូនប្រុសរបស់លោកអេលីបានស្លាប់ដោយសាតែភាពចចេសរឹងរូសរបស់គាត់ (មើល ១សយ ២:២៥ និងការពន្យល់) ។ *នោះត្រូវវិនាសក្នុង១រំពេច* ក៏បញ្ជាក់ចំពោះ ៦:១៥ ប្រៀបធៀបចំពោះវាសនារបស់ពួកចំអកមើលងាយមានក្នុង ១:២២–២៧ ។
**២៩:២** *កាលណាមនុស្សសុចរិតមានអំណាចឡើង នោះជនទាំងឡាយរមែងមានចិត្តរីករាយ* សូមមើល ១១:១០ និងការពន្យល់ ។ *កាលណាមនុស្សអាក្រក់គ្រប់គ្រងវិញ នោះបណ្តាលជនស្រែកថ្ងូរឡើង* សូមមើល ២៨:១២ យហ ២:១៨ និងការពន្យល់ ពច ២:១៨ និងការពន្យល់ ។
**២៩:៣** *អ្នកណាដែលស្រឡាញ់ដល់ប្រាជ្ញា នោះរមែងនាំឱ្យឪពុករីករាយសប្បាយ* សូមមើល ១០:១ និងការពន្យល់ ។ *ដែលគប់រកស្រីសំផឹង នោះស៊ីបង្ហិនទ្រព្យសម្បត្តិគាត់វិញ* សូមមើល ៥:១០ ៦:២៦ លក ១៥:១៣ និងការពន្យល់ ។
**២៩:៤** *ស្តេចរមែងតាំងនគរឱ្យមាំមួន ដោយសារសេចក្តីយុត្តិធម៌* សូមមើល ១៦:១២ និងការពន្យល់ ។ *យកដង្វាយ* សូមមើល ១៧:៨ និងការពន្យល់ ។
**២៩:៥** *អ្នកណាដែលបញ្ចើចដល់អ្នកជិតខាង* សូមមើល ២៨:២៣ ។
**២៩:៦** *មានអន្ទាក់នៅក្នុងអំពើរំលងរបស់មនុស្សអាក្រក់* សូមមើល ១:១៨ និងការពន្យល់ ២២:៥ ។
**២៩:៧** *មនុស្សសុចរិតរមែងពិចារណាយល់ហេតុ* ដូចជាករណីលោកយ៉ូបដែលជាមនុស្សសុចរិតបានពិចារណាពីហេតុផល (យប ២៩:១៦) សូមមើល យរ ២២:១៦ និងការពន្យល់ យប ១:២៧ ប្រៀបធៀប សភ ១៩:១៧ ២២:២២ ២៩:១៤ ។
**២៩:៨** *មនុស្សចំអកមើលងាយ គេអុចអាលឱ្យទីក្រុងឆេះឡើង* សូមមើលការពន្យល់ ៦:១៤ ១១:១១ ក៏សូមមើល ២៦:២១ ។ *មនុស្សចំអក* សូមមើល ១:២២ និងការពន្យល់ ។ *មនុស្សមានប្រាជ្ញាគេបង្វែរបណ្តេញសេចក្តីក្រោធចេញវិញ* សូមមើល យក ៣:១៧–១៨ ។
**២៩:៩** *មនុស្សចំកួតទោះបើអ្នកនោះខឹង ឬសើចក្តី* ពួកគេមានលក្ខណៈដូចជាខ្លាឃ្មុំដែលមានកំហឹង (១៧:១២ អស ៥៧:២០–២១) ។
**២៩:១០** *ពួកមនុស្សដែលកំចាយឈាម នោះរមែងតែស្អប់ដល់មនុស្សត្រឹមត្រូវ* មានការពណ៌នាបន្ថែមទៀតអំពីមនុស្សអាក្រក់ក្នុង ១:១១–១៦ ធៀបនឹង ទដ ៥:៦ ។
**២៩:១១** *សំដែងចេញអស់ទាំងកំហឹងរបស់ខ្លួន* សូមមើល ខ.៩ និងការពន្យល់ ១៤:១៦–១៧ ។ *ហើយរំងាប់ចេញវិញ* សូមមើល ១៦:៣២ និងការពន្យល់ ។
**២៩:១២** *ពួកអ្នកបំរើរបស់គេក៏ជាមនុស្សអាក្រក់ដែរ* សូមមើលការប្រៀបធៀប អស ១:២៣ ។
**២៩:១៣** *តែគឺព្រះយេហូវ៉ាដែលបំភ្លឺភ្នែក* សូមមើលក្នុង នក ៤:១១ ទដ ៩៤:៩ ។
**២៩:១៤** សូមមើល អស ៩:៧ ធៀបនឹង ទដ ២៧:២៤ ។

តាំងឱ្យជាប់ជាដរាប[ន] ។
១៥រំពាត់ និងសេចក្តីប្រៀនប្រដៅ រមែងឱ្យកើតមាន
ប្រាជ្ញា តែកូនណាដែលបណ្តោយឱ្យប្រព្រឹត្តតាមអំពើចិត្ត
នោះតែងធ្វើឱ្យម្តាយមានសេចក្តីខ្មាសវិញ[ប] ។
១៦កាលណាមនុស្សអាក្រក់ចំរើនជាច្រើនឡើង នោះ
សេចក្តីរំលងច្បាប់ក៏ចំរើនឡើងដែរ ប៉ុន្តែពួកសុចរិតនឹង
ឃើញគ្រាដែលគេដួលចុះទៅវិញ[ផ] ។
១៧ចូរស្តីប្រដៅកូនឯងចុះ នោះវានឹងឱ្យឯងបានសំរាក
ចិត្ត អើ វានឹងឱ្យឯងមានចិត្តរីករាយផង[ព] ។
១៨គ្រាណាដែលឥតមានការបើកសំដែង នោះបណ្តា
ជនរមែងលែងទប់ចិត្ត តែអ្នកណាដែលប្រព្រឹត្តតាមបញ្ញត្តិ
ច្បាប់ នោះសប្បាយហើយ[ភ] ។
១៩ខ្ញុំកំដរនឹងរាងចាល ដោយសារតែពាក្យបន្ទោសមិន
បាន ដ្បិតទោះបើវាស្តាប់បាន គង់តែមិនយកចិត្តទុកដាក់
ឡើយ ។
២០ឯងដែលឃើញមនុស្សរហ័សនឹងបញ្ចេញសំដី ឬមាន
សេចក្តីសង្ឃឹម ចំពោះមនុស្សល្ងីល្ងើ ជាជាងអ្នកនោះទៅ
ទៀត[ម] ។
២១អ្នកណាដែលចិញ្ចឹមបាវបំរើដោយថ្នម តាំងពីតូចមក
នោះដល់ជាន់ក្រោយនឹងបានអ្នកនោះដូចជាកូនវិញ ។
២២មនុស្សមួម៉ៅរមែងអុចអាល ឱ្យកើតមានសេចក្តីទាស់
ទែងគ្នា ហើយមនុស្សមានចិត្តក្រោធ នោះរំលងច្បាប់ជា
ច្រើន[យ] ។
២៣ចិត្តឆ្មើងឆ្មៃរបស់មនុស្ស នឹងនាំឱ្យទាបថោកទៅ[រ]
តែអ្នកណាដែលមានចិត្តសុភាពរាបទាប នោះនឹងបានកិត្តិ
ស័ព្ទវិញ[ល] ។
២៤អ្នកណាដែលចូលដៃនឹងចោរ នោះឈ្មោះថាស្អប់
ដល់ព្រលឹងខ្លួន វាឮគេដាក់បណ្តាសាដល់ខ្លួន ប៉ុន្តែមិន
ពោលតបឡើយ[វ] ។
២៥ការដែលខ្លាច[ស]ចំពោះមនុស្ស នោះនាំឱ្យជាប់អន្ទាក់
តែអ្នកណាដែលទុកចិត្តដល់ព្រះយេហូវ៉ា[ហ]ពិត នោះនឹងបាន
សុខវិញ[ឡ] ។
២៦មានមនុស្សជាច្រើនដែលស្វែងរក ឱ្យបានប្រកប
ដោយគុណនៃអ្នកគ្រប់គ្រង[អ] តែសេចក្តីវិនិច្ឆ័យដល់មនុស្ស
នោះស្រេចនៅព្រះយេហូវ៉ាវិញ[ក] ។
២៧ឯមនុស្សទុច្ចរិត គេជាទីស្អប់ខ្ពើមដល់ពួកសុចរិត
ហើយអ្នកណាដែលប្រព្រឹត្តដោយទៀងត្រង់ នោះក៏ជាទី
ស្អប់ខ្ពើមដល់មនុស្សអាក្រក់ដែរ[ខ] ។

## ពាក្យរបស់លោកអេគើរ

**៣០** ១ពាក្យទាំងនេះ[ក] ជាពាក្យរបស់អេគើរ ជាកូនយ៉ាកេ
គឺជាសេចក្តីទំនាយដែលអ្នកនោះបានពោលដល់អ៊ីធាល

**២៩:១៤** ន ខ.៤ ទដ ៧២:១-៥ សភ ១៦:១២
**២៩:១៥** ប ខ.១៧ សភ ១៣:២៤
**២៩:១៦** ផ ទដ ៩១:៨ ៩២:១១
**២៩:១៧** ព ខ.១៥
**២៩:១៨** ភ ទដ ១:១-២ ១៩:១១ ១១៩:១-២
**២៩:២០** ម សភ ១៩:២ ២៦:១២
**២៩:២២** យ សភ ១៤:១៧
**២៩:២៣** រ នអ ៥:១២ ល សភ ១២:២ ១៥:៣៣ ១៦:១៨
**២៩:២៤** វ លវ ៥:១
**២៩:២៥** ស ១សយ ១៥:២៤ ហ សភ ២៨:២៥ ឡ សភ ១៦:២០
**២៩:២៦** អ សភ ១៩:៦ ក សភ ១៦:៣៣
**២៩:២៧** ខ ខ.១០ **៣០:១** ក សភ ២២:១៧

**៣៩:១៥** *រំពាត់នឹងសេចក្តីប្រៀនប្រដៅ* សូមមើលការពន្យល់ ១៣:២៤ ។
**២៩:១៦** *កាលណាមនុស្សអាក្រក់ចំរើនជាច្រើនឡើង* សូមមើល ខ.២ ១១:១១ និងការពន្យល់ ២៨:១២,២៨ ។ *ប៉ុន្តែពួកសុចរិតនឹងឃើញគ្រាដែលគេដួលចុះទៅវិញ* សូមមើល ១០:២៥ ១៤:១១ ២១:១២ ។
**២៩:១៧** *ចូរស្តីប្រដៅកូនឯងចុះ* គឺតម្រូវឱ្យឪពុកម្តាយទាំងឡាយទូន្មានប្រដៅ ដើម្បីឱ្យកូនៗនោះដើរក្នុងផ្លូវល្អ (សូមមើល ១៣:២៤ និងការពន្យល់ ២២:៦) ។
**២៩:១៨** *ការបើកសំដែង* គឺជាព្រះរាជសារពីព្រះអម្ចាស់តាមរយៈពួកហោរាក៏មានក្នុងនិមិត្តរបស់ពួកហោរាផងដែរ (សូមមើល ១សយ ៣:១ អស ១:១) ។ *បណ្តាជនរមែងលែងទប់ចិត្ត* គឺសកម្មភាពជាអំពើបាបរបស់រាស្ត្រអ៊ីស្រាអែលក្នុងខណៈដែលលោកម៉ូសេ នៅលើខ្នងភ្នំស៊ីណាយ (សូមមើល នក ៣២:២៥ និងការពន្យល់) ។ *តែអ្នកណាដែលប្រព្រឹត្តតាមបញ្ញត្តិច្បាប់នោះសប្បាយហើយ* សូមមើល ២៨:៤ និងការពន្យល់ ៨:៣២ ។
**២៩:១៩** *និងរាងចាលដោយសារតែពាក្យបន្ទោសមិនបាន* គឺខ្ញុំកំដរដែលមានលក្ខណៈជាកូនប្រុសៗក៏ត្រូវការកែតម្រូវប្រដៅ (សូមមើលការពន្យល់ ២២:៦ ខ.១៥,១៧) ។
**២៩:២០** *ឯងដែលឃើញមនុស្សរហ័សនឹងបញ្ចេញសំដី* សូមមើល ១០:១៩ ១៧:២៧-២៨ យក ១:១៩,២៦ ។ មានសេចក្តីសង្ឃឹម ពាក្យនេះក៏មានបញ្ជាក់ក្នុង ២៦:១២ ។
**២៩:២២** *មនុស្សមួម៉ៅរមែងអុចអាលឱ្យកើនមានសេចក្តីទាស់ទែងគ្នា* សូមមើលការពន្យល់ ៦:១៤ ១៥:១៨ ។
**២៩:២៣** សូមមើល ១៥:៣៣ និងការពន្យល់ ក៏សូមមើល ១៨:១២ ។
**២៩:២៤** *វាឮគេដាក់បណ្តាសាដល់ខ្លួន* គឺពួកពុំមានសេចក្តីបន្ទាល់ល្អពិតប្រាកដ (ធៀបនឹង លវ ៥:១) ។
**២៩:២៥** *ដែលខ្លាចចំពោះមនុស្ស* ប្រៀបធៀបនឹង ១សយ ១៥:២៤ អស ៥១:១២ យហ ១២:៤២-៤៣ ។ *អ្នកណាដែលទុកចិត្តដល់ព្រះយេហូវ៉ាពិតនោះនឹងបានសុខវិញ* សូមមើល ១៨:១០ ២៨:២៦ និងការពន្យល់ ប្រៀបធៀបនឹង ៣:៥-៦ ។
**២៩:២៦** *មានមនុស្សជាច្រើនដែលស្វែងរក* សូមមើល ១ពវ ១០:២៤ ។ *តែសេចក្តីវិនិច្ឆ័យដល់មនុស្សនោះស្រេចនៅព្រះយេហូវ៉ាវិញ* គឺគ្រប់ទាំងសកម្មភាពរបស់ព្រះមហាក្សត្រ គឺព្រះយេហូវ៉ាជាអ្នកគ្រប់គ្រង (សូមមើលការពន្យល់ ២១:១) ។
**២៩:២៧** គឺជាបទសុភាសិតចុងក្រោយ ក្នុងអត្ថបទនេះគឺជាវគ្គមួយដែលស្តេចសាឡូម៉ូនបានស្រង់ទុក (ជិពូក ២៥:២៩) ។
**៣០:១** *ពាក្យទាំងនេះ* សូមមើល ២២:១៧ និងការពន្យល់ ២៤:២៣ ។ ឯពាក្យថា "ពាក្យនេះ" គឺជាពាក្យពុំនោលរបស់លោកអេគើរ ជាកូនយ៉ាកេគឺជាសេចក្តីទំនាយ ដែលមានកត់ត្រាក្នុងជិពូកនេះ ។ *អេគើរជាកូនយ៉ាកេ* គឺមិនមែនជារាស្ត្រអ៊ីស្រាអែលទេ គឺជាអ្នកប្រាជ្ញមានលក្ខណៈដូចជាលោកយ៉ូប

គឺដល់អ៊ីធាល និងយូកាលផងថា–
២ពិតប្រាកដជាខ្ញុំល្ងង់ជាងអស់ទាំងមនុស្ស ក៏ឥតមាន
យោបល់របស់មនុស្សដែរ ៣ខ្ញុំមិនបានរៀនឱ្យមានប្រាជ្ញាទេ
ក៏គ្មានដំរិះរបស់ព្រះដ៏បរិសុទ្ធផង[ខ] ។
៤តើអ្នកណាបានឡើងទៅ[គ]ឯស្ថានសួគ៌ រួចត្រឡប់ចុះមក
វិញ តើអ្នកណាបានកើបប្រមូលខ្យល់ក្ដាប់នៅដៃ[ឃ] តើអ្នក
ណាបានដក់ក្របួចអស់ទាំងទឹក[ង]នៅក្នុងថ្នក់អាវរបស់ខ្លួន[ច]
តើអ្នកណាបានប្រតិស្ឋានចុងផែនដីទាំងប៉ុន្មាន តើព្រះអង្គ
នោះមានព្រះនាមជាអ្វី[ឆ] ហើយព្រះរាជបុត្ររបស់ទ្រង់
តើមានព្រះនាមជាអ្វី បើឯងដឹង ចូរប្រាប់មក ។
៥គ្រប់ទាំងព្រះបន្ទូលនៃព្រះ សុទ្ធតែបរិសុទ្ធ[ជ] ទ្រង់ជា
ខែល[ឈ]ដល់អស់អ្នកដែលពឹងជ្រកក្នុងទ្រង់ ៦កុំឱ្យបន្ថែម
បញ្ចូល[ញ]ក្នុងព្រះបន្ទូលទ្រង់ឡើយ ក្រែងទ្រង់បន្ទោសដល់
ឯង ហើយឃើញថា ឯងជាមនុស្សភូតភរ ។
៧ទូលបង្គំបានសូមសេចក្ដី២ប្រការពីទ្រង់ សូមកុំខាន
ខឹងប្រទានសេចក្ដីទាំង២នោះដល់ទូលបង្គំ មុនដែលទូល
បង្គំស្លាប់ឡើយ ៨គឺសូមកំចាត់សេចក្ដីភូតភរ និងពាក្យកុហក
ឱ្យឆ្ងាយពីទូលបង្គំទៅ ហើយសូមកុំឱ្យទូលបង្គំមានសេចក្ដី
ទាល់ក្រ ឬជាអ្នកមានដែរ សូមគ្រាន់តែចិញ្ចឹមទូលបង្គំ
ដោយអាហារដែលត្រូវការប៉ុណ្ណោះ[ដ] ៩ក្រែងទូលបង្គំ
បានឆ្អែត ហើយបោះបង់ចោល[ឋ]ទ្រង់ដោយពាក្យថា ព្រះ
យេហូវ៉ាជាអ្នកណាហ្ន៎[ឌ] ឬក្រែងទូលបង្គំមានសេចក្ដីទាល់
ក្រ ហើយទៅជាលួចគេ ព្រមទាំងប្រើព្រះនាមនៃព្រះជាទី
មើលងាយផង[ឍ] ។
១០កុំឱ្យនិយាយបង្កាច់បាវបំរើដល់ចៅហ្វាយវាឡើយ
ក្រែងគេជេរឯង ហើយឯងជាប់មានទោសវិញ ១១មាន
សម័យ១ ដែលមនុស្សហ៊ានជេរដល់ឪពុកខ្លួន ហើយមិនឱ្យ
ពរដល់ម្ដាយផង[ណ] ១២មានសម័យ១ ដែលមនុស្សមើលខ្លួន
ឯង ស្មានថាបរិសុទ្ធ[ត] ប៉ុន្តែគេមិនទាន់បានលាងជំរះសេចក្ដី
ស្មោកគ្រោករបស់គេចេញនៅឡើយទេ[ថ] ១៣មានសម័យ១
ដែលមនុស្សឫកខ្ពស់យ៉ាងណាហ្ន៎[ទ] ហើយមានភ្នែកឆ្មើង
ឆ្មៃផង ១៤មានសម័យ១ ដែលមនុស្សមានធ្មេញ[ធ]ដូចជាដាវ
ហើយមានថ្គាមដូចជាកាំបិត[ន] ដើម្បីខាំស៊ី[ប]មនុស្សទាល់ក្រ[ផ]
ឱ្យបាត់ចេញពីលើផែនដីទៅ ព្រមទាំងពួកកំសត់ទុគ៌តពី
កណ្ដាលចំណោមមនុស្សលោកផង[ព] ។

**៣០:៣** ខ សភ ៩:១០ **៣០:៤** គ ចទ ៣០:១២ ទដ ២៤:១–២ សភ ៨:២២ ៣១ យហ ៣:១៣ អភ ៤:៧–១០ ឃ អស ៤០:១២ ង យប ២៦:៨ ច លប ១:២ ឆ វវ ១៩:១២ **៣០:៥** ជ ទដ ១២:៦ ១៨:៣០ ឈ លប ១៥:១ **៣០:៦** ញ ចទ ៤:២ **៣០:៨** ដ មថ ៦:១១ **៣០:៩** ឋ យស ២៤:២៧ អស ១:៤ ៥៩:១៣ ឌ ចទ ៦:១២ ៨:១០–១៤ ហស ១៣:៦ ឍ ចទ ៨:១២ **៣០:១១** ណ សភ ២០:២០ **៣០:១២** ត សភ ១៦:២ ថ យរ ២:២៣,៣៥ **៣០:១៣** ទ ២សយ ២២:២៨ យប ៤១:៣៤ **៣០:១៤** ធ យប ៤:១១ ទដ ៣:៧ ន ទដ ៥៧:៤ ប យប ២៤:៩ ផ អម ៨:៤ មីក ២:២ ព យប ១៩:២២

និងមិត្តរបស់គាត់ ។ *ជាសេចក្ដីទំនាយ* ជាពិសេសដូចជាសារលិខិតរបស់ពួកហោរា (សូមមើលការពន្យល់ អស ១៣:១) ។

**៣០:២** *ពិតប្រាកដជាខ្ញុំល្ងង់ជាងអស់ទាំងមនុស្ស* គឺលោកប៉ុលបានពណ៌នាពីជីវិតរបស់លោកផ្ទាល់ដែលមាន"បាបយ៉ាងធ្ងន់"(១ធថ ១:១៦) ។

**៣០:៣** *ដំរិះរបស់ព្រះដ៏បរិសុទ្ធផង* សូមមើល ៩:១០ និងការពន្យល់ ។

**៣០:៤** គឺជាការប្រើសំណួរលក្ខណៈវោហាស័ព្ទ ដើម្បីបញ្ជាក់ពីភាពឧត្តម្ភរបស់ព្រះក្នុងនាមទ្រង់ជាព្រះអាទិករលើគ្រប់ទាំងអស់ក៏មានក្នុង យប ៣៨:៤ ៣៩:៣០ អស ៤០:១២–៣១ ។ *កើបប្រមូលខ្យល់ក្ដាប់នៅដៃ* ប្រៀបធៀប ទដ ១៣៥:៧ ។ *ក្របួចអស់ទាំងទឹក នៅក្នុងថ្នក់អាវរបស់ខ្លួន* សូមមើល យប ២៦:៨–៩ ។ *ហើយព្រះរាជបុត្រារបស់ទ្រង់កើតមានព្រះនាមជាអ្វី* សំណួរនេះគេបានយល់តាមរបៀបផ្សេងៗគ្នា ប៉ុន្តែអត្ថន័យនេះនៅតែមានភាពមិនច្បាស់ ។ *បើអ្នកដឹងចូរប្រាប់មក* គឺមានលក្ខណៈស្រដៀងពីការលើកទឹកចិត្តពីព្រះដល់លោកយ៉ូប (សូមមើល យប ៣៨:៤–៥ និងការពន្យល់) ។

**៣០:៥** ខនេះក៏មានបញ្ជាក់ក្នុង ទដ ១៨:៣០ ។ *ខែល* សូមមើលការពន្យល់ ២:៧ ទដ ៣:៣ ។ *ដល់អស់អ្នកដែលពឹងជ្រកក្នុងទ្រង់* សូមមើល ១៤:៣២ ១៨:១០ ។

**៣០:៦** *កុំឱ្យបន្ថែមបញ្ចូលក្នុងព្រះបន្ទូលទ្រង់ឡើយ* ប្រៀបធៀបពីការព្រមានរបស់លោកម៉ូសេចំពោះរាស្ត្រអ៊ីស្រាអែលក្នុង ចទ ៤:២ (សូមមើលការពន្យល់ ៤:២) ប្រៀបធៀប វវ ២២:១៨–១៩ និងការពន្យល់ ។

**៣០:៧** *សេចក្ដីទាំង២* ការប្រើពីបញ្ជីបង្ហាញពីលក្ខណៈសម្បត្តិរបស់ពាក្យពុំនោលរបស់អេគើរ (សូមមើល ខ.១៥,២២,២៤,២៩) ។

**៣០:៨** *ចិញ្ចឹមទូលបង្គំដោយអាហារ* ប្រៀបធៀប យប ២៣:១២ និងការអធិស្ឋានរបស់ព្រះយេហូវ៉ា (សូមមើល មថ ៦:១១ និងការពន្យល់) ។

**៣០:៩** *ក្រែងទូលបង្គំបានឆ្អែត ហើយបោះបង់ចោលទ្រង់* លោកម៉ូសេក៏បានថ្លែងទំនាយថា រាស្ត្រអ៊ីស្រាអែលបានភ្លេចព្រះក្នុងខណៈពេលពួកគេមានអាហារគ្រប់គ្រាន់ និងមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ (មើល ចទ ៨:១២–១៧ ៣១:២០) ។ *ព្រះយេហូវ៉ាទ្រង់ជាអ្នកណាហ្ន៎* ហេតុអ្វីបានជាខ្ញុំត្រូវបម្រើទ្រង់ (សូមមើល យប ២១:១៤–១៥) ។ *សេចក្ដីទាល់ក្រ ហើយទៅជាលួចគេ* ប្រៀបធៀបនិង ៦:៣០ ។

**៣០:១០** *ហើយឯងជាប់មានទោសវិញ* គឺតាំងពីពេលដែលមានការជាប់ជាអ្នកធ្វើបាបដែលជាការធ្លាក់ចុះ គឺជាការជាប់បណ្ដាសារបស់បាវបម្រើ (ប្រៀបធៀប ២៦:២ និងការពន្យល់) ។

**៣០:១១** *ហ៊ានជេរដល់ឪពុកខ្លួន* ប្រៀបនឹង ខ.១៧ សូមមើល ២០:២០ និងការពន្យល់ ។

**៣០:១២** *ដែលមនុស្សមើលខ្លួនឯងស្មានថាបរិសុទ្ធ* គឺដូចជាពួកផារិស៊ី មើលក្នុង លក ១៨:១១ (ប្រៀបធៀប ៦៥:៥ និងការពន្យល់) ។

**៣០:១៣** *ហើយមានភ្នែកឆ្មើងផង* សូមមើលការពន្យល់ ៦:១៣ ក៏សូមមើល អស ៣:១៦ ។

**៣០:១៤** *ដែលមនុស្សមានធ្មេញដូចជាដាវ ហើយមានថ្គាមដូចជាកាំបិត* គឺពួកគេមានសណ្ឋានជាសត្វសាហាវដែលល្មោភស៊ី (មើល យប ២៩:១៧) ។ *ដើម្បីខាំស៊ីមនុស្សទាល់ក្រឱ្យបាត់ចេញពីលើផែនដីទៅ* ប្រៀបធៀប ទដ ១៤:៤ មីក ៣:២–៣ និងកាពន្យល់ ។

១៥ឈ្លើងមានកូនញី២ វាស្រែកថា ចូរឱ្យ ចូរឱ្យមកចុះ
មានសេចក្តី៣មុខ ដែលមិនចេះស្កប់ចិត្តឡើយ[ភ] ក៏មាន៤ផង
ដែលមិនចេះថា "ល្មម" នោះឡើយ ១៦គឺស្ថានឃុំព្រលឹង
មនុស្សស្លាប់១[ម] ពោះស្ត្រីអារ១ ដីដែលមិនបានទឹកជោក១
ហើយនិងភ្លើង ដែលមិនចេះថា "ល្មមហើយ" ១ដែរ ។
១៧ឯភ្នែកដែលចំអក[យ]ឱ្យឪពុក ហើយប្រមាថមើលងាយ
មិនស្តាប់បង្គាប់ម្តាយ នោះក្អែកនៅច្រកភ្នំនឹងចឹកភ្នែកនោះ
ចេញ ហើយត្មាតនឹងជញ្ជែងស៊ីទៅ[រ] ។
១៨មានសេចក្តី៣មុខដែលអស្ចារ្យហួសគំនិតខ្ញុំ អើក៏មាន
៤ផង ដែលខ្ញុំរកស្គាល់មិនបាន ១៩គឺជាដំណើររបស់ឥន្ទ្រី
ហើរនៅលើអាកាស១ ដំណើរនៃពស់លូននៅលើថ្ម១
ដំណើរនាវាបើកនៅកណ្តាលសមុទ្រ១ ហើយដំណើរ
មនុស្សកំលោះនៅចំពោះស្ត្រីក្រមុំ១ ។
២០ឯដំណើររបស់ស្រីសំផឹងរមែងយ៉ាងដូច្នេះ គឺវាស៊ី
ហើយជូតមាត់ រួចពោលថា ខ្ញុំគ្មានធ្វើបាបអ្វីសោះ[ល] ។
២១មានសេចក្តី៣មុខ ដែលធ្វើឱ្យផែនដីញ័រ ក៏មាន៤ផង
ដែលផែនដីទ្រាំមិនបាន[វ] ២២គឺបាវបំរើដែលបានឡើងធ្វើ
ជាស្តេច១" មនុស្សឥតរបប ដែលបានអាហារបរិបូរ១
២៣ស្ត្រីគួរខ្ពើមដែលយកប្តីនោះ១ ហើយខ្ញុំស្រីដែលជាអ្នកស៊ី
មរដកចៅហ្វាយវា១ ។
២៤មានសត្វ៤យ៉ាង ដែលតូចទាបណាស់នៅលើផែនដី
តែមានប្រាជ្ញាដ៏លើសលុប ២៥គឺស្រមោច១ ជាពួកសត្វ
ដែលមានកំឡាំងខ្សោយ តែវាតែងតែប្រមូលទុកអាហារ
នៅរដូវក្តៅ[ស] ២៦ទន្សាយថ្ម[ហ]១ ជាពួកសត្វមិនសូវមាន
កំឡាំងទេ តែវាតាំងលំនៅវានៅក្នុងរូងថ្ម ២៧កណ្តូប[ឡ]១ជា
ពួកសត្វឥតមានស្តេចទេ តែវាលើកគ្នាចេញទៅដោយ
ហ្វូងៗ ២៨ជីងចក់១ ជាសត្វដែលចាប់ដោយដៃបាន តែវា
នៅក្នុងដំណាក់ស្តេចផង ។
២៩មាន៣មុខដែលមានដំណើររុងរឿង ក៏មាន៤ផង
ដែលមានដំណើរយ៉ាងល្អ ៣០គឺជាសិង្ហ១ ជាសត្វខ្លាំងពូកែ
លើសជាងអស់ទាំងពួកសត្វ វាមិនព្រមចៀសផ្លូវដល់សត្វ
ណាឡើយ ៣១សេះចំបាំង១ ពពែឈ្មោល១ ហើយមហា–
ក្សត្រ១ ជាអ្នកដែលគ្មានអ្នកណាហ៊ានលើកខ្លួនទាស់ទទឹង
នឹងទ្រង់ឡើយ ។
៣២បើឯងបានប្រព្រឹត្តបែបចំកួតដោយលើកខ្លួនឡើង ឬ
បើឯងបានគិតគំនិតអាក្រក់ នោះចូរយកដៃខ្ទប់មាត់ចុះ[អ]

**៣០:១៥** ភ សភ ២៧:២០
**៣០:១៦** ម អស ៥:១៤ ១៤:៩,១១ ហប ២:៥
**៣០:១៧** យ ចទ ២១:១៨–២១ រ យប ១៥:២៣
**៣០:២០** ល សភ ៥:៦
**៣០:២២** វ សភ ១៩:១០ ២៩:២
**៣០:២៥** ស សភ ៦:៦–៨
**៣០:២៦** ហ ទដ ១០៤:១៨
**៣០:២៧** ឡ នក ១០:៤
**៣០:៣២** អ យប ២៩:៩

**៣០:១៥,១៨,២២,២៩** សូមមើលការពន្យល់ ៦:១៦ ។
**៣០:១៥** *ឈ្លើងមានកូនញី២* កូនញីទាំងនេះគឺជាអ្នកជញ្ជក់ ដែលជាពួកបរាសិត ដែលជញ្ជក់ឈាមពីជនរងគ្រោះ ។
**៣០:១៦** *ស្ថានឃុំព្រលឹង* ជាកន្លែងមានសេចក្តីស្រេចដែលពុំចេះស្កប់ស្កល់ (អស ៥:១៤ ហប ២:៥) ។
**៣០:១៧** *ឯភ្នែកដែលចំអកឱ្យឪពុក ហើយប្រមាថមើលងាយមិនស្តាប់បង្គាប់ម្តាយ* (សូមមើល ៦.១១,១៣ និងការពន្យល់ ១៥:២០) ។ *នេះក្អែកនៅច្រកភ្នំនឹងចឹកភ្នែកនោះចេញ* កាលដែលបានបាត់ភ្នែកគឺជាសេចក្តីបណ្តាសាដ៏ខ្លាំងមួយ (សូមមើលរឿងសាំសុននៅក្នុង ពច ១៦:២១) ពេលនោះក៏មានសត្វត្មាតស៊ីកំទេចសាកសពខ្មោចស្អុត (សូមមើល យរ ៧:៣៣ និងការពន្យល់ មថ ២៤:២៨) អត្ថន័យនេះអាចសំដៅលើរូបកាយកូនប្រុសដែលល្មើសគុណពុំស្តាប់បង្គាប់ហើយត្រូវដេកស្លាប់ដោយពុំបានបញ្ចុះត្រឹមត្រូវ ។
**៣០:១៨–១៩** សេចក្តីទាំងនោះគឺជាផ្លូវរបស់គេ គឺជា"ផ្លូវ"ទាំងបួនដែលពិបាកយល់ ហើយគេពុំអាចរកបានដោយសារតែពួកគេបានចាកចេញពីដានជើងផ្លូវទាំងនោះ ។
**៣០:១៩** *ជាដំណើររបស់ឥន្ទ្រីហើយ* ដែលបានសំកាំងឆាបប្រកបដោយអំណាចចេស្តា (ប្រៀបធៀប យប ៣៩:២៧ យរ ៤៨:៤០ ៤៩:២២) ។ *ដំណើរមនុស្សកំលោះនៅចំពោះស្ត្រីក្រមុំ១* គឺសំដៅទៅលើអាថ៌កំបាំងពីការចែចង់នឹងវិធីសាស្ត្រ ដើម្បីឈានទៅរកការសម្រេចរួមមួយ ។
**៣០:២០** *ស្រីសំផឹង* សូមមើល ២:១៦ និងការពន្យល់ ។ *គឺវាស៊ីហើយជូតមាត់* ការស៊ីនេះត្រូវបានគេប្រើដើម្បីប្រៀបប្រដូចទៅនឹងការរួមស្នេហ៍ ដែលមានអំពើកំផិតក៏មាននៅក្នុង ៩:១៧ (សូមមើលការពន្យល់ ៩:១៧ ក៏សូមមើល ៧:១៨ និងការពន្យល់) ។
**៣០:២២** *គឺបាវបំរើដែលបានឡើងធ្វើជាស្តេច១* សូមមើល ១៩:១០ ។
**៣០:២៣** *ស្ត្រីគួរខ្ពើមដែលយកប្តីនោះ១* គឺជាការមួយដែលនិយាយទៅលើស្ត្រីដែលជាប្រពន្ធគេជាច្រើនដែលទទួលភាពវេទនា ដោយព្រោះប្តីរបស់នាងទាំងនោះមិនស្រឡាញ់រូបនាង (ប្រៀបធៀប នាងលេអានៅក្នុង លប ២៩:៣១–៣២) ។ ខ្ញុំស្រី (បាវបំរើស្រី) ដែលជាអ្នកស៊ីមរដកចៅហ្វាយវា១ គឺប្រហែលខណៈពេលនាងជាស្រីដែលអាចមានលទ្ធិភាពបង្កើតកូនបាន ក៏ជាលក្ខណៈពេលស្ត្រីជាប្រពន្ធពិតប្រាកដ ជាស្ត្រីអារដែលមិនអាចមានកូនបាន (ប្រៀបធៀបនាងហាការ និងនាងសារ៉ាមានក្នុង លប ១៦:១–៦) ។
**៣០:២៥** *ស្រមោច* សូមមើលការពន្យល់ ៦:៦ ។
**៣០:២៦** *នៅក្នុងរូងថ្ម* គឺបានផ្តល់ទីជម្រកយ៉ាងមាំដល់ពួកស្រមោចទាំងនោះ (សូមមើល ទដ ១០៤:១៨) ។
**៣០:២៧** *កណ្តូប១ជាពួកសត្វឥតមានស្តេចទេ* ប្រៀបធៀបនឹងពួកស្រមោចក្នុង ៦:៦–៧ ។ *តែវាលើកគ្នាចេញទៅដោយហ្វូងៗ* ហ្វូងកណ្តូបគឺសបង្ហាញពីកងទ័ពដ៏មានអនុភាពខ្លាំងពូកែ យអ ២:២–៩ (សូមមើលការពន្យល់ យអ ២:២) ។
**៣០:២៨** *តែវានៅក្នុងដំណាក់ស្តេចផង* ជាប្រភេទសត្វជីងចក់ អាចវារឡើងជញ្ជាំងថ្មយ៉ាងងាយស្រួលបាន ។
**៣០:៣០** *ជាសិង្ហ១ ជាសត្វខ្លាំងពូកែលើសជាងអស់ទាំងពួកសត្វ* សូមមើល ២យស ១:២៣ មីក ៥:៨ ។
**៣០:៣១** *ពពែឈ្មោល១* សត្វពពែនេះគេបានប្រើវាដើម្បីដឹកនាំហ្វូងចៀម (សូមមើល យរ ៥០:៨) ។
**៣០:៣២** *ដោយលើកខ្លួនឡើង* គឺជាភាពមានសេចក្តីអំនួតក៏បានជំនុំជម្រះក្នុង ៨:១៣ ១១:២ ១៦:១៨ ។ *បានគិតគំនិតអាក្រក់* ធៀបនឹង ៦:១៤ ១៦:២៧ ។

៣៣ ដ្បិតការគ្រលុកទឹកដោះគោ នោះធ្វើឱ្យចេញជាខ្លាញ់
ហើយការដែលចាប់មួលច្រមុះ នោះធ្វើឱ្យចេញឈាមមក
យ៉ាងនោះការចាក់រុកដោយក្រោធ ក៏នាំឱ្យមានការឈ្លោះ
ប្រកែកគ្នាដែរ ។

## ពាក្យរបស់ស្តេចលេមយួល

**៣១** ១ ឯពាក្យទាំងនេះ[ក] គឺជាព្រះបន្ទូលរបស់ស្តេចលេម
យួល ជាសេចក្តីទំនាយ ដែលព្រះមាតាទ្រង់បានបង្រៀន
ទ្រង់ទុក ។
២ ម៉ែចកូនអើយ ម៉ែច កូនដែលកើតពីផ្ទៃអញអើយ ឱ
កូន នៃបំណន់អញអើយ តើត្រូវឱ្យអញប្រាប់ឯងដូម្តេច[ខ] ៣ គឺ
កុំឱ្យបង់កំឡាំងឯងប្រគល់ពួកស្រី ឬអំពើឯងដល់ការដែល
បំផ្លាញពួកស្តេចឡើយ[គ] ៤ ឱលេមយួលអើយ មិនគួរឱ្យពួក
ស្តេចបានសោយស្រាទំពាំងបាយជូរ[ឃ] គឺមិនគួរសោះឡើយ
ក៏មិនគួរឱ្យអ្នកដែលជាកំពូលប្រាថ្នាគ្រឿងស្រវឹងដែរ
៥ ក្រែងផឹក[ង] ទៅហើយ នោះភ្លេចបញ្ញត្តិច្បាប់[ច] ហើយ
បង្វែរសេចក្តីយុត្តិធម៌ពីមនុស្សដែលកើតទុក្ខវេទនាចេញ ។
៦ ចូរឱ្យគ្រឿងស្រវឹង ដល់អ្នកណាដែលហៀបនឹងវិនាស
ទៅ ហើយស្រាទំពាំងបាយជូរ[ឆ] ដល់អ្នកដែលមានចិត្តជូរ
ល្វីងវិញ ៧ ឱ្យគេផឹក[ជ] ចុះ ដើម្បីឱ្យបានភ្លេចសេចក្តីកំសត់
ទុគ៌តរបស់គេ ឥតនឹកចាំពីទុក្ខលំបាករបស់ខ្លួនតទៅទៀត
៨ ចូរបើកមាត់[ឈ] និយាយជំនួសមនុស្សគ ក្នុងរឿងក្តីរបស់
ពួកអ្នកដែលឥតមានអ្នកណាជួយ ៩ ចូរបើកមាត់វិនិច្ឆ័យតាម
សេចក្តីសុចរិត ហើយសំរេចសេចក្តីយុត្តិធម៌ដល់មនុស្ស
កំសត់ទុគ៌ត និងមនុស្សក្រលំបាកដែរ[ញ] ។

## អាវសានត្តកថា: ស្ត្រីគ្រប់លក្ខណ៍

១០ ឯស្ត្រីគ្រប់លក្ខណ៍[ដ] តើអ្នកណានឹងរកបាន[ឋ] ដ្បិតស្ត្រី
យ៉ាងនោះមានដំឡៃជាជាងត្បូងទទឹមទៅទៀត ១១ ប្តី[ឌ] នាង
នឹងទុកចិត្តចំពោះនាង ហើយមិនត្រូវខ្វះខាតអ្វីឡើយ[ឍ]
១២ នាងនឹងធ្វើឱ្យប្តីបានសេចក្តីល្អ មិនមែនអាក្រក់ឡើយ
រហូតដល់អស់១ជីវិតនាង ១៣ នាងរករោមចៀមនឹងខ្លូត
ទេស ក៏ធ្វើការដោយដៃយ៉ាងស្មគ្រ័ពីចិត្ត[ណ] ១៤ នាង
ធៀបដូចជានាវាដឹកទំនិញ គឺនាងនាំយកអាហារមកពីទី
ឆ្ងាយ ១៥ នាងក្រោកពីដេកតាំងពីនៅងងឹតនៅឡើយ ក៏ចាត់
ចែងអាហារឱ្យពួកផ្ទះ ហើយបង្គាប់ការដល់ពួកបាវស្រីទាំង

**៣១:១** ក សភ ២២:១៧ **៣១:២** ខ ពច ១១:៣០ **៣១:៣** គ ចទ ១៧:១៧ ១ពវ ១១:៣ សភ ៥:១–១៤ **៣១:៤** ឃ សភ ២០:១ សស ១០:១៦–១៧ អស ៥:២២ **៣១:៥** ង ១ពវ ១៦:៩ ច សភ ១៦:១២ **៣១:៦** ឆ លប ១៤:១៨ **៣១:៧** ជ នអ ១:១០ **៣១:៨** ឈ ១សយ ១៩:៤ **៣១:៩** ញ សភ ២៤:២៣ ២៩:៧ **៣១:១០** ដ នរ ៣:១១ សភ ១៨:២២ ឋ សភ ៨:៣៥ **៣១:១១** ឌ លប ២:១៨ ឍ សភ ១២:៤ **៣១:១៣** ណ ១ធថ ២:៩–១០

*ចូរយកដៃខ្ទប់មាត់ចុះ* គឺជាសញ្ញាឃាត់អំពើអាក្រក់ដែលនឹងផ្ទុះចេញជាយ៉ាងរហ័សនោះ (ធៀប យប ២១:៥ ៤០:៤) ។

**៣០:៣៣** *ការគ្រលុក . . . ចាប់មួល . . . ការចាក់រុក* សូមមើលត្រង់សេចក្តីផ្តើមសុភាសិត និងកមើលការពន្យល់ ៦:១៤ ១៥:១ ក៏សូមមើល ២៩:២២ ។

**៣១:១–៩** ផ្នែកសង្ខេបខ្លីៗនេះ ដែលមានសរសេរពាក្យសុភាសិត៣វគ្គ ក៏ជាអ្នកមានប្រភពដើមមិនមែនជារាស្ត្រអ៊ីស្រាអែលទេ (សូមមើលការពន្យល់ ៣០:១) ។ ស្តេចលេខ១ក៏ពុំសូវមានឈ្មោះល្បីដែរ ក៏មានសេចក្តីទូន្មានបីផ្នែកពីព្រះមហាក្សត្ររបស់ស្តេច ចំពោះទីសម្គាល់ពីសេចក្តីល្បួងទាំងឡាយដល់ខ្សែរាជ្យវង្ស (ការរួមរក្សដោយពុំរើសមុន) ខ.២–៣ ។ ក៏ជាការញៀនសូរា ខ.៤–៧ ក៏ដូចជាការទទួលភារៈកិច្ចចំបងចំពោះរាស្ត្រក្រីក្រ និងអ្នកខ្វះខាត (ខ.៨:៩ សូមមើល យរ ២២:១៥–១៦ និងការពន្យល់) ។

**៣១:១** *សេចក្តីទំនាយ* សូមមើលការពន្យល់ ៣០:១ ។ *មាតាទ្រង់* មានក្នុងជីពូកទាំងមូល បានបង្ហាញបញ្ជាក់ពីតួនាទីនិងលក្ខណៈសម្បត្តិរបស់ស្ត្រីអ្នកប្រាជ្ញ ។ នៅក្នុងតំបន់មជ្ឈឹមបពា៌ ឯមាតាព្រះមហាក្សត្រគឺជារឿយៗមានឥទ្ធិពលច្រើននាសម័យនោះ (សូមមើល ១ពវ ១:១១–១៣ និងការពន្យល់ ១:១១) ។

**៣១:២** *ឱកូននៃបំណន់អញអើយ* គឺជាពាក្យសម្តីនាងហាណា ដែលនាងស្បថសច្ចាសុំឱ្យមានកូនប្រុស១ (សូមមើល ១សយ ១:១១ និងការពន្យល់) ។ *បំណន់* សូមមើល ២០:២៥ និងការពន្យល់ ។

**៣១:៣** *កំឡាំងឯងប្រគល់ពួកស្រី* គឺជាការប្រមានតបនឹងការប្រព្រឹត្តអាក្រក់នៅឯទីកន្លែងស្រីស្នំដែលមានការប្រព្រឹត្ត ការរួមភេទដោយមិនប្រកាន់អ្នកណាជាអ្នកណា (សូមមើល ៥:៩–១១ ១ពវ ១១:១ នហ ១៣:២៦ និងការពន្យល់) ។

**៣១:៤** *មិនគួរឱ្យពួកស្តេចបានសោយស្រាទំពាំងបាជូរ* គឺជាពាក្យដែលត្រូវស្បថ គឺមិនត្រូវឱ្យអ្នកដែលជាអ្នកដឹកនាំ ជាមនុស្សប្រមឹកទេ (សស ១០:១៦–១៧ ធៀបនឹង សភ ២០:១ និងការពន្យល់ ហស ៧:៥ និងការពន្យល់) ។

**៣១:៥** *បង្វែរសេចក្តីយុត្តិធម៌ពីមនុស្សដែលកើតទុក្ខវេទនាចេញ* សូមមើល ៣០:១៤ និងការពន្យល់ ក៏សូមមើល ១៧:១៥ អស ៥:២៣ ១០:២ ។

**៣១:៨–៩** ឯព្រះមហាក្សត្រជាស្តេចដែលតំណាងពីព្រះដើរតួជាអ្នកការពារដល់អ្នកក្រ អ្នកមានភាពខ្វះខាតទាំងឡាយ (សូមមើល ១៦:១០ និងការពន្យល់ ទដ ៨២:៣ ធៀបនឹង លវ ១៩:១៥ យប ២៩:១២–១៧ អស ១:១៧ និងការពន្យល់) ។

**៣១:១០–៣១** ជាឃ្លាមានលក្ខណៈជាកំណាព្យកាបឃ្លោង ក៏ជាឃ្លាសរសើរដល់"ស្ត្រីគ្រប់លក្ខណ៍ដែលមានតម្លៃជាជាងត្បូងទទឹមទៅទៀត" (ខ.១០) ក៏វាជាឃ្លាយោងចំពោះ ១:១–៧ ដែលពណ៌នាពីស្ត្រីដែលចេះកោតខ្លាចដល់ព្រះអម្ចាស់ គឺជានាងមានលក្ខណៈដូចជាប្រាជ្ញាដែលមានតម្លៃលើសជាងត្បូងទទឹម (ខ.១០ ៣:១៥ ៨:១១) ។

**៣១:១០** *ឯស្ត្រីគ្រប់លក្ខណ៍* ដូចជា"នាងរស (នរ ៣:១១) នាងគឺជាមកុដ" (១២:៤ សូមមើលការពន្យល់ ១២:៤) ។

**៣១:១២** *នាងនឹងធ្វើឱ្យប្តីបានសេចក្តីល្អ* សូមមើល ១៨:២២ ១៩:១៤ ។

**៣១:១៣** *ខ្លូតទេស* សរសៃរបស់វាគេយកមកធ្វើជាសំពត់ម្យ៉ាង (សូមមើលការពន្យល់ នក ២៥:៤ ក៏សូមមើល សភ ៣១:១៩,២២,២៤ អស ១៩:៩) ។

**៣១:១៤** *ដូចជានាវាដឹកទំនិញ* (សូមមើល ខ.១៨) ។

**៣១:១៥** *នាងក្រោកពីដេកតាំងពីនៅងងឹតនៅឡើយ* នាងមានលក្ខណៈខុសពីពួកមនុស្សចំអៀក (សូមមើល ៦:៩–១០ ២៦:១៤ និងការពន្យល់) ។ *បង្គាប់ការដល់ពួកបាវស្រីទាំងប៉ុន្មាន* សូមមើល ២៧:២៧ លក ១២:៤២ ។

ប៉ុន្មាន ១៦នាងពិចារណាមើលចំការ១ ហើយក៏ទិញទុក រួច
យកផលនៃស្នាដៃនាង ទៅដាំដំណាំទំពាំងបាយជូរ ១៧នាង
ទំលាប់ចង្កេះឱ្យមានកំឡាំង ហើយឱ្យដៃបានខ្លាំង ឡើងដែរ
១៨នាងឃើញថា ទំនិញរបស់នាងសុទ្ធតែមានកំរៃ ហើយ
យប់ៗចង្កៀងនាងមិនរលត់ទេ ១៩នាងចាប់យកហុង ហើយ
ម្រាមដៃក៏កាន់ខ្នារ ២០នាងឈោងដៃដល់មនុស្សកំសត់ទុគ៌ត
អើ នាងហុចដៃទៅជួយមនុស្សក្រលំបាកផង[ត] ២១ចំណែក
ពួកផ្ទះនាង នោះនាងមិនខ្លាចចំពោះហិមៈទេ ដ្បិតគេសុទ្ធ
តែស្លៀកពាក់សំពត់សក្លាតពណ៌ក្រហម ២២នាងត្បាញ
សំពត់ដណ្តប់ខ្លួន សំលៀកបំពាក់របស់នាងសុទ្ធតែធ្វើពី
សំពត់ខ្លូតទេសយ៉ាងម៉ដ្ត មានពណ៌ស្វាយ ២៣កាលណាប្តី
នាងទៅអង្គុយត្រង់ទ្វារក្រុង ក្នុងចំណោមនៃពួកចាស់ទុំ[ថ]
ក្នុងស្រុក នោះគេក៏ស្គាល់រាប់អានគាត់ដែរ ២៤នាងក៏ធ្វើ
អាវខ្លូតទេសសំរាប់លក់ ហើយធ្វើខ្សែក្រវាត់ឱ្យដល់អ្នក
ជំនួញ ២៥នាងមានកំឡាំងនិងលំអជាគ្រឿងអម្ពរ ក៏នឹកសើច
ពីហេតុណាដែលកើតបាននៅខាងមុខ ២៦នាងពោលដោយ
ប្រាជ្ញា ហើយនៅអណ្តាត នាងមានសេចក្តីសប្បុរស[ទ]
២៧នាងថែមើលអស់ទាំងផ្លូវរបស់ពួកផ្ទះនាងយ៉ាងល្អ ឥត
ដែលបរិភោគអាហារដោយសេចក្តីកំជិលឡើយ ២៨កូន
របស់នាងទាំងប៉ុន្មាន ក្រោកឈរឡើងគោរពដល់ម្តាយ
ថាជាអ្នកមានពរ ប្តីក៏ក្រោកឈរឡើងសរសើរនាងដែរថា
២៩មានស្រីៗជាច្រើន បានប្រព្រឹត្តដោយគ្រប់លក្ខណ៍តែនាង
បានវិសេសលើសជាងគេទាំងអស់ ។

៣០រូបឆោមឆាយជាសេចក្តីបញ្ឆោត ហើយមុខស្រស់
ល្អក៏ឥតប្រយោជន៍ដែរ តែស្ត្រីណាដែលកោតខ្លាចដល់ព្រះ
យេហូវ៉ា នោះនឹងមានគេសរសើរវិញ ៣១ចូរថ្លែងពីផល
ដែលដៃនាងបានបង្កើត ហើយទុកឱ្យស្នាដៃរបស់នាងបាន
ជាទីសរសើរ[ធ]ដល់នាងនៅទ្វារក្រុងចុះ ។

**៣១:២០** ត ចទ ១៥:១១
**៣១:២៣** ថ នក ៣:១៦
**៣១:២៦** ទ សភ ១០:៣១
**៣១:៣១** ធ សភ ១១:១៦

**៣១:១៦** *នាងពិចារណាមើលចំការ១* គឺនាងបង្ហាញការជំនុំជម្រះត្រឹមត្រូវ គឺមានលក្ខណៈមិនដូចពួកចំអៀក(មនុស្សខ្ជិល)ដែលចំការទំពាំងបាយជូររបស់គេសុទ្ធតែបន្លានិងស្រងែ (២៤:៣០–៣១) ។

**៣១:១៧** សូមមើល ១០:៤ និងការពន្យល់ ។

**៣១:១៨** *ទំនិញរបស់នាងសុទ្ធតែមានកំរៃ* គឺមានលក្ខណៈដូចជាប្រាជ្ញា គឺ "មានតម្លៃជាងត្បូងទទឹម" (ខ.១០ សូមមើលការពន្យល់ ខ.១០) ប្រាជ្ញាគឺមានតម្លៃជាងមាសប្រាក់ (៣:១៤ សូមមើលការពន្យល់ ៣:១៤) ។

**៣១:២០** *នាងឈោងដៃដល់មនុស្សកំសត់ទុរគ៌ត* ១៤:២១ សូមមើល ២២:៩ យប ៣១:១៦–២២ ។

**៣១:២១** *សុទ្ធតែស្លៀកពាក់សំពត់សក្លាតពណ៌ប្រហម* គឺជាសំលៀកបំពាក់មានគុណភាពខ្ពស់ដែលសុទ្ធតែធ្វើពីរោមចៀមសុទ្ធ (ប្រៀបធៀប ២សយ ១:២៤ វវ ១៨:១៦) ។

**៣១:២២** *សំពត់ខ្លូតទេសយ៉ាងម៉ដ្ត* ដែលមានលក្ខណៈដូចជាវណ្ណៈអភិជន (សូមមើលការពន្យល់ ៧:១៦ នក ២៥:៤ សូមមើល លប ៤១:៤២) ។ *ពណ៌ស្វាយ* មានទំនាក់ទំនងនិងស្តេច (ពច ៨:២៦ បស ៣:១០) ឬក៏ជាអ្នកមាន (លក ១៦:១៩ វវ ១៨:១៦) ។

**៣១:២៣** *ទ្វារក្រុង* ជាទីកន្លែងជំនុំជម្រះ (សូមមើល ១:២១) ។

**៣១:២៤** *នាងក៏ធ្វើអាវខ្លូតទេស* សូមមើល ពច ១៤:១២ និងការពន្យល់ អស ៣:២៣ ប្រៀបធៀប ខ.១៨ ។

**៣១:២៥** *នាងមានកំឡាំងនឹងលំអជាគ្រឿងអម្ពរ* សូមមើល ទដ ១០៩:២៩ និងការពន្យល់ អស ៥២:១ ១ធថ ២:៩–១០ ។ ដែលវាមានលក្ខណៈផ្ទុយនឹង "សំលៀកបំពាក់នៃភាពខ្មាសអៀន និងសេចក្តីខ្មាសអាប់យស់" (មើល ទដ ៣៥:២៦) ។ *ក៏នឹងសើចពីហេតុណាដែលកើតបាននៅខាងមុខ* គឺនាងបានរួចផុតពីសេចក្តីទុកព្រួយពីភាពថប់បារម្ភណ៍ (ប្រៀបធៀប យប ៣៩:៧) ។

**៣១:២៦** *ពិចារណាមើល* គឺជាការផ្តល់ជាគំនិតដល់កូននាង និងមិត្តឯងនាងជាទីប្រឹក្សាដ៏ឆ្លាតនិងមានសេចក្តីស្រឡាញ់ (សូមមើល ១:៨ ៦:២០) ។

**៣១:២៨** *មានពរ* គឺជាអ្នកដែលសប្បាយនូវកាលៈទេសៈដែលរីករាយនិងស្តែងចេញជាសេចក្តីអំណរ សូមមើល លប ៣០:១៣ ទដ ៧២:១៧ បស ៦:៩ មទ្ឋ ៣:១២ ប្រៀបធៀប នរ ៤:១៤–១៥ ។

**៣១:២៩** *បានប្រព្រឹត្តដោយគ្រប់លក្ខណ៍* គឺជាការសម្តែងចេញពីទឹកចិត្តប្តីចំពោះប្រពន្ធរបស់គាត់ក៏មានសរសេរយ៉ាងច្បាស់នៅក្នុងពាក្យកាព្យក្នុងខ (ខ.១០:២៩) គឺភាពល្អគ្រប់លក្ខណ៍របស់នាង (ខ.១០) ។ ឯអ្នកជាប្តីក៏អះអាងថា នាងជាប្រពន្ធមានលក្ខណៈប្រសើជាងស្ត្រីផ្សេងៗទៀត (ខ.១០) ធៀបនឹង អស ៣២:៨ ។

**៣១:៣០–៣១** គឺទាក់ទងនឹងសេចក្តីបញ្ចប់រួម ដែលឆ្លុះបញ្ចាំងពីតួសេចក្តីសំខាន់ៗក្នុងកំពាព្យ ។

**៣១:៣០** *រូបឆោមឆាយជាសេចក្តីបញ្ឆោត* ធៀបនឹង ៥:៣ និងការពន្យល់ ។ *មុខស្រស់ល្អក៏ឥតប្រយោជន៍ដែរ* សូមមើល ១ពត ៣:៣–៥ និងការពន្យល់ ប្រៀបធៀប យប ១៤:២ ។ *ស្ត្រីណាដែលកោតខ្លាចដល់ព្រះ* សូមមើលការពន្យល់ ១:៧ ។

**៣១:៣១** *ផលដែលដៃនាងបានបង្កើត* សូមមើល ខ.១៦ ១២:១៤ និការពន្យល់ ។ ទុកឱ្យស្នាដៃរបស់នាងបានជាទីសរសើរដល់នាង គឺជាភាពឧត្តមកិត្តិយសត្រូវឆ្លងកាត់ "ភាពបន្ទាប់ខ្លួន និងការកោតខ្លាចដល់ព្រះហូវ៉ា" (២២:៤) ។ *ទ្វារក្រុង* សូមមើល ខ.២៣ និងការពន្យល់ ។

# ព្រះគម្ពីរសាស្ដា

## សេចក្ដីផ្ដើម

### អ្នកនិពន្ធនិងកាលបរិច្ឆេទ

ក្នុងគម្ពីរនេះមិនបានប្រាប់អំពីពេលវេលាច្បាស់លាស់ ឬឈ្មោះរបស់អ្នកនិពន្ធឡើយ ប៉ុន្តែតាមរយៈឯកសារក៏បាននាំមកនូវការសន្និដ្ឋានថាស្ដេចសាឡូម៉ូនគឺជាអ្នកនិពន្ធ (១:១,១២,១៦ ២:៤-៩ ៧:២៦-២៩ ១២:៩ ប្រៀបធៀប ១ពវ ២:៩ ៣:១២ ៤:២៩-៣៤ ៥:១២ ១០:១-៨) ។ ម្យ៉ាងវិញទៀតចំណងជើងរបស់អ្នកនិពន្ធដូចជាពាក្យ"គ្រូប្រដៅ""ភាសាហេព្រើរគឺ"(goheleth)"គឺជាកូហិលិត" មើលការពន្យល់ ១:១ ភាពស៊ីគ្នានិងភាសាហេព្រើរ គឺពីចរិតលក្ខណៈចំពោះអ្នកដឹកនាំ(គឺសន្មត់ថាវាផ្ដោតទៅលើអ្នកដឹកនាំជាជាងទៅលើស្ដេចឬរបបស្ដេច មើល ខ. ៤:១-២ ៥:៨-៩ ៨:២-៤ ១០:២០) អាចបង្ហាញចង្អុលទៅអ្នកណាម្នាក់ (មើល ១:១)។

### គោលបំណងនិងការបង្រៀន

អ្នកនិពន្ធរបស់គម្ពីរសាស្ដាបញ្ជាក់ថា ប្រាជ្ញាជាអំណាចដើម្បីសង្កេតបទពិសោធន៍មនុស្សលោក និងប៉ុន់ប្រមាណអំពីស្ថានភាពរបស់មនុស្ស ។ គឺទស្សនៈរបស់លោក បានកំណត់ចំពោះអ្វីៗដែលកើតមានឡើង "នៅក្រោមពន្លឺព្រះសុរិយា" (គឺមានលក្ខណៈដូចជាប្រាជ្ញារបស់គ្រូប្រដៅផ្សេងៗ)។ លោកក៏បានពិចារណាអំពីជីវិតលោក ដែលទទួលបាននូវបទពិសោធន៍ និងការអង្កេតលើបញ្ហានោះ គឺរវាងដែនកំណត់ជីវិត និងដែនកំណត់នៃសេចក្ដីស្លាប់-គឺជាជីវិតស្ថិតនៅក្នុងភាពកំណត់នៃព្រំដែនរបស់លោកិយ ដែលអាចមើលឃើញបាន ។ តែប្រាជ្ញារបស់លោក ក៏ពុំអាចឆ្លុះបញ្ចាំងឱ្យបានឆ្ងាយជាងដែនកំណត់របស់លោកិយនេះបានដែរ ព្រោះលោកអាចគ្រាន់តែអង្កេតបាននូវបាតុភូតនៃសេចក្ដីស្លាប់និងមានញាណនូវភាពកំណត់លើការងារនោះដែលមានសម្រាប់មនុស្សលោក ។ គឺក្នុងដែនកំណត់នៃបទពិសោធន៍មនុស្ស និងការអង្កេតគាត់ក៏បានញែកឱ្យឃើញអ្វីដែលជា"កាល្អ"សម្រាប់មនុស្សក្នុងការប្រព្រឹត្ត ។ ហើយគាត់ក៏ជាតំណាងនូវប្រាជ្ញាដ៏សុចរិតនិងស្លូតបូត ជីវិតក្នុងលោកិយគឺនៅក្រោមព្រះអម្ចាស់សម្រាប់ការកំបាំងទាំងអស់ ។ ហើយពីពេលនេះគឺអ្វីៗត្រូវចាប់ផ្ដើមដោយភាព"គ្មានន័យ!ភាពគ្មានន័យ!"(១:២)បញ្ចប់ដោយការចងចាំពីព្រះអទិកររបស់អ្នក (១២:១) និងការកោតខ្លាចព្រះ ការរក្សានូវបញ្ញត្តិរបស់ផងទ្រង់ (១២:១៣) ។

ជាមួយនឹងប្រាជ្ញានោះ ដែលបានទៅជាពេញខ្នាត់ចាស់ទុំ ដោយចំណាយពេលវេលាជាច្រើនឆ្នាំ គាត់បានវាស់ស្ទង់ពីនិស្ស័យមនុស្សហើយក៏វាស់ស្ទានពីដែនកំណត់របស់ពួកគេ ។ លោកក៏បានព្យាយាមស្វែងយល់ពីលក្ខណៈសម្បត្តិអ្វីខ្លះដែលប្រាជ្ញាមនុស្សធ្វើបាន ។ (១:១៣,១៦-១៨ ៧:២៤ ៨:១៦)ហើយគាត់បានរកឃើញថាប្រាជ្ញារបស់មនុស្ស គឺផ្ដើមកបាន"ដោយការកោតខ្លាចដល់ព្រះយេហូវ៉ា"(សភ ១:៧) ហើយអំណាចរបស់គេមានកំណត់នូវព្រំដែននៃទស្សនៈរបស់គេ គឺទំនាក់ទំនងនឹងគំនិតរបស់ពួកគេ ។ លក្ខណៈបំភ្លឺភាគច្រើនពុំអាចរកឱ្យឃើញនូវទិសដៅ ដ៏ធំរបស់ព្រះអម្ចាស់ទេ ។

ហើយទោះជាយ៉ាណាលោកបានផ្ដង់មកលើគោលគំនិតរបស់មនុស្សគោលគំនិត ដែលខ្លួនលោកផ្ទាល់បានចូលរួម ។ លោកឃើញមនុស្សមមៀញឹកនឹងគំនរបន្ទុកការងារជាច្រើនគឺជាការព្យាយាមពីការនេះ ពីការនោះ គឺជាការប្រឹងប្រែងដែលមនុស្សអាចជាអ្នកគ្រងពិភពលោកដែលមានទៅដោយការសម្ងាត់យ៉ាងជ្រាលជ្រៅ និងផ្លាស់ប្ដូរចនាសម្ព័ន្ធជាមូលដ្ឋាន ជួនកាលត្រូវតែឆ្លងពុះពារចំណងរបស់ការកំណត់នៃមនុស្សក៏បង្កើតឱ្យខ្លួនពួកគេមានជាការចងចាំឡើងវិញជាអនុស្សាវរីយ៍ ឬសកម្មភាពគ្រប់គ្រងវាសនារបស់ពួកគេក៏សម្រេចនូវផ្នែកនានា និងភាពទទួលបានការរីករាលដល់ប្រជាជនដែលមានអំណាច ។

លោកក៏បានសម្លឹងមើលការបញ្ជាក់នូវជីវិតមនុស្សក្នុងលក្ខណៈបែបនេះគឺ"គ្មានន័យអ្វីទាំងអស់"ការខិតខំទាំងនេះដែលជាការមួយឥតប្រយោជន៍ គឺអ្វីៗពេលនោះប្រាជ្ញាក៏បង្រៀនគាត់ ។

១. ការសម្រេចបានដ៏ជាក់លាក់ ចំពោះការចុងក្រោយគឺមនុស្សពុំអាចធ្វើបានឡើយ ។ (១:៥-១១)មនុស្សក៏ពុំអាចធ្វើបានដោយសារកម្លាំងពួកគេដែរ (១:២-៤ ២:១-១១)ពួកគេក៏ពុំអាចបំផ្លាស់បំប្រែអ្វីមួយបានឡើយ(១:១២-១៥ ៦:១០ ១៧:១៣) ។ តាំងពីពេលនោះមកពួកគេមានការលំបាកយ៉ាងខ្លាំង(៤:៤,៧-៨ ៥:១០-១៧ ៦:៧-៩)។ គឺគ្រប់ទាំងការតស៊ូរបស់ពួកគេ"ក្រោមពន្លឺព្រះអាទិត្យ"(១:៣)បន្ទាប់ពីមានទិសដៅមិនជាក់លាក់ ដែលនាំឱ្យទទួលបាននូវសេចក្ដីស្រងាកចិត្តយ៉ាងខ្លាំង ។

២.ប្រាជ្ញាគឺប្រសើជាងភាពមានកំហុស(២:១៣-១៤ ៧:១-៦,១១-១២,១៩ ៨:១,៥ ៩:១៧-១៨ ១០:១-៣,១២-១៥ ១២:១១) គឺជាអំណោយទានពីព្រះអម្ចាស់ដល់អស់អ្នកណាដែលបំពេញព្រះទ័យទ្រង់(២:២៦) ។ ប៉ុន្តែវាពុំអាចសង្ឃឹមច្រើនជ្រុលជាងប្រាជ្ញានោះមានសមត្ថភាពក្នុងកាដោះស្រាយបញ្ហាបានគ្រប់ពេលនោះឡើយ (១:១៦)ឬក៏រក្សាសុវត្ថិភាពសម្រាប់ភាពស្ថិតស្ថេររបស់វា ឬរង្វាន់ ឬជា

ផលប្រយោជន៍នោះទេ (២:១២–១៧ ៤:២៣–១៦ ៩:១៣–១៣) ។

៣.បទពិសោធន៍ការជួបប្រទះរបស់មនុស្សលោក ដែលមានជាច្រើនបង្ហាញពីភាពមិនចុះសម្រុងគ្នា និងភាពប្រែប្រួល ។ ដែលប្រាជ្ញាពុំអាចបាត់ទៅបាន ។ គឺគ្រប់ការអស្ចារ្យទាំងអស់នៃឆាកជីវិតមនុស្សបានមានទីបញ្ចប់ដូចគ្នា ក៏ដូចជាសត្វពាហនៈដែលត្រូវងាប់ដែរ (២:១៥ ៣:១៦–១៧ ៧:១៥ ១៨:១៤ ៩:១–៣ ១០:៥–៧) ។

៤.ទោះបីជាព្រះអម្ចាស់បានបង្កើតប្រភេទមនុស្សឱ្យមានលក្ខណៈទៀងត្រង់ តែមនុស្សបានបាត់បង់ បែរជាមានផែនការ "អាក្រក់" (ដើម្បីលេចធ្លោទៅរកផលប្រយោជន៍ពីគ្នាទៅវិញទៅមក មើល ៧:២៩ ប្រៀបធៀប ១០:២ ៣៦:៤ ១៤០:២) ។ ដូច្នេះសូម្បីតែមនុស្សគឺក៏ខកចិត្ត (៧:២៤–២៩) ។

៥.មនុស្សពុំអាចស្គាល់ ឬអាចគ្រប់គ្រងនូវអ្វីដែលនឹងកើតឡើង ចំពោះពួកគេជាបន្ទាន់នៅពេលខាងមុខនោះទេ ។ ពោលគឺគ្រប់ទាំងការប្រឹងប្រែងរបស់ពួកគេ គឺមានលំនឹងខាងចុងនៃភាពមិនពិតស្មើសូន្យ (២:១៨ ៦:១២ ៧:១៤ ៩:២) ។

៦.ព្រះអម្ចាស់រក្សាមនុស្សគ្រប់ទីកន្លែងទាំងអស់ (៣:១៦–២២) ។

៧.ព្រះអម្ចាស់បានបញ្ជាឱ្យមានគ្រប់របស់ទាំងអស់ (៣:១–១៥ ៥:១៩ ៦:១–៦ ៩:១) ហើយមនុស្សមិនអាចផ្លាស់ប្តូរការកំណត់របស់ព្រះបានឡើយដោយទ្រង់យល់ពីមនុស្ស និងចូលរួមជាមួយមនុស្ស (៣:១,៧ ១១:១–៦) ប៉ុន្តែ លោកិយនេះគឺពុំមានសណ្តាប់ធ្នាប់នោះទេដោយព្រោះទ្រង់បានធ្វើឱ្យវាមានសណ្តាប់ធ្នាប់ដោយសារតែទ្រង់ ។ ហើយឥឡូវនេះលោកិយជារបស់មនុស្សហើយ មនុស្សទទួលនូវរឿងរ៉ាវដូចដែលទ្រង់បានកំណត់ទុកឱ្យ រួមមានការកំណត់ជីវិតពួកគេមានទាំងពេលវេលា (ជំពូក ៣) ។ គឺជាប្រាជ្ញាជាការផ្តល់ដំបូន្មាន :

១–ទទួលសណ្ឋានជាមនុស្ស គឺដែលបានបង្កើតរូបរាងកាយ ការតែងតាំងរបស់ព្រះនិងសប្បាយពីជីវិតដែលពេញបរិបូរណ៍ ។

២–កុំបង្កើតឱ្យខ្លួនអ្នកមានបញ្ហាដោយសារគោលដៅពុំជាក់លាក់ ត្រូវដឹងនឹងវាសវែងពីសមត្ថភាពរបស់មនុស្ស ។

៣–សូមប្រុងប្រយ័ត្នគ្រប់ទាំងផ្លូវរបស់អ្នក គឺត្រូវតាមការដឹកនាំពីប្រាជ្ញាវិញ ។

៤–កោតខ្លាចដល់ព្រះហើយរក្សាបញ្ញត្តិរបស់ទ្រង់ (១២:១៣) ការផ្តើមឱ្យមានថ្ងៃកាលអ្នកនៅក្មេងមុនពេលថ្ងៃដែលកន្លងនៃជីវិតរីករាយដ៏ខ្លីបានបាត់ទៅហើយ "ថ្ងៃកង្វល់ក៏មកដល់" (១២:១) ពេលមកដល់នូវភាពមិនទៀងទាត់នៃការកើនអាយុ បានរុញកួនដល់អ្នកឱ្យលាក់កំបាំងផុតពីការសាកល្បងរសជាតិ ក៏ឃើញទេសភាព និងអារម្មណ៍ដែលទទួលបានពីរឿងរ៉ាវល្អៗនៃជីវិត ។

សរុបរួមអត្ថន័យមកគឺគម្ពីរ សាស្តាបានផ្តល់នូវសេចក្តីនៃនាំពីជីវិតដែលត្រូវរស់ឱ្យមានន័យ និងមានគោលដៅនៃជីវិតនឹងសេចក្តីអំណរដែលមានការរៀបចំជីវិតតាមបែបទេវសាស្ត្រ ដោយយកព្រះដាក់ក្នុងដួងចិត្តទាំងពោលបំពេញការងារ និងសកម្មភាពផ្សេងៗគឺដោយពេញចិត្តនឹងទទួលវាសនាជីវិតដែលទ្រង់ប្រទានឱ្យមានក្នុងជីវិតម្នាក់ៗ និងដោយការបង្ហាញនូវសេចក្តីពិតនឹងកាស្តាប់បង្គាប់ចំពោះព្រះមហាក្សត្រ ដែលជាព្រះអទិករ ។ ២:២៤–២៦ ៣:១១–១៤,២២ ៥:១៨–២០ ៨:១៥ ៩:៧–១០ ១១:៧–១២:១ ១២:៩–១៤ ។

## ផ្នែកសំខាន់នៃអក្សរសាស្ត្រ

សេចក្តីសំអាងចំពោះគម្ពីរ សាស្តាពុំមានលក្ខណៈហូរហែរតាមលំដាប់លំដោយទេ ។ វាមានលក្ខណៈបត់បែនចុះឡើងនឹងផ្តើមដោយភាពគ្រោកគ្រាតនៃបទពិសោធន៍របស់មនុស្ស ដែលជាលក្ខណៈឆ្លើយតបមកវិញនោះ ។ ក៏មានការប្រមូកប្រមូលនៃកំណាព្យ និងពាក្យរាយផងដែរ ។ ម្យ៉ាងវិញទៀតគម្រោងសង្ខេបខាងក្រោមនេះក៏ឆ្លុះបញ្ចាំងលក្ខណៈទូទៅ ជាការតុបតែងនៃកណ្ឌគម្ពីរ និងការថ្លែងបញ្ជាក់ភាពសំខាន់ៗ ។ ផ្ទៃរឿងដែលបានប្រកាសនេះ "ពីភាពគ្មានន័យ" បានផ្តល់ផ្នែកអក្សរសាស្ត្រនូវគម្រោងរបស់វា ទៅនិងផ្ទៃរឿងទាំងមូល (១:២ ១២:៨) ។ និងចលនា ឬស្វែងចេញពីភាពស្រងាកចិត្ត ដែលពុំមានទំនាក់ទំនងនៅជំពូក ១–២ ឬចំពោះភាពស្ងប់ស្ងៀមហើយភាពភ្លឺស្វាងគឺជាតំរុយនៃជីវិតក្នុងជំពូក ១១–១២ ក៏បង្កើតការអភិវឌ្ឍន៍ក្នុងស្ថានភាពមនុស្ស ។ រូបភាពដ៏ជាក់លាក់នៃកណ្ឌគម្ពីរគឺគេប្រើជារឿយៗនោះគឺជាពាក្យគន្លឹះ និងឃ្លាគន្លឹះឧទាហរណ៍ "ការឥតប្រយោជន៍ទទេ" (មើលការពន្យល់ ១:២ ២:១៤–២៥) "ការងារ/ពលកម្មកិច្ចការលំបាក" (មើលការពន្យល់ ២:១០) "ល្អ!ល្អជាង" (មើលការពន្យល់ ២:១) "អំណោយទាន/ប្រទានពរ" (មើលការពន្យល់ ៥:១៩) "មើលក្រោមថ្ងៃ" (មើលការពន្យល់ ១:៣) "ការដេញតាមខ្យល់" (មើលការពន្យល់ ១:១៤) ។ ក៏មានការកត់សំគាល់គឺជាការបង្ហាញពីអត្ថបទបង្កើតឡើងតាមរយៈកណ្ឌគម្ពីរដែលមានតួនាទីជាគន្លឹះចង្អុលបង្ហាញពីផ្ទៃរឿង របស់អ្នកនិពន្ធនិងគោលបំណង ១:២–៣,១៤,១៧, ២:១០–១១,២៤–២៦,១២–១៣,២២ ៤:៤,៦,១៦ ៥:១៨–២០ ៦:៩,១២ ៧:១៤,២៤ ៨:៧,១៥,១៧ ៩:៧,១២ ១០:១៤ ១១:២,៥–៦,៨–៩ ១២:១,៨,១៣–១៤ (មើលការពន្យល់នូវអត្ថបទទាំងនោះចុះ) ។ សេចក្តីអំណរនៃជីវិតដូចជាព្រះអម្ចាស់ប្រទានមកឱ្យក៏ជាគំនិតគន្លឹះក្នុងគម្ពីរ (មើល ២:២៤–២៥ និងការពន្យល់ ២៦ ៣:១២–១៣ និងការពន្យល់ ២២ ៥:១៨–២០ ៧:១៤ ៨:១៥ និងការពន្យល់

៩:៧-៩១១:៨-៩)។

## គម្រោងសង្ខេប

I. អ្នកនិពន្ធ (១:១)

II. ផ្ទៃរឿង : កាតេតប្រយោជន៍ទទេៗ ដែលចេញពីការប្រឹងប្រែងរបស់មនុស្សដែលផ្ទុយពីព្រះហឫទ័យព្រះអម្ចាស់(១:២)។

III. សេចក្តីផ្តើម : ពុំបានផលប្រយោជន៍ ពីការប្រឹងប្រែងរបស់មនុស្សតាមរយៈការលំបាកៗ ដើម្បីប្រមូលរឿងរ៉ាវក្នុងគោលបំណងដើម្បីសម្រេចការសប្បាយ ។ (១:៣-១១)

IV. សេចក្តីថ្លែងផ្នែកទី១ : មានលក្ខណៈជាពាក្យសួរ ឬពាក្យប្រស្នាចំៗត្រង់ៗ និងដូចជាភាពឥតប្រយោជន៍ទទេវាមានសេចក្តីអំណរសប្បាយដូចជាអំណោយទានពីព្រះអម្ចាស់ (១:១២ ១១:៦)។

**ក,** ចាប់តាំងពីមនុស្សមានប្រាជ្ញា និងការប្រឹងខ្នះខ្នែងសបានម្រេច គឺជាលក្ខណៈឥតប្រយោជន៍ទទេតែមនុស្សគួរតែសប្បាយនឹងជីវិតពីការទាំងនោះដែលជាផលផ្លែ ជាអំណោយទានពីព្រះអម្ចាស់(១:១២-៦:៩) ។

១. សេចក្តីផ្តើម (១:១២-១៨)

ក-សេចក្តីប្រឹងប្រែងរបស់មនុស្ស គឺទុកជាការឥតប្រយោជន៍ទទេ (១:១២-១៥)

ខ-ការដេញតាមរកប្រាជ្ញារបស់មនុស្ស គឺជាការឥតប្រយោជន៍ទទេដែរ (១:១៦-១៨)

២. ការស្វែងរកសេចក្តីសប្បាយ គឺជាការឥតប្រយោជន៍ទទេ (២:១-១១)

៣. ប្រាជ្ញារបស់មនុស្ស គឺឥតប្រយោជន៍ទទេ (២:១២-១៧)

៤. ការប្រឹងប្រែងដោយវេទនាដើម្បីប្រមូលនូវអ្វីៗ គឺជារឿងឥតប្រយោជន៍ទទេ (២:១៨-៦:៩) ។

ក-ពីព្រោះមនុស្សត្រូវទុកនូវផលផ្លែពីកំលាំងញើសឈាមរបស់គេ គឺសម្រាប់អ្នកដទៃទៀត (២:១៨-២៦)។

ខ-ដោយព្រោះសេចក្តីប្រឹងប្រែងរបស់មនុស្ស គឺនៅតែក្រោមការគ្រប់គ្រងពីព្រះអម្ចាស់ ដែលបានរៀបចំឱ្យយើងដែលមនុស្សពុំអាចយល់បានយ៉ាងពេញលេញ ដែលភាពលំបាកវេទនារបស់គេពុំអាចផ្លាស់ប្តូរបាន (៣:១-៤:៣) ។

គ-ពីព្រោះមានរឿងប្រសើសម្រាប់មនុស្ស ជាជាងភាពច្រណែន សេចក្តីលោភលន់ដែលជំរុញឱ្យមានការលំបាកវេទនា (៤:៤-១៦) ។

ឃ-ពីព្រោះផលផ្លែរបស់កម្លាំងមនុស្សអាចបាត់បង់ ដែលនាំមកជាលទ្ធផលមិនបានសម្រេច (៥:១-៥:៩) ។

**ខ,**ខណៈពេលមនុស្សពុំអាចដឹងយ៉ាងពិតប្រាកដនូវអ្វីដែលជាការប្រសើបំផុតសម្រាប់ពួកគេដើម្បីនិងប្រព្រឹត្ត ឬមានអ្វីដែលកើតឡើងនាពេលអនាគត សម្រាប់រូបពួកគេគួរតែសប្បាយអំណរនូវក្នុងខណៈនេះ គឺនូវជីវិតនិងការងារដែលព្រះអម្ចាស់បានប្រទានមកឱ្យពួកគេ(៦:១០-១១:៦) ។

១. សេចក្តីផ្តើម : គឺបង្ហាញការសម្រេចព្រះទ័យពីមុនមកហើយ ដោយព្រះអម្ចាស់គឺអ្វីដែលមិនអាចប្រែប្រួលបានហើយមនុស្សមិនអាចយល់ដល់អ្វីដែលជាការប្រសើបំផុត ឬអ្វីដែលកើតឡើង នាថ្ងៃអនាគត(៦:១០-១២)។

២. មនុស្សមិនអាចដឹងឬយល់យ៉ាងពេញលេញ យ៉ាងប្រសើក្នុងការប្រព្រឹត្ត (ជំពូក ៧-៨)។

៣. មនុស្សមិនអាចដឹង នូវការកើតឡើងនាពេលអនាគតឡើយ (៩:១-១១:៦)។

V. សេចក្តីថ្លែង ផ្នែកទី១ : គឺខណៈដែលជាវ័យចាស់និងសេចក្តីស្លាប់មិនយូរប៉ុន្មានឡើយក៏បានមកដល់មនុស្សគួរតែអសប្បាយរីករាយនិងជីវិត និងភាពវ័យក្មេងរបស់គេ ហើយក៏ត្រូវចងចាំថាព្រះគឺជាចៅក្រមវិន័យ(១១:៧-១២:៧) ។

ក-មនុស្សគួរតែអរសប្បាយជីវិតរបស់គេដែលមាននៅលើផែនដីនេះ អនាគតជាថ្ងៃខាងមុខដែលបន្ទាប់ពីសេចក្តីស្លាប់គឺជាភាពអាថ៌កំបាំង និងជាការឥតប្រយោជន៍ទទេៗសម្រាប់ថ្ងៃបច្ចុប្បន្នរបស់ពួកគេ (១១:៧-៨) ។

ខ-មនុស្សគួរតែអស្សាយ និងភាពនៅក្មេងរបស់គេតែត្រូវចងចាំថា ព្រះអម្ចាស់នឹងវិនិច្ឆ័យទោស (១១:៩-១០) ។

គ-មនុស្សគួរតែចងចាំពីព្រះអទិកររបស់ពួកគេ(និងអំណោយទានរបស់ផងទ្រង់)នៅក្នុងភាពយុវវ័យរបស់ពួកគេមុនពេលដែលភាពយ៉ាបយ៉ឺនដោរាភាពពិការភាព បានមកដល់នឹងភាពដែលមិនអាចដោះស្រាយបាន សម្រាប់ជីវិតរូបកាយគេ(១២: ១៧)

VI. ការរំលឹកពីផ្ទៃរឿង (១២:៨)

VII. សេចក្តីបញ្ចប់: ដោយការគោរពជាទីបំផុតក្នុងការស្តាប់បង្គាប់ព្រះ (១២:៩-១៤)។

## អ្វីៗសុទ្ធតែជាការគ្មានប្រយោជន៍

**១** ១ពាក្យទាំងនេះជាពាក្យរបស់គ្រូប្រដៅ[ក] ដែលជាបុត្រ
របស់ដាវីឌ ស្តេចនៅក្រុងយេរូសាឡិម[ខ] ២"ការឥត
ប្រយោជន៍ទទេៗ" នេះជាពាក្យរបស់គ្រូប្រដៅពោលទុក
ថា ការឥតប្រយោជន៍ទទេៗ គ្រប់ទាំងអស់សុទ្ធតែឥត
ប្រយោជន៍ទទេ[គ] ៣តើមនុស្សមានកំរៃអ្វីខ្លះ ពីអស់ទាំងការ
ដែលខ្លួនខំធ្វើ ដោយនឿយហត់នៅក្រោមថ្ងៃ[ឃ] ៤មនុស្ស
ជំណាន់១កន្លងបាត់ទៅ ហើយជំណាន់១ទៀតកើតឡើង តែផែន
ដីស្ថិតស្ថេរនៅជាដរាប[ង] ៥ថ្ងៃក៏រះឡើង ហើយលិចទៅវិញ
រួចប្រញាប់នឹងវិលទៅឯកន្លែងដែលរះឡើងនោះទៀត[ច]
៦ឯខ្យល់ក៏បក់ទៅខាងត្បូង រួចវិលមកខាងជើងវិញ គឺវិល
ទៅវិលទៅមកជានិច្ច ហើយក៏ត្រឡប់មកតាមផ្លូវដដែល
ទៀត ៧ទន្លេទាំងប៉ុន្មានហូរធ្លាក់ទៅក្នុងសមុទ្រតែសមុទ្រ
មិនចេះពេញឡើយ ហើយទឹកទន្លេក៏ត្រឡប់ទៅហូរតាម
ផ្លូវដដែលវិញទៀត[ឆ] ៨គ្រប់ទាំងអស់ចេះតែជញ្ជាន់
ដដែលៗជានិច្ចទាល់តែមនុស្សរកថ្លែងមិនបាន ភ្នែកមើល
មិនចេះឆ្អែត ហើយត្រចៀកស្តាប់ក៏មិនចេះពេញដែរ[ជ]
៩របស់ដែលមានពីមុនមក គឺរបស់នោះឯងដែលនឹងមាន
តទៅទៀត ហើយការដែលបានធ្វើពីមុនមក គឺការនោះ
ឯងដែលនឹងធ្វើវៀងតទៅដែរ[ឈ] ឥតមានអ្វីជាថ្មីនៅក្រោម
ថ្ងៃឡើយ ១០តើមានអ្វីណាមួយដែលគេអាចនឹងថា មើល
នេះជារបស់ថ្មីទេ ដូច្នេះគឺសុទ្ធតែបានមាននៅ តាំងពី
បុរាណមក ក៏មាននៅអស់ទាំងកល្ប មុនដែលមនុស្សយើង
កើតមកផង ១១គ្មានអ្នកណានឹកចាំពីអ្វីៗនៅជាន់មុនទេ[ញ]
ហើយជំនាន់មនុស្សទៅខាងមុខ ក៏នឹងមិននឹកចាំពីអ្វីៗដែល
ត្រូវមាននៅខាងមុខដែរ[ដ]។

## ប្រាជ្ញាគឺជាការគ្មានប្រយោជន៍

១២យើងគឺជាគ្រូប្រដៅ[ឋ] បានធ្វើជាស្តេចនៃសាសន៍
អ៊ីស្រាអែលនៅក្រុងយេរូសាឡិម[ឌ] ១៣យើងបានផ្ចង់ចិត្ត
ពិនិត្យមើល ហើយស្វែងរកដោយប្រាជ្ញា ពីគ្រប់ទាំងអស់
ដែលកើតមាននៅក្រោមមេឃ[ឍ] នេះហើយជាការមាន

**១:១** ក ខ.១២ សស ៧:២៧ ១២:១០ ខ សភ ១:១
**១:២** គ ទដ ៣៩:៥-៦ ៦២:៩ សស ១២:៨ រម ៨:២០-២១
**១:៣** ឃ សស ២:១១ ២២ ៣:៩ ៥:១៥-១៦
**១:៤** ង យប ៨:១៩
**១:៥** ច ទដ ១៩:៥-៦
**១:៧** ឆ យប ៣៦:២៨
**១:៨** ជ សភ ២៧:២០
**១:៩** ឈ សស ២:១២ ៣:១៥
**១:១១** ញ លប ៤០:២៣ សស ៩:១៥ ដ ទដ ៨៨:១២ សស ២:១៦ ៨:១០ ៩:៥
**១:១២** ឋ ខ.១ ឌ សស ២:៩
**១:១៣** ឍ យប ២៨:៣

**១:១** *គ្រូប្រដៅ* គឺជាគ្រូប្រដៅផ្នែកប្រាជ្ញា (១២:៩) ។ ជាភាសាហេព្រើរចំពោះពាក្យថា"គ្រូប្រដៅ""កូហែលលេត" (goheteth)គឺមានន័យស្មើរ"ការប្រមូលផ្តុំ"(មើល នក ១៦:៣) គឺប្រហែលជាគ្រូប្រដៅដែលមានការងារដូចបានពណ៌នានៅខាងក្រោមនេះក្នុង ១២:៩-១០ ក៏ជាអ្នកជំនួយក្នុងការប្រជុំគ្នា ។ គឺជាលក្ខណៈគ្រីស្ទបរិស័ទជំនាន់ដើម (គ្រីស្ទបរិស័ទដំបូងបង្អស់ដែលបកប្រែពីភាសាក្រិកមកពីគម្ពីរសញ្ញាចាស់) ។ ពាក្យថា"គ្រូប្រដៅ"គឺថាដូចជាចំណងជើងសៀវភៅអង់គ្លេសភាគច្រើនដូចជាពាក្យ"ecclesiastical"ក៏ត្រូវបានគេដកយកមកប្រើ ។ *ជាបុត្រារបស់ដាវីឌ* ដោយសន្មត់ថាសាឡូម៉ូន គិតថានាមរបស់ទ្រង់តែងលេចឡើងមាននៅក្នុងសៀវភៅ ។ បើជាភាសាហេព្រើរពាក្យថា"បុត្រា"អាចសំអាងទៅលើ ពួកពូជអំបូរ (ទោះជាប៉ុន្មានជំណាន់ក៏ដោយ) ឬទោះជាអ្នកណាម្នាក់ដែលមើលក្នុងជំហ៊ានពីអ្នកណាម្នាក់ (មើល លប ៤:២១) មើលសេចក្តីផ្តើមត្រង់ : អ្នកនិពន្ធនឹងកាលបរិច្ឆេទ ។

**១:២** គឺជាការបញ្ជាក់យ៉ាងសង្ខេបពីផ្ទៃរឿងរបស់អ្នកនិពន្ធ (មើល ១២:៨ និងការពន្យល់) ។ *ការឥតប្រយោជន៍ទទេៗ* ពាក្យជាគន្លឹះនៃខនេះបានសរសេរលេខឱ្យឃើញប្រហែលជា៣៥លើកក្នុងគម្ពីរ ដែលមាននៅក្នុងកណ្ឌគម្ពីរផ្សេងៗទៀតតែ១ដងគត់ (យ៉ូប ២៧:១២) ។ ភាសាហេព្រើរចំពោះពាក្យនេះតាមពាក្យដើមមានន័យថា "ខ្យល់ដង្ហើម" (មើល ទដ ៣៩:៥,១១ ៦២:៩ ១៤៤:៤)។ ភាពចាក់ចុចជាមូលដ្ឋាននៃគម្ពីរសាស្តា គឺសម្តែងពីជីវិតដែលជាការឥតប្រយោជន៍ទទេៗ (ឥតមានប្រយោជន៍ ប្រហោងក្នុង ភាពទទេ ភាពឥតបានការ) គឺបើសិនជាមិនបានជាប់ ឬទំនាក់ទំនងនឹងព្រះទេនោះ គឺមានតែពឹងផ្អែកទៅលើព្រះ ហើយនិងព្រះបន្ទូលរបស់ទ្រង់ គឺជាជីវិតទើបមានប្រយោជន៍ ។ *គ្រប់ទាំងអស់* មើល ខ.៨ គឺជាអ្វីៗដែលមនុស្សឃ្លាតឆ្ងាយពីព្រះ ។

**១:៣-១១** អ្នកនិពន្ធបានពណ៌នាយ៉ាងល្អិតល្អន់នូវផ្ទៃរឿងរបស់គាត់ ដែលថាខណៈណាមនុស្សខំប្រឹងប្រែង ដែលបង្ហាញពីភាពគ្មានផលប្រយោជន៍ ឬទិសដៅគឺជាលក្ខណៈគ្មានន័យទាំអស់ ។

**១:៣** ព្រះយេស៊ូវក៏បានបញ្ចេញសំនួរ មក ៨:៣៦-៣៨ ។ *នៅក្រោមថ្ងៃ* គឺមានវោហាស័ព្ទមួយទៀត (បានប្រើ ២៩ ដង) ដែលទាក់ទងរឿងរ៉ាវលោកិយសព្វថ្ងៃនេះ និងដែនកំណត់ដែលកំណត់ជាស្រេច "នៅក្រោមមេឃ" (ខ.១៣ ២:៣ ៣:១) គឺដែលជាសទិសន័យ ។

**១:៤-៩** ការងារនឿយដែលពុំមានផលប្រយោជន៍ (ខ.៣) ដោយព្រោះមនុស្សរស់នៅក្នុងលោកិយ ក្នុងភាពដដែលៗដូចៗគ្នា ដោយពុំមានន័យការងារនេះហាក់ដូចជាគ្មានទីបញ្ចប់ តែក៏ជាភាពបណ្តោះអាសន្ននៃជំនាន់របស់មនុស្ស(ខ.៦) និងចំហាយពពក (ខ.៧) ។ គឺជាភាពដដែលៗ(ខ.៨)ក៏គ្មានអ្វីប្លែកឬថ្មីសោះនៅក្រោមថ្ងៃ(ខ.៩) ។

**១:៤** *តែផែនដីស្ថិតស្ថេរនៅជាដរាប* គឺមានលក្ខណៈផ្ទុយ ចំពោះជីវិតមនុស្សអាចបាត់ផុតកន្លងទៅយ៉ាងឆាប់រហ័ស ។

**១:៨** *គ្រប់គ្រងទាំងអស់* គឺជារឿងរ៉ាវដែលបានបញ្ចប់ក្នុង ខ.៤-៧ (មើលការពន្យល់ ខ.២) ។

**១:១០** *នេះជារបស់ថ្មី* គឺអ្វីៗបែរជាថ្មីដោយព្រោះអតីតកាលវាងាយនឹងភ្លេចទៅវិញពេលនោះផ្លូវចាស់ក៏លេចចេញជាថ្មី ក្នុងអាការៈខាងក្រៅដែលថ្មី ។

**១:១២-១៨** ការបង្កើតបានជាផ្ទៃរឿងរបស់គាត់ ដែលគ្រប់មនុស្សទាំងអស់ប្រែជាភាពទទេ ។ (មើល ជាពិសេសក្នុង ខ.៣,១១ គឺបង្ហាញពីផ្នែកនេះ) ។ ឥឡូវនេះគ្រូប្រដៅបង្ហាញថា ទាំងការប្រឹងប្រែងរបស់មនុស្សលោក (ខ.១២-១៥ ប្រៀប ២:១-១១) ។ និងសេចក្តីប្រដេញរកប្រាជ្ញារបស់មនុស្ស (ខ.១៦-១៨ ប្រៀបធៀប ១២-១៧) គឺជាភាពទទេនិងការឥតប្រយោជន៍ទទេៗ ។

**១:១២** *យើង* អ្នកនិពន្ធបានបំផ្លែងពីបុរសទី១ទៅជា បុរសទី២ឬជាបុរស ទី៣វិញលើកលែងតែក្នុងសេចក្តីបញ្ចប់(១២:៩-១៤) ។

ទំងន់ ដែលព្រះបានប្រគល់មកឱ្យមនុស្សជាតិប្រឹងធ្វើ[ណ]
១៤យើងបានឃើញបណ្ដាការ ដែលមានធ្វើនៅក្រោមថ្ងៃ
ហើយ មើលការទាំងនោះសុទ្ធតែឥតប្រយោជន៍ទទេ ក៏ជា
អសារឥតការផង[ត] ១៥របស់ណាដែលវៀច នោះនឹងធ្វើឱ្យ
ត្រង់ឡើងវិញមិនបាន[ថ] ហើយរបស់ណាដែលខ្វះខាត នោះ
នឹងរាប់មិនបានដែរ ១៦យើងបាននឹកក្នុងចិត្តថា មើល យើង
បានធំឡើងហើយ មានប្រាជ្ញាលើសអ្នកណាដែលនៅក្រុង
យេរូសាឡិមមុនយើងទៅទៀត[ទ] អើ ចិត្តយើងបានធ្លាប់ដឹង
ចំពោះប្រាជ្ញា និងដំរិះជាច្រើនហើយ ១៧យើងក៏បានផ្ចង់
ចិត្តឱ្យបានស្គាល់ប្រាជ្ញា[ធ] ព្រមទាំងសេចក្ដីចំកួត និងសេចក្ដី
ផ្ដេសផ្ដាស[ន] ក៏យល់ឃើញថា ការនោះជាអសារឥតការ
ដែរ ១៨ដ្បិតដែលមានប្រាជ្ញាច្រើន នោះក៏កើតទុក្ខច្រើន[ប]
ហើយអ្នកណាដែលចំរើនចំណេះ នោះក៏ចំរើនសេចក្ដី
ព្រួយឡើងដែរ[ផ]។

## ការសប្បាយគឺជាការគ្មានន័យ

**២** ១យើងបាននិយាយចំពោះចិត្តយើងថា មកចុះ យើង
នឹងល្បងលឯងដោយការអរសប្បាយ[ក] ឯងនឹងបានត្រេក
ត្រេងសប្បាយទទេ តែមើល ការនោះក៏ឥតប្រយោជន៍ដែរ
២យើងបាននិយាយពីការសើចសប្បាយ[ខ]ថា នេះជាការ
ចំកួតទទេ ហើយពីការត្រេកត្រេងថា តើមានផលអ្វី ៣យើង
បាននឹករកក្នុងចិត្ត ពីបែបយ៉ាងណានឹងធ្វើឱ្យសាច់ឈាម
បានរីករាយ ដោយស្រាទំពាំងបាយជូរ[គ] ទាំងនៅមានចិត្ត
នាំដោយប្រាជ្ញាផង ហើយតោងជាប់នឹងសេចក្ដីចំកួតផង[ឃ]
ទាល់តែបានឃើញការណាដែលគួរឱ្យមនុស្សជាតិធ្វើនៅ
ក្រោមមេឃអស់១ជីវិត ៤ដូច្នេះ យើងបានធ្វើការយ៉ាងធំ
គឺបានសង់ផ្ទះជាច្រើន[ង] បានដាំដំណាំទំពាំងបាយជូរ[ច] ៥បាន
ធ្វើសួនច្បារ នឹងសួនឈើសំរាប់ខ្លួនយើងផង បានទាំងដាំ
ដើមឈើមានផ្លែគ្រប់មុខ ក្នុងសួននោះដែរ ៦យើងបានជីក
ស្រះទឹក សំរាប់នឹងស្រោចចំការបណ្ដុះកូនឈើ ៧យើងបាន
ទិញបាវប្រុសបាវស្រី[ឆ]ជាច្រើន ហើយមានកូនរបស់បាវ
កើតមកនៅក្នុងផ្ទះយើង ក៏មានទ្រព្យសម្បត្តិ ជាហ្វូងគោ
ហ្វូងចៀមយ៉ាងសន្ធឹក លើសជាងអស់អ្នកណាដែលនៅក្រុង
យេរូសាឡិមមុនយើង ៨យើងបានប្រមូលប្រាក់ និងមាស[ជ]
ហើយរបស់ថ្លៃវិសេសផ្សេងៗដែលមក ពីពួកស្ដេច ហើយ
ពីខេត្តទាំងប៉ុន្មាន[ឈ] ក៏ប្រមូលបានពួក ចំរៀងទាំងប្រុសទាំង
ស្រី[ញ] និងគ្រប់ទាំងរបស់អ្វីដែលគាប់ចិត្តមនុស្ស ព្រមទាំង
ស្រីអ្នកម្នាងជាច្រើនផង ៩យ៉ាងនោះយើងបានជាធំ ហើយក៏

**១:១៣** ណ លប ៣:១៧ សស ៣:១០
**១:១៤** ត សស ២:១១ ,១៧ ៤:៤ ៦:៩
**១:១៥** ថ សស ៧:១៣
**១:១៦** ទ ១ពវ ៣:១២
**១:១៧** ធ សស ៧:២៣ ៨:១៦ ន សស ២:៣,១២ ៧:២៥
**១:១៨** ប យរ ៤៥:៣ ផ សស ២:២៣ ១២:១២
**២:១** ក ខ.២៤ សស ៧:៤ ៨:១៥
**២:២** ខ សភ ១៤:១៣
**២:៣** គ ខ.២៤–២៥ ពច ៩:១៣ នរ ៣:៣ សស ៣:១២–១៣ ៥:១៨ ៨:១៥ ឃ សស ១:១៧
**២:៤** ង ២រប ២:១ ៨:១–៦ ច បស ៨:១១ **២:៧** ឆ ២រប ៨:៧–៨ **២:៨** ជ ១ពវ ៩:២៨ ឈ ពច ៣:១៥ ញ ២សយ ១៩:៣៥

**១:១៣** *នៅក្រោមមេឃ* មើលការពន្យល់ ខ.៣ ។ *ព្រះ* គឺជាពាក្យភាសាហេព្រើរតែមួយ ដែលអ្នកនិពន្ធបានប្រើសម្រាប់ជាន័យស្មើរ និងព្រះដែលភាសាហេព្រើរថា"អេឡូហ៊ីម" (Elohim) ដែលបានប្រើស្ទើរតែ៣0ដង ហើយបញ្ជាក់ពីភាពជាព្រះមហាក្សត្រទាំងស្រុង។ អ្នកនិពន្ធមិនប្រើពាក្យ"យ៉ាវ៉េស" ដែលប្រែមកថា(គឺជាព្រះយេហូវ៉ា) សូមមើលការពន្យល់ លប ២:៤ នក ៣:១៤–១៥) ។

**១:១៤** នេះជាឃ្លារបង្ហាញយ៉ាងច្បាស់ ពីភាពអាសារឥតការដែលឥតប្រយោជន៍ទទេ (មើលត្រង់សេចក្ដីផ្ដើម គឺជាគន្លឹះគោលបំណងនឹងការបង្រៀន) ។ ពាក្យទាំងនេះបានប្រើចំនួន៩លើកត្រង់ចំណុចពាក់កណ្ដាលនៃផ្នែកទី១ (គឺ ខ.១៧ ២:១១,១៧,២៦,៤,៦,១៦ ៦:៩ និង ៥:១៦) ។

**១:១៥** មើល ៧:១៣ និងការពន្យល់ ។ ដោយឃើញភាពមិនអាចប្រែប្រួលនៃការប្រឹងប្រែងរបស់មនុស្សគឺឥតប្រយោជន៍ទទេ និងអស់សង្ឃឹមយើងគួរតែរៀនទទួលការងារ ដែលអំណរសប្បាយនឹងទទួលពីសំណាងដែលទ្រង់កំណត់ឱ្យក្នុងជីវិតជាគ្រូប្រដៅ និងជាអ្នកឱ្យដំបូន្មាន ។

**១:១៦** *អស់អ្នកណាដែលនៅក្រុងយេរូសាឡិមមុនយើងទៅទៀត* មើល ២:៧,៩ ក៏មិនបានចុះសំរុងគ្នាក្នុងការបដិសេធស្ដេចសាឡូម៉ូនថា ជាគ្រូប្រដៅឡើយ ។ ក៏ជាការសំអាងទៅលើរយះកាលដឹកនាំរបស់ស្ដេចដាវីឌដែរក៏ដូចជាស្ដេចម៉ិលគីស្សាដែក (លប ១៤:១៨) និងស្ដេច អ័ដូនី–សេដិក (យស ១0:១) ។

**១:១៨** ប្រាជ្ញាដែលពុំពឹងដល់ព្រះអម្ចាស់ ក៏នាំមកនូវភាពទុក្ខព្រួយនឹងភាពសោកស្ដាយ ។

**២:១–១១** ឥឡូវនេះគ្រូប្រដៅក៏បង្ហាញថា បើគ្រាន់តែជាការរីករាយសប្បាយប៉ុណ្ណោះ ក៏ពុំអាចផ្ដល់នូវអត្ថន័យថាបានប្រយោជន៍ ឬជាភាពពេញចិត្តបានឡើយ (មើល ១:១២–១៥ និងការពន្យល់ ១:១២–១៥) ។

**២:១–៣** ការដេញតាម ឬស្វែងរកសេចក្ដីសប្បាយអំណរ គឺមិនអាចនាំមកនូវការបំពេញបានសម្រេច និងការស្វែងរករបស់មនុស្សលោកទេ ។

**២:១** *យើងបាននិយាយចំពោះចិត្តយើង* មើល ខ.១៥ ១:១៦ ។ *អរសប្បាយ* គឺជាខគន្លឹះក្នុងកណ្ឌគម្ពីរនេះ (ពាក្យថា "ល្អ"និង "ល្អជាង"ក៏លេចមក ឬសរសេរឱ្យឃើញប្រហែលជា៤0 ដង) ។

**២:៣** *យើងបាននឹកក្នុងចិត្ត ពីបែបយ៉ាងណានឹងធ្វើឱ្យសាច់ . . . មានចិត្តនាំដោយប្រាជ្ញាផង* គឺតាំងពីដំបូងរហូតដល់ចុងបញ្ចប់(ខ.៩) អ្នកនិពន្ធបានប្រើពាក្យប្រាជ្ញា ដើម្បីស្វែងរកការល្អ (ខ.១) និងការអ្វីដែលមានប្រយោជន៍ (ខ.៣) ។ *នៅក្រោមមេឃ* មើលការពន្យល់ ១:៣ ។

**២:៤–៩** មើល ១ពវ ៤–១១ គឺបានបង្ហាញពីភាពរុងរឿងរបស់ស្ដេចសាឡូម៉ូន និងភរិយារបស់លោក ។

**២:៨** *ខេត្តទាំងប៉ុន្មាន* គឺជាតំបន់ដែនដីដែលមានការគ្រប់គ្រងឱ្យមានជាព្រំដែន ។ *ស្រីអ្នកម្នាង* ជាភាសារហេព្រើរក៏ឃើញមានពាក្យនេះតែម្ដងគត់នៅក្នុងគម្ពីរនេះ ដែលសាសន៍អេស៊ីព្ទប្រើក្នុងការសរសេរសំបុត្រ ដែលប្រើស្រដៀងគ្នា និងពួកកាណានដែលប្រើចំពោះស្រីអ្នករាំ ឬស្រីអ្នកម្នាង ។ គឺវាស៊ីទៅនឹងស្ថានភាពក្នុងរជ្ជកាលនាសម័យស្ដេចសាឡូម៉ូន ដែលមានស្រីអ្នកម្នាង៣00នាក់ ហើយបានបន្ថែមទៅនឹងចំនួនភរិយា៧00អង្គថែមទៀត (១ពវ ១១:៣) ។

ចំរើនឡើងលើសជាងអស់ អ្នកដែលនៅក្រុងយេរូសាឡិម[ដ]
មុនយើងទៅទៀត[ឋ] តែប្រាជ្ញារបស់យើងក៏នៅជាប់នឹង
យើងដែរ ១០ហើយរបស់អ្វីដែលភ្នែកចង់បាន នោះយើង
មិនបានបង្អត់ឱ្យឡើយ យើងមិនបានហាមឃាត់ចិត្ត មិនឱ្យ
មានសេចក្តីអំណរណាមួយទេ ដ្បិតចិត្តយើងបានរីករាយ
នឹងបណ្តាការ ដែលយើងធ្វើទាំងនោះ ហើយនោះឯងជា
ផលដែលកើតពីអស់ទាំងការរបស់យើង ១១គ្រានោះ
យើងបានត្រួតមើលគ្រប់ទាំងការដែលដៃ យើងបានធ្វើនឹង
ការនឿយហត់ ដែលយើងបានខំបង្កើតនោះ ហើយមើល
សុទ្ធតែឥតប្រយោជន៍ ហើយអសារឥតការទទេ[ឌ] ឥតមាន
ផលប្រយោជន៍អ្វីនៅក្រោមថ្ងៃឡើយ[ឍ]។

## ប្រាជ្ញា និងភាពល្ងង់ខ្លៅជាការឥតប្រយោជន៍

១២រួចយើងក៏បែរទៅពិចារណាមើលប្រាជ្ញា ព្រមទាំង
សេចក្តីចំកួត និងសេចក្តីផ្តេសផ្តាស[ណ] ដ្បិតតើអ្នកដែលតពី
ស្តេចនឹងធ្វើអ្វីបាន គឺនឹងធ្វើបានតែការដែលបានធ្វើជា
យូរអង្វែងមកហើយ[ត] ១៣នោះយើងឃើញពិតថាប្រាជ្ញា[ថ]
រមែងវិសេសជាងសេចក្តីផ្តេសផ្តាស[ទ] ដូចជាពន្លឺ ក៏វិសេស
ជាងងងឹតដែរ ១៤ឯភ្នែករបស់មនុស្សមានប្រាជ្ញានោះនៅ
ត្រង់ក្បាលគេ តែមនុស្សល្ងីល្ងើ គេរមែងដើរក្នុងសេចក្តី
ងងឹតវិញ ប៉ុន្តែយើងយល់ឃើញថា មានការតែមួយទេ
ដែលកើតដល់គ្រប់គ្នា[ធ] ១៥រួចយើងបាននឹកក្នុងចិត្តថា ការ
ដែលកើតដល់មនុស្សល្ងីល្ងើ នោះនឹងកើត ដល់យើង
ដូចគ្នាដែរ ដូច្នេះ ហេតុអ្វីបានជាយើងមានប្រាជ្ញាលើស
ជាងគេ[ន] រួចយើងបានសំរេចក្នុងចិត្តថា នេះក៏ឥតមានទំនង
ដែរ ១៦ពីព្រោះអ្នកមានប្រាជ្ញា ក៏ដូចគ្នានឹងអ្នកល្ងីល្ងើដែរ
គ្មានអ្នកណានឹកចាំ[ប] ពី១លើសជាង១ជាដរាបទេ ដោយ
ព្រោះយល់ឃើញថា នៅគ្រាជាន់ក្រោយមនុស្សនឹងបាន
ភ្លេចគេ[ផ]ជាយូរលង់មកហើយ ដូច្នេះ មនុស្សមានប្រាជ្ញាគេ
មរណៈជាយ៉ាងណា គឺដូចជាមនុស្សល្ងីល្ងើដែរ[ព]។

## ការដែលខំធ្វើគឺជាការឥតប្រយោជន៍

១៧ហេតុនោះ យើងបានស្អប់ជីវិត ពីព្រោះការដែល
បានធ្វើនៅក្រោមថ្ងៃ ជាការលំបាកដល់យើង ដ្បិតការទាំង
អស់សុទ្ធតែឥតប្រយោជន៍ ហើយជាអសារឥតការទទេ[ភ]។
១៨យើងបានស្អប់បណ្តាការនឿយហត់ទាំងប៉ុន្មាន ដែល
យើងបានខំធ្វើនៅក្រោមថ្ងៃ ដោយយល់ឃើញថា យើង
ត្រូវទុកទាំងអស់ឱ្យដល់មនុស្សដែលបន្តក្រោយយើង[ម]
១៩ហើយតើមានអ្នកណាដឹងពីអ្នកនោះ ថានឹងត្រឡប់ជា
មនុស្សមានប្រាជ្ញា ឬជាមនុស្សល្ងីល្ងើវិញ[យ] ប៉ុន្តែ អ្នកនោះ
នឹងគ្រប់គ្រងលើអស់ទាំងការដែលយើងបានខំធ្វើ ជាការ
ដែលបានធ្វើ ដើម្បីសំដែងខ្លួនជាអ្នកមានប្រាជ្ញានៅក្រោម
ថ្ងៃ នេះក៏ឥតមានទំនងដែរ ២០ដោយហេតុនោះយើងបាន
វិល មកបណ្តាលឱ្យចិត្តលែងសង្ឃឹមចំពោះការទាំងប៉ុន្មាន
ដែលយើងបានខំធ្វើនៅក្រោមថ្ងៃទៅ ២១ដ្បិតមានមនុស្ស
ដែលការខ្លួនធ្វើទាំងប៉ុន្មាន សុទ្ធតែធ្វើដោយប្រាជ្ញា ដោយ
ដំរិះ ហើយដោយស្ទាត់ជំនាញ តែអ្នកនោះត្រូវប្រគល់ការ
ខ្លួន ទុកជាចំណែកដល់ម្នាក់ទៀត ដែលមិនបានខំធ្វើឡើយ
នោះវិញ នេះជាការឥតមានទំនង ហើយក៏អាក្រក់ណាស់
ផង ២២ដ្បិតក្នុងអស់ទាំងការដែលមនុស្សធ្វើ និងសេចក្តី
ដែលចិត្តខំបង្កើត គឺជាការនឿយហត់ដែលខ្លួនខំធ្វើនៅ
ក្រោមថ្ងៃ នោះគឺមានផលអ្វីខ្លះ[រ] ២៣ពីព្រោះអស់ ទាំងថ្ងៃនៃ
អ្នកនោះមានសុទ្ធតែសេចក្តីទុក្ខព្រួយ ហើយកិច្ចធុរៈរបស់
គេសុទ្ធតែលំបាកទទេ[ល] អើ ទោះទាំងពេលយប់ចិត្តអ្នកនោះ

**២:៩** ដ សស ១:១២ ឋ ១រប ២៩:២៥
**២:១១** ឌ សស ១:១៤ ឍ សស ១:៣
**២:១២** ណ សស ១:១៧ ត សស ១:៩
**២:១៣** ថ សស ៧:១៩ ៩:១៨ ទ សស ៧:១១-១២
**២:១៤** ធ ទដ ៤៩:១០ សស ៣:១៩ ៦:៦ ៧:២ ៩:៣,១១-១២
**២:១៥** ន ខ.១៩ សស ៦:៨
**២:១៦** ប ទដ ១១២:៦ ផ សស ១:១១ ព ទដ ៤៩:១០
**២:១៧** ភ សស ១:១៤
**២:១៨** ម ទដ ៣៩:៦ ៤៩:១០
**២:១៩** យ ខ.១៥
**២:២២** រ សស ១:៣
**២:២៣** ល សស ១:១៨

**២:៩** មើល (១ពវ ១១:៣) ។

**២:១០** *បណ្តាការ . . . ការ* គឺជាគន្លឹះក្នុងគម្ពីរសាស្តា ហើយមានអត្ថន័យថា ឥតប្រយោជន៍ទទេ (ខ.១១) ដែលខុសនឹងព្រះ គឺភាពជាព្រះចំពោះគ្រប់ទាំងការលំបាក ពាក្យនេះក៏ធ្លាប់ឃើញចំនួន ៤០ដង ។

**២:១២** *គឺអ្នកដែលតពីស្តេចមក* ក៏ចង់និយាយរួមមានបញ្ចូលទាំងពួកគ្រូប្រដៅផ្ទាល់ (មើល ១:១) ឬក៏ម្នាក់ទៀតដែលនឹងមកបន្ទាប់ពីគេនោះ (ប្រៀបធៀប ៤:១៥-១៦) ។

**២:១៣** *ប្រាជ្ញារមែងវិសេសជាងសេចក្តីផ្តេសផ្តាស* ទោះជាប្រាជ្ញាដែលមិនមែនមកពីព្រះ ឬទាក់ទងនឹងវិជ្ជាព្រះក៏ដោយ ក៏នៅតែប្រសើជាងសេចក្តីផ្តេសផ្តាសដែរ តែនៅទីបញ្ចប់ទៅជាភាពគ្មានតម្លៃ"គឺនិយាយពីពួកទាំងពី" ដែលវាសនាទាស់នឹងពួកគេ (ពោលគឺភ័ព្វសំណាងអាក្រក់ក៏ធ្លាក់មកលើពួកគេទាំងពីរ គឺទាំងអ្នកមានសេចក្តីជំនឿដ៏មានវ័យឆ្លាត និងអ្នកមិនជឿដែលមានភាពខ្លៅល្ងង់ ខ.១៤ មើល ទដ ៤៩:១០) ។ *វិសេសជាង* មើលការពន្យល់ ២:១ ។

**២:១៤** *ឯភ្នែក* ដែលទាក់ទងនឹងការយល់ដឹង ។

**២:១៦** គឺមិនយូរប៉ុន្មានមនុស្សទាំងអស់ និងត្រូវភ្លេចនូវរាល់ហេតុការណ៍ពីការដឹកនាំអស្ចារ្យ និងភាពជាវិរៈបុរសរបស់ពួកគាត់នៅគ្រានោះមិនខាន (សូមមើល ១:១១) ។

**២:១៧-២៣** ជាការស្វែងរករបស់មនុស្សតាមរយៈកិច្ចការ ដែលពួកគេបានធ្វើ"នៅក្រោមកំដៅថ្ងៃ" (ខ.១៧-២០,២២ មើល ១:៣ និងការពន្យល់) ។ គឺជាភាពមិនបានការដែលនាំទៅរកភាពបាតបង់វិញ ហើយផលផ្លែរបស់វាក៏បន្សល់ទុកសម្រាប់ជានិស្ស័យតៗគ្នា ។

**២:១៨** *ត្រូវទុកទាំងអស់ឱ្យដល់មនុស្សដែលបន្តរក្រោយយើង* មើល ខ.២១ ទដ ៣៩:៦ លក ១២:២០ ។

**២:១៩** *តើមានអ្នកណាដឹង* គឺជាការស្វែងរកនូវអ្នក ដែលយល់ដឹង សូមមើល ៣:២១ ។

ក៏មិនសិរាកដែរ[រ] នេះជាការឥតមានទំនងដែរ ។
២៤គ្មានអ្វីវិសេសដល់មនុស្សជាជាងការស៊ីហើយផឹក
ទេ[ស] ព្រមទាំងឱ្យចិត្តបានរីករាយសប្បាយ ដោយផលនៃ
ការ ដែលខ្លួនបានធ្វើផង[ហ] យើងក៏បានឃើញដែរថា ការ
នេះ មកពីព្រះហស្តនៃព្រះទេ[ឡ] ២៥ដ្បិតតើមានអ្នកណាអាច
នឹងបរិភោគ ឬនឹងមានសេចក្តីអំណរជាជាងយើងនេះ[អ]
២៦ពីព្រោះមនុស្សណាដែលគាប់ព្រះហឫទ័យ នោះទ្រង់
ប្រទាន ឱ្យអ្នកនោះមានប្រាជ្ញា[ក] ដំរិះ នឹងសេចក្តីរីករាយផង
តែឯមនុស្សបាបវិញ ទ្រង់ប្រទានឱ្យមានធុរៈ គឺឱ្យបានប្រ
មូល ហើយបង្គរឡើង[ខ] ទុកសំរាប់ប្រគល់ដល់អ្នកដែលគាប់
ព្រះហឫទ័យនៃព្រះវិញ[គ] នេះក៏ជាការឥតមានទំនង ហើយ
ជាអសារឥតការទទេដែរ ។

## មានពេលសម្រាប់គ្រប់ការទាំងអស់

៣ ១មានពេល[ក]សំរាប់គ្រប់ទាំងអស់ គឺមានពេលសំរាប់
គ្រប់ការ ដែលចង់ធ្វើនៅក្រោមមេឃ ២មានពេលសំរាប់
កើតមក នឹងពេលសំរាប់ស្លាប់ទៅ មានពេលសំរាប់ដាំ
នឹងពេលដករបស់ដែលបានដាំនោះ[ខ] ៣មានពេលសំរាប់
សំឡាប់[គ] ហើយពេលសំរាប់មើលឱ្យជា មានពេលសំរាប់
រំលំរំលាយ ហើយពេលសង់ឡើង ៤មានពេលយំ នឹង
ពេលសើច មានពេលសំរាប់សោយសោក នឹងពេល
សំរាប់លោតកញ្ឆេង ៥មានពេលសំរាប់បោះថ្មចោល នឹង
ពេលប្រមូលថ្មមក មានពេលដែលគួរឱបថើប នឹងពេល
ដែលគួរលែងឱបថើប ៦មានពេលសំរាប់ស្វែងរក ហើយ
ពេលសំរាប់បាត់បង់ទៅ មានពេលសំរាប់រក្សាទុក ហើយ
ពេលសំរាប់បោះបង់ចោល ៧មានពេលសំរាប់ហែក
ចោលហើយពេលសំរាប់ដេរភ្ជាប់ មានពេលដែលគួរ
នៅស្ងៀម[ឃ] ហើយមានពេលសំរាប់និយាយ ៨មានពេល
សំរាប់ស្រឡាញ់ហើយពេលសំរាប់ស្អប់ មានពេលសំរាប់
ចំបាំង ហើយពេលសំរាប់សេចក្តីសុខ ៩តើមនុស្សមាន
ផលប្រយោជន៍អ្វីពីការដែលគេខំធ្វើ[ង] ១០យើងបានឃើញ
ការនឿយហត់ដែលព្រះបានប្រគល់ឱ្យមនុស្សជាតិប្រឹងធ្វើ[ច]
១១ទ្រង់បានបង្កើតរបស់សព្វសារពើឱ្យល្អតាមរដូវកាល[ឆ]
ទ្រង់ក៏ធ្វើឱ្យចិត្តគេសង្ឃឹមដល់អស់កល្បទៅមុខ យ៉ាងនោះ
មនុស្សនឹងរកយល់មិនបាន[ជ] ពីកិច្ចការដែលព្រះបានធ្វើ
តាំងពីដើមដរាបដល់ចុងនោះឡើយ[ឈ] ១២យើងដឹងហើយ
ថាគ្មានអ្វីសំរាប់គេ ដែលវិសេសជាងមានចិត្តរីករាយ
ហើយរកបានសេចក្តីល្អដល់ខ្លួនអស់វេលាដែលមានជីវិត
រស់នៅនោះទេ ១៣ហើយការដែលគ្រប់មនុស្សបានស៊ី
ហើយផឹក[ញ] ព្រមទាំងរីករាយ[ដ]ដោយផលល្អ ដែលកើតពី
អស់ទាំងការនឿយហត់របស់ខ្លួន នោះហើយជាអំណោយ
ទាននៃព្រះទេ[ឋ] ១៤យើងក៏ដឹងដែរ ថាការអ្វីដែលព្រះទ្រង់
ធ្វើ នោះនឹងស្ថិតស្ថេរនៅជាដរាប នឹងបន្ថែមអ្វីចូល ឬដកអ្វី
ចេញមិនបានឡើយ១ទៀតព្រះទ្រង់ធ្វើការនោះ ដើម្បីឱ្យ
មនុស្សទាំងឡាយបានកោតខ្លាចនៅចំពោះទ្រង់[ឌ] ១៥អ្វីៗ
ដែលមាននៅនោះបានមានជាយូរអង្វែងមកហើយ[ឍ] ឯអ្វីៗ
ដែលត្រូវមានខាងមុខទៀត នោះក៏បានមានជាយូរមក
ហើយដែរ[ណ] ព្រះទ្រង់ស្វែងរកអ្វីៗដែលកន្លងបាត់ហើយឱ្យ
បានមកវិញ ។
១៦សោតទៀត យើងបានឃើញនៅក្រោមថ្ងៃថា នៅ

**២:២៣** រ លប ៣:១៧ យប ៧:២
**២:២៤** ស ខ.៣ ១កថ ១៥:៣២ ហ ខ.១ សស ៣:២២ ឡ យប ២:១០ សស ៣:១២–១៣ ៥:១៧–១៩ ៧:១៤ ៩:៧–១០ ១១:៧–១០
**២:២៥** អ ទដ ១២៧:២
**២:២៦** ក យប ៩:៤ ខ យប ២៧:១៧ គ សភ ១៣:២២
**៣:១** ក ខ.១១,១៧ សស ៨:៦
**៣:២** ខ អស ២៨:២៤
**៣:៣** គ ចទ ៥:១៧
**៣:៧** ឃ នអ ៤:១៤
**៣:៩** ង សស ១:៣
**៣:១០** ច សស ១:៣
**៣:១១** ឆ ខ.១ ជ យប ១១:៧ ឈ យប ២៨:២៣ រម ១១:៣៣
**៣:១៣** ញ សស ២:៣ ដ ទដ ៣៤:១២ ឋ ចទ ១២:៧,១៨ សស ២:២៤
**៣:១៤** ឌ យប ២៤:១៥ សស ៥:៧ ៧:១៨ ៨:១២–១៣ **៣:១៥** ឍ សស ៦:១០ ណ សស ១:៩

**២:២៤–២៥** ចំណុចសំខាន់ក្នុងគម្ពីរសាស្តា ចំពោះចំណុចដែលត្រូវរំលឹក គឺត្រង់ ខ.៣:១២–១៣,២២ ៥:១៨–២០ ៨:១៥ ៩:៧ និងគឺជាលក្ខណៈសំខាន់បំផុត ១២:១៣ ។ មានតែនៅក្នុងព្រះទេ ដែលជីវិតមានន័យនឹងមានសេចក្តីរីករាយអំណរដ៏ពិតប្រាកដផង តែបើគ្មានទ្រង់ក៏គ្មានអ្វីគ្រប់គ្រាន់សម្រាប់យើងដែរ តែនៅក្នុងទ្រង់យើងអាចស្វែងរកសេចក្តីប៉ងប្រាថ្នាដ៏ពិត និងសេចក្តីរីករាយ ។ សេចក្តីរីករាយយ៉ាងពិតប្រាកដ គឺមានតាមរយៈការទទួលស្គាល់ព្រះអម្ចាស់ (១២:១៣) ។

**២:២៦** *តែឯមនុស្សបាបវិញ* គឺជាករណីលើកលែង ចំពោះគោលការទូទៅដែលមានក្នុង ៨:១៤ ទដ ៧៣:១–១២ ។

**៣:១–២២** មនុស្សមានរឿង ឬចំណងជើងជាច្រើន ត្រូវតែធ្វើក៏ពុំអាចគ្រប់គ្រងពេលវេលា ហើយនិងភាពប្រែប្រួលបានឡើយ ។ ព្រះអម្ចាស់ដែលជាព្រះអស់កល្បជានិច្ច ក៏ជាព្រះមហាក្សត្រដែលបានកំណត់គ្រប់ទាំងរាល់សកម្មភាពទាំងអស់របស់ជីវិតមនុស្ស (ឧទាហរណ៍ ខ.២–៨) ។

**៣:១** ប្រៀបធៀប ៨:៦ ។ *នៅក្រោមមេឃ* មើលការពន្យល់ ១:៣ ។

**៣:២** *មានពេល* គឺជាការកំណត់ពេលដល់មនុស្សទាំងឡាយ (មើល ទដ ៣១:១៥ ទដ ១៦:១–៩) ។

**៣:៩** មើលការពន្យល់ ២:១៧–៣២ ។

**៣:១១** គឺជាការសង្ខេបពីជិពូក : សោភ័ណ្ឌភាពរបស់ព្រះ ប៉ុន្តែលោកិយដែលមានភាពទាក់ទាញហាក់ដូចជាធំណាស់ សម្រាប់ពួកយើងតែភាពដែលធ្វើឱ្យពេញចិត្តគឺមានតិចណាស់ ។ យើងបានមានជីវិតឡើងគឺសម្រាប់តែពេលខាងមុខទៅអនាគតតែអ្វីៗ ក៏ពុំមានពេលគ្រប់គ្រាន់និងឱ្យមានភាពស្កប់ចិត្តឱ្យបានស្ថិតស្ថេរទេ ។

**៣:១២–១៣** គឺជាការចង្អុលបង្ហាញសេចក្តីបញ្ចប់នៃកណ្ឌគម្ពីរនេះ គឺរាស្ត្ររបស់ផងទ្រង់អាចរកបាននូវអត្ថន័យក្នុងជីវិត ក្នុងខណៈពេលណាពួកគេទទួលដោយក្តីអំណរនូវអ្វីៗ ដែលចេញពីព្រះហស្តទ្រង់ ។

**៣:១៤** *កោតខ្លាច* គឺជាសេចក្តីចុងក្រោយនូវអត្ថបទនៃកណ្ឌគម្ពីរ (ប្រៀបធៀប ១២:១៣) ។

**៣:១៥** មើល ១:៩ ។

កន្លែងវិនិច្ឆ័យ នោះមានសេចក្តីទុច្ចរិត ហើយនៅកន្លែងនៃ
សេចក្តីសុចរិត នោះមានសេចក្តីអយុត្តិធម៌វិញ ១៧យើងក៏
នឹកក្នុងចិត្តថា ព្រះទ្រង់ជំនុំជំរះ[ត]ទាំងពួកអ្នកសុចរិត និងពួក
ទុច្ចរិតផង ដ្បិតមានពេលសំរាប់គ្រប់ទាំងបំណងដែលប៉ង
ធ្វើ និងបណ្តាការទាំងពួងផង[ថ] ១៨យើងបាននឹកក្នុង ចិត្តពី
មនុស្សជាតិថា នេះគឺដោយព្រោះព្រះទ្រង់ចង់ល្បងលគេ
ហើយឱ្យគេយល់ឃើញថា ខ្លួនគេជាសត្វតិរច្ឆានទេ[ទ] ១៩ពី
ព្រោះការដែលកើតដល់មនុស្សជាតិ[ធ] នោះក៏កើតដល់សត្វ
តិរច្ឆានដែរ មានការដដែលកើតដល់ទាំង២ពួក ពួក១ស្លាប់
យ៉ាងណា ពួក១ទៀតក៏ស្លាប់យ៉ាងនោះ អើ គេមានដង្ហើម
ជីវិតដូចគ្នាទាំងអស់ ហើយមនុស្សមិនវិសេសជាង សត្វទេ
ដ្បិតគ្រប់ទាំងអស់សុទ្ធតែឥតប្រយោជន៍ទទេ ២០គ្រប់ទាំង
អស់ទៅឯកន្លែងតែ១ប៉ុណ្ណោះទាំងអស់កើតមកពីធូលីដី
ហើយត្រូវត្រឡប់ទៅឯធូលីដីវិញទៀត[ន] ២១តើមានអ្នកណា
ដឹងបានថា វិញ្ញាណនៃមនុស្សឡើងទៅលើ[ប] ហើយវិញ្ញាណ
របស់សត្វចុះទៅក្នុងដីវិញឬទេ ២២ដូច្នេះ យើងបានយល់
ឃើញថា គ្មានអ្វីប្រសើរដល់មនុស្ស ជាជាងឱ្យគេមានចិត្ត
រីករាយ ក្នុងការដែលគេធ្វើនោះទេ[ផ] ដ្បិតនោះហើយជា
ចំណែករបស់គេ[ព] ពីព្រោះតើអ្នកណានឹងនាំមនុស្សមកវិញ
ដើម្បីមើលការដែលនឹងកើតមកក្រោយគេបាន ។

**៣:១៧** ត យប ១៩:២៩ សស ១១:៩ ១២:១៤ ថ ខ.១
**៣:១៨** ទ ទដ ៧៣:២២
**៣:១៩** ធ សស ២:១៤
**៣:២០** ន លប ២:៧ យប ៣៤:១៥
**៣:២១** ប សស ១២:៧
**៣:២២** ផ សស ២:២៤ ព យប ៣១:២

## ការសង្កត់សង្កិន ការប្រឹងប្រែងធ្វើការ ការរាក់ទាក់

៤ ១នោះយើងបានវិលមកពិចារណាមើលអស់ទាំងការ
សង្កត់សង្កិន[ក] ដែលកើតមកនៅក្រោមថ្ងៃ ក៏ឃើញទឹក
ភ្នែករបស់ពួកអ្នកដែលត្រូវគេសង្កត់សង្កិន ហើយឃើញថា
គេគ្មានអ្នកណានឹងជួយដោះទុក្ខឡើយ គេត្រូវរឹបជាន់
ដោយពួកអ្នកមានអំណាច ឥតអ្នកណានឹងជួយដោះទុក្ខទេ[ខ]
២ហេតុនោះយើងក៏សរសើរដល់មនុស្សដែលស្លាប់[គ]ជា
យូរមកហើយ ជាជាងមនុស្សដែលនៅរស់នៅឡើយ[ឃ] ៣អើ
អ្នកដែលមិនទាន់កើតមកនៅឡើយ[ង] ជាអ្នកដែលមិនបាន
ឃើញការអាក្រក់ដែលកើតនៅក្រោមថ្ងៃ នោះវិសេសជាង
ពួកទាំង២នោះទៅទៀត[ច]។
៤រួចយើងបានឃើញអស់ទាំងការនឿយហត់ និងគ្រប់
ការដែលធ្វើបានដោយស្រួលថា ជាហេតុនាំឱ្យអ្នកជិតខាង
មានចិត្តច្រណែនដល់គ្នានឹងគ្នា នេះក៏ជាការឥតមានទំនង
ហើយជាអសារឥតការទទេ[ឆ]។
៥មនុស្សល្ងីល្ងើគេឱបដៃ[ជ] ហើយស៊ីសាច់របស់ខ្លួនគេ
៦បើមានតែ១ក្តាប់ ទាំងប្រកបដោយសេចក្តីសុខ នោះ
វិសេសជាងមាន២ក្តាប់[ឈ] ហើយមានទាំងការនឿយហត់
នឹងការខំជាអសារឥតការផង ។

**៤:១** ក ទដ ១២:៥ ខ បទ ១:១៦
**៤:២** គ យរ ២០:១៧–១៨ ២២:១០ ឃ យប ៣:១៧ ១០:១៨
**៤:៣** ង យប ៣:១៦ ច យប ៣:២២
**៤:៤** ឆ សស ១:១៤
**៤:៥** ជ សភ ៦:១០
**៤:៦** ឈ សភ ១៥:១៦–១៧ ១៦:៨

**៣:១៧** *ជំនុំជំរះ* ការជំនុំជម្រះរបស់ផងទ្រង់ដ៏ពិតប្រាកដ គឺឆ្លើយតបទៅនឹងការចំអកឡកលើយពីភាពយុត្តិធម៌របស់មនុស្ស ។ "គឺពីអតីតកាល" (ខ.១៥) មិនមែនជាការឥតប្រយោជន៍ទទេៗ (ដូចជាមនុស្សបានបណ្តេញការនោះតាំងពីដំបូង ១:១១) រួចព្រះទ្រង់ទទួលជោគជ័យ លើការកាត់ទោសចំពោះអ្នកដែលរឹងរុះចចេស (១.៦) (មើល ១២:១៤) ។ *ពួកអ្នកសុចរិតនឹងពួកបរិសុទ្ធ* ក៏គ្មានអ្នកណាមួយអាចគេចរួច ពីភាពជំនុំជម្រះមកពីព្រះឡើយ (ប្រៀបធៀប រម ១៤:១០ កល ៥:១០ និងការពន្យល់ វវ ២០:១២–១៣) ។

**៣:១៨** *ជាសត្វតិរិច្ឆាន* គឺបញ្ជាក់ថាមនុស្សដែលនៅក្រោមកំដៅថ្ងៃ គឺមានជីវិតអាចស្លាប់ដូចជាសត្វតិរិច្ឆានផងដែរ ។ តែពុំមានលក្ខណៈដូចជាសត្វទាំងស្រុងទេ គេត្រូវឃើញនូវលក្ខណៈនេះតាមរយៈសម្បជញ្ញៈ ហើយពុំដឹងច្បាស់ពីភាពអាប់ឱនរបស់ពួកគេនាពេលអនាគត (ខ.១១) ។

**៣:១៩** *មានដង្ហើមជីវិតដូចគ្នា* សូមមើល ទដ ១០៤:២៩–៣០ ។

**៣:២០** *ឯកន្លែងតែមួយ* គឺមិនមែនជាស្ថានសួគ៌ ឬជាស្ថាននរកទេ តែទីបញ្ចប់គឺជាគោលដៅដែលអាចមើលឃើញរបស់មនុស្ស ជាការត្រឡប់ទៅជាធូលីដីវិញក៏ដូចជាសត្វពាហនៈដែរ ។ តែការស្លាប់របស់មនុស្សមានកំរិតអស្ចារ្យជាងសត្វលោកធម្មតា (មើល ៣:១៩ ទដ ១០៣:១៤) ។

**៣:២១** *តើមានអ្នកណាដឹងបាន . . . ?* មើល ២:១៩ និងការពន្យល់ ប្រៀបធៀប ១២:៧ ។ បើតាមខ្លួនគេគឺមនុស្សពុំអាចដឹង គេបានត្រឹមតែគិតស្មាន ។ ចម្លើយគឺជាការសម្តែងចេញនៅគ្រាដំបូង ក្នុងភាពមួយប្រព្រិចភ្នែក (មើល ឧទាហរណ៍ ទដ ១៦:៩–១១ ៤៩:១៥ ៧៣:២៣–២៦ អស ២៦:១៩ ដយ ១២:២ និងការពន្យល់) ។ តែបានបង្ហាញឱ្យឃើញពិតតាមរយៈដំណឹងល្អវិញ (២ធថ ១:១០ មើល យហ ៥:២៤–២៩) ។

**៣:២២** *គ្មានអ្វីប្រសើរ* គឺជាការបញ្ចប់ដោយខ្លួនឯងនៃការងារដែលឥតប្រយោជន៍ (មើល ៤:៤ ៩:៩) គឺជាការទទួលនោះដូចជារង្វាន់ដែលបានមកពីព្រះ (ខ.១៣–១៤) ។

**៤:១** *ការសង្កត់សង្កិន* ផ្ទៃរឿងបានសម្តែងឱ្យឃើញរួចហើយនៅ (៣:១៦) និងកត្តាមួយទៀតនៅក្នុងសោកនាកម្មរបស់មនុស្ស ។ គឺចំពោះការស្វែងរកនូវភាពឥតប្រយោជន៍ទទេ គឺជាសេចក្តីទុក្ខព្រួយ ដ៏ជោរជន់តែវាជាការទទួលរស់ជាតិគ្មានមនុស្សហួសពីការថ្លែង ។

**៤:២** *គឺជាជាងដែលនៅរស់នៅឡើយ* មើល យប ៣ យរ ២០:១៤–១៨ ។ គឺជាសេចក្តីជំនឿដែលថានឹងឃើញរូបភាពដ៏ធំមួយ មើល ៨:៣៥–៣៩ ។

**៤:៤–៦** ទោះជាការងារលំបាក ឬឧស្សា (ដែលបានលើកទឹកចិត្តរបៀបជាច្រណែន) ឬក៏សេចក្តីខ្ជិលច្រអូសដែលនាំមកនូវភាពរីករាយ អត្ថន័យមានប្រយោជន៍ ឬក៏ការសម្រេចបាន ។

**៤:៤** *អស់ទាំងការនឿយហត់ នឹងគ្រប់ការងារនេះក៏ដូច្នេះដែរ* គឺជាការឥតប្រយោជន៍ទទេលើកលែងតែការប្រព្រឹត្តតាមការ ដែលព្រះបានប្រទានពរ (មើល ៣:១៣ ប្រៀបធៀបភាពជោគជ័យពីការដែលមិនគិតពីខ្លួនឯងរបស់លោកយ៉ូសែប លប ៣៩) ។

**៤:៥** *ភាពហិនហោចរបស់មនុស្សដែលខ្ជិល* គឺបង្ហាញឱ្យឃើញក្នុង ១០:១៨ សភ ៦:៦–១១ ២៤:៣០–៣៤ ។

**៤:៦** *ប្រកបដោយសេចក្តីសុខ* មើល ៣០:៧–៩ គឺលោកប៉ុលបាននិយាយពាក្យនេះចុងក្រោយបង្អស់ស្តីពីប្រធានបទនេះ (កល ៤:១១–១៣) ។

៧រួចយើងងាកបែរមកឃើញការដែលឥតប្រយោជន៍
នៅក្រោមថ្ងៃ ៨គឺមានម្នាក់ដែលនៅតែឯងឥតមានគូ អើ
គ្មានទាំងកូន ឬបងប្អូនផង ប៉ុន្តែការនឿយហត់របស់អ្នក
នោះមិនចេះអស់មិនចេះហើយឡើយ ភ្នែកគេក៏មិនបាន
ស្កប់ស្កល់[ញ]ដោយទ្រព្យសម្បត្តិដែរ គេក៏នឹកថា អញធ្វើការ
នឿយហត់ ហើយបង្អត់សេចក្ដីល្អដល់ព្រលឹងដូច្នេះ នោះ
តើសំរាប់អ្នកណា នេះជាការឥតប្រយោជន៍ដែរ ហើយក៏
អាក្រក់ណាស់ផង ៩មានគ្នា២នាក់ នោះវិសេសជាង
នៅតែឯង ពីព្រោះគេមានរង្វាន់យ៉ាងល្អកើតពីការនឿយ
ហត់របស់ខ្លួន ១០ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នា
ឡើងវិញ តែវរហើយ អ្នកណាដែលដួលក្នុងកាលដែល
នៅតែម្នាក់ឯងឥតមានគ្នានឹងជួយជ្រោងឡើងវិញ ១១មួយ
ទៀត បើដេកមានគ្នា២នាក់ នោះក៏បានកក់ក្ដៅ តែបើ
ដេកតែម្នាក់ឯង នោះធ្វើដូចម្ដេចឱ្យកក់ក្ដៅបាន ១២ហើយ
បើមានខ្មាំងណាមក ដែលមានកំឡាំងជាង នោះ២នាក់
នឹងអាចទប់ទល់បាន ឯពួរ៣ធ្លុងមិនងាយដាច់ទេ ។

## ការមានតំណែងខ្ពស់ជាការគ្មានន័យ

១៣មនុស្សកំឡោះដែលទាល់ក្រ តែមានប្រាជ្ញា នោះ
វិសេសជាងស្ដេចដែលចាស់ជរា ហើយល្ងីល្ងើ ជាស្ដេច
ដែលមិនព្រមទទួលសេចក្ដីដាស់តឿនទៀត ១៤ដ្បិតទោះ
បើអ្នកនោះចេញពីគុកមក ឬកើតមកជាអ្នកក្រក្នុងនគរក៏
ដោយ គង់តែនឹងឡើងសោយរាជ្យបានដែរ ១៥យើង
បានឃើញគ្រប់មនុស្សមានជីវិតរស់ដែលដើរនៅក្រោមថ្ងៃ
ថាគេកាន់ខាងមនុស្សកំឡោះនោះ គឺជាអ្នកទី២ ដែល
បានតាំងឡើងជំនួសគេ ១៦ឯបណ្ដាជនទាំងឡាយ គឺជា
ពួកមនុស្សដែលអ្នកនោះគ្រប់គ្រងលើ នោះប្រមាណមិន
បានឡើយ ប៉ុន្តែពួកមនុស្សដែលកើតមកក្រោយ គេនឹង
មិនសុខចិត្តចំពោះអ្នកនោះទេ នេះពិតប្រាកដជាឥតមាន
ប្រយោជន៍ ហើយអសារឥតការទទេដែរ ។

## ចូលក្នុងដំណាក់ព្រះ

**៥** ១ចូររក្សាជើងឯងក្នុងកាលដែលចូលទៅក្នុងដំណាក់
នៃព្រះ ដ្បិតដែលចូលទៅជិតដើម្បីស្ដាប់ នោះវិសេសជាង
ថ្វាយយញ្ញបូជារបស់មនុស្សល្ងីល្ងើ ពីព្រោះគេមិនដឹងជា
គេធ្វើអាក្រក់ទេ ។
២កុំឱ្យចិត្តឯងរហ័សពេក ក៏កុំឱ្យមាត់ឯងពោលឥតបើ
គិតនៅចំពោះព្រះឡើយ[ក] ដ្បិតព្រះទ្រង់គង់នៅឯស្ថានសួគ៌
ហើយឯងនៅផែនដីទេ ដូច្នេះត្រូវឱ្យឯងមានសំដីតិចវិញ[ខ]
៣ដ្បិតការដែលយល់សប្តិ[គ] នោះកើតមកដោយមានរវល់
ជាច្រើន ហើយសំឡេងរបស់មនុស្សល្ងីល្ងើ ក៏ឮដោយ
មានពាក្យសំដីច្រើនដែរ[ឃ] ៤កាលណាឯងបន់ព្រះ នោះកុំ
ឱ្យបង្អង់នឹងលាបំណន់នោះឡើយ[ង] ពីព្រោះទ្រង់មិនសព្វព្រះ
ហឫទ័យនឹងមនុស្សល្ងីល្ងើទេ ចូរសងតាមដែលឯងបាន
បន់ចុះ[ច] ៥ស៊ូកុំឱ្យឯងបានបន់ ជាជាងបន់ហើយ តែមិន
លាបំណន់នោះវិញ[ឆ] ៦កុំបើកឱ្យមាត់ឯងបណ្ដាលឱ្យរូប
សាច់ឯងធ្វើបាបឡើយ ក៏កុំឱ្យពោលនៅមុខទេវតាថា នេះ
ជាការច្រឡំទេ តើចង់ឱ្យព្រះមានសេចក្ដីខ្ញាល់ ដោយ
សំឡេងឯង ហើយបំផ្លាញការនៃដៃឯងធ្វើអី ៧ដ្បិតក្នុងការ
យល់សប្តិច្រើន ហើយក្នុងពាក្យពោលជាច្រើន នោះតែង
មានសេចក្ដីឥតប្រយោជន៍ គួរឱ្យកោតខ្លាចដល់ព្រះវិញ[ជ]។

**៤:៨** ញ សភ ២៧:២០
**៥:២** ក ពច ១១:៣៥ ខ យប ៦:២៤ សភ ២០:២៥ **៥:៣** គ យប ២០:៨ ឃ សស ១០:១៤ **៥:៤** ង ចទ ២៣:២១ ពច ១១:៣៥ ទដ ១១៩:៦០ ច ជន ៣០:២ ទដ ៦៦:១៣-១៤ **៥:៥** ឆ ជន ៣០:២-៤ យហ ២:៩

**៤:៧-១២** ចំពោះអ្នកដែលខំពុះពារតស៊ូរដើម្បីផលប្រយោជន៍ខ្លួនឯងនោះ ជាការឥតប្រយោជន៍ទទេក៏នាំឱ្យមានជីវិតវេទនា ។

**៤:១៣-១៦** *ភាពរីកចម្រើនដែលពុំមានព្រះ* ក៏បានពន្យល់១ទៀតដែលជាភាពឥតប្រយោជន៍ទទេនៃភាពអសីលធម៌ ។

**៤:១៦** ការឈពីមុខពួកគេដើម្បីបម្រើពួកគេ ។ *ប៉ុន្តែពួកមនុស្សដែលកើតមកក្រោយ* គឺជាពួកមនុស្សជំនាន់ក្រោយ ។

**៥:១-៧** ជាផ្នែករឿងមួយបែបគឺជាការឥតប្រយោជន៍ទទេ ចំពោះសាសនាដែលមានចំណេះដឹងរាក់កំផែលក្នុងការឆ្លុះបញ្ចាំង នៃការបង្កើតពាក្យសន្យាមិនច្បាស់លាស់ ។

**៥:១** *ចូររក្សាជើងឯង* គឺសំដៅទៅលើអ្វីដែលអ្នកនិយាយ និងប្រព្រឹត្ត ។ *ដំណាក់នៃព្រះ* គឺប្រហែលចង់និយាយពីព្រះដំណាកស្ដេចសាឡូម៉ូន ។ *ស្ដាប់* គឺជាការស្ដាប់បង្គាប់ ១សយ ១៥:២២ ។ ការប្រើភាសាហេព្រើរតែមួយគឺមានលក្ខណៈផ្ទុយរវាងការថ្វាយបង្គំដ៏ពិត ។ *ថ្វាយយញ្ញបូជា* គឺវាអាចមានទំនាក់ទំនងនឹងការសច្ចា ឬលាបំណន់ក្នុង ខ.៤-៦ ។

**៥:២** *ចិត្តឯងរហ័សពេក* គឺដូចជាលក្ខណៈការសច្ចាស្បថយ៉ាងរហ័ស ។ *ដ្បិតព្រះទ្រង់គង់នៅឯស្ថានសួគ៌ ហើយឯងនៅផែនដី* ក៏បង្ហាញរវាងព្រះអម្ចាស់ដែលផ្ទុយនឹងមនុស្សលោក ។

**៥:៣** ជាពាក្យសុភាសិតក្នុងអត្ថបទ ដោយគិតពីក្នុងកណ្ដាលក្ដីក្ដាំង គឺជាការយល់សប្តិមួយនៃភាពសុខដុម (ដូចជាមនុស្សអត់ឃ្លានយល់សប្តិឃើញពិធីជប់លៀង) ។ និងក្នុងហេតុការណ៍កើតឡើងជាមុន ក៏ជាការថ្វាយការសច្ចាដែលមិនបានគិតវែងឆ្ងាយ ("ដែលនិយាយជាច្រើន") ចំពោះព្រះអម្ចាស់ (មើល ខ.៧) ។

**៥:៤** *បន់* មើល ចទ ២៣:២១-២៣ ១យស ១:១១,២៤-២៨ ។ *មិនសព្វព្រះហឫទ័យនឹងមនុស្សល្ងីល្ងើទេ* នៅក្នុងអត្ថបទនេះមនុស្សល្ងីល្ងើមិនមែនអ្នកដែលមិនអាចរៀននោះទេប៉ុន្តែ គឺជាអ្នកបដិសេធន៍មិនព្រមរៀន (មើល ទដ ១:២០-២៧ មើលការពន្យល់ ទដ ១:៧) ។

**៥:៦** *ទេវតា* គឺប្រហែលជាសង្ឃ (មើល មឡ ២:៧ និងការពន្យល់) ។ *តើចង់ឱ្យព្រះមានសេចក្ដីខ្ញាល់* ការបំផ្លាញ ឬក្បត់នូវពាក្យ សម្បថគឺជាបញ្ហាធ្ងន់ធ្ងរមួយ (មើល ជន ៣០:២ និងការពន្យល់ ៣០:១-៦) គឺជាផលវិបាកមួយដែលមានគ្រោះថ្នាក់ (មើល ចទ ២៣:២១-២៣) ។

## ការមានទ្រព្យសម្បត្តិច្រើនជាការគ្មានន័យ

៨បើសិនជាឯងឃើញគេសង្កត់សង្កិន[ឈ]មនុស្សទាល់ក្រ
ឬពួកច្រឡោតកំពុងតែបង្វែរសេចក្ដីយុត្តិធម៌ និងសេចក្ដី
សុចរិតនៅក្នុងស្រុកណា នោះកុំឱ្យឆ្ងល់ពីការនោះឡើយ
ដ្បិតមានអ្នកមួយដែលខ្ពស់ជាង គេត្រួតមើលអ្នកធំនោះ
ហើយក៏មានដែលខ្ពស់ជាងគេទៅទៀតផង ៩១ទៀតផល
កើតពីដី នោះសំរាប់គ្រប់គ្នា ទោះទាំងស្ដេចក៏បានស្បៀង
អាហារពីចំការមកដែរ ។

១០អ្នកណាដែលស្រឡាញ់ប្រាក់ នោះនឹងមិនស្កប់ចិត្ត
ដោយប្រាក់ប៉ុណ្ណោះទេ ឬអ្នកណាដែលចូលចិត្តនឹងទ្រព្យ
ដ៏បរិបូរ នោះក៏មិនស្កប់ចិត្តដោយផលចំរើនប៉ុណ្ណោះដែរ
នេះក៏ជាការឥតប្រយោជន៍ទទេ ១១កាលណារបស់ទ្រព្យ
បានចំរើនឡើង នោះពួកអ្នកដែលស៊ីទ្រព្យនោះក៏មានគ្នា
ច្រើនឡើងដែរ ដូច្នេះតើមានប្រយោជន៍អ្វីដល់ម្ចាស់នៃ
ទ្រព្យសម្បត្តិនោះ លើកតែបានឃើញដោយភ្នែកប៉ុណ្ណោះ
១២ឯការដេកលក់នៃមនុស្សដែលធ្វើការនឿយហត់ នោះ
ស្រួលឆ្ងាញ់ ទោះបើបានបរិភោគតិចឬច្រើនក្ដី ប៉ុន្តែការ
បរិភោគហួសប្រមាណរបស់អ្នកមាន នោះមិនឱ្យគេដេក
លក់បានទេ[ញ]។

១៣មានការអាក្រក់យ៉ាងធ្ងន់១មុខ ដែលយើងបានឃើញ
នៅក្រោមថ្ងៃ[ដ] គឺមានទ្រព្យសម្បត្តិដែលម្ចាស់រក្សាទុកដរាប
ដល់កើតអន្តរាយដល់ខ្លួន ១៤ហើយទ្រព្យសម្បត្តិនោះរមែង
បាត់ទៅ ដោយគ្រោះអាក្រក់ណាមួយ បើអ្នកនោះបាន
បង្កើតកូនប្រុស១ នោះគ្មានសល់អ្វីនៅដៃវាទេ ១៥អ្នកនោះ
សំរាលចេញពីផ្ទៃម្ដាយមកយ៉ាងណា នោះក៏ត្រូវត្រឡប់
ទៅវិញខ្លួនទទេ[ឋ] ដូចជាបានមកនោះដែរ ឥតយកអ្វីពីការ
នឿយហត់[ឌ]របស់ខ្លួនជាប់នៅដៃទៅជាមួយបានឡើយ[ឍ]
១៦នេះក៏ជាការអាក្រក់យ៉ាងធ្ងន់ដែរ គឺដែលកើតមកយ៉ាង

**៥:៧** ច សស ៣:១៤
**៥:៨** ឈ ទដ ១២:៥
**៥:១២** ញ យប ២០:២០
**៥:១៣** ដ សស ៦:១-២
**៥:១៥** ឋ យប ១:២១ ឌ ទដ ៤៩:១៧ ១ធថ ៦:៧ ឍ សស ១:៣
**៥:១៦** ណ សស ១:៣
**៥:១៨** ត សស ២:៣ ថ សស ២:១០,២៤
**៥:១៩** ទ ១រប ២៩:១២ ធ សស ៦:២ ន យប ៣១:២ ប សស ២:២៤
**៥:២០** ផ ចទ ១២:៧,១៨
**៦:២** ក សស ៥:១៩ ខ សស ៥:១៣

ណា នោះត្រូវទៅវិញយ៉ាងនោះឯង ការដែលបានធ្វើ
ដោយនឿយហត់ ជាអសារឥតការដូច្នេះ នោះតើមាន
ប្រយោជន៍អ្វីដល់ខ្លួន[ណ] ១៧គ្រប់១ជីវិតនោះត្រូវរោយរៀវ
ទៅក្នុងសេចក្ដីងងឹត ក៏កើតមានទុក្ខព្រួយច្រើន ព្រមទាំង
មានជំងឺបៀតបៀន និងក្រហល់ក្រហាយចិត្តផង ។

១៨នេះហើយជាការដែលយើងបានគិតឃើញថាល្អ
ហើយគួរសម គឺឱ្យមនុស្សបានស៊ីហើយផឹក[ត] ព្រមទាំងមាន
ចិត្តរីករាយក្នុងអស់ទាំងការដែលខ្លួនធ្វើ[ថ] ដោយនឿយហត់
នៅក្រោមថ្ងៃ ដរាបដល់អស់១ជីវិត ដែលព្រះបានប្រទាន
មកខ្លួន ដ្បិតនោះហើយជាចំណែករបស់ខ្លួន ១៩ឯអស់អ្នក
ណាដែលព្រះបានប្រទានឱ្យមានទ្រព្យសម្បត្តិ និងធនធាន[ទ]
ព្រមទាំងឱ្យមានអំណាចនឹងបរិភោគផលនៃរបស់ទាំង
នោះ[ធ] និងទទួលយកចំណែករបស់ខ្លួនបាន[ន] ហើយរីករាយ
ក្នុងការដែលខ្លួនធ្វើដែរ នេះឯងជាអំណោយទានពីព្រះ[ប]
២០ដ្បិតអ្នកនោះនឹងមិននឹកចាំពីអស់ទាំងថ្ងៃនៃអាយុខ្លួន
ប៉ុន្មានទេ ពីព្រោះទ្រង់ផ្សាយសេចក្ដីអំណរមកក្នុងចិត្ត
ហើយ[ផ]។

**៦** ១មានការអាក្រក់១ទៀត ដែលយើងបានឃើញនៅ
ក្រោមថ្ងៃ ជាការដែលមានជាញឹកញយនៅក្នុងពួកមនុស្ស
លោកដែរ ២គឺមានមនុស្សដែលព្រះទ្រង់ប្រទានឱ្យមាន
ទ្រព្យសម្បត្តិ និងធនធាន ហើយកិត្តិយស ដល់ម៉្លេះបាន
ជាគេមិនខ្វះខាតអ្វី ក្នុងគ្រប់ទាំងរបស់ដែលចិត្តប្រាថ្នាចង់
បានឡើយ តែព្រះទ្រង់មិនប្រទានឱ្យមានអំណាចអាចនឹង
បរិភោគបានទេ[ក] គឺមានអ្នកដទៃបរិភោគវិញ នេះជាការ
ឥតមានទំនង ហើយជាគ្រោះថ្នាក់យ៉ាងអាក្រក់ផង[ខ] ៣បើ
សិន ជាមនុស្សណាបង្កើតបានកូន១០០នាក់ ហើយរស់នៅ
ជាយូរឆ្នាំ ដល់ម៉្លេះបានជាមានអាយុយឺនយូរ តែមិនបាន

**៥:៨** *នោះកុំឆ្ងល់ពីការនោះឡើយ* គឺជាសញ្ញានៃការវាយតម្លៃចំពោះសង្គមមនុស្ស មើល ៤:១-៣ គ្រូប្រដៅនេះក៏មានលក្ខណៈ ដូចព្រះយេស៊ូវដែរ "ដែលទ្រង់ស្គាល់អស់ទាំងនិស្ស័យមនុស្ស" (យហ ២:២៥) ដែលទ្រង់យល់ពុំដែលខុសឡើយ ។

**៥:៩** *ស្ដេចក៏បានស្បៀង . . . ពីចំការមកដែរ* សូមមើល អប ៧:១ ។

**៥:១០** សម្បត្តិដ៏ស្តុកស្តម្ភមិនអាចនាំមកនូវភាពស្កប់ស្កល់បានទេ ។ (មើល ១ធថ ៦:៩-១០) ។

**៥:១១-១២** សម្បត្តិយ៉ាងច្រើនស្តុកស្តម្ភ ក៏នាំមកនូវសេចក្តីប៉ងប្រាថ្នាយ៉ាងខ្លាំងដែរ ។

**៥:១១** *ពួកអ្នកដែលស៊ីទ្រព្យនោះ* គឺជាពួកបរាសិត ដែលជាមនុស្សលោភ ។

**៥:១៣** *កើតអន្តរាយ* ក៏មានការខូចខាតអំពីទ្រព្យសម្បត្តិអ្នកដែរ ។

**៥:១៥** *ឥតយកអ្វីពី* មើល លក ១២:១៣-២១ ។

**៥:១៨-២០** មើលការពន្យល់ ២:២៤-២៥ ។

**៦:២-៣,៦** *សេចក្តីល្អ* ការប្រៀបធៀប ខ.២ និង ៥:៩ ក៏បង្ហាញថាសម្បត្តិភាពដើម្បីទទួលសេចក្តីអំណរ និងជាព្រះពររបស់ព្រះ គឺជាប្រាក់លើកទឹកចិត្ត ដែលជាអំណោយទានពីព្រះអម្ចាស់ គឺមិនមែនជាឯកសិទ្ធិ ឬការធានាឡើយ ។ ព្រះអម្ចាស់ត្រាស់ហៅអ្នកដែលភ្លេចពីសេចក្តីពិត គឺជាមនុស្សល្ងីល្ងើវិញ (លក ១២:២០) ។

**៦:២** *គឺមានអ្នកដទៃបរិភោគវិញ* ឧទាហរណ៍បើនៅពេលមនុស្សបានប្លន់នូវទ្រព្យរបស់ពួកគេឬស្លាប់ដោយពុំមានមរដក ។

**៦:៣** *ហើយឥតមានពិធីបញ្ចុះសពខ្លួនឯង* គឺជាសេចក្តីស្លាប់ដែលមិនគួរឱ្យសោកស្តាយឬអាមាស់ដូចជាព្រះមហាក្សត្រយ៉ូយ៉ាគីន (យរ ២២:១៨-១៩) ។

ស្កប់ចិត្តដោយសេចក្ដីល្អ ហើយឥតមានពិធីបញ្ចុះសពខ្លួន
ផង នោះយើងថា កូនដែលរលូតមកមុនកំណត់[គ]ក៏វិសេស
ជាងអ្នកនោះ[ឃ] [៤]ដ្បិតវាកើតមកជាឥតប្រយោជន៍ ហើយក៏
បាត់ទៅក្នុងសេចក្ដីងងឹត ឯឈ្មោះក៏គ្របបាំងដោយងងឹត
ដែរ [៥]១ទៀតវាមិនបានឃើញពន្លឺថ្ងៃ ឬដឹងអ្វីសោះ នេះឯង
បានសេចក្ដីស្រាកស្រាន្តជាងអ្នក១នោះ [៦]អើ ទោះបើអ្នក
នោះរស់នៅ១ពាន់ឆ្នាំ ឬថាទ្វេជា២ផង តែឥតដែលមាន
សេចក្ដីល្អសោះ នោះគង់តែទាំងអស់នឹងចុះទៅ ឯកន្លែងតែ
១ដែរទេតើ[ង]។

[៧]អស់ទាំងកិច្ចការរបស់មនុស្ស នោះសុទ្ធតែសំរាប់
មាត់ខ្លួនទេ បើទុកជាដូច្នោះ គង់តែមិនចេះឆ្អែតផង[ច] [៨]ដ្បិត
ឯមនុស្សមានប្រាជ្ញា តើមានអ្វីលើសជាងមនុស្សល្ងីល្ងើ
យ៉ាងណា[ឆ] ឬមនុស្សទាល់ក្រ តើមានអ្វីលើសជាងគេ បាន
ជាអាចដើរនៅចំពោះមនុស្សមានជីវិតរស់ដូច្នេះ [៩]ការ
ដែលមើលឃើញដោយភ្នែក នោះវិសេសជាងមានចិត្តប៉ង
សាវាវិញ នេះជាការឥតប្រយោជន៍ ហើយក៏អសារឥតការ
ដែរ[ជ]។

[១០]របស់អ្វីៗដែលមានស្រាប់ នោះបានមានឈ្មោះ[ឈ]
តាំងពីយូរមកហើយ ក៏មានដឹងជាមនុស្សបែបយ៉ាងណា
ដែរ ហើយគេពុំអាចនឹងតតាំងនឹងអ្នកដែលពូកែជាងខ្លួន
បានឡើយ [១១]មានសេចក្ដីជាច្រើនមុខ ដែលនាំឱ្យការ
ឥតប្រយោជន៍ចំរើនកើនឡើង ដូច្នេះ តើមនុស្សបានផល
ប្រយោជនបុអ្វីខ្លះ [១២]ដ្បិតតើមានអ្នកណាដឹងពីអ្វីៗដែលល្អ
សំរាប់ដល់មនុស្សក្នុងជីវិតនេះ គឺក្នុងអស់ទាំងថ្ងៃនៃអាយុ
ដ៏ឥតប្រយោជន៍[ញ] ដែលរស់នៅដូចជាស្រមោលនេះ[ដ] ដ្បិត
តើអ្នកណាអាចនឹងប្រាប់ដល់មនុស្សបាន អំពីអ្វីៗដែល
នឹងកើតមកក្រោយខ្លួននៅក្រោមថ្ងៃនេះ ។

**៦:៣** គ យប ៣:១៦ ឃ យប ៣:៣
**៦:៦** ង សស ២:១៤
**៦:៧** ច សភ ២៧:២០
**៦:៨** ឆ សស ២:១៤
**៦:៩** ច សស ១:១៤
**៦:១០** ឈ សស ៣:១៥
**៦:១២** ញ យប ១០:២០ ២០:៨ ដ ១របា ២៩:១៥ យប ១៤:២ ទដ ៣៩:៦
**៧:១** ក សភ ២២:១ ១:៣ ខ ១រប ២៩:១៥ យប ១៤:២ ទដ ៣៩:៦
**៧:២** គ សភ ១១:១៩ ឃ សស ២:១៤
**៧:៣** ង សភ ១៤:១៣
**៧:៤** ច សស ២:១ យរ ១៦:៨
**៧:៥** ឆ សភ ១៣:១៨ ១៥:៣១–៣២
**៧:៦** ច សភ ១៤:១៣ ឈ ទដ ៥៨:៩
**៧:៧** ញ នក ១៨:២១ ២៣:៨
**៧:៨** ដ សភ ១៤:២៩
**៧:៩** ឋ មថ ៥:២២ ឌ សភ ១៤:២៩
**៧:១០** ឍ ទដ ៧៧:៥
**៧:១១** ណ សស ២:១៣ ត សស ១១:៧

## ប្រាជ្ញា

**៧** [១]នាមឈ្មោះល្អ នោះវិសេសជាងប្រេងក្រអូបដ៏មាន
ដំឡៃ[ក] ហើយថ្ងៃមរណៈក៏វិសេសជាងថ្ងៃកើតដែរ[ខ] [២]ស៊ូទៅ
ឯផ្ទះដែលមានការកាន់ទុក្ខ ជាជាងទៅឯផ្ទះដែលមានការ
ជប់លៀង ដ្បិតមរណភាព[គ]ជាចុងបំផុត[ឃ]របស់មនុស្សទាំង
ឡាយ ហើយមនុស្សដែលនៅរស់ នឹងយកចិត្តទុកដាក់
ចំពោះសេចក្ដីនោះ [៣]សេចក្ដីសោយសោកមានប្រយោជន៍
ជាងសេចក្ដីសំណើច[ង] ដ្បិតទឹកមុខព្រួយរមែងបណ្ដាលឱ្យ
ចិត្តសប្បាយឡើង [៤]ដូច្នេះ ចិត្តរបស់មនុស្សមានប្រាជ្ញានោះ
តែងតែនៅក្នុងផ្ទះដែលមានការសោយសោក តែចិត្ត
របស់មនុស្សល្ងីល្ងើ តែងនៅក្នុងផ្ទះដែលមានការសប្បាយ
រីករាយវិញ[ច]។

[៥]ឯការដែលស្ដាប់ពាក្យបន្ទោស[ឆ]នៃមនុស្សមានប្រាជ្ញ
នោះវិសេសដល់មនុស្ស ជាជាងស្ដាប់បទចំរៀងរបស់ពួក
ល្ងីល្ងើ [៦]ដ្បិតសំណើច[ជ]របស់មនុស្សល្ងីល្ងើ នោះឮដូចជា
សូរគុកគីក ពីបន្លា[ឈ]ដែលឆេះក្រោមឆ្នាំង នេះក៏ជាការឥត
ប្រយោជន៍ទទេ [៧]ពិតប្រាកដជាការសង្កត់សង្កិនរមែង
បណ្ដាលឱ្យមនុស្សដែលមានប្រាជ្ញា ទៅជាក្រឡកចិត្តវិញ
ហើយសំណូក[ញ]ក៏បង្ខូចគំនិតផង ។

[៨]ការបង្ហើយអ្វីៗ នោះវិសេសជាងចាប់ផ្ដើមការទៅ
ទៀត ហើយដែលមានចិត្តអត់ធ្មត់[ដ] នោះវិសេសជាងមាន
ចិត្តអំនួតដែរ [៩]កុំឱ្យមានចិត្តរហ័សខឹងឡើយ[ឋ] ដ្បិតសេចក្ដី
កំហឹងរមែងនៅក្នុងទ្រូងរបស់មនុស្សល្ងីល្ងើទេ[ឌ] [១០]កុំឱ្យ
សួរថា ហេតុអ្វីបានជាសម័យជាន់មុន[ឍ]ល្អជាងសម័យសព្វ
ថ្ងៃនេះ ដ្បិតដែលសួរដូច្នេះ នោះមិនមែនដោយប្រាជ្ញាទេ។

[១១]ឯប្រាជ្ញានោះល្អស្មើនឹងមរដក អើ ក៏វិសេសជាង[ណ]
ដល់ពួកអ្នកដែលឃើញពន្លឺថ្ងៃផង[ត] [១២]ដ្បិតប្រាជ្ញាជាគ្រឿង

---

*កូនដែលរលូតមកមុនកំណត់* ចំពោះអ្នកកាន់លទ្ធិផ្សេងៗ គឺជាជីវិតដែលជាការធ្វើដំណើរពុំមានន័យ ទៅរកភាពវិសនាស ដែលរលូតមុនពេលកំណត់ គឺហាក់ដូចជាវារហ័សនឹងងាយស្រួលបំផុត (ប្រៀបធៀប យប ៣:១៦ ទដ ៥៨:៨) ។

**៦:៦** *ឯកន្លែងតែ១* ក៏នៅតែនិយាយពីពាក្យដែលយើងសង្កេតថា (គ្រប់មនុស្សត្រូវស្លាប់) (មើល ខ.១២ ៣:២១) ។

**៦:៧–១២** គឺការប្រឈរនឹងទទួលដោយរីករាយ គ្រូប្រដៅក៏ឱ្យនូវហេតុផលជាច្រើន នៅអ្វីដែលទាក់ទង គឺជាជីវិតដ៏ខ្លី (ខ.៧) ។

**៦:៩** វាប្រសើរណាស់ក្នុងការទទួលនូវអ្វីដែលអ្នកណាម្នាក់មាន គឺជាសេចក្ដីប៉ងប្រាថ្នាដែលពុំអាចឃើញ ឬយកបាន(ប្រៀបធៀប ៤:១១–១២ និងការពន្យល់ ៤:១២ ១ធម ៦:៦,៨) ។

**៦:១០** *បានមានឈ្មោះ* គឺការកំណត់ជាមុនដោយព្រះអម្ចាស់ ។ *បានដឹង* គឺទ្រង់ជ្រាបគ្រប់ការទាំងអស់ ។ *អ្នកដែលពូកែជាងខ្លួន* ព្រះជាអម្ចាស់ ។

**៦:១២** *ដូចជាស្រមោលនោះ* សូមមើល យប ៨:៩ និងការពន្យល់ ។

**៧:១** *ថ្ងៃមរណៈក៏វិសេសជាង* គ្រីស្ទបរិស័ទក៏មានហេតុផលគ្រប់គ្រាន់ក្នុងការនិយាយពីការងារនេះ (២កថ ៥:១–១០ កល ១:២១–២៣) ។ ប៉ុន្តែចំណុចរបស់គ្រូប្រដៅ គឺមានសុពលភាពដូចជាបានពន្យល់ក្នុង ខ.២–៦ ហើយក៏បានបង្រៀនយើងផងដែរ ។

**៧:៦** *សូរគុកគីកពីបន្លា* "គឺជាសំណើចរបស់មនុស្សល្ងីល្ងើ" ក៏ដូចជាភ្លើងដែលឆេះមួយភ្លែត(មើល ទដ ៥៨:៩ និង ការពន្យល់) ។

**៧:៧** *សំណូក* មើល មថ ២៨:១១–១៥ លក ២២:៤–៦ ។

**៧:៩** *កំហឹង* (មើល ឧទាហរណ៍ សភ ១៦:៣២ ១៧:១៤ ១កថ ១៣:៤–៥) ។

**៧:១១** *ឃើញពន្លឺថ្ងៃ* គឺដូចជាមានជីវិត ។

**៧:១២** *ថែរក្សាជីវិត* ភាសាហេព្រើរចំពោះសំនួនវោហាស័ព្ទនេះក៏អាចមាន

ការពារខ្លួន ដូចជាប្រាក់ជាគ្រឿងការពារខ្លួនដែរ ប៉ុន្តែ
ការដែលវិសេសជាងខាងចំណេះគឺ ថាប្រាជ្ញារមែងតែ
រក្សាជីវិតរបស់ពួកអ្នកប្រាជ្ញឱ្យគង់នៅ ១៣ចូរពិចារណា
ស្នាដៃរបស់ព្រះ[ថ] ដ្បិតរបស់អ្វីដែលទ្រង់បានធ្វើឱ្យក្ងិកក្ងក់
នោះតើអ្នកណាអាចនឹងធ្វើឱ្យត្រង់វិញបាន[ទ] ១៤នៅគ្រា
ដែលមានសេចក្តីចំរើន នោះចូរឱ្យមានចិត្តអរសប្បាយចុះ
ហើយនៅគ្រាក្រក្រី នោះចូរពិចារណាវិញ អើ ព្រះទ្រង់
បានដាក់ទាំង២នោះនៅទន្ទឹមគ្នា[ធ] ប្រយោជន៍ឱ្យមនុស្ស
ស្វែងរកឱ្យយល់មិនបានចំពោះការដែលកើតមកខាង
ក្រោយ ។

១៥ក្នុងអាយុឥតប្រយោជន៍របស់យើង[ន] នោះយើងបាន
ឃើញសេចក្តីទាំងនេះ គឺថាមានមនុស្សសុចរិតដែលវិនាស
ទៅក្នុងសេចក្តីសុចរិតរបស់ខ្លួន ហើយក៏មានមនុស្សអាក្រក់
ដែលមានជីវិតចំរើននៅយូរ ក្នុងអំពើអាក្រក់របស់ខ្លួន
ដែរ[ប] ១៦ដូច្នេះ កុំឱ្យប្រព្រឹត្តជាមនុស្សសុចរិតហួសល្បត់
ឡើយ ក៏កុំឱ្យធ្វើខ្លួនឱ្យមានប្រាជ្ញាលើសលន់ដែរ តើចង់
បំផ្លាញខ្លួនធ្វើអី ១៧ម្យ៉ាងទៀត កុំឱ្យប្រព្រឹត្តអាក្រក់ហួសល្បត់
ក៏កុំឱ្យល្ងីល្ងើពេកដែរ ឯងចង់ស្លាប់មុនកំណត់ធ្វើអ្វី[ផ] ១៨ល្អ
ណាស់ហើយ បើឯងចាប់យកសេចក្តី១នេះហើយកុំឱ្យដក
ដៃពីសេចក្តី១នោះផង ដ្បិតអ្នកណាដែលកោតខ្លាចដល់
ព្រះ[ព] នឹងចៀសរួចពីសេចក្តីទាំងនេះបាន ។

១៩ប្រាជ្ញា[ភ]រមែងជាកំឡាំង[ម]ដល់មនុស្សប្រាជ្ញ ជាជាង
អ្នកគ្រប់គ្រង១០នាក់ដែលនៅក្នុងទីក្រុង១ ២០ពិតប្រាកដ
ជាគ្មានមនុស្សសុចរិតណា[យ]នៅផែនដី ដែលប្រព្រឹត្តសុទ្ធតែ
ល្អឥតធ្វើបាបឡើយនោះទេ[រ] ២១១ទៀតកុំឱ្យយកចិត្តទុកដាក់
ចំពោះពាក្យទាំងអស់ដែលគេពោលឡើយ ក្រែងឯង[ល]ឮ
បាវបំរើជេរដល់ឯង ២២ដ្បិតចិត្តឯងក៏ដឹងហើយថា ឯង
បានជេរគេដូច្នេះជាច្រើនដងដែរ ។

២៣យើងបានលមើល ឱ្យដឹងសេចក្តីទាំងនេះច្បាស់
ដោយប្រាជ្ញាហើយ យើងបានសំរេចថា យើងនឹងបាន
ប្រាជ្ញា[វ] ប៉ុន្តែប្រាជ្ញាបាននៅឆ្ងាយពីយើងទេ ២៤ប្រាជ្ញាដែល
មានទាំងប៉ុន្មាន នោះនៅឆ្ងាយ ហើយក៏ជ្រៅណាស់ផង តើ
អ្នកណាអាចនឹងស្ទង់យល់បាន[ស] ២៥ដូច្នេះ យើងក៏វិលមកផ្ចង់
ចិត្តឱ្យបានដឹង ឱ្យស្ទះស្វែង ហើយស្ទួរកប្រាជ្ញា នឹងហេតុ
ការផ្សេងៗ ហើយឱ្យបានដឹងថា អំពើអាក្រក់ ជាសេចក្តីល្ងី
ល្ងើ[ហ] ហើយថា សេចក្តីល្ងីល្ងើនោះជាសេចក្តីចំកួតផង[ឡ]
២៦យើងក៏បានឃើញថា ស្ត្រីដែលមានចិត្ត ជាអន្ទាក់ជាលប់[អ]
ហើយដែលដៃជាចំណងផង នាងនោះជាទី ជូរចត់ជាង
សេចក្តីស្លាប់ទៅទៀត អ្នកណាដែលគាប់ដល់ព្រះហឫទ័យ
នៃព្រះនឹងបានគេចរួចពីស្ត្រីនោះ តែមនុស្សមានបាបនឹង
ត្រូវវាចាប់បានវិញ[ក] ២៧ឯគ្រូប្រដៅ[ខ] លោកមានប្រសាសន៍
ថា មើល ឯសេចក្តីនោះ យើងបានស្វែងរក ឃើញហើយ
ដោយបូករួមសេចក្តីនេះ១នោះ១ ដើម្បីឱ្យបានដឹងហេតុ
២៨ក៏មានសេចក្តីនេះទៀត ដែលចិត្តយើង កំពុងតែរក តែ
មិនទាន់ឃើញនៅឡើយ ក្នុង១ពាន់នាក់ យើងរកបានប្រុស
ពិតតែម្នាក់ទេ តែក្នុងពួកអ្នកទាំងនោះ យើងរកស្រីពិត[គ]
តែ១ក៏មិនបានផង ២៩មើលយើងឃើញតែប៉ុណ្ណោះ គឺថា
ព្រះទ្រង់បានបង្កើតមនុស្សមកជាទៀងត្រង់ ប៉ុន្តែគេបាន
ស្វែងរកបង្កើតការអាក្រក់ជាច្រើនវិញ ។

**៧:១៣** ថ សស ២:២៤ ទ សស ១:១៥
**៧:១៤** ធ យប ១:២១ សស ២:២៤
**៧:១៥** ន យប ៧:៧ ប យប ២១:៧ សស ៨:១២–១៤ យរ ១២:១
**៧:១៧** ផ យប ១៥:៣២
**៧:១៨** ព សស ៣:១៤
**៧:១៩** ភ សស ២:១៣ ម សភ ៨:១៤
**៧:២០** យ ទដ ១៤:៣ រ ២របា ៦:៣៦ យប ៤:១៧ សភ ២០:៩ រម ៣:១២
**៧:២១** ល សភ ៣០:១០
**៧:២៣** វ សស ១:១៧
**៧:២៤** ស យប ២៨:៣
**៧:២៥** ហ យប ២៨:៣ ឡ សស ១:១៧
**៧:២៦** អ នក ១០:៧ ពច ១៤:១៥ ក សភ ២:១៦–១៩ ៥:៣–៥ ៧:២៣ ២២:១៤
**៧:២៧** ខ សស ១:១ **៧:២៨** គ ១ពរ ១១:៣

ន័យថា"ថ្វាយជីវិត"ឬក៏ធ្វើឱ្យជីវិត"មានជាថ្មី" (សូមមើល សភ ៣:១៣–១៨ ១៣:១៤) ។

**៧:១៣** *អ្នកអាចធ្វើឱ្យត្រង់បាន* វាមិនមែនជាកម្មវាសនាទេ តែវាជាការរំលឹកពីសេចក្តីស្លាប់ដែលពុំអាចផ្លាស់ប្តូរបានឡើយ នូវអ្វីដែលព្រះបានកំណត់ (មើលការពន្យល់ ១:១៥ ប្រៀបធៀប ៣:១–២២) ។

**៧:១៤** ព្រះទ្រង់បង្កើតឱ្យមានទាំងពេលអាក្រក់ ក៏បង្កើតឱ្យមានទាំងពេលល្អ ប្រៀបធៀប រម ៨:២៨–២៩ ។

**៧:១៥** *មនុស្សសុចរិតដែលវិនាស* ភាពសុចរិតមិនប្រាកដថាអាចជៀសផុតពីការលំបាក ឬសេចក្តីស្លាប់ ។

**៧:១៦** *កុំឱ្យប្រព្រឹត្តជាមនុស្សសុចរិតហួសល្បត់ឡើយ* ការមានប្រាជ្ញាដែលមិនពិតប្រាកដ នោះពុំអាចជួយអ្វីបានឡើយ ។

**៧:១៧** *កុំឱ្យប្រព្រឹត្តហួសល្បត់* គឺជាអំពើអាក្រក់ដ៏ខ្លាំងជួរជាតិ ។

**៧:១៨** *សេចក្តី១នេះ . . . សេចក្តី១នោះផង* គឺមនុស្សកោតខ្លាចព្រះត្រូវជៀសវាងទាំងពីរករណី (ដែលស្របច្បាប់នឹងភាពគ្មានសីលធម៌)ក៏ជាការណែនាំមកនូវតុល្យភាព នៃភាពសុចរិត និងប្រាជ្ញា–ជីវិតរស់នៅបាន (មើល របា ៦:១៤) ។

**៧:២០** *ពិតប្រាកដជាគ្មានមនុស្សសុចរិតណានៅផែនដី* (មើល រម ៣:១០–២០,២៣) ។

**៧:២៦** មើល ទដ ៧:៦–២៧ ។

**៧:២៧** *គ្រូប្រដៅ* សូមមើលការពន្យល់ ១:១ ។ *ដោយបូករួមសេចក្តីទាំងនេះ១នោះ១ដើម្បីឱ្យបានដឹងហេតុ* ចំពោះវិធីសាស្ត្រដែលបានចង្អុលបង្ហាញឱ្យយើងឃើញនោះ គឺពុំមានលក្ខណៈច្បាស់លាស់ចប់សព្វគ្រប់ឡើយ ឬក៏យើងអាចបង្ហាញពីការបកស្រាយយ៉ាងសមរម្យ គឺតាមគ្រប់សកម្មភាពនៃការសើបអង្កេតរបស់យើង (៣:១១) ។ ប្រាជ្ញារបស់មនុស្ស និងការយល់តែងតែទទួលបាន ឬក៏បង្ហាញពីសេចក្តីពិត ។

**៧:២៨** *ប្រុសពិតតែម្នាក់ទេ . . . រកស្រីពិតតែ១ក៏មិនបាន* តាមរយៈបទពិសោធន៍របស់គ្រូប្រដៅ ក៏គ្មានកន្លែងណាមួយដែលបង្ហាញថាតាមធម្មតាស្ត្រីៗតែងតែរំខាន ។

**៧:២៩** *ព្រះបានបង្កើតមនុស្សមកទៀងត្រង់ ប៉ុន្តែគេបានស្វែងរកការអាក្រក់ជាច្រើនវិញ* មើល លប ៣:១–៦ រម ៥:១២ ។

៨ ១តើមានអ្នកណាដូចអ្នកប្រាជ្ញ តើអ្នកណាចេះកាត់ស្រាយ
ន័យសេចក្ដីអ្វីៗ ប្រាជ្ញារបស់មនុស្សរមែងធ្វើឱ្យទឹកមុខគេ
ផូរផង់ឡើង ហើយទឹកមុខរឹងរបស់គេក៏ផ្លាស់ប្រែទៅ ។

## ស្ដាប់បង្គាប់ស្ដេច

២យើងសូមរំឭកថា ចូរប្រព្រឹត្តតាមបង្គាប់នៃស្ដេចចុះ
នោះ គឺដោយយល់ដល់សម្បថ ដែលខ្លួនបានស្បថដល់ព្រះ
ផង ៣កុំឱ្យប្រញាប់នឹងថយចេញពីចំពោះស្ដេចឡើយ[ក] ក៏
កុំឱ្យស្ថិតចិត្តក្នុងអំពើអាក្រក់ណាដែរ ដ្បិតស្ដេចទ្រង់ធ្វើ
តាមតែព្រះទ័យទ្រង់ ៤ពីព្រោះព្រះបន្ទូលនៃស្ដេចមានឫទ្ធិ
អំណាច តើមានអ្នកណាហ៊ានទូលដល់ទ្រង់ថា តើទ្រង់ធ្វើអ្វី
នោះ[ខ] ៥អ្នកណាដែលប្រព្រឹត្តតាមបញ្ញត្តច្បាប់ នោះនឹងមិន
ស្គាល់ការអាក្រក់ណាឡើយ ១ទៀតចិត្តរបស់មនុស្សមាន
ប្រាជ្ញា រមែងយល់ពេលដែលស្រួលនឹងសេចក្ដីវិនិច្ឆ័យ ៦ក៏
មានពេលវេលា និងសេចក្ដីវិនិច្ឆ័យ សំរាប់គ្រប់ការទាំង
អស់[គ] ពីព្រោះសេចក្ដីអាក្រក់របស់មនុស្សតែងតែសង្កត់លើ
ខ្លួនគេជាធ្ងន់ ៧ដ្បិតគេមិនដឹងជានឹងកើតមានអ្វីទេ តើអ្នក
ណា នឹងប្រាប់ឱ្យគេដឹងជានឹងកើតមានអ្វីបាន ៨គ្មានអ្នកណា
មានអំណាចត្រួតលើវិញ្ញាណ ដើម្បីនឹងឃាត់វិញ្ញាណបាន
ទេ ក៏គ្មានអ្នកណាមានអំណាចលើថ្ងៃមរណៈដែរ គ្មាន
ផ្លូវនឹងគេចរួចចេញពីចំបាំងទេ ហើយសេចក្ដីអាក្រក់ក៏មិន
ជួយឱ្យអ្នកណា ដែលប្រគល់ខ្លួនទៅឱ្យប្រព្រឹត្តតាម បាន
រួចដែរ ។
៩បណ្ដាការទាំងនេះយើងបានឃើញអស់ហើយ ក៏បាន
ផ្ចង់ចិត្តចំពោះគ្រប់ទាំងការដែលកើតមាននៅក្រោមថ្ងៃ
មានគ្រាដែលមនុស្សម្នាក់ មានអំណាចលើម្នាក់ទៀត ឱ្យ
គេត្រូវវេទនា ១០តាមដំណើរនោះ យើងបានឃើញគេហែ
ខ្មោចមនុស្សអាក្រក់ទៅកប់[ឃ]តែចំណែកពួកអ្នកត្រឹមត្រូវវិញ
គេបាត់ចេញពីទីបរិសុទ្ធ ហើយមនុស្សនៅក្នុងទីក្រុងក៏ភ្លេច
គេទៅ នេះក៏ជាការឥតមានទំនងដែរ ១១ចិត្តរបស់ពួក
មនុស្សជាតិបានផ្ចាច់ទៅ ឱ្យប្រព្រឹត្តតាមអំពើអាក្រក់ជានិច្ច
ដោយព្រោះតែការធ្វើទោស ចំពោះអំពើអាក្រក់ មិនបាន
សំរេចជាយ៉ាងឆាប់ ១២ទោះបើមនុស្សមានបាបប្រព្រឹត្ត
អំពើអាក្រក់ដល់ទៅ១០០ដង ហើយចំរើនអាយុយឺនយូរ
ក៏ដោយ គង់តែយើងដឹងថា ពួកអ្នកដែលកោតខ្លាចដល់
ព្រះ[ង] គឺដែលកោតខ្លាចនៅចំពោះទ្រង់[ច] គេនឹងមានសេចក្ដី
សុខស្រួលវិញ[ឆ] ១៣តែមិនបានសេចក្ដីសុខស្រួល ដល់
មនុស្សអាក្រក់ទេ ឯអាយុគេ[ជ] ដែលធៀបដូចជាស្រមោល
នោះក៏មិនបានយឺនយូរដែរ ពីព្រោះគេមិនកោតខ្លាចដល់
ព្រះឡើយ[ឈ]។
១៤មានការឥតមានទំនងម្យ៉ាង ដែលតែងតែមាននៅ
ផែនដី គឺមានមនុស្សសុចរិតដែលទទួលសំណងតាមអំពើ
របស់មនុស្សអាក្រក់វិញ១ទៀត មានមនុស្សអាក្រក់ដែល
ទទួលសំណងតាមអំពើរបស់មនុស្សសុចរិតដែរ[ញ] យើងថា
សេចក្ដីនោះជាការឥតមានទំនងសោះ[ដ] ១៥រួចយើងបាន
និយមខាងសេចក្ដីសប្បាយ[ឋ] ពីព្រោះនៅក្រោមថ្ងៃ មនុស្ស
ឥតមានអ្វីល្អជាងការស៊ីផឹក[ឌ] ហើយមានចិត្តរីករាយនោះ
ទេ[ឍ] ដ្បិតមានតែការប៉ុណ្ណោះ ជាផលពីការនឿយហត់របស់
ខ្លួន ដែលនឹងនៅជាប់រាល់តែថ្ងៃអស់១ជីវិតខ្លួន ដែលព្រះ

**៨:៣** ក សស ១០:៤
**៨:៤** ខ នរអ ១:១៩
**៨:៦** គ សស ៣:១
**៨:១០** ឃ សស ១:១១
**៨:១២** ង នក ១:២០ ច សស ៣:១៤ ឆ ចទ ១២:២៨
**៨:១៣** ជ ចទ ៤:៤០ យប ៥:២៦ ទដ ៣៤:១២ អស ៦៥:២០ ឈ សស ៣:១៤
**៨:១៤** ញ យប ២១:៧ ដ សស ៧:១៥
**៨:១៥** ឋ ទដ ៤២:៨ ឌ នក ៣២:៦ សស ២:៣ ឍ សស ២:១

**៨:២** *បង្គាប់នៃស្ដេច* ជាគោលការពីរ (ខ.២) និងមានជាការប្រុងប្រយ័ត្ន (ខ.៣-៤) កំណត់ពីសេរីភាពរបស់យើង ។ *បានស្បថ* ដែលបង្ហាញភាពស្មោះត្រង់ចំពោះព្រះមហាក្សត្រ(ដូចបានឃើញក្នុង ១រប ២៩:២៤) ។
**៨:៣** *កុំឱ្យប្រញាប់នឹងថយចេញពីចំពោះស្ដេចឡើយ* គឺបង្ហាញពីភាពគ្មានការគោរព ក៏ដូចជាកាពុំស្ដាប់បង្គាប់ដល់ទ្រង់ ។
**៨:៤** *តើមានអ្នកណាហ៊ានទូលដល់ទ្រង់ថា តើទ្រង់ធ្វើអ្វីនោះ* ប្រៀបធៀប អស ៤៥:៩ រម ៩:២០ ។
**៨:៥** *អ្នកណាដែលប្រព្រឹត្តតាមបញ្ញត្តិច្បាប់ នោះនឹងមិនស្គាល់ការអាក្រក់ណាឡើយ* មើល រប ១៣:៣-៥ និងការពន្យល់ ។
**៨:៦** *ពីព្រោះសេចក្ដីអាក្រក់របស់មនុស្ស* មនុស្សគួរតែដាក់បញ្ញត្តិច្បាប់ឱ្យហួសពីសេចក្ដីវេទនារបស់ពួកគេ ។
**៨:៧-៨** *ដ្បិតគេមិនដឹងជា . . . គ្មានអ្នកណាមានអំណាច* មើល ទដ ៣១:១៥ ២កថ ៥:១-១០ យក ៤:១៣-១៦ ។
**៨:៨** *ហើយសេចក្ដីអាក្រក់ក៏មិនជួយឱ្យអ្នកណា ដែលប្រគល់ខ្លួនទៅប្រព្រឹត្តតាម* គឺសីលធម៌អាក្រក់មានអំណាចយ៉ាងខ្លាំង ដើម្បីឱ្យមនុស្សបម្រើជាទាសកររបស់វា ។ (មើល រម ៧:១៥-២៤ និងការពន្យល់ ៧:៧)តែសូមមើល រម ៧:២៥ និងការពន្យល់ ។
**៨:១០** *ឃើញគេហែខ្មោចមនុស្សអាក្រក់ទៅកប់* ក្នុងអត្ថបទនេះលាតត្រដាងនៅការគោរពមិនទំនង ឬខុសឆ្គង (មើលការពន្យល់ ៦:៨ ប្រៀបធៀប យប ២១:២៨-៣៣ លក ១៦:២២) ។
**៨:១១** *ពន្យា ឬខកពីការដាក់ទោស* ហើយក៏ទោរទន់លំអៀងទៅឯខាងការប្រព្រឹត្តអាក្រក់កាន់តែខ្លាំងឡើងៗ ។
**៨:១២** *យើងដឹងថា* ក្នុងនេះគឺពាក្យគ្រូប្រដៅ កំពុងនិយាយពីសេចក្ដីជំនឿ ដ៏រឹងមាំដែលមានតែម្នាក់"ការខំស្វែងរកតែពុំបានជួបប្រទះ" (សូមមើល ៧:២៨) ។ ដូចមានសេចក្ដីប្រកាសស្រដៀងៗគ្នានេះដែរ មើល ៣:១៧ ១១:៩ ១២:១៤ ។
**៨:១៤** យប ២១-២៤ ក៏បានលាតត្រដាងពីការនេះនៅក្នុង ទដ ៨៣ និង យហ ៥:២៨-២៩ ក៏ផ្ដល់នូវការពន្យល់ចុងក្រោយ ។
**៨:១៥** *ការស៊ីផឹក . . . មានចិត្តរីករាយ* (មើល ៥:១៩ ៩:៧ ចទ ៨) គឺចំពោះពាក្យបាននិយាយភាពអួតអាង មើល លក ១២:១៩-២០ ១កថ ១៥:៣២ ។

ទ្រង់បានប្រទានឱ្យរស់នៅក្រោមថ្ងៃ ។
១៦កាលយើងបានផ្ចង់ចិត្តឱ្យស្គាល់ប្រាជ្ញា[ណ] ហើយនឹង
ពិចារណាពីអស់ទាំងការដែលកើតមាននៅផែនដី[ត] ឃើញ
ថា មានមនុស្សដែលមិនចេះដេកលក់ ទោះទាំងយប់ឬថ្ងៃ
ផង ១៧នោះយើងបានយល់ពីការរបស់ព្រះ[ថ]ថា មនុស្ស
នឹងស្វែងរកឱ្យដឹងពីអស់ទាំងការ ដែលកើតមាននៅក្រោម
ថ្ងៃមិនបាន ដ្បិតទោះបើខំប្រឹងស្វែងរកយ៉ាងណា គង់តែ
មិនដែលប្រទះយល់ដែរ ហើយទោះបើមានមនុស្សប្រាជ្ញ
ណាស្មានថានឹងរកស្គាល់បាន ក៏គង់តែមិនអាចនឹងយល់
បានដែរ[ទ]។

## ទីបញ្ចប់នៃមនុស្សគ្រប់គ្នា

**៩** ១អើ គ្រប់សេចក្តីទាំងនេះ យើងបានពិចារណានៅ
ក្នុងចិត្ត ដើម្បីឱ្យបានយល់ច្បាស់ នោះឃើញថា មនុស្ស
សុចរិត និងមនុស្សប្រាជ្ញ ព្រមទាំងកិច្ចការរបស់គេទាំង
ប៉ុន្មាន សុទ្ធតែនៅក្នុងអំណាចព្រះហស្តនៃព្រះ ទោះបើ
ការនោះមក ដោយសេចក្តីស្រឡាញ់ ឬសេចក្តីសំអប់ក្តី
នោះមនុស្សមិនយល់ទេ ប៉ុន្តែទាំងអស់ក៏ច្បាស់នៅចំពោះ
មុខគេ[ក] ២គ្រប់ទាំងអស់កើតដល់មនុស្សទាំងអស់ដូចគ្នា
មានការតែ១មុខកើតដល់ទាំងមនុស្សសុចរិត នឹងមនុស្ស
ទុច្ចរិត មនុស្សល្អ មនុស្សស្អាត និងមនុស្សដែលមិនស្អាត
ហើយមនុស្សដែលថ្វាយយញ្ញបូជា និងមនុស្សដែលមិន
ថ្វាយផង គឺមនុស្សល្អយ៉ាងណា មនុស្សមានបាបក៏យ៉ាង
នោះដែរ ហើយអ្នកណាដែលហ៊ានផ្តាសាដល់ខ្លួន ក៏ដូច
ជាអ្នកដែលខ្លាចពាក្យផ្តាសាដែរ[ខ] ៣នេះជាការអាក្រក់១
ក្នុងអស់ទាំងការដែលកើតមកនៅក្រោមថ្ងៃ គឺដែលមាន
សេចក្តីតែ១ដដែល កើតដល់មនុស្សទាំងអស់[គ] អើ ចិត្តនៃ
មនុស្សជាតិក៏ពេញដោយសេចក្តីអាក្រក់ហើយក៏មានសេចក្តី
ចំកួតក្នុងចិត្ត អស់ពេលដែលរស់នៅ[ឃ] ក្រោយនោះក៏ទៅឯ
ពួកមនុស្សស្លាប់[ង] ៤ដ្បិតមានសេចក្តីសង្ឃឹម ចំពោះអ្នកណា
ដែលនៅជាប់ក្នុងពួកមនុស្សរស់នៅឡើយ ពីព្រោះថា សូម្បី
តែឆ្កែរស់ គង់វិសេសជាងសិង្ហស្លាប់ដែរ ៥ដ្បិតមនុស្ស
ដែលរស់ គេដឹងថាខ្លួននឹងស្លាប់ជាមិនខាន តែមនុស្ស
ស្លាប់ឥតដឹងអ្វីឡើយ[ច] គេក៏គ្មានរង្វាន់អ្វីទៀតដែរ ពីព្រោះ
សេចក្តីនឹកចាំពីគេ[ឆ]បានសូន្យបាត់ហើយ[ជ] ៦ទោះទាំងសេចក្តី
ស្រឡាញ់សេចក្តីសំអប់ និងសេចក្តីឈ្នានីសរបស់គេក៏
វិនាសសូន បាត់ជាយូរមកហើយ គេក៏ឥតមានចំណែកណា
ក្នុងការអ្វីដែលធ្វើនៅក្រោមថ្ងៃជាដរាបតទៅមុខដែរ[ឈ]។
៧ដូច្នេះ ចូរទៅចុះ ឱ្យបរិភោគអាហាររបស់ឯងដោយ
អំណរ ហើយផឹកស្រាទំពាំងបាយជូររបស់ឯង[ញ]ដោយចិត្ត
រីករាយផង[ដ] ដ្បិតព្រះទ្រង់បានទទួលការរបស់ឯងហើយ
៨ចូរឱ្យសំលៀកបំពាក់របស់ឯងបានសនៅជានិច្ច[ឋ] ហើយ
កុំឱ្យខានមានប្រេង នៅលើក្បាលឯងដែរ ៩ចូររស់នៅ
ដោយអំណរ ជាមួយនឹងប្រពន្ធជាទីស្រឡាញ់របស់ឯង[ឌ]
ដរាបពេល ដែលឯងរស់នៅក្នុងជីវិតដ៏ឥតប្រយោជន៍នេះ
ដែលទ្រង់បានប្រទានមកឯងនៅក្រោមថ្ងៃចុះ គឺគ្រប់មួយ
អាយុឥតប្រយោជន៍របស់ឯង ដ្បិតនោះហើយជាចំណែក
របស់ឯង[ឍ] នៅក្នុងជីវិតនេះ ហើយក្នុងការនឿយហត់ដែល
ឯងខំធ្វើនៅក្រោមថ្ងៃផង ១០ការអ្វី[ណ]ដែលដៃឯងអាចធ្វើ
បាន នោះចូរធ្វើដោយអស់ពីកំឡាំងចុះ[ត] ដ្បិតនៅក្នុងស្ថាន
ឃុំព្រលឹងមនុស្សស្លាប់[ថ] ជាកន្លែងដែលឯងត្រូវនៅ នោះ
គ្មានការធ្វើ គ្មានការគិតគូរ គ្មានដំរិះ ឬប្រាជ្ញាឡើយ[ទ]។
១១យើងក៏វិលមកមើលនៅក្រោមថ្ងៃ ឃើញថា ការរត់
ប្រណាំងមិនសំរេចនឹងមនុស្សដែលរត់លឿនការចំបាំងក៏
មិនសំរេចនឹងមនុស្សដែលមានកំឡាំងដែរ[ធ] ឯនំបុ័ង មិន
សំរេចនឹងមនុស្សមានប្រាជ្ញា[ន] ឬទ្រព្យសម្បត្តិនឹងមនុស្សមាន
យោបល់ ឬគុណនឹងមនុស្សស្ទាត់ជំនាញនោះដែរ គ្រប់

**៨:១៦** ណ សស ១:១៧ ត សស ១:១៣
**៨:១៧** ថ យប ២៨:៣ ទ យប ២៨:២៣ រម ១១:៣៣
**៩:១** ក សស ១០:១៤
**៩:២** ខ យប ៩:២២ សស ២:១៤
**៩:៣** គ យប ៩:២២ សស ២:១៤ ឃ យរ ១១:៨ ១៣:១០ ១៦:១២ ១៧:៩ ង យប ២១:២៦
**៩:៥** ច យប ១៤:២១ ឆ ទដ ៩:៦ ជ សស ១:១១
**៩:៦** ឈ យប ២១:២១
**៩:៧** ញ ជន ៦:២០ ដ សស ២:២៤
**៩:៨** ឋ វវ ៣:៤
**៩:៩** ឌ សភ ៥:១៨ ឍ យប ៣១:២
**៩:១០** ណ ១សយ ១០:៧ ត សស ១១:៦ ថ ជន ១៦:៣៣ ទដ ៦:៥ អស ៣៨:១៨ ទ សស ២:២៤
**៩:១១** ធ អម ២:១៤–១៥ ន យប ៣២:១៣ អស ៤៧:១០ យរ ៩:២៣

**៨:១៧** *ក៏គង់តែមិនអាចយល់បានដែរ* ចទ ២៩:២៩ ក៏សង្ខេបនូវអ្វីដែលពុំអនុញ្ញាត្តឱ្យដឹង និងអ្វីដែលអាចឱ្យដឹងបាន (ប្រៀបធៀប រម ១១:៣៣) ។

**៩:១** *ទោះបីការនោះមក ដោយសេចក្តីស្រឡាញ់ ឬសេចក្តីអំណរក្តី* ដោយនៅថ្ងៃអនាគតគឺស្ថិតក្រោមការគ្រប់គ្រងពីព្រះ និងគ្មានអ្នកណាដឹងថាតើនាពេលអនាគត វាទៅជាអាក្រក់ ឬល្អនោះ ។

**៩:២** *កើតដល់មនុស្សទាំងអស់ដូចគ្នា* មិនគ្រាន់តែមនុស្សមានប្រាជ្ញានោះទេ ក៏ឆ្កួតល្ងង់ផងដែរ (២:១៤) តែមានការល្អ និងការអាក្រក់ គឺហាក់ដូចជាមានកំរិត ។ គឺក្នុងអត្ថន័យក្នុងការកំណត់សំគាល់ ៣:២០ ។ គឺចំពោះការផ្លាស់ប្រែរបស់គ្រូប្រដៅ (ដែលហួសពីការស្មាន) ដែលព្រះនឹងកាត់ទោសនៅគ្រាចុងក្រោយ ៨:១២ ។

**៩:៣** *ការអាក្រក់ . . . សេចក្តីអាក្រក់* គឺជានិស្ស័យវាសនាធម្មតារបស់មនុស្សដែលបង្ហាញឱ្យឃើញ (គឺមានទាំងភាពសុចរិត និងសេចក្តីស្លាប់ខាងឯការអាក្រក់) ដែលបានជំរុញឱ្យមនុស្សខ្លះប្រព្រឹត្តអំពើបាបនោះ ។

**៩:៥** *គេក៏គ្មានអ្វីទៀតដែរ* សេចក្តីស្លាប់មុនបាត់បង់ឱកាសទាំងអស់ក្នុងឆាកជីវិត គឺសេចក្តីសប្បាយនឹងរង្វាន់ពីពលកម្មរបស់ពួកគេ (មើល ខ.៦) ។

**៩:៧–៩** ពួកអ្នកបាប៉ុឡូនដែលបង្ហាញក្នុងផ្នែកនេះ (១០,៣០,៦–១៤) ក៏មានអត្ថបទគួឱ្យសំគាល់មួយទៀតដែលស្រដៀងគ្នា ។

**៩:៨** *ចូរឱ្យសំលៀកបំពាក់របស់ឯងបានសនៅជានិច្ច . . . ប្រេងនៅលើក្បាលឯងដែរ* គឺការបញ្ជាក់ពីសេចក្តីអំណរ ។

**៩:១០** ប្រៀបធៀប កល ៣:២៣ ។

**៩:១១** *នៅពេលវេលានឹងឱកាសវិញ* គឺជាពេលទទួលជោគជ័យ ដែលបានមកពីភាពមិនប្រាកដដែលបានទទួលមកតាមរយៈ ព្រឹត្តិការដែលមនុស្សមិន

ទាំងអស់ស្រេចនៅពេលវេលា និងឱកាសវិញ[ប] ១២ពីព្រោះ
មនុស្សក៏មិនដឹងពេលកំណត់របស់ខ្លួនដែរ ឧបមាដូចជាត្រី
ដែលជាប់នៅក្នុងសំណាញ់ដ៏អាក្រក់ ហើយសត្វហើរ ដែល
ជាប់នៅក្នុងអន្ទាក់ គឺយ៉ាងនោះដែលមនុស្សជាតិត្រូវ ជាប់
នៅក្នុងពេលវេលាអាក្រក់[ផ] ក្នុងកាលដែលមានគ្រោះ កើត
ដល់ខ្លួនភ្លាម១រំពេចដែរ[ព] ។

## ប្រាជ្ញាគឺប្រសើរជាងសេចក្តីចំកួត

១៣យើងក៏ឃើញប្រាជ្ញាបែបយ៉ាងនេះទៀតនៅក្រោម
ថ្ងៃ ហើយប្រាជ្ញា[ភ]នោះក៏មើលទៅ ដូចជាធំប្រសើរដល់
យើងដែរ ១៤គឺមានទីក្រុង១តូច ហើយមានមនុស្សតិច
ណាស់ផង រួចមានស្តេចធំ១មកទាស់ ក៏ឡោមព័ទ្ធហើយ
សង់បន្ទាយយ៉ាងធំច្បាំងនឹងទីក្រុងនោះ ១៥រីឯនៅក្រុង នោះ
មានមនុស្សក្រម្នាក់ដែលមានប្រាជ្ញា អ្នកនោះក៏ជួយទីក្រុង
ឱ្យរួច ដោយប្រាជ្ញារបស់ខ្លួន តែគ្មានអ្នកណានឹកគុណពី
មនុស្សក្រនោះសោះ[ម] ១៦នោះយើងបានថា ប្រាជ្ញាវិសេស
ជាងកំឡាំង ប៉ុន្តែគេតែមើលងាយចំពោះប្រាជ្ញារបស់
មនុស្សក្រវិញ ក៏មិនស្តាប់តាមពាក្យរបស់អ្នកនោះដែរ[យ]
១៧ការដែលស្តាប់ពាក្យរបស់មនុស្សមានប្រាជ្ញានៅក្នុងទី
ស្ងាត់ នោះវិសេសជាងសំរែករបស់អ្នកណាដែលគ្រប់គ្រង
លើពួកមនុស្សល្ងីល្ងើ ១៨ប្រាជ្ញា[រ]តែងវិសេសជាងគ្រឿង
ចំបាំង តែមនុស្សមានបាបតែម្នាក់រមែងបំផ្លាញការល្អទៅ
ជាច្រើនវិញ ។

**១០** ១រុយស្លាប់ធ្វើឱ្យប្រេងក្រអូបរបស់អ្នកអប់ប្រេងទៅ
ជាមានក្លិនស្អុយ ហើយសេចក្តីចំកួត[ក]តែបន្តិចបន្តួចក៏បង្ខូច
ប្រាជ្ញា និងកិត្តិយសដូច្នោះដែរ ២ចិត្តរបស់មនុស្សមាន
ប្រាជ្ញារមែងនៅខាងដៃស្តាំ តែចិត្តរបស់មនុស្សល្ងីល្ងើ
នៅខាងដៃឆ្វេងវិញ ៣អើ នេះ១ទៀត កាលណាមនុស្ស
ល្ងីល្ងើដើរតាមផ្លូវ នោះប្រាជ្ញាលះបង់ចោលវាបាត់ ហើយ
វាប្រាប់ដល់គ្រប់គ្នា[ខ]ថាជាមនុស្សល្ងីល្ងើទេ ៤បើអ្នកគ្រប់
គ្រងកើតមានចិត្តមួម៉ៅនឹងឯង នោះកុំឱ្យថយចេញពីទីរបស់
ឯងឡើយ[គ] ពីព្រោះសេចក្តីសំឡូតរមែងរំងាប់ទោសយ៉ាង
ធំ[ឃ] ។

៥មានការអាក្រក់១ ដែលយើងបានឃើញនៅក្រោម
ថ្ងៃ មើលទៅដូចជាការកំហុសដែលកើតឡើងពីអ្នកគ្រប់
គ្រងដែរ ៦គឺថា ពួកល្ងីល្ងើបានតាំងឡើងនៅទីខ្ពស់[ង] តែ
ពួកដែលមានត្រកូលខ្ពស់គេអង្គុយនៅកន្លែងទាបថោកវិញ
៧យើងបានឃើញបាវបំរើកំពុងតែជិះសេះ ហើយកូនស្តេច
កំពុងតែដើរនៅដីដូចជាបាវវិញ[ច] ។

៨អ្នកណាដែលជីករណ្តៅ នោះនឹងធ្លាក់ចុះក្នុងរណ្តៅ
នោះឯង[ឆ] ហើយអ្នកណាដែលទំលុះកំផែងគេ នោះសត្វ
ពស់នឹងចឹកខ្លួន[ជ] ៩អ្នកណាដែលរើថ្មចេញ នោះនឹងត្រូវ
របួសដោយថ្មនោះ ហើយអ្នកណាដែលពុះឧស នោះក៏
មានអន្តរាយដោយសារការនោះឯង[ឈ] ១០បើដែករិល
ហើយម្ចាស់មិនសំលៀងមុខទេ នោះត្រូវតែបញ្ចេញ
កំឡាំងលើសជាងទៅទៀត ឯប្រាជ្ញាមានប្រយោជន៍នឹង
ដំរង់ការ ១១បើពស់បានចឹកមុនដែលគ្រូអាយលម្ភាយមក
នោះគឺមានប្រយោជន៍អ្វីដោយគ្រូអាយលម្ភាយ[ញ] ។

១២ឯពាក្យដែលចេញពីមាត់របស់មនុស្សមានប្រាជ្ញា
នោះសុទ្ធតែប្រកបដោយគុណ[ដ] តែបបូរមាត់របស់មនុស្ស
ល្ងីល្ងើនឹងពន្លិចខ្លួនវិញ[ឋ] ១៣កាលចាប់ផ្តើមបណ្តាញពាក្យ
នោះសុទ្ធតែជាពាក្យល្ងីល្ងើ តែដល់ចុងបំផុតពាក្យសំដីវាជា
សេចក្តីចំកួតយ៉ាងសហ័ស[ឌ] ១៤មនុស្សល្ងីល្ងើក៏ពង្រីកពាក្យ
ពោលជាច្រើន[ឍ] ឯមនុស្សលោកគេមិនដឹងជានឹងកើតមាន
អ្វីទេ ហើយការអ្វីដែលនឹងកើតមកខាងក្រោយខ្លួននោះ
តើអ្នកណានឹងថ្លែងប្រាប់បាន[ណ] ១៥ការដែលមនុស្សល្ងីល្ងើ

**៩:១១** ប សស ២:១៤ ផ ចទ ៨:១៨
**៩:១២** ព សភ ២៩:៦ ភ ទដ ៧៣:២២ សស ២:១៤
**៩:១៣** ម ២សយ ២០:២២
**៩:១៥** យ លប ៤០:១៤ សស ១:១១
**៩:១៦** រ នអ ៦:១៣
**៩:១៨** ល សស ២:១៣
**១០:១** ក សភ ១៣:១៦ ១៨:២
**១០:៣** ខ សភ ១៣:១៦
**១០:៤** គ សស ៨:៣ ឃ សភ ១៦:១៤
**១០:៦** ង សភ ២៩:២
**១០:៧** ច សភ ១៩:១០
**១០:៨** ឆ ទដ ៥៧:៦ ជ នអ ២:២៣ សភ ៩:១៦ អម ៥:១៩
**១០:៩** ឈ សភ ២៦:២៧
**១០:១១** ញ ទដ ៥៨:៥ អស ៣:៣
**១០:១២** ដ សភ ១០:៣២ ឋ សភ ១០:៦ ១៤:៣ ១៥:២ ១៨:៧
**១០:១៤** ឌ សស ៥:៣ ឍ សស ៩:១

អាចគ្រប់គ្រងបាន ។

**៩:១២** *ពេលកំណត់* គឺជាពេលវេលាកំណត់ពីគ្រោះថ្នាក់ ។ *មនុស្សជាតិត្រូវជាប់នៅក្នុងពេលវេលា* ទោះជាជ័យជម្នះដែលកើតឡើង ដោយពុំបានដឹងជាមុន ព្រោះមនុស្សពុំបានដឹងគ្រប់ទាំងការ ដែលកើតឡើងសម្រាប់រូបគេទេ គឺជាវាសនាអាក្រក់ ។

**៩:១៥** *តែគ្មានអ្នកណាដឹងគុណពីមនុស្សនោះសោះ* គឺជាការព្រមានបន្ថែមទៀតចំពោះការដាក់សេចក្តីសង្ឃឹម ដ៏ខ្ពស់ជ្រុលទៅលើប្រាជ្ញារបស់អ្នកណាម្នាក់ ។ គឺជាភាពខ្សោយកិត្តិយសរបស់គេ ការល្អរបស់ពួកគេក៏ពុំបានប្រព្រឹត្ត (ឧ.១៨) ហើយក៏គ្មានចម្លើយចំពោះសេចក្តីស្លាប់ (២:១៥–១៦) ។

**១០:១** *សេចក្តីចំកួតតែបន្តិចបន្តួច* មើល ២ពវ ២០:១២–១៩ គឺជាគំរូមួយសម្រាប់នាសម័យនេះ ។

**១០:២** *រមែងនៅខាងស្តាំ . . . នៅខាងឆ្វេងវិញ* ការទាំងនេះអាចឈរតំណាងអ្នកដែលអស្ចារ្យ និងអត្តន័យ (ប្រៀបធៀប លប ៤:១៣–២០) ឬក៏ប្រហែលជាដូចសំបុត្រពួកយូដា ដែលបានសរសេរចំពោះការល្អ និងការអាក្រក់ (ប្រៀបធៀប មថ ២៥:៣៣–៣៤,៤១) ។

**១០:៥** *ការកំហុសដែល . . . ពីអ្នកគ្រប់គ្រងដែរ* គឺជាការសង្កេតរបស់គ្រូប្រដៅនៅក្នុងរបបរបស់មនុស្សលោក មើល ឧ.៤,៦–៧,១៦–១៧,២០ ៣:១៦ ៤:១–៣,១៣–១៦ ៥:៨–៩ ៨:២–៦,១០–១១ ៩:១៧ ។

**១០:៦–៧** មើល សភ ១៩:១០ និងការពន្យល់ ៣០:២១–២២ ។

**១០:១២** *ឯពាក្យ* គឺជាចំណងជើង ដែលពេញនិយមក្នុងអត្ថបទអក្សរសាស្ត្រនៃប្រាជ្ញា (មើលឧទាហរណ៍ សភ ១៥ យក ៣:២–១២) ។

**១០:១៥** ពីព្រោះគេមិនដឹងទៅឯទីក្រុងតាមផ្លូវណាទេ លក្ខណៈអត្ថបទបង្ហាញ

ខំធ្វើ នោះធ្វើឱ្យមនុស្សនឿយហត់គ្រប់គ្នា ពីព្រោះគេមិនដឹង
ទៅឯទីក្រុងតាមផ្លូវណាទេ ។
១៦ឱស្រុកអើយ វរហើយ កាលណាស្តេចរបស់ឯងជា
កូនក្មេង[ត] ហើយពួកអ្នកដែលជាកំពូលលើឯង គេបរិភោគ
ធំពីព្រលឹម ១៧មានពរហើយ ឱស្រុកអើយ កាលណា
ស្តេចឯងជាពូជពង្សមានត្រកូលខ្ពស់ ហើយពួកអ្នកដែល
ជាកំពូលលើឯង គេបរិភោគតាមត្រូវពេលវិញ ដើម្បីឱ្យតែ
បានកំឡាំង មិនមែនឱ្យបានស្រវឹងទេ[ថ] ១៨ឯដំបូលផ្ទះរមែង
ស្រុតធ្លាក់ ដោយព្រោះតែសេចក្តីខ្ជិលច្រអូសទេ ហើយ
ដោយព្រោះនៅដៃទទេៗ បានជាទឹកភ្លៀងលេចចូលក្នុង
ផ្ទះដែរ[ទ] ១៩មនុស្សតែងតែជប់លៀង ដើម្បីឱ្យបានសើច
សប្បាយ ហើយស្រាទំពាំងបាយជូរ[ធ]នាំចិត្តឱ្យរីករាយ តែ
ប្រាក់នឹងធ្វើឱ្យសំរេចទាំងអស់បាន ២០កុំឱ្យជេរប្រមាថ
ដល់ស្តេច[ន]ឡើយ សូម្បីតែនៅក្នុងគំនិតឯងក៏កុំដែរ ហើយ
កុំឱ្យជេរប្រមាថដល់ពួកអ្នកមាន ទោះទាំងនៅក្នុងបន្ទប់
ដេករបស់ខ្លួនផង ខ្លាចក្រែងសត្វហើរលើអាកាសនាំយក
សំឡេងនោះទៅ ហើយសត្វដែលមានស្លាបវាថ្លែងប្រាប់
តាមរឿងនោះ ។

## នំបុ័ងនៅលើទឹក

**១១** ១ចូរបោះ[ក]នំបុ័ងរបស់ឯងទៅលើទឹក ដ្បិតយូរថ្ងៃ
ក្រោយមក ឯងនឹងបានសគុណនោះមកវិញ[ខ] ២ចូរចែក
ឱ្យដល់៧នាក់ចុះ ហើយដល់៨នាក់ផង ដ្បិតឯងមិនដឹង
ជានឹងកើតមានសេចក្តីអាក្រក់យ៉ោងណានៅផែនដីទេ ៣បើ

**១០:១៦** ណ អស ៣:៤–៥,១២
**១០:១៧** ត ចទ ១៤:២៦ ១សយ ២៥:៣៦ សភ ៣១:៤
**១០:១៨** ថ សភ ២០:៤ ២៤:៣០–៣៤
**១០:១៩** ទ លប ១៤:១៨ ពច ៩:១៣
**១០:២០** ធ នក ២២:២៨
**១១:១** ក ខ.៦ អស ៣២:២០ ហស ១០:១២ ខ ចទ ២៤:១៩
**១១:៥** គ យហ ៣:៨–១០ ឃ ទដ ១៣៩:១៤–១៦
**១១:៦** ង សស ៩:១០
**១១:៧** ច សស ៧:១១
**១១:៨** ឆ សស ១២:១
**១១:៩** ច យប ១៩:២៩ សស ២:២៤ ៣:១៧

កាលណាពពកពេញដោយទឹក នោះនឹងចាក់ភ្លៀងឱ្យធ្លាក់
ចុះមកលើផែនដី ហើយបើដើមឈើណារលំដួលទៅខាង
ត្បូង ឬទៅខាងជើងក្តី នោះនឹងដេកនៅត្រង់កន្លែងដែល
បានដួលនោះឯង ៤អ្នកណាដែលសង្កេតមើលតែខ្យល់
នោះនឹងមិនសាបព្រោះទេ ហើយអ្នកណាដែលសង្កេត
មើលតែពពក នោះក៏មិនច្រូតកាត់ឡើយ ៥ឯងមិនស្គាល់
ផ្លូវនៃវិញ្ញាណ[គ] ដែលបណ្តាលឱ្យកូនកើតឡើងនៅក្នុងផ្ទៃ
របស់ស្ត្រីដែលមានទំងន់ជាយ៉ាងណា[ឃ] នោះក៏មិនស្គាល់
ការរបស់ព្រះ ដែលទ្រង់ធ្វើគ្រប់ទាំងអស់យ៉ាងនោះដែរ
៦នៅពេលព្រឹក ចូរសាបព្រោះពូជរបស់ឯងចុះ ហើយនៅ
ពេលល្ងាចកុំឱ្យទប់ដៃឯងឡើយ[ង] ដ្បិតឯងមិនដឹងជាខាង
ណានឹងចំរើនឡើង ទោះបើខាងណេះឬខាងណោះក្តី
ឬបើទាំង២ និងចំរើនបានល្អដូចគ្នាផង ។

## ចូរនឹកចាំព្រះដែលបង្កើតឯងកាលឯងនៅក្មេងនៅឡើយ

៧ពន្លឺជាគ្រឿងល្អ ហើយដែលភ្នែកបានឃើញពន្លឺថ្ងៃ
នោះក៏ស្រួល[ច] ៨អើ បើមនុស្សណារស់នៅជាយូរឆ្នាំ នោះ
គួរឱ្យមានសេចក្តីអំណរចំពោះ គ្រប់ឆ្នាំទាំងនោះចុះ តែ
ត្រូវឱ្យនឹក[ឆ]ដល់អស់ទាំងថ្ងៃ ដែលមានសេចក្តីងងឹតដែរ
ពីព្រោះនឹងមានជាច្រើនទៀត គ្រប់ទាំងអស់ដែលត្រូវមក
សុទ្ធតែជាការឥតប្រយោជន៍ទទេ ។
៩ឱមនុស្សកំឡោះអើយ ចូរឱ្យមានចិត្តរីករាយក្នុងវ័យ
កំឡោះរបស់ឯងចុះ ហើយឱ្យចិត្តឯងបណ្តាលឱ្យអរ-
សប្បាយ ក្នុងជិនាន់ដែលឯងនៅក្មេងផង ចូរដើរតាមផ្លូវ

ថាមនុស្សឆ្កួត គឺជាមនុស្សបដិសេធន៍ព្រះ និងការបង្រៀនរបស់ព្រះ (មើលការពន្យល់ ៥:៤) ។

**១០:១៦** *កាលណាស្តេចរបស់ឯងជាកូនក្មេង* គឺជាអ្នកមានតែគំនិតអន់ ក៏មិនមែន"ជាអ្នកក្រដែលមានភាពវ័យក្មេងដ៏ឆ្លាត"ដូចជាក្នុង គម្ពីរ ៤:១៣ ។ មើល ២ពវ ១៥:៨–២៥ ហស ៧:៣–៧ ការរៀបរាប់ផ្នែកខ្លីៗខ្លះពីអ្នកដែលទទួលបានអំណាចតែមិនល្អសម្រាប់ជាគំរូ ឬអ្នកអែបអបដែលមានជ័យជម្នះដែលផ្លាស់ប្តូរដោយប្រញាប់ នៃការធ្លាក់ចុះរបស់រាស្ត្រអ៊ីស្រាអែល ។

**១០:១៨** *សេចក្តីខ្ជិលច្រអូស* មើលការពន្យល់ ៤:៥ ។

**១០:១៩** *តែប្រាក់នឹងធ្វើឱ្យសំរេចទាំងអស់បាន* គឺអាចអានបាន យល់បានគ្រប់កំរឹត ក៏ជាច្បាប់លើមនុស្សលោក ដូចជាដំបូន្មានដ៏ល្អដើម្បីរកចំណូលបានច្រើនជីវភាពល្អជាជាងមានពេលដ៏ប្រសើ (មើលពីរបន្ទាត់ដំបូង) (លក ១៦:៩ និងការពន្យល់) ។

**១១:១** ក្នុងខនេះអាចមានន័យថា"បញ្ជូនគ្រាប់ធញ្ញជាតិកាត់សមុទ្របន្ទាប់ពីជាច្រើនថ្ងៃក្រោយមក អ្នកនឹងបានទទួលមកវិញ គឺដូចជាការផ្សងព្រេងដូចជាអ្នកដែលហ៊ានប្រថុយនឹងទទួលបាននូវផលកម្រៃនៃពានិជ្ជកម្មតាមសមុទ្រ ពុំអាចថាវាសុខស្រួលរហូត(មើល សភ ១១:២៤ និងការពន្យល់) ។

**១១:២** វាក៏អាចមានន័យថា"ការដាក់ទុនដោយការផ្សងព្រេងដូចជា ពាក្យថាហើយដល់៨នាក់ផង! គឺចំពោះអ្នកដែលពុំបានដឹង"នោះហើយជាភាពប្រែប្រួលដោយខិតខំប្រឹងប្រែងរបស់អ្នក ហើយអ្នកក៏ពុំដឹងថាការប្រឹងប្រែងរបស់គេគឺត្រូវបរាជ័យ ។ "កុំដាក់ស៊ុតរបស់អ្នកក្នុងកន្ត្រកស្បោងតែ១"កិច្ចការប្លែកៗរបស់អ្នក និងបត្ថយភាពប្រថុយចំពោះមុខ ។

**១១:៣–៦** *ពពក . . . ដើមឈើ . . . សាបព្រោះ* ក៏កុំឱ្យនិយាយលេងដោយប្រើពាក្យថាប្រហែលជានឹងវាអាចជា ។ សូមចាប់ធ្វើចុះបើអាចធ្វើហើយអ្នកនឹងឃើញពីលទ្ធផលនោះ ។

**១១:៥** *វិញ្ញាណ* ប្រៀបធៀប ៣:៨("ពាក្យថាខ្យល់"និង"ព្រះវិញ្ញាណ" ពាក្យទាំងនេះបានប្រែពីពាក្យតែមួយពីប្រភពដើម) ។

**១១:៧–១០** ដូចជាជីវិតរស់ដោយពេញខ្នាត ។

**១១:៨–១០** *ជាឥតប្រយោជន៍ទទេ* គឺជាការប្រមានចំពោះអំណរ ជានិស្ស័យដ៏អស្ចារ្យ ដែលបានបញ្ជាក់នៅក្នុង ខ.៧–១០ ដែលនៅតែជាភាពមិនច្បាស់និងរាយនាម ។ ហើយនៅ ខ.៩ បានផ្តល់ឱ្យយើងនៅហេតុការពិត ។

**១១:៩** *ជិនុំជិវះ* មើល ១១:១៤ និងការពន្យល់ ។ សេចក្តីសង្ឃឹមពីការសរសើដ៏បរិសុទ្ធធ្វើឱ្យមានភាពលំអិតការបញ្ជាក់ពីជីវិត ដែលប្រសើជាងភាពឥតប្រយោជន៍ទទេ ។ ដើម្បីស្គាល់ពីទិសដៅដែលផ្តល់ឱ្យ ចំពោះភ្នែកយើង ។

នៃចិត្តឯង ហើយតាមតែភ្នែកឯងមើលឃើញដែរ ប៉ុន្តែ
ត្រូវឱ្យដឹងថា ព្រះទ្រង់នឹងហៅឯងមកជំនុំជំរះ ដោយព្រោះ
អំពើទាំងនេះជាមិនខាន[ជ] ១០ដូច្នេះ ចូរកាត់សេចក្ដីក្នាញ់
ក្តៅ[ឈ]ចេញពីចិត្តឯងទៅ ហើយបណ្តេញសេចក្តីអាក្រក់ឱ្យ
ឆ្ងាយពីសាច់ឈាមឯងផង ដ្បិតគ្រានៅកំឡោះ ហើយ
វ័យក្មេងរមែងជាឥតប្រយោជន៍ទេ[ញ]។
**១២** ១ចូរនឹកចាំ[ក]ពីព្រះដ៏បង្កើតខ្លួន ក្នុងគ្រាដែលឯងនៅ
ក្មេង មុនដែលអស់ទាំងថ្ងៃអាក្រក់[ខ]មកដល់ ហើយអស់ទាំង
ឆ្នាំមកជិត ដែលឯងនឹកថា អញអស់សប្បាយហើយ ២គឺមុន
ដែលថ្ងៃ ពន្លឺ ខែ និងផ្កាយទាំងប៉ុន្មានទៅជាងងឹត ហើយ
ពពកវិលមកក្រោយដែលភ្លៀង ៣នៅថ្ងៃដែលពួកអ្នកចាំផ្ទះ
ត្រូវញាប់ញ័រ ពួកមនុស្សខ្លាំងពូកែត្រូវ ឱនខ្លួនចុះ ពួកស្រី
ដែលកិនស្រូវត្រូវឈប់ ដោយព្រោះ មានគ្នាតិចពេក ពួក
អ្នកដែលមើលតាមបង្អួចត្រូវងងឹតទៅ ៤ហើយទ្វារដែល
បើកទៅឯថ្នល់ត្រូវបិទ ជាពេលដែលអន់ ឮសូរត្បាល់កិន
កាលគេស្ទុះក្រោកឡើង ដោយឮសំឡេង សត្វហើរយំ
ហើយអស់ទាំងពួកស្រីៗដែលធ្លាប់ច្រៀងត្រូវទាបថោក
វិញ[គ] ៥អើ គេនឹងភ័យខ្លាចចំពោះអន្តរាយ ដែលមកពីខាង
លើ ក៏នឹងមានសេចក្តីស្ញែងខ្លាចតាមផ្លូវ ឯដើមចំបក់នឹងផ្កា
ឡើង ហើយកណ្តូបនឹងសង្កត់លើគេជាធ្ងន់ សេចក្តីប៉ង
ប្រាថ្នានឹងរសាយអស់ទៅ ដោយព្រោះ មនុស្សរមែងទៅឯ
ទីលំនៅ[ឃ]ដ៏នៅអស់កល្បជានិច្ច ហើយពួកអ្នកកាន់ទុក្ខ[ង]ដើរ
ទៅមកតាមផ្លូវ ៦គឺមុនដែលខ្សែប្រាក់ដាច់ ចានមាសបែក
ក្អមបែកនៅឯក្បាលទឹក ឬរហាត់ ទឹកនៅអណ្តូងខូចទៅ
៧ហើយធូលីត្រឡប់[ច]ជាដីដូចដើមវិញ និងវិញ្ញាណត្រឡប់
ទៅឯព្រះ[ឆ] ដែលទ្រង់បានប្រទានមកនោះ[ជ] ៨"ការឥត
ប្រយោជន៍ទទេៗ" នេះហើយ ជាពាក្យដែលគ្រូប្រដៅ
ពោលទុកថា[ឈ] គ្រប់ទាំងអស់សុទ្ធតែឥតប្រយោជន៍ទទេ[ញ]។

**សេចក្តីសន្និដ្ឋាននៃបញ្ហានោះ**

៩ហើយ១ទៀត ដោយព្រោះគ្រូប្រដៅមានប្រាជ្ញា បាន
ជាលោកបង្រៀនប្រជាជន ឱ្យមានដំរិះទៅទៀត អើ លោក
បានរំពឹងគិត ព្រមទាំងស្វែងរក ហើយតែងពាក្យ សុភាសិត
ជាច្រើនតាមរប្រៀបគ្រូប្រដៅ[ដ] ១០លោកបានស្វែង[ឋ]រក
ពាក្យពិរោះ និងសេចក្តីដែលបានតែងទុកយ៉ាងត្រឹមត្រូវ
គឺជាពាក្យដ៏ពិតទាំងអស់[ឌ]។
១១ពាក្យរបស់មនុស្សមានប្រាជ្ញា ធៀបដូចជាជន្លួញ
ហើយពាក្យរបស់ពួកអ្នក ដែលប្រមូលកត់ទុកពាក្យប្រាជ្ញ
នោះក៏ដូចជាដែកគោល[ឍ]បោះភ្ជាប់ ជាពាក្យដែលមកពីអ្នក
គង្វាលតែ១ ១២១ទៀតកូនអើយ ចូរទទួលដំបូន្មានចុះ ដ្បិត
ការដែលធ្វើសៀវភៅជាច្រើន នោះមិនចេះអស់មិនចេះ
ហើយឡើយ ហើយការដែលរៀនជាច្រើន នោះរមែងនាំ
ឱ្យអផ្សុកដល់រូបសាច់[ណ]។
១៣សេចក្តីនេះចប់តែប៉ុណ្ណេះ ទាំងអស់បានសំដែងទុក
ហើយ ដូច្នេះចូរកោតខ្លាចដល់ព្រះ[ត] ហើយកាន់តាមបញ្ញត្តិ
ទ្រង់ចុះ[ថ] ដ្បិតប៉ុណ្ណេះឯងជាកិច្ចទាំងមូលដែលមនុស្សត្រូវ
ធ្វើ[ទ] ១៤ពីព្រោះព្រះទ្រង់នឹងនាំគ្រប់ការទាំងអស់មក ដើម្បី
ជំនុំជំរះ[ធ] ព្រមទាំងអ្វីៗដែលលាក់កំបាំងផង[ន] ទោះល្អ ឬ
អាក្រក់ក្តី ។

**១១:១០** ឈ ទដ ៩៤:១៩ ញ សស ២:២៤
**១២:១** ក សស ១១:៨ ខ ២សយ ១៩:៣៥
**១២:៤** គ យរ ២៥:១០
**១២:៥** ឃ យប ១០:២១ ង យរ ៩:១៧ អម ៥:១៦
**១២:៧** ច លប ២:៧ ទដ ១៤៦:៤ ឆ សស ៣:២១ ជ យប ២០:៨
**១២:៨** ឈ សស ១:១ ញ សស ១:២
**១២:៩** ដ ១ពវ ៤:៣២
**១២:១០** ឋ សស ១:១ ឌ សភ ២២:២០-២១
**១២:១១** ឍ អរ ៩:៨ យប ៦:២៥
**១២:១៣** ត នក ២០:២០ ១៩:១២ យរ ១៦:១៧ ២៣:២៤
**១២:១២** ណ សស ១:១៨ ១សយ ១២:២៤ យប ២៣:១៥ ទដ ១៩:៩ ថ ចទ ៤:២ ទ ចទ ៤:៦ យប ៣៧:២៤
**១ ២:១៤** ធ យប ១៩:២៩ សស ៣:១៧ ន យប ៣៤:២១ ទដ ១៩:១២ យរ ១៦:១៧ ២៣:២៤

គឺមានក្នុងជីពូក ១២ ។
**១២:១** *ក្នុងគ្រាដែលឯងនៅក្មេង* ប្រៀបធៀបនិង បទ ៣:២៧ ។
**១២:២-៥** ការពណ៌នាបានបង្ហាញ ពីដំណើរការពីភាពក្លាយទៅជាចាស់ ។
**១២:៣** *ពួកអ្នកចាំផ្ទះ* នេះគឺជាពាក្យប្រៀបធៀប១ ដែលអាចសំដៅទៅលើផ្នែកនៃរូបរាង្គកាយ(មានដៃជើង ។ល។)តែវាជារូប ប្រៀបហើយគួរតែកុំបកស្រាយច្រើនដែលនាំឱ្យបំផ្លាញដល់ពួកកវីនិពន្ធ ។
**១២:៥** *ដើមចំបក់* សំដៅទៅលើសក់ស្កូវតាមវ័យ ។ *កណ្តូប* មានចលនាយឺតៗរបស់សត្វនេះ នៅព្រឹកព្រលឹមត្រជាក់(ធៀបនឹង ណាហ ៣:១៧) ដូចនេះ គឺសំដៅទៅលើភាពរឹងរូសនៃមនុស្សចាស់ ។ *ទីលំនៅ* តាមបរិបទគឺសំដៅទៅលើស្ថានឃុំព្រលឹងឬផ្នូរ (យប ១០:២១ និងពន្យល់ ១៧:១៣)។
**១២:៦** *ខ្សែប្រាក់ដាក់... មាសបែក* គឺដូចជាចង្កៀងសម្រាប់យួរ ដែលមានក្រវាត់ប្រាក់ផង ។ ចង្កៀងក្នុងខនេះគឺប្រដូចទៅនឹងជីវិតដែលងាយរលុត ។
**១២:៨** *ការឥតប្រយោជន៍ទទេៗ* មើល ១:២ និងការពន្យល់ ក៏មើលសេចក្តីផ្តើមដែលបង្ហាញពីបែបបទអក្សរសាស្ត្រ ។ គឺជាប្រភេទជីវិត"នៅក្រោមកំដៅថ្ងៃ"គឺនៅក្នុងលោកិយដែលមាននិស្ស័យ មិនមែនជាព្រះគឺត្រូវបញ្ចប់ដោយការបែកបាក់ដែលបានមានទំនាក់ទំនងទៅព្រះអទិករ ដែលបានបញ្ជាររួចហើយ (ខ.១) និងមានសេចក្តីពិត នៃការកាត់ទោសជំនុំជម្រះ (១១:៩) ។ *ការឥតប្រយោជន៍ទទេៗ* មិនមែនជាពាក្យចុងក្រោយនោះទេ ។ *គ្រូប្រដៅ* មើលការពន្យល់ ១:១ ។
**១២:៩** *លោកបានរំពឹងគិត* គឺជាការស្តែងនូវការលំបាក ដែលពុំមានការឈឺក្នុងការស្វែងរកសេចក្តីពិត និងសេចក្តីបញ្ញា ។
**១២:១១** *ជាពាក្យដែលមកពីអ្នកគង្វាលតែ១* នេះគឺជាផ្នែកដទៃទៀតនៃរឿងរ៉ាវដោយដឹងថាអត្ថបទនោះក៏មានទំនាក់ទំនងដូចជា ខ.១២ ។
**១២:១៣** *កោតខ្លាចដល់ព្រះ* ការគោរពស្រឡាញ់ដោយកោតខ្លាច គឺជាប្រភពនៃប្រាជ្ញា (មើល ទដ ១១១:១០ សភ ១:៧ និងការពន្យល់) ដូចជាអត្ថបទនេះផ្ទាល់ (យប ២៨:២៨) គឺទិសដៅរបស់វានឹងសេចក្តីបញ្ជាក់ជាកិច្ចការទាំងមូលដែលមនុស្សធ្វើក្នុងនេះ គឺជាការដែលយើងធ្វើ ដែលយើងបានឮនូវការស្រែកយំពីការដែលយើងធ្វើ "គឺការឥតប្រយោជន៍ទទេៗ" ។
**១២:១៤** *គ្រប់ការទាំងអស់មកដើម្បីជំនុំជំរះ* ការឃើញមួយភ្លែតនៃសេចក្តីពិតនេះគឺផ្តល់ឱ្យឃើញភាពចោះៗក្នុងសៀវភៅ មើលការពន្យល់ ៣:១៧ ៨:១២-១៣ ១១:៩ មើល មថ ១២:៣៦ ១កថ ៣:១២-១៥ ២កថ ៥:៩-១០ ហាព ៤:១២-១៣ ។ *ព្រមទាំងអ្វីៗដែលលាក់កំបាំងផង* មើល រម ២:១៦ ។

# ព្រះគម្ពីរបទចម្រៀងសាឡូម៉ូន

## សេចក្ដីផ្ដើម

### ចំណងជើង

តាមព្រះគម្ពីរភាសាហេព្រើរ ចំណងជើងព្រះគម្ពីរនេះគឺ "បទចម្រៀងនៃបទចម្រៀងរបស់ស្ដេចសាឡូម៉ូន"មានន័យថា បទចម្រៀងដែលនិពន្ធដោយស្ដេចសាឡូម៉ូន ឬបទចម្រៀងអំពីស្ដេចសាឡូម៉ូន ។ ឃ្លា "បទចម្រៀងនៃបទចម្រៀង" មានន័យថា បទចម្រៀងដែលអស្ចារ្យបំផុត ក្នុងចំណោមបទចម្រៀងទាំងឡាយ(ធៀបនឹង ចទ ១០:១៧ "ព្រះលើអស់ទាំងព្រះ" និង "ព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់" ១ធថ ៦:១៥ "ស្ដេចលើអស់ទាំងស្ដេច")។

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

តាមខ.១ គេសន្និដ្ឋានថា អ្នកនិពន្ធគឺស្ដេចសាឡូម៉ូន(មើលការពន្យល់ ១:១ និងចំណុច ចំណងជើងខាងលើ)។ ព្រះគម្ពីរនេះបានប្រើឈ្មោះស្ដេចសាឡូម៉ូនប្រាំពីរដង(១:១,៥ ៣:៧,៩,១១ ៨:១១-១២) ហើយមានប្រាំពីរខ ដែលនិយាយអំពី"ស្ដេច"(១:៤,១២ ៧:៥) ប៉ុន្តែ គេនៅតែអាចចោទសួរថា តើស្ដេចសាឡូម៉ូនជាអ្នកនិពន្ធឬយ៉ាងណា ។

គេអាចកំណត់បានថា កាលបរិច្ឆេទនៃការនិពន្ធព្រះគម្ពីរនេះគឺនៅក្នុងរជ្ជកាលស្ដេចសាឡូម៉ូន គឺនៅសតវត្សទី១០ មុនគ.ស ។ ជាការពិតណាស់ ដោយយោងទៅលើការនិយាយអំពីទីក្រុងធីសោ និងទីក្រុងយេរូសាឡិមក្នុងឃ្លាតែមួយ(៦:៤ និងការពន្យល់ខនេះ) គេសន្និដ្ឋានថា កាលបរិច្ឆេទនៃការនិពន្ធព្រះគម្ពីរនេះ គឺនៅមុនរជ្ជកាលស្ដេចអំរី(ឆ្នាំ ៨៨៥-៨៧៤ មុនគ.ស, មើល ១ពវ ១៦:២៣-២៤) ទោះបីជាគេ មិនទាន់ដឹងច្បាស់ ពីមូលហេតុដែលអ្នកនិពន្ធនិយាយ អំពីឈ្មោះទីក្រុងធីសោនេះក៏ដោយ ។ ម្យ៉ាងវិញទៀត មានមនុស្សជាច្រើនបានយល់ថា លក្ខណៈនៃការប្រើភាសានៅក្នុងព្រះគម្ពីរនេះ ជាភស្តុតាងបញ្ជាក់ថា កាលបរិច្ឆេទនៃការនិពន្ធគឺនៅសម័យក្រោយមកទៀត ប៉ុន្តែ តាមភស្តុតាងអំពីលក្ខណៈនៃការប្រើភាសាដែលគេមាននៅក្នុងពេលបច្ចុប្បន្ន គេមិនដឹងច្បាស់ពីលក្ខណៈនៃប្រើភាសានៅក្នុងព្រះគម្ពីរនេះទេ ។

បទចម្រៀងសាឡូម៉ូនបានប្រើភាសា រចនាបថ ការលើកដាក់សម្លេង ការប្រៀបប្រដូច និងបទបន្ទរ ឬវគ្គស្លួន យ៉ាងស៊ីសង្វាក់គ្នា ហើយការនេះបង្ហាញថា ព្រះគម្ពីរនេះមានអ្នកនិពន្ធតែម្នាក់ទេ ។ ទោះជាយ៉ាងណាក៏ដោយ មានមនុស្សជាច្រើនមិនជឿថា ព្រះគម្ពីរនេះមានអ្នកនិពន្ធតែម្នាក់ ឬនិពន្ធនៅក្នុងសម័យ ឬទីកន្លែងតែមួយឡើយ ដោយពួកគេយល់ថា ការដែលព្រះគម្ពីរនេះមានភាពស៊ីសង្វាក់គ្នាគឺមានន័យថា គ្រប់វគ្គទាំងអស់នៃព្រះគម្ពីរនេះគឺសុទ្ធតែត្រូវបាននិពន្ធឡើងតាមប្រពៃណីនៃការនិពន្ធតែមួយ ព្រោះនៅមជ្ឈិមបូព៌ាមានការប្រុងប្រយ័ត្នខ្លាំងណាស់ នៅក្នុងការរក្សារចនាបថនៃការសរសេរឱ្យមានលក្ខណៈតែមួយ ។

### ការកាត់ស្រាយ

ដើម្បីបកស្រាយអាថ៌កំបាំងនៃព្រះគម្ពីរបទចម្រៀងនេះ អ្នកកាត់ស្រាយបានធ្វើការសិក្សាអំពីបទគម្ពីរដែលនិយាយអំពីបទទំនាយប្រាជ្ញា និងការបើកសម្ដែង ព្រមទាំងសិក្សាជាបន្ថែមទៀតអំពីបទចម្រៀងបុរាណរបស់សាសន៍អេស៊ីព្ទ និងសាសន៍បាប៊ីឡូន បទចម្រៀងអាពាពិពាហ៍តាមប្រពៃណីអ្នកមជ្ឈិមបូព៌ា និងបទចម្រៀងដែលទាក់ទងនឹងសាសនាបង្ករបង្កើនផលនៅតំបន់មេសូប៉ូតាមាសម័យបុរាណ ។ ព្រះគម្ពីរនេះមានលក្ខណៈស្រដៀងគ្នាបំផុតនឹងព្រះគម្ពីរសុភាសិតនៅត្រង់ សភ ៥:១៥-២០ ៦:២៤-២៩ ៧:៦-២៣ ។ ការពិពណ៌នាអំពីស្នេហានៅក្នុង ៨:៦-៧(ធៀបនឹង ការពិពណ៌នាអំពីប្រាជ្ញានៅក្នុង សភ ១-៩ និង យប ២៨) ហាក់ដូចជាបញ្ជាក់ថា បទចម្រៀងសាឡូម៉ូនគឺជាព្រះគម្ពីរនៃប្រាជ្ញា ហើយគឺជាការរៀបរាប់អំពីប្រាជ្ញា ដោយនិយាយអំពីទំនាក់ទំនងស្នេហា ។ ព្រះគម្ពីរបរិសុទ្ធនិយាយអំពីប្រាជ្ញា និងសេចក្ដីស្រឡាញ់ ដែលជាអំណោយទានមកពីព្រះ និងត្រូវទទួលដោយការអរព្រះគុណ និងសរសើរតម្កើង ។

ការកាត់ស្រាយខាងលើខុសពីទស្សនៈដែលគេជឿជាយូរមកហើយថា ព្រះគម្ពីរបទចម្រៀងសាឡូម៉ូនគឺជាព្រះគម្ពីរប្រៀបប្រដូចទៅនឹងសេចក្ដីស្រឡាញ់រវាងព្រះ និងរាស្ត្រអ៊ីស្រាអែល ឬព្រះគ្រីស្ទ និងពួកជំនុំ ឬក៏ព្រះគ្រីស្ទ និងវិញ្ញាណ(ព្រះគម្ពីរសញ្ញាថ្មីមិនមានការដកស្រង់ ពីព្រះគម្ពីរនេះ ហើយក៏មិនបាននិយាយអំពីព្រះគម្ពីរនេះដែរ)។ ការកាត់ស្រាយនេះក៏ខុសពីការកាត់ស្រាយនៅសម័យថ្មីដែលថា ព្រះគម្ពីរនេះគឺជាអក្សរសិល្ប៍បែបកំណាព្យដែលលើកតម្កើងតម្លៃនៃភាពបរិសុទ្ធរបស់នារីម្នាក់ និងនិយាយអំពីសេចក្ដីស្រឡាញ់អស់ពីចិត្តដែលនាងមានចំពោះស្នួនសំឡាញ់ដែលជាអ្នកគង្វាលជនបទរបស់នាង ដែលទ្រង់ជាស្ដេចសាឡូម៉ូនដែលបានចៃរចង់នាង ដើម្បីយកមកធ្វើជាស្រីស្នំ ។ តាមការកាត់ស្រាយនេះ គេយល់ឃើញថា ព្រះគម្ពីរនេះគឺជាចម្រៀងដែលមានបទជាច្រើនចងភ្ជាប់គ្នា ដែលបង្ហាញអំពីសេចក្ដី

ស្នេហាដែលចេញពីចិត្ត ដែលមានសម្រស់ អំណាច និងភាពដែលមិនអាចចែករំលែកឱ្យអ្នកដទៃបាន ជាបទពិសោធពួកគេមាននៅក្នុងពេលដែលពួកគេត្រូវនៅឆ្ងាយជាមួយគ្នា ពេលស្និទ្ធស្នាលជាមួយគ្នា ពេលឈឺចាប់ និងពេលសុខស្រួល ពេលតានតឹង និងពេលស្កប់ចិត្ត ។ បទចម្រៀងសាឡូម៉ូនមានលក្ខណៈដូចបទកំណាព្យស្នេហារ នៅក្នុងវប្បធម៌ជាច្រើន ដោយសារបទចម្រៀងនេះនិយាយបំផុសផ្លូវអារម្មណ៍ខ្លាំង ដោយនិយាយប្រដូចទៅនឹងធម្មជាតិ ។

### គោលរឿង និងវិជ្ជាសិក្សាអំពីព្រះ

នៅនគរអ៊ីស្រាអែលសម័យបុរាណ គេប្រើពាក្យដើម្បីបង្ហាញអំពីការផ្សេងៗដូចជា ការគោរព ការដឹងគុណ កំហឹង ទុក្ខព្រួយ ការឈឺចាប់ ការជឿជាក់ មិត្រភាព ការប្តេជ្ញាចិត្ត ភាពស្មោះត្រង់ សេចក្តីសង្ឃឹម ប្រាជ្ញា ការខុសសីលធម៌ ការប្រែចិត្ត ។ នៅក្នុងបទចម្រៀងសាឡូម៉ូន សេចក្តីស្នេហារនាំឱ្យមានការប្រើពាក្យដែលជិរុញចិត្ត ដែលបង្ហាញអំពីសម្រស់ និងការទាក់ទាញ ដែលជាអំណោយទាននៃព្រះ ។ ពាក្យដែលនិយាយដោយសេចក្តីស្នេហានៅក្នុងព្រះគម្ពីរនេះ គឺដូចពាក្យប្រាជ្ញានៅក្នុង ទដ ៨:១–៩:១២ និងជាពាក្យមនុស្សស្រី ដែលការនេះបង្ហាញថា សេចក្តីស្នេហា និងប្រាជ្ញា មានអំណាចធ្វើឱ្យបុរសជាប់ចិត្ត ដោយភាពពិសេស និងអាចកំបាំងនៃភាពទាក់ទាញរបស់ស្ត្រី ។

ភាគគីខាងស្រីបាននិយាយអំពីស្នេហាររបស់នាងដោយការចេះដឹងខ្ពស់ ។ នាងបង្ហាញអំពីសម្រស់ និងភាពសប្បាយរីករាយនៃស្នេហា ។ នាងប្រកាសថា ស្នេហាររបស់នាងជាមួយនឹងទ្រង់មិនអាចចែកឱ្យអ្នកផ្សេងបានឡើយ("ស្ងួនសំឡាញ់ជារបស់ផងខ្ញុំ ខ្ញុំក៏ជារបស់ផងទ្រង់" ២:១៦) ហើយនាងក៏បានបញ្ជាក់ថា សេចក្តីស្នេហាត្រូវកើតចេញពីចិត្តដ៏បរិសុទ្ធ("មិនអង្រួន ឬដាសស្ងួនសំឡាញ់របស់ខ្ញុំឡើយ ចាំទាល់តែទ្រង់សព្វព្រះទ័យ"២:៧)។ នាងក៏បានប្រកាសផងដែរ អំពីអំណាចដ៏ខ្លាំងរបស់ស្នេហា គឺខ្លាំងដូចសេចក្តីស្លាប់ដែលជាខ្មាំងសត្រូវដ៏គួរឱ្យខ្លាច សេចក្តីស្នេហាឆេះឡើង ដោយអណ្តាតភ្លើងសន្ធោសន្ធៅ ទោះទឹកនៃជម្រៅមហាសមុទ្រក៏មិនអាចពន្លត់បានដែរ (៨:៦–៧ក)។ នាងបញ្ជាក់អំពីតម្លៃរបស់សេចក្តីស្នេហា ដែលមិនអាចយកទ្រព្យអ្វីមកទិញ ឬដូរបានឡើយ(៨:៧ខ)។ នាងបាននិយាយពន្លយពាក្យដែលមានន័យថា សេចក្តីស្នេហាគឺជាអំណោយទានរបស់ព្រះ ។

ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យឱ្យសេចក្តីស្នេហាបានធ្វើជាផ្នែកមួយនៃទំនាក់ទំនងរវាងប្តីប្រពន្ធជាធម្មតា គឺដូចជាគ្រាដំបូងដែលទ្រង់បង្កើតមនុស្សមកយ៉ាងល្អ(លប ១:២៦–៣១ ២:២៤) គឺមិនត្រូវបន្ថុចតម្លៃរបស់វា ដូចដែលពួកមនុស្សសម័យបុរាណ និងសម័យថ្មីបានធ្វើនោះឡើយ។ ជាការពិតណាស់ តាមបទចម្រៀងសាឡូម៉ូន ពួកអ៊ីស្រាអែលដែលស្មោះត្រង់អាចយល់ច្បាស់ អំពីរបៀបដែលត្រូវរស់នៅដោយមានសេចក្តីស្នេហា តាមការរៀបចំរបស់ព្រះ ។ សេចក្តីស្នេហានៅក្នុងអាពាពិពាហ៍ដូចនេះ គឺជាការដែលព្រះអាទិករដ៏ជាមហាក្សត្រទ្រង់រៀបចំឱ្យមានក្រឹត្យក្រមដែលមិនត្រូវរំលង ។

### លក្ខណៈអក្សរសាស្ត្រ

ចំពោះអ្នកដែលបានអានព្រះគម្ពីរនេះដោយយកចិត្តទុកដាក់ ប្រាកដជាដឹងថា ព្រះគម្ពីរនេះត្រូវបាននិពន្ធឡើងតាមបែបកំណាព្យយ៉ាងប៉ិនប្រសព្វ ។ អ្នកនិពន្ធបាននិយាយជាពាក្យប្រៀបប្រដូច ដែលមានការបង្ហាញអំពីអារម្មណ៍ ហើយមានជោគជ័យបំផុតនៅក្នុងជៀសវាងការនិយាយអំពីផ្លូវភេទដែលនាំឱ្យអ្នកអានរវាតចិត្ត ។ ភាគច្រើននៃជោគជ័យនេះ គឺដោយសារព្រះគម្ពីរនេះបាននិយាយ ដោយមិនផ្ទាល់ ដោយពាក្យប្រៀបប្រដូច និងដោយលើកឡើងអំពីធម្មជាតិ(ឬអាហារ គ្រឿងផឹក គ្រឿងសម្អាង និងគ្រឿងអលង្ការ)។ អ្នកនិពន្ធបានប្រើជំនាញយ៉ាងប៉ិនប្រសព្វ និងរូបបារម្មណ៍យ៉ាងល្អ ដោយប្រដូចការដែលស្ងួនសំឡាញ់សប្បាយនឹងមាសសំឡាញ់របស់ទ្រង់ ទៅនឹងការដែលសត្វក្តាន់ "រកស៊ីនៅទីមានផ្កាកំភ្លឹង"(២:១៦) ឬប្រដូច សុដន់របស់នាងទៅនឹង "កូនក្តាន់២ ដែលជាកូនភ្លោះរបស់មេ១ ដែលកំពុងរកស៊ីនៅទីមានផ្កាកំភ្លឹង"(៤:៥) ឬប្រដូចមាសសំឡាញ់ទៅនឹងសួនច្បារដែលមានផ្លែឈើល្អៗជាបរិបូរ សម្រាប់ឱ្យស្ងួនសំឡាញ់ទ្រង់ចូលមកសោយ(៤:១២–១៦)។

ពួកអ្នកកាត់ស្រាយនៅតែបន្តការពិភាក្សាអំពីព្រះគម្ពីរបទចម្រៀងសាឡូម៉ូន ដើម្បីឱ្យដឹងប្រាកដ ថាតើព្រះគម្ពីរនេះការផ្សាភ្ជាប់ជាសាច់រឿងតែមួយ ដោយចងវគ្គតូចៗទាំងអស់ឱ្យបន្តគ្នាពីមួយទៅមួយទៀតឬយ៉ាងណា ។ ឆាកស្នេហានៅក្នុងបទចម្រៀងនេះហាក់ដូចជាតភ្ជាប់គ្នាពីមួយទៅមួយទៀត ដែលបង្កើតបានជាសាច់រឿងស្នេហាទាំងមូល(មើលគម្រោងសង្ខេប)។

ជាការពិតណាស់ អ្នកកាត់ស្រាយទាំងអស់សុទ្ធតែជឿថា ចំណុចខ្លាំងបំផុតនៃសាច់រឿងនៃបទចម្រៀងនេះ គឺវគ្គ ៨:៦–៧ ដែលប្រកាសអំពីអំណាច និងតម្លៃនៃសេចក្តីស្នេហាក្នុងអាពាពិពាហ៍ គឺខ្លាំងជាងសេចក្តីស្នេហាប្រភេទដទៃទៀត គឺជាសេចក្តីស្រឡាញ់ដែលនាំ

ឱ្យបុរស និងស្ត្រីបានរួមរួសជាមួយគ្នាយ៉ាងត្រឹមត្រូវ ។ វគ្គបន្ទាប់នៃការប្រកាសនេះ គឺនិយាយអំពីសេចក្ដីដែលធូស្រាលជាង ។ នៅចុងបញ្ចប់នៃបទចម្រៀងនេះ គូស្នេហ៍ទាំងពីរនាក់បង្ហាញពីសេចក្ដីត្រូវការគ្នាទៅវិញទៅមក ដែលមានន័យថា សេចក្ដីស្នេហារបស់ពួកគេនៅតែបន្តទៅមុខទៀត ។ ម្យ៉ាងវិញទៀត គេក៏អាចនិយាយបានថា វគ្គចុងក្រោយនេះ(៨:៨–១៤)គឺនាំអារម្មណ៍របស់អ្នកអានឱ្យត្រឡប់មករកដើមដំបូងនៃបទចម្រៀងវិញផងដែរ ដែលក្នុងនោះ វគ្គ ៨:៨–១២ និង ១:២–៦ បានចងភ្ជាប់ ដោយការនិយាយសំដៅទៅលើបងប្រុសរបស់មាសសំឡាញ់ ចំការទំពាំងបាយជូររបស់នាង និងស្ដេចសាឡូម៉ូន(ស្ដេច)។ នៅក្នុងបទចម្រៀងស្នេហានេះ ពាក្យរបស់ភាគគីខាងស្រី គឺខ្លាំងជាងខាងបុរស ដោយសារនាងបានលើកឡើងបានច្បាស់បំផុត អំពីបទពិសោធន៍ នៃសេចក្ដីស្រឡាញ់ដែលនាងមាន និងបានទទួល ។ បទចំរៀងសាឡូម៉ូនបានចាប់ផ្ដើម ដោយពាក្យដែលនាងទូលសូមឱ្យទ្រង់ថើបនាង ហើយបញ្ចប់ទៅវិញដោយពាក្យដែលនាងអញ្ជើញយ៉ាងទទូច ឱ្យទ្រង់ចូលមករួមស្នេហ៍ ។

**គម្រោងសង្ខេប**

I. ចំណងជើង (១:១)

II. ការជួបគ្នាជាលើកទី១ (១:២–២:៧)

III. ការជួបគ្នាជាលើកទី២ (២:៨–៣:៥)

IV. ការជួបគ្នាជាលើកទី៣ (៣:៦–៥:១)

V. ការជួបគ្នាជាលើកទី៤ (៥:២–៦:៣)

VI. ការជួបគ្នាជាលើកទី៥ (៦:៤–៨:៤)

VII. ចំណុចខ្លាំងបំផុតនៃសាច់រឿង (៨:៥–៧)

VIII. សេចក្ដីសន្និដ្ឋាន (៨:៨–១៤)

**១** នេះជាចំរៀងដែលប្រសើរបំផុតជាងអស់ទាំងចំរៀង[ក]
ជាទំនុករបស់ស្តេចសាឡូម៉ូន ។

**មាសសំឡាញ់**

២ ឱបើប្តីនឹងថើបខ្ញុំដោយព្រះឱស្ឋទៅអេះ
ពីព្រោះសេចក្តីស្រឡាញ់[ខ]របស់ទ្រង់វិសេសជាងស្រា
ទំពាំងបាយជូរ[គ]
៣ ប្រេងអប់របស់ទ្រង់ធុំក្លិនក្រអូបល្អ[ឃ]
ព្រះនាម[ង]ទ្រង់ក៏ដូចជាប្រេងក្រអូបដែលចាក់ចេញហើយ
ហេតុនោះបានជាពួកព្រហ្មចារី[ច]សុទ្ធតែស្រឡាញ់ដល់ទ្រង់
៤ សូមទាញនាំខ្ញុំម្ចាស់ នោះយើងខ្ញុំនឹងរត់តាមទ្រង់ ។
"ស្តេចទ្រង់បាននាំខ្ញុំចូលទៅក្នុងបន្ទប់ទ្រង់"[ឆ]

**មិត្រសំឡាញ់**

យើងខ្ញុំនឹងមានចិត្តអំណរ[ជ]ហើយរីករាយក្នុងអង្គទ្រង់
យើងខ្ញុំនឹងនឹកចាំពីសេចក្តីស្រឡាញ់[ឈ]របស់ទ្រង់ ជាជាង
ស្រាទំពាំងបាយជូរ

**មាសសំឡាញ់**

គេស្រឡាញ់ទ្រង់ នោះគួរណាស់ហើយ ។
៥ ឱពួកកូនស្រីនៃក្រុងយេរូសាឡិមអើយ[ញ]
ខ្ញុំខ្មៅ តែល្អគួរសម[ដ]
ឧបមាដូចជាត្រសាលរបស់ពួកកេដារ[ឋ]
ក៏ដូចជាវាំងននរបស់ស្តេចសាឡូម៉ូន
៦ សូមកុំឱ្យមើលខ្ញុំ ដោយព្រោះខ្ញុំមានសម្បុរស្រគាំឡើយ
ដ្បិតខ្ញុំបានត្រូវហាលថ្ងៃហើយ
ពួកប្រុសៗពោះ១នឹងខ្ញុំ គេខឹងនឹងខ្ញុំ
គេបានឱ្យខ្ញុំថែរក្សាចំការទំពាំងបាយជូរ[ឌ]
ឯចំការរបស់ខ្លួនខ្ញុំវិញ នោះមិនបានថែរក្សាទេ ។
៧ ឱអ្នកដែលចិត្តខ្ញុំម្ចាស់ស្រឡាញ់អើយ
សូមប្រាប់ខ្ញុំម្ចាស់ពីទ្រង់ឃ្វាលហ្វូងសត្វ[ឍ]នៅត្រង់ណាផង
តើនៅកន្លែងណាដែលឱ្យសំរាកពេលថ្ងៃត្រង់
ដ្បិតតើមានទំនងអ្វីឱ្យខ្ញុំម្ចាស់បានដូចជាស្រីដែលត្រូវ
បាំងមុខ[ណ] នៅជាមួយនឹងហ្វូងសត្វរបស់ពួកភឿន
ទ្រង់ដូច្នេះ ។

**មិត្រសំឡាញ់**

៨ ឱនាងដែលល្អលើសជាងគេក្នុងពួកស្រីៗអើយ[ត]
បើមិនដឹងទេ នោះមានតែចេញទៅតាមដានជើងរបស់
ហ្វូងសត្វទៅ
ហើយឃ្វាលកូនពពែរបស់ឯងក្បែរត្រសាលរបស់ពួក
អ្នកគង្វាលចុះ ។

**១:១** ក ១ពវ ៤:៣២ ទដ ៤៥ ចំណងជើង
**១:២** ខ ខ.៤ ៤:១០ ៨:៦ គ លប ១៤:១៨ ពច ៩:១៣
**១:៣** ឃ នអ ២:១២ ទដ ៤៥:៨ ង សស ៧:១ ច ទដ ៤៥:១៤
**១:៤** ឆ ទដ ៤៥:១៥ ជ បស ២:៣ ឈ ខ.២
**១:៥** ញ បស ៥:១៦ ដ ២:១៤ ៤:៣ ឋ លប ២៥:១៣
**១:៦** ឌ បស ២:១៥ ៧:១២ ៨:១២
**១:៧** ឍ អស ១៣:២០ ណ លប ២៤:៦៥
**១:៨** ត បស ៥:៩ ៦:១

**១:១** *របស់ស្តេចសាឡូម៉ូន* មើលសេចក្តីផ្តើមត្រង់ចំណុច ចំណងជើង, អ្នកនិពន្ធ និងកាលបរិច្ឆេទ ។ *ចំរៀងដែលប្រសើរបំផុត* មើលសេចក្តីផ្តើមត្រង់ចំណុច ចំណងជើង ។ តាម ១ពវ ៤:៣២ ស្តេចសាឡូម៉ូនបាននិពន្ធបទចម្រៀង ១០០៥ បទ ។

**១:២–៣** *ថើប . . . សេចក្តីស្រឡាញ់របស់ទ្រង់ . . . ប្រេងក្រអូប* ធៀបនឹង ៤:១០ –១១ "សេចក្តីស្រឡាញ់របស់នាង . . . ប្រេងអប់របស់ឯង . . . បប្អូរមាត់ឯង"។

**១:២** *ប្តី . . ព្រះ . . . របស់ទ្រង់* សព្វនាមទាំងនេះសុទ្ធតែសំដៅទៅលើបុគ្គលតែម្នាក់ គឺស្ងួនសំឡាញ់(ស្តេចសាឡូម៉ូន)។ *សេចក្តីស្រឡាញ់* គឺបង្ហាញនូវសេចក្តីស្រឡាញ់ ដោយការបបោសអង្អែល អោប និងការរួមដំណេក (មើល ខ.៤ ៤:១០ ៧:១២ មើល សភ ៧:១៨ អគ ១៦:៨ ២៣:១៧)។ *វិសេសជាងស្រាទំពាំងបាយជូរ* មើល ខ.៤ ។ នៅក្នុង ៤:១០ ស្ងួនសំឡាញ់និយាយស្រដៀងគ្នាដូចមាសស្ងួន ។

**១:៣** *ប្រេងក្រអូប* គឺគ្រឿងក្រអូប ដែលលាយជាមួយនឹងជ័រម្យ៉ាង និងប្រេងសម្អាង ។ *ព្រះនាមទ្រង់* ការបញ្ចេញឈ្មោះរបស់ស្ងួនសំឡាញ់ធ្វើឱ្យខ្យល់អាកាសប្រែជាមានក្លិនក្រអូបជាទីគាប់ចិត្ត ។ ក្នុងព្រះគម្ពីរភាសារហេព្រើពាក្យ "ឈ្មោះ" និង "ប្រេងក្រអូប" គឺមានការបញ្ចេញសម្លេងដូចគ្នា ។ *ពួកព្រហ្មចារី* ប្រហែលជាពួកស្រីក្មេងៗនៃទីប្រជុំជន ឬរាជធានី(មើល ៦:៨–៩)។

**១:៤** *ស្តេច* គឺស្តេចសាឡូម៉ូន ។ *ក្នុងបន្ទប់ទ្រង់* គឺកន្លែងឯកជនរបស់ស្តេច។ *យើងខ្ញុំ* ប្រហែលជាពួកស្រីក្រមុំនៅក្នុង ខ.៣ ។ *សេចក្តីស្រឡាញ់របស់ទ្រង់ ជាជាងស្រាទំពាំងបាយជូរ* គឺដោយសារមូលហេតុក្នុង ខ.២ ។

**១:៥** *ពួកកូនស្រីនៃក្រុងយេរូសាឡិម* ប្រហែលជាពួកក្រមុំនៃខ.៣ និងតាមធម្មតាគឺជាមិត្រភ័ក្រ្ត ។ *ខ្មៅ* គឺធ្វើឱ្យសំបុរប្រែជាក្រមៅដោយពន្លឺថ្ងៃ(មើល ខ.៦) គឺមិនគួរឱ្យចង់បាន ។ *ត្រសាល . . . វាំងនន* គឺគេផលិតដោយដៃ ពីរោមពពែខ្មៅ ។ *កេដារ* មើលការពន្យល់ អស ២១:១៦ ។

**១:៦** *ពោះ១នឹងខ្ញុំ* ព្រះគម្ពីរបទចម្រៀងសាឡូម៉ូនប្រើពាក្យពោះមួយ ឬម្តាយចំនួន ៧ ដង(៣:៤,១១ ៦:៩ ៨:១–២,៥) តែមិនប្រើពាក្យឪពុកទេ ។ *ចំការទំពាំងបាយជូរ* គឺរូបកាយរបស់នាង ដូចនៅក្នុង ៨:១២(មើល ២:១៥)។ អ្នកនិពន្ធបានប្រៀបធៀបអំពីចំការទំពាំងបាយជូរ ដោយសារគេអាចយកផលស្រាទំពាំងបាយជូរពីចំការនោះបាន ហើយសេចក្តីរីករាយនៃស្នេហាគឺប្រៀបបានទៅនឹងសេចក្តីរីករាយ ដែលកើតពីស្រាទំពាំងបាយជូ(មើលការពន្យល់ខ.២)។ គេប្រៀបប្រដូចមាសសំឡាញ់នោះ ទៅនឹងចំការដែលបង្កើតផលផ្លែដ៏ពិសេស ដល់ស្ងួនសំឡាញ់(មើលការពន្យល់ ៤:១២)។

**១:៧** *អ្នកដែលចិត្តខ្ញុំម្ចាស់ស្រឡាញ់* មើល ៣:១ ។ *ឃ្វាលហ្វូងសត្វនៅត្រង់ណាផង* អ្នកនិពន្ធប្រដូចស្ងួនសំឡាញ់នោះ ទៅនឹងអ្នកគង្វាល ។ ខ.៨ ប្រដូចមាសសំឡាញ់ទៅនឹងអ្នកគង្វាល(ភេទស្រី)។ *ពេលថ្ងៃត្រង់* គឺពេលសម្រាកនៅក្នុងអាកាសធាតុក្តៅ ។ *ស្រីដែលត្រូវបាំងមុខ* គឺស្រីរកស៊ីផ្លូវភេទ(មើល លប ៣៨:១៤–១៥)។ មាសស្ងួនមិនទៅរកស្ងួនសំឡាញ់របស់ខ្លួន នៅក្នុងចំណោមពួកគង្វាលឡើយ ព្រោះការធ្វើដូចនេះគឺមិនខុសពីស្រីរកស៊ីផ្លូវភេទឡើយ ។

**១:៨** *ល្អលើសជាងគេ* គឺមាសសំឡាញ់ គឺដូចនៅក្នុង ខ.១៥ ២:១០,១៣ ៤:១,

**ស្ងួនសំឡាញ់**

៩ មាសសំឡាញ់អើយ
អញបានប្រៀបឯងដូចជាសេះទឹមរាជរថ[ថ] របស់ផារ៉ោន
១០ថ្ពាល់[ទ] ឯងស្រស់ល្អសមនឹងគ្រឿងតែង
ហើយកឯងផង ដែលប្រដាប់ដោយខ្សែដូច្នេះ[ធ]
១១យើងនឹងធ្វើប្រតោកមាសដាំដោយប្រាក់ឱ្យឯង ។

**មាសសំឡាញ់**

១២ កំពុងតែស្តេចទ្រង់គង់នៅតុ
នោះប្រេងទេព្វិរូរបស់ខ្ញុំបានផ្សាយក្លិនក្រអូបទៅ[ន]
១៣ស្ងួនសំឡាញ់របស់ខ្ញុំជាកញ្ចប់កំញាន[ប]
នៅនាវវាងដោះខ្ញុំទាំង២ដល់ខ្ញុំ
១៤ស្ងួនសំឡាញ់[ផ] របស់ខ្ញុំក៏ដូចជាកញ្ចុំផ្កាក្រពេន[ព] ដល់ខ្ញុំ
ដែលដុះនៅក្នុងចំការទំពាំងបាយជូរស្រុកអេន–កេឌី[ភ] ។

**មាសសំឡាញ់**

១៥មើលឯងស្រស់បស់ល្អ[ម] មាសសំឡាញ់អើយ
មើល ឯងស្រស់បស់ល្អណាស់
ភ្នែកឯងដូចជាភ្នែកព្រាប[យ] ។
១៦ មើល ព្រះអង្គក៏ល្អ ស្ងួនសំឡាញ់អើយ[រ]
អើ ទ្រង់គួរស្រឡាញ់ណាស់

**ស្ងួនសំឡាញ់**

១៧ដំណេករបស់យើងខៀវខ្ចី
រតផ្ទះរបស់យើងជាដើមតាត្រៅ[ល]
ហើយធ្នឹមរបស់យើងជាដើមកកោះ

**មាសសំឡាញ់**

**២** ខ្ញុំជាផ្កាកុឡាប[ក] ដែលដុះនៅវាលសារ៉ុន[ខ]
ជាផ្កាកំភ្លឹង[គ] ដែលដុះនៅច្រកភ្នំ ។

**ស្ងួនសំឡាញ់**

២ មាសសំឡាញ់របស់អញនៅកណ្តាលពួកកូនស្រីៗ
ប្រៀបដូចជាកំភ្លឹងដុះនៅកណ្តាលគុម្ពបន្លា ។

**មាសសំឡាញ់**

៣ស្ងួនសំឡាញ់[ឃ] របស់ខ្ញុំនៅកណ្តាលពួកកូនប្រុសៗ
នោះប្រៀបដូចជាដើមសារី នាកណ្តាលពួកឈើនៅព្រៃ
ខ្ញុំបានអង្គុយក្រោមម្លប់នៃទ្រង់ ដោយចិត្តរីករាយជាខ្លាំង[ង]
ហើយផ្លែរបស់ទ្រង់ក៏មានរសផ្អែមដល់អណ្តាតខ្ញុំ[ច]

**១:៩** ថ ២របា ១:១៧
**១:១០** ទ បស ៥:១៣
ធ អស ៦១:១០
**១:១២** ន បស ៤:១១–១៤
**១:១៣** ប លប ៣៧:២៥
**១:១៤** ផ ខ.១៦ បស ២:៣,១៧ ៥:៨
ព បស ៤:១៣
ភ ១សយ ២៣:២៩ ២របា ២០:២
**១:១៥** ម បស ៤:៧ ៧:៦ យ ទដ ៧៤:១៩ បស ២:១៤ ៤:១ ៥:២,១២ ៦:៩ យរ ៤៨:២៨
**១:១៦** រ ខ.១៤
**១:១៧** ល ១ពរ ៦:៩
**២:១** ក អស ៣៥:១
ខ ១របា ២៧:២៩
គ បស ៥:១៣ ហស ១៤:៥
**២:៣** ឃ បស ១:១៤
ង បស ១:៤ ច បស ៤:១៦

៧ ៥:៩ ៦:១,៤,១០ ("ស្រស់ប្រិមប្រិយ ឬស្រស់បស់ល្អ") ។ ខ.១៦ ហៅស្ងួនសំឡាញ់ថា គួរឱ្យស្រឡាញ់ (ក្នុងព្រះគម្ពីរភាសារហេព្រើ ពាក្យស្អាត និងសង្ហាគឺជាពាក្យតែមួយ) ។ *កូនពពែ* នៅត្រង់ចំណុចនេះ អ្នកនិពន្ធបានប្រដូចមាសសំឡាញ់ទៅនឹងអ្នកគង្វាល (ភេទស្រី ខ.៧) ។ *ក្បែរត្រសាលរបស់ពួកអ្នកគង្វាល* មាសសំឡាញ់បានទទួលការបង្រៀនឱ្យស្គាល់ ពីកន្លែងរបស់ស្ងួនសំឡាញ់ ដោយនៅជាមួយនឹងពួកអ្នកគង្វាលនៅក្នុងទីវាល ។

**១:៩** *មាសសំឡាញ់* ពាក្យនេះប្រើសម្រាប់តែភាគគីខាងស្រីប៉ុណ្ណោះ (មើលការពន្យល់ ខ.១៣) ។ *សេះ* គឺជាការប្រៀបប្រដូចបែបចែរចង់ គឺស្រដៀងគ្នានឹងការប្រៀបធៀបរបស់លោកថេអូគ្រីតូស (Theocritus) ដែលសរ–សើរសម្រស់របស់នាងហេលែននៃនគរត្រូយ (Henlen of Troy) ។ *ដូចជាសេះទឹមរាជរថរបស់ផារ៉ោន* គឺមានន័យថា សម្រស់នាងគឺមានការទាក់ទាញយ៉ាងខ្លាំង គឺប្រៀបបាននឹងសេះញីដែលទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំង ពីពួកសេះឈ្មោលដែលទឹមរទេះនៅនគរអេស៊ីព្ទ ។ តាម ១ពរ ១០:២៨ ស្តេចសាឡូម៉ូនបាននាំចូលសេះពីស្រុកអេស៊ីព្ទ ។

**១:១១** *យើង* ប្រហែលជា"ពួកកូនស្រីនៃក្រុងយេរូសាឡិម" (ខ.៥) ។

**១:១២** *ស្តេច* គឺស្តេចសាឡូម៉ូន ។ *នៅតុ* គឺអង្គុយតម្រេតខ្លួននៅលើកៅអីវែងដែលមានដៃ និងប្រើជាមួយនឹងតុ ។ *ប្រេងទេព្វិរូ* គឺសំដៅទៅលើប្រេងក្រអូបដែលគេចំរាញ់ចេញពីឫសតិណជាតិ ដែលដុះគ្រប់រដូវនៅប្រទេសឥណ្ឌា (មើល ៤:១៣–១៤ មក ១៤:៣ យហ ១២:៣) ។

**១:១៣** *ស្ងួនសំឡាញ់* គឺប្រើសម្រាប់តែភាគគីខាងបុរសប៉ុណ្ណោះ (មើលការពន្យល់ ខ.៩) ។ *កញ្ចប់កំញាន* គឺសំដៅទៅលើជ័រក្រអូបដែលចំរាញ់ចេញសម្បកដើមឈើសម្បូរជ័រម្យ៉ាង ដែលដុះនៅតំបន់អារ៉ាប់ ប្រទេសអេត្យូពី និងឥណ្ឌា ។ តាមធម្មតាគេប្រើវា ជាគ្រឿងប្រអូបខ្លាំងសម្រាប់មនុស្សស្រី (នអ ២:១២ សភ ៧:១៧) ។ គេប្រើជ័រក្រអូបនេះសម្រាប់អប់អាវផាយរបស់ស្តេចក្នុងពិធីអភិសេកផងដែរ (ទដ ៤៥:៨) និងសម្រាប់ផ្សំជាមួយប្រេងបរិសុទ្ធសម្រាប់ធ្វើប្រេងតាំងផងដែរ (នក ៣០:២៣) ។ ពួកហោរបាននាំយកជង្វាយកំញានថ្វាយព្រះយេស៊ូវ នៅពេលទ្រង់ទីបនឹងប្រសូត្រផងដែរ ដែលជាការសមនឹងធ្វើថ្វាយស្តេច ។

**១:១៤** *ក្រពេន* គឺសំដៅទៅលើផ្កាម្យ៉ាង (ប្រហែលស្រល់ម្យ៉ាង) ដុះជាកញ្ចុំៗ ហើយពេលរីកសាយភាយក្លិនខ្លាំង ។ *ស្រុកអេន–កេឌី* គឺជាតំបន់ព្រៃដង្គំក្នុងវាលខ្សាច់ដែលមានទឹកបាញ់ពីក្រោមដីមួយកន្លែង ដែលមានទីតាំងនៅខាងលិចនៃសមុទ្រស្លាប់ ។ លោកដាវីឌបានរត់គេពីស្តេចសូល ទៅជ្រកនៅទីនោះផងដែរ (សយ ២៤:១))

**១:១៥** *ស្រស់បស់ល្អ មាសសំឡាញ់* មើល ៤:១ ៦:៤ ធៀបនឹង ខ.១៦ ។ *មាសសំឡាញ់* មើលការពន្យល់ ខ.៩ ។ *ព្រាប* ប្រហែលជាសំដៅទៅលើទម្រង់ និងការផាត់ភ្នែកយ៉ាងស្រស់ស្អាតរបស់នាង (មើល ៤:១) ។

**១:១៦** *គួរស្រឡាញ់* មើលការពន្យល់ ខ.៨ ("ល្អ") ។

**១:១៧** *ខៀវខ្ចី* គឺមានន័យថា គូរស្នេហ៍មួយនោះបានតម្រេតខ្លួននៅលើវាលស្មៅខៀវខ្ចីនៅក្រោមដើមឈើជាច្រើន ។

**២:១** *ផ្កាកុឡាប* មើល អស ៣៥:១–២ ។ *វាលសារ៉ុន* គឺវាលទំនាបនៅតំបន់ឆ្នេរដែលមានដីជាតិនៅភាគខាងត្បូងនៃភ្នំកើមែល ។ *ផ្កាកំភ្លឹង* គឺសំដៅលើផ្កាឈូក ។

**២:២** *មាសសំឡាញ់* មើលការពន្យល់ ១:៩ ។ *ពួកកូនស្រីៗ* មើលការពន្យល់ ១:៣ ។

**២:៣** *ផ្លែរបស់ទ្រង់* ប្រហែលជាការប្រដូចទៅនឹងភាពស្និទ្ធស្នាលរបស់ស្ងួនសម្លាញ់ (មើល ខ.៥ និងការពន្យល់) ។

៤ទ្រង់បាននាំខ្ញុំទៅឯផ្ទះស៊ីលៀង[ឆ]
ហើយទង់[ជ]របស់ទ្រង់ដែលនៅពីលើខ្ញុំ
គឺជាសេចក្តីស្រឡាញ់
៥សូមទប់ទល់ខ្ញុំដោយផែនទំពាំងបាយជូរ
ហើយចំរើនកំឡាំងខ្ញុំជាផ្លែសារីផង[ឈ]
ដ្បិតខ្ញុំឈឺដោយរោគស្រឡាញ់[ញ]
៦ព្រះហស្តឆ្វេងទ្រង់ទ្រក្បាលខ្ញុំ
ហើយព្រះហស្តស្តាំក៏ឱបខ្ញុំ[ដ]
៧ឱពួកកូនស្រីក្រុងយេរូសាឡិមអើយ
ខ្ញុំចាប់ឱ្យនាងរាល់គ្នា[ឋ]ស្បថដោយនូវពួកប្រើស
និងពួកក្តាន់នៅវាលថា
នាងទាំងឡាយនឹងមិនអង្រួន ឬដាស់ស្ងួនសំឡាញ់
    របស់ខ្ញុំឡើយ[ឌ]
ចាំទាល់តែទ្រង់សព្វព្រះទ័យ ។
៨ នុ៎ះន៏ សំឡេងរបស់ស្ងួនសំឡាញ់ខ្ញុំ
មើល ទ្រង់មកមើល កំពុងតែផ្លោះនៅលើភ្នំ
ហើយលោតសំទុះរំលងនៅលើទួល[ឍ]
៩ស្ងួនសំឡាញ់របស់ខ្ញុំប្រៀបដូចជាប្រើស[ណ] ឬក្តាន់ស្ទាវ[ត]
មើល ទ្រង់ឈរនៅខាងក្រៅកំផែងហើយ
ទ្រង់អើតមើលតាមបង្អួច
ហើយក្រឡេកមើលតាមចន្លោះប្រដឺស ។
១០ ស្ងួនសំឡាញ់របស់ខ្ញុំបានមានបន្ទូលនឹងខ្ញុំថា
មាសសំឡាញ់អើយ ចូរក្រោកឡើង
ស្រស់ប្រិមប្រិយអើយ ចូរចេញមក
១១ដ្បិតមើល រដូវរងាកន្លងទៅហើយ
ភ្លៀងក៏រាំងស្រឡះហើយដែរ
១២ផ្កាទាំងប៉ុន្មានកំពុងតែលេចឡើងនៅផែនដី
ពេលដែលសត្វហើរយំកញ្ជ្រៀវបានមកដល់
ក៏ឮសំឡេងលលកនៅក្នុងស្រុកយើងហើយ
១៣ដើមល្វាមានផ្លែខ្ចីកំពុងតែទុំ[ថ]
ហើយដើមទំពាំងបាយជូរកំពុងតែផ្កា[ទ]
ក៏ផ្សាយក្លិនក្រអូបឈ្ងុយ
ដូច្នេះចូរក្រោកឡើង មាសសំឡាញ់អើយ
ឱស្រស់ប្រិមប្រិយអើយ ចូរចេញមក ។

## ស្ងួនសំឡាញ់

១៤ឱព្រាប[ធ]អញអើយ ឯងនៅតែក្នុងក្រហែងថ្ម
ឯងពួនក្នុងទីកំបាំងត្រង់ភ្នំបោតធ្វើអី
សូមឱ្យអញឃើញមុខឯង ហើយស្តាប់សំឡេងឯងផង
ដ្បិតសំឡេងឯងផ្អែមពីរោះ មុខឯងក៏ស្រស់បស់ល្អដែរ[ន] ។
១៥ចូរយើងទៅចាប់ចចក គឺជាកូនចចកទាំងប៉ុន្មាន[ប]
ដែលបំផ្លាញចំការទំពាំងបាយជូរទៅ[ផ]
ដ្បិតទំពាំងបាយជូររបស់យើងកំពុងតែផ្កាហើយ ។[ព]

## ស្ងួនសំឡាញ់

១៦ស្ងួនសំឡាញ់ខ្ញុំជារបស់ផងខ្ញុំ ខ្ញុំក៏ជារបស់ផងទ្រង់ដែរ[ភ]

**២:៤** ឆ នអ ១:១១ ជ ជន ១:៥២
**២:៥** ឈ បស ៧:៨ ញ បស ៥:៨
**២:៦** ដ បស ៨:៣
**២:៧** ឋ បស ៥:៨ ឌ បស ៣:៥ ៨:៤
**២:៨** ឍ ខ.១៧ បស ៨:១៤
**២:៩** ណ ២សយ ២:១៨ ត ខ.១៧ បស ៨:១៤
**២:១៣** ថ អស ២៨:៤ យរ ២៤:២ ហស ៩:១០ មីក ៧:១ ជន ៣:១២ ទ បស ៧:២
**២:១៤** ធ លប ៨:៨ បស ១:១៥ ន បស ១:៥
**២:១៥** ប ពច ១៥:៤ ផ បស ១:៦ ព បស ៧:១២
**២:១៦** ភ បស ៧:១០

**២:៤** *ទង់* មើល ៦:៤ ជន ២:២ ទដ ២០:៥ ។ ស្តេចទ្រង់បង្ហាញសេចក្តីស្រឡាញ់ដែលទ្រង់មានចំពោះនាង ឱ្យគ្រប់គ្នាបានដឹង គឺដូចជាការលើកបង្ហាញទង់ដ៏ធំរបស់កងទ័ពនោះដែរ ។
**២:៥** *ផែនទំពាំងបាយជូរ . . . ផ្លែសារី* ប្រហែលជាការប្រដូចនឹងការបបោសអង្អែល និងការអោបដោយសេចក្តីស្រឡាញ់ ។
**២:៧** ខនេះគឺជាការបន្ទរនៅក្នុងព្រះគម្ពីរបទចម្រៀងនេះ (៣:៥ ៨:៤ ធៀបនឹង ៥:៨)។ បទនេះច្រៀង និងបន្ទរដោយមាសសំឡាញ់ ហើយនិយាយអំពីទំនាក់ទំនងជិតស្និទ្ធជាមួយនឹងស្ងួនសំឡាញ់របស់នាង ។ *ពួកកូនស្រីក្រុងយេរូសាឡិម* មើលការពន្យល់ នក ១:៥ ។ *ពួកប្រើស និងពួកក្តាន់នៅវាល* ប្រហែលជាពាក្យស្រមៃអំពីសេចក្តីស្រឡាញ់ដែលមានពួកប្រើស និងពួកក្តាន់នៅវាលធ្វើជាសាក្សីនៃពាក្យសម្បថ ។ ការច្រៀងឆ្លើយឆ្លងដោយប្រើភាសា ដូចនេះគឺស៊ីសង្វាក់នឹងការដែលអ្នកនិពន្ធនិយាយ រៀបរាប់អំពីធម្មជាតិជាញឹកញាប់ ។ *ចាំទាល់តែទ្រង់សព្វព្រះទ័យ* តាមបទពិសោធន៍ស្នេហានៃមាសស្នេហ៍ សេចក្តីស្នេហាមិនត្រូវបញ្ឆេះដោយកត្តាខាងក្រៅនោះទេ គឺត្រូវចេញពីខាងក្នុងមក ដែលជាការត្រឹមត្រូវតាមសេចក្តីពិត និងសម្រស់នៃសេចក្តីស្នេហា ។
**២:៩** *ប្រើស* គេកោតសរសើររូបរាង្គ និងសម្រស់របស់វា ។ *ក្តានស្ទាវ* គឺជាការប្រៀបប្រដូចទៅនឹងកម្លាំង និងភាគក្លៀវក្លានៃយុវវ័យ (ធៀបនឹង អស ៣៥:៦)។ *អើតមើល . . . តាមចន្លោះប្រដឺស* ស្ងួនសំឡាញ់មានការអន្ទះសារនឹងឃើញមាសសំឡាញ់ នៅពេលដែលនាងកំពុងតែរៀបចំខ្លួនសម្រាប់ការជួបគ្នារបស់ពួកគេទាំងពីរ ។
**២:១០** *ក្រោកឡើង . . . ចេញមក* មើល ខ.១៣ ធៀបនឹង ៧:១១–១៣ ។ *ស្រស់ប្រិមប្រិយអើយ* មើលការពន្យល់ ១:៨ ។
**២:១១–១៣** វគ្គនេះគឺនិយាយអំពីទីសម្គាល់នៃការមកដល់ នៃរដូវផ្ការីក (មើល ៦:១១ ៧:១២) គឺជារដូវនៃសេចក្តីស្នេហា ។
**២:១៤** *ព្រាប . . . ក្នុងទីកំបាំងត្រង់ភ្នំចោតធ្វើអី* ធៀបនឹង ទដ ៥៥:៦–៨ យរ ៤៨:២៨ ។
**២:១៥** ខនេះប្រហែលជាបទរបស់មាសសំឡាញ់ ។ *ចំការទំពាំងបាយជូរ* គឺដូចនៅក្នុង ១:៦ ("គឺចំការទំពាំងបាយជូររបស់ខ្ញុំ") អាចជាការប្រៀបប្រដូចទៅនឹងសម្រស់សាច់ឈាមនៃស្ងួនសំឡាញ់ ។ ដូចនេះចិត្តរបស់ពួកគេគឺចង់ធ្វើយ៉ាងណាឱ្យគូស្នេហ៍របស់ពួកគេនៅតែមានភាពទាក់ទាញគ្នាទៅវិញទៅមកជានិច្ច ។ *កំពុងតែផ្កា* គឺមានន័យថា ភាពទាក់ទាញកំពុងតែមានកម្រិតខ្លាំងបំផុត ។
**២:១៦** *ស្ងួនសំឡាញ់ខ្ញុំជារបស់ផងខ្ញុំ ខ្ញុំក៏ជារបស់ផងទ្រង់ដែរ* មើល ៦:៣ ៧:១០ ។ ពួកគេជាម្ចាស់គ្នាទៅវិញទៅមក នៅក្នុងទំនាក់ទំនងស្នេហាដែលមិនអនុញ្ញាតឱ្យនរណាមករំខានឡើយ ។ *នៅទីមានផ្កាកំភ្លឹង* គឺជាការប្រៀប

ទ្រង់ឃ្វាលហ្វូងសត្វនៅទីមានផ្កាកំភ្លឹង[ម]
១៧ឱស្ងួនសំឡាញ់អើយ[យ] សូមវិលទៅវិញ
ធ្វើដូចជាប្រើស ឬក្តាន់ស្ទាវ[រ] នៅលើភ្នំបេធើរ[ល]
ចាំដល់ថ្ងៃត្រជាក់ ហើយស្រមោលបាត់ទៅសិន[វ] ។

៣នៅរាត្រីយប់កំពុងដេកនៅលើដំណេក
នោះខ្ញុំក៏ស្វែងរក[ក]ព្រះអង្គដែលដួងចិត្តខ្ញុំសំឡាញ់
ខ្ញុំខំស្វែងរក ប៉ុន្តែមិនឃើញទ្រង់សោះ
២ដូច្នេះ ក៏នឹកថា អញនឹងក្រោកឡើងដើរទៅមកក្នុងទីក្រុង
អញនឹងស្វែងរកព្រះអង្គដែលដួងចិត្តអញស្រឡាញ់
នៅតាមផ្លូវទាំងប៉ុន្មាន ហើយនៅទីធ្លាផង
ខ្ញុំក៏ខំស្វែងរក ប៉ុន្មានមិនឃើញទ្រង់សោះ
៣ពួកយាមល្បាតដែលដើរក្រវែលក្នុងទីក្រុង[ខ] គេប្រទះនឹងខ្ញុំ
ហើយខ្ញុំសួរគេថា អ្នករាល់គ្នាបានឃើញព្រះអង្គដែល
ដួងចិត្តខ្ញុំស្រឡាញ់ឬទេ
៤ខ្ញុំបានដើរហួសពីគេតែបន្តិចទេ
ស្រាប់តែប្រទះនឹងព្រះអង្គដែលដួងចិត្តខ្ញុំស្រឡាញ់
ខ្ញុំបានចាប់អង្គទ្រង់
មិនព្រមឱ្យទ្រង់ឃ្លាតទៅឡើយ
ទាល់តែខ្ញុំបាននាំចូលទៅក្នុងផ្ទះរបស់ម្តាយខ្ញុំ[គ]
គឺក្នុងបន្ទប់របស់អ្នកដែលមានគភ៌បង្កើតខ្ញុំមក ។[ឃ]
៥ឱពួកកូនស្រីក្រុងយេរូសាឡិមអើយ
ខ្ញុំចាប់ឱ្យនាងរាល់គ្នា[ង]ស្បថដោយនូវពួកប្រើសនឹងពួក
ក្តាន់នៅវាលថា
នាងខ្ញុំទាំងឡាយនឹងមិនអង្រួន ឬដាស់ស្ងួនសំឡាញ់របស់
ខ្ញុំឡើយ
ចាំទាល់តែទ្រង់សព្វព្រះទ័យ[ច] ។
៦តើអ្នកណានុ៎ះ ដែលឡើងពីទីរហោស្ថានមក[ឆ]
មានហុយដូចជាផ្សែង មានអប់ខ្លួនដោយខ្លឹមចន្ទន៍[ជ]
និងកំញាន
ព្រមទាំងម្សៅក្រអូប[ឈ]គ្រប់យ៉ាងរបស់ពួកជំនួញដូច្នេះ
៧នុ៎ះន៏ គឺជាព្រះសែងរបស់សាឡូម៉ូន
មានមនុស្សស្ទាត់ជំនួញក្នុងពួកខ្លាំងពូកែនៃសាសន៍[ញ]
អ៊ីស្រាអែល៦០នាក់ហែហមទ្រង់
៨គ្រប់គ្នាមានដាវ ហើយក៏ថ្នឹកខាងចំបាំង
គ្រប់គ្នានែបដាវនៅត្រគាក
ក្រែងមានហេតុភ័យនៅរាត្រីយប់[ដ] ។
៩ស្តេចសាឡូម៉ូនបានធ្វើព្រះខែសិវរាប់ទ្រង់
ដោយឈើពីព្រៃល្បាណូន
១០ទ្រង់ធ្វើសសរដោយប្រាក់ ក្រាលកំរាលដោយមាស
ទីគង់បានធ្វើពីសំពត់ពណ៌ស្វាយ
ហើយខាងក្នុងមានសំពត់ដែលពួកកូនស្រីៗក្រុង
យេរូសាឡិមបានប៉ាក់ដោយសេចក្តីស្រឡាញ់ ។
១១ពួកកូនស្រីក្រុងស៊ីយ៉ូនអើយ[ឋ]
ចូរចេញទៅមើលស្តេចសាឡូម៉ូនចុះ
ត្រង់ពាក់មកុដដែលព្រះមាតាបានបំពាក់ថ្វាយ
ក្នុងថ្ងៃវិវាហមង្គលទ្រង់
គឺនៅថ្ងៃដែលទ្រង់មានព្រះទ័យរីករាយសប្បាយ[ឌ] ។

**២:១៦** ម បស ៤:៥ ៦:៣
**២:១៧** យ បស ១:១៤ រ ខ.៩ ល ខ.៨ វ បស ៤:៦
**៣:១** ក បស ៥:៦
**៣:៣** ខ បស ៥:៧
**៣:៤** គ បស ៨:២ ឃ បស ៦:៩ ៨:៥
**៣:៥** ង បស ២:៧
ច បស ៨:៤
**៣:៦** ឆ បស ៨:៥ ជ បស ៤:៦,១៤ ឈ នក ៣០:៣៤
**៣:៧** ញ ១សយ ៨:១១
**៣:៨** ដ យប ១៥:២២ ទដ ៩១:៥
**៣:១១** ឋ អស ៣:១៦ ៤:៤ ៣២:៩–១៣ ឌ អស ៥៤:៥ ៦២:៥ យរ ៣:១៤

ប្រដូចទៅនឹងការដែលស្ងួនសំឡាញ់សប្បាយនឹងសម្រស់របស់នាង (មើល ៦:២–៣) ។

**៣:១** ខនេះនិយាយអំពីឱកាសថ្មីមួយទៀតនៃបទពិសោធន៍ស្នេហា ។ *នៅរាត្រីយប់* ពេលយប់គឺជាពេលគ្មានការរំខានដែលតែងកើតមាននៅថ្ងៃ ដូចនេះចិត្តនាងអាចផ្តោតអារម្មណ៍គិត ។

**៣:៣** *ពួកយាមល្បាត* គឺប្រចាំការនៅទ្វារក្រុង (មើល នហ ៣:២៩ ១១:១៩ ១៣:២២) និងនៅតាមកំផែង (មើល ៥:៧ ២សយ ១៣:៣៤ ១៨:២៤–២៧ ២ពវ ៩:១៧–២០ ទដ ១២៧:១ អស ៥២:៨ ៦២:៦) ។ ពួកនេះដើរយាមល្បាតតាមដងផ្លូវនៅពេលយប់ផងដែរ (មើល ៥:៧) ។

**៣:៤** *របស់ម្តាយ* មើលការពន្យល់ ១:៦ ។

**៣:៥** មើលការពន្យល់ ២:៧ ។ ការចាប់ឱ្យស្បថបានកើតជាថ្មីម្តងទៀតនៅពេលដែលមានការស្និទ្ធស្នាលខ្លាំង ។

**៣:៦–១១** វគ្គនេះប្រហែលជាពាក្យរបស់ពួកមិត្រសំឡាញ់ (មើល ៨:៥) ។ បើពិតជាពាក្យរបស់ពួកមិត្រសំឡាញ់មែន នោះគឺមានន័យថា ស្តេចសាឡូម៉ូន និងកូនក្រមុំរបស់ទ្រង់កំពុងតែបណ្តើរគ្នាឆ្ពោះទៅកាន់ទីក្រុង នៅក្នុងពិធីអភិសេក ។

**៣:៦** ខនេះនិយាយពីការចាប់ផ្តើមឱកាសថ្មីមួយទៀតនៃទំនាក់ទំនងស្នេហា ។ *តើអ្នកណានុ៎ះ . . . ទីរហោស្ថាន* មើល ៨:៥ ដែលនិយាយយោងទៅដល់មាសសំឡាញ់ ។ *ទីរហោស្ថាន* គឺសំដៅទៅលើវាលស្មៅដែលគេមិនធ្វើការច្រូតកាត់នៅក្នុងរដូវណាមួយ ។ *ផ្សែង* គឺផ្សែងចេញពីការដុតគ្រឿងក្រអូប (មើលការពន្យល់ នក ៣០:៣៤) ។ *របស់ពួកជំនួញ* គឺមានន័យថា របស់នាំចូលពីក្រៅប្រទេស ។

**៣:៧** *ព្រះសែង* គឺគ្រែស្នែងរបស់ស្តេចដែលមានការតុបតែងយ៉ាងល្អឆើត (មើល ខ.៩–១០) ។

**៣:៨** *ហេតុភ័យនៅរាត្រីយប់* មើល ទដ ៩១:៥ ។

**៣:៩** *ឈើពីព្រៃល្បាណូន* មើល ៥:១៥ និងការពន្យល់ ។

**៣:១០** *សសរ* គឺសសរទ្រដំបូលក្រណាត់ ។ *ប្រាក់ . . . មាស* គេជឿថា ប្រាក់ និងមាសនោះគឺស្រោបឈើពីព្រៃល្បាណូន ។ *ពណ៌ស្វាយ* មើលការពន្យល់ ៧:៥ នក ២៥:៤ ។

**៣:១១** *ពួកកូនស្រីក្រុងស៊ីយ៉ូន* ខផ្សេងទៀតប្រើពាក្យ "ពួកកូនស្រីក្រុងយេរូសាឡិម" (មើលការពន្យល់ ១:៥) ។ *មកុដ* គឺមកុដដែលប្រើក្នុងពិធីមង្គលការ (មើល អស ៦១:១០) ។ *ព្រះមាតា* គឺនាងបាតសេបា ។

## ស្ងួនសំឡាញ់

៤ មាសសំឡាញ់អើយ ឯងស្រស់បស់ល្អណាស់ហ្ន៎
មើល ឯងជាស្រីស្រស់បស់ល្អ
ភ្នែកឯងដែលបាំងដោយស្បៃ[ក] មើលទៅដូចជាភ្នែកព្រាប[ខ]
សក់ឯងមានភាពដូចជាហ្វូងពពែ ដែលដេកនៅចង្កេះភ្នំ
កាឡាត[គ]
២ ធ្មេញឯងក៏ដូចជាហ្វូងចៀមដែលទើបនឹងកាត់រោម
រួចឡើងមកពីការលាងជំរះវិញ
ជាសត្វដែលមានកូនភ្លោះរៀងរាល់តួ
ឥតមានណាមួយដែលបាត់កូនឡើយ[ឃ]
៣ បបូរមាត់ឯងដូចជាអំបោះក្រហម មាត់[ង]ឯងក៏ល្អមើល[ច]
តើកឯងដែលបាំងដោយស្បៃ មើលទៅដូចជាផ្លែទទឹម
១ចំហៀង[ឆ]
៤ កឯងដូចជាប៉ម[ជ]នៃស្តេចដាវីឌ
ដែលសង់ឡើងសំរាប់ជាទីក្រុងគ្រឿងអាវុធ
ជាកន្លែងដែលមានខែល១ពាន់ព្យួរទុក[ឈ]
គឺជាខែលទាំងប៉ុន្មានរបស់ពួកស្ទាត់ជំនាញ
៥ ដោះ[ញ]ឯងទាំង២ដូចជាកូនក្តាន២
ដែលជាកូនភ្លោះរបស់មេ១[ដ]
ដែលកំពុងរកស៊ីនៅទីមានផ្កាកំភ្លឹង[ឋ]។
៦ អញនឹងចេញទៅឯភ្នំចន្ទន៍[ឌ] ហើយដល់ទួលកំញាន
ចាំទាល់តែថ្ងៃត្រជាក់ ហើយស្រមោលបាត់ទៅសិន[ឍ]។
៧ ឱមាសសំឡាញ់អើយ ឯងស្រស់បស់ល្អ[ណ]សព្វសារពាង្គ
ឥតមានខ្ចោះ[ត]នៅខ្លួននាងឡើយ
៨ ប្រពន្ធអើយ[ថ] ចូរមកពីភ្នំល្បាណូនជាមួយនឹងអញចុះ
គឺពីភ្នំល្បាលណូនទៅមើលពីកំពូលភ្នំអាម៉ាណា
ពីកំពូលភ្នំសេនារ[ទ] ហើយនិងកំពូលភ្នំហើម៉ូនផង[ធ]
គឺពីរូងសត្វសិង្ហ ហើយពីភ្នំរបស់ខ្លារខិន
៩ ឱប្អូន ជាប្រពន្ធអើយ[ន]
ឯងបានចាប់យកដួងចិត្តអញទៅហើយ
ឯងបានចាប់យកដួងចិត្តអញទៅដោយភ្នែកឯងតែ១
ដោយសារខ្សែករបស់ឯងតែ១ប៉ុណ្ណោះ[ប]
១០ ឱប្អូន ជាប្រពន្ធអើយ សេចក្តីស្រឡាញ់[ផ]របស់នាង
ល្អវិសេសណាស់ហ្ន៎[ព]
សេចក្តីស្រឡាញ់របស់ឯងឆាញ់ជាងស្រាទំពាំងបាយជូរ[ភ]
ហើយក្លិនប្រេងអប់របស់ឯងក៏ក្រអូប[ម]ជាគ្រឿងក្រអូប
ទាំងឡាយ

**៤:១** ក លប ២៤:៦៥ ខ បស ១:១៥ គ លប ៣៧:២៥ ជន ៣២:១ បស ៦:៥ យរ ២២:៦ មីក ៧:១៤ **៤:២** ឃ បស ៦:៦ **៤:៣** ង បស ៥:១៦ ច បស ១:៥ ឆ បស ៦:៧ **៤:៤** ជ ទដ ១៤៤:១២ ឈ អគ ២៧:១០ **៤:៥** ញ បស ៧:៣ ដ សភ ៥:១៩ ឋ បស ២:១៦ **៤:៦** ឌ បស ៣:៦ ឍ បស ២:១៧ **៤:៧** ណ បស ១:១៥ ត បស ៥:២ **៤:៨** ថ ខ.៩,១២ បស ៥:១ ទ ចទ ៣:៩ ធ ១រប ៥:២៣ **៤:៩** ន ខ.៨ ប លប ៤១:៤២ ទដ ៧៣:៦ **៤:១០** ផ បស ១:២ ព បស ៧:៦ ភ ពច ៩:១៣ ម ខ.១៦ ទដ ៤៥:៨ អស ៥៧:៩

**៤:១–៧** ចំពោះការពិពណ៌នាអំពីសម្រស់នៃមាសសំឡាញ់នៅក្នុងវគ្គផ្សេងទៀត មើល ៦:៤–៩ ៧:១–៧ ។

**៤:១ខ–២** មើល ៦:៥ខ–៦ ។

**៤:១** *មាសសំឡាញ់អើយ ឯងស្រស់បស់ល្អណាស់ហ្ន៎* មើល ១:១៥ និងការពន្យល់ ។ *ភ្នែកឯងដែលបាំងដោយស្បៃ* មុខរបស់នាងត្រូវបិទបាំងដោយស្បៃទាំងស្រុង ដូចនេះស្ងួនសំឡាញ់ធ្វើការផ្តោតទៅលើភ្នែករបស់នាង ។ *ព្រាប* មើល ១:១៥ និងការពន្យល់ ។ *ហ្វូងពពែ* តាមធម្មតា ពពែនៅស្រុកកាណានមានសម្បុរខ្មៅ (មើលការពន្យល់ ១:៥) ។ សក់របស់ស្ងួនសំឡាញ់ក៏មានពណ៌ខ្មៅដែរ (៥:១១) ។ *ដែលដេកនៅចង្កេះភ្នំកាឡាត* សក់របស់មាសសំឡាញ់ធ្លាក់ចុះមកពីលើក្បាលរបស់នាង ធ្វើឱ្យស្ងួនសំឡាញ់នឹកឃើញដល់ហ្វូងពពែខ្មៅ ដែលនាំគ្នាទាំងហ្វូងចុះពីលើភ្នំកាឡាតដូចជាទឹកធ្លាក់ (ភ្នំនេះសម្បូរទៅដោយស្មៅ) ។

**៤:២** *ដែលទើបនឹងកាត់រោម* គឺកាត់ឱ្យបានសស្អាត ។ *រួចឡើងមកពីការលាងជំរះវិញ* គឺនៅសើមៗនៅឡើយ ដូចធ្មេញសើម ។

**៤:៣** *បបូរមាត់ឯងដូចជាអំបោះក្រហម* ប្រហែលជា មាសសំឡាញ់លាបបបូរមាត់របស់នាង ដូចពួកស្ត្រីអេស៊ីព្ទ ។ *កឯងដែលបាំងដោយស្បៃ* មើលការពន្យល់ ខ.១ ។ *ផ្លែទទឹម១ចំហៀង* គឺមានន័យថា មានរាងមូលហើយឡើងក្រហម ។

**៤:៤** ករបស់មាសសំឡាញ់ត្រង់ និងលម្អដោយការតុបតែង គឺដូចជាប៉មដែលសង់នៅតាមកំផែង ដែលលម្អដោយខែលនៃអ្នកចម្បាំង (ធៀបនឹង ៧:៤) ។

**៤:៥** មើល ៧:៣ ។ *ក្តាន់* គឺសំដៅទៅលើភាពទន់ តូចច្រឡឹង ហើយស្រស់ស្អាត គឺមិនទាន់រីកធំ (ធៀបនឹង ៨:៨) ។ *មេ* មើលការពន្យល់ ២:៩ ។ ខផ្សេងទៀតប្រៀបប្រដូចពាក្យនេះទៅនឹងស្ងួនសំឡាញ់ ។ *រកស៊ីនៅទីមានផ្កាកំភ្លឹង* ចំពោះការប្រើពាក្យនេះនៅក្នុងខផ្សេងទៀត មើល ២:១៦ និងការពន្យល់ ។

**៤:៦** *ភ្នំចន្ទន៍ . . . ទួលកំញាន* គឺជាការប្រៀបប្រដូចទៅនឹងភាពស្និទ្ធស្នាលខ្លាំងនៃគូស្នេហ៍ ។ *ទាល់តែ . . . ស្រមោលបាត់ទៅសិន* មើល ២:១៦ និងការពន្យល់ ។

**៤:៨** ចំពោះស្ងួនសំឡាញ់ មាសសំឡាញ់ហាក់ដូចជាត្រូវបានគេនាំយកទៅទីភ្នំដាច់ស្រយាលមួយ ។ *ភ្នំល្បាណូន . . ភ្នំអាម៉ាណា . . . ភ្នំហើម៉ូន* គឺទៅលើកំពូលភ្នំនៃតំបន់ខាងជើង ។ *ភ្នំសេនារ* គឺជាឈ្មោះរបស់ភ្នំហ៊ើម៉ូន ជាភាសាអាម៉ូរី (ចទ ៣:៩) ។

**៤:៩** *ប្អូន* នៅតំបន់មជ្ឈិមបូព៌ាសម័យបុរាណ ការសរសេរកំណាព្យស្នេហាដោយប្រើពាក្យ "បងប្រុស" និង "ប្អូនស្រី" ដើម្បីឆ្លើយឆ្លងគ្នារវាងគូស្នេហ៍ គឺជារឿងធម្មតា (មើល ខ.១០,១២ ៥:១) ។ *ដោយភ្នែកឯងតែ១* មើល ៦:៥ និងការពន្យល់ ។

**៤:១០** *ល្អវិសេសណាស់ហ្ន៎ . . . ជាងស្រាទំពាំងបាយជូរ* មើលការពន្យល់ ១:២ ។ *ក្លិនប្រេងអប់* មើល ១:៣ ។ *គ្រឿងក្រអូប* មើល ខ.១៤ ៥:១,១៣ ៦:២ ៨:១៤ ។ គ្រឿងក្រអូបនេះគឺជារបស់មានតម្លៃដែលនាំចូលមកពីបរទេស (មើល ១ពវ ១០:២,១០,២៥ អគ ២៧:២២) ។ គេប្រើគ្រឿងក្រអូបជាគ្រឿងផ្សំក្លិនក្រអូបដល់ប្រេងតាំង (នក ២៥:៦ ៣០:២៣–២៥ ៣៥:៨) គ្រឿងផ្សែងក្រអូប (នក ២៥:៦ ៣៥:៨) និងទឹកអប់ផងដែរ ។

១១ឱប្រពន្ធអើយ បបូរមាត់ឯងស្រក់មកជាទឹកឃ្មុំ
មានទឹកឃ្មុំនឹងទឹកដោះគោនៅក្រោមអណ្ដាតឯង[យ]
ហើយក្លិនសំលៀកបំពាក់របស់ឯងដូចជាក្លិនក្រអូប
នៃព្រៃល្បាណូន[រ]
១២ប្អូន ជាប្រពន្ធរបស់អញ[ល] ប្រៀបដូចជាសួនច្បារ[វ]
ដែលរាំងផ្លូវចូល
ជារន្ធទឹកដែលគេហួងហែង ជាទឹកផុសដែលគេបិទខ្ទប់[ស]
១៣ត្រួយឯងជាចំការទទឹម[ហ] មានផ្លែដ៏វិសេស
ក៏មានដើមក្រពេន[ឡ] និងដើមទេព្វិរូ
១៤គឺទេព្វិរូនឹងរមៀត ដើមកន្ទាយហើយសម្បុរល្វែង[អ]
នូវដើមឈើទាំងប៉ុន្មានដែលសំរាប់ធ្វើគ្រឿងក្រអូបដែរ
និងដំរល្វីងទេស[ក] ក្រឹស្នា[ខ] ហើយគ្រឿងក្រអូបយ៉ាង
សំខាន់ទាំងអស់[គ]
១៥ឯងជាក្បាលទឹកដែលស្រោចសួនច្បារ[ឃ] ជាអណ្តូង[ង]
មានទឹករស់ ជាជ្រោះទឹកហូរមកពីភ្នំល្បាណូន ។

**មាសសំឡាញ់**

១៦ ឱខ្យល់ខាងជើងអើយ ចូរភ្ញាក់ឡើង
ហើយខ្យល់ខាងត្បូងអើយ ចូរមកចុះ
ចូរបក់មកលើសួនច្បាររបស់ខ្ញុំ[ច] ដើម្បីឱ្យក្លិនក្រអូប[ឆ]
ផ្សាយចេញទៅ
សូមឱ្យស្ងួនសំឡាញ់[ជ]របស់ខ្ញុំចូលមកក្នុងសួនច្បារទ្រង់
ហើយសោយផលដ៏មានឱជារសរបស់ទ្រង់ចុះ[ឈ] ។

**ស្ងួនសំឡាញ់**

**៥** ឱប្អូន ជាប្រពន្ធអើយ[ក]
អញបានចូលមកក្នុងសួនច្បារអញហើយ[ខ]
អញបានបេះដំរល្វីងទេស និងគ្រឿងក្រអូបរបស់អញ
អញបានបរិភោគសំណុំ និងទឹកឃ្មុំរបស់អញ
អញបានផឹកស្រាទំពាំងបាយជូរ និងទឹកដោះគោហើយ[គ]

**មិត្រសំឡាញ់**

ឱសំឡាញ់រាល់គ្នាអើយ ចូរពិសាចុះ
ឱមាសសំឡាញ់អើយ ចូរផឹកចុះ អើ ផឹកឱ្យបរិបូរទៅ ។

**មាសសំឡាញ់**

២ ខ្ញុំបានដេកលក់ហើយ តែចិត្តខ្ញុំនៅភ្ញាក់ទេ
នោះឮសំឡេងរបស់ស្ងួនសំឡាញ់ខ្ញុំ ទ្រង់គោះទ្វារថា

**៤:១១** យ ទដ ១៩:១០ បស ៥:១ រ ហស ១៤:៦
**៤:១២** ល ខ.៨ វ ខ.១៦ បស ៥:១ ៦:២ អស ៥:៧ ស សភ ៥:១៥–១៨
**៤:១៣** ហ បស ៧:១២ ឡ បស ១:១៤
**៤:១៤** អ នក ៣០:២៣ ក បស ៣:៦ ខ ជន ២៤:៦ គ បស ១:១២
**៤:១៥** ឃ អស ២៧:២ ៥៨:១១ យរ ៣១:១២ ង សភ ៥:១៨
**៤:១៦** ច ខ.១២ ឆ ខ.១០ ជ បស ៧:១៣ ឈ បស ២:៣
**៥:១** ក បស ៤:១២ ខ បស ៤:៨ គ បស ៤:១១ អស ៥៥:១ យអ ៣:១៨

**៤:១១** *បបូរមាត់ឯងស្រក់មកជាទឹកឃ្មុំ* មាសសំឡាញ់និយាយពាក្យនេះទៅកាន់ទ្រង់ ដោយសេចក្ដីស្នេហា (ធៀបនឹង សភ ៥:៣ ១៦:២៤) ។ អ្នករស់នៅមជ្ឈិមបូព៌ាសម័យបុរាណមានទម្លាប់ប្រដូចរស់ជាតិផ្អែម ទៅនឹងរស់ជាតិស្នេហ៍ ។ *ទឹកឃ្មុំ និងទឹកដោះគោ* ពាក្យនេះប្រហែលជារំឭកទៅដល់ការពិពណ៌នាអំពីទឹកដីសន្យា (មើលការពន្យល់ នក ៣:៨) ។ *នៅក្រោមអណ្ដាតឯង* មើល យប ២០:១២ ទដ ១០:៧ ។

**៤:១២** *សួនច្បារ* គឺជាកន្លែងដែលអាចកម្សាន្តអារម្មណ៍ (មើល ខ.១៦ ៥:១ ៦:២ និងការពន្យល់ ១:៦) ។ *រាំងផ្លូវចូល . . . ហួងហែង . . . បិទខ្ទប់* គឺជាពាក្យប្រៀបប្រដូចទៅនឹងភាពបរិសុទ្ធរបស់មាសសំឡាញ់ ឬប្រហែលជាសំដៅទៅលើការដែលនាងរក្សាខ្លួននាងទុកសម្រាប់ប្ដីនាងតែម្នាក់គត់ ។ *រន្ធទឹក . . . ទឹកផុស* គឺជាប្រភពនៃចំណីអាហារ និងជាការប្រៀបប្រដូចអំពីការដែលមាសសំឡាញ់គឺជាដៃគូរួមដំណេកម្នាក់ គឺដូចនៅក្នុង សភ ៥:១៥–២០ ។

**៤:១៣–១៥ខ** វគ្គខ.១៣–១៤បកស្រាយអំពីការប្រៀបប្រដូចទៅនឹងសួនច្បារនៅក្នុង ខ.១២ក និងខ.១៥ បកស្រាយអំពីការប្រៀបប្រដូចទៅនឹងទឹកផុសនៅក្នុង ខ.១២ខ ។ ដើមឈើ និងគ្រឿងក្រអូប នៅក្នុង ខ.១៣–១៤ គឺជាគ្រឿងពិសេសដែលនាំឱ្យមាសសំឡាញ់មានភាពទាក់ទាញ ។

**៤:១៣** *ត្រួយឯង* គឺសំដៅទៅលើលក្ខណៈរបស់មាសសំឡាញ់ ដែលធ្វើឱ្យស្ងួនសំឡាញ់រីករាយ ។ *ទទឹម* គឺសំដៅទៅលើពាក្យនៅក្នុងភាសាហេព្រើ គឺផាឌីស (Pardes ពាក្យនេះគឺជាឫសនៅពាក្យ "ផារ៉ាដាយស៍"Paradises នៅក្នុងភាសាអង់គ្លេសដែលប្រែថា ស្ថានសួគ៌) ជាពាក្យកម្ចីមកពីភាសាពើស៊ីដែលមានន័យថា "ទីមានរបងព័ទ្ធ" ឬ "សួនច្បា"។ នៅក្នុង នហ ២:៨ និង សស ២:៥ ពាក្យនេះគឺសំដៅទៅលើឧទ្យាន និងព្រៃរបស់ស្ដេច ។ *ដើមក្រពេន* មើលការពន្យល់ ១:១៤ ។ *ដើមទេព្វិរូ* មើលការពន្យល់ ១:១២ ។

**៤:១៤** *ដើមកន្ទាយ* គឺសំដៅទៅលើគ្រឿងក្រអូបដែលនាំចូលមកពីបរទេស (មើល យរ ៦:២០ និងការពន្យល់) មានសណ្ឋានបែបដើមអំពៅ ហើយគេប្រើវាជាគ្រឿងផ្សំនៅក្នុងប្រេងតាំងបរិសុទ្ធ (នក ៣០:២៣,២៥ "ឫសកន្ទាយ") និងគ្រឿងផ្សេងក្រអូប (អស ៤៣:២៣–២៤) ។ *សម្បុរល្វែង* សំដៅទៅលើគ្រឿងផ្សំម្យ៉ាងទៀតនៃប្រេងតាំង (នក ៣០:២៣,២៥) ។ *ដំរល្វីងទេស* មើលការពន្យល់ ១:១៣ ។ *ក្រឹស្នា* គឺសំដៅទៅលើគ្រឿងក្រអូបសម្រាប់អប់អាវផាយនៅក្នុងពិធីអភិសេក (ទដ ៤៥:៨) ។ នៅក្នុង សភ ៧:១៧ "ខ្ញុំបានប្រោះដំណេកដោយគ្រឿងក្រអូប គឺដោយដំរល្វីងទេស ក្រឹស្នា និងសម្បុរល្វែង"។

**៤:១៥** *ស្រោច* គឺមានន័យថា ស្រស់ថ្លា គឺមិនដូចទឹកនឹងដែលមានក្លិនស្អុយ ។ *ទឹករស់ . . . មកពីភ្នំល្បាណូន* គឺស្រស់ថ្លា ត្រជាក់ មានពពុះទឹក ជាទឹកធ្លាក់ពីវាលទឹកកកនៅតាមភ្នំល្បាណូន ។

**៤:១៦** ត្រង់ចំណុចនេះគឺមានន័យថា សូមឱ្យក្លិនក្រអូបរបស់ខ្ញុំសាយភាយឡើងធ្វើឱ្យខ្ញុំកាន់តែទាក់ទាញ ដើម្បីនាំម្ចាស់ស្នេហ៍របស់ខ្ញុំចូលមក ដើម្បីសប្បាយនៅក្នុងដំណេកជាមួយនឹងខ្ញុំ ។ *សួនច្បារទ្រង់* គឺមានន័យថា នាងជាកម្មសិទ្ធិរបស់ទ្រង់ ដូចនេះនាងត្រូវថ្វាយរូបកាយនាងដល់ទ្រង់ (មើល ៦:២) ។

**៥:១** ស្ងួនសំឡាញ់បានប្រកាសថា មាសសំឡាញ់នៃទ្រង់គឺជាសួនច្បារទ្រង់ ហើយទ្រង់ត្រូវសប្បាយនឹងភាពពិសេសរបស់នាង ។ *ប្អូន* មើលការពន្យល់ ៤:៩ ។ *ចូរពិសារចុះ ឱមាសសំឡាញ់អើយ* នៅត្រង់ចំណុចនេះ មិត្រសម្លាញ់របស់ស្ងួនសំឡាញ់ បានអបអរសាទរនឹងភាពសប្បាយរីករាយ ដែលពួកគេមាននៅក្នុងទំនាក់ទំនងស្នេហានេះ ។

**៥:២–៨** មើល ៣:១–៥ និងការពន្យល់ ៣:១ ។

ឱប្អូន ជាមាសសំឡាញ់ ឱព្រាប[ឃ] របស់អញ ជាអ្នក
បរិសុទ្ធ[ង] របស់អញអើយ[ច]
ចូរបើកទ្វារឱ្យអញផង ដ្បិតក្បាលអញទទឹកជោកដោយ
សន្សើម
សរសៃសក់អញផង ដោយទឹកដែលធ្លាក់នៅពេលយប់
៣អញបានដោះអាវអញចេញហើយ ធ្វើដូចម្តេចឱ្យអញ
ពាក់វិញបាន
អញបានលាងជើងហើយ ធ្វើដូចម្តេចឱ្យអញប្រឡាក់
ទៀតបាន
៤ស្ងួនសំឡាញ់ខ្ញុំក៏បញ្ចូលព្រះហស្តតាមប្រហោងទ្វារ
ហើយចិត្តខ្ញុំមានសេចក្តីរំជួលដល់ទ្រង់
៥ខ្ញុំបានក្រោកឡើង ដើម្បីទៅបើកទ្វារឱ្យស្ងួនសំឡាញ់ខ្ញុំ
គ្រឿងក្រអូបបានស្រក់ចេញពីដៃខ្ញុំ[ឆ]
ហើយប្រេងក្រអូបក៏ស្រក់ពីម្រាមដៃខ្ញុំទៅលើគន្លឹះទ្វារ
៦ខ្ញុំបានបើកឱ្យស្ងួនសំឡាញ់ខ្ញុំ[ជ]
តែស្ងួនសំឡាញ់ខ្ញុំ ទ្រង់បានចេញទៅបាត់ហើយ[ឈ]
ក្នុងកាលដែលទ្រង់បានបន្ទូលហៅ នោះខ្ញុំមានចិត្តរំជួល
ខ្ញុំខំស្វែងរក[ញ] តែរកទ្រង់មិនឃើញសោះ
ខ្ញុំបានស្រែកហៅ តែទ្រង់មិនឆ្លើយតបឡើយ
៧ពួកយាមល្បាតដែលដើរក្រវែលក្នុងទីក្រុង[ដ] ក៏ប្រទះនឹងខ្ញុំ
គេវាយខ្ញុំ ហើយធ្វើឱ្យខ្ញុំរបួស
ពួករក្សាកំផែង គេកន្ត្រាក់យកស្បៃពីខ្ញុំចេញ
៨ឱពួកកូនស្រីក្រុងយេរូសាឡិមអើយ
ខ្ញុំចាប់ឱ្យនាងរាល់គ្នា[ឋ] ស្បថថា បើឃើញស្ងួនសំឡាញ់ខ្ញុំ[ឌ]
នោះនាងទាំងឡាយនឹងទទួលដល់ទ្រង់ថា
ខ្ញុំឈឺដោយរោគស្រឡាញ់[ឍ] ។

**មិត្រសំឡាញ់**

៩ឱ ឱនាងដែលល្អលើសជាងគេក្នុងពួកស្រីៗអើយ[ណ]
តើស្ងួនសំឡាញ់របស់នាងវិសេសជាងស្ងួនសំឡាញ់
ណាទៀតយ៉ាងណា
បានជានាងចាប់ឱ្យយើងស្បថដូច្នេះ
តើស្ងួនសំឡាញ់របស់នាងវិសេសជាងស្ងួនសំឡាញ់
ណាទៀតយ៉ាងណាទៅ ។

**មាសសំឡាញ់**

១០ឱ ស្ងួនសំឡាញ់របស់ខ្ញុំសប្បុរស មានថ្ពាល់ក្រហម
ទ្រង់ជាឯកអង្គក្នុងពួក១ម៉ឺននាក់[ត]
១១ព្រះសិរទ្រង់ល្អ ដូចជាមាសនព្វគុណ
ព្រះកេសាទ្រង់រីកាញ់ ហើយខ្មៅដូចសារិកា
១២ព្រះនេត្រទ្រង់ដូចជាព្រាប[ថ] នៅមាត់ផ្លូវទឹក
ដែលលាងដោយទឹកដោះ[ទ] ហើយដាំក្នុងក្រោង
យ៉ាងសមល្អ
១៣ព្រះគណ្ឋៈ[ធ] ទ្រង់ដូចជាទីដាំគ្រឿងក្រអូប[ន]
ដូចជាដំណាំស្មៅមានក្លិនផ្អែម
ព្រះរីមទ្រង់ដូចជាផ្កាកំភ្លឹង[ប] ដែលស្រក់ទឹកក្រអូប[ផ]
១៤ព្រះហស្តទ្រង់ដូចជាចិញ្ចៀនមាសដាំដោយត្បូងបេរីល
ព្រះកាយទ្រង់ដូចជារចនាភ្លុកស្រោបដោយនិលរតន៍[ព]
១៥ព្រះបាទទ្រង់ដូចជាសសរថ្មកែវ
ដំកល់នៅលើជើងមាសនព្វគុណ
ឯភាពទ្រង់មានលំអដូចជាភ្នំល្បាណូន[ភ]
វិសេសដូចជាដើមតាត្រៅ

**៥:២** ឃ បស ១:១៥
ង បស ៤:៧
ច បស ៦:៩
**៥:៥** ឆ ខ.១៣
**៥:៦** ជ បស ៦:១
ឈ បស ៦:២
ញ បស ៣:១
**៥:៧** ដ បស ៣:៣
**៥:៨** ឋ បស ២:៧
ឌ បស ១:១៤
ឍ បស ២:៥
**៥:៩** ណ បស ១:៨
**៥:១០** ត ទដ ៤៥:២
**៥:១២** ថ បស ១:១៥
ទ លប ៤៩:១២
**៥:១៣** ធ បស ១:១០
ន បស ៦:២
ប បស ២:១
ផ ខ.៥
**៥:១៤** ព យប ២៨:៦
**៥:១៥** ភ ១ពវ ៤:៣៣
បស ៧:៤

**៥:២** *ខ្ញុំបានដេកលក់ . . . នៅភ្ញាក់ទេ* សេចក្តីស្រឡាញ់នៅតែមានជានិច្ច ទោះបីជាដេកលក់ក៏ដោយ គឺដូចជាម្តាយដែលទើបសម្រាលកូនថ្មីៗ នាងដេកដោយប្រុងត្រចៀកស្តាប់សម្លេងហៀបនឹងយំរបស់កូនតូច ។

**៥:៣** ការឆ្លើយតបដោយពុំបានគិត នាំឱ្យមានការតូញត្អែរដោយឡេះឡោះ មុនពេលប្រើពាក្យស្នេហា ។

**៥:៥** *គ្រឿងក្រអូបបានស្រក់ចេញពីដៃខ្ញុំ* ដៃរបស់មាសសំឡាញ់បានលាបដោយប្រេងក្រអូបយ៉ាងហូរហៀរ ដោយសារតែការអន្ទះអន្ទែងដោយសេចក្តីស្នេហា ។

**៥:៩** នៅក្នុងខនេះ ការចោទសួររបស់ពួកមិត្រសំឡាញ់បាននាំឱ្យមាសសំឡាញ់មានឱកាសរៀបរាប់អំពីភាពសង្ហានៃស្ងួនសំឡាញ់របស់នាង ដែលមានតែនៅក្នុងខជាបន្តបន្ទាប់ប៉ុណ្ណោះ ។

**៥:១០** *ក្រហម* មើល ១សយ ១៦:១២ ។

**៥:១១** *ខ្មៅ* សក់របស់ស្ងួនសំឡាញ់ក៏ខ្មៅផងដែរ (មើលការពន្យល់ ៤:១) ។

**៥:១២** *ព្រាប* មើលការពន្យល់ ១:១៥ ។ *នៅមាត់ផ្លូវទឹក* ភ្នែករបស់ស្ងួនសំឡាញ់មានពន្លឺចាំងផ្លេកៗ ។ *លាងដោយទឹកដោះ* គឺសំដៅទៅលើផ្នែកសនៃកែវភ្នែក ។

**៥:១៣** *គ្រឿងក្រអូប . . . ផ្កាកំភ្លឹង* ការប្រៀបប្រដូចនេះនិយាយអំពីផ្លូវអារម្មណ៍ ជាជាងផ្លូវកាយ គឺដូចការប្រៀបប្រដូចនៅក្នុងខជាបន្តបន្ទាប់ផងដែរ ដែលយ៉ាងហោចណាស់និយាយអំពីផ្លូវអារម្មណ៍ខ្លះ ផ្លូវកាយខ្លះ ។ *ផ្កាកំភ្លឹង* មើលការពន្យល់ ២:១ ។ *ដែលស្រក់ទឹកក្រអូប* ភាពរំភើបនៃសេចក្តីស្នេហា គឺកើតចេញពីបបូរមាត់របស់ស្ងួនសំឡាញ់ ។

**៥:១៤** *ត្បូងបេរីល* មើលការពន្យល់ អក ១:១៦ ។ *និលរតន៍* ពាក្យនេះជាព្រះគម្ពីរភាសាហេព្រើគឺ "សាភា" (Sappir ជាប្ញសនៃពាក្យ "សាហ្វាយ–អ័រ" Sapphire នៃភាសាអង់គ្លេស) ។

**៥:១៥** *ឯភាពទ្រង់មានលំអដូចជាភ្នំល្បាណូន* គឺមានន័យថា ល្អអស្ចារ្យ និងគួរកោតខ្លាច ។ *វិសេសដូចជាដើមតាត្រៅ* ដើមតាត្រៅនៃភ្នំល្បាណូន មានភាពល្បីល្បាញនៅទូទាំងតំបន់មជ្ឈិមបូព៌ានៅសម័យបុរាណ ហើយឈើរបស់វាមានភាពប្រណិត ធ្វើឱ្យគេនិយមប្រើនៅក្នុងការសង់លម្អព្រះវិហារ

**មិត្រសំឡាញ់**

**៦** ឱនាងដែលល្អលើសជាងគេក្នុងពួកស្រីៗអើយ[ក]
តើស្ងួនសំឡាញ់[ខ]របស់នាងបានទៅឯណា
ដើម្បីឱ្យយើងស្វែងរកទ្រង់ជាមួយនឹងនាងផង
តើស្ងួនសំឡាញ់របស់នាងបានបែរទៅខាងណា ។

**មាសសំឡាញ់**

២ ស្ងួនសំឡាញ់របស់ខ្ញុំបានចុះទៅ[គ]ឯសួនច្បាររបស់ទ្រង់[ឃ]
គឺទៅឯទីដាំគ្រឿងក្រអូប[ង]
ដើម្បីឃ្វាលសត្វនៅក្នុងសួនច្បារ ហើយនិងបេះផ្កាកំភ្លឹង
៣ខ្ញុំជារបស់ផងស្ងួនសំឡាញ់នៃខ្ញុំ ហើយទ្រង់
ជារបស់ផងខ្ញុំដែរ[ច]
ទ្រង់ឃ្វាលហ្វូងសត្វនៅទីមានផ្កាកំភ្លឹង[ឆ] ។

**ស្ងួនសំឡាញ់**

៤ ឱមាសសំឡាញ់អើយ
ឯងស្រស់បស់ល្អដូចក្រុងធើសា[ជ]
ហើយស្រស់ប្រិមប្រិយដូចជាក្រុងយេរូសាឡិម[ឈ]
ក៏គួរស្ញែងខ្លាចដូចជាពលទ័ព មានទាំងទង់ជ័យផង[ញ]
៥ចូរបែរភ្នែកចេញពីអញទៅ ដ្បិតភ្នែកឯងឈ្នះអញហើយ
សក់របស់ឯងប្រៀបដូចជាហ្វូងពពែ
ដែលដេកនៅចង្កេះភ្នំកាឡាត[ដ]
៦ធ្មេញឯងដូចជាហ្វូងចៀមដែលទើបនឹងកាត់រោម
រួចឡើងមកពីការលាងជំរះវិញ
ជាសត្វដែលមានកូនភ្លោះរៀងរាល់តួ
ឥតមានណាមួយដែលបាត់កូនឡើយ[ឋ]
៧តើកឯងដែលបាំងដោយស្បៃ[ឌ]
នោះមើលទៅដូចផ្លែទទឹម១ចំហៀង[ឍ]
៨មានពួកភរិយា[ណ]៦០នាក់ និងអ្នកម្នាង៨០នាក់[ត]
ក៏មានស្រីក្រមុំៗឥតគណនា
៩ប៉ុន្តែមានតែ១ទេ ដែលជាព្រាប[ថ]ជាអ្នកបរិសុទ្ធរបស់អញ[ទ]
នាងជាកូនពន្លករបស់ម្តាយ ជាកូនសំឡាញ់
របស់អ្នកដែលបង្កើតនាងមក[ធ]
ពួកកូនស្រីទាំងឡាយបានឃើញនាង
ហើយក៏ហៅថាជាអ្នកមានពរ
អើ ព្រមទាំងពួកភរិយា និងពួកអ្នកម្នាង
ក៏សរសើរនាងដែរ ។

**មិត្រសម្លាញ់**

១០តើនាងណានុ៎ះ ដែលលេចចេញមកដូចជាអរុណរះ
ស្រស់ល្អដូចជាព្រះចន្ទ ហើយភ្លឺត្រចះដូចជាព្រះអាទិត្យ

**៥:១៦** ម បស ៤:៣ យ បស ៧:៩ រ បស ១:៥
**៦:១** ក បស ១:៨ ខ បស ៥:៦
**៦:២** គ បស ៥:៦ ឃ បស ៤:១២ ង បស ៥:១៣
**៦:៣** ច បស ៧:១០ ឆ បស ២:១៦
**៦:៤** ជ យស ១២:២៤ ១ពវ ១៥:៣៣ ឈ ទដ ៤៨:២ ៥០:២ ញ ជន ១:៥២
**៦:៥** ដ បស ៤:១
**៦:៦** ឋ បស ៤:២
**៦:៧** ឌ លប ២៤:៦៥ ឍ បស ៤:៣
**៦:៨** ណ ទដ ៤៥:៩ ត លប ២២:២៤ នអ ២:១៤
**៦:៩** ថ បស ១:១៥ ទ បស ៥:២ ធ បស ៣:៤

និងរាជវាំងនានា (មើល ៣:៩ ១ពវ ៥:១៦ និងការពន្យល់) ។

**៥:១៦** *ព្រះឱស្ឋ* គឺសំដៅទៅលើការថើប និងពាក្យសំដីសាសងស្នេហារបស់ស្ងួនសំឡាញ់ ។ *កូនស្រីក្រុងយេរូសាឡិម* មើលការពន្យល់ ១:៥ ។

**៦:១** សំណួររបស់ពួកមិត្រសំឡាញ់នាំឱ្យមាសសំឡាញ់ប្តូរពីការពិពណ៌នាអំពីស្ងួនសំឡាញ់របស់នាង ទៅជាការទទួលស្គាល់យ៉ាងរីករាយនូវភាពស្និទ្ធស្នាលដែលទ្រង់ផ្តល់ឱ្យនាង និងលក្ខណៈពិសេសនៃទំនាក់ទំនងរបស់ពួកគេទាំងពីរ ។

**៦:២** *សួនច្បាររបស់ទ្រង់* គឺមាសសំឡាញ់របស់ទ្រង់ ។ *ទីដាំគ្រឿងក្រអូប* គឺសំដៅទៅលើការទាក់ទាញអារម្មណ៍របស់នាង (ធៀបនឹង ៥:១៣) ។ *ឃ្វាលសត្វ* គឺមានន័យថា សប្បាយ (មើលការពន្យល់ ២:១៦) ។ *បេះផ្កាកំភ្លឹង* មើលការពន្យល់ ២:១ ។ ការដែលស្ងួនសំឡាញ់ សប្បាយនឹងភាពស្និទ្ធស្នាលជាមួយនឹងមាសសំឡាញ់ គឺប្រៀបបាននឹងសត្វក្តាន់ដែលគួរឱ្យទាក់ទាញ (មើលការពន្យល់ ២:៧,៩) ដែលស៊ីច្រិចៗ ពីផ្កាកំភ្លឹងមួយទៅផ្កាកំភ្លឹងមួយទៀត យ៉ាងសប្បាយរីករាយដោយគ្មានការរំខាន ។

**៦:៣** *ខ្ញុំ . . . នៃខ្ញុំ* មើលការពន្យល់ ២:១៦ ។ នៅក្នុងខនេះ គឺជាឱកាសរបស់នាង នៅក្នុងការនិយាយអំពីការដែលស្ងួនសំឡាញ់របស់នាងទទួលផលដែលនាងមាន ។

**៦:៤** *ក្រុងធើសា* គឺជាទីក្រុងចាស់របស់សាសន៍កាណាន ដែលមានទីតាំងនៅចំកណ្តាលទឹកដីកាណាន (មើល យស ១២:២៤) ។ ស្តេចយេរ៉ូបោមទី១ (ឆ្នាំ ៩៣០–៩០៩ មុនគ.ស) បានជ្រើសរើសទីក្រុងនេះជារាជធានីទីមួយនៃនគរខាងជើង (មើល ១ពវ ១៤:១៧ ១ពវ ១៥:២១ ១៦:២៣–២៤) ។ តាមអត្ថន័យនៃឈ្មោះទីក្រុងនេះ ("ការសប្បាយ ឬសម្ផស្ស") គេសន្និដ្ឋានថា វាជាទីក្រុងដ៏ស្រស់ស្អាត ហើយការនេះប្រហែលជាមូលហេតុដែលអ្នកនិពន្ធយកឈ្មោះរបស់វាមកនិយាយជាមួយនឹងឈ្មោះទីក្រុងយេរូសាឡិម ។ នៅក្នុងតំបន់មជ្ឈិមបូព៌ាសម័យបុរាណ ការប្រដូចសម្រស់នៃមាសសំឡាញ់ទៅនឹងសម្រស់ទីក្រុង ប្រហែលមិនមែនការចម្លែកទេ ព្រោះតាមធម្មតាគេពិពណ៌នាសម្រស់ទីក្រុងដោយប្រដូចទៅនឹងមនុស្សស្រី (ការពន្យល់ ២ពវ ១៩:២១) ។ *គួរស្ញែងខ្លាច* មើល ខ.១០ ។ *ដូចជាពលទ័ព មានទាំងទង់ជ័យផង* សម្រស់របស់មាសសំឡាញ់បានដាស់អារម្មណ៍របស់ស្ងួនសំឡាញ់ ដូចជាការដាស់អារម្មណ៍ដោយការដើរក្បួនរបស់ពលទ័ពដែលមានទាំងទង់ជ័យដែរ ។

**៦:៥–៧** មើល ៤:១–៣ និងការពន្យល់ ។

**៦:៥** *ភ្នែកឯងឈ្នះអញហើយ* ភ្នែករបស់មាសសំឡាញ់បានដាស់សេចក្តីស្នេហាដែលមាននៅក្នុងអារម្មណ៍របស់ស្ងួនសំឡាញ់ ឱ្យឡើងដល់កម្រិតដ៏ខ្លាំងមួយ ដែលធ្វើទ្រង់ត្រូវជាប់ជាឈ្លើយ (មើល ៤:៩) ។

**៦:៨** *ពួកភរិយា . . . អ្នកម្នាង . . . ស្រីក្រមុំ* ប្រហែលសំដៅទៅលើពួកមហេសី និងអ្នកម្នាងទាំងអស់របស់ស្តេចសាឡូម៉ូន ឬគ្រប់ទាំងស្រីស្អាតទាំងអស់នៅក្នុងរជ្ជកាលទ្រង់ ។

**៦:៩** *អ្នកបរិសុទ្ធរបស់អញ* ធៀបនឹង ៥:២ ។ *កូនសំឡាញ់* ធៀបនឹង លប ២២:២ និងការពន្យល់ និង ពច ១១:៣៤ សភ ៤:៣ ។ *ពួកកូនស្រីទាំងឡាយ . . . ក៏សរសើរនាងដែរ* មានន័យថា គ្រប់ទាំងស្ត្រីសុទ្ធតែសរសើរសម្រស់

ក៏គួរ ស្ញែងខ្លាចដូចជាពលទ័ព
មានទាំងទង់ជ័យផងដូច្នេះ ។

**ស្ងួនសម្លាញ់**

១១ ខ្ញុំបានចុះទៅឯចំការ ឈើមានផ្លែគ្រាប់
ដើម្បីមើលកូនឈើខៀវខ្ចីដែលដុះនៅក្នុងច្រកភ្នំ
ហើយឱ្យដឹងបើទំពាំងបាយជូរ ប៉ិចឡើងឬនៅ
ហើយបើទទឹមមានផ្កាផង[ន]
១២[ប]រីឯមុនដែលខ្ញុំដឹងខ្លួន នោះចិត្តបាននាំខ្ញុំ
ទៅដាក់នៅក្នុងព្រះរាជរថនៃសាសន៍ដ៏សទ្ធារបស់ខ្ញុំ ។

**មិត្រសំឡាញ់**

១៣ សូមវិលមក វិញមកវិញ ឱនាងសាសន៍ស៊ូឡាមអើយ
សូមត្រឡប់មក ត្រឡប់មកចុះ ដើម្បីឱ្យយើងខ្ញុំ
បានមើលនាងផង ។

**ស្ងួនសំឡាញ់**

តើអ្នករាល់គ្នាចង់មើលនាងសាសន៍ស៊ូឡាមធ្វើអី
តើដូចជាមើលការរាំ[ប] របស់ពួករបាំ២ពួកឬ ។

**៧** ឱនាង ជាអ្នកមានត្រកូលខ្ពស់អើយ[ក]
ជើងនាងល្អណាស់ហ្ន៎ ដោយពាក់ស្បែកជើងដូច្នេះ
ត្រគាកដែលវៀវក្លំរបស់នាងដូចជាត្បូង
ជាស្នាដៃនៃជាងឆ្នៃយ៉ាងជំនាញ
២ផ្ចិតនាងរាងដូចជាកែវក្រពុំ
ដែលឥតខ្វះស្រាទំពាំងបាយជូរលាយណាឡើយ
ពោះនាងប្រៀបដូចជាគំនរស្រូវសាលី
មានផ្កាកំភ្លឹងដោតជុំវិញ
៣ដោះ[ខ]នាងទាំង២ដូចជាកូនក្តាន់២
ដែលជាកូនភ្លោះរបស់មេ១
៤កនាងប្រៀបដូចជាប៉មធ្វើពីភ្លុក[គ]
ភ្នែកនាងដូចជាស្រះទឹកនៅក្រុងហែសបូន[ឃ]
ដែលនៅជិតទ្វារបាត–រ៉ាប៊ីម
ច្រមុះនាងដូចជាប៉មល្បាណូន[ង] ដែលបែរទៅខាងដាម៉ាស
៥ក្បាលដែលនៅលើខ្លួននាងដូចជាភ្នំកើមែល[ច]
សក់ក្បាលនាងមើលទៅដូចជាពណ៌ស្វាយ
ស្តេចទ្រង់ជាប់ចិត្តដោយដុំសក់នោះ ។
៦ ឱមាសសំឡាញ់អើយ ឯងស្រស់បស់ល្អ[ឆ]
ហើយប្រិមប្រិយ គួររីករាយណាស់ហ្ន៎[ជ]
៧កំពស់ឯងដូចជាដើមលម៉ើ
ហើយដោះ[ឈ]ឯងដូចជាចង្កោមផ្លែលម៉ើ
៨អញបានថា អញនឹងឡើងដើមនោះ
អញនឹងចាប់ធាងតោងឡើង
សូមឱ្យដោះឯងបានដូចជាចង្កោមទំពាំងបាយជូរ
ហើយក្លិនខ្យល់ដង្ហើមឯងបានដូចជាផ្លែសារី[ញ]

**៦:១១** ន បស ៧:១២
**៦:១៣** ប នក ១៥:២០
**៧:១** ក ទដ ៤៥:១៣
**៧:៣** ខ បស ៤:៥
**៧:៤** គ ទដ ១៤៤:១២
ឃ ជន ២១:២៦
ង បស ៥:១៥
**៧:៥** ច អស ៣៥:២
**៧:៦** ឆ បស ១:១៥
ជ បស ៤:១០
**៧:៧** ឈ បស ៤:៥
**៧:៨** ញ បស ២:៥

នាង (មើល ១:៨ ៥:៩ ៦:១) ។

**៦:១០** មើល ៥:៩ ៦:១ ។

**៦:១១** *ផ្លែគ្រាប់* ប្រហែលសំដៅទៅលើផ្លែឈើម្យ៉ាដែលមានតែគ្រប់ធំមួយជាផ្លែដែលអាចបរិភោគបាន ។ *មើល . . . នៅក្នុងច្រកភ្នំ* គឺជាទីសំគាល់ដំបូងនៃការមកដល់នៃរដូវផ្ការីក (មើលការពន្យល់ ២:១១–១៣) ។

**៦:១២** ខនេះគឺពិបាកយល់ជាងគេបំផុតនៅក្នុងព្រះគម្ពីរនេះ ។ *ព្រះរាជរថ* រាជរថរបស់ស្តេចសាឡូម៉ូនក៏មានភាពល្បីល្បាញផងដែរ (១ពវ ១០:២៦) ។

**៦:១៣** *សាសន៍ស៊ូឡាម* គឺសំដៅទៅលើមាសសំឡាញ់ ។ គឺអាចជាស្ត្រីវ័យក្មេងដែលជា "អ្នកស្រុកស៊ូណែម" (មើល ១ពវ ១:៣) ឬជាពាក្យដែលនៅក្នុងព្រះគម្ពីរភាសារហេព្រើមានន័យថា "ស្រីកំណាន់របស់ស្តេចសាឡូម៉ូន" ។ *ពួករបាំ* ប្រហែលសំដៅទៅលើទីក្រុងនៅស្រុកកាឡាត (មើលការពន្យល់ ២សយ ២:៨) ។

**៧:១–៧** នៅក្នុងវគ្គនេះស្ងួនសំឡាញ់ធ្វើការពិពណ៌នា ចាប់ពីជើងឡើងទៅដល់ក្បាលវិញ (ធៀបនឹង ៥:១១–១៥) ។

**៧:១** ធៀបនឹង ខ.៦ ។ *អ្នកមានត្រកូលខ្ពស់* គឺសំដៅទៅលើភាពថ្លៃថ្នូរនៃសម្រស់នាង (មើល ទដ ៤៥:១៣) ។ *ល្អណាស់* ឬស្រឡូនស្អាតណាស់ ។

**៧:២** *កែវ* គឺសំដៅទៅលើចានក្រឡូមធំម្យ៉ាងដែលមានដៃពីរ និងបាតរាងដូចកង (មើល នក ២៤:៦ អស ២២:២៤ និងមើល អម ៦:៦) ។ *មានផ្កាកំភ្លឹងដោតជុំវិញ* មាសសំឡាញ់ប្រហែលពាក់កម្រងផ្កាដ៏ធំ ហើយរលុងនៅជុំវិញចង្កេះរបស់នាង ។

**៧:៣** មើលការពន្យល់ ៤:៥ ។

**៧:៤** *ប៉មធ្វើពីភ្លុក* គឺជាការប្រដូចដោយចំរុះ គឺសំដៅទៅលើទម្រង់ ក៏ដូចជាសម្បុរ និងភាពរលោង ។ *ស្រះទឹក* ភ្នែករបស់ស្ងួនសំឡាញ់មានពន្លឺចាំងព្រិចៗ ដូចផ្ទៃទឹកស្រះ ឬការប្រដូចនេះអាចសំដៅទៅលើភាពស្ងប់សុខ និងទន់ភ្លន់ ។ *ក្រុងហែសបូន* នៅក្នុងរជ្ជកាលស្តេចស៊ីហ៊ុន (ជន ២១:២៦) ទីក្រុងនេះជារាជធានីដែលមានទឹកជាបរិបូរ ដែលមានប្រភពពីទឹកផុស ។ *បាត–រ៉ាប៊ីម* មានន័យថា "កូនស្រីជាច្រើននាក់" គឺប្រហែលជាឈ្មោះទីក្រុងហែសបូនមួយទៀត ដែលមានឈ្មោះល្បី ។ *ប៉មល្បាណូន* ប្រហែលជាប៉មទាហានមួយនៅព្រំដែនខាងជើងនៃនគរស្តេចសាឡូម៉ូន ប៉ុន្តែ ពាក្យនេះប្រហែលជាសំដៅទៅលើជួរភ្នំល្បាណូន ដែលមានទេសភាពស្រស់ស្អាត និងមានរាងដូចប៉មច្រើនជាង ។

**៧:៥** *ភ្នំកើមែល* គឺជាជ្រលងភ្នំដែលនៅចំកណ្តាលតំបន់ឆ្នេរខាងលិច នៃនគរស្តេចសាឡូម៉ូន ដែលនៅលើកំពូលសម្បូរព្រៃឈើ ហើយល្បីថា មានទេសភាពស្រស់ស្អាត ។ *ពណ៌ស្វាយ* គឺសំដៅសំលៀកបំពាក់ស្តេចដែលមានពណ៌ស្វាយ ដូចនៅក្នុង ៣:១០ (មើលការពន្យល់ នក ២៥:៤) ។ *ស្តេច* គឺស្តេចសាឡូម៉ូន ។ *ដុំសក់* នៅក្នុងព្រះគម្ពីរភាសាហេព្រើ ពាក្យនេះសំដៅទៅលើពាក្យដែលមានន័យស្រដៀងនឹងទឹកហូរ (ធៀបនឹង ៤:១ ៦:៥) ។

**៧:៨** *អញបានថា* គឺមានបន្ទូលមកកាន់អង្គទ្រង់ ។ *អញនឹងឡើង* សម្រស់

[ជ]នឹងមាត់ឯងក្រអូបដូចជាស្រាទំពាំងបាយជូរយ៉ាងឯក

**មាសសំឡាញ់**

ដែលហូរចុះទៅដោយស្រួល សំរាប់មាសសំឡាញ់អញ[ឈ]
ក៏ធ្វើឱ្យបបូរមាត់មនុស្សដេកលក់បាននិយាយឡើង ។
១០ ខ្ញុំម្ចាស់ជារបស់ផងស្ងួនសំឡាញ់នៃខ្ញុំ
ហើយទ្រង់មានសេចក្តីប៉ងប្រាថ្នា[ឋ]ចំពោះរូបខ្ញុំម្ចាស់[ឌ]
១១ ឱស្ងួនសំឡាញ់អើយ សូមមក
យើងនឹងចេញទៅឯវាល
សូមឱ្យយើងស្នាក់នៅតាមភូមិគេ
១២ យើងនឹងឡើងទៅឯចំការទំពាំងបាយជូរ[ឍ]ពីព្រលឹម
សូមឱ្យយើងទៅមើលបើទំពាំងបាយជូរបានប៊ិចឡើង[ណ]
ឬមានផ្កា[ត] ហើយឬនៅ
ហើយបើដើមទទឹម[ថ]កំពុងផ្កា[ទ] ឬទេ
នៅទីនោះខ្ញុំម្ចាស់នឹងប្រគល់សេចក្តីស្រឡាញ់ថ្វាយទ្រង់
១៣ ផ្លែស្នេហ៍[ធ]ផ្សាយក្លិនក្រអូបសុសសាយទៅ
ឱស្ងួនសំឡាញ់ខ្ញុំម្ចាស់អើយ
នៅមាត់ទ្វារផ្ទះយើងមានផលយ៉ាងវិសេសគ្រប់មុខ
ទាំងថ្មីនឹងចាស់ផង ដែលខ្ញុំម្ចាស់បានប្រមូលទុក
សំរាប់ទ្រង់[ន] ។
៨ ឱបើទ្រង់ជាប្អូនប្រុសនៃខ្ញុំម្ចាស់ទៅអេះ
ជាអ្នកដែលបានបៅដោះម្តាយរបស់ខ្ញុំម្ចាស់
ដូច្នេះ កាលណាខ្ញុំម្ចាស់ប្រទះនឹងទ្រង់នៅខាងក្រៅ
នោះខ្ញុំម្ចាស់នឹងថើបទ្រង់ចេះតែបាន
ឥតមានអ្នកណាមើលងាយខ្ញុំម្ចាស់ផង
២ ខ្ញុំនឹងនាំទ្រង់ចូលទៅក្នុងផ្ទះ[ក]ម្តាយរបស់ខ្ញុំម្ចាស់
ម្តាយនឹងបង្រៀនដល់ខ្ញុំម្ចាស់
ខ្ញុំម្ចាស់នឹងយកស្រាដែលលាយគ្រឿងក្រអូប
ជាស្រាធ្វើពីទឹកទទឹមមកថ្វាយទ្រង់សោយ
៣ នោះព្រះហស្តឆ្វេងទ្រង់នឹងទ្រក្បាលខ្ញុំម្ចាស់
ហើយព្រះហស្តស្តាំនឹងឱបខ្ញុំម្ចាស់[ខ]
៤ ឱពួកកូនស្រីក្រុងយេរូសាឡិមអើយ
ខ្ញុំចាប់ឱ្យនាងរាល់គ្នាស្បថថា
នាងទាំងឡាយនឹងមិនអង្រួន ឬដាស់ស្ងួនសំឡាញ់ខ្ញុំឡើយ
ចាំទាល់តែទ្រង់សព្វព្រះទ័យ[គ] ។

**មិត្រសំឡាញ់**

៥ តើនាងណានុ៎ះ ដែលឡើងមកពីទីរហោស្ថាន[ឃ]
កំពុងផ្អែកលើអ្នកស្ងួនសំឡាញ់របស់នាងដូច្នេះ ។

**មាសសំឡាញ់**

អញបានបណ្តុលឱ្យឯងមានសេចក្តីស្រឡាញ់នៅ
ក្រោមដើមសារី
ជាទីដែលម្តាយឯងបានឈឺនឹងសំរាល[ង]
ជាទីដែលអ្នកឈឺនឹងសំរាលបានបង្កើតឯងមក ។
៦ សូមបិទត្រាខ្ញុំម្ចាស់និត្យនៅព្រះទ័យទ្រង់ដូចជាត្រា
គឺជាស្នាមត្រានៅលើព្រះពាហុទ្រង់ផង
ដ្បិតសេចក្តីស្រឡាញ់[ច]មានកំឡាំង ដូចជាសេចក្តីស្លាប់
ហើយសេចក្តីប្រចណ្ឌ[ឆ]ក៏សាហាវ ដូចជាស្ថានឃុំព្រលឹង

**៧:៩** ជ បស ៥:១៦
**៧:១០** ឋ ទដ ៤៥:១១ ឌ បស ២:១៦ ៦:៣
**៧:១២** ឍ បស ១:៦ ណ បស ២:១៥ ត បស ២:១៣ ថ បស ៤:១៣ ទ បស ៦:១១
**៧:១៣** ធ លប ៣០:១៤ ន បស ៤:១៦
**៨:២** ក បស ៣:៤
**៨:៣** ខ បស ២:៦
**៨:៤** គ បស ២:៧ ៣:៥
**៨:៥** ឃ បស ៣:៦ ង បស ៣:៤
**៨:៦** ច បស ១:២ ឆ ជន ៥:១៤

មាសសំឡាញ់បានធ្វើឱ្យទ្រង់អត់ទ្រាំពុំបាន ។ *ផ្លែសារី* ប្រហែលសំដៅទៅលើក្លិនក្រអូបរបស់ផ្កានៃដើមផ្លែប៉ោម(ប៉ុន្តែមើលការពន្យល់ ២:៣) ។

**៧:៩** *ស្រាទំពាំងបាយជូរ . . . សំរាប់មាសសំឡាញ់* នៅត្រង់ចំណុចនេះស្ងួនសំឡាញ់ចាក់ស្រាទំពាំងបាយជូរ (មើល ៥:១) នៃក្តីស្នេហ៍របស់ទ្រង់ដល់មាសសំឡាញ់ទ្រង់ ។

**៧:១០** *ជារបស់ផង* មើលការពន្យល់ ២:១៦ ៦:៣ ។ *សេចក្តីប៉ងប្រាថ្នា* ធៀបនឹង លប ៣:១៦ ។

**៧:១១-១២** នៅក្នុងវគ្គ ២:១០-១៣ មាសសំឡាញ់បាននិយាយអំពីការអញ្ជើញស្រដៀងគ្នានឹងការអញ្ជើញនៅក្នុងវគ្គនេះ ដែលធ្វើឡើងដោយស្ងួនសំឡាញ់របស់នាង ។

**៧:១២** *ខ្ញុំម្ចាស់នឹងប្រគល់សេចក្តីស្រឡាញ់ថ្វាយទ្រង់* មានន័យថា នាងថ្វាយខ្លួនជាច់ដល់ស្ងួនសំឡាញ់របស់នាង ។

**៧:១៣** *ផ្លែស្នេហ៍* គឺសំដៅទៅលើតិណជាតិដែលមានមែកខ្លីៗ ហើយដើមនេះមានទំនាក់ទំនងនឹងការបន្តពូជ(មើលការពន្យល់ លប ៣០:១៤) ។ វាមានក្លិនឈ្ងុល ។ *នៅមាត់ទ្វារផ្ទះយើង* គឺកន្លែងដែលគូស្នេហ៍នេះជួបគ្នា ។ *ផលយ៉ាងវិសេសគ្រប់មុខ* គឺជាពាក្យប្រដូចទៅនឹងការសប្បាយដែលមាសសំឡាញ់មានសម្រាប់ស្ងួនសំឡាញ់របស់នាង នៅក្នុង "សួនច្បារ" របស់នាង (ធៀបនឹង ៤:១៣-១៤) ។ *ទាំងថ្មី និងចាស់ផង* គឺសំដៅទៅលើការសប្បាយដែលមានជាមួយគ្នាហើយ ក៏ដូចជាការសប្បាយដែលត្រូវមានជាបន្តទៀតផងដែរ ។

**៨:១** *ឥតមានអ្នកណាមើលងាយខ្ញុំម្ចាស់ផង* មាសសំឡាញ់អាចបើកបង្ហាញសេចក្តីស្នេហាជាសាធារណៈ ឥតមានអ្វីត្រូវខ្មាសអៀនឡើយ ។

**៨:២** *មកថ្វាយទ្រង់សោយ* គឺនាងអាចផ្តល់ឱ្យស្ងួនសំឡាញ់របស់នាងនូវការសប្បាយនៃសេចក្តីស្នេហារបស់នាង ។

**៨:៤** មើល ២:៧ និងការពន្យល់ ។

**៨:៥** *នាងណានុ៎ះ . . . ទីរហោស្ថាន* មើល ៣:៦ និងការពន្យល់ ។ *កំពុងផ្អែកលើ* គឺមានន័យថា កំពុងរួមដំណេក ។

**៨:៦-៧** *សេចក្តីស្រឡាញ់ . . . ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់ . . . ក៏ជាជីហួលនៃភ្លើង* ឃ្លានៃប្រាជ្ញាទាំងបីនេះបញ្ជាក់ថា សេចក្តីស្នេហារវាងប្តីនឹងប្រពន្ធនៅក្នុងអាពាពិពាហ៍ គឺស្នេហាដែលខ្លាំងបំផុត គឺពិបាកបត់បែននិងកែប្រែបំផុត នៅក្នុងបទពិសោធន៍នៃមនុស្ស ។ ឃ្លាទាំងនេះបង្ហាញអំពីកម្រិតខ្លាំងបំផុតនៅក្នុងបទចម្រៀងនេះ ហើយក៏បានបង្ហាញអំពីគោលបំណងនៃបទចម្រៀងនេះផងដែរ ។

**៨:៦** *ត្រា* ត្រាគឺមានតម្លៃណាស់សម្រាប់ម្ចាស់របស់វា គឺជារបស់ផ្ទាល់ខ្លួន

មនុស្សស្លាប់
ហើយជិហ្វូលនៃសេចក្តីនោះក៏ជាជិហ្វូលនៃភ្លើង
ជាអណ្តាតភ្លើងយ៉ាងសហ័សដែលមកពីព្រះ
៧ទឹកជាច្រើនយ៉ាងណាក៏មិនអាចនឹងពន្លត់សេចក្តី
ស្រឡាញ់បានឡើយ
ទឹកជំនន់នឹងពន្លិចក៏មិនបានដែរ
ទោះបើអ្នកណានឹងចំណាយទ្រព្យសម្បត្តិនៅផ្ទះខ្លួនអស់
រលីងឱ្យបានសេចក្តីស្រឡាញ់
គង់តែអ្នកនោះនឹងត្រូវបានសេចក្តីមើលងាយ
ទទេៗវិញ[ជ] ។

**មិត្រសំឡាញ់**

៨ យើងមានប្អូនស្រី១ មិនទាន់ដុះដោះនៅឡើយ
តើយើងនឹងធ្វើយ៉ាងណាចំពោះប្អូនយើង
នៅថ្ងៃដែលមានគេមកដណ្តឹង ។
៩ បើនាងជាកំផែង យើងនឹងធ្វើប៉មពីប្រាក់នៅពីលើ
បើសិនជានាងជាផ្ទាំងទ្វារ នោះយើងនឹងធ្វើក្របពីឈើ
តាត្រៅឱ្យនាង ។

**៨:៧** ជ សភ ៦:៣៥
**៨:១១** ឈ សស ២:៤
ញ អស ៧:២៣
**៨:១២** ដ បស ១:៦

**មាសសំឡាញ់**

១០ ឯខ្ញុំជាកំផែងពិត ដោះរបស់ខ្ញុំក៏ជាប៉មហើយ
តាំងពីនោះខ្ញុំនៅចំពោះព្រះនេត្រទ្រង់ ដូចជាអ្នកដែល
បណ្តាលឱ្យមានសេចក្តីសុខ
១១ ស្តេចសាឡូម៉ូនទ្រង់មានចំការទំពាំងបាយជូរ[ឈ]
នៅត្រង់បាល-ហាម៉ូន
ទ្រង់បានប្រវាស់ទៅឱ្យពួកអ្នកដទៃធ្វើ
ដែលពួកនោះគ្រប់ៗគ្នាត្រូវនាំយកប្រាក់
១ពាន់ដួង[ញ]មកថ្វាយ
ដើម្បីឱ្យបានផលចំការនោះ
១២ ឯចំការ[ដ]ដែលជារបស់ផងខ្ញុំម្ចាស់ នោះនៅខាងមុខ
ខ្ញុំម្ចាស់នេះហើយ
ឯទ្រង់ ឱសាឡូម៉ូនអើយ
ទ្រង់នឹងបានប្រាក់១ពាន់នោះ
ហើយពួកអ្នកដែលធ្វើចំការនឹងបានដល់២រយដែរ

**ស្ងួនសំឡាញ់**

១៣ ឱនាងដែលអាស្រ័យនៅក្នុងសួនអើយ

របស់ពួកគេ ដូចជានាមត្រកូលផងដែរ (មើលការពន្យល់ លប ៣៨:១៨) ។ *ក៏សាហាវ ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់* គួរស្នេហ៍គេចមិនផុតពីសេចក្តីស្នេហាបាន គឺដូចជាការដែលពួកស្លាប់គេចមិនផុតពីស្ថានឃុំព្រលឹងមនុស្សស្លាប់យ៉ាងដូចច្នេះដែរ ។

**៨:៧** *ទឹកជាច្រើន* ពាក្យនេះមិនគ្រាន់តែសំដៅទៅលើទឹកសមុទ្រដ៏ជ្រៅប៉ុន្នោះទេ (មើល ទដ ១០៧:២៣) ប៉ុន្តែ ថែមទាំងសំដៅទៅលើទឹកពីបុរាណដែលអ្នករស់នៅតំបន់មជ្ឈិមបូព៌ាពីបុរាណចាត់ទុកថា ជាទឹកដែលតែងតែគម្រាមគំហែងពិភពលោកជានិច្ច (មើលការពន្យល់ ទដ ៣២:៦) ។ ទឹកក៏មានទំនាក់ទំនងនឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ផងដែរ (មើលការពន្យល់ ទដ ៣០:១) ។ *ទោះបើអ្នកណា . . . បានសេចក្តីមើលងាយទទេៗវិញ* គឺជាពាក្យនៃប្រាជ្ញាទីបួន (មើលការពន្យល់ ខ.៦-៧) ដែលប្រកាសថា សេចក្តីស្នេហារវាងប្តីនិងប្រពន្ធគឺជាសេចក្តីស្នេហាដែលខ្លាំងជាគេបំផុត ។

**៨:៨–១៤** *វគ្គបញ្ចប់នៃបទចម្រៀងនេះ* បង្ហាញអំពីការនិយាយបកទៅរកចំណុចចាប់ផ្តើមនៃព្រះគម្ពីរបទចម្រៀងនេះវិញ (មើល ១:២-៧ និងសេចក្តីផ្តើមត្រង់ចំណុច លក្ខណៈអក្សរសាស្ត្រ) ដោយមានពាក្យរបស់ពួកបងប្រុស (ខ.៨-៩) ពាក្យរបស់មាសសំឡាញ់ដែលសំដៅទៅលើចំការទំពាំងបាយជូររបស់នាង (ខ.១២) និងពាក្យរបស់នាងដែលសំដៅជាចុងក្រោយ ទៅលើស្តេចសាឡូម៉ូន (ខ.១១-១២) ។ វគ្គនេះប្រហែលជារំឭកឡើងវិញ នូវការចម្រើនវ័យរបស់មាសសំឡាញ់ ចូលទៅក្នុងវ័យស្នេហា និងអាពាហ៍ពិពាហ៍ និងចូលទៅក្នុងដំណាក់កាលជោគជ័យនៃសេចក្តីស្នេហាជាមួយនឹងស្ងួនសំឡាញ់របស់នាង ។

**៨:៨** នៅក្នុងតំបន់មជ្ឈិមបូព៌ានៅសម័យបុរាណ ជាញឹកញាប់បងប្រុសគឺជាអ្នកការពាររបស់ប្អូនស្រី ជាពិសេសក្នុងរឿងដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ (មើល លប ២៤:៥០-៦០ ៣៤:១៣-២៧) ។ *ថ្ងៃដែលមានគេមកដណ្តឹង* ជាញឹកញាប់គេចូលស្តីដណ្តឹងអ្នកដែលនៅវ័យក្មេងនៅឡើយ ។

**៨:៩** គេជឿថា ពាក្យប្រៀបប្រដូចក្នុងខនេះ បង្ហាញអំពីការប្តូរផ្តាច់របស់បងប្រុសនៅក្នុងការការពារប្អូនស្រី (មាសសំឡាញ់) រហូតដល់ពេលដែលនាងចូលវ័យស្នេហា និងរៀបការ ។ ម្យ៉ាងវិញទៀត ខនេះអាចមានន័យថា បងប្រុសត្រូវខ្វល់ខ្វាយអំពីការរៀបចំខ្លួនរបស់នាង ឱ្យបានសមរម្យមុននឹងមានគេស្តីដណ្តឹង ។

**៨:១០** *ខ្ញុំជា . . . ប៉មហើយ* នៅក្នុងខនេះ មាសសំឡាញ់សប្បាយរីករាយនឹងភាពគ្រប់ការរបស់ខ្លួន គឺខុសពីពេលដែលនាងត្រូវស្ថិតនៅក្នុងការការពាររបស់បងប្រុសនៅឡើយ (ធៀបនឹង អគ ១៦:៧-៨) ។ ស

៨:**១១–១២** *ប្រាក់១ពាន់ដួង . . . ២រយដែរ* មើល អស ៧:២៣ ។

**៨:១១** *បាល-ហាម៉ូន* នៅក្នុងព្រះគម្ពីរភាសាហេព្រើ ពាក្យ "ហាម៉ូន" ជួនកាលមានន័យថា "ទ្រព្យសម្បត្តិ" ឬ "ភាពបរិបូរណ៍" ដូចនេះពាក្យថា បាល-ហាម៉ូន (បាលមានន័យថា "ម្ចាស់") អាចមានន័យថា "ម្ចាស់នៃភាពបរិបូណ៌" ដូចនេះនៅក្នុងខនេះ ស្តេចសាឡូម៉ូនប្រើពាក្យនេះ សំដៅទៅលើទ្រព្យសម្បត្តិដ៏សម្បូរណ៍ ។

**៨:១២** *ចំការដែលជារបស់ផងខ្ញុំម្ចាស់* គឺសំដៅទៅលើខ្លួនប្រាណរបស់នាង (មើលការពន្យល់ ១:៦) ។ *នៅខាងមុខខ្ញុំម្ចាស់នេះ* ស្តេចសាឡូម៉ូនជាម្ចាស់ចំការរបស់ទ្រង់ ហើយមាសសំឡាញ់គឺជាម្ចាស់នៃភាពទាក់ទាញរបស់នាង ដូចនេះនាងអាចប្រគល់ឱ្យតាមការបំណងចិត្តនាង ហើយនាងបានថែកឱ្យស្តេចសាឡូម៉ូន បានធ្វើជាម្ចាស់ចំការរបស់នាងដែរ ។

**៨:១៣** *នៅក្នុងសួន* នៅក្នុងវគ្គ ៧:១១-១២ មាសសំឡាញ់បានអញ្ជើញស្ងួនសំឡាញ់របស់នាង ឱ្យបានរួមដំណើរជាមួយនាង ទៅកាន់ទីជនបទ និងទៅ

ពួកភឿនរង់ចាំស្ដាប់សំឡេងឯង
សូមឱ្យអញបានឮផង ។

**មាសសំឡាញ់**

**៨:១៤** ឋ សភ ៥:១៩
ឌ បស ២:៩
ឍ បស ២:៨,១៧

១៤ ឱស្ងួនសំឡាញ់របស់ខ្ញុំម្ចាស់អើយ
សូមឆាប់ៗធ្វើដូចជាប្រើស[ឋ] ឬក្ដាន់ស្ទាវ[ឌ]
នៅលើភ្នំគ្រឿងក្រអូបទៅ[ឍ] ។

លេងចំការទំពាំងបាយជូរ ។ តាមការប្រៀបប្រដូចនៅក្នុងខនេះ នាងគឺស្ថិតនៅក្នុងចំការទំពាំងបាយជូរនេះ ។ *ពួកភឿន* គឺពួកប្រុសៗប្រហែលជាពួកបរិវាររបស់ស្ងួនសំឡាញ់ (មើល ១:៧) ។ *សូមឱ្យអញបានឮ* មើល ២:១៤ ។

**៨:១៤** *ដូចជាប្រើស ឬក្ដាន់ស្ទាវ* គឺមានន័យថា សូមប្រើកម្លាំង និងភាពរហ័សរហួននៃភាពជាបុរសរបស់ទ្រង់ ដើម្បីសប្បាយនឹងខ្ញុំម្ចាស់ទៅ (មើលការពន្យល់ ២:៩) ។ *នៅលើភ្នំគ្រឿងក្រអូបទៅ* ធៀបនឹង ២:១៧ ។

# អេសាយ

## សេចក្តីផ្តើម

### ជាការដកស្រង់ចេញពីព្រះគម្ពីរហេព្រើរ

នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ផ្នែកព្រះគម្ពីរអេសាយ គឺបានផ្តើមដោយការចែកដាច់ៗគ្នាជាផ្នែកៗ ដែលគេហៅថាសិបុត្រចុងក្រោយរបស់ពួកហោរា(ឯចំពោះសិបុត្រដំបូងរបស់ពួកហោរា គឺសូមមើលក្នុងសេចក្តីផ្តើមរបស់ព្រះគម្ពីរយ៉ូស្វេ : ចំណងជើង និងផ្ទៃរឿងទេវសាស្ត្រ) ក៏មានទាំងគម្ពីរ យេរេមា អេសេគាល និងពួកហោរា ទាំង១២នាក់(គឺពួកគេមានលក្ខណៈជាគម្ពីរហោរាខ្នាតតូច បើប្រៀបធៀបជាមួយគម្ពីរហោរាសំខាន់ៗនៅក្នុងព្រះគម្ពីរអេសាយ យេរេមា អេសេគាល) ។

### អ្នកនិពន្ធ

គឺជាលោកអេសាយជាកូនប្រុសរបស់លោកអ័រម៉ុស គឺជាហោរាដែលមានភាពល្បីល្បាញខាងឯវិជ្ជានិពន្ធ ។ ឈ្មោះរបស់គាត់មានន័យថា "ព្រះយេហូវ៉ាជាព្រះអង្គសង្គ្រោះ" គាត់ជាមនុស្សដែលរស់នៅសម័យកាល ឬជិនាន់លោកអេម៉ុស លោកហូសេ និងមីកា ហើយលោកក៏ចាប់ផ្តើមបំរើព្រះក្នុង ឆ្នាំ៧៤០ មុនគ.ស គឺឆ្នាំដែលស្តេចអូសៀសបានសុគត (សូមមើលការពន្យល់ ៦:១) ។ ដោយយោងលើការសិក្សា និងការស្វែងយល់អំពីទំនៀមទម្លាប់របស់ពួកសាសន៍យូដា(ឥទ្ធិពលរបស់អេសាយ)ក៏បង្ហាញឱ្យឃើញច្បាស់ពីរាជអំណាចរបស់ស្តេចម៉ានាសេ (ប្រៀបធៀប ហព ១១:៣៧) និងកូនមួយទៀតឈ្មោះ ម៉ាហេ-សាឡាលហាសបាល (៨:៣) ។ លោកអេសាយក៏បានចំណាយពេលវេលាសម្រាប់ជីវិតនៅក្នុងក្រុងយេរូសាឡិម ក៏មានមោទនៈភាពទទួលបានកេរ្តិ៍ឈ្មោះនៅក្រោមការដឹកនាំរបស់ស្តេចអេសេគាល (សូមមើល ៣៧:១-២) ។ លោកអេសាយក៏មានកត្តិគុណដ៏ឧត្តមក្នុងការចងក្រងប្រវត្តិវង្សាវតានៃរាជ្យបល្ល័ង្ករបស់ស្តេចអូសៀស (២រប ២៦:២២) ។

បើអ្នកប្រាជ្ញខាងទេវសាស្ត្រជាច្រើន នាពេលបច្ចុប្បន្ននេះបានអះអាងថា លោកអេសាយជាអ្នកនិពន្ធសៀវភៅនេះទាំងមូលដែលថែមទាំងដាក់ឈ្មោះរបស់គាត់ផង ។ (សូមមើល ១:១ ២:១ ១៣:១) ។ សាច់រឿងសំខាន់ក្នុងគម្ពីរ គឺផ្តោតសំខាន់ទៅលើការបង្ហាញពី "ព្រះអម្ចាស់ដ៏បរិសុទ្ធរបស់រាស្ត្រអ៊ីស្រាអែល" ឯចំណងជើងដែលមានព្រះនាមព្រះយេហូវ៉ាលេចឡើង ១៨ដង ក្នុងជំពូកទី ១-៣៩ ហើយមាន ១៤ដងនៅក្នុងជំពូក ៤០-៦៦ ។ នៅខាងក្រៅគម្ពីរអេសាយចំណងជើងដែលមានព្រះនាមព្រះ គឺមានក្នុងគម្ពីរសញ្ញាចាស់៦ដង ។ ក៏មានហេតុការស្រដៀងគ្នាតាមលេខរៀង ជំពូក ១-៣៩ និងជំពូក ៤០-៦៦ ។ សូមប្រៀបធៀបជាមួយខគម្ពីរខាងក្រោម :

| | |
|---|---|
| ១:២ | ៦៦:២៤ |
| ១:៥-៦ | ៥៣:៤-៥ |
| ៥:២៧ | ៤០:៣០ |
| ៦:១ | ៥២:១៣ ៥៧:១៥ |
| ៦:១១-១២ | ៦២:៤ |
| ១១:១ | ៥៣:២ |
| ១១:៦-៩ | ៦៥:២៥ |
| ១១:១២ | ៤៩:២២ |
| ៣៥:១០ | ៥១:១១ |

ក៏មានពាក្យជាភាសាហេព្រើរយ៉ាងហោចណាស់ ២៥ពាក្យ ឬមានទម្រង់សន្ទនាដែលឃើញក្នុង គម្ពីរអេសាយគម្ពីអេសាយតែងតែប្រើពាក្យថា "ភ្លើង" ជាតំណាងឱ្យភាពជំនុំជម្រះរបស់ព្រះអម្ចាស់ (សូមមើល ១:៣១ ១០:១៧ ២៦:១១ ៣៣:១១-១៤ ៣៤:៩-១០ ៦៦:២៤) ។ ការអះអាងរបស់លោកអេសាយចំពោះ "ភ្នំបរិសុទ្ធ" នៃក្រុងយេរូសាឡិម(សូមមើលការពន្យល់ ២:២-៤) ។ ក៏មានការបញ្ជាក់របស់លោកពីការរៀបផ្លូវទៅកាន់ក្រុងយេរូសាឡិម(សូមមើលការពន្យល់ ១១:១៦) ។ គឺជាផ្ទៃរឿងដែលបានបង្ហាញឱ្យឃើញម្តងទៀតក្នុងគម្ពីរនេះទាំងមូល ។ ឃ្លានិពន្ធរបស់គម្ពីរអេសាយ ក៏បង្ហាញពីការព្យាយាមដើម្បីធ្វើការរួបរួម ឯជំពូក ៣៦-៣៩ ក៏ជាការបង្រួបបង្រួមនូវរយៈពេលចន្លោះដែលបញ្ចប់ដោយជំពូក ៤០-៦៦ (សូមមើលការពន្យល់ ៣៦:១) ។

តាមរយៈខគម្ពីរសញ្ញាថ្មីជាច្រើន ក៏បានផ្តោតសំខាន់ទៅលើហោរាអេសាយដែលមានទំនាក់ទំនងផ្នែកធំៗក្នុងព្រះគម្ពីរទាំងមូលៈ

មថ ១២:១៧–២១ (អស ៤២:១–៤) មថ ៣:៣ និង លក ៣:៤ (អស ៤០:៣) រម ១០:១៦,២០–៤១ (អស ៥៣:១ ៦:១០) ។

## កាលបរិច្ឆេទ

គឺស្ទើរតែគ្រប់ហេតុការណ៍នៅក្នុងជំពូក ១–៣៩ បានបង្ហាញឱ្យឃើញពីកិច្ចការបំរើព្រះរបស់លោកអេសាយ(សូមមើល ៦:១ ១៤:២៨ ៣៦:១) ។ ដូច្នេះគ្រប់ទាំងជំពូកក្នុងកណ្ឌគម្ពីរអេសាយបានបញ្ចប់ទាំងស្រុង គឺក្នុងកំឡុងឆ្នាំ៧០១ មុនគ.ស គឺជាឆ្នាំដែលពួកកងទ័ពអាសស៊ើរបានបរាជ័យ (សូមមើល ១០:១៦ នឹងការពន្យល់ ៣៧:៣៨) ការនិពន្ធរបស់លោកអេសាយចុងក្រោយក្នុងជំពូក ៤០–៦៦ ។

## ជីវប្រវត្តិ

លោកអេសាយបានសរសេរចងក្រងកណ្ឌគម្ពីរនេះ គឺនៅក្នុងកំឡុងពេលមានព្យុះភ្លៀងដែលជារយៈពេលចក្រភពអាសស៊ើររីកដុះដាល ហើយក៏ជាពេលដែលស្រុកអ៊ីស្រាអែលមានភាពធ្លាក់ចុះ ក្រោមការដឹកនាំគ្រងរាជ្យរបស់ស្តេច ។ ទីកឡោត–ពីលេស៊ើរទីIII (១៤៥–៧២៧ មុនគ.ស)ដែលពួកអាសស៊ើរបានរុករានចូលទៅដល់ស្រុកអើរ៉ាម(ស្រុកស៊ីរី) និងស្រុកកាណាន ។ តែប្រហែលជាក្នុងឆ្នាំ ៧៣៣ ពួកស្តេចអើរ៉ាម និងសាសន៍អ៊ីស្រាអែលក៏ព្យាយាមបញ្ចុះបញ្ចូលដោយប្រើអំណាចទៅលើស្តេចអេហាសជាស្តេចស្រុកយូដាឱ្យចូលរួមកម្លាំងចំរុះ ដើម្បីប្រឆាំងតបទល់និងពួកទ័ពអាសស៊ើរ ។ តែស្តេចអេហាសក៏ស្នើសុំឱ្យពួកស្តេចទីកឡាត–ពីលេស៊ើរជួយជំនួសវិញក៏មានការសម្រេចពីអេសាយ(សូមមើលការពន្យល់ ៧:១) ។ ឯពួកអាសស៊ើរក៏មានជំនួយពីពួកយូដាក្នុងការគ្រប់គ្រងនគរផ្នែកខាងជើងក្នុងចន្លោះឆ្នាំ ៧២២–៧២៤ មុនគ.ស ។ បញ្ហានេះធ្វើឱ្យពួកសាសន៍យូដាកាន់តែមានការឈឺចាប់ និងក្នុងឆ្នាំ ៧០១ស្តេចសានហេរីបរបស់ស្រុកអាសស៊ើរក៏បានគំរាមកំហែងដល់ក្រុងយេរូសាឡិមផ្ទាល់ (សូមមើល ៣៦:១ និងការពន្យល់) ។ ចំណែកឯស្តេចហេសេគាបានអធិស្ឋានដោយអស់ពីចិត្ត និងលោកអេសាយក៏បានទូទាយថាព្រះ និងបានបង្ខំដល់ពួកអាសស៊ើរឱ្យដកថយចេញពីទីក្រុង (៣៧:៦–៧) ។

ម៉្យាងវិញទៀត លោកអេសាយបានប្រមានដល់ពួកសាសន៍យូដាថា អំពើបាបរបស់គេនិងត្រូវជាប់ជាឈ្លើយនៅក្នុងដៃរបស់ស្រុកបាប៊ីឡូន ។ ក៏មានការទៅគាល់ថ្វាយរបស់រាជទូតរបស់ស្តេចពួកបាប៊ីឡូនចំពោះស្តេចហេសេគា គឺជាផ្នែកនៃសេចក្តីទំនាយ(សូមមើល ៣៩:១,៦ និងការពន្យល់) ។ ទោះជាការធ្លាក់ចុះទ្រុតទ្រោមរបស់ក្រុងយេរូសាឡិមមិនមានរហូតដល់ឆ្នាំ ៥៨៦ មុនគ.ស ក៏ដោយក៏លោកអេសាយសន្មតថាការទ្រុតទ្រោមរបស់ពួកស្រុកយូដា និងបានរួចពីការធ្វើជាឈ្លើយ (សូមមើល ៤០:២–៣ និងការពន្យល់) ។ គឺទ្រង់និងប្រោសលោះឱ្យរាស្ត្ររបស់ទ្រង់រួចចេញពីក្រុងបាប៊ីឡូន ដូចការរួចផុតចេញពីអេស៊ីព្ទផងដែរ (សូមមើលការពន្យល់) ក៏សូមមើល ៥២:៧ និងការពន្យល់ផងដែរ។

## ផ្ទៃរឿង និងទេវសាស្ត្រ

ព្រះគម្ពីរអេសាយ គឺជាគម្ពីរដែលបង្ហាញពីការ ឫទ្ធិហឹនៃការជំនុំជម្រះរបស់ព្រះយេហូវ៉ា និងសេចក្តីសង្គ្រោះរបស់ទ្រង់ផងដែរ ព្រះអម្ចាស់គឺជា "ព្រះដ៏បរិសុទ្ធរបស់រាស្ត្រអ៊ីស្រាអែល" (សូមមើល ១:៤ ៦:១ និងការពន្យល់) ក៏ជាអ្នកដែលត្រូវដាក់ទណ្ឌកម្មពួកអ្នកដែលប្រឆាំង(១:២) ប៉ុន្តែទ្រង់និងប្រោសលោះជាក្រោយវិញ(៤១:១៤,១៦) ។ រាស្ត្រអ៊ីស្រាអែលជាជាតិសាសន៍ដែលខ្វាក់ និងថ្លង់(៦:៩–១០ ៤២:៧)ឯចំការទំពាំងបាយជូររបស់ទ្រង់ និងត្រូវគេជាន់ឈ្លី(៥:១–៧) ឯមនុស្សដែលគ្មានភាពយុត្តធម៌ ឬសុចរិត (៥:៧ ១០:១–២) ។ ការជំនុំជម្រះនិងដោះលែងពួកអ៊ីស្រាអែល និងគ្រប់ទាំងពូជសាសន៍ដែលប្រុងតែប្រឆាំងតបនិងព្រះ គេហៅថា "ជាថ្ងៃរបស់ព្រះយេហូវ៉ា" ទោះជារាស្ត្រអ៊ីស្រាអែលបានប្រមើលគិតដល់ថ្ងៃទាំងនោះក៏ដោយ(៥:៣០ ៤២:២៥) គឺជាតិសាសន៍ទទួលបានអំណាចចេស្តាពេញលេញ (សូមមើល ២:១១,១៧,២០ និងការពន្យល់) ។ គឺជាថ្ងៃដែលទាក់ទងនិងការយាងមកវិញជាលើកទី២របស់ព្រះអង្គ ដែលមានក្នុងសញ្ញាថ្មីដែលមានទាំងការជំនុំជម្រះ (សូមមើល ២៤:១,២១ ៣៤:១–២ និងការពន្យល់) ។ តាមរយៈព្រះគម្ពីរ "ភ្លើង" ជាតំណែងនៃការកាត់ទោសជំនុំជម្រះ(សូមមើល ១:៣១ ៣០:៣៣ និងការពន្យល់) ទ្រង់ជាព្រះមហាក្សត្រមានអំណាចលើសអស់ទាំង (សូមមើលការពន្យល់ ២៥:៨) ទ្រង់គឺព្រះគ្រប់លើសអស់ទាំងព្រះអស់ទាំងជាតិសាសន៍ (៤០:១៥–២៤) ។

ព្រះអម្ចាស់ក៏មានសេចក្តីមេត្តាករុណាលើរាស្ត្ររបស់ផងទ្រង់ (១៤:១–២) និងជួយសង្គ្រោះពួកគេឱ្យគេចផុតពីការគាបសង្កត់ខាងឯការងារនយោបាយនិងព្រលឹងវិញ្ញាណ ។ ការដែលពួកគេមានភាពសុខសាន្តឡើងវិញនោះ គឺមានលក្ខណៈដូចជាការភៀសខ្លួនថ្មីមួយ(៤៣:២,១៦–១៩ ៥២:១០–១២) គឺដូចជាព្រះបានសង្គ្រោះពួកគេ (សូមមើល ៣៥:៩ ៤១:១៩ និងការពន្យល់) ។ ការជួយសង្គ្រោះពួកគេ (សូមមើល ៤៣:៣ ៤៩:៨ និងការពន្យល់) ព្រះជាព្រះអាទិករដ៏មានព្រះចេស្តា(៤០:២១–២២ ៤៨:១៣)ដែលទ្រង់បង្កើតឱ្យមានជាទីម្លប់នៃថ្មដាជាផ្លូវទឹកហូរក្នុងទីហួតហែង (៣២:២) ។

ភាពសុខសាន្តរុងរឿងជាសញ្ញាជាយុគសម័យព្រះម៉ែស៊ី (១១:៦-៩) ។ ក៏មានព្រះមហាក្សត្រមួយអង្គដែលមានតំណរាជវង្ស ស្តេចដាវីឌដែលនិងសោយរាជ្យដោយការសុចរិតពិតត្រង់(៩:៧ ៣២:១) ហើយគ្រប់សាសន៍ និងទៅជាភ្នំបរិសុទ្ធនៃក្រុងយេរូសាឡិម(សូមមើល ២:២-៤ និងការពន្យល់) ។ ប្រជារាស្ត្ររបស់ព្រះក៏លែងមានការសង្កត់សង្កិនដោយអ្នកដឹកនាំអាក្រក់ទៀតហើយ (១១:១៤ ៤៥:១៤) និងក្រុងយេរូសាឡិម និងទៅជា "ក្រុងរបស់ព្រះយេហូវ៉ា" (៦០:១៤) ។

ព្រះយេហូវ៉ាបានហៅព្រះមហាក្សត្រនៃព្រះម៉ែស៊ី "ជាបាវបំរើរបស់អញ" មើលក្នុងជំពូក ៤២-៥៣ ហើយពាក្យនេះ ក៏យកទៅអនុវត្តប្រើក្នុងស្រុកអ៊ីស្រាអែលដែលដូចជាជាតិសាសន៍មួយ(សូមមើល ៤១:៨-៩ ៤២:១ និងការពន្យល់) ។ ដោយតាមរយៈការឆ្លងកាត់ការឈឺចាប់នៃអ្នកបម្រើដែលជាសេចក្តីសង្គ្រោះក្នុងអត្ថន័យដ៏ពេញលេញ ។ មានស្រុកស៊ីរូស គឺជាឧបករណ៍របស់ព្រះដើម្បីយកទៅដោះលែងរាស្ត្រអ៊ីស្រាអែលចេញពីបាបីឡូន (៤១:២) ប៉ុន្តែព្រះគ្រីស្ទបានរំដោះមនុស្សជាតិចេញពីគុកនៃអំពើបាប (៥២:១៣-៥៣:១២) ។ ទ្រង់ក៏ប្រែក្លាយជា "ពន្លឺក្នុងចំណោមសាសន៍ដទៃ" (៤២:៦) ដូច្នេះពួកសាសន៍ទាំងនោះដែលនិងត្រូវប្រឈរមុខនិងការជំនុំជម្រះ(ជំពូក ១៣-២៣) និងអាចរកសេចក្តីសង្គ្រោះ (៥៥:៤-៥) ។ ឯសាសន៍ដទៃទាំងនោះក៏ប្រែក្លាយជា"អ្នកបំរើដល់ព្រះយេហូវ៉ា"(សូមមើល ៥៤:១៧ និងការពន្យល់) ។

គឺជាអាណាចក្ររបស់ព្រះយេហូវ៉ានៅលើផែនដីដែលមានអ្នកដឹកនាំដ៏សុចរិត និងទិសដៅដ៏សុចរិតរបស់ផងទ្រង់ គឺជាទិសដៅឆ្ពោះទៅរកសេចក្តីសំដែងក្នុងគម្ពីរអេសាយ ។ ភាពរុងរឿងដល់រាស្ត្ររបស់ទ្រង់ ក៏ដោយសារការសរសើរតម្កើង និងការថ្វាយសិរីល្អដល់ព្រះដ៏បរិសុទ្ធរបស់រាស្ត្រអ៊ីស្រាអែលដែលទ្រង់បានបំពេញនូវសេចក្តីសម្រេច ។

**លក្ខណៈអក្សរសាស្ត្រ**

កណ្ឌគម្ពីរអេសាយបានចងក្រងឡើងតាមបែបផែនជាលក្ខណៈពាក្យលាត ឬពាក្យរាយ និងជាលក្ខណៈកំណាព្យក្នុងព្រះគម្ពីរសញ្ញាចាស់ចំណែកឯពាក្យរាយសំខាន់ៗ ក៏យើងឃើញមានក្នុងជំពូក ៣៦-៣៩ រយៈពេលចន្លោះជាប្រវត្តិសាស្ត្រដែលបានបញ្ចូលក្នុងពីរភាគក្នុងគម្ពីរ (សូមមើលត្រង់អ្នកនិពន្ធ) ។ ឯអត្ថបទជាបែបកំណាព្យ ក៏បញ្ចូលវគ្គនៃសេចក្តីទំនាយជាច្រើនវគ្គមានក្នុងជំពូក ១៣-២៣ ។ មានចម្រៀងដែលពោលពាក្យរិះគន់ដល់ស្តេចបាបីឡូន គឺឃើញក្នុង ១៤:៤-២៣ ជំពូក ២៤-២៧ ក៏មិនបង្ហាញពីថ្ងៃចុងក្រោយ (សូមមើលការពន្យល់ ២៤:១-២៧:១៣) ។ កំណាព្យទាក់ទងនិងប្រាជ្ញា គឺមានក្នុង ២៨:២៣-២៩ (ក៏សូមប្រៀបធៀប ៣២:៥-៨) ។ ចម្រៀងថ្លែងពីការចំការទំពាំងបាយជូរ(៥:១-៧) គឺមានលក្ខណៈជាចម្រៀងនៃសេចក្តីស្រឡាញ់ដែលលោកអេសាយបានពណ៌នាពីការចងសម្ព័ន្ធភាពជាមួយពួកអ៊ីស្រាអែល ។ ឯបទទំនុកចំរៀងសរសើរក៏មានក្នុង ១២:១-៦ និង ៣៨:១០-២០ និងសេចក្តីសោកសៅទូទៅជាតិសាសន៍លេចឡើងក្នុង ៦៣:៧-៦៤:១២ ។ ក៏មានបទកំណាព្យខ្លះមានលក្ខណៈផ្សេងគ្នា ។

ផ្នែកមួយនៃការនិពន្ធរបស់លោកអេសាយ គឺជាលក្ខណៈសម្បត្តិរបស់អត្ថបទ ។ មានព្រះច័ន្ទនិងត្រូវជ្រប់មុខ ហើយព្រះអាទិត្យនឹងត្រូវអៀន( ២៤:២៣) គឺជាខណៈពេលវាលរហោស្ថាន និងទឹកដីមានសេចក្តីអំណរ(សូមមើល ៣៥:១ និងការពន្យល់) និងភ្នំ និងព្រៃបង្កើតជាបទចម្រៀង (៤៤:២៣) ព្រៃព្រឹក្សា "ទះដៃរបស់វា" (៥៥:១២) ។ មានចំការទំពាំងបាយជូរដ៏សប្បាយ គឺតំណាងឱ្យរាស្ត្រអ៊ីស្រាអែល (៥: ៧) ។ ការជាន់ក្នុងធុងទំពាំងបាយជូរ គឺជាសញ្ញានៃការកាត់ទោស(សូមមើល ៦៣:៣ និងការពន្យល់) ។ ហើយចំណែកឯការផឹកពីពែងនៃសេចក្តីក្រោធរបស់ទ្រង់ គឺជាការទទួលការជំនុំជម្រះ (សូមមើល ៥១:១៧ និងការពន្យល់) ។ លោកអេសាយប្រើឈ្មោះ"ថ្ម" ដើម្បីពណ៌នាពីព្រះ(១៧:១០) និងសត្វពាហនៈ ដូចជាសត្វសំបើម ជានាគដែលរត់ពួន និងការមានចិត្តអួតជាតំណាងជាតិសាសន៍ (សូមមើល ២៧:១ ៣០:៧ ៥១:៩) ។ អំណាចនៃរូបបំលាក់ជាការស្រមៃរបស់លោកអេសាយ ក៏ស្តែងចេញឱ្យឃើញក្នុង ៣០:២៧-៣៣ ហើយគាត់ពង្រីកអត្ថន័យយ៉ាងពេញលេញដោយពាក្យប្រៀបប្រដូច ក្នុងរូបភាពដែលធ្វើដោយដៃមនុស្ស ក្នុង៤៤:៩-២០ (សូមមើលការពន្យល់ ៥:៧) ។

គម្ពីរអេសាយជារឿយៗបង្ហាញឱ្យឃើញពីព្រឹត្តិការមុនៗ គឺក្នុងប្រវត្តិសាស្ត្ររបស់រាស្ត្រអ៊ីស្រាអែល ជាពិសេសការគេចចេញពីដំណើរស្រុកអេស៊ីព្ទ ។ ការឆ្លងកាត់សមុទ្រក្រហម ក៏ចងក្រងឡើងបានជាជីវប្រវត្តិចំពោះ ១១:១៥ និង ៤៣:២,១៦-១៧ ក៏មានការបញ្ជាក់មួយទៀតលេចឡើងក្នុង ៤:៥-៦ ៣១:៥ ៣៧:៣៦ (សូមមើលការពន្យល់ក្នុងគម្ពីរទាំងនោះ) ។ ការផ្តួលរំលំក្រុងសូដុំម និងក្រុងកូម៉ូរ៉ា គឺសំដៅទៅ ១:៩ និងលោកគេឌានមានជ័យជម្នះលើពួកស្រុកម៉ាឌាន ក៏បានបង្ហាញក្នុងជំពូក ៩:៤ ១០:២៦ (សូមមើល ២៨:២១ ផងដែរ) ក៏ជាច្រើនលើកច្រើនគ្រាដែលលោកអេសាយទាញយកពីបទចម្រៀងរបស់លោកម៉ូសេក្នុង ចទ ៣២(ប្រៀបធៀប ១:២ ជាមួយ ចទ ៣២:១ ៣០:១៧ និងជាមួយ ៣២:៣០ និង ៤៣:១១,១៣ ជាមួយ ចទ ៣២:៣៩) ។ អេសាយមានលក្ខណៈដូចលោកម៉ូសេបានហៅប្រជាជាតិដើម្បី

លន់តួ និងមានសេចក្ដីជំនឿនៅក្នុងព្រះអម្ចាស់ដ៏បរិសុទ្ធ ។ សូមមើលការពន្យល់ ៤៩:៨ ក៏មានបទបន្ទរក្នុង ៤៨:២២ និង ៥៧:២១ ញែកចេញពីជំពូក ៤០–៤៨ ៤៩:៥៧ ៥៨–៦៦ សូមមើលគម្រោងសង្ខេប ។

**គម្រោងសង្ខេប**

***ភាគទី១ : សៀវភៅជំនុំជម្រះ (ជំពូក ១–៣៩)***

**I. អត្ថបទស្តីពីការបន្ទោស និងសេចក្ដីសន្យា (ជំពូក ១–៦)**

**ក.** សេចក្ដីផ្ដើម : ការចោទប្រឆាំង និងពួកយូដាដែលល្មើសនិងសេចក្ដីសញ្ញា (ជំពូក ១)

**ខ.** ការដាក់វិន័យនាពេលអនាគត និងសិរីល្អនៃសាសន៍យូដា និងក្រុងយេរូសាឡិម (ជំពូក ២–៤)

1. ព្រះពរនាថ្ងៃអនាគតដល់ក្រុងយេរូសាឡិម (២:១–៥)
2. ការដាក់វិន័យរបស់ព្រះអម្ចាស់ដល់ពួកយូដា (២:៦–៤:១)
3. ការបង្កើតឱ្យមានភាពល្អឡើងវិញរបស់ក្រុងស៊ីយ៉ូន (៤:២–៦)

**គ.** កិច្ចបេសកកម្មរបស់លោកអេសាយ (ជំពូក ៦)

**II. សេចក្ដីទំនាយបានបើកឱកាសឱ្យតាមរយៈពួកសម្ព័ន្ធសាសន៍អើរ៉ាម និងរាស្ត្រអ៊ីស្រាអែលគំរាមគំហែងដល់ពួកសាសន៍យូដា (ជំពូក ៧–១២)**

**ក.** ស្ដេចអេហាសបានប្រមាថកុំឱ្យខ្លាចពួកសម្ព័ន្ធភាពសាសន៍អើរ៉ាម និងពួកសាសន៍អ៊ីស្រាអែល (ជំពូក ៧)

**ខ.** កូនប្រុសរបស់អេសាយ និងកូនប្រុសស្ដេចដាវីឌ (៨:១–៩:៧)

**គ.** ការជំនុំជម្រះ និងពួកសាសន៍អ៊ីស្រាអែល (៩:៨–១០:៤)

**ឃ.** ចក្រភពអាសស៊ើរ និងនគររបស់រាជវង្សដាវីឌ (១០:៥–១២:៦)

1. ការខូចខាតហិនវិនាសរបស់ពួកសាសន៍អាសស៊ើរ (១០:៥–៣៤) ។
2. ការបង្កើតឡើងនូវព្រះមហាក្សត្រនៃវង្សដាវីឌ និងនគររបស់ផងទ្រង់ (ជំពូក ១១)
3. ចម្រៀងនៃសេចក្ដីអំណរសម្រាប់ការដោះលែង (ជំពូក ១២)

**III. ការជំនុំជម្រះដល់ពួជសាសន៍មួយចំនួន (ជំពូក ១៣–២៣)**

**ក.** ការប្រឆាំងនឹងពួកអាសស៊ើរ និងអ្នកដឹកនាំរបស់ពួកវា (១៣:១–១៤:២៧)

**ខ.** ការប្រឆាំងនឹងពួកភីលីស្ទីន (១៤:២៨–៣២)

**គ.** ការប្រឆាំងនឹងពួកស្រុកម៉ូអាប់ (ជំពូក ១៥–១៦)

**ឃ.** ការប្រឆាំងនឹងពួកអើរ៉ាម និងអ៊ីស្រាអែល (ជំពូក ១៧)

**ង.** ការប្រឆាំងនឹងពួកស្រុកគូស (ជំពូក ១៨)

**ច.** ការប្រឆាំងនឹងពួកបាប៊ីឡូន (២១:១–១០)

**ឆ.** ការប្រឆាំងនឹងពួកសាសន៍អេដំម (២១:១១–១២)

**ជ.** ការប្រឆាំងនឹងពួកប្រទេសអារ៉ាប់ (២១:១៣–១៧)

**ឈ.** ការប្រឆាំងនឹងអំណាចនៃច្រកភ្នំយ៉ាងល្អនៃក្រុងយេរូសាឡិម (ជំពូក ២២)

**ញ.** ការប្រឆាំងនឹងក្រុងទីរ៉ុស (ជំពូក ២៣)

**IV. ការជំនុំជម្រះ និងព្រះបន្ទូលសន្យា (ពីនគររបស់ព្រះយេហូវ៉ា) ជំពូក ២៤–២៧**

**ក.** ការជំនុំជម្រះជាទូទៅចំពោះអំពើបាបជាទូទៅ (ជំពូក ២៤)

**ខ.** ការសង្គ្រោះ និងព្រះពរ (ជំពូក ២៥)

**គ.** ការសរសើរចំពោះការថែរក្សាដល់វង្សក្សត្ររបស់ព្រះយេហូវ៉ា (ជំពូក ២៦)

**ឃ.** ពួកសត្រូវរបស់រាស្ត្រអ៊ីស្រាអែលត្រូវបានដាក់ទោស ប៉ុន្តែពួកសំណល់របស់អ៊ីស្រាអែលបានរស់ឡើងវិញ (ជំពូក ២៧)

**V. សេចក្ដីវេទនា ៦យ៉ាង : ក្នុងនោះមាន៥យ៉ាងពីភាពមិនស្មោះត្រង់ក្នុងស្រុកអ៊ីស្រាអែល និងមួយទៀតនៅក្នុងស្រុកអាសស៊ើរ**

**(ជំពូក ២៨-៣៣)**

**ក.** សេចក្តីវេទនាចំពោះពួកអេប្រាអិម (ពួកស្រុកសាម៉ារី) និងពួកយូដា (ជំពូក ២៨)

**ខ.** សេចក្តីវេទនាចំពោះទីក្រុងដាវីឌ គឺក្រុងយេរូសាឡិម (២៩:១-១៤)

**គ.** សេចក្តីវេទនាចំពោះអ្នកដែលពឹងផ្អែកលើបក្សសម្ព័ន្ធបរទេស (២៩:១៥-២៤)

**ឃ.** សេចក្តីវេទនាចំពោះពួកពូជសាសន៍ដែលចចេសក្បាលរឹង (ជំពូក ៣០)

**ង.** សេចក្តីវេទនាដល់អ្នកដែលពឹងផ្អែកលើពួកស្រុកអេស៊ីព្ទ (ជំពូក ៣១-៣២)

**ច.** សេចក្តីវេទនាចំពោះពួកអាសស៊ើរ ប៉ុន្តែប្រទានពរចំពោះរាស្ត្ររបស់ព្រះអម្ចាស់ (ជំពូក ៣៣)

**VI. សេចក្តីទំនាយបន្ថែមស្តីអំពីការជំនុំជម្រះ និងព្រះបន្ទូលសន្យា (ជំពូក ៣៤-៣៥)**

**ក.** ការការពារក្រុងយេរូសាឡិមពីការគំរាមកំហែងរបស់ពួកអាសស៊ើរ (ជំពូក ៣៦-៣៧)

1. ការឡោមពទ្ធ័ក្រុងយេរូសាឡិមដោយពួកស្តេចសានហេរីប និងកងទ័ពពួកអាសស៊ើរ (ជំពូក ៣៦)

2. ការប្រោសលោះពីព្រះយេហូវ៉ាដល់ក្រុងយេរូសាឡិម (ជំពូក ៣៧)

**ខ.** ព្រះយេហូវ៉ាបានពន្យាអាយុជីវិតរបស់ស្តេចហេសេគា (ជំពូក ៣៨)

**គ.** សេចក្តីទំនាយពីការជម្លៀសទៅឯក្រុងបាប៊ីឡូន (ជំពូក ៣៩)

***ភាគទី២ វគ្គនៃការកម្សាន្តទុក្ខ (ជំពូក ៤០-៦៦)***

**VIII. ប្រោសលោះ និងធ្វើឱ្យរាស្ត្រអ៊ីស្រាអែលមានជីវិតរស់ឡើងវិញ (ជំពូក ៤០-៤៨) ។**

**ក.** ការយាងមកដល់របស់ព្រះអម្ចាស់ដ៏មានជ័យជម្នះ (៤០:១-២៦) ។

**ខ.** កម្លាំងដែលពុំទ្រុតទ្រោមមិនដែលល្ហើយ (៤០:២៧-៣១)

**គ.** ព្រះយេហូវ៉ាជាព្រះនៃប្រវត្តិសាស្ត្រ (៤១:១-៤២:៩)

**ឃ.** ការសរសើរ និងរំឭកដាស់តឿន (៤២:១០-២៥)

**ង.** ការរៀបចំឡើងវិញ និងការធ្វើឱ្យស្រុកអ៊ីស្រាអែលមានជីវិតរស់ឡើងវិញ (៤៣:១-៤៤:៥)

**ច.** ព្រះអម្ចាស់ជាព្រះតែមួយគត់ (៤៤:៦-៤៥:២៥)

**ឆ.** ព្រះយេហូវ៉ាមានអំណាចចេស្តាលើព្រះពួកបាប៊ីឡូន (ជំពូក ៤៦)

**ជ.** ការធ្លាក់ចុះរបស់បាប៊ីឡូន (ជំពូក ៤៧)

**ឈ.** ការកើនរំឭករបស់ព្រះយេហូវ៉ាចំពោះរាស្ត្ររបស់ផងទ្រង់ (ជំពូក ៤៨)

**XI. កិច្ចការបម្រើព្រះរបស់អ្នកបំរើ និងការធ្វើឱ្យរាស្ត្រអ៊ីស្រាអែលរស់ឡើងវិញ (៤៩:៥៧)**

**ក.** ការត្រាស់ហៅ និងបេសកកម្មរបស់អ្នកបម្រើ (៤៩:១-១៣)

**ខ.** ការបង្កើតមានប្រជារាស្ត្រក្នុងក្រុងស៊ីយ៉ូន (៤៩:១៤-២៦)

**គ.** អំពើបាបរបស់ពួកអ៊ីស្រាអែល និងការស្តាប់បង្គាប់របស់អ្នកបម្រើ (ជំពូក ៥០)

**ឃ.** ពួកសំណល់បានលើកទឹកចិត្ត ពីព្រោះឧត្តមគតិរបស់ពួកគេ (៥១:១-៥២:១២)

**ង.** ការឈឺចាប់ និងសិរីល្អរបស់អ្នកបម្រើ ដ៏សុចរិតរបស់ព្រះយេហូវ៉ា (៥២:១៣-៥៣:១២)

**ច.** ភាពរុងរឿងនាពេលអនាគតរបស់ពួកក្រុងស៊ីយ៉ូន (ជំពូក ៥៤)

**ឆ.** ការត្រាស់ហៅរបស់ព្រះយេហូវ៉ាចំពោះការសង្គ្រោះ និងព្រះពរតាមសេចក្តីសញ្ញា (៥៥:១-៥៦:៨)

**ជ.** ការជំនុំជម្រះ ពួកប្រព្រឹត្តការអាក្រក់នៅក្នុងស្រុកអ៊ីស្រាអែល (៥៦:៩-៥៧:២១)

**X. ការសង្គ្រោះដល់អស់កល្បជានិច្ច និងការជំនុំជម្រះដ៏អស់កល្បជានិច្ច (ជំពូក ៥៨-៦៦)**

**ក.** ការថ្វាយបង្គំក្លែងក្លាយ និងថ្វាយបង្គំពិត (ជំពូក ៥៨) ។

**ខ.** ការលន់តួរបស់ពួកក្រុងស៊ីយ៉ូន និងការប្រោសលោះ (ជំពូក ៥៩)

**គ.** សន្តិភាពរបស់ពួកក្រុងស៊ីយ៉ូន និងវិបុលសុខ (ជំពូក ៦០)

**ឃ.** សេចក្តីមេត្តាករុណារបស់ព្រះយេហូវ៉ា (ជំពូក ៦១)

**ង.** ការមានជាថ្មីនៃក្រុងស៊ីយ៉ូន និងសិរីល្អ (៦២:១–៦៣:៦)

**ច.** ការអធិស្ឋានដើម្បីការដោះលែងពីព្រះ (៦៣:៧–៦៤:១២)

**ឆ.** ការដែលព្រះបានឆ្លើយតប : មានមេត្តាករុណា និងការជំនុំជម្រះ (ជំពូក ៦៥)

**ជ.** ការជំនុំជម្រះចំពោះ អ្នកដែលថ្វាយបង្គំក្លែងក្លាយ និងព្រះពរចំពោះអ្នកថ្វាយបង្គំសំដៅទៅលើសេចក្តីពិត(ជំពូក ៦៦) ។

**១** [១]នេះជាការជាក់ស្តែង[ក]ដែលអេសាយ ជាកូនអ៊ីម៉ូសបាន
ឃើញ[ខ]ពីដំណើរស្រុកយូដា និងក្រុងយេរូសាឡិម[គ] ក្នុង
រាជ្យអ៊ូសៀស[ឃ] យ៉ូថាម[ង] អេហាស[ច] ហើយនិងហេសេគា[ឆ]
ជាស្តេចស្រុកយូដា ។

## សាសន៍ដែលបះបោរ

២ឱស្ថានសួគ៌អើយ ចូរស្តាប់ ហើយផែនដីអើយ[ជ] ចូរ
ផ្ទៀងត្រចៀកចុះ ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូល[ឈ]
ហើយថា អញបានចិញ្ចឹមបីបាច់រក្សាកូន[ញ] តែវារាល់គ្នា
បានបះបោរ[ដ]នឹងអញវិញ ៣គោវាស្គាល់[ឋ]ម្ចាស់ ហើយលា
ក៏ស្គាល់ស្នូករបស់ម្ចាស់វាដែរ[ឌ] ប៉ុន្តែអ៊ីស្រាអែលមិន
ស្គាល់[ឍ]សោះ រាស្ត្រអញមិនពិចារណាទេ[ណ] ៤ឱហ្ន៎ ប្រទេស
ដ៏មានបាប ជាសាសន៍ផ្ទុកដោយអំពើទុច្ចរិត[ត] ជាពូជមនុស្ស
ដែលប្រព្រឹត្តអាក្រក់[ថ] ជាពួកកូនចៅដែលប្រព្រឹត្តវៀច
កោង[ទ] គេបានបោះបង់ចោល[ធ]ព្រះយេហូវ៉ា គេបានប្រមាថ
មើលងាយ ដល់ព្រះដ៏បរិសុទ្ធ[ន]នៃសាសន៍អ៊ីស្រាអែល គេ
បានត្រូវព្រាត់ថយទៅក្រោយ[ប] ៥ឯងរាល់គ្នាចង់ត្រូវរំពាត់[ផ]
ទៀតធ្វើអី បានជាចេះតែ[ព]បះបោរកាន់តែច្រើនឡើង
ដូច្នេះ[ភ] គ្រប់ទាំងក្បាលក៏ឈឺ គ្រប់ទាំងចិត្ត[ម]បានល្វើយផង
ហើយ[យ] ៦ចាប់តាំងពីបាតជើងរហូតដល់កំពូលក្បាល[រ] នោះ
ឥតមានកន្លែងណាមាំមួនឡើយ[ល] គឺមានសុទ្ធតែរបួស និង
ជាំ[វ] ហើយស្នាមរំពាត់ថ្មី ឥតបានបិទភ្ជិតឬរុំ[ស] ឬចាក់ប្រេង
ឱ្យធូរស្រាកទេ[ហ] ៧ស្រុករបស់ឯងរាល់គ្នាបានចោលស្ងាត់
ហើយ[ឡ] ទីក្រុងឯងក៏ត្រូវដុតបំផ្លាញអស់ទៅ[អ] ពួកសាសន៍
ដទៃ[ក]គេត្របាក់លេបដីរបស់ឯង នៅចំពោះឯងផង ហើយ
ដីនោះត្រូវចោលស្ងាត់ ដោយពួកសាសន៍ដទៃបំផ្លាញ[ខ] ៨កូន
ស្រីរបស់ក្រុងស៊ីយ៉ូន[គ] នាងត្រូវលះចោល[ឃ] ដូចជាបង្ហាដែល

**១:១** ក ១សយ ៣:១ អស ២២:១ អប ១:១ ណហ ១:១ ខ អស ២:១ ១៣:១ គ អស ៤០:៩ ៤៤:២៦ ឃ ២ពវ ១៤:២១ ២រប ២៦:២២ ង ១រប ៣:១២ ច ២ពវ ១៦:១ ឆ ១រប ៣:១៣ **១:២** ជ ចទ ៤:២៦ ឈ ពច ១១:១០ យរ ៤២:៥ មីក ១:២ ញ អស ២៣:៤ ៦៣:១៦ ដ ខ.៤,២៣ អស ២៤:៥,២០ ៣០:១,៩ ៤៦:៨ ៤៨:៨ ៥៧:៤ ៦៥:២ ៦៦:២៤ អគ ២៤:៣ ហក ១:១២ មឡ ១:៦ ៣:៥ **១:៣** ឋ យប ១២:៩ ឌ លប ៤២:២៧ ឍ យរ ៤:២២ ៥:៤ ៩:៣,៦ ហស ២:៨ ៤:១ ណ ចទ ៣២:២៨ អស ៤២:២៥ ៤៨:៨ ហស ៤:៦ ៧:៩ **១:៤** ត អស ៥:១៨ ថ ខ.២ អស ៩:១៧ ១៤:២០ ៣១:២ យរ ២៣:១៤ ទ ទដ ១៤:៣ ធ ចទ ៣២:១៥ ទដ ១១៩:៨៧ ន ២ពវ ១៩:២២ អស ៥:១៩,២៤ ៣១:១ ៣៧:២៣ ៤១:១៤ ៤៣:១៤ ៤៥:១១ ៤៧:៤ អគ ៣៩:៧ ប សភ ៣០:៩ អស ៥៩:១៣ **១:៥** ផ សភ ២០:៣០ ព យរ ២:៣០ ៥:៣ ៨:៥ ភ ខ.២ អស ៣១:៦ យរ ៤៤:១៦–១៧ ហព ៣:១៦ ម បទ ២:១១ ៥:១៧ យ អស ៣០:២៦ ៣៣:៦,២៤ ៥៨:៨ យរ ៣០:១៧ **១:៦** រ ចទ ២៨:៣៥ ល ទដ ៣៨:៣ វ អស ៥៣:៥ ស ទដ ១៤៧:៣ អស ៣០:២៦ យរ ៨:២២ ១៤:១៩ ៣០:១៧ បទ ២:១៣ អគ ៣៤:៤ ហ ២សយ ១៤:២ ទដ ២៣:៥ ៤៥:៧ ១០៤:១៥ អស ៦១:៣ លក ១០:៣៤ **១:៧** ឡ លវ ២៦:៣៤ អ លវ ២៦:៣១ ចទ ២៩:២៣ ក លវ ២៦:១៦ ពច ៦:៣–៦ អស ៦២:៨ យរ ៥:១៧ ខ ២ពវ ១៨:១៣ ទដ ១០៩:១១ **១:៨** គ ទដ ៩:១៤ អស ១០:៣២ ឃ អស ៣០:១៧ ៤៩:២១

**១:១–៦:១៣** គឺជាផ្នែកទីមួយនៃសេចក្តីទំនាយរបស់ ហោរាអេសាយ ដែលមានចំនួនច្រើនលើសលប់គឺតារយៈសេចក្តីទំនាយពីការជំនុំជម្រះ និងកិច្ចការរបស់លោកអេសាយ ដែលជួបប្រទះក្នុងជំពូក៦ (ប្រៀបធៀបការពន្យល់ ៧:១–១២:៦) ។

**១:១–៣១** ប្រៀបធៀបនូវភស្តុតាងនៃជំពូក១ ជាមួយនិងជំពូក៥ គឺជំពូកទាំងពីរមានទាំងប្រភេទទីមួយនៃពាក្យទំនាយ ជំពូក១ ក៏បង្ហាញនៅក្នុងសេចក្តីដែលមានចំពោះគម្ពីរទាំងមូល ។

**១:១** គឺជាចំណងជើងនៃកណ្ឌគម្ពីរ ក៏មានខ្លះទៀតលេចឱ្យឃើញក្នុង ២:១ ១៣:១ ១៤:២៨ ១៥:១ ១៧:១ ១៩:១ ២១:១ ១១,១៣ ២២:១ ២៣:១ បានឃើញគឺក្នុងអត្ថន័យនៃការ "បើកសំដែងពីទំនាយ"ឬ "សេចក្តីទំនាយ" (សូមមើល សភ ២៩:១៨ និងការពន្យល់ មើល ១សយ ៣:១)។ *អ័ម៉ុស* កុំច្រឡំនិងហោរាអេម៉ុស មានលោករាជ្យ ។ *អូសៀស យ៉ូថាប អេហាស និង ហេសេគា* ពួកទាំងអស់នេះបានសោយរាជ្យតាំងពី ៧៩២ រហូតដល់ ៦៨៦ មុន គ.ស ។ ក៏គ្មានស្តេចរបស់រាស្ត្រអ៊ីស្រាអែលណាមួយបានបង្ហាញសោះ លោកអេសាយគ្រប់គ្រងនៅផ្នែកនគរយូដាខាងត្បូងមក ។

**១:២** អេសាយការចាប់ផ្តើមនិងការបញ្ជាក់ (៦៦:២៤) ដែលមានការកាត់ទោសចំពោះអ្នកដែលប្រឆាំងនិងព្រះ ។ ហោរាបានស្រែកទៅឯស្ថានសួគ៌ និងផែនដីដើម្បីធ្វើសាក្សីនៃសេចក្តីពិត ចំពោះការចោទប្រកាន់របស់ព្រះទាស់នឹងរាស្ត្រអ៊ីស្រាអែលនិងនៃការកាត់ទោស ក្នុងខណៈពួកគេជាបន្ទាល់នៃសេចក្តីសញ្ញា (សូមមើល ចទ ៣០:១៩ និងការពន្យល់ ៣១:២៨ ៣២:១ ទដ ៥០:១ និងការពន្យល់) ។

**១:៣** *ស្នូក* កន្លែងសម្រាប់ឱ្យចំណី ។ *មិនស្គាល់* គឺការមិនទទួលស្គាល់ ឬយល់ពីព្រះតែក្រោយមកបានលទ្ធផល គឺជម្លៀសរបស់សាសន៍យូដាពីស្រុករបស់គេ (៥:១៣) ។

**១:៤** *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* ពាក្យនេះឃើញសរសេរ ២៦ ដងក្នុងគម្ពីរអេសាយ (សូមមើល ៥:២៤) និងតែងតែឃើញសរសេរនៅកន្លែងផ្សេងទៀត ៦ដងក្នុងគម្ពីរសញ្ញាចាស់(មើលសេចក្តីផ្តើម : ត្រង់អ្នកនិពន្ធ) ។ *ព្រះដ៏បរិសុទ្ធ* មើល នក ៣:៥ លវ ១១:៤៤ និងការពន្យល់ ។

**១:៥–៦** លក្ខខ័ណ្ឌវិញ្ញាណដែលគួរឱ្យអាណិតរបស់រាស្ត្រអ៊ីស្រាអែលក្លាយជាអ្នកបម្រើដ៏ឈឺចាប់ក្នុង ៥៣:៤–៥ ពាក្យក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យ "ការវាយផ្តួល""ពាក្យរងរបួស" និងពាក្យ "សាច់ដែលហើម" គឺឆ្លុះបញ្ចាំង ពីភាព "ខ្ទេចខ្ទី""ភាពមិនម៉ឹងម៉ាត់" និង "ការរងរបួស" ។

**១:៦** ជម្ងឺបានបំផ្លាញដល់រូបកាយទាំងមូលដូចជាលោកយ៉ូបដែរ (លប ២:៧) ។ *ប្រេង* តាមធម្មតាប្រេងប្រភេទនេះប្រើសម្រាប់ព្យាបាលជម្ងឺ (សូមមើល លក ១០:៣៤) ។

**១:៧–៩** ភាពឯកកោស្ងាត់ជ្រងំរបស់ទឹកដីស្រុកយូដា គឺដោយសារតែលទ្ធផល ពីការឈ្លានពានរបស់បរទេស ឧ. គឺដោយពួកស្រុកអើរ៉ាម គឺនៅឯនគរភាគខាងជើងនៃស្រុកអ៊ីស្រាអែលស្រុកអេដំម និងស្រុកភីលីស្ទីន (២រប ២៨:៥:–១៨) ក្រោយមក(ឆ្នាំ ៧០១ មុន គ.ស)គឺដឹកនាំដោយស្តេចស្រុកបាប៊ីឡូនសានហេរីប និងក្រុមកងទ័ពស្រុកអាសស៊ើរ (៣៦:១–២) តែក្រោយមកទៀត (ក្នុង ឆ្នាំ ៦០៥–៥៨៦) ដឹកនាំដោយនេប៊ូក្នេសានិងកងទ័ពបាប៊ីឡូន ។

**១:៨** *កូនស្រីរបស់ក្រុងស៊ីយ៉ូន* គឺការបញ្ជាក់លក្ខណៈនៃក្រុងយេរូសាឡិម (មើលការពន្យល់ ២ពវ ១៩:២១) ។ *ជាបង្ហា . . . ដំរុំ* ជាឃ្លាពាក្យដែលអ្នក

នៅចំការទំពាំងបាយជូរ ដូចជាជីរ៉ំ[ង]នៅចំការត្រសក់ ដូច
ជាទីក្រុង ដែលត្រូវខ្មាំងឡោមព័ទ្ធហើយ ៩បើសិនជាព្រះ
យេហូវ៉ា ជាព្រះនៃពួកពលបរិវារ មិនបានទុកឱ្យយើង
មានសំណល់បន្តិចបន្តួចនៅ[ច] នោះយើងរាល់គ្នានឹងបាន
ដូចជាក្រុងសូដុំម ហើយដូចក្រុងកូម៉ូរ៉ាដែរ[ឆ]។
១០ឱពួកគ្រប់គ្រងលើក្រុងសូដុំមអើយ[ជ] ចូរស្តាប់ព្រះ
បន្ទូលនៃព្រះយេហូវ៉ា[ឈ] ម្នាលពួកក្រុងកូម៉ូរ៉ាអើយ[ញ] ចូរ
ផ្ទៀងត្រចៀកស្តាប់ក្រិត្យវិន័យ[ដ] របស់ព្រះនៃយើងរាល់គ្នា
ចុះ ១១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា យញ្ញបូជាដ៏មាន
ច្រើន ម្ល៉េះរបស់ឯងរាល់គ្នា តើជាអ្វីដល់អញ អញធុញ
ទ្រាន់ចំពោះចៀមឈ្មោល និងខ្លាញ់នៃសត្វបំប៉ន[ឋ] ដែលឯង
ដុតថ្វាយណាស់ អញក៏មិនចូលចិត្ត[ឌ] ចំពោះឈាមនៃគោ
ឈ្មោល[ឍ] ឬកូនចៀម ឬពពែនោះទេ[ណ] ១២កាលណាឯង
រាល់គ្នាលេចមកនៅចំពោះអញ នោះតើអ្នកណាបាន
បង្គាប់ឱ្យឯងរាល់គ្នាធ្វើដូច្នេះ[ត] ដើម្បីឱ្យបានចូលមកជាន់
ទីលានរបស់អញនេះ ១៣កុំឱ្យយកដង្វាយដ៏ឥតប្រយោជន៍មក
ទៀតឡើយ[ថ] ឯកំញាន[ទ] ជារបស់ស្អប់ខ្ពើម[ធ]ដល់អញ ឯបុណ្យ
ចូលខែ[ន] និងថ្ងៃឈប់សំរាក ព្រមទាំងការប្រជុំជំនុំ[ប] នោះ
អញទ្រាំមិនបានទេ សូម្បីតែបុណ្យប្រជុំជំនុំមុតមាំ ក៏ជាអំពើ
ទុច្ចរិតដែរ ១៤ចិត្តអញស្អប់ចំពោះបុណ្យចូលខែ[ផ] និងបុណ្យ
មានកំណត់ទាំងប៉ុន្មាន[ព]របស់ឯងរាល់គ្នាណាស់[ភ] ពិធីទាំង
នោះជាបន្ទុកសង្កត់លើអញជាខ្លាំង[ម] អញក៏នឿយណាយ[យ]
ដោយទ្រាំចំពោះការទាំងនោះ ១៥កាលណាឯងរាល់គ្នា
ប្រទូលដៃ[រ] ឡើង នោះអញនឹងបែរ[ល]ភ្នែកពីឯងចេញ អើ
បើកាលណាឯងអធិស្ឋានជាច្រើន នោះអញនឹងមិនស្តាប់
ឡើយ[វ] ដ្បិត ដៃឯងរាល់គ្នា[ស]ប្រឡាក់ពេញដោយឈាម[ហ]
១៦ចូរលាងចេញ[ឡ] ចូរជំរះខ្លួនឱ្យស្អាតចុះ ចូរបំបាត់អំពើ
អាក្រក់ដែលឯងរាល់គ្នាប្រព្រឹត្ត ពីចំពោះភ្នែកអញចេញ[អ]
ហើយលែងប្រព្រឹត្តអំពើអាក្រក់តទៅ[ក] ១៧ចូរហាត់រៀនធ្វើ
ការល្អវិញ[ខ] ចូរស្វែងរក ឱ្យបានសេចក្តីយុត្តិធម៌[គ] ចូរជួយ
ការពារចំពោះមនុស្សដែលត្រូវគេសង្កត់សង្កិន[ឃ] ចូរកាត់ក្តី
ដល់ពួកកំព្រា[ង] ហើយកាន់ក្តីជំនួសពួកស្រីមេម៉ាយចុះ[ច]។
១៨ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មកចុះ យើងនឹង
ពិភាក្សាជាមួយគ្នា[ឆ] ទោះបើអំពើបាបរបស់ឯងដូចជាពណ៌
ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ[ជ] ទោះបើ

**១:៨** ង យប ២៧:១៨ **១:៩** ច លប ៤៥:៧ ២ពវ ២១:១៤ អស ៤:២ ៦:១៣ ២៧:១២ ២៨:៥ ៣៧:៤,៣១–៣២ ៤៥:២៥ ៥៦:៨ យរ ២៣:៣ យអ ២:៣២ ឆ លប ១៩:២៤ រម ៩:២៩ **១:១០** ជ លប ១៣:១៣ ១៨:២០ អក ១៦:៤៩ រម ៩:២៩ វវ ១១:៨ ឈ អស ២៨:១៤ ញ អស ១៣:១៩ ដ អស ៥:២៤ ៨:២០ ៣០:៩ **១:១១** ឋ ទដ ៥០:៨ អម ៦:៤ ឌ យប ៦:២០ ឍ អស ៦៦:៣ យរ ៦:២០ ណ ១សយ ១៥:២២ ទដ ៤០:៦ មទ្ឋ ១:១០ ហព ១០:៤ **១:១២** ត នក ២៣:១៧ ចទ ៣១:១១ **១:១៣** ថ សភ ១៥:៨ អស ៦៦:៣ ហក ២:១៤ ទ យរ ៧:៩ ១៨:១៥ ៤៤:៨ ធ ១ពវ ១៤:២៤ ទដ ១១៥:៨ សភ ២៨:៩ អស ៤១:២៤ មទ្ឋ ២:១១ ន ជន ១០:១០ ប ១របា ២៣:៣១ **១:១៤** ផ នហ ១០:៣៣ ព នក ១២:១៦ លវ ២៣:១–៤៤ ជន ២៨:១១–២៩:៣៩ ចទ ១៦:១–១៧ អស ៥:១២ ២៩:១ ហស ២:១១ ភ ទដ ១១:៥ ម យប ៧:១២ យ ទដ ៦៩:៣ អស ៧:១៣ ៤៣:២២,២៤ យរ ៤៤:២២ មទ្ឋ ២:១៧ ៣:១៤ **១:១៥** រ នក ៩:២៩ ល ចទ ៣១:១៧ អស ៥៧:១៧ ៥៩:២ វ ចទ ១:៤៥ ១សយ ៨:១៨ យប ១៥:៣១ យហ ៩:៣១ ស យប ៩:៣០ ហ អស ៤:៤ ៥៩:៣ យរ ២:៣៤ អគ ៧:២៣ ហស ៤:២ យអ ៣:២១ **១:១៦** ឡ នរ ៣:៣ មថ ២៧:២៤ យក ៤:៨ អ ជន ១៩:១១,១៦ អស ៥២:១១ ក អស ៥៥:៧ យរ ២៥:៥ **១:១៧** ខ ទដ ៣៤:១៤ គ ទដ ៧២:១ អស ១១:៤ ៣៣:៥ ៥៦:១ ៦១:៨ អម ៥:១៤–១៥ មីក ៦:៨ សផ ២:៣ ឃ ចទ ១៤:២៩ ង ខ.២៣ យប ២២:៩ ទដ ៨២:៣ ៩៤:៦ អស ១០:២ ច នក ២២:២២ អគ ១៨:៣១ ២២:៧ លក ១៨:៣ យក ១:២៧ **១:១៨** ឆ ១សយ ២:២៥ អស ៤១:១ ៤៣:៩,២៦

ចាំយាមប្រើឈ្មោះអាសន្ន (យប ២៧:១៨) គឺអ្នកដែលរកមើលពួកចោរ និងអ្នកឈ្លានពាន ។ គឺក្រុងយេរូសាឡិម មិនមែនមិនអាចការពារបានទេ ។ *ត្រសក់* ឬក៏វាអាច"ជាត្រសក់ម្យ៉ាង" ។

**១:៩–១០** *ក្រុងសូដុំម . . . ក្រុងកូម៉ូរ៉ា* គឺជាឧទាហរណ៍ដ៏សំខាន់ចំពោះទីក្រុងដែលពោរពេញ ដោយអំពើបាបដែលត្រូវបានបំផ្លាញទាំងស្រុង (សូមមើល ៣:៩ លប ១៣:១៣ ១៨:២០–២១ ១៩:៥,២៤–២៥) ។ ដូចជាព្រះយេស៊ូវគ្រីស្ទបង្ហាញប្រាប់ពេត្រុស ដែលប្រៀបធៀបទៅអារក្សសាតាំង (មថ ១៦:២៣) ដូច្នេះអេសាយបង្ហាញដល់រាស្ត្រអ៊ីស្រាអែលថាគេជាអ្នកដឹកនាំក្រុងសូដុំមនិងក្រុងកូម៉ូរ៉ា និងជាប្រជាជនក្រុងកូម៉ូរ៉ា ។

**១:៩** កត់សំគាល់ក្នុងគម្ពីរ រម ៩:២៩ ដែលវាជាប់ទំនាក់ទំនងជាមួយគម្ពីរ អស ១០:២២–២៣ លោកអេសាយចង់និយាយសំដៅទៅលើប្រជាជាតិរបស់ផងទ្រង់និងទទួលស្រុកជាទឹកដីជាមរតក (សូមមើល ៤:៣ ១០:២០–២៣ ១១:១១,១៦ ៤៦:៣) ។

**១:១១–១៥** ចរិតលក្ខណៈជាសីលធម៌និងការធ្វើជាអ្នកថ្វាយបង្គំ គឺមិនមែនជាចំនួននៃសកម្មភាពសាសនារបស់ពួកគេទេ ការដែលសំខាន់នោះគឺនៅក្នុង (៦៦:៣ យរ ៧:២១–២៦ ហស ៦:៦ អម ៥:២១–២៤ មីក ៦:៦–៨ នឹងការពន្យល់) ។

**១:១១** *ខ្លាញ់នៃសត្វបំប៉ន* គឺជាសត្វដែលគេចិញ្ចឹមឱ្យចំណីអាហារពិសេសៗ និងថែរក្សាយ៉ាងល្អ ។

**១:១៤** *បុណ្យចូលខែ* គឺជាបុណ្យដែលធ្វើឡើងរាល់ថ្ងៃទី១ ក្នុងខែនិមួយៗនៃសាសន៍ហេព្រើរ ។ គឺជាការថ្វាយយញ្ញបូជាពិសេស និងជាពិធីបុណ្យទាំងអស់ (មើល ជន ២៨:១១–១៥) ឬបុណ្យមានកំណត់ហើយរាប់បញ្ចូលទាំងបុណ្យប្រមូលផល (នក ២៣:១៤–១៧ ៣៤:១៨–២៥ លវ ២៣ ចទ ១៦:១–១៧) ។

**១:១៥** *អញនឹងបែរភ្នែកពីឯងចេញ* ក្នុង ៨:១៧ ៥៩:២ ព្រះបានបែរព្រះនេត្រទ្រង់ចេញពីរាស្ត្រអ៊ីស្រាអែល (មើល មីក ៣:៤ និងការពន្យល់) ។

**១:១៧** មើល យរ ២២:១៦ និងការពន្យល់ យក ១:២៧ ។ *ពួកកំព្រាស្រីមេម៉ាយ* គឺជាតំណាងភាពខ្សោយ គឺមកពីសង្គមមនុស្ស ។ គឺជាថ្នាក់ដឹកនាំមិនបានផ្តល់ផលប្រយោជន៍ (មើល ខ.២៣ ១០:២ យរ ២២:៣) ។

**១:១៨** *ពណ៌ក្រហមទែង . . . ក្រហមឆ្អៅ* គឺសំដៅទៅលើឈាមដែលក្រហមហើយមានភាពសោកសៅនៃដៃកំណាច (សូមមើល ខ.១៥,២១) *សដូចហិមៈ* គឺជាការពណ៌នាពីអំណាចនៃលទ្ធផលនៃការលើកលែងទោស (សូមមើល ទដ ៥១:៧ នឹងការពន្យល់) ។ លក្ខខ័ណ្ឌនៃការអត់ទោសនេះ គឺដើម្បីឱ្យមានជីវិតដែលទ្រង់បានហៅក្នុង ខ.១៩ ។

ក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ[ឈ]
១៩បើសិនជាឯងរាល់គ្នាស្ម័គ្រចិត្តតាម ហើយស្តាប់បង្គាប់[ញ]
នោះនឹងបានបរិភោគផលល្អនៃស្រុកដែរ[ដ] ២០តែបើឯងមិន
ព្រមវិញ ហើយបះបោរផង[ឋ] នោះឯងនឹងត្រូវលេបបាត់
ដោយមុខដាវ[ឌ] ពីព្រោះព្រះឱស្ឋនៃព្រះយេហូវ៉ា បានមាន
បន្ទូលស្រេចហើយ[ឍ]។
២១ទីក្រុងស្មោះត្រង់បានក្បត់ជាសំផឹងដូច្នេះដែរហ្ន៎[ណ] គឺ
ទីក្រុងដែលបានបំពេញដោយសេចក្ដីយុត្តិធម៌ ហើយមាន
សេចក្ដីសុចរិត[ត]អាស្រ័យនៅក្នុងនោះដែរ តែឥឡូវនេះ
មានសុទ្ធ តែពួកអ្នកកាប់សំឡាប់វិញ[ថ] ២២ប្រាក់របស់ឯងបាន
ត្រឡប់ទៅជាអាចម៍ប្រាក់ទៅហើយ[ទ] ឯស្រាទំពាំងបាយជូរ
របស់ឯង ក៏លាយដោយទឹកដែរ ២៣ពួកមេរបស់ឯងជា
ពួកអ្នកបះបោរ[ធ] ហើយជាភឿនមិត្រនឹងពួកចោរ[ន] គ្រប់គ្នា
ចូលចិត្តតែស៊ីសំណូក[ប] ហើយក៏ឧស្សាហ៍តាមរង្វាន់ គេមិន
កាត់ក្តីឱ្យពួកកំព្រាឡើយ ហើយរឿងក្តីរបស់ពួកមេម៉ាយ
ក៏មិនដែលមកដល់គេដែរ[ផ]។
២៤ហេតុនោះបានជាព្រះអម្ចាស់ គឺព្រះយេហូវ៉ានៃ
ពួកពលបរិវារ ជាព្រះដ៏មានព្រះចេស្តា[ព] នៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលថា អា៎ អញនឹងដោះពួកតតាំង
នឹងអញចេញឱ្យធូរខ្លួនវិញ អញនឹងសងសឹក[ភ]ចំពោះពួក
ខ្មាំងសត្រូវ[ម] ២៥អញនឹងលូកដៃទៅលើឯងទៀត[យ] ហើយ
នឹងសំអាត[រ]មន្ទិលសៅហ្មង[ល]របស់ឯងចេញឱ្យស្អាត ព្រម
ទាំងចេញកំចាត់គ្រឿងលាយក្នុងចិត្តឯងផង[វ] ២៦រួចអញ
នឹងតាំងពួកចៅក្រមរបស់ឯងឡើងដូចដើមវិញ[ស] ហើយពួក
ក្រុមប្រឹក្សារបស់ឯង ដូចកាលដាន់មុនដែរ ពីនោះតទៅគេ
នឹងហៅឯងជា[ហ] "ទីក្រុងមានសេចក្ដីសុចរិត[ឡ] គឺជាទី
ដែលស្មោះត្រង់"វិញ[អ] ២៧ក្រុងស៊ីយ៉ូននឹងបានលោះចេញ
ដោយសារសេចក្ដីយុត្តិធម៌ ហើយពួកអ្នកក្រុងដែលវិល
មកវិញ[ក] នោះនឹងរួចដោយសារសេចក្ដីសុចរិត[ខ] ២៨តែឯ
ពួកអ្នករំលង និងពួកមានបាប[គ] គេនឹងត្រូវបំផ្លាញជាមួយគ្នា
ហើយពួកអ្នកដែលបោះបង់ចោល[ឃ]ព្រះយេហូវ៉ា គេនឹង
ត្រូវវិនាសទៅ[ង] ២៩ដ្បិតគេនឹងមានសេចក្ដីខ្មាស[ច] ចំពោះ
ដើមម៉ៃសាក់[ឆ]ដែលឯងរាល់គ្នាធ្លាប់យកជាទីរីករាយចិត្ត[ជ]
ហើយឯងរាល់គ្នានឹងឡើងមុខក្រហម ដោយព្រោះសួន
ច្បារដែលឯងរាល់គ្នាបានរើសយកនោះ ៣០ពីព្រោះឯង
រាល់គ្នានឹងបានដូចជាដើមម៉ៃសាក់ ដែលស្លឹកស្វិតក្រៀម
ទៅ[ឈ] ហើយដូចជាសួនច្បារឥតមានទឹក ៣១នោះពួកមនុស្ស
មានកំឡាំង និងដូចជាអាចម៍បន្ទោះ ការគេធ្វើនឹងដូចជាផ្កា
ភ្លើងហើយទាំង២យ៉ាងនឹងឆេះជាមួយគ្នា ឥតដែលមានអ្នក
ណាពន្លត់សោះឡើយ[ញ]។

**១:១៨** ជ ទដ ៥១:៧ វវ ៧:១៤ ឈ អស ៥៥:៧ **១:១៩** ញ យប ៣៦:១១ អស ៥០:១០ ដ ចទ ៣០:១៥–១៦ អរ ៩:១២ ទដ ៣៤:១០ អស ៣០:២៣ ៥៥:២ ៥៨:១៤ ៦២:៩ ៦៥:១៣,២១–២២ **១:២០** ឋ ១សយ ១២:១៥ ឌ យប ១៥:២២ អស ៣:២៥ ២៧:១ ៦៥:១២ ៦៦:១៦ យរ ១៧:២៧ ឍ ជន ២៣:១៩ អស ២១:១៧ ៣៤:១៦ ៤០:៥ ៥៨:១៤ យរ ៤៩:១៣ មីក ៤:៤ សក ១:៦ វវ ១:១៦ **១:២១** ណ អស ៥៧:៣–៩ យរ ២:២០ ៣:២,៩ ១៣:២៧ អគ ២៣:៣ ហស ២:១–១៣ ត អស ៥:៧ ៤៦:១៣ ៥៩:១៤ អម ៦:១២ ថ សភ ៦:១៧ **១:២២** ទ ទដ ១១៩:១១៩ **១:២៣** ធ ខ.២ ន ចទ ១៩:១៤ មីក ២:១–២ ៦:១២ ប នក ២៣:៨ អម ៥:១២ ផ អស ១០:២ យរ ៥:២៨ អគ ២២:៦–៧ មីក ៣:៩ ហព ១:៤ **១:២៤** ព លប ៤៩:២៤ ភ អស ៣៤:២,៨ ៣៥:៤ ៤៧:៣ ៥៩:១៧ ៦១:២ ៦៣:៤ យរ ៥១:៦ អគ ៥:១៣ ម ចទ ៣២:៤៣ អស ១០:៣ **១:២៥** យ ចទ ២៨:៦៣ រ ទដ ៧៨:៣៨ ល ទដ ១១៩:១១៩ វ ២របា ២៩:១៥ អស ៤៨:១០ យរ ៦:២៩ ៩:៧ អគ ២២:២២ មឡ ៣:៣ **១:២៦** ស យរ ៣៣:៧,១១ មីក ៤:៨ ហ លប ៣២:២៨ ឡ អស ៣២:១៦ ៣៣:៥ ៤៦:១៣ ៤៨:១៨ ៦១:១១ ៦២:១ យរ ៣១:២៣ សក ៨:៣ អ អស ៤:៣ ៤៨:២ ៥២:១ ៦០:១៤ ៦២:២ ៦៤:១០ ដយ ៩:២៤ **១:២៧** ក អស ៣០:១៥ ៣១:៦ ៥៩:២០ អគ ១៨:៣០ ខ អស ៣៥:១០ ៤១:១៤ ៤៣:១ ៥២:៣ ៦២:១២ ៦៣:៤ ហស ២:១៩ **១:២៨** គ អស ៣៣:១៤ ៤៣:២៧ ៤៨:៨ ៥០:១ ៥៩:២ យរ ៤:១៨ ឃ ចទ ៣២:១៥ ង ទដ ៩:៥ អស ២៤:២០ ៦៦:២៤ យរ ១៦:៤ ៤២:២២ ៤៤:១២ ២ថន ១:៨–៩ **១:២៩** ច ទដ ៩៧:៧ អស ៤២:១៧ ៤៤:៩,១១ ៤៥:១៦ យរ ១០:១៤ ឆ អស ៥៧:៥ អគ ៦:១៣ ហស ៤:១៣ ជ អស ៦៥:៣ ៦៦:១៧ **១:៣០** ឈ ទដ ១:៣ **១:៣១** ញ អស ៤:៤ ៥:២៤ ៩:១៨–១៩ ១០:១៧ ២៤:៦ ២៦:១១ ៣០:២៧,៣៣ ៣៣:១៤ ៣៤:១០ ៦៦:១៥–១៦,២៤ យរ ៥:១៤ ៧:២០ ២១:១២ អប ១:១៨ មឡ ៣:២ ៤:១ មថ ២៤:៤១

**១:១៩–២០** *បានបរិភោគ . . . លេបបាត់* គឺមានភាពខុសទាំងស្រុងដូចជាព្រះគម្ពីរភាសាហេព្រើរប្រើជាពាក្យកិរិយាស័ព្ទដែលមានន័យដូចគ្នា ។

**១:២១** *បានក្បត់ជាសំផឹង* ក្រុងយេរូសាឡិម(ជាតំណាងពួកយូដាទាំងអស់) ដែលពួកគេពុំបានស្មោះត្រង់នឹងព្រះយេហូវ៉ា ហើយការមិនស្តាប់បង្គាប់របស់នាងដូចការរំលោភដល់សង្គម រកផលប្រយោជន៍ពីគេ ឬប្រព្រឹត្តបំពាននិងអ្នកជិតខាង និងក្រមសីលធម៌របស់ព្រះយេហូវ៉ា (មើលការពន្យល់ ទដ ៧៣:២៧ ប្រៀបធៀបនឹង នក ៣៤:១៥) ។

**១:២២** *ប្រាក់របស់ឯងបានត្រឡប់ទៅជាអាចម៍ប្រាក់ទៅហើយ* មើល ទដ ១២:៦ និងការពន្យល់ ។

**១:២៤** *ព្រះអម្ចាស់គឺព្រះយេហូវ៉ានៃពួកពលបរិវារជាព្រះដ៏មានព្រះចេស្តានៃសាសន៍អ៊ីស្រាអែល* គឺជាការបញ្ជាក់អំណាចព្រះមហាក្សត្ររបស់ព្រះនៃពួកសាសន៍យូដា(ប្រៀបធៀប ទដ ៥០:១,៦ ប្រៀបធៀប យស ២២:២២ នឹងការពន្យល់) ។ *ព្រះដ៏មានព្រះចេស្តា* មើលការពន្យល់នៅ ១សយ ១:៣ ។

**១:២៥–២៦** *លូកដៃ . . . នឹងតាំង* គឺជាការប្រើពាក្យកិរិយាស័ព្ទភាសាហេព្រើរដែលបង្ហាញពីភាពខុស (មើលការពន្យល់ ខ.១៩–២០) ។

**១:២៥** *ហើយនឹងសំអាតមន្ទិលសៅហ្មងរបស់ឯងចេញឱ្យស្អាត* គឺជាភ្លើងបន្សុសដោយភ្លើង ក៏បានបង្ហាញក្នុង ៤:៤ ៨៤:១០ ។

**១:២៦** *ទីក្រុងមានសេចក្ដីសុចរិត* មើល ខ.២១ គឺជាការប្រើពាក្យទំនាក់ទំនងទៅនឹងព្រះគម្ពីរភាសាហេព្រើរជានាមស័ព្ទ សក ៨:៣ គឺសំដៅទៅលើទីក្រុងយេរូសាឡិមនាថ្ងៃអនាគត គឺជាទីក្រុង "ដែលមានសេចក្ដីពិត" ។

**១:២៧–២៨** ឃ្លានេះមានលក្ខណៈផ្ទុយគ្នារវាងការលោះបាបចំពោះរាស្ត្រក្រុងស៊ីយ៉ូន (គឺក្រុងយេរូសាឡិម) គឺមានលក្ខណៈទាំងស្រុងនិងភាពហិនវិនាសដល់ពួកគេម្នាក់ៗដែលបដិសេធមិនព្រមលន់តួបាបដើម្បីចម្រើនខ្លួន មើលក្នុង ៦៥:៨–១៦ ។

**១:២៩** *ដើមម៉ៃសាក់ . . . សួនច្បារ* ការបូជាយញ្ញរបស់សាសន៍ដទៃ គឺថ្វាយដល់ព្រះ ការរួមរក្សអសីលធម៌ ដែលតែងតែប្រព្រឹត្តនៅទីកន្លែងនោះ (មើល ៦៥:៣ ៦៦:១៧) ។

**១:៣១** *ឆេះ* គឺជាការបង្ហាញពីការដាក់ទណ្ឌកម្ម (សូមមើល ៣៣:១១–១៤

## ភ្នំនៃព្រះអម្ចាស់

*២:១–៤ – មីក ៤:១–៣*

**២** ១ នេះជាសេចក្តីដែលអេសាយ ជាកូនអ័ម៉ូស បានឃើញ
ពីដំណើរស្រុកយូដា និងក្រុងយេរូសាឡិម[ក] ។
២ នៅជាន់ក្រោយបង្អស់[ខ] នោះភ្នំ[គ] ជាទីស្អាងព្រះវិហារ
នៃព្រះយេហូវ៉ា នឹងបានតាំងឡើងខ្ពស់លើសអស់ទាំងភ្នំ
ធំៗ[ឃ] ហើយនឹងបានដំកើងឡើង[ង]ជាប្រសើរជាងអស់ទាំងភ្នំ
តូចៗដែរ អស់ទាំងសាសន៍នឹងចូលហូរហែទៅក្នុងទីនោះ[ច]
៣ ឯប្រជាជាតិជាច្រើន[ឆ] គេនឹងទៅដោយពោលថា ចូរយើង
ឡើង[ជ]ទៅឯភ្នំ[ឈ]នៃព្រះយេហូវ៉ា ដល់ព្រះវិហារនៃព្រះ
របស់ពួកយ៉ាកុបចុះ ទ្រង់នឹងបង្រៀនយើងពីផ្លូវរបស់ទ្រង់
នោះយើងនឹងដើរតាមផ្លូវទាំងនោះ ដ្បិតក្រិត្យវិន័យ[ញ]នឹង
ចេញពីក្រុងស៊ីយ៉ូនទៅ ហើយព្រះបន្ទូលនៃព្រះយេហូវ៉ា
ពីក្រុងយេរូសាឡិមដែរ[ដ] ៤ ទ្រង់នឹងវិនិច្ឆ័យ[ឋ]រវាងអស់ទាំង
នគរ ហើយនឹងសំរេចរឿង[ឌ]ដល់សាសន៍ជាច្រើន នោះគេ
នឹងយកដាវរបស់ខ្លួនដំធ្វើជាផាលនង្គ័ល ហើយលំពែងគេ
ធ្វើជាដង្កាវវិញ[ឍ] នគរ១នឹងមិនលើកដាវទាស់នឹងនគរ១
ទៀតឡើយ[ណ] ក៏មិនហាត់រៀនធ្វើសឹកសង្គ្រាមទៀតដែរ
៥ ឱពួកវង្សនៃយ៉ាកុបអើយ[ត] ចូរមក យើងដើរក្នុងពន្លឺ[ថ]នៃ
ព្រះយេហូវ៉ាចុះ ។

## ថ្ងៃនៃព្រះអម្ចាស់

៦ ហេតុនេះ បានជាទ្រង់បោះបង់ចោល[ទ]ពួកវង្សយ៉ាកុប[ធ]
ជារាស្ត្រទ្រង់ចេញ គឺពីព្រោះមានទំនៀមទំលាប់ពីស្រុក
ខាងកើតបានចូលមកពេញហើយ គេធ្វើជាគ្រូអាបធ្មប់[ន]
ដូចជាសាសន៍ភីលីស្ទីន[ប] ក៏ចងសម្ពន្ធមិត្រ[ផ]នឹងពួកសាសន៍
ដទៃ[ព] ៧ ស្រុកបានបរិបូរដោយមាសនិងប្រាក់[ភ] ឯទ្រព្យ
សម្បត្តិ[ម] នោះរាប់មិនអស់ឡើយ ក៏មានសេះពេញស្រុក[យ]
ហើយរទេះចំបាំងក៏រាប់មិនអស់ដែរ[រ] ៨ ស្រុកបានពេញ
ដោយរូបព្រះ[ល] គេថ្វាយបង្គំ[វ]ចំពោះស្នាដៃរបស់ខ្លួន[ស] គឺជា
របស់ដែលម្រាមដៃ[ហ]គេបានធ្វើ ៩ មនុស្សធម្មតាបានឱនចុះ[ឡ]
ឯពួកអ្នកធំបានបន្ទាបខ្លួន[អ]ហើយ ដូច្នេះ សូមកុំឱ្យអត់ទោស
ដល់គេឡើយ[ក] ។
១០ ចូរឱ្យចូលទៅក្នុងរូងថ្ម ហើយពួនខ្លួន[ខ]នៅក្នុងធូលី
ដីចុះ ដើម្បីឱ្យបានរួចពីសេចក្តីស្ញែងខ្លាចនៃព្រះយេហូវ៉ា

**២:១** ក អស ១:១ **២:២** ខ កច ២:១៧ ហព ១:២ គ អស ១១:៩ ២៤:២៣ ២៥:៦,១០ ២៧:១៣ ៥៦:៧ ៥៧:១៣ ៦៥:២៥ ៦៦:២០ យរ ៣១:២៣ ដយ ១១:៤៥ យអ ៣:១៧ មីក ៤:៧ ឃ អស ៦៥:៩ ង សក ១៤:១០ ច ទដ ១០២:១៥ យរ ១៦:១៩ **២:៣** ឆ អស ៤៥:២៣ ៤៩:១ ៦០:៣–៦,១៤ ៦៦:១៨ យរ ៣:១៧ យអ ៣:២ សផ ៣:៨ សក ១៤:២ ជ អស ៤៥:១៤ ៤៩:១២, ២៣ ៥៥:៥ ឈ ចទ ៣៣:១៩ ទដ ១៣៧:៥ ញ អស ១:១០ ៣៣:២២ ៥១:៤,៧ ដ លក ២៤:៤៧ យហ ៤:២២ **២:៤** ឋ ទដ ៧:៦

៩:១៩ ៩៦:១៣ ៩៨:៩ អស ១:២៧ ៣:១៣ ៩:៧ ៤២:៤ ៥១:៤ យអ ៣:១៤ ឌ លប ៤៩:១០ ឍ យអ ៣:១០ ណ ទដ ៤៦:៩ អស ៩:៥ ១១:៦–៩ ៣២:១៨ ៥៧:១៩ ៦៥:២៥ យរ ៣០:១០ ដយ ១១:៤៥ ហស ២:១៨ មីក ៤:៣ សក ៩:១០ **២:៥** ត អស ៥៨:១ ថ អស ៦០:១,១៩–២០ ១យហ ១:៥,៧ **២:៦** ទ ចទ ៣១:១៧ ធ យរ ១២:៧ ន ចទ ១៨:១០ អស ៤៤:២៥ ប ២ពវ ១:២ ២របា ២៦:៦ ផ សភ ៦:១ ព ២ពវ ១៦:៧ មីក ៥:១២ **២:៧** ភ ចទ ១៧:១៧ ម ទដ ១៧:១៤ យ ចទ ១៧:១៦ រ លប ៤១:៤៣ អស ៣១:១ មីក ៥:១០ **២:៨** ល អស ១០:៩–១១ វវ ៩:២០ វ អស ៤៤:១៧ ស ២របា ៣២:១៩ ទដ ១៣៥:១៥ មីក ៥:១៣ ហ អស ១៧:៨ **២:៩** ឡ ទដ ៦២:៩ អ ខ.១១,១៧ អស ៥:១៥ ១៣:១១ ក នហ ៤:៥ **២:១០** ខ ខ.១៩ ណហ ៣:១១

៣៤:៩–១០ ក៏សូមមើលការពន្យល់ បទ ១:១៣) ។

**២:១** សេចក្តីផ្តើមជាផ្នែកទី១ គឺអាចមានទំនាក់ទំនងទៅនិងជំពូកទី ២–៤ ឬក៏ទៅនិងជំពូក ២–១២ (មើល ១៣:១) ។

**២:២–៥** មើលការពន្យល់ ៤:២–៦ ។

**២:២–៤** ដែលបញ្ជាក់ពីគម្ពីរ មីក ៤:១–៣ គឺជាផ្ទៃរឿងបង្ហាញពីភ្នំរបស់ព្រះយេហូវ៉ា (ជាភ្នំនៅស្រុកអ៊ីស្រាអែល) គឺជារឿងធម្មតានៅស្រុកអ៊ីស្រាអែលក៏ចេញឱ្យឃើញ ក្នុងអត្ថបទបង្ហាញពីការដែលពួកយូដានិងពួកសាសន៍ដទៃមកទីក្រុងយេរូសាឡិម (គឺជាទីក្រុងស៊ីយូន) គឺក្នុងថ្ងៃចុងក្រោយ (មើល ១១:៩ ២៧:១៣ ៥៦:៧ ៥៧:១៣ ៦៥:២៥ ៦៦:២០ មើល ៦០:៣–៥ សក ១៤:១៦ និងការពន្យល់) អ្នកខ្លះជឿជាក់ថាសន្តិភាពដែលពណ៌នាក្នុងអត្ថបទនោះក៏ចាប់ផ្តើមតាមរយៈការដែលព្រះយាងមក និងការអធិប្បាយពីដំណឹងល្អពីព្រះគ្រីស្ទត្រឡប់មក ។ ក៏បង្ហាញពីទំនាយ ពីលក្ខខ័ណ្ឌក្នុងការគ្រងរាជ្យនៃព្រះគ្រីស្ទនៅលើផែនដី ។

**២:២** *នៅជាន់ក្រោយបង្អស់* គឺសំដៅទៅលើជំនាន់ក្រោយៗទៀត (មើល លប ៤៩:១)គឺជារឿយៗបានបង្ហាញពីទស្សនៈពីសករាជព្រះមែស៊ី ។ អត្ថន័យ ដ៏ពិតប្រាកដនៃថ្ងៃចុងក្រោយ គឺចាប់ផ្តើមពីថ្ងៃយាងលើកដំបូងរបស់ព្រះគ្រីស្ទ (មើល កច ២:១៧ ហព ១:១–២ នឹងការពន្យល់) ហើយនិងបំពេញសម្រេច នៅពេលដែលទ្រង់យាងមកជាលើកទី២ ។

**២:៤** *យកដាវរបស់ខ្លួនដំធ្វើជាផាលនង្គ័ល* គឺជាដំណើរការផ្ទុយនិងអ្វីដែលមានជាមួយ យ៉ូអែល ៣:១០ អ្វីដែលមាននៅទីនោះហៅថាជាផាលនង្គ័លដែលមានចុងដែក ដែលមានស្នៀតធ្វើពីឈើ ។ នង្គ័លសម័យដើមគឺពុំមានផាលច្បាស់លាស់ទេ ។

**២:៥** *ស្រុកខាងកើត* គឺប្រហែលជាស្រុកអើរ៉ាម (ស្រុកស៊ីរី) ស្រុកមេសូប៉ូតាមា ។ *គេធ្វើគ្រូធ្មប់ដូចជាសាសន៍ភីលីស្ទីន* មើល ១សយ ៦:២ និងការពន្យល់, និងមើល ចទ ១៨:១០–១១ ដើម្បីពន្យល់ពីការប្រព្រឹត្តរបស់ពួកគេ មើល ចទ ១៨:៩ ។

**២:៧** *ដោយមាសនឹងប្រាក់ ឯទ្រព្យសម្បត្តិ . . . ក៏មានសេះពេញស្រុក* គឺជាជាការប្រមូលផ្តុំនូវទ្រព្យជាច្រើន គឺត្រូវបានហាមឃាត់ចំពោះស្តេច (មើល ចទ ១៧:១៦–១៧ នឹងការពន្យល់) គឺគេដឹកនាំក្នុងផ្លូវខុស ដែលគេចេញពីផ្លូវព្រះហើយពុំជឿដល់ព្រះនៃសាសន៍អ៊ីស្រាអែល (មើល ៣១:១) ។

**២:១០,១៩,២១** ខទាំងនេះគឺមានដោយបទទន្ទេញដែលប្រាប់ពីភាពឧត្តមរបស់ព្រះ ខ.២១ ហើយ ខនិមួយៗក៏បង្ហាញផងដែរ ។

**២:១០** *រូងថ្ម . . . ធូលីដីចុះ* គឺជាអំឡុងពេលនៃការសង្កត់សង្កិនយ៉ាងខ្លាំងដែលធ្វើឱ្យរាស្ត្រអ៊ីស្រាអែលត្រូវបង្ខំចិត្តដើម្បីលាក់ខ្លួនក្នុងរូងភ្នំនិងប្រហោងក្នុងដី (មើល ចទ ៦:១–២ ១សយ ១៣:៦) ។ *ប្ញទ្ធានុភាព* ជាព្រះគម្ពីរភាសាហេព្រើរ គឺបានបកប្រែមកជា "ភាពមានមោទនៈភាព"ដែលប្រជា

ហើយពីសិរីល្អនៃឫទ្ធានុភាពរបស់ទ្រង់[គ] ១១ឫកខ្ពស់[ឃ]របស់
មនុស្សនឹងត្រូវបន្ទាបចុះ[ង] ហើយចិត្តឆ្មើងឆ្មៃ[ច]របស់មនុស្ស
នឹងត្រូវបង្អោនទាបវិញ[ឆ] នៅគ្រានោះមានតែព្រះយេហូវ៉ា
១អង្គប៉ុណ្ណោះទេ ដែលនឹងបានដំកើង[ជ]ឡើង[ឈ] ១២ដ្បិតនឹង
មានថ្ងៃ[ញ]១ របស់ព្រះយេហូវ៉ានៃពួកពលបរិវារមកលើ
គ្រប់ទាំងឫកខ្ពស់[ដ] និងចិត្តឆ្មើងឆ្មៃ[ឋ] ព្រមទាំងលើគ្រប់ទាំង
អស់ដែលបានលើកឡើងផង[ឌ] ហើយនោះនឹងត្រូវបន្ទាបចុះ
វិញ[ឍ] ១៣គឺមកលើអស់ទាំងដើមតាត្រៅនៅភ្នំល្បាណូន[ណ]
ដែលខ្ពស់ ហើយដំកើងឡើង[ត] និងលើគ្រប់ទាំងដើម
ម៉ែសាក់ នៅស្រុកបាសានដែរ[ថ] ១៤មកលើអស់ទាំងភ្នំខ្ពស់
និងភ្នំតូចៗ ដែលបានដំកើងឡើង[ទ] ១៥មកលើអស់ទាំងប៉ម
យ៉ាងខ្ពស់[ធ]នឹងកំផែងមានគ្រឿងចំបាំង[ន] ១៦នឹងលើអស់ទាំង
នាវា[ប]ស្រុកតើស៊ីស ហើយលើអ្វីៗទាំងអស់ដែលគាប់ដល់
ភ្នែកដែរ ១៧នោះសណ្ឋានខ្ពស់របស់មនុស្សនឹងត្រូវបង្អោន
ទាប[ផ] ឯសេចក្តីឆ្មើងឆ្មៃរបស់មនុស្ស ក៏នឹងត្រូវបន្ទាបចុះ[ព]
នៅគ្រានោះ នឹងមានតែព្រះយេហូវ៉ា១អង្គប៉ុណ្ណោះទេ
ដែលនឹងបានដំកើងឡើង[ភ] ១៨អស់ទាំងរូបព្រះ[ម]នឹងសាប
សូន្យឱ្យបាត់ទៅអស់រលីង[យ] ១៩ឯមនុស្ស គេនឹងចូលទៅក្នុង
រអាងថ្ម[រ]ហើយក្នុងរូងដី[ល] ដើម្បីឱ្យបានរួចពីសេចក្តីស្ញែង
ខ្លាច[វ]នៃព្រះយេហូវ៉ា និងពិសិរីល្អនៃឫទ្ធានុភាពរបស់ទ្រង់[ស]
គឺក្នុងកាលដែលទ្រង់ក្រោកឡើង ដើម្បីនឹងអង្រួនផែនដី
ដោយឫទ្ធិយ៉ាងអស្ចារ្យ[ហ] ២០នៅគ្រានោះ[ឡ] មនុស្សនឹងបោះ
ចោលរូបព្រះរបស់ខ្លួន ដែលធ្វើពីមាស[អ] ហើយពីប្រាក់
ជារបស់ដែលគេបានធ្វើ សំរាប់នឹងថ្វាយបង្គំ[ក] ទៅឱ្យកណ្តុរ
ហើយនឹងប្រចៀវ[ខ] ២១ដើម្បីនឹងចូលទៅក្នុងរអាងថ្ម[គ] ហើយ
ក្នុងក្រហែងថ្មរខិញរខុញ ឱ្យបានរួចពីសេចក្តីស្ញែងខ្លាចនៃ
ព្រះយេហូវ៉ា នឹងសិរីល្អនៃឫទ្ធានុភាពរបស់ទ្រង់[ឃ] ក្នុងកាល
ដែលទ្រង់ក្រោកឡើង[ង]នឹងអង្រួនផែនដី ដោយឫទ្ធិយ៉ាង
អស្ចារ្យ[ច] ២២ចូរលែងទុកចិត្តដល់មនុស្ស[ឆ]ដែលមានតែ
ដង្ហើម[ជ]ចេញចូលតាមរន្ធច្រមុះទៅ ដ្បិតតើនឹងពឹងដល់គេ
ឯណាបាន[ឈ] ។

## ការជំនុំជម្រះដល់ក្រុងយេរូសាឡិម និងស្រុកយូដា

៣ ១ដ្បិតមើល ព្រះអម្ចាស់ គឺព្រះយេហូវ៉ានៃពួកពល
បរិវារ ទ្រង់ដកយកទីពឹង ហើយនិងបង្អែកចេញពីក្រុង
យេរូសាឡិម និងស្រុកយូដា ព្រមទាំងពីពឹង[ក]ជាស្បៀង
អាហារ[ខ] និងទឹកផឹកអស់រលីងទៅ[គ] ២អើ ទាំងមនុស្សខ្លាំង
ពូកែ និងមនុស្សថ្មើរចំបាំង[ឃ] ទាំងចៅក្រម និងហោរា
ទាំងគ្រូទាយ[ង] និងអ្នកចាស់ទុំ[ច] ៣ទាំងមេត្រួតលើ៥០នាក់[ឆ]

**២:១០** គ ទដ ១៤៥:១២ ២ថន ១:៩ វវ ៦:១៥–១៦ **២:១១** ឃ នហ ៩:២៩ ហព ២:៥ ង ខ.៩ ច អស ៥:១៥ ១០:១២ ៣៧:២៣ អគ ៣១:១០ ឆ យប ៤០:១១ ជ ទដ ៤៦:១០ ឈ ខ.១៧,២០ អស ៣:៧,១៨ ៤:១,២ ៥:៣០ ៧:១៨ ១៧:៤,៧ ២៤:២១ ២៥:៩ ២៦:១ ២៧:១ **២:១២** ញ អស ១៣:៦,៩ ២២:៥,៨,១២ ៣៤:៨ ៦១:២ យរ ៣០:៧ បទ ១:១២ អគ ៧:៧ ៣០:៣ យអ ១:១៥ ២:១១ អម ៥:១៨ សផ ១:១៤ ដ ទដ ៥៩:១២ ឋ ២សយ ២២:២៨ ឌ ទដ ៧៦:១២ អស ២៤:៤,២១ ៦០:១១ មឡ ៤:១ ឍ យប ៤០:១១ **២:១៣** ណ ពច ៩:១៥ អស ១០:៣៤

២៩:១៧ អគ ២៧:៥ ត អស ១០:៣៣ ថ ទដ ២២:១២ សក ១១:២ **២:១៤** ទ អស ៣០:២៥ ៤០:៤ **២:១៥** ធ អស ៣០:២៥ ៣២:១៤ ៣៣:១៨ ន អស ២៥:២,១២ សផ ១:១៦ **២:១៦** ប លប ១០:៤ ១ពវ ៩:២៦ **២:១៧** ផ ២សយ ២២:២៨ យប ៤០:១១ ព ខ.៩ ភ ខ.១១ **២:១៨** ម ១សយ ៥:២ អគ ៣៦:២៥ យ ចទ ៩:២១ អស ២១:៩ យរ ១០:១១ មីក ៥:១៣ **២:១៩** រ ពច ៦:២ អស ៧:១៩ ល ពច ៦:២ យប ៣០:៦ លក ២៣:៣០ វវ ៦:១៥ វ ចទ ២:២៥ ស ទដ ១៤៥:១២ ហ ខ.២១ យប ៩:៦ អស ១៤:១៦ ហព ១២:២៦ **២:២០** ឡ ខ.១១ អ យប ២២:២៤ អគ ៣៦:២៥ វវ ៩:២០ ក អគ ៧:១៩–២០ ១៤:៦ ខ លវ ១១:១៩ **២:២១** គ នក ៣៣:២២ ឃ ទដ ១៤៥:១២ ង អស ៣៣:១០ ច ខ.១៩ **២:២២** ឆ ទដ ១១៨:៦,៨ ១៤៦:៣ អស ៥១:១២ យរ ១៧:៥ ជ លប ២:៧ ទដ ១៤៤:៤ ឈ យប ១២:១៩ ទដ ៨:៤ ១៨:៤២ ១៤៤:៣ អស ១៧:១៣ ២៩:៥ ៤០:១៥ យក ៤:១៤ **៣:១** ក ទដ ១៨:១៨ ខ លវ ២៦:២៦ អម ៤:៦ គ អស ៥:១៣ ៦៥:១៣ អគ ៤:១៦ **៣:២** ឃ អគ ១៧:១៣ ង ចទ ១៨:១០ ច អស ៩:១៤–១៥ **៣:៣** ឆ ២ពវ ១:៩

រាស្ត្របានគិតថាជាព្រះរបស់ពួកគេតែឯង (មើល ១៤:១៣–១៤) ។

**២:១១,១៧,២០** *នៅគ្រានោះ* គឺសំដៅលើគ្រានៃព្រះយេហូវ៉ា យើងឃើញមានពាក្យនេះ ៧ដងក្នុងជំពូក ២–៣ (មើល ៣:៧,១៨ ៤:១–២) និងជំពូក ២៤–២៧ (មើលការពន្យល់ ២៤:២១) ។ ថ្ងៃនៃព្រះយេហូវ៉ា (សូមមើល ខ.១២) គឺជាពេលឬគ្រាដែលទ្រង់ជំនុំជម្រះ និងប្រទានពរក្នុងនាមជាព្រះដែលមានព្រះទ័យក្តួលអាណិត ក្នុងកិច្ចការជាតិរបស់ផងទ្រង់ (មើល យអ ១:១៥ អម ៥:១៨ សផ ១:១៤–២:៣ និងការពន្យល់) ។ ពួកស្រុកអាសស៊ើរនិងពួកស្រុកបាប៊ីឡូន និងនាំមកនូវការកាត់ទោសដល់ពួកយូដាក្នុងគ្រាលោកអេសាយ (៥:៣០) ។

**២:១៣** *ដើមតាត្រៅនៅភ្នំល្បាណូន* គឺការងារត្រូវបន្ទាបខ្លួនដើម្បីគោរពដល់ "ព្រះយេហូវ៉ាតែមួយអង្គគត់ដែលត្រូវលើកតម្កើង" (ខ.១១) ។ *ស្រុកបាសាន* គឺជាតំបន់នៅផ្នែកខាងកើតទន្លេយ័រដាន់និងផ្នែកខាងជើងដើមឈើម៉ែសាក់ (អគ ២៧:៦) និងសត្វស្រុកសត្វព្រៃជាច្រើន (អគ ៣៩:១៨) ។

**២:១៦** *នាវា* គឺជានាវាជំនួញពីស្រុកតើស៊ីសដែលមានទំហំធំ ដូចនាវាដែលស្តេចសាឡូម៉ូនប្រើ (១ពវ ១០:២២) និងអ្នកស្រុកភេនីស (១សយ ២៣:១, ១៤) ទៅកាន់សមុទ្រដើម្បីជំនួញពាណិជ្ជកម្ម ។ ទីតាំងនៃស្រុកតើស៊ីស គឺសូមមើលការពន្យល់ ២៣:៦ អគ ២៧:១២ ។

**២:២០** ភាពអាសារឥតការទទេរនៃការថ្វាយបង្គំរូបព្រះ ដែលជាការសម្គាល់ត្រូវរំឮកដដែលៗតាមរយៈគម្ពីរអេសាយ (មើល ៣០:២២ ៣១:៧ ៤០:១៩–២០ ៤៤:៩–២០) មើលសេចក្តីពន្យល់ ៤០:១៨–២០ ។

**២:២២** *ចូរលែងទុកចិត្តដល់* "គឺត្រូវឈប់ពីការអ្វីមួយ" ឬ "បោះបង់ចោល" ក្នុងខនេះក៏បានគេប្រើកិរិយាស័ព្ទដើម្បីពណ៌នាពីការបដិសេធព្រះមែស៊ី មើលក្នុង ៥៣:៣ ។ គឺជាការចំអកដល់មនុស្សដែល "បដិសេធ" និង "បោះបង់ចោល" គឺជាអង្គដែលយើងត្រូវគោរពដោយពិតត្រង់និង "ត្រូវពិចារណា" ។

**៣:១–៣** អ្នកដឹកនាំក៏ត្រូវបានយកទៅបាត់ ទោះជាត្រូវស្លាប់ ឬត្រូវនិរទេសក៏ដោយ (សូមមើល ២ពវ ២៤:១៤ ២៥:១៨–២១) ។

**៣:២–៣** *ទាំងគ្រូទាយ . . . អ្នកមានវោហារស័ព្ទយ៉ាងចំណានផង* គឺជាអ្នកអនុវត្តផ្លូវងងឹត និងអ្នកឬគ្រូចាប់ពស់ (សូមមើល ចទ ១៨:១០ និងការពន្យល់ ១៨:៩ យរ ៨:១៧) គឺអ្នកប្រព្រឹត្តអំពើទាំងនោះត្រូវកាត់ទោស ។ ទាំងអំពើត្រឹមត្រូវឬមិនត្រឹមត្រូវរបស់ពួកគេនោះនិងត្រូវនិរទេសទាំងអស់ (សូមមើល

និងមនុស្ស ដែលមានសក្តិយស[ជ] ទាំងអ្នកប្រឹក្សា និងជាង
ប៉ិនប្រសប់[ឈ] ហើយនិងអ្នកមានវោហារយ៉ោងចំណានផង[ញ]
៤នោះអញ នឹងតាំងពួកក្មេងៗឱ្យធ្វើជាចៅហ្វាយលើគេ
ហើយនឹងមានកូនតូចៗត្រួតត្រាលើគេវិញ[ដ] ៥បណ្តាជនទាំង
ឡាយ នឹងត្រូវសង្កត់សង្កិន គឺអ្នក១នឹងសង្កត់សង្កិន១ទៀត
ព្រម ទាំងអ្នកជិតខាងខ្លួនផង[ឋ] ពួកក្មេងៗនឹងប្រព្រឹត្តព្រហើន
ចំពោះចាស់ព្រឹទ្ធាចារ្យ ហើយមនុស្សជាន់ទាបនៅចំពោះ
មនុស្សជាន់ខ្ពស់ដែរ ៦កាលណាមនុស្សម្នាក់នឹងយកបង
ប្អូនពីក្នុងគ្រួរបស់ឪពុកខ្លួនមកនិយាយថា អ្នកឯងមាន
សំលៀកបំពាក់ សូមអ្នកធ្វើជាអ្នកគ្រប់គ្រងទៅ សូមឱ្យ
ស្រុកខ្ទេចខ្ទីនេះនៅក្រោមអំណាចអ្នកចុះ ៧នៅគ្រានោះ[ឌ]
គេនឹងប្រកែកថា ខ្ញុំមិនចង់ធ្វើជាអ្នកមើលឱ្យជាទេ[ឍ] ពីព្រោះ
នៅផ្ទះខ្ញុំគ្មានអាហារ[ណ] ឬសំលៀកបំពាក់អ្វីឡើយ អ្នករាល់
គ្នាមិនត្រូវតាំងខ្ញុំឡើង ឱ្យធ្វើជាអ្នកគ្រប់គ្រងលើបណ្តាជន
ទេ[ត] ៨ដ្បិតក្រុងយេរូសាឡិមខ្ទេចខ្ទីហើយ ស្រុកយូដាក៏
បានដួលដែរ[ថ] ដោយព្រោះអណ្តាត[ទ]គេ ហើយនឹងអំពើ
របស់គេ[ធ] ដែលសុទ្ធតែបង្អុចបង្អាល[ន]ដល់ព្រះនេត្រដ៏មាន
សិរីនៃព្រះយេហូវ៉ា ៩ភាពនៃទឹកមុខគេតែងធ្វើបន្ទាល់
ទាស់[ប]នឹងគេ ក៏បើកបង្ហាញអំពើបាបរបស់គេចេញ ដូចជា
ក្រុងសូដុំម[ផ] គេមិនខំបិទបាំងទេ វេទនាដល់ព្រលឹងគេ
ពីព្រោះគេបានប្រព្រឹត្តអំពើអាក្រក់[ព] ដល់ខ្លួនគេហើយ
១០ចូរថ្លែងប្រាប់ថា មនុស្សសុចរិតនឹងបានសេចក្តីសុខ[ភ]វិញ
ដ្បិតគេនឹងទទួលផលនៃការដែលគេប្រព្រឹត្ត[ម] ១១វេទនាដល់
មនុស្សអាក្រក់[យ] គេនឹងត្រូវសេចក្តីទុក្ខព្រួយ[រ] ដ្បិតការដែល
ដៃគេបានធ្វើ នោះនឹងបានសងដល់[ល]គេវិញ[វ] ១២ឯរាស្ត្រ
របស់អញ គឺជាកូនក្មេង[ស] ដែលសង្កត់សង្កិនគេ ហើយគឺជា
ពួកស្រីៗ ដែលមានអំណាចត្រួតត្រាលើគេដែរ ឱរាស្ត្រ
របស់អញអើយ ពួកអ្នកដែលនាំមុខឯង គេនាំឱ្យវង្វេង[ហ]
ក៏បំផ្លាញផ្លូវ ដែលឯងដើរដែរ ។
១៣ព្រះយេហូវ៉ាទ្រង់កំពុងឈរ[ឡ] ដើម្បីតវ៉ា ទ្រង់ឈរ
ដើម្បីជំនុំជំរះ[អ]ជនជាតិទាំងឡាយ ១៤ព្រះយេហូវ៉ាទ្រង់នឹង
កើតមានក្តី[ក]នឹងពួកចាស់ទុំនៃរាស្ត្រទ្រង់ ហើយនឹងពួកចៅ
ហ្វាយថា គឺឯងរាល់គ្នាហើយ ដែលបាស៊ីបង្ហិនចំការ
ទំពាំងបាយជូរ ឯរបឹប[ខ]ដែលរឹបជាន់យកពីពួកអ្នកទាល់ក្រ[គ]
នោះសុទ្ធតែនៅក្នុងផ្ទះឯងទាំងអស់ ១៥ព្រះអម្ចាស់ គឺព្រះ
យេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលសួរថា តើឯង
រាល់គ្នាមានច្បាប់អីនឹងញាំញីរាស្ត្រអញ[ឃ] ហើយបុកបែន[ង]
មុខរបស់មនុស្សទាល់ក្រដូច្នេះ[ច,ឆ] ។
១៦មួយទៀត ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ដោយ
ព្រោះពួកកូនស្រីក្រុងស៊ីយ៉ូន[ជ]មានឫកខ្ពស់ មានដំណើរងើប
ងើយ[ឈ] ផាត់រង្វង់ភ្នែក ដើរយាងយារ ហើយបំភ្លៃជើងឱ្យ
មានសូររ៉ូងរ៉ុង ១៧ហេតុនេះព្រះអម្ចាស់ ទ្រង់នឹងវាយ
ក្រយៅក្បាលនៃពួកកូនស្រីក្រុងស៊ីយ៉ូនឱ្យកើតតាម ហើយ
ព្រះយេហូវ៉ាទ្រង់នឹងសំរាតកេរខ្មាសគេ[ញ] ១៨នៅគ្រានោះ[ដ]
ព្រះអម្ចាស់ទ្រង់នឹងដកសេចក្តីលំអនៃកងជើង សំណាញ់

**៣:៣** ជ យប ២២:៨ ឈ ២ពវ ២៤:១៤ ញ សស ១០:១១ យរ ៨:១៧ **៣:៤** ដ ខ.១២ សស ១០:១៦ **៣:៥** ឋ ទដ ២៨:៣ អស ៩:១៩ យរ ៩:៨ មីក ៧:២,៦ **៣:៧** ឌ អស ២:១១ ឍ យរ ៣០:១២ អគ ៣៤:៤ ហស ៥:១៣ ណ យអ ១:១៦ ត អស ២៤:២ **៣:៨** ថ អស ១:៧ ទ អស ៩:១៥,១៧ ២៨:១៥ ៣០:៩ ៥៩:៣,១៣ ធ ២រប ៣៣:៦ ន យប ១:១១ ទដ ៧៣:៩,១១ អស ៦៥:៧ **៣:៩** ប ជន ៣២:២៣ អស ៥៩:១២ យរ ១៤:៧ ហស ៥:៥ ផ លប ១៣:១៣ ព ២រប ៣៤:២៤ សភ ៨:៣៦ រម ៦:២៣ **៣:១០** ភ ចទ ៥:៣៣ ១២:២៨ ២៨:១–១៤ ទដ ៣៧:១៧ យរ ២២:១៥ ម លប ១៥:១ ទដ ១២៨:២

**៣:១១** យ យប ៩:១៣ អស ៥៧:២០ រ ចទ ២៨:១៥–៦៨ ល ២រប ៦:២៣ វ យរ ២១:១៤ បទ ៥:១៦ អគ ២៤:១៤ **៣:១២** ស ខ.៤ ហ អស ៩:១៦ ១៩:១៤ ២៨:៧ ២៩:៩ យរ ២៣:១៣ ២៥:១៦ មីក ៣:៥ **៣:១៣** ឡ យប ១០:២ អ ទដ ៨២:១ អស ២:៤ **៣:១៤** ក ១សយ ១២:៧ យប ២២:៤ ខ យប ២៤:៩ យក ២:៦ គ អស ១១:៤ ២៤:៤ **៣:១៥** ឃ ទដ ៩៤:៥ ង យប ២៤:១៤ ច អស ១០:៦ ១១:៤ ២៦:៦ ២៩:១៩ ៣២:៦ ៥១:២៣ ឆ អស ៥:៧ **៣:១៦** ជ បស ៣:១១ ឈ យប ១៥:២៥ **៣:១៧** ញ ខ.២៤ អគ ២៧:៣១ អម ៨:១០ **៣:១៨** ដ អស ២:១១

២ពវ ២៤:១៤–១៦ ហស ៣:៤) ។

**៣:៣** *ទាំងមេត្រួតលើ៥០នាក់* គឺជាកងអនុសេនាធំនៃកងទ័ពដែលគេរៀប (សូមមើល ២ពវ ១:៩) ពាក្យនេះអាចប្រើក្នុងក្រុមការងារស៊ីវិលផងដែរ (នក ១៨:២៥) ។

**៣:៦** តាមធម្មតាការមិនចាំបាច់ណាស់ណានោះទេ ក្នុងការជំរុញឱ្យអ្នកណាម្នាក់ធ្វើជាអ្នកដឹកនាំ ។ ក្នុង ៤:១ គឺភាពច្របូលច្របល់ក្នុងសង្គមដូចជាស្ត្រី៧នាក់ព្រមទទួលបុរសម្នាក់ ។ *អ្នកឯងមានសំលៀកបំពាក់* គឺជាទំនាក់ទំនងជាបងម្នាក់ដែលមិនក្រពេកដូចជាអ្នកដទៃទេ ។ *ស្រុកខ្ទេចខ្ទី* គឺប្រហែលជាក្រុងយេរូសាឡិម (ខ.៨) ។

**៣:៧,១៨** *នៅគ្រានោះ* មើលការពន្យល់ ២:១១,១៧,២០ ។

**៣:៨** *ស្រុកយូដាក៏បានដួលដែរ* គឺបានបំពេញសម្រេចស្ទើរតែមានរយៈពេល ១៥០ឆ្នាំក្រោយមក ៥៨៦ ឆ្នាំមុន ស.គ ។

**៣:៩** *ក្រុងសូដុំម* មើលការពន្យល់ ១:៩–១០ ។

**៣:១២** នៅមជ្ឈឹមបូព៌ាទោះជាច្បាប់ចែងពីវ័យក្មេង ឬក៏ចំពោះស្ត្រីៗ គឺវាសមនិងប្រព្រឹត្ត ។

**៣:១៤** *ចំការទំពាំងបាយជូរ* ជាការតំណាងឱ្យស្រុកអ៊ីស្រាអែល (មើលការពន្យល់ ៥:១) ។

**៣:១៥** មេដឹកនាំកំពុងញាំញីដល់អ្នកក្រដូចជាស្ត្រីកិនគ្រាប់ស្រូវ និងត្បាល់កិន (មើលការពន្យល់ ៩:៥៣) ។

**៣:១៦–២៤** គឺសម្រាប់ជាការព្រមានប្រឆាំងនិងទស្សនៈ ឬអ្វីជាទម្លាប់របស់មនុស្ស មើល ២:៩–១០ ១ពត ៣:៣–៥ និងការពន្យល់ ។

**៣:១៦** *មានដំណើរងើប . . . ដើរយាងយារ* គឺជាដំណើរដែលបោះជំហានបានខ្លី ។

**៣:១៧** *ក្រយៅក្បាល* គឺទាក់ទងទៅនិងការកាន់ទុក្ខ (មើល ខ.២៤ ១៥:២ និងការពន្យល់) ។

**៣:១៨** *កងក* វាមានលក្ខណៈដូចវង់ព្រះចន្ទ្រាគេពាក់គឺដើម្បីជាការគោរព

សក់ កងក[ឋ] ១៩ទំហូ កងដៃ[ឌ] ស្បៃ[ឍ] ២០ក្បាំងសក់[ណ] ខ្សែ
ចង្កេះ ខ្សែក្រវាត់ ក្លងហិត គាថា ២១ចិញ្ចៀនត្បូងតែង
ច្រមុះ[ត] ២២សំលៀកបំពាក់សំរាប់បុណ្យ កន្សែងទទូរ
ផាហ៊ុម[ថ] កាបូបយួរ ២៣កញ្ចក់ អាវសារូ[ទ] មួក[ធ] និងក្រមា
របស់គេចេញ ២៤នោះនឹងមានក្លិនស្អុយជំនួសក្រអូប[ន,ប] ខ្សែ
ចងជំនួសខ្សែក្រវាត់[ផ] ក្បាលទំពែក ជំនួសសក់សំអាង[ព]
សំពត់ធ្មៃ ជំនួសសំពត់ល្បើក[ភ] ស្នាមត្រា[ម] ជំនួសលំអខ្លួន[យ]
២៥ពួកប្រុសៗ របស់ឯងនឹងដួលដោយមុខដាវ[រ] ហើយ
មនុស្សខ្លាំងពូកែរបស់ឯងនឹងស្លាប់ក្នុងចំបាំង[ល] ២៦នោះអស់
ទាំងទ្វារក្រុង[វ]នឹងមានការខ្សឹកខ្សួល[ស] ហើយសោយសោក[ហ]
ឯនាង និងត្រូវចោលនៅតែឯង ហើយអង្គុយនៅដី[ឡ]។

**៤** ១នៅគ្រានោះ[ក] ស្រី៧នាក់នឹងជាប់នៅ ជាមួយប្រុស[ខ]
ម្នាក់ដោយពោលថា យើងនឹងបរិភោគអាហារ[គ]របស់ខ្លួន
យើង ហើយនិងរកប្រដាប់ស្លៀកពាក់ដោយខ្លួនយើងដែរ
សូមតែ ឱ្យយើងបានឈ្មោះជាប្រពន្ធរបស់អ្នកចុះ ដើម្បីនឹង
ដោះសេចក្ដីដំនៀលពីយើងចេញ[ឃ]។

## ខ្នែងរបស់ព្រះអម្ចាស់

២នៅគ្រានោះ[ង] ខ្នែងរបស់ព្រះយេហូវ៉ា[ច] នឹងបានជាល្អ
ប្រពៃ[ឆ] ហើយរុងរឿង ឯផល[ជ]កើតពីដី នឹងបានជាប្រសើរ
ហើយជាលំអ[ឈ] ដល់សំណល់ពួកសាសន៍អ៊ីស្រាអែល ដែល
បានរួច[ញ] ៣សម័យនោះ អ្នកណាដែលសល់នៅក្នុងក្រុង
សីយ៉ូន[ដ] ជាអ្នកដែលនៅ[ឋ]ក្នុងក្រុងយេរូសាឡិមនៅឡើយ
នោះនឹងបានហៅជាអ្នកបរិសុទ្ធ[ឌ] គឺគ្រប់ទាំងមនុស្សក្នុង
ក្រុងយេរូសាឡិម ដែលមានឈ្មោះកត់ទុក[ឍ]ក្នុងពួកមនុស្ស
រស់ ៤ក្នុងកាលដែលព្រះអម្ចាស់ទ្រង់បានលាងជំរះគ្រឿង
លាមក[ណ]របស់ពួកស្រីៗក្រុងសីយ៉ូនចេញ[ត] ហើយបានចំរាញ់
សំអាត[ថ]ឈាម[ទ]នៃក្រុងយេរូសាឡិម ពីកណ្ដាលទីក្រុងទៅ
ដោយអំណាចនៃសេចក្ដីយុត្តិធម៌[ធ] នឹងអំណាចនៃភ្លើងឆេះ
បន្សុស[ន] ៥ព្រះយេហូវ៉ា ទ្រង់នឹងបង្កើត[ប]ឱ្យមានពពក និង
ផ្សែងនៅវេលាថ្ងៃ ហើយភ្លើងដ៏ឆេះបំភ្លឺនៅវេលាយប់[ផ]
ពីលើទីលំនៅទាំងមូលនៅភ្នំសីយ៉ូន[ព] ហើយពីលើទីប្រជុំ
ទាំងប៉ុន្មានរបស់គេ ដ្បិតគ្រប់ទាំងទីគួរគោរព[ភ] នឹងមាន

**៣:១៨** ឋ លប ៤១:៤២ ៣ច ៨:២១ **៣:១៩** ឌ លប ២៤:៤៧ ឍ អក ១៦:១១-១២ **៣:២០** ណ នក ៣៩:២៨ អគ ២៤:១៧,២៣ ៤៤:១៨ **៣:២១** ត លប ២៤:២២ **៣:២២** ថ នរ ៣:១៥ **៣:២៣** ទ អគ ១៦:១០ ២៣:២៦ ធ នក ២៩:៦ បស ៣:១១ អស ៦១:៣ ៦២:៣ **៣:២៤** ន នអ ២:១២ ប អស ៤:៤ ផ សភ ៣១:២៤ ព ខ.១៧ លវ ១៣:៤០ យប ១:២០ ភ លប ៣៧:៣៤ យប ១៦:១៥ អស ២០:២ យរ ៤:៨ បទ ២:១០ អគ ២៧:៣០-៣១ យហ ៣:៥-៨ ម ១ពត ៣:៣ យ ២សយ ១០:៤ អស ២០:៤ **៣:២៥** រ អស ១:២០ ល យរ ១៥:៨ **៣:២៦** វ អស ១៤:៣១ ២៤:១២ ៤៥:២ ស ទដ ១៣៧:១ អស ២៤:៤,៧ ២៩:២ ៣៣:៩ យរ ៤:២៨ ១៤:២ ហ លវ ២៦:៣១ ឡ យប ២:១៣ បទ ៤:៥ **៤:១** ក អស ២:១១ ខ អស ១៣:១២ ៣២:៩ គ ២ថន ៣:១២ ឃ លប ៣០:២៣ **៤:២** ង អស ២:១១ ច អស ១១:១-៥ ៥២:១៣ ៥៤:២ យរ ២៣:៥-៦ ៣៣:១៥-១៦ អគ ១៧:២២ សក ៣:៨ ៦:១២ ឆ អស ៣៣:១៧ ៥៣:២ ជ ទដ ៧២:១៦ អគ ៣៦:៨ ឈ អស ៦០:១៥ អគ ៣៤:២៩ ញ អស ១:៩ **៤:៣** ដ អស ១:២៦ ឋ អស ១:៩ រម ១១:៥ ឌ នក ១៩:៦ អស ២៦:២ ៤៥:២៥ ៥២:១ ៦០:២១ យអ ៣:១៧ អប ១:១៧ សផ ៣:១៣ ឍ ទដ ៥៦:៨ ៨៧:៦ លក ១០:២០ **៤:៤** ណ អស ៣:២៤ ត បស ៣:១១ ថ ទដ ៥១:២ ទ អស ១:១៥ ធ អស ២៨:៦ ន អស ១:៣១ ៣០:៣០ សក ១៣:៩ មថ ៣:១១ លក ៣:១៧ **៤:៥** ប អស ៤១:២០ ៦៥:១៨ ផ នក ១៣:២១ ព វវ ១៤:១ ភ អស ៣៥:២ ៥៨:៨ ៦០:១

ដល់ដួងខែជាព្រះរបស់ពួកគេ ។

**៣:២០** *ក្បាំងសក់* ជាប្រភេទឈ្នួតម្យ៉ាង (មើល អគ ២៤:១៧,២៣) ។

**៣:២១** *ចិញ្ចៀនត្បូងតែងច្រមុះ* ធ្វើពីមាសសម្រាប់ពាក់ដល់កូនក្រមុំ (មើល លប ២៤:២២,៥២) ។

**៣:២៤** *ខ្សែ... ជំនួសខ្សែក្រវាត់* ដូចជាអ្នកចាប់ជាឈ្លើយបានដឹកទៅដោយខ្សែពួរ (មើលការពន្យល់ ៣៧:២៩ ២ពវ ១៩:២៨ អម ៤:២) ។

**៣:២៦** *ទ្វារក្រុង* គឺជាទ្វារនៃនិមិត្តរូប ឬបដិមាករដូចជាបង្ហាញក្នុង ទដ ២៤:៧,៩ គេក៏សម្ដែងការទួញសោក ពីព្រោះហ្វូងមនុស្សដែលធ្លាប់តែប្រមូលផ្ដុំធ្វើទ្វារក្រុងនោះ ក៏បានបាត់បង់ទៅអស់ ។

**៤:១-២** *នៅគ្រានោះ* មើលការពន្យល់ ២:២ និង ២:១១,១៧,២០ គឺបន្ទាប់ពីកាត់ទោស គឺការជំនុំជម្រះសេចក្ដីសង្គ្រោះក៏មកដល់ ។

**៤:១** មើលការពន្យល់ ៣:៦ គឺជាសង្គ្រាមដែលបានសម្លាប់មនុស្សប្រុសៗជាច្រើន គឺជាប្រជាពលរដ្ឋប្រុសៗបានសម្លាប់ ។ (៣:២៥ មើល ១៣:១២ នឹងការពន្យល់) ដែលបន្សល់ទុកនូវស្ត្រីៗជាច្រើន ដែលនៅជាស្ត្រីមេម៉ាយ និងពុំមានកូនដោយក្ដីសៅហ្មង មើល ៥៤:៤ ។

**៤:២-៦** សេចក្ដីទំនាយពីការលោះបាបក្នុងជំពូក ៥ ។ វាក៏បង្ហាញនូវភាពត្រឹមត្រូវដែលយើងឃើញនៅក្នុង ២:២០៥ ដែលរបស់ទៅតាមសេចក្ដីទំនាយដ៏វែងដែលជាភស្តុតាងនៃការជំនុំជម្រះ ក្នុងជំពូក១ (មើលការពន្យល់ក្នុង ១:១-៣១) ។ សេចក្ដីទំនាយទាំងពីរនេះគឺពីការលោះបាប ។

**៤:២-៣** *ដល់សំណល់... អ្នកណាដែលនៅសល់* មើលការពន្យល់ ១:៩ ។

**៤:២** *ខ្នែង* ជាចំណងជើងទាក់ទងនិងព្រះម៉ែស៊ីគឺចំពោះ"ពន្លក"និង"ខ្នែង" (១១:១ ៥៣:២) គឺមកពីអំបូរខ្សែរបស់ដាវីឌ (មើល យរ ២៣:៥ និងការពន្យល់ ៣៣:១៥ សគ ៣:៨ ៦:១២ នឹងការពន្យល់) តែអ្នកខ្លះមានជំនឿថាពាក្យ "ខ្នែង"នេះគឺសំដៅទៅលើពួកយូដា ។ *ជាប្រសើរ* គឺជាការប្រសើរទៅតាមក្រមច្បាប់ក្នុងផលផ្លែពីដីនិងជាតំណាងចរិលក្ខណៈ នៃរជ្ជកាលរបស់ព្រះមែស៊ី (មើល ទដ ៧២:៣,៦,១៦ និងការពន្យល់ ៧២:៣) ។ ដែលផ្ទុយនិងភាពប្រសើរក្នុង ២:១១,១៧ ។ *រុងរឿង* គឺជាផលផ្លែពីដីនិងជាសិរីរុងរឿងរបស់រាស្ត្រអ៊ីស្រាអែល ។ ក្នុង ៤៦:១៣ ការសង្គ្រោះរបស់ព្រះគឺជាសិរីរុងរឿងរបស់នាងៗទាំងនោះ(ភាពប្រសើរ) មើលក្នុង ៦០:១៩ ព្រះអម្ចាស់ជាអង្គ ទ្រង់ផ្ទាល់ ជាសិរីរុងរឿងរបស់នាង ។

**៤:៣** *បរិសុទ្ធ* គឺមានអត្ថន័យញែកខ្លួនឱ្យផុតនិស្ស័យលោកិយដើម្បីទៅរកព្រះ មើលក្នុង ១:២៦ ៦:១៣ និងការពន្យល់ក៏សូមមើល សក ១៤:២០-២១ នឹងការពន្យល់ ។

**៤:៤** *សេចក្ដីយុត្តិ... នៃភ្លើងឆេះបន្សុស* គឺបានរំលឹកនៅក្នុង ១:២៥ (មើល ៤៨:១០ នឹងការពន្យល់) ។

**៤:៥-៦** *ពពក... ភ្លើង... ទីលំនៅ* គឺជាព្រះបន្ទូលទាំងនេះហើយដែលព្រះបានហៅរាស្ត្រអ៊ីស្រាអែល កាលពីដើមបានវង្វេងនៅឯវាលរហោស្ថានក្នុងពេលដែលបង្គោលពពក និងបង្គោលភ្លើងបាននាំនិងការពាររាស្ត្រ

គំរបគ្របបាំងទាំងអស់[ម] ៦ហើយនឹងមានរោងបារាំ[យ]
សំរាប់ជាម្លប់បាំង កំដៅនៅពេលថ្ងៃ នឹងសំរាប់ជាទីជ្រក[រ]
ហើយជាទីបាំងខ្លួនឱ្យរួចពីព្យុះ[ល]នឹងភ្លៀងផង ។

## បទចម្រៀងនៃចំការទំពាំងបាយជូរ

**៥** ១ខ្ញុំសូមច្រៀងបទថ្វាយស្ងួនសំឡាញ់របស់ខ្ញុំ គឺជាបទ
ចំរៀង ច្រៀងពីស្ងួនសំឡាញ់ខ្ញុំ ខាងឯចំការទំពាំងបាយ[ក]
ជូររបស់ទ្រង់ថា–ស្ងួនសំឡាញ់ខ្ញុំ ទ្រង់មានចំការទំពាំង
បាយជូរនៅលើភ្នំ ដែលមានដីជាតិ ២ទ្រង់ក៏កាប់គាស់ដី
ហើយរើសយកដុំថ្មចេញ រួចទ្រង់ដាំទំពាំងបាយជូរយ៉ាងល្អ
បំផុត[ខ] ក៏សង់ប៉ម១[គ]នៅជាកណ្ដាល ហើយធ្វើធុងឃ្នាបគាប
ផ្លែ[ឃ]ផង ក្រោយនោះ ទ្រង់ប្រាថ្នាចង់ឱ្យទំពាំងបាយជូរ
នោះកើតផល តែបានកើតផលក្លាយជាទំពាំងបាយជូរ
ព្រៃវិញ[ង]។
៣ឥឡូវនេះ ឱពួកក្រុងយេរូសាឡិម និងជនជាតិ
យូដាអើយ សូមវិនិច្ឆ័យរឿងអញដែលកើតក្តីនឹងចំការ
ទំពាំងបាយជូររបស់អញនេះចុះ[ច] ៤តើគួរឱ្យអញធ្វើអ្វីទៀត
ដល់ចំការទំពាំងបាយជូររបស់អញ ដែលអញលះបង់មិន
បានធ្វើនោះ[ឆ] ដូច្នេះ កាលអញប្រាថ្នាឱ្យកើតមានផលល្អ
ម្តេចក៏ក្លាយទៅជាមានផ្លែទំពាំងបាយជូរព្រៃវិញ[ជ] ៥ឥឡូវ
នេះ អញនឹងប្រាប់ឱ្យឯងរាល់គ្នាដឹងជាអញនឹងធ្វើអ្វីដល់
ចំការទំពាំងបាយជូររបស់អញនោះ គឺអញនឹងរើរបង
ចេញ[ឈ]នោះសត្វនឹងចូលស៊ីបំផ្លាញ[ញ] អញនឹងរំលំកំផែង
ចេញ នោះចំការនឹងត្រូវជាន់ឈ្លីទៅ[ដ] ៦អញនឹងបំផ្លាញអស់
រលីង[ឋ] នឹងគ្មានអ្នកណាកាត់លួស ឬជ្រួយដីទៀតឡើយ គឺ
នឹងកើតមានអញ្ចាញ ហើយនឹងបន្លា[ឌ]ដុះឡើងវិញ ហើយ
អញនឹងបង្គាប់ដល់មេឃ ហាមមិនឱ្យធ្លាក់ភ្លៀងមក[ឍ]លើ
ចំការនោះតទៅ ៧ពីព្រោះចំការទំពាំងបាយជូរ[ណ]របស់
ព្រះយេហូវ៉ានៃពួកពលបរិវារ នោះគឺជាពូជពង្សរបស់
អ៊ីស្រាអែល និងពួកយូដា ជាដំណាំដែលគាប់ដល់ព្រះនេត្រ
ទ្រង់ ហើយទ្រង់ប្រាថ្នាចង់បានសេចក្តីយុត្តិធម៌[ត] តែមើល
បានតែការកំចាយឈាមវិញ ក៏ប្រាថ្នាចង់បានសេចក្តី
សុចរិតដែរ[ថ] តែមើលបានតែសំរែកក្រលួចវិញ[ទ]។

## សេចក្តីវេទនា និងការជំនុំជម្រះ

៨វេទនា[ធ]ដល់ពួកអ្នកដែលសង់ផ្ទះភ្ជាប់គ្នា ហើយកៀរ
ប្រមូលស្រែចំការតៗគ្នា[ន] ឥតមានចន្លោះណាឡើយ ទាំង
បណ្តាលឱ្យឯងរាល់គ្នានៅតែឯងនាញកស្រុកវិញ ៩ព្រះ

**៤:៥** ម ទដ ១៨:១១ វវ ៧:១៥ **៤:៦** យ លវ ២៣:៣៤–៤៣ ទដ ២៧:៥ អស ៨:១៤ ២៥:៤ អគ ១១:១៦ រ អស ១៤:៣២ ២៥:៤ ៣០:២ ៥៧:១៣ ល ទដ ៥៥:៨ **៥:១** ក ទដ ៨០:៨–៩ អស ២៧:២ យហ ១៥:១ **៥:២** ខ នក ១៥:១៧ អស ១៦:៨ គ ១សយ ២:៩ អស ២៧:៣ ៣១:៥ ៤៩:៨ មថ ២១:៣៣ ឃ យប ២៤:១១ ង មថ ២១:១៩ មក ១១:១៣ លក ១៣:៦ **៥:៣** ច មថ ២១:៤០ **៥:៤** ឆ ២រប ៣៦:១៥ យរ ២:៥–៧ មីក ៦:៣–៤ មថ ២៣:៣៧ ជ យរ ២:២១ ២៤:២ ២៩:១៧ **៥:៥** ឈ ២រប ៣៦:២១ អស ៦:១២ ២៧:១០ ញ អស ១០:៦ ២៦:៦ ២៨:៣,១៨ ៤១:២៥ ៦៣:៣ យរ ១២:១០ ៣៤:២២ បទ ១:១៥ ហស ២:១២ មីក ៧:១០ មឡ ៤:៣ លក ២១:២៤ ដ ទដ ៨០:១២ អស ២២:៥ **៥:៦** ឋ លប ៦:១៣ លវ ២៦:៣២ អស ៦:១៣ ៤៩:១៧,១៩ ៥១:៣ យអ ១:១០ ឌ ខ.១០,១៧ ២សយ ២៣:៦ អស ៧:២៣,២៤ ៣២:១៣ ៣៤:១៣ ៥៥:១៣ អគ ២៨:២៤ ហស ២:១២ ហព ៦:៨ ឍ ចទ ២៨:២៤ ២សយ ១:២១ អម ៤:៧ **៥:៧** ណ ទដ ៨០:៨ អស ១៧:១០ ១៨:៥ ៣៧:៣០ ត អស ១០:២ ២៩:២១ ៣២:៧ ៥៩:១៥ ៦១:៨ អគ ៩:៩ ២២:២៩ ថ អស ១:២១ ទ ទដ ១២:៥ **៥:៨** ធ ខ.១១,១៨, ២០ អស ៦:៥ ១០:១ ២៤:១៦ យរ ២២:១៣ ន យប ២០:១៩ មីក ២:២ ហព ២:៩–១២

របស់ទ្រង់ (មើល នក ១៣:២១ និងការពន្យល់ ១៤:២១–២២) ។ លោក ហោរាអេសាយ ជារឿយៗគាត់បាននិយាយសំដៅទៅលើគ្រានៃការចេញដំណើរ (១១:១៥–១៦ ៣១:៥ ៥១:១០ និងការពន្យល់) ។

**៤:៥** *ទីគួរគោរព* គឺជាការបង្ហាញឱ្យឃើញពីវត្តមានព្រះ ដោយសារអណ្តាតភ្លើង (មើល នក ១៦:១០ ២៤:១៧ ៤០:៣៤–៣៥) ។ *គំរបគ្របបាំង* គឺជាពពកនៃផ្សែងដែលបាំងទាំងអស់ ។

**៤:៦** វត្តមានទ្រង់ក្នុងពពក និងភ្លើងនិងការពារលោះបានដល់ទីក្រុងស៊ីយ៉ូន (ប្រៀបធៀប ២១:៥–៦) ។

**៥:១–៣០** មើលការពន្យល់ ១:១–៣១ ។

**៥:១** *ស្ងួនសំឡាញ់ខ្ញុំ* គឺជាព្រះបន្ទូល ។ *ចំការទំពាំងបាយជូរ* គឺនៅស្រុកអ៊ីស្រាអែល (មើល ខ.៧ ៣:១៤ ទដ ៨០:៨–១៦) ។ ជាពាក្យប្រស្នារបស់ព្រះយេស៊ូវអំពីអម្ចាស់ចំការម្ចាស់ដី (មថ ២១:៣៣–៤៤ មក ១២:១–១១ លក ២០:៩–១៨) គឺផ្តោតទៅលើកាបង្ហាញតាមរយៈបទចម្រៀង ។

**៥:២** *ប៉ម១* គឺមានលក្ខណៈខុសគ្នានឹងទីជម្រកគឺជាជំរុំនៅចំការត្រសក់ មើល ១:៨ ឯចំការទំពាំងបាយជូររបស់ព្រះ គឺពោរពេញដោយគុណសម្បត្តិ (មើល មថ ២១:៣៣ និងការពន្យល់) ។ *"ធុងឃ្នាប់គាបផ្លែ"* គឺសម្រាប់គាបផ្លែបញ្ចេញទឹកទំពាំងបានជូរ (មើល ១៦:១០ ហាក ២:១៦ និងការពន្យល់) ។ *ទ្រង់ប្រាថ្នាចង់ឱ្យ . . . តែបាន* ការបកស្រាយ(ខ.៧) ក៏បម្រើសេចក្តីវោហារដូចគ្នា (ប្រៀបធៀប ៥៩:៩,១១) ។

**៥:៦** *មានអញ្ចាញ ហើយនិងបន្លាដុះឡើង* ឃ្លាទាំងពីរនេះនិងមានឃើញសរសេរ៥ដងទៀតក្នុង (៧:២៣–២៥ ៩:១៨ ២៧:៤) ។ *មិនឱ្យមានធ្លាក់ភ្លៀង* ការឃាត់មិនឱ្យមានភ្លៀងធ្លាក់គឺជាបណ្តាសាដល់ទឹកដីជាស្រុក ។ មើល ចទ ២៨:២៣–២៤ ២សយ ១:២១ ១ពវ ១៧:១ ។

**៥:៧** អត្ថន័យចម្រៀងពីចំការទំពាំងបាយជូរ (ខ.១:៦)ឥឡូវបានបកប្រែមកហើយ ។ គឺផ្នែកនៃផ្ទៃរឿងទាំងមូល : គឺជាព្រះបន្ទូលនៃ"សេចក្តីសុចរិត" និង"ការបង្ហូរឈាម"គឺជាសូរសៀងសម្រាប់អ្នកដែលមាន"សេចក្តីសុចរិត" និង"ភាពទុក្ខព្រួយ" ។

**៥:៨–២៣** សេចក្តីវេទនាទាំង៦ដែលបង្ហាញយ៉ាងច្បាស់ ចំពោះអ្នកដែលល្មើសនិងសេចក្តីសញ្ញារបស់ទ្រង់ (ខ.៨ ១១–១២ ១៨–១៩,២០,២២–២៣) ដែលមានផ្នែកបីបន្តបន្ទាប់ ។ (ខ.៩–១០,១៣–១៥,២៤–២៥) ។

**៥:៨** *សង់ផ្ទះជាប់គ្នា . . . ស្រែចំការតៗគ្នា* ឯដីជាដីរបស់រាស្ត្រអ៊ីស្រាអែល គឺគ្រាន់តែសម្រាប់ប្រគល់ការកាន់កាប់តៗគ្នា គេមិនដែលលក់ទេពីព្រោះជាទំនៀមទម្លាប់ ហើយអ្នកដែលត្រូវទទួលជំនួសនោះ គឺជាគ្រួសាររបស់គេម្នាក់ៗ (មើល ជន ២៧:៧–១១ ១ពវ ២១:១–៣ និងការពន្យល់ ២១:៣) ។

យេហូវ៉ានៃពួកពលបរិវារ[ប] ទ្រង់មានបន្ទូលដាក់ត្រចៀកខ្ញុំ
ថា[ផ] ពិតប្រាកដជាផ្ទះជាច្រើននោះនឹងត្រូវចោលទទេ[ព]
គឺជាផ្ទះធំល្អផង ឥតមានអ្នកណានៅឡើយ ១០ដ្បិតចំការ
ទំហំ១០រ៉ៃ នឹងបានទឹកទំពាំងបាយជូរតែ២ប៉ោត ហើយពូជ
ពង្រោះ១០ថាំងនឹងច្រូតបានតែ១ថាំងទេ[ភ]។
១១វេទនា[ម]ដល់ពួកអ្នក ដែលក្រោកឡើង ពីព្រលឹម
ស្រាង ដើម្បីតែនឹងរកគ្រឿងស្រវឹង ហើយអង្គុយដរាប
ដល់យប់ជ្រៅ ទាល់តែឆេះរោលរាល ដោយសារស្រា
ទំពាំងបាយជូរ[យ] ១២ជាពួកអ្នកដែលមានស៊ុង ពណ៌ ក្រាប់[រ]
ខ្លុយ[ល] និងស្រាទំពាំងបាយជូរក្នុងការស៊ីលៀងរបស់គេ តែ
គេមិនយកចិត្តទុកដាក់[វ] ចំពោះស្នាដៃរបស់ព្រះយេហូវ៉ាទេ
ក៏មិនពិចារណាពីការដែលព្រះហស្តទ្រង់ធ្វើដែរ[ស]។
១៣ហេតុនោះបានជារាស្ត្ររបស់អញ បានត្រូវចាប់
ទៅជាឈ្លើយ[ហ] គឺដោយព្រោះគេខ្វះប្រាជ្ញា[ឡ] ពួកអ្នករុង
រឿង[អ]ត្រូវអត់ឃ្លានរហិតរហៃទៅ ហើយពួកបណ្តាជន
ណែនណាន់ក៏ខះកដោយស្រេកទឹក[ក] ១៤ដូច្នេះ ស្ថានឃុំ
ព្រលឹងមនុស្សស្លាប់[ខ]បានរីកធំឡើង ព្រមទាំងហាមាត់[គ]
ជាធំហួសប្រមាណ ឯពួករុងរឿងឧត្តម ពួកណែនណាន់
តាន់តាប់ ពួកអឺកធឹក នឹងពួកអ្នកដែលរីករាយសប្បាយក្នុង
ពួកគេ ក៏ចុះទៅឯស្ថាននោះ[ឃ] ១៥មនុស្សជាន់ទាបត្រូវឱន
ចុះ[ង] ហើយមនុស្សជាន់ខ្ពស់ក៏ត្រូវបន្ទាបដែរ[ច] ឯភ្នែករបស់
អ្នកមានឫកខ្ពស់[ឆ]នឹងត្រូវសំយុងជ្រប់ ១៦តែព្រះយេហូវ៉ា
នៃពួកពលបរិវារ ទ្រង់បានដំកើងឡើង[ជ]ដោយសេចក្តី
យុត្តិធម៌[ឈ] គឺព្រះបរិសុទ្ធទ្រង់បានរាប់ជាបរិសុទ្ធ[ញ] ដោយ
សេចក្តីសុចរិតវិញ ១៧នៅគ្រានោះកូនចៀមនឹងរកស៊ីនៅ
គ្រប់កន្លែង ដូចជានៅវាលស្មៅរបស់វា[ដ] ឯមនុស្សដទៃគេ
នឹងត្របាក់លេបទ្រព្យសម្បត្តិ បាក់បែករបស់ពួកអ្នកស្កុក
ស្តុក ។
១៨វេទនា[ឋ]ដល់ពួកអ្នក ដែលអូសទាញសេចក្តីទុច្ចរិត
ដោយខ្សែ[ឌ]ជាសេចក្តីភូតភរ ហើយអំពើបាប[ឍ]ដោយខ្សែ
លាមរទេះ ១៩ជាពួកអ្នកដែលថា ចូរឱ្យទ្រង់ប្រញាប់ឡើង
ឱ្យទ្រង់បង្ហើយការឱ្យឆាប់[ណ]ចុះ ដើម្បីឱ្យយើងបានឃើញនឹង
ភ្នែក ចូរឱ្យគំនិតរបស់ព្រះដ៏បរិសុទ្ធ[ត]នៃសាសន៍អ៊ីស្រាអែល
ចូលមកជិត ហើយមកដល់ចុះ ឱ្យយើងបានស្គាល់ផង[ថ]។
២០វេទនា[ទ]ដល់ពួកអ្នក ដែលរាប់សេចក្តីអាក្រក់ថាជា
ល្អ[ធ] ហើយសេចក្តីថាជាអាក្រក់វិញ[ន] ជាពួកអ្នកដែលយក
សេចក្តីងងឹតជាពន្លឺ ហើយយកពន្លឺជាងងឹត[ប] ក៏យកសេចក្តី
ជូរចត់ជាផ្អែម ហើយយកផ្អែមជាជូរចត់វិញ[ផ] ២១វេទនា
ដល់ពួកអ្នកដែលរាប់ខ្លួន[ព]ថា ជាមានប្រាជ្ញា ហើយស្មាន
ថាខ្លួនគេមានគំនិតស្រួច ២២វេទនាដល់ពួកអ្នកដែលប៉ិន
ប្រសប់នឹងផឹកស្រាទំពាំងបាយជូរ[ភ] និងអ្នកដែលខ្លាំងពូកែ
ក្នុងការលាយគ្រឿងស្រវឹង[ម] ២៣ជាពួកអ្នកដែលស៊ីសំណូក[យ]
ដើម្បីរាប់មនុស្សអាក្រក់[រ]ថាជាសុចរិតវិញ ហើយដកសេចក្តី
សុចរិតរបស់មនុស្សសុចរិតចេញ[ល]។
២៤ហេតុដូច្នេះ បែបដូចជាអណ្តាតភ្លើងឆេះ[វ]បន្សុល
ជញ្ជ្រាំង[ស] ហើយស្មៅក្រៀមស្រុតចុះក្នុងភ្លើងយ៉ាងណា

**៥:៩** ប យរ ៤៤:១១ ផ អស ២២:១៤ ព អស ៦:១១-១២ មថ ២៣:៣៨ **៥:១០** ភ ខ.៦ លវ ២៦:២៦ ចទ ២៨:៣៨ សក ៨:១០ **៥:១១** ម ខ.៨ យ ១សយ ២៥:៣៦ សភ ២៣:២៩-៣០ **៥:១២** រ ទដ ៦៨:២៥ អស ២៤:៨ ល យប ២១:១២ វ ១សយ ១២:២៤ ស ទដ ២៨:៥ អគ ២៦:១៣ **៥:១៣** ហ អស ៤៩:២១ ឡ សភ ១០:២១ អស ១:៣ ហស ៤:៦ អ យប ២២:៨ ក អស ៣:១ **៥:១៤** ខ សភ ៣០:១៦ គ ជន ១៦:៣០ ឃ អស ២២:២,១៣ ២៣:៧ ២៤:៨ **៥:១៥** ង អស ១០:៣៣ ច អស ២:៩ ឆ អស ២:១១ **៥:១៦** ជ ទដ ៩៧:៩ អស ៣៣:១០ ឈ អស ២៨:១៧ ៣០:១៨ ៣៣:៥ ៦១:៨ ញ លវ ១០:៣ អស ២៩:២៣ អគ ៣៦:២៣ **៥:១៧** ដ អស ៧:២៥ ១៧:២ ៣២:១៤ សផ ២:៦,១៤ **៥:១៨** ឋ ខ.៨ ឌ ហស ១១:៤ ឍ អស ៥៩:៤-៨ យរ ២៣:១៤ **៥:១៩** ណ អស ៦០:២២ ត អស ១:៤ ២៩:២៣ ៣០:១១,១២ ថ យរ ១៧:១៥ អគ ១២:២២ ២ពត ៣:៤ **៥:២០** ទ ខ.៨ ធ លប ១៨:២៥ ១ពវ ២២:៨ ន ទដ ៩៤:២១ ប យប ២៤:១៣ មថ ៦:២២-២៣ លក ១១:៣៤-៣៥ ផ អម ៥:៧ **៥:២១** ព សភ ៣:៧ អស ៤៧:១០ រម ១២:១៦ ១កថ ៣:១៨-២០ **៥:២២** ភ ១សយ ២៥:៣៦ សភ ២៣:២០ អស ២២:១៣ ម សភ ៣១:៤ អស ៦៥:១១ យរ ៧:១៨ **៥:២៣** យ នក ២៣:៨ អគ ២២:១២ រ ខ.៧ អស ១:១៧ ១០:២ ២៩:២១ ៥៩:៤,១២-១៥ ល ទដ ៩៤:២១ អម ៥:២១ យក ៥:៦ **៥:២៤** វ អស ១:៣១ ស អស ៤៧:១៤ ណ

**៥:១០** *ថាំង* គឺជាត្រូវ១ភាគក្នុង១០ ក្នុង១ហូមើរ (មើល អគ ៤៥:១១) ។ ឯភោគផលតិចតួចគឺជាលទ្ធផលនៃអំពើបាបរបស់ពូជសាសន៍នោះ (ចទ ២៨:៣៨-៣៩ ហាក ២:១៦-១៧) ។ ក្នុងចំណោមស្រា និងផលធញ្ញជាតិ គឺជាកត្តាតូចតាចនៃអ្វីដែលមាននៅក្នុងចំការទំហំ ១០ រ៉ៃ និងគ្រាប់ពូជមួយហូមើរគឺជាផលដែលបានមក ។

**៥:១១-១៣** មើល អម ៤:១-៣ ៦:៤-៧ គឺបង្ហាញប្រភេទជីវិត ឬលក្ខណៈសម្បត្តិរបស់ពួកញៀនស្រាគឺស្រដៀងគ្នានិងពីការកាត់ទោស ។

**៥:១៤** *ស្ថានឃុំព្រលឹង* សូមមើលការពន្យល់ លប ៣៧:៣៥ ស្ថានឃុំព្រលឹងគឺមានសេចក្តីស្រេចឃ្លានមិនចេះស្កប់ស្កល់ ។ (សូមមើល ទដ ៤៩:១៤ និងការពន្យល់) ។

**៥:១៦** *គឺព្រះដ៏បរិសុទ្ធ ទ្រង់បានរាប់ជាបរិសុទ្ធ* មើល លវ ១០:៣ និងការពន្យល់ ។

**៥:១៨** *អូសទាញសេចក្តីទុច្ចរិតដោយខ្សែជាសេចក្តីភូតភរ* មើល ទដ ៥:២២ និងការពន្យល់ ។

**៥:១៩** ព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យ "ប្រញាប់" និង"ឱ្យឆាប់ចុះ" គឺឆ្លើយតបទៅនិងផ្នែកទី១និងទី៣នៃធាតុផ្សំរបស់ឈ្មោះ ម៉ាហេ-សាឡាល-ហាសបាស (មើល ៨:១ និងការពន្យល់) ពេលដែលលោកអេសាយបានដាក់ឈ្មោះកូនប្រុសគាត់ (៨:៣) ក៏វាឆ្លើយតបទៅ និងពាក្យនិយាយឡកឡឺយនៃពួកមានបាប ។ ទ្រង់បាននាំទូវការជំនុំជម្រះដោយផ្អែកតាមព្រះគម្ពីរ ៥:២៦ ។ *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* មើល ១:៤ និងការពន្យល់ ។

**៥:២២** *លាយគ្រឿងស្រវឹង* គឺមានគ្រឿងផ្សំលាយទៅនិងស្រាបៀរនិងស្រា (សូមមើល សភ ២៣:៣០ នឹងការពន្យល់) ។

**៥:២៣** មើល ១:២៣ ១០១-២ ។

**៥:២៤** *មើលងាយចំពោះព្រះបន្ទូលរបស់ព្រះដ៏បរិសុទ្ធ នៃសាសន៍អ៊ីស្រា*

នោះ ឫសរបស់ពួកអ្នកទាំងនោះនឹងបានដូចជាអ្វីដែលពុក
រលួយ[ហ] ហើយផ្កាយរបស់គេនឹងហុយឡើង ដូចជាធូលី
យ៉ាងនោះដែរ[ឡ] ដ្បិតគេបានលះចោលបញ្ញត្តិច្បាប់របស់
ព្រះយេហូវ៉ានៃពួកពលបរិវារ ព្រមទាំងមើលងាយចំពោះ
ព្រះបន្ទូល[អ] របស់ព្រះដ៏បរិសុទ្ធ[ក]នៃសាសន៍អ៊ីស្រាអែលផង
២៥ ហេតុនោះ សេចក្ដីខ្ញាល់[ខ]របស់ព្រះយេហូវ៉ា បានឆេះ
ឡើងទាស់នឹងរាស្ត្រនៃទ្រង់ ហើយទ្រង់បានលូកព្រះហស្ត
មកវាយគេ ឯភ្នំទាំងប៉ុន្មានក៏ញ័រ[គ] ហើយខ្មោច[ឃ]គេបាន
ត្រឡប់ដូចជាសំរាម[ង] នៅកណ្ដាលផ្លូវទាំងប៉ុន្មាន[ច] ទោះបើ
យ៉ាងនោះក៏ដោយ គង់តែសេចក្ដីខ្ញាល់របស់ទ្រង់មិនទាន់
បែរចេញទាំងអស់ទៅដែរ[ឆ] គឺព្រះហស្តទ្រង់ចេះតែលូក
មកទៀត[ជ] ។
២៦ ទ្រង់នឹងលើកទង់ជ័យ[ឈ]សំរាប់ពួកសាសន៍ដែលនៅ
ទីឆ្ងាយ ហើយនិងហួចហៅ[ញ]ឱ្យមកពីចុងផែនដី[ដ] នោះពួក
ខ្មាំងនឹងខិសង្វាតមកដោយប្រញាប់ ២៧ ឥតមានអ្នកណា
មួយអស់កំឡាំង[ឋ] ឬចំពប់ជើងឡើយ ឥតមានអ្នកណាមួយ
ងុយងោក ឬដេកលក់ ក៏ឥតមានអ្នកណាមួយបន្ធូរខ្សែ
ក្រវាត់[ឱ,ឍ] ឬស្រាយខ្សែស្បែកជើងដែរ[ណ] ២៨ ជាពួកអ្នកដែល
មានព្រួញមុតណាស់[ត] ហើយធ្នូ[ថ]ទាំងអស់ក៏ដំឡើងជាស្រេច
ឯក្រចកសេះ[ទ] នោះនឹងបានរាប់ជាថ្មភ្លើង ហើយកង់រទេះ
របស់គេក៏ដូចជាខ្យល់កួច[ធ] ២៩ សូរសន្ធឹករបស់ពួកនោះនឹង
បានដូចជាសូរគ្រហឹមរបស់មេសិង្ហ[ន] គេនឹងគ្រហឹមដូចជា
កូនសិង្ហ អើ គេនឹងគ្រហឹម ហើយចាប់[ប]រំពាយកទៅ ឥត
មានអ្នកណាជួយឱ្យរួចបានឡើយ[ផ] ៣០ នៅគ្រានោះ[ព]គេនឹង
គ្រហឹមដាក់ពួកអ្នកទាំងនោះឱ្យឮ ដូចជាសូរគ្រាំគ្រេងនៃ
សមុទ្រ[ភ] ហើយបើអ្នកណាមើលទៅក្នុងស្រុក នោះនឹង
ឃើញមានតែងងឹត[ម] និងសេចក្ដីវេទនាទទេ[យ] ហើយពន្លឺ
ដែលនៅលើមេឃនឹងងងឹតសូន្យ[រ] ទៅដែរ ។

### បេសកកម្មរបស់លោកអេសាយ

៦ ១ នៅឆ្នាំដែលស្ដេចអ៊ូសៀស[ក]ទ្រង់បានសុគត[ខ] នោះខ្ញុំ
ឃើញព្រះអម្ចាស់[គ]ទ្រង់គង់លើបល្ល័ង្ក[ឃ]នៅទីខ្ពស់ ហើយបាន
ដំកើងឡើង[ង] ឯរំភាយ[ច]ព្រះពស្ត្រទ្រង់សាយមកពេញក្នុង

**៥:២៤** ហ ១:១០ ហ ២ពវ ១៩:៣០ យប ១៨:១៦ ឡ យប ២៤:២៤ អស ៤០:៨ អ ទដ ១០៧:១១ អស ៨:៦ ៣០:៩,១២ ក យប ៦:១០ អស ១:៤ ១០:២០ ១២:៦ **៥:២៥** ខ ២ពវ ២២:១៣ យប ៤០:១១ អស ១០:១៧ ២៦:១១ ៣១:៩ ៦៦:១៥ យរ ៦:១២ គ នក ១៩:១៨ ឃ ទដ ១១០:៦ ង ២ពវ ៩:៣៧ ច ២សយ ២២:៤៣ ឆ យរ ៤:៨ ជយ ៩:១៦ ជ អស ៩:១២,១៧,២១ ១០:៤ **៥:២៦** ឈ ទដ ២០:៥ ញ អស ៧:១៨ សក ១០:៨ ដ ចទ ២៨:៤៩ អស ១៣:៥ ១៨:៣

**៥:២៧** ឋ អស ១៤:៣១ ៤០:២៩–៣១ ឱ អស ២២:២១ អគ ២៣:១៥ ឍ យប ១២:១៨ ណ យអ ២:៧–៨ **៥:២៨** ត យប ៣៩:២៣ ទដ ៤៥:៥ ថ ទដ ៧:១២ ទ អគ ២៦:១១ ធ ២ពវ ២:១ យប ១:១៩ **៥:២៩** ន ២ពវ ១៧:២៥ យរ ៥១:៣៨ សផ ៣:៣ សក ១១:៣ ប អស ១០:៦ ៤៩:២៤–២៥ ផ អស ៤២:២២ មីក ៥:៨ **៥:៣០** ព អស ២:១១ ភ ទដ ៩៣:៣ យរ ៥០:៤២ លក ២១:២៥ ម ១សយ ២:៩ យប ២១:៣០ ទដ ១៨:២៨ ៤៤:១៩ ៨២:៥ យ ពជ ៦:២ អស ២២:៥ ៣៣:២ យរ ៤:២៣–២៨ រ អស ១៣:១០ ៥០:៣ យអ ២:១០ **៦:១** ក ២របា ២៦:២២,២៣ ខ ២ពវ ១៥:៧ គ នក ២៤:១០ ជន ១២:៨ យហ ១២:៤១ ឃ ១ពវ ២២:១៩ ទដ ៩:៤ ១២៣:១ វវ ៤:២ ង អស ៥២:១៣ ៥៣:១២ ច វវ ១:១៣

*អែល* សូមមើល ខ.១៩ ក៏សូមមើល ១:៤ និងការពន្យល់ ។

**៥:២៥** *ភ្នំទាំងប៉ុន្មានក៏ញ័រ* គឺនៅពេលដែលទ្រង់បានធ្វើការអស្ចារ្យនោះ ឯសូម្បីតែភ្នំទាំងប៉ុន្មានក៏ញាប់ញ័រ (សូមមើល ៦៤:៣ ទដ ១៨:៧ យរ ៤:២៤–២៦ មីក ១:៤ ណាហ ១:១៥ ហាប ៣:៦,១០) ។ *ចេះតែលូកមកទៀត* គឺជាការបន្ទរដែលនិយាយឡើងវិញក្នុង ៩:១២,១៧,២១ ១០:៤ ។

**៥:២៦** *ទ្រង់និងលើកទង់ជ័យ* ក៏ជាបង្គោលដោតទង់ជ័យ តាមទម្លាប់គេដាក់លើកំពូលភ្នំ ដើម្បីជាសញ្ញាសម្រាប់នាំឱ្យសាសន៍អ៊ីស្រាអែលត្រឡប់មកវិញ (១១:១០,១២ ៤៩:២២ ៦២:១០) ។ *ពួកសាសន៍ដែលនៅឆ្ងាយ* ដូចពួកសាសន៍អាសស៊ើរដែលជាពលទ័ពប្រឆាំងអ៊ីស្រាអែលនិងយូដា គឺក្នុងឆ្នាំ ៧២២ និង ៧០១ មុន គ.ស និង សាសន៍បាប៊ីឡូន ដែលបានឈ្លានពានក្នុងឆ្នាំ ៦០៥ ។ *ពួក . . . ហើយនិងហួចហៅឱ្យមកពីចុងផែនដី* ដូចជាពួកសាសន៍អេស៊ីព្ទ និង សាសន៍អាសស៊ើរ ។

**៥:២៧** *ឥតមានអ្នកណាមួយអស់កំឡាំង ឬចំពប់ជើងឡើយ* ។ សូមប្រៀបធៀបការប្រើពាក្យទាំងនេះក្នុង ៤០:២៩–៣១ ។

**៥:៣០** *នៅគ្រានោះ* សូមមើលការពន្យល់ ២:១១,១៧,២០ ។ *មានតែងងឹតនឹងសេចក្ដីវេទនា* ជាពាក្យស្រដៀងគ្នានិងពាក្យដែលបានប្រើពណ៌នាក្នុងពេលធ្វើសង្គ្រាម ៨:២២ ។

**៦:១–១៣** ជាវគ្គនៃកិច្ចការរាស្ត្រអ៊ីស្រាអែល ក៏ជាព្រឹត្តការនៃផ្នែកសំខាន់ដំបូងនៃទំនាយរបស់លោកអេសាយ (មើលការពន្យល់ ១:១–៦:១៣) ។ ក្នុង ខ.១–៤ លោកឃើញព្រះយេហូវ៉ា ដែលពេញដោយសិរីល្អ (ខ.១) ក្នុង ខ.៥–៧ ខណៈនោះលោកក៏ឃើញខ្លួនលោកមានភាពមិនស្អាត (ខ.៥) ក្នុង ខ.៨–១៣ ពួកហោរាក៏បានបញ្ជាក់ថា ក៏មានការលើកលែងទោស (ខ.៧) មើលរាស្ត្រដែលពុំបានស្ដាប់បង្គាប់ ដែលព្រះបានបញ្ជូនគេទៅប្រកាសពីរសារពីព្រះយេហូវ៉ាពីការកាត់ទោស ឬជំនុំជម្រះ ។

**៦:១** *នៅឆ្នាំដែលស្ដេចអ៊ូសៀសទ្រង់បានសុគត* គឺ ៧៤០ឆ្នាំ មុន គ.ស (មើលការប្រៀបធៀប ១៤:២៨ និងការពន្យល់) ។ កិច្ចការរបស់លោកអេសាយគឺអាចជាកិច្ចទៅមុខដើម្បីកិច្ចការអធិប្បាយ ។ កិច្ចការត្រូវពន្យាពេល ដើម្បីផ្ដល់នូវការសំដែងទំនាយក្នុងការផ្ដល់នូវការធានាពីការប្រកាសយ៉ាងជាក់លាក់ពីការជំនុំជម្រះ ដែលពួកគេត្រូវទទួល ។ ហើយមនុស្សបានចំអកដល់ "ព្រះដ៏បរិសុទ្ធរបស់សាសន៍អ៊ីស្រាអែល" (៥:១៩) ។ តែពេលនេះអេសាយបានទទួលភារកិច្ចដើម្បីត្រាស់ហៅពួកគេឱ្យទទួល ។ ឯស្ដេចអ៊ូសៀសបានសោយរាជ្យ តាំងពីឆ្នាំ ៧៩២ រហូតដល់ ៧៤០ ក៏ជាព្រះបហាក្សត្រដ៏មានអំណាចព្រះចេស្ដា និងមានព្រះគង់ជាមួយ ។ ខណៈពេលដែលស្ដេចអង្គនេះបានដុតគ្រឿងក្រអូបកំញ៉ានក្នុងព្រះវិហារ ធ្វើឱ្យគាត់មានជម្ងឺឃ្លង់រហូតដល់អស់ព្រះជន្ម ។ (មើល ២របា ២៦:១៦–២១ និងការពន្យល់ ២៦:១៩) ។ គាត់ក៏បានហៅថាអ័សារា (២ពវ ១៤:២១ ២របា ២៦:១) ។ *នោះខ្ញុំឃើញ* គឺជានិមិត្តក្នុងព្រះវិហារ ។ *ព្រះអម្ចាស់* គឺជាព្រះមហាក្សត្រដ៏ពិតប្រាកដ (មើល ខ.៥) ។ *នៅទីខ្ពស់ហើយបានដំកើងឡើង* គឺក៏ដូចជាពាក្យព្រះគម្ពីរភាសាហេព្រើរដែលប្រើចំពោះព្រះអម្ចាស់ ក៏ដូចជានៅក្នុង ៥៧:១៥ ក៏មានពាក្យស្រដៀងគ្នាមួយទៀត ដែលប្រើចំពោះបាវដែលទទួលរងនៅការឈើចាប់ក្នុងគម្ពីរ អស ៥២:១៣ ។ *រំភាយព្រះពស្ត្រទ្រង់* គឺជាព្រះពស្ត្រដែលលាតបណ្ដោយមើល ការប្រៀបធៀបចំពោះព្រះពស្ត្រ "របស់កូនមនុស្ស" ក្នុង វវ

ព្រះវិហារ ២នៅពីលើទ្រង់មានពួកសេរភីម[ឆ] គ្រប់គ្នាមាន
ស្លាប៦ ក៏បាំងមុខដោយស្លាប២ បាំងជើងដោយស្លាប២[ជ]
ហើយប្រើ២សំរាប់ហើរ ៣មួយបន្លឺទៅកាន់១ថា បរិសុទ្ធ
បរិសុទ្ធ[ឈ] គឺព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បរិសុទ្ធ[ញ]
ផែនដីទាំងមូល[ដ]មានពេញដោយសិរីល្អនៃទ្រង់[ឋ] ៤ក្របទ្វារ
ក៏ញ័រដោយសូរសំឡេងនៃសេរភីមដែលបន្លឺនោះ ហើយ
ព្រះវិហារបានពេញទៅដោយផ្សែង[ឌ] ៥នោះខ្ញុំពោលថា
វរ[ឍ] ហើយខ្ញុំ ខ្ញុំត្រូវវិនាសជាពិត[ណ] ដ្បិតខ្ញុំជាមនុស្សមាន
បបូរមាត់មិនស្អាត[ត,ថ] ហើយខ្ញុំនៅកណ្ដាលបណ្ដាមនុស្ស
ដែលមានបបូរមាត់មិនស្អាតដែរ[ទ] ពីព្រោះភ្នែកខ្ញុំបាន
ឃើញ[ធ]មហាក្សត្រ[ន] គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ[ប]
៦ខណនោះ សេរភីម១បានហើរមកឯខ្ញុំ ដៃកាន់រងើកភ្លើង[ផ]
ដែលបានយកពីអាសនាដោយដង្កៀប ៧ក៏ឱ្យប៉ះនឹងមាត់ខ្ញុំ
ដោយពោលថា នែ រងើកនេះបានប៉ះនឹងបបូរមាត់អ្នក
ហើយ[ព] ឯសេចក្ដីទុច្ចរិតរបស់អ្នក នោះបានដកចេញ ហើយ
អំពើបាបរបស់អ្នកបានអត់ទោសឱ្យផង[ភ] ។

៨រួចខ្ញុំឮសូរសៀង[ម]របស់ព្រះអម្ចាស់ មានបន្ទូលមកថា
តើអញនឹងចាត់អ្នកណាឱ្យទៅ[យ] តើអ្នកណានឹងទៅឱ្យអញ[រ]
នោះខ្ញុំទូលឆ្លើយថា ទូលបង្គំនៅឯណេះហើយ[ល] សូមចាត់
ទូលបង្គំចុះ ៩រួចទ្រង់មានបន្ទូលតបថា ចូរទៅ[វ]ប្រាប់ដល់
ជនជាតិនេះថា ចូរឯងរាល់គ្នាស្តាប់ចុះ តែឥតយល់ ហើយ
មើលផង តែឥតដឹងឡើយ[ស] ១០ត្រូវធ្វើឱ្យចិត្តនៃជនជាតិ
នេះទៅជាស្លឹក[ហ] ហើយឱ្យត្រចៀកគេធ្ងន់ ចូរបាំងភ្នែកគេ[ឡ]
ក្រែងគេមើលឃើញដោយភ្នែក ស្តាប់ឮ ដោយត្រចៀក[អ]
ហើយយល់ដោយចិត្ត រួចប្រែចិត្ត ដើម្បីឱ្យបានប្រោសឱ្យ
ជា[ក] ១១នោះខ្ញុំទូលសួរថា ឱព្រះអម្ចាស់អើយ[ខ] តើដល់

**៦:២** ឆ អគ ១:៥ ១០:១៥ វវ ៤:៨ ជ អគ ១:១១ **៦:៣** ឈ នក ១៥:១១ ញ ទដ ៨៩:៨ ដ អស ១១:៩ ៥៤:៥ មឡ ១:១១ ឋ នក ១៦:៧ ជន ១៤:២១ ទដ ៧២:១៩ វវ ៤:៨ **៦:៤** ឌ នក ១៩:១៨ ៤០:៣៤ អគ ៤៣:៥ ៤៤:៤ វវ ១៥:៨ **៦:៥** ឍ អស ៥:៨ ណ ជន ១៧:១២ ចទ ៥:២៦ ត លក ៥:៨ ថ នក ៦:១២ ទ អស ៥៩:៣ យរ ៩:៣–៨ ធ នក ២៤:១០ ន ទដ ៤៥:៣ អស ២៤:២៣ ៣២:១ ៣៣:១៧ យរ ៥១:៥៧ ប យប ៤២:៥ **៦:៦** ផ លវ ១០:១ អគ ១០:២ **៦:៧** ព យរ ១:៩ ដយ ១០:១៦ ភ លវ ២៦:៤១ អស ៤៥:២៥ ដយ ១២:៣ ១យហ ១:៧ **៦:៨** ម យប ៤០:៩ កច ៩:៤ យ យរ ២៦:១២,១៥ រ លប ១:២៦ ល លប ២២:១ នក ៣:៤ **៦:៩** វ អគ ៣:១១ អម ៧:១៥ មថ ២៨:១៩ ស យរ ៥:២១ មថ ១៣:១៥ លក ៨:១០ **៦:១០** ហ នក ៤:២១ ចទ ៣២:១៥ ទដ ១១៩:៧០ ឡ អស ២៩:៩ ៤២:១៨–២០ ៤៣:៨ ៤៤:១៨ អ ចទ ២៩:៤ អគ ១២:២ មក ៨:១៨ ក ចទ ៣២:៣៩ មថ ១៣:១៣–១៥ មក ៤:១២ យហ ១២:៤០ **៦:១១** ខ ទដ ៧៩:៥

១:១៣ ។ *ព្រះវិហារ* គឺប្រហែលព្រះវិហារនៃនគរស្ថានសួគ៌ក៏មានវិហារនៅផែនដី ដែលមានទំនាក់ទំនងយ៉ាងជិតស្និត ។ ឯនិមិត្តរបស់យ៉ូហានចំពោះព្រះស្ដីអំពីបល័ង្កនៃទ្រង់ គឺមានភាពស្រដៀងគ្នា (វវ ៤:១–៨) ។

**៦:២** *ពួកសេរភីម* មើល ឧ.៦ ។ ជីវិតស្ថានសួគ៌មិនធ្លាប់បានបង្ហាញឱ្យឃើញគ្រប់ទីកន្លែងនោះទេ ។ សកម្មភាពនេះគឺទាក់ទងនិងជីវិតរស់នៅបែបធម្មជាតិ វវ ៤:៦–៩ ដែលឃើញពួកសេរភីមនិមួយៗមានស្លាប់ ៦ ។ *ក៏បាំងមុខដោយស្លាប* គឺជាហេតុដែលពួកគេពុំអាចសំឡឹងភ្នែករបស់គេទៅត្រង់ផ្ទាល់ចំពោះសិរីល្អនៃព្រះអម្ចាស់បានឡើយ ។

**៦:៣** *បរិសុទ្ធ បរិសុទ្ធ* សូមមើល លវ ១១:៤៤ និងការពន្យល់ ។ វវ ៤:៨ ពាក្យសង្កត់បីដង ដែលគូសបញ្ជាក់ពីភាពបរិសុទ្ធឥតប្រួលប្រែរបស់ព្រះនៃយើង ។ សូមចំណាំពាក្យថា បីដងប្រើសម្រាប់ "វិហាររបស់ព្រះយេហូវ៉ា" ក្នុង យរ ៧:៤ គឺដើម្បីបញ្ជាក់ពីភាពទុកចិត្តរបស់ប្រជារាស្ត្រក្នុងភាពសុខសាន្តនៃក្រុងយេរូសាឡិមពីព្រោះតែវត្តមានក្នុងទីបរិសុទ្ធ ។ *គឺព្រះយេហូវ៉ានៃពួកពលបរិវា* មើលការពន្យល់ ១សយ ១:៣ ។ *ពេញដោយសិរីល្អនៃទ្រង់* ក្នុងគម្ពីរ ជន ១៤:២១–២២ ទដ ៧២:១៨–១៩ ។ គឺសិរីល្អទ្រង់គ្រប់ទាំងអស់ដែលមានទំនាក់ទំនងទៅនិងទីសម្គាល់ដ៏អស្ចារ្យ ។ (ប្រៀបធៀបការពន្យល់ អគ ១:១–២៨) ។

**៦:៤** *គ្រប់ទ្វារក៏ញ័រ . . . វិហារបានពេញដោយផ្សែង* គឺជាការបើកសំដែងមានលក្ខណៈស្រដៀងទៅនិងអំណាចចេស្ដានៃសូរសំឡេងរបស់ព្រះដែលធ្វើឱ្យរាស្ត្រអ៊ីស្រាអែលញ័រនៅភ្នំស៊ីណាយនិងភ្នំនោះមានពេញដោយពពក ឬ ផ្សែង(មើល នក ១៩:១៨–១៩ ២០:១៨–១៩) ។

**៦:៥** *ពីព្រោះភ្នែកខ្ញុំបានឃើញមហាក្សត្រ* លោកអេសាយក៏ធ្លាក់ទឹកចិត្តដោយសារតែអ្នកណាមួយឃើញព្រះនោះនឹងត្រូវស្លាប់ភ្លាម(មើល លប ១៦:១៣ ៣២:៣០ នឹងការពន្យល់ នក ៣៣:២០) ។

**៦:៦** *ដៃកាន់រងើកភ្លើង* គឺជារងើកភ្លើងត្រូវនាំយកទៅឯទីបរិសុទ្ធបំផុតនៅថ្ងៃលាងបាប(លវ ១៦:១២)ដែលបានធ្វើយញ្ញបូជាដើម្បីកែប្រែសារភាពកំហុសពីអំពើបាប ។ សូមមើលការពន្យល់ ១:២៥ ។

**៦:៧** នោះព្រះយេហូវ៉ាលូកព្រះហស្តមកពាល់មាត់ (ខ្ញុំ) គឺនៅពេលដែលព្រះអម្ចាស់បានបង្គាប់យេរេមា គឺទ្រង់សំដែងដោយយកព្រះហស្តទ្រង់មកពាល់មាត់ហោរា (យរ ១:៩) ។

**៦:៨–១០** កិច្ចការជាហោរារបស់លោកអេសាយ និងមានការចំអកឡកឡឺយប៉ុន្តែឥទ្ធិពលដែលសមនិងទទួលចំពោះចរិតដែលរឹងចចេសនៃរាស្ត្រអ៊ីស្រាអែលដែលប្រឆាំងរឹងរូសដូច្នេះ ទ្រង់ក៏ប្រមាណដល់ពួកគេ (មើល ឧ.១១–១៣) ក៏សូមមើល ១:៨ អគ ២:៣–៤ ។

**៦:៨** ជាព្រះនៃនគរស្ថានសួគ៌បានមានបន្ទូលមកក្នុងមានជាទីប្រឹក្សាពីព្រះ (មើល លប ១:២៦ ទដ ៨២:១ នឹងការពន្យល់) ក្នុងនាមជាហោរាដ៏ពិតលោកអេសាយក៏បានបង្កើតការចូលរួមចំពោះការប្រឹក្សានោះក៏ដូចជាមីកាយ៉ា (១ពវ ២២:១៩–២០) និងយេរេមា (២៣:១៨,២២) ប្រៀបធៀប អម ៣:៧ *បង្គំនៅឯណេះហើយ* មើលការពន្យល់ លប ២២:១ ។

**៦:៩–១០** គឺព្រះគ្រីស្ទបានបញ្ជាក់ដោយពាក្យប្រស្នាទៅនិងអ្នកពង្រោះព្រោះពូជ(មថ ១៣:១៤–១៥ មក ៤:១២ លក ៨:១០) ។ ក៏សូមមើល រម ១១:៧–១០,២៥ នឹងការពន្យល់ ។ *នៃជនជាតិនេះ* ១:៣ ៣:១៥ ៥:១៣ គឺព្រះយេហូវ៉ាចង់បង្ហាញពីរាស្ត្រអ៊ីស្រាអែលដូចជាពាក្យបន្ទូលថា "រាស្ត្ររបស់អញ" ដែលគេបានប្រឆាំងនិងអញ (១:១ ៦៦:២៣) គេក៏បានបង់ចេញពីទ្រង់ (ឧទាហរណ៍ ៨:៦,១២,២៩,១៣–១៤ ប្រៀបធៀប នក ១៧:៤ នឹងការពន្យល់) ។

**៦:១០** *ចិត្ត . . . ត្រចៀក . . . ភ្នែក . . . ភ្នែក . . . ត្រចៀក . . . ចិត្ត* គឺជាការថ្លែងបញ្ច្រាស់គ្នាគឺជាលក្ខណៈទម្លាប់ប្រើគម្ពីរបស់សញ្ញាចាស់ ។ ត្រចៀកគេធ្ងន់ ចូរបាំងភ្នែកគេ ដែលបានរៀបរាប់ពណ៌នាពីភាពថ្លង់ និងភាពខ្សោយរបស់ពួកមនុស្ស ២៩:៩ ៤២:១៨ ៤៣:៨ គង់មានថ្ងៃណាមួយជាតិសាសន៍នោះ និងអាចស្តាប់ឮនិងអាចមើលឃើញ (២៩:១៨ ៣៥:៥) ។

យ៉ូរប៉ុន្មានទៅ រួចទ្រង់មានបន្ទូលតបថា គឺដរាបដល់
កាលណាទីក្រុងទាំងប៉ុន្មានត្រូវចោលស្ងាត់[គ] ឥតមានអ្នក
ណានៅសោះ ហើយផ្ទះទាំងប៉ុន្មានផង ឥតមានអ្នកណានៅ
សោះ ហើយផ្ទះទាំងប៉ុន្មានផង ឥតមានមនុស្ស[ឃ] ដរាបដល់
ស្រុកនេះបានទៅជាទីស្ងាត់ឈឹងទាំងអស់ទៅ[ង] ១២ហើយ
ដរាបដល់វេលាណា ដែលព្រះយេហូវ៉ាបានរើសយក
មនុស្សទាំងឡាយចេញទៅឯទីឆ្ងាយ[ច] ហើយមានកន្លែង
ច្រើនត្រូវចោលស្ងាត់នៅកណ្ដាលស្រុក[ឆ] ១៣នោះទោះបើ
មាន១ភាគក្នុង១០សល់នៅ[ជ]ក្នុងស្រុក គង់តែចំណែកនោះ
នឹងត្រូវវិនាសបាត់ទៅដែរ[ឈ] ដូចជាដើមឈើទាល ហើយ
នឹងដើមម៉ៃសាក់ដែលសល់នៅតែគល់[ញ] ក្រោយដែលគេ
កាប់រំលំហើយ គឺពូជពង្សបរិសុទ្ធ[ដ]ជាគល់ឈើនោះឯង[ឋ] ។

**ទីសំគាល់នៃអេម៉ាញូអែល**

**៧** ១រីឯនៅក្នុងរាជ្យស្តេចអេហាស[ក] បុត្រយ៉ូថាម ដែលជា
បុត្រអ៊ូសៀសស្តេចស្រុកយូដា នោះរេស៊ីន[ខ] ជាស្តេចស្រុក
ស៊ីរី[គ] ហើយពេកា[ឃ]ជាបុត្ររេម៉ាលា[ង]ស្តេចស្រុកអ៊ីស្រាអែល
គេលើកទ័ពឡើង ទៅច្បាំងនឹងក្រុងយេរូសាឡិម តែឈ្នះ
យកមិនបានទេ ២គ្រានោះមានដំណឹងមកដល់ពួកវង្សដាវីឌ[ច]
ថា សាសន៍ស៊ីរីបានចូលដៃនឹងពួកអេប្រាអិម[ឆ] ហើយ ដូច្នេះ
ស្តេចទ្រង់មានព្រះទ័យចំប្រប់[ជ] ព្រមទាំងចិត្តរបស់ពួក
រាស្ត្រទ្រង់ផង ប្រៀបដូចជាដើមឈើនៅព្រៃដែលត្រូវ
ខ្យល់បក់ ។

**៦:១១** គ លវ ២៦:៣១ យរ ៤:១៣ ឃ លវ ២៦:៤៣ អស ២៤:១០ ង ទដ ៧៩:១ ១០៩:១១ យរ ៣៥:១៧ **៦:១២** ច ចទ ២៨:៦៤ ឆ អស ៥:៥,៩ ៦០:១៥ ៦២:៤ យរ ៤:២៩ ៣០:១៧ **៦:១៣** ជ អស ១:៩ ១០:២២ ឈ អស ៥:៦ ញ យប ១៤:៨ ដ លវ ២៧:៣០ ចទ ១៤:២ ឋ យប ១៤:៧ **៧:១** ក ១រប ៣:១៣ ខ ខ.៨ ២ពវ ១៥:៣៧ គ ២រប ២៨:៥ ឃ ២ពវ ១៥:២៥ ង ខ.៥,៩ អស ៨:៦ **៧:២** ច ខ.១៣ ២សយ ៧:១១ អស ១៦:៥ ២២:២២ យរ ២១:១២ អម ៩:១១ ឆ អស ៩:៩ ហស ៥:៣ ជ អស ៦:៤

៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅអេសាយថា ចូរឯង
និងស្អា-យ៉ាស៊ូប[ឈ] ជាកូនឯង ចេញទៅជួបនឹងអេហាស
ត្រង់ចុងប្រឡាយបង្ហូរទឹកមកដល់ស្រះខាងលើ តាមផ្លូវទៅ
ឯទីវាលជាងប្រមោក[ញ] ៤ហើយទូលថា ចូរវាំងខ្លួន ហើយ
សង្រួមចិត្ត[ដ] កុំឱ្យភ័យឱ្យសោះ[ឋ] ក៏កុំឱ្យរាថយ[ឌ] ដោយព្រោះ
កន្ទុយឧសទាំង២ដែលហុយផ្សែង[ឍ]នោះឡើយ គឺដោយ
ព្រោះសេចក្តីកំហឹងដ៏សហ័ស[ណ]របស់រេស៊ីន និងសាសន៍
ស៊ីរី ហើយរបស់កូនរេម៉ាលានោះដែរ[ត] ៥ពីព្រោះសាសន៍
ស៊ីរី និងពួកអេប្រាអិម ព្រមទាំងកូនរេម៉ាលា[ថ]បានគិត
សំរេច[ទ]នឹងធ្វើអាក្រក់ដល់ឯង ដោយពាក្យថា ៦ចូរយើង
ឡើងទៅច្បាំងនឹងស្រុកយូដា យើងនឹងធ្វើឱ្យគេមានសេចក្តី
វេទនា ព្រមទាំងទំលាយឱ្យមានផ្លូវចូលបាន រួចយើងនឹង
តាំងស្តេច១ឡើងនៅក្នុងស្រុកគេ គឺជាកូនរបស់តាបបៀល
៧ឯព្រះអម្ចាស់យេហូវ៉ា[ធ] ទ្រង់មានបន្ទូលថា ការនោះមិន
បានទេ គេនឹងធ្វើមិនកើតឡើយ[ន] ៨ដ្បិតក្បាលរបស់ស្រុក
ស៊ីរី គឺក្រុងដាម៉ាស[ប] ហើយក្បាលរបស់ក្រុងដាម៉ាស គឺ
រេស៊ីននេះហើយ[ផ] ក្នុងរវាង៦៥ឆ្នាំ នោះពួកអេប្រាអិមនឹង

ដយ ៥:៦ **៧:៣** ឈ អស ១០:២១–២២ ញ ២ពវ ១៨:១៧ អស ៣៦:២ **៧:៤** ដ អស ៣០:១៥ បទ ៣:២៦ ឋ លប ១៥:១ ចទ ៣:២ អស ៨:១២ ១២:២ ៣៥:៤ ៣៧:៦ មថ ២៤:៦ ឌ ចទ ២០:៣ អស ២១:៤ ឍ អម ៤:១១ សក ៣:២ ណ អស ១០:២៤ ៥១:១៣ ៥៤:១៤ ត ២ពវ ១៥:២៧ **៧:៥** ថ ខ.១ ទ ខ.២ **៧:៧** ធ អស ២៤:៣ ២៥:៨ ២៨:១៦ ន ទដ ២:១ អស ៨:១០ ១៤:២៤ ២៨:១៨ ១៤:២៤ ២៨:១៨ ៤០:៨ ៤៦:១០ កច ៤:២៥ **៧:៨** ប លប ១៤:១៥ ផ ខ.១ អស ៩:១១

**៦:១២** *ទៅឯទីឆ្ងាយ* មើល ៥:១៣ ។

**៦:១៣** *១ភាគក្នុង១០* គឺជាចំណែកដែលត្រូវបាត់ទៅ ។ *ពូជពង្សបរិសុទ្ធ* គឺមានតែចិត្តប៉ុណ្ណោះដែលស្មោះត្រង់ក្នុងរាស្ត្រអ៊ីស្រាអែល (ប្រៀបធៀប ១ពវ ១៩:១៨ មើលការពន្យល់ ១:៩) ។ *គល់ឈើ* ដែលពេលនោះនឹងបានលូតលាស់ម្តងទៀត ។ ការប្រើពាក្យដែលស្រដៀងគ្នានេះដែរចំពោះពាក្យប្រៀបធៀបនេះ សូមមើល ១១:១ និងការពន្យល់ ។

**៧:១–១២:៦** ផ្នែកទី២នៃបទទំនាយរបស់លោកអេសាយ គឺជាឧត្តមគតិនៅក្នុងបទចម្រៀងសរសើរដែលឃើញក្នុងជំពូក ១២ (ប្រៀបធៀបការពន្យល់ ១:១–៦:១៣) ។

**៧:១** ការឈ្លានពានរបស់ពួករេស៊ីននិងពួកពេកា (គឺក្នុងកំឡុងឆ្នាំ ៧៣៥/៧៣៤ មុន គ.ស ) គឺជាសង្គ្រាមមួយដែលមានពួកអេប្រាអិម ។ ពួកអើរ៉ាម (មានស្រុកស៊ីរី)និងអ៊ីស្រាអែល(ពួកអេប្រាអិម សូមមើលការពន្យល់ ខ.២) ដែលព្យាយាមបញ្ចុះបញ្ចូលស្តេចអេហាស ដើម្បីចូលរួមទ័ពប្រឆាំងពួកអាសស៊ើរ ។ ដែលមានចិត្តឈ្លានពានទៅលើស្រុកផ្នែកខាងលិច ។ លោកអេសាយក៏ព្យាយាមការពារស្តេចអេហាសមិនឱ្យចូលរួមជាមួយនិងពួកអាសស៊ើរ (មើល ២ពវ ១៦:៥–១៨ ២រប ២៨:១៦–២១) ។ *ពួកពេកា* បានដឹកនាំក្នុងឆ្នាំ ៧៥២–៧៣២ មុន គ.ស (សូមមើល ២ពវ ១៥:២៧–៣១) ។

**៧:២** *ពួកវង្សដាវីឌ* គឺចង់សំអាងទៅលើអេហាសដែលត្រូវជាខ្សែរាជវង្សរបស់ស្តេចដាវីឌ (មើល ២សយ ៧:៨–១១) ។ អេប្រាអិមដែលគាត់មានឈ្មោះមួយទៀតគឺអ៊ីស្រាអែល គឺនៅនគរផ្នែកខាងជើង ។ *ព្រះទ្រង់មានព្រះទ័យចំប្រប់* ដែលន័យធម្មតាគឺក្តុកក្តួល ។ ស្តេចអេហាសត្រូវបានពួកអើរ៉ាមនិងពួកអ៊ីស្រាអែលពីសម័យមុន (២រប ២៨:៥–៨) ។

**៧:៣** *ស្អា-យ៉ាស៊ូប* សូមមើល ១០:២០–២២ និងការពន្យល់ ។ លោកអេសាយបានដាក់ឈ្មោះឱ្យកូនប្រុសនិមួយៗតាមនាមសម្គាល់របស់គាត់ (មើល ៨:១,៣,១៨) ។ *ប្រឡាយបង្ហូរទឹកមកដល់ស្រះខាងលើ* មើល ៣៦:២ និងការពន្យល់ ។ ស្តេចអេហាសបានផ្តោតទៅលើការរៀបចំស្រះទឹកដើម្បីឧបត្ថម្ភទឹក ។ *ទីវាលជាងប្រមោក* ឯសំលៀកបំពាក់គេបោកគក់ដោយការជាន់ជើងពីលើដោយប្រើទឹកត្រជាក់និងប្រើសាប៊ូមួយប្រភេទ (គឺសូដា) ឬក៏ថ្នាំធ្វើឱ្យស(មើល មឡ ៣:២ និងការពន្យល់ មក ៩:៣) ។

**៧:៤** *កន្ទុយឧសទាំងពីរ* ក្រុងដាម៉ាស (ជារាជធានីរបស់ស្រុកអើរ៉ាម មើល ខ.៨) ក៏បានបំផ្លាញដោយស្តេចទីកឡាត-ពីលសើរ ទី៣ ក្នុងឆ្នាំ ៧៣២ មុន គ.ស និងស្រុកអ៊ីស្រាអែលក៏បានបំផ្លាញក្នុងឆ្នាំតែមួយដែរ ។

**៧:៦** *តាបបៀល* គឺជាឈ្មោះដាក់តាមនៃជាតិសាសន៍អើរ៉ាមវាក៏ជាការទំនាក់ទំនងស្រុកថូបនៅខាងកើតទន្លេយ័រដាន់ (សូមមើល ពច ១១:៣ និងការពន្យល់) ។

**៧:៨** *ក្នុងរវាង៦៥ឆ្នាំ* គឺប្រហែលជា ៦៧០ ឆ្នាំមុន គ.ស ស្តេចអេសារហា

ត្រូវបែកខ្ញែករតាត់រតាយអស់ទៅ[ត] លែងបានពូជពង្សតទៅ
ទៀត ៩ឯក្បាលរបស់ពួកអេប្រាអិម គឺក្រុងសាម៉ារី[ភ] ហើយ
ក្បាលរបស់ក្រុងសាម៉ារី គឺជាកូនរេម៉ាលានេះហើយ បើ
សិនជាឯងមិនព្រម[ម]ជឿទេ[យ] នោះប្រាកដជាឯងមិនបាន
តាំងនៅជាប់ឡើយ[រ] ។
១០ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងអេហាសថា ១១ចូរ
ឯងសូមទីសំគាល់១[ល]ពីព្រះយេហូវ៉ា ជាព្រះនៃឯងចុះ ចូរ
សូម ទោះបើនៅក្នុងទីជិវៅ ឬនៅទីខ្ពស់ខាងលើក្ដី[វ] ១២តែ
អេហាសតបថា យើងមិនព្រមសូមទេ ក៏មិនព្រមល្បងល
ព្រះយេហូវ៉ាឡើយ[ស] ១៣ដូច្នេះ អេសាយទូលថា ឱពូជពង្ស
របស់ដាវីឌអើយ[ហ] ចូរស្ដាប់ឥឡូវចុះ ការដែលអ្នករាល់គ្នា
ធ្វើឱ្យរំខានចិត្តមនុស្ស នោះតើជាការតូចឬអី[ឡ] បានជាចង់
រំខានដល់ព្រះហឫទ័យ[អ]នៃព្រះ[ក]របស់ទូលបង្គំទៀតផង
១៤ដូច្នេះព្រះអម្ចាស់ទ្រង់នឹងប្រទានទីសំគាល់១[ខ]មកអ្នក
រាល់គ្នា ដោយព្រះអង្គទ្រង់ មើល នាងព្រហ្មចារី[គ]នឹង
មានគភ៌ប្រសូតបានបុត្រា១[ឃ] ហើយនឹងឱ្យព្រះនាមថា
អេម៉ាញូអែល[ង] ១៥បុត្រនោះនឹងបរិភោគខ្លាញ់ទឹកដោះ[ច]
ហើយនិងទឹកឃ្មុំ[ឆ] ដរាបដល់ចេះបដិសេធន៍ចោលរបស់
អាក្រក់ ហើយរើសយករបស់ល្អវិញ ១៦ដ្បិតមុនដែលបុត្រ
នោះចេះ[ជ]បដិសេធចោលរបស់អាក្រក់ ហើយរើសយក
របស់ល្អ[ឈ] នោះស្រុករបស់ស្ដេចទាំង២ ដែលឯងខ្ពើមនោះ
នឹងត្រូវចោលស្ងាត់ទៅ[ញ] ១៧ព្រះយេហូវ៉ាទ្រង់នឹងនាំហេតុ
ការ១មកលើឯង លើរាស្ត្រឯង ហើយលើពួកវង្សរបស់
ឪពុកឯង គឺជាស្ដេចស្រុកអាសស៊ើរ[ដ] ជាការដែលមិនបាន
កើតមាន ចាប់តាំងពីគ្រាដែលអេប្រាអិមបែកចេញ[ឋ]ពីពួក
យូដាមក ។
១៨នៅគ្រានោះ[ឌ] ព្រះយេហូវវ៉ានឹងហួច[ឍ]ហៅរុយ ដែល
នៅទីឆ្ងាយបំផុតនៃទន្លេស្រុកអេស៊ីព្ទ ព្រមទាំងឃ្មុំដែលនៅ

**៧:៨** ត ២ពវ ១៧:២៤ អស ៨:៤ ១៧:១–៣ **៧:៩** ភ ២ពវ ១៥:២៩ អស ៩:៩ ២៨:១,៣ ម ទដ ២០:៨ អស ៨:១០ ៤០:៨ យ ២រប ២០:២០ រ អស ៨:៦–៨ ៣០:១២–១៤ **៧:១១** ល នក ៧:៩ ចទ ១៣:២ វ ទដ ១៣៩:៨ **៧:១២** ស ចទ ៤:៣៤ **៧:១៣** ហ ខ.២ ឡ លប ៣០:១៥ អ អស ១:១៤ ក ទដ ៦៣:១ ១១៨:២៨ អស ២៥:១ ៤៩:៤ ៦១:១០ **៧:១៤** ខ នក ៣:១២ លក ២:១២ គ លប ២៤:៤៣ ឃ លប ៣:១៥ លក ១:៣១ ង លប ២១:២២ អស ៨:៨,១០ មថ ១:២៣ **៧:១៥** ច លប ១៨:៨ ឆ ខ.២២ **៧:១៦** ជ អស ៨:៤ ឈ ចទ ១:៣៩ ញ ចទ ១៣:១៦ អស ១៧:៣ យរ ៧:១៥ ហស ៥:៩,១៣ អម ១:៣–៥ **៧:១៧** ដ ខ.២០ ២រប ២៨:២០ ឋ ១ពវ ១២:១៦ **៧:១៨** ឌ ខ.២០,២១ អស ២:១១ ឍ អស ៥:២៦

ដោន (និងក្នុងពេលចប់បន្ទាប់ពីស្ដេចនេះ គឺមានស្ដេចស្រុកអាសស៊ើរបានដាក់ជាអាណានិគមក្នុងអ៊ីស្រាអែល ។ ពួកគេនោះក៏បានរៀបការជាមួយសាសន៍អ៊ីស្រាអែលជាច្រើន ។ យើងឃើញលទ្ធផលដែលមានក្នុងសាសន៍ស្រុកសាម៉ារី (សូមមើល ២ពវ ១៧:២៤–៣៤ និងការពន្យល់ ១៧:២៩) ក្រោយមកក៏មានការបែកបាក់ជាតិសាសន៍ ។

**៧:៩** *គឺជាកូនរេម៉ាលានេះហើយ* ពេកាដែលជាអ្នកដណ្ដើមអំណាច ហើយក៏បញ្ចុះបញ្ចូលស្ដេចអេហាសជាបុត្រារបស់ស្ដេចដាវីឌដែរ ។ ស្រុកអើរ៉ាម (ខ.៨) និងស្រុកអ៊ីស្រាអែល (ខ.៩) គឺមានក្បាលមនុស្សឯសាសន៍យូដាមានក្បាលពីព្រះវិញ្ញាណ គឺព្រះទ្រង់គង់ជាមួយពួកគេ (ខ.១៤ ៨:៨,១០) *តាំង . . . នៅជាប់* គឺមានលក្ខណៈដូចជាព្រះគម្ពីរភាសាហេព្រើរ ដែលព្រះបានប្រមាន (សូមមើល ១:១៩–២០,២៥ និងការពន្យល់) ។

**៧:១១** *ទីសំគាល់១* ព្រះយេហូវ៉ាមានព្រះទ័យពង្រឹងសេចក្ដីជំនឿរបស់អេហាសតាមរយៈទីសម្គាល់ (សូមមើល នក ៣:១២ និងការពន្យល់) ។

**៧:១៣** *ឱពូជពង្សរបស់ដាវីឌអើយ* សូមមើលការពន្យល់ ខ.២ ។

**៧:១៤** *ទីសំគាល់* ជាធម្មតាត្រូវសម្រេចក្នុងរយៈពេលពីរបីឆ្នាំក្រោយមក (សូមមើល ៣៧:៣០ ២០:៣ ប្រៀបធៀប ៨:១៨) ។ *នាងព្រហ្មចារី* គឺសំដៅទៅលើស្ត្រីក្មេងៗ ដែលបានភ្ជាប់ពាក្យ និងអេសាយរួចហើយ (៨:៣) គឺជាអ្នកដែលត្រូវជាប្រពន្ធចុងរបស់ស្ដេចនោះ (ដោយប្រពន្ធដើមបានស្លាប់បន្ទាប់ពីស្អា–យ៉ាស៊ូបបានប្រសូត) ។ ក្នុង លប ២៤:៤៣ ក៏ដូចជាព្រះគម្ពីរភាសាហេព្រើរបញ្ចេញសំឡេងថា "អលម៉ាហ" ដែលសំដៅទៅលើស្ត្រីដែលជិតរៀបមង្គលការ (មើល សភ ៣០:១៩) ។ មថ ១:២៣ ធ្វើឱ្យយើងយល់ពីលក្ខណៈស្ត្រី ដែលបង្ហាញនៅទីនេះអំពីប្រភេទ (គឺប្រាប់ឱ្យដឹងជាមុន) នៃលក្ខណៈការរៀបការដោយភាពបរិសុទ្ធ ។ *អេម៉ាញូអែល* គឺមានន័យថា "ព្រះអង្គគង់ជាមួយយើង" គឺមានន័យទៀតថាអេហាស គឺមានព្រះអាចជួយសង្គ្រោះលោក បានពីសត្រូវរបស់លោក ។ មើល ជន ១៤:៩ ២រប ១៣:១២ ទដ ៤៦:៧ ។ បើជាព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យ "អេម៉ាញូអែល" ដែលបានប្រើក្នុងគម្ពីរ ៨:៨,១០ ហើយក៏អាចមានន័យមួយទៀតដែលបញ្ចេញសំឡេង "ម៉ាស៊ីសាឡាហាស–បាស"សម្រេចនូវទំនាយដោយព្រោះទ្រង់មាន "ព្រះគង់ជាមួយ"ដែលជាអត្ថន័យពេញ (មថ ១:២៣ ប្រៀបធៀប អស ៩:៦–៧) ។

**៧:១៥** *ខ្លាញ់ទឹកដោះហើយនឹងទឹកឃ្មុំ* ខ្លាញ់ទឹកដោះ (គឺជាប្រភេទទឹកដោះជូរម្យ៉ាង) និងទឹកឃ្មុំមានន័យថា គឺជាការទទួលទានអាហារ ដ៏សាមញ្ញមួយគឺខណៈដែលគេរស់នៅដាច់ឆ្ងាយពីភូមិ ។ ដោយពួកអាសស៊ើរបានឈ្លានពាននិងបំផ្លាញទីជនបទចោល ទើបធ្វើឱ្យវិស័យកសិកម្មត្រូវស្ទះសកម្មភាព (សូមមើល ខ.២២–២៥) ។ *ដរាបដល់ចេះបដិសេធន៍ចោលរបស់អាក្រក់ ហើយរើសយករបស់ល្អវិញ* គឺជាសេចក្ដីធានារ៉ាប់រងនឹងសេចក្ដីសម្រេចដែលអាចធ្វើទៅបាន គឺស្ថិតនៅក្រោមច្បាប់ ។ ក្នុងការដែលគាត់ទទួលទានខ្លាញ់ទឹកដោះ និងទឹកឃ្មុំជំនួសផលិតផលកសិកម្ម គឺព្រោះតែពួកអាសស៊ើរបានឈ្លានពានស្រុកអ៊ីស្រាអែលបំផ្លាញខ្ទេចខ្ទីអស់ មើល ខ.១៦ និង ៨:៤ ។

**៧:១៦** *ដ្បិតមុនដែលបុត្រនោះចេះបដិសេធន៍ចោលរបស់អាក្រក់ ហើយរើសយករបស់ល្អ* មើលការពន្យល់ ខ.៤ ប្រៀប ៨:៤ "មុន"គឺជារយៈពេល ១២ ឬ ១៣ ឆ្នាំគឺស្រុកអើរ៉ាមនិងស្រុកអ៊ីស្រាអែលត្រូវបានគេប្លន់បំផ្លាញបង់ ។ ការងារនេះបានកើតឡើងក្នុងឆ្នាំ ៧៣២ មុន គ.ស ខណៈពេលក្មេងប្រុសនោះមានអាយុប្រហែលពីរឆ្នាំ ។

**៧:១៧** *អេប្រាអិមបែរចេញពីពួកយូដាមក* គឺមានរយៈពេលពីរសតវត្ស (មើល ១ពវ ១២:១៩–២០) ។ *ស្ដេចស្រុកអាសស៊ើរ* ឯស្ដេចអេហាសបានលេចមកឯស្រុកអាសស៊ើរ ក៏នាំឱ្យមានសន្តិភាពបណ្ដោះអាសន្នក្នុងប្រជាជាតិ (២ពវ ១៦:៨–៩) តែជាអកុសលមួយដែលពួកអាសស៊ើរបានវាយប្រហារដល់ស្រុកយូដា (មើល ៨:៧–៨ ៣៦:១ និងការពន្យល់) ។

**៧:១៨** *រុយ . . . ឃ្មុំ* សូមមើល នក ២៣:២៨ និងការពន្យល់ ។

ស្រុកអាសរសេីរផង[ណ] ១៩នោះវានឹងនាំគ្នាមកទំនៅក្នុង
ច្រកភ្នំដែលត្រូវចោលស្ងាត់ នៅក្នុងក្រហែង[ត]ថ្ម នៅលើ
គ្រប់ទាំងរបងបន្លា[ថ] ហើយនៅអស់ទាំងវាលស្មៅផង ។
២០នៅគ្រានោះ[ទ]ព្រះអម្ចាស់ ទ្រង់នឹងកោរ[ធ]សក់ក្បាល
និងរោមជើងផង ដោយកាំបិតដែលបានជួលពីទីនៅត្រើយ
ខាងនាយទន្លេ[ន] គឺដោយស្តេចនៃស្រុកអាសសេីរ[ប] ហើយ
កាំបិតនោះនឹងរំលាងទាំងពុកចង្កា[ផ]ផង[ព]។
២១នៅគ្រានោះ[ភ] មនុស្សម្នាក់នឹងចិញ្ចឹមគោញី១ និង
ចៀម២[ម] ២២ហើយដោយព្រោះសត្វទាំនោះមានទឹកដោះ
ជាបរិបូរ បានជាអ្នកនោះនឹងបរិភោគខ្លាញ់ទឹកដោះ ដ្បិត
ពួកអ្នកដែលនៅសល់ក្នុងស្រុកគេ នឹងបានខ្លាញ់ទឹកដោះ[យ]
និងទឹកឃ្មុំបរិភោគគ្រប់គ្នា[រ] ។
២៣ហើយនៅគ្រានោះ[ល]គ្រប់ទីកន្លែងណា ដែលពីដើម
មានចំការទំពាំងបាយជូរចំនួន១ពាន់ដើម មានដំឡៃជា
ប្រាក់១ពាន់រៀល[វ] នោះនឹងបានជាទីសំរាប់អញ្ចាញ និង
បន្លាវិញ[ស] ២៤ឯអ្នកណាដែលចូលទៅក្នុងទីនោះ នឹងត្រូវ
កាន់ព្រួញនិងធ្នូផង ដ្បិតស្រុកទាំងមូលនឹងដុះ សុទ្ធតែ
អញ្ចាញ[ហ] និងបន្លា ២៥ឯងក៏នឹងមិនឡើងទៅលើទីទួល[ឡ]
ដែលពីដើមមានគេកាប់គាស់ដោយចបដែរ ដោយខ្លាច
អញ្ចាញនិងបន្លា[អ] ទីនោះនឹងបានសំរាប់ជាទីលែងហ្វូងគោ
ហើយសំរាប់ឱ្យហ្វូងចៀមញាំញីទៅប៉ុណ្ណោះ[ក]។

**៧:១៨** ណ អស ១៣:៥
**៧:១៩** ត អស ២:១៩ ថ ខ.២៥ អស ១៧:៩ ៣៤:១៣ ៥៥:១៣
**៧:២០** ទ ខ.១៨ ធ អស ១០:១៥ ២៩:១៦ ន អស ១១:១៥ យរ ២:១៨ ប ខ.១៧ ២ពវ ១៨:១៦ អស ៨:៧ ១០:៥ ផ ២សយ ១០:៤ ព ចទ ២៨:៤៩
**៧:២១** ភ ខ.២៣ អស ២:១៧ ម យរ ៣៩:១០
**៧:២២** យ លប ១៨:៨ រ ខ.១៥ អស ១៤:៣០
**៧:២៣** ល ខ.២១ វ អស ៨:១១ ស អស ៥:៦ ហស ២:១២
**៧:២៤** ហ អស ៥:៦
**៧:២៥** ឡ ហក ១:១១ អ ខ.១៩ ក អស ៥:១៧

## សាសន៍អាសសេីរជាឧបករណ៍នៃព្រះអម្ចាស់

**៨** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំថា ចូរយកក្តារ
ឈ្នួន១ធំ[ក] ហើយសរសេរជាអក្សររបស់មនុស្សថា ការ
រឹបជាន់ជិតណាស់ហើយ គេរួតរះមកចាប់រំពា[ខ] ២ហើយ
អញនឹងយកស្មរបន្ទាល់ស្មោះត្រង់[គ] គឺអ៊ូរី[ឃ] ជាសង្ឃ នឹង
សាការី ជាកូនបេរេគា ដើម្បីកត់សេចក្តីទុក ៣រួចមកខ្ញុំ
បានចូលទៅឯហោរាស្រី[ង] ជាប្រពន្ធខ្ញុំ ហើយនាងមាន
ទំងន់បង្កើតបានកូនប្រុស១[ច] នោះព្រះយេហូវ៉ាទ្រង់មាន
បន្ទូលមកខ្ញុំថា ចូរឱ្យឈ្មោះកូននេះថា ម៉ាហេ–សាឡាល–
ហាសបាស[ឆ] ៤ដ្បិតមុនដែលកូននេះចេះ[ជ]ហៅថា ឱអើយ
ម៉ែអើយ នោះគេនឹងដឹកយកទ្រព្យសម្បត្តិរបស់ក្រុង
ដាម៉ាស[ឈ] ហើយនិងរបឹបនៅស្រុកសាម៉ារី នាំទៅនៅ
ចំពោះស្តេចស្រុកអាសសេីរហើយ[ញ]។
៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំទៀតថា ៦ដោយ
ព្រោះសាសន៍នេះ គេមិនព្រម[ដ]យកទឹកស៊ីឡោម[ឋ] ដែលហូរ
គ្រឿនៗ តែមានសេចក្តីរីករាយចំពោះរេស៊ីន ហើយនិង
កូនរបស់រេម៉ាលាវិញ[ឌ] ៧នោះមើល ព្រះអម្ចាស់ទ្រង់នាំទឹក

**៨:១** ក ចទ ២៧:៨ យប ១៩:២៣ អស ៣០:៨ យរ ៥១:៦០ ខ ខ.៣ ហព ២:២ យរ ២០:៣ ហស ១:៤ **៨:២** គ ខ.១៦ យស ២៤:២២ នរ ៤:៩ យរ ៣២:១០,១២, ២៥,៤៤ ឃ ២ពវ ១៦:១០ **៨:៣** ង នក ១៥:២០ ច លប ៣:១៥ ឆ ខ.១ **៨:៤** ជ អស ៧:១៦ ឈ លប ១៤:១៥ ញ អស ៧:៨ **៨:៦** ដ អស ៥:២៤ ឋ នហ ៣:១៥ យហ ៩:៧ ឌ អស ៧:១

**៧:១៩** *ក្នុងក្រហែងថ្ម* មើលការពន្យល់ ២:១០ គឺពុំមានលទ្ធភាពគេចឱ្យរួចពីដៃរបស់អ្នកឈ្លានពានទេ ។

**៧:២០** *កោរសក់ក្បាល . . . រោមជើង . . . ពុកចង្កា* គឺជាការបង្ខំជាខ្លាំងដែលគេគិតថាវាជាការប្រមាថ (សូមមើល ១០:៤ និងការពន្យល់) រោមជើងពាក្យនេះតាមធម្មតាគេហៅថាមមីស ។

**៧:២៣** *អញ្ចាញ និងបន្លា* មើលការពន្យល់ ៥:៦ ។ គឺជាការបំផ្លាញចំការទំពាំងបាយជូរនិងដីស្រែ ដែលនឹងត្រូវសម្រេច ៥:៥–៦ ។

**៨:១–២** *ក្តារឈ្នួន១ធំ . . . ស្មរបន្ទាល់* គឺសាក្សីបញ្ជាក់ពីក្បួនដ៏ស្របច្បាប់ទៅលើការរៀបអាពាហ៍ពិពាហ៍របស់ប្រជាជនអ៊ីស្រាអែល (មើលការពន្យល់ ៧:១៤) ម៉ាហេ–សាឡាល–ហាសបាស ។ ពាក្យព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យ "ក្តារឈ្នួន"ក៏ទាក់ទងនិងពាក្យ១មានអត្ថន័យថានៅក្នុង យរ ៣២:១១ ។

**៨:២** *គឺអ៊ូរីជាសង្ឃ* ជាសង្ឃដែលបម្រើឱ្យស្តេចអេហាស (មើល ២ពវ ១៦:១០–១១) ។

**៨:៣–១០** មើល ៧:១៤–១៧ និងការពន្យល់ ។

**៨:៣** *ហោរាស្រី . . . បានកូនប្រុស១* វាអាចជាការសម្រេចនូវទំនាយដូចក្នុងគម្ពីរ ៧:១៤ ស្ត្រីក្មេងដែលគេហៅថាជាហោរាព្រោះនាងជាភរិយារបស់ហោរា ។ *ម៉ាហេ–សាឡាល–ហាសបាស* ជាឈ្មោះជាសេចក្តីសញ្ញា (មើលការពន្យល់ ខ.១) ក៏ចង់មានន័យថាសត្រូវរបស់ស្តេចអេហាសនិងត្រូវបានបំផ្លាញបង់ (មើល ខ.៤ និងការពន្យល់ ៧:៤) ក៏ជាការលាតត្រដាងពីសាសន៍យូដាដែលត្រូវទទួលការឈឺចាប់ (មើល ខ.៧–៨) ។

**៨:៤** *ចេះហៅថា* គឺជាសំដីកូនក្មេងមានអាយុពីរឆ្នាំ ។ រយៈពេលនៃពេលវេលាជាសេចក្តីសញ្ញាដែលបញ្ជាក់ក្នុងគម្ពីរ ៨:១៦ (ឬមើលការពន្យល់ ៧:៤,១៦) ។ *គេនឹងដឹកយកទ្រព្យសម្បត្តិរបស់ក្រុងដាម៉ាស ហើយនឹងរបឹបនៅស្រុកសាម៉ារីនាំទៅនៅចំពោះ* គឺជាដំណាក់ការទីមួយចំពោះការខូចខាតរបស់នគរខាងជើង (សូមមើលការពន្យល់ ៧:៤) មិនទាន់ចប់ទេវាបន្តរហូតដល់ឆ្នាំ ៧២២–៧២១ មុន គ.ស (មើលការពន្យល់ ៧:១៥) ។

**៨:៦** *ទឹកស៊ីឡោម* សូមមើលការពន្យល់ នហ ៣:១៥ ។ គឺជាទឹកស្ទឹងក្នុងក្រុងយេរូសាឡិមដែលហូរពីជ្រោះគីហុន បង្ហូរតម្រង់ចុះទៅក្នុងស្រះស៊ីឡោម (មើល ២រប ៣២:៣០) ឬក៏មើល (យហ ៩:៧ និងការពន្យល់) ។ នេះហើយជាសញ្ញាមួយដែលបានទទួលពីព្រះយេហូវ៉ា ។ *រេស៊ីនហើយនិងកូនរបស់រេម៉ាលាវិញ* ឯរេស៊ីនហើយនិងពេកាពួកគេទាំងពីរនាក់បានទទួលមរណៈភាពក្នុងឆ្នាំ ៧៣២ មុន គ.ស (មើល ២ពវ ១៦:៩ មើលការពន្យល់ អស ៧:១) ។

**៨:៧–៨** *ទន្លេដែលហូរខ្លាំងហើយច្រើនមកលើគេ . . . សាយចូលទៅក្នុង* ជាទន្លេដ៏អឹកធឹកដែលប្រើជាសញ្ញានូវអំណាចខ្លាំងក្លា ពីកងទ័ពឈ្លានពាន ។

ទន្លេដែលហូរខ្លាំងហើយច្រើន[ល]មកលើគេ គឺជាស្តេចស្រុក
អាសស៊ើរ[ណ] និងឫទ្ធានុភាពទាំងប៉ុន្មានរបស់ទ្រង់[ត] ទន្លេ
នោះនឹងហូរចេញតាមគ្រប់ទាំងព្រែក ហើយលិចច្រាំង
ទាំងអស់[ថ] [៨]ក៏នឹងសាយចូលទៅក្នុងស្រុកយូដាដែរ ព្រម
ទាំងលិច[ទ] ហូរកាត់ស្រុកឡើងត្រឹមក ហើយនិងជន់រាប[ធ]
ពេញស្រុករបស់ឯង ឱអេម៉ាញូអែលអើយ[ន]។
[៩]ឱជនជាតិទាំងឡាយអើយ ចូរស្រែកសន្ធាប់ចុះ[ប] គង់
តែឯងរាល់គ្នានឹងត្រូវបាក់បែកខ្ទេចខ្ទីវិញ[ផ] នែ អស់ទាំង
ស្រុកដែលនៅឆ្ងាយៗអើយ ចូរផ្ទៀងត្រចៀកស្តាប់ចុះចូរ
ក្រវាត់ចង្កេះខ្លួន[ព]ដែរ នោះឯងនឹងត្រូវបាក់បែកខ្ទេចខ្ទីចូរ
ក្រវាត់ ចង្កេះចុះ នោះឯងនឹងត្រូវបាក់បែកខ្ទេចខ្ទីទៅ
[១០]ចូរប្រឹក្សាគ្នា នោះការសិរេចរបស់ឯងនឹងត្រូវសាបសូន្យ
ទៅ[ភ] ចូរចេញវាចាចុះ តែពាក្យសំដីនោះនឹងមិនស្ថិតស្ថេរ
នៅឡើយ[ម] ដ្បិតព្រះទ្រង់គង់នៅខាងយើងហើយ[យ]។

## កោតខ្លាចព្រះ

[១១]ឯព្រះយេហូវ៉ាទ្រង់មានបន្ទូលមក ដោយព្រះហស្ត
សង្កត់លើខ្ញុំជាខ្លាំង[រ] ទ្រង់ដាស់តឿនខ្ញុំមិនឱ្យដើរតាម[ល]ផ្លូវ
របស់ជនជាតិនេះ ដោយថា [១២]កុំឱ្យឯងថា មានការក្បត់[វ]
ក្នុងគ្រប់ទាំងការដែលជនជាតិនេះថា មានការក្បត់នោះ
ឡើយ ក៏កុំឱ្យភ័យខ្លាចចំពោះការដែលគេភ័យខ្លាចដែរ[ស]
កុំឱ្យតក់ស្លុតឱ្យសោះ[ហ] [១៣]ត្រូវឱ្យរាប់ព្រះយេហូវ៉ានៃពួក
ពលបរិវារទុកជាបរិសុទ្ធ[ឡ] ព្រមទាំងយកទ្រង់ជាទីភ័យ
ខ្លាច[អ] ហើយតក់ស្លុតវិញ[ក] [១៤]នោះទ្រង់នឹងបានសំរាប់ជាទី
បរិសុទ្ធ[ខ] តែជាថ្ម[គ]ចំពប់ ហើយជាថ្មដាដែលបង្អាក់បង្អន់
ចិត្ត[ឃ]ដល់ពួកអ៊ីស្រាអែលទាំង២វង្ស[ង] ហើយជាអន្ទាក់នឹង
ជាជង់ដល់ពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់[ច] [១៥]មនុស្ស
ជា ច្រើននឹងចំពប់នឹងថ្មនោះ[ឆ] ហើយដួលទៅ ព្រមទាំងត្រូវ
បាក់បែក ជាប់អន្ទាក់ ហើយចាប់បានផង [១៦]ចូរចងសេចក្តី
បន្ទាល់[ជ]ទុក ហើយបិទត្រា[ឈ]បញ្ញត្តិច្បាប់នៅក្នុងពួកសិស្ស
របស់អញចុះ [១៧]ឯខ្ញុំៗនឹងទន្ទឹងចាំ[ញ]ព្រះយេហូវ៉ា ដែល
ទ្រង់លាក់ព្រះភក្ត្រ[ដ]នឹងពូជពង្សយ៉ាកុប ខ្ញុំនឹងចាំមើល តែ
ទ្រង់[ឋ] [១៨]មើល ខ្ញុំហើយនិងកូនដែលព្រះយេហូវ៉ាបាន
ប្រទានមកខ្ញុំ យើងខ្ញុំ[ឌ]សំរាប់ជាទីសំគាល់[ឍ] មកពីព្រះយេ–
ហូវ៉ានៃពួកពលបរិវារ ដែលទ្រង់គង់នៅភ្នំស៊ីយ៉ូន ហើយ
ជាទីអស្ចារ្យ[ណ] នៅក្នុងពួកអ៊ីស្រាអែល[ត]។

**៨:៧** ល អស ១៧:១២–១៣ ២៨:២,១៧ ៣០:២៨ ៤៣:២ ដយ ១១:៤០ ណ ហ ១:៨ ណ ២រប ២៨:២០ អស ៧:២០ ត អស ១០:១៦ ថ យស ៣:១៥ **៨:៨** ទ អស ២៨:១៥ ធ អស ១៨:៦ ៤៦:១១ យរ ៤:១៣ ៤៨:៤០ ន អស ៧:១៤ **៨:៩** ប យស ៦:៥ អស ១៧:១២–១៣ ផ យប ៣៤:២៤ ព យរ ៦:៤ ៤៦:៣ ៥១:១២,២៧–២៨ អគ ៣៨:៧ យអ ៣:៩ សក ១៤:២–៣ **៨:១០** ភ យប ៥:១២ ម សភ ១៩:២១ ២១:៣០ អស ៧:៧ យ អស ៧:១៤ មថ ១:២៣ រម ៨:៣១ **៨:១១** រ អគ ១:៣ ៣:១៤ ល អគ ២:៨

**៨:១២** វ អស ៧:២ ២០:៥ ៣០:១ ៣៦:៦ ស អស ៧:៤ មថ ១០:២៨ ហ ១ពត ៣:១៤ **៨:១៣** ឡ ជណ ២០:១២ អ នក ២០:២០ ក អស ២៩:២៣ **៨:១៤** ខ អស ៤:៦ គ ទដ ១១៨:២២ ឃ យរ ៦:២១ អគ ៣:២០ ១៤:៣,៧ លក ២០:១៨ ង លក ២:៣៤ រម ៩:៣៣ ១ពត ២:៨ ច ទដ ១១៩:១១០ អស ២៤:១៧–១៨ **៨:១៥** ឆ សក ៤:១៩ អស ២៩:១១–១២ យរ ៣២:១៤ ដយ ៨:២៦ ១២:៤ **៨:១៦** ជ រន ៤:៧ ឈ អស ២៩:១១–១២ យរ ៣២:១៤ ដយ ៨:២៦ ១២:៤ **៨:១៧** ញ ទដ ២៧:១៤ ដ ចទ ៣១:១៧ ឋ ទដ ២២:៥ ហព ២:១៣ **៨:១៨** ឌ លប ៣៣:៥ ហព ២:១៣ ឍ នក ៣:១២ អគ ៤:៣ ១២:៦ ២៤:២៤ លក ២:៣៤ ណ ទដ ៩:១១ ត ចទ ២៨:៤៦ អគ ១២:១១

(សូមមើល ១៧:១២ និងការពន្យល់ ២៨:១៧–២៩) ។

**៨:៨** *លិចហូរកាត់ស្រុកហូរដល់ត្រឹមក* មើល ៣០:២៨ និងការពន្យល់ ។ ការឈ្លានពានលុកលុយរបស់ស្តេចសានហេរីប ជាស្តេចស្រុកអាសស៊ើរក្នុងឆ្នាំ ៧០១ មុន គ.ស នៅគ្រប់ទីកន្លែងនៅក្នុងស្រុកយូដា (ប្រៀបធៀបចំពោះអត្ថបទយោងដំបូងចំពោះក្រុងដាម៉ាសនិងស្រុកសាម៉ារីគឺក្នុងជំពូក ៧:៨–៨) ក៏មានជាខ្យល់ជំនោរខ្លាំងៗ ។ ក៏ជាការប្រែប្រួលចំពោះបក្សីដែលគេរកប្រមាញ់ ។ *ឱអេម៉ាញូអែលអើយ* គឺគ្រប់ទាំងអស់ដូចជាបាត់បង់ទៅតែ "ព្រះអង្គទ្រង់គង់ជាមួយយើង" (ខ.១០) ហើយក៏បំផ្លាញសត្រូវ (មើលការពន្យល់ ៧:១៤) ។

**៨:៩** *ឱជនជាតិទាំងឡាយអើយ . . . បាក់បែកខ្ទេចខ្ទីវិញ* គឺដូចខណៈពេលពួកស្រុកអើរ៉ាមនិងពួកអ៊ីស្រាអែល និងត្រូវបាក់បែកខ្ទេចខ្ទី (៧:៧–៩) ក៏ដូចជាពួកអាស៊ើរ និងពួកបាប៊ីឡូនដែរនិងត្រូវដួលរលំចុះ ។

**៨:១០** *នឹងមិនស្ថិតស្ថេរនៅឡើយ* គឺមានតែផែនការរបស់ព្រះអម្ចាស់ និងគោលបំណងព្រះទ័យដែលស្ថិតស្ថេរបាន ។ *ព្រះទ្រង់គង់នៅខាងយើងហើយ* សូមមើលការពន្យល់ ២រប ១៣:១២ ។

**៨:១១** *ព្រះហស្តសង្កត់លើខ្ញុំជាខ្លាំង* សូមមើល អគ ១:៣ និងការពន្យល់ ៣៧:១ ៤០:១ ។

**៨:១២** ព្រះយេហូវ៉ាប្រមានដល់រាស្ត្ររបស់ផងទ្រង់ គឺមិនឱ្យទុកចិត្តផ្អែកទៅលើពួកអាសស៊ើរឡើយ (មើលការពន្យល់ ៧:១) ។

**៨:១៣** *យកជាទីភ័យ* សូមមើល ៧:២ ១:៧ និងការពន្យល់ ។

**៨:១៤** *ជាទីបរិសុទ្ធ . . . ជាថ្មចំពប់* សូម្បីតែព្រះយេហូវ៉ាគឺជាថ្មជ្រុងឯកនៃជីវិតរបស់យើង (សូមមើល ២៨:១៦) ឬទ្រង់គឺជាថ្មដែលយើងចំពប់ ។ មើល រម ៩:៣៣ ១ពវ ២:៦ និងការពន្យល់ នៃការអនុវត្តចំពោះព្រះគ្រីស្ទ ។ *ទាំងពីរវង្ស* គឺជាផ្នែកនគរខាងជើងនិងខាងត្បូង គឺសាសន៍អ៊ីស្រាអែលនិងសាសន៍យូដា ។

**៨:១៦** គឺប្រហែលជាសំដៅទៅលើបញ្ញត្តិច្បាប់ទាក់ទងទៅនឹង ខ.១–២ (សូមមើលការពន្យល់នៅទីនោះ) ។ *សេចក្តីបន្ទាល់ទុក* សូមមើល ខ.២០ ។ ក៏មានឃើញពាក្យនេះនៅកន្លែងខ្លះទៀតដូចជានៅ នរ ៤:៧ (ដែលបង្ហាញពីបញ្ញាត្តច្បាប់) ។ *ច្បាប់* មើល ខ.២០ ក្នុងព្រះគម្ពីរភាសាហេព្រើរក៏មានន័យថា "ការបង្រៀន" ឬ "សេចក្តីណែនាំ" ។ ដែលជាឯកសារបង្រៀនរបស់លោកអេសាយ បង្រៀនអំពីការឈ្លានពានរបសប់ពួកអាសស៊ើរក៏ត្រូវបានចង ក្រងបិតត្រាហើយក៏ប្រគលឱ្យអ្នកដើរតាមពួកហោរាដើម្បីបំរុងរហូតដល់ពេលវេលានៃការសម្រេចបានមកដល់ ។ គឺខណៈពេលព្រះទ្រង់បញ្ជាក់ការពិត ពីព្រឹត្តការជាប្រវត្តិសាស្ត្រ (មើល យរ ៣២:១២–១៤,៤៤) ។

**៨:១៧** *ទ្រង់លាក់ព្រះភក្ត្រ* មើលការពន្យល់ ១:១៥ ៥៩:២ មីក ៣:៤ និងការពន្យល់ ។

**៨:១៨** *ជាទីសំគាល់* មើលការពន្យល់ ៧:៣,១៤ ប្រៀបធៀប ២០:៣ ។

១៩ កាលបើអ្នកណាពោលដល់ឯងថា ចូររក[ថ]ពួកគ្រូខាប
និងគ្រូគាថា[ទ] ដែលចេញសំឡេងអ៊ិអ៊ុ ហើយងុមៗ[ធ] នោះត្រូវ
ឆ្លើយថា គួរគប្បីឱ្យបណ្តាជនស្វែងរក[ន]ព្រះរបស់ខ្លួនវិញ
តើនឹងរកចំពោះរូបខ្មោចជាប្រយោជន៍ដល់មនុស្សរស់ធ្វើអ្វី
២០ ចូរទៅបើកគម្ពីរបញ្ញត្តិ[ប] និងសេចក្តីបន្ទាល់[ផ]មើល បើគេ
និយាយមិនត្រូវនឹងព្រះបន្ទូលនោះ នោះគ្មានពន្លឺ[ព]រះឡើង
នៅក្នុងខ្លួនទេ ២១ គេនឹងដើរចុះឡើងក្នុងស្រុក[ភ] មានទាំងទុក្ខ
វេទនា ហើយស្រេកឃ្លាន[ម] កាលណាគេស្រេកឃ្លាន នោះ
នឹងមានចិត្តក្តៅក្រហាយ ហើយនឹងប្រទេចផ្តាសា[យ]ដល់
ទាំងស្តេច និងព្រះរបស់ខ្លួន ដោយងើយមើលទៅលើមេឃ
ផង ២២ រួចងាកមើលទៅផែនដីឃើញមានសុទ្ធតែសេចក្តី
លំបាក សេចក្តីងងឹត និងឈ្លប់សូន្យសុងគ្របសង្កត់ ដោយ
វេទនាចិត្ត[រ] ហើយនឹងត្រូវបណ្តេញទៅក្នុងសេចក្តីងងឹត
យ៉ាងក្រាស់[ល] ។

## បុត្រមួយអង្គបានប្រសូត្រដល់យើង

**៩** ១ ប៉ុន្តែសេចក្តីឈប់សូន្យសុង[ក] និងមិននៅលើស្រុក ដូច
នៅគ្រាដែលមានសេចក្តីវេទនាចិត្តនោះទេ កាលពីដើម
ទ្រង់បានធ្វើឱ្យស្រុកសាប់យូល៉ូន និងស្រុកណែបថាលី[ខ]
ត្រូវគេមើលងាយ តែនៅជាន់ក្រោយទ្រង់នឹងធ្វើឱ្យរុងរឿង
ឧត្តមវិញ គឺជាស្រុកតាមផ្លូវទៅឯសមុទ្រត្រើយខាងនាយ
ទន្លេយ័រដាន់ ជាដែនខេត្តកាលីឡេរបស់សាសន៍ដទៃ ២ ឯ
បណ្តាជនដែលដើរក្នុងសេចក្តីងងឹត[គ] គេបានឃើញពន្លឺ
យ៉ាងធំ[ឃ] ពួកអ្នកដែលអាស្រ័យនៅក្នុងស្រុកនៃម្លប់សេចក្តី
ស្លាប់[ង] គេមានពន្លឺភ្លឺមកលើគេហើយ[ច] ៣ ទ្រង់បានប្រោស
ឱ្យបណ្តាជនចំរើនឡើង[ឆ] ហើយបានធ្វើឱ្យគេមានសេចក្តី
រីករាយជាច្រើនឡើងដែរ[ជ] គេមានសេចក្តីអំណរនៅ
ចំពោះទ្រង់ ដូចជាសេចក្តីអំណរ ក្នុងរដូវចំរូត ហើយដូច
ជាសេចក្តីអំណរនៃមនុស្ស ដែលកំពុងតែចែករបឹបគ្នា[ឈ]
៤ ដ្បិត ទ្រង់បានបំបាក់[ញ]នឹម[ដ]ដែលសង្កត់លើគេ នឹងដង្រែក
នៅស្មាគេ[ឋ] ហើយដំបងរបស់ពួកអ្នកដែលសង្កត់សង្កិនគេ
ផង[ឌ] ដូចជានៅគ្រានៃពួកសាសន៍ម៉ាឌានដែរ[ឍ] ៥ ពីព្រោះ
គ្រប់ទាំងស្បែកជើងរបស់ពួកទាហាន ក្នុងចំបាំងយ៉ាង
អឺកធឹក ហើយសំលៀកបំពាក់ប្រឡាក់ជោកដោយឈាម
នោះនឹងបានសំរាប់ដុត[ណ] ហើយជាចំណីដល់ភ្លើង ៦ ដ្បិត
មានបុត្រ១កើតដល់យើង[ត] ព្រះទ្រង់ប្រទានបុត្រា១មកយើង
ហើយ[ថ] ឯការគ្រប់គ្រង[ទ]នឹងនៅលើស្មារបស់បុត្រនោះ[ធ]
ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាង

**៨:១៩** ថ ១សយ ២៨:៨ ទ លវ ១៩:៣១ ធ អស ២៩:៤ ន ជន ២៧:២១ **៨:២០** ប អស ១:១០ លក ១៦:២៩ ផ នរ ៤:៧ ព ខ.២២ អស ៩:២ ៥៩:៩ ៦០:២ មីក ៣:៦ **៨:២១** ភ យប ៣០:៣ ម យប ១៨:១២ យ នក ២២:២៨ **៨:២២** រ យប ១៥:២៤ ល ខ.២០ យប ៣:១៣ អស ៥:៣០ យអ ២:២ មថ ២៥:៣០ វវ ១៦:១០ **៩:១** ក យប ១៥:២៤ ខ ២ពវ ១៥:២៩ **៩:២** គ ទដ ៨២:៥ ១០៧:១០,១៤ អស ៨:២០ ឃ ទដ ៣៦:៩ អស ៤២:៦ ៤៩:៦ ៦០:១៩ មឡ ៤:២ អភ ៥:៨ ង លវ ១:៧៩ ច អស ៥៨:៨ មថ ៤:១៥–១៦ **៩:៣** ឆ យប ១២:២៣ ជ ទដ ៤:៧ អស ២៥:៩ ឈ នក ១៥:៩ យស ២២:៨ ទដ ១១៩:១៦២ **៩:៤** ញ យប ៣៤:២៤ អស ៣៧:៣៦–៣៨ ដ អស ១៤:២៥ ៥៨:៦,៩ យរ ២:២០ ៣០:៨ អគ ៣០:១៨ ណហ ១:១៣ មថ ១១:៣០ ឋ ទដ ៨១:៦ អស ១០:២៧ ឌ អស ១៤:៤ ១៦:៤ ២៩:៥,២០ ៤៩:២៦ ៥១:១៣ ៥៤:១៤ ៦០:១៨ ឍ ពច ៧:២៥ **៩:៥** ណ អស ២:៤ **៩:៦** ត លប ៣:១៥ អស ៥៣:២ លក ២:១១ ថ យហ ៣:១៦ ទ មថ ២៨:១៨ ធ អស ២២:២២

**៨:១៩** *ពួកគ្រូខាប និងគ្រូគាថា* សូមមើល ចទ ១៨:៩–១២ និងការពន្យល់ ១៨:៩ ក្នុងបច្ចុប្បន្ននេះមនុស្ស បានងាកបែរទៅរកវិញ្ញាណនៃសេចក្តីស្លាប់ ដូចជាស្តេច សូលបានប្រព្រឹត្តការនោះ គឺខណៈពេលដែលលោកទៅរកពួកគ្រូខាបនិងគ្រូគាថា ដែលផ្ទុយនិងវិញ្ញាណនៃសាំយូអែល (១សយ ២៨:៨–១១) បានរៀនអំពីអនាគត មើលការពន្យល់ ៣:២–៣ ។

**៨:២០** *គម្ពីរបញ្ញត្តិ . . . សេចក្តីបន្ទាល់* មើល ខ.១៦ និងការពន្យល់ ។ ការយកចិត្តទុកដាក់ទៅលើព្រះបន្ទូលព្រះតាមរយៈអេសាយដោយជា"ទីសំគាល់ និងនិមិត្តសញ្ញា"(ខ.១៨)ដែលមានអេសាយនិងបុត្រារបស់គាត់ ជាពន្លឺដល់រាស្ត្រអ៊ីស្រាអែល ។

**៨:២១–២២** ការឈ្លានពានរបស់ពួកអាសស៊ើរក៏នាំមកនូវការឈឺចាប់យ៉ាងខ្លាំងចំពោះរាស្ត្រអ៊ីស្រាអែលទាំងអស់ ។

**៨:២១** *ប្រទេចផ្តាសា . . . ស្តេច . . . ព្រះរបស់ខ្លួន* ដោយព្រោះភាពឈឺចាប់ដ៏វេទនារបស់ពួកគេ (ប្រៀបធៀប សភ ១៩:៣) ដែលបង្ហាញពីការដែលត្រូវកាត់ទោសចំពោះអ្នកណាដែលដាក់បណ្តាសាដល់ព្រះនិងថ្នាក់អ្នកដឹកនាំ (នក ២២:២៨ លវ ២៤:១៥–១៦) ។

**៩:១** *ណែបថាលី* ពួកអំបូរនេះគឺរស់នៅស្រុកអ៊ីស្រាអែលផ្នែកខាងជើងដែលទទួលការឈឺចាប់ក្នុងពេលពួកអាសស៊ើរទីកឡាក–ពីលេស៊ើរ ប្រយុទ្ធចូលលុកលុយក្នុងឆ្នាំ ៧៣៤ និងឆ្នាំ ៧៣២ មុន គ.ស (២ពវ ១៥:២៩) ទ្រង់នឹងធ្វើឱ្យរុងរឿងត្រូវបានសម្រេចគឺក្នុងខណៈពេលព្រះយេស៊ូវបំពេញព្រះរាជកិច្ចនៅឯក្រុងការពើណិមក្បែរផ្លូវ ដែលចេញពីអេស៊ីព្ទទៅស្រុកដាម៉ាស ដែលគេនិយមហៅថាផ្លូវទៅកាន់សមុទ្រ (មថ ៤:១៣–១៥) ។

**៩:២** *ពន្លឺយ៉ាងធំ* ព្រះយេហូវ៉ានិងសេចក្តីសង្គ្រោះរបស់ផងទ្រង់នោះគឺជា "ពន្លឺដល់ពួកសាសន៍ដទៃ"(៤២:៦ ៤៩:៦ សូមប្រៀបធៀប មថ ៤:១៥–១៦ និងការពន្យល់ លក ២:៣២) ។

**៩:៤** គឺទ្រង់បានបំបាត់ពួកសង្កត់សង្កិនគេ ដូចជាពួកសាសន៍ម៉ាឌានដែលសង្កត់សង្កិនលើសាសន៍អ៊ីស្រាអែល (ពច ៧:២២–២៥) នឹម ក្នុង ១០:២៦–២៧ គឺលោកអេសាយមានទំនាយថាព្រះអម្ចាស់ និងបំផ្លាញពួកសាសន៍អាសស៊ើរនិងទ័ពវាព្រមទាំងនឹមដែលសង្កត់សង្កិនគេ ។ ហេតុការនេះបានសម្រេចក្នុងឆ្នាំ ៧០១ មុន គ.ស (សូមមើល ៣៧:៣៦–៣៨ និងការពន្យល់) ។

**៩:៦** *បុត្រា១* ជាព្រះរាជបុត្រលួង គឺរាជបុត្រារបស់ស្តេចដាវីឌ (មើលខ.៧ ទដ ២:៧ លក ១:៣២ ៣:១៦ និងការពន្យល់) ។ *ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ* បល្ល័ង្កទាំងបួននិមួយៗមានឈ្មោះរបស់ព្រះដែលមានពីរផ្នែក ។ គឺពុំមានលក្ខណៈដូចជាអេម៉ាញូអែលទេ(មើលការព្យល់ ៧:១៤)ចំណងជើងទាំងនេះគឺពុំមានលក្ខណៈដូចឈ្មោះរបស់មនុស្សក្នុងគ្រាសញ្ញាចាស់ទេ ។ អ្នកដ៏ជួយគំនិតយ៉ាងអស្ចារ្យបានបង្ហាញថាព្រះមែស៊ីគឺជាព្រះមហាក្សត្រមួយអង្គ (មើល មីក ៤:៩) ។ ១៤:២៧ ទដ ២០:៤ (ជាផែនការ) ។ ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ គឺតារយៈបុត្រារបស់ស្តេចដាវីឌនិងអនុវត្តនូវកិច្ចការរាជវង្ស ដែលនិងធ្វើឱ្យលោកិយទាំងមូលទទួលបានភាពរុងរឿងអស្ចារ្យ ។

អស្ចារ្យ[ន] ព្រះដ៏មានព្រះចេស្ដា[ប] ព្រះវរបិតាដ៏គង់នៅអស់
កល្ប[ផ,ព] និងជាម្ចាស់នៃមេត្រីភាព[ភ] ៧ឯសេចក្ដីចំរើននៃរដ្ឋា
ភិបាល[ម]ទ្រង់នឹងសេចក្ដីសុខសាន្ត[យ]របស់ទ្រង់ នោះនឹងមិន
ចេះផុតពីបល្ល័ង្ករបស់ដាវីឌ និងនគរនៃទ្រង់ឡើយ[រ] ដើម្បី
នឹងតាំងឡើង[ល] ហើយទប់ទល់ ដោយសេចក្ដីយុត្តិធម៌[វ] និង
សេចក្ដីសុចរិត[ស] ចាប់តាំងពីឥឡូវនេះជារៀងរាបដរាប
ទៅ[ហ] គឺសេចក្ដីឧស្សាហ៍[ឡ]របស់ព្រះយេហូវ៉ានៃពួកពល
បរិវារ នឹងសំរេចការនេះ ។

## សេចក្ដីក្រោធរបស់ព្រះអម្ចាស់ទាស់នឹងពួកអ៊ីស្រាអែល

៨ព្រះអម្ចាស់ទ្រង់បានផ្ញើព្រះបន្ទូល[អ]មកក្នុងពួកយ៉ាកុប
ហើយព្រះបន្ទូលនោះបានធ្លាក់មក ត្រូវជនជាតិអ៊ីស្រាអែល
៩បណ្ដាជនទាំងអស់គ្នានឹងដឹងដែរ ទោះទាំងពួកអេប្រាអិម[ក]
នឹងពួកអ្នកនៅស្រុកសាម៉ារីផង[ខ] ជាពួកអ្នកនិយាយដោយ
សេចក្ដីអំនួត និងចិត្តធំ[គ]របស់គេថា ១០ជញ្ជាំងឥដ្ឋបាន
រលំហើយ តែយើងនឹងសង់ឡើងដោយថ្មដាប់វិញ[ឃ] ដើម
ឧទុម្ពរ[ង]បានត្រូវកាប់អស់ទៅហើយ តែយើងនឹងយកដើម
តាត្រៅមកជំនួសវិញ[ច] ១១ដូច្នេះ ព្រះយេហូវ៉ាទ្រង់នឹងតាំង
ពួកខ្មាំងសត្រូវរបស់រេស៊ីន[ឆ]ឱ្យទាស់នឹងគេ ហើយនឹងញុះ
ញង់ ពួកសត្រូវរបស់គេដែរ ១២គឺពួកសាសន៍ស៊ីរី[ជ]នៅ
ខាងមុខ ហើយពួកសាសន៍ភីលីស្ទីន[ឈ]នៅខាងក្រោយ ពួក
ទាំងនោះនឹងហាមាត់ ត្របាក់លេប[ញ]សាស់អ៊ីស្រាអែលទៅ
ប៉ុន្តែ ទោះបើធ្វើទោស ជាច្រើនដល់ម្ល៉េះក៏ដោយ គង់តែ
សេចក្ដីខ្ញាល់[ដ]របស់ទ្រង់មិនទាន់បែរចេញនៅឡើយ គឺព្រះ
ហស្តទ្រង់នៅតែលូកមកទៀត[ឋ] ។
១៣រីឯបណ្ដាជនទាំងឡាយ គេមិនបានវិលមក[ឌ]ឯព្រះ
ដែលទ្រង់បានវាយផ្ចាល[ឍ]គេ ក៏មិនស្វែងរក[ណ]ព្រះយេហូវ៉ា
នៃពួកពលបរិវារឡើយ ១៤ហេតុនោះបានជាព្រះយេហូវ៉ា
ទ្រង់នឹងកាត់ទាំងក្បាល និងកន្ទុយ ទាំងមែក ហើយនិង
ធាង[ត]របស់សាសន៍អ៊ីស្រាអែលចេញ ក្នុងថ្ងៃតែ១[ថ] ១៥ឯ
ក្បាល គឺជាពួកអ្នកចាស់ទុំ[ទ] និងពួកមានកិត្តិយស[ធ] ហើយ
កន្ទុយ គឺជាពួកហោរា[ន]ដែលបង្រៀនសេចក្ដីភូតភរ[ប] ១៦ដ្បិត
ពួកអ្នកដែលដឹកនាំ[ផ]សាសន៍នេះ គេនាំឱ្យវង្វេងទេ ហើយ
ពួកអ្នកដែលគេនាំមុខ នោះក៏ត្រូវបំផ្លាញទៅ[ព] ១៧ដូច្នេះ
ព្រះអម្ចាស់ទ្រង់នឹងមិនរីករាយចំពោះពួកកំឡោះគេឡើយ[ភ]
ក៏មិនអាសូរករុណា[ម]ចំពោះពួកកំព្រា និងពួកស្រីមេម៉ាយ
របស់គេដែរ ពីព្រោះគ្រប់គ្នាជាអ្នកទមិលល្មើស[យ] ហើយជា
អ្នកប្រព្រឹត្តលាមកអាក្រក់[រ] គ្រប់ទាំងមាត់ក៏បញ្ចេញ សុទ្ធ

**៩:៦** ន យប ១៥:៨ អស ២៨:២៩ ប ចទ ៧:២១ ១១:២ ៤២:១៣ ផ ទដ ៩០:២ ព នក ៤:២២ អស ៦៤:៨ យហ ១៤:៩–១០ ភ អស ២៦:៣,១២ ៥៣:៥ ៦៦:១២ យរ ៣៣:៦ មីក ៥:៥ លក ២:១៤ **៩:៧** ម អស ២:៤ យ ទដ ៨៥:៨ ១១៩:១៦៥ អស ១១:៩ ២៦:៣,១២ ៣២:១៧ ៤៨:១៨ រ ដយ ២:៤៤ ៤:៣ លក ១:៣៣ យហ ១២:៣៤ ល អស ១:២៦ ៣២:១ ៦០:១៧ ១កថ ១៥:២៥ វ អស ១១:៤ ១៦:៥ ៣២:១,១៦ ៣៣:៥ ៤២:១ យរ ២៣:៥ ៣៣:១៤ ស ទដ ៧២:២ ហ ២សយ ៧:១៣ ឡ ២ពវ ១៩:៣១ អស ២៦:១១ ៣៧:៣២ ៤២:១៣ ៥៩:១៧ ៦៣:១៥

**៩:៨** អ ចទ ៣២:២ **៩:៩** ក អស ៧:២ ខ អស ៧:៩ គ អស ៤៦:១២ ៤៨:៤ អគ ២:៤ សក ៧:១១ **៩:១០** ឃ លប ១១:៣ ង អម ៧:១៤ លក ១៩:៤ ច ១ពវ ៧:២–៣ **៩:១១** ឆ អស ៧:៨ **៩:១២** ជ ២ពវ ១៦:៦ ឈ ២របា ២៨:១៨ ញ ទដ ៧៩:៧ ដ យប ៤០:១១ ឋ អស ៥:២៥ **៩:១៣** ឌ ២របា ២៨:២២ អម ៤:៩ សផ ៣:៧ ហក ២:១៧ ឍ យរ ៥:៣ អគ ៧:៩ ណ អស ២:៣ ១៧:៧ ៣១:១ ៥៥:៦ យរ ៥០:៤ ដយ ៩:១៣ ហស ៣:៥ ៧:៧,១០ អម ៤:៦,១០ សផ ១:៦ **៩:១៤** ត ខ.១៤–១៥ អស ១៩:១៥ ថ វវ ១៨:៨ **៩:១៥** ទ អស ៣:២–៣ ធ អស ៥:១៣ ន អស ២៨:៧ អគ ១៣:២ ប យប ១៣:៤ អស ៣:៨ ៤៤:២០ អគ ១៣:២២ មថ ២៤:២៤ **៩:១៦** ផ មថ ១៥:១៤ ២៣:១៦,២៤ ព អស ៣:១២ **៩:១៧** ភ យរ ៩:២១ ១១:២២ ១៨:២១ ៤៨:១៥ ៤៩:២៦ អម ៤:១០ ៨:១៣ ម យប ៥:៤ អស ២៧:១១ យរ ១៣:១៤ យ អស ១០:៦ ៣២:៦ មីក ៧:២ រ អស ១:៤

កិច្ចការនោះជាកម្មវិធីបង្ហាញឱ្យឃើញក្នុងជិពូក ២៤:២៧ (សូមមើល ២៥:១ "ការដ៏អស្ចារ្យបានកើតឡើង"គឺការដែលជាគម្រោងការពីយូរមកហើយ)។ ២៨:២៩ ក៏ដូចជាព្រះគម្ពីរភាសាហេព្រើរ ដែលសំដែងពីព្រះយេហូវ៉ាជាព្រះដ៏អស្ចារ្យ ដែលជាព្រះជួយគំនិត (មើល ពច ១៣:១៨ និងការពន្យល់) ។ *ព្រះដ៏មានព្រះចេស្ដា* មើល ១០:២១ គឺទ្រង់ជាអ្នកចំបាំងដែលពោរពេញដោយព្រះចេស្ដា ។ *ព្រះវរបិតាដ៏គង់នៅអស្ចារ្យ* គឺជាព្រះនៃសេចក្ដីប្រោសលោះ និងជាអង្គដែលការពារយើងរាល់គ្នា (ធៀបនឹង ៤០:៩–១១) ។ *ជាម្ចាស់នៃមេត្រីភាព* គឺទ្រង់បាននាំមកនូវការរួបរួមគ្នា គឺផ្ដើមពីមនុស្សម្នាក់រហូតដល់សង្គមទាំងមូល (មើល ១១:៦–៩) ។

**៩:៧** *បល្ល័ង្ករបស់ដាវីឌ . . . សេចក្ដីសុចរិត . . . ជារៀងរាបដរាបទៅ* ដែលមានលក្ខណ:ផ្ទុយពីស្ដេចដែលមានបាប ដូចជាស្ដេចអេហាស តែព្រះគ្រីស្ទជាពូជរបស់ស្ដេចដាវីឌ និងគ្រងរាជ្យដឹកនាំក្នុងភាពសុចរិតជារៀងរហូត (សូមមើល ១១:៣–៥ ២សយ ៧:១២–១៣,១៦ យរ ៣៣:១៥,២០–២២) ។

**៩:៨–១០:៤** ទោះជាអត្ថបទសេចក្ដីទំនាយរបស់ហោរា អេសាយគឺផ្ដោត "សំខាន់ទៅលើស្រុកយូដានិងក្រុងយេរូសាឡិម" (១:១) ហើយទ្រង់ក៏ជាអង្គ១ដែលសង្រួបសង្រួមនូវព្រះបន្ទូលរបស់ព្រះ (យ៉ាវេ៎) ចំពោះពួកសាសន៍ "អេប្រាអិមនិងពួនអ្នកស្រុកសាម៉ារី" (៩:៩) ។ ផ្នែកនេះគឺជាពាក្យទំនាយពីការកាត់ក្ដីជំនុំជំរះពីព្រះចំពោះពួកនគរខាងជើង ។ ដែលចែកទំនាយនេះជាបួនគាថា (ខ.៨–១២,១៣–១៧,១៨–១២,១០១–៤) ដែលមានវគ្គចុងបញ្ចប់ដោយទិសដៅតែមួយ (មើល ៩:១២,១៧,២១) ។

**៩:៩** *ពួកអេប្រាអិម* មើលការពន្យល់ ៧:២ ។

**៩:១០** *ជញ្ជាំងឥដ្ឋបានរលំហើយ* គឺជាជញ្ជាំងដែលធ្វើពីដីឥដ្ឋយកទៅហាលថ្ងៃដែលងាយនិងបាក់បែកយ៉ាងស្រួល ។ *ថ្មដាប់វិញ* គឺអេម៉ុសជាទីដែលអ្នកប្រព្រឹត្តការអាក្រក់ដែលបានផល ដើម្បីបានសង់ផ្ទះធ្វើពីថ្មដាប់ (មើល អម ៥:១១) ។ *ដើមតាត្រៅ* គឺជាឈើនៅភ្នំល្បាណូនដែលនាំមកផលព្រៃឈើមានតម្លៃនៅ ក្នុងតំបន់បូព៌ាបូរាណ (សូមមើល ១ពវ ៧:២–៣) ។

**៩:១១** *ពួកខ្មាំសត្រូវរបស់រេស៊ីន* គឺពួកអាសស៊ើរ (មើលការពន្យល់ ៧:១) ។

**៩:១២,១៧,២១** *ទ្រង់មិនទាន់បែរចេញ . . . ព្រះហស្តទ្រង់នៅតែលូកមកទៀត* ផ្នែកនេះក៏បង្ហាញម្ដងទៀតក្នុង ១០:៤ គឺខណ:ពេលដែលការក្រោធរបស់ព្រះយេហូវ៉ាបង្ហាញពីការគេបានចាប់បង្ខំរាស្ត្ររបស់ផងទ្រង់ ។

**៩:១៤** *ទាំងក្បាល នឹងកន្ទុយ . . . ទាំងមែក ហើយនឹងធាង* ដូចជាអ្នកដឹកនាំរបស់ពួកអ៊ីស្រាអែល (មើល ៣:១–៣) ។ ពាក្យទាំងពីរគួរនេះគឺសំដៅទៅលើមេដឹកនាំសាសន៍អេស៊ីព្ទ មើលក្នុង ១៩:១៥ ។

**៩:១៧** *ពួកកំព្រានិងស្ត្រីមេម៉ាយ* ជារឿយៗបានទទួលការឈឺចាប់ក្នុងដៃអ្នក

តែសេចក្ដីចំកួត[ល] ប៉ុន្តែ ទោះបើធ្វើទោសជា ច្រើនម្លេះក៏
ដោយ គង់តែសេចក្ដីខ្ញាល់របស់ទ្រង់ មិនទាន់បែរចេញ
នៅឡើយ គឺព្រះហស្តទ្រង់នៅតែលូកមកទៀត[វ] ។
១៨ដ្បិតអំពើអាក្រក់ឆេះដូចជាភ្លើង[ស] ក៏ឆេះបន្ទុសទាំង
អញ្ចាញ និងគុម្ពបន្លាអស់រលីងទៅ[ហ] អើ ភ្លើងនោះក៏កាត់
ឡើង ក្នុងទីស្ទុកនៅព្រៃ[ឡ] ហើយឆេះរាលឡើងហុយផ្សែង
ទ្រលោម ១៩ដោយសេចក្ដីក្រោធ[អ]របស់ព្រះយេហូវ៉ានៃពួក
ពលបរិវារ នោះស្រុកត្រូវឆេះរលីងទៅ[ក] ហើយបណ្ដាជន
ក៏ដូចជាចំណីភ្លើង[ខ] គ្មានអ្នកណាប្រណីដល់បងប្អូនខ្លួនទេ[គ]
២០ម្នាក់នឹងកញ្ឆក់យកពីខាងស្ដាំ ប៉ុន្តែនឹងនៅតែឃ្លានទៀត[ឃ]
ហើយម្នាក់ខាងឆ្វេងនឹងស៊ីទៅ[ង]ឥតបានឆ្អែតឡើយ គេនឹង
ស៊ីសាច់ដើមដៃខ្លួនគ្រប់ៗគ្នា ២១គឺម៉ាន៉ាសេនឹងស៊ីសាច់
អេប្រាអិម ហើយអេប្រាអិមនឹងស៊ីសាច់ម៉ាន៉ាសេ[ច] ហើយ
ទាំង២ពួកនោះនឹងទាស់ទទឹងនឹងពួកយូដា[ឆ] ប៉ុន្តែទោះបើ
ធ្វើទោសជាច្រើនដល់ម្ល៉េះក៏ដោយ គង់តែសេចក្ដីខ្ញាល់
របស់ទ្រង់មិនទាន់បែរចេញនៅឡើយ គឺព្រះហស្តទ្រង់នៅ
តែលូកមកទៀត[ជ] ។

**១០** ១វេទនា[ក]ដល់ពួកអ្នក ដែលចេញបញ្ញត្តិទុច្ចរិត និងពួក
អ្នកដែលតែងច្បាប់វៀចវេរ[ខ] ២ដើម្បីនឹងបង្វែរ[គ]ពួកកំសត់
ទុគ៌តចេញពីសេចក្ដីយុត្តិធម៌ ហើយដកយកអំណាចច្បាប់
ចេញពីមនុស្សទាល់ក្រ ក្នុងពួករាស្ត្ររបស់អញ[ឃ] ឱ្យតែបាន
ពួកស្រីមេម៉ាយទុកជារបឹប ហើយធ្វើឱ្យពួកកំព្រា បានជា
រំពាដល់ខ្លួន[ង] ៣តើឯងរាល់គ្នានឹងធ្វើដូចម្ដេច ក្នុងថ្ងៃពិនិត្យ
ពិច័យ[ច]ហើយក្នុងការបំផ្លាញ[ឆ] ដែលនឹងមកពីទីឆ្ងាយ តើឯង
រាល់គ្នានឹងរត់ទៅពឹងដល់អ្នកណា[ជ] តើនឹងផ្ញើសក្តិយស
របស់ឯងទុកនៅឯណា ៤នៅគ្រានោះ ឯងនឹងបានតែកន្ទ្វេង
ឱនចុះនៅកណ្ដាលពួកឈ្លើយប៉ុណ្ណោះ[ឈ] ហើយនឹងត្រូវដួល
នៅក្រោមខ្មោចនៃពួកអ្នកដែលត្រូវគេសំឡាប់[ញ] ទោះបើធ្វើ
ទោសជាច្រើនដល់ម្លេះក៏ដោយ គង់តែសេចក្ដីខ្ញាល់របស់
ទ្រង់ មិនទាន់បែរចេញនៅឡើយ[ដ] គឺព្រះហស្តទ្រង់នៅតែ
លូកមកទៀត ។

## ព្រះអម្ចាស់ជំនុំជម្រះពួកសាសន៍អាសស៊ើរ

៥វេទនា[ឋ]ដល់ពួកសាសន៍អាសស៊ើរ[ឌ] ដែលជាដំបង[ឍ]
នៃសេចក្ដីកំហឹងរបស់អញ ហើយរំពាត់[ណ]នៅដៃគេ គឺជា
សេចក្ដីគ្នាន់ក្នាញ់របស់អញ[ត] ៦អញនឹងចាត់គេឱ្យទៅទាស់
នឹងនគរ១ដែលទមិលល្មើស[ថ] ហើយនឹងបង្គាប់ការ[ទ]ដល់គេ
ឱ្យទាស់នឹងសាសន៍១ដែលត្រូវសេចក្ដីក្រោធរបស់អញ[ធ] ឱ្យ
បានចាប់យករបឹប[ន] ចាប់រំពា ហើយជាន់ឈ្លី[ប]សាសន៍នោះ
ដូចជាភក់នៅផ្លូវផង ៧ប៉ុន្តែគេមិនយល់ដូច្នោះទេ ហើយ
ចិត្តគេក៏មិនគិតឃើញដល់ម្ល៉ោះដែរ[ផ] គឺមានចិត្តចង់បំផ្លាញ
វិញ ក៏ចង់កាត់នគរជាច្រើន ឱ្យសូន្យចេញមិនតិចឡើយ
៨ដ្បិតគេថា ឯចៅហ្វាយ[ព]របស់អញទាំងប៉ុន្មាន តើមិនមែន
ជាស្ដេចគ្រប់គ្នាទេឬអី ៩ឯក្រុងកាលនរ[ភ] តើមិនមែនដូច
ជាក្រុងកើកេមីសទេឬអី[ម] ក្រុងហាម៉ាត[យ] តើមិនមែនដូចជា
ក្រុងអើផាឌ[រ] ហើយក្រុងសាម៉ារី[ល] តើមិនមែនដូចជាក្រុង

**៩:១៧** ល អស ៣:៨ មថ ១២:៣៤ រម ៣:១៣-១៤ វ អស ៥:២៥ **៩:១៨** ស ចទ ២៩:២៣ អស ១:៣១ **៩:១៨** ហ អស ៥:៦ ឡ ទដ ៨៣:១៤ **៩:១៩** អ យប ៤០:១១ អស ១៣:៩,១៣ ក យរ ១៧:២៧ ខ ទដ ៩៧:៣ អស ១:៣១ គ អស ៣:៥ **៩:២០** ឃ លវ ២៦:២៦ យប ១៨:១២ ង អស ៤៩:២៦ សក ១១:៩ **៩:២១** ច ពច ៧:២២ ១២:៤ ឆ ២រប ២៨:៦ ជ អស ៥:២៥ **១០:១** ក អស ៥:៨ ខ ទដ ៥៨:២ **១០:២** គ អស ៣:១៤ ឃ អស ៥:២៣ ង ចទ ១០:១៨ យប ៦:២៧ អស ១:១៧ **១០:៣** ច យប ៣១:១៤ ឆ ខ.២៥ ទដ ៥៩:៥ អស ១:២៤ ១៣:៦ ១៤:២៣ ២៤:៦ ២៦:១៤ ៤៧:១១ យរ ៥:៩ ៩:៩ ៥០:១៥ លក ១៩:៤៤

ជ ទដ ១០៨:១២ អស ២០:៦ ៣០:៧ ៣១:៣ **១០:៤** ឈ អស ២៤:២២ សក ៩:១១ ញ អស ២២:២ ៣៤:៣ ៦៦:១៦ យរ ៣៩:៦ ណាហ ៣:៣ ដ អស ៥:២៥ ១២:១ ៦៣:១០ ៦៤:៥ យរ ៤:៨ ៣០:២៤ បទ ១:១២ **១០:៥** ឋ ២ពវ ១៩:២១ អស ២៨:១ ឌ ខ.១២,១៨ អស ៧:២០ ១៤:២៥ ៣១:១៨ ៣៧:៧ សផ ២:១៣ ឍ អស ១៤:៥ ៥៤:១៦ ណខ.១៥,២៤ អស ៣០:៣១ ៤១:១៥ ៤៥:១ យរ ៥០:២៣ ៥១:២០ ត អស ៩:៤ ១៣:៣,៥,១៣ ២៦:២០ ៣០:៣០ ៣៤:២ ៦៣:៦ ៦៦:១៤ អក ៣០:២៤-២៥ **១០:៦** ថ អស ៩:១៧ ទ ហព ១:១២ ធ ២រប ២៨:៩ អស ៩:១៩ ន ពច ៦:៤ អស ៥:២៩ ៨:១ ប ២សយ ២២:៤៣ ទដ ៧:៥ អស ៥:៥ ៣៧:២៦-២៧ **១០:៧** ផ លប ៥០:២០ កច ៤:២៣-២៨ **១០:៨** ព ២ពវ ១៨:២៤ **១០:៩** ភ លប ១០:១០ ម ២រប ៣៥:២០ យ ជន ៣៤:៨ ២រប ៨:៤ អស ១១:១១ រ ២ពវ ១៨:៣៤ ល ២ពវ ១៧:៦

មានអំណាច (សូមមើលការពន្យល់ ១:១៧) ។
**៩:១៨** *អញ្ចាញ និងគុម្ពបន្លា* មើលការពន្យល់ ៥:៦ ។
**៩:១៩** *ចំណីភ្លើង* ជាភាពខុស ខ.៥ ។
**៩:២១** *ម៉ាន៉ាសេ . . . អេប្រាអិម* គឺជាពូជអំបូរដ៏ល្បីល្បាញនៅក្នុងនគរផ្នែកខាងជើងដែលមានតំណរពូជពីកូនប្រុសលោក យ៉ាកុបទាំងពីរ (មើល លប ៤៦:២០ ក៏សូមមើល លប ៤៨:៥-៦ និងការពន្យល់) ។ អំបូរទាំងនេះបានប្រយុទ្ធគ្នាជាច្រើនសតវត្ស (ពច ១២:៤) ។
**១០:១** *វេទនា* ប្រៀបធៀបពាក្យជាច្រើននៃពាក្យវេទនាក្នុង ៥:៨-២៣ ។
**១០:២** *ពួកកំសត់ទុគ៌ត* នក ២២:២១-២៧ ប្រៀបធៀប យរ ២២:១៥-១៦ *ពួកស្រីមេម៉ាយ . . . ពួកកំព្រា* មើលការពន្យល់ ១:១៧ ៩:១៧ ។
**១០:៤** *ពួកឈ្លើយ . . . សំឡាប់* យរ ៣៩:៦-៧ គឺជាការពណ៌នាអំពីការដឹកនាំរបស់ពួកយូដា ខណៈពេលនេប៊ូក្នេសាគ្រប់គ្រងបានក្រុងយេរូសាឡិមក្នុងឆ្នាំ ៥៨៦ គ.ស ។ *ព្រះហស្តទ្រង់នៅតែលូកមក* មើលការពន្យល់ ៩:១២, ១៧,២១ ។
**១០:៥** *ដំបងនៃកំហឹង . . .* មើល ៩:៤ និងការពន្យល់ ។ ដំបងឬញញួរគឺព្រះបានប្រើសម្រាប់ដាក់ទណ្ឌកម្មដល់ជាតិសាសន៍ទាំងឡាយ (យរ ៥០:២៣ ៥១:២០ ហប ១:៦) ។
**១០:៩** *ក្រុងកាលនរ* គឺជាតំបន់នៅផ្នែកខាងជើងស្រុកអើរ៉ាម(ស្រុកស៊ីរី) សូមមើលទីក្រុងកាលនរក្នុងគម្ពីរ អេម៉ុស ៦:២ (សូមមើលសេចក្ដីពន្យល់នៅទីនោះ) ក្រុងកើគេមីស ។ វាជាទីតាំងមាំមួននៅលើតំបន់ទន្លេអើប្រាត ខាងកើតនៃទីក្រុងកាលនរ (មើល យរ ៤៦:២ និងការពន្យល់) ។ *ក្រុងហាម៉ាត* គឺជាទីក្រុងមួយនៅតាមដងទន្លេដែលជាសញ្ញាពង្រីក នៃអំណាចអ្នកដឹកនាំរបស់សាឡូម៉ូន (២រប ៨:៤) សូមមើលការពន្យល់ ២ពវ ១៧:២៤ ។ *ក្រុងអើផាឌ* គឺជាទីក្រុងក្បែរទីក្រុងហាម៉ារី ហើយនៅចំពីខាងត្បូងនៃក្រុងនរ ។ តំបន់អស់ទាំងនេះបានប្រគល់ទៅឱ្យពួកអាសស៊ើរនៅក្នុងឆ្នាំ ៧១៧ មុន គ.ស (មើល ៣៦:១៩) ។

ដាម៉ាសទេឬអី[វ] ១០ដៃអញបានលូកទៅចាប់យកអស់ទាំង
នគរ ដែលគោរពដល់រូបព្រះ[ស] ជាស្រុកដែលមានរូបឆ្លាក់
វិសេសជាងរូបឆ្លាក់នៅក្រុងយេរូសាឡិម នឹងក្រុងសាម៉ារី
ទៅហើយ ១១ចុះតើអញនឹងមិនធ្វើដល់ក្រុងយេរូសាឡិម
នឹងរូបព្រះរបស់គេ ដូចជាបានធ្វើដល់ក្រុងសាម៉ារី និងរូប
ព្រះរបស់គេដែរទេឬអី[ហ]។
១២ព្រោះហេតុនោះ កាលណាអញ ជាព្រះអម្ចាស់បាន
សំរេចគ្រប់ទាំងការ[ឡ]របស់អញ នៅលើភ្នំស៊ីយ៉ូន[អ] និង
ក្រុងយេរូសាឡិមហើយ នោះអញនឹងធ្វើទោសដល់ស្តេច
អាសសើរ[ក] ដោយព្រោះការ ដែលសេចក្ដីអំនួត[ខ]របស់គេ
បានធ្វើ ហើយដល់សេចក្ដីអង់អាចនៃឫកខ្ពស់[គ]របស់គេដែរ
១៣ដ្បិតគេបានថា យើងបានធ្វើការនេះដោយកំឡាំងដៃ
យើង[ឃ] ហើយដោយប្រាជ្ញារបស់យើងដែរ[ង] ដោយយើង
មានយោបល់ពិត យើងបានដកព្រំដែននៃសាសន៍ទាំង
ប៉ុន្មានចោល ក៏បានរឹបយកទ្រព្យសម្បត្តិគេ[ច] ហើយបាន
ប្រព្រឹត្តដូចជាមនុស្សមានចិត្តក្លាហាន គឺបានទំលាក់ស្តេច
ដែលអង្គុយលើបល្ល័ង្កបង់[ឆ] ១៤ដៃយើងយកបានទ្រព្យ
សម្បត្តិ[ជ]នៃអស់ទាំងសាសន៍ ដូចជាយកបានសំបុកសត្វ[ឈ]
ក៏ដូចជាប្រមូលពងសត្វ ដែលមេចោលហើយ ជាយ៉ាងណា
យើងក៏បានប្រមូលរួបរួមលោកទាំងមូលយ៉ាងនោះដែរ[ញ]
ឥតមានណាមួយកំរើកស្លាប ឬហាមាត់ ឬស្រែកចេចចាច
ឡើយ[ដ]។
១៥ឯពូថៅ តើនឹងអួតខ្លួន ចំពោះអ្នកដែលប្រើវាឬអី
តើរណារនឹងដំកើងខ្លួនចំពោះអ្នកដែលអារដែរឬ[ឋ] នេះឧប
មាដូចជារំពាត់ដែលនឹងយារអ្នកដែលលើកវាឡើយ ឬដូច
ជាដំបង[ឌ]នឹងលើកមនុស្សឡើង ជាមនុស្សដែលមិនមែនធ្វើ
ជាឈើផង ១៦ព្រោះហេតុនោះ ព្រះអម្ចាស់ជាព្រះយេហូវ៉ា
នៃពួកពលបរិវារ ទ្រង់នឹងចាត់សេចក្ដីស្គម ស្គាំង[ឍ]ទៅ
កណ្ដាលពួកធាត់ៗរបស់គេ[ណ] ហើយនៅក្រោមសិរីល្អរបស់
គេ[ត]នោះនឹងឆួលឡើងដូចជាភ្លើង[ថ]ឆេះ ១៧ឯពន្លឺនៃសាសន៍
អ៊ីស្រាអែល នោះនឹងបានសំរាប់ជាភ្លើង[ទ] ហើយព្រះដ៏
បរិសុទ្ធ[ធ]របស់គេជាអណ្តាតភ្លើង ភ្លើងនោះនឹងឆេះឡើង
ហើយបន្សុលពួកបន្លា[ន] និងអញ្ចាញរបស់គេ នៅថ្ងៃតែ១[ប]
១៨ព្រមទាំងធ្វើឱ្យលំអនៃព្រៃ[ផ] និងចំការដុះដាលរបស់គេ
សាបសូន្យទៅ ទាំងព្រលឹងនឹងរូបកាយរបស់គេផង[ព] នោះ
នឹងបានដូចជាមនុស្សកើតជំងឺ ដែលនាំឱ្យពួករីងរៃស្លាប់
ទៅ ១៩ឯសំណល់ដើមឈើ ដែលសល់នៅក្នុងព្រៃ[ភ]របស់ គេ
នោះនឹងបានតិចណាស់[ម] ដល់ម្ល៉េះបានជាកូនក្មេងនឹង
អាចកត់ទុកបាន ។

## សំណល់ពួកសាសន៍អ៊ីស្រាអែល

២០នៅថ្ងៃនោះ[យ]សំណល់ពួកសាសន៍អ៊ីស្រាអែល និង
អស់អ្នកក្នុងពូជពង្សយ៉ាកុបដែលបានរួចខ្លួនមក[រ] គេនឹង

**១០:៩** វ លប ១៤:១៥ ២ពវ ១៦:៩ យរ ៤៩:២៤ **១០:១០** ស ២ពវ ១៩:១៨ **១០:១១** ហ ២ពវ ១៩:១៣ អស ២:៨ ៣៦:១៨–២០ ៣៧:១០–១៣ **១០:១២** ឡ អស ២៨:២១–២២ ៦៥:៧ ៦៦:៤ យរ ៥:២៩ អ ២ពវ ១៩:៣១ ក ខ.៥ ២ពវ ១៩:៧ អស ៣០:៣១–៣៣ ៣៧:៣៦–៣៨ យរ ៥០:១៨ ខ អស ២:១១ អគ ២៨:១៧ គ ទដ ១៨:២៧ **១០:១៣** ឃ ចទ ៨:១៧ ង ចទ ៣២:២៦–២៧ អស ៤៧:៧ ដយ ៤:៣០ ច អគ ២៨:៤ ឆ អស ១៤:១៣–១៤ **១០:១៤** ជ យប ៣១:២៥ ឈ អស យរ ៤៩:១៦ អប ១:៤ ហព ២:៦–១១ ញ អស ១៤:៦
ដ ២ពវ ១៩:២២–២៤ អស ៣៧:២៤–២៥ **១០:១៥** ឋ អស ៧:២០ ៤៥:៩ រម ៩:២០–២១ ឌ ខ.៥ **១០:១៦** ឍ ខ.១៨ ជន ១១:១៣ អស ១៧:៤ ណ ទដ ៧៨:៣១ ត អស ៨:៧ ថ យរ ២១:១៤ **១០:១៧** ទ យប ៤១:២១ អស ១:៣១ ៣១:៩ សក ២:៥ ធ អស ៣៧:២៣ ន ជន ១១:១–៣ ២សយ ២៣:៦ ប អស ៩:១៨ **១០:១៨** ផ ២ពវ ១៩:២៣ ព ខ.៥ **១០:១៩** ភ ខ.៣៣–៣៤ អស ៣២:១៩ ម អស ១៧:៦ ២១:១៧ ២៧:១៣ យរ ៤៤:២៨ **១០:២០** យ ខ.២៧ អស ១១:១០,១១ ១២:១,៤ ១៩:១៨,១៩ ២៤:២១ ២៨:៥ ៥២:៦ សក ៩:១៦ រ អស ១:៩ អគ ៧:១៦

**១០:១០,១៤** *ដៃអញបានលូកទៅ* ពាក្យនេះជាព្រះគម្ពីរភាសាហេព្រើរគឺមានន័យដូចគ្នាហើយឃ្លានៃខនេះតែងតែឃើញជាច្រើនដង ។

**១០:១០** *រូបព្រះ . . . ក្រុងយេរូសាឡិមនិងក្រុងសាម៉ារី* គ្មានសាសន៍អ៊ីស្រាអែលណាមួយដែលមានបំណងថ្វាយបង្គំរូបព្រះទេ (មើល នក ២០:៤ និងការពន្យល់) តែនៅក្នុងស្រុកគឺមានទៅដោយរូបព្រះ (២:៨) ។

**១០:១២** ឧបករណ៍របស់ព្រះយេហូវ៉ាគឺសម្រាប់កាត់ទោសជំនុំជម្រះ គឺមិនឱ្យអ្នកណាមួយរួចចេញពីការជំនុំជម្រះបានឡើយ ។ *សេចក្ដីអំនួត* គឺការជំនុំជម្រះចំពោះមនុស្សអំនួត មើល ២:១១,១៧ ។

**១០:១៣–១៤** ខទាំងនេះបង្ហាញពីសេចក្ដីអំនួតរបស់ស្តេចពួកអាសសើរ គឺគេបានប្រើពាក្យអួតអាងប្រាំបួនដង សូមប្រៀបធៀប ១៤:១៣–១៤ និង អគ ២៨:២–៥ ។

**១០:១៦** *ព្រះអម្ចាស់ជាព្រះយេហូវ៉ា នៃពួកពលបរិវារ* សូមមើល ១:២៤ នឹងការពន្យល់ ។ *សេចក្ដីស្គមស្គាំង* ពេលដែលទេវតាដាក់សេចក្ដីស្លាប់មកនោះគឺមានទាហាន ១៨៥០០០ នាក់របស់ពួកអាសសើរត្រូវស្លាប់បង់គឺជាទាហានរបស់ស្តេចសានហេរីប ជាស្តេចស្រុកអាសសើរ ក្នុងឆ្នាំ ៧០១ មុន គ.ស គឺជាសេចក្ដីហិនវិនាសយ៉ាងរហ័ស (មើលការពន្យល់ ៣៧:៣៦ ក៏សូមមើល ២សយ ២៤:១៥–១៦) ។

**១០:១៧–២០** *ព្រះដ៏បរិសុទ្ធ* មើលការពន្យល់ ១:៤ ។

**១០:១៨–១៩** *ព្រៃ* គឺសំដៅទៅលើកងទ័ពពួកអាសសើរ មើល ខ.៣៣–៣៤ នឹងការពន្យល់ ខ.៣៣ ។

**១០:១៩** គឺជាការបំពេញសម្រេចរវាងឆ្នាំ ៦២ មុន គ.ស និងឆ្នាំ ៦០៥ មុន គ.ស (ជាសង្គ្រាមក្នុងស្រុកកើតមីស) ។

**១០:២០,២៧** *នៅថ្ងៃនោះ* គឺជាថ្ងៃនៃជ័យជម្នះនិងសេចក្ដីអំណរគឺជាថ្ងៃសង្ឃឹមនៃថ្ងៃរបស់ព្រះយេហូវ៉ា (មើលការពន្យល់ ២:១១,១៧ ៩:៤) ។ គឺសម្រាប់រាស្ត្រអ៊ីស្រាអែលត្រូវទទួលនិងមនុស្សក៏សរសើរតម្កើងព្រះអម្ចាស់ជំពូក ១១ ទំនាក់ទំនងនិង"ថ្ងៃនេះ"ជាមួយនិងយុគសម័យនៃព្រះមែស៊ី (មើល ១១:១០–១១ នឹងការពន្យល់ សូមមើល ១២:១,៤) ។

**១០:២០–២២** *សំណល់* មើលការពន្យល់ ១:៩ "គឺជាសំណល់នៃអង្គមួយនិងត្រូវត្រឡប់មកវិញ"គឺមានឈ្មោះដូចជាកូនប្រុសដំបូងរបស់លោកអេសាយ (សូមមើលការពន្យល់ ៧:៣) ។ គឺជាអ្នកសំណប់ដ៏ស្មោះត្រង់ដឹកនាំដោយស្តេចហេសេគា ដែលបានរួចពីស្លាប់ពីការឈ្លានពានរបស់ស្រុកអាសសើរពីការនិរទេសទៅស្រុកបាប៊ីឡូន ។

លែងពឹងផ្អែក[ល]លើមនុស្សដែលបានវាយគេតទៅ[វ] ហើយ
នឹងផ្អែក[ស]លើព្រះយេហូវ៉ា ជាព្រះដ៏បរិសុទ្ធនៃសាសន៍
អ៊ីស្រាអែល ដោយពិតត្រង់វិញ[ហ] ២១ឯពួកដែលសល់[ឡ] គឺជា
សំណល់នៃពួកយ៉ាកុប គេនឹងត្រឡប់មក[អ]ឯព្រះដ៏មានព្រះ
ចេស្ដាវិញ[ក] ២២ឱអ៊ីស្រាអែលអើយ ទោះបីជនជាតិឯងបាន
ដូចជាខ្សាច់[ខ]នៅសមុទ្រក៏ដោយ គង់តែនឹងមានតែសំណល់
ប៉ុណ្ណោះដែលមកវិញ[គ] ដ្បិតបានសំរេច[ឃ]ឱ្យមានការបំផ្លាញ
ដោយសេចក្ដីសុចរិតដ៏លើសលន់ ២៣ពីព្រោះព្រះអម្ចាស់
ជាព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់នឹងបង្ហើយការ
បំផ្លាញសព្វគ្រប់[ង]នៅកណ្ដាលស្រុកទាំងមូល ដូចជាបាន
សំរេចហើយ[ច]។
២៤ដូច្នេះ ព្រះអម្ចាស់ ជាព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់មានបន្ទូលថា ឱរាស្ត្រអញ ដែលអាស្រ័យនៅក្រុង
ស៊ីយ៉ូនអើយ[ឆ] កុំឱ្យខ្លាច[ជ]ចំពោះសាសន៍អាសស៊ើរនោះ
ឡើយ ទោះបើគេវាយ[ឈ]ឯងដោយរំពាត់[ញ] ហើយលើក
ដំបងខ្លួនឡើងទាស់នឹងឯង ដូចយ៉ាងសាសន៍អេស៊ីព្ទក៏ដោយ
២៥ដ្បិត នៅតែបន្តិចទៀត[ដ] សេចក្ដីក្នាញ់ក្នាញ់នឹងបានសំរេច
ហើយ សេចក្ដីកំហឹង[ឋ]របស់អញ នឹងបែរទៅជាបំផ្លាញ
ដល់គេវិញ[ឌ] ២៦ព្រះយេហូវ៉ា នៃពួកពលបរិវារទ្រង់នឹង
ពន្យុះ[ឍ]រំពាត់១មកទាស់នឹងគេ បែបដូចជាកាលប្រហារ
ជីវិតសាសន៍ម៉ាឌាន[ណ] នៅត្រង់ថ្មអូរិប ទ្រង់នឹងយារដំបង[ត]
ពីលើទឹកសមុទ្រ[ថ] ដូចយ៉ាងរបៀបនៅស្រុកអេស៊ីព្ទដែរ
២៧នៅថ្ងៃនោះ[ទ]បន្ទុក[ធ]ដែលគេដាក់លើឯង នឹងបាត់ចេញពី
ស្មាឯងទៅ ហើយនឹម[ន]ដែលគេដាក់លើឯង នឹងបាត់ចេញពី
ឯងដែរ[ប]ឯនឹម[ផ]នោះនឹងត្រូវបំផ្លាញ ដោយព្រោះពិធីលាប
ប្រេង ។
២៨គេបានឡើងមកដល់អៃយ៉ាត គេបានដើរកាត់ ស្រុក
មីករ៉ូន[ព] មកដាក់អីវ៉ាន់[ភ]របស់គេនៅត្រង់មីកម៉ាសហើយ[ម]
២៩គេបានឆ្លងមកហួសផ្លូវកាត់ភ្នំ ហើយបានឈប់ស្នាក់នៅ
ត្រង់កេបា[យ] ក្រុងរ៉ាម៉ា[រ]ក៏ភ័យញ័រ ហើយពួកគីបៀរ[ល]ជា
ស្រុករបស់សូលបានរត់អស់ហើយ[វ] ៣០ឱកូនស្រីនៃក្រុង
កាលីមអើយ[ស] ចូរបន្លឺសំឡេងឡើង ឱពួកក្រុងឡាអ៊ីស
អើយ ចូរស្ដាប់ចុះ ឱពួកក្រុងអាន៉ាថោតអើយ[ហ] គួរអាណិត
ឯងណាស់ហ្ន៎ ៣១ពួកម៉ាតមេណាបានរត់រួចទៅហើយ ឯ
ពួកកេប៊ីមក៏កំពុងតែរត់ដែរ ៣២នៅថ្ងៃនេះឯង ពួកខ្មាំងនឹង
ឈប់ស្នាក់នៅត្រង់ក្រុងណូប[ឡ] គេជន្លដៃ[អ]កំហែងភ្នំនៃកូន
ស្រីក្រុងស៊ីយ៉ូន[ក] គឺភ្នំនៃក្រុងយេរូសាឡិម ៣៣មើល ព្រះ
អម្ចាស់ជាព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់នឹងផ្ដាច់[ខ]
មែកឈើ ដោយសេចក្ដីស្ញែងខ្លាច នោះពួកដែលមាន

**១០:២០** ល ២ពវ ១៦:៣ វ ២រប ២៨:២០ ស ២រប ១៤:១១ អស ១៧:៧ ៤៨:២ ៥០:១០ យរ ២១:២ ហស ៣:៥ ៦:១ មីក ៣:១១ ៧:៧ ហ អស ៥:២៤ **១០:២១** ឡ លប ៤៥:៧ អស ៦:១៣ សផ ៣:១៣ អ អស ៧:៣ **១០:២១** ក អស ៩:៦ **១០:២២** ខ លប ១២:២ អស ៤៨:១៩ យរ ៣៣:២២ គ អរ ១:៤ អស ១១:១១ ៤៦:៣ ឃ.២៣ អស ២៨:២២ យរ ៤០:២ ដយ ៩:២៧ **១០:២៣** ង ខ.២២ អស ៦:១២ ២៨:២២ រម ៩:២៧–២៨ **១០:២៤** ឆ ទដ ៨៧:៥–៦ ជ អស ៧:៤ ឈ នក ៥:១៤ ខ.៥ **១០:២៥** ដ អស ១៧:១៤ ២៩:១៧ ហាក ២:៦ ខ.៥ ទដ ៣០:៥ អស ១៣:៥ ២៤:២១ ២៦:២០ ៣០:៣០ ៣៤:២ ៦៦:១៤ ដយ ៨:១៩ ១១:៣៦ ឌ ខ.៣ មីក ៥:៦ **១០:២៦** ឍ អស ៣៧:៣៦–៣៨ ណ អស ៩:៤ ត អស ៣០:៣២ នក ១៤:១៦ **១០:២៧** ទ ខ.២០ ធ ទដ ៦៦:១១ ន លវ ២៦:១៣ អស ៩:៤ ប អស ១៤:២៥ ៤៦:៦ ៥២:២ ផ យរ ៣០:៨ **១០:២៨** ព ១សយ ១៤:២ ភ យស ១:១១ ម ១សយ ១៣:២ **១០:២៩** យ យស ១៨:២៤ នហ ១១:៣១ រ យស ១៨:២៥ ល ពច ១៩:១៤ វ អស ១៥:៥ **១០:៣០** ស ១សយ ២៥:៤៤ ហ នហ ១១:៣២ **១០:៣២** ឡ ១សយ ២១:១ អ យប ១៥:២៥ ក ទដ ៩:១៤ អស ១៦:១ យរ ៦:២៣ **១០:៣៣** ខ អស ១៨:៥ ២៧:១១ អគ ១៧:៤

**១០:២០** *មនុស្សដែលបានវាយគេតទៅ* ដូចជាស្ដេចនៃស្រុកអាសស៊ើរ (មើលការពន្យល់ ៧:១៧) ។
**១០:២១** *ព្រះដ៏មានព្រះចេស្ដា* មើលការពន្យល់ ៩:៦ ។
**១០:២២** *ដូចជាខ្សាច់នៅសមុទ្រ* មើលការពន្យល់ លប ១៣:១៦ ២២:១៧ ។ *ការបំផ្លាញ . . .* ដោយព្រោះអំពើបាបរបស់រាស្ត្រអ៊ីស្រាអែល គឺព្រះបានដាក់ទណ្ឌកម្មដល់ជាតិសាសន៍តាមរយៈការឈ្លានពានរបស់ពួកបរទេស ។
**១០:២៣–២៤** *ព្រះយេហូវ៉ានៃពួកពលបរិវារ* សូមមើល ១:២៤ និងការពន្យល់ ។
**១០:២៤** *រំពាត់ . . . ដំបង* មើល ខ.៥ ៩:៤ និងការពន្យល់ ។
**១០:២៦–២៧** *សាសន៍ម៉ាឌាន . . . បន្ទុក . . . នឹម* មើលសេចក្ដីពន្យល់ ៩:៤។
**១០:២៦** *ថ្មអូរិប* ក៏ជាឈ្មោះមេទ័ពរបស់ពួកសាសន៍ (ពច ៧:២៥) ។ *ទឹក . . . នៅស្រុកអេស៊ីព្ទដែរ* ដូចក្នុងខណៈពេលលោកម៉ូសេយាដៃរបស់លោកដាក់ពីលើទឹកសមុទ្រក្រហម ហើយទឹកក៏ត្រឡប់មកគ្របលើអស់ទាំងពួកពលសេះហើយ និងទ័ពផារ៉ោនទាំងអស់ (សូមមើល ១៤:៣២៦–២៨) ។
**១០:២៧** *ប្រេង* គឺមានលក្ខណៈ ប្រេងរបស់សត្វជើងបួនដែរ ដែលរាស្ត្រអ៊ីស្រាអែលអាចបំបាក់នឹមទាំងនោះបាន ។
**១០:២៨–៣២** ដូចជាបានឃើញពីនិមិត្ត ដែលលោកអេសាយបានពណ៌នាពីពួកពលទ័ពរបស់អាសស៊ើរមកឯក្រុងយេរូសាឡិម ដែលមានចម្ងាយ១៦ គី គ.ម ពីទីក្រុង ។
**១០:២៨** *មីកម៉ាស* ដែលមានទីតាំងប្រហែល១១ គ.ម ពីភាគខាងជើងក្រុងយេរូសាឡិម ។
**១០:២៩** *ក្រុងរ៉ាម៉ា* ជាស្រុកកំណើតរបស់សាំយូអែលវាប្រហែល ៨ គ.ម ពីក្រុងយេរូសាឡិម (១សយ ៧:១៧ នឹងមើលការពន្យល់ ១សយ ១:១) ។ *គីបៀរជាស្រុករបស់សូល* គឺប្រហែល ៤.៥ គ.ម ពីទីក្រុងយេរូសាឡិមក៏ជារាជធានីស្ដេចដំបូងគេក្នុងស្រុកអ៊ីស្រាអែល (សូមមើល ១សយ ១០:២៦) ។
**១០:៣០** *ឱកូនស្រីនៃក្រុងកាលីមអើយ* គឺជាការបង្ហាញពីការរីកដុះដាលនៃពូជបេនយាមីន ក៏ជាទីក្រុងបានមកពីការទំនាក់ទំនងគ្នា (មើល ១សយ ២៥:៤៤ និងមើលការពន្យល់ ២:ពវ ១៩:២១) ។ *ក្រុងអាន៉ាថោកអើយគួរអាណិត* គឺជាស្រុករបស់យេរេមា (មើល យរ ១:១ និងការពន្យល់) ។
**១០:៣២** *ក្រុងណូប* ដែលមានទីតាំងនៅលើភ្នំនៅឯជាយក្រុងយេរូសាឡិម ។ *កូនស្រីក្រុងស៊ីយ៉ូន* គឺជាសណ្ឋានមនុស្សនៅក្នុងក្រុងយេរូសាឡិម (មើលការពន្យល់ ២ពវ ១៩:២១) ។
**១០:៣៣** *ព្រះអម្ចាស់ជាព្រះយេហូវ៉ានៃពួកពលបរិវារ* សូមមើល ១:២៤ និងការពន្យល់ (មើល ខ.១៦–១៩) ។

កំពស់នឹងត្រូវកាប់រំលំចុះ[គ] ហើយពួកនៅទីខ្ពស់[ឃ] នឹងត្រូវ
បន្ទាបវិញ[ង] ៣៤ទ្រង់នឹងត្រាយ[ច]ព្រៃស្តុកដោយគ្រឿងដែក
ហើយព្រៃល្បាណូន[ឆ]នឹងត្រូវដួលទៅ ដោយអំណាចនៃអ្នក
មានអានុភាព[ជ]។

## មែកដែលដុះចេញពីលោកអ៊ីសាយ

**១១** ១មានលំពង់[ក]១នឹងដុះចេញពីគល់[ខ]របស់អ៊ីសាយ[គ]
ហើយមែក[ឃ]១ ដែលចេញពីឫសគាត់ នឹងកើតមានផលផ្លែ[ង]
២ព្រះវិញ្ញាណ[ច]នៃព្រះយេហូវ៉ា នឹងសណ្ឋិតនៅលើអ្នកនោះ
គឺជាព្រះវិញ្ញាណនៃប្រាជ្ញា[ឆ]និងយោបល់ ជាព្រះវិញ្ញាណនៃ
គំនិតវាងវៃ និងឫទ្ធានុភាព[ជ] ជាព្រះវិញ្ញាណនៃសេចក្តីចេះ
ដឹង នឹងសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា ៣អ្នកនោះនឹង
វៃរហ័ស ចំពោះសេចក្តីកោតខ្លាច[ឈ]ដល់ព្រះយេហូវ៉ា
ហើយនឹងជំនុំជំរះ មិនមែនតាមភ្នែកមើលឃើញ[ញ] ឬសំរេច
សេចក្តីតាមត្រចៀកស្តាប់ឮនោះឡើយ[ដ] ៤គឺនឹងជុំជំរះពួក
ទាល់ក្រ[ឋ] ដោយសេចក្តីសុចរិត[ឌ] ហើយសំរេចក្តីឱ្យមនុស្ស
រាបសា[ឍ]នៅផែនដី ដោយសេចក្តីទៀងត្រង់[ណ] ក៏នឹងវាយ
ផែនដីដោយ រំពាត់នៃមាត់ខ្លួនព្រមទាំងប្រហារ[ត]ជីវិត
មនុស្សដែលប្រព្រឹត្តអាក្រក់[ថ] ដោយខ្យល់ដង្ហើម[ទ]ពីបបូរ
មាត់ផង[ធ] ៥សេចក្តីសុចរិត និងបានជាខ្សែក្រវាត់[ន]ចង្កេះ
របស់អ្នកនោះ ហើយសេចក្តីស្មោះត្រង់[ប]ជាខ្សែក្រវាត់
កំឡាំងផង[ផ]។

៦នៅគ្រានោះ ឆ្កែព្រៃនឹងនៅជាមួយនឹងកូនចៀម[ព] ឯ
ខ្លារខិន នឹងដេកនៅជាមួយនឹងកូនពពែ ឯកូនគោនិង
សិង្ហស្ទាវ ព្រមទាំងសត្វបំប៉នយ៉ាងធាត់នឹងនៅជាមួយគ្នា
ហើយក្មេងតូចៗជាអ្នកគង្វាលវា ៧គោញីនឹងខ្លាឃ្មុំនឹងរក
ស៊ីជាមួយគ្នា ហើយកូនវានឹងដេកនៅជាមួយដែរ ឯសិង្ហ
នឹងស៊ីចំបើងដូចជាគោវិញ[ភ] ៨កូន[ម]មនុស្សដែលនៅបៅ
ដោះ នឹងលេងនៅត្រង់មាត់រន្ធពស់ហនុមាន ហើយក្មេង
លែង ដោះនឹងលូកដៃចូលទៅក្នុងរូងពស់វែក[យ]បាន ៩វា
រាល់គ្នា នឹងមិនធ្វើទុក្ខឬបំផ្លាញ[រ]គ្នា នៅគ្រប់លើភ្នំ
បរិសុទ្ធរបស់អញ[ល] ដ្បិតគ្រប់ទាំងអស់នឹងស្គាល់[វ]ព្រះ
យេហូវ៉ា នៅពេញពាសលើផែនដី[ស] ដូចជាទឹកនៅពេញ
ពាសក្នុងសមុទ្រដែរ ១០នៅគ្រានោះ[ហ] ឫសនៃអ៊ីសាយ[ឡ]
នឹងបានតាំងឡើង ទុកជាទង់[អ]ដល់ជនជាតិទាំងឡាយ ឯគ្រប់
សាសន៍[ក] គេនឹងស្វែងរកអ្នកនោះ[ខ] ឯទីសំរាក[គ]របស់អ្នក
នោះនឹងបានជាទីរុងរឿងឧត្តម[ឃ]។

**១០:៣៣** គ នក ១២:១២ ឃ អស ២:១៣ អម ២:៩ អស ៥:១៥ **១០:៣៤** ច ណហ ១:១២ សក ១១:២ ឆ ២ពវ ១៩:២៣ លប ៤៩:២៤ ទដ ៩៣:៤ អស ៣៣:២១ **១១:១** ក ២ពវ ១៩:២៦ យប ១៤:៧ ខ យប ១៤:៨ គ ខ.១០ អស ៩:៧ មថ ១:១ វវ ៥:៥ ឃ អស ៤:២ ង ២ពវ ១៩:៣០ អស ២៧:៦ **១១:២** ច ពជ ៣:១០ អស ៣២:១៥ ៤២:១ ៤៤:៣ ៤៨:១៦ ៥៩:២១ ៦១:១ អក ៣៧:១៤ ៣៩:២៩ យអ ២:២៨ មថ ៣:១៦ យហ ១:៣២–៣៣ ១៦:១៣ ឆ នក ២៨:៣ អភ ១:១៧ កឡ ២:៣ ជ អស ៩:៦ ២ធថ ១:៧ **១១:៣** ឈ អស ៣៣:៦ យហ ៧:២៤ យហ ២:២៥ **១១:៤** ឋ ទដ ៧២:៤ ឌ ទដ ៧២:២ អស ១៤:៣០ ឍ យប ៥:១៦ អស ៣:១៤ ណ អស ៩:៧ វវ ១៩:១១ ត អស ២៧:៧ ៣០:៣១ សក ១៤:១២ មឡ ៤:៦ ថ យប ៤០:១៨ ទដ ២:៩ វវ ១៩:១៥ ទ យប ៤:៩ ទដ ១៨:៨ អស ៣០:២៨,៣៣ ៤០:២៤ ៥៩:៩ អគ ២១:៣១ ២ថន ២:៨ សភ ទដ ១៣៩:១៩ **១១:៥** ន នក ១២:១១ ១ពវ ១៨:៤៦ ប អស ២៥:១ ផ អភ ៦:១៤ **១១:៦** ព អស ៦៥:២៥ **១១:៧** ភ យប ៤០:១៥ **១១:៨** ម អស ៦៥:២០ យ អស ១៤:២៩ ៣០:៦ ៥៩:៥ **១១:៩** រ ជន ២៥:១២ អស ២:៤ ៩:៧ ល ទដ ៤៨:១ អស ២:២ វ នក ៧:៥ អស ១៩:២១ ៤៥:៦,១៤ ៤៩:២៦ យរ ២៤:៧ ៣១:៣៤ ហព ២:១៤ ស ១សយ ១៧:៤៦ ទដ ៩៨:២–៣ អស ៤៥:២២ ៤៨:២០ ៥២:១០ **១១:១០** ហ អស ១០:២០ ឡ ខ.១ អ ទដ ២០:៥ អស ១៨:៣ យរ ៤:៦ យហ ១២:៣២ ក អស ២:៤ ១៤:១ ៤៩:២៣ ៥៦:៣,៦ ៦០:៥,១០ លក ២:៣២ កច ១១:១៨ ខ រម ១៥:១២ គ ទដ ១១៦:៧ អស ១៤:៣ ២៨:១២ ៣២:១៧–១៨ ៤០:២ យរ ៦:១៦ ៣០:១០ ៤៦:២៧ ឃ ហក ២:៩ សក ២:៥

**១០:៣៤** *ព្រៃល្បាណូន* គឺសំដៅទៅលើដើមតាត្រៅនៅភ្នំល្បាណូន(មើលការពន្យល់ ២:១៣ ៩:១០ ១៤:៨) ។

**១១:១** *លំពង់១ . . . ពីគល់* គឺពួកអាសស៊ើរទាំងអស់តែសាសន៍យូដាត្រូវបានបំផ្លាញវាក៏ជាការជំលៀសពួកបាប៊ីឡូន ដែលនាំឱ្យនគរយូដាត្រូវបានបាត់បង់ក្នុងឆ្នាំ ៥៨៦ មុន គ.ស ។ តែព្រះមែស៊ីនិងបានលើកឡើងដូចលំពង់១ (ពន្លក) ដែលចេញពីគល់របស់ពង្សស្តេចដាវីឌ ។ សូមមើល ៦:១៣ និងការពន្យល់ ។ គឺជាព្រះបិតារបស់ដាវីឌ (មើល ១សយ ១៦:១០–១៣) ។ *មែក១* មើលការពន្យល់ ៤:២ មថ ២:២៣ ។

**១១:២** *ព្រះវិញ្ញាណនៃព្រះយេហូវ៉ានិងសណ្ឋិតនៅលើអ្នកនោះ* ក៏មានព្រះមែស៊ីស្តេចដាវីឌ (១សយ ១៦:១៣) និងបានទទួលឫទ្ធានុភាពដោយព្រះវិញ្ញាណបរិសុទ្ធ (សូមមើល ៦១:១ និងការពន្យល់) ។ *ប្រាជ្ញានឹងយោបល់. . . នឹងឫទ្ធានុភាព* គឺជាព្រះវិញ្ញាណនិងជួយដល់អ្នកនោះឱ្យមានប្រាជ្ញា ដើម្បីជាទិសដៅដ៏ឆ្លាតវ៉ៃដែលមានអំណាចព្រះចេស្តាគ្រប់ការទាំងអស់ (សូមមើលការពន្យល់ ៩:៦) ។ *សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើល សភ ១:៧ និងការពន្យល់ ។

**១១:៣** *វៃរហ័សចំពោះសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើល ៨:២៩

**១១:៤** *សេចក្តីសុចរិត . . . សេចក្តីទៀងត្រង់* អ្នកដឹកនាំសាសន៍អ៊ីស្រាអែលសព្វថ្ងៃគឺពុំមានលក្ខណៈសម្បត្តិទាំងអស់នេះទេ (សូមមើល ១:១៧ ៥:៧ ក៏មើលការពន្យល់ ៩:៧) ។ *រំពាត់នៃមាត់ខ្លួន* គឺពួកអាសស៊ើរជារំពាត់របស់ព្រះអម្ចាស់ក្នុង ១០:៥,២៤ ប៉ុន្តែព្រះមែស៊ីនិងដឹកនាំជាតិសាសន៍ដោយប្រើដំបងរាជ្យ (សូមមើល ទដ ២:៩ វវ ២:២៧ និងការពន្យល់ ១៩:១៥) ។

**១១:៥** *ខ្សែក្រវាត់* គឺជាការរៀបចំនូវសកម្មភាពដើម្បីជាការត្រៀម (មើល ៥:២៧) ។

**១១:៦–៩** ភាពសុខសាន្ត និងសុវត្ថិភាពរបស់យុគសម័យព្រះមែស៊ី ដែលបញ្ជាំងពីសេចក្តីពិត ដែលកូនក្មេងពុំមានគ្រោះថ្នាក់អ្វីដល់គេឡើយនៅក្នុងចំណោមសត្វទាំងឡាយ ។ គឺដូចជាការបង្ហាញពីលក្ខខ័ណ្ឌនៃនគរស្ថានសួគ៌ សូមមើល ២:២–៤ ៣៥:៩ ៦៥:២០–២៥ និងការពន្យល់ អគ ៣៤:២៥–២៩ ។

**១១:៩** *ភ្នំបរិសុទ្ធរបស់អញ* សូមមើល ២:២–៤ និងការពន្យល់ ។ ហើយព្រះយេហូវ៉ាមានព្រះនាមល្បីសព្វទីកន្លែងដូចជាព្រះបន្ទូលបានបង្រៀននៅក្នុងក្រុងយេរូសាឡិម (សូមមើល ហប ២:១៤ និងការពន្យល់) ។

**១១:១០** *នៅគ្រានោះ* សូមមើលការពន្យល់ ១០:២០,២៧ ។ *ឫសនៃអ៊ីសាយ* ដែលជាប្រធានបទនៃការងារព្រះមែស៊ី ដែលមានទំនាក់ទំនង ខ.១ (សូមមើល ៥២:២ រម ១៥:១២ វវ ៥:៥ ២២:១៦ និងការពន្យល់ ។

១១នៅគ្រានោះ[ង] ព្រះអម្ចាស់ទ្រង់នឹងលូកព្រះហស្តទ្រង់
ទៅម្តងទៀត ដើម្បីនឹងប្រមូលពួកសំណល់[ច]នៃរាស្ត្រទ្រង់
ដែលសល់នៅ ឱ្យមកពីស្រុកអាសសើរ[ឆ] ស្រុកអេស៊ីព្ទ[ជ]
ស្រុកប៉ាត្រូស ស្រុកគូស[ឈ] ស្រុកអេឡាំ[ញ] ស្រុកស៊ីណើរ
ស្រុកហាម៉ាត[ដ] ហើយពីអស់ទាំងកោះ[ឋ]នៅសមុទ្រមកវិញ[ឌ]
១២ទ្រង់នឹងលើកទង់[ឍ]១ឡើងសំរាប់អស់ទាំងសាសន៍ ហើយ
នឹងប្រមូល[ណ]ពួកព្រាត់ប្រាសនៃសាសន៍អ៊ីស្រាអែល[ត]
ព្រមទាំង រួបរួមពួកខ្ចាត់ខ្ចាយរបស់សាសន៍[ថ]យូដាមកពីទិស
ទាំង៤នៃផែនដី[ទ] ១៣ឯសេចក្តីច្រណែនរបស់ពួកអេប្រាអិម
នោះនឹង បាត់ទៅ ហើយអស់អ្នកក្នុងពួកយូដាដែលធ្វើទុក្ខ
គេ និងត្រូវកាត់ចេញ ពួកអេប្រាអិមនឹងលែងមានសេចក្តី
ច្រណែនចំពោះពួកយូដា ហើយពួកយូដានឹងលែងធ្វើទុក្ខ
ដល់ពួកអេប្រាអិម[ធ] ១៤គេនឹងរួមចិត្តគ្នាឆាបចុះទៅលើ
ស្មាសាសន៍ភីលីស្ទីន[ន]នៅទិសខាងលិច ក៏នឹងប្លន់ពួកអ្នកនៅ
ស្រុកខាងកើតជាមួយគ្នា[ប] គេនឹងលូកដៃទៅបង្ក្រាបសាសន៍
អេដំម[ផ] និងសាសន៍ម៉ូអាប់[ព] ឯពួកកូនចៅអាំម៉ូន[ភ] និងស្តាប់
បង្គាប់គេដែរ[ម] ១៥ព្រះយេហូវ៉ាទ្រង់នឹងបំផ្លាញ[យ]ដៃសមុទ្រ
អេស៊ីព្ទអស់រលីង ហើយនិងលើកព្រះហស្ត[រ]ទៅលើទន្លេ
បញ្ចេញខ្យល់ដ៏ខ្លាំង[ល]របស់ទ្រង់ ទៅវាយទន្លេ[វ] ឱ្យបែកជា
៧ផ្លូវ ដើម្បីឱ្យមនុស្សដែលពាក់ស្បែកជើងដើរឆ្លងទៅ
បាន[ស] ១៦ហើយនិងមានថ្នល់[ហ]១សំរាប់ពួកសំណល់[ឡ]នៃ
រាស្ត្រទ្រង់ ដែលរួចពីស្រុកអាសសើរមក[អ] ដូចជាមាន
សំរាប់សាសន៍អ៊ីស្រាអែល នៅគ្រាដែលគេឡើងរួចពីស្រុក
អេស៊ីព្ទមកដែរ[ក]។

## បទចម្រៀងសរសើរតម្កើង

**១២** ១នៅគ្រានោះ[ក]ឯងនិយាយថា ឱព្រះយេហូវ៉ា អើយ
ទូលបង្គំនឹងអរព្រះគុណ[ខ]ដល់ទ្រង់ ដ្បិតទោះបើទ្រង់បាន
ខ្ញាល់នឹងទូលបង្គំក៏ដោយ តែឥឡូវនេះ សេចក្តីខ្ញាល់នោះ
បានបែរចេញទៅហើយ[គ] ទ្រង់បានកំសាន្តចិត្ត[ឃ]ទូលបង្គំ
វិញ ២មើល ព្រះទ្រង់ជាសេចក្តីសង្គ្រោះរបស់ខ្ញុំ[ង] ខ្ញុំនឹងទុក

**១០:១១** ង អស ១០:២០ ច ចទ ៣០:៤ អស ១:៩ **១១:១១** ឆ អស ១៩:២៤ ហស ១១:១១ មីក ៧:១២ សក ១០:១០ ជ យរ ៤៤:១,១៥ អគ ២៩:១៤ ៣០:១៤ ឈ លប ១០:៦ កច ៨:២៧ ញ លប ១០:២២ ដ អស ១០:៩ ឋ អស ២៤:១៥ ៤១:១,៥ ៤២:៤,១០,១២ ៤៩:១ ៥១:៥ ៥៩:១៨ ៦០:៩ ៦៦:១៩ ឌ អស ៤៩:១២ យរ ១៦:១៥ ៤៦:២៧ អគ ៣៨:៨ សក ៨:៧ **១១:១២** ឍ ទដ ២០:៥ ណ អស ១៤:២ ៤៣:៥ ៤៩:២២ ៥៤:៧ យរ ១៦:១៥ ៣១:១០ ៣២:៣៧ ត នហ ១:៩ ទដ ១០៦:៤៧ អស ១៤:១ ៤១:១៤ ៤៩:៥ ថ អគ ២៨:២៥ សផ ៣:១០ ទ ទដ ៤៨:១០៦៧:៧ អស ៤១:៥ វវ ៧:១ **១១:១៣** ធ ២របា ២៨:៦ យរ ៣:១៨ អគ ៣៧:១៦–១៧,២២ ហស ១:១១ **១១:១៤** ន ២របា ២៦:៦ ២៨:១៨ ប ពច ៦:៣ ផ ជន ២៤:១៨ ទដ ១៣៧:៧ អស ៣៤:៥–៦ ៦៣:១ យរ ៤៩:២២ អគ ២៥:១២ ដយ ១១:៤១ យអ ៣:១៩ អប ១:១ មឡ ១:៤ ព អស ១៥:១ ១៦:១៤ ២៥:១០ យរ ៤៨:៤០ សផ ២:៨–១១ ភ ពច ១១:១៤–១៨ ម អស ២៥:៣ ៦០:១២ **១១:១៥** យ នក ១៤:២២ ចទ ១១:១០ អស ៣៧:២៥ ៤២:១៥ យរ ៥០:៣៨ ៥១:៣៦ រ អស ១៩:១៦ ៣០:៣២ ល លប ៤១:៦ វ អស ៧:២០ ស នក ១៤:២៩ **១១:១៦** ហ អស ១៩:២៣ ៣៥:៨ ៤០:៣ ៤៩:១១ ៥១:១០ ៥៧:១៤ ៦២:១០ យរ ៥០:៥ ឡ លប ៤៥:៧ អ ខ.១១ ក នក ១៤:២៦–៣១ **១២:១** ក អស ១០:២០ ខ ទដ ៩:១ អស ២៥:១ គ យប ១៣:១៦ ឃ ទដ ៧១:២១ **១២:២** ង អស ១៧:១០ ២៥:៩ ៣៣:៦ ៤៥:១៧ ៥១:៥,៦ ៥៤:៨ ៥៩:១៦ ៦១:១០ ៦២:១១

**១១:១១** *ម្តងទៀត* មានលើកទីមួយគឺការចេញពីស្រុកអេស៊ីព្ទ (មើល ខ.១៦) ការធ្វើដំណើរលើកទីពីរគឺចេញពីស្រុកអាសសើរ និងការជម្លៀសពីស្រុកបាប៊ីឡូន ។ តាមរយៈអ្នកបកស្រាយខ្លះពោលថា ការនេះកើតឡើងបន្ទាប់ពីការខូចខាតបាក់បែកក្រុងយេរូសាឡិម ។ គឺក្នុង គ.ស ទី៧០ គឺទាក់ទងនឹងការយាងត្រឡប់មកវិញជាលើកទី២ ។ *ពួកសំណាក់* សូមមើលការពន្យល់ ១:៩ ១០:២០–២២ ។ *ស្រុកអេស៊ីព្ទ* គឺជាតំបន់នៃដីសណ្ឋានទន្លេ (ទន្លេធំ) នៅឯតំបន់ខាងជើងនៃស្រុកអេស៊ីព្ទ (អេស៊ីព្ទតំបន់ខាងលើ) ។ ឯអេស៊ីព្ទខាងត្បូងដែលចេញពីតំបន់ខាងជើងភាគខាងលិចនៃតំបន់ដីទាប (មើល ២១:២ នឹងការពន្យល់ យរ ៤៩:៣៤–៣៩ ដយ ៨:២) ។ *ស្រុកហាម៉ាត* សូមមើលការពន្យល់ ១០:៩ អស់ទាំងកោះនៅសមុទ្រ គឺពពួកកោះនៅតាមសមុទ្រមេឌីទែរ៉ាណេ (សូមមើល ៤១:១,៥ ៤២:៤ លប ១០:៥) ។

**១១:១២** *ប្រមូលពួកព្រាត់ប្រាស់* សូមមើល ២៧:១៣ ៤៩:២២ ៥៦:៨ ៦២:១០ ៦៦:២០ ។ *ពីទិសទាំង៤* "គឺស្លាបទាំង៤"គឺជាមួយភាគបួននៃផែនដីទាំងមូលដែលស្មើនិងចុងបំផុតនៃផែនដី (២៤:១៦ យប ៣៧:៣) ។

**១១:១៣** *សេចក្តីច្រណែនរបស់ពួកអេប្រាអិម* សូមមើលការពន្យល់ ៧:២ គឺពីមុនពួកសាសន៍អេប្រាអិម និងសាសន៍យូដាតែងតែមានជម្លោះវាយគ្នា (មើល ៩:២១ និងការពន្យល់) ។

**១១:១៤** ពួកអ្នកស្រុកខាងកើត គឺប្រហែលជាពួកអ្នកស្រុកម៉ាឌាន ដែលបានបង្ខិនសាសន៍អ៊ីស្រាអែលក៏បញ្ចូលទាំងប្រជារាស្ត្រនៅតំបន់ខាងកើត (មើល ៩:៤) ។ *សាសន៍អេដំម . . . ម៉ូអាប់ . . . កូនពៅអាំម៉ូន* គឺបន្ទាប់ពីការធ្វើដំណើរសាសន៍អ៊ីស្រាអែលពុំបានប៉ះពាល់សាសន៍ទាំងនោះទេ (មើល ពច ១១:១៤–១៨) ។ ក៏មានការជិះជាន់ផ្នែកខាងនយោបាយ ជិនាន់ក្រោយមកទៀតរបស់សាស្ត្រអ៊ីស្រាអែលក៏បង្ហាញក្នុង ១៤:២ ៤៩:២៣ ៦០:១២ (មើល ២៥:១០ ២៤:៥) ។

**១១:១៥** *បំផ្លាញដៃសមុទ្រអេស៊ីព្ទ* គឺជាការនិយាយប្រៀបដូចចំពោះការញែកទឹកសមុទ្រក្នុងរយៈពេលដែលរាស្ត្រអ៊ីស្រាអែលចេញដំណើរ (មើល នក ១៤:២១–២២) ។ *ដៃសមុទ្រ* សូមមើល "ឈូងសមុទ្រ"ក្នុងគម្ពីរ យស ១៥:២,៥) ។ ដូចជាទន្លេអ៊ើប្រាត វវ ១៦:១២ ដែលសម្តែងពីការធ្វើឱ្យទឹកទន្លេអ៊ើប្រាតរីងស្ងួតដែលជាការយករបាំងចេញពីមុខដើម្បីទទួល "ស្តេចមកពីទិសខាងកើត" ។

**១២:១–៦** គឺជាវគ្គទំនុកខ្លីៗពីរវគ្គដែលបង្ហាញឱ្យឃើញ (ខ.១–៣,៤–៦) ក៏សូមមើលការពន្យល់ ៧:១–១២:៦ មើលការពន្យល់ ៦:១ ផងដែរ ។

**១២:១,៤** *នៅគ្រានោះ* មើលការពន្យល់ ១០:២០,២៧ ។

**១២:១** *ទូលបង្គំអរព្រះគុណដល់ទ្រង់* "ទូលបង្គំ"គឺជាពាក្យសំដៅទៅលើជាតិសាសន៍ដែលសរសើរតម្កើងដល់ព្រះ ។ *សេចក្តីខ្ញាល់នោះបានបែរចេញទៅហើយ* មើលការពន្យល់ ៩:១២,១៧,២១ ។ បន្ទាប់ពីព្រះបានដាក់ទណ្ឌកម្មសាសន៍អ៊ីស្រាអែលក្រោយមកសេចក្តីក្រោធរបស់ទ្រង់ គឺសំដៅទៅឯជាតិសាសន៍មួយចំនួនដូចជាអាសសើរនិងបាប៊ីឡូន ។

**១២:២** *ព្រះដ៏ជាព្រះយេហូវ៉ា* មើលការពន្យល់ នក ៣:១៥ ៣៤:៦–៧ ចទ ២៨:៥៨ ។ *ទ្រង់ដែលបានសង្គ្រោះខ្ញុំ* ឃ្លាទាំងនេះបង្ហាញពីគម្ពីរ នក ១៥:២

ចិត្ត[ច]ឥតមានសេចក្ដីខ្លាចឡើយ ពីព្រោះព្រះដ៏ជាព្រះ
យេហូវ៉ា[ឆ] ទ្រង់ជាកំឡាំង[ជ] ហើយជាបទចំរៀងរបស់ខ្ញុំ គឺ
ទ្រង់ដែលបានសង្គ្រោះខ្ញុំ[ឈ] ៣ដោយហេតុនោះឯងរាល់គ្នា
នឹងដងទឹក[ញ] ពីអណ្តូង[ដ]នៃសេចក្តីសង្គ្រោះដោយអំណរ
៤ហើយនៅគ្រានោះ[ឋ] ឯងរាល់គ្នានឹងពោលថា ចូរអរព្រះ
គុណដល់ព្រះយេហូវ៉ា ចូរអំពាវនាវដល់ព្រះនាមទ្រង់[ឌ] ចូរ
សរសើរពីកិច្ចការទាំងប៉ុន្មានរបស់ទ្រង់ចុះ នៅកណ្តាល
ប្រជាជនទាំងឡាយ[ឍ] ចូរប្រកាសប្រាប់ថា ព្រះនាមទ្រង់
ខ្ពស់វិសេស[ណ] ៥ចូរច្រៀង[ត]ថ្វាយព្រះយេហូវ៉ា ពីព្រោះទ្រង់
បានធ្វើការដ៏ប្រសើរ[ថ] ត្រូវឱ្យមនុស្សដឹងដំណឹងនេះ នៅ
ពេញលើផែនដីផង ៦ឱពួកអ្នកនៅក្រុងស៊ីយ៉ូនអើយ ចូរបន្លឺ
សំឡេងឡើង ហើយស្រែកហ៊ោដោយអំណរចុះ[ទ] ដ្បិតព្រះ
ដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល[ធ] ទ្រង់ធំប្រសើរ[ន]នៅកណ្តា
ឯងរាល់គ្នា[ប] ។

## សេចក្តីទំនាយទាស់នឹងសាសន៍បាប៊ីឡូន

**១៣** ១នេះជាសេចក្តីទំនាយយ៉ាងធ្ងន់[ក]ដែលអេសាយ ជា
កូនអ៊ីម៉ូស[ខ] បានឃើញពីស្រុកបាប៊ីឡូន[គ,ឃ] ។
២ចូរលើកទង់[ង]១សំរាប់ឯងរាល់គ្នា នៅលើភ្នំត្រងិល
ចុះចូរបន្លឺសំឡេងឡើង ហើយបោយដៃហៅ ដើម្បីឱ្យគេ
បានចូលទៅ តាមទ្វា[ច]របស់ពួមនុស្សដ៏មានត្រកូលខ្ពស់
៣អញបានបង្គាប់ដល់ពួកបរិសុទ្ធរបស់អញ អើ អញបាន
ហៅពួក ខ្លាំងពូកែ[ឆ]របស់អញ សំរាប់នឹងសំរេចសេចក្តី
កំហឹងរបស់អញ[ជ] គឺជាពួកអ្នកដែលសេចក្តីអំណរ[ឈ]ចំពោះ
សេចក្តីខ្ពង់ខ្ពស់របស់អញ ៤មានឮសូរគឹកកងរបស់មនុស្ស
កកកុញនៅលើភ្នំ គឺជាសូរដូចជាប្រជាជាតិយ៉ាងធំ[ញ]ជាសូរ

**១២:២** ច យប ១៣:១៥ ទដ ២៦:១ ១១២:៧ អស ២៦:៣ ដយ ៦:២៣ ឆ អស ២៦:៤ ៣៨:១១ ជ ទដ ១៨:១ ឈ នក ១៥:២ **១២:៣** ញ ២ពវ ៣:១៧ ទដ ៣៦:៩ យរ ២:១៣ ១៧:១៣ យហ ៤:១០,១៤ ដ នក ១៥:២៥ **១២:៤** ឋ អស ១០:២០ ឌ នក ៣:១៥ ទដ ៨០:១៨ ១០៥:១ អស ២៤:១៥ ២៥:១ ២៦:៨,១៣ ហស ១២:៥ ឍ អស ៥៤:៥ ៦០:៣ យរ ១០:៧ សផ ២:១១ មឡ ១:១១ ណ ទដ ១១៣:២ **១២:៥** ត នក ១៥:១ ថ ទដ ៩៨:១ **១២:៦** ទ លប ២១:៦ ទដ ៩៨:៤ អស ២៤:១៤ ៤៨:២០ ៥២:៨ យរ ២០:១៣ ៣១:៧ សក ២:១០ ធ ទដ ៧៨:៤១ ៩៩:២ អស ១:២៤ ១០:២០ ១៧:៧ ២៩:១៩ ៣៧:២៣ ៤៣:៣,១៤ ៤៥:១១ ៤៩:២៦ ៥៥:៥ អគ ៣៩:៧ ន ទដ ៤៨:១ ប ទដ ៤៦:៥ សផ ៣:១៤–១៧ **១៣:១** ក អស ១៤:២៨ ១៥:១ ២១:១ ណហ ១:១ ហព ១:១ សក ៩:១ ១២:១ មឡ ១:១ អស ២០:២ ៣៧:២ ខ អស ២០:២ ៣៧:២ គ អស ១:១ ឃ ខ.១៩ លប ១០:១០ អស ១៤:៤ ២១:៩ ៤៦:១–២ ៤៨:១៤ យរ ២៤:១ ២៥:១២ វវ ១៤:៨ **១៣:២** ង ទដ ២០:៥ យរ ៥០:២ ៥១:២៧ ច អស ២៤:១២ ៤៥:២ យរ ៥១:៥៨ **១៣:៣** ឆ ខ.១៧ អស ២១:២ យរ ៥១:១១ ដយ ៥:២៨,៣១ យអ ៣:១១ ជ យប ៤០:១១ អស ១០:៥ ឈ ទដ ១៤៩:២ **១៣:៤** ញ យអ ៣:១៤

ដែលបានពណ៌នាពីការវាយបំបាក់ខ្មាំងសត្រូវ គឺពួកសាសន៍អេស៊ីព្ទនៅឯសមុទ្រក្រហម សូមមើល ទដ ១១៨:១៤ និងការពន្យល់ ។

**១២:៣** *អណ្តូង* គឺជាការប្រៀបធៀបពីការដែលព្រះបានប្រទានទឹកឱ្យដល់ពួកអ៊ីស្រាអែលក្នុងខណៈពេលដែលពួកគេវង្វេង នៅឯវាលរហោស្ថាន (ប្រៀប ធៀបនឹង នក ១៥:២៥,២៧) ។ (សូមមើល ទដ ៣៦:៩ យរ ២:១៣ យហ ៤:១០ និងការពន្យល់) ។

**១២:៦** *ចូរបន្លឺសំឡេងឡើងហើយស្រែកហ៊ោដោយអំណរចុះ* ហេតុការដ៏សំខាន់ទាំងពីសណ្ឋាននេះក៏មានលេចឱ្យឃើញក្នុង ៤៥:១ ហើយទីនោះក៏បង្ហាញនូវពួកក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិម) សប្បាយអំណរនូវចំពោះការដែលពួកគេបានគេចផុតពីគ្រោះថ្នាក់ ហើយវិលមករកភាពសុខសាន្តវិញ ។ *ដ្បិតព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* មើលការពន្យល់ ១:៤ ៦:១ ។

**១៣:១–២៣:១៨** នេះគឺជាខ្សែប្រវត្តនៃសេចក្តីទំនាយយ៉ាងច្រើនសន្ធឹកដែលប្រឆាំងនិងជាតិសាសន៍មួយចំនួន (សូមមើល យរ ៤៦–៥១ អគ ២៥–៣២ អម ១–២ សផ ២:៤–១៥ និងការពន្យល់) ។ ការនោះក៏មានកើតឡើងជាមួយនិងពួកបាប៊ីឡូន (១៣:១–១៤:២៣) ហើយនិងពួកសាសន៍អាសស៊ើរ (១៤:២៤–២៧) ។ ទ្រង់បានក្រោធចំពោះជាតិសាសន៍តូចៗខ្លះទៀត ។ (សូមមើល យរ ២៥:២៩) តាមការពិតការជំនុំជម្រះរបស់ព្រះចំពោះជាតិសាសន៍ដែលទ្រង់សង្គ្រោះគឺជារាស្ត្ររបស់ទ្រង់ (សូមមើល ១០:១២) ។

**១៣:១–១៤:២៧** សេចក្តីទំនាយនេះគឺផ្តោតទៅលើពួកបាប៊ីឡូនក្នុងពេលចក្រភពអាសស៊ើរកាន់កាប់ ។ គឺជាជាងក្នុងចក្រភពបាប៊ីឡូន ហើយចក្រភពបាប៊ីឡូនក៏បង្កើតទីក្រុងដ៏សំខាន់របស់គេទាំងពីរ ឆ្នាំ ៧២៩ មុន គ.ស ។ គឺជាផ្ទៃរឿងប្រាប់ពីស្តេចគឺ"ស្តេចស្រុកបាប៊ីឡូន"គ្មានការពន្យល់ណាដែលប្លែកសោះ សូមមើល ១៤:២៤–២៧ ។

**១៣:១** សូមមើលការពន្យល់ ១:១ "ពាក្យឬសេចក្តីទំនាយ" ដែលមានទំនាក់ទំនងនិងព្រះគម្ពីរភាសាព្រើរមានន័យថា"លើកតំកើង" ដូចជាការលើកសំឡេងឡើង ឬក៏ការទទួលបន្ទុក ឬទទួលរងការឈឺចាប់ ។ ដូចជា"សេចក្តីទំនាយ" ជារឿយមានសរសេរទៅដោយអត្ថបទនៃការរងទុក្ខវេទនា ។ *ស្រុកបាប៊ីឡូន* មើល ២១:១–៩ ៤៦:១–២ ៤៧:១–១៥ យរ ៥០:៥១ និងការពន្យល់ ។ ការជំនុំជម្រះបានប្រកាសលើកដំបូង ដោយសារតែមានពួកអាសស៊ើរគំរាម កំហែងដោយសារពួកបាប៊ីឡូន ដែលនាំឱ្យស្រុកយូដានិងក្រុងយេរូសាឡិមដួលធ្លាក់ចុះក្នុងចន្លោះឆ្នាំ ៦០៥ និង ៥៨៦ មុន គ.ស ស្រុកបាប៊ីឡូនត្រូវបាន គ្រប់គ្រងដោយពួកស្តេចស៊ីរូស (មើល ៤៥:១ ៤៧:១) ហើយក្នុងឆ្នាំ ៥៣៩ គេក៏មានអំណាចពេញទាំងផែនដីក៏បំពាក់គ្រឿងសឹកប្រឆាំងនឹងនគរព្រះ (ប្រៀបធៀប ១ពត ៥:១) និងការបរាជ័យចុងក្រោយរបស់ពួកគេបានឃើញក្នុង វវ ១៤:៨ ១៦:១៩,១៧–១៨ ខណៈដែលស្ថិតនៅក្រោមរបស់ចក្រភពអាសស៊ើរ (មើល ១៤:២៤–២៧ និងការពន្យល់ ១៣:១–១៤:២៧) ។

**១៣:២** *ចូរលើកទង់១* សូមមើលការពន្យល់ ៥:២៦ ។

**១៣:៣** *ពួកបរិសុទ្ធរបស់អញ* គឺជាអ្នកញែកខ្លួនជាបរិសុទ្ធ ដើម្បីដើរក្នុងផ្លូវរបស់ព្រះ គឺអនុវត្តទៅតាមព្រះហឫទ័យនៃព្រះ ។ នៅទីនោះក៏បានឃើញពួកស្តេចពើស៊ីដែលស្ថិតនៅក្រោមស៊ីរូស (សូមមើលការពន្យល់ ខ.១) សូមប្រៀបធៀប ១០:៥ ដែលព្រះបានហៅពួកអាសស៊ើរថា"ជាដំបងនៃសេចក្តីកំហឹងរបស់អញ" ។ សូមមើល ៤៥:១ និងការពន្យល់ សេចក្តីកំហឹង គឺកំហឹងរបស់ព្រះលែងមានចំពោះរាស្ត្រអ៊ីស្រាអែលទៀតឡើយ គឺបានងាកបែរទៅរកសត្រូវរបស់អ៊ីស្រាអែលវិញ (សូមមើល ខ.៥,៩,១៣ ប្រៀបធៀប ៣០:២៧) គឺព្រះអម្ចាស់ពិតជាដាក់ទណ្ឌកម្មដល់អំពើបាប (មើល ខ.១១) ។

**១៣:៤** *គឺព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់កំពុងតែត្រួតត្រាមើលពលទ័ព* សូមមើលការពន្យល់ ១សត ១:៣ ។ ព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យ "ពលទ័ព" គឺជាទម្រង់ឯកវចនៈនៃពាក្យ "ពួកពលបរិវា" ព្រះអម្ចាស់គឺជាព្រះសិរសារបស់កងទ័ពសាសន៍អ៊ីស្រាអែល (១សយ ១៧:៤៥) គឺមានទាំង

អ៊ឹកធឹក[ដ] របស់នគរនៃសាសន៍ទាំងប៉ុន្មានប្រជុំគ្នា គឺព្រះ–
យេហូវ៉ានៃពួកពលបរិវារ[ឋ] ទ្រង់កំពុងតែត្រួតត្រាមើល[ឌ]
ពលទ័ពសំរាប់ចូលច្បាំង ៥គេមកពីស្រុកឆ្ងាយជាប្រទេស
នៅជើងមេឃទីបំផុត[ឍ] គឺព្រះយេហូវ៉ា ហើយនិងគ្រឿង
អាវុធ[ណ] នៃសេចក្តីគ្នាន់គ្នាញ់របស់ទ្រង់[ត] ដើម្បីនឹងបំផ្លាញ[ថ]
ស្រុក នះទាំងមូលទៅ ។
៦ចូរទ្រហោសោក[ទ]ពិលាបចុះ ដ្បិតថ្ងៃ[ធ]នៃព្រះយេហូវ៉ា
ជិតដល់ហើយ ថ្ងៃនោះនឹងមកដល់ទុកជាការបំផ្លាញ[ន]ដែល
មកពីព្រះដ៏មានគ្រប់ព្រះចេស្តា[ប] ៧ដោយហេតុនោះបានជា
ដៃមនុស្សទាំងអស់នឹងត្រូវខ្សោយ[ផ] ហើយចិត្តនៃមនុស្សទាំង
អស់នឹងរលត់ទៅ[ព] ៨គេនឹងស្រយុតចិត្តទៅ[ភ]សេចក្តីឈឺចាប់
នឹងសេចក្តីទុកលំបាកនឹងចាប់គេបាន[ម] គេនឹងឈឺចាប់ដូច
ស្ត្រីដែលហៀបនឹងសំរាលកូន[យ] គេនឹងស្រឡាំងកាំង មើល
គ្នាទៅវិញទៅមក ហើយមានទឹកមុខស្រមេះ[រ] ៩មើល ថ្ងៃ[ល]
នៃព្រះយេហូវ៉ាកំពុងតែមកដល់ ជាថ្ងៃដ៏សហ័ស[វ]ដោយ
សេចក្តីក្រោធ[ស] និងកំហឹងយ៉ាងខ្លាំង[ហ]ដើម្បីនឹងបំផ្លាញស្រុក
ឱ្យរលីង ហើយនឹងធ្វើឱ្យមនុស្សមានបាបសូន្យចេញ ១០ពី
ព្រោះអស់ទាំងផ្កាយនៅលើមេឃ និងផ្កាយចក្ររាសី នឹង
លែងបញ្ចេញពន្លឺ[ឡ] ព្រះអាទិត្យនឹង[អ]ងងឹត[ក] តាំងតែពីរះ
ឡើងហើយព្រះចន្ទក៏នឹងអាប់រស្មីទៅដែរ[ខ] ១១អញនឹងធ្វើ
ទោស[គ]ដល់លោកីយ ដោយព្រោះអំពើអាក្រក់របស់គេ
ព្រមទាំង មនុស្សដែលប្រព្រឹត្តបទអាក្រក់[ឃ] ដោយព្រោះ
អំពើទុច្ចរិតរបស់គេផង អញនឹងបំបាត់សេចក្តីឆ្មើងឆ្មៃ
របស់ពួកអំនួត[ង] ហើយនិងបន្ទាបបន្ថោក[ច]ឫកខ្ពស់របស់
មនុស្សកាចអាក្រក់[ឆ] ១២អញនឹងធ្វើឱ្យកម្រមានមនុស្ស[ជ] ដូច
ជាកម្រមានមាសសុទ្ធដែរ គឺនឹងឱ្យមនុស្ស១នាក់កម្រមានជា
ជាងមាសពីស្រុកអូភារទៅទៀត[ឈ] ១៣ដូច្នេះ អញនឹងធ្វើឱ្យ
ផ្ទៃមេឃញាប់ញ័រ[ញ] ហើយផែនដីនឹងត្រូវកក្រើករំពើក[ដ]
ចេញពីកន្លែងធម្មតា គឺក្នុងគ្រានៃសេចក្តីក្រោធ[ឋ]របស់
ព្រះយេហូវ៉ា នៃពួកពលបរិវារ ហើយក្នុងថ្ងៃនៃសេចក្តី
ខ្ញាល់ដ៏សហ័សរបស់ទ្រង់[ឌ] ១៤នោះគេនឹងបានដូចជាប្រើស
ដែលត្រូវគេប្រដេញ[ឍ] ហើយដូចជាហ្វូងចៀមដែលឥតមាន
អ្នកគង្វាល[ណ] គ្រប់គ្នានឹងវិលទៅឯសាសន៍របស់ខ្លួនវិញ
ហើយរត់ទៅ[ត] ឯស្រុករបស់ខ្លួនគ្រប់ៗគ្នា[ថ] ១៥ឯអស់អ្នកដែល
ត្រូវប្រទះឃើញនោះនឹងត្រូវចាក់ទំលុះ ហើយអស់អ្នកណា
ដែលត្រូវចាប់បាន នោះនឹងត្រូវដួល[ទ]ដោយដាវ[ធ] ១៦កូន
ង៉ែត[ន]របស់ គេនឹងត្រូវបោកខ្ទេចខ្ទីនៅចំពោះភ្នែកផ្ទះគេ
នឹងត្រូវរឹបជាន់ឯប្រពន្ធគេ នឹងត្រូវគេកំហែងចិត្ត[ប] ។
១៧មើល អញនឹងញុះញង់[ផ]សាសន៍មេឌីឱ្យទាស់នឹងគេ[ព]

**១៣:៤** ដ ទដ ៤៦:៦ ឋ អស ៤៧:៤ ៥១:១៥ ឌ អស ៤២:១៣ យរ ៥០:៤១ **១៣:៥** ឍ អស ៥:២៦ ណ អស ៤៥:១ ៥៤:១៦ យរ ៥០:២៥ ត អស ១០:២៥ ថ យស ៦:១៧ អស ២៤:១ ៣០:២៥ ៣៤:២ **១៣:៦** ទ អស ១៤:៣១ ១៥:២ ១៦:៧ ២៣:១ អគ ៣០:២ យក ៥:១ ធ អស ២:១២ ន អស ១០:៣ ១៤:១៥ ប លប ១៧:១ **១៣:៧** ផ ២ពវ ១៩:២៦ យប ៤:៣ យរ ៤៧:៣ ព យស ២:១១ អគ ២១:៧ **១៣:៨** ភ ទដ ៣១:១៣ ៤៨:៥ អស ២១:៤ ម នក ១៥:១៤ យ លប ៣:១៦ យហ ១៦:២១ រ យអ ២:៦ ណហ ២:១០ **១៣:៩** ល អស ២:១២ យរ ៥១:២ វ យរ ៦:២៣ ស អស ៩:១៩ ហ អស ២៦:២១ ៦៦:១៦ យរ ២៥:៣១ យអ ៣:២ **១៣:១០** ឡ យប ៩:៧ អ អស ២៤:២៣ សក ១៤:៧ ក នក ១០:២២ អស ៥:៣០ វវ ៨:១២ ខ អគ ៣២:៧ អម ៥:២០ ៨:៩ មថ ២៤:២៩ មក ១៣:២៤ **១៣:១១** គ អស ៣:១១ ១១:៤ ២៦:២១ ៦៥:៦–៧ ៦៦:១៦ ឃ ទដ ១២៥:៣ ង ទដ ១០:៥ សភ ១៦:១៨ ដយ ៥:២៣ ច អស ២:៩ ២៣:៩ អគ ២៨:២ ដយ ៤:៣៧ ឆ អស ២៥:៣,៥ ២៩:៥,២០ ៤៩:២៥,២៦ **១៣:១២** ជ អស ៤:១ ឈ លប ១០:២៩ **១៣:១៣** ញ ទដ ១០២:២៦ អស ៣៤:៣ ៥១:៦ ដ យប ៩:៦ អស ១៤:១៦ មថ ២៤:៧ មក ១៣:៨ ឋ អស ៩:១៩ ឌ យប ៩:៥ **១៣:១៤** ឍ សភ ៦:៥ ណ ១ពវ ២២:១៧ មថ ៩:៣៦ យហ ១០:១១ ត លប ១១:៩ អស ១៧:១៣ ២១:១៥ ២២:៣ ៣៣:៣ យរ ៤:៩ ថ យរ ៤៦:១៦ ៥០:១៦ ៥១:៩ ណហ ៣:៧ **១៣:១៥** ទ យរ ៥១:៤ ធ អស ១៤:១៩ យរ ៥០:២៥ **១៣:១៦** ន ឧ.១៨ ជន ១៦:២៧ ២ពវ ៨:១២ ប លប ៣៤:២៩ ហស ១៣:១៦ **១៣:១៧** ផ យរ ៥០:៩,៤១ ៥១:១ ព ឧ.៣

អំណាច ទេវតា (១ពវ ២២:១៩ លក ២:១៣) ហើយអត្ថបទនេះ ក៏បង្ហាញពីទ័ព ឬពលទ័ពដែលនិងត្រូវបំផ្លាញពួកបាប៊ីឡូន ។

**១៣:៥** *ជាគ្រឿងអាវុធនៃសេចក្តីគ្នាន់គ្នាញ់* ឯពួកអាសស៊ើរគឺជារំពាត់ នៅក្នុងព្រះហស្តរបស់ផងទ្រង់ នូវពេលថ្ងៃរបស់ពួកអ៊ីស្រាអែលនិងពួកបាប៊ីឡូនផ្ទាល់ដែលបម្រើជាអាវុធរបស់ព្រះអម្ចាស់(មើល ១០:៥ និងការពន្យល់) ។

**១៣:៦,៩** *ថ្ងៃនៃព្រះយេហូវ៉ា* សូមមើលការពន្យល់ ២:១១,១៧,២០ ។

**១៣:៦** *ការបំផ្លាញ* សូមមើល យអ ១:១៥ មើលការពន្យល់ ៥:៧ ។ ពាក្យថា "ព្រះដ៏មានគ្រប់ព្រះចេស្តា" (ព្រះគម្ពីរភាសាហេព្រើរនិយាយថា សាដាយ) ក៏ដូចក្នុង យអ ១:១៥ មើលការពន្យល់ លប ១៧:១ ។

**១៣:៧** *ដៃមនុស្សទាំងអស់នឹងត្រូវខ្សោយ* គឺជាភាពបរាជ័យមួយ សូមមើល យរ ៦:២៤ ។

**១៣:៨** *ស្រយុតចិត្ត* គឺជាសង្គ្រាមពីព្រះយេហូវ៉ា គឺក្នុងនាមរបស់ទ្រង់ក៏នាំមកនូវភាពវក់វីស្លន់ស្លោរដល់មាសត្រូវ (មើល នក ១៥:១៤–១៦ ពច ៧:២២ នឹងការពន្យល់) ។ *សេចក្តីឈឺចាប់ . . . នឹងឈឺចាប់* គឺពួកហោរាតែងតែប្រៀបធៀបពីការឈឺចាប់ពីការជិនុំជម្រះ និងសង្គ្រាមទៅនិងការឈឺចាប់និងការដាក់ទណ្ឌកម្មប្រៀបធៀបដូចជាស្ត្រីឆ្លងទន្លេ (មើល ២៦:១៧ យរ ៤:៣១ ៦:២៤) ។

**១៣:១០** *ទាំងផ្កាយ . . . ព្រះអាទិត្យ . . . ព្រះចន្ទ* ដែលមានភាពងងឹតនៃចក្រវាឡដែលមានទំនាក់ទំនងនិងព្រះយេហូវ៉ា ។ សូមមើល យអ ២:១០,១៣ វវ ៦:១២–១៣ ប្រៀបធៀបនឹង ពច ៥:២០ ។

**១៣:១៣** *ផ្ទៃមេឃញាប់ញ័រ . . . ផែនដី . . . កក្រើករំពើក* គឺមានទាំងព្យុះផ្គររន្ទះ និងរញ្ជួយផែនដី បន្ទាប់មកក៏មានអំណាចព្រះចេស្តានៃព្រះយេ–ហូវ៉ា ក៏បានបង្ហាញឱ្យឃើញ (មើលការពន្យល់ ៣០:៣០ យស ១០:១១) ។

**១៣:១៤** *វិលទៅឯ* គឺពួកគេមកពីតំបន់មួយចំនួនក្នុងស្រុកអាសស៊ើរ ។

**១៣:១៦** *កូនង៉ែតរបស់គេនឹងត្រូវបោកខ្ទេចខ្ទី* គឺជាការឈ្លានពានរបស់កងទ័ពក៏ជាញឹកញយបានសម្លាប់កូនង៉ែត ក៏ពុំមានអ្នកចំបាំងទៀតទេ ក៏គ្មានសំណល់អ្វីនៅក្នុងទីក្រុងទេ (សូមមើល ទដ ១៣៧:៨–៩ ហស ១០:១៤ នឹងការពន្យល់ ណហ ៣:១០) ។ *រឹបជាន់ឯប្រពន្ធគេ* គឺជាស្ត្រីក៏ទទួសការឈឺចាប់យ៉ាងសន្ធឹកផងដែរនៅក្នុងសង្គ្រាមចំបាំង ។ ហើយប្តីរបស់គេក៏ត្រូវសម្លាប់ឯប្រពន្ធគេបង្ខំធ្វើស្រីពេស្យា (សូមមើលការពន្យល់ អម ៧:១៧) ។

ជាសាសន៍ដែលមិនរាប់អានប្រាក់ សូម្បីតែមាសក៏មិនមាន
ចិត្តរីករាយដែរ[ភ] ១៨ឯធ្នូ[ម]របស់សាសន៍នោះនឹងផ្តួលពួក
កំឡោះៗអស់រលីងទៅ[យ] គេនឹងឥតមានមេត្តា[រ]ចំពោះ
ផលកើតពីផ្ទៃឡើយ ភ្នែកគេមិនចេះប្រណីដល់ពួកក្មេងៗ
ដែរ[ល] ១៩នោះក្រុងបាប៊ីឡូន[វ]ដែលជាសិរីល្អនៃអស់ទាំង
នគរ[ស] ហើយជាទីលំអ[ហ]នៃសេចក្តីអំនួតរបស់សាសន៍ខាល់–
ដេ និងត្រូវដូចជាកាលព្រះបានរំលាង[ឡ]ក្រុងសូដុំម និងក្រុង
កូម៉ូរ៉ាបង់[អ] ២០ក្រុងនោះនឹងគ្មានអ្នកណានៅ[ក]តទៅទៀត
ឡើយ ក៏មិនដែលមានអ្នកណាអាស្រ័យនៅ ដរាបដល់អស់
ទាំងដំណមនុស្សតទៅ ទោះទាំងសាសន៍អារ៉ាប់[ខ] គេក៏មិន
ដំឡើងត្រសាលនៅទីនោះ ហើយពួកគង្វាលក៏មិននាំហ្វូង
សត្វ របស់គេទៅដេកនៅទីនោះដែរ ២១គឺនឹងមានតែសត្វ[គ]
ដែលនៅទីរហោស្ថានបានដេកនៅទីនោះវិញ ឯផ្ទះគេនឹង
មានពេញដោយសំឡេងសត្វយំ[ឃ] សត្វអូសទ្រីច[ង]នឹងអាស្រ័យ
នៅ ហើយពពែព្រៃ[ច]នឹងលោតកញ្ឆែងនៅទីនោះ ២២ហ្វូង
ឆ្កែព្រៃ[ឆ]នឹងលូនៅក្នុងដំណាក់របស់គេ[ជ] ហើយស្វាន[ឈ]នឹង
នៅក្នុងមន្ទីរ ជាទីសប្បាយរបស់គេដែរ ឯពេលវេលា
របស់ទីក្រុងនោះ ក៏ជិតមកដល់ហើយ[ញ] ថ្ងៃកំណត់នឹង–
មិនបន្ថយប៉ុន្មានទេ[ដ]។

**១៤** ១ពីព្រោះព្រះយេហូវ៉ា ទ្រង់នឹងអាណិតអាសូរ[ក]ដល់
ពួកយ៉ាកុប ហើយនឹងរើស[ខ]អ៊ីស្រាអែលទៀត ព្រមទាំង
ដាក់គេឱ្យនៅក្នុងស្រុករបស់គេវិញ[គ] ឯពួកអ្នកដែលស្នាក់
នៅ[ឃ] នោះនឹងចូលពួកគេ ហើយនៅជាប់នឹងពួកវង្សរបស់
យ៉ាកុប ២គឺសាសន៍ទាំងប៉ុន្មាននឹងនាំយក[ង]គេទៅឯទីកន្លែង
របស់គេវិញ ហើយពួកវង្សរបស់អ៊ីស្រាអែលនឹងបានពួក
សាសន៍ទាំងនោះ[ច]ទុកបាវប្រុសបាវស្រី នៅក្នុងស្រុករបស់
ព្រះយេហូវ៉ា គេនឹងចាប់អ្នកទាំងនោះជាឈ្លើយ[ឆ] ជាអ្នក
ដែលពីដើមបានចាប់ខ្លួនជាឈ្លើយនោះឯង ហើយនឹងគ្រប់
គ្រងលើពួកអ្នកដែលបានសង្កត់សង្កិនខ្លួនវិញ[ជ]។
៣នៅថ្ងៃដែលព្រះយេហូវ៉ាបានប្រោសប្រទាន ឱ្យឯង
បានសំរាក[ឈ]ពីសេចក្តីទុក្ខ សេចក្តីវេទនា[ញ] ហើយពីការបំរើ

**១៣:១៧** ភ ២ពវ ១៨:១៤–១៦ សភ ៦:៣៤–៣៥ **១៣:១៨** ម ទដ ៧:១២ អស ៤១:២ យរ ៥០:៩,១៤,២៩ យ ចទ ៣២:២៥ យរ ៤៩:២៦ ៥០:៣០ ៥១:៤ រ អស ៤៧:៦ យរ ៦:២៣ ៥០:៤២ ល ខ.១៦ អស ១៤:២២ ៤៧:៩ **១៣:១៩** វ ខ.១ ស អស ៤៧:៥ ដយ ២:៣៧–៣៨ ហ ដយ ៤:៣០ ឡ ទដ ១៣៧:៨ វវ ១៤:៨ អ លប ១៩:២៥ អស ១:៩–១០ រម ៩:២៩ **១៣:២០** ក អស ១៤:២៣ ៣៤:១០–១៥ យរ ៥១:២៩–៤៣,៦២ ខ ២រប ១៧:១១ **១៣:២១** គ ទដ ៧៤:១៤ វវ ១៨:២

ឃ យរ ១៤:៦ ង លវ ១១:១៦–១៨ ចទ ១៤:១៥–១៧ ច លវ ១៧:៧ ២រប ១១:១៥ **១៣:២២** ឆ អស ៣៤:១៤ ជ អស ២៥:២ ៣២:១៤ ឈ អស ៣៤:១៣ ៣៥:៧ ៤៣:២០ យរ ៩:១១ ៤៩:៣៣ ៥១:៣៧ មឡ ១:៣ ញ ចទ ៣២:៣៥ យរ ៤៨:១៦ ៥១:៣៣ ដ យរ ៥០:៣៩ **១៤:១** ក ទដ ១០២:១៣ អស ៤៩:១០,១៣ ៥៤:៧–៨,១០ យរ ៣៣:២៦ សក ១០:៦ ខ លប ១៨:១៩ ២រប ៦:៦ អស ៤១:៨ ៤២:១ ៤៤:១ ៤៥:៤ ៤៩:៧ ៦៥:៩,២២ សក ១:១៧ ២:១២ ៣:២ គ យរ ៣:១៨ ១៦:១៥ ២៣:៨ ឃ នក ១២:៤៣ អស ១១:១០ អគ ៤៧:២២ សក ៨:២២–២៣ អភ ២:១២–១៩ **១៤:២** ង អស ១១:១២ ៦០:៩ ច ទដ ៤៩:១៤ អស ២៦:១៥ ៤៣:១៤ ៤៩:៧,២៣ ៥៤:៣ ឆ ទដ ១៤៩:៨ អស ៤៥:១៤ ៤៩:២៥ ៦០:១២ យរ ៤០:១ ជ អស ៦០:១៤ ៦១:៥ យរ ៣០:១៦ ៤៩:២ អគ ៣៩:១០ សផ ៣:១៩ សក ២:៩ **១៤:៣** ឈ អស ១១:១០ ញ យប ៣:១៧

**១៣:១៧** *សាសន៍មេឌី* គឺជាអ្នកស្រុកដើមដែលនៅរស់ ដែលសព្វថ្ងៃគឺជាប្រទេសអ៊ីរ៉ង់ខាងជើងឈាងខាងលិច ។ ហើយក៏មានចំបាំងរវាងពួកអាសស៊ើរនិងម៉ាឌានក្នុងកំឡុងពេលសតវត្សទី៧ មុន គ.ស គឺជាការទំនាក់ទំនងការសម្រេចនូវទំនាយ ចំពោះខនេះគឺក្នុងរយៈពេលដែលពួកសាសន៍មេឌីចូលរួមជាមួយពួកបាប៊ីឡូន ក្នុងការវាយរំលំពួកអាសស៊ើរក្នុងឆ្នាំ ៦១២–៦០៩ តែក្រោយមកក៏ចូលរួមជាមួយពួកស្តេចស៊ីរូសដើម្បីគ្រប់គ្រងបាប៊ីឡូនក្នុងឆ្នាំ ៥៣៩ ។ អរ ៦:២ និងការពន្យល់ យរ ៥១:១១,២៨ ដយ ៥:៣១ ៦:២៨ ។

**១៣:១៩** *សិរីល្អ . . . សេចក្តីអំនួត* ដែលក្រុងបាប៊ីឡូន និងវិហាររបស់ពួកគេនិងរាជវាំងក៏ក្លាយជាទីក្រុងដ៏ល្អ (សូមមើល ដយ ៤:២៩–៣០ និងការពន្យល់ ៤:៣០) ។ មានសួនលំអររបស់ស្តេចនេប៊ូក្នេសា គឺជាសួនម្យ៉ាងក្នុងចំណោមសួនទាំង៧ក្នុងពិភពលោកបូរាណ ។ ក្នុង ៤:២ ឯចក្រភពបាប៊ីឡូនក្នុងឆ្នាំ ៦១២–៥៣៩ មុន គ.ស បានដឹកនាំដោយសាសន៍ខាល់ដេ នៅឯបាប៊ីឡូនភាគខាងត្បូង ។ ស្តេចនេប៊ូប៉ូឡាសា ក៏បានផ្សះផ្សារនូវពូជអំបូរមួយចំនួនបញ្ចូលគ្នាគឺប្រហែលជាក្នុងឆ្នាំ ៦២៦ ហើយបុត្រារបស់ទ្រង់ឈ្មោះនេប៊ូក្នេសា ប្រែក្លាយជាអ្នកដឹកនាំដ៏មានអំណាចបំផុត (៦០៥–៥៦២)។ *ទីក្រុងសូដំម នឹងក្រុងកូម៉ូរ៉ា* គឺកាលនោះសាសន៍អ៊ីស្រាអែល បានប្រដូចសាសន៍យូដាទៅនិងទីក្រុងទាំងនេះ (សូមមើល ១:៩–១០ និងការពន្យល់) ។

**១៣:២០–២២** សូមមើលការពណ៌នាស្រដៀងៗគ្នា និងដំណោះស្រាយពីដំណោះស្រាយក្រុងអេដំមក្នុង ៣៤:១០–១៥ ប្រៀបធៀប វវ ១៨:២ ។

**១៣:២០** *គ្មានអ្នកណានៅតទៅទៀតឡើយ* ក្រុងបាប៊ីឡូន ស្ទើតែបាបបំផ្លាញខូចអស់ដោយសារពួកស្តេច ពើស៊ីទី១ តាំងពីជំនាន់មុនទៀតគឺក្នុងឆ្នាំ ៤៧៨ មុន គ.ស បន្ទាប់មកនៅជំនាន់រាជកាលអ័លេកក្សានត្រុសក្នុង ៣:៣០ ដែលជាទីក្រុងត្រូវបានបំផ្លាញ ។

**១៣:២១** *ពពែព្រៃ* ពាក្យនេះមានទំនាក់ទំនងនៅនិងអារក្ស("គឺជារូបព្រះនៃសត្វពពែ") ក្នុង ១៧:៧ ២រប ១:១៥ វវ ១៨:២ បាប៊ីឡូនដែលដួលចុះគឺពណ៌នាជាលក្ខណៈជាទីអាស្រ័យរបស់អារក្សនិងវិញ្ញាណអាក្រក់ ។

**១៤:១** *អាណិតអាសូរ . . . ស្នាក់នៅ* ការធ្លាក់ចុះនៃក្រុងបាប៊ីឡូនគឺភ្ជាប់ទំនាក់ទំនងនិងការមានឡើងវិញនូវរាស្ត្រអ៊ីស្រាអែល ។ ព្រះអម្ចាស់មានសេចក្តីមេត្តាករុណាដល់រាស្ត្ររបស់ផងទ្រង់ជំពូក ៤០–៦៦ (មើលការពន្យល់ ៤០:១) ។ *នៅក្នុងស្រុករបស់គេវិញ* សូមមើល ២:២–៤ ១១:១០–១២ នឹងការពន្យល់ ។ សូមមើល ១១:១០ ៥៦:៦–៧ ៦០:៣ នឹងការពន្យល់ ។

**១៤:២** *គឺសាសន៍ទាំងប៉ុន្មាន . . . ឯទីកន្លែង* សូមមើលការពន្យល់ ៥:២៦ *នឹងបានពូជសាសន៍ទាំងនោះ* សូមមើលការពន្យល់ ១១:១៤ ។

**១៤:៣–២១** គឺជាការលើកតម្កើងខ្លួនឱ្យខ្ពស់ជាងព្រះគឺជាតារាប្រចាំថ្ងៃ គឺជាផ្កាយព្រឹកដែលទីបញ្ចប់ និងត្រូវធ្លាក់នៅឯស្ថានឃុំព្រលឹងនិងស្ថាននរក (សូមមើល ខ.១២:១៤) ។

**១៤:៣** *ពីសេចក្តីទុក្ខ . . . ពីការបំរើយ៉ាងរឹងរូស* ភាពជាឈ្លើយរបស់ពួកសាសន៍បាប៊ីឡូនគឺមានភាពស្រដៀងគ្នា និងមានបទពិសោធន៍ច្រើនដូចជាសាសន៍អ៊ីស្រាអែលដែរ ។ គឺពេលគេនៅឯស្រុកអេស៊ីព្ទនោះ (សូមមើល នក

យ៉ាងរឹងរូសដែលគេបានចាប់ប្រើឯង[ដ] ៤នោះឯងនឹង
ពោលពាក្យចំអកនេះ[ឋ] ដាក់ស្តេចក្រុងបាប៊ីឡូនថា[ឌ] យីអើ
ពួកសង្កត់សង្កិន[ឍ]បានឈប់ទ្រឹងយ៉ាងណាហ្ន៎ ទីក្រុងមាស
បានរលត់ផុតយ៉ាងណាហ្ន៎ ៥ព្រះយេហូវ៉ាទ្រង់បានបំបាក់
ដំបង[ណ]របស់មនុស្សអាក្រក់[ត] នឹងដំបងពេជ្រ[ថ]នៃអ្នកគ្រប់
គ្រងហើយ ៦ជាអ្នកដែលបានវាយជនជាតិទាំងឡាយ[ទ]ដោយ
ចិត្តក្រេវក្រោធជានិច្ច ហើយបានគ្រប់គ្រង[ធ]លើអស់ទាំង
សាសន៍ ដោយសេចក្តីកំហឹង ជាការញាំញីដែលឥតមានអ្នក
ណាឃាត់ឃាំងឡើយ[ន] ៧ផែនដីទាំងមូលបានស្រាកស្រាន្ត
អស់[ប]ហើយក៏ស្ងៀមសប់ដែរ គេទំលាយសំឡេងច្រៀង
ចេញមក[ផ] ៨អើទាំងដើមកោះ[ព]ក៏រីករាយចំពោះឯង នឹង
ដើមតាត្រៅនៅភ្នំល្បាណូនផង ដោយពាក្យថា តាំងពីឯង
ត្រូវរលំចុះ នោះឥតមានអ្នកណាឡើយមកកាប់រំលំយើង
ទៀតទេ[ភ] ៩ឯស្ថានឃុំព្រលឹងមនុស្សស្លាប់[ម]នៅក្រោម មាន
សេចក្តីរំជួលដោយព្រោះឯង ដើម្បីនឹងទទួលឯងក្នុងកាល
ដែលឯងទៅដល់ ក៏ដាស់ពួកមនុស្សស្លាប់[យ]ឡើង ដោយ
ព្រោះឯង គឺទាំងពួកអ្នកធំ[រ]នៅផែនដីផង ក៏បានឱ្យអស់ទាំង
ស្តេចនៃសាសន៍ទាំងប៉ុន្មាន ក្រោកពីបល្ល័ង្ករបស់គេ[ល] ១០គេ
នឹងនិយាយរចល់មកឯងគ្រប់គ្នាថា អុញន៎ ឯងបានទៅជា
ខ្សោយដូចយើងឬ បានត្រឡប់ដូចជាយើងដែរឬ[វ] ១១ឯ
សេចក្តីរុងរឿងឧត្តមរបស់ឯង បានត្រូវនាំចុះមកដល់ស្ថាន
ឃុំព្រលឹងមនុស្សស្លាប់[ស] ព្រមទាំងសូរដេញពិណរបស់ឯង
ផង[ហ] មានដង្កូវក្រាលក្រោមឯង ហើយនឹងមានដង្កូវ[ឡ]គ្រប
ដណ្តប់ឯងដែរ[អ]។
១២ឱតារាប្រចាំថ្ងៃ ជាផ្កាយព្រឹកអើយ[ក] ន៎ ឯងបាន
ធ្លាក់ចុះ[ខ]មកពីលើមេឃហើយ ឯងដែលបានផ្តេកអស់ទាំង
នគរឱ្យរាប ឯងបានត្រូវកាប់រំលំដល់ដីដែរហ្ន៎[គ] ១៣ឯង
បានគិតក្នុងចិត្តថា អញនឹងឡើង[ឃ]ទៅឯស្ថានសួគ៌ អញ
នឹងដំកើងបល្ល័ង្កអញ[ង] ឱ្យខ្ពស់ជាងអស់ទាំងផ្កាយរបស់ព្រះ
ហើយអញនឹងអង្គុយលើភ្នំជាទីប្រជុំជំនុំ[ច] នៅទីបំផុត[ឆ]នៃទិស
ខាងជើង ១៤អញនឹងឡើងទៅផុតទីខ្ពស់នៃពពក[ជ] អញ
នឹងលើកខ្លួនឱ្យបានដូចជាព្រះដ៏ខ្ពស់បំផុត[ឈ] ១៥តែឯងបាន
ត្រូវទំលាក់ចុះ[ញ]ដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់វិញ[ដ] គឺដល់

**១៤:៣** ដ នក ១:១៤ **១៤:៤** ឋ មីក ២:៤ ហាព ២:៦ ឌ អស ១៣:១ ឍ អស ៩:៤ **១៤:៥** ណ អស ១០:១៥ ត ទដ ១២៥:៣ ថ ទដ ១១០:២ **១៤:៦** ទ អស ១០:១៤ ធ ទដ ៤៧:៣ ន ២ពវ ១៥:២៩ អស ៣៧:៦ ហាព ១:១៧ **១៤:៧** ប ជន ៦:២៦ យរ ៥០:៣៤ សក ១:១១ ផ ទដ ៩៨:១ ១២៦:១–៣ អស ១២:៦ **១៤:៨** ព ១របា ១៦:៣៣ ទដ ៦៥:១៣ អគ ៣១:១៦ ភ ២ពវ ១៩:២៣ អស ៣៧:២៤ **១៤:៩** ម សភ ៣០:១៦ អគ ៣២:២១ យ យប ២៦:៥ រ សក ១០:៣ ល យប ៣:១៤ **១៤:១០** វ អគ ២៦:២០ ៣២:២១ **១៤:១១** ស ជន ១៦:៣០ សភ ៣០:១៦ ហ អស ៥:១២ អគ ២៦:១៣ អម ៦:៥ ឡ យប ៧:៥ ២៤:២០ អស ៥១:៨ ៦៦:២៤ អ យប ២១:២៦ **១៤:១២** ក ២ពត ១:១៩ វវ ២:២៨ ៨:១០ ៩:១ ខ លក ១០:១៨ គ អគ ២៦:១៧ **១៤:១៣** ឃ ដយ ៥:២៣ ៨:១០ អប ១:៤ មថ ១១:២៣ ង អគ ២៨:២ ២ថន ២:៤ ច ទដ ៨២:១ ឆ អស ៣៧:២៤ **១៤:១៤** ជ យប ២០:៦ ឈ លប ៣:៥ ជន ២៤:១៦ អស ១០:១៣ ៤៧:៨ យរ ៥០:២៩ ៥១:៥៣ ដយ ១១:៣៦ ២ថន ២:៤ **១៤:១៥** ញ អស ១៣:៦ ៤៥:៧ ៤៧:១១ យរ ៥១:៨,៤៣ ដ យប ២១:១៣ ឋ មថ ១១:២៣ លក ១០:១៥

១:១៤ និងការពន្យល់) ។

**១៤:៤** *ពោលពាក្យចំអក* សូមប្រៀបធៀបពាក្យដែលចំអកដាក់ពួកសាសន៍បាប៊ីឡូនក្នុង វវ ១៨ ។ *ស្តេចក្រុងបាប៊ីឡូន* និងមានពាក្យខ្លះស្តេចពួកអាសសើរបានប្រើ ។

**១៤:៥** *ដំបង . . . ដំបងពេជ្រ* សូមមើល ១០:៥ នឹងការពន្យល់ ក៏សូមមើល ១០:២៤ ផងដែរ ។

**១៤:៨** *ដើមកកោះ . . . ដើមតាត្រៅ* គឺគម្ពីរ អេសាយបង្ហាញពីនិស្ស័យគួរឱ្យសរសើរដូចជាដើមឈើនៅតាមបណ្តាយភ្នំ ដែលតែងបានជាចម្រៀងក្នុង ៤៤:២៣ (ប្រៀបធៀបនិង ៥៥:១២) *ដើមតាត្រៅនៅភ្នំល្បាណូនផង* ដើមឈើដែលមានតម្លៃត្រូវបាបពួកស្តេចអាសសើរដឹកយក និងពួកស្តេចរបស់បាប៊ីឡូនដឹកយកផងដែរ គឺតាំងពីជាច្រើនសតវត្ស (សូមមើលការពន្យល់ ២:១៣ ៩:១០) ។

**១៤:៩** *ពួកអ្នកធំ* "ពពែ"សត្វពពែជារឿយៗដឹកនាំហ្វូងចៀម (មើល យរ ៥០:៨ នឹងការពន្យល់) ។ សក ១០:៣ ដែលជាពាក្យមានលក្ខណៈប្រហែលគ្នានិងពាក្យ "អ្នកគង្វាល" *ក្រោកពីបល្ល័ង្ករបស់គេ* ។ គឺជាលក្ខណៈក្នុងចំណោមអ្នកដែលស្លាប់បានពណ៌នាក្នុងពាក្យជាតួនាទីរបស់ពួកគេនៅលើផែនដី ។ *អស់ទាំងស្តេចនៃសាសន៍ទាំងប៉ុន្មាន* សូមមើល ខ.១៨ ហើយទោះជាអ្នកមានការអស្ចារ្យនិងមានអំណាចធំបំផុត ក៏ត្រូវចុះទៅឯ "ស្ថានឃុំព្រលឹង" ផងដែរ ។

**១៤:១១** *នាំចុះមកដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់* ក៏បានបញ្ជាក់ឡើងវិញនៅក្នុងខ.១៥ ។ *សេចក្តីរុងរឿងឧត្តម . . . ស្ថានឃុំព្រលឹងមនុស្សស្លាប់* មើលការប្រៀបធៀប ៥:១៤ ។ *សូរដេញពិណ* សូរតន្ត្រីជាសញ្ញាពីភាពមានអំណរសប្បាយ ។ (មើល អម ៦:៥–៦) ។

**១៤:១២–១៥** អ្នកខ្លះគិតថាលោក អេសាយបានផ្តល់នូវការពណ៌នាពីការធ្លាក់ចុះរបស់អារក្សសាតាំង (ប្រៀបធៀប លក ១០:១៨ ដែលទាក់ទងនិងស្ថានភាពជាក់ស្តែងចំពោះព្រះយេស៊ូវគ្រីស្ទ) ។ តែអត្ថបទបានបង្ហាញយ៉ាងច្បាស់ពីរឿងទាក់ទងនិងស្តេចនៅស្រុកបាប៊ីឡូនដែលក្រោយមកមានប្រភេទមនុស្សអាក្រក់ "ជាសត្វសាហាវ" ដែលនិងដឹកនាំស្រុកបាប៊ីឡូននៅថ្ងៃចុងក្រោយ (មើល វវ ១៣:៤ ១៧:៣) ។ ប្រៀបធៀបពីការពណ៌នាពីប្រភេទនៃស្តេចក្នុង អគ ២៨ ។

**១៤:១២** *តារាប្រចាំថ្ងៃជាផ្កាយព្រឹកអើយ* ចំពោះពាក្យនេះក្នុងព្រះគម្ពីរភាសាហេព្រើរ គឺនិយាយថា"លូស៊ីហ្វើរ"ឬហៅថាសាតាំង ។ តែព្រះគម្ពីរភាសាអង់គ្លេសសម័យដើមបកប្រែពាក្យនេះថា"ផ្កាយព្រឹក" ។ សូមមើល វវ ២២:១៦ (ក៏សូមមើល ២ពត ១:១៩ មើលការប្រៀបធៀប ជន ២៤:១៧ នឹងការពន្យល់) ។

**១៤:១៣** *នៅទីផុតនៃទិសខាងជើង* ស្តេចរបស់ពួកបាប៊ីឡូនប្រើពាក្យនេះថាជាជម្រាមួយដែលមានជង្ហុកធំមួយ(ខ.១៥ ចំពោះពាក្យ "នៅទីបំផុតនៃទិសខាងជើង"និងពាក្យថា "ទីជ្រៅ"គឺដូចតែគ្នា) ដែលពួកសាសន៍កាណានចង់បានដូចជាទីដ៏"ខ្ពស់បំផុត"(ខ.១៤)" ។ *លើភ្នំជាទីប្រជុំជុំនំ* ឬភ្នំសាផូនក៏គេហៅថា ភ្នំតាសូរដែលមានទីតាំងនៅឯភាគខាងជើងនៃស្រុកស៊ីរី ។ ពួកសាសន៍កាណានក៏មានជំនឿថា ទីកន្លែងដែលព្រះគង់នៅទាំងឡាយ (សូមមើល ទដ ៤៨:២ និងការពន្យល់ ប្រៀបធៀបនឹង ទដ ៨៤:១ ។

ទីជ្រៅ[ឋ]នៃជង្ហុកធំ[ឌ] ១៦ពួកអ្នកដែលឃើញឯង គេនឹងសំឡឹង
មើលចំឯង ហើយពិចារណាឯងដោយពាក្យថា[ឍ] តើមនុស្ស
នេះឬអី ដែលធ្លាប់ធ្វើឱ្យផែនដីញាប់ញ័រ[ណ] ហើយឱ្យនគរ
ទាំងប៉ុន្មានកក្រើករំពើកនោះ ១៧ជាអ្នកដែលបានធ្វើឱ្យ
លោកីយរលីងដូចជាសមុទ្រខ្សាច់[ត] ព្រមទាំងបំផ្លាញ[ថ]ទីក្រុង
ទាំងប៉ុន្មាន ឥតដែលលែងពួកឈ្លើយឱ្យត្រឡប់ទៅឯផ្ទះ
គេវិញឡើយ[ទ] ១៨ឯសពនៃអស់ទាំងស្តេចរបស់សាសន៍
ទាំងប៉ុន្មាន សុទ្ធតែដេកនៅក្នុងទីរុងរឿងនាម៉ុងរបស់គេ
រៀងខ្លួន[ធ] ១៩តែឯងបានត្រូវបោះចោលចេញ[ន]ឆ្ងាយពីម៉ុង
ឯងទៅ ដូចជាមែកដែលគួរខ្ពើមវិញ គឺដូចជាអាវរបស់
មនុស្សដែលត្រូវគេសំឡាប់[ប] ជាអ្នកដែលត្រូវគេចាក់ទំលុះ
ដោយដាវ[ផ] ហើយក៏ចុះទៅដល់ថ្មនៅក្នុងរណ្តៅ[ព] ដូចជា
ខ្មោចដែលគេជាន់ឈ្លីដោយជើង ២០ឯងនឹងមិនបានមូល
ទៅជាមួយនឹងគេនៅក្នុងផ្នូរទេ[ភ] ពីព្រោះឯងបានបំផ្លាញ
ស្រុករបស់ឯង ហើយបានសំឡាប់ប្រជាជនរបស់ឯងផង
ឯពូជ[ម]នៃមនុស្សអាក្រក់[យ] នឹងឥតមានអ្នកណាចេញឈ្មោះ
គេ[រ] នៅអស់កល្បជានិច្ច ។
២១ចូរចាត់ចែងការសំឡាប់ពួកកូន[ល] ដោយព្រោះអំពើ
ទុច្ចរិតរបស់ឪពុកវា[វ] ដើម្បីកុំឱ្យវាតាំងខ្លួនឡើងធ្វើជាម្ចាស់
ផែនដីទៀត ហើយសង់ទីក្រុងឱ្យពេញពាសក្នុងលោកីយ
ឡើយ ២២ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលថា
អញនឹងក្រោកឡើង[ស]ទាស់នឹងគេ ហើយកាត់ទាំងឈ្មោះ[ហ]
នឹងសំណល់មនុស្ស ទាំងកូននឹងចៅ ចេញពីក្រុងបាប៊ីឡូន
ផង[ឡ] នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ២៣ព្រះយេហូវ៉ានៃ
ពួកពលបរិវារ ទ្រង់មានបន្ទូលថា អញនឹងបំផ្លាស់ទីនោះឱ្យ
ទៅជាលំនៅរបស់សត្វប្រមា[អ] ហើយជាត្រពាំងទឹក អញ
ក៏នឹងបោសដោយអំបោសជាការបំផ្លាញ[ក,ខ] ។

### សេចក្តីទំនាយទាស់នឹងសាសន៍អាសស៊ើរ

២៤ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានស្បថថា[គ]
ពិតប្រាថាជានឹងកើតមានដូចជាអញបានគិតហើយ[ឃ] ក៏នឹង
សំរេចដូចជាអញបានកំណត់ទុកផង[ង] ២៥គឺអញនឹងបំបាក់
ទ័ពពួកអាសស៊ើរ[ច] ដែលនៅក្នុងស្រុកអញ ហើយនឹងជាន់
ឈ្លីគេនៅលើភ្នំរបស់អញ គ្រានោះ នឹម[ឆ]របស់គេនឹងបាត់
ទៅ ហើយបន្ទុករបស់គេនឹងបាត់ពីស្មាចេញ[ជ] ២៦នេះ
ហើយជាការ ដែលបានសំរេច[ឈ]នឹងធ្វើ នៅលើផែនដីទាំង
មូល ហើយនេះជាព្រះហស្ត[ញ] ដែលបានសន្ធឹងទៅលើនគរ
ទាំងពួង ២៧ដ្បិតព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បាន
សំរេចនឹងធ្វើហើយ[ដ] តើអ្នកណានឹងរំលប់រំលាងបាន ព្រះ
ហស្តនៃទ្រង់[ឋ]បានលូកទៅហើយ តើអ្នកណានឹងបង្វិលឱ្យ
ត្រឡប់ទៅវិញបាន[ឌ] ។

### សេចក្តីទំនាយទាស់នឹងសាសន៍ភីលីស្ទីន

២៨នៅឆ្នាំ[ឍ]ដែលស្តេចអេហាស[ណ]សុគតទៅ នោះមាន

**១៤:១៥** ឌ ទដ ៥៥:២៣ អគ ៣១:១៦ ៣២:២៣
**១៤:១៦** ឍ យរ ៥០:២៣ វវ ១៨:៩
**១៤:១៦** ណ អស ២:១៩ ១៣:១៣ យអ ៣:១៦ ហក ២:៦,២១
**១៤:១៧** ត អស ១៥:៦ យអ ២:៣ ថ ទដ ៥២:៧ ទ នក ៧:១៤ ២ពវ ១៥:២៩ យរ ៥០:៣៣ វវ ១៨:១៨
**១៤:១៨** ធ យប ២១:៣២
**១៤:១៩** ន អស ២២:១៦–១៨ យរ ៨:១ ៣៦:៣០ ប អស ៣៤:៣ ផ អស ១៣:១៥ ព យរ ៤១:៧–៩
**១៤:២០** ភ ១ពវ ២១:១៩ ម យប ១៨:១៩ យ អស ១:៤ រ ចទ ៣២:២៦
**១៤:២១** ល ជន ១៦:២៧ វ លប ៩:២៥ លវ ២៦:៣៩
**១៤:២២** ស ទដ ៩៤:១៦ ហ យប ១៨:១៧ ទដ ១០៩:១៣ ឡ ណហ ១:១៤ ឡ ២សយ ១៨:១៨ ១ពវ ១៤:១០ យប ១៨:១៩ ទដ ៩:៦ អស ១៣:១៨ **១៤:២៣** អ លវ ១១:១៦–១៨ អស ៣៤:១១–១៥ សផ ២:១៤ ក អស ១០:៣ យរ ២៥:១២ ខ យរ ៥០:៣ ៥១:៦២ **១៤:២៤** គ អស ៤៥:២៣ ៤៩:១៨ ៥៤:៩ ៦២:៨ ឃ អស ១៩:១២,១៧ ២៣:៨–៩ ២៥:១ ដយ ៤:៣៥ ង យប ៩:៣ អស ៧:៧ ៤៦:១០–១១ អគ ១២:២៥ កច ៤:២៨ **១៤:២៥** ច អស ១០:៥,១២ ៣៧:៣៦–៣៨ ឆ អស ៩:៤ ជ អស ១០:២៧ **១៤:២៦** ឈ អស ២៣:៩ ញ នក ១៥:១២ យប ៣០:២១ **១៤:២៧** ដ យរ ៤៩:២០ ឋ នក ១៤:២១ ឌ ២របា ២០:៦ អស ៤៣:១៣ ដយ ៤:៣៥ **១៤:២៨** ឍ ២ពវ ១៥:៧ ណ ២ពវ ១៦:១

**១៤:១៦–២០** ខគម្ពីរទាំងនេះហាក់ដូចជាបានកើតឡើងនៅនាលោកិយនេះ គឺមិនមែនជាអាណាចក្រនៃសេចក្តីស្លាប់ទេ (គឺស្ថានឃុំព្រលឹងមនុស្សស្លាប់) នោះទេ ក៏សូមមើល ខ.៩–១០ ។
**១៤:១៧** *ពួកឈ្លើយឱ្យត្រឡប់ទៅឯផ្ទះគេវិញ* ពួកបាប៊ីឡូន ឬដូចជាអាសស៊ើរ ដែលបាននិរទេសគឺពួកដែលត្រូវគេបង្ក្រាប ជាពិសេសពួកដែលប្រឆាំងបះបោរ (សូមមើល ២ពវ ២៤:១៤–១៦) ។
**១៤:១៨** *ស្តេចរបស់សាសន៍ទាំងប៉ុន្មាន* សូមមើល ខ.៩ ។
**១៤:១៩** *ត្រូវបោះចោលចេញឆ្ងាយពីម៉ុង* សូមមើល ៥:២៥ ។
**១៤:២១** *សំឡាប់ពួកកូន* ជាកូនរបស់មនុស្សក៏ដូចជាមានទាំងបង្គោលថ្ម សម្រាប់ជាទីរំឭកបង្គោលថ្មនោះគឺជាថ្មដែលដាក់នៅក្បាលផ្នូរ (២សយ ១៨:១៨) ។ ស្តេចស្រុកបាប៊ីឡូនក៏មានលក្ខណៈបែបនេះដែរ (ប្រៀបធៀបនិង ៤៧:៩) ។
**១៤:២២–២៣** គឺជាពាក្យប្រមានជាពិសេសចំពោះពួកក្រុងបាប៊ីឡូនផ្ទាល់ (សូមមើលការពន្យល់ ខ.៣–២១) ការបំពេញសម្រេចសេចក្តីទំនាយនេះគឺតាមរយៈការបំផ្លាញពួកស្តេចសាសន៍ សានហេរីបរបស់ស្រុកអាសស៊ើរនិងស្រុកបាប៊ីឡូនក្នុងឆ្នាំ ៦៨៩ មុន គ.ស ។
**១៤:២២** គឺជាអ្នកសំណល់ដែលរាស្ត្រអ៊ីស្រាអែលនិងបានសង្គ្រោះតាមរយៈដែលពួកគេគេចផុតពីសេចក្តីស្លាប់(សូមមើល ១០:២០–២២ និងការពន្យល់ ១១:១១,១៦) តែពួកសាសន៍បាប៊ីឡូននិងមិនបានរួចទេ ។
**១៤:២៣** សូមមើល ១៣:២០–២២ និងការពន្យល់ ។ *ត្រពាំងទឹក* នៅតំបន់បាប៊ីឡូនដែលជាទីកន្លែងរបស់សាសន៍ខាល់ដេដែលជាអំបូរមួយ (មើលការពន្យល់ អរ ៥:១២) ដែលមានរបៀបរស់នៅជាទម្លាប់តែមួយ ។
**១៤:២៥** *នឹម . . . បន្ទុក* សូមមើល ៩:៤ និងការពន្យល់ ។
**១៤:២៦–២៧** *ព្រះហស្តនៃទ្រង់បានលូកទៅហើយ* សូមមើល ៩:១២ ១២:១ និងការពន្យល់។ ព្រះហស្តទ្រង់បានលូកទៅទាស់និងសាសន៍អេស៊ីព្ទនៅឯសមុទ្រក្រហម (សូមមើល នក ១៥:១២) ។
**១៤:២៨–៣២** មើល យរ ៤៧ អម ១:៦–៨ សថ ២:៤–៧ ។
**១៤:២៨** *សេចក្តីទំនាយ* មើលការពន្យល់ ១៣:១ ។ *នៅឆ្នាំ* គឺប្រហែលជាឆ្នាំ ៧១៥ មុន គ.ស ដែលស្តេចអេហាសបានសុគត ។ ដែលជារយៈពេលនៃពួកភីលីស្ទីនបានបះបោរប្រឆាំងនិងពួកសាសន៍អាសស៊ើរ គឺខណៈពេលស្តេច

សេចក្ដីទំនាយយ៉ាងធ្ងន់[ត]នេះ ២៩គឺថា នែ ពួកភីលីស្ទីន[ថ]អើយ
កុំឱ្យរីករាយពេញល្បុង ដោយព្រោះរំពាត់ដែលធ្លាប់វាយ
ឯងបានបាក់ហើយនោះឡើយ ដ្បិតនឹងកើតមានពស់វែក[ទ]
ចេញពីពូជសត្វពស់មក ហើយកូនរបស់វានឹងទៅជាពស់
ភ្លើងហោះ[ធ] ៣០នោះកូនច្បងរបស់ពួកមនុស្សទាល់ក្រនឹង
មានអាហារបរិភោគ ហើយមនុស្សកំសត់ទុគ៌ត[ន]នឹងដេក
ទៅដោយសុខសាន្ត[ប] តែអញនឹងធ្វើឱ្យពូជពង្សឯងស្លាប់ទៅ
ដោយអំណត់អត់វិញ[ផ] ហើយសំណល់នៃឯងនឹងត្រូវគេ
សំឡាប់[ព]បង់[ភ] ៣១ឱទ្វារក្រុងអើយ[ម] ចូរស្រែកទ្រហោ[យ] ឱទី
ក្រុងអើយ ចូរយំពិលាបចុះ ឱស្រុកភីលីស្ទីនអើយ[រ] ឯងត្រូវ
រលាយទាំងអស់ហើយ ដ្បិតមានផ្សែងចេញមកពីទិសខាង
ជើង[ល] ឥតមានអ្នកណាមួយក្នុងកងទ័ពរបស់គេ ដែលតាម
គ្នាមិនទាន់ឡើយ[វ] ៣២ដូច្នេះ តើត្រូវឆ្លើយដល់ពួករាជទូត[ស]
នៃនគរនោះយ៉ាងណាទៅ គឺត្រូវថា ព្រះយេហូវ៉ាទ្រង់បាន
តាំងក្រុងស៊ីយ៉ូនឡើង[ហ] ហើយពួករាស្ត្ររបស់ទ្រង់ដែល
មានទុក្ខវេទនា គេនឹងពឹងជ្រកក្នុងក្រុងនោះ[ឡ]។

## បទទំនាយទាស់នឹងនគរម៉ូអាប់

*១៦:៦-១២ – យរ ៤៨:២៩-៣៦*

**១៥** ១នេះជាសេចក្ដីទំនាយយ៉ាងធ្ងន់[ក] ពីស្រុកម៉ូអាប់[ខ] ពី
ព្រោះនៅក្នុងយប់១ នោះក្រុងអើរ[គ]របស់ស្រុកម៉ូអាប់ នឹង
ត្រូវបំផ្លាញខ្ទេចខ្ទី[ឃ] ហើយសាបសូន្យទៅ ហើយដោយ
ព្រោះនៅក្នុងយប់១ ក្រុងគារ[ង]របស់ស្រុកម៉ូអាប់ត្រូវបំផ្លាញ
ខ្ទេចខ្ទី ហើយសាបសូន្យទៅដែរ ២គេបានឡើងទៅឯវិហារ
ហើយក៏ទៅឯឌីបូន[ច] ជាទីខ្ពស់[ឆ] ដើម្បីយំ សាសន៍ម៉ូអាប់គេ
ទ្រហោពិលាប[ជ]នឹងក្រុងនេបូរ[ឈ] ហើយនិងក្រុងមេឌីបា គេ
បានកោរ[ញ]សក់ក្បាលគ្រប់គ្នា ក៏កាត់ពុកចង្កាទាំងអស់គ្នា
ដែរ[ដ] ៣នៅតាមផ្លូវ គេស្លៀកសំពត់ធ្មៃ[ឋ] ហើយនៅលើ
ដំបូល[ឌ]ផ្ទះនឹងនៅទីធ្លា[ឍ] គេទ្រហោពិលាប[ណ] ទាំងយំជា
ច្រើន[ត] ៤ក្រុងហែសបូន[ថ] និងក្រុងអេលាលេ[ទ] គេនាំគ្នា
ស្រែកឡើង សំឡេងរបស់គេបានឮរហូតទៅដល់ក្រុង
យ៉ាហាស់[ធ] ហេតុនោះបានជាពួកទាហានរបស់ម៉ូអាប់ គេ

**១៤:២៨** ត អស ១៣:១ **១៤:២៩** ថ យស ១៣:៣ ២ពវ ១:២ ២រប ២៦:៦ **១៤:២៩** ទ អស ១១:៨ ធ ចទ ៨:១៥ **១៤:៣០** ន អស ៣:១៥ ២៥:៤ ប អស ៧:២១-២២ ផ អស ៨:២១ ៩:២០ ៥១:១៩ ព យរ ២៥:១៦ សក ៩:៥-៦ ភ អគ ២៥:១៥-១៧ សផ ២:៥ **១៤:៣១** ម អស ៣:២៦ យ អស ១៣:៦ រ លប ១០:១៤ ល អស ៤១:២៥ យរ ១:១៤ ៤:៦ ៦:១,២២ ១០:២២ ១៣:២០ ២៥:៩ ៤៦:២០,២៤ ៤៦:២ ៥០:៤១ អគ ៣២:៣០ វ អស ៥:២៧ **១៤:៣២** ស អស ៣៧:៩ ហ ទដ ៥១:១៨ ៨៧:២,៥ អស ២:២ ២៦:១ ២៧:១៦ ៣១:៥ ៣៣:៥,២០ ៤៤:២៨ ៥១:២១ ៥៤:១១ ឡ អស ៤:៦ យក ២:៥ **១៥:១** ក អស ១៣:១ ខ ជន ២២:៣-៦ ចទ ២៣:៦ គ ជន ២១:១៥ ឃ ជន ១៧:១២ អស ២៥:១២ ២៦:៥ យរ ៤៨:២៤,៤១ ៥១:៥៨ ង ២ពវ ៣:២៥ **១៥:២** ច ជន ២១:៣០ ឆ ១ពវ ១១:៧ អស ១៦:១២ យរ ៤៨:៣៥ ជ អស ១៣:៦ ៦៥:១៤ ឈ ជន ៣២:៣៨ ញ លវ ១៣:៤០ យប ១:២០ ដ ២សយ ១០:៤ **១៥:៣** ឋ អស ៣:២៤ ឌ យស ២:៨ ឍ យរ ៤៨:៣៨ ណ អស ១៤:៣១ យរ ៤៧:២ ត ខ.៥ អស ១៦:៩ ២២:៤ បទ ២:១១ អគ ៧:១៨ មីក ១:៨ **១៥:៤** ថ ជន ២១:២៥ យស ១៣:២៦ ទ ជន ៣២:៣ ធ ជន ២១:២៣

សេីកុន (មើល ២០:១) ដែលរវល់នឹងការបះបោរយ៉ាងខ្លាំងក្លា ហើយក៏គិតផ្ដោះទៅរកសាសន៍កាណាន ។

**១៤:២៩** *ពួកភីលីស្ទីន* មើលការពន្យល់ លប ១០:១៤ ដោយព្រំស្រុកភីលីស្ទីនត្រូវបានរំលោភដោយចក្រភព (អេស៊ីព្ទ និងអាសស៊ើរ) ដែលស្ថិតនៅតាមផ្លូវមួយចាប់ពីស្រុកអេស៊ីព្ទទៅកាន់ស្រុកមេសូប៉ូតាមា ។ *រំពាត់* ដូចជាស្ដេចស្រុកអាសស៊ើរ ។ *បានបាក់ហើយ* បើសិនជារំពាត់ គឺជាស្ដេចសេីកុនដែលទាក់ទងនិងការគំរាមកំហែងដល់ចក្រភពតាមរយៈនៃការបះបោរដល់ស្រុកបាប៊ីឡូននិងតំបន់អាស៊ីមីណឺរ ។

**១៤:៣១** *ចូរស្រែកទ្រហោ* ប្រៀបធៀបចំពោះប្រតិកម្មស្រដៀងគ្នានេះក្នុងខគម្ពីរ ១៣:៦ ១៥:២ ១៦:៧ ២៣:១ ។ *ផ្សែង* គឺដោយសាររទេះចំបាំងរបស់ពួកអាសស៊ើរ ដែលតែងតែឈ្លានពានពួកសាសន៍កាណាន ពីផ្នែកតំបន់ខាងជើង ។ *តាមគ្នាមិនទាន់ឡើយ* ឃ្លានេះក៏ពុំឃើញមានសរសេរក្នុង ៥:២៦-២៩ ទៀតទេ ។

**១៤:៣២** *បានតាំងក្រុងស៊ីយ៉ូនឡើង* គឺព្រះអម្ចាស់និងការពារនៅទីក្រុងយេរូសាឡិមពីការឈ្លានពានរបស់ពួកអាសស៊ើរ (សូមមើលប្រៀបធៀប ៣១:៤-៥ ជាមួយនិង ២:២) ។

**១៥:១-១៦:១៤** សូមមើល យរ ៤៨ អគ ២៥:៨-១១ អម ២:១-៣ សភ ២:៨-១ និងការពន្យល់ ។

**១៥:១** *សេចក្ដីទំនាយ* សូមមើលការពន្យល់ ១៣:១ ។ *ស្រុកម៉ូអាប់* គឺជាប្រទេសឬស្រុកនៅខាងកើតសមុទ្រស្លាប់ដែលជាសត្រូវប្រឆាំងរបស់សាសន៍អ៊ីស្រាអែល (មើល ២០:១០ និងការពន្យល់២ពវ ១៣:២០) ។ *ត្រូវបំផ្លាញខ្ទេចខ្ទី* គឺពាក្យដូចគ្នានិងការពណ៌នាអំពីអារម្មណ៍របស់អេសាយផ្ទាល់ ៦:៥ ដូចជាការខូចខ្ទេចខ្ទីអស់របស់ស្រុកម៉ូអាប់ ម៉ូអាប់គឺជាលទ្ធផលពីការឈ្លានពានដោយស្ដេចសេីកុនរបស់ស្រុកអាសស៊ើរ នៅក្នុងឆ្នាំ ៧១៥ មុន គ.ស ។ *ក្រុងអើរ* ប្រហែលជាក្រុងគារ-ហារ៉ាសែត (មើលការពន្យល់ ២ពវ ៣:២៥) ។ អើរ មានន័យថា "ទីក្រុង" ។

**១៥:២** *ឌីបូន* ដែលមានទីតាំងប្រហែលជា ៦ គ.ម ខាងជើងទន្លេ អើណូន ហើយក៏បានប្រគល់ឱ្យទៅជាពូជអំបូរហោរាកាឌ នៅពេលមួយនោះ (សូមមើល ជន ៣២:៣៤) ។ *ជាទីខ្ពស់* ជាទីកន្លែងថ្វាយបង្គំរបស់ពួកសាសន៍ដទៃ (សូមមើលការពន្យល់ ១ពវ ៣:២) ។ *ក្រុងនេបូរ* គឺនៅខាងជើងស្ទឹងអើណូនប្រហែលជានៅជិតភ្នំនេបូ (ចទ ៣៤:១) ។ *ក្រុងមេឌីបា* ដែលមានចម្ងាយ ៩ គីឡូម៉ែត្រ ពីទីក្រុងហែសបូន (មើល ខ.៤) ក៏បានអ៊ីស្រាអែលចាប់យកតាំងពីតំបន់ស៊ីហុន (មើល ជន ២១:២៦,៣០) ។ *កោរសក់ក្បាលគ្រប់គ្នា . . . ក៏កាត់ពុកចង្កាទាំងអស់គ្នា* គឺជាលក្ខណៈនៃការកាន់ទុក្ខ (សូមមើល យរ ៤៨:៣៧) ។

**១៥:៣** *សំពត់ធ្មៃ* គឺជាសំលៀកបំពាក់សម្រាប់អ្នកកាន់ទុក្ខស្លៀក (សូមមើលការពន្យល់ វវ ១១:៣) ។ *នៅលើដំបូលផ្ទះ* (សូមមើល យរ ១៩:១៣ និងការពន្យល់) ។

**១៥:៤** *ហែសបូន* មានទីតាំងប្រហែលជា ៣ គ.ម ពីសមុទ្រស្លាប់ ។ សូមមើល យរ ៤៨:៣៤ ហើយស្ដេចស៊ីហុន បានចាប់យកស្រុកនោះមុនពេលពួកអ៊ីស្រាអែលចាប់យក (សូមមើល ជន ២១:២៣-២៦) ។ *អេលាលេ* ដែលមានចម្ងាយ ១.៥ គីឡូម៉ែត្រពីខាងជើងទន្លេអើរ៉ុន ហើយក៏មានចម្ងាយ ៣០

ស្រែកជាខ្លាំង ចិត្តគេញ៉ររក្នុងខ្លួន ⁵ចិត្តខ្ញុំក៏ស្រែកឡើង[ន]នឹង
ម៉ូអាប់ដែរ[ប] ពួកគេដែលរត់យោងខ្លួន[ផ] ក៏រត់រហូតដល់
ស្រុកសូអារ[ព] ដូចជាគោឈ្មោលអាយុ៣ខួប គេដើរទៅ
ទាំងយំតាមផ្លូវឡើងទៅឯក្រុងលូគីត គេស្រែកប្រកាសពី
ការបំផ្លាញ[ភ]តាមផ្លូវទៅឯក្រុងហូរ៉ូណែម[ម] ⁶ពីព្រោះទីទឹក
របស់ក្រុងនីមរីម និងត្រូវចោលសាត់[យ] ឯស្មៅនឹងក្រៀម
ស្វិតទៅ[រ] ហើយស្មៅខ្ចីនឹងរួញទៅវិញ[ល] ឥតមានអ្វីខៀវ
ខ្ចីឡើយ[វ] ⁷ដូច្នេះ គេនឹងប្រមូលរបស់ទ្រព្យដែលគេបាន[ស]
ទាំងប៉ុន្មាន ហើយដែលគេបានសន្សំទុក ឆ្លងជ្រោះដើមចាក
ទៅ ⁸ពីព្រោះសំរែកបានឮព័ទ្ធជុំវិញព្រំស្រុកម៉ូអាប់ហើយ
សូរទ្រហោយំក៏បានឮទៅដល់ក្រុងអេកឡែម សូរទ្រហោយំ
នោះ បានឮរហូតដល់ក្រុងប្អៀរ[ហ]អេលីម ⁹ឯទឹកនៃក្រុង
ឌីម៉ូនបានពេញទៅដោយឈាម ពីព្រោះអញនឹងនាំសេចក្តី
វេទនាមកលើក្រុងឌីម៉ូនទៀត គឺជាសត្វសិង្ហ[ឡ]ឱ្យស្ទុះលើ
ពួកម៉ូអាប់[អ]ដែលរត់រួចបាន ហើយលើពួកដែលសល់នៅ
ក្នុងស្រុកដែរ ។

**១៦** ¹ចូរយកកូនចៀម[ក]ទាំងប៉ុន្មាន ដែលសំរាប់[ខ]អ្នកគ្រប់
គ្រងលើស្រុក ចាប់តាំងពីក្រុងសេឡា[គ] រហូតដល់ទីរហោ
ស្ថាន ផ្ញើទៅឯភ្នំនៃពួកកូនស្រីស៊ីយ៉ូន[ឃ] ²ដ្បិតពួកកូនស្រី
សាសន៍ម៉ូអាប់[ង]នឹងនៅត្រង់ផ្លូវ[ច]ឆ្លងស្ទឹងអើណូន[ឆ] ប្រៀប
ដូចជាសត្វស្លាបដែលហើរទៅមក ហើយដូចជាកូនសត្វ

**១៥:៥** ន ខ.៣ ប អស ១៦:១១ យរ ៤៨:៣១ ផ ជន ២១:២៩ ព លប ១៣:១០ ភ យរ ៤:២០ ៤៨:៥ ម យរ ៤៨:៣,៣៤
**១៥:៦** យ អស ១៩:៥–៧ យរ ៤៨:៣៤ រ ទដ ៣៧:២ អស ១៦:៨ ២៤:៤,៧,១១ ៣៣:៩ ៣៤:៤ ៣៧:២៧ ៤០:៧ ៥១:៦,១២ ហស ៤:៣ យអ ១:១២ ល អស ១៤:១៧ វ យរ ១៤:៥
**១៥:៧** ស អស ៣០:៦ យរ ៤៨:៣៦
**១៥:៨** ហ ជន ២១:១៦
**១៥:៩** ឡ ២ពវ ១៧:២៥ អ អគ ២៥:៨–១១
**១៦:១** ក ២ពវ ៣:៤ ខ ២របា ៣២:២៣ គ ពច ១:៣៦ អប ៣

ដែលពង្រាត់ពីសំបុក[ជ] ³ចូរជួយប្រឹក្សា ហើយសំរេច
សេចក្តីយុត្តិធម៌ចុះ ចូធ្វើឱ្យស្រមោលឯងបានដូចជាពេល
យប់នៅវេលាថ្ងៃត្រង់ ចូរបំពួនពួកអ្នកត្រូវពង្រាត់ចេញ
ពីស្រុក[ឈ] ហើយកុំឱ្យក្បត់ពួកអ្នករត់យោងខ្លួនឡើយ ⁴ចូរឱ្យ
ពួករបស់អញ ដែលត្រូវពង្រាត់នោះ បានអាស្រ័យនៅ[ញ]
ជាមួយនឹងឯងចុះ ចំណែកពួកម៉ូអាប់ ចូរឱ្យឯងធ្វើជាទីគ្រប
បាំងឱ្យគេបានពួនរួចពីអ្នកបំផ្លាញ ទាល់តែពួករឹបជាន់[ដ]
បានសូន្យបាត់ទៅ ការបំផ្លាញ បានឈប់សប់[ឋ] ហើយ
ពួកញាំញីបានអន្តរធាន ចេញពីស្រុកអស់ទៅ ⁵នោះនឹង
មានបល្ល័ង្ក[ឌ]១តាំងឡើង[ឍ] ដោយសេចក្តីសប្បុរស ហើយ
ស្តេច១អង្គក្នុងពូជពង្សរបស់ដាវីឌ[ណ] នឹងគង់លើបល្ល័ង្កនោះ
ដោយសេចក្តីពិត ទាំងជំនុំជំរះ ហើយរកសំរេចសេចក្តី
យុត្តិធម៌[ត]ជាអ្នកដែលរហ័សនឹងធ្វើតាមសេចក្តីសុចរិត ។
⁶យើងបាននិយាយ ពីសេចក្តីអំនួត[ថ]របស់សាសន៍
ម៉ូអាប់[ទ]ថា គេជាអ្នកអួតអាងណាស់ គឺពីសេចក្តីឆ្មើងឆ្មៃ
សេចក្តីអំនួត និងសេចក្តីក្រេវក្រោធរបស់គេផង តែការ
អួតអាងរបស់គេជាអសារឥតការទទេ ⁷ហេតុនោះបានជា

យ អស ១០:៣២ **១៦:២** ង ជន ២១:២៩ ច ពច ១២:៥ ឆ ជន ២១:១៣–១៤ យរ ៤៨:២០ ជ សភ ២៧:៨ **១៦:៣** ឈ ១ពវ ១៨:៤ **១៦:៤** ញ អស ៥៨:៧ ដ អស ៩:៤ ឋ អស ២:២–៤ **១៦:៥** ឌ ១សយ ១៣:១៤ ដយ ៧:១៤ មីក ៤:៧ ឍ សភ ២០:២៨ ណ អស ៧:២ លក ១:៣២ ត អស ៩:៧ **១៦:៦** ថ លវ ២៦:១៩ យប ២០:៦ យរ ៤៩:១៦ អប ១:៣ សផ ២:១០ ទ យរ ២៥:២១ អគ ២៥:៨ អម ២:១ សផ ២:៨

គ.ម ពីហែសបូន (ជន ២១:២៣ យរ ៤៨:៣៤) ។

**១៥:៥** *ក្រុងសូអារ* គឺអាចមានទីតាំងស្ថិតនៅផ្នែកខាងត្បូងនៃសមុទ្រស្លាប់ (សូមមើល លប ១៤:២ ១៩:២៣,៣០) ។

**១៥:៦** *ទឹករបស់ក្រុងនីមរីម* គឺប្រហែលជាចង់បង្ហាញពីតំបន់នៅភាគខាងត្បូងចុងសមុទ្រស្លាប់ ដែលមានចម្ងាយប្រហែល ១៥ គ.ម ពីសមុទ្រស្លាប់ (ប្រៀបធៀប យរ ៤៨:៣៤) ។

**១៥:៨** *ក្រុងអេកឡែម* គឺនៅផ្នែកខាងជើងព្រំដីស្រុកម៉ូអាប់ ឬក្រុងប្អៀរ–អេលីម ។ ប្អៀរមានន័យថា"អណ្តូង" (មើលការប្រៀបធៀប ជន ២១:១៦) តំបន់នេះគឺនៅជិតព្រំដីផ្នែកខាងត្បូង ។

**១៥:៩** *ទឹកនៃក្រុងឌីម៉ូន . . . ឈាម* បើជាព្រះគម្ពីរភាសាហេព្រើរ ចំពោះពាក្យ "ឈាម"គឺបញ្ចេញសម្លេងដូចជា "ឌីម៉ូន"ក៏ជាឈ្មោះការដ្ឋាន១ ដែលធ្លាប់មានឈ្មោះ"ឌីបូន" (ខ.២) ដែលនៅក្បែរស្ទឹងអើណូន ។ មានពួកម៉ូអាប់ជាច្រើន ស្លាប់នៅទីនោះដោយសង្គ្រាម ។ *សត្វសិង្ហ* គឺសំដៅទៅលើកងទ័ពពួកអាសស៊ើរ (ប្រៀបធៀប ៥:២៩ យរ ៥០:១៧) ឬជាសត្វសិង្ហពិតប្រាកដ (ប្រៀប ធៀប ១៣:២១–២២) ។

**១៦:១** *កូនចៀម . . . ផ្ញើ* ដូចជាស្តេចមេសាបានផ្ញើចៀម ១00,000 នៅឯស្តេចអ័ហាប់របស់ពួកអ៊ីស្រាអែលក្នុងឆ្នាំនិមួយៗ (មើល ២ពវ ៣:៤ និងការពន្យល់) ហើយស្តេចស្រុកម៉ូអាប់តែងតែបៀតបៀន ដល់សាសន៍អ៊ីស្រាអែល ក៏បានគេឱ្យជាយោបល់ចំពោះស្តេចស្រុកម៉ូអាប់ ឱ្យចុះចូលដល់ស្តេចក្រុងយេរូសាឡិម ។ *ក្រុងសេឡា* ជារាជធានីដ៏រឹងមាំរបស់ស្រុកអេដំម ដែលនៅខាងត្បូងសមុទ្រស្លាប់ដែលមានស្ថានភាព សំបូរដោយថ្មក៏មានប៉មជាបន្ទាយកំពស់ ៣00 ម៉ែត្រ ស្ថិតនៅក្បែរស្រុកពេត្រា (៤២:១១) ដែលជាឈ្មោះមានន័យថា (ចាំងថ្មចេត) ។ *ពួកកូនស្រីស៊ីយ៉ូន* ដែលបង្ហាញលក្ខណៈរបស់ក្រុងយេរូសាឡិម (មើលការពន្យល់ ពវ ១៩:២១) ។

**១៦:២** *ត្រង់ផ្លូវឆ្លងស្ទឹងអើណូន* គឺស្ត្រីៗភៀសខ្លួនចេញពីតំបន់ខាងត្បូង (សូមមើលការពន្យល់ យស ១២:១) គឺដើម្បីគេចចេញពីពួកឈ្លានពាននៅតំបន់ខាងជើង ។

**១៦:៣** *ចូរបំពួនពួកអ្នកដែលត្រូវពង្រាត់ចេញ* ពួកសាសន៍ម៉ូអាប់ក៏សុំការជ្រកកោនពីពួកយូដា (នរ ១:១ ១សយ ២២:៣ និងការពន្យល់៤) ។

**១៦:៤** *អ្នកបំផ្លាញ* គឺអាចជាពួកអាសស៊ើរ (សូមមើលការពន្យល់ ១៥:១ ៣៣:១) ។

**១៥:៥** *ពូជពង្សរបស់ដាវីឌ* សូមមើល ៩:៧ ២សយ ៧:១–១៦ អម ៩:១១ នឹងការពន្យល់(សូមមើល ៧:២) ទាំងជំនុំជម្រះហើយសម្រេចសេចក្តីយុត្តិធម៌ ។ សូមមើល ១១:២–៤ និងការពន្យល់។ ក៏បង្ហាញពីព្រះមែស៊ី ។

**១៦:៦** *សេចក្តីអំនួតរបស់សាសន៍ម៉ូអាប់* គឺទោះជាពួកសាសន៍ម៉ូអាប់ជាសាសន៍តូចមួយក៏ដោយក៏ពួកគេមានសេចក្តីអំនួតដូចសាសន៍អាសស៊ើរនិងបាប៊ីឡូន ។ ប្រៀបធៀបនិង ១០:១២ ១៤:១៣ ២៥:១១ យរ ៤៨:៤២ ។

**១៦:៧** *ឯងរាល់គ្នា* មើលការពន្យល់ ។ *ក្រុងគារ–ហារ៉ាសែត* មើលការ

សាសន៍ម៉ូអាប់នឹងយំពិលាប[ធ]ចំពោះសាសន៍របស់ខ្លួន គ្រប់
គ្នានឹងទ្រហោយំ ឯងរាល់គ្នានឹងយំស្តាយ ចំពោះផែន
ទំពាំងបាយជូរ[ន]នៃក្រុងគារ–ហារ៉ាសែត[ប] ដោយចិត្តក្តួល
ក្តុក ៨ដ្បិតចំការនៃក្រុងហែសបូន[ផ] សុទ្ធតែស្រពោនទៅ[ព]
ព្រមទាំងដើមទំពាំងបាយជូរនៃក្រុងស៊ីបម៉ា[ភ]ដែរ ពួកចៅ–
ហ្វាយនៃសាសន៍ដទៃទាំងប៉ុន្មាន គេបានកាច់បំបាក់ខ្នែងល្អ
បំផុត[ម] ដែលបានលូតរហូតដល់ក្រុងយ៉ាសេរ[យ] ហើយវា
ប្រទាក់ទៅក្នុងទីរហោស្ថាន លំពង់ក៏លូតទៅតែពាស[រ]
កាត់ទាំងសមុទ្រផង[ល] ៩ដូច្នេះ អញនឹងយំ[វ]ចំពោះដើមទំពាំង
បាយជូរនៃក្រុងស៊ីបម៉ា ដូចជាការយំរបស់ពួកយ៉ាសេរដែរ
ឱក្រុងហែសបូន និងក្រុងអេលាលេអើយ[ស] អញនឹងស្រោច
ឯងដោយទឹកភ្នែក[ហ] ដ្បិតសូរសំរែក[ឡ]របស់សឹកសង្គ្រាម
បានធ្លាក់មកចំនឹងការប្រមូលផល និងការច្រូតកាត់[អ]
របស់ឯងហើយ ១០ដូច្នេះ សេចក្តីអំណរនឹងសេចក្តីរីករាយ
បានដកចេញពីស្រែចំការដ៏ដុះដាលរបស់ឯង[ក] នៅក្នុង
ចំការទំពាំងបាយជូរ ឥតមានឮសូរច្រៀង[ខ] ឬសំឡេង
អំណរឡើយ ក៏នឹងគ្មានអ្នកណាជាន់[គ]បញ្ចេញទឹកទំពាំង
បាយជូរ នៅក្នុងធុងដែរ[ឃ] អញបានបញ្ឈប់សូរសំរែក នៃ
ការធ្វើទំពាំងបាយជូរហើយ ១១ហេតុនោះ ពោះអញនឹង
បញ្ចេញសូរទំនួញ ដូចសូរនៃស៊ុង[ង] ដោយព្រោះម៉ូអាប់[ច]
ហើយចិត្ត[ឆ]អញដែរ ពីព្រោះគារហារ៉ាសែត ១២កាលណា
ម៉ូអាប់ឡើងទៅឯទីខ្ពស់[ជ] ហើយនឿយហត់ដោយការថ្វាយ
បង្គំ ព្រមទាំងចូលទៅអធិស្ឋានក្នុងទីបរិសុទ្ធ[ឈ]ផង នោះក៏
មិនបានអ្វីឡើយ[ញ]។
១៣នេះហើយជាសេចក្តី ដែលព្រះយេហូវ៉ាបានមាន
បន្ទូលពីសាសន៍ម៉ូអាប់កាលពីដើម ១៤តែឥឡូវនេះ ព្រះ
យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ក្នុងរវាង៣ឆ្នាំ[ដ] រាប់តាម
ឆ្នាំរបស់កូនឈ្នួល[ឋ,ឌ] នោះសេចក្តីរុងរឿងឧត្តមរបស់
សាសន៍ម៉ូអាប់ និងត្រូវគេមើលងាយវិញ[ឍ] ព្រមទាំង
ប្រជាជនកុះកររបស់គេផង ឯសំណល់ដែលសល់នៅ
នឹងបានតិចតួចណាស់ ហើយហោចល្អោញផង[ណ]។

## សេចក្តីទំនាយយ៉ាងធ្ងន់ទាស់នឹងក្រុងដាម៉ាស

**១៧** ១នេះសេចក្តីទំនាយយ៉ាងធ្ងន់[ក]ពីក្រុងដាម៉ាស[ខ] ។
មើល គេដកក្រុងដាម៉ាសចេញពីដំណែងជាទីក្រុងទៅ
ហើយនឹងត្រូវត្រឡប់ជាគំនរបំណែកទទេ[គ] ២មនុស្សទាំង
ឡាយ រត់ចោលអស់ទាំងទីក្រុងនៃស្រុកអារ៉ូអើរ[ឃ] ហើយ
ទីក្រុងទាំងនោះនឹងបានសំរាប់ជាទីឃ្វាលហ្វូងចៀម[ង] ដែល
នឹងដេកទៅ[ច] ឥតមានអ្នកណាបង្អើលវាឡើយ[ឆ] ៣ឯបន្ទាយ[ជ]
នឹងបាត់ចេញពីស្រុកអេប្រាអិមទៅ ព្រមទាំងរាជអំណាច

**១៦:៧** ធ អស ១៣:៦ យរ ៤៨:២០ ៤៩:៣ ន ១រប ១៦:៣ ប ២ពវ ៣:២៥ **១៦:៨** ផ ជន ២១:២៥ ព អស ១៥:៦ ភ ជន ៣២:៣ ម អស ៥:២ **១៦:៨** យ ជន ២១:៣២ រ យប ៨:១៦ ល ទដ ៨០:១១ **១៦:៩** វ អស ១៥:៣ អគ ២៧:៣១ ស ជន ៣២:៣ ហ យប ៧:៣ ឡ អគ ៣:១៣ អ យរ ៤០:១២ **១៦:១០** ក អស ២៤:៧–៨ ខ យរ ២៥:៣០ គ ពច ៩:២៧ ឃ យប ២៤:១១ អស ៥:២ **១៦:១១** ង យប ៣០:៣១ ច អស ១៥:៥ ឆ អស ៦៣:១៥ ហស ១១:៨ សភ ២:១ **១៦:១២** ជ ១ពវ ១១:៧ ឈ អស ១៥:២ ញ ១ពវ ១៨:២៩ ទដ ១១៥:៤–៧ អស ៤៤:១៧–១៨ ១កថ ៨:៤ **១៦:១៤** ដ អស ២០:៣ ៣៧:៣០ ឋ លវ ២៥:៥០ ឌ លវ ១៩:១៣ ឍ អស ២៥:១០ យរ ៤៨:៤២ ណ អស ២១:១៧ **១៧:១** ក អស ១៣:១ ខ លប ១៤:១៥ កថ ៩:២ គ ចទ ១៣:១៦ អស ២៥:២ **១៧:២** ឃ ២ពវ ១០:៣៣ ង អស ៥:១៧ ៧:២១ អគ ២៥:៥ ច អស ២៧:១០ ឆ លវ ២៦:៦ យរ ៧:៣៣ មីក ៤:៤ **១៧:៣** ជ អស ២៥:២,១២ ហស ១០:១៤

ពន្យល់ ១៥:១ ជាទីក្រុងទាំងបួនក្នុង ខ.៧–៨ ឬក៏ ខ.៩–១១ ។

**១៦:៨** *ក្រុងហែសបូន* មើលការពន្យល់ ១៥:៤ ។ *ក្រុងស៊ីបម៉ា* គឺប្រហែលជា ៥ គ.ម ពីទិសខាងលិចទីក្រុងហែសបូន សូមមើល យរ ៤៨:៣២ ។ *ខ្នែងល្អបំផុត* គឺជាពាក្យប្រៀបធៀបពួកសាសន៍ម៉ូអាប់ចំពោះចំការទំពាំងបាយជូរ (ធៀបនឹង ៥:១–៧ និងការពន្យល់) ការពណ៌នានេះក៏បានបង្ហាញម្តងទៀតនៅក្នុង ខ.១០ ។ *ក្រុងយ៉ាសេរ* គឺអាចមានទីតាំងប្រហែលជា ២៤ គ.ម ពីខាងជើងសមុទ្រស្លាប់ ។ ទីរហោស្ថាន គឺស្ថិតនៅចុងខាងកើតស្រុកម៉ូអាប់ ។ *លំពង់ក៏លូតទៅតែពាស* ដែលជាលក្ខណៈភាសាដូចក្នុង ទដ ៨០:១១ ដែលសាសន៍អ៊ីស្រាអែលជាដើមទំពាំងបាយជូរ ។ *សមុទ្រ* គឺប្រហែលសំដៅលើសមុទ្រស្លាប់ ។

**១៦:៩** *ទីក្រុងអេលាលេអើ* សូមមើលការពន្យល់ ១៥:៤ ។

**១៦:១០** *ជាន់បញ្ចេញទឹកទំពាំងបាយជូរ* គឺគេបញ្ជាន់ផ្លែទំពាំងបាយជូរហើយទឹកដបវាក៏ហូរចុះទៅក្នុងផើងដាក់ព្រះនោះ (សូមមើល ៥:២ ប្រៀបធៀប យរ ៤៨:៣៣ អម ៩:១៣) ។

**១៦:១១** ប្រៀបធៀប យរ ៤៨:៣៦ ។

**១៦:១២** *ឯទីខ្ពស់* សូមមើល ១៥:២ និងការពន្យល់ ។ *ចូលទៅអធិស្ឋាន . . . ក៏មិនបានអ្វីឡើយ* គឺជាព្រះរបស់ពួកម៉ូអាប់ដែលគ្រាន់តែជារូបសំណាក់ព្រះតែប៉ុណ្ណោះ (សូមមើល ៤៤:១៧–២០ និងការពន្យល់ ១ពវ ១១:៧) ។

**១៦:១៣–១៤** គឺជាគ្រាចុងក្រោយមួយ ១៥:១–១៦:១២ ។

**១៦:១៤** *ក្នុងរវាង៣ឆ្នាំ* គឺជាសេចក្តីសញ្ញាមួយទៀតដែលមានដែនកំណត់ ៣ឆ្នាំ សូមមើលក្នុង ២០:៣ ៣៧:៣០ និងមើលការពន្យល់ ៧:១៤,១៦ ។ ការកំណត់៣ឆ្នាំរបស់ស្តេចម៉ូអាប់ត្រូវបានចប់ក្នុងឆ្នាំ ៧១៥ មុន គ.ស (សូមមើល ១៥:១) ។ *រាប់តាមឆ្នាំរបស់កូនឈ្នួល* សូមធៀបនឹង ២១:១៦–១៧ ក៏មានសេចក្តីទំនាយមួយទៀត ដែលប្រឆាំងនឹងស្តេចកេដារដែលមានលក្ខណៈដូចខគម្ពីរនេះដែរ ។

**១៧:១–១៤** សូមមើល យរ ៤៩:២៣–២៧ អម ១:៣–៥ និងការពន្យល់ ។

**១៧:១** *សេចក្តីទំនាយ* សូមមើលការពន្យល់ ១៣:១ ។ *ក្រុងដាម៉ាស* គឺជារាជធានីរបស់សាសន៍អើរ៉ាម (ស្រុកស៊ីរី) ដែលមានទីតាំងនៅខាងជើងឈាងខាងកើតនៃភ្នំហើម៉ូន គឺជាផ្លូវសម្រាប់យុទ្ធសាស្រ្តពាណិជ្ជកម្មរវាងសាសន៍មេសូប៉ូតាមាសាសន៍អេស៊ីព្ទនិងពួកស្រុកអើរ៉ាម ។ តាំងពីជំនាន់ស្តេចដាវីឌពួកស្រុកអើរ៉ាម នៃស្រុកដាម៉ាសដែលជារឿយៗជាសត្រូវរបស់សាសន៍អ៊ីស្រាអែល (សូមមើល ២សយ ៨:៥ ១ពវ ២២:៣១) ។

**១៧:២** *ក្រុងនៃស្រុកអារ៉ូអើរ* មានចម្ងាយ ២២ គីឡូម៉ែត្រពីខាងកើតសមុទ្រស្លាប់ ។ គឺនៅតាមដងទន្លេអើណូនក៏ជាការដៅចំណាំព្រំដីផ្នែកខាងត្បូងនៃការគ្រប់គ្រងរបស់ពួកអើរ៉ាម (សូមមើល ២ពវ ១០:៣២–៣៣ និងការពន្យល់) ។

ពីក្រុងដាម៉ាស និងពីសំណល់សាសន៍ស៊ីរីផង គេនឹងត្រូវ
ហិនហោច ដូចជាសិរីល្អ[ឈ] របស់ពួកកូនចៅអ៊ីស្រាអែល
ដែរ[ញ] នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពល
បរិវារ ។
៤នៅគ្រានោះ[ដ]សិរីល្អ[ឋ]របស់ពួកយ៉ាកុបនឹងអន់ថយទៅ
ហើយសាច់ធាត់ធំរបស់គេ និងត្រឡប់ជាស្គាំងស្គម[ឌ]ទៅវិញ
៥ដំណើរនោះនឹងដូចជាកាលអ្នកចំរូតកំពុងត្រកងស្រូវ នៅ
ដៃរួចច្រូតកាត់[ឍ]ទៅ អើ នឹងបានដូចជាកាលគេច្រូតសន្ទៀ[ណ]
នៅក្នុងច្រកភ្នំរេផែម[ត] ៦នឹងមានផលខ្លះសល់នៅដែរ[ថ] ដូច
ជាកាលគេអង្រួនដើមអូលីវ[ទ] គង់តែមានផ្លែ២ឬ៣នៅលើ
ចុងមែកដែលខ្ពស់បំផុត ហើយ៤ឬ៥នៅមែកសំយាយនៃ
ដើមណាដែលមានផ្លែច្រើន នេះជាព្រះបន្ទូលរបស់ព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ៧នៅគ្រានោះ[ធ]
មនុស្សទាំងពួងនឹងបែរជាមើល[ន]ទៅ រកព្រះដែលបាន
បង្កើត[ប]ខ្លួនមក ហើយភ្នែករបស់គេ និងមើលចំទៅព្រះដ៏
បរិសុទ្ធ[ផ]នៃសាសន៍អ៊ីស្រាអែល ៨គេនឹងលែងមើលទៅ
រកអាសនា[ព] ជាស្នាដៃរបស់ខ្លួនគេ[ភ] ក៏មិនមើលចំទៅឯរូប
ព្រះ ឬរូបព្រះអាទិត្យ[ម]ដែលម្រាមដៃ[យ]គេបានធ្វើទៀត
ឡើយ ៩នៅគ្រានោះទីក្រុងមាំមួនរបស់គេ នឹងត្រឡប់ដូច
ជាអស់ទាំងទីចោលស្ងាត់នៅក្នុងព្រៃ ហើយនៅលើកំពូល
ភ្នំ[រ] ជាកន្លែងដែលគេបោះបង់ចោល នៅចំពោះមុខ
ពួកកូនចៅអ៊ីស្រាអែល ហើយទីនោះនឹងនៅស្ងាត់ឈឹង
១០ពីព្រោះឯងបានភ្លេច[ល]ព្រះដែលជួយសង្គ្រោះឯង[វ] ហើយ
មិនបាននឹកចាំពីព្រះដ៏ជាថ្មដា[ស]នៃកំឡាំងឯង[ហ] ហេតុនោះ
បានជាឯងដាំដំណាំដែលគាប់ចិត្តឯង ព្រមទាំង ផ្សាំមែក
ប្លែកៗផង[ឡ] ១១នៅថ្ងៃដែលឯងដាំនោះ ក៏បានធ្វើរបងជុំវិញ
ហើយព្រឹក[អ]ឡើង ឯបានធ្វើឱ្យពូជឯងបែកចេញជាប៉ិច
តែឯងចំរូត[ក]វិញ នោះនឹងរំលងបាត់ទៅ[ខ]ក្នុងគ្រាមានទុក្ខ
វេទនា[គ] ហើយសង្រេងយ៉ាងសហ័ស[ឃ]។
១២វរហើយ មានឮសូរអឺកធឹក[ង]របស់ជនជាតិជាច្រើន
ដែលឮសន្ធឹកដូចជាសន្ធឹកសមុទ្រ[ច] និងសូរ[ឆ]របស់សាសន៍
ផ្សេងៗដែលលឿនដូចជាទឹកហូរយ៉ាងខ្លាំង[ជ] ១៣សាសន៍

**១៧:៣** ឈ ខ.៤ អស ២១:១៦ ហស ៩:១១ ញ អស ៧:៨,១៦ ៨:៤ **១៧:៤** ដ អស ២:១១ ឋ ខ.៣ ឌ អស ១០:១៦ **១៧:៥** ឍ ខ.១១ អស ៣៣:៤ យរ ៥១:៣៣ យអ ៣:១៣ មថ ១៣:៣០ ណ យប ២៤:២៤ ត យស ១៧:១៥ ១រប ១១:១៥ **១៧:៦** ថ ចទ ៤:២៧ អស ១០:១៩ ២៤:១៣ ទ ខ.១១ អស ២៧:១២ **១៧:៧** ធ អស ២:១១ ន អស ៩:១៣ ១០:២០ ប ទដ ៩៥:៦ ផ អស ១២:៦ **១៧:៨** ព លវ ២៦:៣០ ភ ២រប ៣២:១៩ អស ២:១៨,២០ ៣០:២២ ៤៦:៦ វវ ៩:២០ ម ពច ៣:៧ ២ពវ ១៧:១០ យ អស ២:៨ **១៧:៩** រ អស ៧:១៩ **១៧:១០** ល ចទ ៦:១២ ៨:១១ ទដ ៥០:២២ ១០៦:២១ អស ៥១:១៣ ៥៧:១១ យរ ២:៣២ ៣:២១ ១៣:២៥ ១៨:១៥ អគ ២២:១២ ២៣:៣៥ ហស ៨:១៤ ១៣:៦ វ អស ១២:២ លក ១:៤៧ ស លប ៤៩:២៤ ហ ទដ ១៨:២ ឡ អស ៥:៧ **១៧:១១** អ ទដ ៩០:៦ ក ខ.៥ ខ លវ ២៦:២០ ហស ៨:៧ យអ ១:១១ ហក ១:៦ គ យរ ១០:១៩ ៣០:១២ ឃ ចទ ២៨:៣៩ យប ៤:៨ **១៧:១២** ង ២ពវ ១០:៣៣ ច អស ៥:១៧ ៧:២១ អគ ២៥:៥ ឆ អស ២៧:១០ ជ លវ ២៦:៦ យរ ៧:៣៣ មីក ៤:៤

**១៧:៣** *ស្រុកអេប្រាអិម* គឺពួកនគរខាងជើង (សូមមើលការពន្យល់ ៧:២) ។ ការបង្ហាញនៅទីនេះដោយសារគេជាបក្សសម្ព័ន្ធជាមួយពួកក្រុងដាម៉ាសក្នុងការប្រឆាំងនិងពួកអាសស៊ើរ (សូមមើលការពន្យល់ ៧:១) ។ *រាជអំណាច* គឺក្នុងឆ្នាំ ៧៣២ មុន គ.ស ដែលទីកឡាត–ពីលេសើរបានចាប់យកក្រុងដាម៉ាសហើយក៏ដាក់វាធ្វើជាខេត្តរបស់ពួកអាស់ស៊ើរ ។ គឺក៏មានទីក្រុងរបស់ប្រទេសអ៊ីស្រាអែលជាច្រើនក៏បានចាប់យកមកធ្វើជាចំណុះផងដែរ (សូមមើល ៩:១) ។ *ដូចជាសំណល់សាសន៍ស៊ីរីផង គេនិងត្រូវហិនហោចដូចជាសិរីល្អរបស់ពួកកូនចៅអ៊ីស្រាអែលដែរ* ដូចពួកអេីរ៉ាមនិងក្លាយជាសំណល់តិចតួចទេ ។

**១៧:៤–១១** ភាពប្រែប្រួលរបស់ពួកហោរា ចេញពីក្រុងដាម៉ាសរហូតដល់ស្រុកអ៊ីស្រាអែល (ដូចជានៅនគរខាងជើង) ដូចបានសម្តែងក្នុង ខ.៣ ។ ការជិនុំជម្រះដែលមានទំនាក់ទំនងជាមួយគ្នា ចំពោះពួកក្រុងដាម៉ាស និងស្រុកអ៊ីស្រាអែល ដែលឆ្លុះបញ្ចាំងពីភាពមានទំនាក់ទំនងដូចៗគ្នា ដូចជានៅក្នុងជំពូក ៧ ។

**១៧:៤,៧,៩** *នៅគ្រានោះ* មើលការពន្យល់ ២:១១,១៧,២០ ១០:២០,២៧ ។

**១៧:៥** *ចំរូតកំពុងត្រកងស្រូវ* ការដែលច្រូតនេះគឺជាតំណាងនៃការជំនុំជម្រះ (សូមមើល យអ ៣:១៣ និងការពន្យល់) ។ គឺជាទឹកដីដែលសម្បូរទៅដោយជីវជាតិស្ថិតនៅខាងលិច ឬខាងត្បូងឈាងខាងលិចក្រុងយេរូសាឡិម (យស ១៥:៨) និង (១រប ១៤:៩) ។

**១៧:៧** *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើល ១:៤ ។

**១៧:៨** *អាសនា* គឺប្រហែលជាអាសនាសម្រាប់ព្រះបាល (ប្រៀបធៀប ១ពវ ១៦:៣២) ។ *រូបព្រះ* សូមមើលការពន្យល់ នក ៣៤:១៣ ពច ២:១៣ ។ គេក៏ធ្វើជាអាសនាទៀនធូប ដែលបង្ហាញពីទីខ្ពស់បំផុត ។ សូមមើល លវ ២៦:៣០ ដូចជាមានអាសនាសម្រាប់ព្រះបាលដូចជានៅក្នុង ២រប ៣៤:៤ ។

**១៧:៩** *គេ* ប្រហែលជាសាសន៍កាណានដែលសាសនារបស់គេដែលគោរពទៅលើរូបព្រះដូចជានៅក្នុង ខ.៨ ។ *ជាកន្លែងដែលគេបោះបង់ចោល* ប្រៀបធៀប ៧:២៣–២៥ ។

**១៧:១០** *ថ្មដា* សូមមើល ២៦:៤ ៣០:២៩ ៤៤:៨ លប ៤៩:២៤ និងការពន្យល់ ចទ ៣២:៤ ១៥:១៨ ទដ ១៨:២ និងការពន្យល់ ១៩:១៤ ។ *ម៉ែកប្លែកៗ* គឺនិយាយតំណាងឱ្យប្រជាជនអ៊ីស្រាអែល (សូមមើល ៥:៧ ១៨:៥ ៣៧:៣០–៣១) ក៏សូមមើល ទដ ៨០:៨–១៦ និង ៨០:៨–១១) ។

**១៧:១១** *គ្រាមានទុក្ខវេទនា . . . ហើយសង្រេងយ៉ាងសហ័ស* គឺដោយសារការឈ្លានពានរបស់ពួកអាសស៊ើរ ។

**១៧:១២–១៤** គឺបង្ហាញពីពេលវេលាមួយ ដែលពួកអ្នកឈ្លានពានដ៏មានអំណាចគឺបង្ហាញក្នុង ១០:២៨–៣៤ គឺអត្ថបទទាំងពីរនេះទំនងជាការបង្ហាញពីការឈ្លានពានរបស់ពួកស្តេចសានហេរីបក្នុង ឆ្នាំ ៧០១ មុន គ.ស (សូមមើល ៣៧:៣៦–៣៧ និងការពន្យល់) តែជាពួកហោរាដែលបង្ហាញក្នុងអត្ថបទនេះ គឺចង់សង្កត់ធ្ងន់ទៅលើសាសន៍អ៊ីស្រាអែលដែលទទួលបទពិសោធន៍ជាច្រើននៃជនជាតិគ្រប់អស់ទាំងពូជសាសន៍ ។

**១៧:១២** *សន្ធឹកសមុទ្រ* ពួកអាសស៊ើរបានសន្ធឹកនេះថា"ទឹកហូរ"ក្នុង ៨:៧ (សូមមើល ៨:៧–៨) ។

**១៧:១៣** *អង្កាមពីលើភ្នំ . . .* គឺជានិមិត្តពីខ្មាំងសត្រូវ ក៏សូមមើល ២៩:៥

ទាំងប៉ុន្មាននឹងលឿន[ឈ]ទៅដូចជាទឹកយ៉ាងធំ តែព្រះទ្រង់នឹង
ស្តីបន្ទោស[ញ]គេ នោះគេនឹងរត់[ដ]ទៅឆ្ងាយ ហើយនឹងត្រូវ
បណ្តេញទៅដូចជាខ្យល់ផាត់អង្កាម[ឋ]ពីលើភ្នំ ហើយដូចជា
ធូលីហុយឡើងពីមុខខ្យល់ព្យុះ[ឌ] [១៤]នៅពេលល្ងាចគេនឹង
មានចិត្ត[ឍ]ស្លុតស្លាំង[ណ]ហើយ វេលាព្រឹកមិនទាន់ភ្លឺនៅឡើយ
នោះគេនឹងបាត់ទៅ[ត] នេះហើយជាសំណាងសងដល់ពួកអ្នក
ដែលរឹបជាន់យើង ហើយជាចំណែករបស់ពួកអ្នកដែល
ប្លន់យើង ។

## បទទំនាយទាស់នឹងនគរគូស

**១៨** [១]វេទនា[ក]ដល់ស្រុកដែលបាំងដោយស្លាប ជាស្រុក
នៅត្រើយខាងនាយទន្លេស្រុកគូស[ខ] [២]ដែលចាត់រាជទូត[គ]ទៅ
តាមផ្លូវសមុទ្រ គឺឱ្យជិះនាវាធ្វើពីឫស្សី[ឃ]ទៅលើទឹកធំ ដោយ
បង្គាប់ថា ចូរទៅចុះ ពួកបំរើយ៉ាងលឿនអើយ ទៅឯ
សាសន៍១ដែលមានរូបខ្ពស់ហើយសាច់រលីង[ង] ជាជាតិ
មនុស្សគួរស្ញែងខ្លាច[ច]តាំងពីគេកើតមក ជាសសន៍ខ្លាំងពូកែ
ដែលជាន់ឈ្លីទាំងអស់ ហើយមានទន្លេហូរកាត់កណ្តាល
ស្រុកគេ[ឆ] [៣]ឱមនុស្សទាំងឡាយដែលនៅក្នុងលោកិយ[ជ] និង
ពួកអ្នកដែលអាស្រ័យនៅលើផែនដីអើយ កាលណាដំឡើង
ទង់[ឈ]១ឡើងនៅលើភ្នំ នោះចូរមើលចុះ ហើយកាលណា
ផ្លុំត្រែ[ញ]ឡើង នោះចូរស្តាប់ដែរ ។
[៤]ព្រះយេហូវ៉ាទ្រង់បានមានបន្ទូលមកខ្ញុំដូច្នេះថា អញ
នឹងនៅតែស្ងៀម[ដ] ហើយពិចារណាមើលពីទីលំនៅរបស់
អញ[ឋ] ដូចជារស្មីត្រចះចាំងមកនៅពេលព្រឹក[ឌ] ហើយដូចជា
ពពក ជាសន្សើម[ឍ]នៅពេលក្តៅកំពុងប្រមូលផល [៥]ដ្បិត
កាលមុនរដូវប្រមូលផល កាលផ្កាបានរោយរុះ ហើយក្តឹប
ទំពាំងបាយជូរកំពុងតែធំឡើងដរាបដល់ទុំ នោះទ្រង់នឹង
យកកាំបិតកាត់[ណ]ទង ហើយនឹងកាត់ខ្នែងចេញដែរ[ត] [៦]ក៏នឹង
ត្រូវបោះបង់ចោលជាមួយគ្នា ដល់សត្វហើរមកពីភ្នំ ដែល
ស៊ីគំរង់[ថ] ហើយដល់សត្វព្រៃនៅផែនដីដែរ[ទ] ឯសត្វហើរ
ទាំងនោះ នឹងអាស្រ័យ ដោយសារខ្មោចគេអស់១រដូវក្តៅ
ហើយសត្វព្រៃនឹងអាស្រ័យ ដោយសារគេអស់១រដូវរងា
[៧]នៅគ្រានោះ គេនឹងនាំយកដង្វាយ[ធ]១ មកថ្វាយព្រះ
យេហូវ៉ានៃពួកពលបរិវារ ពីសាសន៍១ដែលមានរូបខ្ពស់
ហើយសាច់ឈាមរលីង[ន] ជាជាតិមនុស្សគួរស្ញែងខ្លាច[ប]
តាំងពីគេកើតមក ជាសាសន៍ខ្លាំងពូកែ ដែលជាន់ឈ្លីទាំង
អស់ ក៏មានទន្លេ[ផ]ហូរកាត់កណ្តាលស្រុកគេ គឺនឹងនាំដង្វាយ
នោះមកដល់ភ្នំស៊ីយ៉ូន ជាទីរបស់ព្រះនាមព្រះយេហូវ៉ា
នៃពួកពលបរិវារ[ព]។

**១៩** [១]នេះសេចក្តីទំនាយយ៉ាងធ្ងន់[ក]ពីស្រុកអេស៊ីព្ទ[ខ,គ]។
មើល ព្រះយេហូវ៉ាទ្រង់គង់លើពពក[ឃ]យ៉ាងលឿន យាង

**១៧:១៣** ឈ ទដ ៤៦:៣ ញ ចទ ២៨:២០ ទដ ៩:៥ ដ ទដ ៦៨:១ អស ១៣:១៤ ឋ យប ១៣:២៥ អស ២:២២ ៤១:២,១៥–១៦ ដយ ២:៣៥ ឌ យប ២១:១៨ ទដ ៦៥:៧ **១៧:១៤** ឍ អស ២៩:៥ ៣០:១៣ ៤៧:១១ ៤៨:៣ ណ អស ៣៣:១៨ ៥៤:១៤ ត ២ពវ ១៩:៣៥ **១៨:១** ក អស ៥:៨ ខ លប ១០:៦ ទដ ៦៨:៣១ អគ ២៩:១០ **១៨:២** គ អប ១:១ ឃ នក ២:៣ យប ៩:២៦ ង លប ៤១:១៤ ច លប ១០:៨–៩ ២របា ១២:៣ ឆ ខ.៧ **១៨:៣** ជ ទដ ៣៣:៨ ឈ ទដ ៦០:៤ អស ៥:២៦ ១១:១០ ១៣:២ ៣១:៩ យរ ៤:២១ ញ យស ៦:២០ ពច ៣:២៧ **១៨:៤** ដ អស ៦២:១ ៦៤:១២ ឋ អស ២៦:២១ ហស ៥:១៥ មីក ៣:៤ ឌ ពច ៥:៣១ ទដ ១៨:១២ ហព ៣:៤ ឍ ២សយ ១:២១ ទដ ១៣៣:៣ អស ២៦:១៩ ហស ១៤:៥ **១៨:៥** ណ អស ១០:៣៣ ត អស ១៧:១០–១១ អគ ១៧:៦ **១៨:៦** ថ អស ៨:៨ ទ អស ៣៧:៣៦ ៥៦:៩ យរ ៧:៣៣ អគ ៣២:៤ ៣៩:១៧ **១៨:៧** ធ ២របា ៩:២៤ អស ៦០:៧ ន លប ៤១:១៤ ប ហព ១:៧ ផ ខ.២ ព ទដ ៦៨:៣១ **១៩:១** ក អស ១៣:១ ខ អស ២០:៣ យអ ៣:១៩ គ នក ១២:១២ យរ ៤៤:៣ ឃ ចទ ១០:១៤ ២សយ ២២:១០ វវ ១:៧ ង យស ២:១១

៤១:១៥–១៦ ទដ ៨៣:១៣ ។

**១៨:១–៧** សូមមើល សផ ២:១២ និងការពន្យល់។

**១៨:១** *បាំងដោយស្លាប* គឺនិយាយចំពោះសត្វល្អិត (វាអាចជាសត្វកណ្តូប) ឬក៏បង្ហាញពីការពណ៌នាពីកងទ័ពរបស់ស្រុកគូស (សូមមើល ៧:១៨–១៩) ។ *ស្រុកគូស* គឺជាស្រុកដែលមានទីតាំងនៅភូមិភាគខាងត្បូងឈាងខាងកើតរបស់ស្រុកអេស៊ីព្ទ ។ កាលក្នុងឆ្នាំ ៧១៥ មុន គ.ស ស្រុកគូសមានឈ្មោះថា សាបាកូ គឺក្រោមការគ្រប់គ្រងរបស់ស្រុកអេស៊ីព្ទគឺជាខ្សែរាជវង្សទី២៥ ។

**១៨:២** *សមុទ្រ* គឺប្រហែលជាទន្លេនីល (មើលការប្រៀបធៀប ១៩:៥ ណាហ ៣:៨ ហើយក្នុងព្រះគម្ពីរភាសាហេព្រើរក៏ប្រែថា "ទន្លេដែរ") ។ *នាវាធ្វើពីឫស្សី* មើលការពន្យល់ នក ២:៣ ។ *ចូរទៅចុះ* ដែលនាំទាំងសារទៅផង មើលក្នុង ខ.៣–៦ ។ *សាសន៍១ដែលមានរូបខ្ពស់ហើយសាច់រលីង* សូមមើល ខ.៧ ក្នុងនេះគឺអាចនិយាយពីប្រជាជនស្រុកគូសនិងស្រុកអេស៊ីព្ទ ។ (សូមមើលការ ពន្យល់ លប ៤១:១៤) ។ *ទន្លេ* គឺជាទន្លេនីល និងដៃរបស់វា ។

**១៨:៣** *ឱមនុស្សទាំងឡាយដែលនៅក្នុងលោកិយ* គឺគ្រប់ទាំងជាតិសាសន៍ទាំងឡាយដែលជារាស្ត្ររបស់ព្រះ (សូមមើល ១៧:១២–១៤ និងការពន្យល់) ។ *ទ្រង់* សូមមើល ៥:២៦ និងការពន្យល់ ។ *ផ្លុំត្រែ* គឺគេផ្លុំសម្រាប់ប្រមូលទ័ព (សូមមើល ពច ៣:២៧ ៦:៣៤ ២សយ ២:២៨) ។

**១៨:៤** *នៅតែស្ងៀម* នោះតាមការពិតចំពោះសេចក្តីប្រទូស្តភព ឬជិនុំជម្រះដល់ជាតិសាសន៍ទាំងឡាយគឺព្រះយេហូវ៉ាមិនធ្វើភ្លាមៗនោះទេ ប៉ុន្តែនៅពេលដែលគេទុំពេញខ្នាត (ខ.៥) ទ្រង់និងកាត់គេទំលាក់ ។

**១៨:៦** *សត្វហើរមកពីភ្នំដែលស៊ីគំរង់ . . . សត្វព្រៃនៅផែនដី* សូមប្រៀបធៀប ៥៦:៩ និងមើល យរ ៨:៣៣ អគ ៣២:៤ ៣៩:១៧–២០ វវ ១៩:១៧ និងការពន្យល់។

**១៨:៧** សូមមើល ខ.២ និងការពន្យល់ ។ *ដង្វាយ* គឺត្រូវបានគេនាំយកទៅឱ្យស្តេចអេសេគាលបន្ទាប់ពីស្តេច សានហេរីបបានសុគត ។ ហើយពួកម៉ូអាប់ក៏សុំឱ្យបញ្ជូនផ្ញើរកូនចៀមទៅឱ្យពួកក្រុងស៊ីយ៉ូន ។ មើលក្នុង ១៦:១ (ប្រៀបធៀប ៤៥:១៤ សផ ៣:១០) ។ *ជាទីរបស់នាម* មើល ចទ ១២::៥ និងការពន្យល់ ។

**១៩:១–២០:៦** សូមមើល យរ ៤៦ អគ ២៩:៣២ និងការពន្យល់ ។

**១៩:១** *សេចក្តីទំនាយ* មើលការពន្យល់ ១៣:១ ។ *ទ្រង់គង់លើពពកយ៉ាងលឿន* គឺជាពាក្យប្រៀបប្រដូចក៏បានគេប្រើក្នុងគម្ពីរ ទដ ៦៨:៤ (មើលការពន្យល់នៅក្នុងគម្ពីរនោះ) ទដ ១០៣:៣ ប្រៀបធៀប មថ ២៦:៦៤ ។ *រូបព្រះ . . . ញាប់ញ័រ* សូមមើល ៥០:២ នឹងការពន្យល់ក៏ឃើញគ្រាដំបូងព្រះបានជិនុំជម្រះរូបព្រះពួកអេស៊ីព្ទក្នុងពេល ឬតាមរយៈការមានភាពចង្រៃមកញាំញី

មកឯស្រុកអេស៊ីព្ទ អស់ទាំងរូបព្រះរបស់ស្រុកអេស៊ីព្ទនឹង
ញាប់ញ័រ នៅចំពោះទ្រង់ ហើយចិត្តពួកសាសន៍អេស៊ីព្ទ
នឹងរលត់ទៅ[ង]នៅក្នុងខ្លួនគេ ២ អញក៏នឹងញុះញង់ពួកសាសន៍
អេស៊ីព្ទឱ្យទាស់ទែងនឹងគ្នាឯងដែរ គេនឹងច្បាំងគ្នានឹងគ្នា
គឺបងប្អូននិងបងប្អូន[ច] ពួកអ្នកជិតខាងនិងអ្នកជិតខាង ទីក្រុង
១និងទីក្រុង១ទៀត ហើយនគរ១និងនគរ១ទៀតដែរ[ឆ]
៣ គំនិតរបស់សាសន៍អេស៊ីព្ទ និងសូន្យបាត់នៅកណ្ដាលគេ[ជ]
ហើយអញនឹងបំផ្លាញសេចក្ដីប្រឹក្សា[ឈ]របស់គេដែរ[ញ] នោះ
គេនឹងទៅរករូបព្រះ គ្រូសន្ទាប់ គ្រូខាប នឹងពួកគ្រូគាថា
របស់គេ[ដ] ៤ ហើយអញនឹងប្រគល់សាសន៍អេស៊ីព្ទទៅក្នុង
កណ្ដាប់ដៃនៃម្ចាស់១យ៉ាងសាហាវ ជាស្ដេច[ឋ]គួរស្ញែងខ្លាច
ដែលនឹងសោយរាជ្យលើគេ នេះជាព្រះបន្ទូលរបស់ព្រះ
អម្ចាស់ ជាព្រះយេហូវ៉ានៃពួកពលបរិវារ ។
៥ ឯទឹកក្នុងសមុទ្រ នោះនឹងរីងស្ងួតទៅ[ឌ] ហើយទន្លេ
នឹងជ្រាបបាត់ទៅជាហួតហែងវិញ[ឍ] ៦ ដៃទន្លេទាំងប៉ុន្មាន
នឹងធុំស្អុយ[ណ] ហើយព្រែកទាំងពួងនៃស្រុកអេស៊ីព្ទនឹងអន់
ថយហើយរីងស្ងួតទៅ[ត] ឯដើមបបុស[ថ] និងដើមត្រែងនឹង
ស្វិតក្រៀម[ទ] ៧ បណ្ដាវាល[ធ]តាមទន្លេ ហើយនៅមាត់ច្រាំង
និងស្រែ[ន]ទាំងប៉ុន្មានដែលគេសាបព្រោះតាមមាត់ទន្លេ
នោះនឹងក្រៀម ហើយផាត់បាត់ទៅ[ប] ៨ ពួកអ្នកនេសាទ[ផ]នឹង
ថ្ងូរស្ដាយ ឯពួកអ្នកដែលបោះសន្ទូច[ព]ក្នុងទន្លេនឹងស្រណោះ
ស្រណោក ហើយពួកអ្នកដែលបង់សំណាញ់នៅលើទឹក គេ
នឹងរីងរៃទៅ ៩ ១ទៀតពួកអ្នកដែលរកស៊ីធ្វើខ្លូតទេស[ភ] យ៉ាង
ម៉ដ្ដ ហើយពួកដែលត្បាញសំពត់ស[ម] គេនឹងត្រូវស្រឡាំង
កាំង ១០ គោលចារិកទាំងប៉ុន្មាននៃស្រុកនឹងត្រូវរលាយខ្ទេច
ទៅហើយពួកជើងឈ្នួលនឹងស្លុតចិត្ត ។
១១ ពួកចៅហ្វាយនៃក្រុងសូអាន[យ] គេសុទ្ធតែជាមនុស្ស
កំរោលទទេ គំនិតរបស់អ្នកប្រឹក្សា[រ]ដែលស្រៀវស្រួចជាង
គេរបស់ផារ៉ោន នោះបានវង្វេងចេញហើយ[ល] ធ្វើដូចម្ដេច
ឱ្យឯងរាល់គ្នានឹងទូលទៅផារ៉ោនបានថា ទូលបង្គំជាកូន
របស់អ្នកប្រាជ្ញ[វ] គឺជាពូជពង្សនៃស្ដេចពីបុរាណ ១២ ដូច្នេះ
តើពួកអ្នកប្រាជ្ញ[ស]របស់ទ្រង់នៅឯណា ចូរឱ្យគេជំរាបមក
ទ្រង់ឥឡូវ ឱ្យទ្រង់បានជ្រាបពីការដែលព្រះយេហូវ៉ានៃពួក
ពលបរិវារ ទ្រង់បានសំរេច[ហ]ពីដំណើរស្រុកអេស៊ីព្ទចុះ
១៣ ឯពួកចៅហ្វាយនៃក្រុងសូអាន[ឡ] គេបានទៅជាល្ងីល្ងើ
ហើយ ពួកចៅហ្វាយនៃក្រុងណូព[អ] គេត្រូវបញ្ឆោត ពួកអ្នក
ដែលជាសសរកន្លោង[ក]ក្នុងពូជអំបូរ គេបាននាំស្រុកអេស៊ីព្ទ
ឱ្យវង្វេង ១៤ ព្រះយេហូវ៉ាទ្រង់បានបណ្ដាលឱ្យមានគំនិតទទឹង
ទទែងលាយនៅក្នុងពួកគេ[ខ] ហើយគេបាននាំសាសន៍អេស៊ីព្ទ
ឱ្យធ្វើខុសក្នុងគ្រប់ទាំងកិច្ចការរបស់គេ ដូចជាមនុស្សស្រវឹង
ស្រាដែលដើរទ្រេតទ្រោត[គ]ក្នុងកំអួតរបស់ខ្លួន ១៥ ហើយនឹង
គ្មានការអ្វីសំរាប់ឱ្យសាសន៍អេស៊ីព្ទធ្វើ ដែលទោះជាក្បាល
ឬកន្ទុយ ជាមែកឬធាង នឹងអាចធ្វើបាននោះឡើយ[ឃ]។

**១៩:២** ច ពច
៧:២២ ១២:៤ មថ
១០:២១,៣៦ ឆ
២របា ១៥:៦
២០:២៣ មថ ២៤:៧
មក ១៣:៨ លក
២១:១០
**១៩:៣** ជ ទដ
១៨:៤៥ ឈ ខ.១១
យប ៥:១២ ញ ១រប
១០:១៣ ដ លវ
១៩:៣១ អស
៤៧:១៣ ដយ
២:២,១០ ៣:៨ ៥:៧
**១៩:៤** ឋ អស ២០:៤
យរ ៤៦:២៦ អគ
២៩:១៩ ៣២:១១
**១៩:៥** ឌ អស
៤៤:២៧ ៥០:២
យរ ៥០:៣៨ ៥១:៣៦
ឍ ២សយ ១៤:១៤
**១៩:៦** ណ នក ៧:១៨
ត អស ៣៧:២៥ អគ
៣០:១២ ថ លប
៤១:២ យប ៨:១១
ទ អស ១៥:៦
**១៩:៧** ធ ជន ១១:៥
ន ចទ ២៩:២៣
អស ២៣:៣
ប សក ១០:១
**១៩:៨** ផ ជន ១១:៥
អគ ៤៧:១០ ព អម ៤:២ ហព ១:១៥ **១៩:៩** ភ យស ២:៦ ម សភ ៧:១៦ អគ
១៦:១០ ២៧:៧ **១៩:១១** យ ជន ១៣:២២ រ លប ៤១:៣៧ ល ខ.៣ វ ១ពវ
៤:៣០ កច ៧:២២ **១៩:១២** ស ១កថ ១:២០ ហ អស ១៤:២៤ រម ៩:១៧
**១៩:១៣** ឡ ជន ១៣:២២ អ យរ ២:១៦ ៤៤:១ ៤៦:១៤,១៩ អគ ៣០:១៣,១៦
ហស ៩:៦ ក ទដ ១១៩:២២ **១៩:១៤** ខ សភ ១២:៨ មថ ១៧:១៧ គ ទដ
១០៧:២៧ **១៩:១៥** ឃ អស ៩:១៤

(មើល នក ១២:១២ និងការពន្យល់) ។ ហើយចិត្តពួកគេរលត់ សូមមើល ១៣:៧ ។

**១៩:២** *ពួកសាសន៍អេស៊ីព្ទឱ្យទាស់ទែងនឹងគ្នាឯង* សូមប្រៀបធៀប ៩:២១ ។ មានពង្សក្សត្រពីស្រុកលីប៊ីបានប៉ះទង្គិចគ្នានិងពួក "អេធីយ៉ូពី" (ស្រុកគូស៊ី) (សូមមើលការពន្យល់ ១៨:១) ជាមួយនិងពូជពង្សស្ដេចទាំងនោះគឺក្នុងរាជកាលទី២៤ ។

**១៩:៤** *ម្ចាស់១យ៉ាងសាហាវ* គឺជាស្ដេចនៃសាសន៍អាសស៊ើរ (សូមមើល ២០:៤) គឺជាស្ដេចអេសារហាដោនដែលបានគ្រប់គ្រងស្រុកអេស៊ីព្ទ គឺក្នុងឆ្នាំ ៦៧០ មុន គ.ស ។

**១៩:៥** *ឯទឹកក្នុងសមុទ្រនោះនឹងរីងស្ងួតទៅ* គឺជាទន្លេនីលដែលជាខ្សែជីវិតរស់របស់សាសន៍អេស៊ីព្ទទឹកហូរប្រចាំឆ្នាំបានផ្ដល់នូវទឹកដ៏សំខាន់និងផ្ដល់មកនូវដីល្បាប់ដែលមានជីវជាតិផងដែរ ។

**១៩:៦** *ដៃទន្លេ* គឺសម្រាប់ជាធារាសាស្ត្រមួយ ។

**១៩:៧** *គេសាបព្រោះតាមមាត់ទន្លេ* គឺជាភោគផលរបស់ស្រុកអេស៊ីព្ទដែលសម្បូរហូរហៀរ ហើយផលខ្លះក៏នាំចេញទៅលក់ក្រៅស្រុកថែមទៀត ។

**១៩:៨** *ពួកអ្នកនេសាទ* ត្រីជារឿយៗ សម្បូរហូរហៀរ (សូមមើល ជន ១១:៥ និងការពន្យល់) ។

**១៩:១១** *ក្រុងសូអាន* គឺជាក្រុងមួយនៅឯតំបន់ប៉ែកខាងកើតឈៀងខាងជើងនៃទន្លេនីលជាតំបន់ដីដែលធ្វើឱ្យសាសន៍អ៊ីស្រាអែលស្គាល់ច្បាស់នូវភូមិសាស្ត្រទីនោះក្នុងគ្រាពួកគេស្ថិតនៅស្រុកអេស៊ីព្ទ (សូមមើល ជន ១៣:២២ ទដ ៧៨:១២,៤៣) ។ គឺជារាជធានីនៅតំបន់ខាងជើងក្នុងរាជកាលទី២៥ (សូមមើល ១៨:១) ។ *អ្នកប្រាជ្ញ* សូមមើល ខ.១២ គឺជាអ្នកប្រាជ្ញដ៏ល្បីនៅក្នុងស្រុកអេស៊ីព្ទ (សូមមើល ១ពវ ៤:៣០ និងការពន្យល់) ។

**១៩:១៣** *ក្រុងណូព* គឺជាទីក្រុងសំខាន់មួយដែលមានចម្ងាយ ២៤ គ.ម ពីខាងត្បូងតំបន់ដីសណ្ដគឺជាដីទីក្រុងសម័យនគរចាស់ (ប្រហែលជាក្នុងកំឡុងឆ្នាំទី ២៦៨៦–២១៦០ មុន គ.ស) ។ *អ្នកដែលជាសសរកន្លោង* ដូចជា ហោរានិងសង្ឃក៏ដូចជាថ្នាក់ដឹកនាំនយោបាយមួយចំនួន (មើល ៩:១៥–១៦ និងការពន្យល់) ។

**១៩:១៤** *មនុស្សដែលស្រវឹងស្រាដែលដើរទ្រេតទ្រោត* ដូចអ្នកដឹកនាំសាសន៍អ៊ីស្រាអែល មើលក្នុង ២៨:៧–៨ ។

**១៩:១៥** *ជាក្បាល . . . ឬកន្ទុយជាមែកឬធាង* អ្នកដឹកនាំសាសន៍អេស៊ីព្ទ ។ សូមមើល ៩:១៤–១៥ (សូមមើលការពន្យល់ ៩:១៤) ។

១៦នៅគ្រានោះ[ង] សាសន៍អេស៊ីព្ទនឹងបានដូចជាស្រីៗ[ច]
គេនឹងញ័ររន្ធត់ ហើយតក់ស្លុត[ឆ] ដោយព្រោះការជន្លព្រះ
ហស្ត[ជ]របស់ព្រះយេហូវ៉ា នៃពួកពលបរិវារ ដែលទ្រង់ជន្ល
ពីលើគេ ១៧ហើយស្រុកយូដានឹងត្រឡប់ជាទីស្ញែងខ្លាចដល់
សាសន៍អេស៊ីព្ទ អស់អ្នកណាដែលឮនិយាយពីស្រុកនោះ
នឹងភ័យខ្លាច[ឈ] ដោយព្រោះគំនិតដែលព្រះយេហូវ៉ានៃពួក
ពលបរិវារទ្រង់បានសំរេច[ញ] ពីដំណើរស្រុកនោះហើយ ។
១៨នៅគ្រានោះ[ដ]នឹងមានទីក្រុង៥[ឋ]នៅក្នុងស្រុកអេស៊ីព្ទ
ដែលនិយាយភាសារបស់ស្រុកកាណាន គេនឹងស្បថ[ឌ]ដល់
ព្រះយេហូវ៉ានៃពួកពលបរិវារដែរ ឯទីក្រុង១នោះនឹងបាន
ហៅថាក្រុងដែលត្រូវវិនាស[ឍ]។
១៩នៅគ្រានោះ[ណ] នឹងមានអាសនា[ត]១នៅកណ្តាលស្រុក
អេស៊ីព្ទ[ថ] សំរាប់បូរជាថ្វាយដល់ព្រះយេហូវ៉ា ហើយនៅ
ត្រង់ព្រំដែននឹងមានបង្គោល[ទ]១ សំរាប់រំឭកពីព្រះយេហូវ៉ា
២០ឯបង្គោលនោះនឹងជាទីសំគាល់ ហើយជាបន្ទាល់[ធ]ពីព្រះ
យេហូវ៉ានៃពួកពលបរិវារ នៅក្នុងស្រុកអេស៊ីព្ទ ដ្បិតគេនឹង
អំពាវនាវដល់ព្រះយេហូវ៉ា ដោយព្រោះពួកអ្នកដែលសង្កត់
សង្កិនគេ ហើយទ្រង់នឹងចាត់ម្នាក់ឱ្យទៅជួយសង្គ្រោះ[ន]គេ
ជាអ្នកមានសក្តិធំ ដែលនឹងជួយ[ប]ឱ្យគេរួចបាន ២១ព្រះ
យេហូវ៉ា ទ្រង់នឹងសំដែងអង្គដល់ស្រុកអេស៊ីព្ទ ឱ្យគេស្គាល់
ហើយនៅគ្រានោះ សាសន៍អេស៊ីព្ទនឹងទទួលស្គាល់[ផ]ព្រះ
យេហូវ៉ា អើ គេនឹងថ្វាយបង្គំ[ព] ដោយបញ្ញបូជា និងដង្វាយ
ហើយគេនឹងបន់ដល់ព្រះយេហូវ៉ា ព្រមទាំងលាបំណន់នោះ
ដែរ[ភ] ២២ព្រះយេហូវ៉ាទ្រង់នឹងប្រហារ[ម]ស្រុកអេស៊ីព្ទ[យ] គឺ
ទាំងប្រហារ ហើយមើលឱ្យជាផង រួចគេនឹងវិលត្រឡប់
មក[រ]ឯព្រះយេហូវ៉ាវិញ ហើយទ្រង់នឹងទទួលពាក្យអង្វរ
របស់គេ ព្រមទាំងប្រោស[ល]គេឱ្យជាដែរ ។
២៣នៅគ្រានោះ[វ] នឹងមានថ្នល់១[ស] ចេញពីស្រុកអេស៊ីព្ទ
ទៅដល់ស្រុកអាសស៊ើរ[ហ] ឯសាសន៍អាសស៊ើរ គេនឹងមក
ឯស្រុកអេស៊ីព្ទ ហើយសាសន៍អេស៊ីព្ទ នឹងទៅឯស្រុក
អាសស៊ើរដែរ ពួកសាសន៍អេស៊ីព្ទនឹងថ្វាយបង្គំ[ឡ] ជាមួយនឹង

**១៩:១៦** ង អស ២:១៧ ១១:១០ ច យរ ៥០:៣៧ ៥១:៣០ ណហ ៣:១៣ ឆ ចទ ២:២៥ ហព ១០:៣១ ជ អស ១១:១៥ **១៩:១៧** ឈ លប ៣៥:៥ ញ អស ១៤:២៤ **១៩:១៨** ដ អស ១០:២០ ឋ យរ ៥៤:១ ឌ ទដ ២២:២៧ ៦៣:១១ អស ៤៨:១ យរ ៤:២ សផ ៣:៩ ឍ អស ១៧:១ ២៤:១២ ៣២:១៩ យរ ៤៣:១៣ **១៩:១៩** ណ អស ១០:២០ ត យស ២២:១០ ថ ទដ ៦៨:៣១ ទ លប ២៨:១៨
**១៩:២០** ធ លប ២១:៣០ ម ចទ ២៩:២៩ ពច ២:១៨ អស ២៥:៩ ប អស ៤៩:២៤–២៦ **១៩:២១** ផ អស ១១:៩ ៤៣:១១ ព ខ.១៩ លប ២៧:២៩ ទដ ៨៦:៩ អស ៥៦:៧ ៦០:៧ មឡ ១:១១ ភ ជន ៣០:២ ចទ ២៣:២១ **១៩:២២** ម នក ១២:២៣ ហព ១២:១១ យ នក ១១:១០ រ អស ៤៥:១៤ អគ ៣៣:១១ ហស ៦:១ ១០:១២ ១២:៦ ១៤:១ យអ ២:១៣ ល ចទ ៣២:៣៩ **១៩:២៣** វ ខ.១៦,២៤ អស ២០:៦ ស អស ១១:១៦ ហ មីក ៧:១២ ឡ លប ២៧:២៩ អស ២:៣ ២៧:១៣ ៦៦:២៣

**១៩:១៦–២៥** ពីភាពជាប់ៗគ្នានូវសេចក្តីថ្លែងប្រកាសនូវព្រឹត្តិការដែលទ្រង់យាងមក ។ គឺមានទំនាក់ទំនងនិងពាក្យថា"នៅគ្រានោះ"គឺទី១គឺសកម្មភាពនៃការជំនុំជម្រះពីព្រះដែលធ្វើឱ្យសាសន៍អេស៊ីព្ទភ័យញាប់ញ័ររន្ធត់ (ខ.១៦) គឺ ពួកសាសន៍យូដាក៏ភ័យ (មើល ខ.១៦–១៧) ទី២"ទីក្រុងទាំងប្រាំ"និងស្បថដល់ព្រះយេហូវ៉ានៃពួកពលបរិវារ (ខ.១៨) ។ ទី៣ គឺដោយព្រោះព្រះរាជកិច្ចបានដោះលែង និងប្រោសលោះក្នុងពួកមនុស្សនៃសាសន៍អេស៊ីព្ទ ។ អាសនាក៏សម្រាប់ធ្វើជាទីថ្វាយយញ្ញបូជាចំពោះព្រះដែរ (ខ.១៩–២២) ។

**១៩:១៦,១៨–១៩,២៣–២៤** នៅគ្រានោះ គឺជាថ្ងៃយាងមកជាថ្មីរបស់ ព្រះយេហូវ៉ា(មើល ១០:២០,២៧)និងការពន្យល់ប្រៀបធៀប ១១១:១០–១១ ។

**១៩:១៦** *ញ័ររន្ធត់* ដូចជាប្រជាជនរបស់ទីក្រុងយេរេខូរ(យស ២:៩,១១) ។

**១៩:១៧** *ស្រុកយូដា* ពួកអេស៊ីព្ទទទួលស្គាល់ថាយូដាជាស្រុកជាទីស្ញែងខ្លាច ។

**១៩:១៨** *ប្រាំ* គឺប្រហែលជាមានន័យថា"ជាច្រើន" ។ *ដែលនិយាយភាសារបស់ស្រុកកាណាន* ដែលជាការមួយបង្ហាញពីភាពស្មោះត្រង់របស់ពួកស្រុកអេស៊ីព្ទចំពោះព្រះយេហូវ៉ា (មើល ខ.២១–២២,២៥)ឬក៏បង្ហាញពីព្រះទ្រង់គង់នៅក្នុងសាសន៍អេស៊ីព្ទ ។ គឺបន្ទាប់ពីការធ្លាក់ចុះរបស់ក្រុងយេរូសាឡិមក្នុងឆ្នាំ ៥៨៦ មុន គ.ស ។ មានសាសន៍យូដាជាច្រើនបានភៀសខ្លួនទៅស្រុកអេស៊ីព្ទ (មើល យរ ៤៤:១ និងការពន្យល់) ។ *ក្រុងដែលត្រូវវិនាស* គឺដៅទៅលើទីក្រុងបេត–សេមែស គឺជាទីក្រុងព្រះសូរិយាទីក្រុងនេះត្រូវបំផ្លាញដោយពួកស្តេចនេប៊ូក្នេសា (សូមមើល យរ ៤៣:១៣ និងការពន្យល់) ។

**១៩:១៩** *អាសនា* គឺមានខ្លះមានលក្ខណៈដូចវិហារដែលបានសាងសង់ក្នុងស្រុកអេស៊ីព្ទ ក្នុងសតវត្សទី២ មុន គ.ស ដែលជាទីសម្រាប់សន្ទនាជាមួយព្រះយេហូវ៉ា ។

**១៩:២០** *ជាទីសំគាល់ហើយជាបន្ទាល់* ប្រៀបធៀប គឺជាគោលបំណងពីការសាងសង់អាសនានៅក្បែរទន្លេយ័រដាន់ គឺនៅក្បែរអ្នកដែលរស់នៅក្បែរទន្លេយ័រដាន់ យស ២២:២៦–២៧ ។ *ពួកអ្នកដែលសង្កត់. . . សង្គ្រោះ* គឺជាភាសាមកពីគម្ពីរពួកចៅហ្វាយ (សូមមើល ពច ២:១៨ និងការពន្យល់) ។ វានៅតែពុំមានភាពពិតប្រាកដ ពីអ្នកដែលសង្គ្រោះនោះនិងអ្នកការពារ តែជាទំនាយដែលមានគឺត្រូវតែជារាជបុត្រា៩អង្គ គឺតាមព្រះបន្ទូលសន្យាចេញពីរាជវង្សរបស់ស្តេចដាវីឌ (សូមមើល ១១:១០១០ និងការពន្យល់) ។

**១៩:២១** *ទ្រង់នឹងសំដែងអង្គដល់ស្រុកអេស៊ីព្ទឱ្យគេស្គាល់* ប្រៀបធៀប នក ៧:៥ *ថ្វាយបង្គំដោយយញ្ញបូជា* ដង្វាយរបស់អ្នកក្រៅស្រុកក៏បានបកស្រាយក្នុងដង្វាយ ៥៦:៧ ៦០:៧ (ប្រៀបធៀប សក ១៤:១៦–១៩ និងការពន្យល់នៅ ១៤:១៦) ។

**១៩:២២** *ប្រហារស្រុកអេស៊ីព្ទគឺទាំងប្រហារ* គឺជាការធ្វើទុក្ខមួយ (មើល ខ.២០)និងការរុកគួនដែលជាទំម្រេងពីការរងទុក្ខវេទនា ដែលព្រះកំណត់ឱ្យ ។ មានលក្ខណៈផ្ទុយនិងលទ្ធផលនៃការរុកគួនទៅលើកូនដំបូងក្នុង គម្ពីរ នក ១២:២៣ ។ *វិលត្រឡប់មកឯព្រះ. . . ប្រោសគេ* ប្រៀបធៀប ៦:១០ អត្ថបទនៅទីនេះ គឺជាពាក្យប្រដូចពីការបញ្ជូនឱ្យស្រុកអេស៊ីព្ទ"ព្រះអង្គសង្គ្រោះមួយនិងអ្នកការពារមួយ" (ខ.២០)គឺកាលដំបូងស្តេចផារ៉ោនមានព្រះទ័យរឹងទទឹងមិនព្រមងាកទៅរកព្រះយេហូវ៉ាទេ (នក ៩:៣៤–៣៥) ។

**១៩:២៣** *មានថ្នល់១* មើលការប្រៀបធៀប គឺជាផ្លូវដែលឆ្ពោះទៅកាន់ក្រុងយេរូសាឡិមក្នុង ១១:១៦ ៣៥:៨–១០ (មើលការពន្យល់) ជាច្រើនសតវត្សពួកអេស៊ីព្ទនិងពួកសាសន៍អាសស៊ើរក៏ធ្លាប់បានច្បាំងគ្នា (សូមមើល ២០:៤) តែក្នុងថ្ងៃអនាគត ពួកគេបានភ្ជាប់ចំណងមិត្តភាពដែលទៅតាមបញ្ញតិទ្រង់

ពួកសាសន៍អាសស៊ើរ ។
២៤នៅគ្រានោះ[អ] សាសន៍អ៊ីស្រាអែល នឹងជាសាសន៍
ទី៣សម្ពន្ធគ្នាជា១នឹងសាសន៍អេស៊ីព្ទ ហើយនិងសាសន៍
អាសស៊ើរ[ក] គឺជាទីបញ្ចេញពរ[ខ] នៅកណ្តាលផែនដី ២៥ពី
ព្រោះព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានប្រទានពរ[គ]
ដល់គេ ដោយបន្ទូលថា ចូរឱ្យសាសន៍អេស៊ីព្ទ ជារាស្ត្រ
របស់អញ[ឃ] និងសាសន៍អាសស៊ើរ ជាស្នាដៃរបស់អញ[ង]
ហើយសាសន៍អ៊ីស្រាអែល ជាមរដករបស់អញបានប្រកប
ដោយពរចុះ[ច] ។

## បទទំនាយទាស់នឹងនគរអេស៊ីព្ទ និងគូស

**២០** ១នៅក្នុងឆ្នាំដែលថើរថាន បានមកដល់ក្រុងអាសដូឌ
ជាឆ្នាំដែលសើកុន ស្តេចសាសន៍អាសស៊ើរបានចាត់លោក[ក]
ឱ្យទៅ ហើយលោកបានច្បាំងចាប់យកក្រុងអាសដូឌ[ខ]នោះ
២នៅគ្រានោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលបង្គាប់ដល់
អេសាយ ជាកូនអ៊ីម៉ូស[គ]ថា ចូរទៅបកសំពត់ធ្មៃ[ឃ]ពីចង្កេះឯង
ហើយដោះស្បែកជើង[ង]ចេញ នោះលោកក៏ធ្វើតាម គឺ
លោកដើរខ្លួនអាក្រាត[ច]ហើយជើងទទេ[ឆ] ៣ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលថា អេសាយជាអ្នកបំរើ[ជ]អញបានដើរខ្លួន
អាក្រាត ហើយជើងទទេគ្រប់៣ឆ្នាំ[ឈ]នេះទុកជាទីសំគាល់[ញ]
ហើយជាទីអស្ចារ្យ[ដ] ពីដំណើរសាសន៍អេស៊ីព្ទ[ឋ]និងសាសន៍
អេធីយ៉ូពីយ៉ាងណា[ឌ] ៤នោះស្តេច[ឍ]អាសស៊ើរនឹងដឹកពួក
ឈ្លើយ ជាពួកដែលបំបរចេញ[ណ]ពីស្រុកអេស៊ីព្ទ និងពីស្រុក
អេធីយ៉ូពី[ត]ទាំងចាស់ ទាំងក្មេង នាំទៅទាំងខ្លួនអាក្រាត[ថ]នឹង
ជើងទទេព្រមទាំងគូថ បើកឱ្យឃើញផង[ទ] យ៉ាងនោះដែរ
ទុកជាសេចក្តីខ្មាសដល់សាសន៍អេស៊ីព្ទ[ធ] ៥គេនឹងមានសេចក្តី
ស្រយុត ហើយស្រងាកចិត្ត[ន] ដោយព្រោះស្រុកអេធីយ៉ូពី[ប]
ដែលជាទីសង្ឃឹម[ផ]របស់គេ និងស្រុកអេស៊ីព្ទ[ព] ជាទីអួតអាង
របស់គេដែរ ៦នៅថ្ងៃនោះ[ភ] ពួកអ្នកនៅតាមឆ្នេរសមុទ្រ
គេនឹងពោលថា មើលចុះ ទីសង្ឃឹម[ម]ដែលយើងបានរត់ទៅ
ពឹង[យ] ឱ្យបានរួចពីស្តេចអាសស៊ើរ បានត្រឡប់ជា[រ]យ៉ាងនេះ
ទៅវិញហ្ន៎ ឯយើងធ្វើដូចម្តេចឱ្យយើងរួចបាន[ល] ។

## បទទំនាយទាស់នឹងនគរបាប៊ីឡូន

**២១** ១នេះជាសេចក្តីទំនាយយ៉ាងធ្ងន់[ក]ពីដំណើរវាល
រហាល[ខ]ក្បែរសមុទ្រ ។
ការនេះមកពីវាលរហាល គឺជាកន្លែងគួរស្ញែងខ្លាច

**១៩:២៤** អ ខ.២៣ ក អស ១១:១១ ខ លប ១២:២ **១៩:២៥** គ លប ១២:៣ អភ ២:១១-១៤ ឃ ទដ ៨៧:៤ ១០០:៣ ង អស ២៩:២៣ ៤៣:៧ ៤៥:១១ ៦០:២១ ៦៤:៨ អភ ២:១០ ច នក ៣៤:៩ យរ ៣០:២២ ហស ២:២៣ **២០:១** ក ២ពវ ១៨:១៧ ខ យស ១១:២២ ១៣:៣ **២០:២** គ អស ១៣:១ ឃ ២ពវ ១:៨ អស ៣:២៤ សក ១៣:៤ មថ ៣:៤ ង អគ ២៤:១៧,២៣ ច ១សយ ១៩:២៤ ឆ អគ ៤:១-១២ មីក ១:៨ **២០:៣** ជ អស ២២:២០ ៤១:៨-៩ ៤២:១ ៤៣:១០ ៤៩:៣,៥-៧ ៥០:១០ ៥២:១៣ ៥៣:១១ យរ ៧:២៥ ហក ២:២៣ សក ៤:១៤ ឈ អស ១៦:១៤ ញ នក ៣:១២ អស ៨:១៨ ៣៧:៣០ ៣៨:៧ កច ២១:១១ ដ ចទ ២៨:៤៦ ឋ អស ១៩:១ ឌ ខ.៥ លប ១០:៦ អស ៣៧:៩ ៤៣:៣ **២០:៤** ឍ អស ១៩:៤ ណ យរ ៤៦:១៩ ណហ ៣:១០ ត អស ១៨:១ សផ ២:១២ ថ យប ១២:១៧ ទ អស ៣:២៤ ធ អស ៤៧:៣ យរ ១៣:២២,២៦ ណហ ៣:៥ **២០:៥** ន អគ ២៩:១៦ ប ខ.៣ ផ អស ៨:១២ ព ២ពវ ១៨:២១ អស ៣០:៥ **២០:៦** ភ អស ២:១១ ១៩:២៣ ម យរ ៤៦:២៥ យ អស ១០:៣ រ ២ពវ ១៨:២១ ល យរ ៣០:១៥-១៧ ៣១:២ មថ ២៣:៣៣ ១ថន ៥:៣ ហព ២:៣ **២១:១** ក អស ១៣:១ ខ អស ១៣:២១ យរ ៥០:១២ ៥១:៤៣

និងការស្តាប់បង្គាប់ទ្រង់ (២៥:៣) ។ *ថ្វាយបង្គំជាមួយនិង . . .* គឺបង្ហាញពីភាពរួបរួមគ្នា និងមានភាពសុខសាន្ត ក្នុងការថ្វាយបង្គំ ២:២-៤ (សូមមើលការ ពន្យល់ ១៩:២១) ។

**១៩:២៥** *ទ្រង់បានប្រទានពរដល់គេ* គឺជាសេចក្តីសម្រេចតាមគម្ពីរ លប ១២:៣ (សូមមើលការពន្យល់ លប ១២:២-៣) ។ *សាសន៍អេស៊ីព្ទ* គឺជានិមិត្តទូទៅដែលមានសម្រាប់លោកអេសាយដូចជាមានពន្លឺ ដែលនិយាយពី "លំពង់ . . . គល់របស់អ៊ីសាយ" (១:១ មើល ១១:១-១០) ប្រៀបធៀប ៤៥:១៤ អក ២:១១-១៣ ។

**២០:១-៦** គឺជាសេចក្តីសន្និដ្ឋានរួមមួយចំពោះជំពូក ១៨:១៩ ដូចជាក្នុង ១៦:១៣-១៤ ។

**២០:១** *ក្នុងឆ្នាំ* គឺចង់និយាយពីឆ្នាំ ៧១២ មុន គ.ស ។ *សើកុន* គឺជាសើកុនទី២ ដែលបានសោយរាជក្នុងឆ្នាំ ៧២១-៧០៥ មុន គ.ស ។ មានតែខក្នុងគម្ពីរនេះទេដែលឃើញឈ្មោះស្តេចអង្គនេះ ។ *ក្រុងអាសដូឌ* គឺជាទីក្រុងមួយក្នុងចំណោមទីក្រុងរបស់ពួកភីលីស្ទីនទាំងប្រាំ ។ ទីក្រុង អាសដូឌ មានទីតាំងនៅជិតសមុទ្រមេឌីទែរ៉ាណេដែលមានចម្ងាយ ២:៨៩ គ.ម ពីខាងជើងឈាងខាងកើតនៃក្រុងកាសា ។ ជាទីក្រុងធ្លាប់ប្រឆាំងនិងពួកអាសស៊ើរក្រោមការគ្រប់គ្រងនៃស្តេច អាសូរី ។

**២០:២** *សំពត់ធ្មៃ* ជាធម្មតាជាសំលៀកបំពាក់សម្រាប់អ្នកកាន់ទុក្ខ (សូមមើលការពន្យល់ ១១:៣) ជួនកាលវាជាសម្លៀកបំពាក់របស់ពួកហោរា (សូមមើល ២ពវ ១:៨ សក ១២:៤-៦ និងការពន្យល់) ។

**២០:៣** *អ្នកបំរើអញ* សូមមើលការពន្យល់ ៤១:៨-៩ ៣ឆ្នាំសូមមើល ១៦:១៤ នឹងការពន្យល់ *ទីសំគាល់ហើយជាទីអស្ចារ្យ* ។ សូមមើល ៨:១៨ ក៏សូមមើល ៧:៣,១៤ និងការពន្យល់ ។ ចរិតលក្ខណៈរបស់ហោរា អេសេគាល ក៏មានជានិមិត្តបង្ហាញបញ្ជាក់ (អគ ២៤:២៤,២៧ ប្រៀបធៀប សក ៣:៨) ។ *សាសន៍អេស៊ីព្ទ នឹងសាសន៍អេធីយ៉ូពី* សូមមើល ១៨:១ នឹងការពន្យល់ ។

**២០:៥** *ជាទីសង្ឃឹមរបស់គេនឹងស្រុកអេស៊ីព្ទជាទីអួតអាងរបស់គេដែរ* គឺក្រោយពួកសាសន៍អាសស៊ើរនគរអ៊ីស្រាអែលគឺក្នុងឆ្នាំ ៧២២-៧២១ មុន គ.ស ដោយស្តេចហេសេគារបស់ស្រុកយូដា ដែលស្ថិតនៅក្រោមដ៏ខ្លាំងដើម្បីឱ្យសម្ព័ន្ធភាពជាមួយអេស៊ីព្ទមានឡើងវិញ ។ លោកអេសាយ ការជំទាស់និងគោលការ (ប្រៀបធៀប ៣០:១-២ ៣១:១ និងការពន្យល់) ។

**២១:១** *សេចក្តីទំនាយ* សូមមើលការពន្យល់ ១៣:១ ។ *វាលរហាល* គឺពេលការជំនុំជម្រះមកដល់គេបោះបង់ចោល (មើល ខ.៩) (ប្រៀបធៀប ១៣:២០-២២) ។ *សមុទ្រ* គឺសំដៅទៅលើឈូងសមុទ្រ ពើស៊ីដែលមានទីតាំងនៅផ្នែកខាងត្បូងឈាងខាងកើតនៃស្រុកបាប៊ីឡូន ឬក៏ជាវាលទំនាបដែលទេរចុះទៅតាមបណ្តោយ ។ *វាលរហាល . . .* ជាប្រភេទវាលខ្សាច់ជាវាលរហោស្ថានជួនកាលមានខ្យល់យ៉ាងខ្លាំង (សូមមើល ហស ១៣:១៥) គឺប្រៀបដូចជាអ្នកឈ្លានពានមកលុកលុយដែលគួរឱ្យភ័យខ្លាច ដូចជាបានពណ៌នាពីខ្យល់កំបុតត្បូង ។

ដូចខ្យល់កំបុតត្បូង[ក] ដែលបក់មកបោសកាត់ស្រុកត្បូងដែរ[ខ]
២មានការជាក់ស្តែងយ៉ាងធ្ងន់[ង]បានប្រាកដដល់ខ្ញុំហើយ គឺ
មនុស្សឧបាយ គេប្រព្រឹត្តដោយកិច្ចកលរបស់គេ[ច] ពួកអ្នក
ដែលធ្លាប់បំផ្លាញ ក៏បំផ្លាញទៅ ឱស្រុកអេឡាំអើយ[ឆ] ចូរ
ឡើងទៅ ឱសាសន៍មេឌីអើយ[ជ] ចូរឡោមព័ទ្ធច្បាំងនឹងគេ
ចុះ អញបានរំងាប់ដំងូរចេញពីនោះហើយ ៣ហេតុនោះ
បានជាចង្កេះខ្ញុំចុកសៀតជាខ្លាំង[ឈ] សេចក្តីឈឺចាប់បានគ្រប
សង្កត់ខ្ញុំដូចជាស្ត្រីឈឺនឹងសំរាល[ញ] ខ្ញុំបានវល់គំនិតដល់ម្ល៉េះ
បានជាស្តាប់អ្វីមិនឮ ក៏ញ័រខ្លួនទទាក់ដល់ម្ល៉េះបានជាមើល
អ្វីមិនឃើញ[ដ] ៤ទ្រូង[ឋ]ខ្ញុំពើតខ្មោកៗ សេចក្តីស្ញែងខ្លាចយ៉ាង
សំបើមបានបំភ័យខ្ញុំ[ឌ] វេលាព្រលប់ដែលជាពេលសប្បាយ
ដល់ខ្ញុំ នោះបានត្រឡប់ជាវេលាតក់ស្លុត[ឍ]ដលខ្ញុំវិញ ៥គឺ
គេរៀបតុ ហើយដាក់ឱ្យចាំយាម រួចគេស៊ីគេផឹក[ណ] ស្រាប់
តែឮសំរែកថា ចូរក្រោកឡើងពួកមេទាំងឡាយអើយ ចូរ
លាបខែលទៅ[ត] ៦ដ្បិតព្រះអម្ចាស់ទ្រង់បានមានបន្ទូលមក
ខ្ញុំដូច្នេះថា ចូរទៅដាក់អ្នកល្បាតម្នាក់ឱ្យចាំយាម[ថ] ឱ្យគេ
ប្រាប់ហេតុការអ្វីដែលគេឃើញ ៧គេក៏ឃើញកងទ័ពមាន
ពលសេះ[ទ]ដើរទន្ទឹមគ្នា១គូៗ ព្រមទាំងអ្នក១ជិះលើលា នឹង
អ្នក១ជិះលើអូដ្ឋផង[ធ] គេក៏ប្រុសស្តាប់អស់ពីចិត្ត ៨រួចស្រែក
មកដូចសិង្ហថា លោកម្ចាស់អើយ នៅវេលាថ្ងៃខ្ញុំឈរនៅ
លើប៉មជានិច្ច ហើយក៏នៅត្រង់ទីចាំយាម[ន]របស់ខ្ញុំរាល់តែ
យប់ដែរ ៩មើល មានកងទ័ព ជាពលសេះ[ប] ដើរមកទាំង
គូៗ រួចគេបន្លឺសំឡេងឡើងទៀតថា ដួលហើយ ក្រុង
បាប៊ីឡូន[ផ]បានដួលហើយ[ព] អស់ទាំងរូបព្រះ[ភ]ឆ្លាក់របស់គេ
បានត្រូវបែករលេ[ម]នៅលើដី ។
១០ឱពួកអ្នកដែលត្រូវបញ្ជាន់ ជាគ្រាប់ពូជនៅទីលាន
របស់[យ]អញអើយ សេចក្តីដែលបានឮមកពីព្រះយេហូវ៉ានៃ
ពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល នោះបាន
ប្រាប់ដល់ឯងរាល់គ្នាហើយ ។

## បទទំនាយទាស់នឹងស្រុកអេដំម

១១នេះសេចក្តីទំនាយយ៉ាងធ្ងន់ ពីដំណើរពួកឌូម៉ា[រ] មាន
ម្នាក់នៅស្រុកសៀរ[ល]ស្រែកមករកខ្ញុំថា អ្នកយាម អើយ
តើយប់យ៉ាងណាទៅ អ្នកយាមអើយ តើយប់យ៉ាងណាទៅ។
១២អ្នកយាមក៏ឆ្លើយតបថា ពេលព្រឹកកំពុងតែមក ហើយ
យប់ ក៏មកដែរ បើឯងចង់ដឹង ចូរសួរចុះ ចូរត្រឡប់ មកវិញ
ចូរមកចុះ ។

**២១:១** គ យប ១:១៩ ឃ ដយ ១១:៤០ សក ៩:១៤ **២១:២** ង ទដ ៦០:៣ ច អស ២៤:១៦ ៣៣:១ ឆ លប ១០:២២ អស ២២:៦ ជ អស ១៣:៣ យរ ២៥:២៥ ៥១:២៨ **២១:៣** ឈ យប ១៤:២២ ញ លប ៣:១៦ ទដ ៤៨:៦ អស ២៦:១៧ ៣៧:៣ យរ ៣០:៦ ៤៨:៤១ ៤៩:២២ យហ ១៦:២១ ដ ដយ ៧:២៨ ៨:២៧ ១០:១៦ **២១:៤** ឋ អស ៧:៤ ៣៥:៤ ឌ អស ១៣:៨ ដយ ៥:៩ ឍ ទដ ៥៥:៥ **២១:៥** ណ អស ៥:១២ ២២:២,១៣ ២៣:៧ ២៤:៨ ៣២:១៣ យរ ២៥:១៦,២៧ ៥១:៣៩,៥៧ ដយ ៥:២ ត ២សយ ១:២១ ១ពវ ១០:១៦–១៧ យរ ៤៦:៣ ៥១:១១ **២១:៦** ថ ២ពវ ៩:១៧ **២១:៧** ទ ខ.៩ ធ ពច ៦:៥ **២១:៨** ន មីក ៧:៧ ហព ២:១ **២១:៩** ប ខ.៧ ផ អស ១៣:១ ៤៧:១,៥ វវ ១៤:៨ ព អស ៤៧:១១ យរ ៥១:៨ ដយ ៥:៣០ ភ លវ ២៦:៣០ អស ៤៦:១ យរ ៥០:២ ៥១:៤៤ ម អស ២:១៨ **២១:១០** យ អស ២៧:១២ ២៨:២៧,២៨ ៤១:១៥ យរ ៥១:៣៣ មីក ៤:១៣ ហព ៣:១២ មថ ៣:១២ **២១:១១** រ លប ២៥:១៤ អស ៣៤:១១ ល លប ៣២:៣

**២១:២** *ឱស្រុកអេឡាំអើយ* សូមមើលការពន្យល់ ១១:១១ សូមមើល យរ ៤៩:៣៤–៣៩ ។ ពួកអេឡាំគឺជាសត្រូវស្លាប់រស់និងពួកសាសន៍អាសស៊ើរនិង ពួកសាសន៍បាប៊ីឡូន ។ ហើយក្រោយមកទៀតមានកងទ័ពរបស់ពួកស្តេច ពើស៊ីខ្លះបានគ្រប់គ្រងកាន់កាប់ពួកបាប៊ីឡូន គឺក្រោមការដឹកនាំរបស់ស្តេច ស៊ីរូស ក្នុងឆ្នាំ ៥៣៩ មុន គ.ស ។ *សាសន៍មេឌី* សូមមើលការពន្យល់ ១៣:១៧ *គេ* ពាក្យថាគេគឺសំដៅទៅលើពួកបាប៊ីឡូន ។

**២១:៣** *ចង្កេះខ្ញុំចុកសៀតជាខ្លាំង* សូមមើលការពន្យល់ ១៦:៩–១១ ក៏សូម មើលពីការប្រត្តិកម្មរបស់ដានីយ៉ែលចំពោះនិមិត្តក្នុងគម្ពីរ ដានីយ៉ែល ៨:២៧ ១០:១៦–១៧ ។

**២១:៤** *វេលាព្រលប់* គឺប្រហែលសំដៅលើចុងបញ្ចប់របស់ពួកបាប៊ីឡូន គឺ ចក្រភពបាប៊ីឡូនទាំងមូល (សូមមើល ការពន្យល់ ខ.១២) ។ *វាលាតក់ស្លុតដល់ខ្ញុំ* គឺជាភាពខ្ទេចខ្ទីដែលហួសពីការពិត ។

**២១:៥** *គេស៊ីគេផឹក* ដែលជាពិធីបុណ្យមួយរបស់ស្តេចបេលសាសារ (សូម មើល ដយ ៥:១) ជាស្តេចចុងក្រោយរបស់សាសន៍បាប៊ីឡូន ។ *ចូរក្រោកឡើង* គឺជាពាក្យវោហារសាស្ត្រនៃពួកហោរាដែលបានទទួលនូវនិមិត្ត ដែល ត្រូវប្រយុទ្ធគឺសង្គ្រាមកើតឡើង ។ ដែលមានសត្រូវមកប្រយុទ្ធនិងពួកសាសន៍ បាប៊ីឡូន គឺហៅដល់ពួកនាយទាហាន បាប៊ីឡូនឱ្យរៀបចំខ្លួនជាស្រេច ។ *ចូរលាបខែលទៅ* សូមមើលការពន្យល់ ២សយ ១:២១ ។

**២១:៦** *ចូរទៅដាក់អ្នកល្បាតម្នាក់ឱ្យចាំយាម* គឺប្រហែលជាការពង្រាយអ្នក ល្បាតយាមនៅឯកំផែងក្រុងយេរូសាឡិម ។

**២១:៧** *កងទ័ពមានពលសេះ . . . អ្នក១ជិះលើខ្នងលា . . . លើអូដ្ឋផង* គឺជា ក្រុមទ័ពនាំសារមកពីទីឆ្ងាយ ។

**២១:៩** *ក្រុងបាប៊ីឡូនបានដួលហើយ* សូមមើល ១៣:១៩ ។ គឺក្រុងបាប៊ីឡូន បានដួលនៅក្នុងឆ្នាំ ៦៨៩ មុន គ.ស ហើយបានដូចក្នុងឆ្នាំផ្សេងទៀតគឺ ៥៣៩ ពាក្យនេះស្រង់ពីលោក យ៉ូហានក្នុងគម្ពីរ វវ ១៤:៨ ១៨:២ ។ *អស់ទាំងរូបឆ្លាក់ព្រះរបស់គេបានត្រូវបែករលេនៅលើដី* ការធ្លាក់ចុះនៃនគរគឺជាភាព អាម៉ាស់មុខចំពោះរូបព្រះនោះ (ប្រៀបធៀប ៤៦:១–២ ១សយ ៥:៣–៧ នឹងការពន្យល់) ។

**២១:១០** *ត្រូវបញ្ជាន់* គឺជាពួកយូដាដែលទទួលទណ្ឌកម្មពីពួកសាសន៍បាប៊ីឡូន ហើយត្រូវពួកបាប៊ីឡូនយកជាឈ្លើយ (មើល ៣៩:៥–៧ និងការពន្យល់) ។ គឺជាការខូចខាតឬជិនុំជម្រះដោយសារសង្គ្រាម (សូមមើល អម ១:៣ និង ការពន្យល់) ។

**២១:១១** *សេចក្តីទំនាយ* សូមមើលការពន្យល់ ១៣:១ ។ *សៀរ* គឺមានន័យថា ពួកសាសន៍អេដំម(លប ៣២:៣) ។ គឺជាស្រុកកំណើតរបស់ពូជអំបូរអេសាវ នៅឯសមុទ្រស្លាប់ ។ (សូមមើល ៣៤:៥–១៥ ៦៣:១ និងការពន្យល់) ។

**២១:១២** *ពេលព្រឹក . . . ហើយយប់* គឺទំនងជាមានន័យថាការគាបសង្កត់ របស់ពួកអាសស៊ើរមានរយៈពេលមួយយប់ពេញ ហើយក៏ជិតបញ្ចប់ផងដែរ ប៉ុន្តែការនេះមានរយៈពេលខ្លីនៅពេលថ្ងៃ (មើល ខ.៤ និងការពន្យល់) ។

## បទទំនាយទាស់នឹងស្រុកអារ៉ាប់

១៣នេះជាសេចក្ដីទំនាយយ៉ាងធ្ងន់[រ] ពីដំណើរស្រុកនៃ
ពួកអារ៉ាប់[ស] ។
ឱពួកសាសន៍ដេដាន់[ហ] ដែលធ្វើដំណើរដង្ហែគ្នាអើយ
ពួកឯងនឹងស្នាក់នៅក្នុងដងព្រៃនៅស្រុកអារ៉ាប់ ១៤គេបាន
យកទឹកមកឱ្យពួកអ្នកដែលស្រេក ពួកអ្នកនៅស្រុកថេម៉ា[ឡ]
បានយកអាហារមកទទួលពួកអ្នកដែលរត់ ១៥ដ្បិតគេបាន
រត់ឱ្យរួច[អ]ពីដាវ[ក] គឺពីដាវដែលហូតស្រោប់ ពីធ្នូដែលដំឡើង
ជាស្រេច ហើយពីសេចក្ដីវេទនានៃការសឹកសង្គ្រាម ១៦ពី
ព្រោះព្រះអម្ចាស់ទ្រង់បានមានបន្ទូលមកខ្ញុំដូច្នេះថា ក្នុង
រវាង១ឆ្នាំ រាប់តាមឆ្នាំរបស់កូនឈ្នួល[ខ] នោះសិរីល្អ[គ]របស់
ពួកកេដារ[ឃ]នឹងសូន្យបាត់ទៅ ១៧ហើយពួកពលធ្នូ ជាពួក
មនុស្ស ខ្លាំងពូកែក្នុងពួកកូនចៅកេដា ដែលនៅសល់ នឹង
មានគ្នាតិចតួចទេ[ង] ពីព្រោះព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់បានមានបន្ទូលជាស្រេចហើយ[ច] ។

## បទទំនាយអំពីក្រុងយេរូសាឡិម

**២២** ១នេះជាសេចក្ដីទំនាយយ៉ាងធ្ងន់[ក] ពីដំណើរច្រក
ភ្នំ[ខ]នៃការជាក់ស្ដែង[គ] ។
តើមានការអ្វីហ្នឹង បានជាឡើងទៅលើដំបូលផ្ទះគ្រប់គ្នា
ដូច្នេះ[ឃ] ២ឱឯងដែលពេញដោយសំរែក ជាទីក្រុងអ៊ឹកធឹក[ង]
គ្រឹកគ្រេង ជាដំបន់អរសប្បាយអើយ[ច] ពួកឯងដែលត្រូវគេ
សំឡាប់[ឆ] នោះមិនបានស្លាប់ដោយដាវទេ[ជ] ក៏មិនបានស្លាប់
ក្នុងចំបាំងដែរ ៣ពួកអ្នកដែលគ្រប់គ្រងលើឯង គេបានរត់[ឈ]
ទៅជាមួយគ្នា តែពួកពលធ្នូចាប់ចង[ញ]គេបានហើយ ពួកឯង
ដែលគេរកឃើញ ជាពួកអ្នកបានរត់ទៅឆ្ងាយហើយនោះ
ក៏ត្រូវគេចាប់ចងជាមួយគ្នា ៤ដូច្នេះ ខ្ញុំបាននិយាយថា ចូរ
បែរមុខពីខ្ញុំចេញ ខ្ញុំនឹងយំ[ដ]យ៉ាងក្រំចិត្ត កុំឱ្យខំជួយកំសាន្ត
ទុក្ខខ្ញុំ ពីដំណើរពួកកូនស្រីរបស់សាសន៍ខ្ញុំ[ឋ] ដែលត្រូវ
បំផ្លាញឡើយ ៥ដ្បិតនេះជាថ្ងៃ[ឌ]ចលាចល ថ្ងៃជាន់ឈ្លី[ឍ]
ហើយវល់គំនិត[ណ] ដែលមកពីព្រះអម្ចាស់យេហូវ៉ានៃពួកពល
បរិវារ នៅត្រង់ច្រកភ្នំនៃការជាក់ស្ដែង[ត] គឺជាការរំលំ
រំលាយកំផែង[ថ] ហើយជាការស្រែកឮខ្ទរនៅក្នុងភ្នំ ។
៦ពួកអេឡាំ[ទ] ជាអ្នកស្ពាយបំពង់ព្រួញ[ធ] គេក៏មានរទេះ
ចំបាំងពេញដោយមនុស្ស ហើយមានពលសេះផង ឯពួក

**២១:១៣** រ អស ១៣:១ ស ២របា ៩:១៤ ហ លប ១០:៧ ២៥:៣ **២១:១៤** ឡ លប ២៥:១៥ **២១:១៥** អ អស ១៣:១៤ ក អស ៣១:៨ **២១:១៦** ខ លវ ២៥:៥០ គ អស ១៧:៣ ឃ លប ២៥:១៣ **២១:១៧** ង ចទ ៤:២៧ អស ១០:១៩ ច អស ១:២០ ១៦:១៤ **២២:១** ក អស ១៣:១ ខ ទដ ១២៥:២ យរ ២១:១៣ យអ ៣:២,១២,១៤ គ អស ១:១ ឃ យស ២:៨ យរ ៤៨:៣៨ **២២:២** ង អគ

២២:៥ ច អស ៥:១៤ ២១:៥ ឆ អស ១០:៤ ជ ២ពវ ២៥:៣ **២២:៣** ឈ អស ១៣:១៤ ញ ២ពវ ២៥:៦ **២២:៤** ដ អស ១៥:៣ បទ ១:១៦ អក ២១:៦ លក ១៩:៤១ ឋ យរ ៩:១ **២២:៥** ឌ អស ២:១២ ឍ យប ៤០:១២ ទដ ១០៨:១៣ ណ ២សយ ២២:៤៣ អស ១៣:៣ យរ ៣០:៧ បទ ១:៥ អគ ៨:១៧–១៨ ៩:៩–១០ យអ ២:៣១ អម ៥:១៨–២០ សផ ១:១៥ ត អស ១:១ ថ នហ ៦:១៥ ទដ ៨៩:៤០ អស ៥:៥ យរ ៣៩:៨ អគ ១៣:១៤ **២២:៦** ទ អស ២១:២ ធ ទដ ៤៦:៩ យរ ៤៩:៣៥ ៥១:៥៦

**២១:១៣** *ជាសេចក្ដីទំនាយ* សូមមើលការពន្យល់ ១៣:១ ។ *ពួកសាន៍ដេដាន់* គឺជាពូជអំបូរពួកអារ៉ាប់ដែលមានសកម្មភាពមុខជំនួញពាណិជ្ជកម្មដូចជាបានបង្ហាញក្នុង អគ ២៧:២០ ៣៨:១៣ ។ *ក្នុងដងព្រៃ* ជាកន្លែងពួកសាសន៍ដេដាន់លាក់ខ្លួនពីការឈ្លានពានរបស់ពួកអាសស៊ើរ (មើល ពច ៥:៦) ។ ជាពេលដែលពួកអាសស៊ើរវាយប្រហារដល់ពួកសាសន៍អារ៉ាប់ក្នុងឆ្នាំ ៧៤២ មុន គ.ស ។ ឯពួកបាប៊ីឡូនក៏ធ្វើដូច្នេះដែរ គឺក្រោមការគ្រប់គ្រងរបស់ស្ដេចនេប៊ូក្នេសា (មើល យរ ២៥:១៧,២៣–២៤) ។

**២១:១៤** *ស្រុកថេម៉ា* គឺនៅខាងជើងស្រុកអារ៉ាប់ គឺប្រហែលជា ៦៤៣ គីឡូម៉ែត្រពីតំបន់ខាងជើងភាគខាងលិចនៃក្រុងបាប៊ីឡូន (ប្រៀបធៀប យប ៦:១៩ យរ ២៥:២៣) ។

**២១:១៥** *ពីដាវ . . . ពីធ្នូ* គឺធ្នូមានលក្ខណៈសាមញ្ញដែលអាចប្រយុទ្ធទប់ទល់ជាមួយនិងដាវរបស់ពួកអាសស៊ើរយ៉ាងមានប្រសិទ្ធភាព ។

**២១:១៦** *រាប់តាមឆ្នាំរបស់កូនឈ្នួល* សូមមើល ១៦:១៤ និងការពន្យល់ ។ *កូនចៅកេដារ* គឺនៅឯស្រុករបស់ពួកអំបូរមួយដែលចូលចិត្តធ្វើជាជនពនេចរ ដែលធ្វើដំណើរគ្មានទិសដៅនៅលើវាលរហោស្ថាន ។ ស្ដេចនេប៊ូក្នេសាបានវាយប្រយុទ្ធបំបាក់ដល់ប្រជាជនពួកកេដារ (យរ ៤៩:២៨–២៩ ប្រៀបធៀបនឹង យរ ២:១០ និងការពន្យល់) ។

**២១:១៧** *នៅសល់ . . . មានគ្នាតិចតួច* ប្រៀបធៀប ១០:១៩ ១៦:១៤ ១៧:៦។

**២២:១–១៣** គឺជាទីសំគាល់ពីសេចក្ដីទំនាយ ដែលឆ្ពោះទៅរកការហ៊ុំព័ទ្ធដោយពួកស្ដេចសានហេរីបក្នុងឆ្នាំ ៧០១ ។

**២២:១** *សេចក្ដីទំនាយ* សូមមើលការពន្យល់ ១៣:១ ។ *ពីដំណើរនៃច្រកភ្នំ* គឺជា ទីកន្លែងដែលទ្រង់បានសម្ដែងអង្គទ្រង់ គឺប្រហែលជាច្រកភ្នំមួយដែលស្ថិតនៅក្បែរក្រុងយេរូសាឡិម (សូមមើល ខ.៧) ។ សូមមើល ខ.៥ ផងដែរ *នៅលើដំបូល* សូមមើលការពន្យល់ ១៥:៣ ។

**២២:២** *អ៊ឹកធឹកគ្រឹកគ្រេង* សូមមើល ខ.១៣ ១៥:១១–១៣ និងការពន្យល់ ៣២:១៣ ។ ដែលពេលនោះក្រុងយេរូសាឡិម ក៏មានលក្ខណៈដូចក្រុងបាប៊ីឡូន (មើល ២១:៥ និងការពន្យល់ ២៣:៧) ។ *នោះមិនបានស្លាប់ដោយដាវទេ* គឺចង់សម្គាល់ទៅលើការស្លាប់នោះដោយសារជម្ងឺ មិនមែនដោយសារសង្គ្រាមទេ ។

**២២:៣** *អ្នកគ្រប់គ្រងលើឯងគេបានរត់* ដូចជាស្ដេចសេដេគា និងពលទ័ពផងទ្រង់ក៏គេចចេញពីក្រុងយេរូសាឡិម ហើយក៏ត្រូវគេចាប់នៅក្បែរទីក្រុងយេរីខូរ (សូមមើល ២ពវ ២៥:៤–៦) ។

**២២:៤** *របស់សាសន៍ខ្ញុំ* "គឺជាកូនស្រីរបស់ខ្ញុំ" (សូមមើលការពន្យល់ ២ពវ ១៩:២១) ។

**២២:៥** *នេះជាថ្ងៃ* សូមមើល ២:១២ និងការពន្យល់ ២:១១,១៧,២០ ។ ប្រៀបធៀបនិងពាក្យថា "នៅគ្រានោះ" ក្នុង ខ.៨ និងពាក្យថា "នៅគ្រានេះ" ក្នុង ខ.១២ ។ *ចលាចល* គឺជាការសម្រេចនូវបណ្ដាសាតាមរយៈគម្ពីរ ចទ ២៨:២០ ។

**២២:៦** *ពួកអេឡាំ* មើលការពន្យល់ ១១:១១ ក៏សូមមើល យរ ៤៩:៣៩ ។ ពួកអេឡាំគឺមានឃើញក្នុងជួរបម្រើកងទ័ពរបស់ពួកស្រុកបាប៊ីឡូន ។ *ស្ពាយ*

ការ[ន] គេបានដោះស្រោមខែលចេញ ៧យ៉ាងនោះច្រកភ្នំ[ប]
យ៉ាងល្អបំផុតរបស់ឯង បានពេញដោយរទេះចំបាំង ហើយ
ពួកពលសេះកំដីរៀបគ្នានៅមាត់ទ្វារក្រុង[ផ] ៨គេក៏បើកស្បៃ
របាំងចេញពីស្រុកយូដា ហើយនៅថ្ងៃនោះ[ព] ឯងបានទីពឹង
ដល់គ្រឿងសស្ត្រាវុធ[ភ] នៅក្នុងឃ្លាំងដំណាក់ព្រៃ[ម] ៩ឯងរាល់
គ្នាបានឃើញកន្លែងរលំរលាយ[យ] នៅក្រុងដាវីឌថា មាន
ច្រើនណាស់ ឯងរាល់គ្នាបានប្រមូលទឹកនៃស្រះខាងក្រោម
ទុក[រ] ១០ក៏បានរាប់ចំនួនផ្ទះនៅក្រុងយេរូសាឡិម ហើយបាន
រុះផ្ទះ[ល] យកថ្មទៅប៉ះកំផែងក្រុងឱ្យមាំមួនឡើង[វ] ១១ឯងរាល់
គ្នាបានជីកស្រះទឹក នៅកណ្ដាលកំផែងទាំង២[ស] សំរាប់ទឹក
របស់ស្រះចាស់[ហ] ប៉ុន្តែឯងមិនបានពឹងពាក់ដល់ព្រះដែល
ទ្រង់ធ្វើការទាំងនេះ ឬផ្អែក[ឡ]ដល់ទ្រង់ដែលបានសំរេច
ការ[អ] នេះជាយូរមកហើយនោះទេ ។
១២នៅគ្រានោះ[ក] ព្រះអម្ចាស់យេហូវ៉ានៃពួកពលបរិវារ
ទ្រង់បានហៅឯងរាល់គ្នា ឱ្យមកយំ[ខ] ឱ្យមកសោយសោក
កោរសក់[គ] ហើយស្លៀកសំពត់ធ្មៃ[ឃ] ១៣តែមើល មានសុទ្ធ
តែអំណរ ហើយរីករាយវិញ[ង] ជាការសំឡាប់គោ និងចៀម
ស៊ីសាច់ ហើយផឹកស្រាទំពាំងបាយជូរ[ច] ដោយពោលថា
ចូរយើងស៊ីហើយផឹកទៅ ដ្បិតនៅថ្ងៃស្អែកនេះយើង
ត្រូវស្លាប់ហើយ[ឆ] ១៤នោះព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់បានបើកសំដែងអង្គទ្រង់នៅត្រចៀកខ្ញុំថា[ជ] ពិតប្រាកដ
ជាសេចក្ដីទុច្ចរិតនេះ នឹងមិនបានអត់ទោសឱ្យឯងរាល់គ្នា
ឡើយ[ឈ] ដរាបដល់ឯងរាល់គ្នាស្លាប់បង់ នេះជាព្រះបន្ទូល
របស់ព្រះអម្ចាស់យេហូវ៉ានៃពលបរិវារ ។
១៥ព្រះអម្ចាស់ គឺព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់
មានបន្ទូលថា ចូរទៅរកអ្នកឧកញ៉ានោះចុះ គឺសេបណា[ញ]
ដែលត្រួតត្រា[ដ]លើព្រះរាជដំណាក់ហើយសួរថា[ឋ] ១៦ឯង
មានការអ្វីនៅទីនេះ តើមានញាតិសន្តានណានៅទីនេះ បាន
ជាឯងធ្វើម៉ុងសំរាប់ខ្លួនដូច្នេះ ដូចជាអ្នកណាដែលធ្វើម៉ុង[ឌ]
សំរាប់ខ្លួន[ឍ]នៅលើទីខ្ពស់ គឺជាប់ទីលំនៅសំរាប់ខ្លួននៅក្នុង
ថ្ម ១៧មើល ព្រះយេហូវ៉ាទ្រង់នឹងឯបោះបង់ចោល[ណ]ទៅ
ដោយកំឡាំង អើ ទ្រង់នឹងរុំឯងយ៉ាងជិត ១៨ទ្រង់នឹងរុំឆ្វាក់
ឯងជាពិត ហើយបោះ[ត]ឯងទៅក្នុងស្រុក១ធំទូលាយ ដូចជា
គេបោះបុំអំបោះ ឯងនឹងស្លាប់នៅទីនោះវិញ គឺនៅទីនោះ
ដែលនឹងមានរទេះ[ថ]ដ៏រុងរឿងរបស់ឯង ឱអ្នកដែលនាំឱ្យ
ព្រះរាជវង្សនៃចៅហ្វាយខ្លួនមានសេចក្ដីខ្មាសអើយ ១៩អញ
នឹងបណ្ដេញ[ទ]ឯងពីដំណែងចេញ[ធ] ហើយឯងនឹងត្រូវទំលាក់
ចុះពីការងារទៅ ២០នៅគ្រានោះ[ន] អញនឹងហៅអេលាគីម[ប]
ជាកូនហ៊ីលគីយ៉ា ជាអ្នកបំរើ[ផ]របស់អញមក ២១ហើយនឹង

**២២:៦** ន ២ពវ ១៦:៩
**២២:៧** ប យស ១៥:៨ ផ ២រប ៣២:១–២
**២២:៨** ព អស ២:១២ ភ ២រប ៣២:៥ ម ១ពវ ៧:២
**២២:៩** យ នហ ១:៣ រ ២ពវ ១៨:១៧ ២រប ៣២:៤
**២២:១០** ល យរ ៣៣:៤ វ ២រប ៣២:៥
**២២:១១** ស ២ពវ ២៥:៤ ២រប ៣២:៥ យរ ៣៩:៤ ហ ២រប ៣២:៤ ឡ ១សយ ១២:២៤ អ ២ពវ ១៩:២៥
**២២:១២** ក អស ២:១២ ខ យអ ១:៩ ២:១៧ គ លវ ១៣:៤០ មីក ១:១៦ ឃ អស ៣:២៤
**២២:១៣** ង អស ២១:៥ ច ១សយ ២៥:៣៦ សស ៨:១៥ អស ៥:២២ ២៨:៧ ៨ ៥៦:១២ លក ១៧:២៦–២៩ ឆ ១កថ ១៥:៣២ **២២:១៤** ជ អស ៥:៩ ឈ ១សយ ២:២៥ អស ១៣:១១ ២៦:២១ ៣០:១៣–១៤ អគ ២៤:១៣ **២២:១៥** ញ ២ពវ ៦:៣០ ១៨:១៨ ដ ខ.២១ ឋ លប ៤១:៤០ **២២:១៦** ឌ មថ ២៧:៦០ ឍ លប ៥០:៥ ជន ៣២:៤២ **២២:១៧** ណ យរ ១០:១៨ ១៣:១៨ ២២:២៦ **២២:១៨** ត យប ១៨:១១ អស ១៤:១៩ ១៧:១៣ ថ លប ៤១:៤៣ **២២:១៩** ទ ១សយ ២:៧ ទដ ៥២:៥ ធ លក ១៦:៣ **២២:២០** ន ខ.២៥ ប អស ២០:៣ ផ ២ពវ ១៨:១៨ អស ៣៦:៣

*បំពង់ព្រួញ* សូមមើល យរ ៤៩:៣៥ ប្រហែលជាឈ្មោះរបស់ពួកសាសន៍ម៉ាឌាន (សូមមើល ២១:២) ។

**២២:៧** *ច្រកភ្នំយ៉ាងល្អបំផុត* គឺជាច្រកភ្នំដែលលាតសន្ធឹងពីទិសខាងកើតក្រុងយេរូសាឡិមរហូតដល់ទិសខាងលិចនិងខាងត្បូង ។

**២២:៩** *ក្រុងដាវីឌ* សូមមើល ២សយ ៥:៦–៧,៩ និងការពន្យល់ប្រៀបធៀប អស ២៩:១ ។ *ស្រះខាងក្រោម* គឺលក្ខណៈស្រះចាស់ៗដូចក្នុងខទី១១ ស្ដេចហេសេគាបានជីកស្រះ ដើម្បីការពារពីការឈ្លានពានលុកលុយពីពួកស្ដេចសានហេរីប (សូមមើល ២ពវ ២០:២០ នឹងការពន្យល់) ។ ឯស្រះខាងលើក៏បានបង្ហាញក្នុង ៧:៣ ៣៦:២ ។

**២២:១០** *ថ្មទៅប៉ះកំផែងក្រុងឱ្យមាំមួនឡើង* គឺមានការតុបតែងរៀបចំដូចស្ដេចអេសេគាដែរ ២រប ៣២:៥ ។

**២២:១២** *ឱ្យមកយំឱ្យមកសោយសោកកោរសក់* (មើលការប្រៀបធៀប យរ ១៦:៦ អគ ២៧:៣១) ។

**២២:១៣** *សុទ្ធតែអំណរហើយរីករាយវិញ* គឺដូចជាព្រះគម្ពីរហេព្រើរដែរ គឺប្រែមកមានន័យដូចគ្នាសូមមើលក្នុង ៣៥:១០ ៥១:១១ ។ គឺអត្ថបទបានពណ៌នាពីសេចក្ដីសង្ឃឹមយ៉ាងមុតមាំពីសេចក្ដីស្អាងឡើងវិញ ។ តែវាក៏ជាពេលត្រូវយំសោក (សស ៣:៤) មើលការពន្យល់ក្នុង ខ.២ ។ *ចូរយើងស៊ីហើយផឹក ទៅដ្បិតនៅថ្ងៃស្អែកនោះយើងនឹងស្លាប់* ដូចជាការសំគាល់ដោយលោកប៉ុល ក្នុង ១កថ ១៥:៣២ នេះចង់បញ្ជាក់ពីភាពអសារឥតការទទេរ បើពុំមានសេចក្ដីជំនឿពីការមានព្រះជន្មរស់ឡើងវិញ ។ សូមប្រៀបធៀប លក ១២:១៩ ក៏សូមមើលការប្រៀបធៀប សស ៨:១៥ និងការពន្យល់។

**២២:១៥** *សេបណា* ជាជនបរទេស អាចជាពួកសាសន៍អេស៊ីព្ទក៏ជាមនុស្សជិនាន់សម័យស្ដេចហេសេគា ។ *ត្រួតត្រាលើព្រះរាជដំណាក់* ដែលត្រូវមើលការបន្ទាប់ពីស្ដេច (សូមមើលការពន្យល់ ខ.២១ ប្រៀបធៀប ៣៦:៣ ១ពវ ៤:៦ ២ពវ ១៥:៥) ។

**២២:១៦** *ធ្វើម៉ុងសំរាប់ខ្លួន* គឺជាទីមួយសម្រាប់ធ្វើពិធីបញ្ចុះ ដែលមនុស្សចាត់ទុកថាជាការប្រសើរសម្រាប់ពួកគេ ។ សេបណាក៏មានសេចក្ដីលោភលន់ចង់មានផ្នូរដែលមានតម្លៃសម្រាប់ពួកស្ដេច (សូមមើលការប្រៀបធៀប ២រប ១៦:១៤) ។

**២២:១៨** *ឯងនឹងស្លាប់នៅទីនោះវិញ* ក៏បង្ហាញពីការស្លាប់បញ្ចុះដោយឥតប្រយោជន៍ទទេ (សូមមើលការពន្យល់ ១៤:១៩) ។ *រទេះ* ជាសញ្ញាមួយពីកិច្ចការដ៏ប្រសើ (មើល លប ៤១:៤៣) ។

**២២:២០** *នៅគ្រានោះ* គឺជាពេលដែលព្រះយេហូវ៉ាសម្ដែងពីការជំនុំជំរះ (សូមមើល ខ.១៧–១៩) ។ *អ្នកបំរើរបស់អញ* សូមមើលការពន្យល់ជំពូក ២០:៣ ។ *អេលាគីម* សូមមើល ៣៦:៣,១១,២២ ៣៧:២ ។

**២២:២១** *ប្រគល់អំណាចត្រួតត្រារបស់ឯង* គឺក្នុងកំឡុងពេលឆ្នាំ ៧០១ មុន

យកអាវយសរបស់ឯងមកបំពាក់ឱ្យគាត់វិញ ព្រមទាំងឱ្យ
មានកំឡាំងឡើង ដោយខ្សែក្រវាត់[ព]របស់ឯងផង អញនឹង
ប្រគល់អំណាចត្រួតត្រា[ភ]របស់ឯង ទៅក្នុងកណ្ដាប់ដៃគាត់
នោះគាត់នឹងធ្វើជាឪពុក ដល់ពួកអ្នកនៅក្រុងយេរូសាឡិម
និងពូជពង្សយូដាដែរ ២២អញនឹងយកកូនសោ[ម]នៃវង្ស
ដាវីឌ[យ] ដាក់លើស្មា[រ]គាត់ នោះគាត់នឹងបើកឥតមានអ្នកណា
បិទបានឡើយ ក៏នឹងបិទទៅ ឥតមានអ្នកណាបើកបានដែរ[ល]
២៣អញនឹងបោះគាត់ភ្ជាប់ទៅ ដូចជាបោះដែកគោ[វ]ជាប់នៅ
កន្លែង១ដែលស្ថិតស្ថេរ[ស] ហើយគាត់នឹងបានសំរាប់ជា
បល្ល័ង្កដ៏រុងរឿង[ហ]ដល់វង្សារបស់បិតាគាត់ ២៤គេនឹងនាំយក
អស់ទាំងសិរីល្អនៃវង្សារបស់បិតាគាត់ មកបំពាក់នៅលើ
គាត់វិញ គឺទាំងពូជពង្សជិតឆ្ងាយ និងគ្រឿងប្រដាប់តូចៗ
ទាំងប៉ុន្មាន ចាប់តាំងពីពែង រហូតដល់ថូទាំងអស់ផង
២៥ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលថា នៅ
គ្រានោះ[ឡ] ដែកគោល[អ]ដែលបានបោះភ្ជាប់ នៅទីដែលស្ថិត
ស្ថេរ នោះនឹងត្រូវដកចេញ រួចត្រូវកាប់ផ្តួលចុះ ហើយដួល
ជាពិត ឯបន្ទុកដែលគេបានពាក់នៅលើដែកគោនោះនឹង
ត្រូវកាត់ផ្តាច់ចេញ ដ្បិតព្រះយេហូវ៉ា ទ្រង់បានមានបន្ទូល
ហើយ[ក]។

## សេចក្ដីទំនាយទាស់នឹងក្រុងទីរ៉ុស

**២៣** ១នេះជាសេចក្ដីទំនាយយ៉ាងធ្ងន់ ពីដំណើរក្រុង
ទីរ៉ុស[ក]។
នៃពួកនាវា[ខ]តើស៊ីសអើយ[គ] ចូរស្រែកទ្រហោយំចុះ[ឃ]
ពីព្រោះទីក្រុងឯងត្រូវបំផ្លាញ[ង]ហើយ ទាល់តែគ្មានផ្ទះណា
សល់នៅ ឬផ្លូវណាចូលទៅបានឡើយ ដំណឹងនោះបាន
សំដែងឱ្យគេដឹងនៅត្រង់ស្រុកគីទីម ២អស់ពួកអ្នកនៅតាម
ឆ្នេរសមុទ្រ ដែលបានស្បៀងគ្រប់គ្រាន់ ដោយសារពួក
ឈ្មួញ[ច]ពីក្រុងស៊ីដូន[ឆ] ដែលលក់ដូរតាមផ្លូវសមុទ្រអើយ ចូរ
ស្ងៀមនៅចុះ[ជ] ៣ទីក្រុងរបស់ឯងបានកំរៃ ដោយសារស្រូវ
ពីស្រុកស៊ីហោរ[ឈ] ជាចំរូតនៃស្រុកក្បែរទន្លេធំ[ញ] ដែលគេ
ដឹកមកតាមផ្លូវសមុទ្រ ទីក្រុងនោះ[ដ]ក៏ជាផ្សារសំរាប់គ្រប់
ទាំងសាសន៍ ៤ឱក្រុងស៊ីដូន[ឋ]អើយ ចូរមានសេចក្ដីខ្មាសចុះ
ដ្បិត សមុទ្របានពោលហើយ គឺទីមាំមួន នៃសមុទ្របានថា
អញមិនបានឈឺចាប់ ឬសំរាលកូនឡើយ[ឌ] ក៏មិនបានចិញ្ចឹម
មនុស្សកំឡោះ ឬស្រីក្រមុំដែរ ៥កាលណាដំណឹងនេះបាន
ឮទៅដល់ស្រុកអេស៊ីព្ទ នោះគេនឹងសោកសៅជាពន្លឹក[ឍ]
ដោយសារដំណឹងពីក្រុងទីរ៉ុសនោះ[ណ] ៦ឱពួកអ្នកនៅ តាម
ឆ្នេរសមុទ្រអើយ ចូរទ្រហោយំចុះ ហើយឆ្លងទៅឯស្រុក

**២២:២១** ព អស ៥:២៧ ភ ខ.១៥ **២២:២២** ម ១រប ៩:២៧ មថ ១៦:១៩ វវ ៣:៧ យ អស ៩:៦ រ អស ៧:២ ល យប ១២:១៤ **២២:២៣** វ ខ.២៥ អគ ១៥:៣ សក ១០:៤ ស អរ ៩:៨ យប ៦:២៥ ហ ១សយ ២:៧–៨ យប ៣៦:៧ **២២:២៥** ឡ ខ.២០ អ ខ.២៣ ក អស ៤៦:១១ មីក ៤:៤
**២៣:១** ក យស ១៩:២៩ ១ពវ ៥:១ យរ ៣៧:៤ យអ ៣:៤–៨ អម ១:៩–១០ ខ ១ពវ ១០:២២ គ លប ១០:៤ អស ២:១៦ ឃ អស ១៣:៦ ង លប ១:២ អគ ២៦:៤ **២៣:២** ច អគ ២៧:៥–២៤ ឆ ពច ១:៣១ ជ យប ២:១៣ **២៣:៣** ឈ លប ៤១:៥ ញ អស ១៩:៧ ដ ទដ ៨៣:៧ **២៣:៤** ឋ លប ១០:១៥,១៩ ឌ អស ៥៤:១ **២៣:៥** ឍ អគ ៣០:៩ ណ អគ ២៦:១៧–១៨

គ.ស (សូមមើល ៣៦:៣) ។ *អេលាគីម* បានទទួលការជំនួសសេបណាឯសេបណាក៏បានផ្ទេរទៅទទួលបន្ទុកជា "លេខាធិការវិញ" ។

**២២:២២** គឺជាសេចក្ដីបង្រៀនក្នុង ៣:៧(មើលការពន្យល់ក្នុងគម្ពីរនោះ) ។ មានការបង្ហាញនៃពាក្យ "ជាឪពុក" (ខ.២១) និងការធានាខុសត្រូវ"ការទទួលបន្ទុក"ដែលជាពាក្យសំដែងពីព្រះមែស៊ី ។ សូមមើលក្នុង ៩:៦ *យកកូនសោនៃវង្សដាវីឌ* គឺជាអំណាចទាំងឡាយក៏ប្រគល់ឱ្យទ្រង់តាមរយៈស្ដេចជាព្រះមហាក្សត្រាដែលជារបស់ខ្សែរាជវង្សដាវីឌ ។ កូនសោនៃនគរស្ថានសួគ៏បានឱ្យទៅពេត្រុល (មថ ១៦:១៩ មើលការពន្យល់នៅទីនោះ) ។

**២២:២៣** *ដែកគោល* ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យនេះគឺសំដៅលើដែកគោលបោះតង់ តែក្នុងឃ្លានេះគឺដែកគោលសម្រាប់បោះលើឈើក្ដារ (អគ ១៥:៣ សក ១០:៤ និងការពន្យល់) ។ *បល្ល័ង្កដ៏រុងរឿង* ធៀបនឹង ១សយ ២:៨ ។

**២២:២៥** *នៅគ្រានោះ* គឺជាថ្ងៃដែលទ្រង់យាងមកជំនុំជម្រះ ។ *ដែកគោលដែលបានបោះភ្ជាប់ . . . ត្រូវដកចេញ* ។ ស្ដេចហេសេគាដូចជាស្ដេចសេបណាដែរ គឺនឹងត្រូវធ្លាក់ចេញពីអំណាច ។

**២៣:១–១៨** មើល អគ ២៦:១–២៨:១៩ អម ១:៩–១០ និងការពន្យល់ ។

**២៣:១** *សេចក្ដីទំនាយ* សូមមើលការពន្យល់ ១៣:១ គឺជាផែសមុទ្រសំខាន់មួយដែលនៅតាមបណ្ដោយឈូងសមុទ្រ ប្រហែលជាប្រវែង ៥៦ គ.ម ពីខាងជើងភ្នំកើមែល ។ ជាតំបន់មួយនៅក្នុងទីក្រុងដែលបានសង់ឡើងនៅលើកោះដែលមានផ្ទាំងថ្មពីរ ហើយមានចម្ងាយកន្លះគីឡូម៉ែត្រពីរមាត់សមុទ្រស្ដេចហ៊ីរ៉ាមប្រចាំទីក្រុងទីរ៉ុសក៏បានឧបត្ថម្ភនូវឈើដើមសេដានិងឧបករណ៍សិប្បកម្មជាច្រើនដើម្បីជាការសាងសង់ព្រះវិហារ (មើល ១ពវ ៥:៨–៩) និងក៏បញ្ជូនអ្នកជិនាញ ខាងនាវា១ក្រុមដើម្បីជាកិច្ចការមុខជំនួញរបស់ស្ដេចសាឡូម៉ូន (១ពវ ៩:២៧) ។ *នៃពួកនាវា* សូមមើល ខ.១៤ ។ *នាវាស៊ីសអើយ* គឺជាប្រភេទនាវាជំនួញ (សូមមើលការពន្យល់ ២:១៦) ។ *ត្រូវបំផ្លាញហើយ* ក៏ត្រូវបានសម្រេចតាមរយៈពួកសាសន៍អាសស៊ើរ ពួកសាសន៍នេប៊ូក្នេសា ឬ ពួកអ៉លេកក្សានត្រុស ។ ហើយពួកនេប៊ូក្នេសា ក៏ចាប់យកទីក្រុងសំខាន់ៗក្នុង ឆ្នាំ៥៧២ មុន គ.ស ។

**២៣:២,៤,១២** *ក្រុងស៊ីដូន* សូមមើល អក ២៨:២០–២៦ និងការពន្យល់ឬពីទីក្រុងស្រុកកាណានដ៏ល្បីល្បាញផ្សេងៗទៀតដែលមានប្រវែង ៤០ គ.ម ពីខាងជើងទីក្រុងទីរ៉ុស ។

**២៣:២** *ពួកអ្នកនៅតាមឆ្នេរ* គឺនៅទីក្រុងទីរ៉ុស(មើល ខ.១)នឹងការពន្យល់ក៏ជាអ្នករកស៊ីអ្នកធ្វើជំនួញជាច្រើនហើយតែជាចៅហ្វាយ ជាមនុស្សអ្នកធំនៅផែនដីនេះគឺនៅពេញទាំងឆ្នេរសមុទ្រមេឌីទែរ៉ាណេ ។

**២៣:៣** *ស្រុកស៊ីហោរ* គឺជាស្រុកមានសាខាពីទន្លេធំ (មើលការពន្យល់ យរ ២:១៨) ។ *ជាចំរូតនៃស្រុកក្បែរទន្លេធំ* មើល ១៩:៧ និងការពន្យល់ ។

**២៣:៦** *តើស៊ើស* គឺប្រហែលជាស្រុកតើស៊ើសនៅឯប្រទេសអេស្ប៉ាញ(មើលការពន្យល់ អគ ២៧:១២)ឬក៏ជាកោះមួយនៅឯសមុទ្រមេឌីទែរ៉ាណេខាង

តើស៊ីសទៅ[ត] ៧ នេះឬដែលជាទីក្រុងអរសប្បាយរបស់ឯង
រាល់គ្នា[ថ] ដែលមានកំណើតតាំងពីចាស់បុរាណមក ហើយ
ដែលជើងបាននាំទៅអាស្រ័យនៅឯស្រុកឆ្ងាយនោះ ។
៨ តើអ្នកណាបានសំរេចនឹងធ្វើការនេះដល់ក្រុងទីរ៉ុស
គឺជាក្រុងដែលធ្លាប់បំពាក់មកុដដល់គេ ហើយដែលពួក
ជំនួញ[ទ]សុទ្ធតែជាចៅហ្វាយ ហើយអ្នកជួញ[ធ]ប្រែជាមនុស្ស
អ្នកធំនៅផែនដីនោះ ៩ គឺព្រះយេហូវ៉ានៃពួកពលបរិវារ
ដែលបានសំរេច[ន]នឹងធ្វើការនោះទេ ដើម្បីនឹងបង្អាប់[ប]
សេចក្ដីអំនួតរបស់គ្រប់ទាំងការរុងរឿងឧត្តម ហើយនឹង
បន្ទាប[ផ]បណ្ដាសេចក្ដីទាំងប៉ុន្មាន[ព]ដែលនៅផែនដីផង ១០ ឱ
កូនស្រីស្រុកតើស៊ីសអើយ ចូរដើរចុះឡើងក្នុងស្រុក ឯងដូច
ជាទន្លេ គ្មានការឃាត់ឃាំងទៀតឡើយ ១១ ព្រះទ្រង់បានលូក
ព្រះហស្ត[ភ]ទៅលើសមុទ្រ ទ្រង់បានអង្រួនគ្រប់ទាំងនគរ[ម]
ព្រះយេហូវ៉ាទ្រង់បានបង្គាប់ពីដំណើរស្រុកកាណានថា ត្រូវ
ឱ្យបំផ្លាញក្រុងមាំមួនរបស់គេ[យ] ១២ ហើយទ្រង់មានបន្ទូលថា
ឱកូនក្រមុំ[រ]នៃក្រុងស៊ីដូនដែលត្រូវសង្កត់សង្កិនអើយ ឯងនឹង
មិនរីករាយសប្បាយទៀតទេ[ល] ចូរក្រោកឡើងឆ្លងទៅឯ
ស្រុកគីទីមចុះ[វ] តែនៅទីនោះ គង់តែមិនបានស្រាកស្រាន្ត
ដែរ ។
១៣ មើលន៍ ស្រុករបស់សាសន៍ខាល់ដេ[ស] ពួកនេះមិន
មែន ជាសាសន៍ណាទេទាល់តែពួកអាសស៊ើរ[ហ]បានតាំង
នគរឡើង ឱ្យពួកអ្នកដែលនៅទីរហោស្ថាននោះ[ឡ] គេបាន
ដំឡើងប៉មរបស់គេ[អ] ហើយបានរំលំអស់ទាំងដំណាក់នៃ
ក្រុងទីរ៉ុសទាំងបំផ្លាញអស់រលីងទៅ[ក] ១៤ ឱពួកនាវា[ខ]តើស៊ីស
អើយ[គ] ចូរស្រែកទ្រហោយំចុះ ពីព្រោះទីមាំមួនរបស់ឯង
បានត្រូវបំផ្លាញហើយ[ឃ] ១៥ នៅគ្រានោះមនុស្សនឹងភ្លេចក្រុង
ទីរ៉ុស[ង]គ្រប់៧០ឆ្នាំ[ច]តាមព្រះជន្មនៃស្ដេច១អង្គ លុះផុតពី៧០
ឆ្នាំហើយ នោះនឹងកើតដល់ក្រុងទីរ៉ុស ដូចជាសេចក្ដីដែល
ថ្លែងប្រាប់ក្នុងបទចំរៀងរបស់ស្រីសំផឹង ១៦ ឱស្រីសំផឹង[ឆ]
ដែលគេភ្លេចអើយ ចូរកាន់ស៊ុងដើរចុះឡើងក្នុងទីក្រុង
ហើយលេងភ្លេងយ៉ាងពិរោះចុះ ព្រមទាំងច្រៀងឡើង ជា
ច្រើនបទផង ដើម្បីឱ្យគេនឹកចាំពីឯងឡើងវិញ ១៧ លុះដល់
ផុត៧០ឆ្នាំ[ជ] នោះព្រះយេហូវ៉ាទ្រង់នឹងប្រោសក្រុងទីរ៉ុស
ហើយក្រុងនោះនឹងត្រឡប់ទៅឯការស៊ីឈ្នួល ដូចដើមវិញ
ព្រមទាំងធ្វើសំផឹង[ឈ] និងគ្រប់ទាំងនគររបស់លោកីយ ដែល
នៅលើផែនដីផង[ញ] ១៨ ឯការជំនួញ និងឈ្នួញរបស់គេនោះ
នឹងបានជាសេចក្ដីបរិសុទ្ធដល់ព្រះយេហូវ៉ា[ដ] គេនឹងមិន
ប្រមូលទុកទៀតទេ គឺទំនិញរបស់គេនឹងបានសំរាប់អស់អ្នក
ដែលអាស្រ័យនៅចំពោះព្រះយេហូវ៉ា[ឋ] ដើម្បីឱ្យគេបានឆ្អែត
ហើយសំរាប់ជាសំលៀកបំពាក់យ៉ាងជាប់លាប់ដែរ[ឌ]។

**២៣:៦** ត លប ១០:៤ **២៣:៧** ថ ខ.១២ អស ៥:១៤ ២១:៥ ៣២:១៣ អគ ២៦:១៣ **២៣:៨** ទ ណហ ៣:១៦ ធ អគ ២៨:៥ វវ ១៨:២៣ **២៣:៩** ន អស ១៤:២៤ ប យប ៤០:១១ ផ អស ១៣:១១ ព អស ៥:១៣ ៩:១៥ អគ ២៧:៣ **២៣:១១** ភ នក ១៤:២១ ម ទដ ៤៦:៦ យ ខ.១៤ អស ២៥:២ អគ ២៦:៤ សក ៩:៣–៤ **២៣:១២** រ អស ៣៧:២២ ៤៧:១ យរ ១៤:១៧ ៤៦:១១ បទ ២:១៣ សផ ៣:១៤ សក ២:១០ ល ខ.៧ វវ ១៨:២២ វ លប ១០:៤ **២៣:១៣** ស អស ៤៣:១៤ យរ ៥១:១២ ហ អស ១០:៥ ឡ ទដ ៧៤:១៤ អស ១៨:៦ អ ២ពវ ២៥:១ ក អស ១០:៧ **២៣:១៤** ខ ១ពវ ១០:២២ គ លប ១០:៤ អស ២:១៦ ឃ ខ.១១ **២៣:១៥** ង យរ ២៥:២២ ច ទដ ៩០:១០ **២៣:១៦** ឆ សភ ៧:១០ **២៣:១៧** ជ ទដ ៩០:១០ ឈ ចទ ២៣:១៧–១៨ អគ ១៦:២៦ ណហ ៣:៤ វវ ១៧:១ ១៨:៣,៩ ញ យរ២៥:២៦ **២៣:១៨** ដ នក ២៨:៣៦ ៣៩:៣០ យស ៦:១៧–១៩ ទដ ៧២:១០ ឋ អស ១៨:៧ ៦០:៥–៩ ៦១:៦ មីក ៤:១៣ ឌ អម ១:៩–១០ សក ១៤:១,១៤

លិច ឬក៏នៅតំបន់ឈូងសមុទ្រនៃប្រទេសអាហ្វ្រិចខាងជើង ។

**២៣:៧** *អរសប្បាយ* សូមមើលការពន្យល់ ២២:២ ។ *ចាស់បុរាណ* គឺសំដៅលើទីក្រុងចាស់បុរាណ គឺជាទីក្រុងទីរ៉ុស គឺមានតាំងពីឆ្នាំ ២000 មុន គ.ស ។ *អាស្រ័យឯស្រុកឆ្ងាយនោះ* គឺនៅក្នុងស្រុកអាហ្វ្រិចខាងជើងហើយគឺអាចជានិគមរបស់ពួកទីរ៉ុស ។ ឯក្រុងតើស៊ីសក៏មានអណានិគមផ្សេងទៀតដែរ ។

**២៣:៨–៩** *សំរេចនឹងធ្វើការទាំងនោះ* មើល ១៤:២៤,២៦–២៧ ២៥:១ និងការពន្យល់ ។

**២៣:៩** *សេចក្ដីអំនួតគ្រប់ទាំងការរុងរឿងឧត្តម* សូមមើល អគ ២៧:៣–៤ និងការពន្យល់ ។

**២៣:១០** *ឱកូនស្រីស្រុកតើស៊ីសអើយ* គឺបង្ហាញពីលក្ខណៈសម្បត្តិនៃពួកតើស៊ីស (មើលការពន្យល់ ២ពវ ១៩:២១) ។

**២៣:១១** *លូកព្រះហស្ត* សូមមើលការពន្យល់ ១៤:២៦–១២ ។

**២៣:១២** *ឱកូនក្រមុំនៃក្រុងស៊ីដូន* ក៏បង្ហាញពីលក្ខណៈសម្បត្តិរបស់ក្រុងស៊ីដូន (មើលការពន្យល់ ២ពវ ១៩:២១) ។ *ត្រូវសង្កត់សង្កិនអើយ* គឺក្រុងនេះហើយដែលក្រុងអេសារ–ហាដោន បានចាប់យកនៅក្នុងសតវត្សទី៧ មុន គ.ស តែក្រោយមកស្ដេចនេប៊ូក្នេសា គ្រប់គ្រងសង្កត់សង្កិនម្ដង គឺក្នុងឆ្នាំ ៥៨៧ (ប្រៀបធៀប យរ ២៥:២២,២៦ និងការពន្យល់) ។

**២៣:១៣** *ពួកអាសស៊ើរ* គឺពួកស្ដេចសានហេរីបជាស្ដេចស្រុកអាសស៊ើរបានបំផ្លាញទីក្រុងបាប៊ីឡូនក្នុងឆ្នាំ ៦៨៩ មុន គ.ស ។ ស្រុកកាណានមានលក្ខណៈដូចស្រុកបាប៊ីឡូនក្នុងឆ្នាំនោះ ។ *អ្នកដែលនៅទីរហោស្ថាន* សូមប្រៀបធៀប ១៣:២១ ។ *ដំឡើងប៉ម* សូមមើលការពន្យល់ ២ពវ ២៥:១ ។

**២៣:១៤** សូមមើល ខ.១ និងការពន្យល់។

**២៣:១៥** *គ្រប់៧០ឆ្នាំ* ក៏ជាឆ្នាំនៃការត្រួតត្រារបស់ពួកស្ដេចបាប៊ីឡូនទៅលើសាសន៍បរទេស ។ (មើល យរ ២៥:១១–១២ ២៩:១០ និងការពន្យល់) ក៏ជាពេលរបស់ព្រះនៃពួកបាប៊ីឡូនមានវត្តមានគឺព្រះម៉ាដាក ។ ហេតុនេះនាំឱ្យពួកបាប៊ីឡូនទទួលរងនូវភាពវេទនាបន្តទៀត ។

**២៣:១៧** *ស៊ីឈ្នួលដូចដើមវិញព្រមទាំងធ្វើសំផឹង* "ភាពជាសំផឹង" គឺជាតិសាសន៍ដែលស្វែងរកនូវទ្រព្យសម្បត្តិ ក៏ជាការដើម្បីបំពេញនូវភាពស្រើបស្រាលរបស់ខ្លួន (មើលការប្រៀបធៀប វវ ១៤:៨ ១៧:៥ និងការពន្យល់) ។

**២៣:១៨** ការរកចំណូលបានពីអំពើពេស្យាចាគឺមិនគួរនិងថ្វាយព្រះអម្ចាស់ទេ (ចទ ២៣:១៨) តែទីក្រុងប្រាក់ទីក្រុងមាសក៏ត្រូវរលាយខូចខាតទៅដែរ (មើលការពន្យល់ ចទ ២:៣៤) ។ តែអ្វីៗសុទ្ធតែជារបស់ព្រះ (សូមមើល យស ៦:១៧ នឹងការពន្យល់១៩ ប្រៀបធៀប មីក ៤:១៣) ។ *សំរាប់អស់អ្នក* គឺរាស្ត្រអ៊ីស្រាអែល ថ្ងៃមួយនឹងទទួលទ្រព្យសំណាប់សម្រាប់ជាតិសាសន៍របស់

## ព្រះអម្ចាស់ទ្រង់បំផ្លាញលោកិយ

**២៤** ១មើល ព្រះយេហូវ៉ាទ្រង់ធ្វើឱ្យផែនដីនៅទទេសោះ[ក]
ហើយឱ្យស្ងាត់សូន្យ ក៏ធ្វើឱ្យត្រឡប់ត្រឡិន[ខ] ព្រមទាំងកំចាត់
កំចាយ[គ]អស់ពួកអ្នកដែលនៅផែនដីផង ២នៅគ្រានោះពួក
សង្ឃនឹងរងទុក្ខដូចជាមនុស្សធម្មតា[ឃ] ចៅហ្វាយប្រុសនឹង
រងទុក្ខដូចជាបាវប្រុស ចៅហ្វាយស្រីនឹងរងទុក្ខដូចជាបាវ
ស្រី អ្នកលក់ដូរ[ង]នឹងរងទុក្ខដូចជាអ្នកទិញ ម្ចាស់បំណុលនឹង
រងទុក្ខដូចជាកូនបំណុល ហើយអ្នកដែលឱ្យខ្ចីយកការ[ច]
នឹងរងទុក្ខ ដូចជាអ្នកដែលឱ្យការស្មើគ្នាទាំងអស់ ៣ផែនដី
នឹងត្រូវផ្ទឹងឡើងនៅទទេធេង[ឆ] ហើយស្ងាត់សូន្យឈឹង[ជ]
ពីព្រោះព្រះយេហូវ៉ាទ្រង់បានមានបន្ទូល[ឈ]ដូច្នេះហើយ
៤ផែនដីកំពុងតែសោយសោក[ញ] ហើយស្វិតក្រៀមទៅ[ដ] ឯ
លោកីយក៏កំពុងតែរោយរៀវ ហើយស្វិតក្រៀមដែរ ពួក
អ្នកជាន់ខ្ពស់[ឋ]នៅផែនដីគេរោយរៀវទៅ[ឌ] ៥ផែនដីត្រូវ
ស្មោកគ្រោក[ឍ] ដោយសារពួកអ្នកដែលអាស្រ័យនៅ ពី
ព្រោះគេបានរំលង[ណ]អស់ទាំងក្រិត្យក្រម គេបានធ្វើខុស
នឹងច្បាប់ទាំងប៉ុន្មាន ហើយផ្ដាច់សេចក្ដីសញ្ញាដ៏នៅអស់
កល្បជានិច្ចចេញ[ត] ៦ហេតុដូច្នោះបានជាសេចក្ដីបណ្ដាសា[ថ]
បានលេបស៊ីផែនដី ហើយពួកអ្នកដែលអាស្រ័យនៅ ក៏មាន
ទោសទាំងអស់គ្នា បានជាពួកអ្នកអាស្រ័យនៅនោះ គេត្រូវ
ឆេះអស់រលីងទៅ[ទ] មានមនុស្សរស់នៅតែបន្តិចបន្តួចទេ
៧ទឹកទំពាំងបាយជូរកំពុងតែសោយសោក[ធ] ហើយដើម
ទំពាំងបាយជូរក៏ស្វិតក្រៀម[ន]ដែរ ឯអស់អ្នកដែលមានចិត្ត
រីករាយគេដកដង្ហើមធំវិញ[ប] ៨ការសប្បាយដោយវាយ
ក្រាប់[ផ] បានបាត់ឈឹងសំឡេង[ព]របស់ពួកអ្នកដែលកំពុងតែ
រីករាយ ក៏ផុត[ភ] ហើយសេចក្ដីអំណរដោយដេញស៊ុង[ម]ក៏អស់
ទៅ[យ] ៩គេនឹងមិនផឹកស្រាទំពាំងបាយជូរ[រ]ទាំងច្រៀងទៀត
ឡើយ ឯគ្រឿងស្រវឹងនឹងទៅល្វីង[ល] ដល់អស់អ្នកដែលធ្លាប់
ផឹក ១០ទីក្រុងដែលចោលស្ងាត់[វ]នឹងត្រូវរំលំរំលាង[ស] គ្រប់
ទាំងផ្ទះបានបិទ្វារ មិនឱ្យមានអ្នកណាចូលឡើយ ១១នៅតាម
ផ្លូវមានឮសំឡេងគេស្រែក[ហ]រកស្រាទំពាំងបាយជូរ[ឡ]
សេចក្ដីអំណរទាំងអស់បានងងឹតទៅ[អ] ហើយសេចក្ដីរីករាយ
នៅក្នុងស្រុកក៏បាត់អស់ដែរ ១២នៅក្នុងទីក្រុងសុទ្ធតែស្ងាត់
ឈឹងទទេ[ក] ហើយទ្វារ[ខ]ក្រុងក៏ត្រូវវាយបំបាក់ចុះ ១៣ដ្បិតនៅ
ក្នុងបណ្ដាជនជាតិដែលនៅកណ្ដាលផែនដី នឹងត្រូវបាន
ដូច្នោះ ដូចជាការអង្រួនដើមអូលីវ[គ] ហើយដូចការបេះសន្សំ
ផ្លែទំពាំងបាយជូរ ក្រោយដែលបេះរួចពីជាន់ដើមជា
ស្រេចហើយ[ឃ]។

១៤ពួកអ្នកទាំងនេះនឹងបន្លឺឡើង ហើយស្រែកដោយ
អំណរ[ង] គេនឹងស្រែកឡើងជាខ្លាំងពីខាងសមុទ្រ[ច] ដោយ
ព្រោះឫទ្ធានុភាពនៃព្រះយេហូវ៉ា ១៥ដូច្នេះ ចូរលើកដំកើង[ឆ]
ព្រះយេហូវ៉ានៅទិសខាងកើត[ជ]ដែរ គឺលើក[ឈ]ព្រះនាម[ញ]
ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល នៅស្រុកក្បែរ
សមុទ្រ[ដ] ១៦យើងបានឮបទចំរៀងមកពីចុងផែនដី[ឋ]បំផុតថា[ឌ]

**២៤:១** ក ខ.២០ អស ២:១៩–២១ ៣៣:៩ យរ ២៥:២៩ ខ យស ៦:១៧ អស ១៣:៥ គ លប ១១:៩ **២៤:២** ឃ ហស ៤:៩ ង អគ ៧:១២ ១កថ ៧:២៩–៣១ ច លវ ២៥:៣៥–៣៧ ចទ ២៣:១៩–២០ អស ៣:១–៧ **២៤:៣** ឆ លប ៦:១៣ ជ អស ៦:១១–១២ ១០:៦ ឈ អស ៧:៧ **២៤:៤** ញ យរ ១២:១១ ១៤:៤ យអ ១:១០ ដ អស ១៥:៦ ឋ អស ២:១២ ឌ អស ៣:២៦ **២៤:៥** ឍ លប ៣:១៧ ណ អស ១:២ ៩:១៧ ១០:៦ ៥៩:១២ យរ ៧:២៨ ត លប ៩:១១ យរ ១១:១០ **២៤:៦** ថ យស ២៣:១៥ អស ១:៣១ **២៤:៧** ធ យរ ៤៨:៣៣ យអ ១:៥ ន អស ៧:២៣ ១៥:៦ ៣២:១០ ប អស ៣:២៦

១៦:៨–១០ **២៤:៨** ផ លប ៣១:២៧ អស ៥:១២ ព យរ ៧:៣៤ ១៦:៩ ២៥:១០ ៣៣:១១ ហស ២:១១ ភ អស ៥:១៤ ២១:៥ ម ទដ ១៣៧:២ វវ ១៨:២២ យ បទ ៥:១៤ អគ ២៦:១៣ **២៤:៩** រ អស ៥:១១,២២ អស ៥:២០ **២៤:១០** វ អស ២៥:២ ២៦:៥ ស លប ១:២ អស ៦:១១ **២៤:១១** ហ ទដ ១៤៤:១៤ ឡ បទ ២:១២ អស ១៥:៦ ១៦:១០ ៣២:១៣ យរ ១៤:៣ **២៤:១២** ក អស ១៩:១៨ ខ អស ៣:២៦ ១៣:២ **២៤:១៣** គ ចទ ៣០:៤ អស ១៧:៦ ឃ អប ១:៥ មីក ៧:១ **២៤:១៤** ង អស ១២:៦ ច អស ៤៣:៥ ៤៩:១២ **២៤:១៥** ឆ អស ៤២:១២ ៦៦:១៩ ២ថន ១:១២ ជ ទដ ១១៣:៣ ឈ នក ១៥:២ អស ២៥:៣ ៥៩:១៩ មឡ ១:១១ ញ អស ១២:៤ ដ អស ១១:១១ **២៤:១៦** ឋ ទដ ៤៨:១០ ឌ ទដ ៦៥:៨

គេ ។ (សូមមើល ១៨:៧ ធៀបនឹង ៦០:៥–១១ និងការពន្យល់ ៦១:៦) ។

**២៤:១–២៧:១៣** ជំពូក ២៤–២៧ ដែលទំនាក់ទំនងនិងការជំនុំជម្រះនិងការទទួលព្រះពរ គឺក្នុងថ្ងៃចុងក្រោយគឺជាថ្ងៃជ័យជម្នះចុងក្រោយ របស់ព្រះចំពោះកងទ័ពរបស់អារក្សសាតាំង ។ ជំពូកនោះត្រូវបញ្ចប់ដោយតាមរយៈជំពូក ១៣–២៣ ឬក៏ជំពូក ៣៤–៣៥ ឬ ២៨–៣៣ ។

**២៤:១** *ផែនដីនៅទទេសោះ* ប្រៀបធៀប ២:១០,១៩,២១ មើល ១៣:១៣ និងការពន្យល់ ។ *កំចាត់កំចាយអស់ពួកដែលនៅផែនដី* សូមមើល លប ១១:៨–៩ និងការពន្យល់ ។

**២៤:៤** *សោយសោក ហើយស្វិតក្រៀមទៅ* គឺដូចជាស្រុកម៉ូអាប់ដែលនៅជំពូក ១៥:៦ ១៦:៨ ១៦:៨ ប្រៀបធៀបនឹង ៣៤:៤ ។

**២៤:៥** *ហើយផ្ដាច់សេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ច* គឺតម្រូវ ឬសំដៅលើសេចក្ដីសញ្ញានៅក្នុង លប ៩:៨–១៧ (សូមមើល យរ ៣១:៣២ និងការពន្យល់) ។

**២៤:៦** *សេចក្ដីបណ្ដាសា* គឺព្រោះតែគោលបំណង ឬការលោភលន់យ៉ាងខ្លាំងរបស់មាសាតាំងនៅនាលោកិយនេះ ។ សេចក្ដីបណ្ដាសាដែលត្រូវហិនវិនាសរបស់ព្រះនិងដុតកំទ្បោចផែនដីនេះ និងបំផ្លាញលំនៅស្រុករបស់ពួកមនុស្ស (ប្រៀបធៀបនឹង លប ៩:៨–១៧) ។

**២៤:៧** *ទឹកទំពាំងបាយជូរកំពុងតែសោយសោក* មើល ខ.៤ និងការពន្យល់។

**២៤:៩** *ស្រាទំពាំងបាយជូរទាំងច្រៀងទៀតឡើង* នេះបង្ហាញពីចរិតលក្ខណៈរបស់ពួកយូដា មើល ក្នុង ៥:១១–១៣ (សូមមើលការពន្យល់ទីនោះ) ។

**២៤:១០** *ទីក្រុងដែលចោលស្ងាត់* គឺក៏មានគំនិតបានសរសេរដែលយើងឃើញក្នុង ២៥:២ ២៦:៥ រួមបញ្ចូលទីក្រុងទាំងឡាយដូចជាទីក្រុងបាប៊ីឡូន ទីក្រុងទីរ៉ុស ទីក្រុងយេរូសាឡិម និងទីក្រុងរ៉ូម ។

**២៤:១៣** គឺមានតែផ្លែអូលីវនិងផ្លែទំពាំងបាយជូរពីរប៉ុណ្ណោះដែលនៅសល់ (សូមមើល ខ.៦ ១៧:៦,១១) ។

**២៤:១៤** *ពួកអ្នកទាំងនេះ* គឺជាពួកសំណល់ដែលមានព្រះទើបបានរួចផុតពីការជំនុំជម្រះ ។

**២៤:១៥** *ស្រុកក្បែរសមុទ្រ* សូមមើលការពន្យល់ ១១:១១ ។

សិរីសួស្ដី[ព] ចូរមកដល់ព្រះដ៏សុចរិត[ណ] តែខ្ញុំបាននិយាយថា
ខ្ញុំកំពុង តែរីងរៃទៅ វរហើយ[ត] ខ្ញុំៗកំពុងតែរីងរៃទៅ[ថ] ពួក
មនុស្សឧបាយ គេបានប្រព្រឹត្តដោយកិច្ចកល[ទ] របស់គេ អើ
ពួកមនុស្សឧបាយ គេបានប្រព្រឹត្តដោយកិច្ចកលជាខ្លាំង[ធ]
១៧ ឱ មនុស្សនៅលើផែនដីអើយ សេចក្ដីតក់ស្លុត[ន] រណ្ដៅ
និងអន្ទាក់[ប] គ្របលើឯងហើយ[ផ] ១៨ ដូច្នេះ អ្នកណាដែលរត់[ព]
ពីសូរដែលនាំឱ្យតក់ស្លុត នោះនឹងធ្លាក់ទៅក្នុងរណ្ដៅ
ហើយអ្នកណាដែលឡើងរួចពីរណ្ដៅ[ភ] នោះនឹងជាប់អន្ទាក់
វិញ[ម] ពីព្រោះបង្អួចនៅស្ថានលើ[យ] បានបើកចំហហើយ ឯ
ឫសផែនដីក៏ញាប់ញ័រដែរ[រ] ១៩ ផែនដីត្រូវបែកបាក់[ល] អស់
រលីង[វ] ផែនដីត្រូវអង្រួនជាខ្លាំង ២០ ផែនដីនឹងទ្រេតទ្រោត
ដូចជាមនុស្សស្រវឹង[ស] ហើយនិងត្រូវយោលទៅដូចជា
អង្រឹង[ហ] ឯអំពើរំលង[ឡ] របស់មនុស្សលោក និងសង្កត់លើជា
យ៉ាងធ្ងន់ គេនឹងត្រូវដួល[អ] ឥតងើបឡើងវិញឡើយ[ក] ។
២១ នៅគ្រានោះ[ខ] ព្រះយេហូវ៉ាទ្រង់នឹងផ្ចាញ់ផ្ចាល[គ] នៅ
លើមេឃ ចំពោះពួកពលបរិវារ[ឃ] នៃស្ថានខ្ពស់ ព្រមទាំង
ពួកស្ដេច[ង] នៃលោកីយនៅផែនដីដែរ ២២ គេនឹងត្រូវប្រមូល
គ្នា ដូចជាឈ្លើយ[ច] ដែលប្រមូលទុកក្នុងរំលុង ហើយនឹងត្រូវ
ឃុំនៅក្នុងគុក[ឆ] ក្រោយមកជាយូរថ្ងៃ[ជ] គេត្រូវរងទោស
២៣ គ្រានោះ ព្រះចន្ទនឹងត្រូវជ្រប់មុខ ហើយព្រះអាទិត្យ[ឈ] នឹង
ត្រូវអៀនខ្មាស ដោយព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់

**២៤:១៦** ឋ អស ២៨:៥ ៦០:១,១៩ ណ អរ ៩:១៥ ១សយ ៤:៨ ត អស ៥:៨ យរ ១០:១៩ ៤៥:៣ ថ លវ ២៦:៣៩ ទ ទដ ២៥:៣ ធ អស ២១:២ ៣៣:១ យរ ៣:៦,២០ ៥:១១ ៩:២ ហស ៥:៧ ៩:១ **២៤:១៧** ន ចទ ៣២:២៣–២៥ ប អស ៨:១៤ យរ ៤៨:៤៣ ផ លក ២១:៣៥ **២៤:១៨** ព យប ២០:២៤ ភ អស ៤២:២២ ម យប ១៨:៩ អស ៨:១៤ បទ ៣:៤៧ អគ ១២:១៣ យ លប ៧:១១ រ ពច ៥:៤ យប ៩:៦ ទដ ១១:៣ អគ ៣៨:១៩ **២៤:១៩** ល ទដ ៤៦:២ វ ចទ ១១:៦

សោយរាជ្យ[ញ] នៅលើភ្នំស៊ីយ៉ូន[ដ] នាក្រុងយេរូសាឡិម នោះ
នឹងមានសិរីល្អនៅចំពោះមុខពួកចាស់ទុំរបស់ទ្រង់[ឋ] ។

## សរសើរដល់ព្រះអម្ចាស់

**២៥** ១ ឱព្រះយេហូវ៉ាអើយ ទ្រង់ជាព្រះនៃទូលបង្គំទូល[ក]
បង្គំនឹងលើកដំកើងទ្រង់ឡើង ទូលបង្គំនឹងសរសើរដល់
ព្រះនាមទ្រង់[ខ] ពីព្រោះទ្រង់បានធ្វើការយ៉ាងអស្ចារ្យ[គ] គឺជា
ការដែលបានគិតសំរេច[ឃ] នឹងធ្វើតាំងពីបុរាណមក ដោយ
សេចក្ដីស្មោះត្រង់ពិតប្រាកដ[ង] ២ ដ្បិតទ្រង់បានធ្វើទីក្រុងទៅ
ជាគំនរថ្ម[ច] ឱ្យទីក្រុងមានបន្ទាយ[ឆ] ទៅជាធារបំណែក[ជ] ឱ្យ
ទីមាំមួន[ឈ] របស់សាសន៍ដទៃបានលែងធ្វើជាទីក្រុងរៀង
តទៅ ហើយឥតមានអ្នកណាសង់ឡើងវិញឡើយ[ញ] ៣ ហេតុ
នោះនឹងមានសាសន៍១ដែលមានកំឡាំងខ្លាំង គេនឹងសរសើរ

**២៤:២០** ស យប ១២:២៥ ហ យប ២៧:១៨ ឡ អស ១:២,២៨ ៤៣:២៧ ៥៨:១ អ ទដ ៤៦:២ ក យប ១២:១៤ **២៤:២១** ខ អស ២:១១ ១០:២០ វវ ១៦:១៤ គ អស ១០:១២ ១៣:១១ យរ ២៥:២៩ ឃ ១កថ ៦:៣ អភ ៦:១១–១២ ង អស ២:១២ **២៤:២២** ច អស ១០:៤ ឆ អស ៤២:៧,២២ លក ៨:៣៣ វវ ២០:៧–១០ ជ អគ ៣៨:៨ **២៤:២៣** ឈ អស ១៣:១០ ញ ទដ ៩៧:១ វវ ២២:៥ ដ អស ២:២ ហព ១២:២២ ឋ អស ២៨:៥ ៤១:១៦ ៤៥:២៥ ៦០:១៩ អគ ៤៨:៣៥ សក ២:៥ វវ ២១:២៣ **២៥:១** ក អស ៧:១៣ ខ ទដ ១៤៥:២ អស ១២:១,៤ គ ទដ ៤០:៥ ៩៨:១ យអ ២:២១,២៦ ឃ ជន ២៣:១៩ អស ១៤:២៤ ៣៧:២៦ ៤៦:១១ អភ ១:១១ ង អស ១១:៥ **២៥:២** ច អស ១៧:១ ២៦:៥ ៣៧:២៦ ឆ អស ១៧:៣ ជ ចទ ១៣:១៦ ឈ អស ១៣:២២ ញ យប ១២:១៤

**២៤:១៦** *ចុងផែនដីផុត* មើលការពន្យល់ ១១:១២ ។ *ខ្ញុំ* គឺសំដៅទៅលើការប្រមូលផ្ដុំចំពោះសហគមន៍ព្រះទាំងមូល ដែលបានកំពុងបាត់បង់ដោយព្រោះអំពើអាក្រក់របស់ពួកគេ ដែលស្វែងរកការហិនវិនាសនៃជាតិសាសន៍ដែលរៀចវេរដែលស្វែងរកភាពបែកបាក់ ឬកំចាយមនុស្សឬសាសន៍របស់ព្រះ ។ មានតែចំការទំពាំបាយជូររបស់ព្រះយេហូវ៉ានៃពួកពលបរិវាទេ នោះគឺជាពូជពង្សរបស់អ៊ីស្រាអែល និងពួកយូដាជាដំណាំដែលគាប់ដល់ព្រះនេត្រទ្រង់ហើយទ្រង់ប្រាថ្នាចង់បានសេចក្ដីយុត្តិធម៌ ។

**២៤:១៧** *សេចក្ដីតក់ស្លុត រណ្ដៅ និងអន្ទាក់គ្របលើឯងហើយ* មានឧទាហរណ៍មួយទៀត (មើលការពន្យល់ ខ.១៦) ដែលមានលក្ខណៈចុងជួន (មើលការពន្យល់ យរ ៤៨:៤៣) ។ ពាក្យខាងលើបើជាភាសាហេព្រើរ គឺស្រះមានសម្លេងស្រដៀងគ្នាដូចជាពាក្យ "ប៉ាហាដ ប៉ាហានិងប៉ាហ" ។

**២៤:១៨** ក. ការជំនុំជម្រះរបស់ព្រះអម្ចាស់ គឺពុំអាចគេចផុតឡើយ (ប្រៀបធៀប អម ៥:១៩–២០ ៩:២–៤ និងការពន្យល់) ។

**២៤:១៨** ខ. *បង្អួចនៅស្ថានលើ* គឺជាការប្រកាសពីទឹកជំនន់ជំនាន់លោកណូអេ (លប ៧:១១ ៨:២) ។ *ឯឫសផែនដីក៏ញាប់ញ័រដែរ* ដែលជាការរញ្ជួយដី និងផ្គរលាន់កក្រើកមេឃ (សូមមើលការពន្យល់ ១៣:១៣ ប្រៀបធៀបនឹង ៣:១៦) ។

**២៤:២០** *ដូចជាមនុស្សស្រវឹង* ធៀបនឹង ១៩:១៤ ។ *ដូចជាអង្រឹង* មើល ១:៨ និងការពន្យល់ ។

**២៤:២១** *នៅគ្រានោះ* គឺចង់សំដៅទៅលើគ្រារបស់ព្រះ ដែលមានព្រះវត្តមាននៅថ្ងៃជំនុំជម្រះ (សូមមើលការពន្យល់ ២:១១,១៧២០ ១០:២០,២៧) ដែលលេចមកឱ្យឃើញចំនួន៧ដងនៅក្នុងជំពូកទី ២៤–២៧ (សូមមើល ២៥:៩,២៦:១២៧:១–២,១២–១៣) ។ *ចំពោះពួកពលបរិវានៃស្ថានខ្ពស់ . . . ព្រមទាំងស្ដេចនៃលោកិយដែរ* គឺជាការជំនុំជម្រះ អំណាចនៅលើផែនដីដែលទ្រង់បានបង្កើតពួកគេហើយពួកគេតែងលើកតម្កើងពួកគេថា ជាព្រះក៏បានប្រឆាំងទាស់និងព្រះ ។ (សូមមើល ២:៦–១២ អភ ៦:១១–១២) ។

**២៤:២២** *ត្រូវឃុំនៅក្នុងគុក* ប្រៀបធៀប វវ ២០:២ ។ *ក្រោយមកជាយូរថ្ងៃ គេត្រូវរងទោស* ប្រៀបធៀប វវ ២០:៧–១០ ។

**២៤:២៣** *ឱព្រះចន្ទនឹងត្រូវជ្រប់មុខ ហើយព្រះអាទិត្យនឹងត្រូវអៀន* គឺនៅគ្រានោះសូម្បីតែព្រះចន្ទនិងព្រះអាទិត្យ ក៏លែងបញ្ចេញរស្មីទៀតហើយព្រោះជាគ្រាដែលព្រះជំនុំជម្រះលោកិយ (សូមមើល ១៣:១០) ។

**២៥:១–៥** គឺជាចម្រៀងសរសើរតម្កើងត្រូវបានលេចឡើងក្នុងគ្រាជំនុំជម្រះ សូមមើល ជំពូក ២៤ (មើល ២៤:១៤–១៦ ក៏សូមមើល ជំពូក ១២) ។

**២៥:១** *គិតសំរេចនឹងធ្វើតាំងពីបុរាណមក* សូមមើល ១៤:២៤,២៦–២៧ ២៣:៨–៩ ។

**២៥:២** *ទីក្រុង . . . ជាធារបំណែក* មើល ២៤:១០ និងការពន្យល់ ។ *ឥតមានអ្នកណាសង់ឡើងវិញឡើយ* ប្រៀបធៀប ២៤:២០ ។

**២៥:៣** *សាសន៍ដែលមានកំឡាំងខ្លាំង . . .* ដូចជាពួកសាសន៍អេស៊ីព្ទនិងពួក

ដំកើងទ្រង់[ដ] ទីក្រុងរបស់នគរគួរស្ញែងខ្លាច[ឋ]ទាំងប៉ុន្មាន
គេនឹងភ័យញ័រចំពោះទ្រង់ ៤ដ្បិតទ្រង់បានធ្វើជា ទីមាំ
មួន[ឌ]ដល់មនុស្សទាល់ក្រ[ឍ] គឺជាទីមាំមួនដល់មនុស្សកំសត់
ទុគ៌ត[ណ] ក្នុងគ្រាដែលមានទុក្ខលំបាក ជាទីជ្រកកោន ឱ្យរួច
ពីព្យុះសង្ឃរា[ត] ជាម្លប់បាំងកំដៅ ក្នុងកាលដែលខ្យល់ គំហុក
របស់ពួកគួរស្ញែងខ្លាច[ថ] បានដូចជាមានព្យុះក៏បក់ប៉ះនឹង
ជញ្ជាំង ៥ទ្រង់នឹងបន្ទាប[ទ]សូររបស់ពួកសាសន៍ដទៃនោះ[ធ]
ដូចជាចំហាយក្តៅនៅកន្លែងហួតហែង ហើយដូចជាកំដៅ
បានអន់ថយដោយសារម្លប់ពពក នោះបទច្រៀងជ័យរបស់
ពួកគួរស្ញែងខ្លាច[ន] នឹងត្រូវអន់ទៅដូច្នោះដែរ ។
៦នៅលើភ្នំ[ប] នេះព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់
នឹងចាត់ចែងជប់លៀង[ផ]ដល់គ្រប់ទាំងសាសន៍ ដោយម្ហូប
មានឱជារសយ៉ាងពិសេស និងស្រាទំពាំងបាយជូបារាំង
ជាម្ហូបយ៉ាងវិសេសដោយខួរឆ្អឹងជោក ហើយនឹងស្រា
ទំពាំងបាយជូរសំរាំងយ៉ាងល្អ[ព] ៧នៅលើភ្នំនេះ ទ្រង់នឹង
បំផ្លាញស្បៃ[ភ]ដែលបាំងមុខគ្រប់ទាំងសាសន៍[ម] ព្រមទាំងគំរប
ដែលគ្របលើជនជាតិទាំងប៉ុន្មានផង ៨ទ្រង់នឹងបំផ្លាញ
សេចក្តីស្លាប់[យ]ឱ្យសូន្យបាត់ទៅជាដរាប នោះព្រះអម្ចាស់
យេហូវ៉ាទ្រង់នឹងជូតទឹកភ្នែក[រ]ពីមុខមនុស្សទាំងអស់ ហើយ
ទ្រង់នឹងដកសេចក្តីត្មះតិះដៀល[ល]ចំពោះរាស្ត្រទ្រង់ ពីផែនដី
ទាំងមូលចេញ ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូលដូច្នេះ
ហើយ[វ] ។
៩នៅគ្រានោះ[ស] គេនឹងពោលថា មើល នេះគឺជាព្រះនៃ
យើងរាល់គ្នា[ហ] យើងបានរង់ចាំ[ឡ]ទ្រង់ ហើយទ្រង់នឹងជួយ
សង្គ្រោះ[អ]យើង នេះគឺជាព្រះយេហូវ៉ាហើយ យើងបានរង់
ចាំទ្រង់ យើងនឹងមានចិត្តរីករាយ[ក] ហើយត្រេកអរ ដោយ
សេចក្តីសង្គ្រោះរបស់ទ្រង់[ខ] ១០ដ្បិតព្រះហស្តនៃព្រះយេហូវ៉ា
នឹងសណ្ឋិតនៅលើភ្នំនេះ[គ] ឯសាសន៍ម៉ូអាប់[ឃ] នឹងត្រូវជាន់
ឈ្លី នៅក្នុងស្រុករបស់គេ ដូចជាចំបើងដែលត្រូវជាន់ឈ្លី
នៅគំនរអាចម៍ដែរ ១១ហើយគេនឹងកាងដៃនៅកណ្តាល
ស្រុកគេ ដូចជាអ្នកដែលកាងដៃហែលទឹក ប៉ុន្តែទ្រង់នឹង
បន្ទាប[ង]សេចក្តីអំនួត[ច]របស់គេ ព្រមទាំងកលឧបាយរបស់ដៃ
គេដែរ ១២ឯបន្ទាយយ៉ាងខ្ពស់នៅលើកំផែង[ឆ]ឯង នោះទ្រង់
បានរំលំចុះ[ជ]មកដល់ដីវិញ គឺនៅក្នុងធូលីដីផង ។

**ទំនុកតម្កើង**

**២៦** ១នៅគ្រានោះ[ក] គេនឹងច្រៀង[ខ]បទនេះ នៅក្នុងស្រុក
យូដាថា យើងមានទីក្រុង១ដ៏មាំមួន[គ] ទ្រង់នឹងតំរូវឱ្យមាន
សេចក្តីសង្គ្រោះ ទុកជាកំផែង[ឃ] ហើយជាទីការពារយើង[ង]

**២៥:៣** ដ នក ៦:២ ទដ ២២:២៣ អស ១១:១៤ ឋ អស ១៣:១១ **២៥:៤** ឌ ២សយ ២២:៣ ទដ ១១៨:៨ អស ៤:៦ ១៧:១០ ២៧:៥ ៣៣:១៦ យអ ៣:១៦ ឍ អស ៣:១៤ **២៥:៤** ណ អស ១៤:៣០ ២៩:១៩ ត ទដ ៥៥:៨ ថ អស ២៩:៥ ៤៩:២៥ **២៥:៥** ទ យរ ៥១:៥៥ ធ ទដ ១៨:៤៤ ន អស ១៣:១១ **២៥:៦** ប អស ២:២ ផ លប ២៩:២២ ១ពវ ១:២៥ អស ១:១៩ ៥៥:១–២ ៦៦:១១ យអ ៣:១៨ មថ ៨:១១ ២២:៤ វវ ១៩:៩ ព ទដ ៣៦:៨ សភ ៩:២ **២៥:៧** ភ ២កថ ៣:១៥–១៦ អភ ៤:១៨ ម យប ៤:៩ **២៥:៨** យ អស ២៦:១៩ ហស ១៣:១៤ ១កថ ១៥:៥៤–៥៥ រ អស ១៥:៣ ៣០:១៩ ៣៥:១០ ៥១:១១ ៦៥:១៩ យរ ៣១:១៦ វវ ៧:១៧ ២១:៤ ល លប ៣០:២៣ ទដ ១១៩:៣៩ មថ ៥:១១ ១ពត ៤:១៤វវ ៧:១៤ វ អស ៧:៧ **២៥:៩** ស អស ២:១១ ១០:២០ ហ អស ៤០:៩ ឡ ទដ ២២:៥ អស ១២:២ អ ទដ ១៤៥:១៩ អស ១៩:២០ ៣៣:២២ ៣៥:៤ ៤៣:៣,១១ ៤៥:១៥,២១ ៤៩:២៥–២៦ ៦០:១៦ ៦៣:៨ យរ ១៤:៨ ក ទដ ៣២:៤៣ ទដ ៩:២ អស ៩:៣ ៣៥:២,១០ ៤១:១៦ ៥១:៣ ៦១:៧,១០ ៦៦:១៤ ខ ទដ ១៣:៥ អស ១២:២ **២៥:១០** គ អស ២:២ ឃ លប ១៩:៣៧ ជន ២១:២៩ ចទ ២៣:៦ អស ១១:១៤ អម ២:១–៣ **២៥:១១** ង អស ៥:២៥ ១៤:២៦ ១៦:១៤ ច លវ ២៦:១៩ យប ៤០:១២ **២៥:១២** ឆ អស ២:១៥ ជ យប ៤០:១១ អស ១៥:១ យរ ៥១:៤៤ **២៦:១** ក អស ១០:២០ ខ អស ៣០:២៩ គ អស ១៤:៣២ ឃ អស ៣២:១៨ ៦០:១៨ សក ២:៥ ៩:៨ ង ទដ ៤៨:១៣

សាសន៍អាសស៊ើរ (សូមមើល ១៩:១៨–២៥ និងការពន្យល់) ។ *សរសើរដំកើងទ្រង់ . . . នឹងភ័យញ័រចំពោះទ្រង់* សូមមើល ២៤:១៥–១៦ ។

**២៥:៤–៥** *ជាទីមាំមួន . . . ជាទីជ្រកកោន . . . ជាម្លប់បាំង . . . ម្លប់ពពក* សូមមើល ៤:៥–៦ និងការពន្យល់ ឬប្រៀបធៀប ៣២:២ ។

**២៥:៦** *ជប់លៀង . . .* គឺវាទាក់ទងនិងពិធីអភិសេក តែងតាំងអ្នកណាម្នាក់ (១ពវ ១:២៥) ឬក៏អាពាហ៍ពិពាហ៍ (មើល ពច ១៤:១០ និងការពន្យល់) (វវ ១៩:៩) ។ *ជាម្ហូបយ៉ាងពិសេស* គឺជានិមិត្តសញ្ញាបង្ហាញពីព្រះពរខាងឯព្រលឹងវិញ្ញាណ (សូមមើល ៥៥:២ និងការពន្យល់) ។ *ស្រាទំពាំងបាយជូរសំរាំងយ៉ាងល្អ* (សូមមើល យរ ៤៨:១១ និងការពន្យល់ សផ ១:១២) ។

**២៥:៧–៨** គឺព្រះគ្រីស្ទទ្រង់បាននាំមកនូវភាពហិនវិនាសចុងក្រោយ គឺជាសេចក្តីស្លាប់ (សូមមើល ២ធថ ១:១០ ប្រៀបធៀប ហព ២:១៤–១៥ និងការពន្យល់) ។

**២៥:៧** *ស្បៃដែលបាំងមុខ . . . គំរប* គឺសម្រាប់គ្រប ។

**២៥:៨** ដែលជាសេចក្តីដកស្រង់ក្នុងគម្ពីរ ១កថ ១៥:៥៤ ។ *បំផ្លាញសេចក្តីស្លាប់ឱ្យសូន្យបាត់* (សូមមើល ទដ ៤៩:១៤ និងការពន្យល់) ។ គឺជាព្រះយេហូវ៉ានៃពួកពលបរិវាដែលជាអ្នកបំផ្លាញសេចក្តីស្លាប់យ៉ាងធំ ។ មើល ៧:៧ ៣០:១៥ ៦១:១១ ៥៦:១៣ ។ *ជូតទឹកភ្នែកចេញពីមុខមនុស្ស* មើល វវ ៧:១៧ ២១:៤ ។ *ហើយទ្រង់និងដកសេចក្តីត្មះតិះដៀល* មើល ៥៤:៤ ។

**២៥:៩** ចម្រៀងបទទំនុកសរសើរតម្កើងសង្ខេបខ្លីៗខ្លះទៀត ។ *នៅគ្រានោះ* សូមមើល ១២:១,៤ ២៤:២១ ក៏សូមមើល ១០:២០,២៧ និងការពន្យល់ ។ *យើងរង់ចាំទ្រង់យើងនឹងមានចិត្តរីករាយ* ប្រៀបធៀប ទដ ២២:៤–៥ ។ *មានចិត្តរីករាយហើយត្រេកអរ* សូមប្រៀបធៀប ៣៥:១០ ៥១:១១ ៦៦:១០ ។

**២៥:១០** *សាសន៍ម៉ូអាប់* គឺជាបំណងគ្រប់អស់សត្រូវរបស់ព្រះទាំងអស់ ដូចជាពួកសាសន៍អេដំម សូមមើល ៣៥:៥–១៧ និងការពន្យល់ ១៥:១ ។

**២៥:១២** *បន្ទាយយ៉ាងខ្ពស់* មើល ខ.២ ២:១៥ ២ពវ ៣:២៧ យរ ៥១:៤៤ និងការពន្យល់ជិពូក ៥៨ ។

**២៦:១** *នៅគ្រានោះ* សូមមើល ១២:១,៤ ២៤:២១ ២៥:៩ ក៏សូមមើលការពន្យល់ ១០:២០,២៧ ។ ពាក្យថា *សេចក្តីសង្គ្រោះទុកជាកំផែង ហើយជាទីការពារ* គឺជាសេចក្តីសង្គ្រោះរបស់ព្រះ គឺមានលក្ខណៈដូចជាភាពមានសន្តិសុខរបស់ក្រុងស៊ីយ៉ូនផងដែរ និងជាកម្លាំង ។ (សូមមើលការប្រៀបធៀប ទដ ៤៦:៤៨) ។ ពាក្យថា *ទីការពារ* គឺជារបាំងឬប៉មការពារ ឬជាកំផែងថ្មនៅផែនដីដ៏មាំមួន (សូមមើល ២សយ ២០:១៥) ។

២ចូរបើកទ្វារ[ច] ដើម្បីសាសន៍សុចរិត[ឆ] ដែលរក្សាសេចក្ដី
ស្មោះត្រង់បានចូលមកចុះ ៣ឯអ្នកណាដែលមានគំនិតជាប់
តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះ ឱ្យមានសេចក្ដី
សុខ[ជ]ពេញខ្នាត ដោយព្រោះគេទុកចិត្ត[ឈ]នឹងទ្រង់ ៤ចូរទុក
ចិត្ត[ញ]ដល់ព្រះយេហូវ៉ាជាដរាបចុះ[ដ] ដ្បិតព្រះដ៏ជាព្រះ
យេហូវ៉ា ទ្រង់ជាថ្មដា[ឋ]ដ៏នៅអស់កល្បជានិច្ច ៥ទ្រង់បាន
ទំលាក់ពួកអ្នកដែលនៅទីខ្ពស់ ឯទីក្រុងយ៉ាងខ្ពស់ទ្រង់រំលំចុះ
គឺទ្រង់រំលំក្រុងនោះចុះដល់ដី[ឌ] ក៏បន្ទាបទៅដល់ធូលីដីផង[ឍ]
៦ជើងមនុស្សនឹងដើរជាន់[ណ] គឺទាំងជើងរបស់មនុស្សទាល់
ក្រ[ត] និងជំហានរបស់មនុស្សកំសត់ទុគ៌តផង[ថ] ៧សេចក្ដីទៀង
ត្រង់ជាផ្លូវនៃមនុស្សសុចរិត[ទ] គឺទ្រង់ ឱព្រះដ៏ទៀងត្រង់
អើយ[ធ] ទ្រង់ពិនិត្យពិចារណាអស់ទាំងផ្លូវច្រករបស់មនុស្ស
សុចរិត[ន] ។
៨ហ្នឹងហើយ ឱព្រះយេហូវ៉ាអើយ យើងខ្ញុំបានរង់ចាំ
ទ្រង់នៅក្នុងផ្លូវនៃសេចក្ដីយុត្តិធម៌របស់ទ្រង់[ប] ព្រលឹងយើងខ្ញុំ
ប្រាថ្នា[ផ]ដល់ព្រះនាម[ព]ទ្រង់ គឺដល់សេចក្ដីដែលរំឭកពីទ្រង់
៩នៅវេលាយប់[ភ]ព្រលឹងនៃទូលបង្គំប្រាថ្នា[ម]ដល់ទ្រង់ ហ្នឹង
ហើយ វិញ្ញាណនៅក្នុងខ្លួនទូលបង្គំនឹងស្វែងរកទ្រង់ ដោយ
ខ្មីឃ្មាតដ្បិតកំពុងដែលសេចក្ដីយុត្តិធម៌[យ]របស់ទ្រង់នៅលើ
ផែនដី នោះពួកមនុស្ស លោកិយ គេរៀនតាមសេចក្ដី
សុចរិត[រ] ១០បើសិនជាធ្វើគុណ ដល់មនុស្សអាក្រក់[ល] នោះគេ
ក៏មិនរៀនតាមសេចក្ដីសុចរិតដែរ គេនឹងប្រព្រឹត្តសេចក្ដី
កំហុស[វ]នៅក្នុងស្រុកទៀងត្រង់ផង ឥតដែលពិចារណា
មើល[ស] ឬទ្ធានុភាពនៃព្រះយេហូវ៉ាឡើយ ។
១១ឱព្រះយេហូវ៉ាអើយ ព្រះហស្តទ្រង់បានលើកឡើងជា
ស្រេច[ហ] តែគេមិនព្រមឃើញ[ឡ]ទេ ប៉ុន្តែគេនឹងត្រូវឃើញ
សេចក្ដីឧស្សាហ៍[អ]របស់ទ្រង់ចំពោះបណ្ដាជនវិញ នោះគេ
នឹងមានសេចក្ដីខ្មាស[ក] ភ្លើង[ខ]នឹងឆេះបន្សុសពួកខ្មាំងសត្រូវ
ទ្រង់អស់រលីងទៅ ១២ឱព្រះយេហូវ៉ាអើយ ទ្រង់នឹងតាំងឱ្យ
មានសេចក្ដីសុខ[គ]សំរាប់យើងខ្ញុំ ដ្បិតអស់ទាំងការដែល
យើងខ្ញុំធ្វើ នោះគឺជាទ្រង់ដែលបានសំរេច[ឃ]ការនោះឱ្យ
យើងខ្ញុំ ១៣ឱព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំអើយ ពីដើម
មានចៅហ្វាយឯទៀត[ង]ក្រៅពីទ្រង់ បានត្រួតត្រាលើយើងខ្ញុំ
តែឥឡូវនេះដោយសារទ្រង់ នោះយើងខ្ញុំនឹងអំពាវដល់
តែព្រះនាម[ច]ទ្រង់វិញ[ឆ] ១៤គេបានស្លាប់អស់ហើយ[ជ] ឥតរស់
មកវិញទៀតឡើយ គេ[ឈ]កន្លងបង់ហើយ ឥតងើបឡើងវិញ
ទេ ដូច្នេះ ទ្រង់បានធ្វើទោស ហើយបំផ្លាញគេ[ញ] ព្រមទាំង
ធ្វើឱ្យសេចក្ដីនឹកចាំពីគេសូន្យបាត់ទៅ[ដ] ១៥ទ្រង់បានចំរើន
សាសន៍នេះ ឱព្រះយេហូវ៉ាអើយ ទ្រង់បានចំរើនសាសន៍
នេះហើយ[ឋ] គេលើកដំកើងទ្រង់ឡើង ទ្រង់បានវាតព្រំ[ឌ]ស្រុក
ឱ្យធំទូលាយទៅ ។
១៦ឱព្រះយេហូវ៉ាអើយ ក្នុងគ្រាដែលមានទុក្ខ នោះ[ឍ]គេ

**២៦:២** ច ទដ ២៤:៧ ឆ ទដ ២៤:៣–៤ ៨៥:១៣ អស ១:២៦ ៤:៣ ៩:៧ ៥០:៨ ៥៣:១១ ៥៤:១៤ ៥៨:៨ ៦២:២ **២៦:៣** ជ យប ២២:២១ អស ៩:៦,៧ ភល ៤:៧ ឈ ១រប ៥:២០ ទដ ២២:៥ ២៨:៧ អស ១២:២ **២៦:៤** ញ អស ១២:២ ៥០:១០ ដ ទដ ៦២:៨ **២៦:៤** ឋ លប ៤៩:២៤ **២៦:៥** ឌ អស ២៥:១២ អក ២៦:១១ ឍ អស ២៥:២ **២៦:៦** ណ អស ៥:៥ ត អស ៤៩:២៦ ថ អស ៣:១៥ ១៤:៣០ **២៦:៧** ទ ទដ ២៦:១២ ធ ទដ ២៥:៨ ន នក ១៤:១៩ អស ៤០:៤ ៤២:១៦ **២៦:៨** ប ចទ ១៨:១៨ ទដ ១:២ អស ៥៦:១ ៦៤:៥ ផ ទដ ៣៧:៩ ១៣០:៥ ព ទដ ១៤៥:២ អស ១២:៤ **២៦:៩** ភ ទដ ១១៩:៥៥ ម ទដ ៤២:១–៣ ៦៣:១ ៧៨:៣៤ អស ៥៥:៦ យ ១របា ១៦:១៤ រ មថ ៦:៣៣ **២៦:១០** ល មថ ៥:៤៥ វ ទដ ៣២:៦ ៥៩:៧,១៣ ស ១សយ ១២:២៤ អស ២២:១២–១៣ យរ ២:១៩ ហស ១១:៧ យហ ៥:៣៧–៣៨ រម ២:៤ **២៦:១១** ហ ទដ ១០:១២ ឡ អស ១៨:៣ ៤៤:៩,១៨ អ អស ៩:៧ យអ ២:១៨ សក ១:១៤ ក មីក ៧:១៦ ខ អស ១:៣១ ហព ១០:២៧ **២៦:១២** គ ទដ ១១៩:១៦៥ អស ៩:៦ ឃ ទដ ៦៨:២៨ **២៦:១៣** ង អស ២:៨ ១០:៥,១១ ច អស ១២:៤ ឆ អស ៤២:៨ ៦៣:៧ **២៦:១៤** ជ ចទ ៤:២៨ ឈ យប ២៦:៥ ញ ទដ ៩:៥ អស ១០:៣ ដ ទដ ៩:៦ **២៦:១៥** ឋ យប ១២:២៣ អស ១៤:២ ឌ អស ៣៣:១៧ **២៦:១៦** ឍ ពច ៦:២ អស ៥:៣០

**២៦:៣** សូមមើល ៣០:១៥ និការពន្យល់ ។ ពាក្យថា *គំនិតជាប់តាមទ្រង់* គឺសូមមើលត្រង់ការប្រៀបធៀប ទដ ១១២:៦–៨ និងការពន្យល់ ។ ពាក្យថា *ទុកចិត្ត* សូមមើលការប្រៀបធៀប ២៥:៩ ។
**២៦:៤** *ថ្មដា* សូមមើល ១៧:១០ ទដ ១៨:២ និងការពន្យល់ ។
**២៦:៥** *ទីក្រុងយ៉ាងខ្ពស់* សូមមើលការពន្យល់ ២៤:១០ ។ *ក៏បន្ទាបទៅដល់ធូលីដីផង* ចំពោះអត្ថន័យនេះសូមមើលការប្រៀបធៀប ២៥:២,១២ ។
**២៦:៦** *គឺទាំងជើងរបស់មនុស្សទាល់ក្រ* ឃ្លានេះបង្ហាញថាអ្នកដែលជិះជាន់ដល់អ្នកទាល់ក្រក៏ត្រូវអាម៉ាស់ ។ ក៏សូមមើលក្នុង ៤០:២៤–២៦ ៥១:២២–២៣ (ផ្ទុយនឹង ៣:១៤–១៥) ។
**២៦:៧** *ផ្លូវ . . . ពិនិត្យពិចារណា . . . អស់ទាំងផ្លូវ* ពាក្យទាំងនេះក៏បង្ហាញពីផ្ទៃរឿង ហើយក៏ឃើញផងដែរក្នុង ៤០:៣–៤ ៤២:១៦ ៤៥:១៣ (សូមមើលការពន្យល់ក្នុងឃ្លាទាំងអស់នោះ ឬសូមមើល សភ ៤:២៦ និងការពន្យល់) ។
**២៦:៨** គឺជាសេចក្ដីស្រេចឃ្លានប្រាថ្នាចង់បានការបើកសម្ដែង ដោយក្នុងនាមជារាស្ត្រទ្រង់ (សូមមើល ហស ១២:៥–៦) ។ ពាក្យថា *ព្រះនាមទ្រង់គឺដល់សេចក្ដីរំឭកពីទ្រង់* គឺសូមមើលក្នុង ខ.១៣ ២៤:១៥ ២៥:១ ។
**២៦:៩** *សេចក្ដីយុត្តិធម៌* គឺដោយសេចក្ដីជំនុំជម្រះពីទ្រង់ (ធៀបនឹង ៤:៤) ។
**២៦:១០** *ធ្វើគុណ* នេះគឺជាប្រភេទនៃព្រះពរបង្អូរមកនិងក៏ជាភាពសុខសាន្តដែលប្រទានឱ្យទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិត (ប្រៀបធៀប មថ ៥:៤៥ និងការពន្យល់) ។
**២៦:១១** *ព្រះហស្តទ្រង់បានលើកឡើង* ឃ្លានេះបង្ហាញពីសេចក្ដីសញ្ញានៃអំណាចព្រះចេស្ដា ។ មើល ៩:១២,១៧,២១ និងការពន្យល់ ទដ ៨៩:១៣ ។ ពាក្យថា *សេចក្ដីឧស្សាហ៍* មើល ៩:៧ និងការពន្យល់,និងមើលការប្រៀបធៀប ៣៧:៣២ ៦៣:១៥ ។ ពាក្យថា *ភ្លើង* គឺសូមមើល ១:៣១ ។
**២៦:១២** *សេចក្ដីសុខសាន្ត* សូមមើល ខ.៣ ។
**២៦:១៤** *គេបានស្លាប់អស់ហើយ ឥតរស់មកវិញទៀតឡើយ គេកន្លងបង់ហើយ ឥតងើបឡើងវិញទេ* សូមប្រៀបធៀបឃ្លាខាងលើទៅនិងវាសនាអាក្រក់របស់ស្ដេចបាប៊ីឡូន ។ មើល គម្ពីរ ១៤:៩–១០ ផ្ទុយនឹងការដែលទ្រង់មានព្រះជន្មរស់ឡើងវិញ មើលក្នុង ២៦:១៩ (មើលការពន្យល់)។
**២៦:១៥** *ចំរើនសាសន៍* ដែលមានសល់ពីការជម្លៀសចេញពីស្រុកបាប៊ីឡូនក្នុងជំពូក ៥៤:២–៣ ប្រៀបធៀប ៩:៣ និងការពន្យល់ ។

បានរកទ្រង់ គេបានបញ្ចេញពាក្យ[ណ]អធិស្ឋានជាហូរហៀរក្នុង
កាលដែលទ្រង់វាយផ្ចាល[ត]គេ ១៧ឱព្រះយេហូវ៉ាអើយ ស្ត្រី
មានគភ៌ដែលហៀបនឹងសំរាល[ថ] នាងឈឺចាប់ ហើយ
ស្រែកដោយឈឺជាខ្លាំងយ៉ាងណា ឯយើងខ្ញុំក៏ដូច្នោះនៅ
ចំពោះទ្រង់ដែរ ១៨យើងខ្ញុំក៏បានមានគភ៌ យើងខ្ញុំបានឈឺ
ចាប់ តែបានសំរាល[ទ]ចេញជាខ្យល់ទទេ យើងខ្ញុំមិនបាន
បង្កើតការជួយចំរើន[ធ]អ្វីនៅផែនដីសោះ ហើយមនុស្សនៅ
លោកិយក៏មិនទាន់ដួលនៅឡើយដែរ[ន] ១៩ឯពួកស្លាប់[ប]របស់
ឯង គេនឹងរស់ទៀត គេនឹងរស់ឡើងវិញ ជាមួយនឹងសព
របស់អញ ឯងរាល់គ្នា ដែលអាស្រ័យនៅក្នុងធូលីដីអើយ[ផ]
ចូរភ្ញាក់ឡើង ហើយច្រៀងចុះ ដ្បិតទឹកសន្សើម[ព]របស់ឯង
ប្រៀបដូចជាទឹកសន្សើមពេលព្រលឹម ឯដីនឹងបញ្ចេញ
មនុស្សស្លាប់មក[ភ] ។

២០ចូរមក ជនជាតិខ្ញុំអើយ ចូរឱ្យចូលទៅក្នុងបន្ទប់ខ្លួន
ហើយបិទទ្វារ[ម]ចុះ ត្រូវឱ្យពួន[យ]ខ្លួនបន្តិចសិន ទាល់តែសេច
ក្ដីក្រោធ[រ]បានកន្លងហួសទៅ[ល] ២១ដ្បិតមើល ព្រះយេហូវ៉ា
ទ្រង់យាង[វ]ចេញពីស្ថាន[ស]របស់ទ្រង់មក ដើម្បីនឹងសំរេច
ទោស[ហ]ដល់មនុស្សនៅផែនដី ដោយព្រោះអំពើទុច្ចរិត
របស់គេ ឯដី នឹងបើកបង្ហាញឈាម[ឡ]គេឱ្យឃើញ ឥតគ្រប
បាំងមនុស្សដែលត្រូវគេសំឡាប់ទៀតឡើយ ។

**២៦:១៦** ណ ទដ ៣៩:១១ ត អស ២៩:៤
**២៦:១៧** ថ អស ២១:៣ យហ ១៦:២១ វវ ១២:២
**២៦:១៨** ទ អស ៣៣:១១ ៥៩:៤ ធ លប ៤៩:១០ ទដ ១៧:១៤ ន អស ៤២:៦ ៤៩:៦ ៥១:៤ យរ ១២:១៦
**២៦:១៩** ប អស ២៥:៨ អភ ៥:១៤ ផ ទដ ២២:២៩ ព លប ២៧:២៨ អស ១៨:៤ ភ អស ៦៦:២៤ អគ ៣៧:១–១៤ ដយ ១២:២
**២៦:២០** ម នក ១២:២៣ យ ទដ ៩១:១,៤ រ អស ១០:២៥ ៣០:២៧ ល យប ១៤:១៣
**២៦:២១** វ អស ២៦:៦ យដ ១:១៤

## ការរំដោះនគរអ៊ីស្រាអែល

**២៧** ១នៅគ្រានោះ[ក] ព្រះយេហូវ៉ាទ្រង់នឹងយកដាវ[ខ]មុតថ្លា
ដ៏ធំ ហើយមានកំឡាំងរបស់ទ្រង់ ទៅធ្វើទោសដល់សត្វ
សំបើម[គ] ជានាគ[ឃ] ដែលរត់ពួន គឺសត្វសំបើម ជានាគក្ងិកក្ងក់
នោះឯង ហើយទ្រង់នឹងសំឡាប់សត្វសំបើម[ង] ដែលនៅក្នុង
សមុទ្រនោះ ។

២នៅគ្រានោះ[ច]នឹងមានចំការ សំរាប់ធ្វើស្រាទំពាំង–
បាយជូរ ចូរច្រៀង[ឆ]ជូនថា[ជ] ៣អញនេះ គឺព្រះយេហូវ៉ា ជា
អ្នកថែរក្សា អញនឹងស្រោចទឹក[ឈ]ជានិច្ច ហើយនឹងថែ
មើល[ញ]ទាំងយប់ទាំងថ្ងៃ ក្រែងអ្នកណាធ្វើឱ្យអន្តរាយ[ដ] ៤អញ
មិនចេះឃោរឃៅទេ តែបើមានអញ្ចាញនឹងបន្លាមក
ច្បាំងនឹងអញ នោះអញនឹងដើរជាន់លើវា ហើយនឹងដុត
បញ្ឆេះវាអស់រលីង[ឋ] ៥បើពុំនោះ ឱ្យគេមកពឹងពាក់កំឡាំង
អញវិញ[ឱ] ដើម្បីឱ្យបានជាមេត្រី[ឍ]នឹងអញ ចូរឱ្យគេជា
មេត្រីនឹងអញចុះ ៦នៅគ្រាខាងមុខ នោះពួកយ៉ាកុបនឹង

ស អស ១៨:៤ ហ អស ១៣:៩,១១ ៣០:១២–១៤ ឡ យប ១៦:១៨ លក ១១:៥០–៥១ **២៧:១** ក ខ.១៣ អស ២:១១ ២៨:៥ ខ លប ៣:២៤ ចទ ៣២:៤១ អស ៣១:៨ ៣៤:៦ ៦៥:១២ ៦៦:១៦ អគ ២១:៣ ណហ ៣:១៥ គ យប ៣:៨ ឃ យប ២៦:១៣ ង ទដ ៦៨:៣០ ៧៤:១៣ វវ ១២:៩ **២៧:២** ច អស ២៤:២១ ឆ អស ៥:១ ជ យរ ២:២១ **២៧:៣** ឈ អស ៥៨:១១ ញ ទដ ៩១:៤ អស ៥:២ ដ យហ ៦:៣៩ **២៧:៤** ឋ ខ.១១ អស ១០:១៧ មថ ៣:១២ ហព ៦:៨ **២៧:៥** ឱ អស ២៥:៤ ឍ យប ២២:២១ ទដ ១១៩:១៦៥ រម ៥:១ ២កូ ៥:២០

**២៦:១៦–១៨** ពួកហោរាបាននិយាយទៅរកព្រះ គឺក្នុងរាស្ត្ររបស់ទ្រង់ ។

**២៦:១៦** *មានទុក្ខ* គឺប្រហែលជាភាពមានទុក្ខរបស់ពួក អាសស៊ើរក៏ពណ៌នានៅក្នុង ៥:៣០ ៨:២១–២២ (ក៏សូមមើលការពន្យល់) ។ នោះហើយគឺជារយៈពេលជំនុំជម្រះ (សូមមើល ៣ច ៦:២,៦) ។

**២៦:១៧–១៨** *ស្ត្រីមានគភ៌ដែលហៀបនឹងសំរាល និងឈឺចាប់* គឺសូមមើល ១៣:៨ និងការពន្យល់(ប្រៀបធៀប ៣៧:៣) ។

**២៦:១៨** *ការជួយចំរើនអ្វីនៅផែនដីសោះ* សូមមើល ៤៩:៦ ។

**២៦:១៩** *ឯពួកស្លាប់របស់ឯង គេនឹងរស់ទៀត គេនឹងរស់ឡើងវិញ* គឺសំដៅលើពួកអ៊ីស្រាអែលមានជាតិសាសន៍រស់ឡើងវិញ (សូមមើល អគ ៣៧:១១–១២,១៤ និងការពន្យល់) ក៏ជាការរស់ឡើងវិញនៃរូបកាយ (សូមមើល ដយ ១២:២ និងការពន្យល់) ។ ប្រៀបធៀប ២៥:៨ ដែលផ្ទុយនឹង ២៦:១៤ ។ *ទឹកសន្សើម* គឺជាតំណាងនូវភាពមានផលផ្លែ (សូមមើល ២សយ ១:២១ យស ១៤:៥ និងការពន្យល់) ។

**២៦:២០–២១** សូមមើល ២៤:២១–២២ និងការពន្យល់ ២:១,១៧,២០ ។

**២៦:២០** *ត្រូវឱ្យពួនខ្លួនបន្តិចសិន ទាល់តែសេចក្ដីក្រោធបានកន្លងហួសទៅ* សូមមើល ១០:២៥ ៥៤:៧–៨ និងការពន្យល់ ក៏សូមធៀបនឹង ទដ ៣០:៥ និងការពន្យល់ ។ ដូចជាការសង្កត់សង្កិនរបស់ពួកអាសស៊ើរនឹងការនិរទេសរបស់ពួកសាសន៍បាប៊ីឡូន ក៏ដូចជាការគាបសង្កត់ដែលនិងត្រូវបញ្ចប់ទាំងស្រុងផងដែរ ។

**២៦:២១** *សំរេចទោស* មើល ៦៦:១៤–១៦ និងការពន្យល់ ។ *នឹងបើកបង្ហាញឈាមគេ . . . ឥតគ្របបាំង . . . ទៀតឡើយ* ដោយព្រះឈាមនិងរូបកាយរបស់អ្នកគ្មានកំហុសអ្នកបរិសុទ្ធសុចរិត ដែលត្រូវបានគេសម្លាប់ដោយអំណាចពួកអ្នកដែលគាបសង្កត់គេ ហើយគេងើបមកដើម្បីប្រឈមមុខ និងពួកអ្នកដែលគាបសង្កត់គេទាំងនោះ ។ គ្រានោះព្រះអម្ចាស់កាត់ទោសជំនុំជម្រះសងសឹកចំពោះការស្លាប់របស់ពួកគេ (មើល លប ៤:១០ និងការពន្យល់) ។

**២៧:១–២,១២–១៣** *នៅគ្រានោះ* ពាក្យនេះសូមមើល ១០:២០,២៧ និងការពន្យល់ ក៏សូមមើល ១២:១,៤ ២៥:៩ ២៦:១ ។

**២៧:១** ជាពាក្យពិចារណាចំពោះការជំនុំជម្រះក្នុងជំពូក ២៤–២៧ (សូមមើលការពន្យល់ ២៤:១–២៧:១៣) ។ *ដាវ* សូមមើល ទដ ៧:១២–១៣ នឹងការពន្យល់ ។ *សត្វសំបើមជានាគដែលរត់ពួន* ក៏ជានិមិត្តរូបមួយ (គឺជាការដកស្រង់ចេញពីជំនឿខុសឆ្គងរបស់ពួកសាសន៍កាណាន) គឺដូចជាពួកសាសន៍ ដែលទន់ខ្សោយក៏ដូចជាសាសន៍អេស៊ីព្ទ (សូមមើល ៣០:៧) ។ *គឺជាសត្វសំបើម ក្ងិកក្ងក់នោះឯង* សូមមើលការប្រៀបធៀប យប ៣:៨ ៤១:១ ទដ ៧៤:១៣–១៤ ។

**២៧:៤–៥** គឺជារូបភាពបង្ហាញពីភាពមានការកក់ក្ដៅ របស់រាស្ត្រអ៊ីស្រាអែលឆ្ពោះទៅរកព្រះអម្ចាស់មិនមែនទៅកាន់ដើមឈើ ឬគុម្ពបន្លា ឬដើមឈើទេ ។ (ខ.៤) ក៏ដូចជាជាតិសាសន៍មួយចំនួនដែលពួកគេមិនទុកចិត្តទាំងស្រុងទៅលើព្រះអម្ចាស់ទេ (សូមមើល ២៩:១៣ និងការពន្យល់) ។

**២៧:៤** *មានអញ្ចាញនឹងបន្លា* សូមមើល ៥:៦ និងការពន្យល់ ។

ចាក់ឫស[ណ]ទៅ ពួកអ៊ីស្រាអែលនឹងពន្លកចេញឡើង[ត] ហើយ
គេនឹងបង្កើតផលផ្សាយទៅពេញលើផែនដី[ថ] ។
៧តើទ្រង់បានវាយគេ ដូចជាវាយសាសន៍១ដែលបាន
វាយគេដែរឬ តើគេបានត្រូវប្រហារ[ទ]បង់ ដូចជាការ
ប្រហារដល់ពួកអ្នកដែលទ្រង់បានប្រហារនោះឬអី ៨គឺ
ទ្រង់បាន ធ្វើទោសដល់គេ តាមព្រះហឫទ័យសន្តោសវិញ
ដោយបណ្តេញគេទៅ គឺទ្រង់បានផាត់[ធ]គេចេញ ដោយ
ខ្យល់គំហុករបស់ទ្រង់ នៅថ្ងៃដែលខ្យល់[ន]ពីទិសខាងកើត
បក់មក ៩ដូច្នេះ អំពើទុច្ចរិតរបស់ពួកយ៉ាកុប នឹងបានជិរះ[ប]
ដោយការនោះឯង ហើយនេះជាផលដែលកើតពីការដោះ
បាបចេញ[ផ] គឺទ្រង់នឹងធ្វើឱ្យថ្ម[ព]ទាំងប៉ុន្មាននៃអាសនាបានដូច
ជាដីសដែលត្រូវកិនកំទេច ដើម្បីឱ្យរូបព្រះ[ភ]ទាំងប៉ុន្មាន
នឹងរូបព្រះអាទិត្យ[ម] បានងើបឡើងវិញមិនរួចជាដរាប
១០ដ្បិតទីក្រុង មានបន្ទាយបានចោលស្ងាត់ទៅ[យ]គឺជា ទីលំ
នៅដែលគេលែងនៅ ព្រមទាំងបោះបង់ចោល[រ]ហើយ
ប្រៀបដូចជារហោស្ថាន នៅទីនោះកូនគោនឹងរកស៊ី
ហើយ[ល]ដេកនៅ[វ] វានឹងស៊ីមែកខ្ចីដែលនៅទីនោះ ១១កាល
ណាមែកស្វិតក្រៀមទៅហើយ នោះនឹងត្រូវកាប់ចេញ[ស]
ហើយពួកស្រីៗនឹងមកដុតចោល[ហ] ពីព្រោះជនជាតិនេះឥត
មានយោបល់[ឡ] ហេតុដូច្នេះ ព្រះដែលបានបង្កើតគេ ទ្រង់
នឹងមិនប្រណីដល់គេឡើយ ព្រះដែលបានសូនគេឡើង[អ]
ទ្រង់នឹង មិនផ្តល់ព្រះគុណដល់គេសោះ[ក] ។
១២នៅគ្រានោះ ឱពួកកូនចៅអ៊ីស្រាអែលអើយ ព្រះ
យេហូវ៉ាទ្រង់នឹងវាយជិរុះ[ខ]ផលគេ ចាប់តាំងពីទឹកទន្លេ
រហូតដល់ស្ទឹងស្រុកអេស៊ីព្ទ[គ] គ្រានោះឯងរាល់គ្នានឹងបាន
រួមមូលគ្នា[ឃ]មកម្នាក់ម្តងម្នាក់ម្តង ១៣ហើយនៅគ្រានោះ[ង]នឹង
ឮសូរត្រែ[ច]ធំផ្លុំឡើង នោះពួកអ្នកនៅក្នុងស្រុកអាសស៊ើរ
ដែលហៀបនឹងវិនាសបាត់ នឹងពួកអ្នកដែលត្រូវបំបរបង់[ឆ]
ចេញទៅឯស្រុកអេស៊ីព្ទ[ជ] គេនឹងវិលមកថ្វាយបង្គំ[ឈ] ព្រះ
យេហូវ៉ា នៅលើភ្នំ[ញ]បរិសុទ្ធ ត្រង់ក្រុងយេរូសាឡិម ។

### វេទនាដល់ពួកអេប្រាអិម

**២៨** ១វេទនា[ក]ដល់មកុដនៃសេចក្តីអំនួតរបស់ពួកប្រមឹក
ក្នុងពួកអេប្រាអិម[ខ] ដែលគេយកជាទីអួត ហើយដល់ផ្កាដែល
កំពុងតែស្រពោន ជាសេចក្តីលំអដ៏រុងរឿងរបស់គេ ដែល
នៅលើក្បាលច្រកភ្នំ[គ]ដុះដាល របស់ពួកអ្នកដែលស្រវឹង
ស្រាទំពាំងបាយជូរហើយ[ឃ] ២មើល ព្រះអម្ចាស់ទ្រង់មានអ្នក

**២៧:៦** ណ ២ពវ ១៩:៣០ អស ១១:១០ ត លប ៤០:១១ ថ ទដ ៧២:១៦ អស ១១:១ ៣៧:៣១ អគ ១៧:២៣ ៣៦:៨ ហស ១៤:៨ **២៧:៧** ទ អស ១០:២៦ ១១:៤ ៣៧:៣៦–៣៨ **២៧:៨** ធ អស ៤៩:១៤ ៥០:១ ៥៤:៧ ន លប ៤១:៦ **២៧:៩** ប ទដ ៧៨:៣៨ ផ រម ១១:២៧ ព នក ២៣:២៤ ភ នក ៣៤:១៣ ម លវ ២៦:៣០ ២របា ១៤:៥ **២៧:១០** យ លប ១:២ ចទ ១៣:១៦ អស ៥:៦ ៣២:១៤ យរ ១០:២២ ២៦ បទ ១:៤ ៥:១៨ រ អស ៥:៥ ល អស ៥:១៧ វ អស ១៧:២ **២៧:១១** ស អស ១០:៣៣ ហ ខ.៤ អស ៣៣:១២ ឡ ចទ ៣២:២៨ អស ១:៣ អ ចទ ៣២:១៨ អស ៤១:៨ ៤៣:១,៧,១៥ ៤៤:១–២,២១,២៤ ក អស ៩:១៧ យរ ១១:១៦ **២៧:១២** ខ អស ២១:១០ មថ ៣:១២ គ លប ១៥:១៨ ឃ ចទ ៣០:៤ អស ១:៩ ១១:១២ ១៧:៦ **២៧:១៣** ង ខ.១ ច លប ២៥:៩ ពច ៣:២៧ មថ ២៤:៣១ ឆ ទដ ១០៦:៤៧ ជ អស ១០:១៩ ១៩:២១,២៥ ឈ លប ២៧:២៩ ទដ ២២:២៩ ៨៦:៩ ញ អស ២:២ **២៨:១** ក អស ១០:៥ ២៩:១ ៣០:១ ៣១:១ ៣៣:១ ខ ខ.៣ អស ៧:២ ៩:៩ គ ខ.៤ ឃ លវ ១០:៩ អស ៥:១១ ហស ៧:៥ អម ៦:៦

**២៧:៦** *នឹងចាក់ឫសទៅ* សូមមើល ១១:១,១០ និងការពន្យល់ ។ និងពន្លកចេញឡើង សូមមើល ៤:២ និងការពន្យល់។ គឺជាយុគសម័យនៃព្រះមែស៊ីដែលបានបង្ហាញ ។ *ទៅពេញផែនដី* ឃ្លានេះមានលក្ខណៈផ្ទុយនឹង ២៦:១៨។
**២៧:៧–១១** គឺជាថ្ងៃដែលព្រះអម្ចាស់ជាព្រះយេហូវ៉ានិងធ្វើការខ្លះ និងរាស្ត្រអ៊ីស្រាអែល ក្នុងថ្ងៃជំនុំជម្រះ ។
**២៧:៧** *វាយគេ* មើលការប្រៀបធៀប ១០:២៤–២៦ ។
**២៧:៨** *ធ្វើទោស* ដូចជាតាមរយៈការចាប់ជាឈ្លើយពីពួកបាប៊ីឡូន ។ ពាក្យថា *ខ្យល់ទិសខាងកើត* គឺជាខ្យល់ដែលបានបកមកពីតំបន់វាលរហោស្ថាន (សូមមើល យរ ៤:១១ និងការពន្យល់) ។
**២៧:៩** *បានជិរះ* គឺសាសន៍អ៊ីស្រាអែល (គឺពួកយ៉ាកុប) និងបានជំនុំជម្រះដោយព្រោះអំពើកំហុសរបស់ពួកគេ គឺតាមរយៈការជំនុំជម្រះ ។ *សាសនា . . . នឹងរូបព្រះអាទិត្យ* គឺសូមមើល ១៧:៨ និងការពន្យល់ ។ *ដីដែលត្រូវកិនកំទេច* សូមមើល នក ៣៤:១៣ និងការពន្យល់ ។
**២៧:១០** គឺជាការបង្ហាញពីទីក្រុងដែលចោលស្ងាត់ ដែលជាទីក្រុងយេរូសា–ឡិម សូមមើល ៦:១១–១២ ។
**២៧:១២–១៣** ក៏ជាថ្ងៃលោះបាប និងនាំមកនូវថ្ងៃជំនុំជម្រះ ។
**២៧:១២** *នឹងវាយជិរុះ* គឺជាថ្ងៃជំនុំជម្រះចំពោះជាតិសាសន៍មួយចំនួនដែលនាំឱ្យរាស្ត្រអ៊ីស្រាអែលត្រូវបានបាក់បែកខ្ញែកគ្នា (សូមមើល ២១:១០) ។ ការវាយជិរុះនោះបានញែកសាសន៍អ៊ីស្រាអែលចេញពីសាន៍ដទៃពីអ្នកមិនជឿព្រះ ។ *ស្ទឹងស្រុកអេស៊ីព្ទ* គឺមានទីតាំងនៅព្រំប្រទល់ខាងត្បូងនៃទឹកដីសន្យា (ឯទន្លេអ៊ើប្រាតគឺជាព្រំព្រទល់ខាងជើង) ។ សូមមើល លប ១៥:១៨ ១ពវ ៤:២១ ៨:៦៥ ។
**២៧:១៣** *ត្រែធំ* គឺជាត្រែដែលគេប្រើដើម្បីផ្លុំប្រមូលផ្តុំទ័ពឬប្រជាជន (សូមមើល ១សយ ១៣:៣) ។ ពាក្យថា *ស្រុកអាសស៊ើរ . . . ស្រុកអេស៊ីព្ទ* គឺសូមមើល ១១:១–១២ និងការពន្យល់ ។ ពាក្យថា *ភ្នំបរិសុទ្ធ* គឺជាភ្នំនៃក្រុងស៊ីយ៉ូន គឺជាក្រុងយេរូសាឡិម ។ (សូមមើល ២:២–៤ និងការពន្យល់ក៏សូមមើល ១១:៦–៩ ២៤:២៣ ២៥:៦–៧,១០ និងការពន្យល់ ៦៥:២៥) ។
**២៨:១–៣៥:១០** គឺជាខ្សែនៃសេចក្តីវេទនាទាំង៦ (សូមមើល ២៨:១ ២៩:១ ២៩:១៥ ៣០:១ ៣១:១ ៣៣:១) ក៏ត្រូវបញ្ចប់ដោយការប្រកាសពីការជំនុំជម្រះទៅលើពួជសាសន៍ទាំងឡាយ (ជំពូក ៣៤) និងចម្រៀងជាសេចក្តីអំណរនៃការលោះបាប (ជំពូក ៣៥) ។ ក៏មានសេចក្តីវេទាទាំង៦គឺក្នុងជំពូក ៥ (សូមមើលការពន្យល់ ៥:៨–២៣) ។
**២៨:១** *មកុដ* ជាស្រុកសាម៉ារីដែលជារាជធានីរបស់នគរខាងជើងក៏ជាទីក្រុងយ៉ាងស្រស់ស្អាតនៅតំបន់កូនភ្នំដ៏ល្បីល្បាញមួយ (មើលការពន្យល់ ១ពវ ១៦:២៤) ។ ពាក្យថា *សេចក្តីអំនួត* មើល ខ.៣ និងការពន្យល់ ១៦:៦ ។ *ពួកអេប្រាអិម* ពាក្យនេះសូមមើលការពន្យល់ត្រង់ ៧:២ ។ *ពួកប្រមឹក* ដូចជាមាននៅក្នុងសតវត្សទី ៨ មុន គ.ស គឺពួកស្រុកសាម៉ារី ក៏ជា ទីក្រុងមួយក៏គ្មានអ្វីវិកវរទេ ។ សូមមើល ៥:១១–១៣ និងការពន្យល់ ៦:៤–៧ ។

ខ្លាំងពូកែ[ង] ដ៏មានឫទ្ធិម្នាក់ អ្នកនោះនឹងពង្រាបចុះដល់ដី
ដោយអំណាចនៃដៃ ដូចជាព្យុះព្រឹល[ច] ជាព្យុះសង្ឃរាដែល
បំផ្លាញ[ឆ] ហើយដូចជាព្យុះភ្លៀងធំឱ្យទឹកហូរជន់[ជ]លិច ៣ឯ
មកុដនៃសេចក្តីអំនួតរបស់ពួកប្រមឹក ក្នុងពួកអេប្រាអិម[ឈ]
ដែលគេយកមកទីអំនួត នោះនឹងត្រូវជាន់ឈ្លី[ញ]នៅក្រោម
ជើង ៤ហើយផ្កាដែលកំពុងតែស្រពោន ជាសេចក្តីលំអដ៏រុង
រឿងរបស់គេ ដែលនៅលើក្បាលច្រកភ្នំដុះដាល[ដ] នោះនឹង
បានដូចជាផ្លែល្វា[ឋ]ដែលទុំជាដំបូងមុនរដូវក្តៅ ដែលកាល
ណា គេក្រឡេកទៅឃើញ នោះក៏បេះមកដល់ដៃពមចូល
ទៅភ្លាម ៥នៅគ្រានោះ[ឌ] ព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់នឹងជាមកុដដ៏រុងរឿង[ឍ,ណ] ហើយជាគ្រឿងលំអដល់
សំណល់[ត]នៃរាស្ត្រទ្រង់ ៦ហើយជាគំនិតយុត្តិធម៌[ថ] ដល់
អ្នកដែលអង្គុយជំនុំជំរះ[ទ] និងជាឫទ្ធិកំឡាំងដល់អ្នក ដែល
បណ្តេញពួកពលខ្មាំង[ធ] ឱ្យថយចេញពីទ្វារក្រុង ។
៧ឯពួកអ្នកទាំងនោះ គេក៏វិលទៅមក[ន] ដោយស្រាទំពាំង
បាយជូរ[ប] ហើយទ្រេតទ្រោត[ផ]ដោយគ្រឿងស្រវឹងដែរ គឺ
ទាំងពួកសង្ឃ[ព] និងពួកហោរា[ភ] ក៏វិលទៅមកដោយគ្រឿង
ស្រវឹង គេត្រូវបំផ្លាញទៅដោយស្រាទំពាំងបាយជូរ គេ
ទ្រេតទ្រោតដោយគ្រឿងស្រវឹង ក្នុងការជាក់ស្តែង[ម]គេ
យល់ខុសទទេ ក៏រមើលក្នុងការជំនុំជំរះ ៨ដ្បិតតុទាំងអស់
ប្រឡាក់ពេញដោយកំអួត[យ] ហើយកខ្វក់ ឥតមានកន្លែងណា
ស្អាតឡើយ ។
៩ដូច្នេះ តើទ្រង់នឹងបង្រៀនចំណេះដល់អ្នកណា[រ] តើ
ទ្រង់នឹងធ្វើឱ្យអ្នកណាយល់ដំណឹង[ល] គឺពួកដែលទើបនឹង
លែង[វ]បៅ[ស] ជាពួកអ្នកដែលទើបនឹងផ្តាច់ដោះវិញ
១០ដ្បិត ត្រូវបង្រៀនច្បាប់មួយម្តងៗ ហើយឃ្លាមួយម្តងៗ
មុខនេះ បន្តិចមុខនោះ[ហ] ។
១១ទ្រង់នឹងមានបន្ទូលដល់ជនជាតិនេះ[ឡ]ដោយសំដីរឡប់
ហើយនឹងភាសាដទៃ[អ] ១២ទ្រង់បានមានបន្ទូលនឹងគេថា នេះ
នៃជាសេចក្តីសំរាក[ក] ចូរឱ្យពួកអ្នកដែលនឿយហត់ បាន
សំរាកចុះ នេះឯងជាទីលំហើយ តែគេមិនព្រមស្តាប់សោះ
១៣ហេតុដូច្នោះ ព្រះបន្ទូលនៃព្រះយេហូវ៉ា និងបានដល់គេ
ដោយច្បាប់មួយម្តងៗ ហើយនឹងឃ្លាមួយម្តងៗ មុខនេះបន្តិច
មុខនោះបន្តិច[ខ] ដើម្បីឱ្យគេចេញទៅដួលផ្ងារចុះ ព្រមទាំង
ត្រូវបាក់បែក[គ]ជាប់អន្ទាក់ ហើយត្រូវបានចាប់ផង[ឃ] ។
១៤ដូច្នេះ ឱពួកចំអកឡកឡឺយ[ង] ដែលគ្រងលើបណ្តាជន
នៅក្រុងយេរូសាឡិមអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះយេ
ហូវ៉ាចុះ[ច] ១៥ដោយព្រោះអ្នករាល់គ្នាបានពោលថា យើង
រាល់គ្នាបានចុះសញ្ញានឹងសេចក្តីស្លាប់[ឆ] ក៏ព្រមព្រៀង
គ្នានឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ហើយ កាលណាសេចក្តី
ភ័យអន្តរាយដ៏ជន់លិចច្រាំងបានហូរកាត់មក[ជ] នោះនឹង

**២៨:២** ង អស ៤០:១០ ច យស ១០:១១ ឆ អស ២៩:៦ ជ អស ៨:៧ ដយ ៩:២៦ **២៨:៣** ឈ ខ.១ **២៨:៣** ញ យប ៤០:១២ អស ៥:៥ **២៨:៤** ដ ខ.១ ឋ បស ២:១៣ ហស ៩:១០ ណាហ ៣:១២ **២៨:៥** ឌ អស ១០:២០ ២៧:១ ២៩:១៨ ៣០:២៣ ឍ អស ២៤:១៦,២៣ ណ អស ៦២:៣ យរ ១៣:១៨ អក ១៦:១២ ២១:២៦ សក ៩:១៦ ត អស ១:៩ **២៨:៦** ថ ២សយ ១៩:២០ អស ១១:២-៤ ៣២:១,១៦ ៣៣:៥ ទ អស ៤:៤ យហ ៥:៣០ ធ ពច ៩:៤៤-៤៥ ២របា ៣២:៨ **២៨:៧** ន អស ៣:១២ ប លវ ១០:៩ អស ២២:១៣ អភ ៥:១៨ ផ ទដ ១០៧:២៧ ព អស ២៤:២ ភ អស ៩:១៥ ម អស ១:១ ២៩:១១ **២៨:៨** យ យរ ៤៨:២៦ **២៨:៩** រ ខ.២៦ ទដ ៣២:៨ អស ២:៣ ៣០:២០ ៤៨:១៧ ៥០:៤ ៥៤:១៣ យរ ៣១:៣៤ ៣២:៣៣ ល អស ៥២:៧ ៥៣:១ វ ទដ ១៣១:២ ស ហព ៥:១២-១៣ ១ពត ២:២ **២៨:១០** ហ ខ.១៣ **២៨:១១** ឡ អក ៣:៥ ១កថ ១៤:២១ អ លប ១១:៧ អស ៣៣:១៩ យរ ៥:១៥ **២៨:១២** ក នក ១៤:១៤ យប ១:១៣ យប ១១:១៨ អស ១១:១០ មថ ១១:២៨-២៩ **២៨:១៣** ខ ខ.១០ គ មថ ២១:៤៤ ឃ អស ៨:១៥ **២៨:១៤** ង ២របា ៣៦:១៦ ច អស ១:១០ **២៨:១៥** ឆ យប ៥:២៣ អស ៨:១៩ ជ ខ.២,១៨ អស ៨:៧-៨ ១០:២៦ ២៩:៦ ៣០:២៨ ដយ ១១:២២

**២៨:២** *អ្នកខ្លាំងពូកែដ៏មានឫទ្ធិម្នាក់* គឺជាស្តេចក្នុងស្រុកអាសស៊ើរ ។ *ព្យុះព្រឹល . . . ទឹកហូរជន់លិច* សូមមើល ខ.១៧ ៨:៧-៨ និងការពន្យល់ ១៧:១២ និងការពន្យល់ ក៏សូមមើលការប្រៀបធៀប ៣០:៣០ ៣២:១៩ ។

**២៨:៥** *នៅគ្រានោះ* សូមមើល ៤:១-២ ១០:២០,២៧ និងការពន្យល់ ១២:១,៤ ២៤:២១ ២៥:៩ ២៦:១ ២៧:១-២,១២-១៣ ។ ពាក្យថា *ដ៏រុងរឿង . . . ជាគ្រឿងលំអ* ក៏សូមមើល ៤:២ និងការពន្យល់។ *សំណល់* សូមមើលការពន្យល់ ១:៩ ។

**២៨:៦** *គំនិតយុត្តិធម៌* មើល ១១:២-៤ និងការពន្យល់ ។ *ទ្វារក្រុង* គឺជាផ្នែកសំខាន់បំផុតរបស់ទីក្រុង ។

**២៨:៧** *ស្រា . . . គ្រឿងស្រវឹង* តែថ្នាក់ដឹកនាំសាសនាគួរតែពេញទៅដោយព្រះវិញ្ញាណមិនមែនពេញទៅដោយគ្រឿងស្រវឹងនោះទេ ។ សូមមើល លវ ១០:៩ ក៏សូមមើល ជន ១១:២៩ អភ ៥:១៨ និងការពន្យល់។

**២៨:៨** *អំនួត* សូមមើលការប្រៀបធៀប យរ ២៥:១៦,២៧ ។

**២៨:៩-១០** ឃ្លានេះគឺជាការឆ្លើយតបដោយពាក្យបញ្ឈឺពីអ្នកដែលនៅជិតលោកអេសាយ (សូមមើលការពន្យល់ ខ.១០) ប្រៀបធៀប ៥:១៩ ។

**២៨:១១-១២** គឺជាសេចក្តីដកស្រង់ក្នុងគម្ពីរ ១កថ ១៤:២១ ។

**២៨:១១** *សំដីរឡប់* គឺជាភាសារបស់ពួកសាសន៍អាសស៊ើរ ។

**២៨:១២** *កន្លែងសំរាក* គឺជាកន្លែងដែលព្រះយេហូវ៉ាបានប្រទានឱ្យទៅពួកគេ គឺអ្នកដែលមានសេចក្តីពិតក្នុងខ្លួន ។ (សូមមើល ២៦:៣ ៣០:១៥ ៤០:៣១ យស ១:១៣ និងការពន្យល់) ។ ពាក្យថា *មិនព្រមស្តាប់សោះ* ប្រៀបធៀប យរ ៦:១៦ និងការពន្យល់។

**២៨:១៣** ពួកគេនោះនិយាយថា ពួកហោរានិយាយពុំមានន័យអ្វីទាំងអស់ (ខ.៩-១០) ដូច្នេះព្រះបន្ទូលរបស់ព្រះយេហូវ៉ា នៃពួកពលបរិវារ ដែលបានបើកសម្តែងនោះនៅតែគ្មានប្រយោជន៍អ្វីទាំងអស់សម្រាប់ពួកគេ (សូមមើល ៦:៩-១០ និងការពន្យល់) ។

**២៨:១៥,១៨** *ចុះសញ្ញានឹងសេចក្តីស្លាប់* ដោយការប្រើតួលេខចំៗចំពោះសេចក្តីថ្លែងហើយលោកអេសាយក៏បានបដិសេធ ប្រឆាំងនិងភាពភិតភ័យទាំងឡាយទាំងប្រើបបូរមាត់ ប្រកាសឱ្យមានសេចក្តីសញ្ញាជាមួយនឹងសេចក្តីស្លាប់ដែលនិងមិនធ្វើឱ្យពួកគេគ្រោះថ្នាក់ ។ (ប្រៀបធៀបនិង ហស ២:១៨ នឹងការពន្យល់) ។ *សេចក្តីអន្តរាយដ៏ជន់លិចច្រាំង* គឺជាសេចក្តីប្រៀបធៀបរួមបញ្ចូលគ្នាដែលទាក់ទងទៅនិងកងទ័ពរបស់ពួកអាសស៊ើរនិងពួកបាប៊ីឡូន "ជន់លិចច្រាំង" គឺជាសេចក្តីស្រម៉ៃទៅដល់កងទ័ពដូចជាទន្លេដែលមានទឹក

មិនដល់យើងទេ ពីព្រោះយើងបានពឹងពាក់[ឈ] ដល់សេចក្តី
កុហក[ញ] ហើយពួនខ្លួនក្នុងសេចក្តីកំភូតភរ ១៦ហេតុនោះបាន
ជាព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា មើល អញដាក់
ថ្ម១នៅក្រុងស៊ីយ៉ូន[ដ] ទុកជាជើងជញ្ជាំង ជាថ្ម[ឋ]ដែលបាន
ល្បងល ហើយជាថ្មទីជ្រុងដ៏មានដំឡៃ ដែលបានដាក់យ៉ាង
មាំមួន[ឌ] ឯអ្នកណាដែលជឿ នោះមិនត្រូវរួសរាន់ឡើយ[ឍ]
១៧អញនឹងយកសេចក្តីយុត្តិធម៌[ណ]ធ្វើជាខ្សែបន្ទាត់ ហើយនឹង
សេចក្តីសុចរិតជាកូនតឹង[ត] រួចព្យុះព្រឹល[ថ]នឹងបោសរំលីង
ទីជ្រកនៃសេចក្តីភូតភរទៅ ហើយនឹងជន់ឡើង[ទ] លិចទីពំនួន
បង់ ១៨នោះសេចក្តីសញ្ញាដែលឯងរាល់គ្នាបានតាំងនឹង
សេចក្តីស្លាប់ ក៏នឹងត្រូវលើកចោលចេញ ហើយការព្រម
ព្រៀងគ្នានឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះមិនស្ថិតស្ថេរ
នៅដែរ[ធ] ដូច្នេះ កាលណាសេចក្តីអន្តរាយដ៏ជន់លិចច្រាំង
បានហួរកាត់មក[ន] នោះអ្នករាល់គ្នានឹងត្រូវញាំញី[ប]ទៅ
១៩សេចក្តីអន្តរាយនោះហួរកាត់មកវេលាណា ក៏នឹងកៀរ
យកអ្នករាល់គ្នាទៅតែម្តង[ផ] ដ្បិតរាល់តែព្រឹកនឹងហូរកាត់
មក[ព] ហើយទាំងថ្ងៃទាំងយប់ផង ការដែលគ្រាន់តែឮដំណឹង
នោះនឹងបានជាសេចក្តីគួរស្ញែងខ្លាចហើយ[ភ] ២០ដ្បិតគ្រែខ្លី
ពេក នឹងដេកសណ្តូកខ្លួនមិនបាន ហើយភួយក៏តូចផង មិន
ល្មមនឹងដណ្តប់ខ្លួនដែរ[ម] ២១ពីព្រោះព្រះយេហូវ៉ាទ្រង់នឹង
ក្រោកឈរឡើង ដូចជានៅត្រង់ភ្នំពេរ៉ាស៊ីម[យ] ទ្រង់នឹងមាន
សេចក្តីក្រោធ ដូចជានៅក្នុងច្រកភ្នំគីបៀន[រ] ដើម្បីឱ្យទ្រង់
បានធ្វើការរបស់ទ្រង់[ល] គឺជាការយ៉ាងប្លែក ហើយនឹង
សំរេចកិច្ចរបស់ទ្រង់ គឺជាកិច្ចយ៉ាងប្លែក ២២ដូច្នេះ កុំឱ្យអ្នក
រាល់គ្នាធ្វើជាអ្នកចំអកឡកឡឺយទៀត[វ] ក្រែងចំណងរបស់
អ្នករាល់គ្នាត្រូវរឹតរួតកាន់តែខ្លាំងឡើង ព្រោះខ្ញុំបានឮ
ពីព្រះអម្ចាស់យេហូវ៉ា ជាព្រះនៃពួកពលបរិវារថា បាន
សំរេចឱ្យមានការបំផ្លាញ[ស]នៅគ្រប់លើផែនដីហើយ[ហ]។
២៣ចូរផ្ទៀងត្រចៀកស្តាប់[ឡ]សំឡេងខ្ញុំចុះ ចូរផ្ទង់ចិត្ត
ស្តាប់ពាក្យរបស់ខ្ញុំ ២៤ឯអ្នកដែលភ្ជួររាល់ដើម្បីសាបព្រោះ[អ]
តើគេនៅតែភ្ជួរជានិច្ចឬ តើគេចេះតែបំបែកដី ហើយរាស់
ស្រែរបស់ខ្លួនជាដរាបឬ ២៥កាលណាគេបានពង្រាយដី
ហើយ នោះតើមិនព្រោះល្ងស ហើយបាចល្ងខ្មៅ[ក] ព្រម
ទាំងរោយស្រូវភោជ្ជសាលីទៅជាជួរៗ ហើយស្រូវឱក[ខ]នៅ
កន្លែងដែលបានដំរូវទុក និងស្រូវអេប៉ូត[គ]តាមក្បែរភ្លឺផងទេ
ឬអី ២៦ដ្បិតព្រះនៃគេទ្រង់បង្ហាត់បង្រៀន[ឃ]ឱ្យគេមានគំនិត
យល់ ហើយក៏បង្ហាញឱ្យចេះធ្វើ ២៧ពីព្រោះឯល្ងស[ង] នោះ
មិនត្រូវវាយដោយប្រដាប់មុតទេ[ច] ក៏មិនត្រូវឱ្យកង់រទេះកិន
ល្ងខ្មៅដែរ គឺត្រូវគោះល្ងសដោយរំពាត់[ឆ] ហើយល្ងខ្មៅ
ដោយដំបង ២៨ឯស្រូវសំរាប់ធ្វើនំបុ័ង នោះគេបញ្ជាន់
វិញ ពីព្រោះគេមិនចង់វាយប្រឡេះជាដរាបទេ គឺគេបញ្ជាន់
ដោយកង់រទេះ[ជ] ឬដោយសេះវិញ ២៩ដំរិះនេះក៏មកពីព្រះ
យេហូវ៉ានៃពលបរិវារ ដែលទ្រង់ប្រឹក្សា[ឈ]យ៉ាងអស្ចារ្យ
ហើយមានប្រាជ្ញាយ៉ាងវិសេសផង[ញ]។

## វេទនាដល់ទីក្រុងស្តេចដាវីឌ

**២៩** ១វេទនា[ក]ដល់អើរាល គឺអើរាល[ខ] ជាទីក្រុង[គ]ដែល

**២៨:១៥** ឈ ពច ៩:៣៥ អស ២៩:១៥ យរ ២៣:២៤ ញ អស ៩:១៥ **២៨:១៦** ដ អស ១៤:៣២ ឋ ទដ ១១៨:២២ អស ៨:១៤–១៥ ដយ ២:៣៤–៣៥,៤៥ សក ១២:៣ កច ៤:១១ ឌ យរ ៥១:២៦ ១កថ ៣:១១ ២ថន ២:១៩ ឍ អស ២៩:២២ ៤៥:១៧ ៥០:៧ ៥៤:៤ រម ៩:៣៣ ១០:១១ ១ពត ២:៦ **២៨:១៧** ណ ទដ ១១:៧ អស ៥:១៦ ត ២ពវ ២១:១៣ ថ យស ១០:១១ ទ អស ៨:៧ **២៨:១៨** ធ អស ៧:៧ ន ខ.១៥ ប អស ៥:៥ ៦៣:១៨ ដយ ៨:១៣ **២៨:១៩** ផ ២ពវ ២៤:២ ព ទដ ៥:៣ ភ យប ១៨:១១ **២៨:២០** ម អស ៥៩:៦ **២៨:២១** យ លប ៣៨:២៩ ១របា ១៤:១១ រ យស ៩:៣ ល អស ១០:១២

៦៥:៧ លក ១៩:៤១–៤៤ **២៨:២២** វ ២របា ៣៦:១៦ យរ ២៩:១៨ បទ ២:១៥ សផ ២:១៥ ស អស ១០:២២ ហ អស ១០:២៣ **២៨:២៣** ឡ អស ៣២:៩ **២៨:២៤** អ សស ៣:២ **២៨:២៥** ក មថ ២៣:២៣ ខ នក ៩:៣១ គ នក ៩:៣២ អគ ៤:៩ **២៨:២៦** ឃ ទដ ៩៤:១០ **២៨:២៧** ង អស ២១:១០ ច យប ៤១:៣០ ឆ អស ១០:៥ **២៨:២៨** ជ អស ២១:១០ **២៨:២៩** ឈ អស ៩:៦ ញ ទដ ៩២:៥ រម ១១:៣៣ **២៩:១** ក អស ២២:១២–១៣ ២៨:១ ខ ខ.២,៧ គ ២សយ ៥:៧

ជនលិចហៀរ (សូមមើល ៨:៧–៨ និងការពន្យល់) "អ្វីៗដែលឱ្យទុកទោស" គឺជាការផ្តាញពីព្រះ ។

**២៨:១៦** *ថ្ម១* ដូមជាព្រះយេហូវ៉ា (សូមមើល ៨:១៤ ១៧:១០ និងការពន្យល់) ។ *ថ្មទីជ្រុង* មើលការប្រៀបធៀបនិង "ថ្មជ្រុងយ៉ាងឯក "ក្នុងគម្ពីរ ទដ ១១៨:២២ (សូមើលការពន្យល់ផង) ។ ពាក្យថា *ដាក់យ៉ាងមាំមួន* សូមមើល ១កថ ៣:១១ ប្រៀបធៀប ១បត ២:៤–៨ និងការពន្យល់ ។

**២៨:១៧** *សេចក្តីយុត្តិធម៌ធ្វើជាខ្សែបន្ទាត់* នេះគឺជាខ្នាតគំរូមួយ និងការល្បងល ដែលព្រះយេហូវ៉ាបានធ្វើនិងយកមកអនុវត្ត គឺជាភាព "យុត្តិធម៌"និង" សេចក្តីសុចរិតរបស់ផងព្រះ"(សូមមើលកាប្រៀបធៀប ៣៤:១១ និងការពន្យល់) ។ ពាក្យថា *ព្យុះព្រឹល* គឺសូមមើល ខ.២ ៣០:៣០ ៣២:១៩ ។

**២៨:២០** *គ្រែខ្លីពេក . . . ភួយក៏តូចផង* គឺដូចជារាស្ត្រអ៊ីស្រាអែលដែលពុំបានត្រៀមទៅលើផ្នែកខាងចម្បាំងនិងខាងឯព្រលឹងវិញ្ញាណ ។

**២៨:២១** *ភ្នំពេរ៉ាស៊ីម* គឺជាទីតាំងមួយដែលព្រះបានបង្ហាញព្រះទ័យទាស់ប្រឆាំងនិងពួកស្រុកភីលីស្ទីន (សូមមើលការពន្យល់ ២សយ ៥:២០) ។ *ច្រកភ្នំគីបៀន* ក៏ជាទីកន្លែងដែលព្រះបានបញ្ជូនព្យុះព្រឹលដើម្បីបំផ្លាញដល់ពួកអាម៉ូរី (សូមមើល យស ១០:១០–១៣ និងការពន្យល់) ។ ពាក្យថា *ការយ៉ាងប្លែក . . . សំរេចកិច្ចការរបស់ទ្រង់គឺជាកិច្ចការយ៉ាងប្លែក* តែគ្រានេះព្រះអម្ចាស់បែរជាប្រឆាំងនឹងរាស្ត្រអ៊ីស្រាអែលវិញ ។

**២៨:២៣–២៩** គឺជាកំណាព្យប្រាជ្ញា (ក៏ជាកំណាព្យប្រៀបប្រដូច) ក្នុងកថាពីរវគ្គដែលបញ្ចប់ដោយ ខ ឬឃ្លានៃប្រាជ្ញាពីព្រះ ។ ក្នុងអត្ថបទព្រះគម្ពីរបង្ហាញពី "វាលស្រែ ឬចំការដំណាំ" គឺបានបញ្ជាក់(ក្នុង ខ.២៧–២៨) ក៏ប្រៀបទៅនិងការដាក់ទណ្ឌកម្មពីព្រះដល់រាស្ត្រអ៊ីស្រាអែល តាមរង្វាស់នៃពេលវេលាដូចជាកសិករផងដែរ ។ សូមមើល ២៧:១២ និងការពន្យល់ ។

**២៨:២៥** *ល្ងខ្មៅ* គឺជាប្រភេទតិណទេសសម្រាប់ធ្វើជាគ្រឿងសម្ល (មើល មថ ២៣:២៣ និងការពន្យល់) ។ *ស្រូវភោជ្ជ* គឺប្រភេទស្រូវមួយបែប (សូមមើលការពន្យល់ នក ៩:៣២) ។

**២៨:២៧** *វាយ* សូមមើល ១០:៥ និងការពន្យល់ ។

**២៨:២៩** *ប្រឹក្សាយ៉ាងអស្ចារ្យ* សូមមើល ៩:៦ និងការពន្យល់ ។

ដាវីឌបានគង់នៅ ចូរឱ្យគេធ្វើបុណ្យ[ឃ]ទាំងខួបៗ រាល់តែ
ឆ្នាំតទៅចុះ ២នោះអញនឹងធ្វើទុក្ខដល់អើរាល[ង] ហើយគេ
នឹងកើតមានសេចក្តីសោយសោក និងការយំទួញ[ច] ឯទីក្រុង
នឹងបានដូចជាជើងក្រានៃអាសនាដល់អញ[ឆ] ៣អញនឹង
បោះទ័ពឡោមព័ទ្ធឯង ព្រមទាំងដាក់ទាហានបង្ខាំងនៅ
ជុំវិញ[ជ] ហើយចាត់ចែងគ្រឿងចំបាំង[ឈ]ច្បាំងនឹងឯង ៤នោះ
ឯងនឹងត្រូវបន្ទាបចុះ ហើយនិយាយចេញពីដីមក សំដីឯង
នឹងឮខ្សាវៗ[ញ] មកពីធូលីដី[ដ] សំឡេងឯងនឹងចេញពីដីមកដូច
ជាសំឡេងរបស់គ្រូខាប[ឋ] គឺសំដីឯងនឹងឮខ្សឹបចេញពីដីមក
យ៉ាងនោះឯង[ឌ] ។

៥ប៉ុន្តែពួកខ្មាំងសត្រូវដ៏មានច្រើនក្រៃលែងរបស់ឯងនឹង
ដូចជាផង់ធូលីដី[ឍ] ហើយពួកគួរស្ញែងខ្លាច[ណ]ដ៏មានច្រើន
ក្រៃលែង គេនឹងដូចជាអង្កាមដែលកន្លងបាត់ទៅ[ត] អើការ
នោះនឹងកើតតមកភ្លាម១រំពេច[ថ]ផង ៦ព្រះយេហូវ៉ានៃពួក
ពលបរិវារទ្រង់នឹងធ្វើទោសដល់ទីក្រុង[ទ] ដោយផ្គរ[ធ]កក្រើក
ដី[ន] សូរគ្រាំគ្រេង ខ្យល់កួត ព្យុះសង្ឃរា[ប] និងអណ្តាតភ្លើង
ដែលឆេះបំផ្លាញ[ផ] ៧នោះពួកដ៏មានច្រើនក្រៃលែង ពីគ្រប់
ទាំងសាសន៍[ព] ដែលច្បាំងនឹងអើរាល[ភ] គឺអស់អ្នកដែលច្បាំង
នឹងទីក្រុង ហើយនិងបន្ទាយផង ជាពួកអ្នកធ្វើទុក្ខដល់ទីក្រុង
គេនឹងប្រៀបដូចជាសប្តិ[ម] គឺជាការជាក់ស្តែង នៅពេលយប់
ទេ ៨នោះនឹងបានដូចជាកាលមនុស្សឃ្លាន គេយល់សប្តិ
ឃើញថា ខ្លួនបានបរិភោគ តែលុះភ្ញាក់ឡើង[យ] នោះចិត្ត
នឹកឃ្លានវិញ ឬដូចជាកាលណាមនុស្សដែលស្រេក បាន
យល់សប្តិឃើញថា ខ្លួនកំពុងតែផឹក តែគេភ្ញាក់ឡើង
ហើយមើល គេល្ងើយ ហើយចិត្តនឹកស្រេកណាស់[រ] ឯពួកដ៏
មានច្រើនក្រៃលែងពីគ្រប់ទាំងសាសន៍ ដែលច្បាំងនឹងភ្នំ
ស៊ីយ៉ូន គេនឹងដូច្នោះដែរ[ល] ។

៩ចូរឱ្យអ្នករាល់គ្នានៅជាស្ងាក់ស្ទើរ ហើយភាំងធ្ងល់
ចុះ[វ] ចូរឱ្យបិទភ្នែក ហើយធ្វើជាមនុស្សខ្វាក់ទៅ[ស] គេ
ស្រវឹង[ហ] តែមិនមែនដោយស្រាទំពាំងបាយជូរទេ[ឡ] គេទ្រេត
ទ្រោតទៅ[អ] តែមិនមែនដោយគ្រឿងស្រវឹងឡើយ ១០ដ្បិត
ព្រះយេហូវ៉ាទ្រង់បានចាក់វិញ្ញាណ ដែលបណ្តាលឱ្យលក់
ស៊ប់[ក] មកលើអ្នករាល់គ្នា ក៏បានបិទភ្នែកអ្នករាល់គ្នា[ខ] ជាពួក
ហោរា[គ] ហើយបានគ្របភ្ជិតក្បាលអ្នករាល់គ្នា ជាពួកមើល
ឆុត[ឃ] ១១ការជាក់ស្តែង[ង]ទាំងអស់បានត្រឡប់ដូចជាពាក្យ
ក្នុងសៀវភៅ ដែលបិទត្រា[ច]ហើយ ដល់អ្នករាល់គ្នា ជា
សៀវភៅដែលគេជូនដល់ម្នាក់មានចំណេះ ដោយពាក្យថា
សូមអ្នកមើលសៀវភៅនេះទៅ តែអ្នកនោះឆ្លើយតបថា ខ្ញុំ
មើលមិនបានទេ ពីព្រោះបិទត្រាហើយ ១២រួចគេបញ្ជូន
ឱ្យដល់ម្នាក់ដែលគ្មានចំណេះ ដោយពាក្យថា សូមអ្នក
មើលសៀវភៅនេះ តែអ្នកនោះឆ្លើយតបមកវិញថា ខ្ញុំមិន
ចេះអក្សរទេ ។

១៣ព្រះអម្ចាស់ទ្រង់ក៏មានបន្ទូលថា ហេតុដោយព្រោះ
សាសន៍នេះ[ឆ]គេចូលមកជិតអញ ហើយគោរពប្រតិបត្តិដល់
អញ ដោយសំដីនឹងបបូរមាត់របស់គេ[ជ] តែបានដកចិត្តចេញ

**២៩:១** ឃ អស ១:១៤ **២៩:២** ង ខ.១ ច អស ៣:២៦ បទ ២:៥ ឆ អគ ៤៣:១៥ **២៩:៣** ជ លក ១៩:៤៣–៤៤ ឈ ២ពវ ២៥:១ **២៩:៤** ញ អស ៨:១៩ ដ អស ៤៧:១ ៥២:២ ឋ លវ ១៩:៣១ ឌ អស ២៦:១៦ **២៩:៥** ឍ ចទ ៩:២១ ទដ ៧៨:៣៩ ១០៣:១៥ អស ២:២២ ៣៧:២៧ ៤០:៦ ៥១:១២ ណ អស ១៣:១១ ត អស ១៧:១៣ ថ ទដ ៥៥:១៥ អស ១៧:១៤ ១ថន ៥:៣ **២៩:៦** ទ អស ២៦:២១ សក ១៤:១–៥ ធ នក ១៩:១៦ ន មថ ២៤:៧ មក ១៤:៨ លក ២១:១១ វវ ៦:១២ ១១:១៩ ប ទដ ៥០:៣ ៥៥:៨ អស ២៨:១៥ ផ លវ ១០:២ ទដ ៨៣:១៣–១៥

**២៩:៧** ព មីក ៤:១១–១២ សក ១២:៩ ភ ខ.១ ម យប ២០:៨ **២៩:៨** យ ទដ ៧៣:២០ រ ខ.៥,៧ អស ៤១:១១,១៥ យរ ៣០:១៦ សក ១២:៣ ល អស ១៧:១២–១៤ ៥៤:១៧ **២៩:៩** វ ខ.១៤ យរ ៤:៩ ហព ១:៥ ស អស ៦:១០ ហ អស ៥១:១៧ ៦៣:៦ យរ ១៣:១៣ ២៥:២៧ ឡ លវ ១០:៩ អស ២៨:១ ៥១:២១–២២ អ ទដ ៦០:៣ អស ៣:១២ **២៩:១០** ក ពច ៤:២១ យហ ១:៥ ខ ទដ ៦៩:២៣ អស ៦:៩–១០ ៤៤:១៨ រម ១១:៨ ២ថន ២:៩–១១ គ មីក ៣:៦ ឃ ១សយ ៩:៩ **២៩:១១** ង អស ២៨:៧ ច អស ៨:១៦ ដយ ៨:២៦ ១២:៩ មថ ១៣:១១ វវ ៥:១–២ **២៩:១៣** ឆ យរ ១៤:១១ ហក ១:២ ២:១៤ ជ ទដ ៥០:១៦

**២៩:១–២,៧** *អើរាល* គឺដូចជាក្រុងយេរូសាឡិម (ពាក្យថាអើរាលមានន័យថា"ទីក្រុងរបស់ព្រះ") ។ ការមានចម្បាំងនិងការបង់ឈាម និងបំប្រែទីក្រុងក្លាយជា"បេះដូងនៃអាសនាយ៉ាងពិតប្រាកដ" ។

**២៩:១** *វេទនាដល់* សូមមើលការពន្យល់ ២៨:១ ។ ពាក្យថា *ជាទីក្រុងដែលដាវីឌបានគង់នៅ* មើល ២សយ ៥:៦–៩ និងការពន្យល់,ធៀបនឹង អស ២២:៩ ។ *ធ្វើបុណ្យទាំងខួបៗ* មើល ១:១៣–១៤ និងការពន្យល់ ១:១៤ ។

**២៩:៤** *ខ្សឹប* គឺគេប្រើដូចជាពួកគ្រូខាប់ ឬគ្រូគាថា មើលក្នុង ៨:១៩ ។ ក៏ដូចជាពួកយូដាបានប្រើឬនិយាយដែលទាក់ទងនិងអ្នកដែលស្លាប់ (ដី . . . ធូលី . . . ផែនដី) ។

**២៩:៥–៨** ពេលវេលារបស់ព្រះ គឺចំពោះជាតិសាសន៍ទាំងឡាយដែលបំផ្លាញក្រុងយេរូសាឡិម គឺទ្រង់ត្រូវបំផ្លាញគេផងដែរ (មើល ១០:៥–១៩ ២៧:១ ធៀបនឹង លប ១២:២–៣ និងការពន្យល់) ភាពមហន្តរាយភ្លាមៗនៃពួកពលទ័ពដែលស្រដៀងទៅនិងពួកទ័ពអាសស៊ើរផងដែរ ។ ជាពិសេសក្នុងឆ្នាំ ៧០១ មុន គ.ស ។ (សូមមើល ១០:១៦ និងការពន្យល់) ។

**២៩:៥** *អង្កាម* សូមមើល ១៧:១៣ ទដ ១:៤ និងការពន្យល់ ។

**២៩:៦** *ដោយផ្គរកក្រើកដី សូរគ្រាំគ្រេងខ្យល់កួចព្យុះសង្ឃឹម និងអណ្តាតភ្លើងដែលឆេះបំផ្លាញ* ដូចជានៅក្នុង ពច ៥:៤–៥ ទដ ១៨:៧–១៥ ១៨:៧–១៥ ហប ៣:៣–៧ ក៏សូមមើលការពន្យល់ ។

**២៩:៩–១៤** លោកអេសាយ បាននិយាយប្រឆាំងស្ថានភាពផ្នែកខាងព្រលឹងវិញ្ញាណរបស់រាស្ត្រអ៊ីស្រាអែល និងការប្រមានខ្លះៗដោយការជំនុំជម្រះរបស់ព្រះនិងមកដល់ឆាប់ៗជាកំហិត ។

**២៩:៩** *ឱ្យបិទភ្នែក . . . ស្រវឹង* គឺសំដៅទៅលើភាពស្រវឹងខាងឯព្រលឹងវិញ្ញាណ (មើល ៦:១០ និងការពន្យល់ ហើយធៀបនឹង ២៨:១,៧ និងការពន្យល់) ។

**២៩:១០** គឺជាសេចក្តីសម្រងយកចេញពីគម្ពីរ រម ១១:៨ (មើលការពន្យល់នៅទីនោះ) ។ ពាក្យថា *ពួកមើលឆុត* មើល ១សយ ៩:៩ និងការពន្យល់ ២ពវ ១៧:១៣ ។

**២៩:១៣** គឺជាសេចក្តីដកស្រង់ចេញពីព្រះបន្ទូលរបស់ព្រះយេស៊ូវ ដែល

ទៅឆ្ងាយពីអញ[ឈ] ហើយការដែលគេកោតខ្លាចដល់អញ
គ្រាន់តែជាបង្គាប់របស់មនុស្ស ដែលបង្រៀនគេប៉ុណ្ណោះ[ញ]
១៤ហេតុនោះ មើល អញនឹងធ្វើការ១យ៉ាងអស្ចារ្យ នៅ
កណ្ដាលសាសន៍នេះទៀត ជាការយ៉ាងអស្ចារ្យ ហើយ
ចំឡែក[ដ] នោះប្រាជ្ញានៃពួកអ្នកប្រាជ្ញ[ឋ]របស់គេនឹងត្រូវ
សាបសូន្យទៅ ហើយយោបល់នៃពួកវាងវៃរបស់គេនឹង
ត្រូវបិទបាំងដែរ[ឌ]។
១៥វេទនាដល់ពួកអ្នកលាក់គំនិតរបស់ខ្លួនពីព្រះយេហូវ៉ា
ហើយដែលធ្វើការនៅក្នុងទីកំបាំង[ឍ] ដោយថា តើមានអ្នក
ណាបានឃើញ[ណ] តើមានអ្នកណាបានស្គាល់យើង[ត] ១៦យី អើ
អ្នករាល់គ្នាយល់ផ្ទុយអីម៉្លេះ តើនឹងរាប់ជាងស្មូនទុកដូចជាដី
ឥដ្ឋដែរឬ[ថ] បានជារបស់ដែលគេបានបង្កើតមកហើយ និង
ពោលពីអ្នកដែលបានបង្កើតខ្លួនថា គេមិនបានបង្កើត[ទ]អញ
ទេ ឬរបស់ដែលគេសូនធ្វើឡើង[ធ] និងពោលពីអ្នកដែល
បានសូនធ្វើនោះថា គេឥតមានដំរិះ យោបល់អ្វីឡើង
ដូច្នេះ[ន]។
១៧នៅតែបន្តិចទៀយប៉ុណ្ណោះទេ[ប] នោះព្រៃល្បាណូន[ផ]
នឹងត្រឡប់ទៅជាចំការដុះដាល[ព] ហើយចំការដុះដាលនឹង
បានរាប់ទុកដូចជាព្រៃវិញ[ភ] ១៨នៅគ្រានោះ[ម]មនុស្សត្រចៀក
ថ្លង់[យ]នឹងឮព្រះបន្ទូលក្នុងគម្ពីរ ហើយភ្នែករបស់មនុស្សខ្វាក់
នឹងមើលឃើញ[រ]ពីក្នុងសភាពជាងងឹត ហើយសូន្យសុង[ល]
១៩មនុស្សរាបសា[វ]នឹងមានសេចក្ដីអំណរចំរើនឡើង ក្នុង
ព្រះយេហូវ៉ា ហើយពួកអ្នកក្រីក្រ[ស]ក្នុងបណ្ដាមនុស្ស គេនឹង
រីករាយដោយសារព្រះដ៏បរិសុទ្ធ[ហ]នៃសាសន៍អ៊ីស្រាអែល
២០ពីព្រោះមនុស្សដែលគួរស្ញែងខ្លាច[ឡ]បានសូន្យបាត់ទៅ[អ]
ហើយក៏លែងមានមនុស្សចំអកមើលងាយ[ក] ឯពួកមនុស្ស
ដែលរកតែឱកាសនឹងធ្វើការទុច្ចរិត[ខ] គេនឹងត្រូវកាត់ចេញ
អស់រលីង ២១គឺជាពួកអ្នកដែលចាប់ពាក្យមនុស្ស ឱ្យគេមាន
ទោស ហើយដាក់អន្ទាក់ សំរាប់ចាប់ពួកមនុស្សដែលក្រើន
រំឮកនៅត្រង់ទ្វារក្រុង[គ] ព្រមទាំងបង្វែរមនុស្សសុចរិត
ចេញ[ឃ]ដោយរឿងដែលមិនជាហេតុផង[ង]។
២២ហេតុនោះ ព្រះយេហូវ៉ា ជាព្រះដែលប្រោសលោះ[ច]
អ័ប្រាហាំ[ឆ] ទ្រង់មានបន្ទូលពីដំណើរពួកវង្សយ៉ាកុបថា ឥឡូវ
នេះ ពួកយ៉ាកុបមិនត្រូវខ្មាសទៀតឡើយ[ជ] ក៏មិនត្រូវស្លុត

**២៩:១៣** ឈ ទដ ១១៩:៧០ អស ៥៨:២ យរ ១២:២ អគ ៣៣:៣១ ញ មថ ១៥:៨–៩ មក ៧:៦–៧ កល ២:២២ **២៩:១៤** ដ យប ១០:១៦ ឋ យប ៥:១៣ យរ ៨:៩ ៤៩:៧ ឌ អស ៦:៩,១០ ១កថ ១:១៩ **២៩:១៥** ឍ លប ៣:៨ អស ២៨:១៥ ណ យប ៨:៣ ទដ ១០:១១–១៣ ៩៤:៧ អស ៤៧:១០ ៥៧:១២ អគ ៨:១២ ៩:៩ ត ២ពវ ២១:១៦ យប ២២:១៣ **២៩:១៦** ថ យប ១០:៩ អស ១០:១៥ ទ លប ២:៧ ធ អស ៤៥:៩ ៦៤:៨ យរ ១៨:៦ រម ៩:២០–២១ ន យប ៩:១២ **២៩:១៧** ប អស ១០:២៥ ផ អស ២:១៣ ព ទដ ៨៤:៦ ១០៧:៣៣ ភ អស ៣២:១៥ **២៩:១៨** ម អស ២៨:៥ យ មក ៧:៣៧ រ ទដ ១៤៦:៨ អស ៣២:៣ មថ ១១:៥ លក ៧:២២ ល ទដ ១០៧:១៤ **២៩:១៩** វ ទដ ២៥:៩ ៣៧:១១ អស ៦១:១ មថ ៥:៥ ១១:២៩ ស ទដ ៧២:៤ អស ៣:១៥ ១៤:៣០ មថ ១១:៥ លក ៧:២២ យក ១:៩ ២:៥ ហ ខ.២៣ អស ១:៤ ៥:១៩ ១២:៦ ៣០:១១ **២៩:២០** ឡ អស ៩:៤ ១៣:១១ អ អស ៣៤:១២ ក ២របា ៣៦:១៦ អស ២៨:២២ ខ យប ១៥:៣៥ ទដ ៧:១៤ អស ៣២:៧ ៣៣:១១ ៥៩:៤ អគ ១១:២ មីក ២:១ ណាហ ១:១១ **២៩:២១** គ អម ៥:១០,១៥ ឃ សភ ២១:២៨ ង អស ៥:២៣ ៣២:៧ ហាព ១:៤ **២៩:២២** ច នក ៦:៦ ឆ លប ១៧:១៦ អស ៤១:៨ ៥១:២ ៦៣:១៦ ជ ទដ ២២:៥ ២៥:៣ អស ២៨:១៦ ៤៩:២៣ ៦១:៧ យអ ២:២៦ សផ ៣:១១

បង្ហាញពីភាពមានពុតត្បុតរបស់ពួកផារ៉ាស៊ី (សូមមើល មក ៧:៦ និងការពន្យល់) ។ *សាសន៍នេះ* គឺមិនមែនជាពាក្យថា "រាស្ត្ររបស់អញ" នោះទេ (មើលការប្រៀបធៀប ៦:៩ ៨:៦,១១–១២ ប្រៀបធៀប នក ១៧:៤ យរ ១៤:១០–១១ ហាក ១:២ និងការពន្យល់) ។

**២៩:១៤** ក្នុងខនេះជាសេចក្ដីដកស្រង់ចេញពីផ្នែកខ្លះក្នុងគម្ពីរ ១កថ ១:១៩ (សូមមើលការពន្យល់ខនេះ) ។ *១យ៉ាងអស្ចារ្យនៅកណ្ដាលសាសន៍ ជាការយ៉ាងអស្ចារ្យ* គឺដែលទ្រង់បានបង្ហាញភាពអស្ចារ្យនេះតាមរយៈគម្ពីរនិក្ខមនំ (សូមមើល នក ១៥:១១ ទដ ៧៨:១២–១៦ និងការពន្យល់ព្រះក៏នឹងបង្ហាញឱ្យពួកគេឃើញពីភាពយ៉ាងអស្ចារ្យនៅថ្ងៃជំនុំជម្រះ ។ *ប្រាជ្ញានៃពួកអ្នកប្រាជ្ញ . . . និងត្រូវវិនាសសូន្យទៅ* មើលការប្រៀបធៀប ៤៤:២៥ យរ ៨:៩ ។

**២៩:១៥** *វេទនាដល់* គឺជាសេចក្ដីវេទនាថ្មីមួយដែលនិងត្រូវមកដល់ (មើលការពន្យល់ ២៨:១–៣៥:១០) ។ ពាក្យថា *គំនិតរបស់ខ្លួន* គឺជាពាក្យនៃបក្សសម្ព័ន្ធរវាងស្ដេចអេហាស និងស្ដេចស្រុកអេស៊ីព្ទ (មើល ៣០:១–២ និងការពន្យល់) ។ ពាក្យថា *តើមានអ្នកណាបានឃើញ* មើល ទដ ១០:១១ ។

**២៩:១៦** សូមមើល ៤៥:៩ ៦៤:៨ សូមមើលការពន្យល់ យរ ១៨:១–៦ ។ ខនេះគឺយកចេញពីរ (រម ៩:២០ ឬ រម ៩:២០–២១) ។ សូមប្រៀបធៀបការដែលទ្រង់បានបង្កើតអ័ដាម ក្នុង លប ២:៧ (ក៏សូមមើលការពន្យល់ផងដែរ) ប្រៀបធៀប អស ១០:១៥ ទដ ១៣៩ ។

**២៩:១៧–២៤** ក្នុងខទាំងនេះបង្ហាញ ពីការប្រែប្រួលយ៉ាងរហ័សចំពោះដំណើររឿងក្នុងគ្រានោះដែលសំដែងការអស្ចារ្យ ពីការប្រោសលោះដូចជានៅក្នុង ២៨:៥–៨ ។

**២៩:១៧** *ព្រៃល្បាណូន* គឺអាចជានិមិត្តសញ្ញាឱ្យពួកស្រុកអាសស៊ើរ (មើល ១០:៣៤) ។ ដើមឈើខ្ពស់ទាបក្នុងព្រៃល្បាណូនគឺមានសណ្ឋានមិនស្មើគ្នា ។ (មើល ២:១៣ និងការពន្យល់) ដូច្នេះទីវាលដែលមានដីជាតិក៏ប្រែក្លាយជាតំណាងឱ្យទីរាបដែលមានព្រៃវិញ (មើល ៣២:១៥ និងការពន្យល់) ។

**២៩:១៨** *នៅគ្រានោះ* មើលការពន្យល់ ១០:២០ ២៧ ២៦:១ ។ គឺតាំងពីសម័យមុនពីពេលដែលព្រះបានបំផ្លាញពួកអាសស៊ើរ ក៏ទ្រង់តាំងឱ្យមានរាស្ត្រអ៊ីស្រាអែលឡើងវិញ ។ *ថ្លង់នឹងឮ . . . មនុស្សខ្វាក់នឹងមើលឃើញ* គឺជាលក្ខណៈផ្ទុយនិង ៦:៩ ដែលមានទំនាក់ទំនងនិងយុគសម័យព្រះមែស៊ី ។ សូមមើលក្នុង ៣៥:៥ ។

**២៩:២០** សូមមើល ខ.២១ ក៏ប្រៀបធៀប ២៨:១៤,២២ ។

**២៩:២១** សូមមើល ១:១៧ ៩:១៧ និងការពន្យល់ក៏សូមមើល ១០:២ អម ៥០:១០,១២,២៤ និងការពន្យល់ ។

**២៩:២២** *ប្រោសលោះ* ពាក្យនេះគឺចង់បង្ហាញកាលពីព្រះបានលោះរាស្ត្រអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ (សូមមើល នក ៦:៦ និងការពន្យល់ ១៥:១៣) ។ សូមប្រៀបធៀប ៤៣:១,៣ ។ តែលោកអ័ប្រាហាំក៏មានការចាកចេញដំណើរពីពិភពសាសន៍ដទៃ (សូមមើល លប ១២:១ យស ២៤:២–៣,១៤–១៥ និងការពន្យល់) ។ *ខ្មាសទៀតឡើយ* ប្រៀបធៀប ៤៥:១៧ ៥០:៧ ៥៤:៤ ។

ស្លាំងទៀតដែរ[ឈ] ២៣តែកាលកូនចៅ[ញ]គេបានឃើញការ
ដែលដៃ[ដ]អញនឹងធ្វើនៅកណ្ដាលពួកគេ នោះគេនឹងរាប់
ឈ្មោះអញជាបរិសុទ្ធ[ឋ] អើ ក៏នឹងរាប់ព្រះដ៏បរិសុទ្ធនៃ
យ៉ាកុប ទុកជាទីបរិសុទ្ធដែរ[ឌ] ព្រមទាំងកោតខ្លាចដល់ព្រះ
នៃសាសន៍អ៊ីស្រាអែលផង ២៤ឯពួកអ្នកដែលប្រព្រឹត្តខុស[ឍ]
ខាងវិញ្ញាណ គេនឹងមានយោបល់វិញ[ណ] ហើយមនុស្សដែល
រទូរទាំនឹងទទួលសេចក្ដីប្រៀនប្រដៅ[ត]។

## សេចក្ដីវេទនាដល់សាសន៍ដែលរឹងចចេស

**៣០** ១ព្រះយេហូវ៉ាមានបន្ទូលថា វេទនា[ក]ដល់ពួកកូនចៅ
ដែលរឹងចចេស[ខ] ជាពួកអ្នកប្រឹក្សាគ្នា តែមិនមែននឹងអញ
ហើយតាំងសញ្ញា[គ] តែមិនមែនតាមវិញ្ញាណរបស់អញទេ
គឺជាការដែលបន្ថែមអំពើបាបទៅលើបាបរបស់គេទៀត
២គេរៀបចំដំណើរនឹងចុះទៅឯស្រុកអេស៊ីព្ទ[ឃ]ឥតសួរផ្ទាល់
មាត់[ង]នឹងអញឡើយ គេគិតចំរើនកំឡាំងដោយពឹងដល់
កំឡាំងផារ៉ោន[ច] ហើយនឹងជ្រកនៅក្រោមម្លប់នៃស្រុក
អេស៊ីព្ទ[ឆ] ៣ដូច្នេះ កំឡាំងរបស់ផារ៉ោននឹងបានជាសេចក្ដី
ខ្មាសដល់ឯងរាល់គ្នាវិញ ហើយការជ្រកកោនក្រោមម្លប់[ជ]
ស្រុកអេស៊ីព្ទ និងបានជាសេចក្ដីវិលវល់ដល់ឯងដែរ[ឈ] ៤ដ្បិត
ពួកចៅ ហ្វាយរបស់គេសុទ្ធតែនៅក្រុងសូអាន[ញ] ហើយឯ
ពួករាជទូត របស់គេក៏បានមកដល់ក្រុងហានេសដែរ
៥គេនឹងមាន សេចក្ដីខ្មាសទាំងអស់គ្នា ពីដំណើរសាសន៍[ដ]
នោះដែល មិនអាចនឹងមានប្រយោជន៍[ឋ]ដល់គេឡើយ
ជាសាសន៍ដែល មិនមែនជាជំនួយ[ឌ] ឬជាប្រយោជន៍សោះ
គឺនាំឱ្យមានសេចក្ដីខ្មាស និងសេចក្ដីដំនៀលវិញ[ឍ]។
៦នេះជាសេចក្ដីទំនាយយ៉ាងធ្ងន់[ណ] ពីពួកសត្វនៅស្រុក
ត្បូង[ត] គេផ្ទុកទ្រព្យរបស់គេនៅលើខ្នងលាស្ទាវ[ថ] ហើយផ្ទុក
សម្បត្តិ[ទ]របស់គេ នៅលើបូកសត្វអូដ្ឋ ដឹកនាំកាត់ស្រុក
ដែលមានសេចក្ដីលំបាក និងសេចក្ដីថប់ព្រួយ[ធ] ជាទីមាន
សិង្ហញី សិង្ហឈ្មោល[ន] ពស់វែក និងពស់ភ្លើងហោះ[ប] ដើម្បី
ទៅឯសាសន៍មួយ ដែលនឹងគ្មានប្រយោជន៍ដល់គេសោះ
៧ពីព្រោះសាសន៍អេស៊ីព្ទគេជួយជាឥតអំពើ ហើយជាឥត
ប្រយោជន៍ទទេ[ផ] ហេតុនោះបានជាអញបានហៅគេថា
រ៉ាហាប[ព] ជាអ្នកដែលអង្គុយនៅតែស្ងៀម ។
៨ចូរទៅឥឡូវ ឧចារិកសេចក្ដីនេះចុះនៅនឹងបន្ទះថ្ម[ភ]

**២៩:២២** ឈ យរ ៣០:៦,១០ យអ ២:៦,២១ ណហ ២:១០
**២៩:២៣** ញ អស ៤៩:២០–២៦ ៥៣:១០ ៥៤:១–៣ ដ ទដ ៨:៦ អស ១៩:២៥
**២៩:២៣** ឋ មថ ៦:៩ ឌ ខ.១៩ អស ៥:១៩
**២៩:២៤** ឍ ទដ ៩៥:១០ សភ ១២:៨ អស ២៨:៧ ហព ៥:២ ណ អស ១:៣ ៣២:៤ ៤១:២០ ៦០:១៦ ត អស ៣០:២១ ៤២:១៦
**៣០:១** ក អស ២៨:១ ខ ចទ ២១:១៨ អស ១:២ គ ២ពវ ១៧:៤ អស ៨:១២
**៣០:២** ឃ ២ពវ ២៥:២៦ អស ៣១:១ ៣៦:៦ យរ ២:១៨,៣៦ ៤២:១៤
អគ ១៧:១៥ ២៩:១៦ ង លប ២៥:២២ ជន ២៧:២១ ច អស ៣៦:៩ ឆ អស ៤:៦ **៣០:៣** ជ ពច ៩:៨–១៥ ឈ ខ.៥ ទដ ៤៤:១៣ អស ២០:៤–៥ ៣៦:៦ **៣០:៤** ញ ជន ១៣:២២ **៣០:៥** ដ ខ.៧ អស ២០:៥ ៣១:១ ៣៦:៦ ឋ ២ពវ ១៨:២១ ឌ ទដ ១០៨:១២ យរ ៣៧:៣–៥ ឍ ខ.៣ ២ពវ ១៨:២១ អគ ១៧:១៥ **៣០:៦** ណ អស ១៣:១ ត ពច ១:៩ ថ លប ៤២:២៦ ១សយ ២៥:១៨ ទ អស ១៥:៧ ធ នក ១:១៣ ៥:១០,២១ អស ៥:៣០ ៨:២២ យរ ១១:៤ ន អស ៥:២៩ ៣៥:៩ ប ចទ ៨:១៥ **៣០:៧** ផ ២ពវ ១៨:២១ យរ ២:៣៦ ព យប ៩:១៣ **៣០:៨** ភ ចទ ២៧:៨

**២៩:២៣** *កូនចៅគេបានឃើញ* សូមមើលការប្រៀបធៀប ៤៩:២០–២១ ៥៤:១–២ និងការពន្យល់ ។ ការដែលព្រះបានបង្កើតឱ្យមានឡើងវិញ គឺទ្រង់បានដោះពីការត្រូវជម្លៀសព្រាត់ មើល ៥៣:១០ និងការពន្យល់ ។ *កូនចៅគេបានឃើញការដែលដៃអញនឹងធ្វើ* សូមមើល ៤៥:១១ (ប្រៀបធៀប អភ ២:១០ និងការពន្យល់) ។ *គេនឹងរាប់ឈ្មោះអញជាបរិសុទ្ធ . . . ព្រមទាំងកោត* សូមមើល ៨:១៣ នេះជាការគោរពរបស់លោកអេសាយចំពោះព្រះយេហូវ៉ា ។ *ព្រះដ៏បរិសុទ្ធនៃយ៉ាកុប* សូមមើលការប្រៀបធៀប ខ.១៩ ក៏សូមមើលការពន្យល់ ១:៤ ។

**២៩:២៤** *ប្រព្រឹត្តខុសខាងវិញ្ញាណ* មើល ១៩:១៤ គឺគេនឹងកើនឡើងខាងឯគំនិតលោកិយវិញ សូមមើល ១:៣ និងការពន្យល់ ។

**៣០:១** *វេទនា* សូមមើលការពន្យល់ ២៨:១–៣៥:១០ និង ១:២ ។ ពាក្យថា *ពួកអ្នកប្រឹក្សាគ្នាតែមិនមែនអញ* សូមមើល ២៩:១៥ និងការពន្យល់ ។ គឺជាការដើរមិនតាមព្រះវិញ្ញាណបរិសុទ្ធបន្ទាប់ពីស្ដេចសាបាកូប្រែក្លាយជាក្រុមស្ដេចផារ៉ោនគឺក្នុងឆ្នាំ ៧១៥ មុន គ.ស ដែលជាតិសាសន៍តូចមួយនៅក្នុងស្រុកអើរ៉ាម (ឬស្រុកស៊ីរី) និងស្រុកកាណាន ដែលស្រែករកជំនួយដើម្បីប្រឆាំងវាយតបទៅនឹងពួកស្រុកអាសស៊ើរ ។ ចំណែកឯពួកយូដាក៏បានចូលរួមនិងពួកគេដែរ (សូមមើល ២០:៥ និងការពន្យល់) ។ *តាមវិញ្ញាណរបស់អញទេ* គឺក៏បានសំដែងតាមរយៈពួកហោរា ។

**៣០:២** ស្ដេចហេសេគាក៏ប្រព្រឹត្តបែបនេះដែរ (មើល ២ពវ ១៨:២១ និងការពន្យល់) ។ ពាក្យថា *ម្លប់* គឺជាពាក្យប្រៀបប្រដូចដល់ព្រះមហាក្សត្រដែលបានផ្ដល់ជារបាំងការពារទីជម្រក (មើល ពច ៩:១៥ បទ ៤:២០ និងការពន្យល់) ។ គេគួរតែជ្រើសព្រះយេហូវ៉ាជាទីពឹងជ្រករបស់គេ ជាពិសេសដូចជារាស្ត្រអ៊ីស្រាអែលដែលមានព្រះយេហូវ៉ាជាទីពឹងជ្រក"ជាម្លប់" (សូមមើលការប្រៀបធៀប ៤៩:២ ៥១:១៦ មើល ទដ ៩១:១ ១២១:៥ និងការពន្យល់) ។

**៣០:៤** *ក្រុងសូអាន* ជាក្រុងមួយដែលសាសន៍អ៊ីស្រាអែលធ្លាប់ជាប់ជាឈ្លើយនោះ សូមមើល ១៩:១១ និងការពន្យល់ ។ *ក្រុងហានេស* ក្រុងនេះអាចជាទីក្រុងនៅក្នុងតំបន់ទន្លេធំ ដែលជាប់ទៅនិងក្រុងសូអាន ។

**៣០:៦** *សេចក្ដីទំនាយ* មើល ១៣:១ និងការពន្យល់។ *ស្រុកត្បូង* គឺជាតំបន់ដីស្ងួតស្ថិតនៅភូមិភាគខាងត្បូងនៃទឹកដីបរិសុទ្ធ (មើល លប ១២:៩ និងការពន្យល់ ធៀបនឹង ពច ១:៩) ។ *មានសេចក្ដីលំបាក នឹងសេចក្ដីថប់ព្រួយ* គឺដោយពួកគេធ្វើដំណើរវែងឆ្ងាយ ហើយពួកគេប្រើផ្លូវពីខាងក្រោយវិញ ព្រោះផ្លូវពីខាងមុខជាផ្លូវសំខាន់បានពួកអាសស៊ើរកាន់កាប់ (សូមមើល ចទ ៨:១៥ ពច ៥:៦ និងការពន្យល់។ *ពស់ភ្លើងហោះ* សូមមើល ១៤:២៩ ។

**៣០:៧** *រ៉ាហាប* គឺឈ្មោះដែលមានន័យថាសត្វចំលែកនៅសមុទ្រ ដែលជាភាពអរូបិយ ហើយនៅទីនោះជាឈ្មោះតំណាងឱ្យស្រុកអេស៊ីព្ទ ។ ហើយឈ្មោះវាផ្ទាល់មួយទៀត គឺមានន័យថា"ព្យុះ" ក៏មានឈ្មោះមួយទៀតថា "នាគក្ងិកក្ងក់" សូមមើល ២៧:១ "សត្វសំបើម" និងមើលការពន្យល់ ។

**៣០:៨** *ឱ្យចារិកសេចក្ដីនេះ* គឺវាជាឈ្មោះរបស់ "រ៉ាហាបដែលជាតំណាងភាពនឹងថ្កល់មិនកំរើក" ។

ហើយកត់ទុកក្នុងសៀវភៅទៅ[ម] ដើម្បីនឹងទុកសំរាប់ពេល
ទៅមុខជារៀងរាបដរាប[យ] ៩ដ្បិតជនជាតិនេះគេរឹង
ចចេស[រ] ជាពួកកូនចៅភូតកុហក[ល] គឺជាកូនចៅ ដែលមិន
ព្រមផ្ទង់ចិត្តស្តាប់ក្រិត្យវិន័យរបស់ព្រះយេហូវ៉ាទេ[វ] ១០គេ
ប្រាប់ដល់ពួកមើលឆុតថា[ស] កុំឱ្យមើលឡើយ[ហ] ហើយដល់
ពួកហោរាថា កុំឱ្យទាយពីសេចក្តីទៀងត្រង់ ឱ្យយើងស្តាប់ឱ្យ
សោះ គឺត្រូវនិយាយពីសេចក្តីស្រួលបួលវិញ[ឡ] ត្រូវទាយជា
សេចក្តីភូតភរចុះ[អ] ១១ចូរលែងតាមផ្លូវនេះ[ក] ហើយបែរ
ចេញពីផ្លូវច្រកនេះទៅ ឱ្យបំបាត់ព្រះដ៏បរិសុទ្ធ[ខ]នៃសាសន៍
អ៊ីស្រាអែលពីមុខ[គ]យើងចេញ ១២ហេតុនោះ ព្រះដ៏បរិសុទ្ធ[ឃ]
នៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលថា ដោយព្រោះឯង
រាល់គ្នាស្អប់ខ្ពើមចំពោះពាក្យនេះ[ង] ហើយទុកចិត្តនឹងការ
ឆបោក[ច] និងការទទឹងទទែង ព្រមទាំងផ្អែកខ្លួនទៅលើការ
ទាំងនោះ ១៣បានជាអំពើទុច្ចរិតនេះ នឹងបានដូចជាកំផែង
បាក់បែក[ឆ] ដែលហៀបនឹងរលំដល់ឯងរាល់គ្នា ជាកន្លែង
ទ្រេតក្នុងកំផែងយ៉ាងខ្ពស់ ដែលស្រាប់តែបាក់ចុះ[ជ]មកភ្លាម
១រំពេច[ឈ] ១៤ហើយទ្រង់នឹងបំបែកទៅ ដូចជាគេបំបែក
ឆ្នាំង[ញ]នៃជាងស្មូន គឺនឹងបំបែកឱ្យខ្ទេចខ្ទី ឥតប្រណីឡើយ
ទាល់តែរកបំណែកណាមួយ ល្មមនឹងដាក់រងើកភ្លើងពី
ជើងក្រាន ឬនឹងដួសយកទឹកពីពាងមិនបានផង ។
១៥ដ្បិតព្រះអម្ចាស់[ដ]យេហូវ៉ា ជាព្រះដ៏បរិសុទ្ធ[ឋ]នៃពួក
អ៊ីស្រាអែល ទ្រង់មានបន្ទូលថា ឯងរាល់គ្នានឹងបាន
សង្គ្រោះដោយវិលមកវិញ ហើយផ្អាកសំរាក[ឌ] ឯងរាល់គ្នា
នឹងមានកំឡាំងដោយនៅតែស្ងៀម ហើយមានសេចក្តីទុក
ចិត្ត[ឍ] តែឯងរាល់គ្នាមិនចូលចិត្តទេ[ណ] ១៦គឺបានសបឆ្លើយថា
ទេ យើងនឹងជិះសេះរត់[ត]ទៅ[ថ] ដូច្នេះ ឯងរាល់គ្នានឹងត្រូវរត់
ទៅមែន ហើយឯងថា យើងនឹងជិះសត្វលឿនដែរ ដូច្នេះ
គេដែលដេញតាមឯងនឹងបានលឿនដូចគ្នា ១៧មួយពាន់
នាក់នឹងរត់ទៅ ដោយមានតែម្នាក់កំហែងគេ ហើយបើ
មាន៥[ទ]នាក់កំហែង នោះឯងរាល់គ្នានឹងរត់ទៅ[ធ] ទាល់តែ
សំណល់នៃឯង[ន] បានដូចជាបង្គោលមួយ ដោតនៅលើភ្នំធំ
ហើយដូចជាទង់[ប]នៅលើភ្នំតូចប៉ុណ្ណោះ ។
១៨ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាទ្រង់រង់ចាំ
ឱកាស[ផ] នឹងផ្តល់ព្រះគុណដល់ឯងរាល់គ្នាដែរ ហើយទោះ
បើយ៉ាងនោះក៏ដោយ គង់តែទ្រង់នឹងចាំឯងលើកដំកើង
ទ្រង់ឡើង ដើម្បីឱ្យទ្រង់មានសេចក្តីអាណិតមេត្តាដល់ឯង[ព]
ពីព្រោះព្រះយេហូវ៉ាទ្រង់ជាព្រះដ៏ប្រកបដោយយុត្តិធម៌[ភ] ។
មានពរហើយ អស់អ្នកណាដែលរង់ចាំទ្រង់[ម] ១៩អើ ឱ
ជនជាតិនៅក្រុងស៊ីយ៉ូន ជាពួកដែលអាស្រ័យនៅក្រុង
យេរូសាឡិមអើយ ឯងនឹងមិនត្រូវយំទៀតឡើយ[យ] ទ្រង់នឹង
មានព្រះគុណចំពោះឯង ដោយឮសំឡេងឯងស្រែក កាល
ណា[រ]ទ្រង់ឮ នោះទ្រង់នឹងឆ្លើយ[ល]មកឯង ២០ហើយទោះបើ

**៣០:៨** ម នក ១៧:១៤ អស ៨:១ យ យរ ២៥:១៣ ៣០:២ ៣៦:២៨ ហព ២:២ យ យស ២៤:២៦–២៧
**៣០:៩** រ ទដ ៧៨:៨ អស ១:២ អគ ២:៦ ល អស ២៨:១៥ ៥៩:៣–៤ វ អស ១:១០
**៣០:១០** ស ១សយ ៩:៩ ហ យរ ១១:២១ ៣២:៣ អម ៧:១៣ ឡ ១ពវ ២២:៨ យរ ៤:១០ អ យរ ២៣:២៦ ២៥:៩ ២៦:៩ ៣៦:២៩ អគ ១៣:៧ រម ១៦:១៨ ២ថន ៤:៣–៤
**៣០:១១** ក ខ.២១ សភ ៣:៦ អស ៣៥:៨–៩ ៤៨:១៧ ខ អស ២៩:១៩ គ យប ២១:១៤
**៣០:១២** ឃ ខ.១៥ អស ៥:១៩ ៣១:១ ង អស ៥:២៤ ច ទដ ១០:៧ ១២:៥ អស ៥:៧
**៣០:១៣** ឆ នហ ២:១៧ ទដ ៦២:៣ ៨០:១២ ជ ១ពវ ២០:៣០ ឈ អស ១៧:១៤ **៣០:១៤** ញ ទដ ២:៩ **៣០:១៥** ដ យរ ៧:២០ ៣២:១៧ អគ ៣:១១ ឋ ខ.១២ ឌ នក ១៤:១៤ យស ១:១៣ ឍ ២របា ២០:១២ អស ណ អស ៨:៦ ៤២:២៤ ៥៧:១៧ **៣០:១៦** ត យរ ៤៦:៦ ថ ចទ ១៧:១៦ ១ពវ ១០:២៨–២៩ ទដ ២០:៧ អស ៣១:១,៣ ៣៦:៨ **៣០:១៧** ទ លវ ២៦:៨ ធ លវ ២៦:៣៦ ចទ ២៨:២៥ ២ពវ ៧:៧ ន អស ១:៨ ប ទដ ២០:៥ **៣០:១៨** ផ លប ៤៣:៣១ អស ៤២:១៤ ២ពត ៣:៩,១៥ ព ទដ ៧៨:៣៨ អស ៤៨:៩ យហ ៣:១០ ភ ទដ ១១:៧ អស ៥:១៦ ម ទដ ២៧:១៤ អស ២៥:៩ ៣៣:២ ៤០:៣១ ៦៤:៤ បទ ៣:២៥ ដយ ១២:១២ **៣០:១៩** យ អស ២៥:៨ ៦០:២០ ៦១:៣ រ យប ២៤:១២ ល យប ២២:២៧ ទដ ៥០:១៥ ៨៦:៧ អស ៤១:១៧ ៥៨:៩ ៦៥:២៤ សក ១៣:៩ មថ ៧:៧–១១

**៣០:៩** *ជនជាតិនេះគេរឹងចចេស* មើល ខ.១ ក៏មើល ១:២ និងការពន្យល់ ។
**៣០:១០** *ពួកមើលឆុត* សូមមើល ១សយ ៩:៩ និងការពន្យល់២ពវ ១៧:១៣ ពាក្យថា *កុំឱ្យមើលឡើយ* សូមមើលការប្រៀបធៀប អម ២:១២ ៧:១៣ ,១៦ មីក ២:៦ ។ *គឺត្រូវនិយាយពីសេចក្តីស្រួលបួលវិញ* ដូចជាពួកហោរាក្លែងក្លាយធ្វើដូច្នេះដែរ (សូមមើល ១ពវ ២២:១៣ យរ ៦:១៤ ៨:១១ ២៣:១៦–១៧,២៦ ។ មីក ២:១១ ៣:៥,១១ និងការពន្យល់ ។
**៣០:១១–១២,១៥** *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើល ១:៤ និងការពន្យល់ ។
**៣០:១២** *ការឆបោក* ជាពិសេសនៅក្នុងគោលការណ៍ច្បាប់ក្នុងស្រុករបស់ពួកគេ (សូមមើល ១:១៥–១៧,២៣ ៥:៧ ២៩:២១ ៥៨:៣–៤ ៥៩:៣,៦–៨,១៣) ។ *ការទទឹងទទែង* គឺមានកើតឡើងក្នុងគោលការនៃពួកសាសន៍ដទៃរបស់ពួកគេ (សូមមើល ខ.១–២ ២៩:១៥) ។
**៣០:១៣** *កំផែងយ៉ាងខ្ពស់* ដូចជាការឆបោកនិងការទទឹងទទែង (សូមមើល ខ.១២) ។ ការធ្វើជា "កំផែង" គេសង់ឡើងគឺដើម្បីសុវត្ថិភាពរបស់គេនិងដើម្បីភាពសុខសាន្ត តែវាក៏ត្រូវបែកបាក់ជាចំណែកៗ ។
**៣០:១៥** មើល ២៦:៣ ។ *បានសង្គ្រោះដោយវិលមកវិញហើយផ្អាកសំរាក* នេះគឺជាផ្លូវពិតដើម្បីទទួលសេចក្តីសង្គ្រោះនិងបានសេចក្តីសុខសាន្ត ។
**៣០:១៦** *សេះ* សូមមើល ទដ ២០:៧–៨ និងការពន្យល់ ៣៣:១៧ សភ ២១:៣១ និងការពន្យល់ ។
**៣០:១៧** *មួយពាន់នាក់នឹងរតទៅ* គឺជាសេចក្តីសម្រេចពីបណ្តាសាតាមរយៈគម្ពីរ ចទ ៣២:៣០ ។ *ដូចជាបង្គោលមួយដោតនៅលើភ្នំធំ . . . ដូចជាទង់នៅលើភ្នំតូច* មើល ៥:២៦ និងការពន្យល់ (មើល ១:៨ និងការពន្យល់) ។
**៣០:១៨** *រង់ចាំឱកាសនឹងផ្តល់ព្រះគុណ* គឺបន្ទាប់ពីដាក់ទណ្ឌកម្មដល់រាស្ត្រអ៊ីស្រាអែល ពេលនោះព្រះយេហូវ៉ានៃពួកពលបរិវានិងផ្តល់ព្រះពរសាជាថ្មី (ប្រៀបធៀប ៤០:២ និងការពន្យល់) ។
**៣០:១៩** *មិនត្រូវយំទៀតឡើយ* សូមមើល ២៥:៨ និងការពន្យល់។ ការឆ្លើយតបរបស់ព្រះគឺមានលក្ខណៈស្រដៀងគ្នា ចំពោះចំការទំពាំងបាយជូរនៃ (រាស្ត្រអ៊ីស្រាអែល) មើលក្នុង ២៧:២–៦ និងការពន្យល់ ។
**៣០:២០** *សេចក្តីទំនាស់ទុកដូចជាអាហារ . . . សេចក្តីវិបជាប់ទុកជាទឹក* គឺជាអាហាររបស់អ្នកទោស (សូមមើល ១ពវ ២២:២៧) ។ ពាក្យថា "ពួកគ្រូ"

ដែលធ្វើបុណ្យរំលង[រ] ហើយនឹងមានសេចក្ដីរីករាយ[ល]ក្នុង
ចិត្ត ដូចជាវេលាដែលដើរផ្លុំខ្លុយ[វ]ទៅឯភ្នំ[ស]នៃព្រះយេហូវ៉ា
គឺទៅឯព្រះដ៏ជាថ្មដា[ហ]នៃសាសន៍អ៊ីស្រាអែល ៣០ ឯព្រះ
យេហូវ៉ាទ្រង់នឹងបន្លឺព្រះសូរសៀង ដ៏រុងរឿងឧត្តមរបស់
ទ្រង់ឱ្យឮ[ឡ] ហើយនឹងបង្ហាញព្រះពាហុ[អ]ដែលធ្វើទោស
ដោយសេចក្ដីក្នាញ់ក្នាញ់[ក]របស់សេចក្ដីខ្ញាល់ទ្រង់ នឹង
អណ្ដាតភ្លើង[ខ]ដ៏ឆេះបន្សុស ព្រមទាំងសន្ទុះខ្យល់ព្យុះសង្ឃ
រា[គ] និងដុំព្រឹលផង[ឃ] ៣១ ដ្បិតដោយសារព្រះសូរសៀងនៃ
ព្រះយេហូវ៉ា នោះសាសន៍អាសស៊ើរ[ង] នឹងស្រយុតចិត្ត
ទ្រង់នឹងវាយ[ច]គេដោយដំបងរបស់ទ្រង់ ៣២ ហើយគ្រប់ៗ
រយៈដំបង[ឆ] ដែលព្រះយេហូវ៉ាបានដំរូវឱ្យត្រូវវាយគេ នោះ
នឹងឮសូរក្រាប់[ជ] និងស៊ីងប្រគំឡើងជាដរាប ឯក្នុងគ្រប់ទាំង
ពេលតគ្នានោះ ទ្រង់នឹងច្បាំងនឹងគេ ដោយព្រះពាហុលើក
សំរេច[ឈ] ៣៣ ដ្បិតមានទីដុតខ្មោច[ញ]ត្រៀមទុក តាំងពីបូរាណ
មក អើ ទីនោះបានរៀបចំសំរាប់ស្ដេចនោះ ឯងជាទីយ៉ាង
ជ្រៅ ហើយធំទូលាយ មានឧសគរឡើងជាច្រើន ពេញ
ហើយដោយភ្លើង គឺអស្សាសៈ[ដ] នៃព្រះយេហូវ៉ា ដែលដូច
ជាជ្រោះស្ពាន់ធ័រ[ឋ]ហូរមកបង្កាត់ភ្លើងនោះ[ឌ]។

## វេទនាដល់ពួកអ្នកដែលពឹងដល់ស្រុកអេស៊ីព្ទ

**៣១** ១ វេទនា[ក]ដល់ពួកអ្នកដែលចុះទៅឯស្រុកអេស៊ីព្ទ[ខ]
ដើម្បីរកគេជួយ ព្រមទាំងពឹងដល់សេះ[គ] ហើយទុកចិត្តនឹង
រទេះចំបាំង[ឃ] ដោយព្រោះគេមានជាច្រើន ហើយនឹងពល
សេះផង ដោយព្រោះគេមានកំឡាំងណាស់ ឥតសង្ឃឹម
ដល់ព្រះដ៏បរិសុទ្ធ[ង]នៃសាសន៍អ៊ីស្រាអែល ឬស្វែងរកព្រះ
យេហូវ៉ាសោះ[ច] ២ ឯទ្រង់វិញ ទ្រង់ក៏មានប្រាជ្ញាដែរ[ឆ] ទ្រង់
នឹងនាំសេចក្ដីវេទនាមក[ជ] ហើយមិនព្រមដកព្រះបន្ទូលទ្រង់
វិញឡើយ[ឈ] គឺទ្រង់នឹងក្រោកឡើងទាស់នឹងពួកវង្សរបស់
អ្នកដែលប្រព្រឹត្តអាក្រក់[ញ] ហើយទាស់នឹងអស់អ្នកដែលចូល
ដៃជាមួយនឹងពួកប្រព្រឹត្តអំពើទុច្ចរិតនោះ ៣ រីឯពួកសាសន៍
អេស៊ីព្ទ[ដ] គេគ្រាន់តែជាមនុស្សប៉ុណ្ណោះ មិនមែនជាព្រះទេ[ឋ]
ហើយសេះ[ឌ]របស់គេគ្រាន់តែជាសាច់ឈាមដែរ មិនមែន
ជាវិញ្ញាណឡើយ ដូច្នេះ កាលណាព្រះយេហូវ៉ាទ្រង់លូក
សន្ធឹងព្រះហស្តទៅ[ឍ] នោះទោះទាំងអ្នកដែលជួយក៏នឹង
ចំពប់ ហើយអ្នកដែលគេជួយ[ណ] ក៏នឹងដួលដែរ គេនឹងត្រូវ
វិនាសទៅទាំងអស់គ្នា[ត]។
៤ ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំដូច្នេះថា ព្រះ
យេហូវ៉ានៃពួកពលបរិវា ទ្រង់នឹងយាងចុះមក[ថ]ច្បាំងលើភ្នំ

**៣០:២៩** រ អស ២៥:៦ ល អស ១២:១ វ ១សយ ១០:៥ ស ទដ ៤២:៤ មថ ២៦:៣០ ហ លប ៤៩:២៤
**៣០:៣០** ឡ ទដ ៦៨:៣៣ អ អស ៩:១២ ៤០:១០ ៥១:៩ ៥២:១០ ៥៣:១ ៥៩:១៦ ៦២:៨ ៦៣:១២ ក ខ.២៧ អស ១០:២៥ ខ អស ៤:៤ ៤៧:១៤ គ នក ២០:១៨ ទដ ២៩:៣ ឃ នក ៩:១៨ឱ
**៣០:៣១** ង អស ១០:៥,១២ ច អស ១១:៤
**៣០:៣២** ឆ អស ១០:២៦ ជ នក ១៥:២០ ឈ អស ១១:១៥ អគ ៣២:១០
**៣០:៣៣** ញ ២ពវ ២៣:១០ ដ នក ១៥:១០ ២សយ ២២:១៦ ឋ លប ១៩:២៤ វវ ៩:១៧

ឌ អស ១:៣១ **៣១:១** ក អស ២៨:១ ខ ចទ ១៧:១៦ អស ៣០:២,៥ យរ ៣៧:៥ គ អស ៣០:១៦ ឃ អស ២:៧ ង យប ៦:១០ អស ១:៤ ៣០:១២ ច ចទ ២០:១ សភ ២១:៣១ អស ៩:១៣ យរ ៤៦:៩ អគ ២៩:១៦ **៣១:២** ឆ ទដ ៩២:៥រម ១៦:២៧ ជ អស ៤៥:៧ ៤៧:១១ អម ៣:៦ ឈ ជន ២៣:១៩ សភ ១៩:២១ ញ អស ១:៤ ២៩:១៥ ៣២:៦ **៣១:៣** ដ អស ២០:៥ ៣៦:៩ ឋ ទដ ៩:២០ អគ ២៨:៩ ២ថន ២:៤ ឌ អស ៣០:១៦ ឍ នហ ១:១០ យប ៣០:២១ អស ៩:១៧,២១ យរ ៥១:២៥ អគ ២០:៣៤ ណ អស ១០:៣ ៣០:៥–៧ ត អស ២០:៦ យរ ១៧:៥ **៣១:៤** ថ អស ៤២:១៣

មើល ៣១:៥ (ធៀបនឹង មថ ២៦:៣០) ។ *ភ្នំនៃព្រះយេហូវ៉ា* គឺឯក្រុងស៊ីយ៉ូន ដែលជាទីតាំងព្រះវិហារ នៅទីនោះគឺ (មើល ២:២–៤ និងការពន្យល់) ។ *ថ្មដា* គឺសំដៅលើអង្គទ្រង់ផ្ទាល់ (មើល ១៧:១០ និងការពន្យល់) ។

**៣០:៣០–៣១** *ព្រះសូរសៀង* គឺមានទំនាក់ទំនងនិងសម្លេងផ្គរលាន់ សូមមើល ២០:១៨–១៩ ទដ ២៩:៣–៩ (សូមមើលការពន្យល់) ។

**៣០:៣០** សូមមើល ៩:១២,១៧,២១ ៥១:៩ នឹងការពន្យល់ឆេះបន្សុស . . . ដុំព្រឹល សូមមើល ២៨:២ ។

**៣០:៣១** *ព្រះសូរសៀងនៃព្រះយេហូវ៉ា នោះសាសន៍អាសស៊ើរនឹងស្រយុតចិត្ត* សូមប្រៀបធៀបនឹង ១០:៥ ទដ ២៩:៥–៩ ។

**៣០:៣២** *ដំបងដែលព្រះយេហូវ៉ាបានដំរូវឱ្យត្រូវវាយគេ* សូមមើល ១១:៤ នឹងការពន្យល់ ។ *សូរក្រាប់នឹងស៊ីងប្រគំឡើង* ដូចជាខណៈពេលដែលទទួលបានជោគជ័យដ៏ធំធេង គឺពួកស្រីៗគេអរសប្បាយដោយមានការលោតរាំ (សូមមើល នក ៥:២០–២១ និងការពន្យល់ ១សយ ១៨:៦) ។

**៣០:៣៣** *ទីដុតខ្មោច* (ទីកន្លែងតូផែត) គឺជាតំបន់មួយនៅក្រៅក្រុងយេរូសាឡិមដែលជាទីកន្លែង សម្រាប់បូជាកូនក្មេងដោយភ្លើងដើម្បីថ្វាយចំពោះព្រះម៉ូឡុត (សូមមើល ២បវ ២៣:១០ យរ ៧:៣១–៣២ ១៩:៦,១១–១៤ និងការពន្យល់) ម៉ូឡុតជាព្រះរបស់ពួកកូនចៅអាំម៉ូន (សូមមើល ១ពវ ១:៧) ។ ក៏ជាទីកន្លែងសម្រាប់បូជា ។ *ស្ដេច* ជាស្ដេចរបស់ពួកអាសស៊ើរ គឺសំដៅលើព្រះម៉ូឡុក សូមមើលការពន្យល់ ពច ១០:៦) ។ ពាក្យថា *ស្ពាន់ធ័រហូរមកបង្កាត់ភ្លើង* សូមមើល ១:៣១ លប ១៩:២៤ និងការពន្យល់ ។

**៣១:១** សូមមើល ៣០:១ និងការពន្យល់ ។ ក្នុងខនេះគឺជាលក្ខណៈបំព្រួញឯក្នុងជំពូក ៣១ ជាជំពូកដែលសង្ខេបចំណុចសំខាន់ៗនៃប្រយោគ ឬឃ្លានិងមាតិការឿងរបស់ជំពូកទី ៣០ ។ *ចុះទៅស្រុកអេស៊ីព្ទ* មើល លប ២៦:២ ។ *ដល់សេះ . . . រទេះចំបាំង* គឺនិយាយពីសាសន៍អេស៊ីព្ទដែលមានសេះនិងរទេះចំបាំងជាច្រើន (មើល ១ពវ ១០:២៨–២៩ និងការពន្យល់) ។ *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើល ១:៤ និងការពន្យល់ ។

**៣១:២** *ទ្រង់ក៏មានប្រាជ្ញាដែរ* មនុស្សគេបានចោទជាសំណួរ ទៅលើប្រាជ្ញារបស់ផងទ្រង់គឺមាននៅក្នុង ២៩:១៤–១៦ (សូមមើលការពន្យល់) ។

**៣១:៣** *ពួកសាសន៍អេស៊ីព្ទ គេគ្រាន់តែជាមនុស្សប៉ុណ្ណោះ មិនមែនជាព្រះទេ* ឃ្លានេះសូមប្រៀបធៀបនិងគម្ពីរ ហស ១១:៩ ។ ពាក្យថា *ព្រះ . . . វិញ្ញាណ* សូមមើល យហ ៤:២៤ នឹងការពន្យល់។ សូមប្រៀបធៀបទៅនិងខទន្ទេញក្នុង ៥:២៥ (សូមមើលការពន្យល់ផងដែរ) ៩:១២,១៧,២១ ១០:៤ ។

**៣១:៤** *សិង្ហ* គឺមានលក្ខណៈជាពាក្យនិយាយបញ្ចៀងទៅចំពោះស្ដេចសាសន៍អាសស៊ើរ (សូមមើលការពន្យល់ ១៥:៩) ។ ពាក្យថា *ពួកអ្នកគង្វាល* គឺជាការនិយាយបញ្ចៀងតែជាថ្នាក់អ្នកដឹកនាំជាតិសាសន៍ទាំងនោះ (សូមមើលការពន្យល់ ណាហ ៣:១៨) ។

ស៊ីយ៉ូន ហើយលើទីទួលនៃភ្នំនោះ ប្រៀបដូចជាសិង្ហ[ទ]
និងកូនវា ដែលគ្រហឹមពីលើរំពា ទោះបើគេហៅពួកអ្នក
គង្វាល[ធ] ជាច្រើនមកបង្ក្រាបវាក៏ដោយ គង់តែវាមិនភ័យ
ខ្លាចដោយឮសំឡេងគេ ឬក្រាបចុះ[ន] ដោយព្រោះសូរយុក–
យាក់របស់គេឡើយ ៥ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់
នឹងការពារ[ប]ក្រុងយេរូសាឡិម ដូចជាសត្វស្លាបដែលហើរ
វេរ៉ា[ផ]ការពារសំបុកដែរ ទ្រង់នឹងការពារ ហើយជួយឱ្យ
រួច[ព] ទ្រង់នឹងហោះពីលើ[ភ] ហើយរារាំងផង ៦ឱពួកកូនចៅ
អ៊ីស្រាអែល អើយ ចូរត្រឡប់មកឯព្រះអង្គ ដែលអ្នករាល់
គ្នាបានបះបោរ[ម]នឹងទ្រង់ជាខ្លាំងទៅហើយ ៧ពីព្រោះនៅ
គ្រានោះ[យ] គ្រប់មនុស្សទាំងអស់នឹងបោះចោលរូបព្រះធ្វើពី
ប្រាក់ ហើយពីមាស[រ] ដែលដៃអ្នករាល់គ្នាបានធ្វើសំរាប់
ខ្លួន[ល]ជាការដែលរាប់ជាអំពើបាបពិត ៨នោះពួកអាសស៊ើរ[វ]
នឹងដួលស្លាប់ ដោយដាវ មិនមែនជាដាវរបស់មនុស្សដែរ
ហើយដាវនោះ ដែលមិនមែនជារបស់មនុស្សនឹងផ្ដិល[ស]
គេបង់ គេនឹងរត់ពីដាវ ហើយពួកកំឡោះៗរបស់គេនឹងត្រូវ
ធ្វើជាឈ្លើយ[ហ] ៩ឯថ្មដា[ឡ]របស់គេនឹងបាត់ទៅ ដោយព្រោះ
សេចក្ដីតក់ស្លុត ហើយពួកចៅហ្វាយរបស់គេនឹងស្រយុត
ចុះ[អ] ដោយព្រោះទង់ជ័យ[ក] នេះជាព្រះបន្ទូលនៃព្រះយេហូ–
វ៉ា ដែលភ្លើង[ខ]របស់ទ្រង់កំពុងតែឆេះនៅក្រុងស៊ីយ៉ូន
ហើយគុកភ្លើង[គ]របស់ទ្រង់ ក៏នៅក្រុងយេរូសាឡិមដែរ ។

**៣១:៤** ទ ជន ២៤:៩ ១សយ ១៧:៣៤ ហស ១១:១០ អម ៣:៨ ធ យរ ៣:១៥ ២៣:៤ អគ ៣៤:២៣ ណហ ៣:១៨ ន ទដ ៧៤:២៣ **៣១:៥** ប ទដ ៩១:៤ អស ៥:២ សក ៩:១៥ ផ លប ១:២ មថ ២៣:៣៧ ព ទដ ៣៤:៧ អស ៣៧:៣៥ ៣៨:៦ ភ នក ១២:២៣ **៣១:៦** ម យប ២២:២៣ អស ១:២៧ យ អស ១:៥ **៣១:៧** រ អស ២៩:១៨ ល អស ៣០:២២ វ ទដ ១៣៥:១៥ **៣១:៨** ស អស ១០:១២ ហ នក ១២:១២ អស ១០:១២ ១៤:២៥ ២៧:១ ៣៣:១ ៣៧:៧ យរ ២៥:១២

## ទីក្រុងនៃសេចក្ដីសុចរិត

**៣២** ១មើល និងមានស្តេច[ក]១អង្គសោយរាជ្យដោយ
សុចរិត ពួកចៅហ្វាយនឹងគ្រប់គ្រងដោយយុត្តិធម៌[ខ] ២ហើយ
មនុស្សម្នាក់នឹងបានដូចជាទីបាំងឱ្យរួចពីខ្យល់ នឹងជាទីជ្រក[គ]
ឱ្យរួចពីព្យុះសង្ឃរា[ឃ] ដូចផ្លូវទឹក[ង]ហូរនៅទីហួតហែង[ច]
ហើយ ដូចជាម្លប់នៃថ្មដាយ៉ាងធំនៅទីខ្សោះល្វើយ ៣ឯភ្នែក
នៃពួកអ្នកដែលមើលឃើញ នោះនឹងមិននៅជាព្រិលៗ
ទៀត[ឆ] ហើយត្រចៀក[ជ]នៃពួកអ្នកដែលស្តាប់ឮ នឹងប្រុង
ស្តាប់ ៤ចិត្តរបស់ពួករួសរាន់ និងមានដំរិះ[ឈ] ហើយ
អណ្តាត[ញ]នៃពួកដែលនិយាយជាប់ នោះនឹងប្រុងប្រៀប
និយាយឡើងយ៉ាងច្បាស់វិញ ៥គេនឹងមិនហៅមនុស្សល្ងីល្ងើ[ដ]
ថាជាអ្នកសទ្ធាទៀត ក៏មិនហៅមនុស្សទ្រើស្តិស្ទូរថាជាមាន
គុណឡើយ ៦ដ្បិត មនុស្សល្ងីល្ងើនឹងបញ្ចេញតែសេចក្ដី
ចំកួត[ឋ] ហើយចិត្តរបស់គេនឹងប្រព្រឹត្តអំពើទុច្ចរិត[ឌ] ដើម្បីតែ
នឹងសំរេចអំពើសៅហ្មង[ឍ] ហើយនឹងពោលពាក្យខុសឆ្គង[ណ]

ហព ២:៨ ឡ លប ៤៩:១៥ ចទ ២០:១១ **៣១:៩** អ ចទ ៣២:៣១,៣៧ ក យរ ៥១:៩ ណហ ៣:៧ ខ អស ១៨:៣ យរ ៤:៦ គ អស ១០:១៧ ឃ ទដ ២១:៩ មឡ ៤:១ **៣២:១** ក ទដ ១៤៩:២ អស ៦:៥ ៥៥:៤ អគ ៣៧:២៤ ខ ទដ ៧២:១–៤ អស ៩:៧ ២៨:៦ **៣២:២** គ ១ពវ ១៨:៤ ឃ ទដ ៥៥:៨ ង ទដ ២៣:២ អស ៣០:២៥ ៤៩:១០ យរ ៣១:៩ ច ទដ ១០៧:៣៥ អស ៤៤:៣ **៣២:៣** ឆ អស ២៩:១៨ ៣៥:៥ ៤២:៧,១៦ ជ ចទ២៩:៤ **៣២:៤** ឈ អស ៦:១០ ២៩:២៤ ញ អស ៣៥:៦ **៣២:៥** ដ ១សយ ២៥:២៥ **៣២:៦** ឋ សភ ១៩:៣ ឌ សភ ២៤:២ អស ២៦:១០ ឍ អស ៩:១៧ ណ អស ៣:១២ ៩:១៦

**៣១:៥** *សត្វស្លាប . . . នឹងការពារ* សូមប្រៀបធៀប ចទ ៣២:១០–១១ ។ ពាក្យថា *ហោះពីលើ* គឺជាពាក្យបច្ចេកទេសមួយដែលកាលណាទេវតាបានហោះរំលងពីលើផ្ទះទាំងឡាយ ក្នុងស្រុកអេស៊ីព្ទហើយបើផ្ទះណាមានស្នាមឈាមគូសនៅលើជញ្ជាំងមេទ្វារនោះ គឺមិនត្រូវវិនាសឡើយ (សូមមើលការពន្យល់) ក៏សូមប្រៀបធៀប អស ៣៧:៣៥ ។

**៣១:៦** *ចូរត្រឡប់* សូមមើល ១:២ និងការពន្យល់។

**៣១:៧** *បោះចោលរូបព្រះ* សូមមើល ២:២០ និងការពន្យល់។

**៣១:៨** *ដាវនោះ ដែលមិនមែនជារបស់មនុស្សនឹងផ្ដិលគេបង់* គឺមានទេវតារបស់ព្រះយេហូវ៉ា បានវាយសម្លាប់គេបង់អស់ ទាហានចំនួន ១៨៥,000 នាក់ (សូមមើល ៣៧:៣៦ និងការពន្យល់ក៏សូមមើល ទដ ៧:១២–១៣ និងការពន្យល់) ។ *ត្រូវធ្វើជាឈ្លើយ* គឺជាអ្នកទោសនយោបាយ ។

**៣១:៩** *ថ្មដា* ដូចជានីនីវេដែលពួកម៉ាកាយនិងពួកបាប៊ីឡូនវាយកំទេចចោល គឺនៅក្នុងឆ្នាំ ៦១២ មុន គ.ស (សូមមើល ណហ ៣:៧) ។ *ពួកចៅហ្វាយរបស់គេនឹងស្រយុតចិត្ត* សូមមើលការប្រៀបធៀប ណហ ២:១០ និងការពន្យល់ ។ *ភ្លើង . . . គុកភ្លើង* ជាសិរីល្អរបស់ផងទ្រង់ដែលតាំងនៅក្នុងក្រុងស៊ីយ៉ូន គឺសណ្ឋិតនៅក្នុងក្រអៅដួងចិត្តនៃរាស្ត្ររបស់ទ្រង់ ក៏មានភ្លើងនៃសេចក្ដីជំនុំជម្រះ ក៏ផ្ទុះចេញទៅលើមនុស្សអាក្រក់ (សូមមើល ១០:១៧ ៣០:៣៣ នឹងការពន្យល់សូមប្រៀបធៀប លវ ១០:២ យអ ៣:១៦ និងការពន្យល់ អម ១:២ និងការពន្យល់) ។

**៣២:១** *ស្តេច . . . សុចរិត* គឺក្នុងយុគសម័យព្រះមែស៊ីក៏បានបង្ហាញឱ្យឃើញជាទូរលេខផងដែរ ។ (សូមមើល ៩:៧ ១១:៤ ១៦:៥ និងការពន្យល់) ។ សូមមើលការប្រៀបធៀប ខ.១៦–១៧ ៣៣:១៧ និងការពន្យល់។

**៣២:២** *ហើយមនុស្សម្នាក់នឹងបានដូចជា* គឺសេចក្ដីប្រោសលោះរបស់ព្រះយេហូវ៉ា គឺប្រៀបប្រដូចជាប្រភពនៃរបាំងការពារ និងព្រះពរដែលឆ្លុះបញ្ចាំងឱ្យឃើញពីព្រះទ័យទ្រង់ (សូមមើល ខ.៣–៨) ។ *ទីបាំង . . . ទីជ្រក . . . ជាម្លប់* នេះជាពាក្យស្រដៀងៗគ្នាដែលប្រើចំពោះព្រះយេហូវ៉ាគឺក្នុង ២៥:៤ (សូមមើល ៤:៥–៦ និងការពន្យល់) ។ ពាក្យថា ផ្លូវទឹកហូរនៅទីហួតហែង សូមមើល ៣៥:៦–៧ ៤១:១៨ ៤៩:១០ និងការពន្យល់។

**៣២:៣** *ឯភ្នែកនៃពួក . . . នោះនឹងមិននៅជាព្រិលៗ* សូមមើល ៣៥:៥ និងការពន្យល់ទីនោះ) ។

**៣២:៥–៨** ការប្រោសលោះក៏លែងមានក្នុងចំណោមពួកមនុស្សល្ងីល្ងើហើយលក្ខណៈផ្ទុយរវៀងមនុស្សល្ងីល្ងើ និងមនុស្សឆ្លាត ឬក៏អ្នកមានចិត្តសទ្ធាគឺជាលក្ខណៈសម្បត្តិនៃប្រាជ្ញាដែលជាពាក្យអក្សរសាស្ត្រ ។ (សូមប្រៀបធៀប សភ ៩:១–៦ ជាមួយនឹង ៩:១៣–១៨) ។

**៣២:៦** ក្នុងខនេះបានអធិប្បាយនិងបកស្រាយយ៉ាងពេញលេញ នូវពាក្យខ្លះក្នុងសញ្ញាចាស់គឺចំពោះពាក្យ"មនុស្សល្ងីល្ងើ" (សូមមើល សភ ១:៧ និងការពន្យល់) ។ ពាក្យថា *មនុស្សល្ងីល្ងើនឹងបញ្ចេញតែសេចក្ដីចំកួត* គឺសូមមើលជិពូកប្រៀបធៀបក្នុង ៩:១៦–១៧ ទដ ១៤:១ និងការពន្យល់ ៥៣:១ ។

ទាស់នឹងព្រះយេហូវ៉ា ដោយប្រាថ្នានឹងធ្វើឱ្យព្រលឹងមនុស្ស
ឃ្លាន បាននៅទទេ[ត] ហើយបំបាត់គ្រឿងផឹកពីអ្នកដែល
ស្រេកចេញ ៧គ្រឿងប្រដាប់ របស់មនុស្សទ្រឹស្តិស្នូរសុទ្ធតែ
អាក្រក់[ថ] វាមិនគួរការអាក្រក់[ទ] ដើម្បីនឹងបំផ្លាញមនុស្ស
រាបសា ដោយពាក្យកំភូត ទោះទាំងវេលា ដែលមនុស្ស
កំសត់[ធ] និយាយដោយត្រឹមត្រូវផង[ន] ៨តែឯអ្នកមានចិត្ត
សទ្ធាវិញ គេគិតគូរការជាសគុណវិញ ហើយអ្នកនោះនឹង
ស្ថិតស្ថេរនៅដោយការនោះ[ប]ឯង[ផ]។

## ស្ត្រីនៃក្រុងយេរូសាឡិម

៩ឱពួកស្រីៗ[ព] ដែលនៅដោយឥតកង្វល់អើយ ចូរក្រោក
ឡើងហើយស្ដាប់[ភ]សំឡេងខ្ញុំចុះ ឯអ្នករាល់គ្នាជាកូនស្រី
ដែលនៅព្រងើយអើយ[ម] ចូរផ្ទៀងត្រចៀកស្ដាប់ពាក្យខ្ញុំ
១០ឱអ្នករាល់គ្នាដែលនៅព្រងើយដូច្នេះអើយ នៅ១ឆ្នាំ[យ]
ប៉ុន្មានថ្ងៃទៀត នោះនឹងមានសេចក្ដីថប់ព្រួយវិញ ដ្បិតនឹង
ខានមានការបេះទំពាំងបាយជូរទៀត[រ] ហើយរដូវប្រមូល
ផលក៏មិនមកដល់ដែរ ១១ឱពួកស្រីៗដែលនៅដោយឥត
កង្វល់អើយ ចូរញាប់ញ័រចុះ[ល] ឱពួកអ្នកដែលនៅព្រងើយ[វ]
អើយ ចូរមានសេចក្ដីថប់ព្រួយចុះ ចូរដោះសំលៀកបំពាក់
ចេញឱ្យខ្លួននៅទទេ[ស] រួចស្លៀកសំពត់ធ្មៃ[ហ]វិញទៅ ១២គេ
នឹងគក់ទ្រូង[ឡ]យំទួញនឹងចំការដែលគាប់ចិត្ត ហើយនឹងដើម
ទំពាំងបាយជូរដែលដុះដាល[អ] ១៣នៅក្នុងស្រុករបស់រាស្ត្រ
អញ នោះនឹងមានដុះសុទ្ធតែបន្លានឹងអញ្ចាញ[ក] អើ នៅលើ
គ្រប់ទាំងផ្ទះសំរាប់ត្រេកអរ[ខ] នៅទីក្រុងដ៏សប្បាយផង[គ] ១៤ពី
ព្រោះព្រះរាជវាំង[ឃ]នឹងត្រូវចោលស្ងាត់[ង] ហើយទីក្រុង
ដែលមានមនុស្សណែនណាន់នឹងត្រូវចោលទទេ ឯបន្ទាយ
និងប៉មចាំយាម[ច] នោះនឹងបានសំរាប់ជារូងនៅជាដរាប
គឺជាទីសប្បាយដល់លាព្រៃ[ឆ] ហើយជាវាលស្មៅសំរាប់ហ្វូង
សត្វ[ជ] ១៥ដរាបដល់ព្រះវិញ្ញាណ[ឈ]បានចាក់មក លើយើង
រាល់គ្នាពីស្ថានដ៏ខ្ពស់ ហើយទីរហោស្ថានបានត្រឡប់ជា
ចំការដុះដាល[ញ] ហើយចំការដុះដាលបានរាប់ទុកជាព្រៃ
វិញ[ដ]។
១៦នៅគ្រានោះ សេចក្ដីយុត្តិធម៌[ឋ]នឹងស្ថិតនៅ ក្នុងទី
រហោស្ថាន[ឌ] ហើយសេចក្ដីសុចរិត[ឍ]នឹងអាស្រ័យនៅ ក្នុង
ចំការដុះដាល ១៧ឯការនៃសេចក្ដីសុចរិត[ណ] នោះនឹងបាន
ជាសន្តិសុខ[ត] ហើយផលនៃសេចក្ដីសុចរិត នោះនឹងបាន
ជាសេចក្ដីស្រាកស្រាន្ត នឹងជាសេចក្ដីទុកចិត្ត[ថ]ជាដរាបទៅ
១៨ឯរាស្ត្រអញគេនឹងអាស្រ័យក្នុងទីលំនៅដ៏មានសន្តិសុខ[ទ]
ហើយនៅផ្ទះសំបែងមាំមួន[ធ] ជាទីសំរាកក្សេមក្សាន្ត[ន] ១៩តែ

**៣២:៦** ត អស ៣:១៥ **៣២:៧** ថ យរ ៥:២៦–២៨ ដយ ១២:១០ ទ អស ២៩:២០ មីក ៧:៣ ធ សភ ៧២:៤ អស ២៩:១៩ ៦១:១ ន អស ២៩:២១ **៣២:៨** ប ១របា ២៩:៩ សភ ១១:២៥ ផ អស ១៤:២៤ **៣២:៩** ព អស ៤:១ ភ អស ២៨:២៣ ម ឧ.១១ អស ៤៧:៨ ដយ ៤:៤ អម ៦:១ សផ ២:១៥ **៣២:១០** យ អស ៣៧:៣០ រ អស ៥:៥–៦ ២៤:៧ **៣២:១១** ល អស ៣៣:១៤ វ ឧ.៩ ស អស ៤៧:២ មីក ១:៨ ណហ ៣:៥ ហ អស ៣:២៤ **៣២:១២** ឡ ណហ ២:៧ អ អស ១៦:៩ **៣២:១៣** ក អស ៥:៦ ហស ១០:៨

ខ អស ២៤:១១ គ អស ២៣:៧ **៣២:១៤** ឃ អស ១៣:២២ ង អស ៦:១១ ២៧:១០ ច អស ២:១៥ ៣៤:១៣ ឆ ទដ ១០៤:១១ ជ អស ៥:១៧ **៣២:១៥** ឈ អស ១១:២ អគ ៣៧:៩ ញ ទដ ១០៧:៣៥ អស ៣៥:១–២ ដ អស ២៩:១៧ **៣២:១៦** ឋ អស ៩:៧ ២៨:៦ ឌ អស ៣៥:១,៦ ៤២:១១ ឍ ទដ ៤៨:១ អស ១:២៦ **៣២:១៧** ណ ទដ ៨៥:១០ ត ទដ ១១៩:១៦៥ អស ៩:៧ រម ១៤:១៧ ហព ១២:១១ យក ៣:១៨ ថ អស ៣០:១៥ **៣២:១៨** ទ អស ២:៤ ធ អស ២៦:១ ៣៣:២០ ៣៧:៣៣ ៦៥:២១ ៦៦:១៤ អម ៩:១៤ ន យស ១:១៣ យប ១១:១៨ ហស ២:១៨–២៣

**៣២:៧** *វេលាដែលមនុស្សកំសត់និយាយ* មើល ១:១៧ និងការពន្យល់ ។
**៣២:៨** *គិតគូរ . . . ស្ថិតស្ថេរនៅ* សូមមើល ៨:១០ និងការពន្យល់ ។
**៣២:៩** *ស្រីៗ* ពាក្យនេះសូមប្រៀប ៣:១៦–៤:១ និងការពន្យល់ ។ ពាក្យថា *ដោយឥតកង្វល់* សូមមើល ឧ.១១ អម ៦:១ និងការពន្យល់ ។ គឺពាក្យទាំងអស់នេះបានប្រើក្នុងអត្ថន័យដ៏ល្អក្នុង ឧ.១៨ (ព្រះគម្ពីរភាសាហេព្រើរ គឺមានអត្ថន័យដូចគ្នា) ។
**៣២:១០** *១ឆ្នាំ* គឺប្រហែលជាឆ្នាំនៃការលុកលុយរបស់ពួកស្តេចសានហេរីប គឺក្នុងឆ្នាំ (៧០១ មុន គ.ស) ។ *ការបេះទំពាំងបាយជូរទៀត ហើយរដូវប្រមូលផលក៏មិនមកដល់ដែរ* សូមប្រៀបធៀប ៣៧:៣០ ។ កងទ័ពរបស់ពួកអាសស៊ើរ បាននាំមកនូវភាពហិនវិនាសយ៉ាងធំធេង ដូចជាការបំផ្លាញភោគផលនៅរដូវក្តៅ ។
**៣២:១១** *ដោះ* ប្រៀបធៀបនឹង ៤៧:២–៣ និងការពន្យល់ ។ ពាក្យថា *សំពត់ធ្មៃ* សូមមើលការប្រៀបធៀប ៣:២៤ ២២:១២ និងការពន្យល់ លប ៣៧:៣៤ វវ ១១:៣ ។
**៣២:១២** *គក់ទ្រូងយំទួញ* គឺលក្ខណៈដូចជាទាសករ ឬពួកឈ្លើយស្រីៗក្រុងនីនីវេ (ណហ ២:៧) ។ *ដើមទំពាំងបាយជូរដែលដុះដាល* សូមមើលការប្រៀបធៀបក្នុង ១៦:៩ គឺការដែលទ្រង់យំចំពោះដើមទំពាំងបាយជូរ ។
**៣២:១៣** *សុទ្ធតែបន្លានឹងអញ្ចាញ* សូមមើល ៥:៦ ៧:២៣ និងការពន្យល់ ។ ពាក្យថា *សំរាប់ត្រេកអរ . . . ក៏សប្បាយ* គឺសូមមើល ២២:២ និងការពន្យល់ក៏សូមប្រៀបធៀបនិង យរ ១៦:៨–៩ ។
**៣២:១៤** *ព្រះរាជវាំង . . . ទីក្រុងដែលមានមនុស្សណែនណាន់* គឺជាការឈ្លានពានលុកលុយពីពួកស្តេចអាសស៊ើរ ក៏ជាការដែលត្រូវប្រមានដល់ក្រុងយេរូសាឡិម (សូមមើល ២៤:១០ និងការពន្យល់) ។ គឺមានតែថ្ងៃដែលត្រូវបំផ្លាញបង់តែប៉ុណ្ណោះ ។ ពាក្យថា *ដល់លាព្រៃ . . . ហ្វូងសត្វ* សូមមើលការប្រៀបធៀប ៧:២៥ ១៣:២១–២២ ៣៤:១៣ ។
**៣២:១៥** *ដរាបដល់ព្រះវិញ្ញាណបានចាក់មក* គឺជាការចាក់បង្ហូរព្រះវិញ្ញាណបរិសុទ្ធ–ឱ្យមានបរិបូរ សូមមើល ៤៤:៣ (ក៏សូមមើលការពន្យល់ ១១:២ យរ ២:២៨–៣២) ។ ពាក្យថា *ជាចំការដុះដាល . . . ព្រៃ* គឺសំដៅទៅលើព្រៃល្បាណូន (សូមមើល ២៩:១៧ និងការពន្យល់និងការប្រៀបធៀប ៣៥:១–២ និងការពន្យល់) ។
**៣២:១៦** *សេចក្តីយុត្តិធម៌ . . . សេចក្តីសុចរិត* មើល ឧ.១ និងការពន្យល់ ។
**៣២:១៧** *សន្តិសុខ* សូមធ្វើការប្រៀបធៀប ៩:៧ ១១:៦–៩ និងការពន្យល់ ។ *សេចក្តីស្រាកស្រាន្ត និងជាសេចក្តីទុកចិត្ត* គឺមានលក្ខណៈផ្ទុយនឹង ៣០:១៥ ។
**៣២:១៨** *ទីលំនៅក៏មានសន្តិសុខ* សូមមើលការពន្យល់ ឧ.៩ ។ *ទីសំរាប់ក្សេមក្សាន្ត* សូមមើល ២៨:១២ និងការពន្យល់ផង ។
**៣២:១៩** *ធ្លាក់ព្រឹល* សូមប្រៀបធៀប ២៨:២ គឺវាអាចជាស្រុកអាសស៊ើរ ។

នឹងត្រូវធ្លាក់ព្រឹល[ប]មកបំបាក់ព្រៃ[ផ] ហើយទីក្រុងនឹងត្រូវរលំ[ព]
អស់រលីង ២០មានពរហើយ អ្នករាល់គ្នាដែលសាបព្រោះ[ភ]
ក្បែរគ្រប់ទាំងផ្លូវទឹក[ម] ហើយលែងគោនឹងលា ឱ្យដើររកស៊ី
តាមចិត្ត[យ]។

## សេចក្ដីទុក្ខវេទនា និងជំនួយ

**៣៣** ១វេទនា[ក]ដល់ឯងដែលបំផ្លាញគេ ឥតដែលមាន
អ្នកណាបំផ្លាញឯង ហើយដែលក្បត់គេ ឥតមានអ្នកណា
ក្បត់នឹងឯងឡើយ កាលណាឯងបានលែងបំផ្លាញហើយ
នោះឯងនឹងត្រូវបំផ្លាញវិញ[ខ] កាលណាឯងបានសំរេចការ
ក្បត់ហើយ នោះនឹងមានគេក្បត់នឹងឯងដែរ[គ]។
២ឱព្រះយេហូវ៉ាអើយ សូមទ្រង់ផ្ដល់ព្រះគុណ[ឃ]ដល់
យើងខ្ញុំរាល់គ្នា យើងខ្ញុំបានរង់ចាំទ្រង់ សូមទ្រង់ការពារ[ង]
យើងខ្ញុំ ដោយព្រះពាហុរាល់ៗព្រឹក ហើយជួយសង្គ្រោះ[ច]
យើងខ្ញុំនៅក្នុងគ្រាវេទនាដែរ[ឆ] ៣អស់ទាំងជនជាតិបានរត់
ទៅដោយឮសូរអឺកធឹក[ជ] ហើយអស់ទាំងសាសន៍បានត្រូវ
ខ្ចាត់ខ្ចាយ[ឈ] ដោយទ្រង់លើអង្គទ្រង់ឡើង[ញ] ៤របឹបរបស់អ្នក
រាល់គ្នានឹងបានប្រមូលទុក[ដ] ដូចជាចង្រិតប្រមូលទុក[ឋ] ហើយ
មនុស្សនឹងលោតសង្គ្រុបលើ ដូចជាកណ្ដូបលោតដែរ[ឌ]
៥ព្រះយេហូវ៉ាទ្រង់បានថ្កើងឡើងហើយ[ឍ] ដ្បិតទ្រង់គង់នៅ
ស្ថានដ៏ខ្ពស់[ណ] ទ្រង់បានធ្វើឱ្យក្រុងស៊ីយ៉ូនមានពេញដោយ
សេចក្ដីយុត្តិធម៌[ត] និងសេចក្ដីសុចរិត[ថ] ៦នឹងមាន សេចក្ដីសុខ
ស្រួលនៅក្នុងគ្រាឯង ព្រមទាំងសេចក្ដីសង្គ្រោះ[ទ] ប្រាជ្ញា និង
ដំរិះជាបរិបូរដែរ សេចក្ដីកោតខ្លាច[ធ]ដល់ព្រះយេហូវ៉ា
នោះនឹងបានជាឃ្លាំងរបស់ឯង[ន]។
៧មើលពួកទាហាន[ប]ស្ទាត់ជំនាញរបស់គេក៏ស្រែកនៅ
ខាងក្រៅហើយ ឯពួករាជទូត[ផ]ដែលសូមមេត្រីភាព គេយំ
អណ្ដឺតអណ្ដក ៨ថ្នល់ទាំងប៉ុន្មាននៅស្ងាត់ច្រៀប[ព] ឥតឃើញ
មានមនុស្សដើរដំណើរ[ភ]ទៀតឡើយ ពួកខ្មាំងសត្រូវ
គេបានផ្ដាច់សេចក្ដីសញ្ញាហើយ[ម] គេបានមើលងាយដល់
អស់ទាំងទីក្រុង ហើយមិនយោគយល់ដល់អ្នកណាឡើយ
៩ស្រុកកំពុងតែយំសោក[យ] ហើយថយកំឡាំងទៅព្រៃល្បា-
ណូន[រ] មានសេចក្ដីខ្មាស[ល] ហើយស្រពោនទៅស្រុកសារ៉ុន[វ]
បានដូចជាទីរហោស្ថាន ឯស្រុកបាសាន[ស] និងភ្នំកើមែល[ហ]

**៣២:១៩** ប អស ២៨:១៧ ផ អស ១០:១៩ សក ១១:២ ព យប ៤០:១១ អស ១៩:១៨ ២៤:១០ ២៧:១០ **៣២:២០** ភ សស ១១:១ ម ចទ ២៨:១២ យ យប ៣៩:៨ អស ៣០:២៤ **៣៣:១** ក ២ពវ ១៩:២១ អស ២៨:១ ខ អស ៣១:៨ មថ ៧:២ គ អស ២១:២ យរ ៣០:១៦ អគ ៣៩:១០ **៣៣:២** ឃ លប ៤៣:២៩ អរ ៩:៨ ង អស ៤០:១០ ៥១:៩ ៥៩:១៦ ៦៣:៥ ច ទដ ១៣:៥ អស ១២:២ ឆ អស ៥:៣០ **៣៣:៣** ជ ទដ ៤៦:៦ ៦៨:៣៣ ឈ ទដ ៦៨:១ អស ១៣:១៤ ញ ខ.១០ ជន ១០:៣៥ ទដ ១២:៥ អស ៥៩:១៦–១៨ **៣៣:៤** ដ ជន ១៤:៣ ២ពវ ៧:១៦ ឋ អស ១៧:៥ យអ ៣:១៣ ឌ យអ ១:៤ **៣៣:៥** ឍ អស ៥:១៦ ណ យប ១៦:១៩ ត អស ៩:៧ ២៨:៦ ថ អស ១:២៦ **៣៣:៦** ទ អស ១២:២ ២៦:១ ៥១:៦ ៦០:១៨ ធ សភ ១:៧ អស ១១:២–៣ មថ ៦:៣៣ ន លប ៣៩:៣ យប ២២:២៥ **៣៣:៧** ប អស ១០:៣៤ ផ ២ពវ ១៨:៣៧ **៣៣:៨** ព ពច ៥:៦ អស ៣០:២១ ៣៥:៨ ភ អស ៦០:១៥ សក ៧:១៤ ម ២ពវ ១៨:១៤ **៣៣:៩** យ អស ៣:២៦ រ ២ពវ ១៩:២៣ អស ២:១៣ ៣៥:២ ៣៧:២៤ យរ ២២:៦ ល អស ១៥:៦ វ ១រប ២៧:២៩ ស មីក ៧:១៤ ហ ១ពវ ១៨:១៩ អស ៣៥:២ ណហ ១:៤

សូមមើល ១០:៣៣–៣៤ និងការពន្យល់ ។ *ទីក្រុង* សូមមើល ២៤:១០ និងការពន្យល់ ។

**៣២:២០** គឺជាភាពសម្បូរប្រចាំថ្ងៃរបស់ព្រះយេហូវ៉ា ក៏បានពណ៌នាផងដែរ (សូមមើល ៣០:២៣–២៤ និងការពន្យល់) ។

**៣៣:១** *វេទនា* សូមមើលការពន្យល់ ២៨:១–៣៥:១០ ។ *ឯងដែលបំផ្លាញគេ . . . ដែលក្បត់គេ* គឺប្រហែលសំដៅទៅលើពួកអាសស៊ើរ (សូមមើលការពន្យល់ ១០:៥–៦ ១៦:៤ ២១:២ ២៤:១៦ និងការពន្យល់) ។

**៣៣:២–៩** គឺជាការអធិស្ឋានទូលសុំឱ្យព្រះយេហូវ៉ានាំមកនូវភាពរងទុក្ខដល់សាសន៍អាសស៊ើរ ។

**៣៣:២** *ផ្ដល់ព្រះគុណ* សូមមើល ៣០:១៨ និងការពន្យល់ប្រៀបធៀប ជន ៦:២៥ ។ ពាក្យថា *ព្រះពាហុ . . . ជួយសង្គ្រោះ* សូមមើល ១២:២ និងការពន្យល់ ឬប្រៀបធៀបនឹង ៥៩:១៦ និងការពន្យល់ ។ *រាល់ៗព្រឹក* សូមមើល ទដ ៨៨:១៣ ១៤៣:៨ និងការពន្យល់ក៏សូមមើលសេចក្ដីផ្ដើមនៃ ទដ ៥៧ ។ ពាក្យថា *វេទនា* សូមមើល ៣៧:៣ ។

**៣៣:៣** *ឮសូរអឺកធឹក* សូមមើល ៣០:៣០–៣១ និងការពន្យល់ ។ ត្រូវខ្ចាត់ខ្ចាយ ក៏ដូចជាពាក្យប្រៀបប្រដូចចំពោះ ជន ១០:៣៥–៣៦ (សូមមើលការពន្យល់) និងប្រៀបធៀប ទដ ៦៨:១ និងការពន្យល់ ។

**៣៣:៥** *មានពេញ . . . សេចក្ដីសុចរិត* សូមមើល ១:២៦ ៣២:១ និងការពន្យល់ ។

**៣៣:៦** *ប្រាជ្ញា . . . ដំរិះ . . . សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា* គឺជាពាក្យដែលប្រើភ្ជាប់ទំនាក់ទំនងនិងព្រះមែស៊ី សូមមើលក្នុង ១១:២ (សូមមើលការពន្យល់) ។ សូមមើល ៩:៦ សភ ១:៧ និងការពន្យល់ ។

**៣៣:៧** *ពួកទាហានស្ទាត់ជំនាញរបស់គេ* គឺជាទាហានពួកយូដាក្នុងពេលដែលមានការឈ្លានពានរបស់ពួកស្ដេច សានហេរីប គឺក្នុងឆ្នាំ ៧០១ មុន គ.ស (សូមមើល ១០:២៨–៣៤ និងការពន្យល់) ។ *ពួករាជទូតដែលសូមមេត្រីភាព* គឺប្រហែលជាមន្ត្រីបីនាក់ដែលប្រឹក្សាជាមួយពួកអាសស៊ើរ ជាមេបញ្ជាការ (សូមមើល ៣៦:៣,២២) ។

**៣៣:៨** *ថ្នល់ទាំងប៉ុន្មាននៅស្ងាត់ច្រៀប* គឺសំដៅលើការធ្វើដំណើរនិងជំនួញត្រូវបានផ្ដាច់ដោយមានការលំបាកក្នុងវិស័យសេដ្ឋកិច្ច (សូមមើល ពច ៥:៦ នឹងការពន្យល់) ។ ពាក្យថា *សេចក្ដីសញ្ញា* គឺវាអាចជាកិច្ចព្រមព្រៀងមួយដែលធ្វើឡើងនៅពេលដែលស្ដេចហេសេគាបង់ប្រាក់ជាច្រើនទៅឱ្យស្ដេចសានហេរីប (សូមមើល ២ពវ ១៨:១៤ និងការពន្យល់) ។

**៣៣:៩** *ស្រុក . . . ថយកំឡាំងទៅ* គឺជាប្រភេទដីកសិដ្ឋាន និងមានវាលស្មៅដែលត្រូវក្រៀមស្វិតទៅក៏ដោយសារការលុកលុយឈ្លានពានពីសាសន៍ដទៃ សូមមើល ២៤:៤ និងការពន្យល់ ។ *ព្រៃល្បាណូន* ជាព្រៃមានកិត្តិនាមល្បីដោយសារដើមតាត្រៅនិងភាពសម្បូរសត្វពាហនៈ (៤០:១៦) ។ *ស្រុកសារ៉ុន* ជាប្រភេទដីទំនាបមួយ ដែលលាតសន្ធឹងតាមបណ្ដោយឈូងសមុទ្រមេឌីទែរ៉ាណេ គឺត្រង់តំបន់ខាជើងក្រុងយ៉ូបប៉េ ដែលមានភាពស្រស់ស្អាត់គួរឱ្យគយគន់ដោយវាលស្មៅខៀវខ្ចី ។ (មើល ៣៥:២ និងការពន្យល់ ៦៥:១០ ១រប ២៧:២៩) ។ *ទីរហោស្ថាន* ជាដីវាលធំ ដែលមានទំនាក់ទំនងនិងស្រុក

នោះក៏ជិះស្លឹកចុះ ១០ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឥឡូវ
នេះ អញនឹងក្រោកឡើង[ឡ] ឥឡូវនេះ អញនឹងលើកខ្លួនឡើង
ឥឡូវនេះ អញនឹងបានដំកើងឡើងហើយ[អ] ១១ឯងរាល់គ្នា
នឹងមានគភ៌[ក]ជាស្មៅក្រៀម ហើយនិងបង្កើត[ខ] បានជា
ជញ្ជ្រាំងវិញ ខ្យល់ដង្ហើមរបស់ឯងរាល់គ្នាជាភ្លើង[គ] ដែល
នឹងឆេះបំផ្លាញខ្លួន ១២ហើយអស់ទាំងប្រជាជាតិនឹងបានដូច
ជាការដុតធ្វើកំបោរ[ឃ] គឺដូចជាគុម្ពបន្លា[ង]ដែលកាប់យកទៅ
ដុតក្នុងភ្លើង[ច] ។
១៣ឱឯងរាល់គ្នាដែលនៅឆ្ងាយអើយ[ឆ] ចូរស្តាប់[ជ]ពីការ
ដែលអញបានធ្វើ ហើយឯងរាល់គ្នាដែលនៅជិតដែរ ចូរ
ទទួលស្គាល់ឫទ្ធិរបស់អញចុះ ១៤ពួកមនុស្សមានបាប[ឈ]នៅ
ក្រុងស៊ីយ៉ូន គេភ័យខ្លាចសេចក្តីញាប់ញ័រ[ញ]បានចាប់ពួក
មនុស្សគគ្រក់ហើយ តើមានអ្នកណាក្នុងពួកយើងអាចនឹង
នៅចំពោះភ្លើងដ៏ឆេះបន្សុសនេះបាន[ដ] ក្នុងពួកយើងតើមាន
អ្នកណាអាចនឹងនៅចំពោះការ ដ៏ឆេះនៅអស់កល្បជានិច្ច
បាន ១៥គឺអ្នកណាដែលដើរដោយសុចរិត[ឋ] ហើយពោល
សេចក្តីទៀងត្រង់[ឌ] ជាអ្នកដែលស្អប់កំរៃដែលបានមកដោយ
សង្កត់សង្កិន[ឍ] ហើយរាដៃមិនព្រមទទួលសំណូក[ណ] ក៏ចុក
ត្រចៀកមិនស្តាប់រឿងពីការកំចាយឈាម ហើយដែលធ្មេច
ភ្នែក[ត]មិនព្រមមើលការអាក្រក់ផង ១៦អ្នកនោះនឹងបាននៅ
ក្នុងទីខ្ពស់[ថ] ទីពំនាក់[ទ]របស់អ្នកនោះនឹងនៅលើថ្មដាដ៏មាំមួន[ធ]
ឯអាហារនឹងបានប្រទានមកអ្នកនោះ ហើយទឹករបស់អ្នក
នោះនឹងចេះតែមាន[ន]នៅ ។
១៧ភ្នែកឯងនឹងបានឃើញមហាក្សត្រ[ប] មានទាំងសេចក្តី
លំអរុងរឿង[ផ]របស់ទ្រង់ គេនឹងមើលទៅឃើញស្រុក ដល់ទី
ឆ្ងាយបំផុត[ព] ១៨ចិត្តឯងនឹងនឹកជញ្ជឹងពីការដែលបាននាំឱ្យ
ឯងភ័យខ្លាចនោះថា[ភ] តើស្មៀនកត់ត្រានៅឯណា អ្នកដែល
ដែលស្ទួយអាករនៅឯណា ហើយអ្នកដែលបានរាប់អស់
ទាំងប៉ម តើនៅឯណា[ម] ១៩ឯងនឹងលែងឃើញសាសន៍
ដ៏សហ័សនោះ[យ] ជាសាសន៍ដែលមានសំដីយ៉ាងជ្រៅ ដែល
ឯងរកស្តាប់មិនបាន ជាភាសារឡប់[រ]ដែលឯងយល់មិនបាន
២០ចូរពិនិត្យមើលក្រុងស៊ីយ៉ូន[ល] គឺជាកន្លែងដែលធ្លាប់ធ្វើ
បុណ្យមុតមាំរបស់យើងរាល់គ្នា នោះភ្នែកឯងនឹងឃើញ
ក្រុងយេរូសាឡិម ជាទីលំនៅដ៏ស្ងប់រំងាប់[វ] ជាត្រសាល[ស]
ដែលមិនត្រូវរើរុះទៅឯណាឡើយ[ហ] ឯចំរឹងមិនត្រូវដក
ចេញ ហើយខ្សែណាមួយក៏មិនត្រូវដាច់ផង ២១គឺព្រះ

**៣៣:១០** ឡ ខ.៣ អស ២:២១ អ អស ៥:១៦
**៣៣:១១** ក ទដ ៧:១៤ អស ៥៩:៤ យក ១:១៥ ខ អស ២៦:១៨ គ អស ១:៣១
**៣៣:១២** ឃ អម ២:១ ង អស ៥:៦ ច អស ១០:១៧ ២៧:១១
**៣៣:១៣** ឆ ទដ ៤៨:១០ ៤៩:១ ជ អស ៣៤:១ ៤៨:១៦ ៤៩:១
**៣៣:១៤** ឈ អស ១:២៨ ញ អស ៣២:១១ ដ អស ១:៣១ ៣០:៣០ សក ១៣:៩ សក ១៣:៩ ហព ១២:២៩
**៣៣:១៥** ឋ អស ៥៨:៨ ឌ ទដ ១៥:២ ២៤:៤ ឍ អគ ២២:១៣ ៣៣:៣១ ណ សភ ១៥:២៧ ត ទដ ១១៩:៣៧ **៣៣:១៦** ថ ចទ ៣២:១៣ ទ ទដ ៤៦:១ អស ២៥:៤ ធ ទដ ១៨:១–២ អស ២៦:១ ន អស ៤៨:២១ ៤៩:១០ ៦៥:១៣
**៣៣:១៧** ប អស ៦:៥ ផ អស ៤:២ ព អស ២៦:១៥ **៣៣:១៨** ភ អស ១៧:១៤ ម អស ២:១៥ **៣៣:១៩** យ ទដ ៥:៥ រ លប ១១:៧ អស ២៨:១១ **៣៣:២០** ល ទដ ១២៥:១ វ អស ៣២:១៨ ស លប ២៦:២២ ហ ខ.៦ ទដ ៤៦:៥

ឬទន្លេយ័រដាន់និងសមុទ្រស្លាប់ (សូមមើល ចទ ១:១ ២:៨ និងការពន្យល់) ។ *ស្រុកបាសាន* សូមមើល ២:១៣ និងការពន្យល់។ *ភ្នំកើមែល* សូមមើលការពន្យល់ ១ពវ ១៨:១៩ គឺមានអត្ថន័យថា"ដីសម្បូរជីវជាតិ" (ដូចជាមានក្នុង ២៩:១៧ ៣២:១៥) ឬក៏មានន័យម្យ៉ាងទៀតថា"ចំការផ្លែឈើ" (ក៏មានក្នុង ១៦:១០ ៣៥:២ និងការពន្យល់ ណាហ ១:៤ និងការពន្យល់) ។

**៣៣:១០** *លើកខ្លួនឡើង* (សូមមើល ខ.១៤ និងការពន្យល់) ។

**៣២:១១** *មានគភ៌ . . . បង្កើតបានជាជញ្ជ្រាំង* ប្រៀបធៀប ២៦:១៨ ។ *ខ្យល់ដង្ហើមរបស់ឯងរាល់គ្នាជាភ្លើង* នេះជាផលផ្លែចេញពីភាពហិនហោចរបស់ពួកគេ ។

**៣៣:១២** *កំបោរ* ការដុតឱ្យបានចប់សព្វគ្រប់ (សូមមើល អម ២:១) ។

**៣៣:១៣** *ចូរស្តាប់ . . . ទទួលស្គាល់* ប្រៀបធៀប ៣៤:១ ។

**៣៣:១៤** *ពួកមនុស្សមានបាបនៅក្រុងស៊ីយ៉ូន* សូមមើល ១:២៧–២៨ និងការពន្យល់ ៤:៤ ។ *ភ្លើងដ៏ឆេះបន្សុស* គឺជាវត្តមាននៃការជំនុំជម្រះរបស់ព្រះ (សូមមើល ២៩:៦ ៣០:២៧,៣០ នក ២៤:១៧ ចទ ៤:២៤ ៩:៣ ២សយ ២២:៩ ទដ ១៨:៨ ហព ១២:២៩) ។

**៣៣:១៥** គឺមានលក្ខណៈតម្រូវស្រដៀងគ្នាគឺឃើញមានក្នុង ទដ ១៥:២–៥ ២៤:៣–៦ (សូមមើលក្នុងជំពូកនោះផង) ។

**៣៣:១៦** *ទីខ្ពស់ . . . ដ៏មាំមួន* គឺតំណាងឱ្យភាពរឹងមាំមួនដោយមានព្រះយេហូវ៉ាគង់ជាមួយ (ប្រៀបធៀបនឹង ទដ ១៨:២ និងការពន្យល់) ។ *អាហារ . . . ទឹក* មើលការប្រៀបធៀប ៤៩:១០ ។

**៣៣:១៧** *មហាក្សត្រ* សូមមើល ៣២:១ នឹងការពន្យល់ប្រៀបធៀប ៦:១,៥ និងការពន្យល់ ។ ពាក្យថា *ទាំងសេចក្តីលំអរុងរឿងរបស់ទ្រង់* ក៏ឆ្លុះបញ្ចាំងពីរាជវង្សស្តេចដាវីឌ ដែលជានគររបស់ព្រះមែស៊ី (ប្រៀបធៀប ៤:២ ទដ ៤៥:៣–៥ និងការពន្យល់) ។ ក៏មានលក្ខណៈផ្ទុយខ្លះទៅនិង អស ៥៣:២–៣ ក៏សូមមើលការពន្យល់ក្នុងជំពូកនោះ ។ *ស្រុក . . . ឆ្ងាយផុត* សូមមើល ២៦:១៥ និងការពន្យល់ ។

**៣៣:១៨** *នាំឱ្យភ័យខ្លាច* គឺក្នុងខណៈពេលពួកអាសស៊ើរឈ្លានពានលុកលុយ (សូមមើល ១៧:១២–១៤ និងការពន្យល់) ។ ក៏មានការគ្រប់គ្រងដោយពួកអាសស៊ើរ (សូមមើល ២:១៥) ។

**៣៣:១៩** *សាសន៍ដ៏សហ័ស* សូមមើលការប្រៀបធៀប ១០:១២ និងការពន្យល់ ។ ពាក្យថា *មានសំដីយ៉ាងជ្រៅ* គឺភាសាអាសស៊ើរ ដែលមានទំនាក់ទំនងនិងព្រះគម្ពីរភាសាហេព្រើរ តែមានសម្លេងផ្ទុយគ្នាពីភាសាអ៊ីស្រាអែល សូមមើល ២៨:១១ ចទ ២៨:៤៩ ។

**៣៣:២០** *ចូរពិនិត្យមើលក្រុងស៊ីយ៉ូន* គឺជាទីក្រុងបានទទួលការលោះបាបរួចហើយក៏មានលក្ខណៈផ្ទុយពីទីក្រុងដែលបានពណ៌នាក្នុង ខ.៧–៩ ។ ពាក្យថា *បុណ្យមុតមាំ* សូមមើល ១:១៤ និងការពន្យល់ ។ ពាក្យថា *ស្ងប់រំងាប់* សូមមើល ៣២:១៧–១៨ និងការពន្យល់ ។ *ជាត្រសាល . . . មិនត្រូវរើរុះ* ការនិរទេសក៏ត្រូវបញ្ចប់ ។ ពាក្យថា *មិនត្រូវដក . . . ខ្សែ* សូមប្រៀបធៀបនូវការពណ៌នាស្រដៀងគ្នាចំពោះកូនចៅក្រុងយេរូសាឡិមផងដែរ ៥៤:២ ។

**៣៣:២១** *មានទាំងតេជានុភាព* សូមមើល ១០:៣៤ (ប្រៀបធៀប ទដ

យេហូវ៉ាទ្រង់នឹងគង់ជាមួយនឹងយើងរាល់គ្នា នៅទីនោះ
មានទាំងតេជានុភាព[ឡ] គឺជាកន្លែងមានទន្លេ និងផ្លូវទឹកយ៉ាង
ធំ[អ] ឥតមានសំពៅដែលចែវឬនាវា[ក]ដ៏រុងរឿងណាចេញ
ចូលឡើយ ២២ពីព្រោះព្រះយេហូវ៉ាទ្រង់ជាចៅក្រមនៃយើង
រាល់គ្នា[ខ] ព្រះយេហូវ៉ាទ្រង់ជាអ្នកតែងច្បាប់ឱ្យយើងរាល់
គ្នា[គ] ព្រះយេហូវ៉ាទ្រង់ជាមហាក្សត្រនៃយើងរាល់គ្នា[ឃ] ទ្រង់
នឹងជួយសង្គ្រោះ[ង]យើងផង ២៣ខ្សែជ្រែងរបស់ឯងធូរ
ហើយមិនអាចនឹងទប់ជើងដងក្តោងឱ្យមាំបានទេ ពួកនាវា
បង្ហូតក្តោងមិនបានដែរ ដូច្នេះគេបានចាប់របឹបយ៉ាងសន្ធឹក
ចែកគ្នា គឺជាពួកខ្វិន[ច]ដែលចាប់យកបាន[ឆ] ២៤ឯពួកអ្នក
ដែលនៅក្នុងក្រុងគេ នឹងមិនថាខ្ញុំឈឺទៀតឡើយ[ជ] ព្រះទ្រង់
អត់ទោសចំពោះអំពើ ទុច្ចរិតរបស់ប្រជាជនផង[ឈ]។

## ការជំនុំជម្រះទាស់នឹងជាតិសាសន៍

៣៤ ១ឱអស់ទាំងសាសន៍អើយ ចូរឱ្យចូលមកជិត និង
ស្តាប់ចុះ[ក] អស់ទាំងប្រជាជាតិអើយ[ខ] ចូរផ្ទៀងត្រចៀកចុះ
ត្រូវឱ្យផែនដី[គ] នឹងរបស់សព្វសារពើនៅលើផែនដីស្តាប់
ដែរ ព្រមទាំងលោកីយ និងរបស់ទាំងប៉ុន្មានដែលកើត
ចេញពីនោះផង[ឃ] ២ពីព្រោះព្រះយេហូវ៉ាទ្រង់មានសេចក្តី
គ្នាន់ក្នាញ់នឹងគ្រប់ទាំងសាសន៍ ហើយទ្រង់ក្រោធ[ង]ចំពោល
ពលទ័ពទាំងប៉ុន្មារបស់គេដែរ ទ្រង់បានបំផ្លាញ[ច]អស់រលីង
ក៏បានប្រគល់គេទៅឱ្យត្រូវស្លាប់[ឆ] ៣ខ្មោចរបស់គេដែល
ត្រូវសំឡាប់[ជ]នោះ នឹងបានបោះចោលទៅ ក្លិនស្អុយពី
សាកសព[ឈ]ទាំងនោះនឹងសាយឡើយ[ញ] ហើយភ្នំទាំងប៉ុន្មាន
នឹងត្រូវរលាយទៅដោយឈាមគេ[ដ] ៤ឯបណ្តាពលបរិវារ
នៅលើមេឃនឹងត្រូវរៀវសូន្យទៅ[ឋ] ផ្ទៃមេឃនឹងត្រូវមូរ
ឡើង[ឌ] ដូចជារមូលសៀវភៅ ហើយគ្រប់ទាំងពួកពល
បរិវារ នោះនឹងរោយរុះទៅ[ឍ] ដូចជាស្លឹកទំពាំងបាយជូរ
ក្រៀម[ណ]ជ្រុះចាកដើម ក៏ដូចជាស្លឹកស្រពោនជ្រុះចាកដើម
ល្វាដែរ ៥ដ្បិត ដាវ[ត]របស់អញបានឆ្អែតហើយ នៅលើ
មេឃ មើល និងចុះមកលើស្រុកអេដុំម[ថ] គឺលើសាសន៍ដែល
អញបានដាក់បណ្តាសា ដើម្បីនឹងធ្វើទោសដល់គេទៀត[ទ]
៦ដាវ[ធ]របស់ព្រះយេហូវ៉ា បានប្រឡាក់ឈាមដាប ក៏ដោក

**៣៣:២១** ឡ អស ១០:៣៤ អ នក ១៧:៦ ទដ ១:៣ អស ៣២:២ ៤១:១៨ ៤៨:១៨ ៤៩:១០ ៦៦:១២ ណាហ ៣:៨ ក អស ២៣:១ **៣៣:២២** ខ អស ១១:៤ គ អស ២:៣ យក ៤:១២ ឃ ទដ ៨៩:១៨ ង អស ៥:៩ **៣៣:២៣** ច ២ពវ ៧:៨ ឆ ២ពវ ៧:១៦ **៣៣:២៤** ជ អស ៣០:២៦ ឈ ជន ២៣:២១ ២របា ៦:២១ អស ៤៣:១ ៤៨:២១ យរ ៣១:៣៤ ៣៣:៨ ១យហ ១:៧-៩ **៣៤:១** ក អស ៣៣:១៣ ខ អស ៤១:១ ៤៣:៩ គ ចទ ៤:២៦ ទដ ៤៩:១ ឃ ទដ ២៤:១

**៣៤:២** ង អស ១០:២៥ ច អស ១៣:៥ សក ៥:៣ ឆ អស ៣០:២៥ **៣៤:៣** ជ អស ៥:២៥ ១០:៤ ឈ ទដ ១១០:៦ អគ ៣៩:១១ ញ យអ ២:២០ អម ៤:១០ ដ ឧ.៧ ២សយ ១:២២ អស ៦៣:៦ អគ ៥:១៧ ១៤:១៩ ៣២:៦ ៣៥:៦ ៣៨:២២ **៣៤:៤** ឋ យប ៩:៧ អស ១៣:១៣ ២ពត ៣:១០ ឌ អស ៣៨:១២ ហព ១:១២ ឍ មថ ២៤:២៩ មក ១៣:២៥ ណ យប ៨:១២ អស ១៥:៦ មថ ២១:១៩ **៣៤:៥** ត ចទ ៣២:៤១-៤២ យរ ៤៧:៦ អគ ២១:៥ សក ១៣:៧ ថ ២សយ ៨:១៣-១៤ ២របា ២៨:១៧ អម ១:១១-១២ ទ ចទ ១៣:១៥ យស ៦:១៧ អស ២៤:៦ អម ៣:១៤-១៥ ៦:១១ **៣៤:៦** ធ ចទ ៣២:៤១ អស ២៧:១

៩៣:៣-៤ និងការពន្យល់) ។ ពាក្យថា *ទន្លេនឹងផ្លូវទឹកយ៉ាងធំ* គឺដើម្បីការពាទឹកដីនៃស្រុកនោះកុំឱ្យមានការឈ្លានពាន (២៣:១) ឬក៏ (សូមមើល ៣:៨ និងការពន្យល់ ។

**៣៣:២២** *ចៅក្រមនៃយើង* សូមមើល ២:៤ និងការពន្យល់ ។ ពាក្យថា *អ្នកតែងច្បាប់ឱ្យយើង* សូមមើល ២:៣ ៥១:១៤ និងការពន្យល់ ។ ពាក្យថា *មហាក្សត្រនៃយើង* សូមមើល ឧ.១៧ ៣២:១ និងការពន្យល់ និងមើល ទដ ៤៦:៤៦ ។ *សង្គ្រោះ* សូមមើល ពច ២:១៦-១៩ និងការពន្យល់ ។

**៣៣:២៣** *ខ្សែ* គឺជាខ្សែកប៉ាល ហើយក្រុងយេរូសាឡិមតំណាងឱ្យរូបភាពជាកប៉ាល ដែលពុំបានត្រៀមខ្លួនក្នុងការចេញដំណើរទៅច្បាំងនិងពួកអាសស៊ើរ ។ *ដូច្នេះ* គឺជាពេលដែលព្រះអម្ចាស់ផ្តួលពួកអាសស៊ើរ (សូមមើល ១០:៣៣-៣៤ ៣៧:៣៦ និងការពន្យល់) ។

**៣៣:២៤** គឺទាក់ទងដំណើរជីវិតខាងសាចឈាម និងខាងព្រលឹងវិញ្ញាណរបស់លោក អេសាយនៅក្រុងយេរូសាឡិម ក្នុង ឧ.១៧:,២០-២២ ។

**៣៤:១-៣៥:១០** មានជំពូក ៣៤-៣៥ ដែលសេចក្តីសន្និដ្ឋាននៃពិភពមនុស្ស ឬចក្រក្រវាល គឺជាហេតុការណ៍បន្ទាប់ពីការស្លាប់ទៅ ក៏ឆ្លើយតបនិងជំពូក ២៤:២៧ ដែលចប់ដោយជំពូក ១៣:២៣ (សូមមើលការពន្យល់ ២៤:១-២៧:១៣) ។

**៣៤:២** *សេចក្តីគ្នាន់ក្នាញ់ . . . ក្រោធ* គឺសំដែងពីថ្ងៃនៃព្រះយេហូវ៉ា (សូមមើល ២:១១,១៧,២០ ២៦:២០-២១ និងការពន្យល់) ក៏សូមមើល ១៣:៣, ១៣ និងការពន្យល់ ។ *បំផ្លាញអស់រលីង* គឺជាប្រភេទហឹនវិនាសដែលសាសន៍កាណានសំនឹងទទួល សូមមើល ឧ.៥ យស ៦:១៧ និងការពន្យល់ ។ *ត្រូវស្លាប់* សូមមើល ៣០:២៥ និងការពន្យល់ ។

**៣៤:៣** *បោះចោលទៅ* (សូមមើល ១៤:១៩ និងការពន្យល់) ។

**៣៤:៤** *បណ្តាពលបរិវារ . . . ត្រូវរៀវសូន្យទៅ* គឺជាភាពចលាចលក្នុងនគរស្ថានសសួគ៌ ដែលជាលក្ខណៈមួយបង្ហាញពីថ្ងៃរបស់ព្រះយេហូវ៉ា (សូមមើល ១៣:១០,១៣ និងការពន្យល់សូមប្រៀបធៀបនិង អគ ៣២:៧-៨) ។ ពាក្យថា *ផ្ទៃមេឃ . . . នឹងរោយចុះ* ក៏មាននៅក្នុងគម្ពីរ មក ១៣:២៥ (សូមមើលការពន្យល់) វវ ៦:១៣-១៤ ដែលមានទំនាក់ទំនងនិងភាពឈឺចាប់យ៉ាងខ្លាំង (មថ ២៤:២១) និងការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ។

**៣៤:៥-៦** *ដ្បិតដាវរបស់អញ . . . ដាវរបស់ព្រះយេហូវ៉ា* សូមមើល ទដ ៧:១២-១៣ និងការពន្យល់ ។

**៣៤:៥** *បានឆ្អែតហើយ* ប្រៀបធៀប អគ ៣៩:១៨-២០ និងការពន្យល់ ។ *ស្រុកអេដុំម* ដែលជាតំណាងឱ្យសត្រូវរបស់ព្រះអម្ចាស់ទាំងអស់ និងរាស្ត្ររបស់ទ្រង់ដូមជាពួកស្រុកម៉ូអាប់នៅក្នុង ២៥:១០-១២ (សូមមើលការពន្យល់ ២៥:១០) ។ ដោយសាសន៍ពួកស្រុកអេដុំមដែលត្រូវបានជម្លៀសចេញពីស្រុកកំណើតរបស់គេ ដោយសាពួកអាណាចក្របាធៀន ឬពួកអារ៉ាម គឺក្នុងកំឡុងពេលឆ្នាំ ៥០០មុន គ.ស ។

**៣៤:៦** *ខ្លាញ់* បានគេសន្មត់ថាជាសត្វពិសេសសម្រាប់ថ្វាយទៅព្រះយេហូវ៉ាក្នុងពិធីធ្វើយញ្ញបូជា (សូមមើល វវ ៣:៩-១០) ។ *កូនចៀមនឹងពពែ* គឺជានិមិត្តរូបតំណាងឱ្យប្រជាជន ។ *ការថ្វាយបញ្ញបូជា* ក៏ជាសង្គ្រាមដែលតែងតែប្រៀបធៀបនិងយញ្ញបូជា (សូមមើល យរ ៤៦:១០ និងការពន្យល់ ៥០:២៧ អគ ៣៩:១៧-១៩ និងការពន្យល់ក៏ប្រៀបធៀបនឹង វវ ១៩:១៧-

ដោយខ្លាញ់ គឺដោយឈាមកូនចៀមនឹងពពែ ព្រមទាំង
ខ្លាញ់ដែលជាប់នៅអង្គញ់នៃចៀមឈ្មោល ពីព្រោះព្រះ
យេហូវ៉ាទ្រង់មានការថ្វាយយញ្ញបូជា[ន]នៅក្រុងបុសរ៉ា[ប] ក៏
មានការសង្ហារ[ផ]យ៉ាងសំបើមនៅក្នុងស្រុកអេដំម ៧ឯពួក
ទន្សោង[ព]នឹងដួលចុះជាមួយនឹងគេ ព្រមទាំងគោស្ទាវនឹង
គោចាស់ផង[ភ] ស្រុកគេនឹងបានជាបដោយឈាម[ម] ហើយ
ធូលីដី និងបានជោកដោយខ្លាញ់ ។
៨ដ្បិតព្រះយេហូវ៉ា ទ្រង់មានថ្ងៃ[យ]សំរាប់សងសឹក[រ] មាន
ឆ្នាំសំរាប់សង្ខង[ល]ដល់គេជំនួសក្រុងស៊ីយ៉ូន ៩ជ្រោះទឹកនៅ
ស្រុកអេដំមនឹងត្រឡប់ជាជ័រ ធូលីដីនឹងត្រឡប់ជាស្ពាន់ធ័រ[វ]
ហើយស្រុកគេនឹងមានពេញជាជ័រឆេះ ១០ភ្លើងនោះនឹង
មិនរលត់[ស]ទាំងយប់ទាំងថ្ងៃ ហើយផ្សែងនឹងហុយឡើងជា
ដរាបតទៅ[ហ] ស្រុកនោះនឹងនៅជាកំឡោចគ្រប់ទាំងដំណ[ឡ]
នៃមនុស្សតទៅ[អ] ឥតដែលមានអ្នកណាដើរកាត់តាមនោះ
ទៀតឡើយ ១១តែទុង[ក] និងប្រមា នឹងបានស្រុកនោះជា
លំនៅវិញ ហើយគូក និងក្អែក[ខ] នឹងអាស្រ័យនៅទីនោះដែរ
ទ្រង់ នឹងសន្ធឹងខ្សែវាស់នៅលើស្រុកនោះ[គ] ឱ្យត្រូវខូចបង់[ឃ]
ហើយស្ទង់កូនតឹង[ង] ឱ្យត្រូវសូន្យទទេ ១២គេនឹងហៅពួក
ត្រកូលខ្ពស់មកឱ្យតាំងរាជ្យឡើង តែនឹងគ្មានអ្នកណាមក
ឡើយ ឯពួកចៅហ្វាយ[ច]ទាំងប៉ុន្មាន នឹងផុតអស់[ឆ]ទៅ
១៣បន្លា[ជ]នឹងដុះឡើងនៅក្នុងព្រះរាជដំណាក់[ឈ] ហើយ
អញ្ចាញ និងដំបងយក្ខ នឹងដុះនៅក្នុងបន្ទាយរបស់គេដែរ
ស្រុកនោះនឹងបាន ជាទីលំនៅនៃឆ្កែព្រៃ[ញ] ហើយជាព្រះ
រាជរោង សំរាប់សត្វអូសទ្រីច[ដ] ១៤អស់ទាំងសត្វ[ឋ]ដែល
នៅទីរហោស្ថាន នឹងជួបជុំជាមួយនឹងហ្វូងចចក[ឌ] ហើយ
ពពែព្រៃនឹងស្រែកឆ្លើយគ្នា ឯឪឡ[ឍ] នឹងចុះមកទំនៅទីនោះ
ហើយនឹងធ្វើសំបុកនៅដែរ ១៥ពស់វែកនឹងធ្វើសំបុកនៅ
ទីនោះ ព្រមទាំងពង ហើយញាស់កូនផង រួចប្រមូលកូនមក
ការពារ[ណ] អើ ពួករអាត[ត]នឹង មកទាំងគូៗ ប្រជុំនៅទីនោះ
ដែរ ។
១៦ចូរស្វែងរកក្នុងគម្ពីរ[ថ]របស់ព្រះយេហូវ៉ា ហើយ
មើលចុះ នឹងគ្មានសត្វណាមួយនេះខានមក[ទ] ហើយនឹងគ្មាន
ណាមួយឥតគូឡើយ ពីព្រោះព្រះឱស្ឋ[ធ]ទ្រង់បានបង្គាប់
ហើយ[ន] ព្រះវិញ្ញាណទ្រង់ក៏បានប្រមូលមកដែរ ១៧ទ្រង់
បានបោះឆ្នោតឱ្យពួកសត្វទាំងនោះ[ប] ហើយព្រះហស្តទ្រង់
បានវាស់ចែកស្រុកឱ្យ វារាល់គ្នានឹងបានស្រុកនោះជារៀង
រាបដរាប ហើយនិងអាស្រ័យនៅ ដរាបអស់ទាំងដំណ
មនុស្សតរៀងទៅ[ផ] ។

## សេចក្ដីអំណរនៃអ្នកបានសង្គ្រោះ

**៣៥** ១ទីរហោស្ថាន[ក] ហើយទីហួតហែង និងមានសេចក្ដី
អំណរ ឯសមុទ្រខ្សាច់ និងរីករាយ ហើយផ្កាឡើង[ខ] ដូច

**៣៤:៦** ន លវ ៣:៩ ប លប ៣៦:៣៣ ផ អស ៣០:២៥ យរ ២៥:៣៤ វវ ១៩:១៧ **៣៤:៧** ព ជន ២៣:២២ ភ ទដ ៦៨:៣០ ម ២សយ ១:២២ **៣៤:៨** យ អស ២:១២ រ អស ១:២៤ ៣៥:៤ ៤៧:៣ ៦៣:៤ ល អស ៥៩:១៨ អគ ២៥:១២–១៧ យអ ៣:៤ អម ១:៦–៨,៩–១០ **៣៤:៩** វ លប ១៩:២៤ **៣៤:១០** ស អស ១:៣១ ហ វវ ១៤:១០–១១ ១៩:៣ ឡ ខ.១៧ អ អស ១៣:២០ ២៤:១ យរ ៤៩:១៨ អគ ២៩:១២ ៣៥:៣ មឡ ១:៣ **៣៤:១១** ក លវ ១១:១៦–១៨ ចទ ១៤:១៥–១៧ វវ ១៨:២ ខ លវ ៨:៧ គ អស ២១:១១

អគ ៣៥:១៥ យអ ៣:១៩ អប ១:១ មឡ ១:៤ ឃ លប ១:២ ង ២ពវ ២១:១៣ អម ៧:៨ **៣៤:១២** ច យប ១២:២១ ទដ ១០៧:៤០ អស ៤០:២៣ យរ ២១:៧ ២៧:២០ ៣៩:៦ អគ ២៤:៥ ឆ អស ២៩:២០ ៤១:១១–១២ **៣៤:១៣** ជ អស ៥:៦ ៧:១៩ ឈ អស ១៣:២២ ញ ទដ ៤៤:១៩ អស ១៣:២២ យរ ៩:១១ ១០:២២ ដ លវ ១១:១៦–១៨ **៣៤:១៤** ឋ ទដ ៧៤:១៤ ឌ អស ១៣:២២ ឍ វវ ១៨:២ **៣៤:១៥** ណ ទដ ១៧:៨ ត ចទ ១៤:១៣ **៣៤:១៦** ថ អស ៣០:៨ ទ អស ៤០:២៦ ៤៨:១៣ ធ អស ១:២០ ៥៨:១៤ ន អស ១:២០ **៣៤:១៧** ប អស ១៧:១៤ យរ ១៣:២៥ ផ ខ.១០ **៣៥:១** ក អស ២៧:១០ ៣២:១៥,១៦ ៤១:១៨–១៩ ខ អស ២៧:៦ ៥១:៣

១៨) ។ *ក្រុងបុសរ៉ា* គឺជាទីក្រុងសំខាន់នៅក្នុងស្រុកអេដំម ក៏ជាមជ្ឈមណ្ឌលចិញ្ចឹមសត្វចៀមវាមានទីតាំងស្ថិតនៅប្រហែលជា៤០ គ.ម ពីផ្នែកចុងខាងត្បូង នៃសមុទ្រស្លាប់ ។ ហើយឈ្មោះក្រុងនោះមានន័យថា "ការប្រមូលផលពីផ្លែទំពាំងបាយជូរ" (ប្រៀបធៀប ៦៣:១–៣) ។

**៣៤:៧** *គោស្ទាវនិងគោចាស់* ក៏ជាការប្រៀបធៀបនិងអ្នកដឹកនាំនៅស្រុកនោះ ។ *ជាបដោយឈាម* សូមមើល ខ.៣ ។

**៣៤:៨** *ថ្ងៃសំរាប់សងសឹក* សូមមើល ៣៥:៤ ៦១:២ (សូមមើល ២សយ ៨:១៣–១៤) ។

**៣៤:៩** *ស្ពាន់ធ័រ* គឺការខូចខាតដួលរលំរបស់ស្រុកអេដំមនិងក្រុងកូម៉ូរ៉ា និងការដួលរលំរបស់ក្រុងសូដំម (សូមមើល យរ ៤៩:១៧–១៨ និងការពន្យល់) ក៏សូមមើល ១:៣១ លប ១៩:២៤ និងការពន្យល់ផង ។

**៣៤:១០** *ផ្សែងនឹងហុយ . . . ជាដរាប* ក៏ដូចជាមាននៅស្រុកបាប៊ីឡូន សូមមើលក្នុង វវ ១៩:៣ ១៤:១០–១១ និងការពន្យល់) ។

**៣៤:១១** *តែទុង . . . នឹងប្រមា . . . ហើយគូក . . . នឹងក្អែក* ជាប្រភេទសត្វ "មិនស្អាត" (សូមមើល ចទ ១៤:១៤–១៧) ។ ក៏ជាប្រភេទសត្វដែលរសនៅតាមគំនរបាក់បែកនៃស្រុកបាប៊ីឡូន (១៣:២១) និងក្រុងនីនីវេ (សថ ២:១៤) ។ ពាក្យថា *សន្ធឹងខ្សែវាស់* គឺប្រៀបធៀបនឹង ២៨:១៧ និងការពន្យល់។ ពាក្យថា *ត្រូវខូចបង់ . . . ត្រូវសូន្យទទេ* គឺបើក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យទាំងនេះ គឺក៏បានប្រើក្នុង លប ១:២ ក៏សូមមើលការពន្យល់ជំពូកនោះផង ។

**៣៤:១៣** *បន្លា . . . អញ្ចាញ* ប្រៀបធៀប ៧:២៤–២៥ ។

**៣៤:១៤** *ទីរហាស្ថាន . . . នឹងហ្វូងចចក* សូមមើល ១៣:២០–២២ និងការពន្យល់ ។ *ពពែព្រៃ* ពាក្យនេះជួនកាលគេប្រៀបនិងពួកអារក្សឬវិញ្ញាណអាក្រក (សូមមើលការពន្យល់ ១៣:២១) ។

**៣៤:១៥** *ពស់វែក . . . ពួករអាត* គឺជាប្រភេទនៃសត្វមិនស្អាត (សូមមើល ខ.១១ និងការពន្យល់ចទ ១៤:១៣,១៥–១៧) ។

**៣៤:១៦** *ក្នុងគម្ពីរ* គឺជាគ្រាំងដែលលោកអេសាយថ្លែងទំនាយ គឺសម្រាប់ឱ្យមនុស្សបានអានគឺក្នុងគ្រាដែលក្រុងអេដំមបានខូចខាតបាក់បែកទៅ ។

**៣៤:១៧** *បានវាស់ចែកស្រុកឱ្យ* គឺជាព្រះយេហូវ៉ាដែលប្រទានទឹកដីឱ្យទៅពួកគេ មើល ខ.១១,១៣,១៥ ដូចជាស្រុកអេដំម ។

**៣៥:១** *ទីរហោស្ថាន . . . នឹងមានសេចក្ដីអំណរ* គឺជាការបង្ហាញពីនិស្ស័យរបស់មនុស្សដែលជារឿងធម្មតាបានចារក្នុងគម្ពីរ អេសាយ (សូមមើល

ជាកុឡាប[ក] ២គឺនឹងផ្កាឡើងយ៉ាងសន្ធឹក ក៏នឹងរីករាយដោយ
សេចក្តីអំណរ[ឃ] និងបទចំរៀងផង គេនឹងលើកសេចក្តី
សរសើរពីលំអនៃព្រៃល្បាណូន[ង] ផ្ទេរទៅឱ្យដល់សមុទ្រ
ខ្សាច់វិញ ព្រមទាំងសេចក្តីរុងរឿងនៃភ្នំកើមែល[ច] និង
វាលសារ៉ុន[ឆ]ផង គេនឹងឃើញសិរីល្អ[ជ]របស់ព្រះយេហូវ៉ា
គឺជាសេចក្តីរុងរឿងរបស់ព្រះនៃយើងរាល់គ្នា[ឈ]។
៣ចូរចំរើនកំឡាំងដៃដែលខ្សោយ ហើយឱ្យក្បាល
ជង្គង់[ញ]ដែលញ័របានមាំមួនឡើង ៤ត្រូវឱ្យប្រាប់[ដ]ដល់ពួកអ្នក
ដែលមានចិត្តភ័យខ្លាចថា[ឋ] ចូរឱ្យមានកំឡាំងចុះ កុំឱ្យខ្លាច
ឡើយ[ឌ] មើល ព្រះនៃអ្នករាល់គ្នា ទ្រង់នឹងយាងមក[ឍ]សង
សឹក[ណ] ហើយនឹងយករង្វាន់របស់ព្រះមក ទ្រង់នឹងយាងមក
ជួយ[ត] សង្គ្រោះអ្នករាល់គ្នា ។
៥គ្រានោះ ភ្នែករបស់មនុស្សខ្វាក់ នឹងបានភ្លឺឡើង[ថ]
ហើយត្រចៀករបស់មនុស្សថ្លង់[ទ]នឹងឮបាន ៦គ្រានោះ ពួក
មនុស្សខ្វិន[ធ]នឹងលោតដូចជាប្រើស[ន] ហើយអណ្តាត[ប]របស់
មនុស្សគក៏នឹងច្រៀងឡើង[ផ] ដ្បិតនៅទីរហោស្ថាននឹងមាន
ក្បាលទឹកផុសចេញ ហើយនឹងមានផ្លូវទឹកហូរ[ព]នៅសមុទ្រ
ខ្សាច់ដែរ ៧ខ្សាច់ដែលក្តៅព្រាចៗនឹងត្រឡប់ជាត្រពាំង ទឹក
ហើយដីហួតហែង[ភ]នឹងមានក្បាលទឹកហូរ[ម] នៅត្រង់ទីលំនៅ
របស់ចចក[យ] ជាកន្លែងដែលវាដេក នោះនឹងមានដុះស្មៅ
ព្រមទាំងបបុស[រ] និងកក់ផង ៨ហើយនៅទីនោះ នឹងមាន
ថ្នល់១[ល] ជាផ្លូវដែលគេនឹងហៅថា "ផ្លូវបរិសុទ្ធ"[វ] ពួក
មនុស្សស្មោកគ្រោក[ស] នឹងមិនដែលដើរតាមផ្លូវនោះឡើយ
គឺផ្លូវនោះ និងទុកសំរាប់តែពួកអ្នក ដែលបានប្រោសលោះ
ប៉ុណ្ណោះ ឯមនុស្សដែលដើរដំណើរ ទោះបើជាមនុស្សល្ងី
ល្ងើក៏ដោយ គង់តែមិនវង្វេងដែរ ៩នឹងគ្មានសិង្ហ[ហ] ឬសត្វ
កំណាច[ឡ]ណា ឡើងមកតាមនោះឡើយ គេក៏នឹងមិនដែល
ប្រទះឃើញវាដែរ គឺមានតែពួកប្រោសលោះ[អ]ដែលនឹង
ដើរតាមនោះ ១០ឯពួកអ្នកដែលព្រះយេហូវ៉ាបានប្រោស
ឱ្យរួច[ក]គេនឹងវិលមកវិញ គេនឹងមកដល់ក្រុងស៊ីយ៉ូនដោយ
ច្រៀង[ខ] ហើយនិងមានសេចក្តីអំណរដ៏នៅអស់កល្បជានិច្ច
ពាក់នៅលើក្បាលគេ គេនឹងបានសេចក្តីត្រេកអរ[គ] និង
សេចក្តីរីករាយ[ឃ] ឯអស់ទាំងសេចក្តីទុក្ខព្រួយ និងដំងូរទាំង
ប៉ុន្មាននោះនឹងរត់បាត់ទៅ[ង]។

**៣៥:១** គ បស ២:១ **៣៥:២** ឃ លប ២១:៦ ទដ ១០៥:៤៣ អស ១២:៦ ២៥:៩ ៤៤:២៣ ៥១:១១ ៥២:៩ ៥៥:១២ ង អរ ៣:៧ អស ៣៣:៩ ច បស ៧:៥ ឆ ១របា ២៧:២៩ អស ៦៥:១០ ជ នក ១៦:៧ អស ៤:៥ ៥៩:១៩ ឈ អស ២៥:៩ **៣៥:៣** ញ យប ៤:៤ ហព ១២:១២ **៣៥:៤** ដ ២រប ៣២:៦ អស ៤០:២ សក ១:១៣ ឋ ចទ ២០:៣ អស ២១:៤ ឌ យស ១:៩ អស ៧:៤ ឍយ ១០:១៩ ឍ អស ៤០:៩,១០–១១ ៥១:៥ ៦២:១១ វវ ២២:១២ ណ អស ១:២៤ ៣៤:៨ ត អស ២៥:៩ **៣៥:៥** ថ ទដ ១៤៦:៨ យហ ៩:៦–៧ កច ២៦:១៨ ទ អស ២៩:១៨ ៤២:១៨ ៥០:៤ **៣៥:៦** ធ មថ ១៥:៣០ លក ៧:២២ យហ ៥:៨–៩ កច ៣:៨ ន ២សយ ២២:៣៤ ប អស ៣២:៤ មថ ៩:៣២–៣៣ ១២:២២ មក ៧:៣៥ លក ១១:១៤ ផ ទដ ២០:៥ ព នក ១៧:៦ យហ ៧:៣៨ **៣៥:៧** ភ ទដ ៦៨:៦ អស ៤១:១៧ ៤៤:៣ ៥៥:១ ម ទដ ១០៧:៣៥ អស ៤៩:១០ ៥៨:១១ យ អស ១៣:២២ រ យប ៨:១១ ៤០:២១ **៣៥:៨** ល អស ១១:១៦ ៣៣:៨ យរ ៣១:២១ មថ ៧:១៣–១៤ វ អស ៤:៣ ១ពត ១:១៥ ស អស ៥២:១ **៣៥:៩** ហ អស ៣០:៦ ឡ អស ១១:៦ ១៣:២២ ៣៤:១៤ អ នក ៦:៦ លវ ២៥:៤៧–៥៥ អស ៥១:១១ ៦២:១២ ៦៣:៤ **៣៥:១០** ក យប ១៩:២៥ អស ១:២៧ ខ អស ៣០:២៩ គ ទដ ៤:៧ ១២៦:៥ អស ២៥:៩ ឃ ទដ ៥១:៨ អស ៥១:៣ ង អស ៣០:១៩ វវ ៧:១៧ ២១:៤

៣៣:៩ ៤៤:២៣ ៥៥:១២) ។ *សមុទ្រខ្សាច់* ដូចនៅស្រុកវាល (សូមមើលការពន្យល់ ៣៣:៩) ។ *កុឡាប* សូមមើលអត្ថបទពន្យល់ ២:១ ។

**៣៥:២** *រីករាយ . . . សេចក្តីអំណរ* សូមមើល ៥៤:១ និងការពន្យល់ ។ *ព្រៃល្បាណូន . . . នៃភ្នំកើមែល . . . វាលសារ៉ុន* គឺជាតំបន់សម្បូរទៅដោយជីវជាតិដែលមានកេរ្តិ៍ឈ្មោះល្បីពីទេសភាពរបស់ព្រៃឈើទាំងនោះ (សូមមើលការពន្យល់ ៣៣:៩) ។ *សិរីល្អរបស់ព្រះយេហូវ៉ា* សូមមើល ៦:៣ និងការពន្យល់) ។

**៣៥:៣** សូមមើល ហព ១២:១២ ។

**៣៥:៤** *ចូរមានកំឡាំចុះកុំឱ្យខ្លាចឡើយ* គឺជាព្រះបន្ទូលលើទឹកចិត្តដល់លោកយ៉ូស្វេ នៅក្នុង យស ១:៦–៧–៩ (សូមមើលការពន្យល់ យស ១:១៨) ។ *ទ្រង់នឹងយាងមក* សូមប្រៀបធៀប ៤០:៩–១០ គឺជាភាសាតែមួយដែលបានប្រើនិយាយពីការយាងមករបស់ព្រះមែស៊ី (សូមមើល ៦២:១១ និងការពន្យល់ ប្រៀបធៀបនិង វវ ២២:១២,២០ និងការពន្យល់) ។ *សងសឹក . . . យករង្វាន់របស់ព្រះមក* សូមមើលការពន្យល់ ៣៤:៨ ។

**៣៥:៥** *ភ្នែក . . . ត្រចៀក* មើល ២៩:១៨ ៣២:៣ ៤២:៧ និងការពន្យល់ ។ ការសង្គ្រោះផ្នែកខាងសាច់ឈាមនិងខាងព្រលឹងវិញ្ញាណ គឺមានការផ្សារភ្ជាប់ព្រមគ្នាចំពោះកិច្ចការបម្រើព្រះ ឬព្រះរាជកិច្ចរបស់ព្រះគ្រីស្ទ (សូមមើល លក ៧:២២ និងការពន្យល់) ។

**៣៥:៦** *ពួកមនុស្សខ្វិននិងលោក . . . អណ្តាតរបស់មនុស្សគក៏នឹងច្រៀងឡើង* គឺជាសញ្ញានៃយុគ្គសម័យព្រះមែស៊ី (មើល មថ ១២:២២ កជ ៣:៧–៨) ។ ពាក្យថា *ក្បាលទឹក . . . ទឹកហូរ* គឺសូមមើល ៣២:២ និងការពន្យល់ និងប្រៀបធៀបពីការដែលព្រះទ្រង់ប្រទានឱ្យមានទឹកនៅក្នុង នក ១៧:៦ ២ពវ ៣:១៥–២០ (សូមមើលការពន្យល់ ២ពវ ៣:១៧) ។

**៣៥:៧** *ក្បាលទឹកហូរ* សូមប្រៀបធៀបនឹង ៤២:១៨ ។ *មានដុះស្មៅព្រមទាំងបបុស* គឺជាប្រភេទរុក្ខជាតិដែលដុះនៅវាលភក់និងបឹង (មើលការប្រៀបធៀប ១៩:៦–៧) ។

**៣៥:៨** *ថ្នល់១* គឺជាផ្លូវដែលបានកសាងឡើងដើម្បីធ្វើដំណើរស្រួល (សូមមើល ១១:១៦ ៤០:៣ និងកាពន្យល់) ។ *ផ្លូវបរិសុទ្ធ* គឺជាផ្លូវដាច់ដោយឡែកពីផ្លូវធម្មតាគឺសម្រាប់អ្នកបរិសុទ្ធនិងអ្នកដែលប្រោសលោះហើយ (ខ.៩) ក៏បានប្រើនាពេលសម័យបុរាណ ។

**៣៥:៩** *សិង្ហ . . . ឬសត្វកំណាច* ជួនកាលសត្វកំណាចទាំងអស់នេះធ្វើឱ្យការធ្វើដំណើរមានគ្រោះថ្នាក់យ៉ាងខ្លាំង (សូមមើល ចទ ៨:១៥ ពច ១៤:៥ និងការពន្យល់) ។ ពាក្យថា *ពួកប្រោសលោះ* គឺពួកទាំងឡាយណាដែលព្រះយេហូវ៉ាដោះលែងចេញពីចំណង (ប្រៀបធៀប ១:២៧ ៥១:១០ ៦២:១២ នក ៦:៦–៨ និងការពន្យល់លវ ២៥:៤៧–៤៨ ចទ ៧:៨) ។

**៣៥:១០** ក៏បានរំលឹកនៅក្នុង ៥១:១១ ។ *នឹងមកដល់ក្រុងស៊ីយ៉ូនដោយចៀង* គឺដូចជាសាសន៍អ៊ីស្រាអែល ដែធ្វើដូច្នេះដែរ ខណៈពេលពួកគេបានវិលត្រឡប់ពីការជម្លៀសរបស់ពួកបាប៊ីឡូនវិញ (សូមមើលសេចក្តីផ្តើម ទដ ១២៦) សូមមើល ខ.៩ ។ *សេចក្តីទុក្ខព្រួយ . . . រត់បាត់ទៅ* សូមប្រៀបធៀប ២៥:៨ ៦៥:១៩ ។

## ស្ដេចសានហេរីបគម្រាមក្រុងយេរូសាឡិម

*៣៦:១-២២ – ២ពាវ ១៨:១៣-៣៧ ២របា ៣២:៩-១៩*

**៣៦** ១រីឯនៅឆ្នាំទី១៤ក្នុងរាជ្យស្ដេចហេសេគា[ក] នោះ
សានហេរីប[ខ]ជាស្ដេចស្រុកអាសស៊ើរ ទ្រង់ឡើងមកច្បាំង
យកបានអស់ទាំងទីក្រុងមានកំផែងនៅស្រុកយូដា[គ] ២រួច
ស្ដេចអាសស៊ើរទ្រង់ចាត់រ៉ាបសាកេ ឱ្យនាំពលទ័ពយ៉ាងធំ
ពីក្រុងឡាគីស[ឃ] ទៅឯស្ដេចហេសេគា នៅក្រុងយេរូសាឡិម
លោកក៏ឈរនៅត្រង់ប្រឡាយទឹក នៃស្រះខាងលើ តាមផ្លូវ
ទៅឯចំការជាងប្រមោក[ង] ៣នោះអេលាគីម[ច] កូនហ៊ីលគីយ៉ា
ជាឧកញ៉ាវាំង[ឆ] និងសេបណា[ជ] ជាស្មៀនហ្លួង[ឈ] ហើយ
យ៉ូអា[ញ] កូនអេសាភ ជាអ្នកតែងពង្សាវតារ[ដ] ក៏ចេញទៅឯ
លោក ។

៤រ៉ាបសាកេប្រាប់គេថា ចូរទៅប្រាប់ហេសេគាឥឡូវ
ថាស្ដេចដ៏ជាធំ គឺស្ដេចស្រុកអាសស៊ើរ ទ្រង់មានបន្ទូល
ដូច្នេះ តើទីពឹងណាដែលឯងទុកចិត្តនេះ ៥អញថា គំនិត
របស់ឯង នឹងកំឡាំងសំរាប់ច្បាំង នោះជាឥតប្រយោជន៍
ទទេ ចុះតើឯងពឹងដល់អ្នកណា បានជាឯងបះបោរ[ឋ]នឹងអញ
ដូច្នេះ ៦មើល ឯងពឹង[ឌ]ដល់ស្រុកអេស៊ីព្ទ[ឍ,ណ]ទុកជាឈើច្រត់
គឺ ជាដើមត្រែង[ត]កំបាក់នោះ ដែលបើកាលណាផ្អែកទៅលើ
នោះនឹងចាក់ទំលុះដៃវិញ គឺផារ៉ោន ជាស្ដេចអេស៊ីព្ទ គេ
បែបយ៉ាងនោះ ដល់អស់អ្នកណាដែលពឹងដល់គេ ៧តែបើ
ឯងនិយាយមកអញថា យើងរាល់គ្នាទុកចិត្ត[ថ]ដល់ព្រះយេ
ហូវ៉ា ជាព្រះនៃយើងវិញ នោះតើមិនមែនជាព្រះនោះឯង
ដែលហេសេគាបានបំបាត់អស់ទាំងទីខ្ពស់[ទ] និងអាសនា
ទ្រង់ចេញទេឬអី ដោយប្រាប់ដល់ពួកសាសន៍យូដា នឹង
ពួកក្រុងយេរូសាឡិមថា ត្រូវឱ្យឯងរាល់គ្នាថ្វាយបង្គំនៅមុខ
អាសនា១នេះវិញ[ធ] ៨ដូច្នេះ ចូរឯងចុះសន្យានឹងស្ដេចស្រុក
អាសស៊ើរ ជាចៅហ្វាយរបស់អញឥឡូវចុះ នោះអញនឹង
ឱ្យសេះ[ន]២ពាន់ដល់ឯង បើឯងរកអ្នកជិះបាន ៩បើយ៉ាង
នោះ ធ្វើដូចម្ដេចឱ្យឯងឈ្នះមេទ័ព១យ៉ាងតូច ក្នុងពួកអ្នក
បំរើរបស់ចៅហ្វាយអញបាន ទាំងទុកចិត្តនឹងស្រុកអេស៊ីព្ទ[ប]
ឱ្យបានរទេះចំបាំង[ផ] និងទ័ពសេះទៀត[ព] ១០តើអញបានឡើង
មកច្បាំងបំផ្លាញស្រុកនេះ ដោយឥតព្រះយេហូវ៉ាឬអី គឺ
ព្រះយេហូវ៉ាទេតើ ដែលទ្រង់បានមានបន្ទូល[ភ]បង្គាប់អញថា
ចូរឡើងទៅច្បាំងបំផ្លាញស្រុកនេះចុះ ។

១១ឯអេលាគីម សេបណា និងយ៉ូអា[ម] ក៏ឆ្លើយតបទៅ
រ៉ាបសាកេថា សូមមានប្រសាសន៍ ជាភាសាអើរ៉ាមមក

**៣៦:១** ក ២ពាវ ១៨:៩ ខ ២របា ៣២:១ គ ទដ ១០៩:១១ **៣៦:២** ឃ យស ១០:៣ ង អស ៧:៣ **៣៦:៣** ច អស ២២:២០-២១ ៣៧:២ ឆ លប ៤១:៤០ ជ ២ពាវ ១៨:១៨ ឈ ២សយ ៩:១៧ ញ ខ.១១ ដ ២សយ ៨:១៦ **៣៦:៥** ឋ ២ពាវ ១៨:៧ **៣៦:៦** ឌ ២ពាវ ១៧:៤ អស ៨:១២ ឍ អគ ១៧:១៧ ណ អស ៣០:២,៥ ត អស ៤២:៣ ៥៨:៥ អគ ២៩:៦-៧ **៣៦:៧** ថ ទដ ២២:៨ មថ ២៧:៤៣ ទ ២ពាវ ១៨:៤ ធ ចទ ១២:២-៥ ២របា ៣១:១

**៣៦:៨** ន ទដ ២០:៧ អស ៣០:១៦ **៣៦:៩** ប អស ៣១:៣ ផ អស ៣៧:២៤ ព ទដ ២០:៧ អស ៣០:២-៥ **៣៦:១០** ភ ១ពាវ ១៣:១៨ អស ១០:៥-៧ **៣៦:១១** ម ខ.៣

**២៦:១–៣៩:៨** មានផ្នែកជាច្រើនក្នុងជំពូក ៣៦–៣៩ គឺមានហេតុការណ៍ធំៗ ដូចគ្នាដូចជាក្នុង ២ពាវ ១៨:១៣–២០:១៩ (សូមមើលការពន្យល់ផង) ។ អ្នកប្រមូលផ្ដុំចងក្រងនូវព្រះគម្ពីរ ពង្សាវតារក្សត្រទី២ អាចយកគម្ពីរអេសាយ ជំពូក ៣៥–៣៩ មកប្រើផ្សំគ្នា គឺដោយបង្ហាញពីប្រភពរួមតែមួយ ។ ក្នុងជំពូក ៣៦–៣៧ ក៏បានពណ៌នាពីសេចក្ដីសម្រេចពីទំនាយជាច្រើន ដូចជាអំពីការដួលរលំបាក់បែកនៃពួកសាសន៍អាស៊ើរ ឯជំពូក ៣៨–៣៩ គឺបង្ហាញពីការបរិយាយចំពោះក្រុងបាប៊ីឡូនក៏មានជំពូក ៤០–៦៦ ។

**៣៦:១** *នៅឆ្នាំទី១៤ក្នុងរាជ្យស្ដេចហេសេគា* គឺឆ្នាំ ៧០១ មុន គ.ស គឺជារយៈពេលគ្រងរាជ្យ តែស្ដេចអង្គនោះមួយគត់ ។ (សូមមើលការពន្យល់ ២ពាវ ១៨:១) ។ ស្ដេចសានហេរីប បានសោយរាជ្យលើពួកអាសស៊ើរគឺពីឆ្នាំ ៧០៥ រហូតដល់ ៦៨១ មុន គ.ស គឺស្ដេចនោះគ្រប់គ្រងអស់ទាំង ៤៦ ទីក្រុង (សូមមើល ២ពាវ ១៨:១៣) ។

**៣៦:២** *ពលទ័ពយ៉ាងធំ* ប្រៀបធៀប ៣៧:៣៦ និងការពន្យល់ ។ *ក្រុងឡាគីស* គឺជាទីក្រុងសំខាន់ដែលស្ថិតនៅប្រហែលជា ៤៥ គ.ម ពីដំបនខាងត្បូងក្រុងយេរូសាឡិម ក៏ជាទីតាំងការពារដល់រាជធានីនៃស្រុកយូដា (សូមមើល យរ ៣៤:៧ និងការពន្យល់) ក៏សូមមើល ២ពាវ ១៨:១៧ ។

**៣៦:៣** *អេលាគីម* សូមមើល ២២:២០–២១ និងការពន្យល់ ។ *ឧកញ៉ាវាំង* គឺជាអ្នកទទួលបន្ទុកកិច្ចការវាំង (សូមមើល ២២:១៥ និងការពន្យល់) ។ *សេបណា* សូមមើល ២២:១៥ និងការពន្យល់ ។ *ស្មៀនហ្លួង* គឺមានសិទ្ធស្មើនឹងរដ្ឋលេខាធិការ (សូមមើល យរ ៣៦:១២ សូមមើលការពន្យល់ ២សយ ៨:១៧) ។ *អ្នកតែងពង្សាវតារ* តួនាទីជាផ្លូវការគឺមានទំនាក់ទំនងនិង "ស្មៀនហ្លួង" (សូមមើល ១ពាវ ៤:៣) សូមមើលការពន្យល់ ២សយ ៨:១៦ ។

**៣៦:៤,១៣** *ស្ដេចដ៏ជាធំ* សូមមើលការពន្យល់ ២ពាវ ១៨:១៩ ។

**៣៦:៥** *បះបោរ* គឺជាការមិនព្រមទទួល ឬគោរព (សូមមើល ២ពាវ ១៧:៤ ១៨:៧ និងការពន្យល់) ។

**៣៦:៦,៩** *ពឹងដល់ស្រុកអេស៊ីព្ទ* សូមមើលការប្រៀបធៀប ១០:២០ ។

**៣៦:៦** *ស្រុកអេស៊ីព្ទ* ស្ដេចហេសេគា ធ្លាប់នៅក្រោមសំណាក១ក្នុងការចងសម្ពន្ធ័ភាពជាមួយនិងសាសន៍អេស៊ីព្ទ គឺក្នុងឆ្នាំ ៧១៥ មុន គ.ស (សូមមើល ២០:៥ ៣០:១ និងការពន្យល់ ។ *ឈើច្រត់គឺជាដើមត្រែង* គឺក្នុងស្រុកអេស៊ីព្ទបានប្រៀបធៀបទៅនិងត្រែងម្យ៉ាងទៀតក្នុងគម្ពីរ អគ ២៩:៦–៧ (សូមមើលការពន្យល់) ។ *គឺផារ៉ោន* ពាក្យនេះ សូមមើលការប្រៀបធៀប ៣០:៣,៧ ។

**៣៦:៧** *អស់ទាំងទីខ្ពស់នឹងអាសនា* គឺជាកន្លែងដែលស្ដេច ហេសេគាបានកំទេចចោលនូវទីសក្ការៈបូជាគឺសម្រាប់ថ្វាយបង្គំព្រះបាលនោះ (សូមមើលការពន្យល់ ២ពាវ ១៨:៤ ក៏សូមមើល ២របា ៣១:១ ផងដែរ) ។ *អាសនា១នេះវិញ* គឺស្ថិតនៅក្នុងព្រះវិហាររបស់ស្ដេចសាឡូម៉ូន ។

**៣៦:៨** *សេះ២ពាន់* ដែលជាចំនួនពលទ័ពជាច្រើនមានទ័ពសេះនិងរទេះចំបាំង គឺមានតម្លៃខ្ពស់ណាស់ (សូមមើលការពន្យល់ ២ពាវ ១៨:២៣) ។ *អ្នកជិះ* គឺសំដៅទៅលើអ្នកជំនាញបរទេះក្នុងសម័យនោះ (សូមមើល ខ.៩) ។

**៣៦:១០** *គឺព្រះយេហូវ៉ាទេតើ . . . មានបន្ទូលបង្គាប់អញ* គឺព្រះយេហូវ៉ាបានប្រើពួកអាសស៊ើរ ដើម្បីដាក់ទណ្ឌកម្មដល់រាស្ត្រអ៊ីស្រាអែល (សូមមើល ១០:៥–៦) សូមមើល ២របា ៣៥:២១ ។

**៣៦:១១** *អេសាគីម . . . យ៉ូអា* សូមមើល ខ.៣ និងការពន្យល់ ។ *ភាសា*

យើងខ្ញុំប្របាទវិញ[យ] ដ្បិតយើងខ្ញុំស្តាប់បាន សូមកុំមាន
ប្រសាសន៍ជាភាសាយូដាមកយើងខ្ញុំ ឱ្យពួកបណ្តាជន ដែល
នៅលើកំផែងស្តាប់ផងនោះឡើយ ១២តែរ៉ាបសាកេតប
ថា ចុះតើចៅហ្វាយអញបានចាត់អញ ឱ្យមកនិយាយ
សេចក្តីទាំងនេះ ចំពោះតែចៅហ្វាយឯង ហើយនឹងខ្លួនឯង
ប៉ុណ្ណោះឬអី គឺបានចាត់អញឱ្យមក និយាយនឹងមនុស្ស
ដែលអង្គុយនៅលើកំផែងវិញទេតើ ដើម្បីឱ្យគេបានស៊ី
លាមក ហើយផឹកទឹកនោមរបស់ខ្លួន ជាមួយនឹងឯងដែរ[រ] ។
១៣នោះរ៉ាបសាកេក៏ឈរបន្លឺឡើង ជាភាសារបស់
ពួកសាសន៍យូដា[ល] ប្រាប់ថា ចូរស្តាប់ព្រះបន្ទូលនៃស្តេចដ៏
ជាធំ គឺស្តេចអាសស៊ើរចុះ[វ] ១៤ទ្រង់មានបន្ទូលដូច្នេះថា កុំ
បណ្តោយឱ្យពួកហេសេគាបញ្ឆោត[ស]ឯងរាល់គ្នាឡើយ ដ្បិត
វាមិនអាចនឹងជួយ ឱ្យឯងរាល់គ្នារួចបានទេ ១៥ក៏កុំឱ្យ
ហេសេគានាំឱ្យឯងរាល់គ្នាទុកចិត្តដល់ព្រះយេហូវ៉ា ដោយ
ថា ព្រះយេហូវ៉ាទ្រង់នឹងជួយ[ហ]ឱ្យយើងរាល់គ្នារួចជាមិន
ខាន ទីក្រុងនេះនឹងមិនត្រូវប្រគល់ទៅ ក្នុងកណ្តាប់ដៃនៃ
ស្តេចអាសស៊ើរនោះឡើយ[ឡ] ១៦កុំឱ្យស្តាប់តាមហេសេគា
ឱ្យសោះ ដ្បិតស្តេចអាសស៊ើរ ទ្រង់មានបន្ទូលដូច្នេះថា ចូរ
ចងជាស្ពានមេត្រីនឹងអញ ហើយចេញមកឯអញចុះ នោះ
នឹងបានស៊ីផលចំការទំពាំងបាយជូរ និងផលដើមល្វា[អ] ក៏
នឹងផឹកទឹកអណ្តូងរបស់ខ្លួនគ្រប់គ្នា[ក] ១៧ដរាបដល់អញមក
នាំឯងរាល់គ្នាទៅនៅឯស្រុក១ ដូចជាស្រុករបស់ឯងរាល់
គ្នា[ខ]នេះ ជាស្រុកមានស្រូវនិងទឹកទំពាំងបាយជូរ[គ] ជាស្រុក
មាននំបុ័ង និងចំការទំពាំងបាយជូរផង ១៨ចូរប្រយ័ត្នក្រែង

**៣៦:១១** យ អរ ៤:៧ **៣៦:១២** រ ២ពវ ៦:២៥ អគ ៤:១២ **៣៦:១៣** ល ២រប ៣២:១៨ វ អស ៣៧:៤ **៣៦:១៤** ស ២រប ៣២:១៥ **៣៦:១៥** ហ ទដ ៣:២,៧ ឡ អស ៣៧:១០ **៣៦:១៦** អ ១ពវ ៤:២៥ ក សក ៥:១៥ **៣៦:១៧** ខ ២ពវ ១៥:២៩ គ លប ២៧:២៨ ចទ ២៨:៥១ **៣៦:១៩** ឃ ២ពវ ១៨:៣៤ ង ២ពវ ១៧:២៤ ច ២ពវ ១៥:២៩ **៣៦:២០** ឆ ១ពវ ២០:២៣ ជ នក ៥:២ ២រប ២៥:១៥ អស ១០:៨–១១ ៣៧:១០–១៣,១៨–២០ ៤០:១៨ ដយ ៣:១៥ **៣៦:២១** ឈ សភ ៩:៧–៨ ២៦:៤ **៣៦:២២** ញ ២ពវ ១៨:១៨ ដ ២សយ ៨:១៦ ឋ លប ៣៧:២៩ ២រប ៣៤:១៩ **៣៧:១** ក លប ៣៧:២៩ ២រប ៣៤:១៩ ខ លប ៣៧:៣៤

ហេសេគាបបួលឯងរាល់គ្នា ដោយពាក្យថា ព្រះយេហូវ៉ា
ទ្រង់នឹងជួយឱ្យរួចជាមិនខាន តើមានព្រះរបស់សាសន៍
ដទៃណាដែលជួយស្រុកគេ ឱ្យរួចពីកណ្តាប់ដៃនៃស្តេច
អាសស៊ើរបាន ១៩តើព្រះរបស់ពួកក្រុងហាម៉ាត និងក្រុង
អើផាឌនៅឯណា[ឃ] តើព្រះរបស់ពួកក្រុងសេផាវែមនៅ
ឯណា[ង] តើព្រះទាំងនោះជួយពួកសាម៉ារី[ច] ឱ្យរួចពីកណ្តាប់
ដៃអញបានឬ ២០ក្នុងបណ្តាព្រះទាំងប៉ុន្មាននោះ តើមាន
ព្រះ[ឆ]ណា ដែលជួយស្រុកគេ ឱ្យរួចពីកណ្តាប់ដៃអញបាន
បានជាព្រះយេហូវ៉ា ទ្រង់នឹងជួយឱ្យក្រុងយេរូសាឡិម រួចពី
កណ្តាប់ដៃអញបានដែរ[ជ] ។
២១ប៉ុន្តែ គេនៅតែស្ងៀម ឥតឆ្លើយដល់លោក សូម្បី
តែ១ម៉ាត់ផង ដ្បិតស្តេចទ្រង់បានហាមថា កុំឱ្យឆ្លើយនឹង
គេឡើយ ២២នោះអេលាគីម[ឈ] កូនហ៊ីលគីយ៉ា ជាឧកញ៉ាវាំង
និងសេបណា ជាស្មៀនហ្លួង ហើយយ៉ូអា កូនអេសាភ
ជាអ្នកតែងពង្សាវតារ[ញ] គេវិលមកគាល់ហេសេគាវិញ
ទាំងអាវរហែក[ដ] ក៏ទូលទ្រង់តាមពាក្យរបស់រ៉ាបសាកេទាំង
អស់ ។

## បទទំនាយអំពីការរំដោះក្រុងយេរូសាឡិម

*៣៧:១–១៣ – ២ពវ ១៩:១–១៣*

**៣៧** ១លុះកាលស្តេចហេសេគាបានស្តាប់ពាក្យទាំងនោះ
ហើយ នោះទ្រង់ក៏ហែកព្រះពស្ត្រ[ក] ហើយស្លៀកពាក់សំពត់
ធ្មៃវិញ[ខ] រួចយាងចូលទៅក្នុងព្រះវិហារ[គ]នៃព្រះយេហូវ៉ា

*អើរ៉ាម* គឺជាការទូតនាពេលសម័យនោះ (សូមមើល ២ពវ ១៨:២៦) ។ *កុំមានប្រសាសន៍ជាភាសាយូដា* គឺជាសេចក្តីបារម្ភណ៍ដែលពាក្យសម្តី ដែលអាចបំផ្លាញដល់ទឹកចិត្តរបស់មនុស្សបាន ។

**៣៦:១២** *ស៊ី . . . លាមក . . . ផឹក . . . ទឹកនោម* គឺជារបៀបពីការពិណ៌នាស្តីពីភាពអត់អាហារទទួលទាន បើខណៈពេលដែលក្រុងយេរូសាឡិមត្រូវបានខ្មាំងសត្រូវឡោមព័ទ្ធជុំវិញអស់ (សូមមើលការប្រៀបធៀប ២ពវ ៦:២៥ នឹងការពន្យល់) ។ ក៏មានផ្ទុយនិង ខ.១៦ និងការពន្យល់ក្នុងខនោះ) ។

**៣៦:១៤** *បញ្ឆោតឯងរាល់គ្នាឡើយ* សូមមើលការប្រៀបធៀប ៣៧:១០ និងការពន្យល់ ។

**៣៦:១៦** *ស៊ីផលចំការទំពាំងបាយជូរ និងផលដើមល្វា* គឺជានិមិត្តសញ្ញាតំណាងឱ្យភាពសុខសាន្តនិងភាពរុងរឿងក្នុងកាលៈទេសៈ ដ៏គាប់ប្រសើរបំផុត (សូមមើល ១ពវ ៤:២៥ មីក ៤:៤ និងការពន្យល់ សក ៣:១០ និងការពន្យល់) ។

**៣៦:១៧** *អញមកនាំឯងរាល់គ្នាទៅ* (សូមមើល ២ពវ ១៥:២៩ ១៧:៥១ ហក ១:១១ និងការពន្យល់) ។

**៣៦:១៨–២០** ជាពាក្យសំដីរបស់ចៅហ្វាយដែលបានប្រកាសយ៉ាងអង់អាចដល់ពួកអាសស៊ើរ ១០:៨–១១ សូមមើលការពន្យល់ ២ពវ ១៨:៣៣–៣៥ ។

**៣៦:១៩** *ពួកក្រុងហាម៉ាត នឹងក្រុងអើផាឌ* មើល ១០:៩ និងការពន្យល់ ។ *ពួកក្រុងផាវែម* គឺមានទីតាំងស្ថិតនៅខាងជើងស្រុកអើរ៉ាម ក៏មិនឆ្ងាយប៉ុន្មានពីក្រុងហាម៉ាតទេ ។ តែទីលំនៅសព្វថ្ងៃឬក្រោយមកទៀតក្រុងសេផាវែមក៏បានបោះទីតាំងនៅក្នុងស្រុកសាម៉ារី ហើយពួកគេនៅតែថ្វាយបង្គំរូបព្រះអ័ឌរ៉ាម៉ាលេក និងព្រះ អ័ណាម៉ាលេក ។ សូមមើល ២ពវ ១៧:២៤ និងការពន្យល់ ខ.៣១ ។ *ពួកសាម៉ារី* ដែលពួកអាសស៊ើរក៏សន្មតថាប្រជាជននិមួយៗនៃសាសន៍និមួយៗគេតែងតែមានព្រះពួកគេរៀងខ្លួនហើយក៏មិនមានទំនាក់ទំនងនិងព្រះពួកសាសន៍យូដាទេ ឬជាមួយពួកសាម៉ារីទេ ។

**៣៦:២១** *គេនៅតែស្ងៀម* ពួកអាសស៊ើរបានសង្ឃឹមថា គឺជាចិត្តវិជ្ជាដ៏សំខាន់ដែលមានក្នុង ខ.៤–២០ ដែលនិងបានជាលទ្ធផល នូវភាពភ័យខ្លាចមកដល់។

**៣៦:២២** សូមមើល ខ.៣ និងការពន្យល់ ។ *អាវរហែក* សូមមើលការពន្យល់ ២ពវ ១៨:៣៧ ។

**៣៧:១** *ព្រះពស្ត្រ . . . សំពត់ធ្មៃ* សូមមើល លប ៣៧:៣៤ និងការពន្យល់ ក៏សូមមើលការពន្យល់ ២ពវ ១៨:៣៧ ។ *ព្រះវិហារ* គឺជាទីកន្លែងដែលរៀបចំសម្រាប់ធ្វើការអធិស្ឋានរបស់ស្តេចសាឡូម៉ូន (សូមមើល ១ពវ ៨:៣៣) ។

២ទ្រង់ចាត់អេលាគីម[យ] ជាឧកញ៉ាវាំង និងសេបណា[ង] ជា
ស្មៀនហ្លួង ហើយពួកចាស់ទុំក្នុងពួកសង្ឃ ឱ្យស្លៀកពាក់
សំពត់ធ្មៃ ទៅឯហោរាអេសាយ ជាកូនអ័ម៉ូស[ច] ៣គេក៏ជំរាប
ដល់លោកថា ហេសេគាទ្រង់មានបន្ទូលដូច្នេះ ថ្ងៃនេះជា
ថ្ងៃមានសេចក្ដីវេទនា[ឆ] សេចក្ដីផ្ចាញ់ផ្ចាល និងសេចក្ដី
ដំនៀល ប្រៀបដូចជាកូនដែលគ្រប់ខែ[ជ] តែគ្មានកំឡាំងនឹង
សំរាលមកសោះ ៤ប្រហែលជាព្រះយេហូវ៉ា ជាព្រះនៃអ្នក
ទ្រង់នឹងឮអស់ទាំងពាក្យរបស់រ៉ាបសាកេនេះទេដឹង ជា
ពាក្យដែលស្ដេចអាសស៊ើរ ជាចៅហ្វាយគេ បានចាត់ឱ្យមក
ប្រកួត[ឈ]នឹងព្រះដ៏មានព្រះជន្មរស់នៅ[ញ] ហើយទ្រង់នឹង
បន្ទោសដល់គេ ដោយព្រោះពាក្យដែលព្រះយេហូវ៉ាជាព្រះ
នៃអ្នក ទ្រង់បានឮហើយ[ដ] ដូច្នេះ សូមអធិស្ឋាន[ឋ]ឱ្យសំណល់[ឌ]
ដែលនៅសល់ចុះ ។
៥ពួកជំនិតរបស់ស្ដេចហេសេគា ក៏មកឯអេសាយ ៦ហើយ
អេសាយលោកមានប្រសាសន៍ថា ត្រូវឱ្យអ្នករាល់គ្នាទូល
ដល់ចៅហ្វាយអ្នកថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ កុំ
ឱ្យខ្លាច[ឍ]ចំពោះពាក្យសំដីដែលឯងបានឮ ជាពាក្យដែលពួក
បំរើរបស់ស្ដេចអាសស៊ើរ បានប្រមាថ[ណ]ដល់អញនោះ
ឡើយ ៧មើល អញនឹងបណ្ដាលគំនិត[ត]វា ឱ្យសំរេចនឹង
ត្រឡប់ទៅឯស្រុកវាវិញ ដោយវាឮដំណឹង១[ថ] រួចអញនឹង
ឱ្យវាដួលស្លាប់[ទ]ដោយដាវ នៅក្នុងស្រុករបស់វាទៅ ។

**៣៧:១** ក ខ.១៤ ១ពវ ៨:៣៣ មថ ២១:១៣ **៣៧:២** ឃ ២ពវ ១៨:១៨ អស ៣៦:៣ ង ២ពវ ១៨:១៨ ច ខ.២១ អស ១:១ ១៣:១ ៣៨:១ **៣៧:៣** ឆ ពច ៦:២ អស ៥:៣០ ជ អស ២៦:១៨ ៦៦:៩ ហស ១៣:១៣ **៣៧:៤** ឈ ខ.២៣–២៤ ២រប ៣២:១៧ ញ យស ៣:១០ ដ អស ៣៦:១៣, ១៨–២០ ឋ ១សយ ៧:៨ ឌ អស ១:៩ អម ៧:២ **៣៧:៦** ឍ យស ១:៩ អស ៧:៤ ណ ជន ១៥:៣០ **៣៧:៧** ត ១រប ៥:២៦ ថ ខ.៩ ទ អស ៣១:៨ **៣៧:៨** ធ ជន ៣៣:២០ ន យស

៨ចំណែករ៉ាបសាកេ ក៏ត្រឡប់ទៅរកស្ដេចអាសស៊ើរ
ឃើញកំពុងតែច្បាំងនឹងក្រុងលិបណា[ន] ដ្បិតលោកបានឮថា
ទ្រង់ថយពីក្រុងឡាគីសទៅហើយ[ន] ៩ស្ដេច[ប]បានឮនិយាយ[ផ]
ពីទារហាកា ជាស្ដេចអេធីយ៉ូពី[ព] ថាចេញមកច្បាំងនឹងទ្រង់
ហើយ លុះទ្រង់បានឮដូច្នោះ ក៏ចាត់សារទៅឯហេសេគា
ដោយពាក្យថា ១០ចូរឯងរាល់គ្នាប្រាប់ដល់ហេសេគាជា
ស្ដេចយូដាដូច្នេះ កុំឱ្យព្រះរបស់ឯង ដែលឯងទុកចិត្តនោះ
បញ្ឆោត[ភ]ឯងដោយថា ក្រុងយេរូសាឡិមនឹងមិនត្រូវប្រគល់
ទៅក្នុងកណ្ដាប់ដៃនៃស្ដេចអាសស៊ើរនោះឡើយ[ម] ១១មើល
ឯងបានឮនិយាយពីការដែលស្ដេចអាសស៊ើរបានធ្វើ ដល់
ស្រុកទាំងប៉ុន្មានហើយ គឺដែលទ្រង់បានបំផ្លាញគេអស់
រលីងទៅ ដូច្នេះ តើឯងនឹងបានរួចឬ[យ] ១២ឯសាសន៍ដទៃ
ទាំងប៉ុន្មាន ដែលពួកឰយុកោ[រ]អញបានបំផ្លាញ គឺពួកក្រុង
កូសាន ក្រុងខារ៉ាន[ល] ក្រុងរេសែភ និងពួកកូនចៅអេដែន[វ]
ដែលនៅស្រុកធេឡាស៊ើរ តើព្រះរបស់គេបានជួយឱ្យគេរួច
ឬទេ ១៣តើស្ដេចស្រុកហាម៉ាត ស្ដេចក្រុងអើផាឌ[ស] និង
ស្ដេចក្រុងសេផាវែម[ហ] ក្រុងហេណា និងក្រុងអ៊ីវ៉ានៅ
ឯណា[ឡ]។

១០:៣ **៣៧:៩** ប ២រប ៣២:១ ផ ខ.៧ ព អស ២០:៣ **៣៧:១០** ភ ២រប ៣២:១១,១៥ ម អស ៣៦:១៥ **៣៧:១១** យ អស ៣៦:១៨–២០ **៣៧:១២** រ ២ពវ ១៨:១១ ល លប ១១:៣១ ១២:១–៤ កច ៧:២ វ អគ ២៧:២៣ អម ១:៥ **៣៧:១៣** ស អស ១០:៩ ហ ២ពវ ១៧:២៤ ឡ អស ៣៦:២០

ក៏សូមមើល ៣៦:៧,១៥,១៨ នឹងការពន្យល់ ៣៦:៧ ។

**៣៧:២** *អេលាគីម . . . សេបណា* សូមមើលការពន្យល់ ៣៦:៣ ។ *ពួកចាស់ទុំក្នុងពួកសង្ឃ* សូមមើលការពន្យល់ ២ពវ ១៩:២ ។ *អេសាយជាកូនអ័ម៉ូស* សូមមើលការពន្យល់ ១:១ គឺមានទាំងហោរាពួកសង្ឃនិងព្រះមហាក្សត្រ ចូលរួមក្នុងការទូលអង្វរ ។

**៣៧:៣** *នេះជាថ្ងៃមានសេចក្ដីវេទនា* សូមមើល ៥:៣០ ២៦:១៦ ៣៣:២ និងការពន្យល់ ។ ក៏មានការពន្យល់យ៉ាងល្អិតល្អន់ ពីការឈឺពោះក្នុងគ្រាសម្រាលកូននោះ (សូមមើល ១៣:៨ និងការពន្យល់) ។

**៣៧:៤** *បន្ទោស* បើជាព្រះគម្ពីរភាសាហេព្រើរគឺជាការ "ប្រមាថ" មើលក្នុង ខ.១៧,២៣,២៤ ។ *អធិស្ឋាន* សូមមើលការពន្យល់ ២ពវ ១៩:៤ ។ ពាក្យថា *សំណល់* គឺជាស្រុកយេរូសាឡិមត្រូវបានគេបោះបងចោលនៅឯកកោរ (សូម មើល ៣៦:១ និងការពន្យល់ ១:៩ ២ពវ ១៩:៤ សូមមើល ១០:២០–២២ និងការពន្យល់) ។

**៣៧:៦** *កុំឱ្យខ្លាច* សូមមើលការប្រៀបធៀប ៧:៤ និងមើល ៣៥:៤ និងការពន្យល់ ។

**៣៧:៧** *គំនិត* (សូមមើលការប្រៀបធៀប ១រប ៥:២៦) ។ *ដំណឹង១* សូមមើលការពន្យល់ ២ពវ ១៩:៧ ។ *ទៅឯស្រុកវាវិញ . . . វាដួលស្លាប់ដោយដាវ* សូមមើល ខ.៣៧–៣៨ និងការពន្យល់។

**៣៧:៨** *ក្រុងឡាគីស* សូមមើលការពន្យល់ ៣៦:២ ។ *ក្រុងលិបណា* សូមមើលការពន្យល់ ២ពវ ៨:២២ ក៏សូមមើល យស ១០:៣១ ។

**៣៧:៩** *ទារហាកា* គឺជាស្ដេចពួកស្រុកអេធីយ៉ូពីនិងពួកគូស៊ី ។ (ទ្រង់គឺជាព្រះអនុជ "ជាប្អូន" នៃស្ដេចផារ៉ោន សិបប៊ីគូរ ដែលបានបញ្ជូនទ្រង់ព្រមទាំងពលទ័ពដើម្បីស្ដេចហេសេគា ដើម្បីតស៊ូវពីការឈ្លានពានរបស់ពួកអាសស៊ើរ)។ (សូមមើលការពន្យល់ ខ.៣៨) ដូច្នេះគេបានស្គាល់ឈ្មោះស្ដេចទាហាកាសព្វទីកន្លែង សូមមើល ១៨:១ នឹងការពន្យល់។

**៣៧:១០** *ព្រះ . . . បញ្ឆោតឯង* សូមមើល ៣៦:១៤–១៥,១៨ ។ ក៏មានអត្ថបទក្នុង ខ.១០–១៣ ក៏ស្រដៀងនិងជំពូក ៣៦:១៨–២០ (សូមមើលការពន្យល់ជំពូកនោះ) ។

**៣៧:១២** *ក្រុងកូសាន* ជាទីក្រុងដែលស្ថិតនៅតំបន់ភាគខាងជើង នៃស្រុកមេសូប៉ូតាមា ដែលនៅទីនោះមានរាស្ត្រអ៊ីស្រាអែលខ្លះត្រូវបានគេសម្លាប់ដោយសារពួកអាសស៊ើរ (សូមមើល ២ពវ ១៧:៦ និងការពន្យល់) ។ *ក្រុងកូសាន* ជាទីក្រុងដែលលោក អ័ប្រាហាំរសនៅទីនោះជាច្រើនឆ្នាំ (សូមមើល លប ១១:៣១ និងការពន្យល់) ។ *ក្រុងរេសែក* គឺជាទីក្រុងនៅចន្លោះក្រុងកូសាន និងទន្លេអ៊ើប្រាត ។ *អេដែន* គឺជារដ្ឋរបស់ស្រុកប៊ិតអាឌីនី ដែលមានទីតាំងនៅចន្លោះរវាងទន្លេប៊ិលលីក (សូមមើលការពន្យល់ ២ពវ ១៩:១២) ។

**៣៧:១៣** *ស្រុកហាម៉ាត . . . ក្រុងអើផាឌ* មើល ១០:១៣ និងការពន្យល់ក្រុងសេផាវែម សូមមើល ៣៦:១៩ ២ពវ ១៧:២៤ និងការពន្យល់ ។

## សេចក្ដីអធិស្ឋានរបស់ស្ដេចហេសេគា

*៣៧:១៤-២០ – ២ពវ ១៩:១៤-១៩*

១៤ហេសេគាក៏ទទួលសំបុត្រ[អ]នោះ ពីដៃរបស់ពួកទូត
ទៅអានមើល រួចទ្រង់យាងឡើងទៅឯព្រះវិហារ[ក]នៃព្រះ
យេហូវ៉ា លាសំបុត្រនោះនៅចំពោះទ្រង់ ១៥ហេសេគាទ្រង់
ក៏អធិស្ឋាន[ខ]ដល់ព្រះយេហូវ៉ាថា ១៦ឱព្រះយេហូវ៉ានៃពួក
ពលបរិវារជាព្រះនៃសាសន៍អ៊ីស្រាអែល ដែលគង់[គ]ពីលើ
ចេរូប៊ីនអើយ[ឃ] គឺទ្រង់តែ១ព្រះអង្គ[ង] ដែលជាព្រះនៃអស់
ទាំងសាសន៍[ច] នៅលើផែនដី ទ្រង់បានបង្កបង្កើតផ្ទៃមេឃ
នឹងផែនដី[ឆ] ១៧ឱ ព្រះយេហូវ៉ាអើយ សូមទ្រង់ផ្ទៀងព្រះ
កាណ៌ស្ដាប់[ជ] ឱព្រះយេហូវ៉ាអើយ សូមទ្រង់បើកព្រះនេត្រ
ទត[ឈ] សូមស្ដាប់អស់ទាំងពាក្យរបស់សានហេរីប[ញ] ដែល
បានចាត់គេមកប្រកួត[ដ] នឹងព្រះដ៏មានព្រះជន្មរស់នៅ[ឋ] ១៨ឱ
ព្រះយេហូវ៉ាអើយ ស្ដេចអាសស៊ើរបានបំផ្លាញអស់ទាំង
ប្រទេស និងស្រុករបស់គេ ជាប្រាកដមែន[ឌ] ១៩ក៏បានបោះ
ចោលព្រះរបស់គេទៅក្នុងភ្លើង[ឍ]ដែរ ដ្បិតមិនមែនជាព្រះ
ទេ[ណ] គឺជាស្នាដៃដែលមនុស្ស[ត] ធ្វើមកពីឈើនឹងពីថ្មវិញ
ហេតុនោះបានជាគេបំផ្លាញទៅបាន[ថ] ២០ដូច្នេះ ឱព្រះ
យេហូវ៉ាជាព្រះនៃយើងខ្ញុំរាល់គ្នាអើយ សូមទ្រង់ជួយ
សង្គ្រោះ[ទ]យើងខ្ញុំ ឱ្យរួចពីកណ្ដាប់ដៃរបស់គេផង ដើម្បីឱ្យ
គ្រប់ទាំងសាសន៍នៅផែនដី[ធ]បានដឹងថា ទ្រង់ជាព្រះយេហូវ៉ា
គឺទ្រង់តែ១ព្រះអង្គទេ[ន] ។

## ការដួលរលំនៃស្ដេចសានហេរីប

*៣៧:២១-៣៨ – ២ពវ ១៩:២០-៣៧ ២របា ៣២:២០-២១*

២១គ្រានោះ អេសាយជាកូនអ័ម៉ូស[ប] ក៏ចាត់គេឱ្យទៅឯ
ហេសេគា ទូលថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រា-
អែល ទ្រង់មានបន្ទូលដូច្នេះ ដោយព្រោះឯងបានអធិស្ឋាន
ដល់អញ ពីដំណើរសានហេរីបជាស្ដេចសាសន៍អាសស៊ើរ
២២បានជាព្រះយេហូវ៉ា ទ្រង់មានបន្ទូលពាក្យទាំងនេះ ពី
ដំណើរស្ដេចនោះ គឺថា នាងក្រមុំ[ផ]នៃក្រុងស៊ីយ៉ូន[ព]បានស្អប់
ខ្ពើមដល់ឯង ហើយបានមើលងាយដល់ឯង កូនស្រីនៃ
ក្រុងយេរូសាឡិមបានគ្រវីក្បាល[ភ]ដល់ឯងហើយ ២៣តើឯង
បានប្រកួត ហើយប្រមាថដល់អ្នកណា[ម] តើទាស់នឹងអ្នក
ណា ដែលឯងបានដំឡើងសំឡេង[យ] ហើយងើបភ្នែកឡើង
ជាខ្ពស់ដូច្នេះ[រ] គឺទាស់នឹងព្រះដ៏បរិសុទ្ធ[ល]នៃសាសន៍អ៊ីស្រា
អែលទេតើ ២៤ឯងបានប្រកួតនឹងព្រះអម្ចាស់ ដោយពួក
អ្នកដែលចាត់ឱ្យមកនោះ ដោយថា អញបានឡើងទៅឯ
កំពូលភ្នំទាំងប៉ុន្មាន ដោយសាររទេះចំបាំងអញ[វ] ហើយ
ដល់ទីជ្រៅបំផុតនៃព្រៃល្បាណូនផង[ស] អញនឹងកាប់អស់
ទាំងដើមតាត្រៅដែលខ្ពស់[ហ] និងដើមកកោះដែលល្អជាងគេ
នៅទីនោះ[ឡ] អញនឹងចូលទៅដល់ទីខ្ពស់នៅចុងស្រុកគេ គឺ
ដល់ចំការរបស់គេ ដែលដុះដាលដូចជាព្រៃ ២៥អញបាន
ជីក ហើយបានផឹកទឹក អញក៏នឹងធ្វើឱ្យអស់ទាំងទន្លេស្រុក

**៣៧:១៤** អ ២របា ៣២:១៧ ក ខ.១,៣៨ ១ពវ ៨:៣៣ **៣៧:១៥** ខ ២របា ៣២:២០ **៣៧:១៦** គ ទដ ២:៤ ឃ លប ៣:២៤ ង ចទ ១០:១៧ ទដ ៨៦:១០ ៨៦:១០ ១៣៦:២-៣ ច ចទ ៤:៣៤ ឆ លប ១:១ អស ១១:១២ ៤១:៩ ៤៣:៦ កច ៤:២៤ **៣៧:១៧** ជ ១ពវ ៨:២៩ ២របា ៦:៤០ ឈ យរ ២៥:២៩ ដយ ៩:១៨ ញ ២របា ៣២:១ ដ ២របា ៣២:១៧ ឋ យស ៣:១០ **៣៧:១៨** ឌ ២ពវ ១៥:២៩ ណហ ២:១១-១២ **៣៧:១៩** ឍ យស ៧:១៥ ណ ២របា ១៣:៩ អស ៤០:១៧ ៤១:២៤,២៩ យរ ២:១១ ៥:៧ ១៦:២០ កទ ៤:៨ ត ២របា ៣២:១៩ ទដ ១៣៥:១៥ អស ៤០:១៨-២០ ០ ៤៤:៩-១១ ថ អស ២៦:១៤ ៣៦:២ **៣៧:២០** ទ ទដ ៣:២,៧ សភ ២០:២២ ធ យស ៤:២៤ ន ១សយ ១៧:៤៦ ទដ ៤៦:១០ **៣៧:២១** ប ខ.២ **៣៧:២២** ផ អស ២៣:១២ ព អស ១០:៣២ ភ យប ១៦:៤ **៣៧:២៣** ម ខ.៤ ជន ១៥:៣០ អស ៥២:៥ អគ ៣៦:២០,២៣ ដយ ៧:២៥ យ យប ១៥:២៥ រ អស ២:១១ ល អស ១:៤ ១២:៦ **៣៧:២៤** វ អស ៣៦:៩ ស ១ពវ ៧:២ អស ១៤:៨ ៣៣:៩ ហ អស ១៤:១៣ ឡ ១ពវ ៥:៨-១០ អស ៤១:១៩ ៥៥:១៣ ៦០:១៣ ហស ១៤:៨

**៣៧:១៤** *ព្រះវិហារ* សូមមើល ខ.១ និងការពន្យល់ ។ *លាសំបុត្រនោះចំពោះទ្រង់* សូមមើលក្នុង ១:១៥ (សូមមើល ១:១១-១៥) ។

**៣៧:១៦** *ព្រះយេហូវ៉ានៃពួកពលបរិវារ* សូមមើល ១៣:៤ និងការពន្យល់ ។ *ដែលគង់ពីលើចេរូប៊ីនអើយ* សូមមើលការពន្យល់ ១សយ ៤:៤ ២សយ ៦:២ ។ *នៃអស់ទាំងសាសន៍នៅផែនដី* សូមមើលការប្រៀបធៀប ៤០:១៧ និងការពន្យល់ ។ *បង្កើតផ្ទៃមេឃនឹងផែនដី* គឺជាព្រះរាជកិច្ចដែលទ្រង់ចាំបាច់ត្រូវធ្វើក្នុងនាមជាព្រះអទិករ សូមមើលក្នុង ៤០:២៦,២៨ ៤២:៥ ៤៥:១២ (សូមមើល ៤០:២១) ។

**៣៧:១៧** *សូមទ្រង់ផ្ទៀងព្រះការណ៌ស្ដាប់ . . . ទ្រង់បើកព្រះនេត្រទត* ក៏សូមប្រៀបធៀបពីការអធិស្ឋានរបស់ស្ដេចសាឡូម៉ូននៅក្នុង ១ពវ ៨:៥២ ២របា ៦:៤០ ។ *គេមកប្រកួតនឹងព្រះដ៏មានព្រះជន្មរស់នៅ* សូមមើល ខ.៤ និងការពន្យល់ ។

**៣៧:១៩** *មិនមែនជាព្រះទេ* សូមមើល ៣៦:១៩ និងការពន្យល់ ។ *ពីឈើនឹងពីថ្ម* សូមប្រៀបធៀប ២:៨ ៤៤:៩-២០ និងការពន្យល់ ។ នក ២០:៣ សូមមើលការពន្យល់ ចទ ៦:៤ ។

**៣៧:២២** *នាងក្រមុំនៃក្រុងស៊ីយ៉ូនបានស្អប់ . . . កូនស្រីនៃក្រុងយេរូសាឡិម* គឺជាបុគ្គលលក្ខណៈរបស់ក្រុងយេរូសាឡិម (សូមមើលការពន្យល់ ២ពវ ១៩:២១) ។ *បានគ្រវីក្បាល* គឺជាកាយវិការចំអកឡកឡើយ (សូមមើល ទដ ២២:៧ ៤៤:១៤ និងការពន្យល់) ។

**៣៧:២៣** *ងើបភ្នែកឡើងជាខ្ពស់* គឺជាការបង្ហាញពីភាពមានមោទនះភាពរបស់ពួកអាសស៊ើរ ក៏ត្រូវព្រះអម្ចាស់បានកាត់ទោស (សូមមើល ១០:១២ និងការពន្យល់) ។ *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* គឺជាការជ្រើសរើសព្រះនៃរាស្ត្រអ៊ីស្រាអែលដែលបង្ហាញពីលក្ខណៈរបស់លោក អេសាយ (សូមមើល ១:៤ និងការពន្យល់) ។

**៣៧:២៤** *រទេះចំបាំង* សូមមើល ៣៦:៨ នឹងការពន្យល់*អញនឹងចូលដល់ទីខ្ពស់នៅចុងស្រុក* ប្រៀបធៀបនូវព្រះបន្ទូលនៃស្ដេចស្រុកបាប៊ីឡូន ក្នុង ១៤:១៣-១៤ ។ *ព្រៃល្បាណូន* សូមមើល ៣៣:៩ ៣៥:២ និងការពន្យល់ ។ *កាប់អស់ទាំងដើមតាត្រៅដែលខ្ពស់* គឺដោយថា ច្រើនសតវត្សរ៍ស្ដេចនៃស្រុកមេសូប៉ូតាមាបានប្រើដើមតាត្រៅនេះសម្រាប់ការសាងសង់រាជវាំង (សូមមើលការពន្យល់ ២:១៣ ៩:១០ ១៤:៨ ប្រៀបធៀប ១ពវ ៥:៨-១៦) ។

**៣៧:២៥** *ជីកហើយបានទឹកផឹក* ទោះជាវាលរហោស្ថានក៏ពុំអាចឃាត់ទ្រង់បានដែរ ។ *រីងស្ងួតទៅ* គឺជាដៃទន្លេធំដែលបានរីងស្ងួតទៅ សូមមើល

អេស៊ីព្ទរីងស្ងួតទៅ[អ] ដោយបាតជើងរបស់អញ[ក]។
២៦តើឯងមិនបានឮថា អញបានគិតជាស្រេច និងធ្វើ
ការ[ខ]ទាំងប៉ុន្មាននេះ តាំងពីយូរមកហើយ ព្រមទាំងចាត់
ចែង[គ]តាំងពីចាស់បុរាណផងទេឬអី ឥឡូវនេះ អញបាន
សំរេចការនេះហើយ គឺបានឱ្យឯងបំផ្លាញទីក្រុងមានកំផែង
ឱ្យទៅជាគំនរបំណែក[ឃ] ២៧ហេតុនោះបានជាពួកអ្នកក្រុង
ទាំងនោះខ្សោយកំឡាំង គេបានស្រយុតចិត្ត ហើយទ្រឹង
នៅ គេក៏ដូចជាស្មៅនៅវាល និងពន្លកខ្ចី គឺដូចជាស្មៅ[ង]
ដែលដុះនៅលើដំបូលផ្ទះ[ច] និងស្រែពេញដោយស្រូវដែល
មិនទាន់ចាស់ ២៨អញដឹងកន្លែងដែលឯងអង្គុយ និងវេលា
ណា ដែលឯងចេញចូល[ឆ] ក៏ស្គាល់សេចក្តីដែលឯងខឹង
ក្តៅ[ជ]នឹងអញដែរ ២៩ដោយព្រោះឯងខឹងនឹងអញដូច្នេះ
ហើយដោយព្រោះសេចក្តីព្រហើន[ឈ]របស់ឯង បានឮមក
ដល់ត្រចៀកអញ នោះអញនឹងដាក់កន្លុះ[ញ]របស់អញ នៅ
ច្រមុះ[ដ]ឯង នឹងដែកបង្ខាំងរបស់អញនៅមាត់ឯង ហើយអញ
នឹងញាក់ឯងឱ្យវិលត្រឡប់ទៅតាមផ្លូវដដែល ដែលឯងបាន
មកនោះវិញ[ឋ]។
៣០ការនេះនឹងបានជាទីសំគាល់[ឌ] ដល់ឯងរាល់គ្នា គឺ
នៅឆ្នាំនេះ[ឍ] ឯងរាល់គ្នានឹងបរិភោគផលដែលដុះឯង ដល់
ឆ្នាំទី២ នោះនឹងបរិភោគផលដែលកើតពីនោះទៀត តែ
ដល់ឆ្នាំទី៣[ណ] ត្រូវឱ្យឯងរាល់គ្នាសាបព្រោះ ច្រូតកាត់
ហើយដាំចំការទំពាំងបាយជូរ[ត]ទៅ រួចបរិភោគផលទាំង
នោះវិញ[ថ] ៣១ឯសំណល់នៃពួកកូនចៅយូដាដែលរួចជីវិត
គេនឹងចាក់ឫស[ទ]ទៅក្រោម ហើយនឹងបង្កើតផល[ធ]ទៅ
លើ ៣២ដ្បិតនឹងមានសំណល់ចេញពីក្រុងយេរូសាឡិមទៅ[ន]
ព្រមទាំងពួកអ្នកដែលរួចជីវិតពីក្រុងស៊ីយ៉ូនដែរ[ប] សេចក្តី
ឧស្សាហ៍[ផ]របស់ព្រះយេហូវ៉ានៃពួកពលបរិវារ នឹងធ្វើការ
នោះ ។
៣៣ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់មានបន្ទូល ពី
ដំណើរស្តេចអាសស៊ើរដូច្នេះថា គេនឹងមិនចូលមកក្នុង
ក្រុងនេះឡើយ[ព] ក៏មិនបាញ់ព្រួញ ឬកាន់ខែលនៅមុខទីក្រុង
នេះ ឬជីកស្នាមភ្លោះ[ភ]ច្បាំងនឹងទីនេះដែរ ៣៤គឺគេនឹងវិល
ទៅវិញ[ម] តាមផ្លូវដដែល ដែលគេបានមកនោះ ឥតចូល
មកក្នុងទីក្រុងនេះឡើយ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា
៣៥ដ្បិតអញនឹងការពារ[យ]ក្រុងនេះ រក្សាទុកសំរាប់ខ្លួនអញ[រ]
គឺដោយយល់ដល់ដាវីឌ[ល]ជាអ្នកបំរើអញផង ។
៣៦គ្រានោះ ទេវតា[វ]នៃព្រះយេហូវ៉ា ក៏ចេញទៅវាយ
ទីបោះទ័ពរបស់ពួកសាសន៍អាសស៊ើរ[ស] សំឡាប់[ហ]មនុស្ស
អស់១សែន៨ម៉ឺន៥ពាន់នាក់ បានជាកាលគេក្រោកពីព្រឹក
ឡើង នោះឃើញមនុស្សទាំងនោះសុទ្ធតែជាខ្មោចស្លាប់

**៣៧:២៥** អ អស ១៩:៦ ៤៤:២៧ ក ចទ ១១:១០ អស ១០:១៤ ដយ ៤:៣០ **៣៧:២៦** ខ កច ២:២៣ ៤:២៧–២៨ ១ពត ២:៨ គ អស ១០:៦ ២៥:១ ឃ ចទ ១៣:១៦ អស ២៥:២ **៣៧:២៧** ង អស ១៥:៦ ច ទដ ១២៩:៦ **៣៧:២៨** ឆ ទដ ១៣៩:១–៣ ជ ទដ ២:១ **៣៧:២៩** ឈ អស ១០:១២ ញ ២របា ៣៣:១១ ដ យប ៤០:២៤ ឋ ខ.៣៤ **៣៧:៣០** ឌ អស ២០:៣ ឍ អស ៣២:១០ ណ អស ១៦:១៤ ត លវ ២៥:៤ ថ ទដ ១០៧:៣៧ អស ៣០:២៣ ៦៥:២១ យរ ៣១:៥ **៣៧:៣១** ទ អស ១១:១០ ធ អស ២៧:៦ **៣៧:៣២** ន អស ១១:១១ ប អស ១:៩ ផ អស ៩:៧ **៣៧:៣៣** ព អស ៣២:១៨ ភ ២សយ ២០:១៥ **៣៧:៣៤** ម ខ.២៩ **៣៧:៣៥** យ អស ៣១:៥ រ អស ៤៣:២៥ ៤៨:៩,១១ អគ ៣៦:២១–២២ ល ១របា ១៧:១៩ **៣៧:៣៦** វ នក ១២:២៣ ស អស ១០:១២ ហ នក ១២:១២

១១:១៥ ៤៤:២៧ និងការពន្យល់ ។

**៣៧:២៦** គឺជាព្រះរាជកិច្ចក្នុងការបង្កើតអ្វីៗទាំងអស់ឱ្យមានឡើង ។ សូមមើល ទដ ៣៣:១០–១១ ។ ប្រៀបធៀប ៤០:២១ និងការពន្យល់ ។ *ទីក្រុងមានកំផែងឱ្យទៅជាគំនរបំណែក* គឺដូចជាពួកសាសន៍អាសស៊ើរដែលព្រះបានប្រើពួកនោះជាឧបករណ៍ឱ្យគេនោះ ទាស់គ្នាទៅវិញទៅមកគឺឱ្យគេបំផ្លាញទៅវិញទៅមកគឺជាជាតិសាសន៍១ទាស់និងជាតិសាសន៍មួយទៀត ។ (សូមមើល ១០:៥–៦ និងការពន្យល់ ១០:៥) ។

**៣៧:២៧** សូមមើល ៤០:៦–៨ និងការពន្យល់ ទដ ៣៧:១–២ ហើយពាក្យថា *ដូចជាស្មៅដែលដុះនៅលើដំបូលផ្ទះ* គឺជាប្រភេទដំបូលផ្ទះនៅតំបន់មជ្ឈឹមបូពា (សូមប្រៀបធៀប ២សយ ១១:២ និងការពន្យល់) ។

**៣៧:២៩** *កន្លុះរបស់អញនៅច្រមុះឯង* គឺចង់បង្ហាញថា នាសម័យនោះ អាសស៊ើបណ្តើរពួកឈ្លើយរបស់គេដោយប្រើកន្លុះ ដោយនៅច្រមុះបណ្តើរ (សូមមើលការពន្យល់ ២ពវ ១៩:២៨) ។

**៣៧:៣០** *ទីសំគាល់* សូមមើល ៧:១១:១៤ និងការពន្យល់ ។ *ផលដែលដុះឯង* សូមមើលការពន្យល់ ២ពវ ១៩:២៩ ។ *ដល់ឆ្នាំទី២ . . . ដល់ឆ្នាំទី៣* សូមមើលការពន្យល់ ២ពវ ១៩:២៩ ។ គឺដោយឆ្នាំទីពីរមានរយៈពេលនៃការនោះខ្លីគឺរួមមកទីសំគាល់ដែលកើតមានតិចជាង ៣៦ឆ្នាំហើយមានពេលវេលា៣ឆ្នាំផ្សេងទៀតក៏ជាទីសំគាល់បានប្រទានមកគឺក្នុងជំពូក ២០:៣ ។ *ដាំចំការទំពាំងបាយជូរទៅ រួចបរិភោគផលទាំងនោះ* គឺជាការឆ្លើតតបនិងចរិតរបស់ពួកអាសស៊ើរដូចជាក្នុង ៣៦:១៦ (សូមមើលការពន្យល់ត្រង់ជំពូកនោះ) ។

**៣៧:៣១–៣២** *សំណល់* មើលការពន្យល់ ខ.៤ ១:៩ ២ពវ ១៩:៤,៣០–៣១។

**៣៧:៣១** *ចាក់ឫសទៅក្រោម . . . បង្កើតផលទៅលើ* សូមមើល ៤:២ ១១:១,១០ ២៧:៦ និងការពន្យល់ ។

**៣៧:៣២** សូមមើល ៩:៧ និងការពន្យល់ ។

**៣៧:៣៣** គឺជាការមកឡោមព័ទ្ធរបស់ពួកអ្នកដែលឈ្លានពានគេ ដោយជីកស្នាមភ្លោះច្បាំងនឹងទីនោះ (សូមមើល ២សយ ២០:១៥) ។

**៣៧:៣៥** *យល់ដល់ដាវីឌ* ព្រះបានមានបន្ទូលសន្យាដល់ស្តេចដាវីឌថានិងត្រូវគ្រងរាជបល្ល័ង្កក្នុងក្រុងយេរូសាឡិម សូមមើល ៩:៧ ៥៥:៣ ២សយ ៧:១៦ និងការពន្យល់ ។

**៣៧:៣៦** *ទេវតានៃព្រះយេហូវ៉ា . . . សំឡាប់* គឺព្រះយេហូវ៉ាបានបញ្ជូនទេវតានិងភ្នាក់ងាររបស់ផងទ្រង់ នាំនូវគ្រោះសាហាវមកដល់មនុស្សលោក ។ គឺប្រៀបទៅនឹងការវាយកូនច្បងនៃសាសន៍អេស៊ីព្ទ (នក ១២:១២–១៣) ហើយដាវរបស់ទេវតានោះក៏បង្អុលដោយដាវឆ្ពោះទៅក្រុងយេរូសាឡិម (សូមមើល ២សយ ២៤:១៥–១៦ និងការពន្យល់២៤:១៦ ១របា ២១:២២, ២៧) ។ ក៏ជាប្រវត្តិសាស្ត្រ ដែលនាំមកនូវគ្រោះសាហាវដល់ប្រទេសក្រិកក៏

ទាំងអស់ ៣៧ហេតុនោះសានហេរីប[ឡ] ជាស្ដេចអាសស៊ើរ
ក៏ត្រឡប់ទៅអាស្រ័យនៅឯក្រុងនីនីវេ[អ]វិញ ៣៨រួចកាលទ្រង់
កំពុងតែថ្វាយបង្គំ នៅក្នុងវិហារ[ក]របស់ព្រះនីសរូក ជាព្រះ
នៃទ្រង់ នោះអ័ឌ្រាម៉ាលេក និងសារេស៊ើរ ជាបុត្ររបស់
ទ្រង់បានធ្វើគុតទ្រង់ដោយដាវ ហើយរត់រួចទៅឯស្រុក
អារ៉ារ៉ាត[ខ]ទៅ នោះអេសារ-ហាដោន[គ] ជាព្រះរាជបុត្រា
ក៏ឡើងសោយរាជ្យជំនួសព្រះបិតា[ឃ]។

## ជម្ងឺស្ដេចហេសេគា

*៣៨:១-៨ – ២ពវ ២០:១-១១ ២របា ៣២:២៤-២៦*

**៣៨** ១នៅគ្រានោះហេសេគាទ្រង់ព្រះប្រឈួន ហៀបនឹង
សុគត ហើយហោរាអេសាយ ជាកូនអ័ម៉ូស[ក] ក៏មកគាល់
ទ្រង់ទូលថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរផ្ដាំ
ដល់វង្សារបស់ឯងចុះ[ខ] ដ្បិតឯងត្រូវស្លាប់ហើយ មិនរស់
ទេ[គ] ២នោះហេសេគាទ្រង់ក៏បែរព្រះភក្ត្រទៅឯជញ្ជាំង ក៏
អធិស្ឋានដល់ព្រះយេហូវ៉ាថា ៣ឱព្រះយេហូវ៉ាអើយ សូម
ទ្រង់នឹកចាំពីទូលបង្គំដែលបានដើរ[ឃ]នៅចំពោះទ្រង់ ដោយ
ពិតត្រង់ ហើយដោយចិត្តស្មោះចំពោះ[ង] ព្រមទាំងប្រព្រឹត្ត
អំពើដ៏ល្អនៅព្រះនេត្រទ្រង់ជាយ៉ាងណា[ច] រួចហេសេគាទ្រង់
ព្រះកន្សែង[ឆ]ជាខ្លាំង ៤នោះព្រះបន្ទូល[ជ]នៃព្រះយេហូវ៉ាក៏មក
ដល់អេសាយថា ៥ចូរទៅប្រាប់ហេសេគាថា ព្រះយេហូវ៉ា
ជាព្រះនៃដាវីឌ[ឈ] ឰយុកោឯង ទ្រង់មានបន្ទូលដូច្នេះ អញ
បានឮពាក្យអធិស្ឋានរបស់ឯង ក៏បានឃើញទឹកភ្នែកឯង
ហើយ[ញ] មើល អញនឹងចំរើនអាយុឯងឡើង១៥ឆ្នាំ[ដ]ទៀត
៦ហើយនឹងដោះឯង និងទីក្រុងនេះ ឱ្យរួចពីកណ្ដាប់ដៃនៃ
ស្ដេចអាសស៊ើរ ព្រមទាំងការពារ[ឋ]ទីក្រុងនេះផង ៧នេះ
នឹងបានទុកជាទីសំគាល់[ឌ]ពីព្រះយេហូវ៉ាដល់ឯង ថាព្រះ
យេហូវ៉ាទ្រង់នឹងសំរេចការនេះ ដែលទ្រង់បានមានបន្ទូល
ហើយ ៨គឺអញនឹងធ្វើឱ្យស្រមោល ដែលបានជ្រេទៅនៅ
នាលិការ ថ្ងៃរបស់ស្ដេចអ័ហាស បានថយមកវិញ ដូច្នេះ
ស្រមោល ក៏ថយមកវិញ១០ចុច តាមដែលបានជ្រេទៅ
ហើយ[ឍ]។
៩នេះជាពាក្យដែលហេសេគា ជាស្ដេចយូដា បានសរសេរ
ក្នុងកាលដែលទ្រង់ប្រឈួន ហើយបានជាឡើងវិញ ។
១០យើងបានពោលថា យើងនឹងទៅឯទ្វារនៃស្ថានឃុំ
ព្រលឹងមនុស្សស្លាប់[ណ] ក្នុងកាលដែលនៅពាក់កណ្ដាល
អាយុទេ[ត] សំណល់នៃឆ្នាំអាយុបានបង្អត់ដល់យើងហើយ[ថ]
១១យើងបានពោលថា យើងនឹងលែងឃើញព្រះ គឺជាព្រះ
យេហូវ៉ា[ទ] នៅស្ថានរបស់មនុស្សរស់នេះទៀត[ធ] យើងនឹង
ខានឃើញមនុស្ស ដែលនៅកណ្ដាលពួកមនុស្សលោកត

**៣៧:៣៧** ឡ ២របា ៣២:១ អ លប ១០:១១ ណាហ ១:១ **៣៧:៣៨** ក ខ.១៤ ខ លប ៨:៤ យរ ៥១:២៧ គ ២ពវ ១៧:២៤ ឃ អស ៩:៤ ១០:២៦ ១៤:២៥ **៣៨:១** ក អស ៣៧:២ ខ ២សម ១៧:២៣ គ ២ពវ ៨:១០ **៣៨:៣** ឃ ទដ ២៦:៣ ង ១ពវ ៨:៦១ ១របា ២៩:១៩ ច ចទ ៦:១៨ ១០:២០ ឆ ទដ ៦:៨ **៣៨:៤** ជ ១សម ១៣:១៣ អស ៣៩:៥ **៣៨:៥** ឈ ២ពវ ១៨:៣ ញ ទដ ៦:៦ ដ ២ពវ ១៨:២ **៣៨:៦** ឋ អស ៣១:៥ **៣៨:៧** ឌ លប ២៤:១៤ ២របា ៣២:៣១ អស ៧:១១,១៤ ២០:៣ **៣៨:៨** ឍ យស ១០:១៣ **៣៨:១០** ណ យប ១៧:១៦ ទដ ១០៧:១៨ ២របា ១:៩ ត ទដ ១០២:២៤ ថ យប ១៧:១១ **៣៨:១១** ទ អស ១២:២ ធ យប ២៨:១៣ ទដ ១១៦:៩

មានទាហានពលទ័ពជាច្រើនត្រូវស្លាប់ ដែលជាការសម្រេចទំនាយក្នុងគម្ពីរ ១០:៣៣-៣៤ (និងការពន្យល់) ៣០:៣១ ៣១:៨ (សូមមើលការពន្យល់) ។

**៣៧:៣៧** *ក្រុងនីនីវេ* គឺជារាជធានីរបស់ស្រុកអាសស៊ើរ (សូមមើល យហ ១:២ និងការពន្យល់) ។

**៣៧:៣៨** *នៅក្នុងព្រះវិហារ* គឺជាទីកន្លែងដែលស្ដេចហេសេគាបានទៅឯដំណាក់របស់ព្រះហើយក៏កើតកម្លាំងយ៉ាងខ្លាំង (ខ.១,១៤) ។ ម្ភៃឆ្នាំក្រោយមកគឺក្នុងឆ្នាំ ៦៨១ មុន គ.ស ស្ដេចសានហេរីបក៏បានទៅព្រះវិហារដែលមានរូបព្រះរបស់គាត់ហើយក៏ត្រូវបានគេសម្លាប់ (សូមមើលការពន្យល់ លប ៨:៤) ។ *អេសារ-ហាដោន* ជាស្ដេចដែលបានសោយរាជក្នុងកំឡុងឆ្នាំ ៦៨១-៦៦៩ ក៏សូមមើល ២ពវ ១៩:៣៧ និងការពន្យល់ អក ៤:២) ។

**៣៨:១** *នៅគ្រានោះ* គឺជាគ្រាមួយរយៈពេលនៃការឈ្លានពានរបស់ស្ដេចសានហេរីប គឺក្នុងឆ្នាំ ៧០១ មុន គ.ស (សូមមើល ខ.៦) ។ *ហោរាអេសាយ* គឺជាហោរាមានភាពល្បីល្បាញក្នុងរយៈពេលដ៏វែង (ជំពូក ៣៦:៣៩) ។ *ដល់វង្សារបស់ឯងចុះ* សូមមើលការពន្យល់ ២ពវ ២០:១ ។ *ដ្បិតឯងត្រូវស្លាប់ហើយ* សូមមើលការពន្យល់ ២ពវ ២០:១ ឯហោរាអេលីសេក៏បានថ្លែងទំនាយពីការស្រដៀងគឺរឿងស្លាប់របស់ស្ដេចបេន បេនដាឌ់ (សូមមើល ២ពវ ៨:៩-១០ និងការពន្យល់) ។ *មិនរស់ទេ* សូមមើល ខ.២១ និងការពន្យល់ ។

**៣៨:២** *ជញ្ជាំង* គឺប្រហែលជាជញ្ជាំងស្ថិតនៅក្បែរព្រះវិហារ ។ *អធិស្ឋាន* គឺស្ដេចហេសេគា ដែលពុំទាន់មានបុត្រាមួយអង្គណាឡើយក្នុងការទទួលស្នងរាជ (មើលការប្រៀបធៀប ៣៩:៧ ២ពវ ២១:១ និងការពន្យល់) ។

**៣៨:៣** *ដោយចិត្តស្មោះចំពោះ* គឺដូចជាស្ដេចដាវីឌ (១ពវ ១១:៤) ស្ដេចហេសេគា ដែលមានចិត្តស្មោះត្រង់និងព្រះ (សូមមើល ៣៦:៧ ២ពវ ១៨:៣-៥ និងការពន្យល់) ។

**៣៨:៦** *នឹងដោះឯង . . . នឹងទីក្រុងនេះ* សូមមើល ៣១:៥ ៣៧:៣៥ និងការពន្យល់ ។

**៣៨:៧** *ទីសំគាល់* សូមមើល ៧:១១,១៤ និងការពន្យល់ ។

**៣៨:៨** *ថ្ងៃរបស់ស្ដេចអ័ហាស* សូមមើលការពន្យល់ ២ពវ ២០:១១ ។ ក៏មានជាពន្លឺសំដែងពីការអស្ចារ្យ សូមមើល ២ពវ ២០:៩-១១ យស ១០:១២-១៤ និងការពន្យល់ ១០:១៣ ។

**៣៨:១០-២០** ខទាំងនេះបង្ហាញពីបទទំនុកសម្រាប់សរសើរដំកើងដែលមានពីរវគ្គហើយស្រដៀងគ្នានិងបទទំនុកជាច្រើនទៀត ។ ស្ដេចហេសេគា ក៏មានការចាប់អារម្មណ៍យ៉ាខ្លាំង និងបទទំនុករបស់ស្ដេចដាវីឌនិងរបស់លោកអេសាក (សូមមើល ២របា ២៩:៣០) ។

**៣៨:១០-១៤** គឺស្ដេចហេសេគាបានត្អូញត្អែ ពីទុក្ខសោករបស់គាត់កាលពីអតីតកាល (ខ.១) ។

**៣៨:១១** *ព្រះយេហូវ៉ា* សូមមើល ២៦:៤ ។ *នៅស្ថានរបស់មនុស្សរស់* សូមប្រៀបធៀបនឹង ៣៤:៤ (ក៏សូមមើល ហាព ១:១២) ។

ទៅ ១២ជីវិតរបស់យើងបានត្រូវរើចុះចេញ[ន] គឺបានលើក
យកចេញពីយើង ដូចជាត្រសាល[ប]របស់អ្នកគង្វាល យើង
បានមូរបំព្រួញ[ផ]ជីវិត ដូចជាអ្នកត្បាញ ទ្រង់នឹងកាត់យើង
ចេញពីដំបាញ[ព] តាំងពីថ្ងៃដរាបដល់យប់[ភ] ទ្រង់នឹងផ្តាច់
ជីវិតយើងទៅ ១៣ដរាប[ម]ដល់ពេលព្រឹក យើងបានគិតថា
ទ្រង់នឹងបំបាក់[យ]អស់ទាំងឆ្អឹងយើង[រ] ដូចជាសិង្ហ តាំងពីថ្ងៃ
ដរាបដល់យប់[ល]ទ្រង់ផ្តាច់ជីវិតយើង ១៤យើងបានយំចេច
ចាច ដូចជាសត្វត្រចៀកកាំ ឬដូចជាក្រសារ ក៏បានថ្ងូរដូច
ព្រាប[វ]ដែរ ឯភ្នែកយើងបានស្រវាំង[ស]ទៅ ដោយងើយមើល
ទៅលើ ឱព្រះយេហូវ៉ាអើយ ទូលបង្គំត្រូវសង្កត់សង្កិន សូម
ធានាឱ្យទូលបង្គំផង[ហ] ១៥តើទូលបង្គំនឹងថាដូចម្តេច[ឡ] ទ្រង់
បានទាំងមានបន្ទូលមកទូលបង្គំ ហើយបានសំរេចតាម
សំដីផង[អ] ទូលបង្គំបានដើរសន្សឹមៗ[ក]គ្រប់១ជីវិត ដោយ
ព្រោះសេចក្តីជូរចត់នៅក្នុងចិត្ត[ខ] ១៦ឱព្រះអម្ចាស់អើយ គឺ
ដោយសេចក្តីទាំងនេះហើយ ដែលមនុស្សរស់នៅ ហើយ
ជីវិតនៃវិញ្ញាណទូលបង្គំ ក៏នៅទាំងមូលក្នុងសេចក្តីទាំងនេះ
ឯង ដូច្នេះ សូមទ្រង់ប្រោសឱ្យទូលបង្គំបានជា ហើយឱ្យទូល
បង្គំបានរស់វិញ[គ] ១៧មើល ទូលបង្គំមានសេចក្តីជូរចត់យ៉ាង
ខ្លាំង[ឃ] នោះគឺឱ្យទូលបង្គំមានសេចក្តីសុខទេ[ង] ទ្រង់បាន
ប្រោសឱ្យទូលបង្គំរួចពីរណ្តៅ[ច]នៃសេចក្តីពុករលួយ ដោយ
សេចក្តីស្រឡាញ់ដល់ព្រលឹងទូលបង្គំ ដ្បិតទ្រង់បានបោះ
ចោលអស់ទាំងអំពើបាប[ឆ]របស់ទូលបង្គំ ទៅក្រោយទ្រង់
ហើយ[ជ] ១៨ពីព្រោះស្ថានឃុំព្រលឹងមនុស្សស្លាប់[ឈ]នឹងឃោង
ដែរកទ្រង់មិនបាន ហើយសេចក្តីស្លាប់ក៏នឹងអួតសរសើរ
ទ្រង់មិនបានដែរ[ញ] ពួកអ្នកដែលចុះទៅក្នុងរណ្តៅ[ដ] និង
សង្ឃឹមដល់សេចក្តីពិតរបស់ទ្រង់មិនបានឡើយ ១៩ឯមនុស្ស
រស់ គឺជាមនុស្សរស់ហើយ ដែលនឹងសរសើរ[ឋ]ដល់ទ្រង់
ដូចជា ទូលបង្គំនៅថ្ងៃនេះដែរ ឪពុកនឹងបន្តសេចក្តីពិត
របស់ទ្រង់ឱ្យកូន[ឌ]ស្គាល់តទៅ ២០ព្រះយេហូវ៉ា ទ្រង់ជួយ
សង្គ្រោះទូលបង្គំ ដូច្នេះ យើងខ្ញុំនឹងច្រៀង[ឍ]បទរបស់ទូល
បង្គំ តាមប្រដាប់ភ្លេងមានខ្សែ[ណ] នៅក្នុងព្រះវិហារ[ត]នៃព្រះ
យេហូវ៉ាដរាបដល់អស់១អាយុ[ថ]នៃយើងខ្ញុំ ។
២១រីឯអេសាយ លោកបានប្រាប់ថា ត្រូវឱ្យគេយកផែន
ល្វា១មកបិទលើបូស នោះទ្រង់នឹងបានជា ២២ហើយ
ហេសេគាទ្រង់ក៏បានមានបន្ទូលថា តើមានទីសំគាល់[ទ]ណា
ឱ្យយើងបានដឹងថា យើងនឹងឡើងទៅក្នុងព្រះវិហារនៃព្រះ
យេហូវ៉ាបាន ។

### បេសកជនមកពីក្រុងបាប៊ីឡូន

*៣៩:១–៨ – ២ពវ ២០:១២–១៩*

**៣៩** ១នៅគ្រានោះ ម្រដាក់–បាឡាដាន ជាបុត្រនៃ
បាឡាដាន ស្តេចស្រុកបាប៊ីឡូន[ក] ក៏ផ្ញើសំបុត្រ និងជង្វាយ

**៣៨:១២** ន យប ៤:២១ ប អស ៣៣:២០ ២កថ ៥:១,៤ ២ពត ១:១៣–១៤ ផ អស ៣៤:៤ ហព ១:១២ ព ជន ១១:១៥ យប ៧:៦ ទដ ៣១:២២ ភ ឧ.១៣ ទដ ៣២:៤ ៧៣:១៤ឱ **៣៨:១៣** ម ទដ ៣៧:៧ យ យប ៩:១៧ ទដ ៥១:៨ រ យប ១០:១៦ យរ ៤៤:១៧ បទ ៣:៤ ដយ ៦:២៤ ល ឧ.១២ **៣៨:១៤** វ លប ៨:៨ អស ៥៩:១១ ស ទដ ៦:៧ ហ លប ៥០:២៤ យប ១៧:៣ **៣៨:១៥** ឡ ២សយ ៧:២០ អ ទដ ៣៩:៩ ក ១ពវ ២១:២៧ ខ យប ៧:១១ **៣៨:១៦** គ ទដ ១១៩:២៥ ហព ១២:៩ **៣៨:១៧** ឃ យប ៧:១១ ទដ ១១៩:៧១,៧៥ ង រម ៨:២៨ ហព ១២:១១ ច យប ១៧:១៦ ទដ ៣០:៣ ឆ ទដ ១០៣:៣ យរ ៣១:៣៤ ជ ទដ ១០៣:១២ អស ៤៣:២៥ មីក ៧:១៩ **៣៨:១៨** ឈ ជន ១៦:៣០ សស ៩:១០ ញ ទដ ៦:៥ ៨៨:១០–១១ ១១៥:១៧ ដ ទដ ៣០:៩ **៣៨:១៩** ឋ ទដ ១១៨:១៧ ១១៩:១៧៥ ឌ ចទ ១១:១៩ **៣៨:២០** ឍ ទដ ៦៨:២៥ ណ ទដ ៣៣:២ ៤៥:៨ ត ទដ ១១៦:១៧–១៩ ថ ទដ ២៣:៦ ៦៣:៤ ១១៦:២ **៣៨:២២** ទ ២របា ៣២:៣១ **៣៩:១** ក ២របា ៣២:៣១

**៣៨:១៣** *បំបាក់អស់ទាំងឆ្អឹងយើង* គឺជាភាពវេទនាផ្នែកសាច់ឈាម ឬក៏ដូចជាព្រលឹងដែលជារឿយៗគឺគេប្រៀបធៀបនិងការបាក់បែកឆ្អឹង (សូមមើល ទដ ៦:២ ៣២:៣) ។

**៣៨:១៥** *តើទូលបង្គំនឹងថាដូចម្តេច* លោកអេសេគាក៏មានចិត្តនឹងឆ្ងល់ក្នុងចិត្ត ហើយក៏ទូលទៅព្រះថាតើលោកត្រូវសរសើរព្រះដោយវិធីណា (ប្រៀបធៀបនឹង ២សយ ៧:២០) ។

**៣៨:១៦** *គឺដោយសេចក្តីទាំងនេះហើយ* គឺប្រហែលជាចង់សម្តែងពីព្រះបន្ទូលសន្យារបស់ផងទ្រង់ ។

**៣៨:១៧** *រណ្តៅនៃសេចក្តីពុករលួយ ដូចជានៅឯទីផ្នូរ* ឬរាលកប់ខ្មោច (សូមមើល ទដ ៥៥:២៣ និងការពន្យល់) ។ *អស់ទាំងអំពើបាបរបស់ទូលបង្គំ* ដូចជាកាប្រោសលោះខាងឯសាច់ឈាមនិងខាងព្រលឹងវិញ្ញាណ គឺទាំងពីរផ្នែកនេះជួនកាលមានទំនាក់ទំនងរួមគ្នា (សូមមើល ៥៣:៤–៥ និងការពន្យល់) ។ *អំពើបាបរបស់ទូលបង្គំទៅក្រោយទ្រង់ហើយ* គឺទ្រង់មិនគ្រាន់តែដាក់អំពើបាបយើងឱ្យមើលលែងឃើញនោះទេតែទ្រង់ បានយកវាចេញឱ្យផុតពីជីវិតរបស់យើង (ទដ ១០៣:១២ មីក ៧:១៩) ក៏ឱ្យឆ្ងាយពីអារម្មណ៍របស់យើងហើយ លែងឱ្យអំពើបាបនោះមានជីវិតរស់តទៅទៀត (យរ ៣១:៣៤) (អស ៤៣:២៥ ៤៤:២២ ទដ ៥១:១,៩ យរ ៥០:២០ កថ ៣:១៩) ។

**៣៨:១៨** *សង្ឃឹម . . . មិនបាន* គឺការយល់ដឹងពីការដែលផុតជីវិតទៅគឺបានកំណត់នៅក្នុងគ្រាសម័យសញ្ញាចាស់ ប៉ុន្តែដំណឹងល្អពីព្រះគ្រីស្ទក៏មានការនាំមកនូវភាពអសីលធម៌ចំពោះ (២ធថ ១:១០) ។

**៣៨:២០** *ច្រៀងបទរបស់ទូលបង្គំតាមប្រដាប់ភ្លេងមានខ្សែ* គឺជាការប្រកាសជាមួយព្រះយ៉ាងជិតស្និទ្ធដោយបទចម្រៀងសរសើរតម្កើង (ប្រៀបធៀប ទដ ៣៣:១–៣) ។ *នៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា . . . អស់មួយអាយុនៃយើងខ្ញុំ* មានដូចជាស្តេចហេសេគា ស្តេចដាវីឌ (ទដ ២៣:៦) ។

**៣៨:២១** *ឱ្យគេយក . . . មកបិទ* គឺជាកិរិយាស័ព្ទពហុវចនៈ គឺជា ។ *ផែនល្វា១* ដែលគេប្រើសម្រាប់ធ្វើជាថ្នាំនាសម័យបុរាណ ។ *ទ្រង់នឹងបានជា* គឺមានលក្ខណៈផ្ទុយនឹង ខ.១ ដែលព្រះបានឆ្លើយតបនិងការអធិស្ឋានរបស់លោកអេសេគាគឺបានប្រោសឱ្យជាពីជម្ងឺ (មើល ខ.៥) ។

**៣៨:២២** *ទីសំគាល់* គឺក្នុងនេះចង់បង្ហាញពីការប្រោសលើមុខបូសដែលឈឺ (សូមមើល ខ.២១) ។

**៣៩:១** *ប្រដាក់–បាឡាដាន* ជាស្តេចបានសោយរាជ្យក្នុងកំឡុងឆ្នាំ ៧២១–៧១០ មុន គ.ស តែក្រោយមក (មើលការពន្យល់ ២ពវ ២០:១២) ។ *ស្រុកបាប៊ីឡូន* សូមមើលការពន្យល់ ១៣:១ ។ *ផ្ញើសំបុត្រនឹងជង្វាយ* ក្នុងអត្ថន័យនេះប្រហែលជាស្តេចក្រដាក់–បាឡាដានចង់ឱ្យស្តេច ហេសេគា ឧបត្ថម្ភក្នុង

មកថ្វាយហេសេគា ដោយឮថា ទ្រង់បានប្រឈួនហើយ
បានជាវិញ ២ហេសេគាទ្រង់ក៏មានសេចក្ដីអំណរនឹងគេ[ខ]
ហើយទ្រង់បង្ហាញឃ្លាំងនៃព្រះរាជ្យទ្រព្យទាំងប៉ុន្មាន គឺជា
មាស[គ] ប្រាក់ គ្រឿងក្រអូប និងប្រេងវិសេស ហើយឃ្លាំង
គ្រឿងសស្ត្រាវុធរបស់ទ្រង់ទាំងអស់ និងគ្រប់ទាំងអស់ដែល
ឃើញមានក្នុងឃ្លាំងទ្រង់[ឃ] គ្មានអ្វីនៅក្នុងព្រះរាជវាំង ឬនៅ
ក្រោមអំណាចទ្រង់ ដែលហេសេគាមិនបានបង្ហាញដល់គេ
នោះឡើយ ៣នោះហោរាអេសាយ លោកមកគាល់ស្ដេច
ហេសេគា ទូលសួរថា អ្នកទាំងនោះនិយាយអ្វីខ្លះគេមកពី
ណាដែលមកគាល់ទ្រង់នេះ ហេសេគាទ្រង់តបថា គេមកពី
ប្រទេសឆ្ងាយណាស់[ង] គឺពីស្រុកបាប៊ីឡូន ៤រួចលោក
ទូលសួរទៀតថា គេបានឃើញអ្វីខ្លះនៅក្នុងព្រះរាជវាំង
ហេសេគាឆ្លើយថា គេបានឃើញរបស់ទាំងអស់ ដែលនៅ
ក្នុងដំណាក់យើងហើយ ក្នុងព្រះរាជ្យទ្រព្យយើងទាំងប៉ុន្មាន
គ្មានអ្វីដែលយើងមិនបានបង្ហាញដល់គេនោះឡើយ ៥ដូច្នេះ
អេសាយ លោកទូលដល់ហេសេគាថា សូមស្ដាប់ព្រះបន្ទូល[ច]
របស់ព្រះយេហូវ៉ា នៃពួកពលបរិវារសិន ៦មើល និងមាន
គ្រាមកដល់ ដែលគេនឹងមកយកអស់ទាំងរបស់ទ្រព្យនៅក្នុង
ព្រះរាជវាំង និងរបស់ទាំងប៉ុន្មានដែលពួកឰយុកោទ្រង់
បានសន្សំទុក ដរាបដល់សព្វថ្ងៃនេះ នាំទៅឯក្រុងបាប៊ីឡូន[ឆ]
ឥតទុកឱ្យមានសល់អ្វីឡើយ នេះឯងជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ៧ឯពួកបុត្រាទាំងប៉ុន្មានដែលនឹងកើតពីទ្រង់មក
នោះគេនឹងដឹកនាំទៅ ឱ្យធ្វើជាមនុស្ស កំរៀវនៅក្នុង
ដំណាក់នៃស្ដេចស្រុកបាប៊ីឡូន[ជ] ៨ហេសេគា ទ្រង់មានបន្ទូល
ទៅអេសាយថា ព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលបានថា
នោះ ក៏ល្អហើយ[ឈ] ទ្រង់ក៏មានបន្ទូលទៀតថា គឺពីព្រោះនៅ
ក្នុងជីវិតយើង នោះនឹងមានសេចក្ដីសន្តិសុខ ហើយនិង
សេចក្ដីពិតវិញ[ញ]។

## សេចក្ដីកំសាន្តទុក្ខសម្រាប់រាស្ត្ររបស់ព្រះ

**៤០** ១ព្រះនៃឯងរាល់គ្នា ទ្រង់មានបន្ទូលថា ចូរកំសាន្ត
ទុក្ខ[ក] ចូរកំសាន្តទុក្ខរាស្ត្រចុះ ២ត្រូវឱ្យលួងលោមចិត្ត[ខ]នៃ
ក្រុងយេរូសាឡិម ហើយស្រែកប្រាប់គេថា គ្រាធ្វើសឹក
សង្គ្រាម[គ]របស់គេបានសំរេចហើយ[ឃ] អំពើទុច្ចរិតរបស់គេ
ក៏បានអត់ទោសឱ្យ[ង] ហើយគេបានទទួលសំណង១ជា២[ច]
ពីព្រះហស្ត នៃព្រះយេហូវ៉ា ឱ្យស្នងនឹងអំពើបាបគេដែរ ។

**៣៩:២** ខ ២របស ៣២:៣១ គ ២ពវ ១៨:១៥ ឃ ២របស ៣២:២៧–២៩ **៣៩:៣** ង ចទ ២៨:៤៩ **៣៩:៥** ច អស ៣៨:៤ **៣៩:៦** ឆ ពច ៦:៤ ២ពវ ២៤:១៣ **៣៩:៧** ជ ២ពវ ២៤:១៥ ដយ ១:១–៧ **៣៩:៨** ឈ ពច ១០:១៥ យប ១:២១ ទដ ៣៩:៩ ញ ២របស ៣២:២៦ **៤០:១** ក អស ១២:១ ៤៩:១៣ ៥១:៣,១២ ៥២:៩ ៥៧:១៨ ៦១:២ ៦៦:១៣ យរ ៣១:១៣ សជ ៣:១៤–១៧ សក ១:១៧ ២កថ ១:៣ **៤០:២** ខ លប ៣៤:៣ អស ៣៥:៤ គ យប ៧:១ ឃ អស ៤១:១១–១៣ ៤៩:២៥ ង លវ ២៦:៤១ ច អស ៥១:១៩ ៦១:៧ យរ ១៦:១៨ ១៧:១៨ សក ៩:១២ វវ ១៨:៦

យុទ្ធនាការប្រឆាំងនិងពួកអាសស៊ើរ ។ ក្នុងអំឡុងពេលដែលទ្រង់បំពេញភារៈកិច្ចក៏បង្កើតឱ្យមានចលនាតស៊ូរជាច្រើន ប្រឆាំងនិងស្រុកជិតខាងដែលជាពួកដែលទ្រង់ស្អប់ ។ សូមមើលការពន្យល់ ២ពវ ២០:១២ ។

**៣៩:២** *មាស . . . ប្រាក់ . . . ក្នុងឃ្លាំងទ្រង់* សូមមើល ២របស ៣២:២៧–២៩,៣១ និងការពន្យល់ ។ ក៏ទំនងជាស្ដេចហេសេគាកំពុងតែស្វែងរកជំនួយពីពួកសាសន៍បាប៊ីឡូន ដើម្បីប្រឆាំងនិងការគំរាមកំហែងពីពួកអាសស៊ើរ (សូមមើលការពន្យល់ ២ពវ ២០:១៣) ។

**៣៩:៣** *ហោរាអេសាយ* គឺតាំងពីដំបូងព្រះបានបញ្ជូនលោក អេសាយនៅប្រឈរមុខនិងពួកស្ដេចអេហាស (៧:៣) មើលការប្រៀបធៀប (សូមមើល ២សយ ១២:១ និងការពន្យល់) ។

**៣៩:៥** *ព្រះបន្ទូលរបស់ព្រះយេហូវ៉ា* ដែលផ្ទុយនិងព្រះបន្ទូលនៃសេចក្ដីសង្ឃឹមក្នុង ៣៨:៤–៦ ។

**៣៩:៦** *នាំទៅឯស្រុកបាប៊ីឡូន* ការបង្ហាញពីក្រុង បាប៊ីឡូនជាលើកដំបូងគឺមានលក្ខណៈដូចក្រុងយេរូសាឡិមដែលគេគ្រប់គ្រង មើលតារយៈ ១៤:៣–៤ ក៏លាតត្រដាងពីការជម្លៀសនៃពួកបាប៊ីឡូន (សូមមើលការពន្យល់) ការអាក្រក់របស់បុត្រាស្ដេចហេសេគា គឺលោក ម៉ាន៉ាសេ គឺជាបុព្វហេតុចំបងនៃការជាប់ជាឈ្លើយ (សូមមើល ២ពវ ២១:១១–១៥) ។

**៣៩:៧** *ដែលនឹងកើតចេញពីទ្រង់មក* ដូចជាស្ដេច យ៉ូយ៉ាគីន (សូមមើល ២ពវ ២៤:១៥ និងការពន្យល់) ។ *មនុស្សកំរៀវ* សូមប្រៀបធៀបនិង ដយ ១:៣–៦ ដែលភាសាហេព្រើរបានបកប្រែពាក្យ "មនុស្សកំរៀវ" ជាស្ដេចនៃក្រុងបាប៊ីឡូន (ដយ ១:៣) ។

**៣៩:៨** *ព្រះបន្ទូល . . . ក៏ល្អហើយ* សូមមើលការពន្យល់ ២ពវ ២០:១៩ ។ *ពីព្រោះនៅក្នុងជីវិតយើង និងមានសេចក្ដីសន្តិសុខ* សូមមើល ២ពវ ២២:២៦ និងការពន្យល់ ។ "សេចក្ដីសន្តិសុខ"ពាក្យនេះបានលេចឱ្យឃើញក្នុងបទបន្ទូរ ៤៨:២២ ៥៧:២១ ក៏ញែកដាច់ចេញពី ២៧ ជំពូកចុងក្រោយទៅជាបីផ្នែកក្នុងចំណោមជំពូក ៩ (៤០–៤៨ ៤៩–៥៧ ៥៨–៦៦) ។

**៤០:១–៦៦:២៤** ក្នុងជំពូកទី១ រហូតដល់ ៣៥ ជាការថ្លែងទំនាយរបស់លោកអេសាយដែលសំដែងប្រឆាំងនិងពួកអាសស៊ើរ ដែលតែងតែគំរាមកំហែងដល់សាសន៍យូដានិងក្រុងយេរូសាឡិម ដូចជាក្នុងជំពូក ៣៦:–៣៩ អេសាយបានកត់ត្រាពីភាពបរាជ័យរបស់ពួកអាសស៊ើរ និងការប្រមានដល់ស្រុកបាប៊ីឡូនដែលត្រូវប្រឈរមុខនិងគ្រោះភ័យ ក្នុងជំពូក ៤០:៦៦ គឺគាត់សរសេរពីខណៈពេល ដែលពួកបាប៊ីឡូនបានជំលៀសចេញពីស្រុកយូដា (សូមមើល ត្រង់សេចក្ដីផ្ដើមនិងអ្នកនិពន្ធ) ។

**៤០:១** *ចូរកំសាន្តទុក្ខ ចូរកំសាន្តទុក្ខ* ពោលគឺជាការកំសាន្តទុក្ខយ៉ាងខ្លាំងទាក់ទង់និងជំពូក ៥១:៩,១៧ ៥២:១,១១ ៥៧:១៣ ៦២:១០ ។

**៤០:២** *លួងលោមចិត្ត* ដែលបានប្រែមកពីព្រះគម្ពីរភាសាហេព្រើរប្រើក្នុង ២របស ៣២:៦ ដែលក្នុងពេលស្ដេចហេសេគា"លើកទឹកចិត្ត"ដល់ពួកយូដាឱ្យទុកចិត្តដល់ព្រះអម្ចាស់ ដោយមិនគិតពីការលុកលុយរបស់ពួកអាសស៊ើរឡើយ ។ *គ្រាធ្វើសឹកសង្គ្រាម* ក៏ដូចជាក្នុងរយៈពេលពួកបាប៊ីឡូន(ប្រៀបធៀប ទដ ១៣៧:១–៦ បទ ១:១–៦ បទ ១:១–២,៩,១៦–១៧,២១) ។ *អំពើទុច្ចរិតរបស់គេ . . . ក៏បានអត់ទោស* គឺដោយតាមរយៈការដាក់ទណ្ឌកម្មទៅលើពួកឈ្លើយ "គឺជាវិបត្តភ័យទ្វេរដង" ៥១:១៩ ។

៣មានឮសំឡេង១កំពុងតែស្រែកនៅទីរហោស្ថានថាចូរ
រៀបចំផ្លូវ[ឆ]សំរាប់ទទួលព្រះយេហូវ៉ា ចូរធ្វើឱ្យមានថ្នល់
រាប[ជ] ស្មើនៅទីស្ងាត់ថ្វាយព្រះនៃយើងរាល់គ្នាចុះ[ឈ] ៤ឯគ្រប់
ទាំងច្រកភ្នំ នោះនឹងត្រូវលើកឡើង[ញ] ហើយគ្រប់ទាំងភ្នំ
ធំតូច[ដ] នឹងត្រូវពង្រាបទៅ នៅកន្លែងណាដែលគ្រលិក
គ្រលុក នោះត្រូវធ្វើឱ្យស្មើ[ឋ] ហើយកន្លែងណាដែលរដិប
រដុបនឹងត្រូវធ្វើឱ្យរាបចុះ ៥នោះសិរីល្អ[ឌ]នៃព្រះយេហូវ៉ានឹង
សំដែងមក គ្រប់មនុស្សទាំងឡាយនឹងបានឃើញព្រមគ្នា[ឍ]
ដ្បិត ព្រះឱស្ឋនៃព្រះយេហូវ៉ាបានមានបន្ទូលហើយ[ណ]។
៦មានឮសំឡេង១កំពុងតែថា ចូរប្រកាសចុះ នោះមាន
ម្នាក់សួរថា តើត្រូវឱ្យស្រែកថាដូចម្តេច ចូរថា មនុស្សជាតិ
ទាំងឡាយប្រៀបដូចជាស្មៅ[ត] ហើយអំពើដ៏ល្អទាំងប៉ុន្មាន
របស់គេក៏ដូចជាផ្កានៅទីវាល ៧ឯស្មៅក៏ស្វិតក្រៀម[ថ]ទៅ
ហើយផ្ការោយរុះចុះ ដោយព្រោះខ្យល់[ទ]នៃព្រះយេហូវ៉ា
បក់[ធ] មកត្រូវ ឯបណ្តាជន គេពិតដូចជាស្មៅដែរ ៨ស្មៅក៏
ស្វិតក្រៀម ហើយផ្កា[ន]ក៏រោយរុះចុះ តែព្រះបន្ទូល[ប]របស់
ព្រះនៃយើងរាល់គ្នាវិញ នោះស្ថិតស្ថេរនៅ[ផ]ជាដរាប[ព]។

**៤០:៣** ឆ អស ១១:១៦ ៤៣:១៩ មឡ ៣:១ ជ សភ ៣:៥-៦ ឈ មថ ៣:៣ មក ១:៣ យហ ១:២៣
**៤០:៤** ញ អស ៤៩:១១ ដ អស ២:១៤ ឋ ទដ ២៦:១២ អស ២៦:៧ ៤៥:២,១៣ យរ ៤១:៩
**៤០:៥** ឌ នក ១៦:៧ ជន ១៤:២១ អស ៥៩:១៩ ឍ អស ៥២:១០ ៦២:២ លក ២:៣០ ៣:៤-៦ ណ អស ១:២០ ៥៨:១៤
**៤០:៦** ត លប ៦:៣ អស ២៩:៥
**៤០:៧** ថ យប ៨:១២

៩ឱអ្នកដែលនាំដំណឹងល្អ[ភ] មកដល់ក្រុងស៊ីយ៉ូនអើយ
ចូរឡើងទៅប្រកាសប្រាប់ពីលើភ្នំខ្ពស់ចុះ ឱអ្នកដែលនាំ
ដំណឹងល្អមកដល់ក្រុងយេរូសាឡិមអើយ[ម] ចូរបន្លឺសំឡេង
ឡើងជាខ្លាំង ចូរបន្លឺឡើង កុំខ្លាចឡើយ ចូរប្រាប់ដល់ទី
ក្រុងនៃស្រុកយូដាទាំងប៉ុន្មានថា មើលន៏ ព្រះនៃអ្នករាល់
គ្នា[យ] ១០មើល ព្រះអម្ចាស់យេហូវ៉ាទ្រង់នឹងយាងមក[រ] ដោយ
មានព្រះចេស្តា[ល] ហើយព្រះពាហុ[វ]នៃទ្រង់នឹងកាន់កាប់ត្រួត
ត្រា[ស]ឱ្យទ្រង់ មើល ទ្រង់នាំយករង្វាន់[ហ]មកជាមួយ ហើយ
បំណាច់ដែលទ្រង់សងដល់គេក៏នៅចំពោះទ្រង់ ១១ទ្រង់
នឹងឃ្វាលហ្វូងរបស់ទ្រង់[ឡ] ដូចជាអ្នកគង្វាល ទ្រង់នឹង
ប្រមូលអស់ទាំងកូនចៀមមកបីនៅព្រះពាហុ[អ] ហើយលើក

អស ១៥:៦ ទ នក ១៥:១០ យប ៤១:២១ ធ ទដ ១០៣:១៦ អគ ២២:២១ **៤០:៨** ន អស ៥:២៤ យក ១:១០ ប អស ៥៥:១១ ៥៩:២១ ផ សភ ១៩:២១ អស ៧:៧,៩ យរ ៣៩:១៦ ព ទដ ១១៩:៨៩ មថ ៥:១៨ ១ពត ១:២៤-២៥ **៤០:៩** ភ អស ៤១:២៧ ៤៤:២៨ ៥២:៧-១០ ៦១:១ ណហ ១:១៥ កច ១៣:៣២ រម ១០:១៥ ១កថ ១៥:១-៥ ម អស ១:១ យ អស ២៥:៩ **៤០:១០** រ អស ៣៥:៤ ៥៩:២០ មថ ២១:៥ វវ ២២:៧ ល អស ២៨:២ វ ទដ ៤៤:៣ អស ៣០:៣០ ៣៣:២ ស អស ៩:៦-៧ ហ អស ៣៥:៤ វវ ២២:១២ **៤០:១១** ឡ លប ៤៨:១៥ ទដ ២៨:៩ មីក ៥:៤ យហ ១០:១១ អ ជន ១១:១២

**៤០:៣-៥** សូមមើល ៣៥:១-២ និងការពន្យល់ ៣៥:២ ។

**៤០:៣** *ឮសំឡេង* ពាក្យថាសំឡេងបានបង្ហាញបីដង មើលក្នុង (ខ.៣,៦,៩) គឺជាពាក្យកំសាន្តចិត្តដែលមានក្នុង ខ.១ នោះដែរ ។ ក្នុងគ្រាសញ្ញាថ្មីពាក្យថាសំឡេងបានប្រើចំពោះ លោកយ៉ូហានបាទីស្ទ គឺក្នុង មថ ៣:៣ លក ៣:៤ យហ ១:២៣ (ក៏សូមមើលការពន្យល់ផងដែរ) ។ *ចូររៀបផ្លូវ* ដើម្បីឱ្យផ្លូវបានស្អាត និងពុំមានឧបសគ្គរារាំង (មើលការប្រៀបធៀប ៥៧:១៤ ៦២:១០) ។ តាមរយៈពាក្យពេជ្រភាសាក្នុង ខ.៣-៤ បានបង្ហាញពីភាពពិតពីទំនៀមទំលាប់របស់ប្រជាជនតំបន់មជ្ឈឹមបូពាហ៍ នាសម័យបុរាណដែលពេលនោះគេបានបញ្ជូនតំណាងទៅរៀបចំផ្លូវជាមុនសិន គឺដើម្បីទទួលព្រះមហាក្សត្រ ។ គឺបង្ហាញពីរូបភាពមួយរបស់ព្រះយេហូវ៉ាដែលយាងមកទីក្រុងយេរូសាឡិម ។ ក្នុងគម្ពីរ មថ ៣:១-៨ គឺបង្ហាញពីលោកយ៉ូហានបានប្រកាសពីការលន់តួបាប ដែលជាការចាំបាច់បំផុត ដើម្បីជាការរៀបផ្លូវសម្រាប់ព្រះគ្រីស្ទ ។ សូមមើល ១១:១៦,៣៥:៨ និងការពន្យល់ ។

**៤០:៤** *នៅកន្លែងណាដែលគ្រលិកគ្រលុក . . . ត្រូវធ្វើឱ្យស្មើ* សូមមើល ២៦:៧ និងការពន្យល់ ។

**៤០:៥** *សិរីល្អ . . . សំដែងមក* ដោយសារតែព្រះបានប្រោសលោះដល់សាសន៍អ៊ីស្រាអែល ពីពួកបាប៊ីឡូន (សូមមើល ៣៥:៩-១០ ៤៤:២៣-២៤) និងសាសន៍ផ្សេងៗ និងឃើញការប្រោសលោះ (សូមមើល ៥២:១០ និងការពន្យល់ ប្រៀបធៀប លក ៣:៦ និងការពន្យល់) ។ ហើយចុងបញ្ចប់ សិរីល្អរបស់ព្រះនៃការប្រោសលោះ គឺក៏ឃើញព្រះយេស៊ូវព្រះអង្គសង្គ្រោះ (សូមមើល ១:១៤ ១១:៤ ១៧:៤ ហព ១:៣ និងការពន្យល់) ជាពិសេសខណៈពេលទ្រង់យាងត្រឡប់មកវិញ គឺជាខណៈដែលទ្រង់ត្រូវប្រោសលោះផងដែរ (មថ ១៦:២៧ ២៤:៣០ ២៥:៣១ វវ ១:៧) (ក៏សូមមើល ១កថ ១០:៣១ ២កថ ៣:១៨ អភ ៣:២១ និងការពន្យល់) ។

**៤០:៦,៨** សូមមើលសេចក្តីស្រង់ ១ពត ១:២៤-២៥ ។

**៤០:៦** *ប្រៀបដូចជាស្មៅ* សូមមើល ៣៧:២៧ និងការពន្យល់ ៥១:១២ ។ *ហើយអំពើដ៏ល្អទាំងប៉ុន្មានរបស់ពួកគេ . . . ដូចផ្កានៅទីវាល* ទោះជាអំណាចរបស់ពួកអាសស៊ើរ និងពួកបាប៊ីឡូនមិនយូរប៉ុន្មានក៏ត្រូវផុតរលត់ ។

**៤០:៨** *តែព្រះបន្ទូលរបស់ព្រះនៃយើងរាល់គ្នាវិញនោះ ស្ថិតស្ថេរនៅជាដរាប* តែផែនការនិងគោលបំណងរបស់ជាតិសាសន៍ទាំងឡាយក៏ពុំបានទទួលជ័យជម្នះ (សូមមើល ៨:១០ និងការពន្យល់) ។

**៤០:៩** *ដំណឹងល្អ* គឺជាដំណឹងដែលព្រះអម្ចាស់បាននាំរាស្ត្ររបស់ផងទ្រង់ត្រឡប់ទៅស្រុកយូដាវិញ (ខ.១០-១១) ។ ទ្រង់មានព្រះទ័យមេត្តាករុណានិងប្រោសលោះរាស្ត្រទាំងអស់នោះ (សូមមើល ៥២:៧-១០ ៦១:១ និងការពន្យល់) ។ តែគ្រាសញ្ញាថ្មីការពង្រីក "ដំណឹងល្អ" គឺសំដៅទៅលើការសង្គ្រោះដែលព្រះគ្រីស្ទបានផ្តល់មកឱ្យរាស្ត្ររបស់ផងទ្រង់ទាំងអស់ (សូមមើល ១កថ ១៥:២-៣ និងការពន្យល់) ។ *មើលន៏ព្រះនៃអ្នករាល់គ្នា* គឺជាការវិលត្រឡប់មកឯទីក្រុងយេរូសាឡិមវិញរបស់ព្រះយេហូវ៉ា (សូមមើល ខ.១០) ។ ពាក្យទាំងនេះក៏សម្រាប់ប្រើដើម្បីពណ៌នាស្តីពីការវិលត្រឡប់ពីការបំបរបង់(សូមមើល ៥២:៧-៩ និងការពន្យល់) ការយាងមកជាលើកទីមួយរបស់ព្រះយេស៊ូវគ្រីស្ទ(មថ ២១:៥)និងយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (៦២:១១ វវ ២២:១២) ។ សូមមើល ៣៥:៤ និងការពន្យល់ ។

**៤០:១០** *ព្រះពាហុនៃទ្រង់* ប្រៀបធៀប ៥១:៩ ៥៩:១៦ និងការពន្យល់ ។ ទ្រង់មានលក្ខណៈសម្បត្តិផងទ្រង់ទាំងព្រះចេស្តានិងភាពសំឡូត(ខ.១១) ។ (សូមមើល ៦២:១១-១២ និងការពន្យល់) ។

**៤០:១១** *ទ្រង់នឹងឃ្វាលហ្វូងរបស់ទ្រង់* សូមប្រៀបធៀប យរ ៣១:១០ អគ ៣៤:១១-១៦ និងការពន្យល់ ។

ផ្ទាប់នៅព្រះឱរា[ក] ក៏នឹងនាំពួកមេៗ[ខ] ដែលមានកូនខ្ចី ទៅ
ដោយថ្នម[គ] ។
១២តើអ្នកណាបានវាល់ទឹក[ឃ]ទាំងប៉ុន្មាន នៅក្នុងទូកដៃ[ង]
ហើយវាស់ផ្ទៃមេឃដោយចំអាមដែរ[ច] ព្រមទាំងដាក់ធូលីដី
ទាំងអស់ចុះក្នុងរង្វាល់ ហើយថ្លឹងអស់ទាំងភ្នំធំ ដោយ
ជញ្ជីង នឹងភ្នំតូចទាំងប៉ុន្មានដោយត្រាជូ[ឆ] ១៣តើអ្នកណា
បានស្ទង់ព្រះវិញ្ញាណ[ជ]នៃព្រះយេហូវ៉ា ឬបានបង្រៀនទ្រង់
ដោយខ្លួនធ្វើជាអ្នកជួយប្រឹក្សា[ឈ] ១៤តើទ្រង់បានប្រឹក្សានឹង
អ្នកណា ហើយអ្នកណាបានពន្យល់ទ្រង់ ឬបង្រៀនទ្រង់
ក្នុងផ្លូវយុត្តិធម៌ ឬឱ្យទ្រង់មានចំណេះ[ញ] ឬបង្ហាញផ្លូវនៃ
យោបល់ដល់ទ្រង់[ដ] ១៥មើល អស់ទាំងសាសន៍ប្រៀបដូច
ជាទឹក១ដំណក់នៅក្នុងថាំង ហើយក៏រាប់ទុកដូចជាលំអង
ធូលីនៅលើថាសជញ្ជីងដែរ[ឋ] មើល ទ្រង់លើកកោះទាំង
ប៉ុន្មានឡើង ដូចជារបស់យ៉ាងតិចតួច[ឌ] ១៦ឯព្រៃល្បាណូន[ឍ]
នោះមិនគ្រាន់នឹងដុត ហើយសត្វ[ណ]ទាំងប៉ុន្មាននៅព្រៃនោះ
ក៏មិនល្មមនឹងធ្វើជាដង្វាយដុតផង ១៧អស់ទាំងសាសន៍[ត] រាប់
ដូចជាទទេសោះ[ថ]នៅចំពោះទ្រង់ ទ្រង់រាប់គេទុកដូចជា
តិចជាងសូន្យទៅទៀត ហើយជាឥតប្រយោជន៍ផង[ទ] ។
១៨ដូច្នេះ តើអ្នករាល់គ្នានឹងផ្ទៀបផ្ទឹមព្រះ[ធ] ដូចជាអ្នក
ណា ឬប្រៀបទ្រង់នឹងភាព[ន]អ្វី ១៩ឯរូបព្រះ[ប] គឺមានជាងម្នាក់
បានសិតធ្វើទេ ហើយជាងទង[ផ] គេស្រោបដោយមាស[ព]ក៏ធ្វើ
ខ្សែប្រាក់ឱ្យផង ២០ចំណែកអ្នកណាដែលខ្វះខាត គ្មានល្មម
នឹងធ្វើដូច្នោះបាន គេក៏រើសយកឈើ[ភ]ដែលមិនចេះពុកវិញ
គេរកជាងមានស្នាដៃ ឱ្យមកឆ្លាក់ធ្វើរូប[ម]១ដឹកល់ឡើងជាប់
មិនឱ្យត្រូវរើចេញឡើយ[យ] ២១តើអ្នករាល់គ្នាមិនបានដឹងទេ
ឬ តើមិនបានឮ[រ] តើឥតមានអ្នកណាប្រាប់[ល]ដល់ អ្នករាល់គ្នា
តាំងពីដើមមក[វ] តើអ្នករាល់គ្នាមិនបានយល់[ស] សេចក្តីតាំង
ពីកំណើតលោកីយរៀងមកទេឬអី[ហ] ២២គឺព្រះដែលគង់[ឡ]ពី
លើរង្វង់ផែនដី ហើយមនុស្សនៅផែនដី ប្រៀបដូចជាក
ណ្តូបវិញ[អ] គឺទ្រង់ដែលលាតផ្ទៃមេឃ[ក] ដូចជាលាតបារាំ[ខ]
ហើយសន្ធឹងទៅ ដូចជាត្រសាល[គ]សំរាប់អាស្រ័យនៅ[ឃ]
២៣ទ្រង់ទំលាក់ងារពួកអ្នកគ្រប់គ្រង[ង]ឱ្យសូន្យទៅ[ច] ក៏ធ្វើឱ្យពួក
ចៅក្រមនៅផែនដីទៅជាឥតប្រយោជន៍ដែរ ២៤អើ ពួកទាំង
នោះនឹងមិនដែលបានដាំចុះឡើយ ក៏នឹងបានសាបព្រោះ
សឹងតែមិនទាន់ផង អើ ដើមគេនឹងមិនដែលចាក់ឫស[ឆ] ចុះ
ក្នុងដីឡើយ ទ្រង់នឹងផ្លុំ[ជ]ខ្យល់ទៅ នោះគេនឹងស្វិតក្រៀម[ឈ]

**៤០:១១** ក ចទ ២៦:១៩ ខ អស ៤៩:១០ គ លប ៣៣:១៣ ចទ ៣០:៤ **៤០:១២** ឃ យប ១២:១៥ ៣៨:១០ ង សភ ៣០:៤ ច យប ៣៨:៥ ហាព ១:១០–១២ ឆ យប ៣៨:១៨ សភ ១៦:១១ **៤០:១៣** ជ អស ១១:២ ៤២:១ ឈ យប ១៥:៨ រម ១១:៣៤ ១កថ ២:១ **៤០:១៤** ញ យប ២១:២២ កល ២:៣ ដ យប ១២:១៣ ៣៤:១៣ អស ៥៥:៩ **៤០:១៥** ឋ ទដ ៦២:៩ ឌ ចទ ៩:២១ អស ២:២២ **៤០:១៦** ឍ អស ៣៣:៩ ៣៧:២៤ ណ ទដ ៥០:៩–១១ មីក ៦:៧ ហាព ១០:៥–៩ **៤០:១៧** ត អស ៣០:២៨ ថ យប ១២:១៩ អស ២៩:៧ ទ អស ៣៧:១៩ ដយ ៤:៣៥ **៤០:១៨** ធ នក ៨:១០ ១សយ ២:២ ន ចទ ៤:១៥ កច ១៧:២៩ **៤០:១៩** ប នក ២០:៤ ទដ ១១៥:៤ អស ៣៧:១៩ ៤២:១៧ យរ ២:៨,២៨ ១០:៨ ១៦:១៩ ហាព ២:១៨ សក ១០:២ ផ អស ៤១:៧ ៤៦:៦ យរ ១០:៣ ព អស ២:២០ ៣១:៧ **៤០:២០** ភ អស ៤៤:១៩ ម ១សយ ១២:២១ យ ១សយ ៥:៣ **៤០:២១** រ ខ.២៨ ២ពវ ១៩:២៥ អស ៤១:២២ ៤២:៩ ៤៤:៨ ៤៨:៣,៥ ល ទដ ១៩:១ ៥០:៦ កច ១៤:១៧ វ លប ១:១ ស រម ១:១៩ ហ អស ៤៨:១៣ ៥១:១៣ **៤០:២២** ឡ ២របា ៦:១៨ ទដ ២:៤ អ ជន ១៣:៣៣ ក លប ១:១ អស ៤៨:១៣ ខ លប ១:៨ យប ២២:១៤ គ យប ៣៦:២៩ ឃ យប ២៦:៧ **៤០:២៣** ង យប ១២:១៨ អស ៣៤:១២ ច យប ១២:១៩ អម ២:៣ **៤០:២៤** ឆ យប ៥:៣ ជ ២សយ ២២:១៦ អស ១១:៤ ៤១:១៦ ឈ យប ៨:១២ ១៨:១៦

**៤០:១២–៣១** គឺជាឃ្លាសំនួរមានលក្ខណៈខាងវោហារសាស្ត្រ ដែលបានគេប្រើដើម្បីបញ្ចុះបញ្ចូលមនុស្សឱ្យគេទុកចិត្តដល់ព្រះយេហូវ៉ា គឺជាអង្គដែលមានសម្ថភាពជួយដោះលែង ឬពង្រឹងនិងស្អាងដល់រាស្ត្ររបស់ផងទ្រង់ ។
**៤០:១២** *វាល់ទឹកទាំងប៉ុន្មាន* សូមមើល យប ២៨:២៥ ៣៨:៨ ក្នុង យប ៣៨–៤១ គឺព្រះយេហូវ៉ាបានធ្វើឱ្យលោកយ៉ូបឃើញពីភាពអស្ចារ្យរបស់ផងទ្រង់ ដូចការដែលពណ៌នារួចមកហើយ ។ *វាស់ផ្ទៃមេឃដោយចំអាមដែរ* សូមមើល ៤៨:១៣ និងការពន្យល់។
**៤០:១៣** មានសេចក្តីដក់ស្រង់ក្នុង រម ១១:៣៤ ១កថ ២:១៦ ។ *អ្នកជួយប្រឹក្សា* សូមមើល ៩:៦ និងការពន្យល់ ។
**៤០:១៥** *អស់ទាំងសាសន៍ប្រៀបដូចជាទឹក១ដំណក់នៅក្នុងថាំង* សូមមើលការពន្យល់ ខ.៦ ។ *លំអងធូលី* សូមមើល ១៧:១៣ និងការពន្យល់ ២៩:៥ ។
**៤០:១៦** *ព្រៃល្បាណូន* គឺជាព្រៃឈើដើមតាត្រៅ ។ *សត្វទាំងប៉ុន្មាន* ធៀបនឹង ទដ ១០៤:១៦–១៨ និងការពន្យល់ ។ ក៏មិនល្មមនិងធ្វើជាដង្វាយដុតទេ ។
**៤០:១៧** *ជាទទេសោះ . . . ជាឥតប្រយោជន៍ផង* (សូមមើល ១៣:១៩ និងការពន្យល់) ។
**៤០:១៨–២០** គឺមានលក្ខណៈលើសពីហោរាណាៗទាំងអស់ដែលពួកមនុស្សគេបានសិតរូបព្រះដែលធ្វើពីមាស ធ្វើពីឈើល្អដើម្បីថ្វាយបង្គំ ។ ឯលោកអេសាយក៏បញ្ជាប់ពីភាពគ្មានឧត្តមគតិដែលយករូបព្រះមកថ្វាយបង្គំ ។ សូមមើល ៤៤:៩–២០ (សូមមើលការពន្យល់ ៤១:៧,២២–២៤ ៤២:១៧ ៤៦:៥៧ ៤៨:៥ និងការពន្យល់) ។
**៤០:១៩** *គឺមានជាងម្នាក់ . . . ជាងទង* សូមមើល ៤១:៧ ៤៤:១០–១២ ។ *មាស . . . ខ្សែប្រាក់* សូមមើល ២:២០ ហប ២:១៨–១៩ និងការពន្យល់ ។
**៤០:២០** *ឈើ* សូមមើល ៤៤:១៤–១៦,១៩ និងការពន្យល់ ។ ពាក្យថា *ដែលមិនដែលជាប់* សូមមើលការពន្យល់ ៤១:៧ ៤៦:៧ ។
**៤០:២១** *តាំងពីដើមមក* គឺជាព្រះរាជកិច្ចរបស់ព្រះអម្ចាស់ក្នុងនាមទ្រង់ជាព្រះអាទិករ ក៏បានបង្ហាញខ្លះក្នុង (ការប្រៀបធៀបនឹង ៣៧:២៦ ៤១:៤, ២៦) ។
**៤០:២២** *គង់ពីលើ* សូមប្រៀបធៀប ៦៦:១ សូមមើល ៣៧:១៦ និងការពន្យល់ ។ ពាក្យថា *រង្វង់* ឬក៏ "ពេលខាងមុខក៏ជិត" សូមមើលគម្ពីរ យប ២២:១៤ សភ ៨:២៧ ។ ពាក្យថា *លាតផ្ទៃមេឃ . . . ដូចជាត្រសាលសំរាប់អាស្រ័យនៅ* សូមមើល ៤២:៥ ៤៤:២៤ ៥១:១៣ ទដ ១០៤:២ ក៏សូមមើលការពន្យល់ សភ ១៩:៤៦–៦ ។
**៤០:២៣** *ពួកអ្នកគ្រប់គ្រង . . . ពួកចៅក្រម . . . ជាឥតប្រយោជន៍* សូមប្រៀបធៀប យរ ២៥:១៧–២៦ ដយ ២:២១ ។
**៤០:២៤** *ខ្យល់កួច . . . ដូចជាជញ្ជ្រាំង* សូមមើល ១៧:១៣ និងការពន្យល់ ៤១:១៥–១៦ ។

រួចខ្យល់កួចនឹងផាត់យកគេទៅ ដូចជាជញ្ជ្រាំង[ញ] ២៥ដូច្នេះ
ព្រះដ៏បរិសុទ្ធទ្រង់មានបន្ទូលថា ឯងរាល់គ្នានឹងប្រៀបផ្ទឹម
អញដូចជាអ្នកណា[ដ] ឱ្យអញបានស្មើនឹងគេនោះ[ឋ] ២៦ចូរងើយ
ភ្នែកឯងមើលទៅលើ[ឌ] ហើយពិចារណាពីពួកណាដែល
បានបង្កើត[ឍ] របស់ទាំងនេះ ដែលនាំពួកពលបរិវារ[ណ] ចេញ
មកតាមចំនួនដូច្នេះ ទ្រង់ក៏ហៅរបស់ទាំងនោះតាម ឈ្មោះ
រៀងរាល់តួ ដោយព្រះចេស្តាដ៏ធំរបស់ទ្រង់[ត] ហើយគ្មាន
អ្នកណាមួយខានឡើយ[ថ] ដោយព្រោះតែជានុភាពដ៏ខ្លាំងក្លា
ដែរ ។

២៧ឱពួកយ៉ាកុបអើយ ហេតុអ្វីបានជានិយាយ ឱពួក
អ៊ីស្រាអែលអើយ ហេតុអ្វីបានជាថា ផ្លូវដែលឯងប្រព្រឹត្ត
នោះលាក់កំបាំងនឹងព្រះយេហូវ៉ា ហើយរឿងរ៉ាវរបស់ឯង
បានរំលងផុតពីព្រះនៃឯងដូច្នេះ[ទ] ២៨តើឯងមិនបានដឹង តើ
មិនបានឮឬអី[ធ] ថាព្រះដ៏គង់នៅអស់កល្បជានិច្ច[ន] គឺព្រះ
យេហូវ៉ា ជាព្រះដែលបានបង្កើត[ប] ផែនដី រហូតដល់ចុង
បំផុត[ផ] ទ្រង់មិនដែលល្វើយឡើយ ក៏មិនដែលអស់កំឡាំង
ផង[ព] គ្មានអ្នកណាអាចស្ទង់យល់យោបល់របស់ទ្រង់បាន
ទេ[ភ] ២៩ទ្រង់រមែងចំរើនកំឡាំង[ម] ដល់អ្នកដែលល្វើយ[យ]
ហើយចំណែកអ្នកដែលគ្មានកំឡាំងសោះ នោះទ្រង់ក៏
ប្រទានឱ្យ ៣០ទោះទាំងពួកជិទង់ គេនឹងល្វើយ ហើយនឿយ
ហត់ទៅបាន ពួកកំឡោះ[រ] ក៏នឹងដួលជ្រលាកបានផង[ល] ៣១តែ
អស់អ្នកណាដែលសង្ឃឹម[វ] ដល់ព្រះយេហូវ៉ាវិញ នោះនឹង
មានកំឡាំងចំរើនជានិច្ច[ស] គេនឹងហើរឡើងទៅលើ ដោយ
ស្លាបដូចសត្វឥន្ទ្រី[ហ] គេនឹងរត់ទៅឥតដែលហត់ ហើយនឹង
ដើរឥតដែលល្វើយឡើយ[ឡ]។

### អ្នកជួយដល់អ៊ីស្រាអែល

**៤១** ១ឱកោះទាំងប៉ុន្មានអើយ[ក] ចូរនៅស្ងៀម[ខ] នៅមុខអញ
ចុះ ហើយឱ្យប្រជាជាតិទាំងឡាយបានចំរើនកំឡាំង[គ] ឡើង
ត្រូវឱ្យគេចូលមកជិត[ឃ] រួចសឹមឱ្យគេនិយាយចុះ ចូរឱ្យ
យើងមូលគ្នា[ង] មកវិនិច្ឆ័យសំរេចក្តីយើង ២តើអ្នកណាបាន
លើកម្នាក់ឡើង[ច] ពីទិសខាងកើត[ឆ] ទាំងហៅមកដល់ជើងខ្លួន
ក្នុងសេចក្តីសុចរិត[ជ,ឈ] ព្រមទាំងប្រគល់អស់ទាំងសាន៍ ដល់
អ្នកនោះ ហើយលើកឱ្យគ្រប់គ្រងលើអស់ទាំងស្តេចផង ក៏
យកគេដូចជាធូលី[ញ] ប្រគល់ដល់ដាវរបស់អ្នកនោះ ហើយ
ដូចជាជញ្ជ្រាំង[ដ] ដែលត្រូវផាត់ដោយខ្យល់ដល់ធ្នូដែរ[ឋ]

**៤០:២៤** ញ យប ២៤:២៤ អស ៤១:២ **៤០:២៥** ដ ១សយ ២:២ ១រប ១៦:២៥ ឋ អស ១:៤ ៣៧:២៣ **៤០:២៦** ឌ អស ៥១:៦ ឍ ខ.២៨ ទដ ៨៩:១១–១៣ អស ៤២:៥ ៦៦:២ ណ ២ពវ ១៧:១៦ នហ ៩:៦ យប ៣៨:៣២ ត យប ៩:៤ អស ៤៥:២៤ អស ៤៥:២៤ អភ ១:១៩ ថ អស ៣៤:១៦ **៤០:២៧** ទ យប ៦:២៩ ២៧:២ លក ១៨:៧–៨ **៤០:២៨** ធ ខ.២១ ន ចទ ៣៣:២៧ ទដ ៩០:២ ប ខ.២៦ ផ អស ៣៧:១៦ ព អស ៤៤:១២ ភ ទដ ១៤៧:៥ រម ១១:៣៣

**៤០:២៩** ម លប ១៨:១៤ ទដ ៦៨:៣៥ ១១៩:២៨ យ អស ៥០:៤ ៥៧:១៩ យរ ៣១:២៥ **៤០:៣០** រ អស ៩:១៧ យរ ៦:១១ ៩:២១ ល ទដ ២០:៨ អស ៥:២៧ **៤០:៣១** វ ទដ ៣៧:៩ ៤០:១ អស ៣០:១៨ លក ១៨:១ ស ១សយ ២:៤ ២ពវ ៦:៣៣ ២កថ ៤:១៦ ហ នក ១៩:៤ ឡ ២កថ ៤:១ ហព ១២:១–៣ **៤១:១** ក អស ១១:១១ ខ ទដ ៣៧:៧ ហព ២:២០ សផ ១:៧ សក ២:១៣ គ ១សយ ២:៤ ឃ អស ៤៨:១៦ ៥៧:៣ ង អស ១:១៨ ៣៤:១ ៥០:៨ **៤១:២** ច អរ ១:២ ឆ ខ.២៥ អស ១៣:៤,១៧ ៤៤:២៨ ៤៥:១,១៣ ៤៨:១៣ យរ ៥០:៣ ៥១:១១ ជ អស ៤៥:៨,១៣ ឈ អស ៤៤:២៨ យរ ២៥:៩ ញ ២សយ ២២:៤៣ ដ ទដ ១:៤ អស ៤០:២៤ ឋ អស ១៣:១៨

**៤០:២៦** សូមមើល ខ.១៨ គឺរាស្ត្រអ៊ីស្រាអែលបានប្រៀបធៀបព្រះអម្ចាស់ទៅរូបព្រះ ។ ព្រះដ៏បរិសុទ្ធ សូមមើល ១:៤ និងកាពន្យល់ ។

**៤០:២៦** បានបង្កើត សូមមើល ខ.២១–២២ និងការពន្យល់ ។ *ដែលនាំពួក. . . ចេញ* ព្រះគម្ពីរភាសាហេព្រើរចំពោះវោហាស័ព្ទនេះ គឺគេប្រើសម្រាប់ពណ៌នាពីហ្វូងផ្កាយ សូមមើលក្នុង យប ៣៨:៣២ ។ ពាក្យថា *ពួកពលបរិវារ* ក៏ត្រូវ បានមនុស្សគោរពថ្វាយបង្គំផងដែរ (សូមមើល ៤៧:១៣ យរ ១៩:១៣ និងការពន្យល់) ។ *តាមឈ្មោះរៀងរាល់តួ* សូមមើលការពន្យល់ ទដ ១៤៧:៤–៦ ។ *ហើយគ្មានអ្នកណាមួយខានឡើយ* សូមមើល ៣៤:១៦ និងការពន្យល់ ។

**៤០:២៧–៣១** ដូចជានៅក្នុងបទទំនុកសរសើរតម្កើងមួយចំនួន គឺត្រូវបានលោក អេសាយ រៀបរាប់ពីភាពឧត្តមរបស់ព្រះ (សូមមើល ខ.១២–២៦)។ គឺដូចជាព្រះអម្ចាស់មានអំណាចចេស្តាអាចរំដោះរាស្ត្ររបស់ទ្រង់និងធ្វើឱ្យពួកគេវិលមករកស្ថានភាពដើមវិញ បើពួកគេរង់ចាំទ្រង់ដោយសេចក្តីជំនឿ និងទុកចិត្តក្នុងទ្រង់ គឺទ្រង់និងផ្តល់កម្លាំងដល់ពួកគេ ។

**៤០:២៧** *ផ្លូវ* គឺជាលក្ខខណ្ឌ *លាក់កំបាំង* ប្រៀបធៀប ៤៩:២៤ ៥៤:៨ ។

**៤០:២៨** *ព្រះដ៏គង់នៅអស់កល្បជានិច្ច* មើល ៩:៦ ។ *ព្រះដែលបានបង្កើតផែនដី* សូមមើល ២១:២២ និងការពន្យល់ ។ *រហូតដល់ចុងបំផុត* សូមមើល ១១:១២ និងការពន្យល់ និងប្រៀបធៀប ៥:២៦ ៤១:៩ ៤៣:៦ ។ *មិនដែលអស់កំឡាំងផង* មានលក្ខណៈផ្ទុយនឹង ៤៤:១២ ។

**៤០:៣០** *គេនឹងល្វើយ . . . ក៏នឹងដួល* សូមមើលការពន្យល់ ។

**៤០:៣១** *សង្ឃឹមដល់* គឺជាសេចក្តីទុកចិត្តនិងសង្ឃឹម និងបានដូចបំណង (សូមមើល ៥:២ ៤៩:២៣) ។ *ចំរើនជានិច្ច* "ជាការប្រែប្រួល" សូមមើល ៤១:១ នឹងការពន្យល់។ ភាពខ្សោយរបស់ពួកគេ គឺផ្តល់ឱកាសដល់អំណាចចេស្តារបស់ព្រះ (ខ.២៩) ។ *ជាឥន្ទ្រី* ជាសត្វដែលគេទទួលស្គាល់ពីភាពក្លាហានរបស់វា (សូមមើល ១០៣:៥ និងការពន្យល់) ។

**៤១:១,៥** *កោះ* ជាប្រភេទដីនៃកោះសមុទ្រ (សូមមើល ១១:១១ និងការពន្យល់) ។

**៤១:១** *ចំរើនកំឡាំង* មើល ៤០:៣១ និងការពន្យល់ ។ ក៏មានជាតិសាសន៍មួយចំនួន និងរូបព្រះរបស់ពួកគេក៏កំពុងសម្តែងអំណាច និងពង្រីកដូចជាព្រះអម្ចាស់របស់រាស្ត្រអ៊ីស្រាអែលផងដែរ (សូមមើល ខ.២១–២៤) ។

**៤១:២** *ម្នាក់ឡើងពីទិសខាងកើត* គឺសំដៅទៅលើស្តេចស៊ីរូស ជាស្តេចស្រុកពើស៊ី ដែលគ្រងរាជ្យក្នុងឆ្នាំ (៥៥៩–៥៣០ មុន គ.ស) ក៏បានគ្រប់គ្រងកាន់កាប់ស្រុកបាប៊ីឡូនក្នុងកំឡុងឆ្នាំ ៥៣៩ មុន គ.ស (សូមមើល ១២:១៧ នឹងការពន្យល់) ក៏មានហេតុការមួយមានច្បាប់បានអនុញ្ញាត្តិឱ្យពួកយូដាចូលទៅឯទីក្រុងយេរូសាឡិម (សូមមើល អគ ១:១–៤ ៦:៣–៥) ។ មើល ខ.២៥ ៤៤:២៨–៤៥:៥,១៣ ៤៦:១១ ។ *ទាំងហៅមកដល់ជើងខ្លួនក្នុងសេចក្តីសុចរិត* គឺករណីដូចជា អ្នកបម្រើព្រះក្នុង ៤២:៦ ស្តេចស៊ីរូសជាស្តេចអធិរាជ្យរបស់ស្រុកស៊ី គឺគ្រងរាជ្យក្នុងចន្លោះឆ្នាំ (៥៥៩–៥៣០ មុន គ.ស) គេបានជ្រើស

៣អ្នកនោះដេញតាមគេ ក៏ដើរដោយសុខសាន្ត[ឌ] ទៅតាមផ្លូវ
ដែលជើងខ្លួនមិនដែលជាន់ឡើយ ៤តើអ្នកណាបានធ្វើ
ហើយសំរេចការនេះ ដោយហៅ[ឍ]អស់ទាំងដំណមនុស្ស
តាំងពីដើមមក[ណ] គឺអញ យេហូវ៉ានេះ ដែលជាដើម ហើយ
ជាអ្នកនៅជាមួយនឹងមនុស្សជាន់ក្រោយបង្អស់ដែរ[ត] គឺអញ
នេះហើយ[ថ] ៥កោះ[ទ]ទាំងប៉ុន្មានបានឃើញ ហើយក៏ភ័យ
ខ្លាច អស់ទាំងចុងផែនដី[ធ]ក៏ញាប់ញ័រ គេនាំគ្នាចូលមកជិត
៦គេជួយគ្នាទៅវិញទៅមក ហើយគ្រប់គ្នានិយាដល់បងប្អូន
ខ្លួនថា ចូរមានចិត្តក្លាហានឡើង[ន] ៧ដូច្នេះ ជាងឈើ[ប] គេ
កំឡាចិត្តជាងទង[ផ] ហើយអ្នកដែលផែដោយញញួរក៏កំឡា
ចិត្តដល់អ្នកដែលដំដែក ដោយនិយាយពីការផ្សាថា នេះល្អ
ហើយ រួចក៏វាយភ្ជាប់ដោយដែកគោល ដើម្បីមិនឱ្យរើទៅ
ឯណាឡើយ[ព]។
៨តែឯង ឱអ៊ីស្រាអែល ជាអ្នកបំរើអញអើយ[ភ] ព្រមទាំង
យ៉ាកុប ដែលអញបានរើស[ម] ជាពូជអ័ប្រាហាំ[យ]ដ៏ជាសំឡាញ់
របស់អញផង[រ] ៩គឺឯងដែលអញបានចាប់នាំមក ពីចុងផែន
ដី[ល] ហើយបានហៅ[វ]មកពីទីឆ្ងាយបំផុត ដោយនិយាយនឹង
ឯងថា ឯងជាអ្នកបំរើរបស់អញ[ស] អញបានរើស[ហ]ឯង មិន
មែនបោះបង់ចោលឯងទេ ១០កុំឱ្យភ័យខ្លាច[ឡ]ឡើយ ដ្បិតអញ
នៅជាមួយនឹងឯង[អ] កុំឱ្យស្រយុតចិត្តឱ្យសោះ ពីព្រោះអញ
ជាព្រះនៃឯង អញនឹងចំរើនកំឡាំង[ក]ដល់ឯង អើ អញនឹង
ជួយ[ខ]ឯង អើ អញនឹងទ្រឯង[គ] ដោយដៃស្តាំដ៏សុចរិតរបស់
អញ[ឃ] ១១មើល អស់អ្នកដែលខឹងក្តៅក្រហាយ[ង]នឹងឯង គេ
នឹងត្រូវខ្មាស[ច] ហើយជ្រប់មុខនៅ ពួកអ្នកដែលតតាំង[ឆ]នឹង
ឯងគេនឹងបានដូចជាទទេសោះ ហើយនឹងត្រូវវិនាសសូន្យ
ទៅ[ជ] ១២ឯងនឹងរកគេ គឺពួកអ្នកដែលតតាំងនឹងឯងនោះ តែ
មិនប្រទះឃើញឡើយ[ឈ] ឯពួកអ្នកដែលច្បាំងនឹងឯង គេនឹង
បានដូចជាទទេ[ញ]សោះ ហើយដូចជារបស់ដែលគ្មានផង
១៣ដ្បិតអញនេះ គឺយេហូវ៉ាជាព្រះនៃឯង អញនឹងកាន់
ដៃស្តាំ[ដ]ឯង ដោយពោលនឹងឯងថា កុំឱ្យភ័យខ្លាចឡើយ

**៤១:៣** ឌ ដយ ៨:៤ **៤១:៤** ឍ ខ.៩ អស ៤៣:៧ ណ ខ.២៦ លប ១:១ អស ៤៦:១០ ត អស ៤៤:៦ ៤៨:១២ វវ ១:៨,១៧ ថ ចទ ៣២:៣៩ **៤១:៥** ទ អស ១១:១១ អគ ២៦:១៧–១៨ ធ ចទ ៣០:៤ អស ១១:១២ **៤១:៦** ន យស ១:៦ **៤១:៧** ប អស ៤៤:១៣ យរ ១០:៣–៥ ផ អស ៤០:១៩ ព ១សយ ៥:៣ អស ៤៦:៧ **៤១:៨** ភ ទដ ១៣៦:២២ អស ២៧:១១ ម អស ១៤:១ យ អស ២៩:២២ ៥១:២ ៦៣:១៦ រ ២របា ២០:៧ យក ២:២៣ **៤១:៩** ល អស ១១:១២ ៣៧:១៦ វ ខ.៤ ស អស ២០:៣ ហ ចទ ៧:៦ **៤១:១០** ឡ លប ១៥:១ អ ចទ ៣:២២ យស ១:៩ អស ៤៣:២,៥ យរ ៣០:១០ ៤៦:២៧–២៨ រម ៨:៣១ ក ទដ ៦៨:៣៥ ១១៩:២៨ ខ ខ.១៣–១៤ អស ៤៤:២ ៤៩:៨ ៥០:៧,៩ គ ទដ ១៨:៣៥ ១១៩:១១៧ ឃ នក ៣:២០ យប ៤០:១៤ **៤១:១១** ង អស ១៧:១២ ច អស ២៩:២២ ៤៥:២៤ ៥៤:១៧ ឆ នក ២៣:២២ ជ អស ២៩:៨ យរ ២:៣ **៤១:១២** ឈ ទដ ៣៧:៣៥–៣៦ អស ៣៤:១២ ញ យប ៧:៨ អស ១៧:១៤ ២៩:២០ **៤១:១៣** ដ ទដ ៧៣:២៣ អស ៤២:៦ ៤៥:១ ៥១:១៨

រើសឱ្យទៅទទួលកិច្ចការសុចរិតរបស់ព្រះអម្ចាស់ ។ *អស់ទាំងស្តេចផង* ដូចជាស្តេចរបស់ស្រុកលីឌានៅតំបន់អាស៊ីមីណ័រ ។ *ជញ្ជ្រាំងដែលត្រូវផាត់ដោយខ្យល់* សូមមើល ១៧:១៣ និងការពន្យល់ ។ *ផ្លូ* (សូមមើល ខ.៥–៧ និងការពន្យល់) ។

**៤១:៤** *តាំងពីដើមមក* សូមមើល ៤០:២១ នឹងការពន្យល់។ *ដែលជាដើម . . . ជាន់ក្រោយអង្អស់ដែរ* គឺនិយាយតាំងពីរព្រះយេហូវ៉ាបានបង្កើតមនុស្សក្នុងជំនាន់ទីមួយមកម្លេះរហូតមកដល់សព្វថ្ងៃក៏មានពួកគេដែរ គឺទ្រង់ជាព្រះនៃគ្រប់ពូជសាសន៍ក៏ជាព្រះមានព្រះជន្មអស់កល្បជានិច្ច ។ (សូមមើល ហព ១៣:៨ វវ ១:៨,១៧ ២:៨ ២១:៦ ២២:១៣) ។

**៤១:៥–៧** គឺក្នុងកំឡុងឆ្នាំ ៥៤៦ មុន គ.ស ស្តេចស៊ីរុសបានទទួលជ័យជម្នះក្នុងតំបន់ឈូងសមុទ្រ អាស៊ីមីណ័រ ដែលជាតំបន់មានសត្រូវប្រឆាំង គឺជាពួកស្តេចលីឌា ។ ក្នុងខទាំងនេះក៏មានប្រើពាក្យ ចំអកបញ្ឈឺចិត្តដែលអ្នកនិពន្ធយកមកប្រើក្នុងអត្ថបទ (សូមមើល ខ.៦–៧ ប្រៀបធៀប ៤០:១៩–២០) ។

**៤១:៥** *អស់ទាំងចុងផែងដី* សូមមើល ១១:១២ និងការពន្យល់ ។

**៤១:៦** *ចូរមានចិត្តក្លាហានឡើង* សូមមើល ៣៥:៤ និងការពន្យល់ ។

**៤១:៧** *ញញួរ* សូមប្រៀបធៀប ៤៤:១២ ។ ពាក្យថា *ដើម្បីមិនឱ្យរើទៅឯណាឡើយ* សូមមើល ៤០:១៨–២០ និងការពន្យល់ ។

**៤១:៨–៩** *អ្នកបំរើអញអើយ* គឺជាព្រះបន្ទូលសម្រាប់ប្រើបង្ហាញពីអត្តសញ្ញាណដែលព្រះបានកំណត់ដែលមានក្នុងជំពូក ៤១:៥៣ ដែលសំដៅទៅលើជាតិសាសន៍អ៊ីស្រាអែល ។ ក្នុងអត្ថបទគម្ពីរនេះ ឬពាក្យថាអ្នកបម្រើអញអើយគឺចង់បង្ហាញពីអ្នកដែលទទួលនូវតួនាទីពិសេស ក្នុងមុខងារជាឧកញ៉ារាជវាំង ដូចជាលោក ម៉ូសេជាអ្នកបម្រើរបស់ទ្រង់ដែរ ។ (ជន ១២:៧) ដូចជាពាក្យថា"ដាវីឌអ្នកបម្រើអញអើយ" (២សយ ៣:១៨ ៧:៥,៨) ដូចជាពាក្យ "ពួកហោរាជាពួកអ្នកបម្រើអញ"សូមមើល (២ពវ ១៧:១៣ យរ ៧:២៥) ។ សូមមើលការពន្យល់ ៤១:១ ក៏សូមមើល ២០:៣ ២២:២០ ៤២:១,១៩ ៤៣:១០ ៤៤:១–២,២១ ៤៥:៤ ៤៩:៣,៥–៧ ៥០:១០ ៥២:១៣ ៥៣:១១ ។

**៤១:៨** *តែ* គឺបង្ហាញពីភាពខុសនៃចរិតលក្ខណៈពូជសាន៍ជាតិសាន៍ក្នុង ខ.៥–៧ តែជាតិសាសន៍អ៊ីស្រាអែលមិនត្រូវការភ័យខ្លាចទេ (មើល ខ.១០) ។ ពាក្យថា *សំឡាញ់របស់អញ* សូមមើលការពន្យល់ លប ១៨:១៧ ។

**៤១:៩** *ពីចុងផែនដី* សូមមើល ខ.៥ គឺសំដៅទៅលើតំបន់ស្រុកមេសូប៉ូតាមា និងស្រុកអេស៊ីព្ទ (សូមមើល លប ១១:៣១ ១២:១ ១៥:៧ ទដ ១១៤:១–២ យរ ៣១:៣២) ។

**៤១:១០** *កុំឱ្យភ័យខ្លាចឡើយ* សូមមើល ខ.១៣–១៤ ៤៣:១,៥ ក៏សូមមើល ៣៥:៤ និងការពន្យល់ ។ *ចំរើនកំឡាំងដល់ឯង . . . ជួយឯង* គឺជាឃ្លាដែលគេបានស្រែកអំពាវនាវទៅរកព្រះក្នុងកិច្ចការបម្រើព្រះ (សូមមើល ខ.៩, ១៥–១៦) ក៏សូមមើល ខ.១៤ ៤០:២៩ ៤៤:២ ៤៩:៨ ។ ពាក្យថា *ដោយដៃស្តាំ* គឺជាព្រះហស្តដ៏មានអំណាចព្រះចេស្តានិងការសង្គ្រោះ (សូមមើល នក ១៥:៦ ទដ ២០:៦ ៤៨:១០ ៨០:១៣ ៩៨:១) ។

**៤១:១១** *ត្រូវខ្មាសហើយជ្រប់មុខ* ឃ្លានេះសូមប្រៀបធៀប ៤៥:១៧ ៥០:៧ ៥៤:៤ ។ ពាក្យថា *ដូចជាទទេសោះ* សូមមើល ខ.១៥–១៦ និងការពន្យល់ ។

**៤១:១៣** *អញនឹងកាន់ដៃស្តាំឯង* គឺជាការពង្រឹងជំហររបស់ពួកគេ ហើយរក្សាពួកគេពីឧសគ្គចំពោះមុខ ។ *កុំភ័យខ្លាចឡើយ* សូមមើល ខ.១០ និងការពន្យល់ ។

អញនឹងជួយ[ឋ]ឯង ១៤ឱយ៉ាកុបជាដង្កូវ[ឌ]អើយ កុំឱ្យខ្លាច
ឡើយ[ឍ] ហើយឯងរាល់គ្នាជាពូជពង្សអ៊ីស្រាអែលដែរ ដ្បិត
ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា អញនឹងជួយ[ណ]ឯង ព្រះដ៏
បរិសុទ្ធ[ត]នៃសាសន៍អ៊ីស្រាអែល ទ្រង់ជាអ្នកប្រោសលោះ
ឯង[ថ] ១៥មើល អញបានយកឯងធ្វើជាគ្រឿងបញ្ជាន់[ទ]យ៉ាងថ្មី
ហើយមុត ដែលមានធ្មេញ ឯងនឹងបញ្ជាន់អស់ទាំងភ្នំ[ធ]ធំ
ព្រមទាំងវាយកំទេច ហើយនឹងធ្វើឱ្យភ្នំតូចទាំងប៉ុន្មានដូចជា
អង្កាមផង[ន] ១៦ឯងនឹងរោយ[ប]គេ ហើយខ្យល់នឹងផាត់បាត់
ទៅ ឯខ្យល់កួច[ផ]នឹងកំចាត់កំចាយគេអស់ទៅដែរ[ព] នោះឯង
នឹងមានសេចក្តីរីករាយ[ភ]ក្នុងព្រះយេហូវ៉ា ឯងនឹងយកព្រះ
ដ៏បរិសុទ្ធ[ម]នៃសាសន៍អ៊ីស្រាអែលជាទីអួត[យ]របស់ឯង ។
១៧ពួកក្រីក្រ និងពួកកំសត់ទុគ៌ត គេរកទឹក[រ] តែគ្មានសោះ
គេខះកដោយស្រេកទឹក[ល] ឯអញ គឺយេហូវ៉ា អញនឹងតប
ឆ្លើយ[វ]នឹងគេ អញនេះ គឺជាព្រះនៃសាសន៍អ៊ីស្រាអែល អញ
នឹងមិនបោះបង់ចោល[ស]គេឡើយ ១៨អញនឹងបើកផ្លូវទឹកឱ្យ
ហូរ[ហ] នៅលើទីខ្ពស់ត្រងិល ហើយនឹងទឹកផុសនៅកណ្តាល
ច្រកភ្នំ អញនឹងធ្វើឱ្យទីរហោស្ថាន[ឡ]ត្រឡប់ជា ត្រពាំងទឹក[អ]
ហើយឱ្យដីហួតហែងមានរន្ធទឹកហូរ[ក] ១៩អញនឹងធ្វើឱ្យដើម
តាត្រៅ[ខ] ដើមនាងនួន ដើមពពាលខែ និងដើមសំរោង
ដុះនៅទីរហោស្ថាន អញនឹងដាំដើមកកោះ ដើមស្រល់[គ]
ហើយនិងដើមស្រឡៅ[ឃ] ជាមួយគ្នា[ង] នៅទីសមុទ្រខ្សាច់[ច]
២០ដើម្បីឱ្យគេបានឃើញ ហើយដឹង[ឆ] ព្រមទាំងពិចារណា
យល់[ជ]ជាមួយគ្នាថា គឺព្រះហស្ត[ឈ]នៃព្រះយេហូវ៉ា ដែលបាន
សំរេចការនោះ គឺជាព្រះដ៏បរិសុទ្ធ[ញ]នៃសាសន៍អ៊ីស្រាអែល
ដែលបង្កើត[ដ]ឡើង ។
២១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូរសំដែងដើម
ហេតុ[ឋ]នៃរឿងឯងមក មហាក្សត្រនៃពួកយ៉ាកុប ទ្រង់មាន
បន្ទូលថា ចូររ៉ាយរ៉ាប់តាមលំអានរបស់ឯងទាំងប៉ុន្មានចុះ[ឌ]
២២ត្រូវឱ្យគេបញ្ចេញសេចក្តីទាំងនោះមក ហើយប្រាប់
យើងរាល់គ្នាពីការដែលត្រូវកើតឡើង[ឍ] ឱ្យបានដឹង ចូរស
ប្រាប់ពីការដែលកើតមាន កាលពីដើម[ណ] ជាយ៉ាងណាផង
ដើម្បីឱ្យយើងរាល់គ្នាបានពិចារណា ឱ្យដឹងចុងបំផុតនៃការ
ទាំងនោះ ឬបង្ហាញឱ្យយើងឃើញពីការនៅខាងមុខចុះ[ត]
២៣ចូរសំដែងប្រាប់ពីការដែលត្រូវកើតមក នៅខាងមុខ
នោះ ដើម្បីឱ្យយើងរាល់គ្នាបានដឹង[ថ]ថា ឯងរាល់គ្នាជាព្រះ
មែន អើ ចូរធ្វើការអ្វីមួយ ទោះល្អឬអាក្រក់ក្តី[ទ] ដើម្បីឱ្យ
យើងរាល់គ្នាបានស្ញើច[ធ] ហើយឃើញជាមួយគ្នា ២៤មើល
ឯងរាល់គ្នាមិនមែនជាអ្វីទេ[ន] ហើយការរបស់ឯងរាល់
គ្នាក៏ជាទទេសោះ[ប] អ្នកណាដែលរើសយកឯងរាល់គ្នា នោះ

**៤១:១៣** ឋ ខ.១០ **៤១:១៤** ឌ យប ៤:១៩ ទដ ២២:៦ ឍ លប ១៥:១ ណ ខ.១០ ត ខ.១៦,២០ អស ១:៤ ថ នក ១៥:១៣ យប ១៩:២៥ អស ១:២៧ **៤១:១៥** ទ យប ៤១:៣០ អស ១០:៥ ២១:១០ ធ នក ១៩:១៨ ទដ ១០៧:៣៣ យរ ៩:១០ អគ ៣៣:២៨ ន ខ.២ **៤១:១៦** ប យរ ១៥:៧ ៥១:២ ផ អស ៤០:២៤ ព ដយ ២:៣៥ ភ អស ២៥:៩ ម ខ.១៤ មក ១:២៤ យ អស ៤៥:២៥ ៦០:១៩ **៤១:១៧** រ អស ៤៣:២០ ល អស ៣៥:៧ វ អស ៣០:១៩ ស ចទ ៣១:៦ ទដ ២៧:៩ **៤១:១៨** ហ អស ៤៣:១៩ ឡ ២ពវ ៣:១៧ អ យប ៣៨:២៦ អស ៣៥:៧ ក អស ៣០:២៥ **៤១:១៩** ខ អស ៣៥:១ ៥១:៣ គ នក ២៥:៥,១០,១៣ ឃ អស ៣៧:២៤ ង អស ៤៤:១៤ ច អស ៦០:១៣ **៤១:២០** ឆ នក ៦:៧ ជ អស ២៩:២៤ ឈ អរ ៧:៦ ៨:៣១ អស ៥០:២ ៥១:៩ ៥៩:១ ៦៦:១៤ យរ ៣២:១៧ ញ ខ.១៤ អស ៤៣:៣,១៤ ដ អស ៤:៥ **៤១:២១** ឋ ខ.១ ឌ អស ៤៣:១៥ ៤៤:៦ **៤១:២២** ឍ ខ.២៦ អស ៤៣:៩ ៤៤:៧ ៤៥:២១ ៤៨:១៤ ណ អស ៤៣:១៨, ២៦ ៤៦:៩ ៤៨:៣ ត អស ៤២:៩ ៤៣:១៩ ៤៦:១០ ៤៨:៦ ៦៥:១៧ យហ ១៣:១៩ **៤១:២៣** ថ អស ៤៥:៣ ទ យរ ១០:៥ ធ ២ពវ ១៩:២៦ **៤១:២៤** ន អស ៣៧:១៩ ១កថ ៨:៤ ប ១សយ ១២:២១ យរ ៨:១៩ ១០:៥,៨,១៥

**៤១:១៤** *ជាដង្កូវអើយ* ពាក្យនេះចងនិយាយពីភាពខ្សោយរបស់ពួកគេនិងលក្ខខ័ណ្ឌដែលត្រូវបានគេមើលថោក ក្នុងខណពេលដែលពួកគេបាននិរទេស (សូមប្រៀបធៀប យប ២៥:៦ ទដ ២២:៦) ។ *អ្នកប្រោសលោះឯង* គឺអ្នកដែលបានរំដោះពួកគេឱ្យរួចពីការនិរទេសពីទីក្រុងបាប៊ីឡូន (គឺជាពេលវេលានៃការចេញដំណើរថ្មីមួយ) ក្នុងព្រះគម្ពីរជាភាសាហេព្រើរគឺស្មើ និងអ្នកការពារគ្រួសារអ៊ីស្រាអែល គឺដូចជាបិតានៃជាតិសាសន៍អ៊ីស្រាអែល (៦៣:១៦ ៦៤:៨) និងជាប្តី (៥៤:៥) ។ ទ្រង់ជាអ្នកការពារទ្រព្យសម្បត្តិ និងទឹកដីនិងជាអ្នកផ្តល់ឱ្យមានសេរីភាព (៣៥:៩ ៤៣:១–៤ ៤៨:២០ ៥២:១១–១២) ទ្រង់ក៏បានសងសឹកជួសរាស្ត្ររបស់ផងទ្រង់ ។ *ព្រះក៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើល ខ.១៦,២០ និង ១:៤ និងការពន្យល់ផងដែរ ។

**៤១:១៦** *នឹងរោយ* គឺជាសកម្មភាពជំនុំជម្រះ ពាក្យនេះក៏បានប្រើផងដែរក្នុង យរ ៥១:២ (សូមមើលការពន្យល់ នរ ១:២២) ។ *សេចក្តីរីករាយ* ប្រៀបធៀប ២៥:៩ ៣៥:១០ ៥១:១១ ។

**៤១:១៧** *ពួកក្រីក្រនឹងពួកកំសត់ទុគ៌ត* គឺសំដៅលើរាស្ត្រអ៊ីស្រាអែលក្នុងពេលគេបាននិរទេសទៅឬក៏ក្នុងខណពេលពួកគេត្រឡប់មកវិញ (មើល ខ.១៤ ៣២:៧) *នឹងតបឆ្លើយគេ* សូមមើល ៣០:១៩ និងការពន្យល់ ។

**៤១:១៨** *បើផ្លូវទឹកឱ្យហូរនៅលើទីខ្ពស់ត្រងិល* សូមមើល ៣០:២៥ និងការពន្យល់ ។ *ទីរហោស្ថាន . . . ត្រឡប់ជាត្រពាំងទឹក . . . មានរន្ធទឹកហូរ* សូមមើល ៣២:២ ៣៥:៦–៧ និងការពន្យល់ ។

**៤១:១៩** ដើម្បីឈើទាំងនេះនិងបានផ្តល់នូវភាពស្រស់ឆើតឆាយដល់ទីរហោស្ថាន (ប្រៀបធៀប ៣៥:១–២) ក៏មានដើមឈើជាច្រើនមានឈ្មោះនៅក្នុង ៦០:១៣ គឺមានទំនាក់ទំនងនិងការរៀបរយចំតុបតែងទីបរិសុទ្ធរបស់ព្រះ ។ *ដើមនាងនួន* គឺឈើដែលគេបានប្រើសម្រាប់សាងសង់រោងត្រសាល (សូមមើល នក ២៥:៥ និងការពន្យល់ ១០:១៣) ។ ក៏សូមមើល ៥៥:១៣ ។

**៤១:២០** *បង្កើតឡើង* គឺបង្ហាញពីលក្ខខណ្ឌដ៏មានផលផ្លែ ពីការបង្កើតរបស់ព្រះអម្ចាស់គឺក្នុងនាមជារាស្ត្ររបស់ផងទ្រង់ (សូមមើល ៤៨:៧ ៥៧:១៩ ៦៥:១៧–១៨) ។

**៤១:២១–២២** គឺព្រះអម្ចាស់បានយកជាតិសាន៍ទាំងឡាយនិងរូបព្រះដែលមានវិញ្ញាណអរក្សដើម្បីជំនុំជម្រះ (សូមមើល ខ.១ និងការពន្យល់) ។

**៤១:២៣** *ចូរធ្វើការអ្វីមួយ ទោះល្អឬអាក្រក់ក្តី* ឃ្លានេះបង្ហាញក្នុង ៤០:១៨–២០ ។

**៤១:២៤** *មិនមែនជាអ្វីទេ . . . ជាទទេសោះ* គឺជាពួកជាតិសាសន៍មួយចំនួនដែលថ្វាយបង្គំរូបព្រះ សូមមើល ៤០:១៧ ៤៤:៩ ហស ៩:១០ ក៏មានពួកដែលភពប្រសព្វនិងពួកធ្វើរូបព្រះ ក៏និងត្រូវបានសូន្យផងដែរ (មើល មឡ ២:១១

គួរខ្ពើមឆ្អើមហើយ[ផ] ។
២៥ អញបានតាំង[ព]ម្នាក់ពីទិសខាងជើងឡើង[ភ] អ្នកនោះ
បានមកដល់ហើយ អ្នកនោះនឹងអំពាវនាវដល់ឈ្មោះអញ
ពីទិសខាងកើត ក៏នឹងញាំញី[ម]ពួកគ្រប់គ្រង ដូចជាគេជាន់
បាយអ ហើយដូចជាជាងស្មូនជាន់ដីឥដ្ឋ ២៦ តើអ្នកណាបាន
សំដែងសេចក្តីតាំងពីដើមមក[យ] ដើម្បីឱ្យយើងរាល់គ្នាបាន
ដឹង ហើយមុនកំណត់ ដើម្បីឱ្យយើងបានពោលថា អ្នកនោះ
និយាយ[រ]ត្រូវមែន អើ គ្មានអ្នកណាសំដែងទេ អើ គ្មានអ្នក
ណាបង្ហាញសោះ អើ គ្មានអ្នកណាឮពាក្យ[ល]សំដីរបស់ឯង
រាល់គ្នាឡើយ ២៧ គឺអញដើមដំបូង ដែលប្រាប់[វ] ដល់ក្រុង
ស៊ីយ៉ូនថា មើលន៏ គេមកហើយ អញនឹងឱ្យម្នាក់ដល់ក្រុង
យេរូសាឡិម ជាអ្នកដែលនឹងនាំដំណឹងល្អមក[ស] ២៨ អញបាន
សង្កេតមើល តែមិនឃើញមនុស្សណាមួយសោះ[ហ] ទោះ
ទាំងនៅក្នុងពួកទាំងនោះ ក៏ឥតមានណាមួយ ជាអ្នកប្រឹក្សា[ឡ]
ដែលកាលណាអញនឹងសួរ នោះនឹងអាចឆ្លើយ[អ]១ម៉ាត់បាន
ឡើយ ២៩ មើល គេសុទ្ធតែឥតប្រយោជន៍ទទេ ហើយការ
របស់គេក៏អសារឥតការដែរ[ក] រូបសិត[ខ]របស់គេសុទ្ធតែ
ជាខ្យល់[គ] ហើយសូន្យទទេ ។

**អ្នកបម្រើនៃព្រះអម្ចាស់**

**៤២** ១ មើល នេះនែអ្នកបំរើរបស់អញ[ក] ដែលអញទប់
ទល់ គឺជាអ្នកជ្រើសរើស[ខ]របស់អញ ដែលជាទីរីករាយ[គ]
ដល់ចិត្តអញ អញបានដាក់វិញ្ញាណ[ឃ]អញឱ្យសណ្ឋិតលើទ្រង់
ហើយទ្រង់នឹងសំដែងចេញ ឱ្យគ្រប់ទាំងសាសន៍បានឃើញ
សេចក្តីយុត្តិធម៌[ង,ច] ២ ទ្រង់នឹងមិនស្រែក ឬបន្លឺឡើង[ឆ] ឬឱ្យអ្នក
ណា ឮសំឡេងនៅក្នុងផ្លូវឡើយ ៣ ទ្រង់នឹងមិនផ្តាច់ដើម
ត្រែង[ជ]ដែលចាក់ទេ[ឈ] ក៏មិនលត់ប្រឆេះដែលនៅហុយ
ដែរ[ញ] ទ្រង់នឹងសំដែងចេញនូវសេចក្តីយុត្តិធម៌[ដ] ដោយ
សេចក្តីពិត ៤ ទ្រង់នឹងមិនដែលអន់ថយ ឬរសាយចិត្តដរាប
ដល់បានតាំងសេចក្តីយុត្តិធម៌[ឋ]ឡើងនៅផែនដី ហើយ

**៤១:២៤** ផ ទដ ១០៩:៧ អស ១:១៣ ៤៨:៨ **៤១:២៥** ព អរ ១:២ ភ ខ.២ យរ ៥០:៩,៤១ ៥១:៤៨ ម ២សយ ២២:៤៣ អស ៥:៥ ណហ ៣:១៤ **៤១:២៦** យ ខ.៤ រ ខ.២២ អស ៥២:៦ ល ១ពរ ១៨:២៦ ហព ២:១៨–១៩ **៤១:២៧** វ អស ៤៨:៣,១៦ ស អស ៤០:៩ **៤១:២៨** ហ ទដ ២២:១១ អស ៥០:២ ៥៩:១៦ ៦៣:៥ ៦៤:៧ នក ២២:៣០ ឡ អស ៤០:១៣–១៤ អ ១ពរ ១៨:២៦

អស ៦៥:១២ ៦៦:៤ យរ ២៥:៤ **៤១:២៩** ក ១សយ ១២:២១ ខ អស ៣៧:១៩ គ យរ ៥:១៣ **៤២:១** ក អស ២០:៣ មថ ២០:២៨ ខ អស ១៤:១ លក ៩:៣៥ ២៣:៣៥ ១ពត ២:៤,៦ គ មថ ៣:១៧ ឃ អស ១១:២ ៤៤:៣ មថ ៣:១៦–១៧ យហ ៣:៣៤ ង អស ៩:៧ ច លប ៤៩:១០ **៤២:២** ឆ សភ ៨:១–៤ **៤២:៣** ជ អស ៣៦:៦ ឈ យប ៣០:២៤ ញ យប ១៣:២៥ ដ ទដ ៧២:២ ៩៦:១៣ **៤២:៤** ឋ អស ២:៤

និងការពន្យល់) ។

**៤១:២៥** *បានតាំង* សូមមើល ខ.២ និងការពន្យល់ ។ *ស្តេចស៊ីរូសពីទិសខាងកើត* (សូមមើល ខ.២) ដែលជាស្តេចបានគ្រប់គ្រងនគរខាងជើងនៃស្រុកបាប៊ីឡូនតាំងពីពេលស្តេចអង្គនេះបានទទួលរាជបល្ល័ង្កពីដំបូងបង្អស់ ។ មានគេដែលរសនៅឯក្រុងយេរូសាឡិម គិតថាការឈ្លានពានលុកលុយគឺប្រភពមកពីពួកនគរខាងជើង (សូមមើលការពន្យល់ ១៤:៣១ យរ ១:១៤ ៦:១,២២ ១០:២២ ៤៦:២០ ៥០:៣,៩,៤១ ៥១:៤៨) ។ *អំពាវនាវដល់ឈ្មោះអញ* គឺសកម្មភាពស្តេចស៊ីរ៉ូស ដែលបានប្រើព្រះនាមព្រះយេហូវ៉ា នៅក្នុងក្រិតច្បាប់របស់គាត់ (អគ ១:២) តែស្តេចអង្គនេះមិនបានទទួលស្គាល់ទ្រង់ទេ (សូមមើល ៤៥:៤–៥) ។ ពាក្យថា *ក៏នឹកញាំញីពួកគ្រប់គ្រងដូចជាគេជាន់លើបាយអរ . . . ជាន់ដីឥដ្ឋ* ឃ្លានេះគឺមានលក្ខណៈស្រដៀងគ្នានិងពួក អាសស៊ើរ ដូចនៅ ១០:៦ សូមមើលការប្រៀបធៀប មីក ៧:១០ ណហ ៣:១៤ ។

**៤១:២៦** *តាំងពីដើមមក* គឺជាពេលវេលាមុនព្រឹត្តិការណ៍នេះបានមកដល់ ។

**៤១:២៧** *មើលន៍គេមកហើយ* គឺជាពាក្យនិយាយនៅពេលមានការដោះលែងរាស្ត្រអ៊ីស្រាអែលពីក្រុង បាប៊ីឡូន ។ ពាក្យថា *អ្នកដែលនាំដំណឹងល្អមក* ដូចជាលោក អេសាយ សូមមើល ៤០:៩ ៥២:៧ និងការពន្យល់ ។

**៤១:២៨** *តែមិនឃើញមនុស្សណា . . . អាចឆ្លើយ ១ម៉ាត់បានឡើយ* សូមមើល ៤៦:៧ ។

**៤១:២៩** *អសារឥតការដែរ* សូមមើល ខ.២៤ ។

**៤២:១–៤** មានសេចក្តីដកស្រង់ចេញពី មថ ១២:១៨–២១ (សូមមើលការពន្យល់នៅទីនោះ) ក៏មានការនិយាយចំពោះព្រះគ្រីស្ទផងដែរ ។ ក៏មានបទចម្រៀងពី "បាវបម្រើទាំងបួន" ដែលអ្នកបម្រើទាំងនោះគឺជាព្រះមែស៊ី (៤២:១–៤ ឬក៏ ៤២:១–៧ ឬក៏ ៤២:១–៩) ៤៩:១–៦ (ឬក៏ ៤០៩:១–៧ ឬក៏ ៤៩:១–១៣) ៥០:៤–៩ (ឬក៏ ៥០:៤–១១) ៥២:១៣–៥៣:១២ ប្រៀបធៀប និង ៦១:៤–៥ និងការពន្យល់ ។ ទ្រង់គឺរាស្ត្រ"អ៊ីស្រាអែល"ដែលមានសណ្ឋានអង្គទ្រង់ជាលក្ខណៈពិសេស (៤៩:៣) ។ ជាតិសាសន៍គឺជានគររបស់សង្ឃនោះដែរ (សូមមើល នក ១៩:៦ និងការពន្យល់) ប៉ុន្តែព្រះមែស៊ីគឺជាសង្ឃជាន់ខ្ពស់ដែលជាអង្គ ហើយជាអ្នកទទួលយកបាបជំនួសលោកិយទាំងមូល (៥៣:៤–១២) ។ ស្តេចស៊ីរូសត្រូវបានគេបង្ហាញក្នុងជំពូក ៤១ ដែលមានភារៈកិច្ចជាអ្នកសង្គ្រោះរាស្ត្រពីស្រុកបាប៊ីឡូន តែក្នុងនាមជាបាបបម្រើមានភារៈកិច្ចសង្គ្រោះលោកិយពីចំណងអំពើបាប (សូមមើល ខ.៧) ។

**៤២:១** *អ្នកបំរើរបស់អញ* សូមមើល ៤១:៨–៩ សក ៣:៨ និងការពន្យល់ ។ នៅក្នុងពាក្យបច្ចេកវិជ្ជាសម្រាប់ព្រះមហាក្សត្រនាសម័យបុរាណនៅឯមជ្ឈឹមបូពា៌ ដូចជាពាក្យ"អ្នកបម្រើ"ដែលមានអត្ថន័យថា "រាជទូតដែលជាទីទុកចិត្តបំផុត" ឬក៏មានន័យថា "ជាតំណាងដែលជាទីពេញចិត្ត" ។ ពាក្យថា *គឺជាអ្នកជ្រើសរើសរបស់អញ* គឺសូមមើល ៤១:៨–៩ និងការពន្យល់ ។ *ដែលជាទីរីករាយ* សូមប្រៀបធៀប លក ៣:២២ ។ *ដាក់វិញ្ញាណអញឱ្យសណ្ឋិតលើទ្រង់* គឺមានលក្ខណៈដូចជាខ្នែងដែលមានក្នុង ១១:១–២ (សូមមើលការពន្យល់ ១១:២) ប្រៀបធៀបនឹង ៦:១ ។ *សេចក្តីយុត្តិធម៌* គឺត្រូវតាំងមាននៅភពផែនដី (សូមមើល ខ.៤) ក៏សូមមើល ៩:៧ ១១:៤ និងការពន្យល់ ។

**៤២:២** *នឹងមិនស្រែក . . . ឬបន្លឺឡើយ* គឺជាការដែលទ្រង់បាននាំសន្តិភាពមក (សូមមើល ៩:៦) ។ ៤២:៣ ដើមត្រែងដែលជាតំណាងមនុស្សណាម្នាក់ដែលមានភាពខ្សោយ (សូមមើល ទដ ៧២:២,៤) ។ ឯអ្នកបម្រើនិងផ្សះផ្សារជីវិត ដែលបាក់បែកទៅនោះ ។

**៤២:៤** *អន់ថយ* សូមប្រៀបធៀប ៤០:២៨ ។ ពាក្យថា *សេចក្តីយុត្តិធម៌* គឺជាទង្វើល្អត្រឹមត្រូវ (សូមមើល ខ.១ និងការពន្យល់) ។ ពាក្យថា *នឹងសង្ឃឹមដល់ក្រិត្យក្រមរបស់ទ្រង់* គឺដូចបានបង្ហាញក្នុងជាតិសាសន៍មួយចំនួន ក្នុង ២:២–៤ ។ ឯអ្នកបម្រើនោះគឺជាលោកម៉ូសេថ្មី (មើល ចទ ១៨:១៥–១៨

កោះ[ឌ]ទាំងប៉ុន្មាន និងសង្ឃឹមដល់ក្រិត្យក្រម[ឍ]របស់ទ្រង់[ណ]។
៥ឯព្រះដ៏ជាព្រះយេហូវ៉ា ជាព្រះដែលបានបង្កើតអស់
ទាំងជាន់ផ្ទៃមេឃ[ត] ហើយបានលាតផង គឺជាព្រះដែលបាន
ក្រាលផែនដី[ថ] និងរបស់សព្វសារពើដែលចេញពីនោះមក[ទ]
គឺព្រះអង្គដែលប្រទានឱ្យប្រជាជាតិទាំងប៉ុន្មាន នៅផែនដី
មានដង្ហើម[ធ] ព្រមទាំងឱ្យមនុស្សទាំងឡាយដែលដើរក្នុង
លោកមានវិញ្ញាណផង ទ្រង់មានបន្ទូលថា
៦អញនេះ
គឺជាយេហូវ៉ា អញបានហៅ[ន]ឯងមកដោយសេចក្ដីសុចរិត[ប]
អញនឹងកាន់ដៃឯង[ផ] ហើយថែរក្សា[ព]ឯង អញនឹងតាំងឯង
ឡើង ទុកជាសេចក្ដីសញ្ញា[ភ]ដល់បណ្ដាជន ហើយជាពន្លឺភ្លឺ[ម]
ដល់អស់ទាំងសាសន៍[យ]
៧ដើម្បីនឹងធ្វើឱ្យភ្នែកមនុស្សខ្វាក់[រ]
បានភ្លឺឡើង នឹងនាំពួកត្រូវចាប់ចងចេញ[ល]ពីគុកងងឹត[វ]
ហើយឱ្យពួកអ្នកដែលអង្គុយនៅក្នុងទីងងឹត[ស] បានចេញរួច
ពីទីឃុំឃាំង
៨អញជាយេហូវ៉ា[ហ] នេះហើយជាឈ្មោះ
របស់អញ[ឡ] អញមិនព្រមប្រគល់សិរីល្អរបស់អញ ដល់អ្នក
ណាទៀត[អ] ឬឱ្យសេចក្ដីសរសើររបស់អញ ដល់រូបឆ្លាក់
ឡើយ[ក]
៩មើល ការខាងដើម[ខ]ទាំងប៉ុន្មានបានកន្លងទៅ
ហើយ គឺជាការថ្មីដែលអញថ្លែងប្រាប់នេះ អញប្រាប់[គ]ពី
ការទាំងនោះ ដល់ឯងរាល់គ្នា មុនដែលកើតមកផង ។

## បទសរសើរតម្កើងដល់ព្រះអម្ចាស់

១០ឯងរាល់គ្នាដែលចុះទៅឯសមុទ្រ ហើយទាំងអស់
ដែលនៅក្នុងនោះ[ឃ] ព្រមទាំងកោះ[ង] និងពួកនៅកោះទាំង
នោះផង ចូរច្រៀង[ច]បទថ្មី[ឆ]ថ្វាយព្រះយេហូវ៉ា ហើយសេចក្ដី
សរសើរ[ជ]ដល់ទ្រង់ពីចុងផែនដីចុះ[ឈ]
១១ឯទីរហោស្ថាន[ញ]
និងទីអាស្រ័យនៅក្នុងនោះទាំងប៉ុន្មាន ចូរបន្លឺឡើង ព្រម
ទាំងបណ្ដាភូមិដែលពួកកេដារ[ដ]នៅទាំងអស់ផង ត្រូវឱ្យពួក
អ្នកនៅក្រុងសេឡា[ឋ]ច្រៀងឡើង ត្រូវឱ្យគេស្រែកពីកំពូល
ភ្នំចុះ[ឌ]
១២ត្រូវឱ្យគេថ្វាយកិត្តិសព្ទ[ឍ]ដល់ព្រះយេហូវ៉ា ហើយ
បញ្ចេញសេចក្ដីសរសើរ[ណ]របស់ទ្រង់ដល់អស់ទាំងកោះ[ត]
១៣ព្រះយេហូវ៉ាទ្រង់នឹងយាងចេញទៅ ដូចជាមនុស្សខ្លាំង
ពូកែ[ថ] ទ្រង់នឹងបណ្ដាលសេចក្ដីឧស្សាហ៍ឡើង[ទ] ដូចជា
មនុស្សថ្នឹកចំបាំង[ធ] ទ្រង់នឹងស្រែក[ន]ឡើង អើ ទ្រង់នឹងស្រែក
ជាខ្លាំង ហើយនឹងបង្ក្រាបពួកសត្រូវដោយឫទ្ធានុភាព[ប]។
១៤អញបានអត់ទ្រាំ ជាយូរមកហើយ អញបាននៅ
ស្ងៀម[ផ]ហើយបានទប់ចិត្ត[ព] ឥឡូវនេះអញនឹងស្រែកឡើង

**៤២:១** ឌ អស ១១:១១ ឍ ឧ.២១ នក ៤៣:២៩ អស ៥១:៤ ណ លប ៤៩:១០ មថ ១២:១៨–២១ **៤២:៥** ត លប ១:៦ ទដ ១០២:២៥ អស ៤៨:១៣ ថ លប ១:១ ទ ទដ ២៤:២ កច ១៧:២៤ ធ លប ២:៧ កច ១៧:២៥ **៤២:៦** ន នក ៣១:២ ពច ៤:១០ អស ៤១:៩–១០ ៤៣:១ ប អស ៤៥:២៤ យរ ២៣:៦ ដយ ៩:៧ ផ អស ៤១:១៣ ៤៥:១ ព អស ២៦:៣ ២៧:៣ ភ អស ៤៩:៨ ៥៤:១០ ៥៩:២១ ៦១:៨ យរ ៣១:៣១ ៣២:៤០ មឡ ៣:១ លក ២២:២០ ម អស ៩:២ យ អស ២៦:១៨ លក ២:៣២ **៤២:៧** រ ទដ ១៤៦:៨ អស ៣២:៣ មថ ១១:៥ ល អស ៤៩:៩ ៥១:១៤ ៥២:២ សក ២:៧ វ ទដ ៦៦:១១ អស ២៤:២២ ៤៨:២០ សក ៩:១១ លក ៤:១៩ ២ពត ២:២៦ ហព ២:១៤–១៥ ស ទដ ១០៧:១០,១៤ កច ២៦:១៨ **៤២:៨** ហ ទដ ៨១:១០ អស ៤៣:៣,១១,១៥ ៤៦:៩ ៤៩:២៣ ឡ នក ៣:១៥ ៦:៣ អ អស ៤៨:១១ ក នក ៨:១០ ២០:៤ **៤២:៩** ខ អស ៤១:២២ គ អស ៤០:២១ អគ ២:៤ **៤២:១០** ឃ ១របា ១៦:៣២ ទដ ៩៦:១១ ង អស ១១:១១ ច នក ១៥:១ ឆ ទដ ៩៦:១ ជ ១ពវ ១០:៩ អស ៦០:៦ ឈ ចទ ៣០:៤ ទដ ៤៨:១០ ៦៥:៥ អស ៤៩:៦ **៤២:១១** ញ អស ៣២:១៦ ដ លប ២៥:១៣ អស ៦០:៧ ឋ ពច ១:៣៦ ឌ អស ៥២:៧ ណហ ១:១៥ **៤២:១២** ឍ ១របា ១៦:២៤ អស ២៤:១៥ ណ ទដ ២៦:៧ ៦៦:២ ១ពត ២:៩ ត អស ១១:១១ **៤២:១៣** ថ អស ៩:៦ ទ អស ២៦:១១ ធ នក ១៤:១៤ ន យស ៦:៥ យរ ២៥:៣០ ហស ១១:១០ យអ ៣:១៦ អម ១:២ ៣:៤,៨ប អស ៦៦:១៤ **៤២:១៤** ផ នអ ៤:១៤ ទដ ៥០:២១ ព លប ៤៣:៣១ លក ១៨:៧ ២ពត ៣:៩

កច ៣:២១–២៣,២៦) ។ ពាក្យថា *កោះ* មើលការពន្យល់ ១១:១១ ។

**៤២:៥** *បង្កើតអស់ទាំងជាន់ផ្ទៃមេឃ . . . ហើយបានលាកផង* សូមមើល ៤០:២២ និងការពន្យល់ ។

**៤២:៦** *ហៅឯងមក . . . សុចរិត* គឺមានភាពស្រដៀងគ្នានិងការត្រាសហៅស្ដេចស៊ីរូស(សូមមើល ៤១:២ និងការពន្យល់) ។ ពាក្យថា *នឹងកាន់ដៃឯង* សូមមើលក្នុង ៤១:១៣ និងការពន្យល់ ។ ពាក្យថា *សេចក្ដីសញ្ញា* សូមមើល ៤៩:៨ ។ តាមរយៈព្រះមែស៊ីដែលជាស្ដេច និងមានសេចក្ដីសញ្ញាពីវង្សដាវីឌ (សូមមើល ២សយ ៧:១២–១៦ ប្រៀបធៀប អស ៥៥:៣ និងការពន្យល់) ដែលបំពេញបញ្ចប់នូវ (៩:៧) រួចហើយទ្រង់ក៏បង្កើតឱ្យមានសេចក្ដីសញ្ញាថ្មីតាមរយៈការលះបង់ព្រះជន្មទ្រង់ផ្ទាល់ (សូមមើល យរ ៣១:៣១–៣៤ ហព ៨:៦–១៣ ៩:១៥ និងការពន្យល់) ។ ពាក្យថា *បណ្ដាជន* គឺប្រហែល ជាសំដៅលើរាស្ត្រអ៊ីស្រាអែល (សូមមើល ៤៩:៨ កច ២៦:១៧–១៨) ។ ពាក្យថា *ជាពន្លឺភ្លឺដល់អស់ទាំងសាសន៍* សូមមើលការពន្យល់ ៩:២ ។ ពាក្យថា ពន្លឺភ្លឺ គឺជាពាក្យប្រៀបប្រដូចទៅនិង "សេចក្ដីសង្គ្រោះ" នៅក្នុង ៤៩:៦ ឬ (ប្រៀបធៀប ៥១:៤) ។

**៤២:៧** *ខ្វាក់បានភ្លឺ* សូមមើល ២៩:១៨ ៣២:៣ ៣៥:៣ និងការពន្យល់ ។ ពាក្យថា *នាំពួកត្រូវចាប់ចងចេញពីគុកងងឹត* គឺចេញពីគុកនៅឯស្រុកបាប៊ីឡូន ឬក៏ចេញពីចំណងខាងវិញ្ញាណ និងចំណងនៃសីលធម៌ខុសឆ្គង (សូមប្រៀបធៀប ៦១:១ និង លក ៤:១៨) ។

**៤២:៨** *សិរីល្អរបស់អញ* សូមមើល ៤០:៥ និងការពន្យល់ ។

**៤២:៩** *ការខាងដើមទាំងប៉ុន្មានបានកន្លងទៅ* សូមមើល ៤១:២២ និងការពន្យល់ ។ *ពីការទាំងនោះ* គឺជាការដែលព្រះធ្វើឱ្យរាស្ត្រអ៊ីស្រាអែលវិលមករកធាតុដើមឡើងវិញ (៤៣:១៩) សូមមើលប្រៀបធៀបនឹង ៤៨:៦ ។

**៤២:១០** *បទថ្មី* គឺជាការចាប់ផ្ដើមការងារថ្មី សូមមើល ឧ.៩ ។ ពាក្យថា *ចុងផែនដី* សូមមើល ១១:១២ និងការពន្យល់ ៤១:៥ ។ *កោះ* សូមមើល ឧ.១២ ១១:១១ និងការពន្យល់ ។

**៤២:១១** *ទីរហោស្ថាន* សូមមើល ៣៥:១ និងការពន្យល់ ។ *ពួកកេដារ* មើលការពន្យល់ ២១:១៦ ។ *ក្រុងសេឡា* មើលការពន្យល់ ១៦:១ ។

**៤២:១២** *គេថ្វាយកិត្តសព្ទ . . . សេចក្ដីសរសើរ* សូមមើល ២៤:១៤–១៦ ។

**៤២:១៣** *មនុស្សខ្លាំងពូកែ* គឺជាព្រះដែលទ្រង់បានវាយខ្មាំងសត្រូវ គឺដូចកាលដែលទ្រង់បានវាយសត្រូវនៅសមុទ្រក្រហមដូច្នេះដែរ (នក ១៥:៣) សូមមើល ៩:៦ និងការពន្យល់ ។ *ឫទ្ធានុភាព* សូមមើលការប្រៀបធៀប ៩:៧ ៣៧:៣២ ៥៩:១៧ ៦៣:១៥ ។ *ឧស្សាហ៍ឡើងដូចជាមនុស្សថ្នឹកចំបាំងទ្រង់នឹងស្រែកឡើង* គឺឃ្លានេះចង់បង្ហាញសកម្មភាពដែលធ្វើឱ្យសត្រូវមានភាពវឹកវរស្លន់ស្លោរចុះចាញ់ (សូមមើល ១សយ ៤:៥–៨) ។

**៤២:១៤** *អត់ទ្រាំជាយូរមកហើយ* គឺជាកំឡុងពេលដែលរាស្ត្រអ៊ីស្រាអែល

ដូចជាស្រី ដែលឈឺនឹងសំរាលកូន អញនឹងដកដង្ហើមគំហុក
ចូល រួចទំលាយចេញតែម្ដង[ភ] ១៥អញនឹងបំផ្លាញ[ម] ទាំងភ្នំ[យ]
ធំនឹងភ្នំតូច ហើយឱ្យស្មៅនៅលើនោះស្វិតក្រៀមទៅ អញ
នឹងធ្វើឱ្យទន្លេទាំងប៉ុន្មាន ទៅជាកោះវិញ ហើយឱ្យអស់ទាំង
ត្រពាំងទឹករីងគោក ទៅ ១៦អញនឹងនាំ[ល]ពួកមនុស្សខ្វាក់
តាមផ្លូវ១ដែលគេមិនស្គាល់ អញនឹងដឹកគេតាមផ្លូវ ច្រក
ដែលគេមិនធ្លាប់ដើរ អញនឹងធ្វើឱ្យសេចក្ដីងងឹតបានភ្លឺ[ស]
ឡើងនៅមុខគេ ហើយផ្លូវកៀកក្ងក់ឱ្យទៅជាត្រង់វិញ[ហ] គឺការ
ទាំងនេះដែលអញនឹងធ្វើ ហើយមិនបោះបង់ចោល[ឡ]គេ
ឡើយ ១៧ឯពួកអ្នកដែលទុកចិត្តនឹងរូបឆ្លាក់ ហើយដែល
និយាយទៅរូបសិតថា លោកជាព្រះរបស់យើងខ្ញុំ[អ] នោះនឹង
ត្រូវបែរខ្នងចេញវិញ ហើយនឹងមានសេចក្ដីខ្មាសជ្រប់
មុខផង[ក] ។

## ពួកអ៊ីស្រាអែលថ្លង់ និងខ្វាក់

១៨ឱមនុស្សដំឡង់អើយ[ខ] ចូរស្ដាប់ចុះ ហើយពួកកង្វាក់
អើយ ចូរមើល ដើម្បីឱ្យគេបានឃើញ ១៩តើអ្នកណាជាអ្នក
ខ្វាក់[គ] បើមិនមែនជាអ្នកបំរើរបស់អញ[ឃ] ឬថ្លង់ ដូចជាអ្នក
នាំដំណឹង[ង]ដែលអញចាត់ប្រើ តើអ្នកណាខ្វាក់ភ្នែក ដូច
ជាអ្នកដែលមេត្រី[ច]នឹងអញ ហើយខ្វាក់ដូចជាអ្នកបំរើ
របស់ព្រះយេហូវ៉ា ២០ឯងឃើញការជាច្រើនយ៉ាង តែមិន
ពិចារណាទេ ត្រចៀកនៅចំហ តែស្ដាប់មិនឮសោះ[ឆ]
២១ព្រះយេហូវ៉ា ទ្រង់បានសព្វព្រះហឫទ័យ នឹងលើកដំកើង
ក្រិត្យវិន័យ[ជ] ហើយឱ្យមានកិត្តសព្ទ ដោយយល់ដល់[ឈ]សេចក្ដី
សុចរិតរបស់ទ្រង់ ២២ប៉ុន្តែសាសន៍នេះជាសាសន៍ដែលត្រូវ
គេរឹបជាន់[ញ] ហើយប្លន់យក គេសុទ្ធតែជាប់អន្ទាក់នៅក្នុង
រូង[ដ] ហើយក៏លាក់ទុកក្នុងគុក[ឋ] គេសំរាប់ជារំពា ឥតមានអ្នក
ណាដោះឱ្យរួច[ឌ] ហើយសំរាប់ជារបឹបឥតមានអ្នកណាថា
ចូរប្រគល់ទៅឱ្យគេវិញនោះឡើយ ។
២៣តើមានអ្នកណាក្នុងពួកឯងរាល់គ្នា ដែលនឹងផ្ទៀង
ត្រចៀកស្ដាប់សេចក្ដីទាំងនេះ ដែលនឹងប្រុង[ឍ]ស្ដាប់ ហើយ
ឮសំរាប់គ្រាទៅខាងមុខនោះ ២៤តើអ្នកណាបានប្រគល់
ពួកយ៉ាកុបឱ្យទៅជារបឹប[ណ] ហើយពួកអ៊ីស្រាអែលដល់ចោរ
ដូច្នេះ តើមិនមែនជាព្រះយេហូវ៉ាទេឬ[ត] ដែលយើងរាល់
គ្នាបានធ្វើបាបនឹងទ្រង់ ឥតព្រមដើរតាម[ថ]ផ្លូវទ្រង់ ឬស្ដាប់
តាមក្រិត្យវិន័យទ្រង់ឡើយ[ទ] ២៥គឺហេតុនោះបានជាទ្រង់ចាក់
ភ្លើងនៃសេចក្ដីក្រោធរបស់ទ្រង់ទៅលើគេ[ធ] ហើយនិង
អំណាចនៃសង្គ្រាមផង នោះក៏បញ្ឆេះគេនៅព័ទ្ធជុំវិញ[ន]
តែគេមិនបានដឹងទេ[ប] ភ្លើងនោះបានបញ្ឆេះគេ តែគេមិន
បានយកចិត្តទុកដាក់ឡើយ[ផ]។

## ព្រះសង្គ្រោះតែមួយរបស់អ៊ីស្រាអែល

**៤៣** ១ប៉ុន្តែ ឱពួកយ៉ាកុបអើយ ឥឡូវនេះ ព្រះយេហូវ៉ាជា
ព្រះដែលបង្កើត[ក]ឯងមក ហើយឱពួកអ៊ីស្រាអែល អើយ

**៤២:១៤** ភ យរ ៤:៣១ **៤២:១៥** ម អក ៣៨:២០ យ ទដ ១០៧:៣៣ រ អស ១១:១៥ ៥០:២ ណហ ១:៤-៦ **៤២:១៦** ល អស ២៩:២៤ ៤០:១១ ៥៧:១៨ ៥៨:១១ យរ ៣១:៨-៩ លក ១:៧៨-៧៩ វ អស ៣២:៣ ស ទដ ១៨:២៨ អស ៥៨:៨,១០ កច ២៦:១៨ ហ អស ២៦:៧ លក ៣:៥ ឡ ចទ ៤:៣១ ហព ១៣:៥ **៤២:១៧** អ នក ៣២:៤ ក ទដ ៩៧:៧ អស ១:២៩ **៤២:១៨** ខ អស ៣៥:៥ **៤២:១៩** គ អស ៤៣:៨ អក ១២:២ ឃ អស ៤១:៨-៩ ង អស ៤៤:២៦ ហក ១:១៣ ច អស ២៦:៣ **៤២:២០** ឆ អស ៦:៩-១០ ៤៣:៨ យរ ៥:២១ ៦:១០ **៤២:២១** ជ អស ៤៣:២៥ ឈ ខ.៤ ២រប ៣:៧ **៤២:២២** ញ ពច ៦:៤ ២ពវ ២៤:១៣ ដ អស ២៤:១៨ ឋ ទដ ៦៦:១១ អស ២៤:២២ ឌ អស ៥:២៩ **៤២:២៣** ឍ ចទ ៣២:២៩ ទដ ៨១:១៣ អស ៤៧:៧ ៤៨:១៨ ៥៧:១១ **៤២:២៤** ណ ២ពវ ១៧:៦ អស ៤៣:២៨ ៤៧:៦ ត អស ១០:៥-៦ ថ អស ៣០:១៥ ទ យស ១:៧ ទដ ១១៩:១៣៦ អស ៥:២៤ យរ ៤៤:១០ **៤២:២៥** ធ ២ពវ ២២:១៣ យប ៤០:១១ អស ៥១:១៧ អក ៧:១៩ ន ២ពវ ២៥:៩ ងស ៦៦:១៥ យរ ៤:៤ ២១:១២ បទ ២:៣ ណហ ១:៦ ប អស ១:៣ ផ អស ២៩:១៣ ៤៧:៧ ៥៧:១,១១ ហស ៧:៩ **៤៣:១** ក អស ២៧:១១

មានភាពវេទនាទ្រុតទ្រោមនិងបានសម្លាប់ទេ ។ សូមមើល ៦៣:១៥ ៦៤:១២ ជាពាក្យត្អូញត្អែរដូចជាព្រះគម្ពីរភាសាហេព្រើរជាកិរិយាស័ព្ទ ។ ចំពោះលោកយ៉ូសែប ដែលបានគ្រប់គ្រងអារម្មណ៍របស់គាត់ ខណៈដែលគាត់បានល្បងលបងប្អូនប្រុសៗរបស់គាត់ (លប ៤៣:៣១ ៤៥:១) ។ សូមមើល ៣០:១៨ និងការពន្យល់ ។

**៤២:១៥** *នឹងបំផ្លាញ . . . ស្វិតក្រៀម* ឃ្លានេះបង្ហាញពីភាពខុសគ្នានឹង ៣៥:១-២ ៤១:១៨ ។ *ទន្លេទាំងប៉ុន្មានទៅជាកោះវិញ* ដែលនាំឱ្យការធ្វើដំណើរប្រព្រឹត្តទៅបានល្អប្រសើ សូមមើល ៣៧:២៥ ៤៤:២៧ ។

**៤២:១៦** *ខ្វាក់* ជាសាសន៍អ៊ីស្រាអែល(ខ.១៩-២០) ។ *ផ្លូវកៀកក្ងក់ឱ្យទៅជាផ្លូវត្រង់វិញ* សូមមើលសេចក្ដីពន្យល់ ២៦:៧ ។ ពាក្យថា *មិនបោះបង់ចោល* សូមប្រៀបធៀប ៤០:២៧ ៤៩:១៤ ៤៥:៨ ។

**៤២:១៨** *មនុស្សដំឡង់ . . . ពួកកង្វាក់* សូមមើល ៦:១០ និងការពន្យល់ ។

**៤២:១៩** *អ្នកបំរើអញ* ដូចជារាស្ត្រអ៊ីស្រាអែល មើល ៤១:៨-៩ ។ *អ្នកដំណើរដែលអញបានចាត់ប្រើ* ពាក្យនេះគឺសំដៅទៅលើពួកហោរា ដែលទ្រង់បានបញ្ជូន (មើល ហក ១:១៣ ប្រៀបធៀបនឹង អស ៤៤:២៦ មឡ ៣:១) ។

**៤២:២១** *ដំកើងក្រិត្យវិន័យ . . . មានកិត្តសព្ទ* គឺជាពិសេសច្បាប់របស់លោកម៉ូសេដែលបានស្បថសច្ចានៅឯភ្នំស៊ីណាយ (សូមមើល នក ៣៤:២៩) ។

**៤២:២២** *ត្រូវគេរឹបជាន់ហើយប្លន់យក* គឺប្លន់ដោយពួកអាសស៊ើរ (សូមមើល នក ១០:៦ និងការពន្យល់) ។ និងប្លន់ដោយពួក បាប៊ីឡូន (សូមមើល ៣៩:៦) ។ ពាក្យថា *អន្ទាក់នៅក្នុងរូង* គឺសូមមើល ខ.៧ និងការពន្យល់ប្រៀបធៀប ពច ៦:២-៤ ។

**៤២:២៤** *អ្នកណាបានប្រគល់ពួកយ៉ាកុបឱ្យទៅរបឹប* កាលដែលពួកបាប៊ីឡូនបានគ្រប់គ្រងលើពួកអ៊ីស្រាអែល គឺមិនមែនថាព្រះរបស់ពួកគេមានអំណាចខ្លាំងជាព្រះយេហូវ៉ាទេតើ គឺជាការដែលព្រះយេហូវ៉ាដាក់ទោសដល់រាស្ត្ររបស់ផងទ្រង់ដោយពួកគេពុំស្ដាប់បង្គាប់ ។ (សូមមើល ៤០:១៧-១៨ ១ពវ ២០:២៣ និងការពន្យល់) ។

**៤២:២៥** *ចាត់ភ្លើងនៃសេចក្ដីក្រោធរបស់ទ្រង់* គឺដោយសារតែពួកអ៊ីស្រាអែលបានបោះបង់ចោលថ្ងៃរបស់ទ្រង់ (សូមមើល ៥:២៥ ៩:១២,១៧,២១ ១៣:៣ ៣៤:២ និងការពន្យល់ប្រៀបធៀប យរ ១០:២៥) ។

**៤៣:១** *ព្រះដែលបង្កើត* នោះគឺព្រះអម្ចាស់បានបង្កើតសាសន៍អ៊ីស្រាអែល

ព្រះដែលជបសូន[ខ]ឯង ទ្រង់មានបន្ទូលដូច្នេះថា[គ] កុំឱ្យខ្លាច
ឡើយ ដ្បិតអញបានលោះ[ឃ]ឯងហើយ អញបានហៅចំ
ឈ្មោះឯង[ង] ឯងជារបស់ផងអញ[ច] ២កាលណាឯងដើរកាត់
ទឹកធំ[ឆ] នោះអញនឹងនៅជាមួយ[ជ] កាលណាដើរកាត់ទន្លេ
នោះទឹកនឹងមិនលិចឯងឡើយ កាលណាឯងលុយកាត់
ភ្លើង[ឈ] នោះឯងនឹងមិនត្រូវរលាក ហើយអណ្តាតភ្លើងក៏
មិនឆាបឆេះឯងដែរ[ញ] ៣ដ្បិតអញនេះគឺយេហូវ៉ា ជាព្រះនៃ
ឯង[ដ] អញជាព្រះដ៏បរិសុទ្ធ[ឋ]នៃសាសន៍អ៊ីស្រាអែល គឺជា
ព្រះដ៏សង្គ្រោះរបស់ឯង[ឌ] អញបានឱ្យស្រុកអេស៊ីព្ទ[ឍ] ទុកជា
ថ្លៃលោះឯង ព្រមទាំងស្រុកអេធីយ៉ូពី[ណ] និងស្រុកសេបា[ត]
ជំនួសឯងផង[ថ] ៤អញនឹងឱ្យមនុស្សដទៃជំនួសឯង ហើយ
ប្រជាជាតិផ្សេងៗស្នងនឹងជីវិតឯង ដោយព្រោះឯងមាន
ដំឡៃវិសេស[ទ]នៅភ្នែកអញ ក៏គួរលើកដំកើង ហើយជាទី
ស្រឡាញ់[ធ]ដល់អញផង ៥កុំឱ្យខ្លាចឡើយ[ន] ដ្បិតអញនៅ
ជាមួយ[ប] អញនឹងនាំពូជពង្សឯង[ផ]មកពីទិសខាងកើត ហើយ
នឹងប្រមូល[ព]គេមកពីទិសខាងលិច[ភ] ៦អញនឹងបង្គាប់ដល់
ទិសខាងជើងថា ចូរប្រគល់គេមក ហើយដល់ទិសខាង
ត្បូងថា[ម] កុំឃាត់គេទុកឡើយ ចូរនាំអស់ទាំងកូនប្រុស
របស់អញមកពីទីឆ្ងាយ ហើយពួកកូនស្រី[យ]អញមកពីចុង
ផែនដីចុះ[រ] ៧គឺគ្រប់មនុស្សដែលបានហៅតាមនាមឈ្មោះ
អញ[ល] ជាអ្នកដែលអញបានបង្កើត[វ]មកសំរាប់សិរីល្អ[ស]នៃ
អញ គឺជាអ្នកដែលអញបានជបសូន អើ ជាអ្នកដែលអញ
បានតែងតាំងឡើង[ហ] ។
៨ចូរនាំមនុស្សខ្វាក់ដែលមានភ្នែក[ឡ] និងមនុស្សថ្លង់
ដែលមានត្រចៀកចេញមក[អ] ៩ត្រូវឱ្យអស់ទាំងសាសន៍ប្រជុំ
គ្នា[ក] ហើយឱ្យប្រជាជាតិទាំងពួកជំនុំគ្នាចុះ ក្នុងពួកគេ តើ
មានអ្នកណាដែលអាចនឹងទាយ[ខ]ពីការនេះបាន ឬអាចនឹង
សំដែង ឱ្យយើងដឹងពីដំណើរ ដែលកន្លងមកហើយនោះ
ចូរឱ្យគេនាំស្មរបន្ទាល់របស់គេមក ដើម្បីតាំងខ្លួនជាត្រឹម
ត្រូវ បើមិនដូច្នោះទេ នោះត្រូវថា នេះពិតមែនវិញ ១០ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា ឯងរាល់គ្នាជាស្មរបន្ទាល់របស់
អញ[គ] ហើយជាអ្នកបំរើ[ឃ]ដែលអញបានរើសតាំង ដើម្បីឱ្យ
បានស្គាល់[ង] ហើយជឿដល់អញ ព្រមទាំងយល់ថា គឺអញ
នេះហើយ ឥតមានព្រះ[ច]ណាកើតមកមុនអញទេ ហើយ

**៤៣:១** ខ ខ.៧ លប ២:៧ គ លប ៣២:២៨ អស ៤៤:២១ ឃ នក ៦:៦ យប ១៩:២៥ ង អស ៤២:៦ ៤៥:៣–៤ ៤៩:១ ច ចទ ៧:៦ មឡ ៣:១៧ **៤៣:២** ឆ អស ៨:៧ ជ លប ២៦:៣ នក ១៤:២២ ឈ អស ២៩:៦ ៣០:២៧ ញ ទដ ៦៦:១២ ដយ ៣:២៥–២៧ **៤៣:៣** ដ នក ២០:២ ឋ អស ៤១:២០ ឌ នក ១៤:៣០ ពច ២:១៨ ទដ ៣:៨ អស ២៥:៩ ឍ ទដ ៦៨:៣១ អស ១៩:១ អគ ២៩:២០ ណ អស ២០:៣ ត លប ១០:៧ ថ សភ ២១:១៨ **៤៣:៤** ទ នក ១៩:៥ អស ៤៩:៥ ធ អស ៦៣:៩ វវ ៣:៩ **៤៣:៥** ន លប ១៥:១ អស ៤៤:២ ប លប ២១:២២ នក ១៤:២២ យរ ៣០:១០–១១ ផ អស ៤១:៨ ៥៤:៣ ៦១:៩ ៦៦:២២ ព អស ១១:១២ ៤៩:១៨ ភ អស ២៤:១៤ សក ៨:៧ មថ ៨:១១ **៤៣:៦** ម ទដ ១០៧:៣ យ អស ៦០:៤ អគ ១៦:៦១ ២កថ ៦:១៨ រ ចទ ៣០:៤ អស ១១:១២ យរ ២៣:៨ អគ ៣៦:២៤ **៤៣:៧** ល អស ៤៨:១ ៥៦:៥ ៦២:២ ៦៣:១៩ ៦៥:១ យរ ១៥:១៦ យក ២:៧ វ អស ២៧:១១ ស ទដ ៨៦:៩ ហ ខ.១,២១ ទដ ១០០:៣ អស ១៩:២៥ **៤៣:៨** ឡ អស ៦:៩–១០ អ អស ៤២:២០ អគ ១២:២ **៤៣:៩** ក អស ៤១:១ ៤៥:២០ ៤៨:១៤ ខ អស ៤១:២៦ **៤៣:១០** គ ខ.១២ យស ២៤:២២ ឃ អស ២០:៣ ៤១:៨–៩ ង នក ៦:៧ ច ខ.១១ ទដ ៨៦:១០ អស ១៩:២១ ៤៤:៦,៨ ៤៥:៥–៦,១៤ ឆ ចទ ៤:៣៥ ៣២:៣៩ យរ ១៤:២២

គឺដូចដែលព្រះបានបង្កើតមនុស្សប្រុសនិងមនុស្សស្រីដំបូងអញ្ចឹង ។ (សូមមើល លប ១:២៧ និងការពន្យល់ ក៏សូមមើល អស ៤៣:៧,១៥,២១ ៤៤:២,២៤) ។ *កុំឱ្យខ្លាចឡើយ* សូមមើល ៤១:១០ និងការពន្យល់ ។ *បានលោះឯងហើយ* សូមមើលការពន្យល់ ៣៥:៩ ៤១:១៤ ។

**៤៣:២** *ទឹក. . . ទន្លេ* គឺប្រហែលនិយាយសំដៅទៅលើការឆ្លងសមុទ្រក្រហម (នក ១៤:២១–២២) និងទន្លេយ័ដាន់ (សយ ៣:១៤–១៧) ។ ប្រៀបធៀប ទដ ៦៦:៦,១២ ។ *លុយកាត់ភ្លើង* គឺជាការសម្រេចដោយចំៗតែម្តងនៅក្នុងបទពិសោធន៍របស់ សាដ្រាក់ មែសាក់ និងអ័បេឌ–នេកោ (ដយ ៣:២៥–២៧) ។ ដែលខុសនឹង ៤២:២៥ ។

**៤៣:៣** *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើលការពន្យល់ ១:៤ ៤១:១៤ ។ ពាក្យថា *ព្រះដ៏សង្គ្រោះ* គឺជាព្រះសង្គ្រោះរាស្ត្រទ្រង់ពីការគាបសង្កត់ពីស្រុកអេស៊ីព្ទ ឬក៏ស្រុកបាប៊ីឡូន និងពីចំណងនៃការគាបសង្កត់ខាងវិញ្ញាណក្នុងអំពើបាប (សូមមើល ១៩:២០ និងការពន្យល់ ២៥:៩ និងការពន្យល់ ៣៣:២២ ៣៥:៤ និងការពន្យល់ ៤៣:១១–១២ ៤៥:១៥,២១–២២ ៤៩:២៥ ៦០:១៦ ៦៣:៨–៩) ឈ្មោះថា "អេសាយ" មានន័យថា "ព្រះយេហូវ៉ាសង្គ្រោះ" គឺជាការលោះបាប ។ ស្តេចពើស៊ីបានគ្រប់គ្រងស្រុកអេស៊ីព្ទ ស្រុកគូស និងសេបា ។ នេះគឺជារង្វាន់របស់ពួកពើស៊ីដល់រាស្ត្រអ៊ីស្រាអែល (សូមមើលការពន្យល់ ៤១:២ ប្រៀបធៀប អគ ២៩:១៩–២០) ។ *ស្រុកគូស* សូមមើលការពន្យល់ ១៨:១ ។ *ស្រុកសេបា* (ទដ ៧២:១០ វាអាចជាទឹកដីនៅតំបន់អារ៉ាប់ (សូមមើល លប ១០:៧ និងការពន្យល់ ក៏សូមមើល អគ ២៧:២១–២២) ឬក៏នៅក្នុងប្រទេសអាហ្វ្រិចខាងកើត ។

**៣:៥** *កុំឱ្យខ្លាចឡើយ* សូមមើល ៤១:១០ និងការពន្យល់ ។ *ទិសខាងកើត* គឺជាពិសេសស្រុកអាសស៊ើរនិងពួកបាប៊ីឡូន ។ សូមមើល ១១:១១–១២ និងការពន្យល់ប្រៀបធៀប ទដ ១០៧:៣ ។ *ទិសខាងលិច* ឧទាហរណ៍នៅតំបន់ដីកោះក្នុង ១១:១១ (សូមមើលការពន្យល់ ២៤:១៤–១៥ ៤៩:១២) ។

**៤៣:៦** *ទិសខាងជើង* ឧទាហរណ៍ នៅឯស្រុក ឬក្រុងហេម៉ាត (សូមមើល ១០:៩ និងការពន្យល់ ១១:១១) ។ *ទិសខាងត្បូង* ដូចជាស្រុកអេស៊ីព្ទនាចុងផែនដី សូមមើលការពន្យល់ ១១:១២ (ប្រៀបធៀប ៤១:៥ ៤២:១០) ។

**៤៣:៧** *គ្រប់មនុស្សដែលបានហៅតាមនាមឈ្មោះអញ* ដោយមនុស្សទាំងអស់ជារបស់ព្រះ ។ *អញបានបង្កើតមកសំរាប់សិរីល្អនៃអញ* សូមមើល ខ.១ និងការពន្យល់ ។

**៤៣:៨** *មនុស្សខ្វាក់ . . . មនុស្សថ្លង់* ពាក្យនេះគឺពោលសំដៅទៅលើពួកសាសន៍អ៊ីស្រាអែល (សូមមើល ៦:១០ និងការពន្យល់ ៤២:១៨–២០) ។

**៤៣:៩** *អស់ទាំងសាសន៍. . . ប្រជាជាតិទាំងពួងជំនុំគ្នាចុះ* សូមមើល ៤១:២២ និងការពន្យល់ ។ *ស្មរបន្ទាល់* (សូមមើល ៤១:២៦) ។

**៤៣:១០** *ឯងរាល់គ្នាជាស្មរបន្ទាល់របស់អញ* សូមមើល ខ.១២ ៤៤:៨ ។ ព្រះរាជកិច្ចក្នុងនាមជារាស្ត្រអ៊ីស្រាអែល ត្រូវបង្ហាញពីភស្តុតាងនិងពីអំណាចចេស្តានៃការសង្គ្រោះ ។ *អ្នកបំរើ* សូមមើល ៤១:៨–៩ និងការពន្យល់ ។

ក្រោយអញក៏ឥតមានដែរ[ឆ] ១១គឺអញ អញនេះហើយជា
យេហូវ៉ា[ជ] ក្រៅពីអញ គ្មានអ្នកសង្គ្រោះណាទៀតឡើយ[ឈ]
១២អញបានទាយប្រាប់ អញបានជួយសង្គ្រោះ អញបាន
សំដែងឱ្យឃើញហើយ ឥតមានព្រះដទៃ[ញ]ណានៅកណ្ដាល
ឯងរាល់គ្នាឡើយ ហេតុដូច្នោះឯងរាល់គ្នាជាស្មរបន្ទាល់
របស់អញ[ដ] ហើយគឺអញនេះដែលជាព្រះ នេះជាព្រះបន្ទូល
នៃព្រះយេហូវ៉ា ១៣អើ ចាប់តាំងពីមានពេលថ្ងៃ[ឋ]ឡើង
វេលាណា នោះគឺជាអញនេះហើយ[ឌ] ឥតមានអ្នកណាអាច
នឹងដោះឱ្យរួចពីដៃអញបានទេ ឯការដែលអញធ្វើ តើអ្នក
ណានឹងឃាត់បាន[ឍ]។

## សេចក្ដីមេត្តាករុណានៃព្រះ និងភាពមិនស្មោះត្រង់របស់អ៊ីស្រាអែល

១៤ព្រះយេហូវ៉ា ជាព្រះដ៏ប្រោសលោះ[ណ]ឯងរាល់គ្នា គឺ
ជាព្រះបរិសុទ្ធ[ត]នៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលថា
ដោយយល់ដល់ឯងរាល់គ្នា នោះអញចាត់មនុស្សទៅឯ
ក្រុងបាប៊ីឡូន ហើយនឹងទំលាក់គេទាំងអស់គ្នា គេនឹងរត់
រតាត់រតាយទៅ[ថ] ឯពួកខាល់ដេ[ទ] ក៏ចុះនាវាដែលគេយក
ជាទីសប្បាយរបស់គេ ១៥អញនេះ គឺយេហូវ៉ា[ធ] អញជា
ព្រះដ៏បរិសុទ្ធនៃឯងរាល់គ្នា គឺជាព្រះដែលបង្កើតសាសន៍
អ៊ីស្រាអែល[ន] ហើយជាមហាក្សត្ររបស់ឯងរាល់គ្នាផង[ប]
១៦ព្រះយេហូវ៉ា ដែលទ្រង់ធ្វើឱ្យមានផ្លូវក្នុងសមុទ្រ នឹងផ្លូវ
ច្រកនៅទីទឹកធំ[ផ] ១៧ជាព្រះដែលនាំ[ព]រទេះចំបាំង និងពល
សេះចេញមក[ភ] ព្រមទាំងកងទ័ព និងមនុស្សស្ទាត់ជំនាញ
ផង[ម] ពួកទាំងនោះនឹងដេកទៅ[យ]ទាំងអស់គ្នា ឥតក្រោកឡើង
វិញឡើយ គេនឹងសាបសូន្យ ហើយត្រូវរលត់ទៅ ដូចជា
ប្រឆេះ)[រ] ទ្រង់មានបន្ទូលថា ១៨កុំឱ្យឯងរាល់គ្នានឹកចាំពី
ការទាំងប៉ុន្មានដែលកន្លងទៅហើយ[ល] ឬរិះគិតពីអស់ទាំង
ការពីចាស់បុរាណនោះឡើយ ១៩មើល អញនឹងធ្វើការ១ថ្មី
វិញ[វ] ការនោះនឹងលេចឡើងឥឡូវ តើឯងរាល់គ្នានឹងមិន
ស្គាល់ទេឬ អញនឹងធ្វើផ្លូវ១នៅទីរហោស្ថាន[ស] ហើយទន្លេ
នៅសមុទ្រខ្សាច់[ហ] ២០ឯពួកសត្វតិរច្ឆាន[ឡ]ទាំងប៉ុន្មាន នឹង
សរសើរដល់អញ គឺទាំងចចក[អ] និងសត្វអូសទ្រីចផង
ពីព្រោះអញឱ្យមានទឹក[ក]នៅក្នុងទីរហោស្ថាន និងទន្លេនៅ
សមុទ្រខ្សាច់ ដើម្បីឱ្យរាស្ត្រអញ គឺជាពួកជ្រើសរើសនោះ
បានផឹក ២១ជារាស្ត្រដែលអញបានជបសូន[ខ]សំរាប់តែខ្លួន
អញ[គ] ដើម្បីឱ្យគេបានសំដែងចេញជាសេចក្ដីសរសើររបស់
អញផង[ឃ]។

២២ទោះបើយ៉ាងនោះ ឱពួកយ៉ាកុបអើយ គង់តែឯង
មិនបានអំពាវនាវដល់អញដែរ គឺឯងបានណាយចិត្ត[ង]នឹង

**៤៣:១១** ជ នក ៦:២ អស ៤២:៨ ឈ ខ.១០ ទដ ៣:៨ ១៨:១៣ អស ២៥:៩ ៦៤:៤ **៤៣:១២** ញ ចទ ៣២:១២ ដ ខ.១០ **៤៣:១៣** ឋ ទដ ៩០:២ ឌ ចទ ៣២:៣៩ អស ៤៦:៤ ៤៨:១២ ឍ ជន ២៣:៨ យប ៩:១២ **៤៣:១៤** ណ នក ១៥:១៣ យប ១៩:២៥ ត អស ១:៤ ៤១:២០ ថ អស ១៣:១៤-១៥ ទ អស ២៣:១៣ **៤៣:១៥** ធ អស ៤២:៨ ន អស ២៧:១១ ៤៥:១១ ប អស ៤១:២១ **៤៣:១៦** ផ នក ១៤:២៩ ១៥:៨ អស ១១:១៥ **៤៣:១៧** ព ទដ ១១៨:១២ អស ១:៣១ ភ នក ១៤:២២ ម នក ១៤:៩ យ ទដ ៧៦:៥-៦ រ យប ១៣:២៥ យរ ៥១:២១ អគ ៣៨:៤ **៤៣:១៨** ល អស ៤១:២២ **៤៣:១៩** វ អស ៤១:២២ យរ ១៦:១៤-១៥ ២៣:៧-៨ ២កថ ៥:១៧ វវ ២១:៥ ស អស ៤០:៣ ហ ទដ ១២៦:៤ អស ៣៣:២១ ៣៥:៧ **៤៣:២០** ឡ ទដ ១៤៨:១០ អ អស ១៣:២២ ក ជន ២០:៨ **៤៣:២១** ខ ខ.៧ លប ២:៧ គ មឡ ៣:១៧ ឃ ទដ ៦៦:២ ១០២:១៨ ១ពត ២:៩ **៤៣:២២** ង យស ២២:៥ អស ១:១៤

**៤៣:១១** ក្នុងខនេះបង្ហាញពីការទុកចិត្តបំផុតចំពោះព្រះយេហូវ៉ា នៃពួកពលបរិវាដែលបង្ហាញឱ្យឃើញឡើងវិញ ក្នុង ៤៤:៦ ៤៥:៥-៦,១៨,២១-២២ ៤៩:៩ (សូមមើល ចទ ៣២:៣៩) ។ *អ្នកសង្គ្រោះ* សូមមើល ខ.៣ និងការពន្យល់ ។

**៤៣:១២** *មានព្រះដទៃ* ប្រៀប ចទ ៣២:១២,១៦ ។ គឺរាស្ត្រអ៊ីស្រាអែលដែលនៅតែគោរពថ្វាយបង្គំរូបព្រះម្ដងហើយម្ដងទៀត (សូមមើល ពច ២:១២-១៣ និងកាពន្យល់) ។ *ស្មរបន្ទាល់* សូមមើល ខ.១០ និងការពន្យល់ ។

**៤៣:១៣** សូមមើល ខ.១១ ។ ពាក្យថា *ឥតមានអ្នកណាអាចនឹងដោះរួចពីដៃអញ* គឺមានបញ្ជាក់ក្នុង ចទ ៣២:៣៩ ។

**៤៣:១៤** *ព្រះដ៏ប្រោសលោះ* សូមមើល ៤១:១៤ និងការពន្យល់ ។ *ជាព្រះបរិសុទ្ធនៃសាស្ត្រអ៊ីស្រាអែល* សូមមើល ១:៤ ៤១:១៤ និងការពន្យល់ ។ *ក្រុងបាប៊ីឡូន* សូមមើលការពន្យល់ ១៣:១ ។ *គេនឹងរត់...ក៏ចុះនាវា* គឺជាសកម្មភាពពួកបាប៊ីឡូន ដែលបានប្រើផៃបាប៊ីឡូននិងផៃពួកសាសន៍អើប្រាត និងទន្លេអើប្រាតដើម្បីឆ្លងកាត់និងធ្វើជំនួញ (សូមមើលការប្រៀបធៀប ២:១៦) ។ តែក្នុងខណៈពេលថ្ងៃមួយផៃនោះក៏ក្លាយជាទីតាំងភៀសខ្លួននិងលាក់ខ្លួនទៅវិញ (ប្រៀបធៀប យរ ៥១:១៣) ។

**៤៣:១៥** *ព្រះដែលបង្កើត* សូមមើល ខ.១ និងការពន្យល់ ។ ពាក្យថា *ជាមហាក្សត្រ* គឺជាពាក្យដែលរាស្ត្ររបស់ទ្រង់ហៅទៅក៏ចាត់ទ្រង់ថាជាស្តេចលើពួកអ៊ីស្រាអែល ។ មើលក្នុង ចទ ៣៣:៥ (មានលក្ខណៈផ្ទុយនឹង ១សយ ៨:៧) ។

**៤៣:១៦-១៧** ការបង្ហាញពីការឆ្លងកាត់សមុទ្រក្រហម (សូមមើល ខ.២ និងការពន្យល់) ។ ក៏មានរទេះចំបាំង និងពលសេះត្រូវបានព្រះវាយកំចាត់បង់ (សូមមើល ៥១:១០ នក ១៤:២៨ ១៥:៤) ។

**៤៣:១៧** *គេនឹងសាបសូន្យ ហើយត្រូវរលត់ទៅ* ឃ្លានេះមានភាពផ្ទុយនឹង ៤២:៣ ។

**៤៣:១៨-១៩** *ពីការទាំងប៉ុន្មានដែលកន្លងទៅហើយ . . . ធ្វើការ១ថ្មីវិញ* ពាក្យនេះសូមមើល ៤១:២២ ៤២:៩ និងការពន្យល់ ។

**៤៣:១៩** *ផ្លូវ១ទៅនៅទីរហោស្ថាន* មើល ៣៥:៨ ៤០:៣ និងការពន្យល់ ។

**៤៣:២០** *ទាំងចចក...សត្វអូសទ្រីច* ជាសត្វលោកមានជីវិតរស់នៅទីរហោស្ថាន (សូមមើល ១៣:២១-២២ ៤៣:១៣-១៥ ៣៥:៧) ។

**៤៣:២១** *ជារាស្ត្រ . . . សរសើរបស់អញ* សូមមើលការប្រៀបធៀបនិង ៤២:២ ។

**៤៣:២២-២៤** ពេលខ្លះពួករាស្ត្រអ៊ីស្រាអែលបាននាំមកនូវជាដង្វាយដុត ជាយញ្ញបូជាដល់ព្រះយេហូវ៉ាតែចិត្តរបស់ពួកគេឥតមានភាពស្មោះត្រង់និងព្រះទេ (សូមមើល ១:១១-១៥ និងការពន្យល់) ។

**៤៣:២២** *មិនអំពាវនាវ . . . បានណាយចិត្តនិងអញ* គឺបង្ហាញពីការអធិស្ឋាន

អញវិញ ឱអ៊ីស្រាអែលអើយ[ច] ២៣ឯងមិនបាននាំយកចៀម
របស់ឯង មកថ្វាយជាដង្វាយដុតដល់អញទេ[ឆ] ក៏មិនបាន
លើកមុខ[ជ]អញ ដោយយញ្ញបូជារបស់ឯងដែរ[ឈ] អញមិន
បានផ្ទុក[ញ]ឯងដោយដង្វាយ ឬឱ្យឯងនឿយហត់[ដ]ដោយដុត
កំញានទេ[ឋ] ២៤ឯងមិនបានចំណាយប្រាក់ទិញគ្រឿងក្រអូប
ណា[ឌ] ឱ្យអញសោះ ក៏មិនបានឱ្យអញឆ្អែត ដោយខ្លាញ់[ឍ]នៃ
យញ្ញបូជារបស់ឯងដែរ គឺឯងបានផ្ទុកអញដោយអំពើបាប
របស់ឯងវិញ ហើយបាននាំឱ្យអញនឿយហត់[ណ] ដោយអំពើ
ទុច្ចរិតរបស់ឯងផង[ត] ។
២៥គឺអញ អញនេះហើយ ជាអ្នកដែលលុបអំពើរំលង
របស់ឯងចេញ[ថ] ដោយយល់ដល់ខ្លួនអញ[ទ] ហើយអញមិន
នឹកចាំពីអំពើបាប[ធ]របស់ឯងទៀតឡើយ[ន] ២៦ចូររំឭកចុះ
ឱ្យយើងបានតវ៉ាគ្នា[ប] ចូររាប់រៀបប្រាប់ពីហេតុ[ផ]របស់ឯង
មក ដើម្បីឱ្យឯងបានតាំងឡើងជាសុចរិត ២៧ឯឪពុកដើម[ព]
របស់ឯង បានធ្វើបាប ហើយពួកគ្រូឯង[ភ] បានរំលងច្បាប់[ម]
អញដែរ ២៨ហេតុនោះ អញបានបន្ទាបពួកមេនៃទីបរិសុទ្ធ
ក៏បានប្រគល់ពួកយ៉ាកុបទៅឱ្យត្រូវបណ្តាសា[យ] ហើយឱ្យពួក
អ៊ីស្រាអែលត្រូវគេត្មះតិះដៀល[រ] ។

**ពួកអ៊ីស្រាអែល ជាពួករើសតាំង**

**៤៤** ១ប៉ុន្តែ ឱពួកយ៉ាកុប ជាអ្នកបំរើអញ[ក] ហើយពួក
អ៊ីស្រាអែល ដែលអញបានជ្រើសរើសអើយ[ខ] ចូរស្តាប់
ឥឡូវចុះ ២ព្រះយេហូវ៉ាដែលទ្រង់បានបង្កើតឯងមក ហើយ
បានជបសូន[គ]ឯងចាប់តាំងពីនៅក្នុងផ្ទៃម្តាយ[ឃ] គឺជាអ្នក
ដែលនឹងជួយ[ង]ឯង ទ្រង់មានបន្ទូលដូច្នេះថា ឱពួកយ៉ាកុប ជា
អ្នកបំរើអញ[ច] ហើយឯងដែរ យេស៊ូរ៉ុន[ឆ]ដែលអញបានរើស
អើយ កុំឱ្យខ្លាចឡើយ[ជ] ៣ដ្បិតអញនឹងចាក់ទឹក[ឈ]ទៅលើអ្នក
ណាដែលកំពុងស្រេក ព្រមទាំងបង្ហូរទឹកទៅលើដីហួត
ហែងផង[ញ] អញនឹងចាក់វិញ្ញាណ[ដ]អញទៅលើពូជពង្ស
របស់ឯង ហើយពរ[ឋ]របស់អញ ទៅលើកូនចៅរបស់ឯង[ឌ]
៤នោះគេនឹងពន្លកឡើងនៅក្នុងស្មៅ[ឍ] ដូចជាដើមចាក[ណ]តាម
មាត់ទឹក[ត] ៥អ្នក១នឹងថា ខ្ញុំនេះជារបស់ផង[ថ]ព្រះយេហូវ៉ា
ម្នាក់ទៀតនឹងហៅខ្លួនតាមឈ្មោះយ៉ាកុប ឯម្នាក់១ទៀតនឹង
ចុះឈ្មោះដោយដៃខ្លួនថា[ទ] ខ្ញុំជារបស់ផងព្រះយេហូវ៉ា[ធ]
ហើយនឹងយកឈ្មោះអ៊ីស្រាអែលជានាមត្រកូលរបស់ខ្លួន ។

**៤៣:២២** ច អស ៣០:១១ **៤៣:២៣** ឆ នក ២៩:៤១ ជ សក ៧:៥–៦ មឡ ១:៦–៨ ឈ អម ៥:២៥ ញ មី ៦:៣ មឡ ១:១២–១៣ ដ យស ៧:២២ ឋ នក ៣០:៣៥ លវ ២:១ **៤៣:២៤** ឌ នក ២០:២៣ ឍ លវ ៣:៩ ណ អស ១:១៤ ៧:១៣ យរ ៨:២១ ត យរ ៤៤:២២ មឡ ២:១៧ **៤៣:២៥** ថ ២សយ ១២:១៣ ២រប ៦:២១ មក ២:៧ លក ៥:២១ កច ៣:១៩ ទ អស ៣៧:៣៥ អគ ២០:៤៤ ធ អស ៦៤:៩ មីក ៧:១៨ ន យប ៧:២១ អស ៣៨:១៧ **៤៣:២៦** ប អស ១:១៨ ផ អស ៤១:១ ៤៩:២៥ ៥០:៨ **៤៣:២៧** ព លប ១២:១៨ ភ អស ៩:១៥ ២៨:៧ យរ ៥:៣១ ម អស ២៤:២០ ៤៨:៨ **៤៣:២៨** យ ជន ៥:២៧ ចទ ១៣:១៥ អស ៤២:២៤ សក ៥:៣ រ ទដ ៣៩:៨ យរ ២៤:៩ អគ ៥:១៥ **៤៤:១** ក ខ.២១ ខ លប ១៦:១១ អស ១៤:១ **៤៤:២** គ ខ.២១ ទដ ១៤៩:២ ឃ លប ២:៧ ទដ ១៣៩:១៣ អស ២៧:១១ ង អស ៤១:១០ ច អស ៤៣:៥ ឆ យរ ៣០:១០ ៤៦:២៧ ជ ជន ២៣:២១ ចទ ៣២:១៥ **៤៤:៣** ឈ យអ ៣:១៨ យហ ៤:១០ ញ សភ ៩:៥ អស ៣២:២ ៣៥:៧ ដ អស ១១:២ អគ ៣៦:២៧ មក ១:៨ កច ២:១៧ ឋ មឡ ៣:១០ ឌ អស ៦១:៩ ៦៥:២៣ **៤៤:៤** ឍ យប ៥:២៥ ទដ ៧២:១៦ ណ លវ ២៣:៤០ ត យប ៤០:២២ **៤៤:៥** ថ ទដ ១១៦:១៦ អស ១៩:២១ យរ ៥០:៥ ទ នក ១៣:៩ ធ អស ៦០:៣ ៦៦:២៣ សក ៨:២០–២២ ១៣:៩ ១៤:១៦

របស់ពួកគេមានភាពស្មោកស្មើរក្នុងចិត្ត គឺមិនដោយអស់ពីចិត្ត (ក៏ខុសនឹង ៦៩:៣) ។

**៤៣:២៣** *មិនបានផ្ទុកឯងដោយដង្វាយ ឬឱ្យឯងនឿយហត់ដោយ* គឺព្រះអម្ចាស់មិនបានបង្ខំរាស្ត្ររបស់ទ្រង់ហួសប្រមាណទេ ។

**៤៣:២៤** *គ្រឿងក្រអូប* ក៏មានដូចជាធូប (សូមមើល ខ.២៣) ក៏សូមមើលក្នុង ៤:១៤ យរ ៦:២០ ។ *ខ្លាញ់* សូមមើលការពន្យល់ ៣៤:៦ ។

**៤៣:២៥** *លុបអំពើរំលង* គឺមិនត្រឹមតែទ្រង់មិនបានដាក់ទណ្ឌកម្មទេតែទ្រង់បានលើកលែងទោសនូវអំពើរំលងទាំងឡាយរបស់រាស្ត្រផងទ្រង់ (ខ.២៨) (ក៏សូមមើល ១:១៨ ៤៤:២២–២៣ ៤០:២ និងការពន្យល់) ។

**៤៣:២៦** *រាប់រៀបប្រាប់ពីហេតុផល* គឺព្រះយេហូវ៉ាបានប្រមូលរាស្ត្រអ៊ីស្រាអែលដើម្បីជំនុំជម្រះ ដូមកាលទ្រង់ជំនុំជម្រះដល់ជាតិសាសន៍មួយចំនួនដែលចែងក្នុង ៤១:២១–២២ ។

**៤៣:២៧** *ឪពុកដើមរបស់ឯង* (១).ដូមជាលោកអ័ដាមជាឪពុកដំបូង (សូមមើល ៥:៣ និងការពន្យល់ ក៏សូមមើលការពន្យល់ លក ៣:២៣–៣៨) ឬក៏ (២).អ័ប្រាហាំគឺជាឪពុកដ៏មានការទាក់ទង សូមមើល ៥១:២ ឬក៏ (៣).យ៉ាកុបក៏ជាឪពុកផងដែរ ប្រៀបធៀប ខ.២២,២៨ ។ គេទាំងអស់គ្នាជាអ្នកមានបាបហើយ ចំណុចសំខាន់ចំពោះមនុស្សជំនាននេះដែលមានបាបគឺដូចជាពួកសង្ឃនិងពួកហោរា ។

**៤៣:២៨** *ត្រូវបណ្តាសា . . . ត្មះតិះដៀល* សូមមើលការពន្យល់ ៣៤:២ ។ មានទីក្រុងជាច្រើនរបស់ស្រុកអ៊ីស្រាអែលក៏បែរទៅរកការថ្វាយបង្គំរូបព្រះ (ចទ ១៣:១២–១៥) ។ ដែលជាហេតុនាំឱ្យក្រុងយេរូសាឡិមទទួលការខូចខាតឈឺចាប់ដោយដៃរបស់ពួកទាហានបាប៊ីឡូន(២ពវ ២៥:៨–៩) គឺដោយព្រោះពួកគេថ្វាយបង្គំរូបព្រះ (សូមមើល អគ ៧:១៥–២២) ។

**៤៤:១–២** *ជាអ្នកបំរើអញ* សូមមើល ៤១:៨–៩ និងការពន្យល់ ។

**៤៤:២** *បានបង្កើតឯងមក* សូមមើល ៤៣:១ និងការពន្យល់ ។ ពាក្យថា *នៅក្នុងផ្ទៃម្តាយ* សូមមើល ខ.២៤ គឺជាភាពទន់សន្តោសនៃព្រះដែលបានបង្កើត ក៏មានការបង្ហាញក្នុងអត្ថបទ (៤៩:៥ យរ ១:៥ និងការពន្យល់) ។ *កុំឱ្យខ្លាចឡើយ* សូមមើល ខ.៨ ៤១:១០ និងការពន្យល់ ។ ពាក្យថា *យេស៊ូរុន* គឺជារាស្ត្រអ៊ីស្រាអែល (មើល ខ.១) ក៏ពុំឃើញឈ្មោះច្រើនទេគឺមានក្នុង ចទ ៣២:១៥ តែប៉ុណ្ណោះ(សូមមើលការពន្យល់ក្នុងគម្ពីរនោះ) ៣៣:៥,២៦ ។

**៤៤:៣** *ចាក់ទឹក . . . បង្ហូរ* សូមមើល ៣០:២៥ ៣៥:៦–៧ និងការពន្យល់ ៤១:១៨ ។ ពាក្យថា *ចាក់ព្រះវិញ្ញាណអញ* គឺទាក់ទងទៅនិងយុគ្គសម័យព្រះមែស៊ី សូមមើលក្នុង ៣២:១៥ យអ ២:២៨ (សូមមើលការពន្យល់ជំពូកនោះផងដែ ក៏សូមមើលការពន្យល់ សក ១២:១០) ។

**៤៤:៤** *ស្មៅ* គឺបង្ហាញពីប្រភពសុខសាន្តនាតំបន់នោះ ក៏សូមមើល ៣៥:៧ (ផ្ទុយនិងអត្ថបទ ៣៧:២៧ ៤០:៦–៨) ។

**៤៤:៥** *នឹងហៅខ្លួនតាម . . . ឈ្មោះ* គឺជាព្រះទ័យរបស់ផងទ្រង់ក្នុងការហៅរាស្ត្ររបស់ទ្រង់ដែលទ្រង់បានរើសមក សូមមើល ៤៣:៧ និងការពន្យល់ ។

### គឺព្រះអម្ចាស់ មិនមែនរូបព្រះទេ

៦ព្រះយេហូវ៉ា ដ៏ជាមហាក្សត្រ[ន]នៃសាសន៍អ៊ីស្រាអែល
ហើយជាអ្នកដែលប្រោសលោះគេ[ប] គឺព្រះយេហូវ៉ានៃពួក
ពលបរិវារ ទ្រង់មានបន្ទូលដូច្នេះថា អញជាដើម ហើយជា
ចុង[ផ] ក្រៅពីអញគ្មានព្រះណាទៀតឡើយ[ព] ៧តើមានអ្នកណា
ដូចអញ[ភ] ចូរឱ្យគេប្រកាសខ្លួនមក ហើយសំដែងភស្តុតាង
ឱ្យច្បាស់ចុះ រួចរាប់រៀបប្រាប់ឱ្យអញស្តាប់ពីអ្វីៗដែលបាន
កើតឡើង តាំងតែពីអញបានតាំងមនុស្សឡើង ពីកាលដើម
ព្រមទាំងអ្វីៗ ដែលកំពុងតែកើត នឹងអ្វីៗដែលត្រូវកើតមក
ទៅមុខទៀត ចូរឱ្យគេប្រាប់[ម]មកចុះ ៨កុំឱ្យភ័យឡើយ ក៏កុំ
ឱ្យខ្លាចដែរ តើអញមិនបានប្រាប់[យ] ហើយបង្ហាញដល់ឯង
តាំងតែពីដើមមកទេឬ គឺឯងរាល់គ្នាជាស្មរបន្ទាល់របស់
អញ តើមានព្រះណា[រ]ក្រៅពីអញឬទេ អើ គ្មានថ្មដាណា
ទៀតឡើយ[ល] អញមិនស្គាល់ណាមួយសោះ ។
៩ពួកអ្នកដែលឆ្លាក់ធ្វើរូបព្រះ[វ] គេសុទ្ធតែអសារឥតការ
ទាំងអស់[ស] ហើយរបស់ទាំងប៉ុន្មានដែលគេចូលចិត្តនោះ ក៏
គ្មានប្រយោជន៍ដូចគ្នា[ហ] ស្មរបន្ទាល់របស់គេមើលមិនឃើញ
ក៏មិនដឹងអ្វីផង ជាការដែលនាំឱ្យគេត្រូវមានសេចក្តីខ្មាស[ឡ]
១០តើអ្នកណានឹងសូនធ្វើព្រះ[អ] ឬសិតធ្វើរូបដែលឥតមាន
ប្រយោជន៍ដូច្នេះ[ក] ១១មើល ពួកអ្នកដែលគោរពតាម នឹង
ត្រូវខ្មាសទាំងអស់ដែរ[ខ] ហើយពួកជាង នោះគ្រាន់តែជា
មនុស្សប៉ុណ្ណោះ ឱ្យគេប្រជុំគ្នា រួចឈរឡើងចុះ គេនឹងត្រូវ
ភ័យ ហើយមានសេចក្តីខ្មាសទាំងអស់គ្នា[គ] ។

**៤៤:៦** ន អស ៤១:២១ ប យប ១៩:២៥ អស ៤៣:១ ផ អស ៤១:៤ វវ ១:៨,១៧ ព ចទ ៦:៤ ១រប ១៧:២០ ទដ ១៨:៣១ អស ៤៣:១០ **៤៤:៧** ភ ចទ ៣២:៣៩ ម អស ៤១:២២,២៦ **៤៤:៨** យ អស ៤០:២១ ៤២:៩ រ អស ៤៣:១០ ល លប ៤៩:២៤ **៤៤:៩** វ នក ២០:៤ លវ ១៩:៤ អស ៤០:១៩ ស អស ៤១:២៤ ហ អស ២៦:១១ ឡ អស ១:២៩ ៦៥:១៣ ៦៦:៥ យរ ២២:២២ **៤៤:១០** អ អស ៤០:១៩ ក អស ៤១:២៩ យរ ១០:៥ កច ១៩:២៦ **៤៤:១១** ខ ខ.៩ អស ១:២៩ គ ២ពវ ១៩:១៨ អស ៣៧:១៩

១២ឯជាងដែក[ឃ] គាត់ធ្វើពូថៅ១ គាត់ធ្វើការដោយ
ធ្យូង គាត់យកញញួរដំឡើងជារាង ទាំងធ្វើការដោយ
ដើមដៃដ៏មានកំឡាំងរបស់ខ្លួន[ង] អើ គាត់ឃ្លាន ហើយ
អស់កំឡាំង គាត់មិនបានផឹកទឹក ហើយក៏ហេវទៅ[ច] ១៣ឯ
ជាងឈើ[ឆ]គាត់វាយបន្ទាត់ ក៏គូររាងដោយខ្មៅដៃ គាត់
ឈូសយករាង ហើយគូសដោយប្រពាយ រួចឆ្លាក់ឱ្យដូច
ជារូបមនុស្ស[ជ] តាមលំអរបស់មនុស្ស ដើម្បីនឹងតាំងនៅក្នុង
ផ្ទះ[ឈ] ១៤គាត់កាប់ដើមតាត្រៅ១ ក៏យកដើមចន្ទន៍ ក្រឹស្នា
នឹងដើមម៉ៃសាក់ គឺគាត់រើសយកតែឈើណាដែលជាប់ៗ
នៅក្នុងព្រៃ ឬគាត់ដាំដើមខ្ទារ[ញ]ដែលដុះលាស់ឡើងដោយ
សារទឹកភ្លៀង ១៥ទាំងអស់នេះមានប្រយោជន៍ដល់មនុស្ស
សំរាប់ធ្វើឧសដុត[ដ] គេក៏យកខ្លះមកដុតអាំង អើ ក៏យកខ្លះ
បង្កាត់ភ្លើងដុតនំបុ័ង អើ ក៏ធ្វើព្រះ១ឡើង រួចក្រាបថ្វាយ
បង្គំ[ឋ] គឺគាត់ឆ្លាក់ធ្វើជារូប ហើយក្រាបចុះគោរព[ឌ]ដល់រូប
នោះ ១៦ដូច្នេះ គាត់យកខ្លះធ្វើឧសដុត ខ្លះទៀតដុតធ្វើម្ហូប
គឺគាត់អាំងសាច់ ហើយស៊ីឆ្អែត អើ គាត់កំដៅខ្លួនដែរ
ដោយពោលថា អែយ៉ា ក្តៅស្រួលហ្ន៎ ខ្ញុំអាំងភ្លើង ហើយ[ឍ]
១៧ឯឈើដែលសល់ នោះគាត់យកទៅធ្វើជារូបឆ្លាក់សំរាប់
ខ្លួន ក៏ក្រាបចុះថ្វាយបង្គំ[ណ] ហើយអធិស្ឋាន[ត]ដល់រូបនោះ

**៤៤:១២** ឃ អស ៤០:១៩ ៤១:៦–៧ ៥៤:១៦ ង កច ១៧:២៩ ច អស ៤០:២៨ **៤៤:១៣** ឆ អស ៤១:៧ ជ ទដ ១១៥:៤–៧ ឈ ពច ១៧:៤–៥ **៤៤:១៤** ញ អស ៤១:១៩ **៤៤:១៥** ដ ខ.១៩ ឋ នក ២០:៥ វវ ៩:២០ ឌ ២រប ២៥:១៤ **៤៤:១៦** ឍ អស ៤៧:១៤ **៤៤:១៧** ណ នក ២០:៥ អស ២:៨ យរ ១:១៦ ត ១ពវ ១៨:២៦

---

*ចុះឈ្មោះដោយដៃខ្លួនថា* គឺលក្ខណៈកត់សំគាល់ ពីភាពជាម្ចាស់កម្មសិទ្ធ (ប្រៀបធៀប ៤៩:១៦ វវ ១៣:១៦) (ប្រៀបធៀប នក ១៣:៩,១៦) ។

**៤៤:៦** *មហាក្សត្រ* សូមមើល ៤៣:១៥ និងការពន្យល់ ។ ពាក្យថា *អ្នកដែលប្រោសលោះគេ* សូមមើល ខ.២៤ ៤១:១៤ និងការពន្យល់ ។ ពាក្យថា *ជាដើម . . . ជាចុង* សូមមើល ៤១:៤ និងការពន្យល់ ។ *ក្រៅពីអញ . . . គ្មានព្រះណាទៀតឡើយ* សូមមើល ៤៣:១១ នក ២០:៣ និងការពន្យល់ ។

**៤៤:៧** *ចូរឱ្យគេប្រាប់ចុះ* សូមមើល ៤១:២២,២៦ និងការពន្យល់ ។

**៤៤:៨** *គឺឯងរាល់គ្នាជាស្មរបន្ទាល់របស់អញ* សូមមើល ៤៣:១០ និងការពន្យល់ ។ ពាក្យថា *ថ្មដា* សូមមើល ១៧:១០ និងការពន្យល់ ។ ដូចជាក្នុង ខ.២ ៤៣:១១–១៣ ដូចជារាស្ត្រអ៊ីស្រាអែល បានលើកយកបទទំនុកមួយរបស់លោកម៉ូសេ ដែលបានពណ៌នាពីព្រះអម្ចាស់ "ដែលមានសណ្ឋានជា" ថ្មដា (ចទ ៣២:៤,១៥,៣០–៣១) ក៏ប៉ុន្តែមានការប្រៀបធៀបជាលក្ខណៈធម្មតាក្នុងគម្ពីរ ទំនុកដំកើង (សូមមើល ទដ ១៨:២) ។

**៤៤:៩–២០** ខទាំងនេះបង្ហាញពីការដៀលត្មេះរបស់អ្នកនិពន្ធ ចំពោះភាពខ្វះខាតចំពោះការគោរពរូបព្រះ (សូមមើល ៤០:១៨–២០ និងការពន្យល់) ។

**៤៤:៩** *អាសារឥតការទាំងអស់* គឺដូចជាជាតិសាសន៍មួយចំនួននិងរូបព្រះរបស់ពួកគេ ។ (សូមមើល ៤០:១៧ ៤១:២៤ និងការពន្យល់) ។ *សេចក្តីខ្មាស* ប្រៀបធៀប ខ.១១ ៤២:១៧ ៤៥:១៦ ។

**៤៤:១១** *ពួកជាង* សូមមើល ៤០:១៩ និងការពន្យល់ ។

**៤៤:១២–១៣** *ពួកជាង . . . ជាងដែក* សូមមើល ៤៨:៥ ។

**៤៤:១២** *ក៏ហេវទៅ* តែព្រះអម្ចាស់មិនដែលនឿយហត់ទេ (៤០:២៨) ។

**៤៤:១៣** *ឱ្យដូចជារូបមនុស្ស* ដោយសាររូបមនុស្សបាបបង្កើតឡើង គឺមានសណ្ឋានដូចជាអង្គទ្រង់ (សូមមើល លប ១:២៦–២៧ និងការពន្យល់) ឯរូបព្រះធ្វើឡើងក៏មានសណ្ឋានដូចពួករូបព្រះនោះដែរ (មើល លប ១:២៦–២៧ និងការពន្យល់) (សូមមើល ចទ ៤:១៦ រម ១:២៣ និងការពន្យល់) ។

**៤៤:១៤** *ដើមតាត្រៅ . . . ដើមចន្ទន៍ . . . ម៉ៃសាក់* គឺជាប្រភេទឈើដ៏មានតម្លៃក៏ឃើញក្នុង ២:១៣ ៩:១០ ១៤:៨ និងការពន្យល់ ។

**៤៤:១៥** *ក្រាបថ្វាយបង្គំ . . . ក្រាបចុះគោរព* ក្នុង ខ.១៧,១៩ សូមមើល ២:៨,២០ ។

**៤៤:១៦** *អាំងសាច់ . . . ខ្ញុំអាំងភ្លើង* (សូមមើល ខ.១៩) ។

**៤៤:១៧** *សង្គ្រោះខ្ញុំ* គឺជាសម្តីរបស់ស្តេចអ័ហាស៊ីយ៉ាក៏បានកាត់ទោសដោយសារតែថ្វាយបង្គំរូបព្រះនៃពួកសាន់អេដំម គឺជាជាតិសាសន៍បានចាកចេញក្នុងចំបាំង (សូមមើលការពន្យល់ ២រប ២៥:១៤–២៥) ។ គឺលោកអេសាយបានបង្ហាញពីអ្នកដែលបានថ្វាយបង្គំរូបព្រះ ហើយពួកគេរវល់តែគិតធ្វើរូប

ដោយពាក្យថា សូមជួយសង្គ្រោះ[ឋ]ខ្ញុំផង ពីព្រោះលោកជា
ព្រះនៃខ្ញុំ ។
១៨ពួកនោះមិនដឹងទេ ក៏មិនយល់[ទ]សោះ ដ្បិតភ្នែក[ធ]
គេត្រូវបាំងមិនឱ្យមើលឃើញ ហើយចិត្តគេផង ដើម្បីមិន
ឱ្យយល់បាន ១៩គ្មានអ្នកណាមួយនឹកឃើញ គេឥតមាន
ដំរិះ ឬយោបល់នឹងនឹក[ន]ថា ខ្លះបានយកទៅដុតហើយ[ប] ខ្លះ
ប្រើយករងើកដុតធ្វើនំបុ័ង អើ អញបានអាំងសាច់ស៊ីផង
ដូច្នេះ ឈើដែលសល់នៅ តើនឹងយកទៅធ្វើជារបស់គួរ
ស្អប់ខ្ពើមឬ[ផ] តើគួរឱ្យអញក្រាបចុះចំពោះដុំឈើឬអី[ព] ២០អ្នក
នោះស៊ីតែផេះទទេ[ភ] ចិត្តដែលត្រូវបញ្ឆោត[ម]បាននាំគេឱ្យ
វង្វេងអ្នកនោះនឹងដោះព្រលឹងខ្លួនឱ្យរួចមិនបាន ក៏មិនចេះ
ថា ខ្ញុំកាន់របស់ភូតភរនៅដៃស្តាំទេតើនោះឡើយ[យ,រ] ។
២១ឱពួកយ៉ាកុបនឹងពួកអ៊ីស្រាអែលអើយ[ល] ចូរនឹកចាំ[វ]
ពីសេចក្តីទាំងនេះចុះ ដ្បិតឯងជាអ្នកបំរើរបស់អញ[ស] អញ
បានសូនបង្កើតឯង ដូច្នេះ ឯងជាអ្នកបំរើរបស់អញ ឱពួក
អ៊ីស្រាអែលអើយ អញនឹងមិនភ្លេចឯងឡើយ[ហ] ២២អញ
បានលុប[ឡ]អំពើរំលងរបស់ឯងចេញ ដូចជាពពកយ៉ាង
ក្រាស់ និងអំពើបាបឯងដូចជាពពកផង ចូរវិលមក[អ]ឯអញ
វិញ ពីព្រោះអញបានលោះ[ក]ឯងហើយ ២៣ឱផ្ទៃមេឃអើយ
ចូរច្រៀងឡើង[ខ] ដ្បិតព្រះយេហូវ៉ាបានសំរេចការហើយ ឱ
ផែនដី[គ]ដ៏ទាបអើយ ចូរស្រែកឡើង ឱភ្នំទាំងឡាយ[ឃ] ឱព្រៃ
និងអស់ទាំងដើមឈើក្នុងព្រៃអើយ[ង] ចូរធ្លាយចេញជាបទ
ចំរៀងចុះ ពីព្រោះព្រះយេហូវ៉ាទ្រង់បានប្រោសលោះ[ច]
ពួកយ៉ាកុបទាំងអស់ហើយ ទ្រង់នឹងដំកើង[ឆ]អង្គទ្រង់នៅក្នុង
ពួកអ៊ីស្រាអែលផង ។

## ទីក្រុងយេរូសាឡិមត្រូវតាំងជាលំនៅ

២៤ព្រះយេហូវ៉ា ជាព្រះដែលប្រោសលោះឯង[ជ] គឺជា
ព្រះដែលជប់សូន[ឈ]ឯង តាំងពីនៅក្នុងផ្ទៃម្តាយ[ញ] ទ្រង់មាន
បន្ទូលដូច្នេះថា អញជាយេហូវ៉ា ជាព្រះដែលបង្កើតរបស់
សព្វសារពើ អញលាតសន្ធឹងផ្ទៃមេឃតែម្នាក់ឯង[ដ] ហើយ
បានក្រាលផែនដី[ឋ]ដោយខ្លួនអញ ២៥អញលើកទីសំគាល់[ឌ]
របស់ពួកមនុស្សភូតភរចោលចេញ ហើយក៏ធ្វើឱ្យគ្រូទាយ
ទៅជាឆ្កួត[ឍ] ជាពួកអ្នកដែលបំបែរមនុស្សមានប្រាជ្ញា[ណ]
ឱ្យវិលទៅក្រោយ ឱ្យចំណេះរបស់គេទៅជាល្ងីល្ងើវិញ[ត]
២៦អញបញ្ជាក់ពាក្យ[ថ]សំដីដែលនិយាយនឹងអញបំរើអញ
ហើយ សំរេចតាម[ទ]សេចក្តីប្រឹក្សារបស់ពួកអ្នក ដែលអញ
ចាត់ប្រើអញនិយាយពីក្រុងយេរូសាឡិម[ធ]ថា ទីក្រុងនោះនឹង

**៤៤:១៧** ឋ ពច ១០:១៤ អស ៤៥:២០ ៤៦:៧ ៤៧:១៥ **៤៤:១៨** ទ អស ១:៣ ១៦:១២ យរ ៤:២២ ១០:៨,១៤,១៤–១៥ ធ អស ៦:៩–១០ ២៩:១០ **៤៤:១៩** ន ខ.១៨–១៩ អស ៥:១៣ ២៧:១១ ៤៥:២០ ប ខ.១៥ ផ ចទ ២៧:១៥ ព អស ៤០:២០ **៤៤:២០** ភ ទដ ១០២:៩ ម យប ១៥:៣១ រម ១:២១–២៣,២៨ ២ថន ២:១១ ២ធថ ៣:១៣ យ ចទ ៤:២៨ ហស ១០:៥ ១៣:២ រ អស ៥៩:៣,៤,១៣ យរ ៩:៣ ១០:១៤ ៥១:១៧ រម ១:២៥ **៤៤:២១** ល អស ៤៣:១ វ អស ៤៦:៨ សក ១០:៩ ស ទដ ១៣៦:២២ អស ២៧:១១ ហ ទដ ២៧:១០ អស ៤៩:១៥ យរ ៣១:២០ **៤៤:២២** ឡ ២សយ ១២:១៣ ២កថ ៦:២១ កច ៣:១៩ អ យប ២២:២៣ អស ៤៥:២២ ៥៥:៧ យរ ៣៦:៣ មឡ ៣:៧ ក អស ៣៣:២៤ មថ ២០:២៨ ១កថ ៦:២០ **៤៤:២៣** ខ ទដ ៩៨:៤ អស ១២:៦ គ ១កថ ១៦:៣១ ទដ ១៤៨:៧ ឃ ទដ ៩៨:៨ ង ទដ ៦៥:១៣ ច នក ៦:៦ អស ៥១:១១ ៦២:១២ ឆ នក ១៦:៧ លវ ១០:៣ អស ៤:២ ៤៣:៧ ៤៦:១៣ ៤៩:៣ ៥២:១ ៥៥:៥ ៦០:៩,២១ ៦១:៣ យរ ៣០:១៩ **៤៤:២៤** ជ យប ១៩:២៥ អស ៤៣:១៤ ឈ អស ២៧:១១ ញ ទដ ១៣៩:១៣ ដ លប ២:១ អស ៤២:៥ ឋ លប ១:១ **៤៤:២៥** ឌ ទដ ៣៣:១០ ឍ លវ ១៩:២៦ ១សយ ៦:២ អស ២:៦ ៨:១៩ ៤៧:១៣ យរ ២៧:៩ ដយ ២:២,១០ ៤:៧ មីក ៣:៧ សក ១០:២ ណ យប ៥:១៣ ១កថ ១:២៧ ត ២សយ ១៥:៣១ ១កថ ១:១៩–២០ **៤៤:២៦** ថ អស ៥៩:២១ សក ១:៦ ទ អស ៤៦:១០ ៥៥:១១ យរ ២៣:២០ ៣៩:១៦ បទ ២:១៧ ដយ ៩:១២ មថ ៥:១៨ ប អស ១:១ ធ ទដ ៧៤:៣ អស ៥១:៣

ព្រះដើម្បីថ្វាយបង្គំ (សូមមើល ៤៥:២០) (ខ.១៩) ។
**៤៤:១៨** *ដ្បិតភ្នែកគេត្រូវបាំងមិនឱ្យមើលឃើញ* គឺជាលក្ខខ័ណ្ឌជីវិតរបស់រាស្ត្រអ៊ីស្រាអែលក្នុង ៦:៩–១០ (សូមមើលការពន្យល់ផងដែរ) ។ ឃ្លាពិពណ៌នាខាងលើគឺសំដៅទៅលើរូបព្រះ និងពួកអ្នកដែលថ្វាយបង្គំរូបព្រះ សូមមើល ទដ ៨២:៥ និងការពន្យល់ ។
**៤៤:១៩** *ជារបស់គួរស្អប់ខ្ពើម* គឺជាការដែលព្រះយេហូវ៉ាស្អប់ខ្ពើមចំពោះរូបព្រះ (សូមមើល ២៧:១៥) ។ ក្នុង ១ពវ ១១:៥,៧ ២ពវ ២៣:១៣ ។ ដូចជាព្រះម៉ូឡុក និងព្រះកេម៉ូស ដែលជាព្រះគួរឱ្យស្អប់ខ្ពើម ។ ចំណែកឯអ្នកដែលថ្វាយបង្គំរូបព្រះក៏ត្រូវហៅថាជាអ្នកគួរឱ្យស្អប់ខ្ពើមដែរ (សូមមើល ៤១:២៤ និងការពន្យល់) ។
**៤៤:២០** *អ្នកនោះស៊ីតែផេះទទេ* សូមមើលការប្រៀបធៀប ហស ១២:១ ។ *ភូតភរ* សូមមើល ២ថន ២:១១ និងការពន្យល់ ។
**៤៤:២១** *អ្នកបំរើរបស់អញ* សូមមើល ខ.១–២ ៤១:៨–៩ និងការពន្យល់ ។
**៤៤:២២** *លុបអំពើរំលងរបស់ឯងចេញ* សូមមើលក្នុង ៤០:២ (សូមមើលការពន្យល់ក្នុងជិពូកនោះ) ការឈឺចាប់របស់រាស្ត្រអ៊ីស្រាអែលបាននាំមកការត្រួសត្រាយផ្លូវឱ្យមានការសង្គ្រោះ និងឱ្យមានជាតិសាសន៍អ៊ីស្រាអែលឡើងវិញ (សូមមើល ៤៣:២៥ និងការពន្យល់) ។ ពាក្យថា *ចូរវិលមកឯអញវិញ* សូមមើលការប្រៀបធៀប យរ ៣១:១៨ សក ៣១:១៨ សក ១:៣ នឹងការពន្យល់។ ពាក្យថា *បានលោះ* សូមប្រៀបធៀប ខ.២៣ សូមមើលការពន្យល់ ៣៥:១៩ ៤១:១៤ ៤៣:១ ។
**៤៤:២៣** *ច្រៀងឡើង . . . ចូរស្រែកឡើង* គឺជាការត្រាស់ហៅដើម្បីច្រៀងសរសើរដោយក្តីអំណរ (សូមមើល ៣៥:១ ៤៩:១៣) ។ ពាក្យថា "*ចូរស្រែកឡើង*"*ឱភ្នំទាំងឡាយ* សូមមើល ៤៩:១៣ ៥៥:១២ ៤០:៥ នឹងការពន្យល់។
**៤៤:២៤** *ព្រះដែលប្រោះលោះឯង* សូមមើល ៤១:១៤ និងការពន្យល់ ។ និងសូមមើល ៤០:២២ នឹងការពន្យល់សូមមើលការប្រៀបធៀប ៥១:១៣ ។
**៤៤:២៥** *ទីសំគាល់របស់ពួកមនុស្សភូតភរ* សូមមើល ចទ ១៣:១–៥ និងការពន្យល់ ។ ពាក្យថា *គ្រូទាយទៅជាឆ្កួត* គឺក្នុងព្រះគម្ពីរភាសាហេព្រើរ គឺសំដៅទៅលើលោកបាឡាមជាកូនបេអ៊ រ (មើល យស ១៣:២២ និងការពន្យល់) គឺជាគ្រូខាបកាថានៅឯស្រុក អេន–ដោរ (មើល ១សយ ២៨:៨) និងហោរាខ្លែងក្លាយ(សូមមើល យរ ២៧:៩ និងការពន្យល់) ។ ពាក្យថា *បំបែរមនុស្ស មានប្រាជ្ញាចំណេះ* គឺសូមមើល ២៩:១៤ និងការពន្យល់ ។
**៤៤:២៦** *អ្នកដែលអញចាក់ . . . អ្នកបំរើអ្នក* គឺសំដៅទៅលើពួកហោរាពិតប្រាកដ (សូមមើល ៤២:១៩ យរ ៧:២៥ និងការពន្យល់) ។ ពាក្យថា *មនុស្សអាស្រ័យនៅ . . . បានសង់ឡើង* គឺសូមមើល យរ ៣២:១៥ ប្រៀបធៀប អស

មានមនុស្សអាស្រ័យនៅ ហើយនិយាយពីអស់ទាំងទីក្រុងនៃ
ស្រុកយូដាថា ទីក្រុងទាំងនោះនឹងបានសង់ឡើងវិញ អញ
នឹងលើកអស់ទាំងទីបាក់បែក[ន]នោះឡើង[ប] ២៧អញក៏បង្គាប់
ដល់ទីជំរៅថា ចូរឱ្យរីងស្ងួតទៅ[ផ] ហើយអញនឹងធ្វើឱ្យទន្លេ
ទាំងប៉ុន្មានរហួតហៀវទៅដែរ ២៨អញនិយាយពីស៊ីរូស[ព]ថា
ជាអ្នកគង្វាលរបស់អញ ជាអ្នកដែលនឹងសំរេចតាមបំណង
ចិត្តអញទាំងប៉ុន្មាន ហើយបង្គាប់ឱ្យក្រុងយេរូសាឡិម[ភ]បាន
សង់ឡើងវិញ និងឱ្យជើងជញ្ជាំង[ម]នៃព្រះវិហារ[យ]បានដាក់
ចុះ។

**៤៥** ១ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដល់ស៊ីរូស[ក] ដែល
ទ្រង់បានចាក់ប្រេងតាំងឡើង[ខ] ហើយជាអ្នកដែលទ្រង់កាន់[គ]
ដៃស្តាំ ដើម្បីឱ្យបានបង្ក្រាប[ឃ]អស់ទាំងសាសន៍នៅមុខខ្លួន
ហើយនិងបន្ធូរចង្កេះពួកស្តេច ព្រមទាំងបើកទ្វារនៅមុខ
ខ្លួន រួចទ្វារទាំងនោះនឹងមិនត្រូវបិទវិញឡើយ ២គឺមាន
បន្ទូលដូច្នេះថា អញនឹងដើរទៅខាងមុខឯង[ង] ហើយនឹង
ពង្រាប[ច]អស់ទាំងទីរដិបរដុបឱ្យស្មើ អញនឹងបំបែកអស់ទាំង
ទ្វារ[ឆ]លង្ហិនឱ្យខ្ទេចខ្ទី ហើយនឹងបំបាក់រនុកដែកដែរ[ជ] ៣អញ
នឹងឱ្យឃ្លាំងលាក់កំបាំង និងទ្រព្យសម្បត្តិ[ឈ]ដែលកប់ទុក
ដល់ឯង[ញ] ដើម្បីឱ្យឯងបានដឹង[ដ]ថា អញនេះ គឺយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែល ដែលហៅឯងតាមឈ្មោះ[ឋ]
៤អញបានហៅឯងតាមឈ្មោះឯងនេះ ដោយយល់ដល់ពួក
យ៉ាកុបជាអ្នកបំរើអញ[ឌ] និងអ៊ីស្រាអែល ជាអ្នកដែលអញ
បានជ្រើសរើស អញបានកំណត់នាមត្រកូលដល់ឯងហើយ
ទោះបើឯងមិនបានស្គាល់[ឍ]អញក៏ដោយ ៥អញនេះជា
យេហូវ៉ា គ្មានព្រះណាដទៃទៀតឡើយ[ណ] ក្រៅពីអញឥតមានព្រះ
ណាទៀតសោះ[ត] អញនឹងក្រវាត់ឱ្យឯង[ថ] ទោះបើឯងមិន
ស្គាល់អញក៏ដោយ ៦ដើម្បីឱ្យមនុស្សទាំងឡាយ ចាប់តាំងពី
ទិសខាងថ្ងៃរះរហូតដល់ទិសខាងថ្ងៃលិច[ទ] បានដឹង[ធ]ថា
ក្រៅពីអញ[ន] គ្មានព្រះណាផ្សេងទៀតឡើង គឺអញនេះជា
យេហូវ៉ា ឥតមានព្រះណាទៀតសោះ ៧គឺអញដែលបង្កើត
ពន្លឺ ហើយក៏ធ្វើឱ្យមានងងឹតផង[ប] អញធ្វើឱ្យមានសន្តិសុខ
ហើយឱ្យមានសេចក្តីវេទនាដែរ[ផ] គឺអញនេះហើយ ជា
យេហូវ៉ាដែលធ្វើគ្រប់ការទាំងនេះ ។
៨ឱផ្ទៃមេឃអើយ ចូរស្រក់ទឹក[ព]ពីលើមក ហើយឱ្យ

**៤៤:២៦** ន អរ ៩:៩ ទដ ៥១:១៨ អស ៤៩:៨-២១ ៦១:៤ **៤៤:២៧** ប អស ១១:១៥ ១៩:៥ វវ ១៦:១២ **៤៤:២៨** ផ ២របា ៣៦:២២ អស ៤១:២ ព អស ១៤:៣២ ភ អរ ១:២-៤ ម អស ២៨:១៦ ៥៨:១២ **៤៥:១** ក ២របា ៣៦:២២ អស ៤១:២ ខ ទដ ៤៥:៧ គ ទដ ៧៣:២៣ អស ៤១:១៣ ៤២:៦ ឃ អស ៤៨:១៤ យរ ៥០:៣៥ ៥១:២០,២៤ មីក ៤:១៣ **៤៥:២** ង នក ២៣:២០ ច អស ៤០:៤ ឆ អស ១៣:២ ជ ទដ ១០៧:១៦ ១៤៧:១៣ យរ ៥១:៣០

បទ ២:៩ ណាហ ៣:១៣ **៤៥:៣** ឈ ២ពវ ២៤:១៣ យរ ៥០:៣៧ ៥១:១៣ ញ យរ ៤១:៨ ដ អស ៤១:២៣ ឋ នក ៣៣:១២ អស ៤៣:១ **៤៥:៤** ឌ អស ១៤:១ ៤១:៨-៩ ឍ កច ១៧:២៣ **៤៥:៥** ណ អស ៤៤:៨ ត ចទ ៣២:១២ ទដ ១៨:៣១ អស ៤៣:១០ ថ ទដ ១៨:៣៩ អគ ៣០:២៤-២៥ **៤៥:៦** ទ ទដ ១១៣:៣ អស ៤៣:៥ ធ អស ១១:៩ ន ខ.៥,១៨ អស ១៤:១៣-១៤ ៤៧:៨,១០ សផ ២:១៥ **៤៥:៧** ប លប ១:៤ នក ១០:២២ ផ អស ១៤:១៥ ៣១:២ បទ ៣:៣៨ **៤៥:៨** ព ទដ ៧២:៦ ១៣៣:៣ យអ ៣:១៨

៥៨:១២ ៦១:៤ ។ *ទីបាក់បែក . . . នោះឡើង* គឺផ្ទុយនឹង ៦:១១ ។

**៤៤:២៧** *ចូរឱ្យរីងស្ងួតទៅ* គឺនិយាយសំដៅទៅលើការឆ្លងកាត់សមុទ្រក្រហម (សូមមើល ១១:១៥ ៣៧:២៥ ៤៣:១៦-១៧ និងការពន្យល់ប្រៀបធៀបនឹង ៥០:២ ៥១:១០) ។

**៤៤:២៨** *ស៊ីរូស* សូមមើល ៤១:២ និងការពន្យល់ ។ *ជាអ្នកគង្វាល* គឺរឿយៗ គឺសំដៅទៅលើអ្នកដឹកនាំ (សូមមើល ២សយ ៥:២ យរ ២៣:២) ។ ពាក្យថា *ក្រុងយេរូសាឡិម . . . ព្រះវិហារ* គឺជាការចេញក្រិតច្បាប់របស់ស្តេចស៊ីរូស ដែលបញ្ជាឱ្យសាងសង់ព្រះវិហារឡើងវិញ ដែលសំដៅទៅលើការរៀបចំឱ្យមានក្រុងយេរូសាឡិមឡើងវិញ ។

**៤៥:១** *ចាក់ប្រេងតាំង* "ជាព្រះមែស៊ី" ដែលយកចេញពីព្រះកម្ពីរភាសាហេព្រើរ ។ ស្តេចស៊ីរូស គឺជាព្រះចៅអធិរាជនៃប្រទេសក្រៅបានហៅនាមដែលបានចាក់ប្រេងតាំងបែបនេះថា ជា"អ្នកគង្វាលរបស់អញ"(៤៤:២៨) ដោយព្រោះព្រះបានចាត់គាត់ឱ្យបំពេញការងារ ជាអ្នកតំណាងស្ថានសួគ៌ក្នុងតួនាទីជាព្រះមហាក្សត្រ ។ ស្តេចនេប៊ូក្នេសាក៏បានហៅនាមនេះស្រដៀងៗគ្នាដែរគឺគាត់ហៅថា"អ្នកបំរើអញ" (សូមមើល យរ ២៥:៩ និងការពន្យល់ ២៧:៦ ៤៣:១០) ។ ពាក្យថាអ្នកបម្រើ ក៏ដូចជាព្រះគ្រីស្ទ (សូមមើលការពន្យល់ ៤២:១-៤) ក៏បានហៅម្យ៉ាងទៀតថា"អ្នកដែលបានចាកប្រេងតាំង" មើលក្នុង ដយ ៩:២៥-២៦ (សូមមើលការពន្យល់ ។ ពាក្យថា *កាន់ដៃស្តាំ ដើម្បីឱ្យ បានបង្ក្រាប* សូមមើល ៤១:១៣ និងការពន្យល់ ។

**៤៥:២** *ទាំងទ្វារលង្ហិនឱ្យ . . . បាក់រនុកដែកដែរ* តាមធម្មតាគឺជាទ្វាររបស់ទីក្រុងដែលបានធ្វើពីឈើនិងបន្ទះរនុកធ្វើពីដែក (សូមមើល ពច ១៦:៣ និងការពន្យល់) ។

**៤៥:៣** *ដើម្បីឱ្យឯងបានដឹង* គឺជាសកម្មភាពរបស់ព្រះអម្ចាស់ ដែលបើកសម្តែងពីអំណាចព្រះចេស្តា (ប្រៀបធៀប អគ ៦:៧ ៧:២៧) ។ *ដែលហៅឯងតាមឈ្មោះ* គឺបញ្ជាក់ពីការគ្រប់គ្រងរបស់ព្រះអម្ចាស់ចំពោះសកម្មភាពពួកសាសន៍ស៊ីរូស ។ សូមមើល ខ.៤ ក៏សូមមើលការពន្យល់ ៤៣:១ ។

**៤៥:៤** *អ្នកបំរើអញ* សូមមើល ៤១:៨-៩ និងការពន្យល់ ។ ពាក្យថា *ជ្រើសរើស* គឺអាចជាអ្នកដែលព្រះយេហូវ៉ាបាន "ចាក់ប្រេងតាំង" (ខ.១) ។ ពាក្យថា *ទោះបើឯងមិនស្គាល់អញក៏ដោយ* សូមមើល ខ.៥ គឺសំដៅលើពួកស្តេចសាសន៍ស៊ីរូស ក៏លេចឱ្យឃើញពីទង្វើដែលពួកគេបានថ្វាយបង្គំដល់អាទិទេពជារូបព្រះម៉ាដាក ក៏ជាព្រះអទិទេពដ៏ធំបំផុតរបស់ពួកបាប៊ីឡូន ។ ក្នុងគម្ពីរក៏សំដែងពីការដែលស្តេចអង្គនេះបានសរសើរដម្កើងដល់រូបព្រះនោះដែរ ។

**៤៥:៥** *អញនេះ . . . គ្មានព្រះណាដទៃឡើយ* សូមមើល ខ.៦,១៤,១៨,២១-២២ ៤៣:១១ និងការពន្យល់ ។

**៤៥:៦** *ពីទិសខាងថ្ងៃរះ . . . ខាងថ្ងៃលិច* គឺជាការសំគាល់ដល់ផែនដីទាំងមូល (សូមមើល មឡ ១:១១ និងការពន្យល់) ។

**៤៥:៧** *មានងងឹត . . . មានសេចក្តីវេទនា* គឺបង្ហាញពីភាពងងឹតដែលរុកគួនជាគ្រោះចង្រៃដល់ស្រុកអេស៊ីព្ទ (សូមមើល នក ១០:២១-២៣ ទដ ១០៥:២៨ ប្រៀបធៀបនឹង អស ៤៧:១១ អម ៣:៦) ។

ពពកចាក់សេចក្ដីសុចរិតចុះមក[ភ] ចូរឱ្យផែនដីហាឡើង ឱ្យ
បានបង្កើតផលជាសេចក្ដីសង្គ្រោះ[ម] ហើយឱ្យសេចក្ដីសុចរិត
ពន្លកឡើងជាមួយគ្នា ឯអញ គឺយេហូវ៉ា អញបានបង្កើត
សេចក្ដីនោះឡើង ។
៩ វេទនាដល់អ្នកណាដែលតតាំង[យ]នឹងព្រះ ដែលបាន
បង្កើតខ្លួនមក[រ] គេជាអំបែងឆ្នាំង[ល]១នៅក្នុងអស់ទាំងអំបែង
នៅលើផែនដី តើដីឥដ្ឋនឹងប្រកែកចំពោះជាងស្មូនថា[វ] តើ
ធ្វើអ្វីដូច្នេះ[ស] ឬការដែលឯងធ្វើនឹងហ៊ានថា គេគ្មានថ្វីដៃទេ
ឬអី[ហ] ១០ វេទនាដល់អ្នកណា ដែលសួរដល់ឪពុកថា តើបាន
បង្កើតអ្វីដូច្នេះ ឬដល់ម្ដាយខ្លួនថា តើបានសំរាលអ្វីមកយ៉ាង
នេះ ។
១១ ព្រះយេហូវ៉ា ជាព្រះដ៏បរិសុទ្ធ[ឡ]នៃពួកសាសន៍អ៊ីស្រា–
អែល គឺជាព្រះដែលបង្កើតគេមក[អ] ទ្រង់មានបន្ទូលដូច្នេះថា
ចូរសួរអញពីអស់ទាំងការដែលត្រូវមកខាងមុខ ចូរបង្គាប់
មកអញ ពីដំណើរកូនអញទាំងប៉ុន្មាន ហើយពីដំណើរ
ការដែលដៃអញធ្វើផង[ក] ១២ អញបានរៀបចំផែនដី[ខ] ហើយ
បង្កើតមនុស្សឱ្យអាស្រ័យនៅ គឺដៃអញដែលបានលាតផ្ទៃ
មេឃ[គ] ហើយអញបានបង្គាប់ដល់អស់ទាំងពលបរិវារ
ដែលនៅលើស្ថាននោះដែរ[ឃ] ១៣ អញបានលើកសិរូស[ង]
នេះឡើង ដោយសេចក្ដីសុចរិត អញនឹងធ្វើឱ្យគ្រប់ទាំងផ្លូវ
របស់គេបានត្រង់[ច] គេនឹងសង់ទីក្រុង[ឆ]របស់អញឡើង
ហើយនឹងលែងពួកបំបរបង់របស់អញឱ្យវិលមកវិញ មិន
មែនដោយទទួលថ្លៃលោះ ឬរង្វាន់ណាទេ[ជ] នេះជាព្រះ
បន្ទូលរបស់ព្រះ យេហូវ៉ានៃពួកពលបរិវារ ។
១៤ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា កំរៃនៃស្រុក
អេស៊ីព្ទ ហើយផល[ឈ]ចំរើននៃពួកអេធីយ៉ូពី និងពួកសេបា[ញ]
ជាមនុស្សមានមាឌធំ នោះនឹងមកឯឯង[ដ] ហើយខ្លួនគេនឹង
បានជារបស់ផងឯងដែរ គេនឹងដើរតាមក្រោយឯង[ឋ] គេនឹង
ឆ្លងមកទាំងជាប់ច្រវាក់[ឌ] ហើយទំលាក់ខ្លួនក្រាបចុះអង្វរ[ឍ]
ចំពោះឯង ដោយពាក្យថា ព្រះទ្រង់គង់ជាមួយនឹងលោកជា
ពិត[ណ] គ្មានព្រះឯណាទៀតក្រៅពីទ្រង់ឡើយ[ត] ១៥ ឱព្រះនៃ
សាសន៍អ៊ីស្រាអែល ជាព្រះដ៏ជួយសង្គ្រោះ[ថ]អើយ ប្រាកដជា
ទ្រង់ជាព្រះដែលពួន[ទ]អង្គ ១៦ ឯអស់ពួកអ្នកដែលធ្វើរូបព្រះ
គេនឹងត្រូវខ្មាស[ធ] ហើយជ្រប់មុខទាំងអស់គ្នា គេនឹងត្រូវគ្រប
ឃ្លុប ដោយសេចក្ដីអៀនខ្មាសទាំងអស់គ្នា ១៧ តែព្រះយេហូ–
វ៉ាទ្រង់នឹងជួយសង្គ្រោះ[ន]សាសន៍អ៊ីស្រាអែលឱ្យរួច ដោយ
សេចក្ដីសង្គ្រោះដ៏ស្ថិតស្ថេរអស់កល្បជានិច្ច[ប] ឯងរាល់គ្នានឹង
មិនត្រូវខ្មាស ឬជ្រប់មុខ[ផ]ដរាបដល់អស់កល្បតរៀងទៅ ។

**៤៥:៨** ភ ឧ.២៤ ទដ ៨៥:១១ អស ៤១:២ ៤៦:១៣ ៤៨:១៨ ៦០:២១ ៦១:១០,១១ ៦២:១ ហស ១០:១២ យអ ២:២៣ អម ៥:២៤ មឡ ៤:២ ម ទដ ៨៥:៩ អស ១២:៣ **៤៥:៩** យ យប ១២:១៣ ១៥:២៥ ២៧:២ ១កថ ១០:២២ រ យប ៣៣:១៣ ល ទដ ២២:១៥ វ អស ២៩:១៦ រម ៩:២០–២១ ស យប ៩:១២ ដយ ៤:៣៥ ហ អស ១០:១៥ **៤៥:១១** ឡ អស ១:៤ អ ទដ ១៤៩:២ អស ៥១:១៣ ក ទដ ៨:៦ អស ១៩:២៥ **៤៥:១២** ខ លប ១:១ គ លប ២:១ អស ៤៨:១៣ ឃ នហ ៩:៦ យប ៣៨:៣២ **៤៥:១៣** ង ២របា ៣៦:២២ អស ៤១:២ ច ១ពវ ៨:៣៦ ទដ ២៦:១២ អស ៤០:៤ ឆ អស ១:២ ជ អស ៥២:៣ **៤៥:១៤** ឈ ២សយ ៨:២ អស ១៨:៧ ៦០:៥ ញ អស ២:៣ ៦០:១១ ៦២:២ សក ៨:២០–២២ ដ អស ២:៣ ឋ លប ២៧:២៩ ឌ ២សយ ៣:៣៤ អស ១៤:១–២ ឍ យរ ១៦:១៩ សក ៨:២០–២៣ ណ ១កថ ១៤:២៥ ត ទដ ១៨:៣១ អស ១១:៩ ៤៣:១០ **៤៥:១៥** ថ អស ២៥:៩ ទ ចទ ៣១:១៧ ទដ ៤៤:២៤ អស ១:១៥ **៤៥:១៦** ធ ទដ ៣៥:៤ អស ១:២៩ **៤៥:១៧** ន យរ ២៣:៦ ៣៣:១៦ រម ១១:២៦ ប អស ១២:២ ផ លប ៣០:២៣ អស ២៩:២២ ៤១:១១

**៤៥:៨** *ស្រក់ទឹកពីលើ . . . ពពកចាក់សេចក្ដីសុចរិត* គឺជារូបភាពបង្ហាញពីភាពមានជាបរិបូរ (សូមមើល ហស ១០:១២ និងការពន្យល់) ។ *សេចក្ដីសុចរិត* មើលក្នុង ឧ.១៣ ៤១:២ ដូចជាពួកសិរូសក៏បានបង្ហាញក្នុងការទំនាក់ទំនងជាមួយភាពសុចរិតរបស់ព្រះអម្ចាស់ ។ ព្រះបានបង្កើតវត្ថុមកមានលក្ខណៈត្រឹមត្រូវតាមរយៈស្ដេចពើស៊ី ។ *សេចក្ដីសង្គ្រោះពន្លកឡើង* គឺជាការដែលព្រះអម្ចាស់រំដោះរាស្ត្ររបស់ផងទ្រង់ឱ្យរួចខ្លួនវិញ ។ *សេចក្ដីសុចរិតពន្លកឡើង* គឺជាការបើកសម្ដែងឱ្យឃើញពីភាពសុខសាន្ត និងយុត្តិធម៌ (ប្រៀបធៀប ១១:៤) ។
**៤៥:៩** *ដីឥដ្ឋនឹងប្រកែកចំពោះជាងស្មូន* សូមមើល ២៩:១៦ និងការពន្យល់ ប្រៀបធៀបនឹង ៦៤:៨ យរ ១៨:៦ មើល រម ៩:២០–២១ និងការពន្យល់ ។
**៤៥:១១** *ជាព្រះដ៏បរិសុទ្ធនៃពួកសាសន៍អ៊ីស្រាអែល* មើល ១:៤ និងការពន្យល់ ។ *កូនអញទាំង . . . ដៃអញធ្វើផង* មើល ២៩:២៣ និងការពន្យល់ ។
**៤៥:១២** *បានលាក់ផ្ទៃមេឃ* សូមមើល ៤០:២២ និងការពន្យល់ក៏សូមមើល ៤០:២៦ និងការពន្យល់ ។
**៤៥:១៣** *អញបានលើកសិរូសនេះឡើងដោយសេចក្ដីសុចរិត* សូមមើលការពន្យល់ ៤១:២ ។ *អញធ្វើឱ្យគ្រប់ទាំងផ្លូវរបស់គេបានត្រង់* គឺទ្រង់ធ្វើឱ្យគេបានដល់ទិសដៅគេកំណត់ (មើល ឧ.២ ក៏មើល ៤០:៣ និងការពន្យល់) ។ (ប្រៀបធៀប សភ ៣:៦ និងការពន្យល់) ។ ពាក្យថា *សង់ទីក្រុងអញឡើងវិញ* សូមមើលការពន្យល់ ៤៤:២៨ ។ ពាក្យថា *មិនមែនដោយទទួលថ្លៃលោះ* គឺសំដៅលើការមិនទទួលប្រាក់ទៀតទេ នៅពេលទ្រង់បានលាក់ពួកគេ (សូមមើល ៥២:៣) ។
**៤៥:១៤** *កំរៃនៃ . . . ផលចំរើន* សូមមើល ១៨:៧ និងការពន្យល់ ។ សូមមើលការពន្យល់ ១៨:១ ៤៣:៣ ។ *នោះមកឯងហើយ . . . គេនឹងដើរតាមក្រោយឯង* សូមមើល ទដ ៦៨:៣១ គឺជាពេលអនាគតរបស់រាស្ត្រអ៊ីស្រាអែល មានអំណាចគ្រប់គ្រងលើសត្រូវតាំងពីដើមរបស់គេ ក៏បានប្រាប់ក្នុង ១១:១៤ ១៤:១–២ (សូមមើលការពន្យល់ ១៤:១) ។ សូមមើលផ្ទៃរឿង ៤៩:២៣ ៥៤:៣ ៦០:១១–១៤ ។ *ព្រះទ្រង់គង់ជាមួយនឹងលោកជាពិត* គឺសង្ឃឹមថាថ្ងៃ ណាមួយគ្រប់ជាតិសាសន៍និងទទួលស្គាល់ព្រះនៃរាស្ត្រអ៊ីស្រាអែល (សូមមើល ឧ.២៣ ១៩:២៣,២៥ សក ៨:២០–២៨ និងការពន្យល់) ។
**៤៥:១៥** *ពួនអង្គ* គឺសកម្មភាពនិងផែនការរបស់ព្រះអម្ចាស់គឺមានលក្ខណៈអាថ៌កំបាំងចំពោះមនុស្សលោក ។ (ប្រៀបធៀប ៥៤:៨ ៥៥:៨–៩) ។ *ព្រះដ៏ជួយសង្គ្រោះ* សូមមើល ឧ.២១ និងការពន្យល់ក្នុង ៤៣:៣ ។
**៤៥:១៦** *គេនិងត្រូវខ្មាស* សូមមើល ៤២:១៧ ៤៤:៩ ។
**៤៥:១៧** *សេចក្ដីសង្គ្រោះដ៏ស្ថិតស្ថេរអស់កល្បជានិច្ច* សូមប្រៀបធៀប និងពាក្យ "ដោយសេចក្ដីសប្បុរសដ៏នៅអស់កល្បជានិច្ច" ដែលនៅក្នុង ៥៤:៨ ។ ពាក្យថា *មិនត្រូវខ្មាស* សូមមើល ២៩:២២ និងការពន្យល់ ។

[១៨]ដ្បិតព្រះយេហូវ៉ាដែលបានបង្កើតផ្ទៃមេឃ ជាព្រះ
ដែលទ្រង់សូនធ្វើហើយប្រតិស្ឋានផែនដី[ព] ក៏តាំងឡើង មិន
មែនបង្កើតមកឱ្យនៅទទេទេ[ភ] គឺបានជបសូនបង្កើតឱ្យជាទី
អាស្រ័យនៅ[ម] ទ្រង់មានបន្ទូលដូច្នេះថា គឺអញនេះជា
យេហូវ៉ា ឥតមានព្រះឯណាទៀតឡើយ[យ] [១៩]អញមិនបាន
ពោលដោយសំងាត់[រ] ក្នុងទីងងឹតនៅផែនដីទេ[ល] អញមិន
បានបង្គាប់ដល់ពូជពង្សនៃយ៉ាកុបថា[វ] ចូរខំស្វែងរក[ស]អញ
ដោយពោលជាឥតប្រយោជន៍នោះទេ គឺអញ ព្រះយេហូវ៉ា
នេះ អញនិយាយតាមសុចរិត អញថ្លែងប្រាប់សេចក្ដីដែល
ត្រឹមត្រូវ[ហ]។
[២០]ពួកអ្នកដែលរួចពីសាសន៍ដទៃអើយ ចូរមូលមក[ឡ]
ហើយចូលឱ្យជិតចុះ ពួកអ្នកដែលលើកយក[អ]ដុំឈើជារូប
ព្រះឆ្លាក់របស់គេទៅ ហើយអធិស្ឋានដល់ព្រះដែលជួយ
សង្គ្រោះខ្លួនមិនបាន[ក] នោះជាអ្នកអាប់ឥតប្រាជ្ញា[ខ]ទេ [២១]ចូរ
ថ្លែងប្រាប់ ហើយសំដែងហេតុចេញចុះ ត្រូវឱ្យប្រឹក្សាគ្នា
ផង តើអ្នកណាបានប្រាប់[គ]ពីការនេះ ចាប់តាំងពីចាស់
បុរាណមក[ឃ] តើអ្នកណាបានទាយទុក តាំងពីយូរមកហើយ
តើមិនមែនអញ[ង] ជាយេហូវ៉ា ទេឬអី ក្រៅពីអញ គ្មានព្រះឯ
ណាទៀត ដែលជាព្រះសុចរិត[ច]ហើយជាព្រះអង្គសង្គ្រោះ[ឆ]
ទេ គ្មានណាមួយក្រៅពីអញឡើយ [២២]អស់ទាំងមនុស្សនៅ
ចុងផែនដីអើយ ចូរមើលមក[ជ]អញ ហើយទទួលសេចក្ដី
សង្គ្រោះចុះ[ឈ,ញ] ដ្បិតអញនេះជាព្រះ ឥតមានណាទៀត
ឡើយ[ដ] [២៣]អញបានស្បថដោយខ្លួនអញ[ឋ] ពាក្យនោះបាន
ចេញពីមាត់អញ ដោយសេចក្ដីសុចរិត[ឌ] ហើយ ក៏មិន
ដែលប្រែប្រួលដែរ[ឍ] គឺថាគ្រប់ទាំងជង្គង់នឹងលុតចុះនៅមុខ
អញ[ណ] ហើយគ្រប់ទាំងអណ្ដាតនឹងស្បថពីដំណើរអញថា[ត]
[២៤]សេចក្ដីសុចរិត[ថ] និងអានុភាព[ទ] នោះមាននៅក្នុងព្រះ
យេហូវ៉ាតែ១ទេ មនុស្សទាំងឡាយនឹងមកឯទ្រង់ ហើយអស់
អ្នកដែលបានក្ដៅក្រហាយនឹងទ្រង់ គេនឹងត្រូវខ្មាសវិញ[ធ]
[២៥]ឯអស់ទាំងពូជពង្ស[ន]នៃអ៊ីស្រាអែល នឹងបានសុចរិត[ប]
ក្នុងព្រះយេហូវ៉ា ហើយគេនឹងអួតសរសើរ[ផ]។

## ព្រះនៃក្រុងបាប៊ីឡូន

**៤៦** [១]ព្រះបាល[ក] ឱនចុះហើយ ព្រះនេបូរក៏កោងចុះដែរ
គេផ្ទុករូបព្រះនោះ[ខ] លើសត្វពាហនៈ និងលើគោ របស់
ទាំងនោះដែលឯងដឹក[គ]ទៅមក ជាបន្ទុកសង្កត់យ៉ាងធ្ងន់លើ
សត្វនឿយហត់ [២]វាឱនចុះ ក៏កោងចុះហើយ វាជួយបន្ទុក
របស់វាឱ្យរួចពុំបាន គឺទាំងខ្លួនវាក៏ត្រូវចាប់នាំទៅជា
ឈ្លើយដែរ[ឃ]។

**៤៥:១៨** ព លប ១:១ ភ លប ១:២ ម លប ១:២៦ យ ខ.៥ ចទ ៤:៣៥ **៤៥:១៩** រ អស ៤៨:១៦ ៦៥:៤ ល យរ ២:៣១ វ ខ.២៥ អស ៤១:៨ ៦៥:៩ យរ ៣១:៣៦ ស ចទ ៤:២៩ ២រប ១៥:២ ហ ចទ ៣០:១១ **៤៥:២០** ឡ អស ៤៣:៩ អ ទដ ១១៥:៧ អស ៤៦:១ យរ ១០:៥ ក ចទ ៣២:៣៧ អស ៤៤:១៧ ខ អស ៤៤:១៩ **៤៥:២១** គ អស ៤១:២២ ឃ អស ៤៦:១០ ង ខ.៥ ទដ ៤៦:១០ អស ៤៦:៩ មក ១២:៣២ ច ទដ ១១:៧ ឆ ទដ ៣:៨ អស ២៥:៩ **៤៥:២២** ជ អស ៤៤:២២ សក ១២:១០ ឈ ជន ២១:៨-៩ ២រប ២០:១២ ញ លប ៤៩:១០ អស ១១:៩,១២ ៤៩:៦,១២ ដ ហស ១៣:៤ **៤៥:២៣** ឋ លប ២២:១៦ អស ១៤:២៤ ឌ ចទ៣០:១១ ហព ៦:១៣ ឍ អស ៥៥:១១ ណ ខ.១៤ ត ទដ ៦៣:១១ អស ១៩:១៨ រម ១៤:១០ ភល ២:១០-១១ **៤៥:២៤** ថ ខ.៨ យរ ៣៣:១៦ ទ ចទ ៣៣:២៩ ទដ ១៨:៣៩ អស ៤០:២៦ ៦៣:១ ធ អស ៤១:១១ **៤៥:២៥** ន ខ.១៩ ប អស ៤:៣ ៤៩:៤ ផ អស ២៤:២៣ ៤១:១៦ **៤៦:១** ក អស ២១:៩ យរ ៥០:២ ៥១:៤៤ ខ ១សយ ៥:២ គ ខ.៧ អស ៤៥:២០**៤៦:២** ឃ ពច ១៨:១៧-១៨ ២សយ ៥:២១ យរ ៥១:៤៧

**៤៥:១៨** *បានបង្កើត . . . សូនធ្វើ* សូមមើល ៤០:២១-២២ និងការពន្យល់ ។ *នៅទទេ* ឬក៏"គ្មានរូបរាង្គ"(សូមមើល លប ១:២ និងការពន្យល់) ។ ពាក្យថា *បង្កើតឱ្យជាទីអាស្រ័យនៅ* គឺជាទឹកដីឬស្រុកបរិសុទ្ធតែឥឡូវនៅក៏ស្ថិតនៅទទេស្អាត (សូមមើល ៦:១១ យរ ៤:២៣-២៦) មិនយូប៉ុន្មាន ក៏មានមនុស្សតាំងទីលំនៅ (សូមមើល ៤៤:២៦,២៨) និងមានច្បាប់វិន័យឡើងវិញ ។

**៤៥:១៩** *ដោយសំងាត់ក្នុងទីងងឹត* ឃ្លានេះមានលក្ខណៈជាឃ្លានិយាយបញ្ឆៀង (ប្រឌិត) ចំផ្លូវដែលលួចលាក់ខុសច្បាប់នៃពួកគ្រូខាប់គាថា (សូមមើល ៨:១៩-២០ និងការពន្យល់២៩:៤) ។ ពាក្យថា *ចូរខំស្វែងរកអញដោយពោលជាឥតប្រយោជន៍នោះទេ* សូមប្រៀបធៀប យរ ២៩:១៣-១៤ ។

**៤៥:២០** *ជាអ្នកអាប់ឥតប្រាជ្ញា* សូមមើល ៤៤:១៧-១៨ និងការពន្យល់ ។

**៤៥:២១** *ថ្លែងប្រាប់ . . . សំដែងហេតុចេញ* សូមមើល ៤១:២១-២២ និងការពន្យល់ ។ ពាក្យថា *បានប្រាក់ពីការនេះតាំងពីយូរមកហើយ* សូមមើល ៤១:២៦ និងការពន្យល់ ។

**៤៥:២២** *ចូរមើលមកអញ . . . ទទួលសេចក្ដីសង្គ្រោះ* សូមមើល ៤៩:៦ និងការពន្យល់ ក៏សូមមើល ៥៥:៧ ។ ពាក្យថា *នៅចុងផែនដី* សូមមើល ១១:១២ និងការពន្យល់ ៤២:១០ ។

**៤៥:២៣** *អញបានស្បថដោយខ្លួនអញ* ឃ្លានេះក៏បានពន្យល់នៅក្នុង ហព ៦:១២ សូមមើល ៥៥:១០-១១ ។ ពាក្យថា *គ្រប់ទាំងជង្គង់នឹងលុតចុះ . . . គ្រប់ទាំងអណ្ដាតនឹងស្បថ* សូមមើល ខ.១៤ និងការពន្យល់ ។ លោកប៉ុលបានដកស្រង់នូវផ្នែកខ្លះៗ ចេញពីសម្ដីរបស់ លោកអេសាយ ដែលមានសរសេរនៅក្នុងគម្ពីរ រម ១៤:១១ និង ភល ២:១០-១១ គឺដើម្បីពណ៌នាពីតួនាទីដ៏ពិសេសដែលត្រូវតម្កើងឡើងនៃអង្គព្រះគ្រីស្ទ ។

**៤៥:១៤** *សេចក្ដីសុចរិត នឹងអនុភាព . . . ក្នុងព្រះយេហូវ៉ាតែ១ទេ* សូមមើល ខ.៥ និងការពន្យល់ ។

**៤៥:២៥** *អួតសរសើរ* ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះកិរិយាសព្ទនេះត្រូវគេប្រែសម្រួលពីន័យ "សេរីល្អ" ទៅជាមានន័យថា "ការអួតសរសើរ" សូមមើល ក្នុង ៤១:១៦ ។

**៤៦:១** *ព្រះបាល* ជារូបព្រះមួយអង្គដែលមួយទៀតហៅថា ព្រះម៉ាដាក់ គឺជាព្រះអតិទេពដ៏សំខាន់មួយ ជាព្រះអទិទេពដ៏ធំមួយរបស់ពួកសាសន៍បាប៊ីឡូន ។ ឯនាមឈ្មោះ "ព្រះបាល" គឺស្មើនិងភាសាកាណានដែលហៅថា "បាល" (Baal) ដែលមានន័យថា"ព្រះអម្ចាស់" ។ ពាក្យថា *ព្រះនេបូរ* គឺជាព្រះនៃការសិក្សានិងព្រះនៃការនិពន្ធ ដែលត្រូវជាព្រះបុត្រារបស់ព្រះម៉ាដាក់ ។

**៤៦:២** *ត្រូវចាប់នាំទៅជាឈ្លើយ* ក៏មានទាំងរូបព្រះបានចូលរួមជាមួយអ្នកថ្វាយបង្គំក្នុងការដែលគេចាប់នាំទៅ (សូមមើល យរ ៤៨:៧ និងការពន្យល់ ៤៩:៣ ហស ១០:៥ អម ១:១៥) ។

៣ឱពួកវង្សារបស់យ៉ាកុបអើយ និងអ្នករាល់គ្នាជា
សំណល់[ង]នៃវង្សាអ៊ីស្រាអែលដែរ ជាពួកដែលអញបាន
ទទួលជាបន្ទុកតាំងពីកំណើតឯង[ច] ហើយបានបី[ឆ]ឯងតាំងពី
ផ្ទៃម្ដាយមក[ជ] ចូរស្ដាប់[ឈ]អញចុះ ៤គឺអញនេះពិត រហូតដល់
ឯងចាស់ជរាផង[ញ] អញនឹងបីឯង[ដ] ដរាបដល់ឯងមានសក់ស
គឺអញបានបង្កើត ហើយអញនឹងទទួល[ឋ]ឯងជាបន្ទុក អើ
អញនឹងបី ហើយនឹងជួយឯងឱ្យរួចផង ៥តើឯងរាល់គ្នានឹង
ផ្ទៀបអញដូចជាអ្នកណា នឹងផ្ទឹមអញឱ្យស្មើនឹងអ្នកណា ឬ
ប្រៀបអញឱ្យបានដូចជាអ្នកណា[ឌ] ៦ឯពួកអ្នកដែលចាយ
មាសពីថង់ដោយឥតស្ដាយ ហើយថ្លឹងប្រាក់ដោយជញ្ជីង
គេជួលជាងមាស[ឍ] ជាងនោះក៏ធ្វើជាព្រះ១ឱ្យគេ រួចគេ
ទំលាក់ខ្លួនក្រាបចុះ ថ្វាយបង្គំចំពោះរូបនោះ[ណ] ៧គេ
លី[ត]យករូបនោះ ទៅដាក់លំទុកនៅទីកន្លែង ហើយរូបនោះ
ក៏ឈរនៅ ឥតឃ្លាតចេញទៅឯណាឡើយ[ថ] អើ ទោះបើអ្នក
ណាអំពាវនាវដល់រូបនោះ គង់តែមិនចេះតបឆ្លើយ[ទ] ឬជួយ
សង្គ្រោះ[ធ]ឱ្យរួចពីសេចក្ដីទុក្ខវេទនាទៅបានឡើយ ។
៨ចូរនឹកចាំ[ន]ពីសេចក្ដីនេះ ហើយសំដែងខ្លួនជាបុរស
ចុះ ម្នាលពួកសែយសាសន៍អើយ ចូរនឹកពីសេចក្ដីនេះនៅ
ក្នុងចិត្តឯងឡើងវិញ[ប] ៩ចូរនឹកចាំពីការដែលកន្លងទៅ
ហើយ[ផ] តាំងពីបុរាណ[ព] ដ្បិតអញនេះហើយជាព្រះ ឥតមាន
ណាទៀតឡើយ អញជាព្រះ ហើយគ្មានអ្នកណាដូចអញ
សោះ[ភ] ១០តាំងតែពីដើមដំបូង[ម] អញរមែងសំដែងប្រាប់ពី
ការដែលត្រូវមកខាងចុងបំផុត ហើយតាំងពីចាស់បុរាណ[យ]
ក៏ប្រាប់ពីការដែលមិនទាន់មានមកដែរ[រ] ដោយពាក្យថា
គំនិតសំរេចរបស់អញនឹងស្ថិតស្ថេរនៅ[ល] អញនឹងធ្វើតាម
បំណងចិត្តអញគ្រប់ប្រការ ១១អញបានហៅ[វ]ឥន្ទ្រី១មកពី
ទិសខាងកើត[ស] ជាមនុស្សដែលនឹងសំរេចតាមគំនិតរបស់
អញ ឱ្យមកពីស្រុកឆ្ងាយ អើ អញបានចេញវាចាហើយអញ
នឹងធ្វើឱ្យការនោះកើតឡើងផង អញបានគិតសំរេចស្រេច
ហើយ[ហ] អញនឹងធ្វើការនោះឯង[ឡ] ។
១២ឱពួកអ្នកមានចិត្តរឹង[អ] ដែលឃ្លាតឆ្ងាយពីសេចក្ដី
សុចរិតអើយ[ក] ចូរស្ដាប់[ខ]អញចុះ ១៣អញនាំសេចក្ដីសុចរិត[គ]
របស់អញមកជិត សេចក្ដីនោះនឹងមិននៅឆ្ងាយឡើយ ឯ
សេចក្ដីសង្គ្រោះ[ឃ]របស់អញ ក៏មិនបង្អង់ដែរ អញនឹង
តាំងសេចក្ដីសង្គ្រោះរបស់អញនៅក្រុងស៊ីយ៉ូន[ង] សំរាប់ពួក
អ៊ីស្រាអែល ដែលជាសិរីល្អ[ច]របស់អញ ។

### ការដួលចុះនៃក្រុងបាប៊ីឡូន

**៤៧** ១ឱនាងក្រមុំ ជាកូន[ក]នៃក្រុងបាប៊ីឡូនអើយ ចូរចុះ
មកអង្គុយនៅធូលីដី[ខ] ឱកូនស្រីនៃសាសន៍ខាល់ដេអើយ[គ]
ចូរអង្គុយនៅដី ឥតមានបល្ល័ង្កចុះ ដ្បិតគេនឹងលែងហៅ
ឯងថា ជាអ្នកល្វន់ល្វត ហើយទន់ភ្លន់ទៀត[ឃ] ២ចូរយក
ត្បាល់កិន[ង] ហើយកិនម្សៅទៅ[ច] ត្រូវឱ្យដោះស្បៃឯងចេញ[ឆ]
ហើយបកសំលៀកឯងចុះ[ជ] ចូរសើយសំពត់ឯងឡើងលុយ

**៤៦:៣** ង អស ១:៩ ច ទដ ១៣៩:១៣ អស ៤៤:២ ឆ ចទ ១:៣១ ទដ ២៨:៩ ជ ទដ ២២:១០ ឈ ខ.១២ អស ៤៨:១២ ៥១:១ **៤៦:៤** ញ ទដ ៧១:១៨ ដ ចទ ៣២:៣៩ អស ៤៣:១៣ ឋ ទដ ១៨:៣៥ ១១៩:១១៧ **៤៦:៥** ឌ នក ១៥:១១ យប ៤១:១០ អស ៤០:១៨,២៥ យរ ៤៩:១៩ **៤៦:៦** ឍ អស ៤០:១៩ ណ នក ២០:៥ អស ៤៤:១៧ ហស ១៣:២ **៤៦:៧** ត ខ.១ ថ ១សយ ៥:៣ អស ៤១:៧ ទ ១ពវ ១៨:២៦ ធ អស ៤៤:១៧ ៤៧:១៣ **៤៦:៨** ន អស ៤៤:២១ ប អស ១:២ **៤៦:៩** ផ អស ៤១:២២ ព ចទ ៣២:៧ ភ នក ៨:១០ អស ៤៥:៥,២១ មក ១២:៣២

**៤៦:១០** ម អស ៤១:៤ យ អស ៤៥:២១ រ អស ៤១:២២ ល សភ ១៩:២១ អស ៧:៧,៩ ៤៤:២៦ កច ៥:៣៩ អភ ១:១១ **៤៦:១១** វ ពច ៤:១០ អរ ១:២ ស អស ៨:៨ ហ អស ២៥:១ ឡ លប ៤១:២៥ យរ ៤៤:២៨ **៤៦:១២** អ នក ៣២:៩ អស ៩:៩ ក ទដ ១១៩:១៥០ អស ៤៨:១ យរ ២:៥ ខ ខ.៣ **៤៦:១៣** គ អស ១:២៦ ៤៥:៨ រម ៣:២១ ឃ ទដ ៨៥:៩ ង ទដ ៧៤:២ យអ ២:៣២ ច អស ៤៤:២៣ **៤៧:១** ក អស ២១:៩ ២៣:១២ ខ យប ២:១៣ អស ២៩:៤ គ ទដ ១៣៧:៨ យរ ៥០:៤២ ៥១:៣៣ សក ២:៧ ឃ ចទ ២៨:៥៦ **៤៧:២** ង នក ១១:៥ មថ ២៤:៤១ ច ពច ១៦:២១ ឆ លប ២៤:៦៥ ជ អស ៣២:១១

**៤៦:៣** *ជាសំណល់* គឺជាអ្នកសំណល់ (សូមមើល ១:៩ និងការពន្យល់) ។ *ជាពួកដែលអញបានទទួល . . . ពីកំណើត* មើល ៤៤:២ និងការពន្យល់ ។

**៤៦:៤** *ចាស់ជរាផង . . . ដរាបដល់ឯងមានសក់ស* សូមប្រៀបធៀប ទដ ៣៧:២៥ ។

**៦៤:៥–៧** សូមមើល ៤០:១៨–២០ និងការពន្យល់ ។

**៤៦:៦** *ទំលាក់ខ្លួនក្រាបចុះថ្វាយបង្គំចំពោះរូបនោះ* មើល ៤៤:១៥,១៧,១៩ ។

**៤៦:៧** *លីយក* សូមមើល ខ.១ ។ *មិនចេះតបឆ្លើយ . . . ឬជួយសង្គ្រោះ* សូមមើល ៤៤:១៧ និងការពន្យល់។

**៤៦:៨** *ពួកសែយសាសន៍* សូមមើល ១:២ និងការពន្យល់ប្រៀបធៀប ១:២០ ,២៣,២៨ ៣០:១ ៥៧:៤ ។

**៤៦:៩** *កាលដែលកន្លងទៅ* សូមមើល ៤១:២២ និងការពន្យល់ ។ *ឥតមានណាទៀតឡើយ* សូមមើល ៤៣:១១ និងការពន្យល់។

**៤៦:១០–១១** *បំណងចិត្តអញ* ជាពិសេសបំណងព្រះទ័យរបស់ព្រះអម្ចាស់និងជាផែនការដែលទាក់ទង ស្រុកបាប៊ីឡូននិង ស្រុកអ៊ីស្រាអែល (សូមមើល ៨:៩–១០ ១៤:២៤ ៤៨:១៤ និងការពន្យល់) ។ ប្រៀបធៀប ទដ ៣៣:១១ ។

**៤៦:១០** *តាំងតែពីដើមដំបូង* សូមមើល ៤១:២៦ និងការពន្យល់ ។

**៤៦:១១** *អញបានហៅឥន្ទ្រី . . . មកពីទិសខាងកើត* ជាស្ដេចស៊ីរូសនៃស្រុកពើស៊ី (សូមមើល ៤១:២ និងការពន្យល់) ។

**៤៦:១២** *អ្នកមានចិត្តរឹង* សូមមើល ខ.៨ ៤៨:៤ អគ ២:៤ ។

**៤៦:១៣** *សេចក្ដីសុចរិត* គឺមានភាពស្មើគ្នាចំពោះសេចក្ដីសង្គ្រោះ ។ សូមមើល ៤១:២ ៤៥:៨ និងការពន្យល់ ។ *សេចក្ដីសង្គ្រោះ* សូមមើលការពន្យល់ ៤៣:៣ ។ ពាក្យថា *ជាសិរីល្អ* សូមមើល ៣៥:២ ៤០:៥ និងការពន្យល់សូមមើល ៤៤:២៣ ៤៩:៣ ផងដែរ ។

**៤៧:១** *អង្គុយនៅធូលីដី . . . អង្គុយនៅដី* គឺជាសញ្ញាបង្ហាញពីការកាន់ទុក្ខ (សូមមើលការពន្យល់ ៣:២៦) ។ *ឱនាងក្រមុំជាកូននៃក្រុងបាប៊ីឡូនអើយ* ន័យនៃឃ្លានេះគឺចង់បង្ហាញពីលក្ខណៈសម្បត្តិ និងជាទំនៀមទំលាប់របស់ប្រជាជន ក្រុងបាប៊ីឡូន (សូមមើល ការពន្យល់ ២ពវ ១៩:២១) ។

**៤៧:២** *ត្បាល់កិនហើយកិនម្សៅទៅ* គឺជាការងារថោកទាបដែលទទួលបន្ទុកដោយពួកស្ត្រីៗ (សូមមើល នក ១១:៥ ពច ៩:៥៣ និងការពន្យល់) ។ ពាក្យថា *លុយកាត់ទន្លេទៅ* គឺប្រហែលជានៅតាមផ្លូវទៅទីបំបោះបង ។

កាត់ទន្លេទៅ ៣កាយអាក្រាត[ឈ]របស់ឯងនឹងត្រូវបើកចំហ
អើ គេនឹងឃើញកេរខ្មាស[ញ]ឯងផង អញនឹងសងសឹក[ដ] ឥត
ប្រណីដល់អ្នកណាឡើយ[ឋ] ៤ឯព្រះដែលប្រោសលោះយើង[ឌ]
ទ្រង់ព្រះនាម[ឍ]ជាព្រះយេហូវ៉ានៃពួកពលបរិវារ[ណ] គឺជា
ព្រះដ៏បរិសុទ្ធ[ត] នៃសាសន៍អ៊ីស្រាអែល ៥ឱកូនស្រីនៃពួក
ខាល់ដេ[ថ] អើយ ចូរឱ្យឯងអង្គុយស្ងៀម[ទ] ហើយចូលទៅឯ
ទីងងឹតចុះ[ធ] ដ្បិតគេនឹងលែងហៅឯងជាម្ចាស់[ន]នៃអស់ទាំង
សាសន៍ទៀត[ប] ៦អញបានក្រោធ[ផ]ចំពោះរាស្ត្ររបស់អញ ក៏
បានឱ្យមរដក អញត្រូវទាបចុះ[ព] ព្រមទាំងប្រគល់គេទៅក្នុង
កណ្ដាប់ដៃរបស់ឯង[ភ] ឯឯងមិនបានអាណិតមេត្តាដល់គេ
ទេ[ម]ឯងបានដាក់នឹមឯងទៅលើពួកចាស់ៗយ៉ាងធ្ងន់ ៧ហើយ
បានគិតថា ឯងនឹងធ្វើជាម្ចាស់[យ]ជាដរាបទៅ[រ] បានជាឯង
មិនបានយកចិត្តទុកដាក់នឹងសេចក្ដីទាំងនេះ ក៏មិនបានគិត[ល]
ដល់ចុងបំផុតដែរ[វ] ។
៨ដូច្នេះ ចូរស្ដាប់សេចក្ដីនេះឥឡូវ ឯងដែលអាល័យ
តែលេងសប្បាយ ហើយនៅដោយឥតកង្វល់[ស] ឯងនឹកក្នុង
ចិត្តថា គឺអញនេះហើយ ឥតមានអ្នកណាទៀតឡើយ[ហ] អញ
នឹងមិនដែលអង្គុយជាស្រីមេម៉ាយ[ឡ] ក៏មិនដែលស្គាល់ការ
ប្រាសចាកកូនឡើយ ៩តែសេចក្ដីទាំង២មុខនេះនឹងកើត
ដល់ឯងជា១រំពេច[អ] នៅថ្ងៃដដែល គឺទាំងការប្រាសចាក
កូន[ក] ហើយនៅជាមេម៉ាយផង[ខ] នោះនឹងកើតដល់ឯងពេញ
ទី ទោះបើឯងមានរបៀនជាច្រើន[គ] ហើយវេទមន្តជាបរិបូរ
យ៉ាងណាក៏ដោយ[ឃ] ១០ពីព្រោះឯងបានទុកចិត្ត[ង]នឹងអំពើ
កំណាចរបស់ឯង ឯងបានគិតថា គ្មានអ្នកណាឃើញឯង
ទេ[ច] ឯប្រាជ្ញា[ឆ] និងចំណេះរបស់ឯង នោះបានបង្ខូចចិត្ត[ជ]
ឯងហើយ ឯងបាននឹកក្នុងចិត្តថា គឺអញនេះហើយ ឥត
មានអ្នកណាទៀតឡើយ ១១ដោយហេតុនោះនឹងមានការ
អាក្រក់[ឈ]កើតដល់ឯង ដែលឯងនឹងមិនដឹងជាកើតមកពីណា
ផង ហើយនឹងមានសេចក្ដីវេទនាធ្លាក់មកលើឯង ដែល
ឯងនឹងបង្វែរចេញមិនបានឡើយ ក៏នឹងមានសេចក្ដីវិនាស
លោមកលើឯងភ្លាម[ញ] ជាសេចក្ដីដែលឯងនឹងមិនដែលបាន
ស្គាល់ឡើយ ។
១២ចូរឈរឡើងឥឡូវ ដោយពឹងដល់វេទមន្ត និង
របៀនរបស់ឯងដែលមានជាច្រើននោះ[ដ] ជាវិជ្ជាដែលឯង
បានខំប្រព្រឹត្តតាម តាំងតែពីក្មេងមក ហើយលមើលបើ
ឯងនឹងបានប្រយោជន៍ណាខ្លះ ឬបើឯងនឹងអាចឈ្នះបាន
១៣ឯងបានណាយចិត្តហើយ[ឋ] ដោយសេចក្ដីប្រឹក្សាដ៏បរិបូរ
របស់ឯង ចូរឱ្យពួកគ្រូទាយ[ឌ] ពួកគ្រូជតារាសី និងពួកគ្រូ
ទាយដោយខែពេញបូណ៌ ឈរឡើងឥឡូវ ហើយជួយ
សង្គ្រោះ[ឍ]ឯងឱ្យរួចពីការដែលត្រូវមកលើឯងចុះ ១៤មើល

**៤៧:៣** ឈ លប ២:២៥ អរ ១៦:៣៧ ណហ ៣:៥ ញ អស ២០:៤ ដ អស ១:២៤ ៣៤:៨ ឋ អស ១៣:១៨–១៩ **៤៧:៤** ឌ យប ១៩:២៥ ឍ អស ៤៨:២ យរ ៥០:៣៤ អម ៤:១៣ ណ អស ១៣:៤ ត អស ១:៤ ៤៨:១៧ **៤៧:៥** ថ អស ២១:៩ ទ យប ២:១៣ ធ អស ៩:២ ១៣:១០ ន ខ.៧ បទ ១:១ វវ ១៨:៧ ប អស ១៣:១៩ វវ ១៧:១៨ **៤៧:៦** ផ ២របា ២៨:៩ ព ចទ ១៣:១៥ អស ៤២:២៤ យរ ២:៧ ៥០:១១ ភ អស ១០:១៣ ម អស ១៤:៦ **៤៧:៧** យ ខ.៥ វវ ១៨:៧ រ អស ១០:១៣ ដយ ៤:៣០ ល អស ៤២:២៣,២៥ វ ចទ ៣២:២៩ **៤៧:៨** ស អស ៣២:៩ ហ អស ៤៥:៦ ឡ អស ៤៩:២១ ៥៤:៤ បទ១:១ វវ ១៨:៧ **៤៧:៩** អ ទដ ៥៥:១៥ ៧៣:១៩ ១ថន ៥:៣ វវ ១៨:៨–១០ ក អស ១៣:១៨ ខ អស ៤:១ យរ ១៥:៨ ១៩:២១ គ ខ.១២ ណហ ៣:៤ មឡ ៣:៥ ឃ ចទ ១៨:១០–១១ វវ ៩:២១ ១៨:២៣ **៤៧:១០** ង យប ១៥:៣១ ទដ ៥២:៧ ៦២:១០ ច ២ពវ ២១:១៦ អស ២៩:១៥ ឆ អស ៥:២១ ជ អស ៤៤:២០ **៤៧:១១** ឈ អស ១០:៣ ១៤:១៥ ២១:៩ ៣១:២ លក ១៧:២៧ ញ ទដ ៥៥:១៥ អស ១៧:១៤ ១ថន ៥:៣ **៤៧:១២** ដ ខ.៩ នក ៧:១១ **៤៧:១៣** ឋ អស ៥៧:១០ យរ ៥១:៥៨ ហព ២:១៣ ឌ អស ១៩:៣ ៤៤:២៥ ឍ ខ.១៥ អស ៥:២៩ ៤៣:១៣ ៤៦:៧

**៣៧:៣** *កាយអាក្រាតរបស់ឯងនឹងត្រូវបើកចំហរ* សូមមើល អគ ១៦:៣៦ ។ គឺក្រុងបាប៊ីឡូននិងពុំមានស្ដេចសោយរាជ្យទៀតឡើយ (សូមមើល ខ.៥,៧) គឺនាងជាក្សត្រីដែលកាត់បន្ថយពួកបម្រើស្រីៗ ឬក៏ពួកស្រីពេស្យាចារចោល (សូមមើល ខ.៨) ។ *សងសឹក* សូមមើល ៣៤:៨ និងការពន្យល់ ។ ពាក្យថា *ឥតប្រណីដល់អ្នកណា* សូមមើល ១៣:១៨–២០ ។

**៤៧:៤** *ប្រោសលោះ* សូមមើលការពន្យល់ ៤១:១៤ ។ *ព្រះយេហូវ៉ានៃពួកពលបរិវា* សូមមើល ១៣:៤ និងការពន្យល់ ។ ពាក្យថា *គឺជាព្រះបរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើល ១:៤ ៤១:១៤ និងការពន្យល់ ។

**៤៧:៥** *ឱកូនស្រីនៃពួកខាល់ដេអើយ* សូមមើលការពន្យល់ ខ.១ ។ *ម្ចាស់នៃអស់ទាំងសាសន៍* ដែលក្រុងបាប៊ីឡូនគឺជាទីក្រុងមួយដ៏ល្អ (សូមមើល ១៣:១៩ និងការពន្យល់) ។

**៤៧:៦** *អញបានក្រោធ . . . ក៏បានឱ្យមរដក* សូមមើល ១០:៥–៦ (គឺជាឧបករណ៍របស់ព្រះអាសស៊ើរ) ៤២:២៤ និងការពន្យល់ ៤៣:២៨ និងការពន្យល់ បទ ២:២ ។ ដោយពួកគេទទួលការឈឺចាប់ដោយបានសម្រេចតាមរយៈការបណ្ដាសា ដែលពួកគេពុំបានស្ដាប់បង្គាប់តាមសេចក្ដីសញ្ញារបស់ព្រះ (ចទ ២៨:៤៩–៥០) ។

**៤៧:៧** *ឯងនឹងធ្វើជាម្ចាស់ជាដរាបទៅ* សូមប្រៀបធៀប ពាក្យសំដីក្រអឺតក្រអោងរបស់ស្ដេចនេប៊ូក្នេសា សូមមើលក្នុង ដយ ៤:៣០ ។

**៤៧:៨,១០** *អញនេះហើយឥតមានអ្នកណាទៀតឡើយ* គឺជាការប្រកាសពីអំណាចចេស្ដារបស់ព្រះយេហូវ៉ានៃពួកពលបរិវា ហើយព្រះបន្ទូលនៃព្រះអម្ចាស់គឺក្នុង ៤៣:១១ ៤៥:៥–៦,១៨,២២ (ប្រៀបធៀបនឹង នក ៣:១៤–១៥ ២០:៣ ចទ ៦:៤ និងការពន្យល់ ។ មើល អស១៤:១២–១៥ និងការពន្យល់)។

**៤៧:៨** *ហើយនៅដោយឥតកង្វល់* គឺជាការប្រើភាសាដែលស្រដៀងគ្នានិងពួកស្ត្រីនៃក្រុងយេរូសាឡិមដែលពុំមានក្ដីកង្វល់សោះឡើយ មើលក្នុង ៣២:៩ ,១១,១៣,១៦,១៨ ១៤:២២ ។

**៤៧:៩,១២** *វេទមន្ត . . . វេទមន្ត* ការអនុវត្តវេទមន្តបែបនេះគឺដើម្បីការពារខ្លួនរបស់គេហើយធ្វើឱ្យសត្រូវរបស់គេឈឺចាប់វិញ (សូមមើល ៣:២–៣)។

**៤៧:១០** *គ្មានអ្នកណាឃើញឯងទេ* សូមមើល ២៩:១៥ ។

**៤៧:១៣** *ពួកគ្រូជតារាសី . . . នឹងពួកគ្រូទាយ* គឺជាសកម្មភាពពួកក្រុងបាប៊ីឡូនដែលប្រើប្រាស់ការនេះច្រើនជាងសាសន៍នានា (សូមមើល ដយ ២:២,១០) ។

គេនឹងបានដូចជាជញ្ជ្រាំង[ណ] ភ្លើងនឹងឆេះ[ត]គេអស់ទៅ គេ
នឹងដោះខ្លួនឱ្យរួចពីអំណាចភ្លើងមិនបាន[ថ] ភ្លើងនោះនឹងមិន
បានជារងើក ដែលគ្រាន់តែល្មមនឹងអាំងកំដៅខ្លួន ឬជា
ភ្លើងដែលនឹងអង្គុយជុំវិញប៉ុណ្ណោះទេ ១៥របស់ទាំងប៉ុន្មាន
ដែលឯងបានខំតាមនោះ នឹងបានដូច្នោះឯង ហើយពួកអ្នក
ដែលបានខំតាម[ទ]ជាមួយនឹងឯងតាំងតែពីក្មេងមក គេនឹង
ងេងងោងទៅតាមផ្លូវរបស់គេរៀងខ្លួន ហើយនឹងគ្មានអ្នក
ណាសំរាប់ជួយសង្គ្រោះ[ធ]ឯងឡើយ ។

## ពួកអ៊ីស្រាអែលរឹងចចេស

**៤៨** ១ចូរស្តាប់សេចក្តីនេះ ឱពួកវង្សយ៉ាកុបអើយ ជាពួក
អ្នកដែលបានហៅតាមឈ្មោះអ៊ីស្រាអែល[ក] ហើយបាន
ចេញពីទឹករបស់យូដាមក[ខ] ជាពួកអ្នកដែលស្បថ[គ] ដោយព្រះ
នាមព្រះយេហូវ៉ា[ឃ] ព្រមទាំងដំណាល[ង]ពីព្រះនៃសាសន៍
អ៊ីស្រាអែលផង តែមិនមែនដោយស្មោះ[ច]ចំពោះ ឬដោយ
សុចរិតទេ ២(ពីព្រោះគេហៅខ្លួន ជាអ្នកក្រុង[ឆ]បរិសុទ្ធ
ហើយផ្អែកទៅលើ[ជ]ព្រះនៃសាសន៍អ៊ីស្រាអែល ដែលព្រះ
នាមទ្រង់[ឈ] ជាព្រះយេហូវ៉ានៃពួកពលបរិវារ) ៣ឯការ
ដែលបានកើតឡើងតាំងតែពីដើមមក[ញ] នោះអញបានថ្លែង
ប្រាប់[ដ] ចាប់តាំងពីបុរាណហើយ អើ សេចក្តីនោះបានចេញ
ពីមាត់អញទៅ ហើយអញបានសំដែងច្បាស់ ឯការទាំង
នោះ អញបានធ្វើភ្លាម១រំពេច[ឋ] ដូច្នេះ ការទាំងនោះបាន
កើតឡើងហើយ ៤ដ្បិតអញបានដឹងថា ឯងជាមនុស្សរឹង
ចចេស[ឌ] ហើយមានក[ឍ]ដូចជាចំរឹតដែក ឯថ្ងាស[ណ]ឯងក៏ជា
លង្ហិន ៥ហេតុនោះបានជាអញថ្លែងប្រាប់[ត]សេចក្តីនោះ
ដល់ឯងតាំងពីបុរាណ ហើយបានបង្ហាញឱ្យឯងដឹងមុនដែល
ការនោះកើតមកផង ក្រែងឯងនិយាយថា គឺជារូបព្រះ
របស់ឯងដែលធ្វើការនោះវិញ[ថ] ហើយរូបឆ្លាក់ និងរូបសិត
របស់ឯង ដែលបង្គាប់ការនោះឡើង ៦ឯងបានឮហើយ
ចូរពិចារណាការទាំងនេះចុះ ឯឯងតើមិនព្រមថ្លែងប្រាប់
ដែរឬ ឥឡូវនេះអញបានបង្ហាញ ឱ្យឯងឃើញការថ្មីទៀត[ទ]
គឺជាការលាក់កំបាំងដែលឯងមិនបានស្គាល់ផង ៧ការទាំង
នោះទើបនឹងកើត[ធ]ឡើងឥឡូវ មិនមែនកាលពីបុរាណទេ[ន]
ហើយកាលមុនថ្ងៃនេះឯងមិន ដែលបានឮនិយាយពីការ
ទាំងនោះឡើយ ក្រែងឯងនិយាយថា មើល ខ្ញុំបានដឹង[ប]ការ
នោះហើយ ៨អើ ឯងមិនបានឮសោះ អើ មិនបានដឹងផង[ផ]
អើ តាំងពីបុរាណមកត្រចៀក[ព] ឯងមិនទាន់បានបើកឡើង
នៅឡើយ ដ្បិតអញបានដឹងថា ឯងនឹងប្រព្រឹត្តដោយចិត្ត
ក្បត់[ភ] ហើយឯងមានឈ្មោះថា ជាអ្នកបះបោរ[ម]តាំងតែពីផ្ទៃ
ម្តាយមក ៩ប៉ុន្តែ អញនឹងផ្អាកសេចក្តីកំហឹង[យ] ដោយយល់

**៤៧:១៤** ណ អស ៥:២៤ ត អស ៣០:៣០ ថ អស ១០:១៧ យរ ៥១:៣០,៣២,៥៨ **៤៧:១៥** ទ វវ ១៨:១១ ធ ខ.១៣ អស ៤៤:១៧ **៤៨:១** ក លប ១៧:៥ ខ លប ២៩:៣៥ គ អស ១៩:១៨ ឃ ១សយ ២០:៤២ អស ៤៣:៧ ង នក ២៣:១៣ ២សយ ១៤:១១ ទដ ៥០:១៦ អស ៥៨:២ យរ ៧:៩–១០ ៤៤:២៦ ច អស ៥៩:១៤ យរ ៤:២ ៥:២ ដយ ៨:១២ សក ៨:៣ **៤៨:២** ឆ នហ ១១:១ អស ១:២៦ មថ ៤:៥ ជ អស ១០:២០ រម ២:១៧ ឈ អស ៤៧:៤ **៤៨:៣** ញ អស ៤១:២២ ដ អស ៤០:២១ ៤៥:២១ ឋ អស ១៧:១៤
៣០:១៣ **៤៨:៤** ឌ អស ៩:៩ ឍ នក ៣២:៩ ចទ ៩:២៧ កច ៧:៥១ ណ អគ ៣:៩ **៤៨:៥** ត អស ៤០:២១ ៤២:៩ ថ យរ ៤៤:១៥–១៨ **៤៨:៦** ទ អស ៤១:២២ រម ១៦:២៥ **៤៨:៧** ធ អស ៦៥:១៨ ន អស ៤៥:២១ ប នក ៦:៧ **៤៨:៨** ផ អស ១:៣ ព ចទ ២៩:៤ ភ អស ៤១:២៤ មឡ ២:១១,១៤ ម ចទ ៩:៧,២៤ ទដ ៥៨:៣ អស ១:២ ៤៣:២៧ ៥៨:១ **៤៨:៩** យ យប ៩:១៣ អស ៣០:១៨

**៤៧:១៤** *ជញ្ជ្រាំង* វាគឺជារបស់ដែលឆេះឡើងដោយមានភ្លើងមួយរយៈខ្លី ។ សូមមើលការពន្យល់ ១:៣៣១ ដោយប្រៀបធៀបនិង មឡ ៤:១ និងការពន្យល់ ។ ក្នុងលក្ខណៈផ្ទុយដែលអង្គសង្គ្រោះដ៏មានអំណាចព្រះចេស្តារបស់រាស្ត្រអ៊ីស្រាអែល គឺមានអំណាចដ៏អស់កល្បជានិច្ច (សូមមើល ៤៣:៣ និងការពន្យល់) ។ ឯពួកគ្រូទាយទាំងនោះគឺជាគ្រូពុំអាចជួយយើងបានទេពួកគេប្រៀបដូចជារូបព្រះដែលពុំមានអំណាចអ្វីទាំងអស់ (សូមមើល ៤៤:១៧) (សូមមើល ៤៤:១៥) ។

**៤៨:១** *បានហៅតាមឈ្មោះ* ពួកគេគឺជាពួកអំបូរអ៊ីស្រាអែល (សូមមើល ៤៣:៧ និងការពន្យល់) ។ ពាក្យថា *អ៊ីស្រាអែល* សូមមើល លប ៣២:២៨ និងការពន្យល់ ។ ឯឃ្លាថា *មិនមែនដោយស្មោះចំពោះឬដោយសុចរិតទេ* គឺមាន លក្ខណៈខុសនិងពាក្យសម្បថក្នុង ៦៥:១៦ (សូមមើលការពន្យល់នៅក្នុងជិពូកនោះ) ។

**៤៨:២** *ក្រុងបរិសុទ្ធ* ដូចជាក្រុងយេរូសាឡិមគឺជាទីតាំងដែលព្រះវិហារសង់នៅទីនោះ (សូមមើល ២:២–៤ និងការពន្យល់ ៥២:១ ៥៦:៧ ៥៧:១៣ ៦៤:១០–១១ ៦៥:១១) ។ សូមមើលការពន្យល់ ១:២៦ ៤:៣ និងការពន្យល់ ដយ ៩:២៤ ។ ពាក្យថា *ហើយផ្អែកទៅលើព្រះនៃសាសន៍អ៊ីស្រាអែល* (សូមមើល ១០:២០ ដែលខុសនិង ៣១:១ ៣៦:៦,៩ អគ ២៩:៦–៧) ។ *ជាព្រះយេហូវ៉ានៃពួកពលបរិវារ* សូមមើល ១៣:៤ និងការពន្យល់ ។

**៤៨:៣** *ការដែលបានកើតឡើងតាំងតែពីដើមមក* សូមមើល ៤១:២២ និងការពន្យល់ ។ *ដូច្នេះការទាំនោះបានកើតឡើងហើយ* មើល ៤២:៩ ។

**៤៨:៤** *មនុស្សរឹងចចេស . . . ជាលង្ហិន* សូមមើល យរ ៦:២៨ ប្រៀបធៀប អគ ៣:៧ ។

**៤៨:៥** *ហើយរូបឆ្លាក់ នឹងរូបសិតរបស់ឯង ដែលបង្គាប់ការនោះឡើង* សូមមើលពាក្យប្រមាថបន្ទោសអំពីកិច្ចការខាងរូបព្រះ ដូមជាក្នុង ៤៤:១៧–២០ (ក៏សូមមើលការពន្យល់) ។ សូមមើលការពន្យល់ ៤៤:១២–១៣ ។

**៤៨:៦** *ការថ្មីទៀត* មានជាឧទាហរណ៍ដូចជាបង្កើតឱ្យមានរាស្ត្រអ៊ីស្រាអែលឡើងវិញ (សូមមើល ៤២:៩ និងការពន្យល់) ។ ដូចជាយុគ្គសម័យព្រះមែស៊ី និងស្ថានសួគ៌ថ្មី និងផែនដីថ្មីគឺអាចសំដែងឱ្យឃើញ (សូមមើលការប្រៀបធៀបនិង ៦៥:១៧) ។ *ជាការលាក់កំបាំង* សូមមើលការប្រៀបធៀបនិង រម ១៦:២៥–២៦ និងការពន្យល់ ។

**៤៨:៧** *ទើបបានកើតឡើង* ឥឡូវនេះក៏ឃើញសញ្ញាប្រកាសពីហេតុការណ៍ដែលនិងត្រូវមកដល់យ៉ាងពិត ។

**៤៨:៨** *អើ ឯងមិនបានឮសោះ អើ មិនបានដឹងផង* សូមមើល ១:៣ ។ *ត្រចៀក ឯងមិនទាន់បានបើក* សូមមើល ៦:១០ និងការពន្យល់ ។ ពាក្យថា *អ្នកបះបោរ* សូមមើល ១:២ ៤៦:៨ និងការពន្យល់ ។

**៤៨:៩** *ផ្អាកសេចក្តីកំហឹង* ប្រៀបធៀប ទដ ៧៨:៣៨ ។ ពាក្យថា *សេចក្តីសរ*

ដល់ឈ្មោះអញ[រ] និងដោយយល់ដល់សេចក្តីសរសើររបស់
អញ នោះអញនឹងឈប់លែងពីដំណើរឯងក្រែងអញកាត់
ឯងចេញទៅ[ល] ១០មើល អញបានសិរង[វ]ឯង តែមិនមែនដូច
ជាសិរងប្រាក់ទេ គឺអញបានរើស[ស]ឯងនៅក្នុងឡ[ហ]នៃសេច
ក្តីវេទនាវិញ ១១អញនឹងធ្វើការនោះ ដោយយល់ដល់ខ្លួន
អញ គឺដោយយល់ដល់ខ្លួនអញហើយ[ឡ] ដ្បិតធ្វើដូម្តេចឱ្យ
ឈ្មោះអញត្រូវបង្អាប់បាន[អ] ឯសិរីល្អរបស់អញៗមិនព្រម
លើឱ្យទៅអ្នកដទៃឡើយ[ក]។

## ពួកអ៊ីស្រាអែលទទួលសេរីភាព

១២ឱពួកយ៉ាកុប និងអ៊ីស្រាអែល ជាអ្នកដែលអញបាន
ហៅអើយ[ខ] ចូរស្តាប់[គ]អញចុះ គឺអញនេះហើយ[ឃ] អញជា
ដើមហើយជាចុងដែរ[ង] ១៣អើ ដៃអញបានដាក់ឫសនៃផែន
ដី[ច] ហើយដៃស្តាំរបស់អញបានលាតផ្ទៃមេឃ[ឆ] កាលណា
អញហៅ នោះទាំង២ក៏ឈរឡើងជាមួយគ្នា[ជ] ១៤ចូរឱ្យឯង
រាល់គ្នាប្រជុំ[ឈ]ទាំងអស់ ហើយស្តាប់ចុះ ក្នុងពួកគេតើមាន
អ្នកណាដែលថ្លែងប្រាប់[ញ]ពីការទាំងនេះឬ អ្នក១នោះ
ដែលព្រះយេហូវ៉ាទ្រង់ស្រឡាញ់[ដ] គេនឹងសំរេចដល់ក្រុង
បាប៊ីឡូន[ឋ] តាមបំណងព្រះហឫទ័យទ្រង់[ឌ] ដៃរបស់គេនឹង
សង្កត់លើពួកខាល់ដេ ១៥អញ គឺអញនេះហើយ អញបាន
ពោល អើ អញបានហៅ[ឍ]គេ អញបាននាំគេមក ហើយគេ
នឹងបញ្ចៀន[ណ]ការខ្លួនឱ្យកើតឡើងផង ១៦ចូរឱ្យឯងរាល់គ្នា
ចូលមកជិត[ត]អញ ហើយស្តាប់[ថ]សេចក្តីនេះចុះ តាំងតែពី
ដើមដំបូងមក អញមិនបាននិយាយដោយសំងាត់ទេ[ទ] តាំងពី
ការនោះចាប់ផ្តើមកើតឡើង នោះអញក៏មាននៅ ហើយ
ឥឡូវនេះ ព្រះអម្ចាស់យេហូវ៉ា[ធ]ទ្រង់បានចាត់[ន]ខ្ញុំ ជាមួយនឹង
ព្រះវិញ្ញាណទ្រង់ឱ្យមក[ប]។
១៧ព្រះយេហូវ៉ា ជាព្រះដ៏ប្រោសលោះឯង[ផ] គឺជាព្រះ
បរិសុទ្ធ[ព]នៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា
អញនេះ គឺយេហូវ៉ា ជាព្រះនៃឯង ជាអ្នកដែលបង្រៀន[ភ]ឱ្យ
ឯងបានទទួលប្រយោជន៍ ហើយក៏នាំ[ម]ឯងទៅក្នុងផ្លូវ[យ]ដែល
ឯងគួរដើរ ១៨ឱបើឯងបានស្តាប់តាម[រ]បញ្ញត្តទាំងប៉ុន្មាន
របស់អញទៅអេះ នោះសេចក្តីសុខ[ល]របស់ឯងនឹងបានដូច
ជាទន្លេ[វ] សេចក្តីសុចរិត[ស]របស់ឯង និងបានដូចជារលក

**៤៨:៩** រ ១សយ ១២:២២ អស ៣៧:៣៥ ល នហ ៩:៣១ **៤៨:១០** វ អស ១:២៥ សក ១៣:៩ មឡ ៣:៣ ១ពត ១:៧ ស នក ១៥:២៥ ហ នក ១:១៣ ១ពវ ៨:៥១ **៤៨:១១** ឡ ១សយ ១២:២២ អស ៣៧:៣៥ អ លវ ១៨:២១ ចទ ៣២:២៧ យរ ១៤:៧,២១ អគ ២០:៩,១៤,២២,៤៤ ក អស ៤២:៨ **៤៨:១២** ខ អស ៤១:៨ ៤២:៦ ៤៣:១ គ អស ៤៦:៣ ឃ អស ៤៣:១៣ ង អស ៤១:៤ វវ ១:១៧ **៤៨:១៣** ច ហព ១:១០–១២ ឆ លប ២:១ នក ២០:១១ យប ៩:៨ អស ៤០:២២ ៤២:៥ ៤៥:១៨ ៥១:១៦ ៦៥:១៧ ជ អស ៣៤:១៦ **៤៨:១៤** ឈ អស ៤៣:៩ ញ អស ៤១:២២ ដ អស ៤១:២ ឋ អស ២១:៩ ៤៥:១ យរ ៥០:៤៥ ឌ អស ៤៦:១០–១១ **៤៨:១៥** ឍ ពច ៤:១០ អស ៤៥:១ ណ អស ៤៤:២៨–៤៥:៤ **៤៨:១៦** ត អស ៤១:១ ថ អស ៣៣:១៣ ទ អស ៤៥:១៩ ធ អស ៥០:៥,៧,៩ ន សក ២:៩,១១ ប អស ១១:២ **៤៨:១៧** ផ យប ១៩:២៥ អស ៤៩:៧ ៥៤:៨ ព អស ៤៧:៤ ភ អស ២៨:៩ យរ ៧:១៣ ម អស ៤៩:១០ ៥៧:១៨ ៥៨:១១ យ អស ៣០:១១ **៤៨:១៨** រ អស ៤២:២៣ ល ទដ ១៤៧:១៤ អស ៩:៧ ៥៤:១៣ ៦៦:១២ វ អស ៣៣:២១ ស អស ១:២៦ ៤៥:៨

*សើររបស់អញ* គឺជាការសរសើរដល់ព្រះ ជាកិច្ចមានតម្លៃបំផុត ។
**៤៨:១០** *អញបានសិរងឯង* គឺជាលក្ខណៈនៃការជិនុំជម្រះ (សូមមើល ទដ ១២:៦ យរ ៩:៧ អគ ២២:១៨ និងការពន្យល់) ក៏ដូចជាភ្លើងសំអាតឱ្យបរិសុទ្ធបានបង្ហាញក្នុង ១:២៥ ៤:៤ ។ *ឡនៃសេចក្តីវេទនា* គឺជាការ១សម្រាប់រាស្ត្រអ៊ីស្រាអែលអេស៊ីព្ទ គឺក៏ត្រូវជិនុំជម្រះតាមរយៈ "ឡលោហធាតុ" (ចទ ៤:២០ ក៏សូមមើលការពន្យល់ ១ពវ ៨:៥១ យរ ១១:៤) ។ ឯការធ្លាក់ចុះ របស់ពួកអ៊ីស្រាអែល និងពួកបាប៊ីឡូនដែលបានគេបំបោះបង់ គឺជាឡ ជិនុំជម្រះស្រដៀងៗគ្នា ។
**៤៨:១១** *ដោយ . . . អញត្រូវបង្អាប់បាន* គឺការដែលក្រុងយេរូសាឡិមបានដួលចុះ និងដោយរាស្ត្រក៏បានព្រាត់ពីទ្រង់ដោយសារពួកគេពុំបានទទួលស្គាល់ព្រះនាមទ្រង់ (សូមមើល អគ ៣៦:២០–២៣ និងការពន្យល់) ។ សិរីល្អ របស់អញ សូមមើល ៤០:៥ និងការពន្យល់ ។
**៤៨:១២** *បានហៅ* គឺដើម្បីជាបាវបម្រើព្រះ គឺរាស្ត្រដែលទ្រង់បានជ្រើសរើស សូមមើល ៤២:៦ ក៏សូមមើល ៤១:២,៤៣:១ និងការពន្យល់ ។
**៤៨:១៣** *បានដាក់ឫសនៃផែនដី* គឺជាសំដីរបស់លោកអេសាយហើយក៏បង្ហាញថាព្រះនៃការបង្កើត (ព្រះអាទិករ) (មើល ៤០:២១–២២ ៤២:៥ ៥១:១៣ និងការពន្យល់ ។ ប្រៀបធៀប ទដ ១០២:២៥ ។ *កាលណាអញហៅនោះ ទាំង២ក៏ឈរឡើងជាមួយគ្នា* គឺគ្រប់ទាំងស្នាព្រះហស្តទាំងអស់ត្រូវមានវត្តមាន (សូមមើល ៤០:២៦ និងការពន្យល់ ទដ ១០៣:២២) ។
**៤៨:១៤** *ក្នុងពួកគេតើអ្នកណាដែលថ្លែងប្រាប់ពីការទាំងនេះឬ* សូមមើល ៤១:២១–២៣,២៦ ៤៣:៩ និងការពន្យល់ ។ ឯស្តេចស៊ីរូស (សូមមើល ៤១:២ និងការពន្យល់) គោលបំណងរបស់ទ្រង់ សូមមើល ៤៦:១០–១១ និងការពន្យល់ ។ *ក្រុងបាប៊ីឡូន* សូមមើល ១៣:១ និងការពន្យល់ ។
**៤៨:១៥** *បានហៅគេ* ដូចជាស្តេចស៊ីរូស (សូមមើល ៤១:២ និងការពន្យល់) ក៏សូមមើល ៤៤:២៨ ៤៥:១–៤ និងការពន្យល់ ។
**៤៨:១៦** *ស្តាប់សេចក្តីនេះចុះ* គឺជាការថ្លែងទំនាយពីស្តេចស៊ីរូស និងបេសកម្មរបស់គាត់ (សូមមើល ៤១:២៥–២៧ និងការពន្យល់) ។ ពាក្យថា *មិនបាន និយាយដោយសំងាត់* សូមមើល ៤៥:១៩ និងការពន្យល់ ។ ពាក្យថា *ទ្រង់បានចាត់ខ្ញុំមក* ក៏សំដៅទៅលើលោកអេសាយឬអ្នកបម្រើព្រះផ្សេងទៀត ។ *ជាមួយនឹងព្រះវិញ្ញាណទ្រង់* គឺជាព្រះវិញ្ញាណនៃព្រះយេហូវ៉ាដែលមកសណ្ឋិតលើអ្នកបម្រើនោះ មើលក្នុង ៤២:១ (សូមមើលការពន្យល់នៅជិពូកនោះ) ព្រះវិញ្ញាណក៏សណ្ឋិតលើហោរារបស់ព្រះមែស៊ី ៦១:១ (សូមមើលការពន្យល់ ៦១:១) ។
**៤៨:១៧** *ព្រះដ៏ប្រោះលោះ . . . ព្រះបរិសុទ្ធនៃសាន៍អ៊ីស្រាអែល* សូមមើល ៤១:១៤ និងការពន្យល់ ។ ពាក្យថា *ដែលបង្រៀនឱ្យឯងបានទទួលប្រយោជន៍ . . . ក្នុងផ្លូវដែលឯងគួរដើរ* គឺជាកិច្ចការតាមរយៈពួកហោរានិងពួកសង្ឃ (សូមមើល ៣០:២០–២១ ទដ ៣២:៨–១០ និងការពន្យល់) ។
**៤៨:១៨** *សេចក្តីសុខ . . . បានដូចជាទន្លេ . . . សេចក្តីសុចរិតរបស់ឯ* គឺជាភាពបរិបូរហូរហៀរនិងភាពសុខសាន្ត និងភាពសុចរិត ក៏មានទំនាក់ទំនងនិង ៩:៧ ៣២:១៧ ៥៤:១៣–១៤ ៦០:១៧ ទដ ៨៥:១០ (សូមមើលការ

នៃសមុទ្រហើយ ១៩ឯពូជពង្ស[ហ]ឯងក៏នឹងបានច្រើនដូចជា
ខ្សាច់[ឡ] ហើយផលដែលកើតពីឯងមក នោះនឹងបានដូចជា
គ្រាប់ខ្សាច់ទាំងប៉ុន្មាន[អ] ឯឈ្មោះគេក៏មិនត្រូវកាត់ចេញ[ក]
ឬបំផ្លាញពីមុខអញឡើយ ។
២០ចូរចេញពីក្រុងបាប៊ីឡូនទៅ ហើយរត់[ខ]ពីកណ្តាល
ពួកខាល់ដេចេញ ចូរប្រកាសប្រាប់ ដោយឡើងសំឡេង
ច្រៀង[គ] ចូរថ្លែងពីរឿងនេះ ហើយបញ្ជូនរហូតដល់ចុង
ផែនដីផង[ឃ] ចូរប្រាប់ថា ព្រះយេហូវ៉ាទ្រង់បានប្រោស
លោះ[ង]ពួកយ៉ាកុប ជាអ្នកបំរើទ្រង់ហើយ ២១គេមិនបាន
ស្រេក[ច]ឡើយ កំពុងដែលទ្រង់នាំគេដើរកាត់សមុទ្រខ្សាច់
គឺទ្រង់បានធ្វើឱ្យមានទឹកហូរ[ឆ]ចេញពីថ្មដាសំរាប់គេ ទ្រង់ក៏
ប៉ប្រះថ្មដា ឱ្យទឹកផុសចេញមក[ជ] ២២ព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា គ្មានសេចក្តីសុខសោះ[ឈ] ដល់ពួកមនុស្សដែល
ប្រព្រឹត្តអាក្រក់[ញ]។

## អ្នកបម្រើនៃព្រះអម្ចាស់

**៤៩** ១ម្នាលកោះទាំងឡាយអើយ[ក] ចូរស្តាប់[ខ]អញចុះឱ្យ
ប្រជាជាតិទាំងប៉ុន្មាននៅឆ្ងាយអើយ ចូរប្រុងស្តាប់ចុះព្រះ
យេហូវ៉ាទ្រង់បានហៅ[គ]ខ្ញុំ តាំងពីផ្ទៃម្តាយ[ឃ]ទ្រង់បាន
ដំណាលពីឈ្មោះខ្ញុំ តាំងពីនៅក្នុងពោះម្តាយមក[ង] ២ទ្រង់
បានធ្វើឱ្យមាត់[ច]ខ្ញុំបានដូចជាដាវដ៏មុត[ឆ] ក៏បានលាក់ខ្ញុំនៅ
ក្រោមម្លប់នៃព្រះហស្ត[ជ]ទ្រង់ ក៏បានធ្វើឱ្យខ្ញុំដូចជាតួព្រួញ[ឈ]
ដែលខាត់រំលីង ព្រមទាំងដាក់ខ្ញុំទុកភ្ជិតនៅក្នុងបំពង់ព្រួញ
របស់ទ្រង់ ៣ទ្រង់បានមានបន្ទូលមកខ្ញុំថា ឯងជាអ្នកបំរើ
របស់អញ[ញ] គឺអ៊ីស្រាអែល ដែលអញនឹងបានសិរីល្អដោយ
សារឯង[ដ] ៤តែខ្ញុំបានពោលថា ខ្ញុំបានខំប្រឹងធ្វើជាឥត
ប្រយោជន៍ ខ្ញុំបានបង់កំឡាំងខ្ញុំទៅទទេៗជាអសារឥតការ[ឋ]
ប៉ុន្តែសេចក្តីយុត្តិធម៌ ដែលគួរដល់ខ្ញុំ នោះនៅនឹងព្រះ

**៤៨:១៩** ហ អស ៤៣:៥ ៤៤:៣ ៦១:៩ ឡ លប ១២:២ អ យប ៥:២៥ ក អស ៥៦:៥ ៦៥:២៣ ៦៦:២២ យរ ៣៥:១៩ **៤៨:២០** ខ អស ៥២:១១ យរ ៤៨:៦ ៥០:៨ ៥១:៦,៤៥ សក ២:៦–៧ វវ ១៨:៤ គ អស ១២:៦ ៤៩:១៣ ៥១:១១ ឃ លប ៤៩:១០ ចទ ៣០:៤ យរ ២៥:២២ ង នក ៦:៦ អស ៣៣:២៤ ៥២:៩ ៦៣:៩ មីក ៤:១០ **៤៨:២១** ច អស ៣៣:១៦ ឆ អស ៣០:២៥ ជ ជន ២០:១១ អស ៣៥:៦ **៤៨:២២** ឈ យប ៣:២៦ ញ អស ៣:១១ ៥៧:២១ **៤៩:១** ក អស ១១:១១ ខ អស ៣៣:១៣ គ អស ៧:១៤ ៩:៦ ៤៤:២ យរ ១:៥ កទ ១:១៥ ឃ អស ៤៤:២៤ ៤៦:៣ មថ ១:២០ ង នក ៣៣:១២ អស ៤៣:១ **៤៩:២** ច យប ៤០:១៨ ឆ ទដ ៦៤:៣ អភ ៦:១៧ វវ ១:១៦ ជ នក ៣៣:២២ ទដ ៩១:១ ឈ ចទ ៣២:២៣ សក ៩:១៣ **៤៩:៣** ញ អស ២០:៣ សក ៣:៨ ដ លវ ១០:៣ អស ៤៤:២៣ **៤៩:៤** ឋ លវ ២៦:២០ អស ៥៥:២ ៦៥:២៣

ពន្យល់) ។ ហាព ៧:២ យក ៣:១៨ ។

**៤៨:១៩** *ពូជពង្សឯងក៏នឹងបានច្រើនដូចជាខ្សាច់* សូមមើល ១០:២២ លប ១៣:១៦ និងការពន្យល់ ។ លប ២:១៧ យរ ៣៣:២២ និងការពន្យល់ ។ *ឯឈ្មោះគេក៏មិនត្រូវកាត់ចេញ* គឺជាឈ្មោះរាស្ត្រអ៊ីស្រាអែលដែលពុំបានបាត់ពីក្នុងបញ្ជីរទេ(សូមមើល ខ.៩ ៥៤:៣ យរ ៣១:៣៦) ។

**៤៨:២០** *ចេញពីក្រុងបាប៊ីឡូនទៅ . . . រត់ពី* ទោះបីពួកសាសន៍យូដាពុំបានរត់គេចក៏ដោយ (សូមមើល ៥២:១២) តែពួកគេត្រូវបានគេប្រាប់ឱ្យរត់ចេញជាបន្ទាន់ព្រោះការជំនុំជម្រះនឹងមានក្នុងស្រុកបាប៊ីឡូន (សូមមើលការប្រៀបធៀប ១៨:៤) ។ នេះក៏ជាការបង្ហាញចុងក្រោយពីការងារស្រុកបាប៊ីឡូនក៏មានឈ្មោះក្នុងអេសាយ ។ ពាក្យថា *ដោយឡើងសំឡេង* សូមមើល ៤៤:២៣ ៤៩:១៣ ៥២:៩ និងការពន្យល់។ *រហូតដល់ចុងផែនដីផង* មើល ១១:១២ ៤២:១០ និងការពន្យល់ ។ *បានប្រោសលោះ* សូមមើល ៤២:១ នឹងការពន្យល់។ *អ្នកបំរើទ្រង់ហើយ* សូមមើល ៤១:៨–៩ និងការពន្យល់ ។

**៤៨:២១** *មិនបានស្រេក . . . ទឹកហូរចេញពីថ្ម* គឺសំដៅទៅលើការផ្គត់ផ្គង់ពីព្រះបន្ទាប់ពីការចេញដំណើរ(សូមមើល នក ១៧:៦ និងការពន្យល់) ជន ២០:១១ សូមមើល អស ៣២:១ ៣៥:៦ ៤៣:១៩ ៤៩:១០ និងការពន្យល់) ។ ប្រជារាស្ត្ររបស់ព្រះ ត្រូវមានទឹកនៅពេលធ្វើដំណើរត្រឡប់ទៅស្រុកវិញគឺស្រុកបាប៊ីឡូន ។

**៤៨:២២** គឺជាការបង្ហាញឡើងវិញ ដោយមានចំៗ មើលក្នុង ៥៧:២១ ។ *សេក្តីសុខ* សូមមើល ៣៩:៨ និងការពន្យល់ក៏សូមមើលសេចក្តីផ្តើម ។ *មនុស្សប្រព្រឹត្តអាក្រក់* គឺអស់អ្នកដែលធ្វើទាស់ប្រឆាំងនិងព្រះយេហូវ៉ា (សូមមើល ១:២) ។

**៤៩:១** *ម្នាលកោះ* ឬក៏ "ដីដែលមានសមុទ្រអម" មើលក្នុង ៤២:៤ កោះ "គឺសេចក្តីសង្ឃឹមដែលមាន" ក្នុងច្បាប់របស់អ្នកបម្រើ ។ *តាំងពីផ្ទៃម្តាយ . . . ទ្រង់ដំណាលពីឈ្មោះខ្ញុំ* ប្រៀបធៀប ខ.៥ ។ ការប្រៀបភាសានេះគឺមានលក្ខណៈស្រដៀងគ្នានិងពេលទ្រង់ដំណាលពីឈ្មោះហោរាយេរេមា (សូមមើល យរ ១:៥ និងការពន្យល់) និងលោកសាវកប៉ុល (កទ ១:១៥) ប្រៀបធៀប ៤១:៩ ។ *ដំណាលពីឈ្មោះខ្ញុំ* សូមមើល ៤៣:១ និងការពន្យល់ ។

**៤៩:២** *បានធ្វើមាត់ខ្ញុំបានដូចជាដាវដ៏មុត* សូមមើល ១:១៦ ២:១៦ ១៩:១៥, ២១ ប្រៀបធៀប អស ១១:៤ អភ ៦:១៧ ហាព ៤:១២ ។ *ក្រោមម្លប់នៃព្រះហស្តទ្រង់* គឺជាការពណ៌នាពីការការពារពីព្រះ (សូមមើល ៣០:២–៣ ៥១:១៦) ។ ពាក្យថា *តួព្រួញដែលខាត់រំលីង* គឺជាតួព្រួញត្រូវបានប្រើសម្រាប់ការជំនុំជម្រះរបស់ព្រះ សូមមើលក្នុង ចទ ៣២:២៣,៤២ សូមមើល ទដ ៦៤:៣–៤ និង អភ ៦:១១,១៦ ។

**៤៩:៣** *ជាអ្នកបំរើរបស់អញ គឺអ៊ីស្រាអែល* សូមមើលការពន្យល់ ៤១:៨–៩ ៤២:១–៤ ៤១:១ ។ ពាក្យថា *"អ្នកបំរើ"* គឺពុំមានន័យជាជាតិអ៊ីស្រាអែលទាំងស្រុងនោះទេ ។ គឺជាអ្នកបម្រើព្រះមែស៊ី គឺជាអ្នកបម្រើដែលត្រូវសរសើរតម្កើងដល់ព្រះយេហូវ៉ា ។ គឺទ្រង់មានជ័យខណៈពេលដែលជនជាតិអ៊ីស្រាអែលបានបរាជ័យ ។ តាមរយៈការប្រោសលោះទ្រង់និងបានសម្រេច (សូមមើល ៣៥:២ ៤០:៥) ។

**៤៩:៤** *ខ្ញុំបានខំប្រឹងធ្វើជាឥតប្រយោជន៍* ដូចជាជាតិសាសន៍អ៊ីស្រាអែលធ្វើការឥតប្រយោជន៍ជាច្រើន (សូមមើល ៦៥:២៣) ដូចជាព្រះគ្រីស្ទដែលប្រឈរមុខនិងប្រឆាំងជាច្រើនក្នុងរយៈពេលទ្រង់ បម្រើព្រះរាជកិច្ចនៅផែនដីនេះ ហើយការដែលទ្រង់ទទួលការឈឺចាប់ ឬបរាជ័យគ្រាន់តែមានរយៈពេលខ្លីតែប៉ុណ្ណោះ ។ "អ្នកបម្រើដ៏ឈឺចាប់" ក៏មានសាច់រឿងដែលតាមរយៈបទទំនុកចម្រៀងពីអ្នកបម្រើទាំងបួន ។ *ប៉ុន្តែសេចក្តីយុត្តិធម៌ដែលគួរដល់ខ្ញុំនោះនៅនឹងព្រះយេហូវ៉ា ហើយរង្វាន់របស់ខ្ញុំក៏នៅនឹងព្រះនៃខ្ញុំ* ប្រហែលវាសំដៅទៅលើកូននៃព្រលឹងវិញ្ញាណនៃអ្នកបម្រើ (សូមមើលការពន្យល់ ៥៣:១០) ដូចជាពួកយូដានិងពួកសាសន៍ដទៃ គឺដូចគ្នានឹងអ្នកដែលជឿលើទ្រង់ (ខ.៥–៦) មើល ៤០:១០ និងការពន្យល់ ។ ក្នុងករណីនេះហើយដែល

យេហូវ៉ា[ឌ] ហើយរង្វាន់[ឍ]របស់ខ្ញុំក៏នៅនឹងព្រះនៃខ្ញុំដែរ[ណ]។
5 ឥឡូវនេះ ទ្រង់មានបន្ទូលមកខ្ញុំ គឺព្រះយេហូវ៉ា ជាព្រះ
ដែលជបបង្កើតខ្ញុំនៅក្នុងផ្ទៃម្ដាយ[ត] ដើម្បីឱ្យបានធ្វើជាអ្នក
បំរើទ្រង់សំរាប់នឹងនាំពួកយ៉ាកុបមកឯទ្រង់វិញ ហើយឱ្យ
ពួកអ៊ីស្រាអែល[ថ]បានមូលមកឯទ្រង់ ដ្បិតខ្ញុំជាទីរាប់អាន[ទ]
នៅព្រះនេត្រព្រះយេហូវ៉ា ហើយព្រះនៃខ្ញុំទ្រង់ជាកំឡាំងនៃ
ខ្ញុំ[ធ] 6 អើ ទ្រង់មានបន្ទូលថា ការដែលឯងធ្វើជាអ្នកបំរើ
របស់អញ[ន] ដើម្បីលើកអស់ទាំងពូជអំបូរនៃយ៉ាកុបឡើង
ហើយនិងនាំពួកបំរុងទុកក្នុងសាសន៍អ៊ីស្រាអែលឱ្យមក
វិញ[ប] នោះជាការតិចតួចពេលដល់ឯង អញនឹងបន្ថែម
ការនេះឱ្យឯង បានធ្វើជាពន្លឺ[ផ]ដល់សាសន៍ដទៃទាំងប៉ុន្មាន
ទៀត[ព] ដើម្បីឱ្យឯងបានធ្វើជាអ្នកជួយសង្គ្រោះរបស់អញ
រហូតដល់ចុងផែនដីបំផុត[ភ] 7 ព្រះយេហូវ៉ា ជាព្រះដ៏ប្រោស
លោះសាសន៍អ៊ីស្រាអែល[ម] ហើយជាព្រះដ៏បរិសុទ្ធនៃគេ
ទ្រង់មានបន្ទូល ដូច្នេះដល់អ្នកនោះ ដែលមនុស្សទាំងឡាយ
មិនអើពើ ដែលជាទីស្អប់ខ្ពើម[យ] ដល់សាសន៍នេះ គឺជាអ្នក
បំរើរបស់ពួកអ្នកដែលគ្រប់គ្រងថា បណ្ដាក្សត្រ[រ]នឹងឃើញ
ហើយក្រោកឈរឡើង ព្រមទាំងពួកចៅហ្វាយដែរ គេនឹង
ក្រាបថ្វាយបង្គំ[ល] ដោយព្រោះព្រះយេហូវ៉ា ទ្រង់ជាព្រះដ៏
ស្មោះត្រង់[វ] គឺជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលដែល
ទ្រង់បានរើស[ស]ឯង ។

## ការស្តារនគរអ៊ីស្រាអែលឡើងវិញ

8 ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ដល់វេលាដែល
គាប់ចិត្តអញ[ហ] នោះអញបានឆ្លើយដល់ឯង ហើយនៅថ្ងៃ
សំរាប់សង្គ្រោះ នោះអញបានជួយឯង[ឡ] អញនឹងទំនុកបំរុង[អ]
ឯង ហើយតាំងឯងឡើងទុកជាសេចក្ដីសញ្ញាដល់បណ្ដាជន[ក]
ប្រយោជន៍នឹងរៀបចំផែនដី[ខ]ឡើង ឱ្យគេបានគ្រងទីដែល
ចោលស្ងាត់ ទុកជាមរដក[គ] 9 ព្រមទាំងប្រាប់ដល់ពួកអ្នក
ដែលជាប់ចំណង[ឃ]ថា ចូរចេញទៅ ហើយដល់ពួកអ្នក
ដែលនៅក្នុងសេចក្ដីងងឹតថា[ង] ចូរសំដែងខ្លួន ចេញមកចុះ
គេនឹងមានអាហារស៊ីតាមផ្លូវ ហើយនៅលើកំពូលត្រងិល
ទាំងប៉ុន្មាន នឹងបានជាទីរកស៊ីដល់គេ[ច] 10 គេនឹងមិនដែល
ស្រេកឃ្លានទៀត[ឆ] ឯចំហាយក្ដៅឬព្រះអាទិត្យនឹងមិនធ្វើ

**៤៩:៤** ឌ អស ៤៥:២៥ ៥០:៨ ៥៣:១០ ៥៤:១៧ ឍ អស ៣៥:៤ ណ យប ២៧:២ **៤៩:៥** ត ទដ ១៣៩:១៣ កទ ១:១៥ ថ ចទ ៣០:៤ អស ១១:១២ ទ អស ៤៣:៤ ធ ទដ ១៨:១ **៤៩:៦** ន ខ.៣ ប អស ១:៩ ផ អស ៩:២ យហ ១:៩ ព អស ២៦:១៨ ៥៥:៥ សក ៨:២២ លក ២:៣២ ភ ចទ ៣០:៤ ទដ ៤៨:១០ មថ ២៨:១៩ យហ ១១:៥២ កច ១៣:៤៧ **៤៩:៧** ម អស ៤៨:១៧ យ ទដ ២២:៦ ៦៩:៧–៩ រ អរ ១:២ អស ៥២:១៥ ល លប ២៧:២៩ ទដ ២២:២៩ ៨៦:៩ វ ចទ ៧:៩ ១កថ ១:៩ ស អស ១៤:១ **៤៩:៨** ហ ទដ ៦៩:១៣ អស ៦០:១០ ៦១:២ ឡ អស ៤១:១០ ២កថ ៦:២ អ អស ៥:២ ២៦:៣ ក អស ៤២:៦ ខ លវ ២៥:១០ ទដ ៣៧:៩ អស ៤៤:២៦ ៥៨:១២ ៦១:៤ អគ ៣៦:១០,៣៣ អម ៩:១១,១៤ គ ជន ៣៤:១៣ អស ៦០:១២ **៤៩:៩** ឃ អស ៤២:៧ ៦១:១ លក ៤:១៩ ង ទដ ១០៧:១០ ច អស ៤១:១៨ **៤៩:១០** ឆ អស ៣៣:១៦

ទ្រង់ពុំមានទោសឡើយ និងទទួលរង្វាន់ (មើល ៥០:៨ ៥៣:១០–១២ ១ធថ ៣:១៦) ។

**៤៩:៥** *ជបបង្កើតខ្ញុំនៅក្នុងផ្ទៃម្ដាយ* សូមមើល ខ.១ ៤៤:២ និងការពន្យល់ ។ ពាក្យថា *នាំពួកយ៉ាកុបមកឯទ្រង់វិញ . . . ពួកអ៊ីស្រាអែលបានមកឯទ្រង់* គឺជាសេចក្ដីទំនាយដែលបើកសម្ដែង ពីការបានជាប់ជាឈ្លើយនៅក្នុងស្រុកបាប៊ីឡូន (សូមមើល ខ.៩–១២,២២ ៤១:២ និងការពន្យល់) និងជាការជាប់ជាឈ្លើយក្នុងអំពើបាប (សូមមើល ៤២:៧ និងការពន្យល់) ។ *កំឡាំងនៃខ្ញុំ* សូមមើល ១២:២ ។

**៤៩:៦** ដែលមានទាំង លប ១២:១–៣ នក ១៩:៥–៦ ខនេះជួនកាលគេហៅថាព្រះរាជបេសកកម្មដ៏ធំមួយនៅក្នុងគ្រាសញ្ញាចាស់ ក៏មានការដកស្រង់ផ្នែកខ្លះដោយលោកប៉ុល និងបាណាបាស នៅក្នុង កច ១៣:៤៧ ។ *ពួកបំរុងទុក* គឺសំដៅទៅលើពួកសំណល (សូមមើល ១:៩ និងការពន្យល់) ។ *ជាពន្លឺដល់សាសន៍ដទៃទាំងប៉ុន្មានទៀត* សូមមើល ៩:២ ៤២:៦ និងការពន្យល់កច ២៦:២៣ ។ ព្រះគ្រីស្ទជាពន្លឺលោកិយ (លក ២:៣០–៣២ សហ ៨:១២ ៩:៥) និងគ្រីស្ទបរិស័ទ ក៏ជាពន្លឺ (មថ ៥:១៤) ។ *ចុងផែនដីបំផុត* សូមមើល ១១:១២ និងការពន្យល់ ៤១:៥ ៤២:១០ ៤៨:២០ ។

**៤៩:៧** *ព្រះដ៏ប្រោសលោះសាសន៍អ៊ីស្រាអែល . . . ព្រះបរិសុទ្ធ* សូមមើល ៤១:១៤ និងការពន្យល់ ។ *ជាទីស្អប់ខ្ពើម* ក៏ឃើញលេចមកពីរដងពីអ្នកបម្រើដែលទទួលការឈឺចាប់ក្នុង ៥៣:៣ ។ ក្នុង ៦០:១៤ ពួកក្រុងស៊ីយ៉ូនត្រូវបានគេស្អប់ខ្ពើមមិនអើពើដោយពួកសត្រូវទាំងឡាយ ។ *សាសន៍* គឺសំដៅទៅលើពួកអ៊ីស្រាអែល និងសាសន៍ដទៃផងដែរ (១:៤) ។ *ទាំងពួកចៅហ្វាយ . . . ក្រាបថ្វាបង្គំ* សូមមើល ខ.៣៣ ប្រតិកម្មនេះមានលក្ខណៈស្រដៀងនិង ៥២:១៥ ។ ឯអ្នកដែលប្រឆាំង ពីមុនទាំងប៉ុន្មានក៏បានក្រាប់ថ្វាយបង្គំពីមុខក្រុងយេរូសាឡិមថ្មី មើលក្នុង ៦០:១៤ (ប្រៀបធៀប ៤៥:១៤ ៦០:១១–១២ ៦៦:២៣) ។ *បានរើសឯង* សូមមើល ៤១:៨–៩ ៤២:១ និងការពន្យល់ ។

**៤៩:៨** គឺជាសេចក្ដីដកស្រង់ចេញពីផ្នែកខ្លះក្នុងអត្ថបទគម្ពីរ ២កថ ៦:២ ។ *ដល់វេលាដែលគាប់ចិត្តអញ . . . នៅថ្ងៃសំរាប់សង្គ្រោះ* ប្រវត្តិពីការសរសេរខគម្ពីរនៅឆ្នាំនៃខួបគំរប ៥០ឆ្នាំ (សូម មើល ៦១:១–២ លវ ២៥:១០) ។ គឺការវិលត្រឡប់ពីការដែលបានចាក់ចោលស្រុកក៏ជាឆ្នាំដែលមានទឹកដីឡើងវិញគឺជាឆ្នាំនៃសិទ្ធសេរីភាព ។ ពាក្យថា *ទំនុកបំរុងឯង . . . ជាសេចក្ដីសញ្ញា* សូមមើល ៤២:៦ និងការពន្យល់ ។ ពាក្យថា *គ្រប់ទីដែលចោលស្ងាតទុកជាមរដក* សូមមើល ៤៤:២៦ ។ កិច្ចការក៏ធ្លាក់មកលើលោកយ៉ូស្វេក្នុងការបែងចែកទឹកដីឱ្យទៅតាមពូជអំបូរ និងគ្រួសារនិមួយៗ (យស ១៤:១–៥) ។ អ្នកបម្រើដែលជាព្រះមែស៊ី នោះគឺជាលោកយ៉ូស្វេថ្មី ឬម៉ូសេថ្មីទៀត ដែលរំដោះរាស្ត្រអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ និងចេញពីបទពិសោធន៍នៃជីវិតនៅឯវាលរហោស្ថាន តែក្នុងពេលចេញដំណើរ គឺកិច្ចការដែលស្ថិតនៅក្រោមការដឹកនាំរបស់លោកម៉ូសេ (សូមមើល ខ.៩–១០) ។

**៤៩:៩** *ពួកអ្នកដែលជាប់ចំណង* គឺពួកដែលគេចាប់យក សូមមើល ៤២:៧ និងការពន្យល់ ។ លើកំពូលត្រងិល សូមមើល ៤១:១៨ និងការពន្យល់ ។

**៤៩:១០** *មិនដែលស្រេកឃ្លានទៀត* សូមមើល ៤៨:២១ និងការពន្យល់ ។ ពាក្យថា *សេចក្ដីមេត្តា* សូមមើល ៤១:១ នឹងការពន្យល់ ។ ពាក្យថា *នឹងនាំ*

ទុក្ខគេ[ជ] ដ្បិតព្រះដែលផ្តល់សេចក្តីមេត្តា[ឈ]ដល់គេ ទ្រង់នឹង
នាំ[ញ]គេទៅ អើ ទ្រង់នឹងដឹកដៃគេនាំទៅតាមទីមានក្បាល
ទឹក[ដ] ១១អញនឹងធ្វើអស់ទាំងភ្នំរបស់អញឱ្យជាផ្លូវ ឯអស់
ទាំងថ្នល់[ឋ]របស់អញ នឹងបានលើកឡើង[ឌ] ១២មើល ពួកនេះ
នឹងមកពីទីចំងាយ[ឍ] ហើយមើល ពួកនោះនឹងមកពីទិសខាង
ជើង និងពីទិសខាងលិច[ណ] ហើយពួក១នេះពីស្រុកស៊ីនីម
១៣ឱផ្ទៃមេឃអើយ ចូរច្រៀងឡើង[ត] ឱផែនដីអើយ[ថ] ចូរ
ឱ្យអរសប្បាយចុះ ឱភ្នំទាំងឡាយអើយ[ទ] ចូរធ្លាយចេញ
ជាបទចំរៀង ពីព្រោះព្រះយេហូវ៉ាទ្រង់បានកំសាន្តចិត្ត[ធ]
រាស្ត្រទ្រង់ហើយ ទ្រង់នឹងមានព្រះហឫទ័យអាណិតអាសូរ[ន]
ដល់ពួករបស់ទ្រង់ដែលត្រូវរងទុក្ខវេទនាផង[ប] ។
១៤តែក្រុងស៊ីយ៉ូន[ផ]បានថា ព្រះយេហូវ៉ាទ្រង់បានបោះ
បង់ចោល[ព]ខ្ញុំទេ គឺព្រះអម្ចាស់ទ្រង់បានភ្លេចខ្ញុំហើយ ១៥ចុះ
តើស្ត្រីនឹងភ្លេចកូនដែលកំពុងបៅដោះ ឥតមានអាណិត
ដល់កូន[ភ]ដែលចេញពីផ្ទៃខ្លួនមកបានដែរឬ អើ គេនឹងភ្លេច
បាន ប៉ុន្តែអញមិនដែលភ្លេចឯងឡើយ[ម] ១៦មើល អញបាន
ចារិក[យ]ឯងទុកនៅផ្ទៃបាតដៃរបស់អញហើយ អស់ទាំង
កំផែង[រ]ឯងនៅចំពោះភ្នែកអញជានិច្ច ១៧ពួកកូនចៅរបស់
ឯងនឹងប្រញាប់ឡើង ពួកដែលបំផ្លាញឯង ហើយពួកដែល
រំលាង[ល]ឯង គេនឹងចេញពីឯងទៅ ១៨ចូរងើបភ្នែកឡើង
មើលជុំវិញចុះ ពួកទាំងនេះគេមូលគ្នា[វ]ចូលមកឯឯង ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អញស្បថនឹងជីវិតអញថា[ស]
ប្រាកដជាឯងនឹងបានប្រដាប់កាយ[ហ] ដោយអ្នកទាំងនោះ
ដូចជាពាក្យគ្រឿងលំអ ហើយក្រវាត់ខ្លួន ដោយអ្នកទាំង
នោះ ដូចជាប្រពន្ធថ្មោងថ្មីដែលតែងខ្លួនដែរ ១៩ដ្បិតឯទី
កន្លែងដែលរំលាង ហើយចោលស្ងាត់[ឡ] និងស្រុកឯងដែល
ត្រូវបំផ្លាញនោះ[អ] ឥឡូវនេះនឹងបានជាទីចង្អៀតណែនដល់
ពួកអ្នកដែលអាស្រ័យនៅវិញ[ក] ហើយពួកអ្នកដែលបាន
លេប[ខ]ឯង គេនឹងនៅឆ្ងាយពីឯងហើយ ២០ពួកកូនចៅឯង
ដែលកើតក្នុងសេចក្តីទុក្ខលំបាករបស់ឯង គេនឹងនិយាយ
ដាក់ត្រចៀកឯងថា ទីនេះចង្អៀតដល់យើងខ្ញុំណាស់ សូម
ឱ្យមានទីអាស្រ័យនៅផង[គ] ២១នោះឯងនឹងនឹកក្នុងចិត្តថា
តើអ្នកណាបានបង្កើតកូនទាំងនេះឱ្យអញ[ឃ] ដ្បិតអញបាន
បាត់កូនចៅអញអស់ទៅ ហើយអញក៏នៅឯកឯងដូច្នេះ គឺជា
អ្នកដែលត្រូវបំបរបង់[ង] ហើយដើរសាត់ព្រាត់ផង[ច] តើអ្នក
ណាបានចិញ្ចឹមកូនទាំងនេះ[ឆ] មើល អញបានត្រូវចោល[ជ]
នៅតែឯង[ឈ] ដូច្នេះ តើកូនទាំងនេះបាននៅឯណា ។

**៤៩:១០** ជ ទដ ១២១:៦ វវ ៧:១៦ ឈ អស ១៤:១ ញ ទដ ៤៨:១៤ អស ៤២:១៦ ៤៨:១៧ ដ អស ៣៣:២១ ៣៥:៧ **៤៩:១១** ឋ អស ១១:១៦ ឌ អស ៤០:៤ យរ ៣១:៩ **៤៩:១២** ឍ អស ២:៣ ១១:១១ ៤៣:៥–៦ ណ អស ៥៩:១៩ មថ ៨:១១ **៤៩:១៣** ត អស ៤៨:២០ ថ ទដ ៩៦:១១ ទ ទដ ៦៥:១២–១៣ ៩៨:៤ អស ៤៤:២៣ ធ ទដ ៧១:២១ អស ៤០:១ ២កថ ១:៤ ន អស ១៤:១ ប ទដ ៩:១២ **៤៩:១៤** ផ អស ៤០:៩ ព ទដ ៩:១០ ៧១:១១ អស ២៧:៨ **៤៩:១៥** ភ ១ពវ ៣:២៦ អស ៦៦:១៣ ម អស ៤៤:២១ **៤៩:១៦** យ លប ៣៨:១៨ នក ២៨:៩ រ ទដ ៤៨:១២–១៣ អស ៦២:៦ **៤៩:១៧** ល អស ៥:៦ ១០:៦ ៣៧:១៨ **៤៩:១៨** វ អស ១១:១២ ១៤:១ ៤៣:៥ ៥១:៣ ៥៤:៧ ស ជន ១៤:២១ អស ៤៥:២៣ ៥៤:៩ ៦២:៨ រម ១៤:១១ ហ អស ៥២:១ ៦១:១០ យរ ២:៣២ **៤៩:១៩** ឡ លវ ២៦:៣៣ អស ៥៤:១,៣ ៦០:១៨ ៦២:៤ អ អស ៥:៦ ក អគ ៣៦:១០–១១ សក ១០:១០ ខ អស ១:២០ **៤៩:២០** គ អស ៥៤:១–៣ សក ២:៤ ១០:១០ **៤៩:២១** ឃ អស ២៩:២៣ ៦៦:៧–៨ ង អស ៤៧:៨ ៥៤:១ ច អស ៥:១៣ ៥៤:៦ ឆ អស ៦០:៨ ជ អស ១:៨ ឈ ទដ ១៤២:៤ អស ៥១:១៨ យរ ១០:២០

*គេទៅ* គឺជាតួនាទីរបស់អ្នកគង្វាល (សូមមើល ៤០:១១ និងការពន្យល់) ។ ខទាំងនេះគឺក៏ជាការបង្ហាញឱ្យឃើញរូបភាពពិតនៃនគរស្ថានសួគ៌ គឺតាមរយៈ វវ ៧:១៦–១៧ ។

**៤៩:១១** *ទាំងភ្នំរបស់អញឱ្យជាផ្លូវ* សូមមើល ២៦:៧ និងការពន្យល់។ *ថ្នល់ . . . បានលើកឡើង* មើល ១១:១៦ ៣៥:៨ ៤០:៣ ៦៣:១០ និងការពន្យល់ ។

**៤៩:១២** *មកពីទីចំងាយ* មើល ១១:១១ និងការពន្យល់ ៦០:៤ ។ ពាក្យថា *ពីទិសខាងជើងនឹងពីទិសខាងលិច* សូមមើល ៤៣:៥–៦ និងការពន្យល់ ។ *ស្រុកស៊ីនីម* សូមមើល អគ ២៩:១០ និង ៣០:៦ ដែលមានទីតាំងនៅចុងភូមិភាគខាងជើងនៃស្រុកអេស៊ីព្ទ ។

**៤៩:១៣** *ចូរច្រៀងឡើង* គឺជានិស្ស័យមួយក្នុងគម្ពីរ អេសាយ សូមមើល ៤:២៣ និងការពន្យល់ ។ ពាក្យថា បានកំសាន្តចិត្តរាស្ត្រទ្រង់ គឺក្នុងខណៈពេលទ្រង់បានប្រោសលោះនិងបានសង្គ្រោះពួកគេ សូមប្រៀបធៀប ២កថ ១:៣–៤ ។ *នឹងមានព្រះទ័យអាណិតអាសូរ* សូមមើល ខ.១០ និងការពន្យល់ ៥៤:៧–១០ ។

**៤៩:១៤** *បានបោះ . . . ភ្លេចខ្ញុំហើយ* សូមមើល ៤០:២៧ ៥៤:៧ បទ ៥:២០–២២ ។

**៤៩:១៥** *តើស្ត្រីនឹងភ្លេចកូន . . . ?* សូមប្រៀបធៀប ទដ ២៧:១០ ។

**៤៩:១៦** *អញបានចារិតឯងទុកនៅផ្ទៃបាតដៃរបស់អញ* ក្នុងនាមជាពូជអំបូរនៃរាស្ត្រអ៊ីស្រាអែល គឺត្រូវបានចុះចារិតទុកលើផ្ទាំងសីលា និងជាកិច្ចការសង្ឃឹមដ៏ខ្ពស់បំផុតទុកជាទីសម្រាប់នឹកគុណនៅពីខាងមុខព្រះយេហូវ៉ា (នក ២៨:៩–១២ ប្រៀបធៀបនិង ចំរៀងទំនុកដំកើង ៨:៦) ។ ចំពោះមុខអញជានិច្ចប្រៀបធៀប ទដ ១៣៧:៥–៦ ។

**៤៩:១៧** *ពួកកូនចៅ* ឬក៏ជា"អ្នកកសាង"សូមតាមដានអានក្រាំងសមុទ្រស្លាប់និងអត្ថបទសម័យបុរាណ (ប្រៀបធៀបការពន្យល់ ៦២:៥) ។

**៤៩:១៨** *គេមូលចូលមក* សូមមើល ខ.៥,១២ និងការពនព្យល់ ។ *គ្រឿងលំអ* គឺជាសំលៀកបំពាក់ដ៏ស្រស់ស្អាត ដែលបំពាក់ដោយគ្រឿងអលង្ការ ។

**៤៩:១៩–២០** *ជាទីចង្អៀតណែន* តែទ្រង់បានធ្វើឱ្យរាស្ត្រអ៊ីស្រាអែលមានស្រុកឡើងវិញដែលជារឿងគួរឱ្យមានភាពភ្ញាក់ផ្អើល ។ គឺសេចក្តីទំនាយបានសម្រេច គឺក្នុងការដែលបាលវិលត្រឡប់ពីស្រុកបាប៊ីឡូនវិញ (សូមមើលការពន្យល់ ១១:១១) និងចំពោះកូនចៅទាំងសាសន៍យូដា និងសាសន៍ដទៃ (សូមមើល ៥៤:១៧ និងការពន្យល់) ។

**៤៩:១៩** *ត្រូវបំផ្លាញនោះ . . .* សូមប្រៀបធៀប ខ.៨ សូមមើល ៤៤:២៦ និងការពន្យល់ ។

**៤៩:២១** *បានបាត់កូនចៅអញ . . . អញក៏នៅឯកឯង* គឺទស្សនៈរបស់សាសន៍អ៊ីស្រាអែលមានលក្ខណៈដូចជាឯកឯង គឺជាស្ត្រីម្នាក់ដែលបានបញ្ជាក់ក្នុង ៥៤:១ (ប្រៀបធៀប ទដ ១១៣:៩ និងការពន្យល់) ។

២២ព្រះអម្ចាស់យេហូវ៉ា[ញ]ទ្រង់មានបន្ទូលថា មើលអញ
នឹងបោយដៃហៅអស់ទាំងសាសន៍ ហើយនិងលើកទង់ជ័យ[ដ]
អញឡើងសំរាប់ប្រជាជាតិទាំងឡាយ រួចគេនឹងបីយក[ឋ] កូន
ប្រុសៗរបស់ឯងមក ហើយនឹងបញ្ជិះកូនស្រីៗរបស់ឯងនៅ
លើស្មាគេ[ឌ] ២៣ពួកមហាក្សត្រ[ឍ]នឹងធ្វើជាឪពុកចិញ្ចឹមឯង
ហើយពួកអគ្គមហេសីនឹងធ្វើជាម្ដាយបំបៅឯង[ណ] គេនឹង
ក្រាបផ្កាប់មុខ[ត]ដល់ដីនៅមុខឯង ហើយនិងលិទ្ធធូលីដី[ថ]
ដែលជាប់ជើងឯង នោះឯងនឹងដឹងថា អញនេះជាព្រះ
យេហូវ៉ា[ទ] ហើយអស់អ្នកដែលសង្ឃឹម[ធ]ដល់អញនឹងមិនត្រូវ
ខ្មាសឡើយ[ន]។
២៤តើនឹងឆក់យករបឹបពីអ្នកខ្លាំងពូកែ[ប] ឬដោះពួក
ឈ្លើយ ដែលចាប់មកតាមច្បាប់ចេញបានឬទេ ២៥តែ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ទោះទាំងពួកឈ្លើយ[ផ]
របស់មនុស្សខ្លាំងពូកែ[ព]ក៏នឹងត្រូវឆក់យកទៅ ហើយរបឹប
របស់ពួកគួរស្ញែងខ្លាច[ភ]នឹងបានដោះចេញផង ដ្បិតអញនឹង
តតាំងចំពោះអ្នកដែលតតាំងនឹងឯង[ម,យ] ហើយអញនឹងជួយ
សង្គ្រោះកូនចៅឯងដែរ[រ] ២៦អញនឹងធ្វើឱ្យពួកអ្នកដែល
សង្កត់សង្កិន[ល]ឯងត្រូវស៊ី[វ]សាច់របស់ខ្លួនគេវិញ ហើយគេនឹង
ត្រូវស្រវឹងដោយឈាមរបស់ខ្លួន[ស] ដូចជាស្រវឹងដោយស្រា
ទំពាំងបាយជូរថ្មី នោះគ្រប់ទាំងមនុស្សនឹងដឹង[ហ]ថា អញ
នេះ គឺយេហូវ៉ា ជាព្រះអង្គសង្គ្រោះនៃឯង[ឡ] ហើយជាព្រះដ៏
ប្រោសលោះឯង[អ] គឺជាព្រះដ៏មានឥទ្ធិឫទ្ធិនៃយ៉ាកុប[ក]។

**៤៩:២២** ញ លប ១៥:២ ដ អស ១១:១០ ឋ អស ១១:១២ ១៤:២ ឌ លក ១៥:៥ **៤៩:២៣** ឍ អស ៦០:៣,១០–១១ ណ ជន ១១:១២ អស ៦០:១៦ ត លប ២៧:២៩ វវ ៣:៩ ថ លប ៣:១៤ ទដ ៧២:៩ ទ នក ៦:២ ទដ ២២:២៣ អស ៤២:៨ ធ ទដ ៣៧:៩ ១៣០:៥ ន ទដ ២២:៥ អស ២៩:២២ ៤១:១១ **៤៩:២៤** ប មថ ១២:២៩ មក ៣:២៧ លក ១១:២១ **៤៩:២៥** ផ អស ១៤:២ ព យរ ៥០:៣៣–៣៤ មក ៣:២៧ ភ អស ១៣:១១ ២៥:៤ ម អស ២៥:៥ ៤៣:២៦ ៥១:២២ យរ

## អំពើបាបរបស់ពួកអ៊ីស្រាអែល និងការស្ដាប់បង្គាប់របស់អ្នកបម្រើ

**៥០** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា សំបុត្រលះ
លែងដែលអញឱ្យដល់ម្ដាយឯង ដើម្បីបណ្ដេញចេញ[ក]នោះ
តើនៅឯណា ឬតើអញបានលក់[ខ]ឯងដល់ម្ចាស់បំណុលរបស់
អញណាមួយ មើល ដែលឯងត្រូវលក់[គ]ទៅនោះ ក៏ដោយ
ព្រោះអំពើទុច្ចរិត[ឃ]របស់ឯងទេ ហើយដែលម្ដាយឯងត្រូវ
បណ្ដេញនោះ ក៏ដោយព្រោះអំពើរំលងរបស់ឯងរាល់គ្នា
ដែរ ២ដូច្នេះ កាលអញបានមកដល់ ហេតុអ្វីបានជាគ្មានអ្នក
ណាមួយសោះ កាលអញបានហៅនោះ ហេតុអ្វីបានជា
គ្មានអ្នកណាឆ្លើយតប[ង] តើដៃអញបានរួញខ្លី[ច]នឹងជួយលោះ
ឯងមិនបានឬ តើអញគ្មានអំណាច[ឆ]នឹងដោះឱ្យរួចទេឬអី
មើល កាលណាអញស្ដីឱ្យ[ជ] នោះសមុទ្រក៏រីងស្ងួតទៅ[ឈ]
ហើយទន្លេក៏ទៅជាទីហួតហែង[ញ] ឯត្រីក៏ធុំស្អុយ ដោយគ្មាន

៥០:៣៤ យ ១សយ ២៤:១៥ រ អស ២៥:៩ ៣៣:២២ ៣៥:៤ **៤៩:២៦** ល អស ៩:៤ ១៣:១១ វ អស ៩:២០ ស ជន ២៣:២៤ យរ ២៥:២៧ ណាហ ១:១០ ៣:១០ វវ ១៦:៦ ហ នក ៦:៧ អស ១១:៩ អគ ៣៩:៧ ឡ អស ២៥:៩ អ យប ១៩:២៥ អស ៤៨:១៧ ក លប ៤៩:២៤ ទដ ១៣២:២ **៥០:១** ក ចទ ២៤:១ ហស ២:២ មថ ១៩:៧ មក ១០:៤ ខ នហ ៥:៥ មថ ១៨:២៥ គ ចទ ៣២:៣០ ពច ៣:៨ ឃ អស ១:២៨ **៥០:២** ង ១សយ ៨:១៩ អស ៣១:២៨ ច ជន ១១:២៣ អស ៥៩:១ ឆ លប ១៨:១៤ ទដ ៦៨:៣៥ យរ ១៤:៩ ជ ទដ ១៨:១៥ ឈ នក ១៤:២២ ញ ទដ ១០៧:៣៣

**៤៩:២២** *លើកទង់ជ័យអញ* សូមមើល ៥:២៦ និងការពន្យល់ ១៣:២ ។ *បីយកកូនប្រុសៗរបស់ឯងមក . . . បញ្ជិះកូនស្រីៗ* សូមមើល ១១:១២ និងការពន្យល់ ។ គឺជាជាតិសាន៍ទាំងនោះបាននាំសាសន៍អ៊ីស្រាអែលមកឯស្រុកវិញ មើលក្នុង ១៤:២ ៤៣:៦ ៦០:៩ ។ ពាក្យថា *នៅលើស្មាគេ* សូមប្រៀបធៀប ៦០:៩៤ សូមមើល ៤០:១១ និងការពន្យល់ ។

**៤៩:២៣** *ពួកមហាក្សត្រ . . . នឹងក្រាបផ្កាប់មុខដល់ដី* សូមមើល ខ.៧ ១១:១៤ និងការពន្យល់ ។ *នឹងដឹងថាអញនេះជាព្រះយេហូវ៉ា* សូមមើល ខ.២៦ ៦០:១៦ អគ ១២:២០ ១៣:៩ ៣៦:៣៨ ។ *សង្ឃឹមដល់អញ* សូមមើល ៤០:៣១ និងការពន្យល់ ។ *មិនត្រូវខ្មាស់ឡើយ* សូមមើល ២៩:២២ និងការពន្យល់ ។

**៤៩:២៤** *អ្នកខ្លាំងពូកែ* គឺពួកមកពីស្រុកបាប៊ីឡូន (សូមមើល ៥១:១៣) ។

**៤៩:២៥** *ពួកឈ្លើយ . . . ក៏នឹងត្រូវឆក់យកទៅ* មើល អគ ២:១,៦៤–៦៥ យរ ៥០:៣៣–៣៤ ៥២:២៧–៣០ ។ *ហើយអញនិងតាំង* ព្រះអម្ចាស់បានវ៉ាប់រងដល់រាស្ត្ររបស់ផងទ្រង់ គឺទ្រង់និងការពារគ្រប់ហេតុផលទាំងអស់ ។ (យរ ៥០:៣៤) ពាក្យថា *អញនឹងជួយសង្គ្រោះ* សូមមើល ៣៥:៤ និងការពន្យល់ ។

**៤៩:២៦** សូមមើល ១៤:៤ ១៦:៤ ៥១:១៣ ។ ពាក្យថា *ស៊ីសាច់របស់ខ្លួនវិញ* គឺក្នុងពេលមានការឡោមព័ទ្ធទីក្រុងយេរូសាឡិមនិងព័ទ្ធប្រជាជន នោះគេក៏បន្ថយការស៊ីសាច់មនុស្ស (បទ ៤:១០ ប្រៀបធៀប សក ១១:៩ និងការពន្យល់) ។ *ត្រូវស្រវឹងដោយឈាមរបស់ខ្លួន* ប្រៀបធៀប ២២:២៣ ។ ពាក្យថា *គ្រប់ទាំងមនុស្សនឹងបានដឹង* សូមមើល ខ.២៣ និងការពន្យល់ ។ *ព្រះអង្គសង្គ្រោះ* សូមមើល ៤៣:៣ និងការពន្យល់ ៦០:១៦ ។

**៥០:១** *សំបុត្រលះលែង* ក្នុងនាមជាប្ដីគេតម្រូវឱ្យយកសំបុត្រលះលែងទៅឱ្យប្រពន្ធបើគាត់មានបំណងលែងលះ (សូមមើល ចទ ២៤:១–៤ មថ ១៩:៣ មក ១០:២,៥–៦ និងការពន្យល់) ។ បើតាមគម្ពីរ យរ ព្រះបានប្រទានឱ្យពួកនគរខាងជើងស្រុកអ៊ីស្រាអែល នូវសំបុត្រលះលែង ។ អស ៥៤:៦–៧ ក៏បង្ហាញថាព្រះអម្ចាស់បានចាកចេញពីស្រុកយូដា (មើល ៦២:៤) ។ ក៏បង្ហាញថាព្រះអម្ចាស់មិនដែលផ្ដើមឱ្យមានការលែងលះគ្នាទេ ។ ឯសាសន៍យូដាបានផ្ដាច់ចំណងទំនាក់ទំនងជាមួយទ្រង់ ។ ក៏មានការនិរទេសហើយក៏មានការបាក់បែកគ្នាមួយរយៈ (មើល ៥៤:៧) គឺវាប្រសើរជាងការលែងលះ ។

**៥០:២** *អញបានមកដល់ . . . អញបានហៅ* គឺហៅតាមរយៈបាវបម្រើរបស់ទ្រង់គឺជាពួកហោរា (សូមមើល យរ ៧:២៥ និងការពន្យល់) ។ *គ្មានអ្នកណាឆ្លើតតប* គឺរាស្ត្រអ៊ីស្រាអែលមានត្រចៀកផងចំពោះព្រះ (សូមមើល ៦០:១០ និងការពន្យល់ ៦៦:៤) ។ *តើដៃអញបានរួញខ្លី* ដៃគឺជាតំណាងអំណាចព្រះចេស្ដា ។ ពាក្យថា *សមុទ្រក៏រីងស្ងួតទៅ* គឺសំដៅទៅលើការឆ្លងកាត់សមុទ្រក្រហម សូមមើល ៤៣:១៦–១៧ និងការពន្យល់ ទដ ១០៦:៩ ។ *ទន្លេក៏ទៅជាទីហួតហែង* សូមមើល ៤២:១៥ និងការពន្យល់ ។ ពាក្យថា *ឯត្រីក៏ធុំស្អុយ* គឺវាអាចជាការសំដៅទៅលើភាពរុកគួន ឬគ្រោះអាក្រក់ដែលកើតមានក្នុង

ទឹក ហើយនិងស្លាប់ទៅដោយស្រេកដែរ ៣អញបំពាក់ផ្ទៃ
មេឃដោយពពកខ្មៅ[ដ] ហើយក៏ដណ្ដប់ទៅ ដោយសំពត់ផ្ទៃ[ឋ]
ផង ។
៤ព្រះអម្ចាស់យេហូវ៉ា[ឌ] ទ្រង់បានប្រទានឱ្យខ្ញុំមានវោ–
ហារ[ឍ] ដូចជាអ្នកដែលបានរៀនសូត្រហើយ ដើម្បីឱ្យខ្ញុំបាន
ចេះប្រើពាក្យសំដី និងជ្រោងមនុស្សគ្រាកចិត្តឡើង[ណ] ទ្រង់
ដាស់ខ្ញុំរាល់តែព្រឹក[ត] គឺទ្រង់ដាស់ត្រចៀកខ្ញុំ ដើម្បីឱ្យខ្ញុំស្ដាប់
ដូចជាអ្នកដែលកំពុងតែរៀនសូត្រ[ថ] ៥ព្រះអម្ចាស់យេហូវ៉ា[ទ]
ទ្រង់បានបើកត្រចៀកខ្ញុំហើយ[ធ] ខ្ញុំមិនបានរឹងចចេស[ន]ឬ
បែរក្រោយឡើយ ៦ខ្ញុំបានប្រគល់ខ្នងទៅឱ្យពួកអ្នកដែល
វាយ[ប] ហើយថ្ពាល់ខ្ញុំទៅឱ្យពួកដែលបោចពុកចង្កា[ផ] ខ្ញុំមិន
បានគេចមុខពីសេចក្ដីអាម៉ាស់ខ្មាស ឬពីការស្តោះទឹកមាត់
ទេ[ព] ៧ពីព្រោះព្រះអម្ចាស់យេហូវ៉ា[ភ]ទ្រង់នឹងជួយ[ម]ខ្ញុំ ហេតុ
នោះបានជាខ្ញុំមិនត្រូវជ្រប់មុខ ហើយដោយហេតុនោះ
ខ្ញុំបានកាត់ចិត្ត ឱ្យរឹងដូចថ្មដែកភ្លើង[យ]ហើយ ខ្ញុំដឹងថា ខ្ញុំមិន
ត្រូវខ្មាសឡើយ[រ] ៨ព្រះដែលតាំងខ្ញុំជាសុចរិត[ល] ទ្រង់គង់នៅ
ជិត[វ] តើអ្នកណានឹងតវ៉ាចំពោះខ្ញុំទៀត[ស] ចូរយើងឈរឡើង
ជាមួយគ្នា[ហ] តើអ្នកណាដែលជាទំនាស់នឹងខ្ញុំ ត្រូវឱ្យអ្នកនោះ
ចូលមកជិតខ្ញុំចុះ ៩មើល ព្រះអម្ចាស់យេហូវ៉ា[ឡ]ទ្រង់នឹងជួយ[អ]
ខ្ញុំ តើអ្នកណានឹងពោលទោស[ក]ខ្ញុំបាន មើល គេនឹងចាស់ទៅ
ទាំងអស់គ្នា ដូចជាសំលៀកបំពាក់ ហើយកន្លាត[ខ]នឹងកាត់គេ
អស់ទៅ ។
១០ក្នុងពួកឯងរាល់គ្នា តើមានអ្នកណាដែលកោតខ្លាច[គ]
ដល់ព្រះយេហូវ៉ា ដែលស្ដាប់តាម[ឃ]សំឡេងរបស់អ្នកបំរើ
ទ្រង់[ង] ឯអ្នកដែលដើរក្នុងសេចក្ដីងងឹត ឥតមានពន្លឺសោះ[ច]
ត្រូវឱ្យអ្នកនោះទុកចិត្ត[ឆ] ដល់ព្រះនាមនៃព្រះយេហូវ៉ា ហើយ
ផ្អែកទៅលើព្រះនៃខ្លួនចុះ ១១នែ អស់អ្នកដែលបង្កាត់ភ្លើង
ជាអ្នកដែលក្រវាត់ខ្លួនដោយកន្ទុយឧសអើយ[ជ] ចូរឱ្យឯង
រាល់គ្នាដើរក្នុងអណ្ដាតភ្លើង[ឈ]របស់ឯង ហើយកណ្ដាល
កន្ទុយឧសដែលឯងបានបង្កាត់នោះចុះ ឯងនឹងបានតែ

**៥០:៣** ដ នក ១០:២២ អស ៥:៣០ ឋ វវ ៦:១២ **៥០:៤** ឌ ខ.៥ អស ៦១:១ ឍ នក ៤:១២ ណ អស ៤០:២៩ មថ ១១:២៨ ត ទជ ៥:៣ ៨៨:១៣ ១១៩:១៤៧ ១៤៣:៨ ថ អស ២៨:៩ **៥០:៥** ទ អស ៤៨:១៦ ធ អស ៣៥:៥ ន អគ ២:៨ ២៤:៣ មថ ២៦:៣៩ យហ ៨:២៩ ១៤:៣១ ១៥:១០ កច ២៦:១៩ ហព ៥:៨ **៥០:៦** ប អស ៥៣:៥ មថ ២៧:៣០ មក ១៤:៦៥ ១៥:១៩ លក ២២:៦៣ យហ ១៩:១ ផ ២សយ ១០:៤ ព ជន ១២:១៤ ជន ១២:១៤ បទ ៣:៣០ មថ ២៦:៦៧ មក ១០:៣៤ **៥០:៧** ភ អស ៤៨:១៦ ម អស ៤១:១០ ៤២:១ យ យរ ១:១៨ ១៥:២០ អគ ៣:៨–៩ រ អស ២៨:១៦ ២៩:២២ **៥០:៨** ល អស ២៦:២ ៤៩:៤ វ ទជ ៣៤:១៨ ស យប ១៣:១៩ អស ៤៣:២៦ រម ៨:៣២–៣៤ ហ អស ៤១:១ **៥០:៩** ឡ អស ៤៨:១៦ អ អស ៤១:១០ ក រម ៨:១,៣៤ ខ យប ១៣:២៨ អស ៥១:៨ **៥០:១០** គ សភ ១:៧ ឃ អស ១:១៩ ហក ១:១២ ង អស ៤៩:៣ ច ទជ ១០៧:១៤ កច ២៦:១៨ ឆ អស ១០:២០ ២៦:៤ **៥០:១១** ជ សភ ២៦:១៨ ឈ អស ១:៣១ យក ៣:៦

ស្រុកអេស៊ីព្ទ (សូមមើល ១៩:៥–៦,៨ នក ៧:១៨) ។

**៥០:៣** *ផ្ទៃមេឃដោយពពកខ្មៅ* គឺប្រហែលជាការនិយាយបញ្ឈៀងចំពោះគ្រោះអាក្រក់ក្នុងភាពងងឹត (នក ១០:២១) ក៏សូមមើល ១៣:១០ ផងដែរ ។

**៥០:៤–៩ (ឬ ៤–១១)** គឺជាអត្ថន័យនៃបទចម្រៀងទី៣ បង្ហាញពីអ្នកបម្រើបួនអ្នក (សូមមើលការពន្យល់ ៤២:១–៤) ។

**៥០:៤–៥,៧,៩** *ព្រះអម្ចាស់យេហូវ៉ា* ពាក្យនេះបានប្រើតែក្នុងអត្ថបទនេះ គឺជាទំនុករបស់អ្នកបម្រើ ។

**៥០:៤** *ប្រើពាក្យសំដីនឹងជ្រោងមនុស្សគ្រាកចិត្តឡើង* សូមមើលក្នុង ៤២:៣ (គឺមានលក្ខណៈខុសនឹង ៤៩:២) សូមប្រៀបធៀបនិង យរ ៣១:២៥ ។ *ទ្រង់ដាស់ត្រចៀកខ្ញុំ* គឺគ្មានលក្ខណៈដូចជារាស្ត្រអ៊ីស្រាអែលទេ (សូមមើល ខ.២) គឺជាប្រភេទអ្នកបម្រើដែលឆ្លើយតបចំពោះព្រះ ។

**៥០:៥** *បើកត្រចៀកខ្ញុំ* គឺបង្ហាញពីសញ្ញានៃការស្ដាប់បង្គាប់ (សូមមើល ១:១៩ ទជ ៤០:៦ និងការពន្យល់) ។ *ខ្ញុំមិនបានរឹងចចេស* គឺពុំដូចរាស្ត្រអ៊ីស្រាអែលទេ (សូមមើល ១:២ និងការពន្យល់ ១:២០) ។

**៥០:៦** *ប្រគល់ខ្នងទៅឱ្យពួកអ្នកដែលវាយហើយថ្ពាល់ខ្ញុំ* ការវាយធ្វើបាបគឺសម្រាប់ពួកជនឧក្រិដ្ឋ ឬក៏ពួកមនុស្សវិកល (សូមមើល សក ១០:៣០ ១៩:២៩ ២៦:៣ មថ ២៧:២៦ យហ ១៩:១) ។ *ដែលបោចពុកចង្កា* នេះបង្ហាញពីការមិនគោរពដែលមានលក្ខណៈព្រហើន (សូមមើល ២សយ ១០:៤–៥ នហ ១៣:២៥) ។ *ពីសេចក្ដីអាម៉ាស់ខ្មាស់ ឬពីការស្ដោះទឹកម៉ាត់* គឺបញ្ជាក់ពីការដែលស្អប់យ៉ាងខ្លាំង (យប ៣០:១០) ឬជាការប្រមាតមើលងាយ (ចទ ២៥:៩ យប ១៧:៦ មថ ២៧:៣០) ។ គឺសម្ដែងពីការបង្ហាញឱ្យឃើញមុខនូវអ្នកបម្រើពីការឈឺចាប់យ៉ាងខ្លាំង ៥២:១៣–៥៣:១២ ។

**៥០:៧** *នឹងជួយខ្ញុំ* សូមមើល ខ.៩ ៤៩:៨ ។ ពាក្យថា *មិនត្រូវខ្មាសឡើយ* សូមមើល ២៩:២២ និងការពន្យល់ ។ នៅទីបញ្ចប់អ្នកបម្រើនោះនិងត្រូវបានគេគោរពកោតខ្លាច (មើល ៤៩:៧ ៥២:១៣ ៥៣:១០–១២) ។ ពាក្យថា *ត្រូវជ្រប់មុខ* គឺដូចជាពួកហោរា ដែលជាអ្នកបម្រើដែលមានការអត់ធ្មត់ខ្ពស់ក៏មានការសម្រេចចិត្តខ្ពស់ មើលការប្រៀបធៀប លក ៩:៥១ ។ ក៏ដូចជាតំបន់ដែលព្រះយេស៊ូវគ្រីស្ទបានកំណត់យ៉ាងច្បាស់ សម្រាប់ទីក្រុងយេរូសាឡិម) ។

**៥០:៨** *តាំងខ្ញុំជាសុចរិត* គឺដោយបានឃើញពីភាពសុចរិតរបស់គាត់ (សូមមើល ៤៥:២៥) គឺដើម្បីជាការបំពេញសម្រេចចុងក្រោយ ។ សូមមើល ១ធថ ៣:១៦ ។ *ទំនាស់* សូមមើល ៤៩:២៥ និងការពន្យល់ ។ ពីព្រោះព្រះគ្រីស្ទគឺទ្រង់គ្មានបាបគ្មានទោសកំហុស ។ ទ្រង់លើកលែងទោសចំពោះអ្នកណាដែលជឿដល់ព្រះនាមទ្រង់ ។ (សូមមើល រម ៨:៣១–៣៤ និងការពន្យល់) ។ *អ្នកណានឹងតវ៉ាចំពោះខ្ញុំ* សូមមើលការប្រៀបធៀប ៥៤:១៧ ។

**៥០:៩** *តើអ្នកណានឹងពោលទោសខ្ញុំបាន* គឺលោកប៉ុលបានប្រើភាសាដូចគ្នាដូចក្នុងគម្ពីរ រម ៨:៣៤ ។ *គេនឹងចាស់ទៅទាំងអស់គ្នាដូចជាសំលៀកបំពាក់* គឺចំពោះអ្នកដែលចោទប្រកាន់ខុសចំពោះអ្នកបរិសុទ្ធ ។ សូមមើលក្នុង ៥១:៨ (ពួកគេនិងវិនាសសូន្យ) ។

**៥០:១០** *កោតខ្លាចដល់ព្រះយេហូវ៉ា* សូមមើល លប ២០:១១ សភ ១:៧ និងការពន្យល់ ប្រៀបធៀប ២៥:៣ ៥៩:១៩ ។ *ក្នុងសេចក្ដីងងឹត* គឺអាចជាបញ្ហា កង្វល់ឬក៏ភាពវេទនាដែលស្រដៀងចំពោះបទពិសោធន៍ របស់អ្នកបម្រើ (សូមមើលការប្រៀបធៀប ៨:២២) ។ *ទុកចិត្តដល់ . . . ផ្អែកទៅលើ* គឺព្រះយេហូវ៉ាបានលើកទឹកចិត្តឱ្យទុកចិត្តលើការល្អ សូមមើលក្នុង ១២:២ ៣១:១ ។

**៥០:១១** *បង្កាត់ភ្លើង . . . អណ្ដាតភ្លើង* គឺចង់និយាយអំពីពួកដែលប្រព្រឹត្តការ

ប៉ុណ្ណោះពីដៃអញ[ញ] ហើយឯងរាល់គ្នានឹងត្រូវដេកទៅ
ដោយទុក្ខវេទនា[ដ] ។

**សេចក្ដីសង្គ្រោះដ៏អស់កល្បជានិច្ចសម្រាប់ទីក្រុងស៊ីយ៉ូន**

**៥១** ១ឱឯងរាល់គ្នាដែលខំដេញតាមសេចក្ដីសុចរិត[ក]
ហើយស្វែងរក[ខ]ព្រះយេហូវ៉ាអើយ ចូរស្ដាប់[គ]តាមអញចុះ
ចូរមើលចំទៅឯថ្មដា[ឃ] ជាទីដែលបានដាប់ឯងរាល់គ្នាចេញ
មក ហើយទៅឯរំលុង គឺជារណ្ដៅដែលជាកន្លែងបានជីក
យកឯងឡើងមកនោះ ២ចូរមើលទៅឯអ័ប្រាហាំ[ង] ជា
ឰយុកោឯង ហើយទៅឯសារ៉ាដែលបង្កើតឯងមក ដ្បិត
កាលអ័ប្រាហាំនៅតែម្នាក់ឯង នោះអញបានហៅមក ក៏
បានឱ្យពរផង ហើយបានចំរើនឱ្យមានគ្នាជាច្រើនវិញ[ច]
៣ពីព្រោះព្រះយេហូវ៉ា ទ្រង់បានកំសាន្តចិត្ត[ឆ]ក្រុងស៊ីយ៉ូន[ជ]
ទ្រង់បានដោះទុក្ខអស់ទាំងកន្លែងខូចបង់របស់គេ[ឈ] ក៏បាន
ធ្វើឱ្យទីស្ងាត់ឈឹង បានដូចជាច្បាររអេដែន[ញ] ហើយឱ្យវាល
ប្រៃ[ដ]នោះ ត្រឡប់ដូចជាសួនរបស់ព្រះយេហូវ៉ាដែរ នឹង
មានសេចក្ដីអំណរ និងសេចក្ដីរីករាយ[ឋ]នៅក្នុងទីក្រុងនោះ
ព្រមទាំងការអរព្រះគុណ[ឌ] និងសំឡេងពីរំពីរោះផង ។
៤ឱរាស្ត្រអញអើយ ចូរប្រុងស្ដាប់តាមអញ[ឍ] ឱសាសន៍
របស់អញអើយ ចូរផ្ទៀងត្រចៀកចំពោះអញចុះ[ណ] ដ្បិតនឹង
មានច្បាប់[ត]១ចេញពីអញទៅ ហើយអញនឹងតាំងសេចក្ដី
យុត្តិធម៌[ថ]របស់អញ ទុកជាពន្លឺដល់អស់ទាំងសាសន៍[ទ] ៥ឯ
សេចក្ដីសុចរិតរបស់អញបានមកជិត សេចក្ដីសង្គ្រោះ[ធ]
របស់អញបានផ្សាយចេញទៅហើយ[ន] ដើមដៃ[ប]អញនឹង
ជំនុំជំរះអស់ទាំងសាសន៍ ឯបណ្ដាកោះ[ផ]ទាំងប៉ុន្មាន គេ
នឹងសង្ឃឹមដល់អញ ហើយនឹងទុកចិត្ត[ព]នឹងដៃអញដែរ ៦ចូរ
ងើយភ្នែក មើលទៅលើមេឃ ហើយមើលចុះមកផែនដី
ខាងក្រោយនេះទៀត ដ្បិតផ្ទៃមេឃនឹងសូន្យបាត់ទៅ ដូចជា
ផ្សែង[ភ] ហើយផែនដីនឹងចាស់ទៅដូចជាសំលៀកបំពាក់[ម]
ឯពួកអ្នកដែលនៅស្ថាននេះ នឹងស្លាប់ទៅបែបដូច្នោះដែរ
តែសេចក្ដីសង្គ្រោះ[យ]របស់អញនឹងនៅជាដរាប[រ] ហើយ
សេចក្ដីសុចរិតរបស់អញនឹងមិនត្រូវលើកចោលឡើយ[ល] ។
៧ឯងរាល់គ្នាដែលស្គាល់សេចក្ដីសុចរិត[វ] ជាជនជាតិ
ដែលមានច្បាប់របស់អញនៅក្នុងចិត្តអើយ[ស] ចូរស្ដាប់តាម
អញចុះ កុំឱ្យខ្លាចសេចក្ដីត្មះតិះដៀលរបស់មនុស្សឡើយ
ក៏កុំឱ្យស្រយុតចិត្ត ដោយពាក្យបង្អាច់របស់គេដែរ[ហ] ៨ពី

**៥០:១១** ញ ចទ ២១:២២–២៣ សភ ២៦:២៧ ដ យប ១៥:២០ អស ៦៥:១៣–១៥ **៥១:១** ក ខ.៧ ចទ ៧:១៣ ១៦:២០ ទដ ៩៤:១៥ អស ៦៣:៨ រម ៩:៣០–៣១ ខ អស ៤៦:៣ គ អស ៥៥:៦ ៦៥:១០ ឃ អស ១៧:១០ **៥១:២** ង លប ១៧:៦ អស ២៩:២២ រម ៤:១៦ ហព ១១:១១ ច លប ១២:២ **៥១:៣** ឆ អស ៤០:១ ជ ទដ ៥១:១៨ អស ៦១:៤ ឈ អស ៤៤:២៦ ៥២:៩ ៦១:៤ ញ លប ២:៨ ដ អស ៥:៦ ៤១:១៩ ឋ អស ២៥:៩ ៣៥:១០ ៦៥:១៨ ៦៦:១០ យរ ១៦:៩ ឌ យរ ១៧:២៦ ៣០:១៩ ៣៣:១១ **៥១:៤** ឍ នក ៦:៧ ទដ ៥០:៧ អស ៣:១៥ ៦៣:៨ ៦៤:៩ ណ ទដ ៧៨:១ ត ចទ ១៨:១៨ ថ អស ២:៤ ទ អស ២៦:១៨ ៤៩:៦ **៥១:៥** ធ ទដ ៨៥:៩ អស ១២:២ ន អស ៣៥:៤ ប ទដ ៩៨:១ អស ៤០:១០ ៥០:២ ៥២:១០ ៥៩:១៦ ៦៣:១,៥ ផ អស ១១:១១ ព លប ៤៩:១០ ទដ ៣៧:៩ **៥១:៦** ភ ទដ ៣៧:២០ ១០២:២៦ មថ ២៤:៣៥ លក ២១:៣៣ ២ពត ៣:១០ ម ទដ ១០២:២៥–២៦ ហព ១:១០–១២ យ អស ១២:២ រ ខ.៨ ទដ ១១៩:៨៩ ល ទដ ៨៩:៣៣ អស ៥៤:១០ **៥១:៧** វ ខ.១ ស ចទ ៦:៦ ទដ ១១៩:១១ ហ ទដ ១១៩:៣៩ អស ៥០:៧ ៥៤:៤ មថ ៥:១១ លក ៦:២២ កច ៥:៤១

អាក្រក់ គឺនិងត្រូវហីនវិនាសដល់អស់អ្នកណាដែលចូលរួមផងដែរ ។ ឯភ្លើងជាសញ្ញាទៅលើការកាត់ទោស ឬការដាក់ទណ្ឌកម្ម (សូមមើល ១:៣១ និងការពន្យល់ និងការប្រៀបធៀប ៩:១៨,៤៧,១៤ ទដ ៧:១៣) ។ ដោយទុក្ខវេទនា សូមប្រៀបធៀប ៦៦:២៤ ។

**៥១:១** *ចូរស្ដាប់តាមអញចុះ* សូមមើល ខ.៤,៧ ។ ពាក្យថា *ដែលខំដេញតាមសេចក្ដីសុចរិត* សូមប្រៀបធៀប ខ.៧ ចទ ១៦:២០ សភ ១៥:៩ ។ *ថ្មដា* ដូចជាលោកអ័ប្រាហាំ (មើល ខ.២) ដូចជានៅកន្លែងផ្សេងៗទៀតព្រះអម្ចាស់បានហៅឈ្មោះប្រៀបប្រដូចជាថ្មដាដ៏រឹងមាំងមួន (សូមមើល ១៧:១០ និងការពន្យល់) ។

**៥១:២** *នៅតែម្នាក់ឯង* សូមមើល លប ១២:១ អគ ៣៣:២៤ ។ *ក៏បានឱ្យពរផងហើយបានចំរើនឱ្យមានគ្នាជាច្រើនវិញ* ។ សូមមើល លក ១២:២–៣ ១៣:១៦ ១៥:៥ ១៧:៥ និងការពន្យល់ ២២:១៧ ។

**៥១:៣** *បានកំសាន្តចិត្តក្រុងស៊ីយ៉ូនទ្រង់បានដោះទុក្ខអស់ទាំងកន្លែងខូចបង់របស់គេ* សូមមើលការពន្យល់ ។ *ទីស្ងាត់* ទៅជាមានលក្ខណៈដូចជាសួនច្បាររអេដែន និងមានភាពស្ងួតសោះកក្រោះ ក៏មានភាពប្រែប្រួល សូមមើលក្នុង យអ ២:៣ (សូមមើលការពន្យល់ផងដែរ) សូមមើលការប្រៀបធៀប លប ២:៨,១០ ។ *មានសេចក្ដីអំណរ* មើល ខ.១១ ២៥:៩ នឹងការពន្យល់ ។

**៥១:៤** *មានច្បាប់ . . . សេចក្ដីយុត្តិធម៌របស់អញ* គោលច្បាប់របស់អ្នកបម្រើនិងនាំមកនូវភាពយុត្តិធម៌ដ៏ពិត (សូមមើល ២:២–៤ ៤២:៤ និងការពន្យល់) ។ ពាក្យថា *ទុកជាពន្លឺដល់អស់ទាំងសាសន៍* គឺជាអ្នកបម្រើដែលជាពន្លឺ ៤២:៦ ៤៩:៦ ។

**៥១:៥** *សេចក្ដីសុចរិតរបស់អញបានមកជិត* នេះជាការដោះឱ្យរួចផុតពីការចាប់ជំលៀលចេញហើយក៏មានសេចក្ដីសង្គ្រោះ ដែលបានមកដល់តាមរយៈព្រះគ្រីស្ទ គឺដល់គ្រប់ទាំងពូជសាសន៍ ។ សូមមើល ៤៦:១៣ និងការពន្យល់ ។ *ដៃ* គឺជានិមិត្តសញ្ញានៃអំណាចព្រះចេស្ដា ។ *បណ្ដាកោះ* សូម មើល ១១:១១ និងការពន្យល់ ។ *គេនឹងសង្ឃឹមដល់អញ* សូមមើល ៤០:៣១ ៤២:៤ និងការពន្យល់ ។

**៥១:៦** *ចូរងើយភ្នែកមើលទៅលើមេឃ* សូមមើល ៤០:២៦ ។ ពាក្យថា *ផ្ទៃមេឃនឹងសូន្យបាត់ទៅ* សូមមើល ៣៤:៤ និងការពន្យល់ ។ ពាក្យថា *ផែនដីនឹងចាស់ទៅដូចជាសំលៀកបំពាក់* សូមមើល ២៤:៤ ហព ១:១០–១១ សូមប្រៀបធៀបនឹង អស ៥០:៩ ។ *នឹងនៅជាដរាប* សូមមើល ខ.៨ ៤៥:១៧ ឯព្រះបន្ទូលទ្រង់និងមានគង់វង់ជាដរាប (សូមមើល ៤០:៨ និងការពន្យល់ មថ ២៤:៣៥ លក ២១:៣៣) ។

**៥១:៧** *ឯងរាល់គ្នាដែលស្គាល់សេចក្ដីសុចរិត* សូមមើល ខ.១ និងការពន្យល់ ។ *ដែលមានច្បាប់របស់អញនៅក្នុងចិត្តអើយ* សូមមើល ទដ ៣៧:៣១ យរ ៣១:៣៣ និងការពន្យល់ ។ ពាក្យថា *កុំឱ្យខ្លាចសេចក្ដីត្មះតិះដៀលរបស់មនុស្សឡើយ ក៏កុំឱ្យស្រយុតចិត្តដោយពាក្យបង្អាច់របស់គេដែរ* គឺដូចជាអ្នកបម្រើក្នុង ៥០:៦–៧ ។

ព្រោះកន្លាតនឹងកាត់ស៊ីគេ ដូចជាកាត់អាវ[ឡ] ហើយដង្កូវ[អ]នឹង
ចុះគេ ដូចជាចុះសំពត់រោមចៀម តែសេចក្តីសុចរិតរបស់
អញនឹងស្ថិតស្ថេរនៅជាដរាប[ក] ហើយសេចក្តីសង្គ្រោះផង
ដរាបដល់អស់ទាំងដំណមនុស្សតទៅ ។
[៩]ឱព្រះពាហុ[ខ]នៃព្រះយេហូវ៉ាអើយ សូមតើនឡើង សូម
តើនឡើង[គ] ហើយពាក់ជាឥទ្ធិឫទ្ធិ[ឃ] សូមតើនឡើង ដូចជា
កាលពីចាស់បុរាណ ក្នុងគ្រាដំណមនុស្សពីដើម[ង] តើមិន
មែនទ្រង់ដែលកាត់រ៉ាហាប[ច]ខ្ទេចខ្ទី ដែលចាក់ទំលុះសត្វ
សំបើម[ឆ]នោះទេឬអី [១០]តើមិនមែនទ្រង់ទេឬអី ដែលពង្រីង
ទឹកសមុទ្រ[ជ] គឺជាទឹកនៃជំរៅធំ[ឈ] ហើយបានធ្វើឱ្យបាត
សមុទ្រ[ញ]ត្រឡប់ជាផ្លូវ សំរាប់ឱ្យពួកមនុស្សដែលទ្រង់ប្រោស
លោះ[ដ]បានដើរឆ្លងទៅ [១១]ឯពួកអ្នកប្រោសលោះ[ឋ]របស់
ព្រះយេហូវ៉ា គេនឹងវិលមកវិញ ហើយមកដល់ក្រុងស៊ីយ៉ូន
ដោយច្រៀងចំរៀង[ឌ] គេនឹងមានសេចក្តីអំណរ[ឍ]ដ៏នៅអស់
កល្បជានិច្ចពាក់លើក្បាល គេនឹងទទួលបានសេចក្តីរីក
រាយ និងសេចក្តីអំណរ ឯសេចក្តីទុក្ខព្រួយនឹងដំងូរ នោះ
នឹងខ្ចាត់បាត់ទៅ[ណ] ។
[១២]អញ គឺអញនេះហើយ ជាអ្នកដែលកំសាន្តចិត្ត[ត]ឯង
រាល់គ្នា តើឯងជាអ្វីបានជាឯងខ្លាច[ថ]ចំពោះមនុស្សដែល
ត្រូវតែស្លាប់[ទ] ហើយចំពោះពួកអ្នកដែលកើតពីមនុស្សមក
ដូច្នេះ ដែលគេនឹងត្រូវក្រៀមទៅដូចជាស្មៅនោះ[ធ] [១៣]ឯង
បានទាំងភ្លេច[ន]ព្រះយេហូវ៉ា ជាព្រះដែលបង្កើត[ប]ឯងមក
ដែលទ្រង់បានលាតផ្ទៃមេឃ[ផ] ក៏ដាក់ឫសផែនដីផង ហើយ
រាល់តែថ្ងៃឯងមានសេចក្តីភ័យវិញ ដោយខ្លាច[ព]ចំពោះ
សេចក្តីក្រោធរបស់អ្នកដែលសង្កត់សង្កិន ហាក់ដូចជាគេ
រៀបនឹងបំផ្លាញឯងបង់ តែសេចក្តីក្រោធរបស់គេនោះតើ
នៅឯណា[ភ] [១៤]បន្តិចទៀត ពួកអ្នកដែលជាប់ជាឈ្លើយ និង
បានរួចចេញពីចំណងគេជាយ៉ាងឆាប់[ម] គេនឹងមិនត្រូវស្លាប់
ចុះទៅក្នុងរណ្តៅឡើយ ក៏មិនខ្វះខាតអាហារដែរ[យ] [១៥]ដ្បិត
អញជាយេហូវ៉ា គឺជាព្រះនៃឯង ជាព្រះដែលបង្ក្រាប
សមុទ្រ[រ]ក្នុង កាលដែលរលកកំរើកឡើងឮសន្ធឹក[ល] នាមអញ
គឺយេហូវ៉ាជាព្រះនៃពួកពលបរិវារ[វ] [១៦]អញបានដាក់ពាក្យ
ពេចន៍របស់អញនៅក្នុងមាត់[ស]ឯង ហើយបានគ្របបាំងឯង
ដោយស្រមោលនៃដៃ[ហ]អញ ដើម្បីឱ្យអញបានរៀបចំផ្ទៃ
មេឃ ហើយដាក់ឫសផែនដី[ឡ] រួចនិយាយដល់ពួកក្រុង
ស៊ីយ៉ូនថា ឯងជារាស្ត្ររបស់អញ[អ] ។

## ពែងនៃសេចក្តីក្រោធរបស់ព្រះអម្ចាស់

[១៧]ឱក្រុងយេរូសាឡិម ដែលព្រះយេហូវ៉ាបានឱ្យផឹក
ពីពែង[ក]នៃសេចក្តីក្រោធ[ខ]របស់ទ្រង់អើយ ចូរភ្ញាក់ឡើង[គ]

**៥១:៨** ឡ យប ១៣:២៨ យក ៥:២ អ អស ១៤:១១ ក ខ.៦ **៥១:៩** ខ លប ១៨:១៤ ទដ ៦៥:៦ អស ៤០:៣១ ៥២:១ គ ពច ៥:១២ ឃ ទដ ៩៨:១ អស ៣០:៣០ ៣៣:២ ង នក ៦:៦ ចទ ៤:៣៤ ៣២:៧ ច យប ៩:១៣ ឆ ទដ ៦៨:៣០ ៧៤:១៣ **៥១:១០** ជ នក ១៤:២២ សក ១០:១១ វវ ១៦:១២ ឈ នក ១៥:៥,៨ ញ យប ៣៦:៣០ ដ នក ១៥:១៣ **៥១:១១** ឋ អស ៣៥:៩ ៤៤:២៣ ឌ ទដ ១០៨:២៨ អស ៦៥:១៤ យរ ៣០:១៩ សផ ៣:១៤ ឍ អស ៤៨:២០ យរ ៣៣:១១ ណ អស ៣០:១៩ យរ ៣១:១៣ វវ ៧:១៧

**៥១:១២** ត អស ៤០:១ ២កថ ១:៤ ថ ២ពវ ១:១៥ ទ អស ២:២២ ធ អស ១៥:៦ ៤០:៦–៧ ១ពត ១:២៤ **៥១:១៣** ន យប ៨:១៣ អស ១៧:១០ ប យប ៤:១៧ អស ១៧:៧ ៤៥:១១ ៥៤:៥ ផ លប ១:១ អស ៤៨:១៣ ព អស ៧:៤ ភ អស ៩:៤ **៥១:១៤** ម អស ៤២:៧ យ អស ៤៩:១០ **៥១:១៥** រ នក ១៤:២១ ល ទដ ៩៣:៣ វ អស ១៣:៤ **៥១:១៦** ស នក ៤:១២,១៥ ហ នក ៣៣:២២ ឡ អស ៤៨:១៣ អ យរ ៧:២៣ ១១:៤ ២៤:៧ អគ ១៤:១១ សក ៨:៨ **៥១:១៧** ក ខ.២២ ទដ ១៦:៥ មថ ២០:២២ ខ ខ.២០ យប ២១:២០ អស ៤២:២៥ ៦៦:១៥ វវ ១៤:១០ ១៦:១៩ គ ពច ៥:១២ អស ៥២:១

**៥១:៨** *កន្លាតនឹងកាត់ស៊ីគេដូចជាកាត់អាវ* សូមមើល ៥០:៩ និងការពន្យល់ ប្រៀបធៀបនឹង ៥១:៦ ។

**៥១:៩,១៧,៥២:១** *សូមតើនឡើង សូមតើនឡើង* សូមមើល ៤០:១ និងការពន្យល់ ។

**៥១:៩** *ហើយពាក់ជាឥទ្ធិឫទ្ធិ* ប្រៀបធៀប ៥០:២ សូមមើលការពន្យល់ ៤០:៣១ ។ *ព្រះពាហុ* គឺជាតំណាងឱ្យអំណាចព្រះចេស្តារបស់ផងព្រះ (ប្រៀបធៀប ខ.៥) ។ សូមមើល ៣០:៣០ ៥០:២ និងការពន្យល់ ៥២:១០ ៥៣:១ ៦៣:១២ ។ *រ៉ាហាប . . . សត្វសំបើម* គឺជាពួកសាសន៍អេស៊ីព្ទ ។ សូមមើល ២៧:១ ៣០:៧ និងការពន្យល់ ។

**៥១:១០** *ទឹកសមុទ្រ* គឺជាសមុទ្រក្រហម (មើល ៥០:២ និងការពន្យល់) ។ ពាក្យថា *ប្រោសលោះ* សូមមើល ៣៥:៩ និងការពន្យល់ ។

**៥១:១១** ខនេះបានបង្ហាញនៅក្នុង ៣៥:១០ (សូមមើលការពន្យល់ផង) ។

**៥១:១២** *អ្នកដែលកំសាន្ត* សូមមើល ខ.៣ ៤៩:១៣ និងការពន្យល់ ។ ពាក្យថា *ស្មៅ* សូមមើល ៣៧:២៧ ៤០:៦ និងការពន្យល់ ។

**៥១:១៣** *ទ្រង់បានលាតផ្ទៃមេឃ . . . ផែនដីផង* សូមមើល ខ.១៦ ៤៨:១៣ និងការពន្យល់ ។ *សេចក្តីក្រោធរបស់អ្នកដែលសង្កត់សង្កិន* សូមមើល ៤៩:២៦ និងការពន្យល់ ។ ក៏មានសេចក្តីកំហឹងរបស់ពួកបាប៊ីឡូនក៏ដូចជាសេចក្តីកំហឹងរបស់ព្រះផងដែរ (ប្រៀបធៀប ១៣:៣,៥,៣០:២៧) ។

**៥១:១៤** *អ្នកដែលជាប់ជាឈ្លើយបានរួចចេញ* គឺជាការជម្លៀសនៅក្នុងស្រុកបាប៊ីឡូន (សូមើល ៤២:៧ និងការពន្យល់ ៤៩:៩) ។ ទៅក្នុងរណ្តៅឡើយ សូមប្រៀបធៀប ៤២:៧ យរ ៣៧:១៦ ។

**៥១:១៥** *ព្រះដែលបង្ក្រាបសមុទ្រ* ប្រៀបធៀប យប ២៦:១២ ទដ ១០៧:២៥ *ព្រះយេហូវ៉ានៃពួកពលបរិវារ* សូមមើល ១៣:៤ និងការពន្យល់ ។

**៥១:១៦** *ពាក្យពេចន៍របស់អញ* គឺជាពិសេសច្បាប់របស់លោកម៉ូសេ ដែលបានសម្តែងក្នុង ខ.៧ ដែលមានលក្ខណៈជាអ្នកបម្រើ ៤៩:២ ប្រជារាស្ត្រក៏ឆ្លើយតបចំពោះព្រះបន្ទូលរបស់ព្រះ (ប្រៀបធៀប ៥៩:២១ យស ១:៨) ។ *ស្រមោលនៃដៃអញ* សូមមើល ៤៩:២ និងការពន្យល់ ។ *រៀបចំផ្ទៃមេឃ . . . ឫសផែនដី* សូមមើល ខ.១៣ និងការពន្យល់ ។

**៥១:១៧** *ពីពែងនៃសេចក្តីក្រោធរបស់ទ្រង់* សូមើល ខ.២០–២២ ១៣:៣ និងការពន្យល់ ។ ការទទួលបានបទពិសោធន៍នៃការជំនុំជម្រះ គឺជារឿយៗប្រៀបធៀបនិងការស្រវឹងស្រាដ៏ខ្លាំង ។ ក៏វាជាការដួលចុះរបស់ពួកដើរក្នុងការអាក្រក់ ។ សូមមើល ២៩:៩ ៦៣:៦ ទដ ៦០:៣ និងការពន្យល់ ៧៥:៨ យរ ២៥:១៥–១៦ បទ ៤:២១ អគ ២៣:៣១ ហប ២:១៦ សក ១២:២ ប្រៀបធៀប យហ ១៨:១១ ។

ចូរ ភ្ញាក់ឈរឡើងចុះ ឯងបានផឹកស្រូបទាំងកាក[ឃ]ក្នុងពែង
ជាសេចក្ដីទ្រេតទ្រោតអស់រលីងហើយ[ង] ១៨ក្នុងពួកកូន
ប្រុស[ច]ៗ ដែលកើតចេញពីទីក្រុងនោះមក គ្មានណាមួយ
សំរាប់ដឹកនាំមុខគេឡើយ[ឆ] ហើយក្នុងពួកកូនប្រុសៗដែល
ទីក្រុងនោះបានចិញ្ចឹម ក៏គ្មានអ្នកណាមួយចាប់ដៃដឹកទៅ
ដែរ[ជ] ១៩សេចក្ដី[ឈ]ទាំង២មុខនេះបានធ្លាក់មកលើឯងហើយ
គឺសេចក្ដីវិបជាន់នឹងសេចក្ដីបំផ្លាញ[ញ] តើអ្នកឯណានឹងសោក
ស្ដាយនឹងឯង[ដ] ក៏មានសេចក្ដីអំណត់[ឋ] និងដាវ[ឌ]ផង ធ្វើដូច
ម្ដេចឱ្យអញកំសាន្តចិត្តឯងបាន ២០ពួកកូនប្រុសឯងបាន
សន្លប់ទៅហើយ គេដេកតាមក្បាលអស់ទាំងផ្លូវ[ឍ] ដូចជា
ប្រើសដែលជាប់បង្កាត់[ណ] គេមានពេញដោយសេចក្ដី
ក្រោធ[ត]របស់ព្រះយេហូវ៉ា គឺជាសេចក្ដីបន្ទោស[ថ]របស់ព្រះ
នៃឯង ។
២១ដូច្នេះ ឯងដែលត្រូវរងទុក្ខវេទនា[ទ] ហើយក៏ស្រវឹង[ធ]
តែមិនមែនដោយស្រាទំពាំងបាយជូរទេ ចូរស្តាប់សេចក្ដី
នេះឥឡូវ ២២ព្រះអម្ចាស់នៃឯង គឺព្រះយេហូវ៉ាជាព្រះដែល
កាន់ក្ដីជំនួស[ន]រាស្ត្រទ្រង់ ទ្រង់មានបន្ទូលដូច្នេះថា មើល
អញបានដកយកពែងដែលនាំឱ្យទ្រេតទ្រោត គឺជាកាកនៅ
ក្នុងពែង[ប] នៃសេចក្ដីក្រោធរបស់អញចេញពីដៃឯង ហើយ
ឯងនឹងមិនត្រូវផឹកទៀតឡើយ ២៣អញនឹងដាក់ពែងនោះ
ទៅក្នុងដៃរបស់ពួកអ្នកដែលធ្វើទុក្ខឯងវិញ[ផ] ជាពួកអ្នក
ដែលបាននិយាយទៅព្រលឹងឯងថា ចូរឱនចុះ[ព] ដើម្បីឱ្យ
យើងបានដើរ[ភ]លើ ហើយឯងបានដេកទៅ ឱ្យខ្នងឯងបាន
រាបដូចជាដី សំរាប់ជាថ្នល់ឱ្យគេដើរលើ[ម]។

៥២ ១ចូរភ្ញាក់ឡើង ចូរភ្ញាក់ឡើង[ក] ឱក្រុងស៊ីយ៉ូនអើយ
ចូរពាក់កំឡាំងរបស់ឯង[ខ] ឱយេរូសាឡិមជាទីក្រុងបរិសុទ្ធ
អើយ[គ] ចូរប្រដាប់ដោយសំលៀកបំពាក់ដ៏រុងរឿងរបស់
ឯងចុះ[ឃ] ដ្បិតពីនេះទៅមុខនឹងគ្មានពួកមិនកាត់ស្បែក[ង]ឬ
ពួកស្មោកគ្រោក[ច]ចូលមកក្នុងឯងទៀតឡើយ[ឆ] ២ឱក្រុង
យេរូសាឡិមអើយ ចូររលាស់ធូលីដីពីឯងចេញ[ជ] ហើយ
ក្រោកអង្គុយឡើង[ឈ] ឱកូនស្រីនៃក្រុងស៊ីយ៉ូន[ញ]ដែលជា
ឈ្លើយអើយ ចូរដោះចំណងពីកឯងចេញ[ដ]។
៣ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ឯងរាល់
គ្នាបានត្រូវលក់ខ្លួនឥតយកថ្លៃ[ឋ] ហើយនឹងបានលោះមក
វិញ[ឌ] ឥតបង់ប្រាក់ដែរ[ឍ] ៤ដ្បិតព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ កាលដើមដំបូងរាស្ត្រអញបានចុះទៅឯស្រុក
អេស៊ីព្ទ[ណ] ដើម្បីអាស្រ័យនៅ ហើយពួកសាសន៍អាសស៊ើរ[ត]
បានសង្កត់សង្កិនគេដោយឥតហេតុ ៥ដូច្នេះ ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលថា តើអញធ្វើអ្វីនៅទីនេះឥឡូវ ដែលឃើញ

**៥១:១៧** ឃ ទដ ៧៥:៨ ង ខ.២៣ ទដ ៦០:៣ **៥១:១៨** ច ទដ ៨៨:១៨ ឆ យប ៣១:១៨ អស ៤៩:២១ ជ អស ៤១:១៣ **៥១:១៩** ឈ អស ៤០:២ ៤៧:៩ ញ អស ៦០:១៨ ៦២:៤ យរ ៤៨:៣ បទ ៣:៤៧ ដ អស ៤៩:១៣ ៥៤:១១ យរ ១៥:៥ ណាហ ៣:៧ ឋ អស ១៤:៣០ ឌ យរ ១៤:១២ ២៤:១០ **៥១:២០** ឍ អស ៥:២៥ យរ ១៤:១៦ បទ ២:១៩ ណ យប ១៨:១០ ត ខ.១៧ យប ៤០:១១ យរ ៤៤:៦ ថ ចទ ២៨:២០ **៥១:២១** ទ អស ១៤:៣២ ធ ខ.១៧ អស ២៩:៩ **៥១:២២** ន អស ៤៩:២៥ ប ខ.១៧ យរ ២៥:១៥ ៥១:៧ ហព ២:១៦ មថ ២០:២២ **៥១:២៣** ផ អស ១៤:៤ ៤៩:២៦ យរ ២៥:១៥–១៧,២៦,២៨ ៤៩:១២ ព ខ.១៧ សក ១២:២ ភ យស ១០:២៤ ម ទដ ៦៦:១២ មីក ៧:១០ **៥២:១** ក អស ៥១:១៧ ខ ១សយ ២:៤ អស ៥១:៩ គ នក ២៨:២,៤០ នអ ៦:៨ ទដ ១១០:៣ អស ៤៩:១៨ ៦១:១០ សក ៣:៤ ឃ នហ ១១:១ អស ១:២៦ មថ ៤:៥ វវ ២១:២ ង លប ៣៤:១៤ ច អស ៣៥:៨ ឆ យប ៣:១៧ ណាហ ១:១៥ សក ៩:៨ វវ ២១:២៧ **៥២:២** ជ អស ២៩:៤ ឈ អស ៦០:១ ញ ទដ ៩:១៤ ដ ទដ ៨១:៦ អស ១០:២៧ **៥២:៣** ឋ ទដ ៤៤:១២ ឌ អស ១:២៧ ១ពត ១:១៨ ឍ អស ៤៥:១៣ **៥២:៤** ណ លប ៤៦:៦ ត អស ១០:២៤

**៥១:១៨** គឺជាកូនប្រុសៗដែលគេសង្ឃឹមថាជាអ្នកអាចជួយមើលការខុសត្រូវចំពោះឪពុកម្ដាយចាស់ៗ (ប្រៀធៀប ១ធថ ៥:៨) ។

**៥១:១៩** *កំសាន្តចិត្តឯងបាន* គឺជាសំនួរក៏បានសួរក្នុង យរ ១៥:៥ មានភាពខុសនឹង ខ.៣ ។

**៥១:២០** *ដែលជាប់បង្កាត់* សូមមើលការប្រៀបធៀប សភ ៧:២២ ។ *សេចក្ដីបន្ទាល់* សូមមើល ១៧:១៣ ៥៤:៩ ៦៦:១៥ ។

**៥១:២១** *ត្រូវរងទុក្ខវេទនា* មានក្រុងយេរូសាឡិម (សូមមើល ៥៤:១១) ។ *ក៏ស្រវឹង* គឺជាសេចក្ដីក្រោធរបស់ព្រះអម្ចាស់ (សូមមើល ខ.១៧ និងការពន្យល់) ។

**៥១:២៣** *ពួកអ្នកដែលធ្វើទុក្ខឯង* ក៏មានពួកក្រុងបាប៊ីឡូន សូមមើល ខ.១៣–១៤ ១៤:៤ ។ ពាក្យថា *ឱ្យខ្នងឯងបានរាបដូចជាដី* សូមប្រៀបធៀបនឹង យស ១០:២៤ និងការពន្យល់ ។

**៥២:១** *ចូរភ្ញាក់ឡើង ចូរភ្ញាក់ឡើង* សូមមើល ៥១:៩,១៧ ។ ពាក្យថា *ចូរប្រដាប់ដោយសំលៀកបំពាក់ដ៏រុងរឿងរបស់ឯងចុះ* ឃ្លានេះប្រហែលសំដៅទៅលើសំពត់របស់ពួកសង្ឃ ដែលជាតំណាងឱ្យក្រុងយេរូសាឡិមសម្រាប់ជាទីក្រុងបរិសុទ្ធ មើល ៤៩:១៨ និងការពន្យល់ ។ *ទីក្រុងបរិសុទ្ធ* មើល ៤៨:២ និងការពន្យល់ ។ ពាក្យថា *គ្មានពួកមិនកាត់ស្បែក ឬពួកស្មោកគ្រោកចូលមកក្នុងឯងទៀតឡើយ* គឺសំដៅទៅលើពួកអ្នកឈ្លានពានមកពីប្រទេសក្រៅ ឬស្រុកខាងក្រៅ មើល ៣៥:៨ ពច ១៤:៣ និងការពន្យល់ ។

**៥២:២** *ចូររលាស់ធូលីដីពីឯងចេញ* គឺមានលក្ខណៈផ្ទុយនិងជោគវាសនារបស់ពួកក្រុងបាប៊ីឡូនដូចជានៅក្នុង ៤៧:១ (សូមមើលការពន្យល់ផងដែរ) *ចូរដោះចំណងពីកឯងចេញ* មើល ៤២:៧ និងការពន្យល់ ៤៩:៩ ៥១:១៤ ។ ពាក្យថា *ឱកូនស្រីនៃក្រុងស៊ីយ៉ូន* គឺចង់បង្ហាញបីលក្ខណៈសម្បត្តិប្រជាជននៃក្រុងយេរូសាឡិម(សូមមើល ការពន្យល់ ២ពវ ១៩:២១) ។

**៥២:៣** *លក់ខ្លួនឥតយកថ្លៃ* សូមមើល ៤៥:១៣ ៥០:១ និងការពន្យល់ ។ ក៏សូមមើល ៤១:១៤ និងការពន្យល់ ៤៣:១ ៤៥:១៣ ។

**៥២:៤** *ពួកសាសន៍អាសស៊ើរបានសង្កត់សង្កិនគេ* សូមមើល ៩:៤ និងការពន្យល់ ។

**៥២:៥** ក្នុងខនេះគឺជាសេចក្ដីដកស្រង់ចេញពីផ្នែកខ្លះក្នុងគម្ពីរ រម ២:២៤ ។ *ដោយឥតថ្លៃ* មើល ខ.៣ និងការពន្យល់ ។ ពាក្យថា *នាមអញត្រូវប្រមាថជានិច្ច* គឺការចាប់ជាឈ្លើយ នាំឱ្យរាស្ត្ររបស់ផងទ្រង់ពុំបានគោរពដល់ទ្រង់ដែលជាព្រះដោយពួកគេយល់ថាព្រះពុំអាចជួយអ្វីកើតដល់ក្រុងយេរូសាឡិម (សូមមើល អគ ៣៦:២០–២៣ និងការពន្យល់) ។ ប្រៀបធៀបពីទង្វើដែលពួកអាសស៊ើរបានមើលងាយដល់ព្រះក្នុង ៣៧:២៣–២៤ ។

ថា រាស្ត្រអញបានត្រូវយកចេញទៅ ដោយឥតថ្លៃដូច្នេះ
ឯពួកអ្នកដែលឃុំគ្រងលើគេ ក៏ស្រែកគំហក ហើយរាល់
តែថ្ងៃ នាមអញត្រូវប្រមាថជានិច្ច នេះជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា[ថ] ៦ហេតុនោះរាស្ត្រអញនឹងស្គាល់[ទ]នាមអញ[ធ] ហេតុ
នោះគេនឹងដឹងក្នុងថ្ងៃ[ន]នោះថា គឺអញនេះហើយ ដែល
ចេញវាចា[ប] មើល គឺអញនេះហើយ ។
៧អើ ល្អណាស់ហ្ន៎ គឺជើងនៃអ្នកនោះ ដែលដើរលើភ្នំ[ផ]
ជាអ្នកដែលនាំដំណឹងល្អមក[ព] ហើយប្រកាសប្រាប់ពីសេចក្ដី
មេត្រី[ភ] ជាអ្នកដែលនាំដំណឹងល្អពីការប្រសើរមក ហើយ
ថ្លែងប្រាប់ពីសេចក្ដីសង្គ្រោះ គឺជាអ្នកដែលពោលដល់ក្រុង
ស៊ីយ៉ូនថា ព្រះនៃឯងទ្រង់សោយរាជ្យ[ម] ៨មានឮសំឡេងពួក
ចាំយាម[យ]របស់ឯង គេបន្លឺឡើង[រ]ច្រៀងជាមួយគ្នា[ល] ដ្បិត
គេនឹងឃើញ ដោយភ្នែករបស់ខ្លួនគេក្នុងកាលដែល
ព្រះយេហូវ៉ាទ្រង់យាងមក[វ]ឯក្រុងស៊ីយ៉ូនវិញ[ស] ៩អស់ទាំង
ទីខូចបង់[ហ]នៃក្រុងយេរូសាឡិមអើយ ចូរធ្លាយចេញដោយ
សេចក្ដីអំណរ[ឡ] ចូរច្រៀងជាមួយគ្នាចុះ ដ្បិតព្រះយេហូវ៉ា
ទ្រង់បានកំសាន្តទុក្ខ[អ]របស់រាស្ត្រទ្រង់ ក៏បានប្រោសលោះ
ក្រុងយេរូសាឡិមហើយ[ក] ១០ព្រះយេហូវ៉ាទ្រង់បានលាត់ព្រះ
ពាហុ[ខ]បរិសុទ្ធរបស់ទ្រង់ នៅភ្នែកនៃគ្រប់ទាំងសាសន៍[គ]
ហើយអស់ទាំងចុងផែនដី[ឃ] បានឃើញសេចក្ដីសង្គ្រោះ[ង]
របស់ព្រះនៃយើងរាល់គ្នា ។
១១ចូរចេញទៅ[ច] ចូរចេញទៅ ចូរឱ្យឯងរាល់គ្នាចេញ
ពីទីនេះទៅចុះ កុំឱ្យពាល់របស់អ្វីដែលមិនស្អាតឡើយ[ឆ]
ចូរចេញពីកណ្ដាលទីក្រុងនេះទៅ ឱពួកអ្នកលើកយក
គ្រឿង[ជ]នៃព្រះយេហូវ៉ាអើយ ចូរញែកខ្លួនចេញជាស្អាត
ចុះ[ឈ] ១២ដ្បិតឯងរាល់គ្នានឹងមិនចេញទៅដោយរួសរាន់[ញ]
ទេ ក៏មិនត្រូវរត់ចេញឱ្យរួចខ្លួនដែរ ពីព្រោះយេហូវ៉ាទ្រង់
នឹងយាងនាំមុខឯង[ដ] ហើយព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់នឹងការពារនៅខាងក្រោយឯងផង[ឋ] ។

## ការរងទុក្ខ និងសិរីល្អនៃអ្នកបម្រើ

១៣មើល អ្នកបំរើ[ឱ]របស់អញនឹងប្រព្រឹត្តដោយប្រយ័ត្ន
ប្រយែង ទ្រង់នឹងបានដំកើងឡើង គេនឹងលើកទ្រង់ឡើង

**៥២:៥** ថ អស ៣៧:២៣ រម ២:២៤ **៥២:៦** ទ អស ៤៩:២៣ ធ នក ៦:៣ ន អស ១០:២០ ប អស ៤១:២៦ **៥២:៧** ផ អស ៤២:១១ ព ២សយ ១៨:២៦ អស ៤០:៩ រម ១០:១៥ ភ ណាហ ១:១៥ លក ២:១៤ អភ ៦:១៥ ម ១កថ ១៦:៣១ ទដ ៩៧:១ ១កថ ១៥:២៤–២៥ **៥២:៨** យ ១សយ ១៤:១៦ អស ៥៦:១០ ៦២:៦ យរ ៦:១៧ ៣១:៦ អគ ៣:១៧ ៣៣:៧ រ អស ៤០:៩ ល អស ១២:៦ វ ជន ១០:៣៦ ស អស ៥៩:២០ សក ៨:៣

**៥២:៩** ហ ទដ ៧៤:៣ អស ៥១:៣ ឡ ទដ ៩៨:៤ អស ៣៥:២ អ អស ៤០:១ លក ២:២៥ ក អរ ៩:៩ អស ៤៨:២០ **៥២:១០** ខ ២របា ៣២:៨ ទដ ៤៤:៣ អស ៣០:៣០ គ អស ៦៦:១៨ ឃ យស ៤:២៤ អស ១១:៩ ង ទដ ៦៧:២ លក ២:៣០ ៣:៦ **៥២:១១** ច អស ៤៨:២០ ឆ អស ១:១៦ ២កថ ៦:១៧ ជ ២កថ ៣៦:១០ ឈ ជន ៨:៦ ២ធថ ២:១៩ **៥២:១២** ញ នក ១៤:១៩ ដ មីក ២:១៣ យប ១០:៤ ឋ នក ១៤:១៩ **៥២:១៣** ឱ យស ១:៨ អស ៤:២ ២០:៣

**៥២:៦** *ស្គាល់នាមអញ* សូមមើល ៤៩:២៦ និងកាពន្យល់ ។ *ក្នុងថ្ងៃនោះ* គឺជាថ្ងៃ ដែលគេបានដោះលែងចេញពីក្រុងបាប៊ីឡូន សូមមើល ១០:២០, ២៧ និងការពន្យល់ ។ ពាក្យថា *ដែលចេញវាចា* ក៏ក្នុងគ្រាដែលបានត្រឡប់ពីការជម្លៀសចេញពីស្រុក ។

**៥២:៧** *គឺជើងអ្នកនោះដែលដើរលើភ្នំជាអ្នកដែលនាំដំណឹងល្អមក* គឺសំដៅលើពួកហោរាដែលមកពីទីប្រយុទ្ធ ដែលនាំដំណឹងល្អមកជាលទ្ធផលនៃការរង់ចាំព្រះមហាក្សត្រ (សូមមើល ២សយ ១៨:២៦ ណាហ ១:១៥ និងការពន្យល់) ។ នេះគឺជាដំណឹងដែលសម្គាល់លើការបានរួចពីការដាក់ទោសគឺការជម្លៀស (ខ.១១–១២ សូមមើល ៤០:៩ និងការពន្យល់ ៤១:២៧) គឺជាការប្រោសលោះដែលព្រះគ្រីស្ទបានប្រោសលោះឱ្យរួចពីអំពើបាប ។ សូមមើល រម ១០:១៥ អភ ៦:១៥ និងការពន្យល់ ។ *សេចក្ដីសង្គ្រោះ* សូមមើល ៤៩:៨ និងការពន្យល់ ។ *ព្រះនៃឯងទ្រង់សោយរាជ្យ* សូមមើល ទដ ៩៣:១ និងការពន្យល់ ។ ក៏មានការវិលត្រឡប់នៃរាស្ត្ររបស់ព្រះទៅក្រុងយេរូសាឡិម គឺសម្ដែងពីការគ្រប់គ្រងពីព្រះមហាក្សត្រ គឺមានអំណាចលើអស់ទាំងពិភពលោក (សូមមើល ៤០:៩ និងការពន្យល់) ។ និងមាននគររបស់ផងព្រះបានមកដល់ក៏ឃើញកាន់តែច្បាស់ថែមទៀត ក្នុងពេលព្រះគ្រីស្ទយាងមកជាលើកទីពីរ (សូមមើល វវ ១៩:៦) ។

**៥២:៨** *ពួកចាំយាម* គឺអ្នកឈរជើងនៅឯកំផែងក្រុងយេរូសាឡិម(សូមមើល ៦២:៦–៧ ទដ ១២៧:១ និងការពន្យល់) ។

**៥២:៩** *គេបន្លឺឡើងច្រៀង* សូមមើល ៤៤:២៣ និងការពន្យល់ ។ *បានកំសាន្តទុក្ខ* សូមមើល ៤៩:១៣ និងការពន្យល់ ។ *បានប្រោសលោះ* សូមមើល ខ.៣ និងការពន្យល់ ។

**៥២:១០** *ព្រះពាហុបរិសុទ្ធ* សូមមើល ៥១:៩ និងការពន្យល់គឺជាព្រះហស្តរបស់ទ្រង់ដែលជាច្រើនលើកច្រើនគ្រា ពាក្យនេះមានការទាក់ទងនិងការប្រោសលោះនិងការសង្គ្រោះ (សូមមើល នក ៦:៦) ។ ពាក្យថា *ហើយអស់ទាំងចុងផែនដី* គឺអាចស្មើនឹងន័យមួយថា គឺរស់គ្រប់ទាំងពូជសាសន៍ទាំងអស់នៅលើផែនដី (សូមមើលការពន្យល់ ៤០:៥) ។ សូមប្រៀបធៀបនឹង ៤៥:២២ ។

**៥២:១១** ខនេះគឺបានដកស្រង់ពីក្នុងផ្នែកខ្លះ ២កថ ៦:១៧ ។ ពាក្យថា *ចូរចេញ ចូរចេញ* សូមមើលការពន្យល់ ៤០:១ ។ *របស់អ្វីដែលមិនស្អាត* គឺជាការនិយាយសំដៅទៅលើពួកសាសន៍ដទៃ ឬក៏ចំពោះវត្ថុសាសន៍ដូចជារូបព្រះ (ប្រៀបធៀប លប ៣១:១៩ ៣៥:២) ។ ពាក្យថា *ឱពួកអ្នកដែលលើយកគ្រឿងនៃព្រះយេហូវ៉ាអើយ* ពាក្យនេះជាទង្វើមួយ ឱ. ស្ដេចស៊ីរូសក៏បានអនុញ្ញាត្តឱ្យប្រជារាស្ត្រនាំយករបស់មួយចំនួនមកព្រះវិហារវិញ គឺអ្វីដែលបានរឹបអូសដោយស្ដេចនេប៊ូក្នេសា (អគ ១:៧–១១) ។ ឯពួកសង្ឃនិងពួកលេវីក៏ត្រូវទទួលខុសត្រូវពីបញ្ហានេះ (សូមមើល នក ៣:៦–៨ ២របា ៥:៤–៧) ។

**៥២:១២** *នឹងមិនចេញទៅដោយរួសរាន់ទេ* សូមមើល ៤៨:២០ និងការពន្យល់ ។ ពាក្យថា *ទ្រង់នឹងយាងនាំមុខឯង . . . ទ្រង់នឹងការពារនៅខាងក្រោយឯង* គឺដូចជាព្រះបានសំដែងក្នុងគ្រាសាសន៍អ៊ីស្រាអែលបានដោះលែងពីស្រុកអេស៊ីព្ទ (សូមមើល នក ១៣:២១ ១៤:១៩–២០ និងការពន្យល់សូមប្រៀបធៀប អស ៤២:១៦ ៤៩:១០ ៥៨:៨) ។

**៥២:១៣–៥៣:១២** ខទាំងនេះគឺជាផ្នែកទី៤និងផ្នែកដែលវែងជាងគេនៃបទទំនុកចម្រៀងរបស់អ្នកបម្រើ (សូមមើលការពន្យល់ ៤២:១–៤) ។ ក៏មាន

ឱ្យគង់នៅទីខ្ពស់ណាស់[ឃ] ១៤មានមនុស្សជាច្រើនប៉ុណ្ណាបាន
ត្រូវស្រឡាំងកាំង[ណ]ដោយឃើញទ្រង់ (ដ្បិតព្រះភក្ត្រទ្រង់
ត្រូវខូចទៅ[ត]ខុសជាងធម្មតាមនុស្ស ហើយរាងកាយ
ទ្រង់ក៏ខុសនឹងរាងកាយ[ថ]មនុស្សជាតិទាំងពួងផង) ១៥នោះ
ទ្រង់នឹងប្រោសលើ[ទ]សាសន៍ជាច្រើនប៉ុណ្ណោះដែរ ពួក
មហាក្សត្រ[ធ]នឹងបិទមាត់[ន] នៅចំពោះទ្រង់ ដ្បិតគេនឹងឃើញ
ការដែលឥតមានអ្នកណាប្រាប់ដល់គេឡើយ ហើយសេចក្តី
ដែលគេបានឮថ្លែងប្រាប់មកសោះ នោះគេនឹងបានយល់
ច្បាស់វិញ[ប] ។

**៥៣** ១តើមានអ្នកណា បានជឿដំណឹង[ក] ដែលយើងប្រាប់
ហើយព្រះពាហុ[ខ]នៃព្រះយេហូវ៉ាបានសំដែងចេញឱ្យអ្នក
ណាឃើញ[គ] ២ដ្បិតទ្រង់បានចំរើនធំឡើង នៅចំពោះព្រះ
អង្គ ដូចជាលំពង់ទន់ខ្ចី[ឃ] ហើយដូចជាឫស[ង]ដែលពន្លកចេញ
ពីដីហួតហែង ទ្រង់ឥតមានទ្រង់ទ្រាយល្អ ឬសណ្ឋានរុង
រឿងទេ ហើយកាលយើងបានមើលទ្រង់ នោះក៏គ្មានភាព
លំអណា[ច] ដែលឱ្យយើងរីករាយចិត្តដែរ ៣ទ្រង់ត្រូវគេមើល
ងាយ ហើយត្រូវមនុស្សបោះបង់ចោល ទ្រង់ជាមនុស្ស
ទុទុក្ខ[ឆ] ហើយក៏ធ្លាប់ស្គាល់សេចក្តីឈឺចាប់[ជ] ទ្រង់ត្រូវគេ
មើលងាយ ដូចជាអ្នកណាដែលមនុស្សគេចមុខ[ឈ]ចេញ
ហើយយើងរាល់គ្នាមិនបានរាប់អាន[ញ]ទ្រង់សោះ ។
៤ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់
យើង[ដ] ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់
យើងជាពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមាន
ទោសវិញ[ឋ] គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរង

**៥២:១៣** ឃ អស ៦:១ ៥៧:១៥ កច ៣:១៣ ភល ២:៩ **៥២:១៤** ណ លវ ២៦:៣២ យប ១៨:២០ ត ២សយ ១០:៤ ថ យប ២:១២ ១៦:១៦ **៥២:១៥** ទ លប ១៤:៧ ១៦:១៤–១៥ ធ អស ៤៩:៧ ន ពច ១៨:១៩ ទដ ១០៧:៤២ ប រម ១៥:២១ អភ ៣:៤–៥ **៥៣:១** ក អស ២៨:៩ រម ១០:១៦ ខ ទដ ៩៨:១ អស ៣០:៣០ គ យហ ១២:៣៨ **៥៣:២** ឃ ២ពវ ១៩:២៦ យប ១៤:៧ អស ៤:២ ង អស ១១:១០ ច អស ៥២:១៤ **៥៣:៣** ឆ ទដ ៦៩:២៩ ជ ខ.៤,១០ នក ១:១០ មថ ១៦:២១ លក ១៨:៣១–៣៣ ហព ៥:៨ ឈ ចទ ៣១:១៧ អស ១:១៥ ញ ១សយ ២:៣០ ទដ ២២:៦ មថ ២៧:២៩ យហ ១:១០–១១ **៥៣:៤** ដ មថ ៨:១៧ ឋ ចទ ៥:២៤ យប ៤:៥ យរ ២៣:៥–៦ ២៤:៣៤ អគ ៣៤:២៣–២៤ មីក ៥:២–៤ សក ១៣:៧ យហ ១៩:៧

បន្តរផ្នែកសំខាន់មួយទៀតក្នុងជំពូក ៤០–៦៦ ហើយក៏មានក្នុងជំពូក ៤៩–៥៧ (សូមមើលការពន្យល់ ៣៩:៨) ។ ឯបទទំនុកនោះក៏បានតាក់តែងឡើងដោយមានវគ្គគាថាសំខាន់ៗប្រាំ ។ ជាការញឹកញាប់នោះក៏មានការដកស្រង់ចេញពីក្រាសញ្ញាថ្មីច្រើនជាងក្រាសញ្ញាចាស់ ក៏មានការពោលសំអាងលើដំណឹងល្អក្នុងសញ្ញាចាស់ផងដែរ ។

**៥២:១៣** *អ្នកបំរើរបស់អញ* សូមមើលការពន្យល់ ៤២:១ ។ ពាក្យថា *ប្រព្រឹត្តដោយប្រយ័ត្នប្រយែង* គឺជាទីសំគាល់ដែលព្រះបានប្រទានពរ (សូមមើល ១សយ ១៨:១៤) និងការដែលស្តាប់បង្គាប់ចំពោះព្រះបន្ទូលរបស់ផងព្រះ (សូមមើល យអ ២៣:៥) ។ ប្រៀបធៀប ៥៣:១០ ។ ពាក្យថា *នឹងបានដំកើងឡើង គេនឹងលើកទ្រង់ឡើង* ដែលគឺជាព្រះយេហូវ៉ានៅក្នុងនិមិត្តរបស់អេសាយ (មើល ៦:១ និងការពន្យល់ ៥៧:១៥) ។ ក៏មើល ក្នុង កច ២:៣៣ ៣:១៣ អភ ១:២០–២៣ កល ២:៩–១១ (មើល ១ពត ១:១០–១១) ។

**៥២:១៤** *បានត្រូវស្រឡាំកាំដោយ* គឺខណៈពេលដែលពួកគេបានឃើញព្រះគ្រីស្ទទទួលរងការឈឺចាប់នៅលើឈើឆ្កាង ។ សូមធ្វើការប្រៀបធៀបពីប្រត្តិកម្មចំពោះការបាក់បែកទីក្រុងទីរ៉ុស (អគ ២៧:៣៥) ។ ពាក្យថា *ខូចទៅខុសជាងធម្មតាមនុស្ស* គឺជាពាក្យបានប្រើចំពោះសត្វដែលមានស្នាមជាំឬស្រអាប់ ដែលគេមិនត្រូវយកមកថ្វាយទៅចំពោះព្រះទេ (មឡ ១:១៤) ។ (សូមមើល ៥០:៦ និងការពន្យល់) ។ ពាក្យថា *ខុសនឹងរាងកាយរបស់មនុស្សជាតិទាំងពួង* ប្រៀបធៀប ទដ ២២:៦ ។ ប្រត្តិកម្មរបស់ទ្រង់ពុំមានលក្ខណៈដូចមនុស្សធម្មតាទេ ពីព្រោះគឺជាព្រះពិត ។

**៥២:១៥** *ទ្រង់នឹងប្រោសលើសាសន៍ជាច្រើនប៉ុណ្ណោះដែរ* គឺជាការសំអាតដល់សាសន៍របស់ទ្រង់ (មើល ១៤:៧ ជន ៨:៧ ១៩:១៨–១៩) និងការថ្វាយខ្លួនដល់ព្រះ (មើល នក ២៩:២១ លវ ៨:១១,៣០) ។ *ពួកមហាក្សត្រនឹងបិទមាត់* គឺជាការគួរឱ្យតក់ស្លុតចំពោះការឈឺចាប់ដែលបានសរសើរតម្កើងដល់អ្នកបម្រើ (មើល ៤៩:៦–៧ និងការពន្យល់) មើលការប្រៀបធៀប យប ២១:៥ ។ ពាក្យថា *គេនឹងបានយល់ច្បាស់វិញ* គឺជាសេចក្តីដកស្រង់ចេញពីគម្ពីរ រម ១៥:២១ ។ ទោះជាពុំបានឮពីពួកហោរាក៏ដោយព្រះមហាក្សត្របានយល់ពីបេសកម្មរបស់អ្នកបម្រើ (មានភាពផ្ទុយនឹង ៦:៩–១០) ។

**៥៣:១** ខនេះជាសេចក្តីដកស្រង់ចេញពី យហ ១២:៣៨ និងផ្នែកក្នុងគម្ពីរ រម ១០:១៦ ។ ពាក្យថា *ដំណឹងដែលយើងប្រាប់* គឺដំណឹងល្អស្តីពីការសង្រ្គោះតាមពួកហោរា ដល់ពួករាស្ត្រអ៊ីស្រាអែល និងជាតិផ្សេងៗ(សូមមើល ៥២:៧,១០) ។ ពាក្យថា *ព្រះពាហុនៃព្រះយេហូវ៉ា* សូមមើល ៥១:៩ និងការពន្យល់ ។

**៥៣:២** *ដូចជាលំពង់ទន់ខ្ចី* ដែលជាពួក"សាវកដែលជាពួកចេញពីព្រះគ្រីស្ទផ្ទាល់" (១១:១ សូមមើលការពន្យល់ ក៏ប្រៀបធៀប ៤:២ សក ៣:៨ និងការពន្យល់) ។ គឺទ្រង់ផ្តើមឡើងដោយការបន្ទាបខ្លួន ។ *ឫស* សូមមើល ១១:១០ នឹងការពន្យល់ពាក្យថា *ល្អ* ជាព្រះគម្ពីរភាសាហេព្រើរ គឺសំដៅលើស្តេចដាវីឌ មើល ក្នុង ១សយ ១៦:១៨ ក៏ជាការបានបកប្រែមកថា "មើលគួរឱ្យគាប់ភ្នែក" ។ *សណ្ឋានរុងរឿង* ព្រះគីស្ទពុំមានអ្វីអាចមើលទៅស្អាតដែលជាគ្រឿងលំអរទេ ។

**៥៣:៣** *ត្រូវគេមើលងាយ* សូមមើលការពន្យល់ ៤៩:៧ និងការពន្យល់ទដ ២២:៦ . . . មិនបានរាប់អាន ជាព្រះគម្ពីរភាសារហេព្រើរពាក្យដែលប្រើនៅទីនោះ បានលេចឱ្យឃើញក្នុង យហ ២:២២ (សូមមើលការពន្យល់) ។ ប្រៀបធៀប យហ ១:១០–១១ ។ ពាក្យថា *ទុទុក្ខ* បើជាព្រះគម្ពីរភាសាហេព្រើរ គឺមានន័យថា ជាការឈឺចាប់ខាងសាច់ឈាម និងឈឺចាប់ខាងព្រលឹងវិញ្ញាណ(សូមមើល ខ.៤ នក ៣:៧) ។ ពាក្យថា *មនុស្សគេចមុខចេញ* សូមមើល ១:១៥ និងការពន្យល់ ៨:១៧ ។

**៥៣:៤** ខ នេះជាសេចក្តីដកស្រង់ចេញពី មថ ៨:១៧ ដែលបង្ហាញពីព្រះគ្រីស្ទបានប្រោសមនុស្សក្នុងពេលទ្រង់បំពេញព្រះរាជកិច្ច ។ *សេចក្តីឈឺចាប់* គឺជាជម្ងឺមួយដែលជាលទ្ធផលនៃអំពើបាបជាពិសេសតាមរយៈមនុស្សដំបូង (លោក អ័រដាម និងអំពើបាបរបស់លោក) សូមមើល ១:៥–៦ និងការពន្យល់ ។ ពាក្យថា *ព្រះបានវាយ* គឺការដែលព្រះបង្កើតឱ្យមានជម្ងឺជាច្រើន (មើល លប ១២:១៧ ២ពវ ១៥:៥) ក៏តាមរយៈរាស្ត្រអ៊ីស្រាអែលដែលជាអ្នកបម្រើ ក៏ត្រូវរងទុក្ខ ដោយព្រោះអំពើបាបរបស់ខ្លួន (សូមមើល

វេទនា[ឌ] ៥តែទ្រង់ត្រូវរបួស[ឍ] ដោយព្រោះអំពើរំលងរបស់
យើង[ណ] ក៏ត្រូវវាយដំ[ត] ដោយព្រោះអំពើទុច្ចរិតរបស់យើង
ទេ ឯការវាយផ្ចាល[ថ]ដែលនាំឱ្យយើងបានជាមេត្រី[ទ]នោះ
បានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឱ្យជា[ធ]
ដោយសារស្នាម[ន]រំពាត់នៅអង្គទ្រង់ ៦យើងទាំងអស់គ្នា
បានទាសចេញ[ប]ដូចជាចៀម គឺយើងបានបែរចេញទៅតាម
ផ្លូវយើងរៀងខ្លួន[ផ] ហើយព្រះយេហូវ៉ាបានទំលាក់អំពើ
ទុច្ចរិត[ព]របស់យើងទាំងអស់គ្នាទៅលើទ្រង់ ។
៧ទ្រង់ត្រូវគេសង្កត់សង្កិន[ភ] ហើយធ្វើទុក្ខ តែទ្រង់មិន
បានហើបព្រះឱស្ឋសោះ[ម] គឺដូចជាកូនចៀម[យ]ដែលគេដឹក
ទៅសំឡាប់[រ] ហើយដូចជាចៀមដែលគេនៅចំពោះអ្នកកាត់
រោមយ៉ាងណា ទ្រង់ក៏មិនបានហើបព្រះឱស្ឋសោះយ៉ាង
នោះដែរ ៨ទ្រង់ត្រូវដកចេញពីអំណាចការពារ ហើយពី
សេចក្ដីយុត្តិធម៌[ល] ឯសម័យជិនាន់ទ្រង់ តើមានអ្នកណារំពឹង
គិតឃើញថា ទ្រង់បានត្រូវកាត់ចេញពីស្ថានរបស់មនុស្ស
រស់នេះ[វ] ហើយត្រូវវាយ ដោយព្រោះអំពើរំលង[ស]របស់ជន
ជាតិខ្ញុំនោះ ៩ហើយក្នុងកាលដែលទ្រង់សុគត នោះគេក៏

**៥៣:៤** ឌ ខ.៣ លប ១២:១៧ រន ១:២១ **៥៣:៥** ឍ ទដ ២២:១៦ ណ នក ២៨:៣៨ ទដ ៣៩:៨ យហ ៣:១៧ រម ៤:២៥ ១កថ ១៥:៣ ហព ៩:២៨ ត ទដ ៣៤:១៨ ថ អស ៥០:៦ ទ អស ៩:៦ រម ៥:១ ធ អស ១:៦ មថ ២៧:២៦ យហ ១៩:១ ន ចទ ៣២:៣៩ ២រប ៧:១៤ ១ពត ២:២៤–២៥ **៥៣:៦** ប ទដ ៩៥:១០ ១ពត ២:២៤–២៥ ផ ១សយ ៨:៣ អស ៥៦:១១ ៥៧:១៧ មីក ៣:៥ ព ខ.១២ នក ២៨:៣៨ រម ៤:២៥

បញ្ចុះសពទ្រង់នៅជាមួយនឹងពួកអាក្រក់[ហ] ហើយនៅក្នុងផ្នូរ
របស់អ្នកមាន[ឡ]ម្នាក់ ទោះបើទ្រង់មិនដែលធ្វើអំពើទុច្ចរិត
ណាមួយក៏ដោយ[អ] ក៏មិនដែលមានការបញ្ឆោតនៅក្នុង
ព្រះឱស្ឋទ្រង់ឡើយផង[ក]។
១០ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាបានសព្វព្រះ
ហឫទ័យ[ខ]នឹងវាយ[គ]ទ្រង់ឱ្យដំ ហើយឱ្យឈឺចាប់[ឃ] កាល
ណាព្រះជន្មទ្រង់បានត្រូវថ្វាយ ទុកជាយញ្ញបូជាលោះបាប
ហើយ[ង] នោះទ្រង់នឹងបានឃើញពូជពង្ស[ច]របស់ទ្រង់ ហើយ
នឹងចំរើនព្រះជន្មទ្រង់ឱ្យយឺនយូរតទៅ ឯបំណងព្រះហឫ
ទ័យនៃព្រះយេហូវ៉ា នោះនឹងជឿនឡើង[ឆ]ដោយព្រះហស្ត

**៥៣:៧** ភ អស ៤៩:២៦ ម មក ១៤:៦១ ១ពត ២:២៣ យ មថ ២៧:៣១ យហ ១:២៩ រ ទដ ៤៤:២២ **៥៣:៨** ល មក ១៤:៤៩ វ ទដ ៨៨:៥ ដយ ៩:២៦ កច ៨:៣២–៣៣ ស ខ.១២ ទដ ៣៩:៨ **៥៣:៩** ហ មថ ២៧:៣៨ មក ១៥:២៧ លក ២៣:៣២ យហ ១៩:១៨ ឡ មថ ២៧:៥៧–៦០ មក ១៥:៤៣–៤៦ លក ២៣:៥០–៥៣ យហ ១៩:៣៨–៤១ អ អស ៤២:១–៣ ក យហ ១៦:១៧ ១ពត ២:២២ ១យហ ៣:៥ វវ ១៤:៥ **៥៣:១០** ខ អស ៤៦:១០ ៥៥:១១ កច ២:២៣ គ ខ.៥ ឃ ខ.៣ លប ១២:១៧ ង លវ ៥:១៥ យហ ៣:១៧ ច ទដ ២២:៣០ ឆ យស ១:៨ អស ៤៩:៤

ខ.៧ ៥៨:១០) ។

**៥៣:៥** *ត្រូវរបួស* សូមមើល ទដ ២២:១៦ សក ១២:១០ យហ ១៩:៣៤ និងការពន្យល់ ។ ពាក្យថា *ក៏ត្រូវវាយដំ* ទៅលើផ្នែកឯវិញ្ញាណ (មើល ទដ ៣៤:១៨ ប្រៀបធៀបនឹង អស ៥៧:១៥) អំពើបាបរបស់លោកិយទាំងមូលក៏ក្លាយជាបន្ទុកយ៉ាងធ្ងន់ដល់អង្គទ្រង់ ។ ពាក្យថា *ប្រោស* គឺជាអត្ថន័យស្មើរនិងការលើកលែងទោសឱ្យ (សូមមើល ៦:១០ យរ ៣០:១៧ ក៏សូមមើលការពន្យល់ ១ពត ២:២៤) ។

**៥៣:៦** *បានទាសចេញ* សូមប្រៀបធៀប ទដ ១១៩:១៧៦ និងការពន្យល់ យរ ៥០:៦ អគ ៣៤:៤–៦,១៦ ១ពត ២:២៥ និងការពន្យល់ ។ *ទាំងអស់គ្នាទៅលើទ្រង់* គឺទ្រង់ជាអ្នកដែលជួយទទួលរងនូវកំហុសរបស់រាស្ត្រអ៊ីស្រាអែលទាំងអស់ (សូមមើល លវ ១៦:២០–២២ និងការពន្យល់) សូមមើល ១ពត ២:២៤ និងការពន្យល់ ។

**៥៣:៧–៨** ខទាំងនេះគឺពួកសាសន៍អេធីយ៉ូពីជាមនុស្សកំរៀវម្នាក់បានអានក្នុងពេលមានវត្តមានលោកភីលីព (សូមមើល កច ៨:៣៤ និងការពន្យល់) ។

**៥៣:៧** *ត្រូវគេសង្កត់សង្កិន* ក៏ដូចជាសាសន៍អ៊ីស្រាអែលផងដែរ សូមមើល ៤៩:២៦ និងការពន្យល់ ។ បើជាព្រះគម្ពីរភាសាហេព្រើរពាក្យនេះមានន័យថា "ទាសករបើកបរ" សូមមើលក្នុង នក ៥:៦ ។ ពាក្យថា *កូនចៀមដែលគេដឹកទៅសំឡាប់* ប្រៀបធៀប ៤៤:២២ វវ ៥:៦ និងការពន្យល់ ។ ឯលោកយ៉ូហានបាបទីសហៅព្រះនាមព្រះយេស៊ូវថា "កូនចៀមរបស់ព្រះ" (យហ ១:២៩,៣៦ មើលការពន្យល់ ១:២៩) ។ *ទ្រង់ក៏មិនបានហើបព្រះឱស្ឋសោះ* គឺព្រះយេស៊ូវរក្សាភាពស្ងាត់ស្ងៀមនៅក្នុងវត្តមាននៃមេពួកសង្ឃនិងលោកពីឡាត់ (មថ ២៧:១២–១៤ មក ១៤:៦០–៦១ ១៥:៤–៥ យហ ១៩:៨–៩) និងនៅខាងមុខស្ដេចហេរ៉ូត (លក ២៣:៨–៩) ។

**៥៣:៨** *ទ្រង់ត្រូវដកចេញពីអំណាចការពារ ហើយពីសេចក្ដីយុត្តិធម៌* គឺជាការកាត់ទោសជំនុំជម្រះដល់ព្រះយេស៊ូវដោយយុត្តិធម៌បំផុត ។ *ឯសម័យជិនាន់ទ្រង់* ក៏បានសុគតដោយពុំមានកូន ក៏ត្រូវបានគេគិតថា វាគឺជាអំពើឃោរឃៅ (២សយ ១៨:១៨) ។

**៥៣:៩** *ពួកអាក្រក់* គឺសណ្ឋាននៃសេចក្ដីស្លាប់របស់គេ ដែលបញ្ជាក់ថាពួកគេត្រូវស្លាប់ចំណែកឯទ្រង់ក៏ត្រូវបញ្ចុះជាមួយនិងពួកគេដែរ ។ *អ្នកមាន* ក៏មិនបានបញ្ចុះដោយត្រឹមត្រូវទេ ក៏មានអត្ថបទស្រដៀងគ្នារបស់លោកអេសាយបានបង្ហាញយ៉ាងច្បាស់ ពីទំនាក់ទំនងរវាងអ្នកមាននិងពួកមនុស្សអាក្រក់ដូចជាអ្នកនិពន្ធនៅក្នុគម្ពីសញ្ញាចាស់ គឺពួកគេបានស្វែងរកទ្រព្យសម្បត្តិដោយមធ្យោបាយពីការអាក្រក់ ឬបានទុកចិត្តលើទ្រព្យសម្បត្តិរបស់គេជាជាងទុកចិត្តដល់ព្រះអម្ចាស់ (សូមមើល ខ. ទដ ៣៧:១៦,៣៥ សភ ១៨:២៣ ២៨:៦,២០ យរ ៥:២៦–២៧ មីក ៦:១០,១២) ។ ដោយយោងទៅតាមដំណឹងល្អរបស់គម្ពីរម៉ាថាយ(មថ ២៧:៥៧–៦០ និងអត្ថបទផ្សេងៗគ្នាទៀត) ដូចជាលោក យ៉ូសែប ដែលមានភោគទ្រព្យគរនៅឯភូមិអើរីម៉ាថេ បានផ្ដល់កិត្តិយសដល់ព្រះយេស៊ូវដែលបញ្ចុះសពទ្រង់នៅឯកន្លែងផ្នូររបស់គាត់ ។ (សូមមើល លក ៧:៤៧) ។ ពាក្យថា *ទ្រង់មិនដែលធ្វើអំពើទុច្ចរិតណាមួយក៏ដោយ . . . មិនដែលមានការបញ្ឆោត* ឯលោកពេត្រុស បានដក់ស្រង់សេចក្ដីទាំងនេះ ដើម្បីលើកទឹកចិត្តបងប្អូនរួមជំនឿដែលកំពុងឈឺចាប់ដោយអយុត្តិធម៌ (១ពត ២:២២) ។

**៥៣:១០** *វាយទ្រង់* សូមមើល ខ.៥ និងការពន្យល់ ។ *ថ្វាយទុកជាយញ្ញបូជា* គឺជាដង្វាយមួយសម្រាប់ជាថ្លៃលោះបាប ហើយជាពិសេសទៀតទាឱ្យមានការថ្វាយយញ្ញបូជា ជាកូនចៀមព្រះយេស៊ូវជាកូនចៀមនៃព្រះ (សូមមើលការពន្យល់ លវ ៥:១៥) ។ ពាក្យថា *ពូជពង្សរបស់ទ្រង់* គឺជាកូនចៅខាងព្រលឹងវិញ្ញាណ ។ *ចំរើនព្រះជន្មឱ្យយឺនយូរទៅ* គឺជាព្រះគ្រីស្ទដែលមានព្រះជន្មរស់កល្បជានិច្ច (សូមមើល ៩:៧ និងការពន្យល់) ។

ទ្រង់ ១១ទ្រង់នឹងឃើញផល[ជ]នៃការដែលព្រលឹងទ្រង់រង
វេទនា[ឈ] នោះនឹងបានស្កប់ស្កល់ផង អ្នកដ៏សុចរិត គឺជាអ្នក
បំរើ[ញ]របស់អញ ទ្រង់នឹងធ្វើឱ្យមនុស្សជាច្រើនបានសុចរិត[ដ]
ដោយគេស្គាល់ដល់ទ្រង់ ហើយទ្រង់នឹងទទួលរងទោស
ចំពោះអំពើទុច្ចរិតរបស់គេ[ឋ] ១២ហេតុនោះអញនឹងឱ្យទ្រង់
មានចំណែកជាមួយនឹងពួកអ្នកធំ[ឌ] ហើយទ្រង់នឹងចែក
របឹប[ឍ]ជាមួយនឹងពួកអ្នកដ៏ខ្លាំងពូកែ ពីព្រោះទ្រង់បានច្រួច
ព្រលឹងចេញ រហូតដល់ស្លាប់[ណ] គេបានរាប់ទ្រង់ទុកជាអ្នក
ទទឹងច្បាប់[ត] ប៉ុន្តែទ្រង់បានទទួលរងទោស[ថ]នៃអំពើបាប
របស់មនុស្សជាច្រើន[ទ] ហើយបានអង្វរ[ធ]ជំនួសមនុស្សដែល
ទទឹងច្បាប់វិញ ។

## អនាគតសិរីល្អនៃទីក្រុងស៊ីយ៉ូន

**៥៤** ១ឱស្ត្រីអារ ដែលមិនបានបង្កើតកូនអើយ[ក] ចូរច្រៀង
ឡើង ឱអ្នកដែលមិនបានឈឺចាប់នឹងសំរាលអើយ[ខ] ចូរ
ធ្លាយចេញជាបទចំរៀង[គ] ហើយបន្លឺឡើងចុះ ដ្បិតព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា កូន[ឃ]របស់ស្ត្រីដែលបង់ខ្លួន
នៅតែឯង[ង] នោះមានច្រើនជាងកូនរបស់ស្ត្រីដែលមានប្តី
ទៅទៀត[ច] ២ចូរពង្រីកទីដំឡើងត្រសាលឯងឱ្យធំឡើង[ឆ]
ហើយឱ្យវារាល់ក្តាសន្ទឹងសំយាយសំពត់ត្រសាលរបស់ឯង
ទៅ កុំឱ្យសំចៃឡើយ ត្រូវឱ្យបន្តខ្សែឱ្យវែង ហើយបោះចំរឹង
ឱ្យមាំឡើងចុះ[ជ] ៣ដ្បិតឯងនឹងបានរានទីចេញទៅខាងស្តាំនឹង
ខាងឆ្វេង ហើយពូជពង្ស[ឈ]របស់ឯងនឹងចាប់បានអស់ទាំង
សាសន៍ជារបស់ផងខ្លួន[ញ] នឹងឱ្យអស់ទាំងទីក្រុងដែលចោល
ស្ងាត់[ដ]បាន មានមនុស្សអាស្រ័យនៅវិញ ។
៤កុំឱ្យខ្លាចឱ្យសោះ[ឋ] ដ្បិតឯងនឹងមិនដែលត្រូវខ្មាស
ឡើយ[ឌ] ក៏កុំឱ្យរង្កៀសចិត្តដែរ ពីព្រោះឯងនឹងមិនដែលត្រូវ
មានសេចក្តីខ្មាសទេ[ឍ] ឯងនឹងភ្លេចសេចក្តីខ្មាសដែលឯង
មានពីកាលនៅវ័យក្មេង[ណ] ហើយឯងនឹងមិននឹកចាំពីសេចក្តី
ដែលគេត្មះតិះដៀល[ត] ពីការនៅមេម៉ាយតទៅទៀតដែរ[ថ]

**៥៣:១១** ជ អស ២០:៣ កច ៧:៥២ ឈ យប ៣៣:៣០ ញ យហ ១០:១៤–១៨ ដ អស ៦:៧ យហ ១:២៩ កច ១០:៤៣ រម ៤:២៥ ឋ នក ២៨:៣៨ **៥៣:១២** ឌ អស ៦:១ ភល ២:៩ ឍ នក ១៥:៩ ទដ ១១៩:១៦២ លក ១១:២២ ណ មថ ២៦:២៨,៣៨,៣៩,៤២ ត មថ ២៧:៣៨ មក ១៥:២៧ លក ២២:៣៧ ២៣:៣២ ថ ខ.៦ ១ពត ២:២៤ ទ ហព ៩:២៨ ធ អស ៥៩:១៦ រម ៨:៣៤ **៥៤:១** ក លប ៣០:១

ខ លប ២១:៦ ទដ ៩៨:៤ គ អស ៦៦:៧ ឃ អស ៤៩:២០ ង អស ៤៩:១៩ ច ១សយ ២:៥ កទ ៤:២៧ **៥៤:២** ឆ លប ២៦:២២ អស ២៦:១៥ ៤៩:១៩–២០ ជ នក ៣៥:១៨ ៣៩:៤០ **៥៤:៣** ឈ លប ១៣:១៤ អស ៤៨:១៩ ញ លប ១២:២៣ អស ១៤:២ ៦០:៤–១១ ដ អស ៤៩:១៩ **៥៤:៤** ឋ យរ ៣០:១០ យអ ២:២១ ឌ អស ២៨:១៦ ២៩:២២ ឍ លប ៣០:២៣ ទដ ១១៩:៣៩ អស ៤១:១១ ណ ទដ ២៥:៧ យរ ២:២ ២២:២១ ត អស ៥១:៧ ថ អស ៤៧:៨

**៥៣:១១** គឺទ្រង់ជាពន្លឺសម្រាប់ជីវិតទាំងអស់ គឺជាផលតាមរយៈពេលដែលទ្រង់មានព្រះជន្មរស់ឡើងវិញ សូមមើល ១កថ ១៥:៤ ។ ចំពោះពាក្យថា "នៃជីវិត"សូមមើល យប ៣៣:៣០ និងការពន្យល់ ទដ ៤៩:១៩ ៥៦:១៣ និងការពន្យល់ ។ ពាក្យថា *បានស្កប់ស្កល់* មើលក្នុង ១:១១ គឺព្រះយេហូវ៉ាក៏មានភាពស្កប់ស្កល់ជាច្រើនលើសលុប ។ ដូច្នេះទីណាដែលមានការពេញចិត្តឬទទួលភាពស្កប់ស្កល់ ដោយព្រោះទ្រង់ជាព្រះគ្រីស្ទនោះទ្រង់នាំឱ្យទទួលបានភាពស្កប់ស្កល់ដ៏ល្អប្រសើរ ។ (សូមមើល ១:៣ ៦:៩ ៤៣:១០ ៤៥:៤–៥ ៥២:៦ ៥៦:១០) ។ ដោយព្រោះទ្រង់ជាព្រះនៃប្រាជ្ញាវាងវៃនឹងឫទ្ធានុភាព គឺព្រះបានចាត់ព្រះវិញ្ញាណបរិសុទ្ធមកសណ្ឋិតលើព្រះមែស៊ី ប្រៀបធៀប ៥២:១៣ ។ *អ្នកបំរើរបស់អញ* សូមមើល ៤១:៨–៩ និងការពន្យល់ ។

**៥៣:១២** *មានបំណែកជាមួយនឹងពួកអ្នកធំ . . . ជាមួយនឹងពួកអ្នកដ៏ខ្លាំងពូកែ* គឺព្រះនិងប្រទានដល់អ្នកបម្រើរបស់ផងទ្រង់ បើពួកគេជាស្តេចផែនដីគងតែគេបានទទួលជ័យជម្នះលើពួកខ្មាំងសត្រូវ (សូមមើល ៥២:១៥) ។ ពាក្យថា *ចែករបឹប* គឺជាអំណោយទានរបស់ព្រះដែលមានចំពោះអ្នកបម្រើរបស់ទ្រង់ដែលកំពុងវេទនា (ប្រៀបធៀបនិង ៩:៣) ពាក្យថា *ច្រួចព្រលឹងចេញរហូតដល់ស្លាប់* គឺក្នុងពេលដែលទ្រង់ថ្វាយបង្គំទ្រង់ជាយញ្ញបូជា (សូមមើល ខ.១០) ។ ពាក្យថា *រហូតដល់ស្លាប់* សូមមើល ភល ២:៨ និងការពន្យល់ ។ ពាក្យថា *រាប់ទ្រង់ទុកជាអ្នកទទឹងច្បាប់* គឺបានស្រង់ចេញពីគម្ពីរ លក ២២:៣៧ ដែលសំដៅទៅលើព្រះយេស៊ូវ ។ ពាក្យថា *ទទួលរងទោស* ពាក្យនេះជាក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យថាយកដូចជាក្នុង ខ.៤ ។ *បានអង្វរជំនួស* សូមមើល យរ ៧:១៦ គឺការអធិស្ឋាន (អង្វរសុំ) ប្រៀបធៀប ៥៩:១៦ ហព ៧:២៥ ។

**៥៤:១** គឺលោកប៉ុលបានប្រើពាក្យក្នុងខនេះចំពោះនាងសារ៉ា និងសេចក្តីសញ្ញានៃព្រះបន្ទូលសន្យាគឺតំណាងឱ្យ"ក្រុងយេរូសាឡិម"(កទ ៤:២៦–២៧ មើលការពន្យល់ផងដែរ) ។ ពាក្យថា *ចូរច្រៀងឡើង* សូមមើល ១២:៦ ៤៤:២៣ ៥២:៩ នឹងការពន្យល់ ។ *ស្ត្រីអារ* គឺជាអ្នកក្រុងយេរូសាឡិម (ដែលតំណាងឱ្យរាស្ត្រអ៊ីស្រាអែល) ជាពិសេសនាសម័យកាលដែលគេបំបោះបង់ប្រជាជនអ៊ីស្រាអែល (សូមមើល ៤៩:២១) ។ ចំណែកឯពួកអ្នកដែលរស់នៅតំបន់មជ្ឈឹមបុព៌ា ក៏ចាត់ថាភាពជាស្ត្រីអា បាននាំឱ្យមានភាពអាប់កិត្តិយស (មើល ៤:១ និងការពន្យល់) ។ ពាក្យថា *កូនរបស់ស្ត្រីដែលបង់ខ្លួននៅតែឯង នោះមានច្រើនជាងកូនរបស់ស្ត្រីដែលមានប្តីទៅទៀត* សូមមើល ៤៩:១៩–២០ នឹងការពន្យល់តែរាស្ត្រអ៊ីស្រាអែលនិងបានរួចពីការទាំងនេះ ដោយទទួលបាននូវជីវភាពសុខសាន្ត និងព្រះវិញ្ញាណដឹកនាំពួកគេ ។ ចូរប្រៀបធៀប (៦២:៤០) ។

**៥៤:២** សូមមើល ២៦:១៥ ៣៣:២០ និងការពន្យល់ ។ ត្រសាលឯង គឺពួកក្រុងយេរូសាឡិមក៏បានបង្ហាញជាទស្សនៈពីស្ត្រីៗ ដែលនៅក្នុងត្រសាលរបស់នាង ។

**៥៤:៣** *រានទីចេញ* សូមមើល ៤៩:១៩–២០ និងការពន្យល់ប្រៀបធៀប លប ២៨:១៤ ។ *ចាប់បានអស់ទាំងសាសន៍ជារបស់ផងខ្លួន* សូមមើល ១១:១៤ ៤៩:៧ និងការពន្យល់ ។

**៥៤:៤** *មិនដែលត្រូវមានសេចក្តីខ្មាសទេ* មើល ២៩:២២ និងការពន្យល់ ៤៥:១៧ ។ ពាក្យថា *សេចក្តីខ្មាសដែលឯងមានពីកាលនៅវ័យក្មេង* ជាពិសេសគ្រាដែលបានជាប់ជាឈ្លើយនៅស្រុកអេស៊ីព្ទ ។ សូមមើលការប្រៀបធៀប យរ ៣១:១៩ អគ ១៦:៦០ ។ *កាលពីនៅមេម៉ាយតទៅ* គឺចង់សំដៅទៅលើការដែលអ៊ីស្រាអែល ដែលត្រូវគេបំបោះបង់ចោលឱ្យនៅឯកឯង គឺមានលក្ខណៈដូចស្ត្រីមេម៉ាយ (សូមមើល ខ.៦–៧) ។

៥ដ្បិតព្រះដែលបង្កើត[ទ]ឯងមក ទ្រង់ជាប្ដី[ធ]របស់ឯងហើយ
ព្រះនាមទ្រង់ គឺព្រះយេហូវ៉ានៃពួកពលបរិវារ ហើយព្រះដ៏
ប្រោសលោះឯង[ន] គឺជាព្រះដ៏បរិសុទ្ធ[ប]នៃសាសន៍អ៊ីស្រាអែល
គេនឹងហៅទ្រង់ថា ជាព្រះនៃលោកីយទាំងមូល[ផ] ៦ដ្បិត
ព្រះទ្រង់មានបន្ទូលថា ព្រះយេហូវ៉ាទ្រង់បានហៅ[ព]ឯងទុក
ដូចជាស្ត្រីដែលប្ដីបោះបង់ចោល[ភ] ហើយ ដែលមានចិត្តគ្នាន់
ក្នាញ់ គឺជាប្រពន្ធក្រមុំកំឡោះ[ម] ដែលត្រូវបង់ចោលហើយ
៧អញបានបោះបង់ចោល[យ]ឯងតែ១ភ្លែត[រ]ទេ តែអញនឹង
ទទួលឯងមកវិញ[ល] ដោយសេចក្ដីមេត្តា[វ]ជាខ្លាំង ៨ព្រះ
យេហូវ៉ា ជាព្រះដ៏ប្រោសលោះឯង[ស] ទ្រង់មានបន្ទូលថា
អញបានគេច[ហ]មុខចេញពីឯងនៅតែ១ភ្លែតនោះ ដោយ
មានសេចក្ដីក្រោធ[ឡ]ដ៏ហូរហៀរ តែអញនឹងអាណិតអាសូរ[អ]
ដល់ឯង ដោយសេចក្ដីសប្បុរស[ក]ដ៏នៅអស់កល្បជានិច្ចវិញ។
៩ការនេះប្រៀបដូចជាទឹកជន់ នៅជំនាន់ណូអេ ដល់
អញ ហើយដែលអញបានស្បថថា ទឹកជន់នៅជំនាន់ណូអេ
នឹងមិនដែលគ្របលើផែនដីទៀតជាយ៉ាងណា[ខ] នោះអញក៏
ស្បថ[គ]ថា អញនឹងមិនដែលមានសេចក្ដីក្រោធ[ឃ]ចំពោះឯង
ឬបន្ទោស[ង]ឯងតទៅយ៉ាងនោះដែរ ១០ពីព្រោះអស់ទាំងភ្នំធំ
នឹងបាត់ទៅបាន[ច,ឆ] ហើយអស់ទាំងភ្នំតូចនឹងរើចេញទៅ
បានដែរ ប៉ុន្តែសេចក្ដីសប្បុរស[ជ]របស់អញនឹងមិនដែល
ឃ្លាតបាត់ពីឯងឡើយ[ឈ] ហើយសេចក្ដីសញ្ញា[ញ]ពីសេចក្ដី
មេត្រី[ដ] របស់អញក៏មិនត្រូវរើចេញដែរ នេះជាព្រះបន្ទូល
នៃព្រះយេហូវ៉ាដែលទ្រង់ប្រោសមេត្តា[ឋ]ដល់ឯង ។
១១ឱអ្នកមានទុក្ខវេទនា[ឌ] ដែលត្រូវខ្យល់ព្យុះ[ឍ]បោកឥត
មានសេចក្ដីកំសាន្តចិត្តអើយ[ណ] មើល អញនឹងរៀបថ្មឯង
ឡើង[ត] ដោយបាយអមានពណ៌ល្អ ហើយនឹងដាក់ជើង
ជញ្ជាំង[ថ]ឯងដោយត្បូងកណ្ដៀង[ទ] ១២អញនឹងធ្វើកំផែងសីមា
ឯងពីត្បូងទទឹម ហើយទ្វារ[ធ]ឯងពីត្បូងបារកេត និងក្បាច់
ឯងទាំងប៉ុន្មានពីត្បូងមានដំឡៃ ១៣ឯកូនចៅទាំងប៉ុន្មាន
របស់ឯង និងធ្វើជាសិស្សរបស់ព្រះយេហូវ៉ា[ន] ហើយវារាល់
គ្នានឹងមានសន្តិសុខជាបរិបូរ[ប] ១៤ឯងនឹងបានតាំងមាំមួន[ផ]
នៅដោយសេចក្ដីសុចរិត[ព] ហើយនឹងនៅឆ្ងាយពីការសង្កត់
សង្កិន[ភ] ដ្បិតឯងនឹងមិនខ្លាចអ្វីសោះ[ម] ក៏នឹងនៅឆ្ងាយពី
សេចក្ដីស្ញែងខ្លាច[យ]ដែរ ពីព្រោះសេចក្ដីនោះនឹងមិនមកជិត
ឯងឡើយ ១៥មើល នឹងមានគេលើកគ្នាឡើង តែនោះ
មិនមែនមកពីអញទេ ឯអ្នកណាដែលលើកគ្នាទាស់នឹង

**៥៤:៥** ទ ទដ ៩៥:៦ ១៤៩:២ អស ៥១:១៣ ធ បស ៣:១១ យរ ៣:១៤ ៣១:៣២ ហស ២:៧,១៦ ន អស ៤៨:១៧ ប អស ១:៤ ៤៩:៧ ៥៥:៥ ៦០:៩ ផ អស ៦:៣ ១២:៤ **៥៤:៦** ព អស ៤៩:១៤–២១ ភ ខ.៦–៧ អស ១:៤ ៥០:១–២ ៦០:១៥ ៦២:៤,១២ យរ ៤៤:២ ហស ១:១០ ម នក ២០:១៤ មឡ ២:១៥ **៥៤:៧** យ ទដ ៧១:១១ អស ២៧:៨ រ យប ១៤:១៣ អស ២៦:២០ ល អស ៤៩:១៨ វ ទដ ៥១:១ **៥៤:៨** ស អស ៤៨:១៧ ហ អស ១:១៥ ឡ ខ.១០ ទដ ២៥:៦ ៩២:២ អស ៥៥:៣ ៦៣:៧ អ អស ៩:១២ ២៦:២០ ៦០:១០ ក ទដ ១០២:១៣ អស ១៤:១ ហស ២:១៩ **៥៤:៩** ខ លប ៨:២១ គ អស ១៤:២៤ ៤៩:១៨ ឃ ទដ ១៣:១ ១០៣:៩ អស ១២:១ ៥៧:១៦ យរ ៣:៥,១២ អគ ៣៩:២៩ មីក ៧:១៨ ង ចទ ២៨:២០ **៥៤:១០** ច វវ ៦:១៤ ឆ ទដ ៤៦:២ ជ ទដ ៦:៤ ឈ អស ៥១:៦ ហព ១២:២៧ ញ លប ៩:១៦ នក ៣៤:១០ ទដ ៨៩:៣៤ អស ៤២:៦ ដ ជន ២៥:១២ ឋ ខ.៨ អស ១៤:១ ៥៥:៧ **៥៤:១១** ឌ អស ១៤:៣២ ឍ អស ២៨:២ ២៩:៦ ណ អស ៥១:១៩ ត ១រប ២៩:២ វវ ២១:១៨ ថ អស ២៨:១៦ វវ ២១:១៩–២០ ទ នក ២៤:១០ យប ២៨:៦ **៥៤:១២** ធ វវ ២១:២១ **៥៤:១៣** ន អស ២៨:៩ មីក ៤:២ យហ ៦:៤៥ ហព ៨:១១ ប លវ ២៦:៦ អស ៤៨:១៨ **៥៤:១៤** ផ យរ ៣០:២០ ព អស ២៦:២ ភ ២សយ ៧:១០ អស ៩:៤ ម សផ ៣:១៥ សក ៩:៨ យ អស ១៧:១៤

**៥៤:៥** *ប្ដី* សូមមើល ៦២:៤–៥ ។ ពាក្យថា *ព្រះដ៏ប្រោសលោះឯង គឺជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើល ១:៤ ៤១:១៤ និងការពន្យល់ ។
**៥៤:៦–៧** *ជាប្រពន្ធក្រមុំកំឡោះដែលត្រូវបង់ចោល* គឺជាបទពិសោធន៍របស់រាស្ត្រអ៊ីស្រាអែលក្នុងពេលដែលគេនិរទេសទៅ (សូមមើល ៤៩:១៤ ៥០:១ និងការពន្យល់ ៦២:៤) ។
**៥៤:៧–៨,១០** *សេចក្ដីមេត្តា* សូមមើល ១៤:១ ៤៩:១០,១៣ ៥១:៣ ។
**៥៤:៧** *១ភ្លែតទេ* គឺជាការនិរទេសរបស់ពួកបាប៊ីឡូនមានរយៈពេលខ្លី (សូមមើល ២៦:២០ ៥០:១ និងការពន្យល់) ។
**៥៤:៨** *សេចក្ដីក្រោធដ៏ហូរហៀរ* សូមមើល ៩:១២,១៧,២១ និងការពន្យល់ ៦០:១០ ។ ពាក្យថា *គេចមុខចេញពីឯង* សូមមើល ១:១៥ និងការពន្យល់ ។ *ដោយសេចក្ដីសប្បុរសដ៏នៅអស់កល្បជានិច្ច* សូមមើល ខ.១០ ៥៥:៣ និងការពន្យល់ ប្រៀបធៀប ៤៥:១៧ *ព្រះដ៏ប្រោសលោះ* សូមមើល ខ.៥ ។
**៥៤:៩** *មិនដែលគ្របលើផែនដីទៀត* មើល លប ៩:១១ និងការពន្យល់ ។ ពាក្យថា *មិនដែលមានសេចក្ដីក្រោធ* សូមមើល ១២:១ និងការពន្យល់ ។ ពាក្យថា *ឬបន្ទោសឯង* គឺដូចជាកាលទ្រង់បានធ្វើក្នុងពេលដែលបានមានទ្រង់មានបន្ទូលពួកគេទៅបំបោះបង់ ។
**៥៤:១០** *ទាំងភ្នំនឹងបាត់ទៅបាន* សូមមើលប្រៀបធៀប ៥១:៦ ទដ ៤៦:២ ១០២:២៦–២៧ *សេចក្ដីសប្បុរសរបស់អញនឹងមិនដែលឃ្លាតបាត់ពីឯង* គឺសំដៅទៅលើសេចក្ដីសញ្ញាដែលកំណត់ជួយដល់រាស្ត្រអ៊ីស្រាអែល គឺជាមួយលោកអ័ប្រាហាំ និងការតាំងសញ្ញាជាមួយពូជពង្សស្ដេចដាវីឌជាដើម (សូមមើល យរ ៣៣:២០–២១ ឬ ជន ២៥:១១–១៣ ។
**៥៤:១១–១២** ជាការពណ៌នាផ្ដោតសំខាន់លើការសាងសង់ក្រុងយេរូសាឡិមឡើងវិញ ក៏បង្ហាញពីក្រុងយេរូសាឡិមថ្មី ក្នុង *វវ* ២១:១០,១៨–២១ ។
**៥៤:១១** *ឱអ្នកមានទុក្ខវេទនា* ជាអ្នកក្រុងយេរូសាឡិម សូមមើល ៥១:២១ *ដែលត្រូវខ្យល់ព្យុះបោក* សូមមើល ២៨:២ នឹងការពន្យល់ព្យុះនេះបានកើតឡើង ឯព្រះវិហារបង្កើតឯង ព្រះវិហាររបស់ស្ដេចសាឡូម៉ូន (១រប ២៩:២) ។ *ត្បូងកណ្ដៀង* គឺជាការប្រៀបធៀបពីការ "ក្រាលឬលាបជញ្ជាំងដោយត្បូងកណ្ដៀង" (ដែលមានថ្មពណ៌ខៀវ) ក្នុង នក ២៤:១០ (សូមមើល អគ ១:២៦ ១០១) ។
**៥៤:១២** *កំផែងសីមា* គឺមានជញ្ជាំងឬបន្ទប់ពួនបាញ់ នៅលើកំពូលកំផែង ប្រៀបធៀប ២៦:១ ។
**៥៤:១៣** គឺខដែលដកស្រង់ចេញពីផ្នែកខ្លះក្នុង យហ ៦:៤៥ ដែលជាការបង្រៀនរបស់ព្រះយេហូវ៉ា យហ ៦:៤៥ យរ ៣១:៣៤ និងការពន្យល់ ។
**៥៤:១៤** *ពីការសង្កត់សង្កិន . . . មិនខ្លាច . . . ក៏មិននៅឆ្ងាយ* ប្រៀបធៀប ១៤:៤ ៣៣:១៨–១៩ ។
**៥៤:១៥** *គេនឹងដួលចុះដោយព្រោះឯង* សូមមើល ខ.៣ ។

ឯង គេនឹងដួលចុះ[រ] ដោយព្រោះឯង ១៦មើល អញបាន
បង្កើតទាំងជាងដែក[ល] ដែលសប់ភ្លើងធ្វើគ្រឿងសស្ត្រាវុធ[វ]
សំរាប់ជាការរបស់ខ្លួន ហើយក៏បានបង្កើតមេបំផ្លាញ[ស]ទុក
សំរាប់នឹងបំផ្លាញផង ១៧ឯគ្រឿងសស្ត្រាវុធណាដែលគេ
ធ្វើឡើង នោះគ្មានណាមួយនឹងអាចទាស់នឹងឯងបាន
ឡើយ[ហ] ហើយអស់ទាំងអណ្តាតណាដែលកំរើកទាស់នឹង
ឯងក្នុងរឿងក្តី នោះឯងនឹងកាត់ទោសឱ្យ[ឡ]វិញ នេះហើយ
ជាសេចក្តី ដែលពួកអ្នកបំរើ[អ]របស់ព្រះយេហូវ៉ានឹងទទួល
ជាមរដក ហើយសេចក្តីសុចរិត[ក]របស់គេក៏មកពីអញ នេះ
ជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## សេចក្តីអញ្ជើញដល់ពួកស្រេកទឹក

**៥៥** ១ហ៊ឺយ អស់អ្នកដែលស្រេកអើយ[ក] ចូរមកឯទីទឹកចុះ[ខ]
ឯអ្នកដែលគ្មានប្រាក់អើយ ចូរមកទិញ[គ] ហើយបរិភោគទៅ
អើ ចូរមកទិញស្រាទំពាំងបាយជូរ និងទឹកដោះគោ[ឃ]ឥត
បង់លុយ ឥតថ្លៃទេ[ង] ២ហេតុអ្វីបានជាចាយប្រាក់ ឱ្យបាន
តែរបស់ដែលមិនមែនជាអាហារ ហើយបង់កំឡាំង ឱ្យបាន
តែរបស់ដែលមិនស្កប់ចិត្តដូច្នេះ[ច] ចូរស្តាប់តាមអញឱ្យអស់

**៥៤:១៥** រ អស ៤១:១១–១៦
**៥៤:១៦** ល អស ៤៤:១២ វ អស ១០:៥ ស អស ១៣:៥
**៥៤:១៧** ហ អស ២៩:៨ ឡ អស ៤១:១១ អ អស ៥៦:៦–៨ ៦៣:១៧ ៦៥:៨,៩,១៣–១៥ ៦៦:១៤ ក ទដ ១៧:២ សក ១:២០–២១
**៥៥:១** ក សភ ៩:៥ អស ៣៥:៧ មថ ៥:៦ លក ៦:២១ យហ ៤:១៤ ៧:៣៧ ខ យរ ២:១៣ អគ ៤៧:១,១២ សក ១៤:៨ គ បទ ៥:៤ មថ ១៣:៤៤ វវ ៣:១៨ ឃ បស ៥:១

ពីចិត្តចុះ នោះឯងនឹងបានបរិភោគយ៉ាងឆ្ងាញ់[ឆ] ដើម្បីឱ្យ
ព្រលឹងឯងបានស្កប់ស្កល់ ដោយម្ហូបយ៉ាងថ្លៃវិសេស[ជ] ៣ចូរ
ឱនត្រចៀក ហើយមកឯអញ ចូរស្តាប់[ឈ]ចុះ នោះព្រលឹង
ឯងនឹងបានរស់នៅ[ញ] ហើយអញនឹងតាំងសេចក្តីសញ្ញា[ដ]
នឹងឯងរាល់គ្នា ជាសញ្ញាដ៏នៅអស់កល្បជានិច្ច គឺជាសេចក្តី
មេត្តាករុណា[ឋ]ស្មោះត្រង់ ដែលបានផ្តល់ដល់ដាវីឌ[ឌ] ៤មើល
អញបានតាំងដាវីឌទុកជាទីបន្ទាល់[ឍ]ដល់ប្រជាជាតិទាំង
ឡាយ គឺជាអ្នកនាំមុខ ហើយជាអ្នកបង្គាប់[ណ]ដល់គេ ៥មើល
ឯងនឹងហៅសាសន៍[ត]១ដែលឯងមិនបានស្គាល់ ហើយ
សាសន៍១ ដែលមិនបានស្គាល់ឯងគេនឹងរត់មកឯឯង[ថ]ដោយ
ព្រោះព្រះយេហូវ៉ាជាព្រះនៃឯង គឺជាព្រះដ៏បរិសុទ្ធ[ទ]នៃ
សាសន៍អ៊ីស្រាអែល ដ្បិតទ្រង់បានលើកដំកើងឯង ហើយ[ធ] ។

១ពត ២:២ ង ហស ១៤:៤ មថ ១០:៨ វវ ២១:៦ ២២:១៧ **៥៥:២** ច ទដ ២២:២៦ សស ៦:២ អស ៤៩:៤ យរ ១២:១៣ ហស ៤:១០ ៨:៧ មីក ៦:១៤ ហក ១:៦ ឆ អស ១:១៩ ជ អស ៣០:២៣ **៥៥:៣** ឈ ទដ ៧៨:១ ញ លវ ១៨:៥ យហ ៦:២៧ រម ១០:៥ ដ លប ៩:១៦ អស ៥៤:១០ ហព ១៣:២០ ឋ អស ៥៤:៨ ឌ កច ១៣:៣៤ **៥៥:៤** ឍ វវ ១:៥ ណ ១សយ ១៣:១៤ ២របា ៧:១៨ អស ៣២:១ **៥៥:៥** ត អស ៤៩:៦ ថ អស ២:៣ ទ អស ១២:៦ ៥៤:៥ ធ អស ៤៤:២៣

**៥៤:១៦** *បង្កើតមេបំផ្លាញ* ព្រះអម្ចាស់បានលើកពួកសាសន៍អាសស៊ើរ បាប៊ីឡូន ដើម្បីដាក់ទណ្ឌកម្មដល់ពួករាស្ត្រអ៊ីស្រាអែល (សូមមើល ១០:៥ ៣៣:១ និងការពន្យល់) ។

**៥៤:១៧** *ទាំងអណ្តាតណាដែលកំរើកទាស់* គឺគ្មានច្បាប់ណាដែលត្រូវទាស់និងអ្នកបម្រើព្រះយេហូវ៉ាបានទេ ។ បន្ទាប់ពីជំពូក ៥៣ ក៏លែងឃើញមាន "អ្នកបម្រើណាមួយមានមុនក្នុងគម្ពីរ អេសាយទៀតទេ ។ "អ្នកបម្រើទាំងនោះ" គឺអ្នកមានសេចក្តីជំនឿពិត ទាំងពួកសាសន៍យូដានិងពួកសាសន៍ដទៃគឺអ្នកទាំងនោះដែលមានភាពស្មោះត្រង់និងព្រះយេហូវ៉ា គឺពួកគេក៏មានឈ្មោះក្នុងពូជវង្សនៃអ្នកបម្រើ(៥៣:១០)សូមមើល ៤៩:១៩–២០ និងការពន្យល់ ។

**៥៥:១** ការនិរទេសគឺជាការកោះហៅដើម្បីត្រឡប់មកទទួលបំពេញកង្វះខាត ។ ពាក្យថា *ស្រេក* គឺជាការស្រេកខាងឯវិញ្ញាណក៏បានបង្ហាញក្នុង (សូមមើល ៤១:១៧ ៤៤:៣ ទដ ៤២:១–២ និងការពន្យល់ ៦៣:១) ។ ពាក្យថា *ទឹក* គឺសំដៅលើការធ្វើឱ្យជីវិតខាងវិញ្ញាណមានភាពស្រស់ស្រាយ ។ ក៏ជាការសុំប្រាជ្ញាពីព្រះអម្ចាស់ សូមមើលក្នុង សភ ៩:៥ ឯព្រះគ្រីស្ទទ្រង់ក៏ធ្វើដូច្នេះដែរ គឺទ្រង់បានអញ្ជើញរាស្ត្ររបស់ផងទ្រង់ឱ្យមកទទួលទឹករស់ (មើល វវ ២២:១៧) ។ *គ្មានប្រាក់* គឺដោយពេលមានភាពក្រខ្សត់កើតឡើង គឺសូមបីតែទឹកក៏គេត្រូវទិញ ឬដោះដូរដែរ (មើល បទ ៥:៤) ។ *ស្រា . . . នឹងទឹកដោះ* គឺតំណាងឱ្យសេចក្តីសប្បាយដ៏ពេញបរិបូរ និងប្រភព ស្បៀងដោយពុំអស់លុយ ។ ឯការស្លាប់របស់អ្នកបម្រើវិញ ព្រះអង្គបានប្រទានជីវិតថ្មីដោយពុំបាច់បង់ថ្លៃឡើយ(មើល រម ៦:២៣ និងការពន្យល់) ។

**៥៥:២** *ហេតុអ្វី . . . ដែលមិនមែនជាអាហារ* គឺជាការទំលាប់ពីការអនុវត្តនៃសាសនារបស់ពួកសាសន៍ដទៃដែលចំណាយប្រាក់កាក់ឬកម្លាំងទៅលើរឿងឥតប្រយោជន៍ សូមប្រៀបធៀប ចទ ៨:៣ និងការពន្យល់ ។ ពាក្យថា *ម្ហូបយ៉ាងថ្លៃវិសេស* គឺជាព្រះពរដែលទ្រង់ប្រទានឱ្យដែលគេប្រៀបប្រដូចទៅនិងពិធីជប់លៀង (សូមមើល ២៥:៦ និងការពន្យល់ ទដ ២២:២៦ ៣៤:៨ យរ ៣១:១៤) ។

**៥៥:៣** *ជាសញ្ញាដ៏នៅអស់កល្បជានិច្ច* គឺស្តេចដាវីឌបានទទួលព្រះបន្ទូលសន្យាចំពោះពូជពង្សស្តេចដាវីឌជាពង្សក្សត្រា ដែលមានព្រះមែស៊ី ដ៏ឧត្តមជាឈាមជ័រវង្សក្សត្រ (សូមមើល ៩:៧ ៥៤:១០ ៦១:៨ ៦១:៨ ២សយ ៧:១៤–១៦ និងការពន្យល់) ។ ពាក្យថា *គឺជាសេចក្តីមេត្តាករុណាស្មោះត្រង់* គឺជាព្រះបន្ទូលសន្យាបន្តជារៀងរហូត ដល់រាស្ត្ររបស់ផងទ្រង់ ។ សូមមើល ៥៤:៨ និងការពន្យល់ ។ ឯការដែលព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញជាភស្តុតាងបញ្ជាក់ថែមទៀតថា សេចក្តីសប្បុរសរបស់ផងទ្រង់មានចំពោះស្តេចដាវីឌ (សូមមើល កច ១៣:៣៤ ដែលជាសេចក្តីដកស្រង់ចេញពីខនេះ) ។

**៥៥:៤** *ទុកជាបន្ទាល់ដល់ប្រជាជាតិទាំងឡាយ* ក៏សំដៅទៅលើស្តេចដាវីឌផងដែរគឺជាស្តេចបានសរសើរដំកើងព្រះយេហូវ៉ា ក្នុងចំណោមពូជសាសន៍ (មើល ទដ ១៨:៤៣ ៤០–៥០ និងការពន្យល់)ឬចំពោះបុត្រានៃស្តេចដាវីឌនោះហើយជាព្រះរាជកិច្ចរបស់ព្រះមែស៊ីដែលទ្រង់ជាពន្លឺដល់គ្រប់ពូជសាសន៍ទាំងអស់ (សូមមើល ៤២:៦ ៤៩:៦ និងការពន្យល់) ។ ពាក្យថា *គឺជាអ្នកនាំមុខ* មានលក្ខណៈស្រដៀងចំពោះពាក្យគេប្រើសំដៅលើស្តេចដាវីឌដែរ (១សយ ១៣:១៤ ២៥:៣០) និងព្រះមែស៊ី (យយ ៩:២៥) ។

**៥៥:៥** *នឹងហៅសាសន៍* គឺដោយពូជសាសន៍ទាំងនោះមានព្រះធ្វើការក្នុងចិត្តគេតាមរយៈពួកក្រុងស៊ីយ៉ូន គឺក៏គេបានស្គាល់ព្រះនៃសេចក្តីពិតរបស់រាស្ត្រអ៊ីស្រាអែល (សូមមើល ឧ. ២:២–៤ ៤៥:១៤ សក ៨:២២ និងការពន្យល់) ពាក្យថា *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើល ១:៤ ៤១:១៤ និងការពន្យល់ ។ ពាក្យថា *លើកដំកើងឯងហើយ* សូមមើល ៤:២ ៦០:៩ ។ ពីពូជសាសន៍ ដែលទ្រង់បំពេញឱ្យគេមានអាហារខាងឯសាច់ឈាម និង

៦ចូរស្វែងរក[ន]ព្រះយេហូវ៉ា ក្នុងកាលដែលអាចនឹងរក
ទ្រង់ឃើញ[ប] ហើយអំពាវនា[ផ]ដល់ទ្រង់ ក្នុងកាលដែលទ្រង់
គង់នៅជិតចុះ ៧ត្រូវឱ្យមនុស្សអាក្រក់បោះបង់ចោល[ព]ផ្លូវ
របស់ខ្លួន ហើយឱ្យមនុស្សទុច្ចរិតចោលគំនិតអាក្រក់របស់
ខ្លួនដែរ[ភ] រួចឱ្យគេត្រឡប់[ម]មកឯព្រះយេហូវ៉ាវិញ នោះទ្រង់
នឹងអាណិតមេត្តា[យ]ដល់គេ គឺឱ្យវិលមកឯព្រះនៃយើងរាល់
គ្នា ដ្បិតទ្រង់នឹងអត់ទោសឱ្យជាបរិបូរ[រ] ៨ពីព្រោះព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា គំនិតអញ មិនមែនដូចជាគំនិត[ល]
របស់ឯងរាល់គ្នាទេ ឯផ្លូវរបស់ឯងរាល់គ្នាក៏មិនមែនជាផ្លូវ
របស់អញដែរ[វ] ៩ដ្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាង
ណា[ស] នោះអស់ទាំងផ្លូវរបស់អញ ខ្ពស់ជាងផ្លូវរបស់ឯង
ហើយគំនិតរបស់អញ ក៏ខ្ពស់ជាងគំនិតរបស់ឯងរាល់គ្នា
យ៉ាងនោះដែរ[ហ] ១០ពីព្រោះដែលភ្លៀង[ឡ]នឹងហិមៈធ្លាក់ចុះ
មកពីលើមេឃឥតវិលត្រឡប់ទៅលើវិញ គឺមកស្រោចដី
ធ្វើឱ្យកើតចេញជាពន្លកឡើង[អ] ហើយក៏ឱ្យពូជ[ក]ពង្រោះ
ដល់អ្នកដែលព្រោះ និងអាហារដល់អ្នកដែលបរិភោគជា
យ៉ាងណា[ខ] ១១នោះពាក្យ[គ]អញ ដែលចេញពីមាត់អញទៅ
ក៏មិនដែលវិលមកឯអញវិញ ដោយឥតកើតផលយ៉ាង
ដូច្នោះដែរ[ឃ] គឺនឹងធ្វើសំរេចតាមសេចក្តីប៉ងប្រាថ្នានៅក្នុង
ចិត្តអញ ហើយនឹងចំរើនកើនឡើង ក្នុងការអ្វី[ង]ដែលអញ
ចាត់ទៅធ្វើនោះ ១២ដ្បិតឯងរាល់គ្នានឹងចេញទៅដោយ
អំណរ[ច] ហើយគេនឹងនាំឯងចេញទៅ ដោយសុខសាន្ត[ឆ]
ឯអស់ទាំងភ្នំធំ និងភ្នំតូចទាំងប៉ុន្មាននឹងធ្លាយចេញជា
ចំរៀង[ជ]នៅមុខឯង ហើយគ្រប់ទាំងដើមឈើ[ឈ]នៅព្រៃនឹង
ទះដៃផង[ញ] ១៣នោះនឹងមានដើមកកោះដុះឡើង ជំនួសគុម្ព
បន្លា[ដ] ហើយដើមយីថោ[ឋ]នឹងដុះឡើង ជំនួសអញ្ចាញ ការ
ទាំងនេះនឹងបានសំរាប់ជា ល្បីព្រះនាមដល់ព្រះយេហូវ៉ា[ឌ]
ហើយសំរាប់ជាទីសំគាល់ដ៏ស្ថិតស្ថេរ នៅអស់កល្បតរៀង
ទៅ ដែលមិនត្រូវកាត់ផ្តាច់ចេញឡើយ ។

## សេចក្តីសង្គ្រោះសម្រាប់អ្នកដទៃ

**៥៦** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូររក្សា
សេចក្តីយុត្តិធម៌[ក] ហើយប្រព្រឹត្តតាមសេចក្តីសុចរិតចុះ[ខ] ពី
ព្រោះសេចក្តីសង្គ្រោះ[គ]របស់អញបានមកជិតដល់ហើយ ឯ
សេចក្តីសុចរិត[ឃ]របស់អញ ក៏រៀបនឹងសំដែងឱ្យឃើញដែរ
២មានពរហើយ[ង] មនុស្សណាដែលប្រព្រឹត្តយ៉ាងនោះ ព្រម
ទាំងកូនមនុស្សណាដែលកាន់សេចក្តីនេះឱ្យខ្ជាប់ខ្ជួនផង គឺ
ជាអ្នកដែលថែរក្សាថ្ងៃឈប់សំរាក[ច]ឥតបង្អាប់ ហើយរក្សា

**៥៥:៦** ន ចទ ៤:២៩ ២របា ១៥:២ អស ៩:១៣ ប ទដ ៣២:៦ អស ៤៩:៨ កច ១៧:២៧ ២កច ៦:១–២ ផ ទដ ៥០:១៥ អស ៦៥:២៤ យរ ២៩:១២ ៣៣:៣ **៥៥:៧** ព ២របា ៧:១៤ ៣០:៩ អគ ១៨:២៧–២៨ ភ អស ៣២:៧ ៥៩:៧ ម អស ៤៤:២២ យរ ២៦:៣ អគ ១៨:៣២ យ អស ៥៤:១០ រ ២របា ៦:២១ អស ១:១៨ ៤០:២ **៥៥:៨** ល ភល ២:៥ ៤:៨ វ អស ៥៣:៦ មីក ៤:១២ **៥៥:៩** ស យប ១១:៨ ទដ ១០៣:១១ ហ ជន ២៣:១៩ អស ៤០:១៣–១៤ **៥៥:១០** ឡ អស ៣០:២៣ អ លវ ២៥:១៩ យប ១៤:៩ ទដ ៦៧:៦ ក លប ៤៧:២៣ ខ ២កថ ៩:១០ **៥៥:១១** គ ចទ ៣២:២ យហ ១:១ ឃ អស ៤០:៨ ៤៥:២៣ មថ ៥:១៨ ហព ៤:១២ ង សភ ១៩:២១ អស ៤៤:២៦ អគ ១២:២៥ **៥៥:១២** ច ទដ ៩៨:៤ អស ៣៥:២ ឆ អស ៥៤:១០,១៣ ជ ទដ ៦៥:១២–១៣ ៩៦:១២–១៣ ឈ ១របា ១៦:៣៣ ញ ទដ ៩៨:៨ **៥៥:១៣** ដ ជន ៣៣:៥៥ អស ៥:៦ ឋ អស ៤១:១៩ ឌ ទដ ១០២:១២ អស ៦៣:១២ យរ ៣២:២០ ៣៣:៩ **៥៦:១** ក ទដ ១១:៧ អស ១:១៧ យរ ២២:៣ ខ អស ២៦:៨ គ ទដ ៨៥:៩ ឃ យរ ២៣:៦ ដយ ៩:២៤ **៥៦:២** ង ទដ ១១៩:២ ច នក ២០:៨,១០

អាហារខាងឯវិញ្ញាណ ។

**៥៥:៦** *ចូរស្វែងរកព្រះយេហូវ៉ា* សូមមើល យរ ២៩:១៣–១៤ ហស ៣:៥ អម ៥:៤,៦,១៦ (ដែលផ្ទុយការស្វែងរកព្រះរបស់ពួកមានពុធ ៥៨:២) ។

**៥៥:៧** *មនុស្សអាក្រក់បោះបង់ចោលផ្លូវរបស់ខ្លួន* សូមមើល ១:១៦ ។ ឯពាក្យថា *គេត្រឡប់មកឯព្រះយេហូវ៉ាវិញ . . . អត់ទោសជាបរិបូរ* សូមមើល ៤៣:២៥ ៤៤:២២ និងការពន្យល់ ។

**៥៥:៩** *ផ្លូវរបស់អញខ្ពស់ជាង* សូមមើល ទដ ១៤៥:៣ ។

**៥៥:១១** *ពាក្យអញ* ជាពិសេសព្រះបន្ទូលសន្យានៅ ខ.៣,៥,១២ ។ ពាក្យបន្ទូលនោះបង្ហាញឱ្យឃើញដូចជាមានលក្ខណៈជាអ្នកដឹកនាំសារមក ក៏ឃើញមានក្នុង ៩:៨ ទដ ១០៧:២០ (សូមមើលសេចក្តីពន្យល់ ក្នុងនោះផងដែរ) ។ សូមប្រៀបធៀប យហ ១:១ និងការពន្យល់ ។ ពាក្យថា *នឹងសំរេចតាមសេចក្តីប៉ងប្រាថ្នា* សូមមើល ៤៦:១០–១១ និងការពន្យល់ ។

**៥៥:១២** *ចេញទៅដោយអំណរ* គឺជាការចេញដំណើរពីក្រុងបាប៊ីឡូនក៏ជាការបង្ហាញឱ្យឃើញពីប្រវត្តិសាស្ត្រ (សូមមើល ៣៥:១០ ៥២:៩–១២ និងការពន្យល់) ។ ពាក្យថា *ទាំងភ្នំធំនឹងភ្នំតូចទាំងប៉ុន្មាន នឹងធ្លាយចេញជាចំរៀង* សូមមើល ៤៤:២៣ និងការពន្យល់ ។ ពាក្យថា *ដៃ* ជាមែកធាងរបស់ព្រៃឈើដែលមានអំណរនិងបទចម្រៀងដែរ ។

**៥៥:១៣** *ដើមកកោះដុះឡើងជំនួសគុម្ពបន្លា . . . ដើមយីថោនឹងដុះឡើងជំនួសអញ្ចាញ* ឃ្លានេះហាក់ដូចជាមានភាពខុសនិងភាពត្រូវចោលស្ងាតដែលហោរា អេសាយ បានថ្លែងទំនាយតាំងពីដំបូង (៥:៦ ៣២:១៣) ។ តែចំពោះលក្ខណៈសម្បត្តិនៃដើមឈើទាំងនោះ សូមមើល ៣២:២ ឬ ៤១:១៩ និងការពន្យល់ ។ ពាក្យថា *សំរាប់ជាល្បីព្រះនាមដល់ព្រះយេហូវ៉ា* គឺស្រដៀងន័យថា កិត្តិនាមរបស់ទ្រង់ក្នុងពេលទ្រង់នាំរាស្ត្ររបស់ទ្រង់ចេញដំណើរ (សូមមើល ៦៣:១២,១៤) ។ ពាក្យថា *ហើយសំរាប់ជាទីសំគាល់ស្ថិតស្ថេរ នៅអស់កល្បតរៀងទៅ* គឺជាការដោះលោះ ឬប្រោសដល់រាស្ត្រទ្រង់ដែលជាការមិនអាចភ្លេចបាន សូមប្រៀបធៀបលើ ១៩:២០ ៥៦:៥ ។

**៥៦:១** *ចូររក្សាសេចក្តីយុត្តិធម៌ ហើយប្រព្រឹត្តតាមសេចក្តីសុចរិតចុះ* សូមមើលការពន្យល់ ទដ ១១៩:១២ *សេចក្តីសង្គ្រោះរបស់អញ . . . សេចក្តីសុចរិតរបស់អញ* សូមមើល ៤៥:៨ ៤៦:១៣ ៥១:៥ និងការពន្យល់ ។

**៥៦:២** *ថែរក្សាថ្ងៃឈប់សំរាក* សូមមើល ខ.៤,៦ គឺថ្ងៃឈប់សម្រាកដែលគេទើបបានយកមកអនុវត្តបន្ទាប់ពីបានចេញពីស្រុកអេស៊ីព្ទ (សូមមើលការពន្យល់នៅ នក ២០:៨–១០) ដូចជាសេចក្តីសញ្ញាដែលទ្រង់តាំងនៅឯភ្នំស៊ីណាយ ។ (សូមមើល នក ៣១:១៣–១៧ និងការពន្យល់) ដូច្នេះការប្រោសលោះថ្មីរបស់ព្រះយេហូវ៉ាគឺចំពោះអ្នកណាដែលស្តាប់បង្គាប់និងរក្សានូវថ្ងៃឈប់សំរាក (សូមមើល ៥៨:១៣ ៦៦:២៣ យរ ១៧:២១–២៧ និងការពន្យល់ អរ ២០:២០–២១) ។

ដែមិនឱ្យធ្វើការអាក្រក់ណាឡើយ ៣ឯសាសន៍ដទៃ[ង]ណា
ដែលបានភ្ជាប់ខ្លួននឹងព្រះយេហូវ៉ាហើយ នោះមិនត្រូវឱ្យ
ពោលថា ក្រែងព្រះយេហូវ៉ាទ្រង់នឹងញែកខ្ញុំចេញពីរាស្ត្រ
ទ្រង់ទៅ[ជ] នោះឡើយ ក៏មិនត្រូវឱ្យមនុស្សកំរៀវ[ឈ]ពោលថា
មើល ខ្ញុំនេះជាដើមឈើហួតហែងទេ នោះដែរ ៤ដ្បិត
ព្រះយេហូវ៉ា ទ្រង់មានបន្ទូលពីពួកកំរៀវ[ញ] ដែលរក្សាថ្ងៃ
ឈប់សំរាកទាំងប៉ុន្មាន ក៏រើសយកអ្វីៗដែលគាប់ចិត្តអញ
ព្រមទាំងកាន់ខ្ជាប់តាមសេចក្ដីសញ្ញា[ដ]របស់អញថា ៥អញ
នឹងឱ្យគេមានទីកន្លែង[ឋ]១នៅក្នុងវិហារអញ ហើយឱ្យមាន
ឈ្មោះឆ្លាក់នៅជញ្ជាំង[ឌ]ខាងក្នុង ដែលវិសេសជាងកូន
ប្រុសកូនស្រីទៅទៀត អញនឹងឱ្យគេមានឈ្មោះដ៏នៅអស់
កល្បជានិច្ច[ឍ] ជាឈ្មោះដែលមិនត្រូវកាត់ចេញឡើយ[ណ] ។
៦ឯពួកសាសន៍ដទៃ[ត] ដែលភ្ជាប់ខ្លួននឹងព្រះយេហូវ៉ា
ដើម្បីធ្វើការងារ[ថ]ទ្រង់ ហើយនឹងស្រឡាញ់ព្រះនាម[ទ]នៃព្រះ
យេហូវ៉ា ព្រមទាំងធ្វើជាអ្នកបំរើទ្រង់ គឺគ្រប់អស់អ្នកណា
ដែលរក្សាថ្ងៃឈប់សំរាក[ធ]ឥតបង្អាប់ឡើយ ហើយកាន់ខ្ជាប់
តាមសេចក្ដីសញ្ញារបស់អញ ៧នោះអញនឹងនាំគេមកឯភ្នំ[ន]
បរិសុទ្ធរបស់អញ ហើយឱ្យគេបានអរសប្បាយ នៅក្នុង
ដំណាក់របស់អញ ដែលសំរាប់ជាទីអធិស្ឋាន អញនឹង
ទទួលអស់ទាំងដង្វាយដុត និងយញ្ញបូជា[ប]របស់គេ នៅ
លើអាសនា ដ្បិតដំណាក់អញនឹងបានហៅជាទីអធិស្ឋាន
សំរាប់គ្រប់ទាំងសាសន៍[ផ,ព] ៨ព្រះអម្ចាស់យេហូវ៉ា ជាព្រះ
ដែលរក្សាអស់អ្នក ដែលត្រូវបំបរបង់ ក្នុងសាសន៍អ៊ីស្រា–
អែល ទ្រង់មានបន្ទូលថា អញនឹងប្រមូល[ភ]មនុស្សដទៃមក
ជាមួយដែរ គឺជាពួកអ្នកក្រៅពីពួកអ៊ីស្រាអែលដែលបាន
ប្រមូលហើយ ។

## ព្រះអម្ចាស់ចោទប្រកាន់ពួកមនុស្សអាក្រក់

៩នែ អស់ទាំងសត្វនៅវាល ហើយសត្វនៅព្រៃទាំង
ប៉ុន្មានអើយ[ម] ចូរមកហែកស៊ីចុះ ១០ពួកយាមល្បាតរបស់
គេ[យ] សុទ្ធតែខ្វាក់ភ្នែក គេគ្មានដំរិះគ្រប់គ្នា[រ] គេសុទ្ធតែជា
ឆ្កែគ ព្រុសមិនកើត គេតែងតែស្រមៃឃើញ គេចេះតែដេក
ហើយចូលចិត្តតែលក់ទៅ[ល] ១១អើ គេជាពួកឆ្កែសាហាវ
ដែលមិនចេះឆ្អែតឆ្អន់ឡើយ ជាពួកគង្វាល[វ]ដែលមិនចេះ

**៥៦:៣** ង នក ១២:៤៣ ១ពវ ៨:៤១ អស ១១:១០ សក ៨:២០–២៣ ជ ចទ ២៣:៣ ឈ លវ ២១:២០ យរ ៣៨:៧ កច ៨:២៧ **៥៦:៤** ញ យរ ៣៨:៧ ដ នក ៣១:១៣ **៥៦:៥** ឋ ជន ៣២:៤២ ១សយ ១៥:១២ ឌ អស ២៦:១ ៦០:១៨ ឍ អស ៤៣:៧ ណ អស ៤៨:១៩ ៥៥:១៣ **៥៦:៦** ត នក ១២:៤៣ ១ពវ ៨:៤១ ថ ១រប ២២:២ អស ៦០:៧,១០ ៦១:៥ ទ មឡ ១:១១ ធ ខ.២,៤ **៥៦:៧** ន អស ២:២

អគ ២០:៤០ ប អស១៩:២១ រម ១២:១ ភល ៤:១៨ ហព ១៣:១៥ ផ មថ ២១:១៣ លក ១៩:៤៦ ព មក ១១:១៧ **៥៦:៨** ភ ចទ ៣០:៤ អស ១:៩ ១១:១២ ៦០:៣–១១ អគ ៣៤:១២ យហ ១០:១៦ **៥៦:៩** ម អស ១៨:៦ យរ ១២:៩ អគ ៣៤:៥,៨ ៣៩:១៧–២០ **៥៦:១០** យ អស ៥២:៨ ៦២:៦ យរ ៦:១៧ ៣១:៦ អគ ៣:១៧ ៣៣:៧ រ យរ ២:៨ ១០:២១ ១៤:១៣–១៤ ល ណហ ៣:១៨ **៥៦:១១** វ យរ ២៣:១ អគ ៣៤:២

**៥៦:៣** *សាសន៍ដទៃ* សូមមើល ខ.៦ គឺដូចជាពួកសាសន៍មួយចំនួនដែលមករស់នៅក្នុងក្រុងយេរូសាឡិមជាមួយរាស្ត្រអ៊ីស្រាអែល ក៏ពុំបានអនុញ្ញាត្តិឱ្យចូរទទួលបុណ្យរំលង ឬថ្វាយបង្គំទេក៏តម្រូវឱ្យពួកគេនៅបានរហូតជាច្រើនជំនាន់ (សូមមើល នក ១២:៤៣ ចទ ២៣:៣៧–៨) ។ តែកិច្ចការរបស់ពួកអ្នកបម្រើរបស់ព្រះយេហូវ៉ានិងផ្លាស់ប្ដូរស្ថានភាពនេះឱ្យរស់ឡើងវិញ (សូមមើល ៤៩:១៩–២០ ៥៤:១៧ ៦០:១០ និងការពន្យល់) ប្រៀបធៀប ១៤:១ ។ ពាក្យថា *មនុស្សកំរៀវ* សូមមើល ខ.៤ មថ ១៩:១២ និងការពន្យល់ ។ មនុស្សកំរៀវក៏ពុំអាចចូលរួមថ្វាយបង្គំដល់ព្រះយេហូវ៉ាបានដែរ (សូមមើល ចទ ២៣:១ និងការពន្យល់) តែពួកគេក៏នៅតែមានចំណែកជារាស្ត្ររបស់ផងទ្រង់ផងដែរ (សូមមើល កច ៨:៣៨–៤០) ។

**៥៦:៤,៦** *កាន់ខ្ជាប់តាមសេចក្ដីសញ្ញារបស់អញ* ការកាន់ខ្ជាប់នូវថ្ងៃឈប់សម្រាក គឺជាទីសំគាល់នៃការរក្សាបាននូវសេចក្ដីសញ្ញាភ្នំស៊ីណាយ (សូមមើលការពន្យល់ ខ.២ សូមមើល អរ ២០:១២ និងការពន្យល់ ខ.២០ ប្រៀបធៀបការពន្យល់ លប ៩:១២–១៣ ១៧:១១) ។

**៥៦:៥** *មានឈ្មោះឆ្លាក់នៅជញ្ជាំង* ដូចជាអាប់សាឡុំមបានកសាង "បង្គោលជាទីរំឭក" ទុកដើម្បីរំលឹកខណៈពេលដែលគាត់ពុំមានកូនប្រុស ដើម្បីបន្តឈ្មោះទេ (២សយ ១៨:១៨) ។ ពាក្យថា *នាម* បើក្នុងព្រះគម្ពីរភាសាហេព្រើរ មានន័យថា នាមដែលយកចេញពី ខ.៥ គឺជាឈ្មោះថ្មបង្គោលសម្រាប់បូជាដ៏សំខាន់ក្នុងទីក្រុងយេរូសាឡិម គឺក្នុងស្រុងអ៊ីស្រាអែលសម័យថ្មីវិញ ។ *ដែលមិនត្រូវ កាត់ចេញឡើយ* តាមការបកស្រាយ គឺឃ្លានេះសំដៅទៅលើការរក្សាទុកនូវ កេរ្តិ៍ឈ្មោះតាំងពីពួកចាសទុំមកម្លះ ។

**៥៦:៦** *ធ្វើការងារ* សូមប្រៀបធៀប ៦០:៧,១០ ។

**៥៦:៧** *ភ្នំបរិសុទ្ធរបស់អញ* សូមមើល ២:២–៤ និងការពន្យល់ ។ ពាក្យថា *ទទួលទាំងដង្វាយដុត . . . លើអាសនា* សូមប្រៀបធៀប ៦០:៧ តែផ្ទុយនិង ១:១១–១៣ ។ ពាក្យថា *ដ្បិតដំណាក់អញ . . . សំរាប់គ្រប់ទាំងសាសន៍* ជាសេចក្ដីដកស្រង់ព្រះបន្ទូលពេលព្រះយេស៊ូវបានប្រើក្នុងគម្ពីរ មក ១១:១៧ និងពាក្យប្រៀបប្រដូច ។ ពាក្យថា *ដំណាក់របស់អញនឹងបានហៅជាទីអធិស្ឋានសំរាប់គ្រប់ទាំងសាសន៍* គឺស្ដេចសាឡូម៉ូនក៏បានធ្វើដូច្នេះក្នុងការអធិស្ឋានថ្វាយក្នុងព្រះវិហារដល់ព្រះយេហូវ៉ា (សូមមើល ១ពវ ៨:៤១–៤២ និងការពន្យល់) ។

**៥៦:៨** *អស់អ្នកដែលត្រូវបំបរបង់* សូមមើល ១១:១១–១២ និងការ ពន្យល់ ។ ពាក្យថា *ប្រមូលមនុស្សដទៃមកជាមួយដែរ* គឺសំដៅ ឬរាប់បញ្ចូលទាំងពួកសាសន៍ដទៃដែរ (សូមមើល ខ.៣ និងការពន្យល់ប្រៀបធៀបនឹង យហ ១០:១៦ និងការពន្យល់) ។

**៥៦:៩–៥៩:១៥** គឺមាន២ គម្ពីរជាច្រើននៅក្នុងផ្នែកនេះ អាចបានឃើញពីកាលៈទេសៈ មុនពេលឬក្នុងកំឡុងពេលដែលត្រូវគេបំបរបង់ពួកបាប៊ីឡូន ។

**៥៦:៩** *សត្វនៅព្រៃ* គឺជាអ្នកលុកលុយពីខាងក្រៅ (សូមមើល ១៨:៦ និងការពន្យល់) ។

**៥៦:១០** *ពួកយាមល្បាត* មានពួកហោរា (សូមមើលការពន្យល់ អគ ៣:១៧ សូមប្រៀបធៀប ការពន្យល់ អស ៥២:៨) ។ ពាក្យថា *សុទ្ធតែខ្វាក់ភ្នែក . . . គេចេះតែដេក* សូមប្រៀបធៀប ២៩:៩–១០ គឺជា *ឆ្កែព្រុសមិនកើត* (សូមប្រៀបធៀប យប ៣០:១) ។

យល់សោះ[ស] គេបានបែរទៅតាមផ្លូវរបស់គេរៀងខ្លួន[ហ]
គឺឱ្យបានកំរៃរបស់ខ្លួនគេទាំងអស់គ្នា[ឡ] ១២គេថា អញ្ជើញ
មក ខ្ញុំនឹងរកស្រាទំពាំងបាយជូរ[អ] យើងនឹងផឹកគ្រឿងស្រវឹង
ទាល់តែឆ្អែត ហើយថ្ងៃស្អែកនឹងបានដូចជាថ្ងៃនេះដែរ គឺ
ជាថ្ងៃមានបរិបូរលើសលុបផង[ក]។

**៥៧** ១មនុស្សសុចរិតគេវិនាសទៅ[ក] ឥតមានអ្នកណាយក
ចិត្តទុកដាក់ឡើយ[ខ] ហើយមនុស្សចិត្តល្អ គេត្រូវយកទៅឥត
មានអ្នកណាពិចារណាថា មនុស្សសុចរិតបានដក ចេញឱ្យ
រួចពីចំពោះការអាក្រក់នោះទេ[គ] ២អ្នកនោះចូលទៅក្នុង
សេចក្ដីសុខសាន្ត គេសំរាក[ឃ]នៅលើដំណេករបស់ខ្លួន គឺ
គ្រប់ទាំងមនុស្សដែលដើរតាមផ្លូវទៀងត្រង់[ង]។

៣ឯឯងរាល់គ្នា ពួកកូនចៅនៃស្រីដែលជាគ្រូនក្ខកត្ត–
ឫក្ស[ច] គឺជាពូជរបស់អ្នកក្បត់ប្រពន្ធ[ឆ] និងស្រីសំផឹងអើយ[ជ]
ចូរមកជិតនេះចុះ ៤តើឯងរាល់គ្នាឡកឡឺយឱ្យអ្នកណា ឯង
ហាមាត់ចំអក ហើយលៀនអណ្ដាតឱ្យអ្នកណា តើឯងរាល់
គ្នាមិនមែនជាកូនឥតខាន់ស្លា[ឈ] គឺជាពូជមនុស្សភូតភរទេ
ឬអី ៥ឯងរាល់គ្នាជាអ្នកកំរើករោលរាលចំពោះរូបព្រះ[ញ]
នៅក្រោមគ្រប់ទាំងដើមឈើខៀវខ្ចី[ដ] ហើយក៏សំឡាប់កូន
ក្មេង[ឋ]នៅក្រហែងថ្ម ត្រង់អស់ទាំងច្រកភ្នំ ៦ចំណែក[ឌ]របស់
ឯង គឺនៅកណ្ដាលអស់ទាំងថ្មរលីងក្នុងបាតជ្រោះ ឯងបាន
ច្រួចដង្វាយចច្រួច[ឍ] និងដង្វាយម្សៅថ្វាយដល់ថ្មទាំងនោះ
ដូច្នេះ ថ្មទាំងនោះជាចំណែករបស់ឯងហើយ តើគួរឱ្យអញ
សោយសេចក្ដីកំហឹងចំពោះអំពើយ៉ាងនោះឬអី[ណ] ៧ឯងបាន
ដាក់គ្រែដេករបស់ឯងនៅលើកំពូលភ្នំធំខ្ពស់[ត] គឺនៅទីនោះ
ដែលឯងបានឡើងទៅថ្វាយយញ្ញបូជាដែរ[ថ] ៨ឯងបានដំកើង
ទីរំឭកពីឯងនៅខាងក្រោយសន្លឹកទ្វារ និងក្របទ្វារដែរ
ហើយឯងបានបើកខ្លួនឱ្យដល់ ម្នាក់ដទៃទៀតក្រៅពីអញ
ឯងបានឡើងទៅធ្វើឱ្យគ្រែឯងធំទូលាយ ហើយបានតាំង
សញ្ញានឹងគេ ឯងបានស្រឡាញ់ដំណេករបស់គេ[ទ] ក៏បាន
រៀបកន្លែងឱ្យ[ធ] ៩ឯងបាននាំដង្វាយជាប្រេង ទៅគាល់
ស្ដេច[ន] ហើយបានចំរើនគ្រឿងក្រអូប របស់ឯងជាច្រើន
ឡើង[ប] ក៏បានចាត់ទូត[ផ]របស់ឯងឱ្យទៅឯស្រុកឆ្ងាយ ព្រម
ទាំងបន្ទាបខ្លួនឯងចុះ ទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់[ព]
១០ឯងត្រូវអស់កំឡាំង[ភ] ដោយផ្លូវរបស់ឯវែងឆ្ងាយ ប៉ុន្តែ
ឯងមិនបានថាជាបង់កំឡាំងទទេនោះទេ[ម] គឺឯងបានទទួល
សេចក្ដីចំរើនកំឡាំងឡើងវិញ[យ] បានជាឯងមិនបានណាយ
ចិត្តសោះឡើយ ។

**៥៦:១១** ស អស ១:៣ ហ អស ៥៣:៦ ហស ៤:៧–៨ ឡ អស ៥៧:១៧ យរ ៦:១៣ ៨:១០ ២២:១៧ អគ ១៣:១៩ មីក ៣:១១ **៥៦:១២** អ លវ ១០:៩ សភ ២៣:២០ អស ២២:១៣ ក ទដ ១០:៦ លក ១២:១៨–១៩ **៥៧:១** ក ទដ ១២:១ អគ ២១:៣ ខ អស ៤២:២៥ គ ២ពវ ២២:២០ **៥៧:២** ឃ ដយ ១២:១៣ ង អស ២៦:៧ **៥៧:៣** ច នក ២២:១៨ មឡ ៣:៥ ឆ ខ.៧–៨ មថ ១៦:៤ យក ៤:៤ ជ អស ១:២១ យរ ២:២០ **៥៧:៤** ឈ អស ១:២ **៥៧:៥** ញ អស ១:២៩ ដ ចទ ១២:២ ២ពវ ១៦:៤ ឋ លវ ១៨:២១ ចទ ១៨:១០ ទដ ១០៦:៣៧–៣៨ អគ ១៦:២០ **៥៧:៦** ឌ ២ពវ ១៧:១០ យរ ៣:៩ ហព ២:១៩ ឍ យរ ៧:១៨ ១៩:១៣ ៤៤:១៨ ណ យរ ៥:៩,២៩ ៩:៩ **៥៧:៧** ត យរ ៣:៦អគ ៦:៣ ១៦:១៦ ២០:២៩ ថ អស ៦៥:៧ យរ ១៣:២៧ អគ ៦:១៣ ២០:២៧–២៨ **៥៧:៨** ទ អគ ១៦:២៦ ២៣:៧ ធ អគ ១៦:១៥,៣៦ ២៣:១៨ **៥៧:៩** ន លវ ១៨:២១ ១ពវ ១១:៥ ប បស ៤:១១ ផ អគ ២៣:១៦,៤០ ព អស ៨:១៩ **៥៧:១០** ភ អស ៤៧:១៣ ម យរ ២:២៥ ១៨:១២ មឡ ៣:១៤ យ ១សយ ២:៤

**៥៦:១១** *មិនចេះឆ្អែតឆ្អន់ឡើយ* គឺពួកវាស៊ីរឡិរឡប់ បំផ្លាញដល់ហ្វូងចៀម សូមមើល អគ ៣៤:៣ ។ *ពួកគង្វាល* គឺជាប្រភេទអ្នកដឹកនាំក៏មានក្នុងគម្ពីរ អគ ៣៤:២–៥ និងការពន្យល់ ។

**៥៦:១២** *ស្រាទំពាំងបាយជូរ* សូមប្រៀបធៀបនិង ឥរិយាបទរបស់ពួកសង្ឃ និងពួកហោរា នៅក្នុង ២៨:៧ ។ ឯពាក្យថា *ថ្ងៃស្អែកនឹងបានដូចជាថ្ងៃនេះដែរ គឺជាថ្ងៃមានបរិបូរលើសលុបផង* គឺពាក្យឃ្លានេះគឺប្រើពណ៌នាពីម្ហូបអាហារដ៏ល្អ ហើយបរិបូរផង សូមមើលក្នុង លក ១២:១៩ ។

**៥៧:១** *ចេញឱ្យរួចពីចំពោះការអាក្រក់* គឺនាងហ៊ុលដាជាហោរាស្រី បានពន្យល់ថា ស្ដេចដែលមានសេចក្ដីសុចរិត គឺស្ដេចយ៉ូសៀស និងត្រូវសុគតមុនពេលភាពវឹកវរគ្រោះថ្នាក់កើតឡើង (២ពវ ២២:១៩–២០) ។

**៥៧:២** *សេចក្ដីសុខសាន្ត* ដែលមានលក្ខណៈខុសនឹង ខ.២១ ។ *គេសំរាក* ប្រៀបធៀប និងពាក្យសម្ដីរបស់លោកប៉ុល ក្នុងគម្ពីរ ភព ១:២១,២៣ ។

**៥៧:៣** *គ្រូនក្ខត្តឫក្ស* គឺជាស្ត្រីដែលមានមន្តអាគម ឬគ្រូស្រីផ្នែកខាងអន្ទងព្រលឹងខ្មោច ឬព្រាយ (សូមមើល ៣:២–៣ នឹងការពន្យល់៤៧:១២ ចទ ១៨:១០) ។ *អ្នកក្បត់ប្រពន្ធ* ពាក្យនេះបង្ហាញក្នុង (ខ.៥–៨ សូមមើល នក ៣៤:១៥ និងការពន្យល់) ។

**៥៧:៤** *ឡកឡឺយ . . . ចំអក* គឺប្រជាជនខ្លះបាន ឡកឡឺយឱ្យសាស្ត្រាអ៊ីស្រាអែល មើលក្នុង ២៨:៩,១៤ សូមមើល ១:៤ ៤៦:៨ នឹងការពន្យល់។

**៥៧:៥** ដោយមានដើមម៉ៃសាក់ គឺជាដើមឈើល្អ (សូមមើល ១:២៩ និងការពន្យល់) ។ *ទាំងដើមឈើខៀវខ្ចី* គឺជាពាក្យដែលទាក់ទងនិងទីខ្ពស់របស់ពួកសាសន៍ដទៃ គឺដើម្បីទុកជាការថ្វាយបង្គំ ។ មើលក្នុង ១ពវ ១៤:២៣ ប្រៀបធៀប យរ ២:២០ និងការពន្យល់ ៣:១៣ ។ ពាក្យថា *សំឡាប់កូនក្មេងនៅក្រហែង* គឺជារឿយៗ ទាក់ទង់និងការថ្វាយបង្គំដល់ព្រះម៉ូឡុក (ប្រៀបធៀបនិង ខ.៩ និងការពន្យល់ ៣០:៣៣) ឬក៏ថ្វាយបង្គំព្រះបាល ។ (យរ ១៩:៥ មើលការពន្យល់ យរ ៧:៣១–៣២) ។ ទដ ១០៦:៣៧–៣៨ គឺបានបង្ហាថា ពួកក្មេងៗត្រូវបានធ្វើយញ្ញបូជាដើម្បីថ្វាយដល់រូបព្រះនិងថ្វាយអារក្សដែរ ។

**៥៧:៦** *បាត់ជ្រោះ* គឺជាទីបាតជ្រោះដែលមានទីតាំងស្ថិតនៅជ្រលង ហ៊ីនណំម (សូមមើល យរ ៧:៣១ និងការពន្យល់) ។ ពាក្យថា *ដង្វាយច្រួច* ការចាក់ប្រេងច្រួចរបស់ពួកសាសន៍ដទៃដែលពួកគេធ្វើដូច្នេះ គឺជាការពេញនិយមចំពោះសាសន៍របស់គេ ។

**៥៧:៧** *នៅលើកំពូលភ្នំខ្ពស់* គឺស្មើនិងកំពស់ ឬភ្នំដែលចំណោតយ៉ាងខ្លាំង (សូមមើល យរ ៣:៦ អរ ៦:៣ និងការពន្យល់ ១៦:១៦ ២២:៩) ។

**៥៧:៨** *គេឯងបានស្រឡាញ់* គឺសំដៅលើពួកអទិទេព្វ ឬរូបព្រះ ។

**៥៧:៩** ឯព្រះម៉ូឡុក ដែលជាព្រះសំខាន់របស់ពួកកូនចៅអាំម៉ូន (សូមមើល ខ.៥ ១ពវ ១១:៥ និងការពន្យល់) ។ *ជាប្រេង* គឺគេប្រើសម្រាប់ជាគ្រឿងប្រមូល ។ មើល ៤:១០ ដែលព្រះគម្ពីរភាសាហេព្រើរមានន័យស្មើនិងគ្រឿងក្រអូបឬទឹកអប់ ។ *ស្ថានឃុំព្រលឹងមនុស្សស្លាប់* មើលប្រៀបធៀប ៨:១៩ ។

**៥៧:១០** *មិនបានថាជាបង់កំឡាំងទទេ* គឺមនុស្សដែលពុំបានលះចោលពីការថ្វាយបង្គំរូបព្រះ និស្ស័យរបស់គេទេ បានទទួលសេចក្ដីចំរើនកំឡាំងវិញ ប្រៀបធៀប ៤០:១១ និងការពន្យល់ ។

១១ តើឯងបានភ័យខ្លាច ហើយស្រយុតចិត្ត[រ] ចំពោះអ្នក
ណា បានជាឯងកុហក ហើយមិនបាននឹក[ល]ដល់អញឬយក
ចិត្តទុកដាក់[វ] សោះដូច្នេះ តើអញមិនបានអត់ធ្មត់[ស]ជាយូរមក
ហើយទេឬអី ប៉ុន្តែឯងមិនបានកោតខ្លាចដល់អញសោះ
១២ អញនឹងប្រកាសប្រាប់ពីសេចក្ដីសុចរិតរបស់ឯង ហើយ
ការដែលឯងប្រព្រឹត្ត[ហ] នឹងមិនមានប្រយោជន៍ដល់ឯងសោះ
១៣ កាលណាឯងអំពាវនាវ[ឡ] នោះឱ្យពួកដែលឯងបាន
ប្រមូលជួយឯង[អ]ឱ្យរួចចុះ តែខ្យល់នឹងផាត់[ក]គេទៅទាំងអស់
សេចក្ដីទទេៗ នឹងចាប់យកគេទៅអស់រលីង ប៉ុន្តែអស់អ្នក
ណាដែលពឹងជ្រក[ខ]នឹងអញវិញ គេនឹងបានស្រុក[គ]ទុកជាកេរ្តិ៍
អាករ ហើយនឹងបានភ្នំបរិសុទ្ធរបស់អញទុកជាមរដក[ឃ] ។

## សេចក្ដីកម្សាន្តចិត្តសម្រាប់អ្នកដែលភ្ញាក់រឭក

១៤ នោះនឹងមានគេបង្គាប់ថា ចូរលើកដីឡើង ចូរលើក
ដីឡើង ចូររៀបចំថ្នល់[ង] ហើយយកថ្មចំពប់ចេញពីផ្លូវ
របស់រាស្ត្រអញទៅ[ច] ១៥ ដ្បិតព្រះដ៏ជាធំ ហើយខ្ពស់បំផុត[ឆ]
ជាព្រះដ៏គង់នៅអស់កល្បជានិច្ច[ជ] ដែលព្រះនាមទ្រង់ជានាម
បរិសុទ្ធ ទ្រង់មានបន្ទូលដូច្នេះថា អញនៅឯស្ថានដ៏ខ្ពស់[ឈ]
ហើយបរិសុទ្ធ ក៏នៅជាមួយនឹងអ្នកណាដែលមានចិត្ត
សង្រេង[ញ] ហើយទន់ទាប[ដ]ដើម្បីនឹងធ្វើឱ្យចិត្តរបស់មនុស្ស
ទន់ទាបបានសង្ឃឹមឡើង ហើយឱ្យចិត្តរបស់មនុស្សសង្រេង
បានសង្ឃឹមឡើងដែរ ១៦ ដ្បិតអញមិនព្រមតវ៉ា[ឋ]ជាដរាបទៅ
ទេ ក៏មិនមានសេចក្ដីក្រោធជានិច្ចដែរ[ឌ] ព្រោះវិញ្ញាណគេ
នឹងរលត់ទៅនៅមុខអញ ព្រមទាំងព្រលឹង[ឍ]ទាំងប៉ុន្មាន
ដែលអញបានធ្វើនេះដែរ ១៧ អញបានខឹង ហើយបានវាយ
គេ ដោយព្រោះសេចក្ដីទុច្ចរិតនៃចិត្តលោភរបស់គេ[ណ] អញ
បានគេច[ត]មុខ ហើយមានសេចក្ដីក្រោធ តែគេបានចេះតែ
ថយ ទៅតាមអំពើចិត្តជានិច្ច[ថ] ១៨ អញបានឃើញអស់ទាំងផ្លូវ
របស់គេ ហើយអញនឹងប្រោសឱ្យជា[ទ] អញនឹងនាំមុខ[ធ]គេ
ដែរ ព្រមទាំងកំសាន្តចិត្ត[ន]គេ ហើយពួកអ្នកដែលកាន់ទុក្ខ
នឹងគេ ឱ្យបានក្សាន្តឡើងផង ១៩ គឺអញដែលបង្កើតពាក្យ
ចេញពីបបូរមាត់[ប] ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា សូម
សេចក្ដីសុខ សេចក្ដីសុខ[ផ] ដល់អ្នកណាដែលនៅឆ្ងាយ
ហើយដល់អ្នកដែលនៅជិតផង[ព] អញនឹងប្រោសគេឱ្យជា
២០ តែឯពួកមនុស្សអាក្រក់[ភ] គេប្រៀបដូចជាសមុទ្រ[ម]ដែល
ចេះតែកំរើក ឥតមានស្ងប់ឡើយ ហើយទឹកនោះចេះតែ
បាររល្បាប់[យ]និងភក់ឡើង ២១ ព្រះនៃខ្ញុំ ទ្រង់មានបន្ទូលថា
គ្មានសេចក្ដីសុខ[រ] ដល់មនុស្សដែលប្រព្រឹត្តអាក្រក់ឡើយ[ល] ។

## ការតមអាហារដ៏ត្រឹមត្រូវ

**៥៨** ១ ចូរស្រែកឱ្យពេញបំពង់ក[ក] កុំសំចៃឡើយ ចូរបន្លឺ
សំឡេងឡើងដូចជាត្រែ[ខ] ហើយប្រកាសប្រាប់ដល់រាស្ត្រ

**៥៧:១១** រ ២ពរ ១:១៥ សភ ២៩:២៥ អស ៧:២ ល អស ១៧:១០ យរ ២:៣២ ៣:២១ ១៣:២៥ ១៨:១៥ អគ ២២:១២ វ អស ៤២:២៣ ស នអ ៤:១៤ ទដ ៥០:២១ ៨៣:១ **៥៧:១២** ហ អស ២៩:១៥ ៥៨:១ ៥៩:៦,១២ ៦៥:៧ ៦៦:១៨ អគ ១៦:២ មីក ៣:២–៤,៨ **៥៧:១៣** ឡ យរ ២២:២០ ៣០:១៥ អ ពច ១០:១៤ ក អស ៤០:៧,២៤ ខ ទដ ១១៨:៨ គ ទដ ៣៧:៩ ឃ អស ២:២–៣ ៥៦:៧ ៦៥:៩–១១ **៥៧:១៤** ង អស ១១:១៦ ច អស ៦២:១០ យរ ១៨:១៥ **៥៧:១៥** ឆ អស ៥២:១៣ ជ ចទ ៣៣:២៧ ទដ ៩០:២ ឈ យប ១៦:១៩ ញ ទដ ១៤៧:៣ ដ ទដ ៣៤:១៨

៥១:១៧ អស ៦៦:២ មីក ៦:៨ មថ ៥:៣ **៥៧:១៦** ឋ ទដ ៥០:២១ អស ៣:១៣–១៤ ឌ ទដ ១០៣:៩ អស ៥៤:៩ ឍ លប ២:៧ សក ១២:១ **៥៧:១៧** ណ អស ៥៦:១១ យរ ៨:១០ ត អស ១:១៥ ថ អស ១:៤ ៣០:១៥ ៥៣:៦ ៦៦:៣ **៥៧:១៨** ទ ចទ ៣២:៣៩ ២របា ៧:១៤ អស ៣០:២៦ ធ ទដ ៤៨:១៤ អស ៤២:១៦ ៤៨:១៧ ន អស ៤៩:១៣ ៦១:១–៣ **៥៧:១៩** ប អស ៦:៧ ៥១:១៦ ៥៩:២១ហព ១៣:១៥ ផ អស ២:៤ ២៦:៣,១២ ៣២:១៧ លក ២:១៤ ព កច ២:៣៩ **៥៧:២០** ភ យប ១៨:៥–២១ ម លប ៤៩:៤ អភ ៤:១៩ យដ ១:១៣ យ ទដ ៦៩:១៤ **៥៧:២១** រ អស ២៦:៣ ៥៩:៨ អគ ១៣:១៦ ល អស ៤៨:២២ **៥៨:១** ក អស ៤០:៦ ខ នក ២០:១៨

**៥៧:១១** *តើឯងបានភ័យខ្លាច ហើយស្រយុតចិត្តចំពោះអ្នកណា* គឺពួកគេភ័យស្ទើរស្លាប់ (សូមមើល ៥១:១២) សូមមើល ៥១:១៣ ។ *អញមិនបានអត់ធ្មត់ជាយូរមកហើយទេឬ* (សូមមើល ៤២:១៤ និងការពន្យល់) ។

**៥៧:១២** *សេចក្ដីសុចរិត* សូមមើល ៥៨:២–៣ ៦៤:៦ ។

**៥៧:១៣** *ពួកដែលឯងបានប្រមូល ជួយឯងឱ្យរួចចុះ* សូមមើល ៤៤:១៧ និងការពន្យល់ ។ *តែខ្យល់និងផាត់គេទៅទាំងអស់ សេចក្ដីទទេៗនឹងចាប់យកគេ* គឺរូបព្រះទាំងនោះលែងមានអំណាចតទៅទៀតហើយ ព្រះទាំងនោះមានភាពខ្សោយជាងអ្នកដែលគោរពពួកគេ ។ *អ្នកណាដែលពឹងជ្រកនឹងអញវិញគេនឹងបានស្រុកទុកជាកេរ្តិ៍អាករ* មើល ២៥:៤ ៤៩:៩ និងការពន្យល់ ។ *បានភ្នំបរិសុទ្ធរបស់អញ* ២:២–៤ នឹងការពន្យល់ ។

**៥៧:១៤** *ចូរលើកដីឡើង... ចូរលើកដីឡើង* សូមមើលការពន្យល់ ៤:១ ។ ពាក្យថា *ចូររៀបចំថ្នល់* សូមមើល ៤០:៣ និងការពន្យល់ ។

**៥៧:១៥** *ដ៏ជាធំ ហើយខ្ពស់បំផុត* សូមមើល ៦:១ ៥២:១៣ និងការពន្យល់ ប្រៀបធៀប ៣៣:៥ ។

**៥៧:១៦** *មិនព្រមតវ៉ាជាដរាបទៅទេ* (សូមមើល ៣:១៣–១៤) ។ *ក៏មិនមានសេចក្ដីក្រោធជានិច្ចដែរ* សូមមើល ៤៩:៩ និងការពន្យល់យរ ៣:១២ ។

**៥៧:១៧** *អញបានគេចមុខ ហើយមានសេចក្ដីក្រោធ* សូមមើល ៥៤:៨ ក៏សូមមើល ១:១៥ និងការពន្យល់ ។

**៥៧:១៨–១៩** *ប្រោសឱ្យគេជា* សូមមើល ខ.១៩ ៦:១០ ៣០:២៦ យរ ៣:២២ គឺទ្រង់និងលើកលែងទោស ហើយអត់ទោសដល់រាស្ត្ររបស់ផងទ្រង់ និងជួយបំពេញដល់រាស្ត្ររបស់ទ្រង់ ។ ពាក្យថា *នាំមុខគេ* សូមប្រៀបធៀប ៤០:១១ ៤២:១៦ ៤៩:១០ ។ *កំសាន្តចិត្ត* មើល ៤៩:១៣ និងការពន្យល់ ។ ពាក្យថា *អ្នកដែលកាន់ទុក្ខ* ការកាន់ទុក្ខទាំងនោះគឺជាការជិនុំជម្រះក្រុងយេរូសាឡិម (សូមមើល ៦៦:១០) ។ *សេចក្ដីសុខ សេចក្ដីសុខ* គឺមានលក្ខណៈខុសនឹង យរ ៦:១៣–១៤ (សូមមើលសេចក្ដីពន្យល់ ៦:១៤) ។ *អ្នកណាដែលនៅឆ្ងាយ* គឺជាអ្នកដែលជាសាសន៍ដទៃ ឬពួកយូដាដែលត្រូវគេបំបោះបង់ទៅ ដូចជាសាវកប៉ុលក៏មានខគម្ពីរនេះនៅក្នុងអារម្មណ៍របស់គាត់ដែល អភ ២:១៧ (ប្រៀបធៀប កច ២:៣៩) ។

**៥៧:២០** *ដូចជាសមុទ្រដែលចេះតែកំរើក* សូមមើល យរ ៤៩:២៣ *ឥតមានស្ងប់ឡើយ* ដែលខុសនឹង ខ.២ ។

**៥៧:២១** ខនេះមានលក្ខណៈដូចជា ៤៨:២២ (សូមមើលការពន្យល់ ៣៩:៨ និងការពន្យល់) ។

អញពីអំពើរំលងរបស់គេ[ក] នឹងដល់ពូជពង្សនៃយ៉ាកុបពី
អំពើបាបរបស់គេ[ខ] ២រាល់តែថ្ងៃគេស្វែងរក[គ]អញជានិច្ច
ហើយក៏ពេញចិត្តចង់ស្គាល់អស់ទាំងផ្លូវរបស់អញ គេសូម
សេចក្ដីវិនិច្ឆ័យដ៏សុចរិតពីអញ ទុកដូចជាសាសន៍ណាមួយ
ដែលប្រព្រឹត្តដោយសុចរិត ឥតបោះបង់ចោល[ច]សេចក្ដី
យុត្តិធម៌របស់ព្រះនៃគេឡើយ គេរីករាយចិត្តដោយចូល
ទៅជិត[ឆ]ព្រះ ៣គេពោលថា យើងខ្ញុំបានតមអត់[ជ] ហេតុអ្វី
បានជាទ្រង់ មិនឃើញសោះ យើងខ្ញុំបានបញ្ឈឺចិត្ត[ឈ]ខ្លួន
ហេតុអ្វីបានជា ទ្រង់មិនយកចិត្តទុកដាក់ដូច្នេះ[ញ]នេះពីព្រោះ
តែនៅថ្ងៃដែលឯងរាល់គ្នាតមអត់នោះ គឺឯងធ្វើដើម្បីជា
ប្រយោជន៍ដល់ខ្លួនវិញ[ដ] ហើយក៏សង្កត់សង្កិនពួកអ្នកដែល
ធ្វើការឈ្នួលផង ៤មើល ឯងរាល់គ្នាតមអត់ឱ្យតែបានរឿង
ជជែក និងការទាស់ទែងគ្នា[ឋ] ហើយវាយដំដោយអំពើ
អាក្រក់ប៉ុណ្ណោះ ការដែលឯងតមអត់នោះ គឺមិនមែនមាន
ប្រយោជន៍ឱ្យសំឡេងឯងបានឮ[ឌ]ទៅដល់ស្ថានលើឡើយ
៥តើជាការតមអត់[ឍ]បែបយ៉ាងនោះ គឺជាថ្ងៃដែលមនុស្ស
បញ្ឈឺចិត្ត[ណ]ខ្លួនដូច្នេះ ដែលជាទីពេញចិត្តដល់អញឬ ដែល
គ្រាន់តែឱនក្បាល ដូចជាដើមបបុស[ត] ហើយក្រាលសំពត់ធ្មៃ
និងរោយផេះនៅក្រោមខ្លួន[ថ] តើល្មមប៉ុណ្ណោះឬ នេះឬ
ដែលឯងហៅថា ការតមអត់ ជាថ្ងៃដែលគួរឱ្យព្រះយេហូវ៉ា
សព្វព្រះហឫទ័យនោះ ៦តើមិនមែនជាការតមអត់យ៉ាង
នេះវិញ[ទ] ដែលអញពេញចិត្តទេឬអី គឺឱ្យដោះច្រវាក់ដែល
ឯងដាក់គេដោយអំពើអាក្រក់[ធ] ឱ្យស្រាយចំណងដែលឯង
បានចងគេ ហើយឱ្យអ្នកដែលឯងបានសង្កត់សង្កិន[ន]បានរួច
ចេញទទេ ព្រមទាំងបំបាក់គ្រប់ទាំងនឹមផង[ប] ៧តើមិនមែន
ឱ្យឯងបានចែកអាហារដល់អ្នកដែលឃ្លាន[ផ] ហើយនាំមនុស្ស
ក្រដែលត្រូវដេញពីផ្ទះ[ព] គេមកឯផ្ទះឯងទេឬអី ឬបើកាល
ណាឯងឃើញមនុស្សឥតមានសំលៀកបំពាក់[ភ] នោះតើមិន
មែនឱ្យឯងបិទបាំងឱ្យគេ ឥតដែលពួនខ្លួននឹងសាច់ញាតិ
របស់ឯងទេឬអី[ម] ៨យ៉ាងនោះ ទើបពន្លឺរបស់ឯង និងលេច
មក ដូចជារស្មីអរុណ[យ] ហើយសេចក្ដីសុខស្រួល[រ]របស់ឯង
នឹងលេចឡើង ជាយ៉ាងឆាប់ ឯសេចក្ដីសុចរិត[ល]របស់ឯង
នោះនឹងនាំមុខឯង ហើយសិរីល្អនៃព្រះយេហូវ៉ានឹងការ
ពារពីខាងក្រោយឯង[វ] ៩គ្រានោះ បើឯងអំពាវនាវ[ស] ព្រះ
យេហូវ៉ាទ្រង់នឹងតបឆ្លើយ[ហ] បើឯងស្រែករក នោះទ្រង់នឹង
មានបន្ទូលថា អញនៅឯណេះហើយ គឺបើឯងចោលនឹម
របស់ឯងចេញ លែងជន្លក់ហែង[ឡ] ព្រមទាំងលែងពោល

**៥៨:១** គ អស ២៤:២០ ៤៨:៨ ឃ អស ៥៧:១២ អគ ៣:១៧ **៥៨:២** ង អស ៤៨:១ ទត ១:១៦ យក ៤:៨ ច ចទ ៣២:១៥ ទដ ១១៩:៨៧ ឆ អស ២៩:១៣ **៥៨:៣** ជ លវ ១៦:២៩ ឈ នក ១០:៣ ២រប ៦:៣៧ យរ ៤៤:១០ ញ មឡ ៣:១៤ ដ អស ២២:១៣ សក ៧:៥-៦ **៥៨:៤** ឋ ១ពវ ២១:៩-១៣ អស ៥៩:៦ យរ ៦:៧ អគ ៧:១១ មឡ ២:១៦ ឌ ១សយ ៨:១៨ អស ៥៩:២ បទ ៣:៤៤ អគ ៨:១៨ មីក ៣:៤ **៥៨:៥** ឍ សក ៧:៥ ណ ១ពវ ២១:២៧ មថ ៦:១៦ ត អស ៣៦:៦ ថ យប ២:៨ **៥៨:៦** ទ យអ ២:១២-១៤ ធ នហ ៥:១០-១១ ន ចទ ១៤:២៩ អស ៦១:១ យរ ៣៤:៩ អម ៦១:១ យរ ៣៤:៩ អម ៤:១ លក ៣៤:៩ អម ៤:១ លក ៤:១៩ ប អស ៩:៤ **៥៨:៧** ផ យប ២៧:៧ អគ ១៨:១៦ លក ៣:១១ ព អស ១៦:៤ ហត ១៣:២ ភ យប ៣១:១៩-២០ មថ ២៥:៣៦ ម លប ២៩:១៤ លក ១០:៣១-៣២ **៥៨:៨** យ យប ១១:១៧ អស ៩:២ រ អស ១:៥ ៣០:២៦ ល អស ២៦:២ វ នក ១៤:១៩ **៥៨:៩** ស ទដ ៥០:១៥ ហ យប ៨:៦ អស ៣០:១៩ ដយ ៩:២០ សក ១០:៦ ឡ សភ ៦:១៣

**៥៨:១** *សំឡេងឡើងដូចជាត្រែ* គឺសំឡេងដែលជាអំណាចព្រះចេស្ដារបស់ព្រះមានលក្ខណៈដូចសំឡេងត្រែនៅឯភ្នំស៊ីណាយ (សូមមើល នក ១៩:១៩ ២០:១៨-១៩) ។ *ពីអំពើរំលងរបស់គេ* សូមមើល ១:២ និងការពន្យល់ ។ *អំពើបាប* សូមមើល ១:៤ ៥៩:១២-១៣ ។

**៥៨:២** *គេស្វែងរកអញជានិច្ច* សូមមើល ៥៥:៦ និងការពន្យល់ ។ សូមប្រៀបធៀប យញ្ញបូជា ១:១១ ។ *គេរីករាយចិត្តដោយចូលទៅជិតព្រះ* គឺក៏ដូចជាពួកមានពុតដែលបានបង្ហាញក្នុង ២៩:១៣ (និងមើលការពន្យល់) ។

**៥៨:៣** *បានតមអត់ . . . តមអត់* សូមមើល ខ.៦ គឺជាពេលវេលាតម្រូវឱ្យបន្ទាបខ្លួនលន់តួនូវរាល់អំពើបាប គឺនៅពេលក្រុងយេរូសាឡិមបានធ្លាក់ចុះ ចំនួនថ្ងៃនៃការតមអាហារក៏បានកើនឡើង (សូមមើល លវ ១៦:២៩ សក ៨:១៩ និងការពន្យល់) សូមប្រៀបធៀប ២រប ៧:១៤ ១ពវ ២១:២៩ ។ *ក៏សង្កត់សង្កិនពួកអ្នកដែលធ្វើការឈ្នួល* សូមមើល ៣:១៤-១៥ ១០:២

**៥៨:៤** *បានឮទៅដល់ស្ថានលើឡើង* គឺជាសកម្មភាពសាសនារបស់ពួកមានពុធដែលជាឧបសគ្គក្នុងការអធិស្ឋាន (សូមមើល ១:១៥ ៥៩:២) ។

**៥៨:៥** *ការតមអត់ . . . ជាថ្ងៃដែលមនុស្សបញ្ឈឺចិត្តខ្លួនឯង* សូមមើល មថ ៦:១៦-១៨ ។ *ដូចជាដើមបបុស* គឺជាសញ្ញានៃការបន្ទាបខ្លួន ឬជាភាពខ្សោយមួយ (សូមមើល ៤២:៣ និងការពន្យល់) ។ ពាក្យថា *សំពត់ធ្មៃ . . . រោយផេះ . . . ការតមអត់* (សូមមើលការពន្យល់ លប ៣៧:៣៤ អរ ៨:២៣ ១០:៦ យអ ១:១៣-១៤ យហ ៣:៥-៦ វវ ១១:៣ ប្រៀបធៀប ១២:១) ។

**៥៨:៦** *ដោះច្រវាក់ដែលឯងដាក់គេដោយអំពើអាក្រក់* ក្នុងអំឡុងពេលដែលគេបានព័ទ្ធក្រុងយេរូសាឡិម ក៏មានពួកបាវហេព្រើរបានដោះលែង (សូមមើល ៣៤:៨-១១ និងការពន្យល់) ។ ពាក្យថា *នឹម* សូមមើល ខ.៩ ៩:៤ ១០:២៧ ជាទីដែលនឹមបានគេបំពេនដោយពួកអាសសើរ ក៏បានបង្ហាញផងដែរ ។ ពាក្យថា *បានសង្កិតសង្កិន* សូមមើល ១:១៧ ។

**៥៨:៧** *ចែកអាហារ . . . សំលៀកបំពាក់* គឺជាបន្ទាល់ស្ដែងចេញនូវភាពសុចរិត សូមមើល យប ៣១:១៧-២០ អគ ១៨:៧,១៦ និងការសម្ដែងរបស់ព្រះគ្រីស្ទពីភាពឃ្លាននិងភាពនៅទទេគ្មានអ្វី មើលក្នុង មថ ២៥:៣៤-៤០ (សូមមើលការពន្យល់) ។

**៥៨:៨** *ពន្លឺ* គឺសេចក្ដីដែលវិបុលសុខ និងសេចក្ដីសង្គ្រោះបានមកតាមរយៈព្រះយេហូវ៉ា(សូមមើល ៩:២ ៦០:១-៣ ទដ ២៧:១ និងការពន្យល់ ។ សេចក្ដីសុខស្រួលរបស់ឯង មើល ៥៧:១៨ និងការពន្យល់ ។ ពាក្យថា *នោះនឹងនាំមុខឯង . . . ព្រះយេហូវ៉ានឹងនាំការពារពីខាងក្រោយឯង* សូមមើល ៥២:១២ និងការពន្យល់ ។ គឺព្រះយេហូវ៉ាទ្រង់ការពារពួកគេនិងនាំផ្លូវពួកគេ ។ *សិរីល្អនៃព្រះយេហូវ៉ា* គឺអាចសំដៅទៅលើបង្គោលពពក និងភ្លើងក្នុងទីរហោស្ថាន(សូមមើល ៤:៥-៦ នក ១៣:២១ ១៤:២០ និងការពន្យល់) ។

**៥៨:៩** *ព្រះយេហូវ៉ាទ្រង់នឹងតបឆ្លើយ* សូមមើល ៣០:១៩ ។ *អញនៅឯណេះហើយ* មើល ៦៥:៤ (មើលការពន្យល់ សភ ៦:១២-១៤) ។ *ដោយកាចអាក្រក់ផង* សូមមើល សភ ២:១២ ៦:១២,១៧,១៩ និងការពន្យល់ ។

ដោយកាចអាក្រក់ផង[អ] ១០ហើយបើឯងផ្តល់សេចក្តីសប្បុរស
ដល់មនុស្សស្រេកឃ្លាន ទាំងចំអែតចិត្តនៃអ្នកដែលមានទុក្ខ
វេទនា[ក] នោះពន្លឺ[ខ]របស់ឯងនឹងភ្លឺឡើងក្នុងទីងងឹត ហើយ
សេចក្តីងងឹតរបស់ឯងនឹងបានភ្លឺ ដូចជាវេលាថ្ងៃត្រង់[គ]
១១ព្រះយេហូវ៉ាទ្រង់នាំផ្លូវ[ឃ]ឯងជានិច្ច ហើយនឹងចំអែត
ព្រលឹង[ង]ឯងនៅក្នុងទីហួតហែង[ច] ទ្រង់នឹងធ្វើឱ្យឆ្អឹងឯងបាន
មាំមួន[ឆ]ឯងនឹងបាន ដូចជាសួនច្បារដែលគេស្រោចទឹក[ជ]
ហើយដូចជាក្បាលទឹក[ឈ] ដែលមិនខានហូរឡើយ ១២ហើយ
ពួកអ្នកដែលនឹងកើតពីឯងមក គេនឹងសង់ទីចាស់ ដែលខូច
បង់[ញ]ឡើងជាថ្មី ឯងនឹងសង់ឡើងលើជើងជញ្ជាំង ដែល
មាននៅតាំងពីច្រើនដំណតមកហើយ[ដ] ក៏នឹងមាន ឈ្មោះថា
ជាអ្នកជួសជុលទីបាក់បែក[ឋ] គឺជាអ្នកដែលរៀបចំផ្លូវទៅ
ឯទីលំនៅឡើងវិញ ។

១៣បើឯងឃាត់ជើងឯង មិនឱ្យបែរចេញពីថ្ងៃឈប់
សំរាក[ឌ] គឺមិនឱ្យធ្វើតាមអំពើចិត្តនៅថ្ងៃបរិសុទ្ធរបស់អញ
បើឯងរាប់ថ្ងៃឈប់សំរាកទុកជាទីរីករាយចិត្ត[ឍ] ហើយលើក
ថ្ងៃបរិសុទ្ធរបស់ព្រះយេហូវ៉ា ទុកជាថ្ងៃគួរគោរព ព្រម
ទាំងប្រតិបត្តិតាមផង ឥតធ្វើតាមអំពើចិត្តរបស់ខ្លួន ឬស្វែង
រកសេចក្តីអំណរដល់ខ្លួនឯង ឬពោលតែពាក្យរបស់ផង
ខ្លួនឡើយ[ណ] ១៤គ្រានោះឯងនឹងបានចិត្តរីករាយ[ត]ក្នុងព្រះ
យេហូវ៉ា ហើយអញនឹងបញ្ជិះឯងនៅលើទីខ្ពស់[ថ]នៃផែនដី
ហើយនឹងចិញ្ចឹមឯងដោយមរដក[ទ]របស់យ៉ាកុប ជាឰយុកោ
ឯង ដ្បិតព្រះឱស្ឋនៃព្រះយេហូវ៉ាបានចេញវាចាហើយ[ធ]។

**អំពើបាប ការលន់តួរបាប និងសេចក្តីប្រោសលោះ**

**៥៩** ១មើល ព្រះហស្ត[ក]នៃព្រះយេហូវ៉ាមិនមែនរួញខ្លី[ខ]
ដែលនឹងជួយសង្គ្រោះមិនបាននោះទេ ព្រះកាណ៌ទ្រង់ក៏មិន
បានទៅជាធ្ងន់ ដែលនឹងស្តាប់មិនឮនោះដែរ[គ] ២គឺជាអំពើ
ទុច្ចរិតរបស់ឯងរាល់គ្នា ដែលបានខណ្ឌជាកណ្តាល[ឃ]ឯង
ហើយនឹងព្រះនៃឯងទេតើ ហើយអំពើបាបរបស់ឯងរាល់
គ្នាបានបាំងព្រះភក្ត្រទ្រង់មិនឱ្យឯងឃើញ ដល់ម៉្លេះបានជា
ទ្រង់មិនព្រមស្តាប់ទេ[ង] ៣ដ្បិតដៃរបស់ឯងរាល់គ្នាប្រឡាក់
ដោយឈាម[ច] ហើយម្រាមដៃដោយអំពើទុច្ចរិតដែរ[ឆ] បបូរ
មាត់ឯងបានពោលពាក្យកំភូត[ជ] ហើយអណ្តាតឯងពោល
ងាំៗចេញជាសេចក្តីទុច្ចរិត ៤គ្មានអ្នកណាមួយហៅរក
សេចក្តីសុចរិត[ឈ] ឬអ្នកណាដែលប្តឹងដោយសេចក្តីពិត
ឡើយ គេទុកចិត្ត[ញ]នឹងសេចក្តីសោះសូន្យ ហើយពោលតែ
សេចក្តីភូតភរទទេ[ដ] គេមានទំងន់ជាគំនិតបៀតបៀន ហើយ
សំរាលចេញជាអំពើទុច្ចរិត[ឋ] ៥គេភ្ញាស់ពងរបស់ពស់វែក[ឌ]
ហើយក៏ត្បាញជាមងពីងពាង[ឍ] អ្នកណាដែលស៊ីពងនោះ

**៥៨:៩** អ ទដ ១២:២ អស ៥៩:១៣
**៥៨:១០** ក ចទ ១៥:៧–៨ ខ អស ៤២:១៦ គ យប ១១:១៧
**៥៨:១១** ឃ ទដ ៤៨:១៤ អស ៤២:១៦ ៤៨:១៧ ង ទដ ១០៤:២៨ ១០៧:៩ ច ទដ ៦៨:៦ ឆ ទដ ៧២:១៦ ជ បស ៤:១៥ ឈ អស ៣៥:៧ យហ ៤:១៤
**៥៨:១២** ញ អស ៤៩:៨ ដ អស ៤៤:២៨ ឋ នហ ២:១៧
**៥៨:១៣** ឌ នក ២០:៨ ឍ ទដ ៣៧:៤ ៤២:៤ ៨៤:២,១០ ណ អស ៥៩:៣
**៥៨:១៤** ត យប ២២:២៦ ថ ចទ ៣២:១៣ ទ ទដ ១០៥:១០–១១ ធ អស ១:២០
**៥៩:១** ក អស ៤១:២០ ខ អស ៥០:២ គ អស ៣០:១៩ ៥៨:៩ ៦៥:២៤ **៥៩:២** ឃ យរ ៥:២៥ អគ ៣៩:២៣ ង ទដ ១៨:១៤ អស ៥៨:៤ យរ ១១:១១ យហ ៩:៣១ **៥៩:៣** ច ២ពវ ២១:១៦ អស ១:១៥ អគ ២២:៩ ឆ ទដ ៧:៣ ជ អស ៣:៨ **៥៩:៤** ឈ អស ៥:២៣ ញ យប ១៥:៣១ ដ អស ៤៤:២០ ឋ យប ៤:៨ អស ២៩:២០ យក ១:១៥ **៥៩:៥** ឌ អស ១១:៨ មថ ៣:៧

**៥៨:១០** *ដល់មនុស្សស្រេកឃ្លាន . . . ដែលមានទុក្ខវេទនា* សូមមើល ខ.៦–៧ និងការពន្យល់ ។ *ភ្លឺ* សូមមើល ខ.៨ និងការពន្យល់ ។

**៥៨:១១** *នាំផ្លូវឯង* សូមមើល ៥៧:១៨ និងការពន្យល់ ។ *ចំអែតព្រលឹងឯង* ពាក្យនេះ គឺសំដៅលើអាហារខាងឯព្រលឹងវិញ្ញាណ និងអាហារខាងឯសាច់ឈាមផងដែរ (សូមមើលការពន្យល់ ៣២:២) ។ *នៅក្នុងទីហួតហែង* សូមមើល ៣៥:៧ ៤៩:១០ ។ *ឯងនឹងបានដូចជាសួនច្បារដែលគេស្រោចទឹក* សូមមើល ១:៣០ គឺក្រុងយេរូសាឡិមគឺជាសួនច្បារដែលពុំមានប្រភពទឹក ស្រោចប្រស់ ។ ពាក្យថា *ហើយដូចជាក្បាលទឹកដែលមិនខានហូរឡើង* ដែលខុសនឹង យរ ១៥:១៨ សូមប្រៀបធៀប "ទឹករស់ "ដែលព្រះយេស៊ូវ ប្រទានឱ្យមើលក្នុង យហ ៤:១០,១៤ (សូមមើលការពន្យល់) ។

**៥៨:១២** *ទីចាស់ដែលខូចបង់ . . .* សូមមើល ៤៤:២៦,២៨ និងការពន្យល់ ៦១:៤ អគ ៣៦:១០ អម ៩:១១,១៣–១៥ និងការពន្យល់ ។ *ជាអ្នកជួសជុលទីបាក់បែក* សូមប្រៀបធៀបពីកិច្ចការរបស់លោកយេរេមាក្នុងគម្ពីរ នហ ២:១៧ (សូមមើលការពន្យល់ដែរ) ។

**៥៨:១៣** *ថ្ងៃឈប់សំរាក* សូមមើល ៥៦:២ និងការពន្យល់ ។ *ថ្ងៃបរិសុទ្ធរបស់អញ* គឺជាថ្ងៃរបស់អញ គឺជាថ្ងៃដែលបានញែកសម្រាប់ទំនាក់ទំនងជាមួយព្រះ (មើល នក ៣:៥ និងការពន្យល់) ។ ពាក្យថា *ជាទីរីករាយចិត្ត* គឺពួកគេក៏រីករាយចំពោះខ្លួនគេក្នុងព្រះយេហូវ៉ា (ទដ ៣៧:៤) និងក្នុងក្រឹត្យវិន័យរបស់ទ្រង់ (មើល ទដ ១:២ និងការពន្យល់) ។ *ស្វែងរកសេចក្តីអំណរដល់ខ្លួនឯង* គឺប្រហែលជាទាក់ទងក្នុងការរកស៊ីជួញដូរ (មើល អម ៨:៥) ។

**៥៨:១៤** *ចិត្តរីករាយក្នុងព្រះយេហូវ៉ា* សូមមើល ៦១:១០ ។ *បញ្ជិះឯងនៅលើទីខ្ពស់នៃផែនដី* គឺជាកិច្ចការគ្រប់គ្រងដែន សូមមើល ៣៣:១៦ និងការពន្យល់ក៏សូមមើល ហប ៣:១៩ ។ *ចិញ្ចឹមឯងដោយមរដក* គឺជាការសប្បាយរីករាយចំពោះអាហារដ៏ហូរហៀរក្នុងទឹកដីសន្យា (មើល ចទ ៣២:១៣–១៤) ។ *ព្រះឱស្ឋនៃព្រះយេហូវ៉ាបានចេញវាចា* សូមមើល ៤០:៥ និងការពន្យល់ ។

**៥៩:១** *ព្រះហស្ត . . . រួញខ្លី* សូមមើល ៥១:៩ និងការពន្យល់ ។

**៥៩:២** *បាំងភក្ត្រ . . . ទ្រង់មិនព្រមស្តាប់* សូមមើល ១:១៥ និងការពន្យល់ ។

**៥៩:៣–៤** *ពាក្យកំភូត* សូមមើល ១៣:២៨ ហស ៤:២ ។

**៥៩:៣** *ប្រឡាក់ដោយឈាម* សូមមើល ខ.៧ ១:១៥,២១ អគ ៧:២៣ សូមមើល អគ ១៨:៤,២១ ។

**៥៩:៤** *សេចក្តីសុចរិត . . .* គឺអ្នកក្រកំសត់និងអ្នកគ្មានទីពឹងពុំអាចទទួលបាននូវការជំនុំជម្រះដោយយុត្តធម៌ទេ ។ (សូមមើល ខ.១៤ ១:១៧–២៣ ៥:៧,២៣) ។ *គេទុកចិត្តនឹង . . . ចេញជាអំពើទុច្ចរិត* គឺមានបញ្ជាក់ក្នុងគម្ពីរយ៉ូប ១៥:៣៥ (សូមមើលការពន្យល់ផង) សូមប្រៀបធៀប អស ៣៣:១១ ទដ ៧:១៤ ។

នោះរមែងស្លាប់ទៅ ហើយពងណាដែលត្រូវជាន់បែក
នោះក៏ញាស់ចេញជាពស់វែក ៦មងរបស់គេនឹងប្រើធ្វើជា
សំលៀកបំពាក់មិនបាន ហើយគេនឹងបិទបាំងខ្លួន ដោយការ
ដែលគេធ្វើក៏មិនបានដែរ[ណ] ការរបស់គេសុទ្ធតែជាអំពើ
ទុច្ចរិត[ត]ទាំងអស់ ហើយមានអំពើច្រឡោតនៅដៃគេ ៧ជើង
គេរត់ទៅតាមសេចក្តីអាក្រក់ គេក៏រហ័សនឹងកំចាយឈាម
ដែលឥតទោស[ថ] គំនិតរបស់គេគិតតែពីសេចក្តីទុច្ចរិតទទេ[ទ]
មានសេចក្តីវិនាស និងសេចក្តីបំផ្លាញនៅអស់ទាំងផ្លូវរបស់
គេដែរ[ធ] ៨គេមិនស្គាល់ផ្លូវនៃសេចក្តីសុខទេ[ន] ហើយសេចក្តី
យុត្តិធម៌ក៏គ្មាន នៅក្នុងអស់ទាំងដំណើររបស់គេផង គេ
បានធ្វើផ្លូវច្រកក្ងិកក្ងក់សំរាប់ខ្លួន[ប] ឯអ្នកណាដែលចូលតាម
ផ្លូវនោះ ជាអ្នកមិនស្គាល់សេចក្តីសុខឡើយ[ផ] ។
៩ហេតុនោះបានជាសេចក្តីយុត្តិធម៌នៅឆ្ងាយពីយើងខ្ញុំ
ឯសេចក្តីសុចរិតក៏មកតាមយើងខ្ញុំមិនទាន់ផង យើងខ្ញុំ
រង់ចាំពន្លឺ តែមើល មានសុទ្ធតែងងឹតទទេ[ព] ក៏ចាំឱ្យស្វាង
ឡើង តែយើងខ្ញុំដើរក្នុងសេចក្តីសូន្យសុងវិញ ១០យើងខ្ញុំ
ស្រវារាវរកកំផែងដូចជាមនុស្សខ្វាក់[ភ] អើ ស្រវារាវរក
ដូចជាមនុស្សដែលគ្មានភ្នែកសោះ យើងខ្ញុំចំពប់[ម]នៅពេល
ថ្ងៃត្រង់ ដូចជានៅពេលព្រលប់ដែរ ក៏ប្រៀបដូចជាមនុស្ស
ស្លាប់នៅកណ្តាលទីសូន្យ[យ] ១១យើងខ្ញុំគ្រហឹមទាំងអស់គ្នា
ដូចជាខ្លាឃ្មុំ ហើយថ្ងូរជាខ្លាំង ដូចជាព្រាប[រ] យើងខ្ញុំរង់ចាំ
សេចក្តីយុត្តិធម៌ តែគ្មានសោះ ក៏រង់ចាំសេចក្តីសង្គ្រោះ
តែសេចក្តីនោះនៅឆ្ងាយពីយើងខ្ញុំទេ ១២ដ្បិតអំពើរំលង[ល]
របស់យើងខ្ញុំ បានចំរើនជាច្រើនឡើងនៅចំពោះទ្រង់ ឯ
ចំណែកអំពើបាបរបស់យើងខ្ញុំ ក៏ធ្វើបន្ទាល់ទាស់[វ]នឹងយើង
ខ្ញុំដែរ ពីព្រោះអំពើរំលងរបស់យើងខ្ញុំនៅជាប់នឹងយើងខ្ញុំ
ឯអំពើទុច្ចរិតរបស់យើងខ្ញុំ នោះយើងខ្ញុំក៏ស្គាល់ទាំងអស់
ហើយ[ស] ១៣គឺយើងខ្ញុំតែងតែប្រព្រឹត្តរំលង[ហ] ហើយមិនស្មោះ
ត្រង់ចំពោះព្រះយេហូវ៉ា ក៏បែរចេញ[ឡ]លែងតាមព្រះនៃ
យើងខ្ញុំ ហើយពោលតែពីការសង្កត់សង្កិន[អ] និងការ
បះបោរ ព្រមទាំងគិតបង្កើត ហើយពោលពាក្យភូតភរ[ក]
ចេញពីចិត្តមក ១៤ឯសេចក្តីយុត្តិធម៌[ខ] បានត្រឡប់ថយចេញ
ទៅ ហើយសេចក្តីសុចរិត[គ]ក៏ឈរនៅទីឆ្ងាយ ដ្បិតសេចក្តី
ពិត[ឃ]បានដួលនៅកណ្តាលផ្លូវ ហើយសេចក្តីទៀងត្រង់ចូល
មកមិនបាន ១៥អើ សេចក្តីពិត[ង]ក៏គ្មានដែរ ហើយអ្នកណា
ដែលលែងប្រព្រឹត្តអំពើអាក្រក់ នោះសុខចិត្តធ្វើជារំពា
ដល់គេហើយ ។

ព្រះយេហូវ៉ាក៏ទតឃើញហើយ ឯការដែលឥតមាន
សេចក្តីយុត្តិធម៌ដូច្នេះ ក៏អាក្រក់នៅព្រះនេត្រព្រះយេហូវ៉ា[ច]

**៥៩:៥** ល យប ៨:១៤ **៥៩:៦** ណ អស ២៨:២០ ត ទដ ៥៥:៩ សភ ៤:១៧ អស ៥៨:៤ **៥៩:៧** ថ ២ពវ ២១:១៦ សភ ៦:១៧ មីក ៣:១០ ទ សភ ២៤:២ អស ២៦:១០ មក ៧:២១–២២ ធ រម ៣:១៥–១៧ **៥៩:៨** ន រម ៣:១៥–១៧ ប ពច ៥:៦ ផ អស ៥៧:២១ លក ១:៧៩ **៥៩:៩** ព យប ១៩:៨ ទដ ១០៧:១៤ អស ៥:៣០ ៨:២០ លក ១:៧៩ **៥៩:១០** ភ ចទ ២៨:២៩ អស ៦:៩–១០ ៥៦:១០ បទ ៤:១៤ សផ ១:១៧ ម យប ៣:២៣ អស ៨:១៥ យហ ១១:៩–១០ យ បទ ៣:៦ **៥៩:១១** រ លប ៨:៨ ទដ ៧៤:១៩ អស ៣៨:១៤ យរ ៤៨:២៨ អគ ៧:១៦ ណហ ២:៧ **៥៩:១២** ល អរ ៩:៦ អស ៥៧:១២ វ លប ៤:៧ អស ៣:៩ យរ ២:១៩ ស ទដ ៥១:៣ **៥៩:១៣** ហ អស ៤៦:៨ ៤៨:៨ ឡ ជន ១១:២០ សភ ៣០:៩ មថ ១០:៣៣ ទត ១:១៦ អ ទដ ១២:៥ អស ៥:៧ ក អស ៣:៨ ៤៤:២០ មក ៧:២១–២២ **៥៩:១៤** ខ អស ២៩:២១ គ អស ១:២១ ឃ អស ៤៨:១ យរ ៣៣:១៦ **៥៩:១៥** ង យរ ៧:២៨ ៩:៥ ដយ ៨:១២ ច អស ៥:៧

**៥៩:៥** *ពងជាមងពីងពាង* មើល ខ.៦ និងយ៉ូប ៨:១៤–១៥ គឺបង្ហាញពីភាពងាយនិងពុកផុយ ។

**៥៩:៦** *មានអំពើច្រឡោតនៅដៃ* សូមមើល ខ.៣ យរ ៦:៧ អគ ៧:១១ ។

**៥៩:៧** *ជើងគេរត់ទៅតាមសេចក្តីអាក្រក់ . . . កំចាយឈាមដែលឥតទោស* ប្រយោគនេះលេចឃើញមាននៅ សភ ១:១៦ និងការពន្យល់ ។ *គំនិតរបស់គេគិតទេពីសេចក្តីទុច្ចរិត* គំនិតរបស់ព្រះគឺខុសប្លែកពីនេះ (មើល ៥៥:៧–៩) ។ *មានសេចក្តីវិនាស នឹងសេចក្តីបំផ្លាញ* មានភាពខុស ៦០:១៨ ។

**៥៩:៩** *ពីយើង . . . តាមយើង* គឺជាហោរាមានទាំងប្រជារាស្ត្រផងដែរ ។ *ជាសេចក្តីយុត្តិធម៌ . . . សេចក្តីសុចរិត* ដែលបង្ហាញលក្ខណៈសម្បត្តិតាមរយៈ ខ.៤,១៤ និងការពន្យល់ ១:២១ ។ ពាក្យថា *យើងខ្ញុំរង់ចាំពន្លឺ តែមើល . . .* សូមមើល ខ.១១ ប្រៀបធៀបការពន្យល់ ៥:២ ។ ពាក្យថា *មានសុទ្ធតែងងឹតទទេ . . . ក្នុងសេចក្តីសូន្យសុងវិញ* គឺជាការប្រើភាសាមានភាពស្រដៀងគ្នាក្នុងពេលគេប្រើពណ៌នា នាពេលពួកអាសស៊ើរបានឈ្លានពានដល់ស្រុកអ៊ីស្រាអែល (មើល ៥:៣០ ៨:២១ ៩:១–២ មានភាពខុសនឹង ៥៨:៨) ។

**៥៩:១០** *ដូចជាមនុស្សខ្វាក់ អើស្រវារាវរក . . . យើងខ្ញុំចំពប់នៅពេលថ្ងៃត្រង់* គឺជាសេចក្តីបំពេញសម្រេចនូវបណ្តាសា ដែលព្រះបានដាក់មកលើមនុស្សលោកជាពិសេសចំពោះអ្នកមិនស្តាប់បង្គាប់ ក្នុងគម្ពីរ ចទ ២៨:២៩ ប្រៀបធៀបនឹង យប ៥:១៤ ។

**៥៩:១១** *គ្រហឹមទាំងអស់គ្នា ដូចជាខ្លាឃ្មុំ* គឺជាការដែលគ្មានការអត់ធ្មត់ក្នុងចិត្ត ។

**៥៩:១២** *អំពើរំលង . . . អំពើបាប . . . អំពើទុច្ចរិត* ក្នុងព្រះគម្ពីរភាសាហេព្រើរដែលមានក្នុងគម្ពីរបស់ញ្ញាចាស់ ពាក្យទាំង៣នេះ គឺជាទង្វើរបស់ការអាក្រក់ និងទង្វើពីវិញ្ញាណអារក្ស ។ (សូមមើល ទដ ៣២:៥ និងការពន្យល់) ។ *អំពើរំលងរបស់យើងខ្ញុំ បានចំរើនជាច្រើនឡើង* សូមមើល ៥៨:១ ។ *យើងខ្ញុំក៏ស្គាល់ទាំងអស់ហើយ* ដូចជាក្នុងគម្ពីរអែសរ៉ា (៩:៦–៧) គឺនាងអែសរ៉ាក៏បាន លន់តួអំពើបាបជំនួសប្រជារាស្ត្រទាំងអស់ ។

**៥៩:១៣** *ការប៉ះបោរព្រមទាំងគិតបង្កើត* សូមមើល ៤៦:៨ ៤៨:៨ និងការពន្យល់ ។ *ក៏បែរចេញ* សូមមើល ១:៤ ។ *ការសង្កិតសង្កិន* សូមមើល ៣០:១២ ។ ពាក្យថា *ពាក្យភូតភរ* សូមមើល ខ.៣–៤ ។

**៥៩:១៤** *សេចក្តីយុត្តិធម៌ . . . សេចក្តីពិត* ប្រៀបធៀបចំពោះលក្ខណៈសម្បត្តិនៃប្រាជ្ញាក្នុង សភ ៨:១–៩:១២ (សូមមើលការពន្យល់ ៨:១–៣៦) ។ *សេចក្តីសុចរិត ក៏ឈរនៅទីឆ្ងាយ* សូមប្រៀបធៀប ខ.៩ ខុសនឹង ៤៦:១៣ (សូមមើលការពន្យល់នៅទីនោះ) ។

**៥៩:១៥** *សេក្តីពិត* គឺជាការចាប់ផ្តើមឱ្យមានក្រុងយេរូសាឡិមថ្មីឡើងវិញ ដែលគេហៅថាទីក្រុងនៃសេចក្តីពិត ។ មើល សក ៨:៣ (មើល ១:២១,២៦ និងការពន្យល់) ។ ពាក្យថា *ធ្វើជារំពាដល់គេហើយ* សូមមើល ៣២:៧ ។

១៦ ទ្រង់ឃើញថា ឥតមានអ្នកណាមួយឡើយ[ឆ] ហើយក៏នឹក
បែថកពីការដែលឥតមានអ្នកណា សំរាប់ជួយអង្វរជំនួស
គេ[ជ] ដូច្នេះព្រះពាហុរបស់ទ្រង់បាននាំយកសេចក្ដីសង្គ្រោះ[ឈ]
មកឯទ្រង់ ហើយសេចក្ដីសុចរិត[ញ]របស់ទ្រង់ក៏ទប់ទល់ទ្រង់
១៧ ទ្រង់បានប្រដាប់អង្គដោយសេចក្ដីសុចរិត ទុកជាអាវ
ក្រោះ[ដ] ហើយសេចក្ដីសង្គ្រោះនៅលើព្រះសិរទុកជាមួក
ស្លឹក[ឋ] ក៏ទ្រង់ព្រះពស្ត្រ[ឌ]ដោយសេចក្ដីសងសឹក[ឍ] និងសេចក្ដីខ្មី
ឃ្មាត[ណ] ទុកជាព្រះភូសាគ្រលុំអង្គ ១៨ ទ្រង់នឹងសងដល់គេ
តាមអំពើដែលគេបានប្រព្រឹត្ត[ត] គឺជាសេចក្ដីក្រោធដល់ពួក
ទាស់ទទឹងនឹងទ្រង់ ហើយជាសំណង តបដល់ពួកខ្មាំងសត្រូវ
ទ្រង់នឹងសងដល់អស់ទាំងស្រុក[ថ] ក្បែរសមុទ្រយ៉ាងនោះដែរ
១៩ យ៉ាងនោះគេនឹងកោតខ្លាច ដល់ព្រះនាមនៃព្រះយេហូវ៉ា
ចាប់តាំងពីទិសខាងលិច[ទ] ហើយដល់សិរីល្អនៃទ្រង់[ធ] ចាប់
តាំងពីទិសខាងថ្ងៃរះ[ន] កាលណាខ្មាំងនឹងចូលមក ដូចជាទឹក
ជន់ នោះព្រះវិញ្ញាណ[ប]នៃព្រះយេហូវ៉ា និងលើកទង់ជ័យ
ឡើងទាស់នឹងវា ២០ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា និងមាន

**៥៩:១៦** ឆ អស ៤១:២៨ ជ អស ៥៣:១២ ឈ អស ៥១:៥ ញ អស ៤៥:៨,១៣ ៤៦:១៣ **៥៩:១៧** ដ អភ ៦:១៤ ១ថន ៥:៨ ឋ អភ ៦:១៧ ១ថន ៥:៨ ឌ យប ២៧:៦ អស ៦៣:៣ ឍ អស ១:២៤ ណ អស ៩:៧ អគ ៥:១៣ **៥៩:១៨** ត លវ ២៦:២៨ ជន ១០:៣៥ អស ៣៤:៨ មថ ១៦:២៧ ថ អស ១១:១១ ៤១:៥ **៥៩:១៩** ទ អស ៤៨:១២ ថម ៨:១១

អ្នកដ៏ជួយប្រោសលោះ[ផ]មកឯក្រុងស៊ីយ៉ូន[ព] ហើយដល់ពួក
អ្នកក្នុងពូជពង្សយ៉ាកុប ដែលលះលែងពីអំពើរំលង[ភ] ២១ ព្រះ
យេហូវ៉ា ទ្រង់មានបន្ទូលថា ឯអញ នេះឯងជាសេចក្ដី
សញ្ញា[ម]ដែលអញបានតាំងនឹងគេ គឺថាវិញ្ញាណរបស់អញ[យ]
ដែលសណ្ឋិតនៅលើឯង ហើយពាក្យអញដែលអញបាន
ដាក់នៅក្នុងមាត់[រ]ឯង នោះនឹងមិនដែលឃ្លាតចេញពីមាត់
ឯង[ល] ឬពីមាត់នៃពូជពង្សឯង ឬពីមាត់នៃកូនចៅគេចាប់
តាំងពីឥឡូវ នេះដរាបដល់អស់កល្បរៀងទៅ នេះហើយជា
ព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## សិរីល្អនៃក្រុងស៊ីយ៉ូន

**៦០** ១ ចូរក្រោកឡើង[ក] ហើយភ្លឺមកចុះ ដ្បិតពន្លឺ[ខ]របស់ឯង

ធ ទដ ៩៧:៦ អស ២៤:១៥ ៣៥:២ ៤០:៥ ៥២:១០ ៦៦:១៨ ន ទដ ១១៣:៣ ប អស ១១:៤ **៥៩:២០** ផ យប ១៩:២៥ អស ៦០:១៦ ៦៣:១៦ ព អស ៥២:៨ យអ ៣:២១ ភ យប ២២:២៣ អស ១:២៧ យរ ៣៥:១៥ កច ២:៣៨–៣៩ រម ១១:២៦–២៧ **៥៩:២១** ម លប ៩:១៦ ចទ ២៩:១៤ អស ៤២:៦ យ អស ១១:២ ៤៤:៣ រ នក ៤:១៥ ល យស ១:៨ **៦០:១** ក អស ៥២:២ ខ ទដ ៣៦:៩ ១១៨:២៧ អស ៩:២ យហ ៨:១២ អភ ៥:១៤

**៥៩:១៦** *ឥតមានអ្នកណាមួយឡើយ* គឺចងនិយាយពីការដែលគ្មានជំនួយជួយដល់ពួកគេ (សូមមើល ៦៣:៥ គឺជាអត្ថបទដែលមានលក្ខណៈស្រដៀងគ្នាក្នុងខទាំងមូល) ។ សូមប្រៀបធៀប ២២:៣០ និងការពន្យល់ ។ *នឹកប្លែក* ប្រៀបធៀបពីប្រតិកម្មចំពោះអ្នកបម្រើក្នុង ៥២:១៤ ។ *ជួយអង្វរជំនួស* សូមប្រៀបធៀបពីការទូលអង្វររបស់ពួកអ្នកបម្រើក្នុងគម្ពីរ ៥៣:១២ (សូមមើលការពន្យល់ទីនោះ) ។ *ព្រះពាហុរបស់ទ្រង់បាននាំយកសេចក្ដីសង្គ្រោះមកឯទ្រង់* សូមមើល ៥១:៩ ៥២:១០ ។ ចំពោះអត្ថន័យនៃពាក្យសង្គ្រោះ មើល ៤៣:៣ ៤៩:៨ ៥២:៧ និងការពន្យល់ ។ *សេចក្ដីសុចរិត* គឺសម្រាប់ជាការទំនាក់ទំនងរវាងសេចក្ដីសុចរិត និងសេចក្ដីសង្គ្រោះ សូមមើល ៤៥:៨ ៤៦:១៣ និងការពន្យល់ ។

**៥៩:១៧** *ទ្រង់បានប្រដាប់អង្គដោយសេចក្ដីសុចរិត* សូមមើល ទដ ១០៩:២៩ *សេចក្ដីសុចរិតទុកជាអាវក្រោះ* គឺអាវក្រោះ ឬអាវុធរបស់ព្រះយេហូវ៉ាដែលបានប្រៀបធៀប ចំពោះអាវុធរបស់អ្នកជំនឿក្នុងសង្គ្រាមប្រឆាំងនិងអារក្សសាតាំងក្នុង អភ ៦:១៤ (មើលការពន្យល់ ៦:១៤) ។ *ក៏ទ្រង់ព្រះពស្ត្រដោយសេចក្ដីសងសឹក* សូមប្រៀបធៀបនិង ៦៣:១–៣ ។ ការសងសឹករបស់ព្រះក៏មានបង្ហាញក្នុង ៣៤:៨ ផងដែរ (ក៏សូមមើលការពន្យល់ ៦៣:៤ វាក៏ជាផ្នែកមួយនៃថ្ងៃរបស់ព្រះយេហូវ៉ា (មើល ៣៤:២ និងការពន្យល់) ។ *សេចក្ដីខ្មីឃ្មាត* គឺជាសេចក្ដីស្រឡាញ់ដែលមានការប្រច័ណ្ឌរបស់ព្រះអម្ចាស់ដូចជាមានក្នុង ៩:៧ និងការពន្យល់ ៣៧:៣២ ៤២:១៣ ។

**៥៩:១៨** *ពួកខ្មាំងសត្រូវ . . .* ព្រះអម្ចាស់និងជំនុំជម្រះដល់ជាតិសាសន៍មួយចំនួន តែទ្រង់ក៏ត្រូវជំនុំជម្រះដល់ការអាក្រក់របស់សាសន៍ (សូមមើល ៦៥:៦–៧ ៦៦:៦ យរ ២៥:២៩) ។ គឺមានតែពួកសំណល់ប៉ុណ្ណោះដែលត្រូវទទួលពរ (សូមមើល ខ.២០ មើល ១:៩ និងការពន្យល់) ។ *ស្រុកក្បែរសមុទ្រ* សូមមើលការពន្យល់ ១១:១១ ។

**៥៩:១៩** *ចាប់តាំងពីទិសខាងលិច . . . ចាប់តាំងពីទិសខាងថ្ងៃរះ* គឺជាព្រះរាជកិច្ចដែលគ្រប់ជាតិសាសន៍និងបានសង្គ្រោះពីព្រះដោយសារគេទាំងអស់នោះជារាស្ត្ររបស់ផងទ្រង់ (សូមមើល ៤០:៥ ៤៥:៦ ៥២:១០ និងការពន្យល់) ។ ព្រះនាម សូមមើល ៣០:២៧ និងការពន្យល់ ។ *មកដូចជាទឹកជន់* ក៏មានការយាងមកនៃព្រះយេហូវ៉ាដែលពុំអាចទប់ គឺមានលក្ខណៈដូចជា "ការ ជុះកកិតយ៉ាងខ្លាំង" (៣០:២៨) ទៅលើមាសត្រូវ ។

**៥៩:២០** *អ្នកដ៏ជួយប្រោសលោះ* មើល ៤១:១៤ និងការពន្យល់ ។ *មកឯក្រុងស៊ីយ៉ូន* គឺជាការវិលត្រឡប់ពីការបំបោះបង់ ហើយមកក្នុងវត្តមាននៃព្រះ (សូមមើល រម ១១:២៦–២៧ និងការពន្យល់) ។ សូមមើល ៣៥:៤ ៤០:៩ ៥២:៧ និងការពន្យល់ប្រៀបធៀប សក ៨:៣ ។ *អ្នកដែលក្នុងពូជ . . . ដែលលះលែងពីអំពើរំលង* សូមមើល ១:២៧–២៨ និងការពន្យល់ ៣០:១៥ ៣១:៦ ក៏សូមមើល អគ ១៨:៣០–៣២ និងការពន្យល់ ។

**៥៩:២១** *សេចក្ដីសញ្ញា* គឺជាការពណ៌នាដែលរបស់សេចក្ដីសញ្ញាថ្មីដ៏សំខាន់ (សូមមើល ៤២:៦ យរ ៣១:៣១–៣៤ និងការពន្យល់) ។ *វិញ្ញាណរបស់អញ* មើល ១១:២ ៣២:១៥ អគ ៣៦:២៧ យហ ១៦:១៣ និងការពន្យល់ ។ ពាក្យថា *លើឯង...មាត់ឯង... មាត់ឯង... ពង្សឯង* ក្នុងភាសាហេព្រើរសព្វនាម គឺជាឯកវចនៈ គឺគិតជាចំនួនតែមួយ ប៉ុន្តែអាចមានលក្ខណៈជាសមូហនាម ដូចជាប្រជារាស្ត្រនៅក្នុងក្រុងស៊ីយ៉ូន ។ *ពាក្យអញ . . . នៅក្នុងមាត់ឯង* នោះហើយដែលជារាស្ត្រអ៊ីស្រាអែល គឺជារាស្ត្ររបស់ផងព្រះយ៉ាងពិតប្រាកដ (សូមមើល ៥១:១៦ យរ ៣១:៣៣ និងការពន្យល់ ។ *នោះមិនឱ្យឃ្លាតឆ្ងាយចេញពីមាត់ឯង* សូមមើល យស ១:៨ ។

**៦០:១–២** *សិរីល្អ* គឺជាការនិយាយប្រៀបធៀបទៅជើងសរសនៃបង្គោលពពក ប៉ុន្តែក៏ជាការប្រកាស គឺជាការបើកសំដែងថ្មីមួយ ពីសិរីល្អនៃការប្រោសលោះរបស់ព្រះអម្ចាស់ (សូមមើល ៥៨:៨ និងការពន្យល់) សូមមើល ៣៥:២ និងការពន្យល់ផងដែរ ។

**៦០:១** *ពន្លឺ* សូមមើល ៥៨:៨ និងការពន្យល់ក្នុងន័យនេះ ពាក្យថាពន្លឺ គឺសំដៅ

បានមកដល់ហើយ សិរីល្អ[គ]នៃព្រះយេហូវ៉ាក៏បានរះឡើង
ដល់ឯងដែរ ២ដ្បិតមើល សេចក្ដីងងឹត[ឃ]នឹងគ្របលើផែនដី
ហើយសេចក្ដីសូន្យសុង[ង]នឹងគ្របលើអស់ទាំងជនជាតិ តែ
ព្រះយេហូវ៉ាទ្រង់នឹងរះឡើងភ្លឺដល់ឯង ហើយគេនឹងឃើញ
សិរីល្អនៃទ្រង់ស្ថិតលើឯង ៣អស់ទាំងសាសន៍[ច]នឹងមូលគ្នា
មកឯពន្លឺរបស់ឯង[ឆ] ហើយស្ដេច[ជ]ទាំងប៉ុន្មាននឹងមកឯរស្មី
ដែលភ្លឺចេញពីឯង ក្នុងកាលដែលឯងរះឡើង ៤ចូរងើប
ភ្នែកឯងមើលជុំវិញ គេមូល[ឈ]គ្នាមកឯឯងទាំងអស់ ហើយ
ពួកកូនប្រុសៗរបស់ឯងនឹងមកពីឆ្ងាយ[ញ] ហើយនិងមានគេ
បីពួកកូនស្រីៗ[ដ]នៃឯងមកដែរ[ឋ] ៥នោះឯងនឹងឃើញ ហើយ
និងមានសេចក្ដីរីករាយ[ឌ] ចិត្តឯងនឹងខ្លាចហើយរីកធំឡើង[ឍ]
ពីព្រោះសេចក្ដីបរិបូរ[ណ]នៃសមុទ្រ និងត្រូវបង្វែរមកឯង
វិញ ហើយអស់ទាំងរបស់ទ្រព្យនៃសាសន៍ផ្សេងៗ និងមក
ឯឯង ៦ឯងនឹងមានពេញដោយសត្វអូដ្ឋ[ត]យ៉ាងសន្ធឹក គឺជាអូដ្ឋ
ស្ទាវរបស់ពួកម៉ាឌាន[ថ] និងពួកអេផា[ទ] ហើយទាំងអស់ដែល
នៅស្រុកសេបា[ធ]នឹងមកដែរ ព្រមទាំងដឹកយកមាស និង
កំញាន[ន]មក ហើយនិងប្រកាសប្រាប់ពីសេចក្ដីសរសើរ[ប]
របស់ព្រះយេហូវ៉ា ៧អស់ទាំងហ្វូងចៀមរបស់ស្រុកកេដារ[ផ]
នឹងមូលគ្នាមកឯឯង ពួកចៀមឈ្មោលរបស់ ស្រុកនេបាយ៉ូត
នឹងគោរពដល់ឯង វាទាំងឡាយនឹងឡើង[ព] មកលើអាសនា
អញ[ភ] ដោយស្ម័គ្រពីចិត្ត ហើយអញនឹងលើកដំកើងវិហារ
នៃសិរីល្អរបស់អញ[ម] ៨តើពួកណាហ្ន៎[យ] ដែលរសាត់មកដូច
ជាពពក[រ] ហើយហើរមកឯបង្អួចរបស់ខ្លួន គ្រប់គ្នាដូចជា
ព្រាបនោះ ៩ពិតប្រាកដជាអស់ទាំងកោះ[ល]នឹងរង់ចាំអញ
ហើយនាវាពីស្រុកតើស៊ីសនឹងមកមុនគេ[វ] ដើម្បីនឹងនាំ[ស]ពួក
កូនប្រុសៗរបស់ឯងមកពីស្រុកឆ្ងាយ មានទាំងមាសប្រាក់
របស់គេមកជាមួយផង[ហ] ដោយព្រោះ[ឡ]ព្រះនាមព្រះយេហូវ៉ា
ជាព្រះនៃឯង ជាព្រះដ៏បរិសុទ្ធ[អ]នៃសាសន៍អ៊ីស្រាអែល ដ្បិត
ទ្រង់បានលើកដំកើងឯងឡើង[ក]។
១០ពួកសាសន៍ដទៃ[ខ]នឹងសង់កំផែងឯងឡើង ហើយ
ស្ដេចទាំងប៉ុន្មាន[គ]នឹងគោរពដល់ឯង ដ្បិតទោះបើអញបាន
វាយឯងក្នុងពេលដែលមានសេចក្ដីក្រោធក៏ដោយ គង់តែ

**៦០:១** គ នក ១៦:៧ អស ៤:៥ វវ ២១:១១ **៦០:២** ឃ ១សយ ២:៩ ទដ ៨២:៥ ១០៧:១៤ អស ៨:២០ ង យរ ១៣:១៦ កល ១:១៣ **៦០:៣** ច អស ៤៤:៥ ៤៥:១៤ មថ ២:១–១១ វវ ២១:២៤ ឆ អស ៩:២ ៤២:៦ ជ អស ៤៩:២៣ **៦០:៤** ឈ អស ១១:១២ ញ អស ២:៣ យរ ២:៣ យរ ៣០:១០ ដ អស ៤៣:៦ ឋ អស ៤៩:២០–២២ **៦០:៥** ឌ នក ៣៤:២៩ ឍ អស ៣៥:២ ៦៥:១៣ ៦៦:១៤ សក ១០:៧ ណ ចទ ៣៣:១៩ ពច ៣:១៥
វវ ២១:២៦ **៦០:៦** ត ពច ៦:៥ ថ លប ២៥:២ ទ លប ២៥:៤ ធ លប ១០:៧,២៨ ន អស ៤៣:២៣ យរ ៦:២០ មថ ២:១១ ប ១ពវ ៥:៧ អស ៤២:១០ **៦០:៧** ផ លប ២៥:១៣ ព អស ១៨:៧ អគ ២០:៤០ ៤៣:២៧ សផ ៣:១០ ភ អស ១៩:២១ ម ខ.១៣ ហក ២:៣,៧,៩ **៦០:៨** យ អស ៤៩:២១ រ អស ១៩:១ **៦០:៩** ល អស ១១:១១ វ លប ១០:៤ អស ២:១៦ ស អស ១៤:២ ៤៣:៦ ហ ១ពវ ១០:២២ ឡ ទដ ២២:២៣ អ ខ.១៤ អស ១:៤ ៥៤:៥ ក អស ៤៤:២៣ ៥៥:៥ យរ ៣០:១៩ **៦០:១០** ខ នក ១:១១ អស ១៤:១–២ ៦៥:៦ គ អរ ១:២ វវ ២១:២៤

លើព្រះយេហូវ៉ា គឺអង្គផ្ទាល់ដែលបានសំដែងឱ្យឃើញជាពន្លឺ (សូមមើល ខ.១៩–២០) ។

**៦០:២** *សេចក្ដីងងឹត* គឺជានិមិត្តសញ្ញាដែលជាភាពស្រងេះស្រងោច និងងងឹត ឬការសង្កត់សង្កិន និងអំពើបាប (សូមមើល ៨:២២ ៩:២ ៥៩:៩) ។

**៦០:៣** *អស់ទាំងសាសន៍មូលគ្នាមកឯ* សូមមើល ខ.៥,១០–១២ និងការពន្យល់ ផ្ទៃរឿងទាំងនេះ ក៏បានបង្ហាញមុនគេបង្អស់នៅក្នុង ២:២–៤ (សូមមើលការពន្យល់ ២:២–៤) ។ *ពន្លឺ* សូមមើល ៤២:៦ ៤៩:៦ និងការពន្យល់ ។

**៦០:៤** ខនេះក៏មានការបង្ហាញពីសេចក្ដីផ្ដើមក្នុង ៤៩:១៨ ។ ក៏បង្ហាញពីការវិលត្រឡប់មកពីការបំបោះបង់ ។ ពាក្យថា *ពីឆ្ងាយ* សូមមើល ខ.៩ ៤៩:១២ និងការពន្យល់ ។

**៦០:៥** *សេចក្ដីបរិបូរនៃសមុទ្រ* ក៏មានទីក្រុងយេរូសាឡិមដោយបានកើតផលសំបូរដោយជាតិសាសន៍មួយចំនួន ។ (សូមមើល ខ.១១ ៦១:៦ ៦៦:១២ សូមមើល ១៨:៧ ២៣:១៨ ៤៥:១៤ និងការពន្យល់ផងដែរ) ។ ក៏មានវិភាគទានរបស់ស្ដេចដារីយុសចំពោះព្រះវិហារស្ងួរ៉ូបាបិល គឺជាសេចក្ដីសម្រេចមួយផ្នែក(សូមមើល អគ ៦:៨–៩ និងការពន្យល់) ។ តាមរយៈការបកស្រាយខ្លះបង្ហាញថា ការនេះក៏មានពួកសាសន៍ដទៃយកមកអនុវត្តិនៅក្នុងព្រះវិហារ គឺជាសកម្មភាពផ្ដល់ជាវិភាគទានផ្សេងៗ(សូមមើលការពន្យល់ ២:២–៤) ។ មើល វវ ២១:២៦ ក្រុងយេរូសាឡិមថ្មី សូមមើល ហក ២:៧ សក ១៤:១៤ និងការពន្យល់ ។

**៦០:៦** *មានពេញដោយសត្វអូដ្ឋយ៉ាងសន្ធឹក* ដូចជាពួកឬក្រុមអ្នកដំណើរដោយរទេះដែលនាំទំនិញនិងរបស់សំខាន់ៗមកជាមួយ (មើល ៩:៤ ពច ៦:១–៦ និងការពន្យល់) ។ *ពួកម៉ាឌាន* ពួកកូនប្រុសរបស់អ័ប្រាហាំតាមរយៈសាសន៍កិទូរ៉ា (លប ២៥:២) ។ មានពួកម៉ាឌានបានដើរត្រាច់ចរនៅឯវាលរហោស្ថានតាមដងទន្លេយ័រដាន់ ។ *ពួកអេផា* គឺពួកកូនប្រុសរបស់ម៉ាឌាន (លប ២៥:៤) ។ *ស្រុកសេបា* គឺជាស្រុកដែលមានភោគផលល្អ នៅក្នុងស្រុកអារ៉ាប (សូមមើល ២៥:៣ ១ពវ ១០:១ និងការពន្យល់) ។ *មាសនឹងកំញាន* គឺមានម្ចាស់ស្ត្រីសេបាបាននាំមាស និងគ្រឿងទេសទៅថ្វាយស្ដេចសាឡូម៉ូន (១ពវ ១០:២) យរ ៦:២០ ក៏បង្ហាញប្រាប់ពីកំញានរបស់នាងសេបាដែរ សូមប្រៀបធៀប ទដ ៧២:១០ មថ ២:១១ ។ *ប្រកាសប្រាប់ពីសេចក្ដីសរសើរ* សូមប្រៀបធៀបពីពាក្យរបស់ម្ចាស់ស្ត្រីក្នុង ១ពវ ១០:៩ (ប៉ុន្តែសូមមើលការពន្យល់ផងដែរ) ។

**៦០:៧** *អស់ទាំងហ្វូងចៀមរបស់ស្រុកកេដារ* សូមមើលការពន្យល់ ២១:១៦ *ស្រុកនេបាយ៉ូត* ក៏ជាឈ្មោះកូនច្បងរបស់លោកអ៊ីសម៉ាអែល (លប ២៥:១៣) តែក្រោយមកមានឈ្មោះថា នគរ ឬអាណាចក្រ ណាបាធៀន ។ ពាក្យថា *គោរព* សូមមើល ខ.១០ ៥៦:៦ ។

**៦០:៩** *អស់ទាំងកោះនឹងរង់ចាំអញ* សូមមើល ១១:១១ និងការពន្យល់ ។ នាវាពីស្រុកតើស៊ីស សូមមើលការពន្យល់ ២:១៦ នាំពួកកូនប្រុសៗ សូមមើល ៤០:២២ និងការពន្យល់មាសប្រាក់ គឺដូចជានាវាស្រុកតើស៊ីសបាននាំមាសប្រាក់ទាំងនោះទៅឱ្យស្ដេចសាឡូម៉ូន គឺរៀងរាល់បីឆ្នាំម្ដង (១ពវ ១០:២២) ។ ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល មើល ខ.១៤ ១:៤ និងការពន្យល់ ដ្បិតទ្រង់បានលើកដំកើងឯងឡើង មើល ៥៥:៥ និងការពន្យល់ ។

**៦០:១០** *ពួកសាសន៍ដទៃ . . . ស្ដេចទាំងប៉ុន្មាន* សូមមើល ខ.១២ ១៤ ៤៩:៧, ២៣ ៦១:៥ ។ ពាក្យថា *និងសង់កំផែងឯងឡើង* គឺតាំងពីឆ្នាំ ៤៤៤ មុន គ.ស ដែលមានស្ដេច អើថាស៊ើរបានប្រកាសព្រះរាជក្រឹត្យអនុញ្ញាតឱ្យលោក

អញបានអាណិតដល់ឯង[ឃ] ក្នុងគ្រាដែលផ្តល់ព្រះគុណ[ង]វិញ
១១ទ្វារ[ច]កំផែងរបស់ឯងនឹងនៅចំហជានិច្ច ឥតដែលបិទ
ទាំងយប់ទាំងថ្ងៃឡើយ ដើម្បីឱ្យមនុស្សបាននាំយកទ្រព្យ
សម្បត្តិរបស់សាសន៍[ឆ]ទាំងប៉ុន្មានមកឯឯង ព្រមទាំងដឹកនាំ
ស្តេច[ជ]របស់គេមកជាឈ្លើយផង ១២ដ្បិតសាសន៍ណានឹង
នគរណាដែលមិនព្រមគោរព[ឈ]ដល់ឯង នោះនឹងត្រូវ
វិនាស អើ សាសន៍ទាំងនោះនឹងត្រូវសាបសូន្យបាត់ទៅអស់
រលីង[ញ] ១៣សេចក្តីលំអនៃព្រៃល្បាណូន[ដ]នឹងមកឯឯង គឺជា
ឈើកកោះ ឈើស្រល់ និងឈើស្រឡៅផង[ឋ] ដើម្បីនឹងតុប
តែងកន្លែងនៃទីបរិសុទ្ធរបស់អញ[ឌ] ហើយអញនឹងធ្វើឱ្យទី
នៃជើងអញបានរុងរឿងឧត្តម[ឍ] ១៤ពួកកូនចៅរបស់អ្នក
ដែលបានសង្កត់សង្កិនឯង[ណ] គេនឹងមកទាំងឱនក្រាប[ត]នៅ
ចំពោះឯង ហើយអស់អ្នកណាដែលធ្លាប់មើលងាយឯង គេ
នឹងក្រាបចុះនៅទៀបបាតជើងឯង គេនឹងហៅឯងថាជា
ទីក្រុង[ថ]របស់ព្រះយេហូវ៉ា គឺជាក្រុងស៊ីយ៉ូន[ទ]របស់ព្រះដ៏
បរិសុទ្ធ[ធ]នៃសាសន៍អ៊ីស្រាអែល ។
១៥ទោះបើឯង បានត្រូវចោលស្ងាត់[ន] ហើយត្រូវគេ
ស្អប់ ដល់ម្ល៉េះបានជាគ្មានមនុស្សណាដើរកាត់[ប]ឯងឡើយ
គង់តែអញនឹងធ្វើឱ្យឯងបានជាទីប្រសើរ[ផ] នៅអស់កល្បជា
និច្ចវិញ ជាទីអំណរ[ព]ដល់ច្រើនដំណតទៅ ១៦ឯងនឹងបាន
បឺតជញ្ជក់ទឹកដោះ[ភ]នៃអស់ទាំងសាសន៍ ហើយនិងបឺតដោះ
នៃពួកស្តេចដែរ នោះឯងនឹងដឹង[ម]ថា អញនេះគឺយេហូវ៉ា
ជាព្រះដ៏ជួយសង្គ្រោះឯង[យ] ហើយជាព្រះដ៏ប្រោសលោះ
ឯង[រ] គឺជាព្រះដ៏មានចេស្តានៃយ៉ាកុប[ល] ១៧អញនឹងនាំមាស[វ]
មកឱ្យជំនួសលង្ហិន ប្រាក់ឱ្យជំនួសដែក លង្ហិនឱ្យជំនួស
ឈើ ហើយដែកឱ្យជំនួសថ្មផង អញនឹងយកសេចក្តីសុខ[ស]
ធ្វើជារដ្ឋបាលឯង ហើយឱ្យសេចក្តីសុចរិតជាអ្នកគ្រប់គ្រង
លើឯងផង[ហ] ១៨នៅក្នុងស្រុកឯងនឹងមិនដែលឮនិយាយពី
សេចក្តីច្រឡោត[ឡ]ទៀត ឬពីការរឹបជាន់ ឬពីការបំផ្លាញ[អ]
នៅក្នុងព្រំដែនឯងឡើយ គឺឯងនឹងហៅកំផែងឯងថា
"សេចក្តីសង្គ្រោះ"[ក] ហើយទ្វារឯងថា "សេចក្តីសរសើរ"[ខ]
១៩គ្រានោះព្រះអាទិត្យនឹងលែងធ្វើជាពន្លឺដល់ឯង នៅ
ពេលថ្ងៃ ឯព្រះចន្ទក៏នឹងលែងបានសំរាប់ជាពន្លឺដល់ឯង

**៦០:១០** ឃ ទដ ១០២:១៣ ង អស ៥៩:៨ **៦០:១១** ច ខ.១៨ ទដ ២៤:៧ អស ៦២:១០ មីក ២:១៣ វវ ២១:២៥ ឆ ខ.៥ អស ៦១:៦ វវ ២១:២៦ ជ ទដ ១៤៩:៨ អស ២:១២ **៦០:១២** ឈ អស ១១:១៤ ១៤:២ ញ លប ២៧:២៩ ទដ ១១០:៥ ដយ ២:៣៤ **៦០:១៣** ដ អរ ៣:៧ ឋ អស ៤១:១៩ ឌ ខ.៧ ឍ ១រប ២៨:២ **៦០:១៤** ណ អស ១៤:២ ត លប ២៧:២៩ អស ២:៣ វវ ៣:៩ ថ លប ៣២:២៨ អស ១:២៦ ទ ហព ១២:២២

ធ ខ.៩ **៦០:១៥** ន អស ១:៧–៩ ៦:១២ ៥៤:៦ ប អស ៣៣:៨ ផ អស ៤:២ ព ទដ ១២៦:៥ អស ៦៥:១៨ **៦០:១៦** ភ នក ៦:២ អស ៤៩:២៣ ៦៦:១១, ១២ ម នក ៦:៧ យ នក ១៤:៣០ អស ២៥:៩ រ យប ១៩:២៥ អស ៥៩:២០ ល លប ៤៩:២៤ ទដ ១៣២:២ **៦០:១៧** វ ១ពវ ១០:២១ ស ទដ ៨៥:៨ អស ៦៦:១២ ហក ២:៩ ហ អស ៩:៧ **៦០:១៨** ឡ លវ ២៦:៦ ២សយ ៧:១០ អស ៩:៤ អ អស ៤៩:១៩ ៥១:១៩ ក អស ៣៣:៦ ខ អស ៣៣:៩ សផ ៣:២០

យេរេមាសាងសង់កំផែងទីក្រុងយេរូសាឡិមឡើងវិញ (នហ ២:៨) ។ ក៏មានការសាងសង់ព្រះវិហារដោយពួកអ្នកដើរតាមសាសនាដទៃ (កច ១៥:១៤–១៦) ។ *ទោះបើអញ . . . វាយឯង . . . មានសេចក្តីក្រោធក៏ដោយ គង់តែអញបានអាណិតដល់ឯង* សូមមើល ៥៤:៧–៨ និងការពន្យល់ ។

**៦០:១១** *ទ្វារកំផែង . . . នៅចំហរជានិច្ច* គឺមានលក្ខណៈដូចជាទ្វារកំផែងរបស់ក្រុងយេរូសាឡិមថ្មី (វវ ២១:២៥) ។ *ទ្រព្យសម្បត្តិ* សូមមើល ខ.៥ ។

**៦០:១២** *ដ្បិតសាសន៍ . . . នឹងត្រូវវិនាស* គឺជាការជិះជាន់ខាងផ្នែកនយោបាយដល់រាស្ត្រអ៊ីស្រាអែលក៏មានឃើញបង្ហាញក្នុង ១១: ១៤ ១៤:២ ៤៩:២៣ (ប្រៀបធៀប ខ.១០,១៤) ។

**៦០:១៣** *សេចក្តីលំអនៃព្រៃល្បាណូន* គឺជាប្រភេទដើមឈើតាត្រៅបានបង្ហាញភាពឆើតឆាយរុងរឿងនៅតំបន់ព្រៃល្បាណូន ហើយក៏ជាឈើដែលប្រើក្នុងការសាងសង់ព្រះវិហាររបស់ស្តេចសាឡូម៉ូន ក៏ប្រើជាមួយឈើកកោះ (សូមមើល ១ពវ ៥:១០,១៨ ៣៥:២) ។ ក៏មានសិរីល្អនៃយុគសម័យស្តេចសាឡូម៉ូនបានមកដល់ ។ *ឈើស្រល់នឹងឈើស្រឡៅផង* សូមមើល ១៤:១៩ និងការពន្យល់ ។ គឺដើមឈើនោះមិនសម្រាប់ប្រើដើម្បីសាងសង់ប៉ុណ្ណោះទេ ក៏ប្រើសម្រាប់តុបតែងលំអផងដែរ ។ ដើម្បីតុបតែងកន្លែងបរិសុទ្ធរបស់អញ សូមមើល ខ.៧ និងធ្វើជាទីនៃជើងអញ ដូចជាទីក្នុងព្រះវិហារនិង ហឹបនៃសេចក្តីសញ្ញា គឺជាជើងទម្រព្រះបាទទ្រង់ (ជើងទ្រង់) ។

**៦០:១៤** *អ្នកដែលបានសង្កត់សង្កិនឯង គេនឹងមកទាំងឱនក្រាបនៅចំពោះឯង* សូមមើល ៤៩:៧,២៣ និងការពន្យល់ប្រៀបធៀប ខ.១០,១២ ។ *ជាទីក្រុងរបស់ព្រះយេហូវ៉ា* គឺប្រៀបដូចជាឈ្មោះថ្មីរបស់ក្រុងយេរូសាឡិមនាថ្ងៃអនាគត មើលក្នុង ១:២៦ ៦២:៤ អគ ៤៨:៣៥ សគ ៨:៣ ហព ១២:២២ ។

**៦០:១៥** *ត្រូវចោលស្ងាត់ . . . ហើយត្រូវគេស្អប់* សូមមើល ៦:១១–១២ ៦២:៤ យរ ៣០:១៧ ។ *ជាទីប្រសើរនៅអស់កល្បជានិច្ច . . . ជាទីអំណរ* សូមមើល ៤:២ និងការពន្យល់ ។

**៦០:១៦** *បឺតដោះនៃពួកស្តេច* គឺក្រុងយេរូសាឡិមនឹងទទួលបាននូវគ្រឿងបំប៉ន ដ៏ពិសេស "ជាភាពសំបូររុងរឿងរបស់ជាតិសាសន៍ទាំងអស់" (ខ.៥) *អញនេះ . . . នៃយ៉ាកុប* ចំពោះប្រយោគនេះសូមមើល ៤៩:២៦ និងការពន្យល់ ។

**៦០:១៧** *មាស . . . លង្ហិន* ក៏ដូចជានៅក្នុងជំនាន់ស្តេចសាឡូម៉ូន មាសនិងលង្ហិន គឺមានច្រើនសន្ធឹក (សូមមើល ១ពវ ១០:២១,២៧) ក៏ដូចជាទីក្រុងយេរូសាឡិម នាពេលក្រោយមកទៀត និងបំពាក់ដោយលោហៈមានតម្លៃបំផុត និងបំពាក់ដោយដែកដែលរឹងមាំបំផុត សូមប្រៀបធៀប ៩:១០ ។ *សេចក្តីសុខ . . . សេចក្តីសុចរិត* គឺកិច្ចការទាំងពីរនេះមាននៅក្នុងច្បាប់របស់ព្រះមែស៊ីជាព្រះមហាក្សត្រ មើលក្នុង ៩:៧ សូមមើលការពន្យល់ ៤៨:១៨ ។

**៦០:១៨** *មិនដែលឮនិយាយពីសេចក្តីច្រឡោតទៀត* ប្រៀបធៀប ៥៤:១៤ ពីការរឹបជាន់ ឬពីការបំផ្លាញ ។ សូមមើល ៥១:១៩ និងការពន្យល់ ។

**៦០:១៩** *ព្រះអាទិត្យ . . . ព្រះចន្ទ* យោងទៅលើ វវ ២១:២៣ ២២:៥ ពន្លឺរបស់គេក៏លែងត្រូវការទៀតហើយនៅក្នុងក្រុងយេរូសាឡិម ដោយព្រោះវត្តមានព្រះអម្ចាស់ និងកូនចៀមដែលជា "ពន្លឺ" អស់កល្បជានិច្ច ។ ជាសិរីល្អ មើល ខ.១–២ និងការពន្យល់ សក ២:៥ សូមប្រៀបធៀបការពន្យល់ នក

ទៅ គឺព្រះយេហូវ៉ា ទ្រង់នឹងជាពន្លឺដ៏នៅអស់កល្បជានិច្ច
ដល់ឯងវិញ[គ] ហើយព្រះនៃឯងនឹងជាសិរីល្អដល់ឯងដែរ[ឃ]
២០ព្រះអាទិត្យ[ង] របស់ឯងនឹងលែងលិច ហើយព្រះចន្ទរបស់
ឯងនឹងមិនជ្រេទៀតឡើយ ពីព្រោះព្រះយេហូវ៉ានឹងជាពន្លឺដ៏
នៅអស់កល្បជានិច្ចដល់ឯង ហើយគ្រានៃសេចក្ដីសោក
សៅ[ច] របស់ឯងនឹងផុតទៅ ២១ពួកអ្នកនៅក្នុងឯងនឹងបានជា
មនុស្សសុចរិត[ឆ]ទាំងអស់ គេនឹងគ្រងបាន[ជ]ស្រុកជាមរដក
នៅជាដរាប គេជាមែកដែលអញបានផ្សាំ[ឈ] ជាការដែល
ដៃអញបានធ្វើ[ញ] ដើម្បីឱ្យអញបានដំកើងឡើង[ដ] ២២អ្នកតូច
បំផុតនឹងត្រឡប់ជាមនុស្ស១ពាន់ ហើយពួកមានគ្នាតិច និង
ត្រឡប់ទៅជាសាសន៍១យ៉ាងពូកែ[ឋ] អញនេះគឺព្រះយេហូវ៉ា
អញនឹងបញ្ឿនឱ្យការនេះឆាប់កើតឡើង នៅពេល
កំណត់[ឌ] ។

## ឆ្នាំដែលព្រះអម្ចាស់សព្វព្រះហឫទ័យ

**៦១** ១ព្រះវិញ្ញាណ[ក]នៃព្រះអម្ចាស់យេហូវ៉ា[ខ] ទ្រង់សណ្ឋិត
លើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំង[គ] ខ្ញុំឱ្យ
ផ្សាយដំណឹងល្អ[ឃ]ដល់មនុស្សទាល់ក្រ[ង] ទ្រង់បានចាត់ខ្ញុំឱ្យមក
ដើម្បីនឹងប្រោស[ច]មនុស្សដែលមានចិត្តសង្រេង និងប្រកាស
ប្រាប់ពីសេចក្ដីប្រោសលោះ[ឆ]ដល់ពួកឈ្លើយ[ជ] ហើយពីការ
ដោះលែងដល់ពួកអ្នកដែលជាប់ចំណង ២ព្រមទាំងប្រកាស
ប្រាប់ពីឆ្នាំ ដែលព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ[ឈ] និងពី
ថ្ងៃ ដែលព្រះនៃយើងខ្ញុំនឹងសងសឹក[ញ]ផង ហើយឱ្យកំសាន្ត
ចិត្ត[ដ]នៃអស់អ្នកណាដែលសោយសោក[ឋ] ៣នឹងចែកឱ្យដល់
ពួកអ្នកដែលសោយសោក នៅក្រុងស៊ីយ៉ូន បានភួង[ឌ]លំអ
ជំនួសផេះ[ឍ] ហើយប្រេង[ណ]នៃសេចក្ដីអំណរជំនួសសេចក្ដី
សោកសៅ[ត] ព្រមទាំងអាវពាក់នៃសេចក្ដីសរសើរ ជំនួសទុក្ខ
ធ្ងន់ដែលគ្របសង្កត់ ដើម្បីឱ្យគេបានហៅថា ជាដើមឈើ
នៃសេចក្ដីសុចរិត គឺជាដើមដែលព្រះយេហូវ៉ាបានដាំ[ថ]
មានប្រយោជន៍ឱ្យទ្រង់បានថ្កើងឡើង[ទ] ។
៤គេនឹងសង់អស់ទាំងទីដែលខូចបង់[ធ]ពីដើមឡើងវិញ
ហើយរៀបកន្លែងចោលស្ងាត់ពីកាលមនុស្សឡើងថ្មី គេនឹង
ជួសជុលអស់ទាំងទីក្រុងដែលខូចបង់ ហើយអស់ទាំងទី

**៦០:១៩** គ ទដ ៣៦:៩ ១១៨:២៧ វវ ២២:៥ ឃ ទដ ៨៥:៩ អស ២៤:១៦,២៣ វវ ២១:២៣ **៦០:២០** ង អស ៣០:២៦ ច អស ៣០:១៩ ៣៥:១០ វវ ៧:១៧ **៦០:២១** ឆ អស ៤:៣ ២៦:២ វវ ២១:២៧ ជ ទដ ៣៧:១១,២២ អស ៤៩:៨ ៥៧:១៣ ៦១:៧ ៦៥:៩ សក ៨:១២ ឈ នក ១៥:១៧ ទដ ៤៤:២ ៨០:៨–១១ យរ ៣២:៤១ អម ៩:១៥ មថ ១៥:១៣ ញ យប ១០:៣ ទដ ៨:៦ អស ១៩:២៥ អភ ២:១០ ដ លវ ១០:៣ អស ៤៤:២៣ **៦០:២២** ឋ លប ១២:២ ចទ ១:១០ ឌ អស ៥:១៩ **៦១:១** ក អស ១១:២ ២កថ ៣:១៧ ខ អស ៥០:៤ គ ទដ ៤៥:៧ ដយ ៩:២៤–២៦ កច ៤:២៦ ឃ ២សយ ១៨:២៦ អស ៤០:៩ ង យប ៥:១៦ មថ ១១:៥ លក ៧:២២ ច ២ពវ ២២:១៩ យប ៥:១៨ ឆ លវ ២៥:១០ ជ ទដ ៦៨:៦ អស ៤៩:៩ **៦១:២** ឈ អស ៤៩:៨ លក ៤:១៨–១៩ ញ អស ១:២៤ ដ អស ៤០:១ មថ ៥:៤ ឋ យប ៥:១១ លក ៦:២១ **៦១:៣** ឌ អស ៣:២៣ ឍ យប ២:៨ ណ នវ ៣:៣ អស ១:៦ ហព ១:៩ ត យរ ៣១:១៣ មថ ៥:៤ ថ ទដ ១:៣ ៩២:១២–១៣ មថ ១៥:១៣ ១កថ ៣:៩ ទ អស ៤៤:២៣ **៦១:៤** ធ អស ៤៤:២៦ ៥១:៣ ៦៥:២១ អគ ៣៦:៣៣ អម ៩:១៤ សក ១:១៦–១៧

៤០:៣៤ ទដ ២៦:៨ ។

**៦០:២០** *ព្រះអាទិត្យរបស់ឯងនឹងលែងលិច* ក៏លែងមានពេលយប់នៅទីនោះហើយ (ប្រៀបធៀប ២២:៥) តែមានពន្លឺនៃសេចក្ដីអំណរ និងសេចក្ដីសង្គ្រោះ (សូមមើល ៥៨:៨ និងការពន្យល់) ។ *សេចក្ដីសោកសៅរបស់ឯងផុតទៅ* សូមមើល ២៥:៨ ៣៥:១០ ៥១:១១ ៦៦:១៩ វវ ២១:៤ ។

**៦០:២១** *បានជាមនុស្សសុចរិត* ក៏មានតែការប្រោសលោះ (សូមមើល ៤:៣ ៣៥:៨ វវ ២១:២៧) ។ *បានស្រុកជាមរដកនៅជាដរាប* គឺជាការដែលបានទទួលព្រះពរពេញបរិបូរ (សូមមើល ៤៩:៨ និងការពន្យល់) ។ *មែកដែលអញបានផ្សាំ* ប្រៀបធៀបចំការទំពាំងបាយជូរក្នុង ៥:២,៧ (សូមមើល ១១:១) ផងដែរ ។ *ជាការដែលដៃអញបានធ្វើ* គឺជាមានលក្ខណៈដូចជាងស្មូន និងដីឥដ្ឋ (សូមមើល ៦៤:៨ សូមមើល ២៩:២៩ ៤៥:១១ ) ។ សូមមើល ៤៩:៣ ៦១:៣ សូមមើលការពន្យល់ ៣៥:២ ៤០:៥ ។

**៦០:២២** *អ្នកតូចបំផុត នឹងត្រឡប់ជាមនុស្ស១ពាន់* សូមមើល ៥១:២ ៥៤:៣ និងការពន្យល់ ។

**៦១:១–២** ព្រះយេស៊ូវប្រើពាក្យដោយផ្ទាល់នៅសាលាប្រជុំ នៅក្នុងភូមិណាសារ៉ែត (មើល លក ៤:១៦–២០ និងការពន្យល់ ធៀបនឹង មថ ១១:៥) ។

**៦១:១** *ព្រះវិញ្ញាណ . . . សណ្ឋិតលើខ្ញុំ* សេចក្ដីនេះគឺចង់សំដៅលើលោកអេសាយ តែអ្នកបំរើដែលជាព្រះមែស៊ី គឺជាសេចក្ដីបំណងសំខាន់បំផុត(សូមមើលការប្រៀបធៀបពីទ្រង់ ក្នុង ៤២:១ ១១:២ ៤៨:១៦ និងការពន្យល់) ។ នៃព្រះអម្ចាស់យេហូវ៉ា សូមមើល ៥០:៤–៥,៩ និងការពន្យល់ ។ បានចាក់ប្រេងតាំងខ្ញុំ សូមមើល ៤៥:១ និងការពន្យល់ ។ ដំណឹងល្អ សូមមើល ៤០:៩ និងការពន្យល់ ។ *ទាល់ក្រ* ប្រៀបធៀប ១១:៤ ២៩:១៩ មនុស្សដែលមានចិត្តសង្រេង សូមមើល ៣០:២៦ និងការពន្យល់ ។ សេចក្ដីប្រោសលោះដល់ពួកឈ្លើយ បានប្រកាសឡើងក្នុងឆ្នាំនៃថ្ងៃ បុណ្យទី៥០ លវ ២៥:១០ (សូមមើល ៤៩:៨ និងការពន្យល់) ។

**៦១:២** *ឆ្នាំដែលព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ* គឺជាការឆ្លើយតបដល់ថ្ងៃនៃសេចក្ដីសង្គ្រោះ មើលក្នុង ៤៩:៨ (សូមមើលការពន្យល់) ។ ក៏ជាឆ្នាំនៃការប្រោសលោះ ។ មើលក្នុង ៦៣:៤ លក ៤:១៩–២០ បន្ទាប់មកហេតុការនេះ ក៏គ្មានអ្វីកើតឡើងទៀតទេ រហូតដល់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ ថ្ងៃដែលព្រះនៃយើងខ្ញុំ នឹងសងសឹកផង សូមមើល ៣៤:២,៨ និងការពន្យល់ ។ កំសាន្តចិត្តនៃអស់អ្នកណាដែលសោយ សូមមើល ៤៩:១៣ ៥៧:១៩ និងការពន្យល់ ៦៦:១០ យរ ៣:១៣ មថ ៥:៤ ។

**៦១:៣** *បានភួងលំអជំនួស . . . អាវពាក់នៃសេចក្ដីសរសើរ* សូមមើលការពន្យល់ក្នុង ទដ ១០៩:២៩ ភួងលំអ គឺជាប្រភេទ "ឈ្នួត" ម្យ៉ាង (បើក្នុងព្រះគម្ពីរភាសាហេព្រើរ គឺប្រែមានន័យថាគ្រឿងបំពាក់លើក្បាល អគ ២៤:១៧ ៣:២០ ឯស្ត្រីក្រុងយេរូសាឡិមបានបាត់គ្រឿងលំអលើក្បាល ។ *ប្រេងនៃសេចក្ដីអំណរ* គឺជាប្រេងសម្រាប់ចាក់ប្រេងតាំងនៃសេចក្ដីអំណរ (សូមមើល ទដ ២៣:៥ ៤៥:៧ និងការពន្យល់ ១០៤:១៥ ១៣៣:១–២ ប្រៀបធៀប ២សយ ១៤:២) ។ សូមមើល ១:៦ និងការពន្យល់ផងដែរ ។ *អាវពាក់នៃសេចក្ដីសរសើរ* គឺមានលក្ខណៈផ្ទុយចំពោះ "អាវនៃសេចក្ដីសងសឹក" ក្នុង ៥៩:១៧ ។ *ដើមឈើនៃ សេចក្ដីសុចរិត* ក៏មានលក្ខណៈពីដើមឈើនៃសេចក្ដីដែលនៅក្នុង ១:៣០ និងការពន្យល់ ។

**៦១:៤** *សង់អស់ទាំងទីដែលខូចបង់ពីដើមឡើងវិញ* សូមមើល ៦០:២១ និងការពន្យល់ ។

កន្លែងដែលចោលសាត់ តាំងពីច្រើនដំណតមកផង ៥គ្រា
នោះ ពួកសាសន៍ដទៃ[ន]នឹងឃ្វាលហ្វូងសត្វឱ្យឯង ហើយ
មនុស្សប្រទេសក្រៅនឹងភ្ជួររាស់ ហើយថែរក្សាចំការទំពាំង
បាយជូរឱ្យឯង ៦តែឯងរាល់គ្នា នឹងបានហៅថាជាសង្ឃ[ប]
របស់ព្រះយេហូវ៉ា មនុស្សទាំងឡាយនឹងហៅឯងរាល់គ្នា
ជាអ្នកគោរពដល់ព្រះនៃយើងរាល់គ្នា ឯងរាល់គ្នានឹងស៊ី
ទ្រព្យសម្បត្តិ[ផ]របស់អស់ទាំងសាសន៍ ហើយនឹងមានសេចក្ដី
រីករាយដោយរបស់រុងរឿងនៃគេ ៧ឯងរាល់គ្នានឹងបាន
ចំណែក១ជា២ជំនួសសេចក្ដីខ្មាស[ព]របស់ឯង ហើយនឹង
មានសេចក្ដីរីករាយ ដោយចំណែកដែលខ្លួនទទួល[ភ]ជំនួស
សេចក្ដីអាប់យស ដូច្នេះ ឯងនឹងបាន២[ម]ចំណែកនៅក្នុង
ស្រុករបស់ឯង ហើយនឹងមានសេចក្ដីអំណរ[យ] ដ៏នៅអស់
កល្បជានិច្ច ៨ដ្បិតអញ គឺព្រះយេហូវ៉ា អញស្រឡាញ់
សេចក្ដីយុត្តិធម៌[រ] តែស្អប់ការលួចប្លន់ និងសេចក្ដីទុច្ចរិត
វិញ អញនឹងឱ្យរង្វាន់ដល់ឯងដោយសេចក្ដីពិត ហើយ
នឹងតាំងសេចក្ដីសញ្ញា[ល]ដ៏នៅអស់កល្បជានិច្ចនឹងឯង ៩គេ
នឹងស្គាល់ពូជពង្ស[វ]របស់ឯង នៅកណ្ដាលអស់ទាំងសាសន៍
ហើយកូនចៅរបស់ឯង នៅកណ្ដាលជនជាតិទាំងឡាយ
អស់អ្នកណាដែលឃើញឯងនឹងទទួលស្គាល់ថា ឯងជាពួក
អ្នកដែលព្រះយេហូវ៉ាបានប្រទានពរឱ្យ[ស] ។
១០ខ្ញុំនឹងអរសប្បាយចំពោះព្រះយេហូវ៉ា ព្រលឹងខ្ញុំនឹង
រីករាយ[ហ]ចំពោះព្រះនៃខ្ញុំ ពីព្រោះទ្រង់បានប្រដាប់ខ្លួនខ្ញុំ
ដោយសំលៀកបំពាក់នៃសេចក្ដីសង្គ្រោះ ទ្រង់បានគ្រលុំ
ខ្ញុំដោយអាវជាសេចក្ដីសុចរិត[ឡ] ដូចជាប្ដីថ្មោងថ្មីតែងខ្លួន[អ]
ដោយគ្រឿងលំអ ហើយដូចជាប្រពន្ធ[ក]ថ្មោងថ្មី ក៏ប្រដាប់
ដោយត្បូងរបស់ខ្លួនដែរ ១១ដ្បិតដែលដីធ្វើឱ្យចេញពន្លក
ហើយសួនច្បារ[ខ]បណ្ដាលឱ្យពូជផ្សេងៗ ដែលគេដាំនៅទី
នោះ បានដុះឡើងជាយ៉ាងណា នោះព្រះអម្ចាស់យេហូវ៉ា
ទ្រង់នឹងធ្វើឱ្យសេចក្ដីសុចរិត[គ] និងសេចក្ដីសរសើរបាន
លេចឡើង នៅចំពោះអស់ទាំងសាសន៍យ៉ាងនោះដែរ ។

## ឈ្មោះថ្មីរបស់ក្រុងស៊ីយ៉ូន

**៦២** ១ដោយយល់ដល់ក្រុងស៊ីយ៉ូន នោះអញមិនព្រមអត់
ធ្មត់ទេ[ក] ហើយដោយយល់ក្រុងយេរូសាឡិម នោះអញមិន
ព្រមបង្អង់ឡើយ ទាល់តែសេចក្ដីសុចរិត[ខ]របស់ក្រុងនោះ
បានភ្លឺចេញមក[គ] ដូចជារស្មីនៃពន្លឺ ហើយសេចក្ដីសង្គ្រោះ[ឃ]
របស់គេបានដូចជាចង្កៀងដែលឆេះ ២នោះអស់ទាំង
សាសន៍[ង] នឹងឃើញសេចក្ដីសុចរិតរបស់ឯង ហើយស្ដេច
ទាំងឡាយនឹងឃើញសិរីល្អរបស់ឯងដែរ ឯងនឹងមាន
ឈ្មោះថ្មី[ច] ជាឈ្មោះដែលព្រះឱស្ឋនៃព្រះយេហូវ៉ា នឹង
សំរេចឱ្យ ៣ឯងនឹងជាមកុដ[ឆ]ដ៏រុងរឿងនៅព្រះហស្តនៃព្រះ
យេហូវ៉ា ហើយជាព្រះមាលារាជ្យនៅព្រះហស្តរបស់ព្រះ
នៃឯង ៤ឯងមិនត្រូវគេហៅថា ទីក្រុងចោលបង់[ជ] ហើយដី

**៦១:៥** ន អស ១៤:១-២ ៥៦:៦ **៦១:៦** ប នក ១៩:៦ ១ពត ២:៥ ផ ចទ ៣៣:១៩ អស ៦០:១១ **៦១:៧** ព អស ២៩:២២ ៤១:១១ ភ អស ៦០:២១ ម ចទ ២១:១៧ អស ៤០:២ យ ទដ ១២៦:៥ អស ២៥:៩ **៦១:៨** រ ទដ ១១:៧ អស ១:១៧ ៥:១៦ ល លប ៩:១៦ អស ៤២:៦ ហព ១៣:២០ **៦១:៩** វ អស ៤៣:៥ ៤៨:១៩ ស លប ១២:២ ចទ ២៨:៣-១២ **៦១:១០** ហ ទដ ២:១១ អស ៧:១៣ ២៥:៩ ហព ៣:១៨ លក ១:៤៧ ឡ យប ២៧:៦ ទដ ១៣២:៩ អស ៥២:១ វវ ១៩:៨ អ នក ៣៩:២៨ ក អស ៤៩:១៨ វវ ២១:២ **៦១:១១** ខ លប ៤៧:២៣ អស ៥៨:១១ គ អស ៤៥:៨ **៦២:១** ក នអ ៤:១៤ ទដ ៥០:២១ ៨៣:១ ខ អស ១:២៦ ៤៥:៨ គ យប ១១:១៧ ឃ ទដ ៦៧:២ **៦២:២** ង ទដ ៦៧:២ អស ៤០:៥ ៤៥:១៤ ៥២:១០ ច លប ៣២:២៨ អស ១:២៦ វវ ២:១៧ ៣:១២ **៦២:៣** ឆ អស ២៨:៥ ១ថន ២:១៩ **៦២:៤** ជ លវ ២៦:៤៣ អស ៦:១២ ៥៤:៦

**៦១:៥** *ពួកសាសន៍ដទៃ... មនុស្សប្រទេសក្រៅ* សូមមើល ១៤:១-២ ៥៦:៣ ៦០:១០ និងការពន្យល់ ។

**៦១:៦** *ជាសង្ឃរបស់ព្រះយេហូវ៉ា* មើល ៦៦:២១ ។ ប្រជារាស្ត្រអ៊ីស្រាអែលដ៏ពិត និងធ្វើជា "នគររបស់សង្ឃ" ក្នុងចំណោមពួកសាសន៍ដទៃ (មើល នក ១៩:៦ សក ៣:១-១០ និងការពន្យល់ និងមើល ៦០:៥ និងការពន្យល់) ។

**៦១:៧** *សេចក្ដីខ្មាស . . . សេចក្ដីអាប់យស* សូមមើល ៤៥:១៧ ៥៤:៤ *២ចំណែក* គឺជាកូនច្បងអាចទទួលមរតកពីរចំណែក (សូមមើល ចទ ២១:១៧ និងការពន្យល់ សក ៩:១២) ក៏មានដាក់ទណ្ឌកម្មពីរដងគ្នាដែលរាស្ត្រអ៊ីស្រាអែលបានទទួល(៤០:២) ។ *សេចក្ដីអំណរដ៏នៅអស់ជានិច្ច* សូមមើល ៣៥:១០ ៥១:១១ ប្រៀបធៀប ទដ ១៦:១១ ។

**៦១:៨** *ស្រឡាញ់សេចក្ដីយុត្តធម៌* សូមប្រៀបធៀប ៣០:១៨ ៥៩:១៥ ។ *ការលួចប្លន់ និងសេចក្ដីទុច្ចរិត* គឺជារាស្ត្រអ៊ីស្រាអែលដែលបានគេធ្វើបាបយ៉ាងធ្ងន់ធ្ងរ ដោយពួកសត្រូវឈ្លានពានមួយចំនួន សូមប្រៀបធៀប ៤២:២៤ ៥៩:១៨ ។ *សេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ច* គឺអាចជាសេចក្ដីសញ្ញាថ្មី (សូមមើល ៥៥:៣ ៥៩:២១ និងការពន្យល់ប្រៀបធៀប យរ ៣១:៣៥-៣៧ ៣២:៤៧ និងការពន្យល់) ។

**៦១:៩** *ពួកអ្នកដែលព្រះយេហូវ៉ាបានប្រទានពរឱ្យ* សូមមើល ៤៤:៣ ៦៥:២៣ និងសេចក្ដីសន្យាចំពោះលោកអ័ប្រាហាំ ក្នុងលប ១២:១-១៣(សូមមើលការពន្យល់ផង) ។

**៦១:១០** ជាពាក្យសំដីរបស់កូនចៅនៅក្រុងស៊ីយ៉ូន ។ *ទ្រង់បានប្រដាប់ខ្ញុំដោយសំលៀកបំពាក់នៃសេចក្ដីសង្គ្រោះ* សូមមើលការពន្យល់ ទដ ១០៩:២៩ ។ *សំលៀកបំពាក់នៃសេចក្ដីសង្គ្រោះ* សូមមើល ខ.៣ ៥២:១ និងការពន្យល់ ។

**៦១:១១** *ចេញ . . . បានដុះឡើង* ប្រៀបធៀប ៥៥:១០ ។ *ឱ្យសេចក្ដីសុចរិត. . . និងសេចក្ដីសរសើរ* សូមមើល ៤៦:១៣ និងការពន្យល់ ក៏សូមមើល ៤៥:៨ និងការពន្យល់ ។

**៦២:១** *មិនព្រមអត់ធ្មត់ទេ . . . បង្អង់ឡើយ* សូមមើល ខ.៦ ៤២:១៤ ៥៧:១១ និងការពន្យល់ ៤៦:១៣ និងការពន្យល់, និងការប្រៀបធៀប ៥៨:៨ ។

**៦២:២** *ទាំងសាសន៍នឹងឃើញ . . . សិរីល្អ* សូមមើល ៥២:១០ ក៏សូមមើល ៤០:៥ ៦០:៣ និងការពន្យល់ ។ *របស់ឯងដែរ* គឺសំដៅលើក្រុងយេរូសាឡិម ឬអ្នកនៅក្នុងក្រុងយេរូសឡិមទាំងអស់ (សូមមើល ខ.១,៦) ឈ្មោះថ្មីគឺបង្ហាញពីរូបរាងថ្មី (សូមមើល ខ.៤,១២ ១:២៦ ៦០:១៤ លប ៣២:២៨ និងការពន្យល់ ) ។

**៦២:៣** *ជាមកុដដ៏រុងរឿង* មានក្នុង ២៨:៥ ព្រះយេហូវ៉ាជាមកុដរុងរឿងសម្រាប់ប្រជារាស្ត្ររបស់ផងទ្រង់(សូមមើលការប្រៀបធៀប សក ៩:១៦) ។

ឯងក៏មិនត្រូវហៅថា ទីស្ងាត់ជ្រងំទៀតឡើយ[ឈ] គឺឯងនឹង
ត្រូវហៅថា “ទីស្រឡាញ់”[ញ] ហើយដីរបស់ឯងថាជាអ្នក
មានប្តីវិញ ពីព្រោះព្រះយេហូវ៉ាទ្រង់មានសេចក្តីរីករាយ[ដ]
ចំពោះឯង ហើយដីឯងនឹងបានរៀបការ[ឋ] ៥ដ្បិតដែល
មនុស្សកំលោះយកស្រីក្រមុំធ្វើជាប្រពន្ធយ៉ាងណា នោះពួកកូន
ប្រុសៗរបស់ឯង និងមករួមនឹងឯងយ៉ាងនោះដែរ ហើយ
ដែលប្តីថ្មោងថ្មី[ឌ]មានចិត្តរីករាយចំពោះប្រពន្ធយ៉ាងណា
នោះព្រះនៃឯងនឹងមានសេចក្តីរីករាយ[ឍ]ចំពោះឯងយ៉ាង
នោះដែរ ។

៦ឱក្រុងយេរូសាឡិមអើយ អញបានដាក់ពួកយាមល្បាត[ណ]
នៅលើកំផែងឯងហើយ គេនឹងមិននៅមាត់ស្ងៀម ទោះ
យប់ឬថ្ងៃផង ឯងរាល់គ្នាដែលជាអ្នករំឭកព្រះយេហូវ៉ា
អើយ កុំឱ្យនៅស្ងៀមឡើយ[ត] ៧ហើយកុំឱ្យទ្រង់នៅទំនេរ[ថ]
ឱ្យសោះ ដរាបដល់ទ្រង់បានតាំងក្រុងយេរូសាឡិមឡើង ឱ្យ
ជាទីសរសើរ[ទ]នៅលើផែនដី ៨ព្រះយេហូវ៉ា ទ្រង់បានស្បថ[ធ]
ដោយព្រះហស្តស្តាំទ្រង់ ហើយដោយព្រះពាហុដ៏មានឥទ្ធិ
ឫទ្ធិរបស់ទ្រង់ថា ពិតប្រាកដជាអញនឹងមិនឱ្យស្រូវ[ន]របស់
ឯងទៅធ្វើជាអាហារដល់ពួកខ្មាំងសត្រូវឯងទៀត ហើយ
ពួកសាសន៍ដទៃនឹងមិនផឹកទឹកទំពាំងបាយជូរ ដែលឯង
បានខំធ្វើទៀតឡើយ ៩គឺពួកអ្នកដែលបានច្រូតផលនោះ
នឹងស៊ី[ប]វិញ ហើយគេនឹងសរសើរដល់ព្រះយេហូវ៉ា[ផ] ឯពួក
អ្នកដែលបានប្រមូលផ្លែនោះ គេនឹងផឹកនៅក្នុងទីលាននៃ
ទីបរិសុទ្ធរបស់អញ[ព] ។

១០ចូរចូលទៅ ចូរចូលទៅតាមទ្វារចុះ[ភ]ចូររៀបផ្លូវ
សំរាប់ប្រជាជន ចូរលើក ចូរលើកថ្នល់ឡើង[ម,យ] ចូរប្រមូល
យកថ្មចេញ ហើយបង្ហូតទង់ជ័យ[រ]សំរាប់ជនជាតិទាំង
ឡាយ ១១មើល ព្រះយេហូវ៉ាទ្រង់បានប្រកាសប្រាប់រហូត
ដល់ចុងផែនដីបំផុត[ល] ឱ្យប្រាប់ដល់កូនស្រីស៊ីយ៉ូនថា[វ] មើល
សេចក្តីសង្គ្រោះរបស់ឯងបានមកដល់ហើយ[ស] មើល ទ្រង់
យករង្វាន់មកជាមួយ ហើយសំណងរបស់ទ្រង់ក៏នាំមុខ
ទៅ[ហ] ១២គេនឹងហៅ[ឡ]ពួកនោះថា ជាជនជាតិបរិសុទ្ធ[អ] គឺជា
ពួកដែលព្រះយេហូវ៉ាទ្រង់ប្រោសលោះ[ក] នោះឯងនឹងបាន
ហៅថា ទីក្រុងដែលគេស្វែងរក[ខ] ជាទីក្រុងដែលមិនត្រូវ
បង់ចោលឡើយ ។

### ថ្ងៃដែលព្រះអម្ចាស់សងសឹកនិងប្រោសលោះ

**៦៣** ១តើអ្នកណាហ្ន៎ ដែលមកពីស្រុកអេដំម[ក] ស្លៀកពាក់
ដោយសំពត់ពណ៌ក្រុងបុសរ៉ា[ខ] គឺអ្នកនោះដែលមាន

**៦២:៤** ឈ អស ៤៩:១៩ ៥១:១៩ ញ ២ពវ ២១:១ ដ អស ៦៥:១៩ យរ ៣២:៤១ សផ ៣:១៧ មឡ ៣:១២ ឋ អស ៥៤:៥ យរ ៣:១៤ ហស ២:១៩ **៦២:៥** ឌ បស ៣:១១ ឍ ចទ ២៨:៦៣ អស ៦៥:១៩ យរ ៣១:១២ សផ ៣:១៧ **៦២:៦** ណ អស ៥២:៨ ហព ១៣:១៧ ត ទដ ១៣២:៤ **៦២:៧** ថ មថ ១៥:២១-២៨ លក ១៨:១-៨ ទ ចទ ២៦:១៩ អស ៦០:១៨ **៦២:៨** ធ លប ២២:១៦ អស ១៤:២៤ ៤៩:១៨ ន ចទ ២៨:៣០-៣៣ អស ១:៧ **៦២:៩** ប អស ១:១៩ អម ៩:១៤ ផ ចទ ១២:៧ យអ ២:២៦

ព លវ ២៣:៣៩ **៦២:១០** ភ ទដ ២៤:៧ អស ៦០:១១ ម អស ៥៧:១៤ យ អស ១១:១៦ រ អស ១១:១០ **៦២:១១** ល ចទ ៣០:៤ វ ទដ ៩:១៤ សក ៩:៩ មថ ២១:៥ ស អស ៣៥:៤ វវ ២២:១២ ហ អស ៤០:១០ **៦២:១២** ឡ លប ៣២:២៨ អ នក ១៩:៦ ១ពត ២:៩ ក ទដ ១០៦:១០ អស ៣៥:៩ ៤៤:២៣ ខ ទដ ២៧:៩ អស ៤២:១៦ ៥៤:៦ **៦៣:១** ក ២របា ២៨:១៧ អស ១១:១៤ ខ លប ៣៦:៣៣ អម ១:១២

**៦២:៤** *ចោលបង់ . . . ទីស្ងាត់ជ្រងំ* សូមមើល ៥៤:៦-៧ ៦០:១៥ និងការពន្យល់ ។ ទីស្រឡាញ់ (គឺ Hephzibath) គឺជាឈ្មោះភរិយារបស់ស្តេចអេសេគាលផងដែរ (សូមមើល ២ពវ ២១:១) ។ ពាក្យថា *បានរៀបការ* គឺជាការចងសម្ព័ន្ធភាពរវាងរាស្ត្រអ៊ីស្រាអែលនិងព្រះយេហូវ៉ាដែលនាំមកនូវភាពល្អប្រសើរឡើងវិញ សូមមើល ៥០:១ និងការពន្យល់ ។

**៦២:៥** *ពួកកូនប្រុសៗរបស់ឯងនឹងមករួមនិងឯង* គឺរាស្ត្រអ៊ីស្រាអែលនិងបានទទួលមរតក គឺជាដីស្រុកនៅទីរហោស្ថាន ប្រៀបធៀប ៥៤:១ ។ ឬក៏បើក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យ“ពួកកូនប្រុសៗ” អាចមានន័យថា “អ្នកសាងសង់” ឬក៏សំដៅលើព្រះអម្ចាស់តែម្តង (មើលការពន្យល់ ៤៩:១៧) ។

**៦២:៦** *ពួកយាមល្បាត* គឺសំដៅលើពួកហោរា ជាពិសេសខណៈពេលពួកគេកំពុងរង់ចាំអ្នកនាំសារ គឺជាអ្នកនាំដំណឹងល្អមកជាមួយ (សូមមើលការពន្យល់) ។ ពាក្យថា *មិននៅមាត់ស្ងៀម* (សូមមើល ខ.៤) តែត្រូវស្អាងទីក្រុងយេរូសាឡិមឡើងវិញ ។ ពាក្យថា *កុំឱ្យនៅស្ងៀមឡើយ* ដែលប្រៀបដូចជាស្តេចដាវីឌបានផ្ទង់ចិត្តអធិស្ឋាន គឺជាពេលដែលទ្រង់បានអធិស្ឋានរកទីលំនៅ ឬហឹបជាព្រះចេស្តានៃទ្រង់ (ទដ ១៣២:១-៥) ។

**៦២:៧** *ជាទីសរសើរនៅលើផែនដី* ប្រៀបធៀប យរ ៣៣:៩ សផ ៣:១៩-២០ សូមមើល ៦០:៣ និងការពន្យល់ ។

**៦២:៨** *បានស្បថ* សូមប្រៀបធៀប ៤៥:២៣ ៥៤:៩ ។ *ព្រះពាហុដ៏មានឥទ្ធិឫទ្ធិ* សូមមើល ៥១:៩ ។ *មិនឱ្យស្រូវរបស់ឯងទៅធ្វើជាអាហារដល់ពួកខ្មាំងសត្រូវឯងទៀត . . . ពួកសាសន៍ដទៃ នឹងមិនផឹកទឹកទំពាំងបាយជូរ* គឺជាការជំនុំជម្រះដែលលោកម៉ូសេបានប្រមានដែលមានក្នុង លវ ២៦:១៦ ចទ ២៨:២៣ សូមមើល ៥២:១ និងការពន្យល់ យរ ៥:១៧ ផងដែរ ។

**៦២:៩** *ស៊ី . . . ផឹក* មើល ៦៥:១៣,២១-២៣ ។ *នៅក្នុងទីលាននៃទីបរិសុទ្ធរបស់អញ* គឺកំឡុងពេលមានពិធីបុណ្យ ឬខណៈពេលដែលពួកជំនុំយកដង្វាយមកថ្វាយព្រះយេហូវ៉ា (លវ ២៣:៣៩-៤០ ចទ ១៤: ២២-២៦) ។

**៦២:១០** *ចូរចូលទៅ ចូរចូលទៅតាម* គឺជាការចូលតាមទ្វារបាប៊ីឡូន សូមមើលការពន្យល់ ៤០:១ ។ ប្រៀបធៀប ៤៨:២០ មីក ២:១២-១៣) ។ ពាក្យថា *ចូររៀបផ្លូវ . . . ផ្លូវលើកថ្នល់ឡើង* សូមមើល ៤០:៣ ៤៩:១១ និងការពន្យល់ ។ ពាក្យថា *ចូរប្រមូលថ្មចេញ* សូមមើល ៥៧:១៤ ។ *ទង់ជ័យ* សូមមើល ៥:២៦ និងការពន្យល់ ។

**៦២:១១** *ចុងផែនដី* មើល ១១:១២ ៤៩:៦ និងការពន្យល់ ។ *កូនស្រីស៊ីយ៉ូន* គឺជាការបង្ហាញលក្ខណៈសម្បត្តិរបស់ក្រុងយេរូសាឡិម (សូមមើល ២ពវ ១៩:២១) ។ *សេចក្តីសង្គ្រោះរបស់ឯងបានមកដល់ហើយ* សូមមើល ៤០:៩ ៤៣:៣ សក ៩:៩ និងការពន្យល់ មថ ២១:៥ មើល ៤០:១០ និងការពន្យល់ ។

**៦២:១២** *ជាជនជាតិបរិសុទ្ធ* សូមមើល ៤:៣ នញ ១៩:៦ ការពន្យល់ ។ *ប្រោសលោះ* សូមមើល ៣៥:៩ និងការពន្យល់ ។

**៦៣:១** *ស្រុកអេដំម* សូមមើល ២១:១១ ៣៤:៥ និងការពន្យល់ ។ ពាក្យថា ស្រុកអេដំមនៅក្នុងអត្ថបទនេះ គឺតំណាងឱ្យពួកលោកិយដែលបានស្អប់ដល់

សំលៀកបំពាក់រុងរឿង[គ] ហើយក៏ដើរមកដោយឫទ្ធិយ៉ាង
ខ្លាំង[ឃ] គឺអញនេះដែលនិយាយដោយសេចក្ដីសុចរិត ជា
អ្នកពូកែនឹងសង្គ្រោះ[ង] ២ហេតុអ្វីបានជាព្រះពស្ត្រទ្រង់មាន
ពណ៌ក្រហម ហើយព្រះភូសាក៏ដូចជាអ្នកដែលជាន់ក្នុងធុង
ទំពាំងបាយជូរដូច្នេះ[ច] ៣នេះគឺអញបានជាន់ក្នុងធុងទំពាំង
បាយជូរ[ឆ]តែម្នាក់ឯង ឥតមានអ្នកណាក្នុងពួកជនជាតិទាំង
ឡាយនៅជាមួយនឹងអញឡើយ អើ អញបានជាន់[ជ]គេ ដោយ
សេចក្ដីកំហឹង[ឈ] ហើយបានឈ្លីគេដោយសេក្ដីឃោរឃៅ
របស់អញ ឈាមគេបានខ្ទាតមកលើសំលៀកបំពាក់របស់
អញ[ញ] សំលៀកបំពាក់អញបានត្រូវប្រឡាក់ទាំងអស់ ហើយ
៤ដ្បិតនៅក្នុងចិត្តអញបាននឹកពីថ្ងៃសងសឹក[ដ] ឯឆ្នាំកំណត់នៃ
ពួកប្រោសលោះរបស់អញ ក៏បានមកដល់ដែរ ៥អញក៏រក
មើល តែគ្មានអ្នកណា[ឋ]នឹងជួយសោះ អញបានអស្ចារ្យពី
ការដែលគ្មានអ្នកណានឹងជួយទប់ទល់ ដូច្នេះ ដើមដៃ[ឌ]របស់
អញ បាននាំសេចក្ដីសង្គ្រោះមកឯអញ ហើយសេចក្ដី
ឃោរឃៅរបស់អញបានទប់ទល់អញ[ឍ] ៦អញបានជាន់
ឈ្លី[ណ]ជនជាតិទាំងឡាយ ដោយសេចក្ដីកំហឹងរបស់អញ
ក៏ធ្វើឱ្យគេស្រវឹង[ត] ដោយសេចក្ដីឃោរឃៅរបស់អញ
ហើយបានចាក់ឈាម[ថ]គេចុះដល់ដីផង ។

**៦៣:១** គ វវ ១៩:១៣ ឃ យប ៩:៤ អស ៤៥:២៤ ង ខ.៥ អស ៤៦:១៣ ៥១:៥ យរ ៤២:១១ សផ ៣:១៧ **៦៣:២** ច លប ៤៩:១១ **៦៣:៣** ឆ ពច ៦:១១ វវ ១៤:២០ ជ យប ៤០:១២ ទដ ១០៨:១៣ អស ៥:៥ ឈ អស ២២:៥ ញ វវ ១៩:១៣ **៦៣:៤** ដ អស ១:២៤ យរ ៥០:១៥ **៦៣:៥** ឋ ២ពវ ១៤:២៦ អស ៤១:២៨ ឌ ទដ ៤៤:៣ ៩៨:១ អស ៣៣:២ ឍ អស ៥៩:១៦ **៦៣:៦** ណ យប ៤០:១២ ទដ ១០៨:១៣ ត អស ២៩:៩ បទ ៤:២១ ថ អស ៣៤:៣

## ការសរសើរតម្កើង និងអធិស្ឋាន

៧ខ្ញុំនឹងថ្លែងប្រាប់ពីសេចក្ដីសប្បុរស[ទ]របស់ព្រះយេហូវ៉ា
ហើយពីសេចក្ដីដែលគួរសរសើររបស់ទ្រង់ តាមគ្រប់ទាំង
សេចក្ដីដែលព្រះយេហូវ៉ាទ្រង់បានប្រោសដល់យើងរាល់
គ្នា នឹងសេចក្ដីសប្បុរស[ធ]ដ៏ជាធំ ដែលផ្ដល់ដល់ពូជ
ពង្សអ៊ីស្រាអែល ជាសេចក្ដីដែលទ្រង់បានប្រោសដល់គេ
តាមសេចក្ដីមេត្តាករុណា[ន]របស់ទ្រង់ ហើយតាមសេចក្ដី
សប្បុរសដ៏ជាបរិបូររបស់ទ្រង់ ៨ដ្បិតទ្រង់បានមានបន្ទូលថា
គេជារាស្ត្រអញពិត[ប] គឺជាកូនចៅដែលមិនព្រមប្រព្រឹត្ត
ដោយកែកាញ់ឡើយ ដូច្នេះបានជាទ្រង់បានធ្វើជាព្រះអង្គ
សង្គ្រោះដល់គេ[ផ] ៩ក្នុងគ្រប់ទាំងសេចក្ដីទុក្ខវេទនារបស់គេ
នោះទ្រង់ក៏រងទុក្ខដែរ ហើយទេវតា[ព]ដែលនៅចំពោះ[ភ]
ទ្រង់បានសង្គ្រោះ[ម]គេ ទ្រង់បានប្រោសលោះគេ ដោយ
សេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ កាល
ពីចាស់បុរាណ ទ្រង់បានលើកគេបី[យ]ទៅជាដរាប[រ] ។
១០តែគេបានបះបោរ[ល] ហើយបានបញ្ឈឺព្រះហឫទ័យ

**៦៣:៧** ទ អស ៥៤:៨ ធ នក ១៨:៩ ន ទដ ៥១:១ អភ ២:៤ **៦៣:៨** ប ទដ ១០០:៣ អស ៥១:៤ ផ នក ១៤:៣០ អស ២៥:៩ **៦៣:៩** ព នក ១៤:១៩ ភ នក ៣៣:១៤ ម ចទ ៧:៧–៨ អរ ៩:៩ អស ៤៨:២០ យ ចទ ១:៣១ ទដ ២៨:៩ រ ចទ ៣២:៧ យប ៣៧:២៣ **៦៣:១០** ល ទដ ៧៨:១៧ អគ ២០:៨ កច ៧:៣៩–៤២

រាស្ត្ររបស់ផងទ្រង់ ។ *ក្រុងបូសរ៉ា* មើល ៣៤:៦ និងការពន្យល់ ។ *សំលៀកបំពាក់រុងរឿង* សូមប្រៀបធៀបនិងព្រះពស្ត្រជ្រលក់ដោយឈាមរបស់ព្រះគ្រីស្ទ (វវ ១៩:១៣) ក៏ដូចជាការធ្វើសង្គ្រាមក្នុងគ្រាដែលទ្រង់យាងមកជាលើកទីពីរ ។ *ដោយសេចក្ដីសុចរិតជាអ្នកពូកែនិងសង្គ្រោះ* សូមមើល ៤៥:៨ ៤៦:១៣ ៥៩:១៦ និងការពន្យល់ ។

**៦៣:២** *ហេតុអ្វីបានជា* គឺលោកអេសាយបានឆ្លើយតបដោយមានសំណួរជាន់ក្នុងធុងទំពាំងបាយជូរដូច្នេហ សូមមើល ១៦:១០ និងការពន្យល់ ។

**៦៣:៣** *ជាន់ក្នុងធុងទំពាំងបាយជូរ* គឺជាសញ្ញានៃការជំនុំជម្រះ (សូមមើលការពន្យល់ បទ ១:១៥ យអ ៩:១៣ វវ ១៤:១៩ ១៩:១៥) ។ *ដោយសេចក្ដីកំហឹង . . . ដោយសេចក្ដីឃោរឃៅរបស់អញ* គឺក្នុងខណៈពេល ជាថ្ងៃរបស់ព្រះយេហូវ៉ា សូមមើល ខ.៦ ១៣:៣ ៣៤:២ និងការពន្យល់ ។

**៦៣:៤** *ពីថ្ងៃសងសឹក . . . ឆ្នាំកំណើតនៃពួកប្រោសលោះរបស់អញ* មើល ៦១:២ និងការពន្យល់ ។ ថ្ងៃនៃការជំនុំជម្រះដល់ពួកសត្រូវមានន័យថា គឺជាថ្ងៃនៃការប្រោសលោះដល់រាស្ត្ររបស់ផងទ្រង់ផងដែរ សូមមើល ៣៥:៩ ៤១:១៤ និងការពន្យល់ ។

**៦៣:៥** សូមមើល ៥០:១៦ (ដែលបង្ហាញពីហេតុការដូចគ្នាចំពោះខនេះទាំងមូល) ។ *សេចក្ដីឃោរឃៅ* ក្នុង ៥៩:១៦"សេចក្ដីសុចរិត" ក៏កើតមានឡើងដោយមានសេចក្ដីសុចរិត និងភាពបរិសុទ្ធរបស់ព្រះយេហូវ៉ាជាលទ្ធផលតាមរយៈសេចក្ដីឃោឃៅរបស់ផងទ្រង់ ។

**៦៣:៦** *ក៏ធ្វើឱ្យគេស្រវឹង* (សូមមើល ៥១:៧ និងការពន្យល់) ។ *ចាក់ឈាមគេចុះ* ក្នុងខនេះគឺបង្ហាញពីសង្គ្រាមដែលប្រៀបធៀប និងយញ្ញបូជា ដូចជាក្នុង ៣៤:៦ ។

**៦៣:៧–៦៤:១២** នៅក្នុងខទាំងនេះ គឺបញ្ជាក់ពីការអធិស្ឋានរបស់លោកអេសាយ ដែលបានអធិស្ឋានសុំព្រះយេហូវ៉ាឱ្យនាំមកនូវការប្រោសលោះមក គឺឱ្យមានដូចដែលទ្រង់បានសន្យារួចមកហើយ(សូមមើល ៦២:៦ និងការពន្យល់) ។ គឺទ្រង់សន្យាជាមួយពួកហោរា ឬម្នាក់ដែលមានតួនាទីព្រះរាជកិច្ចនាំដំណឹងល្អមកដល់គ្រប់ជាតិសាសន៍ទាំងអស់(សូមមើល ឧ. ទដ ៤៤) ។

**៦៣:៧** *សេចក្ដីសប្បុរស* គឺបង្ហាញបញ្ជាក់ពីសេចក្ដីស្រឡាញ់ឥតពុតមាយាររបស់ព្រះអម្ចាស់ ។ ដូចជាទ្រង់បានឈរជាតំណាងសេចក្ដីពិតចំពោះសេចក្ដីសញ្ញារបស់ទ្រង់ជាមួយរាស្ត្រអ៊ីស្រាអែល ។ ពាក្យថា សេចក្ដីសប្បុរសដ៏ជាធំ សូមប្រៀបធៀប យស ២១:៤៥ ១ពវ ៨:៦៦ ។ *សេចក្ដីមេត្តាករុណា* សូមមើល ៥៤:៧–៨,១០ និងការពន្យល់។

**៦៣:៨** *ជារាស្ត្រអញពិត គឺជាកូនចៅ . . . មិនព្រមដោយកែកាញ់ឡើយ* តែសូមមើល ១:២–៤ ។ ជាព្រះអង្គសង្គ្រោះ សូមមើល ៤៣:៣ នឹងការពន្យល់

**៦៣:៩** *ក្នុងគ្រប់ទាំងសេចក្ដីទុក្ខវេទនារបស់គេ . . . ក៏រងទុក្ខដែរ* គឺដូចជាការឈឺចាប់ក្នុងស្រុកអេស៊ីព្ទ និងក្នុងកំឡុងពេលជំនុំជម្រះ(សូមមើល ពច ១០:១៦)។ *ទេវតាដែលនៅចំពោះទ្រង់* សូមមើល នក ២៣:២០–២៣ ៣៣:១៤–១៥ ។ *ប្រោសលោះ* សូមមើល ៤១:១៤ ៤៣:១ និងការពន្យល់ ។ *បានលើកគេបីទៅជាដរាប* គឺមានលក្ខណៈដូចជាឪពុក (សូមមើល ចទ ១:៣១ ៣២:១០–១២) ។

**៦៣:១០** *បានបះបោរ* ដូចជានៅឯវាលរហោស្ថាន(សូមមើល ១:២ និងការពន្យល់) ។ *បានបញ្ឈឺព្រះហឫទ័យនៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់* សូម

នៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់[វ] ហេតុនោះបានជាទ្រង់
បានត្រឡប់ជាខ្មាំងសត្រូវ[ស]នឹងគេវិញ ហើយអង្គទ្រង់ក៏
តបត[ហ]នឹងគេដែរ ១១ខណនោះ រាស្ត្រទ្រង់បាននឹកដល់គ្រា
ជាន់មុន ហើយពីម៉ូសេដោយថា ព្រះអង្គដែលនាំគេឡើងពី
សមុទ្រ[ឡ]ជាមួយនឹងអ្នកគង្វាលនៃហ្វូងចៀមទ្រង់[អ] តើទ្រង់
នៅឯណា ព្រះអង្គដែលដាក់វិញ្ញាណបរិសុទ្ធ[ក]របស់ទ្រង់ឱ្យ
សណ្ឋិតនៅនឹងគេ នោះតើនៅឯណា ១២គឺព្រះអង្គដែល
ឱ្យព្រះពាហុ[ខ]រុងរឿងឧត្តមរបស់ទ្រង់អមដៃស្តាំម៉ូសេទៅ
ជាព្រះដែលញែកទឹក[គ]ចេញពីគ្នានៅមុខគេ ដើម្បីនឹងធ្វើឱ្យ
ទ្រង់មាននាមដ៏ស្ថិតស្ថេរនៅអស់កល្បតទៅនោះ[ឃ] ១៣ជា
ព្រះដែលនាំ[ង]គេដើរកាត់ទីជំរៅ[ច]មិនឱ្យចំពប់ដួលឡើយ[ឆ]
ដូចជានាំសេះដើរកាត់ទីរហោស្ថាន ១៤ព្រះវិញ្ញាណនៃព្រះ
យេហូវ៉ាបានឱ្យគេឈប់សំរាក[ជ] ដូចជាហ្វូងគោដែលចុះទៅ
ក្នុងច្រកភ្នំ គឺយ៉ាងនោះដែលទ្រង់បាននាំរាស្ត្រទ្រង់ ដើម្បី
នឹងធ្វើឱ្យព្រះនាមទ្រង់បានរុងរឿងឧត្តម ។
១៥សូមទ្រង់ពិចារណាពីលើស្ថានសួគ៌[ឈ] ហើយទត
មើលពីទីលំនៅ[ញ]នៃសេចក្តីបរិសុទ្ធ នឹងសិរីល្អរបស់ទ្រង់
តើសេចក្តីខ្មីឃ្មាត[ដ] និងឫទ្ធានុភាពរបស់ទ្រង់ នៅឯណា ឯ
សេចក្តីកន្លែងក្នុងព្រះហឫទ័យ និងសេចក្តីមេត្តាករុណា[ឋ]
របស់ទ្រង់ នោះបានបង្ខាំងទុក[ឌ] នៅចំពោះទូលបង្គំហើយ
១៦ពីព្រោះទ្រង់ជាព្រះវរបិតារបស់យើងខ្ញុំ[ឍ] ទោះបើលោក
អ័ប្រាហាំមិនបានស្គាល់យើងខ្ញុំ ហើយពួកអ៊ីស្រាអែលមិន
ព្រមទទួលស្គាល់[ណ]យើងខ្ញុំក៏ដោយ គង់តែ ឱព្រះយេហូវ៉ា

**៦៣:១០** វ ទដ ៥១:១១ កច ៧:៥១ អភ ៤:៣០ ស ទដ ១០៦:៤០ អស ១០:៤ ហ យស ១០:១៤
**៦៣:១១** ឡ នក ១៤:២២,៣០ អ ទដ ៧៧:២០ ក ជន ១១:១៧
**៦៣:១២** ខ លប ៤៩:២៤ នក ៣:២០ គ នក ១៤:២១–២២ អស ១១:១៥ ឃ ទដ ១០២:១២ អស ៥៥:១៣ យរ ១៣:១១
**៦៣:១៣** ង ចទ ៣២:១២ ច នក ១៤:២២ ឆ ទដ ១១៩:១១ យរ ៣១:៩
**៦៣:១៤** ជ នក ៣៣:១៤ ចទ ១២:៩
**៦៣:១៥** ឈ ចទ ២៦:១៥ បទ ៣:៥០ ញ ១ពវ ២២:១៩ ទដ ១២៣:១ ដ អស ៩:៧ ២៦:១១ ឋ ១ពវ ៣:២៦ ទដ ២៥:៦ ឌ លប ៤៣:៣១ អស

អើយ ទ្រង់ជាព្រះវរបិតានៃយើងខ្ញុំពិត ហើយតាំងពីអស់
កល្បរៀងមក នោះព្រះនាមទ្រង់ជាព្រះដ៏ប្រោសលោះ[ត]
យើងខ្ញុំ ១៧ឱព្រះយេហូវ៉ាអើយ ហេតុអ្វីបានជាទ្រង់ធ្វើឱ្យ
យើង ខ្ញុំវង្វេងចេញ[ថ]ពីផ្លូវរបស់ទ្រង់ ហើយឱ្យយើងខ្ញុំមាន
ចិត្តរឹងទទឹង[ទ]ចំពោះសេចក្តីកោតខ្លាច[ធ]ដល់ទ្រង់ដូច្នេះ សូម
ទ្រង់វិលមកវិញ[ន] ដោយយល់ដល់ពួកអ្នកបំរើរបស់ទ្រង់ គឺ
ជាពូជអំបូរទាំងប៉ុន្មាននៃមរដករបស់ទ្រង់[ប] ១៨រាស្ត្រ
បរិសុទ្ធរបស់ទ្រង់បានស្រុកនោះមិនយូរប៉ុន្មានទេ[ផ] ឯពួក
ខ្មាំងសត្រូវរបស់យើងខ្ញុំ គេបានជាន់ឈ្លី[ព]ទីបរិសុទ្ធនៃទ្រង់[ភ]
១៩យើងខ្ញុំរាល់គ្នាបានត្រឡប់ដូចជាពួកអ្នក ដែលទ្រង់មិន
បានគ្រប់គ្រងឡើយ គឺដូចជាពួកអ្នក ដែលមិនបានហៅតាម
ព្រះនាមទ្រង់វិញ[ម] ។

**៦៤** ១ឱបើសិនជាទ្រង់នឹងវែកផ្ទៃមេឃ[ក] ហើយយាងចុះ
មកទៅអេះ[ខ]ដើម្បីឱ្យភ្នំទាំងប៉ុន្មាន[គ] បានញាប់ញ័រនៅចំពោះ
ទ្រង់ ២ដូចកាលណាភ្លើងរាលឆេះគំនរស្នាប់ ឬដូចភ្លើង
ធ្វើឱ្យទឹកពុះខ្ទោលឡើងផង ដើម្បីនឹងធ្វើឱ្យពួកខ្មាំងសត្រូវ
ទង់បានស្គាល់ព្រះនាម[ឃ]ទ្រង់ ហើយឱ្យសាសន៍ទាំងប៉ុន្មាន

៦៤:១២ **៦៣:១៦** ឍ នក ៤:២២ យរ ៣:៤ យហ ៨:៤១ ណ យប ១៤:២១ ត អស ៤១:១៤ ៤៤:៦ ៥៩:២០ **៦៣:១៧** ថ លប ២០:១៣ បទ ៣:៩ ទ នក ៤:២១ ធ អស ២៩:១៣ ន ជន ១០:៣៦ ប នក ៣៤:៩ **៦៣:១៨** ផ ចទ ៤:២៦ ១១:១៧ ព អស ២៨:១៨ ដយ ៨:១៣ លក ២១:២៤ ភ លវ ២៦:៣១ ២ពវ ២៥:៩ **៦៣:១៩** ម អស ៤៣:៧ យរ ១៤:៩ **៦៤:១** ក ទដ ១៨:៩ ១៤៤:៥ ខ ខ.៣ មីក ១:៣ គ នក ១៩:១៨ **៦៤:២** ឃ អស ៣០:២៧ ង ទដ ៩៩:១ ១១៩:១២០ យរ ៥:២២ ៣៣:៩

មើល អស ១១:១–២ និងការពន្យល់ប្រៀបធៀបនឹង ។ *បានត្រឡប់ជាខ្មាំងសត្រូវនឹងគេវិញ* ។ សូមមើល ៤៣:២៨ និងការពន្យល់ ។

**៦៣:១១** *សមុទ្រ* គឺជាសមុទ្រក្រហម (សូមមើល ៥០:២ និងការពន្យល់ ៥១:១០) ។ អ្នកគង្វាល គឺសំដៅទៅលើលោកម៉ូសេ ។ *ព្រះវិញ្ញាណបរិសុទ្ធ* សូមមើល ទដ ៥១:១០) ព្រះវិញ្ញាណបានមកសណ្ឋិតលើលោកម៉ូសេ និងចាស់ទុំ៧០នាក់ (ជន ១១:១៧,២៥) សូមមើល ខ.១៤ ។

**៦៣:១២** *ព្រះពាហុរុងរឿងឧត្តមរបស់ទ្រង់* សូមមើល ៥១:៩ និងការពន្យល់ នក ១៥:១៦ ។ *ញែកទឹកចេញពីគ្នា* សូមមើល នក ១៤:២១ ប្រៀបធៀប អស ១១:១៥ ៥១:១០ ។ ពាក្យថា *មាននាមដ៏ស្ថិតស្ថេរនៅអស់កល្បតទៅ* សូមមើល ៥៥:១៣ និងការពន្យល់ ។

**៦៣:១៤** *ចុះទៅក្នុងច្រកភ្នំ* គឺដើម្បីស្វែងរកវាលស្មៅនិងទឹក ។ *ឱ្យគេឈប់សំរាក* គឺគេក៏រកបានស្រុកនៅឯស្រុកកាណាន គឺជាទឹកដីសន្យា (សូមមើល ចទ ១២:៩ យស ១:១៣ និងការពន្យល់២១:៤៤) ។

**៦៣:១៥** *ទីលំនៅនៃសេចក្តីបរិសុទ្ធ* សូមមើល ៦:១ ។ *សេចក្តីខ្មីឃ្មាត* សូមមើល ៩:៧ និងការពន្យល់ ។ *សេចក្តីកន្លែងក្នុងព្រះហឫទ័យ និងសេចក្តីមេត្តាករុណារបស់ទ្រង់* សូមប្រៀបធៀប ១១:៨ ។

**៦៣:១៦** *ព្រះវរបិតា* សូមមើល ៦៤:៨ ចទ ៣២:៦ អ័ប្រាហាំមិនបានស្គាល់យើងខ្ញុំ ហើយពួកអ៊ីស្រាអែលមិនព្រមទទួលស្គាល់ សូម្បីតែឪពុកខាងសាច់ឈាមក៏បានបោះបង់ចោលយើងទេ (សូមមើល ៤៩:១៤–១៥ និងការពន្យល់) ។

**៦៣:១៧** *ធ្វើឱ្យយើងខ្ញុំវង្វេងចេញ* គឺក្នុងរយៈពេលរាស្ត្រអ៊ីស្រាអែលបានទទួលការខាតបង់ (សូមមើល ៥៣:៦) ព្រះយេហូវ៉ាបានឱ្យពួកគេរសាត់ព្រាត់ ។ មានរឹងទទឹង គឺជាចិត្តរបស់មនុស្សដែលរឹងចំពោះព្រះអម្ចាស់ (សូមមើល ៦:១០ ទដ ៩៥:៨) គឺជាការប្រកាសពីព្រះយេហូវ៉ាពីលក្ខខណ្ឌរបស់មនុស្ស (សូមមើល ៦:១០ នក ៤៥:១ និងការពន្យល់) ។ *ពួកអ្នកបំរើ* គឺជាអ្នក ជំនឿទាំងអស់ (សូមមើល ៥៤:១៧ និងការពន្យល់) ។

**៦៣:១៨** *ពួកខ្មាំងសត្រូវ* មានដូចជាពួកបាប៊ីឡូន មើល ទដ ៧៤:៣–៨ (និងការពន្យល់) ។

**៦៤:១** *វែកផ្ទៃមេឃ* ផ្ទៃមេឃក៏បានប្រៀបធៀបនិងវាំងននទាំង១០ ។ ចំពោះឃ្លានេះដែលបង្ហាញពីការពណ៌នាបន្ថែមចំពោះឥទ្ធិពលនៃចក្រវាឡដែលសម្តែងឱ្យឃើញការយាងមករបស់ព្រះអម្ចាស់ ដើម្បីកាត់ទោស និងប្រោសលោះ សូមមើល ពច ៥:៤–៥ ទដ ១៨:៧–១៥ ១៤៤:៥ ណាហ ១:៥ ហាប ៣:៣–៧ និងការពន្យល់ ។

**៦៤:២** *បានស្គាល់ព្រះនាមទ្រង់* សូមមើល ៣០:២៧ ។

ប្រានញាប់ញ័រ[ង]នៅចំពោះទ្រង់ ៣នៅគ្រាដែលទ្រង់បាន
ធ្វើការគួរស្ញែងខ្លាច[ច] ដែលយើងខ្ញុំមិនបានមែចិត្តសោះ
នោះទ្រង់បានយាងចុះមក ហើយភ្នំទាំងប៉ុន្មានបានកក្រើក
ញ័រ[ឆ]នៅចំពោះទ្រង់ ៤ដ្បិតចាប់តាំងពីចាស់បុរាណមក
មនុស្សលោកមិនដែលឮ ក៏មិនដែលដឹងដោយសារត្រចៀក
ហើយភ្នែកមិនដែលឃើញព្រះឯណាក្រៅពីទ្រង់[ជ] ដែលធ្វើ
ការជំនួសអ្នកដែលសង្ឃឹមដល់ទ្រង់ឡើយ[ឈ] ៥ទ្រង់តែងតែ
ប្រោសដល់អ្នកណាដែលមានចិត្តរីករាយ[ញ] ហើយប្រព្រឹត្ត
ដោយសុចរិត គឺដល់ពួកអ្នកដែលនឹកចាំពីទ្រង់ក្នុងអស់ទាំង
ផ្លូវរបស់ទ្រង់ មើល ទ្រង់បានមានសេចក្ដីក្រោធ[ដ] ដោយ
ព្រោះយើងខ្ញុំបានធ្វើបាប យើងខ្ញុំបាននៅជាប់ក្នុងអំពើទាំង
នោះ ជាយូរមកហើយ ដូច្នេះ យើងខ្ញុំនឹងបានសង្គ្រោះឬ
៦ដ្បិតយើងខ្ញុំទាំងអស់គ្នា បានត្រឡប់ទៅដូចជាមនុស្សដែល
មិនស្អាត[ឋ] ហើយអស់ទាំងអំពើសុចរិត[ឌ]របស់យើងខ្ញុំ ក៏ដូច
ជាអាវកខ្វក់ហើយ យើងខ្ញុំរាល់គ្នាស្វិត ក្រៀមទៅដូចជា
ស្លឹកឈើ[ឍ] ហើយអំពើទុច្ចរិតរបស់យើងខ្ញុំ ក៏ផាត់យកយើង
ទៅដូចជាខ្យល់[ណ] ៧ឥតមានអ្នកណាមួយ[ត] ដែលអំពាវនាវ
ដល់ព្រះនាមទ្រង់[ថ] ឬដែលដាស់តឿនខ្លួនឯង ឱ្យចាប់តោង
ទ្រង់ឡើយ ដ្បិតទ្រង់បានគេច[ទ]ព្រះភក្ត្រចេញ ពីយើងខ្ញុំ
ហើយ ក៏បានឱ្យយើងខ្ញុំរលាយទៅ[ធ] ដោយសារអំពើទុច្ចរិត
របស់យើងខ្ញុំផង ។
៨តែឥឡូវនេះ ឱព្រះយេហូវ៉ាអើយ ទ្រង់ជាព្រះវរបិតា

**៦៤:៣** ច ទដ ៦៥:៥ ឆ ទដ ១៨:៧ **៦៤:៤** ជ អស ៤៣:១០–១១ ឈ អស ៣០:១៨ ១កថ ២:៩ **៦៤:៥** ញ អស ២៦:៨ ដ អស ១០:៤ **៦៤:៦** ឋ លវ ៥:២ ១២:២ ឌ អស ៤៦:១២ ៤៨:១ ឍ ទដ ១:៣ ៩០:៥–៦ ណ ទដ ១:៤ យរ ៤:១២ **៦៤:៧** ត អស ៤១:២៨ ៥៩:៤ ៦៣:៥ យរ ៨:៦ អគ ២២:៣០ ថ ទដ ១៤:៤ ទ ចទ ៣១:១៨ អស ១:១៥ ៥៤:៨ ធ អស ៩:១៨ អគ ២២:១៨–២២ **៦៤:៨** ន នក ៤:២២ យរ ៣:៤ ប អស ២៩:១៦ រម ៩:២០–២១ ផ យប ១០:៣ អស ១៩:២៥ **៦៤:៩** ព អស ៥៤:៨ ៥៧:១៧ ៦០:១០

នៃយើងខ្ញុំ[ន] យើងខ្ញុំរាល់គ្នាជាដីឥដ្ឋ ហើយទ្រង់ជាជាង
ស្មូន[ប] យើងខ្ញុំជាស្នាដៃនៃព្រះហស្តទ្រង់ទាំងអស់គ្នា[ផ] ៩ឱ
ព្រះយេហូវ៉ាអើយ សូមទ្រង់កុំក្រោធជាខ្លាំងឡើយ[ព] ក៏សូម
កុំនឹកចាំពីសេចក្ដីទុច្ចរិត[ភ]ជាដរាបដែរ សូមមើល សូមទ្រង់
ពិចារណាថា យើងខ្ញុំរាល់គ្នាសុទ្ធតែជារាស្ត្ររបស់ទ្រង់[ម]
១០អស់ទាំងទីក្រុង[យ]បរិសុទ្ធរបស់ទ្រង់បានត្រឡប់ជាទីចោល
ស្ងាត់ហើយ[រ] ក្រុងស៊ីយ៉ូនបានត្រូវចោលស្ងាត់ ឯក្រុង
យេរូសាឡិមក៏ត្រូវខូចបង់ទៅ ១១ព្រះវិហារដ៏បរិសុទ្ធ
ហើយរុងរឿងរបស់យើងខ្ញុំ[ល] ជាកន្លែងដែលពួកឰយុកោ
នៃយើងខ្ញុំបានសរសើរដល់ទ្រង់ នោះត្រូវគេដុតចោល
ហើយ អស់ទាំងកន្លែង ជាទីពេញចិត្ត[វ]របស់យើងខ្ញុំ ក៏ត្រូវ
ខូចអស់ទៅដែរ ១២ឱព្រះយេហូវ៉ាអើយ ចុះដែលកើតមាន
ការយ៉ាងដូច្នេះ តើទ្រង់នឹងនៅតែអត់សង្កត់ព្រះហឫទ័យឬ
អី[ស] តើទ្រង់នឹងនៅតែស្ងៀម[ហ] ហើយធ្វើទុក្ខដល់យើងខ្ញុំជា
ខ្លាំងទៅទៀតឬ ។

## ការជំនុំជម្រះ និងសេចក្ដីសង្គ្រោះ

**៦៥** ១អញបានតបឆ្លើយនឹងពួកអ្នក ដែលមិនបានសួររក
អញ ហើយពួកអ្នកដែលមិនបានស្វែងរកអញ[ក] នោះអញ

បទ ៥:២២ ភ អស ៤៣:២៥ ម ទដ ១០០:៣ អស ៥១:៤ **៦៤:១០** យ ទដ ៧៨:៥៤ អស ១:២៦ រ ចទ ២៩:២៣ **៦៤:១១** ល លវ ២៦:៣១ ២ពវ ២៥:៩ ទដ ៧៤:៣–៧ បទ ២:៧ វ ខ.១០–១១ បទ ១:៧,១០ **៦៤:១២** ស លប ៤៣:៣១ ទដ ៧៤:១០–១១ ហ នអ ៤:១៤ ទដ ៥០:២១ ៨៣:១ **៦៥:១** ក ហស ១:១០ រម ៩:២៤–២៦ ១០:២០

**៦៤:៣** *បានធ្វើការគួរស្ញែងខ្លាច* មើល ទដ ៦៦:៣,៥–៧ នឹងការពន្យល់ ។

**៦៤:៤** *មិនដែលឃើញព្រះឯណាក្រៅពីទ្រង់* សូមមើល ៤៣:១១ និងការពន្យល់ ។ *សង្ឃឹមដល់ទ្រង់ឡើយ* សូមមើល ៣០:១៨ និង ៤០:៣១ និងការពន្យល់ផង ។

**៦៤:៥** *ប្រព្រឹត្តដោយសុចរិត* សូមមើល ៥៦:១ ។ *ទ្រង់មានសេចក្ដីក្រោធ* សូមមើល ៩:១២,១៧,២១ និងការពន្យល់ ។

**៦៤:៦** *មិនស្អាត* គឺមានសណ្ឋានជាមនុស្សមិនស្អាត(សូមមើល ៦:៥ និងមើលការពន្យល់ លវ ៤:១២ ១១:១២ ១៣:៤៥–៤៦ ប្រៀបធៀបសេចក្ដីផ្ដើមចំពោះព្រះគម្ពីរលេវីវិន័យជារឿងនិយាយពីទេវសាស្ត្រ ។ *អំពើសុចរិត* សូមមើល ៥៧:១២ និងការពន្យល់អាវកខ្វក់ហើយ គឺប្រភេទសម្លៀកបំពាក់ដែលពួកស្ត្រី បានជាពាក់ក្នុងពេលនាងកំពុងស្ថិតក្នុងភាពមិនស្អាត (សូមមើល លវ ១៥:១៩–២៤ អគ ៣៦:១៧) ។ *ស្វិតក្រៀមទៅដូចជាស្លឹកឈើ* ក៏សូមមើល ក្នុង ១:៣០ ។ *ទៅដូចជាខ្យល់* ដែលបក់អង្គាមទៅឆ្ងាយ (សូមមើល ១៧:១៣ ៤០:២៤ ទដ ១:៤ និងការពន្យល់) ។

**៦៤:៧** *ឥតមានអ្នកណាមួយដែលអំពាវនាវដល់ព្រះនាមទ្រង់* តែព្រះយេហូវ៉ាចងឱ្យយើងអធិស្ឋានទៅរកទ្រង់ក្នុងគ្រាដែលមានភាពវេទនា (សូមមើល (.៧:១៧) ។ ពាក្យថា *ដ្បិតទ្រង់បានគេចព្រះភក្ត្រចេញ* សូមមើល ១:១៥ និងការពន្យល់ ។

**៦៤:៨** *ព្រះវរបិតា* សូមមើល ៦៣:១៦ និងការពន្យល់ ។ ពាក្យថា *ជាដីឥដ្ឋ . . . ជាងស្មូន* សូមមើល ២៩:២៦ និងការពន្យល់ ។ *យើងខ្ញុំជាស្នាដៃព្រះហស្តទ្រង់ទាំងអស់គ្នា* សូមមើល ៦០:១ និងការពន្យល់ ។

**៦៤:៩** *កំក្រោធជាខ្លាំង* សូមប្រៀបធៀបពីព្រះបន្ទូលសន្យាដែលទ្រង់ឈប់ក្រោធខឹងតទៅទៀត ៥៤:៧–៨ (សូមមើលការពន្យល់ដែរ) ។ ពាក្យថា *កុំនឹកចាំពីសេចក្ដីទុច្ចរិត* សូមមើល ៤៣:២៥ និងការពន្យល់ យរ ៣១:៣៤ មីក ៧:១៨ ។ ជារាស្ត្ររបស់ផងទ្រង់ សូមមើល ៦៣:១៧–១៩ ទដ ៧៩:១៣ ។

**៦៤:១០** *ទីក្រុងបរិសុទ្ធ* ការមានភាពបរិសុទ្ធ ព្រោះស្រុកអ៊ីស្រាអែលជា "ទឹកបរិសុទ្ធ" (សក ២:១២ ប្រៀបធៀប ទដ ៧៨:៥៤) ។ ឯក្រុងយេរូសាឡិមតាមធម្មតាគេនិយមហៅថាជាទី "ក្រុងបរិសុទ្ធ"(សូមមើល ៤៨:២ និងការពន្យល់) ។ *ក្រុងស៊ីយ៉ូនបានត្រូវចោលស្ងាត់ ឯក្រុងយេរូសាឡិមក៏ត្រូវខូចបង់ទៅ* សូមមើល ១:៧–៩ និងការពន្យល់ ៦:១១ យរ ១២:១១ ។

**៦៤:១១** *ព្រះវិហារដ៏បរិសុទ្ធ ហើយរុងរឿងរបស់យើងខ្ញុំ* សូមមើល ៦០:៧ ៦៣:១៥ ។ *ត្រូវគេដុតចោល* គឺជារាស្ត្ររបស់ទ្រង់ ដូចជាលោកអេសាយត្រូវបានពួកខ្មាំងជាន់ឈ្លីធ្វើបាប ។ សូមមើល ៦៣:១៨ និងការពន្យល់ ។

**៦៤:១២** សូមមើល ៤២:១៤ ៥៧:១១ ៦២:១,៦–៧ និងការពន្យល់ ។

**៦៥:១–៦៦:២៤** ជំពូកទាំងនេះបានបង្ហាញពីសេចក្ដីបញ្ចប់យ៉ាងច្បាស់ ដូចជាជំពូក ៤០–៦៦ ។

បានឱ្យគេប្រទះឃើញអញវិញ អញបាននិយាយដល់
សាសន៍១[ខ] ដែលមិនបានហៅតាមឈ្មោះអញថា[គ] មើល
នេះអញហើយ មើល នេះអញហើយ ២រាល់តែថ្ងៃអញ
បានហុចដៃទៅចង់ទទួលពួកអ្នកបះបោរ[ឃ] ជាពួកអ្នក
ប្រព្រឹត្តតាមផ្លូវដែលមិនល្អ តាមតែគំនិត[ង]របស់ខ្លួនគេ ៣ជា
ជនជាតិ ដែលបណ្តាលឱ្យអញខឹងនៅចំពោះមុខជានិច្ច[ច]
ដោយគេថ្វាយយញ្ញបូជានៅក្នុងសួនច្បារ[ឆ] ហើយដុត
កំញាន[ជ]នៅលើអាសនាធ្វើពីឥដ្ឋ ៤គេអង្គុយនៅកណ្តាល
ផ្នូរខ្មោច[ឈ] ហើយស្នាក់នៅកន្លែងលាក់កំបាំង គេស៊ីសាច់
ជ្រូក[ញ] ហើយមានសំឡគួរឱ្យខ្ពើមនៅក្នុងឆ្នាំងរបស់គេ
៥ក៏ពោលថា ចូរឈរនៅទីនោះដោយខ្លួនទៅ កុំឱ្យមកជិត
អញឡើយ ដ្បិត អញបរិសុទ្ធ[ដ]ជាងឯង ពួកយ៉ាងនោះជា
ផ្សែង[ឋ]នៅក្នុងរន្ធច្រមុះអញ គឺជាភ្លើងដែលឆេះជានិច្ច
៦មើល អំពើទាំងនោះបានកត់ទុកនៅចំពោះអញហើយ
អញមិនព្រមនៅស្ងៀមឡើយ[ឌ] អញនឹងសង[ឍ]ដល់គេ អើ
អញនឹងដាក់សំណងនោះ នៅលើដើមទ្រូង[ណ]របស់គេផង
៧គឺជាអំពើទុច្ចរិត[ត]របស់ឯងរាល់គ្នា ហើយនឹងអំពើទុច្ចរិត
របស់ពួកឰយុកោឯងផង[ថ] ជាការដែលឯងរាល់គ្នាបានដុត
កំញាននៅលើអស់ទាំងភ្នំធំ ហើយបានប្រមាថអញនៅ
លើភ្នំតូចទាំងប៉ុន្មាន[ទ] ដូច្នេះ អញនឹងវាស់អំពើដែលគេបាន
ប្រព្រឹត្តពីដើមទាំងនោះ[ធ] ដាក់នៅដើមទ្រូងគេជាពិត នេះ

**៦៥:១** ខ រម ៩:៣០
អភ ២:១២
គ ទដ ៤៣:៧
**៦៥:២** ឃ ទដ ៧៨:៨
អស ១:២,២៣ រម
១០:២១ ង ទដ
៨១:១១–១២ សភ
២៤:២ អស ៦៦:១៨
**៦៥:៣** ច យប ១:១១
ឆ អស ១:២៩
ជ លវ ២:២ យរ
៤១:៥ ៤៤:១៧
អគ ២៣:៤១
**៦៥:៤** ឈ លវ
១៩:៣១ អស ៨:១៩
ញ លវ ១១:៧
**៦៥:៥** ដ ទដ ៤០:៤
មថ ៩:១១ លក
៧:៣៩ ១៨:៩–១២
ឋ សភ ១០:២៦
**៦៥:៦** ឌ ទដ ៥០:៣
ឍ ២រប ៦:២៣ អស
៥៩:១៨ យរ ១៦:១៨
ណ ទដ ៧៩:១២ អគ
៩:១០ លក ៦:៣៨
**៦៥:៧** ត អស
២២:១៤ ថ នក
២០:៥ យរ ៣២:១៨

ជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
៨ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា កាលណារក
បានថ្លៃទំពាំងបាយជូរ[ន]១ចង្កោមមានទឹកពេញ ហើយមាន
គេហាមថា កុំបំផ្លាញឡើយ ដ្បិតជាផ្លែមានពរហើយ គឺ
យ៉ាងនោះ ដែលអញនឹងប្រព្រឹត្ត ចំពោះពួកអ្នកបំរើរបស់
អញទាំងប៉ុន្មានដែរ[ប] ដើម្បីមិនឱ្យគេត្រូវបំផ្លាញ់អស់រលីង
ឡើយ ៩អញនឹងបង្កើតជំនួរវង្ស១[ផ] ចេញពីយ៉ាកុបមក
ហើយឱ្យ មានពួក១ ចេញពីយូដាមក ដែលនឹងគ្រងបាន[ព]
ស្រុកភ្នំ របស់អញទុកជាមរដក ពួកអ្នកបំរើតាំង[ភ]របស់អញ
នឹងទទួលបានស្រុកនោះ ហើយពួកអ្នកបំរើរបស់អញនឹង
អាស្រ័យនៅឯនោះផង[ម] ១០នោះវាលសារ៉ុន[យ]នឹងបាន
សំរាប់ជាទីឃ្វាលហ្វូងចៀម[រ] ហើយច្រកភ្នំអាកោរ[ល]ជា
កន្លែងឱ្យហ្វូងគោដេកនៅ ដល់ពួករាស្ត្ររបស់អញដែល
បានស្វែងរក[វ]អញ ១១តែឯងរាល់គ្នាដែលបោះបង់
ចោល[ស]ព្រះយេហូវ៉ា គឺជាពួកអ្នកដែលភ្លេចភ្នំបរិសុទ្ធរបស់
អញ[ហ] ហើយក៏រៀបអាសនា១ថ្វាយដល់ព្រះមានលាភ ព្រម

ទ អស ៥៧:៧ ធ សភ ១០:២៤ អស ១០:១២ **៦៥:៨** ន អស ៥:២ ប អស ៥៤:១៧ **៦៥:៩** ផ អស ៤៥:១៩ ព ជន ៣៤:១៣ អស ៦០:២១ យរ ៥០:១៩ អម ៩:១១–១៥ ភ អស ១៤:១ ម អស ៣២:១៨ **៦៥:១០** យ ១រប ២៧:២៩ អស ៣៥:២ កច ៩:៣៥ រ យរ ៣១:១២ ៣៣:១២ អគ ៣៤:១៣–១៤ ល យស ៧:២៦ វ អស ៥១:១ **៦៥:១១** ស ចទ ២៨:២០ ២៩:២៤–២៥ ៣២:១៥ អស ១:២៨ យរ ២:១៣ ១៩:៤ ហ ចទ ៣៣:១៩ ទដ ១៣៧:៥

**៦៥:១–២** *អញបានតបឆ្លើយនិងពួកអ្នក* រម ១០:២០–២១ ក៏សូមមើលការពន្យល់ ៦:៩–១០ ។

**៦៥:១** *ដែលមិនសួររកអញ . . . មិនបានស្វែងរកអញ* ព្រះយេហូវ៉ាបានឆ្លើយតបនូវសេចក្តីអធិស្ឋានរបស់លោកអេសាយ គឺខណៈពេលពួករាស្ត្រអ៊ីស្រាអែលពុំបាននៅគៀកនិងទ្រង់ ។ ទោះពេលខ្លះគេក៏ស្វែងរកទ្រង់ដោយប្រព្រឹត្តក្នុងផ្លូវសុចរិតក៏ដោយ(សូមមើល ៥៥:៦ ៥៨:២ និងការពន្យល់) ។ ដែលមិនបានហៅតាមឈ្មោះអញ(សូមមើល ៥៤:៧ ៥៨:២ និងការពន្យល់) មើលនេះអញហើយ សូមមើល ៥៨:៩ ។

**៦៥:៣** *បណ្តាលឱ្យអញខឹង* គឺដោយព្រោះទង្វើរបស់មនុស្សដែលថ្វាយបង្គំរូបព្រះ(សូមមើល ពច ២:១២–១៣ និងការពន្យល់) ។ *ចំពោះមុខជានិច្ច* (សូមមើលប្រៀបធៀប ៣:៨–៩) ។ *ក្នុងសួនច្បារ* សូមមើល ១:២៩ និងការពន្យល់ ។ ពាក្យថា *ដុតកំញាន* គឺមានក្នុងពេលសម្រាប់ថ្វាយបង្គំព្រះមហាក្សត្រនៃស្ថានសួគ៌ (សូមមើល យរ ៤៤:១៧–១៩ និងការពន្យល់) ។

**៦៥:៤** *គេអង្គុយនៅកណ្តាលផ្នូរខ្មោច* គឺជាគ្រូអន្ទោងខ្មោច ខាបព្រលឹងខ្មោច (សូមមើល ៨:១៩ និងការពន្យល់) ។

**៦៥:៥** *ត្បិតអញបរិសុទ្ធជាងឯង* គឺជាពួកសាសន៍ដទៃដែលមានប្រពៃណីទំនៀមទម្លាប់ ហើយពួកគេគិតថា គេមានលក្ខណៈពិសេស ឬមានអំណាចជាងសាសន៍ផ្សេងៗទៀត ។ (សូមប្រៀបធៀបការប្រព្រឹត្តរបស់ពួកផារ៉ាស៊ីក្នុង មថ ៩:១១ លក ៧:៣៩ ១៨:៩–១២) ។

**៦៥:៦** *អញមិនព្រមស្ងៀមឡើយ* គឺវាឆ្លើយតបនិងជំពូក ៦៥:១២ ។ *សងដល់គេ* សូមមើល ៥៩:១៨ និងការពន្យល់ ។

**៦៥:៧** *បានដុតកំញាននៅលើអស់ទាំងភ្នំធំ* គេធ្វើដូច្នេះដើម្បីថ្វាយតឧទ្ទិសទៅដល់ព្រះបាលនៅឯទីខ្ពស(មើល ៥៧:៧ ហស ២:១៣ និងការពន្យល់) ។ *បានប្រមាថអញ* សូមមើល អគ ២០:២៧–២៨ ។

**៦៥:៨** *១ចង្កោមមានទឹកពេញ* ក៏មានរាស្ត្រអ៊ីស្រាអែលដែលជាចំការទំពាំងបាយជូរដែលបង្កើតផលអាក្រក់(៥:២,៤,៧) ។ *ពួកអ្នកបំរើរបស់អញ* សូមមើល ឧ.៩,១៣–១៤ ៥៤:១៧ និងការពន្យល់ ។ ឯតាមសេចក្តីពន្យល់នៅទីនេះ ពួកអ្នកបំរើរបស់ព្រះយេហូវ៉ា ក៏មានន័យស្មើ និងពួកសំណល់របស់ព្រះ (សូមមើល ១:៩ និងការពន្យល់ ។

**៦៥:៩** *ជំនួរវង្ស* សូមមើល យរ ៣១:៣៦ និងការពន្យល់ ។ *យ៉ាកុបមក . . . យូដាមក* គឺសំដៅលើនគរផ្នែកខាងជើង និងផ្នែកខាងត្បូង ។ *គ្រងបានស្រុកភ្នំរបស់អញទុកជាមរដក* មើល ៤៩:៨ ៦០:២១ និងការពន្យល់ ។ ពាក្យថា *ភ្នំ* គឺសំដៅទៅលើទឹកដីស្រុកទាំងមូល ឬក៏សំដៅទៅលើប្រទេសទាំងមូល សូមមើល ឧ.១ ៥១:១ និងការពន្យល់ ។

**៦៥:១១** *បោះបង់ចោលព្រះយេហូវ៉ា* សូមមើល ១:៤ ។ *ភ្នំបរិសុទ្ធ* មើល ២:២–៤ និងការពន្យល់ ។ *ហើយរៀបអាសនា . . . ចាក់ស្រាពេញពែង* គឺជាអាហារ និងភេសជ្ជៈដើម្បីឧទ្ទិសថ្វាយទៅដល់ពួកទេវតា ។ សូមមើលការពន្យល់ ៥:២២ ប្រៀបធៀប ឧ.៥ យរ ៧:១៨ និងការពន្យល់ ។ *ថ្វាយ*

ទាំងចាក់ស្រា[ឃ]ពេញពែង ថ្វាយដល់ព្រះវាសនា ១២អញនឹង
ឱ្យឯងរាល់គ្នាមានវាសនាជាដាវវិញ[អ] ហើយទាំងអស់គ្នា
នឹងត្រូវឱនទៅ ឱ្យគេកាប់សំឡាប់[ក] ពីព្រោះកាលអញបាន
ហៅនោះឯងរាល់គ្នាមិនបានឆ្លើយសោះ[ខ] ហើយកាលអញ
បាននិយាយ នោះឯងរាល់គ្នាមិនបានឮឡើយ[គ] គឺឯងរាល់
គ្នាបានប្រព្រឹត្តអំពើដែលអាក្រក់នៅភ្នែកអញ ហើយបាន
រើសយករបស់ដែលអញមិនចូលចិត្តវិញ[ឃ] ។
១៣ហេតុនោះ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូល
ដូច្នេះថា មើល ពួកអ្នកបំរើអញនឹងបានស៊ី[ង] តែឯងរាល់
គ្នានឹងត្រូវឃ្លាន[ច] មើល ពួកអ្នកបំរើអញនឹងបានផឹក[ឆ] តែ
ឯងរាល់គ្នានឹងត្រូវស្រេក[ជ] មើល ពួកអ្នកបំរើអញនឹងអរ
សប្បាយ[ឈ] តែឯងរាល់គ្នានឹងត្រូវខ្មាស[ញ] ១៤មើល ពួកអ្នក
បំរើអញនឹងច្រៀង[ដ]ដោយមានចិត្តអំណរ តែឯងរាល់គ្នា
នឹងស្រែកឡើង[ឋ] ដោយមានចិត្តព្រួយ ហើយនឹងទ្រហោយំ
ដោយមានវិញ្ញាណគ្រាំគ្រាវិញ ១៥ឯងរាល់គ្នានឹងបន្តឈ្មោះ
របស់ឯង ទុកជាទីផ្តាសាដល់ពួករើសតាំងរបស់អញ[ឌ]
ហើយព្រះអម្ចាស់យេហូវ៉ាទ្រង់នឹងសំឡាប់ឯងបង់ ទ្រង់នឹង
ដាក់ឈ្មោះផ្សេងទៀតឱ្យដល់ពួកអ្នកបំរើរបស់ទ្រង់[ឍ] ១៦បាន
ជាអ្នកណានៅផែនដី ដែលចង់បានពរ[ណ] នោះនឹងរកពរ
ដោយព្រះនៃសេចក្តីពិត[ត] ហើយអ្នកណានៅផែនដីដែល
ស្បថ នោះនឹងស្បថ[ថ]ដោយព្រះនៃសេចក្តីពិតដែរ ពីព្រោះ
សេចក្តីវេទនា[ទ]ពីជាន់មុនបានភ្លេចទៅហើយ ក៏បានកំបាំង
ពីភ្នែកអញផង ។

## ផ្ទៃមេឃ និងផែនដីថ្មី

១៧ដ្បិតមើល អញនឹងបង្កើតផ្ទៃមេឃថ្មី ហើយនឹង
ផែនដីថ្មី[ធ] ឯរបស់ពីមុនៗ នោះនឹងគ្មានអ្នកណានឹកចាំ
ទៀត ក៏មិនដែលចូលក្នុងគំនិតឡើយ[ន] ១៨ប៉ុន្តែត្រូវឱ្យឯង
រាល់គ្នាមានសេចក្តីអំណរ[ប] ហើយរីករាយឡើងជាដរាប
ចំពោះការដែលអញបង្កើតនោះ ដ្បិតមើល អញនឹងធ្វើឱ្យ
ក្រុងយេរូសាឡិម[ផ]បានជាទីរីករាយ ហើយប្រជាជនទាំង
ឡាយជាសេចក្តីអំណរ ១៩នោះអញនឹងមានសេចក្តីរីក
រាយ[ព]ចំពោះក្រុងយេរូសាឡិម និងសេចក្តីអំណរ[ភ]ចំពោះ
រាស្ត្រអញ រួចនៅក្នុងទីក្រុងនោះ នឹងលែងឮសំឡេងយំ
នឹងសំរែក[ម]ទៀតឡើយ ២០ក៏នឹងលែងមានកូនតូច[យ]ដែល
រស់នៅតែប៉ុន្មានថ្ងៃ ឬមនុស្សចាស់ដែលមិនបានរស់នៅឱ្យ

**៦៥:១១** ឡ អស ៥:២២
**៦៥:១២** អ អស ១:២០ ២៧:១ ក អស ៣០:២៥ ខ សភ ១:២៤–២៥ អស ៤១:២៨ ៦៦:៤ យរ ៧:២៧ គ ២របា ៣៦:១៥–១៦ យរ ៧:១៣ ១៣:១១ ២៥:៣ ២៦:៥ ឃ ទដ ១៤៩:៧ អស ១:២៤ ៦៦:៤ មីក ៥:១៥
**៦៥:១៣** ង អស ១:១៩ ច យប ១៨:១២ លក ៦:២៥ ឆ អស ៣៣:១៦ ជ អស ៣:១ ៤១:១៧ ឈ អស ៦០:៥ ៦១:៧ ញ អស ៤៤:៩
**៦៥:១៤** ដ ទដ ១០៩:២៨ សផ ៣:១៤–២០ យក ៥:១៣ ឋ អស ១៥:២ មថ ៨:១២ លក ១៣:២៨ **៦៥:១៥** ឌ ជន ៥:២៧ ទដ ១០២:៨ ឍ លប ៣២:២៨ វវ ២:១៧ **៦៥:១៦** ណ ចទ២៩:១៩ ត ទដ ៣១:៥ វវ ៣:១៤ ថ ទដ ៦៣:១១ អស ១៩:១៨ ទ យប ១១:១៦ **៦៥:១៧** ធ អស ៤១:២២ ៦៦:២២ ២កថ ៥:១៧ ២ពត ៣:១៣ ន អស ៤៣:១៨ យរ ៣:១៦ វវ ៧:១៧ **៦៥:១៨** ប ចទ ៣២:៤៣ ទដ ៩៨:១–៩ អស ២៥:៩ **៦៥:១៨** ផ វវ ២១:២ **៦៥:១៩** ព អស ៣៥:១០ ៦២:៥ ភ ចទ ៣០:៩ ម អស ២៥:៨ វវ ៧:១៧ **៦៥:២០** យ អស ១១:៨

*ដល់ព្រះវាសនា* គឺជាព្រះវាសនារបស់ពួកសាសន៍ដទៃដែលជាព្រះគ្រប់គ្រងលើជោគវាសនា សូមមើល យស ១១:១៧ ។

**៦៥:១២** *ដាវ* គឺគេបានធ្វើឡើងដើម្បីជាសត្រូវរបស់ព្រះ ក៏ដូចជាអេដំអញ្ចឹង (៣៤:៥–៦) តែប្រព្រឹត្តការអាក្រក់នៃពួកអ៊ីស្រាអែលបានទទួលការឈឺចាប់វេទនា (សូមមើល ១:២០ ៥៩:១៨ និងការពន្យល់ ៦៦:១៦) ។ ពាក្យថា *អញបានហៅឯងរាល់គ្នាមិនបានឆ្លើយសោះ* សូមមើល ៥០:២ ២កថ ២៤:១៩ និងការពន្យល់ ។ ពាក្យថា *បានរើសយករបស់ដែលអញមិនចូលចិត្តវិញ* គឺមានលក្ខណៈផ្ទុយពីពួកអ្នកកំរៀវ ក្នុង ៥៦:៤ ឯបន្ទាត់បួនចុងក្រោយក្នុង ខ.១២ ក៏បានបញ្ជាក់យ៉ាងច្បាស់ពីរឿងរ៉ាវនោះដែរ គឺក្នុង ៦៦:៤ ។

**៦៥:១៣** *បានស៊ី . . . បានផឹក* សូមមើល ៤១:១៧–១៨ ៤៩:១០ ពាក្យថា *ត្រូវឃ្លាន . . . ត្រូវស្រេក* សូមមើល ៥:១៣ ៨:២១ ។ *អរសប្បាយ* សូមមើល ៦១:៧ និងការពន្យល់ ៦៦:១៤ ។ ពាក្យថា *នឹងត្រូវខ្មាស* សូមមើល ៤២:១៧ ៤៤:៩,១១ ។

**៦៥:១៤** *ច្រៀងដោយមានចិត្តអំណរ* សូមមើល ៣៥:១០ ៥៤:១ និងការពន្យល់ ។ *មានវិញ្ញាណគ្រាំគ្រាវិញ* គឺពួកគេបានបដិសេធដល់ការប្រោសលោះពីព្រះ សូមមើល ៦១:១ និងការពន្យល់ ។

**៦៥:១៥** *ពួករើសតាំង* មើល ខ.៩ និងការពន្យល់ ។ *ទុកជាទីផ្តាសា* ដូចជាការបោះបោររបស់ពួកអ៊ីស្រាអែលនាំឱ្យផ្តាសា (មើល យរ ២៩:២២) ។ *ដាក់ឈ្មោះផ្សេងទៀត* មើលក្នុង ៦២:២ (មើលការពន្យល់ដែរ) ។

**៦៥:១៦** *អ្នកណានៅផែនដី ដែលចង់បានពរ* សូមមើល ៤៨:១ ចទ ២៩:១៩ *ព្រះនៃសេចក្តីពិត* គឺព្រះអម្ចាស់មានសេចក្តីពិតត្រង់ និងព្រះបន្ទូលសន្យា ។ ឯក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យ "សេចក្តីពិត" មានន័យថា អាម៉ែន (សូមមើល ២៧:១៥ រម ១:២៥ ១កថ ១៤:១៥–១៧ វវ ៣:១៤ និងការពន្យល់) ។ *ស្បថដោយ* សូមមើល ៤៥:២៣ ដែលមានលក្ខណៈផ្ទុយនិងការស្បថពួកដែលបានស្បថនិងព្រះបាល (សូមមើល យរ ១២:១៦) ។

**៦៥:១៧** *ផ្ទៃមេឃថ្មី ហើយនិងផែនដីថ្មី* សូមមើល ៦៦:២២ គឺបង្ហាញពីកិច្ចការថ្មី ដែលលោកអេសាយបានសន្យា (សូមមើល ៤២:៩ ៤៨:៦ ២ពត ៣:១៣ និងការពន្យល់) ។ *របស់ពីមុនៗ* គឺរឿងរ៉ាវតាមលំដាប់លំដោយពីមុនមក (វវ ២១:៤) ដែលមានទាំងការឈឺចាប់ និងការទុកព្រួយ ។

**៦៥:១៨** *មានសេចក្តីអំណរ ហើយរីករាយ* សូមមើល ៦៦:១០ ក៏សូមមីល ៥១:៣ និងការពន្យល់ ។ *ធ្វើឱ្យក្រុងយេរូសាឡិមបានជាទីរីករាយ* គឺដូចជាលោកយ៉ូហានបានផ្សារភ្ជាប់ទំនាក់ទំនងផ្ទៃមេឃថ្មី និងផែនដីថ្មីជាមួយនិងក្រុងយេរូសាឡិមថ្មី (វវ ២១:១–២) ។ គឺធ្វើឱ្យក្រុងយេរូសាឡិមមានភាពល្អប្រសើរឡើងវិញ បន្ទាប់ពីត្រូវគេបានបំបោះបង់ចោល ហើយនៅក្នុងនគររបស់ព្រះម៉ែស៊ី ក៏បង្ហាញឱ្យឃើញក្រុងយេរូសាឡិមដ៏អស្ចារ្យ សូមមើលការពន្យល់ ៥៤:១១–១២ ។

**៦៥:១៩** *សេចក្តីរីករាយ . . . សេចក្តីអំណរ* សូមមើល ៦២:៤–៥ និងការពន្យល់ ។ *សំឡេងយំ នឹងសំរែកទៀតឡើយ* មើល ២៥:៨ និងការពន្យល់ ៣៥:១០) ។

**៦៥:២០–២៥** សូមមើល ១១:៦–៩ និងការពន្យល់ ។

ពេញកំណត់អាយុតទៅទៀត[រ] ដ្បិតអ្នកណាដែលស្លាប់ក្នុង
អាយុ១០០ឆ្នាំ នោះគេនឹងរាប់ថាជាក្មេងទេ ហើយ មនុស្ស
បាបណាដែលរស់ដល់ត្រឹម១០០ឆ្នាំ នោះនឹងត្រូវបណ្តាសា
វិញ ២១ គ្រានោះ មនុស្សនឹងសង់ផ្ទះ[ល] ហើយនឹងអាស្រ័យនៅ
ផង ក៏នឹងដាំចំការទំពាំងបាយជូរ ហើយនឹងបរិភោគផល
ដែរ[វ] ២២ គេនឹងមិនសង់ រួចមានម្នាក់ទៀតអាស្រ័យនៅ[ស]
ឬដាំ រួចមានម្នាក់ទៀតបរិភោគផលនោះឡើយ ដ្បិតអាយុ[ហ]
របស់រាស្ត្រអញ នឹងបានវែងដូចជាអាយុនៃដើមឈើ[ឡ]
ហើយពួករើសតាំង[អ]របស់អញនឹងប្រើប្រាស់ ការដែលដៃ
គេធ្វើជាយឺនយូរទៅ ២៣ គេនឹងមិនខំធ្វើជាឥតប្រយោជន៍[ក]
ឬបង្កើតមកឱ្យតែបានត្រូវវិនាសទៅនោះឡើយ[ខ] ដ្បិតគេជា
ពូជនៃពួកដ៏មានពរ[គ]របស់ព្រះយេហូវ៉ា ព្រមទាំងកូន[ឃ]
ដែលគេបង្កើតទៅផង ២៤ គ្រានោះ មុនដែលគេ អំពាវនាវ[ង]
នោះអញនឹងតបឆ្លើយ[ច] ហើយកាលគេកំពុងតែចេញសំដី[ឆ]
នៅឡើយ នោះអញនឹងស្តាប់ដែរ ២៥ ឯឆ្កែព្រៃ និងកូន
ចៀម[ជ] វានឹងរកស៊ីជាមួយគ្នា ហើយសិង្ហនឹងស៊ីចំបើងដូច
ជាគោ[ឈ] ចំណែកពស់[ញ] វានឹងមានធូលីដីជាអហារ សត្វ
ទាំងឡាយនឹងមិនបៀតបៀន ឬបំផ្លាញអ្វីនៅគ្រប់ក្នុងស្រុក
ភ្នំបរិសុទ្ធរបស់អញទៀតឡើយ[ដ] នេះជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ។

## សេចក្តីជំនុំជម្រះ និងសេចក្តីសង្ឃឹម

**៦៦** ១ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ផ្ទៃមេឃ
ជាបល្ល័ង្ករបស់អញ[ក] ហើយផែនដីជាកំណល់កល់ជើងអញ[ខ]
ដូច្នេះ តើឯងរាល់គ្នានឹងសង់វិហារ[គ]យ៉ាងណាឱ្យអញ តើ
មានកន្លែងណាសំរាប់ជាទីសំរាកដល់អញ ២ ដ្បិតឯរបស់
ទាំងនេះ គឺដៃអញដែលបានបង្កើតមក[ឃ] ហើយគឺយ៉ាងនោះ
ដែលរបស់ទាំងនេះបានកើតមានឡើង នេះជាព្រះបន្ទូល
នៃព្រះយេហូវ៉ា ប៉ុន្តែអញនឹងយកចិត្តទុកដាក់ចំពោះមនុស្ស
យ៉ាងនេះវិញ គឺចំពោះអ្នកណាដែលក្រលំបាក ហើយ
មានចិត្តខ្ទេចខ្ទាំ[ង] ជាអ្នកដែលញ័រញាក់ ដោយឮពាក្យរបស់
អញ[ច] ៣ អ្នកណាដែលសំឡាប់គោ[ឆ] នោះដូចជាបានប្រហារ
ជីវិតមនុស្ស អ្នកណាដែលថ្វាយកូនចៀមទុកជាយញ្ញបូជា
នោះដូចជាបានបំបាក់កឆ្កែ អ្នកណាដែលថ្វាយដង្វាយ
ម្សៅ នោះដូចជាបានថ្វាយឈាមជ្រូក[ជ] អ្នកណាដែលដុត
កំញានថ្វាយ[ឈ] នោះក៏ដូចជាអ្នកដែលថ្វាយបង្គំដល់រូបព្រះ
ដែរ អើ អ្នកទាំងនោះបានរើសផ្លូវរបស់ខ្លួនគេ[ញ] ព្រលឹង
របស់គេក៏រីករាយ ចំពោះការគួរស្អប់ខ្ពើមរបស់ខ្លួនគេ
ហើយ[ដ] ៤ ឯអញ ក៏នឹងរើសសេចក្តីទំនាស់ចិត្តឱ្យគេ ហើយ
និងនាំសេចក្តីដែលគេស្ញែងខ្លាចមកលើគេវិញ[ឋ] ដ្បិតកាល
អញនិយាយ នោះគេមិនបានស្តាប់ឡើយ គឺគេបានធ្វើអំពើ
ដែលអាក្រក់[ឍ]នៅភ្នែកអញ ហើយបានរើសយករបស់ដែល
បានហៅ នោះគ្មានអ្នកណាតបឆ្លើយសោះ[ឪ] កាលអញបាន
អញមិនចូលចិត្តវិញ[ណ] ។

រ លប ៥:១–៣២ ១៥:១៥ សស ៨:១៣ សក ៨:៤ **៦៥:២១** ល អស ៣២:១៨ ៦១:៤ វ ២ពវ ១៩:២៩ អស ៣៧:៣០ អក ២៨:២៦ អម ៩:១៤ **៦៥:២២** ស ចទ ២៨:៣០ ហ ទដ ២១:៤ ៩១:១៦ ឡ ទដ ១:៣ ៩២:១២–១៤ អ អស ១៤:១ **៦៥:២៣** ក អស ៤៩:៤ ១កថ ១៥:៥៨ ខ ចទ ២៨:៣២,៤១ យរ ១៦:៣–៤ គ លប ១២:២ ចទ ២៨:៣–១២ ឃ អស ៤៤:៣ កច ២:៣៩ **៦៥:២៤** ង អស ៥៥:៦ មថ ៦:៨ ច យប ៨:៦ អស ៣០:១៩ សក ១០:៦ ឆ ដយ ៩:២០–២៣ ១០:១២ **៦៥:២៥** ជ អស ១១:៦ ឈ យប ៤០:១៥ ញ លប ៣:១៤ មីក ៧:១៧ ដ យប ៥:២៣ អស ២:៤ **៦៦:១** ក ២របា ៦:១៨ ទដ ២:៤ ៩:៧ មថ ២៣:២២ ខ ១ពវ ៨:២៧ មថ ៥:៣៤–៣៥ គ ២សយ ៧:៧ យហ ៤:២០–២១ កច ៧:៤៩ ១៧:២៤ **៦៦:២** ឃ អស ៥០:២៦ កច ៧:៥០ ១៧:២៤ ង អស ៥៧:១៥ មថ ៥:៣–៤ លក ១៨:១៣–១៤ ច អរ ៩:៤ **៦៦:៣** ឆ អស ១:១១ ជ លវ ១១:៧ ឈ លវ ២:២ ញ អស ៥៧:១៧ ដ ខ.១៧ ចទ ២៧:១៥ អគ ៨:៩–១៣ **៦៦:៤** ឋ សភ ១០:២៤ អស ១០:១២ ឪ ១សយ ៩:១៩ អស ៤១:២៨ ឍ ២ពវ ២១:២,៤, ៦ អស ៥៩:១២ ណ អស ៦៥:១២

**៦៥:២០** *អាយុ១០០ឆ្នាំ . . .រាប់ថាជាក្មេងទេ* គឺក៏ប្រៀបធៀបចំពោះអ័ដាម និងពួកពូជដំបូងរបស់គាត់មក សូមមើលតាមប្រវត្តិពង្សាវតានៅក្នុង លប (តែសូមមើលការពន្យល់ លប ៥:៥) ។

**៦៥:២១–២២** មានលក្ខណៈខុសនិងបណ្តាសារបស់លោកម៉ូសេ ដោយសារតែការមិនស្តាប់បង្គាប់ មើលក្នុង ចទ ២៨:៣០ ក៏សូមប្រៀបធៀបនិងភាពផ្ទុយគ្នាមួយចំនួនទៀតនៅក្នុង អម ៥:១១ ៩:១៤ ប្រៀបធៀប មីក ៦:១៥ ។

**៦៥:២១** *ដាំចំការទំពាំងបាយជូរ* សូមមើល ៦២:៨–៩ ។

**៦៥:២២** *អាយុនៃដើមឈើ* គឺប្រៀបធៀបនិងភាពបរិសុទ្ធក្នុង ទដ ១:៣ (សូមមើលការពន្យល់ដែរ) ៩២:១២–១៤ ។ *ពួករើសតាំង* សូមមើល ៤១:៨–៩ និងការពន្យល់ ។ ប្រៀបធៀប ទដ ៩១:១៦ ។

**៦៥:២៣** *មិនខំធ្វើឥតប្រយោជន៍* សូមមើល ៤៩:៤ និងការពន្យល់ ។ *ពូជនៃពួកដ៏មានពររបស់ព្រះយេហូវ៉ា* សូមមើល ៦១:៩ និងការពន្យល់ ។

**៦៥:២៤** *មុនដែលគេអំពាវនាវ នោះអញនឹងតបឆ្លើយ* សូមមើល ៣០:១៩ ៥៨:៩ ទដ ១១៨:៥ និងការពន្យល់ មថ ៦:៨ ។

**៦៥:២៥** *ឆ្កែព្រៃ . . . កូនចៀម . . . សិង្ហ* សូមមើល ១១:៦–៩ និងការពន្យល់សូមមើល លប ៣:១៤ និងការពន្យល់ ១១:៨–៩ ។

**៦៦:១** *បល្ល័ង្ក . . . កំណល់កល់ជើង* សូមមើល ៤០:២២ និងការពន្យល់ ។ *តើឯងរាល់គ្នានឹងសង់វិហារយ៉ាងណាឱ្យអញ* គឺស្តេចសាឡូម៉ូនទ្រង់យល់ដឹងយ៉ាងច្បាស់ថា ព្រះដ៏ធំលើសអស់ទាំងព្រះទ្រង់មិនអាចគង់នៅក្នុងព្រះវិហារដែលធ្វើដោយមនុស្សទេ (សូមមើលក ១ពវ ៨:២៧ និងការពន្យល់) ។

**៦៦:២** *ឯរបស់ទាំងនេះ គឺដៃអញដែលបានបង្កើតមក* សូមមើល ៤០:២៦ និងការពន្យល់ ។ សូមមើល ៥៧:១៥ និងការពន្យល់ ។

**៦៦:៣** សូមប្រៀបធៀបពាក្យសំដីប្រមាថរបស់លោកអេសាយ អំពីការថ្វាយយញ្ញបូជាដោយគ្មានប្រសិទ្ធភាព មើលក្នុង ១:១១–១៤ ។ *ដូចជាបានបំបាក់កឆ្កែ* ដែលគេចាត់ជាសត្វឆ្កែជាប្រភេទ "សត្វមិនស្អាត" ក៏មិនយកទៅថ្វាយជាយញ្ញបូជាទេ សូមប្រៀធៀបច្បាប់ពីការវាយបំបាក់កសត្វលា ក្នុង នក ១៣:១៣ ។ ពាក្យថា *ឈាមជ្រូក* សូមមើល ៦៥:៤ និងការពន្យល់ចំពោះសត្វឆ្កែ និងសត្វជ្រូកក៏បានបង្ហាញក្នុង មថ ៧:៦ ២បត ២:២២ ។ *ថ្វាយបង្គំដល់រូបព្រះ* សូមមើល ៤៤:១៩ និងការពន្យល់ ។ *ការគួរស្អប់ខ្ពើម* គឺជាពួករូបព្រះ (សូមមើល យរ ៤:១) ។

**៦៦:៤** *រើសសេចក្តីទំនាស់ចិត្តឱ្យគេ* សូមប្រៀបធៀប ៦៥:៧ ។ ពាក្យថា *ដ្បិតកាលអញ . . . អញមិនចូលចិត្តវិញ* គឺមានក្នុងបន្ទាត់ចុងក្រោយទាំងបួន សូម

៥ឯងរាល់គ្នាដែលញ័រញាក់ ចំពោះព្រះបន្ទូលនៃព្រះ
យេហូវ៉ាអើយ[ត] ចូរស្តាប់ព្រះបន្ទូលទ្រង់ចុះ ពួកបងប្អូន
របស់ឯងរាល់គ្នាដែលស្អប់[ថ]ឯង ជាពួកអ្នកដែលកាត់ឯង
រាល់គ្នាចេញ ដោយព្រោះឈ្មោះអញ គេបានពោលថា
ចូរឱ្យឯងរាល់គ្នាដំកើងព្រះយេហូវ៉ាឡើង ដើម្បីឱ្យយើង
បានឃើញសេចក្តីអំណររបស់ឯងផង ប៉ុន្តែគឺគេដែលដឹង
ត្រូវអៀនខ្មាសវិញ[ទ]
៦មានឮសូរអឺងកងពីទីក្រុងមកជា
សំឡេងដែលចេញពីព្រះវិហារ គឺជាសូរសៀង[ធ]នៃព្រះ
យេហូវ៉ា ដែលទ្រង់សងតប[ន]ដល់ពួកខ្មាំងសត្រូវរបស់ទ្រង់។
៧មុនដែលឈឺពោះ[ប] នោះបានសំរាលកូនមក មុន
ដែលកើតឈឺចាប់ នោះបានបង្កើតកូនប្រុស១ហើយ[ផ]
៨តើ
មានអ្នកណាដែលឮនិយាយពីការយ៉ាងនោះ តើអ្នកណា
ដែលបានឃើញ[ព]ឬ តើនឹងឱ្យស្រុក១កើតឡើងក្នុងថ្ងៃ[ភ]១
បានឬ តើនគរ១នឹងលេចចេញមកភ្លាម១រំពេចឬអី ដ្បិត
វេលាដែលក្រុងស៊ីយ៉ូនបានឈឺចាប់ នោះក៏បានសំរាល
កូនទាំងប៉ុន្មានមកភ្លាម[ម]
៩ព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរ
ថា តើអញនឹងនាំទៅដល់កំណត់ដែលត្រូវសំរាល[យ] ឥតធ្វើ
ឱ្យកើតមកផងឬ ព្រះនៃឯងទ្រង់ក៏មានបន្ទូលសួរថា ឯអញ
ដែលធ្វើឱ្យកើតមក តើអញនឹងបង្ខាំងផ្ទៃឬអី ។
១០ឱពួកអ្នកដែលស្រឡាញ់[រ]ក្រុងយេរូសាឡិមអើយ ចូរ
រីករាយ[ល]ឡើងជាមួយនឹងវា ហើយមានសេចក្តីអំណរ
ដោយព្រោះវាចុះ អស់អ្នកដែលយំទួញ[វ]នឹងទីក្រុងអើយ ចូរ
រីករាយឡើងដោយសេចក្តីអំណរចំពោះវាវិញ
១១ដើម្បីឱ្យ
ឯងរាល់គ្នាបានបៅដោះ[ស] ជាសេចក្តីកំសាន្តចិត្តរបស់វាឱ្យ
ឆ្អែត[ហ] ហើយឱ្យបានជញ្ជក់ទឹកដោះរបស់វា ព្រមទាំងចាប់
ចិត្តចំពោះសិរីល្អដ៏បរិបូររបស់វាផង[ឡ]
១២ដ្បិតព្រះយេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះថា មើល អញនឹងផ្សាយសេចក្តីសុខ[អ]
ឱ្យហូរទៅដល់វាដូចជាទន្លេ[ក] ព្រមទាំងសិរីល្អ[ខ]របស់អស់
ទាំងសាសន៍ ដូចជាទឹកជ្រោះដែលហូរលិចច្រាំងផង នោះ
ឯងរាល់គ្នានឹងជញ្ជក់បៅ វានឹងពរ[គ]ឯង ហើយថ្នមឯងនៅ
លើភ្លៅ
១៣អញនឹងកំសាន្តចិត្តឯង ដូចជាម្តាយដែលលួង
លោមកូន[ឃ] នោះឯងរាល់គ្នានឹងមានសេចក្តីកំសាន្តចិត្ត[ង]
ចំពោះក្រុងយេរូសាឡិមហើយ
១៤ឯងរាល់គ្នានឹងឃើញ
ហើយនឹងមានសេចក្តីអំណររីករាយ[ច]ក្នុងចិត្ត ឯឆ្អឹងឯង
រាល់គ្នា នោះនឹងបានស្រស់[ឆ]ដូចស្មៅខ្ចី ហើយព្រះហស្ត[ជ]
នៃព្រះយេហូវ៉ានឹងសំដែងចេញ ដល់ពួកអ្នកបំរើរបស់
ទ្រង់[ឈ] ហើយសេចក្តីខ្ញាល់[ញ]របស់ទ្រង់ នឹងសង្កត់លើអស់
ទាំងខ្មាំងសត្រូវផង ។
១៥ដ្បិតមើល ព្រះយេហូវ៉ាទ្រង់នឹងយាងមកនាំទាំងភ្លើង
មកជាមួយ[ដ] ហើយព្រះរាជរថ[ឋ]របស់ទ្រង់នឹងបានដូចជា
ខ្យល់កួច[ឌ] ដើម្បីនឹងសំរេចតាមសេចក្តីខ្ញាល់ដ៏សហសរបស់
ទ្រង់ និងតាមពាក្យស្តីបន្ទោស[ឍ]របស់ទ្រង់ ដោយសារ
អណ្តាតភ្លើង
១៦ពីព្រោះព្រះយេហូវ៉ាទ្រង់នឹងសំរេចតាម

**៦៦:៥** ត អរ ៩:៤ ថ ទដ ៣៨:២០ អស ៦០:១៥ យហ ១៥:២១ ទ អស ៤៤:៩ លក ១៣:១៧ **៦៦:៦** ធ ១សយ ២:១០ ទដ ៦៨:៣៣ ន លវ ២៦:២៨ អស ៦៥:៦ យអ ៣:៧ **៦៦:៧** ប អស ៥៤:១ ផ វវ ១២:៥ **៦៦:៨** ព អស ៦៤:៤ យរ ១៨:១៣ ភ អស ៤៩:២០ ម អស ៤៩:២១ **៦៦:៩** យ អស ៣៧:៣ **៦៦:១០** រ ទដ ២៦:៨ ល ចទ ៣២:៤៣ អស ២៥:៩ រម ១៤:១០ វ អស ៥៧:១៩ ៦១:២ **៦៦:១១** ស ជន ១១:១២ អស ៦០:១៦

ហ លប ៤៩:២៥ ឡ ជន ២៥:១ អស ២៥:៦ **៦៦:១២** អ ទដ ១១៩:១៦៥ អស ៩:៦ ក អស ៣៣:២១

ខ ទដ ៧២:៣ អស ៦០:៥ ៦១:៦ គ ជន ១១:១២ អស ៦០:៤ **៦៦:១៣** ឃ អស ៤៩:១៥ ១ថន ២:៧ ង អស ៤០:១ ២កថ ១:៤ **៦៦:១៤** ច អស ២៥:៩ ៦០:៥ យអ ២:២៣ ឆ ទដ ៧២:១៦ ជ អរ ៥:៥ អស ៤១:២០ ឈ អស ៥៤:១៧ ញ អស ១០:៥ ៣០:២៧ **៦៦:១៥** ដ អស ១:៣១ ៤២:២៥ ឋ ២ពវ ២:១១ ទដ ៦៨:១៧ ឌ ២ពវ ២:១ ឍ ចទ ២៨:២០ ទដ ៩:៥ ៣៩:១១

មើល ៦៥:១២ និងការពន្យល់ ។

**៦៦:៥** *ញ័រញាក់* សូមមើល ខ.២ ។ *ពួកបងប្អូនរបស់ឯង* គឺជារាស្ត្រអ៊ីស្រាអែល (សូមមើល កច ១១:១ និងាការពន្យល់) ។ ពាក្យថា *ចូរឱ្យឯងរាល់គ្នា . . . សេចក្តីអំណរ* សូមមើល ៥:២៩ ទដ ២២:៨ ។

**៦៦:៦** *ទីក្រុង* គឺជាទីក្រុងយេរូសាឡិម ។ *សងតបដល់ពួកខ្មាំងសត្រូវរបស់ទ្រង់* សូមមើល ៥៩:១៨ និងការពន្យល់ ៦៥:៦–៧ ។

**៦៦:៧** *មុនដែល . . . បង្កើតកូន* សូមមើល ៥៤:២ និងការពន្យល់ ក៏មានខណៈពេលដែលក្រុងស៊ីយ៉ូនមិនអាចមានកូន ។

**៦៦:៥** *ស្រុក១ . . . កើតឡើងក្នុងថ្ងៃតែ១* សូមមើល ៤៩:១៩–២០ និងការពន្យល់ ។

**៦៦:៩** *សំរាលឥតធ្វើឱ្យកើតមកផង* សូមមើល ៣៧:៣ និងការពន្យល់ ។

**៦៦:១០** *ចូររីករាយ . . . សេចក្តីអំណរ* សូមមើល ៦៥:១៨ និងការពន្យល់។ *អ្នកដែលស្រឡាញ់ក្រុងយេរូសាឡិមអើយ* ប្រៀបធៀប ទដ ១៣៧:៦ ។ *អស់អ្នកដែលយំទួញ* សូមមើល ៥៧:១៩ ៦១:២ និងការពន្យល់ ។

**៦៦:១១** *បានបៅដោះ . . . ជាសេចក្តីកំសាន្តចិត្ត* ក្នុង ៦០:១៦ (មើលការពន្យល់)គឺក្រុងយេរូសាឡិមកំពុងផឹកទឹកដោះរបស់ជាតិទាំងឡាយជាងនោះ ជាក្រុងយេរូសាឡិមដែលជាម្តាយ (ប្រៀបធៀប ខ.១២ ៤៩:២៣) ។

**៦៦:១២** *សេចក្តីសុខ . . . វាដូចជាទន្លេ* សូមមើល ៤៨:១៨ និងការពន្យល់ ។ សូមមើល ៦០:៥ និងការពន្យល់ ។ *ជាទឹកជ្រោះដែលហូរលិចច្រាំងផង* មានលក្ខណៈខុសនិងទឹកជំនន់នាំឱ្យហិនវិនាស ៨:៧–៨ ឬមើល ៤០:១១ ។

**៦៦:១៣** *សេចក្តីកំសាន្តចិត្ត ចំពោះក្រុងយេរូសាឡិមហើយ* សូមមើល ៤៩:១៣ និងការពន្យល់ ។ ប្រៀបធៀប ២កថ ១:៣–៤ ។

**៦៦:១៤** *សេចក្តីអំណររីករាយនៅក្នុងចិត្ត* សូមមើល ៦០:៥ ។ *ស្មៅខ្ចី* គឺជាតំណាងឱ្យភាពខ្សោយ សូមមើល ៣៧:២៧ និងការពន្យល់ ៥១:១២ មានលក្ខណៈខុសនឹង ៤៤:៤ ។ *ព្រះហស្តនៃព្រះយេហូវ៉ា* សូមមើលការប្រៀបធៀប អគ ៧:៩ ៨:៣១ ។ *ពួកអ្នកបំរើ* សូមមើល ៥៤:១៧ និងការពន្យល់ ។ *សេចក្តីខ្ញាស* សូមមើល ខ.១៥ ១៣:៣ និងការពន្យល់ ។

**៦៦:១៥** *ព្រះរាជរថ . . . ដូចជាខ្យល់កួច* មើល ៥:២៨ ២ពវ ២:១១ និងការពន្យល់ ៦:១៧ ទដ ៦៨:១៧ និងការពន្យល់ ។ *សេចក្តីខ្ញាល់* មើល ៣៤:២ ៤២:២៥ និងការពន្យល់ ។ *ពាក្យស្តីបន្ទោស* មើល ៥១:២០ និងការពន្យល់។

**៦៦:១៦** *ដាវ* សូមមើល ២៧:១ ៣៨:៨ ៣៥:៥–៦ និងការពន្យល់ ទដ ៧:១២–១៣ ។ *ប្រហារជីវិត* គឺថ្ងៃរបស់ព្រះយេហូវ៉ា (សូមមើលការពន្យល់

សេចក្ដីយុត្តិធម៌[ណ]ដល់អស់ទាំងមនុស្ស ដោយសារភ្លើង[ត]និង
ដាវ[ថ]របស់ទ្រង់ ដូច្នេះ ពួកអ្នកដែលព្រះយេហូវ៉ាទ្រង់នឹង
ប្រហារជីវិត[ទ] នោះនឹងមានជាច្រើន ១៧ឯពួកអ្នកដែល
ញែកខ្លួន ហើយជំរះខ្លួនចេញ សំរាប់ការថ្វាយបង្គំនៅក្នុង
សួនច្បារ[ធ] ហើយគោរពដល់រូបព្រះ១នៅកណ្ដាលនោះ
ព្រមទាំងស៊ីសាច់ជ្រូក[ន]និងកណ្ដុរ[ប] ជារបស់គួរខ្ពើមឆ្អើម
នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អ្នកទាំងនោះនឹងត្រូវ
វិនាស[ផ]ទៅជាមួយគ្នាទាំងអស់ ។

១៨អញស្គាល់អស់ទាំងអំពើ និងគំនិតរបស់គេហើយ[ព]
នឹងមានពេលវេលាមកដល់ ដែលអញនឹងប្រមូលអស់ទាំង
សាសន៍[ភ]គ្រប់ភាសា គេនឹងមូលមកឃើញសិរីល្អរបស់អញ[ម]
១៩អញនឹងតាំងទីសំគាល់[យ]១នៅកណ្ដាលពួកគេ ហើយចាត់
ពួកគេណាខ្លះដែលរួចខ្លួន[រ] ឲ្យទៅឯសាសន៍ដទៃ គឺទៅឯ
ស្រុកតើស៊ីស[ល] ស្រុកពូល និងស្រុកលូឌ[វ] ជាសាសន៍ដែល
ជំនាញធ្នូ ហើយស្រុកទូបាល[ស] និងស្រុកយ៉ាវ៉ាន[ហ] ហើយ
ទៅឯកោះ[ឡ]ទាំងប៉ុន្មាន ដែលនៅឆ្ងាយ ជាពួកអ្នកដែលមិន
ទាន់ឮនិយាយពីកិត្តិសព្ទរបស់អញ ឬឃើញសិរីល្អរបស់អញ
នៅឡើយ[អ] អ្នកទាំងនោះនឹងប្រកាសប្រាប់ពីសិរីល្អរបស់
អញ នៅកណ្ដាលសាសន៍ទាំងប៉ុន្មាន ២០គេនឹងបញ្ជូន[ក]ពួក
បងប្អូនរាល់គ្នាទាំងប៉ុន្មាន លើសេះ រទេះ អង្រឹងស្នែង
លាកាត់ ហើយលើអូដ្ឋ នាំចេញពីអស់ទាំងសាសន៍មក ទុក
ជាដង្វាយថ្វាយដល់ព្រះយេហូវ៉ា[ខ] គឺមកឯក្រុងយេរូសាឡិម
ជាភ្នំបរិសុទ្ធ[គ]របស់អញ ដូចជាពួកកូនចៅអ៊ីស្រាអែលធ្លាប់
យកដង្វាយរបស់គេ ដាក់ក្នុងភាជនៈ ដ៏ស្អាតមកឯព្រះវិហារ
នៃព្រះយេហូវ៉ាដែរ[ឃ] នេះឯងជាព្រះបន្ទូលនៃព្រះយេហូវ៉ា
២១ព្រះយេហូវ៉ាទ្រង់ក៏មានបន្ទូលថា អញនឹងយកពួកអ្នក
នោះខ្លះ តាំងឡើងជាសង្ឃ[ង] ហើយជាពួកលេវី ។

២២ដ្បិតដែលផ្ទៃមេឃថ្មី និងផែនដីថ្មី[ច] ដែលអញនឹង
បង្កើតឡើងនោះ នឹងស្ថិតស្ថេរនៅចំពោះអញជាយ៉ាង
ណាព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ពូជពង្សរបស់ឯង
និងឈ្មោះឯងរាល់គ្នា ក៏នឹងស្ថិតស្ថេរនៅយ៉ាងនោះដែរ[ឆ]
២៣គ្រានោះនឹងកើតមានដូច្នេះថា ចាប់តាំងពីថ្ងៃចូលខែ១
ដរាបដល់ថ្ងៃចូលខែ១ទៀត ហើយពីថ្ងៃឈប់សំរាក១[ជ]
ដរាបដល់ថ្ងៃឈប់សំរាក១ទៀត នោះគ្រប់មនុស្សទាំងអស់
នឹងមកក្រាបថ្វាយបង្គំ[ឈ]នៅចំពោះអញ នេះជាព្រះបន្ទូល
នៃព្រះយេហូវ៉ា ២៤គេនឹងចេញទៅមើលសាកខ្មោចរបស់
មនុស្សទាំងប៉ុន្មាន[ញ] ដែលបានបះបោរ[ដ]នឹងអញ ដ្បិតដង្កូវ
នៃខ្មោច[ឋ] ទាំងនោះនឹងមិនស្លាប់ឡើយ ហើយភ្លើងក៏មិន
ចេះរលត់[ឌ]ដែរ សាកខ្មោចទាំងនោះនឹងបានជាទីខ្ពើមឆ្អើម
ដល់អស់ទាំងមនុស្ស ។

**៦៦:១៦** ណ អស ១៣:៩,១១ យរ ២:៣៥ អគ ៣៦:៥ ត អស ៣០:៣០ អម ៧:៤ មឡ ៤:១ ថ អស ១:២០ ២៧:១ អគ ១៤:២១ ទ អស ១០:៤ **៦៦:១៧** ធ អស ១:២៩ ន លវ ១១:៧ ប លវ ១១:២៩ ផ ទដ ៣៧:២០ អស ១:២៨ **៦៦:១៨** ព សភ ២៤:២ អស ៦៥:២ ភ អស ២:៣ សក ១២:៣ ម នក ១៦:៧ អស ៥៩:១៩ **៦៦:១៩** យ អស ១១:១០ ៤៩:២២ មថ ២៤:៣០ រ ២ពវ ១៩:៣១ ល អស ២:១៦ វ យរ ៤៦:៩ អគ ២៧:១០ ស លប ១០:២ ហ យរ ៣១:១០ ដយ ១១:១៨ ឡ អស ១១:១១ អ ១របា ១៦:២៤ អស ២៤:១៥

**៦៦:២០** ក អស ១១:១២ យរ ២៤:២២ អគ ៣៤:១៣ ខ អគ ២:៦៦ គ ចទ ៣៣:១៩ អស ២:២ យរ ៣១:២៣ ឃ អស ៥២:១១ **៦៦:២១** ង នក ១៩:៦ ១ពត ២:៥,៩ **៦៦:២២** ច អស ៦៥:១៧ ហព ១២:២៦-២៧ ២ពត ៣:១៣ ឆ អស ៤៨:១៩ យហ ១០:២៧-២៩ ១ពត ១:៤-៥ **៦៦:២៣** ជ អគ ៤៦:១-៣ ឈ ទដ ២២:២៩ អស ១៩:២១ ៤៤:៥ វវ ១៥:៤ **៦៦:២៤** ញ ទដ ១១០:៦ ដ អស១:២ ឋ អស ១៤:១១ ឌ អស ១:៣១ មថ ២៥:៤១ មក ៩:៤៨

២:១១,១៧,២០ ប្រៀបធៀប អគ ៣៨:២១-២២) ។
**៦៦:១៧** *ឯពួកអ្នកដែលញែកខ្លួន ហើយជំរះខ្លួនចេញ* គឺតាមប្រពៃណីនៃសាសនានៃសាសន៍ដទៃ(ធៀបនឹង ២កថ ៣០:១៧)។ *សួនច្បារ* សូមមើល ១:២៩ និងការពន្យល់ ។ *សាច់ជ្រូក* សូមមើល ៦៥:៤ និងការពន្យល់ ។
**៦៦:១៨** *នឹងគំនិតរបស់គេ* មើល ៦៥:២ និងការពន្យល់ ។ *ប្រមូលអស់ទាំងសាសន៍គ្រប់ភាសា* ធៀបនឹង យអ ៣:២ និងការ ពន្យល់ និង សផ ៣:៨ សក ១២:៣ និងពន្យល់ ។ *សិរីល្អរបស់អញ* មើល ៣៥:២-៤ ៤០:៥ និងពន្យល់។
**៦៦:១៩** *ទីសំគាល់* គឺមានលក្ខណៈជាផ្លាកសញ្ញា ១១:១០,១១ (សូមមើលការពន្យល់ ៥:២៦ ប្រៀបធៀប ទដ ៧៤:៤) ប្រៀបធៀបចំពោះ "ទីសម្គាល់របស់កូនមនុស្ស" (មថ ២៤:៣០) គឺកាលដែលទ្រង់យាងមកលើកទី២ ។ *ពួកគេណាខ្លះដែលរួចខ្លួន* បន្ទាប់ពីមានការជំនុំជម្រះក្នុង ខ.១៦ ប្រៀបធៀប សក ១៤:១៦ ។ *ស្រុកតើស៊ីស* គឺពួកដែលរស់នៅផ្នែកខាងលិចស្រុកអេស៊ីព្ទ សូមមើល ២៣:៦ និងការពន្យល់ និងមើល ណហ ៣:៩ ។ *ស្រុកទូបាល* គឺជាទីទៅច្រើនទាក់ទងនិងស្រុកមែសេក (សូមមើល លប ១០:២ អគ ២៧:១៣ ៣៩:១ និងការពន្យល់) ។ វាអាចជាតំបន់ដែលស្ថិតនៅទិសខាងត្បូងឈាងខាងលិចសមុទ្រខ្មៅ ។ *កោះ* សូមមើល ១១:១១ និងការពន្យល់ ។ *ប្រកាសប្រាប់ពីសិរីល្អរបស់អញ* សូមមើល ៤២:១២ ១កថ ១៦:២៤ ។
**៦៦:២០** *បញ្ជូនពួកបងប្អូនឯងរាល់គ្នា* ឯពួកសាសន៍ដទៃក៏នាំពួកសំណល់ (សូមមើល ១១:១១-១២ ៤៩:២២ ៦០:៤ និងការពន្យល់) ។ *ភ្នំបរិសុទ្ធ* សូមមើល ២:២-៤ និងការពន្យល់ ។
**៦៦:២១** *ពួកអ្នកនោះខ្លះ* គឺសំដៅទៅលើសាសន៍យូដាដែលជឿព្រះ(មើល ៦១:៦ និងការពន្យល់) ឬសាសន៍ដទៃដែលមានចំណែកនៅក្នុងពួកជំនុំ ឬនគរនៃព្រះមែស៊ី(មើល ១ពត ២:៥,៩ និងការពន្យល់) ។
**៦៦:២២** *ផ្ទៃមេឃថ្មីនិងផែនដីថ្មី* សូមមើល ៦៥:១៧ និងការពន្យល់ ។ *ពូជពង្សរបស់ឯង និងឈ្មោះឯង* សូមមើល ៤៨:១៩ និងការពន្យល់ ។
**៦៦:២៣** *ថ្ងៃចូលខែ១* មើល ១:១៤ និងការពន្យល់ ។ *នោះគ្រប់មនុស្សទាំងអស់នឹងមកក្រាបថ្វាយបង្គំ* មើល ១៩:២១ សក ១៤:១៦ និងការពន្យល់ ។
**៦៦:២៤** ខនេះ គឺជាសេចក្ដីដកស្រង់ចេញពីគម្ពីរ មក ៩:៤៨(សូមមើលប្រែពីភាសាក្រិក គឺហ្គេហេណា (Gehenna)។ ជ្រលងហ៊ីម៉ូន (ជាភាសារហេព្រើគឺ គេហ៊ិនម៉ូន ជាឫសនៃពាក្យហ្គេហេណានៃភាសាក្រិក) គឺនៅភាគនារតីនៃក្រុងយេរូសាឡិម ហើយគេប្រៀននឹងស្ថាននរក(មើលការពន្យល់ មថ និងមើល នហ ១១:៣០ យរ ៧:៣១ និងការពន្យល់ ។ *សាកខ្មោច* សូមមើល ៥:២៥ ៣៤:៣ ។ *បានបះបោរ* សូមមើល ១:២ និងការពន្យល់ ២៤:២០ ។ *ដង្កូវនៃខ្មោចទាំងនោះ និងមិនស្លាប់ឡើយ* ពួកវានិងធ្វើ ទារុណកម្មដល់អស់កល្បជានិច្ច ។ មើល ១៤:១១ ៤៨:២២ ៥០:១១ ៥៧:២១ ។ *ភ្លើងក៏មិនចេះរលត់* មើល ១:៣១ និងការពន្យល់ មថ ៣:១២ ។

# ព្រះគម្ពីរយេរេមា

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

ព្រះគម្ពីរយេរេមា ជាកណ្ឌគម្ពីរដែលប្រមូលចងក្រងទុក ពីកិច្ចការរបស់ហោរាយេរេមា ដែលមានជីវិតផ្ទាល់ខ្លួននឹងការតស៊ូយ៉ាងខ្លាំងក្លាក្នុងការបង្ហាញឱ្យយើងឃើញយ៉ាងស៊ីជម្រៅ និងលំអិតជាងផ្នែកដទៃទៀតនៃគម្ពីរហោរា ឬគម្ពីរជាសេចក្ដីទំនាយនានា ។ ឯអត្ថន័យរបស់ឈ្មោះហោរានេះ ក៏មិនអាចបង្ហាញច្បាស់ដែរ ។ មានសេចក្ដីសន្និដ្ឋានរួមថាឈ្មោះនេះមានន័យថា "ព្រះយេហូវ៉ាដែលយើងលើកតម្កើង" និង "ទ្រង់តាំងឡើង ឬព្រះយេហូវ៉ាបានតាំងឡើង" ប៉ុន្តែ មានការសន្និដ្ឋានមួយទៀតថា ឈ្មោះនេះមានន័យថា "ព្រះយេហូវ៉ាក្រវែង" ក៏បង្កប់អត្ថន័យថា "បោះចោល" ហោរាទៅក្នុងពិភពលោកដែលជាសត្រូវ ឬថា "ទម្លាក់" ជាតិសាសន៍ទាំងឡាយទៅក្នុងការជំនុំជម្រះពីព្រះអម្ចាស់ ដោយព្រោះអំពើបាបរបស់គេ ។ ឯកិច្ចការបម្រើព្រះតាមរយៈពោលជាសេចក្ដីទំនាយរបស់ហោរាយេរេមាបានចាប់ផ្ដើមតាំងពីឆ្នាំ ៦២៦ មុន គ.ស ក៏បានបញ្ចប់នៅក្រោយឆ្នាំ ៣៨៦ (សូមមើលការពន្យល់ ១:២–៣) ។ កិច្ចការបម្រើព្រះរបស់លោកក៏បានចាប់ផ្ដើមឡើង មុនពេលដែលហោរាសេផានាទៅទៀត ។ ហោរាហាបាគុកបានបម្រើព្រះនាជំនាន់នោះដែរ និងហោរាអូបាឌាក៏ជាអ្នកបម្រើព្រះនាសម័យនោះដែរ ។ គឺចាប់តាំងពីហោរាអេសេគា បានចាប់ផ្ដើមបម្រើក្នុងស្រុកបាប៊ីឡូនក្នុងឆ្នាំ ៥៩៣ គឺលោកជាហោរាធំចុងក្រោយក្នុងក្រុងយេរូសាឡិម ។ តែត្រង់ដែលហោរាយេរេមាស្លាប់នៅពេលណា ឬស្លាប់ដោយសារអ្វីនោះគឺគេពុំបានដឹងឡើយ ម៉្យាងវិញទៀតបើតាមប្រពៃណី ពួកសាសន៍យូដាក៏បានអះអាងថា អ្នករស់នៅក្នុងស្រុកអេស៊ីព្ទបើអ្នកណាមានទោសធ្ងន់ គេត្រូវចោលនឹងដុំថ្មឱ្យស្លាប់ (ធៀប ហព ១១:៣៧) ។

ហោរាយេរេមា គឺជាកូនហ៊ីលគីយ៉ាដែលជាម្នាក់ក្នុងពួកសង្ឃ ឯស្រុករបស់លោកនៅក្រុងអាន៉ាថោត (១:១) ដូច្នេះ លោកអាចជាខ្សែ ឬជាពូជពង្សរបស់អ័បៀថើរ (១ពវ ២:២៦) គឺជាសង្ឃក្នុងអំឡុងពេលរាជកាលនៃស្ដេចសាឡូម៉ូន ។ ព្រះក៏មានព្រះរាជបញ្ជាដល់យេរេមាកុំឱ្យយកប្រពន្ធ និងបង្កើតកូនឡើយ ពីព្រោះការជំនុំជម្រះទៅលើពួកស្រុកយូដា និងបានសម្លាប់ដល់ជំនាន់ក្រោយៗទៀត (១៦:១–៤) ។ ជាពិសេសហោរានៃសេចក្ដីវិនាស លោកបានចាប់យកមិត្តបីនាក់ក្នុងពួកអ័បៀថើរ (២៦:២៤) លោកកេដាលា ជាកូនអ័ហ៊ីកាម (៣៩:១៤) និងលោកអេបេឌ–មេលេក (៣៨:៧–១៣ ធៀបនឹង ៣៩:១៥–១៨) ។ ឯដៃគូររួមដំណើររបស់ហោរាយេរេមាដែលស្និទ្ធស្នាលបំផុតនោះ គឺជាលេខារបស់គាត់ឈ្មោះលោកបារូក ដែលជាអ្នកសរសេរគ្រប់ទាំងពាក្យរបស់ហោរាយេរេមា គឺដូចជាសេចក្ដីទំនាយដែលបានហៅឱ្យកត់ត្រាផងដែរ (៣៦:៤–៣២) ។ លោកក៏បានទទួលដំបូន្មានជាច្រើនពីហោរាយេរេមា គឺកុំឱ្យចុះចាញ់សេចក្ដីល្បួងនៃការលោភចង់បានឡើង តែត្រូវពេញចិត្តនៅអ្វីដែលខ្លួនមានចុះ (ជំពូក ៤៥) ។ លោកក៏យកសំបុត្របញ្ចាំដីធ្លីពីហោរាយេរេមា (៣២:១១–១៦) រួចហើយក៏បានរួមដំណើរជាមួយហោរាយេរេមា តាមផ្លូវទៅឯទីចាប់ជាឈ្លើយនៅក្នុងស្រុកអេស៊ីព្ទ (៤៣:៦–៧) ។ វាក៏ជាពេលមួយដែលលោកបារូកមានលិទ្ធភាពទទួលខុសត្រូវ ដើម្បីចងក្រងកណ្ឌគម្ពីរយេរេមាបានចប់ចុងក្រោយ ។

ហោរាយេរេមាបានវិភាគពិចារណាដោយខ្លួនឯង និងបានរិះគន់ខ្លួនឯងដែរ (១០:២៤) ជាវគ្គបង្ហាញសម្ដែងពីខ្លួនគាត់យ៉ាងច្រើន ។ ទោះពេលខ្លះគាត់មានរារែក ឬស្ទាត់ស្ទៀមដោយព្រោះនិស្ស័យជីវិត (១:៦) គាត់បានទទួការបើកសម្ដែងជាសេចក្ដីធានារបស់ព្រះយេហូវ៉ាថា គាត់នឹងមានភាពខ្លាំង និងសេចក្ដីក្លាហាន (១:១៨ ៦:២៧ ១៥:២០) ។ ក្នុងការ "លន់តួបាប" របស់គាត់ (សូមមើល ១១:១៨–២៣ ១២:១–៤ ១៥:១០–២១ ១៧:១២–១៨ ១៨:១៨–២៣ ២០:៧–១៨ និងការពន្យល់) ។ គាត់បានតស៊ូទ្រាំទ្រវពុះពារយ៉ាងជ្រាលជ្រៅពីទឹកចិត្តខាងក្នុង គណៈពេលខ្លះក៏បញ្ចេញការថ្លែងទៅរកព្រះ ពីអារម្មណ៍របសគាត់ (១២:១ ១៥:១៨) ។ ក្នុងឱកាសដែលទ្រង់បានត្រាស់ហៅលោកឱ្យកែតម្រូវសត្រូវរបស់គាត់ (១២:១–៣ ១៥:១៥ ១៧:១៨ ១៨:១៩–២៣ និងមើលការពន្យល់ ទដ ៥:១០) ។ តាមការអនុវត្តន៍ដែលបានពន្យល់ពីប្រភពដើម នៃពាក្យជាភាសាអង់គ្លេសថា "យេរេមា" ដែលចង់សំដៅទៅលើការពោលពាក្យត្អូញត្អែរ ។ ជារឿយៗហោរាយេរេមាបានបង្ហាញ ឬសម្ដែងនូវសេចក្ដីតានតឹងខាងវិញ្ញាណ (៤:១៩ ៩:១ ១០:១៩–២០ ២៣:៩) លោកបានគេហៅថា "ហោរាទឹកភ្នែក" ។ ប៉ុន្តែក៏មានសេចក្ដីពិត ដែលគាត់បានចងចាំពីការត្រាស់ហៅរបស់ព្រះអម្ចាស់ ចំពោះហោរាយេរេមា (១:១៧) និងការសម្ដែងបង្ហាញជាញឹកញយរបស់ព្រះយេហូវ៉ា ពីបេសកម្មរបស់គាត់ជាហោរា (សូមមើល ឧទាហរណ៍ ៣:១២ ៧:២,២៧–២៨ ១១:២,៦ ១៣:១២–១៣ ១៧:១៩–២០) ដែលធ្វើឱ្យហោរាយេរេមាពុំមានការតក់ស្លុត និងស្មោះត្រង់ក្នុងការបម្រើព្រះអម្ចាស់ (ធៀប ១៥:២០) ។

## ជីវប្រវត្តិ

ហោរាយេរេមាចាប់ផ្ដើមថ្លែងសេចក្ដីទំនាយក្នុងស្រុកយូដា តាំងពីកណ្ដាលឆ្នាំនៃការគ្រងរាជ្យរបស់ស្ដេចយ៉ូសៀល(ឆ្នាំ ៦៤០–៦០៩ មុន ស.គ) ហើយក៏បន្តកិច្ចការនោះក្នុងរយៈពេលឆ្នាំនៃការសោយរាជ្យរបស់ស្ដេចជេដ្ឋាយ៉ូអាហាស(ឆ្នាំ ៦០៩) ស្ដេចយ៉ូគីម (ឆ្នាំ ៦០៩–៥៩៨) ស្ដេចយ៉ូយ៉ាគីន (ឆ្នាំ ៥៩៨–៥៩៧) និងស្ដេចសេដេគា (ក្នុងឆ្នាំ ៥៩៧–៥៨៦) ។ វាគឺជារយៈពេលព្យុះភ្លៀង និងការសង្កត់សង្កិន ក៏ជាពេលដែលសេចក្ដីវិនាសទៅលើពូជសាសន៍ជាច្រើន មានទាំងសាសន៍យូដាផ្ទាល់ក៏បានឃុំឃាំង ។ មានផ្នែកទឹកដីតូចមួយនៃអាស៊ីខាងលិចក៏ត្រួតត្រាដោយពួកមានអំណាចធំ ដូចជាពួអេស៊ីព្ទ ពួកសាសន៍អាសស៊ើរ និងពួស្រុកបាប៊ីឡូន ក៏ដូចជាពេលហោរាយេរេមាបានបម្រើព្រះក៏គ្មានការលើកលែងដែរ ។ ឯស្ដេចអាស៊ើរបានីប៉ាល គឺជាបុត្រារបស់ស្ដេចអាសស៊ើរ ជាអ្នកដឹកនាំពួកសាសន៍អាសស៊ើរដ៏អស្ចារ្យចុងក្រោយបំផុត បានសុគតនៅក្នុងឆ្នាំ ៦២៧ មុន គ.ស ។ ឯអ្នកដែលស្នងរាជ្យរបស់ទ្រង់នោះ គឺមិនសមគ្នានឹងស្ដេចឈ្មោះនេបូប៉ូឡាសា គឺជាអ្នកដែលបង្កើតនគររបស់ចក្រភពបាប៊ីឡូនថ្មី ដែលជាអ្នកចាប់ផ្ដើមដឹកនាំក្នុងឆ្នាំ ៦២៦ (ជាឆ្នាំដែលព្រះបានត្រាស់ហៅហោរាយេរេមាឱ្យថ្លែងសេចក្ដីទំនាយ) ។ បន្ទាប់ក្រោយមកទីក្រុងដែលជារាជធានីរបស់សាសន៍អាសស៊ើរឈ្មោះក្រុងនីនីវេ បានធ្លាក់ទៅក្នុងសង្គ្រាមវាយប្រហាពីចលនារួមរបស់ពួកបាប៊ីឡូន និងម៉ាដាយក្នុងឆ្នាំ ៦១២ ក៏មានសាសន៍អេស៊ីព្ទ (ដែលជាអមិត្ត និងពួកបាប៊ីឡូន) រៀបចំដំណើរយាត្រាក្បួនទ័ពមកទិសខាងជើង ក្នុងការព្យាយាមជួយសង្គ្រោះពួកស្ដេចអាសស៊ើរ ដែលមិនយូរប៉ុន្មានបានក៏បំផ្លាញពួកនោះអស់ទៅ ។ ឯស្ដេចយ៉ូសៀសនៃស្រុកយូដាបានមានកំហុស ដោយព្រោះព្យាយាមបជ្ឈប់ទប់ស្កាត់ការរុលទៅមុខរបស់ពួកទ័ពអេស៊ីព្ទ ហើយក៏បានសុគតនៅក្បែរទីក្រុងមេគីដោក្នុងឆ្នាំ ៦០៩ ដោយសារកណ្ដាប់ដៃពួកស្ដេចផារ៉ោន–នេកាទី២ គឺជាលទ្ធផលដែលទុក្ខសោក (២របា ៣៥:២០–២៤) ។ ហោរាយេរេមាដែលបានជួបប្រទះញាតិក្នុងព្រះអម្ចាស់ខាងឯវិញ្ញាណ ដែលមានក្នុងលោកយ៉ូសៀស ហើយក៏ប្រហែលជាបានប្រកាស់ពីការកត់ត្រានូវព្រះរាជសាមានក្នុង ១១:១–៨ ១៧:១៩–២៧ គឺក្នុងកំឡុងពេលចលនាកែប្រែគោលលិទ្ធិជឿរបស់ស្ដេចគឺពេលដែលទទួលការកាន់ទុក្ខនៃការសុគតរបស់ស្ដេចយ៉ូសៀស (សូមមើល ២របា ៣៥:២៥ និងការពន្យល់) ។

បុត្រារបស់ព្រះមហាក្សត្រយ៉ូសៀសព្រះនាមជេដ្ឋាយ៉ូអាហាស (សូមមើលការពន្យល់ ២២:១១) ទ្រង់ក៏បានគេស្គាល់ដោយឈ្មោះមួយទៀតថា សាលូម គឺនៅក្នុងកណ្ឌគម្ពីរយេរេមាបន្ទាប់មកដោយទទួលបាននូវផ្លូវជីវិតមិនល្អ ។ ស្ដេចផារ៉ោន–នេកោរបានដាក់ច្រវ៉ាក់ស្ដេចជេដ្ឋាយ៉ូអាហាស ហើយរៀបចំអេលាគីម ឬបុត្រារបស់ស្ដេចយ៉ូសៀសមួយទៀត គឺព្រះមហាក្សត្រក្នុងដំណាក់ទ្រង់ ហើយក៏ប្ដូរព្រះនាមទ្រង់ថា ស្ដេចយ៉ូយ៉ាគីម ។ ស្ដេចជេដ្ឋាយ៉ូអាហាសបានដឹកនាំក្នុងរយៈពេលដ៏ខ្លី គឺបានតែបីខែប៉ុណ្ណោះ (២របា ៣៦:២) ចំណែកឯរាជកាលរបស់ផងទ្រង់ ក៏បង្ហាញលក្ខណៈកិច្ចការទូទៅដូចហោរាយេរេមា ។

ឯស្ដេចយ៉ូយ៉ាគីននៅតែជាសត្រូវ ដោយឥតមេត្តាចំពោះហោរារេមាដដែល ។ តែក្នុងឱកាសមួយជាពេលដែលមានការកំណែនប្រមូលនូវសេចក្ដីសំណេររបស់ហោរាជាច្រើន ដើម្បីអានឱ្យស្ដេចយ៉ូយ៉ាគីនស្ដាប់ (៣៦:២១) ព្រះមហាក្សត្រក៏ប្រើកាំបិតសម្រាប់ចារដើម្បីកាត់រមូលក្រាំងក្រដាសនោះជាចំណែក១ គឺកាត់បី ឬបួនប្រឡោះហើយខណៈនោះក៏ក្រវែងម្ដងមួយសន្លឹក១ចូលទៅក្នុងជើងដុតកំដៅក្នុងបន្ទប់កំដៅខែរងារ (ខ.២២–២៣) ។ ត្រង់ចំណុចដែលសរសេរពីព្រះរាជបញ្ជារបស់ព្រះយេហូវ៉ា ខណៈនោះហោរាយេរេមាបានពោលពីសេចក្ដីទំនាយរបស់គាត់ទៅកាន់លោកបារូសជាលើកទីពីរ គឺការបន្ថែមពាក្យពេជ្រស្រដៀងគ្នាទៅក្នុងក្រាំងគម្ពីរ (ខ.៣២) ។

ទាក់ទងនឹងពេលវេលាផ្ដោតទៅលើផ្ទៃរឿងរបស់ជីវិត ហោរាយេរេមាទាំងមូល និងជាព្រឹត្តការណ៍សំខាន់ប្លែក១កើតឡើងដែលជាបុព្វហេតុប្រវត្តិសាស្ត្រក្នុងឆ្នាំ ៦០៥ មុន គ.ស ពួកសាសន៍អេស៊ីព្ទបានបែកខ្ញាយគ្នានៅឯទីក្រុងគើកេមីសត្រង់អើប្រាត ដោយសារតែពួកស្ដេចនេប៊ូក្នេសា (៤៦:២) គឺជាអំណោយទានជាទូទៅបានជោគជ័យ គឺស្ដេចនេប៊ូក្នេសាជាបិតា ជាអ្នកដឹកនាំរបស់ពួកបាប៊ីឡូនដែលក្នុងឆ្នាំតែមួយ ។ នេកោបានត្រឡប់ទៅស្រុកអេស៊ីព្ទបន្ទាប់ពីបានចាញ់សង្គ្រាមយ៉ាងធ្ងន់ធ្ងរ ។ ស្ដេចនេប៊ូក្នេសាបានឡោមព័ទ្ធក្រុងយេរូសាឡិមក្នុងឆ្នាំ ៦០៥ បានធ្វើឱ្យស្ដេចយ៉ូយ៉ាគីន (យដ ១:១–២) បានយកដានីយ៉ែល និងអ្នករួមដំណើរបីនាក់ទៀតទៅឯក្រុងបាប៊ីឡូន (ដយ ១:៣–៦) ។ ក្រោយមកទៀតនៅក្នុងឆ្នាំ ១៩៨–៥៩៧ ស្ដេចនេប៊ូក្នេសាបានវាយប្រហារក្រុងយេរូសាឡិមម្ដងទៀត ។ ឯព្រះរាជបុត្រារបស់ទ្រង់បានដឹកនាំស្រុកយ៉ូដាអស់រយៈពេលតែបីខែគត់ (២របា ៣៦:៩) ។ ហោរាយេរេមាបានថ្លែងសេចក្ដីទំនាយទុកជាមុនពីការដែលគេចាប់ស្ដេចយ៉ូយ៉ាគីន និងអ្នកដើរតាមទ្រង់មួយចំនួន (២២:២៤–៣០) សេចក្ដីទំនាយនោះពេលក្រោយមកទៀតក៏បានសម្រេចសេចក្ដីទំនាយនោះ (២៤:១ ២៩:១–២) ។

ឪពុកមារបស់ម៉ាថានា យ៉ូយ៉ាគីន និងបុត្រារបស់យ៉ូសៀសក៏ផ្លាស់ព្រះនាមទ្រង់ជាស្ដេចសេដេគាវិញ ហើយក៏ប្រគល់ឱ្យទទួលរាជបល្ល័ង្កសោយរាជ្យដោយស្ដេចនេប៊ូក្នេសាក្នុងឆ្នាំ ៥៩៧ មុន គ.ស (៣៧:១ ២របា ៣៦:៩–១៤) ។ ស្ដេចសេដេគាពីមុនឈ្មោះម៉ាថានាជាអ្នក

ដឹកនាំមានភាពខ្សោយ និងមានភាពទន់ជ្រាយមិនច្បាស់លាស់ ពេលខ្លះបង្កើតជាមិនជាមួយហោរាយេរេមា និងស្វែងរកការឱ្យដឹបូន្មានក៏ប៉ុន្តែពេលខ្លះក៏បណ្តោយឱ្យសត្រូវជាច្រើនរបស់ហោរាធ្វើបាប និងចាប់ទ្រង់ដាក់ឃុំឃាំង ។ ខណៈពេលរាជកាលរបស់ស្តេចសេដេគាហោរាយេរេមាបានយល់ព្រមនឹងគ្នា ដោយស្តេចសេដេគាមិនធ្វើបាបដល់ហោរាយេរេមា (៣៨:១៤-២៧) ។ ទោះជាខណៈនោះហោរាបានគេចាប់ឃុំឃាំងរហូតដល់ទីក្រុងយេរូសាឡិមបានគេចាប់យកបានក្នុងឆ្នាំ ៥៨៦ (៣៨:២៨) ។

ខណៈពេលដែលគេព្យាយាមគេចខ្លួនចេញពីទីក្រុង ហើយពួកបាប៊ីឡូនបានចាប់ស្តេចសេដេគា ក្នុងខណៈពេលដែលទ្រង់មានព្រះជន្មហើយព្រះរាជបុត្រារបស់ទ្រង់ជាច្រើនត្រូវគេធ្វើឃាតទាំងអស់ ក្រោយមកទៀតស្តេចនេះខ្វាក់ភ្នែកដោយសារស្តេចនេប៊ូក្នេសា (៣៩:១-៧) ។ ឯស្តេចនេប៊ូសារ៉ាដា គឺជាមេទ័ពធំក៏បានណែនាំឱ្យហោរាយេរេមារស់នៅជាមួយកេដាលា ដែលស្តេចនេប៊ូក្នេសាបានគ្រប់គ្រងលើស្រុកយូដា (៤០:១-៦) ។ កេដាលាបានគេធ្វើគតដោយសារអ្នកដែលជាសត្រូវរបស់ទ្រង់ (៤១:១-៩) ។ ម្យ៉ាងវិញទៀតនៅក្នុងស្រុក ក៏មានការភ័យខ្លាចពួកបាប៊ីឡូនវាយដណ្តើមយកដីវិញ ក៏បានភៀសខ្លួនទៅស្រុកអេស៊ីព្ទ ហើយក៏មានហោរាយេរេមានិងបារូសទៅជាមួយ (៤៣:៤-៧) នៅពេលនោះហោរានោះមានវ័យចំណាស់ជាង៧០ឆ្នាំទៅហើយ ។ ឯពាក្យទំនាយចុងក្រោយរបស់គាត់គឺមានក្នុង ៤៤:២៤-៣០ ហើយជាក្រឹត្យច្បាប់ក្នុងគម្ពីរ ដែលស្តេចផារ៉ោនប្រើក្នុងការដឹកនាំស្រុកអេស៊ីព្ទចាប់តាំងពីឆ្នាំ ៥៨៩ រហូតដល់ឆ្នាំ ៥៧០ មុន គ.ស ។

**ផ្ទៃរឿងនៃការសិក្សាពីព្រះ និងព្រះរាជសារ**

ដោយយោងតាមកណ្ឌគម្ពីរថា "យេរេមាជាហោរា" ក្នុងគម្ពីរ គឺមានឈ្មោះហោរាយេរេមា (២០:២ ២៥:២ ២៨:៥,១០-១២,១៥ ២៩:១,២៩ ៣២:២ ៣៤:៦ ៣៦:៨,២៦ ៣៧:២,៣,៦ ៣៨:៩-១០,១៤ ៤២:២,៤ ៤៣:៦ ៤៥:១,១៣ ៤៧:១ ៤៩:៣៤ ៥០:១) និង-មានក្នុង (២រប ៣៦:១២ ដយ ៩:២ មថ ២:១៧ ២៧:៩ សូមមើល មថ ១៦:១៤) ហោរាយេរេមាស្គាល់ពីការត្រាស់ហៅពីព្រះយេហូវ៉ា (១:៥ ១៥:១៩) ក្នុងការបម្រើព្រះជាហោរា ។ ដូចជាគាត់ក៏បានប្រកាសពីព្រះបន្ទូលតាមរយៈការបើកសម្តែងពីព្រះ (១៩:២) ហើយទ្រង់ក៏បានសម្រេចការនោះ (២៨:៩ ៣២:២៤) ។ ហោរាយេរេមាក៏ត្រូវបានគេរិះគន់ថាជាហោរាដែលពោលសេចក្តីទំនាយមិនពិត (១៤:១៣-១៨ ២៣:១៣-៣០ ២៧:១៤-១៨) ដូចជាហោរាហាណានា (ជំពូក២៨) និងហោរាសេម៉ាយ៉ា (២៩:២៤-៣២) ។ មានសេចក្តីថ្លែងទំនាយរបស់គេជាច្រើន ក៏បានបំពេញសម្រេចរួចហើយក្នុងរយៈពេលដ៏ខ្លី (ឧទាហរណ៍ ១៦:១៥ ២០:៤ ២៥:១១-១៤ ២៧:១៩-២២ ២៩:១០ ៣៤:៤-៥ ៤៣:១០-១១ ៤៤:៣០ ៤៦:១៣) ហើយក៏មានសេចក្តីថ្លែងទំនាយផ្សេង២ទៀតពុំបានសម្រេចនៅឡើយទេ គឺត្រូវចំណាយ រយៈពេលវែងឆ្ងាយ (ឧទាហរណ៍ ២៣:៥-៦ ៣០:៨-៩ ៣១:៣១-៣៤ ៣៣:១៥-១៦) ។

គឺតាំងពីដើមដំបូងដោយមានមនុស្សផ្សេងៗបង្ហាញពីអាការៈ ឬហុចពាក្យសំដីដែលបង្ហាញពីភាពទំនាស់ទាស់ទែងជុំវិញហោរាយេរេមាតាំពីដើមដំបូងមកម្លេះ ។ គាត់ក៏ទាស់ប្រឆាំងនឹងមនុស្សដែលមានអំពើបាប (៤៤:២៣) ក៏ប្រមាថដល់គេជាច្រើនសារដោយព្រោះពួកគេបានថ្វាយបង្គំរូបព្រះ (១៦:១០-១៣,២០ ២២:៩ ៣២:២៩ ៤៤:២-៣,៨,១៧-១៩,២៥) ក៏ជាពេលវេលាដែលទាក់ទងនឹងការថ្វាយយញ្ញបូជាកូនរបស់ពួកគេចំពោះរូបព្រះសាសន៍ដទៃ (សូមមើល ៧:៣០-៣៤ និងការពន្យល់) ។ ប៉ុន្តែហោរាយេរេមាស្រឡាញ់ប្រជាជននៃសាសន៍យូដា ហើយលោកក៏បានអធិស្ឋានឱ្យពួកគេជំនួសអំពើបាបរបស់ពួកគេ (១៤:៧,២០) ទោះពេលខ្លះព្រះយេហូវ៉ាមិនបានមានបន្ទូលឱ្យលោកធ្វើដូច្នេះក៏ដោយ (៧:១៦ ១១:១៤ ១៤:១១) ។

ការជំនុំជម្រះគឺជាផ្នែកមួយនៃផ្ទៃរឿង ដែលបានបង្ហាញលំអិតក្នុងការតែងនិពន្ធរបស់ហោរាយេរេមា ក៏បានបង្ហាញប្រាប់ថា បើមនុស្សបានលន់តួបាបបើគេស្មោះត្រង់នឹងបានអត់ទោសបាប បើពុំនោះសោធទេគេនឹងត្រូវជៀសមិនផុតពីការជំនុំជម្រះ ។ សេចក្តីរបស់គាត់ក៏បានចុះចូលចំពោះក្រុងបាប៊ីឡូន ចំណែកឯព្រះបន្ទូល "នៃជីវិតទូទៅ" ក្នុងការចាប់ជាឈ្លើយពីការនិរទេសដែលបានបោះជាប់ជាគោល និងមានងារដូចជាមនុស្សក្បត់ក្នុងក្រសែភ្នែកមនុស្សជាច្រើន ។ តាមការពិតសេចក្តីដំបូន្មានរបស់ហោរាយេរេមា គឺមិនឱ្យប្រឆាំងនឹងក្រុងបាប៊ីឡូន ក៏បានកំណត់ពីគត់គឺជាអ្នកស្នេហាជាក់ គឺជាបុរសដែលស្រឡាញ់ប្រជាជនផ្ទាល់ខ្លួនរបស់គាត់យ៉ាងខ្លាំង គឺក្នុងការឈរដោយស្ងាត់ស្ងៀម ហើយមើលពួកគេបំផ្លាញគ្នាឯង ។ ក៏តាមរយៈប្រមានពួកគេឱ្យចុះចូល គឺមិនប្រឆាំបះបោរហោរាយេរេមាក៏បានបើកសម្តែងពីព្រះទ័យរបស់ព្រះអម្ចាស់ចំពោះពួកគេគ្រប់ទាំងកាលៈទេសៈ ។

ចំពោះហោរាយេរេមាមានព្រះជាទីខ្ពស់ឧត្តមបំផុត ។ គឺជាការពពោះខាងវិជ្ជាសិក្សាពីព្រះរបស់ហោរាយេរេមា ដោយដឹងថាទ្រង់ជាព្រះអាទិករបានបង្កើតគ្រប់អស់ទាំងជីវិតដែលរស់នៅនេះ (១០:១២-១៦ ៥១:១៥-១៩) ហើយគ្រប់ទាំងអំណាចនៃទ្រង់ (៣២:២៧ ៤៨:១៥ ៥១:៥៧) មានវត្តមានគ្រប់ទីកន្លែង (២៣:២៤) ។ ហោរាយេរេមាបានបង្ហាញហេតុផលចំពោះព្រះអម្ចាស់ដែលហោរាយេរេមា

បានបម្រើនោះ (៣២:១៧–២៥) ក៏បង្ហាញប្រាប់គេទាំអស់គ្នាថា ទ្រង់មិនមែនតែជាព្រះសម្រាប់ពួកសាសន៍យូដាប៉ុណ្ណោះទេ តែទ្រង់ជាព្រះគ្រប់ទាំងពូជសាសន៍ទាំងអស់ (៥:១៥ ១៨:៧–១០ ២៥:១៧–២៨ ជំពូក ៤៦–៥១) ។

ក្នុងពេលតែមួយព្រះយេហូវ៉ាក៏មានព្រះទ័យយកចិត្តទុកដាក់ ចំពោះរាស្ត្ររបស់ផងទ្រង់ និងគ្រប់អស់ទាំងអ្នកដែលបម្រើទ្រង់ ។ សេចក្តីបញ្ជាក់របស់ហោរាយេរេមា នៅក្នុងគំនិតរបស់គាត់ (សូមមើល ឧទាហរណ៍ ៣១:២៩–៣០) គឺមានលក្ខណៈស្រដៀងនឹងសេចក្តីរបស់ហោរាអេសេគាល (សូមមើល អគ ១៨:២–៤) និងបុរសពីរនាក់ដែលក្លាយជា "ហោរាដែលមានការធានាខុសត្រូវផ្សេងៗពីគ្នា" ។ លក្ខណៈមិនអាចផ្តាច់ពីគ្នាបានរវាងអំពើបាប និងផលរបស់វា ឬផលកម្ម គឺអ្វីៗដែលអាចមើលឃើញ ដូចជាហោរាយេរេមាដែលគាតមានលក្ខណៈជាអ្នកមើលដល់ពួកយូដាជាទីស្រឡាញ់របស់គាត់ ក្នុងការដែលសេចក្តីស្លាប់របស់គេបានមកដល់ ដែលធ្វើឱ្យគាត់ខំស្វែងរកពីកិច្ចការដែលមានព្រះគឺជាអ្នកអធិប្បាយដែលពេញដោយព្រះវិញ្ញាណ (៥:១៤ ២០:៩ ២៣:២៩) នៃភាពសុចរិត ។

ជាការត្រាស់ហៅពីព្រះអម្ចាស់ឱ្យទទួលការងារបម្រើព្រះ ដែលជាការងារពុំសប្បាយរីករាយក្នុងការប្រកាសពីភាពហិនវិនាសនៃនគរសាសន៍យូដា (ដោយទទួលការខូចខាតយ៉ាងខ្លាំងដោយសារាជាកាលគ្រប់គ្រងរបស់ស្តេចម៉ាន៉ាសេដ៏យូរអង្វែង និងមានឥទ្ធិពលដល់ការប្រឹងប្រែងរបស់យ៉ូសៀស) វាគឺជាបេសកកម្មរបស់ហោរាយេរេមា ដើម្បីបម្រើកិច្ចការព្រះក្នុងការទាស់ប្រឆាំងនឹងរាស្ត្រដែលមិនទទួលព្រះ និងប្រកាសពីចុងបញ្ចប់នៃយុគសម័យមួយ ។ ក្នុងរយៈពេលដែលមានជាយូរមកហើយ គឺព្រះយេហូវ៉ាក៏នឹងត្រូវទោសចំពោះពួកសំណល់របស់ផងទ្រង់ គឺជាបណ្តាសាតាមរយៈសេចក្តីសញ្ញាចុងក្រោយ (សូមមើល លវ ២៦:៣១–៣៣ ចទ ២៨:៤៩–៦៨) ។ ហោរាយេរេមានឹងស្រាយនូវអ្វីៗដែលលោកបានប្រព្រឹត្តចំពោះពួកគេ ចាប់តាំពីកាត់បាននាំពួកគេចេញពីស្រុកអេស៊ីព្ទ ។ គឺហាក់ដូចជាថ្ងៃចុងក្រោយបានមកដល់ ដែលរាស្ត្រអ៊ីស្រាអែលក្បាលរឹង និងការដែលមិនកាត់ស្បែក (គឺមិនបរិសុទ្ធ) ចិត្តគេព្រះបានដៅចំណាំពីវាសនាចុងក្រោយរបស់ពួកគេ ប៉ុន្តែចំពោះការជំនុំជម្រះរបស់ព្រះអម្ចាស់ចំពោះរាស្ត្រ (និងគ្រប់ជាតិសាសន៍) របស់ទ្រង់គួរឱ្យខ្លាចមានភាពចម្លែកគឺមិនមែនជាព្រះបន្ទូលចុងក្រោយ តែជាព្រះរាជកិច្ចចុងក្រោយក្នុងប្រវត្តិសាស្ត្រ ។ ព្រះមេត្តាករុណា និងភាពសប្បុរសនៃសេចក្តីសញ្ញាបានដោគជ័យលើសេចក្តីក្រោធ ។ ក្រុងបាប៊ីឡូនមានការជំនុំជម្រះ និងមកជំនួសវិញ ។

ឯរាស្ត្រអ៊ីស្រាអែលនឹងមានឡើង ឯគ្រប់ទាំងជាតិសាសន៍ដែលបំផ្លាញអ៊ីស្រាអែល និងខ្ទេចខ្ទីអស់ទៅ ឯសេចក្តីសញ្ញាពីមុនមក (ដែលរាស្ត្រអ៊ីស្រាអែលមានស្តេចដាវីឌ និងពួកលេវី) និងត្រូវបានគេគោរពកោតខ្លាចព្រះអម្ចាស់ក៏បានបង្កើត ឬតាំងសេចក្តីសញ្ញាថ្មីឡើងជាមួយរាស្ត្ររបស់ផងទ្រង់ គឺទ្រង់បណ្តាលឱ្យមនុស្ស ឬបំពេញមនុស្សនូវច្បាប់បញ្ញត្តិរបស់ផងទ្រង់ ដើម្បីសរសេរបញ្ញត្តិនោះឡើង (សូមមើល ៣១:៣១–៣៤ និងការពន្យល់, និងសូមមើល ហព ៨:៨–១២ និងការពន្យល់) និងបានញែកពួកគេឱ្យបរិសុទ្ធ ដើម្បីបម្រើកិច្ចការទ្រង់ ។ សេចក្តីសញ្ញាថ្មីនោះត្រូវបានគេរៀបទុកសម្រាប់ជាសេចក្តីសញ្ញារបស់រាជវង្ស នាសម័យមជ្ឈឹមបូព៌ាបូរាណ និងមានការរៀបចំជាបញ្ញត្តិឡើងជាព្រះបន្ទូលសន្យាដែលគ្មានលក្ខ័ណ្ឌ ស្អាតស្អំ និងមានទំនាក់ទំនងគ្នាល្អជានិច្ច ។ ឯវង្សរបស់ដាវីឌនឹងដឹកនាំប្រជារាស្ត្ររបស់ទ្រង់ ក្នុងភាពសុចរិត និងបម្រើជាសង្ឃដែលមានភាពស្មោះត្រង់ ។ ឯព្រះរាជកិច្ចរបស់ព្រះអម្ចាស់ គឺដើម្បីប្រោះលោះរាស្ត្រអ៊ីស្រាអែលឱ្យគេមានសេចក្តីសុខសាន្ត ដោយសារតែគេជាការបង្កើតរបស់ផងទ្រង់ (ជំពូក ៣៣) ។ ឯព្រះរាជសារជាព្រះបន្ទូលតាមរយៈហោរាយេរេមា បានបំភ្លឺបកស្រាយរហូវដល់ជើងមេឃម្ខាង ។ តែបើអ្នកណាដែលប្រកាសពីភាពសុខសាន្តដែលនឹងមកដល់ គឺដើម្បីប្រឆាំងបះបោរនឹងសាសន៍ណាមួយ គឺជាសេចក្តីមិនពិតវិញ ដូចជាព្រះអម្ចាស់នៃរាស្ត្រអ៊ីស្រាអែលដែលទ្រង់ជាព្រះនៃសន្តិភាព គឺទ្រង់មិនខុសពីសេចក្តីសប្បុរសនៃរាស្ត្រអ៊ីស្រាអែលទេ ។ ប៉ុន្តែព្រះអម្ចាស់ពិតជាអង្គផ្តល់នូវកម្លាំងដល់ហោរាយេរេមាឱ្យប្រកាសកាត់ទោសចំពោះអំពើបាបជាសាធារណៈ ឯការជំនុំជម្រះគឺពឹងផ្អែកលើព្រះអម្ចាស់ដែលបាន ដែលបានផ្តល់អំណាចដល់ហោរាយេរេមា ដើម្បីប្រកាសពីសេចក្តីក្រោធរបស់ព្រះចំពោះចំណោងនៃអំពើបាបនោះ ។

## លក្ខណៈអក្សរសាស្ត្រ

កណ្ឌគម្ពីរយេរេមា គឺជាកណ្ឌគម្ពីរដែលវែងក្នុងព្រះគម្ពីរទាំងមូល ។ ដែលមានពាក្យ ឬបន្ទូលច្រើនជាងកណ្ឌគម្ពីរណាៗទាំងអស់ ទោះបីជាមានជំពូកខ្លះត្រូវបានគេនិពន្ធឡើងក្នុងលក្ខណៈជារាយសំខាន់ៗ (ជំពូក ៧,១១,១៦,១៩,២១,២៤–២៩,៣២–៤៥) រួមបញ្ចូលទាំងសេចក្តីបន្ថែម (ជំពូក ៥២) ឯវគ្គភាគច្រើនមានលក្ខណៈទម្រង់កំណាព្យស្ទើរតែទាំងអស់ ។ ឯផ្នែកកំណាព្យរបស់ហោរាយេរេមា គឺមានកំរិតខ្ពស់ ហើយលក្ខណៈជាកំណាព្យខ្លីៗ ។ ព្រះអាទិករបានតុបតែងឱ្យមានឃ្លាដ៏ល្អពិរោះ ទ្រង់បានប្រទានឱ្យយើងនូវព្រះរាជសារដ៏ពេញបរិបូរ ដែលយើងចងចាំជានិច្ច (ឧទាហរណ៍ ២:១៣,២៦–២៨ ៧:៤,១១,៣៤ ៨:២០,២២ ៩:២៣–២៤ ១០:៦–៧,១០,១២–១៣ ១៣:២៣ ១៥:២០ ១៧:៥–៩ ២០:១៣ ២៩:១៣ ៣០:៧,២២ ៣១:៣,១៥,២៩–៣០,៣១–៣៤ ៣៣:៣ ៥១:១០) ។ ឯពាក្យផ្តួនៗបែបជាកំណាព្យ ដែល

ប្រើដោយហោរាយេរេមាប្រកបដោយជំនាញយ៉ាងជាក់លាក់ (សូមមើល ឧទាហរណ៍ ៤:២៣-២៦ ៥១:២០-២៣) ។ លោកបានយល់ពីភាពអត្ថប្រយោជន៍ពីការប្រើពាក្យផ្ទួនៗ ឬប្រើច្រើនសាដដែលៗ ។ ឧទាហរណ៍ ដូចជាពាក្យ "ដាវអំណត់អត់ និងអាសន្នរោគ" លោកបានបង្កើតការប្រើពាក្យបង្កប់ន័យ (សូមមើលការពន្យល់ ២៥:២៦ ៥១:១,៤១) ទៅលើឱកាសដ៏សំរម្យណាមួយ ។ មានការប្រើចុងចួនព្យញ្ជនៈដើមព្យាង្គ និងពាក្យមានសម្លេងដូចគ្នាក៏បានប្រើក្នុងផ្នែកខ្លះនៃប្រភេទអក្សរនិពន្ធឧទាហរណ៍ដូចជាពាក្យ ("មនុស្សដទៃឱ្យទៅឯក្រុងបាប៊ីឡូនអ្នក . . . នឹងអុកគេ" ៥១:២) ។ ដូចជាហោរាអេសេគាល ហោរាយេរេមា គឺជារឿយៗ ក៏បានប្រើនូវពាក្យដែលជាលក្ខណៈសម្គាល់ដើម្បីគូសបញ្ជាក់ព្រះរាជសាររបស់ទ្រង់ : ដូចជាសំពត់នោះខូចហើយគ្មានប្រយោជន៍ទៀតសោះ (១៣:១-១១) អ្នកណាបំបែកក្អមរបស់ជាងស្មូន (១៩:១-១២) ដូចជានឹងជាឧបករណ៍មួយ និងជាឈើត្រង់មួយ (ជំពូក ២៧) ដូចជាថ្មធំៗប្រើការក្រាលចាក់ធ្វើជាផ្ទះថ្ម (១៦:១-៤) ដូចជាពាក្យកុំឱ្យចូលទៅក្នុងផ្ទះដែលគេកាន់ទុក្ខ ក៏កុំឱ្យទៅយំសោក ឬទួញទំនួញព្រោះគេឡើយ (១៦:៥-៩) ដូចជាការទិញ ឬបញ្ចាំចំការ ដែលនៅឯន៉ាថោតទៅ (៣២:៦-១៥) គឺមានលក្ខណៈស្រដៀងគ្នានឹងព្រះយេហូវ៉ា បានប្រើជំនួយដោយចក្ខុវិញ្ញាណ ក្នុងការពាំនាំព្រះរាជសាទៅដល់ហោរាយេរេមា មានពាក្យថា ដីឥដ្ឋនៅក្នុងដៃជាងស្មូន (១៨:១-១០) ផ្លែល្វា២ល្អី ។

**គម្រោងសង្ខេប**

គឺមានលក្ខណៈមិនដូចគម្ពីរអេសេគាលទេ ដោយសេចក្តីទំនាយក្នុងគម្ពីរយេរេមា គឺមិនបានរៀបតាមលំដាប់លំដោយនៃពង្សាវតារក្សត្រ ។ ដោយមានការរៀបចំតាមលំដាប់លំដោយនៃផ្នែកនិមួយៗ គឺក្នុងគម្ពីរក៏មានរៀបតាមជំពូក ១:១-៧:១៥ ជំពូក ២៦ ៧:១៦-២០:១៨ ជំពូក ២៥,៤១-៥១ ៣៦:១-៨ ជំពូក ៤៥ ៣៦:៩-៣២ ជំពូក ៣៥ ជំពូក ២១-២៤ ជំពូក ២៧-៣១ ៣៤:១-៧ ៣៧:១-១០ ៣៤:៨-២២ ៣៧:១១-៣៨:១៣ ៣៩:១៥-១៨ ជំពូក ៣២-៣៣ ៣៨:១៤-៣៩:១៤ ៥២:១-៣០ ជំពូក ៤០-៤៤ ៥២:៣១-៣៤ ។ ឯគម្រោងសង្ខេបខាងក្រោមនេះ គឺជាការញែកនៃផ្នែកកណ្ឌគម្ពីរយេរេមា ក្នុងលំដាប់លំដោយនៃគម្ពីរនាពេលបច្ចុប្បន្ននេះ ។

I. ការត្រាស់ហៅហោរាយេរេមា (ជំពូក ១)
II. ការព្រមាន និងការជំរុញដល់ស្រុកយូដា (ជំពូក ២-៣៥)
- ក. សេចក្តីថ្លែងប្រាប់ពីដំបូង (ជំពូក ២-៦)
- ខ. ព្រះរាជសានៅក្នុងព្រះវិហារ (ជំពូក ៧-១០)
- គ. សេចក្តីសញ្ញា និងគំនិតក្បត់ (ជំពូក ១១-១៣)
- ឃ. ព្រះរាជសាទាក់ទងនឹងគ្រារាំងស្ងួត (ជំពូក ១៤-១៥)
- ង. ភាពគ្រោះមហន្តរាយ និងការកំសាន្តចិត្ត (១៦:១-១៧:១៨)
- ច. សេចក្តីបញ្ញត្តិឱ្យរក្សាថ្ងៃសម្រាកជាថ្ងៃបរិសុទ្ធ (១៧:១៩-២៧)
- ឆ. មេរៀនចេញពីអ្នកជាជាងស្មូន (ជំពូក ១៨-២០)
- ជ. ការផ្តន្ទាទោសចំពោះព្រះមហាក្សត្រ ពួកហោរា និងទៅលើប្រជារាស្ត្រ (ជំពូក ២១-២៤)
- ឈ. ការថ្លែងសេចក្តីទំនាយពីការជាប់ជាឈ្លើយ នៃសាសន៍បាប៊ីឡូន (ជំពូក ២៥-២៩)
- ញ. ព្រះបន្ទូលសន្យាពីការឱ្យមានសេចក្តីសុខឡើងវិញ (ជំពូក ៣០-៣៣)
- ដ. សេចក្តីបន្ថែមពីប្រវត្តិសាស្ត្រ (ជំពូក ៣៤-៣៥)

III. ការរងការឈឺចាប់ និងការបៀតបៀនចំពោះពួកហោរា (ជំពូក ៣៦-៣៨) ។
- ក. ការដុតក្រាំងគម្ពីររបស់ហោរាយេរេមា (ជំពូក ៣៦)
- ខ. ការដាក់ហោរាយេរេមាក្នុងគុក (ជំពូក ៣៧-៣៨)

IV. ការធ្លាក់ចុះរបស់ក្រុងយេរូសាឡិម និងលទ្ធផលមិនល្អរបស់ក្រុងនោះ (ជំពូក ៣៩-៤៥)
- ក. ការដួលរលំក្រុងនោះ (ជំពូក ៣៩)
- ខ. ការជ្រើសតាំងឡើង និងឃាដកម្មរបស់ស្តេចកេដាលា (៤០:១-៤១:១៥)
- គ. ការធ្វើដំណើរបំលាស់ទីទៅឯស្រុកអេស៊ីព្ទ (៤១:១៦-៤៣:១៣)
- ឃ. សេចក្តីទំនាយទាស់ប្រឆាំង និងអស់អ្នកនៅក្នុងស្រុកអេស៊ីព្ទ (ជំពូក ៤៤)
- ង. ផ្នែកប្រវត្តិសាស្ត្រ : ព្រះបន្ទូលសន្យានឹងបារូក (ជំពូក ៤៥)

V. ការជំនុំជម្រះទាស់ប្រឆាំងនឹងពូជសាសន៍មួយចំនួន (ជំពូក ៤៦–៥១)

ក. ប្រឆាំងនឹងអេស៊ីព្ទ (ជំពូក ៤៦)

ខ. ប្រឆាំងនឹងសាសន៍ភីលីស្ទីន (ជំពូក ៤៧)

គ. ប្រឆាំងនឹងសាសន៍ម៉ូអាប់ (ជំពូក ៤៨)

ឃ. ប្រឆាំងនឹងសាសន៍អាំម៉ូន (៤៩:១–៦)

ង. ជំនុំជម្រះប្រឆាំងនឹងសាសន៍អេដុំម (៤៩:១–៦)

ច. ប្រឆាំងនឹងពួកក្រុងដាម៉ាស (៤៩:២៣–២៧)

ឆ. ប្រឆាំងនឹងពួកក្រុងកេដារ និងស្រុកហាសោរ (ឥឡូវនេះគឺប្រទេសអារ៉ាប៊ី) (៤៩:២៨–៣៣)

ជ. ប្រឆាំងនឹងពួកស្រុកអេឡាំ (៤៩:៣៤–៣៩)

ឈ. ប្រឆាំងនឹងក្រុងបាប៊ីឡូន (ជំពូក ៥០–៥១)

VI. វគ្គប្រវត្តិសាស្ត្រ (ជំពូក ៥២)

**១** ១នេះជាពាក្យរបស់យេរេមា ជាកូនហ៊ីលគីយ៉ា គឺជា
ម្នាក់ក្នុងពួកសង្ឃ ដែលនៅក្រុងអាន៉ាថោត[ក] ក្នុងស្រុក
បេនយ៉ាមីន ២ជាអ្នកដែលព្រះបន្ទូលនៃព្រះយេហូវ៉ាបាន
មក[ខ]ដល់ខ្លួន នៅក្នុងឆ្នាំទី១៣នៃរាជ្យយ៉ូសៀស[គ] ជាបុត្រ
អាំម៉ូន ស្ដេចស្រុកយូដា ៣ក៏មានមកដល់ នៅក្នុងរាជ្យ
យ៉ូយ៉ាគីម[ឃ] ជាបុត្រយ៉ូសៀស ជាស្ដេចស្រុកយូដា ដរាប
ដល់ផុតឆ្នាំទី១១ ក្នុងរាជ្យសេដេគា[ង] ជាបុត្រយ៉ូសៀសដែល
ជាស្ដេចស្រុកយូដា គឺដល់ខែស្រាពណ៍ ជាគ្រាដែលពួក
ក្រុងយេរូសាឡិម ត្រូវចាប់ដឹកនាំទៅជាឈ្លើយនោះឯង[ច] ។

## ការត្រាស់ហៅលោកយេរេមា

៤រីឯព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា ៥មុន
ដែលអញបានជបបង្កើតឯងនៅក្នុងពោះម្ដាយ[ឆ] នោះអញ
ស្គាល់ឯង[ជ]ហើយ កាលមុនដែលឯងសំរាលចេញពីផ្ទៃ
មក[ឈ] នោះអញបានញែកឯងជាបរិសុទ្ធផង[ញ] ក៏បានតាំង
ឯងឡើងជាហោរា ដល់អស់ទាំងសាសន៍[ដ] ៦នោះខ្ញុំបាន

**១:១** ក យស ២១:១៨ **១:២** ខ អគ ១:៣ ហស ១:១ យអ ១:១ គ ២ពវ ២២:១ **១:៣** ឃ ២ពវ ២៣:៣៤ ង ២ពវ ២៤:១៧ ច អរ ៥:១២ យរ ៥២:១៥ **១:៥** ឆ ទដ ១៣៩:១៣ ជ ទដ ១៣៩:៦ ឈ អស ៤៩:១ ញ យហ ១០:៣៦ ដ ខ.១០ យរ ២៥:១៥–២៦

**១:១–៣** ប្រវត្តិដើម និងការបង្កើតព្រះគម្ពីរយេរេមា ត្រូវបានគេឱ្យឈ្មោះថា ការចាប់ផ្ដើមដោយសង្ខេប ប៉ុន្តែវាមានការយល់ស៊ីជម្រៅ ។

**១:១** *នេះជាពាក្យរបស់* មើល ៣៦:១០ មើលផងដែរ នហ ១:១ សស ១:១ អម ១១:១ ធៀបនឹង ចទ ១:១ ។ *យេរេមា* ជាឈ្មោះ១ដែលមានន័យ មើលសេចក្ដីផ្ដើម: អ្នកនិពន្ធ និងកាលបរិច្ឆេទ ។ បុរស៩នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានឈ្មោះដូចគ្នា (មើល ១របា ៥:២៤ ១២:៤,១០,១៣ នហ ១០:២ ១២:១,១២,៣៤) ឈ្មោះបុរស២នាក់មាននៅជំនាន់របស់ហោរា (យរ ៣៥:៣ ៥២:១) ។ *ហ៊ីលគីយ៉ា* មានន័យថា "ព្រះអម្ចាស់ជាមរដករបស់ខ្ញុំ" ហ៊ីលគីយ៉ាមានខ្សែស្រឡាយជាប់នឹងពូជអំបូរបស់សង្ឃដែលចាប់ពីខ្សែពូជ អំបូរស្ដេចសាឡូម៉ូន មើលសេចក្ដីផ្ដើម: អ្នកនិពន្ធ និងកាលបរិច្ឆេទ ហើយបុរស២នាក់ទៀត មានឈ្មោះថាហ៊ីលគីយ៉ា (ជាឈ្មោះសាមញ្ញមួយ នៅសញ្ញាចាស់) ដែលមានឈ្មោះនៅជំនាន់លោកយេរេមាផងដែរ (មើល ២៩:៣ អគ ៧:១ និងការពន្យល់) ។ *ពួកសង្ឃ* ដូចជាលោកអេសេគាល (អគ ១:៣) និងលោកសាការី (មើលសេចក្ដីផ្ដើមសាការីអ្នកនិពន្ធ) លោកយេរេមាមានឈ្មោះទាំង២ គឺគាត់ជាហោរា និងជាសមាជិកម្នាក់នៃគ្រួសារសង្ឃ ។ *ក្រុងអាន៉ាថោត* មើល ១១:២១–២៣ ៣២:៦–៩ ពាក្យហេព្រើរពាក្យពហុវចនៈ ឈ្មោះរបស់សាសន៍កាណានអានាព្រះដែលធ្វើសង្គ្រាម ។ ក្រុងអាន៉ាថោត មានគ្រួសារសង្ឃ ដែលជាប់នៅក្នុងពួកអ៊ីស្រាអែលដូចជា មាននៅជំនាន់ដើម ជំនាន់លោកយ៉ូស្វេ (យស ២១:១៨) និងជំនាន់ស្ដេចសាឡូម៉ូន (១ពវ ២:២៦) ហើយវាចាប់ផ្ដើម នៅជំនាន់ដើមដែលគេសន្មត់បាន ដោយគេបានភ្លេចនៅជំនាន់លោកយេរេមា ។ សព្វថ្ងៃមានឈ្មោះថា ក្រុងអាន៉ាថា ដែលមានចម្ងាយ៣ម៉ាយ នៅទិសឦសាននៃក្រុងយេរូសាឡិម ជាឈ្មោះតាំងពីជំនាន់ពីបុរាណ ដែលគេដាក់ឈ្មោះនៅជំនាន់បុរាណកាលនោះ ។ *បេនយ៉ាមីន* ក្រុងអាន៉ាថោតជាក្រុងមួយនៃក្រុងទាំង៤របស់ពួកលេវី នៅក្នុងទឹកដីរបស់ ពូជអំបូរបេនយ៉ាមីន (យស ២១:១៧–១៨) និងក្រោយពីការតាំងទីលំនៅ ជាថ្មីម្ដងទៀតនៅពេលការចាប់ជាឈ្លើយរបស់ ពួកកូនចៅបេនយ៉ាមីន (នហ ១១:៣១–៣២) ។

**១:២** *ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់* មធ្យោបាយយ៉ាងងាយស្រួលដែលណែនាំឱ្យស្គាល់ពីលក្ខណៈរបស់ព្រះ ដែលមាននៅក្នុងសេចក្ដីទំនាយក្នុងសេចក្ដីផ្ដើម របស់ព្រះគម្ពីរសេចក្ដីទំនាយ (មើល អគ ១:៣ យហ ១:១ និងការពន្យល់ ធៀបនឹង ហស ១:១ យស ១:១ និងការពន្យល់ មីក ១:១ សផ ១:១) ។ *ដល់ខ្លួន* ចាប់ផ្ដើមនៅក្នុង ខ.៤ លោកយេរេមានិយាយនៅក្នុងលក្ខណៈមនុស្សប្រភេទទី១ (មើល ឧទាហរណ៍ក្នុង ខ.១១,១៣ ២:១) ។ *ឆ្នាំទី១៣* នៅឆ្នាំ៦២៦ គ.ស (មើល ២៥:៣) ។ *ស្ដេចយ៉ូសៀស* មើល ៣:៦ ៣៦:២ ទ្រង់ជាស្ដេចដែលគួរឱ្យគោរព និងជាមនុស្សល្អចុងក្រោយគេ របស់ពួកយូដា លោកយេរេមាសង្កត់ធ្ងន់ទៅលើសេចក្ដីគាំទ្ររបស់គាត់ ចំពោះការផ្លាស់ប្រែខាងផ្នែកព្រលឹងវិញ្ញាណ និងការកើតជាថ្មី (មើល ២២:១៥–១៦) ដែលចាប់ផ្ដើមតាមសេចក្ដីសន្យាក្នុងឆ្នាំ ៦២១ (មើល ២ពវ ២២:៣–២៣:២៥ ២របា ៣៤:៨–៣៥:១៩ ធៀបនឹង ២របា ៣៤:៣–៧) ។

**១:៣** *ស្ដេចយ៉ូយ៉ាគីម* ទ្រង់កើតមុន(ស្ដេចយ៉ូអាហាស) និងកើតក្រោយ (ស្ដេចយ៉ូយ៉ាគីម) មិនត្រូវគេលើកមកបញ្ជាក់ទេ តាំងពីស្ដេចនិមួយៗបានគ្រងរាជ្យតែក្នុងរយៈពេល៣ខែគត ដែលផ្ទុយពីបិតារបស់ទ្រង់ ស្ដេចយ៉ូសៀស ស្ដេចយ៉ូយ៉ាគីម បានគ្រងរាជ្យដោយប្រព្រឹត្តអំពើអាក្រក់(មើល ២ពវ ២៣:៣៦–៣៧ ២របា ៣៤:៨–៣៥:១៩ ធៀបនឹង ២របា ៣៤:៣–៧) ។ ដូចជា លោកយេរេមាបានដឹងខ្លួនភ្លាមនៅពេលនោះ (មើលសេចក្ដីផ្ដើមប្រវត្តិដើម ហើយមើលផងដែរ ២២:១៣–១៥ ១៧–១៩ ២៦:២០–២៣) ។ *ដល់ខែស្រាពណ៍ ឆ្នាំទី១១* (ខែកក្កដា–ខែសីហា)ឆ្នាំ ៥៨៦ គ.ស (មើល ៥២:១២) ។ *ស្ដេចសេដេគា* ជាស្ដេចចុងក្រោយរបស់ពួកយូដា (មើលសេចក្ដីផ្ដើម ប្រវត្តិដើម) ដែលគាត់បានប្រព្រឹត្តអំពើអាក្រក់ តាមផ្លូវរបស់គាត់ ដូចជាស្ដេចយ៉ូយ៉ាគីម (មើល ៥២:១–២ ២របា ៣៦:១១–១៤ មើលផងដែរ យរ ២៤:៨ ៣៧:១–២) ។ *ត្រូវចាប់ដឹកនាំទៅជាឈ្លើយ* ការចាប់ពួកយូដាទៅ ព្រមទាំងការបំផ្លាញក្រុងយេរូសាឡិម និងការបំផ្លាញព្រះវិហារស្ដេចសាឡូម៉ូន ដោយសារស្ដេចនេបូក្នេសានៅឆ្នាំ ៥៨៦ (មើល ២ពវ ២៥:៨–១១) ។

**១:៤–១៩** ករណីការត្រាស់ហៅលោកយេរេមា រួមទាំងទស្សនៈនៃសេចក្ដីទំនាយ២យ៉ាង (ខ.១០–១៦) និងពាក្យចុងបញ្ចប់ គឺការលើកសរសើរ និងការលើកទឹកចិត្ត (ខ.១៧–១៩) ។

**១:៤** មើលការពន្យល់ ខ.២ ។

**១:៥** *អញបានជបបង្កើតឯង* មើល អស ៤៩:៥ ព្រះទ្រង់ធ្វើការបង្កបង្កើត (មើល លក ២:៧ ទដ ១១៩:៧៣) ជាមូលដ្ឋានពីការគ្រប់គ្រងរាជ្យរបស់ទ្រង់ (មើល ១៨:៤–៦ អស ៤៣:២១) ទ្រង់ត្រាស់ហៅលោកយេរេមាឱ្យចូលមកក្នុងកិច្ចការបម្រើរបស់ទ្រង់ ។ *អញបានស្គាល់ឯង* ក្នុងន័យដែលធ្វើឱ្យលោកយេរេមាជ្រើសរើសនូវគោលបំណងរបស់គាត់ (មើលការពន្យល់)។ កិរិយាស័ព្ទពាក្យហេព្រើរ នៅទីនេះបានបកប្រែថា "បានជ្រើសរើស" នៅក្នុង លប ១៨:១៩ អម ៣:២ ។ *អញបានញែកឯងចេញ* អញបានតាំងឯងឡើង (ធៀបនឹង ពច ១៣:៥ អស ៤៩:១ រម ១:១ កទ ១:១៥ និងការពន្យល់) ។ *ក៏បានតាំងឯងឡើង* ពាក្យហេព្រើរសម្រាប់កិរិយាស័ព្ទនៃពាក្យនេះ ដូចគ្នានៅក្នុង ខ.១០ ទាំងពីនេះសំដៅទៅលើបេសកកម្មរបស់ហោរា ។ *ហោរា*

ទទួលថា ឱព្រះអម្ចាស់យេហូវ៉ាអើយ មើល ទូលបង្គំគ្មាន
វោហារអធិប្បាយទេ[ឋ] ដ្បិតទូលបង្គំជាមនុស្សក្មេងសុទ្ធ[ឌ] ៧តែ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំថា កុំឱ្យថាឯងជាមនុស្ស
ក្មេងឡើយ ដ្បិតបើអញចាត់ឯងឱ្យទៅឯអ្នកណា នោះឯង
ត្រូវតែទៅ ហើយសេចក្ដីអ្វីដែលអញបង្គាប់ឯង នោះឯង
ត្រូវតែប្រាប់ដែរ ៨ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំថា
កុំឱ្យខ្លាច[ឍ]ចំពោះគេឡើយ ដ្បិតអញនៅជាមួយ[ណ] ដើម្បីនឹង
ជួយ[ត]ឱ្យឯងរួច[ថ] ៩នោះព្រះយេហូវ៉ាទ្រង់លូកព្រះហស្តមក
ពាល់[ទ]មាត់ខ្ញុំ ហើយមានបន្ទូលថា មើល អញបានដាក់ពាក្យ
របស់អញនៅក្នុងមាត់ឯងហើយ[ធ] ១០មើល នៅថ្ងៃនេះ អញ
តាំងឯងលើអស់ទាំងសាសន៍[ន] និងលើនគរទាំងប៉ុន្មាន ដើម្បី
ឱ្យបានដករំលើង[ប]រុះទំលាក់ ហើយបំផ្លាញរំលំចុះ ព្រម
ទាំងសង់ឡើងវិញ ហើយដាំទៀតផង[ផ]។
១១មួយទៀត ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំ

**១:៦** ឋ នក ៣:១១ ៦:១២ ឌ ១ពវ ៣:៧ **១:៨** ឍ លប ១៥:១ យស ៨:១ ណ លប ២៦:៣ យស ១:៥ យរ ១៥:២០ ត ខ.១៩ យរ ១៥:២១ ២៦:២៤ ៣៦:២៦ ៤២:១១ ថ យរ ២០:១១ **១:៩** ទ អស ៦:៧ ធ នក ៤:១២ **១:១០** ន យរ ២៥:១៧ ៤៦:១ ប យរ ១២:១៧ ផ យរ ១៨:៧–១០ ២៤:៦ ៣១:៤,២៨ **១:១១** ព យរ ២៤:៣

សួរថា យេរេមាអើយ[ព] តើឯងឃើញអ្វីនុ៎ះ នោះខ្ញុំទូលតប
ថា ទូលបង្គំឃើញដំបងឈើចំបក់១ ១២រួចព្រះយេហូវ៉ា
មានបន្ទូលមកខ្ញុំថា ឯងបានឃើញត្រូវហើយ ពីព្រោះអញ
ព្យាយាម[ភ]នឹងធ្វើសំរេចតាមពាក្យរបស់អញ ។
១៣ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់ខ្ញុំម្ដងទៀត
សួរថា តើឯងឃើញអ្វីនុ៎ះ[ម] ខ្ញុំក៏ទូលតបថា ទូលបង្គំឃើញ
ថ្លាងទឹកកំពុងតែពុះ ដែលមានមាត់ផ្ងៀងមកពីទិសខាង
ជើង ១៤នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំថា នឹង
កើតមានការអាក្រក់ ផុសចេញពីទិសខាងជើង[យ] មកលើ
ពួកអ្នកស្រុកទាំងអស់ ១៥ដ្បិតមើល អញនឹងហៅគ្រប់
ទាំងគ្រួសារនៃនគរទាំងប៉ុន្មាននៅខាងជើង ហើយគេ
នឹងមកតាំងបល្ល័ង្ករបស់គេរៀងខ្លួន នៅត្រង់មាត់ទ្វារក្រុង

អម ៧:៨ **១:១២** ភ យប ២៩:២ យរ ៤៤:២៧ **១:១៣** ម យរ ២៤:៣ សក ៤:២ ៥:២ **១:១៤** យ អស ១៤:៣១

"ជាមនុស្សម្នាក់ ដែលព្រះទ្រង់បានត្រាសហៅ" ឱ្យធ្វើជាអ្នកដែលថ្លែងអំពីទ្រង់ (មើល នក ៧:១–២ អស ៩:៩ និងការពន្យល់)។ *ដល់អស់ទាំងសាសន៍* ទោះទាំងអ្នកជិតខាងរបស់ពួកយូដា គឺត្រូវតែយកចិត្តទុកដាក់មុនដំបូងគេ (មើល ២៥:៨–៣៨ ជំពូក ៤៦–៥១) ដោយមិនរាប់បញ្ចូលពួកយូដានោះទេ ។

**១:៦** *មើល ទូលបង្គំគ្មានវោហារអធិប្បាយទេ* ដូចជាលោកម៉ូសេ (មើល នក ៤:១០ និងការពន្យល់) លោកយេរេមាបានប្រកាសថា គាត់មិនមានសមត្ថភាព ធ្វើជាហោរាបានទេ ទោះជាយ៉ាងណាក៏ដោយ ព្រះទ្រង់បានតាំងគាត់ឱ្យធ្វើជាអ្នកដែលថ្លែងពីទ្រង់ (១៥:១៩)។ *ដ្បិតទូលបង្គំជាក្មេងសុទ្ធ* មើល ១ពវ ៣:៧ យរ ព្រះអម្ចាស់ទ្រង់បដិសេធន៍ភ្លាម ចំពោះការដែលលោកយេរេមាប្រកែកថា លោកមិនអាចធ្វើបាននោះ (ខ.៧) ។

**១:៧** យុវជន និងមនុស្សដែលគ្មានបទពិសោធន៍ កុំឱ្យបង្ខូចតំលៃខ្លួនឡើយ ថាខ្លួនមិនអាចធ្វើបាន នៅពេលដែលព្រះទ្រង់ត្រាស់ហៅនោះ (មើល ១ធថ ៤:១២) ព្រះទ្រង់ជាអ្នកហ៊ឹកហ្វឺន និងជួយគាំទ្រដល់អស់អ្នកដែលទ្រង់ ប្រទានអំណាចឱ្យធ្វើបេសកកម្ម ។

**១:៨** *កុំឱ្យខ្លាចគេឡើយ* មើល ១០:៥ ៣០:១០ ៤០:៩ ៤២:១១ ៤៦:២៧–២៨ ៥១:៤៦ មើលផងដែរ អស ៣៥:៤ និងការពន្យល់ ៤១:១០ ១៣–១៤ ៤៣:១ សផ ៣:១១ ហក ២:៥ ។ *ដ្បិតអញនៅជាមួយ* មើល ខ.១៩ ១៥:២០ សេចក្ដីសន្យារបស់ព្រះចំពោះវត្តមានទ្រង់ នៅតែគង់នៅជាមួយហោរាពេលដែលគេមានការស្ទាក់ស្ទើរ និងការភ័យខ្លាចនោះ(មើល លក ២៦:៣ នក ៣:១២–១៥ យស ១:៥ និងការពន្យល់) ។ *ដើម្បីនឹងជួយឱ្យឯងរួច* មើល ខ.១៩ ១៥:២០ ៣៩:១៧ ព្រះអម្ចាស់មិនបានសន្យាថា លោកយេរេមានឹងមិនមានការបៀតបៀន រឺត្រូវបានគេចាប់ដាក់គុកនោះទេ ប៉ុន្តែរូបកាយជីវិតរបស់គាត់ មិនត្រូវវិនាសអន្តរាយនោះឡើយ ។

**១:៩** *ទ្រង់លូកព្រះហស្តមកពាល់មាត់ខ្ញុំ* ចំពោះទស្សនៈនៃសេចក្ដីទំនាយ (មើលការពន្យល់ ខ.១១) ។ ការប្រៀបធៀប–ទាំងពីរ (ធៀបនឹង អស ៦:៧) ។ *អញបានដាក់ពាក្យរបស់អញនៅក្នុងមាត់របស់ឯងហើយ* បន្តការនិយាយបានចាប់ផ្ដើមនៅក្នុងសម័យជំនាន់ដើម ឱ្យដឹងអំពីការរៀបរាប់អំពីចំណាត់ថ្នាក់ នៃការទំនាក់ទំនងគ្នា រវាងព្រះអម្ចាស់ និងហោរារបស់ទ្រង់ ( មើល ៥:១៤ នក ៤:១៥ ជន ២២:៣៨ ២៣:៥ ១២,១៦ ចទ ១៨:១៨ អស ៥១:១៦ ធៀបនឹង ២ពត ១:២១) ។

**១:១០** *អញតាំងឯង* មើលការពន្យល់ ខ.៥ ។ *ដើម្បីឱ្យបានដករំលើង រុះទំលាក់ ហើយបំផ្លាញរំលំចុះ ព្រមទាំងសង់ឡើងវិញ ហើយដាំទៀតផង* មើល ១២:១៤–១៥,១៧ ១៨:៧–១០ ២៤:៦ ៣១:២៨ ៤២:១០ ៤៥:៤ កិរិយាស័ព្ទ២ដំបូង គឺប្រយោគបដិសេធន៍ បញ្ជាក់ការពិត ដែលលោកយេរេមាធ្វើជាហោរាមុនគេ ដើម្បីដករំលើង រុះទម្លាក់ បំផ្លាញរំលំចុះ ដោយចង្អុលបង្ហាញថា គាត់ក៏បានតាំងឡើងផងដែរ ឱ្យធ្វើជាហោរានៃការសាងសង់ឡើងវិញ ហើយដាំទៀតផង ។ កិរិយាស័ព្ទទី១គឺ "ដករំលើង" គឺផ្ទុយពី "ដាំ" និងកិរិយាស័ព្ទ ("រុះទម្លាក់ បំផ្លាញ រំលំចុះ" ផ្ទុយពី "សង់ឡើងវិញ" ។

**១:១១** *តើឯងឃើញអ្វីនុ៎ះ* ព្រះអម្ចាស់បានមានបន្ទូល (តំណាងពីទ្រង់) ដើម្បីបង្ហាញពីទស្សនៈសេចក្ដីទំនាយ ដែលទាយទុកជាមុន (មើល ខ.១៣ អម ៧:៨ ៨:២ អគ ៤:២ ៥:២) ។

**១:១២** *ឯងបានឃើញ* មើលការពន្យល់ ដូចជាដើមប្រេងខ្យល់ (ខ.១១) សេចក្ដីហិនវិនាសនៅដើមឆ្នាំ ( ដូច្នេះ "ភ្ញាក់ឡើង" ពីព្រឹក –ពាក្យហេព្រើរសម្រាប់ពាក្យ "បានឃើញ" មានន័យថា ការចាំយាម) ដូច្នេះព្រះអម្ចាស់ទ្រង់តែងតែទតមើល ដើម្បីឱ្យប្រាកដថាព្រះបន្ទូលទ្រង់ ពិតជាបានសម្រេច ។

**១:១៣** *ថ្លាងទឹក* ពាក្យហេព្រើរសម្រាប់ពាក្យនេះ ត្រូវបានបកប្រែថា" ខ្ទះដែក" នៅក្នុង យប ៤១:៣១ ហើយបង្ហាញពីទំហំធំរបស់វា (មើល អគ ២៤:៣–៥) ។

**១:១៤** *នឹងកើតមានការអាក្រក់* មើលការពន្យល់ អស ៤១:២៥ ។ *ផុសចេញពីទិសខាងជើង* ពាក្យហេព្រើរសម្រាប់ពាក្យនេះ មានសំលេងដូចគ្នាទៅនឹងពាក្យ"ការដាំទឹក"នៅក្នុង ខ.១៣ ។ *ពួកអ្នកស្រុក* ពួកយូដា (មើល ខ.១៥) ។

**១:១៥** *នគរទាំងប៉ុន្មាននៅខាងជើង* ចាប់តាំងពីពួកអាសើរីបានចោទសួ

យេរូសាឡិម ទល់នឹងកំផែងទីក្រុងព័ទ្ធជុំវិញ ហើយទល់នឹង
ទីក្រុងរបស់ស្រុកយូដាទាំងអស់ផង នេះជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា[រ] ១៦នោះអញនឹងធ្វើទោស[ល]ដល់ទីក្រុងទាំងនោះ
ដោយព្រោះសេចក្តីទុច្ចរិត[វ]របស់គេទាំងប៉ុន្មាន គឺដែលគេ
បានបោះបង់ចោលអញ[ស] ហើយបានដុតកំញានថ្វាយដល់
ព្រះដទៃ[ហ] ព្រមទាំងថ្វាយបង្គំ[ឡ]ចំពោះរបស់ដែលដៃខ្លួន គេ
បានធ្វើផង[អ] ១៧ដូច្នេះ ចូរឱ្យឯងក្រវាត់ចង្កេះ ហើយក្រោក
ឡើង ទៅប្រាប់[ក]ដល់គេ តាមគ្រប់ទាំងសេចក្តីដែលអញ
បង្គាប់ឯងចុះ កុំឱ្យស្រយុតចិត្ត[ខ]ចំពោះគេឡើយ ក្រែងអញ
ធ្វើឱ្យឯងស្រយុតចិត្តនៅមុខគេជាពិត ១៨ដ្បិតមើល នៅថ្ងៃ
នេះ អញបានតាំងឯងឡើង[គ] ទុកជាទីក្រុងត្រៀមដោយ
គ្រឿងចំបាំង ជាសសរដែក ហើយជាកំផែងលង្ហិន សំរាប់
តនឹងស្រុកទាំងមូល និងស្តេចទាំងប៉ុន្មាននៃសាសន៍យូដា
ព្រមទាំងតនឹងពួកចៅហ្វាយ និងពួកសង្ឃ ហើយនិងបណ្តា
ជនទាំងឡាយនៅស្រុកនេះផង ១៩គេនឹងតនឹងឯងតែមិន
ឈ្នះឯងឡើយ[ឃ] ដ្បិតអញនៅជាមួយ[ង] ដើម្បីនឹងជួយ[ច]ឯងឱ្យ
រួច នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

### ពួកអ៊ីស្រាអែលលះចោលព្រះអម្ចាស់

**២** ១ព្រះបន្ទូល[ក]នៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា ២ចូរទៅ
ចុះ ហើយស្រែកដាក់ត្រចៀកពួកក្រុងយេរូសាឡិមថា ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ គឺអញនឹកចាំពីឯងកាលនៅ
ក្មេង[ខ] ដែលឯងមានចិត្តក្លួចចំពោះអញ ហើយពីសេចក្តី
ស្រឡាញ់របស់ឯង កាលទើបនឹងបានគ្នា គឺដែលឯងបាន
ដើរតាមអញ នៅក្នុងទីរហោស្ថាន[គ] ជាកន្លែងដែលឥត
មានអ្នកណាសាបព្រោះឡើយ ៣គ្រានោះ អ៊ីស្រាអែលជា
ពួកបរិសុទ្ធ[ឃ]ដល់ព្រះយេហូវ៉ា[ង] ជាផលដំបូង[ច]នៃសេចក្តី

**១:១៥** រ យរ ៤:១២ ៩:១១ ១០:២២ **១:១៦** ល យរ ៤:១២ វ លប ៦:៥ យរ ៤៤:៥ ស យរ ២:១៣ ១៧:១៣ ហ នក ២០:៣ យរ ៧:៩ ១៩:៤ ៤៤:៣ ឡ ជន ២៥:៣ អ ទដ ១១៥:៤–៨ ១៣៥:៥ **១:១៧** ក ខ.៧ យរ ៧:២៧ ២៦:២,១៥ ៤២:៤ ខ ចទ ៣១:៦ ២ពវ ១:១៥ **១:១៨** គ អស ៥០:៧ **១:១៩** ឃ ទដ ១២៩:២ ង លប ២៦:៣ អស ៤២:២ យរ ២០:១១ ច ខ.៨

សភ ២០:២២ កច ២៦:១៧ **២:១** ក អស ៣៨:៤ អគ ១:៣ មីក ១:១ **២:២** ខ ទដ ៧១:១៧ អស ៥៤:៤ យរ ៣:៤ អគ ១៦:៨–១៤,៦០ ហស ២:១៥ ១១:១ វវ ២:៤ គ នក ១៣:២១ ចទ ១:១៩ **២:៣** ឃ ចទ ៧:៦ ង នក ១៩:៦ ចទ ៧:៦ ច លវ ២៣:៩–១៤ យស ១:១៨ វវ ១៤:៤

---

គំរាមតិចតួចដល់ពួកយូដា ក្រោយពីការស្លាប់របស់អ័ស្នាផារ នៅឆ្នាំ ៦២៧ គ.ស ដោយសំដៅទៅលើពួកបាប៊ីឡូន និងសម្ព័ន្ធមិត្ររបស់គេ ។ *ហើយគេនឹងមកតាំងបល្ល័ង្ករបស់គេរៀងខ្លួន នៅត្រង់មាត់ទ្វារក្រុងយេរូសាឡិម* ដើម្បីសម្រេចតាមក្រិត្យវិន័យ មើល ៣៩:៣ ។ ទ្វារនៃទីក្រុង ជាទីកន្លែងដែលពួកក្រុមប្រឹក្សាបានធ្វើឡើង (មើលការពន្យល់ លប ១៩:១ នរ ៤:១) ពួកបាប៊ីឡូនដាក់ជំនួសអ្នកគ្រប់គ្រងរបស់គេនៅជាមួយពួកយូដា (ធៀបនឹង ៤៣:១០ ៤៩:៣៨) ។

**១:១៦** *នោះអញនឹងធ្វើទោសដល់ទីក្រុងនោះ* ព្រះសោយរាជ្យលើរាស្ត្ររបស់ទ្រង់ ហើយធ្វើការជំនុំជម្រះតាមអំពើបាបដែលគេប្រព្រឹត្ត ដោយប្រើពួកបាប៊ីឡូនជាអ្នកតំណាងពីទ្រង់ ក្នុងការជំនុំជម្រះនោះ ។ *ហើយបានដុតកំញានថ្វាយដល់ព្រះដទៃ* នៅក្នុងលក្ខណៈមួយដែលគេថ្វាយបង្គំដល់រូបព្រះ (ឧទា. ៧:៩ ១១:១២–១៣,១៧ ១៨:១៥ ១៩:១៣ ៣២:២៩ ៤៤:១៧) ។ *ចំពោះរបស់ដែលដៃខ្លួនគេបានធ្វើផង* គឺរូបព្រះ (មើល ១៦:១៩–២០ ២៥:៦ ២ពវ ២២:១៧ ២រប ៣៣:២២ អស ៤៦:៦) ។

**១:១៧** *ដូច្នេះ ចូរឱ្យឯងក្រវាត់ចង្កេះ ហើយក្រោកឡើងទៅប្រាប់គេ* "ដោយដាក់ខ្សែក្រវាត់នៅជាប់នឹងចង្កេះ" មានទឹកមុខមាំមួន មើល នក ១២:១១ ១ពវ ១៨:៤៦ ២ពវ ៤:២៩ ៩:១ យប ៣៨:៣ ៤០:៧ ។

**១:១៨** *ទុកជាទីក្រុងត្រៀមដោយគ្រឿងចំបាំង* សញ្ញាអំពីសុវត្ថិភាព និងពីការដែលគេមិនអាចច្បាំងដណ្តើមយកបាន (មើល ៥:១៧ សភ ១៨:១១,១៩) ។ *ជាសសរដែក* ដែលមានតែមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ បញ្ជាក់អំពីសារៈសំខាន់នៃកម្លាំង និងអំណាច ។ *កំផែងលង្ហិន* មើល ១៥:២០ ។ លោកយេរេមាអាចទប់ទល់បាននឹងការធ្វើទុក្ខ និងការបៀតបៀន ដើម្បីបំពេញបេសកកម្មរបស់ផងព្រះ ដោយគាត់បានអំពាវនាវរកព្រះ ទោះបីជាគាត់មានខ្មាំងសត្រូវក្តីតែខ្លួនគាត់នោះរឹងមាំប្រៀបដូចជា "លង្ហិន និងដែក" (៦:២៨) ។ *ស្តេច . . . ពួកចៅហ្វាយ . . . ពួកសង្ឃ . . . និងបណ្តាជនទាំងឡាយ* ប្រជាជាតិទាំងមូល គេបានបង្ករឿងចំពោះហោរា និងព្រះ (មើលឧទាហរណ៍ ២:២៦ ២៣:៨ ៣២:៣២) ។

**១:១៩** មើលការពន្យល់ ខ.៨ និងមើលផងដែរ ១៥:២០ ។

**២:១–៦:៣០** វាជាការដែលគេបានយល់ស្របជាទូទៅថា ជំពូកទាំងអស់នេះគឺនៅក្នុងចំណោម ការនិយាយនៅក្នុងព្រះគម្ពីរយេរេមាជំនាន់ដើម បានថ្លែងក្នុងកំឡុងការគ្រងរាជ្យស្តេចយ៉ូសៀស (៣:៦) ។ សាច់រឿងសំខាន់ដែលនិយាយរួមគឺការបោះបង់សេចក្តីជំនឿរបស់ពួកយូដា (ជំពូក ២–៥) ដែលនាំឱ្យគេមិនអាចគេចផុត ពីការដាក់ទណ្ឌកម្មមកពីព្រះ តាមរយៈពួកសាសន៍ដទៃនោះ (ជំពូក ៦) ។

**២:១–៣:៥** រាស្ត្ររបស់ព្រះ គេបានប្រព្រឹត្តការអាក្រក់ ម្តងហើយម្តងទៀតយ៉ាងខ្លាំងក្លា គឺអាចរាប់ចំនួនបាន ហើយឡើងពណ៌យ៉ាងក្រមហមឆ្អិនឆ្អៅ ។

**២:១** មើលការពន្យល់ ១:២ ។

**២:២** *មានចិត្តក្លួច* នៅក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺសំដៅទៅលើភាពស្និទ្ធស្នាលបំផុត ពីចិត្តភក្តីភាព សេចក្តីស្រឡាញ់ និងការស្មោះត្រង់ ដែលសំខាន់បំផុតរវាងមនុស្ស២នាក់ ឬរវាងយើង ហើយនិងព្រះអម្ចាស់ ។ *កាលនៅក្មេង . . . កាលទើបនឹងបានគ្នា* នៅក្នុងប្រវត្តិសាស្ត្រជំនាន់ដើមពួកអ៊ីស្រាអែល គេមានក្តីអំណរ និងការប្រកបគ្នាយ៉ាងជិតស្និទ្ធជាមួយព្រះអម្ចាស់ ដែលព្រះគម្ពីរបានពិពណ៌នាថា ព្រះគឺដូចជាប្តីរបស់អ៊ីស្រាអែល (៣:១៤ ៣១:៣២ អស ៥៤:៥ ហស ២:១៦) ។ *ហើយអំពីសេចក្តីស្រឡាញ់របស់ឯង* ប៉ុន្តែក្រោយមកទៀត រាស្ត្ររបស់ព្រះបានបោះបង់ទ្រង់ចោល ហើយគេបែរទៅជាស្រឡាញ់ដល់ "ព្រះសាសន៍ដទៃវិញ" (ខ.២៥) គេបានបោះបង់ចោលសេចក្តីស្រឡាញ់ដើមរបស់គេ (ធៀបនឹង វវ ២:៤) ។ បាន *ដើរតាមអញ* តែក្រោយមកគេបានដើតតាមរូបព្រះ ដែលឥតប្រយោជន៍ (ខ.៥,៨) "រូបព្រះបាល (ខ.២៣) ។ *នៅក្នុងទីរហោស្ថាន* ភ្នំស៊ីណៃ (មើល ខ.៦) ។

**២:៣** *ពួកបរិសុទ្ធដល់ព្រះយេហូវ៉ា* គេបានញែកចេញ ដើម្បីបម្រើទ្រង់ (មើលការពន្យល់ នក ៣:៥ លវ ១១:៤៤ ចទ ៧:៦ ។ *ជាផលដំបូង* ជាផល

ចំរើនរបស់ទ្រង់ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អស់អ្នក
ណាដែលស៊ីបង្ហិន[ឆ]គេ នោះនឹងត្រូវមានទោស[ជ] សេចក្តី
អាក្រក់នឹងមកគ្របលើអ្នកនោះ ។
៤ឱពួកវង្សរបស់យ៉ាកុប នឹងអស់ទាំងគ្រួសារនៃពួក
អ៊ីស្រាអែលអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ
៥ទ្រង់មានបន្ទូលសួរថា ពួកឰយុកោរបស់ឯងរាល់គ្នាបាន
ឃើញមានសេចក្តីទុច្ចរិតយ៉ាងណានៅក្នុងអញ បានជាគេ
ថយទៅឆ្ងាយពីអញដូច្នេះ ព្រមទាំងប្រព្រឹត្តតាមសេចក្តី
ឥតប្រយោជន៍[ឈ] ហើយក៏ទៅឥតប្រយោជន៍[ញ]គ្រប់គ្នាផង
៦គេក៏មិនបានសួរថា ព្រះយេហូវ៉ា ដែលនាំយើងរាល់គ្នា
ឡើងចេញពីស្រុកអេស៊ីព្ទមក[ដ] ហើយបាននាំយើងដើរកាត់
ទីរហោស្ថាន[ឋ] ជាកន្លែងដែលមានសុទ្ធតែវាលខ្សាច់[ឌ] និង
ជង្ហុក គឺជាទីមានតែដីហួតហែង និងម្លប់នៃសេចក្តីស្លាប់
ទទេ ជាកន្លែងដែលឥតមានមនុស្សដើរកាត់[ឍ] ឬមនុស្ស
ណាអាស្រ័យនៅឡើយ តើទ្រង់នៅឯណា ៧អញក៏បាននាំឯង
រាល់គ្នាចូលទៅក្នុងស្រុកដ៏សំបូរ ដើម្បីឱ្យបានបរិភោគផល
និងរបស់ល្អនៃស្រុកនោះ[ណ] ប៉ុន្តែកាលឯងរាល់គ្នាបាន
ចូលទៅហើយ នោះបានធ្វើឱ្យស្រុកអញទៅជាស្មោកគ្រោក
ហើយឱ្យមរដករបស់អញបានត្រឡប់ជាទីស្អប់ខ្ពើមវិញ[ត]
៨ពួកសង្ឃក៏មិនបានសួរថា តើព្រះយេហូវ៉ាទ្រង់គង់នៅ
ឯណាដែរ គឺពួកអ្នកដែលកាន់ប្រើក្រិត្យវិន័យគេមិនបាន
ស្គាល់អញទេ[ថ] ពួកគ្រប់គ្រង[ទ]បានប្រព្រឹត្តរំលងនឹងអញ
ហើយពួកហោរាបានទាយ ដោយព្រះបាលផង[ធ] គេបានដើរ
តាមតែរបស់ដែលឥតមានប្រយោជន៍អ្វីសោះ[ន] ។
៩ហេតុដូច្នេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញនឹង

**២:៣** ឆ អស ៤១:១១ យរ ១០:២៥ ៣០:១៦ ជ យរ ៥០:៧ **២:៥** ឈ ចទ ៣២:២១ ១សយ ១២:២១ ទដ ៣១:៦ ញ ២ពវ ១៧:១៥ **២:៦** ដ នក ៦:៦ ហស ១៣:៤ ឋ ចទ ១:១៩ ឌ ចទ ៣២:១០ ឍ យរ ៥១:៤៣ **២:៧** ណ ជន ១៣:២៧ ចទ ៨:៧–៩ ១១:១០–១២ ត ទដ ១០៦:៣៤–៣៩ យរ ៣:៩ ៧:៣០ ១៦:១៨ អគ ១១:២១ ៣៦:១៧ **២:៨** ថ ១សយ ២:១២ យរ ៤:២២ ទ យរ ៣:១៥ ២៣:១ ២៥:៣៤ ៥០:៦ ធ ១ពវ ១៨:២២ ន ខ.២៥ អស ៤០:១៩ ៥៦:១០ យរ ៥:១៩ ៩:១៤ ១៦:១៩ ២២:៩

ផ្លែដំបូងយ៉ាងល្អបំផុត សម្រាប់អ៊ីស្រាអែល ផលដំណាំនោះ គេត្រូវនាំយកទៅថ្វាយព្រះអម្ចាស់ (មើល នក ២៣:១៩ មើល ចទ ១៨:១២ ២របា ៣១:៥ អគ ៤៤:៣០ ហើយពួកអ៊ីស្រាអែលគឺជាផលដំបូង និងជាទ្រព្យសម្បត្តិ ដែលទ្រង់ជ្រើសរើស (ធៀបនឹង យក ១:១៨ វវ ១៤:៤ និងការពន្យល់ ។ *សេចក្តីអាក្រក់នឹងមកគ្រប់លើអ្នកនោះ* មើលឧទាហរណ៍ ១៧:៨–១៦ ។

**២:៤** *ចូរស្តាប់* ការស្តាប់បង្គាប់ព្រះ ធ្វើតាមសេចក្តីទំនាយនោះ ការរំឭកដាស់តឿនដល់រាស្ត្ររបស់ព្រះ ព្រមទាំងដល់អស់ទាំងសាសន៍ផងដែរ ពេលចូលដល់ទីកាត់ក្តីរបស់ទ្រង់ ដើម្បីរំឭកគេ អំពីកាតព្វកិច្ចដ៏ត្រឹមត្រូវ ហើយជាការចាំបាច់ នោះគេអាចរួចផុតពីការជំនុំជម្រះ (មើលឧទាហរណ៍ ៧:២ ១៧:២០ ១៩:៣ ២១:១១ ២២:២,២៩ ៣១:១០ ៤២:១៥ ៤៤:២៤,២៦ អស ១:១០ អគ ១៣:២ ហស ៤:១ អម ៧:១៦) ។

**២:៥** *ទ្រង់មានបន្ទូលសួរថា* នេះជាការថ្លែងចំពោះព្រះបន្ទូលរបស់ព្រះ ការសម្តែងព្រះបន្ទូលរបស់ព្រះ តាមរយៈហោរា ។ ទោះបីជាគេបានជួបជារឿយៗក្តី តែគេនៅតែដាក់ព្រំខ័ណ្ឌចំពោះលោកយេរេមា លោកអេសាយ (ឧទាហរណ៍ ៧:៧) អេសេគាល(ឧទាហរណ៍ ២:៤) លោកអេម៉ុស (ឧទាហរណ៍ ១:៣) លោកអូបាឌា (ឧទាហរណ៍ ជំពូក១) លោកមីការ (៣:៥) លោកណាហ៊ុម (១:១២) លោកហាកាយ (ឧទាហរណ៍ ១:២) លោកសាការី (ឧទាហរណ៍ ១:៣) និងលោកមីការ (១:៤) ។ គេថយទៅឆ្ងាយពីអញមើល ៤:១ ២៣:១៣,៣២ ៣១:១៩ ៥០:៦ អស ៥៣:៦ អគ ៣៤:៤–៦,១៦ ១ពត ២:២៥ ។ *ប្រព្រឹត្តតាមសេចក្តីឥតប្រយោជន៍* មើល ខ.៨,២៣ មើលផងដែរការពន្យល់ ខ.២ "សេចក្តីឥតប្រយោជន៍" ជាផ្លូវដែលលោកយេរេមាពេញចិត្តបរិយាយអំពីរបស់ឥតប្រយោជន៍ គឺរូបព្រះ (៨:១៩ ១០:៨,១៥ ១៤:២២ ១៦:១៩ ៥១:១៨) ។ *ហើយក៏ទៅជាឥតប្រយោជន៍គ្រប់គ្នា* មើល ២ពវ ១៧:១៥ ពួកអ្នកដែលថ្វាយបង្គំរូបព្រះ នោះគេមិនល្អជាងរូបព្រះដែលគេថ្វាយបង្គំឡើយ (មើល ទដ ១១៥:៨ និងការពន្យល់) ។

**២:៦** *ព្រះយេហូវ៉ាដែលនាំយើងរាល់គ្នាឡើងចេញពីស្រុកអេស៊ីព្ទ* ព្រះអម្ចាស់ ដែលជាអ្នករំដោះអ៊ីស្រាអែល (មើលការពន្យល់ លប ២:៤ នក ៣:១៥) ទ្រង់បានរំដោះរាស្ត្រទ្រង់ចេញពីទឹកដីអេស៊ីព្ទ ដូច្នេះគេត្រូវបម្រើទ្រង់តែមួយប៉ុណ្ណោះ (នក ២០:២–៦) ។ *ដែលនាំ* ដូចជាអ្នកគង្វាលនាំចៀម (មើល ខ.១៧ ចទ ៨:១៥ ទដ ២៣:២–៣) ។ *ទីរហោស្ថាន ជាទីកន្លែងដែលមានសុទ្ធតែវាលខ្សាច់ និងជង្ហុក គឺជាទីមានតែដីហួតហែង និងម្លប់នៃសេចក្តីស្លាប់* ទីរហោស្ថាន តែងតែជានិមិត្តរូបអំពីសេចក្តីងងឹត ជាមួយអ្នកចូលរួមនឹងការអាក្រក់ និងសេចក្តីស្លាប់(មើល ខ.១៣ និងការពន្យល់ ៩:១០ ១២:១២ ១៧:៦ ២៣:១០ ទដ ៤៤:១៩) ។

**២:៧** *ស្រុកដ៏សំបូរ* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ ។ *ការមែល* (Karmel) បានមកប្រែថា "ផលផ្លែឈើ" នៅក្នុង ៤៨:៣៣ ហើយត្រូវបានគេប្រើផងដែរ ដូចជាឈ្មោះទីកន្លែង (មើល អស ៣៣:៩ និងការពន្យល់)។ នាំឱ្យមាន "ដីដែលសំបូរភោគផល" នៅក្នុង ៤:១២ វាជាស្រុកដែលនៅទល់មុខនឹងវាលរហោស្ថាន ។ *បានធ្វើឱ្យស្រុកនោះទៅជាស្មោគគ្រោក* គេរៀបចំធ្វើ ពិធីបុណ្យផ្សេងដែលស្មោគគ្រោក (មើល ៣:១–២,៩ ១៦:១៨ មើលផងដែរ ការពន្យល់នៅក្នុង លវ ៤:១២) ។ *មរដក* ទឹកដីសន្យា ដែលទ្រង់សន្យាប្រទានដល់អ៊ីស្រាអែល ទុកដូចជាកេរ្តិ៍អាករ ហើយដែលទ្រង់ប្រកបយ៉ាងជិតស្និទ្ធជាមួយនិងពួកគេ (សូមមើលជាពិសេស ១២:៧–៩,១២–១៥ ។ *ជាទីស្អប់ខ្ពើម* មើលការពន្យល់នៅក្នុង លវ ៧:២១) ។

**២:៨** គ្មានអ្នកណាគេបានស្វែងរកព្រះ (មើល ខ.៦) ។ *ពួកសង្ឃ . . . ពួកគ្រប់គ្រង់ . . . ហើយពួកហោរា* មើលការពន្យល់ ១:១៨ ។ *គឺពួកអ្នកដែលកាន់ប្រើក្រិត្យវិន័យ* ពួកសង្ឃ (មើល ចទ ៣១:១១ និងការពន្យល់) ។ *ពួកគ្រប់គ្រង* "ពួកអ្នកគង្វាល" ឃ្លានេះត្រូវបានគេប្រើសំដៅទៅលើពួកអ្នកដឹកនាំ (២៣:១–៤ ៤៩:១៩ ៥០:៤៤ មើលជាពិសេស អគ ៣៤:១–១០,២៣–២៤) ។ *ដោយព្រះបាល* នៅក្នុងឈ្មោះព្រះបាល (ធៀបនឹង ១១:២១ ១៤:១៥ ២៣:២៥ ២៦:៩ មើលការពន្យល់នៅក្នុង ពច ២:១៣) ។ *គេបានដើរតាមតែរបស់ដែលឥតមានប្រយោជន៍អ្វីសោះ* មើល ខ.២៣ ។ *របស់ឥតប្រយោជន៍* "របស់មិនផ្តល់ផលចំណេញ" (មើល ខ.១១) ។

**២:៩** *អញនឹងតវ៉ានឹងឯងរាល់គ្នា* មើលការពន្យល់ ខ.៤ និងមើល ២៥:៣១

តវ៉ា[ប]នឹងឯងរាល់គ្នាទៀត ហើយនិងកូនចៅរបស់ឯងតទៅ
ដែរ ១០ដ្បិតមានតែឆ្លងទៅឯកោះទាំងប៉ុន្មានរបស់ពួក
គីទីម[ផ]មើល ហើយចាត់គេទៅឯស្រុកកេដារ[ព] ឱ្យពិចារណា
យ៉ាងអស់ពីចិត្ត នោះនឹងឃើញបើដែលមានអ្វីឱ្យដូចឬទេ
១១តើដែលមានសាសន៍ណាផ្លាស់ព្រះរបស់ខ្លួន ដែលមិន
មែនជាព្រះ[ភ]ផងឬទេ តែរាស្ត្ររបស់អញបានដូរព្រះដ៏ជា
សិរីល្អ[ម]របស់ខ្លួន ឱ្យបានតែរបស់ដែលឥតមានប្រយោជន៍
វិញ ១២ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱផ្ទៃមេឃអើយ
ចូរឱ្យនឹកប្លែកពីដំណើរនេះ ហើយឱ្យភ័យស្ញើមចុះ ត្រូវឱ្យ
មានចិត្តត្រមោចនៅ ១៣ដ្បិតរាស្ត្រអញបានប្រព្រឹត្តអំពើ
អាក្រក់២យ៉ាង គឺបានទាំងបោះបង់ចោល[យ]អញ ដែលជា
ក្បាល ទឹករស់[រ] ហើយបានដាប់ធ្វើអាងវិញ ជាអាងប្រេះ
បែកដែលទុកទឹកមិនបានផង ។
១៤តើអ៊ីស្រាអែលជាខ្ញុំបំរើ លោះដោយប្រាក់ ឬជាខ្ញុំ
បំរើ[ល]ដែលកើតនៅផ្ទះចៅហ្វាយ ហេតុអ្វីបានជាគេត្រូវរឹប
ជាន់ដូច្នេះ ១៥កូនសិង្ហ[វ]ទាំងប៉ុន្មានបានគ្រហឹម ហើយសន្ទាប់
ដាក់គេ ហើយបានបំផ្លាញ[ស]ស្រុក ឯទីក្រុងគេទាំង ប៉ុន្មាន
បានត្រូវឆេះ[ហ]អស់ហើយ ឥតមានអ្នកណានៅទៀត[ឡ] ១៦ពួក
ក្រុងណូព[អ] និងក្រុងតាហាពេនេស[ក] គេបានបំបែកកំពូល
ក្បាលរបស់ឯងហើយ ១៧តើឯងមិនបាននាំការនេះ មកលើ
ខ្លួនឯង[ខ]ទេឬអី ដោយឯងបានបោះបង់ចោល[គ]ព្រះយេហូវ៉ា
ជាព្រះនៃឯង ក្នុងកាលដែលទ្រង់កំពុងតែនាំឯង តាមផ្លូវ
នោះ ១៨ចុះឥឡូវនេះ តើឯងមានការអ្វី បានជាទៅតាមផ្លូវ
ទៅឯស្រុកអេស៊ីព្ទ[ឃ] ដោយប្រាថ្នាចង់ផឹកទឹកទន្លេស៊ីហោរ
ដូច្នេះ[ង] ឬមានការអ្វីតាមផ្លូវទៅឯស្រុកអាសស៊ើរ[ច] ដើម្បី
នឹងផឹកទឹកទន្លេនោះ[ឆ] ១៩អំពើទុច្ចរិតរបស់ឯង[ជ] នឹងវាយ
ផ្ចាល[ឈ]ឯង ហើយការរាថយរបស់ឯង និងស្តីបន្ទោសឯង

**២:៩** ប យរ ២៥:៣១ ហស ៤:១ មីក ៦:២ **២:១០** ផ លប ១០:៤ ព លប ២៥:១៣ **២:១១** ភ អស ៣៧:១៩ យរ ១៦:២០ កទ ៤:៨ ម ១សយ ៤:២១ រម ១:២៣ **២:១៣** យ ចទ ៣១:១៦ អស ៦៥:១១ រ អស ១២:៣ យហ ៤:១៤ **២:១៤** ល នក ៣:២២ យរ ៣១:៩ **២:១៥** វ យរ ៤:៧ ៥០:១៧ ស អស ១:៧ ហ ២ពវ ២៥:៩ ឡ លវ ២៦:៤៣ **២:១៦** អ អស ១៩:១៣ ក យរ ៤៣:៧–៩ **២:១៧** ខ យរ ៤:១៨ គ អស ១:២៨ យរ ១៧:១៣ ១៩:៤ **២:១៨** ឃ អស ៣០:២ ង យស ១៣:៣ ច ២ពវ ១៦:៧ ហស ៥:១៣ ៧:១១ ៨:៩ ឆ អស ៧:២០ **២:១៩** ជ យរ ៣:១១, ២២ ៧:២៤ ១១:១០ ១៤:៧ ហស ១៤:៤ ឈ អស ៣:៩ ៥៩:១២ ហស ៥:៥

ហស ៤:១ ១២:២ មីក ៦:២ ។

**២:១០** *ពួកគីទីម* មើលការពន្យល់ទី១នៅក្នុងខនេះ និងមើលផងដែរ ជន ២៤:២៤ អគ ២៧:៦ និងការពន្យល់ ។ *ស្រុកកេដា* តំណាងឱ្យប្រជាជាតិនៅទិសខាងកើត (មើលការពន្យល់ផងដែរ ៤៩:២៨ អស ២១:១៦) ។

**២:១១** *តើដែលមានសាសន៍ណាផ្លាស់ព្រះ* សំនួរដែលបំភ្លើសការនិយាយនេះជាក្តីរំពឹងយ៉ាងច្បាស់ ពីចម្លើយជាអវិជ្ជមាន និងការបញ្ជាក់លើអ្វី ដែលមិនគួរឱ្យជឿ ដែលពួកយូដាអនុវត្ត គេថ្វាយបង្គំរូបព្រះ ជាជាងថ្វាយបង្គំដល់ព្រះអម្ចាស់ ។ *ព្រះដ៏ជាសិរីល្អ* គឺព្រះ (មើល ទដ ១០៦:២០ ហស ៤:៧ មើលផងដែរ ១សយ ១៥:២៩) ។ របស់ដែលឥតមានប្រយោជន៍ មើលការពន្យល់ ខ.៨ ។

**២:១២** *ឱផ្ទៃមេឃអើយ ចូរឱ្យនឹកប្លែកពីដំណើរនេះ* មើលការពន្យល់ អស ១:២ មើលផងដែរ មីក ៦:១–២ និងការពន្យល់ ។ ភាសាហេព្រើរសម្រាប់ឃ្លានេះ ជាការលេងពាក្យ ស៊ូម្មូ សាម៉ាយីម (Shommu Shamayim) ។

**២:១៣** មើល ១:១៦ *គឺបានទាំងបោះបង់ចោលអញ* មើល ខ.១៩ ។ *ដែលជាក្បាលទឹករស់* មើល ១៧:១៣ ព្រះទ្រង់ប្រទានជីវិត ដោយផ្តល់អំណាចដល់រាស្ត្រទ្រង់ (មើល ទដ ៣៦:៩ មើលការពន្យល់ផងដែរ យហ ៤:១០ អស ៥៥:១ និងការពន្យល់ វវ ២១:៦) ។ *ជាអាងប្រេះបែកដែលទុកទឹកមិនបាន* អាងទឹកធ្វើឡើងដើម្បីរក្សាទឹកទុក សម្រាប់ការប្រើប្រាស់ នៅពេលណាដែលគ្មានទឹកនោះ ។ រូបព្រះ ប្រៀបដូចជាអាងទឹកដែលបែកធ្លាយទឹក ហើយអ្នកដែលថ្វាយបង្គំដល់រូបព្រះនោះ នឹងត្រូវដួលរលំ ដោយខុសពីការដែលព្រះទ្រង់ប្រទានជីវិតពេញបរិបូរដល់រាស្ត្រទ្រង់ ហើយមិនដួលរលំឡើយ ។

**២:១៤** *ឬជាខ្ញុំបំរើដែលកើតនៅផ្ទះចៅហ្វាយ* សំនួរដែលបំភ្លើសការនិយាយ (មើលការពន្យល់នៅក្នុង ខ.១១) នេះជាការរំពឹងមួយពីចម្លើយជាអវិជ្ជមាន នៅក្នុងពន្លឺនៃការរំដោះរបស់ផងព្រះ នៅក្នុងកំឡុងពេលនិក្ខមនំ (នក ៦:៦ ២០:២) ។ *គេត្រូវរឹបជាន់* ចំពោះពួកអាសេរី និងពួកអេស៊ីព្ទ (មើល ខ.១៥–១៦) ។

**២:១៥** *កូនសិង្ហ* ប្រហែលជានិម្មិតរូបពីអាសេរី (មើល ខ.១៨ ៥០:១៧ មើលការពន្យល់ផងដែរក្នុង ៤:៧ អស ១៥:៩) ។ *បានគ្រហឹម ហើយសន្ទាប់ដាក់គេ* មើល អម ៣:៤ ។ ហើយបានបំផ្លាញស្រុក មើល ៤:៧ ១៨:១៦ ៥០:៣ ។ *ឯទីក្រុងគេទាំងប៉ុន្មានបានត្រូវឆេះអស់ហើយ* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ គឺដូចគ្នានៅក្នុង ៤:៧ មានន័យថា ទីក្រុងនោះនឹងមានសេចក្តីហិនវិនាសដោយគ្មានមនុស្សរស់នៅឡើយ (ធៀបនឹង ២២:៦) ។

**២:១៦** *ពួកក្រុងណូព* មើល ៤៤:១ ៤៦:១៤,១៩ មើលការពន្យល់ផងដែរ អស ១៩:១៣ ក្រុងតាហាពេនេស ប្រហែលជាក្រោយមក ទីក្រុងនោះតាមភាសាក្រិក មានឈ្មោះថា ដេហាពេនា៉យ ដែលមានទីតាំងនៅភាគខាងត្បូងនៃបឹងមិនហ្សាឡា នៅខាងកើតតំបន់ដែនដីសន្ត ស្រុកអេស៊ីព្ទ ហើយសព្វថ្ងៃនេះត្រូវបានគេស្គាល់ថា តែល ដីនេ (Tell Defneh) (មើល ៤៣:៧–៩ ៤៤:១ ៤៦:១៤ អគ ៣០:១៨) ។ *គេបានបំបែកកំពូលក្បាលរបស់ឯងហើយ* នេះជាការប្រៀបធៀបអំពីភាពអាម៉ាស់ និងសេចក្តីហិនវិនាស (មើល ៤៧:៥ ៤៨:៣៧ មើលការពន្យល់ផងដែរ អស ៣:១៧ ៧:២០) ។

**២:១៧** *ទ្រង់កំពុងតែនាំឯង* មើលការពន្យល់ ខ.៦ ។ *តាមផ្លូវ* មើល នក ១៨:៨ ២៣:២០ ចទ ១:៣៣ ។

**២:១៨** មើល ខ.៣៦ ពួកអ៊ីស្រាអែល និងពួកយូដា គេបែរជាទៅពឹងពាក់លើពួកអេស៊ីព្ទ និងពួកអាសេរី ដែលគេដាក់ព្រំដែនចំពោះខ្លួនគេ នៅជំនាន់ពេលលោកយេរេមា (មើលឧទាហរណ៍ ហស ៧:១១ ១២:២) ។ *ប្រថ្នាចង់ផឹកទឹកទន្លេ* បានផ្តល់ឱ្យដោយពួកខ្មាំងសត្រូវ ជាតិសាសន៍នានា ឬខាងវិញ្ញាណ ជាជាងគេប្រថ្នាចង់បានព្រះនោះ (មើល ខ.១៣ អស ៨:៦–៨ និងការពន្យល់) ។

**២:១៩** *អំពើទុច្ចរិតរបស់ឯង* មើល ៣:២២ ៥:៦ ១៤:៧ ពាក្យនេះគឺសំដៅទៅលើអ្វីដែលពួកអ៊ីស្រាអែល បោះបង់ចោលនូវសេចក្តីជំនឿចំពោះព្រះ ។ *ព្រះយេហូវ៉ា ជាព្រះនៃឯង* ជាចំណងជើងអំពីព្រះ ដែលឃើញមានប្រហែល

វិញ ដូច្នេះ ចូរពិចារណា ហើយដឹងថា ការដែលឯងបាន
បោះបង់ចោល[ញ]ព្រះយេហូវ៉ា ជាព្រះនៃឯង ឥតមានចិត្ត
កោតខ្លាច[ដ]ដល់អញនៅក្នុងខ្លួន នោះជាការអាក្រក់ ក៏ជូរ
ចត់ណាស់[ឋ]ហើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា
នៃពួកពលបរិវារ ។
**២០**តាំងពីយូរមកហើយ នោះឯងបានបំបាក់នឹមឯង[ឌ]
ហើយបានផ្តាច់ចំណងឯងចេញ[ឍ] ដោយពាក្យថា យើង
មិនបំរើទៀតទេ[ណ] ដ្បិតនៅលើគ្រប់ទាំងភ្នំតូចៗ[ត] ហើយនៅ
ក្រោមគ្រប់ទាំងដើមឈើខៀវខ្ចី[ថ] នោះឯងបានដេកចុះផិត
អញ[ទ] **២១**អញបានផ្សាំ[ធ]ឯងទុកជាទំពាំងបាយជូរសិរាំង[ន] ជា
ពូជយ៉ាងល្អបំផុត ចុះធ្វើដូម្តេចឱ្យឯងបានក្លាយ[ប]ទៅជាខ្នែង
របស់ដើមទំពាំងបាយជូរដទៃ ដល់អញដូច្នេះ **២២**ដ្បិត ទោះ
បើឯងលាង[ផ]ខ្លួនដោយក្បុង[ព] ហើយប្រើសាប៊ូជាច្រើនក៏
ដោយ គង់តែព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា អំពើ
ទុច្ចរិតរបស់ឯង នៅមានកត់ជាប់ចំពោះអញនៅឡើយ
ដែរ[ភ] **២៣**ធ្វើដូចម្តេចឱ្យឯងបានថា ឯងមិនសៅហ្មងទេ[ម]
ហើយមិនបានគោរពតាមអស់ទាំងព្រះបាលសោះ[យ] ដូច្នេះ
ចូរមើលស្នាមផ្លូវដែលឯងដើរនៅវាលច្រកភ្នំ[រ] ហើយយល់ពី
ការដែលឯងបានធ្វើនោះចុះ ឯងជាសត្វអូដ្ឋក្រមុំយ៉ាង
លឿនហើយសាវ៉ា[ល] **២៤**ជាលាព្រៃក្រមុំ[វ]ដែលធ្លាប់ទៅទី
រហោស្ថាន[ស] ក៏ស្រង់ក្លិនខ្យល់ដោយមានសំរើប លុះរដូវ
កំណត់របស់វា នោះតើអ្នកណានឹងបំបែរចេញបាន អ្នក
ណាដែលរកចាប់វា នោះមិនបាច់នឿយហត់នឹងទៅតាមទេ
ដ្បិតដល់រដូវកំណត់ នោះនឹងបានប្រទះហើយ **២៥**កុំឱ្យ
ប្រថុយខ្លួនឱ្យនៅជើងទទេ ហើយខះកនោះឡើយ តែឯង
បានតបថា ឥតប្រយោជន៍ទេ[ហ] ដ្បិតខ្ញុំបានស្រឡាញ់ពួកដទៃ[ឡ]
ហើយនឹងរត់ទៅតាមគេវិញ[អ]។
**២៦**ឯចោរដែលគេទាន់ឃើញ តែងមានសេចក្តីខ្មាស[ក]
យ៉ាងណា នោះពួកវង្សអ៊ីស្រាអែល ក៏មានសេចក្តីខ្មាស
យ៉ាងនោះដែរ គឺស្តេចគេ ព្រមទាំងពួកគេ ពួកចៅហ្វាយ

**២:១៩** ញ យរ ១៩:៤ ដ ទដ ៣៦:១ ឋ យប ២០:១៤ អម ៨:១០ **២:២០** ឌ លវ ២៦:១៣ ឍ ទដ ២:៣ យរ ៥:៥ ណ យប ២១:១៤ ត អស ៥៧:៧ យរ ៣:២៣ ១៧:២ ថ ចទ ១២:២ ទ អស ១:២១ អគ ១៦:១៥ **២:២១** ធ នក ១៥:១៧ ន ទដ ៨០:៨ ប អស ៥:៤ **២:២២** ផ ទដ ៥១:២ បទ ១:៨,១៧ ព យប ៩:៣០ ភ យរ ១៧:១ **២:២៣** ម សភ ៣០:១២ យ ខ.២៥ យរ ៩:១៤ ២៣:២៧ 

រ ២ពវ ២៣:១០ យរ ៧:៣១ ១៩:២ ៣១:៤០ ល ខ.៣៣ យរ ៣១:២២ **២:២៤** វ លប ១៦:១២ យរ ១៤:៦ ស យប ៣៩:៦ **២:២៥** ហ អស ៥៧:១០ ឡ ចទ ៣២:១៦ យរ ៣:១៣ ១៤:១០ អ ខ.៨,២៣ **២:២៦** ក យរ ៤៨:២៧ បទ ១:៧ អគ ១៦:៥៤ ៣៦:៤

៧៥ដង នៅក្នុងព្រះគម្ពីរយេរេមា ហើយឃើញមានច្រើនជាងគេនៅក្នុងព្រះគម្ពីរសញ្ញាចាស់ផ្សេងទៀត (មើលការពន្យល់ ១សយ ១:៣) ។

**២:២០–៣:៦** ពួកយូដាគេបានបះបោរប្រឆាំងនឹងព្រះ យ៉ាងសកម្ម ដូចជាលោកយេរេមាបាននិយាយថា គេប្រប្រពឹត្តនោះច្រើនអនេក ។

**២:២០** ដូចជាសត្វដែលរឹងចចេស (មើល ហស ៤:១៦) ពួកយូដាបដិសេធន៍ ហើយមិនប្រព្រឹត្តតាមបទបញ្ញត្តិរបស់ផងព្រះ ។ *នោះឯងបានបំបាក់នឹម ហើយបានបំបាក់នឹមឯងចេញ* មើល ៥:៥ មើលផងដែរ ៣១:១៨ ធៀបនឹង ទដ ២:៣ ពួកយូដាគេបានធ្វើឱ្យខូចដល់ក្រិត្យវិន័យរបស់ព្រះ ហើយនិងឱ្យខូចដល់ការតាំងសញ្ញា ។ *ដ្បិតនៅលើគ្រប់ទាំងភ្នំតូចៗ ហើយនៅក្រោមគ្រប់ទាំងដើមឈើខៀវខ្ចី* ជាទីកន្លែងដែលគេថ្វាយបង្គំរូបព្រះ (មើល ១ពវ ១៤:២៣ ២ពវ ១៧:១០ អគ ៦:១៣) ។ *ដូចឯងបានដេកចុះផិត* មើល ខ.២ នក ៣៤:១៥) ។

**២:២១** មើល អស ៥:១–៧ មើលផងដែរ ទដ ៨០:៨–១៦ អគ ១៧:១–១០ អស ១០:១–២ ធៀបនឹង យហ ១៥:១–៨ ។ *ទំពាំងបាយជូរសិរាំង* មើល អស ៥:២ ភាសាហេព្រើរសម្រាប់ពាក្យនេះ គឺសំដៅទៅលើទំពាំងបាយជូរដែលល្អបំផុត ។ *ទំពាំងបាយជូរដទៃ* "ដទៃ" ទំពាំងបាយជូរជានិម្មិតរូបអំពីអ៊ីស្រាអែល ដែលគេមិនគួរដូចជាទំពាំងបាយជូរដទៃ ហើយទំពាំងបាយជូរដទៃប្រៀបដូចជាខ្មាំងសត្រូវរបស់អ៊ីស្រាអែល (មើល ចទ ៣២:៣២) ។

**២:២២** *ទោះបើឯងលាងខ្លួនដោយក្បុង ហើយប្រើសាប៊ូជាច្រើនក៏ដោយ* ការដុសខ្លួនដោយប្រើ ជាតិក្បុងលាយខនិជ និងជាតិបន្លែមានខនិជ ។ អំពើបាបត្រូវបានអត់ទោស ហើយត្រូវបោះបង់ចោល (មើល ទដ ៥១:២,៧ អស ១:១៨) ប៉ុន្តែអំពើត្រូវបានអត់ទោសឱ្យ នៅពេលណាដែលគេបានលន់តួ និងប្រែចិត្ត (មើល សភ ២៨:១៣ ធៀបនឹង ១យហ ១:៧,៩) ។

**២:២៣** *បានសៅហ្មង* ពិធីបុណ្យស្មោគគ្រោក (មើល ១៩:១៣ មើលផងដែរ ការពន្យល់ លវ ៤:១២) ។ *មិនបានគោរពតាម* មើលការពន្យល់ ខ.២ មើលផងដែរ ខ.២៥ ។ *ព្រះបាបិល* មើល ៩:១៤ និងការពន្យល់ ពច ២:១១,១៣ ។ *នៅវាលច្រកភ្នំ* ប្រហែលជាច្រកភ្នំហីនណំម (មើលការពន្យល់ ១៥:៥) ហើយវាត្រូវគេបានស្គាល់ថា ជាច្រកភ្នំបេន–ហីនណំម) (៧:៣១–៣២ ១៩:២,៦ ៣២:៣៥) ។ *យ៉ាងលឿន ហើយសាវ៉ា* ពួកយូដាគួរតែគោរព ស្តាប់បង្គាប់ព្រះអម្ចាស់ ដោយគេមិនត្រូវងាកឆ្វេង ឬស្តាំឡើយ (ចទ ២៨:១៤) ។

**២:២៤** *ជាលាព្រៃ* វាជាសត្វលាព្រៃ ដែលពិបាកគ្រប់គ្រង (មើល លប ១៦:១២) ហើយវាជាសត្វដែលពិបាកបង្ហាត់ (មើល យប ៣៩:៥–៨) ។ *ដែលធ្លាប់នៅទីរហោស្ថាន* មើល ១៤:៦ យប ២៤:៥ ។ *ក៏ស្រង់ខ្លិនខ្យល់* នេះជារូបភាពមួយដែលសត្វលាវាស្រង់ខ្លិនខ្យល់ វាមិនដេកនៅស្ងៀម១កន្លែង (មើល ហស ២:៧,១៣) ។

**២:២៥** *កុំឱ្យប្រថុយខ្លួនឱ្យនៅជើងទទេ* អ្នកត្រូវពាក់ស្បែកជើងរបស់អ្នក ឥតប្រយោជន៍ទេ មើល ១៨:១២ និងការពន្យល់ ។ *ដ្បិតខ្ញុំបានស្រឡាញ់ពួកដទៃ* ដោយផ្ទុយពីសេចក្តីស្រឡាញ់ ដែលពួកយូដាគេបានជឿជាក់ថា ព្រះនៅក្រោមលក្ខខ័ណ្ឌនៃការទំនាក់ទំនងនៃការតាំងសញ្ញា (មើលឧទាហរណ៍ ចទ ៦:៥ ៧:៩ ហស ២:១៦ និងមើលផងដែរ នក ៣៩:១៥ និងការពន្យល់) ។ *ហើយនឹងរត់ទៅតាមគេវិញ* ។ មើល ខ.២៣ មើលផងដែរ ខ.២) ។

**២:២៦** *តែងមានសេចក្តីខ្មាសយ៉ាងណា* មើលឧទាហរណ៍ នក ២២:៣–៤ ។ ព្រះគម្ពីរភាសារហេព្រើរសម្រាប់ពាក្យនេះ "ចិត្តខ្មាស់" វាមានន័យថា "សេចក្តីអាមាស់" ហើយពាក្យនេះត្រូវបានគេប្រើ ដែលមានន័យដូចជាពាក្យនាំឱ្យគេ មើលងាយ ដល់ឈ្មោះព្រះបាល ជាមេចោរព្រះ សាសន៍កាណាន (មើល ១១:១៣ និងការពន្យល់ ហស ៩:១០ មើលការពន្យល់ផងដែរ ពច ៦:៣២) ។ *ស្តេច ពួកចៅហ្វាយ ពួកសង្ឃនិងពួកហោរា* មើលការពន្យល់

ពួកសង្ឃ[ខ] និងពួកហោរារបស់គេផង[គ] ២៧ជាពួកអ្នកដែល
និយាយដល់ដុំឈើថា[ឃ] លោកជាឪពុកខ្ញុំ ហើយដល់ដុំថ្ម[ង]ថា
លោកបានបង្កើតខ្ញុំ ពីព្រោះគេបានបែរខ្នង[ច]ឱ្យអញ មិន
ហ៊ានបែរមុខឡើយ[ឆ] ប៉ុន្តែដល់គ្រាដែលគេកើតមានសេចក្ដី
វេទនា[ជ] នោះគេនឹងអំពាវនាវដល់អញថា សូមទ្រង់ក្រោក
ឡើងជួយសង្គ្រោះ[ឈ]យើងខ្ញុំផង ២៨ឯព្រះ[ញ]ដែលឯងបានធ្វើ
សំរាប់ខ្លួន តើនៅឯណា ចូរឱ្យវាក្រោកឡើងជួយឯងចុះ
បើវាអាចនឹងជួយសង្គ្រោះឯង ក្នុងគ្រាដែលឯងកើតមាន
សេចក្ដីវេទនានោះបាន[ដ] ដ្បិត ឱពួកយូដាអើយ ចំនួនព្រះ
របស់ឯង នោះប្រមាណស្មើនឹងទីក្រុង[ឋ]របស់ឯងដែរ ។
២៩ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ហេតុអ្វីបានជាឯង
រាល់គ្នាចង់តនឹងអញដូច្នេះ ឯងរាល់គ្នា[ឌ]បានរំលងចំពោះ
អញហើយ ៣០ការដែលអញបានវាយផ្ចាលពួកកូនចៅឯង
នោះជាឥតអំពើទេ[ឍ] វាមិនព្រមរាងចាលឡើយ គឺជាដាវ
របស់ខ្លួនឯងរាល់គ្នា ដែលបានត្របាក់លេបពួកហោរា[ណ]
របស់ឯង ដូចជាសិង្ហដែលហែកបំផ្លាញវិញ ៣១ឱដំណ
មនុស្សនេះអើយចូរក្រឡេកមើលព្រះបន្ទូលនៃព្រះយេហូវ៉ា
ចុះតើអញបានដូចជាទីរហោស្ថាន ដល់សាសន៍អ៊ីស្រាអែល
ឬជាទីងងឹតសូន្យសុងឬអី[ត] ហេតុអ្វីបានជារាស្ត្រអញ ពោល
ថា យើងបានផ្តាច់ចំណង ហើយយើងមិនព្រម មកឯទ្រង់
ទៀតឡើយដូច្នេះ[ថ] ៣២តើស្រីក្រមុំនឹងភ្លេចគ្រឿងប្រដាប់
របស់ខ្លួនបានឬ តើប្រពន្ធថ្មោងថ្មីនឹងភ្លេចគ្រឿង តែងខ្លួន
សំរាប់រៀបការបានឬអី ប៉ុន្តែរាស្ត្ររបស់អញបានភ្លេច[ទ]
អញជាយូរថ្ងៃវិញ និងរាប់មិនបានឡើយ ៣៣ឯងប្រសប់
អ្វីម្ល៉េះ និងរៀបផ្លូវរក[ធ]សេចក្ដីស្រឡាញ់ដូច្នេះ ឯងបាន
ទាំងបង្រៀនពួកស្រីៗអាក្រក់ តាមផ្លូវរបស់ឯងដែរ ៣៤១
ទៀតនៅជាយអាវឯង នោះឃើញមានឈាម[ន]របស់មនុស្ស
ក្រីក្រ ជាអ្នកដែលឥតមានទោសផង អញមិនបានដឹងដោយ
ស៊ើបសួររកបែបសំងាត់ទេ[ប] គឺបានឃើញដោយអំពើទាំង
នេះវិញ ៣៥ប៉ុន្តែឯងថា ខ្ញុំគ្មានទោសទេ[ផ] ប្រាកដជាសេចក្ដី
ខ្ញាល់របស់ទ្រង់បានបែរចេញពីខ្ញុំហើយ មើល អញនឹង
កាត់ទោស[ព]ឯងដោយព្រោះឯងថា ឯងគ្មានធ្វើបាបឡើយ
ដូច្នេះ[ភ] ៣៦ហេតុអ្វីបានជាឯងអាល័យតែដើរចុះឡើង ដើម្បី
បំផ្លាស់[ម]កិរិយារបស់ឯង ឯងនឹងត្រូវមានសេចក្ដីខ្មាស
ចំពោះស្រុកអេស៊ីព្ទ[យ] ដូចជាឯងបានខ្មាស ចំពោះស្រុក
អាសស៊ើរដែរ ៣៧ហើយឯងនឹងត្រូវចេញពីស្រុកនោះទៅ
ទាំងដៃខ្ទប់ក្បាល[រ] ពីព្រោះព្រះយេហូវ៉ាទ្រង់មិនព្រមទទួល

**២:២៦** ខ អគ ២២:២៦ គ យរ ៣២:៣២ ៤៤:១៧,២១ **២:២៧** ឃ យរ ១០:៨ ង យរ ៣:៩ ច ១ពវ ១៤:៩ ២របា ២៩:៦ ទដ ១៤:៣ អគ ៨:១៦ ឆ យរ ១៨:១៧ ៣២:៣៣ អគ ៧:២២ ជ ពច ១០:១០ អស ២៦:១៦ ឈ អស ៣៧:២០ ហស ៥:១៥ **២:២៨** ញ អស ៤៥:២០ ដ ចទ ៣២:៣៧ អស ៤០:១៩ ឋ ២ពវ ១៧:២៩ **២:២៩** ឌ យរ ៥:១ ៦:១៣ ដយ ៩:១១ មីក ៣:១១ ៧:២ **២:៣០** ឍ លវ ២៦:៣៣ ណ នហ ៩:២៦ យរ ១១:២១ កច ៧:៥២ ១ថន ២:១៥

**២:៣១** ត អស ៤៥:១៩ ថ យប ២១:១៤ **២:៣២** ទ ចទ ៣២:១៨ អស ៥៧:១១ **២:៣៣** ធ ខ.២៣ **២:៣៤** ន ២ពវ ២១:១៦ សភ ៦:១៧ ប នក ២២:២ **២:៣៥** ផ សភ ៣០:១២ ព អស ៦៦:១៦ យរ ២៥:៣១ ៣៩:៧ ៤៥:៥ អគ ១៧:២០ ២០:៣៥ យអ ៣:២ ភ ២សយ ១២:១៣ ១យហ ១:៨,១០ **២:៣៦** ម យរ ៣១:២២ យ ទដ ១០៨:១២ អស ៣០:២,៣,៧ យរ ៣៧:៧ **២:៣៧** រ ២សយ ១៣:១៩

១:១៨) ។

**២:២៧** មើល អស ៤៤:១៣–១៧ ខុសពី ចទ ៣២:៦,១៨ អស ៦៤:៨ មីក ២:១០ ។ *ដល់ដុំឈើ . . . ដល់ថ្មដា* ជាសម្ភារៈដែលគេប្រើសំរាប់ធ្វើរូបព្រះ (មើល ៣:៩ និងការពន្យល់) ។ *សូមទ្រង់ក្រោកឡើង ហើយជួយសង្គ្រោះ* មើល ខ.២៨) ។

**២:២៨** *ចំនួនព្រះរបស់ឯង នោះប្រមាណស្មើនិងទីក្រុងរបស់ឯងដែរ* មើល ១១:១៣ ធៀបនឹង ១កថ ៨:៥ ពួកអ្នកនៅជិនាន់បុរាណនៅខាងកើតជាទីក្រុងសំខាន់ គេមានទីកន្លែងសម្រាប់ថ្វាយបង្គំព្រះ (ធៀបនឹង កច ១៩:២៨,៣៤–៣៥ មានទីក្រុងជាច្រើនបានដាក់ឈ្មោះតាមទីកន្លែងថ្វាយបង្គំនោះ (មើលឧទាហរណ៍ ការពន្យល់ ១:១) ។

**២:២៩** *ហេតុអ្វីបានជាឯងរាល់គ្នាចង់តនឹងអញយ៉ាងដូច្នេះ* ធៀបនៅក្នុង ខ.៩ មើល ១២:១ យប ៣៣:១៣) ។

**២:៣០** *ការដែលអញបានវាយផ្ចាលពួកកូនចៅឯង* ធៀបនឹង ហព ១២:៦ វាមិនព្រមរាងចាលឡើយ មើល ៥:៣ ដាវរបស់ខ្លួនឯងរាល់គ្នា ដែលបានត្របាក់ពួកហោរា មើលឧទាហរណ៍ ២៦:២០–២៣ ២ពវ ២១:១៦ ២៤:៤ មើលផងដែរ នហ ៩:២៦ ។

**២:៣១** *ឱតំណមនុស្សនេះអើយ* វាមានន័យអាថ៌កំបាំង (មើលឧទាហរណ៍ ចទ ១:៣៥ ៣២:៥ មថ ១២:៣៩ ១៦:៤ ១៧:១៧ កច ២:៤០ ភល ២:១៥ ហព ៣:១០) ។ *តើអញបានដូចជាទីរហោស្ថាន . . . ឬជាទីងងឹតសូន្យសុងឬអី* ពាក្យផ្ទុយ ព្រះអម្ចាស់ទ្រង់បាននាំរាស្ត្ររបស់ទ្រង់ឆ្លងកាត់វាលរហោស្ថាន ហើយងងឹតសូន្យ (ខ.៦) ។ ឃ្លាថា "ទីងងឹតសូន្យ" ការបកប្រែភាសាហេព្រើរ "ភាពងងឹតសូន្យរបស់ព្រះអម្ចាស់" (ឧទាហរណ៍ ព្រះអម្ចាស់ជាអ្នកបញ្ជូនភាពងងឹតធៀបនឹង ១សយ ២៦:១២) ដូចជា "អណ្តាតភ្លើងខ្លាំង" នៅ សស ៨:៦ បានបកប្រែថា "ភ្លើងនៃព្រះអម្ចាស់" (មើលការពន្យល់) ។

**២:៣២** មើល អស ៤៩:១៥ និងការពន្យល់ ។ *ប្រពន្ធថ្មោងថ្មី* ធៀបនឹង ខ.២ *ប៉ុន្តែរាស្ត្ររបស់អញបានភ្លេចអញជាយូរថ្ងៃវិញ* មើល ១៨:១៥ មើលផងដែរ ៣:២១ ១៣:២៥ អស ១៧:១០ អគ ២២:១២ ២៣:៣៥ ហស ៨:១៤ ។ ពួកអ៊ីស្រាអែលគឺត្រូវ "នឹកចាំ" ព្រះអម្ចាស់ ហើយគ្រប់ការទាំងអស់ដែលទ្រង់បានធ្វើសម្រាប់ពួកគេ (ចទ ៧:១៨ ៨:១៨) ហើយទុកចិត្ត និងថ្វាយបង្គំដល់ទ្រង់តែមួយគត់ ប៉ុន្តែគេតែងតែ "ភ្លេចទ្រង់" គេមិនបានយកទ្រង់ដាក់ទុកក្នុងចិត្តសោះ (មើល ពច ២:១០ ហស ២:១៣) ។

**២:៣៣** *សេចក្ដីស្រឡាញ់* មើល ខ.២៥ និងការពន្យល់ ។

**២:៣៤** មើល អម ២:៦–៨ ៤:១ ៥:១១–១២ ។ *អញមិនបានដឹងដោយស៊ើបសួររកដោយបែបសំងាត់ទេ* មើល នក ២២:២ និងការពន្យល់ ។

**២:៣៦** *ឯងនឹងត្រូវមានសេចក្ដីខ្មាស់ចំពោះស្រុកអេស៊ីព្ទ . . . ស្រុកអាសស៊ើរដែរ* មើល ខ.១៥–១៨ និងការពន្យល់ ។ នៅថ្ងៃនៃស្តេចអាហាស (មើល ២របា ២៨:២១) ហើយប្រហែលជាថ្ងៃរបស់ស្តេចសេដេគា (មើល ៣៧:៧) ដែលបានពន្យល់នៅទីនេះ ។

ពួកដែលឯងយកជាទីពឹង[ល] នោះទេ ហើយឯងនឹងមិនបាន
ចំរើននៅជាមួយនឹងគេដែរ ។

**៣** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា បើមនុស្សណាលះ
លែង[ក]ប្រពន្ធ ហើយនាងបានចេញពីអ្នកនោះ ទៅធ្វើជា
ប្រពន្ធរបស់អ្នកដទៃណា នោះតើដែលត្រឡប់ទៅនៅជា
មួយនឹងនាងនោះទៀតដែរឬ តើស្រុកយ៉ាងនោះមិនត្រូវ
អាប់ឱនជាខ្លាំងទេឬអី[ខ] ឯងវិញ ឯងបានផិតអញដោយ
មានសហាយជាច្រើន[គ] ប៉ុន្តែចូរត្រឡប់មកឯអញវិញចុះ[ឃ]
២ចូរងើបភ្នែកឡើងទៅឯទីខ្ពស់[ង]ទាំងប៉ុន្មាន ហើយមើល
កន្លែងណា ដែលគេមិនបានដេកនឹងឯងនោះ គឺឯងបាន
អង្គុយចាំគេតាមផ្លូវ[ច]ដូចជាសាសន៍អារ៉ាប់នៅទីរហោស្ថាន
ដែរ ហើយឯងបានធ្វើឱ្យស្រុក[ឆ]អាប់ឱនទៅ ដោយការ
កំផិត[ជ] និងអំពើទុច្ចរិតរបស់ឯង ៣ហេតុនោះបានជាឥត
មានភ្លៀង១មេៗឡើយ[ឈ] ហើយភ្លៀង[ញ]ចុងរដូវក៏គ្មានដែរ
ម្ល៉ឹងហើយ គង់តែឯងនៅមានមុខងងើល[ដ]ដូចជាស្រីសំផឹង
ទៀត ឯងមិនព្រមអៀនខ្មាសសោះ[ឋ] ៤ឥឡូវនេះ តើឯងមិន
ចង់អំពាវនាវរកអញវិញទេឬអី ដោយថា ឱព្រះវរបិតា[ឌ]
នៃខ្ញុំម្ចាស់អើយ ទ្រង់ជាព្រះដ៏ដឹកនាំខ្ញុំម្ចាស់ពីកាលនៅក្មេង[ឍ]
៥តើទ្រង់នឹងនៅតែខ្ញាល់ជាដរាបឬ[ណ] តើទ្រង់នឹងមានព្រះ
ហឫទ័យក្តៅ ដរាបដល់ចុងបំផុតឬអី តែមើល ឯងបាន
និយាយ ហើយប្រព្រឹត្តអំពើអាក្រក់តាមតែកំឡាំងចិត្តទេ ។

## សាសន៍អ៊ីស្រាអែលមិនស្មោះត្រង់

៦មួយទៀត នៅក្នុងគ្រាស្តេចយ៉ូសៀស[ត] ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលមកខ្ញុំថា តើបានឃើញការដែលអ៊ីស្រាអែល
ជាពួករាថយ[ថ]នោះបានប្រព្រឹត្តឬទេ គឺគេបានឡើងទៅលើ
គ្រប់ទាំងភ្នំខ្ពស់ៗ នឹងនៅក្រោមគ្រប់ទាំងដើមឈើខៀវខ្ចី[ទ]
ហើយបានប្រព្រឹត្តសេចក្តីកំផិត[ធ]នៅទីនោះ ៧លុះក្រោយ
ដែលគេបានប្រព្រឹត្តអំពើទាំងនោះហើយ នោះអញបាន
និយាយថា ចូរឱ្យគេវិលត្រឡប់មកឯអញវិញ តែគេមិន
បានវិលមកទេ ហើយយូដា ជាប្អូនគេ[ន] ដែលមានចិត្តក្បត់
ក៏បានឃើញដែរ[ប] ៨ហើយអញបានឃើញថា ទោះបើអញ
បានលាកលែងអ៊ីស្រាអែលជាពួករាថយនោះ[ផ] ព្រមទាំងឱ្យ

**២:៣៧** ល យរ ៣៧:៧ **៣:១** ក ចទ ២៤:១–៤ ខ លប ៣:១៧ គ ២ពវ ១៦:៧ អស ១:២១ យរ ២:២០,២៥ ៤:៣០ បទ១:២ អគ ១៦:២៦,២៩ ហស ២:៥,១២ ៣:១ ឃ ហស ២:៧ **៣:២** ង ខ.២១ ច លប ៣៨:១៤ អគ ១៦:២៥ ឆ ខ.៩ ជ ជន ១៥:៣៩ អស ១:២១ **៣:៣** ឈ លវ ២៦:១៩ យរ ៥:២៥ អម ៤:៧ ញ ចទ ១១:១៤ យរ ១៤:៤ យអ ១:១០ ដ អគ ៣:៧ ១៦:៣០ ឋ យរ ៦:១៥ ៨:១២ សផ ២:១ ៣:៥
**៣:៤** ឌ ខ.១៩ ចទ៣២:៦ ទដ ៨៩:២៦ អស ៦៣:១៦ ៦៤:៨ យរ ៣១:៩ ឍ យរ ២:២ **៣:៥** ណ ទដ ១០៣:៩ អស ៥៧:៩ **៣:៦** ត ១របា ៣:១៤ ថ ខ.១២,២២ អស ២៤:១៦ យរ ៣១:២២ ៤៩:៤ ទ ចទ ១២:២ យរ១៧:២ អគ ២០:២៨ ហស ៤:១៣ ធ លវ ១៧:៧ យរ ២:២០ **៣:៧** ន អគ ១៦:៤៦ ២៣:២,១១ ប អម ៤:៨ **៣:៨** ផ យរ ១១:១០

**២:៣៧** *ទាំងដៃខ្ទប់ក្បាល* ការរៀបរាប់ពីការរំដោះពួកឈ្លើយនៅពេលដែលគេបានចាប់ចងដៃទាំងពីរ ហើយចងព័ទ្ធខ្ទប់ទៅលើក្បាលនោះ ។ *ពួកដែលឯងយកជាទីពឹងនោះទេ* គឺពួកអេស៊ីព្ទ និងអាសស៊ើរ ។

**៣:១** *ត្រូវអាប់ឱនជាខ្លាំង* ធៀបនឹង ចទ ២៤:១–៤ ការលះលែង និងការរៀបការជាថ្មីម្តងទៀត ពួកអ្នកចូលរួមពិធីនោះ ហើយនិងទឹកដីដែលគេរស់នៅមានពេញដោយសេចក្តីអាប់ឱនជាខ្លាំងផងដែរ (ធៀបនឹង ខ.២ លវ ១៨:២៥–២៨) ។ *ឯងវិញ ឯងបានផិតអញដោយមានសាហាយជាច្រើន* ខនេះមានរហូតទៅដល់ជំពូក២ ហើយប្រើរហូតដល់ជំពូក៣ (មើល ២:២០, ២៥,៣៣ និងការពន្យល់ ២:២៥) ។ *ជាច្រើន* មើលការពន្យល់ ២:២៨ *ចូរត្រឡប់មកឯអញវិញចុះ* ចូរប្រែចិត្តចេញពីអំពើបាបដែលឯងបានបះបោរប្រឆាំងនឹងអញ (មើល ខ.១២–១៤,២២ ៤:១) ។

**៣:២** *ទៅឯទីខ្ពស់ទាំងប៉ុន្មាន* ជាទីកន្លែងដែលគេជួបជុំគ្នា និងថ្វាយបង្គំដល់រូបព្រះនោះ (មើល ខ.២១ ១២:១២ នហ ២៣:៣) ។ *គេមិនបានដេកនឹងឯងនោះ* ធៀបនឹង ចទ ២៨:៣០ ។ *គឺឯងបានអង្គុយចាំគេតាមផ្លូវ* មើល លប ៣៨:១៤ និងការពន្យល់ សភ ៧:១០,១២ ។ *ដូចជាសាសន៍អារ៉ាប់នៅទីរហោស្ថាន* រងចាំអ្នកធ្វើដំណើរតាមផ្លូវដើម្បីវាយប្រហារគេ (ធៀបនឹង លក ១០:៣០) ។ *ឯងបានធ្វើឱ្យស្រុកអាប់ឱនទៅ* មើល ខ.៩ ។

**៣:៣** *ហេតុនោះបានជាឥតមានភ្លៀង១មេៗឡើយ* មើល ១៤:១–៦ អម ៤:៧–៨ នេះគឺការដែលព្រះឆ្លើយឆ្លុយគ្នានៅក្នុង ហស ២:២១ ៦:៣ ។ *ភ្លៀងចុងរដូវ* មើលការពន្យល់ ចទ ១១:១៤ យក ៥:៧ ។ *មានមុខងងើល* មើល សភ ៧:១៣ ។

**៣:៤** *ឱព្រះវរបិតា* មើល ខ.១៩ ធៀបនឹង ២:២៧ និងមើលការពន្យល់ ។ ប្រៀបធៀបទៅនិងសញ្ញាថ្មី ចំណងជើង "បិតា" សម្រាប់ព្រះគឺមានទំនាក់ទំនងជាកម្រនៅសញ្ញាចាស់ តែទោះជាយ៉ាងណាក្តី វាតែងតែកើតមានឡើងចំពោះឈ្មោះបុគ្គលផ្ទាល់ខ្លួន ឈ្មោះដាក់ផ្គុំគ្នា ដោយចាប់ផ្តើមជាមួយនិងពាក្យ អ័ប៊ី (ឧទាហរណ៍ អ័ប៊ីនាដាប់ និងអាប់រ៉ាម) សំដៅទៅលើព្រះថា "ឱព្រះវរបិតា" *នៃខ្ញុំម្ចាស់អើយ* ជាឃ្លាដែលប្រកាសអំពីការទំនាក់ទំនងយ៉ាងជិតស្និទ្ធ (មើល ទដ ៥៥:១៣ សភ ១៦:២៨ ១៧:៩ មីក ៧:៥) នោះជាការអាសអាង ឱ្យយើងធ្វើជាប្រពន្ធដ៏ស្មោះត្រង់របស់ទ្រង់ (ធៀបនឹង សភ ២:១៧) ។ *ពីកាលនៅក្មេង* មើលការពន្យល់ ២:២ ។

**៣:៥** *តើទ្រង់នឹងនៅតែខ្ញាល់ជាដរាបឬ* ទេទ្រង់មិននៅតែខ្ញាល់ជារហូតឡើយ នៅពេលណារាស្ត្ររបស់ទ្រង់ប្រែចិត្តនោះ (ខ.១២–១៣)។

៣:៦–៦:៣០ ភាពមិនស្មោះត្រង់របស់ពួកយូដា (៣:៦–៥:៣១) ហើយចុងក្រោយនឹងនាំឱ្យពួកបាប៊ីឡូនធ្វើទុក្ខគេ ដូចជាការជំនុំជម្រះរបស់ផងព្រះ (ជំពូក ៦) ។

**៣:៦** *ស្តេចយ៉ូសៀស* មើលសេចក្តីផ្តើម ប្រវត្តិដើម មើលការពន្យល់ ១:២ *អ៊ីស្រាអែលជាពួករាថយ* ជាអាណាចក្រនៅខាងជើង ដែលត្រូវបានគេបំផ្លាញនៅឆ្នាំ ៧២២–៧២១ គ.ស (មើល ខ.១២–១៣) ។

**៣:៧** *ហើយយូដា ជាប្អូនគេ ដែលមានចិត្តក្បត់* ជាអាណាចក្រនៅខាង ត្បូង (មើល ខ.៨,១០–១១) ។ ក្រុងសាម៉ារី (ជាទីក្រុងរបស់អ៊ីស្រាអែល) និងក្រុងយេរូសាឡិម (ជាទីក្រុងរបស់ពួកយូដា) បើប្រៀបធៀបទៅ ទីក្រុងទាំង២ជាទីក្រុងបងប្អូននឹងគ្នា ដែលជាទីក្រុងរូបព្រះ នៅក្នុង អគ ២៣ ។ *វា* រូបព្រះរបស់អ៊ីស្រាអែល ។

**៣:៨** *ឱ្យសំបុត្រលះលែងដល់គេ* មើល ខ.១ និងការពន្យល់, និងមើល ចទ

សិបុត្រលះលែង[ព]ដល់គេហើយ ដោយព្រោះគេតែង
ប្រព្រឹត្តសេចក្តីកំផិតនោះ គង់តែយូដា ជាប្អូនគេ ដែលមាន
ចិត្តក្បត់មិនបានខ្លាចដែរ[ភ] គឺបានទៅប្រព្រឹត្តការកំផិតដូចគ្នា
៩ហើយស្រុក[ម]បានអាប់ឱនទៅ ដោយសព្ទរន្ទឺនៃការកំផិត[យ]
របស់គេ គឺបានប្រព្រឹត្តសេចក្តីកំផិតនឹងដុំថ្ម[រ] ហើយនឹងដុំ
ឈើផង[ល] ១០ទោះបើមានយ៉ាងនោះក៏ដោយ គង់តែយូដា
ជាប្អូនគេ ដែលមានចិត្តក្បត់នោះ មិនបានវិលមក[វ]ឯអញ
ដោយអស់ពីចិត្តដែរ គឺមានពុតត្បុតវិញ[ស] នេះហើយជា
ព្រះបន្ទូលនៃព្រះយេហូវ៉ា[ហ]។
១១ព្រះយេហូវ៉ាទ្រង់ក៏មានបន្ទូលមកខ្ញុំថា អ៊ីស្រាអែល
ជាពួករាថយនោះ គេបានសំដែងខ្លួនជាសុចរិត[ឡ] ជាជាង
ពួកយូដា ដែលមានចិត្តក្បត់[អ]នោះ ទៅទៀត[ក] ១២ចូរទៅ
ប្រកាសប្រាប់ពាក្យទាំងនេះទៅទិសខាងជើង[ខ] ដោយពាក្យ
ថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ឱអ៊ីស្រាអែល ជា
ពួករាថយ[គ]អើយ ចូរវិលមកវិញចុះ[ឃ] អញនឹងមិនបំភ័យ
ឯងដោយទឹកមុខអញទេ ដ្បិតអញមានសេចក្តីមេត្តា[ង] ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា អញនឹងមិនក្រោធ[ច]ជាដរាប
ឡើយ ១៣ឱ្យឯងគ្រាន់តែទទួលព្រម[ឆ]ថា ឯងមានសេចក្តី
ទុច្ចរិតមែនប៉ុណ្ណោះ ដោយបានរំលងនឹងព្រះយេហូវ៉ា ជា
ព្រះនៃឯង[ជ] ហើយបានចែកអំពើគោរពរបស់ឯង ឱ្យសុស
សាយ ទៅដល់ព្រះដទៃទាំងប៉ុន្មាន នៅក្រោមគ្រប់ទាំងដើម
ឈើខៀវខ្ចីផង[ឈ] តែព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឯង
រាល់គ្នាមិនបានស្តាប់តាម[ញ]អញសោះ ១៤ព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា ឱពួកក្មេងៗដែលរាថយអើយ ចូរវិលមក
វិញចុះ[ដ] ដ្បិតអញជាប្តីដល់ឯងរាល់គ្នាហើយ[ឋ] នោះអញនឹង
យកឯងរាល់គ្នា ម្នាក់ពីក្រុង១ ហើយ២នាក់ពីពូជអំបូរ១ នាំ
ត្រឡប់ទៅឯក្រុងស៊ីយ៉ូនវិញ ១៥រួចអញនឹងឱ្យឯងរាល់គ្នា
មានអ្នកគ្រប់គ្រងដែលគាប់ចិត្តអញ[ឌ] ជាអ្នកដែលនឹងឃ្វាល[ឍ]
ឯងរាល់គ្នាដោយដំរិះ និងយោបល់ ១៦ព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា នៅគ្រានោះកាលណាឯងរាល់គ្នាបានចំរើន
មានគ្នាច្រើនឡើងនៅក្នុងស្រុក នោះគេនឹងលែងចេញ
ពាក្យថា ហឹបនៃសេចក្តីសញ្ញា[ណ]ផងព្រះយេហូវ៉ា ហឹបនោះ
ក៏មិនដែលចូលក្នុងគំនិតគេ ហើយគេមិនដែលនឹកចាំ[ត] ឬ
រឭករក ក៏មិនដែលមានអ្នកណាធ្វើឡើងវិញ ដរាបតទៅ
១៧នៅគ្រានោះ គេនឹងហៅក្រុងយេរូសាឡិមថា ជាបល្ល័ង្ក[ថ]

**៣:៨** ព ចទ ៤:២៧ ២៤:១ ភ អគ ១៦:៤៧ ២៣:១១ **៣:៩** ម ខ.២ យ លវ ១៧:៧ អស ១:២១ រ អស ៥៧:៦ ល យរ ២:២៧ **៣:១០** វ អស ៣១:៦ អម ៤:៩ ហក ២:១៧ ស យរ ១២:២ អគ ៣៣:៣១ ហ ២ពវ ១៧:១៩ **៣:១១** ឡ អគ ១៦:៥២ ២៣:១១ អ ខ.៧ ក យរ ២:១៩ **៣:១២** ខ ២ពវ ១៧:៣–៦ គ ខ.៦ ឃ ខ.១៤ ចទ ៤:៣០ យរ ៣១:២១,២២ អគ ១៤:៦ ៣៣:១១ ហស ១៤:១ ង ១ពវ ៣:២៦ ទដ ៦:២ ច ទដ ១០៣:៩ អស ៥៤:៩

**៣:១៣** ឆ ចទ ៣០:១–៣ យរ ១៤:២០ ១យហ ១:៩ ជ យរ ២:២៥ ឈ ចទ ១២:២ ញ ខ.២៥ យរ ២២:២១ **៣:១៤** ដ ខ.១២ យប ២២:២៣ យរ ៤:១ ឋ អស ៥៤:៥ **៣:១៥** ឌ អស ៣១:៤ ឍ កច ១៣:២២ **៣:១៦** ណ ជន ៣:៣១ ១រប ១៥:២៥ ត អស ៦៥:១៧ **៣:១៧** ថ ទដ ៤៧:៨ យរ ១៧:១២ ៣៣:១៦ អគ ១:២៦ ៤៣:៧ ៤៨:៣៥

២៤:១–៤ អស ៥០:១ និងការពន្យល់ ។ អញបានលាលែងអ៊ីស្រាអែល អ៊ីស្រាអែល ឱ្យទៅជាប់ជាឈ្លើយនៅឆ្នាំ ៧២១ គ.សគ ។ *គង់តែយូដា ជាប្អូនគេ ដែលមានចិត្តក្បត់មិនបានខ្លាចដែរ* យូដាគេបដិសេធន៍ មិនរៀនពីបទពិសោធន៍របស់សាសន៍អ៊ីស្រាអែលឡើយ ។

**៣:៩** *គឺបានប្រព្រឹត្តសេចក្តីកំផិតនឹងដុំថ្ម ហើយនិងដុំឈើ* ពួកគេបានថ្វាយបង្គំដល់រូបព្រះទាំងនោះ (មើលការពន្យល់ ២:២៧ នក ៣៤:១៥) ។

**៣:១០** *គឺមានពុតត្បុតវិញ* ពួកយូដាគេឆ្លើយតបចំពោះវិធានការ ការកែទម្រង់របស់ស្តេចយ៉ូសៀស (មើលការពន្យល់ ១:២) ដោយមានការស្មោក់ស្មើ និងពុតត្បុតនោះ ។

**៣:១១** *អ៊ីស្រាអែលជាពួករាថយនោះ គេបានសំដែងខ្លួនថាជាសុចរិត ជាជាងពួកយូដា* មើលការពន្យល់ ខ៨ ហើយមើលផងដែរ អគ ១៦:៥១–៥២ ២៣:១១) ។

**៣:១២** *ចូរទៅប្រកាស* មើល ២:២ ។ *ខាងជើង* អាសស៊ើរជាខេត្ត១នៅខាងជើង ជាទីកន្លែងដែលពួកអ៊ីស្រាអែលត្រូវបានគេចាប់យកជាឈ្លើយ ។ *ចូរវិលមកវិញចុះ* ការកែប្រែ (មើល ខ.១៣) ។ *សេចក្តីមេត្តា* ភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានប្រើសំដៅទៅលើព្រះ ទ្រង់មានសេចក្តីមេត្តា មាននៅក្នុង ទដ ១៤៥:១៣,១៧ ដែលគេបានបកប្រែថា "សេចក្តីស្រឡាញ់" *អញនឹងមិនក្រោធជាដរាបឡើយ* មើលការពន្យល់ ខ.៥ ។

**៣:១៣** *ហើយបានចែកអំពើគោរពរបស់ឯង ឱ្យសុសសាយទៅដល់ព្រះដទៃទាំងប៉ុន្មាន* មើល អគ ១៦:១៥,៣៣–៣៤ និងការពន្យល់ ១៦:១៣ ។ ព្រះដទៃ មើលការពន្យល់ ២:២៥ ។ *នៅក្រោមគ្រប់ទាំងដើមឈើខៀវខ្ចីផង* មើលការពន្យល់ ២:២០ ។

**៣:១៤** *ប្តី* មើល ៣១:៣២ ហស ២:១៦–១៧ ពាក្យហេព្រើរ ការគូសចំណាំពាក្យនេះ គឺព្រះបាល ដោយជំនួស គេត្រូវអនុញ្ញាត្តឱ្យព្រះធ្វើជាប្តីរបស់គេ ប៉ុន្តែរាស្ត្ររបស់ទ្រង់បែរជាដើរតាម "ព្រះបាលទៅវិញ" (២:២៣ មើលការពន្យល់ ពច ២:១១) ។ *ម្នាក់ពីក្រុង១ ហើយ២នាក់ពីពូជអំបូរ១* ពួកអ្នកដែលនៅសល់គេនឹងវិលត្រឡប់មកវិញ (មើលការពន្យល់ អស ១០:២០–២២) ។ *ក្រុងស៊ីយ៉ូន* ក្រុងយេរូសាឡិម ។

**៣:១៥** មើល ២៣:៤ *អ្នកដែលនឹងឃ្វាល* អ្នកគ្រប់គ្រង (មើលការពន្យល់ ២:៨) ។ *ដែលគាប់ចិត្តអញ* ដូចជាស្តេចដាវីឌ (មើល ១សយ ១៣:១៤ មើលផងដែរ អគ ៣៤:២៣ ហស ៣:៥) ។

**៣:១៦** *នៅគ្រានោះ* នៅក្នុងកំឡុងយុគសម័យព្រះមេស៊ី (មើល ខ.១៨ ៣១:២៩) ។ *កាលណាឯងរាល់គ្នាបានចំរើនមានគ្នាច្រើនឡើងនៅក្នុងស្រុក* មើល ២៣:៣ អគ ៣៦:១១ សម្រាប់ន័យពេញនៃពាក្យហេព្រើរដែលគូសចំណាំឃ្លានេះ មើលការពន្យល់ លប ១:២៨ ។ *ក៏មិនដែលចូលក្នុងគំនិតគេ* ហឹបនៃសេចក្តីសញ្ញា ជានិម្មិតសញ្ញាអំពីវត្តមានរបស់ព្រះ (មើល ១សយ ៤:៣ និងការពន្យល់) ហើយវាទាក់ទងទៅនឹងដំណើរយាងវិលត្រឡប់មកវិញរបស់ព្រះមេស៊ី ។

**៣:១៧** *បល្ល័ង្ក* ព្រះអម្ចាស់ទ្រង់គង់នៅលើបល្ល័ង្កនៅចន្លោះចេរូប៊ីន ហឹបនៃសញ្ញាខាងលើ (មើល ១សយ ៤:៤ និងការពន្យល់) ប៉ុន្តែក្រុងយេរូសាឡិម

នៃព្រះយេហូវ៉ា ហើយអស់ទាំងសាសន៍[ទ]នឹងមូលគ្នា មកឯ[ធ]
ព្រះនាមនៃព្រះយេហូវ៉ា ក្នុងក្រុងយេរូសាឡិម គេនឹងមិន
ដើរតាមសេចក្ដីរឹងចចេស នៃចិត្តអាក្រក់របស់គេទៀត
ឡើយ[ន] ១៨នៅគ្រានោះ ពួកវង្សយូដានឹងដើរជាមួយនឹងពួក
វង្សអ៊ីស្រាអែល[ប] ហើយគេនឹងចេញពីស្រុកខាងជើង[ផ]ជា
មួយគ្នា[ព] មកឯស្រុក[ភ]ដែលអញបានឱ្យដល់ពួកឰយុកោរបស់
ឯង ទុកជាមរដក ។

១៩តែអញបាននឹកថា ធ្វើដូចម្តេចឱ្យអញដាក់ឯងឱ្យនៅ
ជាមួយនឹងពួកកូនចៅបាន ព្រមទាំងឱ្យស្រុកដ៏គាប់ចិត្ត[ម]
គឺជាមរដកយ៉ាងល្អ[យ]របស់ពួកកកកុញ នៅអស់ទាំងសាសន៍
ដល់ឯងផង នោះអញបានឆ្លើយថា ឯងរាល់គ្នានឹងហៅ
អញថាជាព្រះវរបិតារបស់ឯង[រ] ក៏នឹងលែងងាកបែរចេញ
ពីអញតទៅ ២០ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱពូជពង្ស
អ៊ីស្រាអែលអើយ ពិតប្រាកដជាឯងបានប្រព្រឹត្តអំពើក្បត់[ល]
ចំពោះអញ ប្រៀបដូចជាប្រពន្ធប្រព្រឹត្តក្បត់ចាកចោលប្ដី
ខ្លួន ២១មានឮសំឡេងនៅលើទីខ្ពស់ត្រងិល[វ] គឺជាពួកកូនចៅ
អ៊ីស្រាអែល ដែលយំ[ស] ហើយទូលអង្វរ ដោយព្រោះគេបាន
បង្ខូចផ្លូវខ្លួន ហើយបានភ្លេច[ហ]ព្រះយេហូវ៉ា ជាព្រះនៃខ្លួន
ទៅ ២២ឱពួកកូនដែលរាថយអើយ ចូរវិលមកវិញចុះ[ឡ] អញ
នឹងមើល[អ]អស់ទាំងអំពើរាថយរបស់ឯងឱ្យបានជាឡើង[ក]
មើល យើងខ្ញុំរាល់គ្នាមកឯទ្រង់ហើយ ដ្បិតទ្រង់ជាព្រះ
យេហូវ៉ា ជាព្រះនៃយើងរាល់គ្នា ២៣ការដែលទុកចិត្ត
សង្ឃឹមដល់ភ្នំតូច[ខ] ហើយដល់ពួកអ៊ឹកធឹកនៅលើភ្នំធំ នោះ
ពិតប្រាកដជាឥតប្រយោជន៍ទទេ សេចក្ដីសង្គ្រោះ[គ]នៃ
សាសន៍អ៊ីស្រាអែល នោះស្រេចនឹងព្រះយេហូវ៉ា ជាព្រះនៃ
យើងជាពិតវិញ ២៤ប៉ុន្តែរបស់គួរខ្មាស[ឃ]បានស៊ីបង្ហិនការ
ដែលពួកឪពុកយើងបានខំធ្វើ តាំងពីយើងនៅក្មេងមក
គឺទាំងហ្វូងចៀម ហ្វូងគោ និងកូនប្រុសកូនស្រី របស់គាត់
ផង ២៥គួរឱ្យយើងរាល់គ្នាដេកចុះ ក្នុងសេចក្ដីខ្មាសរបស់
យើង[ង] ហើយឱ្យសេចក្ដីអាប់ឱនគ្របដណ្ដប់យើងដែរ ពី
ព្រោះយើងបានធ្វើបាប[ច]នឹងព្រះយេហូវ៉ា ជាព្រះនៃយើង
រាល់គ្នា គឺទាំងខ្លួនយើង និងពួកឪពុកយើងផង[ឆ] ចាប់តាំង
ពីយើងនៅក្មេង[ជ]ដរាបដល់សព្វថ្ងៃនេះ យើងក៏មិនបាន
ស្តាប់តាម[ឈ]សំឡេងរបស់ព្រះយេហូវ៉ា ជាព្រះនៃយើងរាល់
គ្នាផង ។

៤ ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា បើឯងរាល់គ្នានឹងវិល
មក[ក]វិញ ឱពួកអ៊ីស្រាអែលអើយ បើឯងនឹងមកឯអញវិញ

**៣:១៧** ទ អស ២:៣ មីក ៤:១ ធ ទដ ២២:២៣ យរ ១៣:១១ ៣៣:៩ ន ទដ ៨១:១២ យរ ៧:២៤ ៩:១៤ ១១:៨ ១៣:១០ ១៦:១២ ១៨:១២
**៣:១៨** ប យរ ៣០:៣ អគ ៣៧:១៩ ផ យរ ១៦:១៥ ៣១:៨ ព អស ១១:១៣ យរ ៥០:៤ ភ ចទ ៣១:៧ អស ១៤:១ អគ ១១:១៧ ៣៧:២២ អម ៨:១៥
**៣:១៩** ម ចទ ៨:៧ យ ទដ ១០៦:២៤ អគ ២០:៦ រ ខ.៤ នក ៤:២២ ២សយ ៧:១៤
**៣:២០** ល អស ២៤:១៦
**៣:២១** វ ខ.២ ស យរ ៣១:១៨ ហ អស ៥៧:១១
**៣:២២** ឡ ខ.១២ យប ២២:២៣

អ អស ៣០:២៦ ៥៧:១៨ យរ ៣៣:៦ ហស ៦:១ ក យរ ២:១៩ **៣:២៣** ខ យរ ២:២០ គ ទដ ៣:៨ យរ ១៧:១៤ **៣:២៤** ឃ យរ ១១:១៣ ហស ៩:១០ **៣:២៥** ង អរ ៩:៦ យរ ៣១:១៩ ដយ ៩:៧ ច ពច ១០:១០ ១ពវ ៨:៤៧ ឆ យរ ១៤:២០ ជ ទដ ២៥:៧ យរ ២២:២១ ឈ ខ.១៣ អគ ២:៣ **៤:១** ក ចទ ៤:៣០ ២ពវ ១៧:១៣ ហស ១២:៦

នៅថ្ងៃមួយនឹងក្លាយទៅជាបល្ល័ង្ករបស់ទ្រង់ ។ *ហើយអស់ទាំងសាសន៍នឹងមូលគ្នា* មើល សផ ២:១១ មើលការពន្យល់ផងដែរនៅ អស ២:២–៤ ។ *ពួកគេ* អ៊ីស្រាអែល ។ គេនឹងមិនដើរតាមសេចក្ដីរឹងចចេស នៃចិត្តអាក្រក់របស់គេទៀត ឃ្លានេះសំដៅទៅលើពួកអ៊ីស្រាអែល ដែលមិនស្តាប់បង្គាប់ដល់ព្រះ ហើយគេចូលរួមក្នុងការថ្វាយបង្គំរូបព្រះ (មើល ៩:១៤ ១១:៨ ១៣:១០ ១៦:១២ ១៨:១២ ២៣:១៧) ។

**៣:១៨** *ពួកវង្សយូដានឹងដើរជាមួយនឹងពួកអ៊ីស្រាអែល* នៅក្នុងកំឡុងយុគសម័យព្រះមែស៊ី រាស្ត្ររបស់ព្រះដែលខ្ចាត់ខ្ចាយនោះ គេនឹងមូលមករួមគ្នាតែមួយវិញ(មើលឧទាហរណ៍ ៣១:៣១ អស ១១:១២ អគ ៣៧:១៥–២៣ ហស ១:១១) ។ *ស្រុកខាងជើង* ជាទីកន្លែងដែលពួកគេបានចាប់ជាឈ្លើយទៅ (មើលការពន្យល់ ខ.១២ មើលផងដែរ ៣១:៨) ។ *ស្រុកដែលអញបានឱ្យដល់ពួកឰយុកោរបស់ឯងទុកជាមរដក* មើលការពន្យល់ ២:៧ ។

**៣:១៩** *ពួកកូនចៅ* អ៊ីស្រាអែលជាកូនច្បងរបស់ព្រះអម្ចាស់ (មើល នក ៤:២២ ធៀបនឹង ហស ១១:១ ។ *ព្រមទាំងឱ្យស្រុកដ៏គាប់ចិត្ត* ពាក្យហេព្រើរសម្រាប់ឃ្លានេះត្រូវបានគេបកប្រែថា "ទឹកដីដ៏ពេញចិត្ត" នៅក្នុង ទដ ១០៦:២៤ សក ៧:១៤ ។ *មរដកយ៉ាងល្អ* ពួកយូដា ក្រុងយេរូសាឡិម រាស្ត្ររបស់ព្រះ គេគ្រប់គ្នាជាមនុស្សយ៉ាងល្អ នៅក្នុងព្រះនេត្រព្រះ (មើល ៦:២ ១១:១៦) ។ *ព្រះវរបិតា* មើលការពន្យល់ ខ.៤) ។

**៣:២០** ការសង្ខេបរឿងយ៉ាងខ្លី ដែលបាននិយាយនៅក្នុង ហស ១–៣ (មើលការពន្យល់ នក ៣៤:១៥) ។

**៣:២១** *នៅលើទីខ្ពស់ត្រងិល* មើលការពន្យល់ ខ.២ ។ *ដែលយំ ហើយទូលអង្វរ* ការរៀបរាប់ពីការកែប្រែចិត្តគំនិត ដោយនិយាយចេញពីខាងក្នុងចិត្ត ខ.២២–២៥ ។ *បានភ្លេច* មើលការពន្យល់ ២:៣២ ។

**៣:២២** មើល ខ.១៤ ។ *ចូរវិលមកវិញចុះ អញនឹងមើលអស់ទាំងអំពើរាថយរបស់ឯង* ពាក្យទាំងបីនេះ ក្លាយមកពីពាក្យហេព្រើរ ដែលមានន័យដូចគ្នានេះជាការលេងពាក្យ ។ *ឱ្យបានជាឡើង* មើល ៣០:១៧ ៣៣:៦ ហស ៦:១ ១៤:៤ មើល បណ្ដាជនគេកែប្រែចិត្ត ។

**៣:២៣** *ពួកអ៊ឹកធឹក* មើលឧទាហរណ៍ ១ពវ ១៨:២៥–២៩ ។ *នោះស្រេចនឹងព្រះយេហូវ៉ា ជាព្រះនៃយើងជាពិតវិញ* មើល លក ៤៩:១៨ ទដ ៣:៨ យហ ២:៩ និងការពន្យល់) ។

**៣:២៤** *តាំងពីយើងនៅក្មេងមក* នៅក្នុងកំឡុងពេលនៃពួកចៅហ្វាយ ។ *របស់គួរខ្មាស* មើលការពន្យល់ ២:២៦ ១១:១៣ ។ *បានស៊ីបង្ហិន* ការថ្វាយបង្គំខុសឆ្គង គឺជាការបំផ្លាញដល់ផ្នែកហិរញ្ញវត្ថុ និងផ្នែកខាងព្រលឹងវិញ្ញាណ ។ *និងកូនប្រុសកូនស្រី* គេតែងតែថ្វាយយញ្ញបូជាដល់រូបព្រះ (មើលការពន្យល់ ៧:៣១) ។

**៣:២៥** *ក្នុងសេក្ដីខ្មាស* ភាសាហេព្រើរសម្រាប់ពាក្យនេះ ត្រូវបានគេបកប្រែថា "របស់គួរខ្មាស" នៅក្នុង ខ.២៤ ។

**៤:១** *មិនត្រូវបំបរបង់ទេ* ភាសាហេព្រើរសម្រាប់ពាក្យនេះ ត្រូវបានគេ

ហើយនឹងលះបង់អំពើ[ខ]គួរស្អប់ខ្ពើមរបស់ឯងចេញពីមុខ
អញទៅ នោះឯងរាល់គ្នាមិនត្រូវបំបរបង់ទេ ២ហើយបើ
ឯងនឹងស្បថ[គ]ដោយពិតត្រង់ ដោយសេចក្តីយុត្តិធម៌ និង
សេចក្តីសុចរិតថា ព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់នៅ
ពិត[ឃ] នោះអស់ទាំងសាសន៍នឹងបានពរ[ង]នៅក្នុងទ្រង់ ហើយ
នឹងអួតសរសើរពីទ្រង់[ច] ។
៣ដ្បិតព្រះយេហូវ៉ា ទ្រង់មានបន្ទូល ដល់មនុស្សនៅ
ស្រុកយូដា និងក្រុងយេរូសាឡិមដូច្នេះថា ចូរកំសុលដី[ឆ]
ហាប់របស់ឯងរាល់គ្នាឡើង ហើយកុំឱ្យសាបព្រោះ នៅ
កណ្តាលបន្លាឡើយ[ជ] ៤ឱមនុស្សនៅស្រុកយូដា និងពួកក្រុង
យេរូសាឡិមអើយ ចូរឯងរាល់គ្នាកាត់ស្បែកថ្វាយខ្លួនដល់
ព្រះយេហូវ៉ា ចូរកាត់យកស្បែកចិត្តឯងចោលចេញចុះ[ឈ]
ក្រែងសេចក្តីក្រោធ[ញ]របស់អញចេញមកដូចជាភ្លើង[ដ]
ហើយ ឆេះឥតមានអ្នកណាពន្លត់[ឋ]បាន ដោយព្រោះសេចក្តី
អាក្រក់[ឌ] ដែលឯងរាល់គ្នាប្រព្រឹត្តនោះ ។

## សេចក្តីហិនវិនាសមកពីទិសខាងជើង

៥ចូរថ្លែងប្រាប់នៅស្រុកយូដា ហើយប្រកាសប្រាប់[ឍ]
នៅក្រុងយេរូសាឡិម ដោយពាក្យថា ចូរផ្លុំត្រែ[ណ]នៅក្នុង
ស្រុក ចូរស្រែកឡើងជាខ្លាំងថា ចូរមូលគ្នាមក យើង
ចូលទៅក្នុងទីក្រុងទាំងប៉ុន្មានដែលមានបន្ទាយចុះ[ត] ៦ចូរ
លើកទង់ឡើង[ថ]នៅខាងក្រុងស៊ីយ៉ូន ត្រូវឱ្យរត់ទៅ កុំបង្អង់
ឡើយ ពីព្រោះអញនឹងនាំសេចក្តីអាក្រក់[ទ]មកពីទិសខាង
ជើង[ធ] ព្រមទាំងការបំផ្លាញយ៉ាងធំផង ៧មានសត្វសិង្ហ១[ន]
បានឡើងចេញពីព្រៃស្តុករបស់វាមក[ប] ជាមេបំផ្លាញ[ផ]នគរ
ផ្សេងៗ វាកំពុងតែមកតាមផ្លូវ វាបានចេញពីកន្លែងរបស់
វាមកហើយ ដើម្បីនឹងបំផ្លាញ[ព]ស្រុកឯង ហើយឱ្យទីក្រុង
ទាំងប៉ុន្មានរបស់ឯង ត្រូវបែកបាក់ចោល[ភ] ឥតមានអ្នកណា
នៅ ៨ហេតុនេះ ចូរឱ្យឯងរាល់គ្នាស្លៀកសំពត់ធ្មៃ[ម] ព្រម
ទាំងទួញទំនួញ[យ] ហើយទ្រហោយំចុះ ដ្បិតសេចក្តីខ្ញាល់[រ]ដ៏
សហ័សរបស់ព្រះយេហូវ៉ាមិនបានបែរចេញពីយើងរាល់
គ្នាទេ ៩ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅគ្រានោះព្រះទ័យ
នៃស្តេច និងចិត្តរបស់ពួកចៅហ្វាយ និងរលត់សូន្យទៅ[ល]
ឯពួកសង្ឃនឹងស្រឡាំងកាំងនៅ ហើយពួកហោរនឹងនឹក
ប្លែកដែរ[វ] ។

**៤:១** ខ ២ពវ ២១:៤ យរ ១៦:១៨ ៣៥:១៥ អគ ៨:៥ **៤:២** គ ចទ ១០:២០ អស ១៩:១៨ ៦៥:១៦ ឃ ជន ១៤:២១ យរ ៥:២ ១២:១៦ ៤៤:២៦ ហស ៤:១៥ ង លប ១២:២ កទ ៣:៨ ច យរ ៩:២៤ **៤:៣** ឆ ហស ១០:១២ ជ មក ៤:១៨ **៤:៤** ឈ លវ ២៦:៤១ ញ សផ ១:១៨ ២:២ ដ យប ៤១:២១ ឋ អស ១:៣១ អម ៥:៦ ឌ នក ៣២:២២ **៤:៥** ឍ យរ ៥:២០ ១១:២,៦ ណ ខ.២១ ជន ១០:២,៧ យប ៣៩:២៤ ត យស ១០:២០ **៤:៦** ថ ខ.២១ ទដ ៧៤:៤ អស ១១:១០ ៣១:៩ យរ ៥០:២ ទ យរ ១១:១១ ១៨:១១ ធ អស ១៤:៣១ យរ ៥០:៣ **៤:៧** ន ២ពវ ២៤:១ យរ ២:១៥ ប យរ ២៥:៣៨ ហស ៥:១៤ ១៣:៧ ណហ ២:១២ ផ យរ ៦:២៦ ១៥:៨ ២២:៧ ៤៨:៨ ៥១:១,៥៣ អគ ២១:៣១ ២៥:៧ ព អស ១:៧ អគ ១២:២០ ភ ខ.២៩ លវ ២៦:៣១ អស ៦:១១ **៤:៨** ម ១ពវ ២១:២៧ អស ៣:២៤ យរ ៦:២៦ អគ ៧:១៨ យអ ១:៨ យ យរ ៧:២៩ ៩:២០ អម ៥:១ រ អស ១០:៤ យរ ៣០:២៤ **៤:៩** ល ១សយ ១៧:៣២ វ អស ២៩:៩

អនុវត្តថា ការអស្ចារ្យនៅក្នុង លប ៤:១២,១៤ និងការពន្យល់ ៤:១៦ ។

**៤:២** *ដោយពិតត្រង់ ដោយសេចក្តីយុត្តិធម៌* គន្លឹះនៃពាក្យដែលសង្កត់ធ្ងន់ទៅលើពាក្យនេះ គឺការកែប្រែជីវិត ដោយស្មោះអស់ពីចិត្ត មិនមែនធ្វើឱ្យតែបានបង្គ្រប់កិច្ចនោះទេ ។ *ទ្រង់មានព្រះជន្មរស់នៅពិត* មើលការពន្យល់ លប ៤២:១៥ ។ *នោះអស់ទាំងសាសន៍នឹងបានពរ នៅក្នុងទ្រង់* ការឆ្លុះបញ្ចាំងព្រះបន្ទូលព្រះ អំពីសេចក្តីសន្យាអស្ចារ្យលើទី៧របស់ព្រះ ចំពោះលោកអាប់រ៉ាម (មើល លប ១២:២-៣ និងការពន្យល់) ។ ការកែប្រែជីវិតរបស់អ៊ីស្រាអែល គឺជាលក្ខខ័ណ្ឌដំបូង ដើម្បីនឹងទទួលនូវព្រះពររបស់ព្រះនៅពេលទីបញ្ចប់នោះ ។

**៤:៣** *ចូរកំសុលដីហាប់របស់ឯងរាល់គ្នា* ប្រហែលជាបានដកស្រង់ពី ហស ១០:១២ ។ *ហើយកុំឱ្យសាបព្រោះ នៅកណ្តាលបន្លាឡើយ* មើល មថ ១៣:៧,២២ ។ ការចាប់ផ្តើមសំលឹងមើលទៅឯព្រះអម្ចាស់ គឺជាការចាំបាច់ដែលជាការប្តេជ្ញារួមចំពោះព្រះ (មើល អគ ១៨:៣១) ។

**៤:៤** *ចូរកាត់យកស្បែកចិត្តឯងចោល* ការធ្វើចេញពីក្នុងចិត្ត (មើល ៦:១០ និងការពន្យល់ ៩:២៦ និងការពន្យល់ លប ១៧:១០ ចទ ១០:១៦ ៣០:៦ ធៀបនឹង រម ២:២៩ និងការពន្យល់ ១កថ ៧:១៩ កល ២:១១) ។ *សេចក្តីក្រោធ . . . ហើយឆេះឥតមានអ្នកណាពន្លត់បាន* មើល ២១:១២ និងមើល អស ១:៣១ អម ៥:៦ និងការពន្យល់ ។ *ដោយព្រោះសេចក្តីអាក្រក់ដែលឯងរាល់គ្នាប្រព្រឹត្តនោះ* ប្រហែលជាបានដក់ស្រង់មកពី ចទ ២៨:២០ ។

**៤:៥-៣១** ការរាតត្បាតមកពីខាងជើង នាំឱ្យមានការជំនុំជម្រះរបស់ព្រះទៅលើរាស្ត្រដែលមិនប្រែចិត្ត (មើលជំពូក៦) ។

**៤:៥** *ចូរផ្លុំត្រែ* ដើម្បីប្រយ័ត្នចំពោះសេចក្តីវិនាស (មើល ៦:១ មើលការពន្យល់ផងដែរនៅក្នុង យអ ២:១) ។ *ចូលទៅក្នុងទីក្រុងទាំងប៉ុន្មានដែលមានបន្ទាយចុះ* មើលខ៦ ដើម្បីចៀសវាងការចាប់យកពីសំណាក់ពួកខ្មាំងសត្រូវ ហើយប្រជាជនដែលរស់នៅជិតបន្ទាយនោះ អាចនឹងជ្រកកោននៅជិតកំផែងក្រុងនោះបាន (មើល ៥:១៧ ៤:១៨ ៣៤:៧ ៤៨:១៨) ។

**៤:៦** មើល ៦:១ ។ *ចូលើកទងឡើង* មើលការពន្យល់ អស ៥:២៦ ។ *សេចក្តីអាក្រក់មកពីទិសខាងជើង* មើល ១:១៤ ៦:២២ តាមរយៈពួកបាប៊ីឡូន (មើល ២៥:៩ អស ៤១:២៥ និងការពន្យល់) ។ *ការបំផ្លាញយ៉ាងធំ* មើល ៦:១ ធៀបនឹង ៤៨:៣ ៥០:២២ ៥១:៥៤ ។

**៤:៧** *សត្វសិង្ហ* និម្មិតសញ្ញាពីបាប៊ីឡូន (មើលការពន្យល់ ២:១៥) ។ *មេបំផ្លាញ* ជាធម្មតានិយាយសំដៅទៅលើបាប៊ីឡូន (៦:២៦ ១៥:៨ ៤៨:៨, ៣២) ប៉ុន្តែនៅក្នុង ៥១:១,៥៦ និយាយសំដៅទៅលើពួកពើស៊ី និងសម្ព័ន្ធមិត្ររបស់គេ (មើល ៥១:៤៨ ៥៣) ។ *ទីក្រុងទាំងប៉ុន្មានរបស់ឯង . . . ឥតមានអ្នកណានៅ* មើលការពន្យល់ ២:១៥ មើលការពន្យល់ ខ.២៥ ៤៦:១៩ ។

**៤:៨** *សំពត់ធ្មៃ* មើលការពន្យល់ លក ៣៧:៣៤ វវ ១១:៣ ។ *ដ្បិតសេចក្តីខ្ញាល់ដ៏សហ័សរបស់ព្រះយេហូវ៉ាមិនបានបែរចេញពីយើងឡើយ* ផ្ទុយគ្នានៅក្នុង ២:៣៥ ។

**៤:៩** *នៅគ្រានោះ* មើលការពន្យល់ អស ២:១១,១៧,២០ ។ *ព្រះទ័យនៃស្តេច និងចិត្តរបស់ពួកចៅហ្វាយ និងរលត់សូន្យទៅ ឯពួកសង្ឃនឹងស្រឡាំងកាំង*

១០នោះខ្ញុំបានទូលថា ឱព្រះអម្ចាស់យេហូវ៉ាអើយ ពិត
ប្រាកដជាទ្រង់បានបញ្ឆោត[ស]ជនជាតិនេះ ព្រមទាំងក្រុង
យេរូសាឡិមជាខ្លាំងហើយ ដោយបន្ទូលថា នឹងមានសេចក្ដី
សុខ[ហ]ដល់ឯងរាល់គ្នា តែមានដាវលូកមករកជីវិតគេវិញ ។
១១នៅគ្រានោះនឹងមានសេចក្ដីប្រាប់ដល់ជនជាតិនេះ
ហើយដល់ក្រុងយេរូសាឡិមថា មានខ្យល់ក្ដៅ[ឡ]បក់មកពីទី
ខ្ពស់ត្រងិលនៅទីរហោស្ថាន ទៅខាងកូនស្រីរបស់រាស្ត្រ
អញ មិនមែនសំរាប់រោយស្រូវទេ ក៏មិនមែនសំរាប់សំអាត
ដែរ ១២គឺជាខ្យល់[អ]ពេញកំឡាំងនឹងមកជំនួសអញ ឥឡូវ
នេះ អញនឹងសំរេចទោស[ក]ដល់គេ ១៣មើល អ្នកនោះនឹង
ឡើងមកដូចជាពពក[ខ] ហើយរទេះចំបាំង[គ]របស់គេ នឹងដូច
ជាខ្យល់កួច[ឃ] ឯសេះ[ង]របស់គេក៏លឿនជាងសត្វឥន្ទ្រី[ច] វរ
ហើយយើង ដ្បិតយើងត្រូវវិនាសហើយ[ឆ] ១៤ឱក្រុង
យេរូសាឡិមអើយ ចូរលាង[ជ]ចិត្តឯងឱ្យជ្រះចេញពីសេចក្ដី
ទុច្ចរិតចុះ ដើម្បីឱ្យឯងបានសង្គ្រោះ[ឈ] តើគំនិតអាក្រក់នឹង
ចេះតែនៅជាប់ក្នុងចិត្តខ្លួនដល់កាលណាទៀត[ញ] ១៥ដ្បិតមាន
សំឡេង១បន្លឺចេញពីស្រុកដាន់[ដ] ក៏ចេញពីស្រុកភ្នំអេប្រាអិម
មកប្រកាសពីការអាក្រក់[ឋ] ១៦ចូរដំណាលប្រាប់ដល់អស់
ទាំងសាសន៍ឱ្យដឹង នែ ចូរប្រកាសប្រាប់ទាស់នឹងក្រុង
យេរូសាឡិមថា មានពួកទ័ពកំពុងតែមកពីស្រុកឆ្ងាយ[ឌ]
ដើម្បីឡោមព័ទ្ធឯង គេស្រែក[ឍ]ទាស់នឹងទីក្រុងស្រុកយូដា
ទាំងប៉ុន្មាន[ណ] ១៧គេនៅព័ទ្ធ[ត]ជុំវិញទីក្រុង ដូចជាពួករក្សា
ចំការ ពីព្រោះពួកក្រុងបានបះបោរ[ថ]នឹងអញ នេះជាព្រះ
បន្ទូលនៃព្រះយេហូវ៉ា ១៨គឺជាផ្លូវដែលឯងប្រព្រឹត្ត[ទ] និង
អំពើរបស់ឯង ដែលបាននាំការទាំងនេះមកលើឯង[ធ] នេះ
គឺជា សំណាងនៃអំពើទុច្ចរិតរបស់ឯង ពិតប្រាកដជាជូរ
ចត់[ន]ណាស់ ពីព្រោះការនេះលូកមកប៉ះពាល់ដល់ចិត្តឯង
ហើយ។
១៩ឱពោះខ្ញុំ ពោះខ្ញុំអើយ[ប] ខ្ញុំមានសេចក្ដីឈឺចាប់[ផ]នៅ
ក្នុងចិត្ត បេះដូងខ្ញុំប្រដំ[ព]នៅក្នុងខ្លួន ខ្ញុំនៅស្ងៀមមិនបានទេ[ភ]
ដ្បិតឱព្រលឹងអញអើយ ឯងបានឮសូរត្រែ[ម] ជាសូរអឺងកង
នៃចំបាំងហើយ[យ] ២០គេស្រែកតឿនគ្នាឱ្យបំផ្លាញខ្ទាន់លើ
ការបំផ្លាញ[រ] ពីព្រោះស្រុកទាំងមូលត្រូវខូចអស់ហើយ[ល] ទី

**៤:១០** ស នក ៥:២៣ ២ថន ២:១១ ហ អស ៣០:១០ យរ ៦:១៤ ៨:១១ ១៤:១៣ ២៣:១៧ អគ ១៣:១០ មីក ៣:៥ ១ថន ៥:៣ **៤:១១** ឡ លប ៤១:៦ លវ ២៦:៣៣ យប ១:១៩ **៤:១២** អ អស ៦៤:៦ ក យរ ១:១៦ **៤:១៣** ខ ២សយ ២២:១០ អស ១៩:១ គ អស ៦៦:១៥ អគ ២៦:១០ ណហ ២:៤ ឃ ២ពវ ២:១ ង ហាព ៣:៨ ច ចទ ២៨:៤៩ ហាព ១:៨ ឆ ខ.២០,២៧ អស ៦:១១ ២៤:៣ យរ ៧:៣៤ ៩:១១,១៩ ១២:១១ ២៥:១១ ៤៤:៦ មីក ២:៤ **៤:១៤** ជ នរ ៣:៣ ទដ ៥១:២ យក ៤:៨ ឈ អស ៤៥:២២ ញ ទដ ៦:៣ **៤:១៥** ដ លប ៣០:៦ ឋ យរ ៣១:៦ **៤:១៦** ឌ ចទ ២៨:៤៩ ឍ ខ.១៩ អគ ២១:២២ ណ យរ ១:១៥ **៤:១៧** ត ២ពវ ២៥:១,៤ ថ ១សយ ១២:១៥ យរ ៥:២៣ **៤:១៨** ទ ទដ ១០៧:១៧ អស ១:២៨ យរ ៥:២៥ ធ យរ ២:១៧ ន យរ ២:១៩ **៤:១៩** ប អស ២២:៤ យរ ៦:២៤ ៩:១០ បទ ១:២០ ផ យប ៦:១០ ១៤:២២ យរ ១០:១៩ ព យប ៣៧:១ យរ ២៣:៩ ភ យប ៤:២ យរ ២០:៩ ម ខ.២១ ជន ១០:២ យប ៣៩:២៤ យ ខ.១៦ ជន ១០:៩ យរ ៤៩:២ សផ ១:១៦ **៤:២០** រ ចទ ៣១:១៧ ល ខ.១៣ វ ជន ២៤:៥ យរ ១០:២០ បទ ២:៤

*នៅ ហើយហោរានឹងនឹកប្លែកដែរ* មើលការពន្យល់ ១:១៨ ។

**៤:១០** *បានបញ្ឆោតជនជាតិនេះ* មិនមែនធ្វើដោយផ្ទាល់ទេ ប៉ុន្តែធ្វើដោយប្រយោល តាមរយៈពួកហោរាខុសឆ្គង (មើលឧទាហរណ៍ ១ពវ ២២:២០–២៣ និងការពន្យល់ ២២:៣) ។ *នឹងមានសេចក្ដីសុខសាន្តដល់ឯងរាល់គ្នា* នេះជាពាក្យរបស់ពួកហោរាខុសឆ្គង មិនមែនជាព្រះបន្ទូលរបស់ព្រះទេ (មើល ១៤:១៣ ២៣:១៧ និង ៦:១៣–១៤ ៨:១០–១១) ។ *ជីវិត* ភាសាហេព្រើរសម្រាប់ពាក្យនេះ ជាធម្មតាគឺបានបកប្រែថា "ព្រលឹង" ឬ "ជីវិត" ប៉ុន្តែពាក្យដើមមានន័យថា "បំពងក ដើមក" (ឧទាហរណ៍ ទដ ៦៩:១) ។

**៤:១១** *មានខ្យល់ក្ដៅ* ខ្យល់ក្ដៅ ជាខ្យល់ក្ដៅ និងស្ងួត ដែលបក់នាំខ្សាច់ និងធូលីដី (មើល ទដ ១១:៦ ១១:១៥ យហ ៤:៨) ។ *បក់មក* មើលការពន្យល់ រម ១:២២ ។

**៤:១២** *គឺជាខ្យល់ពេញកំឡាំង* បក់យ៉ាងខ្លាំង (ធ្វើឱ្យស្រូវស្កក និងស្រូវញែកចេញពីគ្នា) សម្អាត (បក់សម្អាតស្រូវស្កក ចេញពីគ្រាប់ស្រូវល្អ) រីឯការជំនុំជម្រះ និងបក់សម្អាតការអាក្រក់ចេញពីការល្អ ។

**៤:១៣** *អ្នកនោះនឹងឡើងមកដូចជាពពក* ធៀបនឹង អគ ៣៨:១៦ ។ ហើយរទេះចំបាំងរបស់គេ និងដូចជាខ្យល់កួច ២ពវ ២:១១ ៦:១៧ ទដ ៦៨:១៧ អស ៦៦:១៥ ។ *ឯសេះរបស់គេលឿនជាងសត្វឥន្ទ្រី* មើល ហាប ១:៨ នៅពេលដែលពួកបាប៊ីឡូនប្រើសេះ "នោះវាលឿនជាងខ្លាដំបងទៅទៀត" ហើយកងទាហានសេះនោះ "រត់លឿន ដូចជាសត្វត្មាតហើ" (ភាសាហេព្រើរសម្រាប់ពាក្យនេះគឺ "សត្វត្មាត" ត្រូវបានគេបកប្រែថា "សត្វឥន្ទ្រី" មើល ចទ ២៨:៤៩ ) ។ *យើងត្រូវវិនាស* មើល ខ.២០ ៩:១៩ ៤៨:១) ។

**៤:១៤** *ក្រុងយេរូសាឡិម* ជាទីក្រុងស្ដេចរបស់យូដា ហើយជារាជធានីយ៉ាងសំខាន់របស់ជាតិ ក្រុងយេរូសាឡិម គឺតំណាងដូចជាជាតិ ។ ចូរលាង មើល ២:២២ និងការពន្យល់ ។ *គំនិតអាក្រក់* ជិទាស់ប្រឆាំងមនុស្សដទៃទៀត (មើល សភ ៦:១៨ អស ៥៩:៧) ។

**៤:១៥** *ស្រុកដាន់* នៅឆ្ងាយ នៅជិតព្រំដែនខាងជើងរបស់អ៊ីស្រាអែល (មើល ៨:១៦) ។ *ស្រុកភ្នំអេប្រាអិម* មានចម្ងាយ៤៨២៧គីឡូម៉ែត្រ ខាងជើងក្រុងយេរូសាឡិម ។ ខ្មាំងសត្រូវនៅក្នុងគំនិតរបស់ហោរា គឺជាការដែលធ្វើឱ្យមានការភ័យខ្លាចដល់ទីក្រុងបរិសុទ្ធ ។

**៤:១៦** *ដើម្បីឡោមព័ទ្ធឯង* មើល អស ១:៨ ។ *ស្រុកឆ្ងាយ* បាប៊ីឡូនគេស្រែកទាស់នឹងក្រុងស្រុកយូដា ភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "ហ្វូងមនុស្ស" ២:១៥ ។

**៤:១៧** *គេនៅព័ទ្ធជុំវិញទីក្រុង* មើល ១:១៥ ។

**៤:១៩–២៦** ពេលកំសាន្តផ្ទាល់ខ្លួនក្នុងរយៈខ្លី វាបានបាត់បង់នៅពេលព្រះមានសេចក្ដីខ្វាល់ក្នុង ខ.២២ ។ សំលេងព្រួយលោកយេរេមា នៅពេលដែលការបំផ្លាញដល់មាតុភូមិ និងប្រជាជនរបស់គាត់ ។

**៤:១៩** មើល ១០:១៩–២០ ។ *សេចក្ដីឈឺចាប់* ប្រៀបដូចជាស្ត្រីសម្រាលកូន (មើល ៦:២៤ ៤៩:២៤ ៥០:៤៣) ។ *បេះដូងខ្ញុំប្រដំនៅក្នុងខ្លួន* មើល យប ៣៧:១ ទដ ៣៨:១០ ហាប ៣:១៦ ។ *ឯងបានឮសូរត្រែ* សូមមើលការពន្យល់ ខ.៥ ។

**៤:២០** *ត្រូវខូចអស់ហើយ* មើល ខ.១៣ ៩:១៩ ៤៨:១ ។ *ទីអាស្រ័យនៅ* "តង់" (ដូចជានៅក្នុង អស ៥៤:២) ជាទូទៅគេធ្វើវាឡើងពីរោមសត្វពពែ

អាស្រ័យនៅរបស់ខ្ញុំស្រាប់តែខូចបាត់ភ្លាម ហើយត្រសាល[រ]
របស់ខ្ញុំបា១រំពេចដែរ 21 តើត្រូវឱ្យខ្ញុំមើលឃើញទង់ជ័យ[ស]
ហើយឮសូរត្រែដល់កាលណាទៀត[ហ] 22 ពិតប្រាកដជា
រាស្ត្ររបស់អញគេល្ងីល្ងើ[ឡ] គេមិនស្គាល់អញសោះ[អ] គេ
សុទ្ធតែជាកូនវង្វេងវង្វាន់ ឥតមានយោបល់ឡើយ[ក] គេមាន
ប្រាជ្ញាខាងឯផ្លូវប្រព្រឹត្តអាក្រក់[ខ] តែគ្មានចំណេះខាងឯការ
ល្អសោះ[គ] ។
23 ខ្ញុំបានពិចារណាមើលផែនដី ឃើញថាខូចហើយ[ឃ]
នៅទទេ រួចមើលទៅលើមេឃ នោះក៏ឥតមានពន្លឺ[ង]ដែរ
24 ខ្ញុំក្រឡេកមើលទៅភ្នំធំ ឃើញថាញ័រទាំងអស់[ច] ហើយ
ភ្នំតូចទាំងប៉ុន្មានក៏កក្រើករញ្ជួយ 25 ខ្ញុំក៏ពិចារណាមើល
ឃើញថា គ្មានមនុស្សណាទៀតសោះ អស់ទាំងសត្វហើរ
លើអាកាសបានហើរទៅបាត់ហើយ[ឆ] 26 រួចខ្ញុំក៏មើលទៅ
ឃើញដីដុះដាល បានត្រឡប់ជាវាលស្ងាត់[ជ] ហើយអស់ទាំង
ទីក្រុងក៏ត្រូវរលំចុះ[ឈ] នៅចំពោះព្រះយេហូវ៉ា ហើយ
ចំពោះ សេចក្ដីខ្ញាល់ដ៏សហ័សរបស់ទ្រង់[ញ] ។
27 ដ្បិតព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ស្រុក
ទាំងមូលនឹងត្រូវខូចបង់[ដ] ប៉ុន្តែអញមិនបំផ្លាញ[ឋ]អស់រលីង
ទេ 28 ដោយហេតុការទាំងនេះ ផែនដីនឹងយំសោក[ឌ] ហើយ
មេឃខាងលើនឹងទៅជាខ្មៅ[ឍ] ពីព្រោះអញបានចេញវាចា
អញបានគិតសំរេចការនេះហើយ អញនឹងមិនប្រែចិត្ត[ណ] ឬ
បែរចេញពីការនេះឡើយ[ត] 29 បណ្ដាមនុស្សនៅទីក្រុងទាំង
ប៉ុន្មានរត់ទៅ[ថ]ដោយព្រោះសូរពលសេះ និងពលធ្នូ[ទ] គេ
ចូលទៅក្នុងទីស្ដុកនៅព្រៃ ហើយឡើងទៅលើថ្មដា[ធ] ទីក្រុង
ទាំងឡាយត្រូវចោលស្ងាត់[ន] ឥតមានអ្នកណានៅឡើយ 30 ឯ
ឯង កាលណាឯងបានត្រូវខូចបង់ហើយ នោះតើឯងនឹងធ្វើ
ដូចម្ដេច[ប] ទោះបើឯងស្លៀកពាក់ពណ៌ក្រហម ហើយតែង
ខ្លួនដោយគ្រឿង[ផ]មាស ព្រមទាំងផាត់រង្វង់ភ្នែកឯង ដោយ
ថ្នាំផងក៏ដោយ[ព] គង់តែឯងនឹងខំធ្វើខ្លួនឱ្យល្អ មើលជាឥត
ប្រយោជន៍ទទេ ពួកសហាយ[ភ]របស់ឯង គេស្អប់ខ្ពើមឯង

**៤:២១** ស ខ.៦ ជន ២:២ អស ១៨:៣ ហ ខ.៥,១៩ យស ៦:២០ យរ ៦:១ ហស ៥:៨ អម ៣:៦ សផ ១:១៦ **៤:២២** ឡ យរ ៥:២១ ១០:៨ អ អស ១:៣ ២៧:១០ យរ ២:៨ ៨:៧ ហស ៥:៤ ៦:៦ ក ទដ ១៤:៤ ៥៣:២ ខ យរ ១៣:២៣ ១កថ ១៤:២០ គ ទដ ៣៦:៣ **៤:២៣** ឃ លប ១:២ ង ខ.២៨ យប ៩:៧ ៣០:២៦ អស ៥:៣០ ៥៩:៩ បទ ៣:២ **៤:២៤** ច នក ១៩:១៨ យប ៩:៦ **៤:២៥** ឆ យរ ៧:២០ ៩:១០ ១២:៤ ហស ៤:៣ សផ ១:៣ **៤:២៦** ជ លប ១៣:១០ យរ ១២:៤ ២៣:១០ ឈ អស ៦:១១ ញ យរ ១២:១៣ ២៥:៣៨ **៤:២៧** ដ ខ.១៣ ឋ លវ ២៦:៤៤ យរ ៥:១០,១៨ ១២:១២ ៣០:១១ ៤៦:២៨ អគ ២០:១៧ អម ៩:៨ **៤:២៨** ឌ យរ ១២:៤,១១ ១៤:២ ហស ៤:៣ ឍ ខ.២៣ ណ ជន ២៣:១៩ ត ខ.៨ យរ ២៣:២០ ៣០:២៤ **៤:២៩** ថ ២ពវ ២៥:៤ ទ ខ.១៣ យរ ៦:២៣ ៨:១៦ ធ នក ៣៣:២២ ១សយ ២៦:២០ ន ខ.៧ អស ៦:១២ **៤:៣០** ប អស ១០:៣–៤ ផ អគ ១៦:១១ ២៣:៤០ ព ២ពវ ៩:៣០ ភ យប ១៩:១៤ បទ ១:២ អគ ២៣:៩,២២

(មើល នក ២៦:៧) ហើយវាអាចការពារពីភាពត្រជាក់ និងទឹកភ្លៀងបាន (មើល ១០:២០) ។

**៤:២១** *ខ្ញុំមើលឃើញទង់ជ័យ ហើយឮសូរត្រែដល់កាលណាទៀត* មើលការពន្យល់ ខ.៥–៦ ។

**៤:២២** ព្រះមានបន្ទូល *ល្ងីល្ងើ* មើលការពន្យល់ សភ ១:៧ ។ *គេមិនស្គាល់អញសោះ* មើល ២:៨ ។ អ្នកដឹកនាំ និងរាស្ត្រគេចូលចិត្តប្រព្រឹត្តអំពើបាប (មើល អស ១:២–៣ អស ៤:១) ។ *វង្វេងវង្វាន់* មើល ៥:២១ ១០:៨,១៤, ២១ ៤១:១៧ ។ *គេមានប្រាជ្ញាខាងឯផ្លូវប្រព្រឹត្តអាក្រក់* មើល មីក ៧:៣ ។ *តែគ្មានចំណេះខាងឯការល្អសោះ* មើល ទដ ១៤:១–៣ និងការពន្យល់ ១៤:១ ។

**៤:២៣–២៦** ការបញ្ជាក់ឡើងវិញថា "ខ្ញុំក្រលេកមើល" នៅដើមខនិមួយៗ ភ្ជាប់មកជាមួយនូវពាក្យកំណាព្យ ហើយសង្កត់ទៅលើការស្រមៃដល់ តួអង្គដូចជា ហោរាមើលឃើញមាតុភូមិរបស់ខ្លួន កំពុងតែវិនាស នៅពេលដែលពួកបាប៊ីឡូន វាយយកទឹកដីនោះ ។ការបង្កើតឡើងវិញនោះចាប់ផ្ដើមសាជាថ្មី ។

**៤:២៣** *ឃើញថាខូចហើយនៅទទេ* ឃ្លានេះមានឃើញនៅក្នុងព្រះគម្ពីរ លប ១:២ (មើលការពន្យល់) ។ ចំពោះចក្ខុវិស័យរបស់លោកយេរេមា គាត់មើលឃើញភាពវឹកវរបានកើតមានឡើង ។ *នោះក៏ឥតមានពន្លឺដែរ* ដែលខុសគ្នានៅក្នុង លប ១:៣ ។

**៤:២៤** មើល ណាហ ១:៥ ។

**៤:២៥** *គ្មានមនុស្សណាទៀតសោះ* ព្រះគម្ពីរភាសាហេព្រើរគូសចំណាំពាក្យនេះ ដែលឃើញមាននៅក្នុងព្រះគម្ពីរ លប ២:៥ ហើយត្រូវបានបកប្រែថា គ្មានមនុស្សណាសោះ "ម្ដងទៀត អ្វីដែលមិនបានបង្កើត នោះត្រូវបានបង្កើតឡើងវិញ" ។

**៤:២៦** *ដីដុះដាល* មើលការពន្យល់ ២:៧ ។ *សេចក្ដីខ្ញាល់ដ៏សហ័សរបស់ទ្រង់* មើល ខ.៨ អស ១៣:១៣ ណាហ ១:៥ ។

**៤:២៧** *អញមិនបំផ្លាញអស់រលីងទេ* មើល ៥:១០,១៨ ៣០:១១ ៤៦:២៨ ។ សេចក្ដីមេត្តារបស់ព្រះ នៅថ្ងៃជំនុំជម្រះ ដូចជានៅក្នុង យរ ខ.២៣–២៦ ។

**៤:២៨** *អញនឹងមិនប្រែចិត្ត* លុះត្រាតែរាស្ត្ររបស់ទ្រង់ប្រែចិត្ត (មើល ១៨:៧–១០ និងការពន្យល់) ។

**៤:២៩** *ពលធ្នូ* អំពើអាក្រក់ដែលពួកបាប៊ីឡូនប្រព្រឹត្តនោះ ទាស់ប្រឆាំងនិងពួកយូដា ដែលធ្វើឱ្យពួកគេមានការភ័យខ្លាច (មើល ៥០:២៩) ។ *គេចូលទៅក្នុងទីស្ដុក* មើល ពច ៦:២ ១យស ១៣:៦ អស ២:១៩,២១ ។ ទោះបីជាប្រជាជនគេរស់នៅទីក្រុងដែលមានការលើកទឹកចិត្តក្ដី នោះគេនៅតែមានអារម្មណ៍ថា គេមានការបាក់ទឹកចិត្ត ។ *ត្រូវចោលស្ងាត់* ដែលខុសគ្នានៅក្នុង អស ៦២:៤ ។

**៤:៣០** *ឯឯង* ជាសព្វនាមមនុស្សទី២ ដែលតំណាងឱ្យសព្វនាមឥត្ថីលិង្គ (ភេទស្រី) ឬកិរយាសព្ទនៅក្នុងពាក្យហេព្រើរ ដោយចង្អុលបង្ហាញពីក្រុងយេរូសាឡិម (មើល ខ.១៤ និងការពន្យល់) ។ នាងអាចរៀបរាប់បានដូចជាប្រពន្ធដែលផិតក្បត់ ធ្វើឱ្យសហាយរបស់ខ្លួនមានការសម្រើប ។ *ផាត់រង្វង់ភ្នែក* ការតុបតែង ប្រដាប់គូរចិញ្ចើមភ្នែក គូរឱ្យកាន់តែស្អាត និងមានការចាប់អារម្មណ៍ពីអ្នកដទៃ (មើល ២ពវ ៩:៣០ អគ ២៣:៤០) ។ *ពួកសាហាយ* ព្រះគម្ពីរភាសាហេព្រើរគូសបញ្ជាក់ពាក្យនេះ អាចរកឃើញនៅកន្លែង១នៅក្នុងព្រះគម្ពីរ អគ ២៣:៥,៧,៩,១២,១៦,២០ ដែលបានប្រើដូចគ្នាចំពោះក្រុងយេរូសាឡិម ជាប្អូនស្រីកំផិត (មើលការពន្យល់ យរ ២:២៥ ៣:១,៧) ដែល "មានតណ្ហា" គឺពួកសាសន៍ដទៃ និងរូបព្រះរបស់គេ ។ *ក៏រក*

ហើយក៏រកជីវិតឯងផង[ម] ៣១ពីព្រោះខ្ញុំបានឮ សំឡេង១ ដូច
ជាសំឡេងរបស់ស្រី ដែលឈឺនឹងសំរាល[យ] កូនជាសេចក្តី
ព្រួយបារម្ភរបស់ស្រី ដែលសំរាលកូនជា ដំបូងគឺសំឡេង
នៃកូនស្រីស៊ីយ៉ូន[រ] ដែលដកដង្ហើមថ្ងូរ[ល] ហើយស្រងាកដៃ[វ]
ដោយថា វរហើយខ្ញុំ ដ្បិតព្រលឹងខ្ញុំល្វើយណាស់ នៅ
ចំពោះពួកកាប់សំឡាប់នេះ[ស]។

## គ្មាននរណាម្នាក់សុចរិត

**៥** ១ចូររត់ទៅមក[ក]តាមផ្លូវក្រុងយេរូសាឡិមមើល ឱ្យដឹង
ឥឡូវ ចូរស្វែងរកនៅទីធ្លាទាំងប៉ុន្មានមើល[ខ] បើមានអ្នក
ណាមួយ[គ] គឺបើមានមនុស្សណាដែលប្រព្រឹត្តដោយសុចរិត[ឃ]
ឬដែលស្វែងរកសេចក្តីពិត នោះអញនឹងអត់ទោស[ង]ដល់ទី
ក្រុង ២ទោះបើគេថា គេស្បថដោយព្រះយេហូវ៉ាដ៏មាន
ព្រះជន្មរស់នៅក៏ដោយ[ច] គង់តែគេស្បថដោយភូតភរទេ[ឆ]
៣ឱ ព្រះយេហូវ៉ាអើយ ព្រះនេត្រ[ជ]ទ្រង់ តើទតមិនឃើញ
សេចក្តី ពិតទេឬអី ទ្រង់បានវាយ[ឈ]គេ តែគេមិនបង្រះសោះ
ទ្រង់បានធ្វើឱ្យគេអន្តរធានទៅ តែគេមិនព្រមទទួលសេចក្តី
ប្រៀនប្រដៅទេ[ញ] គេបានតាំងមុខរឹងជាងថ្ម[ដ] គេមិនព្រម
វិលមកវិញឡើយ[ឋ]។
៤នោះខ្ញុំបានថា មនុស្សទាំងនេះ ប្រាកដជាទាល់ក្រ
ហើយល្ងីល្ងើទេ[ឌ] គេមិនស្គាល់[ឍ]ផ្លូវរបស់ព្រះយេហូវ៉ា ឬ
ក្រិត្យវិន័យរបស់ព្រះនៃគេឡើយ ៥ខ្ញុំនឹងទៅឯពួកអ្នកធំ[ណ]
ហើយនិយាយនឹងគេវិញ ដ្បិតមុខជាគេស្គាល់ផ្លូវរបស់ព្រះ
យេហូវ៉ា និងក្រិត្យវិន័យរបស់ព្រះនៃគេពិត ប៉ុន្តែអ្នកទាំង
នោះ បានព្រមគ្នាបំបាក់នឹម ហើយផ្តាច់ចំណងចេញផង[ត]
៦ដូច្នេះ សិង្ហមួយដែលចេញពីព្រៃ[ថ] នឹងសំឡាប់គេ ឆ្កែព្រៃ
នៅវាលស្ងាត់នឹងបំផ្លាញ[ទ]គេ ហើយខ្លារខិន[ធ]ម៉បចាំនៅមុខ
ទីក្រុងរបស់គេ អស់អ្នកណាដែលចេញពីទីក្រុងនោះ នឹង
ត្រូវហែកខ្ទេចខ្ទី ពីព្រោះអំពើរំលងរបស់គេមានច្រើន
ណាស់ ហើយការរាថយរបស់គេ ក៏បានចំរើនជាច្រើន
ឡើងដែរ[ន]។
៧ធ្វើដូចម្តេចឱ្យអញបានអត់ទោសឱ្យឯងបាន ពួកកូន
ចៅរបស់ឯងបានបោះបង់ចោលអញអស់ហើយ ក៏បាន
ស្បថ[ប]នឹងរបស់ដែលមិនមែនជាព្រះផង[ផ] កាលអញបានឱ្យ
គេស៊ីឆ្អែតជាបរិបូរ នោះគេក៏បែរជាផិត[ព]អញវិញ ហើយ
ប្រជុំគ្នាទាំងហ្វូងនៅឯផ្ទះស្រីសំផឹង[ភ] ៨គេប្រៀបដូចជាសេះ

**៤:៣០** ម ទដ ៣៥:៤ **៤:៣១** យ លប ៣:១៦ យរ ៦:២៤ ១៣:២១ ២២:២៣ ៣០:៦ មីក ៤:១០ រ ទដ ៩:១៤ ល អស ៤២:១៤ វ អស ១:១៥ បទ ១:១៧ ស ចទ ៣២:២៥ បទ ២:២១ **៥:១** ក ២របា ១៦:៩ អគ ២២:៣០ ខ ទដ ៤៥:១០ គ លប ១៨:៣២ យរ ២:២៩ ឃ ខ.៣១ យរ ១៤:១៤ អគ ១៣:៦ ង លប ១៨:២៤ **៥:២** ច យរ ៤:២ ឆ លវ ១៩:១២ **៥:៣** ជ ២របា ១៦:៩ ឈ អស ៩:១៣ ញ លវ ២៦:២៣ ដ យរ ៧:២៦ ១៩:១៥ អគ ៣:៨–៩ ៣៦:២៦ សក ៧:១២ ឋ ២របា ២៨:២២ អស ១:៥ អគ ២:៤–៥ អម ៤:៦ សក ៧:១១ **៥:៤** ឌ ខ.២១ យរ ៤:២២ ឍ សភ ១០:២១ អស ១:៣ **៥:៥** ណ មីក ៣:១,៩ ត យរ ២:២០ **៥:៦** ថ ទដ ១៧:១២ ទ លវ ២៦:២២ ធ ហស ១៣:៧ ន យរ ១៤:៧ ៣០:១៤ **៥:៧** ប យស ២៣:៧ ផ ចទ ៣២:២១ យរ ២:១១ ១៦:២០ កទ ៤:៨ ព ជន ២៥:១ ភ យរ ១៣:២៧

*ជីវិតឯងផង* គេប៉ងចង់សម្លាប់ឯង (មើល ខ.៣១) ។
**៤:៣១** *ដូចជាសំលេងរបស់ស្រី ដែលឈឺនឹងសំរាលកូន* មើល ៦:២៤ ១៣:២១ ២២:២៣ ៣០:៦ ៣១:៨ ៤៨:៤១ ៤៩:២២,២៤ ៥០:៤៣ មើលផងដែរ ខ.១៩ អស ១៣:៨ និងការពន្យល់ ។ *កូនស្រីស៊ីយ៉ូន* ជាគំរូលល្អនៃក្រុងយេរូសាឡិម (មើលការពន្យល់ ២ពវ ១៩:២១) ។ *ដែលដកដង្ហើមថ្ងូរ ហើយស្រងាកដៃ* ការអធិស្ឋានសុំជំនួយ (មើល យប ១១:១៣) ។
**៥:១–៣១** លោកយេរេមាបន្តការពិពណ៌នា នូវទង្វើអាក្រក់យ៉ាងកក្រើករបស់ពួកយូដា និងពួកក្រុងយេរូសាឡិម ។
**៥:១** មើល សផ ១:១២ ព្រះអម្ចាស់ទ្រង់លើកទឹកចិត្តមនុស្សណា ដែលអាចស្វែងរកមនុស្សសុចរិត នៅអ៊ីស្រាអែល ពីព្រោះទីក្រុងនោះពោរពេញទៅដោយសេចក្តីអាក្រក់(មើល ទដ ១៤:១–៣ អស ៦៤:៦–៧ ហស ៤:១–២ មីក ៧:២) ។ *គឺបើមានមនុស្សណាដែលប្រព្រឹត្តដោយសុចរិត ឬដែលស្វែងរកសេចក្តីពិត នោះអញនឹងអត់ទោសដល់ទីក្រុង* មើល លប ១៨:២៦–៣២។
**៥:២** *គេស្បថដោយព្រះយេហូវ៉ាដ៏មានព្រះជន្មរស់នៅ* មើល ៤:២ មើលផងដែរ លប ៤២:១៥ និងការពន្យល់ ។ គង់តែគេស្បថដោយភូតភរទេ អំពើហិង្សានៅក្នុង លវ ១៩:១២ (មើលការពន្យល់ នក ២០:៧) ។ ព្រះគម្ពីរភាសាហេព្រើរគូសចំណាំឃ្លានេះ ដោយបានបកប្រែថា " គេចូលចិត្តការភូតភ" នៅក្នុង ៧:៩ (មើលការពន្យល់) ។
**៥:៣** *គេមិនព្រមទទួលសេចក្តីប្រៀនប្រដៅទេ* មើល ២:៣០ ។ *គេបានតាំងមុខរឹងជាងថ្ម* ការរៀបរាប់ពីការបះបោរ (មើល អគ ៣:៧–៩) ។
**៥:៤** *ទាល់ក្រ* ការយកចិត្តទុកដាក់លើសេចក្តីត្រូវការផ្នែកសាច់ឈាម ជាមូលដ្ឋាន (ធៀបនឹង ៣៩:១០ ៤០:៧ មើលការពន្យល់) គេមិនបានប្រព្រឹត្តតាមព្រះបន្ទូលព្រះ និងផ្លូវរបស់ទ្រង់ទេ ។ *ហើយល្ងីល្ងើ* មើល ៤:២២ មើលផងដែរ ជន ១២:១១ និងការពន្យល់ សភ ១:៧ ។ *គេមិនស្គាល់ផ្លូវរបស់ព្រះយេហូវ៉ា ឬក្រិត្យវិន័យរបស់ព្រះ* គេធ្វើព្រងើយជាងសត្វដែលហើរនៅលើមេឃទៅទៀត (មើល ៨:៧) ។
**៥:៥** *ពួកអ្នកធំ* "អ្នកធំ" ទោះបីជាគេបានទទួលផលប្រយោជន៍ច្រើនក្តី នោះគេមិនមែនសុចរិតជាងអ្នកក្រីក្រ ដែលជាមនុស្សសាមញ្ញនោះឡើយ ។ *អ្នកទាំងនោះនឹងបានព្រមគ្នាបំបាក់នឹម ហើយផ្តាច់ចំណងចេញផង* មើលការពន្យល់ ២:២០ ) ។
**៥:៦** *សិង្ហមួយដែលចេញពីព្រៃ នឹងសំឡាប់គេ ឆ្កែព្រៃនៅវាលស្ងាត់នឹងបំផ្លាញគេ ហើយខ្លារខិនម៉បចាំនៅមុខទីក្រុងរបស់គេ* មើល លវ ២៦:២២ អគ ១៤:១៥ ធៀបនឹង ២ពវ ១៧:២៥–២៦ ។ *ម៉បចាំនៅមុខ* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ គឺបានបកប្រែថា " កំពុងដេកចាំ" នៅក្នុង ១:១២ ។ ពីព្រោះអំពើរំលងរបស់គេ មើល ២:១៩ ៣:២២ ១៤:៧ ។ ពាក្យនេះរលឹកដល់ពួកគេ ឱ្យនឹកចាំឡើងវិញ ចំពោះសេចក្តីជំនឿ ដែលគេបានបោះបង់ចោលនោះ ។
**៥:៧** *ធ្វើដូចម្តេចឱ្យអញបានអត់ទោសឱ្យឯងបាន* មើលខ១ ។ *ពួកកូនចៅរបស់ឯង* ក្រុងយេរូសាឡិម គឺត្រូវបានពណ៌នា ដូចជា "ម្តាយ" ទីក្រុងរបស់ជាតិ ។ *របស់មិនមែនជាព្រះផង* រូបព្រះ (មើល ២:១១) ។ *អញបានឱ្យគេស៊ីឆ្អែតជាបរិបូរ នោះគេ* មើល ចទ ៣២:១៥–១៦ ហស ២:៨ ។ *បែរជាផិតអញវិញ* មើល ២:២៥ និងការពន្យល់ ។

ដែលចិញ្ចឹមដោយល្អ ហើយរត់ទៅមកតាមតែចិត្ត គឺគេ
ស្រែកកញ្ជ្រៀវរកប្រពន្ធរបស់អ្នកជិតខាងគ្រប់គ្នា[ម] ៩ដូច្នេះ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា តើអញមិនត្រូវធ្វើទោស
ចំពោះអំពើយ៉ាងនោះទេឬ[យ] តើព្រលឹងអញមិនត្រូវសង
សឹក[រ]នឹងសាសន៍ណាយ៉ាងដូច្នេះទេឬអី ។
១០ចូរឡើងទៅលើអស់ទាំងកំផែងទីក្រុងរបស់គេ ហើយ
បំផ្លាញទៅ តែកុំឱ្យអស់រលីងឡើយ[ល] ចូរកាច់ខ្នែងគេចេញ
ពីព្រោះខ្នែងទាំងនោះមិនមែនជារបស់ផងព្រះយេហូវ៉ាទេ
១១ដ្បិតពួកវង្សអ៊ីស្រាអែល និងពួកវង្សយូដាបានក្បត់[វ]នឹង
អញជាខ្លាំងហើយ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ១២គឺ
គេបានកុហក[ស]ពីព្រះយេហូវ៉ា ដោយពាក្យថា មិនមែនព្រះ
នោះទេ ឯសេចក្ដីអាក្រក់ នឹងមិនមកលើយើងរាល់គ្នា[ហ]
ហើយយើងនឹងមិនត្រូវឃើញដាវ ឬគ្រាអំណត់អត់ឡើយ[ឡ]
១៣ពួកហោរា[អ]នឹងត្រឡប់ទៅដូចជាខ្យល់[ក] ព្រះបន្ទូលមិននៅ
ក្នុងគេទេ សូមឱ្យគេបានយ៉ាងដូច្នោះចុះ ។
១៤ដូច្នេះ ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ ទ្រង់
មានបន្ទូលថា ដោយព្រោះឯងរាល់គ្នាបានពោលពាក្យ
យ៉ាងនេះ នោះមើល អញនឹងធ្វើឱ្យពាក្យដែលអញដាក់នៅ
មាត់ឯង[ខ] បានដូចជាភ្លើងវិញ[គ] ហើយឱ្យជនជាតិនេះ បាន
ត្រឡប់ជាឧស ភ្លើងនោះនឹងឆេះបន្សុសគេអស់ទៅ[ឃ] ១៥ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា នែ ពួកវង្សអ៊ីស្រាអែលអើយ
មើល អញនឹងនាំសាសន៍១[ង]ពីឆ្ងាយមកលើឯងរាល់គ្នា គឺជា

**៥:៨** ម យរ ២៩:២៣ អគ ២២:១១ ៣៣:២៦
**៥:៩** យ ខ.២៩ យរ ៩:៩ រ អស ៥៧:៦
**៥:១០** ល យរ ៤:២៧ អម ៩:៨
**៥:១១** វ ១ពវ ១៩:១០ ទដ ៧៣:២៧ អស ២៤:១៦
**៥:១២** ស អស ២៨:១៥ ហ យរ ២៣:១៧ ឡ យរ ១៤:១៣ ២៧:៨
**៥:១៣** អ យរ ១៤:១៥ ក ២របា ៣៦:១៦ យប ៦:២៦
**៥:១៤** ខ ហស ៦:៥ គ ទដ ៣៩:៣ យរ ២៣:២៩ ឃ អស ១:៣១
**៥:១៥** ង ចទ ២៨:៤៩ ២ពវ ២៤:២ ច លប ១១:៧ អស ២៨:១១
**៥:១៦** ឆ យប ៣៩:២៣
**៥:១៧** ជ អស ១:៧ យរ ៨:១៦

សាសន៍១យ៉ាងស្វិតស្វាញ ជាសាសន៍ចាស់បុរាណដែលឯង
មិនស្គាល់ភាសា[ច]របស់គេទេ ក៏ស្ដាប់ពាក្យ គេមិនបានដែរ
១៦បំពង់ព្រួញ[ឆ]គេ ដូចជាផ្នូរខ្មោចចំហ គេសុទ្ធតែជាមនុស្ស
ខ្លាំងពូកែ ១៧គេនឹងស៊ី[ជ,ឈ]ផលចំរូត ហើយអាហាររបស់ឯង
អស់ទៅ ជាអាហារដែលទុកសំរាប់កូនប្រុសកូនស្រីឯង
ក៏នឹងស៊ី[ញ,ដ]ហ្វូងចៀម ហ្វូងគោរបស់ឯង ហើយនឹងស៊ី[ឋ]
បំផ្លាញដើមទំពាំងបាយជូរ និងដើមល្វារបស់ឯងដែរ[ឌ] គេ
នឹងវាយរំលំទីក្រុងមានកំផែង[ឍ] ដែលជាទីទុកចិត្តរបស់ឯង
នោះ[ណ] ដោយសារដាវ[ត] ១៨តែព្រះយេហូវ៉ាទ្រង់មានបន្ទូល
ថា ទោះបើមានគ្រាយ៉ាងនោះក៏ដោយ គង់តែអញមិន
បំផ្លាញ[ថ]ឯងរាល់គ្នាឱ្យអស់រលីងដែរ ១៩ដូច្នេះ បើកាលណា
ឯងរាល់គ្នាសួរថា[ទ] ហេតុអ្វីបានជាព្រះយេហូវ៉ា ជាព្រះនៃ
យើង ទ្រង់ប្រព្រឹត្តការយ៉ាងនេះដល់យើង នោះទ្រង់នឹង
ឆ្លើយដល់គេថា ឯងរាល់គ្នាបានបោះបង់ចោលអញ ទៅ
គោរពដល់ព្រះដទៃ[ធ] នៅក្នុងស្រុកឯងជាយ៉ាងណា ឯង
រាល់គ្នានឹងត្រូវគោរពដល់សាសន៍ដទៃ[ន] នៅក្នុងស្រុក១
ដែលមិនមែនជារបស់ផងខ្លួនយ៉ាងនោះដែរ ។
២០ចូរថ្លែងសេចក្ដីនេះនៅក្នុងពួកវង្សយ៉ាកុប ហើយ
ប្រកាសប្រាប់[ប]នៅក្នុងពួកយូដាថា ២១ឱជនជាតិល្ងីល្ងើ

៣០:១៦ ឈ លវ ២៦:១៦ ញ យរ ៥០:៧,១៧ ដ ចទ ២៨:៣២ ឋ ចទ ២៨:៣១ ឌ ជន ១៦:១៤ យរ ៨:១៣ ហស ២:១២ ឍ យស ១០:២០ ណ ចទ ២៨:៣៣ ត លវ ២៦:២៥ **៥:១៨** ថ យរ ៤:២៧ **៥:១៩** ទ ចទ ៤:២៨ ១ពវ ៩:៩ ធ យរ ២:៨ ១៥:១៤ ១៦:១៣ ១៧:៤ ន ចទ ២៨:៤៨ **៥:២០** ប យរ ៤:៥

**៥:៨** *ហើយរត់ទៅតាមតែចិត្ត គឺគេស្រែកកញ្ជ្រៀវរក* មើល ១៣:២៧ ៥០:១១ អគ ២៣:២០ ។

**៥:៩** *តើអញមិនត្រូវធ្វើទោស ចំពោះអំពើយ៉ាងនោះទេឬ* និយាយឡើងវិញនៅក្នុង ខ.២៩ ៩:៩ ។

**៥:១០** *ចូរឡើងទៅ* បញ្ជាក់ពីទាហានរបស់អ៊ីស្រាអែល (មើល ខ.១៥) ។ *ចំការទំពាំងបាយជូររបស់គេ* ទំពាងបាយជូរ និងចំការទំពាំងបាយជូរជានិម្មិតរូបពីអ៊ីស្រាអែល (មើលការពន្យល់ ២:២១ អស ៥:១) ។ *ហើយបំផ្លាញទៅ តែកុំឱ្យអស់រលីងឡើយ* មើលថ១៨ មើលការពន្យល់ផងដែរ ៤:២៧ ។ *ចូរកាត់ខ្នែងគេចេញ* មើល អស ១៨:៥ យហ ១៥:២,៦ ។ *ខ្នែងទាំងនោះមិនមែនជារបស់ផងព្រះយេហូវ៉ាទេ* មើល ហស ១:៩ ។

**៥:១១** មើលការពន្យល់ ៣:៧ ។

**៥:១២** *មិនមែនព្រះនោះទេ* ទោះបីជាល្អ ឬអាក្រក់ក្ដី (មើល សផ ១:១២) ។ ដាវ ឬគ្រាអំណត់អត់ក្ដី លោកយេរេមាបានណែនាំយើងឱ្យ ស្គាល់នូវផ្នែក២ដំបូងអំពីបញ្ហាទាំងបីដូចជា "ដាវ គ្រាអំណត់អត់ និងជម្ងឺអាសន្នរោគ" (មើលការពន្យល់ ១៤:១២) ។

**៥:១៣** *ពួកហោរានឹងត្រឡប់ទៅដូចជាខ្យល់* ដូចជារូបព្រះជាដើម (មើល អស ៤១:២៩) ។ *សូមឱ្យគេបានយ៉ាងដូច្នោះចុះ* មើលការពន្យល់ ៤:២៩ មើលផងដែរ ទដ ៧:១៦ ៥៤:៥ ។

**៥:១៤** *អញនឹងធ្វើឱ្យពាក្យដែលអញបាននៅមាត់ឯង* បានដូចជាភ្លើងវិញ ដែលផ្ទុយទៅនឹងការដែលគ្មានព្រះបន្ទូលព្រះនៅមាត់របស់ហោរាខុសឆ្គង (ខ.១៣) ។ មើល ២០:៩ និងការពន្យល់ ។ *ឆេះបន្សុសគេអស់* មើលការពន្យល់ អស ១:៣១ ។

**៥:១៥** *សាសន៍១ពីឆ្ងាយមក* មើលការពន្យល់ ៤:១៦ ។ *ជាសាសន៍ចាស់បុរាណ* ប្រវត្តិសាស្ត្ររបស់បាប៊ីឡូន បានវិលថយក្រោយ កាល២000ឆ្នាំមុន និងច្រើនជាងនោះ។ *ដែលឯងមិនស្គាល់ភាសាគេ* មើល ចទ ២៨:៤៩ និងការពន្យល់) ។

**៥:១៦** *ដូចជាផ្នូរខ្មោចចំហ* និម្មិតសញ្ញាពីភាពអស្មេរភាព ការបំផ្លិចបំផ្លាញ និងសេចក្ដីស្លាប់ (មើល ទដ ៥:៩ សភ ៣០:១៥–១៦) ។

**៥:១៧** *អាហារដែលទុកសំរាប់កូនប្រុស កូនស្រីឯង* ដូចជាការដែលគេថ្វាយយញ្ញបូជាដល់រូបព្រះ (មើលការពន្យល់ ៣:២៤) ឬការគ្រោះថ្នាក់ ដោយសារសង្គ្រាម (មើល ១០:២៥) ។ *គេនឹងវាយរំលំទីក្រុងមានកំផែង ដែលជាទីទុកចិត្តរបស់ឯងនោះ* មើលការពន្យល់ ៤:៥ មើលការពន្យល់ផងដែរ ចទ ២៨:៥២) ។

**៥:១៨** មើល ខ.១០ និងមើលការពន្យល់ផងដែរ ៤:២៧ ។

**៥:២១** *ចូរស្ដាប់សេចក្ដីទាំងនេះចុះ* មើលការពន្យល់ ២:៤ ។ *ឱជនជាតិល្ងីល្ងើ ហើយឥតយោបល់* មើល ៤:២២ មើលការពន្យល់ផងដែរ សភ

ហើយឥតយោបល់[ផ] ជាពួកអ្នកដែលមានភ្នែក[ព] តែមើល
មិនឃើញ មានត្រចៀក តែស្តាប់មិនឮអើយ ចូរស្តាប់
សេចក្តីនេះឥឡូវចុះ[ភ] ២២ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
តើឯងរាល់គ្នាមិនកោតខ្លាច[ម]ដល់អញទេឬ តើឯងរាល់គ្នា
មិនញាប់ញ័រ[យ]នៅចំពោះអញទេឬអី ដែលអញបានដាក់
ខ្សាច់ធ្វើជាព្រំខណ្ឌសមុទ្រ[រ] ដោយបញ្ញត្តិដ៏នៅជានិច្ច ដើម្បី
មិនឱ្យហូររំលងឡើយ ហើយទោះបើរលកបោកមាត់ច្រាំង
គង់តែនឹងឈ្នះមិនបាន ទោះបើឮសន្ធឹកយ៉ាងណា[ល] គង់តែ
នឹងហូររំលងមិនបានដែរ ២៣តែជនជាតិនេះគេមានចិត្ត
រឹងចចេស ហើយបះបោរ[វ]វិញ គេបានបះបោរចេញ[ស]បាត់
ទៅហើយ ២៤គេក៏មិនដែលនឹកក្នុងចិត្តថា ឥឡូវនេះ ចូរ
យើងកោតខ្លាច[ហ]ដល់ព្រះយេហូវ៉ា ជាព្រះនៃយើងវិញ
ដែលទ្រង់ប្រទានភ្លៀង[ឡ]មក គឺទាំងភ្លៀងដើម ហើយចុង
រដូវផង តាមរដូវភ្លៀង ហើយកំណត់រក្សាទុកប៉ុន្មានអាទិត្យ
ដែលសំរាប់ច្រូតកាត់ដល់យើងដែរ នោះឡើយ[អ] ២៥អំពើ
ទុច្ចរិត របស់ឯងរាល់គ្នាបានបង្វែរការទាំងនោះចេញ
ហើយអំពើបាបរបស់ឯង បានបង្ខាំងសេចក្តីល្អ ចេញពីឯង
រាល់គ្នាដែរ[ក] ២៦ដ្បិតនៅក្នុងរាស្ត្រអញ ឃើញមានមនុស្ស
ដែលប្រព្រឹត្តអាក្រក់[ខ] គេរំពៃចាំ[គ]ដូចជាអ្នកទាក់សត្វហើរ
ពួនចាំដែរ ឯគេគឺដាក់អន្ទាក់[ឃ] ហើយចាប់មនុស្សវិញ
២៧ទ្រុងមានពេញ ដោយសត្វហើរយ៉ាងណា ផ្ទះគេក៏ពេញ
ដោយសេចក្តីឆបោកយ៉ាងនោះដែរ[ង] ដូច្នេះ គេបានត្រឡប់
ជាធំ[ច] ហើយមានឡើង ២៨គេបានឡើងសាច់ធាត់[ឆ] ហើយ
ប៉ផូរ អើ គេប្រព្រឹត្តអំពើអាក្រក់ហួសល្បត់ ឥតដែលកាន់ក្តី
ជំនួសពួកកំព្រា[ជ] ដើម្បីឱ្យពួកនោះបានចំរើនឡើងឡើយ ក៏
មិនសំរេចត្រឹមត្រូវដល់ពួកកំសត់ផង[ឈ] ២៩ព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា តើអញមិនត្រូវធ្វើទោសចំពោះការដូច្នេះទេ
ឬ តើព្រលឹងអញមិនត្រូវសងសឹក[ញ]នឹងសាសន៍យ៉ាងនោះ
ទេឬអី ។

៣០មានការដ៏អស្ចារ្យ[ដ] ហើយគួរស្ញែងខ្លាច បានកើត
ឡើងនៅក្នុងស្រុក ៣១គឺពួកហោរាបានទាយកុហក[ឋ]ពួក
សង្ឃ[ឌ] ក៏គ្រប់គ្រង ដោយកំឡាំងដៃខ្លួនវិញ ឯរាស្ត្រអញ
គេក៏ឃើញ គួរយ៉ាងនោះដែរ ដូច្នេះ ដល់ចុងបំផុត
តើឯងរាល់គ្នានឹងធ្វើដូម្តេចទៅ[ឍ]។

## ទីក្រុងយេរូសាឡិមស្ថិតនៅក្នុងការឡោមព័ទ្ធ

**៦** ១ឱពួកកូនចៅបេនយ៉ាមីនអើយ ចូររត់ទៅចុះ ចូរចេញ
ពីក្រុងយេរូសាឡិមទៅ ហើយផ្លុំត្រែ[ក]នៅត្រង់ត្កូអា[ខ] ត្រូវឱ្យ

**៥:២១** ផ ខ.៤ ចទ ៣២:៦ យរ ៤:២២ ហព ២:១៨ ព អស ៦:១០ អគ ១២:២ ភ ចទ ២៩:៤ អស ៤២:៤ អស ៤២:២០ មថ ១៣:១៥ មក ៨:១៨ **៥:២២** ម ចទ ២៨:៥៨ យ យប ៤:១៤ អស ៦៤:២ រ លប ១:៩ ល ទដ ៤៦:៣ **៥:២៣** វ ចទ ២១:១៨ ស ទដ ១៤:៣ **៥:២៤** ហ ចទ ៦:២៤ ឡ លវ ២៦:៤ ២សយ ១:២១ យក ៥:៧ អ លប ៨:២២ កច ១៤:១៧ **៥:២៥** ក ទដ ៨៤:១១ **៥:២៦** ខ មថ ៧:១៥ គ ទដ ១០:៨ ឃ សស ៩:១២
យរ ៩:៨ ហស ៥:១ មីក ៧:២ **៥:២៧** ង យរ ៨:៥ ៩:៦ ច យរ ១២:១ **៥:២៨** ឆ ចទ ៣២:១៥ ជ សក ៧:១០ ឈ នក ២២:២១–២៤ ទដ ៨២:៣ អស ១:២៣ យរ ៧:៦ អគ ១៦:៤៩ អម ៥:១២ **៥:២៩** ញ អស ៥៧:៦ **៥:៣០** ដ ខ.៣០–៣១ យរ ១៨:១៣ ២៣:១៤ ហស ៦:១០ **៥:៣១** ឋ ខ.១ មីក ២:១១ ឌ បទ ៤:១៣ ឍ ហស ៩:៥ **៦:១** ក ជន ១០:៧ យរ ៤:២១ ខ ២របា ១១:៦ អម ១:១

៦:១០ មើល ចទ ២៩:៤ ទដ ១១៥:៤–៨ ១៣៥:១៥–១៨ ។

**៥:២២** *តើឯងរាល់គ្នាមិនកោតខ្លាចដល់អញទេឬ* មើលការពន្យល់ លប ២០:១១ ។ *ធ្វើជាព្រំខណ្ឌសមុទ្រ* មើល យប ៣៨:៨–១១ ទដ ១០៤:៦–៩ ។

**៥:២៣** ទោះបីជាសមុទ្រដែលនៅជិតតំបន់ដែលជាព្រំដែន ដែលខណ្ឌរវាងគ្នាក្តី ក៏រាស្ត្ររបស់ព្រះ គេបានរំលោភបំពានឆ្លងព្រំដែន ដែលទ្រង់ញែកសម្រាប់គេដែរ ។

**៥:២៤** *ជាព្រះនៃយើងវិញ ដែលទ្រង់ប្រទាន* មើលខ៧ និងការពន្យល់ *ភ្លៀងមក គឺទាំងភ្លៀងដើម ហើយចុងរដូវផង* មើល ៣:៣ មើលការពន្យល់ផងដែរ ចទ ១១:១៤ ។ *ហើយក៏កំណត់រក្សាទុកប៉ុន្មានអាទិត្យ ដែលសំរាប់ច្រូតកាត់ដល់យើងដែរ* ប្រហែលជា៧សប្តាហ៍ នៅចន្លោះរវាងថ្ងៃបុណ្យរំលង និងពិធីបុណ្យប្រចាំសប្តាហ៍ (លវ ២៣:១៥–១៦) ។

**៥:២៦** *ឯគេគឺដាក់អន្ទាក់* "អ្នកបំផ្លាញ" (មើលឧទាហរណ៍ នក ១២:២៣) ឬ "ការបំផ្លិចបំផ្លាញ (មើលឧទាហរណ៍ អគ ២១:៣១) ។ *មនុស្ស* ជាមនុស្សគ្មានទោស(មើល អស ២៩:២១) ជាអ្នកគោរពប្រតិបត្តិដល់ព្រះ ជាមនុស្សសុចរិត (មើល មីក ៧:២) ។

**៥:២៧** *ទ្រុង* ជាអង្គប់របស់មនុស្សអាក្រក់ ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺត្រូវបានបកប្រែថា "ល្អី" នៅក្នុង អម ៨:១–២ ។ សេចក្តីឆបោកអ្នកមាន គេបានចំណេញតាមរយៈ ការឆបោក និងការបោកប្រាស (មើល ហាប ២:៦) ។

**៥:២៨** *គេបានឡើងសាច់ធាត់ ហើយប៉ផូរ* និម្មិតសញ្ញាពីការរីកចំរើន (មើល ចទ ៣២:១៥ យក ៥:៥ និងការពន្យល់) ។ *គេប្រព្រឹត្តអំពើអាក្រក់ហួសល្បត់* មើល ទដ ៧៣:៧ ។ *ឥតដែលកាន់ក្តីជំនួសពួកកំព្រា* អ្វីដែលមនុស្សអាក្រក់មិនបានធ្វើ នោះព្រះធ្វើជំនួសវិញ (ចទ ១០:១៨) ដើម្បីឱ្យអស់អ្នកដែលស្គាល់ពីការនោះ គេបានមម្រើដល់ព្រះ (មើល ២២:១៦ យក ១:២៧) ។

**៥:២៩** រំលឹក ខ.៩ ឡើងវិញ មើលផងដែរ ៩:៩ ។

**៥:៣១** មើល ១:១៨ និងការពន្យល់ ។ គឺពួកហោរាបានទាយកុហក មើល ២០:៦ (ជាទូទៅ គេមានឫកពាអួតអាង ដោយយកឈ្មោះព្រះមកប្រើក្នុងផ្លូវខុស មើល ២៣:២៥ ២៧:១៥ ២៩:៩) ។ *រាស្ត្រអញ គេក៏ឃើញគួរយ៉ាងនោះដែរ* មើលការពន្យល់ អម ៤:៥) ។

**៦:១–៣០** ហោរាបានមើលឃើញនៅថ្ងៃអនាគត ដែលពួកបាប៊ីឡូនវាយប្រហារលើក្រុងយេរូសាឡិម ។

**៦:១** ព្រះអម្ចាស់មានបន្ទូលនៅក្នុង ខ.១–៣ ។ ខ.១ បាននិយាយជាខ្លាំងនៅក្នុង ៤:៦ (មើលការពន្យល់) ។ ប៉ុន្តែនៅក្នុង ៤:៦ និយាយពីការ ស្វែងរកការការពារដល់ក្រុងយេរូសាឡិម នៅក្នុង៦:១ ពួកបណ្តាជនគេបានគេចខ្លួនពីក្រុងយេរូសាឡិម ដោយសាគ្មានទីកន្លែង សូម្បីតែទីក្រុងបរិសុទ្ធ ក៏ទទួលរងការរុកទន្ទ្រានចូលមក ។ ពួកកូនចៅបេនយ៉ាមីន ជាពូជអំបូរដែលនៅជាប់នឹងព្រំប្រទល់ស្រុកយូដា ភាគខាងជើងក្រុងយេរូសាឡិម ។ រីឯលោក

ដុតភ្លើង ទុកជាទីសំគាល់ នៅត្រង់បេត–ហាកេរែមដែរ[គ]
ពីព្រោះមានសេចក្ដីអាក្រក់ បានចេញពីទិសខាងជើងមក[ឃ]
ព្រមទាំងការបំផ្លាញយ៉ាងធំផង ២ឯកូនស្រីស៊ីយ៉ូនដ៏ល្អ[ង]
ហើយរុងរឿង[ច] នោះអញនឹងបំផ្លាញបង់ ៣ពួកអ្នកគង្វាល[ឆ]
នឹងនាំហ្វូងចៀមរបស់គេទៅឯក្រុងនោះ គេនឹងដំឡើង
ត្រសាល នៅផ្ទល់មុខជុំវិញ[ជ]គេនឹងឃ្វាលហ្វូងចៀមរបស់
គេ តាមកន្លែងទីទៃពីគ្នា ៤ចូរចាត់ចែងច្បាំងនឹងទីក្រុង
នេះចុះ ចូររៀបចំឡើង យើងនឹងឡើងទៅក្នុងវេលាថ្ងៃ
ត្រង់[ឈ] វរហើយយើង ពីព្រោះថ្ងៃជ្រេហើយ ស្រមោល
ល្ងាចក៏កាន់តែវែងទៅ ៥ចូរក្រោកឡើង ហើយនឹងឡើង
ទៅទាំងយប់ យើងនឹងបំផ្លាញអស់ទាំងដំណាក់របស់គេ
៦ពីព្រោះព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានមាន
បន្ទូលដូច្នេះថា ចូរកាប់ដើមឈើ[ញ]ចុះ ហើយជីកស្នាមភ្លោះ[ដ]
ទាស់នឹងទីក្រុងយេរូសាឡិមទៅ នេះហើយជាទីក្រុងដែល
ត្រូវទោស ដ្បិតនៅកណ្ដាលនោះ មានសុទ្ធតែការសង្កត់
សង្កិន[ឋ] ៧អណ្ដូងផុសទឹកចេញមកជាយ៉ាងណា ទីក្រុងនេះ
ក៏ផុសចេញ ជាអំពើអាក្រក់យ៉ាងនោះដែរ មានឮសុទ្ធតែ
ការច្រឡោត[ឌ] និងការបំផ្លាញ[ឍ] ឃើញមានតែជំងឺឈឺ នឹង
របួសនៅមុខអញជានិច្ច ៨ឱក្រុងយេរូសាឡិមអើយ ចូរ
ឱ្យឯងរាងចាលចុះ ក្រែងព្រលឹងអញព្រាត់ចេញ[ណ]ពីឯង
ក្រែងលោអញបំផ្លាញឯង ឱ្យទៅជាស្រុកចោលស្ងាត់ទទេ។
៩ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះ
ថា គេនឹងប្រឡេះពួកសំណល់[ត]សាសន៍អ៊ីស្រាអែលអស់
រលីង ដូចជាផ្លែទំពាំងបាជូរ ចូរដាក់ដៃឯងទៅក្នុងកញ្ជ្រែ
វិញ ដូចជាអ្នកបេះផ្លែ ១០តើនឹងឱ្យខ្ញុំនិយាយ ហើយធ្វើ
បន្ទាល់ដល់អ្នកណា ដើម្បីឱ្យគេបានស្ដាប់តាម[ថ] មើល
ត្រចៀកគេមិនបានកាត់ស្បែកទេ[ទ] គេស្ដាប់មិនបាន[ធ] មើល
ព្រះបន្ទូល[ន]នៃព្រះយេហូវ៉ា បានត្រឡប់ជាទីមើលងាយដល់

**៦:១** គ នហ ៣:១៤ ឃ យរ ៤:៦ **៦:២** ង ទដ ៩:១៤ ច បទ ៤:៥ **៦:៣** ឆ យរ ១២:១០ ជ ២ពវ ២៥:៤ លក ១៩:៤៣ **៦:៤** ឈ យរ ១៥:៨ ២២:៧ **៦:៦** ញ ចទ ២០:១៩–២០ ដ ២សយ ២០:១៥ យរ ៣២:២៤ ៥២:៤ អគ ២៦:៨ ឋ ចទ ២៨:៣៣ យរ ២៥:៣៨ សផ ៣:១ **៦:៧** ឌ ទដ ៥៥:៩ អស ៥៨:៤ ឍ យរ ២០:៨

**៦:៨** ណ អគ ២៣:១៨ **៦:៩** ត លប ៤៥:៧ **៦:១០** ថ យរ ៧:១៣,២៤ ៣៥:១៥ ទ យរ ៤:៤ កច ៧:៥១ ធ អស ៤២:២០ ន យរ ១៥:១០,១៥ ២០:៨

យេរេមា គាត់មកពីពូជអំបូរទឹកដីបេនយ៉ាមីន (មើល ១:១) ។ *ហើយផ្លុំត្រែនៅត្រង់ត្កូអា* ។ នៅក្នុងភាសាហេព្រើ ពាក្យត្កូអា មានន័យថា ទីក្រុងកំណើតរបស់អេម៉ូស (មើលសេចក្ដីផ្ដើម អេម៉ូស និងអ្នកនិពន្ធ) ។ *ឱ្យដុតភ្លើង ទុកជាទីសំគាល់* នៅក្នុងព្រះគម្ពីរភាសាហេព្រើរ នេះជាការលេងពាក្យ ហើយមានន័យថា អាចធ្វើបាន ដោយការប្រើនូវពាក្យហេព្រើរខុសគ្នា (បានរកឃើញនៅក្នុងសំបុត្រស្ដេចក្រុងឡាគីស ៤:១០) ចំពោះ "សញ្ញា" បានបង្កឡើងដោយសារផ្សែងភ្លើង មើល ពច ២០:៣៨,៤០) ហើយមួយទៀតបានប្រើនៅក្នុង ៤:៦ ។ *នៅត្រង់បេត–ហាកេរែម* បានបញ្ជាក់នៅកន្លែង១ នៅក្នុង នហ ៣:១៤ (មើលការពន្យល់) ។ *សេចក្ដីអាក្រក់ បានចេញពីទិសខាងជើងមក* មើល ១:១៤ និងការពន្យល់) ។

**៦:២** *កូនស្រីស៊ីយ៉ូន* ជាគំរូយ៉ាងល្អរបស់ក្រុងយេរូសាឡិម (មើលការពន្យល់ ២ពវ ១៩:២១) ។ *ហើយរុងរឿង* បានប្រើដើម្បីពិពណ៌នាអំពីក្រុងបាប៊ីឡូននៅក្នុង អស ៤៧:១ ។

**៦:៣** មើល ១:១៥ *ពួកអ្នកគង្វាលនឹងនាំហ្វូងចៀមរបស់គេ* អ្នកគ្រប់គ្រង និងកូនចៅរបស់គេ (មើលការពន្យល់ ២:៨) ។ *ដំឡើង* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ កិរិយាសព្ទនេះ គឺជាការលេងពាក្យ "ត្កូអា" នៅក្នុងខ (មើលការពន្យល់ ខ.៨) ។ *តាមកន្លែងទីទៃពីគ្នា* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ គឺបានប្រើដូចគ្នានឹងឃ្លា ("តាមទីកន្លែងរៀងៗខ្លួន") នៅក្នុង ជន ២:១៧ ។ *ទៅឯ* កន្លែងស៊ីស្មៅ ឬចេញទៅហើយគ្មានការបំផ្លាញ ។

**៦:៤** អ្នកឈ្លានពាននិយាយនៅក្នុង ខ.៤–៥ ។ *ចូររៀបចំឡើង* "អធិស្ឋាន" (មើលនៅក្នុង យអ ៣:៩ មីក ៣:៥) ។ ចាប់តាំងពីពួកអ្នកជិនាន់បុរាណប្រឆាំងចំពោះសាសនា នៅពួកទាហាន និងកងទ័ពត្រូវរៀបចំខ្លួន ដើម្បីការពារបញ្ហានោះ (មើល ចទ ២០:២–៤ ១សយ ២១:៤ និងការពន្យល់) ។ *ក្នុងវេលាថ្ងៃ* ដើម្បីទាញយកបាននូវការភ្ញាក់ផ្អើល ទាហានគេធ្វើការវាយប្រហារនៅនៅពេលព្រឹកព្រលឹម (មើលឧទាហរណ៍ យស ៨:១០,១៤) ។

**៦:៥** *ទៅទាំងយប់* ជាធម្មតាទាហាន ក្រោយពីការវាយប្រហាមក នោះគេសម្រាកនៅពេលយប់ ហើយដល់ពេលព្រឹក នោះគេធ្វើការឡោមព័ទ្ធ ឃ្លានេះ បញ្ជាក់ពីការដែលគេប្រថ្នាចង់បាន និងការតាំងចិត្តធ្វើ (មើល ពច ៧:១៩ និងការពន្យល់) ។

**៦:៦** ព្រះអម្ចាស់បានមានបន្ទូលអំពីទាហានពួកបាប៊ីឡូន ហើយជីកស្នាមភ្លោះដើម្បីជួយពួកគេ អាចបុកទម្លាយទ្វារក្រុងយេរូសាឡិម (មើល ៣៣:៤) ។ *មានសុទ្ធតែការសង្កត់សង្កិន* ទាស់ប្រឆាំងនឹងរាស្ត្ររបស់ទ្រង់ (មើលការពន្យល់ អស ២០:១២) ។

៦:៧ *មានតែជំងឺឈឺ និងរបួស* ក្រុងយេរូសាឡិមទទួលរងការឈឺចាប់ ដោយសារជម្ងឺខាងសាច់ឈាម និងខាងវិញ្ញាណ (មើល ខ.១៤) និងជម្ងឺផ្សេងទៀតដែលគេមិនដឹងនោះ ។

**៦:៨** *ចូរឱ្យឯងរាងចាលចុះ* គេត្រូវមានប្រាជ្ញាឡើង (មើល ខ.១០ ទដ ២:១០) ។ *ព្រាតចេញពីឯង* ជាការសោកស្ដាយ ប៉ុន្តែវាជាអំពើស្អប់ខ្ពើម ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ ជាការលេងពាក្យ លើពាក្យ "ត្កូអា" នៅក្នុង ខ.១ (មើលការពន្យល់ ខ.៣) ។ *ឱ្យទៅជាស្រុកចោលស្ងាត់ទទេ* មើល ២២:៦ ។

**៦:៩** *គេនឹងប្រឡេះ* មើលការពន្យល់ នរ ២:២ អស ១៧:៥ ។ *ពួកសំណល់* មើល ១១:២៣ ២៣:៣ ៣១:៧ ៤០:១១,១៥ ៤២:២,១៥,១៩ ៤៣:៥ ៤៤:៧,១២,១៤,២៨ ៥០:២០ មើលការពន្យល់ អស ១០:២០–២២ ។ *អស់រលីង* បញ្ឈប់សព្វគ្រប់រាល់ការបំផ្លាញ (មើល ៤:២៧ ៥:១០,១៨ ៣០:១១ ៤៦:២៨) ។ *ទំពាំងបាយជូរ* និម្មិតសញ្ញាពីអ៊ីស្រាអែល (មើល ២:២១ និងការពន្យល់ ៥:១០) ។

**៦:១០** លោកយេរេមាបាននិយាយ *ការធ្វើបន្ទាល់* មើលការពន្យល់ខ៨ ។ *ត្រចៀកគេមិនបានកាត់ស្បែក* មើលការពន្យល់ មើលផងដែរ ៤:៤ និងពន្យល់ ។ ជាការរិះគន់ចំពោះច្រចៀកមិនបានកាត់ស្បែក ដែលរកឃើញមាននៅក្នុង កច ៧:៥២ (មើលការពន្យល់) ។

គេ គេមិនយកជាទីរីករាយចិត្តឡើយ ១១ដូច្នេះ ខ្លួនខ្ញុំមាន
ពេញដោយសេចក្តីក្រោធ[ប]របស់ព្រះយេហូវ៉ា ខ្ញុំទប់ចិត្ត
ទៀតមិនបានទេ[ផ] បើដូច្នេះ ចូរចាក់ទៅលើកូនក្មេង[ព]តាម
ផ្លូវ ហើយលើជំនុំពួកកំឡោះៗ ដ្បិតនឹងត្រូវចាប់យកទាំងប្តី
និងប្រពន្ធ ទាំងមនុស្សចាស់ជរា និងមនុស្សមានវ័យកន្លង
ផង[ភ] ១២ផ្ទះគេនឹងទៅជារបស់ផងមនុស្សដទៃ[ម] ព្រមទាំង
ស្រែចំការ និងប្រពន្ធរបស់គេដែរ[យ] ដ្បិតអញនឹងលូកដៃ[រ]
ទៅលើពួកអ្នកស្រុក នេះហើយជាព្រះបន្ទូលនៃព្រះយេហូវ៉ា
១៣ពីព្រោះចាប់តាំងតែពីអ្នកតូចបំផុត ទៅដល់អ្នកធំបំផុត
ក្នុងពួកគេ[ល] នោះសុទ្ធតែលង់ទៅក្នុងសេចក្តីលោភ[វ] ហើយ
ចាប់តាំងពីហោរា ទៅដល់សង្ឃ នោះគ្រប់គ្នាក៏ប្រព្រឹត្ត
ដោយភូតភរដែរ[ស] ១៤គេបានមើលរបួសរបស់រាស្ត្រអញ
ឱ្យសះតែបន្តិចបន្តួចទេ ដោយពោលតែពាក្យថា សុខៗ
ប៉ុណ្ណោះ ក្នុងកាលដែលឥតមានសេចក្តីសុខឡើយ[ហ] ១៥កាល
គេបានប្រព្រឹត្តការគួរស្អប់ខ្ពើម នោះតើគេមានសេចក្តី
ខ្មាសឬទេ ទេ គេមិនបានខ្មាសសោះ ក៏មិនទាំងឡើងមុខ
ក្រហមផង[ឡ] ដូច្នេះ គេនឹងដួលទៅជាមួយនឹងពួកអ្នកត្រូវ
ដួល ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅវេលាដែលអញ
ធ្វើទោស[អ]ដល់គេ នោះគេនឹងត្រូវចំពប់ដួលជាពិត ។
១៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូរឱ្យឯងរាល់
គ្នាឈរតាមផ្លូវ ហើយមើលចុះ ត្រូវឱ្យសួររកផ្លូវចាស់ទាំង
ប៉ុន្មាន[ក] មើលជាមានផ្លូវ[ខ]ណាដែលល្អ រួចឱ្យដើរតាមផ្លូវ
នោះចុះ នោះឯងរាល់គ្នានឹងបានសេចក្តីសំរាក[គ]ដល់
ព្រលឹង តែគេប្រកែកថា យើងរាល់គ្នាមិនព្រមដើរតាមទេ
១៧អញក៏បានដាក់ពួកចាំយាម[ឃ]ឱ្យត្រួតលើឯងរាល់គ្នា ឱ្យ
ប្រាប់ថា ចូរប្រុសស្តាប់សូរត្រែ[ង] តែគេប្រកែកថា យើងមិន
ព្រមស្តាប់ទេ[ច] ១៨ដូច្នេះ ចូរស្តាប់ចុះ អស់ទាំងសាសន៍អើយ
ហើយពួកជំនុំអើយ ចូរដឹងពីសេចក្តីដែលត្រូវកើតដល់គេ
១៩ម្នាល ផែនដីអើយ[ឆ] ចូរស្តាប់ចុះ មើល អញនឹងនាំសេចក្តី
អាក្រក់[ជ] មកលើជនជាតិនេះ គឺជាផលនៃគំនិតរបស់គេ[ឈ]
ដោយព្រោះគេមិនបានស្តាប់តាមពាក្យ[ញ]របស់អញទេ ឯ
ចំណែកក្រិត្យវិន័យរបស់អញ[ដ] នោះគេបានបោះបង់ចោល
ហើយ ២០តើមានប្រយោជន៍អ្វីដែលមានកំញានមកពីស្រុក
សេបា[ឋ] ហើយនឹងឫសកន្ទាយ[ឌ]ពីស្រុកឆ្ងាយ មកឯអញដូច្នេះ
អញ មិនទទួលដង្វាយដុតរបស់ឯងរាល់គ្នាទេ[ឍ] ហើយយញ្ញ
បូជា[ណ]របស់ឯង ក៏មិនគាប់ចិត្តដល់អញដែរ[ត] ២១ហេតុនោះ
បានជាព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា មើល អញ
នឹងដាក់ថ្មចំពប់មួយ នៅមុខជនជាតិនេះ ហើយទាំងឪពុក
និងកូនផង នឹងចំពប់ចុះ[ថ]លើថ្មនោះជាមួយគ្នា ហើយទាំង

**៦:១១** ប យរ ៧:២០ ១៥:១៧ ផ យប ៣២:២០ យរ ២០:៩ ព ២របា ៣៦:១៧ អស ៤០:៣០ ភ បទ ២:២១ **៦:១២** ម ចទ ២៨:៣០ មីក ២:៤ យ ១ពវ ១១:៤ យរ ៨:១០ ២៩:២៣ ៣៨:២២ ៤៣:៦ ៤៤:៩,១៥ រ អស ៥:២៥ យរ ២១:៥ ៣២:២១ អគ ៦:១៤ ៣៥:៣ សផ ១:៤ **៦:១៣** ល យរ ២:២៩ វ អស ៥៦:១១ ស បទ ៤:១៣ **៦:១៤** ហ អស ៣០:១០ យរ ៤:១០ **៦:១៥** ឡ យរ ៣:៣ ៨:១០–១២ មីក ៣:៧ សក ១៣:៤ អ ២របា ២៥:១៦ យរ ២៧:១៥ **៦:១៦** ក យរ ១៨:១៥ ខ ១ពវ ៨:៣៦ ទដ ១១៩:៣ គ យស ១:១៣ អស ១១:១០ មថ ១១:២៩ **៦:១៧** ឃ អស ៥២:៨ ង នក ២០:១៨ ច យរ ១១:៧–៨ អគ ៣៣:៤ សក ១:៤ **៦:១៩** ឆ ចទ ៤:២៦ យរ ២២:២៩ មីក ១:២ ជ យស ២៣:១៥ យរ ១១:១១ ១៩:៣ ឈ សភ ១:៣១ ញ យរ ២៩:១៩ ដ យរ ៨:៩ អគ ២០:១៣ អម ២:៤ **៦:២០** ឋ លប ១០:៧ ឌ នក ៣០:២៣ ឍ អម ៥:២២ មឡ ១:៩ ណ ទដ ៥០:៨–១០ យរ ៧:២១ មីក ៦:៧–៨ ត អស ១:១១ យរ ១៤:១២ ហស ៨:១៣ ៩:៤ **៦:២១** ថ លប ២៦:៣៧ អស ៨:១៤

**៦:១១** *ហោរាបាននិយាយ* បន្ទាប់មកព្រះអម្ចាស់បន្តវិញកពាក្យនោះ (តាម រយៈ ខ.២៣) ។ *ពេញដោយសេចក្តីក្រោធ* មើល ២៥:៥ និងការពន្យល់ ។ *ចូរចាក់ទៅលើកូនក្មេងតាមផ្លូវ ហើយលើជំនុំពួកកំឡោះៗ ដ្បិតនឹងត្រូវចាប់យកទាំងប្តី និងប្រពន្ធ ទាំងមនុស្សចាស់ជរា និងមនុស្សមានវ័យក្មេងកន្លងផង* មនុស្សទាំងអស់នឹងត្រូវជាប់ការជំនុំជម្រះ តាំងពីមនុស្សក្មេង រហូតដល់មនុស្សចាស់ (មើលខ១៣) ។ *តាមផ្លូវ* ជាទីកន្លែងដែលកុមារលេង (មើល ៩:២១ អគ ៨:៥) ។

**៦:១២–១៥** ការនិយាយឡើងវិញចំៗ ដោយមិនលំអៀង ៨:១០–១២ ។

**៦:១២** *ផ្ទះគេនឹងទៅជារបស់ផងមនុស្សដទៃ ព្រមទាំងស្រែចំការ និងប្រពន្ធរបស់គេដែរ* ធៀបនឹង នក ២០:១៧ ចទ ៥:២១ ។ *នឹងទៅជារបស់ផងមនុស្សដទៃ* មើល ចទ ២៨:៣០ ការព្រមាន–មួយនៅក្នុងចំណោមនៃការតាំងសញ្ញារបស់ផងព្រះ ។ *ដ្បិតអញនឹងលូកដៃទៅលើពួកអ្នកស្រុក* ដើម្បីបំផ្លាញគេ (មើល ១៥:៦) ។

**៦:១៣** មើល ១:១៨ និងការពន្យល់ ។

**៦:១៤** *គេបានមើលរបួស* មើលការពន្យល់ ខ.៧ ។ *សុខៗប៉ុណ្ណោះ ក្នុងកាលដែលឥតមានសេចក្តីសុខឡើយ* ជាសារធម្មតារបស់ហោរាខុសឆ្គង និងលោភលន់ (មើល អគ ១៣:១០ មីក ៣:៥) ។ ទោះបីជាក្នុងករណីណាក៏ដោយ មនុស្សអាក្រក់មិនមានសេចក្តីសុខឡើយ(អស ៤៨:២២ ៥៧:២១) ។

**៦:១៦** *សួររកផ្លូវចាស់ទាំងប៉ុន្មាន* ការព្យាយាមគោរពប្រតិបត្តិ តាមផ្លូវដ៏ត្រឹមត្រូវរបស់ពួកព្ធយុកោយូដា (មើល ១៨:១៥ ចទ ៣២:៧) ។ *រួចឱ្យដើរតាមផ្លូវនោះ* មើល អស ៣០:២១ ។ *នោះឯងរាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង* ព្រះយេស៊ូវទ្រង់បានដកស្រង់ នៅក្នុង មថ ១១:២៩ (មើល អស ២៨:១២ ធៀបនឹង ទដ ១១៩:១៦៥) ។

**៦:១៧** *ពួកចាំយាម* ហោរាពិត (មើល អគ ៣:១៧ និងការពន្យល់ ហាប ២:១) ។ *ចូរប្រុងស្តាប់សូរត្រែ* ដើម្បីព្រមានអំពីគ្រោះថ្នាក់ដែលនឹងមកដល់ (មើល ខ.១ និងមើលការពន្យល់ផងដែរ យអ ២:១) ។

**៦:១៨** *ដូច្នេះ ចូរស្តាប់ចុះអស់ទាំងសាសន៍អើយ* មើល មីក ១:២ ។

**៦:១៩** *ដោយព្រោះគេមិនបានស្តាប់តាមពាក្យរបស់អញ* ការមិនធ្វើតាមក្រិត្យវិន័យរបស់លោកម៉ូសេ (មើល ៨:៨–៩) ។

**៦:២០** *ស្រុកសេបា* ស្ថិតនៅទិសខាងត្បូងអារ៉ាប៊ី វាគឺជាមជ្ឈមណ្ឌលពានិជ្ជកម្ម (មើល អស ៦០:៦ និងការពន្យល់) ។ *ឫសកន្ទាយ* មើល បស ៤:១៤ អស ៤៣:២៤ និងការពន្យល់ ។ ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺគេបានបកប្រែថា "ដំបង" នៅក្នុង នក ៣០:២៣ ឫសកន្ទាយប្រហែលមកពីប្រទេសឥណ្ឌា ជាវត្ថុសក្តិសិទ្ធ ដែលគេធ្វើឡើងដើម្បីចាក់ប្រេងតាំង (នក ៣០:២៥) ។ *អញមិនទទួលដង្វាយដុតរបស់ឯងរាល់គ្នាទេ* ឥរិយាបទចិត្តរបស់មនុស្ស និងរបៀបការរបស់នៅរបស់មនុស្ស នោះវា

អ្នកជិតខាង នឹងមិត្រសំឡាញ់របស់គេផង គេនឹងត្រូវវិនាស
បង់ទាំងអស់ ។
២២ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មើល មាន
ជនជាតិមកពីស្រុកខាងជើង[ទ] គឺសាសន៍១យ៉ាងធំ ដែល
នៅចុងផែនដី នឹងត្រូវកំរើកឡើង[ធ] ២៣គេចាប់កាន់ធ្នូ និង
លំពែង ជាសាសន៍សាហាវ ឥតត្រាប្រណី[ន] សំឡេងគេក៏
លាន់ឮសន្ធឹកដូចជាសមុទ្រ[ប] គេសុទ្ធតែជិះសេះដំរៀបជា
ក្បួនទ័ព[ផ] ដូចជាមនុស្សដែលចូលទៅច្បាំង ឱកូនស្រី
ស៊ីយ៉ូនអើយ គឺច្បាំងនឹងឯងហើយ[ព] ២៤យើងរាល់គ្នាបានឮ
សួរពីការនោះហើយ ដៃយើងក៏បានខ្សោយទៅ[ភ] ហើយ
យើងកើតមានសេចក្ដីបារម្ភព្រួយ[ម] ព្រមទាំងឈឺចាប់ ដូចជា
ស្រីដែលរៀបនឹងសំរាលកូន[យ] ២៥កុំឱ្យចេញទៅឯចំការ
ឡើយ ក៏កុំឱ្យដើរតាមផ្លូវដែរ ដ្បិតដាវរបស់ពួកខ្មាំងសត្រូវ
នឹងសេចក្ដីស្ញែងខ្លាចបាននៅពាសពេញជុំវិញហើយ[រ] ២៦ឱ
កូនស្រីនៃរាស្ត្រអញអើយ ចូរស្លៀកសំពត់ធ្មៃ[ល] ហើយ
ននៀលក្នុងផេះចុះ[វ] ត្រូវឱ្យកាន់ទុក្ខ[ស] ដូចជាកាន់ទុក្ខនឹងកូន
តែ១[ហ] ជាទំនួញយ៉ាងជូរចត់បំផុត ពីព្រោះមេបំផ្លាញ[ឡ]នឹង

**៦:២២** ទ យរ ៤:៦ ធ ចទ ២៨:៤៩ **៦:២៣** ន អស ១៣:១៨ ប ទដ ១៨:៤ ៩៣:៣ ផ យរ ៤:២៩ ព អស ១០:៣២ **៦:២៤** ភ អស ១៣:៧ ម យរ ៤:១៩ យ យរ ៤:៣១ ៥០:៤១–៤៣ **៦:២៥** រ យប ១៥:២១ ទដ ៣១:១៣ យរ ៤៩:២៩ **៦:២៦** ល យរ ៤:៨ វ យប ២:៨ យរ ២៥:៣៤ អគ ២៧:៣០ យហ ៣:៦ ស យរ ៩:១ ១៨:២២ ២០:១៦ ២៥:៣៦ ហ លប

ស្រាប់តែមកលើយើងរាល់គ្នាភ្លាម ។
២៧អញបានតាំងឯងឡើង ឱ្យបានដូចជាប៉មចាំយាម[អ]
ហើយជាបន្ទាយនៅកណ្ដាលរាស្ត្រអញ ដើម្បីឱ្យឯងបាន
ស្គាល់ ហើយល្បងលផ្លូវប្រព្រឹត្តរបស់គេ ២៨គេសុទ្ធតែ
ជាពួកបះបោរយ៉ាងខ្លាំង[ក] គេដើរទៅមកទាំងបង្កាច់មនុស្ស[ខ]
ក៏សុទ្ធតែជាលង្ហិននឹងដែកផង[គ] គេប្រព្រឹត្តសេចក្ដីដ៏លាមក
អាក្រក់គ្រប់ៗគ្នា ២៩ឯស្នប់ក៏សប់យ៉ាងខ្លាំង សំណបាន
សូន្យបាត់ទៅ ការដែលគេនៅតែសំរង[ឃ]ទៀត នោះជាឥត
អំពើសោះ ដ្បិតពួកអាក្រក់មិនទាន់បានដកចេញនៅឡើយ
៣០មនុស្សទាំងឡាយនឹងហៅគេថាអាមច៍ប្រាក់ ពីព្រោះ
ព្រះយេហូវ៉ាទ្រង់បានបោះបង់ចោលគេហើយ[ង] ។

## សាសនាក្លែងក្លាយគ្មានតម្លៃ

**៧** ១ពាក្យនេះជាព្រះបន្ទូល ដែលមកពីព្រះយេហូវ៉ា ដល់

២១:១៦ ឡ នក ១២:២៣ យរ ៤:៧ **៦:២៧** អ យរ ៩:៧ សក ១៣:៩ **៦:២៨** ក យរ ៥:២៣ ខ លវ ១៩:១៦ គ អគ ២២:១៨ **៦:២៩** ឃ មឡ ៣:៣ **៦:៣០** ង សភ ១៧:៣ អគ ២២:១៨ ច ទដ ៥៣:៥ ១១៩:១១៩ យរ ៧:២៩ បទ ៥:២២ ហស ៩:១៧

សំខាន់ជាងយញ្ញបូជាទៅទៀត (មើលការពន្យល់ អស ១:១១–១៥) ។

**៦:២១** *ជំពប់ដួល* ការវាយទន្ទ្រានចូលរបស់ពួកបាប៊ីឡូន (មើល ខ.២២) ។

**៦:២២–២៤** ការនិយាយឡើងវិញចំៗឥតលំអៀងក្នុង ៥០:៤១–៤៣ ។

**៦:២៣** *លំពែង* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "លំពែង" នៅក្នុង ១សយ ១៧:៦ ។ ពាក្យមួយផ្សេងទៀតគឺ "ដាវ" បញ្ជាក់ *សង្គ្រាមរវាងកូននៃពន្លឺ និងកូននៃសេចក្ដីងងឹត* សមុទ្រសេចក្ដីស្លាប់ ។ *លាន់ឮសន្ធឹកដូចជាសមុទ្រ* មើល អស ៥:៣០ មើលផងដែរ អស ១៧:១២ និងការពន្យល់ ។ *ជិះសេះ* មើលការពន្យល់ ៤:១៣ និងមើលការពន្យល់ ៨:១៦ ។ *កូនស្រីស៊ីយ៉ូន* មើល ខ.២ និងការពន្យល់ ។

**៦:២៤–២៦** ហោរានិយាយក្នុងនាមឱ្យរាស្ត្រយូដា ។

**៦:២៤** *ដៃយើងក៏បានខ្សោយទៅ* លើកទឹកចិត្តចំពោះការបរាជ័យ (មើល ៤៧:៣ អស ១៣:៧ និងការពន្យល់) ។ *កើតមានសេចក្ដីព្រួយបារម្ភព្រួយ* មើលការពន្យល់ ៤:១៩ ។ *ស្ត្រីដែលរៀបនឹងសម្រាលកូន* មើលការពន្យល់ ៤:៣១ ។

**៦:២៥** *ដ្បិតដាវរបស់ពួកខ្មាំងសត្រូវ និងសេចក្ដីស្ញែងខ្លាច បាននៅពាសពេញជុំវិញហើយ* ការបញ្ជាក់ពីការពេញចិត្តរបស់លោកយេរេមា (២០:១០ ៤៦:៥ ៤៩:២៩ ធៀបនឹង បទ ២:២២) ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ គឺត្រូវបានប្រើជានាមសារធារណៈ " ម៉ាកោរ–មីស្សាបីប" (២០:៣ មើល ការពន្យល់) ។

**៦:២៦** *ចូរស្លៀកសំពត់ធ្មៃ* មើល ៤:៨ មើលការពន្យល់ផងដែរ លប ៣៧:៣៤ ។ *ហើយននៀលក្នុងផេះចុះ ត្រូវកាន់ទុក្ខ* មើល អគ ២៧:៣០–៣១ ធៀបនឹង មីក ១:១០ ។ *កូនតែ១* ឪពុកជាមនុស្សមានតម្លៃបំផុត (មើល លប ២២:១២,១៦ អស ៨:១០ សក ១២:១០ រម ៨:៣២) ។ មេបំផ្លាញ គឺពួកបាប៊ីឡូន (មើលការពន្យល់ ៤:៧) ។

**៦:២៧–៣០** ព្រះអម្ចាស់ទ្រង់បានមានបន្ទូលទៅកាន់លោកយេរេមា ហើយតែងតាំងគាត់ឱ្យធ្វើការសាកល្បងដល់បណ្ដាជនពួកយូដា ដែលគេប្រៀបដូចស្ករ (មើល ៩:៧ ទដ ១២:៦ និងការពន្យល់ អស ១:២៥ មឡ ៣:២–៣) ។

**៦:២៧** *ឱ្យបានដូចជាប៉មចាំយាម* មើល យប ២៣:១០ ។

**៦:២៨** *គេដើរទៅមកទាំងបង្កាច់មនុស្ស* ដែលផ្ទុយគ្នានៅក្នុង លវ ១៩:១៦ ។ *ក៏សុទ្ធតែជាលង្ហិននិងដែកផង* ជាលោហៈធាតុ ដែលអាចប្រៀបធៀបជាមួយនឹងមាស និងប្រាក់បាន ។ *គេប្រព្រឹត្តសេចក្ដីដ៏លាមកអាក្រក់* មើល ចទ ៣១:២៩ អស ១:៤ ។

**៦:២៩** នៅសម័យបុរាណ សំណគេស្លលាយរ៉ែជាមួយប្រាក់ នៅពេលដែលឡនោះឡើងក្ដៅខ្លាំង នោះសំណនោះរលាយ ហើយវារលាយចូលគ្នា ដ្បិតរ៉ែនោះត្រូវមានកំដៅគ្រប់គ្រាន់ បើមិនដូច្នេះទេ នោះវាមិនសុទ្ធនោះឡើយ (ធៀបនឹង អគ ២៤:១១–១៣) ។

**៦:៣០** *មនុស្សទាំងឡាយហៅគេថាអាចម៍ប្រាក់* "គេជាមនុស្សដែលបះបោរ" (ខ.២៨) "មនុស្សអាក្រក់" (ខ.២៩) គេបានបរាជ័យចំពោះការល្បងលរបស់ព្រះអម្ចាស់ នោះនាំឱ្យគេក្លាយទៅជាមនុស្សឥតប្រយោជន៍ ។

**៧:១–១០:២៥** ជាផ្នែកមួយនៃព្រះបន្ទូល ដែលលោកយេរេមាបានថ្លែងប្រហែលជានៅក្នុងកំឡុងពេលមួយ ជាច្រើនឆ្នាំ ។ នៅក្នុង ២៦:២–៦, ១២–១៥ គឺដូចគ្នាទៅនឹងជំពូក៧ ហើយដូចគ្នានិងជំពូក ៧–១០ កាលបរិច្ឆេទនៃការគ្រប់គ្រងរបស់ស្ដេចយេហូយ៉ាគីម (មើល ២៦:១) ។ ម្យ៉ាងវិញទៀត លោកយេរេមាបាន រំលឹកឡើងវិញ អំពីសាច់រឿងផ្សេងៗគ្នា នៅថ្ងៃសម្រាក់ចំពោះការងាររបស់គាត់ ។ ចំពោះព្រឹត្តិការណ៍ណាមួយ ដូចជានៅក្នុងជំពូក៧–១០ វាមិនមែនជាពេលវេលាសមរម្យ សម្រាប់ស្ដេចយ៉ូសៀសទេ ។

**៧:១–៨:៣** នៅផ្នែកនេះ និយាយអំពីព្រះវិហារស្ដេចសាឡូមូន ក្រុងយេរូសាឡិម មិនអាចគេចផុតពីការបំផ្លាញឡើយ កាលពីសតវត្សជិនាន់ដើម

យេរេមា ថា ២ចូរឈរ[ក]ត្រង់ទ្វារនៃព្រះវិហារព្រះយេហូវ៉ា
ហើយប្រកាសប្រាប់នៅទីនោះតាមពាក្យនេះថា ឱអស់អ្នក
ក្នុងពួកយូដា ដែលចូលទៅថ្វាយបង្គំព្រះយេហូវ៉ា តាមទ្វារ
ទាំងនេះអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ ៣ព្រះ
យេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលដូច្នេះថា ចូរកែផ្លូវប្រព្រឹត្ត[ខ]និងចរិតរបស់
ឯងរាល់គ្នាឱ្យល្អវិញចុះ នោះអញនឹងឱ្យឯងរាល់គ្នាអា–
ស្រ័យនៅ[គ]ទីនេះតទៅ ៤កុំឱ្យទុកចិត្ត[ឃ]នឹងពាក្យកំភូតឡើយ[ង]
ដែលថានេះជាព្រះវិហារនៃព្រះយេហូវ៉ា គឺជាព្រះវិហារ
នៃព្រះយេហូវ៉ា ជាព្រះវិហារនៃព្រះយេហូវ៉ាពិត ៥ដ្បិត
បើឯងរាល់គ្នាកែ[ច]ផ្លូវប្រព្រឹត្ត និងចរិតរបស់ឯងឱ្យល្អហើយ
បើសំរេចក្តីដល់មនុស្ស និងអ្នកជិតខាងដោយយុត្តិធម៌[ឆ]
៦បើឯងមិនសង្កត់សង្កិន[ជ]មនុស្សប្រទេសដទៃ ពួកកំព្រា និង
ពួកស្រីមេម៉ាយ ហើយមិនកំចាយឈាម[ឈ]ដែលឥតមាន
ទោសនៅទីនេះ ក៏មិនគោរពតាមព្រះដទៃ[ញ] ឱ្យខ្លួនបាន
អន្តរាយឡើយ ៧នោះអញនឹងឱ្យឯងរាល់គ្នាអាស្រ័យនៅទី
នេះតទៅ គឺក្នុងស្រុក[ដ]ដែលអញបានឱ្យដល់ពួកឰយុកោ
ឯង[ឋ]ចាប់តាំងពីចាស់បុរាណ ដរាបដល់អស់កល្បជានិច្ច ។
៨មើល ឯងរាល់គ្នាទុកចិត្ត[ឌ]នឹងពាក្យកំភូត[ឍ] ដែលនឹង
មានប្រយោជន៍មិនបាន ៩តើឯងរាល់គ្នានឹងលួចប្លន់[ណ] កាប់
សំឡាប់[ត] ផិតគ្នា[ថ] ស្បថបំពាន[ទ] ដុតកំញានថ្វាយព្រះបាល
[ធ,ន]ហើយគោរពតាមព្រះ[ប]ដទៃ ដែលឯងមិនបានស្គាល់
ពីដើម ១០រួចមកឈរ[ផ]នៅមុខអញក្នុងវិហារនេះ[ព] ដែល
បានហៅតាមឈ្មោះអញ ហើយពោលថា យើងបាន
សង្គ្រោះហើយ គឺដើម្បីឱ្យឯងបានធ្វើអស់ទាំងការគួរស្អប់
ខ្ពើមយ៉ាងនេះឬ[ភ] ១១ព្រះវិហារនេះ[ម]ដែលហៅតាមឈ្មោះ
អញ តើបានត្រឡប់ជារោងចោរ[យ]នៅភ្នែកឯងរាល់គ្នាឬអី
ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា គឺខ្លួនអញបានឃើញ[រ]ការ
នេះហើយ ។

**៧:២** ក យរ ១៧:១៩ **៧:៣** ខ យរ ១៨:១១ ២៦:១៣ ៣៥:១៥ គ ឧ.៧ **៧:៤** ឃ យប ១៥:៣១ ង ឧ.៨ យរ ២៨:១៥ មីក ៣:១១ **៧:៥** ច ឧ.៣ យរ ១៨:១១ ២៦:១៣ ៣៥:១៥ ឆ នក ២២:២២ លវ ២៥:១៧ អស ១:១៧ **៧:៦** ជ យរ ៥:២៨ អគ ២២:៧ ឈ ២ពវ ២១:១៦ យរ ២:៣៤ ១៩:៤ ២២:៣ ញ នក ២០:៣ ចទ ៨:១៩ **៧:៧** ដ ចទ ៤:៤០ ឋ យស ១:៦ **៧:៨** ឌ យប ១៥:៣១ ឍ ឧ.៤

**៧:៩** ណ នក ២០:១៥ ត នក ២០:១៣ ថ នក ២០:១៤ ជន ២៥:១ ទ នក ២០:១៦ លវ ១៩:១២ សក ៨:១៧ មឡ ៣:៥ ធ អស ១:១៣ ន យរ ១១:១៣,១៧ ៣២:២៩ ប នក ២០:៣ ហស ២:១៣ **៧:១០** ផ អស ៤៨:១ ព ឧ.៣០ ២ពវ ២១:៤–៥ យរ ២៣:១១ ៣២:៣៤ អគ ២៣:៣៨–៣៩ ភ អគ ៣៣:២៥ **៧:១១** ម អស ៥៦:៧ យ មថ ២១:១៣ មក ១១:១៧ លក ១៩:៤៦ រ លប ៣១:៥០ ពច ១១:១០ យរ ២៩:២៣ ៤២:៥

នៅត្រង់ស៊ីឡូ បើសិនពួកសង្ឃយូដា នៅតែថ្វាយបង្គំរូបព្រះនោះ ។

**៧:១** *ព្រះបន្ទូលដែលមកពី* មើល ១:២ និងការពន្យល់ ១:៤,១១,១៣ ២:១ ។

**៧:២** *ទ្វារ* ជាទីកន្លែងនៅចន្លោះរវាង ទីលានខាងក្នុង និងទីលានខាងក្រៅនៃព្រះវិហារ ប្រហែលគេឱ្យឈ្មោះថា ទ្វារថ្មី (២៦:១០ ៣៦:១០) ។ ចូរស្តាប់ មើលការពន្យល់ ២:៤ ។ *ឱអស់អ្នកក្នុងពួកយូដា ដែលចូលទៅថ្វាយបង្គំព្រះព្រះយេហូវ៉ា* ប្រហែលជាពេលនៅក្នុងកំឡុងពេលមួយ នៃការធ្វើធម្មយាត្រាមានរយៈពេល៣ដងក្នុង១ឆ្នាំ (មើល ចទ ១៦:១៦ និងការពន្យល់) ។ *ទ្វារ* កន្លែងចូលទៅទីលានខាងក្រៅ ។

៧:៣ នៅទីនេះតទៅ ពាក្យនេះត្រូវបានគេប្រើ៣០ដង នៅក្នុងព្រះគម្ពីរយេរេមា ដើម្បីដាក់ឈ្មោះចំពោះទឹកដី ដែលព្រះបានប្រទានដល់គេ (មើលឧទាហរណ៍ ខ.៧ ១៤:១៣,១៥ ២៤:៥–៦) ។

**៧:៤** *ពាក្យកំភូត* បាននិយាយដោយហោរាខុសឆ្គង ។ ព្រះអម្ចាស់មិនបានបំផ្លាញក្រុងយេរូសាឡិមឡើយ ពីព្រោះព្រះគង់នៅក្នុងវិហាររបស់ទ្រង់ ទ្រង់ជួយបំភ្លឺមនុស្សឱ្យយល់ ពីការអស្ចារ្យ ដែលទ្រង់ការពារដល់ទីក្រុង នៅក្នុងកំឡុងពេល នៃការគ្រងរាជ្យរបស់ស្តេចសេដេគាល (មើល ២ពវ ១៩:៣២–៣៦ ធៀបនឹង ២សយ ៧:១១–១៣ ទដ ១៣២ ១៣–១៤) ។ នៅពេលថ្ងៃ ពួកយូដាបានធ្វើបាប បះបោរប្រឆាំងនឹងព្រះអម្ចាស់ ដោយគំនិតរបស់គេគឺ "ឥតប្រយោជន៍" (ខ.៨ មើល មីក ៣:១១) ។ *នេះជា* "ពួកគេ" សំដៅទៅលើអាគា ដែលសង់ឡើងសម្រាប់ជាព្រះវិហារ ។ *ព្រះវិហារ . . . ព្រះវិហារ . . . ព្រះវិហារ* នេះជាពាក្យប្រើដដែលៗ (ធៀបនឹង មថ ៦:៧) ។ ជាទូទៅ នេះជាការប្រើពាក្យផ្ទួនគ្នា ឬការចង់សង្កត់ទៅលើពាក្យនេះ (មើល ២២:២៩ និងការពន្យល់ផងដែរ អស ៦:៣) ។

**៧:៦** *ពួកអ្នកគ្រប់គ្រង និងរាស្ត្រ* ត្រូវការពួ និងប្រព្រឹត្តតាមពាក្យទំនាយនេះ (មើល ២២:២–៣) ។ *មិនសង្កត់សង្កិនមនុស្សប្រទេសដទៃ ពួកកំព្រា និងពួកស្រីមេម៉ាយ* មើល ចទ ១៦:១១,១៤ ២៤:១៩–២១ ២៦:១២–១៣ ២៧:១៩ ធៀបនឹង យក ១:២៧ ។ *មិនកំចាយឈាមដែលឥតមានទោស* មើល ១៩:៤ ២២:១៧ ២៦:១៥ មើលពីឧទាហរណ៍អំពីការគំរាមកំហែងរបស់ស្តេចម៉ានាសេ (២ពវ ២១:១៦) ។

**៧:៧** *ចាប់តាំងពីចាស់បុរាណ ដរាបដល់អស់កល្បជានិច្ច* មើលការពន្យល់។

**៧:៨** *ពាក្យកំភូត* មើលការពន្យល់ ខ.៤ ។

**៧:៩** នេះជាខមួយ ដែលបញ្ជាក់ពីការដែលធ្វើខុសនឹងក្រិត្យវិន័យ១០ប្រការ (ធៀបនឹង ហស ៤:២ និងការពន្យល់) ។ *ដុតកំញានថ្វាយព្រះបាល* មើលការពន្យល់ ១:១៦ ។ *ហើយគោរពតាមព្រះដទៃ* ដែលឯងមិនបានស្គាល់ពីដើម មើល ១៩:៤ ។ *ភាពទុក្ខព្រួយ* ដូចជាអំពើបាប នាំឱ្យគេត្រូវចាប់យកទៅធ្វើជាឈ្លើយ ទៅទឹកដី១ ដែលគេមិនបានស្គាល់ (មើល ៩:១៤,១៦ ១៦:១១,១៣ ) ។

**៧:១០** *ក្នុងវិហារនេះ ដែលបានហៅតាមឈ្មោះអញ* មើល ខ.១១,១៤,៣០ ២៥:២៩ ៣២:៣៤ ៣៤:១៥ ចទ ១២:៥ និងការពន្យល់ ១ពវ ៨:១៦ និងការពន្យល់ ២របា ៦:៣៣ ២០:៩ ដយ ៩:១៨ "នាម" ជាឈ្មោះរបស់ព្រះ គឺទាក់ទងទៅនឹងព្រះវត្តមានដ៏ថ្លៃវិសេស ដូចជានៅក្នុងខនេះ (មើល ខ.១២,១៥ មើលការពន្យល់ ទដ ៥:១១) ។ *យើងបានសង្គ្រោះ* មើល ១២:១២ ។ *គួរស្អប់ខ្ពើម* មើល ២:៧ មើលផងដែរការពន្យល់ លវ ៧:២១) ។

**៧:១១** ពាក់កណ្តាលនៅក្នុង អស ៥៦:៧ ពាក់កណ្តាលនៅក្នុងខនេះ ព្រះយេស៊ូវបានដកស្រង់យកមកប្រើ ដូចជានៅក្នុង មថ ២១:១៣ មក ១១:១៧ លក ១៩:៤៦ ។ *បានត្រឡប់ជារោងចោរ* ពួកមេចោរបានពួនលាក់ខ្លួន នៅក្នុងរូងថ្ម ហើយគិតថា គេមានសុវត្ថិភាព ដូចជាពួកយូដា បានទុកចិត្ត ដោយ

១២ចូរឱ្យឯងរាល់គ្នាទៅឯទីកន្លែងរបស់អញ ដែល
នៅត្រង់ស៊ីឡូរ[ល]ចុះ ជាកន្លែង[វ]ដែលអញបានតាំងឈ្មោះ
អញ[ស] ឱ្យនៅជាមុខដំបូង ត្រូវឱ្យពិចារណាមើល ដែល
អញបានធ្វើ[ហ]ដល់កន្លែងនោះជាយ៉ាងណា ដោយព្រោះ
អំពើអាក្រក់របស់អ៊ីស្រាអែល ជារាស្ត្រអញ ១៣ហើយឥឡូវ
នេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ដោយព្រោះឯងរាល់
គ្នាបានប្រព្រឹត្តអំពើទាំងនេះ ហើយអញបាននិយាយ[ឡ]នឹង
ឯងរាល់គ្នាទាំងខ្នះខ្នែងរំឭកឯងតាំងពីព្រលឹមស្រាងផង[អ]
តែឯងរាល់គ្នាមិនបានស្តាប់តាមទេ[ក] អញក៏បានហៅ[ខ]ឯង
រាល់គ្នា តែឯងមិនបានឆ្លើយតបសោះ[គ] ១៤ហេតុនោះ
អញនឹងធ្វើដល់វិហារ[ឃ] ដែលហៅតាមឈ្មោះអញ[ង] គឺជា
ទីដែលឯងរាល់គ្នាទុកចិត្តនេះ ហើយដល់ទីកន្លែងដែល
អញបានឱ្យដល់ឯងរាល់គ្នា និងពួកឰយុកោឯងផង ដូចជា
បានធ្វើដល់ស៊ីឡូរ[ច]នោះដែរ ១៥ហើយអញនឹងបោះបង់ឯង
រាល់គ្នាពីភ្នែកអញចេញ[ឆ] ដូចជាបានបោះបង់ពួកបងប្អូន
ឯងដែរ គឺជាពូជអេប្រាអិមទាំងប៉ុន្មាន[ជ] ។
១៦ដូច្នេះ កុំឱ្យអធិស្ឋានឱ្យជនជាតិនេះឡើយ ក៏កុំឱ្យបន្លឺ
សំឡេងអំពាវនាវ[ឈ] ឬអធិស្ឋានឱ្យគេ ឬអង្វរដល់អញ
ជំនួសគេឱ្យសោះ ពីព្រោះអញមិនព្រមស្តាប់[ញ]ឯងទេ ១៧តើ
ឯងមិនឃើញអំពើដែលគេប្រព្រឹត្ត នៅអស់ទាំងក្រុងនៃ
ស្រុកយូដា ហើយនៅផ្លូវក្រុងយេរូសាឡិមទេឬអី ១៨គឺកូន
ក្មេងរើសឧស ឪពុកបង្កាត់ភ្លើងឡើង ហើយពួកស្រីៗ គេ
ច្របាច់ម្សៅធ្វើនំថ្វាយដល់ព្រះចន្ទ[ដ] ព្រមទាំងច្រួចដង្វាយ[ឋ]
ច្រួចថ្វាយដល់ព្រះឯទៀតផង ជាការដែលបណ្តាល[ឌ]ឱ្យអញ
ខឹងក្តៅ ១៩ព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរថា តើគេ
បណ្តាលឱ្យអញមានសេចក្តីកំហឹងមែនឬ[ឍ] តើមិនមែនដល់
ខ្លួនគេវិញ ដរាបដល់មានសេចក្តីខ្មាសជ្រប់មុខផងទេឬអី[ណ]
២០ហេតុនោះព្រះអម្ចាស់[ត]យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា
មើល សេចក្តីកំហឹង[ថ] និងសេចក្តីក្រោធរបស់អញ នឹងបាន
ចាក់[ទ]មកលើទីនេះ គឺលើមនុស្ស លើសត្វ ហើយលើដើម
ឈើនៅចំការ និងលើផលដែលកើតពីដីផង សេចក្តីកំហឹង
នោះនឹងឆេះឡើង ឥតរលត់ឡើយ[ធ] ។
២១ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍

**៧:១២** ល យប ១៨:១ ១សយ ២:៣២ វ នក ៤០:២ យស ១៨:១០ ស ដយ ៩:១៨ ហ ២សយ ៤:១០–១១,២២ ទដ ៧៨:៦០–៦៤ **៧:១៣** ឡ ទដ ៧១:១៧ អស ៤៨:១៧ អស ៣២:៣៣ អ ២របា ៣៦:១៥ ក ខ.២៦ អស ៦៥:១២ ខ សភ ១:២៤ គ យរ ៣៥:១៧ **៧:១៤** ឃ ខ.៤ អក ២៤:២១ ង ១ពវ ៩:៧ ច ពច ១៨:៣១ ១សយ ២:៣២ **៧:១៥** ឆ លប ៤:១៤ នក ៣៣:១៥ ២ពវ ១៧:២០ យរ ២៣:៣៩ ជ ទដ ៧៨:៦៧

**៧:១៦** ឈ នក ៣២:១០ ចទ ៩:១៤ យរ ១៥:១ ញ ជន ២៣:១៩ **៧:១៨** ដ យរ ៤៤:១៧,១៩ ឋ អស ៥៧:៦ ឌ ចទ ៣១:១៧ ១ពវ ១៤:៩ **៧:១៩** ឍ ចទ ៣២:២១ យរ ៤៤:៣ ណ យប ៧:២០ យរ ៩:១៩ ២០:១១ ២២:២២ **៧:២០** ត អស ៣០:១៥ ថ យប ៤០:១១ យរ ៤២:១៨ បទ ២:៣–៥ ទ យរ ៦:១១–១២ បទ ៤:១១ ធ អស ១:៣១ យរ ១១:១៦ ១៣:១៤ ១៥:៦,១៤ ១៧:៤,២៧ អក ២០:៤៧–៤៨

ខុសឆ្គងនៅក្នុងព្រះវិហារ ដើម្បីការពារខ្លួនគេ ពីអំពើបាបរបស់គេ ។

**៧:១២** មើលការពន្យល់ ៧:១–៨:៣ ។ *ដែលនៅត្រង់ស៊ីឡូរចុះ . . . ដែលអញបានធ្វើដល់កន្លែងនោះជាយ៉ាងណា* មើល ខ.១៤ ២៦:៦,៩ ទដ ៧៨:៦០–៦១ ។ រោងឧបោសថត្រូវបានធ្វើឡើងនៅត្រង់ស៊ីឡូរ ក្រោយពីការកាន់កាប់ទឹកដីកាណាន (យស ១៨:១) ហើយជាពេលចុងបញ្ចប់នៃការគ្រប់គ្រងរបស់ពួកចៅហ្វាយ (មើល ១សយ ១:៩ និងការពន្យល់) ។ ស៊ីលូន (Seilun) សម័យថ្មី នៅជិតផ្លូវសំខាន់ មានចម្ងាយប្រហែល២៨គីឡូម៉ែត្រខាងជើងក្រុងយេរូសាឡិម ជាឈ្មោះតាំងពីសម័យបុរាណ ។ ពួកអ្នកបុរាណវត្ថុវិទ្យាបានជីកដី ដោយចង្អុលបង្ហាញពីការបំផ្លាញទីនោះដោយពួកភីលីស្ទីនក្នុងឆ្នាំ១០៥០ មុន គ.ស ។ ហើយរោងឧបោសថនោះមិនត្រូវបានបំផ្លាញឡើយ នៅត្រង់គីបៀរ ក្នុងកំឡុងពេលការគ្រងរាជ្យរបស់ស្តេចដាវីឌ (មើល ១រប ២១:២៩) ។ មានអាគា១ ឬច្រើនជាងនោះបានសាងសងឡើងនៅស៊ីឡូរ នៅជិតរោងឧបោសថ ដែលនៅជាប់នឹងទីកន្លែងថ្វាយបង្គំផ្សេងៗគ្នា (ធៀបនឹងឃ្លា មាត់ទ្វារដំណាក់នៃព្រះអម្ចាស់" នៅក្នុង ១សយ ១:៩) ។ ដូចជាទីក្រុងមួយចំនួនត្រូវបានបំផ្លាញ ប្រហែលជាជួនកាលក្រោយពីព្រឹត្តិការណ៍នោះ មើល ១សយ ៤ ។

**៧:១៣** *ទាំងខ្នះខ្នែងរំឭកឯងតាំងពីព្រលឹមស្រាងផង* ពាក្យក្នុងព្រះគម្ពីរភាសាហេព្រើរគូសបញ្ជាក់នូវឃ្លានេះ បានរកឃើញនៅក្នុងព្រះគម្ពីរយេរេមា (ខ.២៥ ១១:៧ ២៥:៣–៤ ២៦:៥ ២៩:១៩ ៣២:៣៣ ៣៥:១៤–១៥ ៤៤:៤) ហើយមាននៅ កន្លែងផ្សេងទៀតនៅព្រះគម្ពីរសញ្ញាចាស់ ។

**៧:១៥** *ហើយអញនឹងបោះបង់ឯងរាល់គ្នាពីភ្នែកអញចេញ* គេត្រូវចាប់យកទៅធ្វើជាឈ្លើយ (មើល ចទ ២៩:២៨) ។ *ដូចជាអញបានបោះបង់បងប្អូនឯងដែរ* ព្រះបានបញ្ជូនអ៊ីស្រាអែល ដែលជានគខាងជើង ឱ្យត្រូវជាប់ជាចំណាប់ខ្មាំង នៅក្នុងឆ្នាំ ៧២១ គ.ស (មើល ២ពវ ១៧:២០) ។ *អេប្រាអិម* ជាឈ្មោះមួយផ្សេងទៀតរបស់អ៊ីស្រាអែល (មើលឧទាហរណ៍ ៣១:៩) ហើយគេជាពូជអំបូរដែលរងនូវការសើចចំអក ដែលមានទីតាំងនៅត្រង់ស៊ីឡូរ ។

**៧:១៦** ប្រហែលជាមានរឿងជាច្រើននៅក្នុងជំពូក២៦ ប្រវត្តិវិជ្ជានៅចន្លោះរវាង ខ.១៥ និង ខ.១៦ (មើលសេចក្តីផ្តើម និងគម្រោងមេរៀន) ។ *ក៏កុំឱ្យបន្លឺសំឡេងអំពាវនាវ ឬអធិស្ឋានឱ្យគេ* នេះជាពាក្យហោរារបស់ព្រះ (មើល ២៧:១៨ នក ៣២:៣១–៣២ ១សយ ១២:២៣) ។ មើល ១១:១៤ ១៤:១១ ជាក់ស្តែងពួកគេគ្មានសេចក្តីសង្ឃឹមឡើយ (ធៀបនឹង អក ១៤:១៤,២០) ។ ទោះបីជាយ៉ាងណាក្តី លោកយេរេមាបានអធិស្ឋានសម្រាប់ជនជាតិរបស់គាត់ (មើលឧទាហរណ៍ ១៨:២០) ។

**៧:១៨** *កូនក្មេង . . . ឪពុក . . . ពួកស្រីៗ* ពួកគេទាំងអស់គ្នានៅក្នុងគ្រួសារបានចូលរួមថ្វាយបង្គំដល់រូបព្រះ ។ *គេច្របាច់ម្សៅធ្វើនំ* មើល ៤៤:១៩ ។ *ព្រះចន្ទ* ដែលពួកបាប៊ីឡូនហៅថា អ៊ីសាតា ជារូបព្រះ១យ៉ាងសំខាន់នៅបាប៊ីឡូន ភេថេអូន (មើល ៤៤:១៧–១៩,២៥) ។ *ព្រមទាំងច្រួចថ្វាយច្រួចថ្វាយដល់ព្រះឯទៀតផង* ជួនកាលគេច្រួចថ្វាយដល់ព្រះចន្ទ (មើល ៤៤:១៩,២៥) ។ *ជាការបណ្តាលឱ្យអញខឹងក្តៅ* មើល ចទ ៣១:២៩ ។

**៧:១៩** *មានសេចក្តីខ្មាសជ្រប់មុខ* មើល ៣:២៥ ។

**៧:២០** គ្រប់របស់ទាំងអស់នឹងមានការឈឺចាប់ នៅពេលដែលព្រះទ្រង់ជំនុំជម្រះដល់មនុស្សមានបាប (មើល ៥:១៧ រម ៨:២០–២២) ។ សេចក្តីកំហឹងនោះនឹងឆេះឡើង ឥតរលត់ឡើយ ។ មើលផងដែរ អស ១:៣១ អម ៥:៦ ។

អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា ចូរថ្វាយដង្វាយដុត
ថែមលើយញ្ញបូជា[ន] របស់ឯងរាល់គ្នា ហើយស៊ី[ប]សាច់ចុះ
២២ពីព្រោះនៅគ្រាដែលអញបាននាំពួកឰយុកោឯងរាល់គ្នា
ចេញពីស្រុកអេស៊ីព្ទមក នោះអញមិនបាននិយាយនឹងគេ
ឬបង្គាប់[ផ]គេ ពីដំណើរដង្វាយដុត និងយញ្ញបូជាទេ[ព] ២៣គឺ
អញបានបង្គាប់សេចក្តីនេះដល់គេវិញថា[ភ] ចូរស្តាប់តាម[ម]
ពាក្យអញ នោះអញនឹងធ្វើជាព្រះដល់ឯងរាល់គ្នា ហើយ
ឯងរាល់គ្នានឹងបានជារាស្ត្ររបស់អញ[យ] ត្រូវឱ្យឯងរាល់គ្នា
ដើរតាមផ្លូវ[រ]ដែលអញបង្គាប់ឯងគ្រប់ចំពូក ដើម្បីឱ្យឯង
បានសេចក្តីសុខស្រួល[ល] ២៤ប៉ុន្តែគេមិនបានស្តាប់តាមសោះ[វ]
ក៏មិនបានផ្ទៀងត្រចៀកផង[ស] គឺគេបានដើរតាមតែគំនិត
របស់ខ្លួនគេ នឹងសេចក្តីរឹងចចេសក្នុងចិត្តអាក្រក់របស់គេ
វិញ[ហ] គេបានរាថយក្រោយ[ឡ] ឥតជឿនទៅខាងមុខទេ
២៥ចាប់តាំងពីថ្ងៃដែលពួកឰយុកោឯងរាល់គ្នា បានចេញ
ពីស្រុកអេស៊ីព្ទ មកដរាបដល់សព្វថ្ងៃនេះ អញបានបាត់
ពួកហោរា[អ]ជាអ្នកបំរើរបស់អញ[ក] ឱ្យមកឯឯង ដោយខ្នះ
ខ្នែងនឹងចាត់គេពីព្រលឹមស្រាងរាល់តែថ្ងៃផង[ខ] ២៦ប៉ុន្តែឯង
មិនបានស្តាប់តាមអញ ឬផ្ទៀងត្រចៀកមកសោះ[គ] គឺបាន
តាំងក្បាលរឹង[ឃ] ហើយបានប្រព្រឹត្តអាក្រក់ជាងពួកឰយុកោ
ទៅទៀត[ង]។
២៧ត្រូវឱ្យឯងប្រាប់[ច]ដល់គេតាមអស់ទាំងពាក្យនេះ តែ
គេនឹងមិនស្តាប់[ឆ]តាមឯងទេ ហើយឯងនឹងស្រែកហៅគេ
ដែរ តែគេមិនព្រមឆ្លើយតបឡើយ[ជ] ២៨ត្រូវឱ្យឯងប្រាប់គេ
ថា នេះហើយ ជាសាសន៍ដែលមិនបានស្តាប់តាមព្រះបន្ទូល
នៃព្រះយេហូវ៉ា ជាព្រះនៃខ្លួន ក៏មិនបានទទួលសេចក្តីប្រៀន
ប្រដៅឡើយ[ឈ] ឯសេចក្តីពិត[ញ] នោះបានសូន្យបាត់ គឺបាន
កាត់ចេញពីមាត់គេហើយ ។
២៩ចូរកាត់[ដ]សក់ឯងបោះចោលទៅ ហើយចាប់តាំង
ទួញទំនួញ[ឋ]នៅលើទីខ្ពស់ចុះ ពីព្រោះព្រះយេហូវ៉ាទ្រង់បាន
បដិសេធ ហើយបោះបង់ចោល[ឌ]ដំណមនុស្ស ដែលត្រូវ
សេចក្តីខ្ញាល់របស់ទ្រង់ចេញ ។

## ជ្រលងពិឃាត

៣០ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ពួកកូនចៅយូដា
បានប្រព្រឹត្តអំពើដ៏អាក្រក់[ឍ]នៅភ្នែកអញ គេបានទាំងដាក់
របស់គួរស្អប់ខ្ពើមរបស់គេ[ណ] នៅក្នុងវិហារដែលហៅតាម
ឈ្មោះអញផង ដើម្បីនឹងធ្វើឱ្យអាប់ឱន[ត]ទៅ ៣១គេក៏បាន

**៧:២១** ន យរ ៦:២០ អម ៥:២១-២២ ប ១សយ ២:១២-១៧ ហស ៨:១៣ **៧:២២** ផ អស ៤២:២៣ ព ១សយ ១៥:២២ **៧:២៣** ភ ១យហ ៣:២៣ ម នក ១៩:៥ យ លវ ២៦:១២ អស ៥១:១៦ រ ១ពវ ៨:៣៦ ទដ ១១៩:៣ ល ចទ ៥:៣៣ **៧:២៤** វ យរ ៦:១០ ស យរ ១១:៨ ១៧:២៣ ៣៤:១៤ ហ យរ ៣:១៧ ឡ យរ ២:១៩ អគ ៣៧:២៣ **៧:២៥** អ ជន ១១:២៩ យរ ២៥:៤ ៣៥:១៥ ក អស ២០:៣ ខ ២របា ៣៦:១៥ **៧:២៦** គ ខ.១៣,២៤ ២របា ៣៦:១៦ ទដ ៨១:១១ យរ ១៣:១១ ២២:២១ ២៥:៣ ៣៥:១៥ អគ ២០:៨,២១ ឃ នក ៣២:៩ កច ៧:៥១ ង យរ ១៦:១២ មឡ ៣:១៧ លក ១១:៤៧ **៧:២៧** ច អគ ២:៧ ឆ ខ.១៣ អគ ៣:៧ សក ៧:១៣ ជ អស ៦៥:១២ **៧:២៨** ឈ លវ ២៦:២៣ សផ ៣:៧ ញ ទដ ១៥:២ អស ៥៩:១៥ **៧:២៩** ដ លវ ២១:៥ យប ១:២០ ឋ យរ ៤:៨ អក ១៩:១ ឌ យរ ៦:៣០ ១២:៧ ហស ១១:៨ មីក ៥:៣ **៧:៣០** ឍ ខ.១០ លវ ១៨:២១ ណ យរ ២:៧ ៤:១ អគ ៧:២០-២២ ត លវ ២០:៣៣ យរ ៣២:៣៤

**៧:២១** ដោយសារការប្រព្រឹត្តអំពើបាប នោះការថ្វាយយញ្ញបូជារបស់គេនោះទៅជាឥតប្រយោជន៍ គេក៏បរិភោគយញ្ញបូជានោះដោយខ្លួនឯង ។

**៧:២២-២៣** ការថ្វាយយញ្ញបូជាមានប្រយោជន៍ នៅពេលណាដែលគេប្រែចិត្តដោយស្មោះត្រង់ពិតប្រាកដ និងការស្តាប់បង្គាប់ដល់ព្រះដោយក្តីអំណរ (មើល ៦:២០ អស ១:១១-១៥ និងការពន្យល់) ។

**៧:២៣** *ធ្វើជាព្រះដល់ឯងរាល់គ្នា . . . បានជារាស្ត្ររបស់អញ* ការសង្ខេបយ៉ាងសំខាន់បំផុតនោះ គឺការទំនាក់ទំនងរវាងព្រះ និងអ៊ីស្រាអែល ដែលបានបញ្ជាក់ពីការតាំងសញ្ញានៅឯភ្នំស៊ីណៃ (មើល និ ៦:៧ លវ ២៦:១២ អស សក ៨:៨ និងការពន្យល់ ចទ ២៦:១៧-១៨) ។

**៧:២៤** *គឺគេបានដើរតាមតែគំនិតរបស់ខ្លួនគេ* មើលការពន្យល់ ៣:១៧ មើលផងដែរ លប ៦:៥ និងការពន្យល់ ។

**៧:២៥** *ពីព្រលឹមស្រាងរាល់តែថ្ងៃផង* មើលការពន្យល់ ខ.១៣ ។ *អញបានចាត់ពួកហោរា ជាអ្នកបំរើរបស់អញ* មើល ២៥:៤ ២៦:៥ ២៩:១៩ ៣៥:១៥ ៤៤:៤ មើល សក ១:៦ និងការពន្យល់ ។ ព្រះបានសន្យាថា លោកម៉ូសេនឹងធ្វើជាហោរាមុនគេ ដែលជាអ្នកបាននិយាយពីព្រះនាមរបស់ ព្រះអម្ចាស់ និងបំរើទ្រង់ដោយស្មោះត្រង់ (មើល ចទ ១៨:១៥-២២ និងការពន្យល់) ។

**៧:២៦** *បានតាំងក្បាលរឹង* មើល ១៧:២៣ ១៩:១៥ នក ៣២:៩ និងការពន្យល់) ។

**៧:២៨** *មិនបាន . . . ក៏មិនបានទទួលសេចក្តីប្រៀនប្រដៅឡើយ* មើល ២:៣០ ៥:៣ ។ *ឯសេចក្តីពិត . . . គឺបានកាត់ចេញពីមាត់គេហើយ* គ្មានអ្នកណាម្នាក់ស្វែងរកសេចក្តីពិតឡើយ (មើល ៥:១ និងការពន្យល់) ។

**៧:២៩** បញ្ជាក់ពីក្រុងយេរូសាឡិម ។ *ចូរកាត់សក់ឯងចោលទៅ* សញ្ញាពីការកាន់ទុក្ខ(មើល យប ១:២០ មីក ១:១៦) ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ សម្រាប់ពាក្យ "សក់" គឺវាទាក់ទងទៅនឹងពាក្យ "ណ៉ាសារីត" (មើល ជន ៦:២) និងសំដៅទៅលើពាក្យក្បាំង ដែលសម្តេចសង្ឃបានពាក់ (មើល នក ២៩:៦) ។ សក់ របស់ពួកណ៉ាសារីត ជានិមិត្តរូបពីការបែកចេញ ឬវត្ថុសក្តិសិទ្ធិ (នក ៦:៧) ។ ដូចជាពួកណ៉ាសារីតបានកាត់សក់គេចេញ នៅពេលដែលគេរៀបពិធីយ៉ាងលាមកអាក្រក់នោះ (នក ៦:៩) ដូច្នេះ ក្រុងយេរូសាឡិម ត្រូវកាត់សក់ចេញដោយសារគេប្រព្រឹត្តអំពើបាប ។ *ហើយចាប់តាំងទួញទំនួញនៅលើទីខ្ពស់ចុះ* មើល ៣:២១ មើលការពន្យល់ ៣:២ ។

**៧:៣០** *គេបានទាំងដាក់របស់គួរស្អប់ខ្ពើមរបស់គេ នៅក្នុងវិហារ* ពួកម៉ាន៉ាសេបានឆ្លាក់ធ្វើរូបអ្នកតានៅក្នុងវិហារ (មើលការ ពន្យល់ ២ពវ ១៣:៦ ២១:៧) ។ នៅជំនាន់លោកយេរេមា ស្តេចយ៉ូសៀស ជាស្តេចដ៏ល្អបានរើចេញ និងបំផ្លាញចោលរូបអ្នកតា និងទីកន្លែងថ្វាយ បង្គំរូបព្រះចោល (មើល ៣៤:៤-៧) ។ ប៉ុន្តែបន្ទាប់ពី២០ឆ្នាំក្រោយមកទៀត ក្រោយពេលការសុគតរបស់ស្តេចយ៉ូសៀស នោះលោកអេសេគាល បានរាយការណ៍អំពីចំនួនរូបព្រះដែលមាននៅក្នុងព្រះវិហារនោះ (មើល អគ ៨:៣,៥-៦,១០,១២) ។ *ធ្វើឱ្យអាប់ឱនទៅ* មើលការពន្យល់ ២:៧ ) ។

ធ្វើជាទីខ្ពស់ទាំងប៉ុន្មាន នៅត្រង់តូផែត[ថ] ដែលនៅក្នុងច្រក
ភ្នំនៃពួកកូនចៅហ៊ីនណំម[ទ] ដើម្បីនឹងដុតកូនប្រុសកូនស្រី[ធ]
របស់គេក្នុងភ្លើង ជាការដែលអញមិនបានបង្គាប់ឡើយ ក៏
មិនដែលចូលក្នុងគំនិតអញដែរ[ន] ៣២ដូច្នេះ ព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា មើល នឹងមានគ្រាមកដល់ ដែលគេនឹងលែង
ហៅទីនោះថា តូផែត ឬថា ច្រកភ្នំនៃកូនចៅហ៊ីនណំមតទៅ
គឺនឹងហៅថាជាច្រកភ្នំនៃការសំឡេះវិញ[ប] ពីព្រោះគេនឹង
កប់[ផ]ខ្មោចនៅត្រង់តូផែតនោះ ទាល់តែគ្មានកន្លែងទំនេរ
ទៀត ៣៣ហើយខ្មោច[ព]ទាំងប៉ុន្មានរបស់ជនជាតិនេះ នឹងជា
ចំណី[ភ]ដល់សត្វហើរលើអាកាស និងដល់សត្វនៅដីផង ឥត
មានអ្នកណាបង្អើលវាចេញឡើយ[ម] ៣៤នៅគ្រានោះអញនឹង
ធ្វើឱ្យបាត់ឮសំឡេង[យ]អំណរ និងសំឡេងរីករាយ ជាសំឡេង
របស់ប្ដីប្រពន្ធថ្មោងថ្មី[រ] ពីអស់ទាំងក្រុងស្រុកយូដា ហើយពី
ផ្លូវក្រុងយេរូសាឡិម[ល]ទៅ ពីព្រោះស្រុកនេះនឹងត្រឡប់ជាទី
សូន្យបង់[វ] ។
**៨** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅគ្រានោះ គេនឹង
យកឆ្អឹងនៃស្ដេចសាសន៍យូដា ឆ្អឹងពួកចៅហ្វាយ ឆ្អឹងពួក
សង្ឃ ឆ្អឹងពួកហោរា និងឆ្អឹង[ក]របស់ពួកអ្នកនៅក្រុងយេរូ
សាឡិមចេញ[ខ]ពីផ្នូរមក ២គេនឹងរាយឆ្អឹងទាំងនោះ នៅ
ចំពោះព្រះអាទិត្យ ព្រះចន្ទ និងអស់ពួកបរិវារនៅលើមេឃ
ជារបស់ដែលគេបានស្រឡាញ់ គោរពប្រតិបត្តិ ប្រព្រឹត្ត
តាម[គ] ស្វែងរក ហើយថ្វាយបង្គំផង[ឃ] និងគ្មានអ្នកណា
ប្រមូល ឬកប់ឆ្អឹងទាំងនោះឡើយ[ង] គឺនឹងបានសំរាប់ជាដី
នៅដីវិញ[ច] ៣ហើយព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មាន
បន្ទូលថា អស់អ្នកណាដែលសល់អំពីគ្រួសារអាក្រក់នេះ[ឆ]
គឺដែលនៅគ្រប់ទីកន្លែងដែលអញបណ្ដេញគេ នោះនឹងស៊ូ
ស្លាប់ជាជាងរស់នៅ[ជ] ។

## អំពើបាប និងការជំនុំជម្រះ

៤មួយទៀត ត្រូវឱ្យឯងប្រាប់គេថា ព្រះយេហូវ៉ាទ្រង់

**៧:៣១** ថ ២ពវ ២៣:១០ ទ យស ១៥:៨ ២របា ៣៣:៦ ធ លវ ១៨:២១ អគ ១៦:២០ ន យរ ១៩:៥ ៣២:៣៥ អក ២០:៣១ មីក ៦:៧ **៧:៣២** ប យរ ១៩:៦ ផ យរ ១៩:១១ **៧:៣៣** ព លប ១៥:១១ ភ ចទ ២៨:២៦ អគ ២៩:៥ ម យរ ៦:១១ ១៤:១៦ **៧:៣៤** យ អស ២៤:៨ រ វវ ១៨:២៣ ល អស ២៤:៧–១២ យរ ៣៣:១០ វ លវ ២៦:៣៤ សក ៧:១៤ មថ ២៣:៣៨

**៨:១** ក ទដ ៥៣:៥ ខ អស ១៤:១៩ **៨:២** គ ២ពវ ២៣:៥ យរ ១៩:១៣ សផ ១:៥ កច ៧:៤២ ឃ យប ៣១:២៧ ង យរ ១៤:១៦ អគ ២៩:៥ ៣៧:១ ច ២ពវ ៩:៣៧ យរ ៣១:៤០ ៣៦:៣០ **៨:៣** ឆ ចទ ២៩:២៨ ជ យប ៣:២២ វវ ៩:៦

**៧:៣១** *ទីខ្ពស់ទាំងប៉ុន្មាន* ទីកន្លែងរូបព្រះ ដែលមានទីតាំងនៅទីកន្លែងធម្មជាតិ ឬទីកន្លែងភ្នំ (មើល ១សយ ៩:១៣–១៤ ១០:៥ ១ពវ ១១:៧) ។ *នៅត្រង់តូផែត* មើល ខ.៣២ ១៩:៦,១១–១៤ មើលការពន្យល់ផងដែរ អស ៣០:៣៣ ។ នេះជាពាក្យដើមរបស់អារ៉ាមីក មានន័យថា "គំនរភ្លើង" វានៅទីកន្លែងវប្បធម៌ខាងក្រៅរបស់អ៊ីស្រាអែល ហើយពាក្យនេះត្រូវបានប្រើជានាមសាធារណៈ ដែលមានន័យថា "ទីកន្លែងថ្វាយបូជាកូន" វាជាស្រះដែលវាសម្របទៅតាមប្រយោគ ដែលភាសាហេព្រើរ គឺបូសេថ (Boseth) មានន័យថា "របស់គួរឱ្យខ្មាស់" (មើលការពន្យល់ ពច ៦:៣២) ជារឿយៗគេប្រើដោយភ្ជាប់ទៅនឹងទីកន្លែងថ្វាយបង្គំរូបព្រះ (មើលការ ពន្យល់ ២:២៦ ៣:២៥) ។ នៅសញ្ញាចាស់ តូផែតមានគុកភ្លើង (មើល អស ៣០:៣៣) ដែលគេបានបោះកូនមិនបានការ ចូលទៅទីកន្លែងនោះ ។ *ដែលនៅក្នុងច្រកភ្នំនៃពួកកូនចៅហ៊ីនណំម* មើលខ៣២ ១៩:២,៦ ៣២:៣៥ មើលការពន្យល់ យស ១៥:៥ ។ គេបានប្រើវាដូចជាសំរាមដែលគេបោះចោល និងជាទីកន្លែងសំរាប់ការថ្វាយយញ្ញបូជាកូន ដល់រូបព្រះ ។ ពាក្យសង្ខេបឈ្មោះភាសាហេព្រើរ ជី ហ៊ីនណំម (ge´hinmom) ("ច្រកភ្នំហ៊ីនណំម" មើល នហ ១១:៣០ និងការពន្យល់) បានក្លាយមកពាក្យ គីហេនន៉ា (Gehenna) ពាក្យក្រេក គីនន៉ា (geenna) គេបានបកប្រែនៅក្នុងព្រះគម្ពីរសញ្ញាថ្មីថា "ស្ថាននរក" ទីកន្លែងដែលមានភ្លើងឆេះជារៀងរហូត (មើល មថ ៥:២២ និងការពន្យល់ ១៨:៩ មក ៩:៤៧–៤៨) ។ *ដើម្បីនឹងដុតកូនប្រុសកូនស្រីរបស់គេ នៅក្នុងភ្លើង* ជាការគួរឱ្យរន្ធត់ ដែលត្រូវបានហាមប្រាមនៅក្នុងក្រិត្យវិន័យ លោកម៉ូសេ (មើល លវ ១៨:២១ និងការពន្យល់ ចទ ១៨:១០) ប៉ុន្តែស្ដេចអាហាសជាអ្នកអនុវត្ត (មើល ២ពវ ១៦:២–៣) និងស្ដេចម៉ាន៉ាសេ (២ពវ ២១:១,៦) ។ *ក៏មិនដែលចូលក្នុងគំនិតអញដែរ* បញ្ជាក់ពីអ្វីដែលគេប្រព្រឹត្តអំពើបាបចំពោះព្រះ (មើល ១៩:៥ ៣២:៣៥) ។
**៧:៣៣** នេះជាការប្រកាសអំពីការជំនុំជម្រះ ដែលជាបណ្ដាសាមួយ ចំពោះការមិនគោរពតាមសេចក្ដីតាំងសញ្ញា (មើល ចទ ២៨:២៦) ។ *ជាចំណីដល់សត្វហើរលើអាកាស* និងដល់សត្វនៅដីផង មើល ១៦:៤ ១៩:៧ មើលផងដែរ ៣៤:២០ ដូចគ្នានេះជាការជំនុំជម្រះ ចំពោះការរំលោភបំពានលើការតាំងសញ្ញា (៣៤:១៨–១៩) ។ ចំពោះសំណល់នៃខ្មោចដែលស្លាប់ គួរឱ្យខ្ពើមឆ្អើមនៅសម័យបុរាណ ។
**៧:៣៤** មើល ១៦:៩ ២៥:១០ ធៀបនឹង ៣៣:១០–១១ ។ *ពីព្រោះស្រុកនេះនឹងត្រឡប់ជាទីសូន្យបង់* នេះជាការដាក់បណ្ដាសាមួយផ្សេងទៀត (លវ ២៦:៣១,៣៣) ។
**៨:១** *ឆ្អឹងរបស់ពួកអ្នកនៅក្រុងយេរូសាឡិមចេញពីផ្នូរមក* គឺសេចក្ដីអាក្រក់ (មើល ២ពវ ២៣:១៦,១៨ អម ២:១ និងការពន្យល់) ។ *ស្ដេច . . . ពួកចៅហ្វាយ . . . ពួកសង្ឃ . . . ពួកហោរា* មើល ២:២៦ និងការពន្យល់ ១:១៨ ។
**៨:២** *គេរាយឆ្អឹងទាំងនោះនៅចំពោះព្រះអាទិត្យ ព្រះចន្ទ និងអស់ពួកបរិវារនៅលើមេឃ* ដើម្បីធ្វើឱ្យគេបែរចេញ ហើយនោះចង់បញ្ជាក់ពីការដែលស្ដេចយូដាមួយចំនួនបានថ្វាយបង្គំដល់របស់នៅលើមេឃ (មើល ២ពវ ២១:៣,៥ ២៣:១១) នៅក្នុងចំណោមរបស់ដែលគ្មានអំណាចនឹងជួយគេបាននោះឡើយ ។ *គេបានស្រឡាញ់ គោរពប្រតិបត្តិ ប្រព្រឹត្តតាម ស្វែងរក ហើយថ្វាយបង្គំផង* ព្រះសមនឹងទទួលនូវការសរសើរដំកើង និងការថ្វាយបង្គំតែមួយអង្គប៉ុណ្ណោះ ។ *ពួកអ្នក* ឆ្អឹង ។ *នឹងគ្មានអ្នកណាប្រមូល ឬកប់ឆ្អឹងទាំងនោះឡើយ* ផ្ទុយគ្នានៅក្នុង ២សយ ២១:១៣–១៤ ។ *សំរាប់ជាដី* "អាចម៍សត្វ" (មើល ៩:២២ ១៦:៤ ២៥:៣៣) ។
៨:៣ រស់នៅ មើលការពន្យល់ ៦:៩ ។
**៨:៤–៩:២៦** ដែលផ្ទុយគ្នានៅក្នុង ៧:១–៨:៣ នៅក្នុងផ្នែកនេះ គឺមានទម្រង់ជាបែបជាកំណាព្យ លោកយេរេមាបានបន្ត ពង្រីកការអត្ថាធិប្បាយរបស់គាត់ ចំពោះការជំនុំជម្រះរបស់ព្រះ ដែលនឹងត្រូវធ្វើឡើងទៅលើមនុស្សមានបាប ។

មានបន្ទូលដូច្នេះ បើមនុស្សដួល តើមិនក្រោកឡើងវិញ
ទេឬ[ឈ] បើអ្នកណាបែរចេញ[ញ] តើមានវិលមកវិញឬ ៥ចុះ
ហេតុអ្វីបានជាប្រជាជននៅក្រុងយេរូសាឡិមទាំងនេះបាន
រាថយចេញ ហើយជាប់នៅក្នុងការនោះជានិច្ចដូច្នេះគេ
កាន់ខ្ជាប់តាមសេចក្ដីកំភូត[ដ] ហើយមិនព្រមវិលមកវិញទេ[ឋ]
៦អញបានផ្ទៀងត្រចៀក ហើយប្រុងស្ដាប់[ឌ] តែគេមិនបាន
និយាយ ដោយទៀងត្រង់សោះ គ្មានអ្នកណាមួយបានប្រែ
ចិត្តចេញ[ឍ] ពីអំពើអាក្រក់របស់ខ្លួន ដោយថា តើអញបានធ្វើ
អ្វីនេះ គ្រប់គ្នាបានបែរទៅតាមផ្លូវរបស់ខ្លួនវិញ[ណ] ដូចជា
សេះស្ទុះចូលទៅក្នុងសង្គ្រាម ៧ឯសត្វកុកដែលហើរលើអា–
កាស វាក៏ស្គាល់រដូវវាដែរ ឯលលក និងត្រចៀកកាំ ហើយ
ក្រៀល ក៏កាន់ពេលវេលាដែលត្រូវមកដែរ តែរាស្ត្រ
របស់អញ គេមិនស្គាល់[ត]ច្បាប់របស់ព្រះយេហូវ៉ាទេ ។
៨ធ្វើដូចម្ដេចឱ្យឯងរាល់គ្នាថា យើងមានប្រាជ្ញា ក៏មាន
ក្រិត្យវិន័យ[ថ]របស់ព្រះយេហូវ៉ា នៅជាមួយនឹងយើងដែរ
ដូច្នេះ តែមើល ស្លាបប្រកាក្លែងក្លាយរបស់ពួកអាចារ្យ
នោះបានបំផ្លាស់ទៅជាសេចក្ដីភូតភរវិញ ៩ពួកអ្នកប្រាជ្ញា[ទ]
គេត្រូវខ្មាស ត្រូវស្រយុតចិត្ត [ធ]ហើយចាប់បាន[ន] មើល គេ
បានបោះបង់ចោលព្រះបន្ទូល[ប]នៃព្រះយេហូវ៉ា ដូច្នេះ តើ
គេមានប្រាជ្ញា[ផ] នៅក្នុងខ្លួនជាយ៉ាងណាវិញ ១០ហេតុនោះ
អញនឹងលើកប្រពន្ធគេឱ្យដល់អ្នកដទៃ ហើយស្រែចំការ
របស់គេដល់ពួកអ្នកដែលនឹងគ្រប់គ្រងតទៅ[ព] ដ្បិតតាំងពី
អ្នកតូចបំផុត រហូតដល់អ្នកធំជាងគេ នោះសុទ្ធតែមានសេច
ក្ដីលោភ[ភ] ចាប់តាំងពីហោរា[ម] រហូតដល់សង្ឃ គ្រប់គ្នា
ប្រព្រឹត្តសេចក្ដីភូតភរ[យ] ១១គេបានមើលរបួសនៃកូនស្រី
របស់រាស្ត្រអញ ឱ្យសះតែបន្តិចបន្តួចទេ ដោយពោលតែ
ពាក្យថា សុខៗប៉ុណ្ណោះ ក្នុងកាលដែលឥតមានសេចក្ដីសុខ
ឡើយ[រ] ១២កាលគេបានប្រព្រឹត្តអំពើគួរស្អប់ខ្ពើម នោះតើគេ
មានសេចក្ដីខ្មាស[ល]ឬទេ ទេ គេឥតមានសេចក្ដីខ្មាសសោះ
ក៏មិនទាំងឡើងមុខក្រហមផង ហេតុនោះបានជាគេនឹង
ដួលជាមួយនឹងពួកអ្នកដែលត្រូវដួល ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា នៅវេលាដែលអញធ្វើទោសដល់គេ[វ] នោះគេ
នឹងត្រូវចំពប់ដួលជាពិត[ស] ១៣ព្រះយេហូវ៉ាមានបន្ទូលថា
អញនឹងបំផ្លាញ គេអស់រលីង នៅគ្រានោះនឹងគ្មានចង្កោម
ផ្លែនៅដើមទំពាំងបាយជូរ[ហ] ឬផ្លែល្វា[ឡ]នៅដើមល្វាសោះ
ស្លឹកទាំងប៉ុន្មាននឹងស្វិតក្រៀម[អ] ហើយរបស់ទាំងអស់ដែល
អញបានឱ្យដល់គេ នឹងសូន្យបាត់[ក]ទៅ ។
១៤ហេតុអ្វីបានជាយើងរាល់គ្នាអង្គុយតែស្ងៀមដូច្នេះ
ចូរមូលមក យើងនាំគ្នាចូលទៅក្នុងទីក្រុងទាំងប៉ុន្មានដែល
មានកំផែង[ខ] ហើយនៅភាំង នៅទីនោះវិញ ដ្បិតព្រះ

**៨:៤** ឈ សភ ២៤:១៦ មីក ៧:៨ ញ ទដ ១១៩:៦៧ យរ ៣១:១៩
**៨:៥** ដ យរ ៥:២៧ ឋ សក ៧:១១
**៨:៦** ឌ មឡ ៣:១៦ ឍ វវ ៩:២០ ណ ទដ ១៤:១–៣
**៨:៧** ត ទដ ៣២:២៨ យរ ៤:២២
**៨:៨** ថ រម ២:១៧
**៨:៩** ទ អស ២៩:១៤ ធ ២ពវ ១៩:២៦ ន យប ៥:១៣ ប យរ ៦:១៩ ផ សភ ១:៧ ១កថ ១:២០
**៨:១០** ព យរ ៦:១២ ភ អស ៥៦:១១ ម យរ ១៤:១៤ បទ ២:១៤ យ យរ ២៣:១១,១៥
**៨:១១** រ ឧ.១៥ យរ ៤:១០ អគ ៧:២៥
**៨:១២** ល យរ ៣:៣ វ ទដ ៥២:៥–៧ អស ៣:៩ ស យរ ៦:១៥
**៨:១៣** ហ ហស ២:១២ យអ ១:៧ ឡ លក ១៤:៦អ មថ ២១:១៩ ក យរ ៥:១៧
**៨:១៤** ខ យស ១០:២០ យរ ៣៥:១១

**៨:៤** *ត្រូវឱ្យឯងប្រាប់គេថា* ការភ្ជាប់ពាក្យនេះជាមួយនឹងឃ្លាមុន (មើល ៧:២៨) ។ *បើអ្នកណាបែរចេញ តើមិនវិលមកវិញឬ* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់កិរិយាសព្ទទាំង២នេះ គឺបញ្ជាក់ពីការលេងពាក្យ ។
**៨:៥** សេចក្ដីពិតជាទូទៅ បញ្ជាក់នៅក្នុង ខ.៤ ប្រជាជននៅក្រុងយេរូសាឡិមតែងមិនស្ដាប់បង្គាប់ដល់ព្រះជាទម្លាប់ ដោយប្រព្រឹត្តតាមសេចក្ដីកំភូត។ *បានរាថយចេញ . . . ហើយជាប់ក្នុងការនេះជានិច្ច . . . ហើយមិនព្រមវិលវិញ* នេះជាការលេងពាក្យ ខ.៤ ។
**៨:៦** *អញ* គឺជាព្រះអម្ចាស់ ។ បែរទៅតាមព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺជាការលេងពាក្យក្នុង ខ.៤–៥ ។ *ផ្លូវរបស់ខ្លួន* ផ្លូវអំពើបាប (មើល ២៣:១០) ។
**៨:៧** មើល អស ១:៣ សូម្បីតែសត្វហើរលើអាកាស ក៏ស្ដាប់បង្គាប់ដល់ព្រះ ប៉ុន្តែរាស្ត្ររបស់ព្រះ បដិសេធន៍មិនធ្វើតាមក្រិត្យវិន័យរបស់ទ្រង់ ។ សត្វច្រចៀកកាំ វាជាប្រភេទសត្វបក្សីម្យ៉ាងហើរយ៉ាងលឿន (មើល ៣៨:១៤) ប៉ុន្តែវាមិនដូចគ្នានឹងប្រភេទសត្វក្រៀលទេ ។ *គេមិនស្គាល់ច្បាប់របស់ព្រះយេហូវ៉ាទេ* មើលការពន្យល់ ៥:៤ ។
**៨:៨–៩** *ក្រិត្យវិន័យរបស់ព្រះយេហូវ៉ា . . . ព្រះបន្ទូលរបស់ព្រះយេហូវ៉ា* ការបកប្រែខុសនៅលើកទី១ ចំពោះ (សំណេរក្រិត្យវិន័យរបស់លោកម៉ូសេ) នាំឱ្យមានការបដិសេធន៍ជាលើកទី២ ចំពោះ (សេចក្ដីពិតរបស់ព្រះ ដូចជាបានរកឃើញនៅក្នុងក្រិត្យវិន័យ និងបានប្រកាសដោយអ្នកបម្រើរបស់ទ្រង់ គឺពួកហោរា) ។
**៨:៨** *ស្លាបប្រកាក្លែងក្លាយ* និម្មិតរូបអំពីការធ្វើបាប ដោយសារការសេរក្រិត្យវិន័យ ។ *ពួកអាចារ្យ* នៅជំនាន់ដើម គេជាក្រុមមួយ ដែលគេបានស្គាល់ពួកគេបានចាត់ចែងចែងយ៉ាងច្បាស់ដល់គ្រួសារ (មើល ១រប ២:៥៥ ២រប ៣៤:១៣ មើលការពន្យល់ អរ ៧:៦) ។ *បានបំផ្លាស់ទៅជាសេចក្ដីភូតភរវិញ* ខុសគ្នានៅក្នុង ២ធថ ២:១៥ ។
**៨:៩** *គេបានបោះបង់ . . . គេមានប្រាជ្ញា* ខុសគ្នានៅក្នុង ចទ ៤:៤–៦ ។
**៨:១០–១២** មើល ៦:១២–១៥ និងការពន្យល់ ។
**៨:១១** *រាស្ត្ររបស់អញ* សំដៅលើ "កូនស្រីនៃរាស្ត្រអញ" (នៅក្នុង ខ.២១ មើល អស ២២:៤ និងការពន្យល់) ។
**៨:១៣–៩:២៤** នៅក្នុងផ្នែកនេះ គេបានអានជាខ្លាំងៗ នៅក្នុងសាលាប្រជុំជារៀងរាល់ឆ្នាំ នៅឆ្នាំទី៩ នៃអាប៊ី (Ab) នៅថ្ងៃដែលព្រះវិហារនៃក្រុងយេរូសាឡិម ត្រូវបានបំផ្លាញ ដោយសារពួកបាប៊ីឡូន នៅក្នុងឆ្នាំ ៥៨៦ គ.ស និងដោយសារពួករ៉ូម ក្រោយ គ.ស ឆ្នាំ៧0 ។
**៨:១៣** *ទំពាំងបាយជូរ* គឺពួកអ៊ីស្រាអែល (មើល ២:២១ និងការពន្យល់) ។ *ចង្កោមផ្លែនៅដើមទំពាំងបាយ* និម្មិតរូបពីបុគ្គលម្នាក់ៗ ក្នុង មីក ៧:១ មើល ជំពូក ២៤ ។ *ស្លឹកទាំងប៉ុន្មាននិងស្វិតក្រៀម* ខុសគ្នាក្នុង ១៧:៨ ទដ ១:៣ ។
**៨:១៤–១៦** ហោរានិយាយតំណាងឱ្យប្រជាជន ដែលគាត់ស្រមៃអំពីការវាយលុករបស់ពួកបាប៊ីឡូន ។

យេហូវ៉ា ជាព្រះនៃយើង ទ្រង់បានធ្វើឱ្យយើងភាំងហើយ
ក៏បានឱ្យយើងផឹកទឹកពុល[គ]ដែរ ពីព្រោះយើងបានធ្វើបាប[ឃ]
នឹងទ្រង់ ១៥យើងបានទន្ទឹងចាំសេចក្តីសុខ[ង] ប៉ុន្តែឥតមានអ្វី
ល្អមក សោះ ក៏សង្ឃឹមនឹងមានពេលប្រោសឱ្យជា តែមើល
បានតែសេចក្តីវេទនាទទេ[ច] ១៦មានឮសូរឃើសនៃសេះរបស់
គេ ចេញពីដាន់មក កាលណាឮសូរសេះខ្លាំងពូកែរបស់
គេ[ឆ] ស្រែកកញ្ជ្រៀវ[ជ] នោះផែនដីទាំងអស់ក៏ញ័រ[ឈ] ដ្បិតគេ
បានមកហើយ គេបានស៊ីលេប[ញ]ស្រុក និងរបស់ទាំងប៉ុន្មាន
ដែលនៅក្នុងស្រុកផង ព្រមទាំងទីក្រុង និងពួកអ្នកនៅក្នុង
នោះដែរ ១៧ពីព្រោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល
អញនឹងចាត់ពស់[ដ] គឺជាពស់វែក ឱ្យមកកណ្តាលឯងរាល់គ្នា
ដែលមិនព្រមតាមសែកមន្តទេ[ឋ] ពស់ទាំងនោះនឹងចឹកឯង
រាល់គ្នា ។

១៨ឱបើខ្ញុំនឹងអាចកំសាន្តទុក្ខរបស់ខ្ញុំបានទៅអេះ ចិត្ត
របស់ខ្ញុំល្វើយ[ឌ]នៅក្នុងខ្លួន ១៩នំ ឮសំឡេងកូនស្រីរបស់
សាសន៍ខ្ញុំ ដែលស្រែកនៅឯស្រុកឆ្ងាយណាស់ថា[ឍ] តើព្រះ
យេហូវ៉ាមិនគង់នៅក្រុងស៊ីយ៉ូនទេឬអី តើមហាក្សត្រ[ណ]នៃ
ក្រុងនោះមិននៅទេឬ ហេតុអ្វីបានជាគេបណ្តាល[ត]ឱ្យអញ
ខឹង ដោយសាររូបឆ្លាក់របស់គេ ហើយដោយរបស់ឥត
ប្រយោជន៍[ថ]ពីប្រទេសដទៃដូច្នេះ[ទ] ២០រដូវច្រូតកាត់បាន
កន្លងហើយ រដូវក្តៅក៏ផុតទៅ តែយើងរាល់គ្នាមិនទាន់បាន
សង្គ្រោះនៅឡើយ ២១ខ្ញុំត្រូវរបួស[ធ]ដោយឈឺផ្សាលចំពោះ
របួសរបស់កូនស្រីនៃសាសន៍ខ្ញុំ ខ្ញុំកាន់ទុក្ខ[ន] ហើយសេចក្តី
ស្រឡាំងកាំងបានចាប់ខ្ញុំផង ២២តើគ្មានប្រទាលមុខសះ
នៅស្រុកកាឡាតទេឬអី[ប] តើគ្មានគ្រូពេទ្យ[ផ]នៅទីនោះទេឬ
ចុះតើហេតុអ្វីបានជាកូនស្រីនៃសាសន៍ខ្ញុំមិនជា[ព]ដូច្នេះ ។

**៩** ១ឱបើសិនជាក្បាលខ្ញុំ ពេញដោយទឹក ហើយភ្នែកខ្ញុំ
ជារន្ធចេញទឹកជានិច្ចទៅអេះ[ក] ដើម្បីឱ្យខ្ញុំបានយំ[ខ]ទាំងយប់
ទាំងថ្ងៃ ពីដំណើរពួកអ្នកដែលត្រូវគេសំឡាប់ ក្នុងកូនស្រី
នៃសាសន៍ខ្ញុំ[គ] ២ឱបើខ្ញុំមានទីស្នាក់អាស្រ័យនៅទីរហោ
ស្ថាន[ឃ]ជាទីសំណាក់របស់អ្នកដំណើរទៅអេះ ដើម្បីឱ្យខ្ញុំ
បានលះបង់សាសន៍របស់ខ្ញុំ ហើយឃ្លាតចេញពីគេទៅ

**៨:១៤** គ ចទ ២៩:១៨ យរ ៩:១៥ ២៣:១៥ ឃ យរ ១៤:៧,២០ ដយ ៩:៥ **៨:១៥** ង ខ.១១ ច យប ១៩:៨ យរ ១៤:១៩ **៨:១៦** ឆ យរ ៤:២៩ ជ លប ៣០:៦ ឈ យរ ៥១:២៩ ញ យរ ៥:១៧ **៨:១៧** ដ ជន ២១:៦ ចទ ៣២:២៤ ឋ ទដ ៥៨:៥ អស ៣:៣ **៨:១៨** ឌ បទ ៥:១៧ **៨:១៩** ឍ ចទ ២៨:៦៤ យរ ៩:១៦ ណ មីក ៤:៩ ត យរ ៤៤:៣ ថ អស ៤១:២៤ ទ ចទ ៣២:២១ **៨:២១** ធ ទដ ៩៤:៥ ន ទដ ៧៨:៤០ អស ៤៣:២៤ យរ ៤:១៩ ១០:១៩ ១៤:១៧ ៣០:១៤ បទ ២:១៣ អគ ៦:៩ **៨:២២** ប លប ៣៧:២៥ ផ យប ១៣:៤ ព អស ១:៦ យរ ៣០:១២ **៩:១** ក ទដ ១១៩:១៣៦ ខ យរ ១៣:១៧ ១៤:១៧ បទ ២:១១,១៨ ៣:៤៨ គ អស ២២:៤ **៩:២** ឃ ទដ ៥៥:៧ ង ជន ២៥:១ យរ ២៣:១០ ហស ៤:២ ៧:៤

**៨:១៤** ចូរចូលមក មើល ៤:៥ ព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ ជាការលេងពាក្យ ដែលព្រះគម្ពីរភាសាហេព្រើរ គឺ "យកចេញ" និង "ការច្រូតកាត់" ខ.១៣ ។ ចូលទៅក្នុងទីក្រុងទាំងប៉ុន្មាន មើលការពន្យល់ ៤:៥ ។ ក៏បានឱ្យយើងផឹកទឹកពុលដែរ ឃ្លានេះមានតែមួយ ចំពោះហោរាយេរេមា (មើល ៩:១៥ ២៣:១៥ ធៀបនឹង ២៥:១៥) ។

**៨:១៥** ការរំលឹកឡើងវិញ ត្រង់ៗតាមពាក្យនៅក្នុង ១៤:១៩ ។ *សេចក្តីសុខ* ក្រោមកាលៈទេសៈនោះ វាជាសេចក្តីសង្ឃឹមក្លែងក្លាយ (មើល ៤:១០ ៦:១៤) ។ *ប្រោសឱ្យជា* មើលការពន្យល់ ៦:៧ ។

**៨:១៦** *នៃសេះរបស់គេ* មើលការពន្យល់ ៤:១៣ ។ *ដាន់* នៅជិតភាគខាងជើងព្រំស្រុកអ៊ីស្រាអែល ។ វាជាអារម្មណ៍លើកដំបូង នៅពេលដែលមានការឈ្លានពាន ពីសំណាក់ពួកបាប៊ីឡូន ។ *ខ្លាំងពូកែ* សំដៅលើ "អ្នកដែលមានអំណាច" ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែម្តងទៀតថា "ខ្លាំងពូកែ" នៅក្នុង ៥០:១១ "សេះ" នៅក្នុង ៤៧:៣ ។

៨:១៧ គឺជាពស់វែក ឱ្យមកបណ្តាលឯងរាល់គ្នា ដែលមិនព្រមតាមសែកមន្តទេ ដូចជាមនុស្សអាក្រក់តែងតែធ្វើបាប (មើល ទដ ៥៨:៤–៥) ។

**៨:១៨** ហោរានិយាយថា ចិត្តរបស់ខ្ញុំល្វើយនៅក្នុងខ្លួន មើល បទ ១:២២ ៥:១៧ ។

**៨:១៩** ហោរានិយាយនៅក្នុងផ្នែកដំបូងនៃខនេះ ហើយព្រះអម្ចាស់មានបន្ទូលនៅក្នុងផ្នែកចុងក្រោយ ។ *កូនស្រីរបស់សាសន៍ខ្ញុំ ដែលស្រែកនៅស្រុកឆ្ងាយ* ពួកយូដាដែលត្រូវបាននិរទេសនៅឯក្រុងបាប៊ីឡូន (មើល ទដ ១៣៧:១–៤) ដូចជាលោកយេរេមា មើលឃើញអ្វីដែលកើតនៅថ្ងៃអនាគត ។ *តើព្រះយេហូវ៉ាមិនគង់នៅក្រុងស៊ីយ៉ូនទេឬអី* ធៀបនឹង មីក ៣:១១ ។ ប្រជាជនវល់គំនិត ដោយសារអំពើបាបរបស់គេ ព្រះបានអនុញ្ញាតឱ្យមានសេចក្តីហិនវិនាសដល់ទឹកដី និងព្រះវិហារ (មើលការពន្យល់ ៧:៤) ។ *មហាក្សត្រ* ព្រះ (មើល អស ៣៣:២២ និងការពន្យល់) ។ *គេបណ្តាលឱ្យអញខឹង* មើល ៧:១៨ ចទ ៣១:២៩ ។ *ដោយសាររូបឆ្លាក់របស់គេ* មើលការពន្យល់ ២:៥។

**៨:២០** ប្រជាជននិយាយដោយការអស់សង្ឃឹម នៅពេលដែលគេនៅជាប់ជាឈ្លើយនោះ ។ *តែយើងរាល់គ្នាមិនទាន់បានសង្គ្រោះនៅឡើយ* យើងត្រូវបំផ្លាញដោយពួកខ្មាំងសត្រូវហើយ ។

**៨:២១** លោកយេរេមាបានសម្រេចខ្លួន ឱ្យដូចនឹងពួកអ្នកជាប់ជាឈ្លើយនៅទឹកដីរបស់គាត់ ។ *បានចាប់ខ្ញុំផង* មើល ៦:២៤ ។

**៨:២២** *តើគ្មានប្រទាលមុខសះនៅស្រុកកាឡាតទេឬអី* មើល ៤៦:១១ ធៀបនឹង ៥១:៨ ទឹកដីស្រុកកាឡាត ជាស្រុក១ដែលមានធនធានយ៉ាងសំខាន់សម្រាប់ធ្វើថ្នាំផ្សំ ដែលមានខ្លិនយ៉ាងល្អ (មើល លប ៣៧:២៥ និងការពន្យល់ ។ *តើគ្មានគ្រូពេទ្យនៅទីនោះទេឬ* ខុសគ្នានៅក្នុង ៣០:១៧ ។

៩:១–២ ហោរារសាយចិត្ត បញ្ជាក់ពីអ្វីដែលគាត់មិនបាននិយាយផ្អែមល្ហែមសម្រាប់ប្រជាជនរបស់គាត់ ដូចជាបានបញ្ជាក់នៅក្នុង ខ.១ និងការជិនឆ្អន់នឹងការឈឺចាប់ក្នុងចិត្ត ខ.២ ។

**៩:១** គេតែងតែហៅលោកយេរេមាថា "ហោរាយំសោក" នេះជាចំណងជើង១យ៉ាងល្អ (មើលព្រះគម្ពីរបទ ខ.១០ ធៀបនឹង ១សយ ១៨:៣៣ លក ១៩:៤១ រម ៩:២–៤ ១០:១ ) ។

**៩:២** ហោរាគឺចង់គេចឱ្យផុតពីប្រជាជនរបស់គាត់ ដែលធ្វើការអាក្រក់នោះបើសិនជាអាចធ្វើទៅបាន (ធៀបនឹង ទដ ៥៥:៦–៨) ។ *ដ្បិតគេសុទ្ធតែជាពួកកំផិត គឺជាជំនុំមនុស្សក្បត់* មើល ខ.១៤ មើលផងដែរ នក ៣៤:១៥ និងការពន្យល់ ។ *គេសុទ្ធតែ* ព្រះគម្ពីរភាសាហេព្រើសម្រាប់ពាក្យនេះ គឺគេតែងតែប្រើនៅកន្លែង១ ក្នុងព្រះគម្ពីរសញ្ញាចាស់ជាច្រើនដង នៅក្នុងពួកជំនុំ

ដ្បិតគេសុទ្ធតែជាពួកកំផិត[ង] គឺជាជំនុំមនុស្សក្បត់[ច] ៣ព្រះយេ
ហូវ៉ាទ្រង់មានបន្ទូលថា គេដំឡើងអណ្តាតដូចជាធ្នូ សំរាប់
ពាក្យភូតភរ[ឆ] ហើយគេបានចំរើនកំឡាំងនៅក្នុងស្រុកផង
តែមិនមែនសំរាប់សេចក្តីពិតត្រង់ទេ ដ្បិតគេចេះតែជឿនពី
អំពើអាក្រក់១ ទៅដល់អំពើអាក្រក់១ទៀត ហើយគេមិន
ស្គាល់[ជ]អញទេ ៤ចូរឱ្យគ្រប់គ្នាប្រុងប្រយ័ត្នចំពោះអ្នកជិត
ខាងខ្លួន[ឈ] កុំឱ្យទុកចិត្តនឹងបងប្អូនណាមួយឡើយ[ញ] ដ្បិតគ្រប់
ទាំងបងប្អូននឹងដណ្តើមយកប្រយោជន៍អស់រលីង[ដ] ហើយ
គ្រប់ទាំងអ្នកជិតខាងនឹងដើរទៅមកនិយាយបង្កាច់បង្ខិតគេ[ឋ]
៥គ្រប់គ្នានឹងបញ្ឆោតអ្នកជិតខាងខ្លួន[ឌ] ហើយមិនព្រមពោល
សេចក្តីពិតទេ[ឍ] គេបានបង្ហឹកអណ្តាតឱ្យកុហក[ណ] គេខំអស់ពី
ចិត្តនឹងប្រព្រឹត្តអាក្រក់ ៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
ទីលំនៅរបស់ឯង នោះនៅកណ្តាលសេចក្តីប្រវ័ញ្ចន៍
បញ្ឆោត[ត] ដោយព្រោះសេចក្តីប្រវ័ញ្ចន៍បញ្ឆោតនោះ បាន
ជាគេមិនព្រមស្គាល់អញឡើយ ។
៧ហេតុនោះ ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មាន
បន្ទូលដូច្នេះថា មើល អញនឹងរំលាយ[ថ] ហើយសាកល[ទ]គេ
ដ្បិតតើនឹងឱ្យអញធ្វើយ៉ាងណាទៀត ដល់កូនស្រីរបស់
រាស្ត្រអញនេះ ៨អណ្តាត[ធ]គេជាព្រួញដែលសំឡាប់ ក៏ពោល
សុទ្ធតែសេចក្តីប្រវ័ញ្ចន៍បញ្ឆោត គេនិយាយសេចក្តីមេត្រី
នឹងអ្នកជិតខាង[ន]ដោយបបូរមាត់ តែឯក្នុងចិត្ត នោះគេលប
ចាំចាប់[ប]វិញ[ផ] ៩ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា តើមិនត្រូវ
ឱ្យអញធ្វើទោសគេ ដោយព្រោះអំពើយ៉ាងនោះទេឬ តើ
ព្រលឹងអញមិនត្រូវសងសឹក[ព] ចំពោះសាសន៍ណាយ៉ាងនេះ
ទេឬអី ។
១០ខ្ញុំនឹងឡើងសំឡេងយំ ហើយស្រែកទ្រហោនឹងភ្នំទាំង
ប៉ុន្មាន ហើយនឹងទួញទំនួញចំពោះវាលឃ្វាលសត្វ នៅ
ទីរហោស្ថាន[ភ] ពីព្រោះបានឆេះអស់ហើយ ដល់ម្ល៉េះបាន
ជាគ្មានអ្នកណាដើរតាមនោះទៀត ក៏គ្មានអ្នកណាឮសំឡេង
របស់ហ្វូងសត្វដែរ ឯសត្វហើរលើអាកាស[ម] និងសត្វជើង
៤បានបាត់អស់ទៅហើយ ។
១១អញនឹងធ្វើឱ្យក្រុងយេរូសាឡិមត្រឡប់ជាគំនរ[យ] គឺ
ជាទីលំនៅនៃពួកចចក[រ] ហើយនឹងធ្វើឱ្យក្រុងទាំងប៉ុន្មាន
នៅស្រុកយូដា[ល] ត្រូវចោលស្ងាត់ ឥតមានអ្នកណានៅឡើយ[វ]
១២តើអ្នកណាមានប្រាជ្ញា[ស] ដែលអាចនឹងយល់សេចក្តីនេះ
បាន តើព្រះឱស្ឋនៃព្រះយេហូវ៉ាបានមានបន្ទូលចំពោះ
អ្នកណា ដើម្បីឱ្យគេបានថ្លែងប្រាប់តទៅ ហេតុអ្វីបានជា
ស្រុកបានត្រូវវិនាស ហើយឆេះសុសដូចជាទីរហោស្ថាន
ដល់ម្ល៉េះបានជាគ្មានអ្នកណាដើរកាត់ទៀតដូច្នេះ ១៣ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា គឺដោយព្រោះតែគេបានបោះ
បង់ចោលក្រិត្យវិន័យរបស់អញ ដែលអញបានដាក់នៅ
មុខគេ ហើយមិនបានស្តាប់ ឬដើរតាមពាក្យរបស់អញ

**៩:២** ច ពវ ១៩:១០ អស ២៤:១៦ **៩:៣** ឆ ខ.៨ នក ២០:១៦ ទដ ៦៤:៣ អស ៤៤:២០ យរ ១៨:១៨ មីក ៦:១២ ជ អស ១:៣ **៩:៤** ឈ ២សយ ១៥:១២ ញ មីក ៧:៥-៦ ដ លប ២៧:៣៥ ឋ នក ២០:១៦ លវ ១៩:១៦ **៩:៥** ឌ លវ ៦:២ ឍ ទដ ១៥:២ អស ៥៩:១៥ ណ ទដ ៥២:៣ **៩:៦** ត យរ ៥:២៧ **៩:៧** ថ យប ២៨:១ អស ១:២៥ ទ យរ ៦:២៧ **៩:៨** ធ ខ.៣ ទដ ៣៥:២០ ន អស ៣:៥ ប យរ ៥:២៦ ផ ខ.៤ **៩:៩** ព ចទ ៣២:៤៣ អស ១០:៣ **៩:១០** ភ យរ ២៣:១០ យអ ១:១៩ ម យរ ៤:២៥ ១២:៤ ហស ៤:៣ យអ ១:១៨ **៩:១១** យ យរ ២៦:១៨ រ យប ៣០:២៩ អស ៣៤:១៣ ល យរ ១:១៥ វ លវ ២៦:៣១ អស ២៥:២ យរ ៤:១៣ ២៦:៩ ៣៣:១០ ៥០:៣,១៣ ៥១:៦២ បទ ១:៤ **៩:១២** ស ទដ ១០៧:៤៣

(មើលឧទាហរណ៍ ចទ ១៦:៨) ជួនកាលពួកអ្នកដែលថ្វាយបង្គំ បានធ្វើការអាក្រក់ ដែលនាំឱ្យគេធ្លាក់ទៅក្នុងការជំនុំជម្រះរបស់ព្រះ (មើល អស ១:១៣ អម ៥:២១) ។

**៩:៣-៩** ព្រះមានបន្ទូល ។

**៩:៣** *គេនឹងដំឡើងអណ្តាដូចជាធ្នូ* មើល ខ.៥,៨ មើលផងដែរ ទដ ៦៤:៣-៤ ធៀបនឹង យក ៣:៥-១២ ។ *ហើយគេមិនស្គាល់អញទេ* មើល ខ.៦ ពច ២:១០ ១សយ ២:១២ យប ១៨:២១ ហស ៤:១ និងការពន្យល់ រម ១:២៨ ផ្ទុយគ្នានៅក្នុង ហស ៦:៣ ។

**៩:៤** *ដណ្តើមយកប្រយោជន៍* លប ២៥:២៦ និងការពន្យល់ លប ២៧:៣៦ ហស ១២:២-៣ និងការពន្យល់ ១២:២) ។

**៩:៦** *បានជាគេមិនព្រមស្គាល់អញឡើយ* ស្ថានការណ៍នោះបានធ្វើឱ្យខូចដល់ថ្ងៃអនាគត (សូមមើល ខ.៣ និយាយជាសាមញ្ញថា "គេមិនបានស្គាល់អញទេ") ។

**៩:៧** *មើល អញនឹងរំលាយ និងសាកលគេ* សូមមើល ៦:២៧-៣០ និងការពន្យល់ ។ ព្រះអម្ចាស់នឹងសាកល្បងលមើលរាស្ត្ររបស់ទ្រង់ "នៅលើចង្ក្រាន ដើម្បីឱ្យមានការឈឺចាប់" ។

**៩:៨** *អណ្តាគេ . . . សេចក្តីប្រវ័ញ្ចន៍បញ្ឆោត* មើលខ៣ និងការពន្យល់ ។ *ដោយបបូរមាត់ តែឯក្នុងចិត្ត* មើល ទដ ៥៥:២១ ។ *និយាយសេចក្តីមេត្រី* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺត្រូវបានគេបកប្រែថា "សេចក្តីសុខសាន្ត" នៅក្នុង ៦:១៤ (មើលការពន្យល់) ។

**៩:៩** រំឮកឡើងវិញតាំងពីជំពូក ៥:៩,២៩ ។

**៩:១០** ហោរានិយាយ មើល ៤:២៣-២៦ និងការពន្យល់ ។ *ខ្ញុំនឹងឡើងសំឡេងយំ* មើល ខ.១៨ មើលផងដែរ ខ.១ ។ *វាលឃ្វាលសត្វនៅទីរហោស្ថាន* ជាការល្អសម្រាប់អ្នកក្រីក្ររស់នៅទីនោះ (មើល ១សយ ១៧:២៨ ធៀបនឹង នក ៣:១) ។ *ទួញទំនួញ* មានន័យថា "ដុត" (ដូចជានៅក្នុង ២:១៥) បាន ស្ងួតដោយកំដៅព្រះអាទិត្យ ។ *គ្មានអ្នកណាដើរតាមនោះឡើយ* មើល ខ.១២ អគ ៣៣:២៨ ។

**៩:១១** ព្រះអម្ចាស់មានបន្ទូល *ទីលំនៅនៃពួកចចក* មើល ១០:២២ ៤៩:៣៣ ៥១:៣៧ ទដ ៤៤:១៩ អស ១៣:២១-២២ បទ ៥:១៨ អគ ១៣:៤ មទ្ធ ១:៣ ធៀបនឹង អស ៣៥:៧ ។ *ឥតមានអ្នកណានៅឡើយ* មើល ២:១៥ ៤:៧ និងការពន្យល់ ។

**៩:១២** ហោរាសួរសំនួរជាច្រើន ។*តើអ្នកណាមានប្រាជ្ញា* សូមមើល អស ១៤:៩ ។

**៩:១៣** ព្រះអម្ចាស់ឆ្លើយតបតបទៅហោរា និងបន្ទាប់មកទ្រង់បន្តមានបន្ទូលទៅកាន់រាស្ត្រទ្រង់នៅក្នុង ខ.១៩ ។ *ក្រិត្យវិន័យរបស់អញ ដែលអញដាក់នៅមុខគេ* នៅថ្ងៃលោកម៉ូសេ (មើល ចទ ៤:៨) ។

ប៉ុណ្ណោះ[ហ] ១៤គឺគេបានដើរតាមតែចិត្តរឹង[ឡ]របស់គេវិញ
ព្រមទាំងតាម[អ]ព្រះបាលទាំងប៉ុន្មាន ដែលពួកឰយុកោគេ
បានបង្រៀនដល់គេផង ១៥ហេតុនោះ ព្រះយេហូវ៉ានៃពួក
ពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូល
ដូច្នេះថា មើល អញនឹងចិញ្ចឹមគេ គឺជនជាតិនេះឯង ដោយ
ស្លែង[ក] ហើយនឹងឱ្យទឹកពុលទៅគេផឹក[ខ] ១៦អញនឹងកំចាត់
កំចាយគេទៅកណ្តាលគ្រប់ទាំងសាសន៍[គ] ជាសាសន៍ដែល
ខ្លួនគេ ឬពួកឰយុកោគេ ក៏មិនបានស្គាល់ផង[ឃ] ហើយអញ
នឹងចាត់ប្រើដាវ[ង]ឱ្យទៅតាមគេ ដរាបដល់បានបំផ្លាញគេ
អស់រលីង[ច]។
១៧ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលថា
ចូរឱ្យឯងរាល់គ្នាពិចារណាចុះ រួចឱ្យហៅពួកស្រីអ្នកយំ[ឆ]
ឱ្យគេមក ចូរចាត់ទៅហៅពួកស្រីវាងវៃឱ្យមកដែរ ១៨ត្រូវ
ឱ្យគេប្រញាប់ឡើង នឹងលើកបទទំនួញឱ្យយើង ដើម្បីឱ្យ
ភ្នែកយើងបានស្រក់ទឹកចុះ ហើយឱ្យត្របកភ្នែកយើងបាន
ចេញទឹកល្ហល្ហាច[ជ] ១៩ដ្បិតមានឮសំឡេងទ្រហោយំ ពីក្រុង
ស៊ីយ៉ូនមកថា ឱម្ល៉េះសមយើងវេទនា[ឈ]យ៉ាងណាហ្ន៎ យើង
មានសេចក្តីខ្មាសជ្រប់មុខ ដោយព្រោះយើងត្រូវចោល
ស្រុក ហើយដោយព្រោះគេបានរំលំទីលំនៅរបស់យើង
បង់ ២០ប៉ុន្តែ ឱពួកស្រីៗអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះ
យេហូវ៉ាចុះ ហើយឱ្យត្រចៀកទទួលព្រះបន្ទូលពីព្រះឱស្ឋ
ទ្រង់ផង[ញ] ត្រូវឱ្យបង្រៀនកូនស្រីរបស់ឯងរាល់គ្នា ឱ្យចេះ
ទ្រហោយំ ហើយឱ្យអ្នកជិតខាងទាំងប៉ុន្មានចេះទួញទំនួញ[ដ]
២១ពីព្រោះសេចក្តីស្លាប់បានឡើងចូលមក តាមបង្អួច[ឋ]យើង
ក៏បានចូលមកក្នុងដំណាក់របស់យើងដែរ ដើម្បីនឹងបំបាត់
កូនក្មេងពីខាងក្រៅ ហើយពួកកំឡោះៗ[ឌ]ពីផ្លូវចេញ ២២ចូរ
ប្រាប់ចុះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា សាកសព
នៃមនុស្សនឹងធ្លាក់ចុះ ដូចជាដី[ឍ]នៅវាលស្រែ ហើយដូចជា
កណ្តាប់ស្រូវតាមក្រោយអ្នកច្រូត ឥតមានអ្នកណាប្រមូល
វិញឡើយ ។
២៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា កុំបីឱ្យអ្នកប្រាជ្ញ
អួតពីប្រាជ្ញារបស់ខ្លួនឡើយ[ណ] ក៏កុំឱ្យមនុស្សខ្លាំងពូកែអួតពី
កំឡាំងខ្លួន[ត] ឬអ្នកមានអួតពីទ្រព្យសម្បត្តិរបស់ខ្លួនដែរ[ថ]
២៤ឯអ្នកដែលអួត នោះត្រូវឱ្យគេអួត[ទ]តែពីសេចក្តីនេះវិញ
គឺថាខ្លួនមានយោបល់ ហើយក៏ស្គាល់[ធ]ដល់អញថា អញជា
ព្រះយេហូវ៉ា[ន]ដែលប្រោសផ្សាយសេចក្តីសប្បុរស[ប] សេចក្តី

**៩:១៣** ហ ២របា ៧:១៩ ទដ ៨៩:៣០–៣២ **៩:១៤** ឡ យរ ៣:១៧ ៧:២៤ អ យរ ២:៨,២៣ អម ២:៤ **៩:១៥** ក បទ ៣:១៥ ខ យរ ៨:១៤ **៩:១៦** គ លវ ២៦:៣៣ ឃ ចទ ៤:៣២ យរ ៨:១៩ ង យរ ១៤:១២ ២៤:១០ អគ ៥:២ ច យរ ៤៤:២៧ អគ ៥:១២ **៩:១៧** ឆ សស ១២:៥ **៩:១៨** ជ ទដ ១១៩:១៣៦ បទ ៣:៤៨ **៩:១៩** ឈ យរ ៤:១៣ **៩:២០** ញ យរ ២៣:១៦ ដ អស ៣២:៩–១៣

**៩:២១** ឋ យអ ២:៩ ឌ ២របា ៣៦:១៧ អស ៤០:៣០ យរ ១៦:៦ **៩:២២** ឍ ២ពវ ៩:៣៧ **៩:២៣** ណ យប ៤:១២ សស ៩:១១ ត ១ពវ ២០:១១ ថ ទដ ៦២:១០ សភ ១១:២៨ យរ ៤៨:៧ ៤៩:៤ អគ ២៨:៤–៥ **៩:២៤** ទ ទដ ៣៤:២ ១កថ ១:៣១ កទ ៦:១៤ ធ ទដ ៣៦:១០ ន ២របា ១០:១៧ ប ទដ ៥១:១

**៩:១៤** *តាមតែចិត្តរឹង* មើលការពន្យល់ ៣:១៧ ។ *ព្រះបាលទាំងប៉ុន្មាន* មើល ២:២៣ និងការពន្យល់ ។

**៩:១៥** *ហើយនិងឱ្យទឹកពុលទៅគេផឹក* រំឭកឡើងវិញក្នុង ២៣:១៥ មើលការពន្យល់ ៨:១៤ ។ នៅសតវត្សជំនាន់ដើម លោកម៉ូសេបានព្រមានដល់ពួកអ៊ីស្រាអែល ចំពោះអំពើបាបដែលគេបានប្រព្រឹត្ត (មើល ចទ ២៩:១៨) ។

**៩:១៦** *អញនឹងកំចាត់កំចាយគេទៅ* មើល ១៣:២៤ ១៨:១៧ ៣០:១១ ៤៦:២៨ នេះជាសេចក្តីព្រមានមួយ ដែលជាបណ្តាសា ចំពោះការមិនគោរពតាមសេចក្តីតាំងសញ្ញា ។ *ហើយអញនឹងចាត់ប្រើដាវឱ្យទៅតាមគេ* មើល ៤២:១៦ ។ *បានបំផ្លាញគេអស់* ប៉ុន្តែមិនបានបំផ្លាញដល់មនុស្សចុងក្រោយទេ (មើលការពន្យល់ ៤:២៧ ជាពិសេសមើល ៤៤:២៧–២៨) ។

**៩:១៧** *រួចឱ្យហៅពួកស្រីអ្នកយំ ឱ្យចូលមក* ជាអ្នកដែលប្រសប់ទួញទំនួញបានទទួលកំរៃ នៅថ្ងៃពិធីបុណ្យសព និងពិធីកាន់ទុក្ខផ្សេងៗ (មើលជិពូក ៣៥:២៥ សស ១២:៥ អម ៥:១៦) ។

**៩:១៨** *ទំនួញ* មើលខ១០ ។ *ដើម្បីឱ្យភ្នែកយើងបានស្រកទឹកចុះ* មើល ខ.១ ។

**៩:១៩** *ឱម្ល៉េះសមយើងវេទនាយ៉ាងណាហ្ន៎* សូមមើល ៤:១៣,២០ ធៀបនឹង ៤៨:១ ។

**៩:២០–២១** ហោនិយាយ ។

**៩:២០** ពួកស្រីអ្នកយំត្រូវបង្រៀនកូនស្រីរបស់ខ្លួន ឱ្យចេះទ្រហោយំ ដើម្បីឱ្យកម្មវិធីរបស់គេបានល្អប្រសើរ ។

**៩:២១** *សេចក្តីស្លាប់* និយាយនៅទីនេះ (ដូចជានៅក្នុង ហប ២:៥) ។ ពួកកាណាន លើកយកសាច់រឿង និយាយអំពីព្រះ ដោយដាក់ឈ្មោះ ដើម្បីងាយចាំ (ជាពាក្យដែលទាក់ទងទៅនឹងព្រះគម្ពីរភាសាហេព្រើរ គឺ "សេចក្តីស្លាប់" ចំពោះរូបព្រះ ដែលឥតមានប្រយោជន៍ ។ *បានឡើងចូលមកតាមបង្អួចយើង* បាននិយាយសំដៅលើទាហានខ្មាំងសត្រូវនៅក្នុង យអ ២:៩ ។ *កូនក្មេង . . .ពួក កំឡោះៗ* មើល ៦:១១ ។

**៩:២២** *សាកសពនៃមនុស្ស* មើល ៧:៣៣ និងការពន្យល់ ។ *ដូចជាដី* មើលការពន្យល់ ៨:២ ។ *អ្នកច្រូត* គំនិតអំពីសេចក្តីស្លាប់ដូចជា "អ្នកច្រូតដែលមឹងម៉ាត់" និយាយយ៉ាងខ្លាំងនៅក្នុងខនេះ ។

**៩:២៣** *កុំឱ្យមនុស្សខ្លាំងពូកែអួតពីកំឡាំងខ្លួន* ឬអ្នកមានអួតពីទ្រព្យសម្បត្តិរបស់ខ្លួនដែរ នេះជាពាក្យស្របគ្នាដែលកើតឡើងយ៉ាងពិតប្រាកដ នៅក្នុងពាក្យអារ៉ាមិកគឺ អាហ៊ីការ (Ahiqar) បានសរសេរឡើងអស់រយះពេល១សតវត្ស បន្ទាប់ពីពេលវេលាលោកយេរេមា កុំឱ្យមនុស្សមាននិយាយថា "ខ្ញុំមាន ខ្ញុំសំបូរសប្បាយហើយ" ។

**៩:២៤** ១កថ ១:៣១ សង្ខេប " សូមឱ្យគេមានសេចក្តីអំនួន អួតនៅក្នុងព្រះអម្ចាស់ ។ *នោះ . . . សេចក្តីទាំងនេះ* ជាចុងក្រោយនេះ មានតែព្រះ ចំណេះវិជ្ជា និងសេចក្តីស្រឡាញ់របស់យើងសម្រាប់ទ្រង់ ទើបមានប្រយោជន៍ ។ *មានយោបល់ ហើយក៏ស្គាល់* មើល ៣:១៥ មើលការពន្យល់ផងដែរ ៤:២២។ *អញជាព្រះយេហូវ៉ា* នក ៦:២–៨ នេះជាព្រះបន្ទូលយ៉ាងសំខាន់អំពីគោលលិទ្ធិ នៃសេចក្តីប្រោសលោះ តាំងពីការចាប់ផ្តើម រហូតដល់ទីបញ្ចប់ ដែលបញ្ជាក់អំពីព្រះ ។ *សេចក្តីសប្បុរស* ព្រះគម្ពីរភាសាហេព្រើរ

យុត្តិធម៌ និងសេចក្ដីសុចរិត[ផ]នៅផែនដី ដ្បិតអញរីករាយ
ចិត្តចំពោះសេចក្ដីទាំងនោះហើយ នេះជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ។
២៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល នឹងមានគ្រា
មកដល់ ដែលអញនឹងវាយផ្ចាលពួកកាត់ស្បែក ដែលកាត់មិន
ស្មោះត្រង់[ព] ២៦គឺសាសន៍អេស៊ីព្ទ សាសន៍យូដា សាសន៍
អេដំម ហើយពួកកូនចៅអាំម៉ូន និងម៉ូអាប់ ព្រមទាំងអស់
អ្នកនៅទីរហោស្ថាន ដែលកាត់ជ្រុងពុកចង្កាផង[ភ] ដ្បិត
បណ្ដាសាសន៍ទាំងប៉ុន្មានមិនកាត់ស្បែកទេ[ម] ពួកវង្ស
អ៊ីស្រាអែលទាំងអស់ក៏មិនបានកាត់ស្បែកចិត្តដែរ[យ]។

**ព្រះ និងរូបព្រះ**

*១០:១២–១៦ – យរ ៥១:១៥–១៩*

**១០** ១ឱពួកវង្សអ៊ីស្រាអែលអើយ ចូរស្ដាប់សេចក្ដីដែល
ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអ្នករាល់គ្នាចុះ ២គឺទ្រង់មាន
បន្ទូលដូច្នេះថា កុំឱ្យរៀនតាមកិរិយារបស់សាសន៍ដទៃ[ក]
ឡើយ ក៏កុំឱ្យភ័យខ្លាចចំពោះទីសំគាល់[ខ]នៅលើមេឃដែរ
ដ្បិតសាសន៍ដទៃគេខ្លាចទីសំគាល់ទាំងនោះ ៣ពីព្រោះអស់
ទាំងទំនៀមទំលាប់របស់សាសន៍ដទៃ សុទ្ធតែអសារឥតការ
ទទេ គេកាប់ដើមឈើនៅក្នុងព្រៃ គឺជាស្នាដៃរបស់មនុស្ស[គ]
កាន់ពូថៅ[ឃ] ៤គេតាក់តែងដោយប្រាក់[ង] និងមាស គេយក
ញញួរបោះជាប់ដោយដែកគោល ដើម្បីមិនឱ្យរើទៅឯ
ណា[ច] ៥រូបទាំងនោះឈរត្រង់ ដូចជាដើមម៉ើ វាមិនចេះ
និយាយ[ឆ] ហើយត្រូវការឱ្យគេសែងទៅមក ពីព្រោះដើរ
មិនរួច[ជ] កុំឱ្យកោតខ្លាចចំពោះវាឡើយ ដ្បិតវាធ្វើអាក្រក់
មិនបានទេ[ឈ] ក៏មិនអាចនឹងធ្វើល្អបានផង[ញ]។
៦ឱព្រះយេហូវ៉ា អើយ គ្មានណាឱ្យដូចទ្រង់ឡើយ[ដ] ទ្រង់
ធំប្រសើរ[ឋ] ហើយព្រះនាមទ្រង់ក៏មានឥទ្ធានុភាពយ៉ាងខ្លាំង
ដែរ ៧ឱមហាក្សត្រនៃអស់ទាំងសាសន៍អើយ[ឌ] តើមាន
អ្នកឯណាដែលមិនត្រូវកោតខ្លាច[ឍ]ដល់ព្រះយេហូវ៉ា ដ្បិត
សេចក្ដីកោតខ្លាចសំណុំតែនឹងទ្រង់ប៉ុណ្ណោះ ពីព្រោះក្នុង
បណ្ដាមនុស្សប្រាជ្ញទាំងឡាយនៅគ្រប់ទាំងសាសន៍ ហើយ
ក្នុងនគររបស់គេទាំងប៉ុន្មាន នោះគ្មានអ្នកណាមួយឱ្យដូច

**៩:២៤** ផ ទដ ៣៦:៦ **៩:២៥** ព លវ ២៦:៤១ រម ២:២៥ **៩:២៦** ភ យរ ២៥:២៣ ៤៩:៣២ ម ១សយ ១៤:៦ អគ ៣១:១៨ យ កច ៧:៥១ **១០:២** ក នក ២៣:២៤ លវ ២០:២៣ ខ លប ១:១៤ **១០:៣** គ អស ៤០:១៩ ឃ ចទ ៩:២១ ១ពវ ៨:៣៦ យរ ៤៤:៨ អគ ៧:២០ **១០:៤** ង ទដ ១៣៥:១៥ ហស ១៣:២ ហព ២:១៩ ច ១សយ ៥:៣ អស ៤១:៧ **១០:៥** ឆ ១ពវ ១៨:២៦ ១កថ ១២:២ ជ អស ៤៥:២០ ឈ អស ៤១:២៣ ញ អស ៤១:២៤ ៤៤:៩–២០ ៤៦:៧ កច ១៩:២៦ **១០:៦** ដ នក ៨:១០ ឋ ២សយ ៧:២២ ទដ ៤៨:១ **១០:៧** ឌ ទដ ២២:២៨ អស ១២:៤ វវ ១៥:៤ ឍ យរ ៥:២២

សម្រាប់ពាក្យនេះ គឺបានបកប្រែថា "ការថ្វាយបង្គំ" មើល ២:២ និងការពន្យល់ ។ *ដ្បិតអញរីករាយ* មើល ទដ ១១:៧ ៣៣:៥ ៩៩:៤ ១០៣:៦ មីក ៦:៨ ៧:១៨ ។

**៩:២៥–២៦** មើល រម ២:២៥–២៩ មើលផងដែរ លប ១៧:១០ ។

**៩:២៦** *ព្រមទាំងអស់អ្នកនៅទីរហោស្ថាន* ពូជអំបូរអារ៉ាប់ (មើល ២៥:២៣ ៤៩:៣២) តែក្រោយមកបានត្រូវវាយប្រហារ ដោយពួកបាប៊ីឡូន ក្រោមស្ដេចនេប៊ូក្នេសា (មើល ៤៩:២៨–៣៣ និងការពន្យល់ ដែលផ្ទុយគ្នានៅក្នុង លវ ១៩:២៧ ។ *ក៏មិនបានកាត់ស្បែកចិត្តដែរ* មើល ៤:៤ និងការពន្យល់ ។

**១០:១–២៥** លោកយេរេមាសង្ខេប អំពីព្រះបន្ទូលនៅក្នុងព្រះវិហារ នៅក្នុងផ្នែកជាកវីនិពន្ធ ដែលផ្ដោតជាបឋមលើ ភាពខុសគ្នាយ៉ាងធំធេង រវាងរូបព្រះ និងព្រះអម្ចាស់ (ខ.២–១៦) ។ រូបព្រះ និងអ្នកថ្វាយបង្គំរូបព្រះ នឹងត្រូវទទួលទោស នៅក្នុង ខ.២–៥,៨–៩,១១,១៤–១៤ នេះជាព្រះបន្ទូលផ្លាស់ប្ដូរ នៅពេលដែលព្រះនៃសេចក្ដីពិត ត្រូវបានលើកសសើរដំកើង (ខ.៦–៧, ១០,១២–១៣,១៦) ។ មើល អស ៤០:១៨–២០ និងការពន្យល់ ៤១:៧ ៤៤:៩–២០ ៤៦:៥–៧ ។

**១០:១** *ចូរស្ដាប់* មើលការពន្យល់ ២:៤ ។

**១០:២** *ក៏កុំឱ្យភ័យខ្លាច* មើល ១:១៧ ។ *តាមកិរិយា* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ ជាពាក្យឯកវចនៈ ហើយនិយាយសំដៅទៅលើ ការអនុវត្តជំនឿសាសាន៍ដទៃ ។ អ្នកគ្រីស្ទានជំនាន់មុន តែងតែហៅសេចក្ដីជំនឿ និងជីវិតនៃការរស់នៅរបស់គេយ៉ាងច្បាស់ថា"ជាផ្លូវ" (មើល កច ៩:២ ១៩:៩, ២៣ ២២:៤ ២៤:១៤,២២) ។ *ទីសំគាល់នៅលើមេឃ* ព្រះបង្កើតរូបកាយនៅស្ថានសួគ៌ ដោយមានគោលបំណងច្បាស់លាស់ ជាជាងអ្នកដែលថ្វាយបង្គំរូបព្រះ ដោយមិនដឹងអ្វីនោះឡើយ (មើល លប ១:១៤–១៨ និងការពន្យល់) ។ *ដ្បិតសាសន៍ដទៃគេខ្លាចទីសំគាល់ទាំងនោះ* មិនមែនជារូបកាយដែលបានបង្កើតឡើងនៅស្ថានសួគ៌ឡើយ ហើយក៏មិនមែនជាការអស្ចារ្យដែរ (ដូចជា ផ្កាយដុះកន្ទុយ បាតុភូត និងជាសូរ្យគ្រាសឡើយ) ។

**១០:៣** *សុទ្ធតែជាអសារឥតការទទេ* មើលការពន្យល់ ២:៥ ។ *គេកាប់ដើមឈើនៅក្នុងព្រៃ* អស ៤៤:១៤–១៥ ។ ស្នាដៃរបស់មនុស្សកាន់ពូថៅ ពាក្យនេះតែងតែប្រើសំដៅទៅលើអ្នកដែលធ្វើរូបព្រះ ដែលធ្វើការជាធម្មតា ប៉ុន្តែមិនមែនគ្រប់ពេលនោះឡើយ (មើល អស ៤០:១៩) ឈើ (មើល អស ៤១:៧) ។ *ពូថៅ* ធៀបនឹង អស ៤៤:១៣ ។

**១០:៤** *ប្រាក់ និងមាស* រូបព្រះនោះធ្វើពីឈើ ហើយគេតុបតែងវា ដោយដាក់វត្ថុដ៏មានតម្លៃ (មើល អស ៣០:២២ ៤០:១៩) ។ *គេបោះភ្ជាប់ . . . ដើម្បីកុំឱ្យរើទៅឯណា* មើល អស ៤០:២០ ៤១:៧ ធៀបនឹង ៤៦:៧ ធៀបនឹង ១សយ ៥:២–៤ ។

**១០:៥** សារៈសំខាន់នៃរូបព្រះ គឺត្រូវបានគេរៀបរាប់ ក្នុងការបែងចែកជាទម្រង់នៅក្នុង ទដ ១១៥:៤–៧ ១៣៥:១៥–១៨ ។ *ដើមលម៉ើ* នៅក្នុងកំពាព្យទី៧០ នៃសំបុត្ររបស់លោកយេរេមា ដែលបានសរសេរឡើង ត្រូវបានគេប្រើនូវការមើលឃើញដូចគ្នា ។ *រូបទាំងនោះឈរត្រង់* មើល អស ១:៨ និងការពន្យល់ ។ *ហើយត្រូវការឱ្យគេសែងទៅមក* ជាទូទៅវានៅផ្នែកខាងក្រោយនៃសត្វ មើល អស ៤៦:១ ។ *ដ្បិតវាធ្វើអាក្រក់មិនបានទេ ក៏មិនអាចធ្វើល្អបានដែរ* រូបព្រះទាំងនោះមិនអាចធ្វើអ្វីបានទាល់តែសោះ (មើល អស ៤១:២២–២៤) ។

**១០:៦** *គ្មានណា* នៅក្នុងចំណោម (មើល ទដ ៨៥:៨) ។ *ហើយព្រះនាមទ្រង់ក៏មានឥទ្ធានុភាពយ៉ាងខ្លាំងដែរ* មើល ១៦:២១ ។

**១០:៧** *ឱមហាក្សត្រនៃអស់ទាំងសាសន៍អើយ* មើល ទដ ៤៧:៨–៩ និងការពន្យល់ ៩៦:១០ ។ ដែលមិនដូចគ្នាទៅនឹងពូជអំបូរដែលជឿព្រះ ដែលមានព្រំដែនចំពោះទឹកដីរបស់គេ គឺព្រះអម្ចាស់ជាស្ដេចនៅលើគ្រប់អស់ទាំង

ទ្រង់ឡើយ ៨គឺគេសុទ្ធតែជាមនុស្សកំរោល[ណ] ហើយល្ងីល្ងើ[ត]
ឯលទ្ធិរបស់គេជាសេចក្ដីសូន្យសោះ គឺជាដុំឈើទទេ[ថ] ៩គេ
នាំយកប្រាក់ដែលជាផ្ទាំងមកពីស្រុកតើស៊ីស[ទ] និងមាសពីស្រុក
អ៊ូផាស ជាស្នាដៃរបស់ជាងទង និងជាងស្មិត ក៏មានសំពត់
ពណ៌ខៀវ និងពណ៌ស្វាយជាគ្រឿងតែង រូបនោះសុទ្ធតែ
ជាការដែលដៃមនុស្សបានធ្វើទាំងអស់[ធ] ១០តែព្រះយេហូវ៉ា
ទ្រង់ជាព្រះដ៏ពិតវិញ ទ្រង់ជាព្រះដ៏មានព្រះជន្មរស់នៅ[ន]
ក៏ជាមហាក្សត្រដ៏នៅអស់កល្បជានិច្ច[ប] ផែនដីក៏ញ័រ[ផ]ចំពោះ
សេចក្ដីក្រោធរបស់ទ្រង់[ព] ហើយអស់ទាំងសាសន៍មិនអាច
នឹងធន់នៅ ចំពោះសេចក្ដីគ្នាន់ក្នាញ់របស់ទ្រង់បានឡើយ[ភ]
១១ដូច្នេះត្រូវឱ្យប្រាប់គេថា ព្រះទាំងប៉ុន្មានដែលមិនបាន
បង្កើតផ្ទៃមេឃ និងផែនដី នោះនឹងត្រូវវិនាសបាត់[ម]ពីផែន
ដី ហើយពីក្រោមផ្ទៃមេឃទៅ ។
១២ព្រះទ្រង់បានបង្កើត[យ]ផែនដី[រ] ដោយឫទ្ធិតេជះរបស់
ទ្រង់ ទ្រង់បានតាំងលោកីយឡើង ដោយសារប្រាជ្ញា[ល]របស់
ទ្រង់ ហើយបានលាតផ្ទៃមេឃ[វ] ដោយសារយោបល់
១៣កាលណាទ្រង់បញ្ចេញព្រះសៀង[ស] នោះមានទឹកសន្ធឹក
នៅលើមេឃ ទ្រង់ធ្វើឱ្យចំហាយឡើងពីចុងផែនដីទាំងអស់
ក៏បង្កើតផ្លេកបន្ទោរ[ហ] សំរាប់ជូនភ្លៀង[ឡ]មក ហើយ
បញ្ចេញខ្យល់ពីឃ្លាំងរបស់ទ្រង់ផង[អ] ១៤គ្រប់ទាំងមនុស្ស
បានទៅជាកំរោល ហើយឥតមានចំណេះ គ្រប់ទាំងជាងទង
បានត្រូវខ្មាស[ក] ដោយសាររូបដែលគេធ្លាក់ ដ្បិតរូបសិត
របស់គេ ជាសេចក្ដីកំភូតទទេ[ខ] ឥតមានដង្ហើមឡើយ ១៥វា
សុទ្ធតែអសារឥតការ[គ] ជាការបញ្ឆោតហើយ នៅគ្រាដែល
ផ្ចាញ់ផ្ចាល នោះវានឹងវិនាសបាត់ទៅ ១៦ឯព្រះ[ឃ]របស់ពួក
យ៉ាកុប មិនមែនដូចវាទេ គឺទ្រង់ដែលបានបង្កើតរបស់សព្វ
សារពើវិញ[ង] ហើយសាសន៍អ៊ីស្រាអែល ជាពូជអំបូរដែល
ជាមរដក[ច]របស់ទ្រង់ ព្រះនាមទ្រង់ គឺជាព្រះយេហូវ៉ានៃពួក
ពលបរិវារ[ឆ]។

## សេចក្ដីហិនវិនាសដែលត្រូវមកដល់

១៧ឱឯងដែលនៅក្នុងកំឡុង មានទាំងពួកខ្មាំងឡោមព័ទ្ធ
ឯងជុំវិញអើយ ចូរប្រមូលអីវ៉ាន់[ជ]ឯង ចេញពីស្រុកទៅ
១៨ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល ឥឡូវនេះ អញ
នឹងបោះចោល[ឈ]ពួកអ្នកស្រុកនេះចេញ ហើយនឹងធ្វើទុក្ខ[ញ]

**១០:៨** ណ អស ៤៤:១៨ ត អស ៤០:១៩ យរ ៤:២២ ថ ចទ ៣២:២១ **១០:៩** ទ លប ១០:៤ ធ ទដ ១១៥:៤ អស ៤០:១៩ **១០:១០** ន យស ៣:១០ មថ ១៦:១៦ ប លប ២១:៣៣ ដយ ៦:២៦ ផ ពច ៥:៤ យប ៩:៦ ទដ ២៩:៨ ព ទដ ១៨:៧ ភ ទដ ៧៦:៧ យរ ២១:១២ ណហ ១:៦ **១០:១១** ម អស ២:១៨ **១០:១២** យ ១សយ ២:៨ រ ខ.១៦ ល លប ១:៣១ វ លប ១:១,៨ **១០:១៣** ស យប ៣៦:២៩ ហ យប ៣៦:៣០ ឡ ទដ ១០៤:១៣ ១៣៥:៧ អ ចទ ២៨:១២ **១០:១៤** ក ទដ ៩៧:៧ អស ១:២៩ ខ អស ៤៤:២០ **១០:១៥** គ អស ៤១:២៤ យរ ១៤:២២ **១០:១៦** ឃ ចទ ៣២:៩ ទដ ១១៩:៥៧ ង ខ.១២ យរ ៣២:១៧ ៣៣:២ ច នក ៣៤:៩ ទដ ៧៤:២ ឆ យរ ៣១:៣៥ ៣២:១៨ **១០:១៧** ជ អគ ១២:៣–១២ **១០:១៨** ឈ ១សយ ២៥:២៩ អស ២២:១៧ ញ ចទ ២៨:៥២

សាសន៍ ។ *នោះ* ការគោរពយ៉ាងជ្រាលជ្រៅ ។ ពីព្រោះក្នុងបណ្ដាមនុស្សប្រាជ្ញទាំងឡាយ . . . នោះគ្មានអ្នកណាមួយឱ្យដូចជាទ្រង់ឡើយ មើល អស ១៩:១២ ២៩:១៤ ១កថ ១:២០ ។

**១០:៨** *គឺគេសុទ្ធតែមនុស្សកំរោល ហើយល្ងីល្ងើ* មើល ខ.១៤,២១ ៥:២១ មើលការពន្យល់ផងដែរ សភ ១:៧ ។ *ឯលទ្ធិរបស់គេជាសេចក្ដីសូន្យសោះ* ដែលត្រូវជំនួសដោយព្រះអម្ចាស់វិញ (មើល ចទ ១១:២ យប ៥:១៧ សភ ៣:១១ ដែលព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺ "លទ្ធិ" ដែលគេបានបកប្រែថា "ការបង្រៀន" ។ *សេចក្ដីសូន្យ* មើលការពន្យល់ ខ.៣ ។

**១០:៩** *គេនាំយកប្រាក់ . . . មកពីស្រុកតើស៊ីស* មើល អគ ២៧:១២ មើលការពន្យល់ អស ២៣:៦ ។ *អ៊ូផាស* បានបញ្ជាក់នៅទីនេះ ដែលគេមិនបានស្គាល់ទីកន្លែង ។ *ជាស្នាដៃរបស់ជាងទង និងជាងស្មិត* មើល អស ៤០:១៩ និងការពន្យល់ ។ *ក៏មានសំពត់ពណ៌ខៀវ និងពណ៌ស្វាយជាគ្រឿងតែង* ដើម្បីមើលទៅឱ្យដូចជាស្ដេច ។ *ទាំងអស់* សុទ្ធតែជារូបព្រះ ។

**១០:១០** រូបព្រះមិនមែនជាព្រះទេ តែព្រះអម្ចាស់ជាព្រះដ៏ពិត ។ *ដ៏ពិត* មើល ១ថន ១:៩ ។ *ព្រះដ៏ជាព្រះមានព្រះជន្មរស់* សូមមើល ២៣:៣៦ ចទ ៥:២៦ ២ពវ ១៩:៤ និងការពន្យល់ ។ អស់កល្បជានិច្ច សូមមើល នក ១៥:១៨ ទដ ១០:១៦ ២៩:១០ ។ *ចំពោះ . . . សេចក្ដីក្រោធ* សូមមើល ទដ ៩៧:៥ ណហ ១:៥ ។

**១០:១១** មើលការពន្យល់ អត្ថបទភាសាអារ៉ាមីកមួយយ៉ាងធំផ្សេងទៀតនៅព្រះគម្ពីរសញ្ញាចាស់ នៅក្នុង អគ ៤:៨–៦:១៨ ៧:១២–២៦ ដយ ២:៤–៧:២៨ ។ *គេ* ពួកអ្នកថ្វាយបង្គំរូបព្រះ ដែលជាអ្នកយល់ដឹងពីភាសាអារ៉ាមីកជាជាងព្រះគម្ពីរភាសាហេព្រើរ (ភាសានៅកំរិតបាក់ឌុបនៅជំនាន់នោះ) ។ ១០:១២–១៦ បានរំលឹកពាក្យត្រង់ៗ នៅក្នុង ៥១:១៥–១៩ ។

**១០:១២** *ព្រះទ្រង់* ដែលផ្ទុយគ្នាទៅនឹងរូបព្រះ មើល ខ.១១ ។ *ហើយបានលាតផ្ទៃមេឃ* ដូចជាតង់ ឬរនាំងបាំងសាច (មើល ទដ ១០៤:២ អស ៤០:២២ និងការពន្យល់) ។

**១០:១៣** *ទ្រង់ធ្វើឱ្យចំហាយឡើងពីចុងផែនដីទាំងអស់* រំឭកឡើងវិញនៅក្នុង ទដ ១៣៥:៧ ទ្រង់ជាព្រះដ៏ពិត ដែលខុសគ្នានឹងរូបព្រះនោះ (មើល ទដ ១៣៥:៥,១៥–១៧) ធៀបនឹង យប ៣៨:២២ ។

**១០:១៤** *កំរោល* មើល ខ.៨,២១ មើលការពន្យល់ ៤:២២ ។ រូបដែលគេធ្លាក់ ដែលគេធ្វើឡើងពីលោហៈធាតុ ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺត្រូវបានគេបកប្រែថា "រូបព្រះធ្វើពីលង្ហិន" នៅក្នុង អស ៤៨:៥ និង "រូបចម្លាក់សិតឡើងពីលង្ហិន" នៅក្នុង ដយ ១១:៨ ។ *ឥតមានដង្ហើមឡើយ* មើល ទដ ១៣៥:១៧ ។

**១០:១៥** *វាសុទ្ធតែជាអសារឥតការ* មើលការពន្យល់ ខ.៣ ។

**១០:១៦** *ឯព្រះរបស់ពួកយ៉ាកុប* ចំណងជើងអំពីព្រះ គឺត្រូវបានគេប្រើម្ដងទៀត នៅក្នុងតែ ៥១:១៩ (មើល ទដ ៧៣:២៦ និងការពន្យល់ ១១៩:៥៧ ១៤២:៥ បទ ៣:២៤) ។ *ជាពូជអំបូរដែលជាមរដករបស់ទ្រង់* មើល អស ៦៣:១៧ ។ *ព្រះនាមទ្រង់ គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ* មើល ២:១៩ និងការពន្យល់ អស ៥៤:៥ អម ៤:១៣ ។

**១០:១៧–២២** ការបំផ្លាញដល់ពួកអ្នកដែលជាប់ជាឈ្លើយ ។

**១០:១៨** *អញនឹងបោះចោលពួកអ្នកស្រុកនេះចេញ* ដូចជាបោះខ្សែ ។

គេ ឱ្យគេស្គាល់ដៃអញផង ។
១៩វរហើយខ្ញុំ ដោយព្រោះសេចក្ដីឈឺចាប់របស់ខ្ញុំ
របួស[ដ]ខ្ញុំឈឺណាស់ តែខ្ញុំនិយាយថា នេះហើយជាសេចក្ដី
លំបាករបស់ខ្ញុំ ខ្ញុំត្រូវតែទ្រាំទ្រ[ឋ] ២០ត្រសាល[ឌ]ខ្ញុំបានត្រូវ
បំផ្លាញបង់ អស់ទាំងខ្សែក៏ដាច់ចេញហើយ កូនចៅខ្ញុំបាន
ចេញចាកចោលខ្ញុំ ហើយមិននៅទៀតទេ[ឍ] គ្មានអ្នកណា
នឹងដំឡើងត្រសាល ហើយចងរនាំងខ្ញុំទៀតឡើយ ២១ដ្បិត
ពួកអ្នកគង្វាល[ណ] បានត្រឡប់ជាមនុស្សកំរោល[ត]ទាំងអស់
ហើយមិនបានសួរដល់ព្រះយេហូវ៉ាទេ[ថ] ហេតុនោះបានជា
គេមិនបានចំរើន[ទ] ហើយហ្វូងគេទាំងប៉ុន្មានក៏ត្រូវខ្ចាត់ខ្ចាយ
ទៅ[ធ] ២២មានឮសូរសព្ទ ពីការកោលាហលជាខ្លាំង ដែល
ចេញពីស្រុកខាងជើងមក[ន] ដើម្បីនឹងធ្វើឱ្យអស់ទាំងទីក្រុង
នៃស្រុកយូដា ទៅជាទីបំផ្លាញបង់[ប] ជាទីអាស្រ័យរបស់
ចចកវិញ[ផ] ។

## សេចក្ដីអធិស្ឋានរបស់លោកយេរេមា

២៣ឱព្រះយេហូវ៉ាអើយ ទូលបង្គំដឹងថា ផ្លូវរបស់មនុស្ស
មិនស្រេចនៅខ្លួនគេទេ ហើយដែលដំរង់ជីហានរបស់ខ្លួន
នោះក៏មិនស្រេចនៅមនុស្សដែលដើរដែរ[ព] ២៤ឱព្រះយេ–
ហូវ៉ាអើយ សូមផ្ចាលទូលបង្គំចុះ តែគឺតាមសេចក្ដីទៀង
ត្រង់ មិនមែនដោយសេចក្ដីខ្ញាល់[ភ]របស់ទ្រង់ឡើយ ក្រែង
ទ្រង់ធ្វើឱ្យទូលបង្គំសាបសូន្យទៅ[ម,យ] ២៥សូមទ្រង់ចាក់សេចក្ដី
ក្រោធរបស់ទ្រង់ ទៅលើសាសន៍ដទៃ[រ]ទាំងប៉ុន្មាន ដែលមិន
ស្គាល់ទ្រង់វិញ ហើយទៅលើអស់ទាំងគ្រួមនុស្ស ដែលមិន
អំពាវនាវ ដល់ព្រះនាមទ្រង់ផង[ល] ដ្បិតគេបានត្របាក់លេប
ពួកយ៉ាកុប អើ គេបានត្របាក់លេប[វ] ព្រមទាំងរំលីងអស់
ទៅផង ហើយបានទាំងបំផ្លាញទីលំនៅរបស់គេដែរ[ស]។

## ការបំពានសេចក្ដីសញ្ញា

**១១** ១នេះជាព្រះបន្ទូលដែលមកពីព្រះយេហូវ៉ា ដល់
យេរេមាថា ២ចូរស្តាប់អស់ទាំងពាក្យនៃសេចក្ដីសញ្ញា[ក]នេះ
ចុះ រួចនិយាយដល់ពួកមនុស្សនៅស្រុកយូដា និងនៅក្រុង
យេរូសាឡិម ៣ប្រាប់គេថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ ត្រូវបណ្តាសា[ខ]ហើយ
មនុស្សណា ដែលមិនស្តាប់តាមអស់ទាំងពាក្យនៃសេចក្ដី
សញ្ញានេះ ៤គឺជាសេចក្ដី ដែលអញបានបង្គាប់ដល់ពួក
ឰយុកោឯងរាល់គ្នា នៅថ្ងៃដែលអញនាំគេចេញពីស្រុក

**១០:១៩** ដ យបប ៣៤:៦ យរ ១៤:១៧ ១៥:១៨ ៣០:១២,១៥ បទ ២:១៣ មីក ១:៩ ណាហ ៣:១៩ ឋ មីក ៧:៩ **១០:២០** ឌ យរ ៤:២០ ឍ យរ ៣១:១៥ បទ ១:៥ **១០:២១** ណ យរ ២២:២២ ២៣:១ ២៥:៣៤ ៥០:៦ ត ខ.៨ ថ អស ៥៦:១០ ទ យរ ២០:៣០ ធ យរ ២៣:២ អគ ៣៤:៦ **១០:២២** ន យរ ៦:២២ ២៧:៦ ៤៩:២៨,៣០ ប អគ ១២:១៩ ផ អស ៣៤:១៣ **១០:២៣** ព យបប ៣៣:២៩ សភ ៣:៥–៦ ២០:២៤ **១០:២៤** ភ ទដ ៦:១ ៣៨:១ យរ ៧:២០ ១៨:២៣ ម យរ ៤៦:២៨ យ យរ ៣០:១១ **១០:២៥** រ ទដ ៦៩:២៤ សផ ២:២ ៣:៨ ល ទដ ១៤:៤ វ ទដ ៧៩:៧ យរ ២:៣ ស ទដ ៧៩:៦–៧ **១១:២** ក ចទ ៥:២ **១១:៣** ខ ចទ ១១:២៦–២៨ ២៧:២៦ ២៨:១៥–៦៨ កទ ៣:១០

**១០:១៩–២០** ក្នុងនាមឱ្យប្រជាជនរបស់គាត់ ហោរាបានយំដោយព្រោះអំពើបាបរបស់គេ (មើល ៤:១៩–២១) ។

**១០:២០** *កូនចៅខ្ញុំ* ប្រជាជនយូដា និងក្រុងយេរូសាឡិម (លោកយេរេមា មិនដែលបានរៀបការ ឬមានកូនឡើយ មើល ១៦:២) ។ ត្រសាល មើលការពន្យល់ ៤:២០ ។

**១០:២១** *ដ្បិតពួកអ្នកគង្វាល . . . ហ្វូងគេទាំងប៉ុន្មាន* អ្នកគ្រប់គ្រង និងប្រជាជន(មើលការពន្យល់ ២:៨) ។ *មនុស្សកំរោលទាំងអស់* មើល ខ.៨,១៤ មើលការពន្យល់ ៤:២២ ។ *មិនបានសួរដល់ព្រះយេហូវ៉ាទេ* ជំនួសគេបានសួរពីរូបកាយនៅស្ថានសួគ៌ (មើល ៨:២) ។ *ក៏ត្រូវខ្ចាត់ខ្ចាយ* ទៅ មើលការពន្យល់ ៩:១៦ ។

**១០:២២** *មានឮសូរសព្ទ ពីការកោលាហលជាខ្លាំង* នេះជាសូរសំលេងពួកឈ្លានពាន (មើល ៦:២៣ ៨:១៦) ។ *ដែលចេញពីស្រុកខាងជើងមក* ពួកបាប៊ីឡូន (មើល ៤:៦ ៦:២២ មើលការពន្យល់ផងដែរ អស ៤១:២៥) ។ *ជាទីអាស្រ័យរបស់ចចកវិញ* មើល ៩:១១ និងការពន្យល់ ។

**១០:២៣–២៥** ហោរាអធិស្ឋាន ក្នុងនាមឱ្យប្រជាជនសម្រាប់សេចក្ដីយុតិធម៌។

**១០:២៣** មានតែព្រះអម្ចាស់តែមួយគត់ ដែលអាចដំរង់ទិសដៅ នៃផ្លូវរបស់ប្រជាជន (មើល ទដ ៣៧:២៣ សភ ១៦:៩ និងការពន្យល់) ។

**១០:២៥** ការរំឭកពាក្យដែលនិយាយចំៗឡើងវិញ នៅក្នុង ទដ ៧៩:៦–៧ ៧៩:១–៥) បង្ហាញថា សេចក្ដីអធិស្ឋាន មិនមែនជាការអធិស្ឋានដោយមានគំនុំនោះឡើយ តែជាសេចក្ដីអធិស្ឋាន បង្ហាញពីសេចក្ដីយុតិធម៌របស់ព្រះ (មើលការពន្យល់ ៥:១០) ។ ពួកយូដាបានអានខនេះជាប្រចាំឆ្នាំ នៅចំថ្ងៃពិធីបុណ្យរំលង ។

**១១:១–១៣:២៧** ដោយសារការរំលោភបំពាននូវការតាំងសញ្ញារបស់ពួកយូដា ដែលជាកាតព្វកិច្ចគេ នោះប្រជាជននឹងត្រូវចាប់ទៅជាឈ្លើយនៅបាប៊ីឡូន វគ្គនេះប្រហែលជាចំថ្ងៃ នៃគ្រងរាជ្យស្តេចយូសៀស (ប៉ុន្តែមើលការពន្យល់ ១៣:១៨) ។

**១១:១–១៧** រាស្ត្ររបស់ព្រះ បានធ្វើឱ្យខូចការតាំងសញ្ញារបស់គេជាមួយនឹងព្រះ ។

**១១:២** *ចូរស្តាប់* មើលការពន្យល់ ២:៤ ។ អស់ទាំងពាក្យ ន័យចំ "ពាក្យ" ពាក្យបច្ចេកទេស គឺកិច្ចព្រមព្រៀងការតាំងសញ្ញា (មើល ខ.៣–៤,៦ ៣៤:១៨ មើលការពន្យល់ នក ២០:១) ។ សេចក្ដីសញ្ញានេះ មើល ខ.៣,៦, ៨,១០ ចទ ២៩:៩ ដោយយោងទៅលើសេចក្ដីតាំងសញ្ញា ដែលបង្កើតឡើងរវាងព្រះ និងពួកអ៊ីស្រាអែល តាមរយៈលោកម៉ូសេ នៅភ្នំស៊ីណាយ (មើល ខ.៤ នក ១៩–២៤) ។ ការអាននូវការតាំងសញ្ញានៅចំពោះមុខបណ្តាជនជាធម្មតា និងការអនុវត្តចាំបាច់នោះ (មើល ចទ ៣១:១០–១៣ យក ៨:៣៤–៣៥) ។

**១១:៣** *ត្រូវបណ្តាសាហើយមនុស្សណា* ឃ្លានេះឃើញមានការចាប់ផ្តើមខរាល់ការតាំងសញ្ញានៅក្នុង ចទ ២៧:១៥–២៦ ហើយបណ្តាជនគេឆ្លើយឡើងជារៀងរាល់ខ ពាក្យបណ្តាសានោះថា "អាម៉ែន" មានពរហើយអស់អ្នកដែលធ្វើតាមសេចក្ដីសញ្ញានេះ (មើល ចទ ២៨:១–១៤) និងត្រូវបណ្តាសាហើយអ្នកដែលមិនធ្វើតាមសេចក្ដីសញ្ញានេះ (មើល ចទ ២៨:១៥–៦៨ មើលផងដែរ ចទ ១១:២៦–២៨ ២៩:២០–២១) ។

អេស៊ីព្ទមក[គ] គឺចេញរួចពីគុកភ្លើងរំលាយដែក[ឃ]ដោយប្រាប់
គេថា ចូរស្តាប់[ង]ពាក្យរបស់អញ ហើយប្រព្រឹត្តតាមផង គឺ
តាមគ្រប់ទាំងសេចក្តី ដែលអញបង្គាប់ ដល់ឯងរាល់គ្នាចុះ
យ៉ាងនោះ ឯងរាល់គ្នានឹងបានជារាស្ត្ររបស់អញ[ច] ហើយ
អញនឹងធ្វើជាព្រះរបស់ឯង ៥ដើម្បីឱ្យអញបានធ្វើសំរេច[ឆ]
ឯងរាល់គ្នាថា នឹងឱ្យគេបានស្រុកដែលមានទឹកដោះ និង
ទឹកឃ្មុំ[ជ]ហូរហៀរ ដូចជាយ៉ាងសព្វថ្ងៃនេះ នោះខ្ញុំក៏ទូល
ឆ្លើយថា អាម៉ែន[ឈ] ព្រះយេហូវ៉ាអើយ ។
៦រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំថា ចូរប្រកាស
ប្រាប់[ញ]អស់ទាំងពាក្យនេះ នៅក្នុងទីក្រុងទាំងប៉ុន្មានរបស់
ស្រុកយូដា ហើយនៅផ្លូវទាំងប៉ុន្មាននៃក្រុងយេរូសាឡិម
ដែរថា ចូរស្តាប់អស់ទាំងពាក្យនៃសេចក្តីសញ្ញានេះ ហើយ
ប្រព្រឹត្តតាម[ដ]ចុះ ៧ដ្បិតនៅថ្ងៃដែលអញបាននាំពួកឰយុកោ
ឯងរាល់គ្នាឡើងរួចពីស្រុកអេស៊ីព្ទ ដរាបមកដល់សព្វថ្ងៃ
នេះ នោះអញបាននិយាយយ៉ាងម៉ឺងម៉ាត់ដល់គេ ព្រមទាំង
ខ្នះខ្នែងប្រាប់គេ តាំងពីព្រលឹមស្រាងថា[ឋ] ចូរស្តាប់តាម
ពាក្យអញចុះ ៨តែគេមិនបានស្តាប់តាមទេ ក៏មិនបាន
ផ្ទៀងត្រចៀកផង[ឌ] គឺបានប្រព្រឹត្តតាមតែសេចក្តីរឹងចចេស
នៅក្នុងចិត្តអាក្រក់របស់គេរៀងខ្លួនវិញ[ឍ] ហេតុនោះអញ
បាននាំគ្រប់ទាំងពាក្យ[ណ]នៃសេចក្តីសញ្ញានេះមកលើគេ គឺ
ជាសេចក្តីដែលអញបានបង្គាប់ឱ្យគេប្រព្រឹត្តតាម តែគេមិន
បានប្រព្រឹត្តតាមសោះ[ត] ។
៩រួចព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំថា ឃើញមាន
គំនិតគិតក្បត់[ថ]កើតឡើង នៅក្នុងពួកមនុស្សនៅស្រុកយូដា
ហើយនៅក្រុងយេរូសាឡិមដែរ ១០គេបានវិលត្រឡប់ទៅ

**១១:៤** គ ខ.៧ ឃ ១ពវ ៨:៥១ ង នក ២៤:៨ យរ ៧:២៣ ច យរ ៧:២៣ ៣១:៣៣ អគ ១១:២០ **១១:៥** ឆ នក ៦:៨ ១៣:៥ ចទ ៧:១២ ទដ ១០៥:៨-១១ ជ នក ៣:៨ ឈ ចទ ២៧:២៦ **១១:៦** ញ យរ ៤:៥ ដ នក ១៥:២៦ ចទ ១៥:៥ យក ១:២២ **១១:៧** ឋ ២របា ៣៦:១៥ **១១:៨** ឌ យរ ៧:២៦ ឍ សស ៩:៣ យរ ៣:១៧ ណ លវ ២៦:១៤-៤៣ ចទ ២៨:១៥-៦៨ យស ២៣:១៥ ត ២របា ៧:១៩ ទដ ៧៨:១០ យរ ២៦:៤ ៣២:២៣ ៤៤:១០ **១១:៩** ថ អគ ២២:២៥ **១១:១០** ទ ចទ ៩:៧ ២របា ៣០:៧ ធ សក ៧:១១ ន ពច ២:១២-១៣ ១០:១៣ ប យរ ១៦:១១ អគ ២០:៨

តាមអំពើទុច្ចរិតរបស់ពួកឰយុកោគេ[ទ] ដែលមិនព្រមស្តាប់
តាមពាក្យអញ[ធ] គេបានទៅតាមព្រះដទៃផ្សេងៗ[ន] ដើម្បីនឹង
គោរពវារិញ[ប] ពួកវង្សអ៊ីស្រាអែល និងពួកវង្សយូដាបាន
ផ្តាច់សេចក្តីសញ្ញា[ផ] ដែលអញបានតាំងនឹងពួកឰយុកោគេ
ហើយ ១១ហេតុនោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
មើល អញនឹងនាំសេចក្តីអាក្រក់[ព]មកលើគេ ជាសេចក្តី
ដែលគេមិនអាចនឹងគេចរួចចេញបានឡើយ[ភ] នោះគេនឹង
អំពាវនាវ[ម]ដល់អញ តែអញនឹងមិនព្រមស្តាប់[យ]ទេ ១២ទីក្រុង
ស្រុកយូដាទាំងប៉ុន្មាន និងពួកអ្នកនៅក្រុងយេរូសាឡិម គេ
នឹងទៅអំពាវនាវដល់ព្រះ ដែលគេបានដុតកំញានថ្វាយ
នោះ[រ] តែព្រះទាំងនោះនឹងមិនជួយដោះគេឱ្យរួច ក្នុងគ្រា
វេទនា[ល]របស់គេឡើយ ១៣ដ្បិត ឱពួកយូដាអើយ ចំនួនព្រះ[វ]
របស់ឯង នោះប្រមាណស្មើនឹងទីក្រុងទាំងប៉ុន្មានរបស់ឯង
ដែរ ហើយដែលមានផ្លូវនៅក្រុងយេរូសាឡិមប៉ុណ្ណា[ស]នោះ
ឯងក៏បានស្អាងអាសនាថ្វាយដល់របស់គួរខ្មាស[ហ]នោះ ចំនួន
ប៉ុណ្ណោះដែរ គឺជាអាសនាសំរាប់ដុតកំញាន[ឡ]ថ្វាយដល់ព្រះ
បាលផង ។
១៤ដូច្នេះ កុំឱ្យអធិស្ឋាន[អ]ឱ្យជនជាតិនេះឡើយ ក៏កុំឱ្យ
ឡើងសំឡេងអំពាវនាវ ឬអង្វរឱ្យគេដែរ ដ្បិតនៅគ្រាដែល
គេអំពាវនាវដល់អញ ដោយកើតមានសេចក្តីវេទនា នោះ

ផ អស ២៤:៥ យរ ៣៤:១៨ ហស ៦:៧ ៨:១ **១១:១១** ព ២ពវ ២២:១៦ យរ ៤:៦ ភ យប ១១:២០ បទ ២:២២ ម យប ២៧:៩ យរ ១៤:១២ អគ ៨:១៨ មឡ ២:១៣ យ ខ.១៤ ទដ ៦៦:១៨ សភ ១:២៨ អស ១:១៥ ៥៩:២ អគ ៨:៨ សក ៧:១៣ **១១:១២** រ ចទ ៣២:៣៨ យរ ៤៤:១៧ ល ចទ ៣២:៣៧ ពច ១០:១៤ **១១:១៣** វ នក ២០:៣ យរ ១៩:៤ ស ២ពវ ១៧:២៩ ហ យរ ៣:២៤ ឡ យរ ៧:៩ ៤៤:២១ **១១:១៤** អ នក ៣២:១០ ក ខ.១១

**១១:៤** *នៅថ្ងៃដែលអញបាននាំគេចេញពីស្រុកអេស៊ីព្ទមក គឺចេញរួចពីគុកភ្លើងរំលាយដែក* មើលការពន្យល់ ចទ ៤:២០ ។ *ចូរស្តាប់តាមពាក្យអញ* មើល ខ.៧ ៧:២៣ នក ១៩:៥ ។ *ឯងរាល់គ្នានឹងបានជារាស្ត្ររបស់អញ ហើយអញនឹងធ្វើជាព្រះរបស់ឯង* មើលការពន្យល់ ៧:២៣ ។

**១១:៥** *នឹងឱ្យគេបានស្រុកដែលមានទឹកដោះ និងទឹកឃ្មុំហូរហៀរ* មើល ៣២:២២ មើលការពន្យល់ផងដែរ នក ៣:៨ ។ អាម៉ែន មើលការពន្យល់ ខ.៣ ។ *ដើម្បីឱ្យអញបានធ្វើសំរេចតាមសេចក្តីសម្បថ* មើល លប ១៥:១៧-១៨ និងការពន្យល់ ចទ ៧:៨ ។

**១១:៦** ចូរប្រកាសប្រាប់ មើល ២:២ ៣:១២ ។

**១១:៧** តាំងពីព្រលឹមស្រាង មើលការពន្យល់ ៧:១៣ ។

**១១:៨** មើល ៧:២៤ ។ *គឺបានប្រព្រឹត្តតាមសេចក្តីរឹងចចេស នៅក្នុងចិត្តអាក្រក់របស់គេរៀងខ្លួនវិញ* មើលការពន្យល់ ៣:១៧ ។ *គ្រប់ទាំងពាក្យនៃសេចក្តីសញ្ញានេះ* មើលការពន្យល់ ខ.៣ ។ មកលើគេ សូមមើល ២ពវ ១៧:១៨-២៣ ។

**១១:៩** *គំនិតគិតក្បត់* នេះជាការប្រឆាំង១ នៅពេលដែលស្តេចយ៉ូសៀសមានការកែទម្រង់ (មើលសេចក្តីផ្តើម ប្រវត្តិដើម និងមើលការពន្យល់ផងដែរ ១:២) ។

**១១:១០** *ដែលមិនព្រមស្តាប់តាម* គេមិនខ្លាចក្នុងការធ្វើបាប (មើលការពន្យល់ ៩:៦) ។ សេចក្តីសញ្ញា ន័យត្រង់ "សេចក្តីសញ្ញារបស់អញ" ដោយសង្កត់ទៅលើព្រះ ។

**១១:១១** *អញនឹងនាំសេចក្តីអាក្រក់មកលើគេ* ពួកយូដានឹងទទួលនូវការជិនុំជម្រះ ដូចជាពួកអ៊ីស្រាអែល បានទទួលនូវការជិនុំជម្រះ ដូចជានៅកាលពីជំនាន់ដើមដែរ (មើល ខ.១០ មើលផងដែរ ២ពវ ១៧:១៨-២៣) ។

**១១:១២** *ដែលគេបានដុតកំញានថ្វាយនោះ* មើល ខ.១៣,១៧ មើលការពន្យល់ ១:១៦ ។

**១១:១៣** *ចំនួនព្រះរបស់ឯង នោះប្រមាណស្មើនឹងទីក្រុងទាំងប៉ុន្មានរបស់ឯងដែរ* មើលការពន្យល់ ២:២៨ ។ *ហើយដែលមានផ្លូវនៅទីក្រុងទាំងប៉ុណ្ណា* មើល ២របា ២៨:២៤ ។ *ថ្វាយដល់របស់គួរខ្មាសនោះ* មើល ៣:២៤ មើលការពន្យល់ផងដែរ ២:២៦ ពច ៦:៣២ ។

**១១:១៤** *កុំឱ្យអធិស្ឋានឱ្យជនជាតិនេះឡើយ* មើលការពន្យល់ ៧:១៦ ធៀបនឹង

អញមិនព្រមស្តាប់[ក]គេទេ ១៥តើស្ងួនសំឡាញ់របស់អញមាន
ការអ្វីនៅក្នុងផ្ទះអញទៀត ដ្បិតនាងបានប្រព្រឹត្តអំពើដ៏
លាមកអាក្រក់ ជាមួយនឹងមនុស្សជាច្រើនទៅហើយ ឯ
សាច់[ខ]ដែលបានញែកជាបរិសុទ្ធ នោះនឹងបាត់ពីមុខឯង
ទៅ[គ] កាលណាឯងប្រព្រឹត្តអំពើអាក្រក់ នោះឯងមានចិត្ត
រីករាយ ១៦ព្រះយេហូវ៉ាទ្រង់បានដាក់ឈ្មោះឱ្យឯងថា ដើម
អូលីវខ្ចី[ឃ] ជាដើមល្អមើល មានផ្លែដ៏ល្អ តែទ្រង់បានបង្កាត់
ភ្លើងបញ្ឆេះអស់ទៅ[ង] ដោយសូរគ្រាំគ្រាយ៉ាងខ្លាំង ហើយ
មែកវាត្រូវបាក់អស់[ច] ១៧ដ្បិតព្រះយេហូវ៉ានៃពួកពលបរិវារ
ដែលបានដាំ[ឆ]ឯង ទ្រង់បានប្រកាសសេចក្តីអាក្រក់[ជ]ទាស់
នឹងឯង ដោយព្រោះអំពើអាក្រក់របស់ពួកវង្សអ៊ីស្រាអែល
នឹងពួកវង្សយូដា ជាការដែលគេបានប្រព្រឹត្តដល់ខ្លួនគេ
ដោយបណ្តាល[ឈ]ឱ្យអញខឹង ព្រោះការដែលដុតកំញាន
ថ្វាយដល់ព្រះបាល[ញ]។

## គម្រោងការណ៍ទាស់នឹងលោកយេរេមា

១៨ព្រះយេហូវ៉ា ទ្រង់បានសំដែង ឱ្យខ្ញុំដឹងពីការនេះ
ទ្រង់បានបង្ហាញឱ្យខ្ញុំឃើញកិរិយារបស់គេ ១៩ឯខ្ញុំបានដូច
ជាកូនចៀមស្លូត ដែលគេនាំទៅឯទីសំឡាប់[ដ] ខ្ញុំមិនបាន
ដឹងជាគេគិតឧបាយ[ឋ]ទាស់នឹងខ្ញុំសោះ គេថា ចូរយើង
បំផ្លាញទាំងដើមនឹងផលផង ចូរយើងកាត់វាចេញពីស្ថាន
របស់មនុស្សរស់ទៅ[ឌ] ដើម្បីមិនឱ្យអ្នកណានឹកចាំ[ឍ]ពីឈ្មោះ

**១១:១៥** ខ ហាក ២:១២ គ យរ ៧:៩-១០
**១១:១៦** ឃ ទដ ១:៣ ហស ១៤:៦ ង យរ ៧:២០ ២១:១៤ ច អស ២៧:១១ រម ១១:១៧-២៤
**១១:១៧** ឆ នក ១៥:១៧ អស ៥:២ យរ ១២:២ ៤៥:៤ ជ ខ.១១ ឈ យរ ៧:១៨ ញ យរ ៧:៩
**១១:១៩** ដ ទដ ៤៤:២២ ឋ ខ.២១ ទដ ៤៤:១៦ ៥៤:៣ ៧១:១០ យរ ១៨:១៨ ២០:១០ ឌ យប ២៨:១៣ ទដ ១១៦:៩ អស ៥៣:៨ ឍ ទដ ៨៣:៤
**១១:២០** ណ ទដ ៧:១១ ត ១សយ ២:៣ ១របា ២៩:១៧ ថ ទដ ២៦:២ ទ ទដ ៥៨:១០ បទ ៣:៦០

វាទៀតឡើយ ២០តែ ឱព្រះយេហូវ៉ានៃពួកពលបរិវារ ជា
ព្រះដែលជំនុំជំរះដោយសុចរិត[ណ] ហើយក៏ល្បងលចិត្ត[ត]និង
គំនិត[ថ] អើយ ទូលបង្គំនឹងឃើញទ្រង់សងសឹក[ទ]ដល់គេជាមិន
ខាន ដ្បិតទូលបង្គំបានសំដែងដើមហេតុរបស់ទូលបង្គំថ្វាយ
ទ្រង់ជ្រាបហើយ ២១ហេតុនោះព្រះយេហូវ៉ាទ្រង់មានបន្ទូល
ពីដំណើរពួកមនុស្ស នៅក្រុងអាន៉ាថោត[ធ] ដែលរកជីវិត[ន] ខ្ញុំ
ដោយពោលថា មិនត្រូវឱ្យឯងទាយ[ប]ដោយនូវព្រះនាម
ព្រះយេហូវ៉ាទៀតឡើយ ក្រែងឯងស្លាប់[ផ]ដោយដៃរបស់
យើង ២២គឺហេតុនោះបានជាព្រះយេហូវ៉ា ជាព្រះនៃពួក
ពលបរិវារទ្រង់មានបន្ទូលដូច្នេះថា មើល អញនឹងធ្វើ
ទោសគេ ពួកកំឡោះៗ[ព]នឹងស្លាប់ដោយដាវ ពួកកូនប្រុសកូន
ស្រីរបស់ គេនឹងស្លាប់ដោយអំណត់អត់ ២៣ហើយនឹងគ្មាន
សំណល់សល់[ភ]ដល់គេឡើយ ដ្បិតនៅឆ្នាំដែលអញនឹងធ្វើ
ទោសដល់ពួកក្រុងអាន៉ាថោត នោះអញនឹងនាំសេចក្តី
អាក្រក់មកលើគេជាពិត[ម]។

## លោកយេរេមាបង្ហាញពីការមិនពេញចិត្ត

**១២** [១]ឱព្រះយេហូវ៉ាអើយ កាលណាទូលបង្គំជជែកត[ក]នឹង
ទ្រង់ នោះទ្រង់សុចរិតទេ[ខ] ប៉ុន្តែទូលបង្គំចង់តែទូលពិភាក្សា

**១១:២១** ធ យស ២១:១៨ ន ខ.១៩ យរ ១២:៦ ២១:៧ ៣៤:២០ ប អស ៣០:១០ ផ យរ ២:៣០ ១៨:២៣ ២៦:៨,១១ ៣៨:៤ **១១:២២** ព អស ៩:១៧ យរ ១៨:២១ **១១:២៣** ភ យរ ៦:៩ ម យរ ២៣:១២ **១២:១** ក យប ៥:៨ ខ អគ ៩:១៥ យប ៨:៣ ដយ ៩:១៤

១យហ ៥:១៦ ។

**១១:១៥** មើល ៧:១០-១១,២១-២៤ ។ *តើស្ងួនសំឡាញ់របស់អញ* យូដា (មើល ១២:៧ ធៀបនឹង ចទ ៣៣:១២ នៅពេលដែលពួកបេនយ៉ាមីន គឺបានហៅថា "ស្ងួនសំឡាញ់របស់ព្រះអម្ចាស់") ។

**១១:១៦** *បានដាក់ឈ្មោះឱ្យឯងថា* ដើមអូលីវខ្ចី មើល ទដ ៥២:៨ ១២៨:៣ ។ ព្យុះ ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ មាននៅកន្លែងផ្សេងទៀតនៅក្នុង អគ ១:២៤ ដែលគេបានបកប្រែថា "ការច្រួលច្របល់" គឺសំដៅទៅលើ សំឡេងច្រួលច្របល់ ដែលធ្វើឡើងដោយពួកទាហាន (មើល អស ១៣:៤) ។ *ហើយមែកវាត្រូវបាក់អស់* មើល អគ ៣១:១២ ។

**១១:១៧** បានចប់សព្វគ្រប់ នៅពេលដែលពួកយូដាត្រូវបានបំផ្លាញ នៅក្នុងឆ្នាំមុន ៥៨៦ គ.ស (មើល ៤៤:២-៣) ។ *ដោយបណ្តាលអញឱ្យខឹង* មើល ៨:១៩ ចទ ៣១:២៩ ។

**១១:១៨-២៣** នេះជាផ្នែកទី៦ លើកដំបូង "ការលន់តួបាប"(មើលសេចក្តីផ្តើម អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។

**១១:១៨** របស់គេ ខ្មាំងសត្រូវផ្ទាល់ខ្លួនរបស់លោកយេរេមា "មនុស្សក្រុងអានាថោត"នៅឯស្រុករបស់គាត់ (ខ.២១,២៣) ។

**១១:១៩** *ឯខ្ញុំបានដូចជាកូនចៀមស្លូត* មើល ៥១:៤០ មើលការពន្យល់ អស ៥៣:៧ និងការពន្យល់ ។ *ចូរយើងបំផ្លាញទាំងដើមឈើ និងផលផង* ខុសគ្នានៅក្នុង ១២:២ ។ *ចូរយើងកាត់វាចេញពីស្ថានរបស់មនុស្សរស់ទៅ* មើល អស ៥៣:៨ ធៀបនឹង ទដ ២៧:១៣ ។ ឈ្មោះនៅពេលដែលលោកយេរេមាគ្មានកូននោះ ឈ្មោះរបស់គាត់បានបាត់ទៅផងដែរ (សូមមើល ១៦:២) ។ *ដើម្បីមិនឱ្យអ្នកណានឹកចាំពីឈ្មោះវាទៀតឡើយ* នៅពេលដែលគេធ្វើបាប (មើល យប ២៤:២០ អគ ២១:៣២) ។

**១១:២០** រំឭកឡើងវិញ ពីពាក្យត្រង់ នៅក្នុង ២០:១២ និងមើល ១៧:១០ ។ *ដែលជំនុំជម្រះដោយសុចរិត* មើលការពន្យល់ លប ១៨:២៥ ។

**១១:២១** *ពីដំណើរពួកមនុស្សនៅក្រុងអាន៉ាថោត ដែលរកជីវិតខ្ញុំ* មើល ១២:៦ "មនុស្សដែលជាខ្មាំងសត្រូវគាត់ គឺជាមនុស្សនៅក្នុងគ្រួសារគាត់" (មីក ៧:៦ បានដកស្រង់ដោយ ព្រះយេស៊ូវ នៅក្នុង មថ ១០:៣៦ )។

**១១:២២** *ដាវ. . . អំណត់អត់* មើលការពន្យល់ ៥:១២ ។

**១១:២៣** *សំណល់សល់* មើល ៦:៩ អស ១០:២០-២២ និងការពន្យល់ ។ *គេ* អ្នករួមគំនិតក្បត់នៅក្រុងអាន៉ាថោត មិនមែនជាក្រុមមនុស្សមានប្រជាប្រិយឡើយ ដែលមានចំនួន១២៨នាក់ បានវិលត្រឡប់ទៅឯទីក្រុងរបស់គេវិញក្រោយពីគេបានវិលពីការចាប់ជាឈ្លើយនោះ (មើល អគ ២:២៣) ។

**១២:១-៤** នេះជាការ "ការលន់តួ "លើកទី២របស់យេរេមា (មើលសេចក្តីផ្តើម អ្នកនិពន្ធ និងកាលបរិច្ឆេទ) កំពុងបន្ត និងកាន់តែជិតស្និទ្ធទៅនិងផ្នែកដំបូង (១១:១៨-២៣) ។ លោកយេរេមានិយាយនៅក្នុង ខ.១-៤ ហើយព្រះឆ្លើយតបនៅក្នុង ខ.៥-៦ ។

**១២:១** *នោះទ្រង់សុចរិត* មើលការពន្យល់ លប ១៨:២៥ មើលផងដែរ

នឹងទ្រង់ ពីដើមហេតុនៃការណ៍ថា[គ] ហេតុអ្វីបានជាដំណើរ
របស់មនុស្សអាក្រក់តែងតែចំរើនឡើង[ឃ] ហេតុអ្វីបានជា
ពួកអ្នកដែលប្រព្រឹត្តដោយកំបត់ បានទៅជាឥតកង្វល់ ដូច្នេះ
២ ទ្រង់បានដាំ[ង]គេ អើ គេចាក់ឫសចុះ ហើយក៏ធំឡើង អើ
គេកើតផលផង[ច] គេយកទ្រង់មកផ្ទាល់នៅមាត់ តែឱ្យទ្រង់
នៅឆ្ងាយពីចិត្តគេវិញ[ឆ] ៣ តែឱព្រះយេហូវ៉ាអើយ ទ្រង់ស្គាល់
ទូលបង្គំហើយ ទ្រង់ក៏ឃើញ ហើយល្បងល[ជ] ចិត្តទូលបង្គំ
ដែលនៅជិតទ្រង់ជាយ៉ាងណា សូមទ្រង់ ចាប់កញ្ឆក់គេទៅ
ដូចជាចៀម[ឈ] ដែលសំរាប់នាំទៅសំឡាប់ ហើយដំរូវគេទុក
ដល់ថ្ងៃកាប់សំឡាប់[ញ] ៤ ស្រុកនេះនឹងត្រូវសោយសោក[ដ]
ហើយតិណជាតិទាំងឡាយនៅពេញស្រុក ត្រូវស្វិតក្រៀម
ទៅដល់កាលណាទៀត[ឋ] សត្វជើង៤ និងសត្វស្លាប់ទាំង
ប៉ុន្មាន ត្រូវវិនាសបាត់ទៅ[ឌ] ដោយព្រោះអំពើអាក្រក់របស់
ពួកអ្នកដែលនៅក្នុងស្រុកនេះ ដ្បិតគេ និយាយថា ព្រះនឹង
មិនឃើញចុងបំផុតរបស់យើងឡើយ ។

**បន្ទូលតបរបស់ព្រះអម្ចាស់**

៥ បើឯងបានរត់ជាមួយនឹងពួកថ្មើរជើង ហើយគេបាន
នាំឱ្យឯងអស់កំឡាំង ដូច្នេះ ធ្វើដូចម្តេចឱ្យឯងប្រណាំង
នឹងសេះបាន ហើយបើនៅក្នុងស្រុកដ៏មានសន្តិសុខ ឯងមិន
សូវមានសេចក្តីសុខទេ នោះតើឯងនឹងធ្វើដូចម្តេច ក្នុង
កាលដែលទន្លេយ័រដាន់ជន់ពេញកំឡាំង[ឍ]ឡើង ៦ ដ្បិតទោះ
ទាំងពួកបងប្អូនឯង និងពួកគ្រូឪពុកឯង ក៏បានប្រព្រឹត្ត
ដោយកំបត់នឹងឯងដែរ គេបានស្រែកហៅយ៉ាងខ្លាំងតាម
ក្រោយឯងផង[ណ] តែទោះបីនិយាយពាក្យស្រួលល្អក៏ដោយ
គង់តែ មិនត្រូវជឿតាមគេឡើយ[ត] ។
៧ អញបានលះលែង[ថ]គ្រួសាររបស់អញហើយ ក៏បាន
បោះបង់ចោល[ទ]មរដករបស់អញដែរ ឯអ្នកស្ងួនសំឡាញ់[ធ]
នៃដួងចិត្តអញ នោះបានប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួក
ខ្មាំងសត្រូវផង[ន] ៨ ពួកដែលជាមរដករបស់អញ គេបាន
ត្រឡប់ដូចជាសិង្ហ[ប]នៅក្នុងព្រៃដល់អញ គេបានបញ្ចេញ
សំឡេងទាស់នឹងអញ ហេតុនោះបានជាអញស្អប់គេ[ផ] ៩ ពួក

**១២:១** គ អគ ១៨:២៥ ឃ យប ២១:៧,១៣ ទដ ៣៧:៧ យរ ៥:២៧-២៨ **១២:២** ង យរ ១១:១៧ ច យប ៥:៣ ឆ អស ២៩:១៣ យរ ៣:១០ អគ ២២:២៧ មថ ១៥:៨ មក ៧:៦ ទត ១:១៦ **១២:៣** ជ ទដ ៧:៩ ១១:៥ ១៣៩:១-៤ ឈ ទដ ៤៤:១១ ញ យរ ១៦:១៨ ១៧:១៨ ២០:១១ **១២:៤** ដ យរ ៤:២៨ ឋ ខ.១១ យរ ៤:២៦ យអ ១:១០-១២ អម ១:២ ឌ ចទ ២៨:១៥-១៨ យរ ៤:២៥ ៩:១០ **១២:៥** ឍ យរ ៤៩:១៩ ៥០:៤៤ **១២:៦** ណ សក ២៦:២៤-២៥ យរ ៩:៤ ត ទដ ១២:២ **១២:៧** ថ ២ពវ ២១:១៤ ទ យរ ៧:២៩ ធ អស ៥:១ ន យរ ១៧:៤ **១២:៨** ប ទដ ១៧:១២ ផ ទដ ៥:៥ ហស ៩:១៥ អម ៦:៨

១១:២០ ទដ ៥១:៤ រម ៣:៤ ដោយសារព្រះទ្រង់សុចរិត ទ្រង់ជាអជ្ញាកណ្តាលដែលយើងអាចពឹងផ្អែកបាន ហើយទ្រង់ជាអ្នកកាត់ក្តីដោយសុចរិតបំផុត ។ *ប៉ុន្តែ* ទ្រង់មិនដែលព្រងើយកន្តើយ ក្នុងការស្តាប់រាល់សំនួរ និងការតវ៉ារបស់យើង ។ *ហេតុអ្វី . . . មនុស្សអាក្រក់ចំរើនឡើង* សំនួរនេះគឺមិនមែនមានតែម្តងទេ ចំពោះលោកយេរេមា (មើលឧ. យប ២១:៧-១៥ មក ៣:១៥) ។ ព្រះអម្ចាស់បានមានបន្ទូលឆ្លើយតបយ៉ាងច្បាស់លាស់ថា មនុស្សអាក្រក់នៅស្រុកយូដានឹងត្រូវវិនាសជាពិត (ខ.៧-១៣) ហើយមនុស្សអាក្រក់ដែលឈ្លានពានគេ ក៏នឹងត្រូវវិនាសអន្តរាយដែរ (ខ.១៤-១៧) ។

**១២:២** *ទ្រង់បានដាំគេ* ប៉ុន្តែព្រះដែលមានអំណាច ទ្រង់អាចធ្វើការផ្លាស់ប្តូរបាន (មើល ១៨:៩-១០) ។ *គេកើតផលផង* គេចំរើនក្នុងការអាក្រក់ ប្រជាជនលោកយេរេមា ចំរើនក្នុងការអាក្រក់ ដើម្បីបំផ្លាញដល់គាត់ "ផលផ្លែ" (មើល ១១:១៩) ។ *គេយកទ្រង់មកផ្ទាល់នៅមាត់ តែឱ្យទ្រង់នៅឆ្ងាយពីចិត្តគេវិញ* ព្រះយេស៊ូវបានដកស្រង់១ផ្នែក នៅក្នុង មថ ១៥:៨-៩ ។

**១២:៣** *ហើយល្បងលចិត្តទូលបង្គំ* មើល ១១:២០ ។ *សូមទ្រង់ចាប់កញ្ឆក់គេទៅដូចជាចៀម* លោកយេរេមាបានសួរថា មនុស្សអាក្រក់គេបានទទួលទណ្ឌកម្មចំពោះអ្វីដែលគេបានធ្វើ នៅក្នុង ១១:១៩ ។ សំនូមពររបស់គាត់មិនបាននិយាយច្រើន ចេញពីការសងសឹកឡើយ តែដើម្បីការពារចំពោះសេចក្តីសុចរិតរបស់ព្រះ (មើលការពន្យល់ ១០:២៥) ។ ដល់ថ្ងៃកាប់សំឡាប់ ជាការបញ្ជាក់១ ដែលគេបានឃើញនៅកន្លែងផ្សេងទៀត នៅក្នុង យក ៥:៥ (មើលការពន្យល់) ។

**១២:៤** *សោយសោក . . . ស្វិតក្រៀម* មើល ២៣:១០ មើលផងដែរ ៣:៣ ១៤:១ និងការពន្យល់ យ៉ាងច្បាស់ណាស់ គឺមានគ្រោះរាំងស្ងួន នៅស្រុកយូដា នៅពេលដែលលោកយេរេមាធ្វើការងារព្រះ ។ *ព្រះនឹងមិនឃើញ* ខ្មាំងសត្រូវរបស់ហោរា មិនជឿថាសេចក្តីទំនាយរបស់គេនឹងកើតឡើងជាពិតទេ ឬគេជឿថា បើគេនៅរស់ នោះលោកយេរេមានឹងមិនបានរស់នៅដើម្បីឃើញនូវអ្វីដែលគេទាយបានកើតឡើងពិតដែរ ។

**១២:៥** ព្រះអម្ចាស់បានមានព្រះបន្ទូលដល់លោកយេរេមាថា នៅថ្ងៃអនាគត នោះគាត់មានសេចក្តីវេទនាជាខ្លាំង (មើលឧ. ៣៨:៤-៦) ។ បើឯងនៅក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ នោះតែងតែមានន័យថា "ការទុកចិត្ត" (មើលការពន្យល់) ដែលមានន័យជាអវិជ្ជមាន ចំពោះព្រះបន្ទូល២ ឬ៣ ដែលគេបានបកប្រែថា "ការធ្វេសប្រហែស" ។ ជាន់ជនពេញកម្លាំងឡើងផ្តល់ឱ្យសម្រាប់សត្វសឹង្ហ (មើល ៤៩:១៩ ៥០:៤៤ សក ១១:៣) ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ សម្រាប់ពាក្យនេះមានន័យថា "ទឹកជំនន់" (មើលការពន្យល់) នេះជាឧទាហរណ៍អ្នកនៅជំនាន់បុរាណ ដែលបានរៀបរាប់នៅក្នុង យស ៣:១៥ ) ។

**១២:៦** *និងពួកគ្រូឪពុកឯង* ន័យត្រង់ "ក្រុមគ្រួសារ" ការភ្ជាប់ខនេះជាមួយនឹងអត្ថបទ ដូចខាងក្រោម(ខ.៧) សមាជិកក្រុមគ្រួសាររបស់លោកយេរេមា គឺរួមជាមួយនឹងក្រុមមនុស្ស នៅក្រុងអាន៉ាថោត ដែលចង់សម្លាប់គាត់ (១១:២១,២៣) ។

**១២:៧-១៧** ព្រះអម្ចាស់នឹងជំនុំជម្រះដល់ពួកយូដា (ខ.៧-១៣) ព្រមទាំងជំនុំជម្រះដល់អស់ទាំងសាសន៍នៅជិតខាង ដែលប្រព្រឹត្តអាក្រក់ផងដែរ (ខ.១៤-១៧) ។

**១២:៧** *គ្រួសារ* យូដា (មើលឧ. ១១:១៧) ។ *មរដក* ប្រជាជន និងទឹកដីរបស់ព្រះ (មើល ខ.៨-៩,១៤-១៥ មើលផងដែរ នក ១៥:១៧ និងការពន្យល់ ចទ ៤:២០ អស ១៩:២៥ ៤៧:៦) ។ *ឯអ្នកស្ងួនសំឡាញ់* មើលការពន្យល់ ១១:១៥ ។

**១២:៨** *ហេតុនោះបានជាអញស្អប់គេ* អញនឹងដកសេចក្តីស្រឡាញ់ ចេញពីគេដោយប្រគល់គេ "ទៅក្នុងដៃនៃខ្មាំងសត្រូវរបស់គេ" (ខ.៧ មើលមីក ១:៣

ដែលជាមរដករបស់អញ បានត្រឡប់ជាសត្វហើរសម្បុរ
ពព្លាក់ ដែលចាប់រំពា អស់ទាំងសត្វហើរដែលចាប់រំពា
បានឡោមព័ទ្ធវាហើយ ចូរទៅប្រមូលអស់ទាំងសត្វជើង
៤នាំមកឱ្យហែកស៊ីចុះ[ត]
១០មានអ្នកគង្វាល[ភ]ជាច្រើនបាន
បំផ្លាញចំការ ទំពាំងបាយជូររបស់អញ គេបានជាន់ឈ្លីដីជា
ចំណែករបស់អញ គេបានធ្វើឱ្យចំណែកដែលគាប់ចិត្តអញ
ទៅជាទីខូចបង់ហើយ[ម]
១១គេបានធ្វើឱ្យទៅជាទីអន្តរធាន[យ]
ទីនោះសោយសោករកអញ[រ] ដោយត្រូវខូចបង់ ស្រុកទាំង
មូលត្រូវអន្តរធានទៅ ដោយព្រោះគ្មានមនុស្សណាយកចិត្ត
ទុកដាក់ឡើយ
១២មានពួកទ័ពបំផ្លាញឡើងមកលើ គ្រប់ទាំង
ទីខ្ពស់ត្រងិលនៅទីរហោស្ថាន ដ្បិតដាវ[ល]នៃព្រះយេហូវ៉ា[វ]
កំពុងតែស៊ី[ស] ចាប់តាំងពីចុងស្រុកម្ខាង ទៅដល់ចុងស្រុក
ម្ខាង[ហ] ឥតមានមនុស្សណាមានសេចក្តីសុខឡើយ[ឡ]
១៣គេ
បានសាបព្រោះស្រូវសាលី តែច្រូតបានបន្លាវិញ គេបានខំ
ធ្វើទាល់តែឈឺខ្លួន ឥតបានផលប្រយោជន៍អ្វីសោះ[អ] ហើយ
ឯងរាល់គ្នានឹងត្រូវខ្មាស ចំពោះផលរបស់ឯងដែរ ដោយ
ព្រោះសេចក្តីខ្ញាល់ដ៏សហ័សរបស់ព្រះយេហូវ៉ា[ក]។
១៤ព្រះយេហូវ៉ាទ្រង់មានបន្ទូល ទាស់នឹងអស់អ្នកជិត
ខាងដ៏អាក្រក់របស់ខ្ញុំថា ឯពួកអ្នកដែលពាល់ប៉ះដល់មរដក[ខ]
ដែលអញបានចែកដល់ពួកអ៊ីស្រាអែល ជារាស្ត្ររបស់អញ
ឱ្យគ្រងបាន នោះមើល អញនឹងដករំលើង[គ]គេចេញពីស្រុក
ទៅ ហើយនឹងដករំលើង[ឃ]ពួកវង្សយូដាចេញពីកណ្តាលគេ
ដែរ
១៥រួចក្រោយដែលអញបានដករំលើងគេទៅហើយ
នោះអញនឹងត្រឡប់ចិត្ត មកអាណិតមេត្តា[ង]ដល់គេ ព្រម
ទាំងនាំ[ច]គេ ឱ្យវិលត្រឡប់មកវិញ គឺគ្រប់គ្នាដល់មរដក
របស់គេ ហើយដល់ស្រុករបស់គេរៀងខ្លួនផង
១៦យ៉ាង
នោះ បើគេនឹងខ្នះខ្នែងរៀន[ឆ]តាមផ្លូវរបស់រាស្ត្រអញ ឱ្យ
អស់ពីចិត្ត ហើយនឹងស្បថដោយនូវឈ្មោះអញថា ដូចជា
ព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់នៅ[ជ] បែបដូចជាគេបាន
បង្រៀនរាស្ត្រអញ ឱ្យស្បថដោយនូវព្រះបាល[ឈ]ដែរ នោះ
គេនឹងបានស្អាងឡើង នៅកណ្តាលរាស្ត្រអញជាពិត[ញ]
១៧តែ
បើគេមិនព្រមស្តាប់តាមទេ នោះអញនឹងដករំលើងសាសន៍
នោះទៅ គឺទាំងដករំលើង ហើយបំផ្លាញ[ដ]ផង នេះហើយ
ជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## សំពត់ទេសឯកសម្រាប់ក្រវាត់ខ្លួន

**១៣** ១ព្រះយេហូវ៉ា ទ្រង់មានបន្ទូលមកខ្ញុំដូច្នេះថា ចូរ
ទៅទិញសំពត់ទេសឯកសំរាប់ក្រវាត់ខ្លួន ហើយក្រវាត់នៅ

**១២:៩** ត ចទ ២៨:២៦ អស ៥៦:៩ យរ ១៥:៣ អគ ២៣:២៥ ៣៩:១៧–២០ **១២:១០** ភ យរ ២៣:១ ២៥:៣៤ អគ ៣៤:២–១០ ម អស ៥:១–៧ យរ ៩:១០ ២៥:១១ **១២:១១** យ អស ៥:៦ ២៤:៤ រ ខ.៤ យរ ៩:១២ ១៤:៤ ២៣:១០ **១២:១២** ល អគ ២១:៣–៤ វ ចទ ៣២:៤១ អស ៣១:៨ យរ ៤៦:១០ ៤៧:៦ អគ ១៤:១៧ ២១:២៨ ៣៣:២ ស ចទ ៣២:៤២ ហ យរ ៣:២ ឡ យរ ៧:១០ **១២:១៣** អ លវ ២៦:២០ ចទ ២៨:៣៨ ក នក ១៥:៧ យរ ៤:២៦ **១២:១៤** ខ ចទ ២៩:២៨ ២រប ៧:២០ គ ទដ ៩:៦ សក ២:៧–៩ ឃ ចទ ២៨:៦៣ **១២:១៥** ង ទដ ៦:២ ច ចទ ៣០:៣ អម ៩:១៤–១៥ **១២:១៦** ឆ យរ ១៨:៨ ជ យរ ៤:២ ឈ យស ២៣:៧ ញ អស ២៦:១៨ ៤៩:៦ យរ ៣:៧ **១២:១៧** ដ លប ២៧:២៩

និងការពន្យល់) ។

**១២:៩** *បានត្រឡប់ជាសត្វហើរសម្បុរពព្លាក់ដែលចាប់រំពា* ពួកខ្មាំងសត្រូវពួកយូដា (មើល អស ៥៦:៩ និងការពន្យល់) ។

**១២:១០** *មានអ្នកគង្វាលជាច្រើន* អ្នកគ្រប់គ្រង (មើលការពន្យល់ ២:៨) ។ ចំការទំពាំងបាយជូររបស់អញ យូដា (មើល ២:២១ និងការពន្យល់) ។ *ចំណែកដែលគាប់ចិត្តអញ* មើល ៣:១៩ និងការពន្យល់ ។

**១២:១១** *បានសោយសោក* មើលខ.៤ និងការពន្យល់ ។ ការសរុបនូវសូរសំលេង"ស"ទាំង៧ (seven s-sound) និងសូរសំលេង"ម"ទាំង៧ (seven m-sound) នៅក្នុងព្រះគម្ពីរភាសាហេព្រើរ សម្រាប់ខនេះ គឺជាសង្ខេបពីឈ្នាប់សាច់រឿង និងការផ្តល់ជាឧទាហរណ៍ អំពីអំណោយទានផ្នែកអក្សសាស្ត្ររបស់លោកយេរេមា (មើលសេចក្តីផ្តើម ផ្នែកអក្សសាស្ត្រ) ។

**១២:១២** *គ្រប់ទាំងទីខ្ពស់ត្រងិល* ជាទីកន្លែងដែលគេថ្វាយបង្គំរូបព្រះ (មើល ៣:២ ជន ២៣:៣) ។ ពួកទ័ពបំផ្លាញពួកបាប៊ីឡូន (មើលការពន្យល់ ៤:៧) ។ *ដ្បិតដាវនៃព្រះយេហូវ៉ា* ជានិម្មិតរូប ជាឧបករណ៍របស់ព្រះចំពោះការជំនុំជម្រះរបស់ទ្រង់ (មើល ២៥:២៩ ៤៧:៦ និងការពន្យល់ ទដ ៧:១២–១៣) ។ *ចាប់តាំងពីចុងស្រុកម្ខាង ទៅដល់ចុងស្រុកម្ខាង* មើល ២៥:៣៣ ។ *ឥតមានមនុស្សណាមានសេចក្តីសុខឡើយ* ន័យត្រង់ "នឹងគ្មានសន្តិភាពសុវត្ថិភាពសម្រាប់គ្រប់គ្នា" (មើល ៦:១៤ និងការពន្យល់) ។

**១២:១៣** មើល ១៤:២–៤ ។

**១២:១៤** *អ្នកជិតខាងដ៏អាក្រក់* មើលឧ. ២ពវ ២៤:២ ។ *ដែលប៉ះពាល់ដល់* ន័យត្រង់ "ប៉ះពាល់" ត្រូវបានគេប្រើនៅក្នុងអត្ថន័យអំពីការវាយប្រហារ និងការឆក់ប្លន់ នៅក្នុង សក ២:៨ ។ *ដក់រំលើង* នេះជាការអនុវត្តទៅលើពួកអ្នកចាប់ជាឈ្លើយ (មើលឧ. ១ពវ ១៤:១៥) ។

**១២:១៥** ពួកអ្នកចាប់ជាឈ្លើយមកពីស្រុកយូដា មកពីអស់ទាំងសាសន៍នៅជិតខាង ដែលនាំមកដល់ទឹកដីគេ ទៅដល់ទឹកដីគេ (សូមមើល ខ.១៦ ៣២:៣៧,៤៤ ៣៣:២៦ ៤៨:៤៧ ៤៩:៦) ។

**១២:១៦** បានកើតឡើងនៅក្នុងកំឡុងអាយុស្តេចម៉ានាសេ (មើល អស ៥៦:៦–៧ និងការពន្យល់ ៥៦:៧) ។ *តាមផ្លូវ* មើលការពន្យល់ ១០:២ ។ *ព្រះបាល* មើលការពន្យល់ ពច ២:១៣ ។ *នោះគេនឹងបានស្អាងឡើង* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ ដែលគេបានបកប្រែថា "រីកចំរើនឡើង" នៅក្នុង មឡ ៣:១៥ ។

**១៣:១–២៧** នេះជាផ្នែកនៃការព្រមានទាំង៥យ៉ាង ពីរយ៉ាងលើកដំបូងនៅក្នុង (ខ.១–១១,១២–១៤) បានសរសេរជាលក្ខណៈធម្មតា និងចុងក្រោយសរសេរជាលក្ខណៈកំណាព្យ (ខ.១៥–១៧,១៨–១៩,២០–២៧) ។

**១៣:១–១១** នេះជារឿងរ៉ាវនៃសេចក្តីហិនវិនាស ខ្សែក្រវ៉ាត់ដែលឥតប្រយោជន៍ ជាឧទាហរណ៍ចម្បងដំបូង ដែលព្រះបង្គាប់បញ្ជាដល់លោកយេរេមា ឱ្យសំដែងទីសំគាល់ ចំពោះព្រះបន្ទូលរបស់ទ្រង់ (មើលសេចក្តីផ្តើម ផ្នែកអក្សរសាស្ត្រ) ។

**១៣:១–២,៤–៧** *ចូរទៅទិញ . . . ខ្ញុំក៏ទិញ . . . ចូរយកសំពត់ក្រវ៉ាត់ . . . លាក់ទុក . . . ខ្ញុំក៏ទៅលាក់សំពត់នោះ . . . ចូរក្រោកឡើងទៅឯទន្លេអើប្រាត*

ចង្កេះឯងទៅ កុំឱ្យបោកទឹកឡើង ២ដូច្នេះ ខ្ញុំក៏ទិញសិំពត់១
មកក្រវាត់នៅចង្កេះ តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ៣រួច
ព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំម្តងទៀតថា[ក] ៤ចូរ
យកសំពត់ក្រវាត់ដែលបានទិញនោះ ដែលនៅចង្កេះឯង
ហើយក្រោកឡើងទៅឯទន្លេអើប្រាត[ខ] លាក់ទុកនៅក្នុង
ក្រហែងថ្មនៅទីនោះទៅ ៥ដូច្នេះ ខ្ញុំក៏ទៅលាក់សំពត់នោះ
នៅក្បែរទន្លេអឺប្រាត ដូចជាព្រះយេហូវ៉ាបានបង្គាប់មក[គ]
៦ក្រោយមកជាយូរថ្ងៃ នោះព្រះយេហូវ៉ាទ្រង់មានបន្ទូល
មកខ្ញុំថា ចូរក្រោកឡើងទៅឯទន្លេអើប្រាត យកសំពត់
ក្រវាត់ ដែលអញបានបង្គាប់ ឱ្យលាក់ទុកនៅទីនោះមក
វិញ ៧ខ្ញុំក៏ទៅដល់ទន្លេអើប្រាត ជីកយកសំពត់ក្រវាត់ ពី
កន្លែងដែលខ្ញុំបានលាក់ទុកនោះ ហើយមើល សំពត់នោះ
ខូចហើយ គ្មានប្រយោជន៍ទៀតសោះ ។
៨គ្រានោះ ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់ខ្ញុំថា
៩ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ គឺបែបយ៉ាងនេះដែល
អញនឹងបង្ខូចសេចក្តីអំនួតរបស់ពួកយូដា និងសេចក្តីអំនួត[ឃ]
យ៉ាងធំរបស់ក្រុងយេរូសាឡិមដែរ ១០ឯជនជាតិអាក្រក់នេះ
ដែលមិនព្រមស្តាប់តាម[ង]ពាក្យអញ ជាពួកអ្នកដែលដើរ
តាមតែសេចក្តីរឹងចចេស នៅក្នុងចិត្ត[ច]របស់ខ្លួនគេ និងទៅ
តាមព្រះដទៃ[ឆ] ដើម្បីនឹងគោរព ហើយថ្វាយបង្គំដល់វា[ជ] គេ
នឹងបានដូចជាសំពត់ក្រវាត់នេះ ដែលឥតមានប្រយោជន៍
អ្វីទៀត[ឈ] ១១ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា សំពត់
ក្រវាត់ជាប់នៅនឹងចង្កេះមនុស្សយ៉ាងណា នោះអញក៏បាន
ឱ្យពួកវង្សអ៊ីស្រាអែលទាំងមូល និងពួកវង្សយូដាទាំងអស់
នៅជាប់នឹងអញយ៉ាងនោះដែរ ដើម្បីឱ្យគេបានជារាស្ត្រ
សំរាប់អញ ហើយជាកេរ្តិ៍ឈ្មោះ[ញ]ជាសេចក្តីសរសើរ និង
ជាសិរីល្អផង[ដ] តែគេមិនព្រមស្តាប់សោះ[ឋ]។

## ថង់ស្បែកស្រាទំពាំងបាយជូរ

១២ហេតុនោះត្រូវឱ្យឯងប្រាប់ពាក្យនេះដល់គេថា ព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូល
ដូច្នេះ ឯអស់ទាំងឪទីន នោះនឹងបានពេញដោយស្រាទំពាំង
បាយជូរ ហើយគេនឹងឆ្លើយតបមកឯងថា តើយើងមិនដឹង
ពិតថា ឪទីនទាំងអស់នឹងបានពេញដោយស្រាទំពាំងបាយ
ជូរទេឬអី ១៣រួចឯងត្រូវប្រាប់ដល់គេថា ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ មើល អញនឹងធ្វើឱ្យមនុស្សនៅស្រុក
នេះទាំងអស់ ទាំងពួកស្តេចដែលគង់លើបល្ល័ង្ករបស់ដាវីឌ
និងពួកសង្ឃ ពួកហោរា ហើយអស់អ្នកដែលនៅក្រុងយេ–
រូសាឡិមផង បានស្រវឹងពេញទី[ឌ] ១៤ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា អញនឹងបោកគេម្នាក់ផ្ទប់នឹងម្នាក់ទៀត គឺឪពុក

**១៣:៣** ក យរ ៣៣:១
**១៣:៤** ខ លប ២:១៤
**១៣:៥** គ នក ៤០:១៦
**១៣:៩** ឃ លវ ២៦:១៩ មថ ២៣:១២ លក ១:៥១
**១៣:១០** ង យរ ២២:២១ ច សស ៩:៣ យរ ៣:១៧ ឆ ចទ ៨:១៩ យរ ៩:១៤ ជ ៣ជ ១០:១៣ ឈ អក ១៥:៣
**១៣:១១** ញ អស ៦៣:១២ យរ ៣២:២០ ដ នក ១៩:៥–៦ អស ៤៣:២១ យរ ៣:១៧ ឋ អស ៦៥:១២ យរ ៧:២៦
**១៣:១៣** ឌ ទដ ៦០:៣ ៧៥:៨ អស ២៩:៩ យរ ២៥:១៨ ៥១:៥៧

. . . *ខ្ញុំក៏ទៅ ដល់ទន្លេអើប្រាត ជីកយកសំពត់ក្រវ៉ាត់* ដូចជាព្ធយុកោលោក យេរេមាខាងឯ ព្រលឹងវិញ្ញាណ គឺលោកអ័ប្រាហាំ (មើលការពន្យល់ លប ១២:៤) ។ លោកយេរេមាមានឥរិយាបទ ជាអ្នកស្តាប់បង្គាប់ដល់ព្រះ ។

**១៣:១** *សំពត់ទេសឯក* នេះជាសំលៀកបំពាក់ដែលជាងដេរ កាត់សម្រាប់សង្ឃ (មើល អគ ៤៤:១–១៨) និមិត្តរូបអំពីភាពបរិសុទ្ធរបស់អ៊ីស្រាអែល ដូចជា "នគរសង្ឃ" (មើល នក ១៩:៦ និងការពន្យល់) ក្រវ៉ាត់សំពត់នឹងចង្កេះ ជានិមិត្តសញ្ញាអំពីភាពទំនាក់ទំនងយ៉ាងជិតស្និទ្ធពីជំនាន់មុន រវាងព្រះ និងពួកយូដា (មើល ខ.១១) ។ *កុំឱ្យបោកទឹកឡើយ* កុំឱ្យបោកគកវា ជានិមិត្តសញ្ញាអំពីសេចក្តីអំនួត ដែលជាអំពើបាបរបស់យូដា (មើល ខ.៩) ។

**១៣:៣** *រួច* ពេលក្រោយមកទៀត ។

**១៣:៤** *ទន្លេអើប្រាត* ប្រហែលដូចគ្នាទៅនឹងទន្លេប៉ាប្រាត (យស ១៨:២៣) នៅជិត វាឌី ហ្វារ៉ា (Wadi Farah) សព្វថ្ងៃនេះ មានចម្ងាយ៤គីឡូម៉ែត្រ នៅខាងជើងឆៀងខាងកើត ក្រុងអាន៉ាថោត ។ នៅក្នុងអត្ថបទផ្សេងទៀត ចំពោះព្រះគម្ពីរភាសាហេព្រើរទន្លេអើប្រាត គឺសំដៅទៅលើទន្លេអើប៉ាប្រាត (មើល ការពន្យល់) វាជានិមិត្តសញ្ញា១យ៉ាងសមរម្យ អំពីអំពើពុករលួយរបស់ពួកអាសេរី និងអំពើពុករលួយរបស់ពួកបាប៊ីឡូន ដែលមានឥទ្ធិពលលើយូដានៅកំឡុងពេលស្តេចអ័ហាសឡើងសោយរាជ្យ (មើល ២ពវ ១៦) ។ *លាក់ទុកនៅក្នុងក្រហែងថ្មនៅទីនោះទៅ* មើលការពន្យល់ ១៦:១៦ ។

**១៣:៦** *ក្រោយមកជាយូរថ្ងៃ* ប្រហែលជាសំដៅទៅលើការចាប់ទៅធ្វើជាឈ្លើយដោយពួកបាប៊ីឡូនអស់រយៈពេលជាយូរ ។

**១៣:៧** *ជីក* ហោរាបានកប់សំពត់ក្រវ៉ាត់នៅក្នុងដី ឬពួកវាឪបានកប់នៅក្នុងភក់ ។ *សំពត់នោះខូចហើយ* ដូចជាឃើញនៅក្នុង លវ ២៦:៣៩ រាស្ត្ររបស់ព្រះដែលជាប់ជាឈ្លើយត្រូវបានបោះបង់ចោល ដោយសារអំពើបាបរបស់គេ និងអំពើបាបរបស់ព្ធយុកោរបស់គេ ។

**១៣:៩** *សេចក្តីអំនួត . . . និងសេចក្តីអំនួតយ៉ាងធំ* ផ្ទុយគ្នានៅក្នុង ៩:២៣–២៤ សេចក្តីអំនួតរបស់ពួកយូដា ដែលជាហេតុនាំឱ្យគេត្រូវដួលចុះ និងត្រូវចាប់ទៅធ្វើជាឈ្លើយ (មើល ខ.១៥,១៧) ដូចជានៅក្នុង លវ ២៦:១៩ ។

**១៣:១០** *ដែលមិនព្រមស្តាប់តាមពាក្យអញ* មើលការពន្យល់ ៩:៦ ។ *ជាពួកអ្នកដែលដើរតាមតែសេចក្តីរឹងចចេស នៅក្នុងចិត្តគេ* មើលការពន្យល់ ៣:១៧ ។ *ដែលឥតមានប្រយោជន៍អ្វីទៀត* មើល ២៤:៨ ។

**១៣:១១** តែគេមិនព្រមស្តាប់សោះ នេះជាសេចក្តីសន្យាមួយនៅក្នុង ចទ ២៦:១៩ គេបានធ្វើតាមសេចក្តីនោះបានមួយរយៈពេលខ្លី ។

**១៣:១២–១៤** ព្រះអម្ចាស់ប្រើពីរូបភាពឪទីនស្រា ដើម្បីចង្អុលបង្ហាញ ពីការបំផ្លាញដល់អ្នកដឹកនាំយូដា និងប្រជាជនរបស់គេ ។

**១៣:១៣** *បានស្រវឹងពេញទី* នេះគឺជាន័យត្រង់ (មើលឧទាហរណ៍នៅក្នុង អស ២៨:៧) ប៉ុន្តែនេះជានិមិត្តរូបពីប្រសិទ្ធិភាពនៃស្រាទំពាំងបាយជូ ដែលជាសេចក្តីក្រោធរបស់ព្រះ (២៥:១៥–២៩ ទដ ៦០:៣ អស ៥១:១៧–២៣ អគ ២៣:៣២–៣៤) ។ *ពួកស្តេច . . . ពួកសង្ឃ . . . ពួកហោរា . . . និងអស់អ្នកដែលនៅក្រុងយេរូសាឡិមផង* មើល ២៦:១៦ និងមើលការពន្យល់ផងដែរ ១:១៨ ។

ផ្ទប់នឹងកូនផង អញមិនព្រមប្រណី[ល] ឬសំចៃ ឬមេត្តា[ណ]
ដើម្បីមិនឱ្យបំផ្លាញ[ត]គេឡើយ ។

## សេចក្ដីគម្រាមឱ្យជាប់ជាឈ្លើយ

១៥ចូរស្ដាប់ ហើយផ្ទៀងត្រចៀកចុះ កុំឱ្យតាំងចិត្ត
ឆ្មើងឆ្មៃឡើយ ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូលហើយ[ថ]
១៦ចូរសរសើរដំកើង[ទ]ដល់ព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់
គ្នាចុះ ក្រែងទ្រង់ធ្វើឱ្យងងឹត ហើយអ្នករាល់គ្នាចំពប់ជើង[ធ]
នៅលើភ្នំងងឹត ហើយកំពុងដែលអ្នករាល់គ្នាសង្ឃឹមនឹង
បានពន្លឺ នោះទ្រង់នឹងបំប្រែឱ្យទៅជាម្លប់នៃសេចក្ដីស្លាប់
នឹងជាងងឹតយ៉ាងក្រាស់វិញ[ន] ១៧តែបើអ្នករាល់គ្នាមិនព្រម
ស្ដាប់ទេ[ប] នោះព្រលឹងខ្ញុំនឹងយំសោកក្នុងទីសំងាត់ ដោយ
ព្រោះសេចក្ដីអំនួតរបស់អ្នករាល់គ្នា ហើយភ្នែកខ្ញុំនឹងយំ
សស្រាក់[ផ] ពីព្រោះហ្វូងចៀម[ព]របស់ព្រះយេហូវ៉ាបានត្រូវ
គេ ចាប់ដឹកទៅជាឈ្លើយហើយ[ភ] ។
១៨ចូរទូលដល់មហាក្សត្រ[ម] និងអគ្គមហេសីថា[យ] សូម
ឱ្យគង់ចុះនៅទីទាបវិញ ដ្បិតក្បាំងព្រះសិរ គឺជាមកុដ[រ]នៃ
សិរីល្អរបស់ទ្រង់បានធ្លាក់ចុះហើយ ១៩អស់ទាំងទីក្រុងនៅ
ស្រុកត្បូងនឹងបិទជិតហើយ ឥតមានអ្នកណានឹងបើកវិញ
បានឡើយ ពួកយូដា[ល]ទាំងអស់បានត្រូវដឹកទៅជាឈ្លើយ អើ
គេត្រូវដឹកនាំទៅជាឈ្លើយទាំងអស់គ្នាហើយ ។
២០ចូរងើបភ្នែកឡើង ហើយមើលពួកអ្នកដែលមកពី
ទិសខាងជើង[វ] ឯហ្វូងចៀម[ស]ដែលបានប្រគល់ដល់ឯង គឺ
ជាហ្វូងដ៏ល្អរបស់ឯង នោះតើនៅឯណា ២១តើឯងនឹង
ថាដូចម្ដេច ក្នុងកាលដែលទ្រង់តាំងពួកមិត្រសំឡាញ់របស់
ឯងឡើង[ហ] ឱ្យគ្រប់គ្រងលើឯង ដ្បិតគឺខ្លួនឯងហើយ ដែល
បានបង្ហាត់បង្រៀនគេឱ្យធ្វើដូច្នេះ នោះតើសេចក្ដីទុក្ខព្រួយ
ដូចជាស្ត្រី ដែលឈឺចាប់នឹងសំរាលកូន មិនចាប់ឯងទេឬ[ឡ]
២២ហើយបើឯងនឹកសួរក្នុងចិត្តថា ហេតុអ្វីបានជាការទាំង
នេះកើតដល់អញដូច្នេះ[អ] នោះគឺដោយព្រោះអំពើទុច្ចរិតដ៏
បរិបូរ[ក]របស់ឯងទេ បានជាសំពត់របស់ឯងត្រូវបើកសើយ
ឡើង[ខ] ហើយឯងត្រូវនៅកែងជើងទទេ[គ] ២៣តើសាសន៍
អេធីយ៉ូពីនឹងបំផ្លាស់បំប្រែសម្បុរស្បែក របស់ខ្លួនបានឬទេ
ឬខ្លារខិននឹងផ្លាស់សម្បុរពព្លាក់របស់វាទៅបានដែរ បើ
បាន នោះឯងរាល់គ្នាដែលធ្លាប់ប្រព្រឹត្តអាក្រក់ និង

**១៣:១៤** ល អក ៧:៤ ៨:១៨ ៩:៥,១០ ២៤:១៤ សក ១១:៦ ណ អស ៩:១៧ យរ ១៦:៥ ត ចទ ២៩:២០ អស ៩:១៩–២១ យរ ៧:២០ ៤៩:៣២,៣៦ បទ ២:២១ អគ ៥:១០ **១៣:១៥** ថ នក ២៣:២១ ទដ ៩៥:៧–៨ **១៣:១៦** ទ យស ៧:១៩ ធ លវ ២៦:៣៧ យប ៣:២៣ អស ៥១:១៧ យរ ២៣:១២ ន ១សយ ២:៩ យប ៣:៥ ទដ ៨២:៥ **១៣:១៧** ប មឡ ២:២ ផ យរ ៩:១ ព ទដ ៨០:១ យរ ២៣:១ ភ យរ ១៤:១៨ ២៩:១

**១៣:១៨** ម យរ ២១:១១ ២២:១ យ ១ពវ ២:១៩ ២ពវ ២៤:៨ អស ២២:១៧ រ ២សយ ១២:៣០ បទ ៥:១៦ អគ ១៦:១២ ២១:២៦ **១៣:១៩** ល យរ ២០:៤ ៥២:៣០ បទ ១:៣ **១៣:២០** វ យរ ៦:២២ ហព ១:៦ ស យរ ២៣:២ **១៣:២១** ហ ទដ ៤១:៩ យរ ៤:៣០ ២០:១០ ៣៨:២២ អប ១:៧ ឡ យរ ៤:៣១ **១៣:២២** អ ១ពវ ៩:៩ ក យរ ៩:២–៦ ១៦:១០–១២ ខ អស ២០:៤ គ បទ ១:៨ អគ ១៦:៣៧ ២៣:២៦ ណហ ៣:៥–៦

**១៣:១៤** *អញនឹងបោកគេម្នាក់ផ្ទប់និងម្នាក់ទៀត* មានក្រុមផ្សេងៗគ្នានៅក្នុងពួកយូដា ដែលធ្វើឡើង គ្រាន់តែជាការយល់ច្រលំ និងជាការច្របូលច្របល់នៅចំពោះមុខខ្មាំងសត្រូវរបស់គេប៉ុណ្ណោះ ។ *អញមិនប្រណី ឬសំចៃ ឬមេត្តា* មើល ២១:៧ មើលផងដែរ អគ ៥:១១ ។

**១៣:១៥–១៧** ហោរានិយាយថា អំនួតជាអំពើបាប ដែលជាហេតុនាំឱ្យមានការបំផ្លិចបំផ្លាញ ។

**១៣:១៥** *ចូរស្ដាប់* មើលការពន្យល់ ២:៤ ។ *កុំឱ្យតាំងចិត្តឆ្មើងឆ្មៃឡើយ* មើលខ.១៧ មើលការពន្យល់ខ.៩ ។

**១៣:១៦** *ចូរសរសើរដំកើងដល់ព្រះយេហូវ៉ា* ចូរលន់តួបាប (មើល យក ៧:១៩ យហ ៩:២៤ និងការពន្យល់) ។ *អ្នករាល់គ្នាសង្ឃឹមនឹងបានពន្លឺ* ធៀបនឹងការពិពណ៌នាអំពីថ្ងៃរបស់ព្រះអម្ចាស់ នៅក្នុង អម ៥:១៨–២០ ៨:៩ ។

**១៣:១៧** *នោះព្រលឹងខ្ញុំនឹងយំសោក* មើលការពន្យល់ ៩:១ ។ *សេចក្ដីអំនួត* មើល ខ.១៥ មើលការពន្យល់ផងដែរនៅក្នុង ខ.៩ ។ *ហ្វូងចៀម* គឺមនុស្ស (មើល ខ.២០ អគ ១០:៣ មើលការពន្យល់ផងដែរ ១០:២១) ។ *បានត្រូវគេចាប់ដឹកទៅជាឈ្លើយហើយ* ពួកអ្នកដែលចាប់ជាឈ្លើយ (មើល ខ.១៩) ។

**១៣:១៨–១៩** ហោរានិយាយថា ការចាប់ទៅធ្វើជាឈ្លើយកាន់តែនៅកៀកបង្កើយ ។

**១៣:១៨** *ចូរទូលដល់មហាក្សត្រ និងអគ្គមហេសីថា* ប្រហែលជាស្ដេចយ៉ូយ៉ាគីន និងស្ដេចនេហ៊ូលថា (២ពវ ២៤:៨) បើដូច្នោះ កាលបរិច្ឆេទគឺនៅក្នុងឆ្នាំ៥៩៧ មុន គ.ស ប្រហែល១២ឆ្នាំ ក្រោយពីការសុគតស្ដេចយ៉ូសៀស (មើលការពន្យល់ ១១:១–១៣:២៧) ។ *គឺជាមកុដនៃសិរីល្អរបស់ទ្រង់* (មើល ២២:២៤–២៦ ២៩:២ ២ពវ ២៤:១៥ ធៀបនឹង អគ ២១:២៥–២៧ និងការពន្យល់) ។

**១៣:១៩** *ស្រុកត្បូង* ទឹកដីខាងត្បូងដែលស្ងួត (សូមមើលការពន្យល់ លប ១២:៩) ។ *បិទជិត* បិទជិតដោយកំទេចកំទី (មើល អស ២៤:១០) ។ *ពួកយូដាទាំងអស់* ប្រជាជាតិទាំងមូល ។ *គេត្រូវដឹកនាំទៅជាឈ្លើយទាំងអស់គ្នាហើយ* ធៀបនឹង អម ១:៦,៩ ("សហគមន៍ទាំងមូល") ។

**១៣:២០–២៧** ជាដំបូងហោរានិយាយ (ខ.២០–២៣) បន្ទាប់មកព្រះអម្ចាស់បានបន្ទូលថា ដោយសារពួកយូដាស្មគ្រចិត្តបះបោរប្រឆាំង នោះនាំឱ្យគេត្រូវចាប់ទៅជាឈ្លើយ (ខ.២៤–២៧) ។

**១៣:២០** *ងើបភ្នែក . . . ដល់ឯង . . . របស់ឯង* ក្រុងយេរូសាឡិម មានលក្ខណៈដូចជាស្ត្រីម្នាក់ ដែលបានបញ្ជាក់ក្នុងខនេះ (មើល ខ.២១–២២, ២៦–២៧ ) ។ *ពីទិសខាងជើង* គឺជាក្រុងបាប៊ីឡូន (មើល ៤:៦ មើលការពន្យល់ អស ៤១:២៥) ។ *ហ្វូង . . . ហ្វូវចៀម* មើលការពន្យល់ ៤:៣១ ។

១៣:២១ ពួកមិត្រសំឡាញ់របស់ឯង ប្រហែលជាពួកបាប៊ីឡូន និងពួកអេស៊ីព្ទ ដែលផ្លាស់ប្ដូរគ្នា ក្នុងការគ្រប់គ្រងពួកយូដា (មើលសេចក្ដីផ្ដើម ប្រវត្តិដើម) ។ ដូចជាស្ត្រី ដែលឈឺចាប់នឹងសំរាលកូន មើលការពន្យល់ ៤:៣១ ។

**១៣:២២** *បានជាសំពត់របស់ឯងត្រូវបើកហើយសើយឡើង* នេះជាការអាម៉ាស់នៅទីសាធារណៈ ដូចជាស្រីសំផឹងជាទូទៅ (មើល ខ.២៦–២៧ អស ៤៧:២–៣ ហស ២:៣,១០) ។

**១៣:២៣** *តើ . . . សម្បុរស្បែក* ជាសំនួរបន្ទំ ដោយទទួលចម្លើយមកវិញជាចំម្លើយអវិជ្ជមាន (មើល ១៧:៩) ។

អាចប្រព្រឹត្តល្អវិញក៏បានដែរ[ឃ] ២៤ដូច្នេះ អញនឹងកំចាត់
កំចាយឯងដូចជាចំបើង[ង]ដែលរសាត់ទៅបាត់ ដោយខ្យល់
ពីទីរហោស្ថាន[ច] ២៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នេះ
ហើយជាចំណែករបស់ឯងរាល់គ្នា ជាចំណែក[ឆ]ដែលអញ
វាល់ឱ្យឯង ដោយព្រោះឯងបានភ្លេច[ជ]អញ ហើយទុកចិត្ត
នឹងសេចក្តីកំភូតវិញ[ឈ] ២៦ហេតុនោះអញនឹងបើកសើយ
សំពត់របស់ឯង ឡើងគ្របលើមុខឯង ហើយកេរខ្មាសរបស់
ឯងនឹងបានឃើញច្បាស់[ញ] ២៧អញបានឃើញអំពើគួរស្អប់
ខ្ពើមឆ្អើមរបស់ឯងហើយ គឺជាការកំផិត[ដ] និងសូរឆ្លើយ
ឆ្លងរកគ្នារបស់ឯង ព្រមទាំងសេចក្តីឥតខ្មាសនៃការកំផិត
របស់ឯង នៅលើអស់ទាំងទីទួលនៅវាលផង[ឋ] វេទនា
ដល់ឯង ក្រុងយេរូសាឡិមអើយ ឯងមិនព្រមឱ្យបានស្អាតទេ
តើនឹងនៅតែដូច្នេះដល់កាលណាទៀត[ឌ]។

**ភាពរាំងស្ងួត អត់ឃ្លាន ដាវ**

**១៤** ១នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដល់
យេរេមា ពីដំណើរគ្រារាំងភ្លៀង[ក] ២ពួកយូដាគេសោយ
សោក[ខ] ហើយទ្វារក្រុងក៏ថយកំឡាំងចុះ គេអង្គុយនៅដី
ដោយចិត្តព្រួយ ហើយសំរែកនៃក្រុងយេរូសាឡិមក៏ឮឡើង
៣ពួកអ្នក ធំរបស់គេចាត់អ្នកបំរើឱ្យទៅរកទឹក គេក៏ទៅដល់
ស្រះទាំងប៉ុន្មាន តែរកទឹកគ្មានសោះ[គ] គេត្រឡប់ទៅវិញ
ដោយក្អមទទេ គេត្រូវខ្មាស ហើយជ្រប់មុខ ក៏គ្រលុំក្បាល[ឃ]
៤ពីព្រោះដីបែកក្រហែង ដោយគ្មានភ្លៀងធ្លាក់មកលើស្រុក
សោះ[ង] ពួកអ្នកភ្ជួររាស់ក៏ខ្មាស គេគ្រលុំក្បាលដែរ ៥អើទាំង
ក្តាន់ញីនៅវាលក៏ទំលាក់កូន រួចចោលចេញ ព្រោះគ្មាន
ស្មៅ[ច] ៦លាព្រៃក៏ឈរនៅលើទីត្រងិល[ឆ] វាដង្ហាក់ដូចជា
ចចក ភ្នែកវាស្រវាំងទៅ ដោយព្រោះគ្មានស្មៅសោះ[ជ]។
៧ឱព្រះយេហូវ៉ាអើយ ទោះបើអំពើទុច្ចរិតរបស់យើង
ខ្ញុំធ្វើបន្ទាល់[ឈ]ទាស់នឹងយើងខ្ញុំក៏ដោយ តែសូមទ្រង់ប្រោស
មេត្តា ដោយយល់ដល់ព្រះនាមទ្រង់[ញ] ដ្បិតការរាថយ[ដ]របស់
យើងខ្ញុំ នោះច្រើនណាស់ យើងខ្ញុំបានធ្វើបាប[ឋ]នឹងទ្រង់ ៨ឱ
ទីសង្ឃឹម[ឌ]នៃសាសន៍អ៊ីស្រាអែល ជាព្រះដ៏ជួយសង្គ្រោះ[ឍ] គេ
ក្នុងគ្រាលំបាកអើយ[ណ] ហេតុអ្វីបានជាទ្រង់ត្រូវដូចជាអ្នក
ដទៃនៅក្នុងស្រុក ហើយដូចជាអ្នកដើរដំណើរ ដែលឈប់
សំណាក់តែ១យប់ដូច្នេះ ៩ហេតុអ្វីបានជាទ្រង់ត្រូវដូចជា

**១៣:២៣** ឃ ២របា ៦:៣៦ **១៣:២៤** ង ទដ ១:៤ ច លវ ២៦:៣៣ យប ១:១៩ ២៧:២១ **១៣:២៥** ឆ យប ២០:២៩ មថ ២៤:៥១ ជ អស ១៧:១០ ឈ ចទ ៣១:២០ ទដ ៤:២ ១០៦:១៩–២១ **១៣:២៦** ញ បទ ១:៨ អគ ១៦:៣៧ ណាហ ៣:៥ **១៣:២៧** ដ អគ ២៣:២៩ ឋ អស ៥៧:៧ អគ ៦:១៣ ឌ ហស ៨:៥ **១៤:១** ក ចទ ២៨:២២ អស ៥:៦ **១៤:២** ខ អស ៣:២៦ **១៤:៣** គ ចទ ២៨:៤៨ ២ពវ ១៨:៣១ យប ៦:១៩–២០ ឃ នអ ៦:១២ **១៤:៤** ង យរ ៣:៣ ១២:១១ អម ៤:៨ សក ១៤:១៧ **១៤:៥** ច អស ១៥:៦ **១៤:៦** ឆ យប ៣៩:៥–៦ ទដ ១០៤:១១ យរ ២:២៤ ជ លប ៤៧:៣ **១៤:៧** ឈ អស ៣:៩ ហស ៥:៥ ញ ១សយ ១២:២២ ទដ ៧៩:៩ ដ ១សយ ២:១៩ ៥:៦ ឋ យរ ៨:១៤ **១៤:៨** ឌ ទដ ៩:១៨ យរ ១៧:១៣ ៥០:៧ ឍ ទដ ១៨:៤៦ អស ២៥:៩ ណ ទដ ៤៦:១

**១៣:២៤** *ដូចជាចំបើងដែលរសាត់ទៅបាត់* នេះជាទណ្ឌកម្មរបស់មនុស្សអាក្រក់ (មើលឧទាហរណ៍ ទដ ១:៤) ។ ដោយខ្យល់ពីទីរហោស្ថាន មើលការពន្យល់ ៤:១១ ។

**១៣:២៥** *ដោយព្រោះឯងបានភ្លេចអញ* មើល ២:៣២ និងការពន្យល់ ។

**១៣:២៦** មើលខ.២២ និងការពន្យល់ ។

**១៣:២៧** *គឺជាការកំផិត និងសូរឆ្លើយឆ្លងរកគ្នារបស់ឯង* មើលការពន្យល់ ៥:៨ ។ ព្រមទាំងសេចក្តីឥតខ្មាសនៃការកំផិតរបស់ឯង មើល អគ ១៦:២៦ មើលផងដែរ នក ៣៤:១៥ និងការពន្យល់ ។ *តើនឹងនៅតែដូច្នេះដល់កាលណាទៀត* គ្មានសេចក្តីសង្ឃឹមឡើយ តែទោះជាយ៉ាងណាក្តី នោះជាការពន្យាពេលចំពោះសេចក្តីកំហឹងរបស់ព្រះប៉ុណ្ណោះ (ធៀបនឹងឧទាហរណ៍ ១២:១៤–១៦) ។

**១៤:១–១៥:២១** ការថ្លែងព្រះបន្ទូលដោយហោរា ជាពិសេសនៅចំពេលមានគ្រោះរាំងស្ងួត ដែលគេមិនបានស្គាល់កាលបរិច្ឆេទច្បាស់នោះឡើយ ។

**១៤:១–១៥:៩** ក្រោយពីការពិពណ៌នា អំពីគ្រោះរាំងស្ងួត យ៉ាងខ្លាំងពីខាងដើមមក (១៤:២–៦)លោកយេរេមាអធិស្ឋានផ្លាស់ប្តូរគ្នា (១៤:៧–៩,១៣, ១៩–២២) ហើយព្រះអម្ចាស់បានឆ្លើយតបការនោះ (១៤:១០–១២,១៤–១៨ ១៥:១–៩) ។

**១៤:១** *ដំណើរគ្រារាំងភ្លៀង* មើល ១៧:៨ ។ មិនដូចគ្នានៅក្នុង ៣:៣ គេរងទុក្ខយ៉ាងខ្លាំងក្លា នៅពេលដែលពួកខ្មាំងសត្រូវបានទទ្រានចូលឈ្លានពានលើទឹកដីនោះ (មើល ខ.១៨) ។ *គ្រារាំងភ្លៀង* គឺជាបណ្តាសា១ ដែលបានគំរាមកំហែងលើគេ ដោយសារការមិនធ្វើតាមសេចក្តីតាំងសញ្ញា (មើល ២៣:១០ លវ ២៦:១៩–២០ ចទ ២៨:២២–២៤) ។

**១៤:២** *ទ្វារក្រុង* ន័យចំ "ទ្វារ" (មើលការពន្យល់ លប ២២:១៧) មើល ១៥:៧ ។

**១៣:៣** *ពួកអ្នកធំ* គ្រោះរាំងស្ងួត គឺមានការបះពាល់ដល់មនុស្សគ្រប់វណ្ណៈទាំងអស់ ។ ក៏គ្រលុំក្បាល នៅពេលដែលមានការកាន់ទុក្ខ (មើល ខ.៤ ២យស ១៥:៣០ ធៀបនឹង ២សយ ១៩:៤) ។

**១៤:៤** *ដោយគ្មានភ្លៀងធ្លាក់មកលើស្រុកសោះ* មើល ១ពវ ១៧:៧ ខុសគ្នានៅស្រុកអេស៊ីព្ទ មានទឹកមកទីទន្លេនីល ជាទឹកដីបរិសុទ្ធ ដែលពឹងលើទឹកជ្រោះធ្លាក់មក ។

**១៤:៦** *វាដង្ហក់* ក្នុងព្រះគម្ពីរភាសាហេព្រើរគូសបញ្ជាក់ពាក្យនេះ គឺគេបានបកប្រែថា "ការដកដង្ហើមស្រូបយកខ្យល់ចូល" នៅក្នុង ២:២៤ ។ មានលាព្រៃញី១ (ក្រុងយេរូសាឡិម) នៅកណ្តាលថ្ងៃក្តៅ នៅពេលដែលលាព្រៃឈ្មោលកំពុងតែដង្ហក់ជាខ្លាំង ដោយសារគ្រោះរាំងស្ងួតកើតមានឡើងមកពីអំពើបាបរបស់ពួកយូដា ។ *ភ្នែកវាស្រវាំងទៅ* មើល ទដ ៦:៧ និងការពន្យល់ ។

**១៤:៧–៩** ហោរាអធិស្ឋានតំណាងឱ្យបណ្តាជន (មើល ខ.១១) ។

**១៤:៧** *ដោយយល់ដល់ព្រះនាមទ្រង់* សូមមើល ខ.២១ យក ៧:៩ អស ៤៨:៩–១១ ។ *យើងខ្ញុំបានធ្វើបាបនឹងទ្រង់* មើល ២:១៩ ៣:២២ ៥:៦ មានន័យថា ការបោះបង់សេចក្តីជំនឿ ។

**១៤:៨** *ឱទីសង្ឃឹមនៃអ៊ីស្រាអែល* សូមមើល ខ.២២ ១៧:១៣ ៥០:៧ កច ២៨:២០ ។

មនុស្សស្រឡាំងកាំង គឺដូចជាមនុស្សខ្លាំងពូកែដែលពុំអាច
នឹងជួយសង្គ្រោះបានឡើយផង[ត] ប៉ុន្តែ ឱព្រះយេហូវ៉ាអើយ
ទ្រង់គង់កណ្ដាល[ថ]យើងខ្ញុំរាល់គ្នា ហើយយើងខ្ញុំក៏បានហៅ
តាមព្រះនាមទ្រង់ដែរ[ទ] សូមកុំលះចោល[ធ]យើងខ្ញុំឡើយ ។
១០ព្រះយេហូវ៉ាទ្រង់មានបន្ទូលពីជនជាតិនេះដូច្នេះ ថា
គេចូលចិត្តដើរសាត់ព្រាត់ គេមិនបានឃាត់ជើងគេ ឡើយ[ន]
ហេតុនោះព្រះយេហូវ៉ា ទ្រង់ក៏មិនព្រមទទួល[ប]គេ ដែរ
ក្នុងពេលឥឡូវនេះ ទ្រង់កំពុងតែនឹកចាំ[ផ] ពីអំពើទុច្ចរិត
របស់គេ ហើយនឹងធ្វើទោសដល់គេជាពិត[ព] ១១ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលមកខ្ញុំថា កុំឱ្យអធិស្ឋាន[ភ]សូមសេចក្ដីល្អឱ្យជន
ជាតិនេះឡើយ ១២កាលណាគេតមអត់ នោះអញមិនព្រម
ស្ដាប់សំរែករបស់គេទេ[ម] កាលណាគេថ្វាយដង្វាយដុត[យ]
និងដង្វាយម្សៅ[រ] នោះអញមិនព្រមទទួល[ល]ឡើយ គឺនឹងធ្វើឱ្យ
គេសូន្យទៅដោយដាវ[វ] អំណត់អត់[ស]និងអាសន្នរោគវិញ[ហ]។
១៣នោះខ្ញុំទូលថា ឱព្រះអម្ចាស់យេហូវ៉ាអើយ មើល
ពួកហោរា[ឡ]តែងតែប្រាប់គេថា ឯងរាល់គ្នានឹងមិនឃើញ
ដាវទេ ក៏មិនត្រូវសេចក្ដីអំណត់អត់ដែរ[អ] គឺអញនឹងឱ្យ
ឯងរាល់គ្នាមានសេចក្ដីសុខ[ក]នៅទីនេះជាពិត ១៤រួចព្រះ
យេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំថា ពួកហោរាគេទាយកុហក[ខ]
ដោយនូវឈ្មោះអញទេ អញមិនបានចាត់ប្រើ[គ]គេឡើយ ក៏
មិនបានបង្គាប់គេ ឬនិយាយនឹងគេដែរ គេទាយប្រាប់ឯង
រាល់គ្នាពីការជាក់ស្ដែងដែលមិនពិត[ឃ] ជាទំនាយតាម
របៀន[ង] គឺជាសេចក្ដីឥតប្រយោជន៍ទទេ ហើយជាសេចក្ដី
បញ្ឆោតនៃចិត្តខ្លួនគេវិញ ១៥ដូច្នេះ ឯពួកហោរាដែលទាយ
ដោយនូវឈ្មោះអញ ឥតមានអញចាត់ប្រើឡើយ ជាអ្នក
ដែលថាដាវ និងសេចក្ដីអំណត់អត់ នឹងមិនមកក្នុងស្រុក
នេះទេ នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលពីពួកហោរានោះ
ថា គេនឹងត្រូវវិនាសអស់ទៅ[ច]ដោយសារដាវនឹងសេចក្ដី
អំណត់នោះឯង[ឆ] ១៦ហើយពួកជនដែលគេបានទាយប្រាប់
នោះ នឹងត្រូវបោះចោលទៅក្នុងផ្លូវនៃក្រុងយេរូសាឡិម
ដោយព្រោះសេចក្ដីអំណត់ហើយនឹងដាវដែរ ឥតមានអ្នក
ណានឹងកប់[ជ]ខ្មោចគេឡើយ គឺទាំងខ្លួនគេ ប្រពន្ធគេ និងកូន
ប្រុសកូនស្រីគេផង[ឈ] ពីព្រោះអញនឹងចាក់អំពើលាមក
អាក្រក់របស់គេទៅលើគេវិញ[ញ] ១៧ឯងត្រូវប្រាប់ពាក្យនេះ
ដល់គេថា សូមឱ្យខ្ញុំហូរទឹកភ្នែក[ដ]សស្រាក់ទាំយប់ទាំងថ្ងៃ
ឥតឈប់ឈរឡើយ ពីព្រោះកូនក្រមុំ[ឋ]របស់សាសន៍ខ្ញុំបាន
ត្រូវខ្ទេចខ្ទី ជាការបាក់បែកយ៉ាងធំ ដោយរបួសជាទំងន់[ឌ]
១៨បើខ្ញុំចេញទៅឯវាល នោះមើល មានសុទ្ធតែសាកសព
ដែលស្លាប់ដោយដាវ ហើយបើខ្ញុំចូលទៅក្នុងទីក្រុងវិញ
នោះមើល មានសុទ្ធតែមនុស្សដែលឈឺដោយអត់ឃ្លាន[ឍ]

**១៤:៩** ត អស ៥០:២ ថ លប ១៧:៧ យរ ៨:១៩ ទ អស ៦៣:១៩ យរ ១៥:១៦ ធ ទដ ២៧:៩ **១៤:១០** ន ទដ ១១៩:១០១ យរ ២:២៥ ប យរ ៦:២០ អម ៥:២២ ផ ហស ៧:២ ៩:៩ អម ៨:៧ ព យរ ៤៤:២១-២៣ ហស ៨:១៣ អម ៣:២ **១៤:១១** ភ នក ៣២:១០ ១សយ ២:២៥ **១៤:១២** ម ចទ ១:៤៥ ១សយ ៨:១៨ យរ ១១:១១ យ លវ ១:១-១៧ យរ ៧:២១ រ លវ ២:១-១៦ ល អម ៥:២២ វ អស ៥១:១៩ យរ ៩:១៦ ស យរ ១៥:២ ១៦:៤ ហ យរ ២១:៦ ២៧:៨,១៣ ៣២:២៤ ៣៤:១៧ អគ ១៤:២១ **១៤:១៣** ឡ ចទ ១៨:២២ យរ ២៧:១៤ ៣៧:១៩ អ យរ ៥:១២ ក អស ៣០:១០ យរ ៤:១០ **១៤:១៤** ខ យរ ៥:១ ២៣:២៥ ២៧:១៤ អគ ១៣:២ គ យរ ២៣:២១,៣២ ២៩:៣១ អគ ១៣:៦ ឃ យរ ២៣:១៦ បទ ២:៩ ង អគ ១២:២៤ **១៤:១៥** ច យរ ២០:៦ អគ ១៤:៩ ឆ យរ ៥:១២-១៣ ១៦:៤ បទ ១:១៩ **១៤:១៦** ជ ទដ ៧៩:៣ ឈ យរ ៧:៣៣ ញ សភ ១:៣១ យរ ១៧:១០ **១៤:១៧** ដ ទដ ១១៩:១៣៦ ឋ ២ពវ ១៩:២១ អស ២៣:១២ ឌ យរ ៨:២១ **១៤:១៨** ឍ អគ ៧:១៥

**១៤:៩** *ហើយយើងខ្ញុំក៏បានហៅតាមព្រះនាមទ្រង់* យើងជាកម្មសិទ្ធិរបស់ព្រះ ទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើង ដែលមានវត្តមាន គង់នៅសព្វថ្ងៃនេះ (មើលការពន្យល់ ៧:១០) ។

**១៤:១០–១២** ព្រះអម្ចាស់ទ្រង់ឆ្លើយតប ។

**១៤:១០–១១** *ជនជាតិនេះ* ព្រះមិនបានទទួលស្គាល់គេ ជារាស្ត្ររបស់ទ្រង់ទេ (មើល អស ៦:៩–១០ ៨:៦,១១–១២ និងការពន្យល់ផងដែរ នក ១៧:៤) ។

**១៤:១០** *ដើរសាត់ព្រាត់* គេដើរតាមព្រះក្លែងក្លាយ (មើល ២:២៣, ៣១) ។ *ហេតុនោះព្រះយេហូវ៉ា មិនទទួលយកគេទេ . . . អំពើទុច្ចរិតរបស់គេ* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លាទាំងបីនេះ គឺបានដក់ស្រង់ដោយត្រង់តាមពាក្យពី ហស ៨:១៣ (ធៀបនឹង អស ៩:៩) ។

១៤:១១ កុំឱ្យអធិស្ឋាន មើលការពន្យល់ ៧:១៦ ធៀបនឹង ១សយ ៧:៨ ១២:១៩ ។

**១៤:១២** នោះអញមិនព្រមទទួលឡើយ មើលខ.១០ ។ យញ្ញបូជានោះឥតមានប្រយោជន៍ នៅពេលដែលគេធ្វើឡើង ដោយមិនមានការប្រែចិត្តនោះ (មើលការពន្យល់ ៦:២០) ។ ដាវ អំណត់អត់ និងអាសន្នរោគ នេះជាបណ្ដាសា ដោយសារការមិនធ្វើតាមសេក្ដីតាំងសញ្ញា (សូមមើល លវ ២៦:២៥–២៦) បញ្ហាទាំងបីនេះកើតឡើងជាដំបូង ដែលមាន១៥ដង នៅក្នុងព្រះគម្ពីរយេរេមា (មើលសេចក្ដីផ្ដើម ផ្នែកអក្សរសាស្ត្រ មើលផងដែរ អគ ៥:១៦–១៧ និងការពន្យល់) ។

**១៤:១៣** លោកយេរេមារំឭកព្រះអម្ចាស់ ចំពោះអ្វីដែលហោរាខុសឆ្គងបាននិយាយថា *មិនឃើញមានដាវទេ ក៏មិនត្រូវសេចក្ដីអំណត់អត់ដែរ* មើល ៥:១២ ។ *មានសេចក្ដីសុខ* លោកយេរេមានិយាយយ៉ាងល្អិតល្អន់ចំពោះហោរាខុសឆ្គងអំពី "សេចក្ដីសុខសាន្ត សន្តិភាព" (មើល ៦:១៤ ៨:១១) ។

**១៤:១៤–១៨** ព្រះអម្ចាស់ទ្រង់ឆ្លើយតប ។

**១៤:១៤** *គេទាយកុហក* មើល ៥:១២ ។ *ដោយនូវឈ្មោះអញ* មើលចទ ១៨:២០,២២ ។ ហើយជាសេចក្ដីបញ្ឆោតចិត្តខ្លួនគេវិញ មើល ២៣:២៦ ។

**១៤:១៥** *ពួកហោរា . . . គេនឹងត្រូវវិនាសអស់ទៅ* មើល ២៨:១៥–១៧ ចទ ១៨:២០ ។

**១៤:១៦** *ឥតមានអ្នកណានឹងកប់ខ្មោចគេឡើយ* មើលការពន្យល់ ៧:៣៣ ។ *ប្រពន្ធគេ និងកូនប្រុសកូនស្រីគេ* គ្រប់គ្នានឹងត្រូវវិនាស ដោយសារគេថ្វាយបង្គំដល់ព្រះក្លែងក្លាយ (មើលការពន្យល់ ៧:១៨) ។

**១៤:១៧** *សូមឱ្យខ្ញុំហូរទឹកភ្នែកសស្រាក់ទាំងយប់ទាំងថ្ងៃ* មើល ៩:១៨ ១៣:១៧ ។ *កូនក្រមុំរបស់សាសន៍ខ្ញុំ* ន័យចំ "កូនស្រីរបស់រាស្ត្រខ្ញុំ" មើល ៨:១១ អស ២២:៤ និងការពន្យល់ ២ពវ ១៩:២១) ។

ដ្បិតពួកហោរា និងពួកសង្ឃ តែងតែចុះឡើងក្នុងស្រុក
ឥតដឹងអ្វីទេ[ណ] ។
១៩តើទ្រង់បានបោះបង់ចោលពួកយូដាជាដាច់ខាតឬ[ត]
តើព្រះហឫទ័យទ្រង់ស្អប់ខ្ពើមក្រុងស៊ីយ៉ូនឬអី ហេតុអ្វីបាន
ជាទ្រង់វាយយើងរាល់គ្នា ហើយមិនឱ្យជាឡើងវិញសោះ[ថ]
យើងខ្ញុំបានរង់ចាំថានឹងបានសេចក្ដីសុខ តែឥតមានអ្វីល្អ
មកឡើយ ក៏សង្ឃឹមនឹងបានជា តែមើល បានតែសេចក្ដី
ភ័យវិញ[ទ] ២០ឱព្រះយេហូវ៉ាអើយ យើងខ្ញុំទទួលស្គាល់[ធ]អំពើ
អាក្រក់របស់យើងខ្ញុំហើយ ព្រមទាំងសេចក្ដីទុច្ចរិតរបស់
ពួកឰយុកោយើងខ្ញុំផង[ន] ដ្បិតយើងខ្ញុំបានធ្វើបាប[ប]នឹងទ្រង់
ពិត ២១សូមកុំស្អប់យើងខ្ញុំឡើយ ដោយយល់ដល់ព្រះនាម
ទ្រង់[ផ] សូមកុំបង្អាប់បល្ល័ង្កនៃសិរីល្អរបស់ទ្រង់[ព] សូមនឹកចាំ
ឡើងវិញ ហើយកុំផ្ដាច់សេចក្ដីសញ្ញា[ភ] ដែលទ្រង់បានតាំង
នឹងយើងខ្ញុំឡើយ ២២ក្នុងអស់ទាំងព្រះឥតប្រយោជន៍[ម]របស់
សាសន៍ដទៃ តើមានណាមួយបង្អុរឱ្យមានភ្លៀងធ្លាក់មក
បានឬ[យ] តើផ្ទៃមេឃនឹងឱ្យធ្លាក់ភ្លៀង១មេបានឬទេ ឱព្រះ
យេហូវ៉ា ជាព្រះនៃយើងខ្ញុំអើយ តើមិនមែនជាទ្រង់វិញទេ
ឬអី ដូច្នេះ យើងខ្ញុំនឹងទន្ទឹងចាំតែទ្រង់ ដ្បិតគឺទ្រង់ហើយ
ដែលបានធ្វើគ្រប់ការទាំងនេះ[រ] ។

**១៥** ១លំដាប់នោះ ព្រះយេហូវ៉ា ទ្រង់មានបន្ទូលមក ខ្ញុំថា

**១៤:១៨** ណ ២រប ៣៦:១០ យរ ១៣:១៧
**១៤:១៩** ត យរ ៧:២៩ ថ អស ១:៦ យរ ៣០:១២–១៣ ទ យប ១៩:៨ យរ ៨:១៥
**១៤:២០** ធ យរ ៣:១៣ ន លវ ២៦:៤០ ១ពវ ៨:៤៧ អរ ៩:៦ ប ពច ១០:១០ ដយ ៩:៧–៨
**១៤:២១** ផ ខ.៧ យស ៧:៩ ព អស ៦២:៧ យរ ៣:១៧ ភ នក ២:២៤
**១៤:២២** ម អស ៤១:២៤ ៤៤:១០ យរ ១០:១៥ ១៦:១៩ ហព ២:១៨ យ ១ពវ ៨:៣៦ ទដ ១៣៥:៧ រ អស ៤៣:១០
**១៥:១** ក នក ៣២:១១ ជន ១៤:១៣–២០

ទោះបើមានម៉ូសេ[ក] ឬសាំយូអែល[ខ]ឈរនៅមុខអញក៏ដោយ
គង់តែចិត្តអញមិនបែរទៅឯជនជាតិនេះវិញឡើយ[គ] ចូរ
បោះគេឱ្យផុតពីភ្នែកអញចេញ[ឃ] ហើយឱ្យគេចេញទៅចុះ
២បើកាលណាគេសួរឯងថា តើឱ្យយើងចេញទៅឯណា
នោះចូរឱ្យឯងប្រាប់គេថា ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះ ឯពួកណាដែលសំរាប់ស្លាប់ នោះត្រូវចេញទៅស្លាប់
ចុះ ហើយពួកណាដែលសំរាប់ដាវ[ង] ឱ្យគេទៅឯដាវទៅ
និងពួកណាដែលសំរាប់អំណត់អត់ ឱ្យគេអត់ឃ្លានចុះ[ច] ឯពួក
ណាដែលសំរាប់ដឹកទៅជាឈ្លើយ នោះឱ្យគេទៅជាឈ្លើយ
ដែរ[ឆ] ៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញនឹងដំរូវឱ្យមាន
៤មុខ[ជ]កើតឡើងដល់គេ គឺដាវ[ឈ]សំរាប់កាប់សំឡាប់១ឆ្កែ[ញ]
សំរាប់ហែកស៊ី១ និងសត្វហើរ[ដ]លើអាកាស១ ហើយសត្វ
ព្រៃនៅផែនដីសំរាប់ជញ្ជែងស៊ី ហើយបំផ្លាញផង[ឋ] ៤អញ
នឹងធ្វើឱ្យគេត្រូវបោះទៅមក[ឌ]នាកណ្ដាលអស់ទាំងសាសន៍
នៅលើផែនដី[ឍ] ដោយព្រោះម៉ានាសេ[ណ] ជាបុត្រាហេសេគា

ខ ១សយ ១:២០ ៧:៨ គ ១សយ ២:២៥ យរ ៧:១៦ ឃ ២ពវ ១៧:២០ យរ ១៦:១៣ **១៥:២** ង យរ ៤២:២២ ៤៣:១១ ៤៤:១៣ ច ចទ ២៨:២៦ យរ ១៤:១២ បទ ៤:៩ ឆ អគ ១២:១១ វវ ១៣:១០ **១៥:៣** ជ ជន ៣៣:៤ ឈ លវ ២៦:២៥ ញ ១ពវ ២១:១៩ ២ពវ ៩:៣៦ ដ ចទ ២៨:២៦ ឋ លវ ២៦:២២ អគ ១៤:២១ ៣៣:២៧ **១៥:៤** ឌ យរ ២៤:៩ ២៩:១៨ ៣៤:១៧ ឍ ចទ ២៨:២៥ យប ១៧:៦ ណ ២ពវ ២១:២ ២៣:២៦–២៧

**១៤:១៩–២២** ហោរាអធិស្ឋានក្នុងនាមឱ្យបណ្ដាជន ។

**១៤:២០** *សេចក្ដីទុច្ចរិតរបស់ពួកឰយុកោយើងខ្ញុំ* សូមមើល ២:៥–៦ ៧:២៥–២៦ ។ *ដ្បិតយើងខ្ញុំបានធ្វើបាបនឹងទ្រង់ពិត* ការប្រែចិត្តនាំឱ្យមានការស្ដាបនាឡើងវិញ (មើល ចទ ៣០:២–៣) ។

**១៤:២១** *ដោយយល់ដល់ព្រះនាមទ្រង់* មើល អគ ២០:៩ និងការពន្យល់ ។ បល្ល័ង្កនៃសិរីល្អរបស់ទ្រង់ ព្រះវិហារក្រុងយេរូសាឡិម (មើល ១៧:១២ ២ពវ ១៩:១៤–១៥ ទដ ៩៩:១–២) ។ *សូមនឹកចាំឡើងវិញ ហើយកុំផ្ដាច់សេចក្ដីសញ្ញា* លោកយេរេមា ដដែកតវ៉ា ចំពោះសេចក្ដីសន្យារបស់ព្រះនៅជំនាន់ដើម បានឃើញមាននៅក្នុង លវ ២៦:៤៤–៤៥ ។

**១៤:២២** មើល ហស ២:៨,២១–២២ ។ *ក្នុងអស់ទាំងព្រះឥតប្រយោជន៍សាសន៍ដទៃ* មើលការពន្យល់ ២:៥ ។ *ដ្បិតគឺទ្រង់ហើយ* មានតែព្រះអម្ចាស់១គត់ (មិនមែនព្រះបាលឡើយ) ដែលទ្រង់អាចនឹងបង្អោរទឹកភ្លៀង និងធ្វើឱ្យមានគ្រោះរាំងស្ងួត (មើល ខ.១) ។ *ដូច្នេះ យើងខ្ញុំទទឹងចាំតែទ្រង់* មើលការពន្យល់ ខ.៨ ។

**១៥:១–៩** ព្រះអម្ចាស់ទ្រង់ឆ្លើយតប រួមទាំងនៅក្នុងផ្នែកនេះផង (មើលការពន្យល់ ១៤:១–១៥:៩) ។

**១៥:១** *ទោះបើមានម៉ូសេ ឬសាំយូអែល* ទោះបីគេមានកេរ្ដិ៍ឈ្មោះល្បី ហើយអធិស្ឋានទូលអង្វរជំនួសអំពើបាបរបស់អ៊ីស្រាអែលក្ដី (មើល នក ៣២:១១–១៤,៣០–៣៤ ជន ១៤:១៣–៣៣ ចទ ៩:១៨–២០,២៥–២៩ ១សយ ៧:៥–៩ ១២:១៩–២៥ ទដ ៩៩:៦–៨) ។ *ឈរនៅមុខអញ* ជាឥរិយាបទរបស់អ្នកបម្រើរបស់ព្រះ ដែលឈរអធិស្ឋាន នៅចំពោះព្រះភក្ត្រ័របស់ព្រះ (មើល លប ១៨:២២ មក ១១:២៥) ។ *ហើយឱ្យគេចេញទៅចុះ* ព្រះមិនព្រមស្ដាប់តាមសេចក្ដីអធិស្ឋានរបស់មនុស្សអាក្រក់នោះឡើយ គេត្រូវតែរកអ្នកជំនួយរបស់ព្រះឱ្យជួយដល់គេវិញ (មើលការពន្យល់ ៧:១៦ ១៤:១១–១២) ។

**១៥:២** មើល អគ ១៤:២១ ៣៣:២៧ ។ *ស្លាប់* ប្រហែលជាគេស្លាប់ដោយសារជម្ងឺអាសន្នរោគ មើល ១៤:២ និងការពន្យល់ ពេលដែលមាន "ដាវ អាសន្នរោគ និងគ្រោះអំណត់អត់" ទាំងបីយ៉ាងនេះ គឺជាការបំផ្លាញរបស់ព្រះ ពាក្យទាំងបីនេះ គឺមានន័យដូចគ្នានៅក្នុងព្រះគម្ពីរភាសាហេព្រើរគឺ "គ្រោះទុរភិក្ស" ដូចគ្នានឹងពាក្យ "គ្រោះអំណត់អត់" នៅក្នុង ១៤:១២ ។

**១៥:៣–៤** ឃើញមាននៅក្នុង ចទ ២៨:២៥–២៦ ។

**១៥:៣** *តំរូវឱ្យមាន៤មុខ* មិនដូចគ្នាទាំង៤នៅក្នុងខ.២ ប៉ុន្តែបាននិយាយយ៉ាងលំអិត ចំពោះទណ្ឌកម្មបីយ៉ាង ដែលគេបានសម្លាប់គេដោយមុខដាវនៅសតវត្សទី៧មុនគ្រីស្តសករាជ ។ ចំពោះសន្ធិសញ្ញានៅក្រោមចំណុះរបស់ស្ដេចអេសារ–ហាដោន បង្ហាញដូចគ្នា គឺបណ្ដាសា "សូមឱ្យអ្នកដឹកនាំនីនូតា (Ninurta) ដែលជាព្រះរបស់សាសន៍ដទៃ ធ្វើឱ្យគេដួលចុះ ហើយស្លាប់រាបដល់ដី ហើយសាច់គេសម្រាប់សត្វឥន្ទ្រី និងជាចំណីដល់សត្វត្មាតសូមឱ្យឆ្កែ និងជ្រូកស៊ីសាច់គេជាអាហារ ។ *ឆ្កែ* មើល ១ពវ ២១:២៣ ។ *ហើយសត្វព្រៃនៅផែនដីសំរាប់ជញ្ជែងស៊ី* មើល វវ ៦:៨ ។

**១៥:៤** *គេត្រូវបោះទៅមក* ក្នុងព្រះគម្ពីរភាសាហេព្រើសម្រាប់ពាក្យនេះបានបកប្រែថា "របស់គួឱ្យស្អប់ខ្ពើម" ដូចគ្នានៅក្នុង ចទ ២៨:២៥ ។ ដោយ

ស្ដេចស្រុកយូដា និងការដែលទ្រង់បានប្រព្រឹត្តនៅក្រុង
យេរូសាឡិម ។
៥ឱក្រុងយេរូសាឡិមអើយ តើអ្នកណានឹងអាណិតប្រណី[ត]
ដល់ឯង ឬអ្នកណានឹងសោកស្ដាយឯង តើអ្នកណានឹងបែរ
មកសួរពីសេចក្ដីសុខទុក្ខរបស់ឯង ៦ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា ឯងបានបោះបង់ចោល[ថ]អញហើយ ឯងបាន
រាថយចេញ ហេតុនោះបានជាអញលូកដៃ[ទ]ទៅទាស់នឹងឯង
ហើយបំផ្លាញឯងបង់ អញណាយចិត្តហើយ ដោយការផ្លាស់
ប្រែគំនិត[ធ] ៧អញបានអុំ[ន]គេ ដោយចង្អេរ នៅត្រង់ទ្វារក្រុង
ក្នុងស្រុក អញបានធ្វើឱ្យបាត់បង់[ប]កូនអស់ទៅ គឺអញបាន
បំផ្លាញរាស្ត្រអញហើយ[ផ] ព្រោះគេមិនបានបែរត្រឡប់មក
ពីផ្លូវរបស់គេទេ[ព] ៨ស្រីមេម៉ាយ[ភ]របស់គេបានចំរើនជា
ច្រើនឡើងនៅមុខអញ លើសជាងខ្សាច់នៅមាត់សមុទ្រទៅ
ទៀត អញបាននាំអ្នកបំផ្លាញ[ម]ម្នាក់មកលើ ម្ដាយរបស់ពួក
កំឡោះៗទាំងថ្ងៃត្រង់ អញបានបណ្ដាលឱ្យមានសេចក្ដីទុក្ខ
ព្រួយ និងសេចក្ដីស្ញែងខ្លាចលោមកលើគេភ្លាម[យ] ៩ស្ត្រីណា
ដែលបានបង្កើតកូន៧នាក់ក៏ល្វើយទៅ[រ] រួចប្ដូងវិញ្ញាណ
ចេញ[ល]ពន្លឺរបស់នាងបានលិចទៅក្នុងកាលដែលនៅថ្ងៃ
នៅឡើយ នាងបានត្រូវអៀនខ្មាស[វ] ហើយជ្រប់មុខទៅ ឯ
ពួកដែលសល់នៅ នោះអញនឹងប្រគល់ដាវ[ស] នៅមុខ
ពួកខ្មាំងសត្រូវរបស់គេ[ហ] នេះហើយជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ។
១០ម៉ែអើយ វរហើយខ្ញុំ ដ្បិតម៉ែបានបង្កើតខ្ញុំមក[ឡ] ជា
មនុស្សទទឹងទាស់ ហើយជជែកបន្ទោសដលលោកីយទាំង
មូល[អ] ខ្ញុំមិនបានឱ្យអ្នកណាខ្ចី[ក] ក៏មិនបានខ្ចីពីគេផងដែរ
ប៉ុន្តែគេប្រទេចផ្ដាសា[ខ]ខ្ញុំគ្រប់គ្នា ១១ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលតបថា ពិតប្រាកដជាអញនឹងចំរើនកំឡាំងឯង[គ] ឱ្យ
បានសេចក្ដីល្អទៅមុខ ពិតប្រាកដជាអញនឹងបណ្ដាលឱ្យ
ពួកខ្មាំងសត្រូវមកអង្វរ[ឃ]ដល់ឯងក្នុងគ្រាអាក្រក់ ហើយក្នុង
គ្រាវេទនា ។
១២តើដែកអាចនឹងបំបាក់បំបែកដែកពីស្រុកខាងជើង[ង]
ហើយនិងលង្ហិនបានឬទេ ១៣ឯធនធាននិងទ្រព្យសម្បត្តិ[ច]

**១៥:៥** ត អស ២៧:១១ ៥១:១៩ យរ ១៣:១៤ ១៦:១៣ ២១:៧ ណហ ៣:៧ **១៥:៦** ថ ចទ ៣២:១៦ ទ អស ៣១:៣ សផ ១:៤ ធ យរ ៧:២០ អម ៧:៨ **១៥:៧** ន អស ៤១:១៦ ប អស ៣:២៦ ផ យរ ១៨:២១ ព ២របា ២៨:២២ **១៥:៨** ភ អស ៤៧:៩ ម យរ ៤:៧ ៦:៤ យ យប ១៨:១១ **១៥:៩** រ ១សយ ២:៥ ល យប ៨:១៣ វ យរ ៧:១៩ ស យរ ២១:៧ ២៥:៣១ ហ ២ពវ ២៥:៧ យរ ១៩:៧ **១៥:១០** ឡ យប ៣:១ ១០:១៨-១៩ អ យរ ១:១៩ ក លវ ២៥:៣៦ នហ ៥:១-១២ ខ យរ ៦:១០ **១៥:១១** គ ខ.២១ យរ ៤០:៤ ឃ យរ ២១:១-២ ៣៧:៣ ៤២:១-៣ **១៥:១២** ង ចទ ២៨:៤៨ យរ ២៨:១៤ បទ ១:១៤ ហស ១០:១១ **១៥:១៣** ច ២ពវ ២៥:១៥

ព្រោះម៉ានាសេ . . . ទ្រង់បានប្រព្រឹត្តនៅក្រុងយេរូសាឡិម ម៉ានាសេជាស្ដេចល្អដែលជីតារបស់ទ្រង់ ស្ដេចយ៉ូសៀសបានប្រព្រឹត្តអំពើលាមកអាក្រក់ នៅក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែលជាយូរលង់ (មើល ២ពវ ២១:១-១១,១៦) ។ អំពើបាប របស់ទ្រង់ ជាមូលហេតុជាបឋម ដែលនាំឱ្យពួកយូដាត្រូវបំផ្លាញ (មើល ២ពវ ២១:១២-១៥ ២៣:២៦-២៧ ២៤:៣-៤) ។

**១៥:៥-៩** ជាកំណាព្យដែលទាក់ទងទៅនឹងការមកដល់ ការបំផ្លាញក្រុងយេរូសាឡិម នៅឆ្នាំ ៥៨៧ គ.ស (មើល បទ ១:១ ១២:២១ ២:១៣,២០) ។

**១៥:៥** ធៀបនឹង មថ ២៣:៣៧ ។

**១៥:៦** *ឯងបានបោះបង់អញហើយ* នេះជាន័យត្រង់ "ឯងបានបែរក្រោយវិញ" (ធៀបនឹង ៧:២៤ មើលការពន្យល់ ២:១៩) ។

**១៥:៧** *អញបានអុំគេ* មើលការពន្យល់ នរ ១:២២ ។ ការអុំគឺជាសញ្ញាមួយពីការជិនុំជម្រះ បានរកឃើញដែរ ៥១:២ សភ ២០:៨,២៦ អស ៤១:១៦ ។ នៅត្រង់ទ្វារក្រុងក្នុងស្រុក ពាក្យសាមញ្ញគឺ "ទ្វារក្រុង"(ដូចជានៅក្នុង ជន ៣:១៣) ទឹកដី ។ *ធ្វើឱ្យបាត់បង់កូន . . . រាស្ត្រអញ* មនុស្សវ័យក្មេងនឹងធ្លាក់ទៅក្នុងសង្គ្រាម ហើយពួកយូដា និងក្រុងយេរូសាឡិមនឹងទុកកូនចោល (មើល អគ ៥:១៧) ។ *គេមិនបានបែរត្រឡប់មកពីផ្លូវរបស់គេ* ន័យត្រង់គឺ "គេមិនប្រែចិត្ត" ដែលនិយាយនៅក្នុង អម ៤:៦,៨-១១ "គេមិនបានវិលបែរមករកអញវិញសោះ" ដូចគ្នានៅក្នុងកិរិយាសព្ទនៃព្រះគម្ពីរភាសាហេព្រើរបានប្រើ (មើល ការពន្យល់ ៣:១) ។

**១៥:៨** *ស្ត្រីមេម៉ាយរបស់គេបានចំរើនជាច្រើនឡើងនៅមុខអញ លើសជាងខ្សាច់នៅមាត់សមុទ្រទៅទៀត* នេះជាសោកនាដកម្ម ទៅលើកូនចៅគេជាច្រើន ដោយសារការមិនធ្វើតាមសេចក្ដីតាំងសញ្ញា (មើល លប ២២:១៧ និងការពន្យល់) ។ *ទាំងថ្ងៃត្រង់ . . . មកលើគេភ្លាម* ពួកទាហានគេធ្វើការវាយប្រហារនៅវេលាថ្ងៃត្រង់ (មើលការពន្យល់ ៦:៤) ។ *អ្នកបំផ្លាញ* ពួកបាប៊ីឡូន (មើលការពន្យល់ ៤:៧) ។ *បណ្ដាល* មើលការពន្យល់ ៤:១៩ ។

**១៥:៩** *កូន៧នាក់* ពេញលេញ ដែលមានកូនគ្រប់គ្រាន់ (មើល នរ ៤:១៥ និងការពន្យល់) ដែលគេនឹងត្រូវបំផ្លាញយ៉ាងឆាប់ ។ *ពន្លឺរបស់នាងនឹងបានលិចទៅ ក្នុងកាលនៅថ្ងៃនៅឡើយ* មើល អម ៨:៩ ធៀបនឹង មថ ២៧:៤៥ និងការពន្យល់ ។ ឯពួកអ្នកដែលសល់នៅ ន័យត្រង់ នៅសល់ (មើលការពន្យល់ ៦:៩) ។ គេនឹងត្រូវសម្លាប់ដាវមុខដាវ (មើល មីក ៦:១៤) ។

**១៥:១០-២១** នេះជាការលន់តួបាបជាលើកទី៣របស់លោកយេរេមា(មើល សេចក្ដីផ្ដើម អ្នកនិពន្ធ និងកាលបរិច្ឆេទ) ដែលរួមទាំងករណីនេះ ចំពោះការឆ្លើយតបទាំង២យ៉ាងរបស់ព្រះអម្ចាស់ (ខ.១១-១៤,១៩-២១) ។

**១៥:១០** មើល ២០:១៤-១៥ និងការពន្យល់ យក ៣:៣-១០ ។ *ខ្ញុំមិនបានឱ្យអ្នកណាខ្ចី ក៏មិនបានខ្ចីពីគេដែរ* ដែលមិនបានចូលរួមពាក់ព័ន្ធនឹងបញ្ហាដើម្បីដោះស្រាយជម្លោះ ឬឃោបល់ខុសគ្នានោះ ។

**១៥:១១-១៤** ព្រះអម្ចាស់មានបន្ទូលជាដំបូងដល់លោកយេរេមា(ខ.១១) បន្ទាប់មកទ្រង់បានមានបន្ទូលទៅកាន់បណ្ដាជនសាសន៍យូដា(ខ.១២-១៤)។

**១៥:១១** ព្រះលើកទឹកចិត្តលោកយេរេមា ។ *ពិតប្រាកដជាអញនឹងបណ្ដាលឱ្យពួកខ្មាំងសត្រូវមកអង្វរដល់ឯងក្នុងគ្រាអាក្រក់* បានកើតពិតប្រាកដ ឧទាហរណ៍នៅក្នុង ២១:១-២ ៣៧:៣ ៣៨:១៤-២៦ ៤២:១-៣ ។

**១៥:១២** នេះជាសំនួរបន្ទំ ដើម្បីទទួលចម្លើយជាអវិជ្ជមាន ។ *បបែកដែក* និម្មិតពីកំឡាំងខ្លាំងក្លា (មើល ២៨:១៣) ។ ពីស្រុកខាងជើង មកពីពួកក្រុងបាប៊ីឡូន (មើលការពន្យល់ អស ៤១:២៥) ។

របស់ឯង អញនឹងឱ្យដល់គេទុកជារបឹប[ឆ]ដោយឥតគិតថ្លៃ[ជ]
គឺ ដោយព្រោះអស់ទាំងអំពើបាបរបស់ឯង នៅគ្រប់ទាំងព្រំ
ដែនរបស់ឯង[ឈ] ១៤អញនឹងឱ្យឯងឆ្លងទៅជាមួយនឹងពួក
ខ្មាំងសត្រូវឯង ដល់ស្រុក១ដែលឯងមិនស្គាល់[ញ] ដ្បិតមាន
ភ្លើង[ដ]កាត់ឡើងក្នុងសេចក្តីកំហឹងរបស់អញ ភ្លើងនោះនឹង
ឆេះដល់ឯងរាល់គ្នា ។
១៥ឱព្រះយេហូវ៉ាអើយ ទ្រង់ជ្រាបហើយ សូមទ្រង់នឹក
ចាំពីទូលបង្គំ ហើយប្រោសទូលបង្គំផង សូមសងសឹក នឹង
ពួកអ្នកដែលបៀតបៀនទូលបង្គំ[ឋ] សូមកុំដកទូលបង្គំចេញ
ដោយទ្រង់ត្រូវរងទ្រាំជាយូរនោះឡើយ[ឌ] សូមជ្រាបថា ទូល
បង្គំរងទ្រាំងសេចក្តីដំនៀល ដោយយល់ដល់ទ្រង់[ឍ] ១៦ទូល
បង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំក៏បានទទួលទាន
លេបចូល[ណ]អស់ហើយ ព្រះបន្ទូលរបស់ទ្រង់ជាសេចក្តី
អំណរ ហើយជាទីរីករាយចិត្តដល់ទូលបង្គំ[ត] ដ្បិតឱព្រះ
យេហូវ៉ា ជាព្រះនៃពួកពលបរិវារអើយ ទូលបង្គំបានហៅ
តាមព្រះនាមទ្រង់[ថ] ១៧ទូលបង្គំមិនបានអង្គុយ[ទ]ក្នុងចំណោម
នៃពួកអ្នកដែលលេងសប្បាយ ហើយលោតកញ្ឆេងនោះ
ឡើយគឺទូលបង្គំបានអង្គុយតែឯង ដោយព្រះហស្ត[ធ]ទ្រង់
ដ្បិតទ្រង់បានឱ្យទូលបង្គំ ពេញដោយសេចក្តីគ្នាន់ក្នាញ់
១៨ហេតុអ្វីបានជាទូលបង្គំមានសេចក្តីទុក្ខព្រួយ នៅជានិច្ច
ហើយរបួសទូលបង្គំមើលមិនជា ក៏មិនព្រមសះសោះ[ន] ដូច្នេះ
តើទ្រង់នឹងបានដូចជាសេចក្តីបញ្ឆោត ដល់ទូលបង្គំជាពិត
គឺដូចជាទឹកដែលមិនទៀងឬ[ប] ។
១៩ហេតុនោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
បើឯងនឹងវិលមកវិញ នោះអញនឹងនាំឯងទៀត ដើម្បីឱ្យ
ឯងបានឈរនៅមុខ[ផ]អញ ហើយបើឯងនឹងញែករបស់ថ្លៃ
វិសេសចេញពីរបស់ស្មោកគ្រោក នោះឯងនឹងបានដូច
ជាមាត់អញ[ព] គេនឹងវិលមកឯងវិញ តែឯងមិនត្រូវត្រឡប់
ទៅឯគេទេ ២០អញនឹងធ្វើឱ្យឯងជាកំផែង[ភ]លង្ហិន មាន
គ្រឿងសស្ត្រាវុធដល់ជនជាតិនេះ គេនឹងច្បាំងនឹងឯង តែ
មិនអាចនឹងឈ្នះ[ម]បានទេ ដ្បិតអញនៅជាមួយនឹងឯង ដើម្បី
និងជួយសង្គ្រោះ ហើយប្រោសឯងឱ្យរួច[យ] នេះជាបន្ទូលនៃ
ព្រះយេហូវ៉ា ២១អញនឹងជួយឱ្យឯងរួច[រ]ពីកណ្តាប់ដៃនៃ

**១៥:១៣** ឆ ២ពវ ២៤:១៣ អគ ៣៨:១២–១៣ ជ ទដ ៤៤:១២ ឈ យរ ១៧:៣ **១៥:១៤** ញ ចទ ២៨:៣៦ យរ ៥:១៩ ដ ទដ ២១:៩ **១៥:១៥** ឋ ពច ១៦:២៨ ទដ ១១៩:៨៤ ឌ នក ៣៤:៦ ឍ ទដ ៤៤:២២ ៦៩:៧–៩ យរ ៦:១០ **១៥:១៦** ណ អគ ២:៨ ៣:៣ វវ ១០:១០ ត យប ១៥:១១ ទដ ១១៩:៧២,១០៣ ថ អស ៤៣:៧ យរ ១៤:៩ **១៥:១៧** ទ នរ ៣:៣ ទដ ១:១ ២៦:៤–៥ ធ យរ ១៦:៨ ធ ២ពវ ៣:១៥ **១៥:១៨** ន យប ៦:៤ យរ ១០:១៩ ៣០:១២ មីក ១:៩ ប យប ៦:១៥ ទដ ៩:១០ **១៥:១៩** ផ សក ៣:៧ ព នក ៤:១៦ **១៥:២០** ភ អស ៥០:៧ ម ទដ ១២៩:២ យ យរ ១:៨ ២០:១១ ៤២:១១ អគ ៣:៨ **១៥:២១** រ យរ ១:៨

**១៥:១៣–១៤** បានរំឭកឡើងវិញនៅក្នុងផ្នែក១យ៉ាងធំ ក្នុង ១៧:៣–៤ ។

**១៥:១៣** បានកើតឡើងជាប្រាកដនៅក្នុង ៥២:១៧–២៣ ។ *គេទុកជារបឹប ដោយឥតគិតថ្លៃ* ធៀបនឹង អស ៥៥:១ បណ្តាជន និងរបឹប នោះគេអាចយក ដោយសេរី (មើលការពន្យល់ អស ៥២:៣) ។

**១៥:១៤** *ដ្បិតមានភ្លើងកាត់ឡើងក្នុងសេចក្តីកំហឹងរបស់អញ* បានដកស្រង់មក ដោយន័យត្រង់ពី ចទ ៣២:២២ ដែលក្នុងព្រះគម្ពីរភាសាហេព្រើរបាន បកប្រែថា "ភ្លើងនោះបានឆេះឡើងដោយសារសេចក្តីកំហឹងរបស់អញ" ។

**១៥:១៥** *ទ្រង់ជ្រាបហើយ* ព្រះទ្រង់ជ្រាបដឹងរាល់អ្វីគ្រប់យ៉ាង ដែលលោក យេរេមាបានរងទុក្ខនោះ (មើល ខ.១០) ។ នឹកចាំ បញ្ជាក់ពីការនឹកដល់ (មើលការពន្យល់ លប ៨:១) ។

**១៥:១៦** *ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់* អញបានរំលាយគេ អញបាន បង្កើតគេ អញបានធ្វើឱ្យគេមានចំណែកជាមួយនឹងអញ (មើល អគ ២:៨–៣:៣ វវ ១០:៩–១០) ។ បានឃើញ ន័យត្រង់គឺ "បានរកឃើញ" ប្រហែល ជាសំដៅទៅលើ ការរុករកឃើញនូវព្រះគម្ពីរក្រិត្យវិន័យ នៅក្នុងព្រះវិហារ នៅក្នុងកំឡុងនៃការឡើងសោយរាជ្យស្តេចយ៉ូសៀស នៅក្នុង ៦២១ គ.ស (មើល ២ពវ ២២:១៣ ២៣:២ មើលការពន្យល់ ១:២) ។ *ហើយជាទីរីករាយចិត្តដល់ទូលបង្គំ* មើល ទដ ១:២ ។ *ដោយយល់ដល់ទ្រង់* មើល ១៤:៩ ។ ទូលបង្គំជាកម្មសិទ្ធិរបស់ទ្រង់ (មើលការពន្យល់ ៧:១០) ។

**១៥:១៧** *ទូលបង្គំបានអង្គុយតែឯង* លោកយេរេមាមិនដែលបានរៀបការ ឡើយ (មើល ១៦:២) ហើយគាត់បានទាក់ទាញដោយសារមិត្តភ័ក្ររបស់ ២ឬ៣នាក់ (មើលសេចក្តីផ្តើម អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។ *ព្រះហស្តទ្រង់* ព្រះហស្តព្រះ (មើល ២ពវ ៣:១៥ អស ៨:១១ និងការពន្យល់ អគ ១:៣ ៣:១៤,២២ ៣៧:១ ៤០:១) ។ *សេចក្តីគ្នាន់ក្នាញ់* ដោយសារអំពើបាបរបស់ យូដា (មើល ៦:១១) ។

**១៥:១៨** សំនួរបន្ទំ២បានប្រើ ដោយលោកយេរេមា ដើម្បីបញ្ជាក់ពីការ ដែលលោកយេរេមានិយាយជាដដែលអំពីខ្លួនគាត់ បេសកកម្ម និងសេចក្តី ស្មោះត្រង់របស់ព្រះ ។ *ហេតុអ្វីបានជាទូលបង្គំមានសេចក្តីទុក្ខព្រួយ . . . របួសទូលបង្គំមើលមិនជា ក៏មិនព្រមសះសោះ* ក្រុងយេរូសាឡិមបានរៀប រាប់ជាពណ៌នា នៅក្នុង ៣០:១២–១៥ ចំពោះសេចក្តីសន្យារបស់ព្រះ គឺការ ប្រោសឱ្យជា ៣០:១៧ ។ *សេចក្តីបញ្ឆោត* មើល មីក ១:១៤ ដែលពាក្យ "បញ្ឆោត"ប្រហែលជាសំដៅទៅលើ ខ្សែទឹកដែលហូរ ហើយបានរៀបរាប់ នៅក្នុង យប ៦:១៥–២០ ។ លោកយេរេមាគឺជាមនុស្សឯករាជ្យរបស់ព្រះ ដែលផ្ទុយគ្នា ចំពោះព្រះអម្ចាស់ដែលបានរៀបរាប់ តាំងពីដើមថា "ទ្រង់ជា ទឹកដ៏រស់" (មើល ២:១៣ និងការពន្យល់) ។

**១៥:១៩–២១** ព្រះអម្ចាស់បង្គាប់ដល់លោកយេរេមាឱ្យប្រែចិត្ត បន្ទាប់មក ទ្រង់លើកទឹកចិត្តគាត់ និងឆ្លើយតបដល់គាត់ ។

**១៥:១៩** *បើឯងនឹងវិលមកវិញ . . . នាំឯងទៀត . . . គេនឹងវិលមកឯងវិញ . . . មិនត្រូវត្រឡប់ទៅឯគេទេ* ពាក្យហេព្រើរគឺដូចគ្នា ពាក្យទាំង៤នោះ (មើលការពន្យល់ ៣:១ អស ១:២៥–២៦) ។ *បានឈរ* ន័យត្រង់ "ឈរពី មុខ" នេះជាឥរិយាបទដ៏សមរម្យ ចំពោះអ្នកបម្រើដែលស្តាប់បង្គាប់ដល់ព្រះ (មើល ជន ១៦:៩ ចទ ១០:៨) ។ *មាត់អញ* ន័យត្រង់ "មាត់" (មើល ១:៩ និងការពន្យល់ នក ៤:១៥–១៦ មើលផងដែរ នក ៧:១–២) ។

១៥:២០ មើល ១:៨,១៨–១៩ និងការពន្យល់ ។

**១៥:២១** *ជួយឱ្យឯងរួចពីកណ្តាប់ដៃនៃមនុស្សអាក្រក់* មើលឧទាហរណ៍

មនុស្សអាក្រក់[ល] ហើយនឹងលោះ[វ]ឯងចេញពីកណ្ដាប់ដៃ
មនុស្ស ដែលគួរស្ញែងខ្លាច[ស] ។

## ថ្ងៃអន្តរាយ

**១៦** ១ឱ្យព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់ខ្ញុំទៀត ថា
២មិនត្រូវឱ្យឯងយកប្រពន្ធ[ក] ឬបង្កើតកូនប្រុសកូនស្រី នៅ
ទីនេះទេ ៣ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលពីដំណើរកូន
ប្រុសកូនស្រីដែលកើតនៅទីនេះ ហើយពីម្ដាយដែលសំរាល
វាមក និងពីឪពុកដែលបង្កើតវានៅស្រុកនេះ ដូច្នេះថា[ខ]
៤គេនឹងស្លាប់ដោយលំបាកណាស់ឥតមានអ្នកណាយំសោក
ឡើយ ក៏នឹងគ្មានអ្នកណាកប់[គ]ខ្មោចគេដែរ គឺគេនឹងបាន
ដូចជាជីនៅដីវិញ[ឃ] គេនឹងត្រូវវិនាសបង់ដោយដាវ និង
សេចក្ដីអំណត់អត់[ង] ហើយខ្មោចគេនឹងបានសំរាប់ជាអា–
ហារដល់សត្វហើរលើអាកាស និងដល់សត្វព្រៃនៅផែន
ដី[ច] ។
៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា កុំឱ្យចូលទៅ
ក្នុងផ្ទះដែលគេកាន់ទុក្ខ ក៏កុំឱ្យទៅយំសោក ឬទួញទំនួញ
ព្រោះគេឡើយ ដ្បិតអញបានដកសេចក្ដីសុខរបស់អញ
គឺជាសេចក្ដីសប្បុរស និងសេចក្ដីអាណិតអាសូរ[ឆ]ចេញពីជន
ជាតិនេះហើយ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ៦មនុស្ស
ទាំងអស់ ទាំងធំទាំងតូច និងត្រូវស្លាប់នៅស្រុកនេះ[ជ] ឥត
មានអ្នកណាកប់ខ្មោចគេឡើយ[ឈ] មនុស្សក៏នឹងមិនយំសោក
ឬឆូត[ញ]សាច់ ឬកោ[ដ]សក់ដោយព្រោះគេដែរ ៧នឹងគ្មានអ្នក
ណាកាច់នំបុ័ង[ឋ]ក្នុងការសោយសោក[ឌ]នោះ ដើម្បីនឹងកំសាន្ត
ចិត្តពីដំណើរអ្នកដែលស្លាប់សោះ ក៏នឹងគ្មានអ្នកណាជូន
ពែងរំដោះទុក្ខ[ឍ]ដល់គេ ដោយព្រោះឪពុក ឬម្ដាយគេផង
៨ឯផ្ទះដែលគេកំពុងស៊ីលៀង នោះមិនត្រូវឱ្យឯងចូលទៅ
អង្គុយស៊ីផឹកជាមួយនឹងគេដែរ[ណ] ៩ដ្បិតព្រះយេហូវ៉ានៃពួក
ពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូល
ដូច្នេះថា មើល នៅគ្រាអាយុឯង ហើយនៅចំពោះភ្នែកឯង
នោះអញនឹងធ្វើឱ្យសំឡេង[ត]រីករាយ និងសំឡេងអរសប្បាយ
ព្រមទាំងសំឡេងប្ដីប្រពន្ធថ្មោងថ្មី[ថ]បាត់ចេញពីទីនោះទៅ[ទ] ។
១០លុះកាលណា ឯងបានប្រាប់ពាក្យនេះ ដល់ជនជាតិ
នេះរួចជាស្រេច ហើយគេសួរឯងថា ហេតុអ្វីបានជាព្រះ
យេហូវ៉ាមានបន្ទូលពីគ្រប់ទាំងការអាក្រក់យ៉ាងធំនេះទាស់
នឹងយើងដូច្នេះ តើយើងមានសេចក្ដីទុច្ចរិតណា ឬបាន
ប្រព្រឹត្តអំពើបាបយ៉ាងណា ទាស់នឹងព្រះយេហូវ៉ាជាព្រះ
នៃយើង[ធ] ១១នោះឯងត្រូវប្រាប់គេថា ព្រះយេហូវ៉ាទ្រង់

**១៥:២១** ល ទដ ៩៧:១០ វ យរ ៥០:៣៤ ស លប ៤៨:១៦ **១៦:២** ក មថ ១៩:១២ ១កថ ៧:២៦–២៧ **១៦:៣** ខ យរ ៦:២១ **១៦:៤** គ ខ.៦ យរ ២៥:៣៣ ឃ យរ ៩:២២ ង យរ ១៤:១៥ ច ចទ ២៨:២៦ ទដ ៧៩:១–៣ យរ ១៤:១២ ១៩:៧ **១៦:៥** ឆ យរ ១៥:៥ **១៦:៦** ជ យរ ៩:២១ អគ ៩:៥–៦ ឈ ខ.៤ ញ លវ ១៩:២៨ ដ លវ ២១:៥ យប ១:២០ **១៦:៧** ឋ ២សយ ៣:៣៥ ឌ យរ ២២:១០ អគ ២៤:១៧ ហស ៩:៤ ឍ បទ ១:៩,១៦ **១៦:៨** ណ នក ៣២:៦ សស ៧:២–៤ យរ ១៥:១៧ **១៦:៩** ត អស ២៤:៨ ៥១:៣ អគ ២៦:១៣ អម ៦:៤–៧ ថ ទដ ៧៩:៦៣ ទ អស ២២:១២–១៤ វវ ១៨:២៣ **១៦:១០** ធ ចទ ២៩:២៤ យរ ៥:១៩

៣៦:២៦ ៣៨:៦–១៣ ។

**១៦:១–១៧:១៨** ព្រះបន្ទូលអំពីគ្រោះមហន្តរាយ និងការកំសាន្ត និងសេចក្ដីពន្យល់អំពីគ្រោះមហន្តរាយដែលកើតឡើងជាលើសលប់ (១៦:១–១៣, ១៦–១៨ ១៦:២១–១៧:៦ ១៧:៩–១៣,១៨) ។ ពាក់កណ្ដាលផ្នែកនេះដំបូងគឺជាឃ្លាធម្មតា (១៦:១–១៨) និងពាក់កណ្ដាលផ្នែកទី២ គឺជាកំណាព្យ (១៦:១៩–១៧:១៨) ។

**១៦:២** ការងាររបស់លោកយេរេមា គឺជាការងារមួយដែលគាត់ប្រឈមមុខនឹងជីវិតឯកកោ (មើលការពន្យល់ ១៥:១៧) ដោយគ្មានការកំសាន្តចិត្ត និងគ្មានការគាំទ្រពីគ្រួសារ ។ *មិនត្រូវឱ្យឯង* ពាក្យក្នុងព្រះគម្ពីរហេព្រើរគូសបញ្ជាក់ពាក្យនេះ គឺគេបានប្រើក្នុងលក្ខណៈជាការបង្គាប់បញ្ជាជាអវិជ្ជមាន ដូចជា ឧទាហរណ៍នៅក្នុងបទបញ្ញត្តិទាំង១០ប្រការ (មើល នក ២០:៣–៤,១៣–១៧) ។ *នៅទីនេះ* ស្រុកយូដា និងក្រុងយេរូសាឡិម ជាពិសេសនៅពេលក្រោយមកទៀត (មើលឧ. សផ ១:៤) ។

**១៦:៤** ដោយលំបាកណាស់ ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "ការរងទុក្ខ" នៅក្នុង ១៤:៨ ។ ឥតមានអ្នកណាយំសោកឡើយ ក៏នឹងគ្មានអ្នកណាកប់ខ្មោចដែរ មើល ខ.៦ ៧:៣៣ និងការពន្យល់ ៨:២ ១៤:១៦ ២៥:៣៣ ។ *បានដូចជាជី* ន័យត្រង់ "លាមកសត្វ" (មើល ៨:២ ៩:២២ ២៥:៣៣) ។ *គេនឹងត្រូវវិនាសបង់ដោយដាវ និងសេចក្ដីអំណត់អត់* មើល ១៤:១៥–១៦ មើលការពន្យល់ ៥:១២ ។ *សំរាប់ជាអាហារដល់សត្វហើយលើអាកាស និងដល់សត្វនៅផែនដី* មើលការពន្យល់ ៧:៣៣ ។

**១៦:៥** *កុំឱ្យចូលទៅក្នុងផ្ទះដែលគេកាន់ទុក្ខ* មើលការបង្គាប់បញ្ជាដូចគ្នារបស់ផងព្រះនៅក្នុង អគ ២៤:១៦–១៧ ២២–២៣ ។

**១៦:៦** *មនុស្សក៏នឹងមិនយំសោក ឬឆូតសាច់ ឬកោសក់ដោយព្រោះគេដែរ* នេះជាសកម្មភាព ដែលជាការហាមប្រាមនៅក្នុងក្រិត្យវិន័យ (មើល លវ ១៩:២៨ ២១:២៥ និងការពន្យល់ ចទ ១៤:១ និងការពន្យល់) ។ ប៉ុន្តែពួកអ៊ីស្រាអែលបានអនុវត្តវាជាសញ្ញាមួយនៃការកាន់ទុក្ខ (មើល ៤១:៥ អគ ៧:១៨ មីក ១:១៦ ។

**១៦:៧** អាហារគឺតាមទម្លាប់ គេផ្ដល់ជូនដល់អ្នកដែលយំសោក (មើល ២សយ ៣:៣៥ ១២:១៦–១៧ អគ ២៤:១៧ ២២ ហស ៩:៤) ។ *ក៏នឹងគ្មានអ្នកណាជូនពែងរំដោះទុក្ខដល់គេ* ន័យត្រង់ "ពែងនៃការកំសាន្តចិត្ត" ពេលក្រោយមកទៀត នៅក្នុងជំនឿពួកយូដា ពែងពិសេសស្រាទំពាំងបាយជូ គឺសម្រាប់មេកាន់ទុក្ខ ។

**១៦:៨** *នោះមិនត្រូវឯងចូលទៅអង្គុយស៊ីផឹកជាមួយគេដែរ* វិបត្តិសព្វថ្ងៃនេះគឺជាពេលដែលមិនត្រូវជប់លៀង ឬកាន់ទុក្ខអ្វីដែរ (មើល ខ.៥) ។

**១៦:៩** មើល ៧:៣៤ ២៥:១០ ផ្ទុយគ្នានៅក្នុង ៣៣:១០–១១ ។

**១៦:១០–១៣** សំនួរដូចគ្នា ប៉ុន្តែទទួលបាននូវចម្លើយយ៉ាងល្អិតល្អន់ជាងនៅក្នុង ៥:១៩ (មើល ៩:១២–១៦ ២២:៨–៩ ចទ ២៩:២៤–២៨ ១ពវ ៩:៨–៩) ។

**១៦:១០** ធៀបនឹង សំនួរដូចគ្នានៅក្នុង មឡ ១:៦–៧ ២:១៧ ៣:៧–៨,១៣ ។

**១៦:១១** មើល ១១:១០ គេចូលចិត្តប្រព្រឹត្តអំពើបាប ដូចជាអ្នកដែលបាន

មានបន្ទូលថា គឺដោយព្រោះឰយុកោរបស់ឯងរាល់គ្នា
បានបោះបង់ចោលអញ ទៅតាមព្រះដទៃ ព្រមទាំងគោរព
ហើយថ្វាយបង្គំ[ន]ដល់វាផង គេបានបោះបង់ចោលអញ ឥត
ដែលរក្សាច្បាប់អញឡើយ[ប]
១២ហើយចំណែកឯងរាល់គ្នា
នោះបានប្រព្រឹត្តអាក្រក់ លើសជាងពួកឰយុកោឯងទៅ
ទៀត[ផ] ដ្បិតមើល ឯងរាល់គ្នាប្រព្រឹត្តតាមតែសេចក្តីរឹង
ចចេស នៅក្នុងចិត្ត[ព]អាក្រក់របស់ឯងរាល់រៀងខ្លួន ដល់
ម្ល៉េះ បានជាមិនព្រមស្តាប់តាមអញសោះ
១៣ហេតុនោះអញ
នឹងបោះឯងរាល់គ្នាចោលចេញពីស្រុកនេះ[ភ] ឱ្យទៅនៅឯ
ស្រុក១ដែលឯង ឬពួកឰយុកោឯងមិនបានស្គាល់ឡើយ[ម]
ហើយ នៅទីនោះ ឯងរាល់គ្នានឹងគោរពប្រតិបត្តិតាមព្រះ
ដទៃ[យ] ទាំងយប់ទាំងថ្ងៃ ពីព្រោះអញនឹងមិនអាណិតដល់ឯង
ទេ[រ] ។

១៤ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ដូច្នេះមើល នឹងមាន
គ្រាមកដល់[ល]ដែលគេនឹងលែងស្បថថា ដូចជាព្រះយេហូវ៉ា
ទ្រង់មានព្រះជន្មរស់ ជាព្រះដែលបាននាំពួកកូនចៅអ៊ី–
ស្រាអែលឡើងរួចពីស្រុកអេស៊ីព្ទមក[វ]
១៥គឺគេនឹងស្បថ
យ៉ាងនេះវិញថា ដូចជាព្រះយេហូវ៉ាមានព្រះជន្មរស់ ដែល
ទ្រង់បាននាំពួកកូនចៅអ៊ីស្រាអែល ឡើងរួចពីស្រុកខាង
ជើងមក[ស] ហើយពីអស់ទាំងប្រទេសដែលទ្រង់បានបណ្តេញ
គេនោះផង[ហ] អញនឹងនាំគេឱ្យវិលមក[ឡ]ក្នុងស្រុករបស់គេ
ជាស្រុកដែលអញបានឱ្យដល់ពួកឰយុកោគេ[អ] ។

១៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញនឹងចាត់
មនុស្សឱ្យទៅហៅពួកនេសាទជាច្រើនមក អ្នកទាំងនោះ
នឹងបង់សំណាញ់ប្រមូលគេ[ក] លំដាប់នោះអញនឹងចាត់ឱ្យ
ទៅហៅពួកព្រានជាច្រើនមក អ្នកទាំងនោះនឹងដេញចាប់[ខ]
គេនៅលើគ្រប់ទាំងភ្នំធំ និងភ្នំតូច ហើយនៅក្រហែងថ្ម
ទាំងប៉ុន្មានផង[គ]
១៧ដ្បិតភ្នែកអញមើលឃើញអស់ទាំងផ្លូវ
របស់គេ ហើយគេមិនកំបាំង[ឃ]ពីមុខអញទេ ឯអំពើទុច្ចរិត
របស់គេ ក៏មិនបិទបាំងពីភ្នែកអញដែរ[ង]
១៨នោះមុនដំបូង
អញនឹងសង[ច]អំពើទុច្ចរិត និងអំពើបាបរបស់គេ១ជា២[ឆ] គឺ
ព្រោះគេបានធ្វើឱ្យស្រុកអញទៅជាស្មោកគ្រោក ដោយ
សាកសពនៃរូបព្រះ[ជ]គួរស្អប់ខ្ពើម ហើយបានបំពេញស្រុក[ឈ]
ជាមរដករបស់អញ ដោយរបស់[ញ]គួរខ្ពើមឆ្អើមរបស់គេ[ដ] ។

១៩ឱព្រះយេហូវ៉ា ជាកំឡាំងនៃទូលបង្គំ ជាទីមាំមួន
ហើយជាទីពឹងជ្រក[ឋ]ដល់ទូលបង្គំ នៅគ្រាលំបាកអើយ ពួក
សាសន៍ទាំងប៉ុន្មាននឹងមក[ឌ]ឯទ្រង់ ពីអស់ទាំងចុងផែនដី

**១៦:១១** ន យប ៣១:២៧ ប ចទ ២៩:២៥–២៦ ១ពវ ៩:៩ ទដ ១០៦:៣៥–៤៣ **១៦:១២** ផ នក ៣២:៨ យរ ៧:២៦ អគ ២០:៣០ អម ២:៤ ព សស ៩:៣ យរ ៣:១៧ **១៦:១៣** ភ ២រប ៧:២០ ម ចទ ២៨:៣៦ យរ ៥:១៩ យ ចទ ៤:២៨ ១ពវ ៩:៩ រ យរ ១៥:៥ **១៦:១៤** ល យរ ២៩:១០ ៣០:៣ ៣១:២៧,៣៨ វ ចទ ១៥:១៥ **១៦:១៥** ស យរ ៣:១៨ ហ អស ១១:១១ យរ ២៣:៨ ឡ ទដ ៥៣:៦ អស ១១:១២ យរ ៣០:៣ ៣២:៤៤ អគ ៣៨:១៤ យអ ៣:១ អ ចទ ៣០:៣ អស ១៤:១

**១៦:១៦** ក អម ៤:២ ហព ១:១៤–១៥ ខ អម ៩:៣ មីក ៧:២ គ ១សយ ២៦:២០ **១៦:១៧** ឃ លប ៣:៨ សស ១២:១៤ មក ៤:២២ ១កថ ៤:៥ ហព ៤:១៣ ង ទដ ៥១:៩ សភ ១៥:៣ សផ ១:១២ **១៦:១៨** ច អស ៦៥:៦ ឆ អស ៤០:២ យរ ១២:៣ វវ ១៨:៦ ជ ទដ ១០១:៣ ឈ ជន ៣៥:៣៤ យរ ២:៧ ញ ១ពវ ១៤:២៤ ដ យរ ២:៧ ៤:១ អគ ៥:១១ ៨:១០ **១៦:១៩** ឋ ២សយ ២២:៣ ទដ ៤៦:១ ឌ អស ២:២ យរ ៣:១៧

បញ្ជាក់នៅទីនេះ គឺបានហៅថាការមិនធ្វើតាមសេចក្តីតាំងសញ្ញារបស់ព្រះអម្ចាស់ ។

**១៦:១២** ហើយចំណែកឯងរាល់គ្នានោះបានប្រព្រឹត្តអាក្រក់ លើសជាងពួកឰយុកោឯងទៅទៀត មើល ១ពវ ១៤:៩ ។ ការជំនុំជម្រះដែលនឹងកើតមានឡើង នោះនឹងមិនត្រូវបន្ទោសទៅលើអំពើបាបរបស់អ្នកជំនាន់មុនឡើយ (មើល ៣១:២៩–៣០ និងការពន្យល់ អគ ១៨:២–៤) ។ ឯងរាល់គ្នាប្រព្រឹត្តតាមសេចក្តីរឹងចចេស នៅក្នុងចិត្តអាក្រក់គេរៀងខ្លួន មើលការពន្យល់ ៣:១៧ មើលផងដែរ ៧:២៤ ។

**១៦:១៣** មើល ២៨::៣៦,៦៤ ។ *អញនឹងបោះឯងរាល់គ្នាចោលចេញពីស្រុក* ឱ្យទៅជាប់ជាឈ្លើយ (មើល ៧:១៥ ២២:២៦ ចទ ២៩:២៨) ។ *ឱ្យទៅឯស្រុក១ដែលឯង ឬពួកឰយុកោឯងមិនបានស្គាល់ឡើយ* គឺបាប៊ីឡូន (មើល ៩:១៦) ។

**១៦:១៤–១៥** ការរំឭកឡើងវិញចំពោះពាក្យដែលតាមន័យត្រង់ នៅក្នុង ២៣:៧–៨ អត្ថបទគំរោងមេរៀន ជិត១០០០ឆ្នាំ ក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល និក្ខមនំ (ឆ្នាំ ១៤៤៦ គ.ស) ការចាប់ជាឈ្លើយ (ឆ្នាំ ៥៣៧) ។ ការសាងសង់ឡើងវិញ (ឆ្នាំ) មើល អស ៤៣:១៦–២១ ៤៨:២០–២១ ៥១:៩–១១ ។ *ដូចជាព្រះយេហូវ៉ាមានព្រះជន្មរស់* មើលការពន្យល់ លប ៤២:១៥ ។

**១៦:១៥** *ឡើងរួចពីស្រុកខាងជើងមក* ពួកបាប៊ីឡូន (មើលការពន្យល់ អស ៤១:២៥) ។

**១៦:១៦** *ពួកនេសាទ . . . ពួកព្រាន* និមិត្តរូបពីអ្នកចម្បាំង (មើល អគ ១២:១៣ ២៩:៤ អម ៤:២ និងការពន្យល់) ។ *នៅលើគ្រប់ទាំងភ្នំធំ និងភ្នំតូច* ជាទី កន្លែងដែលបណ្តាជនបានគេចខ្លួន (មើល ៤:២ និងការពន្យល់) ។ *ហើយនៅក្រហែងថ្មទាំងប៉ុន្មានផង* ឃ្លានេះកើតឡើងនៅក្នុងព្រះគម្ពីរយេ–រេមា ៧:១៩ ។ ព្រះអម្ចាស់ប្រហែលជាបានហៅជាថ្មីនៅទីនេះ ចំពោះការក្រវាត់ សំពត់ទេសឯក "ដែលបានលាក់ទុកនៅក្នុងក្រហែងថ្ម" (១៣:៤) ។

**១៦:១៧** *ដ្បិតភ្នែកអញមើលឃើញអស់ទាំងផ្លូវរបស់គេ* មើល ៣២:១៩ ។ ហើយគេមិនកំបាំងពីអញឡើយ មើល ២៣:២៤ និងការពន្យល់ ។

**១៦:១៨** *អញនឹងសងអំពើទុច្ចរិត និងអំពើបាបរបស់គេ១ជា២* មើល ១៧:១៨ អស ៤០:២ និងការពន្យល់ ។ ដោយព្រោះគេបានធ្វើឱ្យស្រុកអញទៅជាសេចក្តីស្មោកគ្រោក គេបានធ្វើពិធិបុណ្យយ៉ាងស្មោគគ្រោក (មើល ២:៧ ៣:១–២ មើលការពន្យល់ផងដែរ លវ ៤:១២) ។ *ដោយសាកសពនៃរូបព្រះគួរស្អប់ខ្ពើម* មើល លវ ២៦:៣០ ។ រូបព្រះទាំងនោះគ្មានជីវិតឡើយ (មើល ទដ ១១៥:៤–៧ ១៣៥:១៥–១៧) ។ *ជាមរតករបស់អញ* ទឹកដីរបស់ព្រះ (មើល ១៧:៤ មើលការពន្យល់ផងដែរ ២:៧) ។ *របស់គួរខ្ពើមឆ្អើម* ជារបស់គួរឱ្យស្អប់ខ្ពើម នៅចំពោះព្រះនេត្ររបស់ព្រះ (មើល ២:៧ មើលការពន្យល់ផងដែរ លវ ៧:២១) ។

**១៦:១៩–២០** ហោរាយេរេមា ព្រះដាក់គាត់នៅចន្លោះកណ្តាល ដែលជាអ្នកផ្តល់នូវសេក្តីសង្ឃឹម ។

បំផុត ហើយគេនឹងទូលថា ពួកឰយុកោរបស់យើងខ្ញុំបាន
ទទួលតែសេចក្ដីកំភូតទទេ[ឍ]គឺជាសេចក្ដីអសារឥតការ[ណ]និង
សេចក្ដីដែលឥតមានប្រយោជន៍អ្វីឡើយ[ត] ២០តើមានទំនង
ឱ្យមនុស្សធ្វើព្រះសំរាប់ខ្លួន ដែលមិនមែនជាព្រះពិត ដែល
ឬ[ថ] ២១ដូច្នេះ មើលអញនឹងធ្វើឱ្យគេស្គាល់ អើ ម្តងនេះអញ
នឹងធ្វើឱ្យគេស្គាល់ដៃអញ និងឥទ្ធិឫទ្ធិរបស់អញ នោះគេ
នឹងស្គាល់ឈ្មោះ[ទ]អញ ថាជាព្រះយេហូវ៉ា ។

**១៧** ១អំពើបាបរបស់ពួកយូដាបានចារឹកទុក[ក] ដោយ
ដែលចារមានចុងជាពេជ្រ គឺបានចារឹកទុកនៅបន្ទះចិត្ត[ខ]គេ
ហើយនៅស្នែង[គ]អាសនារបស់គេដែរ ២ម្ល៉ោះហើយ កូន
ចៅគេនឹកចាំតែអាសនា និងរូបព្រះ[ឃ]របស់គេដែលនៅ
ក្រោមអស់ទាំងដើមឈើខៀវខ្ចី នៅលើភ្នំតូចទាំងប៉ុន្មាន[ង]
៣ឱភ្នំនិងវាលរបស់អញអើយ អញនឹងឱ្យគេចាប់យកធន
ធាន និងទ្រព្យសម្បត្តិរបស់ឯងទុកជារឹប[ច] ព្រមទាំងទីខ្ពស់
ទាំងប៉ុន្មានរបស់ឯងផង[ឆ] ដោយព្រោះអំពើបាបដែលប្រ
ព្រឹត្តនៅពេញក្នុងព្រំដែនរបស់ឯង[ជ] ៤ហើយឯងនឹងត្រូវ
ចាកចោលមរដក[ឈ]របស់ឯង ដែលអញបានឱ្យនោះ គឺ
ដោយព្រោះតែកំហុសរបស់ខ្លួនទេ ហើយអញនឹងឱ្យឯង
បំរើដល់ពួកខ្មាំង[ញ] នៅស្រុក[ដ]១ដែលឯងមិនស្គាល់ ដ្បិតឯង
រាល់គ្នាបានបង្កាត់ភ្លើងក្នុងសេចក្ដីកំហឹងរបស់អញ ដែល
នឹងឆេះ[ឋ]ជាដរាប ។

៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ត្រូវបណ្ដាសា
ហើយ អ្នកណាដែលទីពឹងដល់មនុស្ស[ឌ] ហើយយកសាច់
ឈាមជាដៃរបស់ខ្លួន ជាអ្នកដែលមានចិត្តដកថយចេញ
ពីព្រះយេហូវ៉ា[ឍ] ៦ដ្បិតអ្នកនោះនឹងបានដូចជាដើមឈើ
សោះកក្រោះ[ណ]នៅសមុទ្រខ្សាច់ បើកាលណាមានសេចក្ដី
ល្អមកដល់ នោះនឹងមិនឃើញទេ គឺនឹងត្រូវអាស្រ័យនៅ
កន្លែងហួតហែងក្នុងទីរហោស្ថានជាដីប្រៃ[ត] ឥតមានអ្នកណា
នៅវិញ ៧តែមានពរ[ថ]ហើយ អ្នកណាដែលទីពឹង[ទ]ដល់

**១៦:១៩** ឍ ទដ ៤:២ ណ ចទ ៣២:២១ ១សយ ១២:២១ ត អស ៤០:១៩ យរ ១៤:២២ **១៦:២០** ថ ទដ ១១៥:៤–៧ យរ ២:១១ រម ១:២៣ **១៦:២១** ទ នក ៣:១៥ **១៧:១** ក យប ១៩:២៤ ខ ចទ ៦:៦ ២កថ ៣:៣ គ នក ២៧:២ **១៧:២** ឃ ២របា ២៤:១៨ ង យរ ២:២០ **១៧:៣** ច ២ពវ ២៤:១៣ ឆ យរ ២៦:១៨ មីក ៣:១២ ជ យរ ១៥:១៣ **១៧:៤** ឈ បទ ៥:២ ញ ចទ ២៨:៤៨ យរ ១២:៧ ដ យរ ៦:១៣ ២២:២៨ ឋ យរ ៧:២០ **១៧:៥** ឌ ទដ ១០៨:១២ អស ២:២២ ឍ ២កថ ១:៩ **១៧:៦** ណ យប ៣០:៣ ត ចទ ២៩:២៣ យប ៣៩:៦ ទដ ១០៧:៣៤ យរ ៤៨:៩ **១៧:៧** ថ ទដ ១៤៦:៥ ទ ទដ ២៦:១ ៣៤:៨ ៤០:៤ សភ ១៦:២០ យរ ៣៩:១៨

**១៦:១៩** *ជាកំឡាំង . . . ជាទីមាំមួន . . . ជាទីពឹងជ្រករបស់ទូលបង្គំ* នៅគ្រាលំបាក ដូចជាការរៀបរាប់អំពីការពឹងផ្អែក និងអំណាចចេស្ដា ការការពាររបស់ព្រះ នៅក្នុងទំនុកដំកើង (មើលឧ. ទដ ១៨:១–២ ២៨:៧–៨ ៥៩:៩,១៦–១៧) ។ ពួកសាសន៍ទាំងប៉ុន្មាននឹងមកឯទ្រង់ មើល ៤:២ និងការពន្យល់ មើលផងដែរ អស ២:២–៤ ៤២:៤ ៤៥:១៤ ៤៩:៦ អគ ៨:២០–២៣ ១៤:១៦ ។ គឺជាសេចក្ដីអសាឥតការ មើលការពន្យល់ ២:៥ ។ និងសេចក្ដីដែលឥតមានប្រយោជន៍ឡើយ របស់មិនសមរម្យ មិនបានការ (មើលការពន្យល់ ២:៨) ។

**១៦:២០** *ដែលមិនមែនជាព្រះពិត* មើល ៥:៧ ។

**១៦:២១–១៧:៤** ព្រះអម្ចាស់មានបន្ទូលឆ្លើយទៅកាន់លោកយេរេមា បន្ទាប់មកទ្រង់បន្តការព្រមានរបស់ទ្រង់យ៉ាងច្បាស់លាស់ ដែលចាប់ផ្ដើមនៅក្នុង ខ.១ ។

**១៦:២១** *ធ្វើឱ្យគេស្គាល់. . .ធ្វើឱ្យគេស្គាល់. . .គេនឹងស្គាល់* ក្នុងព្រះគម្ពីរហេព្រើរគូសចំណាំនូវពាក្យនិមួយៗទាំងអស់នេះ ព្រះនឹងធ្វើឱ្យគេស្គាល់ ហើយបន្ទាប់មកគេច្បាស់ជានឹងបាន "ស្គាល់" គេ . . . គេប្រហែលជារួមទាំងពួកយូដា និងអស់ទាំងសាសន៍ដទៃ (មើល អគ ៣៦:២៣ ៣៧:១៤) ។ *នោះគេនឹងស្គាល់ឈ្មោះអញ ថាជាព្រះយេហូវ៉ា* "ឈ្មោះ" ជាទូទៅមានន័យថា "មនុស្ស" ឬ "ការរស់នៅ" នៅសញ្ញាចាស់ (មើលការពន្យល់ ទដ ៥:១១) ។ ឃ្លានៅក្នុងព្រះគម្ពីរយេរេមា និងឃ្លានៅក្នុងព្រះគម្ពីរអេសេគាលដូចគ្នាគឺ "នោះគេនឹងស្គាល់ឈ្មោះអញ ថាជាព្រះយេហូវ៉ា" បានរកឃើញនៅក្នុងសេចក្ដីទំនាយរបស់គាត់ប្រហែលជា៧០ដង (មើលសេចក្ដីផ្ដើមនៅក្នុងព្រះគម្ពីរអេសេគាល សាច់រឿង មើលការពន្យល់ផងដែរ អគ ៥:១៣ ។

**១៧:១** *បានចារឹកទុក ដោយដែកចារ* ជាវិធីសាស្ត្រមួយដែលគេប្រើ ដើម្បីរៀបរាប់អំពីការកត់ត្រាឱ្យយូរអង្វែង (មើល យប ១៩:២៤) ។ ចុងជាពេជ្រ ជាគ្រឿងសាស្ត្រាវុធ និងឧបករណ៍ដែលធ្វើឡើងពីថ្មយ៉ាងរឹងបំផុត (មើលការពន្យល់ នក ៤:២៥ យក ៥:២ មើលផងដែរ អគ ៣:៩ អគ ៧:១២) ។ *គឺបានចរឹកនៅបន្ទះចិត្តគេ* ដែលដូចគ្នា មើល សភ ៣:៣ ៧:៣ ។ *ហើយនៅស្នែងអាសនារបស់គេ* ពួកបណ្ដាជនយូដាបានធ្វើបាបយ៉ាងអាក្រក់បំផុត ដែលអំពើបាបគេមិនគ្រាន់តែបានចរឹកនៅក្នុងចិត្តប៉ុណ្ណោះទេ ប៉ុន្តែបានទាំងចរឹកនៅលើអាសនាថែមទៀតផង ធ្វើឱ្យព្រះអម្ចាស់នឹកចាំ ជាជាងការដែលទ្រង់ដាក់ទណ្ឌកម្មដល់គេនោះ (មើល លវ ១៦:១៨) ។

**១៧:២** *អាសនា និងរូបព្រះរបស់គេ* សូមមើលការពន្យល់ នក ៣៤:១៣ ចទ ៧:៥ ។ *អស់ទាំងដើមឈើខៀវខ្ចី នៅលើភ្នំតូចទាំងប៉ុន្មាន* មើលការពន្យល់ ២:២០ ។

**១៧:៣–៤** រំឭកឡើងវិញក្នុង១ផ្នែកធំចាប់តាំងពី ១៥:១៣–១៤ (មើលការពន្យល់នៅទីនោះ) ។

**១៧:៣** *ភ្នំ និងវាលរបស់អញ* ភ្នំស៊ីយ៉ូន ទីតាំងរបស់ព្រះវិហារ នៅក្រុងយេរូសាឡិម (មើល ទដ ២៤:៣ អស ២:៣ អគ ៨:៣) ។ *ទីខ្ពស់ទាំងប៉ុន្មាន* ជាទីកន្លែងដែលគេថ្វាយបង្គំរូបព្រះ (មើលការពន្យល់ ១ពវ ៣:២) ។

**១៧:៤** *មរដក* គឺជាទឹកដីកាណាន (មើល ១៦:១៨ និងការពន្យល់ ២:៧) ។

**១៧:៥–៨** មើល ទដ និងការពន្យល់ ។

**១៧:៥** *ត្រូវបណ្ដាសាហើយ* មើលការពន្យល់ ១១:៣ ។ *សាច់ឈាម* ខុសគ្នាពី "ខាងព្រលឹងវិញ្ញាណ" (មើល អស ៣១:៣ ធៀបនឹង យក ១០:៤) ។

**១៧:៦** *សោះកក្រោះ* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះមានន័យថា ការក្រខ្សត់ (មើល ទដ ១០២:១៧ "ទ័លក្រ") ។ *សេចក្ដីល្អ* ន័យត្រង់ "ល្អ" ។ ក្នុងព្រះគម្ពីរភាសាហេព្រើរគឺបានបកប្រែថា "ការល្អ" នៅក្នុង ចទ ២៨:១២ ដែលវាសំដៅលើភ្លៀង ។ *ដីប្រៃ* ជាភស្ដុតាងមួយអំពីបណ្ដាសារបស់ព្រះនៅក្នុង ចទ ២៩:២៣ ។

**១៧:៧** *ទីពឹង . . . ទុកចិត្ត* ដូចគ្នាក្នុងព្រះគម្ពីរភាសាហេព្រើរគូសចំណាំពាក្យទាំង២នេះ ។

ព្រះយេហូវ៉ា ហើយដែលទុកចិត្តនឹងទ្រង់ ៨ដ្បិតអ្នកនោះ
នឹងបានដូចជាដើមឈើដាំនៅមាត់ទឹក ដែលចាក់ឫសទៅ
ក្បែរទន្លេ[ធ] ឥតដឹងរដូវក្តៅទេ គឺស្លឹកនៅតែខៀវខ្ចីវិញ
ហើយមិនរីតត្បិតនៅឆ្នាំដែលរាំងរីះឡើយ[ន] ក៏មិនដែល
ខាននឹងកើតផលដែរ[ប]។
៩ឯចិត្ត[ផ]ជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយ
ក៏អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន
១០អញនេះ គឺព្រះយេហូវ៉ា អញស្ទង់ចិត្ត[ព] អញក៏ល្បងល
ថ្លើម[ភ] ដើម្បីនឹងសង[ម]ដល់មនុស្សទាំងអស់តាមផ្លូវគេប្រព្រឹត្ត
ហើយតាមផលនៃកិរិយារបស់គេ[យ] ១១ឯទទាដែលក្រាប
ពងឥតបានភ្ញាស់ជាយ៉ាងណា នោះអ្នកដែលប្រមូលទ្រព្យ
សម្បត្តិ មិនមែនដោយទៀងត្រង់ក៏យ៉ាងនោះដែរ ទ្រព្យ
សម្បត្តិនោះនឹងលះចោលគេ កាលនៅពាក់កណ្តាលអាយុ
នៅឡើយ ហើយដល់ចុងបំផុត គេនឹងទៅជាឆ្កួតផង[រ]។
១២កន្លែងនៃទីបរិសុទ្ធរបស់យើងជាបល្ល័ង្ក[ល]ឧត្តមឧត្តុង្គ
ដែលបានដំកល់នៅខ្ពស់ ចាប់តាំងពីដើមមក ១៣ឱព្រះ
យេហូវ៉ា ជាទីសង្ឃឹម[វ]នៃសាសន៍អ៊ីស្រាអែលអើយ អស់
អ្នកណាដែលបោះបង់ចោលទ្រង់ នោះនឹងត្រូវខ្មាស់ ពួក
អ្នកដែលថយចេញ[ស]ពីអញទៅ នោះនឹងមានឈ្មោះកត់
ទុកនៅផែនដី[ហ] ដោយព្រោះគេបានចោលព្រះយេហូវ៉ា
ដែលទ្រង់ជាក្បាលទឹករស់[ឡ] ១៤ឱព្រះយេហូវ៉ាអើយ សូម
ប្រោសទូលបង្គំឱ្យជាផង[អ] នោះទូលបង្គំនឹងបានជាៗពិត
សូមជួយសង្គ្រោះ[ក]ទូលបង្គំ នោះទូលបង្គំនឹងបានរួចពិត
ដ្បិតទ្រង់ជាទីសរសើររបស់ទូលបង្គំ[ខ] ១៥មើល គេសួរទូល
បង្គំថា តើព្រះបន្ទូលនៃព្រះយេហូវ៉ានៅឯណា ឱ្យការនោះ
មកឥឡូវចុះ[គ] ១៦តែឯទូលបង្គំវិញ ទូលបង្គំមិនបានរហ័ស
នឹងលែងធ្វើជាអ្នកគង្វាលតាមទ្រង់ឡើយ ក៏មិនបានប្រាថ្នា
ឱ្យថ្ងៃវេទនានោះមកដែរ ទ្រង់ជ្រាបហើយ ដ្បិតសេចក្តី
ដែលចេញពីបបូរមាត់[ឃ]ទូលបង្គំ សុទ្ធតែនៅចំពោះទ្រង់
ទាំងអស់ ១៧សូមកុំឱ្យទ្រង់បានធ្វើជាសេចក្តីស្ញែងខ្លាច[ង]

**១៧:៨** ធ យប ១៤:៩ ន យរ ១៤:១-៦ ប ទដ ១:៣ ៩២:១២-១៤ អគ ១៩:១០ ៤៧:១២ **១៧:៩** ផ សស ៩:៣ មថ ១៣:១៥ មក ៧:២១-២២ **១៧:១០** ព យស ២២:២២ ២រប ៦:៣០ វវ ២:២៣ ភ ទដ ១៧:៣ ១៣៩:២៣ យរ ១១:២០ ២០:១២ អគ ១១:៥ ៣៨:១០ ម លវ ២៦:២៨ ទដ ៦២:១២ យរ ៣២:១៩ មថ ១៦:២៧ យ យរ ១២:១៣ ១៤:១៦ ២១:១៤ ៣២:១៩ **១៧:១១** រ លក ១២:២០ **១៧:១២** ល យរ ៣:១៧ **១៧:១៣** វ ទដ ៧១:៥ យរ ១៤:៨ ស យរ ២:១៧ ហ ទដ ៦៩:២៨ ៨៧:៦ អគ ១៣:៩ ដយ ១២:១ ឡ អស ១២:៣ យហ ៤:១០ **១៧:១៤** អ អស ៣០:២៦ យរ ១៥:១៨ ក ទដ ១១៩:៩៤ ខ នក ១៥:២ ទដ ១០៩:១ **១៧:១៥** គ អស ៥:១៩ ២ពវ ៣:៤ **១៧:១៦** ឃ ទដ ១៣៩:៤ **១៧:១៧** ង ទដ ៨៨:១៥-១៦

**១៧:៨** *ដាំនៅមាត់ទឹក* ឬ "បានដាំ" ។ *ក្បែរទន្លេ* មើល អស ៤៤:៤ ដែលក្នុងព្រះគម្ពីរភាសាហេព្រើរបានប្រើម្តងទៀត ដើម្បីបង្ហាញពីប្រភពកំម្លាំងរបស់មនុស្សសុចរិត ។ *រដូវក្តៅ* មើលការពន្យល់ ១៤:១ ។ *កើតផល* ព្រះអម្ចាស់ឆ្លើយដល់ការតវ៉ារបស់លោកយេរេមា នៅក្នុង ១២:១-២ (មើលការពន្យល់នៅទីនោះ) ។

**១៧:៩** ហោរាបានធ្វើការអង្កេត បន្ទាប់មកគាត់បានសួរសំនួរបន្លំ ។ ចិត្ត "ជាប្រភពជីវិត" ដែលមនុស្សអាក្រក់មិនត្រូវបានអនុញ្ញាតិឱ្យដងទឹកនេះឡើយ (មើល ទដ ៤:៧ និងការពន្យល់) ។ *បញ្ឆោត* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺឈ្មោះសំខាន់របស់លោកយ៉ាកុប (មើលការពន្យល់ លប ២៧:៣៦) ។

**១៧:១០** ព្រះអម្ចាស់ឆ្លើយតបដល់សំនួរលោកយេរេមា ។ *អញស្ទង់ចិត្ត អញក៏ល្បងល* មើល ១១:២០ ១២:៣ ។ *ថ្លើម* ន័យត្រង់គឺ "ក្រលៀន" (មើល ១១:២០) ។ ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "ចិត្ត"នៅក្នុង ១២:២ ។ *តាមផ្លូវគេប្រព្រឹត្ត* ន័យត្រង់គឺ "ផលផ្លែដែលគេប្រព្រឹត្ត" (ធៀបនឹង ៦:១៩) ។

**១៧:១១** ហោរាបានប្រើសុភាសិត ដើម្បីធ្វើការចង្អុលបង្ហាញ (ដូចជានៅក្នុងខ.៩) ។ *សត្វទទា* បានបញ្ជាក់នៅកន្លែងផ្សេងទៀតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ក្នុងតែ ១សយ ២៦:២០ ។ *ឆ្កួត* ការធ្លាក់ចុះខាងផ្នែកសីលធម៌ និងខាងផ្នែកព្រលឹងវិញ្ញាណ (មើលការពន្យល់ ១:៧) ។

១៧:១២-១៨ "ការលន់តួ" លើកទី៤របស់លោកយេរេមា (មើលសេចក្តីផ្តើម អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។

**១៧:១២** *បល្ល័ង្កឧត្តមឧត្តុង្គ* មើលការពន្យល់ ១៤:២១ មើលផងដែរ អស ៦:១ ។ ព្រះអម្ចាស់តែងតែមានវត្តមានគង់នៅលើបល្ល័ង្ក នៅចន្លោះរវាងចេរូបីន នៅលើទីអាសនាព្រះវិហារ (មើលឧ. ទដ ៨០:១ ៩៩:១) ។ *ដែលបានដំកល់នៅខ្ពស់* លើភ្នំស៊ីយ៉ូន គឺ "ជាភ្នំយ៉ាងខ្ពស់នៅប្រទេសអ៊ីស្រាអែល" (អគ ២០:៤០) ។ *ចាប់តាំងពីដើមមក* ចាប់តាំងពីភ្នំស៊ីយ៉ូន ដែលព្រះបានជ្រើសតាំង ជាទីកន្លែងបរិសុទ្ធតាំងពីយូលង់មកម្លេះ (មើល នក ១៥:១៧) ។

**១៧:១៣** *ជាទីសង្ឃឹមនៃអ៊ីស្រាអែល* មើលការពន្យល់ ១៤:៨ ។ *នៅផែនដី* ន័យត្រង់ "ផែនដី" ជួនកាលនិយាយសំដៅទៅលើ ពិភពលោកទាំងមូល (មើលការពន្យល់ ទដ ៦១:២ មើលការពន្យល់ផងដែរ យក ៧:២១) ដូចជានៅក្នុងទឹកដីកាណានផងដែរ និងនៅក្នុងផ្នែកអក្សរសាស្ត្រ មេសូផូតាមៀ (Mesopotamian) "មានឈ្មោះកត់ទុកនៅផែនដី" ហើយមានន័យថា "បម្រុងទុកពេលស្លាប់" ដែលផ្ទុយពី "ការកត់ទុកនៅក្នុងសៀវភៅជីវិត" (មើល នក ៣២:៣២ ដយ ១២:១ មើលផងដែរ ទដ ៦៩:២៨ លក ១០:២០ វវ ៣:៥ និងការពន្យល់) ។ *បានបោះបង់ចោល. . .ដែលជាក្បាលទឹកដ៏រស់* ធៀបនឹង ១៥:១៨ និងការពន្យល់ ២:១៣ ។

**១៧:១៤** *សូមប្រោសទូលបង្គំឱ្យជាផង* មើល ១៥:១៨ ទដ ៦:២ ដ្បិតទ្រង់ជាទីសរសើររបស់ទូលបង្គំ ន័យត្រង់ "ទ្រង់គឺជាទីសរសើររបស់ទូលបង្គំ" (មើល ទដ ២២:៣ និងការពន្យល់) ។

**១៧:១៥** មើល ២០:៨ ខ្មាំងសត្រូវរបស់លោកយេរេមា ចោទប្រកាន់គាត់ថាជាហោរាខុសឆ្គង (មើល ចទ ១៨:២១-២២) ។ ការចោទប្រកាន់ ជាការធ្វើឡើងជាសំលេងមុនពេលការឈ្លានពាន របស់ពួកបាប៊ីឡូន ចូលយូដាមុនដំបូង នៅក្នុងឆ្នាំ ៦០៥ គ.ស ។ ក្រោយពីសង្គ្រាមនៅក្រុងកើកេមីស (មើល ៤៦:២ សេចក្តីផ្តើម និងប្រវត្តិដើមផងដែរ) ។

**១៧:១៦** *អ្នកគង្វាល* និម្មិតរូបអំពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់លោកយេរេមា ដូចជាហោរា (មើលការពន្យល់ ២:៨ ទដ ២៣:១ យហ ១០:១-៣០) ។

**១៧:១៧** *ទីពឹងជ្រក* មើល ១៦:១៩ និងការពន្យល់ ។ *ក្នុងថ្ងៃអាក្រក់* មើល

ដល់ទូលបង្គំឡើយ ទ្រង់ជាទីពឹងជ្រក[ច]នៃទូលបង្គំក្នុងថ្ងៃ
អាក្រក់[ឆ] [១៨]សូមឱ្យពួកអ្នកដែលបៀតបៀនដល់ទូលបង្គំត្រូវ
អៀនខ្មាស តែកុំឱ្យទូលបង្គំត្រូវខ្មាសឡើយ សូមឱ្យគេត្រូវ
ស្រយុតចិត្តទៅ តែកុំឱ្យទូលបង្គំត្រូវស្រយុតចិត្តឱ្យសោះ
សូមនាំថ្ងៃអាក្រក់នោះឱ្យមកលើគេវិញ ហើយបំផ្លាញគេ
ដោយ ការបំផ្លាញ១ជា២ដង[ជ]។

## ការញែកថ្ងៃឈប់សម្រាកជាបរិសុទ្ធ

[១៩]ព្រះយេហូវ៉ា មានបន្ទូលមកខ្ញុំដូច្នេះថា ចូរទៅ ឈរ
នៅមាត់ទ្វារក្រុងនៃពួកកូនចៅជនជាតិនេះ ជាទ្វារដែល
ពួកស្តេចយូដាធ្លាប់ចេញចូល ហើយនៅត្រង់ទ្វារក្រុង
យេរូសាឡិមទាំងអស់ដែរ[ឈ] [២០]ត្រូវឱ្យប្រាប់គេថា ឱពួក
ស្តេចយូដា និងបណ្តាជនជាតិយូដាទាំងអស់ ហើយពួកអ្នក
នៅក្រុងយេរូសាឡិម[ញ] ដែលចូលតាមទ្វារទាំងនេះ[ដ] អើយ
ចូរស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ [២១]ព្រះយេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះ ចូរប្រុងប្រយ័តខ្លួន កុំឱ្យលីសែងបន្ទុកអ្វី
ចូលមកតាមទ្វារក្រុងយេរូសាឡិម នៅថ្ងៃឈប់សំរាក[ឋ]
ឡើយ [២២]ក៏កុំឱ្យលីសែងបន្ទុកអ្វីចេញពីផ្ទះឯងរាល់គ្នា ឬធ្វើ
ការអ្វីនៅថ្ងៃឈប់សំរាកដែរ ត្រូវឱ្យញែកថ្ងៃឈប់សំរាក
ទុកជាថ្ងៃបរិសុទ្ធវិញ ដូចជាអញបានបង្គាប់ដល់ពួកឰយុកោ
ឯងរាល់គ្នាហើយ[ឌ] [២៣]ប៉ុន្តែគេមិនបានស្តាប់តាម ឬផ្ទៀង
ត្រចៀកឡើយ[ឍ] គឺគេតាំងចិត្តរឹងរូស[ណ]វិញដើម្បីមិនឱ្យឮ
ឬទទួលសេចក្តីប្រៀនប្រដៅសោះ[ត]។

[២៤]ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា បើសិនជាឯងរាល់
គ្នានឹងខំព្យាយាមស្តាប់តាមអញ ដើម្បីមិនឱ្យលីសែងបន្ទុក
ណាចូលមកតាមទ្វារក្រុងនេះ នៅថ្ងៃឈប់សំរាក គឺនឹង
ញែកថ្ងៃឈប់សំរាកទុកជាថ្ងៃបរិសុទ្ធ[ថ]វិញ ឥតធ្វើការអ្វី
នៅថ្ងៃនោះ [២៥]នោះនឹងមានស្តេច ហើយនិងពួកចៅ
ហ្វាយ ដែលគង់លើបល្ល័ង្ក[ទ]ដាវីឌ ចូលមកតាមទ្វារក្រុង
នេះ គេនឹងជិះរាជរថ ហើយនិងសេះ ទាំងខ្លួនគេ និងពួក
ចៅហ្វាយ ព្រមទាំងបណ្តាមនុស្សនៅស្រុកយូដា និងពួក
អ្នកនៅក្រុងយេរូសាឡិមទាំងប៉ុន្មានផង ហើយទីក្រុងនេះ
នឹងស្ថិតស្ថេរនៅជាដរាបតទៅ[ធ] [២៦]មនុស្សនឹងមកពីអស់
ទាំងទីក្រុងនៅស្រុកយូដា ពីដំបន់នៅជុំវិញនៃក្រុងយេរូ–
សាឡិម ពីស្រុកបេនយ៉ាមីន ពីស្រុកទំនាប ពីស្រុកភ្នំ

**១៧:១៧** ច ទដ ៤៦:១ យរ ១៦:១៩ ណហ ១:៧ ឆ ទដ ១៨:១៨
**១៧:១៨** ជ ទដ ៣៥:១–៨ អស ៤០:២ យរ ១២:៣
**១៧:១៩** ឈ យរ ៧:២ ២៦:២
**១៧:២០** ញ យរ ១៩:៣ ដ យរ ២២:២
**១៧:២១** ឋ ជន ១៥:៣២–៣៦ ចទ ៥:១៤ នហ ១៣:១៥–២១ យហ ៥:១០
**១៧:២២** ឌ លប ២:៣ នក ២០:៨ អស ៥៦:២–៦
**១៧:២៣** ឍ យរ ៧:២៦ ណ យរ ១៩:១៥ ត ២របា ២៨:២២ យរ ៧:២៨ សក ៧:១១
**១៧:២៤** ថ ខ.២២
**១៧:២៥** ទ ២សយ ៧:១៣ អស ៩:៧ យរ ២២:២,៤ លក ១:៣២ ធ យរ ៣០:១០ ៣៣:១៦ អគ ២៨:២៦

ខ.១៨ ១៥:១១ ។

**១៧:១៨** *សូមឱ្យអ្នកដែលបៀតបៀនដល់ទូលបង្គំ* មើល ១៥:១៥ ។ *១ជា២* មើល ១៦:១៨ អស ៤០:២ និងការពន្យល់ ។

**១៧:១៩–២៧** ការពង្រីកសេចក្តីអត្ថាធិប្បាយនៅថ្ងៃឈប់សម្រាក (ការចុះសិទ្ធិសញ្ញា ការទំនាក់ទំនងរបស់ព្រះជាមួយអ៊ីស្រាអែល មើល នក ៣១:១៣–១៧ អគ ២០:១២) ប្រហែលជាកំណែថ្មី នៅក្នុង ចទ ៥:១២–១៥ (មើលការពន្យល់ ខ.២២ ខាងក្រោម) ។

**១៧:១៩** *ជនជាតិនេះ* ន័យត្រង់ "កូនប្រុសរបស់មនុស្ស" ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "មនុស្សធម្មតា" នៅក្នុង ២៦:២៣ ២ពារ ២៣:៦ និង "កូនចៅបណ្តាជន" នៅក្នុង ២របា ៣៥:៥,៧ ។ សំបុត្រនេះមានន័យថា "មាត់ទ្វារក្រុងនៃពួកកូនចៅជនជាតិនេះ" ដូចជាទ្វារព្រះវិហារខាងកើត ដែលបណ្តាជនបានប្រជុំ មានគ្នាជាច្រើននាក់ហើយជាទីកន្លែង ដែលស្តេចបានប្រើប្រាស់ជាញឹកញាប់ ។

**១៧:២០** *ពួកស្តេចយូដា* ស្តេចបច្ចុប្បន្ន និងអស់ទាំងអ្នកគ្រប់គ្រងនៅជំនាន់ក្រោយមកទៀត នៅជំនាន់ការគ្រងរាជ្យស្តេចដាវីឌ (មើលឧ. ខ.២៥ ២:២៦ ១៣:១៣ ១៩:៣) ។

**១៧:២១** *ចូរប្រុងប្រយ័ត្នខ្លួន* មើល យក ២៣:១១ ក្នុងព្រះគម្ពីរភាសាហេព្រើរគួសបញ្ជាក់ឃ្លានេះ គឺបានបកប្រែថា "ចូរប្រុងប្រយ័ត្នខ្លួន" នៅក្នុង ចទ ៤:១៥ និងការបញ្ជាក់ដូចគ្នា គឺបានបកប្រែថា "ចូរប្រុងប្រយ័ត្នខ្លួនឯងចំពោះខាងផ្នែក ព្រលឹងវិញ្ញាណ" នៅក្នុង មឡ ២:១៥ បញ្ជាក់ពីភាពប្រាកដច្បាស់ និងការដ៏សំខាន់ ចំពោះបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។

**១៧:២២** *ក៏កុំឱ្យ* មើលការពន្យល់ ១៦:២ ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ការបញ្ជាក់ ជាអវិជ្ជមាន គឺខ្លាំងជាងនៅក្នុង ខ.២១ ។ *កុំឱ្យលីសែង . . . ធ្វើការអ្វី . . . ត្រូវឱ្យញែកថ្ងៃឈប់សំរាកទុកជាថ្ងៃបរិសុទ្ធវិញ* នេះនិយាយសំដៅយ៉ាងច្បាស់លាស់ទៅលើបទបញ្ញតិនៅថ្ងៃឈប់សម្រាក ក្នុង នក ២០:៨,១០ ចទ ៥:១២,១៤ ។ *ដូចជាអញបានបង្គាប់* ក្នុងព្រះគម្ពីរភាសាហេព្រើរគួសចំណាំឃ្លានេះ គឺសំដៅទៅលើបទបញ្ញតិទាំង១០ប្រការ ដូចជាបានកត់ទុកនៅក្នុងចោទិយកថា (មើល ចទ ៥:១២,១៥–១៧ មើលការពន្យល់ក្នុង ខ.១៩–២៧) ។

**១៧:២៣** *ប៉ុន្តែគេមិនបានស្តាប់តាម . . . គឺគេតាំងចិត្តរឹងរូស* រំឭកឡើងវិញពី ៧:២៦ (មើលការពន្យល់នៅទីនោះ មើលផងដែរ ១១:១០) ។ *ឬទទួលសេចក្តីប្រៀនប្រដៅ* មើល ២:៣០ ៥:៣ ។

**១៧:២៥** រំឭកឡើងវិញ១ផ្នែកនៅក្នុង ២២:៤ ។ ពូជពង្សស្តេចដាវីឌ និងសោយរាជ្យជារៀងរហូត (មើល ២៣:៥–៦ ៣០:៩ ៣៣:១៥ ២សយ ៧:១២–១៧) ហើយក្រុងយេរូសាឡិមនឹងមានមនុស្សនៅគ្រប់ពេលវេលា (៣១:៣៨–៤០ អគ ២:២–១២ ៨:៣ ១៤:១១ ១៤:១១) ។ បើសិនជាពួកបណ្តាជនយូដាស្តាប់បង្គាប់ដល់ព្រះអម្ចាស់ (មើល ខ.២៧) ហើយធ្វើតាមទ្រង់ ៣១:៣៣–៣៤ ។

**១៧:២៦** *ពីស្រុកបេនយ៉ាមីន* ជាទីកន្លែងកំណើតលោកយេរេមា (មើល ១:១) ។ ពីស្រុកទំនាប ពីស្រុកភ្នំ មើលការពន្យល់ ចទ ១:៧ ។ ស្រុកត្បូង មើលការពន្យល់ លប ១២:៩ ។ ដង្វាយសំរាប់អរព្រះគុណ ន័យត្រង់ "នាំដង្វាយអរព្រះគុណ" នេះគឺរំឭកឡើងវិញ "ការនាំ" (មើលដើមខ)នោះមានន័យនៅក្នុងព្រះគម្ពីរភាសាហេព្រើរថា "នាំយកដង្វាយដុត . . . ដង្វាយម្សៅ កំញាន និងដង្វាយសម្រាប់អរព្រះគុណ"(ដូចក្នុង ៣៣:១១) ។

ពីស្រុកត្បូង[ន] នាំយកដង្វាយដុត យញ្ញបូជា ដង្វាយម្សៅ
កំញាន និងដង្វាយសំរាប់អរព្រះគុណ មកដល់ទីព្រះវិហារ
នៃព្រះយេហូវ៉ា ២៧តែបើឯងរាល់គ្នាមិនព្រមស្តាប់តាម[ប]
អញដើម្បីនឹងញែកថ្ងៃឈប់សំរាក[ផ]ទុកជាថ្ងៃបរិសុទ្ធ ហើយ
លែងលីសែងបន្ទុកចូលតាមទ្វារក្រុងយេរូសាឡិម នៅថ្ងៃ
ឈប់សំរាកទេ នោះអញនឹងបង្កាត់ភ្លើង[ព]នៅទ្វារក្រុងទាំង
ប៉ុន្មានហើយភ្លើងនោះនឹងឆេះបំផ្លាញអស់ទាំងដំណាក់នៅ
ក្រុងយេរូសាឡិមទៅ ឥតដែលរលត់ឡើយ[ភ] ។

## នៅឯផ្ទះជាងស្មូន

**១៨** ១នេះជាព្រះបន្ទូល ដែលមកពីព្រះយេហូវ៉ាដល់
យេរេមាថា ២ចូរក្រោកឡើង ចុះទៅឯផ្ទះជាស្មូន នៅទី
នោះអញនឹងឱ្យឯងឮពាក្យអញ ៣ដូច្នេះ ខ្ញុំក៏ចុះទៅដល់ផ្ទះ
របស់ជាងស្មូន ហើយមើល គាត់កំពុងតែធ្វើការនៅលើ
តុរិល ៤បើកាលណាភាជនៈ ដែលគាត់កំពុងធ្វើពីដីឥដ្ឋ
បានខូចនៅដៃគាត់ នោះក៏ធ្វើឡើងជាភាជនៈផ្សេងទៀត
វិញ តាមដែលគាត់យល់ឃើញថាគួរ ។
៥ខណនោះ ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា
៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរដូច្នេះ ឱពួកវង្សាអ៊ីស្រា–
អែលអើយ តើអញគ្មានអំណាចនឹងធ្វើដល់ឯងរាល់គ្នាដូច
ជាជាងស្មូននេះបានធ្វើដែរទេឬអី មើល ឱពួកវង្សអ៊ីស្រា–
អែលអើយ ដីឥដ្ឋ[ក]នៅក្នុងដៃ[ខ]របស់ជាងស្មូនយ៉ាងណា នោះ
ឯងរាល់គ្នាក៏នៅក្នុងដៃអញយ៉ាងនោះដែរ ៧នៅវេលា
ណាដែលអញនិយាយពីដំណើរសាសន៍ណា ឬនគរណា
ថានឹងដករំលើងគេព្រមទាំងរំលំ[គ] ហើយបំផ្លាញផង ៨បើ
សិនជានគរដែលអញបាននិយាយនោះ នឹងបែរចេញពី
អំពើអាក្រក់របស់ខ្លួន នោះអញនឹងប្រែគំនិត[ឃ]ចេញពីការ
អាក្រក់[ង] ដែលអញបានគិតធ្វើដល់គេ ក្នុងវេលានោះឯង
៩ហើយនៅវេលាណាដែលអញនិយាយពីសាសន៍ណា ឬ
នគរណាថានឹងស្អាង[ច]គេ ហើយតាំងគេឡើង ១០បើសិន
ជាគេប្រព្រឹត្តអំពើអាក្រក់[ឆ]នៅភ្នែកអញ ហើយមិនស្តាប់
តាមពាក្យអញវិញ នោះអញនឹងប្រែគំនិត[ជ]ចេញពីការល្អ
ដែលអញបានថា នឹងធ្វើដល់គេនៅវេលានោះដែរ[ឈ]
១១ដូច្នេះ ចូរប្រាប់ដល់មនុស្សនៅស្រុកយូដា ហើយពួក
អ្នកនៅក្រុងយេរូសាឡិមឥឡូវនេះថា ព្រះយេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះមើល អញកំពុងតែឡោមព័ទ្ធឯងរាល់គ្នា

**១៧:២៦** ន យរ ៣២:៤៤ ៣៣:១៣ សក ៧:៧ **១៧:២៧** ប ១ពវ ៩:៦ យរ ២២:៥ ផ នហ ១០:៣១ ព យរ ៧:២០ ភ ២ពវ ២៥:៩ ហស ៨:១៤ អម ២:៥ **១៨:៦** ក អស ២៩:១៦ ៤៥:៩ រម ៩:២០–២១ ខ លប ២:៧ **១៨:៧** គ យរ ១:១០ **១៨:៨** ឃ នក ៣២:១៤ ទដ ២៥:១១ យរ ២៦:១៣ ៣៦:៣ យហ ៣:៨–១០ ង យរ ៣១:២៨ ៤២:១០ ដយ ៩:១៤ ហស ១១:៨–៩ យអ ២:១៣ យហ ៤:២ **១៨:៩** ច យរ ១:១០ ៣១:២៨ **១៨:១០** ឆ អគ ៣៣:១៨ ជ ១សយ ២:២៩–៣០ ១៣:១៣ ឈ យរ ១:១០

**១៧:២៧** ការមិនស្តាប់បង្គាប់ នាំឱ្យមានគ្រោះមហន្តរាយកើតមានឡើង យ៉ាងហោចណាស់វាកើតឡើងក្នុងរយៈពេលខ្លី សេចក្តីសន្យាក្នុង ខ.២៤–២៦ ។ ទ្វារក្រុងយេរូសាឡិម និម្មិតរូបអំពីថ្ងៃបរិសុទ្ធ មុនដំបូងដែលត្រូវបានគេបំផ្លាញ ។ *បង្កាត់ភ្លើង . . . នៅក្រុងយេរូសាឡិមទៅ ឥតដែលរលត់ឡើយ* នេះជាសេចក្តីទំនាយរបស់ព្រះ ក្នុងការជំនុំជម្រះទាស់ប្រឆាំងនឹងទីក្រុងដែលបះបោរនឹងទ្រង់ (មើល ៤៩:២៧ ៥០:៣២ អម ១:៤,៧,១០,១២,១៤ ២:២,៥ ធៀបនឹង យរ ២១:១៤) ។

**១៨:១–២០:១៨** បីជំពូកផ្តោតទៅលើមេរៀនដែលព្រះអម្ចាស់បានបង្រៀនដល់លោកយេរេមា នៅកន្លែងជាងស្មូន ប្រហែលមុនឆ្នាំ ៦០៥ គ.ស (មើលការពន្យល់ ១៧:១៥) ។

**១៨:១–១៧** ជាងស្មូនគ្រប់គ្រង ប៉ាន់កែឆ្នៃធ្វើដីឥដ្ឋ ដូចជាព្រះអម្ចាស់ទ្រង់សោយរាជ្យលើរាស្ត្រយូដា ។

**១៨:២** *ចុះទៅ* កន្លែងជាងស្មូន គឺប្រហែលជាមានទីតាំងនៅឯជ្ជរភ្នំបេនហ៊ីនណំ នៅជិតមាត់ទ្វារអំបែងឆ្នាំង (មើល ១៩:២ និងការពន្យល់) ។

**១៨:៣** *តុរិល* ន័យត្រង់ "ថ្ម២ដុំ" ដែលមានកង់ទាំង២នៅសងខាងត្រង់ឡើងទៅលើ ហើយកង់១ដាក់ចូលទៅក្នុងដី ។ ជាងស្មូនអាចបង្វិលកង់ខាងក្រោមដោយជើងគាត់បាន ហើយដីឥដ្ឋធ្វើឆ្នាំងដាក់នៅលើកង់ខាងលើ ដំណើរនេះគឺបានរៀបរាប់នៅក្នុងព្រះគម្ពីរសាស្តា (៣៨:២៩–៣០) ។

**១៨:៤** *ភាជនៈ* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "សំណល់បាក់បែក" នៅក្នុង ១៣:៧ និងការក្រវ៉ាត់សំពត់នៅនឹងចង្កេះដែលលោកយេរេមាបានលាក់ទុក (មើលការពន្យល់នៅទីនោះ) ។ *តាមដែលគាត់យល់ឃើញថាគួរ* ការខូចបែកបាក់នោះដោយសារដីឥដ្ឋប៉ុណ្ណោះ មិនមែនមកពីជាងស្មូនទេ ។

**១៨:៦** *ដីឥដ្ឋ . . .នោះឯងរាល់គ្នា* ព្រះគម្ពីរតែងតែធ្វើការពិពណ៌នា ពីការដែលទ្រង់បង្កើតមនុស្សជាតិមក ប្រៀបដូចជាជាងស្មូន សូនធ្វើដីឥដ្ឋផងដែរ (មើល យក ៤:១៩ និងការពន្យល់ រម ៩:២០–២១) ។ *ជាងស្មូន* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "អ្នកបង្កើត" នៅក្នុង ១០:១៦ ដែល និយាយសំដៅទៅលើព្រះ ។

**១៨:៧–១០** ព្រះអម្ចាស់ទ្រង់រក្សាសិទ្ធិ ចំពោះដែនកំណត់ការគ្រងរាជ្យយ៉ាងពិតប្រាកដរបស់ទ្រង់ នូវការឆ្លើយតបជាមូលដ្ឋាន ដែលទ្រង់ប្រទាននូវការអនុគ្រោះ និងការស្អាងគេឡើងវិញ ការព្រមានអំពីការជំនុំជម្រះ និងការបំផ្លាញ ។ *នៅ . . . បើសិន . . . ហើយនៅ . . . បើសិន* នេះជាលក្ខខ័ណ្ឌមួយនៃសេចក្តីសន្យានិងការព្រមានរបស់ព្រះ ចំពោះសកម្មភាពរបស់មនុស្ស ។ ព្រះព្រះអង្គមិនដែលប្រែប្រួលឡើយ (មើល ជន ២៣:១៩ មឡ ៣:៦ យក ១:១៧) ហើយទ្រង់មិនដែលផ្លាស់ប្តូរ ចំពោះអ្វីដែលទ្រង់បានសន្យា ដើម្បីឆ្លើយតបទៅដល់មនុស្ស ដោយអាស្រ័យទៅលើអ្វីដែលគេធ្វើនោះ (មើលការពន្យល់ ៤:២៨ មើលផងដែរ យអ ២:១៣ យហ ៣:៨–៤:២ និងការពន្យល់ ៣:៩ ៤:១១) ។

**១៨:៧** *ដករំលើងគេ ព្រមទាំងរំលំ ហើយបំផ្លាញ* មើល ១:១០ និងការពន្យល់ ។

**១៨:៨** មើល ២៦:៣ ។ *អំពើអាក្រក់ . . . ចេញពីការអាក្រក់* ក្នុងព្រះគម្ពីរភាសាហេព្រើរ ដូចគ្នាពាក្យទាំងពីនេះ (មាននៅក្នុងផងដែរ ខ.១១) ។

**១៨:៩** *ស្អាងគេ ហើយតាំងគេឡើង* មើល ១:១០ និងការពន្យល់ ។

**១៨:១១** *ឡោមព័ទ្ធ* មើល នអ ៨:៣ ៩:២៥ អគ ៣៨:១០ ។ *ដូច្នេះ ចូរវិលមក*

ជុំវិញ ដោយការអាក្រក់[ញ] ហើយក៏មានគំនិត[ដ]ទាស់នឹងឯង
ដែរ ដូច្នេះ ចូរវិលមក[ឋ]ពីផ្លូវអាក្រក់[ឌ]របស់ឯងរៀងខ្លួន
ហើយឱ្យកែប្រែផ្លូវប្រព្រឹត្តនឹងកិរិយារបស់ឯងឡើងវិញ
ឥឡូវចុះ[ឍ] ១២តែគេឆ្លើយថា ឥតប្រយោជន៍ទេ[ណ] ដ្បិតយើង
រាល់គ្នានឹងដើរតាមតែគំនិតរបស់យើងប៉ុណ្ណោះ យើង
រាល់គ្នានឹងធ្វើតាមតែសេចក្តីរឹងចចេស នៃចិត្តអាក្រក់
របស់យើងរៀងខ្លួន[ត]។

១៣ហេតុនោះព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូរ
ស៊ើបសួររកនៅកណ្តាលសាសន៍ដទៃទាំងប៉ុន្មានចុះ តើ
ដែលមានអ្នកណាឮនិយាយពីការយ៉ាងនេះឬទេ[ថ] នាង
ក្រមុំ[ទ] នៃពួកអ៊ីស្រាអែលបានប្រព្រឹត្តការដ៏ពន្លឹកគួរស្ញើម[ធ]
១៤តើហិមៈនៅលើភ្នំល្បាណូន នឹងលែងមានពីថ្មនៅវាល
បាន ឬតើទឹកត្រជាក់ដែលហូរចុះមកពីទីឆ្ងាយនឹងហួតបាត់
ទៅឬអី ១៥ដ្បិតឯរាស្ត្រអញនេះ គេបានភ្លេច[ន]អញហើយ
គេបានដុតកំញាន[ប]ថ្វាយដល់អស់ទាំងព្រះក្លែងក្លាយ[ផ] ហើយ
គេត្រូវចំពប់[ព]ក្នុងផ្លូវរបស់ខ្លួន គឺជាផ្លូវពីចាស់បុរាណ[ភ]
ឱ្យបានដើរ វាងទៅតាមផ្លូវច្រកដែលមិនបានលើកឡើយ[ម]
១៦ដើម្បីឱ្យស្រុកគេបានត្រឡប់ជាទីស្រឡាំងកាំង[យ] ហើយ
ជាទីដែលមនុស្សធ្វើសឹសស៊ូសឱ្យជានិច្ច[រ] អស់អ្នកណាដែល
ដើរតាមស្រុកនោះ និងភាំងឆ្ងល់[ល] ហើយគ្រវីក្បាលផង[វ]

**១៨:១១** ញ ២ពវ ២២:១៦ យរ ៤:៦ ដ ខ.១៨ ឋ ចទ ៤:៣០ ២ពវ ១៧:១៣ អស ១:១៦–១៩ ឌ យរ ៧:៣ ឍ យប ១៦:១៧
**១៨:១២** ណ អស ៥៧:១០ ត យរ ៣:១៧
**១៨:១៣** ថ អស ៦៦:៨ ទ យរ ៥:៣០ ធ ២ពវ ១៩:២១
**១៨:១៥** ន អស ១៧:១០ ប អស ១:១៣ យរ ៤៤:១៥,១៩ ផ យរ ១០:១៥ ៥១:១៨ ហស ១១:២ ព អក ៤៤:១២ មឡ ២:៨ ភ យរ ៦:១៦ ម អស ៥៧:១៤ ៦២:១០
**១៨:១៦** យ ចទ ២៨:៣៧ យរ ២៥:៩ អគ ៣៣:២៨–២៩

១៧អញនឹងកំចាត់កំចាយគេនៅចំពោះពួកខ្មាំងសត្រូវ ហាក់
ដូចជាមានខ្យល់[ស]ពីទិសខាងកើតផាត់ទៅ ឯអញនឹងបែរ
ខ្នងដល់គេ មិនមែនបែរមុខ[ហ]មើលគេ ក្នុងវេលាដែលគេ
មានសេចក្តីវេទនានោះឡើយ ។

១៨លំដាប់នោះ គេបបួលគ្នាថា ចូរមក យើងរក
បង្កើតឧបាយ[ឡ]ទាស់នឹងយេរេមាចុះ ដ្បិតក្រិត្យវិន័យនឹងមិន
ដែលសូន្យបាត់ពីពួកសង្ឃ[អ] ឬសេចក្តីប្រឹក្សាពីពួកអ្នកប្រាជ្ញ[ក]
ឬព្រះបន្ទូលពីពួកហោរាឡើយ[ខ]ចូរមកចុះ យើងនឹងវាយវា
ដោយអណ្តាត[គ] កុំឱ្យយើងស្តាប់តាមពាក្យណារបស់វាទៀត
ឡើយ ។

១៩ឱព្រះយេហូវ៉ាអើយ សូមទ្រង់ប្រុងស្តាប់ទូលបង្គំ
សូមស្តាប់ពាក្យរបស់ពួកអ្នក ដែលតតាំង[ឃ]នឹងទូលបង្គំផង
២០តើនឹងយកការអាក្រក់ស្នងនឹងការល្អឬអី[ង] ដ្បិតគេបាន
ជីករណ្តៅ[ច] ដើម្បីចាប់ព្រលឹងទូលបង្គំហើយ សូមនឹក
ចាំពីទូលបង្គំ ដែលបានឈរ[ឆ]នៅចំពោះទ្រង់ ដើម្បីសូម

រ យរ ១៩:៨ ៤២:១៨ ល លវ ២៦:៣២ វ ២ពវ ១៩:២១ យប ១៦:៤ ទដ ២២:៧ បទ ១:១២ **១៨:១៧** ស យប ៧:១០ យរ ១៣:២៤ ហ ២របា ២៩:៦ យរ ២:២៧ **១៨:១៨** ឡ ខ.១១ យរ ១១:១៩ អ យរ ២:៨ ហក ២:១១ មឡ ២:៧ ក យប ៥:១៣ អគ ៧:២៦ ខ យរ ៥:១៣ គ ទដ ៥២:២ ៦៤:២–៨ យរ ៩:៣ **១៨:១៩** ឃ ទដ ៧១:១៣ **១៨:២០** ង លប ៤៤:៤ ច ទដ ៣៥:៧ ៥៧:៦ ១១៩:៨៥ ឆ យរ ១៥:១

ក្នុងព្រះគម្ពីរភាសាហេព្រើរគួសបញ្ជាក់ឃ្លានេះ គឺបានបកប្រែថា "ការកែប្រែចិត្ត" ក្នុង ខ.៨ ។

**១៨:១២** *ឥតប្រយោជន៍* មើល ២:២៥ និងការពន្យល់ អស ៥៧:១០ ។ *ធ្វើតាមតែសេចក្តីរឹងចចេសនៃចិត្តអាក្រក់របស់គេរៀងខ្លួន* មើលការ ពន្យល់ ៣:១៧ ។

**១៨:១៣–១៧** មើល ២:១០–១៣ ។

**១៨:១៣** *ការយ៉ាងនេះ* មើល ៥:៣០ ២៣:១៤ ហស ៦:១០ ។ *នាងក្រមុំនៃពួកអ៊ីស្រាអែល* មើលការពន្យល់ ២ពវ ១៩:២១ ។

**១៨:១៤–១៥** ទោះបីជាពួកយូដាអាចទុកចិត្តបាន (ខ.១៤) តែគេជាមនុស្សសាវ៉ា ហើយមិនស្មោះត្រង់ (ខ.១៥) ។

**១៨:១៤** *ភ្នំល្បាណូន* ជាភ្នំមួយយ៉ាងខ្ពស់ ក្នុងចំណោមភ្នំផ្សេងទៀតនៅភាគខាងជើង (មើល ២២:៦) ដែលមានកំពស់៣០៣៨ម៉ែត្រ ។

**១៨:១៥** *ដ្បិតឯរាស្ត្រអញនេះ គេបានភ្លេចអញហើយ* បានរំឮកឡើងវិញពី ២:៣២ (មើលការពន្យល់នៅទីនោះ) ។ *ដុតកំញានថ្វាយ* មើលការពន្យល់ ១:១៦ ។ *ដល់អស់ទាំងព្រះក្លែងក្លាយ* ន័យត្រង់ "ឥតប្រយោជន៍" (ទដ ៣១:១៦ មើល យរ ២:៨ និងការពន្យល់) ។ *ហើយគេត្រូវជំពប់ក្នុងផ្លូវរបស់ខ្លួន* សូមមើល ២របា ២៨:២៣ ។ គឺជាផ្លូវពីចាស់បុរាណ មើលការពន្យល់ ៦:១៦ ។ *ផ្លូវច្រកដែលមិនបានលើកឡើយ* មើលការពន្យល់ អស ៣៥:៨ ។

**១៨:១៦** *ស្រឡាំងកាំង . . . ភាំងឆ្ងល់* ដូចគ្នានឹងព្រះគម្ពីរភាសាហេព្រើរ ដែលគួសចំណាំពាក្យទាំង២នេះ ហើយជាទីដែលមនុស្សធ្វើស៊ីសស៊ូសជានិច្ច មើល ១៩:៨ ២៥:៩,១៨ ២៩:១៨ ៥១:៣៧ ឃ្លានេះជាការសើចចំអក និងមើលងាយ ។ *គេធ្វើស៊ីសស៊ូស* មើល ១៩:៨ ១ពវ ៩:៨ ។ *ហើយគ្រវីក្បាលផង* មើល ៤៨:២៧ យប ១៦:៤ និងការពន្យល់ មើលផងដែរ ទដ ៤៤:១៤ ១០៩:២៥ ។

**១៨:១៧** *ហាក់ដូចជាមានខ្យល់ពីទិសខាងកើតផាត់ទៅ* មើល ៤:១១ ទដ ៤៨:៧ និងការពន្យល់ ។ *ឯអញនឹងបែរខ្នងដល់គេ មិនមែនបែរមុខមើលគេ* ដូចជាបណ្តាជនគេបានធ្វើចំពោព្រះដែរ (មើល ២:២៧) ។ ព្រះភ័ក្រទ្រង់និម្មិតរូបពីព្រះពរដ៏ល្អ និងជាទីពេញចិត្ត (មើល ជន ៦:២៤–២៦) ។

១៨:១៨–២៣ នេះជា "ការលន់តួបាប" លើកទី៥របស់លោកយេរេមា (មើលសេចក្តីផ្តើម អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។

**១៨:១៨** *គេ* ជាខ្មាំងសត្រូវរបស់លោកយេរេមា (សូមមើលការពន្យល់ ១៧:១៥) ។ *យើងមកបង្កើតឧបាយទាស់នឹងយេរេមាចុះ* មើល ខ.១២ ១១:១៨–២៣ ១២:៦ ១៥:១០–១១ ១៥–២១ ។ *ដ្បិតក្រិត្យវិន័យនឹងមិនដែលសូន្យបាត់* ផ្តល់អំណាចដល់ពួកសង្ឃ (មើលការពន្យល់ ហស ៤:៤–៩) ។ *ពួកសង្ឃ . . . ពួកអ្នកប្រាជ្ញ . . . ពួកហោរា* ទោះបីជាសេចក្តីទំនាយរបស់លោកយេរេមាផ្ទុយគ្នាក្តី (មើល ៦:១៣–១៥ ធៀបនឹង ២៣:៩–៤០ អគ ៧:២៦ និងការពន្យល់) ក៏បណ្តាជនបានគិតថា មានប្រភពផ្សេងៗគ្នាក្នុងការទទួលការដឹកនាំពីព្រះ អម្ចាស់ជាបន្តទៀតជាធម្មតាដែរ ។ *យើងនឹងវាយវាដោយអណ្តាត* មើលការ ពន្យល់ ៩:៣ ។

**១៨:២០** *តើនឹងយកការអាក្រក់ស្នង និងការល្អឬ* មើល ទដ ៣៥:១២ ។ *ដ្បិតគេបានជីករណ្តៅ* នេះជានិម្មិតរូបអំពីខ្មាំងសត្រូវរបស់លោកយេរេមាដែលប្រឆាំងនឹងគាត់ (មើល ខ.២២ ទដ ៥៧:៦ និងការពន្យល់ សភ

សេចក្ដីល្អឱ្យគេ[ជ] ហើយនឹងបំបែរសេចក្ដីក្រោធរបស់ទ្រង់
ចេញពីគេដែរ ២១ដូច្នេះ សូមទ្រង់ប្រគល់កូនចៅគេដល់
សេចក្ដីអំណត់អត់[ឈ] ហើយខ្លួនគេដល់អំណាចដាវផង[ញ] សូម
ឱ្យប្រពន្ធគេនៅជាឥតមានកូន និងជាមេម៉ាយ[ដ] ហើយឱ្យពួក
ប្រុសៗរបស់គេត្រូវស្លាប់ និងពួកកំឡោះៗ[ឋ]របស់គេត្រូវ
របួស ដោយដាវក្នុងសង្គ្រាម ២២សូមឱ្យមានឮសំរែក[ឌ]
ចេញពីផ្ទះគេ ក្នុងកាលដែលទ្រង់នាំពួកពលទ័ពមកលើគេ
ភ្លាម ដ្បិតគេបានជីករណ្ដៅ[ឍ] ដើម្បីនឹងចាប់ទូលបង្គំហើយ
ក៏បានលាក់អន្ទាក់[ណ] ដើម្បីនឹងទាក់ជើងទូលបង្គំផង ២៣ប៉ុន្តែ
ឱព្រះយេហូវ៉ាអើយ ទ្រង់ជ្រាបអស់ទាំងគំនិត ដែលគេ
ប្រឹក្សាគ្នា ដើម្បីសំឡាប់[ត]ទូលបង្គំហើយ សូមទ្រង់កុំអត់
ទោស[ថ]ចំពោះសេចក្ដីទុច្ចរិតរបស់គេឡើយ ក៏កុំឱ្យលុបអំពើ
បាបរបស់គេពីចំពោះទ្រង់ដែរ គឺឱ្យគេត្រូវដួលនៅចំពោះ
ទ្រង់វិញ សូមទ្រង់សំរេចដល់គេ ក្នុងវេលាដែលទ្រង់មាន
សេចក្ដីខ្ញាល់ចុះ[ទ] ។

**១៩** ១ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ចូរទៅទិញ
ក្អមធ្វើដោយដី ពីជាងស្មូន[ក]មក រួចនាំពួកចាស់ទុំ[ខ]នៃបណ្ដា
ជន និងពួកចាស់ទុំក្នុងពួកសង្ឃ ២ចេញទៅឯច្រកភ្នំនៃកូន
ចៅហ៊ីនណំម[គ] ដែលនៅត្រង់មុខទ្វារចូលហាស៊ីត ហើយ
ប្រកាសប្រាប់ពាក្យទាំងប៉ុន្មាននៅទីនោះ ដែលអញនឹង
ប្រាប់ដល់ឯង ៣ត្រូវឱ្យប្រាប់ថា ឱពួកស្ដេច[ឃ]ស្រុកយូដា
និងពួកអ្នកនៅក្រុងយេរូសាឡិមអើយ ចូរស្ដាប់ព្រះបន្ទូល
នៃព្រះយេហូវ៉ាចុះ ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះ
នៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា មើលអញ
នឹងនាំសេចក្ដីអាក្រក់[ង]មកលើទីនេះ ដែលអ្នកណាឮ នោះ
នឹងខ្ទ័រត្រចៀក[ច] ៤ដ្បិតគេបានបោះបង់ចោល[ឆ]អញ ហើយ
បានបង្អាប់ទីនេះ ព្រមទាំងដុតកំញាន[ជ]នៅទីនេះថ្វាយដល់
ព្រះដទៃ[ឈ] ជាព្រះដែល ទោះទាំងខ្លួនគេ ពួកឰយុកោគេ ឬ
ពួកស្ដេចសាសន៍យូដា ក៏មិនបានស្គាល់ផង ហើយបាន
ធ្វើឱ្យទីនេះពេញ ដោយឈាមនៃមនុស្ស ដែលឥតមាន
ទោសដែរ[ញ] ៥គេបានស្អាងអស់ទាំងទីខ្ពស់របស់ព្រះបាល
សំរាប់នឹងដុតកូនប្រុសៗ[ដ]របស់គេ ទុកជាដង្វាយដុតថ្វាយ

**១៨:២០** ជ លប ២០:៧ ចទ ៩:១៩ ទដ ១០៦:២៣ យរ ១៤:៧–៩ **១៨:២១** ឈ យរ ១១:២២ ១៤:១៦ ញ ទដ ៦៣:១០ ដ ១សយ ១៥:៣៣ ទដ ១០៩:៩ អស ៤៧:៩ បទ ៥:៣ ឋ អស ៩:១៧ **១៨:២២** ឌ យរ ៦:២៦ ឍ ទដ ១១៩:៨៥ ណ ទដ ៣៥:១៥ ១៤០:៥ យរ ៥:២៦ ២០:១០ **១៨:២៣** ត យរ ១១:២១ ៣៧:១៥ ថ នហ ៤:៥ ទ ទដ ៥៩:៥ យរ ១០:២៤ **១៩:១** ក យរ ១៨:២ ខ ជន ១១:១៧ ១ពវ ៨:១

**១៩:២** គ យស ១៥:៨ **១៩:៣** ឃ យរ ១៧:២០ ង យរ ៦:១៩ ច ១សយ ៣:១១ **១៩:៤** ឆ ចទ ៣១:១៦ ចទ ២៨:២០ អស ៦៥:១១ ជ លវ ១៨:២១ ឈ នក ២០:៣ យរ ១:១៦ ញ ២ពវ ២១:១៦ **១៩:៥** ដ លវ ១៨:២១ ២ពវ ៣:២៧ ទដ ១០៦:៣៧–៣៨

២២:១៤ ២៣:២៧ ។ *ដែលឈរនៅចំពោះទ្រង់* មើលការពន្យល់ ១៥:១ ។ *ដើម្បីសូមសេចក្ដីល្អឱ្យគេ* មើល ១៤:៧–៩,២១ ។

**១៨:២១** *ហើយខ្លួនគេដល់អំណាចដាវផង* ក្នុងព្រះគម្ពីរភាសាហេព្រើរគួសបញ្ជាក់ឃ្លានេះ កើតមានផងដែរនៅក្នុង ទដ ៦៣:១០ អគ ៣៥:៥ ។ ត្រូវស្លាប់ន័យត្រង់ "ត្រូវគេសម្លាប់" ប្រហែលជាសំដៅលើការស្លាប់ដោយជម្ងឺអាសន្នរោគ ដូចជានៅក្នុង ១៥:២ (មើលការពន្យល់) ។

**១៨:២២–២៣** មើល ទដ ១៤១:៨–១០ ។

**១៨:២២** *ក៏បានលាក់អន្ទាក់* មើល ទដ ១៤០:៥ ១៤២:៣ ។

**១៨:២៣** *ប៉ុន្តែឱព្រះយេហូវ៉ា ទ្រង់ជ្រាបអស់ទាំងគំនិត* សូមមើល ១២:៣ ១៥:១៥ ។ *សូមទ្រង់កុំអត់ទោសចំពោះសេចក្ដីទុច្ចរិតរបស់គេឡើយ* សេចក្ដីអធិស្ឋានមិនមែនធ្វើឡើង ដើម្បីសងសឹកចំពោះមនុស្សឡើយ ប៉ុន្តែធ្វើឡើងទៅតាមបំណងព្រះហឫទ័យរបស់ព្រះ (មើលការពន្យល់ ១០:២៥) ។ *ក៏កុំឱ្យលប់អំពើបាបរបស់គេ* មើល ទដ ៥១:១–២ និងការពន្យល់ ។

**១៩:១–១៥** លោកយេរេមាបានធ្វើឱ្យក្អមនោះបែក (ខ.១–១០) ដែលជានិមិត្តរូបអំពីការមកដល់ នៃការបំផ្លាញស្រុកយូដា និងការបំផ្លាញក្រុងយេរូសាឡិម (ខ.១១–១៥) ។ នៅក្នុងជំពូក ១៨ ដីឥដ្ឋនៅកន្លែងជាងស្មូន គឺទន់សើម ដែលអាចកែឆ្នៃធ្វើអ្វីបាន (មើល ១៨:១–១១) ។ នៅក្នុងជំពូក ១៩ តែទោះជាយ៉ាងណាក្តីបើដីឥដ្ឋនោះរឹងពេក ហើយម្ចាស់ដែលធ្វើវាពិបាកឆ្នៃពេក នោះជាងស្មូនមានតែបំបែកវាប៉ុណ្ណោះ ។

**១៩:១** *ក្អម* ភាសាហេព្រើរសម្រាប់ពាក្យនេះ ដូចជាភាជនៈដែលមានកតូចជាងតួខ្លួន មានកំពស់ ០.៣០ សង់ទីម៉ែត្រ ដែលអាចរក្សាទុកទឹកខាងក្នុងបាន ។ *ពួកចាស់ទុំ* មើលការពន្យល់ នក ៣:១៦ ។ *នៃបណ្ដាជន* មើល ១ពវ ៨:១–៣ ។ *ក្នុងពួកសង្ឃ* មើល ២ពវ ១៩:២ "សង្ឃដែលនាំមុខគេ" (ន័យត្រង់ "ពួកចាស់ទុំនៃសង្ឃ") ។ ពួកចាស់ទុំនៅអ៊ីស្រាអែលមាន២ប្រភេទ គឺ១ផ្នែកកាន់តួនាទីបម្រើខាងផ្នែកសង្គមស៊ីវិលជាបឋម និង១ផ្នែកទៀតបំរើខាងផ្នែកសាសនា ។

**១៩:២** *ចេញទៅឯច្រកភ្នំនៃកូនចៅហ៊ីនណំម* មើលការពន្យល់ ៧:៣១ ។ *មុខទ្វារចូលហាស៊ីត* នៅឯក្រុងយេរូសាឡិម ជាឃ្លាអក្សរអារ៉ាមនៅជំនាន់បុរាណ) ដែលបញ្ជាក់ពីមុខទ្វារចូលហាស៊ីត (បានដាក់ហៅដូចនេះដោយសារទីកន្លែងនោះ ជាទីកន្លែងជាងស្មូន) និងកន្លែងក្រោលសត្វ នៅក្នុង នហ ២:១៣ (មើលការពន្យល់) ៣:១៣–១៤ ១២:៣១ ។

**១៩:៣** *ឱពួកស្ដេច* មើលការពន្យល់ ១៧:២០ ។ *សេចក្ដីអាក្រក់... ដែលអ្នកណាឮ... នោះនឹងខ្ទរត្រចៀក* ចម្លើយមកពី ២ពវ ២១:១២ (មើល ១សយ ៣:១១) ។ ឃ្លានេះនិយាយសំដៅទៅលើត្រចៀកដែលហឹង មិនអាចស្ដាប់ឮសេចក្ដីប្រកាស ការព្រមានអំពីការជំនុំជម្រះ ។

**១៩:៤** *ដ្បិតគេ* គេទាំងអស់គ្នាបានព្យាយាមថ្វាយបង្គំរូបព្រះ និងថ្វាយបង្គំដល់ព្រះដ៏ពិតផងដែរ ។ *ទីនេះ* ក្រុងយេរូសាឡិម ។ *ព្រមទាំងដុតកំញាន* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ គឺតែងតែបានបកប្រែថា "ដុតគ្រឿងក្រអូប" មាននៅកន្លែងផ្សេងទៀត នៅក្នុងព្រះគម្ពីរយេរេមា (មើលការពន្យល់ ១:១៦) ។ ហើយបានធ្វើឱ្យទីនេះពេញ ដោយឈាមនៃមនុស្សដែលឥតមានទោសដែរ ឈាមមនុស្សដែលគោរពកោតខ្លាចព្រះ (មើល ២:៣៤ ៧:៦ ២២:៣,១៧ ២៦:១៥) ជាពិសេសដូចជាខ្ទម ដែលបានធ្វើដោយស្ដេចដ៏អាក្រក់ គឺស្ដេចម៉ានាសេ (មើល ១៥:៤ និងការពន្យល់ និងមើលការពន្យល់ ២ពវ ២១:១៦) ។

**១៩:៥–៦** រំឭកឡើងវិញ១ផ្នែកធំពី ៧:៣១–៣២ (មើលការពន្យល់នៅទីនោះ) ។

ព្រះបាល ជាការដែលអញមិនបានបង្គាប់ដល់គេ ឬ
និយាយឡើយ ក៏មិនបានចូលក្នុងគំនិតអញដែរ[ឋ] ៦ដូច្នេះ
ព្រះយេហូវ៉ាមានបន្ទូលថា មើលនឹងមានគ្រាមកដល់ ដែល
គេនឹងលែងហៅទីនេះថា តូផែត[ឌ] ឬថាច្រកភ្នំរបស់កូនចៅ
ហ៊ីនណំមទៀត[ឍ] គឺនឹងហៅថា ច្រកភ្នំសំឡេះវិញ[ណ] ៧គ្រា
នោះអញនឹងធ្វើឱ្យសេចក្តីប្រឹក្សា[ត]របស់ពួកយូដា និងក្រុង
យេរូសាឡិមសូន្យបាត់នៅទីនេះ ព្រមទាំងធ្វើឱ្យគេដួល
ដោយដាវ នៅមុខពួកខ្មាំងសត្រូវរបស់គេ[ថ] ហើយដោយ
ដាវ នៅមុខពួកអ្នកដែលរកជីវិតគេផង ឯសាកសព[ទ]របស់
គេ អញនឹងប្រគល់ជាអាហារ[ធ] ដល់សត្វហើរលើអាកាស
នឹងសត្វជើង៤នៅផែនដី ៨អញនឹងធ្វើឱ្យទីក្រុងនេះទៅ
ជាទីស្រឡាំងកាំង ហើយជាទីដែលគេនឹងធ្វើស៊ីសស៊ូស[ន] ឱ្យ
អស់អ្នកណាដែលដើរមកជិត គេនឹងភាំងឆ្ងល់[ប] ហើយ
នឹងធ្វើស៊ីសស៊ូស ដោយព្រោះគ្រប់ទាំងសេចក្តីវេទនា
របស់ក្រុងនេះ[ផ] ៩អញនឹងធ្វើឱ្យគេស៊ី[ព]សាច់កូនប្រុសកូនស្រី
របស់ខ្លួន ហើយគ្រប់គ្នានឹងស៊ីសាច់ភឿនមិត្ររបស់ខ្លួន
ក្នុងគ្រា ដែលពួកខ្មាំងសត្រូវ[ភ]នឹងធ្វើដល់គេ ដើម្បីរក
ប្រហារជីវិតគេ ។
១០លំដាប់នោះ ត្រូវឱ្យឯងបំបែកក្អម[ម]នោះ នៅមុខ
ពួកមនុស្ស ដែលបានទៅជាមួយនឹងឯង ១១ហើយត្រូវ
ប្រាប់ដល់គេថា ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មាន
បន្ទូលដូច្នេះ គឺបែបយ៉ាងនេះឯង ដែលអញនឹងបំបែក
បំបាក់[យ]ជនជាតិនេះ ហើយទីក្រុងនេះផង គឺដូចជាអ្នកណា
បំបែកក្អមរបស់ជាងស្មូន ឱ្យបង្កើតឡើងវិញមិនបានដែរ
ហើយមនុស្សនឹងកប់[រ]ខ្មោចគេនៅត្រង់តូផែត ទាល់តែគ្មាន
កន្លែងទៀត ១២ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញនឹងធ្វើ
ដូច្នេះដល់ទីនេះ ហើយដល់ពួកអ្នកដែលអាស្រ័យនៅ គឺនឹង
ធ្វើឱ្យទីក្រុងនេះត្រឡប់ទៅដូចជាតូផែតផង ១៣អស់ទាំងផ្ទះ[ល]
នៅក្រុងយេរូសាឡិម និងដំណាក់នៃស្តេចស្រុកយូដាទាំង
ប៉ុន្មាន ដែលគេបានធ្វើឱ្យស្មោកគ្រោក[វ]ហើយ នោះនឹង
បានដូចជាទីតូផែតនេះដែរ គឺអស់ទាំងផ្ទះណាដែលគេ
បានឡើងទៅលើដំបូល[ស] ដើម្បីដុតកំញានថ្វាយដល់ពួក
ពលបរិវារ[ហ]នៅលើមេឃ ហើយច្រួចដង្វាយ[ឡ]ថ្វាយដល់
ព្រះដទៃនោះឯង ។
១៤រួចយេរេមាវិលមកពីតូផែត ជាកន្លែងដែលព្រះ

**១៩:៦** ឋ យរ ៧:៣១ អគ ១៦:៣៦ ឌ ២ពវ ២៣:១០ ឍ យស ១៥:៨ ណ យរ ៧:៣២ **១៩:៧** ត ទដ ៣៣:១០–១១ ថ ខ.៩ លវ ២៦:១៧ ចទ ២៨:២៥ ទ យរ ១៦:៤ ៣៤:២០ ធ ចទ ២៨:២៦ **១៩:៨** ន ចទ ២៨:៣៧ យរ ១៨:១៦ ២៥:៩ ប លវ ២៦:៣២ បទ ២:១៥–១៦ ផ ចទ ២៩:២២ **១៩:៩** ព លវ ២៦:២៩ ចទ ២៨:៤៩–៥៧ បទ ៤:១០ ភ ខ.៧ យរ ២១:៧ ៣៤:២០ **១៩:១០** ម ខ.១ ទដ ២:៩ យរ ១៣:១៤ **១៩:១១** យ ទដ ២:៩ អស ៣០:១៤ រ យរ ៧:៣២ **១៩:១៣** ល យរ ៣២:២៩ ៥២:១៣ អគ ១៦:៤១ វ ទដ ៧៤:៧ ស ២ពវ ២៣:១២ ហ ចទ ៤:១៩ ២ពវ ១៧:១៦ យប ៣៨:៣២ យរ ៨:២ កច ៧:៤២ ឡ អស ៥៧:៦ អគ ២០:២៨

**១៩:៧** *សូន្យបាត់* ន័យត្រង់ "ចាក់ចេញ" (មើលការពន្យល់ ក្នុង ខ.១) ។ ដូចជាលោកយេរេមាបាននិយាយបែបយ៉ាងនេះថា គាត់បាន ចាក់ទឹកចេញពីក្អមទៅលើដី (ធៀបនឹង ២សយ ១៤:១៤) ។ *ព្រមទាំងធ្វើឱ្យ គេដួលដោយដាវនៅមុខពួកខ្មាំងសត្រូវរបស់គេ* ពួកបាប៊ីឡូនគឺជាឧបករណ៍របស់ព្រះ ដើម្បីគំរាមកំហែងដល់គេ (មើល ២០:៦) ។ *សាកសពរបស់គេ អញនឹងប្រគល់ជាអាហារ ដល់សត្វហើរលើអាកាស និងសត្វជើង៤នៅផែនដី* មើល ៧:៣៣ និងការពន្យល់ ។

**១៩:៨** សូរសំលេងអក្សរក្នុង ១៨:១៦ (មើលការពន្យល់ក្នុងខនោះ មើលផងដែរ អគ ២៧:៣៥ សផ ២:១៥) ។ *ជាទីស្រឡាំងកាំង . . . ធ្វើស៊ីសស៊ូស* ដូចគ្នានៅក្នុងព្រះគម្ពីរភាសាហេព្រើរគូសចំណាំពាក្យទាំង២នេះ ការស្រឡាំងកាំងនឹងកើតមានឡើងដល់ទីក្រុង ហើយវាជះឥទ្ធិពលដូចគ្នា ទៅដល់អស់អ្នកដែលមើលឃើញសេចក្តីហិនវិនាសនោះ ។ *ភាំងឆ្ងល់ . . .សេចក្តីវេទនា* ក្នុងព្រះគម្ពីរភាសាហេព្រើរដូចគ្នា គូសចំណាំពាក្យទាំង២នេះ ។

**១៩:៩** នេះជាបណ្តាសា ការតាំងសញ្ញា១ (មើល លវ ២៦:២៩ ចទ ២៨:៥៣–៥៧) ។ គេស៊ីសាច់កូនប្រុសកូនស្រីរបស់ខ្លួន. . .ស៊ីសាច់ភឿនមិត្ររបស់ខ្លួន នៅពេលដែលក្រុងយេរូសាឡិមអស់អាហារ ដើម្បីផ្គត់ផ្គង់ដល់បណ្តាជន ក្នុងកំឡុងពេលដែលពួកបាប៊ីឡូនបានចូលឡោមព័ទ្ធក្រុងយេរូសាឡិមក្នុងឆ្នាំ ៥៨៦ មុន គ.ស លទ្ធផលការស៊ីសាច់មនុស្ស (មើល បទ ២:២០ ៤:១០ អគ ៥:១០) ។ នេះជាសកម្មភាព១ ដែលមិនធ្លាប់មានពីមុនមកនៅអ៊ីស្រាអែល (មើល ២ពវ ៦:២៨–២៩) ហើយវាបានកើតឡើងម្តងទៀត ឆ្នាំទី៧០ក្រោយ គ.ស ក្នុងកំឡុងពេលពួករ៉ូមមាំងបានធ្វើការឡោមព័ទ្ធក្រុងយេរូសាឡិម (មើល សក ១១:៩ និងការពន្យល់) "ស្ត្រីដែលបានភាសខ្លួនទៅក្រុងយេរូសាឡិម បានសម្លាប់កូនប្រុសគេ អាំងកូន និងស៊ីកូនអស់១ចំហៀង តែគេបានលាក់បាំង ហើយជួយសង្គ្រោះមួយចំនួនដែលនៅសល់" (នៅសម័យសង្គ្រាម យ៉ូសែបពើស)

**១៩:១១** *ដែលអញនឹងបំបែកបំបាក់ជនជាតិនេះ . . . បំបែកក្អមរបស់ជាងស្មូន* ការគ្រប់គ្រងពួកអេស៊ីព្ទលើកទី១២ (ឆ្នាំ១៩៩១–១៧៨៦ គ.ស) ដោយបានសរសេរឈ្មោះពួកខ្មាំងសត្រូវរបស់គេ នៅកន្លែងជាងស្មូន ហើយបន្ទាប់មកបំបែកវាចោល ដោយសង្ឃឹមថា អាចបំផ្លាញអំណាចពួកខ្មាំងសត្រូវបាន ។ ឱ្យផ្គុំឡើងវិញមិនបានដែរ មើលការពន្យល់ ខ.១–១៥) ។

**១៩:១៣** *នោះនឹងបានដូចជាទីតូផែតផង* ស្តេចយ៉ូសៀសបាន "ប្រមាថ" ដល់តូផែត នៅជំនាន់ដើម (២ពវ ២៣:១២) ។ *ដើម្បីដុតកំញានថ្វាយ* មើលការពន្យល់ ១:១៦ ។ *បានឡើងទៅលើដំបូល* មើល ៣២:២៩ មើលការពន្យល់ អស ១៥:៣ ។ ពួកស្តេចយូដាបានស្អាងអាសនារូបព្រះនៅលើដំបូលក្រុងយេរូសាឡិម (មើល ២ពវ ២៣:១២) ។ ការនិយាយអំពីយូហ្គារិទិចខេរេត (Ugaritic Keret) នៅសតវត្សទី១២ មុន គ.ស ដែលបានពិណនាការអនុវត្តដូចគ្នាថា "ចូរឡើងទៅលើកំពូលប៉ម កន្នែកជើងឈរនៅលើកំពូលជញ្ជាំង គោរពដល់ព្រះបាល ដោយថ្វាយយញ្ញបូជា ហើយបន្ទាប់មកចុះពីដំបូលផ្ទះមក" ។ *ពួកពលបរិវានៅលើមេឃ* នោះជាការថ្វាយបង្គំដល់ព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយ នោះជារឿងធម្មតារបស់ពួកយូដា ទូទាំងប្រវត្តិសាស្ត្រក្រោយមកទៀត របស់ស្តេចជំនាន់នោះ (មើលឧ. ២ពវ ១៧:១៦ ២១:៣,៥ ២៣:៤–៥ សផ ១:៥) ។ *ហើយច្រួចដង្វាយថ្វាយដល់ព្រះដទៃនោះផង* មើលការពន្យល់ក្នុង ៧:១៨ ។

**១៩:១៤** *បណ្តាជនទាំងឡាយ* មានហ្វូងមនុស្សជាច្រើនជាងពួកចាស់ទុំ ខ.១ ។

យេហូវ៉ា បានចាត់ឱ្យលោកទៅទាយនោះ លោកក៏ឈរ
នៅទីលានព្រះវិហារ[អ]នៃព្រះយេហូវ៉ា មានប្រសាសន៍ដល់
បណ្តាជនទាំងឡាយថា ១៥ព្រះយេហូវ៉ានៃពួកពលបរិវារ
ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ មើល
អញនឹងនាំគ្រប់ទាំងសេចក្តីអាក្រក់[ក]មកលើក្រុងនេះ ហើយ
និងអស់ទាំងដំបន់នៅជុំវិញ ដូចជាអញបានប្រកាសប្រាប់
ទាស់នឹងគេ ពីព្រោះគេបានតាំងចិត្តរឹងរូស[ខ] ដើម្បីនឹងឱ្យឮ[គ]
ពាក្យរបស់អញឡើយ ។

## លោកយេរេមា និងលោកផាសហ៊ើរ

**២០** ១រីឯផាសហ៊ើរ ជាកូនអ៊ីមមើរដ៏ជាសង្ឃ[ក] ដែល
ជានាយកធំ[ខ]ក្នុងព្រះវិហារនៃព្រះយេហូវ៉ា លោកបានឮ
កំពុងដែលយេរេមាទាយសេចក្តីទាំងនេះ ២ដូច្នេះ លោក
ក៏វាយ[គ]ហោរាយេរេមា ហើយយកទៅដាក់គុក[ឃ] ដែលនៅ
ត្រង់ទ្វារបេនយ៉ាមីន[ង]ខាងលើ នាកំផែងរបស់ព្រះវិហារនៃ
ព្រះយេហូវ៉ា ៣លុះដល់ស្អែកឡើងផាសហ៊ើរក៏នាំយេរេមា
ចេញពីគុកមក ខណនោះយេរេមាប្រាប់លោកថា ព្រះ
យេហូវ៉ាទ្រង់មិនបានហៅឈ្មោះ[ច]លោកថា ផាសហ៊ើរ
នោះទេ គឺហៅថា ម៉ាកោរ-មីស្សាប៊ីបវិញ[ឆ] ៤ដ្បិតព្រះ
យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ មើល អញនឹងធ្វើឱ្យឯង
ជាទីស្ញែងខ្លាចដល់ខ្លួន ហើយដល់អស់ទាំងមិត្រសំឡាញ់
របស់ឯងផង គេនឹងដួលដោយដាវរបស់ពួកខ្មាំងសត្រូវ
ហើយភ្នែក[ជ]របស់ឯងនឹងឃើញដែរ អញនឹងប្រគល់[ឈ]ស្រុក
យូដាទាំងមូល ទៅក្នុង[ញ]កណ្តាប់ដៃនៃស្តេចបាប៊ីឡូន ព្រម
ទាំងសំឡាប់គេដោយដាវផង ៥១ទៀតអញនឹងប្រគល់
អស់ទាំងទ្រព្យសម្បត្តិ[ដ]នៃក្រុងនេះ ហើយផលដែលកើត
មានទាំងប៉ុន្មាន ព្រមទាំងរបស់ថ្លៃវិសេសទាំងអស់ផង អើ
អញនឹងប្រគល់ព្រះរាជទ្រព្យ របស់ពួកស្តេចយូដាទាំង
ប៉ុន្មាន ទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវគេ ពួកនោះ
នឹងចាប់យក[ឋ]ជារបឹប នាំទៅឯស្រុកបាប៊ីឡូន ៦ឯឯង
ផាសហ៊ើរអើយ ឯង និងអស់អ្នកដែលអាស្រ័យនៅផ្ទះឯង
នឹងត្រូវដឹកនាំទៅជាឈ្លើយ គឺឯងនឹងត្រូវទៅដល់ក្រុង
បាប៊ីឡូន នៅទីនោះឯងនឹងត្រូវស្លាប់ ហើយគេនឹងកប់
ឯងនៅស្រុកនោះ គឺទាំងឯង និងពួកមិត្រសំឡាញ់ឯង
ដែលឯងបានទាយ[ឌ]កុហកដល់គេនោះផង ។

**១៩:១៤** អ ២រប ២០:៥ យរ ៧:២ ២៦:២ **១៩:១៥** ក ខ.៣ យរ ១១:១១ ខ នហ ៩:១៦ កថ ៧:៥១ គ យរ ២២:២១ **២០:១** ក ១រប ២៤:១៤ ខ ២ពវ ២៥:១៨ លក ២២:៥២ **២០:២** គ ចទ ២៥:២-៣ យរ ១:១៩ ១៥:១៥ ៣៧:១៥ ២កថ ១១:២៤ ឃ យប ១៣:២៧ យរ ២៩:២៦ កថ ១៦:២៤ ហព ១១:៣៦ ង យប ២៩:៧ យរ ៣៧:១៣ ៣៨:៧ សក ១៤:១០ **២០:៣** ច ហស ១:៤ ឆ ខ.១០ ទដ ៣១:១៣ **២០:៤** ជ យរ ២៩:២១ ឈ យរ ២១:១០ ២៥:៩ ញ យរ ១៣:១៩ ៣៩:៩ ៥២:២៧ **២០:៥** ដ ២ពវ ២៥:១៥ យរ ១៧:៣ ឋ ២ពវ ២០:១៧ **២០:៦** ឌ យរ ១៤:១៥ បទ ២:១៤

**១៩:១៥** *ហើយអស់ទាំងដំបន់នៅជុំវិញ* ទីក្រុងយូដា គឺបានពឹងផ្អែកលើក្រុងយេរូសាឡិម (មើល ១:១៥ ៩:១១) ។ *ពីព្រោះគេបានតាំងចិត្តរឹងរូស ដើម្បីមិនឱ្យឮពាក្យរបស់អញឡើយ* រំឭកឡើងវិញពីក្នុង ៧:២៦ (មើលការពន្យល់ក្នុងខនេះ មើលផងដែរ ១១:១០) ។

**២០:១-៦** ផាសហ៊ើរ ជាកូនអ៊ីមមើរដ៏ជាសង្ឃ ដែលជានាយកធំក្នុងវិហារនៃព្រះ និងការឆ្លើយតបរបស់លោកផាសហ៊ើរ គឺជានិមិត្តនៃសកម្មភាពការងារចំពោះហោរាយេរេមា (ខ.១-២) និងជាការឆ្លើតបរបស់ហោរាយេរេមា (ខ.៣-៦) ។

**២០:១** *ផាសហ៊ើរ* មានមនុស្សឈ្មោះដូចគាត់ជាច្រើន ប៉ុន្តែជាមនុស្សផ្សេងគ្នា ដូចមានប្រាប់នៅក្នុង ២១:១ ៣៨:១ ។ *អ៊ីមើរ* គាត់ប្រហែលជាកូចៅ នៃអ្នកនាំមុខដ៏ជាសង្ឃ ទី១៦ នៅក្នុងព្រះវិហារក្រុងយេរូសាឡិម (១រប ២៤:១៤) ។ *នាយកធំ* គឺជាសង្ឃ ដែលទទួលរ៉ាប់រងនូវការដាក់ទោសចំពោះអ្នកដែលបង្ករបញ្ហា ដើម្បីបញ្ជាក់ថា ពិត ឬ មិនពិតនៅក្នុងការកាត់ក្តី (សូមមើល ខ.២ ២៩:២៦) ។ ជាមុខងារទីពីរដែលបន្ទាប់ពីសម្តេចសង្ឃ (ប្រៀបធៀប ២៩:២៥-២៦ និង ៥២:២៤) ។

**២០:២** កាលពីលើដំបូង គឺមានការកត់ចុះនៅក្នុងបញ្ជីជាច្រើន នូវសកម្មភាពនៃការប្រើអំពើហិង្សាប្រឆាំងទាស់ មកលើរាង្គកាយរបស់ហោរា យេរេមា ។ *ហោរា* កាលពីគ្រាមុន ហោរាយេរេមាត្រូវបានទទួលការត្រាស់ហៅមកអំពីព្រះដើម្បីធ្វើជាហោរា គឺនៅក្នុងព្រះគម្ពីរយេរេមា (សូមមើលសេចក្តីផ្តើមនៅត្រង់ខ្លឹមសារ វិជ្ជាសិក្សាអំពីព្រះ និងខ្លឹមសារទូទៅ) ។ នៅត្រង់ចំណុចនេះ ជាការបញ្ជាក់អំពីរការងារយ៉ាងធំរបស់លោកផាសហ៊ើ ។ *ក៏វាយ* ប្រហែលជាការអនុញ្ញាតឱ្យប្រព្រឹត្តតាមក្រឹត្យវិន័យរបស់លោកម៉ូសេ ចទ ២៥:២-៣ (សូមមើលការពន្យល់នៅក្នុង ចទ ២៥:៣) ។ គុក ន័យត្រង់គឺហៅថា "ការបង្ខាំងទុកនៅក្នុងមន្ទីរឃុំឃាំង" ។ *ត្រង់ទ្វារបេនយ៉ាមីនខាងលើ* ទំនងដូចជានៅ "ទ្វារខាងជើងដែលស្ថិតនៅទីលានខាងក្នុង" (អគ ៨:៣ សូមមើល ២ពវ ១៥:៣៥ សូមមើល អគ ៩:២ ផងដែរ) ។ *ព្រះវិហារនៃព្រះយេហូវ៉ា* គឺគេចាត់ទុកព្រះវិហារនៃព្រះយេហូវ៉ា ជាកន្លែងល្បីឈ្មោះនៅត្រង់ទ្វារនៃព្រះវិហាររបស់បេនយ៉ាមីនដែរ "ចាប់ពីទ្វារបេនយ៉ាមីន" ដែលនៅក្នុងជញ្ជាំងទីក្រុង (៣៧:១៣ ៣៨:៧) ។ ទ្វារទាំងពីរនេះ គឺស្ថិតនៅភាគផ្នែកខាងជើងនៃទីក្រុង ដែលនៅពីមុខដែនដីរបស់លោកបេនយ៉ាមីន ។

**២០:៣** *ម៉ាកោ-មីស្សាប៊ីប* សូមមើការពន្យល់ ៦:២៥ ។

**២០:៤** ឈ្មោះថ្មីរបស់លោកផាសហ៊ើរ គឺជានិមត្តរូបសំគាល់ពីភាពតក់ស្លុតចំពោះពួកយូដាទាំងអស់ ដែលមនុស្សទាំងនោះត្រូវបាននិរទេសបំបរបង់ទៅកាន់ស្រុកបាប៊ីឡូនដើម្បីឱ្យបានទទួលសេចក្តីស្លាប់ ។ *មិត្រសំឡាញ់* ជាការទំនាក់ទំនង នៃការរួបរួមនិងការចងសម្ព័ន្ធមិត្រ នៅក្នុងការតាំងសញ្ញាជាមួយគ្នា (សូមមើល ខ.៦) ។ *ស្តេចបាប៊ីឡូន* ស្តេចនេប៊ូក្នេសារ ទ្រង់គឺជាស្តេចនៃទីស្រុកបាប៊ីឡូន ដែលទ្រង់បានឡើងគ្រងរាជ្យ ក្នុងឆ្នាំ ៦០៥ មុន គ.ស (សូមមើល ការពន្យល់នៅ ១៧:១៥ ១៨:១-២០:១៨) ។

**២០:៥** បានកើតឡើងក្នុងឆ្នាំ ៥៩៧ មុន គ.ស (សូមមើល ២ពវ ២៤:១៣) និងនៅក្នុងឆ្នាំ ៥៨៦ មុន គ.ស (សូមមើល ៥២:១៧-២៣ ២ពវ ២៥:១៣-១៧) ។

**២០:៦** *ឯង ផាសហ៊ើរអើយ . . . នឹងត្រូវដឹកនាំទៅជាឈ្លើយ* ទំនងជាកើតឡើងនៅក្នុងឆ្នាំ ៥៩៧ មុន គ.ស ពីព្រោះជារយៈពេលដ៏ខ្លីបន្ទាប់ពីឆ្នាំនោះមក (សូមមើល ២៩:២) ។ បន្ទាប់មកមានមនុស្សពីរនាក់ផ្សេងទៀត ដែលបានឡើងគ្រងស្នងរាជ្យជំនួសលោកផាសហ៊ើរ ដើម្បីឱ្យធ្វើជាមេនាយកនៅក្នុងព្រះវិហារ (សូមមើល ២៩:២៥-២៦) ។ *ឯងបានទាយកុហក* ផាស-

## លោកយេរេមាបង្ហាញអំពីការមិនពេញចិត្ត

៧ឱព្រះយេហូវ៉ាអើយ ទ្រង់បានបញ្ចុះបញ្ចូល[ឍ]ទូលបង្គំ
ហើយទូលបង្គំក៏បណ្ដោយតាម ទ្រង់មានកំឡាំងជាង[ណ] ក៏
បានឈ្នះទូលបង្គំហើយ ឯទូលបង្គំ បានត្រឡប់ជាទីសើច
ឡក[ត] រាល់ថ្ងៃជានិច្ច មនុស្សទាំងអស់ចំអកឡកឡឺយ[ថ]ឱ្យទូល
បង្គំ ៨ដ្បិតវេលាណាដែលទូលបង្គំនិយាយ នោះទូលបង្គំ
ស្រែកឡើង ទូលបង្គំបន្លឺពីការច្រឡោត និងការបំផ្លាញ
ទទេ[ទ] ពីព្រោះគេយកព្រះបន្ទូលនៃព្រះយេហូវ៉ាធ្វើឱ្យត្រឡប់
ជាសេចក្ដីដំនៀលដល់ទូលបង្គំ ហើយជាសេចក្ដីឡកឡឺយ[ធ]
ឱ្យទូលបង្គំជានិច្ចរាល់ថ្ងៃ ៩តែបើកាលណាទូលបង្គំសំរេច
ថា មិននិយាយដំណាលពីទ្រង់ ឬនិយាយដោយនូវព្រះ
នាមទ្រង់ទៀតឡើយ[ន] នោះនៅក្នុងចិត្តទូលបង្គំ កើតមាន
ដូចជាភ្លើងឆេះ[ប] ដែលកប់នៅក្នុងឆ្អឹងរបស់ទូលបង្គំ ហើយ
ទូលបង្គំក៏នឿយហត់ដោយខំទ្រាំទប់[ផ] ទាល់តែទ្រាំមិនបាន
ទៀត ១០ដ្បិតទូលបង្គំបានឮពាក្យបង្កាច់របស់មនុស្សជា
ច្រើន ហើយមានសេចក្ដីស្ញែងខ្លាច[ព]នៅព័ទ្ធជុំវិញ អស់ទាំង
សំឡាញ់ស្និទ្ធស្នាល[ភ]របស់ទូលបង្គំ គេជាពួកអ្នកដែលចាំ
មើលតែទូលបង្គំដួល[ម]ដែរ គេថា ចូរសប្រាប់[យ]ចុះ នោះ
យើងនឹងសប្រាប់ដូចគ្នា ប្រហែលជាយើងនឹងបញ្ចុះបញ្ចូល[រ]
វាបានទេដឹង ដូច្នេះ យើងនឹងឈ្នះវាបាន នោះយើងនឹង
សងសឹក[ល]នឹងវា ១១ប៉ុន្តែព្រះយេហូវ៉ា[វ]ទ្រង់គង់ជាមួយនឹង
ទូលបង្គំ ទុកជាមនុស្សខ្លាំងពូកែដែលគួរស្ញែងខ្លាច ហេតុ
នោះពួកអ្នកដែលបៀតបៀន[ស]ទូលបង្គំ គេនឹងត្រូវចំពប់ដួល
ឥតឈ្នះបានឡើយ[ហ] គេនឹងត្រូវខ្មាសជាទីបំផុត ពីព្រោះគេ
នឹងធ្វើតាមបំណងចិត្តមិនបាន គឺជាសេចក្ដីអាម៉ាស់ខ្មាស[ឡ]
ដ៏ស្ថិតស្ថេរអស់កល្បជានិច្ច ឥតភ្លេចបានឡើយ ១២ប៉ុន្តែ
ឱព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះដែលល្បងលពួក
សុចរិត ហើយទតឃើញចិត្តនឹងថ្លើមអើយ[អ] សូមឱ្យទូល
បង្គំឃើញទ្រង់សងសឹក[ក]នឹងគេ ដ្បិតទូលបង្គំបានសំដែង[ខ]
ដើមហេតុនៃទូលបង្គំដល់ទ្រង់ហើយ ១៣ចូរច្រៀង[គ]ថ្វាយ
ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ដ្បិត
ទ្រង់បានដោះ[ឃ]ព្រលឹងរបស់មនុស្សវេទនា ឱ្យរួចចេញពី
កណ្ដាប់ដៃនៃពួកដែលប្រព្រឹត្តអាក្រក់[ង] ។

**២០:៧** ឍ នក ៥:២៣ ២២:១៦ ណ អស ៨:១១ អម ៣:៨ ១កថ ៩:១៦ ត យប ១២:៤ ថ យប ១៧:២ ទដ ១១៩:២១ **២០:៨** ទ យរ ៦:៧ ២៨:៨ ធ ២របា ៣៦:១៦ យរ ៦:១០ **២០:៩** ន យរ ៤៤:១៦ ប ទដ ៣៩:៣ យរ ៤:១៩ ផ យប ៤:២ យរ ៦:១១ អម ៣:៨ កច ៤:២០ **២០:១០** ព យរ ៦:២៥ ភ យប ១៩:១៤ យរ ១៣:២១ ម ទដ ៥៧:៤ យរ ១៨:២២ លក ១១:៥៣–៥៤ យ នហ ៦:៦–១៣ អស ២៩:២១ រ ១ពវ ១៩:២ ល ១សយ ១៨:២៥ យរ ១១:១៩ **២០:១១** វ យរ ១:៨ រម ៨:៣១ ស យរ ១៥:១៥ ១៧:១៨ ហ ទដ ១២៩:២ ឡ យរ ៧:១៩ ២៣:៤០ **២០:១២** អ ទដ ៧:៩ យរ ១៧:១០ ក ចទ ៣២:៣៥ រម ១២:១៩ ខ ទដ ៦២:៨ យរ ១១:២០ **២០:១៣** គ អស ១២:៦ ឃ ទដ ៣៤:៦ ៣៥:១០ ង ទដ ៩៧:១០

ហើរ គឺជាសង្ឃដែលបានធ្វើពុតជាហោរាទាយកុហកភូតភរ ។

**២០:៧–១៨** ឆ្នាំទីប្រាំមួយក្រោយ គឺជារយៈពេលយូរបំផុតចំពោះ"សារភាពលន់តួបាប" របស់ហោរាយេរេមា (សូមមើលសេចក្ដីផ្ដើមៈ ខ្លឹមសារនិងកាលបរិច្ឆេទ និងមើលការពន្យល់នៅ ១១:១៨–២៣) ។ នៅក្នុងការគោរពវាជាសេចក្ដីក្លាហានយ៉ាងខ្លាំង និងដើម្បីជួយដល់សេចក្ដីជូរចត់របស់ពួកគេទាំងអស់ ។

**២០:៧** ធៀបនឹង ១៥:១៨ *បញ្ចុះបញ្ចូល* ពាក្យត្រង់មានន័យថា " ល្បួងលួងលោម" ឬ "បបួល"(១ពវ ២២:២០–២២) សូមមើល ខ.១០ លោកយេរេមាមានអារម្មណ៍ថា នៅពេលដែលព្រះអម្ចាស់បានត្រាស់ហៅគាត់ក្លាយទៅជាហោរា ដោយព្រះទ្រង់បានធ្វើការបញ្ចុះបញ្ចូលដល់គាត់ (សូមមើល ១:៧–៨, ១៧–១៩ ធៀបនឹង អគ ១៤:៩) ។

**២០:៨** ហោរាយេរេមាបានថ្វាយនូវការឈឺចាប់នេះ ទៅចំពោះព្រះអម្ចាស់ ពីព្រោះជីវិតរបស់គាត់ គឺជារបស់ផងទ្រង់ ។ *ការច្រឡោត និងការបំផ្លាញ* គឺហោរាបានប្រកាសនៅព្រះបន្ទូលរបស់ព្រះអម្ចាស់ (សូមមើល ៦:៧) ។ *សេចក្ដីឡកឡឺយ* សូមមើល ទដ ៤៤:១៣ ៧៩:៤ ។

**២០:៩** និយាយដំណាលរៀបរាប់ពីការទាយទុកជាមុន តាំងពីបុរាណមកម្ល៉េះថា ហោរាយេរេមាមានការស្ទាក់ស្ទើរ ចំពោះការត្រាស់ហៅរបស់ព្រះ ប៉ុន្តែការទទួលជ័យជម្នះនោះ គឺដោយសារព្រះអាទិករទ្រង់ជាអ្នកសម្រេច (សូមមើល ១:៦–៨ អម ៣:៨ កច ៤:២០ ១កថ ៩:១៦) ។ *ព្រះនាមទ្រង់ . . . ដូចជាភ្លើង* សូមមើល ៥:១៤ ២៣:២៩ ។ នៅគ្រានោះ ព្រះហស្តរបស់ទ្រង់បានលូកព្រះហស្តពាល់ដល់ហោរាយេរេមា (សូមមើល បទ ១:១៣) ។

**២០:១០** នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរពីរបន្ទាត់ដំបូង គឺដូចគ្នាទៅនិងពីរបន្ទាត់ដំបូងនៃព្រះគម្ពីរ ទដ ៣១:១៣ ដែរ ។ *សេចក្ដីស្ញែងខ្លាចនៅព័ទ្ធជុំវិញ* សូមមើលការពន្យល់នៅ ៦:២៥ ។ នៅត្រង់ឃ្លានេះគឺជាពាក្យដែលបានប្រើដើម្បីចំអកដល់ហោរាយេរេមា នៅក្នុងការអុចអាលនូវភាពកំសត់របស់គាត់ ។ *សំឡាញ់ស្និទ្ធស្នាល* មានន័យថា"គឺជាមនុស្សដែលផ្ដល់សេចក្ដីសុខសាន្តដល់ខ្ញុំ ឬអ្នកដែលផ្ដល់សុខុមាលភាពដល់ខ្ញុំ" (ធៀបនឹង ទដ ៤១:៩ និងការពន្យល់) ។ *ចាំមើលតែទូលបង្គំដួល* មើល ទដ ៣៥:១៥ ៨:១៦ ។ *បញ្ចុះបញ្ចូល* សូមមើល ខ. ៧ និងការពន្យល់ ។ *យើងនឹងឈ្នះ វាបាន* គឺពួកគេបានគិតយ៉ាងខ្លាំងថា នឹងទទួលបានជ័យជម្នះ (សូមមើល ខ.១១) ។ *យើងសងសឹកនឹងវា ខ្មាំងសត្រូវរបស់គាត់ទោះបីយ៉ាងណាក៏មិន* ព្រមចុះចាញ់នៅចំពោះមុខគាត់ឡើយ (សូមមើល ១១:១៩ ១២:៦ ២៦:១១ ធៀបនឹង ទដ ៥៦:៥–៦ ៧១:១០) ។

**២០:១១** *ព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងទូលបង្គំ* សូមមើល ១:៨ និងការពន្យល់ ។ *មនុស្សខ្លាំងពូកែ* នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរពាក្យនេះគឺបានប្រែថា "មនុស្សកាចសាហាវ" មើលនៅក្នុង ១៥:២១ គឺជាការពិពណ៌នារៀបរាប់ពីមនុស្សកាចសាហាវ ដែលជាខ្មាំងសត្រូវប្រឆាំងទាស់នឹងហោរាយេរេមា ។ នៅត្រង់ចំណុចនេះ គឺវាមានន័យខុសប្លែកពីគ្នាបន្តិចបន្តួច ជាការទូលសូមទៅព្រះដែលជា"កម្លាំង"ដើម្បីទទួលនូវជ័យជម្នះលើអស់ទាំង"មនុស្សខ្លាំងពូកែ" ។ *គួរស្ញែងខ្លាច* សូមមើលការពន្យល់ នក ១៤:១៤ ១៥:៣ ។

**២០:១២** ខគម្ពីរនេះគឺបានរំឭកឡើងវិញត្រង់ៗពី ១១:២០ ។

**២០:១៣** *ចូរច្រៀង. . .ចូរសរសើរ* សូមមើល ៣១:៧ សូមមើលការបង្ហាញនៅក្នុងព្រះគម្ពីរ ទដ ៩ ។ *ដោះព្រលឹង. . . ឱ្យរួចចេញពីកណ្ដាប់ដៃនៃពួកដែលប្រព្រឹត្តអាក្រក់* សូមមើល ១៥:២១ ២១:១២ ។ *វេទនា* សូមមើល ២២:១៦ គឺនៅគ្រានោះហោរាយេរេមាបានធ្លាក់ក្នុង "សេចក្ដី

១៤ សូមឱ្យថ្ងៃដែលខ្ញុំកើតមក[ច]ត្រូវបណ្ដាសាចុះ កុំឱ្យ
ថ្ងៃ ដែលម្ដាយបានសំរាលខ្ញុំចេញមកនោះ បានពរឡើយ
១៥ សូមឱ្យត្រូវបណ្ដាសា ដល់អ្នកដែលនាំដំណឹងមកប្រាប់
ឱ្យឪពុកខ្ញុំមានសេចក្ដីអំណរជាខ្លាំង ដោយថា អ្នកបាន
កូនប្រុសហើយ ១៦ សូមឱ្យមនុស្សនោះបានដូចជាអស់ទាំង
ទីក្រុង[ឆ] ដែលព្រះយេហូវ៉ាបានបំផ្លាញឥតស្ដាយចុះ ឱ្យគេ
ឮតែសំរែក[ជ]នៅពេលព្រឹក ហើយសូរហ៊ោនៅថ្ងៃត្រង់
១៧ ពីព្រោះគេមិនបានសំឡាប់ខ្ញុំពីកាលនៅក្នុងផ្ទៃម្ដាយនៅ
ឡើយ[ឈ] ឱ្យម្ដាយខ្ញុំជាផ្នូររបស់ខ្ញុំ ហើយមានពោះធំជាដរាប
១៨ ហេតុអ្វីបានជាខ្ញុំបានចេញពីផ្ទៃម្ដាយមក[ញ] ឱ្យឃើញតែ
ការនឿយហត់[ដ] និងសេចក្ដីទុក្ខព្រួយ ឱ្យថ្ងៃអាយុខ្ញុំបានសូន្យ
ទៅ ដោយសេចក្ដីអាម៉ាស់ខ្មាសដូច្នេះ[ឋ] ។

**ព្រះយេហូវ៉ាបដិសេធការទូលសូមរបស់ស្ដេចសេដេគា**

**២១** ១ នេះជាព្រះបន្ទូល ដែលមកពីព្រះយេហូវ៉ា ដល់
យេរេមា ក្នុងកាលដែលស្ដេចសេដេគា[ក]បានចាត់ផាស-
ហើរ[ខ] ជាកូនម៉ាលគា និងសេផានា[គ] ជាកូនម្អាសេយ៉ាដ៏ជា
សង្ឃ មកឯលោកដោយពាក្យថា ២ សូមទូលសួរ[ឃ]ដល់ព្រះ
យេហូវ៉ា ឱ្យយើងផង ដ្បិតនេប៊ូក្នេសា[ង] ជាស្ដេចបាប៊ីឡូន[ច]

**២០:១៤** ច យបៈ ៣:៨,១៦ យរ ១៥:១០ **២០:១៦** ឆ លប ១៩:២៥ ជ យរ ៦:២៥ **២០:១៧** ឈ យប ៣:១៦ ១០:១៨–១៩ **២០:១៨** ញ យប ៣:១០–១១ សស ៤:២ ដ លប ៣:១៧ យប ៥:៧ ឋ ១ពវ ១៩:៤ ទដ ៩០:៩

១០២:៣ **២១:១** ក ២ពវ ២៤:១៨ យរ ៥២:១ ខ ១រប ៩:១២ គ ២ពវ ២៥:១៨ **២១:២** ឃ លប ២៥:២២ ២ពវ ២២:១៨ ង ២ពវ ២៥:១ ច លប ១០:១០

ក្រខ្សត់ និងសេចក្ដីវេទនា" ដោយសារការទ្រាំទ្រនឹងសេចក្ដីវេទនា គឺគាត់បានរស់នៅជាមួយនឹង"សេចក្ដីសុចរិត" (សូមមើល អម ២:៦ សូមមើលការពន្យល់ ទដ ៩:១៨ ៣៤:៦) ផងដែរ ។

**២០:១៤–១៨** សូមមើល យប ៣:៣–១៩ ពីទីកំពស់ទាំងឡាយនៃសេចក្ដីត្រេកអរ (ខ.១៣) ឥឡូវនេះ ហោរាយេរេមាបានធ្លាក់ចូលទៅក្នុងទីជម្រៅនៃសេចក្ដីអស់សង្ឃឹម ។ គាត់មិនបានអត់ទ្រាំចំពោះការត្រាស់ហៅរបស់ព្រះអម្ចាស់បានឡើយ (ខ.៩) ដោយព្រោះមានការក្បត់ចិត្តលាក់ពុតពីមិត្រសម្លាញ់ទាំងឡាយរបស់គាត់ (ខ.១០) និងមានការប្រដេញតាមពីខ្មាំងសត្រូវទាំងឡាយឥតឈប់ឈរ (ខ.៧,១១) ដែលបានធ្វើការបដិសេធន៍ និងការដាក់ទណ្ឌកម្មចំពោះរូបលោក នៅពេលដែលគាត់នាំព្រះបន្ទូលទៅកាន់ពួកគេ(ខ.៨) ការទាំងអស់នេះបានរៀបចំផ្ដល់ឱ្យមាត់របស់គាត់ ដើម្បីចាប់ផ្ដើមនិយាយសម្ដែងចេញពីការខូចចិត្ត និងពីសេចក្ដីអស់សង្ឃឹម ។ ឆ្លងកាត់ក្នុងការបម្រើទាំងនេះ គឺដូចជាស្ពានដើម្បីឆ្ពោះទៅកាន់ការងារដ៏សំខាន់ដែលមាននៅក្នុងព្រះគម្ពីរ ។ ហោរាយេរេមា នឹងនិយាយមកយ៉ាងឆាប់ទៅកាន់ស្រុកយូដា និងក្រុងយេរូសាឡិមថា គឺឥឡូវនេះឯងនឹងត្រូវវិនាសដោយមិនអាចបដិសេធន៍បាន ដោយព្រោះការប្រព្រឹត្តអាក្រក់របស់ពួកគេ (សូមមើល ២១:១–១០) ។

**២០:១៤** *សូមឱ្យថ្ងៃដែលខ្ញុំកើតមកត្រូវបណ្ដាសាចុះ* សូមមើលការពន្យល់ យប ៣:៣ គន្លឹះនៃការចោទសួរជាច្រើនរបស់ហោរាចំពោះបេសកម្មរបស់ព្រះអម្ចាស់(សូមមើល ១:៥) ។

**២០:១៥** ដំណឹងពីកំណើតរបស់កូនប្រុស ធម្មតាគឺជាការប្រទានពរតាំងពីសម័យបុរាណមក(សូមមើល ឧទាហរណ៍ លប ២៩:៣១–៣៥) ហោរាយេ-រេមាបានរកឃើញនូវបណ្ដាសា នៅក្នុងជីវិតរបស់គាត់ផ្ទាល់ដែលជាបញ្ហាសម្រាប់គាត់ក្នុងការបម្រើទ្រង់ ។ *សូមឱ្យត្រូវបណ្ដាសា ដល់អ្នក* បណ្ដាសានិងត្រូវធ្លាក់មកលើអ្នកដែលបំភ្លៃរោហារពិត គឺមិនមែនប្រឆាំងទាស់ជាមួយមនុស្សឡើយ ។

**២០:១៦** *អស់ទាំងទីក្រុង ដែលព្រះយេហូវ៉ាបានបំផ្លាញ* ទីក្រុងសូដុម និងទីក្រុងកូម៉ូរ៉ា (សូមមើល លប ១៩:២៤–២៥, ២៩) ដោយនៅគ្រាដែលហោរាយេរេមា គឺពួកគេបានប្រព្រឹត្តការអាក្រក់អស់រយៈពេលជាយូរប្រៀបដូចជាសុភាសិត(សូមមើល ២៣:១៤ ចទ ២៩:២៣ សូមមើលការពន្យល់នៅ អស ១:៩–១០ផងដែរ) ។ *ឮតែសំរែក* សូមមើល ៤:១៩ ។ *នៅថ្ងៃត្រង់* សូមមើលការពន្យល់នៅក្នុង ៦:៤ ។

**២០:១៧** *មានពោះធំ* មានន័យថា"មានផ្ទៃពោះ"នៅត្រង់ចំណុចនេះគឺចង់បញ្ជាក់ពីការថប់បារម្ភណ៍នៅក្នុងចិត្ត ដែលហោរាយេរេមាបានសូមប្រាថ្នាតាំងពីគាត់នៅក្នុងពោះម្ដាយរបស់គាត់មកម្ល៉េះ ដែលជាអ្នកផ្ដល់កំណើតដល់គាត់ ហើយការដែលជីវិតរបស់គាត់នៅក្នុងផ្ទៃពោះម្ដាយនោះ គឺជាតំណាងឱ្យផ្នូរនៃសេចក្ដីស្លាប់អស់កល្បជានិច្ច ។

**២១:១–២៤:១០** ការថ្លែងទំនាយប្រកាសបដិសេធមិនយល់ព្រមយ៉ាង ឱឡារិក ជាមួយនឹងអ្នកគ្រប់គ្រងនៃពួកសាសន៍យូដា(២១:១–២៣:៧) ទាស់នឹងសេចក្ដីទំនាយក្លែងក្លាយទាំងឡាយ (២៣:៨–៤០) និងទាស់ជាមួយមនុស្សដែលពោរពេញដោយអំពើបាប (ជំពូក ២៤)ទោះជាផ្នែកភាគច្រើនមួយចំនួននៅជំពូក ១–២០ គឺវាទាក់ទងនិងព្រឹត្តការណ៍មួយចំនួន តាមលក្ខណៈជាលំដាប់លំដោយ ទៅតាមកាលប្រវត្តិពង្សាវតា មានដូចជាជំពូក ២១–៥២ ដែលគេបានរៀបចំឡើង នូវគន្លឹះសំខាន់ៗទាក់ទងនឹងប្រធានបទច្រើននឹងប្រវត្តិសាស្ត្រដើម(សូមមើល ២៤:១ ២៥:១ ២៦:១ ២៧:១ ២៩:២ ៣២:១ ៣៥:១ ៣៦:១ ៣៧:១ ៤៥:១ ៤៩:៣៤ ៥១:៥៩ ៥២:៤) ។

**២១:១–២៣:៧** អ្នកគ្រប់គ្រងនៃពួកសាសន៍យូដា ដែលទទួលជាលើដំបូងនូវសេដ្ឋកិច្ចលើគ្រប់ជាតិសាសន៍ ដែលជាសង្គមមួយពេញដោយវិញ្ញាញនៃការឈឺចាប់ ហើយគឺជាលើកដំបូងបង្អស់ ដែលហោរាយេរេមាបានថ្លែងទំនាយប្រកាសបដិសេធមិនយល់ព្រមជាឱឡារិក ចំពោះការប្រព្រឹត្តអាក្រក់របស់ពួកគេឡើយ ។

**២១:១** *ព្រះបន្ទូល ដែលមកពីព្រះយេហូវ៉ា* នៅត្រង់ឃ្លានេះ គ្មានការបង្ហាញប្រាប់ម្ដងទៀតឡើយ ២៥:១ និងសូមមើលការណែរនាំនៅ ជំពូក ២១–២៤ ដែលបានបង្ហាញប្រាប់ទាំងអស់នៅក្នុងព្រះគម្ពីរទាំងនេះ ។ *ស្ដេចសេដេគា* មានន័យថា"ព្រះយេហូវ៉ាគឺជាសេចក្ដីសុចរិតរបស់ខ្ញុំ" សូមមើលសេចក្ដីផ្ដើម និងប្រវត្តិដើម ។ *ផាសហើរជាកូនមាលគា* មិនមែនដូចជា លោកផាស-ហើរនៃ ២០:១–៦ ទេ (សូមមើល ៣៨:១) ។ *សេផានា ជាកូនម្អាសេយ៉ាដ៏ជាសង្ឃ* មិនដូចជាហោរាសេផានាទេ(សូមមើល ២៩:២៥,២៩ ៣៧:៣ ៥២:២៤ សូមមើល សផ ១:១ ផងដែរ) ។

**២១:២** *សូមទូលសួរដល់ព្រះយេហូវ៉ា* គឺជាការទូលសុំនូវប្រាជ្ញា ឬទូលសុំដំណឹងពតីមានពីព្រះ (សូមមើល លប ២៥:២២ ២ពវ ២២:១៣) គឺមិនមែនជាការចាំបាច់ ចំពោះការជួយដល់ស្ដេចនេប៊ូក្នេសាឡើយ សូមមើលការ

ច្បាំងនឹងយើងហើយ ប្រហែលជាព្រះយេហូវ៉ាទ្រង់ប្រោស
យើង តាមអស់ទាំងការអស្ចារ្យ[ឆ]របស់ទ្រង់ ដើម្បីឱ្យស្តេច
នោះបានថយចេញពីយើងទៅទេដឹង ។
៣ដូច្នេះ យេរេមាឆ្លើយតបថា ចូរអ្នករាល់គ្នាទូលតប
នឹងសេដេគាយ៉ាងនេះ ៤ព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលថា មើល អញនឹងបំបែរ[ជ]
គ្រឿងសស្ត្រាវុធ ដែលនៅក្នុងដៃឯងរាល់គ្នានោះឱ្យ
ត្រឡប់ថយ ជាគ្រឿងដែលប្រើច្បាំងតនឹងស្តេចបាប៊ីឡូន
ហើយនិងពួកខាល់ដេដែលឡោមព័ទ្ធ[ឈ]ឯងរាល់គ្នាខាង
ក្រៅកំផែង អញនឹងប្រមូលគេមកនៅកណ្តាលទីក្រុងនេះ
៥ហើយខ្លួនអញក៏នឹងច្បាំងត[ញ]នឹងឯងរាល់គ្នា ដោយដៃលូក
ចេញ[ដ] នឹងដើមដៃខ្លាំងពូកែ[ឋ] គឺដោយសេចក្តីកំហឹង សេចក្តី
ក្រោធ និងសេចក្តីគ្នាន់ក្នាញ់ជាខ្លាំង ៦អញនឹងប្រហារ[ឌ]ពួក
អ្នកនៅក្រុងនេះ ទាំងមនុស្ស និងសត្វផង គេនឹងត្រូវស្លាប់
ដោយអាសន្នរោគយ៉ាងធំ[ឍ] ៧ហើយព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា លំដាប់នោះ អញនឹងប្រគល់សេដេគា[ណ] ជាស្តេច
យូដា ហើយពួកហាតលិក និងបណ្តាជនទាំងឡាយ គឺអស់
អ្នកនៅក្នុងទីក្រុងនេះ[ត] ដែលសល់ពីអាសន្នរោគ ពីដាវ
ហើយពីអំណត់អត់ ទៅក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសា ជា
ស្តេចបាប៊ីឡូន[ថ] គឺក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ[ទ]គេ ជា
ពួកអ្នកដែលស្វែងរកជីវិតគេ[ធ] ស្តេចនោះនឹងប្រហារគេ
ដោយមុខដាវ[ន] ឥតប្រណី ឥតមេត្តា ឥតអាណិតអាសូរ
ឡើយ[ប] ។
៨ហើយឯងត្រូវប្រាប់ជនជាតិនេះថា ព្រះយេហូវ៉ា ទ្រង់
មានបន្ទូលដូច្នេះ មើល អញដាក់ផ្លូវជីវិត[ផ] និងផ្លូវស្លាប់នៅ
មុខឯងរាល់គ្នា ៩អ្នកណាដែលនៅជាប់ក្នុងក្រុងនេះ នឹងត្រូវ
ស្លាប់ដោយដាវ ដោយអំណត់អត់ ហើយដោយអាសន្ន
រោគ[ព] តែឯអ្នកណាដែលចេញទៅខាង[ភ]ពួកខាល់ដេ ជា
ខ្មាំងដែលឡោមព័ទ្ធឯងរាល់គ្នា នោះនឹងរស់នៅវិញ

**២១:២** ឆ ទជ ៤៤:១–៤ យរ ៣២:១៧
**២១:៤** ជ យរ ៣២:៥ ឈ យរ ៣៧:៨–១០
**២១:៥** ញ យស ១០:១៤ អគ ៥:៨ ដ ២ពវ ២២:១៣ យរ ៦:១២ ឋ នក ៣:២០
**២១:៦** ឌ យរ ៧:២០ ឍ យរ ១៤:១២
**២១:៧** ណ ២ពវ ២៥:៧ យរ ៥២:៩ អគ ១២:១៤ ត យរ ១៤:១២ ២៧:៨ ថ ២រប ៣៦:១០ យរ ២៧:៦ ៣២:៤ ៣៤:៣ ៣៧:១៧ ៣៨:១៨ ៣៩:៥ អគ ២៩:១៩ ទ លវ ២៦:១៧ យរ ១៩:៩ ធ យរ ១១:២១ ន យរ ១៥:៩ ប ២រប ៣៦:១៧ យរ ១៥:៥ អគ ៧:៩ ហព ១:៦ **២១:៨** ផ ចទ ៣០:១៥ **២១:៩** ព យរ ១៤:១២ អគ ៥:១២ ភ យរ ២៧:១១ ៤០:៩

ពន្យល់នៅក្នុង ២ពវ ២៤:១ ។ *ច្បាំង* ចម្បាំងនេះ ប្រហែលនៅក្នុងឆ្នាំ ៥៨៨ មុន គ.ស ដោយព្រោះស្តេចសេដេគាល ទ្រង់បានរួសរាន់នឹងប្រឆាំបះបោរទាស់មួយស្រុកបាប៊ីឡូន (សូមមើល ៥២:៣) ។ *យើង* គឺនិយាយសំដៅទៅលើទីក្រុងយេរូសាឡិម ។ *ទ្រង់នឹងប្រោសយើងតាមអស់ទាំងការអស្ចារ្យ* ដ្បិតនេះ គ្រាន់តែជាឧទាហរណ៍នៅក្នុងប៉ុន្មានថ្ងៃប៉ុណ្ណោះរបស់ស្តេចហេសេគា (សូម មើល អស ៣៧:៣៦) ។ *ស្តេចនោះបានថយចេញ* សូមមើល អស ៣៧:៣៧ ។

**២១:៤** *បំបែរគ្រឿងសស្ត្រាវុធ* ការការពារក្រុងយេរូសាឡិមរបស់ឯងនឹងមិនបានសម្រេចជោគជ័យឡើយ ។ *ស្តេចបាប៊ីឡូន* សូមមើលការពន្យល់នៅ យប ១:១៧ ។ *ខាងក្រៅកំផែងអញនឹងប្រមូលគេមកនៅកណ្តាលទីក្រុងនេះ* គឺដូចជាករណីទី (១).គ្រឿងសស្ត្រាវុធ មានន័យថា ពួកទាហានសាសន៍យូដា គ្មានសមត្ថភាពដើម្បីការពារទីក្រុងរបស់ពួកគេបានឡើយ ។ ដូចគ្នានិងករណីទី(២).ពួកបាប៊ីឡូន មានន័យថា ការបរាជ័យរបស់ពួកក្រុងយេរូសាឡិម គឺជាភាពអាសន្ន និងមិនអាចចៀសរួច ។

**២១:៥** *អញក៏នឹងច្បាំងតនឹងឯងរាល់គ្នា* នៅត្រង់ឃ្លានេះមានន័យថា ព្រះយេហូវ៉ាទ្រង់ជាអ្នកការពារថែរក្សាដល់រាស្ត្ររបស់ទ្រង់ ឥឡូវនេះពួកគេត្រូវបានបំផ្លាញ ហើយនិងបោះត្រាដៅចំណាំរាល់ការអាក្រក់របស់គេ ។ *ដោយដៃលូកចេញ និងដើមដៃខ្លាំពូកែ* សូមមើល ២៧:៥ ៣២:១៧ ។ គឺដូចជាឃ្លាមួយដែលធ្លាប់បាននិយាយថា ព្រះអម្ចាស់ជាព្រះពេញដោយអំណាចនៃការ ប្រោសលោះបាប ដល់ពួកអ៊ីស្រាអែលទាំងអស់ (សូមមើល ៣២:២១ ចទ ៤:៣៤ ៥:១៥ ៧:១៩ ២៦:៨) ប៉ុន្តែនៅទីនេះព្រះទ្រង់បែរមកមានសេចក្តីក្រោធទាស់ប្រឆាំង នឹងរាស្ត្ររបស់ទ្រង់ផ្ទាល់វិញ ។ *សេចក្តីកំហឹង សេចក្តីក្រោធ នឹងសេចក្តីគ្នាន់ក្នាញ់* ទំនងជាដកស្រង់មកពី ចទ ២៩:២៨ នៅត្រង់ឃ្លាក្នុងព្រះគម្ពីរហេព្រើរចំណុចនេះ គឺបានប្រែថា "សេចក្តីក្រេវក្រោធពេញដោយកំហឹង និងសេចក្តីក្រោធដ៏ខ្លាំង" ។

**២១:៧** *អញនឹងប្រគល់សេដេគា . . . ហើយពួកមហាតលិក នឹងបណ្តាជនទាំងឡាយ* បានសម្រេចនៅក្នុង ៥២:៨–១១,២៤–២៧ (សូមមើល អគ ១២:១៣–១៤) ។ *អាសន្នរោគ ពីដាវ ហើយពីអំណត់អត់ សូមមើល ខ.៩* សូមមើលការពន្យល់ ១៤:១២ គ្មានការប្រោសប្រណី ឬគ្មានសេចក្តីអាណិតអាសូរ និងគ្មានសេចក្តីមេត្តាករុណាឡើយ សូមមើល ១៣:១៤ សូមមើល អគ ៥:១១ ផងដែរ ។

**២១:៨–១០** សូមមើល ២៧:១២–១៣ ស្រដៀងគ្នា និងការណែរនាំក្នុងការថ្វាយ សូមមើលនៅក្នុង ៣៨:២–៣,១៧–១៨ (សូមមើល ចទ ៣០:១៥–២០) ។

**២១:៨** *មើល អញដាក់ផ្លូវជីវិត* សូមមើល ចទ ១១:២៦ ។ បណ្តាជនទាំងឡាយ បានជ្រើសរើសក្នុងការថ្វាយដង្វាយ ត្រឹមតែពីរបីដែលពួកគេ នឹងធ្វើការសម្រេចចិត្តដោយត្រឹមត្រូវ ។ *ផ្លូវជីវិត និងផ្លូវស្លាប់* សូមមើល ចទ ៣០:១៥,១៩ សូមមើល សភ ៦:២៣ ផងដែរ ។

**២១:៩** គឺជាការរំឭកត្រង់ៗឡើងវិញស្ទើរតែទាំងអស់ មើលក្នុង ៣៨:២ ហោរាយេរេមាបានប្រាប់ថា គាត់ជាអ្នកចុះចាញ់ នឹងត្រូវដូចជាជនក្បត់នៅចំពោះភ្នែកមនុស្សជាច្រើន (សូមមើល ៣៧:១៣) ។ ប៉ុន្តែគាត់ បានប្រឈមមុខនឹងការពិតនៅចំពោះអ្នកស្នេហាជាតិ ដែលត្រូវការ ដើម្បីអាស្រ័យនៅក្នុងស្រុកយូដា ។ ព្រឹត្តិការណ៍បន្ទាប់មកក្រុងយេរូសាឡិមគឺត្រូវបានបំផ្លាញ (សូមមើល ៣៧:១៤ ៤០៦ ៤២:៧–២២) ។ *អ្នកណា . . . ទៅខាងឯពួកខាល់ដេ . . . ដែលឡោមព័ទ្ធ . . . នោះនឹងរស់នៅ* បានសម្រេចនៅ ៣៩:៩ ៥២:១៥ ។ *ហើយនឹងបានជីវិតទុកដូចជារបឹប* ន័យត្រង់នេះមានន័យថា "ជីវិតរបស់គាត់ត្រូវបានរួចជីវិតដោយសារការដណ្តើមជ័យជម្នះពីខ្មាំងត្រូវ" ។ គឺជាការដែលបានជ័យជម្នះនៅក្នុងការតស៊ូ អាចផ្តល់សង្ឃឹមដើម្បីចែករបឹបដែលបានច្បាំងឈ្នះពីសង្គ្រាម ដែលជាជោគវាសនារបស់ពួកគេប្រសិនបើការរស់នៅរបស់ពួកគេបានរួចជីវិត ។

ហើយនឹងបានជីវិតខ្លួនទុកដូចជារបឹប[ម] ១០ដ្បិត ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលថា អញបានតាំងមុខទាស់នឹងទីក្រុងនេះ
សំរាប់ជាការអាក្រក់[យ] មិនមែនជាការល្អទេ ទីក្រុងនេះនឹង
ត្រូវប្រគល់ទៅក្នុងកណ្ដាប់ដៃ[រ]នៃស្តេចបាប៊ីឡូន ស្តេចនោះ
នឹងដុតដោយភ្លើងចោល[ល] ។

១១ត្រូវឱ្យឯងប្រាប់ពីដំណើរវង្សា[វ]នៃស្តេចយូដាថា ចូរ
ស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ ១២ឱពួកវង្សាដាវីឌ
អើយព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូរសំរេចតាម
សេចក្តីយុត្តិធម៌[ស]ចាប់តាំងពីពេលព្រលឹមស្រាងចុះ ហើយ
ដោះអ្នកណាដែលត្រូវគេប្លន់ ឱ្យរួចពីកណ្តាប់ដៃនៃពួកអ្នក
ដែលសង្កត់សង្កិន[ហ]នោះផង ក្រែងសេចក្តីក្រោធរបស់អញ
ចេញទៅដូចជាភ្លើង[ឡ] ហើយឆេះជាខ្លាំង ដល់ម្ល៉េះបានជា
គ្មានអ្នកណាអាចនឹងពន្លត់បានឡើយ ដោយព្រោះអំពើ
អាក្រក់[អ]ដែលឯងរាល់គ្នាប្រព្រឹត្ត[ក] ១៣ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថានែ ឯងដែលអាស្រ័យនៅច្រកភ្នំ[ខ] ជាថ្មដានៅវាល
អើយ អញទាស់នឹង[គ]ឯងហើយ ឯងអួតថា តើអ្នកណានឹងចុះ
មកទាស់នឹងយើង ឬអ្នកណានឹងចូលមកក្នុងទីលំនៅរបស់
យើងបាន[ឃ] ១៤ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញនឹង
ផ្ចាលឯងឱ្យសមតាមផលការដែលឯងបានប្រព្រឹត្ត[ង] គឺអញ
នឹងបង្កាត់ភ្លើង[ច]នៅក្នុងព្រៃឯង[ឆ] ភ្លើងនោះនឹងឆេះបំផ្លាញ

**២១:៩** ម យរ ២៧:១២ ៣៨:២,១៧ ៣៩:១៨ ៤៥:៥ **២១:១០** យ យរ ៤៤:១១,២៧ អម ៩:៤ រ យរ ២០:៤ ៣២:២៨ ៣៨:២–៣ ល ២ពវ ២៥:៩ ២រប ៣៦:១៩ **២១:១១** វ យរ ១៣:១៨ **២១:១២** ស នក ២២:២២ លវ ២៥:១៧ ហ ទដ ២៧:១១ ឡ យរ ៤២:២៥ យរ ១០:១០ អ យរ ២៣:២ ក អស ១:៣១ **២១:១៣** ខ ទដ ១២៥:២ គ យរ ២៣:៣០ ៥០:៣១ ៥១:២៥ អគ ៥:៨ ១៣:៨ ២១:៣ ២៩:១០ ៣៤:១០ ណហ ២:១៣ ៣:៥

របស់ទាំងអស់ដែលនៅជុំវិញផង ។

## ការជំនុំជម្រះពួកស្តេចអាក្រក់

២២ ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូរចុះទៅឯ
ដំណាក់ស្តេច[ក]យូដា ហើយពោលពាក្យនេះនៅទីនោះ ២គឺ
ប្រាប់ថា ឱស្តេចសាសន៍យូដាដែលគង់លើបល្ល័ង្កនៃដាវីឌ[ខ]
ព្រមទាំងពួកមហាតលិក និងបណ្តាជនរបស់ទ្រង់ ដែល
ចូលតាមទ្វារទាំងនេះអើយ[គ] ចូរស្តាប់[ឃ]ព្រះបន្ទូលនៃព្រះ
យេហូវ៉ាចុះ ៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូរ
សំរេចសេចក្តីយុត្តិធម៌[ង] និងសេចក្តីសុចរិត ហើយដោះ អ្នក
ដែលត្រូវគេប្លន់ ឱ្យបានរួចពីកណ្តាប់ដៃនៃពួកអ្នកដែល
សង្កត់សង្កិន[ច]នោះ កុំឱ្យរីបជាន់ ឬគំហកកំហែងដល់អ្នក
ដទៃ ដែលមកស្នាក់នៅ ឬដល់ពួកកំព្រា និងស្រីមេម៉ាយ[ឆ]
ឡើយ ក៏កុំឱ្យកំចាយឈាម[ជ]របស់មនុស្សដែលឥតទោសនៅ
ទីនេះដែរ ៤ដ្បិតបើសិនជាឯងរាល់គ្នានឹងធ្វើតាមពាក្យនេះ

ឃ ២សយ ៥:៦–៧ យរ ៤៩:៤ បទ ៤:១២ អប ១:៣–៤ **២១:១៤** ង សភ ១:៣១ អស ៣:១០–១១ យរ ១៧:១០ ច ២រប ៣៦:១៩ បទ ២:៣ ឆ ២ពវ ១៩:២៣ អគ ២០:៤៧ **២២:១** ក យរ ១៣:១៨ ៣៤:២ **២២:២** ខ យរ ១៧:២៥ លក ១:៣២ គ យរ ១៧:២០ឃ អម ៧:១៦ **២២:៣** ង លវ ២៥:១៧ អស ៥៦:១ យរ ៥:១ អគ ៣៣:១៤ ៤៥:៩ ហស ១២:៦ អម ៥:២៤ មីក ៦:៨ សក ៧:៩ ច ទដ ៧២:៤ យរ ២១:១២ ឆ នក ២២:២២ អស ១:១៧ យរ ៥:២៨ ជ យរ ៧:៦

**២១:១០** *បានតាំង* មានន័យថា"បានតាំងនៅមុខខ្ញុំ" (សូមមើល ៤៤:១១ អស ៥០:៧ និងការពន្យល់) *សំរាប់ជាការអាក្រក់ មិនមែនជាការល្អទេ* សូមមើល អម ៩:៤ មានភាពខុសគ្នា ២៤:៦ ។ *នឹងត្រូវប្រគល់ទៅ . . . នឹងដុតដោយភ្លើងចោល* សូមមើល ៣៤:២ ។

**២១:១២** *ចូរសំរេចតាមសេចក្តីយុត្តិធម៌* សូមមើល ៥:២៨ ២២:១៦ ១ពវ ៣:២៨ បទ ៣:៥៩ ។ ស្តេចត្រូវមានរាជកិច្ច ក្នុងការសម្រេចសេចក្តីយុត្តិធម៌ និងនាំមកនូវសេចក្តីសង្ឃឹម គឺដូចជាព្រះមែស៊ីដែលទ្រង់និងធ្វើនៅគ្រាអនាគត(សូមមើល ២៣:៥ ៣៣:១៥) ។ *ពេលព្រលឹមស្រាង* គឺពេលដែលមានចិត្តគំនិតជ្រះស្រឡះ និងជាពេលត្រជាក់(សូមមើល ទដ ១០១:៨ និងការពន្យល់) ។ *ហើយដោះ . . . ប្លន់* បានរំឭកឡើងវិញនៅក្នុង ២២:៣ ។ *សេចក្តីក្រោធរបស់អញ . . . គ្មានអ្នកណាអាចនឹងពន្លត់បានឡើយ* បានរំឭកឡើងវិញនៅ ៤:៤ (សូមមើល អម ៥:៦) ។ *សេចក្តីក្រោធ . . . ហើយឆេះ* សូមមើល ១៥:១៤ ១៧:៤,២៧ ។

**២១:១៣** *ច្រកភ្នំ* ក្រុងយេរូសាឡិមបានឡោមព័ទ្ធទៅដោយច្រកភ្នំបី(សូមមើលការពន្យល់ អស ២២:៧) ។ គឺត្រូវបានហៅថា"ច្រកភ្នំ នៃការបើកសម្តែងឱ្យឃើញ" នៅក្នុង អស ២២:១,៥ ។ *ថ្មដានៅវាល* គឺជាភ្នំល្បាណូន ។ *ឯងអួតថា* ជាស័ព្ទនាមនៃពហុវចនៈទាំងឡាយ នៅក្នុងកណ្តាលវគ្គឃ្លាទីពីរ (គឺសំដៅទៅលើអ្នកស្រុកយេរូសាឡិម) *តើអ្នកណានឹងចុះមកទាស់នឹងយើង* ប្រជាជនគិតថា គ្មាននរណាម្នាក់អាចទទួលបាននូវការដោគជ័យក្នុងការឡោមព័ទ្ធដល់ពួកគេឡើយ (សូមមើលការពន្យល់ ៧:៤ ៨:១៩) ។

**២១:១៤** *អញនឹងផ្ចាលឯងឱ្យសមតាមផល* សូមមើលការពន្យល់ ១៧:១០ ។ *បង្កាត់ភ្លើង . . . បំផ្លាញ* សូមមើលការពន្យល់ ១៧:២៧ ។ *ព្រៃ* នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរចំពោះពាក្យនេះ គឺជាឯកវចនៈ ហើយប្រហែលជាការប្រៀបធៀបសំដៅទៅលើ ព្រះរាជតំណាក់ក្រុងយេរូសាឡិម ដែលហៅថា "ព្រះរាជតំណាក់នៃព្រៃល្បាណូន"(១ពវ ៧:២ ១០:១៧,២១ សូមមើល អស ២២:៨) ដោយព្រោះដើមម៉ៃសាក់(សូមមើល ២២:៧,១៤,១៥,២៣) ដែលបានប្រើវានៅក្នុងការសាងសង់ ។ ព្រះរាជតំណាក់(សូមមើល ២២:១)គឺបានប្រៀបធៀបទៅនឹង"ការចុះចូលនៃស្រុកល្បាណូន" នៅក្នុង ២២:២៣ ហើយនិងការពន្យល់) ។

**២២:១** *ចូរចុះទៅ* ព្រះរាជតំណាក់នៅទាប ប៉ុន្តែខ្ពស់ជាង ព្រះវិហារ (សូមមើល ២៦:១០ ៣៦:១០–១២) ។ *ស្តេចយូដា* គឺប្រហែលជាស្តេចសេដេគា (សូមមើល ២១:៣,៧ ប្រៀបធៀបនឹង ខ.៣ ហើយនិង ២១:១២) ។ អ្នកសោយរាជ្យមុនៗត្រូវបាននិយាយនៅក្នុងជំពូកមុនគឺមាន (ស្តេចយ៉ូសៀស ខ.១០ក,១៥ក,១៧–១៦ ស្តេចយ៉ូអាហាសឬហៅថាស្តេចសាលូម ខ. ១០ក–១២ ស្តេចយេហូយ៉ាគីម ខ.១៣–១៥ក,១៧–១៩ ស្តេចយេហូយ៉ាគីនឬហៅថាស្តេចកូនៀរ ខ.២៤–៣០) ។

**២២:២** *បល្ល័ង្កនៃដាវីឌ* ថ្វីបើ ស្តេចទាំងអស់ នៃពូជវង្សហ្លួងដាវីឌបានធ្លាក់ចុះក៏ដោយ តែនឹងមានគ្រាមកដល់របស់ព្រះមែស៊ី ដែលនឹងមានលំពង់សុចរិត១ លិចមកនៅក្នុងរាជ្យវង្សហ្លួងដាវីឌ ហើយលំពង់នោះនឹងសោយរាជ្យទុកដូចជាស្តេច (មើល ២៣:៥ និងការពន្យល់ ៣៣:១៥ អគ ៣៤:២៣–២៤ មថ ១:១) ។ *ដែលចូលតាមទ្វារទាំងនេះ* មើល ១៧:២៥ និងការពន្យល់ ។

**២២:៣** មានភាពផ្ទុយគ្នា អស ១១:៣–៥ និង អគ ២២:៦–៧ ។

ជាប្រាកដ នោះនឹងមានស្តេច[ឈ]ដែលគង់លើបល្ល័ង្កដាវីឌ
ជិះរាជរថនឹងសេះយាងចូលតាមទ្វារនេះ ព្រមទាំងពួក
មហាតលិក និងរាស្ត្ររបស់ទ្រង់ផង ៥ តែបើឯងរាល់គ្នាមិន
ព្រមស្តាប់តាម[ញ]ពាក្យទាំងនេះទេ នោះព្រះយេហូវ៉ា ទ្រង់
មានបន្ទូលដូច្នេះ អញស្បថ[ដ]នឹងខ្លួនអញថា ដំណាក់នេះនឹង
ត្រូវបំផ្លាញអស់រលីង ៦ ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលពី
ដំណើរដំណាក់នៃស្តេចយូដាដូច្នេះ ឯងទុកដូចជាស្រុក
កាឡាត[ឋ] ហើយដូចកំពូលភ្នំល្បាណូនដល់អញ[ឌ] ប៉ុន្តែ
ប្រាកដជាអញនឹងធ្វើឱ្យឯងទៅជាទីស្ងាត់ជ្រងំវិញ[ឍ] ជាទី
ក្រុងដែលឥតមានមនុស្សនៅ ៧ ហើយអញនឹងតាំងពួក
បំផ្លាញ[ណ]ឱ្យមកទាស់នឹងឯង គ្រប់គ្នានឹងកាន់គ្រឿងអាវុធ
របស់ខ្លួន គេនឹងកាប់[ត]រំលំដើមតាត្រៅ ដែលជ្រើសរើស
របស់ឯង ហើយបោះទៅក្នុងភ្លើង[ថ] ៨ សាសន៍ជាច្រើននឹង
ដើរមកតាមទីក្រុងនេះ គ្រប់គ្នានឹងនិយាយដល់គូកនខ្លួនថា
ហេតុអ្វីបានជាព្រះយេហូវ៉ាទ្រង់ធ្វើដូច្នេះដល់ក្រុងធំនេះ[ទ]
៩ នោះគេនឹងឆ្លើយតបថា គឺពីព្រោះគេបានបោះបង់ចោល
សេចក្តីសញ្ញារបស់ព្រះយេហូវ៉ា ជាព្រះនៃគេក៏ថ្វាយបង្គំ
ហើយគោរពប្រតិបត្តិដល់ព្រះដទៃផង[ធ] ។
១០ កុំឱ្យយំនឹងមនុស្សដែលស្លាប់ឡើយ[ន] ក៏កុំឱ្យសោក
ស្តាយ[ប]គេដែរ ត្រូវឱ្យយំជាខ្លាំងនឹងអ្នកដែលចាកចេញពីទី
នេះវិញ ដ្បិតគេនឹងមិនដែលវិលមក[ផ]ទៀតឡើយ ក៏មិន
ដែលឃើញស្រុកកំណើតរបស់ខ្លួនទៀតផង ១១ ពីព្រោះឯ
សាលូម[ព] ជាបុត្រយ៉ូសៀស ស្តេចយូដា ដែលសោយរាជ្យ
ជំនួសយ៉ូសៀស ជាបិតា ហើយបានចាកចេញពីទីនេះទៅ
ហើយ នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា គេនឹង
មិនដែលមកឯទីនេះវិញទៀតឡើយ ១២ នៅកន្លែងណា
ដែលត្រូវដឹកនាំទៅជាឈ្លើយ នោះគេនឹងស្លាប់[ភ]នៅទីនោះ
ឥតដែលឃើញស្រុកនេះទៀត ។
១៣ វេទនា[ម]ដល់អ្នកដែលសង់[យ]ផ្ទះខ្លួន ដោយការទុច្ចរិត

**២២:៤** ឈ យរ ១៧:២៥ **២២:៥** ញ យរ ១៧:២៧ ដ លប ២២:១៦ ហព ៦:១៣ **២២:៦** ឋ លប ៣១:២១ បស ៤:១ ឌ ១ពរ ៧:២ អស ៣៣:៩ ឍ មីក ៣:១២ **២២:៧** ណ យរ ៤:៧ ៦:៤ ត ទដ ៧៤:៥ អស ១០:៣៤ ថ ២របា ៣៦:១៩ សក ១១:១ **២២:៨** ទ ចទ ២៩:២៥–២៦ ១ព ៩:៨–៩ យរ ១៦:១០–១១ **២២:៩** ធ ១ពរ ៩:៩ យរ ១៦:១១ អគ ៣៩:២៣ **២២:១០** ន សស ៤:២ ប ខ.១៨ អគ ២៤:១៦ ផ ខ.២៧ យរ ២៤:៩ ២៩:១៨ ៤២:១៨ **២២:១១** ព ២ពរ ២៣:៣១ **២២:១២** ភ ២ពរ ២៣:៣៤ **២២:១៣** ម អស ៥:៨ យ មីក ៣:១០ ហព ២:៩

**២២:៤** បានរំឭកឡើងវិញនៅក្នុង ១៧:២៥ ។

**២២:៥** សូមមើល ១៧:២៧ និងការពន្យល់ ។ *អញស្បថនឹងខ្លួនអញថា* សូមមើលការពន្យល់នៅ លប ២២:១៦ អស ៤៥:២៣ សូមមើល ៤៩:១៣ ៥១:១៤ ធៀបនឹង ៤៤:២៦ ផងដែរ ។ *ត្រូវបំផ្លាញអស់រលីង* បានរំឭកឡើងវិញនៅក្នុង ៥២:១៣ (សូមមើល ២៧:១៧) ។

**២២:៦** *កាឡាត . . . ភ្នំល្បាណូន* គឺជាស្រុកដែលមានភាពល្បីល្បាញសំបូរទៅដោយព្រៃជាច្រើន ។ ស្រុកល្បាណូនជាស្រុកវិសេសដាច់គេ ដែលបានផ្តល់ដើមម៉ៃសាក់ សម្រាប់សង់ព្រះរាជតំណាក់ (សូមមើលការពន្យល់នៅក្នុង ២១:១៦ សូមមើល ១ពរ ៥:៦,៨–១០ ៧:២–៣ ១០:២៧) ។

**២២:៧** *តាំង* មានន័យថា "ការញែកចេញជាបរិសុទ្ធ"(សូមមើលការពន្យល់នៅ ៦:៤) ។ *ពួកបំផ្លាញ* គឺជាពួកបាប៊ីឡូន(សូមមើលការពន្យល់នៅក្នុង ៤:៧ សូមមើល ១២:១២ ផងដែរ) ។ *គ្រប់គ្នានឹងកាន់គ្រឿងអាវុធរបស់យើង* សូមមើល អគ ៩:២ ។ *គេនឹងកាប់រំលំដើមតាត្រៅ* ធៀបនឹង អស ១០:៣៣–៣៤ ។ គឺជាការរៀបរាប់យ៉ាងពិសេសចំពោះការបាក់បែកខ្ទេចខ្ទីរបស់ពួកទាហានបាប៊ីឡូន ពួកគេនឹងបាក់បែកទៅជាក្រុមៗ នៅក្នុងព្រះវិហារនៃក្រុងយេរូសាឡិម ជាមួយពូថៅហើយនិងញញួររបស់ពួកគេ (ទដ ៧៤:៣–៦) ។

**២២:៨–៩** ខគម្ពីរទាំងនេះ បានឃើញនៅក្នុង ១ពរ ៩:៨–៩ សូមមើល ចទ ២៩២៤–២៦ ។

**២២:៩** *បោះបង់ចោលសេចក្តីសញ្ញា . . . ហើយគោរពប្រតិបត្តិដល់ព្រះដទៃ* ការគោរពប្រតិបត្តិដល់ព្រះដទៃគឺជាការប្រព្រឹត្តិខុសទីមួយ ហើយការបោះបង់ចោលកិច្ចព្រមព្រៀងនៃការតាំងសញ្ញា នៅលើភ្នំស៊ីណាយជាកំហុសឆ្គងលើកទីពីរ (សូមមើល នក ២០:៣–៥ និងការពន្យល់) ។

**២២:១០** *យំនឹងមនុស្សដែលស្លាប់* "ស្តេច" ពួកយូដា និងពួកក្រុងយេរូសាឡិមបានយំកាន់ទុក្ខនិងស្តេចយ៉ូសៀសយ៉ាងយូរ ក្រោយពីការសុគតរបស់ទ្រង់(សូមមើល ២របា ៣៥:២៤–២៥) ។ *អ្នកដែលចាកចេញ* គឺស្តេចយ៉ូអាហាស ។ នៅក្នុងឆ្នាំ ៦០៦ មុន គ.ស ស្តេចផារ៉ោន នេកោជាស្តេចនៃសាសន៍អេស៊ីព្ទ ហើយពួកគេ "បានសែងសពរបស់ទ្រង់ទៅកាន់ស្រុកអេស៊ីព្ទ ហើយទ្រង់បានសុគតនៅទីនោះ" (សូមមើល ២ពរ ២៣:៣៤) ។

**២២:១១** *ស្តេចសាលូម* សូមមើល ១របា ៣:១៥ "សាលូម" ដែលជាឈ្មោះផ្ទាល់ខ្លួនរបស់គាត់ ហើយមួយទៀតមានឈ្មោះថា "ស្តេចយ៉ូអាហាស" នៅពេលដែលទ្រង់ឡើងគ្រងរាជ្យ(ក្រោយមកមានន័យថា "ព្រះអម្ចាស់នៃការរឹបជាន់" ។

**២២:១២** *នៅកន្លែងណាដែលត្រូវដឹកនាំទៅជាឈ្លើយ* គឺទៅកាន់ស្រុកអេស៊ីព្ទ(សូមមើលការពន្យល់នៅ ខ.១០) ។

**២២:១៣–១៩** ខព្រះគម្ពីរនៅត្រង់នេះ គឺនិយាយអំពីការបរិហាររិះគន់យ៉ាងខ្លាំងចំពោះស្តេចយេហូយ៉ាគីម ដែលជាការរៀបរាប់ពីបុគ្គលទីបី (ខ.១៣–១៤) នៅក្នុងខណៈដែលស្តេចយេហូយ៉ាគីមបានបំភ្លៃការពិត នឹងមានសេចក្តីលោភក្នុងការអាស្រ័យនៅជាមួយបុគ្គលទីពីរ (ខ.១៥,១៧) ម្យ៉ាងវិញទៀតបានកត់សម្គាល់ពីភិនភាគ គឺដោយសារឈ្មោះ (ខ.១៨) មានន័យថា "ព្រះអម្ចាស់នៃការងើបឡើង" ស្តេចយ៉ូសៀសជាស្តេចដែលគ្រប់គ្រងល្អ គឺមើលនៅក្នុង ខ.១៥ខ–១៦ ជាមធ្យោបាយគ្រប់គ្រងមានភាពផ្ទុយគ្នា ។

**២២:១៣** *វេទនាដល់អ្នកណាដែលសង់ផ្ទះខ្លួន* សូមមើល ហប ២:៩,១២ ។ *ដោយ ការទុច្ចរិត . . . មិនទៀងត្រង់* ផ្ទុយគ្នានឹង ខ.៣ ២១:១២ ។ *ធ្វើបន្ទប់* សូមមើលការពន្យល់ ពច ៣:២០ ។ *ប្រើប្រាស់អ្នកជិតខាងខ្លួនទទេ* គឺធ្វើការងារដោយមិនបានទទួលប្រាក់ឈ្នួល ដែលជាការខុសចំពោះច្បាប់ (សូម មើល លវ ២៥:៣៩ ចទ ២៤:១៤–១៤) ។ ការបដិសេធរបស់ស្តេចយេហូយ៉ាគីមដើម្បីប្រគល់ពួកគេ ឱ្យបានទៅជាបំណុលគឺជាមនុស្សដែលគ្មានសមត្ថភាព ចាប់តាំងពីពួកយូដានៅក្រោមការបង់ពន្ធយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងពេលនៅស្រុកអេស៊ីព្ទ ជារជ្ជកាលសម័យដំបូងរបស់ទ្រង់ (សូម

ហើយធ្វើបន្ទប់ខ្ពស់ដោយការមិនទៀងត្រង់ ជាអ្នកដែល
ប្រើប្រាស់អ្នកជិតខាងខ្លួនទទេ ឥតចេញឈ្នួល[រ]ឱ្យ ១៤ហើយ
ក៏ពោលថា អញនឹងសង់ផ្ទះ១ធំ[ល] ដែលមានបន្ទប់ទូលាយ
សំរាប់អញ ក៏ធ្វើបង្អួច ហើយបិទជញ្ជាំងដោយក្តារតាត្រៅ[វ]
រួចលាបពណ៌ក្រហមស្រស់[ស] ១៥តើត្រូវឱ្យឯងសោយរាជ្យ
ដោយព្រោះតែឯងមានចិត្តសង្វាតនឹងចំរើនឈើតាត្រៅឬ
អី ឯឪពុកឯង តើមិនបានស៊ី ហើយផឹកដែរទេឬអី ប៉ុន្តែ
បានប្រព្រឹត្តសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិត[ហ] បានជា
មានសន្តិសុខ[ឡ]ក្នុងគ្រានោះ ១៦គាត់បានកាត់ក្តីឱ្យពួកក្រីក្រ
និងពួកកំសត់ទុគ៌ត[អ] ដូច្នេះ ក៏មានសេចក្តីសុខ ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលសួរថា ដែលប្រព្រឹត្តដូច្នោះ តើមិនមែន
ជាស្គាល់[ក]ដល់អញទេឬអី ១៧តែឯភ្នែកឯង និងចិត្តឯង
នោះរកតែបំពេញសេចក្តីលោភរបស់ឯងវិញ[ខ] ក៏កំចាយ
ឈាមរបស់មនុស្សដែលឥតមានទោស[គ] ព្រមទាំងរីបជាន់
និងប្រព្រឹត្តសេចក្តីច្រឡោតផងប៉ុណ្ណោះ[ឃ] ១៨ហេតុនោះ
ព្រះយេហូវ៉ា ក៏មានបន្ទូលពីដំណើរយេហូយ៉ាគីម ជាបុត្រ
យ៉ូសៀស ស្តេចសាសន៍យូដាដូច្នេះថា មនុស្សនឹងមិនសោក
ស្តាយ[ង]ដោយពាក្យថា ឱបង ឱប្អូនអើយ ក៏មិនដែលសោក
ស្តាយថា ឱព្រះអម្ចាស់អើយ ឬថា ព្រះករុណាដ៏ឧត្តមអើយ
នោះឡើយ ១៩គេនឹងកប់សព[ច] យេហូយ៉ាគីម ដូចជាកប់
ខ្មោចសត្វលា គឺគេនឹងអូសទៅបោះចោល[ឆ] នៅខាងក្រៅ
ទ្វារនៃក្រុងយេរូសាឡិមបង់ ។
២០ចូរឡើងទៅលើភ្នំល្បាណូន ហើយស្រែកឡើង[ជ]
ចូរបន្លឺសំឡេងនៅស្រុកបាសាន[ឈ] ហើយស្រែកពីភ្នំបារីម
ចុះ[ញ] ពីព្រោះបណ្តាសហាយ[ដ]របស់ឯងបានត្រូវបំផ្លាញ
ហើយ ២១កាលនៅគ្រាសំបូរ នោះអញបាននិយាយនឹង
ឯងហើយ[ឋ] តែឯងឆ្លើយតបថា យើងមិនព្រមស្តាប់ទេ គឺ

**២២:១៣** រ លវ ១៩:១៣ យក ៥:៤ **២២:១៤** ល អស ៥:៨–៩ វ ២រប ៧:២ ស អគ ២៣:១៤ **២២:១៥** ហ ២ពវ ២៣:២៥ ឡ ទដ ១២៨:២ អស ៣:១០ **២២:១៦** អ ទដ ៧២:១–៤,១២–១៣ ៨២:៣ សភ ២៤:២៣ ក ទដ ៣៦:១០ **២២:១៧** ខ អស ៥៦:១១ គ ២ពវ ២៤:៤ ឃ ចទ ២៨:៣៣ អគ ១៨:១២ មីក ២:២ **២២:១៨** ង ២សយ ១:២៦ **២២:១៩** ច ២ពវ ២៤:៦ ឆ យរ ៨:២ ៣៦:៣០ **២២:២០** ជ អស ៥៧:១៣ ឈ ទដ ៦៨:១៥ ញ ជន ២៧:១២ ដ ខ.២២ យរ ៣០:១៤ បទ ១:១៩ អគ ១៦:៣៣–៣៤ ហស ៨:៩ **២២:២១** ឋ សក ៧:៧

មើល ២ពវ ២៣:៣៥) ។

**២២:១៤** *ធ្វើបង្អួច* បានរៀបរាប់ពីរបស់មានតម្លៃ ដូចជាបានរកឃើញនៅក្នុងសំណល់បាក់បែកនៅត្រង់ទីក្រុងបេត–ហាកេរែម(សូមមើល ៦:១ សូមមើលការពន្យល់ នហ ៣:១៤) ដែលបានរកឃើញដោយសារបុរាណវត្ថុវិទូនៅក្នុងរជ្ជកាលសម័យដំបូងនៃទសវត្សរ៍ឆ្នាំ១៩៦០ ។ *ក្តារ* ហោរាហាកាយមិនចង់យកបន្ទះក្តារមានតម្លៃមកប្រើក្នុងការងារមិនចាំបាច់ឡើយ ប៉ុន្តែនៅពេលក្នុងស្ថានការណ៍ពិសេសគាត់បានប្រើបន្ទះក្តារនេះវិញ (សូមមើល ហាក ៤:១) ។

**២២:១៥** *ឯឪពុកឯង* គឺនិយាយប្រៀបធៀបពីស្តេចយ៉ូសៀស ។ *បានស៊ីហើយផឹកដែរ* នៅត្រង់ចំណុចនេះ គឺនិយាយពីភាពសប្បាយនៃជីវិត (សូមមើល សស ២:២៤–២៥ ៣:១២–១៣ ។ *បានប្រព្រឹត្តសេចក្តីយុត្តិធម៌ នឹងសេចក្តីសុចរិត* មានលក្ខណៈដូចជាព្ធយុកោរបស់ស្តេចដាវីឌដែរ (សូមមើល ២សយ ៨:១៥) មានភាពផ្ទុយគ្នាពី ខ.១៣ (សូមមើលការពន្យល់ ទដ ១១៩:១២១) ។

**២២:១៦** លោកយ៉ាកុបបានបង្ហាញដាច់ខ្សែកពីគ្នា អំពីការទំនាក់ទំនងទៅកាន់ព្រះដែលប្រហែលជាពេលកំណត់ (យក ១:២៧) មានភាពខុសគ្នា ៥:២៨ (សូមមើលការពន្យល់នោះ) ។ *ពួកក្រីក្រ និងពួកកំសត់ទុគ៌ត* សូមមើលការពន្យល់ ២០:១៣ ។ *ស្គាល់ដល់អញ* គឺជាសេចក្តីស្រឡាញ់នៃព្រះពោរពេញ ដែលជាលទ្ធផលទាំងឡាយចំពោះការរស់នៅ ដោយមានសេចក្តីជំនឿពិតប្រាកដនៃជីវិត ចាំបាច់ក្នុងការបម្រើព្រះ (សូមមើល ចទ ១០:១២–១៣ ហស ៦:៦ ២១:១២ មីក ៦:៨) ។

**២២:១៧** *ឯង* គឺនិយាយពីស្តេចយេហូយ៉ាគីម (សូមមើល ខ.១៨) ។ *បំពេញសេចក្តីលោភ* សូមមើល ៦:១៣ ៨:១០ ។ *កំចាយឈាមរបស់មនុស្សដែលឥតមានទោស* សូមមើលការពន្យល់នៅ ១៩:៤ គឺជាការពន្យល់បង្ហាញពីភាពឃោរឃៅរបស់ស្តេចយេហូយ៉ាគីម នៅក្នុងសិទ្ធិអំណាចនេះ ។ សូមមើល ២៦:២០–២៣ ។ *រីបជាន់* សូមមើល ខ.៣ ៦:៦ ២១:១២ ។

**២២:១៨** ភាពផ្ទុយគ្នានិង ២របា ៣៥:២៤–២៥ ។ *មនុស្សនឹងមិនសោកស្តាយដោយពាក្យថា ឱបង ឱប្អូនអើយ* ខុសគ្នានឹង ១ពវ ១៣:៣០ ។

**២២:១៩** *កប់ខ្មោចសត្វលា* គ្មានផ្នូរកប់ខ្មោចណាដូចគ្នាទាំងអស់ឡើយ (សូមមើល ៣៦:៣០) និងបានបង្ហាញនៅក្នុង ២ពវ ២៤:៦ មិនមានកន្លែងកប់ខ្មោចណាដែលបានរៀបរាប់ជាក់ច្បាស់ទេ ប៉ុន្តែស្តេចយេហូយ៉ាគីមនិយាយពីវាថា"បានសម្រាក់ជាមួយនឹងពួកព្ធយុកោរបស់ទ្រង់"គឺជាការម្រាលពាក្យកំសាន្តចិត្តចំពោះសេចក្តីស្លាប់ (សូមមើលការពន្យល់ លប ២៥:៨ ១ពវ ១:២១) ។ *នឹងអូសទៅបោះចោល* សូមមើល ១៥:៣ ។

**២:២០–២៣** ព្រះយេហូវ៉ាមានបន្ទូលទៅកាន់ក្រុងយេរូសាឡិមថា សំដីរបស់ពួកគេដូចជាស្ត្រី (សូមមើល ខ.២៣) ។

**២២:២០** *ភ្នំល្បាណូន . . . ស្រុកបាសាន . . . ភ្នំអាបារីម* ជាស្រុកដែលសំបូរទៅដោយដំភ្នំជាច្រើន (សូមមើល ខ.៦ ជន ២៧:១២ ៣៣:៤៧–៤៨ ចទ ៣២:៤៩ ពច ៣:៣ ទដ ៦៨:១៥) ភ្នំពីរជួរដំបូងគឺស្ថិតនៅតំបន់ខាងជើងហើយមួយទៀតស្ថិតនៅផ្នែកខាងត្បូងវិញ ដែលស៊ីផ្ទៃកំពស់នៃស្រុកអ៊ីស្រាអែល ដែលអាចឱ្យគេពិពណ៌នាយ៉ាងច្បាស់ពីភូមិសាស្ត្រផ្ទៃដី ។ *បណ្តាសហាយ* មានន័យថា"គូររួមស្នេហ៍"(មើល ៤:៣០ និងការពន្យល់) នៅត្រង់ចំណុចនេះគឺសំដៅទៅលើគ្រប់ទាំងសាសន៍បានរួមគ្នាដោយសារការតាំងសន្ធិសញ្ញាជាមួយគ្នា ។ កាលពីមុនពួកយូដាបានចងសម្ព័ន្ធមិត្រជាមួយសាសន៍អេស៊ីព្ទ និងសាសន៍អាសសើរ (សូមមើល ២:៣៦) សាសន៍អេដំម សាសន៍ម៉ូអាប់ សាសន៍អាំម៉ូន និងពួកសាសន៍ភេនីស (សូមរមីល ២៧:៣) ។ សាសន៍អស់នេះដែលបានច្បាំងយកជ័យជម្នះយ៉ាងឆាប់រហ័សដោយសារស្តេចបាប៊ីឡូន (សូមមើល ២៧:៦–៧ ២៨:១៤) ។ *ត្រូវបំផ្លាញហើយ* (សូមមើល ១៤:១៧) ។

**២២:២១** *យើងមិនព្រមស្តាប់ទេ . . . គឺមិនព្រមស្តាប់តាមពាក្យអញឡើយ* សូមមើល ៧:២២–២៦ ១១:៧–៨ ។ *តាំងពីក្មេងមក* គឺគ្រប់ទាំងថ្ងៃរបស់ពួកអ៊ីស្រាអែល ដែលជាប្រវត្តិសាស្ត្រមុនដំបូងបង្អស់នៅក្នុងស្រុកអេស៊ីព្ទ

បែបយ៉ាងនេះ ដែលបានប្រព្រឹត្តតាំងតែពីក្មេងមក[ឌ] គឺមិន
ព្រមស្តាប់តាម[ឍ]ពាក្យអញឡើយ ២២ខ្យល់[ណ]នឹងស៊ីបំផ្លាញពួក
គង្វាល[ត]របស់ឯង ហើយពួកសហាយ[ថ]របស់ឯងនឹងត្រូវដឹក
ទៅជាឈ្លើយ ដូច្នេះឯងនឹងត្រូវខ្មាស[ទ] ហើយជ្រប់មុខ
ដោយព្រោះអំពើអាក្រក់ដែលឯងប្រព្រឹត្តជាមិនខាន
២៣ឱអ្នកដែលអាស្រ័យនៅព្រៃល្បាណូន[ធ] ដែលធ្វើសំបុក
នៅដើមតាត្រៅអើយ កាលណាសេចក្តីទុក្ខវេទនាមកលើ
ឯង ដូចជាស្ត្រីដែលឈឺចាប់[ន]នឹងសំរាលកូន នោះឯងនឹង
គួរអាណិតយ៉ាងណាទៅ ។
២៤ព្រះយេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ ទោះ
បើយេកូនាស ជាបុត្រយេហូវ៉ាគីម[ប] ស្តេចសាសន៍យូដាជា
ចិញ្ចៀនត្រា[ផ]នៅដៃស្តាំអញក៏ដោយ គង់តែអញនឹងកន្ត្រាក់
ចេញទៅដែរ ២៥អញនឹងប្រគល់ឯងទៅ[ព]ក្នុងកណ្តាប់ដៃ
នៃពួកអ្នកដែលរកជីវិតឯង ហើយក្នុងកណ្តាប់ដៃនៃពួកអ្នក
ដែលឯងបានខ្លាចនោះ គឺក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសាជា
ស្តេចបាប៊ីឡូន ហើយក្នុងកណ្តាប់ដៃនៃសាសន៍ ខាល់ដេផង
២៦អញនឹងបោះ[ភ]ឯងចោលចេញព្រមទាំង ម្តាយ[ម]ដែល
បង្កើតឯងផង ទៅក្នុងស្រុក១ ដែលមិនមែនជាស្រុក
កំណើតរបស់ឯង ហើយឯងនឹងស្លាប់ នៅក្នុងស្រុក នោះ
២៧តែឯស្រុកដែលចិត្តគេរញ្ជួកចង់វិលទៅនៅវិញនោះ គេ
នឹងមិនត្រឡប់[យ]ទៅនៅវិញឡើយ ២៨ឯមនុស្សឈ្មោះ
យេកូនាស[រ]នេះ តើជាភាជនៈ កំបែក[ល] ហើយសំអប់ឬអី
តើជាប្រដាប់ដែលឥតមានអ្នកណាពេញចិត្តដែរឬ ហេតុអ្វី
បានជាគេត្រូវបោះ[វ]ចេញ ដូច្នេះ ព្រមទាំងពូជពង្សរបស់
គេផង គឺបោះចោលទៅនៅស្រុក[ស]១ដែលគេមិនស្គាល់នោះ
២៩ឱផែនដី[ហ] ផែនដី ផែនដីអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះ
យេហូវ៉ាចុះ ៣០ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ត្រូវកត់
ឈ្មោះរបស់មនុស្ស នេះថាជាគ្មានកូន[ឡ] ជាមនុស្សដែលនឹង
មិនចំរើន[អ]ក្នុងជិនាន់របស់ខ្លួនឡើយ ដ្បិតនឹងគ្មានពូជពង្ស[ក]
គេណាមួយ ដែលនឹងអាចអង្គុយលើបល្ល័ង្ក[ខ] នៃដាវីឌ

**២២:២១** ឌ ចទ ៩:៧ ទដ ២៥:៧ អស ៥៤:៤ យរ ៣:២៥ ៣១:១៩ ៣២:៣០ ឍ យរ ៣:១៣ ៧:២៣–២៨ សផ ៣:២ **២២:២២** ណ ចទ ២៨:៦៤ យប ២៧:២១ ត យរ ១០:២១ ថ ខ.២០ ទ យរ ៧:១៩ **២២:២៣** ធ ១ពវ ៧:២ អគ ១៧:៣ ន យរ ៤:៣១ **២២:២៤** ប ២ពវ ២៤:៦,៨ ផ លប ៣៨:១៨ **២២:២៥** ព ២ពវ ២៤:១៦ ២របា ៣៦:១០ **២២:២៦** ភ ១សយ ២៥:២៩ ២ពវ ២៤:៨ ២របា ៣៦:១០ អស ២២:១៧ អគ ១៩:៩–១៤ ម ១ពវ ២:១៩ **២២:២៧** យ ខ.១០ **២២:២៨** រ ២ពវ ២៤:៦ ល ទដ ៣១:១២ យរ ១៩:១០ ២៥:៣៤ ៤៨:៣៨ វ យរ ១៥:១ ស យរ ១៧:៤ **២២:២៩** ហ យរ ៦:១៩ **២២:៣០** ឡ ១របា ៣:១៨ យរ ៣៨:២៣ ៥២:១០ មថ ១:១២ អ យរ ១០:២១ ក យប ១៨:១៩ ខ ទដ ៩៤:២០

(សូមមើល ២:២ និងការពន្យល់ ហស ២:១៥) ។

**២២:២២** *ខ្យល់នឹងស៊ី . . . ត្រូវដឹកទៅ* សូមមើល ១៣:២៤ យប ២៧:២១ អស ២៧:៨ ។ *ពួកគង្វាល* សូមមើល ២:៨ និងការពន្យល់ ១០:២១ ២៣:១–៤ ។ សេចក្តីទំនាយបានសម្រេចនៅឆ្នាំ ៥៩៧ មុន គ.ស (សូមមើល ២ពវ ២៤:១២–១៦) ។

**២២:២៣** *ព្រៃល្បាណូន . . . ដើមតាត្រៅ* សូមមើលការពន្យល់ ២១:១៤ និងការពន្យល់ អគ ១៧:៣–៤,១២ ។ *ដូចជាស្ត្រីដែលឈឺចាប់នឹងសំរាលកូន* សូមមើល ៤:១៩,៣១ និងការពន្យល់ ។

**២២:២៤–៣០** នៅក្នុងខគម្ពីរទាំងនេះ គឺជាសេចក្តីទំនាយ ប្រឆាំងទាស់នឹងស្តេច យេហូយ៉ាគីម បានសម្រេចនៅក្នុង ២៤:១ ២៩:២) ដែលគេបានស្គាល់ដូចជា កូនាសជាបុត្រយេហូយ៉ាគីម (សូមមើលការពន្យល់ ខ.២៤) ហើយឈ្មោះពេញរបស់គាត់គឺយេកូនាស (សូមមើលការពន្យល់ ២៤:១) ហើយសូមមើល សេចក្តីដើម និងប្រវត្តិដើម ។ ទាំងអស់មានបីប្រភេទចំពោះឈ្មោះនេះមានន័យថា"ព្រះអម្ចាស់ដែលបានបង្កើត" ។

**២២:២៤** *ដូចជាអញរស់នៅ* សូមមើលការពន្យល់ លប ៤២:១៥ ។ *ទោះបើ . . . ជាចិញ្ចៀនត្រា* គឺជាបណ្តាសានឹងធ្លាក់ទៅលើស្តេច យេហូយ៉ាគីម ដែលអាចមើលឃើញច្បាស់ពីភាពខុសគ្នានៅ ហាក ២:២៣ (សូមមើលការពន្យល់ដែលមាននៅទីនោះ) ។

**២២:២៥** *កណ្តាប់ដៃនៃពួកអ្នក ដែលឯងបានខ្លាចនោះ* មានភាពផ្ទុយគ្នាពីជិពូក ៣៩:១៧ ។

**២២:២៦** ខនេះបានសម្រេចនៅក្នុងឆ្នាំ ៥៩៧ មុន គ.ស(សូមមើល ២៩:២ ២ពវ ២៤:១៥) ។ *បោះឯងចោលចេញ . . . ទៅក្នុងស្រុក១* នៅត្រង់វគ្គនេះនិយាយពីការនិរទេសពួកគេ ទៅកាន់ស្រុកបាប៊ីឡូន(សូមមើល ៧:១៥ ១៦:១៣ ចទ ២៩:២៨) ។ *បោះឯងចោលចេញ ព្រមទាំងម្តាយដែលបង្កើតឯងផង* នៅត្រង់ឃ្លានេះគឺនិយាយអំពីស្តេចយេហូយ៉ាគីន និងព្រះមាតាទ្រង់ព្រះនាមនេហ៊ូថា(សូមមើលការពន្យល់នៅក្នុង ១៣:១៨) ។

**២២:២៨** មានសំណួរពីរដែលមានលក្ខណៈពិបាកយល់ បានឆ្លើយនៅក្នុង ខ. ៣០ ។ *ភាជនៈបំបែក. . .បោះចេញ* និយាយសំដៅទៅលើស្តេចយេហូយ៉ាគីន និងពូជពង្សរបស់ទ្រង់ ដែលដូចជាពួកយូដា (សូមមើល ១៩:១០–១១)គឺនៅក្រោមការជំនុំជម្រះរបស់ព្រះ ។ *ព្រមទាំងពូជពង្សរបស់* ថ្វីបើស្តេចយេហូយ៉ាគីន មានព្រះជន្ម១៨ឆ្នាំគត់ នៅគ្រាដែលទ្រង់ត្រូវបាននិរទេស (សូមមើល ២ពវ ២៤:៨) គឺទ្រង់មានមហេសី១បន្ថែមទៀត(សូមមើល ២ពវ ២៤:១៥) ដូច្នេះប្រហែលជាទ្រង់មានបុត្រ១ អង្គឬច្រើនអង្គទៀត ។

**២២:២៩** *ឱផែនដី ផែនដីអើយ* គឺជាសេចក្តីរំឭកនិងបញ្ជាក់ឡើងវិញ អំពីភាពខ្លាំងពូកែបំផុត ដែលមានលទ្ធភាព និងបង្ហាញពីកម្លាំង(សូមមើល ៧:៤ និងការពន្យល់ ២៣:៣០–៣២ អស ៦:៣ ហើយនិងការពន្យល់ អគ ២១:២៧) ។

**២២:៣០** *ជាគ្មានកូន* គឺនៅគ្រប់ពូជពង្សនៃស្តេចយេហូយ៉ាគីនគ្មានកូនដើម្បីនឹងអង្គុយលើបល្ល័ង្កបានឡើយ(គឺទ្រង់មានបុត្រតែ៧នាក់ប៉ណ្ណោះ សូមមើល ១របា ៣:១៧–១៨) ប៉ុន្តែមិនមានបុត្រណាមួយបានអង្គុយលើបល្ល័ង្ក នៃស្តេចដាវីឌ នៅក្នុងពួកយូដា ។ ចៅប្រុសរបស់ស្តេចយេហូយ៉ាគីន គឺសូរ៉ូបាបិល (សូមមើល ១របា ៣:១៧–១៩ មថ ១:១២) ។ ដែលគាត់បានក្លាយទៅជាចៅហ្វាយនៃស្រុកយូដា(សូមមើល ហាក ១:១) តែសូរ៉ូបាបិលមិនមែនជាស្តេចឡើយ ។ ស្តេចសេដេគាគឺជាព្រះបុត្រានៃស្តេចយ៉ូសៀស(សូមមើល ៣៧:១) ទ្រង់មិនមែនជាបុត្រារបស់ស្តេចយេហូយ៉ាគីនទេ ក្រោយមកទ្រង់និង បុត្រារបស់ទ្រង់បានសុគត(សូមមើល ៥២:១០–១១) ។ ដូច្នេះហើយស្តេចយេហូយ៉ាគីន គឺជាស្តេចនៃពួកយូដាដែលទ្រង់មានព្រះជន្មរហូតដល់រាជវង្សស្តេចដាវីឌ និងមកដល់ព្រះគ្រីស្ទ ។

ហើយគ្រប់គ្រងលើស្រុកយូដាបានទៀតឡើយ ។

**លំពង់សុចរិត**

**២៣** ១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា វេទនាដល់ពួក
គង្វាល[ក]ដែលបំផ្លាញ ហើយកំចាត់កំចាយ[ខ]ហ្វូងចៀមនៃ
ទីឃ្វាល[គ]របស់អញ ២ហេតុនោះព្រះយេហូវ៉ា ជាព្រះនៃ
ពួកសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលទាស់នឹងពួកអ្នក
គង្វាល[ឃ]ដែលឃ្វាលជនជាតិរបស់ខ្ញុំ ដូច្នេះថា ឯងរាល់
គ្នាបានកំចាត់កំចាយហ្វូងចៀម[ង]របស់អញ ហើយបណ្តេញ
ចេញបង់ ឥតមើលរក្សាវាឡើយ ដូច្នេះ អញនឹងទំលាក់
អំពើអាក្រក់[ច]របស់ឯងរាល់គ្នាទៅលើឯងវិញ នេះហើយ
ជាព្រះបន្ទូលនៃព្រះយេហូវ៉ា ៣រួចអញនឹងប្រមូលសំណល់[ឆ]
នៃហ្វូងរបស់អញចេញពីគ្រប់ទាំងស្រុក ដែលអញបាន
បណ្តេញគេទៅនោះ ហើយនាំវិលត្រឡប់មក ឯក្រោល
គេវិញ[ជ] នោះគេនឹងបង្កើតផល ហើយចំរើនឡើង ៤អញ
នឹងតាំងអ្នកគង្វាល[ឈ]លើគេដែលនឹងឃ្វាលគេ គ្រានោះគេ
នឹងមិនភ័យ[ញ] ឬស្រយុតចិត្តទៀតឡើយ ក៏មិនដែលបាត់បង់[ដ]
ណាមួយដែរ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល នឹងមានគ្រាមក
ដល់ ដែលអញនឹងបង្កើតឱ្យដាវីឌមានលំពង់សុចរិត[ឋ] ១
លំពង់នោះទ្រង់នឹងសោយរាជ្យ[ឌ]ទុកដូចជាស្តេច[ឍ]ហើយ
នឹងប្រព្រឹត្តដោយវាងវៃ ព្រមទាំងសំរេចសេចក្តីយុត្តិធម៌
និងសេចក្តីសុចរិត[ណ]នៅក្នុងស្រុកផង ៦នៅគ្រារបស់ទ្រង់
ពួកយូដានឹងបានសង្គ្រោះ ហើយពួកអ៊ីស្រាអែលនឹងនៅ
ដោយសន្តិសុខ[ត] ឯព្រះនាម[ថ]ដែលគេនឹងហៅទ្រង់ នោះគឺ
"ព្រះយេហូវ៉ាដ៏ជាសេចក្តីសុចរិតនៃយើងរាល់គ្នា"[ទ] ៧ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា គឺហេតុនោះបានជាមានគ្រា

**២៣:១** ក យរ ១០:២១ ១២:១០ ២៥:៣៦ អគ ៣៤:១–១០ សក ១០:២ សក ១១:១៥–១៧ ខ អស ៥៦:១១ គ ទដ ១៣:១៧ អគ ៣៤:៣១ **២៣:២** ឃ យហ ១០:៨ ង យរ ១០:២១ ១៣:២០ ច យរ ២១:១២ អគ ៣៤:៨–១០ **២៣:៣** ឆ អស ១១:១០–១២ យរ ៣២:៣៧ អគ ៣៤:១១–១៦ ជ ១ពវ ៨:៤៨

**២៣:៤** ឈ លប ៤៨:១៥ អស ៣១:៤ យរ ៣១:១០ ញ យរ ៣០:១០ ៤៦:២៧–២៨ ដ យហ ៦:៣៩ **២៣:៥** ឋ ២ពវ ១៩:២៦ អស ៤:២ អគ ១៧:២២ ឌ អស ៩:៧ មថ ១:១ ឍ មថ ២:២ ណ លប ១៨:១៩ **២៣:៦** ត លវ ២៥:១៨ ចទ ៣២:៨ ហស ២:១៨ ថ នក ២៣:២១ យរ ៣៣:១៦ មថ ១:២១–២៣ ទ អរ ៩:១៥ អស ៤២:៦ រម ៣:២១–២២ ១រប ១:៣០

**២៣:១–៨** គឺជាការថ្លែងសង្ខេបពីស្តេចសេដេគា (ប្រហែលជាការចុះថ្ងៃខែកំណត់ពីការសោយរាជរបស់ស្តេចសេដេគា សូមមើលការពន្យល់ក្នុង ខ.៦) ។ នៅក្នុងខនេះបានបញ្ជាក់បន្ថែមពីបំណងព្រះហឫទ័យរបស់ព្រះផងដែរ ដើម្បីនិងជំនុំជម្រះដល់ពួកអ្នកគ្រប់គ្រងអាក្រក់ និងដល់អ្នកដឹកនាំនៃពួកយូដាទាំងអស់ (ខ.១២) និងពេលចុងក្រោយបំផុតគឺជាពេលវេលាដែលត្រូវដឹកនាំប្រជារាស្ត្ររបស់ទ្រង់ឱ្យពួកគេវិលត្រឡប់ពីការនិរទេសមកវិញ (ខ.៣–៤,៧–៨) ហើយនៅគ្រានោះនិងមានដំណវង្សនៃស្តេចដាវីឌបានឡើងគ្រងរាជ្យលើពួកគេ (សូមមើល ៥–៦) ។

**២៣:១** សូមមើល ១០:២១ និងការពន្យល់ ។ *ហ្វូងចៀម* គឺនិយាយពីពួកសាសន៍យូដា (សូមមើល ខ.២) ។

**២៣:២** *មើលរក្សា . . . ទំលាក់អំពើអាក្រក់* ក្នុងព្រះគម្ពីរជាភាសាហេព្រើរ គឺបានវិភាគពីឫសគល់នៅឃ្លាទាំងពីរនេះដូចគ្នា (សូមមើល ខ.៤ និងការពន្យល់) ។ ជាអ្វីដែលអ្នកគ្រប់គ្រងនៃពួកយូដាបានប្រព្រឹត្តខុស គឺបានសង្ខេបនៅក្នុង អគ ៣៤:៤ ។

**២៣:៣** *សំណល់* សូមមើលការពន្យល់នៅក្នុង ៦:៩ ។ *អញបានបណ្តេញ* ទោះបីអំពើបាបនៃពួកយូដា និងបាបរបស់ ពួកគេបាននាំមកនូវបណ្តាសាដល់គេគឺ "ត្រូវបានបណ្តេញចេញ" (ខ.២) ដោយការនិរទេស ។ នៅពេលចុងក្រោយព្រះយេហូវ៉ាទ្រង់ផ្ទាល់ បានបង្ហាញឱ្យប្រជារាស្ត្ររបស់ទ្រង់បានដឹងពីលទ្ធផលនៃការប្រព្រឹត្តខុស ជាមួយនិងសេចក្តីសញ្ញាដែលពួកគេបានធ្វើសេចក្តីសន្យាជាមួយនឹងទ្រង់ ។ *និងបង្កើតផល ហើយចំរើនឡើង* សូមមើលការពន្យល់នៅក្នុង លប ១:២៨ ។

**២៣:៤** *ស្រយុតចិត្ត . . . បាត់បង់* គឺជាការខ្វល់ខ្វាយរបស់អ្នកគង្វាលក្នុងការប្រយុទ្ធជាមួយសត្វសាហាវទាំងឡាយ (សូមមើល អគ ៣៤:៨) ។ *ដែលបាត់បង់* សូមមើល ៣១:៤៩ ព្រះគម្ពីរជាភាសាហេព្រើរ បានធ្វើការវិភាគពីឫសគល់ចំពោះឃ្លានេះ គឺមានន័យដូច្នេះ" ឥតមើលរក្សាវាឡើយ អញនឹងទំលាក់អំពើអាក្រក់" មើលនៅក្នុង ខ.២ និងការពន្យល់ ។

**២៣:៥–៦** នៅត្រង់ខនេះ គឺជាផ្នែកមួយដែលមានសារៈសំខាន់បំផុត ចំពោះព្រះបន្ទូលរបស់ព្រះមែស៊ីនៅក្នុងកណ្ឌគម្ពីរយេរេមា ត្រូវបានប្រកាសឱ្យដឹងនៅក្នុង ៣៣:១៥–១៦ ។

**២៣:៥** *បង្កើត* សូមមើល ២សយ ៧:១២ សូមមើល ៣០:៩ អគ ៣៤:២៣–២៤ ៣៧:២៤ ផងដែរ ។ នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរ សម្រាប់ឃ្លានេះគឺបានបកប្រែថា "តាំង" មើល ខ.៤ ។ *ឱ្យដាវីឌ* សូមមើល មថ ១:១ និងការពន្យល់ មថ ១:១៧ ។ គឺព្រះមែស៊ីមានភាពខុសប្លែកពីពូជវង្សហ្លួងដាវីឌនៅត្រង់ចំណុចខ្លះៗកាលពីមុន ដែលស្តេចដាវីឌគ្រាន់តែជាស្តេចតំណាងឱ្យផែនដីប៉ុណ្ណោះ ។ ទ្រង់នឹងសរុបសេចក្តីដោយអង្គទ្រង់ផ្ទាល់ទាំងអស់ដោយហ្មត់ចត់និងប្រកបដោយប្រសិទ្ធិភាពបំផុត ពោះអ្នកគ្រប់គ្រងទាំងឡាយហើយនិងគ្មានដែនកំណត់ ។ *មានលំពង់* គឺជាសេចក្តីទំនាយទាយពីព្រះមែស៊ី (សូមមើលការពន្យល់ អស ៤:២ សក ៣:៨ ៦:១២) ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើរហៅថាតាហ្គាម (Targum) ហើយភាសាអារ៉ាប់ ប្រយោគនេះហៅថា "មែស៊ី" ។ *សោយរាជ្យទុកដូចជាស្តេច* សូមមើលការពន្យល់ អស ៥២:១៣ ។ *សំរេចសេចក្តីយុត្តិធម៌ នឹងសេចក្តីសុចរិត* សូមមើល ២២:៣,១៥ បាននិយាយពីស្តេចដាវីឌផងដែរ (សូមមើល ២សយ ៨:១៥) ។

**២៣:៦** *ពួកយូដា . . . ហើយពួកអ៊ីស្រាអែល* គឺព្រះទ្រង់បានបង្រួបបង្រួមរាស្ត្ររបស់ទ្រង់នឹងបានសង់គេឡើងវិញ (សូមមើល ៣១:៣១ និងការពន្យល់ អគ ៣៧:១៥–២២) ។ *នឹងបានសង្គ្រោះ . . . នឹងនៅដោយសន្តិសុខ* ព្រះយេហូវ៉ាទ្រង់នឹងរំដោះគេទាំងរូបកាយ ហើយនិងវិញ្ញាណឱ្យរួច (សូមមើល ចទ ៣៣:២៨–២៩) ។ *"ព្រះយេហូវ៉ាដ៏ជាសេចក្តីសុចរិតនៃយើងរាល់គ្នា"* ថ្វីបើស្តេចសេដេគាមិនបានរស់ឡើងវិញ ប៉ុន្តែឈ្មោះរបស់ទ្រង់មានន័យថា" ព្រះអម្ចាស់ជាសេចក្តីសុចរិតរបស់ខ្ញុំ" ព្រះមែស៊ីនឹងមើលរក្សាលើរាស្ត្ររបស់ទ្រង់ ហើយនឹងប្រទានពរជាបរិបូរ (សូមមើល អគ ៣៤:២៥–៣១) បានមកដោយសាព្រះហស្តនៃស្តេចដែលបានប្រព្រឹត្ត "តើអ្វីជាសេចក្តីសេចក្តីយុត្តិធម៌ នឹងសេចក្តីសុចរិត" (ខ. ៥) ។

មក[ធ] ដែលគេនឹងលែងស្បថថា ដូចជាព្រះយេហូវ៉ាមានព្រះ
ជន្មរស់ ដែលទ្រង់បាននាំពួកកូនចៅអ៊ីស្រាអែលឡើង
ចេញពីស្រុកអេស៊ីព្ទមក[ន] ៨គឺគេនឹងថា ដូចជាព្រះយេហូវ៉ា
ទ្រង់មានព្រះជន្មរស់ ដែលទ្រង់បាននាំពូជពង្សនៃអ៊ីស្រា–
អែលឡើងរួច ហើយដឹកនាំគេចេញពីស្រុកខាងជើង
និងពីគ្រប់ទាំងស្រុកដែលអញបានបណ្តេណគេនោះវិញ
នោះគេនឹងនៅក្នុងស្រុករបស់ខ្លួនគេតទៅ[ប] ។

## ពួកហោរា

៩ពីដំណើរពួកហោរា ។
ចិត្ត[ផ]នៅក្នុងខ្លួនខ្ញុំត្រូវញាំញីហើយ អស់ទាំងឆ្អឹងខ្ញុំក៏
ញ័រ[ព] ខ្ញុំដូចជាមនុស្សស្រវឹង គឺដូចជាមនុស្សដែលស្រា
ទំពាំងបាយជូរបានឈ្នះហើយ ដោយព្រោះព្រះយេហូវ៉ា
ហើយដោយព្រោះព្រះបន្ទូលដ៏បរិសុទ្ធរបស់ទ្រង់[ភ] ១០ដ្បិត
ស្រុកនេះមានពេញដោយមនុស្សដែលប្រព្រឹត្តកំផិត[ម] ហើយ
ស្រុកក៏យំសោកដោយព្រោះសេចក្តីបណ្តាសា[យ] អស់ទាំង
ទីឃ្វាលសត្វ[រ] នៅទីរហោស្ថាន បានហួតហែងអស់ហើយ[ល]
គេរត់តាមតែសេចក្តីអាក្រក់ ហើយគេប្រើអំណាចសំរាប់
តែការទុច្ចរិតទេ ១១ដ្បិតទាំងហោរានិងសង្ឃផង សុទ្ធតែ
ស្មោកគ្រោកទាំងអស់គ្នា[វ] អើ ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ថា អញបានឃើញអំពើអាក្រក់របស់គេ នៅក្នុងព្រះវិហារ[ស]
របស់អញផង ១២ហេតុនោះផ្លូវរបស់គេនឹងបានដូចជា
កន្លែងរលាក់[ហ]នៅទីងងឹតដល់គេ គេនឹងត្រូវច្រានទៅ ហើយ
ដួលចុះនៅទីនោះ ដ្បិតអញនឹងនាំសេចក្តីអាក្រក់មកលើគេ
គឺជាឆ្នាំដែលត្រូវធ្វើទោសដល់គេ[ឡ] នេះជាព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ។
១៣អញបានឃើញ សេចក្តីចំកួតក្នុងពួកហោរា នៅ
ក្រុងសាម៉ារីដែរ គេទាយទំនាយដោយសារព្រះបាល[អ] ក៏
នាំពួកអ៊ីស្រាអែល ជារាស្ត្រអញឱ្យវង្វេងដែរ[ក] ១៤ឯក្នុងពួក
ហោរានៅក្រុងយេរូសាឡិម នោះអញក៏ឃើញមានសេចក្តី
គួរស្ញើមណាស់ដែរ[ខ] គេប្រព្រឹត្តសេចក្តីកំផិត ហើយដើរ
តាមតែសេចក្តីកំភូតទទេ[គ] គេចំរើនកំឡាំងដៃនៃពួកអ្នក
ដែលប្រព្រឹត្តអំពើអាក្រក់[ឃ] ដល់ម៉្លេះបានជាគ្មានអ្នកណាមួយ
វិលត្រឡប់ពីអំពើអាក្រក់របស់ខ្លួនឡើយ[ង] គេបានត្រឡប់
ដូចជាក្រុងសូដុំម[ច]ទាំងអស់គ្នា ពួកអ្នកនៅក្រុងនេះ ក៏ដូច
ជាក្រុងកូម៉ូរ៉ា ដល់អញហើយ[ឆ] ១៥ហេតុនោះ ព្រះយេហូវ៉ា
នៃពួកពលបរិវារ ទ្រង់មានបន្ទូលពីដំណើរពួកហោរា
ដូច្នេះថា មើល អញនឹងចិញ្ចឹមគេដោយស្លែង ហើយនឹងឱ្យ
គេផឹកទឹកពុល[ជ] ដ្បិតមានសេចក្តីល្មើស[ឈ]ចំពោះព្រះបាន
ចេញពីពួកហោរានៅក្រុងយេរូសាឡិមទៅពេញក្នុងស្រុក
ហើយ ។
១៦ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលដូច្នេះ
ថា កុំឱ្យស្តាប់តាម[ញ]ពាក្យរបស់ហោរា ដែលគេទាយប្រាប់

**២៣:៧** ធ យរ ៣០:៣ ន ចទ ១៥:៥ **២៣:៨** ប អស ១៤:១ ៤៣:៥–៦ យរ ៣០:១០ អគ ២០:៤២ ៣៤:១៣ អម ៩:១៤–១៥ **២៣:៩** ផ យរ ៤:១៩ ព យប ៤:១៤ ភ យរ ២០:៨–៩ **២៣:១០** ម យរ ៩:២ យ ចទ ២៨:២៣–២៤ រ ទដ ១០៧:៣៤ យរ ៩:១០ ល យរ ៤:២៦ ១២:១១ **២៣:១១** វ យរ ៦:១៣ ៨:១០ សផ ៣:៤ ស ២ពវ ២១:៤ យរ ៧:១០ **២៣:១២** ហ ចទ ៣២:៣៥ យប ៣:២៣ យរ ១៣:១៦ ឡ យរ ១១:២៣ **២៣:១៣** អ ១ពវ ១៨:២២ ក ខ.៣២ អស ៣:១២ អគ ១៣:១០ **២៣:១៤** ខ យរ ៥:៣០ ហស ៦:១០ គ យរ ២៩:២៣ ឃ ខ.២២ ង អស ៥:១៨ ច លប ១៨:២០ មថ ១១:២៤ ឆ យរ ២០:១៦ អម ៤:១០ **២៣:១៥** ជ យរ ៨:១៤ ៩:១៥ ឈ យរ ៨:១០ **២៣:១៦** ញ យរ ២៧:៩–១០,១៤ មថ ៧:១៥

**២៣:៧–៨** នៅខគម្ពីរទាំងនេះបាននិយាយឡើងវិញនៅក្នុង ១៦:១៤–១៥ (សូមមើលការពន្យល់នៅត្រង់ចំណុចនោះ) ។
**២៣:៩–៤០** នៅខគម្ពីរទាំងនេះបានចង្អុរបង្ហាញពីហោរាក្លែងក្លាយជាច្រើន (សូមមើល ២:៨ ៤:៩ ៥:៣០–៣១ ៦:១៣–១៥ ៨:១០–១២ ១៤:១៣–១៥ ១៨:១៨–២៣ ២៦:៨,១១,១៦,២៧–២៨ អស ២៨:៧–១៣ អគ ១៣ មីក ៣:៥៩ ។ *ពីដំណើរ* មានបង្ហាញនៅ ក្នុង ៤៦:២ ៤៨:១ ៤៩:១,៧,២៣, ២៨ ។
ព្រះបន្ទូលដ៏*សុចរិតរបស់ទ្រង់* គឺមានភាពខុសគ្នានឹងពាក្យភូតភររបស់ហោរាក្លែងក្លាយទាំងនោះ (សូមមើល ខ. ១៦–១៨) ។
២៣:១០ សូមមើល អស ២៤:៤–៦ ។ *មនុស្សដែលប្រព្រឹត្តកំផិត* សូមមើល ៥:៧–៨ ៩:២ និងការពន្យល់ ។ *សេចក្តីបណ្តាសា គឺជាលទ្ធផល* នៃការប្រព្រឹត្តល្មើសខុសចំពោះសេចក្តីសញ្ញារបស់ព្រះអម្ចាស់ (សូមមើល ១១:៣ នឹងកាពន្យល់ ១១:៨) ។ ទីរហោស្ថាន*... បានហួតហែង សូមមើល* ១២:៤ និងការពន្យល់ ។ ចំពោះការថ្វាយបង្គំដល់ព្រះដទៃ ជាការបដិសេធមិនយល់ព្រមចូលទៅក្នុងសេចក្តីសន្យា ជាទីកន្លែងសំបូរទៅដោយភោគផលដ៏បរិបូរ ដែលព្រះអម្ចាស់នាំមក (សូមមើល ហស ២:៥–៨,២១–២២ អម ៤:៤–៩) ។ *ទីឃ្វាលសត្វនៅទីរហោស្ថាន* សូមមើលការពន្យល់នៅក្នុង ៩:១០ ។ *សេចក្តីអាក្រក់* សេចក្តីអាក្រក់មិនមែនកើតមកពីព្រះ គឺដោយព្រោះតែការប្រព្រឹត្តរបស់ពួកគេផ្ទាល់ (សូមមើល ៨:៦) ។
**២៣:១១** *អំពើអាក្រក់របស់គេ នៅក្នុងព្រះវិហាររបស់អញ* សូមមើល ឧទាហរណ៍ ៣២:៣៤ ២ពវ ១៦:១០–១៤ ២១:៥ អគ ៨:៥,១០,១៤,១៦ ។
**២៣:១២** *ផ្លូវរបស់គេនឹងបានដូចជា កន្លែងរលាក់នៅទីងងឹត* សូមមើល ទដ ៣៥:៥–៦ សូមមើល ទដ ៧៣:១៨ ។
**២៣:១៣** *គេទាយទំនាយដោយសារព្រះបាល* សូមមើល ២:៨ និងការពន្យល់ និងមើល ១ពវ ១៨:១៩–៤០ ។
**២៣:១៤** *គេ . . . ដើរតាមតែសេចក្តីកំភូត* មើល ១៤:១៣ និងការពន្យល់ផ្ទៀបនឹង ១យហ ១:៦ ។ *កំលាំងដៃនៃ* នៅក្នុងព្រះគម្ពីរភាសាហេព្រើរជាមូលដ្ឋាន ឃ្លានេះ គឺប្រែថា "លើកទឹកចិត្ត" នៅក្នុង អគ ១៣:២២ ។ *គ្មានអ្នកណាមួយ វិលត្រឡប់ពីអំពើអាក្រក់របស់ខ្លួនឡើយ* សូមមើល អគ ១៣:២២ ។ *ដូចជាក្រុងសូដុំម . . . ក៏ដូចជាក្រុងកូម៉ូរ៉ា* សូមមើលការពន្យល់ ២០:១៦ ។
**២៣:១៥** *អញនឹង . . . ផឹកថ្នាំពុល* នៅត្រង់ឃ្លានេះបាននិយាយឡើងវិញនៅក្នុង ៩:១៥ (សូមមើលការពន្យល់នៅទីនោះ) ។ *សេចក្តីល្មើសចំពោះព្រះ* សូមមើល ខ.១១ ។
**២៣:១៦** *សំដែង គឺជា "ការបើកសម្តែង"* ឬ "សេចក្តីទំនាយ" (សូមមើល ១សយ ៣:១ សភ ២៩:១៨ ១សយ ១:១ អប ១ និងការពន្យល់) ។ *គេនឹក*

ឯងរាល់គ្នាឱ្យសោះ គេនាំឯងរាល់គ្នាឱ្យវង្វេងទេ គេ
សំដែងចេញតែពីការដែលគេនឹកឃើញ[ដ]ក្នុងចិត្តខ្លួនគេ មិន
មែនជាសេចក្ដីដែលចេញពីព្រះឱស្ឋ[ឋ]នៃព្រះយេហូវ៉ាឡើយ
១៧ គេចេះតែប្រាប់[ឌ]ដល់ពួកអ្នកដែលមើលងាយអញថា ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ឯងរាល់គ្នានឹងមានសន្តិសុខ
ទេ[ឍ] ហើយក៏ប្រាប់ដល់ពួកអ្នកដែលប្រព្រឹត្តតាមតែសេចក្ដី
រឹងចចេស[ណ]នៅក្នុងចិត្តថា និងគ្មានសេចក្ដីអាក្រក់[ត]ណា
កើតដល់ឯងរាល់គ្នាឡើយ ១៨ ដ្បិតតើអ្នកណាបានឈរក្នុង
ពួកប្រឹក្សា[ថ]នៃព្រះយេហូវ៉ា ឱ្យបានឃើញ ហើយឮព្រះ
បន្ទូលរបស់ទ្រង់ តើអ្នកណាបានប្រុងស្ដាប់ ហើយឮព្រះ
បន្ទូលនៃទ្រង់ ១៩ មើល ព្យុះសង្ឃរា[ទ]របស់ព្រះយេហូវ៉ា
គឺជាសេចក្ដីក្រោធរបស់ទ្រង់ បានចេញទៅហើយ អើ ជា
ព្យុះក្តួច[ធ]ដែលនឹងធ្លាយមក លើក្បាលរបស់ពួកមនុស្ស
អាក្រក់ ២០ សេចក្ដីខ្ញាល់[ន]របស់ព្រះយេហូវ៉ានឹងមិនវិលទៅ
វិញ[ប] ទាល់តែទ្រង់បានធ្វើសំរេច ហើយបានបង្ហើយតាម
បំណងព្រះហឫទ័យទ្រង់ ឯជាន់ក្រោយ នោះឯងរាល់គ្នានឹង
យល់ច្បាស់ ២១ អញមិនបានចាត់[ផ]ប្រើពួកហោរាទាំងនេះទេ
គង់ តែគេបានរត់ទៅ អញមិនបាននិយាយនឹងគេសោះ គង់
តែគេបានទាយ ២២ ប៉ុន្តែបើគេបានគ្រាន់តែឈរនៅក្នុង
ពួកប្រឹក្សារបស់អញ[ព] នោះគេនឹងបានប្រាប់[ភ]ឱ្យរាស្ត្រអញ
ស្ដាប់ពាក្យរបស់អញហើយ ព្រមទាំងបំបែរ[ម]គេចេញពីផ្លូវ
អាក្រក់ និងពីអំពើដ៏លាមកដែលប្រព្រឹត្តរៀងខ្លួនផង[យ]។
២៣ ព្រះយេហូវ៉ាទ្រង់មានបន្ទូលសួរថា តើអញជាព្រះ
ដែលនៅឆ្ងាយ ឥតនៅជិតបង្កើយផងដែរឬអី[រ] ២៤ ព្រះ
យេហូវ៉ាទ្រង់សួរដូច្នេះទៀតថា តើមានអ្នកណានឹងពួនខ្លួន[ល]
នៅទីសំងាត់ឯណា ឱ្យអញមើលមិនឃើញបានឬ តើអញ
មិននៅពេញស្ថានសួគ៌ និងផែនដីផងទេឬអី នេះជាព្រះ
បន្ទូលនៃព្រះយេហូវ៉ា[វ] ២៥ អញបានឮសេចក្ដីដែលពួក
ហោរាប្រាប់ ជាពួកអ្នកដែលទាយកុហក[ស] ដោយនូវឈ្មោះ
អញថា ខ្ញុំបានយល់សប្តិឃើញ[ហ]ដូច្នេះមួយៗ ២៦ សេចក្ដី
យ៉ាងនេះនឹងនៅក្នុងចិត្តនៃពួកហោរាដែលទាយកុហក ជា
ពួកអ្នកដែលបញ្ឆោតតាមសេចក្ដី[ឡ]នៅក្នុងចិត្តខ្លួនគេ តើ
ដល់កាលណាទៀត[អ] ២៧ គេពិតតែបណ្ដាលឱ្យរាស្ត្រអញ
ភ្លេច[ក]ឈ្មោះអញ ដោយការយល់សប្តិរបស់គេ ដែលថ្លែង
ប្រាប់ដល់អ្នកជិតខាងគេរៀងខ្លួន ដូចជាពួកឰយុកោគេបាន

**២៣:១៦** ដ យរ ១៤:១៤ អគ ១៣:៣ ឋ យរ ៩:២០ **២៣:១៧** ឌ ខ.៣១ ឍ ១ពវ ២២:៨ យរ ៤:១០ ណ យរ ១៣:១០ ត យរ ៥:១២ អម ៩:១០ មីក ៣:១១ **២៣:១៨** ថ ១ពវ ២២:១៩ រម ១១:៣៤ **២៣:១៩** ទ យរ ៣០:៣០ យរ ២៥:៣២ ៣០:២៣ ធ សក ៧:១៤ **២៣:២០** ន ២ពវ ២៣:២៦ ប យរ ៤:២៨ **២៣:២១** ផ យរ ១៤:១៤ ២៧:១៥ **២៣:២២** ព ១ពវ ២២:១៩ ភ ចទ ៣៣:១០ ម ២ពវ ១៧:១៣ យរ ២៥:៥

សក ១:៤ យ ខ.១៤អម ៣:៧ **២៣:២៣** រ ទដ ១៣៩:១–១០ **២៣:២៤** ល លប ៣:៨ យប ១១:២០ ២២:១២–១៤ សស ១២:១៤ អស ២៨:១៥ ១កថ ៤:៥ វ ១ពវ ៨:២៧ **២៣:២៥** ស ខ.១៦ យរ ១៤:១៤ ២៧:១០ ហ ខ.២៨, ៣២ ចទ ១៣:១ យរ ២៧:៩ ២៩:៨ **២៣:២៦** ឡ អស ៣០:១០ ១ធថ ៤:១–២ អ យរ ១៤:១៤ អគ ១៣:២ **២៣:២៧** ក ចទ ១៣:១–៣ យរ ២៩:៨

*ឃើញក្នុងចិត្តខ្លួនគេ* សូមមើល ខ.២៦ ១៤:១៤ ។ ពួកហោរាក្លែងក្លាយគឺដូចជាអ្នកអធិប្បាយ "ខុសពីដំណឹងល្អ" (សូមមើល កទ ១:៦–៩) ។

**២៣:១៧** *ឯងរាល់គ្នានឹងមានសន្តិសុខ* វាជាពាក្យសំដីរបស់ហោរាក្លែងក្លាយទាំងឡាយ(សូមមើល ៦:១៤ និងការពន្យល់ ៨:១១ ១៤:១៣ ហើយនិងការពន្យល់ ធៀបនិង ២៨:៨–៩) ។ *សេចក្តីរឹងចចេសនៅក្នុងចិត្ត* សូមមើលការពន្យល់នៅក្នុង ៣:១៧ ។

**២៣:១៨** *ពួកប្រឹក្សានៃព្រះយេហូវ៉ា* ជាមនុស្សសំណព្វរបស់ព្រះនៃស្ថានសួគ៌ (សូមមើល ខ.២២ យប ១៥:៧–១០ និងការពន្យល់ សូមមើល ១ពវ ២២:១៩–២២ យប ១:៦ ២:១ ២៩:៤ និងការពន្យល់ ទដ ៨៩:៧) ។ នៅក្នុង អម ៣:៧ នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរមានន័យថា "ប្រឹក្សា" ហើយពាក្យនេះប្រែមកដូច្នេះ "ផែនការណ៍" ជាបំណងព្រះហឫទ័យរបស់ព្រះដែលទ្រង់បានសន្យា ដើម្បីបង្ហាញឱ្យឃើញច្បាស់ពីការជ្រើសរើសអ្នកបម្រើរបស់ទ្រង់(សូមមើល ខ.២០) ។

**២៣:១៩–២០** ខទាំងនេះបាននិយាយម្តងទៀត នៅក្នុង ៣០:២៣–២៤ ។

**២៣:១៩** *ព្យុះសង្ឃរា . . . ព្យុះក្តួច* គឺជារូបភាពបង្ហាញពីសេចក្តីក្រោធរបស់ព្រះ ។

**២៣:២០** *នោះឯងរាល់គ្នានឹងយល់ច្បាស់* មិនដូចជាហោរាក្លែងក្លាយទាំងឡាយ ដែលបានបន្តនាំពួកគេឱ្យប្រព្រឹត្តខុស គឺជាព្រឹត្តិការណ៍នៅក្នុងស្រុកបាប៊ីឡូនបន្ទាប់ពីត្រូវបាននិរទេសនៃឆ្នាំ ៥៩៧ មុន គ.ស (សូមមើល ២៩:២០–២៣) ។

**២៣:២១** *អញមិនបានចាត់* សូមមើល ខ.៣២ ២៩:៩ ខុសពី ១:៧ អស ៦:៨ អគ ៣:៥ ។ *អញមិនបាននិយាយនឹងគេសោះ* សូមមើល ២៩:២៣ ។

**២៣:២២** *ពួកប្រឹក្សារបស់អញ* សូមមើលការពន្យល់ ខ.១៨ ។

**២៣:២៣** *ព្រះដែលនៅឆ្ងាយ ឥតនៅជិត* ទ្រង់គឺជាព្រះដែលគង់នៅអស់កល្បជានិច្ច និងមិនដែលរលំឡើយ ។ ទ្រង់គង់នៅ "*ស្ថានដ៏ខ្ពស់ ហើយបរិសុទ្ធ ក៏នៅជាមួយអ្នកណាដែលមានចិត្តសង្រេង ហើយទន់ទាប*" (អស ៥៧:១៥) ។

**២៣:២៤** *ពួនខ្លួន . . . ឱ្យអញមើលមិនឃើញ* សូមមើល យប ២៦:៦ ទដ ១៣៩:៧–១២ អម ៩:២–៤ ។ *តើអញមិនបាននៅពេញស្ថានសួគ៌ នឹងផែនដីទេឬអី* សូមមើល អស ៦៦:១ ។

**២៣:២៥** *កុហក* សូមមើល ៥:១២ ។ *ដោយនូវឈ្មោះអញថា* សូមមើល ចទ ១៨:២០,២២ ។ *យល់សប្តិ នេះគឺជាវិធីដ៏ល្អឥតខ្ចោះក្នុងការបើកសម្តែងពីសេចក្តីពិតរបស់ពួកហោរា* សូមមើល ២៧:៩ ចទ ១៣:១–៣ ១សយ ២៨:៦ សក ១០:២ តែធៀបនឹង ជន ១២:៦ យអ ២:២៨) ។

**២៣:២៦** *នៅក្នុងចិត្ត . . . នៅក្នុងចិត្ត* នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរ ព្រះបន្ទូលទាំងពីរឃ្លានេះគឺដូចគ្នា(សូមមើលការពន្យល់ ទដ ៤:៧) ។ *នៅក្នុងចិត្តខ្លួនគេ* សូមមើលការពន្យល់ ខ.១៦ ។

**២៣:២៧** *ឈ្មោះអញ* ចំពោះការភ្លេចឈ្មោះរបស់អញ គឺដូចគ្នានឹងការបំភ្លេចដល់ទ្រង់ដែរ(សូមមើល ទដ ៥:១១) ។ *បានភ្លេច . . . ឈ្មោះព្រះបាលវិញដែរ* នៅពេលដែលឰយុកោរនៃសាសន៍យូដាបានភ្លេចព្រះ គឺពួកគេបានចាប់ផ្តើមបម្រើដល់ព្រះបាលវិញ (សូមមើល ពច ៣:៧ ១សយ ១២:៩–១០) ។ *បានភ្លេច* សូមមើល ទដ ៩:១៩ និងការពន្យល់ ។

ភ្លេច[ខ]ឈ្មោះអញ ឱ្យយកឈ្មោះព្រះបាលវិញដែរ[គ] ២៨ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា ឯហោរាណាដែលយល់សប្តិ[ឃ]
ឱ្យគេប្រាប់តាមសប្តិនោះចុះ ហើយហោរាណាដែលបាន
ទទួលពាក្យ[ង]អញ ត្រូវឱ្យអ្នកនោះប្រាប់ពាក្យអញ ដោយ
ស្មោះត្រង់ទៅ តើចំបើងជាអ្វីចំពោះស្រូវ ២៩ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលសួរថា ឯពាក្យរបស់អញ តើមិនមែនដូច
ជាភ្លើង[ច] ហើយដូចជាញញួរ[ឆ] ដែលបំបែកថ្មខ្ទេចខ្ទីទេឬអី
៣០ហេតុនោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញ
ទាស់នឹង[ជ]ពួកហោរា[ឈ] ដែលលួចពាក្យអញចេញពីគ្នាទៅ
វិញទៅមក ៣១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញ
ទាស់នឹងពួកហោរាដែលប្រើអណ្តាតនិយាយថា ព្រះអង្គ
មានបន្ទូល[ញ] ៣២ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញ
ទាស់នឹងពួកអ្នកដែលទាយកុហកតាមយល់សប្តិ[ដ] ព្រមទាំង
ផ្សាយប្រាប់សប្តិនោះ ហើយនាំឱ្យរាស្ត្រអញវង្វេងចេញ[ឋ]
ដោយសារសេចក្តីកំភូតរបស់គេ[ឌ] ហើយដោយសារសេចក្តី
អំនួតឥតប្រយោជន៍របស់គេដែរ តែព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា អញមិនបានចាត់[ឍ]គេ ឬបង្គាប់គេឡើយ គេក៏
គ្មានប្រយោជន៍[ណ]អ្វីដល់ជនជាតិនេះដែរ ។

## បទទំនាយក្លែងក្លាយ និងហោរាក្លែងក្លាយ

៣៣កាលណាជនជាតិនេះ ឬហោរាណា ឬសង្ឃណា
នឹងសួរឯងថា ឯបន្ទុក[ត]ពីព្រះយេហូវ៉ា តើថាយ៉ាងណា
នោះឯងត្រូវឆ្លើយតបថា តើបន្ទុកណានោះ ឯព្រះបន្ទូល
របស់ព្រះយេហូវ៉ា នោះគឺថា អញនឹងបោះបង់ចោល[ថ]ឯង
រាល់គ្នាចេញ ៣៤ឯហោរាណា សង្ឃណា ឬជនជាតិណា
ដែលពោលថា នេះជាបន្ទុក[ទ]ពីព្រះយេហូវ៉ាហើយ អញ
នឹងធ្វើទោស[ធ]ដល់អ្នកនោះ ព្រមទាំងពួកវង្សគេផង ៣៥ឯង
រាល់គ្នាត្រូវសួរអ្នកជិតខាង ហើយនឹងបងប្អូនឯងរៀងខ្លួន
ដូច្នេះវិញថា តើព្រះយេហូវ៉ាទ្រង់បានឆ្លើយយ៉ាងដូចម្តេច[ន]
ហើយថា តើព្រះយេហូវ៉ាបានមានបន្ទូលយ៉ាងណា ៣៦មិន
ត្រូវឱ្យឯងរាល់គ្នានិយាយ ពីបន្ទុករបស់ព្រះយេហូវ៉ាទៀត
ឡើយ ឯបន្ទុករបស់ឯងរាល់គ្នា នោះគឺជាពាក្យរបស់
គ្រប់គ្នាវិញ ពីព្រោះឯងរាល់គ្នា បានបំផ្លាស់បំប្រែ[ប]ព្រះ
បន្ទូលនៃព្រះដ៏មានព្រះជន្មរស់[ផ] គឺព្រះយេហូវ៉ានៃពួកពល
បរិវារ ជាព្រះនៃយើងរាល់គ្នាឱ្យខុសទៅហើយ ៣៧ត្រូវឱ្យ
ឯងសួរហោរាយ៉ាងដូច្នេះថា តើព្រះយេហូវ៉ាបានឆ្លើយ
នឹងអ្នកយ៉ាង ដូចម្តេច ហើយថា តើព្រះយេហូវ៉ាបានមាន
បន្ទូលយ៉ាងណាខ្លះនោះវិញ ៣៨ប៉ុន្តែបើឯងរាល់គ្នាហ៊ាន
និយាយថា នេះជាបន្ទុករបស់ព្រះយេហូវ៉ាហើយ នោះព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះឯងរាល់គ្នា
ចេញពាក្យនេះគឺ "បន្ទុករបស់ព្រះយេហូវ៉ា" ហើយអញ
បានចាត់គេឱ្យមកឯងហាមថា កុំឱ្យនិយាយពីបន្ទុកព្រះ
យេហូវ៉ាឡើយ ៣៩ដូច្នេះមើល អញនឹងភ្លេចឯងរាល់គ្នាអស់
រលីង ហើយនឹងបោះបង់ចោល[ព]ឯងរាល់គ្នាឆ្ងាយពីមុខ
អញទៅ ព្រមទាំងទីក្រុងដែលអញបានឱ្យដល់ឯង និងពួក
ឰយុកោឯងផង ៤០រួចអញនឹងនាំសេចក្តីដំនៀលដ៏នៅ
ជាប់អស់កល្ប មកលើឯងរាល់គ្នា ព្រមទាំងសេចក្តីខ្មាស[ភ]ដ៏
នៅជាប់ជានិច្ចដែលនឹងភ្លេចមិនបានឡើយផង ។

**២៣:២៧** ខ ពច ៣:៧ ៨:៣៣–៣៤ គ យរ ២:២៣ **២៣:២៨** ឃ ខ.២៥ ង ១សយ ៣:១៧ **២៣:២៩** ច ទដ ៣៩:៣ យរ ៥:១៤ ១កថ ៣:១៣ ឆ ហព ៤:១២ **២៣:៣០** ជ ទដ ៣៤:១៦ ឈ ខ.២ ចទ ១៨:២០ យរ ១៤:១៥ ២១:១៣ **២៣:៣១** ញ ខ.១៧ **២៣:៣២** ដ ខ.២៥ ឋ ខ.១៣ យរ ៥០:៦ ឌ យប ១៣:៤ អគ ១៣:៣ ២២:២៨ ឍ យរ ១៤:១៤ ណ យរ ៧:៨ បទ ២:១៤ **២៣:៣៣** ត មឡ ១:១ ថ ២ពវ ២១:១៤ **២៣:៣៤** ទ បទ ២:១៤ ធ សក ១៣:៣ **២៣:៣៥** ន យរ ៣៣:៣ ៤២:៤ **២៣:៣៦** ប កទ ១:៧–៨ ២ពត ៣:១៦ ផ យស ៣:១០ **២៣:៣៩** ព យរ ៧:១៥ **២៣:៤០** ភ យរ ២០:១១ អគ ៥:១៤–១៥

**២៣:២៨–២៩** *ព្រះបន្ទូលដ៏ពិតរបស់ព្រះ* គឺមាននិមិត្តរូបបី នៅក្នុងពាក្យប្រៀបធៀប(ស្រូវ,ភ្លើង,ញញួរ) ។
**២៣:២៨** *ដូចជាភ្លើង* សូមមើលការពន្យល់ ២០:៩ ។ ភ្លើងគឺជាព្រះបន្ទូលដ៏មានសារៈសំខាន់សម្រាប់គ្រាចុងក្រោយដើម្បីនឹងសាកល្បង "សាកមើលការដែលនិមួយៗធ្វើ" (១កថ ៣:១៣ សូមមើលការពន្យល់នៅទីនោះ) ។ *ដូចជាញញួរ* ជាព្រះបន្ទូលដ៏ល្អឥតខ្ចោះ ប្រៀបដូចជាដាវនិងញញួរដើម្បីនឹងជំនុំជម្រះដោយឥតមេត្តា គ្រប់ការដែលគេបានប្រព្រឹត្ត "*ទាំងពិចារណាអស់ទាំងគំនិត ដែលចិត្តគិត*" (ហព ៤:១២ មើលការពន្យល់នៅទីនោះ) ។
**២៣:៣០–៣២** *អញទាស់នឹង* មានការថ្លែងទំនាយបីដងដែលជាការបញ្ជាក់(សូមមើល ការពន្យល់ ២២:២៩) ។
**២៣:៣១** *ពួកហោរាដែល...ព្រះអង្គមានបន្ទូល* ពួកហោរាក្លែងក្លាយទាំងនោះបានប្រកាសថា ខ្លួនគេបានទាយទំនាយរបស់ព្រះជាច្រើន ។ នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរចំពោះពាក្យទាំងនេះ គឺបានប្រើតែម្តងគត់នៅទីនេះ ជាមួយអ្នកណាម្នាក់ ឬអ្នកដទៃ ជាងព្រះដូចជាប្រធាន ។ នៅត្រង់ឃ្លានេះ "ព្រះអង្គមានព្រះបន្ទូលពីព្រះយេហូវ៉ា" ឬ វាមានន័យស្មើនឹងការដែលកើតឡើងរាប់រយឆ្នាំនៅគ្រាព្រះគម្ពីរសញ្ញាចាស់ ដែលបាននិយាយជាញឹកញាប់នៅក្នុងកណ្ឌព្រះគម្ពីរយេរេមា(ក្នុងអំឡុងឆ្នាំ១៧៥ នៅយុគសម័យមុន) ជាងព្រះគម្ពីរផ្សេងដទៃទៀត ។
**២៣:៣២** *អញមិនបានចាត់គេ* សូមមើល ខ.២១ និងការពន្យល់ ។
**២៣:៣៣** *បន្ទុក* នៅក្នុងព្រះគម្ពីរជាភាសារហេព្រើរពាក្យនេះ អាចមានន័យថា "បន្ទុក" ផងដែរ ដែលជាការសម្តែងចេញនូវសេចក្តីទំនាយយ៉ាងធ្ងន់មកអំពីព្រះយេហូវ៉ា (សូមមើល ឧទាហរណ៍ ណាហ ១:១) ។
**២៣:៣៦** មានបីចំណុចសំខាន់ នៅចុងបញ្ចប់នៃខគម្ពីរនេះ បានប្រកាសឡើងជាឧឡារិក នូវអ្វីដែលទ្រង់មានបន្ទូល ។ *ព្រះដ៏មានព្រះជន្មរស់* សូមមើល ១០:១០ ចទ ៥:៦ ។
**២៣:៣៩** *នឹងភ្លេច* នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរចំពោះពាក្យនេះ គឺជាការលេងពាក្យ ដែលមានន័យថា "បន្ទុក" មើលនៅក្នុង ខ.៣៣–៣៤, ៣៦,៣៨ ដោយសារលោកហោរាយេរេមាបានកត់ត្រាចំណាំ នូវព្រះបន្ទូលរបស់ទ្រង់នៃការជំនុំជម្រះ ។ *ទីក្រុង* គឺនិយាយពីទីក្រុងយេរូសាឡិម ។
**២៣:៤០** ត្រូវបានផ្សព្វផ្សាយឱ្យដឹង នៅក្នុង ២០:១១ ។

## ផ្លែល្វាទាំងពីរល្អី

**២៤** ១ ព្រះយេហូវ៉ា ទ្រង់បង្ហាញ ឱ្យខ្ញុំឃើញផ្លែល្វា២ល្អី
ដាក់នៅមុខព្រះវិហារនៃព្រះយេហូវ៉ា ក្នុងពេលក្រោយ
ដែលនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ទ្រង់បានចាប់យេកូនាស
ជាបុត្រយេហូវយ៉ាគីម[ក] ស្តេចយូដា នាំទៅជាឈ្លើយ ព្រម
ទាំងពួកចៅហ្វាយនៃស្រុកយូដា និងពួករចនា ហើយពួក
ជាង ដឹកចេញពីក្រុងយេរូសាឡិម ទៅដល់ស្រុកបាប៊ីឡូន
ផង ២ ល្អី១មានផ្លែល្វា[ខ]យ៉ាងល្អណាស់ ដូចជាផ្លែល្វាដែលទុំ
មុនគេ[គ] ឯល្អី១ទៀតមានផ្លែល្វាអាក្រក់[ឃ]ណាស់ ដែលនឹង
បរិភោគមិនបាន ដោយព្រោះអាក្រក់ក្រៃពេក ៣ នោះព្រះ
យេហូវ៉ាទ្រង់មានបន្ទូលសួរខ្ញុំថា យេរេមាអើយ ឯងឃើញ
អ្វីនុ៎ះ[ង] ខ្ញុំក៏ទូលឆ្លើយថា ឃើញផ្លែល្វា ឯផ្លែល្អ នោះល្អ
ណាស់ ហើយផ្លែអាក្រក់ ក៏អាក្រក់ណាស់ដែរ និងបរិភោគ
មិនបាន ពីព្រោះអាក្រក់ក្រៃពេក ។
៤ នោះព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា ៥ ព្រះ
យេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូល
ដូច្នេះថា ដូចជាឯងបានស្គាល់ផ្លែល្វាល្អនេះ អញក៏នឹង
ស្គាល់ពួកយូដា ដែលត្រូវគេដឹកនាំទៅជាឈ្លើយនោះដែរ
ដើម្បីនឹងប្រោសឱ្យគេបានសេចក្តីល្អ គឺជាពួកអ្នកដែល
អញបានបណ្តោយចេញ[ច]ពីទីនេះ ទៅដល់ស្រុកខាល់ដេ
ហើយ ៦ ដ្បិតអញនឹងតាំងភ្នែកមើលតាមគេ ឱ្យបាន
សេចក្តីល្អ ហើយនឹងនាំគេមក[ឆ]ក្នុងស្រុកនេះវិញ អញនឹង
ស្អាងគេឡើង[ជ] មិនរុះវិញឡើយ ក៏នឹងដាំ[ឈ]គេចុះ ឥតរំលើង
ចេញដែរ ៧ អញនឹងឱ្យគេមានចិត្តដែលស្គាល់[ញ]អញថា ជា
ព្រះយេហូវ៉ា នោះគេនឹងបានជារាស្ត្ររបស់អញ[ដ] ហើយ
អញនឹងធ្វើជាព្រះរបស់គេ ពីព្រោះគេនឹងវិលមក[ឋ]ឯអញ
ដោយអស់ពីចិត្ត[ឌ] ។
៨ ឯផ្លែល្វាអាក្រក់[ឍ] ដែលនឹងបរិភោគមិនបាន ដោយ
ព្រោះអាក្រក់ក្រៃពេក នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលជា
ប្រាកដថា អញនឹងឱ្យសេដេគា[ណ] ជាស្តេចយូដា បានយ៉ាង
ដូច្នោះដែរ ព្រមទាំងពួកចៅហ្វាយ[ត]នឹងសំណល់មនុស្ស[ថ]
នៅក្រុងយេរូសាឡិម ដែលសល់នៅក្នុងស្រុកនេះ ហើយ
និងពួកដែលនៅស្រុកអេស៊ីព្ទផង[ទ] ៩ អញនឹងប្រគល់គេទៅឱ្យ

**២៤:១** ក ២ពវ ២៤:១៦ ២របា ៣៦:៩ **២៤:២** ខ នក ២៣:១៩ ចទ ២៦:២ អម ៨:១-២ គ សស ២:១៣ ឃ អស ៥:៤ **២៤:៣** ង យរ ១:១១ អម ៨:២ **២៤:៥** ច យរ ២៩:៤,២០ **២៤:៦** ឆ ចទ ៣០:៣ យរ ២៧:២២ ២៩:១០ ៣០:៣ អគ ១១:១៧ ជ យរ ៣៣:៧ ៤២:១០ ឈ ចទ ៣០:៩ យរ ១:១០ អម ៩:១៤-១៥ **២៤:៧** ញ អស ១១:៩ ដ ល ២៦:១២ អម ៥១:១៦ សក ២:១១ ហព ៨:១០ ឋ យរ ៣២:៤០

ឌ ២របា ៦:៣៧ អគ ១១:១៩ **២៤:៨** ឍ យរ ២៩:១៧ ណ យរ ៣២:៤-៥ ៣៨:១៨,២៣ ៣៩:៥ ៤៤:៣០ ត យរ ៣៩:៦ ថ យរ ៣៩:៩ ទ យរ ៤៤:១,២៦ ៤៦:១៤

**២៤:១-១០** សូមមើល អម ៨:១-៣ ។ គឺជាការប្រកាសយ៉ាងឧឡារិកអំពីអ្នកដឹកនាំទាំងឡាយនៃសាសន៍យូដា (២១-២៣:៨)និងហោរាក្លែងក្លាយជាច្រើន(២៣:៩-៤០) ហើយឥឡូវនេះហោរាយេរេមាបាននិយាយរៀបរាប់ពីការញែក ប្រជារាស្ត្រសាសន៍យូដាទៅក្នុងសេចក្តីល្អ និងសេចក្តីអាក្រក់(២៤:១-៣) ហើយនិងសេចក្តីសង្ខេបពីការសម្រេចព្រះហឫទ័យនៃព្រះអម្ចាស់ ដើម្បីសង់សេចក្តីល្អឡើងវិញ (ខ.៤-៧) ប៉ុន្តែទ្រង់បំផ្លាញសេចក្តីអាក្រក់ចោលចេញ (ខ.៨-១០) ។

**២៤:១** *យេហូយ៉ាគីម...នាំទៅជាឈ្លើយ ព្រមទាំងពួកចៅហ្វាយ* នៅក្នុងឆ្នាំ៥៩៧ មុន គ.ស ។ *ពួករចនា និងពួកជាង* សូមមើល ២៩:២ ២ពវ ២៤:១៤,១៦ គឺជាមុខរបរសម្រាប់ប្រជាជនអ្នកក្រ និងអ្នកខ្សត់ខ្សោយតែប៉ុណ្ណោះ ដែលជាការដើរថយក្រោយនៅក្នុងសាសន៍យូដា(សូមមើល ២ពវ ២៤:១៤ ឆ្នាំ"៥៨៦" គឺជាយុគសម័យចុងក្រោយ ធៀបនឹង យរ ៣៩:១០) ។ *ព្រះយេហូវ៉ា ទ្រង់បង្ហាញ ឱ្យខ្ញុំឃើញ* គឺព្រះយេហូវ៉ាទ្រង់បានបង្ហាញឱ្យពួកហោរាទាំងឡាយឃើញការជាក់ស្តែង(សូមមើល អម ៧:១,៤,៧ ។ *ផ្លែល្វា* សូមមើលការពន្យល់ ៨:១៣ ។ *ព្រះវិហារ* នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរគឺជាគ្រឹះមូលដ្ឋាន ហើយពាក្យនេះប្រែថា"ប្រជុំ"មើលក្នុង ឧទាហរណ៍ ២៩:៤២-៤៣ ។ គឺដូចដែលព្រះយេហូវ៉ាទ្រង់មានបំណងព្រះហឫទ័យ ដើម្បីឱ្យពួកអ៊ីស្រាអែលប្រជុំគ្នានៅត្រង់ច្រកទ្វារចូល ទៅកាន់ទីសក្ការបូជា ដូច្នេះផ្លែល្វាទាំងឡាយនោះជា(និមិត្តរូបតំណាងឱ្យប្រជាជននៃសាសន៍យូដា) ។ ដែលបម្រុងទុកសម្រាប់"បានប្រជុំគ្នា"ដោយសារទ្រង់គង់នៅពីមុខនៃព្រះវិហារយេរូសាឡិម ។

**២៤:២** *ផ្លែល្វាយ៉ាងល្អណាស់...ដែលទុំមុនគេ* ផ្លែល្វាទាំងនេះ ចាប់ផ្តើមផ្លែនៅដើមខែមិថុនា ជាពិសេសមានទឹកច្រើន និងមានរស់ជាតិឈ្ងុយឆ្ងាញ់ (សូមមើល អស ២៨:៤ ហស ៩:១០ មីក ៧:១ ណាហ ៣:១២) ។

**២៤:៣** *ឯងឃើញអ្វីនុ៎ះ* សូមមើលការពន្យល់ ១:១១ ។

**២៤:៥-៦** យុត្តិធម៌ត្រឹមត្រូវគឺដូចជា ផ្លែល្វាដ៏ល្អដែលគួរតែត្រូវបានការពារនិងថែរក្សាដោយពួកគេផ្ទាល់ ។ ដូច្នេះពួកគេត្រូវបាននិរទេសនៅឆ្នាំ ៥៩៧ មុន គ.ស ដែលជាការប្រសើរបំផុតរបស់អ្នកដឹកនាំ និងពួករចនានៃសាសន៍យូដា(សូមមើល ២ពវ ២៤:១៤-១៦)ជាការបម្រុងមើលនិងត្រូវបានថែរក្សាដោយព្រះអម្ចាស់(សូមមើល ២៩:៤-១៤) ។

**២៤:៦** *ដ្បិតអញនឹងតាំងភ្នែកមើលតាមគេ ឱ្យបានសេចក្តីល្អ* គឺខុសពីព្រះបន្ទូលនៃការជំនុំជម្រះ នៅក្នុង អម ៩:៤ ។ *នាំគេមកក្នុងស្រុកនេះវិញ* នៅក្នុងឆ្នាំ ៥៣៨-៥៣៧ មុន គ.ស ។ *អញនឹងស្អាងគេឡើង មិនរុះវិញឡើយ ក៏នឹងដាំគេចុះ* សូមមើល ១:១០ និងការពន្យល់ ។

**២៤:៧** *មានចិត្តដែលស្គាល់អញ គឺជាសេចក្តីទំនាយយ៉ាងឆាប់ និងរាប់ទាំងសេចក្តីសន្យាដែលដូចគ្នា* សូមមើល ៣១:៣១-៣៤ ។ *រាស្ត្ររបស់អញ...ជាព្រះរបស់ពួកគេ* គឺជារបៀបនៃការតាំងសញ្ញាក្នុងការទំនាក់ទំនង(សូមមើល ៣១:៣៣ ៣២:២៨ សូមមើលការពន្យល់ លប ១៧:៧ សក ៨:៨ ) ។ *គេនឹងវិលមកឯអញដោយអស់ពីចិត្ត* សូមមើល ២៩:១៣ ។

**២៤:៨** *នៅស្រុកអេស៊ីព្ទ* ប្រហែលពួកគេទាំងឡាយនោះបានត្រូវនិរទេសជាមួយស្តេចយ៉ូអាហាស នៅក្នុងឆ្នា៦០៩ មុន គ.ស(សូមមើល ១០ខ-១២ និងការពន្យល់ ២ពវ ២៣:៣១-៣៤) ហើយពួកទាំងនោះបានភៀសខ្លួនរត់ទៅកាន់អេស៊ីព្ទ ក្រោយពីពួកសាសន៍បាប៊ីឡូនបានចម្បាំងវាយឈ្នះពួកសាសន៍អេស៊ីព្ទ ក្នុងការតស៊ូប្រយុទ្ធនៅត្រង់ស្រុកកើកេមីស ក្បែរមាត់ទន្លេអឺប្រាត នៅក្នុងឆ្នាំ ៦០៥ មុន គ.ស(សូមមើល ៤៦:២) ។

**២៤:៩** *ត្រូវរសាត់អណ្តែត នៅកណ្តាលអស់ទាំងនគរនៅលើផែនដី* សូម

ត្រូវរសាត់អណ្តែត[ធ] នៅកណ្តាលអស់ទាំងនគរ នៅផែនដី
វិញឱ្យបានសេចក្តីអាក្រក់ ដើម្បីឱ្យគេបានជាទីដៀលត្មះ[ន] ជា
ពាក្យទំនៀម ជាទីអុចអាល ហើយជាទីផ្តាសា[ប] នៅគ្រប់
ទីកន្លែងណាដែលអញនឹងបណ្តេញទៅនោះ ១០អញនឹង
ចាត់ប្រើដាវ[ផ] និងសេចក្តីអំណត់អត់[ព] ហើយអាសន្នរោគ[ភ]ឱ្យ
នៅកណ្តាលពួកគេ ដរាបដល់គេសូន្យបាត់អស់រលីងពី
ស្រុកដែលអញបានឱ្យដល់គេ ហើយដល់ពួកឰយុកោគេ
ទៅ[ម] ។

## ការជាប់ជាឈ្លើយ៧០ឆ្នាំ

**២៥** ១នេះជាព្រះបន្ទូល ដែលមកពីព្រះយេហូវ៉ា ដល់
យេរេមា ពីដំណើរបណ្តាជន នៅស្រុកយូដាទាំងប៉ុន្មាន
ក្នុងឆ្នាំទី៤ នៃរាជ្យយេហូវ៉ាគីម[ក] ជាបុត្រយ៉ូសៀស ស្តេច
យូដា (ឆ្នាំនោះជាឆ្នាំដំបូង នៃរាជ្យនេប៊ូក្នេសា[ខ] ជាស្តេច
បាប៊ីឡូន) ២ជាសេចក្តីដែលហោរាយេរេមាបានប្រាប់ដល់
បណ្តាជននៅស្រុកយូដា[គ] និងពួកអ្នកនៅក្រុងយេរូសាឡិម
ទាំងអស់ថា ៣ចាប់តាំងពីឆ្នាំទី១៣ ក្នុងរាជ្យយ៉ូសៀស[ឃ]
ជាបុត្រអាំម៉ូន ស្តេចយូដា ដរាបដល់សព្វថ្ងៃនេះ គឺអស់
២៣ឆ្នាំនេះហើយ នោះព្រះបន្ទូលនៃព្រះយេហូវ៉ាបានមក
ដល់ខ្ញុំ ហើយខ្ញុំបានទាំងក្រោកពីព្រលឹមស្រាងប្រាប់ដល់
អ្នករាល់គ្នាផង[ង] តែអ្នករាល់គ្នាមិនបានស្តាប់តាមទេ[ច] ៤ឯ
ព្រះយេហូវ៉ាទ្រង់បានចាត់ពួកហោរា[ឆ]ទាំងប៉ុន្មាន ជាអ្នក
បំរើរបស់ទ្រង់ ឱ្យមកឯអ្នករាល់គ្នាដែរ គឺបានក្រោកពី
ព្រលឹមស្រាងនឹងចាត់គេផង តែអ្នករាល់គ្នាមិនបានស្តាប់
តាម ឬផ្ទៀងត្រចៀកនឹងស្តាប់សោះ[ជ] ៥ទ្រង់បានមាន
បន្ទូលថា ចូរឱ្យអ្នករាល់គ្នាវិលមក[ឈ]ពីផ្លូវអាក្រក់របស់ខ្លួន
ហើយពីអំពើអាក្រក់ដែលគ្រប់គ្នាប្រព្រឹត្តឥឡូវចុះ នោះឯង
រាល់គ្នានឹងបាននៅក្នុងស្រុក[ញ]ដែលព្រះយេហូវ៉ាបាន
ប្រទានដល់ឯង និងពួកឰយុកោឯង ចាប់តាំងពីបុរាណ
ហើយសំរាប់ជាដរាបតទៅ ៦កុំឱ្យទៅតាមព្រះដទៃ[ដ] ដើម្បី
នឹងគោរព ហើយថ្វាយបង្គំដល់វាឡើយ ក៏កុំឱ្យបណ្តាលឱ្យ
អញខឹង ដោយសារការដែលដៃឯងរាល់គ្នាធ្វើដែរ យ៉ាង
នោះអញនឹងមិនប្រទូស្តដល់ឯងរាល់គ្នាទេ ៧ប៉ុន្តែព្រះ
យេហូវ៉ា ទ្រង់មានបន្ទូលថា ឯងរាល់គ្នាមិនបានស្តាប់តាម
អញសោះ គឺជាការដែលនាំឱ្យអញខឹង[ឋ] ដោយសារការ
ដែលដៃឯងបានធ្វើវិញ[ឌ] ឱ្យអញបានប្រទូស្ត[ឍ]ដល់ឯង
៨ហេតុនោះព្រះយេហូវ៉ា នៃពួកពលបរិវារ ទ្រង់មាន
បន្ទូលដូច្នេះថា ដោយព្រោះឯងរាល់គ្នាមិនបានស្តាប់តាម
ពាក្យអញ ៩នោះមើល អញនឹងចាត់ទៅនាំយក[ណ]អស់ទាំង
ពួកគ្រួនៅស្រុកខាងជើង[ត] និងនេប៊ូក្នេសា[ថ] ស្តេចបាប៊ីឡូន

**២៤:៩** ធ យរ ១៥:៤ ២៥:១៨ ន ចទ ២៨:២៥ ១ពរ ៩:៧ ប ២ពរ ២២:១៩ យរ ២៩:១៨ ផ ចទ ២៨:៣៧ ដយ ៩:៧ **២៤:១០** ព អស ៥១:១៩ យរ ៩:១៦ វវ ៦:៨ ភ យរ ១៥:២ ម យរ ២៧:៨ យ ចទ ២៨:២១ **២៥:១** ក ២ពរ ២៣:២ ខ ២ពរ ២៤:១ **២៥:២** គ យរ ១៨:១១ **២៥:៣** ឃ ១រប ៣:១៤ ង យរ ១១:៧ ២៦:៥ ច អស ៦៥:១២ យរ ៧:២៦ **២៥:៤** ឆ យរ ៦:១៧ ៧:២៥ ២៩:១៩ ជ យរ ៧:២៦ ៣៤:១៤ ៤៤:៥ **២៥:៥** ឈ ពច ៦:៨ ២រប ៧:១៤ ៣០:៩ យរ ២៣:២២ ញ លប ១២:៧ ចទ ៤:៤០ **២៥:៦** ដ នក ២០:៣ ចទ ៨:១៩ **២៥:៧** ឋ យរ ៣០:១៤ ៣២:៣៥ ៤៤:៥ ឌ ចទ ៣២:២១ ឍ ២ពរ ១៧:២០ ២១:១៥ **២៥:៩** ណ អស ១៣:៣–៥ ត អស ១៤:៣១ ថ ២រប ៣៦:៦

មើល ៣៤:១៧ ។ *ជាទីដៀលត្មះ . . . ជាទីអុចអាល* មើល ចទ ២៨:៣៧ ។ *ជាពាក្យទំនៀម* សូមមើលការពន្យល់ ១ពរ ៩:៧ យប ១៧:៦ ។

**២៤:១០** *ដាវ និងសេចក្តីអំណត់ ហើយអាសន្នរោគ* មើលការពន្យល់ ១៤:១២ ។ *សូន្យបាត់អស់រលីងពីស្រុក* គឺនៅក្នុងឆ្នាំ ៥៨៦ មុន គ.ស (សូមមើល ៥២:៤–២៧) ។

**២៥:១–២៩:៣២** ជាការគ្រប់គ្រងរបស់អ្នកនិពន្ធ នៅក្នុងជំពូក ២៥–២៩ ដែលនឹងកើតឡើងនូវវិនាសកម្មនៃក្រុងយេរូសាឡិម និងរៀបរាប់ពីការនិរទេសទៅកាន់ស្រុកបាប៊ីឡូន នៅក្នុងឆ្នាំ ៥៨៥ មុន គ.ស (ការណែនាំសង្ខេបនៅក្នុង ២៤:១០) ។

**២៥:១–២៥** ព្រះអាទិករនឹងជំនុំជម្រះមិនមែនសម្រាប់តែពួកយូដាមួយប៉ុណ្ណោះឡើយ ប៉ុន្តែ"សម្រាប់មនុស្សគ្រប់អស់ទាំងសាសន៍" (ខ.៩) ដូចគ្នា (ធៀបនឹង ការពន្យល់ មីក ១:២) ។

**២៥:១** *ក្នុងឆ្នាំទីបួន នៃរាជ្យយេហូយ៉ាគីម . . . (ឆ្នាំនោះជាឆ្នាំដំបូង នៃរាជ្យនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន)* ហេតុការណ៍ដែលកើតឡើងដូចគ្នា គឺបានកំណត់កាលបច្ឆេទ ឆ្នាំ ៦០៥ មុន គ.ស (សូមមើលការពន្យល់ ដយ ១:១) ។

**២៥:៣** *២៣ ឆ្នាំ* អស់រយះពេលដប់ប្រាំបួនឆ្នាំ ដែលពួកគេនៅក្រោមការគ្រប់គ្រងរបស់ស្តេចយ៉ូសៀស និងស្តេចយេហូយ៉ាគីម សូមមើល ខ.១) ។ *ឆ្នាំទី១៣ ក្នុងរាជ្យយ៉ូសៀស* នៅឆ្នាំ ៦២៦ មុន គ.ស (ឬអាចកើតឡើងមុនឆ្នាំ ៦២៧) សូមមើល ១:២ ។ *ក្រោកពីព្រលឹមស្រាង* សូមមើល ខ.៤ សូមមើលការពន្យល់ ៧:១៣ ផងដែរ ។ *អ្នករាល់គ្នាមិនបានស្តាប់តាមទេ* ឥឡូវនេះគឺជាពាក់កណ្តាលដែលហោរាយេរេមាបានទាយទុកជាមុន នូវការងាររបស់គាត់ តាមរយះការព្រមាន នៅគ្រាដែលទ្រង់បានត្រាសហៅ ប្រជាជាតិយូដា តែគេបែរជាប្រឆាំងជាមួយនឹងទ្រង់វិញ (មើល ១:១៧–១៧) ។

**២៥:៤** បានរំឭកឡើងវិញ ពី ៧:២៥–២៦ សូមមើលផងដែរ ៣៥:១៥ ។ *ពួកហោរាទាំងប៉ុន្មាន ជាអ្នកបម្រើរបស់ទ្រង់* មើលការពន្យល់ ៧:២៥ ។

**២៥:៥** *នៅក្នុងស្រុក ដែលព្រះយេហូវ៉ាបានប្រទាន . . . ពួកឰយុកោឯង ចាប់តាំងពីបុរាណ ហើយសំរាប់ជាដរាបតទៅ* បានរំឭកឡើងវិញ ពី ៧:៧ សូមមើល លប ១៧:៨ និងការពន្យល់ ។

**២៥:៦** *កុំឱ្យបណ្តាលឱ្យអញខឹង* សូមមើល ៧:១៨ ចទ ៣១:២៩ ។ *ដោយសារការដែលដៃឯងរាល់គ្នាធ្វើដែរ* នៅត្រង់ឃ្លានេះគឺសំដៅទៅលើព្រះក្លែងក្លាយ ដែលពួកគេបានធ្វើដោយដៃ (សូមមើលការពន្យល់ ១:១៦) ។

**២៥:៧** *ឱ្យអញបានប្រទូស្តដល់ឯង* សូមមើល ៧:៧ ។

**២៥:៩** *ពួកគ្រួនៅស្រុកខាងជើង* ពួកអ្នកស្រុកបាប៊ីឡូន អ្នកស្រុកនោះបានចងសម្ព័ន្ធមិត្រជាមួយគ្នា (សូមមើល ១:១៥ និងការពន្យល់) ។ នេប៊ូក្នេសា *ស្តេចបាប៊ីឡូន ជាអ្នកបំរើរបស់អញ* សូមមើល ២៧:៦ ៤៣:១០ ។ នៅត្រង់ឃ្លានេះគឺនិយាយពី"អ្នកបម្រើ" ហើយការប្រើពាក្យនេះ មិនមែនមានន័យថា"ជាអ្នកនាំថ្វាយបង្គំទេ" ប៉ុន្តែមានន័យថា"ជាបម្រើការ" ឬ "ជាអ្នកកាត់ក្តីជំនុំជម្រះ ដូចជាស្តេចស៊ីរូសជាអ្នកដឹកនាំសាសន៍ដទៃ ដែលគេបានហៅទ្រង់

ជាអ្នកបំរើ[ទ]របស់អញមក ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា
អញនឹងនាំគេមកទាស់នឹងស្រុកនេះ និងពួកអ្នកនៅក្នុងស្រុក
ហើយទាស់នឹងសាសន៍ទាំងប៉ុន្មាននៅជុំវិញផង អញនឹង
បំផ្លាញពួកស្រុកនេះអស់រលីង[ធ] ព្រមទាំងធ្វើឱ្យទៅជាទី
ស្រឡាំងកាំង ជាទីដែលគេធ្វើសឺសស៊ូសឱ្យ[ន] ហើយជាទី
ខូចបង់នៅអស់កល្បជានិច្ច[ប] ១០មួយទៀត អញនឹងបំបាត់
សំឡេង[ផ]អរសប្បាយ និងសំឡេងរីករាយ ជាសំឡេងប្ដី
ប្រពន្ធថ្មោងថ្មី[ព] និងសូរត្បាល់កិន[ភ] ហើយពន្លឺចង្កៀងពីពួក
គេចេញ[ម] ១១ដូច្នេះ ស្រុកនេះទាំងមូលនឹងទៅជាស្ងាត់ជ្រងំ[យ]
ហើយជាទីស្រឡាំងកាំងផង សាសន៍ទាំងនេះនឹងត្រូវបំរើ[រ]
ស្ដេចបាប៊ីឡូនអស់៧០ឆ្នាំ[ល] ។
១២លុះដល់គ្រប់៧០ឆ្នាំ[វ]នោះហើយ នោះអញនឹងធ្វើ
ទោសស្ដេចបាប៊ីឡូន[ស] និងពួកសាសន៍នោះ ដោយព្រោះ
អំពើទុច្ចរិតរបស់គេ ឯស្រុករបស់ពួកខាល់ដេ នោះអញ
នឹងធ្វើឱ្យស្ងាត់ជ្រងំ[ហ]ជាដរាបទៅ នេះជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ១៣អញនឹងសំរេចតាមអស់ទាំងពាក្យដែលអញ
បានប្រកាសទាស់នឹងស្រុកនោះ គឺតាមគ្រប់ទាំងសេចក្ដី
ដែលបានកត់ទុក[ឡ]ក្នុងសៀវភៅនេះហើយ ជាពាក្យដែល
យេរេមាបានទាយទាស់នឹងនគរទាំងប៉ុន្មាន ១៤ដ្បិតសាសន៍
ជាច្រើន[អ] និងស្ដេចធំៗ និងចាប់ប្រើ[ក]សាសន៍ខាល់ដេនោះ
វិញ ហើយអញនឹងសង[ខ]គេ តាមអំពើដែលគេបានប្រព្រឹត្ត
នឹងតាមការដែលដៃគេបានធ្វើ ។

## ពែងនៃសេចក្ដីក្រោធរបស់ព្រះ

១៥ដ្បិតព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលមកខ្ញុំដូច្នេះថា ចូរយកពែង[គ]ស្រាជាសេចក្ដី
ឃោរឃៅនេះពីដៃអញទៅ ហើយបំផឹកអស់ទាំងសាសន៍
ដែលអញចាត់[ឃ]ឯងឱ្យទៅនោះចុះ ១៦គេនឹងផឹក[ង] ហើយនឹង
ដើរវិលវង់[ច]ទៅមក ហើយទៅជាឆ្កួត[ឆ]ដោយព្រោះដាវ[ជ]
ដែលអញនឹងចាត់ទៅកណ្ដាលពួកគេ ១៧ដូច្នេះ ខ្ញុំក៏យក
ពែងនោះ ពីព្រះហស្តនៃព្រះយេហូវ៉ា ទៅបំផឹកអស់ទាំង
សាសន៍ដែលព្រះយេហូវ៉ាបានចាត់[ឈ]ឱ្យខ្ញុំទៅនោះ ១៨គឺក្រុង
យេរូសាឡិម[ញ] និងទីក្រុងស្រុកយូដាទាំងប៉ុន្មាន ព្រមទាំង

**២៥:៩** ទ អស ៤១:២ យរ ២៧:៦ ធ ជន ២១:២ ន ២រប ២៩:៨ ប យរ ១៩:៨ ២០:៤ អគ ១២:២០ **២៥:១០** ផ អស ២៤:៨ អគ ២៦:១៣ ព យរ ៧:៣៤ ៣៣:១១ ភ អគ ១២:៣-៤ ម យប ១៨:៥ បទ ៥:១៥ ១៨:២២-២៣ **២៥:១១** យ ល ២៦:៣១,៣២ យរ ៤:២៦-២៧ ១២:១១-១២ រ យរ ២៨:១៤ ល ២រប ៣៦:២១ **២៥:១២** វ យរ ២៧:៧ ២៩:១០ ស លប ១០:១០ ទដ ១៣៧:៨ ហ អស ១៣:១៩-២២ ១៤:២២-២៣ **២៥:១៣** ឡ អស ៣០:៨ **២៥:១៤** អ យរ ៥០:៩ ៥១:២៧-២៨ ក អស ១៤:៦ យរ ២៧:៧ ខ ចទ ៣២:៤១ យប ២១:១៩ យរ ៥១:៦ **២៥:១៥** គ អស ៥១:១៧ យរ ៤៩:១២ បទ ៤:២១ អគ ២៣:៣១ វវ ១៤:១០ ឃ យរ ១:៥ **២៥:១៦** ង ខ.២៦ ច ទដ ៦០:៣ ឆ យរ ៥១:៧ ជ ខ.២៧:២៩ **២៥:១៧** ឈ យរ ១:១០ ២៧:៣ **២៥:១៨** ញ យរ ១៣:១៣

ថាជាអ្នកគង្វាលរបស់ព្រះយេហូវ៉ា"មានក្នុង អស ៤៤:២៨ ។ ហើយទ្រង់ត្រូវបាន"ចាក់ប្រេងតាំង" នៅក្នុង អស ៤៥:១ ។ *ស្រុកនោះ* គឺនិយាយពីស្រុកយូដា ។ *សាសន៍ទាំងប៉ុន្មាននៅជុំវិញ* មានឈ្មោះនៅក្នុង ខ.១៩-២៦ ។ *បំផ្លាញពួកស្រុកនេះអស់រលីង* សូមមើលការពន្យល់ ៥០:២១,២៦ ៥១:៣ សូមមើលការពន្យល់ ចទ ២:៣៤ ផងដែរ ។ *ធ្វើឱ្យជាទីស្រឡាំងកាំង ជាធ្វើសឺសស៊ូស* សូមមើលការពន្យល់ ១៨:១៦ ។ *ជាទីខូចបង់នៅអស់កល្បជានិច្ច* សូមមើល ៤៩:១៣ ទដ ៧៤:៣ អស ៥៨:១២ និងការពន្យល់ ។

**២៥:១១-១២** *៧០ឆ្នាំ* នេះជាចំនួនឆ្នាំបង្គ្រប់(ដូចមាននៅក្នុង ទដ ៩០:១០ អស ២៣:១៥) ប្រហែលជានៅក្នុងអំឡុងឆ្នាំ ៦០៥ មុន គ.ស(សូមមើលការពន្យល់ ខ.១ ដយ ១:១) ទៅឆ្នាំ ៥៣៨-៥៣៧ មុន គ.ស ដែលបានកត់សម្គាល់ ពីការចាប់ផ្តើមរបស់ពួកសាសន៍យូដា បានវិលត្រឡប់ពីនិរទេស (សូមមើល ២រប ៣៦:២០-២៣ សូមមើលការពន្យល់ផងដែរនៅក្នុង ដយ ៩:១-២) ។ រយៈពេល ៧០ឆ្នាំ នៃព្រះគម្ពីរ សក ១:១២ ដែលមិនមែនជាការចាំបាច់ ដូចអ្វីដែលបានឃើញទាំងឡាយនៅត្រង់ ២៩:១០ នេះឡើយ ។ ពួកគេប្រហែលជាកើតឡើងនៅអំឡុងពេល ឆ្នាំ ៥៨៦ មុន គ.ស (នៅពេលដែលព្រះវិហាររបស់ស្តេចសាឡូម៉ូន គឺត្រូវបានបំផ្លាញ) ។ នៅឆ្នាំ ៥១៦ មុន គ.ស (ពេលដែលព្រះវិហាររបស់ស្តេចសូរ៉ូបាបិល គឺត្រូវបានសង់រួចរាល់ឡើងវិញ) សូមមើលការពន្យល់ សក ៧:៥ ។

**២៥:១១** *ដូច្នេះ ស្រុកនេះ សាសន៍ទាំងនេះ* គឺសំដៅទៅលើពួកសាសន៍យូដា និងឈ្មោះនៃសាសន៍ទាំងឡាយ មាននៅក្នុង ខ.១៩-២៦ ។

**២៥:១២** *ធ្វើទោសស្ដេច... នឹងពួកសាសន៍នោះ* សូមមើល ៥០:១៨ ។ ទីក្រុងនៃបាប៊ីឡូន គឺត្រូវបានដណ្តើមយកដោយសាសន៍មេឌី និងសាសន៍ពើស៊ី នៅក្នុងឆ្នាំ ៥៣៩ មុន គ.ស (នៅជិតចុងបញ្ចប់នៃអាយុ៧០ឆ្នាំរបស់ហោរាយេរេមា សូមមើលការពន្យល់ ខ. ១១-១២) ។ *ដោយព្រោះអំពើទុច្ចរិតរបស់គេ* សូមមើល ៥០:១១,៣១-៣២ ៥១:៦,៤៩,៥៣,៥៦ អស ១៣:១៩ ។ *ធ្វើឱ្យស្ងាត់ជ្រងំជាដរាបទៅ* សូមមើល ៥០:១២-១៣ ៥១:២៦ សូមមើលការពន្យល់ផងដែរនៅក្នុង អស ១៣:២០ ។

**២៥:១៤** *សាសន៍ជាច្រើន* នៅត្រង់ឃ្លានេះគឺនិយាយសំដៅទៅលើ សាសន៍មេឌី សាសន៍ ពើស៊ី ដែលពួកគេបានចងសម្ព័ន្ធមិត្រជាមួយគ្នា ។ *ស្ដេចធំៗ* គឺនិយាយពីស្ដេចស៊ីរូស និងជិនួរវង្សរបស់ទ្រង់ ។ *តាមអំពើដែលគេបានប្រព្រឹត្ត* សូមមើល ៥០:២៩ ៥១:២៤ ។

**២៥:១៥** *ពែងស្រាជាសេចក្ដីឃោរឃៅ* ជានិមិត្តសញ្ញានៃការជំនុំជំម្រះរបស់ព្រះអាទិករ ដែលពិសេសនោះគឺប្រឆាំងទាស់និសេចក្ដីអាក្រក់ដល់គ្រប់ទាំងសាសន៍(សូមមើល អស ៥១:១៧ និងការពន្យល់ សូមមើលផងដែរ ៥១:៧ វវ ១៨:៦ ។ *អស់ទាំងសាសន៍ដែលអញចាត់ឯងឱ្យទៅកណ្ដាលពួកគេ* សូមមើល ១:៥ និងការពន្យល់ ។

**២៥:១៦** *នឹងដើរវិលវង់ទៅមក ហើយទៅជាឆ្កួត* សូមមើល ១៣:១២-១៤ និងការពន្យល់ដទៃទៀត វវ ១៤:៨ ។ *ដោយព្រោះដាវ* គឺដោយសារតែស្រាដែលបណ្តាលឱ្យមនុស្សវង្វេង ដូច្នេះទម្ងន់នៃដាវរបស់ពួកគេ និងត្រូវធ្លាក់ចុះ មិនដែលងើបឡើងវិញម្តងទៀតឡើយ(សូមមើល ខ.២៧) ។

**២៥:១៧** នៅខព្រះគម្ពីរនេះ គឺបាននិយាយរៀបរាប់ទីសម្គាល់របស់ហោរាយេរេមា ដែលគាត់បានធ្វើការប្រកាសពីសេចក្ដីជំនុំជំម្រះនៃព្រះអាទិករប្រឆាំងទាស់ដល់គ្រប់ទាំងសាសន៍ ។

**២៥:១៨** *ក្រុងយេរូសាឡិម និង... ស្រុកយូដា* ព្រះអម្ចាស់ទ្រង់នឹងជំនុំជម្រះរាស្ត្ររបស់ទ្រង់មុនគេ(សូមមើល ខ.២៩ សូមមើលផងដែរ អគ ៩:៦ ១ពត ៤:១៧) ។ *ព្រមទាំងស្ដេច* សូមមើលការពន្យល់ ១៧:២០ ។ *ខូចបង់...*

ស្តេច និងពួកចៅហ្វាយរបស់គេផង ដើម្បីឱ្យគេទៅជា
ទីខូចបង់[ដ] ជាទីស្រឡាំងកាំង[ឋ] ជាទីដែលគេធ្វើសិសស៊ូសឱ្យ[ឌ]
ហើយជាទីផ្តាសាដូចជាសព្វថ្ងៃនេះ[ឍ] ១៩នឹងផារ៉ោន ជា
ស្តេច[ណ]ស្រុកអេស៊ីព្ទ ពួកមហាតលិក និងពួកចៅហ្វាយ
ហើយជនជាតិរបស់គេផង ២០អស់ទាំងសាសន៍លាយគ្នា ពួក
ស្តេចនៅស្រុកអ៊ូស[ត] និងអស់ទាំងស្តេចរបស់ស្រុកភីលីស្ទីន[ថ]
គឺក្រុងអាសកាឡូន[ទ] ក្រុងកាសា[ធ] ក្រុងអេក្រុន និងសំណល់
នៃក្រុងអាសដូឌ ២១សាសន៍អេដំម[ន] សាសន៍ម៉ូអាប់[ប] និងពួក
កូនចៅអាំម៉ូន[ផ] ២២អស់ទាំងស្តេចក្រុងទីរ៉ុស[ព] ស្តេចក្រុង
ស៊ីដូន[ភ] និងស្តេចទាំងប៉ុន្មានដែលនៅកោះ[ម]ខាងនាយសមុទ្រ
២៣ពួកដេដាន់[យ] ពួកថេម៉ា[រ] និងពួកប៊ូស[ល] ហើយអស់ពួកអ្នក
ដែលកាត់ជ្រុងពុកចង្កា[វ] ២៤អស់ទាំងស្តេចសាសន៍អារ៉ាប់[ស]
និងស្តេចនៃសាសន៍លាយគ្នា[ហ] ដែលអាស្រ័យនៅទីរហោ–
ស្ថាន ២៥ពួកស្តេចស៊ីមរី[ឡ] ស្តេចអេឡាំ[អ] និងអស់ទាំងស្តេច
សាសន៍មេឌី[ក] ២៦ស្តេចទាំងប៉ុន្មាននៃស្រុកខាងជើង[ខ] ទាំង
ជិតទាំងឆ្ងាយជាមួយគ្នា ព្រមទាំងនគរទាំងអស់[គ]នៅក្នុង
លោកីយ ដែលនៅលើផែនដីផង រួចស្តេចសេសាក[ឃ]និង
ត្រូវផឹកជាខាងក្រោយបង្អស់ ។
២៧ត្រូវឱ្យឯងប្រាប់គេថាព្រះយេហូវ៉ានៃពួកពលបរិវារ
ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ ចូរ

**២៥:១៨** ដ យបប ១២:១៩ ឋ ២របា ២៩:៨ ឌ លប ១៩:១៣ យរ ៤៤:២២
**២៥:១៩** ឍ ២ពរ ១៨:២១ ណ អស ១៩:១ ២០:៣ យរ ៤៤:៣០ អគ ២៩:២
**២៥:២០** ត លប ១០:២៣ ថ យស ១៣:៣ ២របា ២៦:៦ ២៨:១៨ សផ ២:៤–៧ ទ យរ ៤៧:៥ អម ១:៧–៨ ធ លប ១០:១៩
**២៥:២១** ន លប ២៥:៣០ ប លប ១៩:៣៧ ចទ ២៣:៦ ផ លប ១៩:៣៨ យរ ២៧:៣ ៤៩:១
**២៥:២២** ព យស ១៩:២៩ ភ លប ១០:១៥ ម អស ១១:១១ ៤៨:២០ ៦៦:២០ យរ ៣១:១០ អគ ២៧:១៥ ៣៩:៦ ដយ ១១:១៨ **២៥:២៣** យ លប ២៥:៣ រ លប ២៥:១៥ ល លប ២២:២១ វ យរ ៩:២៦ ៤៩:៣២ **២៥:២៤** ស ២របា ៩:១៤ ហ ខ.២០ **២៥:២៥** ឡ លប ២៥:២ អ លប ១០:២២ ក អស ២១:២
**២៥:២៦** ខ ខ.៩ យរ ៥០:៣,៩ ៥១:១១, ៤៨ គ អស ២៣:១៧ ឃ យរ ៥១:៤១

*ស្រឡាំងកាំង . . . សិសស៊ីស . . . ផ្តាសា* មើល ខ.៩,១១ ១៨:១៦ ១៩:៨ ។

**២៥:១៩–២៦** នៅខព្រះគម្ពីរទាំងនេះ គឺនិយាយរៀបរាប់ពីបញ្ជីឈ្មោះនៅគ្រប់អស់ទាំងសាសន៍ ដែលចាប់ផ្តើមពី ពួកសាសន៍អេស៊ីព្ទនិងចុងបំផុតជាមួយពួកសាសន៍បាប៊ីឡូន ដូចមាននៅក្នុង ជំពូក ៤៦–៥១ ប៉ុន្តែ ពួកទីក្រុងដាម៉ាសគឺត្រូវបានលុបចោល ព្រមទាំងបានបន្ថែមតំបន់ពីរបីផ្សេងទៀតផង (សូមមើល ៤៩:២៣–២៧) ។

**២៥:១៩** *ស្រុកអេស៊ីព្ទ* សូមមើល ៤៦:២–២៨ ។

**២៥:២០** *អស់ទាំងសាសន៍លាយគ្នា* សូមមើល ខ. ២៤ នហ ១៣:៣ ។ *ស្រុកអ៊ូស* សូមមើលការពន្យល់ យប ១:១ ។ *ស្រុកភីលីស្ទីន* សូមមើល ជំពូក ៤៧ សូមមើលការពន្យល់ផងដែរនៅក្នុង លប ១០:១៤ ។ *ក្រុងអាសកាឡូន ក្រុងកាសា ក្រុងអេក្រុន* សូមមើលការពន្យល់ ពច ១:១៨ ។ *សំណល់នៃក្រុងអាសដូឌ* យោងតាមព្រះគម្ពីរភាសាក្រិចគឺទីក្រុងនេះ ត្រូវបានបំផ្លាញបន្ទាប់ពីឡោមព័ទ្ធអស់រយៈពេលយ៉ាងយូរ ។ ហើយដោយសារហោរានេហេមាគ្រានោះបានតាំងទីក្រុងនោះឡើងវិញ (សូមមើលការពន្យល់ នហ ៤:៧) មានន័យថាមេសាសន៍ភីលីស្ទីនទាំងប្រាំជាអ្នកត្រួតត្រា ទីក្រុងកាថ (សូមមើល យស ១៣:៣) ដែលសុទ្ធតែជាមនុស្សសំខាន់មុនគេ(សូមមើលឧទាហរណ៍ ១សយ ២១:១០–១២) គឺត្រូវបានបំផ្លាញ ហើយឃើញថាមិនមានការសង់ឡើងវិញឡើយ(នៅពេលរាប់រយឆ្នាំក្រោយមក វាក៏មិនបានសរសេរនៅទីក្រុងបួនដទៃទៀតដែរ សូមមើល អម ១:៦–៨ សផ ២:៤ សក ៩:៥–៦) ។

**២៥:២១–២២** សូមមើល ២៧:៣–៥ ។

**២៥:២១** *សាសន៍អេដំម* សូមមើល ៤៩:៧–២២ និងសូមមើលការពន្យល់ផងដែរនៅក្នុង លប ៣៦:១ ។ *សាសន៍ម៉ូអាប់ និងពួកកូនចៅ អាំម៉ូន* សូមមើល ៤៨:១–៤៩:៦ និងសូមមើលការពន្យល់ផងដែរនៅក្នុង លប ១៩:៣៦–៣៨ ។

**២៥:២២** *ស្តេចក្រុងទីរ៉ុស ស្តេចក្រុងស៊ីដូន* សូមមើល៤៧:៤ និងសូមមើលការពន្យល់ផងដែរនៅក្នុង អស ២៣:១–២,៤,១២ ។ *នៅកោះខាងនាយសមុទ្រ* កោះជាច្រើននេះ ស្ថិតនៅតំបន់សមុទ្រមេឌីទែរ៉ាណេ ហើយជាទីកន្លែងនាវាចរណ៍ នៅក្រោមការគ្រប់គ្រងរបស់ស្រុកភេនីស (សូមមើល អគ ២៥:១៥ ដយ ១១:១៨ និងការពន្យល់ផ្សេងទៀត) ។

**២៥:២៣** *ពួកដេដាន់* សូមមើល ៤៩:៨ និងសូមមើលការពន្យល់ផងដែរនៅក្នុង អស ២១:១៣ អគ ២៥:១៣ ។ *ពួកថេម៉ា* សូមមើលការពន្យល់ អស ២១:១៤ ។ *ពួកប៊ូស* ពួកគេស្ថិតនៅតំបន់វាលរហោស្ថានខាងកើត ។ *ហើយអស់ពួកអ្នកដែលកាត់ជ្រុងពុកចង្កា* សូមមើលការពន្យល់ ៩:២៦ ។

**២៥:២៤** *សាសន៍អារ៉ាប់* សូមមើល ៤៩:២៨–៣៣ និងសូមមើល ៣:២ផងដែរ ។ *សាសន៍លាយគ្នា* សូមមើល ខ. ២០ នហ ១៣:៣ ដូចនៅក្នុងព្រះគម្ពីរភាសាហេព្រើរ គឺបានវិភាគពីឫសគាល់នៃ"សាសន៍អារ៉ាប់" និង "សាសន៍លាយគ្នា" ។

**២៥:២៥** *ស្តេចស៊ីមរី* មិនមែនជាស្តេចនៃសាសន៍អ៊ីស្រាអែលនោះឡើយ ស្តេចឈ្មោះស៊ីរីគឺប្រហែលដូចជាស៊ីមរ៉ាន ដែលឈ្មោះកិទូរ៉ា និងអាប់រ៉ាម (សូម មើល លប ២៥:១–២) តំបន់ដែលគេបានស្គាល់នោះគឺដូចជាស៊ីមរី ប៉ុន្តែ (គ្មានអ្នកណាបានដឹងពីតំបន់នោះច្បាស់ទេ) គ្រាពេលក្រោយមកទើបគេបានស្គាល់ឈ្មោះរបស់ទ្រង់ ។ *ស្តេចអេឡាំ* សូមមើល ៤៩:៣៤–៣៩ និងសូមមើលការពន្យល់ផងដែរនៅក្នុង លប ១០:២២ ។ *ស្តេចសាសន៍មេឌី* ក្រោយមកស្តេចសាសន៍មេឌីនេះបានរួបរួមជាមួយនិងសាសន៍ពើស៊ី ដើម្បីច្បាំងជាមួយស្តេចបាប៊ីឡូន (សូមមើល ៥១:១១,២៨ និងសូមមើលការពន្យល់ផងដែរនៅក្នុង អស ១៣:១៧) ។

**២៥:២៦** *ស្តេចសេសាក* អត្ថន័យទីមួយ ជាទម្រង់លិខិតនៃការសរសេរអក្សរសម្ងាត់ សម្រាប់ជំនួសព្យញ្ជនៈដំបូង នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ហើយបញ្ចប់ទៅដោយស្រះខាងចុង ។ អត្ថន័យទីពី នៅក្នុងអត្ថបទចុងក្រោយវាជាគោលបំណង គឺមិនបានយល់ពេញលេញ ថ្វីបើនៅក្នុងករណីខ្លះទៀតបញ្ជាក់ពីលក្ខណៈការសរសេរអក្សរសម្ងាត់ ដែលមានខ្លឹមសារសមរម្យនោះ (សូមមើលការពន្យល់ ៥១:១) ដូច្នេះស្តេចសេសាកនឹងត្រូវផឹកជាខាងក្រោយបង្អស់ ។ *នឹងត្រូវផឹកជាខាងក្រោយបង្អស់* គឺជាការជំនុំជម្រះរបស់ព្រះអម្ចាស់ ហើយពួកគេមិនអាចគេចផុតពីសេចក្តីជំនុំជម្រះរបស់ទ្រង់បានឡើយ (សូមមើល ៥១:៤៨–៤៩) ។

ផឹកចុះ ហើយឱ្យស្រវឹងផង[ង] ចូរក្អួតចេញ ហើយដួលចុះ
ឥតដែលក្រោកឡើងវិញឡើយ ដោយព្រោះដាវ[ច]ដែលអញ
នឹងចាត់ទៅកណ្ដាលពួកឯងរាល់គ្នា ២៨ បើកាលណាគេ
មិនព្រមផឹកពីពែងនៅដៃឯងទេ[ឆ] នោះត្រូវឱ្យឯងប្រាប់គេ
ថា ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ ទ្រង់មានបន្ទូល
ដូច្នេះ ត្រូវឱ្យឯងរាល់គ្នាផឹកជាពិត ២៩ ដ្បិតមើល អញចាប់
តាំងធ្វើទោស[ជ]ដល់ទីក្រុង ដែលបានហៅតាមឈ្មោះអញ[ឈ]
ដូច្នេះ តើឯងរាល់គ្នានឹងរួចខ្លួនឥតមានទោសសោះបានឬ[ញ]
អញនឹងហៅឱ្យមានដាវ[ដ]មកលើគ្រប់[ឋ]ទាំងមនុស្សនៅផែនដី
នេះ[ឌ] ជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
៣០ ដូច្នេះ ចូរទាយអស់ទាំងពាក្យនេះ ទាស់នឹងគេ
ហើយប្រាប់គេថា ព្រះយេហូវ៉ា ទ្រង់មិនគ្រហឹម[ឍ]ពីខាងលើ
ហើយនឹងបញ្ចេញព្រះសូរសៀង[ណ]ទ្រង់ ពីទីលំនៅ[ត]បរិសុទ្ធ
របស់ទ្រង់ ទ្រង់នឹងគ្រហឹមជាខ្លាំងក្រៃលែងទាស់នឹងក្រោល
ទ្រង់ ក៏នឹងស្រែកឡើងទាស់នឹងពួកអ្នកនៅផែនដីទាំងអស់
ដូចជាសំរែកនៃពួកអ្នកដែលជាន់[ថ]ផ្លែទំពាំងបាយជូរ ៣១ នឹង
ឮសូរ[ទ]រហូតដល់ចុងផែនដីបំផុតផង ដ្បិតព្រះយេហូវ៉ាទ្រង់
មានការណ៍[ធ]ទាស់ទទឹងនឹងសាសន៍ទាំងប៉ុន្មាន ទ្រង់នឹង
កើតក្តី[ន]នឹងគ្រប់ទាំង[ប]មនុស្ស ឯពួកមនុស្សអាក្រក់ នោះទ្រង់
នឹងប្រគល់ដល់ដាវ[ផ] នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
៣២ ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលថា
មើល សេចក្តីអាក្រក់[ព]នឹងចេញពីនគរ១ដល់នគរ១[ភ] ហើយ
នឹងកើតមានព្យុះសង្ឃរា[ម]យ៉ាងសំបើម មកពីចុងផែនដី
បំផុត[យ] ៣៣ នៅថ្ងៃនោះ សាកសពនៃមនុស្សដែលព្រះ
យេហូវ៉ាបានប្រហារ[រ] នឹងនៅរាយពេញ ពីចុងផែនដីម្ខាង
ទៅដល់ចុងផែនដីម្ខាង ឥតមានអ្នកណាសោកស្តាយគេ ឬ
ប្រមូល[ល] ខ្មោចគេទៅកប់ឡើយ[វ] គឺគេនឹងទៅជាដីនៅលើដី
៣៤ ឱ ពួកអ្នកគង្វាលអើយ[ស] ចូរស្រែកទ្រហោយំចុះ ឱពួកជា
ប្រធានក្នុងហ្វូងអើយ ចូរដេកននៀល[ហ]ក្នុងផេះចុះ ដ្បិតគ្រា
ដែលសំឡេះ[ឡ]ឯង ហើយកំចាត់កំចាយឯង បានមកដល់
ហើយ ឯងរាល់គ្នានឹងត្រូវធ្លាក់ចុះ ដូចជាភាជនៈមានដំឡៃ[អ]
៣៥ ឯពួកអ្នកគង្វាល នឹងគ្មានផ្លូវណារត់ឱ្យរួចឡើយ ហើយ
ពួកដែលជាប្រធានក្នុងហ្វូង ក៏ឥតមានផ្លូវនឹងរួចបានដែរ[ក]
៣៦ មានឮសំរែកនៃពួកអ្នកគង្វាល និងសូរទ្រហោយំ[ខ] របស់
ពួកជាប្រធានក្នុងហ្វូង[គ] ពីព្រោះយេហូវ៉ា ទ្រង់បំផ្លាញ
ទីឃ្វាលរបស់គេ ៣៧ ហើយក្រោលសុខសាន្តទាំងប៉ុន្មាន
បានត្រឡប់ជាស្ងាត់ច្រៀប ដោយព្រោះសេចក្តីខ្ញាល់ដ៏
សហ័សនៃព្រះយេហូវ៉ា ៣៨ ទ្រង់បានចេញពីទីលំនៅរបស់
ទ្រង់ ដូចជាសិង្ហ[ឃ] ដ្បិតរបស់គេបានត្រឡប់ជាស្ងាត់ជ្រងំ[ង]
ដោយសេចក្តីច្រឡោតនៃពួករីបជាន់[ច] និងសេចក្តីខ្ញាល់ដ៏
សហ័សនៃទ្រង់[ឆ] ។

## ការគម្រាមដល់ជីវិតលោកយេរេមា

**២៦** ១ កាលនៅដើមរាជ្យនៃយេហូយ៉ាគីម[ក] ជាបុត្រ
យ៉ូសៀស ស្តេចយូដា នោះព្រះបន្ទូលនេះបានមកពីព្រះ

**២៥:២៧** ង ខ.១៦,២៨ អស ២៩:៩ ៥៩:២៦ យរ ៥១:៥៧ អក ២៣:៣២–៣៤ ណាហ ៣:១៨ ហព ២:១៦ ច យរ ១២:១២ អក ១៤:១៧ ២១:៤ **២៥:២៨** ឆ អស ៥១:២៣ **២៥:២៩** ជ ២សយ ៥:៧ អស ១០:១២ យរ ១៣:១២–១៤ ៣៩:១ ឈ ចទ ២៨:១០ អស ៣៧:១៧ ញ សភ ១១:៣១ ដ ខ.២៧ ឋ ខ.៣០–៣១ អស ៣៤:២ ឌ អស ២៤:១ **២៥:៣០** ឍ អស ១៦:១០ ៤២:១៣ ណ ទដ ៤៦:៦ ត ទដ ៦៨:៥ ថ អស ៦៣:៣ យអ ៣:១៣ វវ ១៤:១៩–២០ **២៥:៣១** ទ យរ ២៣:១៩ ធ យរ ២:៩ ន ១សយ ១២:៧ យរ ២:៣៥ អក ៣៦:៥ ប ខ.២៩ ផ យរ ១៥:៩

**២៥:៣២** ព អស ៣០:២៥ ភ អស ៣៤:២ ម យរ ២៣:១៩ យ ចទ ២៨:៤៩ **២៥:៣៣** រ អស ៦៦:១៦ អក ៣៩:១៧–២០ ល យរ ៨:២ វ ទដ ៧៩:៣ **២៥:៣៤** ស យរ ២:៨ សក ១០:៣ ហ យរ ៦:២៦ ឡ ទដ ៤៤:២២ អស ៣៤:៦ យរ ៥០:២៧ ៥១:៤០ សក ១១:៤,៧ អ យរ ២២:២៨ **២៥:៣៥** ក យប ១១:២០ **២៥:៣៦** ខ យរ ៦:២៦ គ យរ ២៣:១សក ១១:៣ **២៥:៣៨** ឃ យប ១០:១៦ យរ ៤:៧ ង យរ ៤៤:២២ ច យរ ៤៦:១៦ ៥០:១៦ ឆ នក ១៥:៧ យរ ៤:២៦ **២៦:១** ក ២ពវ ២៣:៣៦

**២៥:២៧** *ដួលចុះ . . . ដោយព្រោះដាវ* មើលការពន្យល់នៅក្នុង ខ.១៦ ។

**២៥:២៩** *ចាប់តាំងធ្វើ* សូមមើលការពន្យល់នៅក្នុង ខ. ១៨ ។ *ទីក្រុង ដែលបានហៅតាមឈ្មោះអញ* នៅត្រង់ឃ្លានេះគឺនិយាយទីក្រុងយេរូសាឡិម(សូមមើលការពន្យល់នៅក្នុង ៧:១០) ។ *ដាវ* សូមមើលការពន្យល់នៅក្នុង ១២:១២ ។

**២៥:៣០** *ព្រះយេហូវ៉ាទ្រង់មិនគ្រហឹម . . . ហើយនិងបញ្ចេញព្រះសូរសៀង* គឺបានរំឭកឡើងវិញនៅក្នុងព្រះគម្ពីរ យអ ៣:១៦ អម ១:២(សូមមើលការពន្យល់នៅត្រង់នោះ និងសូមមើលផងដែរ ហស ១១:១០ អម ៣:៨) ។ *ទីលំនៅបរិសុទ្ធរបស់ទ្រង់* នៅត្រង់ឃ្លានេះគឺនិយាយពីស្រុកយូដា ។ *សំរែកនៃពួកអ្នកដែលជាន់ផ្លែទំពាំងបាយជូរ* សូមមើល អស ៩:៣ ១៦:៩–១០ ៦៣:៣ និងការពន្យល់ សូមមើល អស ១៦:១០ និងការពន្យល់ ។

**២៥:៣១** *នឹងឮសូរ* គឺជាសម្លេងនៃសង្គ្រាម(សូមមើល អម ២:២) ។ *នឹងមានការណ៍ទាស់ទទឹង . . . នឹងកើតក្តី* សូមមើលការពន្យល់នៅក្នុង ២:៩ និងសូមមើល ២:៣៥ ១២:១ ផងដែរ ។

**២៥:៣២** *មានព្យុះសង្ឃរាយ៉ាងសំបើម មកពីចុងផែនដីបំផុត* គឺជាសេចក្តីក្រោធរបស់ព្រះ (សូមមើល ២៣:១៩) ដែលជាការរាតត្បាតរបស់ពួកសាសន៍បាប៊ីឡូន (សូមមើលការពន្យល់នៅក្នុង អស ៤១:២៥) ។

**២៥:៣៣** *ឥតមានអ្នកណាសោកស្តាយគេ . . . គឺគេនឹងទៅជាដីនៅលើដី* ជាការរំឭកឡើងវិញ (សូមមើលការពន្យល់នៅ ៨:២) និងសូមមើល ១៦:៤ ។

**២៥:៣៤–៤៦** *ឱពួកអ្នកគង្វាលអើយ . . . ឱពួកជាប្រធានក្នុងហ្វូងអើយ* សូមមើល ២:៨ និងការពន្យល់ ១០:២១ ២២:២២ អគ ៣៤:២ និងការពន្យល់ ។

**២៥:៣៤** *ននៀលក្នុងផេះ* ឬ "ដេកននៀលនៅក្នុងធូលីដី" (ដូចនៅក្នុង ៦:២៦) ។ *គ្រាដែល . . . បានមកដល់ហើយ* សូមមើល បទ ៤:១៨ ។ *នឹងត្រូវធ្លាក់ចុះ ដូចជាភាជនៈមានដំឡៃ* ធៀបនឹង ។ នៅត្រង់ឃ្លានេះគឺនិយាយរៀបរាប់ស្តេចយេហូយ៉ាគីម មើលនៅក្នុង ២២:២៨ ។

**២៥:៣៦** *ទីឃ្វាលរបស់គេ* គឺជាស្រុកយូដា ។

**២៦:១–២៤** ការសង្ខេប (ខ.២–៦) និងលទ្ធផល (ខ.៧–២៤) នេះជាព្រះបន្ទូលរបស់តាមរយៈលោកយេរេមា នៅឯព្រះវិហារ ក្នុងជពូក៧ (មើលការពន្យល់ ៧:១–១០:២៥) ។

យេហូវ៉ាថា 2 ព្រះយេហូវ៉ាទ្រង់មានបន្ទូលបង្គាប់ដូច្នេះ ចូរ
ទៅឈរក្នុងទីលាន[ខ]ព្រះវិហារនៃព្រះយេហូវ៉ាចុះ ហើយ
ប្រាប់ដល់មនុស្សនៅអស់ទាំងទីក្រុងស្រុកយូដា ដែលមក
ថ្វាយបង្គំក្នុងព្រះវិហារនៃព្រះយេហូវ៉ា[គ] តាមគ្រប់ទាំង
ពាក្យ ដែលអញបង្គាប់ឱ្យឯងប្រាប់ដល់គេ កុំឱ្យបន្ថយ[ឃ]ពាក្យ
ណាមួយឡើយ 3 ប្រហែលជាគេនឹងស្តាប់តាម ហើយបែរ[ច]
ចេញពីផ្លូវអាក្រក់ដែលគេប្រព្រឹត្តរៀងខ្លួនទៅដឹង ដើម្បីឱ្យ
អញបានប្រែគំនិតចេញពីការអាក្រក់ ដែលអញសំរេច
នឹងធ្វើ[ឆ] ដល់គេដោយព្រោះអំពើអាក្រក់ដែលគេប្រព្រឹត្ត
នោះ 4 ត្រូវឱ្យឯងប្រាប់គេថា ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះ បើឯងរាល់គ្នាមិនព្រមស្តាប់[ជ]តាមអញ ដើម្បីនឹងដើរ
តាមច្បាប់[ឈ] ដែលអញបានដាក់នៅមុខឯងរាល់គ្នា
5 ប្រយោជន៍នឹងស្តាប់តាមពាក្យរបស់ពួកហោរា ជាអ្នក
បំរើរបស់អញ ដែលអញចាត់ឱ្យមកឯឯងរាល់គ្នា ដោយ
ក្រោកពីព្រលឹមស្រាង និងចាត់គេផង តែឯងរាល់គ្នាមិន
បានស្តាប់តាមសោះ[ញ] 6 នោះអញនឹងធ្វើឱ្យវិហារនេះបាន
ដូចជាស៊ីឡូរ[ដ]វិញ ហើយនិងធ្វើឱ្យទីក្រុងនេះត្រឡប់ជាទីផ្តា
សា[ឋ]ដល់អស់ទាំងសាសន៍នៅផែនដីផង 7 ឯពួកសង្ឃ ពួក
ហោរា និងបណ្តាជនទាំងឡាយ ក៏ឮយេរេមាប្រាប់ពាក្យ
ទាំងនេះនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ាដែរ ។
8 លុះដល់យេរេមាបានប្រាប់គ្រប់ទាំងសេចក្តី ដែល
ព្រះយេហូវ៉ាបានបង្គាប់[ឌ] ឱ្យលោកប្រាប់ដល់ជនទាំងឡាយ
រួចអស់ហើយ នោះពួកសង្ឃ និងពួកហោរា ហើយ
បណ្តាជនទាំងអស់ ក៏ចាប់[ឍ]លោកដោយពាក្យថា ឯងត្រូវ
ស្លាប់ហើយ[ណ] 9 ហេតុអ្វីបានជាឯងទាយដោយនូវព្រះនាម
ព្រះយេហូវ៉ាថា ព្រះវិហារនេះនឹងបានដូចជាស៊ីឡូរ ហើយ
ទីក្រុងនេះនឹងត្រូវខូចបង់ ឥតមានអ្នកណានៅដូច្នេះ[ត] រួច
ប្រជាជន[ថ]ក៏មូលគ្នាមកព័ទ្ធជុំយេរេមា នៅក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា ។
10 កាលពួកចៅហ្វាយ[ទ]នៃស្រុកយូដា បានឮសេចក្តី
ទាំងនោះហើយ គេក៏ចេញពីដំណាក់ស្តេច ឡើងទៅឯ
ព្រះវិហារនៃព្រះយេហូវ៉ា រួចអង្គុយចុះត្រង់ទ្វារ[ធ]ថ្មីនៃព្រះ
វិហារព្រះយេហូវ៉ា 11 នោះពួកសង្ឃនឹងពួកហោរា គេ
ជំរាបដល់ពួកចៅហ្វាយ ហើយដល់ជនទាំងអស់ថា មនុស្ស
នេះគួរស្លាប់ហើយ[ន] ដ្បិតគេបានទាយទាស់នឹងក្រុងនេះ
ដូចជាអស់លោកអ្នកបានឮដោយត្រចៀកស្រាប់[ប] 12 រួច
យេរេមាលោកក៏ជំរាបដល់ពួកចៅហ្វាយ[ផ] និងជនទាំងអស់
ថា ព្រះយេហូវ៉ា ទ្រង់បានចាត់ខ្ញុំឱ្យមកទាយ[ព]ប្រាប់អស់ទាំង
ពាក្យដែលអ្នករាល់គ្នាបានឮ ទាស់នឹងព្រះវិហារ ហើយ

**២៦:២** ខ យរ ១៩:១៤ គ យរ ១៧:១៩ ឃ ខ.១២ យរ ១:១៧ មថ ២៨:២០ កច ២០:២៧ ង ចទ ៤:២ **២៦:៣** ច ចទ ៣០:២ ២រប ៣៣:១២–១៣ អស ៥៥:៧ យរ ៣៥:១៥ ៣៦:៣ ឆ យរ ១៨:៨ **២៦:៤** ជ លវ ២៦:១៤ យរ ២៥:៣ ឈ នក ២០:១–២៣:៣៣ ១ពវ ៩:៦ យរ ១១:៨ **២៦:៥** ញ សភ ១:២៤ អស ៦៥:១២ យរ ២៥:៤ ៤៤:៥ **២៦:៦** ដ យស ១៨:១ ពច ១៨:៣១ ឋ ចទ ២៨:២៥ ២ពវ ២២:១៩ **២៦:៨** ឌ យរ ៤៣:១ ឍ កច ៦:១២ ២១:២៧ ណ លប ២៤:១៥–១៦ នហ ៩:២៦ យរ ១១:២១ **២៦:៩** ត លវ ២៦:៣២ យរ ៩:១១ ថ កច ២១:៣២ **២៦:១០** ទ ខ.១៦ យរ ៣៤:១៩ អគ ២២:២៧ ធ លប ២៣:១០ **២៦:១១** ន ចទ ១៨:២០ យរ ១១:២១ ១៨:២៣ មថ ២៦:៦៦ កច ៦:១១ ប ទដ ៤៤:១**២៦:១២** ផ យរ ១:១៨ ព អស ៦:៨ អម ៧:១៥ កច ៤:១៨–២០ ៥:២៩

**២៦:១** *កាលនៅដើមរាជ្យ* មើល ២៧:១ ដៃគូររបស់ពួកបាប៊ីឡូន នៅក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ បញ្ជាក់ពីឆ្នាំដំបូងនៃការសោយរាជ្យរបស់ស្តេចយេហូយ៉ាគីម (ឆ្នាំ៦០៩–៦០៨ គ.ស) ជាឆ្នាំសោយរាជ្យអាក្រក់របស់ទ្រង់ ។

**២៦:២** *ចូរទៅឈរក្នុងទីលានព្រះវិហារនៃព្រះយេហូវ៉ាចុះ* ប្រហែលជានៅជិតមាត់ទ្វារថ្មី (មើល ខ.១០ មើលការពន្យល់ផងដែរ ៧:២) ។ *ដែលមកថ្វាយបង្គំ* មើល ៧:២ និងការពន្យល់ ។ *កុំឱ្យបន្ថយពាក្យណាមួយឡើយ* មើល ចទ ៤:២ និងការពន្យល់ ។

**២៦:៣** មើល ៧:៣,៥–៧ ។ *ប្រែគំនិត* មើល ខ.១៣,១៩ មើលការពន្យល់ ៤:២៨ ១៨:៧–១០ ។

**២៦:៤** *បើឯងរាល់គ្នាមិនព្រមស្តាប់តាមអញ* មើល ខ.៥ ៧:១៣ ។ *ដើរតាមច្បាប់* មើល ៧:៦,៩ និងការពន្យល់ ។

**២៦:៥** មើល ៧:១៣,២៥–២៦ ។ *ពួកហោរា* ជាអ្នកបំរើរបស់អញ មើលការពន្យល់ ៧:២៥ ។ *ពីព្រលឹមស្រាង* មើលការពន្យល់ ៧:១៣ ។

**២៦:៦** *នោះអញនឹងធ្វើឱ្យវិហារនេះបានដូចជាស៊ីឡូរវិញ* មើល ខ.៩ មើលការពន្យល់ ៧:១២ ។ *ទីក្រុងនេះ* គឺទីក្រុងយេរូសាឡិម ។ *ត្រឡប់ជាទីផ្តាសា* មើល ២៤:៩ ២៥:១៨ មើលការពន្យល់ផងដែរក្នុង សក ៨:១៣ ។

**២៦:៨** *ឯងត្រូវស្លាប់ហើយ* ឃ្លានេះបានរៀបរាប់ដូចគ្នា ចុងក្រោយទាំងអស់ចំពោះការដែលប្រព្រឹត្តរំលង ក្រិត្យវិន័យរបស់លោកម៉ូសេ (មើលខ. នក ២១:១៥ លវ ២៤:១៦–១៧ ២១ ចទ ១៨:២០ ធៀបនឹង ១ពវ ២១:១៣) ។ ២៦:៩ ក៏មូលគ្នាមកព័ទ្ធជុំ សត្រូវលោកយេរេមាបានព័ទ្ធជុំវិញ (មើល ជន ១៦:៣) ។

**២៦:១០** *កាលពួកចៅហ្វាយនៃស្រុកយូដា* អស់អ្នកដែលទទួលខុសត្រូវ ក្នុងការធ្វើការសម្រេចដ៏ស្របច្បាប់ ទាក់ទងទៅនឹងជម្លោះ ដែលកើតឡើងនៅក្នុងបរិវេណព្រះវិហារ ។ ពួកសង្ឃនិងហោរាក្លែងក្លាយ បានទទួលផលប្រយោជន៍ពីព្រះវិហារ មានអារម្មណ៍ថា លោកយេរេមាគួរតែត្រូវកាត់ទោសប្រហាជីវិត ដោយសាគាត់បាននាំឱ្យមានសេចក្តីហិនវិនាស ដល់អស់ទាំងទីក្រុង និងដំណាក់របស់ព្រះអម្ចាស់ (មើល ខ.៨–៩,១១) ។ ក្រោយពីស្តាប់ ការការពារក្តីរបស់លោកយេរេមា (ខ.១២–១៥) ពួកចៅហ្វាយបានសម្រេចចិត្ត ស្តប់ចិត្តវិញ ។ បណ្តាជនមានចិត្តសាវ៉ា ហើយមុនដំបូងគេបានប្រឆាំងនឹងលោកយេរេមាភ្លាម (ខ.៨–៩) តែក្រោយមកទៀតគេបានគាំទ្រគាត់វិញ (សូមមើល ខ.១៦) ។ *ទ្វារថ្មី* សូមមើល ៣៦:១០ ដែលដូចគ្នានឹង "ទ្វារខាងលើរបស់ពួកបេនយ៉ាមីន" (មើល ២០:២ និងការពន្យល់) ។

**២៦:១១** ពួកខ្មាំងសត្រូវរបស់លោកយេរេមា បានកាត់ក្តីគាត់ មុនពេលដែលគាត់មានឱកាស ដើម្បីការពារខ្លួនឯង (ធៀបនឹង ចទ ១៩:៦ យក ២០:១–៩ និងការពន្យល់) ។

**២៦:១២** *ព្រះយេហូវ៉ា ទ្រង់បានចាត់ខ្ញុំ* ខុសគ្នានៅក្នុង ២៣:២១ ។

និងទីក្រុងនេះ[ភ] [១៣]ដូច្នេះ ចូរកែ[ម]ផ្លូវ និងកិរិយារបស់អ្នក
រាល់គ្នាឥឡូវ ហើយស្តាប់តាម[យ]ព្រះបន្ទូលនៃព្រះយេហូវ៉ា
ជាព្រះនៃអ្នករាល់គ្នាចុះ នោះព្រះយេហូវ៉ាទ្រង់នឹងប្រែ
គំនិត[រ]ចេញពីសេចក្តីអាក្រក់ ដែលទ្រង់បានប្រកាសទាស់
នឹងអ្នករាល់គ្នាវិញ [១៤]តែឯខ្លួនខ្ញុំនេះ ខ្ញុំនៅក្នុងកណ្តាប់ដៃ
នៃអ្នករាល់គ្នាហើយ[ល] ចូរធ្វើដល់ខ្ញុំតាមដែលអ្នករាល់គ្នា
ឃើញថាល្អហើយទៀងត្រង់ចុះ [១៥]ប៉ុន្តែត្រូវឱ្យដឹងពិតថា
បើអ្នករាល់គ្នាសំឡាប់ខ្ញុំ នោះនឹងនាំឱ្យឈាម[វ]ដែលឥតមាន
ទោសប្រឡាក់លើខ្លួនអ្នករាល់គ្នា លើទីក្រុងនេះនឹងពួកអ្នក
ដែលអាស្រ័យនៅផង ដ្បិតព្រះយេហូវ៉ាបានចាត់ខ្ញុំឱ្យមក
ដើម្បីនឹងប្រាប់ពាក្យ[ស]ទាំងនេះ នៅត្រចៀកអ្នករាល់គ្នាជា
ពិត ។

[១៦]នោះពួកចៅហ្វាយ[ហ]និងជនទាំងឡាយ ក៏និយាយ
នឹងពួកសង្ឃ ហើយនិងពួកហោរាថា មនុស្សនេះមិនគួរ
នឹងស្លាប់ទេ[ឡ] ដ្បិតបានគ្រាន់តែប្រាប់យើងរាល់គ្នា ដោយ
នូវព្រះនាមព្រះយេហូវ៉ា ជាព្រះនៃយើងទេតើ [១៧]រួចមាន
ពួកចាស់ទុំខ្លះក្នុងស្រុក គេក្រោកឡើងប្រាប់ដល់ប្រជុំជន ថា
[១៨]មីកា[អ] ជាពួកម៉ូរ៉ាស៊ីត បានទាយ នៅក្នុងរាជ្យ ហេសេគា
ជាស្តេចយូដា ហើយប្រាប់ដល់ពួកជននៅស្រុកយូដាថា
ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានមានបន្ទូល ដូច្នេះ
គេនឹងភ្ជួរភ្នំស៊ីយ៉ូន[ក] ដូចជាភ្ជួរស្រែចំការ ហើយក្រុងយេរូ-
សាឡិមនឹងត្រឡប់ជាកងគំនរ[ខ] ឯភ្នំ[គ]នៃព្រះវិហារ នោះនឹង
ដូចជាទីខ្ពស់នៅព្រៃណាមួយ[ឃ] [១៩]ចុះតើហេសេគា[ង] ជា
ស្តេចយូដា នឹងពួកយូដាទាំងអស់បានសំឡាប់លោកឬអី តើ
ទ្រង់មិនបានកោតខ្លាចដល់ព្រះយេហូវ៉ាវិញ ហើយទូល
អង្វរចំពោះ[ច]ព្រះអង្គទេឬអី ឯព្រះយេហូវ៉ាទ្រង់ក៏ប្រែគំនិត[ឆ]
ចេញពីសេចក្តីអាក្រក់[ជ] ដែលទ្រង់បានប្រកាសទាស់នឹងគេ
ដែរ ធ្វើដូច្នេះយើងនឹងឈ្មោះថាបានប្រព្រឹត្តអំពើអាក្រក់[ឈ]
យ៉ាងធំ ទាស់នឹងព្រលឹងយើងហើយ ។

[២០]មួយទៀតក៏មានម្នាក់ដែលទាយដោយនូវព្រះនាម
ព្រះយេហូវ៉ា ឈ្មោះអ៊ូរីយ៉ា ជាកូនរបស់សេម៉ាយ៉ា ពីក្រុង
គារយ៉ាត់-យារីម[ញ] អ្នកនោះទាយទាស់នឹងទីក្រុង ហើយ
និងស្រុកនេះ តាមអស់ទាំងពាក្យរបស់យេរេមាដែរ [២១]លុះ
កាលស្តេចយេហូវ៉ាគីម[ដ] ព្រមទាំងមនុស្សខ្លាំងពូកែរបស់
ទ្រង់ និងពួកចៅហ្វាយ[ឋ] បានឮពាក្យរបស់អ្នកនោះ ហើយ
នោះស្តេចក៏រកសំឡាប់អ៊ូរីយ៉ា[ឌ] តែកាលគាត់បានដឹងនោះ
ក៏ភ័យ ហើយបានរត់[ឍ]ទៅឯស្រុកអេស៊ីព្ទ [២២]តែស្តេច
យេហូវ៉ាគីម ទ្រង់ចាត់មនុស្ស ឱ្យទៅឯស្រុកអេស៊ីព្ទ គឺអែល
ណាថាន[ណ] ជាកូនអ័កបោរ និងមនុស្សខ្លះទៀត ឱ្យទៅជា

**២៦:១២** ភ ខ.២,១៥
**២៦:១៣** ម យរ ៧:៥ យអ ២:១២-១៤ យ យរ ១១:៤ រ យរ ១៨:៨
**២៦:១៤** ល យស ៩:២៥ យរ ៣៨:៥
**២៦:១៥** វ ចទ ១៩:១០ ស ខ.១២ យរ ១:១៧
**២៦:១៦** ហ ខ.១០ កច ២៣:៩ ឡ កច ២៣:២៩
**២៦:១៨** អ មីក ១:១ ក អស ២:៣ ខ ២ពវ ២៥:៩ នហ ៤:២ យរ ៩:១១ គ មីក ៤:១ សក ៨:៣ ឃ យរ ១៧:៣
**២៦:១៩** ង ១របា ៣:១៣ ២របា ៣២:២៤-២៦ អស ៣៧:១៤-២០ ច ១សយ ១៣:១២ ឆ នក ៣២:១៤ យរ ១៨:៨ ជ យរ ៤៤:៧ ឈ ហាព ២:១០ **២៦:២០** ញ យស ៩:៧ **២៦:២១** ដ ១ពវ ១៩:២ ឋ ខ.១០ ឌ យរ ២:៣០ មថ ២៣:៣៧ ឍ លប ៣១:២១ មថ ១០:២៣
**២៦:២២** ណ យរ ៣៦:១២,២៥

**២៦:១៣** *ដូច្នេះ ចូរកែផ្លូវ និងកិរិយារបស់អ្នករាល់គ្នា* រំឭកឡើងវិញពី ៧:៣ (មើលផងដែរ ១៨:១១ ៣៥:១៥) ។ *ប្រែគំនិត* មើល ខ.៣,១៩ មើលផងដែរ មថ ២៧:២៤-២៥ កច ៥:២៦ ។

**២៦:១៥** *នោះនឹងនាំឱ្យឈាមដែលឥតមានទោស* មើល ៧:៦ និងការពន្យល់ មើលផងដែរ មថ ២៧:២៤-២៥ កច ៥:២៨ ។

**២៦:១៦** ខុសគ្នានៅក្នុង ខ.១១ មើលការពន្យល់ ខ.១០ ។

**២៦:១៧** *ពួកចាស់ទុំ* មើល ១៩:១ និងការពន្យល់ ។

**២៦:១៨-១៩** ពួកចាស់ទុំរាប់ឈ្មោះមុនពេលលោកមីកា ដែលបានរស់នៅ នៅសតវត្សជិនាន់ដើម និងអស់អ្នកដែល (នៅជាមួយលោកអេសាយ) បានជឿទុកចិត្តលើស្តេចហេសេគាល ដើម្បីជួយអធិស្ឋាន សុំឱ្យមានការអត់ទោសជិនួសពួកគេ ។ ព្រះអម្ចាស់បានឆ្លើយតប សេចក្តីអធិស្ឋានរបស់ស្តេច និងពួកហោរា ហើយនិងនៅក្នុងឆ្នាំ៧០១មុន គ.ស ក្រុងយេរូសាឡិម និងព្រះវិហារបាននៅសល់ មិនត្រូវបានបំផ្លាញឡើយ(មើល អស ៣៧:៣៣-៣៧) ។

**២៦:១៨** *មីកា ជាពួកម៉ារ៉ាសិត* មើលសេចក្តីផ្តើមក្នុងគម្ពីរមីកា អ្នកនិពន្ធ ។ *គេនឹងភ្ជួរភ្នំស៊ីយ៉ូន . . . នោះនឹងដូចជាទីខ្ពស់នៅព្រៃណាមួយ* បានដក់ស្រង ដោយន័យត្រង់ពី មីក ៣:១២ (មើលការពន្យល់ក្នុងខនេះ) មានតែ១កន្លែង គត់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានហោរាម្នាក់ដក់ស្រង់ពីកន្លែង១ផ្សេងទៀត ហើយគាត់បញ្ជាក់នូវឃ្លានោះ ។

**២៦:១៩** *ហើយទូលអង្វរចំពោះព្រះអង្គទេឬអី* ន័យត្រង់ "ទូលអង្វព្រះ" (ធៀបនឹង ទដ ១១៩:៥៨) "ការពិនិត្យមើលខ្លួននៅចំពោះព្រះ" (មើល ៣២:១១ ១សយ ១៣:១២ ២ពវ ១៣:៤) ។ *ប្រែគំនិត* មើល ខ.៣,១៣ មើលការពន្យល់ផងដែរ ៤:២៨ ១៨:៧-១០ ។

**២៦:២០-២៣** នេះជាឧទាហរណ៍មួយ ដែលផ្ទុយគ្នារវាងស្តេចល្អ គឺស្តេចហេសេគាល បានប្រព្រឹត្ត ចំពោះហោរារបស់ព្រះអម្ចាស់ និងពីអ្វីដែលស្តេចអាក្រក់ គឺស្តេចយេហូយ៉ាគីម បានប្រព្រឹត្ត ចំពោះហោរារបស់ព្រះ ។

**២៦:២០** *អ៊ូរីយ៉ា* មិនមែនបញ្ជាក់នៅកន្លែងផ្សេងទៀតទេ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ទោះជាមានការអាសអាងក្តី (ប៉ុន្តែមិនមានការចង្អុលជាភស្តុតាងទេ) ដែលឃើញមាននៅក្នុងសាររបស់ស្តេចក្រុងឡាគីស (មើលការពន្យល់ ៣៤:៧) ។

**២៦:២១** *មនុស្សខ្លាំងពូកែ* ន័យត្រង់ "មនុស្សខ្លាំង" (ប្រហែលជាអង្គរក្សរបស់ស្តេច) ។ *នោះស្តេចក៏រកសំឡាប់អ៊ូរីយ៉ា . . . ហើយបានរត់ទៅឯស្រុកអេស៊ីព្ទ* នោះជាកំហុស១ ដែលគាត់ត្រូវបានចោទប្រកាន់ថា ជាអ្នកក្បត់ជាតិ និងជាអ្នកដែលបះបោះ ។

**២៦:២២** *អែលណាថាន ជាកូនអ័កបោរ* គាត់ជាមន្ត្រីជាន់ខ្ពស់របស់ស្តេចយេហូយ៉ាគីម (មើល ៣៦:១២) គាត់បានចាប់អារម្មណ៍ទៅលើសេចក្តីទំនាយរបស់លោកយេរេមា (មើល៣ ៦:១៦) " បានជម្រុញស្តេច មិនឱ្យដុតគម្ពីរលោកយេរេមា (៣៦:២៥) ហើយបានព្រមានដល់ហោរាឱ្យលាក់គម្ពីរនោះទុក (មើល ៣៦:១៩) ។ លោកអែលណាថាន (ប្រហែលជាមនុស្សដូច

មួយ ២៣អ្នកទាំងនោះក៏នាំយកអ៊ូរីយ៉ា ពីស្រុកអេស៊ីព្ទមក
ថ្វាយដល់ស្តេចយេហូយ៉ាគីម ហើយទ្រង់ក៏សំឡាប់គាត់
ដោយដាវ[ត] ព្រមទាំងបោះខ្មោចរបស់គាត់ទៅក្នុងផ្នូរនៃ
ពួកមនុស្សធម្មតាទៅ[ថ] ២៤ប៉ុន្តែអ័ហ៊ីកាម[ទ] ជាកូនសាផាន
លោកជួយខាងយេរេមា ដើម្បីមិនឱ្យគេប្រគល់លោកទៅ
ក្នុងកណ្តាប់ដៃនៃពួកជនឱ្យគេសំឡាប់លោកឡើយ ។

## សាសន៍យូដាត្រូវបម្រើស្តេចនេប៊ូក្នេសា

**២៧** ១នៅដើមរាជ្យនៃសេដេគា[ក] ជាបុត្រយ៉ូសៀស ស្តេច
យូដា នោះព្រះបន្ទូលនេះបានមកពីព្រះយេហូវ៉ាដល់
យេរេមាថា ២ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំដូច្នេះ ចូរ
ធ្វើនឹម[ខ] និងខ្សែ ហើយពាក់នៅកឯង ៣លំដាប់នោះត្រូវផ្ញើ[គ]
ទៅថ្វាយដល់ស្តេចសាសន៍អេដំម ស្តេចសាសន៍ម៉ូអាប់
ស្តេចពួកកូនចៅអាំម៉ូន[ឃ] ស្តេចក្រុងទីរ៉ុស និងស្តេចក្រុង
ស៊ីដូន[ង] ដោយដៃពួកទូតដែលមកដល់ក្រុងយេរូសាឡិម
ដើម្បីគាល់សេដេគា ជាស្តេចយូដា ៤ព្រមទាំងផ្តាំឱ្យគេ
ប្រាប់ដល់ចៅហ្វាយគេ ដោយពាក្យថា ព្រះយេហូវ៉ានៃពួក
ពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូល
ដូច្នេះ ចូរឱ្យអ្នករាល់គ្នាជំរាបដល់ចៅហ្វាយខ្លួនយ៉ាងនេះ
ថា ៥អញបានបង្កើត[ច]ផែនដី និងមនុស្ស ហើយសត្វ[ឆ] ដែល
នៅលើផែនដីទាំងប៉ុន្មាន ដោយសារឫទ្ធិដ៏ធំ និងដៃ[ជ]លើក
សំរេចរបស់អញ ក៏ប្រគល់[ឈ]ដល់អ្នកណាដែលអញគិត
ឃើញថាគួរ ៦ឥឡូវនេះ អញបានប្រគល់ស្រុកទាំងនេះ ទៅ
ក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសា[ញ] ស្តេចបាប៊ីឡូន ជាអ្នកបំរើ[ដ]
របស់អញហើយ ក៏បានឱ្យអស់ទាំងសត្វនៅវាល សំរាប់នឹង
បំរើគេដែរ[ឋ] ៧សាសន៍ទាំងអស់នឹងបំរើ[ឌ]ស្តេចនោះ និងកូន

**២៦:២៣** ត ហ៣ ១១:៣៧ ថ ២ពវ ២៣:៦ **២៦:២៤** ទ ២ពវ ២២:១២ **២៧:១** ក ២របា ៣៦:១១ **២៧:២** ខ លវ ២៦:១៣ ១ពវ ២២:១១ **២៧:៣** គ យរ ២៥:១៧ ឃ យរ ២៥:២១ ង លប ១០:១៥ យរ ២៥:២២ **២៧:៥** ច លប ១:១ ឆ លប ១:២៥ ជ លប ១:១ ឈ ទដ ១១៥:១៦ ដយ ៤:១៧ **២៧:៦** ញ យរ ២៥:៩ ដ យរ ២១:៧ ឋ យរ ២៨:១៤ ដយ ២:៣៧–៣៨ **២៧:៧** ឌ ២របា ៣៦:២០ ដយ ៥:១៨

គ្នា) គឺជាឪពុកក្មេករបស់ស្តេចយេហូយ៉ាគីម (មើល ២ពវ ២៤:៦,៨) ។ អ័កបោរ (ប្រដែលជាឪពុករបស់អែលណាថាន) ជាមន្ត្រីជាន់ខ្ពស់របស់ស្តេចយ៉ូសៀស (មើល ២ពវ ២២:១២,១៤ មើលការពន្យល់ផង ខ.១៤) ។

**២៦:២៣** *អ្នកទាំងនោះក៏នាំយកអ៊ូរីយ៉ា ពីស្រុកអេស៊ីព្ទ* នេះជាកិច្ចព្រមព្រៀងរវាងគ្នាទៅវិញទៅមក មួយដ៏ត្រឹមត្រូវ ដែលពួកអេស៊ីព្ទ បានដាក់ឱ្យពួកយូដាគោរពតាម នៅពេលដែលស្តេចយេហូយ៉ាគីម បាននៅក្រោមចំណុះប្រទេសអេស៊ីព្ទ គឺស្តេចផារ៉ោននេកោទី២ (មើល ២ពវ ២២:៣៤–៣៥ ) ។ *មកថ្វាយដល់ស្តេចយេហូយ៉ាគីម ហើយទ្រង់ក៏សំឡាប់គាត់ដោយដាវ* នេះជាផ្នែក១ ដែលជាការអន្តរាគមន៍មកពីព្រះ បើមិនដូច្នោះទេ ប្រហែលជាលោកយេរេមាបានក្លាយខ្លួនជាជនរងគ្រោះ ដូចរឿងនោះដែរ (មើល ៣៦:២៦) ។ *ព្រមទាំងបោះខ្មោចរបស់គាត់ទៅក្នុងផ្នូរនៃពួកមនុស្សធម្មតាទៅ* មើលការពន្យល់ ១៧:១៩ ។ ខ្មោចរបស់មនុស្សធម្មតា បានកប់នៅជ្រោះកេដ្រុន នៅខាងកើតក្រុងយេរូសាឡិម (មើល ២ពវ ២៣:៦) ។

**២៦:២៤** *ប៉ុន្តែអ័ហ៊ីកាម ជាកូនសាផាន* គាត់ជាមន្ត្រីជាន់ខ្ពស់ម្នាក់ របស់ស្តេចយ៉ូសៀស (មើល ២ពវ ២២:១២,១៤) ដែលមានទំនាក់ទំនងជាមួយនឹងអ័កបោរ គាត់គឺជាឪពុករបស់អែលណាថាន ក្នុង ខ.២២ (មើលការពន្យល់ក្នុងខនេះ) ។ លោកអ័ហ៊ីកាម គឺជាឪពុករបស់កេដាលាផងដែរ បានក្លាយជាអ្នកគ្រប់គ្រងនៅស្រុកយូដា ក្រោយពីក្រុងយេរូសាឡិមត្រូវបានបំផ្លាញ នៅក្នុងឆ្នាំ៥៨៦មុន គ.ស (មើល ៤០:៥) ហើយគាត់ជាមិត្តរបស់លោកយេរេមាផងដែរ (មើល ៣៩:១៤) ។ *លោកជួយខាងហោរាយេរេមា* លោកអ័ហ៊ីកាម មានតួនាទីយ៉ាងខ្ពស់ នៅក្នុងផ្នែកតុលាការរបស់ស្តេចយេហូយ៉ាគីម ដែលគាត់ជាឧបករណ៍យ៉ាងសំខាន់ ក្នុងការជួយសង្គ្រោះដល់ជីវិតហោរា ។

**២៧:១–២៩:៣២** លោកយេរេមាមានបំណងលល្អ ដើម្បីជំទាស់ចំពោះសេចក្តីបង្រៀនរបស់ហោរាខុសឆ្គង ដែលបានអះអាងថា សេចក្តីហិនវិនាសរបស់បាប៊ីឡូននៅជិតបង្កើយ និងការបះបោរប្រឆាំងជាមួយ ស្តេចនេប៊ូក្នេសា នោះអាចទទួលយកបាន ។

**២៧:១–២២** លោកយេរេមាប្រាប់ដល់ប្រជាជាតិ (ខ.៣–១១) ស្តេចសេដេគាល (ខ.១២–១៥) ពួកសង្ឃនិងបណ្តាជនយូដា (ខ.១៦–២២) ឱ្យចុះចូលជាមួយនឹមពួកបាប៊ីឡូន ។

**២៧:១** *នៅដើមរាជ្យ* មើលការពន្យល់ ២៦:១ នៅក្នុងករណីនេះ ទោះបីជាយ៉ាងណា ឃ្លានេះបានពង្រីកអត្ថន័យរួម ក្នុងការគ្រប់គ្រងនៅឆ្នាំទី៤ របស់ស្តេចសេដេគាល (ឆ្នាំ ៥៩៣ គ.ស មើល ២៨:១) ។

**២៧:២** *ចូរធ្វើនឹម* នេះជានឹមដែលគេទឹមគោឈ្មោល វាជានិមិត្តរូបអំពីនយោបាយ ការចុះចូល (មើល ខ.៨,១១–១២ លវ ២៦:១៣) ។ ដែលលោកយេរេមាបានពាក់នឹមនៅកយ៉ាងច្បាស់ នៅក្នុងពេលមួយ ក្នុង ២៨:១០,១២ ។

**២៧:៣** *ត្រូវទៅថ្វាយ* នៅក្នុងតួនាទីរបស់គាត់ "ហោរាទៅដល់ប្រជាជាតិ" (១:៥) ។ *ស្តេចសាសន៍អេដំម ស្តេចសាសន៍ម៉ូអាប់ ស្តេចពួកកូនចៅអាំម៉ូន* នៅឯស្រុកយូដាខាងកើត និងខាងត្បូង (មើល ២៥:២១ និងការពន្យល់) ។ *ស្តេចក្រុងទីរ៉ុស និងស្តេចក្រុងស៊ីដូន* ជាក្រុងដែលមើលឃើញពីស្រុកភេនីសនៅខាងជើងស្រុកយូដា (មើល ២៥:២២) ។ *ដោយដៃពួកទូតដែលមកដល់ក្រុងយេរូសាឡិម ដើម្បីគាល់សេដេគា* ប្រហែលជាការពិភាក្សាគ្នា ដើម្បីបះបោរប្រឆាំងពួកបាប៊ីឡូន ពួកគេបានទទួលនូវការគាំទ្រពីអេស៊ីព្ទ នៅពេលដែល សាមេទីកូសទី២ (Psameticus II) បានក្លាយជាស្តេចផារ៉ោន១ឆ្នាំកាលនៅជំនាន់ដើម (៥៩៥ គ.ស) ។ ស្តេចសេដេគា បានទៅក្រុងបាប៊ីឡូននៅក្នុងឆ្នាំ៥៩៣ (មើល ៥១:៥៩) ហើយស្តេចនេប៊ូក្នេសា បានចោទសួរស្តេចសេដេគា ក្នុងករណីណាមួយ ដែលស្តេចសេដេគាបានបះបោរប្រឆាំងនឹងទ្រង់នោះ (មើល ៥២:៣) ។

**២៧:៥** *ដោយសារឫទ្ធិដ៏ធំ និងដៃលើកសំរេចរបស់អញ* មើលការពន្យល់ ២១:៥ ។

**២៧:៦** *នេប៊ូក្នេសា ស្តេចបាប៊ីឡូន ជាអ្នកបំរើរបស់អញ* មើលការពន្យល់ ២៥:៩ ។ *ក៏បានឱ្យអស់ទាំងសត្វនៅវាល សំរាប់នឹងបំរើគេដែរ* គ្មានអ្វីមួយអាចប៉ះពាល់ដល់អំណាចរបស់ស្តេចនេប៊ូក្នេសា (មើល ២៨:១៤ ដយ ២:៣៨) ។

**២៧:៧** *សាសន៍ទាំងអស់នឹងបំរើស្តេចនោះ និងកូន ហើយនិងចៅរបស់គេ*

ហើយនិងចៅរបស់គេផង ដរាបដល់កំណត់[ឍ]នៃស្រុកគេ
នោះសាសន៍ជាច្រើន ហើយស្តេចធំនឹងចាប់[ណ]ស្តេចនោះ
ប្រើជាបាវវិញ ៨រីឯសាសន៍ណា ឬនគរណា ដែលមិនព្រម
បំរើនេប៊ូក្នេសា ជាស្តេចបាប៊ីឡូននេះ ហើយមិនព្រមឱនក
ទទួលនឹមរបស់ស្តេចបាប៊ីឡូន នោះព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា អញនឹងធ្វើទោស[ត]ដល់សាសន៍នោះ ដោយដាវ[ថ]
អំណត់អត់[ទ] និងអាសន្នរោគ[ធ] ទាល់តែអញបានឱ្យគេសូន្យ
បាត់ ដោយដៃរបស់ស្តេចនោះទៅ ៩តែឯងឯងរាល់គ្នា កុំឱ្យ
ស្តាប់តាមពួកហោរារបស់ឯង[ន] ឬតាមពួកគ្រូទាយ[ប] ពួក
យល់សប្តិ[ផ] ពួកគ្រូអង្គុយធម៌[ព] ឬពួកគ្រូនក្ខត្តឫក្ស[ភ] ដែល
និយាយនឹងឯងរាល់គ្នាថា មិនត្រូវឱ្យបំរើ[ម]ស្តេចស្រុក
បាប៊ីឡូននោះឡើយ ១០ដ្បិតគេទាយជាសេចក្តីកុហក[យ]ដល់
ឯងរាល់គ្នាទេ ដើម្បីឱ្យឯងត្រូវព្រាត់ចាក[រ]ឆ្ងាយពីស្រុក
របស់ឯង គឺឱ្យអញបានបណ្តេញឯងរាល់គ្នាចេញ ហើយឱ្យ
ឯងត្រូវវិនាសបង់ ១១តែសាសន៍ណាដែលឱនក ទទួលនឹម[ល]
ហើយបំរើដល់ស្តេចបាប៊ីឡូនវិញ នោះអញនឹងទុកគេ
ឱ្យនៅក្នុងស្រុករបស់ខ្លួន គេនឹងភ្ជួររាស់ដី ហើយអាស្រ័យ
នៅ[វ]ផង នេះហើយជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
១២ខ្ញុំក៏បានទូលដល់សេដេគា ជាស្តេចយូដា តាមគ្រប់
ទាំងពាក្យនេះថា ចូរឱ្យអ្នករាល់គ្នាឱនកទទួលនឹម[ស] ទៅបំរើ
ដល់ស្តេចបាប៊ីឡូន និងរាស្ត្ររបស់គេចុះនោះនឹងបានរួច
ជីវិត[ហ] ១៣តើចង់ស្លាប់[ឡ]ធ្វើអី គឺទាំងអង្គទ្រង់នឹងរាស្ត្ររបស់

**២៧:៧** ឍ យរ ២៥:១២ ណ យរ ២៥:១៤ ៥១:៤៧ ដយ ៥:២៨
**២៧:៨** ត យរ ៩:១៦ ថ យរ ២១:៩ ទ យរ ៥:១២ ធ យរ ១៤:១២
**២៧:៩** ន អគ ១៣:១–២៣ ប លប ៣០:២៧ អស ៤៤:២៥ ផ ចទ ១៣:១ យរ ២៣:២៥ ព ចទ ១៨:១១ ភ នក ៧:១១ ម យរ ៦:១៤
**២៧:១០** យ យរ ២៣:២៥ មក ១៣:៥ រ ២ពវ ២៣:២៧
**២៧:១១** ល ២១:៩ វ ចទ ៦:២
**២៧:១២** ស យរ ១៧:៤ ហ យរ ២១:៩
**២៧:១៣** ឡ អគ ១៨:៣១ អ យរ ១៤:១២
**២៧:១៤** ក យរ ២៣:១៦ ខ យរ

ទ្រង់ផង ដោយដាវអំណត់អត់ និងអាសន្នរោគ[អ] ដូចជាព្រះ
យេហូវ៉ាបានមានបន្ទូល ពីដំណើរសាសន៍ណា ដែលមិន
ព្រមបំរើដល់ស្តេចបាប៊ីឡូនដូច្នេះ ១៤កុំឱ្យស្តាប់តាម[ក]ពាក្យ
របស់ហោរា[ខ] ដែលនិយាយនឹងអ្នករាល់គ្នាថា មិនត្រូវបំរើ
ដល់ស្តេចបាប៊ីឡូននោះឡើយ ដ្បិតគេទាយជាសេចក្តី
កុហក[គ]ទេ ១៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញមិនបាន
ចាត់[ឃ]គេឱ្យមកសោះ គឺគេទាយជាសេចក្តីកំភូត ដោយនូវ
ឈ្មោះអញវិញ[ង] ដើម្បីឱ្យអញបានបណ្តេញឯងរាល់គ្នាចេញ
ហើយឱ្យឯងរាល់គ្នាត្រូវវិនាសបង់[ច] គឺទាំងខ្លួនឯងរាល់គ្នា
និងពួកហោរាដែលទាយដល់ឯងផង ។
១៦ខ្ញុំក៏បានប្រាប់ដល់ពួកសង្ឃ និងពួកជនទាំងឡាយថា
ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ កុំឱ្យស្តាប់តាមពាក្យ
របស់ពួកហោរា ដែលទាយដល់ឯងរាល់គ្នាថា មើល បន្តិច
ទៀត គេនឹងនាំយកអស់ទាំងគ្រឿងប្រដាប់[ឆ] របស់ព្រះវិហារ
នៃព្រះយេហូវ៉ា ពីក្រុងបាប៊ីឡូនមកវិញ ដ្បិតគេទាយជា
សេចក្តីកុហកដល់ឯងរាល់គ្នាទេ ១៧កុំឱ្យស្តាប់តាម[ជ]គេឡើយ
ត្រូវឱ្យបំរើស្តេចបាប៊ីឡូនចុះ នោះនឹងបានរួចជីវិត[ឈ] តើ
មានទំនងអ្វី ឱ្យទីក្រុងនេះត្រូវខូចបង់ ១៨បើគេជាហោរាពិត
ហើយបើព្រះបន្ទូលនៃព្រះយេហូវ៉ានៅជាមួយនឹងគេ នោះ

១៤:១៣ គ យរ ១៤:១៤ មថ ៧:១៥ **២៧:១៥** ឃ យរ ២៣:២១ ង យរ ២៩:៩ ៤៤:១៦ ច យរ ៦:១៥ មថ ១៥:១២–១៤ **២៧:១៦** ឆ ១ពវ ៧:៤៨–៥០ ២ពវ ២៤:១៣ **២៧:១៧** ជ យរ ២៣:១៦ ឈ យរ ៤២:១១

*ផង* កូនចៅជំនាន់ក្រោយទាំងបីជំនាន់ នៃអ្នកគ្រប់គ្រង មិនមែនជាការចាំបាច់ ក្នុងការទំនាក់ទំនងដោយផ្ទាល់រវាងឪពុក និងកូននោះឡើយ (មើលការពន្យល់ ដយ ៥:១ មើលការពន្យល់ផងដែរ លប ១០:២,៨) ។ *ដរាបដល់កំណត់នៃស្រុកគេ* ពួកបាប៊ីឡូននឹងត្រូវទទួលនូវការជំនុំជម្រះ (មើល ២៥:២៦) ។ *សាសន៍ជាច្រើន ហើយស្តេចធំ* មើលការពន្យល់ ២៥:១៤ ។

**២៧:៨** *ទទួលនឹម* មើលការពន្យល់ ខ.២ ។ *ដោយដាវ អំណត់អត់ និងអាសន្នរោគ* មើលការពន្យល់ ១៤:១២ ។ *ទាល់តែអញបានឱ្យគេសូន្យបាត់* មើល ៩:១៦ ២៤:១០ ។

**២៧:៩** មើល ២៩:៨ ។ *កុំឱ្យស្តាប់តាមពួកហោរារបស់ឯង ពួកហោរាខុសឆ្គង ឬតាមពួកគ្រូទាយ ពួកយល់សប្តិ ពួកគ្រូអង្គុយធម៌ ឬពួកគ្រូនក្ខត្តឫក្ស* ទាំងអស់នេះ គឺត្រូវបានហាមឃាត់នៅក្នុងពួកអ៊ីស្រាអែល (មើល លវ ១៩:២៦ ចទ ១៨:១០–១១) ។ *ពួកយល់សប្តិ* រួមទាំងពួកហោរា និងគ្រូទាយផងដែរ (មើល ២៣:២៥–២៨ ១៩:៨) ។

**២៧:១០** *ដ្បិតគេទាយជាសេចក្តីកុហក* មើលការពន្យល់ ៥:៣១ ធៀបនឹង ២ធថ ៤:៣–៤ ។

**២៧:១១** *ដែលឱនក ទទួលនឹម* មើលការពន្យល់ ខ.២ ។ *អញនឹងទុកគេ . . . ភ្ជួររាស់ដី* នៅក្នុងព្រះគម្ពីរភាសាហេព្រើរគូសបញ្ជាក់ពាក្យទាំងពីរនេះដូចគ្នា ("ការងារ" គឺនៅក្នុងនោះមានការភ្ជួររាស់ដី) ។

**២៧:១២** *ចូរឱ្យអ្នករាល់គ្នាឱនកទទួលនឹម ទៅបំរើ . . . នោះនឹងបានរួចជីវិត* រួចជីវិត នៅក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យទាំងអស់នេះ គឺជាពាក្យពហុវចនៈ នៅពេលដែលលោកយេរេមា កំពុងនិយាយទៅកាន់បណ្តាជនយូដា ដូចជាគាត់បានទូលទៅកាន់ស្តេចសេដេគា (មើល ខ.១៣) ។ *នឹម* មើលការពន្យល់ ខ.២ ។

**២៧:១៣** មើល ខ.៣ ។ *ដោយដាវអំណត់អត់ និងអាសន្នរោគ* មើលការពន្យល់ ១៤:១២ ។

**២៧:១៤** មើល ខ.៩–១០ ។

**២៧:១៥** មើល ១៤:១៤ ២៣:២១ និងការពន្យល់ ។

**២៧:១៦** *ពាក្យរបស់ពួកហោរា ដែលទាយដល់ឯងរាល់គ្នាថា មើលបន្តិចទៀត* ដូចជាហោរាហាណានាបាននិយាយថា (មើល ២៨:១–៣) ។ *គេនឹងនាំយកអស់ទាំងគ្រឿងប្រដាប់របស់ព្រះវិហារនៃព្រះយេហូវ៉ា* ដែលមួយចំនួនត្រូវបាននាំយកទៅបាប៊ីឡូន ដោយស្តេចនេប៊ូក្នេសា នៅក្នុងឆ្នាំ ៦០៥ គ.ស ។ (មើល ដយ ១:១–២) និងមួយចំនួនទៅត្រូវបាននាំយកទៅនៅក្នុងឆ្នាំ ៥៩៧ (មើល ២ពវ ២៤:១៣) ។ ហើយនិងអ្នកផ្សេងទៀតបាននាំយកទៅនៅក្នុងឆ្នាំ ៥៨៦ (មើល ខ.២១–២២ ៥២:១៧–២៣) ។

**២៧:១៨** *បើគេជាហោរាពិត . . . នោះឱ្យគេទូលអង្វរ* បើសិនគេជាហោរាពិត ហើយមានទំនាក់ទំនងជាមួយនឹងព្រះអម្ចាស់មែន សូមឱ្យគេទូលអង្វរ

ឱ្យគេទូលអង្វរ[ញ] ដល់ព្រះយេហូវ៉ានៃពួកពលបរិវារ ឥឡូវ
នេះចុះ ដើម្បីសូមកុំឱ្យគ្រឿងប្រដាប់ដែលនៅសល់ក្នុងព្រះ
វិហារនៃព្រះយេហូវ៉ា ហើយនៅក្នុងដំណាក់ស្តេចយូដា
ដែលនៅក្រុងយេរូសាឡិម បានត្រូវដឹកនាំយកទៅឯក្រុង
បាប៊ីឡូនទៀត ១៩ដ្បិតព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់
មានបន្ទូលពីដំណើរសសរ សមុទ្រ[ដ] និងជើងថ្កល់ ហើយនិង
គ្រឿងប្រដាប់[ឋ]ដែលនៅសល់ក្នុងទីក្រុងនេះ ២០ជាគ្រឿង
ដែលនេប៊ូក្នេសា ស្តេចបាប៊ីឡូនមិនបានយកទៅ ក្នុងកាល
ដែលចាប់យកយេកូនាស[ឌ] ជាបុត្រយេហូយ៉ាគីម ស្តេចយូដា
នាំចេញ[ឍ]ពីក្រុងយេរូសាឡិមទៅជាឈ្លើយដល់ក្រុងបាប៊ី–
ឡូន ព្រមទាំងពួកអ្នកធំនៃស្រុកយូដា និងក្រុងយេរូសាឡិម
ផង ២១អើ ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃ
សាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលពីដំណើរគ្រឿងប្រដាប់
ទាំងប៉ុន្មាន ដែលនៅសល់ក្នុងព្រះវិហារនៃព្រះយេហូវ៉ា
ហើយក្នុងដំណាក់ស្តេចយូដា ដែលនៅក្រុងយេរូសាឡិម
ថា ២២គេនឹងដឹកនាំ[ណ]គ្រឿងទាំងនោះ ទៅឯក្រុងបាប៊ីឡូន
ហើយនឹងត្រូវនៅទីនោះ ដរាបដល់ថ្ងៃ[ត]ដែលអញប្រោស
នោះអញនឹងនាំយក[ថ]ឡើងមក ដាក់នៅត្រង់កន្លែងដើម វិញ
នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

### ហោរាក្លែងក្លាយហាណានា

**២៨** ១លំដាប់នោះ ក្នុងឆ្នាំដដែល គឺនៅដើមរាជ្យនៃ
សេដេគា[ក] ស្តេចយូដា ក្នុងខែស្រាពណ៍ឆ្នាំទី៤ នោះហោ

**២៧:១៨** ញ ជន ២១:៧ ១សយ ៧:៨
**២៧:១៩** ដ ១ពវ ៧:២៣–២៦ ឋ ១ពវ ៧:៥១ យរ ៥២:១៧–២៣
**២៧:២០** ឌ យរ ២២:២៤ មថ ១:១១ ឍ ចទ ២៣:៣៦ ២របា ៣៦:១០
**២៨:១** ក ២របា ៣៦:១១
ខ យស ៩:៣
**២៨:២** គ យរ ២៧:១២
**២៨:៣** ឃ ២ពវ ២៤:១៣
**២៨:៤** ង ២ពវ ២៥:៣០ យរ ២២:២៤–២៧ ច ហស ៧:៣
**២៨:៦** ឆ សក ៦:១០

រាហាណានា ជាកូនអ័ស៊ើរ ដែលនៅគីបៀន[ខ]បាននិយាយ
នឹងខ្ញុំ នៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា ចំពោះពួកសង្ឃ
នឹងបណ្តាជនថា ២ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះ
នៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ អញបាន
បំបាក់នឹម[គ]របស់ស្តេចបាប៊ីឡូនហើយ ៣នៅរវាងគំរប់២
ឆ្នាំទៀត នោះអញនឹងនាំយកអស់ទាំងគ្រឿងប្រដាប់[ឃ]របស់
ព្រះវិហារនៃព្រះយេហូវ៉ា ដែលនេប៊ូក្នេសា ជាស្តេច
បាប៊ីឡូនបានយកពីទីនេះទៅដល់ស្រុកបាប៊ីឡូនត្រឡប់មកឯ
កន្លែងដើមវិញ ៤អញក៏នឹងនាំយេកូនាស ជាបុត្រយេហូ–
យ៉ាគីម[ង] ស្តេចយូដា និងពួកយូដាទាំងប៉ុន្មាន ដែលត្រូវដឹក
នាំទៅជាឈ្លើយ ដល់ក្រុងបាប៊ីឡូន ឱ្យវិលមកឯទីនេះវិញ
ដែរ ដ្បិតអញនឹងបំបាក់នឹមរបស់ស្តេចបាប៊ីឡូនពិត នេះ
ហើយជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ច] ។
៥រួចហោរាយេរេមា ក៏និយាយនឹងហាណានា នៅ
ចំពោះពួកសង្ឃ និងបណ្តាជនដែលឈរនៅក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា ៦គឺហោរាយេរេមានិយាយថា អាម៉ែន
សូមឱ្យព្រះយេហូវ៉ាធ្វើដូច្នោះចុះ សូមឱ្យព្រះយេហូវ៉ា
សំរេចតាមពាក្យដែលអ្នកបានទាយនោះ ដើម្បីនឹងនាំយក
អស់ទាំងគ្រឿងប្រដាប់របស់ព្រះវិហារនៃព្រះយេហូវ៉ា និង
អស់អ្នកដែលត្រូវដឹកទៅជាឈ្លើយនោះ ឱ្យត្រឡប់មកពីក្រុង
បាប៊ីឡូនដល់ទីនេះវិញ[ឆ] ៧ប៉ុន្តែចូរស្តាប់ពាក្យដែលខ្ញុំ
ពោលនៅត្រចៀកអ្នក និងនៅត្រចៀករបស់បណ្តាជនទាំង

ជិន្ទូសពួកយូដា ពីព្រោះព្រះអម្ចាស់បានប្រកាសថា ទ្រង់នឹងជិនុំជម្រះដល់ពួកយូដា ។

**២៧:១៩** *ពីដំណើរសសរ សមុទ្រ និងជើងថ្កល់* មើល ៥២:១៧ មើលផងដែរ ១ពវ ៧:១៥–១៧ និងការពន្យល់ ។

**២៧:២២** *គេនឹងដឹកនាំគ្រឿងទាំងនោះ* ទៅឯក្រុងបាប៊ីឡូន នៅក្នុងឆ្នាំ ៥៨៦ គ.ស (មើល ៥២:១៧–២៣) ។ *អញនឹងនាំយកឡើងមក* នៅក្នុងឆ្នាំ ៥៣៧ និងមួយរយៈខ្លីក្រោយមក (មើល អគ ១:៧–១១) ។

**២៨:១–១៧** ហោរាពិត គឺហោរាយេរេមា បានប្រឈមមុខជាមួយនឹងហោរាក្លែងក្លាយ គឺហោរាហាណានា ។

**២៨:១** *ក្នុងឆ្នាំដដែល . . . សេដេគាល* នៅក្នុងឆ្នាំ ៥៩៣ គ.ស ។ *នៅដើមរាជ្យ* មើលការពន្យល់ ២៦:១ ២៧:១ ។ *ហោរា* ពាក្យគឺបានប្រើសម្រាប់ហោរា ទាំងអស់ ទាំងហោរាពិត (ខ.៥,១០–១២) ឬទាំងហោរាខុសឆ្គង (ខ.១,៥,១០,១២,១៥,១៧) ។ *ហាណានា* គឺមានន័យថា "ព្រះអម្ចាស់ទ្រង់ល្អ" ជាឈ្មោះមួយដ៏សមរម្យ សម្រាប់ហោរាដែលមានជំនឿយ៉ាងរឹងមាំ (ទោះបីជាគេមានកំហុសក្តី) ដែលព្រះអម្ចាស់នឹងនាំពួកអ្នកដែលជាប់ជាឈ្លើយ ពួកយូដា និងគ្រឿងប្រដាប់របស់ព្រះវិហារ ត្រឡប់មកវិញ (ខ.៣–៤,១១) ។ *ដែលនៅគីបៀន* មើល ៤១:១២,១៦ មើលការពន្យល់ផងដែរ យក ៩:៣ ។

**២៨:២** *ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃអ៊ីស្រាអែល ទ្រង់មានបន្ទូលយ៉ាងដូច្នេះ* មើល ខ.១១ ។ ទោះបីជាហោរាខុសឆ្គង ហោរាហាណានា អះអាងឱ្យមានអំណាចដូចគ្នានឹងលោកយេរេមាក្តី (មើល ខ.១៣–១៤,១៦ មើលផងដែរ ២៣:៣១) ។ *នឹម* មើលការពន្យល់ ២៧:២ ។

**២៨:៣** ពាក្យទំនាយដោយផ្ទាល់របស់ហោរាហាណានា គឺខុសគ្នាទៅនឹងសេចក្តីទំនាយរបស់ហោរាយេរេមា (មើល្ប ២៧:១៦–២២ និងការពន្យល់) ។ នៅរវាងគំរប់២ឆ្នាំ មើល ខ.១១ ផ្ទុយគ្នាទៅនឹងការគំរប់៧០ឆ្នាំរបស់លោកយេរេមា (២៥:១១–១២ ២៩:១០) ។

**២៨:៤** *អញក៏នឹងនាំ* គេនិយាយជំទាស់នឹងសេចក្តីទំនាយរបស់លោកយេរេមា (មើល ២២:២៤–២៧) ដែលបានកើតឡើង (មើល ៥២:៣៤) ។ *យេហូយ៉ាគីម . . . ដែលត្រូវដឹកនាំទៅជាឈ្លើយ ដល់ក្រុងបាប៊ីឡូន* នៅក្នុងឆ្នាំ ៥៩៧ គ.ស ។ *នឹម* មើលការពន្យល់ ២៧:២ ។

**២៨:៦** មើល ១ពវ ១:៣៦ ។ *អាម៉ែន* មើល ១១:៥ និងការពន្យល់ ។ *សូមឱ្យព្រះយេហូវ៉ាសំរេច* នេះជាទីសម្គាល់មួយនៃសេចក្តីទំនាយពិត (មើល ខ.៩ មើលផងដែរ ចទ ១៨:២១–២២ និងការពន្យល់) ។ ចំពោះទីសម្គាល់មួយផ្សេងទៀត(ឬការសាកល្បង) មើល ចទ ១៣:១–៥ និងការពន្យល់ ។

**២៨:៧** *ប៉ុន្តែ* ទោះបីជានេះដូចជាការអាណិតអាសូ ចំពោះអ្វីដែលហោរាហាណានាកំពុងទាយក្តី នោះលោកយេរេមារំឭកថា ចុងក្រោយសេចក្តី

នេះឥឡូវចុះ ⁸ឯពួកហោរាកាលពីដើម ដែលនៅមុខខ្ញុំ
ហើយនិងអ្នក គេបានទាយទាស់នឹងស្រុកជាច្រើន ហើយ
ទាស់នឹងនគរយ៉ាងធំ គឺទាយពីចំបាំង ពីការអាក្រក់ និងពី
អាសន្នរោគ[ជ]ផង ៩តែហោរាណាដែលទាយពីសន្តិសុខ
បើកាលណាទំនាយរបស់ហោរានោះ បានសំរេចហើយ
នោះទើបនឹងស្គាល់ហោរានោះថា ព្រះយេហូវ៉ាបានចាត់
ប្រើមកមែន[ឈ] ១០នោះហោរហាណានា ក៏យកនឹម[ញ]ពីក
ហោរាយេរេមាទៅបំបាក់ចោល ១១រួចហាណានានិយាយ[ដ]
ចំពោះបណ្តាជនទាំងឡាយថា ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះគឺយ៉ាងនេះឯង ដែលអញនឹងបំបាក់នឹមរបស់នេប៊ូ-
ក្នេសា ជាស្តេចបាប៊ីឡូន ចេញពីកនៃអស់ទាំងសាសន៍ក្នុង
រវាងគំរប់២ឆ្នាំទៅមុខនេះ នោះហោរាយេរេមាក៏ចេញ
ទៅបាត់ ។

១២រួចមក ក្នុងពេលក្រោយដែលហោរាហាណានា
បានបំបាក់នឹមពីកយេរេមាចេញហើយ នោះព្រះបន្ទូល
នៃព្រះយេហូវ៉ាបានមកដល់លោកថា ១៣ចូរទៅប្រាប់ដល់
ហាណានាថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អ្នកបាន
បំបាក់នឹមដែលធ្វើពីឈើ តែឯងបានធ្វើនឹមដែកជំនួសវិញ
១៤ដ្បិតព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃពួកសាសន៍
អ៊ីស្រាអែលទ្រង់មានបន្ទូលដូច្នេះថា អញបានដាក់នឹមដែក[ឋ]
នៅកនៃសាសន៍ទាំងនេះហើយ ដើម្បីឱ្យគេត្រូវបំរើ[ឌ] នេប៊ូ-
ក្នេសា[ឍ] ជាស្តេចបាប៊ីឡូន ហើយគេនឹងបំរើពិតមែនអញក៏
បានឱ្យសត្វនៅវាល ដល់គេដែរ[ណ] ១៥រួចហោរាយេរេមា
និយាយទៅហោរាហាណានាថា នែ ហាណានាចូរស្តាប់
ឥឡូវចុះ ព្រះយេហូវ៉ាមិនបានចាត់[ត] ប្រើអ្នកទេ គឺអ្នកនាំ
ឱ្យសាសន៍នេះទុកចិត្តចំពោះសេចក្តីកំភូតវិញ[ថ] ១៦ហេតុ
នេះព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មើល អញនឹង
បណ្តេញ ឯងឱ្យបាត់ចេញពីផែនដីទៅ[ទ] គឺឯងនឹងត្រូវស្លាប់
ក្នុងឆ្នាំនេះ[ធ] ពីព្រោះឯងបានពោលសេចក្តីបះបោរ[ន]ទាស់
នឹងព្រះយេហូវ៉ា ១៧ដូច្នេះ នៅខែអស្សុជ ក្នុងឆ្នាំនោះឯង
ហោរាហាណានាក៏ស្លាប់ទៅ[ប] ។

## សំបុត្រទៅកាន់ពួកជាប់ជាឈ្លើយ

**២៩** ១នេះឯងជាសេចក្តីចុះក្នុងសំបុត្រ[ក] ដែលហោរា
យេរេមាបានផ្ញើពីក្រុងយេរូសាឡិម ទៅឯសំណល់ពួក
ចាស់ទុំ ក្នុងពួកដែលត្រូវដឹកទៅជាឈ្លើយ ហើយនឹងពួក
សង្ឃ ពួកហោរា និងបណ្តាជនទាំងអស់ ដែលនេប៊ូក្នេសា
បានដឹកជាឈ្លើយ ពីក្រុងយេរូសាឡិមទៅឯស្រុកបាប៊ីឡូន[ខ]
២គឺក្នុងគ្រាក្រោយដែលស្តេចយេកូនាស[គ] និងអគ្គមហេសី[ឃ]
ពួកសេនាបតី ពួកចៅហ្វាយនៃស្រុកយូដា និងក្រុងយេរូ-
សាឡិម ព្រមទាំងពួកជាងឈើនឹងជាងដែក បានចេញពី
ក្រុងយេរូសាឡិមអស់ហើយ ៣លោកផ្ញើសំបុត្រនោះដោយ
សារដៃអេលាសារ ជាកូនសាផាន និងកេម៉ារ៉ាជាកូន

**២៨:៨** ជ លវ ២៦:១៤–១៧ អស ៥:៥–៧ ណហ ១:១៤
**២៨:៩** ឈ ចទ ១៨:២២ អគ ៣៣:៣៣
**២៨:១០** ញ លវ ២៦:១៣ ១ពវ ២២:១១
**២៨:១១** ដ យរ ១៤:១៤ ២៧:១០
**២៨:១៤** ឋ ចទ ២៨:៤៨ យរ ១៥:១២ ឌ យរ ២៥:១១ ឍ យរ ៣៩:១ ដយ ១:១ ៥:១៨ ណ យរ ២៧:៦
**២៨:១៥** ត យរ ២៩:៣១ ថ យរ ៧:៤ ២០:៦ ២៩:២១ បទ ២:១៤ អគ ១៣:៦
**២៨:១៦** ទ លប ៧:៤ ធ ចទ ១៨:២០ សក ១៣:៣ ន ចទ ១៣:៥ យរ ២៩:៣២
**២៨:១៧** ប ២ពវ ១:១៧

**២៩:១** ក ខ.២៨ ខ ២របា ៣៦:១០ យរ ១៣:១៧ **២៩:២** គ ២ពវ ២៤:១២ ឃ ២ពវ ២៤:៨

ទំនាយរបស់ហោរាខុសឆ្គង នោះគឺសេចក្តីហិនវិនាស (មើល ខ.៨) ។

**២៨:៨** *គឺទាយពីចំបាំង ពីការអាក្រក់ និងពីអាសន្នរោគផង* នេះជាកត្តាទាំងបីដែលលោកយេរេមា ប្រាប់ឱ្យបណ្តាជនធ្វើការប្រែឱ្យបានត្រឹមត្រូវ (មើលការពន្យល់ ១៤:១២) ។

**២៨:៩** *ទាយពីសន្តិសុខ* នេះជាពាក្យដើមរបស់ហោរាខុសឆ្គង (មើល ៦:១៤ និងការពន្យល់) ។

**២៨:១០** *ក៏យកនឹមពីកហោរាយេរេមាទៅបំបាក់ចោល* មើលការពន្យល់ ២៧:២ ។ បំបាក់ចោល ប្រហែលជាបញ្ជាក់ពីការបំបាក់ចោល អំណាចសេចក្តីទំនាយនៅជំនាន់ដើមរបស់លោកយេរេមា (មើល ២៥:១១–១២ ២៧:៧) ដោយគេនិយាយជំទាស់នឹងសេចក្តីទំនាយរបស់លោក ។

**២៨:១១** *ក្នុងរវាងគំរប់២ឆ្នាំ* មើលការពន្យល់ ខ.៣ ។

**២៨:១៣** *នឹមដែក* ជានឹមដែលធ្វើជាមួយនឹមឈើ (មើលការពន្យល់ ២៧:២) ដែលអាចផ្លាស់ប្តូរជាមួយនឹមដែក (មើល ខ.១៤ ៣៨:១៧–២៣) ។

**២៨:១៤** *សាសាន៍ទាំងនេះហើយ ដើម្បីឱ្យគេត្រូវបំរើ* មើល ២៧:៧ ។ *អញក៏ឱ្យសត្វនៅវាលដល់គេដែរ* មើល ២៧:៦ និងការពន្យល់ ។

**២៨:១៥** *ព្រះយេហូវ៉ាមិនបានចាត់ប្រើអ្នកទេ* នេះជាការចំណាំពីហោរាខុសឆ្គង (មើល ២៣:២១ និងការពន្យល់) ។

**២៨:១៦** *បណ្តេញ* ក្នុងព្រះគម្ពីរភាសាហេព្រើរគួសបញ្ជាក់ពាក្យនេះ គឺគួសបញ្ជាក់ដូចគ្នានឹងពាក្យ "បញ្ជូន" នៅក្នុង ខ.១៥ ។ ព្រះអម្ចាស់មិនបាន "ចាត់បញ្ជូន" ហោរាហាណានាឡើយ ដូច្នេះគាត់ត្រូវតែ "បណ្តេញចេញ" ឱ្យត្រូវស្លាប់ ។ *ពីព្រោះឯងបានពោលសេចក្តីបះបោរទាស់នឹងព្រះយេហូវ៉ា* ដូចជាសកម្មភាពរបស់ហោរាខុសឆ្គងពីអតីតកាល គឺត្រូវកាត់ទោសឱ្យស្លាប់(មើល ចទ ១៣:៥ និងមើល ចទ ១៨:២០ ធៀបនិង អគ ១១:១៣ កច ៥:១–១១) ។

**២៨:១៧** *នៅខែអស្សុជ ក្នុងឆ្នាំនោះឯង* ហោរាហាណានាក៏ត្រូវស្លាប់ ហោរាហាណានាបានទាយពីការសាងសងឡើងវិញ ដោយខុសឆ្គង "ក្នុងរយៈពេល២ឆ្នាំ" (មើល ខ.៣,១១) បានស្លាប់នៅពេល២ខែក្រោយមក (សូមមើល ខ.១) ។

**២៩:១–៣២** សំបុត្ររបស់លោកយេរេមាបានផ្ញើទៅដល់ពួកអ្នក ដែលជាប់ជាឈ្លើយនៅក្នុងឆ្នាំ៥៩៧ គ.ស (ខ.៤–២៣) គឺទៅតាមព្រះបន្ទូលព្រះអំពីសេចក្តីជំនុំជម្រះ ប្រឆាំងនិងហោរាខុសឆ្គង គឺហោរាសេម៉ាយ៉ា (មើល ខ.២៤–៣២) ។

**២៩:២** *អគ្គមហេសី* ព្រះនាមជានេហ៊ូលថា (មើលការពន្យល់ ១៣:១៨) ។ ព្រមទាំងពួកជាងឈើ និងជាងដែក មើល ២៤:១ និងការពន្យល់ ។

**២៩:៣** *លោកផ្ញើរសំបុត្រនោះ* មុនដំបូងមាននៅជំនាន់បុរាណ ចំពោះការទំនាក់ទំនងការទូត ដោយស្មើភាពគ្នា ដើម្បីធានាថាសំបុត្រនោះផ្ញើរទៅដល់ដោយសុវត្ថិភាព ។ *ជាកូនសាផាន* ប្រហែលជាឪពុករបស់អ័ហ៊ីកាមផងដែរ

ហ៊ីលគីយ៉ា ជាអ្នកដែលសេដេគា ស្ដេចយូដាបានចាត់
ទៅឯស្រុកបាប៊ីឡូន ដល់នេប៊ូក្នេសា ជាស្ដេចស្រុកនោះថា
៤ ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដល់ពួកឈ្លើយទាំងប៉ុន្មាន
ដែលទ្រង់បានឱ្យគេដឹក[ង]ជាឈ្លើយ ចេញពីក្រុងយេរូសាឡិម
ទៅដល់ស្រុកបាប៊ីឡូនថា ៥ ចូរឱ្យឯងរាល់គ្នាសង់[ច]ផ្ទះ ហើយ
អាស្រ័យនៅចុះចូរដាំដំណាំ ហើយស៊ីផលនោះទៅ ៦ ចូរ
យកប្រពន្ធ ហើយបង្កើតកូនប្រុសកូនស្រី ព្រមទាំងរក
ប្រពន្ធឱ្យកូនប្រុសឯង ហើយលើកកូនស្រីរបស់ឯងឱ្យមាន
ប្ដីផង ដើម្បីឱ្យបានបង្កើតកូនប្រុសកូនស្រីដែរ ចូរឱ្យចំរើន
ជាច្រើនឡើងនៅទីនោះ កុំឱ្យថយចំនួនឯងឡើយ[ឆ] ៧ ចូរខំ
ប្រឹងធ្វើឱ្យ[ជ]ទីក្រុង ដែលអញបានឱ្យគេដឹកនាំឯងទៅនៅជា
ឈ្លើយនោះ បានសេចក្ដីសុខ ហើយត្រូវអធិស្ឋាន[ឈ] ដល់ព្រះ
យេហូវ៉ាឱ្យទីនោះផង ដ្បិតក្នុងសេចក្ដីសុខរបស់ក្រុងនោះ
ឯងរាល់គ្នានឹងបានសេចក្ដីសុខដែរ ៨ ពីព្រោះព្រះយេហូវ៉ា
នៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែលទ្រង់មាន
បន្ទូលដូច្នេះ កុំឱ្យពួកហោរា[ញ] និងពួកគ្រូទាយរបស់ឯង
ដែលនៅកណ្ដាលពួកឯងរាល់គ្នាបញ្ឆោត[ដ]ឯងឡើយ ក៏កុំឱ្យ
ស្ដាប់តាមសប្តិ[ឋ]របស់ឯង ដែលឯងរាល់គ្នាបានយល់សប្តិ
នោះដែរ[ឌ] ៩ ដ្បិតគេទាយកុហក[ឍ]ដល់ឯងរាល់គ្នាដោយនូវ
ឈ្មោះអញទេ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញមិនបាន
ចាត់[ណ]គេឡើយ ១០ ដ្បិតព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ
លុះកាលបានសំរេចគ្រប់៧០ឆ្នាំ[ត] នៅស្រុកបាប៊ីឡូនហើយ
នោះអញនឹងប្រោសឯងរាល់គ្នា[ថ] ហើយនឹងធ្វើសំរេចដល់
ឯងរាល់គ្នា តាមពាក្យ[ទ]ល្អរបស់អញ ដោយធ្វើឱ្យឯងរាល់
គ្នាវិលមកឯទីនេះវិញ[ធ] ១១ ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូល
ថា អញស្គាល់សេចក្ដី[ន]ដែលអញគិតពីដំណើរឯងរាល់គ្នា
មិនមែនគិតធ្វើសេចក្ដីអាក្រក់ទេ គឺគិតឱ្យបានសេចក្ដីសុខ
វិញ[ប] ដើម្បីដល់ចុងបំផុត ឱ្យឯងរាល់គ្នាបានសេចក្ដីសង្ឃឹម[ផ]
១២ នោះឯងរាល់គ្នានឹងអំពាវនាវ[ព]ដល់អញ ហើយនិងទៅ
អធិស្ឋាន[ភ]ដល់អញ រួចអញនឹងយល់ព្រម[ម]តាម ១៣ ឯងរាល់
គ្នានឹងស្វែងរក[យ]អញ ហើយនិងឃើញផង គឺកាលណាឯង
ស្វែងរកអញឱ្យអស់អំពីចិត្ត[រ] ១៤ ហើយព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា អញនឹងឱ្យឯងរាល់គ្នារកអញឃើញ អញនឹងដោះ
ឯងរាល់គ្នាឱ្យរួចពីសណ្ឋានជាឈ្លើយហើយនឹងប្រមូល[ល]

**២៩:៤** ង យរ ២៤:៥
**២៩:៥** ច ខ.២៨
**២៩:៦** ឆ យរ ៣០:១៩
**២៩:៧** ជ នអ ៣:៨ ឈ ១ធថ ២:១–២
**២៩:៨** ញ ១យហ ៤:១ ដ យរ ៣៧:៩ ឋ ចទ ១៣:១ យរ ២៣:២៥ ឌ យរ ២៣:២៧
**២៩:៩** ឍ យរ ២៧:១៥ បទ ២:១៤ អគ ១៣:៦ ណ យរ ២៣:២១
**២៩:១០** ត ២រប ៣៦:២១ ដយ ៩:២ ថ នរ ១:៦ ទ ១ពវ ៨:៥៦ យរ ៣២:៤២ ៣៣:១៤ ធ យរ ១៦:១៤ ២៤:៦
**២៩:១១** ន ទដ ៤០:៥ ប អស ៥៥:១២ ផ យប ៨:៧ សក ៨:១៥
**២៩:១២** ព ហស ២:២៣ សជ ៣:១២ សក ១៣:៩ ភ ១ពវ ៨:៣០ ម ទដ ១៤៥:១៩ អស ៥៥:៦ **២៩:១៣** យ មថ ៧:៧ រ ចទ ៤:២៩ ២រប ៦:៣៧
**២៩:១៤** ល ចទ ៣០:៣ យរ ៣០:៣ អគ ៣៩:២៥ អម ៩:១៤ សជ ៣:២០

(មើល ២៦:២៤ និងការពន្យល់) និងកេម៉ារា (មើល ៣៦:១០) លោកទាំងពីរ គឺជានិមិត្តសញ្ញាអំពីលោកយេរេមា និងបេសកកម្មរបស់គាត់ ។ *កេម៉ារា* ជាឈ្មោះសាមញ្ញ នៅជំនាន់លោកយេរេមា (មើលខ. ៣៦:១០) បានរកឃើញក្នុងក្រុងឡាគីស ក្រុងអាសេកា (មើលការពន្យល់ ៣៤:៧) ព្រមទាំងនៅឯឡេបាណន (មើលការពន្យល់ ៣២:១០)មួយសតវត្សក្រោយមក ។ *ហ៊ីលគីយ៉ា* ប្រហែលជាហ៊ីលគីយ៉ាជាសង្ឃជាន់ខ្ពស់នៅក្រោមការគ្រប់គ្រងស្ដេចយ៉ូសៀស (មើល ២ពវ ២២:១២ ដែលហ៊ីលគីយ៉ា និងសាផានបានបញ្ជាក់ជាមួយគ្នាផងដែរ) ។ *ជាអ្នកដែលសេដេគា ស្ដេចយូដាបានចាត់បញ្ជូនឯស្រុកបាប៊ីឡូន ដល់នេប៊ូក្នេសា* នៅចំពេលតែមួយ (៥៩៣ គ.ស) ដែលស្ដេចសេដេគា បានយាងទៅបាប៊ីឡូនមួយរយៈពេលខ្លី (សូមមើល ៥១:៥៩) ក្នុងគោលបំណងធ្វើដំណើរដោយមិនបានគ្រោងទុកជាមុន ។

**២៩:៤** *អញ* គឺព្រះអម្ចាស់ (មើល ខ.៧) ។ តាំងពីពេលដែលទ្រង់បាននិទេសរាស្ត្រទ្រង់ចេញទៅ នោះគេបានចុះចូលជាមួយនឹងអ្នកដែលចាប់គេទៅដោយមិនហ៊ានបះបោរប្រឆាំងឡើយ ។

**២៩:៥** *សង់ផ្ទះ . . . ចូរដាំដំណាំ* និយាយពីការត្រាសហៅលោកយេរេមា (មើល ១:១០) ប៉ុន្តែនៅទីនេះគឺបានប្រើក្នុងន័យត្រង់ ។ *ហើយអាស្រ័យនៅចុះ* លោកអេសេគាល ខ. គាត់បានរស់នៅក្នុងផ្ទះរបស់គាត់នៅបាប៊ីឡូន (មើល ៨:១ និងការពន្យល់) ។

**២៩:៦** *ចូរយកប្រពន្ធ* ប៉ុន្តែនៅក្នុងចំណោមពួកអ្នកជាប់ជាឈ្លើយ មិនមែនរកស្រីនៅក្នុងចំណោមពួកបាប៊ីឡូន(ធៀបនឹង ចទ ៧:៣–៤ អគ ៩:១–២) ។

**២៩:៧** នេះជាគំនិតដែលមិនដែលមានពីមុនមក នៅជំនាន់បុរាណ ដោយធ្វើការឆ្ពោះទៅមុខ និងការអធិស្ឋានសម្រាប់ភាពសំបូរសប្បាយ ដល់អ្នកដែលចាប់ចងនោះ ។ *សេចក្ដីសុខ ដ្បិតសេចក្ដីសុខរបស់ក្រុង . . . បានសេចក្ដីសុខដែរ* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះសាឡូម (Shalom) ចំពោះឃ្លាទាំងបីនេះ ។ *ទីក្រុង* មើល អគ ៦:១០ និងការពន្យល់ មថ ៥:៤៤ ) ។

**២៩:៨** *កុំឱ្យពួកហោរា និងពួកគ្រូទាយ . . . តាមសប្តិរបស់ឯង* មើល ២៧:៩ និងការពន្យល់ ។ ដែលនៅកណ្ដាលពួកឯងរាល់គ្នា ចំពោះពួកអ្នកជាប់ជាឈ្លើយនៅបាប៊ីឡូន នៅក្នុងចំណោមពួកគេមានហោរាក្លែងក្លាយ (មើល ខ.២១,៣១) បានជូនដំណើរគេ នៅពេលដែលគេបាននិរទេសខ្លួនទៅនោះក្នុងឆ្នាំ ៥៩៧ គ.ស ។

**២៩:៩** មើល ខ.៣១ មើលការពន្យល់ផងដែរ ២៣:១៦,២១ ។

**២៩:១០** *គ្រប់៧០ឆ្នាំ* មើលការពន្យល់ ២៥:១១–១២ ។ *ដោយធ្វើឱ្យឯងរាល់គ្នាវិលមកឯទីនេះវិញ* មើលការពន្យល់ ២៧:២២ ។

**២៩:១១** *អញស្គាល់* មើល ខ.២៣ ទោះបីមានការផ្ទុយគ្នាក្ដី នោះព្រះអម្ចាស់មិនភ្លេចរាស្ត្រទ្រង់ឡើយ ។ *គឺគិតឱ្យបានសេចក្ដីសុខវិញ* (មើលការពន្យល់ ខ.៧) ។ *មិនមែនគិតធ្វើសេចក្ដីអាក្រក់ទេ* ព្រះជាប្រភពចុងក្រោយទាំងការល្អ និងការអាក្រក់ (មើល អស ៤៥:៧) ។

**២៩:១២–១៣** ដកស្រង់ពី ចទ ៤:២៩–៣០ អំណោយទានដ៏ល្អរបស់ព្រះអម្ចាស់អំពីសេចក្ដីសុខ នោះអាស្រ័យទៅលើរាស្ត្រទ្រង់ ដែលចង់ធ្វើការកែប្រែចិត្ត ។

**២៩:១៤** ការសង្ខេបនៅក្នុង ចទ ៣០:៣–៥ ។ *អញនឹងដោះឯងរាល់គ្នាឱ្យរួចពីសណ្ឋានជាឈ្លើយ* មើលការពន្យល់ មើលផងដែរ ៣០:៣,១៨ ៣១:២៣

ឯងពីគ្រប់ទាំងសាសន៍ នឹងពីគ្រប់កន្លែងណាដែលអញបាន
បណ្តេញឯង នាំវិលត្រឡប់មកឯកន្លែងដែលអញបានឱ្យ
គេចាប់ទៅជាឈ្លើយនោះវិញ នេះហើយជាព្រះបន្ទូលនៃ
ព្រះយេហូវ៉ា[វ] ។
១៥ហេតុដែលអ្នករាល់គ្នានិយាយថា ព្រះយេហូវ៉ាទ្រង់
បានបង្កើតឱ្យយើងមានពួកហោរា នៅស្រុកបាប៊ីឡូននេះ
១៦នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ពីដំណើរស្តេច
ដែលគង់លើបល្ល័ង្ករបស់ដាវីឌ ហើយពីដំណើរជនទាំង
ឡាយដែលអាស្រ័យនៅទីក្រុងនេះ គឺជាបងប្អូនរបស់ឯង
រាល់គ្នា ដែលមិនបានដឹកទៅជាឈ្លើយជាមួយនឹងឯងរាល់
គ្នាទេ ១៧ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលថា
មើលអញនឹងចាត់ដាវ សេចក្តីអំណត់អត់ និងអាសន្នរោគ[ស]
មកលើគេ ហើយនឹងធ្វើឱ្យគេត្រឡប់ទៅដូច ជាផ្លែល្វា
អាក្រក់[ហ] ដែលបរិភោគមិនបាន ១៨ហើយអញនឹងដេញ
តាមគេ ដោយដាវ អំណត់អត់ និងអាសន្នរោគ ព្រមទាំង
ប្រគល់គេទៅឱ្យត្រូវសាត់អណ្តែត[ឡ] នៅកណ្តាលអស់ទាំង
សាសន៍នៅផែនដី ឱ្យបានជាទីផ្តាសា[អ] ជាទីស្រឡាំងកាំង[ក]
ហើយជាទីដែលគេធ្វើស៊ីសស៊ូស[ខ]ឱ្យ និងជាទីត្មះតិះដៀល
នៅកណ្តាលអស់ទាំងសាសន៍ ដែលអញនឹងបណ្តេញគេ
នោះ ១៩គឺដោយព្រោះគេមិនបានស្តាប់តាមពាក្យអញ[គ]
ដែលព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញបានចាត់ពួក
ហោរា ជាអ្នកបំរើរបស់អញទៅឯគេ ព្រមទាំងក្រោកពី
ព្រលឹមស្រាង[ឃ] ដើម្បីនឹងចាត់គេផង[ង] តែឯងរាល់គ្នា
មិនបានស្តាប់តាមសោះ នេះហើយជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ។
២០ដូច្នេះ ឯងរាល់គ្នា ជាពួកឈ្លើយ ដែលអញបាន
បណ្តេញ[ច]ចេញពីក្រុងយេរូសាឡិម ទៅឯស្រុកបាប៊ីឡូន
អើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ ២១ព្រះ
យេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលពីដំណើរអ័ហាប់ ជាកូនកូឡាយ៉ា និង
សេដេគាជាកូនម្អាសេយ៉ា ដែលគេទាយជាសេចក្តីកុហក[ឆ]
ដល់ឯងរាល់គ្នា ដោយនូវព្រះនាមទ្រង់ គឺទ្រង់មានបន្ទូលថា
មើលអញនឹងប្រគល់គេ ទៅក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសា
ជាស្តេចបាប៊ីឡូន ហើយស្តេចនោះនឹងសំឡាប់អ្នកទាំង២
នោះ នៅមុខឯងរាល់គ្នា ២២ហើយពួកឈ្លើយជាសាសន៍
យូដា ដែលនៅក្រុងបាប៊ីឡូន និងយករឿងនោះប្រើជា
ពាក្យផ្តាសាដល់អ្នកដទៃថា សូមឱ្យព្រះយេហូវ៉ាធ្វើឱ្យឯង
បានដូចជាសេដេគា និងអ័ហាប់ ដែលស្តេចបាប៊ីឡូនបាន
ឆ្អើរ[ជ]នឹងភ្លើងនោះចុះ ២៣ពីព្រោះគេបានប្រព្រឹត្តអំពើចំកួត
ក្នុងពួកអ៊ីស្រាអែល គេបានសហាយស្មន់[ឈ]នឹងប្រពន្ធរបស់
អ្នកជិតខាង ហើយពោលពាក្យកុហក ដោយនូវឈ្មោះអញ
ជាសេចក្តីដែលអញមិនបានបង្គាប់ដល់គេឡើយ ហើយព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា គឺអញហើយដែលដឹង[ញ]អញជា
បន្ទាល់[ដ]ពិត ។

## សំបុត្រទៅកាន់លោកសេម៉ាយ៉ា

២៤រីឯដំណើរសេម៉ាយ៉ា ជាអ្នកនៅស្រុកនេហេលេម
នោះត្រូវឱ្យឯងប្រាប់ថា ២៥ព្រះយេហូវ៉ានៃពួកពលបរិវារ
ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ ដោយ
ព្រោះឯងបានធ្វើសំបុត្រដោយនូវឈ្មោះខ្លួនឯង ផ្ញើដល់
អស់អ្នកនៅក្រុងយេរូសាឡិម និងដល់សេផានា[ឋ] ជាកូន
ម្អាសេយ៉ាដ៏ជាសង្ឃ ហើយដល់ពួកសង្ឃទាំងអស់ផងថា

**២៩:១៤** វ យរ ២៣:៣–៤ ៣០:១០ ៤៦:២៧ អគ ៣៧:២១
**២៩:១៧** ស យរ ២៧:៨ ហ អស ៥:៤
**២៩:១៨** ឡ យរ ១៥:៤ អ ជន ៥:២៧ យរ ១៨:១៦ ២២:១០ ៤៤:១២ ក ចទ ២៨:២៥ ខ ចទ ២៨:៣៧ អស ២៨:២២ មីក ២:៦
**២៩:១៩** គ យរ ៦:១៩ ឃ យរ ៧:២៥ ង យរ ២៥:៤
**២៩:២០** ច យរ ២៤:៥
**២៩:២១** ឆ ខ.៩ យរ ១៤:១៤
**២៩:២២** ជ ដយ ៣:៦
**២៩:២៣** ឈ យរ ២៣:១៤ ញ ហព ៤:១៣ ដ លប ៣១:៤៨ យរ ៧:១១ **២៩:២៥** ឋ ២ពវ ២៥:១៨

៣២:៤៤ ៣៣:៧,១១,២៦ ៤៨:៤៧ ៤៩:៦,៣៩ និងការពន្យល់ ទដ ១២៦:៤ ។
**២៩:១៥** *មានពួកហោរា នៅបាប៊ីឡូន* មើលការពន្យល់ ខ.៨ ។
**២៩:១៦** *ពីដំណើរស្តេចដែលគង់លើបល្ល័ង្ករបស់ដាវីឌ* ស្តេចសេដេគា ។ *គង់លើ . . . ដែលមិនបានដឹកទៅ* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យទាំងពីរ គឺបញ្ជាក់ស្តេច និងពួកបណ្តាជន គឺជាអ្នកដែលជាប់ពិរុទ្ធភាព ។
**២៩:១៧** *ដាវ សេចក្តីអំណត់អត់ និងអាសន្នរោគមកលើគេ* មើល ខ.១៨ និងការពន្យល់ ១៤:១២ ។ *ជាផ្លែល្វាអាក្រក់ ដែលបរិភោគមិនបាន* មើល ២៤:៨ ។
**២៩:១៨** មើល ២៤:៩ និងការពន្យល់ ។
**២៩:១៩** *ព្រមទាំងក្រោកពីព្រលឹមស្រាង* មើលការពន្យល់ ៧:១៣ ។ *អញបានចាត់ពួកហោរា ជាអ្នកបំរើរបស់អញ* មើលការពន្យល់ ៧:២៥ ។ *តែឯងរាល់គ្នាមិនបានស្តាប់តាមសោះ* មើល អគ ២:៥,៧ ៣:៧,១១ ។
**២៩:២១** *អ័ហាប់ . . . និងសេដេគា* មិនមែនជាស្តេចដែលគេមិនបានស្គាល់ (របស់ពួកអ៊ីស្រាអែល និងយូដាគោរព) ដែលគេគឺជាពួកហោរាខុសឆ្គង (មើលការពន្យល់ ខ.៨) ។
**២៩:២២** *ភ្លើង* បានប្រើរនៅបាប៊ីឡូនដូចជាវិធីមួយដើម្បីធ្វើការចោទប្រកាន់ (មើល ដយ ៣:៦,២៤) ។
**២៩:២៣** *ប្រព្រឹត្តអំពើចំកួតក្នុងពួកអ៊ីស្រាអែល* មើល លប ៣៤:៧ និងការពន្យល់ ។ *គេបានសាហាយស្មន់នឹង . . . ហើយពោលពាក្យកុហក* មើលការពន្យល់ ២៣:១០ ។ *គឺអញហើយដែលដឹង* មើល ខ.១១ ។
**២៩:២៤** *សេម៉ាយ៉ា* ជាហោរាខុសឆ្គងម្នាក់ (មើល ខ.៣១) ។ ស្រុកនេហេលេម ភាសាហេព្រើសម្រាប់ពាក្យនេះ គឺដូចគ្នានិងពាក្យ "សុបិន្ត" នៅក្នុង ខ.៨ (មើល ២៧:៩ និងការពន្យល់) ។ លោកយេរេមាប្រហែលជាស្នើរថា សេម៉ាយ៉ា គឺមិនមែនជាហោរាពិតទេ ប៉ុន្តែនោះគ្រាន់តែជាការយល់សប្តិប៉ុណ្ណោះ ។
**២៩:២៥** *សេផានា* មិនមែនជាហោរាឈ្មោះនេះឡើយ (មើល ២១:១) ។

២៦ ព្រះយេហូវ៉ា ទ្រង់បានតាំងឯងឡើងធ្វើជាសង្ឃ ជំនួស
យេហូយ៉ាដ៏ជាសង្ឃ ដើម្បីឱ្យមានពួកនាយកក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា ប្រយោជន៍ឱ្យឯងបានចាប់អស់អ្នកឆ្កួត[ឌ]
ដែលតាំងខ្លួនឡើងធ្វើជាហោរា ដាក់គុក[ឍ] ដាក់ខ្នោះ
២៧ ចុះ
ហេតុអ្វីបានជាមិនបានបន្ទោសដល់យេរេមា ដែលនៅក្រុង
អាន៉ាថោត ជាអ្នកដែលតាំងខ្លួនឡើងជាហោរា ដល់លោក
រាល់គ្នានោះ
២៨ ពីព្រោះវាបានផ្ញើសំបុត្រ[ណ] ទៅយើងរាល់
គ្នា នៅឯស្រុកបាប៊ីឡូន ប្រាប់ថា ដំណើរនេះនឹងត្រូវយូរ
នៅ[ត] ចូរធ្វើ[ថ] ផ្ទះ ហើយអាស្រ័យនៅចុះចូរដាំដំណាំ ហើយ
ស៊ីផលទៅ
២៩ ឯសេផានា[ទ] ដ៏ជាសង្ឃ ក៏អានមើលសំបុត្រ
នោះឱ្យហោរាយេរេមាស្តាប់
៣០ ខណៈនោះព្រះបន្ទូលនៃ
ព្រះយេហូវ៉ាក៏មកដល់យេរេមាដូច្នេះ
៣១ ចូរផ្ញើទៅប្រាប់
ដល់ពួកអ្នកដែលនៅជាឈ្លើយថា ព្រះយេហូវ៉ាទ្រង់មាន
បន្ទូល ពីដំណើរសេម៉ាយ៉ា[ធ] ជាអ្នកដែលមកពីស្រុក នេហ-
លេមថា ដោយព្រោះសេម៉ាយ៉ា ជាអ្នកដែលអញមិនបាន
ចាត់ប្រើ[ន] ឡើយ បានទាយដល់ឯងរាល់គ្នា ហើយបាននាំឱ្យ
ឯងរាល់គ្នាទុកចិត្តចំពោះសេចក្តីកំភូត
៣២ បានជាព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា មើលអញនឹងធ្វើទោសដល់
សេម៉ាយ៉ា ជាអ្នកស្រុកនេហេលេម ព្រមទាំងពូជពង្សគេ
ផង[ប] គេនឹងគ្មានពូជណា អាស្រ័យនៅកណ្តាលជនជាតិនេះ
ឡើយ ក៏នឹងមិនឃើញការល្អ[ផ] ដែលអញនឹងប្រោសដល់
រាស្ត្រដែរ ពីព្រោះគេ បានពោលជាសេចក្តីបះបោរ[ព] ទាស់
នឹងព្រះយេហូវ៉ា នេះហើយជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## ការស្តារអ៊ីស្រាអែលឡើងវិញ

**៣០** ១ នេះជាព្រះបន្ទូលដែលមកពីព្រះយេហូវ៉ា ដល់
យេរេមាថា
២ ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលដូច្នេះ ចូរឱ្យឯងសរសេរ[ក] អស់ទាំងពាក្យចុះ
ក្នុងសៀវភៅ ដូចអញបានប្រាប់ឯង
៣ ដ្បិតព្រះយេហូវ៉ា
ទ្រង់មានបន្ទូលថា មើល នឹងមានគ្រា[ខ] មកដល់ ដែលអញនឹង
នាំរាស្ត្រអញ ជាពួកឈ្លើយនោះ គឺពួកអ៊ីស្រាអែល និងពួក
យូដាឱ្យត្រឡប់[គ] មកវិញ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា
អញនឹងធ្វើឱ្យគេវិល[ឃ] ទៅឯស្រុកដែល អញបានឱ្យដល់ពួក
ព្ធយុកោគេ ហើយគេនឹងបានស្រុកនោះ ជារបស់ផងខ្លួន ។
៤ នេះជាសេចក្តី ដែលព្រះយេហូវ៉ាទ្រង់មានបន្ទូល ពី
ដំណើរពួកអ៊ីស្រាអែល និងពួកយូដា
៥ ដ្បិតព្រះយេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ យើងបានឮសំឡេងញាប់ញ័រ[ង] គឺ

**២៩:២៦** ឌ ១សយ ១០:១១ ហស ៩:៧ យហ ១០:២០
ឍ យរ ២០:២
**២៩:២៨** ណ ឧ.១ ត ឧ.១០ ថ ឧ.៥
**២៩:២៩** ទ យរ ២១:១
**២៩:៣១** ធ ឧ.២៤ ន យរ ១៤:១៤
**២៩:៣២** ប ១សយ ២:៣០–៣៣
ផ ឧ.១០ ព យរ ២៨:១៦
**៣០:២** ក អស ៣០:៨ យរ ៣៦:២
**៣០:៣** ខ យរ ១៦:១៤ ២៤:៦
គ យរ ២៩:១៤
ឃ យរ ១៦:១៥
**៣០:៥** ង យរ ៦:២៥

**២៩:២៦** *យេហូយ៉ាដា* មិនមែនដូចគ្នាទៅនឹងសង្ឃនៅជំនាន់ស្តេចយ៉ូសៀស នោះឡើយ (មើល ២ពវ ១២:៧) ។ *ក្នុងព្រះវិហារនៃព្រះយេហូវ៉ា* មើលការពន្យល់ ២០:១ ។ *អស់អ្នកឆ្កួត* ជួនកាលលក្ខណៈសេចក្តីទំនាយ អាចធ្វើឱ្យខូចដល់អ្នកដែលអង្កេតជាធម្មតា (មើល ២ពវ ៩:១១) ។ ដាក់គុក មើល ២០:២ និងការពន្យល់ ។

**២៩:២៧** *ក្រុងអាន៉ាថោត* មើលការពន្យល់ ១:១ ។

**២៩:២៨** មើលខ.៥ និងការពន្យល់ ។ *ដំណើរនេះនឹងត្រូវយូរទៅ* រយៈពេល ៧០ឆ្នាំ (មើល ២៥:១១–១២ និងការពន្យល់ មើលផងដែរ ២សយ ៣:១) ។

**២៩:២៩** *សេផានា ក៏* គាត់និយាយសំដៅទៅលើលោកយេរេមា (មើល ២១:១–២ ៣៧:៣) ។

**២៩:៣១–៣២** សេចក្តីព្រមានប្រឆាំងរបស់ព្រះអម្ចាស់ ចំពោះសេម៉ាយ៉ា គឺដូចគ្នាដែលទ្រង់ប្រឆាំងចំពោះហោរាហាណានាផងដែរ (សូមមើល ២៨:១៥–១៦) ។

**២៩:៣១** *ហើយបាននាំ . . . ទុកចិត្តចំពោះសេចក្តីកំភូត* មើល ២៨:១៥ ។

**២៩:៣២** *ពីព្រោះគេបានពោលជាសេចក្តីបះបោរទាស់នឹង* មើល ២៨:១៦ និងការពន្យល់ ។

**៣០:១–៣៣:២៦** គេតែងតែហៅព្រះគម្ពីរយេរេមាថា ព្រះគម្ពីរការលួងលោមកំសាន្តចិត្ត នៅក្នុងផ្នែកនេះពណ៌នា អំពីការសាងសង់ឡើងវិញជាចុងក្រោយ សម្រាប់អ៊ីស្រាអែល (នគរខាងជើង) និងយូដា (នគរខាងត្បូង) និងជាព្រះបន្ទូលយ៉ាងវែង ក្នុងព្រះគម្ពីរយេរេមា ដែលទាក់ទងទៅនឹងសេចក្តីសង្ឃឹមអនាគត សម្រាប់រាស្ត្ររបស់ព្រះ (សម្រាប់ផ្នែកផ្សេងទៀតជាអត្ថបទយ៉ាងសង្ខេប អំពីការសាងសង់ឡើងវិញ មើល ៣:១៤–១៨ ១៦:១៤–១៥ ២៣:៣–៨ ២៤:៤–៧) ។ ព័ត៌មាននៅក្នុង ៣២:១ ប្រហែលជាបានប្រើកាលបរិច្ឆេទនៅក្នុងផ្នែកនេះ ក្នុងឆ្នាំ ៥៨៧ គ.ស ជាឆ្នាំមុនពេលដែលក្រុងយេរូសាឡិមត្រូវបានបំផ្លាញ ដោយស្តេចនេប៊ូក្នេសា និងប្រជាជនរបស់រាស្ត្រទ្រង់ ដែលបាននិរទេសខ្លួនទៅបាប៊ីឡូន ។

**៣០:១–៣១:៤០** ភាគច្រើនបានសរសេរឡើង តាមលក្ខណៈបែបជាកំណាព្យទាំង២ជំពូកនេះ ដែលមានភាពសុទិដ្ឋិនិយម ដូចជាហោរាមានសេចក្តីសង្ឃឹម ដល់ពេលមួយ ដែលព្រះបានប្រោសលោះរាស្ត្រទ្រង់ ។

**៣០:១** ជាក្បាលដំបូងនៅក្នុងជំពូក ៣០–៣១ (និងប្រហែលនៅក្នុងជំពូក ៣២–៣៣ ផងដែរ) ។

**៣០:២** *សរសេរ* ដើម្បីទុកសម្រាប់អនាគតជំនាន់ក្រោយ ជាសេចក្តីទំនាយអំពីការសាងសង់ឡើងវិញ ។ *ក្នុងសៀវភៅ* នៅក្នុងឯកសារ (មើលឧ. ៣៦:២,៤ ៤៥:១ មើលផងដែរ នក ១៧:១៤ និងការពន្យល់) ។ *អស់ទាំងពាក្យ ចុះក្នុងសៀវភៅ ដូចជាអញបានប្រាប់ឯង* នោះផ្តោតទៅលើ ការប្រោសលោះរាស្ត្ររបស់ព្រះ នៅពេលអនាគត ។ នៅក្នុងឃ្លានេះគឺមិនសូវស៊ីជម្រៅដូចនៅក្នុង ៣៦:២ ។

**៣០:៣** *នាំ . . . ឱ្យត្រឡប់មកវិញ* មើលការពន្យល់ ២៩:១៤ ។ *អ៊ីស្រាអែល និងពួកយូដា* គឺនគរខាងជើង និងនគរខាងត្បូង ការចាប់ជាឈ្លើយលើកទី១ គឺនៅក្នុងឆ្នាំ ៧២១ គ.ស និងការចាប់ជាឈ្លើយលើកទី២ គឺជាពេលចូលទៅក្នុងដំណាក់កាលចុងក្រោយ នៅក្នុងពេលប្រហែលជា១ឆ្នាំ (មើលការពន្យល់ ៣០:១–៣៣:២៦) ។

**៣០:៥** *យើងបានឮសំឡេងញាប់ញ័រ គឺមានសេចក្តីភិតភ័យ* ជាសំឡេងអំពីសង្គ្រាម និងការបំផ្លិចបំផ្លាញ ។

មានសេចក្តីភិតភ័យ មិនមែនជាសេចក្តីសុខទេ ៦ចូរសើប
សួរឥឡូវ ឱ្យដឹង បើមនុស្សប្រុសដែលឈឺនឹងសំរាលកូន ឬ
ចុះហេតុអ្វីបានជាឃើញប្រុសៗទាំងអស់ កំពុងតែយកដៃ
ស្ទឹមចុចចង្កេះ ដូចជាស្រីដែលឈឺចាប់ហៀបនឹងសំរាល
កូន[ច] ហើយមុខគេក៏ស្លេកស្លាំងគ្រប់គ្នាដូច្នេះ[ឆ] ៧វរហើយ
ដ្បិតថ្ងៃនោះ[ជ]ជាថ្ងៃគួរស្ញើម ដល់ម្លេះបានជាគ្មាន ថ្ងៃណា
មួយឱ្យដូចឡើយ នោះជាគ្រាវេទនា[ឈ]របស់ពួកយ៉ាកុប ប៉ុន្តែ
គេនឹងបានប្រោសឱ្យរួច[ញ]ចេញពីគ្រានោះ ៨ព្រះយេហូវ៉ា
នៃពួកពលបរិវារទ្រង់មានបន្ទូលថា នៅថ្ងៃនោះអញនឹង
បំបាក់នឹម[ដ]គេពីកឯងចេញ ហើយផ្តាច់ចំណងឯងផង[ឋ] នោះ
ពួកសាសន៍ដទៃនឹងមិនចាប់ប្រើឯងជាបាវទៀតឡើយ[ឌ] ៩គឺ
ឯងនឹងបំរើព្រះយេហូវ៉ា ជាព្រះនៃឯង និងដាវីឌ[ឍ]ជា
ស្តេច[ណ]របស់ឯង ជាអ្នកដែលអញនឹងបង្កើតឡើងដល់ឯង
១០ដូច្នេះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱយ៉ាកុប ជាអ្នក
បំរើអញអើយ[ត] កុំឱ្យខ្លាចឡើយ[ថ] ឱអ៊ីស្រាអែលអើយ កុំឱ្យ
ស្រយុតចិត្តដែរ ដ្បិតមើល អញនឹងជួយសង្គ្រោះ[ទ]ឯង ពី
ចំងាយនឹងពូជពង្សឯង ឱ្យរួចពីស្រុកដែលគេនៅជាឈ្លើយ
នោះផង នោះពួកយ៉ាកុបនឹងវិលត្រឡប់មកវិញ ហើយនិង
នៅដោយសុខស្រួល[ធ] និងសេចក្តីស្ងប់ស្ងាត់ ឥតមានអ្នក
ណាបំភ័យឡើយ[ន] ១១ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
អញនៅជាមួយ ដើម្បីនឹងជួយសង្គ្រោះឯង[ប] ពីព្រោះអញ
នឹងធ្វើឱ្យអស់ទាំងនគរ ដែលអញបានកំចាត់កំចាយ[ផ]ឯង
ទៅ នោះត្រូវផុតអស់រលីងទៅ តែមិនធ្វើឱ្យឯងផុតទេ
គឺអញនឹងវាយផ្ចាល[ព]ឯងតាមខ្នាតវិញ អញនឹងមិនបណ្តោយ
ឱ្យឯងនៅដោយឥតវាយផ្ចាលឡើយ[ភ]។
១២ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ថាដំបៅ[ម]
ឯងមើលមិនជាទេ ហើយរបួសឯងក៏ធ្ងន់ណាស់ផង[យ]
១៣គ្មានអ្នកណានឹងកាន់ក្តីឯង[រ] ដើម្បីនឹងរុំរបួសឯងសោះ
ឯងក៏គ្មានថ្នាំណាផ្សះ[ល]ផង ១៤អស់ទាំងសហាយ[វ]របស់ឯង
បានភ្លេចឯងហើយ គេមិនរកឯងទៀតទេ ពីព្រោះអញ
បានវាយឯងឱ្យរបួស ដូចជាខ្មាំងសត្រូវ[ស]វាយដែរ ហើយ
បានវាយផ្ចាលឯងឱ្យរបស់ដូចជាមនុស្សសាហាវ[ហ] ដោយ
ព្រោះចំនួនអំពើទុច្ចរិតឯងមានច្រើនណាស់ បាប[ឡ] ឯងបាន
ចំរើនច្រើនឡើងហើយ ១៥ហេតុអ្វីបានជាឯងស្រែក
ដោយព្រោះដំបៅឯងដូច្នេះ សេចក្តីឈឺចាប់របស់ឯង នោះ
មើលមិនជាទេ[អ] អញបានធ្វើដល់ឯងយ៉ាងនេះ ដោយព្រោះ

**៣០:៦** ច យរ ៤:៣១ ឆ អស ២៩:២២ **៣០:៧** ជ អស ២:១២ ឈ អស ២២:៥ សផ ១:១៥ ញ ខ.១០ យរ ២៣:៣ **៣០:៨** ដ អស ៩:៤ ឋ ទដ ១០៧:១៤ ឌ យរ ២៥:១៤ ២៧:៧ អគ ៣៤:២៧ **៣០:៩** ឍ មថ ១:១ ណ ខ.២១ ១សយ ១៣:១៤ យរ ៣៣:១៥ អគ ៣៤:២៣–២៤ ៣៧:២៤ ហស ១:១១ ៣:៥ **៣០:១០** ត អស ៤៤:២ ថ អស ៤១:១០ ទ ខ.៧ យរ ២៩:១៤ ធ អស ៣៥:៩ យរ ១៧:២៥ ន អស ២៩:២២ ៥៤:៤ យរ ២៣:៤ អគ ៣៤:២៥–២៨

**៣០:១១** ប យស ១:៥ ផ លវ ២៦:៤៤ យរ ៥:១៨ ៤៦:២៨ ព យរ ១០:២៤ ភ ហស ១១:៩ អម ៩:៨ **៣០:១២** ម យប ៦:៤ យរ ១០:១៩ យ យរ ៨:២២ **៣០:១៣** រ ពច ៦:៣១ ល យរ ៨:២២ ១៤:១៩ ៤៦:១១ ណហ ៣:១៩ **៣០:១៤** វ យរ ២២:២០ បទ ១:២ ស យប ១៣:២៤ ហ យប ៣០:២១ ឡ យរ ២៥:៧ **៣០:១៥** អ យរ ១០:១៩

**៣០:៦** *ដូចជាស្រីដែលឈឺចាប់* នេះជានិម្មិតរូបអំពីការប៉ះពាល់ផ្លូវចិត្ត និងការឈឺចាប់ (មើលការពន្យល់ ៤:១៩,៣១) ។

**៣០:៧** ការពណ៌នាអំពីថ្ងៃរបស់ព្រះអម្ចាស់ (មើលការពន្យល់ក្នុង អស ២:១១,១៧,២០ អម ៥:១៨ ៨:៩) ។ ខព្រះគម្ពីរយេរេមា គឺជាការមើលឃើញនៅថ្ងៃអនាគត (មើល ខ.៨,១៨) ប៉ុន្តែជាពេលមួយនៅដាច់ឆ្ងាយ ពីពេលយុគស័យព្រះមេស៊ីផងដែរ ។ *គួរស្ញើម* ន័យត្រង់ "អស្ចារ្យ" (ដូចជានៅក្នុង យអ ២:១១ សផ ១:១២ ធៀបនឹង យអ ១:១៥) ។ *បានជាគ្មានថ្ងៃណាមួយឱ្យដូចឡើយ* មើល ដយ ១២:១ យអ ២:២ មថ ២៤:២១ ។ នោះជាគ្រាវេទនា ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ គឺបានបកប្រែថា "ពេលវេលានៃសេចក្តីទុក្ខព្រួយ" នៅក្នុង ដយ ១២:១ (មើល មថ ២៤:២១ និង ការពន្យល់ វវ ១៦:១៨) ។ *យ៉ាកុប* គឺអ៊ីស្រាអែល (មើល ខ.១០) ។

**៣០:៨** *នៅថ្ងៃនោះ* មើលការពន្យល់ អស ២:១១,១៧,២០ ។ *បំបាក់នឹម* មើលការពន្យល់ ២៧:២ ។ *ហើយផ្តាច់ចំណងឯងផង* ក្នុងព្រះគម្ពិរភាសាហេព្រើរគូសបញ្ជាក់ឃ្លានេះ គឺបានបកប្រែថា "ផ្តាច់ច្រវ៉ាក់" នៅក្នុង ទដ ២:៣ នៅពេលដែលសាសន៍នានា ចង់ឱ្យខ្លួនគេមានសេរីភាព ពីព្រះអម្ចាស់ និងអ្នកគ្រប់គ្រង ដែលទ្រង់បានចាក់ប្រេងតាំង ។ ព្រះអម្ចាស់សន្យា ដើម្បីរំដោះរាស្ត្រទ្រង់ ឱ្យមានសេរីភាពពីភាពជាទាសករ ។ *នោះពួកសាសន៍ដទៃ* ប៉ុន្តែមិនរាប់បញ្ចូលពួកបាប៊ីឡូនឡើយ ។

**៣០:៩** *និងដាវីឌ ជាស្តេចរបស់ឯង* ព្រះមែស៊ី (មើលការពន្យល់ ២៣:៥) ។ តាហ្គាម (Targum ជាអត្ថបទភាសាអារ៉ាមមិក នៅជំនាន់សម័យបុរាណ) នៅទីនេះអានពីពាក្យ "ព្រះមែស៊ី ជាព្រះរាជបុត្រាពូជពង្សស្តេចដាវីឌ ជាស្តេចរបស់គេ" ។ *បង្កើតឡើង* មើល ២៣:៥ និងការពន្យល់ ។

**៣០:១០–១១** រំឭកឡើងនូវពាក្យន័យត្រង់ឡើងវិញ ក្នុង ៤៦:២៧–២៨ ។

**៣០:១០** *យ៉ាកុប* ជាអ្នកបំរើអញ មើល អស ៤១:៨–៩ និងការពន្យល់ ៤៤:១–២,២១ ៤៥:៤ ៤៨:២០ ។ *ឥតមានអ្នកណាបំភ័យឡើយ* ផ្ទុយគ្នានៅក្នុងខ. ៥ មើល លវ ២៦:៦ យប ១១:១៩ អស ១៧:២ អគ ៣៤:២៨ ៣៩:២៦ មីក ៤:៤ និងការពន្យល់ សផ ៣:១៣ ។

**៣០:១១** *អញនៅជាមួយ ដើម្បីនឹងជួយសង្គ្រោះឯង* នេះជាព្រះបន្ទូលដើមដែលព្រះបានមានបន្ទូលដោយផ្ទាល់ ទៅកាន់លោកយេរេមាតែម្នាក់ឯងគត់ (មើល ១:៨,១៩ ១៥:២០) ឥឡូវនេះព្រះបន្ទូលនេះទៅកាន់រាស្ត្ររបស់ព្រះទាំងអស់គ្នា ។ *បានកំចាត់កំចាយ* មើល ៩:១៦ និងការពន្យល់ ២៣:១–២ ។ តែមិនធ្វើឱ្យឯងផុតទេ មើល ៤:២៧ និងការពន្យល់ ។ *អញនឹងមិនបណ្តោយឯងនៅដោយឥតវាយផ្ចាលឡើយ* មើល ២៥:២៩ ៤៩:១២ ។

**៣០:១២–១៣** មើល ៨:២២ ហស ៥:១៣ ៦:១ ៧:១ ១១:៣ ។

**៣០:១២** *ឯង* យូដា ។ *ដំបៅឯងមើលមិនជាទេ* សូមមើល ១៥:១៨ និងការពន្យល់ ។ *ហើយរបួសឯងក៏ធ្ងន់ណាស់ផង* មើល ១៤:១៧ ។

**៣០:១៣** *នឹងកាន់ក្តីឯង* ប្រឆាំងជាមួយនឹងខ្មាំងសត្រូវរបស់ឯង ។ *ដើម្បីនឹងរុំរបួសឯងសោះ* មើល ហស ៥:៣ ។

**៣០:១៤** *អស់ទាំងសាហាយ* មើលការពន្យល់ ២២:២០ អេស៊ីព្ទ ឧ. តែងតែគាំទ្រពួកយូដា ប្រឆាំងនឹងបាប៊ីឡូន (មើល ៣៧:៥–៧) ។ *ដោយព្រោះចំនួនអំពើទុច្ចរិតរបស់ឯងមានច្រើនណាស់* មើល ៥:៦ ១៣:២២ ។ ភាសាហេព្រើរសម្រាប់ឃ្លានេះ គឺបានរំឭកពីពាក្យត្រង់ នៅក្នុង ខ.១៥ ។

ចំនួនអំពើទុច្ចរិតរបស់ឯងមានច្រើនណាស់បាបឯងបាន
ចំរើនឡើងជាច្រើនហើយ[ក] ១៦ដូច្នេះ អស់អ្នកណាដែល
ត្របាក់ស៊ី[ខ]ឯង និងត្រូវគេត្របាក់ស៊ីវិញ ឯអស់ទាំងខ្មាំង
សត្រូវរបស់ឯង គេនឹងត្រូវចាប់ទៅជាឈ្លើយគ្រប់គ្នាដែរ[គ]
ពួកអ្នកដែលរឹបជាន់[ឃ]ឯង នឹងត្រូវគេរឹបជាន់ដូចគ្នា ហើយ
អស់អ្នកដែលប្លន់ឯង នោះអញនឹងឱ្យដល់គេ ទុកជារំពារវិញ
១៧ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញនឹងមើល[ង]ឯង
ឱ្យជា ហើយនឹងធ្វើឱ្យរបួសឯងបានសះទៅ ពីព្រោះគេ
បានហៅឯងជាពួកបំបរបង់[ច] ដោយពាក្យថា នេះក្រុង
ស៊ីយ៉ូន ដែលឥតមានអ្នកណាស្វែងរកសោះ[ឆ]។
១៨ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មើល អញ នឹង
នាំ[ជ]ពួកឈ្លើយ ដែលចាប់ពីត្រសាល[ឈ]របស់យ៉ាកុប ឱ្យ
ត្រឡប់មកវិញ អញនឹងមានសេចក្ដីអាសូរ[ញ]ដល់ទីលំនៅ
របស់គេ ហើយទីក្រុងនឹងបានសង់ឡើងវិញ[ដ]នៅលើគំនរ
ចាស់ ហើយដំណាក់នឹងមាននៅដូចពីដើម ១៩ក៏នឹងឮពាក្យ[ឋ]
អរព្រះគុណ[ឌ] និងសំឡេងអរសប្បាយ[ឍ]ចេញពីនោះមក
អញនឹងធ្វើឱ្យគេចំរើនឡើង[ណ] គេនឹងមិនមានគ្នាតិចឡើយ
អញក៏នឹងធ្វើឱ្យគេថ្កុំថ្កើងឡើងដែរ[ត] គេនឹងមិនមែនជា
នគរតូចទាបទេ ២០កូនចៅរបស់គេ[ថ]នឹងបានដូចជាកាល
ពីដើម ហើយពួកជំនុំរបស់គេ នឹងបានតាំងឡើង[ទ]នៅ
ចំពោះអញអ ញនឹងធ្វើទោស[ធ]ដល់អស់អ្នកណា ដែលសង្កត់
សង្កិនគេ ២១ពួកអ្នកធំ[ន]របស់គេនឹងកើតពីពួកគេមក[ប] ហើយ
ចៅហ្វាយរបស់គេនឹងចេញពីកណ្ដាលពួកគេដែរ អញនឹង
នាំគេ ហើយគេនឹងចូលមកជិត[ផ]អញ ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា តើដែលមានអ្នកណាមានចិត្តក្លាហានហ៊ានចូល
មកជិតអញដូច្នេះឬ ២២នោះឯងរាល់គ្នានឹងបានជារាស្ត្រ
របស់អញ[ព] ហើយអញនឹងធ្វើជាព្រះដល់ឯងរាល់គ្នា[ភ]។
២៣មើល ព្យុះសង្ឃរា[ម]របស់ព្រះយេហូវ៉ា គឺជាសេចក្ដី
ក្រោធរបស់ទ្រង់បានចេញមកហើយ គឺជាខ្យល់កួចដែល
បោសរំលីង ខ្យល់នោះនឹងធ្លាយមកលើក្បាលរបស់ពួក
អាក្រក់ ២៤សេចក្ដីខ្ញាល់ដ៏សហ័ស[យ]របស់ព្រះយេហូវ៉ា នឹង
មិនវិលមកវិញ[រ]ដរាបដល់ទ្រង់បានធ្វើសំរេច ហើយបាន
បង្ហើយតាមបំណងព្រះហឫទ័យ ឯនៅគ្រាជាន់ក្រោយបង្អស់
នោះឯងរាល់គ្នានឹងយល់[ល]បាន ។

# ៣១

១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅគ្រានោះអញ

**៣០:១៥** ក សភ ១:៣១ បទ ១:៥ **៣០:១៦** ខ អស ២៩:៨ ៣៣:១ យរ ២:៣ គ អស ១៤:២ យអ ៣:៤-៨ ឃ យរ ៤៩:២ ៥០:១០ **៣០:១៧** ង អស ១:៥ ហស ៦:១ ច អស ៦:១២ យរ ៣៣:២៤ ឆ ទដ ១៤២:៤ **៣០:១៨** ជ ខ.៣ ចទ ៣០:៣ យរ ៣១:២៣ ៣២:៤៤ ឈ ជន ២៤:៥ ញ ទដ ១០២:១៣ យរ ៣៣:២៦ អគ ៣៩:២៥ ដ យរ ៣១:៤,២៤,៣៨ អគ ៣៦:១០,៣៣ អម ៩:១៤ **៣០:១៩** ឋ ទដ ៩:២ អស ៣៥:១០ ៥១:១១ ឌ អស ៥១:៣ ឍ ទដ ១២៦:១-២ យរ ៣១:៤ ណ លប ១៥:៥ ២២:១៧ យរ ៣៣:២២ អគ ៣៧:២៦ សក ២:៤ ត អស ៤៤:២៣ ៦០:៩ **៣០:២០** ថ អស ៥៤:១៣ យរ ៣១:១៧ សក ៨:៥ ទ អស ៥៤:១៤ ធ នក ២៣:២២ **៣០:២១** ន ខ.៩ យរ ២៣:៥-៦ ប ចទ ១៧:១៥ ផ ជន ១៦:៥ **៣០:២២** ព អស ១៩:២៥ ហស ២:២៣ ភ លវ ២៦:១២ **៣០:២៣** ម យរ ២៣:១៩ **៣០:២៤** យ យរ ៤:៨ បទ ១:១២ រ យរ ៤:២៨ ល យរ ២៣:១៩-២០

**៣០:១៦** *អស់អ្នកណាដែលត្របាក់ស៊ីឯង* សូមមើល ៣:២៤ ៥:១៧ ៨:១៦ ១០:២៥ ។ *នឹងត្រូវគេត្របាក់ស៊ីវិញ* មើលការពន្យល់ ២៥:២៦ មើលផងដែរ ៥១:៤៨-៤៩ ។ ហើយអស់អ្នកដែលប្លន់ឯង មើល អស ១៧:១៤ ។

**៣០:១៧** *អញនឹងមើលឯងឱ្យជា* ខុសគ្នានៅក្នុង ៨:២២ មើល ៣៣:៦ អស ៥៨:៨ ។ *ភ្នំស៊ីយ៉ូន* មើលការពន្យល់ ២សយ ៥:៧ ។

**៣០:១៨** *មើល អញនឹងនាំពួកឈ្លើយ* មើលការពន្យល់ ២៩:១៤ ។ *ហើយទីក្រុង . . . ដូចពីដើម* ន័យត្រង់ " ទីក្រុង . . . ដូចពីដើម" ប្រហែលជានិយាយសំដៅទៅលើទីស្រុកយូដា និងទីកន្លែងទូទៅ (មើល អម ៩:១៤) វាអាចធ្វើបាន ទោះបីជាយ៉ាងណា មានតែក្រុងយេរូសាឡិម១ប៉ុណ្ណោះ និងទីកន្លែងនោះបានសាងសង់ឡើងវិញ ។ *គំនរចាស់* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺនិយាយសំដៅទៅលើគំនរសំរាម សល់ពីការបាក់បែក ដែលវាបានប្រមូលពីកំទេចកំទីជាច្រើនឆ្នាំ ឬអស់រយៈពេលជាច្រើនសតវត្សក្រោយពីការកាន់កាប់ និងក្រោយពេលដែលទទួលបានជ័យជម្នះ ហើយទីក្រុងនោះបានសាងសង់ឡើងវិញ (មើលឱ. យក ១១:១៣ និងការពន្យល់) ។

**៣០:១៩** *ក៏នឹងឮពាក្យអរព្រះគុណ* មើល ៣៣:១១ ។ *អរសប្បាយ* មើល ៣១:៤ និងការពន្យល់ ខុសគ្នានៅក្នុង ១៥:១៧ ។ *អញនឹងធ្វើឱ្យគេចំរើនឡើង* មើល ២៩:៦ អគ ៣៦:៣៧-៣៨ ។ *ថ្កុំថ្កើងឡើងដែរ គេមិនមែនជានគរតូចទាបទេ* មើល អស ៩:១ ។

**៣០:២០** *កាលពីដើម* ប្រហែលជានៅថ្ងៃជំនាន់ដើម មាននគរមួយដែលមានការរួបរួម ជាពិសេសនៅពេលការឡើងសោយរាជ្យរបស់ស្ដេចដាវីឌ ។ *ពួកជំនុំ* នៅក្នុង ១ពវ ១២:២០ ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "ពួកជំនុំ" ការគ្រប់គ្រងខាងផ្នែកនយោបាយ និងសាសនារបស់ បណ្ដាជន ។ *នឹងបានតាំងឡើង នៅចំពោះអញ* មើល ទដ ១០២:២៨ និងការពន្យល់ ។

**៣០:២១** *ពួកអ្នកធំ . . . ចៅហ្វាយ* ថ្វីបើតាហ្គាម (Targum) និយាយសំដៅទៅលើ "ព្រះមែស៊ី" ពាក្យនេះប្រហែលជានិយាយសំដៅទៅលើទីកន្លែងដំបូងពួកចៅហ្វាយយូដា ក្រោយពីការចាប់ជាឈ្លើយ ។ ប៉ុន្តែព្រះយេស៊ូវគ្រីស្ទ ជាអ្នកដែលបំពេញសេចក្ដីសន្យាចុងក្រោយបំផុត ។ *នឹងកើតពីពួកមក . . . ចេញពីកណ្ដាលពួកគេ* មិនមែនជាសាសន៍ដទៃនោះឡើយ (ធៀបនឹង ចទ ១៨:១៥,១៨) ។ *អញនឹងនាំគេ ហើយគេនឹងចូលមកជិតអញ* មើល ជន ១៦:៥ ខុសគ្នានៅក្នុង ២៤:២ ។ ការដែលមិនអាចចូលដល់វត្តមានរបស់ព្រះ គឺដោយសារអំពើបាប (មើល ១៩:២១ ជន ៨:១៩ ។

**៣០:២២** មើល ៣១:១ មើលការពន្យល់ផងដែរ ៧:២៣ ។

**៣០:២៣-២៤** ការរំឭកឡើងវិញ ចំពោះពាក្យដែលនិយាយត្រង់ៗតាមពាក្យនៅក្នុង ២៣:១៩-២០ (មើលការពន្យល់) ។

**៣១:១-៤០** បន្តសាច់រឿង និយាយពីការចាប់ផ្ដើមការសាងសង់ឡើងវិញនៅក្នុង ៣០:១ លោកយេរេមាបានកត់ត្រាព្រះបន្ទូលរបស់ព្រះអម្ចាស់សម្រាប់ (១).រាស្ត្ររបស់ព្រះគ្រប់រូប ខ.១ បែបជាសុភាសិត (២).ការស្អាងឡើងវិញដល់នគរខាងជើង គឺអ៊ីស្រាអែល ខ.២-២២ បែបជាកំពាព្យ (៣).ការស្អាងឡើងវិញដល់នគរខាងត្បូង គឺយូដា ខ.២៣-២៦ និង(៤).

នឹងធ្វើជាព្រះ[ក] ដល់គ្រប់ទាំងគ្រួនៃសាសន៍អ៊ីស្រាអែល
ហើយគេនឹងបានជារាស្ត្ររបស់អញ ២ព្រះយេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា ពួកជនដែលសល់នៅពីដាវ គឺជាពួក
អ៊ីស្រាអែល គេបានប្រកបដោយគុណ[ខ]នៅទីរហោស្ថាន
ក្នុងកាលដែលអញទៅប្រោសឱ្យបានសេចក្តីសំរាក[គ] ៣ព្រះ
យេហូវ៉ាទ្រង់បានលេចមកឱ្យខ្ញុំឃើញកាលពីដើម ដោយ
បន្ទូលថា អើ អញបានស្រឡាញ់[ឃ]ឯង ដោយសេចក្តី
ស្រឡាញ់ដ៏ស្ថិតស្ថេរនៅអស់កល្ប ហេតុនេះបានជាអញ
ទាញនាំ[ង]ឯងមក ដោយសេចក្តីសប្បុរស ៤ឱព្រហ្មចារី[ច]នៃ
សាសន៍អ៊ីស្រាអែលអើយ អញនឹងសង់ឯងឡើងវិញ[ឆ] នោះ
ឯងនឹងបានតាំងនៅ ឯងនឹងបានតាក់តែងដោយក្រាប់ជា
ថ្មីទៀត[ជ] ព្រមទាំងចេញទៅលោតកញ្ឆែង[ឈ]ជាមួយនឹងពួក
អ្នកដែលលេងសប្បាយ[ញ] ៥ឯងនឹងដាំ[ដ]ដំណាំទំពាំងបាយជូរ
នៅលើភ្នំស្រុកសាម៉ារីទៀត[ឋ] ម្ចាស់ដំណាំនឹងដាំទៅហើយ
ទទួលផលផង[ឌ] ៦ដ្បិតនឹងមានថ្ងៃមកដល់ ដែលពួកយាម[ឍ]
នៅលើភ្នំស្រុកអេប្រាអិម និងស្រែកឡើងថា ចូរក្រោក
ឡើងយើងនឹងឡើងទៅឯព្រះយេហូវ៉ា ជាព្រះនៃយើង
នៅក្រុងស៊ីយ៉ូន[ណ]។
៧ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូរច្រៀង[ត]
ដោយចិត្តអរសប្បាយ ព្រោះពួកយ៉ាកុប ហើយស្រែក
ឡើងដោយអំណរ ដោយព្រោះមេប្រធាន[ថ]នៃអស់ទាំង
សាសន៍ចូរប្រកាសប្រាប់ចុះ ចូរលើកសរសើរ ដោយពាក្យ
ថាព្រះយេហូវ៉ាអើយ សូមជួយសង្គ្រោះ[ទ]សំណល់[ធ]នៃ
សាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ទ្រង់ផង ៨មើលអញនឹង

**៣១:១** ក លវ ២៦:១២
**៣១:២** ខ ជន ១៤:២០ គ នក ៣៣:១៤ ចទ ១២:៩
**៣១:៣** ឃ ចទ ៤:៣៧ ង ហស ១១:៤ យហ ៦:៤៤
**៣១:៤** ច ២ពវ ១៩:២១ ឆ យរ ១:១០ ៣០:១៨ ជ លប ៣១:២៧ ឈ នក ១៥:២០ ញ យរ ៣០:១៩
**៣១:៥** ដ ចទ ២០:៦ ឋ យរ ៣៣:១៣ ៥០:១៩ អប ១:១៩ ឌ អស ៣៧:៣០ អម ៩:១៤
**៣១:៦** ឍ អស ៥២:៨ ៥៦:១០ ណ ខ.១២ ចទ ៣៣:១៩ យរ ៥០:៤-៥ មីក ៤:២
**៣១:៧** ត អស ១២:៦ ថ ចទ ២៨:១៣ អស ៦១:៩ ទ ទដ ១៤:៧ ២៨:៩ ធ អស ៣៧:៣១

ការស្ដារឡើងវិញដល់នគរទាំងពីរ គឺអ៊ីស្រាអែល និងយូដា ខ.២៧-៤០ (បែបជា សុភាសិត ខ.២៧-៣០ លក្ខណៈជាកំណាព្យ ខ.៣១-៣៧ ហើយសេចក្តីបញ្ចប់ ខ.៣៨-៤០ ផ្នែកនិមួយៗមានផ្ដើមដោយពាក្យ "ថ្ងៃនោះនឹងមកដល់" មើល ការពន្យល់ ខ.៣១ ។

**៣១:១** មើល ៣០:២២ មើលការពន្យល់ ៧:២៣ ។ *ដល់គ្រប់ទាំងគ្រួនៃសាសន៍អ៊ីស្រាអែល* គឺពូជអំបូរទាំង ។

**៣១:២** *ពួកជនដែលសល់នៅពីដាវ* មនុស្សសុច្ចរិតដែលនៅសល់ (មើល ខ.៧ មើលការពន្យល់ផងដែរ ៦:៩) ដែលវិលត្រឡប់ពីការចាប់ជាឈ្លើយ ។ ទីរហោស្ថាន ទីរហោស្ថានអាប់រ៉ាម គឺខុសគ្នាទៅនឹងទីរហោស្ថានភ្នំស៊ីណៃ តាមរយៈការតភ្ជាប់ពួកព្យុកោអ៊ីស្រាអែល បន្ទាប់ពីសម័យនិក្ខមនំ ។ ការវិលត្រឡប់មកពីការនិរទេសខ្លួន គឺបានពិណនាដូចជា ឬការរំដោះពួកទាសកពីស្រុកអេស៊ីព្ទ នៅពេលមួយនៃសម័យនិក្ខមនំ (មើល ១៦:១៤-១៥ អស ៣៥:១-១១ និងការពន្យល់ ៤០:៣-៤ ៤២:១៤-១៦ ៤៣:១៨-២១ ៤៨:២០-២១ ៥១:៩-១១ ធៀបនឹង ហស ២:១៤-១៥) ។ *សេចក្តីសំរាក* មើល ៦:១៦ ខុសគ្នានៅក្នុង ចទ ២៨:៦៥ មើលការពន្យល់ ចទ ៣:២០ យក ១:១៣ ។ *អ៊ីស្រាអែល* គឺនគរខាងជើង (មើលផងដែរ ខ.៦,៩,១៨,២០) លោកយ៉ាកុប (ខ.៧,១១) និងនាងរ៉ាជែល (ខ.១៥) ។

**៣១:៣** *ដោយសេចក្តីសប្បុរស* ក្នុងព្រះគម្ពីរភាសាហេព្រើរគួសបញ្ជាក់ឃ្លានេះ គឺបានបកប្រែថា "បន្តក្តីស្រឡាញ់" នៅក្នុង ទដ ៣៦:១០ (មើលការពន្យល់ ទដ ៦:៤) ។

**៣១:៤** *អញនឹងសង់ឯងឡើងវិញ* មើល ១:១០ និងការពន្យល់ ។ *ឱព្រហ្មចារីនៃសាសន៍អ៊ីស្រាអែល* មើលការពន្យល់ ២ពវ ១៩:២១ ។ *តាក់តែងដោយក្រាប់* គេបានប្រើវាសម្រាប់ក្នុងឱកាសដែលធ្វើឱ្យសប្បាយ (មើល ទដ ៦៨:២៥) ជាពិសេសនៅពេលទទួលបានជ័យជំនះខាងផ្នែកទាហាន (មើល នក ១៥:២០ និងការពន្យល់ ពច ១១:៣៤ ដែលខុសគ្នាទៅនឹងបទពិសោធន៍របស់ពួកយូដា នៅក្នុងកំឡុងពេលនៃការចាប់ជាឈ្លើយ (មើល ទដ ១៣៧:១-៣) ។ *លោតកញ្ឆែង* មើលខ.១៣ ជាសកម្មភាពជំនឿសាសន៍ នៅសម័យជំនាន់បុរាណ (មើល ២សយ ៦:១៤ ទដ ១៤៩:៣ ១៥០:៤) ។

**៣១:៥** *ដាំដំណាំ* មើល ខ.១៣ និងការពន្យល់ ។ *ស្រុកសាម៉ារី* ជាស្រុកដែលបានច្បាំងដណ្ដើមបាន នៅក្នុងឆ្នាំ ៧២២-៧២១ មុន គ.ស (មើល ២ពវ ១៧:២៤) នៅថ្ងៃមួយវានឹងធ្វើឱ្យបានត្រឹមត្រូវ ដោយសារាស្ត្ររបស់ព្រះ ។ *ម្ចាស់ដំណាំនិងដាំទៅ* ហើយទទួលផលផង មើល ចទ ២៨:៣០ អស ៦២:៨-៩ ៦៥:២១-២២ ។ ក្រិត្យវិន័យនោះបញ្ជាក់ ផលផ្លែពីដើមឈើនោះ មិនអាចបរិភោគបានឡើយ រហូតទាល់តែបានរយៈពេល៥០ឆ្នាំ ក្រោយពីដាំដើមឈើនោះ (មើល លវ ១៩:២៣-២៥) ការវិលមករកភាពជាធម្មតាឡើងវិញ ។

**៣១:៦** *ដែលពួកយាមនៅលើភ្នំស្រុកអេប្រាអិម* ពួកអ្នកយាម គឺជាអ្នកឈរនៅទីកន្លែងមួយដ៏សមរម្យ ដើម្បីអង្កេតមើលនូវដំណើរការផ្សេងៗគ្នា នៃព្រះច័ន្ទ នៅក្នុងពិធីជប់លៀងយ៉ាងសំខាន់ (សូមមើល ចទ ១៦:១៦ និងការពន្យល់) ។ *ភ្នំស្រុកអេប្រាអិម... ក្រុងស៊ីយ៉ូន* នៅក្នុងថ្ងៃស្តេចយេរ៉ូបោមទី១ បណ្ដាជននៅនគរខាងជើង គឺតំរូវឱ្យថ្វាយបង្គំព្រះនៅផ្នែកខាងជើងនោះ (មើល ១ពវ ១២:២៦-៣០) ។ ទោះជាយ៉ាងណាក្តី នៅថ្ងៃអនាគត នោះគេត្រូវថ្វាយបង្គំដល់ព្រះអម្ចាស់តែមួយគត់ នៅក្នុងក្រុងយេរូសាឡិម (ធៀបនឹង យហ ៤:២០) ។ *ឡើងទៅ* នៅសម័យបុរាណ ពួកអ៊ីស្រាអែលតែងតែ "ឡើងទៅ" ក្រុងយេរូសាឡិម (មើលឧ. អគ ១:៣ ៧:៧ អស ២:៣ យហ ២:១៣) មិនមែន ដោយព្រោះតែសម្រាប់អ្នកដែលនៅជនបទប៉ុណ្ណោះទេ តែគឺសម្រាប់អ្នកនៅទីក្រុងផងដែរ និងទីនោះជាចំណុចកណ្ដាលដ៏សំខាន់សម្រាប់ជីវិត ការគោរពជំនឿសាសានាដល់អស់ទាំងសាសន៍ ។

**៣១:៧** *ដោយព្រោះមេប្រធាននៃអស់ទាំងសាសន៍* មើល ចទ ២៦:១៩ អម ៦:១ ។ អ៊ីស្រាអែលគឺជាសាសន៍មួយដ៏ធំ មិនមែនដោយសារអ្វីដែលគេមាននោះទេ ប៉ុន្តែដោយសារតែព្រះគុណ និងការតែងតាំងរបស់ព្រះ ចំពោះពួកគេ (មើល ចទ ៧:៦-៨ ២សយ ៧:២៣-២៤) ។ *សូមជួយសង្គ្រោះ* ក្នុងព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ សំដៅទៅលើពាក្យដ៏សំខាន់ គឺ "ហូសាណា" សម្រែករបស់បណ្ដាជននៅក្នុងក្រុងយេរូសាឡិម ក្នុងថ្ងៃអាទិត្យ (មើល មថ ២១:៩ និងការពន្យល់ មើលផងដែរ ទដ ២០:៩ ២៨:៩ ៨៦:២ និងជាពិសេស ១១៨:២៥) ។ *សំណល់* មើលការពន្យល់ ៦:៩ ។

នាំគេមកពីស្រុកខាងជើង[ន] ហើយនឹងប្រមូល[ប]គេពីចុងផែន
ដីបំផុត មានទាំងពួកខ្វាក់[ផ] ពួកខ្វិន[ព] ស្រីមានទំងន់ នឹងស្រី
ដែលរៀបនឹងសំរាលកូនផង ជាពួកមនុស្សយ៉ាងធំ ដែល
នឹងវិលមកនៅទីនេះវិញ ៩ គេនឹងមកដោយទឹកភ្នែក[ភ] និង
ពាក្យទូលអង្វរ អញនឹងនាំមុខគេ ហើយដំរង់[ម]គេដើរទៅ
ក្បែរមាត់ទន្លេ[យ] តាមផ្លូវត្រង់[រ] ជាផ្លូវដែលគេមិនចំពប់ដួល
ឡើយ ដ្បិតអញជាឪពុកដល់សាសន៍អ៊ីស្រាអែល[ល] ហើយពួក
អេប្រាអិមជាកូនច្បងរបស់អញ ។
១០ ឱសាសន៍ដទៃទាំងប៉ុន្មានអើយ ចូរឱ្យឯងរាល់គ្នា
ស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ា ហើយថ្លែងប្រាប់ដល់ ពួក
កោះដែលនៅឆ្ងាយថា[វ] ព្រះដែលបានកំចាត់កំចាយ[ស]
សាសន៍អ៊ីស្រាអែលទៅ ទ្រង់នឹងប្រមូល[ហ]គេមកវិញ ហើយ
នឹងរក្សាគេដូចជាអ្នកគង្វាលឃ្វាលហ្វូងចៀមរបស់ខ្លួន[ឡ]
១១ ពីព្រោះព្រះយេហូវ៉ាទ្រង់បានលោះយ៉ាកុបហើយ ទ្រង់
បានដោះ[អ]គេចេញពីកណ្តាប់ដៃនៃពួកអ្នកដែលខ្លាំងជាង[ក]
ខ្លួន ១២ គេនឹងមក ហើយច្រៀង[ខ]នៅ លើទីខ្ពស់[គ]នៃភ្នំស៊ីយ៉ូន
ហើយនឹងមកហូរហែ ដល់សេចក្តីសប្បុរស[ឃ]របស់ព្រះ
យេហូវ៉ា គឺមកដល់ស្រូវ ទឹកទំពាំងបាយជូរ ប្រេង[ង] និងកូន
ចៀម កូនគោ ពីហ្វូងសត្វ[ច] ហើយព្រលឹងគេនឹងបានដូចជា
សួនច្បារ ដែលមានទឹកស្រោច[ឆ] នោះគេនឹងមិនមានសេច
ក្តីព្រួយ[ជ]ទៀតឡើយ ១៣ គ្រានោះ នាងក្រមុំនឹងមានចិត្តរីក
រាយក្នុង ការលោតកញ្ឆេង ព្រមទាំងពួកកំឡោះៗ និង
ពួកចាស់ៗទាំងអស់គ្នាផង ដ្បិតអញនឹងបំប្រែសេចក្តីសោក
សៅ[ឈ]របស់គេទៅជាសេចក្តីអំណរវិញ ហើយកំសាន្តចិត្ត[ញ]
គេ ព្រមទាំងឱ្យគេរីករាយ[ដ]ចេញពីសេចក្តីទុក្ខព្រួយរបស់
គេ ១៤ អញក៏នឹងចំអែត[ឋ]ព្រលឹងនៃពួកសង្ឃ[ឌ] ដោយ
សេចក្តីបរិបូរ ហើយរាស្ត្រអញនឹងបានស្កប់ចិត្ត ដោយ
សេចក្តីសប្បុរសរបស់អញ[ឍ] នេះហើយជាព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ។
១៥ ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា មានឮសូរ
សំឡេងនៅរ៉ាម៉ា[ណ] ជាសូរទំនួញ និងសូរយំយ៉ាងជូរចត់ គឺ
នាងរ៉ាជែលយំនឹងកូននាង ហើយមិនព្រមកំសាន្តចិត្ត[ត] ពី
ដំណើរកូនសោះ ដ្បិតវាវិនាសបាត់ហើយ[ថ] ១៦ ព្រះយេហូវ៉ា

**៣១:៨** ន យរ ៣:១៨ ប លប ៣៣:១៣ ចទ ៣០:៤ ទដ ១០៦:៤៧ អគ ៣៤:១២–១៤ ផ អស ៤២:១៦ ព អគ ៣៤:១៦ មីក ៤:៦ **៣១:៩** ភ អរ ៣:១២ ទដ ១២៦:៥ ម អស ៦៣:១៣ យ ជន ២០:៨ ទដ ១:៣ អស ៣២:២ រ អស ៤០:៤ ៤៩:១១ ល នក ៤:២២ យរ ៣:៤ **៣១:១០** វ អស ៤៩:១ ៦៦:១៩ យរ ២៥:២២ ស លវ ២៦:៣៣ ហ ចទ ៣០:៤ អស ១១:១២ យរ ៥០:១៩ ឡ អស ៤០:១១ អគ ៣៤:១២ **៣១:១១** អ នក ៦:៦ សក ៩:១៦ ក ទដ ១៤២:៦

**៣១:១២** ខ ទដ ១២៦:៥ គ អគ ១៧:២៣ ២០:៤០ ៤០:២ មីក ៤:១ ឃ ទដ ៣៦:៨ យអ ៣:១៨ ង ជន ១៩:១២ ហស ២:២១–២២ យអ ២:១៩ ច ខ.២៤ អស ៦៥:១០ ឆ បស ៤:១៥ ជ អស ៣០:១៩ ៦២:៥ យហ ១៦:២២ វវ ៧:១៧ **៣១:១៣** ឈ អស ៦១:៣ ញ អស ៤០:១ ដ ទដ ៣០:១១ អស ៥១:១១ **៣១:១៤** ឋ ខ.២៥ ឌ លវ ៧:៣៥–៣៦ ឍ ទដ ៣៦:៨ អស ៣០:២៣ **៣១:១៥** ណ យស ១៨:២៥ ត លប ៣៧:៣៥ ថ យរ ១០:២០ មថ ២:១៧–១៨

**៣១:៨** *ស្រុកខាងជើង* មើល ៣:១៨ ៤:៦ និងការពន្យល់ ៦:២២ ១៦:១៥ ។ *ពីចុងផែនដីបំផុត* មើល ៦:២២ ២៥:៣២ ។ *ពួកខ្វាក់ ពួកខ្វិន* មើល អស ៣៥:៥–៦ និងការពន្យល់ ៤២:១៦ ។ *ស្រីដែលរៀបនឹងសំរាលកូនផង* មើលការពន្យល់ ៤:៣១ ។

**៣១:៩** *គេនឹងមកដោយទឹកភ្នែក* ខុសគ្នានៅក្នុង ទដ ១២៦:៥–៦ អស ៥៥:១២ ។ *អញនឹងនាំមុខគេ* មើល អស ៤០:១១ ៤៨:២១ ខុសគ្នានៅក្នុង អស ២០:៤ ។ *ក្បែរមាត់ទន្លេ* មើល អស ៤៩:១០ មើលផងដែរ ៤១:១៨ ។ *តាមផ្លូវត្រង់* មើល អស ៤០:៣–៤ និងការពន្យល់ ៤៣:១៦,១៩ ។ ដ្បិតអញជាឪពុកដល់សាសន៍អ៊ីស្រាអែល មើល ៣:៤ និងការពន្យល់ មើលផងដែរ ចទ ៣២:៦ អស ៦៣:១៦ ៦៤:៨ ។ *ជាកូនច្បង* ធៀបនឹង ខ.២០ មើល អគ ៤:២២ និងការពន្យល់ ហស ១១:១–៤ ។

**៣១:១០** *ពួកកោះដែលនៅឆ្ងាយ* ជាតំបន់ដែលនៅដាច់ស្រយាល នៅខាងលិចអ៊ីស្រាអែល (មើល ២:១០ ២៥:២២ និងការពន្យល់ ៤៧:៤ ទដ ៧២:១០ អស ៤១:១,៥ ៤២:១០,១២ ៤៩:១) ។ *កំចាត់កំចាយសាសន៍អ៊ីស្រាអែលទៅ ទ្រង់នឹងប្រមូលគេមកវិញ* មើល ២៣:១–៣ និងការពន្យល់ ។

**៣១:១១** *ទ្រង់បានដោះគេ* មើលការពន្យល់ នរ ២:២០ ដូចជាព្រះអម្ចាស់បានរំដោះរាស្ត្រទ្រង់ចេញពីទាសកនៅស្រុកអេស៊ីព្ទ (មើល នក ៦:៦ និងការពន្យល់ ១៥:១៣ ចទ ៧:៨ ៩:២៦) ដូច្នេះហើយទ្រង់បានរំដោះកូនចៅរបស់ទ្រង់ពីភាពជាឈ្លើយនៅបាប៊ីឡូន (មើល អស ៤១:១៤ ៤៣:១ និងការពន្យល់ ៥២:៩) ។ កណ្តាប់ដៃនៃពួកអ្នកដែលខ្លាំងជាងខ្លួន មើល ទដ ៣៥:១០ ។

**៣១:១២** *ទីខ្ពស់នៃភ្នំស៊ីយ៉ូន* មើលការពន្យល់ ១៧:១២ ។ *សេចក្តីសប្បុរសរបស់ព្រះយេហូវ៉ា* ព្រះពរខាងផ្នែកទ្រព្យសម្បត្តិ (សូមមើល ខ.១៤ ហស ៣:៥) ។ *ស្រូវ ទឹកទំពាំងបាយជូរ ប្រេង* មើលការពន្យល់ ចទ ៧:១៣ មើលផងដែរ ហស ២:៨ ។ *ដូចជាសួនច្បារ ដែលមានទឹកស្រោច* មើល អស ៥៨:១១ និងការពន្យល់ ។ *នោះគេនឹងមិនមានសេចក្តីព្រួយទៀតឡើយ* មើល អស ២៥:៨ ។

**៣១:១៤** *សេចក្តីបរិបូរ* ពាក្យផ្សេងគឺ (១).ពាក្យនេះមានន័យដូចគ្នាទៅនឹងពាក្យ សេចក្តីសប្បុរសរបស់ព្រះ (មើល ទដ ៣៦:៨ ៦៣:៥ អស ៥៥:២) ឬ (២).សំដៅទៅលើយញ្ញបូជាសត្វ ជាចំណែកដ៏ពិសេស ទុកសម្រាប់ពួកសង្ឃ (មើល លវ ៧:៣១–៣៦) ។

**៣១:១៥** បានដកស្រង់នៅក្នុង មថ ២:១៨ នៅពេលដែលស្តេចហេរ៉ូឌបានបញ្ជាឱ្យសម្លាប់ទារកប្រុសៗទាំងអស់ " នៅភូមិបេថ្លេហិម និងភូមិជិតនោះ" (មថ ២:១៦) វាបានកើតឡើង ដើម្បីសម្រេចនៅក្នុងព្រះបន្ទូលនេះ ។ *រ៉ាម៉ា* ដែលមានទីតាំងនៅចម្ងាយ៥គីឡូម៉ែត្រ ពីភាគខាងជើង ក្រុងយេរូសាឡិម វាជាទីក្រុង១ដែលបណ្តាជនបានដើរកាត់តាម ទីក្រុងយេរូសាឡិម តាមផ្លូវនោះទៅដល់ទីកន្លែងការចាប់ជាឈ្លើយនៅក្រុងបាប៊ីឡូន (មើល ៤០:១ ធៀបនឹង អស ១០:២៩ ហស ៥:៨) ។ *នាងរ៉ាជែល* ជាប្រពន្ធសំណប់របស់លោកយ៉ាកុប (មើល លប ២៩:៣០) និងជាជីដូនរបស់លោកអេប្រាអិម និងលោកម៉ានាសេ (មើល លប ៣០:២២–២៤ ៤៨:១–២) ពូជអំបូរ២ដែលមានអំណាចបំផុត នៅនគរខាងជើង ឈ្មោះនោះគឺបានប្រើសម្រាប់បញ្ជាក់នគរនោះ (មើលការពន្យល់ ខ.២) ។

ទ្រង់មានបន្ទូលដូច្នេះថា ចូរទប់សំឡេងឯងមិនឱ្យយំនឹង
ភ្នែកឯងមិនឱ្យហូរសស្រាក់ឡើយ[ទ] ដ្បិតព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា ការរបស់ឯងនឹងបានរង្វាន់ជាពិត[ធ] ហើយ
វារាល់គ្នានឹងវិលមក[ន]ពីស្រុករបស់ខ្មាំងសត្រូវវិញ ១៧ព្រះ
យេហូវ៉ាទ្រង់ក៏មានបន្ទូលថា មានសេចក្ដីសង្ឃឹម[ប]សំរាប
ចុងបំផុតរបស់ឯងកូនចៅ[ផ]ឯងនឹងវិលមកឯព្រំដែនរបស់
គេវិញ ១៨ពិតប្រាកដជាអញបានឮពួកអេប្រាអិម កំពុងតែ
ត្អូញត្អែរថា ទ្រង់បានវាយផ្ចាល[ព]ទូលបង្គំ គឺពួកទូលបង្គំត្រូវ
វាយពង្រាប ដូចជាកូនគោ[ភ]ដែលមិនធ្លាប់ទឹម សូមទ្រង់
ទាញញាក់[ម]ទូលបង្គំមកវិញ នោះទូលបង្គំនឹងវិលបែរមក
ហើយ ដ្បិតគឺទ្រង់ហើយជាព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំ
១៩ក្រោយដែលទ្រង់បានទាញញាក់ទូលបង្គំមកវិញ[យ] នោះ
ទូលបង្គំបានប្រែគំនិតឡើងជាពិត កាលទូលបង្គំបានទទួល
សេចក្ដីប្រៀនប្រដៅហើយ នោះក៏វាយទះ[រ]ភ្លៅខ្លួន ទូលបង្គំ
មានសេចក្ដីខ្មាស[ល] អើ ក៏ជ្រប់មុខផង ពីព្រោះទូលបង្គំធន់
រងសេចក្ដីអាម៉ាសខ្មាសនៃវ័យនៅក្មេង[វ] ២០តើអេប្រាអិមជា
កូនសំឡាញ់របស់អញឬ តើជាកូនសំណប់[ស]ឬអី ដ្បិត ដែល
អញនិយាយទាស់នឹងវេលាណា នោះអញក៏នឹករឭក[ហ]ដល់
វានៅវេលានោះឯង ដូច្នេះអញមានចិត្តរំជួល[ឡ]ដល់វា
ហើយនឹងអាណិតមេត្តាដល់វាជាមិនខាន នេះហើយជាព្រះ
បន្ទូលនៃព្រះយេហូវ៉ា ។
២១ចូរធ្វើទីសំគាល់តាមផ្លូវ ហើយដោតដំរុយចុះ[អ] ចូរ
តាំងដំរង់ទៅឯថ្នល់[ក] គឺជាផ្លូវដែលឯងបានទៅតាម នោះឱ
ព្រហ្មចារី[ខ]នៃសាសន៍អ៊ីស្រាអែលអើយ ចូរវិលមកវិញ[គ]
ចូរវិលមកឯទីក្រុងរបស់ឯងទាំងនេះចុះ ២២ឱកូនស្រីដែល
រាថយ[ឃ]អើយ ឯងនឹងនៅតែដើរសាត់អណ្ដែត តើដល់កាល
ណាទៀត[ង] ដ្បិតព្រះយេហូវ៉ាទ្រង់បានបង្កើតការថ្មី[ច]នៅ
ផែនដីគឺមនុស្សស្រីនឹងឡោមព័ទ្ធ[ឆ]មនុស្សប្រុស ។
២៣ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា កាលណាអញនាំពួក
គេ ដែលជាឈ្លើយមកវិញនោះ[ជ] នៅក្នុងស្រុកយូដាហើយ
អស់ទាំងទីក្រុងនៅស្រុកនោះ គេនឹងនិយាយពាក្យនេះឡើង
ជាថ្មីទៀត គឺថា ឱទីលំនៅនៃសេចក្ដីសុចរិត[ឈ] ហើយភ្នំនៃ
សេចក្ដីបរិសុទ្ធអើយ[ញ] សូមព្រះយេហូវ៉ាប្រទានពរ[ដ]ដល់
ឯង ២៤នោះពួកយូដា និងអស់អ្នកនៅ[ឋ]ទីក្រុងរបស់គេ គឺជា
ពួកអ្នកធ្វើស្រែចំការ ហើយពួកអ្នកដែលឃ្វាលហ្វូងសត្វ
ដែរ គេនឹងនៅទីនោះ[ឌ] ២៥ដ្បិតអញបានចំអែតព្រលឹង
មនុស្សដែលល្វើយ[ឍ] ហើយឯងព្រលឹងព្រួយលំបាក នោះ
អញបានឱ្យស្កប់ចិត្តឡើងវិញ[ណ] ២៦មកដល់ត្រឹមនេះ ខ្ញុំបាន
ភ្ញាក់ដឹងខ្លួនឡើង[ត] ហើយមើល ការដេកលក់របស់ខ្ញុំបាន
ផ្អែមឆ្ងាញ់ដល់ខ្ញុំណាស់ ២៧ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា

**៣១:១៦** ទ ទដ ៣០:៥ អស ២៥:៨ ៣០:១៩ ធ នរ ២:១២ ២របា ១៥:៧ ន យរ ៣០:៣ អគ ១១:១៧ **៣១:១៧** ប យប ៨:៧ បទ ៣:២៩ ផ យរ ៣០:២០ **៣១:១៨** ព យប ៥:១៧ ភ យរ ៥០:១១ ហស ៤:១៦ ១០:១១ ម ទដ ៨០:៣ **៣១:១៩** យ ទដ ៩៥:១០ យរ ៨:៤ អគ ៣៦:៣១ រ អគ ២១:១២ លក ១៨:១៣ ល អរ ៩:៦ វ ទដ ២៥:៧ យរ ២២:២១ **៣១:២០** ស បទ ៣:៣៣ ហ អស ៤៤:២១ ឡ ១ពវ ៣:២៦ **៣១:២១** អ អគ ២១:១៩ ក អស ៣៥:៨ យរ ៥០:៥ ខ ខ.៤ គ អស ៥២:១១ យរ ៣:១២ **៣១:២២** ឃ យរ ៣:៦ ង យរ ២:២៣ ច អស ៤៣:១៩ ឆ ចទ ៣២:១០ **៣១:២៣** ជ យរ ៣០:១៨ ឈ អស ១:២៦ ញ លប ២៨:៣ ជណ ៦:២៤ ដ ទដ ៤៨:១ អស ២:២ **៣១:២៤** ឋ យរ ៣០:១៨ សក ៨:៤–៨ ឌ ខ.១២ **៣១:២៥** ឍ អស ៣០:២៩ ណ យរ ៤:១៤ **៣១:២៦** ត សក ៤:១

**៣១:១៦** *ការរបស់ឯងនឹងបានរង្វាន់ពិត* បាននិយាយនៅក្នុង ២របា ១៥:៧ នេះជាការងារដែលបានកើតផលផ្លែ និងជារង្វាន់សម្រាប់កូនចៅ ។

**៣១:១៧** *មានសេចក្ដីសង្ឃឹមសំរាប់ចុងបំផុតរបស់ឯង* មើល ២៩:១១ ។ *កូនចៅនឹងវិលមកឯព្រំដែនរបស់គេវិញ* ធៀបនឹង ហស ១១:១០–១១ ។

**៣១:១៨–១៩** *ទាញញាក់. . . នឹងវិលបែរមក. . . ប្រែគំនិត* ព្រះគម្ពីរភាសាហេព្រើរដូចគ្នានឹងពាក្យនេះទាំង៣នេះ (មើល ៨:៤–៥ និងការពន្យល់) ។

**៣១:១៩** *នោះក៏វាយទះភ្លៅខ្លួន* ជាសញ្ញាពីការកាន់ទុក្ខ (សូមមើល អគ ២១:១២) ។ នេះជាការបញ្ជាក់ដូចគ្នា ដែលបានរកឃើញនៅក្នុងកន្លែងផ្សេងទៀតនៅក្នុងផ្នែកអក្សរសាស្ត្រជិតនាន់បុរាណ ។ *ធន់រងសេចក្ដីអាម៉ាស់ខ្មាស់* មើល អស ៤៥:១៦ ។ *វ័យនៅក្មេង* ប្រវត្តិសាស្ត្រនៅជំនាន់ដើម (មើល ២:២ ៣:២៤–២៥ ២២:២១ ៣២:៣០ អស ៥៤:៤ អគ ១៦:២២) ។

**៣១:២០** *តើជាកូនសំណាប់ឬអី* ធៀបនិង អស ៥:៧ ។ *ដូច្នេះ. . . ហើយអញនឹងអាណិតមេត្តាដល់វាជាមិនខាន* មើល ហស ១១:១–៤,៨–៩ ។ *មានចិត្តរំជួល* មើល អស ១៦:១១ ។

**៣១:២១** ការចាកចេញរបស់ពួកអ្នកជាប់ជាឈ្លើយ គឺបានកើតឡើង ដោយមានអ្នកនាំមុខដើរតាមផ្លូវនោះ នៅពេលនោះដើម្បីឱ្យពួកគេអាចរកផ្លូវឃើញពេលវិលត្រឡប់ទៅយូដាវិញ ។ *ទីសំគាល់តាមផ្លូវ* ដែលមានថ្មបញ្ឈរឡើងគូសចំណាំ (មើល ២ពវ ២៣:១៧ អគ ៣៩:១៥) ។ *ឱព្រហ្មចារីនៃសាសន៍អ៊ីស្រាអែល* មើល ខ.៤ និងការពន្យល់ ។

**៣១:២២** *ឱកូនស្រីដែលរាថយអើយ* នេះជាលក្ខណ:សម្បត្តិរបស់បណ្ដាជនយូដា (មើលការពន្យល់ ២ពវ ១៩:២១) ដែលជាអ្នកបោះបង់សេចក្ដីជំនឿរបស់ខ្លួន(មើល ៣:១៤,២២) ។ *បង្កើតជាថ្មី* មើល អស ៤២:៩ និងការពន្យល់ ។ *ឡោមព័ទ្ធ* នេះជាការឱបដោយថ្នម ដែលពេញដោយសេចក្ដីស្រ–ឡាញ់ យូដានឹងវិលមកឯព្រះអម្ចាស់វិញនៅថ្ងៃមួយ ហើយស្រឡាញ់ទ្រង់ ដូចជាប្រពន្ធស្រឡាញ់ប្ដីដោយឥតលក្ខខ័ណ្ឌ (មើល ខ.៣២ និងការពន្យល់) ។

**៣១:២៣** *កាលណាអញនាំពួកគេ ដែលជាឈ្លើយមកវិញ* មើលការពន្យល់ ២៩:១៤ ។ *សូមព្រះយេហូវ៉ាប្រទានពរដល់ឯង* សូមមើល ទដ ១២៨:៥ ១៣៤:៣ ។ *ឱទីលំនៅនៃសេចក្ដីសុចរិត* គឺជាទីក្រុងយេរូសាឡិម (ធៀបនឹង អស ១:២១, ២៦) ។ *ឱភ្នំនៃសេចក្ដីបរិសុទ្ធអើយ* កូនភ្នំនៃព្រះវិហារ (មើល ទដ ២:៦ ៤៨:១–២ អស ២:២–៣ ១១:៩ ២៧:១៣ ៦៦:២០) ។

**៣១:២៦** *ខ្ញុំបានភ្ញាក់ដឹងខ្លួនឡើង* លោកយេរេមាបានទទួលនូវការជាក់ស្ដែងជាមុន ដែលព្រះបានបើកសំដែងដល់គាត់ (ចាប់ផ្ដើមនៅក្នុង ៣:៣) នៅក្នុងការយល់សប្តិ (ចំពោះឧទាហរណ៍ដូចគ្នា មើល ចទ ១០:៩ សក ៤:១) ។ *ការដេកលក់. . . ផ្អែមឆ្ងាញ់ដល់ខ្ញុំណាស់* សូមមើល សភ ៣:២៤ និងការពន្យល់ ។

**៣១:២៧** *ពូជមនុស្ស. . . ពូជសត្វ* មើល អគ ៣៦:៨–១១ ព្រះគម្ពីរភាសា

មើល នឹងមានគ្រាមកដល់[ច] ដែលអញនឹងយកពូជមនុស្ស
និងពូជសត្វព្រោះចុះ[ទ]ក្នុងពួកវង្សអ៊ីស្រាអែល ហើយនិង
ពួកវង្សយូដា ២៨ រួចដែលអញបានមើល[ធ]គេ ដើម្បីនឹងដក
រំលីង[ន] កាច់បំបាក់រំលំបំ ផ្លាញ ហើយធ្វើទុក្ខជាយ៉ាងណា[ប]
នោះអញនឹងមើលគេ ដើម្បីនឹងសង់គេឡើង ហើយដាំគេ
យ៉ាងនោះដែរ[ផ] នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ២៩ នៅ
គ្រានោះ គេនឹងលែងនិយាយថា "ពួកឪពុក[ព]បានស៊ីផ្លែ
មានរសជូរ ហើយពួកកូន ក៏សង្កៀតធ្មេញ"[ភ] ៣០ គឺគ្រប់គ្នា
នឹងត្រូវស្លាប់ ដោយព្រោះអំពើទុច្ចរិត របស់គេរៀងខ្លួន
វិញ[ម] ឯអស់អ្នកណាដែលស៊ីផ្លែមានរសជូរ គឺអ្នកនោះឯង
ដែលនឹងសង្កៀតធ្មេញទេ ។
៣១ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នឹងមានគ្រាមកដល់
ដែលអញនឹងតាំងសញ្ញាថ្មី[យ] និងពួកវង្សអ៊ីស្រាអែលហើយ
និងពួកវង្សយូដា ៣២ មិនមែនតាមសញ្ញា[រ] ដែលអញបាន
តាំងនឹងពួកព្ធយុកោគេ[ល] នៅថ្ងៃដែលអញបានចាប់ដៃដឹកគេ
ចេញពីស្រុកអេស៊ីព្ទមក[វ] នោះទេ ជាសេចក្ដីសញ្ញា ដែល
ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា គេផ្ដាច់ចេញហើយទោះ
បើអញជាប្ដី[ស]ដល់គេក៏ដោយ ៣៣ គឺព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា សេចក្ដីសញ្ញាដែលអញនឹងតាំងចំពោះពួកវង្ស
អ៊ីស្រាអែល ក្នុងពេលក្រោយគ្រានោះ គឺយ៉ាងដូច្នេះ អញ
នឹងដាក់ក្រិត្យវិន័យរបស់អញ នៅក្នុងខ្លួនគេ[ហ] ទាំងចារឹកទុក
ក្នុងចិត្តគេ[ឡ] នោះអញនឹងធ្វើជាព្រះដល់គេ ហើយគេនឹង
បានជារាស្ត្ររបស់អញ[អ] ៣៤ រួចគេនឹងលែងបង្រៀន[ក]អ្នក
ជិតខាង ហើយនឹងបងប្អូនគេរៀងខ្លួនទៀតថា ចូរឱ្យស្គាល់[ខ]

**៣១:២៧** ច យរ ១៦:១៤ ទ ហស ២:២៣ **៣១:២៨** ធ យប ២៩:២ ន ចទ ២៩:២៨ ប យរ ១៨:៨ ផ ចទ ២៨:៦៣ ៣០:៩ យរ ១:១០ អគ ៣៦:១០–១១ អម ៩:១៤ **៣១:២៩** ព លប ៩:២៥ ចទ ២៤:១៦ បទ ៥:៧ ភ អគ ១៨:២ **៣១:៣០** ម ២ពវ ១៤:៦ អស ៣:១១ កទ ៦:៧ **៣១:៣១** យ ចទ ២៩:១៤ អស ៤២:៦ ៥៤:១០ លក ២២:២០ ហព ៨:៨–១២ ១០:១៦–១៧ **៣១:៣២** រ នក ២៤:៨ ល ចទ ៥:៣ វ យរ ១១:៤ ស អស ៥៤:៥ **៣១:៣៣** ហ នក ៤:១៥ ឡ ចទ ៦:៦ ២កថ ៣:៣ អ យរ ១១:៤ ហព ១០:១៦ **៣១:៣៤** ក ១យហ ២:២៧ ខ អស ១១:៩ យហ ៦:៤៥ គ ទដ ៨៥:២ ១៣០:៤ យរ ៣៣:៨ ៥០:២០

ហោព្រៃដូចគ្នានឹងពាក្យទាំង២ដែលបានគូសបញ្ជាក់នេះ ។ *ពួកវង្សអ៊ីស្រាអែល . . . ហើយនិងពួកវង្សយូដា* ពួកវង្សនៅខាងជើង និងខាងត្បូងបានរួមបញ្ចូលគ្នា តែ១ម្ដងទៀត (មើល ៣:១៨ និងការពន្យល់) ។

**៣១:២៨** *អញបានមើលគេ . . . នោះអញនឹងមើលគេ* មើលការពន្យល់ ១:១២ ។ *ដករំលើងកាច់បំបាក់ រំលំ បំផ្លាញ . . . នឹងសង់គេឡើង . . . ហើយដាំ* មើល ការពន្យល់ ១:១០ ។

**៣១:២៩** *ពួកឪពុក . . . សង្កៀរ* បានរំឭកឡើងវិញនៅក្នុង អគ ១៨:២ នេះជាសុភាសិត១ដែលមានប្រជាប្រិយ ដែលបានធ្វើឱ្យមានការយល់ច្រលំ ដូចជាអត្ថបទនេះ ដូចគ្នានៅក្នុង នក ២០:៥ និងជន ១៤:១៨ ដែលបង្រៀនថា អំពើបាបនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមាន ទៅលើកូនចៅជំនាន់ក្រោយ ។ នៅជំនាន់លោកយេរេមា និងលោកអេសេគាល ពួកបណ្ដាជនមានអារម្មណ៍ថា ព្រះហស្តរបស់ព្រះ ទាស់ប្រឆាំងចំពោះពួកគេ មិនមែនមកពីអំពើបាបរបស់គេទេ តែជាដោយសារអំពើបាបរបស់ពួកដូនតារបស់គេវិញ ។

**៣១:៣១–៣៤** ចំណុចខ្ពស់នៃសេចក្ដីទំនាយរបស់លោកយេរេមា ក្នុងអត្ថបទនេះគឺដូចគ្នាយ៉ាងវែង នៅក្នុងខព្រះគម្ពីរសញ្ញាចាស់ ហើយវាបានដកស្រង់នៅក្នុងសញ្ញាថ្មី (មើលការពន្យល់ ហព ៨:៨–១២ មើលផងដែរ ហព ១០:១៦–១៧) ។ ខ.៣១ មានតែអត្ថបទនៅសញ្ញាចាស់ បានប្រើឃ្លានេះថា "សញ្ញាថ្មី" (ដែលបានប្រើផងដែរនៅសញ្ញាថ្មី" បានមកដល់យើងថា "ព្រះគម្ពីរសញ្ញាថ្មី" ឈ្មោះនេះក្រោយមកបានប្រើ ចំពោះគ្រីស្ទាន ដោយយកព្រះគម្ពីរជាគោល ។

**៣១:៣១** *នឹងមានគ្រាមកដល់* ន័យត្រង់ "ថ្ងៃនោះនឹងមកដល់" (ដូចជានៅក្នុង ខ.២៧,៣៨) ឃ្លានេះតែងតែនិយាយសំដៅទៅលើសម័យព្រះមែស៊ី ។ *អញ នឹងតាំង* ន័យត្រង់ "កាត់" (មើលការពន្យល់ ៣៤:១៨ លប ១៥:១៨) ។ *សញ្ញាថ្មី* មើលការពន្យល់ ខ.៣១–៣៤ ។ ដូចជានៅក្នុងព្រះគម្ពីរសញ្ញាចាស់ និយាយអំពីការច្រួចឈាមសត្វ ជាថ្នូរនឹងអំពើបាប (នក ២៤:៤–៨) ហើយនៅព្រះគម្ពីរសញ្ញាថ្មី និយាយអំពីការច្រួចព្រះលោហិតរបស់ព្រះយេស៊ូវ ដើម្បី ប្រោសលោះអំពើបាប (មើល មថ ២៦:២៨ និងការពន្យល់ មក ១៤:២៤ លក ២២:២០ និងការពន្យល់ ១កថ ១១:២៥ ២កថ ៣:៦ ហព ៩:១៥ ១២:២៤) ។ *ពួកវង្សអ៊ីស្រាអែល ហើយនិងពួកវង្សយូដា* នេះជាការប្រមូលផ្ដុំរាស្ត្រ របស់ព្រះ (មើល ៣:១៨ និងការពន្យល់) ។

**៣១:៣២** *សញ្ញាដែលអញបានតាំងនឹងពួកព្ធយុកោគេ* មើល ៧:២៣ ១១:១–៨ នក ១៩:៥ ២០:២២–២៣:១៩ និងការពន្យល់ ការតាំងសញ្ញានៅលើភ្នំស៊ីណៃ ជាការពិតដែលគេបានស្គាល់ថា "ការតាំងសញ្ញានៅសញ្ញាចាស់" (២កថ ៣:១៤) ឬ "ការតាំងសញ្ញាជាលើកដំបូង" (ហព ៨:៧ ៩:១៥,១៨) ។ *អញបានចាប់ដៃដឹកគេ* មើល ហស ១១:៣–៤ ។ ជាសេចក្ដីសញ្ញាដែលព្រះយេហូវ៉ាទ្រង់មានបន្ទូលថា គេផ្ដាច់ចេញហើយ មើល ១១:១០ ។ មនុស្សជាអ្នករំលោភបំពាន ទៅលើសេចក្ដីសញ្ញានោះ មិនមែនព្រះឡើយជាអ្នកធ្វើខុស (មើលការពន្យល់ អស ២៤:៥) ។ *អញជាប្ដីដល់គេ* មើល ៣:១៤ និងការពន្យល់ ។

**៣១:៣៣** *ពួកវង្សអ៊ីស្រាអែល* នេះគឺរួមទាំងអ៊ីស្រាអែល និងយូដា (មើល ខ.៣១ និងការពន្យល់ ៣:១៨) ។ *អញនឹងដាក់ក្រិត្យវិន័យរបស់អញ* នៅខាងក្នុងគេ ក្នុងចិត្តគេ (មើល ចទ ៦:៦ ១១:១៨ ៣០:១៤ អគ ១១:១៩ ១៨:៣១ ៣៦:២៦–២៧) ដោយផ្ទុយពីឃ្លានោះគឺដាក់ក្រិត្យវិន័យរបស់ទ្រង់ខាងក្រៅនៅមុខគេ (មើល ៩:១៣ ចទ ៤:៨ ១១:៣២) ។ *ទាំងចរិកទុកក្នុងចិត្តគេ* ដើម្បីឱ្យវាមានប្រសិទ្ធិភាពក្នុងការដឹកនាំជីវិតគេ ដោយផ្ទុយពីឃ្លានោះ គឺមិនមានប្រសិទ្ធិភាព គឺការចរិកវានៅលើថ្ម (មើល នក ២៤:៤ ៣១:១៨ ៣២:១៥–១៦ ៣៤:២៨–២៩ ចទ ៤:១៣ ៥:២២ ៩:៩,១១ ១០:៤)។ *នោះអញនឹងធ្វើជាព្រះដល់គេ ហើយគេនឹងធ្វើជារាស្ត្ររបស់អញ* មើលការពន្យល់ ៧:២៣ ។ សញ្ញា "ថ្មី" មិនបានលុបសញ្ញា "ចាស់" ចោលទេ ប៉ុន្តែវាបានបំពេញ និងសម្រេចនូវគោលបំណងនោះ (ធៀបនឹង មថ ៥:១៧ និងការពន្យល់) ។

**៣១:៣៤** *រួចគេនឹងលែងបង្រៀនដល់អ្នកជិតខាងរបស់គេ* នៅពេលដែលព្រះអម្ចាស់បានធ្វើការងារថ្មីរបស់ទ្រង់ នោះនឹងមិនមាននៅក្នុងចំណោមរាស្ត្រទ្រង់ ដែលព្រងើយកន្តើយ ឬការមិនធ្វើតាមបំណងព្រះហឫទ័យរបស់

អញគ្រប់ៗគ្នា តាំងពីអ្នកតូចបំផុត រហូតដល់អ្នកធំបំផុតក្នុង
ពួកគេ ព្រោះអញនឹងអត់ទោស[គ]ចំពោះអំពើទុច្ចរិតរបស់
គេ ហើយនឹងលែងចាំពីអំពើបាប[ឃ]គេទៀតជាដរាបទៅ ។
៣៥ឯព្រះ ដែលប្រទាន[ង]ព្រះអាទិត្យ សំរាប់ជាពន្លឺនៅ
ពេលថ្ងៃ ហើយតាំងរបៀបនៃព្រះចន្ទនឹងតារា ទាំងប៉ុន្មាន
សំរាប់បំភ្លឺនៅពេលយប់[ច] ជាព្រះដែលបណ្តាលឱ្យសមុទ្រ[ឆ]
កំរើកឡើង ដល់ម៉្លេះបានជាឮសន្ធឹករលក[ជ] ដែលព្រះនាម
ទ្រង់ជាព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូល
ដូច្នេះថា[ឈ] ៣៦បើបញ្ញត្តច្បាប់[ញ]ទាំងនោះឃ្លាតចេញពីមុខ
អញទៅកាលណានោះ នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
ពួក[ដ]អ៊ីស្រាអែលក៏នឹងលែងធ្វើជានគរ នៅមុខអញជា
ដរាបទៅកាលនោះដែរ ៣៧ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះថា បើអាចនឹងវាស់[ឋ]ផ្ទៃមេឃខាងលើ ហើយស្ទង់
ឫសផែនដីនៅខាងក្រោមបាន នោះអញនឹងបោះបង់
ចោល[ឌ]ពូជអ៊ីស្រាអែល ដោយព្រោះអស់ទាំងការដែលគេ
បានប្រព្រឹត្តដែរ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
៣៨ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល នឹងមានគ្រា
មកដល់ ដែលទីក្រុងនេះនឹងបានសង់ឡើង[ឍ] ថ្វាយព្រះ
យេហូវ៉ា ចាប់តាំងពីប៉មហាណានាល[ណ] រហូតទៅដល់ទ្វារ
ជ្រុងកំផែង[ត] ៣៩ហើយខ្សែរង្វាស់[ថ] នឹងវាស់ត្រង់ចេញទៅ
ដល់ភ្នំការេប រួចនឹងបត់មកដល់កូអាត ៤០ឯច្រកភ្នំទាំង
មូល[ទ]នៃសាកសព[ធ] ហើយនិងផេះ ព្រមទាំងចំការទាំង
ប៉ុន្មាន រហូតដល់ជ្រោះកេដ្រុន[ន] និងដល់ជ្រុងកំផែងទ្វារ
សេះ[ប] ដែលបើកទៅទិសខាងកើត នោះនឹងបានជាទី
បរិសុទ្ធ[ផ]ដល់ព្រះយេហូវ៉ាទាំងអស់ និងមិនត្រូវដករំលើង ឬ
រំលំបំផ្លាញទៀតឡើយ នៅជាដរាបតទៅ ។

## លោកយេរេមាទិញចំការមួយកន្លែង

៣២ ១នេះជាព្រះបន្ទូល ដែលមកពីព្រះយេហូវ៉ា ដល់
យេរេមាក្នុងឆ្នាំទី១០[ក] នៃរាជ្យសេដេគាស្តេចយូដា ដែល
ត្រូវនឹងឆ្នាំទី១៨[ខ]នៃរាជ្យនេប៊ូក្នេសា ២រីឯគ្រានោះពួកទ័ព
របស់ស្តេចបាប៊ីឡូន កំពុងឡោមព័ទ្ធ[គ] ច្បាំងនឹងក្រុងយេរូ–
សាឡិម ហើយហោរាយេរេមាត្រូវឃុំទុក[ឃ]នៅក្នុងទីលាន
គុក[ង] ដែលនៅក្នុងវាំងនៃស្តេចយូដា ៣ពីព្រោះសេដេគាជា

**៣១:៣៤** ឃ យប ៧:២១ អស ៣៨:១៧ មីក ៧:១៩ ហព ១០:១៧ **៣១:៣៥** ង ទដ ១៣៦:៧–៩ ច លប ១:១៦ ឆ នក ១៤:២១ ជ ទដ ៩៣:៣ ឈ យរ ១០:១៦ **៣១:៣៦** ញ យប ៣៨:៣៣ យរ ៣៣:២០–២៦ ដ ទដ ៨៩:៣៦–៣៧ **៣១:៣៧** ឋ យប ៣៨:៥ យរ ៣៣:២២ ឌ យរ ៣៣:២៤–២៦ រម ១១:១–៥ **៣១:៣៨** ឍ យរ ៣០:១៨ ណ នហ ៣:១ ត ២ពរ ១៤:១៣ ២របា ២៥:២៣ **៣១:៣៩** ថ ១ពរ ៧:២៣ **៣១:៤០** ទ យរ ២:២៣ ៧:៣១–២៣ ធ យរ ៨:២ ន ២សយ ១៥:២៣ យហ ១៨:១ ប ២ពរ ១១:១៦ ផ អស ៤:៣ យអ ៣:១៧ សក ១៤:២១ **៣២:១** ក ២ពរ ២៥:១ ខ យរ ២៥:១ **៣២:២** គ ២ពរ ២៥:១ ឃ ទដ ៨៨:៨ ង នហ ៣:២៥

ព្រះ ។ ចំណេះដឹងយ៉ាងពិតប្រាកដរបស់ព្រះអម្ចាស់ នឹងចែកចាយទៅដល់មនុស្សទាំងអស់ ទាំងក្មេង និងចាស់ ដោយរីករាយ និងដោយព្រះចេស្តាបំផុត(មើល ៥:៤–៥ និងការពន្យល់ មើលផងដែរ ៣២:៣៨–៤០ អស ៥៤:១៣ និងការពន្យល់ អគ ១១:១៩–២០ ៣៦:២៥–២៧ អភ ៣:១២ ហព ៤:១៦ ១០:១៩–២២) ។ *ស្គាល់* ដោយទទួលបាននូវបទពិសោធន៍មិនគ្រាន់តែដោយចំណេះប៉ុណ្ណោះទេ តែដោយវិញ្ញាណយល់ដឹងយ៉ាងពិតប្រាកដវិញ (មើល នក ៦:៣ និងការពន្យល់) ។ *ហើយនឹងលែងនឹកចាំអំពើបាបគេទៀតជាដរាបទៅ* សិរីល្អជាមូលដ្ឋាន នៃសញ្ញាថ្មី (មើល ហព ១០:១៤–១៧) ។

**៣១:៣៥** *ដែលប្រទានព្រះអាទិត្យ . . . ព្រះចន្ទ និងតារា* មើល លប ១:១៦–១៨ និងការពន្យល់ ។ *ដែលព្រះនាមទ្រង់ជាព្រះយេហូវ៉ានៃពួកពលបរិវារ* ឃ្លានេះដូចគ្នាបានរកឃើញនៅក្នុង អស ៥១:១៥ (មើល ទដ ៤៦៣ អស ១៧:១២) ។

**៣១:៣៦** មើល ៣៣:២០–២១,២៥–២៦ ដំណើរការ ការបង្កើតរបស់ព្រះ គឺដើម្បីជួយសង្គ្រោះ ហើយអ៊ីស្រាអែលជាកូនចៅរបស់ទ្រង់ ។

**៣១:៣៧** *បោះបង់* អ៊ីស្រាអែលនឹងនៅតែជាពួកសំណល់ (ធៀបនឹង រម ១១:៥ និងការពន្យល់) នៅពេលដែលការជំនុំជម្រះគួរឱ្យស្ញែងខ្លាច គឺដើម្បីបោសសម្អាតនគរយូដាចេញ ។

**៣១:៣៨–៤០** មើល សក ១៤:១០–១១ ។

**៣១:៣៨** *ទីក្រុងនេះ* គឺទីក្រុងយេរូសាឡិម ។ *ពីប៉មហាណានាល រហូតដល់ទ្វារជ្រុងកំផែង* ចុងបញ្ចប់ភាគខាងកើត ឆៀងខាងត្បូងនៃជញ្ជាំងខាងជើង (មើលការពន្យល់ សក ១៤:១០) ។

**៣១:៣៩** *ខ្សែរង្វាស់* បញ្ជាក់អំពីការទំនាក់ទំនងគ្នា អំពីការសាងសង់ក្រុងយេរូសាឡិមឡើងវិញ នៅក្នុង អគ ៤០:៣ សក ១:១៦ ២:១ ។ *ភ្នំការេប . . . កូអាត* ប្រហែលជានៅភាគខាងលិច នៃក្រុងយេរូសាឡិម ។

**៣១:៤០** *ច្រកភ្នំ* ប្រហែលជាច្រកភ្នំហើមូន (មើល ២៣: និងការពន្យល់) កំផែងទ្វារសេះ មើលការពន្យល់ នហ ៣:២៨ ។ *ទីបរិសុទ្ធដល់ព្រះយេហូវ៉ា* មើល សក ១៤:២០ និងការពន្យល់ ។ *នឹងមិនត្រូវដករំលើង ឬរំលំបំផ្លាញ* មើលការពន្យល់ ១:១០ ក្រុងយេរូសាឡិម ជាទីក្រុងរបស់ព្រះដ៏នៅស្ថិតស្ថេរដែលបានសម្រេចចុងក្រោយ ធៀបនឹង លប ៤:២៦ និងការពន្យល់ វវ ២១:១–៥ ។

**៣២:១–៤៤** ទោះបីជាមានការស្នាក់ស្នើរក្តី (លោកយេរេមាស្តាប់បង្គាប់ចំពោះព្រះរាជបញ្ជារបស់ព្រះអម្ចាស់ ដើម្បីទិញវាលចំការ នៅក្រុងអាន៉ាថោត ពីបងប្អូនជីដូនមួយរបស់គាត់ (មើល៦.៨–៩) បើទោះបីពួកបាប៊ីឡូន បានឡោមព័ទ្ធក្រុងយេរូសាឡិមក្តី (មើល ៦.២,២៤) ។

**៣២:១** *ក្នុងឆ្នាំទី១១ នៃរាជ្យសេដេគា . . . ឆ្នាំទី១៨នៃរាជ្យនេប៊ូក្នេសា* ក្នុងឆ្នាំ ៥៨៧ គ.ស មួយឆ្នាំមុនពេលដែលទីក្រុងយេរូសាឡិម ត្រូវបានបំផ្លាញដោយ ពួកបាប៊ីឡូន (មើល ៥២:១២–១៣) ។ ការឡោមព័ទ្ធទីក្រុងនោះបានចាប់ ផ្តើមនៅក្នុងឆ្នាំ ៥៨៨ (មើល ៣៩:១ ៥២:៤) ។

**៣២:២** *ត្រូវឃុំទុកនៅក្នុងទីលានគុក* មើល នហ ៣:២៥ និងការពន្យល់ ។ លោកយេរេមា គឺបានចាប់ដាក់ក្នុងគុក ដោយស្តេចសេដេគា (មើល ៣៧:២១) និងនៅតែនៅក្នុងគុក រហូតដល់ទីក្រុងយេរូសាឡិមបានដួលរលំ (មើល ៣៨:១៣,២៨ ៣៩:១៤) ។

**៣២:៣–៥** មើល ២១:៣–៧ ៣៤:២–៥ ៣៧:១៧ ការនោះបានសម្រេច

ស្ដេចយូដា បានឃុំលោក ដោយពាក្យថា ហេតុអ្វីបានជាឯង
ទាយ[ច]ថា ព្រះយេហូវ៉ាមានបន្ទូលដូច្នេះ មើលអញនឹង
ប្រគល់ក្រុងនេះ ទៅក្នុងកណ្ដាប់ដៃនៃស្ដេចបាប៊ីឡូន ហើយ
គេនឹងចាប់យក[ឆ]បាន ⁴ហើយសេដេគា[ជ] ជាស្ដេចយូដានឹង
មិនរួច[ឈ]ពីកណ្ដាប់ដៃនៃពួកខាល់ដេ[ញ]ឡើយ គឺនឹងត្រូវ
ប្រគល់ទៅ ក្នុងកណ្ដាប់ដៃនៃស្ដេចស្រុកបាប៊ីឡូនជាពិត
ហើយនិងនិយាយនឹងគេផ្ទាល់មាត់គ្នា ឯភ្នែកទ្រង់ក៏នឹង
ឃើញភ្នែកគេដែរ ⁵គេនឹងនាំយក[ដ]សេដេគា ទៅឯក្រុង
បាប៊ីឡូនហើយទ្រង់នឹងត្រូវនៅទីនោះទាល់តែអញប្រោស[ឋ]
នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ទោះបីឯងរាល់គ្នាតស៊ូនឹង
ពួកខាល់ដេក៏ដោយ គង់តែនឹងឈ្នះមិនបានដែរ[ឌ]។
⁶យេរេមានិយាយថា ព្រះបន្ទូលនៃព្រះយេហូវ៉ាបាន
មកដល់ខ្ញុំ ប្រាប់ដូច្នេះ ⁷មើល ហាណាមាល ជាកូនសាលូម
ឪពុកធំឯង នឹងមកនិយាយនឹងឯងថា សូមទទួលបញ្ជាំចំការ
របស់ខ្ញុំ ដែលនៅឯអាន៉ាថោត[ឍ]ទៅ ដ្បិតអំណាច[ណ]ដែល
នឹងលោះបងប្អូន នោះស្រេចនឹងអ្នកទេ ⁸ដូច្នេះហាណា
មាលជាកូនរបស់ឪពុកធំខ្ញុំ ក៏មកឯខ្ញុំនៅក្នុងទីលានគុក តាម
ព្រះបន្ទូលនៃព្រះយេហូវ៉ា ហើយគាត់និយាយនឹងខ្ញុំថា សូម
ទទួលបញ្ជាំចំការ[ត]របស់ខ្ញុំ ដែលនៅឯអាន៉ាថោត ក្នុងស្រុក
បេនយ៉ាមីនទៅ ដ្បិតអ្នកមានច្បាប់នឹងគ្រងបានជាមរដក
ហើយអំណាចលោះក៏ស្រេចនៅលើអ្នកដែរ ដូច្នេះ សូម
ទទួលបញ្ជាំទុកសំរាប់ខ្លួនអ្នកចុះ យ៉ាងនោះទើបខ្ញុំបានដឹង
ថា ជាព្រះបន្ទូលនៃព្រះយេហូវ៉ាពិត ⁹ខ្ញុំក៏ទទួលបញ្ជាំ
ចំការ[ថ] ដែលនៅឯអាន៉ាថោត ពីហាណាមាល ជាកូន
របស់ឪពុកធំខ្ញុំ ហើយបានថ្លឹងប្រាក់១៧រៀលឱ្យដល់គាត់[ទ]
¹⁰ក៏ធ្វើសំបុត្រ ហើយបិទត្រា[ធ]រួច ហៅស្មរបន្ទាល់មក[ន]
ហើយថ្លឹងប្រាក់ក្នុងជញ្ជីងប្រគល់ដល់គាត់ ¹¹ដូច្នេះ ខ្ញុំបាន
យកសំបុត្របញ្ជាំ ទាំងសំបុត្រដែលបិទត្រាតាមច្បាប់ តាម
ទំនៀម និងសំបុត្រ១ដែលនៅបើកដែរ ¹²រួចប្រគល់
សំបុត្របញ្ជាំដល់បារូក[ប] ជាកូននេរីយ៉ា[ផ]ដែលជាកូន
ម៉ាសេយ៉ា នៅចំពោះមុខហាណាមាល ជាកូនរបស់ឪពុកធំ
ខ្ញុំ និងនៅចំពោះស្មរបន្ទាល់ ដែលបានចុះឈ្មោះក្នុងសំបុត្រ
បញ្ជាំនោះ នៅមុខពួកយូដាទាំងប៉ុន្មាន ដែលអង្គុយនៅ
ទីលាននៃគុក ¹³ខ្ញុំក៏ផ្ដាំបារូកនៅមុខគេថា ¹⁴ព្រះយេហូវ៉ា
នៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មាន
បន្ទូលដូច្នេះ ចូរយកសំបុត្របញ្ជាំនេះ គឺជាសំបុត្របញ្ជាំ
ដែលបិទត្រា[ព] និងសំបុត្រដែលនៅចំហ ទៅដាក់ក្នុងភាជនៈ
ដី ដើម្បីឱ្យបានទុកជាយូថ្ងៃតទៅ ¹⁵ដ្បិតព្រះយេហូវ៉ានៃ

**៣២:៣** ច យរ ២៦:៨–៩ ឆ ខ.២៨ យរ ២១:៤ ៣៤:២–៣ **៣២:៤** ជ យរ ៣៤:២១ ៤៤:៣០ ឈ យរ ២១:៧ ៣៨:១៨,២៣ ៣៩:៥–៧ ៥២:៩ ញ ខ.២៤ **៣២:៥** ដ យរ ៣៩:៧ អគ ១២:១៣ ឋ ២ពវ ២៥:៧ ឌ យរ ២១:៤ បទ ១:១៤ **៣២:៧** ឍ យស ២១:១៨ ណ លវ ២៥:២៤–២៥ នរ ៤:៣–៤ មថ ២៧:១០ **៣២:៨** ត ខ.២៥ **៣២:៩** ថ យរ ៣៧:១២ ទ លប ២៣:១៦ **៣២:១០** ធ លប ២៣:២០ ន រម ៤:៩ អស ៨:២ **៣២:១២** ប ខ.១៦ យរ ៣៦:៤ ៤៣:៣,៦ ៤៥:១ ផ យរ ៥១:៥៩ **៣២:១៤** ព អស ៨:១៦

ដោយបានកត់ទុកនៅក្នុង ៥២:៧–១៤ ។

**៣២:៥** *ទាល់តែអញប្រោស* ក្រោយពីពួកគេត្រូវបានចាប់ទៅជាឈ្លើយដោយពួកបាប៊ីឡូន ស្ដេចសេដេគាត្រូវបានដឹកនាំទៅក្រុងបាប៊ីឡូន ហើយទ្រង់បានសុគតនៅទីនោះ (មើល ៥២:១១) ។ *គង់តែនឹងឈ្នះមិនបានដែរ* មើលការពន្យល់ ២៩:៤ ។

**៣២:៧** *នៅឯអាន៉ាថោត* ជាស្រុកកំណើតរបស់លោកយេរេមា (មើលការពន្យល់ ១:១) ។ *ដ្បិតអំណាចដែលនឹងលោះបងប្អូន នោះស្រេចនឹងអ្នកទេ* យោងទៅតាមក្រិត្យវិន័យ នៃការប្រោសលោះ នៅសម័យជំនាន់បុរាណ (មើល លវ ២៥:២៣–២៥ និងការពន្យល់ ២៥:២៤–២៥ មើលការពន្យល់ផងដែរ នរ ២:២០ ៤:៣) ។

**៣២:៨** *ក៏មកឯខ្ញុំនៅក្នុងទីលានគុក* ទោះបីជាលោកយេរេមាត្រូវបានជាប់គុកក្ដី ក៏លោកត្រូវបានអនុញ្ញាតឱ្យមានអ្នកមកសួរសុខទុក្ខគាត់ដែរ ។ *ក្នុងស្រុកបេនយ៉ាមីន* ជួនកាលនៅសម័យជំនាន់បុរាណ លោកយេរេមាបានធ្វើដំណើរទៅផ្ទះគាត់ "ដើម្បីទៅទទួលចំណែកទ្រព្យសម្បត្តិរបស់គាត់" នៅបេនយ៉ាមីន (៣៧:១២) ប៉ុន្តែគាត់បែរជាត្រូវគេចាប់ ដោយចោទប្រកាន់ការខុស ថាក្បត់ជាតិ និងនាំយកទៅដាក់គុក (មើល ៣៧:១៣–១៦) ។

**៣២:៩** *ខ្ញុំក៏ទទួលបញ្ជាំ* ដើម្បីស្ដាប់បង្គាប់ ចំពោះព្រះរាជបញ្ជារបស់ព្រះអម្ចាស់ (មើលខ.៧) ។ ហើយបានថ្លឹង នៅពេលនោះគេមិនទាន់បានបោះពុម្ពលុយនៅឡើយ ។ *ហើយបានថ្លឹងប្រាក់១៧រៀល* មើលការពន្យល់ ។ ទំហំនៃចំការនោះមិនដឹងឡើយ ប៉ុន្តែតម្លៃចំការនោះមិនថ្លៃហួសពេកឡើយ (ខុសគ្នានៅក្នុង លប ២៣:១៥ មើលការពន្យល់) ។

**៣២:១០** *បិទត្រា* មិនមែនជាហត្ថលេខាទេ (ដូចជាឧ. នៅក្នុង នអ ៣:១២ មើលការពន្យល់ លប ៣៨:១៨) ប៉ុន្តែដើម្បីបញ្ជាក់សំបុត្រនោះ និងដើម្បីរក្សាពីការចង់ធ្វើអ្វី១នោះ (មើល អស ៨:១៦ ២៩:១១ ដយ ១២:៤,៩ វវ ១៥:១–៥) ។

**៣២:១១** *សំបុត្រ១ដែលនៅបើក* ជាច្បាប់យោង ដែលត្រឹមត្រូវ ដោយមានការធានា ដែលសំបុត្រនោះបានបាត់ និងខូច ឬមានការផ្លាស់ប្ដូរ (ពិគ្រោះគ្នាជាមុនសិន) ។ ឧទាហរណ៍ដូចជាឯកសារ និងសំបុត្រនៅសម័យជំនាន់សតវត្សទី១៥ មុន គ.ស ។ ដោយបានរកឃើញវានៅអែលបាណន ក្នុងស្រុកអេស៊ីព្ទភាគខាងត្បូង នៅក្នុងទីរហោស្ថានយូដា ខាងត្បូងនៃសមុទ្រស្លាប់ និងនៅទីកន្លែងផ្សេងទៀត ។

**៣២:១២** *បារូក* មានន័យថា "ព្រះពរ" (ដោយសារព្រះអម្ចាស់) ។ គាត់គឺជាមិត្តភ័ក្រ និងជាលេខាដ៏ស្មោះត្រង់បស់លោកយេរេមា (មើលសេចក្ដីផ្ដើម អ្នកនិពន្ធ និងកាលបរិច្ឆេទ) ។

**៣២:១៤** *ទៅដាក់ក្នុងភាជានៈដី ដើម្បីឱ្យបានទុកជាយូរថ្ងៃតទៅ* ឯកសារនោះបានរកឃើញនៅក្នុងភាជនៈ នៅអែលបាណន (មើលការពន្យល់ ខ.១១) និងឃ្យូមរាន (Qumran) (នៅខាងលិចសមុទ្រស្លាប់) ត្រូវបានគេទុកជាទីកន្លែងបរិសុទ្ធបំផុត ច្រើនជាង២០០០ឆ្នាំ ។

**៣២:១៥** សំបុត្របញ្ជាំរបស់លោកយេរេមា អាចជួយឱ្យគាត់ប្រកាសពីដីចំការថា អាចបន្តធ្វើសកម្មភាពផ្នែកសេដ្ឋកិច្ចជាធម្មតា ក្រោយពីការធ្វើ

ពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មាន
បន្ទូលដូច្នេះថា នឹងមានគេបញ្ជាំទាំងផ្ទះ និងចំការ ហើយ
និងដំណាំទំពាំងបាយជូរនៅក្នុងស្រុកនេះទៀត[ភ] ។
១៦ ក្រោយដែលខ្ញុំបានប្រគល់សំបុត្របញ្ជាំដល់បារូក[ម] ជា
កូននេរីយ៉ាហើយ នោះខ្ញុំក៏អធិស្ឋានដល់ព្រះយេហូវ៉ាថា
១៧ ឱព្រះអម្ចាស់យេហូវ៉ាអើយ[យ] មើល ទ្រង់បានបង្កើតផ្ទៃ
មេឃនឹងផែនដី[រ] ដោយសារព្រះចេស្តាដ៏ធំរបស់ទ្រង់ នឹង
ព្រះពាហុដ៏លើកសំរេច[ល] គ្មានអ្វីដែលពិបាក[វ]ដល់ទ្រង់ទេ
១៨ គឺទ្រង់សំដែងសេចក្តីសប្បុរស[ស] ដល់មនុស្សទាំងពាន់ៗ
ហើយក៏សងអំពើទុច្ចរិតរបស់ពួកឪពុកៗ ទៅលើទ្រូង[ហ]នៃ
ពួកកូនចៅគេ[ឡ] នៅតាមក្រោយ ទ្រង់ជាព្រះដ៏ធំហើយមាន
ឫទ្ធិ[អ] ព្រះនាមទ្រង់ គឺព្រះយេហូវ៉ានៃពួកពលបរិវារ[ក]
១៩ ទ្រង់ប្រសប់ក្នុងការជួយគំនិត ហើយក៏មានឫទ្ធិក្នុងការ
ធ្វើ[ខ] ព្រះនេត្រទ្រង់ទតឃើញអស់ទាំងផ្លូវរបស់ពួកមនុស្ស
ជាតិ ដើម្បីនឹងសងគ្រប់គ្នាតាមផ្លូវគេប្រព្រឹត្ត[គ] ហើយតាម
ផលនៃកិរិយារបស់គេរៀងខ្លួន[ឃ]
២០ ទ្រង់ក៏បានធ្វើទីសំគាល់
និងការអស្ចារ្យ[ង]នៅស្រុកអេស៊ីព្ទ[ច] ដរាបដល់សព្វថ្ងៃនេះ
ព្រមទាំងនៅពួកអ៊ីស្រាអែល ហើយកណ្តាលពួកមនុស្សដទៃ
ផង ទ្រង់ក៏បានតាំងកិត្តិនាម[ឆ]របស់ទ្រង់ឡើងដូចជា មាន
សព្វថ្ងៃនេះ
២១ ហើយបាននាំអ៊ីស្រាអែល ជារាស្ត្រទ្រង់
ចេញពីស្រុកអេស៊ីព្ទមក ដោយទីសំគាល់ និងការអស្ចារ្យ
ដោយព្រះហស្ត[ជ]ខ្លាំងពូកែ និងព្រះពាហុ[ឈ]លើកសំរេច
ព្រមទាំងការស្ញែងខ្លាចយ៉ាងធំផង[ញ]
២២ ក៏បានប្រទានស្រុក
នេះឱ្យដល់គេ ជាស្រុកដែលទ្រង់បានស្បថនឹងពួកឪពុកគេ
ថានឹងឱ្យដល់គេ គឺជាស្រុកមានទឹកដោះ និងទឹកឃ្មុំហូរ
ហៀរ[ដ]
២៣ គេក៏ចូលមកចាប់យកស្រុក[ឋ] ប៉ុន្តែមិនបានស្តាប់
តាមព្រះបន្ទូលនៃទ្រង់ ឬដើរតាមក្រិត្យវិន័យរបស់ទ្រង់
ឡើយ[ឌ] ក៏មិនបានធ្វើអ្វី១ដែលទ្រង់បានបង្គាប់ដល់គេដែរ
ហេតុនោះបានជាទ្រង់បណ្តាល ឱ្យការអាក្រក់[ឍ]ទាំងនោះ
មកលើគេ
២៤ មើល ប្រដាប់ចំបាំង[ណ]របស់ពួកខាល់ដេបាន
មកដល់ ដើម្បីនឹងចាប់យកទីក្រុង ក្រុងនេះបានត្រូវប្រគល់
ទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេ ដែលមកតយុទ្ធហើយ គឺ
ត្រូវប្រគល់ទៅដោយចាញ់ដាវ អំណត់អត់និងអាសន្នរោគ[ត]
ឯអស់ទាំងការដែលទ្រង់បានមានបន្ទូល[ថ] នោះបានកើត
មកហើយ[ទ]ទ្រង់ក៏ទតឃើញដែរ
២៥ ហើយ ឱព្រះអម្ចាស់
យេហូវ៉ាអើយ ទ្រង់បានមានបន្ទូលមកទូលបង្គំថា ចូរឯង
ទទួលបញ្ជាំចំការ[ធ]ដោយប្រាក់ហើយ ហៅស្មរបន្ទាល់មក
តែទីក្រុងនេះបានត្រូវប្រគល់ ទៅក្នុងកណ្តាប់ដៃនៃពួក
ខាល់ដេហើយ[ន] ។
២៦ លំដាប់នោះព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់
យេរេមាថា
២៧ មើល អញនេះជាព្រះយេហូវ៉ា ជាព្រះនៃ

**៣២:១៥** ភ ខ.៤៣–៤៤ អស ៤៤:២៦ យរ ៣០:១៨ អគ ២៨:២៦ អម ៩:១៤–១៥ **៣២:១៦** ម ខ.១២ **៣២:១៧** យ យរ ១:៦ រ លប ១:១ យរ ១០:១៦ ល ចទ ៩:២៩ ២ពវ ១៩:១៥ ទដ ១០២:២៥ វ ២ពវ ៣:១៨ យរ ៥១:១៥ មថ ១៩:២៦ **៣២:១៨** ស ចទ ៥:១០ ហ ទដ ៧៩:១២ ឡ នក ២០:៥ ទដ ១០៩:១៤ អ យរ ១០:៦ ក យរ ១០:១៦ **៣២:១៩** ខ យប ១២:១៣ ដយ ២:២០ គ យប ១៤:១៦ សភ ៥:២១ យរ ១៦:១៧ ឃ យប ៣៤:១១ មថ ១៦:២៧ **៣២:២០** ង នក ៣:២០ យប ៩:១០ ច នក ៩:១៦ ឆ អស ៥៥:១៣ យរ ១៣:១១ **៣២:២១** ជ នក ៦:៦ ដយ ៩:១៥ ឈ ចទ ៥:១៥ យរ ៦:១២ ញ ចទ ២៦:៨ **៣២:២២** ដ នក ៣:៨ អគ ២០:៦ **៣២:២៣** ឋ ទដ ៤៤:២ ៧៨:៥៤–៥៥ ឌ នក ១៦:២៨ យស ១:៧ ១ពវ ៩:៦ យរ ១១:៨ ឍ ចទ ២៨:៦៤ ៣១:២៩ ដយ ៩:១៤ **៣២:២៤** ណ ២សយ ២០:១៥ យរ ៦:៦ ត យរ ១៤:១២ ថ ចទ ៤:២៥–២៦ យស ២៣:១៥–១៦ ទ ចទ ២៨:២ **៣២:២៥** ធ ខ.៨ ន អស ៨:២

និទេសខ្លួននោះ ។

**៣២:១៧** មើល ២៧:៥ *ដោយសារព្រះចេស្តាដ៏ធំរបស់ទ្រង់ និងពាហុដ៏លើកសំរេច* មើល ខ.២១ មើលការពន្យល់ផងដែរ ២១:៥ ។ *គ្មានអ្វីដែលពិបាកដល់ទ្រង់ទេ* មើលការពន្យល់ លប ១៨:១៤ ។ ព្រះអម្ចាស់ទ្រង់ឆ្លើយតបដល់លោកយេរេមានូវពាក្យទាំងបីនេះ (មើល ខ.២៧) ។

**៣២:១៨** *គឺទ្រង់សំដែងសេចក្តីសប្បុរស ដល់មនុស្សទាំងពាន់ៗ ហើយ . . . អំពើទុច្ចរិតរបស់ពួកឪពុកៗ* មើល នក ២០:៥–៦ ៣៤:៧ មើលការពន្យល់ផងដែរ នក ២០:៦ ។ *ហើយក៏សង . . . នៅតាមក្រោយ* ជានិម្មិតរូបពីឈ្នួលនៃអំពើបាប (មើល ទដ ៧៩:១២ អស ៦៥:៦–៧ ធៀបនឹង លក ៦:៣៨ និងការពន្យល់) ។ *ទ្រង់ជាព្រះដ៏ធំ ហើយមានឫទ្ធិ* មើល ចទ ១០:១៧ ។ *ព្រះនាមទ្រង់ គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ* មើល ៣១:៣៥ អស ៥៤:៥ អម ៤:១៣ មើលការពន្យល់ផងដែរ ១សយ ១:៣ ។

**៣២:១៩** *ទ្រង់ប្រសប់ក្នុងការជួយគំនិត* សូមមើល ទដ ៦៦:៥ អស ៩:៦ ២៨:២៩ ។ *ដើម្បីនឹងសងគ្រប់គ្នាតាមផ្លូវគេប្រព្រឹត្ត* រំឮកឡើងវិញ ដោយត្រង់តាមពាក្យពី ១៧:១០ (មើលការពន្យល់ និងមើលផងដែរ រម ២:៦ និងការពន្យល់ ១កថ ៣:៨ អភ ៦:៨) ។

**៣២:២០** *ទ្រង់ក៏បានធ្វើទីសំគាល់ និងការអស្ចារ្យ* មើល ខ.២១ នក ៧:៣ មើលការពន្យល់ផងដែរ នក ៣:១២ ៤:៨ ។

**៣២:២១** រំឮកឡើងវិញក្នុង ចទ ២៦:៨ (មើលផងដែរ ចទ ៤:៣៤)។ *ដោយព្រះហស្តខ្លាំងពូកែ និងព្រះពាហុលើកសំរេច* មើល ខ.១៧ និងការពន្យល់ ២១:៥ ។ *ព្រមទាំងការស្ញែងខ្លាចយ៉ាងធំ* មើល នក ១៥:១៤–១៦ ។

**៣២:២២** *គឺជាស្រុកមានទឹកដោះ និងទឹកឃ្មុំហូរហៀរ* មើល ១១:៥ មើលការពន្យល់ នក ៣:៨ ។

**៣២:២៤** *ប្រដាប់ចំបាំង* មើល ៦:៦ ៣៣:៤ មើលការពន្យល់ផងដែរ អស ៣៧:៣៣ ។ *ដាវ អំណត់អត់ និងអាសន្នរោគ* មើលការពន្យល់ ១៤:១២ ។

**៣២:២៥** *លោកយេរេមា បញ្ជាក់ពីការយកចិត្តទុកដាក់របស់គាត់ជាខ្លាំងថា គាត់មិនមែនដូចជាអ្នកជំនួយវ័យឆ្លាតទេ* ទោះជាយ៉ាងណាក៏ដោយ គាត់នៅតែជាអ្នកបម្រើដែលស្តាប់បង្គាប់ដល់ព្រះដែរ (មើលចុង ខ.៨–៩) ។

**៣២:២៧** *អញនេះជាព្រះយេហូវ៉ា ជាព្រះនៃគ្រប់ទាំងសាច់* រំឮកឡើងវិញក្នុង ជន ១៦:២២ ២៧:១៦ សង្កត់បញ្ជាក់ពីអំណាចការគ្រប់គ្រងលើសាកលលោករបស់ព្រះ ។ *តើមានការអ្វីដែលពិបាកពេកដល់អញដែរឬ* នេះជាការឆ្លើយតបចំពោះការរៀបរាប សេចក្តីអធិស្ឋានរបស់លោកយេរេមា (មើល ខ.១៧ និងការពន្យល់ លប ១៨:១៤) បញ្ជាក់ពីអំណាចដ៏ខ្លាំងពូកែរបស់ព្រះទ្រង់ជាព្រះដ៏ថ្លៃវិសេស គួរឱ្យស្តាប់បង្គាប់ ដ្បិតទ្រង់តែងតែស្មោះត្រង់ ក្នុង

គ្រប់ទាំងសាច់[ប] តើមានការអ្វីដែលពិបាកពេកដល់អញ
ដែរឬ[ផ] ២៨ហេតុនេះព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
មើលអញនឹងប្រគល់ទីក្រុងនេះ ទៅក្នុងកណ្ដាប់ដៃនៃ
នេប៊ូក្នេសា[ព]ជាស្ដេចបាប៊ីឡូន ហើយគេនឹងចាប់យកបាន[ភ]
២៩ពួកខាល់ដេដែលតយុទ្ធនឹងទីក្រុងនេះ គេនឹងចូលមកដុត
ចោល[ម] ព្រមទាំងផ្ទះទាំងប៉ុន្មានផង[យ] ជាទីដែលមនុស្សបាន
ដុតកំញានថ្វាយដល់ព្រះបាលហើយច្រួចដង្វាយច្រួច[រ]ដល់
ព្រះដទៃ[ល]នៅលើដំបូល ជាការដែលបណ្ដាលឱ្យអញខឹង
៣០ពីព្រោះពួកកូនចៅអ៊ីស្រាអែល និងពួកកូនចៅយូដា បាន
ប្រព្រឹត្ត សុទ្ធតែការដែលអាក្រក់ នៅភ្នែកអញ តាំងតែ
ពីក្មេងមក[វ] ដ្បិតពួកកូនចៅអ៊ីស្រាអែលបានបណ្ដាល[ស]ឱ្យ
អញខឹង ដោយការដែលដៃគេធ្វើ[ហ] នេះហើយជាព្រះបន្ទូល
នៃព្រះយេហូវ៉ា ៣១ទីក្រុង[ឡ]នេះជាទីអុចអាល ឱ្យអញមាន
សេចក្ដីកំហឹង និងឃោរឃៅ ចាប់តាំងពីគ្រា ដែលគេសង់
ឡើង ដរាបដល់សព្វថ្ងៃនេះ បានជាគួរឱ្យអញបំបាត់ចេញ[អ]
ពីមុខអញទៅ ៣២ដោយព្រោះអស់ទាំងអំពើអាក្រក់[ក] ដែល
ពួកកូនចៅអ៊ីស្រាអែល និងពួកកូនចៅយូដាបានប្រព្រឹត្ត
ជាហេតុបណ្ដាល[ខ]ឱ្យអញខឹង គឺទាំងខ្លួនគេ ស្ដេចគេ ពួកចៅ
ហ្វាយ[គ] ពួកសង្ឃ និងពួកហោររបស់គេ អស់ទាំងពួក
ស្រុកយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នាផង
៣៣គេបានបែរខ្នង[ឃ]ឱ្យអញ មិនមែនជាមុខឡើយ ហើយ
ទោះបើអញបានបង្ហាត់បង្រៀនគេ ព្រមទាំងក្រោកឡើងពី
ព្រលឹមស្រាងដើម្បីនឹងបង្រៀន[ង]ផងក៏ដោយ គង់តែគេមិន
បានស្ដាប់តាម ដើម្បីនឹងទទួលសេចក្ដីប្រៀនប្រដៅដែរ[ច]
៣៤គឺគេបានតាំងរបស់[ឆ]គួរស្អប់ខ្ពើមរបស់គេ នៅក្នុងវិហារ
ដែលហៅតាមឈ្មោះ[ជ]អញ ជាការដែលបង្អាប់[ឈ]ដល់
ទីនោះវិញ ៣៥គេក៏បានធ្វើទីខ្ពស់ទាំងប៉ុន្មាននៃព្រះបាល
ដែលក្នុងច្រកភ្នំរបស់កូនចៅហ៊ីនណោម[ញ] សំរាប់នឹងធ្វើឱ្យកូន
ប្រុសកូនស្រីគេ ដើរកាត់ភ្លើងថ្វាយដល់ព្រះម៉ូឡុក[ដ] ជាការ
ដែលអញមិនបានបង្គាប់គេឡើយ ក៏មិនដែលចូលក្នុងគំនិត
អញ[ឋ]ឱ្យគេបានធ្វើការគួរស្អប់ខ្ពើមនេះ[ឌ] ដើម្បីនឹងនាំឱ្យពួក
យូដាបានធ្វើបាបផងដែរ[ឍ]។
៣៦ដោយហេតុនោះ ឥឡូវនេះព្រះយេហូវ៉ា ជាព្រះនៃ
សាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលពីដំណើរទីក្រុងដែល
ឯងថា បានត្រូវប្រគល់ទៅក្នុងកណ្ដាប់ដៃនៃស្ដេច បាប៊ីឡូន
ដោយសារដាវ អំណត់អត់ ហើយនិងអាសន្នរោគ[ណ]នេះថា
៣៧មើល អញនឹងប្រមូល[ត]គេចេញពីអស់ទាំងស្រុក ដែល
អញបានបណ្ដេញគេទៅនោះដោយសេចក្ដីកំហឹង[ថ] សេចក្ដី
ឃោរឃៅ ហើយនិងសេចក្ដីគ្នាន់ក្នាញ់ដ៏ជាខ្លាំងរបស់អញក៏
នឹងនាំគេមកឯទីនេះវិញ ព្រមទាំងឱ្យគេនៅដោយសុខ
សាន្ត[ទ] ៣៨នោះគេនឹងបានជារាស្ត្ររបស់អញ[ធ] ហើយអញ
នឹងធ្វើជាព្រះដល់គេ ៣៩អញនឹងឱ្យគេមានទឹកចិត្តតែ១[ន] និង
ផ្លូវប្រព្រឹត្តតែ១ ប្រយោជន៍ឱ្យគេបានកោតខ្លាច[ប]ដល់អញ
ជាដរាប សំរាប់ជាសេចក្ដីល្អដល់គេ និងកូនចៅគេតរៀង
ទៅ ៤០អញនឹងតាំងសេចក្ដីសញ្ញា[ផ]នឹងគេ ជាសេចក្ដីសញ្ញា
ដ៏ស្ថិតស្ថេរនៅអស់កល្បជានិច្ចថា អញនឹងមិនបែរចេញពី

**៣២:២៧** ប ជន ១៦:២២ ផ លប ១៨:១៤ ២ពវ ៣:១៨ **៣២:២៨** ព ២រប ៣៦:១៧ ភ ខ.៣ យរ ២១:១០ **៣២:២៩** ម ២រប ៣៦:១៩ យ យរ ១៩:១៣ រ យរ ៤៤:១៨ ល យរ ៧:៩ **៣២:៣០** វ ទដ ២៥:៧ យរ ២២:២១ ស យរ ៨:១៩ ហ យរ ២៥:៧ **៣២:៣១** ឡ ១ពវ ១១:៧-៨ ២ពវ ២១:៤-៥ មថ ២៣:៣៧ អ ២ពវ ២៣:២៧ **៣២:៣២** ក ដយ ៩:៨ ខ ១ពវ ១៤:៩ គ យរ ២:២៦ ៤៤:៩ **៣២:៣៣** ឃ ១ពវ ១៤:៩ ទដ ១៤:៣ យរ ២:២៧ អគ ៨:១៦ សក ៧:១១ ង ដយ ៤:៥ អស ២៨:៩ យរ ៧:១៣ ច យរ ៧:២៨ **៣២:៣៤** ឆ ២ពវ ២១:៤ អគ ៨:៣–១៦ ជ យរ ៧:១០ ៣៤:១៥ ឈ យរ ៧:៣០ **៣២:៣៥** ញ យរ ១៩:២ ដ លវ ១៨:២១ ឋ យរ ១៩:៥ ឌ ១ពវ ១៤:២៤ ឍ យរ ២៥:៧ **៣២:៣៦** ណ ខ.២៤ **៣២:៣៧** ត អស ១១:១២ ថ យរ ២១:៥ ទ លវ ២៥:១៨ អគ ៣៤:២៨ ៣៩:២៦ **៣២:៣៨** ធ យរ ២៤:៧ ២កថ ៦:១៦ **៣២:៣៩** ន ២រប ៣០:១២ ទដ ៨៦:១១ យហ ១៧:២១ កច ៤:៣២ ប ចទ ៦:២៤ ១០:១៦ **៣២:៤០** ផ លប ៩:១៦ អស ៤២:៦ ៣ ចទ ៤:១០

ការបំពេញសេចក្ដីសន្យារបស់ទ្រង់ ។

**៣២:២៩** *ដុតចោល* មើល ២១:១០ ៣៤:២ ៣៧:៨ ។ *បានបណ្ដាលឱ្យអញខឹង* មើល ៧:១៨ ចទ ៣១:២៩ ។ *បានដុតកំញានថ្វាយដល់ព្រះបាល* មើល ១:១៦ និងការពន្យល់ ។ *នៅលើដំបូល* មើលការពន្យល់ ១៩:១៣ ។ *ហើយច្រួចដង្វាយដល់ព្រះដ៏ទៃ* មើល ៧:១៨ និងការពន្យល់ ១៩:១៣ ។

**៣២:៣០** ចម្លើយនៅក្នុង ចទ ៣១:២៩ ។ *តាំងតែពីក្មេងមក* មើលការពន្យល់ ៣១:១៩ ។ *ដោយការដែលដៃគេធ្វើ* នេះនិយាយសំដៅទៅលើការធ្វើរូបព្រះ ។

**៣២:៣១** *បានជាគួរឱ្យអញបំបាត់ចេញពីមុខអញទៅ* មើល ៥២:៣ ២ពវ ២៤:៣ ។

**៣២:៣២** *ស្ដេចគេ ពួកចៅហ្វាយ ពួកសង្ឃ* មើល ១:១៨ និងការពន្យល់ ។

**៣២:៣៣** *ក្រោកឡើងពីព្រលឹមស្រាង* មើលការពន្យល់ ៧:១៣ ។ *មិនស្ដាប់តាម . . . សេចក្ដីប្រៀនប្រដៅដែរ* មើល ២:៣០ ៥:៣ ៧:២៨ ១៧:២៣ ។

**៣២:៣៤–៣៥** រំឭកឡើងវិញក្នុង ៧:៣០–៣១ (មើលការពន្យល់) ។

**៣២:៣៤** *វិហារដែលហៅតាមឈ្មោះអញ* មើល ៧:១០ និងការពន្យល់ ។

**៣២:៣៥** *ព្រះម៉ូឡុក* ជាព្រះរបស់ពួកអាំម៉ូន (មើល ៤៩:១,៣ មើលការពន្យល់ លវ ១៨:២១) ។ *ក៏មិនដែលចូលក្នុងគំនិតអញ* មើល ៧:៣១ និងការពន្យល់ ។

**៣២:៣៦** *ឯង* បណ្ដាជនយូដាទាំងអស់ ។ *ដាវ អំណត់អត់ ហើយនិងអាសន្នរោគ* មើលការពន្យល់ ១៤:១២ ។ *ដោយហេតុនេះ* ក្រោយពីការជំនុំជម្រះទៅលើមនុស្សអាក្រក់ ការស្ដារឡើងវិញសម្រាប់មនុស្សសុចរិត ។

**៣២:៣៧** មើល ចទ ៣០:១–៥ ។ *ដោយសេចក្ដីកំហឹង សេចក្ដីឃោរឃៅ* មើលការពន្យល់ ២១:៥ ។ *ក៏នឹងនាំគេមកទីនេះវិញ ព្រមទាំងឱ្យគេនៅដោយសុខសាន្ត* មើល អគ ៣៦:១១,៣៣ ហស ១១:១១ ។ ក្នុងព្រះគម្ពីរភាសាហេព្រើរគូសបញ្ជាក់ឃ្លាដំបូង មានសំលេងដូចគ្នានិងឃ្លាទី២ ។

**៣២:៣៨** មើល ៣១:៣៣ មើលការពន្យល់ផងដែរ ៧:២៣ ។

**៣២:៤០** *ជាសេចក្ដីសញ្ញាដ៏ស្ថិតស្ថេរនៅអស់កល្បជានិច្ច* មើល អស ៥៥:៣ និងការពន្យល់ អគ ១៦:៦០ ៣៧:២៦ មិនដូចគ្នានឹងសេចក្ដីសញ្ញានៅក្នុងព្រះគម្ពីរសញ្ញាចាស់ទេ (មើល ៣១:៣២ អស ២៤:៥) ហើយសេចក្ដីសញ្ញាថ្មីនេះនឹងមិនត្រូវបំផ្លាញឡើយ ។ *អញនឹងដាក់សេចក្ដីកោតខ្លាចដល់អញក្នុង*

គេឡើង គឺនឹងឱ្យគេបានសេចក្ដីល្អវិញ អញនឹងដាក់[ព]
សេចក្ដីកោតខ្លាចដល់អញក្នុងចិត្តគេ ប្រយោជន៍កុំឱ្យគេ
ឃ្លាតចេញពីអញឡើយ[ភ] ៤១អើ អញនឹងយកគេជាទីរីករាយ
ចិត្ត[ម] ដើម្បីនឹងប្រោសសេចក្ដីល្អ[យ]ដល់គេ ពិតប្រាកដជា
អញនឹងដាំ[រ] គេចុះ នៅក្នុងស្រុកនេះ ឱ្យអស់ពីចិត្ត ហើយអស់
ពីព្រលឹងអញ[ល] ៤២ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ
ថា អញបាននាំអស់ទាំងការអាក្រក់យ៉ាងធំនេះ[វ] មកលើជន
ជាតិនេះយ៉ាងណា អញក៏នឹងនាំអស់ទាំងការដែលអញបាន
សន្យា[ស]ដល់គេ មកលើគេយ៉ាងនោះដែរ ៤៣គ្រានោះ
មនុស្សនឹងទទួលបញ្ចាំ[ហ]ចំការ នៅក្នុងស្រុកនេះទៀតជា
ស្រុកដែលឯងរាល់គ្នាថា បានចោលស្ងាត់[ឡ]ហើយ ឥតមាន
មនុស្ស ឬសត្វនៅទៀតឡើយ គឺបានប្រគល់ទៅក្នុងកណ្ដាប
ដៃនៃពួកខាល់ដេ ៤៤មនុស្សនឹងទទួលបញ្ចាំស្រែចំការ
ដោយប្រាក់ ព្រមទាំងចុះឈ្មោះ[អ] និងបិទត្រា ហើយហៅ
ស្មរបន្ទាល់[ក]មកផង គឺនៅក្នុងស្រុកបេនយ៉ាមីននេះឯងនឹង
នៅក្រវល់ក្រុងយេរូសាឡិម នៅអស់ទាំងទីក្រុងរបស់ស្រុក
យូដា នៅទីក្រុងស្រុកភ្នំ ទីក្រុងស្រុកទំនាប និងក្នុងទីក្រុងនៃ
ស្រុកត្បូង[ខ]ទាំងប៉ុន្មានដែរ ដ្បិតអញនឹងធ្វើឱ្យ[គ]ពួកគេដែល
ជាប់ជាឈ្លើយ បានត្រឡប់មកវិញ នេះហើយជាព្រះបន្ទូល
នៃព្រះយេហូវ៉ា ។

## ព្រះបន្ទូលសន្យានឹងស្អាងឡើងវិញ

**៣៣** ១ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់យេរេមា ម្ដង
ទៀត ក្នុងកាលដែលលោកនៅជាប់ឃុំ[ក]ក្នុងទីលាន[ខ]គុកថា[គ]
២ព្រះយេហូវ៉ាដែលធ្វើការទាំងនេះ[ឃ] គឺព្រះយេហូវ៉ា ដែល
ជបសូនបង្កើត ដើម្បីនឹងតាំងឡើង ដែលមានព្រះនាមជា
ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា[ង] ៣ចូរអំពាវនាវ[ច]ដល់អញ
នោះអញនឹងឆ្លើយតប ហើយនឹងបង្ហាញឱ្យឯងឃើញការ
យ៉ាងធំ ហើយមុតមាំ ដែលឯងមិនដឹង[ឆ] ៤ដ្បិតព្រះយេហូវ៉ា
ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលពីដំណើរអស់
ទាំងផ្ទះនៅទីក្រុងនេះ នឹងពីដំណាក់ស្ដេចយូដា ដែលត្រូវ
រំលំ ដោយសារប្រដាប់ចំបាំង[ជ,ឈ] ហើយនឹងដាវ ៥ដែលគេ
បានចេញទៅតយុទ្ធនឹងពួកខាល់ដេ ហើយក៏បំពេញផ្ទះទាំង
នោះ ដោយសាកសពនៃមនុស្ស ដែលអញសំឡាប់ ដោយ

**៣២:៤០** ភ យរ ២៤:៧
**៣២:៤១** ម ចទ ២៨:៦៣ អស ៦២:៤ យ ចទ ២៨:៣–១២ រ យរ ២៤:៦ ៤១:២៨ ល មីក ៧:១៨
**៣២:៤២** វ បទ ៣:៣៨ ស យរ ២៩:១០
**៣២:៤៣** ហ ខ.១៥ ឡ យរ ៣៣:១២
**៣២:៤៤** អ ខ.១០ ក នរ ៤:៩ អស ៨:២ ខ យរ ១៧:២៦ គ អរ ៩:៩ ទដ ១៤:៧
**៣៣:១** ក ទដ ៨៨:៨ ខ យរ ៣៧:២១ ៣៨:២៨ គ យរ ១៣:៣
**៣៣:២** ឃ ទដ ១៣៦:៦ យរ ១០:១៦ ង នក ៣:១៥ **៣៣:៣** ច អស ៥៥:៦ ឆ យប ២៨:១១
**៣៣:៤** ជ ២ពវ ២៥:១ អគ ៤:២ ឈ យរ ៣២:២៤ អគ ២៦:៨ ហព ១:១០

*ចិត្តគេ* មើល ចទ ៦:២៤ មើលការពន្យល់ផងដែរ លប ២០:១១ ។ *ប្រយោជន៍កុំឱ្យឃ្លាតចេញពីអញឡើយ* មើល ២៦:៣ អស ៥៣:៦ ។

**៣២:៤១** *អញនឹងយកគេជាទីរីករាយចិត្ត* មើលចទ ៣០:៩ អស ៦២:៥ ៦៥:១៩ ។

**៣២:៤៣–៤៤** *មនុស្សនឹងទទួលបញ្ចាំចំការ* លោកយេរេមាបានទិញចំការនោះ (មើលខ.៩) និមិត្តរូបអំពីចំការជាច្រើននឹងត្រូវទិញ នៅស្រុកយូដាក្រោយពីការនិទេសខ្លួន ដោយពួកបាប៊ីឡូន នៅពេលដែលសេដ្ឋកិច្ចវិលត្រឡប់ទៅរកស្ថានភាពធម្មតាវិញ (មើលការពន្យល់ខ.១៥) ។

**៣២:៤៣** *ឯងរាល់គ្នា* មើលការពន្យល់ខ.៣៦ ។ *ឥតមានមនុស្ស ឬសត្វនៅទៀតឡើយ* មើល ៤:២៣–២៦ និងការពន្យល់ ។

**៣២:៤៤** *គឺនៅក្នុងស្រុកបេនយ៉ាមីននេះឯង* មើល ១:១ បេនយ៉ាមីនគឺបានបញ្ជាក់នៅទីនេះលើកដំបូង ដ្បិតវាជាតំបន់នៅទីក្រុងរបស់លោកយេរេមា (មើលចុងខ.៧–៨ និងការពន្យល់) ។ *នៅទីក្រុងស្រុកភ្នំ ទីក្រុងស្រុកទំនាប និងក្នុងទីក្រុងនៃស្រុកត្បូងទាំងប៉ុន្មានដែរ* មើលការពន្យល់ ចទ ១:៧ ។ *ស្រុកត្បូង* មើលការពន្យល់ លប ១២:៩ ។ *ពួកគេដែលជាប់ជាឈ្លើយ បានត្រឡប់មកវិញ* មើលការពន្យល់ ២៩:១៤ ។

**៣៣:១–២៦** ការសង្ខេបនៅក្នុង "ព្រះគម្ពីរលួងលោមកំសាន្តចិត្ត" (មើលការពន្យល់ ៣០:១–៣៣:២៦) នៅក្នុងផ្នែកនេះបែងចែកជា២ផ្នែក (១). ខ.១១–១៣ ដែលបន្ត និងបង្កើតនៅក្នុងជំពូក ៣២ និង (២). ខ.១៤–២៦ ដែលសង្ខេបអត្ថបទកាលពីនៅជំនាន់ដើម ក្នុងព្រះគម្ពីរយេរេមា និងនៅកន្លែងផ្សេងទៀត ។ ផ្នែកនេះមិនរកឃើញនៅក្នុង ស៊ីពូអេជីន (Septuagint) (ការបកប្រែភាសាក្រិក គ្រីស្ទានជំនាន់មុន នៅសញ្ញាចាស់) ។

**៣៣:១** *នៅតែជាប់ឃុំ* នៅក្នុងឆ្នាំ ៥៨៧ គ.ស (មើលការពន្យល់ ៣២:១) ។ *ក្នុងទីលានគុក* មើល ៣២:២ និងការពន្យល់ ។ *ម្ដងទៀត* ជំពូក ៣២ បញ្ចូលនៅក្នុងលើកដំបូង ។

**៣៣:២** មើល ១០:១២ ៣២:១៧ ៥១:១៥ មើលផងដែរ ៣១:៣៥ និងការពន្យល់ ។

**៣៣:៣** *ចូរអំពាវនាវដល់អញ នោះអញនឹងឆ្លើយតប* សំណូមពរសេចក្ដីអធិស្ឋានរាស្ត្ររបស់ព្រះការធានា និងការឆ្លើយបត (មើល ទដ ៣:៤ ៤:៣ ១៨:៦ ២៧:៧ ២៨:១–២ ៣០:៨ ៥៥:១៧ ១១៨:៥ និងការពន្យល់ មថ ៧:៧ ផ្ទុយគ្នានៅក្នុង ១១:១៤) ។ *ការយ៉ាងធំ ហើយមុតមាំ ដែលឯងមិនដឹង* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ តែងតែនិយាយសំដៅទៅលើទីក្រុងដ៏អស្ចារ្យ គឺទីក្រុងកាណាន ហើយបានបកប្រែថា "ទីក្រុងធំដែលមានជញ្ជាំងខ្ពស់ឡើងទៅលើមេឃ" (ចទ ១:២៨ មើល ជន ១៣:២៨ ចទ ៩:១ យស ១៤:១២) ។ *ហើយមុតមាំ ដែលឯងមិនដឹង* ព្រះគម្ពីរភាសាហេព្រើរ (ផ្លាស់ប្ដូរតួរអក្សរមួយ) សម្រាប់ឃ្លាមានចម្លើយនៅក្នុង អស ៤៨:៦ "វត្ថុដែលលាក់ទុកដែលឯងមិនដឹង" ក្រៅពីក្នុងជំពូក ៣៣ ដោយស្រាយបំភ្លឺថាព្រះអម្ចាស់នឹង ជំនុំជម្រះដល់រាស្ត្រទ្រង់មុនគេ (ក្នុង ខ.៤–៥) និងបន្ទាប់មកទ្រង់នឹងស្អាងគេឡើងវិញ ដែលមិនមានអ្វីមកកាត់ផ្ដាច់សេចក្ដីជំនឿរបស់គេឡើយ (ខ.៦–២៦) ។

**៣៣:៤** អស់ទាំងផ្ទះនៅក្រុងយេរូសាឡិម រួមទាំងដំណាក់របស់ស្ដេច ត្រូវរំលំចុះ ដើម្បីយកថ្មនោះទៅប្រើសម្រាប់ជួលជុលកំផែងក្រុង ក្រោយពីសង្គ្រាមបំផ្លាញ (មើល អស ២២:១០ និងការពន្យល់) ។ *ប្រដាប់ចំបាំង* មើល ៦:៦ និងការពន្យល់ ។

**៣៣:៥** *ដែលគេបានចេញទៅតយុទ្ធ នឹងពួកខាល់ដេ* មើល ៣២:៥ ។ ដោយសាកសពនៃមនុស្ស អ្នកចាំយាមនៅក្រុងយេរូសាឡិម ។

សេចក្ដីកំហឹង និងសេចក្ដីឃោរឃៅរបស់អញ[ញ] ហើយបាន
គេចមុខ[ដ]ចេញពីទីក្រុងនេះ ដោយព្រោះអស់ទាំងអំពើ
អាក្រក់ទាំងប៉ុន្មានរបស់គេ ៦មើល អញនឹងនាំសេចក្ដីសុខ
ស្រួល និងការរំងាប់រោគមកដល់ ហើយនិងមើល[ឋ]គេឱ្យជា
ព្រមទាំងបើកសេចក្ដីសុខ[ឌ] និងសេចក្ដីពិតជាបរិបូរឱ្យគេ
ឃើញ ៧អញនឹងធ្វើឱ្យពួកយូដា[ឍ] និងពួកអ៊ីស្រាអែល ដែល
ជាឈ្លើយវិលមកវិញ[ណ] ហើយនឹងសង់[ត]គេឡើងដូចកាល
ពីដើម[ថ] ៨ក៏នឹងសំអាត[ទ]គេ ឱ្យស្អាតពីអស់ទាំងអំពើទុច្ចរិត
របស់គេ ជាអំពើដែលគេបានប្រព្រឹត្តរំលងនឹងអញ ហើយ
អញនឹងអត់ទោស[ធ]ចំពោះអស់ទាំងសេចក្ដីទុច្ចរិត ដែលគេ
ធ្វើបាប ហើយប្រព្រឹត្តរំលងនឹងអញនោះ ៩ឯទីក្រុងនេះ នឹង
បានសំរាប់ជាហេតុនាំឱ្យអរសប្បាយ[ន] ដល់អញសំរាប់ជា
សេចក្ដីសរសើរ[ប] និងសិរីល្អ[ផ]ផង នៅចំពោះអស់ទាំងនគរ
នៅផែនដី ជាពួកអ្នកដែលនឹងឮនិយាយពីអស់ទាំងការល្អ
ដែលអញប្រោសដល់គេ រួចគេនឹងកោតខ្លាច ហើយភ័យ
ញ័រ[ព] ដោយព្រោះគ្រប់ទាំងសេចក្ដីល្អ និងសេចក្ដីសុខទាំង
ប៉ុន្មាន ដែលអញផ្ដល់ដល់គេ ។
១០ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា នៅទីនេះ
ដែលឯងរាល់គ្នាថា ជាទីខូចបង់ឥតមានមនុស្ស ឬសត្វ
ណានៅទៀត[ភ] គឺនៅក្នុងទីក្រុងនៃស្រុកយូដាទាំងប៉ុន្មាន
ហើយនៅអស់ទាំងផ្លូវរបស់ក្រុងយេរូសាឡិម ដែលចោល
ស្ងាត់នោះ[ម] ឥតមានអ្នកណាអាស្រ័យនៅ ឬមនុស្ស ឬសត្វ
ណាឡើយ នោះនឹងមានឮសំឡេងមនុស្សម្ដងទៀត ១១ជា
សំឡេងអរសប្បាយ និងសំឡេងរីករាយ[យ] គឺសំឡេងរបស់
ប្ដីប្រពន្ធថ្មោងថ្មី និងសំឡេងពួកអ្នក[រ]ដែលពោលថា ចូរ
លើកសរសើរព្រះយេហូវ៉ានៃពួកពលបរិវារ ដ្បិតព្រះ
យេហូវ៉ាទ្រង់ល្អ[ល] ពីព្រោះសេចក្ដីសប្បុរសរបស់ទ្រង់ស្ថិត
ស្ថេរនៅអស់កល្ប[វ] ហើយសំឡេងរបស់ពួកដែលនាំយក
ដង្វាយអរព្រះគុណចូលក្នុងព្រះវិហារនៃព្រះយេហូវ៉ាដែរ
ដ្បិតអញនឹងធ្វើឱ្យ ពួកអ្នកស្រុកនេះ ដែលនៅជាឈ្លើយ បាន
វិលមកវិញ[ស]ដូចកាលពីដើម[ហ] នេះហើយជាព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ។
១២ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលដូច្នេះ
ថា នៅស្រុកនេះដែលខូចបង់[ឡ] ឥតមានមនុស្ស ឬសត្វណា[អ]
សោះ ហើយនៅអស់ទាំងទីក្រុង នោះនឹងមានទីលំនៅ
របស់ពួកអ្នកគង្វាល ដែលឱ្យហ្វូងសត្វរបស់គេដេកសំរាក
ម្ដងទៀត[ក] ១៣ហ្វូងសត្វនឹងចូលក្រោមដៃ[ខ]នៃអ្នកដែលរាប់
វាម្ដងទៀត នៅអស់ទាំងទីក្រុងនៅស្រុកភ្នំ[គ] ស្រុកទំនាប
ស្រុកត្បូង[ឃ] ស្រុកបេនយ៉ាមីន និងគ្រប់កន្លែងជុំវិញក្រុង
យេរូសាឡិម ហើយនៅទីក្រុងស្រុកយូដាទាំងប៉ុន្មានផង នេះ
ជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
១៤ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល នឹងមានគ្រា
មកដល់ ដែលអញនឹងសំរេចតាមពាក្យល្អ[ង] ដែលអញបាន
និយាយពីដំណើរពួកវង្សអ៊ីស្រាអែល និងពួកវង្សយូដា
១៥នៅគ្រានោះ គឺនៅជាន់នោះឯង អញនឹងធ្វើឱ្យមាន
លំពង់[ច]ដ៏សុចរិត[ឆ]ពន្លកឡើងដល់ដាវីឌ[ជ] លំពង់នោះទ្រង់
នឹងសំរេចសេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិតនៅក្នុងស្រុក
១៦នៅគ្រានោះ ពួកយូដានឹងបានសង្គ្រោះ[ឈ] ហើយក្រុង
យេរូសាឡិមនឹងនៅដោយសុខសាន្ត[ញ] ឯលំពង់នោះ គេនឹង
ហៅថា[ដ] "ព្រះយេហូវ៉ាដ៏ជាសេចក្ដីសុចរិតនៃយើងរាល់

**៣៣:៥** ញ យរ ២១:៤-៧ **៣៣:៥** ដ ចទ ៣១:១៧ អស ៨:១៧ **៣៣:៦** ឋ ចទ ៣២:៣៩ អស ៣០:២៩ ឌ អស ៩:៦ **៣៣:៧** ឍ យរ ៣២:៤៤ ណ យរ ៣០:៣ អគ ៣៩:២៥ អម ៩:១៤ ត យរ ២៤:៦ ថ អស ១:២៦ **៣៣:៨** ទ លវ ១៦:៣០ ហាព ៩:១៣-១៤ ធ ២សយ ២៤:១៤ យរ ៣១:៣៤ **៣៣:៩** ន អស ៥៥:១៣ ប អស ៦០:១៨ ផ យរ ៣:១៧ ព អស ៦៤:២ **៣៣:១០** ភ យរ ៣២:៤៣ ម លវ ២៦:៣២ យរ ៩:១១ **៣៣:១១** យ ទដ ៥១:៨ អស ២៤:៨ ៥១:៣ រ លវ ៧:១២ ល ២របា ៧:១៣ ទដ ២៥:៨ ១៣៦:១ ណហ ១:៧ វ ១របា ១៦:៣៤ ២របា ៥:១៣ ទដ ១០០:៤-៥ ស ទដ ១៤:៧ ហ អស ១:២៦

**៣៣:១២** ឡ យរ ៣២:៤៣ អ ខ.១០ ក អស ៦៥:១០ អគ ៣៤:១១-១៥ **៣៣:១៣** ខ លវ ២៧:៣២ គ យរ ៣១:៥ ឃ យរ ១៧:២៦ អប ១:២០ **៣៣:១៤** ង ចទ ២៨:១-១៤ យស ២៣:១៥ យរ ២៩:១០ **៣៣:១៥** ច អស ៤:២ ឆ ទដ ៧២:២ ជ ២សយ ៧:១២ **៣៣:១៦** ឈ អស ៤៥:១៧ ញ យរ ១៧:២៥ ៣២:៣៧ ដ អស ៥៩:១៤ យរ ៣:១៧ អគ ៤៨:៣៥ សផ ៣:១៣ សក ៨:៣,១៦

**៣៣:៦-១៦** ការស្អាងភាពរុងរឿងឡើងវិញ របស់ក្រុងយេរូសាឡិម (មើល អស ៣៥:១-១០ និងការពន្យល់) ។

**៣៣:៦** *ការរំងាប់រោគមកដល់ ហើយនិងមើលគេឱ្យជា* មើល ១០:១៧ ដែលខុសគ្នានៅក្នុង ៨:២២ ។

**៣៣:៧** *ដែលជាឈ្លើយវិលមកវិញ* មើល ខ.១១,២៦ មើលការពន្យល់ផងដែរ ២៩:១៤ ។ *ពួកយូដា និងពួកអ៊ីស្រាអែល* មើលការពន្យល់ ៣:១៨ ។

**៣៣:៨** *ហើយអញនឹងអត់ទោសចំពោះអស់ទាំងសេចក្ដីទុច្ចរិត* នេះច្បាប់ ដ៏សំខាន់នៃសញ្ញាថ្មី (មើល ៣១:៣៤ និងការពន្យល់ មើលផងដែរ ៥០:២០ អគ ៣៦:២៥-២៦) ។

**៣៣:៩** *ហើយភ័យញ័រ ដោយព្រោះគ្រប់ទាំងសេចក្ដីល្អ* មើល ហស ៣:៥ និងការពន្យល់ ។

**៣៣:១០** មើល ៣២:៤៣ និងការពន្យល់ ។

**៣៣:១១** *ជាសំឡេងអរសប្បាយ និងសំឡេងរីករាយ គឺសំឡេងរបស់ប្ដីប្រពន្ធថ្មោងថ្មី* ការប្រកាសអំពីការជំនុំជម្រះនឹងកើតមានឡើង នៅក្នុង ៧:៣៤ ១៦:៩ ២៥:១០ ។ *សំឡេងពួកដែលនាំយកដង្វាយអរព្រះគុណ* មើលការពន្យល់ ១៧:២៦ ។ *ដែលនៅជាឈ្លើយ បានវិលមកវិញ* មើលការពន្យល់ ២៩:១៤ ។

**៣៣:១៣** *គ្រប់កន្លែងជុំវិញក្រុងយេរូសាឡិម ហើយនៅទីក្រុងស្រុកយូដាទាំងប៉ុន្មានផង* មើល ១៧:២៦ និងការពន្យល់ ៣២:៤៤ ។ *ហ្វូងសត្វនឹងចូលក្រោមដៃនៃអ្នកដែលរាប់វាម្ដងទៀត* មើល អគ ២០:៣៧ និងការពន្យល់ ។

**៣៣:១៥-១៦** រំឭកឡើងវិញពី ២៣:៥-៦ (មើលការពន្យល់)

**៣៣:១៥** *សេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិត* ដទ ១១៩:១២១ ។

**៣៣:១៦** *គេនឹងហៅថា* ពីព្រោះក្រុងយេរូសាឡិមមានការទំនាក់ទំនងយ៉ាងជិតស្និទ្ធិទៅនឹងព្រះមែស៊ី គេនឹងផ្ដល់ឈ្មោះដូចគ្នា ដោយគេនឹងហៅទ្រង់ថា នៅក្នុង ២៣:៦ (ចំពោះឧទាហរណ៍ផ្សេងទៀត មើល ពច ៦:២៤ អគ ៤៨:៣៥) ។

គ្នា"[ឋ] [១៧]ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ដាវីឌ
នឹងមិនដែលអាក់ខាន[ឌ]មានមនុស្ស សំរាប់អង្គុយលើបល្ល័ង្ក
របស់ពូជពង្សនៃអ៊ីស្រាអែលឡើយ [១៨]ហើយពួកសង្ឃ[ឍ] និង
ពួកលេវី[ណ] ក៏មិនដែលអាក់ខានមានមនុស្ស នៅចំពោះអញ
សំរាប់ថ្វាយដង្វាយដុត ដង្វាយម្សៅ ហើយនឹងយញ្ញបូជា
ជាប់នៅជានិច្ចដែរ[ត]។
[១៩]ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់យេរេមាថា
[២០]ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ បើសិនជាឯងរាល់គ្នា
អាចនឹងផ្តាច់សេចក្តីសញ្ញារបស់អញ ពីដំណើរថ្ងៃ[ថ]និងយប់
ដើម្បីមិនឱ្យមានថ្ងៃឬយប់តាមធម្មតាបាន[ទ] [២១]នោះសេចក្តី
សញ្ញា[ធ] ដែលអញបានតាំងនឹងដាវីឌ ជាអ្នកបំរើអញក៏នឹង
ផ្តាច់ទៅបានដែរ ដើម្បីមិនឱ្យដាវីឌមានកូនចៅណាមួយ
សោយរាជ្យ នៅលើបល្ល័ង្ករបស់លោក ព្រមទាំងសេចក្តី
សញ្ញាដែលតាំងនឹងពួកលេវី[ន]ដ៏ជាសង្ឃ ជាពួកអ្នកដែល
ទទួលការងាររបស់អញផង[ប] [២២]ហើយដូចជាពុំអាចនឹង
រាប់[ផ]ពួកពលបរិវារនៅលើមេឃ ឬវាលខ្សាច់នៅសមុទ្រ
ជាយ៉ាងណា នោះអញនឹងចំរើនពូជដាវីឌ ជាអ្នកបំរើអញ
និងពួកលេវី ជាពួកអ្នកទទួលការងាររបស់អញឱ្យ មាន

**៣៣:១៦** ឋ ១កថ ១:៣០
**៣៣:១៧** ឌ ២សយ ៧:១៣ ២រប ៧:១៨ ទដ ៨៩:២៩–៣៧ លក ១:៣៣
**៣៣:១៨** ឍ ជន ២៥:១១–១៣ ហព ៧:១៧–២២ ណ ចទ ១៨:១ ត ហព ១៣:១៥
**៣៣:២០** ថ ទដ ៨៩:៣៦ ទ លប ១:១៤
**៣៣:២១** ធ ទដ ៨៩:៣៤ ន ចទ ១៨:១ ប ២សយ ៧:១៣ ២រប ៧:១៨
**៣៣:២២** ផ លប ១២:២ យរ ៣០:១៩ ហស ១:១០
**៣៣:២៤** ព អគ ៣៧:២២ ភ នហ

ច្រើនឡើងយ៉ាងនោះដែរ ។
[២៣]រួចព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់យេរេមា
ថា [២៤]ឯងមិនបានពិចារណាសេចក្តីដែលជនជាតិទាំងនេះ
ពោលថា គ្រួ[ព]ទាំង២ដែលព្រះយេហូវ៉ាបានរើសតាំង
នោះទ្រង់បានបោះបង់ចោលវិញ ទេឬអី គឺយ៉ាងនោះដែល
គេមើលងាយ[ភ]ដល់រាស្ត្រអញ ដោយបំណងនឹងឱ្យគេលែង
ធ្វើជានគរនៅមុខខ្លួនតទៅ[ម] [២៥]ដូច្នេះ ព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា បើសិនជាសេចក្តីសញ្ញាពីដំណើរថ្ងៃហើយ
និងយប់[យ]មិនស្ថិតស្ថេរនៅ បើអញមិនបានតាំងអស់ទាំង
របៀប[រ]នៃផ្ទៃមេឃ និងផែនដីទេ[ល] [២៦]នោះអញនឹងបោះ
បង់ចោល[វ]ពូជពង្សយ៉ាកុប[ស] និងដាវីឌ ជាអ្នកបំរើរបស់អញ
បានដែរ ដើម្បីមិនឱ្យពូជលោកណាមួយបានតាំងឡើងជា
អ្នកគ្រប់គ្រង លើពូជនៃអ័ប្រាហាំ អ៊ីសាក និងយ៉ាកុបឡើយ
ដ្បិតអញនឹងនាំពួកគេ ដែលជាប់ជាឈ្លើយ ឱ្យបានមកវិញ[ហ]
ហើយនឹងអាណិតមេត្តា[ឡ]ដល់គេផង ។

៤:៤ ម យរ ៣០:១៧ អគ ៣៦:២០ **៣៣:២៥** យ លប ១:១៨ រ ទដ ១៤៨:៦ ល ទដ ៧៤:១៦–១៧ **៣៣:២៦** វ លវ ២៦:៤៤ ស អស ១៤:១ ហ ខ.៧ ទដ ១៤:៧ ឡ យរ ៣០:១៨

**៣៣:១៧–២៦** ការពិតការជំនុំជម្រះ ហើយអស់ទាំងសាសន៍នឹងត្រូវបោសសម្អាត ហើយទឹកដីសេចក្តីសន្យា នឹងបង្រួមតូច ហើយនឹងត្រូវបំផ្លាញ គ្រប់ទាំងសេចក្តីសញ្ញារបស់ព្រះកាលពីមុន ជាមួយរាស្ត្រទ្រង់ នោះលែងមានប្រសិទ្ធិភាពទៀតឡើយ សេចក្តីសញ្ញារបស់ទ្រង់ជាមួយអ៊ីស្រាអែល ស្តេចដាវីឌ និងលោកភីនេហាស ។ តែទោះជាយ៉ាងណាក្តី គ្រប់ទាំងសេចក្តីទំនាយ ផ្តល់នូវសេចក្តីធានាថា សេចក្តីសញ្ញានៅសម័យបុរាណ មិនត្រូវបោះបង់ចោលនោះឡើយ ដែលគេត្រូវរក្សាទុក នូវសេចក្តីសញ្ញារបស់ ព្រះចំពោះការបង្កើតរបស់ទ្រង់ និងនៅថ្ងៃអនាគត ការស្អាងឡើងវិញមិនទាន់បានសម្រេចនៅឡើយ ។

**៣៣:១៧** មើល ២សយ ៧:១២–១៦ ១ពវ ២:៤ ៨:២៥ ៩:៥ ២រប ៦:១៦ ៧:១៨ ។ ព្រះបន្ទូលនេះនឹងបានសម្រេចនៅថ្ងៃចុងក្រោយ តាមរយៈព្រះយេស៊ូវ (មើល លក ១:៣២–៣៣ និងការពន្យល់) ។

**៣៣:១៨** មើល ជន ២៥:១៣ សេចក្តីសញ្ញាអំពីសង្ឃចំពោះពួកលេវី ដូចជាសេចក្តីសញ្ញារបស់ស្តេច ជាមួយស្តេចដាវីឌ មិនមែនមានលក្ខណៈជាឯកជនទៅដល់គ្រួសារសង្ឃទេ វាមានការចូលរួមពីគ្រួសារ និងព្រះអម្ចាស់ ។ វាជាការចូលរួមដោយការដោះស្រាយរបស់ព្រះអម្ចាស់ ជាមួយរាស្ត្រទ្រង់ដែលអ៊ីស្រាអែលត្រូវទទួលនូវកិច្ចការជាសង្ឃ ដោយព្រះអម្ចាស់ទទួលយកគេបាន ហើយគេអាចចូលរួមទំនាក់ទំនងជាមួយទ្រង់ដោយអរសប្បាយ ។ កិច្ចការនោះ គឺបានសម្រេចតាមរយៈព្រះយេស៊ូវ ដែលទ្រង់ជាអ្នកបម្រើដ៏ល្អ និងជាសម្តេចសង្ឃដ៏ខ្ពង់ខ្ពស់ (មើល ទដ ១១០:៤ ហព ៥:៦–១០ ៦:១៩–២០ ៧:១១–២៥) ។ *ពួកសង្ឃ និងពួកលេវី* មើល ចទ ១៧:៩,១៨ ។

**៣៣:២០** *សេចក្តីសញ្ញារបស់អញ គឺពីដំណើរថ្ងៃ និងយប់* មើល ខ.២៥ ៣១:៣៥–៣៦ ខនេះនិយាយអំពីកាលពីដំបូង នៃការបង្កើតរបស់ព្រះ ដូចគ្នាយ៉ាងខ្លាំងទៅនឹងសេចក្តីសញ្ញាក្នុង លប ៩:៨–១៧ (មើល លប ៨:២២) ។

**៣៣:២១** សេចក្តីសញ្ញា ដែលតាំងនឹងពួកលេវី មើល មឡ ២:៤ ។

**៣៣:២២** ពាក្យនេះនិយាយសំដៅលើសេចក្តីសន្យា នៃសេចក្តីសញ្ញា ចំពោះពូជពង្សសង្ឃ (លោកអ័ប្រាហាំ លប ២២:១៧ លោកអ៊ីសាក លប ២៦:៤ លោកយ៉ាកុប លប ៣២:១២) ព្រះអម្ចាស់បានធ្វើឱ្យមានការីកចម្រើនដល់ពូជពង្សគ្រួសារ២ (ពូជពង្សស្តេច និងពូជពង្សសង្ឃ) ហើយទ្រង់បន្តកិច្ចការនេះ ដល់រាស្ត្រទ្រង់ខាងផ្នែកព្រលឹងវិញ្ញាណ ដោយទ្រង់បានបង្កើតគេឡើង ។ សេចក្តីសន្យានេះមានដល់កូនចៅគេ ទាំងគ្រួសារស្តេច និងគ្រួសារសង្ឃ ដោយឥតមានការសង្ស័យអ្វីឡើយ ដែលគេនឹងបានសោយរាជ្យឡើងជាមួយនឹងព្រះគ្រីស្ទ (មើល រម ៥:១៧ ៨:១៧ ១កថ ៦:៣ ២ធថ ២:១២ វវ ៣:២១ ៥:១០ ២០:៥–៦ ២២:៥ មើលផងដែរ មថ ១៩:២៨ លក ២២:៣០) ហើយព្រះគ្រីស្ទត្រូវបានតាំងឡើងធ្វើជាសង្ឃ (មើល ១ពត ២:៥,៩ វវ ១:៦ ៥:១០ ២០:៦ មើលផងដែរ អស ៦៦:២១ រម ៦:១៣ ១២:១ ១៥:១៦ អភ ៥:២ ភល ៤:១៨ ហព ១៣:១៥–១៦) ។

**៣៣:២៤** *គ្រួទាំង២* គឺអ៊ីស្រាអែល និងយូដា ក្នុងព្រះគម្ពីរភាសាហេព្រើរប្រើពាក្យមួយដែលជាធម្មតានិយាយសំដៅទៅលើគ្រួសារ (មើលការពន្យល់) ហើយ ប្រហែលជានិយាយសំដៅទៅលើពូជពង្ស២ (ពូជពង្សគ្រួសារស្តេច និងពូជ ពង្សគ្រួសារសង្ឃ ឬនិយាយសំដៅទៅលើគ្រួសារលោកយ៉ាកុប និងគ្រួសារស្តេចដាវីឌ (មើល ខ.២៦) ។ *ព្រះយេហូវ៉ាបានរើសតាំង* មើល អម ៣:២ និងការពន្យល់ ។

**៣៣:២៥–២៦** មើល ខ.២០ និងការពន្យល់ ។

**៣៣:២៦** *ដ្បិតអញនឹងនាំពួកគេ ដែលជាប់ជាឈ្លើយ ឱ្យបានមកវិញ ហើយនិងអាណិតដល់គេផង* ដកស្រង់ពី ចទ ៣០:៣ មើលការពន្យល់ ២៩:១៤ ។

## ការព្រមានដល់ស្តេចសេដេគា

**៣៤** ១ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដល់
យេរេមា ក្នុងកាលដែលនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន និង
ពលទ័ពទាំងប៉ុន្មានរបស់គេ ហើយអស់ទាំង នគរនៅផែនដី
ដែលនៅក្រោមអំណាចគេ ព្រមទាំងប្រជាជាតិ[ក]ទាំងឡាយ
កំពុងតែច្បាំងនឹងក្រុងយេរូសាឡិម[ខ] ហើយនឹងទីក្រុងទាំង
ប៉ុន្មាន គឺថា ២ព្រះយេហូវ៉ា ជាព្រះនៃសសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលដូច្នេះ ចូរទៅទូលសេដេគា[គ] ជាស្តេចយូដា
ថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ មើល អញនឹងប្រគល់
ទីក្រុងនេះ ទៅក្នុងកណ្តាប់ដៃនៃស្តេចបាប៊ីឡូន ហើយគេ
នឹងដុតចោល[ឃ] ៣ឯឯង នឹងមិនរួចពីកណ្តាប់ដៃនៃគេដែរ គឺ
នឹងត្រូវចាប់បាន ហើយប្រគល់[ង]ទៅក្នុងកណ្តាប់ដៃគេ ជា
ពិត ឯងនឹងឃើញស្តេចបាប៊ីឡូនប្រទល់មុខគ្នា ហើយគេនឹង
និយាយនឹងឯងផ្ទាល់មាត់ រួចឯងនឹងត្រូវទៅឯក្រុងបាប៊ីឡូន
៤ប៉ុន្តែ ឱសេដេគា ជាស្តេចយូដាអើយ ចូរស្តាប់ព្រះបន្ទូល
នៃព្រះយេហូវ៉ាចុះ ព្រះយេហូវ៉ា ទ្រង់មានបន្ទូលពីដំណើរ
ទ្រង់ថា ឯងនឹងមិនស្លាប់ដោយដាវទេ[ច] ៥គឺឯងនឹងស្លាប់
ដោយសេចក្តីសុខវិញ ហើយគេនឹងបូជាសពរបស់ឯង ដូច
ជាបានបូជាភ្លើង[ឆ] ថ្វាយដល់ពួកឰយុកោឯង គឺជាពួកស្តេច
ដែលនៅមុខឯងដែរ គេនឹងយំទួញនឹងឯងថា ឱព្រះអម្ចាស់
អើយ[ជ] ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញបានចេញ
វាចាហើយ ។
៦នោះហោរាយេរេមា ក៏ទូលគ្រប់ទាំងបន្ទូលនេះ ដល់
សេដេគា ជាស្តេចយូដា នៅក្រុងយេរូសាឡិម ៧ក្នុងកាល
ដែលពួកពលទ័ពរបស់ស្តេចបាប៊ីឡូន កំពុងតែច្បាំងនឹង
ក្រុងយេរូសាឡិម ហើយនឹងអស់ទាំងទីក្រុងនៃស្រុកយូដា
ដែលនៅសល់ គឺនឹងក្រុងឡាគីស[ឈ] ហើយនិងក្រុង
អាសេកា[ញ] ដ្បិតក្នុងនៃស្រុកយូដាទាំងប៉ុន្មាន ដែលមាន
កំផែង នោះសល់នៅតែប៉ុណ្ណោះទេ ។

## សេរីភាពសម្រាប់ពួកទាសករ

៨នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ជាពាក្យដែលមក
ដល់យេរេមា ក្នុងពេលក្រោយដែលស្តេចសេដេគា និង
ប្រជានជន[ដ]ទាំងឡាយ ដែលនៅក្រុងយេរូសាឡិមបានតាំង

**៣៤:១** ក យរ ២៧:៧ ខ ២ពវ ២៥:១ យរ ៣៩:១
**៣៤:២** គ ២របា ៣៦:១១ ឃ ខ.២២ យរ ៣២:២៩ ៣៧:៨
**៣៤:៣** ង ២ពវ ២៥:៧ យរ ២១:៧
**៣៤:៤** ច យរ ៥២:១១
**៣៤:៥** ឆ ២រប ១៦:១៤ ជ យរ ២២:១៨
**៣៤:៧** ឈ យស ១០:៣ ញ យស ១០:១០ ២រប ១១:៩
**៣៤:៨** ដ ២ពវ ១១:១៧

**៣៤:១–៣៥:១៩** ការបែងចែកផ្នែកដំបូងជាចម្បង (ជំពូក ២–៣៥) ឥឡូវនេះរហូតដល់ទីបញ្ចប់ ។ លោកយេរេមាបានព្រមាន និងដាស់តឿនពួកយូដាដោយបញ្ចប់នូវសេចក្តីសង្ខេបជារួម (ជំពូក ៣៤–៣៥) វិធីសាស្ត្រដើម្បីបញ្ចប់នូវការបែកចែកព្រះគម្ពីរ (ជំពូក ៣៩–៤៥) ព្រមទាំង (មើលការពន្យល់ ៤៥:១–៥) ជំពូក ៥២ បានសរសេរដោយអ្នកណាម្នាក់ផ្សេងទៀតក្រៅពីលោកយេរេមា ទុកជាព្រះគម្ពីរប្រវត្តិសាស្ត្រ ។

**៣៤:១–២២** ជំពូកនេះបែកចែកជា២ផ្នែក (ខ.១–៧ និង ខ.៨–២២) កាលបរិច្ឆេទនិមួយៗនៅក្នុងឆ្នាំ ៥៨៨ គ.ស មើលការពន្យល់ ខ.៧,២១–២២) ។

**៣៤:១–៧** លោកយេរេមាបានព្រមានដល់ស្តេចសេដេគា ដូចគ្នានិងការដាស់តឿនរបស់ហោរាផងដែរ នៅក្នុង ២១:១–១០ មើលការពន្យល់ ។

**៣៤:១** *ហើយអស់ទាំងនគរនៅផែនដីដែលនៅក្រោមអំណាចគេ* ការគ្រប់គ្រងរបស់ចក្រភពនេប៊ូក្នេសា (មើល អគ ២៦:៧ ដយ ៣:២–៤ ៤:១ ធៀបនឹង ការពណ៌នាដូចគ្នានៅក្នុង ៥១:២៨) ។ *ច្បាំងនឹងក្រុងយេរូសាឡិម* សាសន៍នានាបានចូលរួមទ័ព ដើម្បីប្រឆាំងនឹងស្តេចនៃទីក្រុងនេះផងដែរ (មើល ២ពវ ២៤:២) ។ នៅក្នុងសតវត្សទី១៤ គ.ស សិទ្ធិសញ្ញារវាងពួកអ្នកគ្រប់គ្រង ហេតុ ម៉ូស៊ីលីស ទី២ និងស្តេច ឌីពី តេសើប ( Mursilis II and Duppi-Tessub king ) នៃសាសន៍អាំម៉ូន ម៉ូស៊ីលីស និយាយថា "បើឯងរាល់គ្នាមិនបញ្ជូនកូនប្រុសរបស់ឯង ឬបងប្អូនប្រុសរបស់ឯងចូលរួមក្នុងកងទ័ព និងទ័ពសេះចម្បាំង ដើម្បីជួយដល់ស្តេចហេតទេ នោះឯងចាត់ទុកដូចជាការមិនគោរពចំពោះព្រះ និងក្បត់សម្បថ ។ *ហើយនឹងទីក្រុងទាំងប៉ុន្មាន* មើល ៩:១៥ និងការពន្យល់ ។

**៣៤:២–៣** មើល ៣២:៣–៥ និងការពន្យល់ មើលផងដែរ ៣៩:៤–៧ អគ ១២:១២–១៣ ១៧:១១–២០ ។

**៣៤:៤** *ឯងនឹងមិនត្រូវស្លាប់ដោយដាវទេ* មើល ៣២:៥ ៣៨:១៧,២០ ៥២:១១ អគ ១៧:១៦ ។

**៣៤:៥** *ហើយគេនឹងបូជាសពរបស់ឯង . . . គឺជាពួកស្តេចដែលនៅមុខឯងដែរ* មិនមែនដុតទេ តែជាការបញ្ចុះសព (មើល ២រប ១៦:១៤ ២១:១៩ និងការពន្យល់ អម ៦:១០) ។ *ឱព្រះអម្ចាស់អើយ* នេះជាពាក្យរបស់អ្នកកាន់ទុកនៅថ្ងៃដែលស្តេចសុគត (មើល ២២:១៨ ធៀបនឹង ១ពវ ១៣:៣០) ។

**៣៤:៧** *ក្រុងឡាគីស ហើយនិងក្រុងអាសេកា* ស្តេចហេរូបោម ជាបុត្រារបស់ស្តេចសាឡូមូនបានលើកទឹកចិត្តពួកគេ (មើល ២រប ១១:៥,៩) ប៉ុន្តែក្រោយមកក្រុងឡាគីសត្រូវបានគេឡោមព័ទ្ធ (ឆ្នាំ ៧០១ គ.ស) នៅក្នុងកំឡុងពេលការឡើងសោយរាជ្យស្តេចហេសេគា ដែលគ្រប់គ្រងដោយស្តេចសាហេរីបស្តេចអាសសើរ (មើល ២រប ៣២:៩) ។ ការពណ៌នាអំពីពិធីជប់លៀង នៅសម័យស្តេចសាហេរីប ដែលបញ្ជាក់ថា "ទ្រង់បានគង់នៅលើបល្ល័ង្គ ហើយមានអំពើឆក់ប្លន់កើតឡើងមកពីក្រុងឡាគីស" នៅថ្ងៃទី១៨ ឆ្នាំ១៩៣៥ (ភាជនះនោះបានបែក បានប្រើប្រាស់ សម្រាប់ទុកការសរសេរ) ដែលវាបានរកឃើញនៅក្រុងឡាគីស ហើយវាត្រូវបានបំផ្លាញចោលស្ទើតែខ្ទេចក្នុងការកាន់កាប់នៅពេលចុងក្រោយនោះ (ឆ្នាំ ៥៨៨ គ.ស) នៅឯទ្វារប៉មរបស់អ៊ីស្រាអែល ។ អូស្ត្រាខនទី៤ បានសរសេរទៅមេបញ្ជាការនៅក្រុងឡាគីសដោយសង្ខេប ក្រោយពីព្រឹត្តិការណ៍នោះបានកើតឡើង នៅទីបញ្ចប់ "យើងបានចាំយាមមើលបង្គោលភ្លើងនៅក្រុងឡាគីស ហេតុនេះយើងមិនអាចឃើញក្រុងអាសេកាទៀតឡើយ" មើលការពន្យល់ ៦:១ ។

**៣៤:៨–២២** ការកើតឡើងព្រមគ្នាចំពោះព្រឹត្តិការណ៍មួយនៅក្នុង ៣៧:៤–១២ (មើលការពន្យល់ ខ.២១–២២) ។

**៣៤:៨** *ដើម្បីនឹងប្រកាសប្រាប់ពីការប្រោសលែង* មើល លវ ២៥:១០ និងការពន្យល់ ។ *ប្រោសលែងដល់គេ* ដោយយោងទៅតាមការបែងចែកជាទូទៅនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ (មើល នក ២១:២–១១ និង

សេចក្ដីសញ្ញា ដើម្បីនឹងប្រកាសប្រាប់ ពីការប្រោសលែង[ឋ]
ដល់គេ [៩]គឺឱ្យគ្រប់ទាំងមនុស្សបាន បើកឱ្យបាវប្រុសបាវ
ស្រីរបស់ខ្លួន ដែលជាសាសន៍ហេព្រើររួចចេញទៅ ហើយ
កុំឱ្យអ្នកណាចាប់ប្រើសាសន៍ហេព្រើរ ដែលជាបងប្អូននឹង
គ្នា ទុកជាបាវបំរើទៀតឡើយ[ឌ] [១០]ពួកចៅហ្វាយទាំងប៉ុន្មាន
នឹងបណ្ដាជនទាំងឡាយ ដែលបានចូលក្នុងសេចក្ដីសញ្ញា
នេះ ក៏ស្ដាប់បង្គាប់តាម ដើម្បីនឹងបើកលែងបាវប្រុស បាវ
ស្រីរបស់ខ្លួន ឱ្យរួចចេញទៅឥតមានអ្នកណាចាប់ ប្រើគេ
ទុកជាបាវបំរើទៀត គេក៏ស្ដាប់តាម ហើយលែងអ្នកទាំង
នោះឱ្យរួចចេញទៅ [១១]ប៉ុន្តែក្រោយមក គេក៏បែរជា[ឍ]បង្ខំ
បាវប្រុស បាវស្រីទាំងប៉ុន្មាន ដែលគេបានលែងទៅហើយ
នោះ ឱ្យវិលមកនៅក្នុងបង្គាប់ខ្លួន និងធ្វើជាបាវប្រុសបាវ
ស្រីវិញទៀត ។
[១២]ហេតុនោះ ព្រះបន្ទូលក៏មកពីព្រះយេហូវ៉ា ដល់
យេរេមាថា [១៣]ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលដូច្នេះ អញបានតាំងសេចក្ដីសញ្ញានឹងពួក
ព្ធយុកោ[ណ]ឯងរាល់គ្នា នៅថ្ងៃដែលអញបាននាំគេចេញ
ពីស្រុកអេស៊ីព្ទ ឱ្យរួចពីសណ្ឋានជាបាវបំរើ[ត]ដោយពាក្យថា
[១៤]លុះផុត៧ឆ្នាំហើយ នោះឯងរាល់គ្នាត្រូវលែងបងប្អូនឯង
ជាសាសន៍ហេព្រើរដែលបានលក់ខ្លួនដល់ឯង ហើយបាន
បំរើឯងអស់៦ឆ្នាំ គឺឯងត្រូវលែងគេឱ្យរួចចេញ ពីឯងទៅ[ថ]

**៣៤:៨** ឋ នក ២១:២ លវ ២៥:១០, ៣៩–៤១ នហ ៥:៥–៨
**៣៤:៩** ឌ ចទ ១៥:១២–១៨
**៣៤:១១** ឍ ទដ ៧៨:៣៧
**៣៤:១៣** ណ នក ២៤:៨ ត ចទ ១៥:១៥
**៣៤:១៤** ថ នក ២១:២ ទ ២ពវ ១៧:១៤ យរ ៧:២៦
**៣៤:១៥** ធ ខ.៨ ន យរ ៣២:៣៤
**៣៤:១៦** ប អគ ៣:២០ ១៨:២៤ ផ លវ ១៩:១២
**៣៤:១៧** ព មថ ៧:២ កទ ៦:៧ ភ យរ ២១:៧ ម យរ ១៤:១២ យ យរ ១៥:៤ ២៤:៩ ២៩:១៨
**៣៤:១៨** រ យរ ១១:១០

ប៉ុន្តែពួកព្ធយុកោឯងរាល់គ្នាមិនបានស្ដាប់តាមអញទេក៏មិន
បានផ្ទៀងត្រចៀក[ទ]ផង [១៥]ឯឯងរាល់គ្នា ទើបនឹងវិលមក
ធ្វើការ ដែលត្រឹមត្រូវនៅភ្នែកអញដោយប្រកាសប្រាប់
សេចក្ដីប្រោសលោះ ដល់អ្នកជិតខាងឯងរៀងខ្លួនអំបាញ់
មិញ[ធ] ហើយបានតាំងសញ្ញានៅមុខអញក្នុងព្រះវិហារ
ដែលហៅតាមឈ្មោះអញផង[ន] [១៦]តែឥឡូវនេះ បានបែរទៅ
ជា[ប]បង្អាប់[ផ]ដល់ឈ្មោះអញវិញ ដោយបានបង្ខំឱ្យពួកបាវ
ប្រុសបាវស្រីរបស់ឯងរៀងខ្លួន ដែលឯងបានលែងឱ្យរួច
ចេញតាមបំណងចិត្តនោះ ឱ្យវិលមកនៅក្នុងបង្គាប់ខ្លួន
នឹងធ្វើជាបាវប្រុសបាវស្រីរបស់ឯងរាល់គ្នាវិញទៀត ។
[១៧]ហេតុនោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
ឯងរាល់គ្នាមិនបានស្ដាប់តាមអញ ដើម្បីនឹងប្រកាសប្រាប់
ពីសេចក្ដីប្រោសលោះ ដល់បងប្អូនឯងរៀងខ្លួនទេ[ព] ដូច្នេះ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញប្រកាសប្រាប់ពី
សេចក្ដីប្រោសលោះដល់ឯងរាល់គ្នាវិញ គឺឱ្យរួចចេញទៅ
ដល់ដាវ ដល់អាសន្នរោគ[ភ] ហើយដល់អំណត់អត់ដែរ[ម]
អញនឹងធ្វើឱ្យឯងរាល់គ្នា ត្រូវសាត់អណ្ដែតទៅមក កណ្ដាល
អស់ទាំងនគរនៅផែនដី[យ] [១៨]ហើយអញនឹងប្រគល់ពួក
មនុស្សដែលបានក្បត់នឹងសេចក្ដីសញ្ញា[រ]របស់អញ ជាពួកអ្នក
ដែលមិនបានធ្វើតាមពាក្យនៃសេចក្ដីសញ្ញា ដែលគេបាន
តាំងនៅមុខអញ ក្នុងកាលដែលគេបានពុះកូនគោជា២

ការពន្យល់ លវ ២៥:៣៩–៥៥ ចទ ១៥:១២–១៨) ។

**៣៤:៩** *សាសន៍ហេព្រើរ* មើល នក ២១:២ និងការពន្យល់ ។ *កុំឱ្យអ្នកណាចាប់ប្រើសាសន៍ហេព្រើរ ដែលជាបងប្អូននឹងគ្នា ទុកជាបាវបំរើទៀតឡើយ* មើល លវ ២៥:៣៩,៤២ ។ *សាសន៍ហេព្រើរ* ជាពាក្យខ្ចីមកពីពាក្យ "យូដា" (ពួកអ្នកនៅនគរយូដា ដែលមានសំណល់ពីពួកអ៊ីស្រាអែល ដែលមានជីវិតរស់នៅ) ។ ការនិយាយសំដៅទៅលើពាក្យ "យូដា" និយាយសំដៅទៅលើរាស្ត្ររបស់ព្រះនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយពួកកូនចៅរបស់គេតាំងពីសម័យការចាប់ជាឈ្លើយនៅបាប៊ីឡូន ។

**៣៤:១០** *បើកលែងបាវប្រុសបាវស្រី* ដើម្បីឱ្យគេទទួលនូវព្រះពររបស់ព្រះ និងជាក្ដីសង្ឃឹមដល់គេ ឱ្យគេបានជួយការពារដល់ក្រុងយេរូសាឡិម ។

**៣៤:១១** *ប៉ុន្តែក្រោយមក* នៅពេលដែលពួកបាប៊ីឡូនឡោមព័ទ្ធ នោះគ្រាន់ជាការបណ្ដោះអាសន្ន ក្នុងរយៈពេលខ្លី នៅពេលដែលពួកអេស៊ីព្ទបានជួយធ្វើអន្តរាគម (មើលខ.២១–២២ ៣៧:៥,១១) ។ *គេក៏បែរជាបង្ខំបាវប្រុសបាវស្រីទាំងប៉ុន្មាន ដែលគេបានលែងទៅហើយ* នេះជាអំពើហឹង្សាមួយក្នុង ចទ ១៥:១២ ។ *នឹងធ្វើជាបាវប្រុសបាវស្រីវិញទៀត* សូមធៀបនឹង ២របា ២៨:១០ ។

**៣៤:១៣** *ឱ្យរួចពីសណ្ឋានជាបាវបំរើ* ន័យត្រង់ "គ្រួសារនៃបាវបំរើ" (មើល នក ១៣:៣,១៤ ២០:២ ចទ ៥:៦ ៦:១២ ៨:១៤ ១៣:៥ យក ២៤:១៧ ពច ៦:៨) ។ ពួកអ៊ីស្រាអែល គឺបានដោះលែងឱ្យមានសេរីភាព ពីភាពជាទាសកពីព្រោះកាលពីដំនាន់ដើម ព្រះបានរំដោះពួកអ៊ីស្រាអែលឱ្យមានសេរីភាព (មើល ចទ ១៥:១៥) ។

**៣៤:១៤** *លុះផុត៧ឆ្នាំហើយ . . . គឺឯងត្រូវលែងគេឱ្យរួចចេញពីឯងទៅ* នេះជាការរួចចំណង នៅក្នុង ចទ ១៥:១២ ។

**៣៤:១៥–១៦** *ទើបនឹងវិល . . . បានបែរទៅជាបង្អាប់* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លា២នេះ គឺបញ្ជាក់ពីការលេងពាក្យ (មើលការពន្យល់ ខ.១៨) ។

**៣៤:១៥** *ក្នុងព្រះវិហារដែលហៅតាមឈ្មោះអញផង* មើល ៧:១០ និងការពន្យល់ ។

**៣៤:១៦** *បានបែរទៅជាបង្អាប់ដល់ឈ្មោះអញវិញ* ដោយគេបានធ្វើឱ្យខូចដល់សេចក្ដីសញ្ញារបស់ព្រះអម្ចាស់ ។ ស្ដេចសេដេគា ជាមនុស្សដែលមានបន្ទូលមកមិនគួរឱ្យជឿទុកចិត្ត (មើល អគ ១៧:១៥,១៨) ។ *ឱ្យរួចចេញតាមបំណងចិត្តគេនោះ* មើល ចទ ២១:១៤ ។

**៣៤:១៧** *ដល់ដាវ ដល់អាសន្នរោគ ហើយដល់អំណត់អត់ដែរ* មើលការពន្យល់ ១៤:១២ *កណ្ដាលអស់ទាំងនគរនៅផែនដី* មើល ១៥:៤ និងការពន្យល់ ។

**៣៤:១៨** *ក្បត់ . . . រួចដើរ* ព្រះគម្ពីរភាសាហេព្រើរ បានគូសបញ្ជាក់ពាក្យទាំង២នេះដូចគ្នា គឺជាការលេងពាក្យ (មើលការពន្យល់ ខ.១៥–១៦) ។ *បានតាំងឡើង . . . គេបានពុះ* ព្រះគម្ពីរភាសាហេព្រើរបានគូសចំណាំពាក្យ

ចំហៀងរួចដើរនៅកណ្ដាលចំហៀងទាំង២នោះ[ល] ១៩ជា
ពួកចៅហ្វាយនៃស្រុកយូដា ពួកចៅហ្វាយ[វ]នៃក្រុងយេរូ–
សាឡិមពួកសេនាបតី ពួកសង្ឃ និងពួកជនទាំងឡាយនៅ
ក្នុងស្រុក ដែលបានដើរកណ្ដាលចំហៀងនៃកូនគោនោះ
២០គឺអញនឹងប្រគល់[ស]គេ ទៅក្នុងកណ្ដាប់ដៃនៃពួកអ្នក ដែល
រកជីវិតគេ[ហ] ឯសាកសពរបស់គេនឹងជាចំណី ដល់សត្វហើរ
លើអាកាស និងសត្វជើង៤នៅផែនដី[ឡ] ២១ហើយអញនឹង
ប្រគល់សេដេគា[អ]ជាស្តេចយូដា និងពួកចៅហ្វាយ[ក] ទៅក្នុង
កណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ[ខ] ហើយក្នុងកណ្ដាប់ដៃនៃពួក
អ្នក ដែលរកជីវិតគេ និងក្នុងកណ្ដាប់ដៃនៃពួកទ័ពរបស់
ស្តេចបាប៊ីឡូន[គ]ដែលទើបនឹងថយចេញ[ឃ] ពីឯងរាល់គ្នា
នោះ ២២ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញនឹង
បង្គាប់ ហើយនឹងធ្វើឱ្យគេវិលមកឯទីក្រុងនេះវិញ នោះគេ
នឹងច្បាំងចាប់យក[ង]ទីក្រុងនេះបាន រួចដុតនឹងភ្លើងចោល[ច]
អញនឹងធ្វើឱ្យទីក្រុងទាំងប៉ុន្មាននៃស្រុកយូដាត្រូវខូចបង់[ឆ]
ឥតមានអ្នកណានៅ ។

## ពួករេកាប

៣៥ ១នេះជាព្រះបន្ទូលដែលមកពីព្រះយេហូវ៉ា ដល់
យេរេមា នៅក្នុងរាជ្យនៃយេហូយ៉ាគីម[ក] ជាបុត្រយ៉ូសៀស
ស្តេចយូដា ២ចូរទៅឯផ្ទះនៃពួករេកាប[ខ] និយាយនឹង
គេហើយនាំគេចូលទៅឯបន្ទប់[គ]១ ក្នុងព្រះវិហារនៃព្រះ
យេហូវ៉ាចុះ រួចចាក់ស្រាទំពាំងបាយជូរឱ្យគេផឹកទៅ
៣ដូច្នេះ ខ្ញុំក៏នាំយកយ្អាសានា ជាកូនយេរេមា ដែលជាកូន
ហោបាស៊ីនា ព្រមទាំងពួកបងប្អូននឹងកូនចៅគាត់ ហើយ
ពូជពង្សនៃពួករេកាបទាំងអស់គ្នា ៤ចូលទៅក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា គឺក្នុងបន្ទប់របស់កូនចៅហាណាន ជាកូន
យីកដាលា អ្នកសំណប់របស់ព្រះ[ឃ] ដែលនៅផ្ទាប់នឹងបន្ទប់
របស់ពួកចៅហ្វាយ នៅពីលើបន្ទប់របស់ម្អាសេយ៉ា កូន
សាលូម[ង] ជាអ្នកឆ្មាំទ្វារ[ច] ៥រួចខ្ញុំដាក់ដបស្រាទំពាំងបាយជូរ
និងពែងនៅមុខកូនចៅនៃពួករេកាប ហើយប្រាប់ថា

**៣៤:១៨** ល លប ១៥:១០
**៣៤:១៩** វ យរ ២៦:១០ សផ ៣:៣–៤
**៣៤:២០** ស យរ ២០:៧ អគ ១៦:២៧ ២៣:២៨ ហ យរ ១១:២១ ឡ ចទ ២៨:២៦
**៣៤:២១** អ យរ ៣២:៤ ក ២ពវ ២៥:២១ យរ ៣៩:៦ ៥២:២៤–២៧ ខ យរ ២១:៧ គ ២រប ៣៦:១០ ឃ យរ ៣៧:៥
**៣៤:២២** ង យរ ៣៩:១–២ ច នហ ២:១៧ យរ ៣៨:១៨ ៣៩:៨ អគ ២៣:៤៧

ឆ លវ ២៦:៣២ អស ១:៧ **៣៥:១** ក ២រប ៣៦:៥ **៣៥:២** ខ ២ពវ ១០:១៥ គ ១ពវ ៦:៥ **៣៥:៤** ឃ ចទ ៣៣:១ ង ១រប ៩:១៩ ច ២ពវ ១២:៩ ២៣:៤

ទាំង២នេះ ។ នៅសម័យជំនាន់បុរាណ ការតាំងសេចក្ដីសញ្ញា គឺជាការចូលរួមធ្វើសេចក្ដីសម្បថផ្ទាល់ខ្លួន (សូមឱ្យការនេះបានកើតឡើងលើទូលបង្គំចុះ បើទូលបង្គំមិនកាន់តាមសេចក្ដីសញ្ញានោះ) ដែលជានិមិត្តរូបអំពីការពុះសត្វនោះជា២ ហើយដើរកាត់នៅចំកណ្ដាលនោះ (មើល ១៥:១៨ និងការពន្យល់) ។ *ចំហៀងទាំង២នោះ* មើលការពន្យល់ លប ១៥:១៧ ។

**៣៤:២០** *នឹងជាចំណី ដល់សត្វហើរលើអាកាស និងសត្វជើង៤នៅផែនដី* មើលការពន្យល់ ៧:៣៣ និងការពន្យល់ ។

**៣៤:២១–២២** ដោយសារការមកដល់ពួកអេស៊ីព្ទ ពួកបាប៊ីឡូននៅក្នុងឆ្នាំ ៥៨៨ គ.ស បានឡោមព័ទ្ធក្រុងយេរូសាឡិមជាបណ្ដោះអាសន្ន (មើលការពន្យល់ខ.១១ ៣៧:៣) ។

**៣៤:២១** *ដែលទើបនឹងថយចេញពីឯងរាល់គ្នានោះ* មើលសេចក្ដីសង្ឃឹមដែលបានបញ្ជាក់នៅក្នុង ២១:២ ។

**៣៤:២២** *ហើយនឹងធ្វើឱ្យគេវិលមកឯទីក្រុងនេះវិញ* មើល ៣៧:៨ ។

**៣៥:១–១៩** គ្រួសាររបស់ពួករេកាប ដែលបានធ្វើតាមការបញ្ជារបស់ពួកឰយុកោគេ គឺជាឧទាហរណ៍មួយ និងដើម្បីបន្ទោស ដល់បណ្ដាជនយូដាដែលមិនស្តាប់បង្គាប់ដល់ព្រះអម្ចាស់ (មើល ខ.១៦) ។ ការបញ្ជាក់ពី "កងទ័ពពួកបាប៊ីឡូន និងកងទ័ពអារ៉ាមៀន" (ខ.១១) កាលបរិច្ឆេទនៃជំពូកនេះ គឺនៅជំនាន់ដើម រយៈពេល៨ឆ្នាំនៃស្តេចយេហូយ៉ាគីម ដែលបានចាប់ផ្ដើមឡើងសោយរាជ្យនៅក្នុងឆ្នាំ ៦០៩ គ.ស ដែលក្រុងយេរូសាឡិមត្រូវបានឡោមព័ទ្ធនៅក្នុងឆ្នាំ៦០៥ (មើល ដយ ១:១ និងការពន្យល់) ដោយស្តេចនេប៊ូក្នេសា និង បានបះបោរប្រឆាំងស្តេចនេប៊ូក្នេសា ៣ ឬ៤ឆ្នាំក្រោយមកទៀតនោះ ហើយស្តេចនេប៊ូក្នេសា ពួកអារ៉ាមៀន និងកងទ័ពផ្សេងទៀតបានវាយទន្ទ្រានចូលយកទឹកដីនោះ (មើល ២ពវ ២៤:១–២) ការទន្ទ្រានចូលនោះ គឺប្រហែលជាបានឆ្លុះបញ្ចាំងនៅក្នុង ១២:៧–១៣ ។

**៣៥:១** *នៅក្នុងរាជ្យនៃយេហូយ៉ាគីម* ជំពូក ៣៥–៣៦ (មើល ៣៦:១) គឺចង្អុលទៅលើការគ្រងរាជ្យនៃស្តេចយេហូយ៉ាគីម (ឆ្នាំ៦០៩–៥៩៨ គ.ស មើលសេចក្ដីផ្ដើម គម្រោងសង្ខេប)។

**៣៥:២** *ផ្ទះនៃពួករេកាប* ជាក្រុមពូជអំបូរ១ ដែលជាប់ទាកទងនឹងពួកសាសន៍កែន (មើល ១រប ២:៥៥) មួយចំនួនបានរស់នៅក្នុងចំណោម ឬបានរស់នៅជិតពួកអ៊ីស្រាអែល (មើល ពច ១:១៦ ៤:១១ ១សយ ២៧:១០ និងជាអ្នករាក់ទាក់ជាមួយពួកគេ (មើល ១យស ១៥:៦ ៣០:២៦,២៩) ។ *ហើយនាំគេចូលទៅឯបន្ទប់១ ក្នុងវិហារនៃព្រះយេហូវ៉ា* បានប្រើប្រាស់សម្រាប់ទុកសម្ភារៈ ឬសម្រាប់ជាទីកន្លែងស្នាកនៅ (មើល ១ពវ ៦:៥ ១រប ២៨:១២ ២រប ៣១:១១ នហ ១៣:៤–៥) ។

**៣៥:៣** *យ្អាសានា* មានន័យថា "ព្រះអម្ចាស់ស្តាប់" នេះជាឈ្មោះសាមញ្ញនៅជំនាន់លោកយេរេមា (មើល ៤០:៨ អគ ៨:១១ ១១:១) ហើយឃើញមាននៅពេលបោះត្រា (បានរកឃើញនៅតំបន់ តែល អិន ណាបេ Tell en-Nasbeth ខាងជើងក្រុងយេរូសាឡិម និងក្នុងកាលបរិច្ឆេទក្នុងឆ្នាំ៦០០ គ.ស) និងជាក្រុង១ នៅក្រុងឡាគីស អស្ត្រាកា (មើលការពន្យល់ ៣៤:៧) ។ *ជាកូនយេរេមា* គាត់មិនមែនជាហោរាទេ ។

**៣៥:៤** *កូន* ប្រហែលជានៅទីនេះមានន័យថា "សិស្ស" (មើល អម ៧:១៤ និងការពន្យល់) ។ *អ្នកសំណប់របស់ព្រះ* មានន័យដូចគ្នានិងពាក្យ "ហោរា" (មើល ១ពវ ១២:២២ មើលការពន្យល់ផងដែរ ១សយ ៩:៩) បញ្ជាក់ពីការទំនាក់ទំនងរបស់គាត់ទៅនឹងព្រះដែលត្រាសហៅគាត់ ។ *ម្អាសេយា* ប្រហែលជាបុរស មានឈ្មោះដូចគ្នាដែលបានបញ្ជាក់នៅក្នុង ២១:១ ២៩:២៥ ៣៧:៣ ។ *អ្នកឆ្មាំទ្វារ* ជាម្នាក់នៅក្នុងចំណោមអ្នកគ្រប់គ្រងទាំងបី (មើល ៥២:២៤) ដែលគ្រប់គ្រងលើឆ្មាំទ្វារក្រុងយេរូសាឡិម (មើល ២ពវ ១២:៩) ។

**៣៥:៥** *ដបស្រា* ជាដបធំដែលគេចាក់ចូលទៅក្នុងពែងតូចខ្ញុំពេញសម្រាប់ផឹក ។

អញ្ជើញពិសាស្រាទំពាំងបាយជូរចុះ ៦តែគេឆ្លើយតបថា
យើងរាល់គ្នាមិនព្រមទទួលទានស្រាទំពាំងបាយជូរទេ ពី
ព្រោះយ៉ូណាដាប[ឆ] ជាកូនរេកាប ព្ធយុកោយើងបានផ្តាំថា
កុំឱ្យឯងរាល់គ្នាផឹកស្រាទំពាំងបាយជូរឡើយ ទោះទាំងឯង
ឬកូនចៅឯងតរៀងទៅ[ជ] ៧ក៏មិនត្រូវឱ្យឯងធ្វើផ្ទះ ឬសាប
ព្រោះ ឬដាំ ឬមានចំការទំពាំងបាយជូរឡើយ គឺឯងរាល់
គ្នាត្រូវនៅក្នុងត្រសាលអស់១ជីវិត[ឈ] ដើម្បីឱ្យបានរស់ជា
យឺនយូរនៅក្នុងស្រុក[ញ]ដែលឯងរាល់គ្នាកំពុងស្នាក់នៅនោះ
៨ហើយយើងរាល់គ្នាបានស្តាប់បង្គាប់យ៉ូណាដាប ជាកូន
រេកាប ដែលជាព្ធយុកោ[ដ]យើង តាមគ្រប់ទាំងសេចក្តីដែល
គាត់បានផ្តាំមក គឺមិនបានទទួលទានស្រាទំពាំងបាយជូរ
ដរាបដល់អស់១ជីវិតយើង ព្រមទាំងប្រពន្ធ និងកូនប្រុស
កូនស្រីរបស់យើងផង ៩ក៏មិនបានធ្វើផ្ទះសំរាប់អាស្រ័យនៅ
ហើយគ្មានដំណាំទំពាំងបាយជូរ ឬចំការ ឬពូជពង្រោះណា
ផង[ឋ] ១០គឺយើងរាល់គ្នាបានអាស្រ័យនៅតែក្នុងត្រសាល
ហើយបានស្តាប់បង្គាប់ ទាំងប្រព្រឹត្តតាមគ្រប់សេចក្តីដែល
យូណាដាបជា ព្ធយុកោយើងបានផ្តាំទុក ១១ប៉ុន្តែ កាល
នេប៊ូក្នេសា ជាស្តេចបាប៊ីឡូនបានឡើងមកក្នុង[ឌ]ស្រុក នោះ
យើងបាននិយាយគ្នាថា ចូរយើងចូលទៅក្នុងក្រុងយេរូ–
សាឡិម[ឍ] ឱ្យរួចពីពួកទ័ពខាល់ដេ និងពួកទ័ពស៊ីរីចេញ
ហេតុនោះបានជាយើងរាល់គ្នាអាស្រ័យនៅក្នុងក្រុងយេរូ–
សាឡិមសព្វថ្ងៃនេះ ។
១២នោះព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់យេរេមា
ថា ១៣ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ ចូរទៅនិយាយ[ណ]នឹងពួក
ស្រុកយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមថា តើឯងរាល់
គ្នាមិនព្រមទទួលសេចក្តីប្រៀនប្រដៅ[ត] ដើម្បីនឹងស្តាប់តាម
ពាក្យអញទេឬ នេះហើយជាព្រះបន្ទូលនៃព្រះយេហូវ៉ា ១៤ឯ
ពាក្យរបស់យ៉ូណាដាប ជាកូនរេកាប ដែលបានហាមដល់
ពួកកូនចៅ មិនឱ្យផឹកស្រាទំពាំងបាយជូរ នោះបានសំរេច
ហើយ ដ្បិតគេមិនផឹកសោះ ដរាបដល់សព្វថ្ងៃនេះ ពីព្រោះ
គេស្តាប់តាមបង្គាប់របស់ព្ធយុកោគេ[ថ] ឯអញវិញអញបាន
និយាយនឹងឯងរាល់គ្នា ព្រមទាំងក្រោកឡើងពីព្រលឹម
ស្រាង ដើម្បីនឹងប្រាប់ផង[ទ] តែឯងរាល់គ្នាមិនបានស្តាប់[ធ]
អញសោះ ១៥អញក៏បានចាត់ពួកហោរា[ន]ទាំងប៉ុន្មាន ជាអ្នក
បំរើអញ ឱ្យមកឯងដែរទាំងក្រោក ឡើងពីព្រលឹមស្រាង
ដើម្បីនឹងចាត់គេផង ឱ្យប្រាប់ថា ចូរឱ្យឯងទាំងអស់គ្នាវិល
មក[ប]ពីផ្លូវអាក្រក់របស់ខ្លួនឥឡូវ ហើយកែ[ផ]កិរិយារបស់ឯង
ផង កុំឱ្យទៅតាមព្រះដទៃ[ព] ដើម្បីគោរពដល់វានោះឡើយ
នោះឯងរាល់គ្នានឹងបាននៅជាប់ក្នុងស្រុក[ភ] ដែលអញបាន
ឱ្យដល់ឯង និងពួកព្ធយុកោឯង តែឯងរាល់គ្នាមិនបានផ្ទៀង
ត្រចៀក ឬស្តាប់តាម[ម]អញសោះ ១៦ដូច្នេះ ដោយឃើញថា
ពួកកូនចៅយ៉ូណាដាប ជាកូនរេកាប បានសំរេចតាម
បង្គាប់របស់ព្ធយុកោ[យ]គេ ដែលផ្តាំមកនោះ តែជនជាតិទាំង
នេះមិនបានស្តាប់តាមអញទេ ១៧ហេតុនោះព្រះយេហូវ៉ា
ជាព្រះនៃពួកពលបរិវារ គឺជាព្រះនៃសាសន៍ អ៊ីស្រាអែល
ទ្រង់មានបន្ទូលដូច្នេះថា មើលអញនឹងនាំគ្រប់ទាំងសេចក្តី
អាក្រក់[រ]មកលើពួកយូដា ហើយលើពួកអ្នកនៅក្រុង
យេរូសាឡិម ដូចជាអញបានពោលទាស់នឹងគេហើយ ពី
ព្រោះអញបានប្រាប់ដល់គេ តែគេមិនបានស្តាប់ទេ[ល] ហើយ
អញបានហៅគេ តែគេមិនបានឆ្លើយតបឡើយ[វ] ។
១៨រួចយេរេមា លោកប្រាប់ដល់ពួកវង្សនៃរេកាបថា

**៣៥:៦** ឆ ២ពវ ១០:១៥ ជ លវ ១០:៩ ជន ៦:២–៤ លក ១:១៥
**៣៥:៧** ឈ ហព ១១:៩ ញ នក ២០:១២ អភ ៦:២–៣
**៣៥:៨** ដ សក ១:៨ កល ៣:២០
**៣៥:៩** ឋ ១ធថ ៦:៦
**៣៥:១១** ឌ ២ពវ ២៤:១ ឍ យស ១០:២០ យរ ៨:១៤
**៣៥:១៣** ណ យរ ១១:៦ ត យរ ៦:១០ ៣២:៣៣
**៣៥:១៤** ថ ឧ.៦–១០,១៦ ទ យរ ៧:១៣ ធ អស ៣០:៩
**៣៥:១៥** ន យរ ៧:២៥ ប ២ពវ ១៧:១៣ យរ ២៦:៣ ផ អស ១:១៦–១៧ ៥៩:២០ យរ ៤:១ ១៨:១១ អគ ១៤:៦ ១៨:៣០ ព នក ២០:៣ ភ ចទ ៤:៤០ យរ ២៥:៥ ម យរ ៦:១០ ៧:២៦ ៤៤:៤–៥
**៣៥:១៦** យ លវ ២០:៩ មឡ ១:៦
**៣៥:១៧** រ យស ២៣:១៥ ១ពវ ១៣:៣៤ យរ ២១:៤–៧ ល សភ ១:២៤ រម ១០:២១ វ យរ ៧:១៣

**៣៥:៦** *យើងរាល់គ្នាមិនព្រមទទួលយកស្រាទំពាំងបាយជូរទេ* នេះជាការធ្វើសម្បថមួយនៅជារៀងរហូតរបស់ពួករេកាប ធៀបទៅនឹងសេចក្តីសម្បថរបស់ពួកណាសារីត គ្រាន់តែជាបណ្តោះអាសន្ន (មើល ជន ៦:២–៣ ពច ១៣:៤–៧) ។ ម៉ាលគា គឺជាកូនប្រុសរបស់រេកាប ដែលបានបោះបង់សេចក្តីជំនឿ លើកលែងតែសេចក្តីសម្បថ ដែលគេបានធ្វើឡើងជាមួយ ពួករេកាប តាំងពីពេលដែលគេបានធ្វើជា "នាយជំរួតឃុំបេត–ហាកេរែម (មើល នហ ៣:១៤) ដែលមានន័យថា "ចំការទំពាំងបាយជូរ" ។ យ៉ូណាដាប ប្រកបថា "យ៉េហូណាដាប" នៅក្នុង ២ពវ ១០:១៥,២៣ ។ ជិត ២៥០ឆ្នាំមុនថ្ងៃរបស់លោកយេរេមា គាត់បានជួយដល់ស្តេចយេហូ ដើម្បីបំផ្លាញទីកន្លែងថ្វាយបង្គំព្រះបាល (យ៉ាងហោចណាស់ក៏ក្នុងមួយរយៈពេលខ្លី) នៅក្នុងនគរខាងជើង ។
**៣៥:៧** *គឺឯងរាល់គ្នាត្រូវនៅក្នុងត្រសាលអស់១ជីវិត* លើកលែងតែនៅចំពេលហេតុការណ៍បន្ទាន់ប្រទេសជាតិណាមួយ (មើល ខ.១១) ។ *ដើម្បីឱ្យបានរស់ជាយឺនយូរ នៅក្នុងស្រុកដែលឯងរាល់គ្នាកំពុងស្នាក់នៅនោះ* ដកស្រង់នៅក្នុង នក ២០:១២ ការធ្វើតាមការបង្គាប់បញ្ជារបស់ ឪពុកម្តាយ ។
**៣៥:៨** *ហើយយើងរាល់គ្នាបានស្តាប់បង្គាប់យ៉ូណាដាប* ខុសគ្នាទៅនឹងយូដាដែលមិនស្តាប់បង្គាប់ដល់ព្រះ (មើល ខ.១៦) ។
**៣៥:១១** មើលការពន្យល់ ខ.១–១៩ ។
**៣៥:១៣** *ទទួលសេចក្តីប្រៀនប្រដៅ* ព្រះគម្ពីរភាសាហេព្រើយ៉ាងសំខាន់ឃ្លានេះ គឺបានបកប្រែថា "ការឆ្លើយតបយ៉ាងត្រឹមត្រូវ" នៅក្នុង ២:៣០ ៧:២៨ (មើល ៥:៣ ១៧:២៣ និងការពន្យល់) ។
**៣៥:១៤–១៥** *ព្រមទាំងក្រោកតាំងពីព្រលឹមស្រាង* មើលការពន្យល់ ៧:១៣។
**៣៥:១៥** មើល ២៥:៤–៥ និងការពន្យល់ ។
**៣៥:១៧** មើល ១១:១១ ។

ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រា–
អែលទ្រង់មានបន្ទូលថា ដោយព្រោះឯងរាល់គ្នាបានស្តាប់
តាមបង្គាប់យ៉ូណាដាប ជាឰយុកោឯង[ស] ហើយរក្សាអស់
ទាំងបញ្ញត្តិរបស់គាត់ ព្រមទាំងសំរេចតាមអស់ទាំងពាក្យ
ដែលគាត់បានផ្តាំមក 19ដូច្នេះ ព្រះយេហូវ៉ានៃពួកពល
បរិវារជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលថា
យូណាដាប ជាកូនរេកាប នឹងមិនដែលអាក់ខាន[ហ]មាន
មនុស្សសំរាប់ឈរនៅមុខ[ឡ]អញជាដរាបទៅឡើយ ។

## យេហូយ៉ាគីមដុតបំផ្លាញក្រាំងរបស់លោកយេរេមា

**៣៦** 1នៅឆ្នាំទី៤ ក្នុងរាជ្យនៃយេហូយ៉ាគីម[ក] ជាបុត្រ
យ៉ូសៀសស្តេចយូដា ព្រះបន្ទូលនេះបានមកពីព្រះយេហូវ៉ា
ដល់យេរេមាថា 2ចូរយកក្រាំង[ខ]១មកកត់អស់ទាំងពាក្យ[គ]
ដែលអញបានប្រាប់ដល់ឯង ទាស់នឹងពួកអ៊ីស្រាអែល និង
ពួកយូដា ហើយទាស់នឹងសាសន៍ទាំងប៉ុន្មាន ចាប់តាំងពីថ្ងៃ
ដែលអញផ្តើមនិយាយនឹងឯង គឺតាំងពីគ្រាយ៉ូសៀស[ឃ]ដរាប
ដល់សព្វថ្ងៃនេះ 3ប្រហែលជា[ង]ពួកវង្សយូដានឹងស្តាប់[ច]អស់
ទាំងសេចក្តីអាក្រក់ ដែលអញសំរេចនឹងធ្វើដល់គេទេដឹង
ប្រយោជន៍ឱ្យគេបានវិលមក[ឆ]ពីផ្លូវអាក្រក់របស់គេ រៀងខ្លួន
ដើម្បីឱ្យអញបានអត់ទោស[ជ]ចំពោះអំពើទុច្ចរិត និងអំពើ
បាបរបស់គេ ។
4ដូច្នេះ យេរេមាក៏ហៅបារូក[ឈ] ជាកូននេរីយ៉ាមក[ញ]
ហើយបារូកក៏សរសេរអស់ទាំងព្រះបន្ទូលនៃព្រះយេហូវ៉ា
ចុះក្នុងក្រាំង តាមមាត់[ដ]យេរេមា ជាព្រះបន្ទូលដែលទ្រង់
បានមានបន្ទូលដល់លោក[ឋ] 5រួចយេរេមាប្រាប់បារូកថា
អញនៅជាប់ឃុំ និងចូលទៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា
មិនបាន 6ដូច្នេះ ចូរឯងយកក្រាំងនេះ ដែលឯងបាន
សរសេរតាមមាត់អញ ទៅអានមើលព្រះបន្ទូលនៃព្រះ
យេហូវ៉ា នៅត្រចៀករបស់បណ្តាជនក្នុងព្រះវិហារនៃព្រះ
យេហូវ៉ា នៅថ្ងៃកាន់ត្រណមទៅ[ឌ] ហើយត្រូវឱ្យអានមើល[ឍ]
នៅត្រចៀក ពួកសាសន៍យូដា[ណ]ទាំងអស់ ដែលចេញពី
ទីក្រុងរបស់គេមកដែរ 7ប្រហែលជាគេនឹងទូលអង្វរ[ត]ដល់
ព្រះយេហូវ៉ា ហើយនិងវិលមក[ថ]ពីផ្លូវអាក្រក់របស់គេរៀង
ខ្លួនទេដឹង ដ្បិតសេចក្តីខ្ញាល់[ទ] និងសេចក្តីឃោរឃៅដែល
ព្រះយេហូវ៉ាបានពោលទាស់នឹងសាសន៍នេះ នោះធ្ងន់ក្រៃ
លែង 8ដូច្នេះបារូក ជាកូននេរីយ៉ា ក៏សំរេចតាមគ្រប់ទាំង
សេចក្តីដែលហោរាយេរេមាបានបង្គាប់ គឺបានអានមើល
ព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលកត់ចុះក្នុងក្រាំង នៅក្នុងព្រះ
វិហារនៃព្រះយេហូវ៉ា ។
9រីឯនៅខែមិគសិរ[ធ] ក្នុងឆ្នាំទី៥ នៃរាជ្យយេហូយ៉ា
គីមជាបុត្រយ៉ូសៀសស្តេចយូដា នោះប្រជាជនទាំងឡាយ
នៅក្រុងយេរូសាឡិម ហើយបណ្តាលជនដែលមកឯក្រុង
យេរូសាឡិម ពីទីក្រុងស្រុកយូដាទាំងប៉ុន្មាន ក៏ប្រកាសឱ្យ
មានថ្ងៃតម[ន]នៅចំពោះព្រះយេហូវ៉ា 10ខណនោះ បារូកក៏
អានមើលក្រាំង ជាពាក្យរបស់យេរេមា ក្នុងព្រះវិហារនៃ

**៣៥:១៨** ស លប ៣១:៣៥
**៣៥:១៩** ហ អស ៤៨:១៩ យរ ៣៣:១៧ ឡ យរ ១៥:១៩
**៣៦:១** ក ២រប ៣៦:៥
**៣៦:២** ខ ខ.៤ នក ១៧:១៤ ទដ ៤០:៧ យរ ៣០:២ ហព ២:២ គ អគ ២:៧ ឃ យរ ១:២ ២៥:៣
**៣៦:៣** ង ខ.៧ អគ ១២:៣ អម ៥:១៥ ច អស ៦:៩ មក ៤:១២ ឆ ២ពវ ១៧:១៣ អស ៤៤:២២ យរ ២៦:៣ អម ៣:១៩ ជ យរ ១៨:៨
**៣៦:៤** ឈ យរ ៣២:១២ ញ យរ ៥១:៥៩ ដ ខ.១៨
ឋ ខ.២ អគ ២:៩ ដយ ៧:១ សក ៥:១
**៣៦:៦** ឌ ខ.៩ ឍ នក ៤:១៦ ណ ២រប ២០:៤
**៣៦:៧** ត យរ ៣៧:២០ ៤២:២ ថ យរ ២៦:៣ ទ ចទ ៣១:១៧ **៣៦:៩** ធ ខ.២២ ន ២រប ២០:៣

**៣៥:១៩** *នឹងមិនដែលអាក់ខានមានមនុស្សសំរាប់ឈរនៅមុខអញជាដរាបត ទៅឡើយ* មើល ៣៣:១៨ ។ ប្រពៃណីផ្សេងៗគ្នានៅក្នុងយូដា មីសណា (មើលការពន្យល់ នហ ១០:៣៤) ប្រកាសថា ពួករេកាបក្រោយមកបានផ្តល់នូវតួនាទី ដើម្បីសម្តែងក្នុងការទំនាក់ទំនងជាមួយនឹងក្រុងយេរូសាឡិម បានកសាងក្រោយពីការវិលពីការចាប់ជាឈ្លើយនៅបាប៊ីឡូន ។

**៣៦:១–៣២** នេះដំណើររឿង១ការប៉ុនប៉ងស្តេចយេហូយ៉ាគីម ដើម្បីបំផ្លាញសំណេរសេចក្តីទំនាយរបស់លោកយេរេមា ។

**៣៦:១** *នៅឆ្នាំទី៤ ក្នុងរាជ្យនៃយេហូយ៉ាគីម* ក្នុងឆ្នាំ ៦០៥ គ.ស នេះជាឆ្នាំនៃការរិះគន់នៅក្នុងប្រវត្តិសាស្ត្រយូដា (មើលការពន្យល់ ២៥:១ ៤៦:២) ។

**៣៦:២** *ចូរយកក្រាំង១* មើលការពន្យល់ ៣០:២ នក ១៧:១៤ ។ *មកកត់* ជារាជសាររបស់លោកយេរេមា ដើម្បីទុកសម្រាប់កូនចៅជំនាន់ក្រោយនៅថ្ងៃអនាគត ។ អស់ទាំងពាក្យដែលអញបានប្រាប់ដល់ឯង "នេះជាការបោះពុម្ពនៅសម័យជំនាន់ដើម" នៃសេចក្តីទំនាយរបស់លោកយេរេមា និងរួមស្មើតែក្នុងជំពូក ១–២៦ ៤៦–៥១ ។ *គឺតាំងពីគ្រាយ៉ូសៀសដរាបដល់សព្វថ្ងៃនេះ* មើលការពន្យល់ ១:២ ។

**៣៦:៣** *ប្រហែល . . . ដើម្បី* បើបណ្តាជនប្រែចិត្ត នោះព្រះអម្ចាស់នឹងទន់ព្រះហឫទ័យ (មើល ១៨:៧–១០ និងការពន្យល់ ២៦:៣) ។

**៣៦:៤** *បារូក* មើលការពន្យល់ ៣២:១២ ។

**៣៦:៥** អញនៅជាប់ឃុំ នេះជាព្រះរាជសារមួយមិនសូវមានប្រជាប្រិយ (មើល ៧:២–១៥ ២៦:២–៦) ហើយបានកត់ត្រាទុកព្រឹត្តិការណ៍នោះក្នុង ១៩:១–២០:៦ ។

**៣៦:៦** *នៅថ្ងៃកាន់ត្រណម* ប្រកាសពីភាពអាសន្នអំពីប្រទេសជាតិ (ធៀបនឹង យអ ២:១៥) ហើយពួកបាប៊ីឡូនធ្វើការវាយប្រហារនៅក្នុងឆ្នាំ ៦០៥ គ.ស (មើល ដយ ១:១ និងការពន្យល់) ។

**៣៦:៧** មើល ខ.៣ និងការពន្យល់ ។

**៣៦:៨** *ព្រះគម្ពីរនេះបានបង្ហាញអំពីសេចក្តីទំនាយរបស់លោកយេរេមា* តាមលំដាប់លំដោយ ជំពូក ៤៥ នឹងបង្ហាញបន្ទាប់ពីខនេះ (មើលសេចក្តីផ្តើមគម្រោងសង្ខេប) ។

**៣៦:៩** *រីឯនៅខែមិគសិរ ក្នុងឆ្នាំទី៥* នៅខែធ្នូ ឆ្នាំ៦០៤ គ.ស នៅក្នុងកំឡុងពេលនៃរដូវរងា (មើល ខ.២២) ។

**៣៦:១០** ធៀបនឹង ២ពវ ២៣:២ ។ *បន្ទប់* មើលការពន្យល់ ៣៥:២ ។ *សៀនកេម៉ារាជាកូនសាផាន* នេះជាឈ្មោះមន្ត្រីម្នាក់ ដែលបានរកឃើញនៅក្នុងក្រុងយេរូសាឡិម ។ *សាផាន* ជាលេខារបស់ស្តេចយូសៀស (មើល ២ពវ ២២:៣ មើលការពន្យល់ ២៦:២៤ ២៩:៣) ។ *ត្រង់ទ្វារថ្មី* មើល ២៦:២

ព្រះយេហូវ៉ាឱ្យបណ្ដាជនស្ដាប់ គឺក្នុងបន្ទប់របស់ស្មៀន
កេម៉ារា[ប]ជាកូនសាផាន[ផ,ព] ដែលនៅទីលានខាងលើ ត្រង់
ទ្វារ[ភ]ថ្មីនៃព្រះវិហារព្រះយេហូវ៉ា ។
១១ លុះកាលមីកា ជាកូនកេម៉ារា ដែលជាកូនរបស់
សាផានបានឮអស់ទាំងព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលនៅ
ក្នុងក្រាំងនោះហើយ ១២ នោះក៏ចុះទៅព្រះរាជវាំងចូលក្នុង
បន្ទប់ស្មៀន[ម] ឃើញមានពួកចៅហ្វាយទាំងប៉ុន្មាននៅទីនោះ
គឺស្មៀនអេលីសាម៉ា ហើយដេឡាយ៉ា ជាកូនសេម៉ាយ៉ា និង
អែលណាថាន[យ] ជាកូនអ័កបោរ កេម៉ារា ជាកូនសាផាន
សេដេគា ជាកូនហាណានា ហើយពួកចៅហ្វាយទាំងអស់
ផង[រ] ១៣ មីកាក៏ជំរាបគេតាមគ្រប់ទាំងពាក្យដែលខ្លួនបានឮ
ក្នុងកាលដែលបារូកអានមើលក្រាំងនោះឱ្យបណ្ដាជនស្ដាប់
១៤ ដូច្នេះ ពួកចៅហ្វាយទាំងនោះក៏ចាត់យេហ៊ូឌី[ល] ជាកូន
នេថានា ដែលជាកូនសេលេមា ដែលជាកូនគូសី ឱ្យទៅឯ
បារូកប្រាប់ថា ចូរយកក្រាំង[វ]ដែលឯងបានអានមើលឱ្យ
បណ្ដាជនស្ដាប់នោះមក បារូកជាកូននេរីយ៉ាក៏យកក្រាំង
កាន់នៅដៃទៅឯគេ ១៥ រួចគេប្រាប់ថា ចូរឯងអង្គុយអាន
មើលឱ្យយើងស្ដាប់ផង នោះបារូកក៏អានមើល ១៦ លុះ
កាលគេបានឮពាក្យនោះរួចហើយ នោះគេក៏បែរមើលគ្នា
ទៅវិញទៅមក ដោយភិតភ័យ[ស] ហើយនិយាយទៅបារូកថា
យើងនឹងទូលដល់ស្ដេច ពីពាក្យទាំងនេះជាមិនខាន ១៧ រួច
គេសួរបារូកថា ចូរប្រាប់យើងមក ធ្វើដូចម្ដេចឱ្យឯងបាន
កត់[ហ]អស់ទាំងពាក្យនេះតាមមាត់គាត់បាន ១៨ បារូកឆ្លើយថា
លោកបានប្រាប់[ឡ]ពាក្យទាំងនេះដល់ខ្ញុំ ហើយខ្ញុំក៏យកទឹក
ខ្មៅសរសេរចុះក្នុងក្រាំងនេះ ១៩ នោះពួកចៅហ្វាយ[អ]ប្រាប់
បារូកថា ចូរឯងនឹងយេរេមាទៅពួនខ្លួនទៅ[ក] កុំឱ្យអ្នកណា
ដឹងជានៅឯណាឡើយ ។
២០ រួចគេចូលទៅគាល់ស្ដេចនៅក្នុងដំណាក់ តែឯក្រាំង
គេបានដាក់ទុកនៅក្នុងបន្ទប់របស់ស្មៀន អេលីសាម៉ា ហើយ
គេទូលដល់ស្ដេចអស់ទាំងពាក្យនោះ ២១ ដូច្នេះស្ដេចទ្រង់
ចាត់យេហ៊ូឌី[ខ] ឱ្យទៅយកក្រាំងពីបន្ទប់ស្មៀន អេលីសាម៉ា
មក រួចយេហ៊ូឌីក៏អានមើលថ្វាយស្ដេច[គ] នៅត្រចៀកនៃ
ពួកចៅហ្វាយទាំងអស់ ដែលឈរនៅខាងស្ដេចដែរ
២២ ខណៈនោះ ស្ដេចទ្រង់គង់ក្នុងដំណាក់សំរាប់រដូវរងា[ឃ]
នៅខែមិគសិរ ហើយមានភ្លើងឆេះនៅជើងក្រានចំពោះ
ទ្រង់ ២៣ ដូច្នេះ កាលយេហ៊ូឌីបានអានមើលបីបួនទំព័រ
ហើយ[ង] នោះស្ដេចទ្រង់យកកាំបិតកាត់ រួចបោះទៅ ក្នុង
ភ្លើងនៅជើងក្រាន ទាល់តែក្រាំងទាំងមូលបានឆេះអស់
ទៅ[ច] ២៤ ដំណើរនេះគេឥតមានស្លុតចិត្ត[ឆ] ឬហែកសំលៀក
បំពាក់គេសោះ ទោះទាំងស្ដេច ឬពួកមហាតលិក ដែលឮ
ពាក្យទាំងនោះផង[ជ] ២៥ មានតែអែលណាថាន ដេឡាយ៉ា[ឈ]
និងកេម៉ារា[ញ] ដែលបានទូលអង្វរដល់ស្ដេចសូមកុំឱ្យទ្រង់
ដុតក្រាំងប៉ុណ្ណោះ តែស្ដេចមិនព្រមស្ដាប់តាមទេ ២៦ រួច
ស្ដេចទ្រង់បង្គាប់យេរ៉ាម្អែល ជាកូនហាម៉ាលេក និង
សេរ៉ាយ៉ា ជាកូនអាសរាល ហើយសេលេមា ជាកូន
អាប់ឌាល ឱ្យទៅចាប់[ដ] ស្មៀនបារូក និងហោរាយេរេមា
មក តែព្រះយេហូវ៉ា ទ្រង់បានលាក់[ឋ]លោកទុក ។

**៣៦:១០** ប ខ.១២,២៥ យរ ២៩:៣ ផ យរ ២៦:២៤ ព យរ ៥២:២៥ ភ លប ២៣:១០
**៣៦:១២** ម ២របា ៨:១៧ យ យរ ២៦:២២ រ យរ ៣៨:៤
**៣៦:១៤** ល ខ.២១ វ ខ.៤
**៣៦:១៦** ស ទដ ៣៦:១
**៣៦:១៧** ហ យរ ៣០:២
**៣៦:១៨** ឡ ខ.៤
**៣៦:១៩** អ យរ ២៦:១៦ ក ១ពវ ១៧:៣
**៣៦:២១** ខ ខ.១៤ គ ២ពវ ២២:១០
**៣៦:២២** ឃ អម ៣:១៥
**៣៦:២៣** ង ខ.២ ច ១ពវ ២២:៨
**៣៦:២៤** ឆ ទដ ៣៦:១ ជ លប ៣៧:២៩ ជន ១៤:៦
**៣៦:២៥** ឈ ខ.១២ ញ ខ.១០
**៣៦:២៦** ដ មថ ២៣:៣៤ ឋ ១ពវ ១៧:៣ ទដ ១១:១ យរ ១:៨ ១៥:២១

៦:១០ និងការពន្យល់ ។

**៣៦:១២** *អែលណាថាន ជាកូនអ័កបោរ* មើលការពន្យល់ ២៦:២២ ។

**៣៦:១៨** *ទឹកខ្មៅ* បញ្ជាក់មានតែនៅក្នុងព្រះគម្ពីរសញ្ញាចាស់ (ប៉ុន្តែមើលផង ដែរ ២កថ ៣:៣ ២យហ ១៣ ៣យហ ១៣) ។ នៅសម័យជំនាន់បុរាណ ទឹកខ្មៅបានធ្វើពីផ្សែងខ្មៅ ឬបាត់ខ្ទះ លាយនឹងជ័រកៅស៊ូនៅអារ៉ាប ឬលាយជាមួយ ប្រេង (ដូចជាមាននៅក្រុងឡាគីស មើលការពន្យល់ ៣៤:៧) ។

**៣៦:១៩** ពួកអ្នកធំយល់ពីបញ្ហាសុវត្ថិភាពរបស់លោកយេរេមា និងលោកបារូក (ធៀបនឹង ២៦:២០–២៣) ។

**៣៦:២០** *គេបានដាក់* នៅកន្លែងមានសុវត្ថិភាព (ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺបានបកប្រែថា "រក្សាទុក" នៅក្នុង អស ១០:២៨) ។

**៣៦:២២** រដូវរងានៅខែមិគសិរ មើលការពន្យល់ ខ.៩ ។ ដំណាក់សម្រាប់រដូវរងា ន័យត្រង់ "ដំណាក់រដូវរងា" (ដូចជានៅក្នុង អម ៣:១៥) ដែលជាបន្ទប់ធំក្នុងដំណាក់ស្ដេច ។ ភ្លើងឆេះនៅជើងក្រាន បញ្ជាក់ពីភាជនៈនៅកន្លែងជាន់កណ្ដាល ដែលទុកធ្យូងសម្រាប់កំដៅបន្ទប់នោះឱ្យក្ដៅ ។

**៣៦:២៣** ខុសគ្នាទៅនឹងបំណងប្រាថ្នារបស់ស្ដេចយ៉ូសៀស ចង់ស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះ និងស្ដាប់បង្គាប់ទ្រង់ (មើល ២ពវ ២២:១១–២៣:៣ ២៣:២១–២៤) ។ *បីបួនទំព័រ* ន័យត្រង់ "ទ្វារ" ដែលគេហៅទីនោះដោយព្រោះវាមាន៤ជ្រុង ។ *កាត់* ន័យត្រង់ "ហែក" ជំនួសពីការហែកសំលៀកបំពាក់របស់គាត់ (មើលការពន្យល់ ខ.២៤) ស្ដេចនោះបានហែកក្រាំងរបស់ហោរាចោល ។

**៣៦:២៤** *ពួកមហាតលិក . . . គេឥតមានស្លុតចិត្ត* មើល ខ.៣១ ។ ខុសគ្នាទៅនឹងការឆ្លើយតបរបស់ "មន្ត្រី" (ខ.១២ មើល ខ.១៦,២៥) ។ *ឬហែកសំលៀកបំពាក់គេសោះ* ខុសគ្នាទៅនឹងការឆ្លើយតបព្រះបិតារបស់ស្ដេចយេហូយ៉ាគីម គឺស្ដេចយ៉ូសៀស (មើល ២ពវ ២២:១១ ធៀបនឹង ១ពវ ២១:២៧) ។

**៣៦:២៦** *យេរ៉ាម្អែល ជាកូន* ជាឈ្មោះមន្ត្រី សមទៅនឹងតួនាទីរបស់ គាត់ ដែលបានរកឃើញនៅលើការឆ្លាក់ត្រា១ ដែលបានរុករកឃើញនៅទីកន្លែងរក្សាឯកសារទុកនៅជិតក្រុងយេរូសាឡិម ។ *កូន* ស្ដេចយេហូយ៉ាគីម តាំងពីទ្រង់មានព្រះជន្ម៣០ឆ្នាំ (មើល ២ពវ ២៣:២៦) ឃ្លានោះដែលគេជឿថា គេមិនអាចមើលយល់ទេ ប៉ុន្តែមានន័យថា "សមាជិកជំនួវង្សស្ដេច" (ដូច

២៧ ក្រោយដែលស្តេចបានដុតក្រាំងជាពាក្យទាំងនោះ
ដែលបារូកបានសរសេរទុកតាមមាត់យេរេមា[ឌ]ហើយ
នោះព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់យេរេមាថា ២៨ចូរ
យកក្រាំង១ទៀត[ឍ]ហើយសរសេរទុកពាក្យដើមទាំងប៉ុន្មាន
ដូចបានសរសេរចុះក្នុងក្រាំងមុននោះ ដែលយេហូយ៉ាគីម
ជាស្តេចយូដាបានដុតចោលទៅហើយនោះ ២៩រួចឯដំណើរ
យេហូយ៉ាគីម ជាស្តេចយូដា នោះត្រូវឱ្យឯងប្រាប់ថា ព្រះ
យេហូវ៉ា ទ្រង់មានបន្ទូលយ៉ាងដូច្នេះ ឯងបានដុតក្រាំងនោះ
ចោល ដោយពាក្យថា ហេតុអ្វីបានជាសរសេរដូច្នេះថា
ស្តេចបាប៊ីឡូននឹងមក ហើយបំផ្លាញស្រុកនេះទៅ ព្រមទាំង
ធ្វើឱ្យលែងមានទាំងមនុស្ស និងសត្វ[ណ]ជាពិត[ត] ៣០ហេតុនោះ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលពីដំណើរយេហូយ៉ាគីម[ថ] ជា
ស្តេចយូដាដូច្នេះថា វានឹងគ្មានអ្នកណាសំរាប់អង្គុយលើ
បល្ល័ង្ករបស់ដាវីឌឡើយ ហើយសពវានឹងត្រូវបោះចោល
ទៅក្រៅ[ទ] ឱ្យហាល[ធ]ក្តៅនៅពេលថ្ងៃ និងសន្សើមកកនៅ
ពេលយប់[ន] ៣១អញនឹងធ្វើទោសដល់ពូជវា[ប] ព្រមទាំងពួក
មហាតលិកទាំងប៉ុន្មាន ដោយព្រោះអំពើទុច្ចរិតរបស់វា
រាល់គ្នា ហើយអញនឹងនាំអស់ទាំងសេចក្តីអាក្រក់[ផ]មកលើវា
រាល់គ្នា និងលើពួកអ្នកនៅក្រុងយេរូសាឡិម ហើយ លើពួក
មនុស្សនៅស្រុកយូដាទាំងប៉ុន្មានផង តាមដែលអញបាន
ពោលទាស់នឹងវារាល់គ្នាហើយ តែគេមិនព្រមស្តាប់តាម
សោះ[ព] ៣២ដូច្នេះ យេរេមាក៏យកក្រាំង១ទៀត ឱ្យដល់ស្មៀន
បារូក ជាកូននេរីយ៉ា ហើយគាត់ក៏សរសេរ[ភ]ទុកអស់ទាំង
ពាក្យនោះតាមមាត់[ម]យេរេមា ដូចជាមាននៅក្នុងក្រាំង
ដែលយេហូយ៉ាគីម ស្តេចយូដាបានដុតចោល[យ]នោះ ក៏មាន
សេចក្តីបែបដូចគ្នា ជាច្រើនទៀតបានបន្ថែមបញ្ចូលផង ។

## លោកយេរេមានៅក្នុងគុក

**៣៧** ១សេដេគា[ក] ជាបុត្រនៃយ៉ូសៀសក៏សោយរាជ្យ[ខ] ឡើង
ជំនួសយេកូនា ជាបុត្ររបស់យេហូយ៉ាគីម[គ] ដែលនេប៊ូក្នេសា
ជាស្តេចបាប៊ីឡូន បានតាំងឡើងជាស្តេច នៅស្រុកយូដា
២ប៉ុន្តែទោះទាំងស្តេច ឬពួកមហាតលិក ឬបណ្តាជននៅក្នុង
ស្រុកនោះ ក៏មិនបានស្តាប់តាម[ឃ]ព្រះបន្ទូលនៃព្រះយេហូវ៉ា
ដែលទ្រង់មានបន្ទូលមក ដោយសារហោរាយេរេមា
ឡើយ ។
៣ឯស្តេចសេដេគា ទ្រង់ចាត់[ង]យេហ៊ូកាល[ច] ជាកូន
សេលេមា និងសេផានា[ឆ] ជាកូនម្អាសេយ៉ាដ៏ជាសង្ឃ ឱ្យទៅ
ឯយេរេមា ដោយផ្តាំថា ចូរអធិស្ឋាន[ជ]ដល់ព្រះយេហូវ៉ា
ជាព្រះនៃយើងរាល់គ្នាឱ្យយើងឥឡូវផង ៤រីឯយេរេមា
លោកទៅមកក្នុងបណ្តាជន ដ្បិតគេមិនទាន់បានឃុំទុក
លោកនៅឡើយ[ឈ] ៥គ្រានោះពលទ័ពរបស់ផារ៉ោន ក៏លើក
ចេញពីស្រុកអេស៊ីព្ទមក[ញ] កាលពួកខាល់ដេ ដែលកំពុងតែ
ឡោមព័ទ្ធក្រុងយេរូសាឡិម បានឮដំណឹងនោះហើយ គេក៏

**៣៦:២៧** ឌ ខ.៤
**៣៦:២៨** ឍ ខ.២
**៣៦:២៩** ណ យរ ៣៣:១២ ត អស ៣០:១០
**៣៦:៣០** ថ យរ ៥២:២ ទ អស ១៤:១៩ ធ ២ពវ ២៤:៦ ន យរ ៨:២
**៣៦:៣១** ប នក ២០:៥ ផ សភ ២៩:១ ព សភ ១:២៤
**៣៦:៣២** ភ នក ៣៤:១ យរ ៣០:២ ម ខ.៤ យ ខ.២៣
**៣៧:១** ក ២ពវ ២៤:១៧ ខ ១សយ ១១:១ អគ ១៧:១៣ គ ២ពវ ២៤:៨,១២ យរ ២២:២៤
**៣៧:២** ឃ ២ពវ ២៤:១៩
**៣៧:៣** ង ខ.១៧ យរ ៣៨:១៤ ច យរ ៣៨:១ ឆ ២ពវ ២៥:១៨ យរ ២៩:២៥ ៥២:២៤ ជ នក ៨:២៨ ជន ២១:៧ ១សយ ១២:១៩ ១ពវ ១៣:៦ ២ពវ ១៩:៤ យរ ៤២:២ **៣៧:៤** ឈ ខ.១៥ យរ ៣២:២
**៣៧:៥** ញ លប ១៥:១៨ អស ៣១:១ អគ ១៧:១៥

ជាមានផងដែរនៅក្នុង ៣៨:៦ ១ពវ ២២:២៦ សផ ១:៨) ។

**៣៦:៣០** *យេហូយ៉ាគីម . . . វានឹងគ្មានអ្នកណាសំរាប់អង្គុយលើបល្ល័ង្ក* បុត្រាទ្រង់គឺស្តេចយេកូនា (មើល ២ពវ ២៤:៦) បានឡើងសោយរាជ្យបានតែ៣ខែគត់ (មើល ២ពវ ២៤:៨) និងបន្ទាប់មកទ្រង់ត្រូវបានគេចាប់ចងហើយនិងដឹកនាំយកទៅជាឈ្លើយនៅបាប៊ីឡូន (មើល ២ពវ ២៤:១៥) ទ្រង់ក៏បានសុគតនៅទីនោះ (មើល ៥២:៣៣–៣៤) ។ *ហើយសាកសពវាត្រូវបោះចោលទៅក្រៅ* ទណ្ឌកម្មចំពោះការពិតនោះ គឺទ្រង់ "បានបោះបង់ចោល"(ខ.២៣) ក្រាំងរបស់ហោរាទៅក្នុងភ្លើង (មើល ២២:១៨–១៩ និងការពន្យល់) ។

**៣៦:៣១** មើល ១១:១១ ១៩:១៥ ៣៥:១៧ ។ *ពួកមហាតលិក* មើលការពន្យល់ ខ.២៤ ។

**៣៦:៣២** *ក្រាំង១ទៀត* ធៀបនឹង ភាពដូចគ្នានៅក្នុង ចទ នក ៣៤:១ ។ *ស្មៀនបារូក ជាកូននេរីយ៉ា ហើយគាត់ក៏សរសេរទុក* ការបញ្ជាក់យ៉ាងត្រឹមត្រូវបានរកឃើញនៅកន្លែងបោះត្រា (ធ្វើពីត្រាតែមួយ) បានរុករកឃើញនៅកន្លែងរក្សាឯកសាទុកដូចគ្នា នៅក្នុងការពន្យល់ ខ.២៦ ។

**៣៧:១–៣៨:២៨** នៅក្នុងកំឡុងនៃការឡើងសោយរាជ្យរយៈពេល២ឆ្នាំរបស់ស្តេចសេដេគា (ឆ្នាំ៥៨៨–៥៨៦ គ.ស) នោះពួកអាជ្ញាធបានចាប់លោកយេរេមាដាក់គុក (មើល ២០:២ និងការពន្យល់) ។

**៣៧:១** មើល ២ពវ ២៤:១៥,១៧–១៨ ។ *សេដេគា* មានន័យថា "ព្រះអម្ចាស់គឺជាសេចក្តីសុចរិតរបស់ខ្ញុំ" មើលសេចក្តីផ្តើម ប្រវត្តិដើម ។ គាត់បានឡើងជំនួសយេកូនា នៅក្នុងឆ្នាំ៥៩៧ គ.ស ។ ការណ៍នេះបានសម្រេចសេចក្តីទំនាយ លើស្តេចយេហូយ៉ាគីម នៅក្នុង ៣៦:៣០ ។

**៣៧:៣** *ឯស្តេចសេដេគា ទ្រង់ចាត់ . . . ទៅឯយេរេមា* មើល ២១:១ ។ *យេហ៊ូកាល ជាកូនសេលេមា* ក្រោយមកបានក្លាយទៅជាខ្មាំងសត្រូវរបស់លោកយេរេមា (មើល ៣៨:១,៤) ។ *សេផានា ជាកូនម្អាសេយ៉ាដ៏ជាសង្ឃ* មើល ២១:១ និងការពន្យល់ ។ *ចូរអធិស្ឋាន . . . ឱ្យយើងឥឡូវផង* មើល ២១:២ និងការពន្យល់ ។ ដើម្បីទូលសួរដល់ព្រះអម្ចាស់ ឱ្យពួកបាប៊ីឡូនដកចេញជារៀងរហូត នៅក្នុងឆ្នាំ៥៨៨ គ.ស ( មើលការពន្យល់ ៣៤:២១–២២) ។

**៣៧:៥** *ពលទ័ពរបស់ផារ៉ោន* គឺជាពលទ័ពរបស់ហុបរ៉ា(មើល ៤៤:៣០) ។ ក៏លើកចេញពីស្រុកអេស៊ីព្ទមក ដើម្បីជួយដល់ស្តេចសេដេគា នៅពេលមានសំណើររបស់ទ្រង់ អូស្រ្តាកន ឡាគីសទី៣ (មើលការពន្យល់ ៣៤:៧) បញ្ជាក់ពីការធ្វើដំណើរទស្សនៈកិច្ចទៅស្រុកអេស៊ីព្ទ ដែលរៀបចំដោយ មេបញ្ជាការកងទ័ពយូដា ។ គ្រប់ទាំងកលល្បិចរបស់ស្តេចសេដេគា គឺបានបរាជ័យ (មើល អគ ១៧:១៥,១៧) ។ *កាលពួកខាល់ដេ . . . គេក៏ថយចេញ* ដើម្បីដោះស្រាយជាមួយនឹងការគំរាមកំហែងរបស់ពួកអេស៊ីព្ទ (សូមមើល

ថយចេញ[ង]ពីក្រុងយេរូសាឡិម[ច] ។
៦ខណនោះ ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់
ហោរាយេរេមាថា ៧ព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ ត្រូវឱ្យឯងឆ្លើយតបនឹង
ស្តេចយូដា ដែលចាត់ឯងឱ្យមកសួរ[ឆ]ដល់អញថា មើល ពួក
ពលទ័ពរបស់ផារ៉ោន ដែលលើកចេញមក[ឈ]ជួយឯង គេនឹង
វិលត្រឡប់ទៅឯស្រុកអេស៊ីព្ទ ជាស្រុករបស់គេវិញ[ណ] ៨រួច
ពួកខាល់ដេនឹងមកម្តងទៀត ច្បាំងនឹងទីក្រុងនេះ ហើយនិង
ចាប់យក[ត]បានផង រួចគេនឹងដុតចោល[ថ] ៩ព្រះយេហូវ៉ាទ្រង់
មានបន្ទូលយ៉ាងដូច្នេះថា កុំឱ្យបញ្ឆោត[ទ]ខ្លួនឯងរាល់គ្នា
ដោយថា ពួកខាល់ដេនឹងថយចេញពីយើងជាប្រាកដនោះ
ឡើយដ្បិតគេនឹងមិនថយចេញទៅទេ ១០ពីព្រោះទោះបើឯង
រាល់គ្នាបានវាយពលទ័ពទាំងមូល របស់ពួកខាល់ដេដែល
ច្បាំងនឹងឯង ឱ្យមានសល់តែមនុស្សរបួសប៉ុណ្ណោះក៏ដោយ
គង់តែគេនឹងក្រោកឡើង នៅក្នុងត្រសាលគេរៀងខ្លួន មក
ដុត[ធ]ទីក្រុងនេះចោលដែរ ។
១១នៅគ្រាដែលពលទ័ពរបស់ពួកខាល់ដេ បានថយ
ចេញ[ន]ពីក្រុងយេរូសាឡិមទៅ ដោយខ្លាចពួកពលទ័ពរបស់
ផារ៉ោនហើយ ១២នោះយេរេមាក៏ចេញពីក្រុងយេរូសាឡិម
ចង់ទៅឯស្រុកបេនយ៉ាមីន ដើម្បីទទួលដីជាចំណែក[ប]របស់
លោក នៅកណ្តាលពួកអ្នកស្រុកនោះ ១៣តែកាលលោក
កំពុងចេញតាមទ្វារបេនយ៉ាមីន[ផ] នោះមានមេទ័ពពួកល្បាត
នៅទីនោះឈ្មោះយារីយ៉ា ជាកូនសេលេមា ដែលជាកូន
ហាណានា អ្នកនោះក៏ចាប់ហោរាយេរេមា ដោយចោទថា
ឯងរវាតចូលទៅខាងពួកខាល់ដេឬ[ព] ១៤យេរេមាប្រកែក
ថាមិនមែនទេ ខ្ញុំមិនរវាតចូលទៅខាងពួកខាល់ដេឡើយ
ប៉ុន្តែ យារីយ៉ាមិនព្រមជឿលោកសោះ ក៏ចាប់[ភ] យេរេមានាំ
ទៅឯពួកចៅហ្វាយ ១៥នោះពួកចៅហ្វាយមានសេចក្តី
ក្រោធនឹងយេរេមា ក៏វាយ[ម]លោក ហើយនាំទៅឃុំទុក[យ]ក្នុង
ផ្ទះ[រ]ស្មៀនយ៉ូណាថាន ដ្បិតគេបានយកផ្ទះនោះធ្វើជាគុក
ហើយ ។
១៦កាលយេរេមាបានចូលទៅក្នុងបន្ទប់នៃគុកនៅក្រោម
ដីនោះ រួចបាននៅទីនោះជាយូរថ្ងៃទៅ ១៧នោះស្តេច
សេដេគាក៏ចាត់ឱ្យគេឱ្យទៅនាំ[ល]លោកមក ស្តេចទ្រង់សួរ[វ]
លោកដោយសំងាត់នៅក្នុងដំណាក់ថា[ស] តើមានព្រះបន្ទូល
ណាមកពីព្រះយេហូវ៉ាឬទេ យេរេមាទូលតបថា មានដែរ
លោកក៏ទូលថា ទ្រង់នឹងត្រូវប្រគល់ទៅ[ហ]ក្នុងកណ្តាប់ដៃ
នៃស្តេចបាប៊ីឡូន ១៨មួយទៀត យេរេមាក៏ទូលសួរស្តេច
សេដេគាថា តើទូលបង្គំបានធ្វើខុសអ្វី[ឡ]នឹងទ្រង់ ឬនឹងពួក
នាម៉ឺនទ្រង់ ឬនឹងពួកជនជាតិនេះ បានជាដាក់ទូលបង្គំនៅ
ក្នុងគុកដូច្នេះ ១៩ឥឡូវ តើពួកហោរា[អ]របស់ទ្រង់នៅឯណា
ដែលគេទាយថា ស្តេចបាប៊ីឡូននឹងមិនមកទាស់នឹងទ្រង់ឬ
ទាស់នឹងស្រុកនេះឡើយនោះ ២០ឥឡូវនេះ ឱព្រះករុណា
ជាព្រះអម្ចាស់នៃទូលបង្គំអើយ សូមព្រះសណ្តាប់ សូមមេត្តា
ប្រោសឱ្យទូលបង្គំបានទូលអង្វរបន្តិច សូមកុំឱ្យទូលបង្គំ
ត្រឡប់ទៅ ក្នុងផ្ទះរបស់ស្មៀនយ៉ូណាថាទៀតឡើយ ក្រែង
ទូលបង្គំស្លាប់នៅទីនោះ[ក] ២១ដូច្នេះស្តេចសេដេគាទ្រង់
បង្គាប់ឱ្យគេឃុំលោកទុកនៅទីលានគុកវិញ ហើយឱ្យគេយក

**៣៧:៥** ង យរ ៣៤:២១ ច អស ៣០:៥ យរ ៣៤:១១ **៣៧:៧** ឆ លប ២៥:២២ ២ពវ ២២:១៨ ឈ ខ.៥ ណ ២ពវ ១៨:២១ យរ ២:៣៦ បទ ១:៧ ៤:១៧ **៣៧:៨** ត យរ ៣៨:៣ ថ យរ ២១:១០ ៣៨:១៨ ៣៩:៨ **៣៧:៩** ទ យរ ២៩:៨ មក ១៣:៥ **៣៧:១០** ធ យរ ២១:១០ **៣៧:១១** ន ខ.៥ **៣៧:១២** ប យរ ៣២:៩ **៣៧:១៣** ផ យរ ២០:២ ព យរ ២១:៩ **៣៧:១៤** ភ អស ៥៨:៦ យរ ៤០:៤ **៣៧:១៥** ម យរ ២០:២ ហព ១១:៣៦ យ ១ពវ ២២:២៧ រ ខ.២០ យរ ៣៨:២៦ **៣៧:១៧** ល ខ.៣ វ លប ២៥:២២ យរ ១៥:១១ ស យរ ៣៨:១៦ ហ យរ ២១:៧ **៣៧:១៨** ឡ ១សយ ២៦:១៨ យហ ១០:៣២ កច ២៥:៨ **៣៧:១៩** អ យរ ១៤:១៣ អគ ១៣:២ **៣៧:២០** ក ខ.១៥

៣៤:២១ និងការពន្យល់) ។

**៣៧:៧** *មើល ពួកពលទ័ពរបស់ផារ៉ោន . . . គេនឹងវិលត្រឡប់ទៅឯស្រុកអេស៊ីព្ទ* ហុបរ៉ា ឆាប់ៗនោះបានវាយចាញ់ស្តេចនេប៊ូក្នេសា (មើលការពន្យល់ អគ ៣០:២១) ។

**៣៧:១០** *របួស* ន័យត្រង់ "ការធ្វើឱ្យរបួស" "របួសដល់ស្លាប់" ទោះបីជាមានការពិការក្តី ក៏ពួកបាប៊ីឡូននៅតែបំផ្លាញក្រុងយេរូសាឡិមផងដែរ ។

**៣៧:១២** *ស្រុកបេនយ៉ាមីន* ជាទីក្រុងកំណើតរបស់លោកយេរេមា គឺក្រុងអាន៉ាថោត (មើលការពន្យល់ ១:១) ។ *ដើម្បីទទួលដីជាចំណែករបស់លោក* នៅពេលដែលមានការស្ងប់ស្ងៀម ពីការវាយលុកចូលរបស់ពួកបាប៊ីឡូនក្នុងរយៈពេលខ្លី លោកយេរេមាចង់ដោះស្រាយពីបញ្ហារឿងដីធ្លី ជាមួយនឹងសមាជិកគ្រួសារដទៃទៀតរបស់គាត់ ។

**៣៧:១៣** *ទ្វារបេនយ៉ាមីន* មើល ៣៨:៧ មើលការពន្យល់ សក ១៤:១០ ។ ឯងបានរវាតចូលទៅខាងពួកខាល់ដេឬ លោកយារីយ៉ា បានធ្វើឱ្យមានការភ័យខ្លាច ហើយលោកយេរេមាបានត្រូវឡោមព័ទ្ធដោយពួកខាល់ដេ (មើល ២១:៩ ៣៨:២) និងពួកយូដាជាច្រើននាក់បានទទួលនូវការបរាជ័យ (មើល ៣៨:១៩ ៣៩:៩ ៥២:១៥) ។

**៣៧:១៤** *មិនមែនទេ* ន័យត្រង់ "ការកុហក" (មើល ២ពវ ៩:១២) ។

**៣៧:១៥** *ក៏វាយលោក* មើល ២០:២ និងការពន្យល់ ។ *ផ្ទះស្មៀនយ៉ូណាថាន* ក្រោយមកលោកយេរេមាបានមើលត្រឡប់ទៅខាងក្រោយ ចំពោះការដែលគាត់បានជាប់គុកថា ជាទីកន្លែងដ៏គួរឱ្យគ្រោះថ្នាក់ខ្លាំងសម្រាប់គាត់ (មើល ខ.២០ ៣៨:២៦) ។

**៣៧:១៦** *គុកនៅក្រោមដី* ន័យត្រង់ "ផ្ទះនៅក្រោមដី" (សូមមើល នក ១២:២៩) ។

**៣៧:១៧** *នោះស្តេចសេដេគា . . . សួរទ្រង់ដោយសំងាត់* មិនចង់ធ្វើអ្វីនៅចំពោះមុខមន្ត្រី ដែលគាត់មានការភ័យខ្លាច (មើលការពន្យល់ ៣៨:៥) ។ ទ្រង់នឹងត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃស្តេចបាប៊ីឡូន សូមមើល ៣២:៤ ៣៤:៣ ។

**៣៧:១៩** *ហោរារបស់ទ្រង់* ហោរាខុសឆ្គង (មើល ចទ ១៨:២២ និងការពន្យល់) ។

**៣៧:២០** *សូមមេត្តាប្រោសឱ្យទូលបង្គំ* មើល ៣៦:៦ ។

នំបុ័ង១ដុំពីផ្លូវ នៃពួកដុតនំបុ័ងមកឱ្យលោករាល់ៗថ្ងៃ ដរាប
ដល់នំបុ័ង[ខ]ទាំងប៉ុន្មាននៅទីក្រុងបានអស់ហើយ[គ] ដូច្នេះ
យេរេមាក៏នៅជាប់ក្នុងទីលានគុកនោះ[ឃ]។

## លោកយេរេមាត្រូវឃុំក្នុងអណ្តូង ជាគុកងងឹត

**៣៨** ១ ឯសេផាធា ជាកូនម៉ាត់ថាន និងកេដាលា ជាកូន
ផាសហើរ[ក] យេហ៊ូកាល[ខ]ជាកូនសេលេមា ហើយផាសហើរ
ជាកូនម៉ាលគា គេក៏ឮពាក្យដែលយេរេមាប្រាប់បណ្តាជន
ទាំងឡាយថា ២ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អ្នកណា
ដែលកៀចនៅក្នុងទីក្រុងនេះ នឹងត្រូវស្លាប់ដោយដាវ
ដោយអំណត់អត់ ឬដោយអាសន្នរោគ[គ] តែអ្នកណាដែល
ចេញទៅឯពួកខាល់ដេ នោះនឹងបានរស់នៅវិញ ជីវិតអ្នក
នោះនឹងរាប់ទុកដូចជារបឹបដល់ខ្លួន អ្នកនោះនឹងរស់នៅត
ទៅ[ឃ] ៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ទីក្រុងនេះនឹង
ត្រូវប្រគល់ទៅ ក្នុងកណ្តាប់ដៃនៃពួកទ័ពរបស់ស្តេច
បាប៊ីឡូន ហើយគេនឹងចាប់យកបានជាពិត[ង] ៤ដូច្នេះ ពួក
ចៅហ្វាយទាំងប៉ុន្មាន[ច] ក៏ទូលស្តេចថា សូមទ្រង់អនុញ្ញាត
ឱ្យមនុស្សនេះ ត្រូវទោសដល់ស្លាប់ចុះ[ឆ] ពីព្រោះវានាំឱ្យ[ជ]ពួក
ទាហានដែលសល់នៅក្នុងទីក្រុង និងពួកបណ្តាជនទាំង
ឡាយខ្សោយដៃទៅ ដោយពោលពាក្យយ៉ាងនេះដល់គេ
ដ្បិតមនុស្សនេះមិនស្វែងរកសេចក្តីល្អ ដល់ជនជាតិនេះទេ
គឺរកតែឱ្យគេបានអន្តរាយវិញ ៥ស្តេចសេដេគាមានបន្ទូល
តបថា មើល វានៅកណ្តាប់ដៃនៃអ្នករាល់គ្នាហើយ[ឈ] ដ្បិត
ស្តេចមិនអាចនឹងធ្វើអ្វី[ញ] ទាស់ទទឹងនឹងអ្នករាល់គ្នាបានទេ
៦នោះគេក៏ចាប់យកយេរេមាទៅដាក់ក្នុងគុកងងឹតរបស់
ម៉ាលគា ជាកូនហាម៉ាលេក ដែលនៅទីលានគុក[ដ] គេយក
ខ្សែ[ឋ]សំរូតយេរេមាចុះទៅ រីឯងនៅក្នុងគុកងងឹតនោះគ្មាន
ទឹកទេ[ឌ] មានសុទ្ធតែភក់វិញ ហើយយេរេមាក៏ផុងទៅក្នុងភក់
នោះ[ឍ]។

៧កាលអេបេឌ-មេលេក[ណ]ជាមនុស្សគំរៀវសាសន៍
អេធីយ៉ូពី ដែលនៅក្នុង[ត]វាំងហ្លួង គាត់បានឮថា គេដាក់
យេរេមាក្នុងគុកងងឹតដូច្នោះ (គ្រានោះស្តេចកំពុងតែគង់
នៅត្រង់ទ្វារបេនយ៉ាមីន[ថ]) ៨នោះអេបេឌ-មេលេកក៏ចេញ
ពីព្រះរាជវាំងទៅទូលស្តេចថា ៩ឱព្រះករុណា ជាព្រះ
អម្ចាស់នៃទូលបង្គំអើយ ក្នុងការទាំងប៉ុន្មានដែលមនុស្ស
ទាំងនេះបានធ្វើដល់ហោរាយេរេមា គឺដែលគេបានដាក់
លោកឱ្យនៅក្នុងគុកងងឹត[ទ] នោះជាការអាក្រក់ណាស់ ដ្បិត
មុខជាលោកនឹងស្លាប់នៅទីនោះ ដោយព្រោះអំណត់ជា មិន

**៣៧:២១** ខ លវ ២៦:២៦ អស ៣៣:១៦ យរ ៣៨:៩បទ ១:១១ គ ២ពវ ២៥:៣ ឃ យរ ៣២:២ ៣៨:៦,១៣, ២៨ ៣៩:១៣-១៤ **៣៨:១** ក ១រប ៩:១២ ខ យរ ៣៧:២ **៣៨:២** គ យរ ៣៤:១៧ ឃ ខ.១៧ យរ ២១:៩ ៣៩:១៨ ៤៥:៥ **៣៨:៣** ង យរ ២១:៤,១០ **៣៨:៤** ច យរ ៣៦:១២ ឆ យរ ១១:២១ ជ ១សយ ១៧:៣២ **៣៨:៥** ឈ យរ ២៦:១៤ ញ ១សយ ១៥:២៤ **៣៨:៦** ដ យរ ៣៧:២១ ឋ យស ២:១៥ ឌ លប ៣៧:២៤ ឍ យប ៣០:១៩ បទ ៣:៥៣ **៣៨:៧** ណ យរ ៣៩:១៦ ត អស ៥៦:៣-៥ កច ៨:២៧ ថ យប ២៩:៧ **៣៨:៩** ទ លប ៣៧:២០

**៣៧:២១** *ទុកនៅទីលានគុកវិញ* ក្រោយពីការចោទប្រកាន់ហើយ បន្ទាប់មកយកទៅដាក់ក្នុងគុកក្នុង ខ.១៦ (មើលការពន្យល់ ៣២:២) ។ *ពីផ្លូវនៃពួកដុតនំបុ័ងមកឱ្យលោករាល់ៗថ្ងៃ* ប្រហែលជានៅជិតទីក្រុងអូរិន (មើលការពន្យល់ ៣:១១) ។ *ដរាបដល់នំបុ័ងទាំងប៉ុន្មាននៅទីក្រុងបានអស់ហើយ* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ "នំបុ័ង" គឺបានបកប្រែថា "អាហារ" នៅក្នុង ៥២:៦) ។

**៣៨:១** *ផាសហើរ* មើលការពន្យល់ ២០:១ ។ យេហ៊ូកាល ជាកូនសេលេមា មើលការពន្យល់ ៣៧:៣ ។ ហើយផាសហើរ ជាកូនម៉ាលគា មើលការពន្យល់ ២១:១ ។ គេក៏ឮពាក្យយេរេមាប្រាប់ដល់បណ្តាជនទាំងឡាយ ទោះបីជាគាត់ជាប់នៅក្នុងគុកក្តី (មើល ៣៧:២១) គាត់ត្រូវគេបានអនុញ្ញាតឱ្យមានអ្នកមកសួរសុខទុក្ខគាត់ និងនិយាយដោយសេរីទៅកាន់គាត់ (សូមមើល ៣២:៨,១២) ។

**៣៨:២** រំឮកឡើងវិញនៅក្នុង ២១:៩ (មើលការពន្យល់នៅខាងលើ) ។

**៣៨:៣** រំឮកឡើងវិញនៅក្នុង ៣២:២៨ (មើល ៣៤:២ ៣៧:៨) ។

**៣៨:៤** *ដូច្នេះ ពួកចៅហ្វាយទាំងប៉ុន្មាន* ឈ្មោះទាំងនោះនៅក្នុង ខ.១ ។ ខ្សោយដៃទៅ មើល អគ ៤:៤ ន័យត្រង់ "ដៃដែលខ្សោយ" ដូចជានៅក្នុងស្ថានភាពមួយស្រដៀងគ្នា នៅក្នុងក្រុងឡាគីស អូស្ត្រាកនទី៦ (Lachish ostracon 6) (មើលការពន្យល់ ៣៤:៧) ពាក្យរបស់ពួកចៅហ្វាយ គឺមិនល្អនោះឡើយ គេបម្រើនៅពេលណាដែលដៃចុះខ្សោយ "ដោយខុសគ្នានៅក្នុង អស ៣៥:៣ ។ ស្វែងរកសេចក្តីល្អ ព្រះគម្ពីរភាសាហេព្រើរយ៉ាងសំខាន់ចំពោះឃ្លានេះ គឺបានបញ្ជាក់ថា "ស្វែងរកសន្តិភាព និងសេចក្តីសុខសាន្ត" នៅក្នុង ២៩:៧ (មើលការពន្យល់ក្នុងខនោះ) ។ *សេចក្តីល្អ . . . អន្តរាយ* ព្រះគម្ពីរភាសាហេព្រើរសំខាន់សម្រាប់ឃ្លានេះ គឺបានបកប្រែថា "សេចក្តីសុខសាន្ត . . . គ្រោះមហន្តរាយ" នៅក្នុង អស ៤៥:៧ ។

**៣៨:៥** *ដ្បិតស្តេចមិនអាចធ្វើអ្វី* មិនមែនដោយសាការដែលមិនមានលទ្ធភាព ឬមិនមានអំណាចនោះទេ ប៉ុន្តែដោយសាការភ្លេចភ្លាំង ទ្រង់ភ័យខ្លាចចំពោះពួកចៅហ្វាយរបស់ទ្រង់ (មើល ខ.២៥-២៦ មើលការពន្យល់ ៣៧:១៧ និងការពន្យល់) ។

**៣៨:៦** *គុកងងឹត* គឺជារណ្តៅមួយយ៉ាងជ្រៅ ដែលនៅខាងលើមានគំរបតូច (មើល ៣៧:១៦) ។ *ជាកូនហាម៉ាលេក* មើលការពន្យល់ ៣៦:២៦ ។ *រីឯនៅក្នុងគុកងងឹតនោះគ្មានទឹកទេ* ពួកចៅហ្វាយរបស់ស្តេចសេដេគា ចង់សម្លាប់លោកយេរេមា (មើល ខ.៤) ប៉ុន្តែគេមិនមែនចង់សម្លាប់ដោយសាដៃរបស់ពួកគេផ្ទាល់ (ធៀបនឹង លប ៣៧:២០-២៤) ។

**៣៨:៧** *កាលអេបេឌ-មេលេក* មានន័យថា "អ្នកបម្រើស្តេច" ។ *(គ្រានោះស្តេចកំពុងតែគង់នៅត្រង់ទ្វារបេនយ៉ាមីន)* មើល ៣៧:១៣ មើលការពន្យល់ សក ១៤:១០ ។ ច្រកទ្វារនោះគឺគេតែងតែបានប្រើសម្រាប់ជាទីផ្សា ឬសម្រាប់ជាសាលប្រជុំ (មើលការពន្យល់ លប ១៩:១ នរ ៤:១) ស្តេចសេដេគាបានសាងសង់ទីកន្លែងសម្រាប់ជំនុំជម្រះ ដោយស្របច្បាប់ខុសៗគ្នា នៅសម័យកាលនោះ (២សយ ១៥:២-៤) និងដើម្បីនឹងជួយដល់ការងារអេបេឌ-មេលេក ។

**៣៨:៩** ពីព្រោះគ្មានអាហារនៅក្នុងទីក្រុងទៀតទេ មើល ៣៧:២១ និងការពន្យល់ ។

ខានពីព្រោះគ្មានអាហារ[ធ]នៅក្នុងទីក្រុងទៀតទេ
១០ដូច្នេះ ស្តេចទ្រង់បង្គាប់អេបេឌ–មេលេក ជាសាសន៍អេធីយ៉ូពីថា ចូរនាំយកមនុស្ស៣០នាក់ពីទីនេះទៅជាមួយនឹងឯង ហើយស្រង់ហោរាយេរេមាចេញពីពកុកងងឹតមក ក្រែងលោកស្លាប់
១១អេបេឌ–មេលេកក៏នាំយកមនុស្សទាំងនោះទៅជាមួយចូលទៅខាងក្រោមឃ្លាំងក្នុងព្រះរាជវាំង ក៏យកកំណាត់ចាស់ៗ និងអាវរយ៉ើរយ៉ៃទៅសិរូតចុះ[ន]ដល់យេរេមានៅក្នុងគុកងងឹត
១២រួចអេបេឌ–មេលេក ជាសាសន៍អេធីយ៉ូពី ក៏ប្រាប់យេរេមាថា សូមទ្រាប់កំណាត់ចាស់នឹងអាវរយ៉ើរយ៉ៃទាំងនេះនៅក្រោម ក្លៀកលោកពីក្រោមខ្សែពួរទៅ យេរេមាក៏ធ្វើដូច្នោះ
១៣រួចគេយោងទាញយេរេមាឡើងរួចពី គុកងងឹតមក ហើយលោកបាននៅជាប់ក្នុងទីលានគុកវិញ[ប]។

## ស្តេចសេដេគាសួរលោកយេរេមាម្តងទៀត

១៤គ្រានោះ ស្តេចសេដេគាទ្រង់ចាត់[ផ]គេទៅនាំហោរាយេរេមាមកឯទ្រង់ នៅត្រង់ទ្វារទី៣ក្នុងព្រះវិហារនៃព្រះយេហូវ៉ា ស្តេចទ្រង់មានបន្ទូលដល់យេរេមាថា យើងចង់សួរបន្តិច កុំឱ្យលាក់[ព]អ្វីនឹងយើងឡើយ
១៥ដូច្នេះ យេរេមាលោកទូលដល់សេដេគាថា បើសិនជាទូលបង្គំទូលទ្រង់ឱ្យបានជ្រាប នោះតើទ្រង់មិនសំឡាប់ទូលបង្គំជាប្រាកដទេឬ ហើយបើទូលបង្គំទូន្មានទ្រង់ នោះទ្រង់ក៏មិនព្រមស្តាប់តាមដែរ
១៦នោះស្តេចសេដេគាទ្រង់ស្បថឱ្យយេរេមា ដោយសំងាត់[ភ]ថា ដូចជាព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់នៅ ដែលទ្រង់បានបង្កើតព្រលឹងឱ្យយើងនេះ[ម] នោះប្រាកដជាយើងមិនសំឡាប់ ឬប្រគល់អ្នកទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលរកជីវិតអ្នកឡើយ[យ]។
១៧រួចយេរេមាទូលដល់ស្តេចសេដេគាថា ព្រះយេហូវ៉ាជាព្រះនៃពួកពលបរិវារ គឺជាព្រះនៃសាសន៍អ៊ីស្រាអែលទ្រង់មានបន្ទូលដូច្នេះ បើទ្រង់យាងចេញទៅ[រ]ឯពួកចៅហ្វាយរបស់ស្តេចបាប៊ីឡូន នោះទ្រង់នឹងគង់ព្រះជន្មនៅ ហើយទីក្រុងនេះក៏មិនត្រូវដុតនឹងភ្លើងដែរ គឺទ្រង់នឹងពួកវង្សាទ្រង់នឹងបានរួចជីវិត[ល]
១៨ប៉ុន្តែបើទ្រង់មិនព្រមចេញទៅឯពួក ចៅហ្វាយរបស់ស្តេចបាប៊ីឡូនទេ នោះទីក្រុងនេះនឹងត្រូវប្រគល់[វ]ទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេ ហើយគេនឹងដុតចោល[ស] ឯទ្រង់ក៏មិនរួច[ហ]ពីកណ្តាប់ដៃគេដែរ
១៩ស្តេចសេដេគា ទ្រង់មានបន្ទូលនឹងយេរេមាថា យើងខ្លាច[ឡ]ពួកសាសន៍យូដា ដែលរវាតចូលទៅ[អ]ខាងពួកខាល់–ដេហើយក្រែងសាសន៍ខាល់ដេ ប្រគល់យើងទៅក្នុងកណ្តាប់ដៃគេហើយគេត្មះតិះដៀលយើង
២០តែយេរេមាទូលតបថា គេនឹងមិនប្រគល់ទ្រង់ទៅទេ ទូលបង្គំអង្វរទ្រង់ សូមស្តាប់[ក]ព្រះបន្ទូលនៃព្រះយេហូវ៉ា តាមសេចក្តីដែលទូលបង្គំទូលដល់ទ្រង់ចុះ នោះទ្រង់នឹងបានសេចក្តីសុខ[ខ] ហើយនឹងមានព្រះជន្ម[គ]នៅ
២១តែបើសិនជាទ្រង់មិនព្រមយាងចេញទៅទេ នោះព្រះយេហូវ៉ា ទ្រង់បានសំដែងសេចក្តីនេះមក ឱ្យទូលបង្គំឃើញថា
២២មើល ពួកស្រីៗ[ឃ]ទាំងប៉ុន្មាន ដែលសល់នៅក្នុងដំណាក់របស់ស្តេចយូដា នឹងត្រូវនាំចេញទៅឯពួកចៅ

**៣៨:៩** ធ យរ ៣៧:២១
**៣៨:១១** ន យស ២:១៥
**៣៨:១៣** ប យរ ៣៧:២១
**៣៨:១៤** ផ យរ ៣៧:៣ ព ១សយ ៣:១៧
**៣៨:១៦** ភ យរ ៣៧:១៧ ម អស ៤២:៥ ៥៧:១៦ យ ខ.៤
**៣៨:១៧** រ យរ ២៧:៨ ល យរ ២១:៩
**៣៨:១៨** វ ខ.៣ ស យរ ៣៧:៨ ហ យរ ២៤:៨ ៣២:៤
**៣៨:១៩** ឡ អស ៥១:១២ យហ ១២:៤២ អ យរ ៣៩:៩ ៥២:១៥
**៣៨:២០** ក យរ ១១:៤ ខ ចទ ៥:៣៣ យរ ៤០:៩ គ អស ៥៥:៣
**៣៨:២២** ឃ យរ ៦:១២

**៣៨:១០** *មនុស្ស៣០នាក់* ជាចំនួនធំដែលគេជឿថា គឺដើម្បីការពារថែរក្សាពួកចៅហ្វាយ (មើល ខ.៤) និងមិត្តភក្ដិរបស់គេ មកព្យាយាមការពារ ជួយសង្គ្រោះលោកយេរេមា ។

៣៨:១១ ចូលទៅក្នុងឃ្លាំងក្រោមក្នុងព្រះរាជវាំង ប្រហែលជាបន្ទប់សម្រាប់រក្សាទុកអីវ៉ាន់ (មើល ២ពវ ១០:២២) ។

**៣៨:១២** *សូមទ្រាប់កំណាត់ចាស់ និងអាវរយ៉ើរយ៉ៃទាំងនេះ* នេះជាសេចក្ដីសប្បុរសរបស់លោកអេបេឌ–មេលេក ចំពោះលោកយេរេមា គឺជាភស្ដុតាង ដែលគាត់បានទុកចិត្តដល់ព្រះអម្ចាស់ ហើយព្រះអម្ចាស់បានផ្ដល់ប្រទានរង្វាន់ដល់គាត់ (មើល ៣៩:១៥–១៨) ។

**៣៨:១៣** *ហើយលោកបាននៅជាប់ក្នុងទីលានគុកវិញ* មើលការពន្យល់ ៣២:២ ។

**៣៨:១៤–២៦** ការសម្ភាសចុងក្រោយរបស់លោកយេរេមាជាមួយនឹងស្ដេចសេដេគា ។

**៣៨:១៤** នៅត្រង់ទ្វារទី៣ មានតែបញ្ជាក់នៅក្នុងខនេះ ប្រហែលជាដំណើរឯកជនរបស់ស្ដេចទៅឯព្រះវិហារ ។ ចង់សួរបន្តិច . . . កុំលាក់អ្វីនឹងយើង ន័យត្រង់ "ពាក្យ . . . ពាក្យ ឃ្លានេះគេជឿថានិយាយសំដៅទៅលើ "ព្រះបន្ទូលមកពីព្រះអម្ចាស់ (មើល ៣៧:១៧) ។

**៣៨:១៦** *ដូចជាព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់នៅ* មើលការពន្យល់ លប ៤២:១៥ ។ ឬប្រគល់អ្នកទៅក្នុងកណ្ដាប់ដៃនៃពួកអ្នកដែលរកជីវិតអ្នកឡើយ ពួកចៅហ្វាយ (មើល ខ.៤ និងការពន្យល់) ។

**៣៨:១៧–១៨** មើល ខ.២–៣ ២១:៩–១០ ៣២:៣–៤ ៣៤:២–៥ ។ *មិនព្រមចេញទៅឯ* ន័យត្រង់ "ចេញទៅ" (មើល ២ពវ ១៨:៣១ ២៤:១២) ។ *ប្រគល់ទៅក្នុងកណ្ដាប់ដៃនៃពួកខាល់ដេ* អស់អ្នកទទួលខុសត្រូវចំពោះការឡោមព័ទ្ធក្រុងយេរូសាឡិម (មើល ៣៩:៣,១៣) ។

**៣៨:១៩** *យើងខ្លាច* មើល ខ.៥ និងការពន្យល់ ។ ប្រសិនបើស្ដេចសេដេគាបានទុកចិត្តដល់ព្រះអម្ចាស់ នោះទ្រង់មិនត្រូវភ័យខ្លាចដល់ពួកចៅហ្វាយដទៃទៀតឡើយ ឬធ្វើដូចជាអ្នករត់ចោលជួរនោះឡើយ (មើល សភ ២៩:២៥ និងការពន្យល់) ។ *ដែលវាចូលទៅខាងពួកខាល់ដេរហើយ* មើល ៣៧:១៣ និងការពន្យល់ ។ *គេត្មះតិះដៀលយើង* គេប្រើអំពើហឹង្សាលើខ្ញុំ (មើល ពច ១៩:២៥ ១រប ១០:៤) ។

**៣៨:២២** *មើល ពួកស្រីៗ . . . ក្នុងដំណាក់នឹងត្រូវនាំចេញទៅឯពួកចៅហ្វាយរបស់ពួកបាប៊ីឡូន* ពួកស្រីៗ នៅក្នុងដំណាក់ស្រីស្នំរបស់ស្ដេច ដែលបានច្បាំងឈ្នះពីសង្គ្រាម បានក្លាយទៅជាទ្រព្យសម្បត្តិរបស់អ្នកឈ្នះ (ធៀបនឹង ២សយ ១៦:២១–២២) ។ *ពួកជិតរបស់ទ្រង់បានបញ្ឆោតទ្រង់ ហើយក៏*

ហ្វាយរបស់ស្ដេចបាប៊ីឡូន ហើយស្រីៗទាំងនោះនឹងពោល
ថា ពួកជិនិត[ង]របស់ទ្រង់បានបញ្ឆោតទ្រង់ ហើយក៏ឈ្នះ
ទ្រង់ផង ឥឡូវនេះ ដែលព្រះបាទទ្រង់ផុងជាប់ទៅក្នុងភក់
ហើយ[ច] នោះគេបានងាកចេញពីទ្រង់ទៅ ២៣គេនឹងនាំ
ភរិយា និងព្រះរាជបុត្រ[ឆ]របស់ទ្រង់ទាំងប៉ុន្មាន ចេញទៅ
ឯពួកខាល់ដេ ហើយអង្គទ្រង់ក៏មិនរួច[ជ]ពីកណ្ដាប់ដៃគេដែរ
គឺដៃស្ដេចបាប៊ីឡូននឹងចាប់ទ្រង់បាន[ឈ] ហើយទ្រង់នឹងជា
ហេតុឱ្យទីក្រុងនេះត្រូវឆេះដោយភ្លើង[ញ] ។
២៤នោះសេដេគា ទ្រង់មានបន្ទូលដល់យេរេមាថា កុំឱ្យ
អ្នកណាដឹង[ដ]ពីពាក្យទាំងនេះឡើយ នោះអ្នកមិនត្រូវស្លាប់ទេ
២៥ប៉ុន្តែបើពួកចៅហ្វាយឮថា យើងបាននិយាយនឹងអ្នក
ហើយគេមកឯអ្នកដោយពាក្យថា ចូរប្រាប់យើងពីសេចក្ដី
ដែលអ្នកបានទូលដល់ស្ដេចមក កុំឱ្យលាក់អ្វីពីយើងឱ្យសោះ
នោះយើងនឹងមិនឱ្យអ្នកត្រូវស្លាប់ទេ ហើយប្រាប់យើង
ពីសេចក្ដីដែលស្ដេចបានមានបន្ទូលដល់អ្នកដែរ ២៦យ៉ាង
នោះត្រូវឱ្យអ្នកប្រាប់[ឋ]ដល់គេថា ខ្ញុំបានគ្រាន់តែទូលអង្វរ
ស្ដេច សូមកុំឱ្យខ្ញុំត្រូវវិលត្រឡប់ទៅក្នុងផ្ទះ[ឌ]យ៉ូណាថាន ឱ្យ
ស្លាប់នៅទីនោះប៉ុណ្ណោះទេ ២៧រួចមកពួក ចៅហ្វាយទាំង
ប៉ុន្មាន ក៏មកឯយេរេមាសួរយ៉ាងនោះមែន ហើយលោក
ប្រាប់គេតាមគ្រប់ទាំងពាក្យដែលស្ដេចបានបង្គាប់មក
ដូច្នេះ គេក៏លែងនិយាយនឹងលោកទៅ ពីព្រោះការនោះ

**៣៨:២២** ង យប ១៩:១៤ យរ ១៣:២១ ច យប ៣០:១៩ ទដ ៦៩:១៤
**៣៨:២៣** ឆ ២ពវ ២៥:៦ ជ យរ ៣២:៤ អគ ១៧:១៥ ឈ យរ ២៤:៨ ញ យរ ២១:១០ ៣៧:៨
**៣៨:២៤** ដ យរ ៣៧:១៧
**៣៨:២៦** ឋ ១សយ ១៦:២ ឌ យរ ៣៧:១៥
**៣៨:២៨** ឍ យរ ៣៧:២១ ណ យរ ២៥:២៩
**៣៩:១** ក ២របា ៣៦:១១ ខ ២ពវ ២៤:១ យរ ២៨:១៤ គ ២ពវ ២៥:១ យរ ៥២:៤ អគ ៤:៣ ២៤:២
**៣៩:២** ឃ សក ៨:១៩ ង ២ពវ ១៤:១៣ ច អគ

មិនបានបើកឱ្យគេឃើញទេ ២៨ឯយេរេមា លោកក៏នៅជាប់
ក្នុងទីលានគុក[ឍ] ដរាបដល់ថ្ងៃដែលគេចាប់យកក្រុងយេរូ-
សាឡិម[ណ]បាន ឯវេលាដែលគេចាប់យកទីក្រុងបាននោះ
លោកនៅទីនោះនៅឡើយ ។

## ការដួលរលំទីក្រុងយេរូសាឡិម

*៣៩:១-១០ – ២ពវ ២៥:១-១២ យរ ៥២:៤-១៦*

**៣៩** ១រីឯនៅខែបុស្ស ឆ្នាំទី៩នៃរាជ្យសេដេគា[ក] ស្ដេច
យូដា នោះនេប៊ូក្នេសា[ខ] ជាស្ដេចបាប៊ីឡូន និងពលទ័ពទ្រង់
ទាំងអស់ ក៏មកឡោមព័ទ្ធច្បាំង[គ]នឹងក្រុងយេរូសាឡិម
២ហើយនៅថ្ងៃ៩ ខែអាសាធ[ឃ] ឆ្នាំទី១១ នៃរាជ្យសេដេគា
នោះគេបំបែកទំលាយកំផែង[ង]ទីក្រុងបានហើយ[ច] ៣រួច
ពួកចៅហ្វាយ[ឆ]របស់ស្ដេចបាប៊ីឡូនទាំងប៉ុន្មាន ក៏ចូលមក
អង្គុយនៅទ្រង់ទ្វារជាន់កណ្ដាល គឺមាននេកាល-សារេ
សើរ១ សាំកា-នេបូរ១ សាសេគិម១ រ៉ាប-សារីស១
នេកាល-សារេសើរ១ ហើយរ៉ាប-ម៉ាក់១ ព្រមទាំងពួក
ចៅហ្វាយរបស់ស្ដេចបាប៊ីឡូនឯទៀតទាំងប៉ុន្មានផង ។
៤កាលសេដេគា ជាស្ដេចយូដា និងពួកទាហានទាំង
ប៉ុន្មានបានឃើញគេ នោះក៏រត់ចេញពីទីក្រុង ទៅទាំងយប់
តាមផ្លូវសួនច្បាររបស់ស្ដេច ដែលចេញតាមទ្វារនៅ
កណ្ដាលកំផែងទាំង២[ជ] ទ្រង់ចេញដំរង់ទៅឯស្រុកវាល[ឈ]

៣៣:២១ **៣៩:៣** ឆ ខ.១៣ យរ ២១:៤ **៣៩:៤** ជ អស ២២:១១ ឈ អគ ១២:១២

*ឈ្នះទ្រង់ផង* រំឮកពាក្យទាំងនោះឡើងវិញនៅក្នុង អប ៧ (មើល ២០:១០ និងការពន្យល់) ។ ស្ដេចសេដេគាបានហៅមិត្តភ័ក្រទ្រង់ ឱ្យធ្វើជាពួកចៅហ្វាយ (មើល ខ.៤) និងហោរាខុសឆ្គង (មើល ៣៧:១៩) ។ *ដែលព្រះបាទទ្រង់ផុងជាប់នៅក្នុងភក់ហើយ* និម្មិតរូបពីការឈឺចាប់យ៉ាងខ្លាំងបំផុត (មើល ទដ ៦៩:១៤) ។

**៣៨:២៦** មើល ៣៧:២០ ។ *ទៅក្នុងផ្ទះយ៉ូណាថាន* មើល ៣៧:១៥ និងការពន្យល់ ។

**៣៨:២៧** *ហើយលោកប្រាប់គេតាមគ្រប់ទាំងពាក្យ ដែលស្ដេចបានបង្គាប់មក* លោកយេរេមាមិនបានតំរូវឱ្យផ្ដល់ព័តមាន ដល់ពួកចៅហ្វាយទាំងនោះទេ គាត់បាននិយាយដោយមានជំនឿជឿជាក់ ។

**៣៨:២៨** *ឯយេរេមាក៏នៅជាប់នៅទីលានគុក* មើលខ.១៣ មើលការពន្យល់ ៣២:២ ។

**៣៩:១-៤៥:៥** ដំណើររឿងដ៏សំខាន់នៅសញ្ញាចាស់ អំពីពួកខាល់ដេច្បាំងដណ្ដើមយកក្រុងយេរូសាឡិម និងលទ្ធផលដែលបានទទួល ។ នៅក្នុងផ្នែកនេះរួមទាំងការសង្ខេបនៅក្នុង (ជំពូក ៤៥) ។

**៣៩:១-១០** ការសង្ខេបយ៉ាងខ្លី អំពីការឡោមព័ទ្ធ និងការដួលរលំនៃក្រុងយេរូសាឡិម និងការនិរទេសរបស់ពួកអ្នកស្រុក (មើល ៥២:៤-២៧) ។

**៣៩:១-២** សង្ខេបនៅក្នុង ៥២:៤-៧ក. ។

**៣៩:១** *រីឯនៅខែបុស្ស ឆ្នាំទី៩នៃរាជ្យសេដេគា* ការឡោមព័ទ្ធចុងក្រោយរបស់ក្រុងយេរូសាឡិម បានចាប់ផ្ដើមនៅថ្ងៃទី១០នៃដើមខែ (មើល ៥២:៤ ២ពវ ២៥:១ អគ ២៤:១-២) ឬនៅថ្ងៃទី១៥ ខែមករា ឆ្នាំ ៥៨៨ គ.ស ។

**៣៩:២** *ហើយនៅថ្ងៃទី៩ ខែអាសាធ ឆ្នាំទី១១* នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ៥៨៦ គ.ស (មើល ៥២:៥-៦ ២ពវប ២៥:២-៣) ។ ការឡោមព័ទ្ធចុងក្រោយនៅក្នុងកំឡុងរយៈពេល២ឆ្នាំកន្លះ ។

**៣៩:៣** *ក៏ចូលមកអង្គុយនៅត្រង់ទ្វារជាន់កណ្ដាល* បានបំពេញនៅក្នុង ១:១៥ ទ្វារកណ្ដាលប្រហែលជាមានទីតាំងនៅកន្លែងទ្វារ ដែលនៅចន្លោះភ្នំស៊ីយ៉ូននៅទីក្រុងទំនាប ដែលបំរើដូចជាទីកន្លែងយុទ្ធសាស្ត្រដ៏ខ្ពស់ សម្រាប់ពួកអ្នកឈ្លានពាន ។ នេកាល-សារេសសើរ មានន័យថា "ព្រះនេកាល មើល ២ពវ ១៧:៣០ ការពារស្ដេច ។ ជាឈ្មោះបុរសម្នាក់ ក្នុងចំណោមបុរស២នាក់ (មើលខ.១៣) ដែលគេជឿថា នេរីលីសា (Neriglissar) ពេលក្រោយមកបានក្លាយជាអ្នកជោគជ័យ របស់ស្ដេចនេប៊ូក្នេសា ជាអ្នកគ្រប់គ្រងនៅក្រុងបាប៊ីឡូន (ឆ្នាំ៥៦០-៥៥៦ មុនគ.ស) ។ *ពួកចៅហ្វាយ* មើលខ.១៣ ព្រះគម្ពីរភាសាហេព្រើរសម្រាប់ឃ្លានេះ បញ្ជាក់ពីពួកបាប៊ីឡូនដូជា រ៉ាប់ម៉ូនជី (Rabmungi) មន្ត្រីជាន់ខ្ពស់ ជួនកាលបានបម្រើដូចជា ទូតដែលគ្រប់គ្រងលើសាសន៍ដទៃ ។

**៣៩:៤-៧** មើល ៥២:៧-១១ មើលការពន្យល់ ២ពវ ២៥:៤-៧ និងការពន្យល់ ។

**៣៩:៤** *ទៅឯស្រុកវាល* មើលការពន្យល់ ចទ ១:១ ។

៥តែពលទ័ពសាសន៍ខាល់ដេ ក៏ដេញតាមសេដេគា[ញ]ទាន់
នៅត្រង់វាលយេរីខូរ កាលគេចាប់[ដ]ទ្រង់បានហើយ នោះ
ក៏នាំទៅឯនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ត្រង់រីបឡា[ឋ] នៅ
ស្រុកហាម៉ាត ហើយនេប៊ូក្នេសាក៏កាត់ទោសទ្រង់ ៦រួចស្តេច
បាប៊ីឡូនទ្រង់សំឡាប់ពួកបុត្រារបស់សេដេគា នៅចំពោះ
ព្រះនេត្រទ្រង់ត្រង់រីបឡានោះ ក៏សំឡាប់ពួកអ្នកមាន
ត្រកូលខ្ពស់[ឌ]ទាំងប៉ុន្មាននៃស្រុកយូដាដែរ ៧ហើយចាក់
បង្ខូចព្រះនេត្រ[ឍ]របស់សេដេគា រួចដាក់ច្រវាក់ដឹកនាំទៅ
ឯស្រុកបាប៊ីឡូន[ណ] ៨ពួកខាល់ដេក៏ដុត[ត]ព្រះរាជវាំង និងផ្ទះ
ទាំងប៉ុន្មានរបស់បណ្តាជនចោល ព្រមទាំងរំលំកំផែង[ថ]
ស្រុកយេរូសាឡិមផង ៩រួចមកនេប៊ូសារ៉ាដាន ជាមេទ័ពធំ
លោកដឹកនាំសំណល់ពួកបណ្តាជនដែលនៅក្នុងទីក្រុង និង
ពួកអ្នកដែលរវាតទៅខាងលោក[ទ] ព្រមទាំងសំណល់នៃ
ប្រជាជនទាំងឡាយទៅជាឈ្លើយ ដល់ស្រុកបាប៊ីឡូន[ធ] ១០តែ
នេប៊ូសារ៉ាដាន ជាមេទ័ពធំ លោកទុកពួកអ្នកក្រីក្រក្នុង
បណ្តាជន ជាពួកអ្នកដែលគ្មានអ្វីសោះ ឱ្យនៅក្នុងស្រុក
យូដា ហើយនៅគ្រានោះក៏ចែកដំណាំទំពាំងបាយជូរ និង
ចំការឱ្យដល់គេផង ។

១១រីឯនេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ទ្រង់បានបង្គាប់
នេប៊ូសារ៉ាដាន ជាមេទ័ពធំ ពីដំណើរយេរេមាថា ១២ចូរ
យកយេរេមាទៅទំនុកបំរុងដោយល្អផង កុំឱ្យធ្វើបាប[ន]ដល់
លោកឡើយ គឺត្រូវឱ្យប្រព្រឹត្តនឹងលោកតាមដែលលោក
ប្រាប់ចុះ ១៣ដូច្នេះ នេប៊ូសារ៉ាដាន ជាមេទ័ពធំ ហើយ
នេប៊ូសាសបាន រ៉ាប- សារីស នើកាល-សារេសើរ រាប-
ម៉ាក់ ព្រមទាំងចៅហ្វាយ[ប]ធំៗទាំងអស់របស់ស្តេចបាប៊ីឡូន
១៤ក៏ចាត់គេឱ្យទៅយកយេរេមាពីទីលានគុកមក[ផ] ប្រគល់
ដល់កេដាលា[ព] ជាកូនអ័ហ៊ីកាម[ភ] ដែលជាកូនសាផាន[ម] ឱ្យ
បាននាំលោកទៅឯផ្ទះខ្លួន យ៉ាងនោះលោកបាននៅជាមួយ
នឹងពួកជន[យ] ។

១៥រីឯកាលយេរេមាកំពុងជាប់នៅក្នុងទីលានគុកនៅ
ឡើយ នោះព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់លោកថា
១៦ចូរទៅប្រាប់អេបេឌ-មេលេក[រ] ជាសាសន៍អេធីយ៉ូពី
ដូច្នេះគឺថាព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ មើល អញនឹងនាំអស់
ទាំងពាក្យ[ល]របស់អញមកលើក្រុងនេះ ឱ្យបានសេចក្តី
អាក្រក់[វ]មិនមែនជាសេចក្តីល្អទេ ពាក្យទាំងនោះនឹងបាន
សំរេចនៅមុខឯងក្នុងថ្ងៃនោះ ១៧តែព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា អញនឹងជួយ[ស]ឯងឱ្យរួចនៅថ្ងៃនោះ ហើយឯង
មិនត្រូវប្រគល់ទៅក្នុងកណ្តាប់ដៃនៃពួកមនុស្សនោះ ដែល
ឯងខ្លាចឡើយ ១៨ដ្បិតអញនឹងជួយសង្គ្រោះ[ហ]ឯងជាពិត
ឯងមិនត្រូវដួលដោយដាវ[ឡ]ឡើយ គឺនឹងបានជីវិតទុកដូច
ជារបឹបរិញ[អ] ពីព្រោះឯងបាន យកអញជាទីទុកចិត្ត[ក]នេះ
ជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## លោកយេរេមាត្រូវបានដោះលែង

**៤០** ១នេះជាព្រះបន្ទូល ដែលមកពីព្រះយេហូវ៉ា ដល់
យេរេមា ក្រោយដែលនេប៊ូសារ៉ាដានជាមេទ័ពធំបាន
លែងលោកនៅត្រង់រ៉ាម៉ាហើយ[ក] ក្នុងកាលដែលគេបាន

**៣៩:៥** ញ យរ ២៤:៨ ៣២:៤ ដ យរ ២១:៧ ឋ ជន ៣៤:១១ **៣៩:៦** ឌ អស ៣៤:១២ **៣៩:៧** ឍ ជន ១៦:១៤ អក ១២:១៣ ណ យរ ២:៣៥ **៣៩:៨** ត យរ ៣៤:២២ ថ នហ ១:៣ ទដ ៨០:១២ អស ២២:៥ បទ ២:៨ **៣៩:៩** ទ យរ ២១:៩ ធ យរ ៤០:១ បទ ១:៥ **៣៩:១២** ន សភ ១៦:៧ យរ ១៥:២០ –២១ ១ពត ៣:១៣ **៣៩:១៣** ប ខ.៣ **៣៩:១៤** ផ នហ ៣:២៥ យរ ៣៧:២១ ព ២ពវ ២៥:២២ ភ ២ពវ ២២:១២ ម ២ពវ ២២:៣ យ យរ ៤០:៥ **៣៩:១៦** រ យរ ៣៨:៧ ល ទដ ៣៣:១១ អស ១៤:២៧ ៤០:៨ យរ ៤៤:២៨ បទ ២:១៧ មថ ១:២២

វ យស ២៣:១៥ យរ ២១:១០ **៣៩:១៧** ស ទដ ៣៤:២២ ៤១:១-២ **៣៩:១៨** ហ ១សយ ១៧:៤៧ កច ១៦:៣១ ឡ យប ៥:២០ អ យរ ២១:៩ ៣៨:២ ក យរ ១៧:៧ រម ១០:១១ **៤០:១** ក យស ១៨:២៥ ១សយ ៨:៤ មថ ២:១៨

**៣៩:៥** *ត្រង់* ព្រះគម្ពីរភាសាហេព្រើរសម្រាប់ពាក្យនេះ គឺជាពាក្យពហុវចនៈ "ត្រង់" (ខ.៤) ។

**៣៩:៨-១០** មើល ៥២:១២-១៦ មើលចទ ២ពវ ២៥:៨-១២ និងការពន្យល់ ។

**៣៩:១២** *ទំនុកបំរុងឱ្យល្អផង* មើលការពន្យល់ ៤០:៤ ។

**៣៩:១៤** *ក៏ចាត់គេឱ្យទៅយកលោកយេរេមាពីទីលានគុក* តាមន័យនេះ (១).ការសង្ខេបពីការរំដោះលោកយេរេមាចេញពីគុក ការពន្យល់យ៉ាងលំអិត គឺមាននៅក្នុង ៤០:១-៦ ។ (២).ការពណ៌នាយ៉ាងសង្ខេបអំពីការដោះលែង២លើកមុនគេ ហើយលើកទី២ គឺជាការចាំបាច់ ពីព្រោះលោកយេរេមា ត្រូវបានចាប់ម្តងទៀត ដោយសារកំហុសមួយ ដែលគេយល់ច្រលំពីរឿងចាប់ចង និងការធ្វើដំណើរដល់ពួកអ្នកចាប់ជាឈ្លើយរាប់ពាន់អ្នកដោយលំអិតនៅក្នុង ៤០:១-៦ ។ *ទីលានគុក* មើលការពន្យល់ ៣២:២ ។ *កេដាលា ជាកូនអ័ហ៊ីកាម ដែលជាកូនសាផាន* មើលការពន្យល់ ២៦:២៤ ។ *ផ្ទះខ្លួន* លំនៅដ្ឋានរបស់អ្នកគ្រប់គ្រងនៅដើមសតវត្សទី៦ ដែលបានរកឃើញនៅក្រុងឡាគីស សូមអានឃ្លានេះ កម្មសិទ្ធិរបស់លោកកេដាលា ដែលគេជឿថា ជាឈ្មោះរបស់បុរសម្នាក់នៅក្នុងខនេះ ដែលជាម្ចាស់ផ្ទះនេះ ។

**៣៩:១៥-១៨** មើលការពន្យល់ ៣៨:១២ ។

**៣៩:១៦** *ចូរទៅប្រាប់* ទោះបីជាគាត់បានជាប់នៅទីឃុំឃាំងក្តី នោះលោកយេរេមាត្រូវបានអនុញ្ញាត្តិ ឱ្យមានអ្នកមកសួរសុខទុក្ខ (មើលការពន្យល់ ៣៨:១) ។ *មើលអញនឹងនាំអស់ទាំងពាក្យរបស់អញមកលើក្រុងនេះ* មើល ១៩:១៥ ។

**៣៩:១៧** *ដែលឯងខ្លាចឡើយ* ជាកន្លែងកាត់ក្តីពួកចៅហ្វាយ (មើល ៣៨:១) ចំពោះការជំនុំជម្រះលោកអេបេឌ-មេលេក "គេបានប្រព្រឹត្តយ៉ាអាក្រក់" (៣៨:៩) ។

**៣៩:១៨** *ជួយសង្គ្រោះឯងជាពិត* មើលការពន្យល់២១:៩ ។ *ឯងបានយកអញជាទីទុកចិត្ត* លោកអេបេឌ-មេលេក បានសម្តែងសេចក្តីជំនឿរបស់គាត់ចំពោះព្រះ ដោយបានជួយសង្គ្រោះលោកយេរេមាចេញពីគុក (មើល ៣៨:៧-១៣ មើលការពន្យល់ ៣៨:១២) ។

**៤០:១-៤៤:៣០** ជាវគ្គមានជាបែបដ៏រស់រវើក ដែលជាលទ្ធផលនៃការធ្លាក់ចុះរបស់ក្រុងយេរូសាឡិម ។ គឺជារយៈពេលកាលប្រវត្តិមួយ ដែល

ចាប់លោកដាក់ច្រវាក់ ជាមួយនឹងពួកក្រុងយេរូសាឡិមនឹង
ពួកស្រុកយូដាទាំងប៉ុន្មាន[ខ] ដែលគេដឹកជាឈ្លើយទៅឯ
ស្រុកបាប៊ីឡូននោះ ២មេទ័ពធំ[គ]ក៏យកយេរេមាមកនិយាយ
ថា ព្រះយេហូវ៉ា ជាព្រះនៃអ្នក ទ្រង់បានប្រកាស[ឃ]សេចក្ដី
អាក្រក់[ង]នេះទំលាក់លើទីនេះ[ច] ៣ហើយព្រះយេហូវ៉ាបាន
នាំការនេះមក ព្រមទាំងសំរេចតាមព្រះបន្ទូលទ្រង់ផង
ពីព្រោះឯងរាល់គ្នាបានធ្វើបាប[ឆ]នឹងទ្រង់ ហើយមិនបាន
ស្តាប់តាម[ជ]ព្រះបន្ទូលទ្រង់ឡើយ ហេតុនោះបានជាការនេះ
កើតដល់ឯងរាល់គ្នា ៤ដូច្នេះមើល នៅថ្ងៃនេះខ្ញុំដោះ[ឈ]
ច្រវាក់[ញ]ពីដៃអ្នកចេញ បើសិនជាអ្នកចូលចិត្តទៅឯស្រុក
បាប៊ីឡូនជាមួយនឹងខ្ញុំ ក៏ចូលមកចុះ ខ្ញុំនឹងទំនុកបំរុងអ្នក
ដោយល្អ តែបើមិនគាប់ចិត្តនឹងទៅឯស្រុកបាប៊ីឡូនជាមួយ
នឹងខ្ញុំទេ នោះតាមតែចិត្តចុះ មើល ស្រុកទាំងមូលនៅមុខ
អ្នកហើយ នៅកន្លែងណាដែលអ្នកគិតឃើញថាស្រួល
ហើយគួរឱ្យអ្នកទៅ នោះឱ្យអ្នកទៅចុះ[ដ] ៥រីឯកាលលោក
កំពុងកន្ទុះរានៅឡើយ នោះមេទ័ពធំប្រាប់ថា ចូរអ្នកវិល
ទៅឯកេដាលា[ឋ]ជាកូនអ័ហ៊ីកាម[ឌ]ដែលជាកូនសាផាន ជាអ្នក
ដែលស្តេចបាប៊ីឡូនបានតាំង[ឍ] ឱ្យត្រួតត្រាលើទីក្រុង[ណ]ស្រុក
យូដាទាំងប៉ុន្មាន ហើយឱ្យនៅជាមួយនឹងលោកកណ្តាល
បណ្តាជនចុះ ឬឱ្យទៅឯកន្លែងណា តាមដែលចិត្តគិតឃើញ
ថាគួរ[ត] នោះមេទ័ពធំ ក៏ចែកស្បៀងអាហារឱ្យ ព្រមទាំងឱ្យ
រង្វាន់[ថ]រួចលែងឱ្យទៅ ៦ដូច្នេះ យេរេមាក៏ទៅឯកេដាលា
ជាកូនអ័ហ៊ីកាមនៅត្រង់មីសប៉ា[ទ] ហើយអាស្រ័យនៅជាមួយ
នៅកណ្តាលបណ្តាជនដែលសល់នៅក្នុងស្រុក ។

## កេដាលាត្រូវគេធ្វើឃាត

*៤០:៧-៩ ៤១:១-៣ – ២ពវ ២៥:២២-២៦*

៧រីឯពួកមេទ័ពទាំងប៉ុន្មាន ដែលពួននៅស្រុកស្រែចំ
ការព្រមទាំងពួកទាហានរបស់គេ កាលបានឮថា ស្តេច
បាប៊ីឡូនបានតាំងកេដាលា ជាកូនអ័ហ៊ីកាមឡើងជាចៅ
ហ្វាយ[ធ]លើស្រុក ហើយបានផ្ទុកផ្តាក់មនុស្សទាំងប្រុសទាំង
ស្រី និងកូនក្មេងជាអ្នកក្រីក្របំផុត[ន]ក្នុងស្រុក ដែលមិនបាន
ដឹកទៅជាឈ្លើយ ដល់ស្រុកបាប៊ីឡូន ឱ្យនៅក្នុងអំណាច
លោក ៨នោះគេក៏មកឯកេដាលា ត្រង់មីសប៉ា[ប] គឺមាន
អ៊ីសម៉ាអែល[ផ] ជាកូននេថានា យ៉ូហាណាន និងយ៉ូណាថាន[ព]
ជាកូនការា សេរ៉ាយ៉ា ជាកូនថានហ៊ូមែត និងពួកកូនរបស់
អេផាយពីស្រុកនថូផា[ភ] ហើយយេសានា ជាកូនរបស់ម្នាក់
នៅម៉ាកាធី[ម] ព្រមទាំងពួកទាហានរបស់គេផង ៩នោះ
កេដាលា ជាកូនអ័ហ៊ីកាម ដែលជាកូនសាផាន ក៏ស្បថនឹង
មេទ័ពទាំងនោះ ហើយនឹងទាហានរបស់គេ ដោយពាក្យថា
កុំឱ្យខ្លាចនឹងបំរើ[យ]ពួកខាល់ដេឡើយ[រ] ចូរអាស្រ័យនៅក្នុង
ស្រុកនេះ ហើយបំរើដល់ស្តេចបាប៊ីឡូនចុះ នោះអ្នករាល់
គ្នានឹងបានសេចក្តីសុខ[ល] ១០ឯចំណែកខ្ញុំ មើល ខ្ញុំនឹងនៅត្រង់
មីសប៉ា[វ] ដើម្បីនឹងធ្វើជាអ្នកដំណាង នៅមុខពួកខាល់ដេណា
ដែលនឹងមកឯយើងរាល់គ្នា តែអ្នករាល់គ្នាវិញ ចូរទៅ
ប្រមូលផលទំពាំងបាយជូរ[ស]និងផលរដូវក្តៅព្រមទាំងប្រេង
ដាក់ទុក ក្នុងភាជនៈរបស់អ្នករាល់គ្នាទៅ[ហ] ហើយឱ្យនៅក្នុង
ទីក្រុងទាំងប៉ុន្មាន ដែលអ្នករាល់គ្នាចាប់បាននោះ[ឡ] ១១មួយ
ទៀត ពួកយូដាទាំងប៉ុន្មាន ដែលនៅស្រុកម៉ូអាប់[អ] និងនៅ

**៤០:១** ខ ចទ ២១:១០ ២ពវ ២៤:១ ២របា ៣៦:១០ ណហ ៣:១០ **៤០:២** គ រម ១៣:៤ ឃ អស ១០:២២ ង ២របា ៣៤:២៤ ទដ ១៨:១៨ សភ ៨:៣៦ កទ ៦:៧-៨ ច យស ២៣:១៥ **៤០:៣** ឆ សភ ១៣:២១ រម ៦:២៣ យស ១:១៥ ជ លវ ២៦:៣៣ ចទ ២៨:៤៥-៥២ ២៩:២៤-២៨ ៣១:១៧-១៨ ១ពវ ៩:៩ យរ ២២:៨-៩ ដយ ៩:១៤ កច ៧:៣៩ រម ២:៥-៩ **៤០:៤** ឈ ទដ ១០៥:១៨-២០ យរ ៣៧:១៤ ញ បទ ៣:៧ ដ លប ១៣:៩ **៤០:៥** ឋ ២ពវ ២៥:២២ ឌ ២ពវ ២២:១២-១៤ ឍ នហ ៥:១៤ យរ ៤១:២ ណ យរ ៤៤:២ សក ១:១២ ត យរ ៣៩:១៤ ថ លប ៣២:២០ ១សយ ៩:៧ **៤០:៦** ទ ខ.១០ ពច ២០:១ ១សយ ៧:៥-១៧ **៤០:៧** ធ លប ៤១:៤១ នហ ៥:១៤ ន ២ពវ ២៤:១៤ កច ២៤:១៧ យក ២:៥ **៤០:៨** ប ខ.១៣ ផ ខ.១៤ យរ ៤១:១,២ ព ខ.១៥ យរ ៤១:១១ ភ ២សយ ២៣:២៨ ម ចទ ៣:១៤ **៤០:៩** យ យរ ៥:១៩ ២៧:១១ រម ១៣:១-២ អភ ៦:៥-៨ រ អក ២៣:២៣ ល យរ ៣៨:២០ បទ ១:១ **៤០:១០** វ ខ.៦ ស លប ២៧:២៨ ហ នក ៧:១៩ ២កច ៤:៧ ឡ ចទ ១:៣៩ **៤០:១១** អ ជន ២១:១១ ២៥:១

បង្ហាញពីប្រវត្តិសាស្ត្រនាសម័យនោះ គឺមានក្នុងជំពូកមួយចំនួន ជាជំពូកចុងក្រោយក្នុងកណ្ឌគម្ពីរនេះ (ទោះជា ៥២:៣១-៣៤ គឺជាជំពូកចុងក្រោយ) ។

**៤០:១** *ព្រះបន្ទូលមកពី* គឺជាសេចក្តីផ្តើមពីចំណងជើង នៃទំនាយរបស់ហោរាយេរេមា បន្ទាប់ពីការធ្វើនិរទេសដូចជា "ព្រះបន្ទូល . . . មក" (១:២) បានណែនាំពីភាពជាហោរារបស់គាត់ គឺជារយៈពេលកេណ្ឌទៅឱ្យជាប់ជាឈ្លើយ (សូមមើល ១:៣) ។ *នេប៊ូសារ៉ាដាន . . . បានលែងលោក* សូមមើលការពន្យល់ ៣៩:១៤ ។ *រ៉ាម៉ា* ជាឈ្មោះទីកន្លែងមួយស្ថិតត្រង់កន្លែងតាមបណ្តោយផ្លូវទៅឯស្រុកបាប៊ីឡូន ជាកន្លែងដែលគេលែងលោកយេរេមា សូមមើលការពន្យល់ ៣១:១៥ ។ *ដាក់ច្រវាក់* គឺសម្រាប់ចងនៅកដៃ (សូមមើល ខ.៤ និង យប ៣៦:៨ អស ៤៥:១៤) ។

**៤០:២-៣** នេប៊ូសារ៉ាដាន ជាពាក្យមាតិការរឿងសំខាន់នៃសាលិខិតហោរាយេរេមាប្រឆាំងនឹងក្រុងយេរូសាឡិម ហើយអត្ថបទនេះក៏បាននិយាយម្តងទៀតចំពោះសេចក្តីទំនាយក្នុងលក្ខណៈទម្រង់សង្ខេប ។

**៤០:៤** *ខ្ញុំនឹងទំនុកបំរុងអ្នកដោយល្អ* នេប៊ូសារ៉ាដានបានសន្យាថា និងអនុវត្តតាមសេចក្តីប្រាថ្នារបស់ស្តេចនេប៊ូក្នេសា ដែលទាក់ទងនឹងលោកយេរេមា (សូមមើល ៣៩:១២) ។ *ស្រុកទាំងមូលនៅមុខអ្នកហើយ* ប្រៀបធៀបពីការថ្វាយរបស់លោកអាប់រ៉ាម ចំពោះលោកឡុតមានក្នុង លប ១៣:៨-៩ ។

**៤០:៥-៩** សូមមើល ២ពវ ២៥:២២-២៤ និងការពន្យល់ ។

**៤០:៥** *កេដាលាជកូនអ័ហ៊ីកាម* សូមមើលការពន្យល់ ២៦:២៤ ។ *ក៏ចែកអាហារ* បើភាសាហេព្រើរពាក្យនេះបកប្រែថា "ការព្រមឱ្យ" មានក្នុង ៥២:៣៤ ។

**៤០:៨** *យេសានា* សូមមើលការពន្យល់ ២ពវ ២៥:២៣ ។

**៤០:១០** *ប្រមូលផលទំពាំងបាយជូរ និងផលរដូវក្តៅព្រមទាំងប្រេង* នេហ៊ូសារ៉ាដាន(មើល ៣៩:៩) បានមកដល់ក្នុងក្រុងយេរូសាឡិម ក្នុងខែសីហានាឆ្នាំ ៥៨៦ មុន ស.គ (មើលការពន្យល់ ២ពវ ២៥:៨) ។ ផ្លែទំពាំងបាយជូរ ផ្លែល្វាផ្លែអូលីវ ត្រូវបានគេប្រមូលផលនៅក្នុងខែសីហា ឬនៅខែកញ្ញា ។

កណ្ដាល ពួកកូនចៅអាំម៉ូន ហើយនៅស្រុកអេដំម[ក] ព្រម
ទាំងនៅគ្រប់ទាំងស្រុកផ្សេងៗទៀត[ខ]ផងកាលបានឮថា
ស្ដេចបាប៊ីឡូនបានទុកសំណល់ពួកយូដាឱ្យសល់នៅ ហើយ
បានតាំងកេដាលា ជាកូនអ័ហ៊ីកាមដែលជា កូនសាផានឱ្យ
ត្រួតត្រាលើគេ ១២នោះពួកយូដាទាំងនោះ ក៏ចេញពីគ្រប់ទី
កន្លែងដែលគេត្រូវបណ្ដេញទៅវិលមកក្នុងស្រុកយូដា ដល់
កេដាលាត្រង់មីសប៉ា[គ] ហើយគេក៏ប្រមូលផលទំពាំងបាយ–
ជូរ និងផលរដូវក្ដៅជាច្រើនណាស់ ។
១៣រីឯយ៉ូហាណាន[ឃ] ជាកូនការា និងពួកមេទ័ពទាំង
ប៉ុន្មាន ដែលពួននៅស្រុកស្រែចំការ គេក៏មកឯកេដាលា
នៅត្រង់មីសប៉ា[ង] ១៤គេជំលោកថា តើលោកជ្រាបឬទេថា
បាលីស ជាស្ដេចពួកកូនចៅអាំម៉ូន[ច] បានចាត់អ៊ីសម៉ាអែល[ឆ]
ជាកូននេថានា ឱ្យមកសំឡាប់លោក តែកេដាលា ជាកូន
អ័ហ៊ីកាមមិនជឿគេទេ ១៥គ្រានោះយ៉ូហាណាន[ជ] ជាកូន
ការា ក៏ពិគ្រោះនឹងកេដាលា ដោយសំងាត់នៅត្រង់មីសប៉ា
ថា សូមអនុញ្ញាតឱ្យខ្ញុំទៅចុះ នោះខ្ញុំនឹងសំឡាប់[ឈ] អ៊ីស–
ម៉ាអែល ជាកូននេថានាបង់ ឥតឱ្យអ្នកណាដឹងឡើយ និង
ទុកឱ្យវាមកសំឡាប់លោកធ្វើអី យ៉ាងនោះពួកយូដាទាំង
ប៉ុន្មាន ដែលបានមូលមកឯលោក គេនឹងត្រូវខ្ចាត់ខ្ចាយ[ញ]
ទៅ ហើយសំណល់[ដ]ពួកយូដានឹងត្រូវវិនាសបង់ ១៦តែ
កេដាលា ជាកូនអ័ហ៊ីកាម ប្រាប់ដល់យ៉ូហាណាន[ឋ] ជាកូន
ការាថា កុំឱ្យធ្វើដូច្នោះឡើយ ដ្បិតអ្នកនិយាយកុហកពី
ដំណើរអ៊ីសម៉ាអែលទេ ។

**៤១** ១លុះដល់ខែអស្សុជ នោះអ៊ីសម៉ាអែល[ក] ជាកូននេថា–
នា ដែលជាកូនអេលីសាម៉ា ក្នុងវង្សាស្ដេច ហើយជានាយក
ធំម្នាក់របស់ស្ដេច ព្រមទាំង១០នាក់ទៀត ក៏មកឯកេដាលា
ជាកូនអ័ហ៊ីកាម នៅត្រង់មីសប៉ា ហើយគេបានបរិភោគ
អាហារជាមួយគ្នានៅទីនោះ ២រួចអ៊ីសម៉ាអែល[ខ] ជាកូន
នេថានា និង១០នាក់ដែលនៅជាមួយ ក៏ក្រោកឡើងប្រហារ
កេដាលា ជាកូនអ័ហ៊ីកាម ដែលជាកូនសាផាន ដោយដាវ
ទៅ[គ] គឺសំឡាប់អ្នកដែលស្ដេចបាប៊ីឡូនបានតាំងឡើង[ឃ]
ធ្វើជាចៅហ្វាយលើស្រុកនោះ[ង] ៣អ៊ីសម៉ាអែលក៏សំឡាប់
ពួកយូដាទាំងអស់ ដែលនៅជាមួយនឹងកេដាលា ត្រង់
មីសប៉ាដែរ ព្រមទាំងពួកខាល់ដេ ជាទាហានដែលនៅទី
នោះផង ។
៤ដល់កន្លងបាន២ថ្ងៃក្រោយ ដែលសំឡាប់កេដាលា
ហើយ ឥតមានអ្នកណាដឹងសោះ ៥នោះមានមនុស្សមកពី
ស៊ីកែម[ច] ស៊ីឡូរ[ឆ] និងសាម៉ារី[ជ]ចំនួន៨០នាក់ គេបានកោរ
ពុកចង្កា[ឈ] ព្រមទាំងហែកអាវ[ញ] ហើយអារ[ដ] សាច់ខ្លួន ក៏

**៤០:១១** ក លប ២៥:៣០ ខ យរ ១២:១៤ **៤០:១២** គ យរ ៤៣:៥ **៤០:១៣** ឃ យរ ៤២:១ ង ខ.៨ **៤០:១៤** ច លប ១៩:៣៨ ២សយ ១០:១–១៩ យរ ២៥:២១ ៤១:១០ ៤៩:១ ឆ ខ.៨ **៤០:១៥** ជ ខ.៨ ឈ ចទ ៥:១៧ មថ ៥:២១–២២ ញ លប ១១:៤ លវ ២៦:៣៣ មថ ២៦:៣១ យហ ១១:៥២ យក ១:១ ដ ២ពវ ២១:១៤ អស ១:៩ រម ១១:៥ **៤០:១៦** ឋ យរ ៤៣:២ **៤១:១** ក យរ ៤០:៨ **៤១:២** ខ ទដ ៤១:៩ ១០៩:៥ គ យស ១១:១០ យរ ៤០:១៥ ហព ១១:៣៧ ឃ យរ ៤០:៥ ង ២សយ ៣:២៧ ២០:៩–១០ យរ ៤០:៨ **៤១:៥** ច លប ១២:៦ ៣៣:១៨ ពច ៩:១–៥៧ ១ពវ ១២:១ ឆ យស ១៨:១ ជ ១ពវ ១៦:២៤ ឈ លវ ១៩:២៧ យរ ៤៧:៥ ៤៨:៣៧ ញ លប ៣៧:២៩ លវ ១០:៦ មក ១៤:៦៣ ដ លវ ១៩:២៨

**៤០:១៤** *បាលីស* ជាឈ្មោះស្ដេចពួកកូនចៅអាំម៉ូន ក៏មានចារជាអក្សរចារឹកពីឈ្មោះរាជវង្សមានបីឈ្មោះ ដែលគេបានរកឃើញវាទាក់ទងទៅនឹងឈ្មោះស្ដេចបីអង្គ (១).គឺជាស្ដេចមានព្រះនាមថា បាលី "ដែលបានចារក្នុងសិលាចរិកនៅសតវត្សទី៦មុន ស.គ បានរុករកឃើញក្នុងទន្លេយ័រដាន់នូវវត្ថុដូចជាដប ។ (២)."បាលីស" ជាស្ដេចពួកកូនចៅអាំម៉ូន ក៏ជាស្ដេចមានឈ្មោះនៅលើត្រាសម្រាប់បោះ ដែលគេបានរកឃើញក្នុងតំបន់ថែលអិលយូមើរី ក្នុងទន្លេយ័រដាន់នៅឆ្នាំ ១៩៨៤ ។ (៣)."ស្ដេចបាលីសជាស្ដេចរបស់ពួកកូនចៅអាំងម៉ូនៗ" មានឈ្មោះលើត្រាក្នុងឆ្នាំ ១៩៩៨ ។ *ពួកកូនចៅអាំម៉ូន* ក៏ជាពួកកូនចៅមួយក្នុងចំណោមពូជសាសន៍ទាំងឡាយ ដែលបានចូលជាសម្ព័ន្ធមិត្ត ក្នុងការវាយប្រឆាំងនឹងពួកបាប៊ីឡូន (សូមមើល ២៧:៣ និងការពន្យល់, និងមើល អស ២១:១៨–៣២) ។

**៤០:១៥** *ដោយសំងាត់* សូមមើលការពន្យល់ ៣៨:១៦ ។ *សំណល់* សូមមើលការពន្យល់ ៦:៩ ។

**៤០:១៦** តាមបែបអក្សរសាស្ត្រគឺនិយាយ"ភូតភរ ឬមិនពិត"(សូមមើល ៣៧:១៤ និងការពន្យល់) ។ កេដាលាមានសេចក្ដីជំនឿយ៉ាងមុតមាំ ក្នុងសេចក្ដីសុចរិតរបស់លោកអ៊ីសម៉ាអែល ដែលនាំឱ្យបាត់បង់ជីវិតរបស់គាត់ (សូមមើល ៤១:២) ។

**៤១:១** *ជានាយកធំម្នាក់របស់ស្ដេច* ភាពស្មោះត្រង់របស់អ៊ីសម៉ាអែលចំពោះស្ដេចសេដេគា ក៏អាចពន្យល់ពីការធ្វើគត់របស់គាត់ចំពោះស្ដេចកេដាលានោះ គឺជាអ្នកដែលគេគិតថា ធ្វើជាអ្នកដឹកនាំជាអាយ៉ងនៃពួកបាប៊ីឡូន ។ *គេបានបរិភោគអាហារជាមួយគ្នា* គឺជាទំនៀមទម្លាប់បុរាណដែលមានការគោរពក៏ជាការស្វាគមន៍មួយ ក្នុងការសន្ទតរបស់លោកកេដាលាដែលភ្ញៀវរបស់គាត់ មិនបានធ្វើឱ្យគាត់មានគ្រោះថ្នាក់ ក៏មិនប្រថុយនឹងសេចក្ដីស្លាប់ច្រើន (សូមមើលការពន្យល់ ពច ៤:២១) ។

**៤១:៥** *គេបានកោរពុកចង្កា ព្រមទាំងហែកអាវ ហើយអាសាច់ខ្លួន* គឺជាសញ្ញា ឬក៏និមិត្តនៃការកាន់ទុក្ខ (សូមមើល ១៦:៦ និងការពន្យល់ អគ ៩:៣) ជាពិសេស ក្នុងគ្រាដែលទីក្រុងយេរូសាឡិមបានទទួលការបាក់បែបហឹនវិនាស ។ *មកពី* គឺនៅក្នុង "ខែទី៧" ដើម្បីប្រារព្ធពិធីបុណ្យនៃរោងត្រសាល (សូមមើលការពន្យល់ នក ២៣:១៦) ។ *ស៊ីគែម ស៊ីឡូរ និងសាម៉ារី* ពីមុន គឺជាទីថ្វាយបង្គំនៅតំបន់ផ្នែកខាងជើង (សូមមើលការពន្យល់ ៧:១២ លប ១២:៦ សូមមើល យស ២៤:២៥–២៦) ។ បន្ទាប់ពីនគរខាងជើងបានបែកមើលក្នុង ៧២២–៧២១ មុន ស.គ ។ មានប្រជាជនអ៊ីស្រាអែលជាច្រើនបានធ្វើពិធីធម្មយាត្រាទៅក្រុងយេរូសាឡិម ជាពិសេសក្នុងកំឡុងពេលមានការរៀនចំចលនានៃស្ដេចហេសេគា (សូមមើល ២របា ៣០:១១) និងយ៉ូសៀស (មើល ២របា ៣៤:៩) ។ *ដង្វាយម្សៅ និងកំញាន* ដង្វាយឥតមានឈាម គឺចាប់តាំងពីអាសនារបស់ព្រះវិហាក្រុងយេរូសាឡិមបានបំផ្លាញ ។ *ព្រះវិហារនៃព្រះយេហូវ៉ា* ទោះជាព្រះវិហារត្រូវបានបំផ្លាញក៏ដោយ ក៏ទីនោះនៅតែមានភាពបរិសុទ្ធដដែល ។

កាន់ដង្វាយម្សៅ និងកំញាន[ឋ] ដើម្បីនាំយកទៅព្រះវិហារនៃ
ព្រះយេហូវ៉ា[ឌ] ៦ឯអ៊ីសម៉ាអែល ជាកូននេថានា ក៏ចេញពី
មីសប៉ាទៅទទួលគេទាំងយំ[ឍ]បណ្តើរ កាលបានទៅដល់គេ
ហើយ នោះក៏និយាយថា សូមទៅឯកេដាលា ជាកូន
អ័ហ៊ីកាម[ណ] ៧រួចកាលគេបានចូលទៅក្នុងទីក្រុងហើយ នោះ
អ៊ីសម៉ាអែល ជាកូននេថានា និងពួកអ្នកដែលនៅជាមួយ
ក៏សំឡាប់គេបោះចោលទៅក្នុងរណ្តៅ[ត] ៨ប៉ុន្តែមាន១០នាក់
ក្នុងពួកគេ ដែលអង្វរដល់អ៊ីសម៉ាអែលថាសូមកុំសំឡាប់
យើងខ្ញុំឡើយ ពីព្រោះយើងខ្ញុំមានស្បៀងអាហារ ជាស្រូវ
សាលី ស្រូវឱក ប្រេង និងទឹកឃ្មុំកប់ទុកនៅចំការ[ថ] ដូច្នេះ
អ៊ីសម៉ាអែលក៏អាក់ខានមិនបានសំឡាប់អ្នកទាំងនោះ ជា
មួយនឹងបងប្អូនគេទេ ៩រីឯរណ្តៅដែលអ៊ីសម៉ាអែលបោះ
ចោលអស់ទាំងសាកសពនៃមនុស្ស ដែលបានសំឡាប់ទៅ
ជាមួយនឹងកេដាលា នោះគឺជារណ្តៅដែលស្តេចអេសា[ទ]
បានជីក ដោយខ្លាច[ធ]បាសា[ន] ជាស្តេចស្រុកអ៊ីស្រាអែល
ឯអ៊ីសម៉ាអែល ជាកូននេថានា ក៏បំពេញរណ្តៅ ដោយសព
របស់មនុស្សដែលបានសំឡាប់នោះ ១០អ៊ីសម៉ាអែលក៏ចាប់
យកសំណល់បណ្តាជន[ប] ដែលនៅមីសប៉ា នាំទៅជាឈ្លើយ
គឺទាំងបុត្រី[ផ]ស្តេចទាំងប៉ុន្មាន និងជនទាំងឡាយដែលសល់
នៅត្រង់មីសប៉ា ជាពួកអ្នកដែលនេប៊ូសារ៉ាដាន មេទ័ពធំ
បានផ្ញើផ្តាក់កេដាលា ជាកូនអ័ហ៊ីកាម នោះអ៊ីសម៉ាអែល
ជាកូននេថានា ក៏ដឹកនាំគេទៅជាឈ្លើយទាំងអស់ រួចចេញ
ដំណើរទៅ ដើម្បីនឹងឆ្លងទៅឯពួកកូនចៅអាំម៉ូន[ព] ។
១១កាលយ៉ូហាណាន[ភ] ជាកូនការា និងពួកមេទ័ព ទាំង
ប៉ុន្មានដែលនៅជាមួយ បានឮនិយាយពីអស់ទាំងការអាក្រក់
ដែលអ៊ីសម៉ាអែល ជាកូននេថានាបានធ្វើ ១២នោះគេក៏នាំ
ពួកទាហានរបស់ខ្លួនទាំងអស់ លើកចេញទៅច្បាំង[ម] នឹង
អ៊ីសម៉ាអែល ជាកូននេថានា ក៏ប្រទះគ្នាត្រង់ស្រះធំ[យ]នៅ
គីបៀន ១៣រីឯពួកជនទាំងឡាយ[រ] ដែលនៅជាមួយនឹង
អ៊ីសម៉ាអែល កាលបានឃើញយ៉ូហាណាន ជាកូនការា
និងពួកមេទ័ពដែលនៅជាមួយហើយ នោះគេមានចិត្តអរ
ណាស់ ១៤ដូច្នេះ ពួកជនដែលអ៊ីសម៉ាអែលបានចាប់ពី
មីសប៉ា[ល]ដឹកនាំទៅជាឈ្លើយទាំងប៉ុន្មាន គេក៏វិលត្រឡប់មក
ខាងយ៉ូហាណាន ជាកូនការាវិញ ១៥ប៉ុន្តែអ៊ីសម៉ាអែលជា
កូននេថានា គេចរួច[វ]ពីយ៉ូហាណាន ទៅឯពួកកូនចៅអាំម៉ូន
ទៅ ហើយមាន៨នាក់ទៅជាមួយ ។

## ការគេចខ្លួនទៅស្រុកអេស៊ីព្ទ

១៦លំដាប់នោះយ៉ូហាណាន ជាកូនការា និងពួកមេទ័ព[ស]
ដែលនៅជាមួយគេក៏នាំយកសំណល់ជន[ហ]ពីមីសប៉ាទៅ គឺជា
ពួកអ្នកដែលបាន ដោះឱ្យរួចពីអ៊ីសម៉ាអែល ជាកូននេថានា
មកក្រោយ ដែលវាបានសំឡាប់កេដាលា ជាកូនអ័ហ៊ីកាម
ហើយ គឺបាននាំទាំងពួកទាហាន ពួកស្រីៗ និងកូនក្មេង
ហើយពួកមនុស្សគំរៀវដែលបាននាំត្រឡប់មកពីគីបៀនវិញ
១៧គេក៏ចេញទៅអាស្រ័យនៅត្រង់ទីសំណាក់របស់គីមហាំ[ឡ]
ដែលនៅជិតបេថ្លេហិម[អ] ដើម្បីនឹងចូលទៅក្នុងស្រុកអេស៊ីព្ទ[ក]
១៨ពីព្រោះគេខ្លាច[ខ]ពួកខាល់ដេ ដោយព្រោះអ៊ីសម៉ាអែល
ជាកូននេថានា បានសំឡាប់កេដាលា[គ] ជាកូនអ័ហ៊ីកាម ជា
អ្នកដែលស្តេចបាប៊ីឡូនតាំងឡើង ជាចៅហ្វាយលើស្រុក ។
**៤២** ១គ្រានោះមេទ័ពទាំងប៉ុន្មាន និងយ៉ូហាណាន[ក] ជាកូន
ការា ហើយយេសានា ជាកូនហូសាយ៉ា[ខ] ព្រមទាំងបណ្តាជន

**៤១:៥** ឋ ជន ១៦:៤០ លក ១:៩ ឌ ១ពវ ៣:២ ៦:៣៨ ២ពវ ២៥:៩ **៤១:៦** ឍ ២សយ ៣:១៦ ណ ទដ ៥:៩ ហស ៧:១១ វវ ២០:១០ **៤១:៧** ត លប ៣៧:២៤ ២ពវ ១០:១៤ **៤១:៨** ថ អស ៤៥:៣ **៤១:៩** ទ ១ពវ ១៥:២២ ២រប ១៦:៦ ធ ពច ៦:២ ន ២រប ១៦:១ **៤១:១០** ប យរ ៤០:៧,១២ ផ យរ ៣៨:២៣ ព យរ ៤០:១៤ **៤១:១១** ភ យរ ៤០:៨ **៤១:១២** ម នក ១៤:១៤ យហ ១៨:៣៦ យ យស ៩:៣ យហ ៩:៧ **៤១:១៣** រ ខ.១០ **៤១:១៤** ល យរ ៤០:៦ **៤១:១៥** វ យប ២១:៣០ សភ ២៩:១៧ **៤១:១៦** ស យរ ៤២:១ ៤៣:២ ហ អស ១:៩ យរ ៤៣:៤ អគ ៧:១៦ ១៤:២២ សផ ២:៩ **៤១:១៧** ឡ ២សយ ១៩:៣៧ អ លប ៣៥:១៩ មីក ៥:២ ក យរ ៤២:១៤ **៤១:១៨** ខ ជន ១៤:៩ អស ៥១:១២ យរ ៤២:១៦ លក ១២:៤-៥ គ ២ពវ ២៥:២២ **៤២:១** ក លប ២០:៧ យរ ៣៦:៧ កច ៨:២៤ យក ៥:១៦ ខ អស ១:៩

**៤១:៦** *យំបណ្តើរ* គឺជាសកម្មភាពធ្វើជាមានកង្វល់ ដើម្បីចូលរួមការកាន់ទុក្ខ ដែលមានជាទម្លាប់នៅភូមិភាគខាងជើង ។

**៤១:៧** *ទីក្រុង* នៅតំបន់មីសប៉ា ។ *ក្នុងរណ្តៅ* ជាទីកន្លែងពេញចិត្ត ដែលគេយកជនរងគ្រោះទៅដាក់នៅទីនោះ ក៏ដូចជាជីវិតរស់នៅ ឬស្លាប់ក្តី (សូមមើល ៣៧:១៦ ការពន្យល់ ៣៨:៦) ។

**៤១:៨** *ជាស្រូវសាលី ស្រូវឱក ប្រេង និងទឹកឃ្មុំកប់ទុក* ដូចជាលោកអ៊ីសម៉ា–អែលបានទទួលទានអាហារនេះ ក្នុងខណៈពេលគាត់បានភៀសខ្លួនទៅអាំម៉ូន (សូមមើល ខ.១៥) ។

**៤១:៩** *រីឯរណ្តៅដែលអ៊ីសម៉ាអែលបោះ . . . ជារណ្តៅដែលស្តេចអេសាបានជីក* គឺវាអាចជាផ្នែកតំបន់មួយ នៃតំបន់ព្រំការពាររបស់សត្រូវ ដែលសង់នៅតំបន់ក្រុងមីសប៉ា (សូមមើល ១ពវ ១៥:២២) គឺចាប់តាំងពីរណ្តៅនោះមានសារៈសំខាន់ ក្នុងការផ្ទុកទឹកក្នុងកំឡុងពេលមានហ៊ុំព័ទ្ធពីសំណាក់ពួកសត្រូវ ។ អ្នកវត្ថុបុរាណវិទ្យាបានរកឃើញរណ្តៅជាច្រើន ដែលបែកបាក់នៅក្នុងតំបន់មីសប៉ា ដែលមានកន្លះគីឡូចេញពីក្រុងយេរូសាឡិមនៅខាងជើងទីក្រុង ។

**៤១:១០** *បុត្រីស្តេច* គឺជាក្រុមស្ត្រីដែលជាសមាជិកក្រុមជំនុំកាត់ក្តីរបស់ស្តេចសេដេកា គឺមិនគ្រាន់តែមានកូនស្រីស្តេចប៉ុណ្ណោះនោះទេ (សូមមើលការពន្យល់ ៣៦:២៦) ។ *ពួកកូនចៅអាំម៉ូន* សូមមើល ៤០:១៤ និងការពន្យល់ ។

**៤១:១២** *ស្រះធំនៅគីបៀន* ស្រះនេះប្រហែលជាមានលក្ខណៈដូចរណ្តៅដែលគេបានបង្ហាញពីមុននៅក្នុង ខ.៩ មើលក្នុង ២:១៣ ។

**៤១:១៥** *មាន៨នាក់ទៅជាមួយ* លោកអ៊ីសម៉ាអែលបានបាត់បង់មនុស្សរបស់គាត់ពីរនាក់តែប៉ុណ្ណោះ (សូមមើល ខ.២) ក្នុងការវាយប្រយុទ្ធជាមួយយ៉ូហាណាន ។

**៤១:១៧** *គីមហាំ* គឺវាអាចជាកន្លែងទីស្នាក់អាស្រ័យរបស់"គីមហាំ"គឺជាមិត្តរបស់ស្តេចដាវីឌ ដែលបានត្រឡប់ជាមួយគាត់ទៅក្រុងយេរូសាឡិម បន្ទាប់ពីអាប់សាឡុំបានសុគតទៅ (សូមមើល ២សយ ១៩:៣៧–៤០) ។

ទាំងអស់ចាប់តាំងពីអ្នកតូចបំផុត រហូតដល់អ្នកធំបំផុត[គ] គេ
ក៏ចូលមកជិត ២ហើយគេនិយាយនឹងហោរាយេរេមាថា
សូមឱ្យលោកមេត្តាស្តាប់សេចក្តី ដែលយើងខ្ញុំអង្វរ[ឃ]ដល់
លោក ហើយសូមអធិស្ឋានដល់ព្រះយេហូវ៉ាជាព្រះនៃ
លោកឱ្យយើងខ្ញុំផង គឺឱ្យពួកមនុស្សដែលសល់នៅ[ង]ទាំងនេះ
ដ្បិតយើងខ្ញុំដែលមានគ្នាច្រើន បានសល់នៅតែបន្តិច[ច]ទេ
ដូចជាលោកឃើញស្រាប់ ៣ដើម្បីឱ្យព្រះយេហូវ៉ា ជាព្រះនៃ
លោក បានបង្ហាញផ្លូវដែលយើងខ្ញុំត្រូវដើរ នឹងការដែល
ត្រូវធ្វើ[ឆ] ៤ហោរាយេរេមាក៏ឆ្លើយតបថា ខ្ញុំបានឮហើយ
មើល ខ្ញុំនឹងអធិស្ឋាន[ជ]ដល់ព្រះយេហូវ៉ាជាព្រះនៃអ្នករាល់
គ្នា តាមពាក្យសំណូមរបស់អ្នករាល់គ្នា ហើយសេចក្តីអ្វី
ដែលព្រះយេហូវ៉ាទ្រង់ឆ្លើយមក នោះខ្ញុំនឹងឱ្យអ្នករាល់
គ្នាដឹង ឥតលាក់លៀម[ឈ]អ្វីនឹងអ្នករាល់គ្នាឡើយ[ញ] ៥ដូច្នេះ
គេជំរាបយេរេមាថា បើយើងខ្ញុំមិនធ្វើតាមគ្រប់ទាំងសេចក្តី
ដែលព្រះយេហូវ៉ា ជាព្រះនៃលោក និងចាត់លោកមក
ប្រាប់ដល់យើងខ្ញុំ នោះសូមឱ្យព្រះយេហូវ៉ាទ្រង់ជាសាក្សី[ដ]
ពិត[ឋ] ហើយស្មោះត្រង់[ឌ]ទាស់នឹងយើងខ្ញុំចុះ ៦ទោះបើជាការ
ល្អឬអាក្រក់ក្តី គង់តែយើងខ្ញុំនឹងស្តាប់តាមព្រះបន្ទូលរបស់
ព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំ ដែលយើងខ្ញុំឱ្យលោកទៅ
សួរដល់ទ្រង់នោះ ដើម្បីឱ្យយើងខ្ញុំរាល់គ្នាបានសេចក្តីសុខ[ឍ]
ដោយស្តាប់តាម[ណ]ព្រះបន្ទូលរបស់ព្រះយេហូវ៉ា ជាព្រះនៃ
យើងខ្ញុំ ។

៧ក្រោយ១០ថ្ងៃមក នោះព្រះបន្ទូលនៃព្រះយេហូវ៉ាក៏
មកដល់យេរេមា ៨រួចលោកហៅយ៉ូហាណាន ជាកូនការា
និងពួកមេទ័ព[ត]ទាំងប៉ុន្មានដែលនៅជាមួយ ហើយបណ្តាជន
ទាំងឡាយ ចាប់តាំងពីអ្នកតូចបំផុត រហូតដល់អ្នកធំបំផុត[ថ]
៩លោកក៏ប្រាប់គេថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ដែលអ្នករាល់គ្នាបានចាត់ខ្ញុំឱ្យទៅនាំពាក្យ
អង្វរ[ទ]របស់អ្នករាល់គ្នា ទៅថ្វាយដល់ទ្រង់នោះទ្រង់មាន
បន្ទូលដូច្នេះថា[ធ] ១០បើឯងរាល់គ្នានឹងនៅជាប់ក្នុងស្រុកនេះ
តទៅ[ន] នោះអញនឹងសង់[ប]ឯងឡើងឥតរំលំចុះឡើយ ក៏នឹង
ដាំ[ផ]ឯងរាល់គ្នាឥតរំលើងវិញដែរ[ព] ដ្បិតអញប្រែគំនិតចេញ
ពីការអាក្រក់ ដែលអញបានធ្វើដល់ឯងរាល់គ្នាហើយ[ភ]
១១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា កុំឱ្យខ្លាចចំពោះស្តេច
បាប៊ីឡូន[ម] ដែលឯងរាល់គ្នាកំពុងតែខ្លាចនោះ[យ] កុំឱ្យខ្លាចគេ
ឡើយ ដ្បិតអញនៅជាមួយ ដើម្បីនឹងជួយសង្គ្រោះ[រ]ឯងរាល់
គ្នា ហើយនិងដោះឯងរាល់គ្នា ឱ្យរួចពីកណ្តាប់របស់គេ[ល]
១២អញនឹងប្រោសមេត្តា[វ]ដល់ឯងរាល់គ្នា ដើម្បីឱ្យគេបាន
អាណិតឯង ហើយឱ្យត្រឡប់ទៅឯស្រុករបស់ឯងរៀងខ្លួន
វិញ[ស] ១៣តែបើឯងរាល់គ្នា យើងខ្ញុំមិនព្រមនៅជាប់ក្នុង
ស្រុកនេះតទៅទេ គឺឯងរាល់គ្នាមិនព្រមស្តាប់តាម[ហ]ព្រះ
បន្ទូលរបស់ព្រះយេហូវ៉ា ជាព្រះនៃឯង ១៤ដោយថាទេ
យើងរាល់គ្នានឹងទៅនៅឯស្រុកអេស៊ីព្ទវិញ[ឡ] ជាកន្លែង
ដែលយើងខ្ញុំនឹងមិនឃើញចំបាំងទៀត ក៏មិនឮសូរត្រែ[អ] ឬ
ត្រូវអត់ឃ្លានឡើយ គឺនៅទីនោះ ដែលយើងខ្ញុំនឹងអាស្រ័យ
នៅវិញ[ក] ១៥ដូច្នេះ ឱសំណល់ពួកយូដាអើយ ចូរស្តាប់ព្រះ
បន្ទូលនៃព្រះយេហូវ៉ាឥឡូវចុះ[ខ] ព្រះយេហូវ៉ានៃពួកពល
បរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ
បើឯងរាល់គ្នាកាត់ចិត្តនឹងទៅឯស្រុកអេស៊ីព្ទជាពិតហើយក៏

**៤២:១** គ លវ ២៦:២២ បទ ១:១ **៤២:២** ឃ លប ២០:៧ យរ ៣៦:៧ កច ៨:២៤ យក ៥:១៦ ង អស ១:៩ ច លវ ២៦:២២ បទ ១:១ **៤២:៣** ឆ ខ.២០ ទដ ៨៦:១១ សភ ៣:៦ យរ ១៥:១១ **៤២:៤** ជ នក ៨:២៩ ១សយ ១២:២៣ ឈ យរ ១:១៧ ញ ជន ២២:១៨ ១សយ ៣:១៧ **៤២:៥** ដ លប ៣១:៤៨ ចទ ៤:២៦ អស ១:២ រម ១:៩ វវ ១:៥ ឋ ១ពវ ២២:១៦ ទដ ១១៩:១៦០ រម ៣:៤ ឌ ចទ ៧:៩ យហ ៨:២៦ ១កថ ១:៩ **៤២:៦** ឍ ចទ ៥:២៩ ៦:៣ យរ ៧:២៣ ២២:១៥ ណ ខ.១៩ នក ២៤:៧ យស ២៤:២៤ **៤២:៨** ត ខ.១ ថ យរ ៤១:១៦ មក ៩:៣៥ លក ៧:២៨ ហព ៨:១១ **៤២:៩** ទ ខ.២ ធ ២ពវ ២២:១៥ **៤២:១០** ន យរ ៤៣:៤ ប យរ ២៤:៦ ផ ចទ ៣០:៩ ព ចទ ២៩:២៨ សស ៣:២ យរ ៤៥:៤ អគ ៣៦:៣៦ ដយ ១១:៤ ភ ២រប ៣៤:២៤ អស ៣០:២៦ យរ ១៨:៨ **៤២:១១** ម យរ ២៧:១១ យ ជន ១៤:៩ ១សយ ១៥:២៤ ទដ ២៣:៤ មថ ១០:២៨ ២ធថ ១:៧ រ ទដ ១៨:២៧ ៦៩:៣៥ ១១៩:៩៤ អស ៦៣:១ ហព ៧:២៥ ល ទដ ៣:៧ សភ ២០:២២ យរ ១:៨ រម ៨:៣១ **៤២:១២** វ នក ៣:២១ ២សយ ២៤:១៤ ២កថ ១:៣ ស លប ៣១:៣ នហ ១:៩ ទដ ១០៦:៤៤–៤៦ **៤២:១៣** ហ ចទ ១១:២៨ **៤២:១៤** ឡ ជន ១១:៤–៥ ចទ ១៧:១៦ អស ៣០:២ អ យស ៦:២០ មថ ២៤:៣១ ក ចទ ៨:៣ ១សយ ២:៥ សភ ១០:៣ អស ៦៥:១៣ មថ ៤:២–៤ **៤២:១៥** ខ យរ ៤៤:២៤

**៤២:១** *យេសានាជាកូនហូសាយ៉ា* "អាចមានលក្ខណៈដូចលោក យ្ហាសានា ជាកូនប្រុសម៉ាកាធី" (៤០:៨ តាមការជាក់ស្តែងគេបានស្គាល់លោកយេសានាជាឈ្មោះអ័សារាវិញ (សូមមើលការពន្យល់ ៤៣:២) ដូចជាស្តេចអូសៀស (សូមមើលការពន្យល់ ២ពវ ១៤:២១ ២រប ២៦:១) ។

**៤២:២** *យេរេមា* ក៏ជាម្នាក់ដែលបានសង្គ្រោះចេញពីទីចម្បាំងមីសប៉ា (៤១:១៦) ។ *មេត្តាស្តាប់សេចក្តីដែលយើងខ្ញុំអង្វរដល់លោក* សូមមើល ខ.៩,៣៧,២០ ។ *មនុស្សដែលសល់* សូមមើល ខ.១៥,១៩ និងការពន្យល់ ៦:៩ ។

**៤២:៣** មនុស្សអាចទូលសូមដល់ព្រះយេហូវ៉ាឱ្យទ្រង់បើកសម្តែងនូវអ្វីដែលជាសេចក្តីជំនឿយ៉ាងជាក់លាក់ ដែលពួកគេត្រូវប្រកាន់យក : ការភៀសខ្លួនទៅស្រុកអេស៊ីព្ទ (សូមមើល ខ.១៧ ៤១:១៧) ។

**៤២:៦** *ស្តាប់តាមព្រះបន្ទូលរបស់ព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំ* ពួកគេបានប្រកាសពីរដងនៅត្រង់នេះ គឺបង្ហាញពីសេចក្តីស្រេកឃ្លានរបស់ពួកគេចំពោះការស្វែងរកព្រះហឫទ័យ គឺជាការដែលពួកគេមានទំនោរចិត្តទៅរក (សូមមើល ៤៣:២) ។

**៤២:៧** *ក្រោយ១០ថ្ងៃមក* ហោរាយេរេមាពុំបាននាំព្រះបន្ទូលទៅដល់មនុស្សរហូតដក់គាត់បានមានការជឿជាក់លើខ្លួនឯង យ៉ាងច្បាស់សិន (សូមមើល ២៨:១០–១៧) ។

**៤២:១០** *សង់ឯងឡើងឥតរំលំចុះ . . . ដាំឯងរាល់គ្នាឥតរំលើងវិញ* សូមមើល ១:១០ និងការពន្យល់, និងមើល ៣១:៤,២៨ ៣៣:៧ ។

**៤២:១២** *ឱ្យគេបានអាណិតឯង* គឺជាឧទាហរណ៍ដែលមានលក្ខណៈស្រដៀងគ្នា សូមមើល លប ៤៣:១៤ ១ពវ ៨:៥០ ។

ទៅអាស្រ័យនៅឯនោះ ១៦ យ៉ាងនោះដាវ[គ]ដែលឯងរាល់គ្នា
ខ្លាច[ឃ]នោះនឹងតាមឯងទាន់ នៅស្រុកអេស៊ីព្ទ ហើយអំណាត់
អត់[ង]ដែលឯងរាល់គ្នាខ្លាចដែរ និងជាប់ប្រកិតតាមឯងរាល់
គ្នា ទៅក្នុងស្រុកអេស៊ីព្ទនោះឯង ហើយឯងរាល់គ្នានឹងត្រូវ
ស្លាប់នៅទីនោះ[ច] ១៧ ឯអស់អ្នកដែលកាត់ចិត្តនឹងទៅអាស្រ័យ
នៅក្នុងស្រុកអេស៊ីព្ទ នោះនឹងបានដូច្នោះ គឺគេនឹងស្លាប់
ដោយដាវ ដោយអំណាត់អត់ និងអាសន្នរោគ[ឆ] ឥតមានពួក
គេណាមួយសល់នៅ ឬរួចពីការអាក្រក់ ដែលអញនឹងនាំ
មកលើគេនោះឡើយ ។
១៨ ពីព្រោះ ព្រះយេហូវ៉ា នៃពួកពលបរិវារ ជាព្រះនៃ
សាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា សេចក្តីកំហឹង
និងសេចក្តីក្រោធ[ជ]របស់អញ ដែលបានចាក់ចេញទៅលើ
ពួកអ្នក នៅក្រុងយេរូសាឡិម[ឈ]ជាយ៉ាងណា នោះសេចក្តី
ក្រោធរបស់អញ នឹងត្រូវចាក់ចេញ លើឯងរាល់គ្នាយ៉ាង
នោះដែរ គឺក្នុងកាលដែលចូលទៅក្នុងស្រុកអេស៊ីព្ទនោះ
នៅស្រុកនោះឯងរាល់គ្នានឹងត្រឡប់ទៅជាទីត្មះតិះដៀល[ញ]
ជាទីស្រឡាំងកាំង[ដ] ជាទីផ្តាសា ហើយជាទីជេរប្រមាថ[ឋ] ឯង
រាល់គ្នានឹងមិនបានឃើញទីនេះទៀតឡើយ[ឌ] ១៩ ឱ សំណល់[ឍ]
នៃពួកយូដាអើយ ព្រះយេហូវ៉ាទ្រង់មានបន្ទូល ពីដំណើរ
ឯងរាល់គ្នាថា កុំឱ្យទៅឯស្រុកអេស៊ីព្ទឡើយ[ណ] ចូរឱ្យដឹង
ជាក់ថា នៅថ្ងៃនេះខ្ញុំបានបន្ទាល់ដល់អ្នករាល់គ្នាហើយ
២០ ដ្បិតអ្នករាល់គ្នាបានបញ្ឆោតចិត្តខ្លួន ពីព្រោះអ្នករាល់គ្នា
បានចាត់ខ្ញុំឱ្យទៅឯព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នា
ដោយពាក្យថា សូមអធិស្ឋានដល់ព្រះយេហូវ៉ា ជាព្រះនៃ
យើងរាល់គ្នាឱ្យយើងផង ហើយសូមប្រាប់មកយើង តាម
គ្រប់ទាំងសេចក្តីដែលព្រះយេហូវ៉ា ជាព្រះនៃយើង ទ្រង់
មានបន្ទូលមក នោះយើងនឹងប្រព្រឹត្តតាម[ត] ២១ ដូច្នេះ នៅថ្ងៃ
នេះឯង ខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាហើយតែអ្នករាល់គ្នា
មិនបានស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ា ជាព្រះនៃអ្នក
រាល់គ្នា ក្នុងការអ្វីដែលទ្រង់បានចាត់ខ្ញុំមកប្រាប់អ្នករាល់
គ្នានោះសោះ[ថ] ២២ ដូច្នេះ ចូរឱ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នក
រាល់គ្នា នឹងត្រូវស្លាប់ដោយដាវ ដោយអំណាត់អត់[ទ] ហើយ
ដោយអាសន្នរោគ[ធ] នៅក្នុងទីដែលអ្នករាល់គ្នាចូលចិត្តចង់
ទៅអាស្រ័យនៅនោះ[ន] ។

**៤៣** ១ កាលយេរេមា បានប្រាប់ដល់បណ្តាលជនទាំង
ឡាយ[ក] តាមអស់ទាំងព្រះបន្ទូលរបស់ព្រះយេហូវ៉ា ជាព្រះ
នៃគេ គឺសេចក្តីដែលព្រះយេហូវ៉ាជាព្រះនៃគេ ទ្រង់បាន
ចាត់លោកឱ្យទៅប្រាប់ គឺជាពាក្យទាំងនេះចប់ហើយ ២ នោះ
អ័សារា ជាកូនហូសាយ៉ា[ខ] និងយ៉ូហាណាន[គ] ជាកូនការា
ព្រមទាំងមនុស្សឆ្មើងឆ្មៃ[ឃ]ទាំងប៉ុន្មាន គេតបទៅយេរេមា
ថាលោកនិយាយកុហកទេ[ង] ព្រះយេហូវ៉ា ជាព្រះនៃយើង
ទ្រង់មិនបានចាត់លោកឱ្យមកប្រាប់យើងថា កុំឱ្យទៅអា-
ស្រ័យនៅឯស្រុកអេស៊ីព្ទនោះទេ[ច] ៣ គឺបារូក[ឆ] ជាកូននេរីយ៉ា
បានចាក់រុកលោកឱ្យទាស់នឹងយើងវិញ ដើម្បីនឹងប្រគល់
យើងទៅក្នុងកណ្តាប់ដៃនៃពួកខាល់ដេ ឱ្យគេបានសំឡាប់
យើង ហើយនាំទៅជាឈ្លើយ ដល់ស្រុកបាប៊ីឡូន[ជ] ៤ ដូច្នេះ
យ៉ូហាណាន ជាកូនការា និងពួកមេទ័ពទាំងអស់ ព្រមទាំង
ជនទាំងឡាយ[ឈ] គេមិនបានស្តាប់តាមព្រះបន្ទូលនៃព្រះ
យេហូវ៉ា[ញ] ដើម្បីនឹងនៅក្នុងស្រុកយូដាទេ[ដ] ៥ គឺយ៉ូហាណាន
ជាកូនការា និងពួកមេទ័ពទាំងអស់ គេប្រមូលសំណល់
ពួកយូដាដែលបានវិលមក ដើម្បីអាស្រ័យនៅក្នុងស្រុកយូដា
វិញ ពីគ្រប់ទាំងប្រទេសដែលគេត្រូវបណ្តេញទៅនោះ[ឋ] ៦ គឺ
ទាំងប្រុសទាំងស្រី[ឌ] និងកូនក្មេង ពួកបុត្រីរបស់ស្តេច និង
បណ្តាមនុស្សដែលនេប៊ូសារ៉ាដាន ជាមេទ័ពធំ បានទុកឱ្យ
នៅជាមួយនឹងកេដាលា ជាកូនអ័ហ៊ីកាម ដែលជាកូនសា

**៤២:១៦** គ លវ ២៦:៣៣ អគ ១១:៨ ១៤:១៧ ឃ យរ ៤១:១៨ ង លប ៤១:៥៥ ច លប ២:១៧ ២របា ២៥:៤ យប ២១:២០ អគ ៣:១៩ ១៨:៤ **៤២:១៧** ឆ ខ.២២ យរ ២១:៧ ៤៤:១៣ **៤២:១៨** ជ ចទ ២៩:១៨–២០ ២របា ១២:៧ ឈ ២របា ៣៦:១៩ យរ ៣៩:១–៩ ញ ជន ៥:២៧ យរ ២៥:១៨ ដ ចទ ២៨:២៥,៣៧ ឋ ទដ ៤៤:១៣ ឌ យរ ២២:១០ **៤២:១៩** ឍ យរ ៤០:១៥ ណ ខ.៦ ចទ ១៧:១៦ អស ៣០:៧ យរ ៤៣:២ ៤៤:១៦ **៤២:២០** ត ខ.២ អគ ១៤:៧–៨ **៤២:២១** ថ នក ២៤:៧ យរ ៤០:៣ អគ ២:៧ ១២:២ សក ៧:១១–១២ **៤២:២២** ទ អស ១:២៨ ធ ខ.១៧ យរ ២៤:១០ អគ ៦:១១ ន យរ ១៥:២ ហស ៩:៦ **៤៣:១** ក យរ ២៦:៨ ៤២:៩–២២ **៤៣:២** ខ យរ ៤១:១៦ គ យរ ៤០:១៦ ឃ នហ ៩:២៩ ១កថ ៤:១៨–២១ ង លប ១៩:១៤ ចទ ១៣:៣ រម ៩:១ ២កថ ១១:៣១ ១ធថ ២:៧ ច នក ២៤:៧ ២ពរ ២៥:២៤ យរ ១៨:១៩ ៤២:១៩ អគ ៣៧:១៤ **៤៣:៣** ឆ យរ ៣២:១២ ជ យរ ៣៨:៤ ៤១:១៨ ៥២:៣០ **៤៣:៤** ឈ យរ ៤១:១៦ ញ ២របា ២៥:១៦ យរ ៤២:៥–៦ ដ យរ ៤២:១០ **៤៣:៥** ឋ យរ ៤០:១២ **៤៣:៦** ឌ យរ ៦:១២

**៤២:១៦** *ដាវដែលឯងរាល់គ្នាខ្លាចនោះ និងតាមឯងទាន់* មើល ៤៣:១១ និងការពន្យល់ ។

**៤២:១៧–១៨** សូមមើល ៤៤:១១–១៤ ។

**៤២:១៧** *ដោយដាវ ដោយអំណាត់អត់ និងអាសន្នរោគ* សូមមើលការពន្យល់ ១៤:១២ ។

**៤២:១៨** *សេចក្តីកំហឹង និងសេចក្តីក្រោធរបស់អញ ដែលបានចាក់ចេញទៅលើពួកអ្នក* សូមមើល ៧:២០ ៤៤:៦ និងការពន្យល់ ២៤:៩ ២៥:១៨ និងមើល ២៩:១៨ ។ *ទីនេះ* ពាក្យថាទីនេះគឺសំដៅលើក្រុងយេរូសាឡិម ។

**៤២:១៩** ជាសេចក្តីដាស់តឿន កើនរំលឹករបស់ព្រះ សូមមើល ១១:៧ ។

**៤៣:២** *អ័សារា* សូមមើលការពន្យល់ ៤២:១ ។ *មនុស្សឆ្មើងឆ្មៃ* ពួកគេបានបង្ហាញខ្លួនគេ ឬបង្ហាញអត្តសញ្ញាណរបស់គេដោយពាក្យសម្តី ។

**៤៣:៣** *បារូក* សូមមើលការពន្យល់ ៣២:១២ គឺជាអ្នកប្រឆាំងនិងយេរេមាក៏សម្រេចដាក់ការស្តីបន្ទោសទៅលើអ្នកណាម្នាក់ដែលគេយល់ថា មានព្រះវិញ្ញាណខ្សោយថាខ្លួនគេជាហោរា ។

**៤៣:៥** *សំណល់ពួកយូដា* គឺជាពួកយូដាដែលបានភៀសខ្លួនពីក្រុងបាប៊ីឡូនទៅកាន់ប្រទេសជិតខាង (សូមមើល ៤០:១១–១២) ។

**៤៣:៦** *ពួកបុត្រីរបស់ស្តេច* មើលការពន្យល់ ៤១:១០ ។ *ហោរាយេរេមាយើងក៏ដឹងហើយ* គឺពួកគេបានទៅស្រុកអេស៊ីព្ទ ដោយមានចេតនា សូមមើល

ផាន ព្រមទាំងហោរាយេរេមា និងបារូក[ឍ] ជាកូននេរីយ៉ា
៧ នាំចូលទៅក្នុងស្រុកអេស៊ីព្ទ[ណ]ទាំងអស់គ្នា ពីព្រោះគេមិន
ព្រមស្តាប់តាមព្រះបន្ទូលនៃព្រះយេហូវ៉ាទេ គេក៏ទៅដល់
ក្រុងថាផ្នេស[ត] ។
៨ នៅគ្រានោះ ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់
យេរេមានៅត្រង់ថាផ្នេស[ថ]ដូច្នេះ ៩ ចូរយកថ្មធំៗ[ទ]ទៅកប់
ទុកក្នុងបាយអនៃកំរាលឥដ្ឋ[ធ] ដែលនៅមុខដំណាក់[ន]ផារ៉ោន
ត្រង់ថាផ្នេស នៅភ្នែកនៃពួកយូដាទៅ ១០ ហើយប្រាប់
គេថាព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍
អ៊ីស្រាអែលទ្រង់មានបន្ទូលដូច្នេះថា មើល អញនឹងចាត់
ទៅនាំយកនេប៊ូក្នេសា[ប] ស្តេចបាប៊ីឡូន ជាអ្នកបំរើ[ផ]របស់
អញមក ហើយនឹងតាំងបល្ល័ង្ក[ព]របស់គេ នៅពីលើថ្ម ដែល
អញបានលាក់ទុកនេះ គេនឹងដំឡើងព្រះរាជពន្លា[ភ]របស់គេ
នៅពីលើផង ១១ គេនឹងមកវាយស្រុកអេស៊ីព្ទ[ម] គ្រានោះ
មនុស្សណាដែលសំរាប់ស្លាប់[យ] និងត្រូវ[រ]ស្លាប់ទៅ អ្នកណា
ដែលសំរាប់ដឹកទៅជាឈ្លើយ នឹងត្រូវដឹកទៅ[ល] ហើយ
អ្នកណាដែលសំរាប់ដាវ នឹងត្រូវប្រគល់ទៅដល់ដាវ[វ]
១២ អញនឹងបង្កាត់ភ្លើង[ស]នៅក្នុងព្រះវិហារ[ហ] នៃព្រះ[ឡ]ទាំង
ប៉ុន្មានរបស់ស្រុកអេស៊ីព្ទ ហើយគេនឹងដុតចោល ព្រមទាំង
ដឹកនាំរូបព្រះទាំងនោះទៅជាឈ្លើយ[អ] គេនឹងប្រដាប់ខ្លួន[ក]
ដោយស្រុកអេស៊ីព្ទ ដូចជាអ្នកគង្វាលពាក់អាវខ្លួន រួចគេ
នឹងចេញពីទីនេះទៅដោយសុខសាន្ត ១៣ គេក៏នឹងបំបែក
បំបាក់រូបព្រះ[ខ]នៅបេត-សេមែស[គ] ដែលនៅក្នុងស្រុក

**៤៣:៦** ឍ យរ ៣២:១២
**៤៣:៧** ណ ២ពវ ២៥:២៦
**៤៣:៧** ត យរ ២:១៦ ៤៤:១ ៤៦:១៤ អគ ៣០:១៨
**៤៣:៨** ថ ទដ ១៣៩:៧ យរ ២:១៦
**៤៣:៩** ទ លប ៣១:៤៥-៥៣ យស ៤:១-៧ ១ពវ ១៨:៣១-៣២ ធ លប ១១:៣ ន លប ៤៧:១៤
**៤៣:១០** ប យរ ៤៦:១៣ ផ អស ៤៤:២៨ ៤៥:១ យរ ២៥:៩ ២៧:៦ ព យរ ៤៩:៣៨ ភ ទដ ១៨:១១
**៤៣:១១** ម យរ ៤៦:១៣-២៦ អគ ២៩:១៩-២០ យ សក ១១:១៩ រម ៦:២៣ រ ទដ ៤៩:១៤ ហាព ៩:២៧ ល ចទ ២៨:៦៤ វវ ១៣:១០ វ យរ ១៥:២ អគ ៣២:១១

អេស៊ីព្ទដែរ ព្រមទាំងដុតវិហារនៃព្រះរបស់ស្រុកអេស៊ីព្ទ
ទាំងប៉ុន្មានផង ។

## សេចក្តីហិនវិនាសដែលបណ្តាលមកពីការថ្វាយបង្គំរូបព្រះ

**៤៤** ១ នេះជាព្រះបន្ទូល ដែលមកដល់យេរេមាពីដំណើរ
ពួកយូដាទាំងប៉ុន្មាន ដែលនៅស្រុកអេស៊ីព្ទ[ក] គឺត្រង់មីកដុល[ខ]
ថាផ្នេស[គ]ណូព[ឃ] ហើយនៅស្រុកប៉ាត្រុសថា[ង] ២ ព្រះយេហូវ៉ា
នៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មាន
បន្ទូលដូច្នេះ ឯងរាល់គ្នាបានឃើញគ្រប់ទាំងសេចក្តីអា-
ក្រក់[ច] ដែលអញបាននាំមកលើក្រុងយេរូសាឡិម និងលើ
អស់ទាំងទីក្រុងស្រុកយូដា[ឆ]ហើយ មើលសព្វថ្ងៃនេះ ទីក្រុង
ទាំងនោះត្រូវខូចបង់[ជ] ឥតមានអ្នកណានៅឡើយ ៣ ដោយ
ព្រោះអំពើអាក្រក់[ឈ] ដែលគេបានប្រព្រឹត្តជាការដែលនាំឱ្យ
អញខឹង[ញ] ដោយគេបានទៅដុតកំញាន[ដ]គោរពដល់ព្រះដទៃ[ឋ]
ជាព្រះដែលគេ ឬឯងរាល់គ្នា ឬពួកឰយុកោ[ឌ]ឯង មិន
បានស្គាល់ផង ៤ ប៉ុន្តែអញបានចាត់ពួកហោរាទាំងប៉ុន្មាន[ឍ]
ជាអ្នកបំរើរបស់អញឱ្យមកឯឯងរាល់គ្នា គឺបានក្រោកពី
ព្រលឹមស្រាង[ណ] ដើម្បីនឹងចាត់គេផង ដោយពាក្យថា ឱសូម

សក ១១:៩ **៤៣:១២** ស យស ៧:១៥ ហ ១ពវ ១៦:៣២ ឡ ខ.១៣ នក ១២:១២ អស ២:១៨ យរ ៤៦:២៥ អគ ៣០:១៣ សក ១៣:២ អ ដយ ១១:៨ ក ទដ ១០៤:២ ១០៩:១៨-១៩ **៤៣:១៣** ខ យរ ៥២:១៧ អគ ២៦:១១ គ លប ១:១៦ អស ១៩:១៨ ចទ ៤:១៩ **៤៤:១** ក ចទ ៣២:៤២ យរ ២៤:៨ ខ នក ១៤:២ គ យរ ៤៣:៧,៨ ឃ អស ១៩:១៣ ង អស ១១:១១ **៤៤:២** ច ២របា ៣៤:២៤ ឆ យរ ៤០:៥ ជ លវ ២៦:៣១ ចទ ២៩:២៣ អស ៦:១១ **៤៤:៣** ឈ នក ៣២:២២ ញ ជន ១១:៣៣ ដ ជន ១៦:៤០ ឋ ខ.៨ ជន ២៥:៣ ចទ ១៣:៦-១១ ២៩:២៦ អស ១៩:១ ឌ ពច ២:១៩ **៤៤:៤** ឍ យរ ៧:១៣ ណ ជន ១១:២៩

៣២:៦-១៥ ៤០:១-៦ ៤២:១៣-២២ ។

**៤៣:៧** *ក្រុងថាផ្នេស* សូមមើលការពន្យល់ ២:១៦ ។

**៤៣:៩** *ដំណាក់ផារ៉ោន* ក៏មិនសំខាន់ទៅលើទីរាជ្យដ៏សំខាន់ ឬធំឡើយ ។ ការដែលបានបង្ហាញនៅខនេះ គឺចង់បញ្ជាក់ពីដំណាក់របស់ស្តេច ដែលជាព្រះរាជ្យដំណាក់ដែលសមរម្យ សម្រាប់ការប្រើប្រាស់របស់ស្តេចផារ៉ោន ខណៈពេលដែលស្តេចផារ៉ោន បាននៅព្រះពាធទៅលេងអីលីបាទីន ក្នុងស្រុកអេស៊ីព្ទខាងត្បូង ។

**៤៣:១០** *នេប៊ូក្នេសា ស្តេចបាប៊ីឡូនជាអ្នកបំរើរបស់អញមក* មើលការពន្យល់ ២៥:៩ ។ *តាំងបល្ល័ង្ករបស់គេ* គឺជាតំណាងឱ្យពីអំណាចគ្រប់គ្រងរបស់ទ្រង់។

**៤៣:១១** សូមមើល ១៥:២ និងការពន្យល់ ។ *គេនឹងមកវាយស្រុកអេស៊ីព្ទ* ជាផ្នែកចែកដាច់ពីគ្នា ក៏មានការគ្រប់គ្រងដោយសារៈមន្ទីអង់គ្លេសក្នុងរដ្ឋឡុនដុនដែលស្តេចនេប៊ូក្នេសាបានអនុវត្តនូវកិច្ចប្រត្តបត្តិការណ៍កងទ័ព ដើម្បីព្រមាណប្រឆាំងនឹងពួកអេស៊ីព្ទក្នុងឆ្នាំទី ៣៧ គឺក្នុងចន្លោះឆ្នាំ (៥៦៨-៥៦៧ មុន ស.គ) គឺក្នុងកំឡុងពេលការគ្រងរាជ្យរបស់ស្តេចផារ៉ោន (សូមមើល អគ ២៩:១៧-២០ និងការពន្យល់) ។

**៤៣:១២** *ដូចជាអ្នកគង្វាលពាក់អាវខ្លួន* ទម្លាប់ធ្វើដដែលៗ ហើយជាការសម្ងាត់ ។

**៤៣:១៣** វិហារនៃព្រះរបស់ស្រុកអេស៊ីព្ទ គឺជាតំបន់ "បេត-សេមែស គឺនៅក្នុងស្រុកអេស៊ីព្ទ" ក៏កុំច្រឡំស្រុកបេត-សេមែស នៅក្នុងស្រុកយូដា (២ពវ ១៤:១១) ។ ជាទីក្រុងនៃប្រទេសអេស៊ីព្ទ ក៏បង្ហាញពីទីក្រុងឈ្មោះហែលី-ប៉ូលីស ជាភាសាក្រិកគឺជា"ទីក្រុងនៃព្រះអាទិត្យ" ឯក្នុងព្រះគម្ពីរភាសាហេព្រើរគេហៅថា "អន" (On) (សូមមើលការពន្យល់ លប ៤១:៤៥) ។ *រូបព្រះ* ដែលពីមុនជារូបព្រះធ្វើពីថ្មហើយមានឈ្មោះល្បីល្បាញណាស់ ។

**៤៤:១-៣០** គឺជាវគ្គទំនាយកត់ត្រាពីហោរាយេរេមា ចុងក្រោយបំផុត (សូមមើលការពន្យល់ ៤០:១-៤៤:៣០) ។

**៤៤:១** *ពួកយូដាទាំងប៉ុន្មាន ដែលនៅស្រុកអេស៊ីព្ទ* គឺជាលទ្ធផលដោយសារការនិរទេសតាំងពីមុនមកម្លេះ (មើល ឧទាហរណ៍ ២ពវ ២៣:៣៤) ។ គឺជាពួកយូដាដែលបានបង្ហាញប្រាប់ក្នុង ៤៣:៥-៧ មានករណីខ្លះក៏មានពេលកន្លង ឬចន្លោះរវាងជំពូកទី ៤៣ និង ៤៤ គឺជាការប្រមូលផ្តុំគ្នាមាន ខ.១៥ ។ គឺត្រង់អេស៊ីព្ទទីទំនាបស្រុកអេស៊ីព្ទទីខ្ពស់ ។ សូមមើលការពន្យល់ អស ១១:១១ ។ *ត្រង់មីកដុល* គឺប្រហែលជានៅត្រង់អេស៊ីព្ទខាងជើង (សូមមើល ៤៦:១៤) ។ ហើយសូមមើលការពន្យល់ ២:១៦ អស ១៩:១៣ ។

**៤៤:៣** សូមមើលការពន្យល់ ១:១៦ ១១:១៧ ១៩:៤ ៣២:៣២ ។

**៤៤:៤** សូមមើល ៧:២៥ និងការពន្យល់ ។ *កុំធ្វើការគួរខ្ពើម* សូមមើល ពច

កុំធ្វើការគួរខ្ពើម[ត] ដែលអញស្អប់នេះឡើយ ៥តែគេមិនបាន
ស្តាប់តាម ឬផ្ទៀងត្រចៀក[ថ,ទ] ដើម្បីនឹងបែរចេញពីអំពើ
អាក្រក់[ធ]របស់គេ ដោយលែងដុតកំញាន[ន]ថ្វាយដល់ព្រះដទៃ
ឡើយ[ប] ៦ហេតុនោះបានជាសេចក្តីកំហឹង និងសេចក្តីក្រោធ
របស់អញបានចាក់ចេញ[ផ] ហើយកាត់ឆេះឡើង នៅក្នុងទី
ក្រុងស្រុកយូដាទាំងប៉ុន្មាន និងនៅអស់ទាំងផ្លូវរបស់ក្រុង
យេរូសាឡិមផង ដូច្នេះ ទីក្រុងទាំងនោះត្រូវខូចបង់ ហើយ
ចោលស្ងាត់[ព] ដូចជាសព្វថ្ងៃនេះ ៧ហេតុនោះឥឡូវនេះ
ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់មានបន្ទូលថា ហេតុអ្វីបានជាឯងរាល់គ្នា
ប្រព្រឹត្តអំពើអាក្រក់[ភ]យ៉ាងធំនេះ ទាស់នឹងព្រលឹងរបស់
ខ្លួនដូច្នេះ ជាការដែលនឹងកាត់ពួកឯងរាល់គ្នាទាំងប្រុស
ទាំងស្រី[ម] ទាំងក្មេង និងកូនចៅបៅ ចេញពីពួកយូដា ឥតទុក
ឱ្យមានណាមួយនៅសល់ឡើយ[យ] ៨ដោយដៃឯងរាល់គ្នាតែង
ប្រព្រឹត្ត[រ]ការដែលនាំឱ្យអញខឹង គឺការដុតកំញាន[ល]ថ្វាយដល់
ព្រះដទៃនៅក្នុងស្រុកអេស៊ីព្ទ[វ] ជាកន្លែងដែលឯងរាល់គ្នា
បានទៅ ស្នាក់នៅនោះ[ស] ជាការដែលនឹងកាត់ឯងរាល់គ្នា
ចេញ ហើយឱ្យឯងរាល់គ្នាត្រឡប់ជាទីផ្តាសា និងជាទីត្មះតិះ
ដៀល[ហ] នៅកណ្តាលអស់ទាំងសាសន៍នៅផែនដី ៩តើឯង
រាល់គ្នាបានភ្លេចអំពើអាក្រក់របស់ពួកឰយុកោឯង[ឡ] ហើយ
អំពើអាក្រក់របស់ពួកស្តេច[អ]យូដា និងភរិយា[ក]របស់គេ ព្រម
ទាំងអំពើអាក្រក់ដែលខ្លួនឯងរាល់គ្នា និងប្រពន្ធ[ខ]របស់ឯង
រាល់គ្នាប្រព្រឹត្តផង គឺជាការដែលគ្រប់គ្នាបានធ្វើនៅក្នុង
ស្រុកយូដា ហើយនៅផ្លូវក្រុងយេរូសាឡិមទាំងប៉ុន្មានឬអី[គ]
១០ដរាបដល់សព្វថ្ងៃនេះ ឯងរាល់គ្នាមិនទាន់បន្ទាបខ្លួននៅ
ឡើយ[ឃ] ក៏មិនបានកោតខ្លាច[ង] ឬប្រព្រឹត្តតាមក្រិត្យវិន័យនិង
បញ្ញត្ត[ច]ច្បាប់[ឆ]របស់អញ ដែលអញបានដាក់នៅមុខឯង
រាល់គ្នា និងពួកឰយុកោរបស់ឯងរាល់គ្នាផង[ជ]។
១១ហេតុនោះ ព្រះយេហូវ៉ានៃពួលពលបរិវារ[ឈ] ជា

**៤៤:៤** ត ចទ ១៨:៩ ១ពវ ១៤:២៤ ១ពត ៤:៣
**៤៤:៥** ថ ដយ ៩:៦ ទ យរ ២៥:៤ ធ លប ៦:៥ រម ១:១៨ ២ធថ ២:១៩ ន ខ.២១ យរ ១:១៦ អក ៨:១១ ១៦:១៨ ២៣:៤១ ប យរ ១១:៨–១០ ២៥:៧
**៤៤:៦** ផ អក ៨:១៨ ២០:៣៤ ព លវ ២៦:៣១,៣៤ ចទ ២៩:២៣ បទ ១:១៣ សក ៧:១៤
**៤៤:៧** ភ យរ ២៦:១៩ ម យរ ៥១:២២ យ ២ពវ ២១:១៤
**៤៤:៨** រ អស ៤០:១៨–២០ យរ ១០:៣ រម ១:២៣ ល ខ.១៧–២៥ យរ ៤១:៥ វ ខ.៣ នក ១២:១២ ស ១កថ ១០:២២ ហ ទដ ៤៤:១៣
**៤៤:៩** ឡ ពច ២:១៩ អ ២ពវ ២៣:១១ ក ១ពវ ២១:២៥ ខ សភ ៣១:១០ យរ ៦:១២ គ ខ.១៧,២១ យរ ១១:១២ ៣២:៣២
**៤៤:១០** ឃ ចទ ៨:៣ មថ ២៣:១២ ភល ២:៨ ង ចទ ៦:១៣

ព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា មើល
អញនឹងតាំងមុខទាស់នឹងឯងរាល់គ្នាសំរាប់ជាការអាក្រក់[ញ]
គឺដើម្បីនឹងកាត់ពួកយូដាទាំងអស់ចេញ ១២អញនឹងចាប់យក
សំណល់[ដ]ពួកយូដា ដែលបានតាំងចិត្តនឹងទៅអាស្រ័យនៅ
ឯស្រុកអេស៊ីព្ទ ឱ្យគេវិនាសអស់រលីងទៅ គឺគេនឹងដួលនៅ
ក្នុងស្រុកអេស៊ីព្ទ គេនឹងសូន្យទៅដោយដាវ នឹងអំណត់អត់
គេនឹងស្លាប់ទៅ ចាប់តាំងពីអ្នកតូចបំផុតរហូតដល់អ្នកធំ
បំផុត[ឋ] ដោយសារដាវ និងអំណត់អត់[ឌ] នោះគេនឹងត្រឡប់
ជាទីត្មះតិះដៀល ជាទីស្រឡាំងកាំង និងជាទីផ្តាសា
ហើយជាទីប្រមាថមើលងាយ[ឍ] ១៣ដ្បិតអញនឹងធ្វើទោស[ណ]
ដល់ពួកអ្នក ដែលស្នាក់នៅក្នុងស្រុកអេស៊ីព្ទនេះ ដូចជាអញ
បានធ្វើទោសដល់ក្រុងយេរូសាឡិមដោយដាវ[ត] អំណត់អត់
និងអាសន្នរោគដែរ[ថ] ១៤ដល់ម៉្លេះបានជាក្នុងសំណល់ពួក
យូដា ដែលបានមកអាស្រ័យនៅក្នុងស្រុកអេស៊ីព្ទ នោះនឹង
គ្មានអ្នកណាមួយរួចខ្លួនឬសល់នៅ ដើម្បីនឹងវិលទៅក្នុង
ស្រុកយូដា ដែលគេប្រាថ្នាចង់ត្រឡប់ទៅអាស្រ័យនៅនោះ
ឡើយ ដ្បិតនឹងគ្មានអ្នកណាវិលទៅវិញសោះ លើកលែងតែ
ពួកអ្នកដែលនឹងរត់រួចបានប៉ុណ្ណោះ[ទ]។
១៥ឯបណ្តាមនុស្សទាំងប៉ុន្មានដែលដឹងថា ប្រពន្ធ[ធ]ខ្លួន
ធ្លាប់ដុតកំញាន[ន]ថ្វាយដល់ព្រះដទៃ និងពួកស្រីៗ[ប]ទាំងអស់
ដែលឈរនៅទីនោះ ជាជំនុំយ៉ាងធំ គឺបណ្តាមនុស្សដែល
អាស្រ័យនៅត្រង់ប៉ាត្រូសក្នុងស្រុកអេស៊ីព្ទ[ផ] គេឆ្លើយដល់
យេរេមាថា ១៦ឯពាក្យដែលលោកបានប្រាប់មកយើង
ដោយនូវព្រះនាមព្រះយេហូវ៉ានោះ យើងមិនព្រមស្តាប់

ទដ ៥:៧ ច យស ១:៧ យរ ១១:៨ មថ ៥:១៧–២០ កទ ៣:១៩ ១យហ ៣:៤ ឆ លវ ១៨:៤ ជ ១ពវ ៩:៦–៩ ២ពវ ១៧:១៧ **៤៤:១១** ឈ វវ ៤:៨ ញ ២របា ៣៤:២៤ អម ៩:៤ **៤៤:១២** ដ ខ.៧ យរ ៤០:១៥ ឋ យរ ៤២:១ ឌ អស ១:២៨ ឍ ចទ ២៨:២៥ យរ ២៩:១៨ **៤៤:១៣** ណ នក ៣២:៣៤ លវ ២៦:១៤–១៧ ត យរ ១៥:២ ថ យរ ៤២:១៧ **៤៤:១៤** ទ យរ ២២:២៤–២៧ ៤៩:៥ បទ ៤:១៥ អក ៦:៨ រម ៩:២៧ **៤៤:១៥** ធ សភ ៣១:១០ យរ ៦:១២ ន យរ ១៨:១៥ ប លប ៣:៦ ១ធថ ២:១៤ ផ អស ១១:១១

១៩:២៤ ។

**៤៤:៦** *សេចក្តីកំហឹង និងសេចក្តីក្រោធរបស់អញបានចាកចេញ* សូមមើល ៧:២០ ៤២:១៨ ។

**៤៤:៧** *ប្រព្រឹត្តការអាក្រក់យ៉ាងធំនេះ ទាស់នឹងព្រលឹងរបស់ខ្លួន* សូមមើល ២៦:១៩ ។ *ទាំងប្រុស ទាំងស្រី ទាំងក្មេង និងកូននៅបៅ* អត្ថន័យឃ្លានៃពាក្យទាំងនេះគឺ ចំពោះ"មនុស្សគ្រប់រូបទាំងអស់" (សូមមើល ១សយ ១៥:៣ ២២:១៩) ។

**៤៤:៨** *ដោយដៃឯងរាល់គ្នាតែងប្រព្រឹត្តការដែលនាំឱ្យអញខឹង* គឺជាការទាក់ទងនិងការថ្វាយបង្គំរូបព្រះ ឬវិញ្ញាណអាក្រក់ (សូមមើល ១:១៦ និងការពន្យល់ នក ៣៤:១៥) ។ *ត្រឡប់ជាទីផ្តាសា និងជាទីត្មះតិះដៀល* សូមមើល ៤២:១៨ ២៤:៩ ២៥:១៨ ។

**៤៤:៩** *អំពើអាក្រក់របស់ពួកឰយុកោឯង . . . ពួកស្តេច . . . ភរិយារបស់គេ* ស្ត្រីបានចូលរួមនិងប្តី ពួគេត្រូវការថ្វាបង្គំព្រះ "ស្តេចនៃស្ថានសួគ៌"(ខ.១៩ សូមមើល ខ.១៥) ។

**៤៤:១០** *ឬប្រព្រឹត្តតាមក្រិត្យវិន័យ* សូមមើល ៩:១៣ ២៦:៤ ៧:៩ និងការពន្យល់ ។

**៤៤:១១** *និងតាំងមុខ* "គឺការផ្តោតភ្នែក ឬមុខមើលទៅលើ" (សូមមើល ២១:១០ និងការពន្យល់) ។

**៤៤:១៥** *ប្រពន្ធ . . . ពួកស្រីៗ* សូមមើល ខ.១៩ និងការពន្យល់ ខ.៩ ។ *នៅត្រង់ប៉ាត្រូសក្នុងស្រុកអេស៊ីព្ទ* សូមមើល ខ.១ និងការពន្យល់ អស ១១:១១ ។

តាម[ព]ទៅ[ភ] ១៧គឺយើងនឹងប្រព្រឹត្តតាមតែពាក្យទាំងប៉ុន្មាន
ដែលចេញពីមាត់យើងវិញ[ម] ដើម្បីនឹងដុតកំញាន[យ]ថ្វាយដល់
ព្រះចន្ទ[រ] ហើយនឹងច្រូចដង្វាយច្រូចថ្វាយទ្រង់ដែរ ដូចជា
យើងបានធ្លាប់ធ្វើមកហើយ ទោះទាំងខ្លួនយើង ពួកព្ធយុកោ
យើង និងពួកស្ដេច ហើយពួកចៅហ្វាយ[ល]របស់យើង នៅ
ក្នុងទីក្រុងទាំងប៉ុន្មានរបស់ស្រុកយូដា ហើយនៅអស់ទាំង
ផ្លូវរបស់ក្រុងយេរូសាឡិមផង[វ] ដ្បិតនៅគ្រានោះ យើងមាន
អាហារ[ស]ជាបរិបូរ ហើយក៏នៅដោយសប្បាយ ឥតឃើញ
សេចក្ដីអាក្រក់ណាឡើយ[ហ] ១៨តែតាំងពីយើងលះលែងការ
ដុតកំញានថ្វាយដល់ព្រះចន្ទ ហើយច្រូចដង្វាយច្រូច[ឡ] ថ្វាយ
ទ្រង់ទៅ នោះយើងចេះតែខ្វះខាតគ្រប់ទាំងអស់ ហើយបាន
វិនាសទៅដោយដាវ និងអំណត់អត់ផង[អ,ក] ១៩មួយទៀត
កាលយើងបានដុតកំញាន[ខ]ថ្វាយដល់ព្រះចន្ទ[គ] ហើយច្រូច
ដង្វាយច្រូចថ្វាយទ្រង់ នោះតើយើងបានធ្វើនំ[ឃ]សំរាប់
គោរពដល់ទ្រង់[ង] ហើយច្រូចដង្វាយច្រូច ថ្វាយដល់ទ្រង់
ក្រៅពីប្ដី[ច]យើងឬ ។
២០ឯបណ្ដាជនប្រុសស្រីទាំងឡាយ គឺអស់មនុស្សដែល
បានឆ្លើយមកយេរេមាដូច្នោះ នោះលោកប្រាប់ដល់គេថា
២១កំញាន[ឆ]ដែលអ្នករាល់គ្នាបានដុត នៅក្នុងទីក្រុងស្រុក
យូដាទាំងប៉ុន្មាន ហើយនៅអស់ទាំងផ្លូវក្រុងយេរូសាឡិម[ជ]
ទោះទាំងអ្នករាល់គ្នា ពួកព្ធយុកោ[ឈ] ពួកស្ដេច ពួក
ចៅហ្វាយ និងបណ្ដាជននៅក្នុងស្រុកទាំងប៉ុន្មាន[ញ] នោះតើ
ព្រះយេហូវ៉ាមិនបាននឹកចាំ[ដ] តើទ្រង់មិនបានរឭកពីអំពើ
ទាំងនោះទេឬអី ២២ដល់ម៉្លេះបានជាព្រះយេហូវ៉ាទ្រង់ទ្រាំ
មិនបានទៀត[ឋ] ដោយព្រោះអំពើអាក្រក់ទាំងប៉ុន្មានរបស់
អ្នករាល់គ្នា ហើយដោយព្រោះការគួរខ្ពើម ដែលអ្នករាល់
គ្នាបានប្រព្រឹត្ត គឺហេតុនោះបានជាស្រុករបស់អ្នករាល់គ្នា
ត្រូវចោលស្ងាត់[ឌ] ហើយបានត្រឡប់ជាទីស្រឡាំងកាំង និងទី
ផ្តាសា[ឍ] ឥតមានអ្នកណាអាស្រ័យនៅ ដូចជាសព្វថ្ងៃនេះ[ណ]
២៣ពីព្រោះ អ្នករាល់គ្នាបានដុតកំញាននោះ ហើយធ្វើបាប
នឹងព្រះយេហូវ៉ាវិញ ក៏មិនបានស្ដាប់តាមព្រះបន្ទូលរបស់
ព្រះយេហូវ៉ា ឬប្រព្រឹត្តតាម[ត]ក្រិត្យវិន័យទ្រង់ ឬតាមបញ្ញត្ត
ច្បាប់[ថ] ឬសេចក្ដីបន្ទាល់របស់ទ្រង់ឡើយ គឺហេតុនោះបាន
ជាការអាក្រក់នេះ[ទ]បានកើតដល់អ្នករាល់គ្នា ដូចជាសព្វថ្ងៃ
នេះ[ធ] ។
២៤មួយទៀត យេរេមាក៏ប្រាប់ដល់ជនទាំងឡាយ គឺ
ដល់ទាំងពួកស្រីៗផងថា[ន] នែ ពួកយូដាទាំងប៉ុន្មាន ដែល
អាស្រ័យនៅស្រុកអេស៊ីព្ទអើយ[ប] ចូរស្ដាប់ព្រះបន្ទូលនៃព្រះ
យេហូវ៉ាចុះ ២៥ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃ
សាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះ ឯងរាល់គ្នា
ព្រមទាំងប្រពន្ធរបស់ឯង[ផ] បានចេញវាចាពីមាត់រៀងខ្លួន
ហើយ ក៏បានសំរេចតាម ដោយដៃខ្លួនដែរ ថាយើងរាល់
គ្នានឹងលាបំណន់ ដែលយើងបានបន់ជាមិនខាន គឺនឹងដុត
កំញានថ្វាយដល់ព្រះចន្ទ[ព] ហើយច្រូចដង្វាយច្រូចថ្វាយ ទ្រង់
ដែរ ដូច្នេះ ចូរឱ្យឯងរាល់គ្នាបន់ទៅ ហើយលាបំណន់
របស់ឯងចុះ[ភ] ២៦នែ ពួកយូដាទាំងប៉ុន្មាន ដែលអាស្រ័យ
នៅស្រុកអេស៊ីព្ទអើយ[ម] ចូរស្ដាប់តាមព្រះបន្ទូលនៃព្រះ
យេហូវ៉ាចុះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល អញបាន
ស្បថ[យ] ដោយឈ្មោះដ៏ធំរបស់អញថា ឈ្មោះអញនឹងមិន
ដែលចេញពីមាត់របស់ពួកយូដាណាមួយ ដែលអាស្រ័យ
នៅក្នុងស្រុកអេស៊ីព្ទទៀត តាមសំបថដែលគេធ្លាប់ស្បថថា
ដូចជាព្រះអម្ចាស់យេហូវ៉ា[រ] ទ្រង់មានព្រះជន្មរស់នៅនោះ

**៤៤:១៦** ព ១សយ ៨:១៩ យប ១៥:២៥–២៦ យរ ១១:៨–១០ ភ យរ ៤២:១៩ **៤៤:១៧** ម ខ.២៨ ចទ ២៣:២៣ សក ១:៦ យ អស ៦៥:៣ រ ខ.២៥ យរ ១១:១២ ល នហ ៩:៣៤ វ ខ.៩ យរ ២:២៦ ស នក ១៦:៣ ជន ១១:៤–៦ ហ យប ២១:១៥ អស ៣:៩ ហស ២:៥–១៣ ៩:១ **៤៤:១៨** ឡ លវ ៣:១៨ អ មឡ ៣:១៣–១៥ ក យរ ៤២:១៦ **៤៤:១៩** ខ យរ ១៨:១៥ គ យរ ៧:១៨ ឃ លវ ៧:១២ ង លវ ២៦:១ កច ១៧:២៩ ច លប ៣:៦ អភ ៥:២២ **៤៤:២១** ឆ យរ ១១:១៣ ជ ខ.៩ ឈ ទដ ៧៩:៨ ញ យរ ២:២៦ ដ អស ៦៤:៩ យរ ១៤:១០ ហស ៨:១៣ **៤៤:២២** ឋ អស ១:១៤ ឌ លវ ២៦:៣១,៣២ ឍ យរ ២៥:១៨ ណ លប ១៩:១៣ ទដ ១០៧:៣៣–៣៤ អគ ៣៣:២៨–២៩ **៤៤:២៣** ត ១ពវ ៩:៦ ថ លវ ១៨:៤ ទ យរ ៤០:២ ធ លវ ២៦:៣៣ ១ពវ ៩:៩ យរ ៧:១៣–១៥ អគ ៣៩:២៣ ដយ ៩:១១–១២ **៤៤:២៤** ន លប ៣:៦ ប យរ ៤៣:៧ **៤៤:២៥** ផ សភ ៣១:១០ ព ខ.១៧ ចទ ៣២:៣៨ ភ សភ ២០:២៥ អគ ២០:៣៩ យក ១:១៣–១៥ **៤៤:២៦** ម យរ ២៤:៨ យ លប ២២:១៦ អស ៤៨:១ កច ១៩:១៣ ហព ៦:១៣–១៧ រ លប ១៥:២

**៤៤:១៧** *ថ្វាយដល់ព្រះចន្ទ* សូមមើលការពន្យល់ ៧:១៨ ។
**៤៤:១៨** *យើងលះលែងការដុតកំញាន* ដោយសារលទ្ធផលនៃចលនាតែសត្រូវរបស់ស្ដេចយ៉ូអសដែលចាប់ផ្ដើមនៅឆ្នាំ ៦២១ មុន ស.គ ។ *នោះយើងចេះតែខ្វះខាតគ្រប់ទាំងអស់* គឺមានតាំងពីកាលដែលស្ដេចយ៉ូអាស បានទទួលមរណៈភាពមកម្លេះ គឺក្នុងឆ្នាំង ៦០៩ គឺការទទួលរងនូវភាពហិនវិនាសខ្លោចផ្សា មានទាំងការលុកលុយឈ្លានពានពីពួកសត្រូវ និងការបំបោះបង់ក៏បានទទួលរងដល់ពួកយូដា ។ ប្រជារាស្ត្របានយល់(ថាវាគឺជាកំហុស) ថាជាអកុសលដោយសារពួកគេខកខានក្នុងការថ្វាយបង្គំដល់ព្រះចន្ទ ។
**៤៤:១៩** *កាលយើងបាន* ជាពាក្យសម្ដីរបស់ពួកស្រីៗទាំងអស់ ដែលដុតកំញានថ្វាយដល់ព្រះចន្ទ ដោយពេលនោះពួកស្រីៗដើរតួនាទីសំខាន់ក្នុងការថ្វាយបង្គំ ។ *ក្រៅពីប្ដីយើង* គឺដើម្បីឱ្យគេទទួលស្គាល់ ឬយកជាការក្នុងការសច្ចារស្បថតាមទំលៀមទម្លាប់សាសនា ដែលធ្វើឱ្យស្ត្រីដែលរៀបការរួច (សូមមើល ខ.២៥) ក៏បានបញ្ជាក់ពីប្ដីរបស់នាងផងដែរ (មើល ជន ៣០:១០–១៥) ។ *យើងបានធ្វើនំសំរាប់គោរពដល់ទ្រង់* សូមមើល ៧:១៨ ។
**៤៤:២២** *ជាទីផ្តាសា* សូមមើល ខ.១២ ។ *ត្រូវចោលស្ងាត់* សូមមើល ខ.៦ ។
**៤៤:២៣** *សេចក្ដីបន្ទាល់* គឺជារបស់ព្រះយេហូវ៉ាជាមួយនិងរាស្ត្ររបស់ផងទ្រង់ (សូមមើល ចទ ៤:៤៥ ៦:១៧,២០) ។
**៤៤:២៥** *ចូរឱ្យឯងរាល់គ្នាបន់ទៅ* គឺជាការមានបន្ទូលចំអកឱ្យ (សូមមើល ៧:២១ និងការពន្យល់) ។
**៤៤:២៦** *អញបានស្បថដោយឈ្មោះដ៏ធំរបស់អញថា* សូមមើលការពន្យល់ ២២:៥ ។ *ធ្លាប់ស្បថថាដូចជាព្រះអម្ចាស់យេហូវ៉ា ទ្រង់មានព្រះជន្មរស់នៅ* សូមមើលការពន្យល់ លប ៤២:១៥ ។

ឡើយ[ល] ២៧ មើល អញនឹងត្រួតមើល[វ]គេ សំរាប់ជាសេចក្តី
អាក្រក់[ស] មិនមែនជាសេចក្តីល្អទេ ហើយពួកយូដាទាំង
ប៉ុន្មានដែលអាស្រ័យនៅក្នុងស្រុកអេស៊ីព្ទ និងសាបសូន្យ[ហ]
ទៅដោយដាវ និងអំណត់អត់[ឡ] ដរាបដល់អស់រលីងទៅ[អ]
២៨ ឯពួកអ្នកដែលរួចពីដាវ[ក] គេនឹងចេញពីស្រុកអេស៊ីព្ទ
វិលទៅឯស្រុកយូដាវិញ មានគ្នាតិចទេ[ខ] នោះសំណល់[គ]ពួក
យូដាទាំងប៉ុន្មាន ដែលបានទៅអាស្រ័យនៅស្រុកអេស៊ីព្ទ
គេនឹងដឹងជាពាក្យណាដែលនឹងស្ថិតស្ថេរនៅ[ឃ] ទោះបើជា
ពាក្យរបស់អញ ឬពាក្យរបស់គេក្តី[ង] ២៩ ហើយព្រះយេហូវ៉ា
ទ្រង់មានបន្ទូលថា នេះនឹងបានជាទីសំគាល់[ច]ឲ្យឯងរាល់គ្នា
ដឹងថា អញនឹងធ្វើទោស[ឆ]ដល់ឯងនៅទីនេះ ដើម្បីឲ្យឯង
រាល់គ្នាបានដឹងថា ពាក្យរបស់អញនឹងបានតាំងទាស់នឹង
ឯង សំរាប់ជាការអាក្រក់[ជ] ៣០ គឺព្រះយេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះថា មើល អញនឹងប្រគល់ផារ៉ោន[ឈ]-ហុបរ៉ា
ស្តេចស្រុកអេស៊ីព្ទទៅក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ
គឺទៅក្នុងកណ្តាប់ដៃនៃពួកអ្នកដែលរកជីវិតវា ដូចជាអញ
បានប្រគល់ដល់សេដេគា[ញ] ជាស្តេចយូដា នៅក្នុងកណ្តាប់
ដៃនៃនេប៊ូក្នេសា ស្តេចបាប៊ីឡូន ដែលជាខ្មាំងសត្រូវ ហើយ
ក៏រកជីវិតវាដែរ[ដ]។

## ព្រះរាជសារដល់លោកបារូក

**៤៥** ១ នេះជាពាក្យដែលហោរាយេរេមាបាននិយាយនឹង
បារូក[ក] ជាកូននេរីយ៉ា[ខ] ក្នុងកាលដែលបារូកបានសរសេរ
ពាក្យទាំងនេះ ចុះក្នុងក្រាំង[គ]តាមមាត់យេរេមា គឺនៅក្នុងឆ្នាំ
ទី៤នៃរាជ្យយេហូយ៉ាគីម[ឃ] ជាបុត្រយ៉ូសៀស ស្តេចយូដា
២ គឺថា ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់
មានបន្ទូលដល់បារូកឯងដូច្នេះ ៣ ឯងបាននិយាយថា ឥឡូវ
នេះ វរហើយ[ង]ខ្ញុំ ដ្បិតព្រះយេហូវ៉ា ទ្រង់បានបន្ថែមសេចក្តី
សោកសៅ[ច] ដល់សេចក្តីទុក្ខព្រួយ[ឆ]របស់ខ្ញុំ ខ្ញុំក៏ល្វើយទៅ
ដោយថ្ងូរ[ជ] ឥតមានសេចក្តីសំរាកឡើយ[ឈ] ៤ ត្រូវឲ្យនិយាយ
នឹងវាយ៉ាងនេះថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ មើល
របស់អ្វីដែលអញបានស្អាងឡើង នោះអញនឹងរំលំចុះ
ហើយរបស់អ្វីដែលអញបានដាំ[ញ] នោះអញនឹងដករំលើង
វិញ[ដ] ក៏នឹងធ្វើយ៉ាងនោះនៅពេញក្នុងស្រុកផង[ឋ] ៥ ដូច្នេះ តើ
ឯងស្វែងរកការយ៉ាងធំ[ឌ]សំរាប់ខ្លួនឬ កុំឡើយ[ឍ] ដ្បិតព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា មើល អញនឹងនាំសេចក្តី
អាក្រក់[ណ]មកលើគ្រប់ទាំងសាច់[ត] តែឯជីវិតឯង នោះអញនឹង
ឲ្យដល់ឯងទុកជារំពា នៅគ្រប់ទីកន្លែងណាដែលឯងនឹង
ទៅ[ថ]ផង[ទ]។

## ព្រះរាជសារអំពីនគរអេស៊ីព្ទ

**៤៦** ១ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដល់

**៤៤:២៦** ល ចទ ៣២:៤០ ទដ ៥០:១៦ យរ ៤:២ **៤៤:២៧** វ យរ ១:១២ ស យរ ២១:១០ ហ លវ ២៦:៣៨ យប ១៥:២២ ២ពត ៣:៩ ឡ លប ៤១:៥៥ អ យរ ៩:១៦ ដយ ៩:១៤ អម ៩:៨ **៤៤:២៨** ក យរ ៤៥:៥ អក ៦:៨ ខ ខ.១៣-១៤ អស ១០:១៩ គ ២ពវ ២១:១៤ ឃ អស ៧:៩ យរ ៣៩:១៦ ៤២:១៥-១៨ ង ខ.១៧,២៥-២៦ **៤៤:២៩** ច លប ២៤:១៤ អគ ៣:១២ ជន ១៦:៣៨ មថ ១២:៣៨ ២៤:៣ ឆ នក ៣២:៣៤ ជ សភ ១៩:២១ **៤៤:៣០** ឈ យរ ២៥:១៩ ៤៦:២៦ អគ ៣០:២១ ៣២:៣២ ញ ២ពវ ២៥:១-៧ យរ ២៤:៨ ដ យរ

៤៣:៩-១៣ **៤៥:១** ក យរ ៣២:១២ ខ យរ ៥១:៥៩ គ នក ១៧:១៤ ទដ ៤០:៧ ឃ ២រប ៣៦:៥ **៤៥:៣** ង អស ២៤:១៦ ១កថ ៩:១៦ ច ទដ ១១៩:២៨ មក ១៤:៣៤ រម ៩:២ ឆ យប ៦:១០ ជ យប ២៣:២ ទដ ៦៩:៣ ឈ យស ១:១៣ មថ ១១:២៨ ហត ៤:៣ **៤៥:៤** ញ យរ ១១:១៧ ដ យរ ៤២:១០ ឋ ចទ ២៨:៦៣ ៣០:៩ អស ៥:៥-៧ យរ ១៨:៧-១០ **៤៥:៥** ឌ ទដ ១៣១:១ ឍ មថ ៦:២៥-២៧,៣៣ ណ យរ ១១:១១ ៤០:២ ត យរ ២:៣៥ ថ ទដ ៦៨:២០ យរ ៤៤:២៨ ទ យរ ២១:៩

**៤៤:២៧** *ត្រួតមើលគេ* សូមមើលការពន្យល់ ១:១២ និងមើល ៣១:២៨ ។

**៤៤:២៨** *មានគ្នាតិចទេ* សូមមើល ខ.១៤ ។

**៤៤:៣០** *ផារ៉ោន-ហុបរ៉ា* ជាស្តេចដឹកនាំប្រទេសអេស៊ីព្ទក្នុងឆ្នាំ ៥៨៩-៥៧០ មុន ស.គ (សូមមើល ៣៧:៥ និងការពន្យល់) ។ *ដែលជាខ្មាំងសត្រូវហើយក៏រកជីវិតវាដែរ* មានស្តេចហុបរ៉ាដែលជាតិសាសន៍អេស៊ីព្ទរបស់ទ្រង់បានសម្លាប់ទ្រង់ ។ *បានប្រគល់សេដេគាជាស្តេចយូដា ទៅក្នុងកណ្តាប់ដៃនៃនេប៊ូក្នេសា* សូមមើល ៣៩:៥-៧ ។

**៤៥:១៥** គឺជាវគ្គសំបុត្រសង្ខេបស្តីពីការលើកទឹកចិត្តចំពោះបារូក គឺជាលេខា ឬជាអ្នកកត់ត្រាដ៏ស្មោះត្រង់របស់ហោរាយេរេមា (សូមមើលការពន្យល់ ៣២:១២) ។ ទោះជាមិនបានតាមលំដាប់នៃឯកសារកាលប្បវត្តិក៏ដោយ ក៏ផ្នែកនេះបានផ្តល់នូវវគ្គជាចំណងជើងទៅតាមប្រធាន ឬតាមសាច់រឿងច្បាស់លាស់ ដូចជាជំពូកទី ៣៩-៤៤ ក៏បានបង្ហាញពីផ្ទៃរឿងតគ្នាទៅជំពូក ៤៦-៥១ (សូមមើលការពន្យល់ ខ.១ ៤៦:២) ។

**៤៥:១** *គឺនៅក្នុងឆ្នាំទី៤នៃរាជ្យយេហូយ៉ាគីម* ឆ្នាំ៦០៥ មុន ស.គ ជំពូក ៤៥ ដែលស៊ីគ្នានឹងពង្សាវតាក្នុងរវាងចន្លោះជំពូក ៣៦:៣,៩ (សូមមើលការពន្យល់ ៣៦:៨) ។ *បារូកបានសរសេរពាក្យទាំងនេះចុះក្នុងក្រាំង* សូមមើល ៣៦:៤ និងការពន្យល់ ៣៦:២ ។

**៤៥:៣** ជាទំហំដែលបារូក ចែកចាយពីភាពទុក្ខកង្វល់របស់យេរេមាលទ្ធផលនៃការត្រាស់ហៅតាមទំនាយរបស់ហោរាយេរេមា និងកិច្ចការបំរើព្រះ (សូមមើល ឧទាហរណ៍ ៨:១៨ ៩:២ ២០:៧-១៨) ។ *ល្វើយទៅដោយថ្ងូរ ឥតមានសេចក្តីសំរាកឡើយ* សូមមើល ទដ ៦:៦ ។ *ឥតមានសេចក្តីសំរាកឡើយ* សូមមើល បទ ៥:៥ ។

**៤៥:៤** *ស្អាងឡើង . . . រំលំចុះ . . . អញបានដាំ . . . ដករំលើងវិញ* សូមមើលការពន្យល់ ១:១០ និងមើល ២:២១ ៣១:៤-៥,២៨,៤០ ៣២:៤១ ៣៣:៧ ។ *ស្រុក* ឬក៏ជា "ផែនដីទាំងមូល" (សូមមើល "ប្រជារាស្ត្រទាំងអស់" ក្នុង ខ.៥ សូមមើល ២៥:១៥,៣១,៤៦-៥១) ។

**៤៥:៥** *ការយ៉ាងធំ . . . មើល* សូមមើល ទដ ១៣:១ សេរ៉ាយ៉ាគឺជាបទរបស់បារូក បានកាន់កាប់ការងារធំក៏មានតួនាទីយ៉ាងសំខាន់ក្រោមការគ្រប់គ្រងរបស់ស្តេចសេដេគា (សូមមើល ៣២:១២ ៥១:៥៩) ប៉ុន្តែលោកបារូកខ្លួនឯងផ្ទាល់ ពុំមានចិត្តលោភលន់នោះទេ ។ ឬក៏ព្យាយាមស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនទេ ។ *ដែលឯងនឹងទៅផង* មើលការពន្យល់ ២១:៩ ។

**៤៦:១-៥១:៦៤** សូមមើលការពន្យល់ ២៥:១-៣៨ ២៥:១៣ ២៥:១៩-២៦ ។ ជំពូក ៤៦:៥១ មានវគ្គជាខ្សែភាគពីសេចក្តីទំនាយ ប្រឆាំងនឹងជាតិសាសន៍ (សូមមើល អស ១៣-២៣ អគ ២៥-៣២ អម ១-២ សផ ២:៤-១៥) ។

ហោរាយេរេមា ពីដំណើរសាសន៍ដទៃទាំងប៉ុន្មាន[ក]។
២ពីស្រុកអេស៊ីព្ទ[ខ] គឺពីដំណើរពលទ័ពរបស់ផារ៉ោន
នេកោ[គ] ជាស្ដេចស្រុកអេស៊ីព្ទ ដែលនៅត្រង់កើតមីស[ឃ]
ក្បែរមាត់ទន្លេអ៊ើប្រាត[ង] ជាស្រុកដែលនេប៊ូក្នេសា ស្ដេច
បាប៊ីឡូនបានវាយយក ក្នុងឆ្នាំទី៤នៃរាជ្យយេហូយ៉ាគីម[ច]
ជាបុត្រយ៉ូសៀសស្ដេចយូដា ៣ចូររៀបចំខែលតូចខែលធំ[ឆ]
ហើយចូលទៅឯចំបាំងចុះ ៤ឱពួកពលសេះអើយ ចូរត្រៀម
សេះ ហើយឡើងជិះចុះ ចូរចេញមកទាំងពាក់មួកសឹក
ចូរខាត់[ជ] លំពែង ហើយពាក់អាវក្រោះទៅ[ឈ] ៥ហេតុអ្វី
បានជាអញត្រូវឃើញដូច្នេះ គេត្រូវស្លុតចិត្ត ហើយបាន
ថយចេញទៅ ពួកខ្លាំងពូកែរបស់គេបានត្រូវវាយផ្ដួលចុះ
ក៏រត់ទៅ[ញ]ឥតងាកបែរទៅខាងក្រោយឡើយ ព្រោះមាន
សេចក្ដីស្ញែងខ្លាច[ដ]នៅគ្រប់ជុំវិញ នេះជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ៦កុំបើកឱ្យមនុស្សលឿនរត់ទៅបាត់[ឋ] ឬមនុស្សខ្លាំង
ពូកែរួចខ្លួនឡើយ គេបានចំពប់ដួលចុះ[ឌ] នៅស្រុកខាងជើង
ក្បែរទន្លេអ៊ើប្រាត[ឍ]ហើយ ៧តើអ្នកណានេះ ដែលឡើងមក
ដូចជាទឹកជន់ ដែលទឹកនោះកំរើកឡើងដូចជាទន្លេ[ណ] ៨ស្រុក
អេស៊ីព្ទឡើង មកដូចជាទឹកជំនន់[ត] ហើយទឹកនោះក៏កំរើក
ឡើងដូចជាទន្លេ គេអួតថា អញនឹងក្រោកឡើង អញនឹង
គ្របលើផែនដី អញនឹងបំផ្លាញអស់ទាំងទីក្រុង និងមនុស្ស
ដែលអាស្រ័យនៅផង[ថ] ៩សេះទាំងឡាយអើយ ចូរឡើងទៅ
រទេះចំបាំងទាំងឡាយអើយ[ទ] ចូរសំរុកចូលចុះ ហើយត្រូវ
ឱ្យមនុស្សស្ទាត់ជំនាញចេញទៅដែរ គឺទាំងពួកគូស[ធ] និងពួក
ពូត ជាពួកអ្នកដែលកាន់ខែល ហើយពួកលូឌ[ន]ដែលកាន់
ហើយដំឡើងធ្នូ ១០ដ្បិតថ្ងៃនេះជាថ្ងៃ[ប]របស់ព្រះអម្ចាស់
យេហូវ៉ានៃពួកពលបរិវារ គឺជាថ្ងៃសងសឹក[ផ] សំរាប់ទ្រង់
បានសងសឹកនឹងពួកខ្មាំងសត្រូវ ហើយដាវនឹងស៊ី[ព]ទាល់តែ
ឆ្អែត ក៏ផឹកឈាមគេយ៉ាងស្កប់ស្កល់[ភ] ពីព្រោះព្រះអម្ចាស់
យេហូវ៉ា នៃពួកពលបរិវារ ទ្រង់មានយញ្ញបូជា[ម]នៅស្រុក
ខាងជើង ក្បែរទន្លេអ៊ើប្រាត[យ] ១១ឱកូនស្រីក្រមុំ[រ]នៃស្រុក
អេស៊ីព្ទអើយ ចូរឡើងទៅឯស្រុកកាឡាត យកប្រទាលមុខ

**៤៦:១** ក យរ ១:១០ **៤៦:២** ខ នក ១:៨ គ ២ពវ ២៣:២៩ ឃ ២របា ៣៥:២០ ង លប ២:១៤ ច យរ ១:៣ ២៥:១ ៣៥:១ ៣៦:១ ៤៥:១ ដយ ១:១ **៤៦:៣** ឆ អស ២១:៥ **៤៦:៤** ជ អគ ២១:៩–១១ ឈ ១សយ ១៧:៥,៣៨ ២របា ២៦:១៤ នហ ៤:១៦ **៤៦:៥** ញ ខ.២១ យរ ៤៨:៤៤ ដ ទដ ៣១:១៣ ៤៨:៥ **៤៦:៦** ឋ អស ៣០:១៦ ឌ ខ.១២,១៦ ទដ ២០:៨ ឍ លប ២:១៤ ១៥:១៨

**៤៦:៧** ណ យរ ៤៧:២ **៤៦:៨** ត អគ ២៩:៣,៩ ៣០:១២ អម ៨:៨ ថ ដយ ១១:១០ **៤៦:៩** ទ យរ ៤៧:៣ អគ ២៦:១០ ណាហ ៣:២ ធ លប ១០:៦ ន អស ៦៦:១៩ **៤៦:១០** ប អគ ៣២:១០ យអ ១:១៥ អប ១:១៥ ផ ជន ៣១:៣ ចទ ៣២:៤១ ២ពវ ២៣:២៩–៣០ ព ចទ ៣២:៤២ ២សយ ២:២៦ សផ ២:១២ ភ ចទ ៣២:៤២ ម លវ ៣:៩ សផ ១:៧ យ លប ២:១៤ ១៥:១៨ **៤៦:១១** រ ២ពវ ១៩:២១

ពួកគេបានផ្ដើមចេញពីស្រុកអេស៊ីព្ទ (ក្នុងជំពូក ៤៦) គឺមានអំណាចពីរដែលប្រឆាំងនឹងការគ្រប់គ្រងរបស់ពួកយូដាក្នុងកំឡុងពេលហោរាយេរេមាកំពុងបម្រើព្រះ ។ ក៏មានការរៀបចំនៅសេចក្ដីទំនាយទាំងឡាយ គឺក្នុងទិសដៅកំណត់ចាប់ផ្ដើមទិសខាងលិច និងទិសខាងកើត ។

**៤៦:១** *នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដល់ហោរាយេរេមា* សូមមើល ១៤:១ ៤៧:១ ៤៩:៣៤ ៥០:១ ។ *សាសន៍ទាំងប៉ុន្មាន* គឺចំពោះអស់អ្នកដែលហោរាយេរេមាហៅថាជាសេចក្ដីទំនាយ (សូមមើល ១:៥ និងការពន្យល់) ។ ដែលពួកហោរាខ្លះចេញពីពួកគេមក ។

**៤៦:២** *ពីស្រុកអេស៊ីព្ទ* សូមមើល អស ១៩:២០ អគ ២៩:៣២ ។ *នេកោ* ដែលឈ្មោះពេញ គឺស្ដេចផារ៉ោននេកោ បានដឹកនាំស្រុកអេស៊ីព្ទក្នុងឆ្នាំ ៦១០–៥៩៥ មុន ស.គ ។ *កើតមីស* ជាទីស្រុកមួយក្បែរមាត់ទន្លេអ៊ើប្រាត សូមមើល ២របា ៣៥:២០ អស ១០:៩ និងការពន្យល់ ។ ឯឈ្មោះដែលមានន័យ "បន្ទាយរបស់ព្រះកេម៉ូស" (ជាព្រះដ៏សំខាន់របស់ពួកសាសន៍ម៉ូអាប់ សូមមើល ២ពវ ២៣:១៣) ។ *ទន្លេអ៊ើប្រាត* សូមមើលការពន្យល់ លប ១៥:១៨ ។ *ស្ដេចនេប៊ូក្នេសា* ការវាយរបស់ស្រុកអេស៊ីព្ទ ដោយពួកបាប៊ីឡូននៅឯកើតមើស គឺជាសង្គ្រាមមួយ ក្នុងចំណោមសង្គ្រាមដ៏សាហាវបំផុតនៅក្នុងពិភពលោកនាសម័យបុរាណ ក៏បានបញ្ចប់ការពុះពារតវ៉ា និងការទាមទាររបស់ពួកអេសីព្ទ ដើម្បីគ្រប់គ្រងក្នុងពួកសាសន៍ភីលីស្ទីន ។ *ក្នុងឆ្នាំទី៤នៃរាជ្យយេហូយ៉ាគីម* ក្នុងឆ្នាំ៦០៥ មុន ស.គ គឺជាឆ្នាំដំបូងរបស់ស្ដេចនេប៊ូក្នេសាក្នុងការគ្រងរាជ្យ (សូមមើល ២៥:១) ។

**៤៦:៣** *ចូររៀបចំ* គឺជាការនិយាយទៅកាន់ពួកសាសន៍អេស៊ីព្ទ ក្នុងលក្ខណៈចំអកឱ្យ (សូមមើល ឧទាហរណ៍ នហ ២:១ ៣:១៤ និងការពន្យល់) ។

**៤៦:៤** *ពលសេះ* នៅស្រុកអេស៊ីព្ទគឺជាពលសេះរបស់ស្ដេច គឺជាសេះល្អៗបំផុត (សូមមើល ១ពវ ១០:២៨) ។ *ពាក់មួកសឹក* សូមមើល ៥១:៣ ។

**៤៦:៥** *សេចក្ដីស្ញែងខ្លាចនៅគ្រប់ជុំវិញ* វគ្គឃ្លាដែលគេបានប្រើមានក្នុង ៦:២៥ (សូមមើលការពន្យល់ ៦:២៥) គឺសំដៅលើកងទ័ពពួកបាប៊ីឡូន (សូមើល ៦:២២ និងការពន្យល់) ។

**៤៦:៧–៨** *ទឹកនោះកំរើកឡើងដូចជាទន្លេ* ជាដៃទន្លេអេស៊ីព្ទខាងជើង ដែលទីនោះដៃរបស់ទន្លេធំក៏ចេញទៅជាដៃតូចៗជាច្រើន ។

**៤៦:៨** *អញនឹងក្រោកឡើង . . . អញនឹងគ្របលើផែនដី* ក៏មានពាក្យប្រៀបប្រដូចដែលគេបានប្រើនៅស្រុកអាសស៊ើរ មើលក្នុង អស ៨:៧–៨ និងការពន្យល់ ។ *ទីក្រុង* ជារពះគម្ពីរភាសាហេព្រើរចំពោះពាក្យថាទីក្រុងមានលក្ខណៈឯកវចនៈ ប៉ុន្តែគេបានប្រើជាលក្ខណៈ ជាពហុវចនៈខ្លះដែរ គឺទៅតាមប្រភេទ (ពាក្យថា"ទីក្រុង"មានប្រភេទទីក្រុងដែលមានក្នុង ៨:១៦) ។

**៤៦:៩** *សេះ* សូមមើលការពន្យល់ ខ.៣ និងមើល ៨:៦ នហ ៣:៣ ។ *ចូរឡើងទៅរទេះចំបាំងទាំងឡាយអើយ* សូមមើល នហ ២:៤ ។ *ពួកពូត* សូមមើល ការពន្យល់ លប ១០:៦ ។ *ពួកលូឌដែល* មើលការពន្យល់ អស ៦៦:១៩ ។

**៤៦:១០** *គឺជាថ្ងៃសងសឹក* សូមមើល អស ៣៤:៨ និងការពន្យល់ ។ ព្រះយេហូវ៉ានឹងសងសឹកមនុស្សគ្មានមេត្តាធម៌របស់ពួកអេស៊ីព្ទ ដែលធ្វើចំពោះពួកយូដា (សូមមើល ឧទាហរណ៍ ២ពវ ២៣:២៩,៣៣–៣៥) ។ *ដាវនឹងស៊ីទាល់ឆ្អែត* សូមមើល ខ.១៤ ។ *ក៏ផឹកឈាមគេយ៉ាងស្កប់ស្កលឆ្អែត* ការសម្លាប់ក្នុងសង្គ្រាមជារឿយៗ គេប្រៀបធៀបនឹងការបូជា (សូមមើល អស ៣៤:៥–៧ និងការពន្យល់ សផ ១:៧,៨) ។

**៤៦:១១** *ចូលឡើងទៅឯស្រុកកាឡាត* សូមមើល ៨:១១ និងការពន្យល់ ។ *កូនស្រីក្រមុំនៃស្រុកអេស៊ីព្ទអើយ* ជាការបង្ហាញលក្ខណៈសម្បត្តិរបស់ស្រុក

សះចុះ[ល] ឯងនឹងប្រើថ្នាំច្រើនមុខ ជាឥតប្រយោជន៍ទេ ឯង
នឹងមើល[វ]ខ្លួនមិនជាឡើយ ១២អស់ទាំងសាសន៍បានឮនិយាយ
ពីសេចក្តីអាម៉ាស់ខ្មាសរបស់ឯង ហើយផែនដីក៏ឮពេញ
ដោយសំរែករបស់ឯងដែរ ដ្បិតមនុស្សខ្លាំងពូកែបាន
ចំពប់ដួលនឹងមនុស្សខ្លាំងពូកែ ហើយទាំង២បានដួល[ស]ជា
មួយគ្នា ។
១៣នេះជាព្រះបន្ទូលដែលព្រះយេហូវ៉ាទ្រង់មានបន្ទូល
នឹងហោរាយេរេមា ពីដំណើរនេប៊ូក្នេសា ជាស្តេចសាសន៍
បាប៊ីឡូន[ហ] ដែលនឹងមកវាយស្រុកអេស៊ីព្ទ[ឡ] ១៤ចូរថ្លែងប្រាប់
នៅស្រុកអេស៊ីព្ទ ហើយប្រកាសប្រាប់នៅក្រុងមីកដុល
ព្រមទាំងនៅក្រុងណូព[អ] និងនៅក្រុងថាផ្នេសផង[ក] ត្រូវឱ្យ
ប្រាប់ថា ចូរឈរឡើង ហើយរៀបខ្លួនចុះ ដ្បិតដាវ
បានស៊ី[ខ]នៅព័ទ្ធជុំវិញឯងអស់ហើយ ១៥ហេតុអ្វីបានជា
មនុស្សខ្លាំងពូកែរបស់ឯងត្រូវកៀរយកទៅដូច្នេះ គេមិន
បានឈរនឹងនៅទេ គឺពីព្រោះព្រះយេហូវ៉ាទ្រង់បានច្រាន
គេទៅ[គ] ១៦ទ្រង់បានធ្វើឱ្យច្រើនគ្នាចំពប់[ឃ] អើ គេបានដួល[ង]
គរលើគ្នា គេបាននិយាយគ្នាថា ចូរយើងក្រោកឡើងវិល
ទៅឯសាសន៍[ច]យើង នៅស្រុកកំណើតរបស់យើងវិញទៅ
ដើម្បីនឹងរួចពីដាវដែលធ្វើទុក្ខ[ឆ] ១៧នៅទីនោះ គេបាន

**៤៦:១១** ល លប ៣៧:២៥ វ យរ ៣០:១៣ មីក ១:៩
**៤៦:១២** ស ខ.៦ អស ១៩:៤ ណាហ ៣:៨–១០
**៤៦:១៣** ហ ខ.២៦ អគ ៣២:១១ ឡ អស ១៩:១ យរ ២៧:៧
**៤៦:១៤** អ អស ១៩:១៣ ក យរ ៤៣:៨ ខ ចទ ៣២:៤២ ២សយ ២:២៦ យរ ២៤:៨
**៤៦:១៥** គ យស ២៣:៥ អស ៦៦:១៥–១៦
**៤៦:១៦** ឃ លវ ២៦:៣៧ ង ខ.៦ ច អស ១៣:១៤ ឆ យរ ២៥:៣៨
**៤៦:១៧** ជ ១ពវ ២០:១០–១១ ឈ អស

ស្រែកឡើងថា ផារ៉ោន ជាស្តេចអេស៊ីព្ទ ទ្រង់ជាសូរកំទរ
ទទេ[ជ] ទ្រង់បានទុកឱ្យពេលដែលស្រួកកន្លងហួសទៅ[ឈ] ១៨ឯ
មហាក្សត្រ[ញ] ដែលទ្រង់ព្រះនាមជាព្រះយេហូវ៉ានៃពួក
ពលបរិវារ ទ្រង់ស្បថដោយព្រះជន្មទ្រង់ដ៏រស់នៅថា ភ្នំ
តាបោរ[ដ]នៅកណ្តាលស្រុកភ្នំ ហើយភ្នំកើមែល[ឋ]នៅឆ្នេរ
សមុទ្រជាយ៉ាងណា នោះពិតប្រាកដជាគេនឹងមកយ៉ាងនោះ
ដែរ ១៩ឱកូនស្រីដែលនៅស្រុកអេស៊ីព្ទអើយ ចូរផ្គត់ផ្គង់
ដល់ខ្លួនសំរាប់នឹងទៅជាឈ្លើយចុះ[ឌ] ដ្បិតក្រុងណូព[ឍ]នឹង
ត្រូវខូចបង់[ណ] ហើយដុតចោល ឥតមានអ្នកណានៅ ២០ស្រុក
អេស៊ីព្ទជាគោក្រមុំយ៉ាងល្អក្រៃលែង ប៉ុន្តែមេបំផ្លាញបាន
ចេញពីស្រុកខាងជើងមក ក៏មកដល់ហើយ[ត] ២១មួយ
ទៀតជើងឈ្នួល[ថ]របស់ស្រុកអេស៊ីព្ទ ប្រៀបដូចជាកូនគោ
បំប៉ន់នៅកណ្តាលស្រុក[ទ] គេក៏បានបែរខ្នងដែរ គេបាន
រត់ចេញ[ធ]ទៅជាមួយគ្នា ឥតឈរនឹងនៅទេ ដ្បិតថ្ងៃ[ន]
អន្តរាយរបស់គេ គឺជាវេលា[ប]ធ្វើទោសដល់គេបានមកលើ
គេហើយ ២២សូរសន្ធឹកនៃថ្ងៃនោះ ដូចជាសូរនៃពស់លូន

១៩:១១–១៦ **៤៦:១៨** ញ យរ ៤៨:១៥ ដ យស ១៩:២២ ឋ ១ពវ ១៨:៤២ **៤៦:១៩** ឌ អស ២០:៤ ឍ អស ១៩:១៣ ណ អគ ២៩:១០,១២ ៣៥:៧ **៤៦:២០** ត ខ.២៤ អស ១៤:៣១ យរ ៤៧:២ **៤៦:២១** ថ ២ពវ ៧:៦ ទ លវ ១៥:២៧ ធ ខ.៥ យប ២០:២៤ ន ទដ ១៨:១៨ ៣៧:១៣ យរ ១៨:១៧ ប យប ១៨:២០

អេស៊ីព្ទទាំងមូល (សូមមើលការពន្យល់ ២ពវ ៩:២១) ។ *និងប្រើច្រើនមុខជាឥតប្រយោជន៍ទេ . . . ឯងមើលខ្លួនមិនជាឡើយ* គឺជាការប្រាប់ដោយចំអកក្នុងពន្លឺរបស់កេរ្តិ៍ឈ្មោះសាសន៍អេស៊ីព្ទ ចំពោះការមានជំនាញក្នុងការព្យាបាលជម្ងឺដល់មនុស្ស ។

**៤៦:១២** *បានចំពប់នឹងមនុស្សខ្លាំងពូកែ . . . បានដួលជាមួយគ្នា* សូមមើល ខ.៦,១៦ ។

**៤៦:១៣** *នេប៊ូក្នេសា . . . វាយស្រុកអេស៊ីព្ទ* នៅក្នុងឆ្នាំ ៥៦៨–៥៦៧ មុន ស.គ (សូមមើលការពន្យល់ ៤៣:១១) គឺបន្ទាប់ពីសង្គ្រាមនៅកើតមីសយូបន្តិចមក ស្តេចនេប៊ូក្នេសាក៏បានវាយយកស្រុកអេស៊ីព្ទ (មើលការពន្យល់ ខ.១) ។

**៤៦:១៤** *នៅក្រុងមីកដុស* សូមមើល ៤៤:១ និងការពន្យល់ ២:១៦ អស ១៩:១៣ ។ *ចូរឈរឡើង* មើល ខ.៤ ។ *ដាវបានស៊ីនៅព័ទ្ធ* មើល ខ.១០ ។

**៤៦:១៥** *មនុស្សខ្លាំពូកែ* ក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះពាក្យនេះគឺពុំមានលក្ខណៈដូចគ្នានឹងពាក្យថា"មនុស្សខ្លាំពូកែ"ទេ គឺដូចជាក្នុង ខ.៥,៩,១២ ។ "ជាអ្នក ដែលមានកម្លាំងរឹងមាំ" ក៏ជារឿយៗគេចង់សំដៅទៅលើសត្វពាហនៈ ដ៏មានកម្លាំង (ដូចជាសេះឈ្មោលឥតក្រៀវមានក្នុង ៨:១៦ ៣៤:៧) ក្នុងព្រះគម្ពីរភាសា ហេព្រើរត្រូវបានគេបកស្រាយថាជា "គោឡើងក" (សូមមើលការពន្យល់ ទដ ៦៨:៣០) ។

**៤៦:១៦** *ឱ្យច្រើនគ្នាចំពប់* សូមមើល ខ.១២ ដោយទ្រង់ធ្វើឱ្យគេចំពប់ជាច្រើននាក់ ។ *គេបាននិយាយគ្នាថា ចូរយើងក្រោកឡើងវិញ* គឺជាពួកទាហានស៊ីឈ្នួលនៅក្នុងជួរកងទ័ពរបស់ស្តេចផារ៉ោន (មើល ខ.៩ និងការពន្យល់) ដែលសម្រេចវិលត្រឡប់ទៅស្រុកកំណើតពួកគេវិញ ។ *ដាវដែលធ្វើទុក* សូមមើល ២៥:៣៨ ។

**៤៦:១៧** *សូរកំទរទទេ* ក្នុង អស ៣០:៧ អត្ថន័យនេះក្នុងស្រុកអេស៊ីព្ទមានន័យថា "ពុំបានធ្វើអ្វីទាំងអស់" ។ *កន្លងហួសទៅ* គឺគណៈពេលសង្គ្រាមនៅកើតមីសបានកន្លងផុតទៅ (សូមមើល ខ.២) ស្តេចនេប៊ូក្នេសាបានត្រឡប់ទៅក្រុងបាប៊ីឡូនវិញ ដើម្បីសិក្សាស្វែងយល់ពីការសុគតរបស់ព្រះបិតារបស់ទ្រង់ ។ ឯស្រុកអេស៊ីព្ទបានបាត់បង់ឱកាសរបស់ពួកគេ ។

**៤៦:១៨** *ព្រះជន្មទ្រង់ដ៏រស់នៅ* មើលការពន្យល់ លក ២២:១៦ ៤២:១៥ ។ *មហាក្សត្រ* គឺជាព្រះនាមព្រះដែលគេហៅថា "ព្រះមហាក្សត្រ" ក៏មាននៅក្នុង ៨:១៩ ១០:៧,១០ ៤៨:១៥ ៥១:៥៧ ។ *ភ្នំតាបោរនៅកណ្តាល . . . ភ្នំកើមែល* ភ្នំទាំងនេះជាភ្នំដ៏មានឈ្មោះល្បីល្បាញនៅក្នុងប្រទេសអ៊ីស្រាអែល (សូមមើលការពន្យល់ ពច ៤:៦ បស ៧:៥ អស ៣៣:៩) ។

**៤៦:១៩** *ចូរផ្គត់ផ្គង់ដល់ខ្លួនសំរាប់នឹងទៅជាឈ្លើយចុះ* ក៏ឃើញមាននៅក្នុង ១២:៣ ។ *ស្រុកអេស៊ីព្ទ* ក្នុងឃ្លានេះគឺសំដៅទៅលើ "កូនស្រីស្រុកអេស៊ីព្ទ" (សូមមើល ខ.១១ និងការពន្យល់) ។ *ខូចបង់* មានក្នុងពួកយ៉ូដាបានពណ៌នាពីករណីនេះដែរ ២:១៥ ៩:១២ ។

**៤៦:២០** *គោក្រមុំ* គឺសំដៅទៅលើការចំអកឱ្យការថ្វាយបង្គំគោឡើងក នៃពួកស្រុកអេស៊ីព្ទ (សូមមើលនៅក្នុង ខ.១៥) ។ *មេបំផ្លាញ* នេប៊ូក្នេសាបានប្រើពាក្យនេះជាតំណាងឱ្យពួកសត្រូវ ដែលបានវាយប្រហារដល់យើង (សូមមើលការពន្យល់ នក ២៣:២៨) ។

**៤៦:២១** *ជើងឈ្នួល* សូមមើលការពន្យល់ ខ.៩ ។ *កូនគោបំប៉ន* សូមមើល ខ.២០ ។ *ថ្ងៃអន្តរាយ* សូមមើល ១៨:១៧ ។ *វេលាធ្វើទោសដល់គេបានមកលើគេហើយ* សូមមើល ១១:២៣ ២៣:១២ ៥០:២៧ ។

**៤៦:២២** *ពស់លូន* ជាញឹកញាប់គេប្រើក្នុងស្រុកអេស៊ីព្ទ ដែលស្តេចផារ៉ោន

ដ្បិតពួកនោះនឹងដើរមកជាក្បួនទ័ពក៏នឹង មកទាស់នឹងគេ
មានទាំងពូថៅ ដូចអ្នកកាប់ឈើផង[ផ] [២៣]ព្រះយេហូវ៉ាទ្រង់
មានបន្ទូលថា គេនឹងកាប់រំលំព្រៃរបស់ស្រុកអេស៊ីព្ទរបស់
ទោះបើជាព្រៃស្តុក ដល់ចូលមិនបានក៏ដោយ ដ្បិតគេមាន
គ្នាច្រើនជាងកណ្តូប[ព] គឺហួសប្រមាណនឹងរាប់បាន [២៤]កូន
ស្រីរបស់ស្រុកអេស៊ីព្ទនឹងត្រូវខ្មាស នាងនឹងត្រូវប្រគល់ទៅ
ក្នុងកណ្តាប់ដៃរបស់ពួកសាសន៍ ពីស្រុកខាងជើង[ភ] [២៥]ព្រះ
យេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់មានបន្ទូលថា មើល អញ និងធ្វើ ទោសដល់អាំម៉ូន–
នរ[ម] និងផារ៉ោន[យ] ហើយស្រុកអេស៊ីព្ទ ព្រមទាំងព្រះទាំង
ប៉ុន្មាន[រ] និងស្តេចរបស់គេផង គឺផារ៉ោន និងអស់អ្នកដែល
ទុកចិត្ត[ល]ដល់វា [២៦]អញនឹងប្រគល់គេ ទៅ[វ]ក្នុងកណ្តាប់ដៃនៃ
ពួកអ្នកដែលរកជីវិតគេ គឺទៅក្នុងកណ្តាប់ ដៃនៃនេប៊ូក្នេសា
ជាស្តេច[ស]បាប៊ីឡូន និងទៅក្នុងកណ្តាប់ដៃនៃ ពួកអ្នកបំរើវា
ដែរ ក្រោយមកស្រុកអេស៊ីព្ទនឹងមានគេអាស្រ័យនៅ[ហ] ដូច
កាលពីដើមឡើងវិញនេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
[២៧]ប៉ុន្តែ ឱយ៉ាកុប[ឡ] ជាអ្នកបំរើរបស់អញអើយ[អ] កុំឱ្យ
ខ្លាចឱ្យសោះ[ក] ឱអ៊ីស្រាអែលអើយ កុំឱ្យស្រយុតចិត្តឡើយ
ដ្បិតមើល អញនឹងជួយសង្គ្រោះឯង ឱ្យបានរួចពីទីឆ្ងាយ
ហើយពូជឯងចេញពីស្រុកដែលគេនៅជាឈ្លើយ[ខ] នោះពួក
យ៉ាកុបនឹងវិលមកវិញ ហើយនឹងនៅដោយសុខស្រួល នឹង
សេចក្តីស្ងាប់ស្ងាត់ ឥតមានអ្នកណាបំភ័យឡើង [២៨]ព្រះយេ
ហូវ៉ាទ្រង់មានបន្ទូលថា ឱយ៉ាកុប ជាអ្នកបំរើរបស់អញ
អើយ កុំឱ្យខ្លាចឱ្យសោះ ដ្បិតអញនៅជាមួយនឹងឯងហើយ[គ]
អញនឹងធ្វើឱ្យអស់ទាំងនគរ ដែលអញបានបណ្តេញឯង
ទៅនោះ បានផុតអស់រលីងទៅ[ឃ] តែអញនឹងបំផុតឯង
អស់រលីងទេ គឺនឹងគ្រាន់តែវាយផ្ចាលឯងតាមខ្នាតប៉ុណ្ណោះ
ប៉ុន្តែអញមិនទុកឱ្យឯងនៅជាឥតទោសឡើយ ។

## ព្រះរាជសារអំពីពួកសាសន៍ភីលីស្ទីន

**៤៧** [១]នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដល់
ហោរាយេរេមា ពីដំណើរពួកសាសន៍ភីលីស្ទីន[ក] កាលមុន
ដែលផារ៉ោនបានវាយយកក្រុងកាសា[ខ] [២]ព្រះយេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា មើល មានទឹកឡើងចេញពីទិសខាង
ជើង[គ] ទឹកនោះនឹងត្រឡប់ជាទន្លេដែលលិចច្រាំង ក៏នឹង
ជន់ឡើងលិចស្រុក នឹងបណ្តាដែលនៅក្នុងទាំងប៉ុន្មានដែរ
គឺទាំងទីក្រុង និងមនុស្សដែលអាស្រ័យនៅផង នោះបណ្តា
មនុស្សនឹងស្រែកឡើង ពួកអ្នកដែលអាស្រ័យនៅទាំង
ប៉ុន្មាននឹងទ្រហោយំ[ឃ] [៣]ដោយឮសូរព្រួសព្រឹបនៃជើងសេះ
ដ៏ខ្លាំងពូកែរបស់គេ ដោយសូររន្ទាន់របស់រទេះចំបាំង[ង]គេ
និងសូររ៉ូងរ៉ាងនៃកង់រទេះផង ឪពុកទាំងប៉ុន្មាន នឹងមិន
ងាកទៅក្រោយមើលកូនឡើយ ដោយព្រោះខ្សោយដៃ[ច]
[៤]ដ្បិតថ្ងៃដែលត្រូវបំផ្លាញពួកភីលីស្ទីនទាំងអស់បានមកដល់

**៤៦:២២** ផ ទដ ៧៤:៥ **៤៦:២៣** ព ចទ ២៨:៤២ ពច ៧:១២ **៤៦:២៤** ភ ២ពវ ២៤:៧ **៤៦:២៥** ម អគ ៣០:១៤ ណហ ៣:៨ យ ២ពវ ២៤:៧ អគ ៣០:២២ រ យរ ៤៣:១២ ល អស ២០:៦ **៤៦:២៦** វ យរ ៤៤:៣០ ស ឧ.១៣ អស ១៩:៤ ហ អគ ២៩:១១–១៦ **៤៦:២៧** ឡ អស ៤១:៨ ៤៤:១ មឡ ១:២ អ អស ៤៤:២ ក អស ៤៣:៥ យរ ៥១:៤៦ ខ អស ១១:១១ យរ ២៩:១៤ ៥០:១៩ **៤៦:២៨** គ នក ១៤:២២ ជន ១៤:៩ អស ៨:៩–១០ ឃ យរ ៤:២៧ **៤៧:១** ក លប ១០:១៤ ពច ៣:៣១ ខ លប ១០:១៩ សក ៩:៥–៧ **៤៧:២** គ អស ១៤:៣១ ឃ អស ១៥:៣ **៤៧:៣** ង យរ ៤៦:៩ អគ ២៣:២៤ ច អស ១៣:៧ យរ ៥០:៤៣ អគ ៧:១៧ ២១:៧

ចាត់ទុកថាវាជាអធិបតេយ្យភាពរបស់ពួកគេ (សូមមើលការពន្យល់ នក ៤:៣) ។ *ដើរមកជាក្បួនទ័ពក៏នឹងមកទាស់នឹងគេ* សូមមើល ២១:១៤ និង មើល អស ១០:១៨–១៩,៣៣–៣៤ និងការពន្យល់ ។

**៤៦:២៣** *គេមានគ្នាច្រើនជាងកណ្តូប* នៅក្នុងឃ្លានេះ ពួកកងទ័ពដែលឈ្លានពាន គឺគេបានប្រៀបធៀបទៅនិងសត្វកណ្តូប ។ នៅក្នុង យអ ២:១១,២៦ ឯ សត្វកណ្តូបនេះគឺប្រៀបប្រដូចជាកងទ័ពឈ្លានពាន (សូមមើល ៥១:១៤) ។

**៤៦:២៤** *កូនស្រីរបស់ស្រុកអេស៊ីព្ទ* សូមមើល ឧ.១១ និងការពន្យល់ ។

**៤៦:២៥** *អាំម៉ូន–នរ* ជាឈ្មោះរូបព្រះយ៉ាងធំមានឈ្មោះល្បីនៅស្រុកអេស៊ីព្ទ ដែលមានជាប្រវត្តិសាស្ត្រយ៉ាងច្រើន ក៏មានស្តេចម៉ានាសេដ៏អាក្រក់បាន ដាក់ឈ្មោះឱ្យព្រះរាជបុត្រារបស់ទ្រង់ មាននាមដូច្នេះគឺដូចជានាមរបស់ អាទិទេព្វរបស់អេស៊ីព្ទ (សូមមើល ២ពវ ២១:១៨ ២រប ៣៣:២២) ។

**៤៦:២៦** *អេស៊ីព្ទនឹងមានគេអាស្រ័យនៅដូចកាលពីដើម* ប្រៀបធៀប ៤៨:៤៧ ៤៩:៦,៣៩ សាសន៍អេស៊ីព្ទ និងបានកើតឡើងក្នុងយុគ្គសម័យព្រះម៉ែស៊ី (សូមមើល អស ១៩:២៣–២៥ និងការពន្យល់) ។

**៤៦:២៧–២៨** គឺជាហេតុការដែលបង្ហាញនូវភាពស្រដៀងគ្នា គឺចាប់ពីជំពូក ៣០:១០–១១ (សូមមើលការពន្យល់ ៣០:១០–១១) ។

**៤៧:១** *ពីដំណើរពួកសាសន៍ភីលីស្ទីន* សូមមើល អស ១៤:២៨–៣២ អគ ២៥:១៥–១៧ អម ១:៦–៨ សផ ២:៤–៧ ។ *ផារ៉ោន* វាមានលក្ខណៈមិន ជាក់លាក់មិនដឹងថា គឺជានេកោទី២ (សូមមើល ៤៦:២ និងការពន្យល់ ២ពវ ២៣:២៩) ឬក៏មើលការពន្យល់ ៣៧:៥ ៤៤:៣០) ។ *ក្រុងកាសា* សូមមើល ឧ.៥ ២៥:២០ និងការពន្យល់ ១:១៨ ។

**៤៧:២** *មានទឹកឡើង* សូមមើលការពន្យល់ ៤៦:៧–៨ ។ *ខាងជើង* គឺជាក្រុងបាប៊ីឡូន ដូចមានក្នុង ១:១៣–១៤ ៤៦:២០ ។ *ស្រុកទាំងប៉ុន្មានដែរ គឺជាក្រុងនិងមនុស្សដែលអាស្រ័យនៅផង* នៅក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះឃ្លានេះបានបង្ហាញឡើងវិញ ហើយមានន័យដូចគ្នាក្នុង ៨:១៦ ។ *ស្រុក* នេះគឺជាទីស្រុកកេនីស និងស្រុកភីលីស្ទីន ។ *ទីក្រុង* សូមមើលការពន្យល់ ៤៦:៨ មានទាំងទីក្រុងទីរ៉ុស និងស៊ីដូន (សូមមើល ឧ.៤) ក៏មានទីក្រុងកាសា ផងដែរ និងអាសកាឡូន (សូមមើល ឧ.៥) ហើយនិងទីក្រុងរបស់សាសន៍ ភីលីស្ទីនផ្សេងទៀត ។

**៤៧:៣** *សេះ* "ជាប្រភេទសេះដ៏ខ្លាំងពូកែ" (មើលការពន្យល់ ៤៦:១៥) ។ *មិនងាកទៅក្រោយមើលកូនឡើយ ដោយព្រោះខ្សោយដៃ* ដោយមានលក្ខណៈរំភើបភ័យខ្លាចព្រោះសេចក្តីស្លាប់ខិតជិតមក (សូមមើល ៦:២៤ អស ១៣:៧ និងការពន្យល់) ។

**៤៧:៤** *ក្រុងទីរ៉ុស និងក្រុងស៊ីដូន* មើលការពន្យល់ ឧ.២ ២៥:២២ ២៧:៣ ។ *ជាសំណល់មនុស្ស* សូមមើល ឧ.៥ ២ពវ ១៩:៣០–៣១ អស ១:៩ ១០:២០–២២ និងការពន្យល់ ។ *កោះកាប់ថោរ* ក្នុងកោះក្រេត ក៏មានពួកសាសន៍

ហើយ ដើម្បីនឹងកាត់អស់ទាំងអ្នកជំនួយ ដែលនៅសល់
ចេញពីក្រុងទីរ៉ុស[ឆ] និងក្រុងស៊ីដូនបង់[ជ] ពីព្រោះព្រះ
យេហូវ៉ាទ្រង់នឹងបំផ្លាញសាសន៍ភីលីស្ទីន[ឈ] គឺជាសំណល់
មនុស្សដែលមកពីកោះកាប់ថោរទៅ[ញ] ៥ក្រុងកាសាបានទៅ
ជាទំពែក[ដ]ហើយ ក្រុងអាសកាឡូន[ឋ]បានត្រូវសាបសូន្យទៅ
ព្រមទាំងសំណល់មនុស្សនៅវាលច្រកភ្នំនោះផង តើឯង
នឹងអារ[ឌ]សាច់ខ្លួន ដល់កាលណាទៀត ៦ឱដាវ[ឍ]នៃព្រះ
យេហូវ៉ាអើយ តើដល់កាលណាបានឯងឈប់ទ្រឹងវិញ ចូរ
ស៊កខ្លួនទៅក្នុងស្រោមចុះ ចូរផ្អាក ហើយស្ងៀមនៅ[ណ] ៧ឯង
នឹងនៅស្ងៀមឯណាបាន[ត] ដ្បិតឃើញថា ព្រះយេហូវ៉ាបាន
បង្គាប់ការហើយ គឺទ្រង់ដំរូវឱ្យទាស់នឹងក្រុងអាសកាឡូន
ហើយនឹងឆ្នេរសមុទ្រផង[ថ]។

## ព្រះរាជសារអំពីពួកម៉ូអាប់

*៤៨:២៩-៣៦ – អស ១៦:៦-១២*

**៤៨** ១ពីស្រុកម៉ូអាប់[ក]។

ព្រះយេហូវ៉ានៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ី–
ស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា វេទនាដល់ក្រុងនេបូរ[ខ]
ពីព្រោះត្រូវបំផ្លាញហើយ ក្រុងគារយ៉ាថែម[គ]ក៏ត្រូវខ្មាស គឺ
ត្រូវគេចាប់យកបាន ក្រុងមីសកាបត្រូវខ្មាសដែរ ហើយត្រូវ
ខូចបង់ ២សាសន៍ម៉ូអាប់លែងបានសេចក្តីអំនួត[ឃ] ពីក្រុង
ហែលបូន[ង]ហើយ មានគេបានបង្កើតការអាក្រក់ទាស់នឹងវា
ថា ចូរមក យើងនឹងកាត់គេចេញ ពីដំណែងជានគរទៅ[ច]
ហើយឯង ឱម៉ាតម៉ែនអើយ ឯងនឹងត្រូវស្ងៀមនៅដែរ
ដាវនឹងដេញតាមឯង ៣មានឮសូរសំរែកចេញពីក្រុងហូរ៉ូ–
ណែម[ឆ] គឺជាការខូចបង់ ហើយបំផ្លាញយ៉ាងសំបើម ៤ស្រុក
ម៉ូអាប់បានត្រូវបំផ្លាញហើយ ពួកតូចៗរបស់គេបានស្រែក
ឱ្យឮ ៥ដ្បិតគេនឹងឡើងតាមផ្លូវទៅឯលូគីត[ជ] ទាំងយំបណ្តើរ
ជានិច្ច ឯត្រង់ផ្លូវចុះទៅឯហូរ៉ូណែម[ឈ] នោះមានឮសំរែក
ថប់ព្រួយពីការបំផ្លាញ ៦ចូររត់ទៅ[ញ] ឱ្យរួចជីវិតឯងចុះ ត្រូវ
ឱ្យនៅដូចជាដើមឈើសោះកក្រោះ នៅទីរហោស្ថាន[ដ]
៧ដ្បិតដោយព្រោះឯងបានទុកចិត្តនឹងការរបស់ឯង ហើយ
នឹងទ្រព្យសម្បត្តិរបស់ឯង[ឋ] បានជាឯងនឹងត្រូវគេចាប់ យក
ដែរ ហើយព្រះកេម៉ូស[ឌ]នឹងត្រូវនាំចេញទៅជាឈ្លើយ[ឍ]
ព្រមទាំងពួកសង្ឃ និងពួកចៅហ្វាយរបស់វាទាំងអស់ផង[ណ]

**៤៧:៤** ឆ អស ២៣:១ អម ១:៩-១០ សក ៩:២-៤ ជ លប ១០:១៥ យរ ២៥:២២ ឈ លប ១០:១៤ យអ ៣:៤ ញ ចទ ២:២៣ **៤៧:៥** ដ យរ ៤១:៥ ឋ យរ ២៥:២០ ឌ លវ ១៩:២៨ **៤៧:៦** ឍ អស ៣៤:៥ យរ ១២:១២ ៤៨:១០ ៥០:៣៥ ណ អគ ២១:៣០ **៤៧:៧** ត អគ ២៤:១៥-១៧ **៤៨:១** ក លប ១៩:៣៧ ចទ ២៣:៦ ខ ជន ៣២:៣៨ គ ជន ៣២:៣៧ យស ១៣:១៩ **៤៨:២** ឃ អស ១៦:១៤ ង ជន ២១:២៥ យស ១៣:២៦ ច ខ.៤២ **៤៨:៣** ឆ អស ១៥:៥ **៤៨:៥** ជ អស ១៥:៥ ឈ ខ.៣ **៤៨:៦** ញ លប ១៩:១៧ ដ យរ ១៧:៦ **៤៨:៧** ឋ ទដ ៤៩:៦ សភ ១១:២៨ ឌ ជន ២១:២៩ ឍ អស ៤៦:១-២ យរ ៤៩:៣ ណ អម ២:៣

កេលធីមផងដែរ សថ ២:៥ គឺជាតំបន់កោះនៅតាមសមុទ្រមេឌីទែរ៉ានេ ដែលគេគិតថា វាគឺជាស្រុកកំណើតដើមរបស់ពួកពូជសាសន៍ភីលីស្ទីន (សូមមើល លប ១០:១៤ និងការពន្យល់ និងមើល ចទ ២:២៣) ។

**៤៧:៥** *ក្រុងកាសា* សូមមើល ខ.១ ២៥:២០ និងការពន្យល់ ពច ១:១៨ ។ *ទៅជាទំពែកហើយ* គឺជាសញ្ញានៃការកាន់ទុក្ខចំពោះគ្រោះផ្សេងៗ សូមមើលការពន្យល់ ១៦:៦ និងមើល ៤៨:៣៧ ។ *ក្រុងអាសកាឡូន* សូមមើល ខ.៧ ២៥:២០ និងមើល ពច ១:១៨ ។ *បានត្រូវសាប់សូន្យ* ពាក្យនេះជាសញ្ញានៃការរងទុក្ខវេទនា (សូមមើល បទ ២:១០) ។ *វាលច្រកភ្នំ* គឺដូចជាកាត់យកក្រុងកាសាដ៏ល្អចេញទៅបាត់ ដែលវាលាតសន្ធឹងទៅទិសខាងលិចឈៀងខាងជើងភ្នំដែលញែកភីលីស្ទីនចេញពីស្រុកយូដា ។ *អារសាច់ខ្លួន* សូមមើលការពន្យល់ ១៦:៦ និងមើល ៤៨:៣៧ ។

**៤៧:៦** *ដាវ* មើល ១២:១២ និងការពន្យល់ ។ *ឯង* មានដូចជាពួកភីលីស្ទីន ។

**៤៧:៧** *ទាស់នឹងក្រុងអាសកាឡូន* គឺជាការបំពេញភារៈកិច្ចដោយបន្ទាន់ពីស្តេចនេប៊ូក្នេសានៅក្នុងឆ្នាំ ៦០៤ មុន ស.គ ។ *ឆ្នេសមុទ្រ* សូមមើល អគ ២៥:១៦ គឺជាទីវាលរបស់ស្រុកភីលីស្ទីន (សូមមើលការពន្យល់ ខ.៥) ។

**៤៨:១** *ពីស្រុកម៉ូអាប់* សូមមើល អស ១៥-១៦ អគ ២៥:៨-១១ អម ២:១-៣ សផ ២:៨-១១ ។ លោកយ៉ូសែបភើស (១០,៩,៧) បានលាតត្រដាងពីបទទំនាយរបស់ហោរាយេរេមា ទាក់ទងនិងភាពមហន្តរាយជាបន្តបន្ទាប់របស់ពួកស្រុកម៉ូអាប់ដែលបានសម្រេចសេចក្តីទំនាយនៅក្នុង "ឆ្នាំទី ២៣ របស់រាជកាលគ្រងរាជ្យនៃនេប៊ូក្នេសា" (ក្នុងឆ្នាំ ៥៨២ មុន គ.ស) ។ *ក្រុងនេបូរ* សូមមើល ខ.២២ គឺជាទីក្រុងដែលញែក ឬកាត់ទៅឱ្យពូជអំបូររូបេន (សូមមើល ជន ៣២:៣៧-៣៨ អស ១៥:២ និងការពន្យល់) ។ *ក្រុងគារយ៉ាថែម* សូមមើល ខ.២៣ គឺជាទីក្រុងបុរាណមួយ (សូមមើល លប ១៤:៥) វាក៏បានកាត់ទៅឱ្យពូអំបូររូបេនដែរ (សូមមើល យស ១៣:១៩ និងការពន្យល់) ។ ក្រុងនេបូរ ក្រុងគារយ៉ាថែម និងក្រុងជាច្រើនដទៃទៀត បើតាមព្រះបន្ទូលក្នុងជំពូកនេះ គឺជាទីក្រុងសំខាន់ដោយតាមសេចក្តីសរសេរចងក្រងរបស់ស្តេចមេសា ជាស្តេចក្រុងម៉ូអាប់ (សូមមើល ២ពវ ៣:៤) ដែលគេស្រាវជ្រាវឃើញជាឯកសារក្នុងឆ្នាំង ១៨៦៨ ។

**៤៨:២** *ក្រុងហែសបូន* សូមមើល ខ.៣៤,៤៥ ៤៩:៣ ជន ២១:២៥ ។ បានកាត់ចេញទៅឱ្យពួករូបេន (សូមមើល ជន ៣២:៣៧ យស ១៣:១៧) តែក្រោយមកទីក្រុងនេះបានគេផ្ទេរទៅឱ្យពួកកូនចៅកាត់ ដែលកាត់ជាកូនយ៉ាកុបហើយជាទីក្រុងនៃពួកគ្រូលេវី (សូមមើល យស ២១:៣៩) ។ *ឱម៉ាតម៉ែនអើយ* ពាក្យនេះប្រហែលជាការប្រកបតួអក្សរយ៉ាងវែង របស់ពាក្យថា "ឌីម៉ុន" មានន័យថាខ្សែទឹកនៃសមុទ្រស្លាប់ មានទីតាំងនៅក្រុងម៉ូអាប់ (សូមមើល អស ១៥:៩) នៅក្នុងគម្ពីរ អស ២៥:១០ ពាក្យនេះមានទម្រង់ជាលក្ខណៈឥត្ថិលិង្គ (ភេទស្រី) ក្នុងព្រះគម្ពីរភាសាហេព្រើរមានន័យថាវាជា "ដីអាចម៍សត្វ" ។ *ដាវនឹងដេញតាមឯង* សូមមើល ៩:១៦ ៤២:១៤ ។

**៤៨:៤** *ត្រូវបំផ្លាញហើយ* គឺបំផ្លាញដូចក្អម ឬពាងដែលធ្វើពីដីឥដ្ឋបានបែកអញ្ចឹង (សូមមើល ១៩:១១) ។

**៤៨:៧** *ព្រះកេម៉ូស* សូមមើល ខ.១៣,៤៦ គឺជាព្រះរបស់ជាតិសាសន៍ពួកម៉ូអាប់ (សូមមើល ១ពវ ១១:៧,៣៣ ២ពវ ២៣:១៣) ។ ជាព្រះគម្ពីរភាសាហេព្រើរនៅក្នុងខនេះ គឺបញ្ជាក់ពីសម្លេងថាព្រះកេមីសូ ដូចជាពាក្យថា "ស្រុកកេមីស"(សូមមើលការពន្យល់ ៤៦:២) ។ *និងត្រូវនាំចេញទៅជាឈ្លើយ* (សូមមើល ៤៩:៣ អម ១:១៥) ។ គឺដូចជារូបព្រះអាទិទេពរបស់ពួកសាសន៍ដទៃ ដែលតាមទម្លាប់ពួកគេបានដឹកជញ្ជូនព្រះនោះ ពីកន្លែងមួយទៅកន្លែងទៀត (សូមមើល ៤៣:១២ អម ៥:២៦) ។

៨នឹងមានមេបំផ្លាញ[ត]មកលើគ្រប់ទាំងទីក្រុង ឥតមានណា
មួយរួចឡើយ ឯច្រកភ្នំ និងត្រូវវិនាសទៅ ហើយស្រុក
វាល[ថ]នឹងត្រូវបំផ្លាញដែរ ដូចជាព្រះយេហូវ៉ាបានមាន
បន្ទូលហើយ ៩ចូរឱ្យម៉ូអាប់មានស្លាបចុះ[ទ] ដើម្បីឱ្យបានហើរ
ទៅឱ្យរួច ដ្បិតទីក្រុងទាំងប៉ុន្មានរបស់គេនឹងត្រូវខូចបង់[ធ]
ឥតមានអ្នកណានៅឡើយ ១០អ្នកណាដែលធ្វើការរបស់ព្រះ
យេហូវ៉ា ដោយព្រងើយកន្តើយ នោះត្រូវបណ្តាសាហើយ
អ្នកណាដែលទប់ដាវ[ន]ខ្លួនមិនឱ្យកំចាយឈាម[ប] នោះក៏ត្រូវ
បណ្តាសាដែរ ។
១១សាសន៍ម៉ូអាប់ បាននៅ[ផ]ដោយឥតកង្វល់ តាំងពី
ក្មេងមក គេបានរងនៅលើកកររបស់គេ[ព] ឥតដែលចាក់
ផ្ទេរពីដប១ទៅដល់ដប១ទៀត ក៏មិនដែលត្រូវនាំទៅជា
ឈ្លើយឡើយ ហេតុនោះបានជាគេមានរសជាតិនៅដូច
ដដែល ហើយក្លិនរបស់គេក៏មិនបានផ្លាស់ប្រែទៅដែរ
១២ដូច្នេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល នឹងមាន
គ្រាមកដល់ ដែលអញនឹងចាត់ប្រើមនុស្សទៅឯគេ ដែល
នឹងចាក់ផ្ទេរចេញឱ្យដបនៅទទេ ហើយនឹងបំបែកដបឱ្យ
ខ្ទេចខ្ទីដែរ ១៣នោះម៉ូអាប់នឹងខ្មាស[ភ]ចំពោះព្រះកេម៉ូស[ម] ដូច
ជាពួកវង្សអ៊ីស្រាអែលបានខ្មាសចំពោះបេត–អែល ជាទី
ទុកចិត្តរបស់គេដែរ[យ] ១៤ធ្វើដូចម្តេចឱ្យឯងរាល់គ្នាថា យើង
ជាមនុស្សខ្លាំងពូកែ[រ] ហើយស្ទាត់ជំនាញក្នុងចំបាំងបាន
១៥ស្រុកម៉ូអាប់បានត្រូវខូចបង់ហើយ ទីក្រុងរបស់គេបាន
ហុយឡើងជាផ្សែង ពួកកំឡោះ[ល]ជ្រើសរើសរបស់គេបាន
ចុះ ទៅឯទីសំឡេះ[វ] នេះជាព្រះបន្ទូលនៃមហាក្សត្រ[ស] ដែល
ទ្រង់ ព្រះនាមជាព្រះយេហូវ៉ានៃពួកពលបរិវារ[ហ] ១៦សេចក្តី
អន្តរាយរបស់សាសន៍ម៉ូអាប់ជិតមកដល់ហើយ[ឡ] សេចក្តី
វេទនារបស់គេក៏ប្រញាប់រួសរាន់ដែរ ១៧ឯងរាល់គ្នាដែល
នៅជុំវិញគេអើយ ចូរយំទួញនឹងគេចុះ ហើយឯងរាល់គ្នា
ដែលស្គាល់ឈ្មោះគេអើយ[អ] ចូរពោលថា ដំបងខែងមាំ
នោះបានចាក់យ៉ាងណាហ្ន៎[ក] ជាដំបងរុងរឿងផង ១៨ឱកូន
ស្រីដែលអាស្រ័យនៅក្រុងឌីបូនអើយ[ខ] ចូរចុះពីសណ្ឋានរុង
រឿងឧត្តមរបស់ឯងមក ហើយអង្គុយនៅទីស្រេកវិញ[គ]
ចុះដ្បិតមេដែលបំផ្លាញស្រុកម៉ូអាប់បានឡើងមកទាស់នឹង
ឯងហើយ គេបានបំផ្លាញទីមាំមួនរបស់ឯងបង់[ឃ] ១៩ឱអ្នក

**៤៨:៨** ត នក ១២:២៣ យរ ៤:៧ ថ យស ១៣:៩ **៤៨:៩** ទ ពច ៩:៤៥ ធ យរ ៥១:២៩ **៤៨:១០** ន យរ ៤៧:៦ ប ១សយ ១៥:១១ ១ពវ ២០:៤២ ២ពវ ១៣:១៥–១៩ **៤៨:១១** ផ សក ១:១៥ ព សផ ១:១២ **៤៨:១៣** ភ ហស ១០:៦ ម ខ.៧ យ យស ៧:២ **៤៨:១៤** រ ទដ ៣៣:១៦ **៤៨:១៥** ល អស ៩:១៧ វ យរ ៥១:៤០ ស យរ ៤៦:១៨ ហ យរ ៥១:៥៧ **៤៨:១៦** ឡ អស ១៣:២២

**៤៨:១៧** អ ២ពវ ៣:៤–៥ ក ទដ ១១០:២ **៤៨:១៨** ខ ជន ២១:៣០ យរ ១៣:៩ គ អស ៤៧:១ ឃ ខ.៨

**៤៨:៩** *មេបំផ្លាញ* សូមមើល ខ.៣២ គឺអាចសំដៅទៅលើស្តេចនេប៊ូក្នេសា ។ *ឯច្រកភ្នំ . . . ស្រុកវាល* មានច្រើននៅខាងកើតស្រុកម៉ូអាប់ ជាទេសភាពក្នុងច្រកភ្នំនៅតំបន់ទន្លេយ័រដាន់ ។

**៤៨:៩** សូមមើល ១៧:៦ និងការពន្យល់ ពច ៩:៤៥ ។

**៤៨:១០** *ដោយព្រងើយកន្តើយ* ឬមានន័យថា"ខ្ជិលច្រអូស" (មានក្នុង សភ ១០:៤ ១២:២៤) ។ គឺអស់អ្នកដែលព្រះយេហូវ៉ាបានចាត់តាំងឱ្យធ្វើកិច្ចការបំផ្លាញដល់ពួកម៉ូអាប់ ។

**៤៨:១១** ជាការចំលងមកពីព្រះគម្ពីរភាសាហេព្រើរ ឯពាក្យទាំងនេះក៏បានឃើញចារលើផ្ទាំងឥដ្ឋ ដែលចុះថ្ងៃគ្រីស្ទបរិស័ទសម័យដើម ហើយមានលក្ខណៈជាត្រា គេក៏ប្រើសម្រាប់បោះត្រានៅលើមាត់ពាងស្រា ។ *តាំងពីក្មេងមក* គឺតាំងពីជីវប្រវត្តិដើមដំបូង (សូមមើល ខ.៣២២–៣៣ អស ១៦:៨–១០) និង (សូមមើល អស ២៥:៦) ។ *ក៏មិនដែលត្រូវនាំទៅជារឈ្លើយ* ដែលមានលក្ខណៈ ខុសពីរាស្ត្រអ៊ីស្រាអែល ។

**៤៨:១២** សាសន៍ម៉ូអាប់នឹងត្រូវខូចខាត (សូមមើលការពន្យល់ ខ.១) ។ *ចាក់ផ្ទេរចេញឱ្យដបនៅទទេ* គឺដើម្បីទុកចោលកុំឱ្យមានកករនៅបាទវា ។ តែមនុស្សទាំងនេះនឹងជាភ្នាក់ងារជិនុំជម្រះ ដែលមានវត្តមានទ្រង់ និង"បំផ្លាញ"ម៉ូអាប់ (សូមមើល ខ.៤ និងការពន្យល់) ។

**៤៨:១៣** *ដូចជាពួកវង្សអ៊ីស្រាអែល* គឺនៅផ្នែកនគរខាងជើង ដែលបានបំផ្លាញខូចខាត ហើយបានជាប់ជាឈ្លើយក្នុងកំឡុងឆ្នាំ ៧២២–៧២១ មុន គ.ស ។ *បេត–អែល* គឺមានទាំង (១).ទីក្រុងល្បីល្បាញជាទីកន្លែងដែលគេដំកល់រូបព្រះធ្វើពីមាស ជារូបព្រះរបស់យេរូបោមដែលបានដំកល់នៅទីនោះ (សូមមើល ១ពវ ១២:២៨–៣០) ឬក៏(២).គឺក្នុងលក្ខណៈពិការភាពជាមួយនឹងព្រះកេម៉ូសមកពីក្រុងបាប៊ីឡូន ជាព្រះពួកសាសន៍សឹម ក៏មានកត់ត្រាក្នុងក្រាំងសតវត្សក្រោយៗមកទៀត ។

**៤៨:១៤** *ធ្វើដូចម្តេចឱ្យឯងរាល់គ្នា* សូមមើល ២:២៣ ៨:៨ ។

**៤៨:១៥** *ធ្វើដូចម្តេចឱ្យឯងរាល់គ្នា* សូមមើល ៥០:២៧ ដូចជាការពណ៌នាពីការសម្លាប់សត្វដើម្បីធ្វើយញ្ញបូជា សូមមើល អស ៣៤:៦ និងការពន្យល់ ។ *មហាក្សត្រ* សូមមើលការពន្យល់ ៤៦:១៨ ។ តែឯព្រះមហាក្សត្រដ៏ពិតប្រាកដ គឺជាព្រះយេហូវ៉ាមិនមែនរូបព្រះកេម៉ូសទេ ។

**៤៨:១៦** សូមមើល ចទ ៣២:៣៥ ។

**៤៨:១៧** *ឯងរាល់គ្នាដែលនៅជុំវិញគេអើយ . . . ឈ្មោះគេអើយ* គឺជាសាសន៍ទាំងឡាយដែលនៅជិតនៅឆ្ងាយ ក៏គួឱ្យគោរពយ៉ាងខ្លាំង ។ *រុងរឿយ* នៅមានពេលមួយស្រុកម៉ូអាប់បានមានអំណាចចេស្តា និងគ្មានភាពភ័យខ្លាច (សូមមើល ២៧: ២ពវ ១:១ ៣:៥ ២៤:២) ។ *ដំបងខែងមាំ* ជានិមិត្តសញ្ញានៃដំបងរាជ្យជាអំណាចចេស្តា និងជាការគ្រប់គ្រង (សូមមើល លប ៤៩:១០ ទដ ២:៩ អគ ១៩:១១,១៤) ។

**៤៨:១៨** *ចូរចុះពី . . . អង្គុយ* សូមមើល អស ៤៧:១ និងការពន្យល់ ។ *ឱកូនស្រី . . . ក្រុងឌីបូនអើយ* គឺបង្ហាញពីលក្ខណៈសម្បត្តិនៃភាពសំខាន់របស់ទីក្រុងម៉ូអាប់នៃក្រុងឌីបូន គឺក្នុងរាជ្យកាលសម័យនោះ (សូមមើលការពន្យល់ ២ពវ ១៩:២១) ក៏ជាទីកន្លែងដែលគេឃើញរូបសំណាកព្រះពួកម៉ូអាប់ដែលមានឈ្មោះល្បីនៅទីនោះ គឺជាស្តេចមេសា មើលសេចក្តីផ្តើម ១ពវ កន្លែងផ្ទៃរឿង : គឺបង្ហាញពីភាពជាព្រះមហាក្សត្រ និងសេចក្តីសញ្ញា ។ *ក្រុងឌីបូន* សូមមើល ខ.២២ ជន ២១:៣០ សូមមើលការពន្យល់ ១៥:២ ។

**៤៨:១៩** *ក្រុងអារ៉ូអើរ* សូមមើលការពន្យល់ ខ.៦ និងមើល ជន ៣២:៣៤ ចទ

ដែលអាស្រ័យនៅក្រុងអារ៉ូអើរអើយ[ង] ចូរឈរក្បែរផ្លូវ
មើលចុះ ចូរសួរអ្នកដែលរត់ ហើយស្រីដែលបានរួចមក
ថា តើកើតមានអ្វី
២០ សាសន៍ម៉ូអាប់ត្រូវខ្មាស ពីព្រោះត្រូវ
រំលំហើយ ចូរស្រែកទ្រហោយំ[ច]ចុះ ចូរប្រាប់នៅមាត់ស្ទឹង
អើណូន[ឆ]ថា ម៉ូអាប់ត្រូវខូចបង់ហើយ
២១ ការសំរេចទោស
បានធ្លាក់មកលើស្រុកវាល[ជ] គឺលើហូឡូន[ឈ] យ៉ាហាស[ញ] និង
មេផ្អាត[ដ]
២២ លើឌីបូន[ឋ] នេបូរ[ឌ] បេត-ឌីប្លាយថែម
២៣ លើ
គារយ៉ាថែម[ឍ] បេត-កាមូល[ណ] បេត-មេយ៉ូន
២៤ ហើយលើ
កេរីយ៉ុត[ត] បុសរ៉ា[ថ] និងអស់ទាំងទីក្រុង[ទ] នៅស្រុកម៉ូអាប់
ទាំងជិតទាំងឆ្ងាយផង
២៥ ឯស្នែង[ធ]របស់សាសន៍ម៉ូអាប់នោះ
បានកាន់ចេញហើយ ដៃ[ន]គេក៏ត្រូវបាក់ដែរ នេះជាព្រះ
បន្ទូលនៃព្រះយេហូវ៉ា ។

២៦ ចូរបង្អកឱ្យគេស្រវឹងចុះ[ប] ដ្បិតគេបានដំកើងខ្លួន
ទាស់[ផ]នឹងព្រះយេហូវ៉ា ម៉ូអាប់នឹងត្រូវននៀលក្នុងអកំអួត
របស់ខ្លួន[ព] ហើយនឹងត្រូវគេមើលងាយឯងផង[ភ]
២៧ ដ្បិត
តើសាសន៍អ៊ីស្រាអែលមិនមែនជាទីមើលងាយដល់ឯងឬ[ម]
តើបានឃើញគេនៅកណ្តាលពួកចោរឬអី[យ] ដ្បិតវេលាណា
ដែល ឯងនិយាយពីគេ នោះឯងចេះតែគ្រវីក្បាល[រ,ល]
២៨ ឱ
ពួក អ្នកស្រុកម៉ូាប់អើយ ចូរចេញពីទីក្រុងទាំងប៉ុន្មាន ទៅ
អាស្រ័យនៅក្នុងថ្មចុះ ត្រូវឱ្យបានដូចជាព្រាប[វ] ដែលធ្វើ
សំបុកនៅមាត់ចំរែះអាង[ស]
២៩ យើងបានឮនិយាយពីសេចក្តី
អំនួតរបស់សាសន៍ម៉ូអាប់ថា គេអួតអាងខ្លាំងណាស់[ហ] និង
ពីសេចក្តីលើកខ្លួន សេចក្តីអំនួត សេចក្តីវាយឫក និង
ពីសេចក្តីឆ្មើងឆ្មៃ[ឡ]ក្នុងចិត្តគេដែរ
៣០ ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា អញស្គាល់សេចក្តីឃោរឃៅរបស់គេថា មិនជា
អ្វីទេ អស់ទាំងសេចក្តីអំនួត[អ]របស់គេ មិនបានបង្កើតអ្វី
សោះ
៣១ ដូច្នេះ អញនឹងទ្រហោយំ[ក]នឹងសាសន៍ម៉ូអាប់ អើ
អញនឹងស្រែកឡើង ដោយព្រោះសាសន៍ម៉ូអាប់ទាំងមូល
ក៏នឹងសោយសោកចំពោះពួកមនុស្ស នៅគារ-ហារ៉ាសែត
ដែរ[ខ]
៣២ ឱដើមទំពាំងបាយជូរ នៅត្រង់សិបម៉ាអើយ[គ] អញ
នឹងយំនឹងឯង លើសជាងយំនឹងយ៉ាសេរ[ឃ]ទៅទៀត ខ្នែង
របស់ឯងបានបោះចេញទៅដល់ត្រើយសមុទ្រម្ខាង បាន
លូកទៅដល់សមុទ្រយ៉ាសេរផង មេបំផ្លាញបានធ្លាក់មក
លើផលរដូវក្តៅ នឹងលើផលទំពាំងបាយជូររបស់ឯង
៣៣ ឯសេចក្តីរីករាយ នឹងសេចក្តីអំណរនោះបានដកចេញ

**៤៨:១៩** ង ជន ៣២:៣៤ **៤៨:២០** ច អស ១៦:៧ ឆ ជន ២១:១៣ **៤៨:២១** ជ យស ១៣:៩,២១ ឈ យស ១៥:៥១ ញ ជន ២១:២៣ អស ១៥:៤ ដ យស ១៣:១៨ **៤៨:២២** ឋ ជន ២១:៣០ យស ១៣:៩,១៧ ឌ ជន ៣២:៣៨ **៤៨:២៣** ឍ ជន ៣២:៣៧ យស ១៣:១៩ ណ យស ១៣:១៧ **៤៨:២៤** ត អម ២:២ ថ យរ ៤៩:១៣ ទ អស ១៥:១ **៤៨:២៥** ធ ទដ ៧៥:១០ ន ទដ ១០:១៥ ៣៧:១៧ អគ ៣០:២១ **៤៨:២៦** ប យរ ២៥:១៦,២៧ ៥១:៣៩ ផ ខ.៤២ ១សយ ១៧:២៦ ព អស ២៨:៨ ភ ខ.៣៩ **៤៨:២៧** ម យរ ២:២៦ យ ២ពវ ១៧:៣-៦ រ យប ១៦:៤ ទដ ៤៤:១៤ យរ ១៨:១៦ ល ចទ ២៨:៣៧ មីក ៧:៨-១០ សផ ២:៨,១០ **៤៨:២៨** វ លប ៨:៨ បស ១:១៥ ស ពច ៦:២ **៤៨:២៩** ហ លប ២៦:១៩ យប ៤០:១២ ឡ ទដ ១០:៥ សភ ១៦:១៨ **៤៨:៣០** អ ទដ ១០:៣ **៤៨:៣១** ក ខ.៣៦ អស ១៥:៥-៨ ខ ២ពវ ៣:២៥ **៤៨:៣២** គ ជន ៣២:៣ ឃ យស ១៣:២៥

២:៣៦ ។

**៤៨:២០** *ស្ទឹងអើណូន* គឺជាស្ទឹងដែលមានសារៈសំខាន់បំផុតក្នុងក្រុងម៉ូអាប់ ។

**៤៨:២១** *ស្រុកវាល* សូមមើលការពន្យល់ ខ.៨ ។ *ហូឡូន* គឺជាស្រុកវាល ឬស្រុកយ៉ាហាស និងមេផ្អត ក៏ពុំមានដូចការបង្ហាញពីយ៉ាងក្នុង យស ១៥:៥១ ២១:១៥ ។ *យ៉ាហាស* សូមមើល ១រប ៦:៧៨ ក៏មានកន្លែងខ្លះគេហៅថា យ៉ាហា (សូមមើល ខ.៣៤ និងមើល អស ១៥:៤ និងការពន្យល់) ។

**៤៨:២២** *ក្រុងឌីបូន* សូមមើល ខ.១៨ ។ *នេបូរ* សូមមើលការពន្យល់ ខ.១ ។ *បេត-ឌីផ្លាថែម* (សូមមើល ជន ៣៣:៤៦) ។

**៤៨:២៣** *គារយ៉ាថែម* សូមមើលការពន្យល់ ខ.១ ។ *បេត-កាមូល* មានចម្ងាយ ៧ គ.ម ចេញពីទីក្រុងអារ៉ូអើ ។ *បេត-មេយ៉ូន* មានលក្ខណៈដូចគ្នានិងបល់-មេយ៉ូន (សូមមើល នក ៣២:៣៨) ។

**៤៨:២៤** *កេរីយ៉ុត* សូមមើលការពន្យល់ អម ២:២ ។ *បុសរ៉ា* គឺពុំមានលក្ខណៈដូចបុសរ៉ា ក្នុងស្រុកអេដំម (សូមមើល ៤៩:១៣,២២) ក៏ប៉ុន្តែមានឈ្មោះមួយទៀតគឺក្រុងបេសើរ នៅក្នុងស្រុកម៉ូអាប់ (សូមមើលការពន្យល់ ចទ ៤:៤៣) ។

**៤៨:២៦** ជាព្រះបន្ទូលនៃព្រះយេហូវ៉ា មានបន្ទូលទៅកាន់ពួកឈ្លានពានស្រុកបាប៊ីឡូន ។ *ឱ្យគេស្រវឹង* គឺការទទួលទានពីពែងកំហឹង ជាសេចក្តីក្រោធរបស់ព្រះអម្ចាស់ (សូមមើល ១៣:១៣ ២៥:១៥-១៧,២៨) ។ *ននៀលក្នុងកំអួតរបស់ខ្លួន* សូមមើលក្នុង ២៥:២៧ អស ១៩:១៤ ។ *ហើយនិងត្រូវគេមើលងាយ* ក៏ដូចជាគេបានធ្វើលើគេឯទៀតផងដែរ (សូមមើល ខ.២៧ សផ ២:៨,១០) ។

**៤៨:២៧** *ឯងចេះតែគ្រវីក្បាល* សូមមើល ១៨:១៦ និងការពន្យល់, និងមើល ៦៤:៨ ។

**៤៨:២៨** *ដូចជាព្រាប . . . ធ្វើសំបុកនៅមាត់ចំរែះរអាង* សូមមើល ទដ ៥៥:៦-៨ បស ២:១៤ ។

**៤៨:២៩-៣០** វគ្គនេះជាការលាតត្រដាងពីអត្ថបទ ដែលពណ៌នានៃស្រុកម៉ូអាប់ក៏មានឃើញក្នុង អស ១៦:៦ ។

**៤៨:២៩** *សេចក្តីអំនួតរបស់សាសន៍ម៉ូអាប់* គឺការងារដែលសាសន៍ម៉ូអាប់ប្រកាន់យកក៏ក្លាយជាកំណត់ត្រាក្នុងគម្ពីរ ដូចជាសុភាសិតប្រដៅដ៏រង់ (សូមមើល អស ២៥:១០-១១ សផ ២:៨-១០) ។

**៤៨:៣១-៣៣** សូមមើល អស ១៦:៧-១០ ។

**៤៨:៣១-៣២** *អញ* គឺជាហោរា (ដូចមានក្នុង អស ១៦:៩ ប្រៀបធៀប អស ១៥:៥) ។

**៤៨:៣១** *ទ្រហោយំ* គឺមានលក្ខណៈដូចជាសត្វព្រាបដែលថ្ងូរ (សូមមើល អស ៣៨:១៤ ៥៩:១១) ។ *គារ-ហារ៉ាសែត* សូមមើល អស ១៦:៧,១១ និងមើលការពន្យល់ អស ១៥:១ ។

**៤៨:៣២** *យ៉ាសេរ* (មើលក្នុង អស ១៦:៩) ។ *ត្រង់សិបម៉ា . . . ត្រើយសមុទ្រម្ខាង* សូមមើល អស ១៦:៨ ។ *ទំពាំងបាយជូរ* មើលការពន្យល់ ខ.១១ ។ *មេបំផ្លាញ* សូមមើល ខ.៨ គឺអាចទាក់ទងនឹងស្តេចនេប៊ូក្នេសា ។

**៤៨:៣៣** *ចំការដុះដាល* សូមមើលការពន្យល់ ២:៧ ។ *ជាន់* សូមមើលការ

ពីចំការដុះដាល ហើយពីស្រុកម៉ូអាប់ទៅ អញបានធ្វើឱ្យ
លែងមានស្រាទំពាំងបាយជូរ[ង] នៅក្នុងធុងឃ្នាបទៀត ក៏
នឹងគ្មានអ្នកណាជាន់ផ្លែ ដោយសំរែកខៀវខ្ញារឡើយ[ច] សូរ
សំរែករបស់គេ នឹងមិនមែនជាសំរែកពិតទេ ៣៤ មានឮ
សំរែកនៅក្រុងហែសបូន[ឆ] រហូតដល់អេលាលេ[ជ] គេបាន
បញ្ចេញសំឡេងរហូតដល់យ៉ាហាស[ឈ] ហើយពីសូអារ[ញ]ទៅ
ដល់ហូរ៉ូណែម[ដ] ដូចជាគោញីអាយុ៣ខួប ដ្បិតទឹកនៃ នីម-
រីមបានរីងស្ងួតទៅហើយ[ឋ] ៣៥ មួយទៀត ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលថា អញនឹងធ្វើឱ្យលែងមានអ្នកណាថ្វាយ
ដង្វាយនៅលើទីខ្ពស់[ឌ] នឹងអ្នកណាដែលដុតកំញាន[ឍ]ថ្វាយ
ដល់ព្រះខ្លួន នៅក្នុងស្រុកម៉ូអាប់ទៀត ។
៣៦ ដូច្នេះ ចិត្តអញនឹងឮឡើង[ណ]ដូចជាខ្លុយ ដោយព្រោះ
ម៉ូអាប់ ហើយចិត្តអញនឹងឮឡើងដូចជាខ្លុយ ដោយព្រោះ
មនុស្សដែលអាស្រ័យនៅគារ-ហារ៉ាសែតដែរ[ត] ពីព្រោះ
ផលបរិបូរ ដែលគេបានប្រមូលទុក[ថ] បានវិនាសអស់ទៅ
ហើយ ៣៧ ដ្បិតគ្រប់ទាំងមនុស្សបានកោរត្រងោល[ទ] ហើយ
កាត់ពុកចង្កា[ធ] គេបានឆូតសាច់ដៃគ្រប់គ្នា ហើយបានស្លៀក
សំពត់ធ្មៃ[ន] ៣៨ នៅលើដំបូលផ្ទះ ហើយនៅក្នុងផ្លូវ[ប]នៃស្រុក
ម៉ូអាប់ នោះមានឮសុទ្ធតែសូរទំនួញគ្រប់កន្លែង ដ្បិតអញ
បានបំបែកសាសន៍ម៉ូអាប់ ដូចជាភាជនៈ[ផ]ដែលឥតមានអ្នក
ណាចូលចិត្តឡើយ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ៣៩ គេ
នឹងស្រែកទ្រហោថា ស្រុកត្រូវបែកបាក់ខ្ទេច[ព]យ៉ាងណាហ្ន៎
សាសន៍ម៉ូអាប់បានបែរខ្នង ដោយខ្មាសហ្ន៎ គឺយ៉ាងនោះ
ដែលសាសន៍ម៉ូអាប់នឹងត្រឡប់ជាទីមើលងាយ[ភ] និងជា
ទីស្ញែងខ្លាច ដល់អស់អ្នកនៅព័ទ្ធជុំវិញគេ ៤០ ដ្បិតព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មើល ខ្មាំងសត្រូវនឹង
ហើរមក[ម]ដូចជាឥន្ទ្រី ហើយនឹងត្រដាងស្លាប[យ]ពីលើស្រុក
ម៉ូអាប់ ៤១ កេរីយ៉ុត[រ]ត្រូវចាប់យកហើយ គេក៏ចាប់បានទី
មាំមួនទាំងប៉ុន្មានដែរ នៅថ្ងៃនោះចិត្តនៃមនុស្សខ្លាំងពូកែ[ល]
ក្នុងសាសន៍ម៉ូអាប់ នឹងបានដូចជាចិត្តរបស់ស្រីដែលឈឺនឹង
សំរាលកូន[វ] ៤២ ម៉ូអាប់នឹងត្រូវបំផ្លាញ[ស]ចេញពីដំណែងជា
សាសន៍[ហ]ទៅ ពីព្រោះគេបានដំកើងខ្លួនទាស់នឹង[ឡ]ព្រះ
យេហូវ៉ា ៤៣ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱពួកអ្នកស្រុក
ម៉ូអាប់អើយ សេចក្តីស្ញែងខ្លាច[អ] រណ្តៅ និងអន្ទាក់[ក] មកលើ
ឯងហើយ ៤៤ អ្នកណាដែលរត់[ខ]ពីសេចក្តីស្ញែងខ្លាច នឹង
ធ្លាក់ទៅក្នុងរណ្តៅ ហើយអ្នកណាដែលឡើងរួចពីរណ្តៅ
នោះនឹងជាប់អន្ទាក់វិញ ដ្បិតអញនឹងនាំឆ្នាំ[គ]ដែលត្រូវធ្វើ
ទោសមកលើគេ គឺមកលើសាសន៍ម៉ូអាប់ នេះជាព្រះបន្ទូល
នៃព្រះយេហូវ៉ា ។
៤៥ ពួកអ្នកដែលរត់ គេឈរនៅទាំងអស់កំឡាំងក្រោម
ម្លប់ក្រុងហែសបូន ប៉ុន្តែមានភ្លើងចេញពីហែលបូន នឹង
អណ្តាតភ្លើងចេញពីកណ្តាលស៊ីហុន[ឃ] ទៅបញ្ឆេះទីបំផុតនៃ
ស្រុកម៉ូអាប់ និងក្រយៅក្បាល[ង]នៃពួកជ្រួលជ្រើមទៅ ៤៦ ឱ

**៤៨:៣៣** ង អស ២៤:៧ ច យអ ១:១២ អម ៥:១៧
**៤៨:៣៤** ឆ ជន ២១:២៥ យស ១៣:២៦ ជ ជន ៣២:៣ ឈ ជន ២១:២៣ អស ១៥:៤ ញ លប ១៣:១០ ដ អស ១៥:៥ ឋ អស ១៥:៦
**៤៨:៣៥** ឌ អស ១៥:២ ឍ យរ ១១:១៣
**៤៨:៣៦** ណ ខ.៣១ ត ២ពរ ៣:២៥ ថ អស ១៥:៧
**៤៨:៣៧** ទ អស ១៥:២ យរ ៤១:៥ អគ ២៧:៣១ ២៩:១៨ ធ លវ ១៩:២៧ ២សយ ១០:៤ ន លប ៣៧:៣៤ អស ៣:២៤ យរ ១៦:៦ អម ៨:១០
**៤៨:៣៨** ប អស ១៥:៣ ផ យរ ២២:២៨
**៤៨:៣៩** ព យរ ៥០:២៣ ភ ខ.២៦

**៤៨:៤០** ម ចទ ២៨:៤៩ ហព ១:៨ យ អស ៨:៨ **៤៨:៤១** រ អស ១៥:១ ល អម ២:១៦ វ អស ២១:៣ **៤៨:៤២** ស អស ១៦:១៤ ហ ខ.២ ឡ ខ.២៦ **៤៨:៤៣** អ យរ ៤៩:៥ ក អស ២៤:១៧ **៤៨:៤៤** ខ ១ពវ ១៩:១៧ យប ២០:២៤ អស ២៤:១៨ យរ ៤៦:៥ គ យរ ១១:២៣ ២៣:១២ **៤៨:៤៥** ឃ ជន ២១:២១,២៦-២៨ យស ១២:២ ង ជន ២៤:១៧

ពន្យល់ អស ១៦:១០ ។ *មិនមែនជាសំរែកពិតទេ* តែជាសំរែកនៃការជំនុំជម្រះ (សូមមើល ២៥:៣០ ៥១:៤-៦) ។

**៤៨:៣៤** សូមមើល អស ១៥:៤-៦ និងការពន្យល់ ។

**៤៨:៣៦** សូមមើល អស ១៦:១១ ។ *ខ្លុយ* ជាឧបករណ៍ភ្លេងដែលគេលេង ឬផ្លុំវានៅក្នុងពិធីកាន់ទុក្ខបុណ្យខ្មោច (សូមមើល មថ ៩:៣៣-២៤ និងការពន្យល់ ៩:២៣) ។

**៤៨:៣៧** ខនេះបង្ហាញពីការកាន់ទុក្ខ (សូមមើល អស ១៥:២-៣ និងការពន្យល់) ។ *កាត់* សូមមើលការពន្យល់ ១៦:៦ ។

**៤៨:៣៨** *បំបែកសាសន៍ម៉ូអាប់ . . . ឥតមានអ្នកណាចូលចិត្តឡើយ* សូមមើល ខ.៤ និងការពន្យល់ ខ.១២ សូមមើលការប្រៀបធៀបពីសេចក្តីផ្តើមពណ៌នារបស់ស្តេចយ៉ូយ៉ាគីន នៅក្នុង ២២:២៨ (និងមើលការពន្យល់) ។

**៤៨:៣៩** *ត្រឡប់ជាទីមើលងាយ* សូមមើល ខ.២៦ ។

**៤៨:៤០-៤១** មើល ៤៩:២២ និងការពន្យល់ ។

**៤៨:៤០** *ឥន្ទ្រី* នេប៊ូក្នេសា (ដូចមានក្នុង អគ ១៧:៣) សូមមើល ចទ ២៨:៤៩ និងការពន្យល់ ។

**៤៨:៤១** *ស្រីដែលឈឺនឹងសំរាលកូន* សូមមើលការពន្យល់ ៤:៣១ ។

**៤៨:៤៣** *សេចក្តីស្ញែងខ្លាចរណ្តៅ និងអន្ទាក់មកលើឯងហើយ* តាមរយៈព្រះគម្ពីរភាសាហេព្រើរ គឺបង្ហាញពីភាពពេញចិត្តរបស់លោកយេរេមា (មើលសេចក្តីផ្តើម : តាមរយៈករណីនេះបង្ហាញថា លោកយេរេមាមិនមែនជាព្រះអាទិករទេ (មើល អស ២៤:១៧-១៨ និងការពន្យល់ ២៤:១៧) ។

**៤៨:៤៤** *អ្នកណាដែលរត់រួចពី . . . និងធ្លាក់ទៅក្នុងរណ្តៅ . . . អ្នកណាដែលឡើងរួចពីរណ្តៅ . . . និងជាប់អន្ទាក់វិញ* គឺជាការជំនុំជម្រះពីព្រះយេហូវ៉ា គឺជាការសម្រេចព្រះទ័យតែម្តងប៉ុណ្ណោះ គឺគ្រប់ទាំងអស់ដែលមិនអាចគេចផុតពីការជំនុំជម្រះបានឡើយ (សូមមើល អម ៥:១៩) ។

**៤៨:៤៥-៤៦** ជាហេតុការណ៍ដែលលេចចេញពី ជន ២១:២៨-២៩ ២៤:១៧ ។ ដូចជាសេចក្តីទំនាញរបស់បាឡាប ជាកូនបេអ័រ ដែលទាស់ប្រឆាំងនឹងស្តេចម៉ូអាប់ ដែលជិតបានសម្រេចសេចក្តីទាំងនោះ ។

**៤៨:៤៥** *ក្រុងហែសបូន* សូមមើលការពន្យល់ ខ.២ ក្រុងនោះក៏បានគ្រប់គ្រងដោយពួកកូនចៅអាំម៉ូន (សូមមើល ៤៩:៣) ។ *ស៊ីហុន* គឺសំដៅទៅលើការទាក់ទងស្តេចស៊ីហុន នៃពួកកូនចៅអាំម៉ូនដែលមានទីក្រុងសំខាន់គឺក្រុងហែសបូន (សូមមើល ជន ២១:២៧) ក្នុងកំឡុងពេលចេញដំណើរ ។ *ពួកជ្រួលជ្រើម* សូមមើលការពន្យល់ ខ.២៩ ។

ម៉ូអាប់អើយ[ច] វរដល់ឯហើយ ពួកព្រះកេម៉ូសកំពុងវិនាស
ទៅ ដ្បិតពួកកូនប្រុសកូនស្រីរបស់ឯងត្រូវចាប់ដឹកទៅជា
ឈ្លើយហើយ ៤៧ប៉ុន្តែ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ដល់
ជាន់ក្រោយ អញនឹងនាំ[ឆ]ពួកម៉ូអាប់ ដែលជាឈ្លើយនោះ
មកវិញ ទោសរបស់សាសន៍ម៉ូអាប់ត្រូវប៉ុណ្ណោះហើយ ។

## ព្រះរាជសារអំពីសាសន៍អាំម៉ូន

**៤៩** ១ពីពួកកូនចៅអាំម៉ូន[ក] ។
ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា តើអ៊ីស្រាអែល
គ្មានកូនប្រុសទេឬអី តើគ្មានអ្នកណានឹងគ្រងមរដកទេឬ
ចុះហេតុអ្វីបានជាព្រះម៉ូឡុក[ខ] បានគ្រងស្រុកកាឌជាមរដក[គ]
ហើយពួកវានឹងអាស្រ័យនៅ ក្នុងទីក្រុងនៃស្រុកនោះដូច្នេះ
២ហេតុនេះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល នឹងមាន
គ្រាមកដល់ ដែលអញនឹងធ្វើឱ្យឮសំរែក[ឃ]ប្រាប់ពីចំបាំង
នៅក្រុងរ៉ាបាត[ង]របស់ពួកចៅអាំម៉ូន ហើយទីក្រុងនោះនឹង
ទៅជាគំនរបំណែកនៅស្ងាត់ច្រៀប[ច] ហើយដំបន់នៅជុំវិញ
ទាំងប៉ុន្មាន និងត្រូវដុតចោលទៅ គ្រានោះសាសន៍អ៊ីស្រា–
អែលនឹងបានមរដក ដែលពួកកូនចៅអាំម៉ូនបានយកជា
របស់ផងគេនោះមកវិញ[ឆ] នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា
៣ឱហែសបូនអើយ[ជ] ចូរទ្រហោយំចុះ ដ្បិតក្រុងអៃយ[ឈ]ត្រូវ
ខូចបង់ហើយ ឱពួកកូនស្រីនៃក្រុងរ៉ាបាតអើយ ចូរស្រែក
ឡើង ចូរស្លៀកសំពត់ធ្មៃ[ញ] ហើយទួញទំនួញចុះ ត្រូវឱ្យរត់
ទៅមកតាមរបង ដ្បិតព្រះម៉ូឡុក[ដ]នឹងត្រូវចាប់យកទៅជា
ឈ្លើយ[ឋ]ព្រមទាំងពួកសង្ឃ និងពួកចៅហ្វាយផងទាំងប៉ុន្មាន
ផង ៤ឱកូនស្រីដែលរាថយអើយ[ឌ] ជាអ្នកដែលទុកចិត្តនឹង
ទ្រព្យសម្បត្តិ[ឍ]របស់ខ្លួន ហើយពោលថា តើអ្នកណានឹង
មកទាស់នឹងអញ[ណ] ហេតុអ្វីបានជាឯងអួតពីច្រកភ្នំរបស់ឯង
គឺជាច្រកភ្នំដែលមានទឹកហូរនោះ ៥ព្រះអម្ចាស់ ជាព្រះ
យេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលថា មើល អញ
នឹងនាំសេចក្ដីស្ញែងខ្លាចមកលើឯង ពីគ្រប់ទាំងសាសន៍
ដែលនៅជុំវិញឯង ហើយឯងរាល់គ្នានឹងត្រូវបណ្ដេញ
ចេញទៅខាងមុខរៀងខ្លួន ឥតមានអ្នកណានឹងប្រមូលផ្ដុំ
ពួកអ្នក ដែលរត់ទៅនោះឡើយ[ត] ៦ប៉ុន្តែ ជាន់ក្រោយអញ
នឹងនាំ[ថ]ពួកកូនចៅអាំម៉ូន ដែលជាឈ្លើយមកវិញ នេះជា
ព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## ព្រះរាជសារអំពីសាសន៍អេដំម

*៤៩:៩–១០ – អប ៥–៦*

*៤៩:១៤–១៦ – អប ១–៤*

៧ពីសាសន៍អេដំម[ទ]
ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះ ថា
តើគ្មានអ្នកប្រាជ្ញានៅក្នុងថេម៉ានទៀតទេឬ[ធ] តើសេចក្ដី

**៤៨:៤៦** ច ជន ២១:២៩ **៤៨:៤៧** ឆ ទដ ១៤:៧ អស ១១:១១ យរ ១២:១៥ ៤៩:៦,៣៩ អគ ១៦:៥៣ ដយ ១១:៤១ **៤៩:១** ក លប ១៩:៣៨ ១សយ ១១:១–១១ ២សយ ១០:១–១៩ ខ លវ ១៨:២១ គ លប ៣០:១១ **៤៩:២** ឃ យរ ៤:១៩ ង ចទ ៣:១១ ច ចទ ១៣:១៦ ឆ អស ១៤:២ យរ ៣០:១៦ អគ ២១:២៨–៣២ ២៥:២–១១ **៤៩:៣** ជ យស ១៣:២៦ ឈ លប ១២:៨ យស ៨:២៨ ញ លប ៣៧:៣៤ ដ សផ ១:៥ ឋ យរ ៤៨:៧ **៤៩:៤** ឌ យរ ៣:៦ ឍ យរ ៩:២៣ ១ធថ ៦:១៧ ណ យរ ២១:១៣ **៤៩:៥** ត យរ ៤៤:១៤ **៤៩:៦** ថ យរ ១២:១៤–១៧ ៤៨:៤៧ **៤៩:៧** ទ លប ២៥:៣០ ទដ ៨៣:៦ ធ លប ៣៦:១១,១៥,៣៤

**៤៨:៤៦** *ពួកព្រះកេម៉ូស* សូមមើលការពន្យល់ ខ.៧ ។

**៤៨:៤៧** សូមមើល ៤៦:២៦ និងការពន្យល់ ២៩:១៤ ។ *ដល់ជាន់ក្រោយ* គឺក្នុងយុគសម័យព្រះម៉ែស៊ី (សូមមើល ៥១:៦៤) ។

**៤៩:១** *ពីពួកកូនចៅអាំម៉ូន* សូមមើល អគ ២៥:១–៧ អម ១:១៣–១៥ សផ ២:៨–១១ ។ ពួកកូនចៅអាំម៉ូននៅផ្នែកខាងកើតទន្លេយ័រដាន់ និងនៅផ្នែកខាត្បូងស្រុកម៉ូអាប់ (សូមមើលការពន្យល់ លប ១៩:៣៦–៣៨) ។ *តើអ៊ីស្រាអែល . . . អ្នកណានឹងគ្រងមរដក* គឺជាសំនួរបែបខាងវោហារសាស្ត្រ ដើម្បីបង្ហាញឱ្យកាន់តែច្បាស់ពីពួកកូនចៅអាំងម៉ូនបានមើលស្រាលដល់រាស្ត្រអ៊ីស្រាអែល ។ *ព្រះម៉ូឡុត* គឺជាព្រះធំជាងគេរបស់ពួកកូនចៅអាំម៉ូន (សូមមើល ១ពវ ១១:៥,៧,៣៣) ឯព្រះនោះក៏មានឈ្មោះមួយទៀតថាព្រះមីលកូម (សូមមើលការពន្យល់ ១ពវ ១១:៥) ។ ឯពាក្យទាំងពីរនេះគឺជាពាក្យមានទំនាក់ទំនងនឹងលោកខាងលិច ជាពាក្យសម្រាប់"ស្ដេច" ។ *ស្រុកកាឌជាមរដក* គឺអាចសំដៅទៅលើកាលៈទេសៈមានជ័យជម្នះរបស់ស្ដេចទីកឡាក–ពីលេសើរ នៃស្រុកនៅតាមដងទន្លេយ័រដាន់នាសម័យឆ្នាំ ៧៣៤–៧៣២ មុន គ.ស ។ មានពួកកូនចៅអាំងម៉ូនក្នុងគ្រានោះក៏បានរួចផុតពីការវាយផ្ដួល និងផុតពីតំបន់ត្រួតត្រារបស់រាស្ត្រអ៊ីស្រាអែល ដែលជាកូនកាឌ ។ *ពួកវា* គឺជាព្រះម៉ូឡុត ។

៤៩:២ *ស្រែកប្រាប់ពីចំបាំង* សូមមើល អម ១:១៤ ។ *ក្រុងរ៉ាបាតរបស់ពួកកូនចៅអាំម៉ូន* សូមមើលការពន្យល់ ចទ ៣:១១ ។ *គំនរបំណែក* សូមមើល ៣០:១៨ និងការពន្យល់ ។

**៤៩:៣** *ហែសបូន* មើលការពន្យល់ ៤៨:៤៥ និងមើល ពច ១១:២៦–២៧ ។ *ក្រុងអៃយ* គឺមិនមែនជាក្រុងអៃយមានក្នុង យស ៨ នោះទេ ។ *របង* ពាក្យនេះក្នុងព្រះគម្ពីរភាសាហេព្រើរ គឺមិនមែរបស់ ឬកំផែងទីក្រុងទេ តែវាជារបងរបស់ចំការទំពាំងបាយជូរវិញ ដែលគេប្រើដើម្បីញែកព្រំខណ្ឌចំការនិមួយៗ(មើល ២២:២៤ អស ៥:៥) ។ *ព្រះម៉ូឡុក* មើលការពន្យល់ ខ.១ ។ *ត្រូវចាប់យកទៅជាឈ្លើយ . . . ពួកចៅហ្វាយ* មើលការពន្យល់ ៤៨:៨ ។

**៤៩:៤** *កូនស្រីដែលរាថយអើយ* គឺបង្ហាញលក្ខណៈសម្បត្តិរបស់ពួកអាំម៉ូន (សូមមើលការពន្យល់ ២ពវ ១៩:២១) ក៏មានការប្រើភាសាដូចគ្នាដែលពួកសាសន៍យូដាបានប្រើក្នុង ៣១:២២ ។ *អ្នកដែលទុកចិត្តនឹងទ្រព្យសម្បត្តិរបស់ខ្លួន* គឺព្រះមានបន្ទូលដល់ពួកស្រុកម៉ូអាប់ក្នុង ៤៨:៧ ។ *តើអ្នកនឹងមកទាស់នឹងអញ* ដោយយោងតាមលោកយ៉ូសែមភើសថា ពួកស្ដេចនេប៊ូក្នេសាបានបំផ្លាញអាំម៉ូនក្នុងឆ្នាំទី ២៣ នៃរាជកាលគ្រងរាជរបស់ស្ដេចអង្គនោះ (៥៨២ មុន ស.គ) ។

**៤៩:៧–២២** ជាការបង្ហាញវគ្គឃ្លាខ្លះ និងទស្សនៈដែលមានទំនាក់ទំនងនឹងគម្ពីរអូបាឌ (សូមមើលសេចក្ដីផ្ដើមគម្ពីរ អូបាឌា : កន្លែងការរួបរួម និងផ្ទៃរឿង) ។

**៤៩:៧** *ពីសាសន៍អេដំម* សូមមើល អស ២១:១១–១២ អគ ២៥:១២–១៤ អម ១:១២ អម ១–១៦ ។ *ប្រាជ្ញា* គឺចំពោះពួកអេដំម (សូមមើលការពន្យល់

ប្រឹក្សាបានសូន្យបាត់ពីពួកមនុស្សឆ្លៀវឆ្លាតឬអី តើប្រាជ្ញា
របស់គេបានរលាយបាត់ទៅឬ ៨ឱពួកអ្នកដែលអាស្រ័យ
នៅស្រុកដេដាន់អើយ[ន] ចូររត់ទៅ ចូរបែរខ្នងចុះ ត្រូវឱ្យ
ទៅជ្រកនៅរអាងយ៉ាងជ្រៅទៅ[ប] ដ្បិតអញនឹងនាំសេចក្ដី
អន្តរាយរបស់អេសាវមកលើគេ គឺជាវេលាដែលអញនឹង
ធ្វើទោសដល់គេ ៩បើមានពួកសិរាប់បេះផ្លែទំពាំងបាយជូរ
មកឯឯង នោះតើគេមិនទុកផ្លែខ្លះឱ្យបេះសន្សំជាន់ក្រោយ
ទេឬ បើចោរមកនៅពេលយប់ នោះតើវាមិនបំផ្លាញ ឱ្យ
ល្មមតែស្កប់ចិត្តប៉ុណ្ណោះទេឬអី ១០ប៉ុន្តែអញៗបានធ្វើឱ្យ
អេសាវអាក្រាតនៅទទេ អញបានបើកកេរខ្មាសគេឱ្យ
ឃើញផង[ផ] គេនឹងមិនអាចបិទបាំងខ្លួនបានទេ ពូជពង្សគេ
ត្រូវបំផ្លាញហើយ ព្រមទាំងបងប្អូន និងអ្នកជិតខាងគេផង
ឯខ្លួនគេក៏មិននៅទៀតដែរ[ព] ១១ចូរលះចោលកូនកំព្រា
របស់ឯងចុះ[ភ] អញនឹងចិញ្ចឹមវាឱ្យរស់នៅ ហើយត្រូវឱ្យពួក
មេម៉ាយ[ម] របស់ឯងទុកចិត្តនឹងអញទៅ ១២ដ្បិតព្រះយេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះថា មើល ពួកអ្នកដែលមិនមានទោស
ជាត្រូវផឹកពីពែង[យ] នោះនឹងត្រូវផឹកវិញជាមិនខាន ឯឯង
តើជាអ្នក ដែលនឹងអាចរួចពីទោសទាំងអស់ឬ[រ] ឯងមិនត្រូវ
នៅជាឥតទោសទេ គឺឯងនឹងត្រូវផឹកពីពែងនេះជាពិតវិញ
១៣ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញបានស្បថ[ល]នឹង
ខ្លួនអញថា ក្រុងបុសរ៉ា[វ]នឹងត្រឡប់ជាទីស្រឡាំងកាំង ជាទី
ត្មះតិះដៀល[ស] ជាទីខូចបង់[ហ] ហើយឡើយជាទីផ្ដាសា ឯអស់
ទាំងភូមិនៅជុំវិញនឹងទៅ ជាកន្លែងខូចបង់នៅអស់កល្ប
តទៅ[ឡ]។
១៤ខ្ញុំបានឮដំណឹងមកពីព្រះយេហូវ៉ា ទ្រង់ក៏បានចាត់
ទូត១ ឱ្យទៅឯសាសន៍ទាំងប៉ុន្មានប្រាប់ថា ចូរមូលគ្នាមក
ទាស់នឹងគេ ហើយលើកគ្នាទៅច្បាំងចុះ ១៥ដ្បិតមើល អញ
បានធ្វើឱ្យឯងយ៉ាងតូច នៅកណ្ដាលពួកសាសន៍ទាំងប៉ុន្មាន
ហើយឱ្យមនុស្សទាំងឡាយ មើលងាយឯងផង ១៦ត្រង់
សេចក្ដីគួរស្ញែងខ្លាចរបស់ឯងនោះ គឺជាសេចក្ដីអំនួត[អ]ក្នុង
ចិត្តឯង បានបញ្ឆោតខ្លួនទេ ឱឯងដែលអាស្រ័យនៅ
ក្រហែងថ្មដា[ក] ជាអ្នកដែលរក្សាកន្លែង នៅជាប់លើទីខ្ពស់
អើយ ទោះបើឯងធ្វើសំបុក[ខ]នៅទីខ្ពស់ ដូចជាឥន្ទ្រីក៏ដោយ
គង់តែអញនឹងទំលាក់ឯងចុះពីនោះមកដែរ នេះជាព្រះ
បន្ទូលនៃព្រះយេហូវ៉ា ១៧ស្រុកអេដំមនឹងត្រឡប់ជាទី
ស្រឡាំងកាំង[គ] ឯអស់អ្នកដែលដើរតាមទីនោះ គេនឹង
អស្ចារ្យក្នុងចិត្ត ហើយនឹងធ្វើស៊ីសស៊ូសឱ្យ ដោយព្រោះ
អស់ទាំងសេចក្ដីវេទនារបស់ស្រុកនោះ[ឃ] ១៨ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលថា និងគ្មានមនុស្សណាអាស្រ័យនៅ[ង]ស្រុក
នោះ ឬមនុស្សជាតិណាស្នាក់នៅទីនោះឡើយ ដូចក្នុង
ការបំផ្លាញក្រុងសូដុំម[ច] និងក្រុងកូម៉ូរ៉ា[ឆ] ព្រមទាំងទីក្រុងជិត

**៤៩:៨** ន លប ១០:៧ ២៥:៣ ប ពច ៦:២ **៤៩:១០** ផ លប ៣:៨ ព អស ៣៤:១០–១២ យរ ១១:២៣ អគ ៣៥:៤ អប ១:១៨ មឡ ១:២–៥ **៤៩:១១** ភ ហស ១៤:៣ ម ចទ ១០:១៨ យក ១:២៧ **៤៩:១២** យ អស ៥១:២៣ យរ ២៥:១៥ មថ ២០:២២ រ សភ ១១:៣១ **៤៩:១៣** ល លប ២២:១៦ វ លប ៣៦:៣៣ ស ខ.១៧ ហ យរ ៤២:១៨ ឡ យរ ១៩:៨ អគ ៣៥:៩ **៤៩:១៦** អ អគ ៣៥:១៣ អប ១:១២ ក យប ៣៩:២៨ ខ យប ៣៩:២៧ **៤៩:១៧** គ ខ.១៣ ឃ ចទ ២៩:២២ អគ ៣៥:៧ **៤៩:១៨** ង ខ.៣៣ អស ៣៤:១០ ច យរ ២៣:១៤ ឆ លប ១៩:២៤

យប ១:១ ២:១១) ។ *ក្រុងថេម៉ាន* គឺជាទីក្រុងអេដុំដ៏សំខាន់ ដែលមានទីតាំងត្រង់ខាងត្បូងសមុទ្រស្លាប់ (សូមមើល យប ២:១១) ។ ក្នុង ខ.២០ ដែលមានហេតុការណ៍ស្រដៀងគ្នា និងអេដុំមផ្ទាល់ ។

**៤៩:៨** *ចូររត់ទៅ ចូរបែរខ្នងចុះ* សូមមើល ខ.២៤ ៤៦:២១ ។ *ស្រុកដេដាន់* សូមមើល ២៥:២៣ និងការពន្យល់ អស ២១:១៣ អគ ២៥:១៣ ។ *លោកអេសាវ* គឺជាបងប្រុសរបស់លោកយ៉ាកុប បានបង្កើតឱ្យមានភាពខឹងសម្បាក្នុងសាសន៍អេដុំមចំពោះរាស្ត្រអ៊ីស្រាអែល (មើល អម ១:១១ អប ១០) ។

**៤៩:៩–១០** ក៏មានហេតុការណ៍ក្នុង អប ៥–៦ (សូមមើលការពន្យល់គម្ពីរនោះផងដែរ) ។

**៤៩:៩** *ពួកសិរាប់បេះផ្លែទំពាំងបាយជូរ* សូមមើលការពន្យល់ ខ.១៣ ។ *ទុកផ្លែខ្លះឱ្យបេះសន្សំជាន់ក្រោយ* គឺសម្រាប់ភាពក្រីក្រមកដល់ (សូមមើលការពន្យល់ នរ ២:២) ។

**៤៩:១០** *ធ្វើឱ្យអេសាវអាក្រាត* សូមមើលការពន្យល់ ១៣:២២ ។ សូមមើល ៣១:១៥ អស ១៩:៧ ។

**៤៩:១១** នៅពេលដែលមនុស្សប្រុសៗរបស់ពួកស្រុកអេដុំម បានចាកចេញទៅធ្វើសង្គ្រាម ហើយក៏បានស្លាប់ ចំពោះស្ត្រីមេម៉ាយ និងក្មេងកំព្រាគឺព្រះយេហូវ៉ាទ្រង់ជាអ្នកការពារពួកគេ ។

**៤៩:១២** ក៏មានលក្ខណៈដូចគ្នាក្នុង ២៥:២៨–២៩ ។ *ពួកអ្នកដែលមិនមានទោសជាត្រូវផឹកពីពែង* ទោះអ្នកដែលព្រះបានជ្រើសតាំងក៏ដោយប្រជារាស្ត្រនៅស្រុកយូដានឹងទទួលកម្ម ដោយព្រោះអំពើបាបរបស់ពួកគេ (សូមមើល ២៥:២៨ អម ៣:២ និងការពន្យល់) ។

**៤៩:១៣** *ស្បថនឹងខ្លួនអញ* សូមមើលការពន្យល់ លប ២២:១៦ អស ៤៥:២៣ សូមមើល ២២:៥ ៥១:១៤ ។ *ក្រុងបុសរ៉ា* មិនមែនក្រុងបុសរ៉ាក្នុង ៤៨:១៤ (សូមមើលការពន្យល់ក្នុងជំពូកនោះ) ឯទីក្រុងបុសរ៉ា គឺអាចជារាជធានីរបស់ស្រុកអេដុំម គឺក្នុងសម័យហោរាយេរេមា (មើល ខ.២២ លប ៣៦:៣៣ សូមមើលនៅក្នុងគម្ពីរ ៣៤:៦ អម ១:១២) ។ ក្នុងព្រះគម្ពីរភាសាហេព្រើរ បានពិភាគយ៉ាងល្អិតល្អន់នូវឫស្សគល់ពីទីក្រុងបុសរ៉ា ក៏មានលក្ខណៈដូចគ្នានឹង "ពួកអ្នកសម្រាប់បេះផ្លែទំពាំងបាយជូរ" មានក្នុង ខ.៩ ។ *ជាទីខូចបង់ . . . ជាទីផ្ដាសា* សូមមើល ២៥:៩ ទដ ៧៤:៣ អស ៥៨:១២ និងការពន្យល់ ។

**៤៩:១៤–១៦** ជាហេតុការណ៍ស្រដៀងគ្នា និងហេតុការណ៍ក្នុង អប ១–៤ ។

**៤៩:១៦** *អំនួត* គឺជាអំពើបាបដែលបិទបាំងជុំវិញរបស់ពួកស្រុកអេដុំម (សូមមើល ខ.៤ អប ១១–១៣ ប្រៀបធៀប ៤៨:២៩–៣០) ។ *ថ្មដា* ពាក្យនេះប្រហែលសំដៅលើថ្មភីត្រា (សូមមើលការពន្យល់ ២ពវ ១៤:៧) ជាភ្នំដែលសាសន៍អេដុំមចាត់ទុកថាជាទីតាំងរឹងមាំសម្រាប់ពួកគេ ។

**៤៩:១៧** ដែលមាននៅក្នុង ១៩:៨ ។

**៤៩:១៨** ក៏បានឃើញនិយាយជាច្រើនសារក្នុង ៥០:៥០ ក៏ឃើញក្នុង ខ.៣៣ ។ *ការបំផ្លាញក្រុងសូដុំម និងក្រុងកូម៉ូរ៉ា* សូមមើល លប ១៩:២៤–២៥ ។ ក៏មានការប្រៀបធៀបពីវិបត្តិក្រុងសូដុំម និងក្រុងកូម៉ូរ៉ា (សូមមើលការ

ខាងនោះទាំងប៉ុន្មានដែរ ១៩មើល នឹងមានមនុស្សឡើងមក
ទាស់នឹងទីលំនៅមាំមួននោះ ដូចជាសិង្ហ[ជ]ដែលឡើងពី
ទីជិនន់[ឈ]នៃទន្លេយ័រដាន់ ដ្បិតអញនឹងធ្វើឱ្យគេរត់ពីទីនោះ
ទៅភ្លាម រួចអ្នកដែលបានរើសតាំងឡើង នោះអញនឹង
ដំរូវឱ្យគ្រប់គ្រងលើទីនោះវិញ ដ្បិតតើមានអ្នកឯណាឱ្យ
ដូច[ញ] អញ តើអ្នកណានឹងដាក់កំណត់ឱ្យអញបាន[ដ] តើមានអ្នក
គង្វាល[ឋ]ណាដែលនឹងអាចឈរនៅមុខអញបាន ២០ដូច្នេះ
ចូរស្តាប់សេចក្តីប្រឹក្សានៃព្រះយេហូវ៉ា ដែលទ្រង់បាន
សំរេចទាស់នឹងស្រុកអេដំម[ឌ] និងដំរិះដែលទ្រង់បានគិត[ឍ]
ទាស់នឹងពួកអ្នកនៅក្រុងថេម៉ាន[ណ] គឺថា ពួកតូចបំផុតក្នុង
ហ្វូង[ត] និងអូសគេចេញជាពិត ទាំងឱ្យទីលំនៅរបស់គេទៅ
ជាស្ងាត់ច្រៀប[ថ]ពីលើគេ[ទ] ២១ផែនដីក៏ញ័រ[ធ]ដោយសូរគេ
ធ្លាក់ចុះ ក៏មានឮសំរែក[ន]ដែលឮរហូតដល់សមុទ្រក្រហម
២២មើល គេនឹងឡើងមក ទាំងហើរ[ប]ដូចជាឥន្ទ្រី គេនឹង
ត្រដាងស្លាបលើក្រុងបុសរ៉ា[ផ] នៅថ្ងៃនោះចិត្តនៃមនុស្សខ្លាំង
ពូកែនៅស្រុកអេដំម[ព] និងបានដូចជាចិត្តនៃស្រីដែលរៀប
នឹងសំរាលកូន[ភ] ។

## ព្រះបន្ទូលអំពីក្រុងដាម៉ាស

២៣ពីក្រុងដាម៉ាស[ម] ។

ឯក្រុងហាម៉ាត[យ] និងក្រុងអើផាឌ[រ] គេត្រូវខ្មាសជ្រប់មុខ
ហើយ ពីព្រោះគេបានឮដំណឹងអាក្រក់ ហើយចិត្តគេ
រលាយទៅ សេចក្តីទុក្ខព្រួយរបស់គេដូចជាសមុទ្រដែល
កំរើកឡើង នឹងឱ្យស្ងប់វិញមិនបាន[ល] ២៤ក្រុងដាម៉ាសបាន
ទៅជាខ្សោយ គេបែរទៅរៀបនឹងរត់ សេចក្តីភ័យញ័រក៏
ចាប់គេហើយ គេកើតមានសេចក្តីថប់ព្រួយ និងសេចក្តី
ទុក្ខវេទនា ដូចជាស្រីដែលឈឺនឹងសំរាលកូន[វ] ២៥ទីក្រុង
គួរសរសើរ ជាទីរីករាយដល់អញ ដូចម្តេចបានជាគេមិន
សំចៃទុកឯងដូច្នេះហ្ន៎ ២៦ហេតុនោះ ពួកកំលោះៗ[ស]របស់
ក្រុងនោះនឹងដួលនៅក្នុងផ្លូវ ហើយអស់ទាំងទាហាននឹង
ត្រូវស្ងៀមស្ងាត់[ហ]នៅថ្ងៃនោះ នេះជាព្រះបន្ទូលរបស់ព្រះ
យេហូវ៉ានៃពួកពលបរិវារ ២៧ហើយអញនឹងបង្កាត់ភ្លើង
ឡើង[ឡ] នៅក្នុងកំផែងក្រុងដាម៉ាស[អ] ភ្លើងនោះនឹងឆេះ[ក]
ដំណាក់របស់បេន-ហាដាឌទៅ[ខ] ។

## ព្រះរាជសារអំពីពួកកេដា និងហាសោរ

២៨ពីពួកកេដារ[គ] និងពីនគរទាំងប៉ុន្មានដែលនៅស្រុក
ហាសោរ[ឃ] ដែលនេប៊ូក្នេសា[ង]ជាស្តេចបាប៊ីឡូនបានវាយ ។
ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ ចូរក្រោកឡើង
ឡើងទៅឯពួកកេដារ ហើយបំផ្លាញពួកកូនស្រុកនៅខាង
កើតចុះ[ច] ២៩ពួកខ្មាំងសត្រូវនឹងចាប់យកត្រសាល និងហ្វូង

**៤៩:១៩** ជ ១សយ ១៧:៣៤ ឈ យរ ១២:៥ ញ នក ៨:១០ ២របា ២០:៦ អស ៤៦:៥ ដ យប ៩:១៩ យរ ៥០:៤៤ ឋ ១សយ ១៧:៣៥ **៤៩:២០** ឌ អស ៣៤:៥ ឍ អស ១៤:២៧ ណ ខ.៧ លប ៣៦:១១ ត យរ ៥០:៤៥ ថ ខ.១០ អប ១:១០ មទ្ឋ ១:៣-៤ ទ យរ ៥០:៤៥ **៤៩:២១** ធ ទដ ១១៤:៧ អក ២៦:១៥ ២៧:២៨ ៣១:១៦ ន យរ ៥០:៤៦ ៥១:២៩ អក ២៦:១៨ **៤៩:២២** ប ចទ ២៨:៤៩ ហស ៨:១ ហព ១:៨ ផ លប ៣៦:៣៣ ព យរ ៥០:៣៦ ណហ ៣:១៣ ភ អស ១៣:៨ **៤៩:២៣** ម លប ១៤:១៥ ២ពវ ១៤:២៨ ២របា ១៦:២ កច ៩:២ យ ១ពវ ៨:៦៥ អស ១០:៩ អក ៤៧:១៦ អម ៦:២ សក ៩:២ រ ២ពវ ១៩:៣៤ ១៩:១៣ ល លប ៤៩:៤ **៤៩:២៤** វ យរ ១៣:២១ **៤៩:២៦** ស អស ៩:១៧ ១៣:១៨ ហ អស ១៧:១២-១៤ **៤៩:២៧** ឡ យរ ២១:១៤ ៤៣:១២ ៥០:៣២ អក ៣០:៨ ៣៩:៦ អម ១:៤ អ លប ១៤:១៥ ក អស ១៧:១ ខ ១ពវ ១៥:១៨ **៤៩:២៨** គ លប ២៥:១៣ ឃ យស ១១:១ ង យរ ១០:២២ ច ពច ៦:៣

ពន្យល់ អម ៤:១១) ។ *ទីក្រុងជិតខាងនោះ* (សូមមើល លប ១៤:២,៨ ចទ ២៩:២៣ ហស ១១:៨ និងការពន្យល់) ។ មានក្រុងសំខាន់ៗមួយចំនួនគឺ ក្រុងអាត់ម៉ា និងក្រុងសេបោម (សូមមើល លប ១៤:២,៨ ចទ ២៩:២៣ ហស ១១:៨ និងការពន្យល់) ។

**៤៩:១៩-២១** ជាហេតុការណ៍បង្ហាញឡើងវិញដដែលៗ នៅក្នុងទំនាយប្រឆាំងនឹងពួកបាប៊ីឡូន (សូមមើល ៥០:៤៤-៤៦) ។

**៤៩:១៩** *ពីទីជិនន់នៃទន្លេយ័រដាន់* សូមមើល ១២:៥ និងការពន្យល់ ។ *អ្នកគង្វាល* គឺជាអ្នកដឹកនាំ (សូមមើលការពន្យល់ ២:៨) ។

**៤៩:២០** *ក្រុងថេម៉ាន* សូមមើលការពន្យល់ ខ.៧ ។ *ហ្វូង* គឺសំដៅលើប្រជាជនរបស់ស្រុកអេដំម ។

**៤៩:២២** មានលេចចេញពីរ ៤៨:៤០-៤១ ។ *ឥន្ទ្រី* គឺតំណាងឱ្យស្តេចនេប៊ូក្នេសាដ៏មានអំណាចក្នុង ៤៨:៤០ (សូមមើលការពន្យល់ ៤៨:៤០) ក្នុងគ្រានោះក៏មានកំលាំងចុះចូលរបស់ពួកអេដំម គឺវាអាចសម្រេចជោគជ័យដោយអាណាចក្រណាបៀនក្រុងអារ៉ាប (ដូចជានៅទីរហោស្ថានក្នុង មទ្ឋ ១:៣) គឺចាប់តាំងពីរក្នុងគ្រាឆ្នាំ ៥៥០ មុន គ.ស ។ *ក្រុងបុសរ៉ា* សូមមើលការពន្យល់ ខ.១៣ ។ *សំរាលកូន* សូមើលការពន្យល់ ៤:៣១ ។

**៤៩:២៣** *ពីក្រុងដាម៉ាស* សូមមើល អស ១៧ អម ១:៣-៥ (និងមើលការពន្យល់ អស ១៧:១) ។ *ក្រុងហាម៉ាត* គឺជាទីក្រុងដ៏ល្អក្នុងនគរអារ៉ាម (សូមមើលការពន្យល់ អស ១០:៩ និងការពន្យល់) ។ *ក្រុងអើផាឌ* សូមមើលការពន្យល់ អស ១០:៩ ។ *ដំណឹងអាក្រក់* ការគំរាមកំហែងពីការឈ្លានពានរបស់ពួកសាសន៍បាប៊ីឡូន ។ *សេចក្តីទុក្ខព្រួយរបស់គេដូចជាសមុទ្រ* ដែលកំរើកឡើង សូមមើល អស ៥៧:២០ ។

**៤៩:២៤** *សេចក្តីទុក្ខវេទនា* សូមមើលការពន្យល់ ៤:១៩ ។

**៤៩:២៦** ជាការបង្ហាញឡើងវិញមានលក្ខណៈចំៗ ដូចជាក្នុង ៥០:៣០ ។

**៤៩:២៧** ជាព្រះបន្ទូលទៅតាមទំនៀមទម្លាប់ នៃការជំនុំជម្រះ (សូមមើលការពន្យល់ អម ១:៤) ។

**៤៩:២៨** *ពីពួកកេដារ* សូមមើល អស ២១:១៣-១៧ និងមើល ២:១០ និងការពន្យល់ ។ *នៅស្រុកហាសោរ* សូមមើល ខ.៣០,៣៣ គឺមិនមែនស្រុកហាសោរនៅខាងជើងសមុទ្រកាលីឡេទេ (សូមមើល យស ១១:១) ។ ស្រុកបួនគរទាំងនោះមានស្រុក ដេដាន់ ស្រុកឬក្រុងថេម៉ាន ស្រុកប៊ូស ហើយនិងតំបន់អារ៉ាបដទៃទៀត (សូមមើល ២៥:២៣-២៤ និងការពន្យល់) គឺតាំងពីព្រះគម្ពីរភាសាហេព្រើរ គឺជាឫសគល់ពីឈ្មោះដ៏ជាក់លាក់ ។ ពាក្យថាហាសោរ គឺមានលក្ខណៈជាសាធារណៈនាម មានន័យថា "ការដោះស្រា" (សូមមើល អស ៤២:១១ និងមើល លប ២៥:១៦) ។ *នេប៊ូក្នេសា . . . បានវាយ* នៅក្នុង ឆ្នាំ ៥៩៩-៥៩៨ មុន គ.ស ។ *ពួកកូនស្រុកនៅខាងកើត* សូមមើល ពច ៦:៣ និងការពន្យល់ យប ១:៣ អគ ២៥:៤ ។

ចៀម[ឆ]របស់គេ ក៏នឹងដឹកនាំង អស់ទាំងភាជនៈ និងសត្វ
អូដ្ឋរបស់គេ ទៅទុកសំរាប់ខ្លួន ហើយមនុស្សនឹងស្រែក
ប្រាប់គេថា មានសេចក្ដីស្ញែងខ្លាច[ជ] នៅគ្រប់ទិសហើយ
៣០ឱឯងរាល់គ្នាជាពួកអ្នកស្រុកហាសោរអើយ[ឈ] ចូររត់ទៅ
ចូរដើរសាត់ព្រាត់ទៅឱ្យឆ្ងាយ ត្រូវឱ្យជ្រកនៅរអាងយ៉ាង
ជ្រៅចុះ[ញ] ដ្បិតនេប៊ូក្នេសា[ដ] ជាស្ដេចបាប៊ីឡូនបានប្រឹក្សាការ
ហើយកើតមានគំនិតទាស់នឹងឯង នេះជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ៣១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូរក្រោក
ឡើងៗទៅឯសាសន៍១ ដែលនៅជាសុខ ហើយឥតកង្វល់
ចុះ គេគ្មានទ្វារ គ្មានរនុក[ឋ] ជាពួកអ្នកដែលនៅតែគ្នាគេ
ប៉ុណ្ណោះ ៣២ហ្វូងអូដ្ឋ[ឌ]របស់គេនឹងបានជារបឹង ហើយហ្វូង
សត្វ[ឍ]ដ៏សន្ធឹករបស់គេ នឹងបានជារបស់សំរាប់ប្លន់ អញនឹង
កំចាត់កំចាយពួកអ្នកដែលកាត់ជ្រុងពុកចង្កា[ណ]ឱ្យទៅគ្រប់
ទិស[ត] ហើយនឹងនាំសេចក្ដីអន្តរាយរបស់គេ មកពីគ្រប់ដំបន់
ជុំវិញ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ៣៣នោះក្រុង
ហាសោរ[ថ] នឹងត្រឡប់ជាទីលំនៅរបស់សត្វស្វាន[ទ] ជាទីខូច
បង់[ធ]ជាដរាបតទៅ នឹងគ្មានមនុស្សណាអាស្រ័យនៅ ឬ
មនុស្សជាតិណាមួយស្នាក់នៅ[ន]ទីនោះឡើយ ។

## ព្រះរាជសារអំពីពួកអេឡាំ

៣៤នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដល់
ហោរាយេរេមា ពីដំណើរស្រុកអេឡាំ[ប] នៅដើមរាជ្យនៃ
សេដេគា[ផ]ស្ដេចយូដា ថា ៣៥ព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់មានបន្ទូលដូច្នេះ មើល អញនឹងបំបាក់ធ្នូ[ព]របស់ពួក
អេឡាំ គឺជាដើមកំឡាំងរបស់គេ ៣៦អញនឹងនាំខ្យល់[ភ] ទាំង
៤ឱ្យមកពីទាំង៤ទិស[ម] ធ្លាក់លើស្រុកអេឡាំ ហើយនឹងកំចាត់
កំចាយគេទៅគ្រប់ទិសទាំង៤នោះ ឥតមាននគរណាមួយ
ដែលពួកបំបរបង់របស់សាសន៍អេឡាំ មិនបានទៅដល់
ឡើយ ៣៧អញនឹងធ្វើឱ្យពួកសាសន៍អេឡាំ ស្រយុតចិត្ត នៅ
មុខខ្មាំងសត្រូវ ហើយនៅមុខពួកអ្នកដែលរកជីវិតគេ ក៏នឹង
នាំសេចក្ដីអាក្រក់មកលើគេ គឺជាសេចក្ដីកំហឹងដ៏សហ័ស
របស់អញផង[យ]នោះជាព្រះបន្ទូលនៃព្រះយេហូវ៉ា អញនឹង
ចាត់ដាវ[រ]ឱ្យដេញតាមក្រោយគេ ទាល់តែបានបំផ្លាញគេ
អស់រលីងទៅ ៣៨អញនឹងតាំងបល្ល័ង្កអញ នៅស្រុកអេឡាំ
ហើយនឹងបំផ្លាញទាំងស្ដេច និងពួកចៅហ្វាយពីស្រុកនោះ
ចេញ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ៣៩ប៉ុន្តែដល់ជាន់
ក្រោយ នោះអញនឹងនាំ[ល]ពួកអេឡាំ ដែលនៅជាឈ្លើយ
ឱ្យមកវិញ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## ព្រះរាជសារអំពីក្រុងបាប៊ីឡូន

*៥១:១៥–១៩ – យរ ១០:១២–១៦*

**៥០** ១នេះជាព្រះបន្ទូលដែលព្រះយេហូវ៉ា ទ្រង់មានបន្ទូល
ពីដំណើរក្រុងបាប៊ីឡូន[ក] គឺពីស្រុករបស់ពួកខាល់ដេ ដោយ
សារហោរាយេរេមា ។
២ចូរថ្លែងប្រាប់នៅកណ្ដាលអស់ទាំងសាសន៍ ហើយ
ប្រកាស[ខ]ទៅ ចូរលើកទង់ជ័យ[គ]ឡើង ត្រូវឱ្យប្រកាសប្រាប់
ឥតលាក់ទុកអ្វីសោះឡើយ ចូរប្រាប់ថា គេចាប់យកក្រុង

**៤៩:២៩** ឆ ខ.៣២ ជ យរ ៦:២៥
**៤៩:៣០** ឈ យស ១១:១ ញ ពច ៦:២ ដ យរ ១០:២២
**៤៩:៣១** ឋ អគ ៣៨:១១
**៤៩:៣២** ឌ ពច ៦:៥ ឍ ខ.២៩ ណ ខ.៣៦ យរ ១៣:២៤ ត យរ ៩:២៦
**៤៩:៣៣** ថ យស ១១:១ ទ អស ១៣:២២ ធ យរ ៤៨:៩ ន ខ.១៨ យរ ៥១:៣៧
**៤៩:៣៤** ប លប ១០:២២ ផ ២ពវ ២៤:១៨
**៤៩:៣៥** ព ទដ ៣៧:១៥ អស ២២:៦
**៤៩:៣៦** ភ ខ.៣២ ម ដយ ១១:៤
**៤៩:៣៧** យ យរ ៣០:២៤ រ យរ ៩:១៦ អគ ៣២:២៤
**៤៩:៣៨** ល យរ ៤៨:៤៧
**៥០:១** ក លប ១០:១០ ទដ ១៣៧:៨
**៥០:២** ខ ចទ ៣០:៤ យរ ៤:១៦ គ ទដ ២០:៥ អស ១៣:២

**៤៩:២៩** *មានសេចក្ដីស្ញែងខ្លាចនៅគ្រប់ទិស* សូមមើលការពន្យល់ ៦:២៥ ។
**៤៩:៣០** *ជ្រកនៅរអាងយ៉ាជ្រៅ* សូមមើល ខ.៨ ។
**៤៩:៣១** *ដែលនៅជាសុខ* ជារាស្ត្រដែលទទួលបានសេចក្ដីសុខសប្បាយយ៉ាងខ្លាំង (សូមមើល យប ២១:២៣) ។ *ឥតកង្វល់* គឺជាភាពឥតមានការសង្ស័យលើហេតុការណ៍ផ្សេងៗ (មើល ពច ១៨:៧ និងការពន្យល់ អគ ៣៨:១១) ។ *គេគ្មានទ្វារ គ្មានរនុក* គឺជាការរស់នៅក្នុងភូមិគ្រឹះដែលពុំមានរបង ឬជញ្ជាំង (សូមមើល ចទ ៣:៥ ប្រៀបធៀប ១សយ ២៣:៧) ។
**៤៩:៣២** *កំចាត់កំចាយពួកអ្នក* សូមមើល អគ ៥:១២ ១២:៤ ។ *ពួកអ្នកដែលកាត់ជ្រុងពុកចង្កា* សូមមើលការពន្យល់ ៩:២៦ ។ *នាំសេចក្ដីអន្តរាយរបស់គេមកពីគ្រប់ដំបន់ជុំវិញ* គឺមានលក្ខណៈផ្ទុយពីការពណ៌នានៃបទទំនុករបស់ស្ដេចសាឡាម៉ូនមានក្នុង ១ពវ ៥:៤ ។
**៤៩:៣៣** *ទីលំនៅរបស់សត្វស្វាន* សូមមើលការពន្យល់ ៩:១១ ។ *គ្មានមនុស្សណាអាស្រ័យនៅ* មើល ខ.១៨ ។
**៤៩:៣៤** *នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដល់* សូមមើលការពន្យល់ ៤៦:១ ។ *ស្រុកអេឡាំ* សូមមើលការពន្យល់ អស ១១:១១ ។
**៤៩:៣៥** *ធ្នូ* ពួកអេឡាំត្រូវបានសម្លាប់ដោយព្រួញធ្នូ (សូមមើល អស ២២:៦) ។ ៤៩:៣៦ មានលក្ខណៈផ្ទុយ អស ១១:១២ ។ *នាំខ្យល់ទាំង៤* គឺតំណាងឱ្យកម្លាំងទាំងគ្រប់ទិស (សូមមើល អគ ៣៧:៩ ដយ ៧:២ ៨:៨) ។
**៤៩:៣៧** *អញនឹងធ្វើឱ្យពួកសាសន៍អេឡាំស្រយុតចិត្ត . . . តែបានបំផ្លាញគេអស់រលីងទៅ* មើលក្នុង ៩:១៦ ។
**៤៩:៣៨** *តាំងបល្ល័ង្កអញនៅស្រុក* សូមមើល ១:១៥ និងការពន្យល់ ។
**៥០:១–៥១:៦៤** សូមមើល អស ១៣:១–១៤:២៣ ២១:១–៩ គឺជាបទទំនាយរបស់ហោរាយេរេមាទាក់ទងនឹងស្រុកបាប៊ីឡូន មានលក្ខណៈយូអង្វែងនៃសេចក្ដីទំនាយដែលប្រឆាំងទាស់នឹងជាតិសាសន៍ផ្សេងៗ (ជំពូក ៤៦–៥១) ឯសេចក្ដីទាំងនេះតាំងពីដំបូងក៏មានលក្ខណៈសង្ខេប (សូមមើល ២៥:១២–១៤,២៦) ។ ក៏បានកំណត់ពេលវេលាតាំងពីឆ្នាំ ៥៩៣ មុន ស.គ (សូមមើល ៥១:៥៩ និងការពន្យល់) ។ ក៏មានពីជំពូកដែលចែងទៅជាបីវគ្គសំខាន់ៗ (៥០:២–២៨ ៥០:២៩–៥១:២៦ ៥១:២៧–៥៨) វគ្គនិមួយៗបានចាប់ផ្ដើមដោយការប្រកាសពីការទាស់និងពួកសាសន៍បាប៊ីឡូន ដែលជាសត្រូវស្លាប់រស់របស់ពួកយូដា (សូមមើល ៥០:២–៣ ៥០:២៩–៣២ ៥១:២៧–៣២) ។
**៥០:១** *ព្រះបន្ទូល* គឺជារាជសារដែលបានផ្ញើរដោយហោរាទៅកាន់ស្រុកបាប៊ីឡូនផ្ទាល់(សូមមើល ៥១:៥៩–៦១) ។
**៥០:២** *ចូរថ្លែងប្រាប់នៅកណ្ដាលអស់ទាំងសាសន៍ ហើយប្រកាសទៅ* សូមមើល ៤:៥ ៤៦:១៤ ។ *ចូរលើកទង់ជ័យឡើយ* សូមមើលការពន្យល់ អស

បាប៊ីឡូនហើយ[ឃ] ព្រះបាល[ង]បានត្រូវខ្មាសទៅ[ច] ព្រះមដាក់[ឆ]
បានត្រូវបាក់រលំចុះ រូបឆ្លាក់[ជ]របស់គេបានត្រូវខ្មាស
រូបព្រះរបស់គេបានបាក់រលំចុះហើយ ៣ដ្បិតនៅស្រុកខាង
ជើង[ឈ] មានសាសន៍១លើកគ្នាឡើងមកទាស់នឹងគេ ជាពួក
ដែលនឹងធ្វើឱ្យស្រុកគេវិនាសទៅ ឥតមានអ្នកណាអាស្រ័យ
នៅ[ញ]ឡើយ ទោះទាំងមនុស្សនិងសត្វផង[ដ]បានរត់ទៅ គេ
បាត់អស់ហើយ ៤ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅគ្រា
នោះ គឺនៅវេលានោះឯង ពួកកូនចៅអ៊ីស្រាអែលនឹងមក
ទាំងខ្លួនគេ នឹងពួកកូនចៅយូដាទាំងអស់គ្នា[ឋ]ផង គេនឹងដើរ
តាមផ្លូវ ទាំងយំ[ឌ]បណ្តើរ ហើយនឹងស្វែងរក[ឍ]ព្រះយេហូវ៉ា
ជាព្រះនៃគេ ៥គេនឹងស៊ើបសួរពីដំណើរ[ណ]ក្រុងស៊ីយ៉ូន ទាំង
មានមុខដំរង់ទៅចំពោះក្រុងនោះ ដោយពាក្យថា ចូរមក[ត]
យើងនឹងភ្ជាប់ខ្លួននឹងព្រះយេហូវ៉ា ដោយសេចក្តីសញ្ញាដ៏
នៅអស់កល្បជានិច្ច[ថ] ជាសេចក្តីសញ្ញាដែលនឹងភ្លេចមិន
បានឡើយ ។
៦រាស្ត្ររបស់អញជាហ្វូងចៀមដែលវង្វេងបាត់[ទ] ពួក
អ្នកគង្វាល[ធ]របស់គេបានបណ្តាលឱ្យគេវង្វេងទៅ[ន] ក៏បាន
បំបែរគេចេញនៅលើភ្នំ គេបានដើរពីភ្នំធំ ចុះទៅដល់ភ្នំ
តូច[ប] ហើយបានភ្លេចក្រោលរបស់គេទៅ[ផ] ៧អស់អ្នកណា
ដែលប្រទះនឹងគេ បានត្របាក់ស៊ី[ព]គេ ហើយពួកខ្មាំងសត្រូវ
គេបានពោលថា យើងគ្មានទោសទេ[ភ] ពីព្រោះគេបានធ្វើ
បាបនឹងព្រះយេហូវ៉ា ដែលជាទីលំនៅនៃសេចក្តីសុចរិត

**៥០:២** ឃ ខ.៩ យរ ៥១:៣១ ង អស ២១:៩ ៤៦:១ ច ទដ ៩៧:៧ យរ ៥១:៥២ ឆ ខ.៣៨ អស ៤៦:៦ យរ ៥១:៤៧ ជ លវ ២៦:៣០ **៥០:៣** ឈ ខ.២៦ អស ៤១:២៥ យរ ២៥:២៦ ញ ខ.១៣ អស ១៤:២២-២៣ យរ ៩:១១ ដ សផ ១:៣ **៥០:៤** ឋ យរ ៣:១៨ អគ ៣៧:២២ ឌ អរ ៣:១២ ឍ អស ៩:១៣ អគ ៣៧:១៧ ហស ៣:៥ **៥០:៥** ណ អស ១១:១៦ យរ ៣១:២១ ត ១សយ ២៩:១ យរ ៣៣:៧ ថ ចទ ២៩:១៤ អស ៥៥:៣ យរ ៣២:៤០ ហព ៨:៦-១០ **៥០:៦** ទ ទដ ១១៩:១៧៦ មថ ៩:៣៦ ១០:៦

គឺព្រះយេហូវ៉ាជាទីសង្ឃឹម[ម]របស់ពួកឰយុកោគេ ៨ចូររត់[យ]ពី
កណ្តាលក្រុងបាប៊ីឡូនទៅ[រ] ហើយចេញពីស្រុករបស់ពួក
ខាល់ដេឱ្យផុត ឱ្យបានដូចជាជាពពែឈ្មោលដែលនាំហ្វូង
ចុះ ៩ដ្បិតមើល អញនឹងដាស់[ល]នគរធំៗ[វ] ១ពួក នៅស្រុក
នៅខាងជើងឡើង[ស] ហើយបណ្តាលឱ្យគេមកទាស់នឹងក្រុង
បាប៊ីឡូន ពួកទាំងនោះនឹងដំរៀបគ្នាច្បាំងនឹងទីក្រុង ហើយ
នឹងចាប់យកបាន[ហ] ព្រួញ[ឡ]របស់គេនឹងបានដូចជាព្រួញ
របស់មនុស្សស្ទាត់ជំនាញ ហើយខ្លាំងពូកែ ឥតមាននណា
មួយបាញ់ទៅ ជាឥតប្រយោជន៍នោះទេ ១០នោះស្រុក
ខាល់ដេ នឹងត្រូវជារំពា[អ] ហើយអស់អ្នកដែលចាប់យក
នោះនឹងបានឆ្អែត នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
១១នៃ ឯងរាល់គ្នាដែលប្លន់មរដករបស់អញអើយ[ក]
ដោយព្រោះឯងរាល់គ្នាមានចិត្តអំណរ ដោយព្រោះចិត្តឯង
រាល់គ្នាបានរីករាយឡើង ដោយព្រោះឯងរាល់គ្នាមានចិត្ត
លោភ ដូចជាគោក្រមុំ[ខ]ដែលឈ្លីស្មៅ ហើយកញ្ជ្រៀវដូច
ជាសេះយ៉ាងខ្លាំង ១២នោះម្តាយឯងរាល់គ្នានឹងមានសេចក្តី
ខ្មាសគ្រប់យ៉ាង[គ] អ្នកដែលបានបង្កើតឯងមកនឹងត្រូវជ្រប់

ធ យរ ២:៨ ១០:២១ ន ទដ ៩៥:១០ យរ ២៣:៣២ អគ ១៣:១០ ប យរ ៣:៦ អគ ៣៤:៦ ផ ខ.១៩ **៥០:៧** ព យរ ៥:១៧ ១០:២៥ អគ ៣៥:១២ ភ យរ ២:៣ ម យរ ១៤:៨ **៥០:៨** យ អស ៤៨:២០ រ ខ.២៨ **៥០:៩** ល អស ១៣:១៧ វ យរ ២៥:១៤ ស អស ៤១:២៥ យរ ២៥:២៦ ហ ខ.២ ឡ អស ១៣:១៨ **៥០:១០** អ អស ៤៧:១១ យរ ៣០:១៦ **៥០:១១** ក អស ៤៧:៦ ខ យរ ៣១:១៨ **៥០:១២** គ យរ ៥១:៤៧

៥:២៦ ។ ពាក្យក្នុងព្រះគម្ពីរភាសាហេព្រើរចំពោះឃ្លានេះ គេបកប្រែថា "ការលើកទង់ឡើង" មានក្នុង ៤:៦ ។ គេចាប់យកក្រុងបាប៊ីឡូន ការនេះគេបានសម្រេចក្នុងឆ្នាំ ៥៣៩ មុន ស.គ ។ *ព្រះបាល* មើល ៥១:៤៤ អស ៤៦:១ និងការពន្យល់ ។ *បានត្រូវខ្មាសទៅ* ជាការបង្ហាញឱ្យឃើញជាច្រើនសារថា ព្រះដ៏ធំរបស់ពួកបាប៊ីឡូន និងរូបព្រះផ្សេងៗ ឬរូបសំណាក់គឺទទួលគ្រោះកម្មខូចទៅអស់ មើលការពន្យល់ លវ ២៦:៣០ (សូមមើល អស ៤៤:៩-២០) ។

**៥០:៣** *ស្រុកខាងជើងមានសាសន៍១* ក្នុងទំនាយហោរាយេរេមាចេញពីទិសខាងជើង គឺតាមធម្មតាសំដៅលើពួកបាប៊ីឡូន (សូមមើល ឧទាហរណ៍ ១:១៤-១៥) ។ ឯក្នុងអត្ថបទនេះគឺសំដៅលើពួកស្តេចពើស៊ី ។ ទណ្ឌកម្មដល់ពួកបាបប៊ីឡូន ក៏បានរីកដុះដាលដល់សាសន៍ដទៃផ្សេងទៀតជាច្រើន មើលក្នុង ខ.៩ ក៏បង្ហាញយ៉ាងច្បាស់ដោយឈ្មោះផ្ទាល់ក្នុង ៥១:២៧-២៨ ។ *មនុស្សនិងសត្វផងបានរត់ទៅ* គឺក្រុងបាប៊ីឡូននឹងត្រូវឈឺចាប់ ឬមានវាសនាទទួលទោសដូចក្នុងយេរូសាឡិមផងដែរ (សូមមើល ៣៣:១២) ។

**៥០:៤** *ពួកកូនចៅអ៊ីស្រាអែលនឹង . . . ពួកកូនចៅយូដា* សូមមើលការពន្យល់ ៣:១៨ ។ ទាំងយំបណ្តើរ ជាការបង្ហាញពីការលន់តួកំហុស (សូមមើល ៣:២១-២២ ៣១:៩) ។

**៥០:៥** *សេចក្តីសញ្ញាដ៏នៅអស់កល្បជានិច្ច* សូមមើលការពន្យល់ ៣២:៤០ និងការពន្យល់ ។ ក៏សូមមើល ៣១:៣១-៣៤ ៣៣:២០-២១ ។

**៥០:៦** *ហ្វូងចៀមដែលវង្វេងបាត់* សូមមើលពាក្យប្រស្នារបស់ព្រះយេស៊ូវក្នុង លក ១៥:៣-៧ ។ *ពួកអ្នកគង្វាល* ជាអ្នកដឹកនាំ (មើលការពន្យល់ ២:៨) ។ *ពីភ្នំធំចុះទៅដល់ភ្នំតូច* ជាទីកន្លែងដែលព្រះពួកសាសន៍ដទៃ ដែលគេបានថ្វាយបង្គំ (មើលការពន្យល់ ២:២០) ជាទីកន្លែងសុខសាន្តរបស់ពួកគេ ។ ព្រះយេហូវ៉ា (មើល ខ.៧) ។

**៥០:៧** *ជាទីសង្ឃឹមរបស់ពួកឰយុកោគេ* គឺជាឃ្លាដែលយើងឃើញនៅក្នុងទីកន្លែងនេះទេ (សូមមើល ១៤:៨,២២ ប្រៀបធៀប កច ២៨:២០) ។

**៥០:៨** *ដូចជាពពែឈ្មោលដែលនាំមុខហ្វូង* គឺដូចជាពួកស្រុកយូដាជារាស្ត្រដែលគេបានចាប់ជាឈ្លើយមុនបង្អស់ ហើយក៏បានរំដោះឱ្យរួចពីការចាប់ជាឈ្លើយវិញក្នុងស្រុកបាប៊ីឡូន ។

**៥០:៩** *និងដាស់នគរធំៗ១ពួក* សូមមើល អស ១៣:៤ ពួកគេមានឈ្មោះនៅក្នុង ៥១:២៧-២៨ (សូមមើលការពន្យល់ ខ.៣) ។

**៥០:១១** *ឯងរាល់គ្នា* គឺជាពួកបាប៊ីឡូន ។ *មរដករបស់អញ* គឺជាដីស្រុករបស់ព្រះអម្ចាស់ និងប្រជាជនទ្រង់ (សូមមើល ២:៧ ១២:៧ និងការពន្យល់) ។ *ដូចជាគោក្រមុំដែលឈ្លីស្មៅ* សូមមើល មឡ ៤:២ ។ *សេះ* សូមមើលការពន្យល់ ៨:១៦ ។

**៥០:១២** *ម្តាយ* ពាក្យនេះមាននៅក្នុង (១).ទីក្រុង ឬក៏មានលក្ខណៈជា (២).ដីស្រុក (សូមមើល អស ៥០:១ ហស ២:៥) ។ *ក្រោយបំផុត* តាម

មុខចុះ មើល គាត់នឹងត្រូវជាប្រទេសក្រោយបំផុត គឺជា
ទីរហោស្ថាន ជាដីហួតហែង ជាទីសមុទ្រខ្សាច់[យ] ១៣ឥត
មានអ្នកណានៅ ដោយព្រោះសេចក្ដីក្រោធរបស់ព្រះ
យេហូវ៉ា គឺនឹងត្រូវចោលស្ងាត់នៅទទេ[ង] អស់អ្នកណាដែល
ដើរកាត់មុខក្រុងបាប៊ីឡូននឹងអស្ចារ្យក្នុងចិត្ត[ច] ហើយនឹងធ្វើ
សឹសស៊ូសឱ្យ[ឆ] ដោយព្រោះគ្រប់ទាំងសេចក្ដីវេទនារបស់ទី
ក្រុង[ជ] ១៤នែ ពួកអ្នកដែលដំឡើងធ្នូអើយ[ឈ] ចូរដំរៀបគ្នានៅ
ព័ទ្ធជុំវិញ ច្បាំងនឹងក្រុងបាប៊ីឡូនចុះ ចូរចាញ់ទៅ កុំឱ្យ
សំចៃព្រួញឡើយ[ញ] ដ្បិតទីក្រុងនេះបានធ្វើបាបនឹងព្រះយេ
ហូវ៉ាហើយ ១៥ចូរហ៊ោឡើង[ដ]ជុំវិញទាស់នឹងវាចុះ គេបាន
ទទួលចាញ់ហើយ របងសំរាប់ការពារបានដួលកំផែង[ឋ]
ទីក្រុងបានរលំហើយ ដ្បិតនេះជាសេចក្ដីសងសឹក[ឌ]របស់ព្រះ
យេហូវ៉ា ចូរសងសឹកនឹងគេ[ឍ]ចុះ ចូរសងគេឱ្យស្នងនឹងការ
ដែលគេបានធ្វើដល់ឯង[ណ] ១៦ត្រូវឱ្យកាត់អ្នកដែលសាប
ព្រោះ នឹងអ្នកដែលកាន់កណ្ដៀវក្នុងរដូវចំរូត ចេញពីក្រុង
បាប៊ីឡូនទៅ គេនឹងវិលទៅឯសាសន៍របស់គេរៀងខ្លួន[ត]
ហើយរត់ទៅឯស្រុកគេគ្រប់គ្នា[ថ] ដោយខ្លាចដាវ[ទ]ដែល
កំពុងតែធ្វើទុក្ខ ។
១៧ពួកអ៊ីស្រាអែល គេប្រៀបដូចជាចៀម ដែលត្រូវ
ប្រដេញកំចាយទៅ[ធ] ពួកសិង្ហ[ន]បានដេញកំចាយគេហើយ
មុនដំបូង គឺស្ដេច[ប]អាសស៊ើរបានត្របាក់ស៊ី[ផ]គេ ឥឡូវនេះ
នេប៊ូក្នេសា[ព] ជាស្ដេច[ភ]បាប៊ីឡូន បានបំបាក់ឆ្អឹង[ម]គេ ជាខាង
ក្រោយ ១៨ហេតុនោះ ព្រះយេហូវ៉ានៃពួកពលបរិវារ ជា
ព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា មើល
អញនឹងធ្វើទោសដល់ស្ដេចបាប៊ីឡូន ហើយនឹងស្រុករបស់
គេ ដូចជាបានធ្វើទោសដល់ស្ដេច[យ]អាសស៊ើរដែរ[រ] ១៩អញ
នឹងនាំ[ល]អ៊ីស្រាអែលវិលមកឯក្រោលរបស់ខ្លួនវិញ នោះ
គេនឹងរកស៊ីនៅលើភ្នំកើមែល ហើយនៅស្រុកបាសានឯ
ព្រលឹងគេនឹងបានស្កប់ស្កល់[វ] នៅលើភ្នំ[ស]អេប្រាអិម ហើយ
នៅស្រុកកាឡាត[ហ] ២០ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅ
គ្រានោះ គឺនៅវេលានោះឯងគេនឹងរកសេចក្ដីទុច្ចរិតរបស់
ពួកអ៊ីស្រាអែល តែនឹងមិនប្រទះទេ[ឡ] ហើយរកអំពើបាប[អ]
របស់ពួកយូដា តែនឹងមិនឃើញឡើយ ពីព្រោះអញនឹង
អត់ទោស[ក]ដល់ពួកអ្នក ដែលអញទុកឱ្យសល់នៅ[ខ] ។
២១ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូរឡើងទៅច្បាំង
នឹងស្រុកមេរ៉ាថែមចុះ គឺទាស់នឹងគេ ហើយទាស់នឹងពួក

**៥០:១២** យ ខ.១៣ អស ២១:១ យរ ២៥:១២ ៥១:២៦ **៥០:១៣** ង ខ.៣,១២ យរ ៩:១១ ៤៨:៩ ៥១:៦២ ច យរ ៥១:៤១ ឆ យរ ១៨:១៦ ៥១:៣៧ អគ ២៧:៣៦ ហព ២:៦ ជ ចទ ២៩:២២ **៥០:១៤** ឈ ខ.២៩,៤២ ញ អស ១៣:១៨ **៥០:១៥** ដ យរ ៥១:១៤ ឋ ២ពវ ២៥:៤ យរ ៥១:៤៤,៥៨ ឌ ខ.២៨ អស ១០:៣ ៦៣:៤ យរ ៥១:៦ ឍ ខ.២៩ ទដ ១៣៧:៨ វវ ១៨:៦ ណ យរ ៥១:២៤ ហព ២:៧–៨ **៥០:១៦** ត អស ១៣:១៤ ថ យរ ៥១:៩ ទ យរ ២៥:៣៨

**៥០:១៧** ធ លវ ២៦:៣៣ ទដ ១១៩:១៧៦ ន ២ពវ ២៤:១ យរ ២:១៥ ប ចទ ៤:២៧ ២ពវ ១៤:២៩ ផ យរ ៥:១៧ ព យរ ៥១:៣៤ ភ ២ពវ ២៤:១៧ ២៥:៧ ម ជន ២៤:៨ បទ ៣:៤ **៥០:១៨** យ អស ១០:១២ រ អគ ៣១:៣ សផ ២:១៣ **៥០:១៩** ល យរ ៣១:១០ អគ ៣៤:១៣ វ យរ ៣១:១៤ ស យរ ៣១:៥ ហ មីក ៧:១៤ សក ១០:១០ **៥០:២០** ឡ ទដ ១៧:៣ អ ទដ ១០៣:១២ អស ៣៨:១៧ អគ ៣៣:១៦ មីក ៧:១៨,១៩ សក ៣:៤,៩ ក អស ៣៣:២៤ ខ លប ៤៥:៧ អស ១:៩ ១០:២០–២២ រម ៩:២៧

បែបអក្សរសាស្ត្រគឺមានន័យថា "ក្រោយ" ។ លោកអាម៉ាលេក"ជាមនុស្សទីមួយក្នុងចំណោមជាតិសាសន៍" (ជន ២៤:២០) ដែលបានវាយប្រហារស្រុកអ៊ីស្រាអែល ក៏ត្រូវគេបំផ្លាញឱ្យខូចបង់ដូចស្រុកបាប៊ីឡូនដែរ ក្រោយមកក៏វាយប្រហារអ៊ីស្រាអែល (រហូតដល់ជិនាន់ហោរាយេរេមា) ។

**៥០:១៣** *ឥតមានអ្នកណានៅ* សូមមើល អស ១៣:២០ និងការពន្យល់ ។ *អស់អ្នកណាដែលដើរកាត់មុខក្រុងបាប៊ីឡូន . . . ព្រោះគ្រប់ទាំងសេចក្ដីវេទនា* ជាការនិយាយពីក្រុងយេរូសាឡិមមានក្នុង ១៩:៨ និងស្រុកអេដំមក្នុង ៤៩:១៧ ។

**៥០:១៤** *ពួកអ្នកដែលដំឡើងធ្នូអើយ* គឺមានពួកម៉ាដាយ (សូមមើល អស ១៣:១៧–១៨) ។

**៥០:១៥** *ចូរហ៊ោ* គឺជាការស្រែកយំនៅក្នុងសង្គ្រាម (មើល សយ ៦:១៦) ។ *សេចក្ដីសងសឹករបស់ព្រះយេហូវ៉ា* សូមមើល ខ.២៨ ៥១:១១ ។ ទោះជាព្រះទ្រង់ជាអង្គដែលបង្កើតអ្វីៗក្នុងភាពបរិសុទ្ធរបស់ផងទ្រង់ តែគ្រប់សេចក្ដីសងសឹក ឬការកាត់ទោសអ្វីនោះ គឺទ្រង់បានប្រើរាស្ត្ររបស់ទ្រង់ឱ្យធ្វើការងារ (សូមមើល ជន ៣១:៣) ។ *សងសឹកនឹងគេចុះ . . . ស្នងនឹងការដែលគេបានធ្វើដល់ឯង* សូមមើល ខ.២៨ ៥១:១១ ។ តាមរយៈភាពសប្បុរសរបស់ផងទ្រង់ ។ សូមមើល ខ.២៩ អប ១៥ និងការពន្យល់ប្រៀបធៀប កទ ៦:៧–៨ ។

**៥០:១៦** *ដាវដែលកំពុងធ្វើទុក្ខ* មើល ៤៦:១៦ ។ *គេនឹងវិលទៅឯសាសន៍របស់គេរៀងខ្លួន . . . ស្រុកគេគ្រប់គ្នា* ក្នុងគម្ពីរហោរាចំពោះអត្ថបទនេះគឺមានលក្ខណៈស្រដៀងនឹង អស ១៣:១៤ ។ ឯមនុស្សដែលត្រូវគេចាប់ជាឈ្លើយក៏បានគេគំរាមឱ្យចាកចេញពីបាប៊ីឡូន ក្នុងគោលបំណងជៀសវាងនូវការកាប់សម្លាប់ដោយពួកឈ្លានពានទាំងនោះ ។

**៥០:១៧** *ចៀមដែលត្រូវប្រដេញកំចាយទៅ* សូមមើល ៣:២ ។ *ពួកសិង្ហ* គឺសំដៅលើ ឬសំគាល់លើពួកអាសស៊ើរ និងពួកបាប៊ីឡូន (សូមមើល ៤:៧ អស ១៥:៩ និងការពន្យល់) ។ *មុនដំបូង គឺជាស្ដេចអាសស៊ើរបានត្របាក់ស៊ីគេ* ជាពួកអាសស៊ើរបានបំផ្លាញពួកអ៊ីស្រាអែល (គឺនៅស្រុកផ្នែកខាងជើង) ក្នុងឆ្នាំ ៧២២–៧២១ មុន ស.គ ។ *នេប៊ូក្នេសាជាស្ដេចបាប៊ីឡូន បានបំបាក់ឆ្អឹងគេជាខាងក្រោយ* បំផ្លាញស្រុកយូដា (គឺស្រុកផ្នែកខាងត្បូង) គឺនៅឆ្នាំ ៥៨៦ មុន ស.គ ។

**៥០:១៨** *ដូចជាបានធ្វើទោសដល់ស្ដេចអាសស៊ើរដែរ* នៅក្រុងនីនីវេ សេចក្ដីអួតរបស់រាជធានីនៃពួកអាសស៊ើរបានចុះក្នុងឆ្នាំង៦១២ មុន ស.គ ។ ឯស្រុកពួកអាសស៊ើរត្រូវបានពួកសម្ព័ន្ធម៉ាដាយ និងបាប៊ីឡូនគ្រប់គ្រងក្នុងឆ្នាំ៦០៩ ។

**៥០:១៩** *ភ្នំកើមែល* សូមមើល អស ៣៣:៩ និងការពន្យល់ ។ *ស្រុកបាសាន* សូមមើលការពន្យល់ អស ២:១៣ ។ *ភ្នំអេប្រាអិម* ជាភ្នំយ៉ាងត្រសុំត្រសាយនៃស្រុកអ៊ីស្រាអែលកណ្ដាល (សូមមើល អគ ៣៤:១៣–១៤) ។

**៥០:២០** មើល ៣៣:៨ និងការពន្យល់ និងមើល ៣៦:៣ មីក ៧:១៨–១៩ ។

**៥០:២១** *ស្រុកមេរ៉ាថែមចុះ* មានន័យថា "ការទាស់ប្រឆាំងពីរលើក គឺ

អ្នកនៅស្រុកពេកូឌដែរ[គ] ចូរសំឡាប់ ហើយបំផ្លាញអស់
រលីងតាមក្រោយគេ ត្រូវឱ្យធ្វើតាមគ្រប់ទាំងសេចក្តី ដែល
អញបានបង្គាប់ដល់ឯង ២២ មានឮ[ឃ]សូរចំបាំងនៅក្នុងស្រុក
ជាសូរនៃការបំផ្លាញយ៉ាងសំបើម ២៣ ញញួរ[ង]ដែលវាយ
ផែនដីទាំងមូល[ច]បានកាច់បាក់យ៉ាងណាហ្ន៎ ក្រុងបាប៊ីឡូន
បានត្រឡប់ជាទីខូចបង់[ឆ] នៅកណ្តាលអស់ទាំងសាសន៍
យ៉ាងណាហ្ន៎ ២៤ នែ បាប៊ីឡូនអើយ អញបានដាក់អន្ទាក់[ជ]
សំរាប់ចាប់ឯង ហើយឯងត្រូវជាប់ដែរ ឯងមិនបានដឹងខ្លួន
សោះ គឺបានរកឯងឃើញ ហើយចាប់[ឈ]បានផង ពីព្រោះ
ឯងបានតយុទ្ធ[ញ]នឹងព្រះយេហូវ៉ា ២៥ ព្រះយេហូវ៉ាទ្រង់បាន
បើកឃ្លាំងអាវុធរបស់ទ្រង់ ហើយយកគ្រឿងសស្ត្រាវុធ[ដ]នៃ
សេចក្តីគ្នាន់ក្នាញ់របស់ទ្រង់ចេញមក ដ្បិតព្រះអម្ចាស់ ជា
ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានការដែលត្រូវធ្វើ
នៅស្រុករបស់ពួកខាល់ដេ[ឋ] ២៦ ចូរមកច្បាំងនឹងក្រុង
បាប៊ីឡូនពីគ្រប់ទីឆ្ងាយបំផុត[ឌ] ត្រូវឱ្យបើកជង្រុកគេ[ឍ] ត្រូវឱ្យ
ជាន់ឈ្លីគំនរបំណែកទីក្រុង ហើយបំផ្លាញ[ណ]ឱ្យអស់រលីង
កុំឱ្យមានសល់អ្វីឡើយ ២៧ ចូរសំឡាប់អស់ទាំងគោរបស់គេ[ត]
ឱ្យវា ចុះទៅឯទីសំឡាប់ចុះ[ថ] វរដល់គេ ដ្បិតថ្ងៃ[ទ]កំណត់
របស់គេបានមកដល់ហើយ គឺជាវេលា[ធ]ធ្វើទោសដល់គេ

**៥០:២១** គ អគ ២៣:២៣ **៥០:២២** ឃ យរ ៤:១៩–២១ ៥១:៥៤ **៥០:២៣** ង អស ១០:៥ ច យរ ៥១:២៥ ឆ អស ១៤:១៦ **៥០:២៤** ជ យរ ៥១:១២ ឈ យ ៥១:៣១ ញ យប ៩:៤ **៥០:២៥** ដ អស ១៣:៥ ឋ យរ ៥១:២៥,៥៥ **៥០:២៦** ឌ ខ.៣,៤១ យរ ៥១:១១ ឍ រម ៣:៧ ណ អស ១៤:២២–២៣ **៥០:២៧** ត ទដ ៦៨:៣០ យរ ៤៨:១៥ ថ អស ៣០:២៥ យរ ២៥:៣៤ ទ យប ១៨:២០ ធ យរ ៥១:៦

២៨ មានឮសំឡេងនៃពួកអ្នក ដែលរត់រួច[ន]ពីក្រុងបាប៊ីឡូន
ដើម្បីនឹងថ្លែងប្រាប់នៅក្រុងស៊ីយ៉ូន[ប] ពីការសងសឹក[ផ]នៃ
ព្រះយេហូវ៉ា ជាព្រះនៃយើង គឺជាការសងសឹកស្នងនឹង
ព្រះវិហារនៃទ្រង់[ព] ។
២៩ ចូរហៅពួកពលធ្នូ ឱ្យមកច្បាំងនឹងក្រុងបាប៊ីឡូនចុះ
គឺអស់អ្នកណាដែលធ្លាប់យឹតធ្នូ[ភ] ត្រូវឱ្យបោះទ័ពនៅព័ទ្ធ
ជុំវិញ កុំឱ្យពួកគេណាមួយរួចឡើយ[ម] ចូរសង[យ]តាមការ
ដែលគេបានធ្វើចុះ[រ] ត្រូវឱ្យប្រព្រឹត្តនឹងគេតាមគ្រប់ទាំងអំពើ
ដែលគេបានប្រព្រឹត្ត ដ្បិតគេបានមានចិត្តឆ្មើងឆ្មៃ[ល]ចំពោះ
ព្រះយេហូវ៉ា គឺនៅចំពោះព្រះដ៏បរិសុទ្ធ[វ]នៃសាសន៍
អ៊ីស្រាអែល ៣០ ហេតុនោះ ពួកកំឡោះៗ[ស]របស់គេនឹងដួល
ចុះ នៅក្នុងផ្លូវ ហើយអស់ទាំងមនុស្សថ្មីកច្បាំងរបស់គេ និង
ត្រូវស្ងៀមស្ងាត់នៅថ្ងៃនោះ នេះជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា ៣១ ព្រះអម្ចាស់ ជាព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់មានបន្ទូលថា នែ អ្នកឆ្មើងឆ្មៃយ៉ាងខ្លាំងអើយ អញទាស់

**៥០:២៨** ន ខ.៨ ប អស ៤៨:២០ យរ ៥១:១០ ផ ខ.១៥ ព ២ពវ ២៤:១៣ យរ ៥១:១១ ៥២:១៣ **៥០:២៩** ភ ខ.១៤ ម អស ១៣:១៨ យរ ៥១:៣ យ ចទ ៣២:៤១ យប ២១:១៩ យរ ៥១:៦ វវ ១៨:៦ រ អគ ៣៥:១១ អប ១:១៥ ល អស ១៤:១៣–១៤ ៤៧:១០ ដយ ៥:២៣ វ ទដ ៧៨:៤១ អស ៤១:២០ យរ ៥១:៥ **៥០:៣០** ស អស ១៣:១៨

ប្រឆាំងនឹងព្រះយេហូវ៉ា" ក៏អាចជាការសំដៅទៅលើ ខ.២៤,២៩ (សូមមើល ពច ៣:៨ អស ៤០:២ និងការពន្យល់) ។ គឺជាការលេងពាក្យលើពាក្យក្រុងបាប៊ីឡូន តែពេលខ្លះចង់សំដៅលើតំបន់ស្រុកបាប៊ីឡូនខាងត្បូង គឺជាលក្ខណៈសម្បត្តិនៃទឹកសមុទ្រ ។ *ស្រុកពេកូឌ* សូមមើល អគ ២៣:២៣ មានន័យថា"ដាក់ទណ្ឌកម្ម ពីព្រះយេហូវ៉ា" ។ ឯពួកបាប៊ីឡូនដាក់ឈ្មោះនេះសម្រាប់ពួកពូជអំបូរអើរ៉ាម ដែលនៅតាមមាត់ទន្លេហ៊ីដេកែល ។ *បំផ្លាញអស់* សូមមើលការពន្យល់ ខ.២៦ ២៥:៩ ៥១:៣ សូមមើល ចទ ២:៣៤ ។

**៥០:២២** *បំផ្លាញយ៉ាងសំបើម* សូមមើល ៤:៦ ៦:១ ប្រៀបធៀប ៤៨:៣ ៥១:៥៤ ។

**៥០:២៣** *ញញួរដែលវាយផែនដី* សូមមើលការពន្យល់ អស ១០:៥ ។ *ក្រុងបាប៊ីឡូនបានត្រឡប់ជាទីខូចបង់ នៅកណ្តាលសាសន៍យ៉ាងណាហ្ន៎* ក្នុងគម្ពីរភាសាហេព្រើរចំពោះឃ្លាប្រយោគនេះ បាននិយាយច្រើនសាចំៗដដែលៗ មើលក្នុង ៥១:៤១ ។

**៥០:២៤** *សំរាប់ចាប់ឯង ហើយឯងត្រូវជាប់ដែរ* ឃ្លាប្រយោគខាងលើនេះបង្ហាញពីការឈ្លានពានលុកលុយរបស់ពួកសាសន៍ពេរ្សក្នុងឆ្នាំ ៥៣៩ មុន គ.ស ដែលបានចាប់យកទីក្រុងបាប៊ីឡូន ដោយមានភាពញ៉ាប់ញ៉ូរ (សូមមើល ៥១:៨ អស ៤៧:១១) ។

**៥០:២៥** *គ្រឿងសស្ត្រាវុធនៃសេចក្តីគ្នាន់ក្នាញ់របស់ទ្រង់ចេញ* នេះជាការបង្ហាញពីការក្រោធ ជាសេចក្តីគ្នាន់ក្នាញរបស់ព្រះយេហូវ៉ា តទាស់នឹងពួកស្រុកបាប៊ីឡូន ដោយទ្រង់បានបញ្ជូនជាតិសាសន៍មួយចំនួនឱ្យមកវាយផ្ចាញគ្រប់គ្រងពួកបាប៊ីឡូន (សូមមើល អស ១៣:៥ និងការពន្យល់) ។ *ទ្រង់មានការត្រូវធ្វើ* សូមមើល ៤៨:១០ ។

**៥០:២៦** *គំនរបំណែក* ក្នុងគម្ពីរភាសាហេព្រើរ ចំពោះសំនួនវោហានេះត្រូវបានគេប្រើក្នុង នហ ៤:២ ដែលពណ៌នាអំពីគំនរបាក់បែកកំទេចតូចៗដែលបានឆេះ ។ *បំផ្លាញឱ្យអស់រលីង* ដោយការដុត (សូមមើលការពន្យល់ ខ.២១ និងមើល យស ១១:១១–១៣) ។

**៥០:២៧** *គោរបស់គេ* ពាក្យនេះបើក្នុងស្រុកបាប៊ីឡូន គឺសំដៅទៅលើទាហានប្រយុទ្ធ (សូមមើល អស ៣៤:៦–៧ និងការពន្យល់) ។ *ចុះទៅទីសំឡាប់ចុះ* សូមមើលការពន្យល់ ៤៨:១៥ ។ *ជាវេលាធ្វើទោស* សូមមើល ១១:២៣ ២៣:១២ ៤៦:២១ ។

**៥០:២៨** *ពួកអ្នកដែលរត់រួច* ការចាប់ជាឈ្លើយរបស់ពួកយូដា ដែលនាំឱ្យទទួលគ្រោះមហន្តរាយដល់បាប៊ីឡូនវិញ ។ *ការសងសឹកនឹងព្រះវិហារនៃទ្រង់* សូមមើល ខ.១៥ និងការពន្យល់ ៤៦:១០ ៥១:៦ ។ ការវាយគ្រប់គ្រងស្រុកបាប៊ីឡូន គឺជាការឆ្លើយតបរបស់ព្រះយេហូវ៉ា ដោយសារពួកគេបានដុតកំទេចព្រះវិហារក្រុងយេរូសាឡិមនោះ ។

**៥០:២៩** *ចូរសងតាមការដែលគេបានធ្វើចុះ* ជាឃ្លាធ្លាប់បានឃើញច្រើនសាមានក្នុង ២៥:១៤ (សូមមើល ៥១:២៤) ។ *ត្រូវឱ្យប្រព្រឹត្តនឹងគេតាមគ្រប់ទាំងអំពើដែលគេបានប្រព្រឹត្ត* សូមមើល ខ.១៥ និងការពន្យល់ ។ *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* ពាក្យជាចំណងជើងបង្ហាញពីព្រះនាមព្រះដែលតែងតែជួបជារឿយៗ ក្នុងកណ្ឌគម្ពីរអេសាយ (សូមមើលការពន្យល់ អស ១:៤) វាគឺលេចឱ្យឃើញក្នុងគម្ពីរយេរេមា នៅក្នុងជំពូកនេះ និងក្នុង ៥១:៥ ។

**៥០:៣០** ក៏មានឮនៅក្នុង ៤៩:២៦ ។

**៥០:៣១–៣២** គឺមានក្នុង ២១:១៣–១៤ ការនិយាយក្នុងជំពូកនោះ គឺចង់

នឹង[ហ]ឯង ដ្បិតថ្ងៃកំណត់[ឡ]របស់ឯងបានមកដល់ហើយ គឺជា
វេលាដែលអញនឹងធ្វើទោសដល់ឯង ៣២នោះអ្នកឆ្មើងឆ្មៃ[អ]
នឹងចំពប់ដួល[ក] ឥតមានអ្នកណាលើកឡើងវិញឡើយ[ខ] អញ
នឹងបង្កាត់ភ្លើង[គ] នៅអស់ទាំងទីក្រុងរបស់គេ ហើយភ្លើង
នោះនឹងឆេះគ្រប់ទាំងអស់ដែលនៅជុំវិញគេផង ។
៣៣ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលដូច្នេះ
ថា ពួកកូនចៅអ៊ីស្រាអែល និងពួកកូនចៅយូដា ត្រូវគេ
សង្កត់សង្កិនជាមួយគ្នា[ឃ] ពួកអ្នកទាំងប៉ុន្មានដែលចាប់គេនាំ
ទៅជាឈ្លើយ នោះក៏ឃុំឃាំងគេជាប់នៅ មិនព្រមលែង
ចេញទេ[ង] ៣៤ឯព្រះដ៏ប្រោសលោះ[ច]គេ ទ្រង់មានឥទ្ធិឫទ្ធិ
ព្រះនាមទ្រង់ គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ[ឆ] ទ្រង់នឹង
កាន់ក្តីគេ[ជ] ដើម្បីនឹងប្រោសឱ្យផែនដីបានសេចក្តីស្រាក
ស្រាន្ត[ឈ] ហើយឱ្យពួកអ្នកនៅក្រុងបាប៊ីឡូន កើតមានភ័យ
អាសន្នវិញ ៣៥ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា មានដាវ[ញ]
មកលើពួកខាល់ដេ និងលើពួកអ្នកនៅក្រុងបាប៊ីឡូន[ដ] លើ
ពួកចៅហ្វាយ និងពួកអ្នកប្រាជ្ញ[ឋ]របស់គេផង ៣៦មានដាវមក
លើពួកភូតភរ គេនឹងត្រឡប់ជាវិងវង់ស្មារតី មានដាវមក
លើពួកខ្លាំងពូកែរបស់គេ[ឌ] ហើយពួកនោះនឹងភ័យស្លុត
ទៅ[ឍ] ៣៧មានដាវមកលើសេះទាំងប៉ុន្មាន និងរទេះចំបាំង[ណ]
របស់គេ ហើយលើជនជាតិលាយឡំទាំងប៉ុន្មាន ដែលនៅ
ក្នុងក្រុងបាប៊ីឡូនដែរ គេនឹងត្រឡប់ទៅដូចជាស្រីវិញ[ត] មាន
ដាវមកលើអស់ទាំងទ្រព្យសម្បត្តិរបស់គេ[ថ] ហើយទាំងអស់
នឹងត្រូវប្លន់យកទៅ ៣៨មានរដូវរាំងរីងមកលើទីទឹករបស់
គេ[ទ] ហើយទឹកទាំងនោះនឹងរីងស្ងួត[ធ]ទៅ ពីព្រោះស្រុកនោះ
មានសុទ្ធតែរូបឆ្លាក់[ន] ក៏វក់នឹងរូបព្រះផង ៣៩ហេតុនោះ
សត្វ[ប]ព្រៃនៅទីស្ងាត់ ហើយចចក នៅអាស្រ័យនៅទីនោះ
ព្រមទាំងសត្វអូសទ្រីចផង ឥតមានមនុស្សណានៅស្រុក
នោះជាដរាបតទៅ ក៏នឹងគ្មានអ្នកណានៅគ្រប់ទាំងដំណ
មនុស្សតរៀងទៅដែរ[ផ] ៤០ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
នឹងគ្មានមនុស្សណាអាស្រ័យនៅទីនោះ ឬមនុស្សជាតិណា
ស្នាក់នៅឡើយ ដូចកាលព្រះទ្រង់បំផ្លាញក្រុងសូដុំម និង
ក្រុងកូម៉ូរ៉ា[ព] ហើយទីក្រុងនៅជិតខាងទាំងប៉ុន្មានដែរ[ភ]។
៤១មើល មានសាសន៍១មកពីទិសខាងជើង[ម] ជាសាសន៍
យ៉ាងធំ និងស្តេចជាច្រើន បានត្រូវដាសឡើង[យ]ពីចុងផែន
ដី[រ] ៤២គេចាប់យកធ្នូ[ល] និងលំពែង ជាពួកសាហាវណាស់[វ]
ឥតមានត្រាប្រណីឡើយ[ស] សំឡេងគេឮសន្ធឹកដូចសមុទ្រ[ហ]
គេសុទ្ធតែជិះសេះ គេដំរៀបគ្នា ដូចជាមនុស្សដែល រៀប
ទៅច្បាំង ឱកូនស្រីក្រុងបាប៊ីឡូនអើយ[ឡ] គេមកទាស់ នឹងឯង
ហើយ ៤៣ស្តេចក្រុងបាប៊ីឡូនបានឮដំណឹងពីគេ ព្រះហស្ត
ទ្រង់ក៏ខ្សោយទៅ[អ] មានសេចក្តីថប់ព្រួយចាប់ទ្រង់ ទ្រង់ក៏
ឈឺចាប់ ដូចជាស្រីដែលឈឺនឹងសំរាលកូន[ក] ៤៤មើលខ្មាំង
សត្រូវនឹងឡើងមកទាស់នឹងទីលំនៅមាំមួន ដូចជាសិង្ហ
ដែលឡើងមកពីទីជិនន់នៃទន្លេយ័រដាន់[ខ] ដ្បិតអញនឹងធ្វើឱ្យ
ពួកក្រុងបាប៊ីឡូនរត់ចេញភ្លាម រួចអ្នកណាដែលបានរើស
តាំង[គ] នោះអញនឹងតាំងឱ្យគ្រប់គ្រងវិញ តើអ្នកណាដូចអញ
តើអ្នកណានឹងដាក់កំណត់ឱ្យអញបាន[ឃ] តើមានអ្នកគង្វាល
ណា ដែលអាចនឹងឈរនៅចំពោះអញបាន ៤៥ដូច្នេះ ចូរ

**៥០:៣១** ហ យរ ២១:១៣ ឡ យប ១៩:២០ វវ ១៨:៧–៨
**៥០:៣២** អ ទដ ១១៩:២១ ក ទដ ២០:៨ ខ អម ៥:២ គ យរ ៤៩:២៧
**៥០:៣៣** ឃ អស ៥៨:៦ ង អស ១៤:១៧
**៥០:៣៤** ច នក ៦:៦ យប ១៩:២៥ ឆ យរ ៣១:៣៥ ៥១:១៩ ជ ទដ ១១៩:១៥៤ អស ៤៩:២៥ យរ ១៥:២១ ៥១:៣៦ បទ ៣:៥៨ ឈ អស ១៤:៧
**៥០:៣៥** ញ យរ ៤៧:៦ ដ អស ៤៥:១ ឋ ដយ ៥:៧
**៥០:៣៦** ឌ យរ ៤៩:២២ ឍ យរ ៥១:៣១,៣២
**៥០:៣៧** ណ ២ពវ ១៩:២៣ យរ ៥១:២១ ត អស ១៩:១៦ ថ អស ៤៥:៣
**៥០:៣៨** ទ ទដ ១៣៧:១ យរ ៥១:២១ ធ អស ១៩:១៦ ន អស ៤៥:៣ **៥០:៣៩** ប ទដ ៧៤:១៤ ផ អស ១៣:១៩–២២ ៣៤:១៣–១៥ យរ ៥១:៣៧ វវ ១៨:២ **៥០:៤០** ព លប ១៩:២៤ មថ ១០:១៥ ភ យរ ៥១:៦២ **៥០:៤១** ម ខ.២៦ អស ៤១:២៥ យ អស ១៣:១៧ រ អស ១៣:៤ យរ ៥១:២២–២៨ **៥០:៤២** ល ខ.១៤ វ យប ៣០:២១ ស អស ១៣:១៨ ហ អស ៥:៣០ ឡ អស ៤៧:១ **៥០:៤៣** អ យរ ៤៧:៣ ក យរ ៦:២២–២៤ **៥០:៤៤** ខ យរ ១២:៥ គ ជន ១៦:៥ ឃ យប ៤១:១០ អស ៤៦:៩ យរ ៤៩:១៩

សំដៅទៅលើក្រុងយេរូសាឡិម ប៉ុន្តែនៅក្នុងជំពូកនេះគឺចង់បង្ហាញពីក្រុងបាប៊ីឡូនវិញ ។

**៥០:៣៣** *ចាប់គេ* សូមមើល អស ១៤:២ ។ *គេជាប់នៅ មិនព្រមលែងចេញទេ* គឺជាការនឹកឃើញឡើងវិញ នូវការរំលឹករបស់ស្តេចផារ៉ោន ដែលបដិសេធ ឬមានចិត្តរឹងរូស (សូមមើល នក ៧:១៤ ៨:២,៣២ ៩:២,៧) ។

**៥០:៣៤** *ព្រះដ៏ប្រោសលោះគេ* មើល ៣១:១១ និងការពន្យល់ ។ *ទ្រង់នឹងកាន់ក្តីគេ* មើល ៥១:៣៦ ។ *សេចក្តីស្រាកស្រាន្ត* មើល ៣១:២ និងការពន្យល់ ក៏មើល អស ១៤:៣,៤ និងការពន្យល់ ចទ ៣:២០ យស ១:១៣ ។

**៥០:៣៥–៣៨** ប្រៀបនឹង អគ ២១ ។

**៥០:៣៦** *ពួកភូតភរ គេនឹងត្រឡប់ជាវិងវង់ស្មារតី* សូមមើល អស ៤៤:២៥ មើល នក ១២:១១ និងការពន្យល់ ទដ ១:៧ ។

**៥០:៣៧** *ដាវមកលើសេះទាំងប៉ុន្មាន និងរទេះចំបាំងរបស់គេ* សូមមើល អស ៤៣:១៧ និងមើល ២០:៧ ។ *ជនជាតិលាយឡំទាំងប៉ុន្មាន* សូមមើល ២៥:២០,២៤ នង ១៣:៣ ។ *គេនឹងត្រឡប់ទៅដូចជាស្រីវិញ* សូមមើល ណហ ៣:១៣ និងការពន្យល់ ។

**៥០:៣៨** *រូបព្រះ* សូមមើល ៥១:៥២ និងការពន្យល់ អស ២១:៩ ។ *ក៏វក់* សូមមើល ២៥:១៦ និងការពន្យល់ ។

**៥០:៣៩** សូមមើល អស ១៣:២០–២២ និងការពន្យល់ ។

**៥០:៤០** ដែលមានក្នុង ៤៩:១៨ (សូមមើលការពន្យល់) ។

**៥០:៤១–៤៣** ក៏មានបកស្រាយនៅក្នុង ៦:២២–២៤ (សូមមើលការពន្យល់) និងមើលពីបទទំនាយពីមុនមក ដែលទាក់ទងនឹងក្រុងយេរូសាឡិមនៅទីនេះ ធ្វើសម្រាប់ក្រុងបាប៊ីឡូន ។

**៥០:៤២** *ឱកូនស្រីក្រុងបាប៊ីឡូនអើយ* គឺបញ្ជាក់ពីលក្ខណៈសម្បត្តិរបស់ទីក្រុងបាប៊ីឡូន (សូមមើលការពន្យល់ ២ពវ ១៩:២១) ។

**៥០:៤៣** *ស្រីដែលឈឺនឹងសំរាលកូន* សូមមើលការពន្យល់ ៤:៣១ ។

**៥០:៤៤–៤៦** គឺមានក្នុង ៤៩:១៩–២១ (សូមមើលការពន្យល់ ៤៩:១៩–២១) ក្នុងគម្ពីរនោះជាសេចក្តីទំនាយទាស់ប្រឆាំងនឹងពួកអេដំម តែនៅត្រង់នេះចង់បង្ហាញពីការទាស់ប្រឆាំងនឹងពួកបាប៊ីឡូនវិញ ។

ស្តាប់សេចក្តីប្រឹក្សារបស់ព្រះយេហូវ៉ា ជាសេចក្តីដែលទ្រង់
បានគិតសំរេច[ង] ទាស់នឹងពួកអ្នកស្រុកខាល់ដេចុះ[ច] គឺថាពួក
តូចបំផុតក្នុងហ្វូងនឹងអូសគេចេញជាពិត ហើយឱ្យទីលំនៅ
របស់គេទៅជាស្ងាត់ច្រៀបពីលើគេ
៤៦ផែនដីក៏ញ័រ[ឆ]
ដោយសូរនៃការចាប់យកក្រុងបាប៊ីឡូន សំរែក[ជ]របស់គេ
ក៏បានឮ នៅកណ្តាលអស់ទាំងសាសន៍ ។

**៥១**
១ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មើលអញ
នឹងបង្កើត[ក]ឱ្យមានខ្យល់ ដែលបំផ្លាញទាស់នឹងក្រុងបាប៊ីឡូន[ខ]
ហើយទាស់នឹងពួកអ្នកនៅកណ្តាលសាសន៍ ដែលលើកខ្លួន
ឡើងទាស់នឹងអញដែរ
២អញនឹងចាត់មនុស្សដទៃ[គ]ឱ្យទៅ
ឯក្រុងបាប៊ីឡូន អ្នកទាំងនោះនឹងអុំ[ឃ]គេ ហើយនឹងរំលីង
ទាំងអស់ ចេញពីស្រុកទៅ ដ្បិតនៅថ្ងៃ[ង]អន្តរាយ អ្នកទាំង
នោះនឹងឡោមព័ទ្ធជុំវិញគេ
៣ចូរឃឹតធ្នូបាញ់[ច] ពួកអ្នកដែល
ឃឹតធ្នូចុះ ព្រមទាំងអ្នកដែលក្រោកឡើងទាំង ពាក់អាវ
ក្រោះផង[ឆ] កុំឱ្យប្រណីពួកកំឡោះៗរបស់គេឡើយ ត្រូវឱ្យ
បំផ្លាញពលទ័ពគេឱ្យអស់រលីងទៅ
៤គេនឹងត្រូវដួល[ជ] ស្លាប់
នៅក្នុងស្រុករបស់ពួកខាល់ដេ គេនឹងត្រូវចាក់ទំលុះនៅផ្លូវ
ទីក្រុង[ឈ] ។
៥ដ្បិតព្រះនៃពួកអ៊ីស្រាអែល និងពួកយូដា គឺជាព្រះ
យេហូវ៉ានៃពួកពលបរិវារ ទ្រង់មិនបានព្រាត់ប្រាសពីគេ
ឡើយ[ញ] ទោះបើស្រុកគេមានពេញ ដោយទោស[ដ] ចំពោះ
ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលក៏ដោយ
៦ចូរឱ្យគ្រប់
ទាំងមនុស្សរត់ចេញ[ឋ]ពីកណ្តាលក្រុងបាប៊ីឡូន ដើម្បីឱ្យរួច
ជីវិតចុះ កុំឱ្យខ្លួនត្រូវកាត់ចេញ ដោយសេចក្តីទុច្ចរិតរបស់
គេឡើយ[ឌ] ដ្បិតនេះគឺវេលាកំណត់[ឍ]នៃសេចក្តីសងសឹករបស់
ព្រះយេហូវ៉ា[ណ] ទ្រង់នឹងតបស្នង[ត]ដល់គេ
៧ពីដើមបាប៊ីឡូន
ជាពែងមាស[ថ]នៅព្រះហស្តនៃព្រះយេហូវ៉ា ជាពែងដែលឱ្យ
ផែនដីទាំងមូលស្រវឹង សាសន៍ទាំងប៉ុន្មានបានផឹកស្រា
ទំពាំងបាយជូររបស់គេ ហេតុនោះបានជាសាសន៍ទាំង
អស់បានត្រឡប់ជារវើរវាយទៅ
៨ក្រុងបាប៊ីឡូនស្រាប់តែ
រលំ[ទ] ហើយត្រូវបំផ្លាញទៅភ្លាម ចូរទ្រហោយំនឹងវាចុះ
ត្រូវ ឱ្យយកប្រទាលមុខសះ[ធ]ទៅបិទឱ្យវាបាត់ឈឺ បើសិនជា
នឹងមើលឱ្យជាបាន
៩យើងរាល់គ្នាចង់តែមើលបាប៊ីឡូន
ឱ្យជាដែរ តែវាមិនបានជាសោះ ចូរយើងលះចោល[ន]វា
ទៅ ហើយត្រឡប់ទៅឯស្រុកយើងរៀងខ្លួនវិញ ដ្បិតទោស[ប]
វាលូតរហូតដល់លើ គឺបានឡើងទៅដល់ផ្ទៃមេឃតែម្តង
១០ព្រះយេហូវ៉ាទ្រង់បាននាំ[ផ]សេចក្តីសុចរិតរបស់យើងចេញ
មកហើយ ចូរមក យើងនឹងថ្លែងប្រាប់នៅក្រុងស៊ីយ៉ូន ពី
ការនៃព្រះយេហូវ៉ា ជាព្រះនៃយើង[ព] ។
១១ចូរសំរួចព្រួញឱ្យមុត[ភ] ចូរចាប់ខែលកាន់ឱ្យមាំចុះ[ម]
ព្រះយេហូវ៉ា ទ្រង់បានដាស់វិញ្ញាណរបស់ពួកស្តេច[យ]

**៥០:៤៥** ង ទដ ៣៣:១១ យរ ៥១:១១ ច អស ៤៨:១៤ **៥០:៤៦** ឆ ពច ៥:៤ យរ ៤៩:២១ ជ យប ២៤:១២ វវ ១៨:៩–១០ **៥១:១** ក អស ១៣:១៧ ខ យរ ២៥:១២ **៥១:២** គ អស ១៣:៥ ឃ អស ៤១:១៦ មថ ៣:១២ ង អស ១៣:៩ **៥១:៣** ច យរ ៥០:២៩ ឆ យរ ៤៦:៤ **៥១:៤** ជ អស ១៣:១៥ ឈ អស ១៣:១៨ **៥១:៥** ញ លវ ២៦:៤៤ អស ៥៤:៦–៨ ដ ហស ៤:១ **៥១:៦** ឋ អស ៤៨:២០ ឌ ជន ១៦:២៦ វវ ១៨:៤ ឍ យរ ៥០:២៧ ណ អស

១:២៤ យរ ៥០:១៥ ត ខ.២៤,៥៦ ចទ៣២:៣៥ យប ២១:១៩ យរ ២៥:១៤ ៥០:២៩ បទ ៣:៦៤ **៥១:៧** ថ អស ៥១:២២ យរ ២៥:១៥–១៦ ៤៩:១២ វវ ១៤:៨–១០ **៥១:៨** ទ អស ១៤:១៥ ២១:៩ វវ ១៤:៨ ធ យរ ៨:២២ ៤៦:១១ **៥១:៩** ន អស ១៣:១៤ ៣១:៩ យរ ៥០:១៦ ប វវ ១៩:៤–៥ **៥១:១០** ផ មីក ៧:៩ ព ទដ ៦៤:៩ យរ ៥០:២៨ **៥១:១១** ភ យប ៥០:៩ ម អស ២១:៥ យ អស ៤១:២

**៥១:១** *មានខ្យល់ដែលបំផ្លាញទាស់នឹងក្រុង* សូមមើល ១រប ៥:២៦ ហក ១:១៤ ក្នុងព្រះគម្ពីរភាសាហេព្រើរបានវិភាគឃ្លានេះត្រូវគេបានបកប្រែថា "ការពញ្ញាក់ស្មារតី . . . ភាពជាសត្រូវ" ២រប ២១:១៦ ។ *ដែលបំផ្លាញ* សូមមើលការពន្យល់ ៤:៧ តែត្រង់វគ្គនេះមានបញ្ជូន "ស្តេចម៉ាដាយ" (ខ.១១) ។ *ពួកអ្នកនៅកណ្តាលសាសន៍* (សូមប្រៀបធៀប វវ ១៧:៥ ត្រង់ដែលសាសន៍បាប៊ីឡូនត្រូវបានគេហៅថា ជាមាតានៃភាពពេស្យាចារ និងជាមាតានៃអំពើគួរឱ្យស្អប់ខ្ពើមនៃលោកកិយ) ។ សូមមើលការពន្យល់ ២៥:២៦ ។

**៥១:២** *មនុស្សដទៃ . . . អ្នកទាំងនោះនឹងអុំគេ* ក្នុងឃ្លានេះជាព្រះគម្ពីរភាសាហេព្រើរ គឺជាឧទាហរណ៍គំរូនៃការសរសើរឱ្យមានភាពចុងជួននិងសម្លេងស្រះ (សូមមើលសេចក្តីផ្តើម : ពីលក្ខណៈអក្សរសាស្ត្រ) ។

**៥១:៣** *បំផ្លាញពលទ័ពគេឱ្យអស់រលីង* សូមមើលការពន្យល់ ២៥:៩ ៥០:២១,២៦ និងការពន្យល់ ចទ ២:៣៤ ។

**៥១:៤** *ត្រូវដួលស្លាប់ . . . នៅផ្លូវទីក្រុង* សូមមើល ៤៩:២៦ ៥០:៣០ ។

**៥១:៥** *ព្រាត់ប្រាសពីគេឡើយ* តាមបែបអក្សរសាស្ត្រ"គឺជាស្ត្រីមេមាយ" ដែលផ្ទុយនឹង អស ៥៤:៤,៦–៧ និងការពន្យល់ ។ *ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល* សូមមើលការពន្យល់ ៥០:២៩ ។

**៥១:៦** *រត់ចេញពី . . . ដើម្បីឱ្យ* សូមមើល ខ.៤៥ ៤៨:៦ នេះគឺជាការនិយាយចំពោះមនុស្សស្រុកយូដា (ដូចក្នុង ៥០:៨) ។ *សេចក្តីសងសឹងរបស់ព្រះយេហូវ៉ា* សូមមើលការពន្យល់ ៥០:១៥ ។ *ទ្រង់នឹងស្នងដល់គេ* សូមមើល អស ៥៩:១៨ ៦៦:៦ ។

**៥១:៧** សូមមើល ២៥:១៥–១៦ និងការពន្យល់ ។ *បាប៊ីឡូនជាពែងមាស* សូមមើលការពន្យល់ ដយ ២:៣២–៤៣ ។

**៥១:៨** *ក្រុងបាប៊ីឡូន . . . ត្រូវបំផ្លាញទៅភ្លាម* មើលការពន្យល់ ៨:២២ ។

**៥១:៩** អ្នកនិយាយនៅក្នុងឃ្លានេះគឺជាជាតិសាសន៍ ដែលបានគ្រប់គ្រងដោយពួកបាប៊ីឡូន ។ *ហើយត្រឡប់ទៅឯស្រុកយើងរៀងខ្លួ* សូមមើល ៥០:១៦ និងការពន្យល់ ។ *ដ្បិតទោសវាលូតរហូតដល់លើ* គឺជាអំពើបាបរបស់ពួកគេ ដែលសមនឹងទទួលការកាត់ទោស ។ *គឺបានឡើងទៅដល់ផ្ទៃមេឃតែម្តង* មាន លក្ខណៈដូចជាកំណាព្យ ដែលហួសពីការពិត (សូមមើល ចទ ១:២៨ ទដ ៥៧:១០ ១០៨:៤) ។

**៥១:១០** ពាក្យសម្តីយូដា (សូមមើល ៥០:២៨) ។ *ព្រះយេហូវ៉ាបាននាំសេចក្តីសុចរិតរបស់យើងចេញ* សូមមើល ទដ ៣៧:៦ ។

**៥១:១១** *ដាស* តាមបែបអក្សរសាស្ត្រ "គឺជាការដាស់វិញ្ញាណ" (សូមមើលការពន្យល់ ខ.១) ។ *ស្តេចសាសន៍មេឌី* សូមមើល ខ.២៨ អស ១៣:១៧ និង

សាសន៍មេឌីឡើង[រ] ពីព្រោះទ្រង់មានគំនិត[ល]ទាស់នឹង
បាប៊ីឡូន ដើម្បីនឹងបំផ្លាញចេញ ដ្បិតនេះជាសេចក្ដីសង
សឹក[វ]របស់ព្រះយេហូវ៉ា គឺជាការសងសឹកស្នងព្រះវិហារ
នៃទ្រង់[ស] ១២ចូរដំឡើងទង់ជ័យ[ហ]ទាស់នឹងកំផែងក្រុង
បាប៊ីឡូនចុះ ត្រូវឱ្យពួកយាមបានកំឡាំងឡើង ចូរដាក់ពួក
ចាំយាម[ឡ] ហើយរៀបទ័ពបង្កប់ទៅ[អ] ដ្បិតព្រះយេហូវ៉ាទ្រង់
បានសំរេច[ក] ហើយបានបង្ហើយការដែលទ្រង់មានបន្ទូលពី
ដំណើរពួកអ្នកនៅក្រុងបាប៊ីឡូន ១៣ឱក្រុងដែលតាំងនៅលើ
ទីទឹកជាច្រើន[ខ] ហើយមានទ្រព្យសម្បត្តិដ៏បរិបូរអើយ[គ]
ចុងបំផុតរបស់ឯងបានមកដល់ហើយ សេចក្ដីលោភរបស់
ឯងក៏ដល់កំណត់ផង[ឃ] ១៤ព្រះយេហូវ៉ា នៃពួកពលបរិវារ
ទ្រង់បានស្បថដោយព្រះអង្គទ្រង់ថា[ង] ពិតប្រាកដជាអញនឹង
ធ្វើឱ្យឯងបានពេញដោយមនុស្ស ដូចជាពេញដោយដង្កូវ[ច]
ហើយគេនឹងស្រែកឡើង[ឆ]ទាស់នឹងឯង ។
១៥ឯព្រះទ្រង់បានបង្កើតផែនដី ដោយសារព្រះចេស្ដា
ទ្រង់ក៏បានតាំងលោកីយឡើង ដោយប្រាជ្ញា[ជ]របស់ទ្រង់ ក៏
បានលាត[ឈ]ផ្ទៃមេឃ ដោយយោបល់ទ្រង់[ញ] ១៦កាលណា
ទ្រង់បញ្ចេញព្រះសូរសៀង[ដ] នោះមានឮសូរសន្ធឹកនៃទឹក
នៅលើមេឃ ហើយទ្រង់បណ្ដាលឱ្យចំហាយទឹកឡើងពីចុង
ផែនដី ទ្រង់បង្កើតផ្លេកបន្ទោរសំរាប់ភ្លៀង[ឋ] ក៏បញ្ចេញ
ខ្យល់ពីឃ្លាំងនៃទ្រង់ផង[ឌ] ១៧គ្រប់គ្នាបានត្រឡប់ជាមនុស្ស
កំរោល ហើយក៏ឥតមានដំរិះផង គ្រប់ទាំងជាងទងបាន
ត្រូវខ្មាស ដោយសាររូបឆ្លាក់របស់គេ ដ្បិតរូបសិតរបស់
គេជាសេចក្ដីភូតភរ[ឍ] គ្មានខ្យល់ដង្ហើមនៅក្នុងវាឡើយ ១៨វា
សុទ្ធតែឥតប្រយោជន៍[ណ] ជារបស់ក្លែងបញ្ឆោតទទេ នៅគ្រា
ដែលធ្វើទោសវា នោះវានឹងសូន្យបាត់ទៅ ១៩ឯចំណែក[ត]

**៥១:១១** រ ខ.២៨ អស ១៣:៣ ៤១:២៥ ល យរ ៥០:៤៥ វ លវ ២៦:២៥ ស យរ ៥០:២៨ **៥១:១២** ហ ខ.២៧ ទដ ២០:៥ ឡ ២សយ ១៨:២៤ អគ ៣៣:២ អ យរ ៥០:២៤ ក ទដ ៣៣:១១ **៥១:១៣** ខ យរ ៥០:៣៨ គ អស ៤៥:៣ អគ ២២:២៧ ហព ២:៩ ឃ យរ ៥០:៣ **៥១:១៤** ង លប ២២:១៦ អម ៦:៨ ច ខ.២៧ អម ៧:១ ណហ ៣:១៥ ឆ យរ ៥០:១៥ **៥១:១៥** ជ ទដ ១០៤:២៤ ឈ លប ១:១ ទដ ១០៤:២ ញ ទដ ១៣៦:៥ **៥១:១៦** ដ ទដ ១៨:១១–១៣ ឋ យប ២៨:២៦ ឌ ចទ ២៨:១២ ទដ ១៣៥:៧ យហ ១:៤ **៥១:១៧** ឍ អស ៤៤:២០ ហព ២:១៨–១៩ **៥១:១៨** ណ យរ

របស់ពួកយ៉ាកុប មិនមែនដូច្នោះទេ ដ្បិតគឺទ្រង់ដែលជប
សូនរបស់សព្វសារពើ ហើយសាសន៍អ៊ីស្រាអែលជាពូជ
អំបូរដែលជាមរដករបស់ទ្រង់[ថ] ព្រះនាមទ្រង់ គឺជាព្រះ
យេហូវ៉ានៃពួកពលបរិវារ ។
២០ឯងជាពូថៅចំបាំង ហើយជាគ្រឿងសស្ត្រាវុធ[ទ]របស់
អញ អញនឹងបំបាក់បំបែក[ធ]អស់ទាំងសាសន៍[ន] ឱ្យខ្ទេចខ្ទី
ដោយសារឯង ហើយនឹងបំផ្លាញនគរផ្សេងៗ ដោយសារ
ឯងដែរ ២១អញនឹងបំបាក់បំបែកទាំងសេះ និងអ្នកជិះផង[ប]
ដោយសារឯង អញនឹងបំបាក់បំបែកទាំងរទេះចំបាំង[ផ] និង
អ្នកបរដោយសារឯង ២២អញនឹងបំបាក់បំបែកទាំងប្រុស
ទាំងស្រី ដោយសារឯង អញនឹងបំបាក់បំបែកទាំងចាស់ទាំង
ក្មេង ដោយសារឯងអញនឹងបំបាក់បំបែកទាំងពួកកំឡោះ
និងក្រមុំ[ព] ដោយសារឯង ២៣អញនឹងបំបាក់បំបែក ទាំងអ្នក
គង្វាល និងហ្វូងសត្វ ដោយសារឯង អញនឹងបំបាក់បំបែក
ទាំងអ្នកភ្ជួរនឹងគោ ដោយសារឯង អញនឹងបំបាក់បំបែក
ទាំងចៅហ្វាយ និងនាយផង[ភ] ដោយសារឯង ២៤ហើយអញ
នឹងសង[ម]ដល់ក្រុងបាប៊ីឡូន[យ]នឹងពួកអ្នកស្រុក ខាល់ដេទាំង
ប៉ុន្មាននៅភ្នែកឯង តាមគ្រប់ទាំងការអាក្រក់ ដែលគេបាន
ធ្វើដល់ក្រុងស៊ីយ៉ូន នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
២៥ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱភ្នំដែលបំផ្លាញ
គឺដែលបំផ្លាញផែនដីទាំងមូលអើយ[រ] មើល អញទាស់នឹង[ល]
ឯង អញនឹងលូកដៃ[វ]ទៅលើឯង ហើយប្រមៀលឯងទំលាក់

១៨:១៥ **៥១:១៩** ត ទដ ១១៩:៥៧ ថ នក ៣៤:៩ **៥១:២០** ទ អស ១០:៥ សក ៩:១៣ ធ យប ៣៤:២៤ មីក ៤:១៣ ន អស ៤៥:១ **៥១:២១** ប នក ១៥:១ ផ អស ៤៣:១៧ យរ ៥០:៣៧ **៥១:២២** ព ២របា ៣៦:១៧ អស ១៣:១៧–១៨ **៥១:២៣** ភ ខ.៥៧ **៥១:២៤** ម ខ.៦,៣៥ ចទ ៣២:៤១ យរ ៥០:១៥ បទ ៣:៦៤ យ អស ៤៥:១ **៥១:២៥** រ អស ២១:១៣ ល យរ ៥០:២៣ វ នក ៣:២០

ការពន្យល់ អស ២១:២ ដយ ៥:២៨,៣១ ៦:៨,១២,១៥ ៨:២០ ។ *ការសងសឹកស្នងព្រះវិហារនៃទ្រង់* សូមមើលការពន្យល់ ៥០:២៨ ។

**៥១:១២** *រៀបទ័ពបង្កប់* គឺរក្សាការពារបន្ថែមទៀត ដើម្បីឱ្យទីតាំងរបស់គេបានរឹងមាំ (សូមមើល យស ៨:១៤–២២ ពច ២០:២៩–៣៩) ។

**៥១:១៣** *ទីជាច្រើន* ជាទឹកទន្លេបាប៊ីឡូន (ទដ ១៣៧:១) មានបញ្ចូលក្នុងទន្លេអើប្រាតដ៏មានអំណាចចេស្ដា ក៏មានប្រព័ន្ធដ៏ឆើតឆាយប្រកបដោយកិត្តិគុណនៃប្រឡាយដែលជាធារាសាស្ត្រ ។ *ក៏ដល់កំណត់ផង* គឺមានលក្ខណៈដូចជាការគំរាមកំហែងពីអ្វីដែលលេចឡើយ (សូមមើល អស ៣៨:១២) ។

**៥១:១៤** *ទ្រង់បានស្បថដោយព្រះអង្គទ្រង់ថា* សូមមើលការពន្យល់ លប ២២:១៦ ។ *ពេញដោយមនុស្សដូចជាពេញដោយដង្កូវ* សូមមើល ៤៦:២៣ ។ *ស្រែកឡើងទាស់នឹងឯង* (សូមមើលការពន្យល់ ៤៦:២៣) ។

**៥១:២០–២៣** គឺជាការពេញចិត្តរបស់ហោរាយេរេមា ក្នុងការបង្ហាញប្រាប់នូវឃ្លាប្រយោគរៀបរាប់យ៉ាងមានប្រសិទ្ធភាព ឆាប់យល់ដោយប្រើពាក្យនិយាយដដែលៗ (សូមមើល ៤:២៣–២៦ និងមើលសេចក្ដីផ្ដើម ត្រង់កន្លែងលក្ខណៈអក្សរសាស្ត្រ) ។

**៥១:២០** *ឯងជាពូថៅចំបាំង* ធៀបនឹង សភ ២៥:១៨ និងមាន (១).ស៊ីរូសជាស្ដេចស្រុកពើស៊ី ក្រោយមកក៏គ្រប់គ្រងត្រួតត្រាស្រុកបាប៊ីឡូន ឬក៏ (២).ក្រុងបាប៊ីឡូនអ្នកបំផ្លាញដល់ជាតិសាសន៍ផ្សេងៗ (សូមមើល ៥០:២៣ និងមើលការពន្យល់ អស ១០:៥) ។ *បំបាក់បំបែក* សូមមើល ខ.២១–២៣ ។ មានឫសគល់ចេញពីព្រះគម្ពីរភាសាហេព្រើរចំពោះកិរិយាស័ព្ទនេះ គឺមានលក្ខណៈដូចគ្នានឹងពាក្យ"ជាពូថៅចំបាំង" មើល នក ១៥:៦ ។ ក៏មានកិរិយាស័ព្ទ ក្នុងព្រះគម្ពីរភាសាហេព្រើរមួយទៀតបានបកប្រែថា "បោកកំទេច (បំបែកឱ្យខ្ទេច)" មើល ទដ ២:៩ ១៣៧:៩ ហស ១០:១៤ ១៣:១៦ ។

**៥១:២៤** *ឯងតាមគ្រប់តាំងការអាក្រក់* សូមមើល ខ.៦ ៥០:១៥,២៩ និងការពន្យល់ ។

**៥១:២៥** *ឱភ្នំដែលបំផ្លាញ* គឺជាដំណាងនគរដែលមានអំណាចចេស្ដា (សូមមើល ដយ ២:៣៥,៤៤–៤៥) ទីនេះក៏បង្ហាញពីបាប៊ីឡូន ។ បន្ទាប់ពីជំនុំជម្រះដោយព្រះយេហូវ៉ាក្រុងបាប៊ីឡូន និងមានលក្ខណៈដូចជាភ្នំភ្លើងដែលខូច

ពីលើថ្មដា ព្រមទាំងឱ្យឯងឆេះអស់ទៅ[ស] ២៦គេនឹងមិនយក
ថ្មពីឯង សំរាប់ធ្វើជាថ្មជ្រុងផ្ទះ ឬជាឬសជញ្ជាំងឡើយ គឺ
ឯងនឹងត្រូវចោលស្ងាត់[ហ]ជាដរាបតទៅ នេះជាព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ។
២៧ចូរដំឡើងទង់ជ័យ[ឡ]នៅក្នុងស្រុក ចូរផ្លុំត្រែនៅនា
កណ្តាលសាសន៍ទាំងប៉ុន្មាន ត្រូវឱ្យប្រមូលផ្តុំអស់ទាំង
សាសន៍ មកទាស់នឹងក្រុងបាប៊ីឡូនចុះ ចូរហៅនគរទាំង
ប៉ុន្មាន[អ] នៅស្រុកអារ៉ារ៉ាត[ក] មីនី និងអ័សក្នាស[ខ] ឱ្យគេមូល
គ្នាមកទាស់នឹងទីក្រុង ចូរតាំងមេទ័ពធំម្នាក់ ឱ្យទាស់នឹងវា
ចុះ ហើយឱ្យមានសេះឡើងមក បែបដូចជាដង្កូវមានរោម
ច្រោង[គ] ២៨ចូរប្រមូលផ្តុំសាសន៍ទាំងប៉ុន្មានមកទាស់នឹងវា
គឺអស់ទាំងស្តេចនៃសាសន៍មេឌី[ឃ] និងពួកចៅហ្វាយពួក
នាយរបស់គេ ព្រមទាំងស្រុកទាំងមូល ដែលនៅក្រោម
អំណាចគេផង[ង] ២៩ផែនដីកំពុងញាប់ញ័រ[ច] ក៏ឈឺចាប់
ពីព្រោះការដែលព្រះយេហូវ៉ាទ្រង់សំរេច[ឆ]នឹងធ្វើដល់ក្រុង
បាប៊ីឡូន នោះស្ថិតស្ថេរនៅ ដើម្បីនឹងធ្វើឱ្យស្រុកបាប៊ីឡូន
ត្រូវខូចបង់[ជ] ឥតមានអ្នកណានៅ[ឈ] ៣០ពួកខ្លាំងពូកែ[ញ]របស់
ក្រុងបាប៊ីឡូន គេបានអាក់ខានតស៊ូ គេនៅក្នុងទីមាំមួន
របស់គេ កំឡាំងគេស្បើយហើយ ក៏បានត្រឡប់ដូចជាស្រី
វិញ[ដ] ផ្ទះនៅក្នុងទីក្រុងបានឆេះអស់ហើយ[ឋ] រនុក[ឌ]ទ្វារក្រុង
ទាំងអស់ត្រូវបាក់ផង ៣១អ្នកយាម[ឍ]នឹងរត់ច្រវាត់ទៅមក
ហើយអ្នកនាំដំណឹងនឹងរត់ប្រទាក់គ្នា ដើម្បីនឹងបន្តដំណឹង
ដល់ស្តេចបាប៊ីឡូនឱ្យជ្រាបថា ទីក្រុងត្រូវគេចាប់យកនៅ
គ្រប់ទិសហើយ[ណ] ៣២ឯផ្លូវទឹក គេចាប់យកបាន ហើយវាល
បឹងគេ ដុតអស់ទៅ[ត] ដូច្នេះ ពួកទាហានមានចិត្តភ័យខ្លាច[ថ] ។
៣៣ដ្បិតព្រះយេហូវ៉ា នៃពួកពលបរិវារ គឺជាព្រះនៃ
សាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលដូច្នេះថា កូនស្រីនៃ
ក្រុងបាប៊ីឡូន[ទ]ធៀបដូចជាលានស្រូវ នៅរដូវបញ្ជាន់[ធ] នៅ
តែបន្តិចទៀតរដូវចំរូត[ន]នឹងមកដល់នាង[ប] ៣៤នេប៊ូក្នេសា[ផ]
ជាស្តេចបាប៊ីឡូនបានស៊ីបង្ហិន[ព]ខ្ញុំ[ភ] បានទាំងជាន់ឈ្លី បានធ្វើ
ឱ្យខ្ញុំដូចជាភាជនៈទទេបានលេបខ្ញុំទៅ ដូចជាសត្វសំបើម
ក៏បានបំពេញផ្ទៃ ដោយរបស់ទាំងប៉ុន្មាន ដែលគាប់ចិត្តខ្ញុំ
ហើយបានបោះ[ម]ខ្ញុំចេញទៅក្រៅ ៣៥សូមឱ្យការយកយាក់[យ]
ដែលគេបានធ្វើដល់ខ្ញុំ ហើយដល់សាច់ខ្ញុំបានធ្លាក់ទៅលើ
បាប៊ីឡូនវិញ នេះជាពាក្យដែលពួកអ្នកនៅក្រុងស៊ីយ៉ូននឹង
ថា គឺពួកអ្នកនៅក្រុងយេរូសាឡិម នឹងពោលថា សូមឱ្យ
ឈាមរបស់ខ្ញុំធ្លាក់ទៅលើពួកអ្នក នៅស្រុកខាល់ដេដែរ[រ]
៣៦ហេតុនោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មើល

**៥១:២៥** ស សក ៤:៧
**៥១:២៦** ហ ខ.២៩ អស ១៣:១៩-២២ យរ ៥០:១២
**៥១:២៧** ឡ ទដ ២០:៥ អស ១៣:២ អ យរ ២៥:១៤ ក លប ៨:៤ ខ លប ១០:៣ គ ខ.១៤
**៥១:២៨** ឃ ខ.១១ ង ខ.៤៨
**៥១:២៩** ច ពច ៥:៤ យរ ៤៩:២១ ឆ ទដ ៣៣:១១ ជ យរ ៤៨:៩ ឈ ខ.៤៣ អស ១៣:២០
**៥១:៣០** ញ យរ ៥០:៣៦ ដ អស ១៩:១៦ ឋ អស ៤៧:១៤ ឌ អស ៤៥:២
**៥១:៣១** ឍ ២សយ ១៨:១៩-៣១ ណ យរ ៥០:២ ដយ ៥:៣០ **៥១:៣២** ត អស ៤៧:១៤ ថ យរ ៥០:៣៦ **៥១:៣៣** ទ អស ៤៧:១ ធ អស ២១:១០ ន អស ១៧:៥ ប អស ១៣:២២ **៥១:៣៤** ផ យរ ៥០:១៧ ព ណាហ ២:១២ ភ ហស ៨:៨ ម ខ.៤៤ លវ ១៨:២៥ **៥១:៣៥** យ យអ ៣:១៩ ហព ២:១៧ រ ខ.២៤ ទដ ១៣៧:៨

រលួយទៅ ។

**៥១:២៦** *ត្រូវចោលស្ងាត់ជាដរាបតទៅ* សូមមើល ២៥:១២ ៥០:១២-១៣ និងការពន្យល់ អស ១៣:២០ ។

**៥១:២៧** សូមមើល ៥០:២៩ ។ *ចូរដំឡើងទង់ជ័យនៅ . . . ចូរផ្លុំត្រែនៅ* សូមមើល ៤:៥-៦ ៦:១ និងការពន្យល់ ។ *ត្រូវឱ្យប្រមូលផ្តុំអស់ទាំង . . . មកទាស់នឹង* តាមបែបអក្សរសាស្ត្រគឺ "ញែកខ្លួនជាបរិសុទ្ធ" (សូមមើលការពន្យល់ ៦:៤) ។ *នគរទាំងប៉ុន្មាន* គឺជាស្រុកសម្ព័ន្ធមិត្តរបស់ម៉ាដាយ (សូមមើល ខ.១១ និងការពន្យល់) ។ *ស្រុកអារ៉ារ៉ាត* សូមមើលការពន្យល់ លប ៨:៤ ។ *មីនី* គឺជាទីកន្លែង ឬតំបន់ដែលបានបង្ហាញក្នុងអក្សរចារិករបស់ស្រុកអាសស៊ើរ វាមានទីតាំងក្នុងតំបន់ស្រុកអារ៉ារ៉ាត ។ *អ័សក្នាស* សូមមើលការពន្យល់ លប ១០:៣ ។ *មេទ័ពធំម្នាក់* មានក្នុងគម្ពីរភាសាហេព្រើរចំពោះពាក្យនេះមានសរសេរក្នុងសញ្ញាចាស គឺនៅក្នុងគម្ពីរ ណាហ ៣:១៧ តែប៉ុណ្ណោះមានន័យថា ("មន្ត្រីជាន់ខ្ពស់") ។ វាជាពាក្យកម្ចី (ពាក្យដែលយកពីភាសាផ្សេងទៀត) មានន័យថា អ្នកនិពន្ធ ឬអ្នកចាត់ចែង ។ *ដូចជាដង្កូវ* សូមមើលការពន្យល់ ៤៦:២៣ ។

**៥១:២៨** *សាសន៍មេឌី* សូមមើលការពន្យល់ ខ.១១ ។ *ព្រមទាំងស្រុកទាំងមូលដែលក្រោមអំណាចគេ* មើលការពន្យល់ ៣៤:១ និងមើល ១ពវ ៩:១៩ ។

**៥១:២៩** *ផែនដីកំពុងញាប់ញ័រ* គឺជាការបង្ហាញពីទស្សនៈភ័យខ្លាចក្នុងសង្គ្រាម ។

**៥១:៣០** *គេស្បើយហើយ . . . ស្រីវិញ* បើក្នុងគម្ពីរភាសាហេព្រើរមានការសម្តែងពីពាក្យនេះ ។ *ក៏បានត្រឡប់ដូចជាស្រីវិញ* សូមមើលការពន្យល់ ៥០:៣៧ ណាហ ៣:១៣ និងការពន្យល់ ។

**៥១:៣១** *អ្នកយាមនឹងរត់ច្រវាត់ទៅមក* គឺពួកអ្នកយាមជាប្រជារាស្ត្របានទៅព្រះរាជ្យដំណាក់ដែលចេញពីគ្រប់ផ្នែកនៃទីក្រុង ។

**៥១:៣២** *ឯផ្លូវទឹក* ជាកន្លែងចម្លង ឬដើរឆ្លងក្នុងទឹក និងជាសាឡាងសម្រាប់ឆ្លង (ក៏អាចជាស្ពានចម្លង) ។ *វាលបឹងគេដុតអស់ទៅ* គឺជាការបំផ្លាញរុក្ខជាតិតូចៗ ដូចជាដើមត្រែងជាដើម ។

**៥១:៣៣** *កូនស្រីនៃក្រុងបាប៊ីឡូន* គឺជាការបង្ហាញពីលក្ខណៈសម្បត្តិរបស់ទីក្រុងបាប៊ីឡូន (សូមមើលការពន្យល់ ២ពវ ១៩:២១) ។ *លានស្រូវ* ដូចជាការហិនវិនាសរបស់ទីក្រុង ឬក៏ជាតិសាសន៍គឺជារឿយៗ ត្រូវបានគេពណ៌នាប្រៀបប្រដូចជាការប្រមូលផល (សូមមើល អស ២៧:១២ យអ ៣:១៣ និងការពន្យល់ មីក ៤:១២-១៣ ប្រៀបនឹង វវ ១៤:១៤-២០ និងការពន្យល់ ១៤:១៥) ។

**៥១:៣៤** *សត្វសំបើម* បើជាគម្ពីរភាសាហេព្រើរ ចំពោះពាក្យនេះគេបានបកប្រែថា "សត្វចម្លែក" មានក្នុង អស ៥១:៩ គឺជានិមិត្តសញ្ញាពួកអេស៊ីព្ទ (សូមមើល លប ១:២១ និងការពន្យល់) ។

**៥១:៣៥** *សាច់* សូមមើល លប ៤៩:២០ ។

**៥១:៣៦** *សងសឹកជំនួសឯង* សូមមើល ៦:១១ និងការពន្យល់ ៥០:១៥ ។

អញនឹងកាន់ក្ដីឯង[ល] ហើយនឹងសងសឹកជំនួសឯង អញនឹង
ពង្រីង[ស]សមុទ្រគេទៅ ហើយធ្វើឱ្យរន្ធទឹករបស់គេស្ងួតដែរ
៣៧ ឯក្រុងបាប៊ីឡូននឹងត្រឡប់ជាកងគំនរ ជាទីលំនៅ[ហ]របស់
សត្វស្វាន ជាទីស្រឡាំងកាំង ហើយជាទីដែលគេធ្វើស៊ីស
ស៊ូសឱ្យ[ឡ] ឥតមានអ្នកណានៅឡើយ[អ] ៣៨ គេនឹងស្រែកជា
មួយគ្នា ដូចជាសិង្ហស្ទាវ[ក] គេនឹងគ្រហឹមដូចជាកូនសិង្ហ
៣៩ កាលណាគេក្ដៅខ្លួន នោះអញនឹងរៀបជប់លៀងឱ្យគេ
អញនឹងធ្វើឱ្យគេស្រវឹង[ខ] ដើម្បីឱ្យគេបានរីករាយចិត្ត ហើយ
ឱ្យដេកលក់ទៅជានិច្ច[គ] ឥតភ្ញាក់ឡើងវិញឡើយ នេះជា
ព្រះបន្ទូលនៃព្រះយេហូវ៉ា[ឃ] ៤០ អញនឹងនាំគេចុះទៅដល់ទី
សំឡាប់ ដូចជាកូនចៀមទាំងប៉ុន្មាន គឺដូចជាចៀមឈ្មោល
និងពពែឈ្មោលផង[ង]។

៤១ សេសាក[ច]បានត្រូវចាប់យកយ៉ាងណាហ្ន៎[ឆ] ទីគួរលើក
សរសើររបស់ផែនដីទាំងមូល ត្រូវចាប់បានយ៉ាងណាហ្ន៎
អើ បាប៊ីឡូន បានទៅជាទីស្ងាត់ច្រៀប[ជ] នៅកណ្ដាល
អស់ទាំងសាសន៍យ៉ាងណាហ្ន៎ ៤២ សមុទ្របានឡើងមកលើ
ស្រុកបាប៊ីឡូន វាត្រូវគ្របដោយរលកដ៏ក្រាស់ក្រៃ[ឈ] ៤៣ ទី
ក្រុងទាំងប៉ុន្មាន បានត្រឡប់ជាទីស្ងាត់ច្រៀប[ញ] ជាដីហួត
ហែង ជាវាលស្ងាត់ ជាទីដែលឥតមាអ្នកណានៅហើយ
គ្មានមនុស្សជាតិណាមួយដើរតាមនោះឡើយ[ដ] ៤៤ អញនឹង
ធ្វើទោសដល់ព្រះបាល[ឋ] នៅស្រុកបាប៊ីឡូន ហើយនឹងធ្វើឱ្យ
របស់ទាំងប៉ុន្មាន ដែលវាបានលេបទៅ បានចេញពីមាត់
មកវិញ[ឌ] នោះអស់ទាំងសាសន៍នឹងលែងទៅជាហូរហែរក
វាទៀត ហើយកំផែង[ឍ]នៃក្រុងបាប៊ីឡូននឹងរំលំចុះ ។

៤៥ ឱរាស្ត្រអញអើយ ចូរចេញ[ណ]ពីកណ្ដាលពួកគេទៅ
ត្រូវឱ្យគ្រប់គ្នាដោះ[ត]ខ្លួន ឱ្យរួចពីសេចក្ដីខ្ញាល់ដ៏សហ័ស[ថ]
របស់ព្រះយេហូវ៉ា ៤៦ កុំឱ្យឯងរាល់គ្នាស្រយុតចិត្ត[ទ]ឡើយ ក៏
កុំឱ្យភ័យខ្លាច[ធ]ចំពោះដំណឹងដែលឮនៅក្នុងស្រុកដែរ ដ្បិត
នៅឆ្នាំ១ នឹងមានឮសំណឹង[ន]មកដល់ រួចដល់ឆ្នាំក្រោយ ក៏
នឹងឮដំណឹង១ទៀតព្រមទាំងមានការយុកយាក់នៅក្នុងស្រុក
ផង គឺជាស្ដេច១ទាស់នឹងស្ដេច១ទៀត ៤៧ ហេតុនោះ មើល
នឹងមានគ្រាមកដល់ ដែលអញនឹងសំរេចទោសដល់អស់
ទាំងរូបឆ្លាក់[ប]របស់ស្រុកបាប៊ីឡូន ហើយស្រុកទាំងមូលនឹង
ត្រូវជ្រប់មុខ[ផ] ឯពួកអ្នកទាំងប៉ុន្មាន ដែលត្រូវគេសំឡាប់
នោះ និងដួលនៅកណ្ដាលវាល[ព] ៤៨ គ្រានោះទាំងផ្ទៃមេឃ
ហើយផែនដី និងរបស់សព្វសារពើដែលនៅស្ថាន ទាំង
នោះ និងច្រៀង[ភ]អរសប្បាយ ពីដំណើរក្រុងបាប៊ីឡូន
ពីព្រោះពួកបំផ្លាញ[ម]នឹងមកដល់វា ពីទិសខាងជើង[យ] នេះជា
ព្រះបន្ទូលនៃព្រះយេហូវ៉ា ៤៩ រីឯក្រុងបាប៊ីឡូនបានធ្វើឱ្យ
សាសន៍អ៊ីស្រាអែលដួលស្លាប់ទៅយ៉ាងណា នោះពួកអ្នក
ស្រុកទាំងមូលនឹងត្រូវដួលស្លាប់ នៅត្រង់ក្រុងបាប៊ីឡូនយ៉ាង

**៥១:៣៦** ល ទដ ១៤០:១២ យរ ៥០:៣៤ បទ ៣:៥៨ វ ខ.៦ យរ ២០:១២ រម ១២:១៩ ស អស ១១:១៥ ១៩:៥ ហស ១៣:១៥ **៥១:៣៧** ហ អស ១៣:២២ វវ ១៨:២ ឡ ណហ ៣:៦ មឡ ២:៩ អ យរ ៥០:១៣,៣៩ **៥១:៣៨** ក អស ៥:២៩ **៥១:៣៩** ខ អស ២១:៥ គ ទដ ១៣:៣ ឃ ខ.៥៧ យរ ៥០:២៤ **៥១:៤០** ង អគ ៣៩:១៨ **៥១:៤១** ច យរ ២៥:២៦ ឆ អស ១៣:១៩ ជ យរ ៥០:១៣ **៥១:៤២** ឈ ទដ ១៨:៤ អស ៨:៧ **៥១:៤៣** ញ អស ២១:១ ដ ខ.២៩,៦២ អស ១៣:២០ យរ ២:៦

**៥១:៤៤** ឋ អស ២១:៩ ៤៦:១ ឌ ខ.៣៤ ឍ ខ.៥៨ ២ពវ ២៥:៤ អស ២៥:១២ យរ ៥០:១៥ **៥១:៤៥** ណ ខ.៥០ ត អស ៤៨:២០ ថ ទដ ៧៦:១០ ៧៩:៦ **៥១:៤៦** ទ ទដ ១៨:៤៥ ធ យរ ៤៦:២៧ ន ២ពវ ១៩:៧ **៥១:៤៧** ប អស ៤៦:១-២ យរ ៥០:២ ផ យរ ៥០:១២ ព យរ ២៧:៧ **៥១:៤៨** ភ យប ៣:៧ ទដ ១៤៩:២ វវ ១៨:២០ ម ខ.៥៣,៥៦ យ ខ.១១ អស ៤១:២៥ យរ ២៥:២៦

*សមុទ្រ . . . រន្ធទឹក* មើលការពន្យល់ ខ.១៣ ។ ក្រុងបាប៊ីឡូនត្រូវបានគេហៅថា "វាលខ្យល់ក្បែរសមុទ្រ" ក្នុង អស ២១:១ (មើលការពន្យល់ ២១:១) ។

**៥១:៣៧** សូមមើល ៩:១១ ១៨:១៦ និងការពន្យល់ ។

**៥១:៣៨** *គ្រហឹមដូចជាកូនសិង្ហ* សូមមើល ២:១៥ និងការពន្យល់ ។

**៥១:៣៩** *ក្ដៅខ្លួន* តាមអក្សរសាស្ត្រ"មានកម្ដៅ" ដែលមានលក្ខណៈស្រដៀង ហស ៧:៤-៧ ។ *គេស្រវឹង* សូមមើល ខ.៥៧ និងការពន្យល់ ២៥:១៥-១៦,២៦ ។

**៥១:៤០** *កូនចៀម . . . ដូចជាចៀមឈ្មោលនឹងពពែឈ្មោលផង* ជានិមិត្តតំណាងប្រជាជន (សូមមើល អស ៣៤:៦ អគ ៣៩:១៨) នៃស្រុកបាប៊ីឡូន ។ *សំឡាប់* សូមមើល អស ៥៣:៧ និងការពន្យល់ ។

**៥១:៤១** *សេសាក* សូមមើលការពន្យល់ ២៥:២៦ ។ តាមឯកសាពាក្យសេសាកជាពាក្យមានន័យស្មើនឹងបាប៊ីឡូន ។

**៥១:៤២** *សមុទ្រ . . . រលកដ៏ក្រាស់ក្រៃ* សូមមើល អស ១៧:២១ និងការពន្យល់ និងមើលក្នុង ខ.៥៥ មានសត្រូវរបស់បាប៊ីឡូន (សូមមើល ៤៦:៧ និងការពន្យល់) ។

**៥១:៤៣** សូមមើល ៤៨:៩ ៤៩:១៨,៣៣ ៥០:១២-១៣ ។

**៥១:៤៤** *ព្រះបាល* សូមមើល ៥០:២ អស ៤៦:១ និងការពន្យល់ ។ *វាបានលេបទៅ បានចេញពីមាត់វិញ* គឺជាប្រជាជនដែលបានចាប់ជាឈ្លើយ (ក៏មានបញ្ចូលទាំងពួកយូដា) ក៏មានការប្លន់យកទ្រព្យសម្បត្តិ (មានដូចជាប្រភពសំខាន់ដែលជាសរសៃឈាមចេញពីវិហារក្នុងក្រុងយេរូសាឡិម សូមមើល ដយ ៥:២-៣) ។ *កំផែងនៃក្រុងបាប៊ីឡូន* គឺជាកំផែងដែលសាងសង់ឡើងមានលក្ខណៈភ្លោះពីជិតគ្នា ឯកំផែងខាងក្រៅ (មានទទឹងកម្រាស ៣.៦៦ ម៉ែត្រ) ក៏មានលក្ខណៈញែកដាច់ដោយឡែកពីកំផែងខាងក្នុង (មានកម្រាស់ទទឹង ១២.៨៣ ម៉ែត្រ) ដែលគេញែកដាច់ពីផ្នែកខាងក្នុងនៃកំផែង ។

**៥១:៤៥** *ចូរចេញពីកណ្ដាលពួកគេ* សូមមើលការពន្យល់ ខ.៦ ។ *សេចក្ដីខ្ញាល់ដ៏សហាស* សូមមើល ៤:៨,២៦ អស ១៣:១៣ ណហ ១:៦ ។

**៥១:៤៦** *កុំឱ្យឯងរាល់គ្នាស្រយុតចិត្ត . . . ក៏កុំឱ្យភ័យខ្លាច* គឺខណៈពេលមានការថ្លែងពីដើមអូលីវរបស់ផងទ្រង់ដោយព្រះយេស៊ូវ បានថ្លែងពីឃ្លាព្រះបន្ទូលនេះ (សូមមើល មថ ២៤:៦ មក ១៣:៧ លក ២១:៩) ។

**៥១:៤៧** *អញនឹងសំរេចទោសដល់អស់ទាំងរូបឆ្លាក់របស់ស្រុកបាប៊ីឡូន* សូមមើល ខ.៥២ និងការពន្យល់ ៥០:២ ។

**៥១:៤៨** *ទាំងផ្ទៃមេឃ ហើយផែនដី . . . និងច្រៀងអរសប្បាយ* មើល អស ៤៤:២៣ វវ ១៨:២០ ១៩:១៣ ។ *ពីទិសខាងជើង* មើលការពន្យល់ ៥០:៣ ។

**៥១:៤៩** សូមមើលការពន្យល់ ២៥:២៦ ។

នោះដែរ[រ] ។
៥០នៃ ឯងរាល់គ្នា ដែលបានរួចពីដាវអើយចូរទៅ[ល]ចុះ
កុំបង្អង់ឡើយ ចូរនឹក[វ]ដល់ព្រះយេហូវ៉ាពីទីចំងាយ[ស] ហើយ
ឱ្យក្រុងយេរូសាឡិមចូលក្នុងគំនិតឯងដែរ ៥១យើងរាល់
គ្នាត្រូវខ្មាស[ហ] ដោយបានឮពាក្យត្មះតិះដៀល យើងរាល់
គ្នាបានឡើងមុខក្រហមហើយ ដ្បិតមានសាសន៍ដទៃចូល
ទៅក្នុងទីបរិសុទ្ធរបស់ព្រះវិហារនៃព្រះយេហូវ៉ា[ឡ] ៥២ហេតុ
នោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មើល នឹងមានគ្រា
មកដល់ ដែលអញនឹងសំរេចទោស ដល់អស់ទាំងរូបឆ្លាក់
របស់គេ[អ] ហើយពួកគេដែលត្រូវរបួសក៏នឹងថ្ងូរ នៅពេញ
ក្នុងស្រុក[ក] ៥៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ទោះបើក្រុង
បាប៊ីឡូននឹងលើកខ្លួនឡើងដល់ផ្ទៃមេឃ[ខ] ហើយចំរើន
កំឡាំងនៃទីខ្ពស់របស់គេ ឱ្យរឹងរឹតតែមាំមួនឡើងក៏ដោយ
គង់តែអញនឹងឱ្យពួកបំផ្លាញ[គ]ឡើងទៅដល់គេដែរ ។
៥៤មានឮសូរសំរែក[ឃ]ចេញពីក្រុងបាប៊ីឡូនមក និងសូរ
នៃការបំផ្លាញ[ង]យ៉ាងសំបើម មកពីស្រុករបស់ពួកខាល់ដេ
៥៥ដ្បិតព្រះយេហូវ៉ាទ្រង់រំលាងក្រុងបាប៊ីឡូន ហើយក៏
បំផ្លាញសំឡេង[ច]យ៉ាងធំឱ្យបាត់ចេញពីវាទៅ រលក[ឆ]គេឮ
សន្ធឹកដូចជាទឹកធំ ក៏ឮសូររបស់គេចេញមក ៥៦ដ្បិតមេ
បំផ្លាញ[ជ]បានមកលើវាហើយ គឺលើក្រុងបាប៊ីឡូន ពួកខ្លាំង
ពូកែរបស់វាត្រូវគេចាប់បាន ហើយធ្នូទាំងប៉ុន្មានរបស់គេ
ត្រូវបាក់ខ្ទេចខ្ទី[ឈ] ពីព្រោះព្រះយេហូវ៉ាទ្រង់ជាព្រះដែល
សងសំណង ទ្រង់នឹងតបស្នង[ញ]ជាមិនខាន ៥៧ឯពួកមេទ័ព[ដ]
ពួកអ្នកប្រាជ្ញ[ឋ] ពួកចៅហ្វាយ ពួកនាយ និងពួកមនុស្សខ្លាំង
ពូកែទាំងប៉ុន្មានរបស់វា នោះអញនឹងធ្វើឱ្យស្រវឹង[ឌ] គេនឹង
ដេកលក់[ឍ]ទៅជារៀងរាបដរាប ឥតភ្ញាក់ឡើងវិញឡើយ
នេះជាព្រះបន្ទូលនៃមហាក្សត្រ[ណ] ដែលព្រះនាមទ្រង់ជាព្រះ
យេហូវ៉ានៃពួកពលបរិវារ ៥៨ព្រះយេហូវ៉ានៃពួកពល
បរិវារទ្រង់មានបន្ទូលថា កំផែង[ត]យ៉ាងក្រាស់របស់ក្រុង
បាប៊ីឡូននឹងត្រូវរលំអស់រលីង ហើយទ្វារ[ថ]ដ៏ខ្ពស់ទាំងប៉ុន្មាន
នឹងត្រូវភ្លើងឆេះ គឺយ៉ាងនោះដែលជនជាតិ[ទ]ទាំងឡាយ
បានខំធ្វើការ[ធ]ឱ្យតែបានទទេៗ ហើយសាសន៍ទាំងប៉ុន្មាន
ឱ្យតែបានជាចំណីភ្លើងដែរ[ន] គេនឹងនឿយហត់ទៅ ។
៥៩នេះជាពាក្យ ដែលហោរាយេរេមាបានផ្តាំ ដល់
សេរ៉ាយ៉ា ជាកូននេរីយ៉ា[ប] ដែលជាកូនម៉ាសេយ៉ា ក្នុងកាល
ដែលលោកបានទៅឯក្រុងបាប៊ីឡូន ជាមួយនឹងសេដេគា[ផ]
ស្តេចយូដា នៅឆ្នាំទី៤[ព]ក្នុងរាជ្យទ្រង់ រីឯសេរ៉ាយ៉ានេះ
លោកជាចៅហ្វាយស្ងួតល្អ ៦០យេរេមាក៏សរសេរចុះក្នុង
សៀវភៅ[ភ] ពីគ្រប់ទាំងការអាក្រក់ ដែលត្រូវកើតដល់ក្រុង
បាប៊ីឡូន គឺគ្រប់ទាំងពាក្យទាំងនេះដែលបានកត់ទុកពី
ដំណើរក្រុងបាប៊ីឡូនហើយ ៦១យេរេមាក៏ជំរាបសេរ៉ាយ៉ា
ថាកាលណាលោកទៅដល់ក្រុងបាប៊ីឡូនហើយ នោះត្រូវ
ឱ្យលោកអានមើលអស់ទាំងព្រះបន្ទូលនេះ ៦២បន្ទាប់មក

**៥១:៤៩** រ ទដ ១៣៧:៨ យរ ៥០:២៩
**៥១:៥០** ល ខ.៤៥ វ ទដ ១៣៧:៦ ស យរ ២៣:២៣
**៥១:៥១** ហ ទដ ៤៤:១៣–១៦ ៧៩:៤ ឡ បទ ១:១០
**៥១:៥២** អ ខ.៤៧ ក យប ២៤:១២
**៥១:៥៣** ខ លប ១១:៤ អស ១៤:១៣–១៤ គ ខ.៤៨ យប ១៥:២១
**៥១:៥៤** ឃ យប ២៤:១២ ង យប ៥០:២២
**៥១:៥៥** ច យប ២៤:១២ ឆ ទដ ១៨:៤
**៥១:៥៦** ជ ខ.៤៨ យប ១៥:២១ ឈ ទដ ៤៦:៩ ញ ខ.៦ លប ៤:២៤ ចទ ៣២:៤១ ទដ ៩៤:១–២ ហព ២:៨
**៥១:៥៧** ដ ខ.២៣ ឋ យប ៥:១៣ ឌ អស ២១:៥ ឍ ខ.៣៩ ទដ ៧៦:៥ យរ ២៥:២៧ ណ អស ៦:៥
**៥១:៥៨** ត ខ.៤៤ ២ពវ ២៥:៤ អស ១៥:១ ថ អស ១៣:២ ទ ខ.៦៤ ធ អស ៤៧:១៣ ន អស ៤៧:១៤
**៥១:៥៩** ប យរ ៣៦:៤ ផ យរ ៥២:១ ព យរ ២៨:១
**៥១:៦០** ភ នក ១៧:១៤ យរ ៣០:២ ៣៦:២

**៥១:៥០** *ចូរទៅចុះ* សូមមើលការពន្យល់ ខ.៦ ។
**៥១:៥១** *សាសន៍ដទៃចូលទៅក្នុងទីបរិសុទ្ធ* គឺសំដៅទៅលើការដើរជាក្បួនរបស់ពួកស្តេចនៃប៊ីក្មេសា នៅឯព្រះវិហារក្រុងយេរូសាឡិមក្នុងឆ្នាំ ៥៨៥ មុន គ.ស ដូចគ្នានឹងការប្រមាថ ដែលពួកក្រុងអាន់ទីយ៉ូក បានធ្វើនាឆ្នាំ ១៦៨ មុន គ.ស និងក្នុងឆ្នាំ ៧០ ស.គ ។
**៥១:៥៣** *ឡើងដល់ផ្ទៃមេឃ* សូមមើល លប ១១:៤ និងការពន្យល់ អស ១៤:២៣–៣ ។ *ពួកបំផ្លាញ* សូមមើល ៤៨:៥៦ ។
**៥១:៥៤** មើល ៥០:៤៦ ។ *ការបំផ្លាញយ៉ាងសំបើម* មើលការពន្យល់ ៤:៦ ។
**៥១:៥៥** *រលក* សូមមើលការពន្យល់ ខ.៤២ ។ *ដូចជាទឹកធំ* សូមមើលការពន្យល់ ទដ ៣២:៦ ។
**៥១:៥៦** *ព្រះដែលសងសំណង* សូមមើលការពន្យល់ ខ.២៤ ។
**៥១:៥៧** *ឯពួកមេទ័ព ពួកអ្នកប្រាជ្ញ* មើល ៥០:៣៥ ។ *ស្រវឹង* មើល ខ.៣៩ ឬមើលការពន្យល់ ២៥:១៥–១៦,២៦ ។ *មហាក្សត្រ* សូមមើល ការពន្យល់ ៤៦:១៨ ។ ព្រះមហាក្សត្រដ៏ពិតប្រាកដគឺជាព្រះយេហូវ៉ា មិនមែនព្រះបាល ឬរូបព្រះម៉ាដាក់ទេ (សូមមើល ៥០:២ និងការពន្យល់) ។
**៥១:៥៨** *កំផែងយ៉ាងក្រាស់* សូមមើលការពន្យល់ ខ.៤៤ ។ *ទ្វារដ៏ខ្ពស់* គឺជាទ្វារដ៏មានភាពល្បីល្បាញ គឺមានកំពស់ប្រវែង ១២.១៦ ម៉ែត្រ ។ *ហើយសាសន៍ទាំងប៉ុន្មានឱ្យតែបានជាចំណីភ្លើង* ជាហេតុការណ៍មានលក្ខណៈស្រដៀងនឹងគម្ពីរ ហាប ២:១៣ ។
**៥១:៥៩–៦៤** ជាសេចក្តីបញ្ជាក់ដែលពណ៌នាយ៉ាងលំអិតក្នុងគម្ពីរ ចំពោះសេចក្តីទំនាយដែលទាស់ប្រឆាំងនឹងពួកសាសន៍បាប៊ីឡូន ។
**៥១:៥៩** *ចៅហ្វាយស្ងួតល្អ* (សូមមើល ជន ១០:៣៣) ។ គឺជាអ្នកទទួលបន្ទុកចាត់ចែងការស្វែងរកទីកន្លែងសម្រាក ខណៈពេលដែលទាហានរបស់គេកំពុងធ្វើដំណើរតាមផ្លូវ ជាពិសេសការឈប់សម្រាកនៅពេលយប់ ។ *សេរ៉ាយ៉ាជាកូននេរីយ៉ា* ជាឈ្មោះដែលបានឃើញនៅលើត្រាសម័យបុរាណដែលបានចារក្នុងសិលាចារិក "ជាកម្មសិទ្ធរបស់សេរ៉ាយ៉ាជាកូននេរីយ៉ា" ក៏មានអំណាស់អំណាងយ៉ាងច្បាស់អំពីមនុស្សបានបង្ហាញនៅទីនោះ ។ គាត់គឺជាបងប្រុសរបស់លេខាធិការយេរេមា គឺបារូត (សូមមើល ៣២:១២) ។ *សេដេគាស្តេចយូដា នៅឆ្នាំទី៤ក្នុងរាជ្យទ្រង់* គឺឆ្នាំ ៥៩៣ មុន គ.ស ។ ឯស្តេចសេដេគា ត្រូវបានស្តេចនៃប៊ីក្មេសាកោះហៅឱ្យចូលទៅក្រុងបាប៊ីឡូនដើម្បីសួរដេញដោល (សូមមើលការពន្យល់ ២៧:៣) ។
**៥១:៦០** *សៀវភៅ* សូមមើលការពន្យល់ នក ១៧:១៤ ។ *គឺគ្រប់ពាក្យទាំងនេះដែលបានកត់ទុកពីដំណើរក្រុងបាប៊ីឡូនហើយ* គឺវាមានលក្ខណៈបទទំនាយមានក្នុង ៥០:២–៥១:៥៨ (សូមមើលការពន្យល់ ៥០:១) ។

ត្រូវថា ឱព្រះយេហូវ៉ាអើយ ទ្រង់បានមានបន្ទូលសេចក្តីទាំង
នេះពីដំណើរទីនេះ ដើម្បីនឹងកាត់ចេញ ឱ្យឥតមានអ្វីនៅ
ទៀតឡើយ ទោះមនុស្សឬសត្វក្តី គឺឱ្យទីនេះបាននៅចោល
ស្ងាត់[ម]ជារៀងរាបដរាបទៅ ៦៣រួចកាលណាលោកអាន
មើលសៀវភៅនេះសព្វគ្រប់ហើយ នោះត្រូវយកថ្មមកចង
ភ្ជាប់ ហើយបោះទំលាក់ទៅកណ្តាលទន្លេអើប្រាតទៅ[យ]
៦៤រួចត្រូវថា ក្រុងបាប៊ីឡូននឹងលិចបាត់យ៉ាងដូច្នេះដែរ ឥត
ដែលងើបឡើងវិញឡើយ[រ] ដោយព្រោះការអាក្រក់ដែល
អញនឹងនាំមកលើវា នោះគេ[ល]នឹងនឿយហត់ទៅ[វ] ។

ពាក្យរបស់យេរេមាចប់[ស]តែប៉ុណ្ណោះ ។

## ការដួលរលំនៃក្រុងយេរូសាឡិម

*៥២:១–៣ – ២ពវ ២៤:១៨–២០ ២រប ៣៦:១១–១៦*

*៥២:៤–១៦ – យរ ៣៩:១–១០*

*៥២:៤–២១ – ២ពវ ២៥:១–២១ ២រប ៣៦:១៧–២០*

**៥២** ១លុះកាលសេដេគា[ក]ចាប់តាំងសោយរាជ្យឡើង
នោះទ្រង់មានព្រះជន្ម២១ឆ្នាំហើយ ទ្រង់ក៏សោយរាជ្យ
នៅក្រុងយេរូសាឡិមបានគ្រប់១១ឆ្នាំ ព្រះមាតាទ្រង់នាម
ជាហាមូថាល ជាបុត្រីយេរេមាដែលនៅក្រុងលិបណា[ខ]
២ទ្រង់បានប្រព្រឹត្តអំពើដ៏លាមកអាក្រក់ នៅព្រះនេត្រព្រះ
យេហូវ៉ាតាមគ្រប់ទាំងការដែលយេហូយ៉ាគីម[គ]បានធ្វើ
៣គឺហេតុនោះបានជាសេចក្តីខ្ញាល់នៃព្រះយេហូវ៉ាកើត
ឡើង ដល់ក្រុងយេរូសាឡិម និងស្រុកយូដា[ឃ] ទាល់តែទ្រង់
បានបោះ បង់ចោលគេចេញពីចំពោះទ្រង់ទៅ[ង] ឯសេដេគា
ក៏បះបោរ[ច]នឹងស្តេចបាប៊ីឡូនដែរ ។

៤ដល់ឆ្នាំទី៩ក្នុងរាជ្យទ្រង់ គឺនៅថ្ងៃ១០[ឆ] ខែបុស្សនោះ
នេប៊ូក្នេសា ជាស្តេចបាប៊ីឡូន ព្រមទាំងពលទ័ពរបស់ទ្រង់
ទាំងប៉ុន្មាន ក៏មកបោះទ័ពច្បាំងនឹងក្រុងយេរូសាឡិម[ជ] គេ
តាំងបន្ទាយ[ឈ]ប្រទល់មុខនឹងទីក្រុងជុំវិញ[ញ] ៥យ៉ាងនោះ
ទីក្រុងត្រូវគេឡោមព័ទ្ធ ដរាបដល់ឆ្នាំទី១១ក្នុងរាជ្យស្តេច
សេដេគា ៦លុះដល់ថ្ងៃ៩ខែអាសាធ នោះនៅក្នុងទីក្រុងមាន
អំណត់ជាខ្លាំងណាស់ ដល់ម្ល៉េះបានជាគ្មានអាហារសំរាប់
បណ្តាជនសោះ[ដ] ៧នៅគ្រានោះ គេទំលាយកំផែងទីក្រុងបាន
រួចពួកទាហានទាំងអស់ក៏រត់ចេញ[ឋ]ពីទីក្រុងទាំងយប់ទៅ
តាមផ្លូវទ្វារកណ្តាលកំផែងទាំង២ ដែលនៅជិតច្បារស្តេច
ហើយគេរត់ដំរង់ទៅឯស្រុកវាល (ចំណែកពួកខាល់ដេគេ
នៅឡោមព័ទ្ធទីក្រុង) ៨ប៉ុន្តែពលទ័ពសាសន៍ខាល់ដេ គេ
ដេញតាមសេដេគាទាន់ នៅត្រង់វាលយេរីខូរ ហើយបណ្តា
ទ័ពរបស់ទ្រង់ត្រូវខ្ចាត់ខ្ចាយពីទ្រង់អស់ទៅ ៩គេចាប់ស្តេច[ឌ]
នាំទៅឯស្តេចបាប៊ីឡូន ត្រង់ក្រុងរីបឡា[ឍ]ក្នុងស្រុកហាម៉ាត[ណ]
ស្តេចបាប៊ីឡូនក៏កាត់ទោសដល់ទ្រង់ ១០ហើយសំឡាប់ពួក
បុត្រា[ត]នៃសេដេគា នៅចំពោះព្រះនេត្រទ្រង់ ក៏សំឡាប់
អស់ទាំងចៅហ្វាយរបស់ស្រុកយូដា នៅត្រង់រីបឡាដែរ
១១ហើយ ចាក់បង្ខូចព្រះនេត្ររបស់សេដេគា រួចមកស្តេច
បាប៊ីឡូនដាក់ច្រវាក់លង្ហិន នាំយកទៅដល់ក្រុងបាប៊ីឡូន
ឃុំទុកនៅក្នុងគុក ដរាបដល់ថ្ងៃសុគត[ថ] ។

១២រីឯនៅថ្ងៃខែស្រាពណ៍[ទ] ក្នុងឆ្នាំទី១៩ នៃរាជ្យ
នេប៊ូក្នេសា[ធ] ជាស្តេចបាប៊ីឡូន នោះនេប៊ូសារ៉ាដានជា
មេទ័ពធំ ដែលឈរនៅចំពោះស្តេចបាប៊ីឡូន លោកចូល
មកក្នុងក្រុងយេរូសាឡិម ១៣ក៏ដុត[ន]ព្រះវិហារ[ប]នៃព្រះ
យេហូវ៉ានឹងដំណាក់ស្តេច ព្រមទាំងបណ្តាផ្ទះ[ផ]នៅក្រុង
យេរូសាឡិមផង គឺលោកដុតអស់ទាំងផ្ទះធំៗចោល ១៤ឯ
ពួកទ័ពសាសន៍ខាល់ដេទាំងប៉ុន្មាន ដែលនៅជាមួយនឹង
មេទ័ពធំ គេក៏មករំលំកំផែង[ព]នៃទីក្រុងយេរូសាឡិមគ្រប់

**៥១:៦២** ម អស ១៣:២០ យរ ៩:១១ ៥០:១៣,៣៩ **៥១:៦៣** យ លប ២:១៤ **៥១:៦៤** រ អក ២៦:២១ ២៨:១៩ ល ខ.៥៨ វ វវ ១៨:២១ ស យប ៣១:៤០ **៥២:១** ក ២ពវ ២៤:១៧ ខ ជន ៣៣:២០ យស ១០:២៩ ២ពវ ៨:២២ **៥២:២** គ យរ ៣៦:៣០ **៥២:៣** ឃ អស ៣:១ ង លប ៤:១៤ នក ៣៣:១៥ ច នក ១៧:១២–១៦ **៥២:៤** ឆ សក ៨:១៩ ជ យរ ៣៤:១ ឈ យរ ៦:៦ ញ អក ២៤:១–២ **៥២:៦** ដ លវ ២៦:២៦ អស ៣:១ បទ ១:១១ **៥២:៧** ឋ បទ ៤:១៩ **៥២:៩** ឌ យរ ២១:៧ ៣២:៤ ឍ ជន ៣៤:១១ ណ ជន ១៣:២១ **៥២:១០** ត យរ ២២:៣០ **៥២:១១** ថ យរ ៣៤:៤ អក ១២:១៣

១៧:១៦ **៥២:១២** ទ សក ៧:៥ ៨:១៩ ធ ខ.២៦ **៥២:១៣** ន ២រប ៣៦:១៩ ទដ ៧៤:៨ បទ ២:៦ ប ចទ ២៩:២៤ ទដ ៧៩:១ មីក ៣:១២ ផ ចទ ១៣:១៦ យរ ១៩:១៣ **៥២:១៤** ព នហ ១:៣ បទ ២:៨

**៥១:៦២** *ទ្រង់បានមានបន្ទូល* សូមមើល ខ.២៦ ។

**៥១:៥៤** *ពាក្យរបស់យេរេមាចប់តែប៉ុណ្ណោះ* គឺជាការកត់ត្រាចំណាំដោយអ្នកកត់ត្រាប្រវត្តិសាស្ត្រទាំងមូល ដែលបានបញ្ចប់ព្រះគម្ពីរយេរេមា (សូមមើល ៤៨:៤៧) ។

**៥២:១–២៧,៣១–៣៤** ជាហេតុការដូចគ្នាស្ទើតែចំៗឥតល្អៀងនៅក្នុង ២ពវ ២៤:១៨–២៥:២១,២៧–៣០ (សូមមើលការពន្យល់គម្ពីរនោះផងដែរ) ។ (៥២:៤–២៧ ក៏បានសង្ខេបនៅក្នុង ៣៩:១–១០ និងមើលការពន្យល់) អ្នកនិងពន្ធរបស់គម្ពីរពង្សាវតារក្សត្រ និងអ្នកនិពន្ធព្រះគម្ពីរយេរេមា (គឺប្រហែលជាលោកបារូក) ក៏គ្មានសង្ស័យឡើយដោយមានតម្រុយបង្ហាញពីប្រភពដូចគ្នាខ្លះៗ ។ វាមិនគួរឱ្យជឿសោះដែលផ្នែករឿងទាំងពីបានចម្លងពីគ្នាដោយកំឡុងពេលនោះកិច្ចការនិមួយៗ មានលក្ខណៈខុសៗគ្នាដោយកិច្ចការមានលក្ខណៈធំ ។ ជាការបញ្ជាក់តាមការប្រៀបធៀប តាមលក្ខណៈអត្ថបទខ្លះគឺគម្ពីរយេរេមា គឺមានលក្ខណៈពេញលេញច្រើនជាព្រះគម្ពីរពង្សាវតារក្សត្រ (សូមធៀប ខ.១០–១១ និង ២ពវ ២៥:៧ ខ.១៥ និង ២ពវ ២៥:១១ ខ.១៩–២៣ និង ២ពវ ២៥:១៥–១៧ ខ.៣១ និង ២ពវ ២៥:២៧ ខ.៣៤ និង ២ពវ ២៥:៣០) ។

**៥២:១** *យេរេមា* យេរេមាទីនេះមិនមែនជាហោរាទេ ។ *ក្រុងលិបណា* មើលការពន្យល់ ២ពវ ៨:២២ ។

**៥២:១២** *នៅថ្ងៃ១០* គឺស្របគ្នាទៅនឹង ២ពវ ២៥:៨ អានត្រង់"ថ្ងៃទី៧" មានលេខមួយបានចំលង "ខុស" ប៉ុន្តែយើងពុំអាចថាមួយណាបានទេ (មើល ខ.២២,២៥,៣១ និងការពន្យល់) ។

ជុំវិញ ១៥រួចនេប៊ូសារ៉ាដាន ជាមេទ័ពធំ លោកនាំ[ភ]ពួក
ក្រីក្របំផុតក្នុងបណ្ដាជន និងសំណល់មនុស្សដែលនៅ
ក្នុងទីក្រុង ព្រមទាំងពួកអ្នកដែលបានរវាតចូល[ម]ទៅខាង
ស្ដេចបាប៊ីឡូន និងសំណល់នៃមនុស្សទៅជាឈ្លើយ ១៦តែ
នេប៊ូសារ៉ាដាន ជាមេទ័ពធំ លោកទុក[យ]ពួកអ្នកក្រីក្រ
ខ្លះនៃស្រុកនោះ ឱ្យថែចំការទំពាំងបាយជូរ ហើយភ្ជួររាស់
ដី ។

១៧ឯសសរលង្ហិន[រ] ដែលនៅក្នុងព្រះវិហារនៃព្រះ
យេហូវ៉ា និងជើងថ្កល់[ល] ហើយសមុទ្រ[វ]លង្ហិនដែលនៅក្នុង
ព្រះវិហារនៃព្រះយេហូវ៉ា នោះពួកខាល់ដេបំបែកជាដុំៗ
ដឹកយកលង្ហិនទាំងនោះទៅឯស្រុកបាប៊ីឡូនទៅ[ស] ១៨ឯ
កន្ថោរ ចបចូក ឃ្នាបប្រឆេះ បានគោម[ហ] កូនចាន និង
គ្រឿងប្រដាប់លង្ហិនទាំងប៉ុន្មានដែលប្រើសំរាប់គោរព
នោះគេក៏យកទៅដែរ[ឡ] ១៩ហើយទាំងផើង ជើងក្រាន[អ]
ចានគោមកន្ថោរ ជើងចង្កៀង[ក] កូនចាន[ខ] និងពែង[គ] ដែល
ធ្វើពីមាស ហើយដែលធ្វើពីប្រាក់ នោះមេទ័ពក៏យកទៅ
ទាំងអស់[ឃ] ២០ឯសសរទាំង២ សមុទ្រ១ និងគោ[ង]លង្ហិនទាំង
១២ទ្រពីក្រោម ដែលស្ដេចសាឡូម៉ូនបានធ្វើសំរាប់ព្រះ
វិហារនៃព្រះយេហូវ៉ា នោះនឹងថ្លឹងលង្ហិននៃរបស់ទាំង
នោះមិនបានឡើយ[ច] ២១ត្រង់ឯសសរនោះមួយៗ មានកំពស់
១៨ហត្ថ ហើយវាស់ជុំវិញត្រូវជា១២ហត្ថ មានកំរាស់៤ធ្នាប់
មានប្រហោងក្នុង[ឆ] ២២ក៏មានក្បាច់ក្បាលសសរ[ជ]លង្ហិននៅ
ពីលើក្បាលសសរមួយៗ កំពស់៥ហត្ថ មានទាំងក្បាច់ក្រឡា
អួន និងផ្លែទទឹម[ឈ] សុទ្ធតែធ្វើពីលង្ហិននៅជាប់ជុំវិញផង
ហើយសសរទី២ក៏មានក្បាច់ក្រឡាអួន និងផ្លែទទឹមដូចគ្នា
ដែរ ២៣មានផ្លែទទឹម៩៦នៅគ្រប់ជុំវិញ ហើយនឹងផ្លែទទឹម[ញ]
ទាំងអស់ ដែលនៅជាប់នឹងក្បាច់ក្រឡាអួននោះ មានចំនួន
១០០[ដ] ។

២៤មេទ័ពធំក៏យកសេរ៉ាយ៉ា[ឋ] ជាសង្ឃធំ និងសេផានា[ឌ]
ជាសង្ឃទី២ ហើយពួកឆ្មាំទ្វារទាំង៣នាក់[ឍ] ២៥ក៏យកមេ
ម្នាក់ ដែលបានត្រួតលើពលទ័ព ពីក្នុងទីក្រុង និងមនុស្ស
៧នាក់ ដែលធ្លាប់ឃើញព្រះភក្ត្រស្ដេច ដែលឃើញមាន
នៅក្នុងទីក្រុង ហើយស្មៀន[ណ]របស់មេទ័ពធំ ដែលកែណ្ឌ
ពួកអ្នកស្រុក ព្រមទាំងពួកអ្នកស្រុក៦០នាក់ ដែលឃើញ
មាននៅក្នុងទីក្រុងផង ២៦នោះនេប៊ូសារ៉ាដាន[ត] ជាមេទ័ពធំ
លោកនាំអ្នកទាំងនោះ ទៅឯស្ដេចបាប៊ីឡូនត្រង់រីបឡា
២៧ស្ដេចបាប៊ីឡូនក៏ប្រហារជីវិតគេ នៅត្រង់រីបឡា[ថ] ក្នុង
ស្រុកហាម៉ាតទៅ គឺយ៉ាងនោះដែលពួកយូដាត្រូវដឹកនាំ
ចេញ[ទ]ពីស្រុករបស់ខ្លួនទៅជាឈ្លើយ ។

២៨នេះជាពួកបណ្ដាជន ដែលនេប៊ូក្នេសាបានដឹកនាំ
ទៅជាឈ្លើយ[ធ] នៅឆ្នាំទី៧ គឺមានពួកយូដា អស់ចំនួន
៣០២៣នាក់ ២៩នៅឆ្នាំទី១៨នៃនេប៊ូក្នេសា នោះទ្រង់
នាំយកមនុស្សចំនួន៨៣២នាក់ ចេញពីក្រុងយេរូសាឡិម
ទៅជាឈ្លើយ ៣០រួចនៅឆ្នាំទី២៣នៃនេប៊ូក្នេសា នោះ
នេប៊ូសារ៉ាដាន ជាមេទ័ពធំ ក៏នាំយកពួកសាសន៍យូដា
ចំនួន៧៤៥នាក់ទៅជាឈ្លើយ[ន]ទៀត បូករួមមនុស្សទាំងអស់
មានចំនួន៤៦០០នាក់[ប] ។

## ស្ដេចយ៉ូយ៉ាគីនត្រូវបានដោះលែង

*៥២:៣១–៣៤ – ២ពវ ២៥:២៧–៣០*

៣១លុះដល់ឆ្នាំទី៣៧ ដែលយ៉ូយ៉ាគីន[ផ] ជាស្ដេចយូដា
នៅជាឈ្លើយ គឺនៅថ្ងៃ២៥ខែផល្គុណ នោះអេវីលមេរ៉ូដាក
ស្ដេចបាប៊ីឡូនក៏លើកមុខយ៉ូយ៉ាគីន ជាស្ដេចយូដាឡើង នៅ
ក្នុងឆ្នាំទី១នៃរាជ្យទ្រង់ ហើយដោះទ្រង់ឱ្យរួចចេញពីគុក

**៥២:១៥** ភ ២ពវ ២៤:១ យរ ១:៣ ម យរ ៣៨:១៩ **៥២:១៦** យ យរ ៤០:៦ **៥២:១៧** រ ១ពវ ៧:១៥ ល ១ពវ ៧:២៧–៣៧ វ ១ពវ ៧:២៣ ស យរ ២៧:១៩–២២ **៥២:១៨** ហ ជន ៤:១៤ ឡ នក ២៧:៣ ១ពវ ៧:៤៥ **៥២:១៩** អ លវ ១០:១ ១ពវ ៧:៥០ ក ជន ៣:៣១ ខ នក ២៥:២៩ គ ជន ៤:៧ ឃ អរ ១:៧ ដយ ៥:២ **៥២:២០** ង ១ពវ ៧:២៥ ច ១ពវ ៧:៤៧ **៥២:២១** ឆ ១ពវ ៧:១៥ **៥២:២២** ជ ១ពវ ៧:១៦ ឈ នក ២៨:៣៣ **៥២:២៣** ញ ១ពវ ៧:២០ ដ ឌ.១៧ យរ ២៧:១៩ **៥២:២៤** ឋ ២ពវ ២៥:១៨ ឌ ២ពវ ២៥:១៨ យរ ៣៧:៣ ឍ ២ពវ ១២:៩ **៥២:២៥** ណ យរ ៣៦:១០ **៥២:២៦** ត ឌ.១២

**៥២:២៧** ថ ជន ៣៤:១១ ទ យរ ២០:៤ **៥២:២៨** ធ ចទ ២៨:៣៦ ២រប ៣៦:២០ នហ ១:២ **៥២:៣០** ន យរ ៤៣:៣ ប យរ ១៣:១៩ **៥២:៣១** ផ ២រប ៣៦:៩

**៥២:១៨–១៩** សូមមើលការពន្យល់ ១ពវ ៧:៤០,៤៥,៥០ ។
**៥២:២០** *គោលង្ហិនទាំង១២* សូមមើលការពន្យល់ ២រប ៤:៤ ។
**៥២:២១–២៣** សូមមើលការពន្យល់ ១ពវ ៧:១៥–២៣ ។
**៥២:២២** *៥ហត្ថ* មានហេតុការណ៍ស្រដៀងគ្នានៅក្នុង ២ពវ ២៥:១៧ ។
**៥២:២៥** *៧នាក់* ជាហេតុការណ៍ដូចគ្នាដដែលៗនៅក្នុង ២ពវ ២៥:១៩ សូមអាន ពាក្យ "ប្រាំអ្នក" មើលក្នុង ឌ.១២ ។
**៥២:២៨** *ឆ្នាំទី៧* គឺជាឆ្នាំនៃការគ្រងរាជ្យរបស់ស្ដេចនេប៊ូក្នេសា (សូមមើល ឌ.២៩–៣០) ដែលនៅក្នុងឆ្នាំ ៥៩៧ មុន ស.គ ។ មើលក្នុង ២ពវ ២៤:១៤,១៦ បានបញ្ជាក់ពីស្ថានភាព ។
**៥២:២៩** *នៅឆ្នាំទី១៨* គឺក្នុងឆ្នាំ ៥៨៦ មុន ស.គ មានក្នុង ឌ.១២ ក៏ដូចជាឆ្នាំមួយទៀតដែលគេហៅថា "ឆ្នាំទី ១៩" ការដែលខុសគ្នានោះគឺយោងទៅលើរបៀបផ្លាស់គ្នានៃឆ្នាំដែលគេគណនាកំណត់ចំពោះករណីស្រដៀងៗគ្នា សូមមើលការពន្យល់ ដយ ១:១ ។
**៥២:៣០** *ឆ្នាំទី២៣* គឺក្នុងឆ្នាំ ៥៨១ មុន ស.គ ។ *នេប៊ូក្នេសារ៉ាដាន ជាមេទ័ពធំក៏នាំយកពួកសាសាន៍យូដា . . . ទៅជាឈ្លើយ* ក៏មានទាំង (១).ជាការបង្ក្រាបកុំឱ្យមានការបះបោរកើតឡើងបន្តទៀត (សូមមើល ឌ.៣) និងមានទាំង(២).ក្នុងការវាយសម្លាប់ដូចជាការធ្វើគត់ដល់កេដាលា ដែលស្ដេចបាប៊ីឡូនបានតាំងជាអ្នកត្រួតត្រានោះ (សូមមើល ៤១:១–៣) ។
**៥២:៣១–៣៤** ជាវគ្គដែលជាហេតុការណ៍បានកើងឡើងដូចៗគ្នា ចំៗមានក្នុង ២ពវ ២៥:២៧–៣០ (និងមើលការពន្យល់) ។ ស្ដេចយេរេមានិងស្ដេចមួយចំនួនទីបញ្ចប់បានទទួលភាពសុខសាន្ត ។
**៥២:៣១** *ថ្ងៃ២៥* ហេតុការដូចគ្នានិងក្នុង ២ពវ ២៥:២៧ សូមមើលពាក្យ

៣២ក៏មានបន្ទូលនឹងទ្រង់ដោយផ្អែមពីរោះ ហើយតាំងបល្ល័ង្ក
ទ្រង់ឱ្យខ្ពស់ជាងបល្ល័ង្កនៃស្តេច ដែលនៅជាមួយក្នុងក្រុង
បាប៊ីឡូន ៣៣ក៏ផ្លាស់សំលៀកបំពាក់គុកពីទ្រង់ចេញ រួច
យ៉ូយ៉ាគីនក៏សោយព្រះស្ងោយ នៅចំពោះស្តេចបាប៊ីឡូន
ជានិច្ចដរាបដល់អស់ព្រះជន្មទ្រង់[ព] ៣៤ឯចំណែកសំរាប់
ចិញ្ចឹមទ្រង់ នោះមាន១ចំណែកចេញ ពីស្តេចបាប៊ីឡូនទៅ
រាល់ៗថ្ងៃជានិច្ច[ភ]ដរាបដល់អស់ព្រះជន្មទ្រង់ ។

**៥២:៣៣** ព ២សយ ៩:៧
**៥២:៣៤** ភ ២សយ ៩:១០

"ទី២៧" ក្នុងការពន្យល់ ខ.១២។

**៥២:៣២** សូមមើល ២ពវ ២៥:២៨ និងការពន្យល់ ។

**៥២:៣៤** *ដរាបដល់អស់ព្រះជន្មទ្រង់* មើល ខ.១១ ។ ជាឃ្លាពុំមានលេចឱ្យឃើញជាលក្ខណៈដូចគ្នា និងក្នុងគម្ពីរពង្សាវតារក្សត្រទី២ទេ ក៏មានករណីខ្លះបានបង្ហាញពីគោលបំណងក្នុងការបំភ្លឺនូវភាពខុសគ្នា រវាងស្តេចសេដាគាដែលស្ថិតក្នុងបន្ទប់ឃុំឃាំងរហូវដល់ថ្ងៃដែលទ្រង់សុគត (មើល ខ.១១) ។ ស្តេចយ៉ូគីន ដែលទ្រង់ត្រូវបានគេដោះលែងចេញពីគុក ហើយត្រូវស្តេចបាប៊ីឡូនយកចិត្តទុកដាក់រហូតដល់ថ្ងៃដែលទ្រង់សុគត (មើល ខ.១១) ។

# បរិទេវ
## របស់លោកយេរេមា

## សេចក្តីផ្តើម

### ចំណងជើង

ចំណងជើងព្រះគម្ពីរនេះ តាមព្រះគម្ពីរភាសាហេព្រើរ គឺ "អេកាហ៍"(ekah គឺមានន័យថា "... យ៉ាងណាហ្ន៎") ដែលពាក្យនេះមានប្រើនៅក្នុង ១:១ ២:១ និង ៤:១ ផងដែរ ។ ដោយសម្អាងទៅលើអត្ថន័យនៃព្រះគម្ពីរនេះ តាមទំនៀមទម្លាប់នៃសាសន៍យូដា គេហៅព្រះគម្ពីរនេះជាភាសាហេព្រើរថា "គីណុត"(qinot) ដែលប្រែថា "បទទំនួញ ឬបរិទេវ" ដែលព្រះគម្ពីរនេះត្រូវបានកំណត់យកចំណងជើង តាមការហៅដូចនេះ ដោយក្រុមអ្នកបកប្រែព្រះគម្ពីរសែបទូជិន(ក្រុមអ្នកបកប្រែព្រះគម្ពីរសញ្ញាចាស់មកជាភាសាក្រិកដំបូងបំផុតមុនគ.ស) និងក្រុមអ្នកបកប្រែវ៉ាល់ហ្គេត(Vulgate ដែលបកប្រែព្រះគម្ពីរមកជាភាសាឡាតាំងនៅសតវត្សទី៤នៃគ.ស)។

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

អ្នកនិពន្ធមិនបានប្រាប់ឈ្មោះរបស់ខ្លួននៅក្នុងព្រះគម្ពីរនេះទេ ប៉ុន្តែ តាមទំនៀមទំម្លាប់របស់សាសន៍យូដា និងពួកជំនុំដំបូងគេបានសន្និដ្ឋានថា លោកហោរាយេរេមា ជាអ្នកនិពន្ធនៃព្រះគម្ពីរនេះ ។ ការកំណត់យកតាមទំនៀមទំម្លាប់នេះ គឺទី១ ដោយយោងទៅលើ ២របា ៣៥:២៥(គឺទោះបីជាពាក្យ"សរសេរបទទំនួញ"នៅក្នុងខនេះ គឺមិនសំដៅដោយផ្ទាល់ ទៅលើការសរសេរព្រះគម្ពីរបរិទេវក៏ដោយ) ទី២ ដោយយោងទៅលើ យរ ៧:២៩ ៨:២១ ៩:១,១០,២០ និងទី៣ ដោយយោងទៅលើ ភាពស្រដៀងគ្នានៃការប្រើពាក្យ និងលក្ខណៈនៃការនិពន្ធ រវាងព្រះគម្ពីរបរិទេវ និងព្រះគម្ពីរយេរេមា ។ ជាងនេះទៅទៀត ការសន្និដ្ឋាននេះក៏សម្អាងផងដែរ ទៅលើភាពជាស្មរបន្ទាល់ដ៏ពិតរបស់យេរេមា ចំពោះការជំនុំជម្រះរបស់ព្រះអម្ចាស់មកលើទីក្រុងយេរូសាឡិមនៅក្នុងឆ្នាំ ៥៨៦ មុនគ.ស ដែលបានរៀបរាប់នៅក្នុងព្រះគម្ពីរនេះយ៉ាងច្បាស់លាស់ ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនអាចដឹងច្បាស់បានទេ ថាតើនរណាជាអ្នកនិពន្ធអត្ថបទកំណាព្យបានយ៉ាងប៉ិនប្រសព្វដូចនេះ ឬនរណាជាអ្នករៀបចំអត្ថបទកំណាព្យទាំងនោះឱ្យក្លាយជាព្រះគម្ពីរតែមួយ ។ ព្រះគម្ពីរបរិទេវនិយាយស៊ីជម្រៅអំពីសេចក្តីទុក្ខជាទម្ងន់របស់ជាតិសាសន៍មួយ ដែលរងការបាត់បង់ ដែលបណ្តាលមកពីការបំផ្លាញទីក្រុងយេរូសាឡិម និងព្រះវិហារ និងការត្រូវនិរទេសពួកសាសន៍យូដា ពីទឹកដីដែលព្រះអម្ចាស់បានសន្យាប្រទានដល់កូនចៅអ៊ីស្រាអែល ជាមាតុភូមិជានិរន្ត ។

កាលបរិច្ឆេទដ៏សក្តិសមបំផុតនៃព្រះគម្ពីរនេះ គឺយ៉ាងយូរណាស់នៅ ឆ្នាំ ៥៨៦ មុនគ.ស ឬឆាប់បំផុតនៅឆ្នាំ ៥១៦ មុនគ.ស(នៅពេលសម្ពោតព្រះវិហារក្រុងយេរូសាឡិមដែលបានស្អាងឡើងវិញ)។ តាមការពិពណ៌នាដោយឆ្លុះបញ្ចាំង អំពីហេតុការណ៍ដែលទើបតែកើតឡើង នៅក្នុងព្រះគម្ពីរនេះ កាលបរិច្ឆេទប្រហែលជានៅមុនឆ្នាំ ៥៧៥ ។

### លក្ខណៈអក្សរសាស្ត្រ

ព្រះគម្ពីរនេះទាំងមូលមានលក្ខណៈកំណាព្យ ។ បទទំនួញទី១ ទី២ និងទី៣ សុទ្ធតែមាន ២២ខ ដែលជាការឆ្លុះបញ្ចាំងអំពីចំនួនព្យញ្ជនៈនៃភាសារហេព្រើរ ។ នៅក្នុងបទទំនួញ ទី១ និងទី២ ក្នុងមួយខមានបីឃ្លា ។ នៅក្នុងបទទី៤ ក្នុងមួយខមានពីឃ្លា ហើយនៅក្នុងបទទី៥ ក្នុងមួយខមានតែមួយឃ្លាទេ ។ នៅក្នុងបទទី ១ ទី ២ និងទី៤ ខនីមួយៗគឺចាប់ផ្តើមដោយព្យញ្ជនៈនៃភាសាហេព្រើ គឺពីមួយខទៅមួយខទៀត ត្រូវតម្រៀបតាមលំដាប់នៃព្យញ្ជនៈនៃភាសាហេព្រើ ។ បទទំនួញទី៣(បទកណ្តាល) គឺមានលក្ខណៈខុសពីបទផ្សេងទៀត ដោយសារក្នុងខនីមួយៗនៃខទាំង២២ គឺមានបីឃ្លា(ដូចបទទី១ និងទី២ដែរ) ប៉ុន្តែ នៅក្នុងឃ្លាទាំងបីនៃខនីមួយៗ គឺចាប់ផ្តើមដោយព្យញ្ជនៈដូចគ្នា ហើយពីខមួយទៅខមួយទៀត គឺផ្តើមដោយព្យញ្ជនៈផ្សេងគ្នា តាមលំដាប់ព្យញ្ជនៈនៃភាសាហេព្រើ(ឧទាហរណ៍: ឃ្លាទាំងបីនៃខនីមួយៗចាប់ផ្តើមដោយអក្សរ "អាលែប" *aleph* ហើយឃ្លាទាំងបីនៃខបន្ទាប់សុទ្ធតែចាប់ផ្តើមដោយអក្សរ "បេថ"*beth* ។ល។)គឺតាមរបៀបនៃការនិពន្ធ ទដ ១១៩ ។ បទទី៥ គឺមាន២២ខ និងចាប់ផ្តើមដោយព្យញ្ជនៈផ្សេងៗពីគ្នានៃភាសាហេព្រើផងដែរ ប៉ុន្តែពីមួយឃ្លាទៅមួយឃ្លាទៀត គឺមិនតម្រៀបតាមលំដាប់ព្យញ្ជនៈឡើយ(មើលការពន្យល់ ៥:១-២២)។ ការនិពន្ធដោយការចាប់ផ្តើមតាមព្យញ្ជនៈដូចនេះ គឺបង្ហាញថា ព្រះគម្ពីរនេះជាបទទំនួញដែលត្រូវបានរៀបចំឡើងមក យ៉ាងប្រុងប្រយ័ត្ន និងមានរបៀប ។

### គោលរឿង និងវិជ្ជាសិក្សាអំពីព្រះ

ក្រៅពីព្រះគម្ពីរបរិទេវ មានព្រះគម្ពីរសញ្ញាចាស់មួយចំនួនទៀតដែលនិយាយអំពីបទទំនួញរបស់បុគ្គល ឬសហគមន៍ ។ មួយផ្នែកធំនៃព្រះគម្ពីរទំនុកតម្កើង គឺជាបទកំណាព្យបែបទំនួញ ហើយក្រៅពីព្រះគម្ពីរហាកាយ ព្រះគម្ពីរហោរាទាំងអស់សុទ្ធតែ មាននិយាយជាលក្ខណៈបទទំនួញមួយដង ឬច្រើនដង ។ ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរបរិទេវទាំងមូល គឺបទទំនួញ ។

ព្រះគម្ពីរបរិទេវជាបទទំនួញដែលមានជាច្រើនវគ្គ ដែលស្ដីអំពីការបំផ្លាញទីក្រុងយេរូសាឡិម (គឺរាជធានីដែលព្រះអម្ចាស់បានប្រទាន) នៅឆ្នាំ ៥៨៦ មុនគ.ស ហើយការនេះបានរំឭកអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលនាំឱ្យមានការនិពន្ធរបស់អ្នកមិនជឿសាសន៍ស៊ូម៉េរ (Sumerian) អំពី "បទទំនួញអំពីការបំផ្លាញក្រុងអ៊ើរ" "បទទំនួញអំពីការបំផ្លាញនគរសូម៉េរ និងក្រុងអ៊ើរ" និង "បទទំនួញអំពីការបំផ្លាញទីក្រុងនីពួរ (Nippur)"។ តាមប្រពៃណីពួកសាសន៍យូដាដែលអភិរក្សនិយម គេអានព្រះគម្ពីរនេះទាំងមូលៗ នៅថ្ងៃទី៩នៃខែអ័ប (Ab) គឺថ្ងៃបុណ្យនៃការបំផ្លាញព្រះវិហារស្ដេចសាឡូម៉ូននៅឆ្នាំ ៥៨៦ មុនគ.ស ហើយក៏ជាថ្ងៃបុណ្យនៃការបំផ្លាញព្រះវិហាររបស់ស្ដេចហេរ៉ូឌនៅឆ្នាំ ៧០ នៃគ.ស ផងដែរ ។ ពួកគេជាច្រើននាក់ទៀតក៏បានអានព្រះគម្ពីរនេះ នៅរាងរាល់សប្ដាហ៍នៅជញ្ជាំងខាងលិច (ឬ "ជញ្ជាំងទ្រហោយំ "Wailing Wall) នៅក្នុងទីក្រុងយេរូសាឡិមដ៏ចំណាស់ ។ ជាងនេះទៅទៀត នៅក្នុងទំនៀមទម្លាប់នៃនិកាយកាតូលិក គេអានព្រះគម្ពីរនេះ នៅក្នុង៣ថ្ងៃចុងក្រោយនៃសប្ដាហ៍បរិសុទ្ធ ។

ព្រះគម្ពីរបរិទេវមិនគ្រាន់តែជាបទទំនួញអំពីការបំផ្លាញទីក្រុងយេរូសាឡិមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានវិជ្ជាសិក្សាអំពីព្រះផងដែរ ។ មានការពិពណ៌នាជាលម្អិត នូវភាពវេទនាដោយការបំផ្លាញទីក្រុងយេរូសាឡិមដោយចក្រភពបាប៊ីឡូន ដោយចែកជាវគ្គដូចតទៅ:

១. ការបំផ្លាញទ្រព្យសម្បត្តិ និងសម្លាប់ពួកអស់ផ្លូវដូចជា ពួកស្ដេច (២:៦,៩ ៤:២០) ពួកបុត្រាស្ដេច (១:៦ ២:២,៩ ៤:៧–៨ ៥:១២) ពួកចាស់ទុំ (១:១៩ ២:១០ ៤:១៦ ៥:១២) ពួកសង្ឃ (១:៤,១៩ ២:៦,២០ ៤:១៦) ពួកហោរា (២:៩,២០) ពួករាស្ត្រសាម័ញ្ញ (២:១០–១២ ៣:៤៨ ៤:៦) ។

២. ម្ដាយដែលអត់ឃ្លានត្រូវធ្លាក់ខ្លួនស៊ីសាច់កូនរបស់ខ្លួន (២:២០ ៤:១០)

៣. ពួកកំលោះក្រមុំនៅស្រុកយូដា ត្រូវគេនិរទេសបណ្ដេញចេញទៅ ដោយក្ដីអាម៉ាស់ (១:៣,១៨)

៤. ការធ្វើពិធីបុណ្យ និងកម្មវិធីថ្វាយបង្គំត្រូវបញ្ចប់ (១:៤,១០)

ប៉ុន្តែការពិពណ៌នាទាំងនេះបានចងភ្ជាប់គ្នាជាកំណាព្យ ដែលបង្ហាញអំពីរបៀបដែលព្រះដ៏ជាម្ចាស់នៃប្រវត្តិសាស្ត្រ ទ្រង់ដោះស្រាយចំពោះរបៀបប្រព្រឹត្តនៃរាស្ត្រទ្រង់ ។

អ្នកនិពន្ធនៃបទទំនួញទាំងនេះយល់ច្បាស់ថា ពួកសាសន៍បាប៊ីឡូន គឺជាគ្រាន់តែជាក្រុមមនុស្សដែលព្រះទ្រង់ប្រើដើម្បីធ្វើការជំនុំជម្រះ ។ ដូចនេះព្រះទ្រង់ជាអ្នកបំផ្លាញទីក្រុង និងព្រះវិហារ (១:១២–១៥ ២:១–៨,១៧,២២ ៤:១១) ។ ព្រះទ្រង់ធ្វើការនេះ គឺដោយសារទ្រង់ស្អប់ខ្ពើមអំពើបាប និងការបះបោរប្រឆាំងទាស់នឹងសេចក្ដីសញ្ញា ដែលនាំឱ្យរាស្ត្រដែលមិនស្ដាប់បង្គាប់នេះត្រូវមានសេចក្ដីទុក្ខជាទម្ងន់ (១:៥,៨–៩ ៤:១៣ ៥:៧,១៦) ។ នៅពេលទទួលការជំនុំជម្រះ គឺមានការស្រែកយំ (១:២២ ៣:៥៩–៦៦) ដោយចង់ឱ្យខ្មាំងសត្រូវទទួលទោស (១:២២ ៣:៥៩–៦៦) ជារឿងធម្មតា (មើលការពន្យល់ ទដ ៥:១០) ប៉ុន្តែ ការដែលត្រូវធ្វើនោះ គឺត្រូវទទួលស្គាល់អំពើបាបដែលខ្លួនបានប្រព្រឹត្ត (១:៥,៨,១៤,២២ ២:១៤ ៣:៣៩ ៤:១៣ ៥:៧,១៦) ហើយមានចិត្តសោកស្ដាយ (៣:៤០–៤២) ។ ការទុកចិត្តចំពោះសេចក្ដីមេត្តាករុណា និងសេចក្ដីស្មោះត្រង់របស់ព្រះអម្ចាស់ គឺត្រូវមានជានិច្ច ។ ព្រះគម្ពីរនេះចាប់ផ្ដើមដោយបទទំនួញ (១:១–២) ហើយបញ្ចប់ទៅវិញដោយការអង្វរលន់តួសូមឱ្យព្រះអម្ចាស់ទ្រង់ធ្វើការស្ដារឡើងវិញ (៥:២១–២២) ។

នៅក្នុងពាក់កណ្ដាលនៃព្រះគម្ពីរនេះ មានបង្កប់ដោយវិជ្ជាសិក្សាអំពីព្រះខ្លាំងបំផុត ដោយមានការផ្ដោតទៅលើសេចក្ដីល្អនៃព្រះ។ ទ្រង់ជាព្រះនៃសេចក្ដីសង្ឃឹម (៣:២១,២៤–២៥) សេចក្ដីស្រឡាញ់ (៣:២២) សេចក្ដីស្មោះត្រង់ (៣:២៣) សេចក្ដីសង្គ្រោះ និងសេចក្ដីស្ដារឡើងវិញ (៣:២៦) ។ ទោះបីជាទ្រង់ធ្វើការជំនុំជម្រះក៏ដោយ ក៏ "សេចក្ដីមេត្តាករុណារបស់ទ្រង់" នោះមិនចេះផុតឡើយ "សេចក្ដីទាំងនោះចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្ដីស្មោះត្រង់របស់ទ្រង់ធំណាស់" (៣:២២–២៣) ។

នៅជិតចុងបញ្ចប់នៃព្រះគម្ពីរនេះ សេចក្ដីជំនឿគឺកើតមានឡើងពីស្ថានភាពសោកសង្រេងនៃទីក្រុងយេរូសាឡិម ដើម្បីទទួលស្គាល់រាជ្យដ៏អស់កល្បជានិច្ចនៃព្រះអម្ចាស់: "ឱព្រះយេហូវ៉ាអើយ ទ្រង់គង់នៅអស់កល្បជានិច្ច រាជ្យទ្រង់ស្ថិតស្ថេរនៅដល់អស់ទាំងដំណមនុស្សតរៀងទៅ" (៥:១៩ មើលសេចក្ដីផ្ដើម ទដ ៤៧ ៩៣ និងការពន្យល់ ទដ ១០២:១២) ។

**គម្រោងសង្ខេប**

I. សេចក្ដីវេទនា និងបំផ្លាញនៃក្រុងយេរូសាឡិម (ជំពូក១)

II. សេចក្ដីកំហឹងនៃព្រះអម្ចាស់ទាស់នឹងរាស្ត្រទ្រង់ (ជំពូក ២)

III. ការតវ៉ារបស់ពួកយូដា និងប្រភពនៃការកម្សាន្តចិត្ត (ជំពូក ៣)

IV. ភាពខុសគ្នារវាងទីក្រុងស៊ីយ៉ូនកាលពីអតីតកាល និងបច្ចុប្បន្ន (ជំពូក ៤)

V. នគរយូដាអង្វរលន់តួរដល់ព្រះអម្ចាស់ ទូលសូមការអត់ទោស និងការស្ដារឡើងវិញ (ជំពូក ៥)

(ពាក្យនេះធៀបក្រុងយេរូសាឡិមដូចជាស្រីមេម៉ាយ)
**១** ១ ទីក្រុងដែលពីដើមមានពេញដោយមនុស្ស ឥឡូវបាន
ត្រមោច[ក]នៅយ៉ាងណាហ្ន៎[ខ] នាងដែលពីដើមជាប្រធាន[គ]
នៅកណ្ដាលអស់ទាំងសាសន៍ ឥឡូវនេះបានត្រឡប់ជា
មេម៉ាយ[ឃ]វិញយ៉ាងណាហ្ន៎ ពីដើមជាបុត្រីនៅកណ្ដាលខេត្ត
ទាំងប៉ុន្មាន តែឥឡូវនេះបានទៅជាចំណុះគេវិញយ៉ាងណា
ហ្ន៎[ង] ២ នាងយំអណ្ដិតអណ្ដក[ច]នៅពេលយប់ ទឹកភ្នែករហាម
នៅលើថ្ពាស់ផង ក្នុងពួកអ្នកដែលស្រឡាញ់នាង[ឆ] នោះឥត
មានណាមួយជួយដោះទុក្ខឡើយ ពួកភឿនមិត្រទាំងអស់
បានក្បត់[ជ]នាងហើយ គេបានត្រឡប់ទៅជាខ្មាំងសត្រូវវិញ[ឈ]
៣ ពួកយូដាបានទៅជាឈ្លើយហើយ[ញ] ក៏ត្រូវរងទុក្ខ ហើយ
បំរើយ៉ាងធ្ងន់ នាងអាស្រ័យនៅកណ្ដាលអស់ទាំងសាសន៍[ដ]
ឥតមានសេចក្ដីសំរាកឡើយ ពួកអ្នកដែលបៀតបៀននាង[ឋ]
បានតាមនាងទាន់ នៅច្រកចង្អៀត ៤ អស់ទាំងផ្លូវនៃក្រុង
ស៊ីយ៉ូនកំពុងតែយំទួញ[ឌ] ពីព្រោះគ្មានអ្នកណាមកឯជំនុំមុត
មាំសោះ អស់ទាំងទ្វារទីក្រុងនៅស្ងាត់ច្រៀប[ឍ] ហើយពួក
សង្ឃក៏ថ្ងូរ ពួកក្រមុំៗមានសេចក្ដីទុក្ខ ហើយតួទីក្រុងក៏មាន
សេចក្ដីជូរចត់ដែរ[ណ] ៥ ពួកអ្នកដែលតតាំងនឹងនាងបានឡើង
ជាកំពូល ហើយពួកខ្មាំងសត្រូវមានសេចក្ដីចំរើន ដ្បិតព្រះ
យេហូវ៉ា ទ្រង់បានធ្វើទុក្ខនាង[ត] ដោយព្រោះអំពើរំលងដ៏
បរិបូរ[ថ] ពួកក្មេងៗត្រូវបំបរទៅជាឈ្លើយ[ទ] នៅពីមុខពួក
ដែលតតាំង[ធ] ៦ គ្រប់ទាំងសេចក្ដីលំអបានបាត់ពីកូនស្រីនៃ
ក្រុងស៊ីយ៉ូនចេញ[ន] ពួកចៅហ្វាយរបស់នាងបានត្រឡប់ដូច
ជាប្រើស ដែលរកទីស្មៅមិនបាន ហើយគេរត់ពីមុខ[ប]អ្នក
ដែលដេញតាម ដោយល្វើយកំឡាំង ។
៧ នៅគ្រារងទុក្ខវេទនា ហើយលំបាក នោះក្រុងយេរូ–
សាឡិមនឹកចាំពីសេចក្ដីដ៏ល្អទាំងប៉ុន្មាន ដែលធ្លាប់មានពី
កាលដើម ក្នុងកាលដែលជនទាំងឡាយបានធ្លាក់ទៅក្នុង
កណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ ឥតមានអ្នកណាជួយសោះ[ផ]
នោះពួកខ្មាំងសត្រូវបានឃើញនាង ហើយបានចំអកឱ្យ[ព]

**១:១** ក លវ ២៦:៤៣ ខ យរ ៤២:៣ គ ១ពវ ៤:២១ ឃ អស ៤៧:៨ ង អស ៣:២៦ យរ ៤០:៩ អគ ៥:៥ **១:២** ច ទដ ៦:៦ ឆ យរ ៣:១ ជ យរ ៤:៣០ មីក ៧:៥ ឈ ខ.១៦ យរ ៣០:១៤ **១:៣** ញ យរ ១៣:១៩ ដ ចទ ២៨:៦៥ ឋ នក ១៥:៩ **១:៤** ឌ ទដ ១៣៧:១ ឍ អស ២៧:១០ យរ ៩:១១ ណ ខ.២១ យអ ១:៨–១៣ **១:៥** ត អស ២២:៥ យរ ៣០:១៥ ថ ទដ ៥:១០ ទ យរ ១០:២០ ៣៩:៩ ៥២:២៨–៣០ ធ ទដ ១៣៧:៣ បទ ២:១៧ **១:៦** ន ទដ ៩:១៤ យរ ១៣:១៨ ប លវ ២៦:៣៦ **១:៧** ផ ២ពវ ១៤:២៦ យរ ៣៧:៧ បទ ៤:១៧ ព យរ ២:២៦

**១:១–២២** ព្រះគម្ពីរបរិទេវបាន ប្រៀបប្រដូចទីក្រុងយេរូសាឡិមទៅនឹងស្ត្រីម្នាក់ ហើយទៅនឹងនគរមួយ ដែលមានទីក្រុងនេះជារាជធានី និងបេះដូង ហើយការប្រៀបប្រដូចនេះក៏ត្រូវបានធ្វើឡើងយ៉ាងទូលំទូលាយ នៅក្នុងព្រះគម្ពីរហោរា និងព្រះគម្ពីរទំនុកតម្កើងផងដែរ ។
**១:១–១១** វគ្គនេះគឺជាបទទំនួញទីមួយ ហើយនៅក្នុងផ្នែកពាក់កណ្ដាលទីមួយនៃវគ្គនេះ អ្នកនិពន្ធបានរៀបរាប់អំពីស្ថានភាពនៃទីក្រុងយេរូសាឡិម ដោយប្រើសព្វនាមទីបីដើម្បីនិយាយអំពីទីក្រុងនេះ ក្នុងលក្ខណៈជាបទទំនួញអំពីស្ថានភាពដ៏សែនវេទនានៃទីក្រុងនេះ ។ អ្នកនិពន្ធបានដកស្រង់នូវសម្ដីរបស់ទីក្រុងនេះនៅក្នុងចុង ខ.១១ ផងដែរ ។
**១:១** . . . *យ៉ាងណាហ្ន៎* ឃ្លានេះបង្ហាញអំពីអារម្មណ៍រន្ធត់ និងស្រងាកចិត្ត (មើល ២:១ ៤:១–២ ២សយ ១:២៥,២៧ យរ ៩:១៩ ៤៨:១៧,៣៩ អគ ២៦:១៧)។ *បានត្រមោចនៅ* ពាក្យនេះនៅក្នុងព្រះគម្ពីរភាសារហេព្រើគឺត្រូវបានបកប្រែថា "អង្គុយតែឯង" នៅក្នុង យរ ១៥:១៧ ដែលនៅក្នុងបទគម្ពីរនេះ លោកហោរាត្រូវអង្គុយនៅតែឯង ហើយនៅពេលនេះ ទីក្រុងជាទីស្រឡាញ់របស់លោក ក៏ត្រូវអង្គុយនៅតែឯងដែរ ។ *ទីក្រុង* គឺទីក្រុងយេរូសាឡិម ។ *ពីដើមមានពេញដោយមនុស្ស* ធៀបនឹង អស ១:២១ ។ *ជាប្រធាននៅកណ្ដាលអស់ទាំងសាសន៍* ធៀបនឹង យរ ៤៩:១៥ ។ *ចំណុះគេវិញ* នៅក្នុងព្រះគម្ពីរ នក ១:១១ ១ពវ ៤:៦ ឃ្លានេះត្រូវបានគេបកប្រែតាមព្រះគម្ពីរភាសារហេព្រើថា "ដោយការនឿយលំបាក" ។
**១:២** *នាងយំអណ្ដឹតអណ្ដក* គឺយំដូចលោកយេរេមា ហើយដោយមូលហេតុដូចគ្នា(យរ ១៣:១៧)។ *នៅពេលយប់* មើល ២:១៨–១៩ ។ *ពួកអ្នកដែលស្រឡាញ់នាង . . . ពួកភឿនមិត្រ* គឺពួកសម្ព័ន្ធមិត្រដែលជាសាសាន៍ដទៃ ដែលពួកក្រុងយេរូសាឡិម និងពួកយូដាបានស្វែងរកជំនួយផ្នែកសន្តិសុខជាជាងស្វែងរកអំពីព្រះអម្ចាស់(មើល យរ ២:៣៦–៣៧ ២៧:៣ អគ ១៦:២៦,២៨–២៩ ២៣:១១–២១ មើល នក ៣៤:១៥ និងការពន្យល់)។ *ឥតមានអ្នកណាមួយជួយដោះទុក្ខឡើយ* មើល ខ.៩,១៦–១៧,២១ ។ *ទាំងអស់បានក្បត់នាងហើយ* មើល ខ.១៩ គឺដូចជានគរអេដុំម(៤:២១–២២ ទដ ១៣៧:៧) និងអាំម៉ូន(យរ ៤០:១៤ អគ ២៥:២–៣,៦)។ *ត្រឡប់ទៅជាខ្មាំងសត្រូវវិញ* មើល ខ.១៧ ។
**១:៣** *ទៅជាឈ្លើយ* គឺទៅជាឈ្លើយនៅក្រុងបាប៊ីឡូន(មើល យរ ២០:៤–៥ និងពេលបន្ទាប់មកទៀត)។ *នៅកណ្ដាលអស់ទាំងសាសន៍ ឥតមានសេចក្ដីសម្រាកឡើយ* គឺដូចការព្រមានរបស់លោកម៉ូសេ នៅក្នុង ចទ ២៨:៦៥ ។
**១:៤** *យំទួញ* គឺដោយសារត្រូវចោលស្ងាត់(មើល ពច ៥:៦ អស ៣៣:៨ និងការពន្យល់)។ *ជំនុំមុតមាំ* មើល នក ២៣:១៤–១៧ និងការពន្យល់ និងមើល លវ ២៣:២ ។ *ពួកក្រមុំមានសេចក្ដីទុក្ខ* គឺបង្ហាញអំពីបរាជ័យយ៉ាងធ្ងន់ធ្ងរ(មើល យរ ៩:២០ ធៀបនឹង នក ១៥:២០ និងការពន្យល់ ១សយ ១៨:៦ ទដ ៦៨:២៥ យរ ៣១:១៣)។
**១:៥** *ជាកំពូល* តាមន័យត្រង់នៅក្នុង ចទ ២៨:៤៤ គឺ "ជាអ្នកដឹកនាំ" (ធៀបនឹង ចទ ២៨:១៣)។
**១:៦** *កូនស្រីនៃក្រុងស៊ីយ៉ូន* គឺពាក្យប្រៀបប្រដូចទីក្រុងយេរូសាឡិមទៅនឹងតួអង្គមនុស្ស(មើលការពន្យល់ ២ពវ ១៩:២១)។ *ពួកចៅហ្វាយនាង . . . រត់ពីមុខអ្នកដែលដេញតាម* មើល យរ ៥២:៧–៨ ។ *ដូចជាប្រើស ដែលរកទីស្មៅមិនបាន* មានន័យថា ត្រូវខ្សត់ខ្សោយ និងងាយត្រូវគេចាប់ជាអាហារ ។
**១:៧** *រងទុក្ខវេទនា ហើយលំបាក* មើល ៣:១៩ ។ *សេចក្ដីដ៏ល្អទាំងប៉ុន្មាន* មើល ខ.១០–១១ ។ *ពីកាលដើម* ដូចជានៅរជ្ជកាលស្ដេចដាវីឌ និងស្ដេចសាឡូម៉ូនជាដើម ។ *ធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ* មើល ២សយ ២៤:១៤ ។ *ដំណើរដែលនាងឈប់ផ្អាកនៅ* មើលការពន្យល់ លប ២:២–៣ និងមើល ២:២ ។ តាមព្រះគម្ពីរភាសារហេព្រើ ឫសនៃពាក្យនេះ និឫសនៃពាក្យ "ថ្ងៃឈប់សម្រាក" គឺដូចគ្នាទេ ហើយការប្រើពាក្យនេះ នៅក្នុងខនេះប្រហែលជាការលេងពាក្យ(មើល លវ ២៦:៣៤–៣៥)។

ពីដំណើរដែលនាងឈប់ផ្អាកនៅ ៨ក្រុងយេរូសាឡិមបាន
ធ្វើបាបយ៉ាងធ្ងន់[ភ] ហេតុនោះបានជាត្រូវត្រឡប់ដូចជារបស់
ស្មោកគ្រោក[ម] អស់អ្នកដែលធ្លាប់លើកមុខនាង ឥឡូវគេ
មើលងាយវិញ ពីព្រោះគេបានឃើញកេរខ្មាសនាងហើយ[យ]
អើ នាងកំពុងតែថ្ងូរ[រ] ហើយបែរថយក្រោយ ៩សេចក្ដី
ស្មោកគ្រោករបស់នាងនៅត្រង់ជាយសំពត់ នាងមិននឹកពី
ចុងបំផុតរបស់ខ្លួនសោះ[ល] ហេតុនោះបានជានាងត្រូវចុះ
មក[វ]យ៉ាងអស្ចារ្យ ឥតមានអ្នកណានឹងជួយដោះទុក្ខឡើយ[ស]
ឱ ព្រះយេហូវ៉ាអើយ សូមទ្រង់ទតសេចក្ដីវេទនារបស់ខ្ញុំ
ម្ចាស់ចុះ[ហ] ដ្បិតខ្មាំងសត្រូវមានសេចក្ដីឆ្មើងឆ្មៃ ១០ពួកសង្កត់
សង្កិនបានលូកដៃមកលើរបស់ទាំងប៉ុន្មាន[ឡ] ដែលគាប់ចិត្ត
នាង នាងបានឃើញសាសន៍ដទៃចូលទៅក្នុងទីបរិសុទ្ធរបស់
នាង[អ] ជាពួកមនុស្សដែលទ្រង់បានផ្ដាំទុក[ក] មិនឱ្យគេចូល
ទៅក្នុងជំនុំរបស់ទ្រង់ឡើយ ១១បណ្ដាជនរបស់នាងកំពុង
តែថ្ងូរ[ខ] គេរកអាហារ[គ] គេបានឱ្យរបស់ដែលគាប់ចិត្តទាំង
ប៉ុន្មាន ផ្លូវនឹងអាហារ សំរាប់ចំរើនកំឡាំងឡើងវិញ ឱព្រះ
យេហូវ៉ាអើយ សូមទតមើល ដ្បិតខ្ញុំម្ចាស់បាន ត្រឡប់ជា
ទាបថោកហើយ ។
១២ឱអ្នករាល់គ្នា ដែលដើរបង្ហួសអើយ[ឃ] តើមិនអំពល់
ដល់អ្នករាល់គ្នាទេឬ សូមពិចារណាមើល បើមានសេចក្ដី
ទុក្ខព្រួយណា[ង] ដូចយ៉ាងសេចក្ដីទុក្ខព្រួយរបស់ខ្ញុំនេះ ដែល
ព្រះយេហូវ៉ាបាននាំមកធ្វើទុក្ខដល់ខ្ញុំ នៅថ្ងៃនៃសេចក្ដីខ្ញាល់
ដ៏សហ័សរបស់ទ្រង់[ច] ១៣ទ្រង់បានចាត់ភ្លើងឱ្យមកពីស្ថាន
ដ៏ខ្ពស់ចូលក្នុងឆ្អឹងខ្ញុំ[ឆ] ភ្លើងនោះក៏ឈ្នះផង ទ្រង់បានដាក់
មង[ជ]សំរាប់ចាប់ជើងខ្ញុំ ទ្រង់បានបង្វែរខ្ញុំឱ្យថយទៅ
ក្រោយ[ឈ] ក៏បានធ្វើឱ្យខ្ញុំនៅស្ងាត់ ហើយល្វើយ[ញ]ជានិច្ច
១៤ឯនឹមនៃអំពើរំលងរបស់ខ្ញុំ[ដ] នោះគឺព្រះហស្តទ្រង់បាន
ចងជាប់ហើយ ឯអំពើទាំងនោះបានជំពាក់ជាប់គ្នា ក៏បាន
ឡើងមកពាក់លើកខ្ញុំ ទ្រង់បានឱ្យកំឡាំងខ្ញុំស្បើយទៅព្រះ
អម្ចាស់ទ្រង់ បានប្រគល់ខ្ញុំទៅក្នុង[ឋ]កណ្ដាប់ដៃគេ ជាពួក
ដែលខ្ញុំពុំអាចនឹងទទឹងទាស់បានឡើយ ១៥ព្រះអម្ចាស់ទ្រង់
បានមើកងាយពួកមនុស្សខ្លាំងពូកែនៅកណ្ដាលខ្ញុំហើយ[ឌ]
ទ្រង់បានប្រជុំជំនុំមុតមាំ[ឍ]ទាស់នឹងខ្ញុំដើម្បីនឹងកិនពួកកំឡោះៗ
[ណ]របស់ខ្ញុំឱ្យខ្ទេចខ្ទី ព្រះអម្ចាស់ទ្រង់បានជាន់[ត]នាងក្រមុំ[ថ]
ស្រុកយូដា ដូចជាជាន់ធុងទំពាំងបាយជូរ[ទ] ១៦ព្រោះហេតុ–

**១:៨** ភ ខ.២០ អស ៥៩:២–១៣ ម យរ ២:២២ យ យរ ១៣:២២,២៦ រ ខ.២១,២២ ទដ ៦:៦ ៣៨:៨ **១:៩** ល ចទ ៣២:២៨–២៩ អគ ២៤:១៣ វ យរ ១៣:១៨ ស សស ៤:១ យរ ១៦:៧ ហ ទដ ២៥:១៨ **១:១០** ឡ អស ៦៤:១១ អ ទដ ៧៤:៧–៨ ៧៩:១ យរ ៥១:៥១ ក ចទ ២៣:៣ **១:១១** ខ ទដ ៦:៦ ៣៨:៨ គ យរ ៣៧:២១ ៥២:៦ **១:១២** ឃ យរ ១៨:១៦ ង ខ.១៨ ច អស ១០:៤ ១៣:១៣ យរ ៣០:២៤ **១:១៣** ឆ យប ៣០:៣០ ទដ ១០២:៣ ជ យប ១៨:៨ ឈ យរ ៤៤:៦ ញ ហព ៣:១៦ **១:១៤** ដ ចទ ២៨:៤៨ អស ៤៧:៦ យរ ១៥:១២ ឋ យរ ៣២:៥ **១:១៥** ឌ យរ ៣៧:១០ ឍ អស ៤១:២ ណ អស ២៨:១៨ យរ ១៨:២១ ត អស ៥:៥ ថ យរ ១៤:១៧ ទ ពច ៦:១១

**១:៨** *ស្មោកគ្រោក* មើល ខ.១៧ និងការពន្យល់ ។ គឺសំដៅទៅលើការមិនស្អាត ដោយការមានរដូវរបស់ស្ត្រី ដែលការនេះមានចែងនៅក្នុងក្រឹត្យវិន័យ(មើល លវ ១២:២,៥ ១៥:១៩)។ *កេរខ្មាសនាង* មើល អស ៤៧:៣ អគ ១៦:៣៧ និងការពន្យល់ ។

**១:៩** *សេចក្ដីស្មោកគ្រោក* ការមិនស្អាតតាមក្រឹត្យវិន័យ(មើលការពន្យល់ លវ ៤:១២) នៅត្រង់ចំណុចនេះ គឺបណ្ដាលមកពីការប្រព្រឹត្តបាបដោយចេតនា ។ *នាងមិននឹកពីចុងបំផុតរបស់ខ្លួន* គឺដូចដែលក្រុងបាប៊ីឡូនមិនបាននឹកដល់អនាគតរបស់ខ្លួនដែរ(អស ៤៧:៧)។ *ព្រះយេហូវ៉ាអើយ សូមទ្រង់ទត* ពាក្យទំនួញស្រែកយំចេញពីបបូរមាត់របស់ក្រុងយេរូសាឡិម ត្រូវបានដងស្រង់យកមកនិយាយ ដើម្បីពិពណ៌នាជាបន្តទៀតអំពីសេចក្ដីវេទនា របស់ទីក្រុងយេរូសាឡិម(មើល ខ.១១ និងការពន្យល់)។ *ខ្មាំងសត្រូវមានសេចក្ដីឆ្មើងឆ្មៃ* មើល ខ.១៦ ។

**១:១០** *មិនឱ្យគេចូលទៅក្នុងជំនុំរបស់ទ្រង់ឡើយ* មើល អគ ៤៤:៧,៩ និងការពន្យល់ ។

**១:១១** *រកអាហារ* ការខ្វះខាតចំណីអាហារគឺកើតមានឡើង ទាំងនៅក្នុងពេល និងក្រោយពេលនៃការឡោមទ័ពទីក្រុងយេរូសាឡិម ។ *សំរាប់ចំរើនកំឡាំងឡើង* មើល ខ.១៩ ២ពវ ៦:២៤–២៩ ។ *ឱព្រះយេហូវ៉ាអើយ សូមទតមើល* នៅត្រង់ចំណុចនេះ សេចក្ដីទំនួញស្រែករបស់ក្រុងយេរូសាឡិម គឺត្រូវបានលើកឡើងម្ដងទៀតភ្លាមៗ ។ ចាប់តាំងពីខនេះរហូតដល់ចុងបញ្ចប់នៃបទទំនួញ អ្នកនិពន្ធពិពណ៌នាអំពីទីក្រុងយេរូសាឡិម ដោយនិយាយពីតួអង្គមនុស្សតំណាងឱ្យទីក្រុងនេះ ។

**១:១២** *ដើរបង្ហួស* មើល យរ ១៨:១៦ និងការពន្យល់ ។ *សូមពិចារណាមើល . . . ដូចយ៉ាងសេចក្ដីទុក្ខព្រួយរបស់ខ្ញុំនេះ* នៅត្រង់ចំណុចនេះ អ្នកនិពន្ធបង្ហាញអំពីទំហំនៃសេចក្ដីទុក្ខ ហើយទំហំនៃទុក្ខដែលព្រះមែស៊ីទ្រង់ទទួល(ដូចមានចែងនៅក្នុង អស ៥៣:៤) គឺបានឆ្លើយតបនឹងសំណួរនេះ (ធៀបនឹង អស ៥៣:៣ "មនុស្សទូទុក្ខ")។ *សេចក្ដីខ្ញាល់ដ៏សហ័សរបស់ទ្រង់* មើល ២:៣,៦ ៤:១១ ។ អ្នកនិពន្ធបានប្រើពាក្យដូចនេះ ជាធម្មតានៅក្នុងព្រះគម្ពីរយេរេមាផងដែរ(មើល យរ ៤:៨,២៦ ១២:១៣ ២៥:៣៧–៣៨ ៤៤:៦ ៤៩:៣៧ ៥១:៤៥)។

**១:១៣** *ទ្រង់បានចាត់ភ្លើងឱ្យមកពីស្ថានដ៏ខ្ពស់* គឺភ្លើងនៃសេចក្ដីជំនុំជម្រះរបស់ទ្រង់(មើល ២:៣–៤ លវ ១០:២ ជន ១១:១–៣ ១៦:៣៥ ២ពវ ១:១០,១២ អស ២៩:៦ ៣០:៣០ ៦៦:១៥–១៦ យរ ៤:៤ ២១:១៤ ៤៩:២៧ ៥០:៣២ អម ៧:៤)។ *ឆ្អឹងខ្ញុំ* គឺឆ្អឹងនៃក្រុងយេរូសាឡិម(នៅត្រង់ចំណុចនេះអ្នកនិពន្ធលើកឡើងអំពីទីក្រុងនេះ ដោយប្រដូចទៅនឹងតួអង្គស្ត្រី មើលការ ពន្យល់ ខ.៨)។ នៅក្នុងលក្ខណៈស្រដៀងគ្នាមួយទៀត ព្រះបន្ទូលនៃព្រះអម្ចាស់ គឺប្រៀបបានទៅនឹងភ្លើងដែលឆេះនៅក្នុងឆ្អឹងនៃលោកហោរា(មើល យរ ២០:៩ និងការពន្យល់)។ *ដាក់មងសំរាប់ចាប់ជើងខ្ញុំ* មើល ទដ ៥៧:៦ សភ ២៩:៥ ។ *នៅស្ងាត់* គឺដូចជាព្រះនាងតាម៉ា ដែលជាម្ចាស់ប្អូនរបស់ព្រះអង្គម្ចាស់អាប់សាឡុំម(មើល ២សយ ១៣:២០)។

**១:១៥** *ជាន់ . . . ដូចជាជាន់ធុងទំពាំងបាជូរ* គឺជាពាក្យប្រៀបប្រដូចការជំនុំជម្រះនៃព្រះអម្ចាស់(មើល អស ៦៣:២–៣ យអ ៣:១៣ វវ ១៤:១៩–២០ ១៩:១៥)។ *នាងក្រមុំស្រុកយូដា* គឺជាការនិយាយអំពីនគរយូដាដោយប្រៀបប្រដូចទៅមនុស្ស(មើលការពន្យល់ ២ពវ ១៩:២១)។

**១:១៦** *ភ្នែកខ្ញុំហូរសស្រាក់* មើល ២:១១ ៣:៤៨ យរ ៩:១ និងការពន្យល់

ការណ៍ ទាំងនេះបានជាខ្ញុំយំ ភ្នែកខ្ញុំហូរសស្រាក់[ធ] ដោយ
ព្រោះអ្នកកំសាន្តចិត្ត[ន] ដែលគួរមកលំហើយព្រលឹងខ្ញុំ គេ
នៅឆ្ងាយពីខ្ញុំវិញ កូនចៅខ្ញុំត្រូវចោលស្ងាត់ ដោយព្រោះ
ពួកខ្មាំងសត្រូវបានឈ្នះហើយ[ប] ។
១៧ ក្រុងស៊ីយ៉ូនលូកដៃទៅ[ផ] តែគ្មានអ្នកណានឹងជួយដោះ
ទុក្ខសោះព្រះយេហូវ៉ាទ្រង់បានបង្គាប់ពីដំណើរយ៉ាកុបថា
ត្រូវឱ្យពួកអ្នកដែលនៅជុំវិញ ធ្វើជាខ្មាំងសត្រូវនឹងគាត់[ព]
ក្រុងយេរូសាឡិមនៅកណ្តាលគេ ទុកដូចជារបស់[ភ]ស្មោក
គ្រោក[ម] ១៨ ព្រះយេហូវ៉ាទ្រង់សុចរិតទេ[យ] ដ្បិតខ្ញុំបានបះ
បោរ[រ]នឹងបញ្ញត្តទ្រង់ ឱសាសន៍ទាំងឡាយអើយ សូមស្តាប់
ហើយពិចារណាមើលសេចក្តីទុក្ខព្រួយរបស់ខ្ញុំ[ល] ពួកក្រមុំៗ
និងពួកកំលោះៗរបស់ខ្ញុំ គេបានទៅជាឈ្លើយអស់ហើយ[វ]
១៩ ខ្ញុំបានហៅពួកអ្នកដែលធ្លាប់ស្រឡាញ់ខ្ញុំ[ស] តែគេបាន
បញ្ឆោតខ្ញុំវិញ ពួកសង្ឃ នឹងពួកចាស់ទុំរបស់ខ្ញុំបានរលត់
ទៅ[ហ]នៅក្នុងទីក្រុង កំពុងដែលគេរកអាហារសំរាប់ចំរើន
កំឡាំងខ្លួន ។
២០ ឱព្រះយេហូវ៉ាអើយ សូមទតមើល ដ្បិតខ្ញុំម្ចាស់
មានសេចក្តីវេទនា[ឡ] ចិត្តខ្ញុំម្ចាស់ទុរន់ទុរា[អ] ចិត្តខ្ញុំម្ចាស់
ក្រឡាប់ចុះ[ក]នៅក្នុងខ្លួន ពីព្រោះខ្ញុំម្ចាស់បានបះបោរជា
ខ្លាំង[ខ]ហើយ នៅខាងក្រៅដាវបង្ហួតបង់ ហើយនៅឯផ្ទះ
ក៏មានដូចជាសេចក្តីស្លាប់ដែរ[គ] ២១ គេបានឮថា ខ្ញុំម្ចាស់ថ្ងូរ[ឃ]
តែគ្មានអ្នកណានឹងជួយដោះទុក្ខខ្ញុំម្ចាស់ទេ[ង] ពួកខ្មាំងសត្រូវ
ទាំងប៉ុន្មាន បានឮដំណឹងពីសេចក្តីលំបាករបស់ខ្ញុំម្ចាស់
ហើយគេសប្បាយចិត្ត[ច] ដោយព្រោះទ្រង់បានធ្វើយ៉ាងនេះ
ឯទ្រង់ៗនឹងឱ្យថ្ងៃ[ឆ] ដែលទ្រង់បានប្រកាសប្រាប់នោះ បាន
មកដល់ នោះគេនឹងបានដូចជាខ្ញុំម្ចាស់វិញ ២២ សូមឱ្យ
គ្រប់ទាំងអំពើទុច្ចរិតរបស់គេ បានលេចមកនៅចំពោះទ្រង់
ហើយសូមទ្រង់ធ្វើដល់គេ ដូចជាទ្រង់បានធ្វើដល់ខ្ញុំម្ចាស់
ដោយព្រោះអស់ទាំងអំពើរំលងរបស់ខ្ញុំម្ចាស់ដែរ[ជ] ដ្បិតខ្ញុំ
ម្ចាស់ថ្ងូរជាច្រើន[ឈ] ហើយចិត្តខ្ញុំម្ចាស់ក៏ល្វើយផង ។

២ ១ ព្រះអម្ចាស់ទ្រង់បានគ្របបាំងកូនស្រីនៃក្រុងស៊ីយ៉ូន
ដោយពពក ក្នុងកាលដែលទ្រង់ខ្ញាល់[ក] យ៉ាងណាហ្ន៎ ទ្រង់
បានទំលាក់សេចក្តីលំអររបស់អ៊ីស្រាអែល ចុះពីស្ថានសួគ៌
មកដល់ដី ក៏មិនបាននឹកចាំពីកំណល់កល់ព្រះបាទ[ខ]ទ្រង់ នៅ
ថ្ងៃដែលទ្រង់ខ្ញាល់នោះទេ[គ] ២ ព្រះអម្ចាស់ទ្រង់បានលេប[ឃ]
អស់ទាំងទីលំនៅរបស់យ៉ាកុបបាត់ទៅ ឥតមានប្រណី[ង]
ឡើយ ក្នុងគ្រាដែលទ្រង់មានសេចក្តីក្រោធ នោះទ្រង់បាន
រំលំអស់ទាំងទីមាំមួន[ច]របស់កូនស្រីយូដា ទ្រង់បានពង្រាប

**១:១៦** ធ យប ៧:៣ ទដ ១១៩:១៣៦ អស ២២:៤ បទ ២:១១,៨ ៣:៤៨–៤៩ ន ទដ ៦៩:២០ សស ៤:១ យរ ១៦:៧ ប ខ.២ យរ ១៣:១៧ ១៤:១៧
**១:១៧** ផ យរ ៤:៣១ ព នក ២៣:២១ ភ លវ ១៨:២៥–២៨ ម យរ ២:២២
**១:១៨** យ នក ៩:២៧ អរ ៩:១៥ រ ១សយ ១២:១៤ ល ខ.១២ វ ចទ ២៨:៣២,៤១
**១:១៩** ស យរ ២២:២០ ហ យរ ១៤:១៥ បទ ២:២០
**១:២០** ឡ យរ ៤:១៩ អ បទ ២:១១ ក យប ២០:២ ខ ខ.៨ គ ចទ ៣២:២៥ អគ ៧:១៥
**១:២១** ឃ ខ.៨ ទដ ៦:៦ ៣៨:៨ ង ខ.៤ ច បទ ២:១៥ ឆ អស ៤៧:១១ យរ ៣០:១៦
**១:២២** ជ នហ ៤:៥ ឈ ខ.៨ ទដ ៦:៦
**២:១** ក បទ ៣:៤៤ ខ ទដ ៩៩:៥ ១៣២:៧ គ យរ ១២:៧
**២:២** ឃ ទដ ២១:៩ ង ខ.១៧ បទ ៣:៤៣ ច ទដ ៨៩:៣៩–៤០ មីក ៥:១១

និងមើល ៩:១៨ ១៣:១៧ ១៤:១៧ ។ *ពួកខ្មាំងសត្រូវបានឈ្នះហើយ* មើល ខ.៩ ។

**១:១៧** *ធ្វើជាខ្មាំងសត្រូវនឹងគាត់* មើល ខ.២ ។ *របស់ស្មោកគ្រោក* មើលការពន្យល់ ខ.៨ ហើយចំពោះការបង្ហាញអំពីរូបភាពដូចនេះ នៅក្នុងព្រះគម្ពីរផ្សេងទៀត មើល អរ ៩:១១ អស ៣០:២២ ៦៤:៦ អគ ៧:១៩–២០ ៣៦:១៧ ។

**១:១៨** *សុចរិត* គឺមានន័យថា ព្រះទ្រង់ផ្តល់ដំណោះស្រាយដល់ខ្ញុំយ៉ាងត្រឹមត្រូវ ។ *សូមស្តាប់ ហើយពិចារណាមើល* សាសន៍ទាំងឡាយបានទទួលការហៅឱ្យមកធ្វើការកត់សំគាល់ អំពីការជំនុំជម្រះដ៏សុចរិតរបស់ព្រះអម្ចាស់ ក៏ដូចជាការប្រោះលោះដ៏សុចរិតរបស់ទ្រង់ផងដែរ ។

**១:១៩** *ពួកអ្នកដែលធ្លាប់ស្រឡាញ់ខ្ញុំ ... បានបញ្ឆោតខ្ញុំវិញ* មើល ខ.២ និងការពន្យល់ ។ *សំរាប់ចំរើនកំឡាំងខ្លួន* មើលការពន្យល់ ខ.១១ ។

**១:២០** *ចិត្តខ្ញុំម្ចាស់ទុរន់ទុរា* ពាក្យនេះបានលើកមកនិយាយម្តងទៀតនៅក្នុង ២:១១ ។ *នៅខាងក្រៅ ... នៅឯផ្ទះ* មើល យរ ១៤:១៨ ។

**១:២១** *ថ្ងៃ ដែលទ្រង់បានប្រកាសប្រាប់នោះ* គឺថ្ងៃព្រះអម្ចាស់ទ្រង់ជំនុំជម្រះជាតិសាសន៍ទាំងឡាយ (មើល ៤:២១–២២ យរ ២៥:១៥–៣៨ និងការពន្យល់) ។

**១:២២** *អំពើទុច្ចរិត ... នៅចំពោះទ្រង់* មើល ទដ ១០៩:១៤–១៥ ។ *ចិត្តខ្ញុំម្ចាស់ក៏ល្វើយផង* ឃ្លាដូចនេះមានប្រើនៅក្នុង យរ ៨:១៨ ផងដែរ (មើល បទ ៥:១៧ អស ១:៥)

**២:១–២២** នៅក្នុងវគ្គនេះ អ្នកនិពន្ធបានពិពណ៌នាអំពីទីក្រុងយេរូសាឡិម ដោយប្រដូចទៅនឹងស្ត្រីម្នាក់ ហើយទីក្រុងនេះគឺតំណាងឱ្យនគរមួយ (មើលការពន្យល់ ១:១–២២) ។ នៅក្នុងវគ្គ ខ.១–១០ អ្នកនិពន្ធបានរៀបរាប់អំពីបទពិសោធន៍ ដែលទីក្រុងយេរូសាឡិមមានជាមួយនឹងសេចក្តីក្រោធរបស់ព្រះអម្ចាស់ ដោយប្រើសព្វនាមទីបីជំនួសឱ្យទីក្រុងនេះ ។ វគ្គ ខ.១២–១៩ បានរៀបរាប់អំពីទីក្រុងយេរូសាឡិម ដោយគ្មានការប្រៀបប្រដូចអ្វីឡើយ ។ ពាក់កណ្តាលវគ្គ (ខ.១១–១២) ចាប់ផ្តើមនិយាយអំពីទីក្រុងនេះ ដោយប្រើសព្វនាមទីមួយ (មើលការពន្យល់ ១:១–១១) ។ ពាក្យសម្តីដែលប្រើសព្វនាមពីមួយនៅក្នុង ខ.២០–២២ គឺពាក្យរបស់ទីក្រុងយេរូសាឡិម ។

**២:១** *យ៉ាងណាហ្ន៎* មើលការពន្យល់ ១:១ ។ *កូនស្រីនៃក្រុងស៊ីយ៉ូន* គឺជាការរៀបរាប់អំពីក្រុងយេរូសាឡិម ដោយប្រៀបប្រដូចទៅនឹងមនុស្ស (មើលឃ្លាស្រដៀង ឬដូចគ្នានឹងឃ្លានេះ នៅក្នុង ខ.២,៤–៥,៨,១០,១៣,១៥,១៨ និងមើលការពន្យល់ ២ពវ ១៩:២១) ។ *ទំលាក់សេចក្តីលំអររបស់អ៊ីស្រាអែល* គឺប្រៀបបានទៅនឹងផ្កាយព្រឹកដែលត្រូវទម្លាក់ចុះមក (អស ១៤:១២) ។ *កំណល់កល់ព្រះបាទ* គឺ (១).ហិបសញ្ញា (មើល ១រប ២៨:២) ឬ (២).ភ្នំស៊ីយ៉ូន (មើល ទដ ៩៩:៥ និងការពន្យល់) ។

**២:២** *លេបអស់ទាំងទីលំនៅ* មើល ខ.៥ ។ *កូនស្រីយូដា* មើលការពន្យល់ ខ.១ ។

ទីទាំងនោះចុះដល់ដី[ឆ] ហើយបានបន្ទាបបន្ថោកទាំងនគរ
នឹងពួកចៅហ្វាយផង ៣ក្នុងគ្រាដែលទ្រង់មានសេចក្ដីខ្ញាល់
ដ៏សហ័ស នោះទ្រង់បានកាត់ស្នែង[ជ]របស់អ៊ីស្រាអែលចេញ
ក៏បានដកព្រះហស្តស្តាំ[ឈ]ទ្រង់ចេញពីមុខខ្មាំងសត្រូវ ហើយ
បានបញ្ឆេះយ៉ាកុបដូចជាភ្លើងឆេះថ្កោលឡើងបន្សុសគ្រប់
ជុំវិញ[ញ] ៤ទ្រង់បានយឹតធ្នូ[ដ] ដូចជាខ្មាំងសត្រូវ ទ្រង់បានលើ
ព្រះហស្ត ដូចជាអ្នកតាំង ក៏បានប្រហារជីវិតនៃគ្រប់ទាំង
អស់ដែលគាប់ភ្នែក[ឋ] ឯនៅក្នុងត្រសាល[ឌ]នៃកូនស្រីស៊ីយ៉ូន
នោះទ្រង់បានចាក់សេចក្ដីក្រោធរបស់ទ្រង់ចេញ[ឍ]ដូចជា
ភ្លើង[ណ] ៥ព្រះអម្ចាស់ទ្រង់បានត្រឡប់ដូចជាខ្មាំងសត្រូវ[ត]
ហើយបានលេបអ៊ីស្រាអែលបាត់ទៅ ទ្រង់បានលេបអស់
ទាំងដំណាក់របស់គេ ហើយបំផ្លាញទីមាំមួនទាំងប៉ុន្មាន[ថ]
ព្រមទាំងចំរើនការសោកសៅ និងការយំទួញ[ទ] ក្នុងកូន
ស្រីយូដាជាច្រើនឡើង[ធ] ៦ទ្រង់បានកន្ត្រាក់យកព្រះពន្លា
របស់ទ្រង់ចេញ ដោយកំឡាំង ទុកដូចជាសួនច្បារ ក៏បាន
បំផ្លាញ[ន]ទីក្រុងរបស់ទ្រង់ចោល[ប] ព្រះយេហូវ៉ាទ្រង់បាន
បំភ្លេចជំនុំមុតមាំ និងថ្ងៃឈប់សំរាក[ផ] ឱ្យសូន្យបាត់ពីក្រុង
ស៊ីយ៉ូនទៅហើយ ក្នុងសេចក្ដីគ្នាន់ក្នាញ់របស់សេចក្ដីខ្ញាល់
ទ្រង់ នោះទ្រង់បានស្អប់ខ្ពើមដល់ទាំងស្តេច និងសង្ឃផង[ព]
៧ព្រះអម្ចាស់ ទ្រង់បានបោះបង់ចោលអាសនារបស់ទ្រង់
ហើយបានខ្ពើមឆ្អើមចំពោះទីបរិសុទ្ធរបស់ទ្រង់ដែរ[ភ] ទ្រង់
បានប្រគល់អស់ទាំងកំផែងនៃព្រះរាជវាំង[ម]នៅក្នុងកណ្ដាប់
ដៃនៃពួកខ្មាំងសត្រូវ គេបានស្រែកហ៊ោនៅក្នុងព្រះវិហារ
នៃព្រះយេហូវ៉ា ដូចនៅថ្ងៃបុណ្យហឺកហ៊ាក់[យ] ៨ព្រះយេហូវ៉ា
ទ្រង់បានសំរេចនឹងបំផ្លាញកំផែងនៃកូនស្រីស៊ីយ៉ូនបង់[រ] ក៏
បានលាតខ្សែរង្វាស់ហើយ[ល] ឥតដកព្រះហស្តចេញពីការ
បំផ្លាញឡើយ ទ្រង់បានបណ្ដាលឱ្យទាំងរបងសីមា[វ] និង
កំផែងទួញទំនួញ ហើយរោយរៀវទៅជាមួយគ្នា[ស] ៩ទ្វារ
ទីក្រុង[ហ]ទាំងប៉ុន្មានបានស្រុតចុះទៅក្នុងដី ទ្រង់បានបំបាក់
បំផ្លាញរនុក[ឡ]ផង ឯស្តេច និងពួកចៅហ្វាយ គេនៅ[អ]
កណ្ដាលពួកសាសន៍ដទៃទាំងប៉ុន្មាន ឃ្លាតផុតពីក្រិត្យវិន័យ[ក]
អើ ទាំងពួកហោរា[ខ]ក៏លែង ឃើញការជាក់ស្តែង[គ]ពីព្រះ
យេហូវ៉ាទៀតដែរ ១០ពួកចាស់ទុំរបស់កូនស្រីស៊ីយ៉ូន គេ
អង្គុយនៅដី ឥតមាត់កអ្វីឡើយ[ឃ] គេបានបាចធូលីដី[ង]ទៅលើ
ក្បាល[ច] ហើយស្លៀកសំពត់ធ្មៃ[ឆ] ពួកក្រមុំៗនៃក្រុងយេរូសា–
ឡិមក៏សំយុកក្បាលដល់ដី[ជ]។
១១ភ្នែកខ្ញុំរលាយទៅដោយហូរហាម[ឈ] ចិត្ត[ញ]ខ្ញុំក៏ទន់

**២:២** ឆ អស ២៥:១២ **២:៣** ជ ទដ ៧៥:៥,១០ ឈ ទដ ៧៤:១១ ញ អស ៤២:២៥ យរ ២១:៤–៥,១៤ **២:៤** ដ យប ៣:២៣ ១៦:១៣ បទ ៣:១២–១៣ ឋ ទដ ៤៨:២ អគ ២៤:១៦,២៥ ឌ យរ ៤:២០ ឍ ២របា ៣៤:២១ អគ ២០:៣៤ ណ អស ៤២:២៥ យរ ៧:២០ **២:៥** ត យប ១៣:២៤ ថ ខ.២ ទ អស ២៩:២ ធ យរ ៧:២០ ៩:១៧–២០ **២:៦** ន ២របា ៣៦:១៩ ប យរ ៥២:១៣ ផ សផ ៣:១៨ ព អស ៤៣:២៨ យរ ៧:១៤ បទ ៤:១៦ ៥:១២ **២:៧** ភ លវ ២៦:៣១ អគ ៧:២៤ ម ទដ ៧៤:៧–៨ អស ៦៤:១១ យរ ៣៣:៤–៥ អគ ៧:២១–២២ យ យរ ២១:៤ ៥២:១៣ **២:៨** រ ខ.១៨ ល ២ពវ ២១:១៣ វ ទដ ៤៨:១៣ ស អស ៣:២៦ យរ ៣៩:៨ ៥២:១៤ **២:៩** ហ នហ ១:៣ ឡ អស ៤៥:២ ហស ១១:៦ អ ចទ ២៨:៣៦ ២ពវ ២៤:១៥ យរ ១៦:១៣ ហស ៣:៤ ក ២របា ១៥:៣ ខ ១សយ ៣:១ គ យរ ១៤:១៤ **២:១០** ឃ បទ ៣:២៨ ង សហ ៧:៦ ច យប ២:១២ ឆ អស ៣:២៤ ជ យប ២:១៣ អស ៣:២៦ អគ ២៧:៣០–៣១ **២:១១** ឈ ទដ ១១៩:៨២ អស ១៥:៣ បទ ១:១៦ ៣:៤៨–៥១ ញ យប ៣០:២៧ បទ១:២០

**២:៣** *កាត់ស្នែងរបស់អ៊ីស្រាអែល* ស្នែងគឺជានិមិត្តរូបនៃកំឡាំង ។ *ភ្លើងឆេះថ្កោលឡើងបន្សុសគ្រប់* មើល ១:១៣ និងការពន្យល់ ។

**២:៤** *យឹតធ្នូ* មើល ៣:១២ ចទ ៣២:៤២ ទដ ៧:១២–១៣ ហាព ៣:៩ ។ *ចាក់... ចេញ* ព្រះគម្ពីរសញ្ញាចាស់ប្រើពាក្យនេះយ៉ាងទូលំទូលាយ ដើម្បីបង្ហាញអំពីសេចក្ដីក្រោធរបស់ព្រះ(មើល ទដ ៦៩:២៤ ៧៩:៦ យរ ៦:១១ ៧:២០ ១០:២៥ ៤២:១៨ ៤៤:៦ ហស ៥:១០ សផ ៣:៨)។ *កូនស្រីស៊ីយ៉ូន* មើលការពន្យល់ ខ.១ ។

**២:៥** *ដំណាក់... ទីមាំមួន* មើល ហស ៨:១៤ ។ *កូនស្រីយូដា* មើលការពន្យល់ ខ.១ ។

**២:៦** *ព្រះពន្លារបស់ទ្រង់ . . . ទីប្រជុំរបស់ទ្រង់* គឺព្រះវិហារក្រុងយេរូសាឡិម(មើល ១ពវ ៨:២៩ ៩:៣ ២របា ៦:២ ៧:១–៣ ទដ ២៧:៧–១០ និងការពន្យល់ និងមើល ១៣២:៨,១៣–១៤)។ *ទុកដូចជាសួនច្បារ* ធៀបនឹង អស ៥:៥–៦ យរ ៥:១០ ១២:១០ ។

**២:៧** *បោះបង់ចោលអាសនារបស់ទ្រង់ នោះទ្រង់បានស្អប់ខ្ពើម* ពាក្យទាំងពីរនេះមានប្រើនៅក្នុង ទដ ៨៩:៣៨–៣៩("បោះបង់ចោល . . . លើកចោល") ដែលមានទំនាក់ទំនងនឹងការដែលព្រះអម្ចាស់ទ្រង់បោះបង់ចោលក្សត្រដែលចេញពីវង្សដាវីឌ ។ *គេបានស្រែកហ៊ោនៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា* មើល ទដ ៧៤:៤ ។ *ដូចនៅថ្ងៃបុណ្យហឺកហាក់* មើល ទដ ៤២:៤ ៤៧:៥ ៨១:១–៤ ។ នៅត្រង់ចំណុចនេះ ការស្រែកហ៊ោរបស់ពួកខ្មាំងសត្រូវដែលបានទទួលជ័យជំនះ បានធ្វើឱ្យមានភាពស្ងប់ស្ងាត់ ដល់ការស្រែកហ៊ោដោយអំណររបស់ពួកអ្នកដែលថ្វាយបង្គំនៅព្រះវិហារ ។

**២:៨** *បានសំរេចនឹងបំផ្លាញ* មើល យរ ១:១៥ ៣២:៣១ ។ *កូនស្រីស៊ីយ៉ូន* មើលការពន្យល់ ខ.១ ។ *បានលាតខ្សែរង្វាស់ហើយ* គឺបំផ្លាញតាមរង្វាស់ដែលបានប្រើនៅក្នុងការងារសំណង់(មើល អស ២៨:១៧ អម ៧:៧–៨ និងការពន្យល់)។ *របងសីមា និងកំផែង* ធៀបនឹង អស ២៦:១ ។ របងសីមាគឺសម្រាប់ការពារផ្នែកខាងក្រៅ(មើល ២សយ ២០:១៥)។

**២:៩** *ឃ្លាតផុតពីក្រិត្យវិន័យ* គឺមានន័យថា គ្មានពួកសង្ឃ(មើល ខ.២០) បង្រៀន និងកាត់ស្រាយក្រិត្យវិន័យទៀតទេ(មើល យរ ១៨:១៨ ហស ៤:៤–៩ និងការពន្យល់)។ *ពួកហោរាក៏លែងឃើញការជាក់ស្តែង* នៅត្រង់ចំណុចនេះ ព្រះអម្ចាស់ទ្រង់ឈប់មានបន្ទូលទៅកាត់រាស្ត្ររបស់ទ្រង់ តាមរយៈពួកហោរាទៀតឡើយ(មើល ទដ ៧៤:៩ អម ៨:១១ និងការពន្យល់ និងមើល មីក ៣:៧)។

**២:១០** *ពួកចាស់ទុំ* មើលការពន្យល់ នក ៣:១៦ ។ *កូនស្រីស៊ីយ៉ូន* មើលការពន្យល់ ខ.១ ។ *អង្គុយនៅដី ឥតមាត់កអ្វីឡើយ . . . បាចធូលីដីទៅលើក្បាល ហើយស្លៀកសំពត់ធ្មៃ . . . សំយុងក្បាល* គឺជាសញ្ញានៃការកាន់ទុក្ខ(មើល យប ២:១២–១៣ ទដ ៣៥:១៣–១៤) ។ *ពួកក្រមុំៗនៃក្រុងយេរូសាឡិម*

ទុរន់ទុរា[ដ] ហើយត្រូវស្រលុងចុះ[ឋ]ដល់ដីផង ដោយព្រោះ
ការបំផ្លាញកូនស្រីនៃសាសន៍ខ្ញុំ[ឌ] ហើយដោយព្រោះកូនតូច
នឹងកូនដែលនៅបៅ វាសន្លប់[ឍ]ទៅនៅតាមផ្លូវទីក្រុង ១២វា
សួរដល់ម្តាយថា តើអង្ករនឹងស្រាទំពាំងបាយជូរនៅឯ
ណា[ណ] ក៏វាសន្លប់ទៅតាមផ្លូវនៃទីក្រុង[ត] ដូចជាមនុស្ស
របួសវាដាច់ខ្យល់នៅលើទ្រូងម្តាយ[ថ] ១៣ឱកូនស្រីនៃក្រុង
យេរូសាឡិម អើយ តើត្រូវឱ្យខ្ញុំធ្វើបន្ទាល់ដល់នាងយ៉ាង
ណា[ទ] តើនឹងធៀបនាងដូចជាអ្វី ឱកូនស្រីក្រមុំ[ធ]នៃស៊ីយ៉ូន
អើយ[ន] តើខ្ញុំនឹងផ្ទឹមនាងនឹងអ្វី ដើម្បីនឹងកំសាន្តចិត្តនាងបាន
ដ្បិតការអន្តរាយរបស់នាងធំដូចជាសមុទ្រហើយ[ប] តើអ្នក
ណានឹងមើលឱ្យជាបាន ១៤ពួកហោរារបស់នាងបានឃើញ
ការជាក់ស្តែងក្លែងក្លាយ[ផ] ហើយផ្តេសផ្តាស គេមិនបាន
បើកឱ្យឃើញសេចក្តីទុច្ចរិតរបស់នាង ប្រយោជន៍នឹងនាំ
ពួកនាង ដែលនៅជាឈ្លើយឱ្យបានមកវិញទេ[ព] គឺគេបាន
ឃើញតែសេចក្តីកំភូត និងសេចក្តីដែលបណ្តាលឱ្យត្រូវ
និរទេសវិញប៉ុណ្ណោះ[ភ] ១៥អស់អ្នកណាដែលដើរបង្ហួស
គេទះដៃឡកឱ្យនាង[ម] គេធ្វើសឺសស៊ូស[យ] ហើយគ្រវីក្បាល[រ]
ដល់កូនស្រីក្រុងយេរូសាឡិម[ល] ដោយពាក្យថា ទីក្រុងនេះ
ឬដែលមនុស្សបានហៅថាជាទីល្អបំផុត[វ] ហើយជាទីរីករាយ
ដល់ផែនដីទាំងដុំមូលនោះ[ស] ១៦ពួកខ្មាំងសត្រូវទាំងប៉ុន្មាន
របស់នាងបានហាមាត់ធំដាក់នាង[ហ] គេធ្វើសឺសស៊ូស ហើយ
សង្កៀតធ្មេញ[ឡ] ដោយពាក្យថា យើងបានលេបវាបាត់
ហើយ[អ] ពិតប្រាកដជាថ្ងៃនេះហើយ ជាថ្ងៃដែលយើងសង្ឃឹម
ចង់បាននោះ ឥឡូវបានប្រទះបានឃើញហើយ[ក] ១៧ព្រះ
យេហូវ៉ា ទ្រង់បានធ្វើការដែលទ្រង់គិតធ្វើ ទ្រង់បានសំរេច
តាម[ខ]ព្រះបន្ទូលដែលទ្រង់បានបង្គាប់ពីចាស់បុរាណ[គ] គឺទ្រង់
បានរំលំឥតប្រណី[ឃ] ហើយបានធ្វើឱ្យខ្មាំងសត្រូវមានសេច
ក្តីអំណរ[ង] ពីដំណើរនាងទ្រង់បានលើកដំកើងស្នែងរបស់
ពួកដែលតតាំងនឹងនាង[ច]។
១៨ចិត្តរបស់គេបានអំពាវនាវដល់ព្រះអម្ចាស់[ឆ]. . . ឱ
កំផែងនៃកូនស្រីស៊ីយ៉ូនអើយ[ជ] ចូរឱ្យមានទឹកភ្នែក[ឈ]ហូរ
សស្រាក់ ដូចជាទន្លេទាំងយប់ទាំងថ្ងៃចុះ[ញ] កុំឱ្យឈប់សំរាក
ឡើយ កុំឱ្យប្រស្រីភ្នែករបស់នាងឈប់ផ្អាកឱ្យសោះ[ដ] ១៩ចូរ

**២:១១** ឈ ទដ ១១៩:៨២ អស ១៥:៣ បទ ១:១៦ ៣:៤៨–៥១ ញ យប ៣០:២៧ បទ ១:២០ ដ ខ.១៩ ទដ ២២:១៤ ឋ អស ១:៥ ឌ យរ ៩:១ ឍ បទ ៤:៤ **២:១២** ណ អស ២៤:១១ ត យប ៣:២៤ ថ បទ ៤:៤ **២:១៣** ទ អស ១:៦ ធ ២ពរ ១៩:២១ ន អស ៣៧:២២ ប យរ ១៤:១៧ ៣០:១២–១៥ បទ ១:១២ **២:១៤** ផ យរ ២៨:១៥ ព យរ ៨:១១ ភ យរ ២:៨ ២០:៦ ២៣:២៥–៣២,៣៣–៤០ ២៩:៩ អគ ១៣:៣ ២២:២៨ **២:១៥** ម ជន ២៤:១០ អគ ២៥:៦ យ ចទ ២៨:៣៧ អស ២៨:២២ យរ ១៩:៨ ណហ ៣:១៩ រ យប ១៦:៤ ល បទ១:២១ វ ទដ ៤៥:១១ ៤៨:២ ៥០:២ អគ ១៦:១៤ ស ទដ ៤៨:២ **២:១៦** ហ ទដ ២២:១៣ បទ ៣:៤៦ ឡ យប ១៦:៩ អ ទដ ៣៥:២៥ អគ ៣៦:៣ មីក ៤:១១ **២:១៧** ខ យរ ៣៩:១៦ គ ចទ ២៨:១៥–៤៥ ឃ ខ.២ អគ ៥:១១ ៧:៩ ៨:១៨ ង ទដ ២២:១៧ ច ទដ ៨៩:៤២ អស ៤៤:២៦ បទ ១:៥ សក ១:៦ ឌ ខ.៤៤ ចទ ១:៤៥ យប ៣០:២០ទដ ២២:២ **២:១៨** ឆ ទដ ១១៩:១៤៥ ជ ខ.៨ ឈ បទ ១:១៦ ញ យរ ៩:១ ដ បទ៣:៤៩

មើល ១:១៤ និងការពន្យល់ ។

**២:១១** *ខ្ញុំ . . . ខ្ញុំ . . . ខ្ញុំ* មើលការពន្យល់ ខ.១–២២ ។ អ្នកនិយាយនៅក្នុងខនេះ ក៏បាននិយាយនៅក្នុង ខ.១–១០ និង ១:១–១១ ផងដែរ(មើលការពន្យល់ក្នុងវគ្គ នេះ)។ នៅក្នុងខនេះ គាត់និយាយដោយចាប់ផ្តើមរៀបរាប់អំពីទុក្ខសោកដ៏ខ្លាំងរបស់ខ្លួន ដោយសាស្ថានភាពរបស់ទីក្រុងយេរូសាឡិម ជាពិសេសសេចក្តីវេទនារបស់កូនតូចៗរបស់ទីក្រុងនេះ(ខ.១១–១២) ហើយគាត់ក៏និយាយអំពីទីក្រុងយេរូសាឡិមដោយចំៗ មិនមានការប្រៀបប្រដូចអ្វីឡើយ(ខ.១៣–១៩)។ *ហូររហាម* មើលការពន្យល់ ១:១៦ ។ *ចិត្តខ្ញុំក៏ទុរន់ទុរា* ពាក្យបានប្រើម្តងទៀត បន្ទាប់ពី ១:២០ ។ *កូនស្រីនៃសាសន៍ខ្ញុំ* មើលការពន្យល់ ខ.១ ។ ឃ្លានេះក៏មានប្រើនៅក្នុង ៣:៤៨ ៤:៣,៦,១០ អស ២២:៤ យរ ៨:១១,២១ ធៀបនឹង យរ ១៤:១៧ ។

**២:១៣** *តើត្រូវឱ្យខ្ញុំធ្វើបន្ទាល់ដល់នាងយ៉ាងណា* មានន័យថា អ្នកនិពនលោកមិនដឹងជាត្រូវប្រើពាក្យអ្វី ដើម្បីកម្សាន្តសេចក្តីទុក្ខរបស់ទីក្រុងយេរូ–សាឡិមទេ ។ *កូនស្រីនៃក្រុងយេរូសាឡិម . . . កូនស្រីក្រមុំនៃស៊ីយ៉ូន* មើលការពន្យល់ ខ.១ ។

**២:១៤** *ពួកហោរា . . . ក្លែងក្លាយ* លោកយេរេមាតែងតែនិយាយទាស់ប្រឆាំងនឹងពួកហោរក្លែងក្លាយជានិច្ច(មើល យរ ៥:១២–១៣ ៦:១៣–១៤ ៨:១០–១១ ១៤:១៣–១៥ ២៣:៩–៤០ ២៧:៩–២៨:១៧ ធៀបនឹង យរ ២៦:៧–១១,១៦ អគ ២២:២៦,២៨)។ *ផ្តេសផ្តាស* ឬមានន័យម្យ៉ាងទៀតថា "គ្របបាំងការពិត" ។ ចំពោះការពន្យល់អត្ថន័យនៃពាក្យនេះ មើល អគ ១៣:១០–១៦ ២២:២៨ ។ *បណ្តាលឱ្យត្រូវនិរទេស* នៅក្នុងព្រះគម្ពីរភាសាហេព្រើ ពាក្យនេះ និងពាក្យ "ព្រាត់ចាកឆ្ងាយ" នៅក្នុង យរ ២៧:១០,១៥ គឺមានឫសដូចគ្នា ។

**២:១៥** *អស់អ្នកណាដែលដើរបង្ហួស* មើល ១:១២ ។ *ទះដៃ* មើល យប ២៧:២៣ ៣៤:៣៧ ។ *ធ្វើសឺសស៊ូស* មើល ខ.១៦ និងមើលការពន្យល់ យរ ១៩:៨ ។ *គ្រវីក្បាល* មើល យប ១៦:៤ និងការពន្យល់ និងមើល ទដ ៤៤:១៤ ៦៤:៨ ១០៩:២៥ យរ ១៨:១៦ ។ *កូនស្រីក្រុងយេរូសាឡិម* មើលការពន្យល់ ខ.១ ។ *បានហៅថាជាទីល្អបំផុត* គឺដូចនៅក្នុង ទដ ៥០:២ (មើលការពន្យល់ខនេះ)។ *ជាទីរីករាយដល់ផែនដីទាំងមូល* គឺដូចនៅក្នុង ទដ ៤៨:២(មើលការពន្យល់ខនេះ និងធៀបនឹង យរ ៥១:៤១)។

**២:១៦** *បានហាមាត់ធំ* គឺដើម្បីស្តីបន្ទោសឱ្យ ឬដើម្បីត្របាក់លេបទាំងមូល (មើល ជន ១៦:៣០ ទដ ២២:១៣ អស ៥:១៤ ៩:១២)។ *បានលេបវាបាត់ហើយ* មើល ខ.២,៥ យរ ៥១:៣៤ ។

**២:១៧** *ធ្វើការដែលទ្រង់គិតធ្វើ* មើល អស ៥៥:១១ និងការពន្យល់ ។ *ពីចាស់បុរាណ* គឺតាំងពីសម័យលោកម៉ូសេ(មើលឧទាហរណ៍នៃការគម្រាមកំហែងនៅក្នុង លវ ២៦:២៣–៣៩ ចទ ២៨:១៥–៦៨)។ *លើកដំកើងស្នែង* គឺមានន័យថា បង្កើនកម្លាំង(មើល ១សយ ២:១ ទដ ៧៥:៤)។

**២:១៨** មើល យរ ១៤:១៧ ។ *ឱ កំផែង* ទ្វារក្រុងត្រូវបានលើកឡើងតាមរបៀបស្រដៀងគ្នានេះផងដែរនៅក្នុង អស ១៤:៣១ ។ *កូនស្រីស៊ីយ៉ូន* មើលការពន្យល់ ខ.១ ។

ក្រោកឡើងទាំងយប់ ហើយស្រែកនៅពេលដើម យាមចុះ
ត្រូវឱ្យចាក់ចិត្តនាងចេញ[ឋ] ដូចជាទឹកនៅចំពោះព្រះភក្ត្រ
អម្ចាស់[ឌ] ចូរប្រទូលដៃ[ឍ]ឡើងទៅឯទ្រង់ ដើម្បីអង្វរឱ្យបាន
ជីវិតនៃក្មេងតូចៗរបស់នាង ដែលសន្លប់[ណ]ទៅ ដោយឃ្លាន
ត្រង់គ្រប់ទាំងក្បាលផ្លូវ ឱ្យបានគង់នៅវិញ ។
២០ ឱព្រះយេហូវ៉ាអើយ សូមទតពិចារណាមើល ដែល
ទ្រង់បានធ្វើការនេះដល់អ្នកណា តើត្រូវឱ្យពួកស្រីៗស៊ីកូន
ខ្លួន[ត] គឺជាកូនដែលម្តាយបីក្រសោបនៅដៃឬអី[ថ] តើពួកសង្ឃ
នឹងពួកហោរានឹងត្រូវគេសំឡាប់[ទ] នៅក្នុងទីបរិសុទ្ធនៃព្រះ
អម្ចាស់ឬ[ធ] ២១ ទាំងពួកជំទង់ និងពួកចាស់ៗសុទ្ធតែដេក នៅ
ដីតាមផ្លូវ ឯពួកក្រមុំ និងពួកកំលោះៗរបស់ខ្ញុំម្ចាស់ គេបាន
ដួលស្លាប់ដោយដាវ[ន] ទ្រង់បានប្រហារជីវិតគេ ក្នុងថ្ងៃ
ដែលទ្រង់ខ្ញាល់ ទ្រង់បានកាប់សំឡាប់គេឥតប្រណីឡើយ[ប]
២២ ទ្រង់បានហៅប្រមូល ដូចជានៅថ្ងៃបុណ្យមុតមាំ ឱ្យសេច
ក្ដីស្ញែងខ្លាច[ផ]មកលើខ្ញុំម្ចាស់នៅគ្រប់ជុំវិញ គ្មានអ្នកណា
រត់រួច[ព] ឬសល់នៅ ក្នុងថ្ងៃនៃសេចក្តី ខ្ញាល់របស់ព្រះ
យេហូវ៉ាឡើយ ពួកកូនដែលខ្ញុំម្ចាស់បានបី ក្រសោបនៅដៃ
ហើយបានបីបាច់ចិញ្ចឹមមក[ភ] នោះខ្មាំងសត្រូវរបស់ខ្ញុំម្ចាស់
បានសំឡាប់អស់ហើយ ។
**៣** ១ ខ្ញុំជាមនុស្ស ដែលបានឃើញសេចក្តីវេទនា[ក] ដោយ
ដំបងនៃសេចក្ដីក្រោធរបស់ទ្រង់[ខ] ២ ទ្រង់បាននាំខ្ញុំឱ្យដើរ
ក្នុងសេចក្តីងងឹត[គ] មិនមែនក្នុងពន្លឺទេ ៣ ពិតប្រាកដជាទ្រង់
បានបែរព្រះហស្តមកទាស់នឹងខ្ញុំ[ឃ]ខ្ទាន់ៗជានិច្ចរាល់តែថ្ងៃ
៤ ទ្រង់បានធ្វើឱ្យសាច់ ហើយស្បែកខ្ញុំរោយរៀវទៅ[ង] ហើយ
បានបំបាក់ឆ្អឹងខ្ញុំផង[ច] ៥ ទ្រង់បានធ្វើរបងឃុំឃាំងខ្ញុំ ហើយ
បានឡោមព័ទ្ធខ្ញុំដោយថ្នាំពុល[ឆ] និងការដែលនឿយលំបាក[ជ]
៦ ទ្រង់បានឱ្យខ្ញុំអាស្រ័យនៅទីងងឹត ដូចជាពួកដែលបាន
ស្លាប់ជាយូរមកហើយ[ឈ] ៧ ទ្រង់បានធ្វើកំផែងព័ទ្ធជុំវិញខ្ញុំ
ដើម្បីមិនឱ្យខ្ញុំចេញទៅក្រៅឡើយ[ញ] ដ៏មិនបានធ្វើឱ្យច្រវាក់ខ្ញុំ
ជាធ្ងន់[ដ] ៨ អើកាលណាខ្ញុំអំពាវនាវ ហើយស្រែកឡើងឱ្យ

**២:១៩** ឋ ១សយ ១:១៥ ឌ ខ.១១ អស ២៦:៩ ឍ ទដ ២៨:២ ណ អស ៥១:២០ **២:២០** ត ចទ ២៨:៥៣ យរ ១៩:៩ អគ ៥:១០ ថ បទ ៤:១០ ទ ទដ ៧៨:៦៤ យរ ១៤:១៥ ២៣:១១–១២ ធ បទ ១:១៩ **២:២១** ន ចទ ៣២:២៥ ២របា ៣៦:១៧ ទដ ៧៨:៦២–៦៣ យរ ៦:១១ ប យរ ១៣:១៤ បទ ៣:៤៣ សក ១១:៦ **២:២២** ផ ទដ ៣១:១៣ យរ ២០:១០ ព យរ ១១:១១ ភ យប ២៧:១៤ ហស ៩:១៣ **៣:១** ក យរ ១៥:១៧–១៨ ខ យប ១៩:២១ ទដ ៨៨:៧ **៣:២** គ យប ១៩:៨ ទដ ៨២:៥ យរ ៤:២៣ **៣:៣** ឃ ទដ ៣៨:២ អស ៥:២៥ **៣:៤** ង យប ៣០:៣០ បទ ៤:៨ ច ទដ ៥១:៨ អស ៣៨:១៣ យរ ៥០:១៧ **៣:៥** ឆ ខ.១៩ ជ យរ ២៣:១៥ **៣:៦** ឈ ទដ ៨៨:៥–៦ ១៤៣:៣ អស ៥៩:១០ **៣:៧** ញ យប ៣:២៣ ដ យរ ៤០:៤

**២:១៩** *ក្រោកឡើងទាំងយប់* មើលការពន្យល់ ពច ៧:១៩ និងមើល ទដ ៦៣:៦ ។ *ចាក់ចិត្តនាងចេញ* គឺចាក់ចិត្តនៅក្នុងការអធិស្ឋានដ៏ខ្លាំងអស់ពីចិត្ត (មើល ទដ ៦២:៨) ។ *ដូចជាទឹក* គឺជាការប្រៀបធៀបដូចពាក្យ "ចាក់ចិត្តផងដែរ" (មើល ចទ ១២:១៦,២៤ ១៥:២៣ ទដ ៧៩:៣ ហស ៥:១០) ។ *ប្រទូលដៃឡើង* គឺនៅក្នុងការអធិស្ឋាន (មើល ទដ ២៨:២ និងការពន្យល់ និងមើល ១ធថ ២:៨) ។ *ក្មេងតូចៗរបស់នាង ដែលសន្លប់ទៅដោយឃ្លាន* មើល ខ.១១–១២ ។

**២:២០–២២** វគ្គនេះគឺអំពីការអធិស្ឋានដោយឈឺចាប់ របស់ក្រុងយេរូ–សាឡិម ដែលជាការឆ្លើយតបនឹង ខ.១៩ ។

**២:២០** *ពួកស្រីៗស៊ីកូនខ្លួន* មើលការពន្យល់ យរ ១៩:៩ ។

**២:២១** មើល យរ ៦:១១ និងការពន្យល់ ។

**២:២២** *ហៅប្រមូល ដូចជានៅថ្ងៃបុណ្យមុតមាំ* កាលពីមុនព្រះអម្ចាស់ទ្រង់ត្រាសហៅពួកអ៊ីស្រាអែលឱ្យមកឯទ្រង់ ដើម្បីថ្វាយបង្គំទ្រង់ និងសសើរអរព្រះគុណទ្រង់ ដែលបានធ្វើការសង្គ្រោះនៅក្នុងប្រវត្តិសាស្ត្រពួកគេ (មើលឧទាហរណ៍នៅក្នុង ទដ ៨១,៩៥,១១៤) ហើយនៅពេលនេះព្រះអម្ចាស់ទ្រង់ធ្វើការត្រាសហៅដែលផ្សេងពីមុន ។ *សេចក្តីស្ញែងខ្លាចមកលើខ្ញុំម្ចាស់* មើល ១:១៥ ។ *នៅគ្រប់ជុំវិញ* មើលការពន្យល់ យរ ៦:២៥ ។ *ថ្ងៃនៃសេចក្តីខ្ញាល់របស់ព្រះយេហូវ៉ា* ពាក្យនេះបានប្រើនៅចុងបញ្ចប់នៃបទទំនួញ ដូចដែលបានប្រើនៅខាងដើមបទទំនួញផងដែរ (មើល ខ.១) ។ *គ្មានអ្នកណារត់រួច ឬសល់នៅ* មើល យរ ៤២:១៧ ៤៤:១៤ ។ *ពួកកូនដែលខ្ញុំម្ចាស់បានបីក្រសោបនៅដៃ* គឺអ្នកដែលតាំងលំនៅនៅក្នុងក្រុងយេរូសាឡិម ។

**៣:១–៦៦** វគ្គនេះគឺជាបទទំនួញមួយទៀត ដែលមានលក្ខណៈខុសពីបទទំនួញដទៃទៀតនៅក្នុងព្រះគម្ពីរនេះ ។ នៅក្នុងព្រះគម្ពីរភាសាហេព្រើ នៅក្នុងជំពូក ១ និង ២ មានការចែកជា២២ល្បះ ដែលល្បះនីមួយៗមាន៣ ឃ្លាហើយពីល្បះមួយទៅល្បះមួយទៀត គឺចាប់ផ្តើមដោយព្យញ្ជនៈតាម លំដាប់នៅក្នុងភាសាហេព្រើ ប៉ុន្តែ នៅក្នុងបទទំនួញនេះវិញ ល្បះនីមួយៗចាប់ផ្តើមដោយព្យញ្ជនៈដូចគ្នា (មើលសេចក្តីផ្តើម ត្រង់ចំណុចលក្ខណៈ អក្សរសាស្ត្រ) ។ បទទំនួញនេះចាប់ផ្តើមនៅ ខ.១–៣៩ ដែលនិយាយអំពីសេចក្តីអធិស្ឋានផ្ទាល់ខ្លួន ដូចនេះក្នុងព្រះគម្ពីរទំនុកតម្កើង ហើយបន្ត ដោយ ខ.៤០–៦៦ (មើលការពន្យល់ ខ.៤៨–៦៦) ដែលជាការបង្ហាញអំពីរបៀបដែលសហគមន៍នៃសាសន៍យូដាត្រូវឆ្លើយតប ចំពោះស្ថានភាពដ៏លំបាក ដែលពួកគេកំពុងជួបប្រទះ ។

**៣:១** ខនេះគឺជាចំណុចកណ្តាលនៃព្រះគម្ពីរនេះ ។ អ្នកនិយាយនៅក្នុងខនេះបានបង្ហាញអំពីអត្តសញ្ញាណរបស់ខ្លួន ដោយប្រើឧទាហរណ៍អំពីអ្នកដែលរងសេចក្តីវេទនាយ៉ាងខ្លាំង ដោយដំបងនៃសេចក្តីក្រោធរបស់ទ្រង់ ។ *សេចក្តីវេទនា* មើល ខ.១៩ ។ *ដំបងនៃសេចក្តីក្រោធរបស់ទ្រង់* មើល យប ៩:៣៤ ២១:៩ ធៀបនឹង អស ១០:៥ និងការពន្យល់ ។

**៣:២** *សេចក្តីងងឹត មិនមែនក្នុងពន្លឺទេ* មើល យប ១២:២៥ ទដ ១៤៣:៣ អស ៥០:១០ ៥៩:៩ ធៀបនឹង អម ៥:១៨ និងការពន្យល់ ។

**៣:៤** *រោយរៀវទៅ* មើល ទដ ៣២:៣ (ខ្សោះទៅ) ទដ ៤៩:១៤ (សូន្យទៅ) ។ *បំបាក់ឆ្អឹងខ្ញុំ* មើល ទដ ៥១:៨ អស ៣៨:១៣ និងការពន្យល់ ។

**៣:៥** *បានឡោមព័ទ្ធខ្ញុំ* មើល យប ១៩:៦ ។ *ថ្នាំពុល* មើល យរ ៨:១៤ និងការពន្យល់ ។ *នឿយលំបាក* មើល នក ១៨:៨ ជន ២០:១៤ នហ ៩:៣២ ។

**៣:៦** មើល ទដ ១៤៣:៣ និងការពន្យល់ ។

**៣:៧** *កំផែង* មើល យប ១៩:៨ និង ហស ២:៦ ។ *មិនឱ្យខ្ញុំចេញទៅក្រៅ* មើល ទដ ៨៨:៨ ។

**៣:៨** *ស្រែកឡើងឱ្យជួយ* មើល ខ.៤៤ យប ៣០:២០ ទដ ១៨:៤១ ២២:២ សភ ១:២៨ យរ ៧:១៦ និងការពន្យល់ ។

ជួយ[ឋ] នោះទ្រង់រាំងមិនឱ្យសេចក្ដីអធិស្ឋានរបស់ខ្ញុំចូលទៅ
ឡើយ[ឌ] ៩ទ្រង់បានយកថ្មដាប់ធ្វើកំផែងរាំង[ឍ]ផ្លូវខ្ញុំ ហើយ
បានធ្វើឱ្យផ្លូវច្រកខ្ញុំវៀចទាំងអស់[ណ] ១០ទ្រង់ប្រៀបដូចជាខ្លា
ឃ្មុំដែលលបសង្គ្រប់ ហើយដូចជាសិង្ហ[ត]នៅទីស្ងាត់កំបាំង
ដល់ខ្ញុំ[ថ] ១១ទ្រង់បានបង្វែរអស់ទាំងផ្លូវរបស់ខ្ញុំ កំហែង[ទ]ខ្ញុំ
ឱ្យខ្ទេចខ្ទី ហើយបានឱ្យខ្ញុំត្រមោចនៅ ១២ទ្រង់បានយឺតធ្នូ[ធ]
ហើយតាំងខ្ញុំទុកជាវង់[ន]សំរាប់ព្រួញ[ប] ១៣ទ្រង់បានធ្វើឱ្យត្បួ
ព្រួញពីបំពង់ទ្រង់ទំលុះ[ផ]ថ្លើមខ្ញុំ[ព] ១៤ខ្ញុំបានទៅជាទីសំណើច[ភ]
ដល់ជនជាតិទាំងឡាយរបស់ខ្ញុំ[ម] ហើយជាបទចំរៀង[យ]របស់
គេជានិច្ចរាល់ថ្ងៃ ១៥ទ្រង់បានចំអែតខ្ញុំ ដោយសេចក្ដីជូរ
ចត់ ព្រមទាំងឱ្យខ្ញុំស្រវឹងដោយស្លែងផង[រ] ១៦ទ្រង់បាន
បំបាក់ធ្មេញខ្ញុំដោយក្រួស[ល] ហើយបានព្រលាំងខ្ញុំដោយ
ផេះ[វ] ១៧ហើយទ្រង់បោះបង់ចោលព្រលឹងរបស់ខ្ញុំឆ្ងាយ
ចេញពីសេចក្ដីសុខទៅ ខ្ញុំបានភ្លេចសេចក្ដីចំរើនហើយ
១៨ខ្ញុំបានថា កំឡាំងខ្ញុំសូន្យបាត់អស់ទៅ សេចក្ដីសង្ឃឹមរបស់
ខ្ញុំក៏ផុតចាកពីព្រះយេហូវ៉ាហើយ[ស]។
១៩ខ្ញុំនឹកចាំពីសេចក្ដីទុក្ខលំបាក និងពីសេចក្ដីវេទនា[ហ]
របស់ខ្ញុំ ព្រមទាំងស្លែង និងថ្នាំពុលផង[ឡ] ២០ព្រលឹងខ្ញុំនៅ
តែចាំបាននៅឡើយ ហើយក៏ឱនចុះ[អ]នៅក្នុងខ្លួនខ្ញុំ[ក] ២១តែ
ខ្ញុំនឹកឡើងវិញពីសេចក្ដីនេះ បានជាខ្ញុំបានសេចក្ដីសង្ឃឹម
ឡើង ២២គឺនឹកពីសេចក្ដីនេះថា កុំតែមានសេចក្ដីសប្បុរស[ខ]
របស់ព្រះយេហូវ៉ា នោះយើងបានសូន្យបាត់អស់រលីងទៅ
ហើយ[គ] ឯសេចក្ដីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុត
ឡើយ[ឃ] ២៣សេចក្ដីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជា
និច្ច សេចក្ដីស្មោះត្រង់របស់ទ្រង់ធំណាស់[ង] ២៤ព្រលឹងខ្ញុំ
បានពោលថា ព្រះយេហូវ៉ាជាចំណែកនៃខ្ញុំ[ច] ហេតុនោះខ្ញុំ
នឹងសង្ឃឹមដល់ទ្រង់ ២៥ព្រះយេហូវ៉ាទ្រង់ល្អដល់អស់អ្នក
ដែលរង់ចាំទ្រង់ គឺដល់ព្រលឹងនៃអ្នកណាដែលស្វែងរក
ទ្រង់[ឆ] ២៦បើមនុស្សនឹងសង្ឃឹមដល់ ហើយរង់ចាំសេចក្ដី

**៣:៨** ឋ ទដ ៥:២ ឌ ខ.៤៤ ចទ ១:៤៥ យប ៣០:២០ ទដ ២២:២ **៣:៩** ឍ យប ១៩:៨ ណ យប ៩:២៤ អស ៦៣:១៧ ហស ២:៦ **៣:១០** ត យប ១០:១៦ ថ ហស ១៣:៨ អម ៥:១៨–១០ **៣:១១** ទ ហស ៦:១ **៣:១២** ធ បទ ២:៤ ន យប ៧:២០ ប យប ១៦:១២ ទដ ៧:១២–១៣ ៣៨:២ **៣:១៣** ផ យប ១៦:១៣ ព យប ៦:៤ **៣:១៤** ភ លប ៣៨:២៣ ទដ ២២:៦–៧ យរ ២០:៧ ម យប

យ យប ៣០:៩ ១៧:២ **៣:១៥** រ ខ.១៩ យរ ៩:១៥ **៣:១៦** ល សភ ២០:១៧ វ ទដ ៧:៥ **៣:១៨** ស ខ.៥៤ យប ១៧:១៥ **៣:១៩** ហ ខ.៥ ឡ ខ.១៥ **៣:២០** អ ទដ ៤២:៥ ក ទដ ៤២:១១ ៤៣:៥ **៣:២២** ខ ទដ ១០៣:១១ គ យប ៣៤:១៥ ហស ១១:៩ ឃ ទដ ៧៨:៣៨ ១៣០:៧ **៣:២៣** ង នក ៣៤:៦ សផ ៣:៥ **៣:២៤** ច ទដ ១១៩:៥៧ **៣:២៥** ឆ ទដ ៣៣:១៨ អស ២៥:៩ ៣០:១៨

**៣:៩** *ថ្មដាប់* គឺមានទំហំធំក្រៃលែង គឺដូចថ្មដែលគេប្រើនៅក្នុងសំណង់គ្រឹះព្រះវិហារស្ដេចសាឡូម៉ូន(មើល ១ពវ ៥:១៧)។ *ធ្វើឱ្យ . . . វៀច* គឺធ្វើឱ្យមិនស្មើ(មើល អស ២៦:៧ ៤៥:២ យរ ៣១:៩ និងការពន្យល់) ឬត្រង់ (មើល ទដ ៥:៨ សភ ៣:៦ និងការពន្យល់ ១១:៥ អស ៤៥:១៣)។

**៣:១០** *ដូចជាខ្លាឃ្មុំ . . . ដូចជាសិង្ហ* មើល យរ ៤:៧ ៥:៦ ៤៩:១៩ ៥០:៤៤ អម ១:២ និងការពន្យល់ និងមើល ៥:១៩ ធៀបនឹង ទដ ៧:២ និងការពន្យល់ ។

**៣:១១** មើល ១:២ ។

**៣:១២** *យឺតធ្នូ* មើលការពន្យល់ ២:៤ ។ *តាំងខ្ញុំទុកជាវង់សំរាប់ព្រួញ* មើលការពន្យល់ យប ៦:៤ ។

**៣:១៣** *ថ្លើម* មើល យប ១៦:១៣ ។ *ព្រួញ* មើល ទដ ៣៨:២ និងការពន្យល់ ។

**៣:១៤** មើលពាក្យត្អូញត្អែររបស់លោកយេរេមានៅក្នុង យរ ២០:៧ ។ *ជាបទចំរៀងរបស់គេ* មើល ខ.៦៣ ទដ ៦៩:១២ ទដ ២២:៦–៧ ធៀបនឹង អស ២៨:៩–១០ និងការពន្យល់ ។

**៣:១៥** *ចំអែតខ្ញុំ ដោយសេចក្ដីជូរចត់* មើល យប ៩:១៨(មើលការពន្យល់ យរ ៩:១៥)។ ពួកអ៊ីស្រាអែលមានប្រពៃណីបរិភោគស្លឹកម្យ៉ាងដែលជូរចត់នៅក្នុងពេលអាហារបុណ្យរំលង(មើល នក ១២:៨)។

**៣:១៦** *បំបាក់ធ្មេញខ្ញុំដោយក្រួស* ធៀបនឹង ទដ ៧២:៩ មីក ៧:១៧ ។ *ព្រលាំងខ្ញុំដោយផេះ* មើល ទដ ៧:៥ ។

**៣:១៨** *សេចក្ដីសង្ឃឹមរបស់ខ្ញុំក៏ផុតចាកពីព្រះយេហូវ៉ា* មើល ទដ ៣៩:៧ ។ ជំពូក៣ និយាយអំពីព្រះអម្ចាស់ច្រើនជាលើកទីមួយនៅក្នុងព្រះគម្ពីរនេះ ។

**៣:១៩–២០** នៅក្នុងវគ្គនេះ អ្នកនិពន្ធបានរំឭកឡើងវិញអំពីគ្រប់ទាំងទុក្ខវេទនាដែលលោកមាន ហើយការនេះគឺជាការត្រៀមនឹងនិយាយអំពីសេចក្ដីសង្ឃឹម និងការលើកទឹកចិត្តនៅក្នុង ខ.២១–៣៩ ។

**៣:១៩** *សេចក្ដីទុក្ខលំបាក និងពីសេចក្ដីវេទនា* មើល ១:៧ ។ *ស្លែង និងថ្នាំពុល* មើល ខ.៥,១៥ ធៀបនឹង យរ ៩:១៥ ។

**៣:២១–២៦** នៅក្នុងព្រះគម្ពីរនេះ វគ្គនេះនិយាយច្រើនបំផុតអំពីវិជ្ជាសិក្សាអំពីព្រះ និងលក្ខណៈវិញ្ញាណ(មើលសេចក្ដីផ្ដើមត្រង់ចំណុច ខ្លឹមសារ និងវិជ្ជាសិក្សាអំពីព្រះ )។

**៣:២២** *សេចក្ដីសប្បុរសរបស់ព្រះយេហូវ៉ា* មើល ខ.៣២ ។ នៅក្នុងភាសាហេព្រើពាក្យនេះគឺជាពហុវចនៈ(ដូចនៅក្នុង ទដ ១០៧:៤៣) ហើយអត្ថន័យនៃពាក្យនេះ គឺសេចក្ដីស្មោះត្រង់ដោយព្រះទ័យស្រឡាញ់របស់ព្រះ ចំពោះសេចក្ដីសន្យានៅក្នុងសេចក្ដីសញ្ញា(មើល ទដ ៨៩:១)។ មើលការពន្យល់ ទដ ៦:៤ មើល អស ៦៣:៧ ("សេចក្ដីសប្បុរស") និងការពន្យល់ ។ *យើង* គឺរាស្ត្ររបស់ព្រះអម្ចាស់ ។

**៣:២៣** *សេចក្ដីទាំងនោះ* គឺ"សេចក្ដីស្រឡាញ់" និង "សេចក្ដីអាណិត" (ខ.២២) នៃព្រះអម្ចាស់ ។ *ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច* មើល ទដ ៣០:៥ និងការពន្យល់ និងមើល អស ៣៣:២ ។ *សេចក្ដីសប្បុរសដ៏បរិបូររបស់ទ្រង់* គឺមិនអាចវាស់ស្ទង់បាន(មើលការពន្យល់ ខ.៣២ និងមើល ទដ ៣៦:៥ និងការពន្យល់)។

**៣:២៤** *ព្រះយេហូវ៉ាជាចំណែកនៃខ្ញុំ* មើល ទដ ៧៣:២៦ ១៤២:៥ និងការពន្យល់ ។ ព្រះអម្ចាស់ទ្រង់មានចំណែកជាមរដកដល់ពួកសង្ឃ និងពួកលេវី (មើល ជន ១៨:២០ និងការពន្យល់ លប ១៥:១)។ *ហេតុនោះខ្ញុំនឹងសង្ឃឹមដល់ទ្រង់* មើល ទដ ២៧:១៤ ៧១:១៤ និងការពន្យល់ ។

**៣:២៥** *ព្រះយេហូវ៉ាទ្រង់ល្អ* មើល ទដ ៣៤:៨ និងការពន្យល់ ៣៤:៨–១៤ ៨៦:៥ ។ *អ្នកដែលរង់ចាំទ្រង់* មើល ទដ ២៥:៣ ៣៣:១៨ ៣៧:៩ និងការពន្យល់ ។

សង្គ្រោះរបស់ព្រះយេហូវ៉ា ឥតបារម្ភព្រួយ[ជ] នោះល្អ
ហើយ[ឈ] ២៧ ឯការដែលមនុស្សទទួលរងនឹម ក្នុងកាលដែល
នៅវ័យក្មេង នោះក៏ល្អដែរ ២៨ អ្នកនោះនឹងអង្គុយតែឯង
ហើយនៅមាត់ស្ងៀម[ញ] ពីព្រោះគឺទ្រង់ដែលដាក់នឹមលើខ្លួន
២៩ អ្នកនោះនឹងព្រមដាក់មាត់ចុះក្នុងធូលីដី[ដ] បើប្រសិនជានឹង
មានទីសង្ឃឹមបាន[ឋ] ៣០ ក៏នឹងបែរកំផ្លៀងទៅឱ្យដល់អ្នក
ដែលទះខ្លួន[ឌ] ហើយនឹងទ្រាំឱ្យបានពេញ ដោយសេចក្ដីត្មះ
តិះដៀល[ឍ] ៣១ ដ្បិតព្រះអម្ចាស់ ទ្រង់មិនបោះបង់ចោលនៅ
ជាដរាបទេ[ណ] ៣២ តែទោះបើទ្រង់ធ្វើទុក្ខក៏ដោយ គង់តែទ្រង់
នឹងអាណិតមេត្តា ដោយសេចក្ដីសប្បុរសដ៏បរិបូររបស់ទ្រង់
ដែរ[ត] ៣៣ ពីព្រោះទ្រង់មិនធ្វើទុក្ខ ឬឱ្យមនុស្សជាតិត្រូវវេទនា
ដោយស្ម័គ្រពីព្រះហឫទ័យទេ[ថ] ៣៤ ឯការដែលជាន់ឈ្លី
ពួកឈ្លើយនៅផែនដី ៣៥ ឬបង្វែរសេចក្ដីយុត្តិធម៌ពីមនុស្ស
នៅចំពោះព្រះដ៏ខ្ពស់បំផុត[ទ] ៣៦ ឬបង្គាច់បំភាន់មនុស្សណា
ក្នុងរឿងក្ដី នោះជាការដែលព្រះអម្ចាស់ទ្រង់មិនសព្វព្រះ
ហឫទ័យឡើយ[ធ] ៣៧ បើព្រះអម្ចាស់ ទ្រង់មិនបានបង្គាប់គេ
នោះ តើមានអ្នកណានឹងអាចទាយទំនាយ ហើយការនោះ
មាន កើតឡើងបានជាពិត[ន] ៣៨ ឯការអាក្រក់នឹងការល្អ នោះ
តើមិនមែនចេញពីព្រះឱស្ឋ របស់ព្រះដ៏ខ្ពស់បំផុតមក
ទេឬអី[ប] ៣៩ ដូច្នេះ ហេតុអ្វីបានជាមនុស្សរស់ត្រូវត្អូញត្អែរ
គឺមនុស្សណាដែលរងទោស ដោយព្រោះអំពើបាបដែល
ខ្លួនបានប្រព្រឹត្តដូច្នេះ[ផ]។
៤០ ចូរយើងពិចារណា ហើយល្បងលផ្លូវដែលយើង[ព]
ប្រព្រឹត្តរួចត្រឡប់បែរទៅឯព្រះយេហូវ៉ាវិញចុះ[ភ] ៤១ ចូរឱ្យ
យើងដំរង់ចិត្តឡើងទៅឯព្រះ ដែលគង់នៅស្ថានសួគ៌[ម] ជា
មួយនឹងដៃយើងផង ៤២ យើងខ្ញុំបានរំលង ព្រមទាំងបះ
បោរហើយ[យ] ទ្រង់មិនបានអត់ទោសឱ្យទេ[រ] ៤៣ ទ្រង់បាន

**៣:២៦** ជ អស ៧:៤ ឈ ទដ ៣៧:៧ ៤០:១ **៣:២៨** ញ យរ ១៥:១៧ បទ ២:១០ **៣:២៩** ដ យប ២:៨ ឋ យរ ៣១:១៧ **៣:៣០** ឌ យប ១៦:១០ អស ៥០:៦ ឍ មីក ៥:១ **៣:៣១** ណ ទដ ៩៤:១៤ អស ៥៤:៧ **៣:៣២** ត ទដ ៧៨:៣៨ ១០៦:៤៣–៤៥ ហស ១១:៨ ណហ ១:១២ **៣:៣៣** ថ យប ៣៧:២៣ យរ ៣១:២០ អគ ១៨:២៣ ៣៣:១១ **៣:៣៥** ទ លប ១៤:១៨,១៩,២០,២២ **៣:៣៦** ធ ទដ ១៤០:១២ សភ ១៧:១៥ យរ ២២:៣ ហព ១:១៣ **៣:៣៧** ន ទដ ៣៣:៩–១១ សភ ១៩:២១ ២១:៣០ **៣:៣៨** ប យប ២:១០ អស ៤៥:៧ យរ ៣២:៤៧ **៣:៣៩** ផ យរ ៣០:១៥ មីក ៧:៩ **៣:៤០** ព ២កច ១៣:៥ ភ ទដ ១១៩:៥៩ ១៣៩:២៣–២៤ **៣:៤១** ម ទដ ២៥:១ ២៨:២ **៣:៤២** យ យរ ១៤:២០ ដយ ៩:៥ រ ២ពវ ២៤:៤ យរ ៥:៧–៩

**៣:២៦** មើល ទដ ៤០:១ អស ២៦:៣ ៣០:១៥ ។

**៣:២៧** *ការដែលមនុស្សទទួលរងនឹម* គឺនិយាយឡើងវិញនូវខ.១ "មនុស្សដែលបានឃើញសេចក្ដីវេទនា"។ *ក្នុងកាលដែលនៅវ័យក្មេង* ធៀបនឹង សស ១២:១ ។ *នោះក៏ល្អ* មើល សភ ៣:១១–១២ និងការពន្យល់ ។

**៣:២៨** *អង្គុយតែឯង* គឺមានន័យថា ទ្រាំនឹងការចំអកឱ្យរបស់ខ្មាំងសត្រូវ (មើលខ.៣០)។ *នៅមាត់ស្ងៀម* មើល ខ.៣៩ ទដ ៣៩:៩ ។

**៣:២៩** *ដាក់មាត់ចុះក្នុងធូលីដី* គឺបង្ហាញអំពីការចុះចូលចំពោះព្រះអម្ចាស់ដោយការបន្ទាបខ្លួន ។ *បើប្រសិនជានឹងមានទីសង្ឃឹម* មើល ២សយ ១២:២២ យប ២:១៤ អម ៥:១៥ យហ ៣:៩ ។

**៣:៣០** *បែរកំផ្លៀង* មើល មថ ៥:៣៩ ។ *ដោយសេចក្ដីត្មះតិះដៀល* មើល ទដ ១២៣:៣–៤ ។

**៣:៣១** *ទ្រង់មិនបោះបង់ចោលនៅជាដរាបទេ* មើល អស ៤៩:១៤–១៦ ។ ធៀបនឹងការពន្យល់ យរ ៣:៥ ។

**៣:៣២** ព្រះអម្ចាស់ទ្រង់ជិនុំជម្រះពួកគេ ហើយទ្រង់ក៏ស្អាងពួកគេឡើងវិញផងដែរ (មើល ទដ ៣០:៥ អស ៥៤:៧–៨)។ *សេចក្ដីសប្បុរសដ៏បរិបូររបស់ទ្រង់* មើលការពន្យល់ ខ.២២ និងមើល "សេចក្ដីស្មោះត្រង់របស់ទ្រង់ធំណាស់"(ខ.២៣) ។ សេចក្ដីស្មោះត្រង់ និងសេចក្ដីស្រឡាញ់នៃទ្រង់គឺត្រូវបានប្រើរួមគ្នា ដើម្បីបង្ហាញនូវសេចក្ដីមេត្តានៃទ្រង់តាមសេចក្ដីសញ្ញាដែលទ្រង់មានចំពោះរាស្ត្រទ្រង់(មើល ទដ ២៥:១០ ២៦:៣ និងការពន្យល់)។

**៣:៣៣** *ទ្រង់មិនធ្វើទុក្ខ . . . ដោយស្ម័គ្រពីព្រះហឫទ័យ* មើល អរ ១៨:២៣, ៣២ ហស ១១:៨ ២ពត ៣:៩ ។

**៣:៣៤** *ជាន់ឈ្លី* ពួកបាប៊ីឡូនបានធ្វើ ការនេះនៅក្នុងឆ្នាំ ៥៨៦ មុនគ.ស ។

**៣:៣៥** *បង្វែរសេចក្ដីយុត្តិធម៌* គឺដូចជាការដែលពួកស្ដេចយូដាបានធ្វើដែលជាអំពើរំលងក្រឹត្យវិន័យដោយផ្ទាល់(មើល នក ២៣:៦)។ *នៅចំពោះព្រះដ៏ខ្ពស់បំផុត* គឺនៅក្នុងវត្តមាននៃអ្នក ដែលព្រះអម្ចាស់ទ្រង់បានរៀបចំឱ្យពួកគេសម្រេចយុត្តិធម៌(មើល នក ២២:៨–៩ និងសេចក្ដីផ្ដើមនៃទំនុកដំកើង ៨២)។ *ដ៏ខ្ពស់បំផុត* មើលការពន្យល់ លប ១៤:១៩ ។

**៣:៣៦** *បង្គាច់បំភាន់* មនុស្សអាចធ្វើការបំភាន់ ប៉ុន្តែព្រះទ្រង់មិនធ្វើការនេះឡើយ(មើល យប ៨:៣ ៣៤:១២)។ *ព្រះអម្ចាស់ទ្រង់មិនសព្វព្រះហឫទ័យឡើយ* គឺផ្ទុយពីអ្វីដែលពួកមនុស្សអាក្រក់បានគិត(មើល ទដ ១០:១១ និងការពន្យល់) ព្រះអម្ចាស់ទ្រង់ទតឃើញ ហើយនឹងសម្រេចតាមយុត្តិធម៌ (មើល ទដ ១០:១៣–១៥)។

**៣:៣៧** *ទាយទំនាយ ហើយការនោះមានកើតឡើងបានជាពិត* គ្មាននរណាម្នាក់អាចស្មើនឹងព្រះបាន(មើល លប ១:៣ និងការពន្យល់, ទដ ៣៣:៩–១១ និងការពន្យល់ ៣៣:៤–១១) ដូចនេះគ្មាននរណាអានបំពានអំណាចគ្រប់គ្រងនៃព្រះបានឡើយ(ធៀបនឹង យប ១:១២ ២:៦ និងការពន្យល់)។

**៣:៣៨** មើល យប ២:១០ សភ ៣:១១–១២ អស ៤៥:៧ អម ៣:៣–៦ និងការពន្យល់ និងមើលយ យរ ៣២:៤២ ។

**៣:៣៩** *ត្អូញត្អែរ* មើល ខ.២៨ និងការពន្យល់ ។

**៣:៤០–៤១** នៅក្នុងវគ្គនេះ សម្លេងបានបន្លឺឡើងពីសហគមន៍ ដែលជាការឆ្លើយតបនឹងគម្រូដែលមានពីមុនមកនៅក្នុង ខ.១–៣៩(មើលការពន្យល់ ខ.១)។ សហគមន៍នេះបានចាប់ផ្ដើមបន្លឺសម្លេង ដោយការសារភាពបាប (មើល ១:៨ និងការពន្យល់ និងមើល ទដ ៣២:៣–៥ ៣៩:៧–១០ ៤០:១១–១២ ៤១:៤)។

**៣:៤០** *ត្រឡប់បែរទៅឯព្រះយេហូវ៉ា* មើល ហស ៦:១ ធៀបនឹង យរ ៣:១ ៤:១ ហស ១៤:១ យអ ២:១២–១៣ សក ១:៣ ។

**៣:៤២** *យើងខ្ញុំបានរំលង ព្រមទាំងបះបោរហើយ* ចំពោះការបះបោរស្រដៀងគ្នានេះ មើល ទដ ១០៦:៦ ដយ ៩:៥ ។

**៣:៤៣** *គ្រលុំអង្គ ដោយសេចក្ដីខ្ញាល់* ធៀបនឹង អស ៥៩:១៧–១៨ ។ *ដេញ*

ត្រសុំអង្គ ដោយសេចក្តីខ្ញាល់ ហើយដេញតាម[ល] យើងខ្ញុំ
ទ្រង់បានប្រហារជីវិត ឥតប្រណីសោះ[វ] ៤៤ទ្រង់បាំងអង្គ
ដោយពពក[ស] ដើម្បីមិនឱ្យសេចក្តីអធិស្ឋាន[ហ]ណាចូលទៅ
ដល់បានឡើយ[ឡ] ៤៥ទ្រង់បានធ្វើឱ្យយើងខ្ញុំទៅជាកាក[អ]
ហើយជាសំរាម នៅកណ្តាលអស់ទាំងសាសន៍ ៤៦ពួកខ្មាំង
សត្រូវទាំងប៉ុន្មានរបស់យើងខ្ញុំ បានហាមាត់ធំ[ក]ដាក់យើងខ្ញុំ[ខ]
៤៧ចំណែករបស់យើងខ្ញុំ គឺជាសេចក្តីភ័យខ្លាច ហើយនិង
រណ្តៅ[គ] ព្រមទាំងសេចក្តីបំផ្លាញ និងសេចក្តីវិនាសផង[ឃ]
៤៨ភ្នែក[ង]ខ្ញុំហូរចេញជាផ្លូវទឹក[ច] ដោយព្រោះការបំផ្លាញកូន
ស្រីរបស់សាសន៍ខ្ញុំ[ឆ] ៤៩ភ្នែកខ្ញុំនឹងហូរសស្រាក់ឥតឈប់
ឈរ ឥតស្រាកឡើយ[ជ] ៥០ទាល់តែព្រះយេហូវ៉ាទ្រង់ ឈ្ងោក
មើល ហើយពិចារណាពីស្ថានសួគ៌មក[ឈ] ៥១ភ្នែកខ្ញុំធ្វើឱ្យចិត្ត
ខ្ញុំកើតទុក្ខ ដោយព្រោះពួកកូនស្រីនៃក្រុងរបស់ខ្ញុំ ៥២ពួកអ្នក
ដែលជាខ្មាំងសត្រូវនឹងខ្ញុំ ដោយឥតហេតុ គេបានដេញតាម
ខ្ញុំ ដូចជាដេញតាមសត្វស្លាប[ញ] ៥៣គេ បានកាត់ជីវិតខ្ញុំចេញ
ដោយដាក់គុកងងឹត[ដ] ហើយបាន ទាំងដាក់ថ្មសន្ទាប់ពីលើខ្ញុំ
ផង ៥៤មានទឹកហូរមកលិចក្បាលខ្ញុំ[ឋ] នោះខ្ញុំបានថា ខ្ញុំស្លាប់
ហើយ[ឌ] ។
៥៥ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់
ព្រះនាមទ្រង់ពីក្នុងទីជិតរៅ[ឍ]នៃគុកងងឹត[ណ] ៥៦ទ្រង់ក៏ឮសំឡេង

**៣:៤៣** ល ខ.៦៦ ទដ ៣៥:៦ វ បទ ២:២,១៧,២១
**៣:៤៤** ស ទដ ៩៧:២ បទ ២:១ ហ ខ.៨ សក ៧:១៣ ឡ អស ៥៨:៤
**៣:៤៥** អ ១កច ៤:១៣
**៣:៤៦** ក ទដ ២២:១៣ ខ បទ ២:១៦
**៣:៤៧** គ យរ ៤៨:៤៣ ឃ អស ២៤:១៧–១៨ ៥១:១៩
**៣:៤៨** ង យរ ៩:១,១៨ បទ ១:១៦ ច ទដ ១១៩:១៣៦ ឆ បទ ២:១១
**៣:៤៩** ជ យរ ១៤:១៧ បទ ២:១៨
**៣:៥០** ឈ ទដ ១៤:២ ៨០:១៤ អស ៦៣:១៥
**៣:៥២** ញ ទដ ៣៥:៧

របស់ទូលបង្គំ សូមកុំគេចព្រះកាណ៌ទ្រង់ចេញពីដំងូរ[ត] និង
សំរែករបស់ទូលបង្គំឡើយ ៥៧នៅថ្ងៃដែលទូលបង្គំបាន
អំពាវនាវដល់ទ្រង់ នោះទ្រង់បានយាងមកជិត[ថ] ហើយមាន
បន្ទូលថា កុំឱ្យខ្លាចឡើយ[ទ] ៥៨ឱព្រះអម្ចាស់អើយ ទ្រង់
បានកាន់ក្តីនៃព្រលឹងទូលបង្គំហើយ[ធ] ទ្រង់បានលោះជីវិត
របស់ទូលបង្គំផង[ន] ៥៩ឱព្រះយេហូវ៉ាអើយ ទ្រង់បានឃើញ
ការកំហុសដែលគេបានធ្វើដល់ទូលបង្គំ[ប] សូមទ្រង់ជំនុំជំរះ
ក្តីរបស់ទូលបង្គំចុះ[ផ] ៦០ទ្រង់បានឃើញការសងសឹកទាំង
ប៉ុន្មានរបស់គេ និងអស់ទាំងកិច្ចកលដែលគេធ្វើដល់ទូល
បង្គំដែរ[ព] ៦១ឱព្រះយេហូវ៉ាអើយ ទ្រង់បានឮពាក្យប្រមាថ
របស់គេ[ភ] និងអស់ទាំងកិច្ចកលដែលគេគិតធ្វើដល់ទូលបង្គំ
ហើយ ៦២ក៏ឮពាក្យសំដីរបស់ពួកអ្នកដែលលើកគ្នាទាស់
នឹងទូលបង្គំ ហើយជ្រាបការដែលគេគិតប្រទូស្តនឹងទូល
បង្គំជានិច្ចដែរ[ម] ៦៣សូមទ្រង់ទតក្នុងកាលដែលគេអង្គុយ
ចុះហើយក្រោកឡើងផងទូលបង្គំជាបទចំរៀងរបស់គេ
ហើយ[យ] ៦៤ឱព្រះយេហូវ៉ាអើយទ្រង់នឹងសងគេតាមការ
ដែលដៃគេបានធ្វើ[រ] ៦៥ទ្រង់នឹងបណ្តាលឱ្យចិត្តគេរឹងរូស[ល]

**៣:៥៣** ដ យរ ៣៧:១៦ ៣៨:៦ **៣:៥៤** ឋ ទដ ៦៩:២ យហ ២:៣–៥ ឌ ខ.១៨ ទដ ៨៨:៥ អគ ៣៧:១១ **៣:៥៥** ឍ ទដ ៨៨:៦ ណ ទដ ១៣០:១ យហ ២:២ **៣:៥៦** ត ទដ ៥៥:១ ១១៦:១–២ **៣:៦២** ម អគ ៣៦:៣ **៣:៦៣** យ យប ៣០:៩ **៣:៦៤** រ ទដ ២៨:៤ យរ ៥១:៦ **៣:៦៥** ល នក ១៤:៨ ចទ២:៣០អស៦:១០

*តាមយើងខ្ញុំ ទ្រង់បានប្រហារជីវិត ឥតប្រណីសោះ* មើល ខ.៦៦ ២:២១ យរ ២៩:១៨ ។

**៣:៤៦** មើល ២:១៦ និងការពន្យល់ ។

**៣:៤៨–៦៦** នៅក្នុងវគ្គនេះ សម្លេងបានបញ្ចេញមក ដោយប្រើសព្វនាមទីមួយឯកវចនៈ ។ សម្លេងនេះអាចជាសម្លេងតែមួយ ដែលបានបន្លឺនៅក្នុង ខ.១–៣៩ ប៉ុន្តែ នៅក្នុងខនេះ សហគមន៍នោះទំនងជាប្រើសព្វនាមទីមួយឯកវចនៈ(មើលឧទាហរណ៍ ទដ ៤៤:១,៤ និងការពន្យល់ ៤៤:៤) ។ នៅក្នុងការអធិស្ឋាន សហគមន៍នោះបានបង្ហាញអំពីការជឿជាក់ថា សម្លេងរបស់ពួកគេត្រូវបានព្រះអម្ចាស់ទ្រង់ឮ ហើយបង្ហាញអំពីការទូលអង្វរ ឱ្យទ្រង់ជំនុំជម្រះដល់ពួកខ្មាំងសត្រូវដែលបានវាយប្រហារពួកគេ "ដោយឥតហេតុ" ដែលការបង្ហាញទាំងពីរនេះគឺជាលក្ខណៈជាធម្មតា នៃការអធិស្ឋាននៃអ្នកនិពន្ធទំនុកតម្កើង(ធៀបនឹង ទដ ៥:១០ ទដ ៥៤ និងការពន្យល់) ។

**៣:៤៨** *ភ្នែកខ្ញុំហូរចេញ* មើលការពន្យល់ ១:១៦ ។ *សាសន៍ខ្ញុំ* ឬ "កូនស្រីនៃសាសន៍ខ្ញុំ"(មើលការពន្យល់ ២:១១) ។

**៣:៥០** *ឈ្ងោកមើល ហើយពិចារណា* មើល ៥:១ ទដ ៨០:១៤ អស ៦៣:១៥

**៣:៥១** *ពួកកូនស្រីនៃក្រុងរបស់ខ្ញុំ* មើល ១:៤,១៨ ២:២០–២១ ៥:១១ ។

**៣:៥២** *ខ្មាំងសត្រូវនឹងខ្ញុំ ដោយឥតហេតុ* មើលការពន្យល់ ទដ ៣៥:១៩ ។ *ដេញតាមសត្វស្លាប* មើល ទដ ១២៤:៧ ។

**៣:៥៣** *កាត់ជីវិតខ្ញុំចេញ ដោយដាក់គុកងងឹត* មើល ទដ ៣៥:៧ ។ *ដាក់ថ្មសន្ទប់* មើល ២សយ ១៦:៦ ១ពវ ១២:១៨ ។

**៣:៥៤** *មានទឹកហូរមកលិចក្បាលខ្ញុំ* មើល ទដ ៣២:៦ ៤២:៧ ៦៩:១–២ និងការពន្យល់ ។ *ខ្ញុំស្លាប់ហើយ* មើល ទដ ៣១:២២ អស ៥៣:៨ ។

**៣:៥៥** *ពីក្នុងទីជិតរៅនៃគុកងងឹត* មើល ទដ ៣០:១ និងការពន្យល់ ។

**៣:៥៦** *ដំងូរ និងសំរែករបស់ទូលបង្គំ* មើល យប ៣២:២០ ទដ ១១៨:៥ ។

**៣:៥៧** *អំពាវនាវ . .យាងមកជិត* មើល ទដ ១៤៥:១៨ ។ *កុំឱ្យខ្លាចឡើយ* គឺជាពាក្យកំឡាចិត្តមកអំពីព្រះអម្ចាស់ដែលមានជាញឹកញាប់(មើល យរ ១:៨ និងការពន្យល់) ។

**៣:៥៨** *បានលោះជីវិតរបស់ទូលបង្គំ* មើល ទដ ២៥:២២ ១០៣:៤ និងការពន្យល់ ។

**៣:៥៩** *ទ្រង់បានឃើញ* មើល ទដ ១០:១៤ ៣៥:២២ ។ *សូមទ្រង់ជំនុំជំរះក្តីរបស់ទូលបង្គំ* មើល ទដ ៣៥:២៣ ៤៣:១ ១១៩:១៥៤ ។

**៣:៦១** *ទ្រង់បានឮពាក្យ* ព្រះអម្ចាស់ទ្រង់បានឮក៏ដូចជាបានទតឃើញ (ខ.៥៩ –៦០) នូវអ្វីដែលពួកខ្មាំងសត្រូវកំពុងធ្វើ ។

**៣:៦២** *ពាក្យសំដី . . . ដែលគេគិតប្រទូស្ត* មើល ៥:៩ និងការពន្យល់ ។

**៣:៦៣** *អង្គុយចុះ ហើយក្រោកឡើង* គឺមានន័យថា ចូលរួមនៅក្នុងរាល់សកម្មភាព(មើល ចទ ៦:៧ ១១:១៩ ទដ ១៣៩:២ អស ៣៧:២៨) ។ *ទូលបង្គំ*

**៣:៦៥** *បណ្តាលចិត្តគេរឹងរូស* ដើម្បីធ្វើឱ្យគេមិនអាចដឹងអំពីកំហុសដែលមាននៅក្នុងដំណើររបស់ពួកគេ ឬមើលដឹងជាមុនអំពីលទ្ធផលនៃការដែលគេធ្វើ ។ *គឺជាសេចក្តីបណ្តាសាដល់គេ* មើល ទដ ១០៩:១៦–២០ និងការពន្យល់ ។

គឺជាសេចក្ដីបណ្ដាសាដល់គេ ៦៦ទ្រង់នឹងដេញតាម[វ] គេដោយ
សេចក្ដីខ្ញាល់ ហើយបំផ្លាញគេឱ្យសូន្យចេញពីក្រោមស្ថាន
របស់ព្រះយេហូវ៉ាទៅ ។
**៤** ១មាសបានទៅជាស្រអាប់ យ៉ាងណាហ្ន៎ ឯមាសសុទ្ធនោះ
បានផ្លាស់ប្រែយ៉ាងណាហ្ន៎ ថ្មទាំងប៉ុន្មាននៃទីបរិសុទ្ធបាន
ចាក់ចោល នៅត្រង់ក្បាលគ្រប់ទាំងផ្លូវ[ក] ២ឯពួកកូនប្រុសៗ
របស់ក្រុងស៊ីយ៉ូន[ខ] ដែលមានដំដៃដូចជា មាសយ៉ាងសំរាំង
នោះបានរាប់ទុកដូចជាភាជនៈដីវិញ ជាការដែលដៃជាង
ស្មូនធ្វើយ៉ាងណាហ្ន៎ ៣ទោះទាំងមេស្វាន ក៏បើកដោះឱ្យ
កូនបៅដែរ តែឯកូនស្រីរបស់សាសន៍ខ្ញុំវិញ នោះមានចិត្ត
ខ្មៅ ដូចជាសត្វអូសទ្រីចនៅទីរហោស្ថាន[គ] ៤អណ្ដាតកូន
ដែលនៅបៅ បានជាប់នៅក្រអូមមាត់[ឃ] ដោយស្រេក[ង]
កូនតូចៗវាសូមនំបុ័ង តែគ្មានអ្នកណាកាច់ហុចឱ្យវាឡើយ[ច]
៥ពួកអ្នកដែលធ្លាប់បរិភោគតាមរបៀបរុងរឿង គេស្រេងល់
ស្រងាកនៅកណ្ដាលផ្លូវពួកអ្នកដែលធ្លាប់ស្លៀកពាក់សំពត់
ពណ៌ស្វាយ[ឆ] គេនៅក្បែរនគរអាចម៍សត្វវិញ[ជ] ៦ដ្បិតសេចក្ដី
ទុច្ចរិតរបស់កូនស្រីនៃសាសន៍ខ្ញុំ បានធ្ងន់ជាងអំពើបាប
របស់ក្រុងសូដុំមទៅទៀត[ឈ] ជាទីក្រុងដែលត្រូវបំផ្លាញក្នុង
១រំពេច ឥតមានដៃអ្នកណាធ្វើឡើយ ៧ពួកអ្នកមានត្រកូល
ខ្ពស់នៅក្នុងទីក្រុង គេបរិសុទ្ធជាងហិមៈ គេស្អាតជាងទឹក
ដោះគោ សម្បុរគេឡើងក្រហមជាងត្បូងទទឹមទៅទៀត
ហើយរាងកាយគេក៏ភ្លឺដូចជាត្បូងកណ្ដៀង ៨ឥឡូវនេះមុខ
គេខ្មៅជាងធ្យូងវិញ[ញ] គ្មានអ្នកណាស្គាល់គេតាមផ្លូវទេ
ស្បែកគេជាប់នឹងឆ្អឹង[ដ] ក៏ស្វិតក្រៀមដូចជារំកាច់ឈើ ៩ពួក
អ្នកដែលស្លាប់ដោយដាវ នោះវិសេសជាងពួកអ្នកដែល
ស្លាប់ដោយស្រេកឃ្លាន[ឋ] ដ្បិតពួក១នេះ គេហេវទៅហើយ
ត្រូវស្លាប់ដោយស្រេកឃ្លាន ដ្បិតពួក១នេះគេហេវទៅ
ហើយត្រូវស្លាប់ដោយខ្វះខាតស្បៀងអាហារ[ឌ] ១០ពួកស្រីៗ
ដែលមានចិត្តទន់សន្ដោស បានស្ងោរកូនខ្លួនស៊ី ដោយដៃ
ខ្លួនឯង កូនទាំងនោះជាអាហារដល់គេ[ឍ] ក្នុងគ្រាបំផ្លាញកូន
ស្រីនៃសាសន៍ខ្ញុំ ១១ព្រះយេហូវ៉ាទ្រង់បានសំរេចសេចក្ដី
ក្រោធរបស់ទ្រង់[ណ] ក៏បានចាក់សេចក្ដីខ្ញាល់ដ៏សហ័សរបស់
ទ្រង់ចេញ[ត] ហើយ[ថ] ទ្រង់បានបង្កាត់ភ្លើង[ទ] នៅក្នុងក្រុង
ស៊ីយ៉ូន ជាភ្លើងដែលឆេះ ដល់ទាំងឫសជញ្ជាំងផង[ធ] ១២ពួក
ស្ដេចនៅផែនដី ហើយមនុស្សទាំងឡាយដែលនៅលោកីយ
គេមិនបានជឿថា ពួកតតាំង និងពួកខ្មាំងសត្រូវ នឹងអាច
ចូលតាមទ្វារក្រុងយេរូសាឡិមបានទេ[ន] ១៣នេះគឺដោយ
ព្រោះអំពើបាបរបស់ពួកហោរា និងអំពើទុច្ចរិតរបស់
ពួកសង្ឃ[ប] ជាពួកអ្នកដែលគេបានកំចាយឈាម[ផ] របស់ពួក

**៣:៦៦** វ ខ.៤៣ **៤:១** ក អគ ៧:១៩ **៤:២** ខ អស ៥១:១៨ **៤:៣** គ យប ៣៩:១៦ **៤:៤** ឃ ចទ ២៨:៤៨ ២ពវ ១៨:៣១ ង ទដ ២២:១៥ ច បទ ២:១១,១២ **៤:៥** ឆ យរ ៦:២ ជ អស ៣:២៦ អម ៦:៣–៧ **៤:៦** ឈ លប ១៩:២៥ **៤:៨** ញ យប ៣០:២៨ ដ ទដ ១០២:៣–៥ បទ ៣:៤ **៤:៩** ឋ ២ពវ ២៥:៣ ឌ យរ ១៥:២ ១៦:៤ បទ៥:១០ **៤:១០** ឍ លប ២៦:២៩ ចទ ២៨:៥៣–៥៧ យរ ១៩:៩ បទ ២:២០ អគ ៥:១០ **៤:១១** ណ យប ២០:២៣ ត ២របា ៣៤:២១ ថ ណហ ១:៦ សផ ២:២ ៣:៨ ទ យរ ១៧:២៧ ធ ចទ៣២:២២ យរ ៧:២០ អគ ២២:៣១ **៤:១២** ន ១ពវ ៩:៩ យរ ២១:១៣ **៤:១៣** ប យរ ៥:៣១ ៦:១៣ អគ ២២:២៨ មីក ៣:១១ ផ ២ពវ ២១:១៦

**៣:៦៦** *តាមគេ* នៅត្រង់ចំណុចនេះ មានន័យថា ព្រះអម្ចាស់ទ្រង់តាមពួកគេដោយគ្មានមេត្តា ដោយសារការដែលពួកគេធ្វើមកលើពួកយើង គឺដូចកាលដែលទ្រង់តាមពួកយើងដោយឥតមេត្តា ដោយសារអំពីបាបរបស់ពួកយើង (ខ.៤៣) ។

**៤:១–២២** វគ្គនេះនិយាយអំពី បទទំនួញអំពីការកាន់កាប់ទីក្រុងយេរូសាឡិមដោយពួកបាប៊ីឡូន គឺជាបទទំនួញរបស់អ្នក ដែលបានឆ្លងកាត់បទពិសោធន៍យ៉ាងយូរជាមួយនឹងការឡោមព័ទ្ធទីក្រុងនេះ និងការត្រូវខ្ចាត់ខ្ចាយរបស់សាសន៍របស់គាត់ ។ ខ.១–១០ ពិពណ៌នាអំពីស្ថានភាពដ៏អាក្រក់នៃការឡោមព័ទ្ធ, ខ.១១–១៩ និយាយអំពីការចូលកាន់កាប់ទីក្រុង និងជោគវាសនានៃជនភាសខ្លួន, ខ.២០ បង្ហាញអំពីសេចក្ដីវន្ទត់ និងទុក្ខព្រួយរបស់សាសន៍យូដា ដោយសារស្ដេចដែលជាហ្លួងនៃស្ដេចដាវីឌ ត្រូវធ្លាក់ទៅក្នុងដៃសត្រូវ និង ខ.២១–២២ បញ្ចប់បទទំនួញ ដោយប្រៀការប្រៀបធៀបអនាគតរបស់ស្រុកអេដំមដែលពេញដោយមេទនភាព និងក្រុងស៊ីយ៉ូនដែលត្រូវចោលស្ងាត់ ។

**៤:១** *យ៉ាងណាហ្ន៎* មើលការពន្យល់ ១:១ ។ *មាស . . . ថ្ម* គឺជាការប្រៀបធៀបអំពីរាស្ត្រដែលព្រះបានជ្រើសតាំង (មើល ខ.២) ។ ចំពោះការប្រៀបធៀបស្រដៀងគ្នានេះ មើល បស ៥:១១–១២,១៤–១៥ សក ៩:១៦ ។ *នៅត្រង់ក្បាលគ្រប់ទាំងផ្លូវ* មើល ២:១៩ អស ៥១:២០ ។

**៤:៣** *កូនស្រីរបស់សាសន៍ខ្ញុំ* មើលការពន្យល់ ២:១១ ។ *នោះមានចិត្តខ្មៅ* មើល ខ.១០ និងការពន្យល់ ។ *ដូចជាសត្វអូសទ្រីច* មើល យប ៣៩:១៤–១៦ ។

**៤:៥** *របៀបរុងរឿង . . . ពណ៌ស្វាយ* មើល លប ៤៩:២០ ។ ពណ៌ស្វាយ គឺជាពណ្ណ៌កញ្ចកសក្សត្រ (មើលឧទារណ៍ នៅក្នុង ពច ៨:២៦ និងការពន្យល់ បស ៧:៥) ។ *គំនរអាចម៍សត្វ* មើល យប ២:៨ និងការពន្យល់, ធៀបនឹង យរ ៦:២៦ និងការពន្យល់ ។

**៤:៦** *ក្រុងសូដុំម* មើលការពន្យល់ យរ ២០:១៦ ។ *ត្រូវបំផ្លាញក្នុង១រំពេច* មានន័យថា ត្រូវដួលរលំដោយមិនបាច់ត្រូវរងវេទនា ដោយសារការឡោមដ៏យូរ (ដូចទីក្រុងយេរូសាឡិម) ។

**៤:៧** *បរិសុទ្ធ . . . ក្រហម* នៅក្នុងព្រះគម្ពីរភាសារហេព្រើ ឃ្លានេះគឺប្រែមកថា "ភ្លឺចាំង . . . ក្រហម " នៅក្នុងព្រះគម្ពីរ បស ៥:១០ ។ *ជាងត្បូងទទឹម* មើល យប ២៨:១៨ ។ *ត្បូងកណ្ដៀង* មើល បស ៥:១៤ អស ៥៤:១១ និងការពន្យល់ ។

**៤:៨** *ស្បែកគេជាប់នឹងឆ្អឹង* មើល យប ១៩:២០ ។

**៤:១០** មើល យរ ១៩:៩ និងការពន្យល់ ។

**៤:១១** *សេចក្ដីខ្ញាល់ដ៏សហ័ស* មើល ១:១២ និងការពន្យល់ ។ *បង្កាត់ភ្លើង . . . ឆេះ* មើល យរ ១៧:២៧ និងការពន្យល់ ។

**៤:១២** *មនុស្សទាំងឡាយ* ឬ "អ្នកដឹកនាំ" (គឺន័យដូចនឹងពាក្យ "ស្ដេច") នៅក្នុងព្រះគម្ពីរភាសាហេព្រើ ពាក្យនេះបកប្រែថា "អ្នកកាន់ដំបងរាជ្យ" នៅក្នុង អម ១:៥,៨ ។

**៤:១៣** មើល ២:១៤ និងការពន្យល់ និងមើល អគ ២២:២៦,២៨ ។

មនុស្សសុចរិត នៅកណ្ដាលទីក្រុងទេ ១៤គេដើរវីមវាម ដូច
ជាមនុស្សខ្វាក់[ព] នៅតាមផ្លូវ គេសុទ្ធតែប្រឡាក់ដោយឈាម[ភ]
ដល់ម្ល៉េះបាន ជាគ្មានអ្នកណាអាចនឹងពាល់សំលៀកបំពាក់
របស់គេបានឡើយ ១៥មនុស្សទាំងឡាយស្រែកដល់គេថា
ចូរទៅចុះ អាគំរក់ ចូរចេញទៅ ទៅៗ កុំមកពាល់អ្វីឡើយ
កាលគេបានរត់ទៅ ហើយដើរសាត់ព្រាត់ទៀត[ម] នោះ
មនុស្ស នៅកណ្ដាលអស់ទាំងសាសន៍បានថា គេនឹងមិន
អាស្រ័យនៅទីនេះទៀតឡើយ[យ] ១៦សេចក្ដីខ្ញាល់របស់ព្រះ
យេហូវ៉ា បានកំចាត់កំចាយគេទៅ ទ្រង់មិនព្រមទតមើល
គេទៀតទេ[រ] គេមិនបានគោរពប្រតិបត្តិដល់ពួកសង្ឃ ក៏មិន
បានរាប់អានពួកចាស់ទុំ[ល]ដែរ[វ] ។
១៧ភ្នែកយើងរាល់គ្នាស្រវាំងទៅ[ស] ដោយចាំមើលឱ្យ
បានជំនួយ[ហ] ដែលឥតប្រយោជន៍មកជួយយើង ការដែល
យើងបានរង់ចាំនោះ គឺយើងចាំមើលផ្លូវសាសន៍១[ឡ] ដែល
ជួយសង្គ្រោះមិនបាន ១៨គេដេញតាមជំហានយើងដល់ម្ល៉េះ
បានជាយើងចេញទៅឯផ្លូវមិនបាន ឯចុងបំផុតរបស់យើង
កាន់តែជិតដល់ កំណត់យើងក៏សំរេច ដ្បិតចុងបំផុតរបស់
យើងបានមកដល់ហើយ[អ] ១៩ពួកអ្នកដែលដេញតាមយើង
គេរហ័សជាងឥន្ទ្រី[ក]នៅលើអាកាស គេបានដេញយើង[ខ]ឱ្យ
ទៅលើភ្នំ ក៏លបចាំយើងនៅទីរហោស្ថាន[គ] ២០ព្រះអម្ចាស់
ជីវិតរបស់យើង គឺជាស្តេចដែលព្រះយេហូវ៉ាបានចាក់
ប្រេងតាំងឱ្យ[ឃ] ទ្រង់ត្រូវគេចាប់ក្នុងអន្លង់របស់គេ[ង] គឺពីទ្រង់
ហើយ ដែលយើងបានថាយើងរាល់គ្នានឹងជ្រកក្រោមម្លប់[ច]
របស់ទ្រង់ នៅកណ្ដាលពួកសាសន៍ដទៃ ។
២១ឱកូនស្រីនៃស្រុកអេដំម ជាអ្នកដែលអាស្រ័យនៅ
ស្រុកអ៊ូសអើយ[ឆ] ចូរមានចិត្តរីករាយ ហើយសប្បាយឡើង
ពែងនេះ[ជ]នឹងឆ្លងដល់នាងដែរ នាងនឹងត្រូវស្រវឹង ហើយនឹ
ងសំរាតខ្លួន[ឈ] ២២ឱកូនស្រីនៃក្រុងស៊ីយ៉ូនអើយ ទោសនៃ
អំពើទុច្ចរិតរបស់នាងបានគ្រប់ចំនួនហើយ[ញ] ទ្រង់នឹងមិនឱ្យ
នាងទៅជាឈ្លើយទៀតឡើយ ឱកូនស្រីស្រុក អេដំមអើយ
ទ្រង់នឹងធ្វើទោសចំពោះអំពើទុច្ចរិតរបស់នាង ទ្រង់នឹង
បើកអំពើបាបរបស់នាងឱ្យឃើញច្បាស់[ដ] ។
៥ ១ឱព្រះយេហូវ៉ាអើយ សូមទ្រង់នឹកចាំពីការដែលបាន
កើតដល់យើងខ្ញុំរាល់គ្នា សូមទ្រង់ទតមកឱ្យឃើញសេចក្ដី
ដែលគេត្មះតិះដៀលដល់យើងខ្ញុំ[ក] ២ចំណែកមរដក[ខ]របស់
យើងខ្ញុំបានបែរទៅជារបស់ពួកអ្នកដទៃ[គ] ឯផ្ទះសំបែង[ឃ]
របស់យើងខ្ញុំ ក៏បានទៅជារបស់សាសន៍ក្រៅហើយ[ង]

**៤:១៤** ព អស ៥៩:១០ ភ យរ ១៩:៤ **៤:១៥** ម យរ ៤៤:១៤ យ លវ ១៣:៤៦ មីក ២:១០ **៤:១៦** រ អស ៩:១៤–១៦ ល បទ ៥:១២ វ បទ ២:៦ **៤:១៧** ស លប ១៥:១៨ អស ២០:៥ អគ ២៩:១ ហ បទ ១:៧ ឡ យរ ៣៧:៧ **៤:១៨** អ អគ ៧:២–១២ អម ៨:២ **៤:១៩** ក ចទ ២៨:៤៩ ខ លវ ២៦:៣៦ អស ៥:២៦–២៨ គ យរ ៥២:៧ **៤:២០** ឃ ១សយ ២៦:៩ ២សយ ១៩:២១ ង យរ ៣៩:៥ អគ ១២:១២–១៣ ១៩:៤,៨ ច ទដ ៩១:១

**៤:២១** ឆ លប ១០:២៣ ជ ទដ ១៦:៥ យរ ២៥:១៥ ឈ អស ៣៤:៦–១០ ៦៣:៦ អគ ៣៥:១៥ អម ១:១១–១២ អប ១:១៦ ហព ២:១៦ **៤:២២** ញ អស ៤០:២ យរ ៣៣:៨ ដ ទដ ១៣៧:៧ អគ ២៥:១២–១៤ មឡ ១:៤ **៥:១** ក ទដ ៤៤:១៣–១៦ ៨៩:៥០ **៥:២** ខ ទដ ៧៩:១ គ ទដ ១០៨:១១ ឃ សផ ១:១៣ ង យរ ១៧:៤

**៤:១៤** *ដើររវីមវាម ដូចមនុស្សខ្វាក់នៅតាមផ្លូវ* មើល ចទ ២៨:២៨–២៩ អស ២៩:៩ និងការពន្យល់, ៥៩:១០ និងការពន្យល់ និងមើល សផ ១:១៧។ *ប្រឡាក់ដោយឈាម* មើល អស ៥៩:៣ ។

**៤:១៥** *អាគំរក់* គឺដោយសារតែជម្ងឺស្បែកដែលគួរឱ្យខ្លាច(មើល លវ ១៤:៤៥)។ *មនុស្ស... មិនអាស្រ័យនៅទីនេះទៀតឡើយ* ការនេះគឺជាការគម្រាមដែលធ្វើឡើងនៅក្នុង ចទ ២៨:៦៥–៦៦ ។

**៤:១៦** ខនេះគឺជាការព្រមាន ដូចដែលមាននៅក្នុង ចទ ២៨:៤៩–៥០ ។

**៤:១៧** *ភ្នែកយើងរាល់គ្នាស្រវាំងទៅ* មើល ចទ ២៨:២៨ ទដ ៦៩:៣០ ។ *សាសន៍១ ដែលជួយសង្គ្រោះមិនបាន* ឧទាហរណ៍ សាសន៍អេស៊ីព្ទ(មើល អគ ២៩:១៦)។

**៤:១៩** *ឥន្ទ្រី* មើល យរ ៤:១៣ ៤៨:៤០ និងការពន្យល់ ។

**៤:២០** *ព្រះយេហូវ៉ាបានចាក់ប្រេងតាំងឱ្យ* គឺស្តេចសេដេគាដែលជាវង្សនៃស្តេចដាវីឌ ដែលនៅក្រោមការដឹកនាំរបស់ស្តេចនេះ ពួកបណ្ដាជនមានសេចក្ដីទំនុកចិត្ត ដោយសារព្រះអម្ចាស់បានតាំងសញ្ញានឹងស្តេចដាវីឌ (មើល ២សយ ៧ ទដ ៨៩,១៣២ អស ៥៥:៣ និងការពន្យល់)។ *គេចាប់* មើល យរ ៣៩:៤–៧ ៥២:៧–១១ ។ *ម្លប់* គឺការការពារ (មើល ពច ៩:១៥ ទដ ១៧:៨ និងការពន្យល់)។ ខនេះបង្ហាញអំពីសេចក្ដីសង្ឃឹមចំពោះព្រះមែស៊ីដែលត្រូវមកតាមសេចក្ដីសន្យា ដែលទ្រង់ជាព្រះដែលបានទទួលប្រេងតាំង និងចេញពីវង្សនៃហ្លួងដាវីឌ ។

**៤:២១** *កូនស្រីនៃស្រុកអេដំម* ការប្រើពាក្យនេះ គឺសំដៅទៅលើស្រុកអេដំមដោយការប្រៀបធៀបទៅនឹងលក្ខណៈមនុស្ស(២ពវ ១៩:២១)។ *អេដំម* សាសន៍នេះមានទំនាក់ទំនងជិតស្និទ្ធនឹងសាសន៍អ៊ីស្រាអែល កាលពីដើមដំបូង តែក្រោយមកបានប្រែជាទាស់ប្រឆាំងនឹងអ៊ីស្រាអែលជានិច្ចវិញ (មើលការពន្យល់ លប ២៥:២៦) ដូចនេះ អ្នកនិពន្ធព្រះគម្ពីរសញ្ញាចាស់បានប្រើឈ្មោះសាសន៍នេះ ជាតំណាងឱ្យខ្មាំងសត្រូវនៃសាសន៍អ៊ីស្រាអែលទាំងអស់(មើល ទដ ១៣៧:៧ និងការពន្យល់ និងមើល អស ១៣:១–៦ និងការពន្យល់ ១៣:១, ៣៤:៥ និងការពន្យល់, យរ ៤៩:៧–២២ និងការពន្យល់ ៤៩:៨, អម ៩:១២ និងការពន្យល់, និងមើលសេចក្ដីផ្ដើមព្រះគម្ពីរអូបាឌាត្រង់ចំណុច ខ្លឹមសារ ហើយ អប ៨ និងការពន្យល់)។ *ស្រុកអ៊ូស* មើល យរ ២៥:២០ និងមើលការពន្យល់ យប ១:១ ។ *ហើយសប្បាយឡើង* ពាក្យនេះត្រូវបានប្រើក្នុងន័យចម្អកឱ្យថា ចូរអសប្បាយនឹងពេលបន្តិចបន្តួចដែលឯងនៅមាន មុននឹងព្រះអម្ចាស់ទ្រង់ជំនុំជម្រះឯង(មើល ខ.២២)។ *ពែង* មើលការពន្យល់ យរ ២៥:១៥ ។ *សំរាតខ្លួន* មើល ១:៨៩ និង យរ ៤៩:១០ ណាហ ៣:៥ ។

**៤:២២** *កូនស្រីនៃក្រុងស៊ីយ៉ូន* គឺនិយាយសំដៅទីក្រុងយេរូសាឡិម ដោយប្រៀបប្រដូចទៅនឹងលក្ខណៈជាមនុស្ស(មើលការពន្យល់ ២ពវ ១៩:២១)។ *នឹងមិនឱ្យនាងទៅជាឈ្លើយទៀតឡើយ* មើល យរ ៣១–៣៣ ។ *បើកអំពើបាបរបស់នាងឱ្យឃើញច្បាស់* ធៀបនឹង ទដ ៣២:១ ៨៥:២ ។

**៥:១–២២** នៅក្នុងព្រះគម្ពីរភាសាព្រើ វគ្គនេះនៃបទទំនួញនេះ គឺមិនមានការតំរៀបល្បះតាមមលំដាប់ព្យញ្ជនៈ ដូចជំពូក ១–៤ ទេ ប៉ុន្តែ គឺតំរៀប

[៣]យើងខ្ញុំជាកូនកំព្រា ឥតមានឪពុកម្ដាយយើងខ្ញុំបានទៅជា
មេម៉ាយ[ច] [៤]យើងខ្ញុំផឹកទឹករបស់ខ្លួន[ឆ] ដោយបង់ប្រាក់ ឯ
ឱសរបស់យើងខ្ញុំ គេក៏លក់ដល់យើងខ្ញុំដែរ[ជ] [៥]ពួកអ្នក
ដែលដេញតាម គេជិះកយើងខ្ញុំ យើងខ្ញុំក៏អស់កំឡាំង[ឈ]
ឥតមានពេលសំរាកឡើយ[ញ] [៦]យើងខ្ញុំបានហុចដៃទៅឯពួក
សាសន៍អេស៊ីព្ទ និងពួកសាសន៍អាសស៊ើរផង[ដ] ដើម្បីឱ្យ
បានអាហារបរិភោគ [៧]ពួកឰយុកោ[ឋ]យើងខ្ញុំបានធ្វើបាប
ហើយក៏វិនាសអស់ទៅ ឯយើងខ្ញុំក៏បានត្រូវរងអំពើទុច្ចរិត
របស់គាត់ដែរ[ឌ] [៨]មានពួកអ្នកបំរើ[ឍ]ធ្វើជាចៅហ្វាយលើ
យើងខ្ញុំឥតមានអ្នកណានឹងដោះយើងខ្ញុំឱ្យរួចពីកណ្ដាប់ដៃ
គេឡើយ[ណ] [៩]យើងខ្ញុំបានអាហារមក ដោយប្រថុយជីវិត
ចំពោះដាវនៅទីរហោស្ថាន [១០]ស្បែកយើងខ្ញុំក្ដៅដូចជា
ជើងក្រាន ដោយព្រោះកំដៅនៃការអត់ឃ្លាន[ត] [១១]គេបាន
ចាប់កំហែង[ថ]ពួកស្រីនៅក្រុងស៊ីយ៉ូន និងពួកក្រមុំៗនៅអស់
ទាំងទីក្រុងនៃស្រុកយូដា [១២]ឯពួកចៅហ្វាយបានត្រូវគេចង
ដៃព្យួរ ហើយគេមិនខ្លាចមុខពួកចាស់ទុំ[ទ]ទេ[ធ] [១៣]ពួកកំឡោះ
ៗ បានត្រូវសែងត្បាល់កិន ហើយកូនក្មេងដើរទន់ជើងទ្រេត
ទ្រោតក្រោមបាច់ឧស [១៤]ពួកចាស់ទុំបានដុតបាត់ពីទ្វារ
ក្រុងទៅ ហើយពួកកំឡោះៗក៏លែងលេងភ្លេងទៀត[ន] [១៥]ឯ
សេចក្ដីអំណររបស់ចិត្តយើងខ្ញុំ បានត្រឡប់ទៅជាការ
សោយសោកវិញ[ប] [១៦]មកុដ[ផ]បានធ្លាក់ចុះពីក្បាលយើងខ្ញុំ[ព]
ហើយវរហើយយើងខ្ញុំ ពីព្រោះយើងខ្ញុំបានធ្វើបាប[ភ]
[១៧]ដោយហេតុនេះបានជាចិត្ត[ម]យើងខ្ញុំស្រយុតចុះ[យ] ហើយ
ភ្នែក[រ] យើងខ្ញុំក៏បានត្រឡប់ទៅជាងងឹតដោយព្រោះការ
ទាំងនេះដែរ[ល] [១៨]គឺដោយព្រោះតែភ្នំស៊ីយ៉ូន[វ]ត្រូវចោល
ស្ងាត់ទៅ[ស] ហើយមានតែឆ្កែចចកដើរនៅលើបុំណ្ណោះ [១៩]ឱ

**៥:៣** ច នក ២២:២៤ យរ ១៥:៨ ១៨:២១
**៥:៤** ឆ អស ៥៥:១ អគ ៤:១៦–១៧ ជ អស ៣:១
**៥:៥** ឈ នហ ៩:៣៧ អស ៤៧:៦ ញ យស ១:១៣
**៥:៦** ដ យរ ២:៣៦ ហស ៥:១៣ ៧:១១ ៩:៣
**៥:៧** ឋ យរ ៣១:២៩ ឌ យរ ១៤:២០ ១៦:១២
**៥:៨** ឍ នហ ៥:១៥ ណ សក ១១:៦
**៥:១០** ត យប ៣០:៣០ បទ ៤:៨–៩
**៥:១១** ថ លប ៣៤:២៩ សក ១៤:២
**៥:១២** ទ លវ ១៩:៣២ ធ បទ ២:៦ ៤:១៦ **៥:១៤** ន អស ២៤:៨ យរ ៧:៣៤ **៥:១៥** ប យរ ២៥:១០ អម ៨:១០
**៥:១៦** ផ ទដ ៨៩:៣៩ យរ ១៣:១៨ ព យប ១៩:៩ ភ អស ៣:១១ យរ ១៤:២០
**៥:១៧** ម អស ១:៥ យ យរ ៨:១៨ រ ទដ ៦:៧ ល យប ១៦:៨ **៥:១៨** វ ទដ ៧៤:២–៣ ស អស ២៧:១០ មីក ៣:១២

តាមព្យញ្ជនៈដោយប្រើតែ២២ល្បះដែលល្បះនីមួយៗមានតែ១ឃ្លា (មើលសេចក្ដីផ្ដើមនៅក្នុងការពន្យល់ ទដ ៣៣)។ វគ្គនេះប្រើសព្វនាមទីមួយពហុវចនៈ គឺបង្ហាញថាសម្ដីនៅក្នុងវគ្គនេះគឺជាសម្ដីរបស់សហគមន៍ទាំងមូល (គឺដូចនៅក្នុង ទដ ៤៤,៦០,៧៤,៨០)។ វគ្គនេះនិយាយអំពីស្ថានភាពភ្លាមៗបន្ទាប់ពីទីក្រុងយេរូសាឡិមបានដួលរលំ គឺនៅពេលដែលអ្វីៗគ្រប់យ៉ាងលែងមានសណ្ដាប់ធ្នាប់ (មើល ខ.៨ និង យរ ៤០:៧–៤១:៤៥)។

**៥:១** *នឹកចាំ . . . ទតមក* គឺជាពាក្យចាប់ផ្ដើមនៃការអធិស្ឋានទូលអង្វរដល់ព្រះអម្ចាស់ សូមឱ្យទ្រង់ជួយដល់សេចក្ដីវេទនានៃរាស្ត្រទ្រង់ (មើល ទដ ៤៤:១៣ ៧៩:៤)។

**៥:២** *មរដករបស់យើងខ្ញុំ* គឺទឹកដីនគរយូដា (មើល យរ ២:៧ និងការពន្យល់ និងមើល ៣:១៨)។

**៥:៣** *ខ្ញុំជាកូនកំព្រា . . . មេម៉ាយ* គឺត្រូវក្លាយជាឥតទីពឹង ដូចកូនកំព្រា និងស្ត្រីមេម៉ាយ (មើលការពន្យល់ នក ២២:២១–២៧ អស ១:១៧)។

**៥:៤** *យើងខ្ញុំផឹកទឹក . . . ឧស* គឺខុសពី ចទ ២៩:១១ យស ៩:២១,២៣,២៧។

**៥:៥** *ឥតមានពេលសំរាក* "ការសំរាក" ដែលពួកគេទទួលតាមសេចក្ដីសន្យា នៅពេលនេះត្រូវដកចេញពីពួកគេវិញ (មើល ចទ ៣:២០ និងការពន្យល់)។

**៥:៦** *បានហុចដៃទៅឯ* មើល ១រប ២៩:២៤ ២រប ៣០:៨ យរ ៥០:១៥ ២ពវ ១០:១៥ អរ ១០:១៩ អគ ១៧:១៨ ។ *សាសន៍អេស៊ីព្ទ . . . អាសស៊ើរ* នៅត្រង់ចំណុចនេះ ពួកគេនិយាយអំពីនគរមហាអំណាចនៅសម័យនោះ ដែលពួកគេបានចងសម្ព័ន្ធមិត្រ ដើម្បីទទួលបាននូវការការពារ (មើល អស ៧:១៨ ១១:១៦ ១៩:២៣–២៥ ៥២:៤ យរ ២:១៨,៣៦ និងមើល ហស ៧:១១ ៩:៣ ១១:៥,១១ ១២:១ និងការពន្យល់ ធៀបនឹង មីក ៧:១២ សក ១០:១០ និងការពន្យល់)។

**៥:៧** នៅត្រង់ចំណុចនេះ ទាំងឪពុក ទាំងកូនប្រុស គឺសុទ្ធតែត្រូវទទួលខុសត្រូវ ចំពោះគ្រោះមហន្តរាយដែលបានកើតឡើង ចំពោះទីក្រុងយេរូសាឡិម (មើល ខ.១៦ យរ ៣:២៥ ១៦:១១–១២ ៣១:២៩–៣០ អគ ១៨:២–៤ ធៀបនឹង អស ៦៥:៧)។

**៥:៨** *ពួកអ្នកបំរើ* គឺជាពាក្យចម្អក សំដៅទៅលើ ពួកនាម៉ឺននៃចក្រភពបាប៊ីឡូន ដែលកំពុងតែគ្រប់គ្រងទីក្រុងយេរូសាឡិម (ដែលពីមុនអ្នកនិពន្ធបានហៅពួកគេថា "ជាបុត្រីនៅកណ្ដាលខេត្តទាំងប៉ុន្មាន" នៅក្នុង ១:១) មើល សភ ៣០:២១–២២ ។

**៥:៩** *ដាវនៅទីរហោស្ថាន* គឺសំដៅទៅលើ ពួកចោរព្រៃដែលនៅលួចប្លន់នៅទីរហោស្ថាន ។

**៥:១២** *ព្យួរ* គឺជាការបន្ថោកជាបន្ថែម ដល់អ្នកដែលទោសដែលត្រូវបានប្រហារជីវិតហើយ (មើលការពន្យល់ ចទ ២១:២២–២៣)។

**៥:១៣** *ត្រូវសែងត្បាល់កិន* គឺជាការបន្ថោក ដោយការងារ (មើលការពន្យល់ ពច ៩:៥៣ និងមើល អស ៤៧:២)។

**៥:១៤** *ទ្វារក្រុង* គឺជាសំដៅទៅលើ តុលាការក្រុង (មើល យស ២០:៤) ប៉ុន្តែ ក៏ជាកន្លែងជួបជុំគ្នាសម្រាប់ការសន្ទនា និងកម្សាន្តសប្បាយផងដែរ (ធៀបនឹង ១:៤)។

**៥:១៥** មើល យរ ៧:៣៤ ១៦:៩ ២៥:១០ ធៀបនឹង ទដ ៣០:១១ យរ ៣១:១៣ ។

**៥:១៦** *មកុដ* គឺជានិមិត្តសញ្ញាដំណាងឱ្យសិរីល្អ និងកិត្តិយសនៃទីក្រុងយេ–រូសាឡិម (មើល ១:១ ២:១៥ ធៀបនឹង អស ២៨:១,៣)។

**៥:១៧** *ចិត្តយើងខ្ញុំស្រយុតចុះ* មើលការពន្យល់ ១:២២ ។ *ភ្នែក . . . ងងឹត*

ព្រះយេហូវ៉ាអើយ ទ្រង់គង់នៅអស់កល្បជានិច្ច[ឃ] រាជ្យ
ទ្រង់ក៏ស្ថិតស្ថេរនៅ[ង]ដល់អស់ទាំងដំណមនុស្សតរៀងទៅ
[២០]ហេតុអ្វីបានជាទ្រង់ ភ្លេចយើងខ្ញុំជារៀងរាបដរាប[អ]
ហើយបោះបង់ចោល[ក] យើងខ្ញុំជាយូរអង្វែងដូច្នេះ [២១]ឱ
ព្រះយេហូវ៉ាអើយ សូមបំបែរយើងខ្ញុំឱ្យវិលមក[ខ]ឯទ្រង់វិញ
នោះយើងខ្ញុំនឹងបានបែរមកហើយ សូមកែជីវិតរបស់យើង
ខ្ញុំឡើងវិញ ដូចជាកាលពីដើម [២២]តើទ្រង់បានបោះបង់
ចោលយើងខ្ញុំ[ក] ជាដាច់ខាតឬត្រង់មានសេចក្ដីខ្ញាល់ក្ដៅនឹង
យើងខ្ញុំយ៉ាងខ្លាំងហើយ[ឃ]។/

**៥:១៩** ហ ១រប ១៦:៣១ ឡ ទដ ៤៥:៦ ១០២:១២, ២៤-២៧ **៥:២០** អ ទដ ១៣:១ ៤៤:២៤ ក ទដ ៧១:១១ **៥:២១** ខ ទដ ៨០:៣ អស ៦០:២០-២២ **៥:២២** ក ទដ ៥៣:៥ ៦០:១-២ យរ ៦:៣០ ឃ អស ៦៤:៩

មើល ២:១១ និងការពន្យល់ ទដ ៦:៧ ។

**៥:១៨** *ឆ្កែចចក* នៅក្នុងព្រះគម្ពីរភាសាហេព្រើ ពាក្យនេះត្រូវបានប្រើផង ដែរនៅក្នុង ៤:៣ ដែលអាចមានន័យថា "កញ្ជ្រោង" (មើលការពន្យល់ ពច ១៥:៤)។ ចំពោះការប្រៀបប្រដូចអំពីការត្រូវចោលស្ងាត់ស្រដៀងគ្នានេះ សូមមើល អស ១៣:២១-២២ ៣៤:១១-១៥ សផ ២:១៣-១៥ ។

**៥:១៩** ខនេះគឺដូចគ្នានឹង ទដ ១០២:១២ (មើលការពន្យល់ខនេះ)។ នៅក្នុង បទគម្ពីរផ្សេងទៀត ក៏មានការចាប់ផ្ដើមអធិស្ឋានដោយពាក្យសរសើរ តម្កើងផងដែរ (ទដ ៤៤:១-៨ ៧៤:១២-១៤ ៨០:១-២ ៨៩:១-១៨ ធៀប នឹង កច ២៤:២៣ និងការពន្យល់)។

**៥:២០** *ហេតុអ្វី . . . ដូច្នេះ* មើលការពន្យល់ ទដ ៦:៣ ។

**៥:២១** *បំបែរយើងខ្ញុំឱ្យវិលមកឯទ្រង់វិញ* ពាក្យនេះប្រើនៅក្នុងការ អធិស្ឋានទូលសូមការចាប់ផ្ដើមប្ដេជ្ញាចិត្តសាជាថ្មីថ្វាយព្រះអម្ចាស់ (មើល ១ពវ ៨:៣៣,៤៨ នហ ១:៩ យរ ៣:៧,១០ ហស ៧:១០)។ *យើងខ្ញុំនឹង បានបែរមក* មើល យរ ៣១:១៨ និងការពន្យល់ ៣១:១៨-១៩ ។ *កែ . . . ឡើងវិញ* មើល ទដ ១០៤:៣០ ។

**៥:២២** មើល យរ ១៤:១៩ ។ *តើ . . . ឬ* បទទំនួញនេះបញ្ចប់ទៅវិញដោយ ពាក្យនៃសេចក្ដីទុក្ខ គឺស្រដៀងគ្នាបទទំនួញផ្សេងទៀតនៅក្នុងព្រះគម្ពីរនេះ ក៏ដូចនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដទៃទៀតផងដែរ (មើល ឧទាហរណ៍ ទដ ៨៨ ព្រះគម្ពីរអេសាយ និងម៉ាឡាគី)។

# ព្រះគម្ពីរអេសេគាល

## សេចក្តីផ្តើម

### ជីវប្រវត្តិ

ហោរាអេសេគាលបានរស់នៅក្នុងកំឡុងពេលនាសម័យវិជើបរិជ្ជល គ្រប់ទាំងពូជសាសន៍ ។ ចក្រភពអាសេរីដែលបានគ្រប់គ្រងទឹកដីតំបន់ភីលីស្ទីន និងបំផ្លាញនគរអ៊ីស្រាអែលផ្នែកខាងជើង (ដែលនៅក្នុងកណ្តាប់ដៃពួកសាសន៍អាសេរីក្នុងឆ្នាំ ៧២២-៧២១ មុន ស.គ) ក៏ចាប់ផ្តើមបែកបាក់ នៅក្រោមការវាយប្រហាររបស់ពួកសាសន៍បាប៊ីឡូន ដែលមានគ្នាច្រើនសន្ធឹក ។ នៅក្នុងឆ្នាំ ៦១២ មានទឹកដីជាអណាចក្រអាសេរីនៃក្រុងនីនីវេ ក៏ចូលរួមជាកម្លាំងជាមួយសាសន៍បាប៊ីឡូន និងសាសន៍ម៉ាដាយ ។ បីឆ្នាំក្រោយមក ស្តេចផារ៉ោននេកោទី២របស់ប្រទេសអេស៊ីព្ទ បានប្រមូលផ្តុំបង្រួមទឹកដីនគរខាងជើងដើម្បីជាជំនួយដល់ពួកសាសន៍អាសេរី និងព្យាយាមពង្រីកអំណាចឥទ្ធិពលតាំងពីយូណាស់មកហើយរបស់ស្រុកអេស៊ីព្ទ ទៅលើពួកសាសន៍កាណាន និងស្រុកអើរ៉ាម ។ ឯនៅក្រុងមេគីដោមានស្តេចឈ្មោះយ៉ូសៀ ដែលបានចងសម្ព័ន្ធមិត្តជាមួយក្រុងបាប៊ីឡូន ក្នុងនាមស្តេចហេសេគាលបានព្យាយាមរារាំងកម្លាំងទ័ពអេស៊ីព្ទ ប៉ុន្តែក៏ត្រូវបានបាត់បង់ព្រះជន្មក្នុងសង្គ្រាមទៅ (សូមមើល ២ពវ ២៣:២៩-៣០ ២រប ៣៥:២០-២៤) ។

យ៉ូអាហាស គឺបុត្រារបស់ស្តេចយ៉ូសៀសបានដឹកនាំស្រុកយូដាអស់រយៈពេលបីខែ បន្ទាប់ពីនេកោជាស្តេចបានប្រគល់អំណាចទៅឱ្យបុត្រាមួយអង្គទៀតរបស់ស្តេចយ៉ូសៀសធ្វើជាបរិវារ នៃរាជវាំងក្រុងយេរូសាឡិម (ក្នុងឆ្នាំ ៦០៩ មុន ស.គ) ។ នៅក្នុងឆ្នាំ៦០៥ ពួកបាប៊ីឡូនបានចាប់យកកងទ័ពអេស៊ីព្ទនៅត្រង់កើកេមីស (សូមមើល ៤៦:២) គឺមានចម្ងាយស្មើគ្នាទៅនឹងតំបន់វាលស្រុកភីលីស្ទីន ។ ក្នុងឆ្នាំដដែលនោះ នេប៊ូក្នេសាក៏បានអភិសេកឡើងគ្រងរាជបល្ល័ង្កនៅស្រុកបាប៊ីឡូន ចំណែកឯលោកយ៉ូយ៉ាគីនក៏លែងមានភាពស្មោះត្រង់ចំពោះទ្រង់ ។ រយៈពេលពីរបីឆ្នាំក្រោយមកទៀត កម្លាំងទ័ពសាសន៍អេស៊ីព្ទនិងសាសន៍បាប៊ីឡូនបានជួបប្រទះសង្គ្រាមចម្បាំង លោកយ៉ូយ៉ាគីនក៏បះបោរប្រឆាំងនឹងស្តេចអធិរាជថ្មីរបស់គាត់ ។

មិនយូរប៉ុន្មានស្តេចនេប៊ូក្នេសាបានបញ្ជូនកម្លាំងទ័ព ដើម្បីឆ្លើយតបនឹងស្ថានភាពហើយប្រឆាំងនឹងពួកក្រុងយេរូសាឡិម គឺបានបង្ក្រាបទីក្រុងនោះក្នុងឆ្នាំ ៥៩៧ មុន ស.គ ។ បុត្រារបស់ស្តេចយេហូយ៉ាគីមព្រះនាមយ៉ូយ៉ាគីន និងពួកយូដាប្រហែល១០ពាន់នាក់ (សូមមើល ២ពវ ២៤:១៤) មានទាំងហោរាអេសេគាលផងដែរ បាននិរទេសទៅស្រុកបាប៊ីឡូនដែលពួកគេបានចូលរួម ជាមួយអ្នកដែលគេនិរទេស "នៅឆ្នាំទី៣" នៃការគ្រងរាជ្យរបស់ស្តេចយេហូយ៉ាគីម (សូមមើល ដយ ១:១ និងការពន្យល់) ។ ស្តេចនេប៊ូក្នេសាចាត់ឪពុកមារបស់យ៉ូយ៉ាគីនក្នុងការគ្រប់គ្រងរាជ្យបល្ល័ង្កនៃក្រុងយេរូសាឡិម ប៉ុន្តែក្នុងរយៈពេល៥ ឬ៦ឆ្នាំទ្រង់បានបះបោរប្រឆាំងវិញ ។ ក៏មានការឡោមព័ទ្ធពីពួកសាសន៍បាប៊ីឡូនដល់ក្រុងយេរូសាឡិមក្នុងឆ្នាំង ៥៨៨ ឯកំផែងជាច្រើនបានប្រេះបែក ចំណែកឯទីក្រុងនោះក៏បានរឹបអូសលួចប្លន់យកទ្រព្យសម្បត្តិអស់រលីង គឺក្នុងខែសីហាទី១៤ឆ្នាំ ៥៨៦ ទីក្រុងនិងព្រះវិហារត្រូវបានគេដុតកំទេចអស់ ។

ក្រោមការគ្រប់គ្រងរាជអំណាចរបស់ស្តេចនេប៊ូក្នេសា និងអ្នកដែលត្រូវស្នងរាជពីទ្រង់នោះ គឺក្រុងបាប៊ីឡូនបានគ្រប់គ្រងត្រួតត្រាជាតិសាសន៍មួយចំនួន រហូតដល់អំណាចនោះដួលទៅវិញដោយសារតែពួកសាសន៍ស៊ីរ៉ូស(ពីស្រុកពើស៊ី)ក្នុងឆ្នាំ ៥៣៩ មុន ស.គ ។ ការគ្រងរាជ្យរបស់រាជវង្សស្តេចដាវីឌបានបញ្ចប់នគរសាសន៍យូដា លែងជាជាតិសាសន៍ដែលមានឯករាជ្យ ក្នុងស្រុកទៀតហើយក្រុងយេរូសាឡិម និងព្រះវិហារនៃព្រះយេហូវ៉ាបានបាក់បែកខូចខាតអស់ ។

### អ្នកនិពន្ធ

អ្វីដែលគេបានស្គាល់ពីហោរាអេសេគាល គឺលោកបានចូលរួម ឬមានឈ្មោះក្នុងកណ្ឌគម្ពីរនេះ ហោរាយេរេមាក៏ជាមនុស្សម្នាក់ក្នុងចំណោមពួកយូដាដែលគេចាប់ជាឈ្លើយទៅឯស្រុកបាប៊ីឡូន ដោយស្តេចនេប៊ូក្នេសាក្នុងឆ្នាំ ៥៩៧ មុន ស.គ រួចនៅក្នុងប្រជាជនដែលដែលគេចាប់ជាឈ្លើយនោះ មានហោរាយេរេមាបានទទួលការត្រាស់ហៅពីព្រះឱ្យធ្វើជាហោរា (សូមមើល ១:១-៣) ។ គាត់បានរៀបអាពាហ៍ពិពាហ៍ (សូមមើល ២៤:១៥-១៨) បានរស់នៅក្នុងផ្ទះផ្ទាល់ខ្លួនរបស់គាត់ (សូមមើល ៣:២៤ ៨:១) ហើយក្នុងដំណើរចាប់ជាឈ្លើយទៅនោះ គឺពុំមានសេរីភាពក្នុងការដើរឆ្លងទេ ។ នៅទីនោះមានអត្ថិភាពរស់នៅមានសង្ឃឹម (សូមមើលការពន្យល់ ១:៣) ហេតុដូច្នេះហើយគាត់អាចទទួលបាននូវការត្រាស់ហៅជាអ្នកបម្រើព្រះជាសង្ឃ ។ ជាសង្ឃហោរាត្រូវបានព្រះត្រាស់ហៅ ដើម្បីបម្រើព្រះក្នុងចំណោមពួកជាប់ជាឈ្លើយ (ដែលបានឃ្លាតឆ្ងាយពីព្រះវិហារនៃព្រះយេហូវ៉ា ដើម្បីឱ្យមានភាពប្រកបស្និទ្ធ ភាពលះបង់ គឺដើម្បីជំនួយក្នុងការលើកទឹកចិត្ត ឬរំដោះនូវភាពតានតឹង និងឱ្យមានសកម្មភាពថ្វាយបង្គំព្រះ) ឯអត្ថបទរបស់គាត់បានបង្ហាញជាច្រើនពីរឿង

ព្រះវិហារជាពិសេសសូមមើល ជំពូក ៨–១១, ៤០–៤៨) និងពិធីបុណ្យផ្សេងៗ ។

ហោរាអេសេគាល គឺជាហោរាដែលមានចំណេះដឹងចេះយ៉ាងទូលំទូលាយ គឺមិនមែនគ្រាន់តែចេះដឹងពីប្រពៃណីរបស់ជាតិសាសន៍ផ្ទាល់ខ្លួនប៉ុណ្ណោះទេ តែលោកអាចចេះពីកិច្ចការអន្តរជាតិ និងប្រវត្តិសាស្ត្រផងដែរ ។ ចំណេះដឹងផ្ទាល់ខ្លួនរួចផ្សំនឹងរឿងរ៉ាវទូទៅវេប្បធម៌ ក៏ចេះផ្នែកសាងសង់នាវារហូតដល់ផ្នែកអក្សរសាស្ត្រ គឺគួរឱ្យអស្ចារ្យស្ញប់ស្ញែងបំផុត ។ គាត់បានទទួលអំណោយទានដែលមានប្រាជ្ញាប្រកបដោយអំណាចចេស្តាដឹងគ្រប់ទាំងស្ថានភាពធំៗទាំងឡាយ (សូមមើល ១៦:២៣) ។

ក៏មានភាពប្រសើរជាងហោរាផ្សេងទៀយ (គឺមានលក្ខណៈពិសេសជាងហោរាហូសេ និងហោរាយេរេមា) លោកក៏បានទទួលការណែនាំឱ្យចូលរួមផ្នែកកិច្ចការវិជ្ជានៃព្រះបន្ទូលដោយផ្ទាល់ ដោយស្តែងចេញសកម្មភាពជាហោរាក្នុងការបម្រើរព្រះ ។

**ព្រឹត្តិការណ៍សំខាន់ៗ គោលបំណងនិងការសង្ខេបមាតិការរឿង**

ទោះបីជាហោរាយេរេមាបានរស់នៅជាមួយមិត្តភ័ក្ត្រ ឬប្រជាជនដែលគេបានចាប់ជាឈ្លើយនៅឯស្រុកបាប៊ីឡូនក៏ដោយ ក៏ការត្រាស់ហៅពីព្រះចំពោះរូបលោក បានជំរុញឱ្យលោកផ្តោតលើសេចក្តីសង្ឃឹម ទុកថាបានត្រឡប់ទៅក្រុងយេរូសាឡិមមុនពេលទីក្រុងនោះត្រូវបានបាក់បែក ។ រយៈពេល៧ឆ្នាំដំបូងនៃកិច្ចការបម្រើព្រះរបស់ហោរាយេរេមា (ឆ្នាំ ៥៩៣–៥៨៦ មុន ស.គ) លោកមានទំនាក់ទំនងយ៉ាងល្អចំពោះជនជាតិយូដា ក៏សម្រេចបានការដ៏ត្រឹមត្រូវពីព្រះវិញ្ញាណបរិសុទ្ធ : ដោយសារអំពើបាបនៃរាស្ត្រអ៊ីស្រាអែល នោះស្រុកអ៊ីស្រាអែលក៏ធ្លាក់ចុះ (សូមមើល ជំពូក ១–២៤) ។ តាមពិតរាស្ត្រអ៊ីស្រាអែល គឺប្រជាជនបានភ្ជាប់សេចក្តីសញ្ញាជាមួយព្រះដែលមានក្រុងយេរូសាឡិម គឺជាព្រះវិហាររបស់ផងព្រះតាំងពីមុនៗមក ដែលនាំឱ្យពួកគេផុតការចាប់ជាឈ្លើយ ឬការពារក្រុងយេរូសាឡិមពីការបែកបាក់ (សូមមើល យរ ២៩–៣០) ។ សេចក្តីសង្ឃឹមមានតែមួយគត់ហោរាត្រូវបានទទួលអំណាចចេស្តាក្នុងការពង្រីកសេចក្តីទំនាយឱ្យដល់អស់អ្នកដែលទទួលស្តាប់បាន គឺរស់នៅដោយសន្តិភាពរវាងខ្លួនរបស់ពួកគេ និងព្រះអម្ចាស់ក្នុងគ្រាដែលពួកគេត្រូវបានជាប់ជាឈ្លើយ ។

បន្ទាប់ពីព្រះយេហូវ៉ាបានបើកសម្តែងឱ្យដឹងថាក្រុងយេរូសាឡិមនឹងត្រូវបានគេឡោមព័ទ្ធ និងត្រូវដួលរលំ (១៤:១–១៤) ឯហោរាអេសេគាលក៏បានគេប្រាប់ថាប្រពន្ធរបស់គាត់ ក៏ត្រូវស្លាប់ដែរ ។ សេចក្តីពេញចិត្តខាងឯកែវភ្នែករបស់លោក និងឃ្លាតចេញពីលោកមានលក្ខណៈដូចជាព្រះវិហារដែរ ឯសេចក្តីប៉ងប្រាថ្នានៃភ្នែករបស់រាស្ត្រអ៊ីស្រាអែល ក៏នឹងយកចេញពីរាស្ត្រអ៊ីស្រាអែល ។ លោកក៏ពុំបានយំកាន់ទុក្ខជាចំហរចំពោះភរិយាលោក ដែលជាសញ្ញាភ្ជាប់ទំនាក់ទំនងនឹងរាស្ត្ររបស់លោក គឺមិនមែនកាន់ទុក្ខជាចំហរដល់ក្រុងយេរូសាឡិមដែរ (២៤:១៥–២៧) ។ ព្រះវិញ្ញាណបានបណ្តាលឱ្យលោកប្រកាសពីការជំនុំជម្រះ ទៅលើពូជសាសន៍ទាំងប្រាំពីរមានដូចជា សាសន៍អាំម៉ូន ម៉ូអាប់ អេដំម ពួកកូនចៅភីលីស្ទីន ពួកក្រុងទីរ៉ុស ពួកក្រុងស៊ីដូន និងស្រុកអេស៊ីព្ទ (ជំពូក ២៥–៣២) ។ ឯថ្ងៃនៃការក្រោធរបស់ព្រះអម្ចាស់ និងមកជាឆាប់ៗ ប៉ុន្តែមិនមែនតែចំពោះរាស្ត្រអ៊ីស្រាអែលប៉ុណ្ណោះទេ ។

ក៏មានសេចក្តីមួយទៀតបានទទួលមកថា ក្រុងយេរូសាឡិមនឹងត្រូវធ្លាក់ចុះ គឺជាសាររបស់ហោរាអេសេគាល ដែលជាព្រះរាជសារនៃព្រះយេហូវ៉ា តែទ្រង់នឹងនាំឱ្យមានសេចក្តីសង្ឃឹមចំពោះរាស្ត្ររបស់ទ្រង់ ពួកគេនឹងទទួលបានបទពិសោធន៍នៃការងើបឡើងវិញ ហើយមានភាពល្អឡើងវិញ និងអនាគតដ៏រុងរឿងដោយបានប្រោះលោះបាប និងនៅនគរគ្រប់ល័ក្ខរបស់ព្រះអម្ចាស់នៅនាលោកីយ (ជំពូក ៣៣–៤៨) ។

**កាលបរិច្ឆេទ**

កណ្ឌគម្ពីរអេសេគាបាននិពន្ធឡើងដោយមានការកំណត់កាលបរិច្ឆេទជាច្រើន (សូមមើលតារាងខាងក្រោម) គឺច្រើនជាងកណ្ឌគម្ពីរហោរានៃសញ្ញាចាស់ផ្សេងៗទៀត ។ ឯពាក្យជាសេចក្តីទំនាយក្នុងកណ្ឌគម្ពីរនេះក៏មានកំណត់កាលបរិច្ឆេទច្បាស់លាស់ ។ ក៏មានសេចក្តីបន្ថែមខ្លះនៃអ្នកបណ្ឌិតវិជ្ជា ក្នុងផ្នែកបូរាណវិជ្ជា (ពីផ្នែកកំណត់ប្រវត្តិសាស្ត្រស្តីអំពីបន្ទះថ្មសិលាចារិត) និងតារាសាស្ត្រ (ជាការកំណត់កាលបរិច្ឆេទច្បាស់លាស់ ពីភាពបាំងឬចន្លោះពេលពុំមានសកម្មភាពប្រវត្តិសម័យដើមនោះ) ។

កាលកំណត់កាលបរិច្ឆេទទាំង១៣លើកបានបញ្ជាក់យ៉ាងច្បាស់ កណៈពេលហោរាអេសេគាលបានទទួលព្រះរាជសាពីព្រះ ។ ឯកាលបរិច្ឆេទដទៃទៀត គឺការមកដល់របស់អ្នកនាំសារក៏ប្រាប់ពីការធ្លាក់ចុះរបស់ក្រុងយេរូសាឡិម (៣៣:២១) ។

បានទទួលការត្រាស់ហៅនៅក្នុងខែតុលាឆ្នាំ៥៩៣មុន ស.គ ហោរាអេសេគាលមានសកម្មភាពបម្រើព្រះអស់រយៈពេល២២ឆ្នាំការកំណត់ពីសេចក្តីទំនាយរបស់លោកចុងក្រោយ ដែលទទួលពីព្រះនៅខែមករាឆ្នាំ៥៧១ (សូមមើល ២៩:១៧) ។

**គោលរឿង**

## កាលបរិច្ឆេទក្នុងព្រះគម្ពីរអេសេគាល

| សេចក្តីយោងលើខយោង | | ឆ្នាំ | ខែ | ថ្ងៃ | ការកណត់ពីសម័យកាល | ព្រឹត្តិការណ៍ |
|---|---|---|---|---|---|---|
| ១. | ១:១ | ៣០ | ៤ | ៥ | ៣០/០៧/៥៩៣ មុន ស.គ | ការបង្ហាញពីនិមិត្ត |
| | ១:២ | ៥ | – | ៥ | | |
| | ៣:១៦ | "ចុងបញ្ចប់នៃរយៈពេល៧ថ្ងៃ" | | | | |
| ២. | ៨:១ | ៦ | ៦ | ៥ | ១៧/កញ្ញា/៥៩២ | ការផ្លាស់ប្តូរនៅក្រុងយេរូសាឡិម |
| ៣. | ២០:១ | ៧ | ៥ | ១០ | ១៤/សីហា/៥៩១ | ទស្សនះអវិជ្ជមានរបស់ប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែល |
| ៤. | ២៤:១ | ៩ | ១០ | ១០ | ១៥/មករា/៥៨៨ | ការឡោមព័ទ្ធទីក្រុង (សូមមើល ២ពវ ២៥:១) |
| ៥. | ២៦:១ | ១១ | – | ១ | ២៣/មេសា/៥៨៧ រហូតដល់ ១៣/៥៨៦ | សេចក្តីទំនាយទាស់ប្រឆាំងនិងពួកទីក្រុងទីរ៉ុស (មើល ២៦:១) |
| ៦. | ២៩:១ | ១០ | ១០ | ១២ | ៧/មករា/៥៨៧ | សេចក្តីទំនាយប្រឆាំងនិងអេស៊ីព្ទ |
| ៧. | ២៩:១៧ | ២៧ | ១ | ១ | ២៦/មេសា/៦៧១ | ស្រុកអេស៊ីព្ទបានដោះដូរគ្នានិងស្រុកទីរ៉ុស |
| ៨. | ២៩:២០ | ១១ | ១ | ៧ | ២៩/មេសា/៥៨៧ | សេចក្តីទំនាយទាស់ប្រឆាំង និងស្តេចផារ៉ោន |
| ៩. | ៣១:១ | ១១ | ៣ | ១ | ២១/មិថុនា/៥៨៧ | សេចក្តីទំនាយទាស់ប្រឆាំង និងស្តេចផារ៉ោន |
| ១០. | ៣២:១ | ១២ | ១២ | ១ | ៣/មិនា/៥៨៥ | ពាក្យទំនួញពីដំណើរស្តេចផារ៉ោន |
| ១១. | ៣២:១៧ | ១២ | – | ១៥ | ១៣/មេសា/៥៨/ រហូតដល់ខែមេសា /១/៥៨៥ | ការផុតរលត់នៃស្រុកអេស៊ីព្ទ |
| ១២. | ៣៣:២១ | ១២ | ១០ | ៥ | ខែមករា/៨/៥៨៥ | ការមកដល់បន្ទាប់ពីកគេចខ្លួនដំបូង |
| ១៣. | ៤០:១ | ២៥ | ១ | ១០ | ២៨/០៤/៥៧៣ | ទស្សនះសម្រាប់ថ្ងៃអនាគត |

ព្រះគម្ពីរសញ្ញាចាស់បង្ហាញពីលក្ខណៈទូទៅ និងមានសេចក្តីទំនាយក្នុងលក្ខណៈទាយទុកជាមុន និងបង្រៀនពីការគ្រប់គ្រងអំណាចពីព្រះអម្ចាស់ ដែលមានអំណាចលើគ្រប់អស់ទាំងនៃការបង្កើតជាស្នាព្រះហស្តរបស់ទ្រង់ គឺលើអស់ទាំងមនុស្សនិងជាតិសាសន៍គ្រប់ទាំងប្រវត្តិសាស្ត្រ ។ ក៏គ្មានព្រះគម្ពីរដទៃទៀតឡើយដែលបានបង្ហាញច្បាស់លាស់ជាងកណ្ឌព្រះគម្ពីរអេសេគាលឡើយ ។ ចាប់តាំងពីជំពូកដំបូងក៏បានពណ៌នាយ៉ាងច្បាស់ ពីការរាតត្បាតលុកលុយដោសង្គ្រាមឈ្លានពាន ក៏មានវត្តមានព្រះយេហូវ៉ាក្នុងទឹកដីហោរាអេសេគាល គឺជាឃ្លាចុងក្រោយនៃទស្សនៈចុងក្រោយរបស់ហោរាអេសេគាល (គឺមានវត្តមានព្រះយេហូវ៉ា) កណ្ឌគម្ពីរបង្ហាគ្រប់ទិសទីថាទ្រង់គ្រងរាជ្យអំណាចលើគ្រប់ទាំងអស់ ។

ព្រះអម្ចាស់ជាព្រះមហាក្សត្រទ្រង់បានដោះស្រាយនូវរាល់បញ្ហា ដែលគ្រប់មនុស្សនឹងបានស្គាល់ក៏ទទួលស្គាល់ទ្រង់ផង ។ ក៏មានវគ្គនិពន្ធខ្លះៗជាង៦៥វគ្គ "ពេលនោះពួកគេនឹងបានស្គាល់ថាអញគឺជាយេហូវ៉ា" ដែលជាស្នបន្ទាល់ពីសេចក្តីសុចរិតនៃព្រះ ដែលមានព្រះទ័យចំពោះរាស្ត្រ (សូមមើលការពន្យល់ ៦:៧) ទាំងអស់គ្នាមានក្នុងជំពូក ១–២៤ ក៏បានបង្រៀនយើងថាព្រះអម្ចាស់នឹងបើកសម្តែងឱ្យយើងឃើញក្នុងខណៈពេលមានការធ្លាក់ចុះឬខ្សោយនៃក្រុងយេរូសាឡិម ហើយនិងមានការបាក់បែកព្រះវិហារ ។ ជំពូក ២៥–៣២ ក៏បានបង្រៀនថា ជាតិសាសន៍ទាំងអស់នឹងបានស្គាល់ព្រះអម្ចាស់តាមរយៈការជំនុំជម្រះរបស់ព្រះ ចំណែកជំពូក ៣៣–៤៨ ជាព្រះបន្ទូលសន្យាដែលទ្រង់មានបន្ទូលថា ទ្រង់នឹងបានរាស្ត្រទ្រង់តាមរយៈការស្រោចស្រង់ឱ្យមានភាពល្អឡើងវិញ និងការចាក់បំពេញព្រះវិញ្ញាណដល់រាស្ត្រអ៊ីស្រាអែលឱ្យមានឡើងវិញ ។

ភាពជាព្រះមហាក្សត្ររបស់ព្រះអម្ចាស់ គឺជាបន្ទាល់មួយក្នុងព្រះរាជកិច្ចរបស់ទ្រង់ ។ ទ្រង់ក៏ពុំបានដាក់តំណាងចំពោះព្រះវិហារក្នុងក្រុងយេរូសាឡិមទេ ។

ព្រះទ្រង់ឆ្លើយតបចំពោះអំពើបាបរបស់រាស្ត្រទ្រង់តាមរយៈការបន្សល់ ឬស្ពានទីបរិសុទ្ធរបស់ទ្រង់ក្នុងស្រុកអ៊ីស្រាអែល ដើម្បីជាទីសម្រាប់ព្រះយេហូវ៉ាមកប្រកបស្និទ្ធជាមួយរាស្ត្រទ្រង់នៅឯស្រុកបាប៊ីឡូន ដែលបានគេចាប់ជាឈ្លើយ ។

ព្រះអម្ចាស់ទ្រង់ជំនុំជម្រះដោយយុត្តិធម៌ និងស្មើភាពទាំងអស់ ។ ការជំនុំជម្រះដោយប្រឹតប្រៀន លើពួកអ៊ីស្រាអែលជាលើកចុងក្រោយ គឺដោយព្រះគុណនៃទ្រង់ ។ ទ្រង់ក៏អនុញ្ញាតឱ្យញែកដាច់ពីគ្នានៃនយោបាយរបស់រាស្ត្រអ៊ីស្រាអែល និងជីវិតខាងសេចក្តីជំនឿសាសនា ដើម្បីជីវិតរបស់គេមានលក្ខណៈជាថ្មីស្រស់ឡើងក្នុងវត្តមានទ្រង់ និងរាស្ត្រអ៊ីស្រាអែលដែលជាអំណោយទានពីព្រះយេហូវ៉ាដែលជាព្រះលើគ្រប់ទាំងអស់ ។

ឯលក្ខណៈបន្ថែមទៀតក្នុងនាមជាអ្នកនាំព្រះរាជសារនៃព្រះអម្ចាស់ ដែលមានហោរាអេសេគាល "ជាកូនមនុស្ស" (សូមមើលការពន្យល់ ២:១) ដែលត្រូវបានព្រះជ្រើសរើសឱ្យធ្វើជាអ្នកបម្រើទ្រង់ ។

**លក្ខណៈអក្សរសាស្ត្រ :**

មានហោរាសំខាន់ៗបី (ហោរាអេសាយ ហោរាយេរេមា ហោរាអេសេគាល) ចំណែកឯហោរាសេផានាក៏មាននូវព្រះរាជសារជាសេចក្តីទំនាយស្រដៀងគ្នាដែរ (១).សេចក្តីទំនាយទាស់ប្រឆាំងនឹងរាស្ត្រអ៊ីស្រាអែល (២).សេចក្តីទំនាយទាស់ប្រឆាំងនឹងជាតិសាសន៍ផ្សេងៗ (៣).សេចក្តីសម្រាលទុក្ខចំពោះរាស្ត្រអ៊ីស្រាអែល ។ ក៏គ្មានកណ្ឌគម្ពីរណាទៀតទេ ដែលបានបញ្ជាក់ឬបង្ហាញឱ្យឃើញច្បាស់ជាងកណ្ឌគម្ពីរអេសេគាលឡើយ (សូមមើលគម្រោងសង្ខេប) ។

ក្រៅពីភាពច្បាស់លាស់ទាំងនេះ កណ្ឌគម្ពីរអេសេគាលក៏បង្ហាញភាពស៊ីគ្នា ឬសមនឹងកាលៈទេសៈ ។ ទស្សនៈនៃព្រះវិហារដែលបានដួលចុះក៏សមនឹងភាពខូចខាត (ជំពូក ៨–១១) ក៏មានទស្សនៈថ្មីមកជំនួស ដែលនាំឱ្យមានភាពបរិសុទ្ធនៃវិហាររបស់ព្រះ (ជំពូក ៤០–៤៨) ។

ព្រះអម្ចាស់បានបង្ហាញពីសេចក្តីក្រោតយ៉ាងរញ្ជួយ (ជំពូក ១) ព្រះអម្ចាស់ក៏បានបង្ហាញឱ្យដឹងថា ទ្រង់ជាព្រះនៃសេចក្តីកំសាន្តចិត្ត (៤៨:៣៥) ។ ការត្រាស់ហៅហោរាអេសេគាល គឺដើម្បីធ្វើជាអ្នកប្រកាសចាំយាមពីការជំនុំជម្រះពីព្រះបានមកដល់ (ជំពូក ៣) ក៏ធ្វើឱ្យស្ថានភាពល្អប្រសើរដោយការត្រាស់ហៅឱ្យធ្វើជាអ្នកប្រកាសដោយចាំយាមចំពោះយុគសម័យថ្មី (ជំពូក ៣៣) ។ ក្នុងកន្លែងមួយ (ជំពូក ៦) ភ្នំរបស់រាស្ត្រអ៊ីស្រាអែលទទួលនូវការបន្ទោសពីព្យាការី ប៉ុន្តែការមួយទៀត (ជំពូក ៣៦) ពួកគេក៏បានលួងចិត្តពីព្រះ ។

កណ្ឌគម្ពីរហោរាជាទូទៅគឺសរសេរជាបែបកំណាព្យ ឬបង្ហាញពីការនិមិត្តស្រមៃ និងរបៀបជាលក្ខណៈចង្វាក់ ។ ភាគច្រើននៃគម្ពីរអេសេគាល ត្រូវបានគេសរសេរជាពាក្យរាយ គឺតាមតែប្រវត្តិកាលនៃសង្ឃ ។ ឯពាក្យផ្តនៗរបស់លោកបានបាន់ឆ្ពោះមកយើងដែលធ្វើឱ្យយើងមិនអាចភ្លេចបាននឹងសេចក្តីណែនាំក្នុងភាពជាសង្ឃរបស់លោក ក៏មានឥទ្ធិពលក្នុងក្តីក្តាំងនៃការជំនុំជម្រះ (ប្រៀបធៀប ៣:១៩

"បើអ្នកបានព្រមានណែនាំដល់មនុស្សអាក្រក់មានក្នុង ២១:២" បើអ្នកទិញអ្នកបម្រើជាតិសាសន៍ហេព្រើរ) ។ កណ្ឌគម្ពីរបាននិពន្ធឡើងដោយមានទស្សនៈសំខាន់១៤ (ជំពូក ១–៣ ៨–១១ ៣៧:១–១៤ ៤០–៤៨) និងសកម្មភាពជានិមិត្តរូបមាន១២ (៣:២២–២៦ ៤:១–៣ ៤:៤–៨ ៤:១៤ ៥:១–៣ ១២:១–១៦ ១២:១៧–២០ ២១:៦–៧ ២១:១៨–២៤ ២៤:១៥–២៤ ៣៧:១៥–២៨) ។ ឯព្រះរាជសាមាន៥បែបដែលសរសេរជាទំរង់ពាក្យប្រស្នា (ជំពូក ១៥,១៦,១៧,១៩,២៣) ។

**លក្ខណៈសំខាន់នៃវិជ្ជាសិក្សាពីព្រះ**

ហោរាដទៃទៀតមានទំនាក់ទំនងជាច្រើន និងការថ្វាយបង្គំរូបព្រះក្នុងស្រុកនៃរាស្ត្រអ៊ីស្រាអែល ដែលរាស្ត្រអ៊ីស្រាអែលនៅពេលនោះមានអំពើពុករលួយផ្នែកខាងសីលធម៌ វាគឺជាទង្វើរួម ឬជាទង្វើផ្ទាល់ខ្លួននឹងល្បិចកលទុច្ចរិតទៅនឹងសម្ពន្ធភាពអន្តរជាតិរបស់រាស្ត្រអ៊ីស្រាអែល ដែលពួកគេបានពឹងផ្អែកលើសមត្ថភាពខ្លួនឯង ជាជាងពឹងទៅលើព្រះយេហូវ៉ា ។ ពួកគេបានប្រកាសពីការជំនុំជម្រះក្នុងការរារាំងដល់ព្រះអម្ចាស់ ចំពោះជាតិសាសន៍ដែលប្រឆាំងដល់ទ្រង់ ប៉ុន្តែបាននិយាយពីការលោះបាបដល់ថ្ងៃក្រោយ : គឺមានការចេញដំណើរថ្មី ការតាំងសញ្ញាថ្មី មានក្រុងយេរូសាឡិមថ្មី មានរាជ្យវង្សស្តេចដាវីឌជាថ្មី ក៏មានការទទួលស្គាល់ជាច្រើនពីព្រះយេហូវ៉ា និងស្ថានសួគ៌ដែលជាទីសុខដុម ។

ទម្រង់និងភាពផ្លាស់ប្តូរនៃរាជសាររបស់ហោរាអេសេគាល គឺមានភាពស្រដៀងគ្នា ប៉ុន្តែលោកបានផ្តោតលើអត្ថន័យរួមមួយចំពោះរាស្ត្រអ៊ីស្រាអែល ដែលមានសដ្ឋានជារាស្ត្រដ៏បរិសុទ្ធ ដែលមានព្រះវិហារបរិសុទ្ធ ជាទីក្រុងបរិសុទ្ធ និងស្រុកបរិសុទ្ធ ។ ដោយធ្វើការបំផ្លាញការថ្វាយបង្គំរាស្ត្រអ៊ីស្រាអែលបានប្រគល់ខ្លួនរបស់ពួកគេ ដែលមិនស្អាតនឹងព្រះវិហារដែលស្មោគរោគមានដូចជាទីក្រុង ស្រុកទៅព្រះ ។ គឺដើម្បីឱ្យព្រះអម្ចាស់ដកនូវការជំនុំជម្រះចេញពីរាស្ត្រទ្រង់វិញ ក៏ដូចជាការហិនវិនាសគ្រប់ទាំងពូជសាសន៍ ។

ប៉ុន្តែភាពសប្បុរសរបស់ព្រះអម្ចាស់ចំពោះសេចក្តីសញ្ញារបស់ទ្រង់ និងព្រះទ័យទ្រង់ដើម្បីសង្គ្រោះមនុស្សលោកមានភាពវិសេស ដែលជាហេតុនាំឱ្យទ្រង់បានភ្ជាប់ទំនាក់ទំនងនិងរាស្ត្រទ្រង់ឡើងវិញ ដោយឃ្វាលពួកគេដែលជារាស្ត្រទ្រង់ប្រកបដោយសេចក្តីមេត្តាករុណា ព្រះបានសម្អាតរាស្ត្រទ្រង់ឱ្យស្អាតចេញពីអំពើអាក្រក់របស់ពួកគេ ក៏បានរៀបតម្រង់ជីវិតពួកគេឡើងវិញដូចអ្វីៗដែលទ្រង់បានសម្តែងពីនគរទ្រង់នៅក្រោមស្នាព្រះហស្តនៃ "ស្តេចដាវីឌ" (២៣:២៣–២៤) ។

បទពណ៌នាយ៉ាងមានអំណាចចេស្តារបស់ហោរាអេសេគាល បង្ហាញពីភាពអស្ចារ្យនិងសេរីល្អនៃការគ្រងរាជរបស់ព្រះអម្ចាស់ (សូមមើលគោលរឿង) និងភាពបរិសុទ្ធរបស់ទ្រង់ ដែលទ្រង់ការពារយ៉ាងប្រាកដប្រជា ។ ឯចំណុចរួមនៃប្រវត្តិព្រះរាជកិច្ចក្នុងកណ្ឌគម្ពីរនេះ គឺបង្ហាញត្រដាងពីគោលបំណងនៃសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ ក្នុងប្រវត្តិសាស្ត្រពិភពលោក គឺចាប់ពីពេលដែលទ្រង់បានដកចេញវិញនូវការអាក្រក់ទាំងឡាយពីរាស្ត្រទ្រង់ ដែលទ្រង់បានសន្យាដើម្បីប្រោសលោះគ្រប់ទាំងអស់ ។

**គម្រោងសង្ខេប**

I. សេចក្តីទំនាយពីការជំនុំជម្រះដល់រាស្ត្រអ៊ីស្រាអែល (ជំពូក ១–២៤)
- ក. ទស្សនៈបានបើកសម្តែងរបស់ហោរាអេសេគាល (ជំពូក ១–៣)
  - ១. ការបង្ហាញពីភាពអស្ចារ្យនៃសេរីល្អរបស់ព្រះយេហូវ៉ា (ជំពូក ១)
  - ២. ការត្រាស់ហៅលោកយេរេមាធ្វើជាហោរា (២:១–៣:១៥)
  - ៣. កិច្ចការរបស់ហោរាយេរេមាជាអ្នកចាំមើល (គឺមើលខុសត្រូវដល់រាស្ត្រអ៊ីស្រាអែល) (៣:១៦–២១)
  - ៤. ការហ៊ឹកហ្វឺនឡើងវិញចំពោះកិច្ចការបម្រើព្រះជាហោរារបស់ហោរាអេសេគាល (៣:២២–២៧)
- ខ. គឺជាសកម្មភាពជាសញ្ញាបង្ហាញពីការឡោមព័ទ្ធ (ជំពូក ៤–៥)
  - ១. ហោរាអេសេគាលបង្ហាញសញ្ញាពីការឡោមព័ទ្ធក្រុងយេរូសាឡិម (ជំពូក ៤)
  - ២. កាំបិតជំនុំជម្រះរបស់ព្រះអម្ចាស់កាត់ទោសដល់កិច្ចការមនុស្សធ្វើ (ជំពូក ៥)
- គ. សេចក្តីទំនាយពីការជំនុំជម្រះពីព្រះ (ជំពូក ៦–៧)
  - ១. ថ្ងៃជំនុំជម្រះដល់ភ្នំស្រុកអ៊ីស្រាអែល (ជំពូក ៦)
  - ២. ថ្ងៃកំណត់នៃស្រុកបានមកដល់ (ជំពូក ៧)
- ឃ. ភាពពុករលួយក្នុងព្រះវិហារ និងផលអាក្រក់ដែលកើតឡើងនៅក្នុងនោះ (ជំពូក ៨–១១)

១. ការថ្វាយបង្គំរូបព្រះក្នុងព្រះវិហារ (ជំពូក ៨)
២. ការជំនុំជម្រះដល់អ្នកថ្វាយបង្គំរូបព្រះ (ជំពូក ៩)
៣. សិរីល្អនៃព្រះអម្ចាស់បានដកចេញពីព្រះវិហារ (ជំពូក ១០)
៤. សេចក្តីជំនុំជម្រះរបស់ព្រះអម្ចាស់ចំពោះក្រុងយេរូសាឡិម (១១:១-១៤)
៥. អស់អ្នកដែលបានចាប់ជាឈ្លើយ ក៏បានរួចមកវិញ (១១:១៥-២១)
៦. ការបញ្ចប់ទស្សនៈ (១១:២២-២៥)
ង. ការបង្ហាញពីទីសម្គាល់ពីហោរាអេសេគាល ពីការនិរទេសចាកចេញពីក្រុងយេរូសាឡិម (ជំពូក ១២)
១. ឥវ៉ាន់របស់អ្នកនិរទេស (១២:១-១៦)
២. ការទទួលទានអាហារដោយរន្ធត់ (១២:១៧-២០)
៣. ការជំនុំជម្រះមកជាប់ប្រកិត (១២:២១-២៨)
ច. សេចក្តីទំនាយទាក់ទងនឹងការជំនុំជម្រះពីព្រះអម្ចាស់ ទៅលើពួកយូដា (១៣:១-២៤:១៤)
១. ការជំនុំជម្រះចំពោះពួកហោរាក្លែងក្លាយ (ជំពូក ១៣)
២. ការជំនុំជម្រះចំពោះពួកអ្នកថ្វាយបង្គំរូបព្រះ (១៤:១-១១)
៣. គ្មានអ្នកសង្រ្គោះណាអាចបង្វែការជំនុំជម្រះរបស់ព្រះចេញបានឡើយ (១៤:១២-២៣) ។
៤. ក្រុងយេរូសាឡិមមានសណ្ឋានដូចជាបំណែកដើមទំពាំងបាយជូរ ដែលត្រូវគេដុតចោល (ជំពូក ១៥) ។
៥. សេចក្តីថ្លែងអធិប្បាយប្រដូចក្រុងយេរូសាឡិមជាប្រពន្ធដែលមានចិត្តកំផិតក្បត់ (ជំពូក ១៦)
៦. ពាក្យប្រស្នានៃសត្វឥន្ទ្រីពីរ និងមែកទំពាំងបាយជូរមួយមែក (ជំពូក ១៧)
៧. ព្រលឹងណាដែលធ្វើបាបព្រលឹងនោះនឹងត្រូវស្លាប់វិញ (ជំពូក ១៨)
៨. បទទំនួញពីការធ្លាក់ចុះនៃស្តេចក្រុងយេរូសាឡិម (ជំពូក ១៩)
៩. រាស្ត្រអ៊ីស្រាអែលបានប្រព្រឹត្តខុសត្រូវបានព្រះជម្រះសម្អាត នឹងទាញឱ្យគេមករកការល្អជាថ្មី តាមរយៈការជំនុំជម្រះ (២០:១-៤៤)
១០. ក្រុងបាប៊ីឡូនមានដាវនៃព្រះបានជំនុំជម្រះ (២០:៤៥-២១:៣២)
១១. អំពើបាបដែលមានក្នុងក្រុងយេរូសាឡិមក៏បានជំនុំជម្រះ (ជំពូក ២២)
១២.ក្រុងយេរូសាឡិម និងអ្នកក្រុងសាម៉ារីបានបកស្រាយបង្ហាញថា ជាក្រុងដែលធៀបដូចជាកូនស្រីៗដែលផិតក្បត់ (ជំពូក ២៣)
១៣. ក្រុងយេរូសាឡិមបានដុតនៅលើភ្លើង (២៤:១-១៤)
ឆ. ការស្លាប់នៃព្រះព័ន្ធរបស់ហោរាអេសេគាលជាការបង្ហាញពីការធ្លាក់ចុះនៃក្រុងយេរូសាឡិម (២៤:១៥-២៧) ។
II. សេចក្តីទំនាយពីការជំនុំជម្រះចំពោះជាតិសាសន៍ផ្សេងៗ (២៥:៣២)
ក. ការថ្លែងទំនាយប្រឆាំងនឹងពួកកូនចៅអាំម៉ូន (២៥:១-៧)
ខ. សេចក្តីថ្លែងទំនាយប្រឆាំងទាស់នឹងស្រុកម៉ូអាប់ (២៥:៨-១១)
គ. សេចក្តីទំនាយប្រឆាំងទាស់នឹងសាសាន៍អេដំម (២៥:១២-១៤)
ឃ. សេចក្តីទំនាយប្រឆាំងទាស់នឹងភីលីស្ទីន (២៥:១៥-១៧)
ង. សេចក្តីទំនាយប្រឆាំងទាស់នឹងទីក្រុងទីរ៉ុស (២៦:១-២៨:១៩)
១. សេចក្តីថ្លែងប្រកាសពីការហិនវិនាសរបស់ទីក្រុងទីរ៉ុស (ជំពូក ២៦)
២. បទទំនួញចំពោះទីក្រុងទីរ៉ុស (ជំពូក ២៧)
៣. សេចក្តីទំនាយប្រឆាំងទាស់នឹងស្តេចទីក្រុងទីរ៉ុស (២៨:១-១៩)
ច. ការថ្លែងទំនាយប្រឆាំងទាស់នឹងសាសន៍ស្រុកស៊ីដូន (២៨:២០-២៦) (ចំពោះរាស្ត្រអ៊ីស្រាអែល គឺជាការដែលធ្វើឱ្យពួកគេខិតចូលមករកភាពដើមឡើងវិញ ២៨:២៥-២៦)

ឆ. សេចក្តីទំនាយប្រឆាំងទាស់នឹងស្រុកអេស៊ីព្ទ (ជំពូក ២៩–៣២)

១. ស្រុកអេស៊ីព្ទបានកំចាត់សត្វសំបើម (២៩:១–១៦)

២. ការប្រគល់ស្រុកអេស៊ីព្ទទៅឱ្យស្តេចនេប៊ូក្នេសា (២៩:១៧–២១)

៣. សេចក្តីបទទំនួញចំពោះស្រុកអ៊ីស្រាអែល (៣០:១–១៩)

៤. កងទ័ពរបស់ស្តេចផារ៉ោនបានបរាជ័យ (៣០:២០–២៦)

៥. ស្តេចផារ៉ោនបានកាប់រំលំដើមតាត្រៅនៅព្រៃល្បាណូន (ជំពូក ៣១)

៦. បទទំនួញចំពោះស្តេចផារ៉ោន (៣២:១–១៦)

៧. ស្តេចផារ៉ោននិងពួកទ្រង់បានស្លាប់ (៣២:១៧–៣២) ។

III. សេចក្តីទំនាយពីសេចក្តីលួងកម្សាន្តចិត្តដល់រាស្ត្រអ៊ីស្រាអែល (ជំពូក ៣៣–៤៨)

ក. បង្ហាញឱ្យឃើញពីការត្រាស់ហៅរបស់ហោរាអេសេគាលឱ្យធ្វើជាអ្នកចាំយាម (៣៣:១–២០)

ខ. បង្វៃការធ្លាក់ចុះនៃក្រុងយេរូសាឡិមឱ្យបានល្អដូចដើមវិញ និងការជំនុំជម្រះដល់ពួកសំណល់ (៣៣:២១–៣៣)

គ. ព្រះយេហូវ៉ាធ្វើជាអ្នកកង្វាលដល់រាស្ត្រអ៊ីស្រាអែល (ជំពូក ៣៤)

ឃ. សេចក្តីទំនាយទាស់នឹងស្រុកអេដំម (ជំពូក ៣៥)

ង. ការប្រកាសពីការធ្វើឱ្យស្រុកអ៊ីស្រាអែលវិលមករកភាពល្អដូចដើមវិញ (ជំពូក ៣៦)

ច. ការរាំងស្ងួតនៃស្រុកអ៊ីស្រាអែលក៏បានធ្វើឱ្យជីវិតរស់និងមានការរួបរួមគ្នាជាថ្មី (ជំពូក ៣៧)

១. ការរាំងស្ងួតរបស់អ៊ីស្រាអែលត្រឡប់ជាមានជីវិតរស់ឡើងវិញ (៣៧:១–១៤)

២. ការតម្រូវឱ្យជាតិសាសន៍បានចុះចូលក្រោមការត្រួតត្រាដោយស្តេចតែមួយអង្គវិញ (៣៧:១៥–២៨)

ឆ. សង្គ្រាមយ៉ាងធំក្រៃលែងក្នុងសម័យនោះ (ជំពូក ៣៨–៣៩)

ជ. មានទិសដៅច្បាប់ទម្លាប់ថ្មីសម្រាប់រាស្ត្រអ៊ីស្រាអែលឱ្យបានស្អាតល្អឡើងវិញ (ជំពូក ៤០–៤៨)

១. ទីតាំងព្រះវិហារបានវិញមកមានលក្ខណៈដូចដើមវិញ (៤០:១–៤៧)

២. មានព្រះវិហារថ្មី (៤០:៤៨–៤២:២០)

៣. សិរីល្អនៃព្រះអម្ចាស់វិលមកគង់សណ្ឋិតលើព្រះវិហាររបស់ទ្រង់វិញ (៤៣:១–១២)

៤. ការស្អាងអាសនាដ៏ធំឡើងវិញ (៤៣:១–១២)

៥. ការរៀបឱ្យមានសង្ឃឡើងវិញ (ជំពូក ៤៤)

៦. ការបង្កើតឱ្យមានច្បាប់គ្រប់គ្រងរាជ្យអំណាចឡើងវិញ (ជំពូក ៤៥–៤៦)

៧. មានទន្លេជីវិតហូរចេញពីព្រះវិហារ (៤៧:១–១២)

៨. ការកំណត់ព្រំដីនៃស្រុកទាំងមូល (៤៧:១៣–២៣)

៩. ការចែកដីនៃស្រុកផ្សេងៗ (៤៨:១–២៩)

១០. ទ្វារទាំង១២របស់ទីក្រុងថ្មី ៤៨:៣០–៣៥)

## តួមានជីវិត និងសិរីល្អនៃព្រះអម្ចាស់

**១** ១នៅថ្ងៃ៥ខែអាសាធ ឆ្នាំទី៣០ កាលខ្ញុំនៅជាមួយ
និងពួកឈ្លើយ[ក] នៅមាត់ទន្លេកេបារ[ខ] នោះមេឃក៏របើក
ឡើង[គ] ហើយខ្ញុំឃើញការជាក់ស្តែង[ឃ]ពីព្រះ ២រីឯនៅថ្ងៃ៥
ក្នុងខែនោះឯង ដែលជាឆ្នាំទី៥ តាំងពីស្តេចយ៉ូយ៉ាគីន[ង]នៅ
ជាប់ជាឈ្លើយ ៣នោះព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់
អេសេគាល[ច] ជាកូនប៊ូស៊ី ដែលជាសង្ឃ នៅស្រុកខាល់ដេ
ក្បែរទន្លេកេបារ ហើយព្រះហស្តនៃព្រះយេហូវ៉ាក៏ស្ថិតលើ
លោកនៅទីនោះ[ឆ] ។
៤ខ្ញុំក៏ក្រឡេកទៅ ឃើញមានខ្យល់ព្យុះ[ជ]ចេញពីទិស
ខាងជើងមក[ឈ] មានពពកយ៉ាងធំ និងភ្លើងចំរុះគ្នា ហើយ
មានរស្មីភ្លឺនៅជុំវិញ ឯពីកណ្តាលពពកនោះ មានចេញជា
ពណ៌លង្ហិនស្រងៅ គឺចេញពីកណ្តាលភ្លើងនោះ[ញ] ៥ហើយ
ពីកណ្តាលនោះ ក៏មានចេញភាពដូចជាតួមានជីវិត៤រូប[ដ]
ដែលមើលទៅបែបយ៉ាងនេះ គឺគ្រប់គ្នាមានភាពដូចជា
មនុស្ស[ឋ] ៦គ្រប់គ្នាមានមុខ[ឌ]៤ ហើយគ្រប់គ្នាមានស្លាប៤
៧ឯជើងរាល់តួនោះ សុទ្ធតែត្រង់ បាតជើងក៏ដូចជាបាត
ជើងនៃកូនគោ ហើយភ្លឺព្រោងព្រាត ដូចជាលង្ហិនខាត់
យ៉ាងភ្លឺ[ឍ] ៨តួទាំងនោះមានដៃនៃមនុស្ស[ណ] នៅក្រោមស្លាប
គ្រប់ទាំង៤មុខ ឯមុខនិងស្លាបទាំងប៉ុន្មានរបស់តួទាំងនោះ

**១:១** ក ចទ ២១:១០ អគ ១១:២៤–២៥ ខ ទដ ១៣៧:១ គ មថ ៣:១៦ ឃ នក ២៤:១០ **១:២** ង ២ពវ ២៤:១៥ **១:៣** ច អគ ២៤:២៤ ឆ ២ពវ ៣:១៥ អស ៨:១១ អគ ៣:១៤,២២ ៨:១ ៣៣:២២ ៣៧:១ ៤០:១ **១:៤** ជ យប ៣៨:១ ឈ យរ ១:១៤ ញ អគ ៨:២ **១:៥** ដ អស ៦:២ វវ ៤:៦ ឋ ខ.២៦ ដយ ៧:១៣ **១:៦** ឌ អគ ១០:១៤ **១:៧** ឍ អគ ៤០:៣ ដយ ១០:៦ វវ ១:១៥ **១:៨** ណ អគ ១០:៨

**១:១–២៨** ពួកគេត្រូវបានបង្ខំឱ្យចូលទៅក្រុងបាប៊ីឡូន ដោយធ្វើជាឈ្លើយទៅឆ្ងាយចេញពីព្រះវិហារព្រះអម្ចាស់ និងទីសម្គាល់ជាសិរីល្អរបស់ព្រះ (មើលការពន្យល់ នក ២៦:១ ៤០:៣៤ មើលផងដែរ ទដ ២៤:៨–១០ ២៦:៨ ២៩:៩ ៩៦:៦ និងមើលការពន្យល់) ព្រះគម្ពីរអេសេគាលបានឆ្លងចូលដល់សេចក្តីទំនាយរបស់គាត់ដែលបានទាយទុក (មើល ១:១ និងការពន្យល់) ដោយឃើញការជាក់ស្តែង នៃសិរីរុងរឿងរបស់ព្រះជាច្រើនលើសលុប ដូចជាលោកអេសាយ បានឃើញការជាក់ស្តែងរបស់ព្រះគួរអោយស្ញែងខ្លាច ដែលទ្រង់គង់លើបល្ល័ង្កដ៏ខ្ពស់ ដោយមានទាំងស្លាបផង"ពួកសេរភីម" (មើល អស ៦:១–២ និងការពន្យល់) និងបានកើតឡើងដូចជា សេចក្តីទំនាយរបស់គាត់ (ខយោង ១ពវ ២២:១៩ និងការពន្យល់) ។

**១:១** *ឆ្នាំទី៣០* ប្រហែលក្នុងកំឡុងអាយុរបស់លោកអេសេគាល ។ យោងតាម ជន ៤:៣ មនុស្សម្នាក់បានធ្វើកិច្ចការសង្ឃ យ៉ាងសកម្មក្នុងរយៈពេល៣០ឆ្នាំរបស់គាត់ គាត់បានបដិសេធន៍កិច្ចការធ្វើជាសង្ឃ លោកអេសេគាលបានទទួលបេសកកម្មមួយផ្សេង គឺការធ្វើជាហោរា ។ *ទន្លេកេបារ* គឺជាព្រែកនៃទន្លេអឺប្រាត នៅជិតទីក្រុងនីបពូ ដែលស្ថិតនៅប៉ែកខាងត្បូងនៃទីក្រុងបាប៊ីឡូន ហើយជាទីកន្លែង អធិស្ឋានសម្រាប់ពួកជាប់ជាឈ្លើយ (មើល ទដ ១៣៧:១ ធៀបនឹង កច ១៦:១៣) ការជាក់ស្តែងអំពីព្រះ ជាពាក្យពិសេស ហើយវាបានសរសេរឡើងជាពហុវចនៈ ហើយភ្ជាប់មកជាមួយពាក្យ "ព្រះ" មិនមែនប្រើពាក្យ "ព្រះអម្ចាស់" តែឯងនោះទេ ។ ជាពាក្យសង្កត់ធ្ងន់ដែលនាំមុខនៃពាក្យនេះ និងការមើលឃើញ២ផ្សេងទៀតរបស់ហោរា (៨:៣ ៤០:២ ) ។

**១:២** *ឆ្នាំទី៥ តាំងពីស្តេចយ៉ូយ៉ាគីននៅជាប់ជាឈ្លើយ* ខ.២–៣ បានសរសេជាមនុស្សទី៣ (មានតែមនុស្សទី៣ទេដែលបានសរសេរក្នុងព្រះគម្ពីរនេះ បញ្ជាក់ពីកាលបរិច្ឆេទក្នុង ខ.១ ស្តេចយ៉ូយ៉ាគីន ត្រូវបានបង្ខំឱ្យអមដំណើរជាមួយពួកអ្នកជាប់ជាឈ្លើយ ជិនាន់ដើមទៅក្រុងបាប៊ីឡូនក្នុងឆ្នាំ ៥៩៧ មុន គ.ស (មើលសេចក្តីផ្តើមប្រវត្តិដើម) ។ លោកអេសេគាល ស្ថិតនៅក្នុងចំណោមពួកគេក្នុងការដែលជាប់ជាឈ្លើយទៅក្រុងបាប៊ីឡូន ដោយគាត់បានទទួលនូវការត្រាសហៅឱ្យថ្លែងសេចក្តីទំនាយនៅក្នុងឆ្នាំ៥៩៣ ។

**១:៣** *លោកអេសេគាល* ជាឈ្មោះរបស់ហោរា ដែលមាននៅក្នុងព្រះគម្ពីរ ២៤:២៤ នេះតែប៉ុណ្ណោះ (មើលការពន្យល់) ហើយវាជាពាក្យថ្លែងទំនាយដ៏ចម្បងនៅក្នុងសេចក្តីទំនាយរបស់គាត់ ។ ឈ្មោះគាត់មានន័យថា "ព្រះគឺជាអ្នកខ្លាំងពូកែ"(ធៀបនឹង ៣:១៤)"ព្រះជាអ្នកចម្រើនកម្លាំង" (ធៀបនឹង ៣០:២៥ ៣៤:១៥) ឬព្រះជាអ្នកធ្វើឱ្យរឹងមាំ (ធៀបនឹង ៣:៨) ។ *សង្ឃ* សមាជិកក្រុមគ្រួសារសង្ឃ ព្រះហស្តរបស់ព្រះអម្ចាស់ ។ ឃ្លានេះកើតមានឡើង៧ដងនៅក្នុងព្រះគម្ពីរ (មើលផងដែរ ៣:១៤,២២ ៨:១ ៣៣:២២ ៣៧:១ ៤០:១)។ ការចង្អុលបង្ហាញពីបទពិសោធន៍នៃការបើកសម្តែងអំពីភាពជាព្រះរបស់ទ្រង់ ។

**១:៤** *ខ្ញុំក៏ក្រឡេកទៅ* សេចក្តីផ្តើមផ្នែកទី១នៃការជាក់ស្តែង ខ្យល់ព្យុះ និងតួមានជីវិត (ខដូចគ្នា ៤–១៤) ។ "ខ្ញុំកំពុងតែមើល" ខ.១៥ សេចក្តីផ្តើមផ្នែកទី២នៃការជាក់ស្តែង កង់ និងសិរីល្អរបស់ព្រះអម្ចាស់ ។ *ខ្យល់ព្យុះ* ខ្យល់ព្យុះមានទាំងពពក ហើយមានផ្លេកបន្ទោរ និងរន្ទះបាញ់ នោះគឺបង្ហាញពីព្រះចេស្តារបស់ផងព្រះ ដែលទ្រង់កំពុងតែមានវត្តមានគង់នៅសព្វថ្ងៃនេះ (មើល នក ១៩:១៦–១៨ ទដ ១៨:៧–១៥ ៧៧:១៦–១៩ និងការពន្យល់ ធៀបនឹង យប ៣៨:១)។

**១:៥** *តួមានជីវិត៤* "បួន" ជិន្ទូសភាពពេញលេញ (ធៀបនឹង ទិសទាំង៤ ក្នុង លប ១៣:១៤ និងភាគទាំង៤នៃផែនដី អស ១១:១២) គឺត្រូវបានប្រើជាញឹកញាប់នៅក្នុងជិពូកនេះ ហើយលើសជាង៤០ដងនៅក្នុងព្រះគម្ពីរ ។ តួមានជីវិត មានឈ្មោះថា "ចេរូប៊ីន" ក្នុងជិពូក១០ គឺជាបល្ល័ង្ក នក ២៥:១៨ និងការពន្យល់) (មើល ខ.១០ និងការពន្យល់) ពួកគេលះបង់ពីអ្វីដែលមើលគួរស្ញប់ស្ញែង ដែលជាតំណាងពីការបង្កើតរបស់ព្រះ នៃតួមានជីវិតទាំង៤ (ធៀបនឹង"សេរភីម" មើល អស ៦:២–៤ បង្ហាញម្តងទៀតក្នុង វវ ៤:៧ ផ្នែកទាំង៤ គឺត្រូវបានពិពណ៌នាក្នុងការលាប និងផ្នែកសិល្បៈនៅជិនាន់កណ្តាល ប៉ុន្តែក្រោយមកទៀត ពាក្យទាំង៤នេះ គឺប្រើសម្រាប់តំណាងពីដំណឹងល្អទាំង៤ ។ *គឺគ្រប់គ្នាមានភាពដូចជាមនុស្ស* មនុស្សជាស្នាព្រះហស្តពិសេសរបស់ព្រះនៅលើផែនដីនេះ ។

**១:៦** *មុខ៤* មើល ខ.១០ និងការពន្យល់ ។ *ស្លាបទាំង៤* សំខាន់ការធ្វើចលនាដែលបល្ល័ង្កមានស្តេចនៃស្ថានសួគ៌គង់នៅ ដែលមិនដែលមាននៅក្នុងប្រវត្តិសាស្រ្ត ។

**១:៧** *ដូចជាកូនគោ* ប្រហែលជាចង្អុលបង្ហាញពីការប៉ិនប្រសប់ (ធៀបនឹង ទដ ២៩:៦ មទ្ទ ៤:២) ។

គឺយ៉ាងដូច្នេះ ៩ស្លាបទាំងនោះជាប់តៗគ្នា គ្រប់គ្នាហោះ
ត្រង់ទៅខាងមុខ ឥតងាកបែរឡើយ[ត] ១០ឯភាពនៃមុខតួ
ទាំងនោះ គ្រប់គ្នាមានមុខជាមនុស្ស ហើយទាំង៤មាន
មុខជាសិង្ហខាងស្តាំ ទាំង៤ក៏មានមុខជាគោនៅខាងឆ្វេង
ហើយទាំង៤មានមុខជាឥន្ទ្រីដែរ[ថ] ១១ឯមុខ ហើយនិងស្លាប
នោះដាច់ពីគ្នាខាងលើ ស្លាប[ទ]២របស់រាល់តួនោះ បានជាប់
តគ្នា ហើយស្លាប២ទៀតក៏គ្របខ្លួន ១២គ្រប់គ្នាក៏ហោះចំទៅ
ខាងមុខ ទីណាដែលព្រះវិញ្ញាណត្រូវទៅ តួទាំងនោះក៏ទៅ
ដែរ ឥតងាកបែរឡើយ[ធ] ១៣ឯភាពនៃតួមានជីវិតទាំងនោះ
គឺមើលទៅដូចជារងើកភ្លើង ហើយក៏ដូចជាចន្លុះឆេះ[ន]
ដែលទ្រោលចុះឡើងនៅកណ្តាលតួមានជីវិតទាំងនោះ ឯ
ភ្លើងនោះ ក៏ភ្លឺចាំងហើយមានផ្លេកបន្ទោរ[ប]ចេញពីភ្លើង
នោះមក ១៤តួមានជីវិតទាំងនោះ ក៏ហោះទៅមក មើលទៅ
ដូចជាផ្លេកបន្ទោរ[ផ]។

១៥កាលខ្ញុំកំពុងតែមើលតួមានជីវិតនោះ[ព] ខ្ញុំក៏ឃើញ
កង់១[ភ] នៅលើដីក្បែរតួមានជីវិតទាំងនោះ សំរាប់មុខ
និមួយគ្រប់ទាំង៤ ១៦ភាពនឹងបែបផែននៃកង់ទាំងនោះ
ក៏មើលទៅដូចជាត្បូងបេរីល[ម] កង់ទាំង៤មានរាងដូចគ្នា
ឯភាពនិងសណ្ឋានវា ក៏មើលទៅដូចជាកង់១នៅក្នុងកង់
១ទៀត ១៧កាលណាវាទៅ នោះក៏ទៅទាំង៤មុខឥតបែរ[យ]
ទៅខាងណាឡើយ ១៨ឯខ្នងកង់នោះ ខ្ពស់គួរស្ញែងខ្លាច
ហើយខ្នងកង់ទាំង៤នោះ មានភ្នែក[រ]នៅពេញជុំវិញ ១៩កាល
ណាតួមានជីវិតទាំង៤បានហោះទៅ នោះកង់ទាំងនោះ
ក៏អមទៅដែរ កាលណាតួមានជីវិតទាំង៤ បានលើកឡើង
ផុតពីដីទៅ នោះកង់ទាំងនោះក៏បានលើកឡើងដូចគ្នា

**១:៩** ត អគ ១០:២២
**១:១០** ថ អគ ១០:១៤ វវ ៤:៧
**១:១១** ទ អស ៦:២
**១:១២** ធ អគ ១០:១៦–១៩
**១:១៣** ន ២ សយ ២២:៩ ប វវ ៤:៥
**១:១៤** ផ ទដ ២៩:៧
**១:១៥** ព អគ ៣:១៣ ភ អគ ១០:២ ដយ ៧:៩
**១:១៦** ម ២៨:២០
**១:១៧** យ ខ.៩
**១:១៨** រ វវ ៤:៦
**១:២០** ល ខ.១២
**១:២១** វ អគ ១០:៩–១២
**១:២២** ស អគ ១០:១
**១:២៤** ហ ទដ ៤៦:៣ អគ ៣:១៣ ឡ អគ ១០:៥ ៤៣:២ ដយ ១០:៦ វវ ១:១៥ ១៤:២ ១៩:៦ អ ២ពវ ៧:៦
**១:២៦** ក ១ពវ ២២:១៩ អស ៦:១ យរ ៣:១៧ ខ នក ២៤:១០ គ ខ.៥ អគ ២:១ វវ ១:១៣

២០នៅទីណាដែលព្រះវិញ្ញាណត្រូវទៅ នោះវាក៏ទៅដែរ[ល]
គឺវិញ្ញាណរបស់វាក៏ទៅកន្លែងដដែល កង់ទាំងនោះបាន
លើកឡើងអមទៅ ពីព្រោះវិញ្ញាណរបស់តួមានជីវិត ក៏នៅ
ក្នុងកង់ដែរ ២១កាលណាពួកនោះចេញទៅ ពួកនេះក៏ទៅ
ដែរ កាលណាពួកនោះឈប់នៅ ពួកនេះក៏ឈប់ដែរ ហើយ
កាលណាពួកនោះបានលើកឡើងផុតពីដី នោះកង់ទាំង
ឡាយ ក៏បានលើងឡើង អមទៅព្រមគ្នា ដ្បិតវិញ្ញាណរបស់
តួមានជីវិត បាននៅជាប់ក្នុងកង់ដែរ[វ]។

២២នៅពីលើក្បាលនៃតួមានជីវិត នោះមានដូចជាផ្ទៃ
មេឃ ដែលមើលទៅដូចជាចរណៃគួរស្ញែងខ្លាច ហើយ
ក៏លាត[ស]ពីលើក្បាលតួទាំងនោះ ២៣ឯក្រោមផ្ទៃមេឃ នោះ
មានស្លាបរបស់តួទាំងឡាយ ត្រដាងទៅត្រង់តៗគ្នា គ្រប់គ្នា
មានស្លាប២ ដែលបាំងខ្លួនម្ខាង ហើយស្លាប២ ដែលបាំង
ខ្លួនម្ខាងទៀត ២៤កាលណាហោះទៅ នោះខ្ញុំឮសូរសន្ធឹក
ស្លាប ដូចជាសូរនៃទឹកធំ[ហ] គឺដូចជាព្រះសូរសៀង[ឡ] នៃព្រះ
ដ៏មានគ្រប់ព្រះចេស្តា ជាសូរគឹកកង ដូចជាសូរនៃ កងទ័ព[អ]
កាលណាតួទាំងនោះឈប់នៅ នោះក៏សំរបស្លាបចុះមកវិញ
២៥កាលបានឈប់សំរបស្លាបចុះមកវិញហើយ នោះមានឮ
សំឡេងពីផ្ទៃមេឃ ដែលនៅពីលើក្បាលតួទាំងនោះ ។

២៦នៅពីលើផ្ទៃមេឃដែលនៅពីលើក្បាល នោះមាន
ភាពជាបល្ល័ង្ក[ក] ដែលមើលទៅដូចជាត្បូងកណ្ដៀង[ខ] ហើយ
នៅលើភាពដែលមើលទៅដូចជាបល្ល័ង្ក នោះឃើញមាន
ទ្រង់ទ្រាយដូចជាមនុស្សអង្គុយនៅលើ[គ] ២៧ខ្ញុំក៏ឃើញពណ៌
ដូចជាលង្ហិនខាត់យ៉ាងភ្លឺ ដែលមើលទៅដូចជាភ្លើង នៅ
ខាងក្នុង ហើយនៅជុំវិញ ចាប់តាំងពីកន្លែងដែលមើល

**១:១០** *មុខជាមនុស្ស* ការលើកតាំងរបស់ព្រះដែលគ្រប់គ្រងនៅលើផែនដី (មើល លប ១:២៦–២៨ ទដ ៨:៣–៥ និងការពន្យល់) ។ *សត្វសិង្ហ* ជាប្រភេទសត្វយ៉ាងកាចសាហាវលើអស់សត្វព្រៃ គេបានស្គាល់វានៅអ៊ីស្រាអែល និងមេសូប៉ូតាមៀ ហើយខ្លាំងពូកែអស់ទាំងសត្វព្រៃ (មើល ពច ១៤:១៨) ។ *គោ* ជាប្រភេទសត្វស្រុកយ៉ាងខ្លាំង ។ *មុខជាឥន្ទ្រី* ជាប្រភេទសត្វស្លាបយ៉ាងខ្លាំងបំផុត ធៀបនឹង *វវ* ៤:៧ និងការពន្យល់ ។

**១:១២** *ទៅខាងមុខ* មិនត្រឡប់ថយក្រោយការធ្វើចលនាច្រើន (មើល ខ.១៤) ។ *វិញ្ញាណ* មានវត្តមានដោយផ្ទាល់នៅក្នុងចេរូប៊ីន (សូមមើល ខ.២០) ។

**១:១៣** *ដូចជារងើកភ្លើង* ធៀបនឹង ទដ ១៨:៨ ។ *ដូចភ្លើង* ធៀបនឹង លប ១៥:១៧ ។

**១:១៥** *កង់* ជារូបសញ្ញាការធ្វើចលនា (មើលការពន្យល់ ខ.១២) ។

**១:១៦** *ត្បូង* ការសំគាល់ពីថ្មនេះមិនច្បាស់ ។ មើល នក ២៨:២០ ថ្មនោះមាននៅកន្លែងសង្ឃ ។ *ក៏មើលទៅដូចជាកង់មួយនៅក្នុងកង់១ទៀត* ប្រហែលជាកង់២ គឺដាច់ពីគ្នានៅខាងទេវតាខាងស្តាំ ដើម្បីនឹងកំរើកទៅទិសទាំង៤ (មើល ខ.១៤) រូបនោះតំណាងពីវត្តមានរបស់ព្រះគង់នៅគ្រប់ទីកន្លែង ។

**១:១៨** *មានភ្នែកនៅពេញជុំវិញ* និម្មិតសញ្ញាពីការដែលព្រះទ្រង់ទតឃើញគ្រប់របស់ទាំងអស់ ។

**១:២២** *ផ្ទៃមេឃ* ពាក្យដូចគ្នាកើតឡើងនៅក្នុង លប ១:៦–៨ ជាកន្លែងដែលញែកទឹកចេញពីដី គឺការញែករបស់ដែលព្រះបានបង្កើត និងសិរីរុងរឿងរបស់ព្រះអម្ចាស់ ។ *ក៏លាតពីលើក្បាលតួទាំងនោះ* ធៀបនឹង *វវ* ៤:៦ និងការពន្យល់ ១៥:២ ។

**១:២៥** *ឈប់សំរបស្លាបចុះមកវិញ* រងចាំទទួលពាក្យពីបល្ល័ង្ក ។

**១:២៦** *នៅពីលើផ្ទៃមេឃ . . . នោះមានភាពជាបល្ល័ង្ក* ធៀបនឹង នក ២៤:១០ ។ *នោះឃើញមានទ្រង់ទ្រាយដូចជាមនុស្សអង្គុយនៅលើ* លោកអេសេគាលបកស្រាយពីការជាក់ស្តែងរបស់គាត់ ប៉ុន្តែមានការប្រុងប្រយ័ត្នចំពោះការដែលគាត់និយាយថា គាត់បានឃើញព្រះផ្ទាល់ (មើល លក ១៦:១៣ នក ៣:៦ ពច ១៣:២២) ។

ទៅដូចជាចង្កេះទៅខាងលើ ហើយចាប់តាំងពីកន្លែងដែល
មើលទៅដូចជាចង្កេះ ចុះទៅខាងក្រោម នោះខ្ញុំឃើញ
ភាពមើលទៅដូចភ្លើង ហើយមានរស្មីភ្លឺនៅជុំវិញអង្គ
នោះ[ឃ] ២៨ឯរស្មីដែលភ្លឺ នៅព័ទ្ធជុំវិញនោះ ក៏មានភាពដូច
ជាឥន្ទធនូ[ង,ច]ដែលនៅលើពពក ក្នុងថ្ងៃដែលមានភ្លៀងនេះ
ជាគំរូពីភាពនៃសិរីល្អ[ឆ]របស់ព្រះយេហូវ៉ា កាលខ្ញុំបាន
ឃើញហើយ នោះខ្ញុំក្រាបមុខចុះដល់ដី[ជ] ហើយខ្ញុំឮព្រះសូរ
សៀងមានបន្ទូលមក ។

### ការត្រាស់ហៅលោកអេសេគាល

២ ១ទ្រង់មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ[ក] ចូរក្រោក
ឈរឡើង[ខ] នោះអញនិងនិយាយនឹងឯង[គ] ២កាលទ្រង់កំពុង
មានបន្ទូលនឹងខ្ញុំ នោះព្រះវិញ្ញាណក៏មកសណ្ឋិតនៅក្នុងខ្ញុំ
ហើយបានបញ្ឈរខ្ញុំឡើង[ឃ]រួមខ្ញុំក៏ឮព្រះអង្គដែលមានបន្ទូល
មកខ្ញុំ ៣ទ្រង់មានបន្ទូលថា កូនមនុស្សអើយ អញចាត់ឯងឱ្យ
ទៅឯពួកកូនចៅអ៊ីស្រាអែល គឺដល់សាសន៍ដែលរឹងចចេស
ដែលបានបះបោរនឹងអញ ទោះទាំងខ្លួនគេនិងពួកឰយុកោ
ក៏បានរំលងទាស់នឹងអញ ដរាបដល់ថ្ងៃនេះឯង[ង] ៤គេជាកូន
ចៅមានមុខរឹង ហើយចិត្តខែង[ច] គឺដល់ពួកអ្នកនោះដែល
អញចាត់ឯង ត្រូវឱ្យឯងប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ[ឆ] ៥ឯគេ ទោះបើគេនឹងព្រមស្តាប់[ជ]
ឬមិនព្រមក្តី (ដ្បិតគេ ជាពូជពង្សរឹងចចេស)[ឈ] គង់តែគេ
នឹងដឹងថា មានហោរា១ បានមកក្នុងពួកគេហើយ[ញ] ៦ឯឯង
កូនមនុស្សអើយ កុំឱ្យខ្លាច[ដ]គេឡើយ ក៏កុំឱ្យខ្លាចចំពោះពាក្យ
សំដីរបស់គេដែរ ទោះបើមានបន្លា ហើយនិងអញ្ចាញ[ឋ] មក
ទាស់ជានឹងឯង ហើយឯងមានទីអាស្រ័យនៅកណ្តាលពួក
ខ្យាដំរីក៏ដោយ កុំឱ្យខ្លាចពាក្យសំដីគេឱ្យសោះ ក៏កុំឱ្យស្លុត
ចិត្តនឹងទឹកមុខគេដែរ ទោះបើគេជាពូជពង្សរឹងចចេស
ក៏ដោយ[ឌ] ៧ត្រូវឱ្យឯងថ្លែង[ឍ]ពាក្យរបស់អញប្រាប់ដល់គេ
ទោះបើគេនឹងព្រមស្តាប់ ឬមិនព្រមក្តី ដ្បិតគេរឹងចចេស
ណាស់[ណ] ។
៨តែឯឯង កូនមនុស្សអើយ ចូរស្តាប់សេចក្តីដែល
អញប្រាប់ដល់ឯងចុះ កុំឱ្យឯងមានចិត្តរឹងចចេស[ត,ថ] ដូចជា
ពូជពង្សរឹងរូសនេះឡើយ[ទ] ចូរហាមាត់ស៊ី[ធ]របស់ដែល
អញឱ្យដល់ឯង ៩រួចកាលខ្ញុំកំពុងតែមើល នោះឃើញ
មានដៃ[ន]១ លូកមកដល់ខ្ញុំ ក៏ឃើញក្រាំង១ នៅក្នុងដៃនោះ[ប]
១០ទ្រង់ក៏បើកត្រដាងក្រាំងនោះនៅមុខខ្ញុំ នោះឃើញមាន
សរសេរ ទាំងខាងក្នុង និងខាងក្រៅផង មានកត់ទុក
សុទ្ធតែជាពាក្យទំនួញ ពាក្យសោកសៅ និងសេចក្តីវេទនា

**១:២៧** ឃ អគ ៨:២ **១:២៨** ង លប ៩:១៣ វវ ១០:១ ច វវ ៤:២ ឆ នក ១៦:៧ ២៤:១៦ លក ២:៩ ជ លប ១៧:៣ ជន ១៤:៥ **២:១** ក យប ២៥:៦ ទដ ៨:៤ អគ ១:២៦ ដយ ៧:១៣ ៨:១៥ ខ យរ ១០:១១ កច ១៤:១០ ២៦:១៦ គ កច ៩:៦ **២:២** ឃ អគ ៣:២៤ ដយ ៨:១៨ **២:៣** ង យរ ៣:២៥ អគ ៥:៦ ២០:៨–២៤ ២៤:៣ **២:៤** ច នក ៣២:៩ អស ៩:៩ អគ ៣:៧ ឆ អម ៧:១៥ **២:៥** ជ អគ ៣:១១ ឈ ៣:២៧ ញ យរ ៥:៣ អគ ៣៣:៣៣ យហ ១៥:២២ **២:៦** ដ ចទ ៣១:៦ ២ពវ ១:១៥ ឋ ជន ៣៣:៥៥ អស ៩:១៨ មីក ៧:៤ ឌ អស ១:២ ៣០:៩ អគ ២៤:៣ ៤៤:៦ **២:៧** ឍ យរ ៧:២៧ ណ យរ ១:៧ ៤២:២១ អគ ៣:១០–១១ **២:៨** ត ជន ២០:១០–១៣ ថ អស ៨:១១ ទ អស ៥០:៥ ធ ទដ ៨១:១០ យរ ១៥:១៦ វវ ១០:៩ **២:៩** ន អគ ៨:៣ ប ទដ ៤០:៧ យរ ៣៦:៤ វវ ៥:១–៥ ១០:៨–១០

**១:២៨** *ជាគំរូពីភាពនៃសិរីល្អ* មើលការពន្យល់ ឧ.២៦ ។ *សិរីល្អរបស់ព្រះយេហូវ៉ា* សិរីរុងរឿងរបស់ទ្រង់និមិត្តសញ្ញាពីការបើកសម្តែង គឺមានពន្លឺចែងជះ ខ្លាំងណាស់ (មើល នក ៤០:៣៤ និងការពន្យល់ អស ៦:៣) ។ អ្វីជាការកត់សម្គាល់ពីបទពិសោធន៍របស់លោកអេសេគាល គឺថាសិរីរុងរឿងរបស់ព្រះសាយភាយពេញនៅក្នុងព្រះវិហាររបស់ទ្រង់ នៅក្នុងក្រុងយេរូសាឡិម (មើល ១ពវ ៨:១១ ទដ ២៦:៨ ៦៣:២ ៩៦:៦ ១០២:១៦) ។ ឥឡូវនេះព្រះបានយាងចេញពីព្រះវិហារ ហើយបានបង្ហាញអង្គទ្រង់ ឱ្យរាស្ត្រទ្រង់ជាពួកនិរទេសខ្លួនឃើញនៅបាប៊ីឡូន នេះជាអត្ថបទពាក់កណ្តាលដំបូងនៃសាររបស់លោកអេសេគាល (មើល ១០:៤១ ១:២៣) នៅក្នុងការបើកសម្តែងរបស់គាត់ពីការស្ថាបនាឡើងវិញនៃក្រុងយេរូសាឡិម ហោរាបានឃើញសិរីល្អរបស់ព្រះអម្ចាស់សាយភាយឡើង (៤៣:២) ។ *ខ្ញុំក្រាបមុខចុះ* មើល លប ១៧:៣ នប ៣:៦ ធៀបនឹង អស ៦:៥ ។

**២:១–៣:១៥** ព្រះមិនបានភ្លេចចំពោះការតាំងសញ្ញារបស់ទ្រង់ ទោះបីជាទ្រង់បានបណ្តេញគេមិនឱ្យចូលទឹកដីសន្យាក្តី ដោយសារពួកគេបានទាស់ប្រឆាំងនឹងទ្រង់ ។ ទ្រង់បានបញ្ជាដល់អេសេគាលឱ្យនាំព្រះបន្ទូលទ្រង់ទៅដល់ពួកនិរទេសខ្លួន ទ្រង់នៅតែត្រាស់ហៅពួកគេឱ្យធ្វើការតាំងសញ្ញាដាក់ឈ្មោះពួកគេ "អ៊ីស្រាអែល"(មើល ២:៣ ៣:៤–៥,៧ ធៀបនឹង អម ៨:១១ និងការពន្យល់) ។ បេសកកម្មរបស់លោកអេសេគាល គឺនាំព្រះបន្ទូលដល់ពួកអ្នកជាប់ជាឈ្លើយ ដូចគ្នាព្រះបន្ទូលនោះ សម្រាប់ខ្លួនគាត់ផងដែរ ។ សមាជិកផ្សេងទៀត នៃក្រុមគ្រួសាររបស់សង្ឃ ត្រូវបានហៅឱ្យទៅធ្វើការងារជាហោរា បេសកកម្មទាំងនោះ គឺទៅដល់ពួកអ៊ីស្រាអែលនៅតែមាននៅខាងក្នុង និងជុំវិញក្រុងយេរូសាឡិម ។

**២:១** *កូនមនុស្ស* ជាពាក្យមួយត្រូវបានប្រើ៩៣ដង ក្នុងអេសេគាល សង្កត់ធ្ងន់ភាពជាមនុស្សរបស់ហោរា ដូចជាគាត់បានបញ្ជាក់ពីឧត្តមភាពរបស់ព្រះ (មើលការពន្យល់ ទដ ៨:៤) ។ ដយ ៧:១៣ និង ៨:១៧ ជាកន្លែងមួយផ្សេងទៀតតែ១គត់ ដែលឃ្លានេះត្រូវបានប្រើសម្រាប់ចំណងជើងនៅសញ្ញាចាស់ ព្រះយេស៊ូវបានប្រើជារឿយៗឃ្លានេះ ក្នុងការពោលទៅលើអង្គទ្រង់ដោយបង្ហាញថា ទ្រង់បានមានបន្ទូលនៅក្នុង ដយ ៧:១៣ (មើល ឧទាហរណ៍ មក ៨:៣១ និងការពន្យល់) ។

**២:២** *នោះព្រះវិញ្ញាណក៏មកសណ្ឋិតនៅក្នុងខ្ញុំ ហើយបានបញ្ឈរខ្ញុំឡើង* ព្រះវិញ្ញាណរបស់ព្រះគ្រប់គ្រង និងផ្តល់អំណាចដល់ការងាររបស់ហោរាទាំងស្រុង ។ (មើល ១១:៥ ៣៦:២៧ ៣៩:២៩ មើលផងដែរ ៣:១២ និងការពន្យល់ ។

**២:៣** *គឺដល់សាសន៍ដែលរឹងចចេស* សាច់រឿងនោះបានក្លាយជាចំណុចសំខាន់ នៃសេចក្តីប្រកាសរបស់លោកអេសេគាល ។

**២:៦** *បន្លាហើយនិងអញ្ចាញ . . . ខ្យាដំរី* រូបភាពរស់រវើកនៃអស់អ្នកដែលចូលចិត្តធ្វើឱ្យជីវិតពិបាកដល់ហោរា ។

**២:១០** *ទាំងខាងក្នុង* ជាធម្មតាក្រដាសនោះត្រូវបានសរសេរលើតែម្ខាងប៉ុណ្ណោះ មើល នក ៣២:១៥ និងការពន្យល់ ។ *ពាក្យទំនួញ ពាក្យសោកសៅ* ទោះបីជាលោកអេសេគាល យឺតយាវប្រកាសពីក្តីសង្ឃឹមក្តី (មើល ៣៣:១–

ទទេ[ផ] ។

៣ ១ទ្រង់ក៏មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ ចូរឯង
ស៊ីរបស់ដែលឯងឃើញនេះ គឺស៊ីក្រាំងនេះទៅ រួចចូរទៅ
និយាយនឹងពូជពង្សអ៊ីស្រាអែលចុះ ២ដូច្នេះ ខ្ញុំក៏ហាមាត់
ឡើង ហើយទ្រង់ធ្វើឱ្យខ្ញុំបរិភោគក្រាំងនោះទៅ ៣ទ្រង់
បង្គាប់ដល់ខ្ញុំថា កូនមនុស្សអើយ ចូរឱ្យពោះឯងទទួលចុះ
ហើយឱ្យបានឆ្អែតដោយក្រាំងនេះ ដែលអញឱ្យដល់ឯងផង
នោះខ្ញុំក៏បរិភោគ[ក]ទៅ ឯនៅក្នុងមាត់ខ្ញុំ ក្រាំងនោះមានរស
ផ្អែមដូចជាទឹកឃ្មុំ[ខ] ។

៤រួចទ្រង់មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ ចូរទៅ
ចូរទៅឯពូជពង្សអ៊ីស្រាអែល ហើយប្រាប់គេតាមពាក្យ
របស់អញចុះ[គ] ៥ដ្បិតអញមិនចាត់ឯង ឱ្យទៅសាសន៍ណា
ដែលមានពាក្យសំដីប្លែក និងភាសាពិបាកនោះទេ[ឃ] គឺឱ្យ
ទៅឯពូជពង្សអ៊ីស្រាអែលវិញ ៦មិនមែនទៅឯសាសន៍ជា
ច្រើន ដែលមានពាក្យសំដីប្លែក នឹងភាសាពិបាក ដែល
ឯងនឹងស្តាប់ពាក្យរបស់គេមិនបាននោះទេ បើសិនជាអញ
ចាត់ឯងឱ្យទៅឯសាសន៍ទាំងនោះ ប្រាកដជាគេនឹងស្តាប់
ឯងជាពិត[ង] ៧តែពូជពង្សអ៊ីស្រាអែលមិនព្រមស្តាប់តាមឯង
ទេ[ច] ពីព្រោះគេមិនព្រមស្តាប់តាមអញហើយ ដ្បិតពូជពង្ស
អ៊ីស្រាអែលសុទ្ធតែមានក្បាលរឹង ហើយមានចិត្តចចេស[ឆ]
៨មើល អញធ្វើឱ្យមុខឯងបានរឹងតនឹងមុខគេ ហើយក្បាល
ឯងបានរឹងតនឹងក្បាលគេដែរ[ជ] ៩អញបានធ្វើឱ្យក្បាល[ឈ] ឯង
រឹង ដូចជាពេជ្រដែលរឹងជាងថ្មដែកភ្លើទៅទៀត[ញ] កុំឱ្យ
ខ្លាចគេឡើយ ក៏កុំឱ្យស្លុតនឹងទឹកមុខរបស់គេដែរ ទោះបើ
គេជាពូជពង្សរឹងចចេសក៏ដោយ[ដ] ១០ទ្រង់ក៏មានបន្ទូលមក
ខ្ញុំទៀតថា កូនមនុស្សអើយ ចូរទទួលអស់ទាំងពាក្យ ដែល
អញនឹងប្រាប់ដល់ឯង ទុកនៅក្នុងចិត្ត[ឋ]ចុះ ហើយស្តាប់
ដោយត្រចៀកផង ១១រួចទៅ[ឌ]ចុះ ចូរទៅឯពួកអ្នកដែល
នៅជាឈ្លើយ គឺជាពួកកូនចៅរបស់សាសន៍ឯង ហើយ
និយាយប្រាប់ដល់គេថា ព្រះអម្ចាស់យេហូវ៉ា ទ្រង់មាន
បន្ទូលដូច្នេះ[ឍ] នេះគឺទោះបើគេនឹងព្រមស្តាប់តាម ឬមិន
ព្រមស្តាប់ក្តី[ណ] ។

១២លំដាប់នោះ ព្រះវិញ្ញាណទ្រង់លើកខ្ញុំឡើង[ត] ហើយ
ខ្ញុំឮសូរអឺងអាប់ជាខ្លាំងពីក្រោយខ្ញុំថា សូមឱ្យសិរីល្អនៃព្រះ
យេហូវ៉ាបានពរពីស្ថានរបស់ទ្រង់មក ១៣ហើយក៏ឮសូរ
សន្ទឹកនៃស្លាបរបស់តួមានជីវិត[ថ]ទាំងនោះ ដែលប៉ះគ្នា និង
សូររបស់កង់ទាំងនោះដែលអមទៅ គឺជាសូរអឺងអាប់យ៉ាង
ខ្លាំង[ទ] ១៤ដូច្នេះ ព្រះវិញ្ញាណ[ធ]ទ្រង់លើកខ្ញុំឡើង[ន] យកទៅ ឯ
ខ្ញុំក៏ទៅដោយមានសេចក្តីជូរចត់ ហើយដោយសេចក្តីក្តៅ
ក្រហាយនៃវិញ្ញាណខ្ញុំ ព្រះហស្តនៃព្រះយេហូវ៉ា[ប]ក៏សណ្ឋិត
លើខ្ញុំជាខ្លាំងដែរ ១៥នោះខ្ញុំទៅដល់ពួកឈ្លើយ ដែលនៅ
ត្រង់ថេល–អាប៊ីប នៅក្បែរទន្លេកេបារ[ផ] រឹងនៅកន្លែង

**២:១០** ផ អស ៣:១១ វវ ៨:១៣
**៣:៣** ក យរ ១៥:១៦ ខ ទដ ១៩:១០ វវ ១០:៩–១០
**៣:៤** គ អគ ១១:៤,២៥
**៣:៥** ឃ អស ២៨:១១ យហ ១:២
**៣:៦** ង យណ ៣:៥–១០ មថ ១១:២១–២៣ កច ១៣:៤៦–៤៨
**៣:៧** ច យរ ៧:២៧ ឆ អស ៤៨:៤ យរ ៣:៣ អគ ២:៤ យ ១៥:២០–២៣
**៣:៨** ជ យរ ១:១៨ ១៥:២០
**៣:៩** ឈ អស ៤៨:៤ ញ យរ ៥:៣ ដ អស ៥០:៧ អគ ២:៦ ៤៤:៦ មីក ៣:៨
**៣:១០** ឋ យប ២២:២២
**៣:១១** ឌ អស ៦:៩ ឍ ខ.២៧ ណ អគ ២:៤–៥,៧ ១១:២៤–២៥
**៣:១២** ត ខ.១៤ អគ ៨:៣ ៤៣:៥ **៣:១៣** ថ អគ ១:១៥ ទ អគ ១:២៤ ១០:៥, ១៦–១៧ **៣:១៤** ធ ១ពវ ១៨:១២ ន ខ.១២ ប ខ.២២ អស ៨:១១ អគ ៣៧:១
**៣:១៥** ផ ទដ ១៣៧:១ ព លប ៥០:១០

៤៨:៣៥) ក៏បេសកកម្មដំបូងរបស់គាត់ (រហូតដល់ការធ្លាក់ចុះក្រុងយេរូសាឡិម) បានប្រកាសពីសេចក្តីព្រួយព្រះទ័យរបស់ព្រះ និងពីការជំនុំជម្រះដ៏ជាក់លាក់លើក្រុងយេរូសាឡិម និងពួកយូដាទាំងអស់គ្នា ។

**៣:១** *ស៊ីក្រាំង* លោកអេសេគាលត្រូវតែលេបនូវព្រះបន្ទូលរបស់ព្រះ គាត់ត្រូវទទួលបញ្ជាឱ្យនាំព្រះបន្ទូល ទៅដល់ពួកអ្នកជាប់ជាឈ្លើយ ដូច្នេះ បេសកកម្មនេះ ក្លាយទៅព័ន្ធកិច្ចរបស់គាត់ បំពេញថ្វាយទ្រង់ (ធៀបនឹង យរ ១៥:១៦ និងការពន្យល់) ។

**៣:៣** *មានរសផ្អែមដូចជាទឹកឃ្មុំ* គឺបទពិសោធន៍ផ្ទាល់របស់លោកយេរេមា (យរ ១៥:១៦) ជាបទពិសោធន៍ ដែលលោកអេសេគាលមានខាងឯវិញ្ញាណ ព្រះបន្ទូលមកពីព្រះ គឺផ្អែមគួរចង់ឱ្យភ្លក់ (មើល ទដ ១៩:១០ ១១៩:១០៣) ទោះបីជារឿងនោះ មានការឈឺចាប់ក្តី (មើល ១០:២០–២១) ។

**៣:៦** *បើសិនជាអញចាត់ឯងឱ្យទៅឯសាសន៍ទាំងនោះ ប្រាកដជាគេនឹងស្តាប់ឯងជាពិត* សម្រាប់មនុស្សដទៃទៀតឮ និងយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូល មើល យហ ៣:៥ មទ្យ ១:១០–១១ មថ ១១:២០–២៤ រម ១០:២១–២១ ។

**៣:៩** *អញបានធ្វើឱ្យក្បាលឯងរឹង ដូចជាពេជ្រដ៏រឹងជាងថ្មដែកទៅទៀត* កំលាំងនិងសេចក្តីក្លាហាន គឺជាឧបករណ៍ដ៏ចាំបាច់សម្រាប់ហោរាជាពិសេសពេលប្រកាសពីការជំនុំជម្រះរបស់ហោរាយេរេមា គឺប្រៀបដូចជាឧបកណ៍ផងដែរ (មើល យរ ១:១៨ ធៀបនឹង អស ៥០:៧) ។

**៣:១០** *ទុកនៅក្នុងចិត្តចុះ ហើយស្តាប់ដោយត្រចៀកផង* ហោរាគឺឈរនៅកន្លែងមួយច្បាស់លាស់ ដោយធ្វើឱ្យខុសពីមនុស្សដែលមិនបានស្តាប់ ។

**៣:១១** *ចូរទៅឯពួកអ្នកដែលនៅជាឈ្លើយ* ការងាររបស់លោកអេសេគាល គឺទៅដល់សហគមន៍ ដែលជាឈ្លើយភាគច្រើននៃពួកគេ គឺបានបដិសេធន៍ជឿដល់ព្រះ ដែលមានភាពពេញបរិបូរណ៍នៅក្រុងយេរូសាឡិម ។ ក្រោយពីការធ្លាក់ចុះទីក្រុងយេរូសាឡិម ដូច្នេះពួកគេ គឺបានបាក់ទឹកចិត្តយ៉ាងខ្លាំង ។

**៣:១២–១៥** ការសន្និដ្ឋានគួរឱ្យរំភើប ចំពោះបទពិសោធន៍របស់លោកអេសេគាល ចំពោះការមើលឃើញរបស់គាត់ ។

**៣:១២** *ព្រះវិញ្ញាណទ្រង់លើកខ្ញុំឡើង* មើល ខ.១៤ ៨:៣ ១១:១,២៤ ៣៧:១ ៣៨:៥ ធៀបនឹង ២:២ កន្លែងដែលទ្រង់គង់នៅ ភាគច្រើននៅទីនេះ លោកអេសេគាលពោលសំដៅទៅរកទីកន្លែងដែលព្រះគង់នៅ គឺនគរស្ថានសួគ៌ ជាកន្លែងសរសើរដម្កើង ដែលពទ្ធ័ជុំវិញ មានពេញទៅដោយវត្តមានរបស់ព្រះនៅទីនោះ (ធៀបនឹង ទដ ១០៣:២០–២១ ១៤៨:១–៦) ។

**៣:១៤** *ដោយមានសេចក្តីជូរចត់ ហើយដោយសេក្តីក្តៅក្រហាយនៃវិញ្ញាណខ្ញុំ* ហោរាយល់ពីសេចក្តីត្រឹមត្រូវនៃសេចក្តីក្រោធរបស់ព្រះដោយផ្ទាល់ ការបញ្ជាក់ពីព្រះទ័យរបស់ព្រះ ។ *ព្រះហស្តនៃព្រះយេហូវ៉ាក៏សណ្ឋិតលើខ្ញុំជាខ្លាំងដែរ* មើលការពន្យល់ ១:៣ ។

**៣:១៥** *ថេល–អាប៊ីប* ការបញ្ជាក់ទៅលើទីកន្លែងមួយដ៏ជាក់លាក់ដែលពួក

ដែលគេអាស្រ័យនៅ នោះខ្ញុំក៏នៅកណ្ដាលគេអស់៧ថ្ងៃ[ត]
ដោយស្រឡាំងកាំង ។

## ការព្រមានដល់ពួកអ៊ីស្រាអែល

១៦លុះផុតពី៧ថ្ងៃនោះមក ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏
មកដល់ខ្ញុំថា[ភ] ១៧កូនមនុស្សអើយ អញបានតាំងឯងឱ្យជា
អ្នកយាម[ម] ដល់ពូជពង្សអ៊ីស្រាអែល ដូច្នេះ ត្រូវឱ្យឯងស្ដាប់
ពាក្យពីមាត់អញ រួចទៅប្រាមប្រាប់គេឱ្យអញផង[យ] ១៨កាល
ណាអញប្រាប់ដល់មនុស្សអាក្រក់ថា ឯងនឹងត្រូវស្លាប់ជាពិត[រ]
នោះបើឯងមិនទៅប្រាប់គេ ឬប្រាមប្រាប់មនុស្សអាក្រក់
នោះ ឱ្យលះបង់ផ្លូវអាក្រក់របស់ខ្លួន ដើម្បីឱ្យបានរួចជីវិត
យ៉ាងនោះ មនុស្សអាក្រក់នឹងស្លាប់ក្នុងអំពើទុច្ចរិតរបស់ខ្លួន
មែន តែអញនឹងទារឈាមរបស់គេពីដៃឯងវិញ[ល] ១៩ប៉ុន្ដែ
បើឯងប្រាមប្រាប់ដល់មនុស្សអាក្រក់នោះវិញ តែគេមិន
ព្រមបែរចេញ[វ]ពីអំពើអាក្រក់[ស] ឬពីផ្លូវអាក្រក់របស់ខ្លួនទេ
នោះគេនឹងត្រូវស្លាប់[ហ]ក្នុងអំពើទុច្ចរិតរបស់ខ្លួនជាពិត តែ
ឯងនឹងបានដោះព្រលឹងខ្លួនឱ្យរួចវិញ[ឡ] ២០មួយទៀត
កាលណាមនុស្សសុចរិតបានលះចោល[អ]អំពើសុចរិតរបស់
ខ្លួន ទៅប្រព្រឹត្តអំពើទុច្ចរិតវិញ ហើយអញដាក់ហេតុឱ្យ
ចំពប់[ក]នៅមុខគេ នោះគេនឹងត្រូវស្លាប់ ហើយដោយព្រោះ
ឯងមិនបានប្រាមប្រាប់គេ នោះគេនឹងស្លាប់ក្នុងអំពើបាប
របស់ខ្លួនគេ ហើយនិងលែងមានសេចក្ដីនឹកចាំពីអំពើ
សុចរិតទាំងប៉ុន្មាន ដែលគេបានប្រព្រឹត្តនោះដែរ តែអញ
នឹងទារឈាមគេពីដៃឯងវិញ[ខ] ២១ប៉ុន្ដែបើឯងប្រាមប្រាប់
ដល់មនុស្សសុចរិត ដើម្បីឱ្យគេបានរវាំងខ្លួនមិនឱ្យធ្វើបាប
ឡើយ ហើយគេក៏វៀរចេញពីអំពើបាបទៅ នោះគេនឹង
រស់នៅជាពិត ដោយព្រោះបានទទួលតាមពាក្យប្រាមប្រាប់
របស់ឯង យ៉ាងនោះ ឯងនឹងបានដោះព្រលឹងខ្លួន ឱ្យបាន
រួចផង[គ] ។

២២នៅទីនោះ ព្រះហស្តនៃព្រះយេហូវ៉ា[ឃ]ក៏សណ្ឋិតនៅ
លើខ្ញុំ ទ្រង់មានបន្ទូលមកខ្ញុំថា ចូរក្រោកឡើង ចេញ[ង]ទៅឯ
វាល[ច] នៅទីនោះ អញនឹងនិយាយនឹងឯង ២៣ដូច្នេះ ខ្ញុំក៏
ក្រោកឡើងចេញទៅឯវាល ហើយមើល មានសិរីល្អនៃ
ព្រះយេហូវ៉ាសណ្ឋិតនៅទីនោះ ដូចជាសិរីល្អដែលខ្ញុំបាន
ឃើញនៅក្បែរទន្លេកេបារដែរ[ឆ] ខ្ញុំក៏ដួលផ្កាប់មុខចុះ[ជ]
២៤រួចព្រះវិញ្ញាណទ្រង់មកសណ្ឋិតនៅក្នុងខ្ញុំ[ឈ] ហើយលើក
ខ្ញុំបញ្ឈរឡើង ទ្រង់មានបន្ទូលនឹងខ្ញុំ ហើយប្រាប់ថា ចូរឯង
ចូលទៅក្នុងផ្ទះ ហើយបិទទ្វារទៅ[ញ] ២៥ប៉ុន្ដែ ឱកូនមនុស្ស
អើយ មើល គេនឹងដាក់ចំណងជាប់នឹងឯង ទាំងចងឯង
ដោយចំណងនោះ ហើយឯងនឹងចេញចូលនៅកណ្ដាលគេ
មិនបាន[ដ] ២៦អញនឹងធ្វើឱ្យអណ្ដាតឯង ជាប់នៅនឹងក្រអូម
មាត់[ឋ] ឱ្យឯងបានគ ដើម្បីមិនឱ្យធ្វើជាអ្នកបន្ទោសដល់គេ

**៣:១៦** ភ យរ ៤២:៧ **៣:១៧** ម អស ៥២:៨ យ អស ៥៨:១ យរ ១:១៧ អគ ១១:៤ ហព ២:១ **៣:១៨** រ ២:១៧ យហ ៨:២១,២៤ ល ខ.២០ **៣:១៩** វ ទដ ៧:១២ ស លប ៦:៥ ហ យរ ៤២:១៦ ឡ ២ពវ ១៧:១៣ អគ ១៤:១៤,២០ កច ១៨:៦ ២០:២៦ ១ធថ ៤:១៤–១៦ **៣:២០** អ យរ ៣៤:១៦ ក ២៦:៣៧ អស ៨:១៤ អគ ៧:១៩ ខ ខ.១៨ ទដ ១២៥:៥ អគ ១៨:២៤ ៣៣:១២,១៨ **៣:២១** គ កច ២០:៣១ **៣:២២** ឃ ខ.១៤ អគ ១:៣ ង កច ៩:៦ ច អគ ៨:៤
**៣:២៣** ឆ អគ ១:១ ជ លប ១៧:៣ **៣:២៤** ឈ អគ ២:២ ញ យរ ១៥:១៧ **៣:២៥** ដ អគ ៤:៨ **៣:២៦** ឋ ទដ ២២:១៥

ឈ្លើយបានរស់នៅ ។ នៅក្រុងបាប៊ីឡូនឈ្មោះនោះមានន័យថា"ភ្នំនៃទឹកលិច" ហើយត្រូវបានប្រើសំដៅទៅក្រុងពួកបរិសុទ្ធ ដែលបានធ្វើឱ្យធូរស្រាលពីការយំសោក ។ ពេលដែលត្រូវបានប្រើប្រាស់ទីក្រុងទំនើបរបស់អ៊ីស្រាអែល ថេល អាវីវ ឈ្មោះនេះគឺ (អាប៊ីប និងអាវីវ គឺដូចគ្នានឹងឈ្មោះហេព្រើរ គឺមានន័យថា"ភ្នំនៃការលូតលាស់ថ្មី" ។ *៧ថ្ងៃ* រយៈពេលនៃការកាន់ទុក្ខ (មើល ៥០:១០ ១សយ ៣១:១៣) ។ *ស្រឡាំងកាំង* ដោយសារសេចក្ដីវន្ទត់បានកើតឡើង នៅបន្ទប់របស់យូដា (ធៀបនឹង អគ ៩:៣–៤ យប ២:១៣ និងការពន្យល់ ដយ ៨:២៧) ។

**៣:១៦–២១** ព្រះបានតែងតាំងលោកអេសេគាលឱ្យធ្វើជា "អ្នកចាំយាម" សម្រាប់អ៊ីស្រាអែល ។ ជាពាក្យប្រៀបធៀបបានដកចេញពីអ្នករស់នៅជនបទ ។ ភារកិច្ចចាំបាច់របស់គាត់ ជាអ្នកចាំយាម ដែលបានលើកមកបកស្រាយ គឺជាតួអង្គដ៏សំខាន់បំផុតក្នុងជំពូក៨ ។

**៣:១៧** *អញបានតាំងឯងឱ្យជាអ្នកយាម* នៅក្នុងពួកអ៊ីស្រាអែលជំនាន់បុរាណ អ្នកយាម គឺដូចជាទីក្រុងដែលមានជញ្ជាំង ដើម្បីបម្រើដូចជាភ្នែកនៃទីក្រុង (មើល ២សយ ១៨:២៤–២៧ ២ពវ ៩:១៧–២០ បស ៣:៣ ៥:៧ ១សយ ៥២:៨ ៦២:៦) ជាពិសេសគឺព្រមានពីភាពគ្រោះថ្នាក់ (មើល ៣៣:២–៣,៦ ទដ ១២៧:១ ១សយ ២១:៦ ៥៦:១០ យរ ៦:១៧ ហស ៩:៨) ។

**៣:២០** *អញនឹងដាក់ហេតុឱ្យជំពប់នៅមុខគេ* ចំពោះអស់អ្នកដែលលះចោលសេចក្ដីសុច្ចរិត ហើយចាប់យកនូវអំពើទុច្ចរិត គេនឹងត្រូវដាក់ឱ្យព្រះល្បងលមើល (មើល ១៤:៩ ធៀបនឹង ចទ ១៣:៣ ២សយ ២៤:១ និងការពន្យល់ ២របា ៣២:៣១ ទដ ៦៦:១០ និងការពន្យល់ និងមើលផងដែរ មថ ៦:១៣) ។

**៣:២២–២៧** ព្រះកំណត់ព្រំដែនសេរីភាពការបម្រើរបស់លោកអេសេគាល ដើម្បីអនុវត្តបេសកកម្មរបស់ទ្រង់ វាមានន័យថា ព្រះទ្រង់ជ្រាបដឹងថាពួកឈ្លើយមិនឆ្លើយតបចំពោះការព្រមានរបស់ទ្រង់ឡើយ ។

**៣:២២** *ព្រះហស្តនៃព្រះយេហូវ៉ា* មើលការពន្យល់ ១:៣ ។

**៣:២៥** *ចងឯងដោយចំណងនោះ* ប្រហែលល្អជាង "គេនឹងចង់ឯងដោយចំណងនោះ"(ពាក្យប្រៀប) ព្រះគម្ពីរភាសាហេព្រើរជួនកាល គឺមានន័យស្មើរនឹងឃ្លារងនូវអំពើ ។ ដោយយោងតាមខនេះ គឺព្រះធ្វើចលនាពេលដែលលោកអេសេគាលធ្វើការនោះ (ធៀបនឹង ៤:៨) ។

**៣:២៦** *ឱ្យឯងបានគ* ខ.២៦–២៧ ដោយចង្អុលបង្ហាញថា ហោរាមិនអាចនិយាយបានទេ លើកលែងតែគាត់មានពាក្យផ្ទាល់មកពីព្រះអម្ចាស់ ។ គាត់ត្រូវបង្ខំចិត្តអោយនៅស្ងៀម និយាយចំពោះសេចក្ដីរឹងចចេសរបស់អ៊ីស្រាអែល ដែលគេបដិសេធន៍មិនអនុវត្តតាមព្រះបន្ទូលព្រះ ហើយវាគឺជាផ្នែកមួយនៃការជំនុំជម្រះរបស់ព្រះ ទៅលើមនុស្សដែលបះបោរប្រឆាំង(មើល ៧:២៦ និងការពន្យល់ ២០:៣,៣១) ។ លក្ខខណ្ឌគឺបានធូស្រាលឡើងវិញក្រោយពីការដួលរលំនៃទីក្រុងយេរូសាឡិម (២៤:២៧ ៣៣:២២) ។ តាំងពីពេលនោះមក លោកអេសេគាល បាននិយាយពីព្រះបន្ទូលនៃក្ដីសង្ឃឹម ដោយគាត់បានបន្ដចែកចាយជាមួយនឹងពួកអ្នកដែលជាប់ជាឈ្លើយ ។

ទៀត ដ្បិតគេជាពូជពង្សរឹងចចេស[ឌ] ២៧ប៉ុន្តែ កាលណាអញ
និយាយនឹងឯង នោះអញនឹងបើកមាត់ឯងឡើង ហើយឯង
នឹងប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ[ឍ]
អ្នកណាដែលស្តាប់ ចូរស្តាប់ចុះ ឯអ្នកណាដែលមិនព្រម
ស្តាប់ទេ នោះក៏តាមចិត្តចុះ ដ្បិតគេជាពូជពង្សរឹងចចេស
ហើយ[ណ]។

## និមិត្តរូបនៃការឡោមព័ទ្ធក្រុងយេរូសាឡិម

**៤** ១មួយទៀត កូនមនុស្សអើយ ចូរយកក្បឿង១មក ដាក់
នៅមុខឯង ហើយគូរផែនទីក្រុងយេរូសាឡិមនៅលើ
ក្បឿងនោះ ២រួចនាំទាហានមកឡោមព័ទ្ធច្បាំងនឹងវា ព្រម
ទាំងសង់ប៉ម ជីកស្នាមភ្លោះ[ក] តាំងបន្ទាយទាស់នឹងវា ហើយ
ធ្វើគ្រឿងបុកទំលាយកំផែងនៅជុំវិញផង[ខ] ៣ត្រូវឱ្យយកបន្ទះ
ដែក[គ]មកដាក់កណ្តាលឯង ហើយនិងទីក្រុងទុកជាកំផែង
ដែក រួចឱ្យដំរង់មុខឯងទាស់នឹង[ឃ]វា នោះទីក្រុងនឹងត្រូវគេ
ឡោមព័ទ្ធហើយ ដោយឯងឡោមព័ទ្ធច្បាំងនឹងគេដូច្នេះ
ការនេះនឹងបានជាទីសំគាល់[ង] ដល់ពួកវង្សអ៊ីស្រាអែល[ច]។
៤មួយទៀត ចូរឯងដេកផ្អៀងទៅខាងឆ្វេង ហើយផ្ទុក
សេចក្តីទុច្ចរិតរបស់ពូជពង្សអ៊ីស្រាអែល នៅលើខ្លួនចុះ
ត្រូវឱ្យឯងទទួលសេចក្តីទុច្ចរិតរបស់គេ តាមចំនួនថ្ងៃដែល
ឯងដេកផ្អៀងខាងនោះ ៥ដ្បិតអញបានរាប់ចំនួនថ្ងៃ ឱ្យស្មើ
នឹងចំនួនឆ្នាំ ដែលគេត្រូវរងសេចក្តីទុច្ចរិតរបស់ខ្លួន គឺ
៣៩០ថ្ងៃ ត្រូវឱ្យឯងទទួលអំពើទុច្ចរិតរបស់ពូជពង្សអ៊ីស្រា
អែល នៅលើខ្លួនយ៉ាងដូច្នោះ ៦រួចកាលណាឯងបាន
សំរេចថ្ងៃទាំងនោះហើយ នោះត្រូវឱ្យឯងដេកផ្អៀងទៅ
ខាងស្តាំវិញ ហើយត្រូវទទួលអំពើទុច្ចរិត[ឆ]របស់ពូជពង្ស
យូដា អស់៤០ថ្ងៃទៀត អញបានកំណត់១ថ្ងៃ ទុកជា១ឆ្នាំដល់
ឯង[ជ] ៧លំដាប់នោះ ត្រូវឱ្យឯងដំរង់មុខ[ឈ]ទៅខាងការឡោម
ព័ទ្ធច្បាំងនឹងក្រុងយេរូសាឡិម ដោយមានដើមដៃឯងបើក
ទទេនៅ ហើយត្រូវទាយទាស់នឹងទីក្រុងដែរ ៨មើលអញ
ដាក់ខ្សែនេះចងឯងជាប់ មិនឱ្យប្រែខ្លួនពីម្ខាងទៅម្ខាង
ឡើយ ដរាបដល់បានសំរេចកំណត់ថ្ងៃដែលឯងឡោមព័ទ្ធ
ច្បាំងនោះ[ញ]។
៩ត្រូវឱ្យឯងយកម្សៅភោជ្ជសាលី ម្សៅឱក សណ្តែក
អង្គុយ សណ្តែកបាយ ថ្លៅ ហើយស្រូវអេប៉ូត[ដ]មកដាក់
ក្នុងផើង ហើយប្រើធ្វើជានំបុ័ងសំរាប់ខ្លួន តាមចំនួនថ្ងៃ
ដែលឯត្រូវដេកផ្អៀងនោះ គឺឯងត្រូវស៊ីនំបុ័ងនោះគ្រប់
៣៩០ថ្ងៃ ១០ឯអាហារដែលឯងនឹងស៊ី នោះត្រូវថ្លឹងជា

**៣:២៦** ឌ អក ២:៥
២៤:២៧ ៣៣:២២
ហស ៤:៤
**៣:២៧** ឍ ខ.១១
ណ អក ២:៥ ១២:៣
២៤:២៧ ២៩:២១
៣៣:២២ វវ
២២:១១
**៤:២** ក យរ ៦:៦
អក ១៧:១៧ យរ
១១:១៥ ខ យរ
៣៣:៤ អក ២១:២២
**៤:៣** គ លវ ២:៥ ឃ
ខ.៧ អក ២០:៤៦
២១:២ ង អស
៨:១៨ ២០:៣ យរ
១៣:១–៧ ១៨:១–៤
១៩:១–២ អក ៥:១–
៤ ១២:៣–៦ ច យរ
៣៩:១
**៤:៦** ឆ នក ២៨:៣៨
ជ ជន ១៤:៣៤ យរ
៩:២៤–២៦
១២:១១–១២
**៤:៧** ឈ ខ.៣ អក
៦:២ ១៣:១៧ **៤:៨** ញ អក ៣:២៥ **៨:៩** អស ២៨:២៥

**៤:១–៥:១៧** តាមន័យនេះ ទីសម្គាល់ដែលលោកអេសេគាលពិពណ៌នាពីការឡោមពទ្ធ័ក្រុងយេរូសាឡិម និងភាពជោគជ័យ ។ នៅក្នុង ៤:១–៣ ការឡោមពទ្ធ័ទីក្រុងនោះត្រូវបានពិពណ៌នានៅក្នុង ៤:៤–៨ លោកអេសេគាលចង់មានន័យពីសេចក្តីជំនុំជម្រះទៅលើពួកអ៊ីស្រាអែល និងពួកយូដា ក្នុង ៤:៩–១៧ លោកអេសេគាលបានចាត់ចែងម្ហូប ជាទីសម្គាល់ទាំង២ ម្ហូបដែលមានសមល្មម សម្រាប់អស់អ្នកដែលនៅក្រោមការឡោមព័ទ្ធ កំពុងរងទុក្ខ និងការពិតដែលពួកអ្នកដែលជាប់ជាឈ្លើយ ត្រូវបង្ខំចិត្តឱ្យបរិភោគអាហារដែលក្រិត្យវិន័យថា "មិនស្អាត" ហើយត្រូវបានហាមប្រាម ក្នុង ៥:១–៤ លោកអេសេគាល ត្រូវបានណែនាំឱ្យកោសក់ ដែលជាសញ្ញាបង្ហាញថា ពួកអ៊ីស្រាអែលនៅមានចំនួនតិចតួច និងបានរួចផុតពីសេចក្តីជំនុំជម្រះរបស់ព្រះ ក្នុង ៥:៥–១៧ ។

**៤:១** *ចូរយកក្បឿងមួយមកដាក់នៅមុខឯង* ទីសម្គាល់ពីបីដំបូងដែលបានបង្ហាញដោយហោរា ។ ក្រោយពីការសរសេរពីភាពដូចគ្នានៃទីក្រុងយេរូ–សាឡិម នៅលើក្បឿងនោះ ដូចជាការសរសេរពាក្យនោះ បានប្រើនៅក្រុងបាប៊ីឡូន ។ លោកអេសេគាល ត្រូវបានដាក់នៅជុំវិញ ឱ្យធ្វើជាគំរូពីការងារដែលនៅជុំវិញក្រុង នៅក្រោមការវាយប្រហារ (ខ.២) បន្ទាប់មកគាត់ត្រូវបានដាក់នៅកន្លែងជាងស្មូន (ប្រហែលជាកន្លែងដុតនំ) រវាងខ្លួនគាត់ និងទីក្រុងនោះ (ខ.៣) ចង្អុលបង្ហាញពីកំម្លាំងដែលមិនអាចឡោមព័ទ្ធបាន ។

**៤:៣** *ដោយឯងឡោមព័ទ្ធច្បាំងនឹងគេ* វត្តមានរបស់លោកអេសេគាល ក្នុងរូបភាពមួយដែលមានន័យថា ការឡោមពទ្ធ័គឺធ្វើឡើងដោយព្រះអម្ចាស់ ។ *សញ្ញា* លោកអេសេគាលគឺជា "សញ្ញាមួយ" មើលផងដែរ ១២:៦,១១ ២៤:២៤,២៧ ខទាំងនេះសំដៅទៅលើ "សញ្ញា" ការកត់សម្គាល់ ការបកប្រែអក្សរសាស្ត្រយ៉ាងសំខាន់នៅក្នុងព្រះគម្ពីរ (មើល ១២:១–២៨ ២៤:១៥–២៧) ។

**៤:៤** *ត្រូវឱ្យឯងទទួលសេចក្តីទុច្ចរិតរបស់គេ* ដោយទទួលយកនូវអំពើបាបជំនួសគេ ។ សកម្មភាពរបស់ហោរាជាសញ្ញាបង្ហាញថា អ៊ីស្រាអែល នឹងទទួលនូវការជំនុំជម្រះ និងរងទុក្ខចំពោះអំពើទុច្ចរិតរបស់គេ ហើយវាមិនរំលងពីគេឡើយ ។

**៤:៥** *៣៩០ថ្ងៃ* ៣៩០ឆ្នាំ (មើល ខ.៦) ជាតំណាងពីពេលមួយទៅពេលមួយដែលជាអំពើទុច្ចរិតរបស់ស្តេចសាឡូម៉ូន រហូតដល់ការដួលរលំក្រុងយេរូសាឡិម ។ ការឆ្លើយតបអស់៤០ឆ្នាំក្នុង ខ.៤ តំណាងពីការគ្រងរាជ្យដ៏អាក្រក់របស់ស្តេចម៉ាន៉ាសេ មុនពេលការប្រែចិត្តរបស់គាត់ (មើល ២ពវ ២១:១១–១៥ ២៣:២៦–២៧ ២៤:៣–៤ ២របា ៣៣:១២–១៣) ។

**៤:៦** *នៅខាងស្តាំ* ដេកផ្អៀងទៅខាងឆ្វេង (មើល ខ.៤) ទល់មុខក្រុងយេរ៉ូសាឡិម (ខ.៧) ប្រហែលជាព្រះដាក់អេសេគាលទៅទិសខាងជើងជាទីសម្គាល់នៃទីក្រុង (ខ.១) ដេកផ្អៀងទៅខាងស្តាំ ព្រះទ្រង់ដាក់គាត់ទៅទិសខាងត្បូង បញ្ជាក់ពីអាណាចក្រខាងជើង និងអាណាចក្រខាងត្បូង ។

**៤:៧** *ទាយទាស់នឹងទីក្រុង* តាមន័យនេះ លោកអេសេគាលចង់បង្ហាញពីការដែលគាត់ធ្វើទីសម្គាល់ ។

**៤:៩** *ត្រូវឱ្យឯងយកម្សៅភោជ្ជសាលី ម្សៅឱក សណ្តែកអង្គុយ សណ្តែកបាយ ថ្លៅ និងស្រូវអេប៉ូត* ការបង្អត់ ការតមសាច់ បង្ហាញពីការផ្គត់ផ្គង់ មិនគ្រាប់គ្រាន់សម្រាប់ទីក្រុងដែលគេបានឡោមព័ទ្ធ ។

កន្លះនាលិ[ឋ]សំរាប់១ថ្ងៃ ហើយត្រូវស៊ីបន្តិចម្តងៗ ១១ក៏ត្រូវ
ផឹកទឹកដោយវាល់ដែរ គឺ២កំប៉ុងក្នុង១ថ្ងៃ ហើយត្រូវផឹក
បន្តិចម្តងៗដូចគ្នា[ឌ] ១២ត្រូវឱ្យឯងស៊ីនំបុ័ងនោះទុកដូចជានំ
ម្សៅឱក ហើយត្រូវចំអិននំបុ័ងនោះនៅមុខគេ ដោយដុត
លាមក[ឍ]ដែលចេញពីមនុស្ស ១៣ព្រះយេហូវ៉ាទ្រង់ក៏មាន
បន្ទូលថា ពួកកូនចៅអ៊ីស្រាអែលនឹងស៊ីនំបុ័ងស្មោកគ្រោក
របស់គេយ៉ាងដូច្នោះ នៅកណ្តាលអស់ទាំងសាសន៍ដែល
អញបណ្តេញគេទៅ[ណ] ១៤ខ្ញុំក៏ប្រកែកថា ឱព្រះអម្ចាស់
យេហូវ៉ាអើយ[ត] មើល ព្រលឹងទូលបង្គំមិនដែលត្រូវស្មោក
គ្រោកឡើយ ចាប់តាំងពីក្មេង ដរាបដល់សព្វថ្ងៃនេះ
ទូលបង្គំមិនដែលទទួលទានអ្វីដែលស្លាប់ឯង[ថ] ឬដែលត្រូវ
សត្វណា ហែកហួរឡើយ ក៏មិនដែលមានសាច់គួរខ្ពើម
ចូលក្នុងមាត់ទូលបង្គំដែរ[ទ] ១៥នោះទ្រង់មានបន្ទូលមកខ្ញុំថា
មើល អញឱ្យឯងប្រើអាចម៍គោ ជំនួសលាមករបស់មនុស្ស
វិញ ឯងនឹងចំអិននំបុ័ងឯង ដោយដុតអាចម៍គោនោះបាន
១៦ទ្រង់មានបន្ទូលមកខ្ញុំទៀតថា កូនមនុស្សអើយ អញនឹង
ផ្តាច់ស្បៀងចេញ[ធ]ពីក្រុងយេរូសាឡិម គេនឹងស៊ីនំបុ័ង
ដោយថ្លឹង ហើយបារម្ភព្រួយ ក៏នឹងផឹកទឹកដោយវាល់
ហើយភ្លាំងភ្លឹកដែរ[ន] ១៧ដើម្បីឱ្យគេខ្វះនំបុ័ងនិងទឹក[ប] ព្រម
ទាំងមានសេចក្តីភ្លាំងភ្លឹកជាមួយគ្នា ហើយរោយរៀវទៅ
ក្នុងអំពើទុច្ចរិតរបស់គេ[ផ] ។

**៥** ១មួយទៀត កូនមនុស្សអើយ ចូរយកកាំបិតមុតជា
កាំបិត[ក] របស់ជាងកោរ មកកោរ[ខ]សក់និងពុកចង្កាឯងចុះ[គ]
រួចយកត្រាជូមកថ្លឹង ហើយបែងចែកសក់នោះ ២ឯ១ភាគ
ក្នុង៣[ឃ] ត្រូវឱ្យឯងដុត[ង]នៅកណ្តាលទីក្រុង ក្នុងកាលដែល
ចំនួនថ្ងៃនៃការឡោមព័ទ្ធនោះបានសំរេច ១ភាគក្នុង៣
ទៀត ត្រូវឱ្យយកកាំបិតកាត់ក្រឡឹងជុំវិញ ហើយ១ភាគ
ក្នុង៣ទៀត ត្រូវឱ្យគ្រវែងចោលឱ្យខ្យល់ផាត់ទៅ[ច] រួចអញ
នឹងហូតដាវទៅតាមក្រោយ[ឆ] ៣ត្រូវឱ្យឯងយកសរសៃសក់
នោះប្រមាណបន្តិចមកចងនៅជាយអាវឯង[ជ] ៤រួចពីចំនួន
សរសៃសក់ទាំងនោះ ត្រូវឱ្យឯងយកខ្លះបោះទៅក្នុងភ្លើង[ឈ]
ដុតទៅ នឹងមានភ្លើងចេញពីនោះមក ទាស់នឹងពូជពង្ស
អ៊ីស្រាអែលទាំងអស់ ។

៥ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា នេះ
គឺជាក្រុងយេរូសាឡិម ដែលអញបានតាំងឱ្យនៅកណ្តាល
អស់ទាំងសាសន៍ និងប្រទេសទាំងប៉ុន្មាននៅជុំវិញ[ញ] ៦ប៉ុន្តែ
វាបានរឹងទទឹងនឹងបញ្ញត្តិច្បាប់របស់អញ ដោយប្រព្រឹត្ត
អំពើអាក្រក់ លើសជាអស់ទាំងសាសន៍ ហើយរឹងទទឹង
នឹងក្រិត្យក្រមរបស់អញ លើសជាងប្រទេសនៅជុំវិញទាំង
ប៉ុន្មាន ដ្បិតគេបានបោះបង់ចោលបញ្ញត្តិច្បាប់របស់អញ
ឥតដែលដើរតាមសោះ[ដ] ៧ហេតុនោះបានជាព្រះអម្ចាស់
យេហូវ៉ា ទ្រង់មានបន្ទូលថា ដោយព្រោះឯងរាល់គ្នាជ្រួល
ជ្រើមលើសជាងអស់ទាំងសាសន៍ ដែលនៅជុំវិញឯង ក៏
មិនបានដើរតាមច្បាប់អញ ឬរក្សាបញ្ញត្តិអញ ហើយមិន
បានប្រព្រឹត្តតាមបញ្ញត្តិរបស់សាសន៍ទាំងប៉ុន្មាន ដែលនៅ
ជុំវិញឯងផង[ឋ] ៨បានជាព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល
ថា មើល អញ គឺអញនេះហើយ បានទាស់នឹងឯង អញ

**៤:១០** ឋ នក ៣០:១៣ **៤:១១** ឌ ខ.១៦ **៤:១២** ឍ អស ៣៦:១២ **៤:១៣** ណ ហស ៩:៣ អម ៧:១៧ **៤:១៤** ត យរ ១:៦ អគ ៩:៨ ២០:៤៩ ថ លវ ១១:៣៩ ទ នក ២២:៣១ ចទ ១៤:៣ ៣២:៣៧–៣៨ ចទ ១:៨ ហស ៩:៣–៤ **៤:១៦** ធ ទដ ១០៥:១៦ ន ខ.១១–១២ លវ ២៦:២៦ អស ៣:១ អគ ១២:១៩ **៤:១៧** ប បទ ៥:៤ អគ ៥:១៦ ១២:១៨–១៩ អម ៤:៨ ផ លវ ២៦:៣៩ អគ ២៤:២៣ ៣៣:១០ **៥:១** ក ជន ៦:៥ ខ ៤៤:២០ គ លវ ២១:៥ ២សយ ១០:៤ **៥:២** ឃ សក ១៣:៨ ង យរ ២១:១០ អគ ១៥:៧ ច ខ.១០ យរ ១៣:២៤ ឆ ខ.១២ លវ ២៦:៣៣ យរ ៩:១៦ ៣៩:១–២ **៥:៣** ជ ២ពវ ២៥:១២ ទដ ៧៤:១១ យរ ៣៩:១០ **៥:៤** ឈ អគ ១០:៧ ១៥:៧ **៥:៥** ញ ចទ ៤:៦ បទ ១:១ អគ ១៦:១៤ **៥:៦** ដ ២ពវ ១៧:១៥ នហ ៩:១៧ យរ ១១:១០ អគ ២:៣ ១៦:៤៧–៥១ សក ៧:១១ **៥:៧** ឋ ២ពវ ២១:៩ ២របា ៣៣:៩ យរ ២:១០–១១ អគ ១៦:៤៧

**៤:១៥** *អាចម៍គោ* នៅពេលស្ងួត ជាធម្មតា គេបានប្រើវានៅជិតទិសខាងកើត ដូចជាប្រេងសម្រាប់ដុតនំហើយជួនកាលគេនៅតែប្រើវារហូតដល់សព្វថ្ងៃ ។ ម្តងទៀតលោកអេសេគាលបង្ហាញពីការមិនពេញចិត្ត ចំពោះពិធីដែលមិនស្អាត ។ (មើលការពន្យល់ ១:៣) ហើយព្រះទ្រង់ឆ្លើយយ៉ាងសមសួន ចំពោះការជំទាស់របស់ហោរា ពីអ្វីដែលជាអំពើអាក្រក់របស់មនុស្ស ។

**៥:១–១៧** អំពើបាបរបស់មនុស្សនៅក្រុងយេរូសាឡិម នៅថ្ងៃជំនុំជម្រះ នោះនឹងកើតមានឡើងពិតប្រាកដចំពោះពួកគេ មានតែមួយចំនួនតិចតួចប៉ុណ្ណោះដែលបានរួចខ្លួន (ធៀបនឹងការពន្យល់នៅក្នុង ២ពវ ១៩:៣០–៣១ អស ១:៩ ១០:២០–២២) ។

**៥:១** *ចូរយកកាំបិតមុតជាកាំបិតរបស់ជាងកោរ* អ្វីដែលលោកអេសាយបានបញ្ជាក់ជាពាក្យប្រៀបធៀប ហើយលោកអេសេគាលក៏បានថ្លែងនូវសេចក្តីសេចក្តីទំនាយអំពីទីសម្គាល់នោះ (មើល អស ៧:២០) ។

**៥:២** *អញនឹងហូតដាវ* មើល ១២:១៤ ២១:៣–៥ ៣០:២៥ ៣២:១០ ទដ ៧:១២–១៣ និងការពន្យល់ ។

**៥:៥** *នេះគឺជាក្រុងយេរូសាឡិម* ក្រោយពីលោកីយនេះស្ងាត់ស្ងៀម មិនសូវមានទីសម្គាល់ (ផ្តើមឡើងនៅក្នុងជំពូក ៤:១) លោកអេសេគាលបានទទួលការបើកសម្តែងអំពីព្រះចេស្តានៃព្រះ ។ *តាំងឱ្យឯងនៅកណ្តាលអស់ទាំងសាសន៍* ព្រះទ្រង់បានជ្រើសរើសអ៊ីស្រាអែលរាស្ត្ររបស់ទ្រង់ និងព្រះវិហារជំនាន់ដើម ជាទីកន្លែងសម្រាប់ឆ្លងកាត់ទ្វីបអាហ្វ្រិក ទ្វីបអាស៊ី និងទ្វីបអឺរ៉ុប ដូច្នេះ ចំពោះអ្វីដែលទ្រង់ធ្វើសម្រាប់អ៊ីស្រាអែល នោះគេត្រូវតែធ្វើជាទីបន្ទាល់យ៉ាងល្អ សម្រាប់អស់ទាំងសាសន៍ ដែលទ្រង់ជាព្រះតែ១អង្គគត់ សម្រាប់មនុស្សគ្រប់រូប ត្រូវធ្វើបន្ទាល់ ហើយសម្រាប់អស់អ្នកដែលចង់បានជីវិត និងចង់បានព្រះពរ ។ ការនេះធ្វើឱ្យពួកអ៊ីស្រាអែល ត្រូវទទួលខុសត្រូវ និងទទួលការជំនុំជម្រះរាល់ទង្វើរដែលគេធ្វើនោះ (មើល ៣៨:១២ និងការពន្យល់) ។

**៥:៦** *លើសជាងអស់ទាំងសាសន៍ . . . នៅជុំវិញទាំងប៉ុន្មាន* មើល ខ.៧ ១៦:៤៧–៤៨ ២ពវ ២១:៩ អម ៣:៩ និងការពន្យល់ ។

**៥:៨** *គឺអញនេះហើយបានទាស់នឹងឯង* លោកអេសេគាលតែងតែបានប្រើអំពីពាក្យខ្លី ហើយមានប្រសិទ្ធិភាពអំពីការជំនុំជម្រះ (មើល ១៣:៨ ២១:៣ ២៦:៣ ២៨:២២ ២៩:៣,១០ ៣០:២២ ៣៤:១០ ៣៥:៣ ៣៨:៣ ៣៩:១

នឹងសំរេចសេចក្ដីយុត្តិធម៌ នៅកណ្ដាលឯង ឱ្យសាសន៍
ដទៃបានឃើញដែរ[ឌ] ៩អញនឹងធ្វើការ១នៅក្នុងឯង ជា
ការដែលអញមិនដែលធ្វើពីដើមមក ហើយទៅមុខទៀត
ក៏មិនដែលធ្វើឱ្យដូចឡើយ ដោយព្រោះអស់ទាំងការគួរ
ស្អប់ខ្ពើមរបស់ឯង[ឍ] ១០ដូច្នេះ ឪពុកនឹងស៊ីកូន ហើយកូន
នឹងស៊ីឪពុក[ណ] នៅកណ្ដាលឯង ហើយអញនឹងសំរេចសេចក្ដី
យុត្តិធម៌ដល់ឯង ព្រមទាំងកំចាត់កំចាយសំណល់របស់
ឯងទៅតាមខ្យល់ ពីគ្រប់ទិស[ត] ១១ហេតុនោះព្រះអម្ចាស់
យេហូវ៉ា[ថ]ទ្រង់ស្បថថា ដូចជាអញរស់នៅ[ទ] នោះប្រាកដ
ជាអញ នឹងបន្ថយឱ្យឯងកាន់តែតិចទៅ ភ្នែកអញនឹង
មើលឯង ដោយឥតប្រណី ហើយអញនឹងមិនអាណិតមេត្តា
ដល់ឯងឡើយ[ធ] ដោយព្រោះបានបង្អាប់ទីបរិសុទ្ធ[ន]របស់
អញ ដោយអស់ទាំងរបស់គួរស្អប់ខ្ពើម[ប] ហើយគួរឆ្អើម
របស់ឯង[ផ] ១២ពួកឯង១ភាគក្នុង៣នឹងត្រូវស្លាប់ដោយ
អាសន្នរោគ ហើយនិងត្រូវសូន្យទៅ ដោយអំណត់អត់នៅ
កណ្ដាលឯង ឯ១ភាគក្នុង៣ទៀត នឹងដួលស្លាប់ដោយដាវ
នៅជុំវិញឯង ហើយភាគទី៣ អញនឹងកំចាត់កំចាយទៅ
តាមខ្យល់[ព]គ្រប់ទិស រួចនឹងហូតដាវតាមក្រោយគេទៀត[ភ] ។
១៣គឺយ៉ាងនោះឯង ដែលសេចក្ដីកំហឹងរបស់អញ នឹង
បានសំរេច ហើយអញនឹងឱ្យសេចក្ដីក្រោធ[ម]របស់អញនៅ
លើគេ នោះអញនឹងបានរសាយចិត្ត[យ] កាលណាអញបាន
សំរេចសេចក្ដីក្រោធរបស់អញដល់គេ នោះគេនឹងដឹងថា
ជាអញនេះហើយ គឺព្រះយេហូវ៉ា ដែលបាននិយាយ ដោយ
សេចក្ដីស្រវាស្រទេញរបស់អញ[រ] **១៤**អញនឹងធ្វើឱ្យឯងទៅ
ជាទីខូចបង់ ហើយជាទីមើលងាយ នៅកណ្ដាល អស់ទាំង
សាសន៍ ដែលនៅជុំវិញឯង ឱ្យគ្រប់មនុស្សដែល ដើរបង្ហួស
បានឃើញផង[ល] ១៥ដូច្នេះ ការនោះ នឹងបានជាហេតុ[វ]
នាំឱ្យមានសេចក្ដីត្មះតិះដៀល សេចក្ដីអុចអាល សេចក្ដី
ប្រៀនប្រដៅ[ស] និងសេចក្ដីស្រឡាំងកាំង ដល់អស់ទាំង
សាសន៍ដែលនៅជុំវិញឯង ក្នុងកាលដែលអញ សំរេច
សេចក្ដីយុត្តិធម៌ដល់ឯង ដោយសេចក្ដីកំហឹង សេចក្ដី
ឃោរឃៅ និងពាក្យបន្ទោសដោយក្ដៅខ្លាំង[ហ] (អញនេះ
គឺយេហូវ៉ា បានចេញវាចាហើយ)[ឡ] ១៦គឺក្នុងកាលដែលអញ
នឹងចាត់ប្រើព្រួញដ៏អាក្រក់នៃសេចក្ដីអំណត់ ដែលសំរាប់
បំផ្លាញ ជាសេចក្ដីដែលអញ នឹងចាត់មកលើឯងរាល់គ្នា
នោះអញនឹងធ្វើឱ្យសេចក្ដីអំណត់អត់ ចំរើនឡើង ដល់ឯង
ហើយនិងផ្ដាច់ស្បៀងអាហាររបស់ឯងរាល់គ្នាបង់[អ] ១៧អញ
នឹងចាត់សេចក្ដីអំណត់អត់ និងសត្វកំណាច[ក]មកលើឯង
រាល់គ្នា នោះអញនឹងបំរាសកូនឯងទៅ ហើយនឹងមាន
ទាំងអាសន្នរោគ និងឈាម[ខ] មកកណ្ដាលឯងផង អញនឹង
នាំដាវមកលើឯង អញនេះ គឺយេហូវ៉ាបានចេញវាចា
ហើយ[គឃ] ។

**៥:៨** ឌ យរ ២១:៥,១៣ ២៤:៩ អគ ១១:៩ ១៥:៧ សក ១៤:២ **៥:៩** ឍ យរ ៩:១២ មថ ២៤:២១ **៥:១០** ណ លវ ២៦:២៩ បទ ២:២០ ត លវ ២៦:៣៣ ទដ ៤៤:១១ យរ ១៣:១៤ អគ ១២:១៤ អគ ១២:១៤ **៥:១១** ថ លប ១៥:១២ ទ ជន ១៤:២១ ធ យប ២៧:២២ យរ ១៦:១៨ បទ ២:១៧ អគ ៧:៤,៩ ៨:១៨ ៩:៥ ន លប ១៥:៣១ ប អគ ៧:២០ ១១:១៨ ផ ២របា ៣៦:១៤ អគ ៨:៦ **៥:១២** ព ខ.១០ យរ ១៣:២៤ ភ ខ.២,៧ ទដ ១០៧:៣៩ យរ ១៥:២ ២១:៩ អគ ៦:១១-១២ ៧:១៥ ១២:១៤ អម ៩:៤ សក ១៣:៨ វវ ៦:៨

**៥:១៣** ម ២របា ១២:៧ យប ២០:២៣ អគ ២១:១៧ ២៤:១៣ យ អស ១:២៤ រ អស ៥៩:១៧ អគ ១៦:៤២ ៣៨:១៩ ហស ១០:១០ សក ៦:៨ **៥:១៤** ល លវ ២៦:៣២ ណហ ២:១៧ ទដ ៧៤:៣-១០ ៧៩:១-៤ អស ៦៤:១១ អគ ៦:៦ ២២:៤ ដយ ៩:១៦ មីក ៣:១២ **៥:១៥** វ អស ៤៣:២៨ ស ចទ ២៨:៤៦ ហ ចទ ២៨:២០ ១ពវ ៩:៧ យរ ២២:៨-៩ ២៤:៩ អគ ១៤:៨ ឡ យរ ២៣:៤០ **៥:១៦** អ លវ ២៦:២៦ ចទ ៣២:២៤ **៥:១៧** ក អគ ១៤:១៥ ខ អគ ៣៨:២២ គ ខ.១២ លវ ២៦:២៥ អគ ១៤:២១ ២៨:២៣

មើលផងដែរ យរ ២៣:៣០-៣២ ៥០:២៥ នហ ២:១៣ ៣:៥) ។ *អញនឹងសំរេចសេចក្ដីយុតិធម៌ នៅកណ្ដាលឯងឱ្យសាសន៍ដទៃបានឃើញដែរ* ព្រះទ្រង់ប្រព្រឹត្តចំពោះអ៊ីស្រាអែល ដោយប្រទានឯកសិទ្ធិ និងសេរីភាពឱ្យដល់គេ (មើល លវ ២៦:៤៥ យស ២:១១ ៥:១ ធៀបនឹង អស ៥២:១០) ។

**៥:១០** *ឪពុកនឹងស៊ីកូន* គេស៊ីសាច់មនុស្ស គេប្រព្រឹត្តយ៉ាងឃោរឃៅ គួរឱ្យខ្ពើមឆ្អើមចំពោះជីវិតនានាដែលរស់នៅក្រោមការឡោមព័ទ្ធ ដែលគេនឹងទទួលផលអាក្រក់ នៅពេលគេធ្វើឱ្យខូចដល់ការតាំងសញ្ញានោះ (មើល ២ពវ ៦:២៨ ចទ ២៨:៥៣ មើល យរ ១៩:៩ និងការពន្យល់ បទ ២:២០ សផ ១១:៩ និងការពន្យល់) ។

**៥:១១** *ដូចជាអញរស់នៅ* ពាក្យសម្បថចំពោះព្រះ ការបើកសម្ដែងអំពីគោលបំណងរបស់ព្រះដែលមិនអាចផ្លាស់ប្ដូរបាន ហើយវាតែងតែត្រូវបានប្រើប្រាស់ជាញឹកញាប់នៅក្នុងព្រះគម្ពីរអេសេគាល (មើល ១៤:១៦,១៨,២០ ១៦:៤៨ ១៧:១៦ ១៩ ១៨:៣ ២០:៣,៣១ ៣៣:១១,២៧ ៣៤:៨ ៣៥:៦,១១ មើលផងដែរ ៦:១៣ និងការពន្យល់) ។ *ដោយព្រោះបានបង្អាប់ទីបរិសុទ្ធរបស់អញ* (មើលជំពូក ៨) ។

**៥:១៣** *អញនឹងឱ្យសេចក្ដីក្រោធរបស់អញនៅលើគេ* ព្រះអម្ចាស់បានសម្ដែងជារឿយៗនៅក្នុងព្រះគម្ពីរនេះ (មើល ៦:១២ ៧:៨ ១៣:១៥ ២០:៨ ២១) ។ *នោះគេនឹងដឹងថាជាអញនេះហើយ គឺព្រះយេហូវ៉ាដែលបាននិយាយ* មើល ១៧:២១ ៣៦:៣៦ ៣៧:១៤ មើលផងដែរ ៦:៧ និងការពន្យល់ ។

**៥:១៥** *នាំឱ្យមានសេចក្ដីត្មេះតេះដៀល សេចក្ដីអុចអាល សេចក្ដីប្រៀនប្រដៅ និងសេចក្ដីស្រឡាំងកាំង* (មើលការពន្យល់ ១:៥) ។

**៥:១៦-១៧** ខទាំងនេះបានបញ្ជាក់ពីសេចក្ដីជំនុំជម្រះ ដែលនឹងកើតមានឡើងចំពោះការដែលគេមិនរក្សានូវការតាំងសញ្ញារបស់គេជាមួយទ្រង់ ដូចជាក្នុង ចទ ៣២:២២-២៥ សេចក្ដីពន្យល់ពិសេសអំពី "ព្រួញ" របស់ព្រះចំពោះសេចក្ដីជំនុំជម្រះយ៉ាងសំខាន់ ដែលបណ្ដាលឱ្យគេស្លាប់ ក្នុងចំណោមមនុស្សជំនាន់បុរាណ ស្ថិតនៅទិសខាងកើត ដូចជា អំណត់អត់ឃ្លាន ជម្ងឺអាសន្នរោគ ដាវ (គេស្លាប់ដោយសាដៃមនុស្ស) និង សត្វចង្រៃ (មើល ១៤:១២-២១ មើលផងដែរ ៦:១១-១២ ៧:១៥ ១២:១៦ ធៀបនឹង ៣៤:២៥-៣១ មើលផងដែរ យរ ១៤:១២ និងការពន្យល់ ធៀបនឹង វវ ៦:៨) ។

**៥:១៦** *អញនឹងចាត់ប្រើព្រួញរបស់អញ* ភាពព្រៃផ្សៃ ត្រូវបានគេប្រើជាពាក្យប្រៀបធៀបអំពីការជំនុំជម្រះរបស់ព្រះ (មើលការពន្យល់ លក ៩:១៣) ។

## បទទំនាយទាស់នឹងភ្នំស្រុកអ៊ីស្រាអែល

**៦** ១ ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់ខ្ញុំថា ២ កូន
មនុស្សអើយ ចូរដំរង់មុខ[ក] ទៅឯភ្នំ[ខ] ស្រុកអ៊ីស្រាអែល ហើយ
ទាយប្រាប់គេថា[គ] ៣ ម្នាលភ្នំស្រុកអ៊ីស្រាអែលអើយ ចូរ
ស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដល់ទាំងភ្នំធំ ភ្នំតូច ទាំងជ្រោះទឹក និងច្រក
ភ្នំទាំងប៉ុន្មានថា[ឃ] មើល អញ គឺអញនេះហើយនឹងនាំដាវ
មកលើឯងរាល់គ្នា ហើយអញនឹងបំផ្លាញអស់ទាំងទីខ្ពស់
របស់ឯងបង់[ង] ៤ អស់ទាំងអាសនា[ច] របស់ឯងនឹងត្រូវខូច
លាញ ហើយរូបព្រះអាទិត្យរបស់ឯង នឹងត្រូវបាក់បែក
អញនឹងបោះពួកឯង ដែលត្រូវស្លាប់ចុះ នៅមុខរូបព្រះ
របស់ឯង[ឆ] ៥ អញនឹងផ្តេកសាកសពរបស់ពួក កូនចៅ
អ៊ីស្រាអែល នៅមុខរូបព្រះរបស់គេ ហើយនិងកំចាត់
កំចាយឆ្អឹង[ជ] ឯង នៅជុំវិញអាសនារបស់ឯង[ឈ] ៦ នៅអស់
ទាំងទីណាដែលឯងរាល់គ្នាអាស្រ័យនៅ[ញ] នោះទីក្រុង
ទាំងប៉ុន្មាននឹងត្រូវខូចបង់ ហើយអស់ទាំងទីខ្ពស់[ដ] នឹងត្រូវ
ចោលស្ងាត់ ដើម្បីឱ្យអាសនា ទាំងប៉ុន្មានរបស់ឯង ត្រូវ
បំផ្លាញ ហើយនៅស្ងាត់ច្រៀប នឹងឱ្យរូបព្រះ[ឋ] ទាំងប៉ុន្មាន–
របស់ឯងត្រូវបាក់បែក ហើយលែងមានទៀត ព្រមទាំង
ឱ្យរូបព្រះអាទិត្យ[ឌ] របស់ឯងត្រូវកាប់រំលំផង ប្រយោជន៍
ឱ្យស្នាដៃទាំងប៉ុន្មានរបស់ឯងបានសាបសូន្យទៅ[ឍ] ៧ ពួកអ្នក
ដែលត្រូវសំឡាប់[ណ] គេនឹងដួលនៅកណ្តាលឯង នោះឯង
រាល់គ្នានឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ត]។
៨ ប៉ុន្តែអញនឹងឱ្យមានសល់នៅខ្លះ ដើម្បីឱ្យឯងរាល់គ្នា
មានអ្នកខ្លះ ដែលនឹងរួច[ថ] ពីដាវនៅកណ្តាលសាសន៍ដទៃ
ក្នុងកាលដែលឯងរាល់គ្នាត្រូវខ្ចាត់ខ្ចាយទៅ នៅអស់ទាំង
ស្រុក[ទ] ៩ ឯពួកអ្នកដែលរួច គេនឹងនឹកចាំពីអញនៅកណ្តាល
អស់ទាំងសាសន៍ ដែលគេត្រូវដឹកនាំទៅជាឈ្លើយនោះ គឺ
នឹក[ធ] ពីអញ ដែលបានបំបាក់ចិត្ត[ន] កំផិតរបស់គេ ដែលបាន
ប្រាសចេញពីអញទៅ ព្រមទាំងភ្នែកគេ ដែលផិតតាមរូប
ព្រះរបស់ខ្លួនផង[ប] នោះគេនឹងមើលខ្លួន ដោយខ្ពើមឆ្អើម
ព្រោះអំពើអាក្រក់[ផ] ដែលគេបានប្រព្រឹត្ត ក្នុងអស់ទាំងការ
គួរស្អប់ខ្ពើមរបស់គេ[ព] ១០ គេនឹងដឹងថា អញនេះ ជាព្រះ
យេហូវ៉ាពិត[ភ] ហើយដែលអញបានថា នឹងធ្វើការអាក្រក់
ទាំងនេះដល់គេ នោះមិនមែនជាពាក្យលេងទេ[ម]។
១១ ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ចូរ
ទះដៃ ហើយតន្ត្រំជើងចុះ ដោយពាក្យថា វរហើយ ដោយ
ព្រោះការគួរស្អប់ខ្ពើម ដ៏អាក្រក់ របស់ពូជពង្សអ៊ីស្រាអែល
ដ្បិតគេនឹងត្រូវដួលដោយដាវ ដោយអំណត់អត់ ហើយ
ដោយអាសន្នរោគ[យ] ១២ អ្នកណាដែលនៅឆ្ងាយ នឹងស្លាប់
ដោយអាសន្នរោគ អ្នកដែលនៅជិត នឹងស្លាប់ដោយដាវ

**៦:២** ក អគ ៤:៧ ខ អគ ១៨:៦ មីក ៦:១ គ ខ.១៣ **៦:៣** ឃ អគ ៣៦:៤ ង លវ ២៦:៣០ **៦:៤** ច ២រប ១៤:៥ ឆ អគ ៩:៦ ១៤:៣ ២០:១៦ **៦:៥** ជ ជន ១៩:១៦ ទដ ៥៣:៥ យរ ៨:១–២ ឋ ខ.១៣ លវ ២៦:៣០ **៦:៦** ញ នក ១២:២០ ដ ហស ១០:៨ ឋ អគ ៣០:១៣ មីក ១:៧ សក ១៣:២ ឌ លវ ២៦:៣០ ធ ១សយ ៥:៤ អស ៦:១១ អគ ៥:១៤ **៦:៧** ទ អគ ៩:៧ ណ ខ. ១០,១៣,១៤ អគ ១១:១០១២ **៦:៨** ត ទដ ៦៨:២០ រយ ៤៤:២៨ ប លប ១១:៤ ទដ ៤៤:១១ អស ៦:១៣ យរ ៤៤:១៤ អគ ៧:១៦ ១២:១៦ ១៤:២២ **៦:៩** ថ ទដ ១៣៧:៦ សក ១០:៩ ទ អស ៧:១៣ យរ ៨:២១ ធ នក ២២:២០ អគ ២០:៧,២៤ មីក ៥:១៣ ន នក ៣២:២២ ប យប ៤២:៦ អគ ២០:៤៣ ២៣:១៤–១៦ ៣៦:៣១ **៦:១០** ផ ខ. ៧ ម ចទ ២៨:៥២ យរ ៤០:២ **៦:១១** យ យរ ៤២:២២ អគ ២១:១៤,១៧ ២២:១៣ ២៥:៦

**៦:១–១៤** ក្រោយពីការថ្លែងប្រកាស អំពីការជំនុំជម្រះមកលើទីក្រុងយេរូសាឡិម (ជំពូក ៤៥) ។ លោកអេសេគាលបានបង្ហាត់បង្រៀន ដើម្បីថ្លែងពីការជំនុំជម្រះទៅលើទឹកដីទាំងមូល និងភ្នំទាំងឡាយរបស់អ៊ីស្រាអែល គឺជាការជំនុំជម្រះយ៉ាងធ្ងន់ធ្ងរមកលើផលដំណាំ និងតំបន់នៅចំកណ្តាលទីខ្ពស់ទាំងប៉ុន្មាន (សូមមើល ទដ ១០៤:១៣–១៥ និងមើលការពន្យល់) នេះគឺជាមេរៀនមួយសំខាន់បំផុត ដែលបានផ្តល់ដល់ពួកសាសន៍ដទៃដែលថ្វាយបង្គំដល់ព្រះបាល ។ ការជំនុំជម្រះរបស់លោកអេសេគាលនេះគឺជាការប្រកាសឱ្យបានឮសព្វទិសទី លវ ២៦:២៧–៣៩ ។

**៦:៣** *អស់ទាំងទីខ្ពស់* គឺជាច្រកទ្វារធំក្នុងព្រះវិហារនៃសាសនាកាណានដែលបានទទួលទណ្ឌកម្មទាំងស្រុងក្នុងព្រះគម្ពីរសញ្ញាចាស់ ។ អស់ទាំងអាសនា គឺសំដៅទៅលើទីកន្លែងបូជាទាំងអស់ដូចជាការដុតគ្រឿងក្រអូប ដើម្បីបូជាដល់រូបព្រះទាំងឡាយ (ខ.៤) ដូចជាតួរមានជីវិតទាំងបួន ដែលបានកត់ចុះនៅក្នុងបញ្ជី (សូមមើលការពន្យល់ ១:៥) ។

**៦:៤** *អស់ទាំងអាសនា* អាសនាទាំងនេះធ្វើឡើងដោយដុតដីឥដ្ឋដែលមានកំពស់ ០.៧ ម៉ែត្រជាធម្មតាគេបានចាររវាដូចជារូបសត្វ និងរូបចម្លាក់ទាំងអស់នៃព្រះ ព្រមទាំងរូបព្រះជាច្រើនរបស់សាសន៍កាណាន ។ ពាក្យនៅក្នុងព្រះគម្ពីរជាភាសាហេព្រើរ គឺជាការចំអកមើលងាយជាទីបំផុត (សូមមើលការពន្យល់ លវ ២៦:៣០) ជាពិសេសលោកអេសេគាលបានប្រើ (៣៨ ដងគឺបានជិទាស់ ហើយ៩ដងគត់នៅកន្លែងផ្សេងទៀតក្នុងគម្ពីរសញ្ញាចាស់) ។

**៦:៧** *ឯងរាល់គ្នានិងដឹងថា អញនេះជាព្រះយេហូវ៉ាពិត* នេះជាព្រះបន្ទូលដែលបានបញ្ជាក់ថាព្រះទ្រង់មានអនុភាពរាល់កិច្ចការជាច្រើន នៅក្នុងប្រវត្តិសាស្ត្រ(ការដោះស្រាយរបស់ទ្រង់ សម្រាប់ប្រជាជនអ៊ីស្រាអែលជាមួយនឹងការជំនុំជម្រះដល់ពួកគេ ហើយរំដោះបាបគេឱ្យមានជីវិតរស់នៅជាមួយទ្រង់នៅក្នុងចំណោមជាតិសាសន៍ទាំងឡាយ) ហើយជាលទ្ធផលក្នុងការរស់នៅរបស់ជាតិសាសន៍ទាំងអស់ ដើម្បីឱ្យពួកគេបានស្គាល់ពីអំណាចព្រះចេស្តារបស់ទ្រង់ដោយសារការជំនុំជម្រះដល់ពួកអ៊ីស្រាអែល ជំពូក ៦–៣៩ (មើលការបង្ហាញ និងមើលសាច់រឿងដែរ ៥:១៣ និងការពន្យល់) ។

**៦:៩** *ដែលគេត្រូវដឹកនាំទៅជាឈ្លើយគឺនឹកចាំពីអញ* នេះជាលទ្ធផលដ៏ត្រឹមត្រូវដែលព្រះជំនុំជម្រះដោយសុចរិត និងធ្ងន់ធ្ងរបំផុត (មើល ខ:១០) ។ ពួកគេមានចិត្តផិតក្បត់ និងមានតណ្ហាឈ្លក់វង្វេងបន្ទាប់ពីពួកគេថ្វាយបង្គំដល់រូបព្រះផ្សេងៗ ។ សូមមើល ឧទាហរណ៍ ៣៤:១៥ ហើយនិងការពន្យល់ ។

**៦:១១** *ចូរទះដៃហើយតន្ត្រំជើងចុះ* ព្រះបន្ទូលរបស់ទ្រង់បានបង្គាប់ទៅលោកអេសេគាល គឺដើម្បីជំនុំជម្រះដល់ពួកគេតាមការប្រព្រឹត្តរៀងខ្លួន ។ (សូមមើល ២១:១៤៤ មានរបៀបនឹងកិច្ចការជាច្រើនដែលប្រជារាស្ត្រអ៊ីស្រាអែលទាំងឡាយបានតាំងចិត្តតាំងចំពោះខ្មាំងសត្រូវ នៅក្នុង ២៥:៦ ។ *ដាវសេចក្តីអំណត់ និងមានអាសន្នរោគ* (មើល ៥:១៦–១៧) និងការពន្យល់ ។

ហើយពួកសល់នៅក្នុងទីក្រុង ដែលត្រូវគេឡោមព័ទ្ធ នោះ
នឹងស្លាប់ដោយអំណត់អត់វិញ គឺយ៉ាងនោះដែលអញនឹង
សំរេចសេចក្ដីក្រោធ[រ]របស់អញដល់គេ[ល] ១៣ឯងរាល់
គ្នានឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុងកាលដែល
ពួកអ្នក ដែលត្រូវគេសំឡាប់ បានដេករណែលកណ្ដាល
អស់ទាំងរូបព្រះរបស់ខ្លួន[វ] នៅជុំវិញអាសនា លើគ្រប់ទាំង
ទួលខ្ពស់ គ្រប់ទាំងកំពូលភ្នំ នៅក្រោមគ្រប់ទាំងដើមឈើ
ខៀវខ្ចី និងនៅក្រោម គ្រប់ទាំងដើមម៉ៃសាក់ញឹកស្និត[ស]
ជាកន្លែងដែល គេបានដុតគ្រឿងក្រអូប ថ្វាយដល់រូបព្រះ
ទាំងប៉ុន្មានរបស់គេ[ហ] ១៤អញនឹងលូកដៃ[ឡ]ទៅលើគេ នឹង
ធ្វើឱ្យស្រុកគេត្រូវខូចបង់ ហើយស្ងាត់ច្រៀប លើសជាង
ទីរហោស្ថានដែល នៅខាងឌីបឡាទៅទៀត គឺនៅគ្រប់ទាំង
ទីកន្លែងណា ដែលគេអាស្រ័យនៅផង នោះគេនឹងដឹងថា
អញនេះ ជាព្រះយេហូវ៉ាពិត[អ] ។

**ទីបញ្ចប់បានមកដល់**

**៧** ១ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់ខ្ញុំថា ២ឱកូន
មនុស្សអើយ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលនឹងស្រុក
អ៊ីស្រាអែលដូច្នេះថា ដល់កំណត់ហើយ គឺដល់ចុងបំផុត[ក]
នៃស្រុកទាំង៤ទិស[ខ]ហើយ ៣ពេលនេះជាចុងបំផុតរបស់
ឯងពិត អញនឹងចាត់សេចក្ដីកំហឹងរបស់អញ ទៅលើឯង
ហើយនឹងជំនុំជំរះឯង តាមគ្រប់ទាំងអំពើ[គ]របស់ឯង ព្រម
ទាំងទំលាក់អស់ទាំងអំពើគួរស្អប់ខ្ពើមរបស់ឯង មកលើឯង
ផង[ឃ] ៤ភ្នែកអញនឹងមិនប្រណី ឬអាណិតមេត្តា[ង] ដល់ឯង
ឡើយ គឺអញនឹងទំលាក់អស់ទាំងអំពើរបស់ឯង នោះអស់
ទាំងរបស់គួរស្អប់ខ្ពើមរបស់ឯង នឹងនៅកណ្ដាលឯងហើយ
ដូច្នេះ ឯងនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ច] ។
៥ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មាន
ការអាក្រក់ គឺការអាក្រក់តែ១[ឆ] មើល ការនោះកំពុងតែ
មកហើយ ៦ដល់ចុងបំផុត[ជ]ហើយ ចុងបំផុតបានមកដល់
គឺបានភ្ញាក់ឡើងមកទាស់នឹងឯង មើលន៎ កំពុងតែមក ហើយ
៧ឱអ្នកស្រុកអើយ កំណត់ឯងបានមកដល់ហើយ ពេលក៏បាន
មក ថ្ងៃនោះជិតដល់ គឺជាថ្ងៃ[ឈ]ដែលឮសូរអឺងកង[ញ] មិន
មែនជាសូរសំរែកដោយអំណរនៅលើភ្នំទេ ៨ឥឡូវនេះ
អញហៀបនឹងចាក់សេចក្ដីក្រោធ[ដ]របស់អញទៅលើឯង
ហើយនិងសំរេចសេចក្ដីកំហឹងរបស់អញដល់ឯង អញនឹង
ជំនុំជំរះឯងតាមអំពើដែលឯងប្រព្រឹត្ត ហើយនិងទំលាក់
អស់ទាំងអំពើគួរស្អប់ខ្ពើមរបស់ឯងទៅលើឯងផង[ឋ] ៩ភ្នែក
អញនឹងមិនប្រណីឡើយ អញក៏មិនអាណិតមេត្តាដល់ឯង
ដែរ[ឌ] អញនឹងសងឯងតាមអំពើដែលឯងប្រព្រឹត្ត ហើយ
របស់គួរស្អប់ខ្ពើម ទាំងប៉ុន្មានរបស់ឯង នឹងនៅកណ្ដាល
ឯងដែរ[ឍ] នោះឯងរាល់គ្នា នឹងដឹងថា គឺអញនេះហើយ
ជាព្រះយេហូវ៉ាដែលវាយឯងពិត[ណ] ។
១០មើលន៎ ថ្ងៃដល់ហើយ មើល កំពុងតែមកកំណត់
បានចេញបំព្រាងមកហើយ ឯដំបង[ត] បានបែកផ្កា សេចក្ដី
អំនួតបានបុិចឡើង ១១សេចក្ដីច្រឡោត[ថ]បានដុះឡើងជា
ដំបងនៃសេចក្ដីអាក្រក់ ឥតមានពួកគេណា ឬពួកទំពកក
កុញរបស់គេ ឬទ្រព្យសម្បត្តិរបស់គេណាបានរួចឡើយ
ក៏នឹងគ្មានអ្នកណាសោកស្រណោះដល់គេដែរ[ទ] ១២ពេល
វេលាបានមកដល់ ថ្ងៃកាន់តែជិតហើយ កុំបីឱ្យអ្នកដែល
ទទួលបញ្ចាំ[ធ] បានអរសប្បាយ ឬអ្នកដែលលក់ បញ្ចាំឱ្យគេ
បានស្តាយឡើយ ដ្បិតសេចក្ដីក្រោធបានមកលើអស់ទាំង
ពួកកកកុញនេះហើយ[ន] ១៣ឯអ្នកដែលបញ្ចាំ ទោះបើបាន
គង់ជីវិតនៅក៏ដោយ គង់តែមិនត្រឡប់ទៅឯធនធានដែល
បានបញ្ចាំវិញនោះទេ ដ្បិតការជាក់ស្តែង នេះដំរូវលើជន
ជាតិទាំងអស់គ្នា នឹងគ្មានណាមួយវិលមកវិញឡើយ ក៏ឥត

**៦:១២** រ យប ២០:២៣ ល អគ ៥:១២ ៧:១៥ **៦:១៣** វ លវ ២៦:៣០ ស អស ១:២៩ ហ ១ពវ ១៤:២៣ យរ ២:២០ អគ ១៨:៦ ២០:២៨ ហស ៤:១៣ **៦:១៤** ឡ នក ៧:៥ យប ៣០:២១ យរ ៦:១២ ១៥:២៥ អគ ២០:៣៤ អ អគ ១២:១៩ ១៤:១៣ **៧:២** ក អម ៨:២,១០ ខ វវ ៧:១ ២០:៨ **៧:៣** គ អគ ១៨:៣០ ឃ លប ៦:១៣ **៧:៤** ង យរ ១៣:១៤ អគ ៥:១១ ច អគ ៥:១១ ២៣:៤៩ **៧:៥** ឆ ២ពវ ២១:១២ **៧:៦** ជ អគ ៣៩:៨ **៧:៧** ឈ យប ១៨:២០ អស ២:១២ អម ៥:១៨–២០ ញ អគ ១២:២៣ ៣០:៣ សផ ១:១៤ មឡ ៣:២ **៧:៨** ដ អស ៤២:២៥ អគ ៩:៨ ១៤:១៩ ២២:២២ ហស ៥:១០ ណហ ១:៦ ឋ អគ ២០:៨,២១ ៣៦:១៩ **៧:៩** ឌ យរ ២១:៧ អគ ៥:១១ ឍ អគ ២២:៣១ ណ ចទ ៣២:៣៥ ទដ ៣៩:១០ អស ៩:១៣ **៧:១០** ត ទដ ៨៩:៣២ អស ១០:៥ **៧:១១** ថ ទដ ៥៥:៩ អស ៥៨:៤ ទ យរ ១៦:៦ សផ ១:១៨ **៧:១២** ធ អស ២៤:២ ន ខ.៧ អស ៥:១៣–១៤ អគ ៣០:៣

**៦:១៤** *អញនិងលូកដៃទៅលើគេ* បង្ហាញឱ្យឃើញជាទូទៅនៅក្នុងអេសេគាល (មើល ១៤:៩,១៣ ១៦:២៧ ២៥:៧ ៣៥:៣) ។

**៧:១–២៧** ព្រះបន្ទូលនៃព្រះ បានជំនុំជម្រះមកលើទីខ្ពស់ទាំងប៉ុន្មានរបស់អ៊ីស្រាអែល (សូមមើល ៦:២ មើល ជំពូក ៦ ហើយនិងការពន្យល់នៅក្នុង ៦:១–១៤) គឺបានបរិយាយយ៉ាងល្អិតល្អន់អំពីការអាក្រក់របស់ពួកគេ ប៉ុន្តែព្រះទ្រង់មានព្រះហឫទ័យអត់ធ្មត់ ចំពោះចិត្តរឹងរូសនិងការបះបោររបស់ប្រជារាស្ត្រអ៊ីស្រាអែល រហូតទាល់តែការអាក្រក់ទាំងអស់នេះបានចេញបាត់ពីពួកគេ "ចុងបំផុតហើយទីបំផុតបានមកដល់" (ខ.២ សូមមើល ខ.៣, ៦,២៤ សូមមើល យរ ៥១:១៣ បទ ៤:១៨ អម ៧:៨ ៨:២) ។

**៧:៧** *ថ្ងៃ* "ថ្ងៃនៃសេចក្ដីក្រោធរបស់ព្រះអម្ចាស់" (ខ.១៩) ពោល គឺជាថ្ងៃជំនុំជម្រះនៅពេលដែលព្រះអម្ចាស់យាងចុះមក និងជំនុំជម្រះដោយសេចក្ដីសុចរិតហើយសេចក្ដីក្រោធនៃព្រះ បានមកលើប្រជារាស្ត្ររបស់ទ្រង់ (នៅក្នុងព្រះអេសេគាល ប្រហែលជាបានផ្សព្វផ្សាយឱ្យដឹងជាមុនថា "ថ្ងៃនៃព្រះអម្ចាស់" ដែលហោរាជាច្រើនបានថ្លែងទំនាយ (សូមមើល អម ៥:១៨ និងការពន្យល់) ។ ភ័យស្លន់ស្លោគ្មានសន្តិភាព ធៀបនឹង អម ៥:២០ (សេចក្ដីងងឹតគ្មានពន្លឺ) ។

**៧:៨** *ចាក់សេចក្ដីក្រោធរបស់អញ* (បង្ហាញឱ្យឃើញជាទូទៅនៅក្នុង អគ (សូមមើល ៩:៨ ១៤:១៩ ២០:៨,១៣,២១ ២២:៣១ ៣០:១៥ ៣៦:១៨ ។

**៧:១២** *កុំបីឱ្យអ្នកដែលទទួលបញ្ចាំបានអរសប្បាយ* នៅត្រង់វគ្គនេះស្រដៀងនិងពាក្យដំបូន្មានរបស់ព្រះយេស៊ូវ (សូមមើល មថ ២៤:១៧–១៨) ។

មានអ្នកណាអាចឱ្យជីវិតខ្លួនស្ថិតស្ថេរនៅ ដោយអំពើទុច្ចរិតបានដែរ[ប]។

១៤ គេបានផ្លុំត្រែ[ផ] ហើយទាំងអស់បានរៀបជាស្រេច តែគ្មានអ្នកណាចេញទៅតស៊ូឡើយ ដ្បិតសេចក្ដីក្រោធ[ព] របស់អញ គ្របសង្កត់លើពួកទំពកកកុញរបស់គេទាំងអស់ ១៥ ឯខាងក្រៅ មានដាវ ហើយខាងក្នុង មានអាសន្នរោគ និងអំណត់អត់ អ្នកណាដែលនៅឯវាល នឹងត្រូវស្លាប់ដោយដាវ ហើយអ្នកដែលនៅក្នុងទីក្រុង នោះអំណត់អត់ និងអាសន្នរោគនឹងលេបគេទៅ[ភ] ១៦ តែពួកណាដែលរត់រួចបាន នោះនឹងរួចជីវិត[ម] ហើយនិងនៅលើភ្នំដូចជាព្រាប[យ] នៃច្រកភ្នំ គ្រប់គ្នាកំពុងតែយំថ្ងូរ ដោយព្រោះអំពើទុច្ចរិតរបស់រៀងខ្លួន[រ] ១៧ មនុស្សទាំងអស់នឹងខ្សោយដៃ[ល] ហើយជង្គង់គ្រប់គ្នានឹងទន់ដូចជាទឹក[វ] ១៨ គេនឹងស្លៀកសំពត់ធ្មៃ[ស] ហើយនិងមានសេចក្ដីស្ញែងខ្លាចហ៊ុមហាគេ[ហ] មុខគេទាំងអស់នឹងមានសេចក្ដីខ្មាស ហើយគេនឹងកោរសក់គ្រប់គ្នា[ឡ] ១៩ គេនឹងបោះចោលប្រាក់របស់គេទៅក្នុងផ្លូវ[អ] ហើយមាសគេនឹងទុកដូចជារបស់មិនស្អាត អស់ទាំងប្រាក់និងមាសរបស់គេនឹងជួយឱ្យគេរួច នៅថ្ងៃនៃសេចក្ដីក្រោធរបស់ព្រះយេហូវ៉ា[ក]មិនបាន គេនឹងមិនស្កប់ចិត្ត[ខ]ឡើយ ក៏មិនបានឆ្អែតពោះ ដោយរបស់នោះដែរ ពីព្រោះគឺរបស់នោះឯងដែលនាំឱ្យគេចំពប់ដួល[គ]ទៅក្នុងអំពើទុច្ចរិតរបស់ខ្លួន[ឃ] ២០ ឯគ្រឿងដ៏លំអរបស់គេ នោះទ្រង់បានតាំងឡើងឱ្យមានសេចក្ដីរុងរឿង តែគេបានធ្វើ[ង]រូប នៃអស់ទាំងរបស់គួរស្អប់ខ្ពើម និងរបស់គួរឆ្អើមរបស់គេ[ច] នៅក្នុងទីនោះវិញ បានជាអញធ្វើឱ្យត្រឡប់ដូចជា របស់ស្មោកគ្រោកដល់គេ[ឆ] ២១ អញនឹងប្រគល់ទៅក្នុងកណ្ដាប់ដៃ នៃសាសន៍ដទៃទុកជារំពា[ជ] និងដល់ពួកអាក្រក់នៅផែនដីទុកជារបឹប ហើយពួកនោះនឹងធ្វើបង្អាប់ទៅ[ឈ] ២២ អញនឹងបែរមុខ[ញ]ចេញពីគេ ហើយគេនឹងបង្អាប់ទីកំបាំងរបស់អញដែរ និងមានពួកចោរចូលទៅធ្វើបង្អាប់ទីនោះ[ដ] ។

២៣ ចូរធ្វើច្រវាក់ចុះ ពីព្រោះស្រុកនេះមានពេញដោយទោសជាកំចាយឈាម[ឋ] ហើយទីក្រុងក៏មានពេញដោយសេចក្ដីច្រឡោត[ឌ] ២៤ ដូច្នេះ អញនឹងនាំសាសន៍ដែលកាចអាក្រក់បំផុតឱ្យមក សាសន៍នោះនឹងចាប់យកផ្ទះសំបែងរបស់គេបាន អញនឹងបំបាត់សេចក្ដីអំនួតរបស់មនុស្សខ្លាំងពូកែដែរ ហើយទីបរិសុទ្ធ[ឍ]ទាំងប៉ុន្មានរបស់គេ នឹងត្រូវអាប់ឱនចុះ[ណ] ២៥ មានការបំផ្លាញមក នោះគេនឹងស្វែងរកសេចក្ដីសុខសាន្ត តែនឹងគ្មានសោះ[ត] ២៦ សេចក្ដីវិនាស[ថ] នឹងមកខ្ទាន់ៗ ហើយនិងឮដំណឹងមកផ្ទួនៗ នោះគេនឹងស្វែងរកការជាក់ស្តែងពីពួកហោរា[ទ] ប៉ុន្តែក្រិត្យវិន័យនឹងវិនាស បាត់ពីពួកសង្ឃ ហើយសេចក្ដីប្រឹក្សាពីពួកចាស់ទុំទៅដែរ[ធ] ២៧ ឯស្តេច ទ្រង់នឹងទួញពិលាប ហើយពួកចៅហ្វាយនឹងប្រដាប់ខ្លួនដោយសេចក្ដីស្រឡាំងកាំង[ន] ឯដៃនៃប្រជាជននៅក្នុងស្រុក នោះនឹងត្រូវញ័ររន្ធត់ អញនឹងធ្វើដល់គេតាមអំពើដែលគេប្រព្រឹត្ត[ប] ហើយនិងជំនុំជំរះគេ តាមគួរនិងទោសរបស់គេ នោះគេនឹងដឹងថា អញនេះហើយជាព្រះយេហូវ៉ាពិត[ផ]។

**៧:១៣** ប លវ ២៥:២៤–២៨ **៧:១៤** ផ យបប ៣៩:២៤ ព យរ ២៥:៣៨ **៧:១៥** ភ ចទ ៣២:២៥ យរ ១៤:១៨ លវ ១:២០ អគ ៥:១២ ៣៣:២៧ **៧:១៦** ម អស ១០:២០ យរ ៤១:១៦ ៤២:១៧ យ លប ៨:៨ អស ៥៩:១១ រ អគ ៩:១៥ យរ ៨:១៩ អគ ៦:៨ **៧:១៧** ល ២ពវ ១៩:២៦ យរ ៤៧:៣ អគ ២១:៧ ២២:១៤ វ ដយ ៥:៦ **៧:១៨** ស យរ ៤:៨ ៤៨:៣៧ ៤៩:៣ ហ ទដ ៥៥:៥ ឡ អស ១៥:២–៣ អគ ២៧:៣១ អម ៨:១០ **៧:១៩** អ បទ ៤:១ ក អស ៤២:២៥ អគ ១៣:៥ ៣០:៣ យអ ១:១៥ ២:១ សផ ១:៧,១៨ ២:២ ខ អស ៥៥:២ គ អគ ៣:២០ ១៤:៣ ហស ៤:៥ ឃ សភ ១១:៤ **៧:២០** ង យរ ១០:៣ ច អគ ៥:១១ ឆ អស ២:២០ ៣០:២២ អគ ១៦:១៧ **៧:២១** ជ ជន ១៤:៣ ឈ ២ពវ ២៤:១៣ **៧:២២** ញ យរ ២:២៧ អគ ៣៩:២៣–២៤ ដ ទដ ៧៤:៧–៨ យរ ១៩:១៣ បទ ២:៧ **៧:២៣** ឋ ២ពវ ២១:១៦ អស ១:១៥ អឡ ២២:៩ ឌ លប ៦:១១ អគ ១១:៦ **៧:២៤** ឍ បទ ២:៧ អគ ២៤:២១ ណ ២របា ៧:២០ អគ ២៨:៧ **៧:២៥** ត យរ ៦:១៤ ៨:១១ អគ ១៣:១០,១៦ **៧:២៦** ថ ចទ ២៩:២១ ៣១:១៧ ទ ១សយ ៣:១ ធ អស ៤៧:១១ យរ ១៨:១៨ អគ ២០:១–៣ អម ៨:១១ មីក ៣:៦ **៧:២៧** ន ទដ ១០៩:១៩ អគ ២៦:១៦ ប អស ៣:១១ អគ ១៨:២០ ផ ខ.៤

**៧:១៥** *មានដាវ . . . មានអាសន្នរោគ និងអំណត់អត់* សូមមើល ៥:៦–១៧ និងការពន្យល់ ។

**៧:១៧** *ហើយជង្គង់គ្រប់គ្នានឹងទន់ដូចជាទឹក* ឬ "គ្រប់ទាំងជង្គង់នឹងទទឹកដោយទឹកនោម" ។

**៧:១៨** *គេនិងស្លៀកសំពត់ធ្មៃ . . . ហើយគេនឹងកោរសក់* គឺសម្គាល់ពីការកាន់ទុក្ខ (សូមមើល លប ៣៧:៣៤ យប១:២០ អស ១៥:២ វវ ១១:៣ និងការពន្យល់ដ៏ទៃទៀត) ។

**៧:១៩** *គេនឹងបោះចោលប្រាក់របស់គេ* សូមមើល អស ២:២០ ។

**៧:២០** *គ្រឿងដ៏លំអរ* សូមមើល នក ៣២:២–៤ ។

**៧:២២** *ទីកំបាំងរបស់អញ* គឺជាព្រះវិហារយេរូសាឡិម ។

**៧:២៣** *ពេញដោយទោសកំចាយឈាម...សេចក្ដីច្រឡោត* សូមមើល ៩:៩ ១១:៦ ១២:១៩ សូមមើល ២ពវ ២១:១៦ ២៤:៤ យរ ១៩:៤ ២២:១៧ បទ ៤:១៣ មីក ៣:១០ ហព ១:២–៤ ធៀបនឹង ហព ២:៨,១២,១៧ ។

**៧:២៤** *សេចក្ដីអំនួតរបស់មនុស្សខ្លាំងពូកែ* ព្រះវិហារយេរូសាឡិមបានរៀបរាប់ដោយសារពាក្យនៃ "សេចក្ដីអំនួត" (ដូចនៅក្នុង ២៤:២១ ៣៣:៣៨) ។

**៧:២៦** *ពួកហោរា . . . ពួកសង្ឃ . . . ពួកចាស់ទុំ* បានធ្វើការបដិសេធន៍ចំពោះការដឹកនាំអំពីព្រះ និងបដិសេធន៍ចំពោះការគ្រប់គ្រងរបស់ពួកចាស់ទុំ (១សយ ២៨:៦ អម ៨:១១–១២ និងការពន្យល់នៅ ៨:១១ មីក ៣:៦–៧ សូមមើលផងដែរ យរ ១៨:១៨ និងការពន្យល់) ។

**៧:២៧** *ស្តេច . . . ពួកចៅហ្វាយ* មុខងារទាំងពីរនៅទីនេះប្រហែលជាសំដៅទៅលើមនុស្សដូចគ្នា គឺស្តេចយេហូយ៉ាគីម ។ *ប្រដាប់ខ្លួនដោយ* មើលការពន្យល់នៅ ទដ ១០៩:២៩ ។ *ប្រជាជននៅក្នុងស្រុក* ពេញដោយប្រជាពលរដ្ឋនៃសាសន៍យូដា (ទីដីទាំងឡាយ គឺបានជាមរតក និងជាកម្មសិទ្ធិគ្រួសារ ហើយជាកម្មសិទ្ធិអ្នកបម្រើក្នុងកងទ័ព មើល ១២:១៩ ៤៥:១៦,២២

## ការថ្វាយបង្គំរូបព្រះ នៅក្នុងព្រះវិហារ

**៨** ១នៅថ្ងៃ៥ខែភទ្របទ ក្នុងឆ្នាំទី៦ កាលខ្ញុំកំពុងអង្គុយ
នៅក្នុងផ្ទះខ្ញុំ មានទាំងពួកចាស់ទុំ[ក]សាសន៍យូដាអង្គុយនៅ
មុខ[ខ]ផង នោះព្រះហស្តនៃព្រះអម្ចាស់យេហូវ៉ាក៏សណ្ឋិត
លើខ្ញុំ[គ] ២ខ្ញុំក៏មើលទៅឃើញភាពរូបមានសណ្ឋានដូចជា
ភ្លើង ពីសណ្ឋានចង្កេះទៅក្រោម នោះសុទ្ធតែជាភ្លើង
ហើយពីចង្កេះទៅខាងលើ នោះមើលទៅដូចជាពន្លឺចាំង
គឺដូចជាលង្ហិនខាត់យ៉ាងភ្លឺ[ឃ] ៣ទ្រង់ក៏លូកចេញមក មានរាង
ដូចជាដៃ[ង] ចាប់សក់ក្បាលខ្ញុំ រួចព្រះវិញ្ញាណទ្រង់លើកខ្ញុំ
ឡើង[ច]ទៅកណ្តាលមេឃ ហើយនិងដី ក៏នាំខ្ញុំទៅឯក្រុង
យេរូសាឡិម ដោយការជាក់ស្តែង[ឆ]នៃព្រះ គឺទៅដល់មាត់
ទ្វារនៃទីលានខាងក្នុង[ជ] ដែលបើកទៅទិសខាងជើង ជា
កន្លែងមានរូបនៃសេចក្តីប្រចណ្ឌ[ឈ] ដែលបណ្តាលឱ្យ
ប្រចណ្ឌ ៤នៅទីនោះ ឃើញមានសិរីល្អ[ញ]នៃព្រះរបស់
សាសន៍អ៊ីស្រាអែល ដូចជាការជាក់ស្តែង ដែលខ្ញុំបាន
ឃើញ នៅឯវាលពីមុននោះ[ដ]។

៥នោះទ្រង់មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ ចូរ
ងើបភ្នែកឡើង មើលទៅទិសខាងជើងឥឡូវ ដូច្នេះ ខ្ញុំក៏
ងើបភ្នែកឡើងមើលទៅខាងជើងទៅ នោះខាងជើងទ្វារ
ដែលចូលទៅឯអាសនា ឃើញមានរូប[ឋ] នៃសេចក្តីប្រចណ្ឌ
នៅទីនោះ ៦ទ្រង់ក៏មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ
ឯងឃើញការដែលគេប្រព្រឹត្តឬទេ គឺជាការគួរស្អប់ខ្ពើម
យ៉ាងសំបើម[ឌ] ដែលពូជពង្សអ៊ីស្រាអែលធ្វើនៅទីនេះ
ដើម្បីឱ្យអញបានឃ្លាតចេញ ឆ្ងាយពីទីបរិសុទ្ធរបស់អញ[ឍ]
តែចាំមើល ឯងនឹងឃើញការគួរស្អប់ខ្ពើម យ៉ាងសំបើម
ជាទៅទៀត ។

៧គ្រានោះ ទ្រង់នាំខ្ញុំទៅដល់ទ្វារទីលាន កាលខ្ញុំបាន
ក្រឡេកមើលទៅ នោះឃើញមានប្រហោង១ក្នុងកំផែង
៨រួចទ្រង់មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ ចូរជីកទៅ
ក្នុងកំផែងឥឡូវ កាលខ្ញុំបានជីកក្នុងកំផែងហើយ នោះ
ឃើញមានទ្វារ១ ៩ទ្រង់មានបន្ទូលមកខ្ញុំថា ចូរឱ្យឯងចូល
ទៅខាងក្នុង មើលការគួរស្អប់ខ្ពើម យ៉ាងអាក្រក់ ដែល
គេធ្វើនៅទីនេះ ១០ដូច្នេះ ខ្ញុំក៏ចូលទៅមើល ហើយឃើញ
មានគំនូរគ្រប់ទាំងសត្វលូនវា សត្វគួរខ្ពើមឆ្អើម[ណ] និងអស់
ទាំងរូបព្រះ របស់ពូជពង្សសាសន៍អ៊ីស្រាអែល[ត] ដែលគេគូរ
នៅជញ្ជាំង[ថ]ជុំវិញ ១១ក៏មានពួកចាស់ទុំ[ទ]នៃពួកអ៊ីស្រាអែល
៧០នាក់ ឈរនៅមុខរូបទាំងនោះ ហើយមានយ៉ាសានាជា

**៨:១** ក ២ពវ ៦:៣២ អគ ១៤:១ ខ អគ ៣៣:៣១ គ អគ ១:១–៣ ២៤:១ ៤០:១
**៨:២** ឃ អគ ១:៤,២៦–២៧
**៨:៣** ង អគ ២:៩ ច អគ ៣:១២ ១១:១ ឆ អគ ២៤:១០ ជ ខ.១៦ ឈ ខ.៥ និ ២០:៥ ចទ ៣២:១៦
**៨:៤** ញ នក ២៤:១៦ ដ អគ ៣:២២
**៨:៥** ឋ ទដ ៧៨:៥៨ យរ ៤:១ ៣២:៣៤
**៨:៦** ឌ ទដ ៧៨:៦០ អគ ៥:១១ ឍ ហស ៥:៦
**៨:១០** ណ យរ ៤៤:៤ ត នក ២០:៤ ចទ ៤:១៥–១៨ យរ ១៦:១៨ អគ ១១:១២ ថ ពច ១៧:៤–៥ អគ ២៣:១៤ **៨:១១** ២៣:១៤

៤៦:៣) ។

**៨:១–១១:២៥** មានការបើកសម្តែង ៦យ៉ាង (១).ព្រះទ្រង់បង្ហាញឱ្យលោកអេសេគាលឃើញមានការថ្វាយបង្គំរូបព្រះ យ៉ាងប៉ិនប្រសប់នៅក្នុងព្រះវិហារយេរូសារឡិម (ជំពូក ៨) ។ (២).ព្រះទ្រង់ប្រកាសពីការជំនុំជម្រះដល់ពួកអ្នកដែលថ្វាយបង្គំរូបព្រះនៅទីនោះ (ជំពូក ៩) ។ (៣).ព្រះទ្រង់បានបង្ហាញឱ្យលោកអេសេគាលបានឃើញសិរីល្អរបស់ព្រះ លិចមកនៅផ្នែកខាងលើនៃព្រះវិហារ (ជំពូក ១០) ។ (៤).ព្រះទ្រង់បានថ្លែងប្រកាស និងសព្វព្រះទ័យចំពោះក្រុងយេរូសាឡិម ដោយគេចចេញពីការជំនុំជម្រះរបស់ទ្រង់ (១១:១–១៣) ។ (៥).ព្រះទ្រង់សន្យាថា និងនិរទេសចំពោះអ្នកទាំងឡាយដែលស្នាក់នៅក្នុងក្រុងយេរូសាឡិមត្រូវបានលប់ចោល ហើយនិងបានសាងសង់ទីក្រុងនោះឡើងវិញ ។ (១១:១៤–២១) និង (៦).ការបញ្ចប់នៃការនិម្មិត (១១:២២–២៥) ។

**៨:១–៨** លោកអេសេគាលបានឃើញការបើកសម្តែង៤យ៉ាង នៃការបូជាថ្វាយបង្គំដល់រូបព្រះជាច្រើន ដែលបានញួរនៅក្នុងដំណាក់នៃព្រះអម្ចាស់ គឺ (១).“រូបនៃសេចក្តីប្រចណ្ឌ”(ខ.៥) ។ (២).“រូបគំនូរគ្រប់ទាំងសត្វលូនវា និងសត្វគួរខ្ពើមឆ្អើម”(ខ.១០) ។(៣).“អង្គុយយំនិងព្រះថាមូស”(ខ.១៤) ។ (៤).“ថ្វាយបង្គំព្រះអាទិត្យ”(ខ.១៦) ។

**៨:១** *នៅថ្ងៃទី៥ខែភទ្របទ ក្នុងឆ្នាំទី៦* ថ្ងៃទី ១៧ ខែ កញ្ញា ៥៩២ មុន គ.ស ទី២គឺចំនួន១៣ថ្ងៃនៃលោកអេសេគាល ដូចនៅ ១:២ និង ៤០:១ ការបង្ហាញការនិម្មិតការអង្គុយក្នុងផ្ទះ ។ ការដឹកនាំទៅជាឈ្លើយនិងសេរីភាពក្នុងការសង់ផ្ទះ(សូមមើល យរ២៩:៥) ពួកចាស់ទុំនៃយូដាគឺបានអង្គុយមុនខ្ញុំ ។ ពួកគេបានមានសេរីភាពក្នុងការផ្លាស់ប្តូរការប្រជុំ និងការថ្វាយបង្គំ (សូមមើល ១៤:១ ២០:១) ។ មួយឆ្នាំពីរខែបន្ទាប់ពីការផ្តើមដំបូងនៃការបើកសម្តែង និងការអធិប្បាយពួកហោរាបានទទួលបង្គាប់ពីព្រះ ដោយការស្តាប់ព្រះបន្ទូលព្រះ ។ ដូចបានឃើញនៅថ្ងៃប្រជុំជំនុំ ក្នុងការចាប់ផ្តើមសង់កន្លែងសម្រាប់ថ្វាយបង្គំ ។ *ព្រះហស្តនៃព្រះអម្ចាស់* មើលការពន្យល់នៅ ១:៣ ។

**៨:២** មានសណ្ឋានដូចជាមនុស្សម្នាក់ ក្នុងការលេចមកស្រដៀងនិងសណ្ឋានទេវតាដែលជាការបើកសម្តែងរបស់ព្រះ ១:២៦–២៧ ។ *មានសណ្ឋានដូចជាភ្លើង . . . ដូចជាពន្លឺចាំង គឺដូចជាលង្ហិនខាត់យ៉ាងភ្លឺ* (សូមមើល មថ ២៨:៣ ធៀបនឹង កច ៩:៣) ។

**៨:៣** *ព្រះវិញ្ញាណទ្រង់លើកខ្ញុំឡើង* សូមមើល ៣:១២ និងការពន្យល់ ។ *ទ្រង់នាំខ្ញុំទៅឯក្រុងយេរូសាឡិម* លោកអេសេគាលបានទទួលសេចក្តីទំនាយអំពីការជំនុំជម្រះយ៉ាងធ្ងន់មកលើក្រុងយេរូសាឡិម (ជំពូក ១៧) ឥឡូវនេះគឺគាត់បានដឹកនាំទៅក្រុងយេរូសាឡិម ដើម្បីទទួលការបើកសម្តែងរបស់ព្រះ (សូមមើល ១១:២៤) និងបានបង្ហាញឱ្យឃើញនូវ ហេតុផលនៃការប្រព្រឹត្តខុសនៅក្នុងក្រុងយេរូសាឡិម ។ *មានរូបនៃសេចក្តីប្រចណ្ឌ* មានរូបខ្លះទៀតនៅក្នុងព្រះវិហារ ដែលបណ្តាលឱ្យមានសេចក្តីប្រចណ្ឌនៅចំពោះព្រះអម្ចាស់ (មើលឧទាហរណ៍ ២០:៥ និងការពន្យល់) ។ ប៉ុន្តែនេះជារូបចម្លាក់មួយដែលបានឃើញ គឺជារូបព្រះរបស់ពួកសាសន៍កាណាន ដែលហោរាហូសេបានបំបែកបំផ្លាញក្នុងកំឡុងពេល ៣០ ឆ្នាំ(មើល ២ពវ ២៣:៦) ។

**៨:៥** *រូបនៃសេចក្តីប្រចណ្ឌ* សូមមើល ការពន្យល់ នៅ ខ. ៣ ។

**៨:១០** *មានគំនូរគ្រប់ទាំងសត្វលូនវារសត្វគួរខ្ពើមឆ្អើម* ប្រហែលជាការឆ្លុះបញ្ចាំងពីឥទ្ធិពលនៃប្រជាជនអេស៊ីព្ទ(ធៀបនឹង ២ពវ ២៣:៣១–៣៥) ។

**៨:១១** *យ៉ាសានា* សម្គាល់ដូចជាមនុស្ស នៅក្នុង ១១:១ ។ ការបង្ហាញពីការ

កូនសាផាន ឈរនៅកណ្ដាលគេ គ្រប់គ្នាកាន់ជើងពាន[ធ]
ហើយផ្សែងនៃគ្រឿងក្រអូប[ន] ក៏ហុយឡើងយ៉ាងក្រាស់[ប]
១២ នោះទ្រង់មានបន្ទូលសួរខ្ញុំថា កូនមនុស្សអើយ តើឃើញ
អំពើ ដែលពួកចាស់ទុំសាសន៍អ៊ីស្រាអែលធ្វើដោយសំងាត់[ផ]
នៅក្នុងគំនិតយល់ឃើញនៃគេរៀងខ្លួនឬទេ ដ្បិតគេថា
ព្រះយេហូវ៉ាទ្រង់មិនឃើញយើង[ព]ទេ ព្រះយេហូវ៉ា បាន
បោះបង់ចោលស្រុកនេះហើយ ១៣ ទ្រង់ក៏មានបន្ទូលមកខ្ញុំ
ទៀតថា ចាំមើល ឯងនឹងឃើញការគួរស្អប់ខ្ពើមយ៉ាង
សំបើម ដែលគេប្រព្រឹត្តទៀត ។
១៤ រួចទ្រង់នាំខ្ញុំទៅដល់មាត់ទ្វាររបស់ព្រះវិហារ នៃព្រះ
យេហូវ៉ា ដែលបើកទៅខាងជើង នៅទីនោះក៏ឃើញពួក
ស្រីៗអង្គុយយំនឹងព្រះថាមូស[ភ] ១៥ នោះទ្រង់មានបន្ទូលសួរ
ខ្ញុំថា កូនមនុស្សអើយ ឯងឃើញឬទេ ចាំមើល ឯងនឹង
ឃើញការគួរស្អប់ខ្ពើមយ៉ាងសំបើម ជាងនេះទៅទៀត ។
១៦ រួចទ្រង់នាំខ្ញុំ ចូលទៅឯទីលាន[ម]ខាងក្នុងរបស់ព្រះ
វិហារនៃព្រះយេហូវ៉ា នោះឃើញត្រង់មាត់ទ្វារព្រះវិហារ
នៃព្រះយេហូវ៉ា នៅកណ្ដាលបាំងសាច និងអាសនា[យ] មាន
មនុស្សប្រហែលជា២៥នាក់ បែរខ្នងទៅខាងព្រះវិហារ
នៃព្រះយេហូវ៉ា ហើយមុខទៅខាងកើត គេកំពុងតែ
ថ្វាយបង្គំព្រះអាទិត្យ[រ] នៅទិសខាងកើតនោះ[ល] ១៧ ទ្រង់មាន
បន្ទូលសួរខ្ញុំថា កូនមនុស្សអើយ ឯងឃើញឬទេ
តើពួកវង្សយូដារាប់ការគួរស្អប់ខ្ពើមទាំងនោះ[វ] ដែលគេ
ប្រព្រឹត្តនៅទីនេះថា ជាការស្រាលឬអី ដ្បិតគេបានធ្វើ
ឱ្យស្រុកនេះមានពេញដោយសេចក្ដីច្រឡោត[ស] ហើយបាន
បែរជាបណ្ដាលឱ្យអញខឹងម្ដងទៀត[ហ] ហើយមើល គេលើក
មែកឈើប្រណម្យ នៅច្រមុះគេផង ១៨ ដូច្នេះ អញនឹង

**៨:១១** ធ លវ ១០:១ ជន ១៦:១៧ ន ជន ១៦:៣៥ យរ ៤៤:៥ ប អគ ១១:១-២
**៨:១២** ផ យប ២២:១៣ ព ២ពវ ២១:១៦ ទដ ១០:១១ អស ២៩:១៥ អគ ៩:៩ សផ ១:១២
**៨:១៤** ភ អគ ១១:១២
**៨:១៦** ម ខ.១៣ យ យអ ២:១៧ រ លប ១:១៦ ល ចទ ៤:១៩ ១៧:៣ យប ៣១:២៨ យរ ២:២៧ អគ ៩:៦ ១១:១,២ ៤០:៦ ៤៣:១
**៨:១៧** វ អគ ១៦:២ ស លប ៦:១១ ហ ជន ១១:៣៣ ១ពវ ១៤:៩ អគ ១៦:២៦
**៨:១៨** ឡ យរ ៤៤:៦ អ យរ ១៣:១៤ អគ ៥:១១ ៩:១០ ២៤:១៤ ក ១សយ ៨:១៨ អស ៥៨:៤ យរ ១១:១១
**៩:២** ក លវ ១៦:៤ អគ ១០:២ ដយ ១០:៥ ១២:៦ វវ ១៥:៦
**៩:៣** ខ ១សយ ៤:២១ អគ ១០:៤

ប្រព្រឹត្តដោយសេចក្ដីក្រោធដែរ[ឡ] ភ្នែកអញនឹងមិនប្រណី
ឡើយ អញនឹងមិនអាណិតមេត្តា[អ]ទេ ទោះបើគេអំពាវនាវ
ដោយសំឡេងយ៉ាងខ្លាំងដាក់ត្រចៀកអញក៏ដោយ គង់តែ
អញមិនព្រមស្ដាប់[ក]ឡើយ ។

## ពួកថ្វាយបង្គំរូបព្រះ ត្រូវស្លាប់

**៩** ១ លំដាប់នោះ ទ្រង់មានបន្ទូលដាក់ត្រចៀកខ្ញុំ ដោយ
ព្រះសៀងយ៉ាងខ្លាំងថា ចូរឱ្យពួកអ្នកដែលត្រួតត្រាការក្នុង
ទីក្រុងចូលមកជិតចុះ ត្រូវឱ្យគ្រប់គ្នាកាន់គ្រឿងប្រហារ
របស់ខ្លួននៅដៃផង ២ នោះឃើញមានមនុស្ស៦នាក់ មកតាម
ផ្លូវទ្វារខាងលើ ដែលបើកទៅទិសខាងជើង គ្រប់គ្នាក៏កាន់
គ្រឿងសំឡេះនៅដៃ ហើយមានម្នាក់ស្លៀកពាក់សំពត់
ទេសឯក[ក] នៅកណ្ដាលគេ មានស្លាយដបទឹកខ្មៅ អ្នកទាំង
នោះក៏ចូលទៅឈរក្បែរអាសនាលង្ហិន ។
៣ ខណនោះ សិរីល្អ[ខ]របស់ព្រះនៃសាសន៍អ៊ីស្រាអែល
បានឡើងផុតពីចេរូប៊ីន[គ] ជាកន្លែងដែលធ្លាប់សណ្ឋិតនៅ
ទៅដល់មាត់ទ្វារព្រះវិហារ ទ្រង់ក៏មានបន្ទូលហៅអ្នកម្នាក់
ដែលស្លៀកពាក់សំពត់ទេសឯក ហើយស្លាយដបទឹកខ្មៅ
នោះ ៤ ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅអ្នកនោះថា ចូរដើរ
បង្ហូតទីក្រុង គឺបង្ហូតកណ្ដាលក្រុងយេរូសាឡិម[ឃ]ទៅ ហើយ
ធ្វើទីសំគាល់[ង] នៅថ្ងាសរបស់ពួកមនុស្ស ដែលដង្ហើមធំ
ហើយថ្ងូរ[ច] ដោយព្រោះការគួរស្អប់ខ្ពើមដែលមនុស្ស
ប្រព្រឹត្តនៅក្នុងទីក្រុង[ឆ] ៥ ហើយទ្រង់មានបន្ទូលដល់៥នាក់
ឯងទៀត នៅត្រចៀកខ្ញុំថា ចូរឯងរាល់គ្នាដើរបង្ហូតទីក្រុង

គ អគ ១១:១២**៩:៤** ឃ យរ ២៥:២៩ ង លប ៤:១៥ នក ១២:៧ ២កថ ១:២២ វវ ៧:៣ **៩:៤** ច ទដ ១១៩:១៣៦ យរ ៧:២៩ ១៣:១៧ អគ ២១:៦ អម ៦:៦ ឆ ទដ ១១៩:៥៣

ចំអកឡកឡឺយឈ្មោះនេះមានន័យថា"ព្រះអម្ចាស់ស្ដាប់ញ"គឺជាការចំអកឡកឡឺយដ៏មុតស្រួច ដែលដកស្រង់ពី ខ.១២ ។

**៨:១៤** *ព្រះថាមូស* មានការបញ្ជាក់តែមួយដងគត់នៃព្រះគម្ពីរគឺជាព្រះនៃពួកបាប៊ីឡូន ។ ស្ត្រីនៃក្រុងយេរូសាឡិម គឺបានយំសោកចំពោះការស្លាប់របស់ព្រះថាមូស ។ នៅក្នុង ដយ ១១:៣៧ "ចំពោះបំណងចិត្តរបស់ពួកស្រីៗ សូមមើលការពន្យល់ ។

**៨:១៦***មានមនុស្សប្រហែល២៥នាក់* ដែលតំណាងឱ្យចំនួន (មើល ១១:១) ។ *បែរខ្នងទៅខាងព្រះវិហារ* វិហារបុរាណស្ទើរតែទាំងអស់បែរមុខទៅរកទិសខាងកើត ។ ការថ្វាយបង្គំព្រះអាទិត្យដូចជាព្រះអាទិត្យបានរះឡើងតម្រូវឱ្យមនុស្សត្រឡប់បែរទៅរកព្រះវិហារ ។ *ថ្វាយបង្គំព្រះអាទិត្យ* មានការបញ្ជាក់ផ្សេងទៀតពីការថ្វាយបង្គំព្រះអាទិត្យ សូមមើល ចទ ៤:៩ ១៧:៣ ២ពវ ២៣:៥,១១ ធៀបនឹង ២ពវ ១៧:១៦ ២១:៣,៥ យរ ៤៣:១៣ ។

**៨:១៧** *ស្រុកនេះមានពេញដោយសេចក្ដីច្រឡោត* សូមមើល ៧:២៣ និងការពន្យល់ ។

**៩:១-១១** សូមមើលការពន្យល់នៅក្នុង ៨:១-១១:២៥ ។

**៩:១** *ដោយព្រះសៀងយ៉ាងខ្លាំង* សម្លេងផ្គរលាន់នៃព្រះ (សូមមើល នក ១៩:១៩ សូមមើលផងដែរ ទដ ២៩) ។ *ពួកអ្នកដែលត្រួតត្រា* សូមមើល ៤៤:១១ ២ពវ ១១:១៨ ។

**៩:២** *មានមនុស្ស៦នាក់មកតាមផ្លូវទ្វារខាងលើ* ទេវតាទាំងនេះបានការពារថែរក្សាទីក្រុង ថែមទាំងតែងកាយទាំង៧ ដោយព្រះពស្ត្រ យាងមកពីកន្លែងរូបនៃសេចក្ដីប្រចណ្ឌ (សូមមើល ៨:៣ និងការពន្យល់) ។

**៩:៣** *សិរីល្អ . . . បានឡើងផុត* ព្រះទ្រង់បានចាប់ផ្ដើមយាងចេញពីវិហារ ហើយសិរីល្អរបស់ទ្រង់ចេញពីមាត់ទ្វារ (សូមមើលការពន្យល់នៅក្នុង ៨:១-១១:៥) ។

**៩:៤** *ទីសំគាល់* ស្បែកពណ៌ស អក្សរចុងក្រោយនៃអក្សរសាស្ត្រនៃប្រជាជនហេព្រើរ ដែលមានជាលំដាប់ដូចធ្លាប់បានឃើញ (សូមមើល វវ ៧:២៤ និងការពន្យល់នៅ ៧:២ ធៀបនឹង វវ ១៣:១៦ និងការពន្យល់) ។ *ដែលដកដង្ហើមធំហើយថ្ងូរ* (សូមមើល ១ពវ ១៩:១៨) ។

តាមអ្នក១នោះ ហើយប្រហារទៅ កុំឱ្យភ្នែកឯងប្រណី[ជ]
ឬអាណិតអាសូរឡើយ[ឈ] ៦ត្រូវឱ្យសំឡាប់[ញ]ទាំងពួកចាស់
ពួកកំឡោះ ពួកក្រមុំ ពួកក្មេង[ដ] និងពួកស្រីៗ ឱ្យអស់
រលីងទៅ ប៉ុន្តែកុំឱ្យចូលទៅជិតមនុស្សណា ដែលមាន
ទីសំគាល់[ឋ]នៅខ្លួនឡើយ ហើយត្រូវឱ្យចាប់ផ្តើមការតាំង
ពីទីបរិសុទ្ធរបស់អញផង ដូច្នេះ អ្នកទាំងនោះ ក៏ផ្តើមការ
ចាប់តាំងពីពួកចាស់ទុំ[ឌ] ដែលនៅមុខព្រះវិហារ[ឍ] ៧ទ្រង់
ក៏បង្គាប់ថា ចូរបង្អាប់វិហារ ចុះត្រូវសំឡាប់គេ ឱ្យទីលាន
បានពេញដោយសាកសព[ណ]ទៅ ចូរចេញទៅចុះ ដូច្នេះ
គេក៏ចេញទៅប្រហារនៅក្នុងទីក្រុង ៨កាលគេកំពុងតែ
សំឡាប់ហើយមានតែខ្ញុំសល់នៅ នោះខ្ញុំក៏ទំលាក់ខ្លួនផ្កាប់
មុខ[ត]អំពាវនាវថា ឱព្រះអម្ចាស់យេហូវ៉ាអើយ[ថ] តើទ្រង់នឹង
បំផ្លាញសំណល់សាសន៍អ៊ីស្រាអែលទាំងអស់ ដោយចាក់
សេចក្តីក្រោធ[ទ]របស់ទ្រង់មកលើក្រុងយេរូសាឡិមឬអី[ធ] ។
៩ទ្រង់មានបន្ទូលតបមកខ្ញុំថា សេចក្តីទុច្ចរិតរបស់ពូជ
ពង្សអ៊ីស្រាអែល និងយូដា នោះធំក្រៃលែងណាស់ ស្រុក
នេះក៏ពេញដោយឈាម ហើយទីក្រុងមានពេញដោយ
សេចក្តីវៀចកោងដែរ[ន] ដ្បិតគេថា ព្រះយេហូវ៉ាបានបោះ
បង់ចោលស្រុកនេះ ហើយព្រះយេហូវ៉ាទ្រង់មើលមិន
ឃើញទេ[ប] ១០រីឯអញវិញ ភ្នែកអញនឹងមិនប្រណី[ផ]ទេ អញ
មិនអាណិតមេត្តាឡើយ គឺអញនឹងទំលាក់ អំពើរបស់គេ
មកលើក្បាលគេវិញ[ព] ១១នោះមើល មនុស្សដែលស្លៀក
ពាក់សំពត់ទេសឯក ហើយស្ពាយដបទឹកខ្មៅក៏មកថែងថា
ទូលបង្គំបានធ្វើសំរេចតាមបង្គាប់ទ្រង់ហើយ ។

**៩:៥** ជ យរ ១៣:១៤ អគ ៥:១១ ឈ នក ៣២:២៧ អស ១៣:១៨
**៩:៦** ញ យរ ៧:៣២ ដ យរ ១៦:៦ ឋ លប ៤:១៥ នក ១២:៧ ឌ អគ ៨:១១–១៣,១៦ ឍ ២រប ៣៦:១៧ យរ ២៥:២៩ អគ ៦:៤ ១ពត ៤:១៧
**៩:៧** ណ អគ ៦:៧
**៩:៨** ត យស ៧:៦ ថ អគ ៤:១៤ ទ អគ ៧:៨ ធ អគ ១១:១៣ អម ៧:១–៦
**៩:៩** ន ទដ ៥៨:២ យរ ១២:១ អគ ២២:២៩ ហប ១:៤ ប យប ២២:១៣ អគ ៨:១២ ១៤:២៣
**៩:១០** ផ យរ ១៣:១៤ អគ ៨:១៨ ព អស ២២:៥ ៦៥:៦ អគ ១១:២១ ២៣:៤៩
**១០:១** ក នក ២៤:១០ យ អគ ១:២២ ខ វវ ៤:២ គ លប ៣:២៤
**១០:២** ង អគ ៩:២

## សិរីល្អចាកចេញពីព្រះវិហារ

**១០** ១គ្រានោះ ខ្ញុំក្រឡេកទៅឃើញនៅក្នុងអាកាស ដែល
នៅពីលើក្បាលចេរូប៊ីន មានភាពដូចជាត្បូងកណ្តៀង[ក]
ដែលមើលទៅដូចជាសណ្ឋាននៃបល្ល័ង្ក[ខ] លេចមកពីលើ[គ]
ចេរូប៊ីនោះ[ឃ] ២ទ្រង់ក៏មានបន្ទូលដល់មនុស្សដែលស្លៀក
សំពត់ទេសឯកថា[ង] ចូរឱ្យចូលទៅកណ្តាលកង់ទាំងនោះ[ច]
គឺក្រោមចេរូប៊ីន ហើយកើបរងើកភ្លើង[ឆ]ពេញ[ជ]ដៃទាំង២ ពី
កណ្តាលចេរូប៊ីននោះ រួចបាចទៅលើទីក្រុងទៅ អ្នកនោះ
ក៏ចូលទៅនៅចំពោះភ្នែកខ្ញុំ ៣កំពុងដែលមនុស្សនោះចូល
ទៅ ចេរូប៊ីនក៏នៅខាងស្តាំព្រះវិហារ ហើយពពកក៏នៅ
ពេញក្នុងទីលានខាងក្នុង ៤នោះសិរីល្អនៃព្រះយេហូវ៉ា[ឈ]
បានឡើងផុតពីចេរូប៊ីន ទៅនៅប្រឡោះទ្វារនៃព្រះវិហារ
វិញ ឯព្រះវិហារក៏ពេញដោយពពកនោះ ហើយទីលាន
មានពេញដោយរស្មីនៃសិរីល្អរបស់ព្រះយេហូវ៉ា ៥ក៏មាន
ឮសូរ សន្ធឹកស្លាបរបស់ចេរូប៊ីន រហូតដល់ទីលានខាងក្រៅ
ហាក់ដូចជាព្រះសៀង[ញ] នៃព្រះដ៏មានគ្រប់ព្រះចេស្តា ក្នុង
កាលដែលទ្រង់មានបន្ទូល[ដ] ៦រីឯកាលទ្រង់បានបង្គាប់
មនុស្សដែល ស្លៀកសំពត់ទេសឯក ឱ្យកើបយករងើកភ្លើង
ពីកណ្តាលកង់ទាំងនោះ[ឋ] គឺពីកណ្តាលចេរូប៊ីនហើយ នោះ
លោក ក៏ចូលទៅឈរនៅក្បែរកង់ទាំងនោះ ៧ចំណែក
ចេរូប៊ី១ ក៏លូកដៃពីកណ្តាលពួកចេរូប៊ីន ទៅចាប់យកភ្លើង[ឌ]

ច អគ ១:១៥ ឆ ២សយ ២២:៩ ជ វវ ៨:៥ **១០:៤** ឈ នក ២៤:១៦ អគ ៩:៣ ៤៤:៤ **១០:៥** ញ យប ៤០:៩ ដ អគ ៣:១៣ **១០:៦** ឋ ដយ ៧:៩ **១០:៧** ឌ អគ ៥:៤

**៩:៥** *ហើយប្រហារទៅ កុំឱ្យភ្នែកឯងប្រណី ឬអាណិតអាសូរឡើយ* សូមមើល បទ ២:២១ ។

**៩:៦** *តាំងពីទីបរិសុទ្ធរបស់អញ* ពីព្រោះដើមដំបូងសេចក្តីអាក្រក់នោះបានជ្រួតជ្រាបនៅពេញទីក្រុងយេរូសាឡិម (សូមមើល ជំពូក ៨) ធៀបនឹង ១ពត ៤:១៧ ។

**៩:៨** *ឱព្រះអម្ចាស់យេហូវ៉ាអើយ!* សូមមើល ១១:១៣ ។ ដូចជាអ្នកទាំងនោះនៅជាកណ្តាលរវាងព្រះនិងមនុស្សរបស់ទ្រង់ ជាញឹកញាប់ពួកហោរាបានជួយលន់តួទោសឱ្យ ក្នុងនាមតំណាងឱ្យមនុស្សនៅពេលព្រះទ្រង់ជំនុំជម្រះដ៏ជាទីស្ញែងខ្លាច (សូមមើល នក ៣២:៣១ ជន ១៤:១៣–១៩ ១សយ ១២:២៣ យរ ១៤:១៩–២១ ១៥:១ អម ៧:២,៥) ។

**៩:៩** *ស្រុកនេះក៏ពេញដោយឈាម* សូមមើល ៧:២៣ និងការពន្យល់ ។

**១០:១–២២** មើលការពន្យល់នៅ ៨:១–១១:២៥ ។

**១០:១** *ខ្ញុំក្រឡេកទៅឃើញ* ជំពូក ១០ បានផ្សព្វផ្សាយឱ្យដឹងនៅក្នុងជំពូក ១ ជាការគូសបញ្ជាក់នូវភាពដូចគ្នា អ្វីដែលលោកអេសេគាលបានឃើញនៅមាត់ទន្លេបោរ ជាមួយអ្វីដែលបានឃើញនៅក្នុងការនិមិត្តរបស់គាត់ (មើល ៨:៤ ។ តួរមានជីវិត ជំពូក ១ គឺនៅទីនេះហៅថា ចេរូប៊ីន (មើលការពន្យល់ ១:៥) ។

**១០:២** *កើបរងើកភ្លើង* ខណៈពេលដែលនៅក្នុង ១:១៣ បានបកស្រាយអំពីជីវិតសត្វលោក ដែលរស់នៅក្នុងរងើកភ្លើងកំពុងឆេះយ៉ាងសន្ធោសន្ធៅ ហើយនៅក្នុងអត្ថបទនេះ ក៏បានបញ្ជាក់អំពីរងើកភ្លើងយ៉ាងពិតប្រាកដផងដែរ ។ *រួចបាចទៅលើទីក្រុងទៅ* គឺជាការជំនុំជម្រះដោយសារភ្លើង (សូមមើល លប ១៩:២៤ អម ៧:៤) ។

**១០:៣** *ពពក* ពពកដែលបានព័ទ្ធជុំវិញ "គឺជាសិរីល្អរបស់ព្រះអម្ចាស់" (ខ.៤) ណាមួយនៅពេលដែលយើងឃើញសិរីល្អយ៉ាងដូច្នោះ នោះអាចនឹងធ្វើឱ្យយើងខ្វាក់ភ្នែក នៅពេលដែលយើងសំឡឹងមើលវា ។ (សូមមើល ១:៤ ឧទាហរណ៍ ១៦:១០ ២៤:១៥–១៧ ៤០:៣៤–៣៨ ជន ៩:១៥ ១៦:៤២ ចទ ៥:២៣ ១ពវ ៨:១០–១២ ហក ២:៧ និងការពន្យល់ ធៀបនឹង មថ ១៣:៥ ២៤:៣០ ២៦:៦៤ មក ៩:៧ ១៣:២៦ ១៤:៦២ លក ៩:៣៤–៣៥ ២១:២៧ កច ១:៩ វវ ១:៧ ១៤:១៤–១៦) ។

**១០:៧** *ចេរូប៊ីន១ ក៏លូកដៃ* សូម្បីតែ "មនុស្សដែលស្លៀកសំពត់ទេសឯក" គឺជាដើមដំបូងដែលបានបង្គាប់ឱ្យទទួលរងើកភ្លើងនោះ ដោយខ្លួនគាត់ផ្ទាល់ ។ (ខ.២) គាត់បានទទួលពួកគេពីដៃនៃចំណោមមនុស្សលោកទាំងឡាយ (សូម

ដែលនៅកណ្ដាលចេរូប៊ី ទៅដាក់ក្នុងដៃរបស់មនុស្ស ដែល
ស្លៀកសំពត់ទេសឯក ហើយអ្នកនោះទទួលយក រួចចេញ
ទៅ ៨ខណៈនោះ នៅក្រោមស្លាបរបស់ចេរូប៊ីន ឃើញមាន
សណ្ឋាន ដូចជាដៃមនុស្សលេចមក[ឈ] ។
៩ខ្ញុំក៏ក្រឡេកទៅ ឃើញមានកង់៤ នៅខាងចេរូប៊ីន
គឺកង់១ ខាងចេរូប៊ីន១ ហើយកង់១ ខាងចេរូប៊ីន១ទៀត
កង់ទាំងនោះមើលទៅដូចជាត្បូងបេរីល[ណ] ១០ឯភាពនៃកង់
ទាំង៤នោះ មានសណ្ឋានដូចគ្នាទាំងអស់ គឺបែបដូចជា
មានកង់១នៅក្នុងកង់១ទៀត ១១កាលណាទៅ នោះក៏ទៅ
ទាំង៤ខាង ឥតងាកបែរទៅឯណាក្នុងកាលដែលកំពុង
តែទៅនោះឡើយ គឺទិសណាដែលដំរង់ទៅ នោះទាំង
អស់ក៏ទៅតាម ឥតងាកបែរទៅឯណាឡើយ ១២ហើយតួ
ទាំងមូល និងខ្នង ដៃ ស្លាប ព្រមទាំងកង់ផង ក៏មានពេញ
ដោយភ្នែកនៅជុំវិញ[ត] គឺទាំងកង់៤នោះផង[ថ] ១៣រីឯកង់ទាំង
នោះ ខ្ញុំឮគេហៅថា "កង់វិល" ១៤គ្រប់គ្នា[ទ]មានមុខ៤[ធ] មុខ
ទី១ ជាមុខដូចជាចេរូប៊ីន មុខទី២ជាមុខមនុស្ស មុខទី៣
ជាមុខសិង្ហ[ន] ហើយមុខទី៤ ជាមុខឥន្ទ្រី[ប] ១៥ពួកចេរូប៊ីននោះ
ក៏ឡើងទៅ នេះហើយជាតួមានជីវិត[ផ] ដែលខ្ញុំឃើញក្បែរ
ទន្លេកេបារ[ព] ១៦កាលណាចេរូប៊ីនទៅឯណា នោះកង់ក៏អម
ទៅជាមួយ ហើយកាលណាចេរូប៊ីនកាងស្លាប ដើម្បីឡើង
ផុតពីដី នោះកង់ក៏មិនខាននឹងអមទៅជាមួយដែរ ១៧កាល
ណាពួកនេះឈប់ ពួកនោះក៏ឈប់ដែរ ហើយកាលណា
ពួកនេះហើរឡើងទៅ ពួកនោះ ក៏ឡើងទៅជាមួយគ្នា ដ្បិត
វិញ្ញាណនៃតួមានជីវិត សណ្ឋិតនៅក្នុងទាំងអស់[ភ] ។
១៨ឯសិរីល្អ[ម]នៃព្រះយេហូវ៉ា ក៏ចេញពីប្រឡោះទ្វារនៃ
ព្រះវិហារ ទៅសណ្ឋិតពីលើពួកចេរូប៊ីន[យ] ១៩រួចចេរូប៊ីនក៏
កាងស្លាប ក្នុងកាលដែលចេញទៅនោះ ហើយហើរឡើង
ផុតពីដី នៅចំពោះភ្នែកខ្ញុំ មានទាំងកង់អមទៅផង[រ] នោះ
ក៏ទៅឈរនៅមាត់ទ្វារកំផែងទិសខាងកើតរបស់ព្រះវិហារ
នៃព្រះយេហូវ៉ា ហើយសិរីល្អ[ល]របស់ព្រះនៃសាសន៍
អ៊ីស្រាអែលក៏សណ្ឋិតនៅពីលើ ។
២០នេះជាតួមានជីវិត ដែលខ្ញុំបានឃើញនៅក្រោមព្រះ
នៃសាសន៍អ៊ីស្រាអែល ត្រង់ទន្លេកេបារ[វ] ហើយខ្ញុំបានដឹង
ថា នោះជាពួកចេរូប៊ីនដែរ ២១គ្រប់គ្នាមានមុខ៤[ស] ហើយ
គ្រប់គ្នាមានស្លាប៤ដែរ[ហ] នៅក្រោមស្លាបនោះ ក៏មាន
សណ្ឋានដូចជាដៃមនុស្ស ២២ឯសណ្ឋានមុខរបស់តួទាំង
នោះ គឺជាមុខដែលខ្ញុំបានឃើញ នៅក្បែរទន្លេកេបារ[ឡ]
ព្រមទាំងភាពនិងតួទាំងនោះផង គ្រប់គ្នាបានហើរត្រង់ទៅ
ខាងមុខរៀងខ្លួន ។

## សេចក្ដីជំនុំជម្រះដល់ពួកចៅហ្វាយសាសន៍អ៊ីស្រាអែល

**១១** ១លំដាប់នោះ ព្រះវិញ្ញាណទ្រង់លើខ្ញុំឡើង នាំទៅឯ
ទ្វារកំផែងទិសខាងកើតរបស់ព្រះវិហារនៃព្រះយេហូវ៉ា
ជាទ្វារដែលបើកទៅទិសខាងកើត នោះឃើញនៅមាត់
ទ្វារកំផែង មានមនុស្ស២៥នាក់ ហើយនៅកណ្ដាលអ្នក
ទាំងនោះ ខ្ញុំឃើញមានយ៉ាសានា ជាកូនអ័ស៊ើរ ហើយ
ពេឡាធា[ក] ជាកូនបេណាយ៉ា ទាំង២នាក់ជាចៅហ្វាយ[ខ]លើ
បណ្ដាជន[គ] ២នោះទ្រង់មានបន្ទូលមកខ្ញុំថា កូនមនុស្ស
អើយ គឺមនុស្សទាំងនេះឯងដែលគិតគូរបង្កើតការទុច្ចរិត[ឃ]
ហើយទូន្មានសេចក្ដីអាក្រក់នៅក្នុងទីក្រុងនេះ[ង] ៣គេថា នេះ
មិនមែនជាពេលទេ ចូរយើងសង់ផ្ទះទៅ ទីក្រុងនេះជា
ថ្លាង[ច] ហើយយើងរាល់គ្នាជាសាច់[ឆ] ៤ដូច្នេះ កូនមនុស្ស
អើយ ចូរទាយ[ជ]ទាស់នឹងគេ ចូរទាយចុះ ។
៥នោះព្រះវិញ្ញាណនៃព្រះយេហូវ៉ា ក៏មកសណ្ឋិតលើខ្ញុំ

**១០:៨** ឈអគ ១:៨
**១០:៩** ណ អគ ២៨:២០ វវ ២១:២០
**១០:១២** ត វវ ៤:៦-៨ ថ អគ ១:១៥-២១
**១០:១៤** ទ ១ពវ ៧:៣៦ ធ អគ ១:៦ ន ១ពវ ៧:២៩ ប អគ ១:១០ ៤១:១៩ វវ ៤:៧
**១០:១៥** ផ អស ៦:២ ព ទដ ១៣៧:១
**១០:១៧** ភ អគ ៣:១៣
**១០:១៨** ម អស ៤:២១ យ ទដ ១៨:១០
**១០:១៩** រ អគ ១១:១,២២ ល អគ ៤៣:៤
**១០:២០** វ អគ ១:១
**១០:២១** ស អគ ៤១:១៨ ហ អគ ១:៦
**១០:២២** ឡ អគ ១:១
**១១:១** ក ខ.១៣ ខ យរ ៥:៥ គ អគ ៨:១៦ ១០:១៩ ៤៣:៤-៥
**១១:២** ឃ អស ២៩:២០ ណហ ១:១១ ង អគ ៨:១១
**១១:៣** ច យរ ១:៣ អគ ២៤:៣ ឆ ខ.៧,១១ អគ ១២:២២,២៧
**១១:៤** ជ អគ ៣:៤,១៧

មើល ១:៨) ។ *ហើយអ្នកនោះទទួលយក រួចចេញទៅ* មិនមានរបាយការច្បាស់លាស់បានបញ្ជាក់ឱ្យចំៗឡើយ ប៉ុន្តែវាជាការបង្ហាញ និងលាតត្រដាងពីការហិនវិនាសដោយសារភ្លើង មកលើទីក្រុងយេរូសាឡិមគឺជាការស្មាន ។

**១០:១៤** *មុខទី១ជាមុខដូចចេរូប៊ីន* ឯភាពនៃមុខតួទាំងនោះ គឺមានដូចជាមនុស្ស ដូចជាគោ និងដូចជាទេវតាសុទ្ធសាធ នៅក្នុង ១:១០ (សូមមើលការពន្យល់នៅក្នុង ១:១៥) គោនៅទីនេះត្រូវបានគេហៅថា ចេរូប៊ីន ១ ។ (សូមមើលការពន្យល់នៅក្នុង លប ៣:២៤) ។

**១០:១៥** *ទន្លេកេបារ* សូមមើល ១:១ និងការពន្យល់ ។

**១០:១៩** *នៅមាត់ទ្វារកំផែងទិសខាងកើត...ហើយសិរីល្អរបស់ព្រះនៃសាសន៍អ៊ីស្រាអែលក៏សណ្ឋិតនៅពីលើ* សិរីល្អរបស់ព្រះមកសណ្ឋិតជាលើកទីពីរម្ដងទៀតនៅពីទិសខាងកើតនៃកន្លែងទីចាត់ការ (សូមមើល ៩:៣ ១០:៤ សូមមើលការពន្យល់ ៨:១-១១:២៥ ផងដែរ) ។ សូមមើល ជំពូក ៤៣ ដ្បិតសិរីល្អរបស់ព្រះអម្ចាស់ ត្រឡប់ទៅព្រះវិហារតាមផ្លូវនៃមាត់ទ្វារខាងកើត (សូមមើលការពន្យល់នៅ ៤៣:១-១២) ។

**១១:១-១៣** មើលការពន្យល់ ៨:១-១១:២៥ ។

**១១:១** *ព្រះវិញ្ញាណទ្រង់លើកខ្ញុំឡើង* មើល ៣:១២ និងការពន្យល់ ។ *មនុស្ស២៥នាក់* មើល ៨:១៦ និងការពន្យល់ ។ *យ៉ាសានា* មើល ៨:១១ និងការពន្យល់ ។ *ពេឡាធា* មានន័យថា "ព្រះអម្ចាស់ទ្រង់គឺជាអ្នករំដោះ" ។

**១១:៣** *នេះជាពេលសង់ផ្ទះរឺ* អ្នកដែលតាំងលំនៅក្នុងក្រុងយេរូសាឡិមដែលមិនមែនជាឈ្លើយដោយសារពួកបាប៊ីឡូនក្នុងឆ្នាំ ៥៩៧ គ.ស ។ មានអារម្មណ៍ថាមានសុវត្ថិភាព ដោយគិតថាគេមិនភ័យខ្លាចចំពោះការគំរាមកំហែងរបស់ពួកបាប៊ីឡូនទៀតទេ ។ *ថ្លាង* ដូចជានៅក្នុងជំពូក ២៤ ក្រុងយេរូសាឡិម គឺប្រៀបដូចជាថ្លាង ។ អស់អ្នកដែលទុកថានៅខាងក្រោយពួកគេគឺជា "សាច់" ជម្រើសគឺធាត់ដែលអាចគិតបានថា ពួកអ្នកដែលជាប់ជាឈ្លើយនៅបាប៊ីឡូន គឺជាឆ្អឹងត្រូវបានបោះបង់ចោល (មើល ខ.១៥) ។

**១១:៥** *នោះព្រះវិញ្ញាណនៃព្រះយេហូវ៉ា ក៏មកសណ្ឋិតលើខ្ញុំ* មើល ២:២ និង

ហើយទ្រង់មានបន្ទូលមកខ្ញុំថា ចូរទាយចុះ ព្រះយេហូវ៉ា
មានបន្ទូលដូច្នោះ ឱពូជពង្សអ៊ីស្រាអែលអើយ ឯងរាល់
គ្នាបាននិយាយយ៉ាងដូច្នេះ អញស្គាល់អស់ទាំងសេចក្ដី
ដែលកើតក្នុងគំនិតរបស់ឯងរាល់គ្នាហើយ[ឈ] ៦ឯងរាល់គ្នា
បានសំឡាប់មនុស្ស នៅក្នុងទីក្រុងនេះ កាន់តែច្រើនឡើង
ក៏បានសំឡាប់គេឱ្យពេញគ្រប់ទាំងផ្លូវហើយ[ញ] ៧ហេតុនោះ
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ពួកអ្នកដែល
ឯងរាល់គ្នាបានសំឡាប់ផ្ដេកនៅកណ្ដាលទីក្រុង គឺគេវិញ
ដែលជាសាច់នោះ ហើយទីក្រុងនេះជាថ្លាង[ដ] តែចំណែក
ឯងរាល់គ្នា អញនឹងនាំចេញទៅក្រៅ[ឋ] ៨ឯងរាល់គ្នាបាន
ខ្លាចដាវ[ឌ] ដូច្នេះ អញនឹងនាំដាវមកលើឯង នេះជាព្រះ
បន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ឍ] ៩អញនឹងនាំឯងរាល់គ្នា
ចេញទៅក្រៅទីក្រុង ហើយប្រគល់ទៅ[ណ]ក្នុងកណ្ដាប់ដៃនៃ
សាសន៍ដទៃ ព្រមទាំងសំរេចសេចក្ដីយុត្តិធម៌នៅកណ្ដាល
ឯង[ត] ១០ឯងរាល់គ្នានឹងត្រូវដួលដោយដាវ អញនឹងជំនុំជំរះ
ឯង នៅត្រង់ព្រំស្រុកអ៊ីស្រាអែល[ថ] នោះឯងរាល់គ្នានឹងដឹង
ថា អញនេះជាព្រះយេហូវ៉ាពិត ១១ទីក្រុងនេះនឹងមិនបានជា
ថ្លាង[ទ]ដល់ឯងរាល់គ្នាឡើយ ឯងរាល់គ្នាក៏មិនត្រូវជាសាច់
នៅក្នុងថ្លាងនោះដែរ គឺអញនឹងជំនុំជំរះឯង នៅត្រង់ព្រំ
ស្រុកអ៊ីស្រាអែលវិញ ១២នោះឯងរាល់គ្នានឹងដឹងថា អញ
នេះជាព្រះយេហូវ៉ាពិត[ធ] ដ្បិតឯងរាល់គ្នាមិនបានប្រព្រឹត្ត
តាមក្រិត្យក្រម[ន]របស់អញសោះ ក៏មិនបានសំរេចតាម
បញ្ញត្តិច្បាប់របស់អញដែរ គឺបានប្រព្រឹត្តតាម បញ្ញត្តិច្បាប់
របស់សាសន៍ដទៃទាំងប៉ុន្មាន ដែលនៅជុំវិញឯងវិញ[ប]
១៣រីឯកាលខ្ញុំកំពុងតែទាយ នោះពេឡាធា[ផ] ជាកូន
បេណាយ៉ាក៏ស្លាប់ទៅ ដូច្នេះ ខ្ញុំក៏ទំលាក់ខ្លួនផ្កាប់មុខអំពាវ
នាវដោយសំឡេងយ៉ាងខ្លាំងថា ឱព្រះអម្ចាស់យេហូវ៉ាអើយ
តើទ្រង់នឹងធ្វើឱ្យសំណល់សាសន៍អ៊ីស្រាអែល ត្រូវផុតទៅឱ្យ
អស់រលីងឬ[ព] ។
១៤នោះព្រះបន្ទូល នៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា
១៥កូនមនុស្សអើយ គឺជាបងប្អូនឯងបង្កើតទេតើ ព្រមទាំង
បងប្អូនឯង ដែលជាញាតិសន្ដាន និងពូជពង្សអ៊ីស្រាអែល
ទាំងប៉ុន្មាន ដែលពួកអ្នកនៅក្រុងយេរូសាឡិមបានប្រាប់ថា
ចូរថយឆ្ងាយពីព្រះយេហូវ៉ាទៅ ស្រុកនេះបានប្រគល់ដល់
យើងរាល់គ្នាទុកជាកេរ្ដិ៍អាករហើយ[ភ] ។

## ការសន្យារបស់ពួកអ៊ីស្រាអែលថា នឹងវិលត្រឡប់

១៦ហេតុនោះត្រូវឱ្យឯងប្រាប់ថា ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ ទោះបើអញបានឱ្យគេទៅនៅឯទី
ឆ្ងាយ កណ្ដាលអស់ទាំងសាសន៍ដទៃ ហើយទោះបើអញ
កំចាត់កំចាយគេ ទៅនៅគ្រប់ទាំងប្រទេសក៏ដោយ គង់តែ
អញនឹងធ្វើជាទីបរិសុទ្ធ[ម]ដល់គេ នៅវេលាបន្តិច ក្នុងស្រុក
ទាំងប៉ុន្មានដែលគេត្រូវទៅនោះ ១៧ហេតុនោះ ចូរប្រាប់ថា
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អញនឹងប្រមូល
ឯងរាល់គ្នាចេញពីអស់ទាំងសាសន៍ ហើយនិងប្រជុំឯង
ពីគ្រប់ទាំងប្រទេស ដែលឯងត្រូវខ្ចាត់ខ្ចាយទៅនោះ ឱ្យមូល
គ្នាវិញ រួចអញនឹងប្រគល់ស្រុកអ៊ីស្រាអែល ឱ្យដល់ឯង
រាល់គ្នា[យ] ១៨នោះពួកឯងនឹងមកឯទីនេះវិញ ហើយគេនឹង
ដកយកអស់ទាំងរបស់គួរឆ្អើម[រ] និងគ្រប់ទាំងសេចក្ដីគួរ
ស្អប់ខ្ពើមចោលចេញ[ល] ១៩រួចអញនឹងឱ្យគេមានចិត្តតែ១[វ]
ហើយនិងដាក់វិញ្ញាណថ្មី នៅក្នុងឯងរាល់គ្នា អញនឹងដក
ចិត្តដែលរឹងដូចថ្ម[ស]ពីរូបសាច់គេចេញ ហើយនិងឱ្យមាន
ចិត្តជាសាច់វិញ[ហ] ២០ដើម្បីឱ្យគេប្រព្រឹត្តតាមក្រិត្យក្រមរបស់
អញហើយរក្សាបញ្ញត្តិច្បាប់របស់អញ[ឡ] ព្រមទាំងប្រព្រឹត្ត
តាមផង នោះគេនឹងបានជារាស្ត្ររបស់អញ[អ] ហើយអញ

**១១:៥** ឈ ទដ ២៦:២ យរ ១៧:១០
**១១:៦** ញ អគ ៧:២៣ ២៦:៦
**១១:៧** ដ យរ ១:១៣ ឋ ខ.៣ អគ ២៤:៣–១៣
**១១:៨** ឌ លវ ២៦:២៥ យរ ៤២:១៦ ឍ សភ ១០:២៤ អស ៦៦:៤
**១១:៩** ណ ទដ ១០៦:៤១ ត ចទ ២៨:៣៦ អគ ៥:៨
**១១:១០** ថ ២ពវ ១៤:២៥
**១១:១១** ទ ខ.៣ អគ ២៤:៦
**១១:១២** ធ អគ ៦:៧ ន លវ ១៨:៩ ប អគ ៨:១០
**១១:១៣** ផ ខ.១ ព អគ ៩:៨ អម ៧:២
**១១:១៥** ភ អគ ៣៣:២៤
**១១:១៦** ម ទដ ៣១:២០ ៩០:១ ៩១:៩ អស ៤:៦
**១១:១៧** យ ណហ ១:៩ យរ ៣:១៨ ២៤:៥–៦ ៣១:១៦ អគ ២០:៤១ ២៨:២៥ ៣៤:១៣ ៣៦:២៨
**១១:១៨** រ អគ ៥:១១ ល អគ ៣៧:២៣
**១១:១៩** វ ២របា ៣០:១២ ទដ ៨៦:១១ ស សក ៧:១២ រម ២:៥ ហអឡ ១៨:៣១ ២កថ ៣:៣ **១១:២០** ឡ ទដ ១:២ អ យរ ១១:៤ ៣២:៣៨

ការពន្យល់ ។
**១១:៦** *បានសំឡាប់គេ ឱ្យពេញគ្រប់ទាំងផ្លូវ* សូមមើល ៧:២៣ និងការពន្យល់ ។
**១១:៧** *ពួកអ្នកដែលឯងរាល់គ្នាបានសំឡាប់ផ្ដេកនៅកណ្ដាលទីក្រុង ជាសាច់* ឱ្យអត្ថន័យដោយសារហោរា មិនមែនអស់អ្នកដែលមានអំណាចនៅក្រុងយេរូសាឡិម (តើអ្នកណានឹងត្រូវបោះចេញទៅក្រៅ) ប៉ុន្តែមនុស្សសុចរិតត្រូវបានសម្លាប់ ។
**១១:១១** *នៅត្រង់ព្រំស្រុកអ៊ីស្រាអែល* នៅឯរីបឡា (មើល ២ពវ ២៥:២០–២១) ។
**១១:១៣** *ឱព្រះអម្ចាស់យេហូវ៉ាអើយ* មើល ៩:៨ ។
**១១:១៤–២១** មើលការពន្យល់ ៨:១–១១:២៥ ។
**១១:១៦** *អញនឹងធ្វើជាទីបរិសុទ្ធដល់គេ* នេះជាខសំខាន់នៅក្នុងព្រះគម្ពីរអេសេគាល ទោះបីពួកអ្នកដែលជាប់ជាឈ្លើយ បានបណ្ដេញចេញពីក្រុងយេរូសាឡិម និងទីកន្លែងបរិសុទ្ធក្ដី (និម្មិតសញ្ញាពីវត្តមានរបស់ព្រះគង់នៅកណ្ដាលចំណោមរាស្ត្ររបស់ទ្រង់) ក៏ព្រះទ្រង់បានធ្វើជាទីបរិសុទ្ធដល់ពួកគេផងដែរ ឧទា. វត្តមានរបស់ទ្រង់ គឺដើម្បីការពារ និងប្រទានពរដល់គេ ។
**១១:១៩** *មានចិត្តតែ១ ហើយនិងដាក់វិញ្ញាណថ្មី* និងផ្លាស់ប្រែផ្នែកសីលធម៌ដោយដួងចិត្តមានការប្ដេជ្ញាចំពោះព្រះអម្ចាស់ និងចំពោះព្រះហឫទ័យទ្រង់ (មើល ៣៦:២៦) ។ *ដកចិត្តដែលរឹងដូចថ្ម ពីរូបសាច់គេចេញ ប្រទានចិត្តថ្មី*ដល់អ៊ីស្រាអែលឆ្លើយតបទៅនឹងព្រះហឫទ័យរបស់ព្រះ (មើល ២កថ ៣:៣ និងការពន្យល់ ។
**១១:២០** *គេជារាស្ត្ររបស់អញ ហើយអញជាព្រះរបស់គេ* សេចក្ដីសន្យានៃការតាំងសញ្ញា ឱ្យគេធ្វើតាមព្រះហឫទ័យរបស់ព្រះ (មើល នក ៦:៧ ៧:២៣) ។

នឹងធ្វើជាព្រះដល់គេ[ក] ២១តែត្រង់ឯពួកអ្នកដែលមានចិត្ត
ប្រព្រឹត្តតាមរូបព្រះគួរឆ្អើម និងសេចក្តីគួរស្អប់ខ្ពើមរបស់
គេ នោះ[ខ]អញនឹងទំលាក់អំពើរបស់គេទៅលើក្បាលគេវិញ
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[គ] ។
២២នោះពួកចេរូប៊ីនកាងស្លាបហោះទៅ កង់ទាំងនោះ
ក៏ទៅជាមួយដែរ ហើយសិរីល្អ[ឃ]របស់ព្រះនៃសាសន៍
អ៊ីស្រាអែលសណ្ឋិតពីលើ[ង] ២៣សិរីល្អ[ច]របស់ព្រះយេហូវ៉ា
យាងឡើងពីកណ្តាលទីក្រុង ទៅសណ្ឋិតលើភ្នំ[ឆ]នៅខាង
កើតទីក្រុង ២៤នោះព្រះវិញ្ញាណ[ជ]ក៏លើកខ្ញុំឡើង ហើយ
ក្នុងការជាក់ស្តែងទ្រង់នាំខ្ញុំទៅដល់ស្រុកខាល់ដេ ដោយ
នូវព្រះវិញ្ញាណនៃព្រះ គឺទៅឯពួកអ្នកដែលនៅជាឈ្លើយ
នោះការជាក់ស្តែង[ឈ]ដែលខ្ញុំបានឃើញក៏បាត់ពីខ្ញុំទៅ
២៥រួចខ្ញុំនិយាយប្រាប់ដល់ពួកអ្នកដែលនៅជាឈ្លើយ
តាមគ្រប់ទាំងការដែលព្រះយេហូវ៉ាបានបង្ហាញខ្ញុំ[ញ] ។

## និម្មិតសញ្ញានៃការនិរទេស

**១២** ១ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំទៀតថា
២កូនមនុស្សអើយ ឯងនៅកណ្តាលពូជពង្សរឹងចចេស[ក]
ជាពួកអ្នកដែលមានភ្នែកសំរាប់មើលតែមើលមិនឃើញទេ
ក៏មានត្រចៀកសំរាប់ស្តាប់ តែស្តាប់មិនឮដែរ ដ្បិតគេជា
ពូជពង្សរឹងចចេស[ខ] ៣ដូច្នេះ កូនមនុស្សអើយ ចូររៀបចំអី–
វ៉ាន់សំរាប់ដំណើរនិរទេស ហើយដើរចេញទៅទាំងថ្ងៃនៅ
ចំពោះភ្នែកគេចុះ ត្រូវឱ្យឯងរើចេញពីកន្លែងឯងទៅនៅ
កន្លែង១ទៀត នៅចំពោះភ្នែកគេ ប្រហែល[គ]ជាគេ នឹង
ពិចារណាយល់[ឃ] ទោះបើគេជាវង្សរឹងចចេសក៏ដោយ[ង]
៤ត្រូវឱ្យឯងរើយកអីវ៉ាន់ឯងចេញ នៅពេលថ្ងៃ ចំពោះភ្នែក
គេ ធ្វើដូចជារៀបចំនឹងត្រូវនិរទេសទៅ ហើយខ្លួនឯងត្រូវ
ចេញទៅនៅពេលល្ងាចចំពោះភ្នែកគេ បែបដូចជាមនុស្ស
ដែលត្រូវនិរទេស[ច] ៥ចូរជីកទំលុះកំផែង[ឆ]នៅចំពោះភ្នែក
គេ ហើយបញ្ចេញអីវ៉ាន់ទៅតាមនោះចុះ ៦ត្រូវឱ្យឯងលី
អីវ៉ាន់ ឯងនៅមុខគេចេញទៅក្នុងងងឹត ក៏ត្រូវបាំងមុខ
ដើម្បីមិន ឱ្យឃើញស្រុកឡើយ ដ្បិតអញបានតាំងឯងឡើង
ទុកជាទីសំគាល់[ជ]ដល់ពូជពង្សអ៊ីស្រាអែល ៧ខ្ញុំក៏ធ្វើតាម
បង្គាប់[ឈ] ខ្ញុំយកអីវ៉ាន់ចេញទាំងថ្ងៃ ទុកដូចជាអីវ៉ាន់សំរាប់
ដំណើរនិរទេស ហើយនៅពេលល្ងាចខ្ញុំជីកទំលុះកំផែង
ដោយដៃ ខ្ញុំក៏បញ្ចេញអីវ៉ាន់ក្នុងងងឹត ហើយលីយកទៅនៅ
ចំពោះភ្នែកគេ ។
៨លុះព្រឹកឡើង ព្រះបន្ទូលនៃព្រះយេហូវ៉ាមកដល់ខ្ញុំ
សួរថា ៩កូនមនុស្សអើយ តើពូជពង្សអ៊ីស្រាអែលជាពួក
រឹងចចេសនោះ មិនបានសួរឯងទេឬអីថា អ្នកធ្វើអ្វីដូច្នេះ[ញ]
១០ត្រូវឱ្យប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះថា ព្រះបន្ទូលនេះ សំដៅដល់ចៅហ្វាយនៃក្រុងយេរូ–
សាឡិម និងពូជពង្សអ៊ីស្រាអែលទាំងប៉ុន្មានដែលនៅទី
នោះដែរ ១១ចូរប្រាប់ថា ខ្ញុំជាទីសំគាល់[ដ]ដល់អ្នករាល់គ្នា
ឯការដែលខ្ញុំបានធ្វើនេះ នោះនឹងមានគេធ្វើយ៉ាងនោះដល់

**១១:២០** ក នក ៦:៧ នក ១៤:១១ ៣៤:៣០ ៣៦:២៦–២៨ ហស ១:៩ សក ៨:៨ ហព ៨:១០
**១១:២១** ខ យរ ១៦:១៨ គ យរ ១៦:១១ អគ ៩:១០ ១៦:៤៣
**១១:២២** ឃ នក ២៤:១៦ ង អគ ៩:៣ ១០:១៩
**១១:២៣** ច អគ ១:២៨ ១០:៤ ឆ សក ១៤:៤
**១១:២៤** ជ អគ ៣៧:១ ៤៣:៥ ឈ ២កថ ១២:២–៤
**១១:២៥** ញ អគ ៣:៤,១១
**១២:២** ក ទដ ៧៨:៤០ យរ ៤២:២១ ខ អស ៦:១០ មថ ១៣:១៥ មក ៤:១២ ៨:១៨
**១២:៣** គ យរ ៣៦:៣ ឃ ២៦:៣ ង ខ.១១ អគ ៣:២៧ ២ធថ ២:២៥–២៦
**១២:៤** ច ខ. ១២ ២ពវ ២៥:៤ យរ ៣៩:៤ **១២:៥** ឆ យរ ៥២:៧ អម ៤:៣
**១២:៦** ជ ខ.១២ អស ៨:១៨ ២០:៣ **១២:៧** ឈ អគ ១៧:១២ ២០:៤៩ ២៤:១៩
**១២:៩** ញ អគ ១៧:១២ ២០:៤៩ ២៤:១៩ **១២:១១** ដ អស ៨:១៨ សក ៣:៨

**១១:២២–២៥** មើលការពន្យល់ ៨:១–១១:២៥ ។

**១១:២៣** *សិរីល្អរបស់ព្រះយេហូវ៉ាយាងឡើង* សិរីល្អរបស់ទ្រង់យាងទៅទិសខាងកើត (ពេលដែលទ្រង់យាងចេញពីព្រះវិហារ) ហើយទ្រង់ឈប់នៅលើភ្នំអូលីវ (សូមមើល ៩:៣ ១០:៤ ១៩ មើលការពន្យល់ផងដែរ ៨:១–១១:២៥) ។

**១១:២៤** មើលការពន្យល់ ៨:៣ ។

**១២:១–២៨** សេចក្តីសង្ខេបពីសេចក្តីទំនាយលើកទី១ ដែលព្រះបានហៅគាត់ដើម្បីឱ្យបង្ហាញពីទីសម្គាល់ អំពីសកម្មភាពដែលគាត់ធ្វើ និងការមកដល់នៃការចាប់ទៅជាឈ្លើយរបស់ពួកក្រុងយេរូសាឡិម ។ និងសេចក្តីសង្ខេបអំពីសេចក្តីទំនាយលើកទី២ (២៤:១៥–២៧) លោកអេសេគាលបានរងទុក្ខនៅពេលដែលប្រពន្ធរបស់គាត់បានស្លាប់ ហើយវាជាសញ្ញាមួយដែលបង្ហាញពីការធ្លាក់ចុះនៃក្រុងយេរូសាឡិម ។ ខ.១–២ ដាក់ជាជំពូក មានសញ្ញាសម្គាល់២យ៉ាង (ខ.៣–១៦ ១៧–២០) គឺការបដិសេធ៍ពាក្យ២ ដែលពួកយេរ៉ូសាឡិម ព្យាយាមដោយគ្មានន័យ ដើម្បីធានាខ្លួនរបស់គេ (ខ.២១–២៥ ២៦–២៧) ។

**១២:២** *មានភ្នែកសំរាប់មើល តែមើលមិនឃើញ* ភាពរឹងចចេស អំពីការដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់លោកអេសាយ (មើល អស ៦:៨–១០) ពួកអ៊ីស្រាអែលនៅក្រុងយេរូសាឡិម បដិសេធន៍ទទួលស្គាល់ពីពេលទីបញ្ចប់មិនបានមកដល់ពួកគេឡើយ (មើល ខ.៧:២–៦) ។

**១២:៣** *ចូររៀបចំឥវ៉ាន់* ជាសញ្ញាមួយផ្សេងទៀត ដូចអស់អ្នកដែលនៅក្នុងជំពូក ៤–៥ តាមការជាក់ស្តែងនោះ ។ *ប្រហែលជាគេនឹងពិចារណាយល់* សេចក្តីសង្ឃឹមខ្លះ ដែលគេបានផ្លាស់ប្តូរ ។

**១២:៥** *ជីកទំលុះកំផែង* មិនមែនកំផែងទីក្រុងដែលបានធ្វើពីថ្ម ហើយមានកម្រាស់ខ្ពស់នោះទេ តែត្រូវយករបស់ផ្សេងធ្វើជាកំផែងនៃក្រុងនោះ ។

**១២:៦** *ទីសំគាល់* ហោរាត្រូវបានបង្រៀនឱ្យសំដែងពីទីសំគាល់ (មើល ឧទា ខ.១១ ២៤:២៤,២៧ ធៀបនឹង ១ពវ ១១:២៩–៣១ ១៣:២៣–៣២ ២០:៣៥–៤៣ អស ៨:១៨ យរ ១៣:១–១១ ១៦:១–៩ ១៩:១–១៥ ២៧:២–២៨:១៤ ៣២:៦–១៥) ។

**១២:៨** *នៅពេលព្រឹក* ក្រោយពីលោកអេសេគាល "បានធ្វើតាមព្រះរាជបញ្ជា"(ខ.៧) ។ ម្តងទៀត ការពន្យល់អំពីភាពជាព្រះ ដោយហោរាស្តាប់បង្គាប់ព្រះ ដោយឥតមានការសង្ស័យឡើយ (មើលការពន្យល់ ៨:៣) ។

**១២:៩** *អ្នកធ្វើអ្វីដូច្នេះ* ការចង្អុលបង្ហាញជាដំបូងនៃព្រះគម្ពីរនេះ គឺការឆ្លើយតបរបស់មនុស្ស ចំពោះទីសំគាល់របស់ហោរា ។

**១២:១០** *ចៅហ្វាយនៃក្រុងយេរូសាឡិម* ស្តេចសេដេគា ។

ពូជពង្សអ៊ីស្រាអែលដែរ គេនឹងត្រូវនិរទេសទៅ ព្រមទាំង
ដឹកនាំទៅជាឈ្លើយផង[ថ] ១២គ្រានោះ ចៅហ្វាយដែលនៅ
កណ្តាលពួកគេ លោកនឹងលីអីវ៉ាន់របស់លោកចេញទៅ
ក្នុងងងឹត[ឌ] គេនឹងជីកទំលុះកំផែង ដើម្បីបញ្ចេញអីវ៉ាន់តាម
នោះ លោកនឹងបាំងមុខ ដើម្បីមិនឱ្យភ្នែកឃើញស្រុក
ឡើយ[ឍ] ១៣អញនឹងលាតមង[ណ]អញទៅពីលើលោក ហើយ
លោកនឹងជាប់អន្ទាក់របស់អញ[ត] អញនឹងនាំលោកទៅឯ
បាប៊ីឡូន ជាស្រុករបស់ពួកខាល់ដេ[ថ] ប៉ុន្តែលោកនឹងមិន
ឃើញ[ទ]ស្រុកនោះទេ ទោះបើលោកស្លាប់នៅទីនោះក៏
ដោយ[ធ] ១៤អញនឹងកំចាត់កំចាយពួកអ្នកដែលនៅជុំវិញ
លោក និងកងទ័ពរបស់លោកទាំងប៉ុន្មានទៅតាមខ្យល់
គ្រប់ទិស រួចអញនឹងហូតដាវទៅតាមក្រោយគេ[ន] ១៥ដូច្នេះ
កាលណាអញបានបែងចែកគេ ទៅនៅកណ្តាលអស់ទាំង
សាសន៍[ប] ហើយបានកំចាត់កំចាយគេទៅនៅគ្រប់ប្រទេស
នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ១៦ប៉ុន្តែអញ
នឹងឱ្យមានពួកគេខ្លះ រួចពីដាវពីអំណត់អត់ នឹងពីអាសន្ន
រោគដែរ ដើម្បីឱ្យគេបានថ្លែងប្រាប់ពីគ្រប់ទាំងអំពើគួរ
ស្អប់ខ្ពើមរបស់ខ្លួន នៅកណ្តាលពួកសាសន៍ដទៃទាំងប៉ុន្មាន
ដែលគេត្រូវទៅនៅនោះ ដូច្នេះ គេនឹងដឹងថា អញនេះជា
ព្រះយេហូវ៉ាពិត[ផ] ។

១៧ព្រះបន្ទូលរបស់ព្រះយេហូវ៉ា ក៏មកដល់ខ្ញុំទៀតថា
១៨កូនមនុស្សអើយ ចូរស៊ីអាហារឯងដោយរន្ធត់[ព] ព្រម
ទាំងផឹកទឹកដោយញាប់ញ័រ ហើយថប់ព្រួយចុះ ១៩រួចចូរ
ប្រាប់ដល់ពួកជនក្នុងស្រុកថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលពីដំណើរពួកក្រុងយេរូសាឡិម និងពួកអ្នកនៅស្រុក
អ៊ីស្រាអែលថា គេនឹងស៊ីអាហាររបស់គេ ដោយភ័យខ្លាច
ហើយផឹកទឹករបស់គេដោយតក់ស្លុត ដ្បិតស្រុកគេនឹងត្រូវ
ខូចបង់ ព្រមទាំងរបស់ទាំងអស់[ភ]ដែលនៅក្នុងស្រុកនោះ
ដែរ ដោយព្រោះសេចក្តីច្រឡោតរបស់ពួកអ្នកដែលនៅ
ស្រុកនោះ[ម] ២០អស់ទាំងទីក្រុងដែលមានមនុស្សនៅ នឹង
ត្រូវបំផ្លាញ ហើយស្រុកនឹងត្រូវខូចបង់ទៅ នោះឯងរាល់
គ្នានឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[យ] ។

២១ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់ខ្ញុំថា ២២កូន
មនុស្សអើយ ពាក្យទំនៀម[រ]យ៉ាងណានោះ ដែលឯងរាល់
គ្នាធ្លាប់និយាយ នៅស្រុកអ៊ីស្រាអែល ដោយថា កំណត់
ថ្ងៃបានបន្ថយទៅ ហើយគ្រប់ទាំងការជាក់ស្តែងក៏ខាន
មាន[ល] ២៣ដូច្នេះត្រូវឱ្យប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ អញនឹងធ្វើឱ្យពាក្យទំនៀមនោះបាត់
ទៅគេ នឹងលែងប្រើពាក្យនោះទុកជាទំនៀម នៅស្រុក
អ៊ីស្រាអែលទៀត ប៉ុន្តែត្រូវប្រាប់គេថា វេលាកំណត់ជិត[វ]
ដល់ហើយ ព្រមទាំងពេលដែលនឹងសំរេច តាមគ្រប់ទាំង
ការជាក់ស្តែងនោះផង[ស] ២៤ដ្បិតនឹងគ្មានការជាក់ស្តែង
ក្លែងក្លាយ ឬពាក្យទំនាយបញ្ចើច[ហ] នៅក្នុងពូជពង្ស
អ៊ីស្រាអែលទៀតឡើយ ២៥ពីព្រោះអញនេះ គឺយេហូវ៉ា
អញនឹងចេញបង្គាប់ ហើយពាក្យដែលអញប្រាប់នោះ នឹង
បានសំរេចជាពិត ឥតដែលបន្ថយទៀតឡើយ[ឡ] ដ្បិតឱពូជ
ពង្សរឹងចចេសអើយ នៅគ្រារបស់ឯង អញនឹងចេញវាចា
ហើយនិងធ្វើសំរេចតាម[អ]ផង នេះជាព្រះបន្ទូលនៃព្រះ
អម្ចាស់យេហូវ៉ា[ក] ។

**១២:១១** ថ ២ពវ ២៥:៧ យរ ១៥:២ ៥២:១៥ **១២:១២** ឌ យរ ៣៩:៤ ឍ យរ ៥២:៧ **១២:១៣** ណ អគ ១៧:២០ ១៩:៨ ៣២:៣ ហស ៧:១២ ត អស ២៤:១៧-១៨ ថ អគ ១:១៦៥៧ ទ យរ ៣៩:៧ ធ យរ ២៤:៨ ៥២:១១ បទ ៤:២០ អគ ១៧:១៦ **១២:១៤** ន ២ពវ ២៥:៥ យរ ២១:៧ អគ ៥:១០,១២ ១៧:១២ **១២:១៥** ប លវ ២៦:៣៣ **១២:១៦** ផ យរ ២២:៨-៩ អគ ៦:៨-១០ ១៤:២២ ៣៦:២០ **១២:១៨** ព បទ ៥:៩ **១២:១៩** ភ យរ ១០:២២ អគ ៦:៦-១៤ មីក ៧:១៣ សក ៧:១៤ ម អគ ៤:១៦ ២៣:២៣ **១២:២០** យ អគ ៧:២៣-២៤ យរ ៤:៧ ២៥:៩ **១២:២២** រ ទដ ៤៩:៤ ល អស ៥:១៩ អគ ១១:៣ អម ៦:៣ ២ពត ៣:៤ **១២:២៣** វ អគ ៧:៧ ស ទដ ៣៧:១៣ អគ ១៨:៣ យអ ២:១ សផ ១:១៤ **១២:២៤** ហ យរ ១៤:១៤ អគ ១៣:២៣ មីក ៣:៦ សក ១៣:២-៤ **១២:២៥** ឡ ហព ២:៣ អ ជន ១១:២៣ អគ ១៣:៦ ក ជន ២៨:៣៤ អគ ១៤:២៤ ៥៥:១១ យរ ១៦:៩ ហព ១:៥

**១២:១៣** *ពួកខាល់ដេ* មើល ២៣:២៣ អរ ៥:១២ យប ១:១៧ គេនឹងមិនមើលឃើញ ។ មនុស្សរបស់នេប៊ូក្នេសាបានចាក់បង្ខូចព្រះនេត្ររបស់ស្តេចសេដេគាល (មើល ២ពវ ២៥:៧) ។

**១២:១៤** *អញនឹងហូតដាវទៅតាមក្រោយគេ* មើល ៥:២ និងការពន្យល់ ។

**១២:១៥** *ដឹងថាអញនេះជាព្រះយេហូវ៉ាពិត* មើល ១៦:២០ មើលការពន្យល់ផងដែរ ៦:៧ ។

**១២:១៦** *ដាវ ពីអំណត់ និងពីអាសន្នរោគ* មើល ៥:១៦-២០ និងមើលការពន្យល់ ។

**១២:១៨** *ចូរស៊ីអាហារឯងដោយរន្ធត់* ទីសម្គាល់មួយទៀតរបស់ហោរាជាសេចក្តីរន្ធត់របស់លោកអេសេគាល ពោពេញទៅដោយសេចក្តីសាហាវពីព្រោះពាក្យនៅក្នុងព្រះគម្ពីរហេព្រើរ "សេចក្តីរន្ធត់" គឺបានប្រើសម្រាប់ទីកន្លែងណាមួយ ពណ៌នាអំពីការរញ្ជួយផែនដី (សូមមើល ១ពវ ១៩:១១ អម ១:១) ។

**១២:១៩** *ពួកជនក្នុងស្រុក* មើល ៧:២៧ ដោយសារសេចក្តីឃោរឃៅ មើល ៧:២៣ និងមើលការពន្យល់ ។

**១២:២២** សម្រាប់រយៈពេលជាង៣០ឆ្នាំ លោកយេរេមាបានទាយពីការដួលរលំនៃទីក្រុងយេរូសាឡិម តែទីក្រុងនៅតែមាន ដូច្នេះនៅចំណោមអ្នកស្រុកនោះ អ្នកខ្លះដែលថ្លង់គ មិនអាចស្តាប់ឮចំពោះសេចក្តីព្រមានរបស់លោកយេរេមាទេ (ខ.២) ហើយសុភាសិតក្លែងក្លាយ ធ្វើឱ្យវិលវល់ ដែលបានធ្វើឡើង ដោយពួកហោរាក្លែងក្លាយ (មើល ជំពូក ១៣ យរ ២៣:៩-៤០,២៨) បាននិយាយហាក់ដូចជាត្រឹមត្រូវ "ថ្ងៃបានបន្ថយទៅ" ហើយគ្រប់ទាំងការជាក់ស្តែង ក៏ខានមាន នោះជាការបំភាន់ ដូច្នេះចូរបំភ្លេចពួកគេចុះ ។

**១២:២៣** ព្រះអម្ចាស់ជិទាស់ពាក្យទំនៀមរបស់ពួកអ៊ីស្រាអែល (ខ.២២) ដែលគេមិនបានស្តាប់តាមពាក្យទំនាយរបស់ហោរា ដោយអាងលើការកាត់ក្តីរបស់ពួកគេ ។

**១២:២៤** *ដ្បិតនឹងគ្មានការជាក់ស្តែងក្លែងក្លាយ ឬពាក្យទំនាយបញ្ចើច* ទ្រង់នឹងបិទមាត់ហោរាក្លែងក្លាយ "ការជាក់ស្តែងនោះ ជាការក្លែងក្លាយ ហើយពាក្យទំនាយបញ្ចើចរបស់គេ គឺជាការកុហក" (១៣:៦) ។

២៦ព្រះបន្ទូល នៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំទៀតថា
២៧កូនមនុស្សអើយ មើល ពូជពង្សអ៊ីស្រាអែល គេនិយាយ
ថា ការជាក់ស្តែងដែលគាត់ឃើញ នោះសំដែងពីគ្រាទៅ
មុខជាយូរ គាត់ទាយពីវេលា ដែលនៅឆ្ងាយនៅឡើយ[ខ]
២៨ដូច្នេះ ចូរប្រាប់ដល់គេថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ នឹងគ្មានពាក្យរបស់អញណាមួយត្រូវបន្ថយ
ទៀតឡើយ គឺពាក្យដែលអញបញ្ចេញ នោះនឹងបាន
សំរេចជាពិត នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ។

## ហោរាក្លែងក្លាយត្រូវទទួលទោស

**១៣** ១ព្រះបន្ទូលរបស់ព្រះយេហូវ៉ា បានមកដល់ខ្ញុំថា
២កូនមនុស្សអើយ ចូរទាយទាស់នឹងពួកហោរា[ក]នៃសាសន៍
អ៊ីស្រាអែលដែលធ្លាប់ទាយ ហើយប្រាប់ដល់ពួកអ្នកដែល
ទាយចេញពីចិត្តខ្លួនគេចុះ[ខ] ដោយពាក្យថា ចូរស្តាប់ព្រះ
បន្ទូលនៃព្រះយេហូវ៉ា[គ] ៣ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ វេទនាដល់ពួកហោរាល្ងីល្ងើ[ឃ]ដែលទាយតាម
តែចិត្តរបស់ខ្លួន ឥតមានឃើញអ្វីឡើយ[ង] ៤ឱពួកអ៊ីស្រាអែល
អើយ ពួកហោរារបស់ឯងបានធ្វើដូចជាឆ្កែចចក នៅទី
ចោលស្ងាត់ ៥ឯងរាល់គ្នាមិនបានឡើងទៅឯចន្លោះដែល
គេបំបាក់ទំលាយកំផែងទេ ក៏មិនបានសង់[ច]កំផែងឡើង
ការពារពួកអ៊ីស្រាអែល ដើម្បីឱ្យគេអាចឈរនៅក្នុងគ្រា
ចំបាំង នៅថ្ងៃនៃព្រះយេហូវ៉ានោះដែរ[ឆ] ៦គេបានឃើញ
សេចក្តីភូតភរ[ជ] និងពាក្យទំនាយកុហក ហើយក៏ថា ព្រះ
យេហូវ៉ាទ្រង់មានបន្ទូល តែព្រះយេហូវ៉ាទ្រង់មិនបានចាត់[ឈ]
គេសោះ ហើយគេធ្វើឱ្យមនុស្សសង្ឃឹមថា ពាក្យនោះនឹង
បានសំរេចជាពិត[ញ] ៧ការដែលឯងរាល់គ្នាថា ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ តែអញមិនបានពោលសោះ នោះ
តើមិនមែនជាឃើញការជាក់ស្តែងកំភូត[ដ]ហើយនឹងទំនាយ
កុហកទេឬអី ។
៨ហេតុនោះព្រះអម្ចាស់យេហូវ៉ាទ្រង់ មានបន្ទូលដូច្នេះ
ថា ដោយព្រោះឯងរាល់គ្នាបញ្ចេញសេចក្តីកំភូត ហើយ
ឃើញពាក្យកុហកដូច្នេះ បានជាព្រះអម្ចាស់យេហូវ៉ាទ្រង់
មានបន្ទូលថា មើល អញទាស់នឹងឯងរាល់គ្នាហើយ[ឋ] ៩ដៃ
អញក៏ទាស់នឹងពួកហោរា ដែលឃើញការជាក់ស្តែង កំភូត
ហើយដែលទាយសេចក្តីកុហកនោះ[ឌ] គេនឹងមិននៅក្នុងពួក
ប្រឹក្សារបស់រាស្ត្រអញឡើយ ក៏មិនបានកត់ទុកក្នុង បញ្ជី[ឍ]នៃ
ពូជពង្សអ៊ីស្រាអែល ឬចូលទៅក្នុងស្រុកអ៊ីស្រាអែលដែរ
នោះឯងរាល់គ្នានឹងដឹងថា អញនេះជាព្រះអម្ចាស់យេហូវ៉ា
ពិត[ណ] ១០ពីព្រោះ គឺពីព្រោះតែគេបានលួងលោមបញ្ឆោត
រាស្ត្រអញ[ត] ដោយចេញពាក្យថា "សន្តិសុខ"[ថ] តែគ្មាន

**១២:២៧** ខ អគ ១១:៣ ដយ ១០:១៤ មថ ២៤:៤៨-៥០ ២ពត ៣:៤ **១៣:២** ក អស ៩:១៥ ខ យរ ២៨:១៥ គ ខ.១៧ យរ ២៣:១៦ ៣៧:១៩ អគ ២២:២៨ **១៣:៣** ឃ បទ ២:១៤ ហស ៩:៧ ង យរ ២៣:២៥-៣២ **១៣:៥** ច អស ៥៨:១២ អគ ២២:៣០ ឆ អគ ៧:១៩ ៣០:៣ **១៣:៦** ជ យរ ៥:១ ២៣:១៦ ឈ យរ ១៤:១៤ ញ យរ ២៨:១៥ ២៩:៩ អគ ១២:២៤-២៥ ២២:២៨ **១៣:៧** ដ អស ៣០:១០ **១៣:៨** ឋ យរ ២១:១៣ **១៣:៩** ឌ ចទ ១៣:៣ **១៣:៩** ឍ នក ៣២:៣២ យរ ១៧:១៣ ណ នក ៦:២ យរ ២០:៣-៦ អគ ២០:៣៨ **១៣:១០** ត យរ ២៣:១៣ ៥០:៦ ថ យរ ៤:១០

**១២:២៧** ពាក្យទំនៀមដទៃទៀត (មើលការពន្យល់ ខ.២៣) គឺបានកន្លងហួសនៅក្នុងពួកអ៊ីស្រាអែល តែវាឃើញមាននៅក្នុងពួក អ្នកដែលជាប់ជាឈ្លើយវិញ ។ វាទាក់ទិនទៅនឹង "ការជាក់ស្តែង" របស់លោកអេសេគាល ហើយគេមិនជឿថា ការជាក់ស្តែងនោះពិត និងគេថាការជាក់ស្តែងនោះនៅឆ្ងាយ នៅឡើយហេតុនេះពួកគេមិនចាំបាច់ព្រួយបារម្ភ ដល់ពួកអ្នកជំនាន់នេះឡើយ ។

**១២:២៨** *នឹងគ្មានពាក្យរបស់អញណាមួយត្រូវបន្ថយទៀតឡើយ* ព្រះអម្ចាស់ក៏បានជំទាស់ពាក្យទំនៀម (ខ.២៧) ដែលវិលវល់នៅក្នុង "រាស្ត្រដែលបះបោរ" (មើលការពន្យល់ ១២:១-២៨) ។

**១៣:១-២៣** ព្រះអម្ចាស់ទ្រង់ដាក់ទណ្ឌកម្មលើពួកហោរាក្លែងក្លាយ ទាំងបុរស និងស្ត្រី តាមរយៈលោកយេរេមានៅក្រុងយេរូសាឡិម (យរ ២៣:៩-៤០ ២៨) តាមរយៈលោកអេសេគាលនៅក្រុងបាប៊ីឡូន ។ ការនេះគឺចាប់ផ្តើមតាមផ្នែកនៃសេចក្តីទំនាយ ចំពោះសេចក្តីជំនុំជម្រះរបស់ព្រះទៅលើពួកយូដា និងទីក្រុងយេរូសាឡិម វាប្រៀបដូចជាថ្លាងដែលកំពុងនៅលើភ្លើង (២៤:១-១៤) ។

**១៣:២** *ពួកអ្នកដែលទាយចេញពីចិត្តខ្លួនគេ* ឧយោង ២៣:១៦,២៦-៣២ ។

**១៣:៣** *ឥតមានឃើញអ្វីឡើយ* ដោយគ្មានការបើកសំដែងណាដែលមក ដែលគេបានទទួលពីព្រះអម្ចាស់នោះទេ (ឧយោង យរ ២៣:១៨ ២២ និងការពន្យល់ ២៣:១៨) ។

**១៣:៤** *ឆ្កែចចក* ជាប្រភេទសត្វដែលដើរជាហ្វូង ហើយស៊ីសាច់សត្វងាប់ជាអាហារ ហើយវាតំណាងរូបសំណាក់ដែលមានអំណាច (មើល ទដ ៦៣:១០ បទ ៥:១៨) ។

**១៣:៥** *សង់កំផែងឡើងការពារពួកអ៊ីស្រាអែល* នេះជាតួនាទីរបស់ហោរាត្រឹមត្រូវ (ឧយោង ២២:៣០ ទដ ១០៦:២៣) ថ្ងៃរបស់ព្រះអម្ចាស់ មើលការពន្យល់ ៧:៧ ។

**១៣:៦** *សេចក្តីភូតភរ និងពាក្យទំនាយកុហក* នៅពេលណាដែលហោរាក្លែងក្លាយឃើញការជាក់ស្តែងកំភូត តែគេបែរជាប្រកាសថា គេបានទទួលការបើកសម្តែងមកពីព្រះ ប៉ុន្តែពាក្យថ្លែងរបស់គេ គឺគ្រាន់តែជាការឡើងទៅតាមចិត្តរបស់ពួកបណ្តាជនប៉ុណ្ណោះ (មើល អស ៣០:១០ យរ ២៣:៩-១៧ ២ធថ ៤:៣) ។

**១៣:៨** *អញទាស់នឹងឯងរាល់គ្នាហើយ* មើល ៥:៨ និងការពន្យល់ ។

**១៣:៩** *គេនឹងមិននៅក្នុងពួកប្រឹក្សារាស្ត្រអញឡើយ . . . ឬចូលទៅក្នុងស្រុកអ៊ីស្រាអែលដែរ* ព្រះទ្រង់ដាក់ទណ្ឌកម្មលើគេមួយជាបីទៅលើពួកគេ ចាប់តាំងពីពួកអ្នកសហគមន៍ ពួកប្រឹក្សានៃរាស្ត្ររបស់ព្រះ មើល ទដ ១១១:១ រាប់ចំនួនផ្ទះអ៊ីស្រាអែល មើល អរ ២:៦២ ធៀបនឹង ដយ ១២:១ មើល ទដ ៦៩:២៨ និងការពន្យល់ ។

**១៣:១០** *ចេញជាពាក្យថា "សន្តិសុខ"* វាដូចជាសម្លេងនៃសេចក្តីអធិស្ឋានរបស់សង្ឃ (មើល ជន ៦:២៤-២៦ និងការពន្យល់ ៦:២៦) ការព្រងើយចំពោះការពិត ដែលជាសេចក្តីសន្យារបស់ព្រះចំពោះ "សន្តិសុខ" សម្រាប់រាស្ត្ររបស់ទ្រង់ គេត្រូវតែស្មោះត្រង់ចំពោះទ្រង់ នៅពេលណាគ្មានសន្តិសុខ

សេចក្តីសន្តិសុខសោះប៉ុណ្ណោះឯង រាស្ត្រអញធ្វើកំផែង
ឡើង តែចំណែកគេៗបូកដោយល្បាប់វិញ[ទ] ១១ចូរប្រាប់
ដល់ពួកអ្នកដែលបូកដោយល្បាប់នោះថា កំផែងនោះនឹង
រលំទៅ ដោយមានភ្លៀងរំលា ហើយឯង ឱគ្រាប់ព្រឹល
យ៉ាងធំ[ធ]អើយ ឯងនឹងធ្លាក់មក[ន] ក៏នឹងមានខ្យល់ព្យុះយ៉ាង
ខ្លាំងបំបាក់រលំកំផែងទៅ[ប] ១២ដូច្នេះ កាលណាកំផែងបាន
រលំហើយ នោះតើគេមិនសួរឯងរាល់គ្នាទេឬអីថា ល្បាប់
ដែលឯងរាល់គ្នាបានបូកនោះ តើនៅឯណា ១៣ហេតុនោះ
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា អញនឹងរំលំ
កំផែងនោះ ដោយខ្យល់គំហុក ក្នុងសេចក្តីក្រោធរបស់អញ
ហើយនិងមានភ្លៀងរំលា[ផ]ដោយសេចក្តីកំហឹងរបស់អញ
ព្រមទាំងគ្រាប់ព្រឹលយ៉ាងធំ[ព] ដោយសេចក្តីឃោរឃៅ
របស់អញ ដើម្បីនឹងបំផ្លាញបង់[ភ] ១៤គឺ យ៉ាងនោះដែលអញ
នឹងរំលំកំផែង[ម] ដែលឯងរាល់គ្នាបានបូកដោយល្បាប់នោះ
អញនឹងរំលំចុះដល់ដី ឱ្យឫស[យ]បានបើកឱ្យឃើញ កំផែង
នោះនឹងរលំចុះ[រ] ហើយឯងរាល់គ្នា នឹងសាបសូន្យទៅ
នៅកណ្តាលនោះផង ដូច្នេះឯងរាល់គ្នានឹងដឹងថា អញនេះ
ជាព្រះយេហូវ៉ាពិត ១៥គឺយ៉ាងនោះ ដែលអញនឹងសំរេច
សេចក្តីក្រោធរបស់អញនៅលើកំផែងនោះ ហើយលើពួក
អ្នកដែលបានបូកដោយល្បាប់ផងដែរ រួចអញនឹងនិយាយ
នឹងឯងរាល់គ្នាថា កំផែងនោះមិនមានទៀតទេ ព្រមទាំង
ពួកអ្នកដែលបូកផង ១៦គឺជាពួកហោរា របស់សាសន៍
អ៊ីស្រាអែល ដែលទាយពីដំណើរក្រុងយេរូសាឡិម ហើយ
ឃើញការជាក់ស្តែងពីសេចក្តីសុខសំរាប់ទីក្រុង តែឥត
មានសេចក្តីសុខឡើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
យេហូវ៉ា[ល]។

១៧ឯងឯង កូនមនុស្សអើយ ចូរតាំងមុខ[វ]ទាស់នឹងពួក
កូនស្រី[ស]របស់សាសន៍ឯង ដែលទាយចេញពីចិត្តខ្លួនគេ
ហើយទាយទាស់នឹងគេ[ហ] ១៨ដោយពាក្យថា ព្រះអម្ចាស់
យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ វេទនាដល់ពួកស្រីៗដែល
ដេរកែបកំណល់ភ្ជាប់ នៅកួយដៃមនុស្ស ហើយធ្វើស្បៃ
បាំងមុខ សំរាប់ក្បាលគ្រប់មនុស្ស ទោះទាំងធំទាំងតូច
ដើម្បីនឹងចាប់ព្រលឹងគេ ឯងរាល់គ្នារកចាប់ព្រលឹងរបស់
សាសន៍អញដូច្នេះ នោះតើនឹងអាចជួយសង្គ្រោះព្រលឹងគេ
ដែលមកឯឯងឱ្យរស់នៅបានឬ ១៩ឯងរាល់គ្នាបានបន្ទាប
បន្ថោក[ឡ]អញ នៅកណ្តាលរាស្ត្រអញ ឱ្យតែបានស្រូវ
ឱក១កំប៉ុងពីរ និងចំណិតនំបុ័ងតិចតួចប៉ុណ្ណោះ[អ] ដើម្បី
នឹងសំឡាប់ព្រលឹងមនុស្សដែលមិនគួរស្លាប់ទេ ហើយនិង
រក្សាព្រលឹងឱ្យរស់នៅ ដែលមិនគួររស់នៅវិញ ដោយ
ឯងកុហកដល់រាស្ត្រអញ ដែលស្តាប់តាមសេចក្តីកុហក
នោះឬអី[ក]។

២០ហេតុនោះ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូល
ដូច្នេះថា មើល អញទាស់នឹងកែបកំណល់របស់ឯងរាល់គ្នា
ដែលឯងប្រើសំរាប់ដេញតាមព្រលឹងមនុស្ស ឱ្យហើរទៅ
ទាក់ជាប់នោះ អញនឹងហែកចេញពីដៃឯងរាល់គ្នាវិញ
ហើយនិងលែងព្រលឹងទាំងនោះឱ្យរួច គឺជាព្រលឹងដែល
ឯងរាល់គ្នាបានរកដេញតាម ឱ្យហើរទៅទាក់ជាប់នោះ
ឯង[ខ] ២១អញនឹងហែកស្បៃរបស់ឯងរាល់គ្នាដែរ ព្រមទាំង
ជួយឱ្យរាស្ត្រអញរួចពីកណ្តាប់ដៃឯងរាល់គ្នាផង នោះគេ
នឹងមិននៅក្នុងកណ្តាប់ដៃឯងរាល់គ្នា ឱ្យឯងដេញចាប់ទៀត
ឡើយ ដូច្នេះ ឯងរាល់គ្នានឹងដឹងថា អញនេះជាព្រះយេ–
ហូវ៉ាពិត[គ] ២២ហើយដោយព្រោះឯងរាល់គ្នាបានបញ្ឈឺចិត្ត
ពួកសុចរិត ដោយសេចក្តីកំភូត[ឃ] ជាពួកអ្នកដែលអញមិន
បានឱ្យព្រួយចិត្តសោះ ហើយឯងបានចំរើនកំឡាំងដៃនៃ
មនុស្សអាក្រក់ ដើម្បីមិនឱ្យគេលះចោលផ្លូវអាក្រក់របស់
ខ្លួន ឱ្យបានសង្គ្រោះរួចជីវិតវិញឡើយ[ង] ២៣ហេតុនោះ ឯង

**១៣:១០** ទ អគ ៧:២៥ ២២:២៨
**១៣:១១** ធ យស ១០:១១ ន យប ៣៨:២៣ ប ទដ ១១:៦ អគ ៣៨:២២
**១៣:១៣** ផ យប ១៤:១៩ ព យស ១០:១១ វវ ១១:១៩ ១៦:២១ ភ នក ៩:២៥ យប ៣៨:២៣ អស ៣០:៣០
**១៣:១៤** ម អស ២២:៥ យ មីក ១:៦ រ យរ ៦:១៥
**១៣:១៦** ល អស ៥៧:២១ យរ ៦:១៤ អគ ៧:២៥
**១៣:១៧** វ អគ ៤:៧ ២៥:២ ២៨:២១ ស នក ១៥:២០ វវ ២:២០ ហ ខ.២
**១៣:១៩** ឡ យរ ៤៤:២៦ អគ ២០:៣៩ ២២:២៦ ៣៦:២០ ៣៩:៧ អ អស ៥៦:១១ ក សភ ២៨:២១ មីក ៣:១១
**១៣:២០** ខ ទដ ១២៤:៧
**១៣:២១** គ ទដ ៩១:៣
**១៣:២២** ឃ អស ៩:១៥ ង យរ ២៣:១៤ អគ ១៨:២១ ៣៣:១៤–១៦

មើល ខ.១៦ យរ ៦:១៤ និងការពន្យល់ ៨:១១ កំបោរ មើល ខ.១១ ១៤–១៥ ២២:២៨ ជាពាក្យចម្លែក ត្រូវបានប្រើដោយលោកអេសេគាលប្រហែលជាវាត្រូវបានជ្រើសរើស ដើម្បីឱ្យគេនឹកចាំពីន័យពាក្យ "វត្ថុគួរឱ្យខ្ពើម" នៅក្នុង យរ ២៣:១៣ និង "វត្ថុគ្មានតំលៃ" នៅក្នុង បទ ២:១៤ ពាក្យទាំងពីរនេះ គឺវាជាប់ទាក់ទិនទៅនឹងសេចក្តីប្រកាសរបស់ពួកហោរាក្លែងក្លាយ ។

**១៣:១១** *មានភ្លៀងរំលា* មានទាំងផ្គរលាន់ និងផ្លេកបន្ទោរ នោះគឺជាការជំនុំជម្រះរបស់ព្រះ (វាជារូបភាពមួយត្រូវបានប្រើជាញឹកញាប់ នៅសញ្ញាចាស់) ហើយត្រូវបានបក់ផាត់យកគេទៅ (មើល ឧទាហរណ៍ ទដ ១៨:៧–១៥ ៧៧:១៧–១៨ ៨៣:១៥ អស ២៨:១១៧ ៣០:៣០ យរ ២៣:១៩ ៣០:២៣) ។

**១៣:១៨** *កែបកំណល់ភ្ជាប់នៅកួយដៃមនុស្ស* របស់ដែលពួកស្រីៗធ្វើ នោះប្រហែលជាយើងអត់ស្គាល់ ប៉ុន្តែវាដូចជាក្រណាត់ពណ៌ខ្មៅម្យ៉ាង ដូចជាពាក្យវូដូ (voodoo) ព្រះគម្ពីរមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះការបកស្រាយអត្ថន័យដែលពិបាកយល់ ។

**១៣:១៩** *ឯងរាល់គ្នាបានបន្ទាបបន្ថោកអញ* មើលការពន្យល់ លវ ១៩:២១ ត្រូវនាំដង្វាយមកថ្វាយព្រះ ដោយព្រោះការរំលង វាជាប់ទាក់ទិនទៅនឹងជំនឿនៅក្នុងសាសនា នៅពេលណាដែលបណ្តាជនបានធ្វើបាប ដូចមានការចែងនៅក្នុងព្រះគម្ពីរ (មើល ឧទា. យរ ៦:១៣ ៨:១០ មីក ៣:៥,១១ កច ៨:៩–២៤ ២កថ ២:១៧ ទត ១:១១) ។ ត្រូវមានឥរិយាបទសមរម្យ និងមានការលើកទឹកចិត្តដល់គ្នា មើល ២កថ ១១:៧ ២ថន ៣:៨ ១ធថ ៣:៣ ។ *គេបានសម្លាប់ឯង* ពួកស្រីៗគេបានប្រើអំណាចនៃសេចក្តីអាក្រក់ ដោយគ្មានភាពយុតិធម៌ដល់ទីបញ្ចប់ រហូតដល់អស់ជីវិត ។

រាល់គ្នានឹងមិនឃើញការជាក់ស្តែងកំភូត[ច] ឬទាយទំនាយ
ទៀតឡើយ[ឆ] ហើយអញនឹងជួយ[ជ]រាស្ត្រអញឱ្យរួចពីកណ្តាប់
ដៃរបស់ឯង នោះឯងរាល់គ្នានឹងដឹងថា អញនេះជាព្រះ
យេហូវ៉ាពិត[ឈ]។

## ពួកថ្វាយបង្គំរូបព្រះត្រូវទទួលទោស

**១៤** ១ គ្រានោះ មានពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលខ្លះ
មកឯខ្ញុំ ហើយក៏អង្គុយនៅចំពោះមុខខ្ញុំ[ក] ២ នោះព្រះបន្ទូល
នៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា ៣ "កូនមនុស្សអើយ ពួកអ្នក
ទាំងនេះបានតាំងរូបព្រះរបស់គេ នៅក្នុងចិត្តខ្លួន[ខ] ក៏បាន
ដាក់ហេតុចំពប់[គ]របស់អំពើទុច្ចរិតខ្លួន នៅចំពោះមុខហើយ
ដូច្នេះ តើគួរឱ្យគេមកសួរអញឬអី[ឃ] ៤ ចូរឯងប្រាប់ដល់គេ
ថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ឯអស់អ្នក
ណានៅក្នុងពួកវង្សអ៊ីស្រាអែល ដែលតាំងរូបព្រះរបស់
ខ្លួននៅក្នុងចិត្ត ហើយដាក់ហេតុចំពប់នៃអំពើទុច្ចរិតរបស់
ខ្លួននៅចំពោះមុខដូច្នេះ រួចមករកហោរា នោះអញនេះ
គឺព្រះយេហូវ៉ា នឹងឆ្លើយដល់គេតាមចំនួនរូបព្រះរបស់គេ
វិញ ៥ ដើម្បីឱ្យអញបានចាប់ទោសពួកវង្សអ៊ីស្រាអែល
ដោយនូវចិត្តរបស់ខ្លួនគេ ពីព្រោះគេសុទ្ធតែព្រាត់ប្រាស់[ង]ពី
អញដោយសាររូបព្រះរបស់គេទាំងអស់ហើយ[ច]។
៦ ត្រូវឱ្យប្រាប់ដល់ពួកវង្សអ៊ីស្រាអែលថា ព្រះអម្ចាស់
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរវិលមកវិញ[ឆ] ចូរបែរ
ចេញពីរូបព្រះរបស់ឯងរាល់គ្នាទៅ ហើយងាកមុខពីអស់
ទាំងការគួរស្អប់ខ្ពើមរបស់ឯងរាល់គ្នាចុះ[ជ] ៧ ដ្បិត ឯអស់អ្នក
ណា[ឈ] ក្នុងពួកវង្សអ៊ីស្រាអែល ឬក្នុងពួកអ្នកដទៃជាអ្នកស្នាក់
នៅក្នុងស្រុកអ៊ីស្រាអែល ដែលញែកខ្លួនចេញពីអញ ហើយ
តាំងរូបព្រះរបស់ខ្លួននៅក្នុងចិត្ត ព្រមទាំងដាក់ហេតុចំពប់[ញ]
នៃសេចក្តីទុច្ចរិតរបស់ខ្លួននៅចំពោះមុខ ដូច្នេះ រួចនឹងមក
រកហោរា ដើម្បីសួរ[ដ]អញពីដំណើរខ្លួន នោះអញនេះ គឺ
ព្រះយេហូវ៉ា អញនឹងឆ្លើយដល់អ្នកនោះ ដោយខ្លួនអញ
៨ ហើយអញនឹងតាំងមុខទាស់នឹង[ឋ]អ្នកនោះ ព្រមទាំងធ្វើឱ្យ
ជាទីស្រឡាំងកាំង ជាទីសំគាល់[ឌ] និងជាពាក្យទំនៀម[ឍ] អញ
ក៏នឹងកាត់អ្នកនោះចេញពីកណ្តាលរាស្ត្រអញទៅ នោះឯង
រាល់គ្នានឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ណ] ៩ បើ
ហោរា[ត]ណាត្រូវបញ្ឆោត[ថ] ហើយបានបញ្ចេញពាក្យណា
នោះ គឺ ព្រះយេហូវ៉ា អញនេះហើយ ដែលបានបញ្ឆោតគេ
ហើយអញនឹងលូកដៃទៅលើគេ ព្រមទាំងបំផ្លាញគេចេញ
ពីពួកអ៊ីស្រាអែល ជារាស្ត្រអញទៅផង[ទ] ១០ គេនឹងត្រូវទ្រាំទ្រ
ចំពោះសេចក្តីទុច្ចរិតរបស់ខ្លួន ឯសេចក្តីទុច្ចរិតរបស់
ហោរា នោះបានដូចជាសេចក្តីទុច្ចរិត របស់អ្នកដែលរកគេ
ដែរ ១១ ដើម្បីកុំឱ្យពួកវង្សអ៊ីស្រាអែលវង្វេង[ធ]ចេញពីអញ
ឬនាំឱ្យខ្លួនបានស្មោកគ្រោក ដោយអំពើរំលងទាំងប៉ុន្មាន
របស់ខ្លួនទៀតឡើយ គឺឱ្យគេបានជារាស្ត្រអញវិញ[ន] ហើយ
ឱ្យអញបានជាព្រះរបស់គេ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
យេហូវ៉ា[ប]។

## សេចក្តីជំនុំជម្រះដែលជៀសមិនរួច

១២ ព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា ១៣ កូន

**១៣:២៣** ច នហ ៦:១២ ឆ អគ ១២:២៤ ជ ទដ ៧២:១៤ ឈ មីក ៣:៦
**១៤:១** ក អគ ៨:១ ២០:១
**១៤:៣** ខ អគ ៦:៤ គ ខ.៧ អគ ៧:១៩ ឃ អស ១:១៥ អគ ២០:៣១
**១៤:៥** ង ចទ ៣២:១៥ អគ ១៦:៤៥ ហស ៥:៧ សក ១១:៨ ច យរ ២:១១
**១៤:៦** ឆ នហ ១:៩ យរ ៣:១២ ៣៥:១៥ ជ អស ២:២០ ៣០:២២
**១៤:៧** ឈ នក ១២:៤៨ ២០:១០ ញ ខ.៣ អស ៨:១៤ ហស ៤:៥ ៥:៥ ដ លប ២៥:២២
**១៤:៨** ឋ អគ ១៥:៧ ឌ ជន ១៦:៣៨ ឍ ទដ ១០២:៨ អគ ៥:១៥ ណ យរ ៤២:២០
**១៤:៩** ត យរ ១៤:១៥ ថ អស ៦៣:១៧ យរ ៤:១០ ទ ១ពវ ២២:២៣ ២រប ១៨:២២ សក ១៣:៣ **១៤:១១** ធ អគ ៤៨:១១ ន អស ៥១:១៦ ប អគ ១១:១៩–២០ ៣៧:២៣

**១៤:១–១១** ព្រះទ្រង់ដាក់ទណ្ឌកម្មលើពួកអ៊ីស្រាអែល ពេលដែលគេថ្វាយបង្គំរូបព្រះ ដោយគេមិនបានថ្វាយបង្គំដល់ព្រះយេហូវ៉ា (Yahweh) នោះ (មើលការពន្យល់ លប ២០:៩ នក ៣៤) ពួកបណ្តាជន គិតថាគេអាចយករូបព្រះទៅតាមខ្លួនបាន ពួកអ៊ីស្រាអែលបានបោះបង់សេចក្តីជំនឿ សេចក្តីសញ្ញានៃការទំនាក់ទំនង ដែលគេបានតាំងឡើង ជាមួយព្រះយេហូវ៉ា (Yahweh) (មើល នក ២០:៣–៥) ។ ហើយពួកអ្នកដែលកំពុងរស់នៅក្រុងយេរូសាឡិម គេមានរូបព្រះជាច្រើន ដូចជាលោកអេសេគាលបានប្រឈមមុខផងដែរក្នុងចំណោមពួកអ្នក ដែលជាប់ជាឈ្លើយនោះ ។

**១៤:១** *ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែល* ដូចគ្នានិងឃ្លា "ពួកចាស់ទុំសាសន៍យូដា" (មើលការពន្យល់ ៨:១) ។

**១៤:៣** *រូបព្រះ* មើលការពន្យល់ ៦:៤ សេចក្តីអាក្រក់ សាច់ឈាម គឺតំណាងដូចរូបព្រះ ។ គេស្វែងរកសេចក្តីទំនាយមកពីហោរា (មើល ២ពវ ១:១៦ ៣:១១ ៨:៨) ។

**១៤:៤** *នោះអញនេះគឺជាព្រះយេហូវ៉ា នឹងឆ្លើយដល់គេតាមចំនួនរូបព្រះរបស់គេ* មិនមែនតាមរយៈហោរាទេ តែតាមរយៈសកម្មភាពគេផ្ទាល់ ។ ព្រះទ្រង់ដាក់ទណ្ឌកម្មលើអ្នកដែលថ្វាយបង្គំរូបព្រះ គឺសេចក្តីស្លាប់ (ចទ ១៣:៦–១៨) ។

**១៤:៦** *ចូរបែរចេញ* ការត្រាសហៅបីផ្នែកដំបូងឱ្យគេប្រែចិត្ត តាមរយៈលោកអេសេគាល សម្រាប់អស់អ្នកដែលទទួលស្គាល់ថា គេនឹងត្រូវជាប់ការជំនុំជម្រះ (មើល ១៨:៣០ ៣៣:១១) ។

**១៤:៩** *បញ្ឆោត* ពាក្យនេះទាក់ទិនទៅនឹងការសាកល្បងរបស់ព្រះ ចំពោះរាស្ត្រដែលស្មោះត្រង់របស់ទ្រង់ (មើល ៣:២០ ធៀបនឹង ១ពវ ២២:១៩–២៣) ។

**១៤:១១** ព្រះនឹងធ្វើការជំនុំជម្រះយ៉ាងធំធេង ទៅលើពួកអ៊ីស្រាអែលដែលថ្វាយបង្គំរូបព្រះ ក្រោយពេលដែលទ្រង់បានបោសលោះគេរួចពីបាប ។ ទ្រង់បានស្អាងគេឡើងវិញ ដើម្បីឱ្យគេកាន់តាមបញ្ញត្តិដ៏ស្មោះត្រង់របស់ទ្រង់ (មើល ២០:៣២–៤៤ ធៀបនឹង ៣៣:១១) ។ *គេជារាស្ត្ររបស់អញ ហើយអញធ្វើជាព្រះដល់គេ* នេះបញ្ញត្តិច្បាប់របស់ព្រះ (សូមមើលការពន្យល់ ១១:២០) ។

**១៤:១២–២៣** ពួកអ៊ីស្រាអែលត្រូវតែដឹងថា នៅថ្ងៃមួយព្រះនឹងដាក់ទណ្ឌកម្មដល់ប្រជាជាតិដែលមិនស្មោះត្រង់ គ្មានអ្នកណាអាចបញ្ចុះបញ្ចូលទ្រង់ដើម្បីហៅពួកគេឱ្យគេបែរមករកទ្រង់បានទេ ការនេះនឹងកើតមានយ៉ាងពិតប្រា

មនុស្សអើយ បើស្រុកណាធ្វើបាប[ផ]នឹងអញ ដោយប្រព្រឹត្ត
រំលងអ្វី រួចអញលូកដៃទៅលើគេ ឱ្យផ្តាច់ស្បៀងអាហារ[ព]
ហើយឱ្យគេកើតមានសេចក្តីអំណត់ ព្រមទាំងកាត់មនុស្ស
និងសត្វចេញពីស្រុកនោះផង[ភ] ១៤នោះព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលថា ទោះបើមនុស្សទាំង៣នាក់នេះ គឺ
ណូអេ[ម] ដានីយ៉ែល[យ] និងយ៉ូប[រ] បាននៅក្នុងស្រុកនោះ គង់
តែសេចក្តីសុចរិតរបស់អ្នកទាំងនោះនឹងជួយបានតែព្រលឹង
ខ្លួនឱ្យរួចប៉ុណ្ណោះទេ[ល] ១៥បើកាលណាអញឱ្យសត្វកំណាច[វ]
មកនៅក្នុងស្រុកនោះ ហើយវាសំឡាប់មនុស្សទៅ ឱ្យស្រុក
នោះនៅជាស្ងាត់ច្រៀប ដល់ម៉្លេះបានជាឥតមានអ្នកណា
ហ៊ានដើរតាមនោះឡើយ ដោយព្រោះសត្វទាំងនោះឯង[ស]
១៦នោះព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់
នៅ ទោះបើមនុស្សទាំង៣នាក់នោះនៅក្នុងស្រុកក៏ដោយ
គង់តែនឹងជួយកូនប្រុសកូនស្រីខ្លួនឱ្យរួចមិនបានដែរ រួច
បានតែខ្លួនគេប៉ុណ្ណោះ តែឯស្រុកនោះនឹងត្រូវចោលស្ងាត់
វិញ[ហ] ១៧ឬបើសិនជាអញនាំដាវ[ឡ]មកលើស្រុកនោះ ដោយ
បង្គាប់ថា ដាវអើយ ចូរដើរចុះឡើងក្នុងស្រុកចុះ ហើយ
អញកាត់ទាំងមនុស្សនឹងសត្វចេញពីនោះផង[អ] ១៨នោះព្រះ
អម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ ទោះបើ
មនុស្សទាំង៣នាក់នោះនៅក្នុងស្រុកក៏ដោយ គង់តែនឹង
ជួយកូនប្រុសកូនស្រីខ្លួន ឱ្យរួចមិនបានដែរ រួចបានតែខ្លួន
គេប៉ុណ្ណោះ ១៩ឬបើសិនជាអញនឹងចាត់ប្រើអាសន្នរោគ
ទៅក្នុងស្រុកនោះ ហើយចាក់សេចក្តីឃោរឃៅ[ក]របស់អញ
ចេញទៅលើស្រុកនោះ ដោយកំចាយឈាម[ខ] ដើម្បីនឹង
កាត់ទាំងមនុស្ស និងសត្វចេញផង[គ] ២០នោះព្រះអម្ចាស់
យេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ ទោះបើណូអេ
ដានីយ៉ែល និងយ៉ូបបាននៅក្នុងស្រុកនោះក៏ដោយ គង់តែ
នឹងជួយកូនប្រុសកូនស្រីខ្លួន ឱ្យរួចមិនបានដែរ គឺសេចក្តី
សុចរិតរបស់អ្នកទាំងនោះ នឹងជួយបានតែព្រលឹងរបស់ខ្លួន
ឱ្យរួចប៉ុណ្ណោះ[ឃ]។
២១ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា កាល
ណាអញចាត់ប្រើសេចក្តីវេទនា[ង]ទាំង៤យ៉ាងនេះ ទៅលើ
ក្រុងយេរូសាឡិម គឺជាដាវ[ច] ជាអំណត់អត់[ឆ] ជាសត្វសាហាវ
និងអាសន្នរោគ[ជ] ដើម្បីនឹងកាត់ទាំងមនុស្សនឹងសត្វចេញផង
នោះតើនឹងបានតឹងជាងអំបាលម៉ានទៅទៀត[ឈ] ២២ប៉ុន្តែ
មើល នឹងមានសំណល់សល់[ញ]នៅក្នុងក្រុងនោះ គេនឹងត្រូវ
នាំចេញមក ទាំងប្រុសទាំងស្រី មើល គេនឹងចេញមក
ឯឯងរាល់គ្នា[ដ] នោះឯងនឹងឃើញផ្លូវ នឹងអំពើ[ឋ]របស់គេ
រួចឯងនឹងបានក្សាន្តចិត្ត[ឌ] ពីដំណើរការអាក្រក់ ដែលអញ
បានទំលាក់ទៅលើក្រុងយេរូសាឡិម គឺពីគ្រប់ទាំងការ
ដែលអញបាននាំទៅលើក្រុងនោះ ២៣គេនឹងកំសាន្តចិត្ត
ឯងរាល់គ្នា ដោយឯងឃើញផ្លូវ នឹងអំពើដែលគេប្រព្រឹត្ត
ទាំងប៉ុន្មាន ហើយឯងរាល់គ្នានឹងដឹងថា ការដែលអញ
បានធ្វើដល់គេ នោះមិនមែនដោយឥតហេតុទេ នោះជា
ព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ឍ]។

## ក្រុងយេរូសាឡិម គឺជាស្រោទំពាំងបាយជូរដែលគ្មានតម្លៃ

**១៥** ១រួចព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់ខ្ញុំថា
២កូនមនុស្សអើយ តើដើមទំពាំងបាយជូរ[ក]វិសេសជាងដើម
ឈើណាទៀត ឬមែកឈើណានៅក្នុងព្រៃផង ៣តើយក
សាច់ឈើវាទៅធ្វើអ្វីបានឬ[ខ] តើមនុស្សនឹងយកកំណាត់[គ]
១បោះភ្ជាប់សំរាប់ព្យួរប្រដាប់ណាបានឬ ៤មើល គេបោះ
ទៅក្នុងភ្លើងទុកជាឧសវិញ ភ្លើងក៏ឆេះចុងសងខាង ហើយ

**១៤:១៣** ផ សភ ១៣:២១ ព លវ ២៦:២៦ ភ អគ ៥:១៦ ៦:១៤ ១៥:៨ **១៤:១៤** ម លប ៦:៨ យ ខ.២០ អគ ២៨:៣ ដយ ១:៦ ៦:១៣ រ យប ១:១ ល លប ៦:៩ យប ៤២:៩ យរ ១៥:១ អគ ៣:១៩ ១៨:២០ **១៤:១៥** វ អគ ៥:១៧ ស លវ ២៦:២២ **១៤:១៦** ហ លប ១៩:២៩ អគ ១៨:២០ **១៤:១៧** ឡ លវ ២៦:២៥ យរ ២៥:២៧ ៤២:១៦ អ អគ ២៥:១៣ សផ ១:៣ **១៤:១៩** ក សក ៧:៨ ខ អស ៣៤:៣ គ យរ ១៤:១២ អគ ៣៨:២២ **១៤:២០** ឃ ខ.១៤ **១៤:២១** ង ជន ៣៣:៤ ច អស ៣១:៨ ៣៤:៦ ៦៦:១៦ អគ ២១:៣,១៩ ឆ ២សយ ២៤:១៣ ជ យរ ១៤:១២ ២៧:៨ ឈ យរ ១៥:៣ អគ ៥:១៧ ៣៣:២៧ អម ៤:៦-១០ វវ ៦:៨ **១៤:២២** ញ យរ ៤១:១៦ ដ អគ ១២:១៦ ឋ អគ ២០:៤៣ ឌ អគ ៣១:១៦ ៣២:៣១ **១៤:២៣** ឍ យរ ២២:៨-៩ អគ ៨:៦-១៨ ៩:៩ **១៥:២** ក ទដ ៨០:៨-១៦ អស ៥:១-៧ ២៧:២-៦ យរ ២:២១ ហស ១០:១ យហ ១៥:២ **១៥:៣** ខ យរ ១៣:១០ គ អស ២២:២៣

កដនៅក្រុងយេរូសាឡិម (ធៀបនឹង យរ ១៥:១) ។ ទណ្ឌកម្មមានបួនប្រភេទ តែងតែលើកមកបញ្ជាក់នៅក្នុងព្រះគម្ពីរអេសេគាល ដូចជា : (១).សេចក្តីអំណត់ (ខ.១៣) (២).សត្វកំណាច (ខ.១៥) ដាវ (ខ.១៧) និងជំងឺអាសន្នរោគ (ខ.១៩ មើលផងដែរ ខ.២១ និងការពន្យល់ ១៥:១៦-១៧) ។

**១៤:១៤,២០** *ណូអេ ដានីយ៉ែល និងយ៉ូប* បុព្វបុរសទាំងបីដែលមានកេរ្តិ៍ឈ្មោះ ត្រូវបានជ្រើសតាំងឡើង ដើម្បីបង្ហាញនូវសេចក្តីសុចរិតរបស់ទ្រង់ទៅដល់ពួកបណ្តាជន ។ ព្រះគម្ពីរបាននិយាយអំពីសេចក្តីសុចរិតរបស់លោកដានីយ៉ែល (លោកដានីយ៉ែល និងលោកអេសេគាល បានរស់នៅជិតនាន់សម័យកាលនោះ មើល ដយ ១:១) ។

**១៤:២០** *កូនប្រុស កូនស្រី* នៅពេលដែលព្រះយាងមកជាលើកទី២ ដើម្បីធ្វើការជំនុំជម្រះដល់ប្រជាជាតិ ឬដល់បណ្តាជន នោះពួកគេមិនអាចអាងលើសេចក្តីសុចរិតរបស់អ្នកដទៃទៀតបានទេ ទោះបីជាសេចក្តីសុចរិតរបស់ឪពុកម្តាយក៏មិនអាចជួយរំដោះពួកកូនចៅរបស់ខ្លួនបានដែរ ។

**១៤:២៣** *ឯងរាល់គ្នា* ពាក្យពហុវចនៈ ឧទា. ពួកអ្នកជាប់ជាឈ្លើយនៅក្រុងបាប៊ីឡូន ។ *នឹងកំសាន្តចិត្ត* នៅពេលពួកអ្នកជាប់ជាឈ្លើយឃើញសេចក្តីអាក្រក់កើតមានឡើង ដោយសារពួកអ្នកនៅក្រុងយេរូសាឡិមបាននាំយកទៅក្រុងបាប៊ីឡូន នោះពួកគេដឹងថា ព្រះបានដាក់ទណ្ឌកម្មលើក្រុងនេះហើយ ។

**១៥:១-៨** ព្រះទ្រង់ប្រៀបធៀបទីក្រុងយេរូសាឡិម ដូចជាដើមទំពាំងបាយជូរ (មើល ទដ ៨០:៨-១៦) បើទំពាំងបាយជូរពុំមានផ្លែ នោះវាគ្មានប្រយោជន៍អ្វីទេ ប៉ុន្តែវាទុកសំរាប់ជាឧសដុត ។

**១៥:៣** *តើមនុស្សនឹងយកកំណាត់១បោះភ្ជាប់សំរាប់ព្យួរប្រដាប់ណាបានឬ* មើល អស ២២:២៣-២៥ ។

**១៥:៤** *តើមានប្រយោជន៍នឹងធ្វើការអ្វីបានឬទេ* អស (៥:១-៧) និង យរ (២:២១) បង្ហាញពីការដែលព្រះទ្រង់ខកព្រះទ័យ ចំពោះភាពបរាជ័យ

កណ្ដាលក៏ឆេះដែរ តើមានប្រយោជន៍នឹងធ្វើការអ្វីបានឬ
ទេ[យ] ៥មើល កាលនៅជាទាំងមូលនៅឡើយ ក៏ប្រើធ្វើ
ការអ្វីមិនបានទៅហើយ ចំណង់បើកាលណាភ្លើងបាន
ឆេះអស់ទៅ សល់នៅតែរងើកប៉ុណ្ណោះ នោះតើនឹងប្រើ
ការអ្វីណាបាន ៦ហេតុនោះព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះថា ឯដើមទំពាំងបាយជូរក្នុងពួកដើមឈើនៅ
ព្រៃទាំងប៉ុន្មាន ដែលអញបានប្រគល់ដល់ភ្លើងទុកជាឧស
យ៉ាងណា នោះអញនឹងប្រគល់ពួកក្រុងយេរូសាឡិមទៅ
យ៉ាងនោះដែរ ៧ហើយអញនឹងតាំងមុខទាស់[ង]នឹងគេ គេ
នឹងចេញពីភ្លើង១[ច,ឆ] តែភ្លើង១ទៀតនឹងឆេះគេទៅ នោះ
ឯងរាល់គ្នានឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុងកាល
ដែលអញតាំងមុខទាស់នឹងគេ[ជ] ៨អញនឹងធ្វើឱ្យស្រុកនេះ
ត្រូវចោលស្ងាត់[ឈ] ដោយព្រោះគេបានប្រព្រឹត្តរំលង[ញ] នេះ
ជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ។

**១៥:៤** យ អគ ១៧:៣–១០ ១៩:១៤ យហ ១៥:៦ **១៥:៧** ង លវ ២៦:១៧ ទដ ៣៤:១៦ អគ ១៤:៨ ច អគ ៥:២ ឆ អគ ៥:៤ ជ អស ២៤:១៨ អម ៩:១–៤ **១៥:៨** ឈ អគ ១៤:១៣ ញ អគ ១៧:២០ ១៨:២៤ **១៦:២** ក អស ៥៧:១២ អគ ២៣:៣៦ ខ អគ ៨:១៧ ២០:៤ ២២:២ **១៦:៣** គ លប

## ការចោទប្រកាន់ក្រុងយេរូសាឡិមដែលមិនស្មោះត្រង់

**១៦** ១ព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំម្ដងទៀតថា
២កូនមនុស្សអើយ ចូរធ្វើ[ក]ឱ្យក្រុងយេរូសាឡិមស្គាល់អំពើ
គួរស្អប់ខ្ពើមរបស់ខ្លួនចុះ[ខ] ៣ហើយប្រាប់ថា ព្រះអម្ចាស់
យេហូវ៉ា ទ្រង់មានបន្ទូលនឹងក្រុងយេរូសាឡិមដូច្នេះ ជិនួរ
វង្ស[គ] និងកំណើតរបស់ឯង នោះចេញពីស្រុករបស់សាសន៍
កាណាន មកឪពុក[ឃ]ឯងជាសាសន៍អាម៉ូរី[ង] ហើយម្ដាយឯង
ជាសាសន៍ហេត[ច] ៤ឯកំណើតឯង គឺនៅថ្ងៃដែលឯងកើត
មក[ឆ] នោះគេមិនបានកាត់ផ្ចិតឯងទេ ក៏មិនបានលាងជិរះឯង
ដោយទឹក ឬលាបអំបិល ឬរុំសំពត់ឱ្យផង ៥គ្មានភ្នែកណា
ប្រណីឯង ដើម្បីនឹងធ្វើការទាំងនោះដល់ឯង ដោយ
អាណិតអាសូរចំពោះឯងឡើយ គឺគេបោះចោលឯងនៅទី

១១:២៥–២៩ អគ ២១:៣០ ឃ លប ១២:១៨ ង លប ១៥:១៦ ច ខ.៤៥ លប ១០:១៥ ចទ ៧:១ យស ២៤:១៤–១៥ **១៦:៤** ឆ ហស ២:៣

ដែលពួកអ៊ីស្រាអែល មិនបានបង្កើតផលផ្លែល្អថ្វាយដល់ទ្រង់ ហើយលោកអេសេកាល ក៏បានសោកស្ដាយផងដែរ ចំពោះការដែលពួកគេមិនបានបង្កើតផលផ្លែល្អនោះ ។

**១៥:៧** *គេនឹងចេញពីភ្លើង១* នៅពេលដែលទីក្រុងយេរូសាឡិមត្រូវបានឡោមព័ទ្ធក្នុងឆ្នាំ ៥៩៧ គ.ស នៅពេលនោះហើយដែលពួកអ៊ីស្រាអែលត្រូវបានចាប់ទៅជាឈ្លើយ ហើយលោកអេសេកាល ក៏បានភាសខ្លួនទៅជាមួយពួកគេផងដែរ (មើល ១:២ ២ពវ ២៤:១០–១៦) ។ *តែភ្លើង១ទៀតនឹងឆេះគេទៅ* សេចក្ដីទំនាយចំពោះការឡោមព័ទ្ធ និងការបំផ្លិចបំផ្លាញនៃទីក្រុង ហើយត្រង់នេះ គឺជាសេចក្ដីទំនាយដ៏សំខាន់របស់លោកអេសេកាល មុនឆ្នាំ ៥៨៦ គ.ស (មើល ៥:២,៤ ១០:២,៧) ។

**១៦:១–៦៣** ការលំអិតនៃប្រវត្តិសាស្ត្រទាំងអស់របស់ព្រះ ជាមួយនឹងទីក្រុងយេរូសាឡិម គឺបានសរសេរចារឹតជារូបភាពបង្ហាញជាពិសេស ដើម្បីបញ្ជាក់ពីភាពអស្ចារ្យរបស់ព្រះអម្ចាស់ ហើយម្យ៉ាងវិញទៀតស្នាដៃទាំងអស់នេះបានបង្ហាញពីការស៊ីជម្រៅនៃទីក្រុង និងបញ្ជាក់បង្ហាញពីមនុស្សដទៃទៀត ដែលរស់នៅដែលពុំមានភាពស្មោះត្រង់ចំពោះទ្រង់ ។ ទីក្រុងយេរូសាឡិមនៅទីនេះ គឺប្រៀបដូចជាទីក្រុងស្ដេចនៅក្នុងចំណោមទីក្រុងទាំងឡាយនៃពិភពលោក និងផ្ដោតទៅលើការបម្រើអ្វីមួយផ្សេងទៀត ហើយនិងតំណាងឱ្យប្រទេសអ៊ីស្រាអែល ។ យេរូសាឡិម គឺជាទីក្រុងរបស់ព្រះអម្ចាស់ ដែលបានជ្រើសរើសទុកជាវិហារដែលទ្រង់សណ្ឋិត (១ពវ ៩:៣ ២របា ៧:១–៣ ទដ ៦៨:១៦ ៧៨:៦៨–៦៩ ១៣២:១៣–១៦) ។ ហើយបានលើកតម្កើងទីក្រុងយេរូសាឡិមដូចជា "ទីក្រុងដ៏អស្ចារ្យនៃស្ដេច" (ទដ ៤៨:២) ទីក្រុងនេះ គឺជាមជ្ឈមណ្ឌលនៃលោកិយ ទុកសម្រាប់ជាច្បាប់ដល់ស្ដេចនឹងកិច្ចការរបស់មនុស្ស ។ ទ្រង់បានរៀបការជាមួយនាង (ខ.៨ និងការពន្យល់) ហើយបានទ្រង់បានទំនុកបម្រុងដល់នាង ពេញដោយទ្រព្យសម្បត្តិដ៏ហូរហៀរ ប៉ុន្តែ នាងបានវិលបែរទៅរកព្រះក្លែងក្លាយដែលនាងត្រូវការ ហើយនាងបានចងសម្ព័ន្ធភាពជាមួយការអស្ចារ្យ និងឥទ្ធិពល ដែលនៅជុំវិញនាង ។ ដូចជាប្រទេសអេស៊ីព្ទ (ខ.៦) ប្រទេសអាសេរី (ខ.២៨) ហើយនិងទីក្រុងបាប៊ីឡូន (ខ.២៩) ដើម្បីសន្តិសុខរបស់នាង ។ ដូច្នេះព្រះអម្ចាស់ បានដាក់បណ្ដាសាដល់នាងដែលពុំមានសេចក្ដីជំនឿលើ ទ្រង់ប្រៀបដូចជាប្រពន្ធផិតក្បត់ (សូមមើល នក ៣៤:១៥ និងការពន្យល់) ។

**១៦:៣** *ជិនួរវង្សនិងកំណើតរបស់ឯង* ទីក្រុងយេរូសាឡិម បានសង់ឡើងជាច្រើនសតវត្សរ៍មកហើយ និងជាប្រវត្តិសាស្ត្រនៃប្រជាជនអ៊ីស្រាអែលរហូតដល់ពេលបច្ចុប្បន្ននេះ (សូមមើលការពន្យល់នៅក្នុង លប ១៤:១៨ សស ១:១៦) ហើយទីក្រុងនេះប្រជាជនអ៊ីស្រាអែលបានដណ្ដើមសញ្ជ័យជាយូរលង់មកហើយ (យស ១៥:៦៣) ។ វាបានក្លាយជាពោរពេញទៅដោយប្រជាជនអ៊ីស្រាអែលតែមួយគាត់ ដែលបានរស់ក្រោយពីសញ្ជ័យរបស់ស្ដេចដាវីឌ (២សយ ៥:៦–៩) ។ *ឪពុកឯង . . . ហើយម្ដាយឯង* យោងតាមសេចក្ដីបញ្ជាក់ពីទីក្រុងយេរូសាឡិមសព្វថ្ងៃ គឺគ្មានប្រជាជនអ៊ីស្រាអែលជិនាន់ដើមណាដែលជាក់លាក់ពិតប្រាកដឡើយ ។ *សាសន៍អាម៉ូរី* ធៀបនឹង ខ.៤៥ គឺដូចជាសាសន៍កាណាន សាសន៍អាម៉ូរី គឺជាសាសន៍អ៊ីស្រាអែលបច្ចុប្បន្ន ។ ចំណែកពួកមជ្ឈឹមបូព៌ា គឺប្រើភាសារបស់សាសន៍កាណាន (សូមមើល លប ១០:១៦ និងការន្យល់ ៤៨:២២ យស ៥:១ ហើយនិងការពន្យល់ ១០:៥ ពច ១:៣៤–៣៦) ។ *សាសន៍ហេត* គឺជាពួកមជ្ឈឹមបូព៌ា ហើយមិនបានតាំងទីលំនៅជាមួយពួកសាសន៍កាណានទេ សាសន៍នេះបានរីកដុះដាលយ៉ាងឆាប់រហ័ស នៅក្នុងអាស៊ីមីណ័រក្នុងកំឡុងពេលពីពាន់ ឆ្នាំមុន គ.ស (សូមមើល លប ១០:១៥ និងការពន្យល់ ២៣:១០–២០ ២៦:៣៤ ១សយ ២៦:៦ ២សយ ១១:២–២៧ ១ពវ ១១:១) ។

**១៦:៤** *លាបអំបិល* គឺពួកគេបានអនុវត្តន៍ប្រើអំបិល លាបលើផ្ចិតទារកក្នុងចំណោមអ្នកស្រែអារ៉ាប់មានចុងក្រោយបំផុតនៅ គ.ស ១៩១៨ ។ *រុំសំពត់* ធៀបនឹង លក ២:៧ ។

**១៦:៥** *គឺគេបោះចោលឯងនៅទីវាលទទេ* គឺពួកគេត្រូវបានបោះបង់ចោលឱ្យស្លាប់នៅឯវាលរហោស្ថាន ជាទារកដែលបានឃើញពន្លឺព្រះអាទិត្យជាធម្មតាមានតាំងពីបុរាណមកនៅក្នុងសង្គមអ្នកដែលមិនជឿដល់ព្រះ គេតែងតែប្រព្រឹត្តយ៉ាងដូច្នេះ ហើយការប្រព្រឹត្តបែបនេះ គឺជាទីស្អប់ខ្ពើមចំពោះ

វាលទទេ ពីព្រោះគេខ្ពើមរូបឯង ក្នុងថ្ងៃដែលឯងបានកើត
មកនោះ ។
៦កាលអញបានដើរតាមនោះជិតឯង ឃើញឯងឈ្លី
ឈ្លក់នៅក្នុងឈាមខ្លួន នោះអញបាននិយាយទៅឯងក្នុង
កាលដែលនៅក្នុងឈាមនោះថា ចូរមានជីវិតទៅចុះ អើ
កាលឯងនៅក្នុងឈាមឯងនោះ អញបានថា ចូរមានជីវិត
នៅចុះ[ជ] ៧អញក៏ធ្វើឱ្យឯងមានវ័យចំរើនឡើង[ឈ]ដូចជាស្មៅ
នៅវាល ហើយឯងបានកើនឡើងត្រឡប់ជាធំ ដល់ទៅមាន
រូបឆើតល្អ ដោះឯងបានដុះពេញរាងឡើងសក់ឯងក៏បាន
វែងហើយ ប៉ុន្តែឯងនៅជាអាក្រាត ហើយខ្លួនទទេ[ញ]
៨គ្រានោះ កាលអញបានដើរតាមទីនោះមើលឯង នោះ
ឃើញថា ដល់ពេលស្រឡាញ់ហើយ ដូច្នេះអញបាន
យកជាយអាវ[ដ]អញគ្របលើឯង ព្រមទាំងបិទបាំងសណ្ឋាន
អាក្រាតរបស់ឯង អើ អញបានស្បថនឹងឯង ហើយតាំង
សញ្ញា[ឋ]នឹងឯងផង នោះឯងបានត្រឡប់ជារបស់ផងអញ[ឌ]
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ៩ខណនោះ អញ
បានលាងឯងដោយទឹក អើ អញបានជំរះ[ឍ]ឈាមឯងចេញ
យ៉ាងស្អាត រួចចាក់ប្រេងលាបឱ្យ ១០អញបានតែងតួឯង
ដោយសំពត់ប៉ាក់[ណ] ក៏បំពាក់ស្បែកជើងធ្វើពីស្បែកផ្សោតឱ្យ
ឯង ហើយក្រវាត់ឯងដោយសំពត់ទេសឯក[ត] រួចគ្រលុំ

១៦:៦ ជ ខ.២២ នក ១៩:៤ អគ ១៨:២៣,៣២
១៦:៧ ឈ ចទ ១:១០ ញ នក ១:៧
១៦:៨ ដ នរ ៣:៩ ឋ ខ.៥៩ យរ ១១:១០ មឡ ២:១៤ ឌ យរ ២:២ ហស ២:៧,១៩–២០
១៦:៩ ឍ នរ ៣:៣
១៦:១០ ណ នក ២៦:៣៦ អស ១៩:៩ ត អគ ២៧:១៦ ថ ខ.១៨ អស ៣:២៣
១៦:១១ ទ យរ ៤:៣០ អគ ២៣:៤០ ធ អស ៣:១៩ អគ ២៣:៤២ ន លប ៤១:៤២ ទដ ៧៣:៦
១៦:១២ ប អស ៣:២១ ផ លប ៣៥:៤ ព អស ២៨:៥ យរ ១៣:១៨ ភ សភ ១:៩ អស ៣:១៩

ដោយសំពត់ព្រៃ[ថ] ១១ក៏បានតាក់តែងឯងដោយគ្រឿងលំអ[ទ]
បានបំពាក់កង[ធ]នៅដៃឯង ហើយខ្សែ[ន]នៅក ១២ព្រមទាំង
បំពាក់ក្រវិលនៅច្រមុះ[ប] ហើយទំហូ[ផ]នៅត្រចៀក និងក្បាំង
យ៉ាងល្អ[ព]នៅក្បាលឯង[ភ] ១៣ដូច្នេះ ឯងបានប្រដាប់ដោយ
មាស ហើយនិងប្រាក់ ឯសំលៀកបំពាក់[ម]របស់ឯង នោះ
បានធ្វើពីសំពត់ទេសឯកយ៉ាងម៉ដ្ត និងព្រៃ ហើយសំពត់
ប៉ាក់ ឯងបានចិញ្ចឹមខ្លួនដោយម្សៅយ៉ាងម៉ដ្ត ទឹកឃ្មុំ
និងប្រេង[យ] ឯងមានរូបល្អឆើតក្រៃលែង ហើយបានចំរើន
ឡើងដល់ទៅមានអំណាចជាស្តេច[រ] ១៤ឯកិត្តិស័ព្ទ[ល] ពីលំអរុង
រឿង[វ]របស់ឯង បានខ្ចរខ្ចាយទៅដល់អស់ទាំងនគរ ពីព្រោះ
លំអរបស់ឯងបានគ្រប់លក្ខណ៍ ដោយសាររស្មីរបស់អញ
ដែលអញបានឱ្យស្ថិតលើឯង នេះហើយជាព្រះបន្ទូលនៃ
ព្រះអម្ចាស់យេហូវ៉ា[ស] ។
១៥ប៉ុន្តែឯងបានទុកចិត្តនឹងរូបលំអរបស់ឯង ហើយបាន
ធ្វើជាស្រីសំផឹង ដោយព្រោះល្បីឈ្មោះនោះ ក៏បានត្រូវការ
នឹងអស់អ្នកណាដែលដើរកាត់មុខឯង[ហ] ឯងបានសំរាប់ជា
របស់គេហើយ[ឡ] ១៦ឯងបានយកសំលៀកបំពាក់របស់ឯង

**១៦:១៣** ម នអ ៥:១ យ ១សយ ១០:១ រ ចទ ៣២:១៣–១៤ ១ពវ ៤:២១ នអ ២:៩,១៧ **១៦:១៤** ល ១ពវ ១០:២៤ **១៦:១៤** វ នអ ១:១១ ទដ ៤៨:២ បទ ២:១៥ ស អគ ៥:៥ **១៦:១៥** ហ ខ.២៥ ឡ អស ៥៧:៨ យរ ២:២០ អគ ២៣:៣ ២៧:៣

ប្រជាជនអ៊ីស្រាអែលយ៉ាងខ្លាំង ។

**១៦:៦** *ឈាម* ឈាមនៅត្រង់នេះសំដៅទៅលើឈាមអ្នកឆ្លងទន្លេ ។ *ចូរមានជីវិតនៅចុះ* ព្រះអម្ចាស់ គឺជាបំណងប្រាថ្នាដ៏សំខាន់សម្រាប់មនុស្សទាំងអស់ដែលរស់នៅលើលោកិយ (មើល ១៨:២៣,៣២ ១ធថ ២:៤ ២ពត ៣:៩) ។

**១៦:៧** *សក់* គឺសំដៅទៅលើរោមប្រដាប់បន្តពូជ ។

**១៦:៨** *អញបានយកជាយអាវអញគ្របលើឯង* នេះគឺជានិមិត្តរូបទាក់ទងទៅនឹងមនុស្សដែលពេញវ័យរៀបការ (សូមមើលការពន្យល់នៅក្នុង ចទ ២២:៣០ នរ ៣:៩) ។ *តាំងសញ្ញា* ជាការបញ្ជាក់ពីនិមិត្តសញ្ញាពីស្រីក្រមុំដំបូងដែលរស់នៅទីក្រុងយេរូសាឡិម ការនេះមិនមែនសំដៅទៅលើក្រឹត្យវិន័យទេប៉ុន្តែវាគឺជា និមិត្តសញ្ញាដែលពេញវ័យរៀបការ ។ (សូមមើល មឡ ២:១៤) ។

**១៦:៩** *ឈាម* គឺសំដៅទៅលើឈាមរដូវរបស់ស្ត្រី មជ្ឈឹមវ័យ "ស្ត្រីវ័យកណ្តាល" (សូមមើលការពន្យល់ ខ.៧) ។

**១៦:១០** *សំពត់ប៉ាក់... ស្បែកផ្សោត... សំពត់ទេសឯង* សម្ភារៈទាំងអស់នេះគឺតំណាងឱ្យសំលៀកបំពាក់ដែលមានតម្លៃខ្ពស់បំផុត ។ *សំពត់ប៉ាក់* សូមមើល ២៧:១៦,២៤ មានពណ៌ស្នាមឆ្នូតវែងៗ គឺជាសម្ភារៈសម្រាប់ផ្គត់ផ្គង់ដល់ម្ចាស់ក្សត្រី (សូមមើល ទដ ៤៥:១៤) ។ *ស្បែកផ្សោត* គឺដូចជាប្រភេទស្បែកសត្វដែលគេបានប្រើវាដើម្បីបិទបាំង សម្រាប់ចូលទីសក្ការបូជា ("ស្បែកផ្សោត" នក ២៥:៥ ២៦:២៤) ។

**១៦:១២** *ក្រវិលនៅច្រមុះ* មិនមែនជាការចោះប្រមុះទេ ប៉ុន្តែគេបានពាក់ក្រវិលនេះនៅលើផ្នែកខាងក្រៅនៃច្រមុះវិញ (សូមមើល លប ២៤:៤៧) ។ *ទំហូនៅត្រចៀក* គឺវាមានជារង្វង់មូលដែលជាគ្រឿងតុបតែងសម្រាប់បំពាក់វានៅត្រចៀករបស់មនុស្សប្រុស (ជន ៣១:៥០) ។ ពួកហេព្រើរបានប្រើពាក្យនេះ គឺមិនដូចគ្នាដែលធ្លាប់បានប្រើនៅក្នុង លប ៣៥:៤ នក ៣២:២–៣ ។ *ក្បាំង* គឺគេតែងតែពាក់វានៅពេលរៀបការ (សូមមើល បប ៣:១១ ដែលកូនកម្លោះតែងតែពាក់វា) ។

**១៦:១៣** *មាស ហើយនិងប្រាក់* ធៀបនឹង ហស ២:៨ ។ *ម្សៅយ៉ាងម៉ដ្ត* ម្សៅនេះគេប្រើសម្រាប់ក្នុងការថ្វាយដង្វាយ ហេតុដូច្នេះហើយម្សៅម៉ដ្តដែលប្រើសម្រាប់ការថ្វាយដង្វាយនេះ គឺវាមានគុណភាពខ្ពស់ (សូមមើល ខ.១៩ ៤៦:១៤) ។ *ប្រេង* ធៀបនឹង ហស ២:៨ ដ្បិតគេផ្សំវាឡើងពីទឹកឃ្មុំ ហើយនិងប្រេង សូមមើល ចទ ៣២:១៣ ។ *ឯងមានរូបល្អឆើតក្រៃលែង* ធៀបនឹង អស ៥:២៧ ។

**១៦:១៤** *ឯកិត្តិយសពីលំអរុងរឿងរបស់ឯង* ជាពិសេសគឺនៅសម័យស្តេចដាវីឌ និងស្តេចសាឡូម៉ូនដែលទ្រង់បានសោយរាជ្យ ។

**១៦:១៥** *ល្បីឈ្មោះ* ត្រង់នេះសំដៅទៅលើភាពល្បីឈ្មោះខាងផ្លូវភេទ ។ ពាក្យនេះវាជាទម្រង់កិរិយាសព្ទ និងជានាមដែលមានប្រើនៅក្នុងពួកសាសន៍ហេព្រើរ គឺមានប្រើទៅដល់ចំនួន២៣ដងនៅក្នុងជំពូកនេះ ។ *អស់អ្នកណាដែលដើរកាត់មុខឯង* ធៀបនឹង លប ៣៨:១៤–១៦ ។

**១៦:១៦** *សំលៀកបំពាក់* គឺតាំងពីមុនមកព្រះអម្ចាស់បានប្រទានសំលៀកបំពាក់ទាំងអស់នេះឱ្យស្រីសំផឹងដោយប្រើផ្ទាល់ខ្លួនរបស់នាង នៅក្នុងក្រុងយេរូសាឡិម ។ ក្រណាត់ខ្លះគឺជាប្រភេទក្រណាត់ដែលត្រូវការជាចាំបាច់សម្រាប់ប្រើនៅក្នុងការថ្វាយបង្គំរូបព្រះ (សូមមើល ២ពវ ២៣:៧) ។ ពួក

ទៅ ធ្វើជាទីខ្ពស់តាក់តែងដោយពណ៌ផ្សេងៗ[អ] រួចបានភប់
ប្រសព្វនឹងគេនៅលើទីនោះ[ក] ជាការដែលមិនធ្លាប់មានពី
មុនឡើយ ហើយទៅមុខក៏នឹងឥតមានដែរ ១៧ឯងក៏យក
គ្រឿងលំអរបស់ឯង ដែលធ្វើពីមាសនឹងប្រាក់របស់អញ ជា
គ្រឿងដែលអញបានឱ្យដល់ឯងនោះ ទៅធ្វើជារូបមនុស្ស
ប្រុស ហើយឯងបានភប់ប្រសព្វនឹងរូបនោះដែរ[ខ] ១៨ឯង
បានយកសំលៀកបំពាក់ប៉ាក់របស់ឯង ទៅតែងឱ្យវា ព្រម
ទាំងតាំងប្រេង និងកំញានៃ[គ]របស់អញនៅមុខវា ១៩ឯ
អាហារដែលអញបានឱ្យដល់ឯង គឺជាម្សៅយ៉ាងម៉ដ្តប្រេង
និងទឹកឃ្មុំនោះ ដែលអញឱ្យសំរាប់ចិញ្ចឹមឯង នោះឯង
បានថ្វាយនៅចំពោះរូបទាំងនោះ សំរាប់ជាក្លិនឈ្ងុយវិញ
គឺយ៉ាងនោះដែលឯងបានប្រព្រឹត្ត នេះជាព្រះបន្ទូលនៃព្រះ
អម្ចាស់យេហូវ៉ា[ឃ] ២០មួយទៀត ឯងបានយកកូនប្រុសកូន
ស្រី[ង]ឯង ដែលបានបង្កើតឱ្យអញ[ច] ទៅថ្វាយជាយញ្ញបូជា
ដល់ព្រះទាំងនោះ ឱ្យត្រូវវិនាសទៅផង ដូច្នេះ តើការកំផិត
របស់ឯង ជាការយ៉ាងស្រាលឬ[ឆ] ២១បានជាឯងសំឡាប់កូន
អញ ហើយប្រគល់ទៅឱ្យត្រូវចូលក្នុងភ្លើង ថ្វាយដល់រូប
ទាំងនោះទៀត[ជ] ២២ហើយក្នុងអស់ទាំងការគួរស្អប់ខ្ពើម និង
ការកំផិតរបស់ឯង នោះឯងមិនបាននឹកពីការឯងនៅ
ក្មេង[ឈ] ក្នុងកាលដែលឯងនៅអាក្រាត ហើយខ្លួនទទេ[ញ] ព្រម
ទាំងឈ្លក់ឈ្លីនៅក្នុងឈាមឯងនោះទេ[ដ] ។

២៣ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា វេទនា[ឋ]ៗ
ដល់ឯង ដ្បិតក្រោយអស់ទាំងអំពើដ៏លាមកអាក្រក់របស់
ឯង ២៤នោះឯងបានសង់ផ្ទះបនសំរាប់ខ្លួន ហើយធ្វើទី
យ៉ាងសំខាន់[ឌ]សំរាប់ខ្លួន នៅគ្រប់ទាំងផ្លូវនោះទៀត[ឍ] ២៥ឯង
បានធ្វើទីយ៉ាងសំខាននោះ ត្រង់ក្បាលគ្រប់ទាំងផ្លូវ[ណ] ហើយ
បានធ្វើឱ្យសេចក្តីលំអរបស់ឯងទៅជាទីខ្ពើមឆ្អើមវិញ ឯង
បានបើកជើងទទួលគ្រប់ទាំងប្រុសៗ ដែលដើរមកតាម
នោះ ហើយបានចំរើនការកំផិតរបស់ឯងជាច្រើនឡើង[ត]
២៦ឯងបានសហាយស្មន់[ថ]នឹងសាសន៍អេស៊ីព្ទ[ទ] ជាពួកជិត
ខាងឯងដែលធំធាត់ ព្រមទាំងចំរើន[ធ]ការកំផិតរបស់ឯង
ជាច្រើនឡើង ជាការដែលបណ្តាលឱ្យអញខឹង[ន] ២៧ដូច្នេះ
មើលអញបានលូកដៃ[ប]ទៅលើឯងហើយ ក៏បន្ថយចំណែក
របស់ឯងចុះ ហើយបានប្រគល់ឯងដល់[ផ]បំណងចិត្តរបស់
ពួកអ្នកដែលស្អប់ឯង គឺដល់ពួកកូនស្រីសាសន៍ភីលីស្ទីន[ព]
ដែល អៀនចំពោះអំពើឥតខ្មាសរបស់ឯង ២៨ឯងបាន
ភប់ប្រសព្វ និងសាសន៍អាសស៊ើរដែរ[ភ] ដ្បិតឯងមិនចេះ
ឆ្អែតឆ្អន់ឡើយ អើ ឯងបានរួមបវេណីនឹងគេ ក៏នៅតែមិន
ស្កប់ស្កល់ទៀត[ម] ២៩ដូច្នេះ ឯងបានចំរើនការកំផិតរបស់ឯង
រហូតដល់ស្រុកនៃពួកឈ្មួញ ជាសាសន៍ខាល់ដេ[យ] នៅក្នុង
ស្រុកកាណាន ប៉ុន្តែឯងនៅតែមិនទាន់ឆ្អែតទៀត[រ] ។

៣០ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា ចិត្តឯងទន់
អីម្ល៉េះ ដែលឯងបានប្រព្រឹត្តអំពើទាំងនេះ ជាការរបស់ស្រី
សំផឹងដ៏ឈ្នះឈ្នាន[ល] ៣១ដោយឯងបានសង់ផ្ទះបនរបស់
ឯង នៅត្រង់ក្បាលគ្រប់ទាំងផ្លូវ និងទីសំខាន់[វ]របស់ឯងនៅ
អស់ទាំងផ្លូវថ្នល់ តែឯងមិនមែនដូចជាស្រីសំផឹងទេ ពី
ព្រោះឯងមិនរមិលមើលថ្លៃឈ្នួលឡើយ ៣២យ៉ើះ ឯងជា

**១៦:១៦** អ អស ៥៧:៧ ក ២ពវ ២៣:៧
**១៦:១៧** ខ អគ ៧:២០ ហស ២:១៣
**១៦:១៨** គ យរ ៤៤:៥
**១៦:១៩** ឃ ហស ២:៨
**១៦:២០** ង យរ ៧:៣១ ច នក ១៣:២ ឆ ទដ ១០៦:៣៧–៣៨ អស ៥៧:៥ អគ ២៣:៣៧
**១៦:២១** ជ ២ពវ ១៧:១៧ យរ ១៩:៥
**១៦:២២** ឈ ទដ ២៥:៧ ៨៨:១៥ យរ ២:២ ហស ២:១៥ ១១:១ ញ ហស ២:៣ ដ ខ.៦
**១៦:២៣** ឋ អគ ២៤:៦
**១៦:២៤** ឌ ខ.៣១ អស ៥៧:៧ ឍ ទដ ៧៨:៥៨ យរ ២:២០ ៣:២ ៤៤:២១ អគ ២០:២៨
**១៦:២៥** ណ យរ ៣:២ ត ខ.១៥ សភ ៩:១៤
**១៦:២៦** ថ អស ២៣:១៧ ទ យរ ៣:១ ធ ១ពវ ១៤:៩ អគ ៨:១៧ ន អស ៥៧:៨ យរ ១១:១៥ អគ ២០:៨ ២៣:១៩–២១
**១៦:២៧** ប អគ ២០:៣៣ ២៥:១៣ ផ យរ ៣៤:២០ ព ២របា ២៨:១៨
**១៦:២៨** ភ ២ពវ ១៦:៧ ម អស ៥៧:៨
**១៦:២៩** យ យរ ៣:១ អគ ២៣:១៤–១៧ រ ណហ ៣:៤
**១៦:៣០** ល យរ ៣:៣
**១៦:៣១** វ ខ.២៤

គេអាចប្រើប្រាស់ប្រាសក្រណាត់សំពត់នេះ មកធ្វើជាវាំងននបាំងបន្ទប់ ឬក៏អាចយកមកក្រាលកន្លែងដេកបានផងដែរ (សូមមើល អម ២:៧–៨) ។

**១៦:២០** *កូនប្រុសកូនស្រីឯង . . . ទៅថ្វាយជាយញ្ញបូជា* សូមមើល ២០:២៦, ៣១ និងការពន្យល់ ២៣:៣៧ ២ពវ ២១:៦ ២៣:១០ យរ ៧:៣១ ហើយនិងការពន្យល់ ១៩:៥ ៣២:៣៥ ។ ពួកគេបានទាស់ប្រឆាំងនិងបញ្ញត្តិរបស់ព្រះ ដោយថ្វាយកូនជាដង្វាយទៅព្រះដទៃ សូមមើល លវ ១៨:២១ ចទ ១៨:១០ ធៀបនឹង លវ ២០:២–៥ ចទ ១២:៣១ ។

**១៦:២៤** *ផ្ទះបន . . . ធ្វើទីសំខាន់សំរាប់ខ្លួន* គឺជាមជ្ឈមណ្ឌលសង់ឡើងសម្រាប់ថ្វាយបង្គំដល់រូបព្រះក្លែងក្លាយ មិនមែនសង់ឡើងសម្រាប់ថ្វាយបង្គំដល់រូបព្រះតែប៉ុណ្ណោះទេ ប៉ុន្តែវាសង់ឡើងសម្រាប់អ្នកដែលនៅជនបទនៃទីក្រុងយេរូសាឡិមផ្ទាល់ផងដែរ ។

**១៦:២៦–២៩** *សាសន៍អេស៊ីព្ទ . . . សាសន៍ភីលីស្ទីន . . . សាសន៍អាសស៊ើរ . . . សាសន៍ខាល់ដេ* គឺជាប្រវត្តិសាស្ត្រដែលពួកក្រុងយេរូសាឡិមបានចងសម្ព័ន្ធមិត្រ និងធ្វើនយោបាយជាបន្តបន្ទាប់ជាមួយអំណាចទាំងបួននេះ ។

**១៦:២៦** *សហាយស្មន់* ពួកសាសន៍ហេព្រើរ គឺគេត្រូវការពង្រីកនៅឥទ្ធិពលរបស់គេបន្ថែមទៀត "ចំពោះពួកគេ គឺមានមហិច្ឆិតាលោភលន់" ដោយពាក្យសម្តី និងភាសារបស់ពួកគេ គឺជាទីស្អប់ខ្ពើមនៅចំពោះព្រះហើយក៏ជាទីស្អប់ខ្ពើមរបស់លោកអេសេគាលផងដែរ នៅអ្វីដែលកើតមានឡើងនៅក្នុងទីក្រុងយេរូសាឡិមដោយប្រព្រឹត្តតាមសាសនាដទៃ ។ *ពួកជិតខាង* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គ្មានកន្លែងណាផ្សេងទៀតបានសរសេរប្រាប់ពីសាសន៍អេស៊ីព្ទគឺត្រូវបានហៅថា "ពួកជិតខាង" ឡើយ ។

**១៦:២៧** *បន្ថយចំណែករបស់ឯងចុះ* បន្ទាប់ពីឆ្នាំ ៧០១ មុន គ.ស មកស្តេចសានហេរីប ជាស្តេចនៃសាសន៍អាសស៊ើរបានឡោមព័ទ្ធនៃទីក្រុងយេរូសា–ឡិម ហើយក៏បានបែងចែកអាណាខេត្តនៃក្រុងយេរូសាឡិមមួយភាគ ទៅឱ្យពួកសាសន៍ភីលីស្ទីន ។ *ដែលអៀនចំពោះអំពើឥតខ្មាសរបស់ឯង* ធៀបនឹង អម ៣:៩,១៣ ហើយនិងការពន្យល់ផ្សេងទៀត ។

**១៦:២៩** *សាសន៍ខាល់ដេ នៅក្នុងស្រុកកាណាន* សូមមើលការពន្យល់នៅក្នុង វវ ១៤:៨ សូមមើល វវ ១៨:១១–១៩ ផងដែរ ។

**១៦:៣២** *ជាស្រីដែលយកមនុស្សដទៃ មកជំនួសប្តីហើយ* មានន័យថាព្រះអម្ចាស់ទ្រង់ផ្ទាល់ប្រៀបដូចជាប្តី (មើល ខ.៨ និងការពន្យល់) ។ នៅកន្លែង

ស្រីដែលប្រព្រឹត្តសេចក្ដីកំផិត ជាស្រីដែលយកមនុស្សដទៃ
មកជំនួសប្ដីហើយ ៣៣គេតែងតែឱ្យឈ្នួល[ស]ដល់ស្រីសំផឹង
ទាំងប៉ុន្មាន តែឯងវិញ ឯងឱ្យឈ្នួល[ហ]ដល់សហាយឯងទាំង
អស់ ក៏សូកគេឱ្យមកឯឯងពីគ្រប់ទិសជុំវិញ សំរាប់ទទួល
រួមបវេណី[ឡ] ៣៤ហើយឯងខុសពីស្រីធម្មតា ក្នុងការសំផឹង
របស់ឯង ដោយឥតមានអ្នកណារកតាមឯង ដើម្បីរួម
ដំណេកនឹងឯងឡើយ ហើយដោយឯងចេញឈ្នួលឱ្យគេ
មិនមែនគេចេញឈ្នួលដល់ឯងទេ យ៉ាងនោះបានជាឯង
ខុសពីគេហើយ ។
៣៥ដូច្នេះ ឱស្រីសំផឹងអើយ ចូរស្ដាប់ព្រះបន្ទូលនៃព្រះ
យេហូវ៉ាចុះ ៣៦ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ
ថា ដោយព្រោះឯងបានប្រព្រឹត្តអំពើអាសអាភាសរបស់
ឯងជាហូរហែ ហើយបានបើកកេរខ្មាសឯង ដោយរួម
បវេណីនឹងពួកសហាយឯង ដោយព្រោះគ្រប់អស់ទាំងរូប
ដំណាងព្រះដ៏គួរស្អប់ខ្ពើមរបស់ឯង នឹងឈាមរបស់កូន
ចៅឯងដែលឯងបានថ្វាយដល់វា[អ] ៣៧នោះមើល អញ
នឹងប្រមូលពួកសហាយឯង ដែលឯងបានត្រេកអរជាមួយ
គ្នា និងពួកទាំងប៉ុន្មានដែលឯងបានស្រឡាញ់នោះ ព្រម
ទាំងពួកដែលឯងបានស្អប់ផង អើ អញនឹងប្រមូលគេឱ្យ
មកទាស់នឹងឯងនៅគ្រប់ទិស រួចអញនឹងបើក[ក]កេរខ្មាស
ឯងឱ្យគេឃើញច្បាស់ ដើម្បីឱ្យគេបានឃើញទាំងអស់[ខ]
៣៨នោះអញនឹងជំនុំជំរះឯង ដូចជាគួរជំនុំជំរះដល់ស្រីដែល
ផិតប្ដី ហើយកំចាយឈាមផង[គ] អញនឹងទំលាក់ឈាម
ទៅលើឯង ដោយសេចក្ដីក្រោធ និងសេចក្ដីប្រចណ្ឌ[ឃ]
៣៩អញនឹងប្រគល់[ង]ឯងទៅក្នុងកណ្ដាប់ដៃរបស់គេ នោះគេ
នឹងបំផ្លាញផ្ទះបនរបស់ឯង ហើយរំលំអស់ទាំងទីសំខាន់
របស់ឯងដែរ គេនឹងបកសំលៀកបំពាក់ឯងចេញ ហើយ
កាន់យកគ្រឿងលំអរបស់ឯង ព្រមទាំងចោលឯងឱ្យនៅ
អាក្រាត ហើយខ្លួនទទេ[ច] ៤០គេនឹងនាំហ្វូងមនុស្សឡើង
មកទាស់នឹងឯង និងចោលឯងដោយថ្ម[ឆ] ហើយចាក់ទំលុះ
ឯងដោយដាវ ៤១រួចគេនឹងដុត[ជ]ផ្ទះឯងចោល ហើយនឹង
សំរេចសេចក្ដីយុត្តិធម៌ដល់ឯង នៅចំពោះភ្នែកពួកស្រីៗ
ជាច្រើន[ឈ] ដូច្នេះ អញនឹងធ្វើឱ្យឯងលែង[ញ]ប្រព្រឹត្តការ
សំផឹង ហើយឯងនឹងមិនចេញថ្លៃឈ្នួលឱ្យគេទៀតឡើយ
៤២គឺយ៉ាងនោះ ដែលអញនឹងសំរាកសេចក្ដីក្រោធអញ
ចំពោះឯង ហើយសេចក្ដីប្រចណ្ឌរបស់អញ នឹងថយចេញពី
ចំពោះឯងទៅ នោះអញនឹងស្ងៀមនៅវិញ ឥតមានសេចក្ដី
កំហឹងទៀត[ដ] ៤៣អញនឹងទំលាក់[ឋ]អំពើរបស់ឯងទៅលើ
ក្បាលឯងវិញ ដោយព្រោះឯងមិនបាននឹក[ឌ]ពីកាលឯងនៅ
ក្មេងទេ គឺបានចាក់រុកអញ ដោយសារអំពើទាំងនោះឯង
យ៉ាងនោះឯងនឹងមិនប្រព្រឹត្តអំពើគួរខ្មាសនេះ ព្រមទាំង
ការគួរស្អប់ខ្ពើមទាំងប៉ុន្មានរបស់ឯងទៀត[ឍ] នេះជាព្រះ
បន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ។
៤៤មើល អស់អ្នកណាដែលធ្លាប់ប្រើពាក្យសុភាសិត[ណ]
គេនឹងពោលពាក្យនេះទាស់នឹងឯងថា ម្ដាយយ៉ាងណាកូនស្រី
ក៏យ៉ាងនោះដែរ ៤៥ឯងជាកូនស្រីរបស់ម្ដាយឯង ដែលបាន
ស្អប់[ត]ប្ដី[ថ] និងកូនខ្លួន ឯងក៏ជាប្អូនស្រីរបស់ពួកបងប្អូនស្រីឯង
ដែលគេបានស្អប់ប្ដី និងកូនគេដែរ ម្ដាយឯងជាសាសន៍
ហេត ហើយឪពុកឯងជាសាសន៍អាម៉ូរី[ទ] ៤៦បងស្រី[ធ]ឯង គឺ
សាម៉ារី ដែលនៅខាងឆ្វេងឯង ទាំងខ្លួនបង នោះនឹងកូន
ស្រីរបស់បងដែរ ហើយប្អូនស្រីឯងដែលនៅខាងស្ដាំ នោះ

**១៦:៣៣** ស លប ៣០:១៥ ហ អស ៣០:៦ ៥៧:៩ ឡ ហស ៨:៩-១០ **១៦:៣៦** អ យរ ១៩:៥ អគ ២៣:១០ **១៦:៣៧** ក ហស ២:៣ ខ អស ៤៧:៣ យរ ១៣:២២ អគ ២៣:២២ ហស ២:១០ ៨:១០ វវ ១៧:១៦ **១៦:៣៨** គ លប ៣៨:២៤ ឃ លវ ២០:១០ ទដ ៧៩:៣,៥ អគ ២៣:២៥ សផ ១:១៧ **១៦:៣៩** ង ២ពវ ១៨:១១ ច អគ ២១:៣១ ហស ២:៣ **១៦:៤០** ឆ យហ ៨:៥,៧ **១៦:៤១** ជ ចទ ១៣:១៦ យរ ១៩:១៣ ឈ អគ ២៣:១០ ញ អគ ២២:១៥ ២៣:២៧,៤៨ **១៦:៤២** ដ ២សយ ២៤:២៥ អស ៤០:១-២ ៥៤:៩ អគ ៥:១៣ ៣៩:២៩ **១៦:៤៣** ឋ អគ ២២:៣១ ឌ នក ១៥:២៤ ទដ ៧៨:៤២ ឍ អគ ១១:២១ **១៦:៤៤** ណ ទដ ៤៩:៤ **១៦:៤៥** ត អគ ១៤:៥ ថ យរ ៤៤:១៩ ទ ខ.៣ អគ ២៣:២ **១៦:៤៦** ធ យរ ៣:៧

ផ្សេងទៀតពួកហោរាទាំងឡាយបាននិយាយថា ព្រះអម្ចាស់ប្រៀបដូចជាប្ដីនៃប្រជារាស្ត្ររបស់ទ្រង់ (សូមមើល យរ ៣:១៤ ៣១:៣២ ហស ២:១៦-១៧ និងការពន្យល់ ធៀបនឹង ឧទាហរណ៍ នក ៣៤:១៥ និងការពន្យល់) ។

**១៦:៣៣** *ឯងឱ្យឈ្នួលដល់សហាយឯងទាំងអស់* មានន័យថា ពួកនៅក្រុងយេរូសាឡិម គឺគេបានប្រព្រឹត្តការខូចអាក្រក់ ដូចជាមានបង្ហាញនៅរូបភាពដ៏អាក្រក់ទាំងឡាយដែលជារូបភាពពីការផិតក្បត់ ហើយរូបភាពទាំងអស់នេះគឺវាអាក្រក់ជាងស្រីសំផឹងទៅទៀត (សូមមើល ខ.៤) ។

**១៦:៣៧** *អញនិងបើកកេរខ្មាសឯង* គឺអាពាហ៍ពិពាហ៍របស់ឯងនិងប្រែមកជាទីបិទបាំង (ខ.៨) ដែលបានរៀបរាប់នៅក្នុង ខ.៧ ។

**១៦:៣៨** *អញនិងជំនុំជំរះឯង* គឺព្រះបានដាក់បញ្ញត្តិនៃការដាក់ទោសនៅក្នុងក្រឹត្យវិន័យ គឺជាសេចក្ដីស្លាប់ (សូមមើល លវ ២០:១០,ចទ ២២:២២) ដោយបន្ទុះថ្មក្រឹត្យវិន័យ (ចទ ២២:២១-២៤ យហ ៨:៥-៧) ។ *ដោយសេចក្ដីក្រោធ និងសេចក្ដីប្រចណ្ឌ* សូមមើល នក ២០:៥ យរ ១:១៤ ។

**១៦:៣៩** *នោះគេនិងបំផ្លាញផ្ទះបនរបស់ឯង ហើយរំលំអស់ទាំងទីសំខាន់របស់ឯងដែរ* សូមមើល ខ.២៤-២៥ ។

**១៦:៤០** សូមមើល ២៣:៤៦-៤៧ ។

**១៦:៤៣** *អញនិងទំលាក់អំពើរបស់ឯងទៅលើក្បាលឯងវិញ* សូមមើលការពន្យល់ យរ ៥០:១៥ ។

**១៦:៤៤** *ម្ដាយយ៉ាងណា កូនស្រីក៏យ៉ាងនោះដែរ* គឺជានិមិត្តរូបសំដៅទៅលើក្រុងយេរូសាឡិម ដែលមានការលំអៀងទៅរកវិញ្ញាណអាក្រក់ឥតឈប់ឈរ (ធៀបនឹង ខ.៣,៤៥) ។

**១៦:៤៥** *សាសន៍ហេត . . . សាសន៍អាម៉ូរី* សូមមើលការពន្យល់ នៅ ខ.៣ ។

**១៦:៤៦** *បងស្រីឯង គឺសាម៉ារី ជាប្រវត្តិសាស្ត្រ* គឺសាសន៍សាម៉ារីមិនបានស្ថាបនាឡើងដូចជាទីក្រុងនៃស្ដេចទេ រហូតដល់ ៨៨០ មុន គ.ស (សូមមើលការពន្យល់ នៅ ១ពវ ១៦:២៤) ដូច្នេះ " បងស្រី" និយាយឱ្យងាយយល់និងការជាក់ស្ដែង គឺជាពាក្យដៀមដាមចំពោះហេតុការណ៍ដែលកើតមានឡើង

គឺជាសូដុំម[ន] និងកូនស្រីរបស់គេ ៤៧ប៉ុន្តែ ឯងមិនបានដើរ
តាមផ្លូវគេ ឬប្រព្រឹត្តតាមអំពើគួរស្អប់ខ្ពើមរបស់គេទេ គឺ
ឯងបានប្រព្រឹត្តខូចអាក្រក់ជាងគេ ក្នុងអស់ទាំងផ្លូវរបស់
ឯងទៅទៀត ដោយស្មានថាអំពើរបស់គេតិចតួចទេ[ប]
៤៨ព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថ[ផ]ថា ដូចជាអញរស់នៅ
នោះប្រាកដជាសូដុំម[ព] ជាប្អូនឯង ព្រមទាំងកូនផង មិនបាន
ប្រព្រឹត្តដូចជាឯង[ភ] និងកូនស្រីរបស់ឯងទេ ៤៩មើល ឯអំពើ
ទុច្ចរិតរបស់សូដុំម[ម] ជាប្អូនស្រីឯង ព្រមទាំងកូនផង នោះ
គឺមានសេចក្ដីអំនួត[យ] មានអាហារបរិភោគឆ្អែតហើយនៅ
ក៏ឥតកង្វល់[រ] ទាំងមានសេចក្ដីចំរើន ឥតដែលចំរើនកំឡាំង
ដៃនៃពួកក្រីក្រ និងមនុស្សកំសត់ទុគ៌តឡើយ[ល] ៥០គេក៏មាន
ចិត្តឆ្មើងឆ្មៃ[វ] ហើយបានប្រព្រឹត្តអំពើគួរស្អប់ខ្ពើម នៅ
ចំពោះអញ ហេតុនោះបានជាអញដកគេចេញ តាមដែល
អញឃើញថាគួរ[ស] ៥១ឯសាម៉ារី ក៏មិនបានប្រព្រឹត្តដល់ត្រឹម
ពាក់កណ្ដាលនៃអំពើបាបរបស់ឯងដែរ គឺឯងបានចំរើន
អំពើគួរស្អប់ខ្ពើមរបស់ឯង ជាច្រើនជាងគេទៅទៀត ហើយ
ឯងបានធ្វើឱ្យបងប្អូនស្រីឯង មើលទៅដូចជាសុចរិតទេ
ដោយអំពើគួរស្អប់ខ្ពើមដែលឯងបានប្រព្រឹត្តនោះ[ហ] ៥២ឯ
ឯងដែលបានថ្កោលទោសបងប្អូនស្រីឯង ចូរទទួលរង
សេចក្ដីខ្មាសរបស់ខ្លួនចុះ គេសុចរិត[ឡ]ជាងឯងវិញ ដោយ
ព្រោះអំពើបាបដែលឯងបានប្រព្រឹត្ត ឱ្យគួរស្អប់ខ្ពើមជាង
គេនោះ អើ ចូរឱ្យឯងជ្រប់មុខចុះ ហើយទទួលរង[អ]សេចក្ដី
ខ្មាសរបស់ខ្លួន ដោយព្រោះឯងបានធ្វើឱ្យបងប្អូនស្រីឯង
មើលទៅដូចជាសុចរិតវិញ ។
៥៣អញនឹងនាំពួកគេ ដែលនៅជាឈ្លើយ ឱ្យមកវិញ[ក]
គឺសូដុំម ព្រមទាំងកូនដែលនៅជាឈ្លើយ សាម៉ារី ព្រម
ទាំងកូនដែលនៅជាឈ្លើយ និងពួកឯងទាំងប៉ុន្មានដែល
នៅជាឈ្លើយ ឱ្យមកបណ្ដាលគេផង[ខ] ៥៤ដើម្បីឱ្យឯង
បានទទួលរងសេចក្ដីខ្មាសរបស់ខ្លួន ហើយឱ្យមានសេចក្ដី
ខ្មាស[គ] ដោយព្រោះគ្រប់ទាំងអំពើដែលឯងបានប្រព្រឹត្តនោះ
ដោយឯងជាទីកំសាន្តចិត្តដល់គេ ៥៥ឯប្អូនស្រីឯង គឺសូដុំម
និងកូនស្រីវា គេនឹងត្រឡប់ទៅឯសណ្ឋានដើមរបស់ខ្លួន
ហើយសាម៉ារី និងកូនវា គេនឹងត្រឡប់ទៅឯសណ្ឋានដើម
របស់ខ្លួនវិញ ចំណែកឯង និងកូនឯង ក៏នឹងវិលត្រឡប់
ទៅដូចជាសណ្ឋានដើមរបស់ឯងរាល់គ្នាដែរ[ឃ] ៥៦ដ្បិតនៅ
គ្រានៃសេចក្ដីអំនួតរបស់ឯង នោះឈ្មោះសូដុំម ជាប្អូនស្រី
ឯង មិនបានចេញពីមាត់ឯងឡើយ ៥៧គឺក្នុងកាលដែល
សេចក្ដីទុច្ចរិតរបស់ឯង មិនទាន់បើកឱ្យឃើញ នៅឡើយ
ដូចនៅវេលាដែលបន្ទោស[ង]ដល់ពួកកូនស្រីស៊ីរី[ច] និងពួក
អ្នកនៅជុំវិញ ហើយពួកកូនស្រីភីលីស្ទីន ដែលប្រទូសរ៉ាយ
ដល់ឯងនៅព័ទ្ធជុំវិញ ៥៨ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
ឯងត្រូវទទួលរងសេចក្ដីខ្មាស និងអំពើគួរស្អប់ខ្ពើមរបស់
ឯងហើយ[ឆ] ៥៩ដ្បិតព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះថា អញនឹងប្រព្រឹត្តនឹងឯង ដូចជាឯងបានប្រព្រឹត្ត
នោះ គឺដែលឯងបានមើលងាយដល់ពាក្យសម្បថ ដោយ
ផ្ដាច់សេចក្ដីសញ្ញាចេញ[ជ] ។
៦០ប៉ុន្តែ អញនឹងនឹកចាំ ពីសេចក្ដីសញ្ញា[ឈ] ដែលអញ

**១៦:៤៦** ន លប ១៣:១០-១៣ ១៨:២០ យរ ៣:៨-១១ អក ២៣:៤ វវ ១១:៨ **១៦:៤៧** ប អក ៥:៧ **១៦:៤៨** ផ លប ១៥:២ ព លប ១៩:២៥ ភ មថ ១០:១៥ ១១:២៣-២៤ **១៦:៤៩** ម អស ១:១០ យ ទដ ១៣៨:៦ អក ២៨:២ រ អស ២២:១៣ ល លប ១៣:១៣ ១៩:៩ យរ ៥:២៨ អក ១៨:៧,១២,១៦ អម ៦:៤-៦ លក ១២:១៦-២០ ១៦:១៩ យក ៥:៥ **១៦:៥០** វ ទដ ១៨:២៧ ស លប ១៨:២០-២១ ១៩:៥ **១៦:៥១** ហ យរ ៣:៨-១១ អក ៥:៦-៧ ២៣:១១ **១៦:៥២** ឡ យរ ៣:១១ អ អក ២៣:៣៥ **១៦:៥៣** ក ចទ ៣០:៣ អស ១៩:២៤-២៥ យរ ៤៨:៤៧ ខ អក ៣៩:២៥ **១៦:៥៤** គ យរ ២:២៦ **១៦:៥៥** ឃ អក ៣៦:១១ មឡ ៣:៤ **១៦:៥៧** ង ទដ ១៣៧:៣ ច ២ពវ ១៦:៦ **១៦:៥៨** ឆ អក ២៣:៤៩ **១៦:៥៩** ជ ខ.៨ អក ១៧:១៩ **១៦:៦០** ឈ លប ៦:១៨ ៩:១៥

នៅក្រុងសាម៉ារី ហើយក៏ជាវិន័យមួយដ៏សំខាន់ដែរ ចំពោះក្រុងយេរូសាឡិមដែរ ។ *កូនស្រី* គឺប្រៀបដូចជា ជាយក្រុង ឬជាក្រុងរណប ។

**១៦:៤៧** *គឺឯងបានប្រព្រឹត្តខូចអាក្រក់ជាងគេ* នៅក្នុងព្រះគម្ពីរជាញឹកញាប់ បានធ្វើការប្រៀបធៀប ទៅនិងមនុស្សដែលរស់នៅទីក្រុងសូដុំមដែលបានប្រព្រឹត្តអំពើអាក្រក់ (សូមមើល ខ.៤៦) ។ វាគឺជាការចុះចូលនិងវិញ្ញាណអាក្រក់ ដែលជាទីបង្អាប់ដល់ព្រះ(សូមមើល លប ១៣:១០ និងការពន្យល់ ចទ ២៩: ២៣ ៣២:៣២ អស ១:៩-១០ និងការពន្យល់ ៣:៩ យរ ២៣:១៤ បទ ៤:៦ មថ ១០:១៥ ១១:២៣-២៤ ពច ៧) ។

**១៦:៤៩** *អំពើទុច្ចរិតរបស់សូដុំម ជាប្អូនស្រីឯង* ត្រង់នេះចង់និយាយពីសង្គមអមនុស្សធម៌គឺវាហាក់បីដូចជាអំពើផិតក្បត់ ។(លប ១៩) គឺជាការបញ្ជាក់ ។

**១៦:៥១-៥២** *សេចក្ដីសុចរិត* គឺទំនាក់ទំនងទៅនិងការគ្មានទោស ។

**១៦:៥៦** *នៅគ្រានៃសេចក្ដីអំនួតរបស់ឯង* យោងទៅតាមពេលដ៏យូរលុងមុនលោកអេសេគាល ដែលក្រុងយេរូសាឡិម (ជាទីក្រុងនៃសាសន៍អ៊ីស្រាអែល) នៅគ្រាដែលស្តេចដាវីឌ ហើយនៅឆ្នាំនៃស្តេចសាឡូម៉ូនដែលទ្រង់ទាំងពីរអង្គ ឡើងសោយរាជ្យគឺទាក់ទងទៅនិងសេចក្ដីអំនួតនៅគ្រានោះ ។

**១៦:៥៧** *ដូចនៅវេលាដែលបន្ទោសដល់ពួកកូនស្រីស៊ីរី* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ជាញឹកញាប់ តែងតែកាត់ទោសដល់ពួកសាសន៍ស៊ីរី (សូមមើល ២៥:១២-១៤ ៣៥:៥ និងការពន្យល់ អស ៦៣:១ ការណែនាំចំពោះអូបាឌាគឺការរួបរួម និងការនិពន្ធរឿង អប ១០-១៤ និងការពន្យល់) ។

**១៦:៥៩-៦៣** ព្រះបន្ទូលរបស់ទ្រង់ បានមានបន្ទូលសំដៅទៅពីអនាគតនៃទីក្រុងយេរូសាឡិម ដែលបានកែប្រែហើយស្ថាបនាឡើងវិញ ជាទីក្រុងដ៏ល្អប្រណិត ដំណាងឱ្យប្រជាជាតិអ៊ីស្រាអែល និងបានពិពណ៌នាពីផ្នែកខាងមុខ (សូមមើលការពន្យល់ ខ.១-៦៣) ដូច្នេះ ព្រះបន្ទូលរបស់ទ្រង់ គឺជាការរំឭកពីសេចក្ដីសញ្ញាដែលព្រះបានតាំងឡើង ដ៏ស្ថិតស្ថេរនៅអស់កល្បជានិច្ច (សូមមើល ខ.៦០ ធៀបនឹង ខ.៦២) ស្របគ្នានិងអ្វីនៅកន្លែងផ្សេងទៀតដែលទ្រង់បានមានបន្ទូលអំពីប្រទេសអ៊ីស្រាអែលផ្ទាល់ (សូមមើល ៣៧:២៦ អស ៥៥:៣ យរ ៣២:៤០ និងការពន្យល់ផ្សេងទៀត) ។

**១៦:៥៩** *សេចក្ដីសញ្ញា* សូមមើល ខ.៨ និងការពន្យល់ ។

**១៦:៦០** *អញនឹងនឹកចាំ ពីសេចក្ដីសញ្ញា* ទោះបីក្រុងយេរូសាឡិមមិនបាននឹកចាំក៏ដោយ(សូមមើល ខ.៤៣) ។

បានតាំងនឹងឯង ក្នុងកាលដែលឯងនៅក្មេងនោះ[ញ] ហើយ
អញនឹងតាំងសញ្ញា[ដ]១នឹងឯង ដ៏ស្ថិតស្ថេរ នៅអស់កល្បជា
និច្ចទៀត [61]នោះឯងនឹងនឹកឃើញពីផ្លូវរបស់ឯង ហើយ
នឹងមានសេចក្ដីខ្មាស[ឋ] ក្នុងកាលដែលឯងទទួលបងប្អូនស្រី
ឯង គឺបងបង្អស់របស់ឯងនឹងប្អូនឯងផង គ្រានោះអញនឹង
ឱ្យបងប្អូននោះដល់ឯង ទុកជាកូនស្រីវិញ[ឌ] តែមិនមែនតាម
សេចក្ដីសញ្ញារបស់ឯងទេ [62]អញនឹងតាំងសេចក្ដីសញ្ញា[ឍ]
របស់អញដល់ឯង នោះឯងនឹងដឹងថា អញនេះជាព្រះ
យេហូវ៉ាពិត[ណ] [63]ដើម្បីឱ្យឯងបាននឹកចាំ[ត] ហើយត្រូវជ្រប់
មុខ ឥតដែលហើបមាត់[ថ]ឯងឡើងទៀតឡើយ ដោយឯង
មានសេចក្ដីអៀនខ្មាស[ទ] ក្នុងកាលដែលអញ បានអត់ទោស
ដល់ឯង ចំពោះគ្រប់ទាំងអំពើដែលឯងបានប្រព្រឹត្តនោះ
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ធ]។

## សត្វឥន្ទ្រីទាំងពីរ និងដើមទំពាំងបាយជូរមួយដើម

**១៧** [1]ព្រះបន្ទូល នៃព្រះយេហូវ៉ា បានមកដល់ខ្ញុំថា [2]កូន
មនុស្សអើយ ចូរដាក់ប្រស្នា ហើយពោលសេចក្ដីប្រៀប
ធៀបដល់ពួកវង្សអ៊ីស្រាអែលថា[ក] [3]ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ មានសត្វឥន្ទ្រី[ខ]យ៉ាងធំ ពេញដោយ
ស្លាបគ្រប់ពណ៌ ដែលមានចំអេងស្លាបធំ ហើយវែង វា
ហើរមកដល់ព្រៃល្បាណូន[គ] កាច់យកចុងដើមតាត្រៅ១ [4]វា
កាច់[ឃ]យកលំពង់ នៅចុងបំផុតនៃដើមនោះ យកទៅដល់
ស្រុកជំនួញ ដាក់ទៅក្នុងទីក្រុងនៃមនុស្សជួញប្រែ [5]វាក៏
យកពូជពង្រោះពីស្រុកនោះ ទៅព្រោះនៅក្នុងដីដុះដាល
គឺបានដាំនៅក្បែរទឹកធំ ដូចជាដើមចាក[ង] [6]ដើមនោះក៏ដុះ
ឡើង ត្រឡប់ជាដើមទំពាំងបាយជូរលូតលាស់ទាបៗ ដែល
ខ្នែង[ច]ក៏បែរមកខាងឥន្ទ្រីនោះ ឯឫសក៏នៅពីក្រោមវាដែរ
ដូច្នេះ ដើមនោះបានត្រឡប់ជាដើមទំពាំងបាយជូរ ក៏បែក
ខ្នែង ហើយចេញត្រួយផង[ឆ] [7]មានសត្វឥន្ទ្រីធំ១ទៀតមាន
ស្លាបច្រើន ហើយចំអេងស្លាបយ៉ាងធំ រីឯដើមទំពាំងបាយ
ជូរ នោះបានបត់ឫសពីដីដែលដាំ នោះទៅខាងវាវិញ
ហើយបោះមែកចេញទៅខាងវាដែរ ដើម្បីឱ្យវាបាន
ស្រោចទឹក[ជ] [8]ដើមនោះបានដាំក្នុងដីល្អនៅ ក្បែរទឹកធំ
ដើម្បីឱ្យបានបែកខ្នែង[ឈ] ហើយកើតផលផ្លែ ប្រយោជន៍ឱ្យ
បានជាដើមទំពាំងបាយជូរយ៉ាងល្អ [9]ត្រូវឱ្យឯងថា ព្រះ
អម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ តើដើមនោះនឹង
ចំរើនឡើងបានឬ តើឥន្ទ្រីមុននោះមិនដករំលើង ទាំងឫស
ហើយកាត់ផ្លែចេញ ឱ្យបានស្វិតទៅ ហើយឱ្យអស់ទាំងស្លឹក
ខ្ចីៗបានក្រៀមទៅដែរទេឬអី ឥតចាំមានដៃខ្លាំងពូកែ ឬ

**១៦:៦០** ញ ទដ ២៥:៧ យរ ២:២ ដ លប ៩:១៦ អគ ៣៧:២៦ **១៦:៦១** ឋ ខ.៦៣ អគ ២០:៤៣ ៤៣:១០ ៤៤:១៣ ឌ អស ៤៣:៦ **១៦:៦២** ឍ ចទ ២៩:១៤ ណ យរ ២៤:៧ អគ ២០:៣៧,៤៣–៤៤ ៣៤:២៥ ៣៧:២៦ ហស ២:១៩–២០ **១៦:៦៣** ត ទដ ៦៥:៣ ៧៨:៣៨ ៧៩:៩ ថ រម ៣:១៩ ទ អគ ៣៦:៣១–៣២ ធ ទដ ៣៩:៩ ដយ ៩:៧–៨ **១៧:២** ក ពច ១៤:១២ អគ ២០:៤៩ **១៧:៣** ខ ចទ ២៨:៤៩ យរ ៤៩:២២ ដយ ៧:៤ ហស ៨:១ គ យរ ២២:២៣ **១៧:៤** ឃ អស ១០:៣៣ **១៧:៥** ង ចទ ៨:៧–៩ ទដ ១:៣ អស ៤៤:៤ អគ ៣១:៥ **១៧:៦** ច អស ១៨:៥ ឆ យប ៥:៣ **១៧:៧** ជ អគ ៣១:៤ **១៧:៨** ឈ យប ១៨:១៩ មឡ ៤:១

**១៦:៦១** *និងនឹកឃើញ . . . និងមានសេចក្ដីខ្មាស* សូមមើល ខ.៦៣ ក្រុងយេរូសាឡិម (នៅក្នុងប្រទេសអ៊ីស្រាអែល) និងនឹកចាំ ចំពោះសេចក្ដីខ្មាសរបស់នាង និងស្ថិតស្ថេរ នៅអស់កល្បជានិច្ច ។

**១៦:៦៣** *ដើម្បីឱ្យឯងបាននឹកចាំ ហើយត្រូវជ្រប់មុខ* ព្រះនឹងធ្វើឱ្យពួកគេ គ្មានភាពស្មោះត្រង់ ឬគ្មានការ ជឿជាក់ចំពោះទីក្រុងយេរូសាឡិមឡើយ នូវអ្វីដែលនាងមិនអាចធ្វើចំពោះខ្លួននាងផ្ទាល់ (ធៀបនឹង រម ៣:២៣ ១យហ ២:២ និងការពន្យល់ផ្សេងទៀត) ។

**១៧:១–២៤** សេចក្ដីប្រៀបធៀប និងឧបមាដូចជានិមិត្តសញ្ញារបស់ស្ដេចសេដេគា ដែលមានការប្រែប្រួលនៃភាពដឹកនាំនយោបាយរបស់ទ្រង់ដែលបានធ្លាក់ចុះ ។ សេចក្ដីប្រៀបធៀប គឺបានបង្ហាញនៅក្នុង ខ.១–១០ សម្រាប់ការពន្យល់របស់វាដូចតទៅ នៅក្នុង ខ.១១–២១ និង ខ.២២–២៤ ការបន្ថែមនូវសេចក្ដីសន្យា ពេលវេលាដ៏ប្រសើរ និងមកដល់គឺជានិមិត្តរូបនៃសេចក្ដីប្រៀបធៀបអំពីការយាងមករបស់ទ្រង់ ។

**១៧:៣** *សត្វឥន្ទ្រីយ៉ាងធំ* ប្រៀបធៀបនឹងស្ដេចនេប៊ូក្នេសា (សូមមើល ខ.១២) ។ *ចំអេងស្លាបធំ* គឺប្រៀបធៀបទៅនឹងទីក្រុងយេរូសាឡិម (សូមមើល ខ.១២) ។ *ដើមតាត្រៅ* គឺប្រៀបធៀបអំពីព្រះរាជ្យរបស់ស្ដេចដាវីឌ និងជាព្រះរាជ្យវង្សរបស់ទ្រង់ ។

**១៧:៤** *វាកាច់យកលំពង់* គឺប្រៀបធៀបអំពីស្ដេចយេហូយ៉ាគីន ។ *ស្រុកជំនួញ* គឺប្រៀបធៀបពីទីក្រុងបាប៊ីឡូន (សូមមើល ខ.១២ ១៦:២៩ និងការពន្យល់) ។ *ទីក្រុងនៃមនុស្សជួញប្រែ* គឺក្រុងបាប៊ីឡូន ។

**១៧:៥** *ពូជពង្រោះ* គឺសំដៅទៅលើពូជសេដេគាដែលជាកូនរបស់លោកយ៉ូសៀស គាត់ជាបងប្រុសរបស់យ៉ូអាហាស និងយេហូយ៉ាគីម ត្រូវជាពូរបស់យេហូយ៉ាគីន (សូមមើល ២ពវ ២៣–២៤) ។ *ដាំនៅក្បែរទឹកធំ* គឺទ្រង់នឹងបង្កើតពូជរបស់សេដេគាជាស្ដេច (២ពវ ២៤: ១៧) ។

**១៧:៦** *ដើមទំពាំងបាយជូរលូតលាស់ទាបៗ* គឺដើមវាមិនវែងជាង ឬមិនខ្ពស់ជាងដើមតាត្រៅទេ ។ គឺចង់ប្រៀបធៀបពីសាសន៍យូដារាប់ពាន់នាក់ត្រូវបាននិរទេស ឬត្រូវដឹកនាំទៅជាឈ្លើយ (សូមមើល ២ពវ ២៤:១៥–១៦ សូមមើល យរ ៥២:២៨) ។ និងមើលការពន្យល់ ១៥:១–៨ ។

**១៧:៧** *សត្វឥន្ទ្រីធំ១ទៀត* គឺដំណាងឱ្យផារ៉ោនដែលជាស្ដេចស្រុកអេស៊ីព្ទ ឬស្ដេចសាមមេទីកូស ទី២ (Psammetichus II, ឆ្នាំ ៥៩៥–៥៨៩ មុន គ.ស) ឬស្ដេចហុបរ៉ា (Hophra ឆ្នាំ ៥៨៩–៥៧០ មុន គ.ស) ។ ស្ដេចហុបរ៉ាបានសរសេរនៅក្នុង យរ ៤៤:៣០ គឺប្រហែលជាស្ដេចផារ៉ោនដែលបានស្នើឱ្យជួយដល់ទីក្រុងយេរូសាឡិម នៅក្នុងឆ្នាំ ៥៨៦ មុន គ.ស (សូមមើល យរ ៣៧:៥) ហេតុការណ៍ពិត គឺនៅក្នុងជំពូក ៨,១៧ (ដែលបានចុះកាលបរិច្ឆេទនៅឆ្នាំ ៥៩២ មុន គ.ស) ហើយនិង ជំពូក ២០ (ដែលបានចុះកាលបរិច្ឆេទនៅឆ្នាំ ៥៩១ មុន គ.ស) ស្ដេចសាមមេទីកូស (Psammetichus) គឺមានន័យថាជាអ្នកជំនាញខាងផ្នែកប្រវត្តិវិជ្ជាមួយយ៉ាងសំខាន់ ។ *បានបត់ឫសពីដីដែលដាំ នោះទៅខាងវាវិញ* គឺស្ដេចសេដេគាបានជ្រើសរើសសាសន៍អេស៊ីព្ទសម្រាប់ធ្វើជាកងទ័ពជំនួយ (ខ.១៥) ជាសកម្មភាពចង់ធ្វើបដិវត្តន៍បះបោរប្រឆាំងជាមួយស្ដេចនេប៊ូក្នេសា (សូមមើល ២ពវ ២៤:២០) ។

មនុស្សជាច្រើន ដើម្បីនឹងដករំលើងទាំងឫសផងឡើយ[ញ]
១០អើ មើល ដែល[ដ]បានដាំដូច្នេះហើយ តើនឹងចំរើនឡើង
បានឬ តើមិនស្វិតក្រៀមទៅទាំងអស់ ដោយគ្រាន់តែមាន
ខ្យល់ពីខាងកើតបក់មកប៉ះត្រូវទេឬអី អើ នឹងត្រូវស្វិតក្រៀម
ទៅ នៅកន្លែងដែលដុះនោះឯង[ឋ]។
១១ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំម្តងទៀតថា
១២ចូរសួរដល់ពួកវង្សរឹងចចេសនោះថា តើឯងរាល់គ្នា
មិនយល់ន័យសេចក្តីទាំងនេះទេឬអី[ឌ] ចូរប្រាប់គេថា មើល
ស្តេចបាប៊ីឡូនបានមកដល់ក្រុងយេរូសាឡិម កៀរយក
ទាំងស្តេច និងពួកចៅហ្វាយទីក្រុង[ឍ] នាំទៅជាមួយដល់
ក្រុងបាប៊ីឡូន[ណ] ១៣នោះក៏រើសយកពូជស្តេច១អង្គមកតាំង
សញ្ញា[ត]នឹងគ្នា ហើយក៏ចាប់ឱ្យស្បថ[ថ] រួចបានដឹកនាំពួកអ្នក
ខ្លាំងពូកែ[ទ] ក្នុងស្រុកចេញទៅ ១៤ដើម្បីឱ្យរាជ្យនោះបាន
ទាបថោក[ធ] ឥតដែលងើបឡើងទៀតបានឡើយ តែឱ្យបាន
ជាប់នៅ ដោយការរក្សាសញ្ញានោះ ១៥ប៉ុន្តែ ស្តេចយើង
បានបះបោរ[ន]នឹងទ្រង់វិញ ដោយចាត់រាជទូតទៅឯស្រុក
អេស៊ីព្ទ[ប] ដើម្បីឱ្យគេបានឱ្យសេះ និងពលទ័ពមកជាច្រើន
ដូច្នេះ[ផ] តើនឹងចំរើនឡើងបានឬ តើអ្នកណាដែលប្រព្រឹត្ត
ដូច្នេះនឹងរួចខ្លួនបឬ តើនឹងអាចផ្តាច់សេចក្តីសញ្ញា ហើយ
រួចខ្លួនបានឬ[ព] ១៦ព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូចជា
អញរស់នៅ នោះប្រាកដជាស្តេចយើង នឹងត្រូវស្លាប់[ភ] នៅ
កន្លែងនៃស្តេច ដែលបានតាំងទ្រង់ឡើង ឱ្យសោយរាជ្យ
ដែលទ្រង់បានមើលងាយពាក្យសម្បថ ហើយផ្តាច់សេចក្តី
សញ្ញារបស់ស្តេចនោះបង់ គឺនឹងត្រូវស្លាប់ នៅកណ្តាល
ក្រុងបាប៊ីឡូនជិតស្តេចនោះឯង[ម] ១៧ហើយផារ៉ោន[យ] និង
ពលទ័ពដ៏ខ្លាំងពូកែនឹងមិនមកជួយក្នុងចំបាំង ដោយមាន
គ្នាសន្ទឹករបស់ទ្រង់ ក្នុងកាលដែលគេជីកស្នាមភ្លោះ[រ] ហើយ
ធ្វើប៉មបុកទំលាយកំផែងឡើង ដើម្បីនឹងកាត់ជីវិតមនុស្ស
ជាច្រើនចេញនោះដែរ[ល] ១៨ដ្បិតស្តេចយើងបានមើលងាយ
ពាក្យសម្បថ[វ] ដោយផ្តាច់សេចក្តីសញ្ញានោះចេញ ហើយ
មើល ទ្រង់ក៏ចាប់ដៃស្បថផង តែបានធ្វើយ៉ាងដូច្នេះវិញ
ដូច្នេះ តើនឹងរួចខ្លួនបឬ ១៩ហេតុនោះ ព្រះអម្ចាស់យេហូវ៉ា
ទ្រង់ស្បថថា ដូចជាអញរស់នៅ នោះប្រាកដជាអញនឹង
ទំលាក់ពាក្យសម្បថរបស់អញ ដែលវាបានមើលងាយ នឹង
សេចក្តីសញ្ញារបស់អញ ដែលវាបានផ្តាច់ចេញនោះ ទៅ
លើក្បាលវាវិញ[ស] ២០អញនឹងលាតមង[ហ]អញទៅលើវា នោះ
វានឹងត្រូវជាប់នៅក្នុងអន្ទាក់របស់អញ អញនឹងនាំវាទៅ
ឯក្រុងបាប៊ីឡូន ហើយនិងមានរឿងគ្នា[ឡ]នៅទីនោះ ដោយ
ព្រោះអំពើរំលង[អ] ដែលវាបានប្រព្រឹត្តនឹងអញ ២១ឯអស់ពួក
អ្នកក្នុងកងទ័ពវាដែលរត់រួច គេនឹងត្រូវដួល ដោយដាវ[ក]
ឯពួកអ្នកដែលសល់នៅ[ខ] គេនឹងត្រូវខ្ចាត់ខ្ចាយទៅគ្រប់ទិស[គ]
នោះឯងរាល់គ្នានឹងដឹងថា អញនេះ គឺយេហូវ៉ា អញបាន

**១៧:៩** ញ យរ ៤២:១០ អម ២:៩ **១៧:១០** ដ យប ១:១៩ ហស ១២:១ ១៣:១៥ ឋ អគ ១៩:៤ **១៧:១២** ឌ អគ ១២:៩ ឍ ២ពវ ២៤:១៥ ណ ចទ ២១:១០ ២រប ៣៦:១០ អគ ២៤:១៩ **១៧:១៣** ត នក ២៣:៣២ យរ ៣៧:១ ថ ២រប ៣៦:១៣ ទ អស ៣:២ **១៧:១៤** ធ អគ ២៩:១៤ **១៧:១៥** ន យរ ៥២:៣ ប អស ៣០:២ យរ ៣៧:៥ ផ ចទ ១៧:១៦ ព ទដ ៥៦:៧ អស ៣០:៥ យរ ៣៤:៣ ៣៨:១៨ អគ ២៩:១៦ **១៧:១៦** ភ យរ ៥២:១១ អគ ១២:១៣ ម ២ពវ ២៤:១៧ **១៧:១៧** យ យរ ៣៧:៧ រ អគ ៤:២

ល អស ៣៦:៦ យរ ៣៧:៥ អគ ២៩:៦–៧ **១៧:១៨** វ ២ពវ ១០:១៥ ១រប ២៩:២៤ **១៧:១៩** ស យរ ៧:៩ អគ ១៦:៥៩ ២១:២៣ ហស ១០:៤ **១៧:២០** ហ អគ ១២:១៣ ៣២:៣ ឡ យរ ២:៣៥ អ អគ ១៥:៨ **១៧:២១** ក អគ ១២:១៤ ខ ២ពវ ២៥:១១ គ លវ ២៦:៣៣ ២ពវ ២៥:៥ សក ២:៦

**១៧:១០** *ខ្យល់ពីខាងកើត* គឺជារដូវក្តៅ មានខ្យល់បក់មកបន្តិចបន្តួចណាស់ ដែលធ្វើឱ្យរាំងស្ងួតហួតហែង ទទួលចំហាយមកពីវាលខ្សាច់សាហារ៉ា ធ្វើឱ្យរុក្ខជាតិទាំងឡាយក្រៀមស្វិត (មើល ១៩:១២) ។ អត្ថន័យនៅទីនេះគឺចង់បង្ហាញពីការឈរដឹកនាំរបស់ស្តេចនេប៊ូក្នេសា និងកម្លាំងរបស់ទ្រង់នៅទីក្រុងបាប៊ីឡូន ។

**១៧:១២** *ពួកវង្សរឹងចចេសនោះថា* (សូមមើល ២:៣ និងការពន្យល់ ។

**១៧:១៥** *តើនឹងអាចផ្តាច់សេចក្តីសញ្ញា ហើយរួចខ្លួនបានឬ* អត្ថន័យ គឺមាននៅជិពូកនេះ (សូមមើល ខ.១៦,១៨) ។

**១៧:១៩** *ពាក្យសម្បថរបស់អញ . . . សេចក្តីសញ្ញារបស់ស្តេច* គឺជាស្តេចនៃសាសន៍យូដានឹងបានស្បថដោយភាពស្មោះត្រង់ ដើម្បីចុះការតាំងសញ្ញានៅចំពោះព្រះនាមព្រះអម្ចាស់ ។ ពាក្យសម្បថរបស់ទ្រង់នឹងចាប់យកពួកអ្នកខ្លះដូចជា "ព្រះអម្ចាស់អាចនឹងសម្លាប់ខ្ញុំ ប្រសិនបើខ្ញុំមិនប្រព្រឹត្តតាមសេចក្តីពិត និងការតាំងសញ្ញានេះ" ។ (ពាក្យសម្បថគឺជាបណ្តាសាសម្រាប់ខ្លួនឯង សូមមើលការពន្យល់ លប ៩:១៣ ១៥:១៧ ១៧:១០) ។ ស្បថគឺដូចគ្នានិងពាក្យសម្បថសម្រាប់អ្នកណាដែលប្រព្រឹត្តល្មើស និងការតាំងសញ្ញារបស់ព្រះអម្ចាស់ ប៉ុន្តែ វាហាក់បីដូចជាគ្មានឥទ្ធិពល ឬអំណាចអ្វីនៅចំពោះទ្រង់ឡើយ ។

ចេញវាចាហើយ[ឃ]។
២២ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា អញ
នឹងកាច់យកចុងដើមតាត្រៅយ៉ាងខ្ពស់ ទៅដាំចុះ អញ
នឹងកាច់យកលំពង់[ង]១យ៉ាងទន់ ពីចុងបំផុតរបស់ដើមនោះ
ទៅដាំនៅលើភ្នំយ៉ាងខ្ពស់ស្រទ្បៀត[ច] ២៣គឺអញនឹងដាំនៅ
លើភ្នំយ៉ាងខ្ពស់[ឆ]នៃស្រុកអ៊ីស្រាអែល ដើមនោះនឹងបោះ
មែក ហើយកើតផល[ជ] ព្រមទាំងត្រឡប់ទៅជាដើមតាត្រៅ
យ៉ាងល្អ ឯអស់ទាំងសត្វស្លាបគ្រប់មុខ នឹងជ្រកនៅក្រោម
ហើយធ្វើសំបុកនៅក្រោមម្លប់នៃមែកវា[ឈ] ២៤ដូច្នេះ អស់
ទាំងដើមឈើនៅផែនដី[ញ]នឹងដឹងថា អញគឺយេហូវ៉ា អញ
បានបន្ទាបដើមឈើខ្ពស់ចុះមក[ដ] ហើយបានដំកើងដើម
ឈើទាបឡើងវិញ អញបានធ្វើឲ្យដើមឈើខ្ចីស្វិតក្រៀម
ទៅ ហើយឲ្យដើមឈើ ដែលស្វិតក្រៀមបានប៉ិចឡើងវិញ[ឋ]
គឺអញ យេហូវ៉ានេះហើយ ដែលបានចេញវាចា ព្រមទាំង
ធ្វើការនេះផង[ឌ]។

**១៧:១៩** ឃ យរ ២៧:៨
**១៧:២២** ង ២ពវ ១៩:៣០ អស ៤:២ ច ខ.២៣ អស ២:២ យរ ២៣:៥ អគ ២០:៤០ ៣៦:១,៣៦ ៣៧:២២ ៤០:២ ៤៣:១២
**១៧:២៣** ឆ ខ.២២ យរ ៣១:១២ ជ អស ២៧:៦ ឈ ទដ ៩២:១២ អស ២:២ អគ ៣១:៦ ដយ ៤:១២ ហស ១៤:៥–៧ មថ ១៣:៣២
**១៧:២៤** ញ ទដ ៩៦:១២ អស ២:១៣ ដ ទដ ៥២:៥ ឋ ជន

## វិញ្ញាណដែលធ្វើបាបនឹងត្រូវស្លាប់

**១៨** ១ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់ខ្ញុំម្តងទៀត
ថា ២ឯងរាល់គ្នាប្រើពាក្យសុភាសិតនេះ និយាយពីដំណើរ
ស្រុកអ៊ីស្រាអែលថា ឪពុកបានស៊ីផ្លែជូរ ហើយកូនត្រូវ
សង្កៀតធ្មេញទៅ នោះតើចង់ថាដូចម្តេច[ក] ៣ព្រះអម្ចាស់
យេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ នោះប្រាកដជាឯង
រាល់គ្នាមិនមានឱកាសនឹងនិយាយសុភាសិត[ខ]នេះ នៅក្នុង
ស្រុកអ៊ីស្រាអែលទៀតឡើយ ៤មើល ព្រលឹងទាំងអស់ជា
របស់ផងអញ ទោះទាំងព្រលឹងនៃឪពុក និងព្រលឹងនៃកូន
ផង ក៏ជារបស់ផងអញដូចគ្នា ឯព្រលឹងណាដែលធ្វើបាប[គ]
គឺព្រលឹងនោះឯងនឹងត្រូវស្លាប់វិញ[ឃ]។
៥ប៉ុន្តែបើមនុស្សណាសុចរិត ជាអ្នកប្រព្រឹត្តសេចក្តី

១៧:៨ ដយ ៥:២១ ឌ ១សយ ២:៧–៨ អគ ១៩:១២ ២១:២៦ ២២:១៤ ៣៧:១៣ អម ៩:១១ **១៨:២** ក យប ២១:១៩ អស ៣:១៥ យរ ៣១:២៩ **១៨:៣** ខ ទដ ៤៩:៤ **១៨:៤** គ ២ពវ ១៤:៦ សភ ១៣:២១ ឃ ខ.២០ លប ១៨:២៣ នក ១៧:១៤ យប ២១:២០ អស ៤២:៥ អគ ៣៣:៨ រម ៦:២៣

**១៧:២២** *អញនឹង* គឺជានិមិត្តសញ្ញាបង្ហាញពីព្រះបន្ទូលសន្យាពិសេសតាមរយៈព្រះមែស៊ី មានសារៈប្រយោជន៍និងសំខាន់បំផុតពីព្រោះវាជាព្រះបន្ទូលសន្យាដែលកើតមានឡើងតាំងពីមុនមក ដែលយើងមិនអាចនឹកស្មានដល់ និងគ្មានសង្ឃឹម ។ *លំពង់១* គឺចង់និយាយពីចំនួនពូជពង្សរបស់ស្តេចដាវីឌ (ធៀបនឹង អស ១១:១ យរ ៣:៨ ៦:១២ និងការពន្យល់) ។ *ដើមតាត្រៅ* សូមមើលការពន្យល់ ខ.៣ ។ *ទៅដាំចុះ* គឺរាជ្យរបស់ទ្រង់ជាស្តេច (សូមមើល ខ.៥) ។ *ពីចុងបំផុតរបស់ដើមនោះ ទៅដាំនៅលើភ្នំយ៉ាងខ្ពស់ស្រទ្បៀត* គឺចង់និយាយសំដៅទៅលើទីក្រុងយេរូសាឡិម (សូមមើល អស ២:២–៤ និងការពន្យល់) ។

**១៧:២៣** *អស់ទាំងសត្វស្លាប... ហើយធ្វើសំបុកនៅក្រោមម្លប់នៃមែកវា* ជានិមិត្តរូបបង្ហាញពីអានុភាពនៃស្តេច សូមមើល ដយ ៤:១០–១២ ២០–២២ ធៀបនឹង មក ៤:៣២ ។

**១៧:២៤** *អស់ទាំងដើមឈើនៅផែនដីនឹងដឹងថា* គឺតំណាងឲ្យស្តេចទាំងឡាយ ហើយនិង អ្នកគ្រប់គ្រងទាំងអស់នៅលើលោកិយ៍ ។ *ដំកើងឈើទាបឡើងវិញ . . . ធ្វើឲ្យដើមឈើខ្ចីស្វិតក្រៀមទៅ* សូមមើល ១ស យ ២:៤–៨ និងការពន្យល់ អស ២:១២–១៨ ។

**១៨:១–៣២** ពួកគេបានបោះបង់ចោលព្រះបន្ទូលរបស់ព្រះដោយព្រោះពួកគេបានរអ៊ូរទាំចំពោះការឈឺចាប់ ដោយសារតែអំពើបាបពួកព្ធយុកោគេ គឺវាហាក់បីដូចជាពិបាកជាង ការប្រព្រឹត្តអំពើបាបផ្ទាល់ខ្លួនឯងទៅទៀត ។ (សូមមើលឧទាហរណ៍ នក ២០:៥ ពច ៧:២៤ ១ពវ ១៤:១៤–១៦ និងការពន្យល់សូមមើល នក ៣៤:៧ ១ពវ ២២:១៦–២០ ២៣:២៦–២៧ ២៤:១–៤ ២ពវ ២១:១០–១៥ អស ៥:១–៧ យរ ១:១៥–១៦ ៥:១–១៧ ១៧:១–៤ អម ២:៤–១៦ ៥:១២) ។ ប៉ុន្តែក្រុងយេរូសាឡិមបានផ្ទុកពេញដោយសេចក្តីអយុត្តិធម៌ និងប្រព្រឹត្តសេចក្តីរំលងនៅចំពោះព្រះ ។ ប្រសិនបើឯងមិនព្រមវិលបែរចេញពីអំពើបាបដ៏អាក្រក់របស់ពួកព្ធយុកោគេទេ នោះព្រះបន្ទូលរបស់ទ្រង់ត្រឹមត្រូវ និងជិនុំជម្រះពួកគេដោយសេចក្តីយុត្តិធម៌ នៅ ខ.១៤–១៧ ២៧–២៨ ។ នេះជាការបង្ហាញ ភស្តុតាងពីផ្លូវរបស់ព្រះក្នុងការឈរនៅជាអាជ្ញាកណ្តាល ចំពោះពួកអ៊ីស្រាអែលនៃការស្វែងរកការទស្សន៍ទាយ ១៣:១–២៤:១៤ (សូមមើលការពន្យល់ ១៣:១–២៣) ។

**១៨:២** *សុភាសិតទាំងនេះ* យរ ៣១:២៩ គឺបានចង្អុលបង្ហាញប្រាប់ថា ពាក្យសុភាសិតបានរស់ឡើងវិញមុនដំបូងនៅក្នុងក្រុងយេរូសាឡិម។ ហោរាយេ–រេមា គាត់បានទស្សន៍ទាយពីការបញ្ឈប់ពាក្យនៃសុភាសិត ចំណែកឯហោរាអេសេគាលលោកបាននិយាយថា វាគឺជាចុងបញ្ចប់ដែលត្រូវបានមក ។ *ពីដំណើរស្រុកអ៊ីស្រាអែល* ដោយសារការប្រព្រឹត្តអំពើបាបធ្វើឲ្យស្រុកអ៊ីស្រាអែលបានទទួលលទ្ធផលនៃការឈឺចាប់ និងសេចក្តីស្លាប់ ។ *ឪពុក . . . សង្កៀតធ្មេញ* ពាក្យសុភាសិតនេះបានបញ្ជាក់ពីសេចក្តីអាណិត ខ្លួនឯងនិងជាពាក្យចំអកដល់សេចក្តីយុត្តិធម៌របស់ព្រះ ។
*សង្កៀតធ្មេញ* តាមព្រះគម្ពីរភាសារហេព្រើរឃ្លានេះ ប្រហែលមានន័យថា រិល ឬ រិចរិល(ធៀបនិង សស ១០:១០) ប៉ុន្តែវាអាចសំដៅទៅលើអារម្មណ៍នៅពេលដែលមាត់បរិភោគរបស់អ្វីហើយមានជាតិល្វីង ឬជាតិជូរ ។

**១៨:៣** *ដូចជាអញរស់នៅ* សូមមើលការពន្យល់ ៥:១១ ។

**១៨:៤** *ឯព្រលឹងណាដែលធ្វើបាប គឺព្រលឹងនោះឯងនិងត្រូវស្លាប់វិញ* ឬព្រលឹងតែមួយ. . ."លោកអេសេគាល បាននិយាយចេញប្រឆាំងជិទាស់ចំពោះមនុស្សណាដែលបង្កើតនៅគោលលិទ្ធិក្លែងក្លាយ គេនិងទទួលបាននូវមរតនៃសេចក្តីអាក្រក់(ប្រហែលជាការយល់ខុសរបស់ពួកគេ នក ២០:៥ ៣៤:៧) ។ អ្វីដែលមានតទៅនេះគឺជាការពិពណ៌នារបស់ទ្រង់អំពីមនុស្សបីនាក់ សម្រាប់ពួកគេអាចឈរដឹកនាំបានបីជំនាន់កន្លងមក ហើយការដឹកនាំនេះគឺបែកចែកចេញបីភាគបួនជំនាន់ដែលទុកជាគំរូ ។ *ព្រលឹង* គឺជាជីវិតឬបុគ្គលអត្តន័យនៅត្រង់នេះមិនមែនសម្គាល់ទៅលើវិ ញ្ញាណនៃរូបកាយទេ ។

**១៨:៥** *មនុស្សសុចរិត* គឺជាមនុស្សជំនាន់ដើមដែលបានរក្សាក្រឹត្យវិន័យ ។ សូមមើលក្រឹត្យវិន័យ ១០ប្រការនៅក្នុង នកជំពូក២០ និង ចទ ជំពូក៥ ធៀបនឹង ទដ ១៥:២–៥ ២៤:៣–៦ អស ៣៣:១៥ ធៀបនឹងការពន្យល់ ទដ

ដែលត្រឹមត្រូវហើយទៀងត្រង់ ៦ឥតដែលស៊ីនៅលើភ្នំ[ង] ឬ
ងើបភ្នែក មើលទៅឯរូបព្រះ[ច]របស់ពួកវង្សអ៊ីស្រាអែល ក៏
មិនបានបង្អាប់ប្រពន្ធរបស់អ្នកជិតខាងខ្លួន ឬចូលទៅជិត
ស្រីដែលមានរដូវកាល[ឆ] ៧ហើយមិនបានសង្កត់សង្កិន[ជ]អ្នក
ណា គឺបានប្រគល់របស់បញ្ចាំ[ឈ]ដល់អ្នកដែលជំពាក់ខ្លួនវិញ
ក៏មិនបានប្លន់យករបស់គេ[ញ] គឺបានចែកអាហារដល់ពួកអ្នក
ដែលឃ្លាន[ដ] ហើយបិទបាំងអ្នកដែលនៅខ្លួនទទេ[ឋ] ដោយ
សំលៀកបំពាក់វិញ ៨គឺបើអ្នកនោះមិនបានឱ្យគេខ្ចីដោយ
យកការ[ឌ] ឬយកកំរៃអ្វីឡើយ គឺបានដកដៃពីអំពើទុច្ចរិត
ចេញ បានសំរេចសេចក្ដីយុត្តិធម៌[ឍ]ចំពោះគ្នានឹងគ្នា ៩ព្រម
ទាំងប្រព្រឹត្តតាមក្រឹត្យក្រម[ណ]របស់អញ ហើយរក្សាបញ្ញត្តិ
ច្បាប់[ត]របស់អញ ដើម្បីនឹងប្រព្រឹត្តដោយពិតត្រង់ នោះព្រះ
អម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា អ្នកនោះជាមនុស្ស
សុចរិតពិត អ្នកនោះនឹងរស់នៅជាប្រាកដ[ថ]។
១០បើអ្នកនោះបង្កើតកូនប្រុសមកដែលធ្វើជាចោរ ជា
អ្នកដែលកំចាយឈាម[ទ] ឬប្រព្រឹត្តការអ្វីយ៉ាងនោះ ១១ឥត
ដែលប្រព្រឹត្តការទាំងប៉ុន្មានដែលគួរធ្វើទេ គឺបានស៊ីនៅ
លើភ្នំវិញ[ធ] ហើយបង្អាប់ប្រពន្ធរបស់អ្នកជិតខាងខ្លួន ១២ព្រម
ទាំងសង្កត់សង្កិនពួកអ្នកក្រីក្រ[ន] ហើយកំសត់ទុគ៌ត ឬប្លន់
គេ ក៏មិនបានប្រគល់របស់បញ្ចាំទៅវិញ[ប] ហើយបានងើប
ភ្នែកមើលទៅឯរូបព្រះ គឺបានប្រព្រឹត្តការដ៏គួរស្អប់ខ្ពើម[ផ]
១៣បានទាំងឱ្យគេខ្ចីដោយយកការ ហើយយកកំរៃផង[ព] តើ
កូននោះនឹងរស់នៅ ឬវាមិនត្រូវរស់ទេ វាបានប្រព្រឹត្តអំពើ
គួរស្អប់ខ្ពើមទាំងនោះ ដូច្នេះ វាត្រូវស្លាប់ជាមិនខាន ឈាម
វានឹងធ្លាក់ទៅលើវាវិញ[ភ]។
១៤ប៉ុន្តែ មើលបើអ្នកនោះបង្កើតកូនប្រុសមក ដែល
ឃើញអស់ទាំងអំពើបាបដែលឪពុកប្រព្រឹត្ត ក៏ពិចារណា
ហើយមិនប្រព្រឹត្តតាមអំពើយ៉ាងនោះឡើយ[ម] ១៥គឺមិនស៊ី
នៅលើភ្នំ[យ]ឬងើបភ្នែកមើលទៅឯរូបព្រះ[រ]របស់ពួកវង្សអ៊ី
ស្រាអែល ក៏មិនបានបង្អាប់ប្រពន្ធរបស់អ្នកជិតខាងខ្លួន ១៦ឬ
សង្កត់សង្កិនអ្នកណា ឬទទួលបញ្ចាំរបស់គេ ក៏មិនបាន
ប្លន់ដែរ គឺបានចែកអាហាររបស់ខ្លួន ដល់ពួកអ្នកដែល
ឃ្លាន[ល] ហើយបិទបាំងអ្នកដែលនៅខ្លួនអាក្រាតទទេ[វ] ដោយ
សំលៀកបំពាក់ ១៧ក៏ដកដៃចេញពីអ្នកក្រីក្រ ហើយមិន
បានយកការ ឬកំរៃអ្វីឡើយ គឺបានសំរេចតាមក្រឹត្យក្រម[ស]
របស់អញ ហើយប្រព្រឹត្តតាមបញ្ញត្តច្បាប់របស់អញទាំង
ប៉ុន្មាន កូននោះនឹងមិនស្លាប់ ដោយព្រោះសេចក្ដីទុច្ចរិត
របស់ឪពុកខ្លួនឡើយ គឺនឹងរស់នៅជាពិតវិញ ១៨តែឯ
ចំណែកឪពុកវា នោះនឹងត្រូវស្លាប់ក្នុងអំពើទុច្ចរិតរបស់ខ្លួន

**១៨:៦** ង អគ ៦:២ ច ចទ ៤:១៩ អគ ៦:១៣ ២០:២៤ អម ៥:២៦ ឆ លវ ១២:២ ១៥:២៤ **១៨:៧** ជ នក ២២:២១ មឡ ៣:៥ យក ៥:៤ ឈ នក ២២:២៦ ញ នក ២០:១៥ ដ យប ២២:៧ ឋ ចទ ១៥:១១ អគ ១៦:៤៩ មថ ២៥:៣៦ លក ៣:១១ **១៨:៨** ឌ នក ១៨:២១ ២២:២៥ លវ ២៥:៣៥–៣៧ ចទ ២៣:១៩–២០ ឍ យរ ២២:៣ សក ៨:១៦ **១៨:៩** ណ លវ ១៩:៣៧ ត ហព ២:៤ ថ លវ ១៨:៥ អគ ១១:១២ ២០:១១ អម ៥:៤ **១៨:១០** ទ នក ២១:១២ អគ ២២:៦ **១៨:១១** ធ អគ ២២:៩

**១៨:១២** ន នក ២២:២២ យប ២៤:៩ អម ៤:១ ប នក ២២:២៧ ផ ២ពវ ២១:១១ អស ៥៩:៦–៧ យរ ២២:១៧ អគ ១៦:៤៩ ហព ២:៦ **១៨:១៣** ព នក ២២:២៥ ភ លវ ២០:៩ អគ ៣៣:៤–៥ ហស ១២:១៤ **១៨:១៤** ម ២របា ៣៤:២១ សភ ២៣:២៤ **១៨:១៥** យ អគ ២២:៩ រ ទដ ២៤:៤ **១៨:១៦** ល អស ៥៨:៧ វ នក ២២:២៧ ទដ ៤១:១ អស ៥៨:១០ អគ ១៦:៤៩ **១៨:១៧** ស ទដ ១:២

១:៥ ១១៩:១២១ ។ *ត្រឹមត្រូវហើយទៀងត្រង់* បានបញ្ជាក់នៅក្នុងព្រះគម្ពីរអេសេគាលជំពូក ១៨ (សមមើល ខ.១៩,២១,២៧) និង ៣៣ (មើល ខ.១៤,១៦,១៩) ។

**១៨:៦** *ស៊ីនៅលើភ្នំ ឬងើបភ្នែក* នៅត្រង់ចំណុចនេះ ការស៊ីសាច់ គឺជាយញ្ញបូជាដែលត្រូវថ្វាយទៅដល់រូបព្រះឬព្រះក្លែងក្លាយនៅទីកន្លែងខ្ពស់ៗ(សូមមើល ៦:៣ ហស ៤:១៣) ។ *មើលទៅ* សូមស្វែងរកជំនួយ (សូមមើល ២៣:២៧ ៣៣:៣២ ទដ ១២១:១)។ *រូបព្រះ* សូមើល ការពន្យល់ ៦:៤ ។ *បង្អាប់* គឺជាការផិតក្បត់(ត្រូវទទួលទោស មើលនៅក្នុង នក ២០:១៤ ចទ ២២:២២ លវ ១៨:២០ ២០:១០) ។ ត្រង់វគ្គនេះសំដៅទៅលើការផិតក្បត់ទាក់ទងទៅនិងការមានរដូវរបស់ស្រ្តី ដែលជាការហាមឃាត់ ដូច្នេះមិនត្រូវប៉ះពាល់ស្រ្តី ឬរួមដំណេកជាមួយស្រ្តីនៅពេលមានរដូវឡើយ(សូមមើល លវ ១៥:១៩–២៤ ១៨:១៩ ២០:១៨)។ គឺជាការបង្ហាញនូវអវត្តមានពីការមិនស្តាប់បង្គាប់ដែលមានដូចខាងក្រោម (ធៀបនឹង ខ.១១,១៥) ។

**១៨:៧** *សង្កត់សង្កិន* ត្រង់នេះមានន័យថាពួកអ្នកមានតែងតែកេងចំណេញផលប្រយោជន៍ពីអ្នកក្រីក្រ ។ *គឺបានប្រគល់របស់បញ្ចាំដល់អ្នកដែលជំពាក់ខ្លួនវិញ* សូមមើល នក ២២:២៦ ចទ ២៤:១២–១៣ អម ២:៨ ។ *ប្លន់* សូមមើល សេចក្ដីបញ្ញត្តិប្រឆាំងទាស់នឹងការលួចប្លន់នៅក្នុង នក ២០:១៥ ចទ ៥:១៩ ។ ការប្រព្រឹត្តដូចនេះ គឺជាអំពើឃោរឃៅ(បានធ្វើដោយដៃ)។ ការលួច គឺជាការធ្វើសកម្មភាពលបលួចដោយសម្ងាត់របស់ចោរ ។ (សូមមើល លវ ១៩:១៣) ។ *ចែកអាហារដល់ពួកអ្នកដែលឃ្លាន* សូមមើល ចទ ១៥:៧–១១ មថ ២៥:៣១–៤៦ ។

**១៨:៨** *ខ្ចីដោយយកការ* សូមមើល ២២:១២ មើលផងដែរ នក ២២:២៥–២៧ ហើយនិងការពន្យល់ ។

**១៨:៩** *អ្នកនោះជាមនុស្សសុចរិតពិត អ្នកនោះនឹងរស់នៅជាប្រាកដ* គឺជាមនុស្សដែលចៅក្រមបានចេញសេចក្ដីសម្រេចសាលក្រមថា ជាមនុស្សឥតមានទោស (ធៀបនឹង ទដ ១៥:៥ ២៤:៥) ។ *រស់នៅ* សូមមើលការពន្យល់នៅក្នុង ១៦:៦ ។ ជីវិតដែលរស់នៅយូរអង្វែង គឺជាជីវិតអស់កល្បជានិច្ចដោយសារយើងចូលទៅកៀកជិតជាមួយនិងទ្រង់ ហើយយកព្រះអម្ចាស់ទុកជាទីពឹង (សូមមើល ទដ ៦៣:៣ ៧៣:២៧–២៨) ។

**១៨:១០** *បង្កើតកូនប្រុសមកដែលធ្វើជាចោរ* ឃ្លាត្រង់នេះនិយាយសំដៅទៅលើវិញ្ញាណអាក្រក់ គឺពីរជំនាន់ ជាបញ្ញត្តិទីប្រាំបី ។

**១៨:១៣** *ឈាមវានឹងធ្លាក់ទៅលើវាវិញ* គឺគេនឹងទទួលខុសត្រូវនៅការប្រព្រឹត្តអំពើបាបរបស់គេផ្ទាល់រៀងខ្លួនៗ (សូមមើល លវ ២០:៩,១១–១២,១៦,២៧) ។

**១៨:១៤** *កូនប្រុស* ន័យត្រង់នេះនិយាយសំដៅទៅលើមនុស្សសុចរិត គឺបីជំនាន់ ជាបញ្ញត្តិទីដប់ពីរ ។

ទៅ ដោយព្រោះបានសង្កត់សង្កិនយ៉ាងកំណាច ហើយ
បានប្លន់បងប្អូន ព្រមទាំងប្រព្រឹត្តការដែលមិនល្អផង នៅ
កណ្តាលសាសន៍ខ្លួនហើយ ។
១៩ប៉ុន្តែឯងរាល់គ្នាសួរថា ហេតុអ្វីបានជាកូនមិនត្រូវ
រងសេចក្តីទុច្ចរិតរបស់ឪពុក ដូច្នេះ កាលណាកូនបាន
ប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ ហើយទៀងត្រង់ ព្រមទាំង
រក្សាក្រិត្យក្រមរបស់អញ ហើយប្រព្រឹត្តតាមផង នោះវា
នឹងរស់នៅជាពិតវិញ[ហ] ២០ឯព្រលឹងណាដែលធ្វើបាប គឺ
ព្រលឹងនោះឯងនឹងត្រូវស្លាប់[ឡ] កូនមិនត្រូវរងសេចក្តីទុច្ចរិត
របស់ឪពុកទេ ហើយឪពុកក៏មិនត្រូវរងសេចក្តីទុច្ចរិតរបស់
កូនដែរ សេចក្តីសុចរិតរបស់មនុស្សសុចរិតនឹងនៅលើអ្នក
នោះឯង ហើយសេចក្តីទុច្ចរិតរបស់មនុស្សទុច្ចរិតនឹងនៅ
លើខ្លួនអ្នកទុច្ចរិតនោះឯងដែរ[អ] ។
២១តែឯមនុស្សទុច្ចរិត បើ[ក]បែរចេញពីអស់ទាំងអំពើ
បាប ដែលខ្លួនបានប្រព្រឹត្ត ហើយរក្សាអស់ទាំងក្រិត្យក្រម[ខ]
របស់អញ ព្រមទាំងប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ ហើយ
ទៀងទ្រង់វិញ អ្នកនោះនឹងរស់នៅជាពិត ឥតត្រូវស្លាប់
ឡើយ[គ] ២២ឯអំពើរំលងទាំងប៉ុន្មានដែលខ្លួនបានប្រព្រឹត្ត
នោះនឹងមិននឹងចាំបទណាមួយទាស់នឹងគេទេ គឺគេនឹងរស់
នៅ ដោយសេចក្តីសុចរិតដែលខ្លួនបានប្រព្រឹត្តវិញ[ឃ]
២៣ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលសួរថា តើអញមាន
សេចក្តីអំណរដោយមនុស្សទុច្ចរិត ស្លាប់ទៅឬ តើមិនមែន
អរ[ង] ដោយគេបែរចេញពីផ្លូវរបស់ខ្លួនវិលមក ឱ្យបានរស់
នៅវិញទេឬអី[ច] ២៤តែឯមនុស្សសុចរិត បើគេបែរចេញ[ឆ]
ពីអំពើសុចរិតរបស់ខ្លួន ទៅប្រព្រឹត្តទុច្ចរិត ហើយធ្វើគ្រប់
ទាំង ការស្អប់ខ្ពើម ដែលមនុស្សទុច្ចរិតតែងប្រព្រឹត្តវិញ
នោះ តើនឹងរស់នៅឬ ឯអំពើសុចរិតទាំងប៉ុន្មាន ដែល
អ្នកនោះបានធ្វើ នោះនឹងគ្មាននឹកចាំពីបទណាមួយឡើយ
អ្នកនោះ នឹងត្រូវស្លាប់ក្នុងអំពើរំលង[ជ]ដែលខ្លួនបានប្រព្រឹត្ត
ហើយក្នុង អំពើបាបដែលខ្លួនបានធ្វើនោះវិញ[ឈ] ។
២៥ទោះបើយ៉ាងនោះ គង់តែឯងរាល់គ្នាថា ផ្លូវរបស់
ព្រះអម្ចាស់មិនស្មើទេ[ញ] ដូច្នេះ ឱពួកវង្សអ៊ីស្រាអែលអើយ
ចូរស្តាប់ចុះ តើផ្លូវរបស់អញមិនស្មើមែនឬ[ដ] តើមិនមែនជា
ផ្លូវរបស់ឯងរាល់គ្នា ដែលមិនស្មើវិញទេឬ ២៦កាលណា
មនុស្សសុចរិតបែរចេញពីអំពើសុចរិតរបស់ខ្លួនទៅប្រព្រឹត្ត
ទុច្ចរិតវិញ ហើយត្រូវស្លាប់ទៅ នោះគឺនឹងត្រូវស្លាប់ក្នុង
អំពើទុច្ចរិត ដែលខ្លួនបានប្រព្រឹត្តនោះឯង ២៧មួយទៀត
កាលណាមនុស្សទុច្ចរិតបែរចេញពីអំពើទុច្ចរិត ដែលខ្លួន
បានធ្វើ ទៅប្រព្រឹត្តសេចក្តីដែលត្រឹមត្រូវ ហើយទៀងត្រង់
វិញ នោះគេនឹងធ្វើឱ្យព្រលឹងខ្លួនរស់នៅ[ឋ] ២៨គឺនឹងរស់
នៅជាពិត ឥតស្លាប់ឡើយ ដោយព្រោះគេបានពិចារណា
ហើយបែរចេញពីអំពើរំលងដែលខ្លួនបានប្រព្រឹត្តនោះ[ឌ]
២៩ប៉ុន្តែពួកវង្សអ៊ីស្រាអែលគេថា ផ្លូវរបស់ព្រះអម្ចាស់មិន
ស្មើទេ ឱពួកវង្សអ៊ីស្រាអែលអើយ តើផ្លូវរបស់អញមិន
ស្មើមែនឬ តើមិនមែនជាផ្លូវរបស់ឯងរាល់គ្នាដែលមិនស្មើ
វិញទេឬ ៣០ហេតុនោះព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល
ថា ឱពួកវង្សអ៊ីស្រាអែលអើយ អញនឹងជំនុំជំរះឯងរាល់
គ្នាគ្រប់គ្នាតាមអំពើប្រព្រឹត្តរៀងខ្លួនចូរឯងរាល់គ្នាវិលមក
វិញ ចូរបែរចេញ[ឍ]ពីអំពើរំលងរបស់ឯងទៅ យ៉ាងនោះ
សេចក្តីទុច្ចរិតនឹងមិនបំផ្លាញឯងទេ[ណ] ៣១ចូរបោះបង់
ចោល[ត] អំពើរំលងទាំងប៉ុន្មានរបស់ឯង ដែលឯងរាល់គ្នា

**១៨:១៩** ហ នក ២០:៥ ចទ ៥:៩ យរ ១៥:៤ សក ១:៣–៦ **១៨:២០** ឡ ជន ១៥:៣១ អ ចទ ២៤:១៦ ១ពវ ៨:៣២ ២ពវ ១៤:៦ អស ៣:១១ អក ៧:២៧ ១៤:១៤ មថ ១៦:២៧ យហ ៩:២ **១៨:២១** ក យរ ១៨:៨ ខ លប ២៦:៥ គ អក ១៣:២២ ៣៦:២៧ **១៨:២២** ឃ ទដ ១៨:២០–២៤ អស ៤៣:២៥ ដយ ៤:២៧ មីក ៧:១៩ **១៨:២៣** ង ទដ ១៤៧:១១ ច យប ៣៧:២៣ បទ ៣:៣៣ អក ១៦: ម១៦:៦៧៦ មីក ៧:១៨ ១ធថ ២:៤ **១៨:២៤** ឆ យរ ៣៤:១៦
ជ អក ១៥:៨ ១សយ ១៥:១១ ២របា ២៤:១៧–២០ យប ៣៥:៨ សភ ២១:១៦ អក ៣:២០ ២០:២៧ ២ពត ២:២០–២២ **១៨:២៥** ញ យរ ២:២៩ លប
១៨:២៥ យរ ១២:១ អក ៣៣:១៧ សផ ៣:៥ មឡ ២:១៧ ៣:១៣–១៥
**១៨:២៧** អស ១:១៨ អក ១៣:២២ **១៨:២៨** អស ៥៥:៧ **១៨:៣០** ឍ អស ១:២៧ យរ ៣៥:១៥ មថ ៣:២ ណ អក ៧:៣ ២៤:១៤ ៣៣:២០ ហស ១២:៦ ១ពត ១:១៧ **១៨:៣១** ត ពច ៦:៨

**១៨:២០** *សេចក្តីសុចរិត . . . នឹងនៅលើអ្នកនោះឯង* មើល ទដ ១០៦:៣១ និងការពន្យល់ ។

**១៨:២១** *ឯមនុស្សទុច្ចរិតនឹងបែរ . . . ហើយរក្សា . . . អ្នកនោះនឹងរស់នៅពិត* នៅ ខ.១–២០ បានចង្អុលប្រាប់ថា វាជាចំណងនៃការទទួលបានមរតករបស់សេចក្តីទុច្ចរិត ហើយវានឹងត្រូវបានបំផ្លាញឱ្យខ្ទេចខ្ទី មើល ខ.២១–២៩ ដែលបានបង្រៀនប្រាប់ ពីអំណាចនៃសេចក្តីទុច្ចរិតបានកើនឡើងនៅខាងក្នុងចិត្តរបស់មនុស្សម្នាក់ដែលនឹងអាចកើតឡើងបាន ។

**១៨:២៣** *តើអញមានសេចក្តីអំណរដោយមនុស្សទុច្ចរិតស្លាប់ទៅឬ* នៅក្នុងសេចក្តីបន្ថែមចំពោះចម្លើយនេះគឺមាននៅ ខ.៣២ សូមមើល ៣៣:១១ យហ ៤:១១ និងការពន្យល់ ។

**១៨:២៤** *តែឯមនុស្សសុចរិត បើគិតបែរចេញ* សូមមើល ហព ២:៣ ២ពត ២:២០–២២ គឺជាការរំឭក ឬជាការព្រមានទាស់នឹងអ្នកដែលអួតថាមានចំណេះដឹកខ្ពស់ទាំងឡាយ ហើយឱ្យគេវិលបែរមកដើរតាមផ្លូវសុចរិតវិញ ។

**១៨:២៥** *តើផ្លូវរបស់អញមិនស្មើមែនឬ* សូមមើល ៣៣:១៧ ធៀបនឹង លប ១៨:២៥ និងការពន្យល់ ចទ ៣២:៤ យរ ១២:១ និងការពន្យល់ ។

**១៨:២៦** *កាលណាមនុស្សសុចរិត* សូមមើល ចាប់ពី ខ.២៦–២៩ គឺជាការរំឭកឡើងវិញពីការលូតលាស់ខាងសេចក្តីទាស់ទែងគ្នានៅក្នុង ខ.២១–២៥ ។

**១៨:៣០** *ហេតុនោះ* គឺជាការសង្ខេបនៅសេចក្តីទំនាយ ដែលប្រៀបធៀបនិងសេចក្តីបញ្ចប់នៃភាសារ ជាមួយការបញ្ចប់របស់ពាក្យចុងក្រោយនៃសេចក្តីទំនាយ ហើយសេចក្តីទំនាយទាំងនេះគឺមាននៅក្នុង (២៤:១៤) ។ *គ្រប់គ្នា* គឺចង់បញ្ជាក់ប្រាប់ពីខណៈពេលដែលផ្ទះពួកអ៊ីស្រាអែលទាំងអស់ពេញដោយសេចក្តីទុច្ចរិត ហើយព្រះអម្ចាស់ជំនុំជម្រះពួកគេដោយសេចក្តីយុត្តិធម៌ចំពោះបុគ្គលដែលបានប្រព្រឹត្តសេចក្តីទុច្ចរិតរៀងៗខ្លួន ។ *ប្រែចិត្ត* ត្រង់វគ្គទីពីរនេះ មានន័យថា ការស្តាយក្រោយនូវកំហុសដែលបានប្រព្រឹត្តិខុសពីមុនមក (សូមមើល ១៤:៦ និងការពន្យល់ ។

**១៨:៣១** *ហើយឱ្យខ្លួនមានចិត្តថ្មី* គឺជាអ្វីដែលដែលព្រះអម្ចាស់បានសន្យា

ប្រព្រឹត្តនោះ ហើយឱ្យខ្លួនមានចិត្តថ្មី[ថ] នឹងវិញ្ញាណថ្មីចុះ[ទ]
ដ្បិត ឱពូជពង្សអ៊ីស្រាអែលអើយ ឯងរាល់គ្នាចង់ស្លាប់
ធ្វើអ្វី[ធ] ៣២ពីព្រោះអញឥតមានសេចក្ដីអំណរ ចំពោះការ
ស្លាប់ របស់អ្នកដែលត្រូវស្លាប់នោះទេ ដូច្នេះចូរឯង
រាល់គ្នាវិលមក[ន] ដើម្បីឱ្យបានរស់នៅវិញ[ប] នេះជាព្រះ
បន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ។

**បទទំនួញពីដំណើរពួកចៅហ្វាយនៃសាសន៍អ៊ីស្រាអែល**

**១៩** ១មួយទៀត ចូរឯង ចាប់តាំងពោលបទទំនួញ[ក]ពី
ដំណើរពួកចៅហ្វាយ[ខ]នៃសាសន៍អ៊ីស្រាអែល ២ចូរថា តើ
ម្ដាយឯងជាអ្វី គឺជាសិង្ហញី[គ] ដែលបានក្រាបនៅកណ្ដាល
សិង្ហឈ្មោល ក៏បំបៅកូន[ឃ] នៅកណ្ដាលពួកសិង្ហស្ទាវ ៣ក៏
បានចិញ្ចឹមកូន១ ដែលត្រឡប់ទៅជាសិង្ហស្ទាវ ហើយបាន
ហាត់ចាប់រំពា វាក៏ត្របាក់លេបមនុស្សទៅ ៤អស់ទាំង
សាសន៍បានឮនិយាយពីវា រួចគេចាប់វាបានក្នុងរណ្ដៅ
របស់គេ ក៏ខ្លះ[ង]ដឹកនាំទៅឯស្រុកអេស៊ីព្ទ[ច] ៥រីឯមេ កាល
ឃើញថារង់ចាំជាយូរ តែទីសង្ឃឹមបានបាត់ហើយ នោះ
ក៏យកកូន[ឆ]១ទៀតផឡើងជាសិង្ហស្ទាវ[ជ] ៦រួចកូននោះក៏ដើរ
ទៅមកជាមួយនឹងពួកសិង្ហឈ្មោល វាត្រឡប់ជាសិង្ហស្ទាវ
ឡើង ហើយក៏ហាត់ចាប់រំពា វាត្របាក់លេបមនុស្សទៅ
ដែរ[ឈ] ៧វាស្គាល់អស់ទាំងដំណាក់របស់គេ ហើយបាន
បំផ្លាញ[ញ]ទីក្រុងគេ ស្រុកនោះនឹងរបស់សព្វសារពើនៅក្រុង
នោះ ក៏ខូចបង់ ដោយសូរគ្រហឹមរបស់វា ៨គ្រានោះអស់
ទាំងសាសន៍[ដ]ក៏លើកគ្នាទាស់នឹងវា ពីស្រុកជុំវិញគ្រប់ទិស
គេត្រដាងមង[ឋ]ពីលើវា ហើយវាជាប់ក្នុងរណ្ដៅរបស់គេ
ទៅ[ឌ] ៩គេខ្លះ[ឍ]ច្រមុះវាដាក់ក្នុងទ្រុង ដឹកនាំទៅថ្វាយស្ដេច
បាប៊ីឡូន[ណ] គេនាំវាចូលទៅក្នុងទីមាំមួន ដើម្បីមិនឱ្យឮសូរ
សំឡេង[ត]វានៅលើភ្នំស្រុកអ៊ីស្រាអែលទៀតឡើយ[ថ] ។
១០ម្ដាយឯងបានដូចជាដើមទំពាំងបាយជូរ[ទ] ក្នុងចំការ
របស់ឯង ដែលដាំនៅក្បែរមាត់ផ្លូវទឹក[ធ] ក៏កើតមានផល
ហើយមានខ្នែងជាច្រើន ដោយនៅជិតទឹកបរិបូរ[ន] ១១ដើម
នោះមានមែកមាំ សំរាប់ជាដំបងរាជ្យនៃពួកអ្នកដែលគ្រប់
គ្រង ក៏លូតឡើងខ្ពស់ជាងមែកដ៏ញឹកស្និត វាទាញនាំភ្នែក
គេដោយកំពស់ និងមែកយ៉ាងសន្ធឹករបស់វា[ប] ១២តែវាត្រូវ
ដករំលើង[ផ] ដោយសេចក្ដីឃោរឃៅ ហើយត្រូវបោះ
ចុះដល់ដីរួចខ្យល់[ព]ពីទិសខាងកើតក៏ធ្វើឱ្យផលវាស្វិតក្រៀម
ទៅ មែកដ៏មាំរបស់វាត្រូវបាក់ ហើយក្រៀមស្ងួតទៅ ឯ
ភ្លើងក៏ឆេះអស់រលីង[ភ] ១៣ឥឡូវនេះ វាត្រូវដាំនៅទីរហោ

**១៨:៣១** ថ ទដ ៥១:១០ ទ យរ ២៧:១៣ ធ អស ១:១៦–១៧ អគ ១១:១៩ ៣៦:២៦ **១៨:៣២** ន យប ២២:២៣ អស ៥៥:៧ មឡ ៣:៧ ប ២រប ៧:១៤ យប ៣៧:២៣ អគ ១៦:៦ ៣៣:១១ **១៩:១** ក ខ.១៤ យរ ៧:២៩ ៩:១០,២០ អគ ២៦:១៧ ២៧:២,៣២ ២៨:១២ ៣២:២,១៦ អម ៥:១ ក ២ពវ ២៤:៦ **១៩:២** គ ជន ២៣:២៤ ឃ លប ៤៩:៩ **១៩:៤** ង យប ៤១:២ ច ២ពវ ២៣:៣៣–៣៤ ២ពវ ៣៦:៤ បទ ៤:២០ **១៩:៥** ឆ លប ៤៩:៩ ជ ២ពវ ២៣:៣៤ **១៩:៦** ឈ ២ពវ ២៤:៩ ២រប ៣៦:៩ **១៩:៧** ញ អគ ២៩:១០ ៣០:១២ **១៩:៨** ដ ២ពវ ២៤:២ ឋ អគ ១២:១៣ ឌ ២ពវ ២៤:១១ បទ ៤:២០ **១៩:៩** ឍ ២ពវ ១៩:២៨ ណ ២ពវ ២៥:៧ ២រប ៣៦:៦ ត សក ១១:៣ ថ ២ពវ ២៤:១៥ **១៩:១០** ទ លប ៤៩:២២ ធ យក ១៧:៨ ន ទដ ៨០:៨–១១ **១៩:១១** ប អគ ៣១:៣ ដយ ៤:១១ **១៩:១២** ផ ចទ ២៩:២៨ ព លប ៤១:៦ ភ អស ២៧:១១ អគ ១៧:២៤ ២៨:១៧ ហស ១៣:១៥

ដោយគ្មានលក្ខខ័ណ(១១:១៩ ៣៦:២៦) ឃ្លាត្រង់នេះគឺព្រះអម្ចាស់និងប្រទានឱ្យរាស្ត្ររបស់ទ្រង់មានចិត្តថ្មី ហើយនិងដាក់វិញ្ញាណថ្មីនៅក្នុងចិត្តពួកគេ ដោយគ្មានលក្ខខ័ណ(ធៀបនឹង ភល ២:១២ និង ២:១៣) ។

**១៨:៣២** *អញឥតមានសេចក្ដីអំណរ* មើល ខ.២៣ គឺត្រូវបានផ្សព្វផ្សាយនៅក្នុងសេចក្ដីបញ្ចប់ដ៏សំខាន់ ដែលព្រះបានត្រាស់ហៅអ្នកខ្លះដើម្បីឱ្យនាំព្រះរាជសារនៃព្រះបន្ទូលរបស់ព្រះដ៏មានសារៈសំខាន់បំផុតនៅក្នុងព្រះគម្ពីរអេសេគាលទាំងមូល (សូមមើលការពន្យល់នៅក្នុង ១៦:៦) ។

**១៩:១–១៤** បទទំនួញនៃភ្លេងសពបានធ្លាក់មកលើពួកវង្សស្ដេចសាសន៍យូដា ហើយស្ដេចសាសន៍យូដាគឺជានិមិត្តរូបសិង្ហញី ហើយនាងនិងកើតកូនមកក្នុងពេល ដំណាលគ្នា(ខ.១–៩) ហើយបានចម្រើនលូតលាស់ដូចជានិមិត្តរូបដើមទំពាំងបាយជូរ(ខ.១០–១៤) ។

**១៩:១** *ពោលបទទំនួញ* នៅត្រង់នេះគឺជាបទចម្រៀងទំនួញស្មូតដែលតាក់តែងឡើង សម្រាប់ប្រើនៅក្នុងពិធីបញ្ចុះសព(ដូចនៅក្នុង ២សយ ១:១៧–២៧) ប៉ុន្តែជារឿយៗគឺត្រូវបានយកមកប្រើនៅក្នុងការចំអកបញ្ឈឺចិត្តផងដែរ ដែលពួកហោរាបានប្រើបទទំនួញនេះនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដើម្បីស្មូតចំអក ឡកឡឺយដល់ការទស្សទាយពីសេចក្ដីស្លាប់របស់ប្រជាជាតិ (សូមមើល អស ១៤:៤–២១ អម ៥:១–៣ និងការពន្យល់នៅក្នុង ៥:១ និងមើលផងដែរ ២:១០ ព្រះអម្ចាស់ គឺជាស្ដេច ។

**១៩:២** យោងតាមខគម្ពីរនេះគឺជាការប្រៀបធៀបពីប្រជាជនអ៊ីស្រាអែល ឬជាតិសាសន៍យូដា ។

**១៩:៣** *ចិញ្ចឹមកូន១* ពាក្យនេះចង់និយាយពីស្ដេចយ៉ូអាហាស(សូមមើល ២ពវ ២៣:៣១–៣៤ យរ ២២:១០–១២) ដែលបានគ្រងរាជ្យតែរយៈពេលបីខែតែប៉ុណ្ណោះ ។ *ត្របាក់លេបមនុស្ស* គឺមានន័យថា ស្ដេចយ៉ូអាហាសបានប្រើអំណាចគ្រប់គ្រងប្រទេសដោយធ្វើនយោបាយសង្កត់សង្កិនឬជិះជាន់មកលើប្រជាជននៅក្នុងយុគសម័យនោះ ។

**១៩:៥** *យកកូន១ទៀតឱ្យឡើងជាសិង្ហស្ទាវ* ឃ្លាត្រង់នេះប្រហែលចង់ប្រៀបធៀបពីស្ដេចយេហូយ៉ាគីន (ដែលបានគ្រងរាជ្យតែរយៈពេលបីខែតែប៉ុណ្ណោះ ២ពវ ២៤:៨) ប៉ុន្តែ ទំនងជាស្ដេចសេដេគា (ដែលបានបង្ហាញនៅក្នុង ខ.៧ ទំនងជាពិពណ៌នាយ៉ាងច្រើនអំពីស្ដេចសេដេគា) ។ គឺស្ដេចទាំងពីរអង្គបាន ចាប់យកទីក្រុងបាប៊ីឡូន(ខ.៩) ។ ប្រសិនបើយោងតាមខនេះ គឺប្រហែលជាចង់និយាយពីស្ដេចយ៉ូយ៉ាគីន (២ពវ ២៤:១៥) នេះគឺជាបទទំនួញពិតប្រាកដរបស់ស្ដេចសេដេគាដែលបានថ្លែងទំនាយ(២ពវ ២៥:៧)។

**១៩:១០** *ម្ដាយឯងបានដូចជាដើមទំពាំងបាយជូរ* នៅគ្រាមុនមានរូបភាពមួយលេចមកដូចជាសិង្ហញីដែលហោរាអេសេគាលបានឃើញ (ខ.២) នេះគឺជាដើមទំពាំងបាយជូរ(ហើយដើមទំពាំងបាយជូរនេះសម្រាប់ប្រើជានិមិត្តរូប នៃការលូតលាស់ សូមមើល ខ.១៥:១–៨ ១៧:៧ និងការពន្យល់) ។

**១៩:១២** *ខ្យល់ពីទិសខាងកើត* ចង់និយាយពីស្ដេចនេប៊ូក្នេសា និងកងទ័ពរបស់ទ្រង់(សូមមើលការពន្យល់ ១៧:១០)។

ស្ថានវិញ[ម] គឺក្នុងទីហួតហែង ហើយសោះស្ងួត[យ] ១៤មាន
ភ្លើងចេញពីដំបង១ ដែលធ្វើពីខ្នែងវា ទៅបញ្ឆេះ[រ]ផលវា
ហើយវាគ្មានខ្នែងណាមាំ សំរាប់ធ្វើដំបងរាជ្យពួកអ្នកគ្រប់
គ្រងទៀតសោះ[ល] នេះជាបទទំនួញ ហើយនឹងបានទុកជា
ពាក្យទួញតទៅ[វ] ។

## ពួកអ៊ីស្រាអែលដែលបះបោរ

**២០** ១នៅថ្ងៃ១០ ខែស្រាពណ៍ ក្នុងឆ្នាំទី៧ នោះពួកចាស់
ទុំខ្លះនៃសាសន៍អ៊ីស្រាអែលបានមក ដើម្បីទូលសួរ[ក]ដល់
ព្រះយេហូវ៉ា ហើយគេអង្គុយនៅមុខខ្ញុំ[ខ] ២នោះព្រះបន្ទូល
នៃព្រះយេហូវ៉ាបានមកដល់ខ្ញុំថា ៣កូនមនុស្សអើយ ចូរ
និយាយប្រាប់ដល់ពួកចាស់ទុំ[គ] នៃសាសន៍អ៊ីស្រាអែលថា
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ឯងរាល់គ្នាបាន
មកសួរ[ឃ]ដល់អញឬ ព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូច
ជាអញរស់នៅ នោះប្រាកដជាអញមិនឱ្យឯងរាល់គ្នាសួរ
ដល់អញទេ[ង] ៤កូនមនុស្សអើយ ឯងចង់ជំនុំជំរះគេឬ តើ
ចង់ជំនុំជំរះគេឬទេ ចូរឱ្យគេដឹងអំពីអស់ទាំងអំពើគួរស្អប់
ខ្ពើមរបស់ពួកឰយុកោគេ[ច] ៥ហើយប្រាប់គេថាព្រះអម្ចាស់
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ នៅថ្ងៃដែល អញបានរើស[ឆ]
អ៊ីស្រាអែល ហើយស្បថ[ជ]ដល់ពូជពង្សយ៉ាកុប ព្រមទាំង
សំដែង ឱ្យគេស្គាល់អញនៅស្រុកអេស៊ីព្ទ គឺកាលដែលអញ
បានស្បថដល់គេថា អញនេះជាយេហូវ៉ា ជាព្រះនៃឯង
រាល់គ្នា[ឈ] ៦នៅថ្ងៃនោះឯង អញបានស្បថ[ញ]ដល់គេថា
នឹងនាំគេចេញពីស្រុកអេស៊ីព្ទ ទៅក្នុងស្រុក១ ដែលអញ
បានស្វែងរកឱ្យគេ ជាស្រុកមានទឹកដោះ និងទឹកឃ្មុំ
ហូរហៀរ[ដ] ជាទីរុងរឿងជាងស្រុកទាំងអស់[ឋ] ៧អញក៏ប្រាប់
គេថា ចូរឱ្យគ្រប់គ្នាបោះចោលអស់ទាំងរបស់គួរស្អប់ខ្ពើម[ឌ]
ដែលគាប់ភ្នែកឯងចេញ កុំធ្វើឱ្យខ្លួនសៅហ្មង ដោយរូប
ព្រះ[ឍ]របស់ស្រុកអេស៊ីព្ទឡើយ អញគឺយេហូវ៉ានេះ ជាព្រះ
នៃឯងរាល់គ្នាហើយ[ណ] ៨តែគេបានរឹងចចេសនឹងអញ ឥត
ព្រមស្តាប់តាមអញឡើយ[ត] ក៏មិនបានលះចោលរបស់គួរ
ស្អប់ខ្ពើម ដែលនៅគាប់ដល់ភ្នែកគេរៀងខ្លួនសោះ ឬបោះ
បង់ចោលរូបព្រះរបស់សាសន៍អេស៊ីព្ទដែរ[ថ] ដូច្នេះ អញ

**១៩:១៣** ម អគ ២០:៣៥ ហស ២:១៤ យ ហស ២:៣
**១៩:១៤** រ អគ ២០:៤៧ ល អគ ១៥:៤ វ ខ.១
**២០:១** ក លប ២៥:២២ ខ អគ ១:១–២ ៨:១ ២១:១
**២០:៣** គ អគ ៧:២៦ ឃ លប ២៥:២២ អគ ១៤:៣ ង ១សយ ២៨:៦ អស ១:១៥ អម ៨:១២ មីក ៣:៧
**២០:៤** ច អគ ១៦:២ ២២:២ មថ ២៣:៣២
**២០:៥** ឆ ចទ ៧:៦ ជ លប ១៤:២២ ជន ១៤:៣០ ឈ លវ ១១:៤៤
**២០:៦** ញ នក ៦:៨ ដ នក ៣:៨ ឋ ចទ ៨:៧ ដយ ៨:៩ ១១:៤១ មឡ ៣:១២
**២០:៧** ឌ នក ២០:៤ ឍ អគ ៦:៩ ណ នក ២០:២ លវ ១៨:៣ ចទ ២៩:១៨
**២០:៨** ត យរ ៧:២៦ ថ យរ ១១:១០ អគ ៧:៨ ១៦:២៦

**១៩:១៣** *ទីរហោស្ថាន* គឺប្រៀបធៀបពីទីក្រុងបាប៊ីឡូន ដែលពួកអ៊ីស្រាអែលចាត់ទុកហាក់បីដូចជាវាលរហោស្ថានហួតហែង ហើយសោះស្ងួតសម្រាប់ពួកគេធ្លាប់បានឆ្លងកាត់កន្លងមក (សូមមើល ២០:៣៥) ។

**១៩:១៤** *ភ្លើង* ជាសេចក្តីក្រោធនៃព្រះយេហូវ៉ាដែលប្រឆាំងទាស់នឹងក្រុងយេរូសាឡិម ហើយនិងស្រុកយូដា (សូមមើល ២ពវ ២៤:២០) វាគឺជាផ្នែកសំខាន់ដែលជាការព្រមានដល់ពួកគេ។ ស្តេចសេដេគាបានពោលពាក្យទំនួញនេះដើម្បីទុកជាការរំឭកដល់គេ ដែលបានបញ្ជាក់ប្រាប់ (សូមមើល ទដ ១៣៧:១) ។

**២០:១–៤៤** ព្រះបន្ទូលរបស់ព្រះចង់បញ្ជាក់ប្រាប់ពីការរស់នៅរបស់ពួកឰយុកោនៃសាសន៍អ៊ីស្រាអែលបានមកឯហោរាអេសេគាលនៅខែប្រាំបី ទី១៤ ឆ្នាំ៥៩១ មុនគ.ស អស់រយៈពេល ១១ខែ បន្ទាប់ពីមុនដាក់ថ្ងៃខែនៃការនិមិត្ត (សូម មើល ៨:១ និងការពន្យល់នៅក្នុង ៨:១–១១:១៥) វាគឺជាការចាប់ផ្តើមពីប្រវត្តិសង្ខេបនៃសាសន៍អ៊ីស្រាអែល និងរៀបរាប់ពីប្រវត្តិសាសនារបស់ពួកគេ (សូមមើលខ.១–២៩) ដែលជាការនាំចូលទៅក្នុងការថ្លែងប្រកាសពីគោលបំណងរបស់ព្រះអម្ចាស់ទ្រង់សម្អាតនិងលាងជម្រះសាជាថ្មីតាមរយៈការជំនុំជម្រះឱ្យទាន់ពេលចំពោះពួកគេ (សូមមើល ៣០–៤៤) ។

**២០:១** *នៅថ្ងៃទី១០ . . . ខែស្រាពណ៍ . . . ក្នុងឆ្នាំទី ៧* នៅវគ្គនេះមានកាលបរិច្ឆេទបីដង (សូមមើលការពន្យល់ពីមុន) ដែលបានផ្តល់ការពន្យល់នៅក្នុងព្រះគម្ពីរអេសេគាល (សូមមើល ១:២ ៨:១) ។ *ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែល* (សូមមើលការពន្យល់នៅក្នុង ៨:១ ១៤:១ ។ *ទូលសួរ* សូមមើល ខ.៣ និងការពន្យល់នៅក្នុង ១៤:៣ ។

**២០:៣** *ដូចជាអញរស់នៅ* សូមមើលការពន្យល់នៅក្នុង ៥:១១ ។ *អញមិនឱ្យឯងរាល់គ្នាសួរដល់អញទេ* សូមមើល ខ.៣១ សូមមើលផងដែរ ៣:២៦ ៧:២៦ និងការពន្យល់ផ្សេងទៀត ។

**២០:៤** *ឯងចង់ជំនុំជម្រះគេឬ . . . ចូរឱ្យគេដឹង* វគ្គនេះមានន័យថា នៅគ្រាមួយនោះមានសេចក្តីប្រកាសពីសេចក្តីជំនុំជម្រះរបស់ព្រះអម្ចាស់មកលើពួកអ៊ីស្រាអែលដើម្បីឱ្យពួកគេដឹងខ្លួន ដូចជាហោរាអេសេគាលបានបង្ហាត់បង្រៀនហើយសរសេរចេញមកថា "អស់ទាំងអំពើគួរស្អប់ខ្ពើម" ហើយខណៈនោះ សេចក្តីជំនុំជម្រះរបស់ព្រះនិងធ្លាក់មកលើពួកគេ (សូមមើល ២២:២ ២៣:៣៦) ផងដែរ ។

**២០:៥–២៦** នៅក្នុងខគម្ពីរទាំងនេះគឺបង្ហាញប្រាប់ពីប្រវត្តិសាស្ត្រនៃសាសនារបស់ពួកអ៊ីស្រាអែលមានការប្រព្រឹត្តិបីយ៉ាង (កច ១:៥–៩ ស្រុកអ៊ីស្រាអែល កច ២:១០–១៧ ទីរហោស្ថាន តំបន់ទី១ កច ៣:១៨–២៦ ទីរហោស្ថាន តំបន់ទី២) នៅទីនោះពួកគេមានការប្រព្រឹត្តបួនយ៉ាងគឺ (១).ការបរិហារ (២).ការបះបោរ (៣).កំហឹង និង (៤).ការពិចារណាឡើងវិញ ប៉ុន្តែ សូមមើលការពន្យល់នៅក្នុង ខ.២៨ ផងដែរ ។

**២០:៥** លើកដៃឡើង គឺជានិមិត្តរូបពីសកម្មភាពនៃការចុះចូលនិងធ្វើតាមការស្បថ នៃសម្បថនោះ (សូមមើល ខ.១៥,២៣,៤២ លប ១៤:២២ និងការពន្យល់ នក ៦:៨) ។ *អញនេះជាព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា* សូមមើល នក ៣:៦ ១៤–១៥ ហើយនិងការពន្យល់ផ្សេងទៀត ។

**២០:៦** *ជាស្រុកមានទឹកដោះ និងទឹកឃ្មុំហូរហៀរ* សូមមើលការពន្យល់នៅក្នុង នក ៣:៨ ។ *ជាទីរុងរឿងជាងស្រុកទាំអស់* ធៀបនឹង ចទ៨:៧–១០ យរ ៣:១៩ ។ ដ្បិតកន្លែងនោះគឺជាទឹកដីធម្មជាតិដែលមានសោភ័ណភាពស្រស់ល្អត្រកាល ។ គឺវាពិតជាទឹកដីក្រាលទៅដោយលំអរដែលព្រះអម្ចាស់បានជ្រើសរើស ហើយដូចជាទីកន្លែងព្រះគង់សណ្ឋិត (មើល ចទ ១២:៥ ១១) ។

**២០:៧** *រូបព្រះ* សូមមើលការពន្យល់នៅក្នុង ៦:៤ ។

**២០:៨** *តែគេបានរឹងចចេស* សូមមើល ខ. ១៣,២១ សូមមើលផងដែរ យស ២៤:១៤ ។ *ដូច្នេះ អញបានថា អញនឹងចាក់សេចក្តីឃោរឃៅរបស់អញ*

បានថាអញនឹងចាក់សេចក្ដីឃោរឃៅរបស់អញទៅលើគេ
ដើម្បីនឹងសំរេច សេចក្ដីកំហឹងរបស់អញ ទាស់នឹងគេ
នៅកណ្ដាលស្រុកអេស៊ីព្ទ[ទ] ៩ប៉ុន្តែអញបានប្រព្រឹត្តដោយ
យល់ដល់ឈ្មោះអញ ដើម្បីមិនឱ្យត្រូវទាបថោក[ធ] នៅ
ចំពោះភ្នែកនៃសាសន៍ដទៃ ជាសាសន៍ដែលគេនៅកណ្ដាល
ហើយដែលអញបានសំដែងឱ្យគេស្គាល់អញ នៅចំពោះ
ភ្នែកនៃសាសន៍នោះ ដោយនាំគេចេញពីស្រុកអេស៊ីព្ទមក
នោះដែរ[ន]។
១០ដូច្នេះ អញបានធ្វើឱ្យគេចាក់ចេញពីស្រុកអេស៊ីព្ទ
ហើយបាននាំចូលទៅក្នុងទីរហោស្ថាន[ប] ១១អញក៏ព្រមក្រិត្យ
ក្រមរបស់អញដល់គេ ព្រមទាំងសំដែងឱ្យគេស្គាល់បញ្ញត្តិ
ច្បាប់ទាំងប៉ុន្មានរបស់អញ ដែលបើអ្នកណាប្រព្រឹត្តតាម
អ្នកនោះនឹងបានរស់ដោយសារច្បាប់នោះ[ផ] ១២អញក៏តាំង
ថ្ងៃឈប់សំរាក[ព]របស់អញឱ្យគេដែរទុកសំរាប់ជាទីសំគាល់[ភ]
ដែលអញហើយនិងគេ[ម] ប្រយោជន៍ឱ្យគេបានដឹងថា អញ
ជាព្រះយេហូវ៉ាដែលញែកគេចេញជាបរិសុទ្ធ[យ] ១៣ប៉ុន្តែពូជ
ពង្សនៃពួកអ៊ីស្រាអែលបានរឹងចចេស[រ]នឹងអញ នៅទីរហោ
ស្ថានវិញ គេមិនបានប្រព្រឹត្តតាមច្បាប់[ល]អញទេ ក៏បោះបង់
ចោលអស់ទាំងបញ្ញត្តរបស់អញ ជាច្បាប់ដែលអ្នកណា
ប្រព្រឹត្តតាម នោះនឹងបានរស់ដោយសារច្បាប់នោះផង
ហើយគេក៏បង្អាប់ថ្ងៃឈប់សំរាករបស់អញយ៉ាងក្រៃលែង[វ]
នោះអញបានថា អញនឹងចាក់សេចក្ដីឃោរឃៅ[ស]របស់
អញ ទៅលើគេនៅក្នុងទីរហោស្ថាន ដើម្បីនឹងរំលីង[ហ]គេឱ្យ
អស់ទៅ[ឡ] ១៤ប៉ុន្តែអញបានប្រព្រឹត្តដោយយល់ដល់ឈ្មោះ
អញវិញ ដើម្បីមិនឱ្យឈ្មោះអញត្រូវទាបថោក[អ] នៅផ្នែក
នៃអស់ទាំងសាសន៍ដែលអញបាននាំគេចេញ នៅចំពោះ
មុខនោះឡើយ[ក] ១៥មួយទៀត អញបានស្បថ[ខ]នឹងគេ នៅ
ទីរហោស្ថានថា អញមិនព្រមនាំគេចូលទៅក្នុងស្រុក ដែល
អញបានឱ្យដល់គេ ជាស្រុកមានទឹកដោះ និងទឹកឃ្មុំហូរ
ហៀរ ដែលជាស្រុករុងរឿងជាងអស់ទាំងស្រុកនោះទេ[គ]
១៦ពីព្រោះគេបានបោះបង់ចោលក្រិត្យក្រម[ឃ]របស់អញ ឥត
ប្រព្រឹត្តតាមបញ្ញត្តច្បាប់របស់អញ ក៏បង្អាប់ថ្ងៃឈប់សំរាក
របស់អញដែរ ដ្បិតចិត្ត[ង]គេជាប់តាមរូបព្រះរបស់គេវិញ[ច]
១៧ប៉ុន្តែភ្នែកអញបានប្រណីដល់គេ ហើយអញមិនបាន
បំផ្លាញ[ឆ]គេឡើយ ក៏មិនបានឱ្យគេសូន្យផុតទៅ នៅទីរហោ
ស្ថានដែរ ។
១៨អញ បានប្រាប់ដល់កូនចៅគេ នៅទីរហោស្ថាន ថា

**២០:៨** ទ នក ៣២:៧ ចទ ៩:៧ អស ៦៣:១០
**២០:៩** ធ អស ៤៨:១១ ន អគ ៣៦:២២ ៣៩:៧
**២០:១០** ប នក ១៣:១៨ ១៩:១
**២០:១១** ផ នក ២០:១-២៣ លវ ១៨:៥ ចទ ៤:៧-៨ អគ ១៨:៩ រម ១០:៥
**២០:១២** ព នក ២០:១០ ភ នក ៣១:១៣ ម យរ ១៧:២២ យ លវ ២០:៨
**២០:១៣** រ ទដ ៧៨:៤០ ល យរ ៦:១៩ ១១:៨ វ ខ.២៤ ស ចទ ៩:៨ ហ នក ៣២:១០ ឡ លវ ២៦:១៥,៤៣ ជន ១៤:២៩ ទដ ៩៥:៨-១០ អស ៥៦:៦
**២០:១៤** អ អស ៤៨:១១ ក អគ ៣៦:២៣ **២០:១៥** ខ ចទ ១:៣៤ គ ជន ១៤:២២-២៣ ទដ ៩៥:១១ ១០៦:២៦ ហព ៣:១១ **២០:១៦** ឃ យរ ១១:៨ អម ២:៤ ង ជន ១៥:៣៩ ច ខ.២៤ អគ ៦:៤ អម ៥:២៦ **២០:១៧** ឆ យរ ៤:២៧

*ទៅលើគេ* ឃ្លាត្រង់នេះមានន័យថា ព្រះអម្ចាស់មានសេចក្ដីក្រោធមកលើពួកអ៊ីស្រាអែលនៅពេលដែលពួកគេមិនបានប្រព្រឹត្តតាមច្បាប់របស់ព្រះ (សូមមើល ខ.១៣,២១) សូមមើលការពន្យល់ផងដែរនៅក្នុង ៧:៨ ។ *ដើម្បីនឹងសម្រេចសេចក្ដីកំហឹងរបស់អញទាស់នឹងគេ* សូមមើលការពន្យល់នៅក្នុង ៥:១៣ ។

**២០:៩** *អញបានប្រព្រឹត្ត ដោយយល់ឈ្មោះអញ* សូមមើល ខ.១៤,២២,៤៤ ។ ឈ្មោះរបស់ទ្រង់គឺមានភ្ជាប់ទំនាក់ទំនងយ៉ាងស្និទ្ធស្នាលបំផុតនៅក្នុងព្រះគម្ពីរ ។ ព្រះនាមរបស់ទ្រង់ជានាមលើអស់ទាំងនាម ហើយអត្តសញ្ញាណនិងកិត្តិសព្ទរបស់ទ្រង់មាននាមល្បីរន្ទឺរទូទាំងផែនដី គឺជាព្រះដែលជ្រាបគ្រប់ទាំងអស់(សូមមើលការពន្យល់នៅក្នុង ទដ ៥:១១ ។ ឃ្លាដែលប្រើនៅទីនេះគឺមានអត្ថន័យដូចគ្នា គឺ "*រក្សាទុកសម្រាប់ខ្លួនអញ*" (ធៀបនឹង អស ៣៧:៣៥ ៤៣:២៥) ។ កិច្ចការសង្គ្រោះរបស់ទ្រង់ តាំងពីអតីតកាល នឹងនាថ្ងៃអនាគតគឺជាកិច្ចការរបស់ទ្រង់ ដែលបង្ហាញឱ្យគេដឹងពីសេចក្ដីពិតរបស់ទ្រង់ (សូមមើល ៣៦:២២,ទដ ២៣:៣ ហើយនិងការពន្យល់ផ្សេងទៀត អស ៨:៩) ។ *មិនត្រូវទាបថោក* វគ្គនេះមានន័យថា ព្រះទ្រង់នាំយើងឱ្យដើរនៅក្នុងពន្លឺមិនត្រូវបង្អាប់ដល់ព្រះនាមទ្រង់ឡើយ (មើល ជន ១៤:១៥-១៦) ។

**២០:១០** *ទីរហោស្ថាន* គឺទ្រង់បានឱ្យពួកអ៊ីស្រាអែលចាកចេញពីស្រុកអេស៊ីព្ទ ហើយបាននាំចូលទៅក្នុងទីរហោស្ថានមើលកិច្ចការ២(សូមមើលការពន្យល់នៅក្នុង ខ.៥-២៦) ។

**២០:១១** *នឹងបានរស់* សូមមើល ខ.១៣,២១ គឺមានភាពខុសគ្នា ខ.២៥ សូមមើលការពន្យល់នៅក្នុង ១៨:៩ សូមមើលផងដែរ លវ ១៨:៥ ហើយនិងការពន្យល់ ។

**២០:១២** *អញក៏តាំងថ្ងៃឈប់សំរាករបស់អញឱ្យគេដែរ ទុកសម្រាប់ជាសំគាល់* ថ្ងៃឈប់សម្រាក គឺជាសេចក្ដីបញ្ញត្តិរបស់ព្រះអម្ចាស់ ដែលពួកអ៊ីស្រាអែលត្រូវតែប្រតិបត្តិតាមមិនអាចខានបាន ហើយវាក៏ជាទីសម្គាល់នៃការបម្រើដល់មនុស្សបរិសុទ្ធរបស់ព្រះអម្ចាស់ផងដែរ (សូមមើល នក ៣១:១៦-១៧ ហើយនិងការពន្យល់) ។ ហោរាអេសេគាល បានកត់សម្គាល់ទុកថាគឺជាថ្ងៃឈប់សម្រាក (សូមមើល ២២:៨,២៦ ២៣:៣៨ ៤៤:២៤ ៤៥:១៧ ៤៦:៣) គឺដូចជាហោរាយេរេមាធ្លាប់បានប្រព្រឹត្តផងដែរ (សូមមើល យរ ១៧:១៩-២៧ ធៀបនឹង នហ ១៣:១៧-១៨) ។ ពួកសាសន៍យូដាក្រោយមកបានកែប្រែនៅបញ្ញត្តិនេះថា ជាច្បាប់ថ្ងៃឈប់សម្រាក់របស់ពួកគេ (សូមមើល (មថ ១២:១១៤) ។

**២០:១៣** *បង្អាប់* មានន័យថា ការមិនគោរពបញ្ញត្តិថ្ងៃឈប់សម្រាក គឺជាការបង្អាប់ដល់ព្រះ (សូមមើល យរ ១៧:២១-២៣) ការដែលមិនប្រព្រឹត្តតាមបញ្ញត្តិថ្ងៃឈប់សម្រាក គឺជាការបង្អាប់ ចំណែកឯអ្នកណាប្រព្រឹត្តតាមបញ្ញត្តិនោះវិញ ព្រះវិញ្ញាណនៃព្រះនឹងប្រទានពរ (សូមមើល អម ៨:៥) ។

**២០:១៥** *ជាស្រុកមានទឹកដោះ និងទឹកឃ្មុំហូរហៀរ* សូមមើលការពន្យល់នៅក្នុង នក ៣:៨ ។

**២០:១៨** *អញបានប្រាប់ដល់កូនចៅគេ* មើលព្រះគម្ពីរកិច្ចការ ៣ (សូមមើលការពន្យល់នៅក្នុង ខ.៥-២៦) ។ ព្រះអម្ចាស់ចាប់ផ្ដើមដឹកនាំពួកកូនចៅ

កុំឱ្យដើរតាមច្បាប់របស់ពួកឰយុកោ[ជ]ឯងរាល់គ្នា ឬកាន់
តាមបញ្ញត្តិរបស់គេ ឬធ្វើឱ្យខ្លួនសៅហ្មង[ឈ]ដោយរូប
ព្រះរបស់គេឡើយ ១៩អញនេះ គឺយេហូវ៉ា ជាព្រះនៃឯង
រាល់គ្នា[ញ] ចូរប្រព្រឹត្តតាមអស់ទាំងក្រិត្យក្រមអញ ហើយ
រក្សាបញ្ញត្តច្បាប់របស់អញ ព្រមទាំងប្រព្រឹត្តតាមវិញ[ដ]
២០ចូរញែកថ្ងៃឈប់សំរាក[ឋ]របស់អញចេញជាបរិសុទ្ធ នោះ
នឹងបានជាទីសំគាល់[ឌ]ដល់អញ ហើយនឹងឯងរាល់គ្នា ដើម្បី
ឱ្យឯងបានដឹងថា អញនេះគឺយេហូវ៉ា ជាព្រះនៃឯងរាល់
គ្នា[ឍ] ២១ប៉ុន្តែកូនចៅទាំងនោះក៏រឹងចចេសនឹងអញដែរ គេ
មិនព្រមប្រព្រឹត្តតាមអស់ទាំងច្បាប់[ណ]របស់អញឡើយ ក៏មិន
បានរក្សាបញ្ញត្តទាំងប៉ុន្មានរបស់អញ ដើម្បីនឹងប្រព្រឹត្តតាម
ផង ជាច្បាប់ដែលអ្នកណាប្រព្រឹត្តតាម អ្នកនោះនឹងបាន
រស់នៅ ដោយសារច្បាប់នោះឯង គេបានបង្អាប់ថ្ងៃឈប់
សំរាករបស់អញទៅ ដូច្នេះ អញបានថា អញនឹងចាក់
សេចក្តីឃោរឃៅរបស់អញទៅលើគេ ដើម្បីនឹងសំរេច
សេចក្តីកំហឹង[ត] របស់អញនៅលើគេ នៅក្នុងទីរហោស្ថាន[ថ]
២២ប៉ុន្តែអញបានដក[ទ]ដៃចេញវិញ ហើយបានប្រព្រឹត្តដោយ
យល់ដល់ឈ្មោះ[ធ]អញ ដើម្បីមិនឱ្យឈ្មោះអញ ត្រូវទាប
ថោក នៅភ្នែកនៃសាសន៍ដទៃ ដែលអញបាននាំគេចេញ
ទៅ នៅចំពោះមុខនោះឡើយ ២៣មួយទៀត អញបាន
ស្បថនឹងគេនៅទីរហោស្ថានថា អញនឹងកំចាត់កំចាយគេ
ទៅនៅកណ្តាលអស់ទាំងសាសន៍ ហើយបែងចែក[ន]គេទៅ
នៅគ្រប់ស្រុកទាំងអស់ ២៤ពីព្រោះគេមិនបានប្រព្រឹត្តតាម
អស់ទាំងក្រិត្យក្រម[ប]របស់អញឡើយ គឺបានបោះបង់ចោល
បញ្ញត្តច្បាប់ទាំងប៉ុន្មានរបស់អញ ព្រមទាំងបង្អាប់ថ្ងៃឈប់
សំរាក[ផ]របស់អញវិញហើយភ្នែកគេក៏ជាប់តាម[ព]រូបព្រះ
របស់ពួកឰយុកោគេដែរ[ភ] ២៥អញក៏ឱ្យក្រិត្យក្រមដល់[ម]គេ
ដែលមិនស្រួលល្អ ហើយនិងបញ្ញត្តច្បាប់ ដែលគ្មានអ្នកណា
អាចនឹងរស់បានតាមច្បាប់នោះទេ[យ] ២៦អញក៏បានធ្វើឱ្យគេ
ស្មោកគ្រោក ដោយសារដង្វាយរបស់គេ ពីព្រោះគេបាន
យកកូនកើតដំបូងរបស់ខ្លួន ទៅធ្វើឱ្យឆ្លងកាត់ភ្លើង[រ] ដើម្បី
ឱ្យអញបានធ្វើឱ្យគេនៅស្ងាត់ ប្រយោជន៍ឱ្យគេបានដឹងថា
អញនេះជាព្រះយេហូវ៉ាពិត[ល] ។
២៧ហេតុនោះ កូនមនុស្សអើយ ចូរនិយាយប្រាប់ដល់
ពួកវង្សអ៊ីស្រាអែលថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះ ពួកឰយុកោ[វ]ឯងរាល់គ្នាបានប្រមាថ[ស]ដល់អញ ក្នុង
ការនោះទៀត គឺគេបានប្រព្រឹត្តអំពើរំលងទាស់នឹងអញ[ហ]
២៨ដ្បិតកាលអញបាននាំគេចូលមកក្នុងស្រុក[ឡ] ដែលអញ
បានស្បថថា នឹងឱ្យដល់គេ នោះគេបានឃើញគ្រប់ទាំង
ទួលខ្ពស់ ហើយគ្រប់ទាំងដើមឈើស៊ុបទ្រុប រួចគេក៏ថ្វាយ
យញ្ញបូជារបស់គេ នៅលើទីនោះ គឺនៅទីនោះគេបាន
ថ្វាយដង្វាយជាគ្រឿងដុតដាលនៅទីនោះ គេក៏បានថ្វាយ
ដង្វាយសំរាប់ជាក្លិនឈ្ងុយរបស់គេ ហើយបានច្រួចដង្វាយ
ច្រួចរបស់គេនៅទីនោះដែរ[អ] ២៩នោះអញបានសួរគេថា ទី
ខ្ពស់[ក] ដែលឯងតែងតែទៅនោះ តើដូចម្តេច ដូច្នេះទីនោះ
បានហៅឈ្មោះថា "បាម៉ា" ដរាបដល់សព្វថ្ងៃនេះ ។

## ការជំនុំជម្រះ និងការស្តារឡើងវិញ

៣០ហេតុនោះ ត្រូវឱ្យប្រាប់ដល់ពួកវង្សអ៊ីស្រាអែលថា
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ឯងរាល់គ្នាតែង

**២០:១៨** ជ ២រប ៣០:៧ សក ១:៤ ឈ ទដ ១០៦:៣៩ **២០:១៩** ញ ន ២០:២ ដ ចទ ៥:៣២–៣៣ ៦:១–២ ៨:១ ១១:១ ១២:១ **២០:២០** ឋ នក ២០:១០ ឌ នក ៣១:១៣ ឍ យរ ១៧:២២ **២០:២១** ណ យរ ៧:២៦ ត ជន ២៥:៣ ថ អគ ៧:៨ **២០:២២** ទ ទដ ៧៨:៣៨ ធ អស ៤៨:១១ **២០:២៣** ន លវ ២៦:៣៣ ទដ ៩:១១ **២០:២៤** ប អម ២:៤ ផ ខ.១៣ ព អគ ៦:៩ ភ ខ.១៦ អគ ២:៣ ១៨:៦ **២០:២៥** ម ទដ ៨១:១២ រម ១:២៨ យ អស ៦៦:៤ ២ថន ២:១១ **២០:២៦** រ លវ ១៨:២១ ល លវ ២០:២–៥ ២ពវ ១៧:១៧ **២០:២៧** វ ទដ ៧៨:៥៧ ស ជន ១៥:៣០ រម ២:២៤ ហ អគ ១៨:២៤ **២០:២៨** ឡ នហ ៩:២៣ ទដ ៧៨:៥៥, ៥៨ អ យរ ២:៧ ៣:៦ ១៩:១៣ អគ ៦:១៣ **២០:២៩** ក អគ ១៦:១៦ ៤៣:៧ **២០:៣០** ខ ខ.៤៣ គ ពច ២:១៦–១៩ យរ ១៦:១២

អ៊ីស្រាអែលជាថ្មី ពីរជំនាន់នៅក្នុងទីរហោស្ថាន (សូមមើល នហ ១៤:២៦–៣៥) ។

**២០:២៥** *អញក៏ឱ្យក្រិត្យក្រមដល់គេ . . . ដែលគ្មានអ្នកណាអាចនិងរស់បានតាមច្បាប់នោះទេ* វគ្គនេះចង់ប្រាប់ថា ព្រះអម្ចាស់នឹងជំនុំជម្រះដោយយុត្តិធម៌ឱ្យពួកគេវិនាស ហើយទ្រង់បានរៀបចំបង្កើតគេឡើងវិញជាថ្មី (សូមមើលការពន្យល់នៅក្នុង លប ៦:៩–៩) ហើយប្រវត្តិសាស្ត្ររបស់មនុស្សនឹងត្រូវវិនាសអស់ (សូមមើលការពន្យល់នៅក្នុង លប ១១:១–៩) ដូច្នេះ ការជំនុំជម្រះរបស់ទ្រង់នឹងផ្តល់ឱ្យយើង ជាមធ្យោបាយនាំឱ្យមានជីវិត (សូមមើល ខ.១២–១៣,២១ និងការពន្យល់នៅក្នុង ខ.១១) ការចូលទៅក្នុងក្រឹត្យវិន័យទាំងនោះគឺជាការបង្កើតសេចក្តីស្លាប់ ។ គ្មានអ្នកណាប្រព្រឹត្តតាមក្រឹត្យវិន័យបានឡើយ ពីព្រោះវាគឺជាច្បាប់ដែលពិបាកបំផុតសម្រាប់មនុស្សអនុវត្តន៍តាម ប៉ុន្តែព្រះត្រូវការផ្តល់ក្រឹត្យវិន័យច្រើនបំផុតសម្រាប់ពួកអ៊ីស្រាអែលដើម្បីឱ្យពួកគេប្រព្រឹត្តតាម ដូចជាព្រះឱ្យពួកអ៊ីស្រាអែលគ្រប់គ្នាត្រូវតែថ្វាយគ្រប់ទាំងកូនប្រុសច្បងទៅព្រះ (សូមមើល នក ១៣:២ ២២:២៩) ដូចដែលស្តេចអាហាស និងលោកមាន៉ាសេគឺរស់នៅក្រោមឥទ្ធិពលនៃអ្នកមិនជឿព្រះ ។ ឯពួកអ៊ីស្រាអែលគេមានទំនាក់ទំនងជាមួយសាសនាផ្សេងៗនៃប្រទេសជិតខាង ដែលនៅក្នុងក្រឹត្យវិន័យមានន័យថា យញ្ញបូជានៃកូនច្បងបានទៅជាស្មោកគ្រោក (សូមមើល ខ.២៦ ធៀបនឹង រម ១:២៤–៣២ និងការពន្យល់ផ្សេងទៀត) ។

**២០:២៦** *កូនកើតដំបូង* សូមមើល ខ.៣១ និងការពន្យល់នៅក្នុង ១៦:២០ ។ *ប្រយោជន៍ឱ្យគេបានដឹងថា អញនេះជាព្រះយេហូវ៉ាពិត* វគ្គនេះមានន័យថា ព្រះទ្រង់នឹងយាងទៅកន្លែងផ្សេងទៀតដើម្បីរើសយកមនុស្សដែលគេទទួលស្គាល់ទ្រង់ (សូមមើលការពន្យល់នៅក្នុង ៦:៧) ។

**២០:២៨** *ដ្បិតកាលអញបាននាំគេចូលមកក្នុងស្រុក* គឺបានបង្ហាញប្រាប់យ៉ាងពិតប្រាកដនៅក្នុងព្រះគម្ពីរ កិច្ចការ៤ នេះជាប្រវត្តិនៃហោរាសេដេគាល (សូមមើលការពន្យល់នៅ ខ.៥–២៦) ។

**២០:៣០–៤៤** សូមមើល ការពន្យល់នៅក្នុង ខ.១–៤៤ ។

**២០:៣០** *ឯងរាល់គ្នាតែងធ្វើឱ្យខ្លួនស្មោកគ្រោក តាមបែបពួកឰយុកោឯង*

ធ្វើឱ្យខ្លួន[ខ]ស្មោកគ្រោក តាមបែបពួកឰយុកោឯងដូច្នេះដែរ
ឬព្រមទាំងប្រព្រឹត្តសេចក្តីកំផិត តាមព្រះគួរស្អប់ខ្ពើមរបស់
គេឬអី[គ] ៣១ដ្បិតកាលណាឯងរាល់គ្នាថ្វាយដង្វាយរបស់ខ្លួន
កាលណាធ្វើឱ្យកូន[ឃ]ខ្លួនឆ្លងកាត់ភ្លើង នោះគឺឯងធ្វើឱ្យខ្លួន
ស្មោកគ្រោក ដោយសាររូបព្រះទាំងប៉ុន្មានរបស់ឯង ដរាប
ដល់សព្វថ្ងៃនេះ ដូច្នេះ ឱពួកវង្សអ៊ីស្រាអែលអើយ តើអញ
នឹងឱ្យឯងរាល់គ្នាសួរដល់អញឬ ព្រះអម្ចាស់យេហូវ៉ាទ្រង់
ស្បថថា ដូចជាអរស់នៅ នោះប្រាកដជាអញមិនឱ្យឯង
រាល់គ្នាសួរដល់អញទេ[ង] ៣២ហើយសេចក្តីដែលកើតក្នុង
គំនិតឯងរាល់គ្នា នោះមិនបានកើតមកឡើយ គឺជាសេចក្តី
ដែលឯងថា យើងនឹងធ្វើដូចជាអស់ទាំងសាសន៍ដទៃ នឹង
ដូចជាអស់ទាំងគ្រួសារ នៅស្រុកផ្សេងៗ ដោយគោរព
ប្រតិបត្តដល់ទាំងឈើនឹងថ្មផង ។
៣៣ព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ
នោះប្រាកដជាអញនឹងសោយរាជ្យលើឯងរាល់គ្នា ដោយ
ដៃខ្លាំងពូកែ ហើយលើកសំរេច[ច] ព្រមទាំងចាក់សេចក្តី
ក្រោធចេញ[ឆ] ៣៤អញនឹងនាំឯងរាល់គ្នាចេញពីអស់ទាំង
សាសន៍[ជ] ហើយនឹងប្រមូល[ឈ]ឯងរាល់គ្នាមកពីស្រុកទាំង
ប៉ុន្មាន ដែលឯងត្រូវខ្ចាត់ខ្ចាយទៅនោះ ដោយដៃខ្លាំង
ពូកែ[ញ] ហើយលើកសំរេច ព្រមទាំងចាក់សេចក្តីក្រោធ
ចេញផង[ដ] ៣៥អញនឹងនាំឯងរាល់គ្នាទៅ ឱ្យនៅឯទីសូន្យ
ស្ងាត់[ឋ]នៃអស់ទាំងសាសន៍ នៅទីនោះអញនឹងមានរឿង[ឌ]
តវ៉ានឹងឯង ប្រទល់គ្នា ៣៦អញបានមានរឿងតវ៉ានឹងពួក
ឰយុកោឯងរាល់គ្នា នៅក្នុងទីរហោស្ថាននៃស្រុកអេស៊ីព្ទ
ជាយ៉ាងណា អញក៏នឹងមានរឿងតវ៉ានឹងឯងរាល់គ្នាយ៉ាង
នោះដែរ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ឍ]
៣៧នោះអញនឹងឱ្យឯង រាល់គ្នាចូលក្រោមដំបង[ណ] រួចនឹង
នាំជាប់ចំណងនៃសេចក្តីសញ្ញា[ត] ៣៨អញនឹងញែក[ថ]ពួករឹង
ចចេសពីឯងចេញ ព្រមទាំងពួកអ្នក ដែលតែងតែប្រព្រឹត្ត
រំលង ទាស់នឹងអញផង អញនឹងនាំគេចេញពីស្រុក ដែលគេ
ស្នាក់នៅនោះ តែគេមិនបានចូលទៅក្នុងស្រុកអ៊ីស្រាអែល
ឡើយ នោះឯងរាល់គ្នានឹងដឹងថា អញនេះជាព្រះយេហូវ៉ា
ពិត[ទ] ៣៩តែចំណែកឯងរាល់គ្នា ឱពួកវង្សអ៊ីស្រាអែលអើយ
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរទៅចុះ ពីនេះ
ទៅមុខ ឯងរាល់គ្នាមិនព្រមស្តាប់តាមអញទេ ដូច្នេះ ចូរ
ទៅគោរពដល់រូបព្រះ[ធ]របស់ឯងរៀងខ្លួនចុះ តែមិនត្រូវឱ្យ
បង្អាប់ឈ្មោះ[ន]បរិសុទ្ធរបស់អញ ដោយដង្វាយនឹងរូបព្រះ
របស់ឯងទៀតឡើយ[ប] ។
៤០ដ្បិតព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា នៅលើភ្នំ
បរិសុទ្ធរបស់អញ គឺជាភ្នំយ៉ាងខ្ពស់របស់ស្រុកអ៊ីស្រាអែល[ផ]
នោះពួកវង្សអ៊ីស្រាអែលទាំងមូល នឹងគោរពដល់អញ

**២០:៣១** ឃ អគ ១៦:២០ ង ទដ ១០៦:៣៧–៣៩ យរ ៧:៣១ អគ ១៤:៣ អម ៨:១២ សក ៧:១៣ **២០:៣៣** ច អគ ១៦:២៧ ឆ យរ ២១:៥ អគ ២៥:១៦ **២០:៣៤** ជ ២កថ ៦:១៧ ឈ ចទ ៣០:៤ ទដ ១០៦:៤៧ ញ អស ៣១:៣ ដ អស ២៧:១២–១៣ យរ ៤៤:៦ បទ ២:៤ អគ ៦:១៤ **២០:៣៥** ឋ អគ ១៩:១៣ ឌ ១សយ ១២:៧ យប ២២:៤ យរ ២:៣៥ **២០:៣៦** ឍ ជន ១១:១–៣៥ ១៤:២៨–៣០ ១កថ ១០:៥–១០ **២០:៣៧** ណ លវ ២៧:៣២ ត អគ ១៦:៦២ **២០:៣៨** ថ អគ ៣៤:១៧–២២ អម ៩:៩–១០ ទ ទដ ៩៥:១១ យរ ៤៤:១៤ អគ ១៣:៩ ២៣:៤៩ ហស ២:១៤ សក ១៣:៨–៩ មឡ ៣:៣ ៤:១–៣ ហព ៤:៣ **២០:៣៩** ធ យរ ៤៤:២៥ ន នក ២០:៧ អគ ១៣:១៩ ប អគ ៤៣:៧ អម ៤:៤ **២០:៤០** ផ អគ ១៧:២២ ៣៤:១៤

*ដូច្នេះដែរឬ...?* សូមមើលការពន្យល់នៅក្នុង ខ.៥–២៦ ។
**២០:៣១** *សួរ* គឺមានន័យថា ស៊ើបអង្កេត សូមមើល ខ.៣ និងការពន្យល់ ។
**២០:៣២** *ដូចជាអស់ទាំងសាសន៍ដទៃ* ឃ្លាត្រង់នេះបង្ហាញប្រាប់ពីការប៉ុនប៉ងដើម្បីចុះចាញ់នៃសាសន៍ដទៃ ក្នុងរូបភាពតែមួយ ដែលជានិច្ចកាលគឺសម្រាប់អ៊ីស្រាអែលបច្ចុប្បន្ន (សូមមើល ១សយ ៨:៥ និងការពន្យល់ ។ *នោះមិនបានកើតមកឡើយ* ដូចធ្លាប់បានកើតឡើងជាមួយនិងពួកអ៊ីស្រាអែលដែលពួកគេទាំងអស់ត្រូវបាននិរទេសទៅកាន់ស្រុកអេស៊ីព្ទ (សូមមើល យរ ៤៤:១៥–១៩) ។ ព្រះនឹងមិនលើកលែងទោសដល់ពួកគេឡើយដោយសារគេទាំងអស់គ្នានោះបានថ្វាយបង្គំដល់រូបព្រះក្លែងក្លាយ ប៉ុន្តែពួកគេនឹងវិលបែរមករកផ្លូវរបស់ទ្រង់វិញ តាមរយៈនៃការតាំងសេចក្តីសញ្ញាដែលពេញដោយសេចក្តីជំនឿនៅចំពោះទ្រង់ ។
**២០:៣៣** *ដោយដៃខ្លាំងពូកែ ហើយលើកសំរេច* គឺជាពាក្យបច្ចេកទេសដែលមានន័យថាការចេញទៅទាំងហ្វូង (ធៀបនឹង ចទ ៤:៣៤ ៥:១៥ ៧:១៩ ១១:២ ២៦:៨) ។
**២០:៣៥** *ទីសូន្យស្ងាត់នៃអស់ទាំងសាសន៍* នៅវគ្គនេះក្នុងរវាងគ្រប់អស់ទាំងសាសន៍ត្រូវបាននិរទេស ដូចជាពួកអ៊ីស្រាអែលបានវិលត្រឡប់ទៅឯទីរហោស្ថានដើម្បីឆ្ពោះទៅឯទឹកដីដែលព្រះបានសន្យា (សូមមើល ហស ២:១៤ និងការពន្យល់ ) ។
**២០:៣៧** *ចូលក្រោមដំបង* គឺជារបៀបមួយដែលអ្នកគង្វាលចៀមបានប្រើដំបងនេះ សម្រាប់រាប់ចំនួនចៀម ឬបំបែកវាចេញពីហ្វូង ដែលជាការងាយស្រួលក្នុងការថែរក្សានិងការពារកុំឱ្យបាត់បង់ (សូមមើល លវ ២៧:៣២ យរ ៣៣:១៣ ធៀបនឹង មថ ២៥:៣២–៣៣) ។ នៅត្រង់វគ្គនេះ មានន័យថាព្រះអម្ចាស់នឹងថែរក្សាការពារដល់រាស្ត្ររបស់ទ្រង់ ។ *រួចនឹងនាំឱ្យជាប់ចំណងនៃសេចក្តីសញ្ញា* ដូចជាទ្រង់បានដាក់សេចក្តីសញ្ញានៅឯទីរហោស្ថានស៊ីណាយ (សូមមើលការពន្យល់នៅក្នុង ១៦:៥៩–៦៣) ។
**២០:៣៨** *ញែក* ដូចជានៅក្នុងទីរហោស្ថានដំបូងគឺជាបទពិសោធន៍បង្ហាញថាមានមនុស្សជាច្រើននៅគ្រានោះដែលព្រះបានញែកពួកគេចេញ ហើយមិនអនុញ្ញាតឱ្យគេចូលទៅក្នុងទឹកដីសន្យាបានឡើយ (សូមមើល ជន ១៤:២៦–៣៥ និងការពន្យល់) ។
**២០:៣៩** *ចូរទៅគោរពដល់រូបព្រះរបស់ឯងរៀងខ្លួនចុះ* ឃ្លានេះគឺជាការនិយាយចំអកឡកឡឺយ ដូចមាននៅក្នុង អម ៤:៤ ។ *បង្អាប់ដល់ឈ្មោះបរិសុទ្ធរបស់អញ* សូមមើល លវ ១៨:២១ និងការពន្យល់ ។
**២០:៤០** *នៅលើភ្នំបរិសុទ្ធរបស់អញ* បានសរសេរនៅទីនេះតែមួយដងគត់នៅក្នុងព្រះគម្ពីរអេសេគាល ហើយគឺវាសំដៅទៅលើទីក្រុងយេរូសាឡិម ឬជាទីក្រុងស៊ីយ៉ូនជាទីកន្លែងដែលទ្រង់គង់នៅក្នុងសម័យនោះ (សូមមើល ទដ ២:៦ អស ២:២–៤ និងការពន្យល់ ៦៥ អប ១៦ សជ ៣:១១) ។ *ពួកវង្ស*

គ្រប់គ្នានៅក្នុងស្រុករបស់ខ្លួន នៅទីនោះអញនឹងទទួលគេ
ហើយនៅទីនោះ អញនឹងសុខចិត្តទទួលដង្វាយ[ព]របស់ឯង
រាល់គ្នា និងផលដំបូងពីដង្វាយឯង ព្រមទាំងគ្រឿងបរិសុទ្ធ
របស់ឯងរាល់គ្នាទាំងអស់ដែរ[ភ] ៤១អញនឹងទទួលឯងរាល់
គ្នា ទុកដូចជាក្លិនក្រអូប[ម] ក្នុងកាលដែលអញបាននាំឯង
ចេញពីពួកសាសន៍ដទៃ ហើយប្រមូល[យ]ឯងពីអស់ទាំងស្រុក
ដែលឯងត្រូវខ្ចាត់ខ្ចាយទៅនោះ អញនឹងបានបរិសុទ្ធ[រ]ក្នុង
ពួកឯងរាល់គ្នា នៅចំពោះភ្នែកនៃអស់ទាំងសាសន៍ដទៃ[ល]
៤២មួយទៀតកាលណាអញបាននាំឯងរាល់គ្នាចូលទៅក្នុង
ស្រុកអ៊ីស្រាអែល[វ] គឺក្នុងស្រុកដែលអញបានស្បថថា នឹង
ឱ្យដល់ពួកឰយុកោឯងហើយ[ស] នោះឯងរាល់គ្នានឹងដឹងថា
អញនេះជាព្រះយេហូវ៉ាពិត[ហ] ៤៣នៅក្នុងស្រុកនោះឯងរាល់
គ្នានឹងនឹកចាំពីអស់ទាំងអំពើ[ឡ] និងកិរិយាទាំងប៉ុន្មានរបស់
ខ្លួន ជាការដែលនាំឱ្យឯងស្មោកគ្រោក នោះឯងរាល់គ្នា
នឹងខ្ពើមខ្លួន[អ] ដោយព្រោះអំពើអាក្រក់ទាំងប៉ុន្មានដែលឯង
បានធ្វើនោះ[ក] ៤៤នោះឱពួកវង្សអ៊ីស្រាអែលអើយ ឯងរាល់
គ្នានឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុងកាលដែល
អញបានប្រព្រឹត្តនឹងឯង ដោយយល់ដល់ឈ្មោះអញ[ខ] មិន
មែនតាមអំពើអាក្រក់របស់ឯងរាល់គ្នាឬតាមកិរិយាស្មោក
គ្រោករបស់ឯងនោះទេ នេះឯងជាព្រះបន្ទូលនៃព្រះអម្ចាស់
យេហូវ៉ា[គ]។

**២០:៤០** ព អស ៦០:៧ភ អស ៥៦:៧ មទ្ឍ ៣:៤ **២០:៤១** ម ២កថ ២:១៤ យ ចទ ៣០:៤ រ អគ ២៨:២៥ ៣៦:២៣ ល អស ៥:១៦ អគ ១១:១៧ ២កថ ៦:១៧ **២០:៤២** វ យរ ២៣:៨ អគ ៣៤:១៣ ៣៦:២៤ ស យរ ៣០:៣ អគ ៣៤:២៧ ៣៧:២១ ហ អគ ៣៨:២៣ **២០:៤៣** ឡ អគ ១៤:២២ អ លវ ២៦:៤១ ក អគ ៦:៩ ១៦:៦១ ហស ៥:១៥ **២០:៤៤** ខ ទដ ១០៩:២១ អស ៤៣:២៥ អគ ៣៦:២២ គ អគ ១៦:៦២ ៣៦:៣២ **២០:៤៦** ឃ អគ ៤:៣

## សេចក្តីទំនាយទាស់នឹងនគរខាងត្បូង

៤៥នោះព្រះបន្ទូល នៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា
៤៦កូនមនុស្សអើយ ចូរដំរង់មុខទៅ[ឃ]ខាងត្បូង ហើយពោល
ទៅខាងត្បូងនោះ ត្រូវឱ្យទាយទាស់[ង]នឹងព្រៃនៅវាលស្រុក
ត្បូងចុះ[ច] ៤៧ហើយប្រាប់ដល់ព្រៃស្រុកត្បូងថា[ឆ] ចូរស្តាប់
ព្រះបន្ទូល នៃព្រះយេហូវ៉ាចុះ ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ មើល អញនឹងបង្កាត់ភ្លើងនៅក្នុងឯង ភ្លើង
នោះនឹងឆេះ[ជ]អស់ទាំងឈើស្រស់ និងដើមឈើសោះ
កក្រោះនៅក្នុងឯង ភ្លើងដ៏ឆេះនោះនឹងមិនរលត់ឡើយ
ហើយមុខមនុស្សទាំងប៉ុន្មាន ចាប់តាំងពីខាងត្បូង រហូតដល់
ខាងជើង[ឈ] នឹងត្រូវរោលទាំងអស់[ញ] ៤៨ដូច្នេះគ្រប់ទាំង
មនុស្សនឹងឃើញថា គឺអញព្រះយេហូវ៉ានេះ ដែលបាន
បង្កាត់ភ្លើងនោះ ភ្លើងនោះនឹងមិនរលត់ឡើយ[ដ] ៤៩នោះខ្ញុំក៏
ទូលថា ឱព្រះអម្ចាស់យេហូវ៉ាអើយ[ឋ] គេនិយាយពីទូលបង្គំ
ថា អ្នកនេះតើមិនមែនជាអ្នកនិយាយ សុទ្ធតែពាក្យប្រៀប
ធៀបទេឬអី[ឌ]។

១៣:១៧ ង អគ ២១:២ អម ៧:១៦ ច អស ៣០:៦ យរ ១៣:១៩ **២០:៤៧** ឆ ២ពវ ១៩:២៣ ជ អគ ១៩:១៤ ឈ អគ ២១:៤ ញ អស ៩:១៨–១៩ ១៣:៨ **២០:៤៨** ដ យរ ៧:២០ អគ ២១:៥,៣២ ២៣:២៥ **២០:៤៩** ឋ អគ ៤:១៤ ឌ ពច ១៤:១២ ទដ ៧៨:២ អគ ១២:៩ មថ ១៣:១៣ យហ ១៦:២៥

*អ៊ីស្រាអែលទាំងមូល* គឺជាការរាប់បញ្ចូលនូវចំនួនមនុស្សដែលនៅសល់នៃនរគភាគខាងជើងដែលបានដួលរលំនៅក្នុងឆ្នាំ ៧២២–៧២១ មុន គ.ស (សូមមើល ១១:១៥ ៣៦:១០ និងការពន្យល់) ។ *ដង្វាយ* គឺធ្វើតាមសេចក្តីបញ្ញត្តិដែលព្រះបានបង្គាប់មក ។ មានការបញ្ជាក់ ១៩ដង នៅក្នុងព្រះគម្ពីរអេសេគាលរបស់ពួកសាសន៍ហេព្រើរ ហើយចំពោះពាក្យទាំងនេះគឺបានកំណត់នៅជំពូក ៤៤–៤៨ នៅកន្លែងផ្សេងទៀត និងមានបញ្ជាក់ផងដែរ ចំពោះការដាក់ទឹកដីមួយភាគសម្រាប់វិហារនិងថ្វាយដល់ពួកសង្ឃ (សូមមើល ៤៥:១ ៤៨:៨–១០"មួយភាគ ឬមួយចំណែក"ដែលជាដង្វាយពិសេសត្រូវថ្វាយទៅដល់ពួកសង្ឃ (សូមមើល ៤៤:៣០) ។ *ផលដំបូងពីដង្វាយឯង* គឺជាដង្វាយថ្វាយស្ម័គ្រពីចិត្តដោយបានកំណត់ចំនួន ។

**២០:៤១** *ដូចជាក្លិនក្រអូប* ជាការប្រៀបធៀបអំពីគ្រឿងក្រអូប(ដូចនៅក្នុង អភ ៥:២) ។ *នាំឯងចេញ* ធៀបនឹង ខ.៣៤ ។ *គ្រឿងបរិសុទ្ធរបស់ឯង* សូមមើល លវ ១០:៣ និងការពន្យល់ ។

**២០:៤៣** *ឯងរាល់គ្នានឹងនឹកចាំ . . . នឹង . . . នាំឱ្យឯងស្មោកគ្រោក* នៅវគ្គនេះគឺចង់បង្ហាញប្រាប់ពីការសោកស្តាយនូវអ្វី ដែលខ្លួនបានប្រព្រឹត្តកន្លងមក (សូមមើល ៦:៩ និងការពន្យល់ ១៦:៦៣ ៣៦:៣១ លក ១៥:១៧–១៩) ។

**២០:៤៤** *ដោយយល់ដល់ឈ្មោះអញ* គឺជាសេចក្តីសង្ខេប និងសេចក្តីបញ្ចប់នៃទំនាយ(សូមមើលការពន្យល់នៅ ខ.៩) ។

**២០:៤៥–២១:៣២** ក្រុងបាប៊ីឡូននឹងពេញដោយដាវរបស់ព្រះដើម្បីនឹងនាំមកនូវសេចក្តីហិនវិនាសដល់ស្រុកនេះ ហើយការបំផ្លាញនេះគឺប្រៀបបីដូចជាភ្លើងឆេះព្រៃជាដំបូងមកលើស្រុកយូដា និងក្រុងយេរូសាឡិមដែរ (២០:៤៥–២១:២៧) ប៉ុន្តែសេចក្តីហិនវិនាសនេះក៏បានមកដល់ស្រុកអាប់ម៉ូនផងដែរ (២១:២៨–២៩) ហើយបន្ទាប់មកក្រុងបាប៊ីឡូននឹងពេញដោយសេចក្តីក្រោធនៃព្រះ (២១:៣០–៣២) ។

**២០:៤៦** *ចូរដំរង់មុខទៅ* គឺជាឥរិយាបថមួយដែលហោរាអេសេគាលត្រូវការពេលវេលាចំនួន៨ដងដើម្បីតម្រង់មុខសម្លឹងទៅឯព្រះ (១៣:១៧ ២១:២ ២៥:២ ២៨:២១ ២៩:២ ៣៥:២ ៣៨:២) ។ *ទៅខាងត្បូង* ចង់និយាយដំដៅទៅលើស្រុកយូដា និងក្រុងយេរូសាឡិម ដែលពួកសាសន៍បាប៊ីឡូនមួយចំនួនបានលុកលុយឈ្លានពានឆ្លងកាត់សមុទ្រអ៊ីស្រាអែលចាប់ពីទិសខាងជើងទៅដល់ទិសខាងត្បូង (សូមមើល ២៦:៧ និងការពន្យល់) ។

**២០:៤៧** *បង្កាត់ភ្លើង* គឺជានិមិត្តរូបនៃការបំផ្លាញនិងការជំនុំជម្រះរបស់ព្រះ (សូមមើល អស ១០:១៦–១៩)។ ដែលជាញឹកញាប់ គឺគេបានយកមកដើម្បីបញ្ជាក់ពីនិមិត្តរូបដោយអំណាចរបស់លោកកិយ៍(សូមមើល អម ១:៤ និងការពន្យល់) ។ *ឈើស្រស់និងដើមឈើសោះក៏ក្រោះ* គឺនិយាយសំដៅទៅលើដើមឈើទាំងអស់ (ធៀបនឹង ១៧:២៤ លក ២៣:៣១) ។ *ចាប់តាំងពីខាងត្បូងរហូតដល់ខាងជើង* នៅវគ្គនេះគឺចង់បង្ហាញពីចំនួនសរុបទាំងអស់ "ចាប់តាំងពីព្រំដែនខាងស្តាំទៅដល់ព្រំដែនខាងឆ្វេង" ។

**២០:៤៩** *ពាក្យប្រៀបធៀប* សូមមើល ការពន្យល់នៅក្នុង ១៧:១–២៤ ។ ដ្បិតមានការចំអកដទៃទៀតរបស់ហោរាអេសេគាល សូមមើល ១២:២១–២៨ ៣៣:៣២ ។

## ក្រុងបាប៊ីឡូន ជាដាវនៃការជំនុំជម្រះនៃព្រះអម្ចាស់

**២១** ១រួចព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់ខ្ញុំថា[ក]
២កូនមនុស្សអើយ ចូរដំរង់មុខឯងទៅឯ[ខ]ក្រុងយេរូសាឡិម
ហើយពោលទៅខាងទីបរិសុទ្ធទាំងប៉ុន្មាន[គ] ត្រូវឱ្យទាយ
ទាស់នឹង[ឃ]ស្រុកអ៊ីស្រាអែលចុះ ៣ហើយប្រាប់ដល់ស្រុក
អ៊ីស្រាអែលថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ មើល
អញទាស់ទទឹង[ង]ឯង អញនឹងហូតដាវ[ច]របស់អញ ចេញពី
ស្រោម ហើយនឹងកាត់ទាំងមនុស្សសុចរិត និងមនុស្ស
ទុច្ចរិតចេញពីឯងផង[ឆ] ៤ដូច្នេះ ដោយព្រោះអញនឹងកាត់
ទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតចេញពីឯង នោះ
ដាវ[ជ]របស់អញនឹងចេញពីស្រោម ទៅទាស់នឹងគ្រប់ទាំង
មនុស្ស ចាប់តាំងពីខាងត្បូងរហូតដល់ខាងជើង[ឈ] ៥នោះ
គ្រប់ទាំងមនុស្សនឹងដឹងថា អញគឺព្រះយេហូវ៉ាបានហូត
ដាវ[ញ]របស់អញពីស្រោមចេញហើយ ដាវនោះនឹងមិនបាន
ស៊កចូលទៅវិញ[ដ]ទៀតឡើយ[ឋ] ៦ដូច្នេះ ឱកូនមនុស្សអើយ
ចូរដកដង្ហើមធំចុះ ឯងនឹងត្រូវដកដង្ហើមធំ នៅចំពោះភ្នែក
គេ ដោយចុកសៀតចង្កេះ ហើយមានចិត្តជូរចត់[ឌ] ៧រួច
កាលណាគេសួរឯងថា ហេតុអ្វីបានជាដកដង្ហើមធំដូច្នេះ[ឍ]
នោះត្រូវឱ្យឯងប្រាប់ថា គឺដោយព្រោះបានឮដំណឹង ពី
ព្រោះការនោះកំពុងតែមក ហើយចិត្តមនុស្សទាំងអស់នឹង
រលាយទៅ[ណ] ដៃទាំងអស់នឹងអន់ខ្សោយ[ត] វិញ្ញាណទាំង
អស់នឹងស្រយុតចុះ[ថ] ហើយក្បាលជង្គង់ទាំងប៉ុន្មាននឹងទន់
ដូចជាទឹក[ទ] មើលការនោះកំពុងតែមកហើយ ក៏នឹងបាន
សំរេចផង នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
៨ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា ៩កូនមនុស្ស
អើយ ចូរទាយប្រាប់ថា ព្រះយេហូវ៉ាទ្រង់មានបន្ទូល ដូច្នេះ
ចូរថា នំមានដាវហើយ ជាដាវដែលបានសំលៀងជា
ស្រេច ហើយខាត់ឱ្យភ្លឺផ្លេកផង ១០ដាវនោះបានសំលៀង
ដើម្បីនឹងសំឡេះយ៉ាងសន្ធឹក[ធ] ក៏បានខាត់ឱ្យភ្លឺ ដើម្បីឱ្យបាន
ដូចផ្លេកបន្ទោរ ដូច្នេះ តើគួរឱ្យយើងលេងសប្បាយឬអី
ដំបងដែលវាយកូនអញ នោះមើលងាយគ្រប់ទាំងឈើផង[ន]
១១ដាវនោះបានប្រគល់ដល់គេឱ្យខាត់ឱ្យភ្លឺ[ប] ដើម្បីនឹងដាក់
នៅដៃ នៃអ្នកដែលកាប់សំឡាប់ ដាវនោះបានសំលៀង
ហើយ អើ ក៏ខាត់ឱ្យភ្លឺផង ដើម្បីនឹងដាក់នៅដៃនៃគេ ១២កូន
មនុស្សអើយ ចូរស្រែក ហើយទ្រហោយំចុះ ពីព្រោះដាវ
នោះបានមកលើរាស្ត្ររបស់អញ ក៏មកលើពួកចៅហ្វាយ
ទាំងប៉ុន្មាននៃសាសន៍អ៊ីស្រាអែល ដែរគេត្រូវប្រគល់ដល់
ដាវជាមួយនឹងរាស្ត្រអញ ដូច្នេះ ចូរទះភ្លៅឯងចុះ[ផ] ១៣ដ្បិត
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា មានការល្បងល
ហើយ ដូច្នេះបើទាំងដំបង ដែលមើលងាយមិននៅទៀត

**២១:១** ក អគ ២០:១ **២១:២** ខ អគ ១៣:១៧ គ អគ ៩:៦ ឃ យរ ២៦:១១–១២ អគ ២០:៤៦ **២១:៣** ង យរ ២១:១៣ ច អស ២៧:១ អគ ១៤:២១ ឆ ខ.៩–១១ យប ៩:២២ អស ៥៧:១ យរ ៤៧:៦–៧ **២១:៤** ជ លវ ២៦:២៥ យរ ២៥:២៧ ឈ អគ ២០:៤៧ **២១:៥** ញ អស ៣៤:៥ ដ ខ.៣០ ឋ អគ ២០:៤៧–៤៨ ណហ ១:១៩ **២១:៦** ឌ ខ.១២ អស ២២:៤ យរ ៣០:៦ អគ ៩:៤ **២១:៧** ឍ យប ២៣:២ ណ យស ៧:៥ ត យរ ៤៧:៣ អគ ២២:១៤ ថ ទដ ៦:២ ទ លវ ២៦:៣៦ យប ១១:១៦ **២១:១០** ធ ទដ ១១០:៥–៦ អស ៣៤:៥–៦ ន ចទ ៣២:៤១ **២១:១១** ប យរ ៤៦:៤ **២១:១២** ផ យរ ៣១:១៩

**២១:២** *ចូរតំរង់មុខឯង* មើលការពន្យល់ ២០:២០:៤៦ *ហើយពោលទៅខាងទីបរិសុទ្ធ* មើល ៩:៦ និងការពន្យល់។

**២១:៣–៥** *ដាវរបស់អញ . . . ដាវរបស់អញ . . . ដាវរបស់អញ* មើល ៥:២ និងការពន្យល់ ។

**២១:៣** *មើលអញទាស់ទទឹងនឹងឯង* មើលការពន្យល់ ៥:៨ ។ *ដាវរបស់អញ* នេះគឺជាដាវទី១ ក្នុងចំណោមដាវទាំង៥ (មើល ខ៨–១៧ ១៨–២៤ ២៥–២៧ ២៨–៣២) ដាវនៅទីនេះ គឺសំដៅលើដាវរបស់ក្រុងបាប៊ីឡូន និងស្តេចនេបូក្នេសា(ខ.១៩) ។ *ទាំងសេចក្តីសុចរិត និងសេចក្តីទុច្ចរិត* ដោយចង្អុលបង្ហាញពីការជំនុំជម្រះរបស់ព្រះទៅលើអ៊ីស្រាអែលយ៉ាងពិតប្រាកដ គ្មានអ្នកណាអាចនឹងរត់រួចពីសេចក្តីអាក្រក់នេះបានឡើយ ដ្បិតមនុស្សសុចរិតនៅទីក្រុងនេះមានចំនួនតិចពេក មិនអាចនឹងជួយខ្លួនបានទេ ប៉ុន្តែព្រះទ្រង់បានរំដោះ លោកណូអេ និងលោកឡុតឱ្យរួចជីវិត (លក ៦:៧–៨ ១៨:២៣ ១៩:១២–១៣) ។

**២១:៤** *ចាប់តាំងពីខាងត្បូងរហូតដល់ខាងជើង* សូមមើលការពន្យល់ ២០:៤៧ ។

**២១:៦** *ជូចត់ ដោយចុកសៀតចង្កេះ ហើយមានចិត្តជូចត់* លោកអេសេគាល មានបំណងបង្ហាញពីភាពជូចត់ ទីសំគាល់នៃសេចក្តីទំនាយ អំពីព្រះបន្ទូលនៃការជំនុំជម្រះរបស់ព្រះ ទៅលើពួកអ៊ីស្រាអែល នេះជាទីសំគាល់ទី៧របស់លោកអេសេគាល ។

**២១:៧** *ក្បាលជង្គង់ទាំងប៉ុន្មាននឹងទន់ដូចជាទឹក* សូមមើល ៧:១៧ និងការពន្យល់ ។

**២១:៩** *ដាវ ដាវ* ដាវនៃបទចម្រៀង(មើល ខ.៣–៥) និងការពន្យល់ ។ ច្រៀង និងលោតរាំ ដូចជាបទចម្រៀងគេបានច្រៀងឡើង មុនពេលចូលទៅធ្វើចម្បាំង (មើល ការពន្យល់ ២សយ ១:១៨) ។

**២១:១០** *តើគួរឱ្យយើងលេងសប្បាយឬអី . . . គ្រប់ទាំងឈើផង* ដោយគិតថា ពួកបាប៊ីឡូននឹងច្បាំងដណ្តើមគ្រប់ទាំងទីក្រុងនានា លើកលែងតែទីក្រុងយូដា ដែលទីក្រុងនោះជាការអស់សង្ឃឹម ។ *ដំបងរាជ្យ* តំណាងពីរាជ្យ ការគ្រប់គ្រង រឺអាណាចក្រ ។ *កូនអញ* យូដា ឆ្លើយតបទៅ "រាស្ត្ររបស់អញ" នៅ ខ.១២ (មើល លក ៤៩:៩) អាចបកប្រែថា "កូនសំឡាញ់" ដោយសំដៅទៅលើការគ្រងរាជ្យនៅក្នុងដំណាក់ស្តេចដាវីឌ (មើល ទដ ២:៧ និងការពន្យល់) ។ *ដាវ* គឺដូចជាស្តេចបាប៊ីឡូន និងស្តេចនេបូក្នេសា (ខ.១៩)។

**២១:១១** *សំលៀង* ស្តេចនេបូក្នេសាសំលៀងដាវនោះ (ខ.១២) ។

**២១:១២** *ចូរស្រែក ហើយទ្រហោយំចុះ . . . ចូរទះភ្លៅឯងចុះ* តាមន័យពន្យល់ ។ *ចូរទះទ្រូងឯងចុះ* នេះជាទីសំគាល់ទី៨ ។

**២១:១៣** *មានការល្បងលហើយ* នៅលើពួកយូដា *បើទាំងដំបង . . . មិននៅទៀត* មើលការពន្យល់ ខ.១០ មានភាពច្របូកច្របល់កើតឡើងនៅក្នុងរាជ្យស្តេចដាវីឌ ហើយវាកើតមានឡើងនៅក្នុងឆ្នាំ ៥៨៦ គ.ស (សូមមើលក្នុង ខ.២៥–២៧) ។

នោះធ្វើដូចម្ដេចទៅ ១៤ហេតុនោះកូនមនុស្សអើយ ចូរឯង
ទាយចុះ ហើយទះដៃ[ត]ផង នោះត្រូវឱ្យដាវបានកាប់ដល់២
ដង ហើយ៣ដងទៅ គឺដាវនោះដែលកាប់សំឡាប់ ជាដាវ
ដែលធ្វើឱ្យទាំងពួកអ្នកធំត្រូវរបួស ហើយកំចាត់ចូលទៅ
ក្នុងបន្ទប់ដេករបស់គេផង[ភ] ១៥អញបានតាំងដាវ ដែលផ្គង
ចាំនៅមាត់ទ្វារទាំងប៉ុន្មាននៃទីក្រុងគេ ដើម្បីឱ្យចិត្តគេ
រលាយទៅ[ម] ហើយឱ្យគេចំពប់ដួលកាន់តែច្រើនឡើង
អែយ៉ា ដាវនោះបានធ្វើឱ្យដូចជាផ្លេកបន្ទោរ ក៏បាន
សំលៀងសំរាប់កាប់សំឡេះ[យ] ១៦ចូរមូលគ្នា ចូរទៅខាងស្តាំ
ចូរដំរៀបគ្នា ចូរទៅខាងឆ្វេង ខាងណាក៏ដោយ ដែលឯង
ដំរង់មុខទៅ ១៧អញក៏នឹងទះដៃអញដែរ[រ] រួចនឹងធ្វើឱ្យ
សេចក្ដីក្រោធ[ល]របស់អញ សំរាកទៅវិញ គឺអញជាព្រះ
យេហូវ៉ានេះ អញបានចេញវាចាហើយ[វ] ។

១៨ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំម្ដងទៀតថា
១៩កូនមនុស្សអើយ ចូរឱ្យឯងដំរូវឱ្យមានផ្លូវ២ ដែលដាវ[ស]
របស់ស្តេចបាប៊ីឡូននឹងមកបាន ផ្លូវទាំង២នោះត្រូវចេញ
ពីស្រុកតែ១ ត្រូវឱ្យធ្វើជាដៃចង្អុល[ហ] ដាក់នៅត្រង់ដើមផ្លូវ
ចូលទៅក្នុងទីក្រុង ២០ចូរឯងដំរូវឱ្យមានផ្លូវ១ សំរាប់ឱ្យដាវ
បានទៅដល់ក្រុងរ៉ាបាតនៃពួកកូនចៅអាំម៉ូន[ឡ] និង១ទៀត
ចូលទៅក្នុងស្រុកយូដា ដល់ក្រុងយេរូសាឡិម ជាទីក្រុង
មាំមួន ២១ដ្បិតស្តេចបាប៊ីឡូនបានឈរត្រង់ផ្លូវបែក គឺនៅ
ត្រង់ដើមផ្លូវទាំង២នោះ ដើម្បីនឹងប្រើរបៀនក៏អង្រួន[អ] ព្រួញ
សួរដល់រូបព្រះ[ក] ហើយមើលទំនាយក្នុងថ្លើម[ខ] ២២ឯ
ឆ្នោតដែលកាន់នៅដៃស្តាំ បានសំដៅទៅក្រុងយេរូសាឡិម
ដើម្បីនឹងរៀបគ្រឿងបុកទំលាយកំផែង ឱ្យបានចន្លោះចំហ
ចូលទៅដល់ការកាប់សំឡាប់ និងបន្លឺសំឡេងហ៊ោ[គ] ហើយ
តាំងគ្រឿងសំរាប់ទំលាយទ្វារកំផែង ព្រមទាំងការដីកស្នាម
ភ្លោះ[ឃ] ហើយសង់បន្ទាយ[ង] ២៣តែសាសន៍ឯងនឹងមើល
សេចក្ដីទំនាយនោះ ទុកជាភូតភរទេ ដ្បិតគេបានតាំង
សម្បថ នឹងអ្នកដទៃហើយ តែស្តេចនោះនឹងរំឭក[ច]ពីអំពើ
ទុច្ចរិតវិញ[ឆ] ដើម្បីនឹងចាប់យកគេបាន ។

២៤ហេតុនោះ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូល
ដូច្នេះ ដោយព្រោះឯងរាល់គ្នាបានរឭកពីអំពើទុច្ចរិត
របស់ខ្លួន ដោយបើកអំពើរំលងរបស់ខ្លួនឱ្យឃើញ ហើយ
អំពើបាបរបស់ខ្លួនក៏បានឃើញច្បាស់ ក្នុងគ្រប់ការដែលឯង
ធ្វើ បានជាឯងនឹងត្រូវដៃគេចាប់បាន ២៥ឯឯង ឱចៅហ្វាយ
ដ៏សៅហ្មង ហើយកំណាចរបស់អ៊ីស្រាអែល ដែលថ្ងៃឯង
បានមកដល់[ជ] ក្នុងគ្រានៃអំពើទុច្ចរិតនៅចុងបំផុតអើយ[ឈ]
២៦ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរដោះក្បាំង
ដោះមកុដចេញ[ញ] នេះមិនដូចធម្មតាទេ ចូរលើកអ្វីដែល

**២១:១៤** ត ខ.១៧ ជន ២៤:១០ ភ អក ៦:១១ ៣០:២៤ **២១:១៥** ម ២សយ ១៧:១០ យ ទដ ២២:១៤ **២១:១៧** រ ខ.១៤ អក ២២:១៣ ល អក ៥:១៣ វ អក ៦:១១ ១៦:៤២ **២១:១៩** ស អក ១៤:២១ ៣២:១១ ហ យរ ៣១:២១ **២១:២០** ឡ ចទ ៣:១១ **២១:២១** អ សក ១៦:៣៣ ក សក ១០:២ ខ ជន ២២:៧ ២៣:២៣ **២១:២២** គ យរ ៤:១៦ ឃ យរ ៣២:២៤ ង ២ពវ ២៥:១ អក ៤:២ ២៦:៩ **២១:២៣** ច ជន ៥:១៥ ឆ អក ១៧:១៩ **២១:២៥** ជ អក ២២:៤ ឈ អក ៣៥:៥ **២១:២៦** ញ អស ២៨:៥ យរ ១៣:១៨

**២១:១៤** *ហើយទះដៃផង* មើល ៦:១១ និងការពន្យល់ *ឱ្យដាវបានកាប់ដល់ ២ដង* ធៀបនឹង ២ពវ ១៣:១៨–១៩ ។

**២១:១៧** *អញក៏នឹងទះដៃអញដែរ* ដូចជាលោកអេសេគាល ដែលព្រះបញ្ជាឱ្យគាត់ទះដៃ នៅក្នុង ខ.១៤ ។

**២១:១៩** *ស្តេចនៃទីក្រុងបាប៊ីឡូន* គឺស្តេចនេប៊ូក្នេសា មានស្រុកដូចគ្នា ទីក្រុងបាប៊ីឡូន អាចហៅថាអាប់រ៉ាម(សេរ៉ា) ហើយរាជ្យដំណាក់របស់ស្តេចនេប៊ូក្នេសា គឺស្ថិតនៅឯរីបឡា ក្នុងភាគខាងជើងនៃអាប់រ៉ាម (មើល ២ពវ ២៥:៦) ។

**២១:២០** *ក្រុងរ៉ាបាត* ជាទីក្រុងអាំម៉ូន (យរ ៤៩:២) ហើយទីក្រុងដ៏ទំនើបនៃអាំម៉ាន( ទីក្រុងរបស់យ័ដាន់) ។

**២១:២១** *អង្រួនព្រួញ* ការបែកចែកព្រួញ ដើម្បីនឹងស្វែងរករបៀនយ៉ាងល្អ សំរាប់ពេលធ្វើការប្រកួតប្រជែងគ្នា វាត្រូវបានលើកមកបញ្ជាក់មាននៅកន្លែងមួយនៅក្នុងព្រះគម្ពីរ ។ ព្រួញជាស្លាកសញ្ញាមួយ (ឧទា. "រីបឡា" "ក្រុងយេរូសាឡិម គេកាន់ឆ្នោតនៅដៃ ហើយដៃស្តាំរបស់គេ សម្រាប់ធ្វើជារបៀនយ៉ាងល្អ(មើល ខ.២២) ។ *រូបព្រះ* ក្នុងភាសាហេព្រើរ ពាក្យនេះត្រូវបានបកប្រែថា"កន្លែងនៃរូបព្រះ" មើល លក ៣១:១៩(មើលការពន្យល់)។ ផ្តល់ប្រឹក្សាដល់គេ ដែលមាននៅក្នុង ហស ៣:៤ សក ១០:២ ទីកន្លែងរូបព្រះ លក ៣១:៣១–៣៥ ដែលមានកន្លែងល្មមអាចលាក់ពួនខ្លួនបាន ហើយរូបព្រះទាំងនោះគ្មានជីវិតទេ (១សយ ១៩:១៣–១៦) ។ *ការព្យាបាលថ្លើម* ការពិនិត្យមើលពីរូបរាងក្រៅនៃថ្លើមសត្វចៀម ដើម្បីធ្វើការប្រមើលពីថ្ងៃខាងមុខ ដែលកើតមានឡើងដល់ពួកបាប៊ីឡូន និងពួករ៉ូមជំនាន់ដើម ប៉ុន្តែសម្រាប់ការអនុវត្តមិនបានបញ្ជាក់នៅក្នុងព្រះគម្ពីរ។

**២១:២៣** *ការធ្វើរបៀនខុសឆ្គង* ពួកដឹកនាំក្រុងយេរូសាឡិម កាលពីមុន គេបានចុះចូលចំពោះស្តេចនេប៊ូក្នេសា ប៉ុន្តែក្រោយមក គេបានបះបោរប្រឆាំងវិញ (២ពវ ២៤:២០) យើងជឿថាលទ្ធផលនៃការស្វែងរករបៀននោះ គឺជាការយល់ខុស(ក្នុង ខ.២១–២២) ។

**២១:២៥,២៩** *ថ្ងៃនោះ . . . ក្នុងគ្រានៃអំពើទុច្ចរិតនៅចុងបំផុត* ដូចគ្នា ដែលស្តេចយូដារងចាំវាសនារបស់ខ្លួន ក្នុងគ្រានៃអំពើទុច្ចរិតនៅចុងបំផុត ។

**២១:២៥** *ចៅហ្វាយរបស់ពួកអ៊ីស្រាអែល* ស្តេចសេដេគា (មើលការពន្យល់ ៧:២៧) ។

**២១:២៦** *ក្បាំងមកុដ* ពាក្យនេះបញ្ជាក់ពីមកុដរបស់ស្តេច ហើយសង្ឃបានបំពាក់ឱ្យដល់ទ្រង់ (នក ២៨:៤,៣៧,៣៩ ២៩:៦ ៣៩:២៨,៣១ លវ ៨:៩ ១៦:៤) ហើយវាត្រូវបានបំពាក់នៅពេលដែលស្តេចរៀបអភិសេក (នក ២៨:៣៨–៣៧ ២៩:៦ ៣៩:៣១ លវ ៨:៩) វាធ្វើពីសំពត់ខ្លូតទេស (នក ២៨:៣៩ ៣៩:២៨ ។ *ចូរលើកអ្វីដែលទាបថោក ហើយបន្ទាបអ្វីដែលខ្ពង់ខ្ពស់ចុះ* ព្រះគម្ពីរបញ្ជាក់ពីការកែប្រែជាថ្មី នៃរបៀបរស់នៅរបស់មនុស្ស នៅពេលដែលព្រះទ្រង់ធ្វើការនៅក្នុងជីវិតរបស់គេ (មើល ១៧:២៤ និង អស ១សយ ២:៧–៨ លក ១:៥២–៥៣ និងការពន្យល់)។

ទាបថោក ហើយបន្ទាបអ្វីដែលខ្ពង់ខ្ពស់ចុះ[ដ] ២៧អញនឹងធ្វើ
ឱ្យត្រឡប់ត្រឡិន ត្រឡប់ត្រឡិនទៅ នេះក៏មិននៅទៀតដែរ
ដរាបដល់អ្នកនោះកើតឡើង ដែលមានច្បាប់ទទួល[ឋ] រួច
អញនឹងប្រគល់ដល់អ្នកនោះ[ឌ]។

២៨ឯឯង កូនមនុស្សអើយ ចូរទាយប្រាប់ថា ព្រះអម្ចាស់
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ពីដំណើរពួកកូនចៅអាំម៉ូន[ឍ]
ហើយពីពាក្យត្មះតិះដៀលរបស់គេ ចូរប្រាប់ថា ន៎ មាន
ដាវ[ណ] មានដាវហូតជាស្រេច ដាវនោះបានខាត់ឱ្យភ្លឺសំរាប់
ការសំឡេះយ៉ាងសន្ធឹក ដើម្បីឱ្យបានស៊ីបំផ្លាញ ហើយឱ្យបាន
ដូចជាផ្លេកបន្ទោរ ២៩ក្នុងពេលដែលគេកំពុង តែឃើញ
ការជាក់ស្តែង[ត]កំភូតសំរាប់ឯង ហើយកំពុងដែលគេទាយ
សេចក្តីកុហកដល់ឯងនោះ ដើម្បីឱ្យឯងបានដួលទៅលើក
នៃពួកមនុស្សអាក្រក់ ដែលត្រូវរបួសដល់ស្លាប់ ជាពួកអ្នក
ដែលថ្ងៃគេបានមកដល់ ក្នុងគ្រានៃអំពើទុច្ចរិតនៅចុង
បំផុត[ថ] ៣០ចូរឱ្យស៊កដាវទៅក្នុងស្រោមវិញ[ទ] អញនឹង
វិនិច្ឆ័យឯង នៅត្រង់កន្លែងដែលបានបង្កើតឯងមក គឺនៅ
ក្នុងស្រុកកំណើតរបស់ឯង[ធ] ៣១អញនឹងចាក់សេចក្តីគ្នាន់
ក្នាញ់របស់អញទៅលើឯង ហើយនឹងផ្លុំ[ន]លើឯងដោយ
ភ្លើងនៃសេចក្តីក្រោធ[ប]របស់អញ ក៏នឹងប្រគល់ឯងទៅក្នុង
កណ្តាប់ដៃមនុស្សកំរោលដែលប្រសប់បំផ្លាញ[ផ] ៣២ឯងនឹង
ត្រូវទុកជាឧសសំរាប់ភ្លើង[ព] ឈាមរបស់ឯងនឹងខ្ចាយនៅ
កណ្តាលស្រុក ឥតមានអ្នកណានឹងចាំ[ភ]ពីឯងទៀតឡើយ
ដ្បិតអញ គឺព្រះយេហូវ៉ានេះ អញបានចេញវាចាហើយ ។

## អំពើបាបនៃក្រុងយេរូសាឡិម

**២២** ១ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំទៀតថា
២ឯឯង កូនមនុស្សអើយ តើឯងចង់ជំនុំជំរះឬ តើចង់ជំនុំ
ជំរះទីក្រុង ដែលតែងតែកំចាយឈាមឬអី[ក] ដូច្នេះ ចូរធ្វើឱ្យ
វាស្គាល់អស់ទាំងអំពើគួរស្អប់ខ្ពើមរបស់វាចុះ[ខ] ៣ត្រូវឱ្យឯង
ប្រាប់ថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ យី៎ះទី
ក្រុងណាដែលកំចាយឈាម[គ] នៅកណ្តាលខ្លួន ដើម្បីឱ្យ
កំណត់ខ្លួនញបានមកដល់ ហើយធ្វើរូបព្រះសំរាប់ទាស់នឹង
ខ្លួន ដើម្បីឱ្យខ្លួនស្មោកគ្រោកទៅដូច្នេះ ៤ឯងមានទោស
ដោយឈាមដែលឯងបានកំចាយ[ឃ]នោះ ហើយក៏ស្មោក
គ្រោកដោយរូបព្រះដែលឯងបានធ្វើដែរ ឯងបានធ្វើឱ្យថ្ងៃ
កំណត់ឯងជិតមកដល់[ង] ឯងដល់កំណត់ឆ្នាំរបស់ឯងហើយ
ហេតុនោះបានជាអញធ្វើឱ្យត្រឡប់ទៅជាទីត្មះតិះដៀល[ច]
ដល់អស់ទាំងសាសន៍ ហើយជាទីចំអកឡកឡឺយ ដល់ស្រុក
ទាំងប៉ុន្មានផង[ឆ] ៥ឱឯងដែលស្អុយឈ្មោះ ហើយពេញដោយ
ការវឹកវរអើយ ពួកអ្នកដែលនៅជិត ហើយពួកអ្នកដែល
នៅឆ្ងាយផង គេនឹងចំអកឡកឡឺយឱ្យឯង[ជ]។

៦មើល ពួកចៅហ្វាយនៃសាសន៍អ៊ីស្រាអែលគ្រប់គ្នា

**២១:២៦** ដ ទដ ៧៥:៧ អស ៤០:៤ អគ ១៧:២៤ មថ ២៣:១២ **២១:២៧** ឋ លប ៤៩:១០ ឌុ ទដ ២:៦ យរ ២៣:៥-៦ អគ ៣៧:២៤ ហក ២:២១-២២ **២១:២៨** ឍ លប ១៩:៣៨ សផ ២:៨ ណ យរ ១២:១២ **២១:២៩** ត យរ ២៧:៩ ថ ខ.២៥ អគ ២២:២៨ ៣៥:៥ **២១:៣០** ទ ខ.៥ យរ ៤៧:៦ ធ អគ ១៦:៣ **២១:៣១** ន ទដ ១៨:១៥ អស ១១:៤ ប ទដ ៧៩:៦ អគ ២២:២០-២១ ផ យរ ៤:៤:៧ ៥១:២០-២៣ អគ ១៦:៣៩ **២១:៣២** ព អគ ២០:៤៧-៤៨ មឡ ៤:១ **២២:២** ក អគ ២៤:៦,៩ ហស ៤:២ ណហ ៣:១ ហប ២:១២ ខ អគ ១៦:២ ២៣:៣៦ **២២:៣** គ ខ.៦:១៣,២៧ អគ ២៣:៣៧,៤៥ ២៤:៦ **២២:៤** ឃ ២ពវ ២១:១៦ ង អគ ២១:២៥ ច ទដ ១៣៧:៣ ឆ ទដ ៤៤:១៣-១៤ អគ ៥:១៤ **២២:៥** ជ អស ២២:២

**២១:២៧** *ត្រឡប់ត្រឡិន ត្រឡប់ត្រឡិនទៅ* បញ្ជាក់ដោយរំលឹកឡើងវិញ (១សយ ៦:៣ យរ ៧:៤) ។ *អ្នកនោះ* មកុដ (ខ.២៦) តំណាងពីការគ្រប់គ្រង (អាណាចក្ររបស់យូដា) ។ *ដរាបដល់អ្នកនោះកើតឡើង* ព្រះម៉ែស៊ីមានការចែងនៅក្នុង លក ៤៩:១០ ។

**២១:២៨** *ពួកកូនចៅអាំម៉ូន* មើល ខ.២០ ក្រោយពីការដាក់ទណ្ឌកម្មលើក្រុងយេរូសាឡិម នោះពួកគេប្រឈមមុខនឹង (មើល ២៥:១-៧ មើលផងដែរ យរ ៩:២៦ ៤៩:១-៦ អម ១:១៣-១៥ សផ ២:៨-១១) ។ *ពាក្យត្មះតិះដៀលរបស់គេ* មើល ២៥:៣,៦ ធៀបនឹង ៣៦:១៥ ។ *ដាវ ដាវរបស់ស្តេចនេបូក្នេសា* (មើលក្នុង ខ.៩,១៩) ។

**២១:២៩** *ការជាក់ស្តែងកំភូត . . . កំពុងដែលគេទាយសេចក្តីកុហក* ជាក់ស្តែងពួកអាំម៉ូន គេមានពួកហោរាខុសឆ្គង (មើល ខ.១០ ១៣:១០ យរ ៦:១៤ ៨:១១-១២) ។

**២១:៣០-៣២** ព្រះអម្ចាស់បានសម្រេចបំណងព្រះហឫទ័យទ្រង់តាមរយៈពួកបាប៊ីឡូន ហើយព្រះនឹងជំនុំជម្រះដល់ពួកបាប៊ីឡូនផងដែរ ចំពោះសេចក្តីអាក្រក់ដែលគេបានប្រព្រឹត្ត (មើល យរ ៥០:១៥,២៧,២៩,៣១ ៥១:៦,៤៩ ហប ២:៤-២០ ធៀបនឹង អស ១០:៥-១៩ និងការពន្យល់ ១០:១២)។

**២១:៣០** *ចូរឱ្យស៊កដាវទៅក្នុងស្រោមវិញ* ប្រាប់ដល់ស្តេចនេបូក្នេសារ ។

**២១:៣១** *មនុស្សកំរោល* ក្រុមមនុស្សនៅទិសខាងកើត ដូចជានៅ ២៥:៤ ។

**២១:៣២** *ឧសសំរាប់ភ្លើង* មើល ២០:៤៧ និងការពន្យល់ ។

**២២:១-៣១** ព្រះទ្រង់បានបង្រៀនដល់លោកអេសេគាល ឱ្យហ៊ានប្រឈមមុខនឹងក្រុងយេរូសាឡិម(ក្នុង ខ.១-១២) និងទឹកដីស្រុកយូដា (ក្នុង ខ.២៣-២៩) គ្រប់ទាំងអំពើបាបដែលគេបានប្រព្រឹត្ត ហើយអំពើបាបទាំងនោះគឺក្រហាមឆ្អៅ ដែលធ្វើឱ្យព្រះយេហូវ៉ា (Yahweh) មានសេចក្តីក្រោធ (ក្នុង ខ១៣-២២, ៣០-៣១)។ ក្រោមរាជ្យរបស់ស្តេចម៉ាន៉ាសេ ស្តេចអាំម៉ូន និងស្តេចយេហូយ៉ាគីម នោះទីក្រុងយេរូសាឡិម បានក្លាយទៅជាទីក្រុងនៃរូបព្រះ និងទីក្រុងដែលប្រព្រឹត្តដោយអំពើអសីលធម៌ អំពើពុករលួយ(មើល ២ពវ ២១:២-២៦ យរ ២២:១៣-១៧) នៅក្នុងស្រុកយូដា ពួកអ្នកគ្រប់គ្រងទាំងអស់ដែលប្រព្រឹត្តសេចក្តីអាក្រក់ បានធ្លាក់ចុះ និងខ្សោយកំលាំង ។

**២២:២** *តើឯងចង់ជំនុំជំរះឬ* ធៀបនឹង ២០:៤ និងការពន្យល់ ។ *ទីក្រុងនេះ* ក្រុងយេរូសាឡិម វាតែងតែមានចំណុចស្របគ្នា ដូចគ្នានិងសេចក្តីទំនាយនៅក្នុងព្រះគម្ពីរអេសេគាល (មើល ៥:៥ និងការពន្យល់) ។

**២២:៣** *កំចាយឈាមនៅកណ្តាលខ្លួន . . . ធ្វើរូបព្រះទាស់ទទឹងនឹងខ្លួន* អំពើបាប មាន២យ៉ាងគឺ: (១).អំពើអយុតិធម៌នៅក្នុងសង្គម (២).ការថ្វាយបង្គំរូបព្រះ មើលការពន្យល់ ៦:៤ ។

**២២:៦** *ពួកចៅហ្វាយរបស់អ៊ីស្រាអែល* ពួកអ្នកដឹកនាំ មិនមែនជាស្តេចទេ ២១:១២ និង១៩:១ ។

បាននៅក្នុងឯង តាមអំណាចដែលអាចនឹងកំចាយឈាម[ឈ]
៧នៅក្នុងឯងគេបានមើលងាយទាំងឪពុកម្តាយផង[ញ] នៅ
កណ្តាលឯង គេបានសង្កត់សង្កិនពួកអ្នកដែលស្នាក់នៅ[ដ]
ហើយនៅក្នុងឯងគេបានរឹបជាន់ពួកកំព្រា និងស្រីមេម៉ាយ[ឋ]
៨ឯងបានខ្ពើមគ្រឿងបរិសុទ្ធរបស់អញ ហើយបានបង្អាប់
ថ្ងៃឈប់សំរាករបស់អញដែរ[ឌ] ៩នៅក្នុងឯងមានមនុស្ស[ឍ]
ដែលនិយាយបង្កាច់គេ ដើម្បីនឹងកំចាយឈាម[ណ] នៅក្នុង
ឯងគេបានស៊ីនៅលើភ្នំ[ត] នៅកណ្តាលឯងគេបានប្រព្រឹត្ត
ការអាស្រូវបារាយណ៍[ថ] ១០នៅក្នុងគេបានបើកកេរខ្មាស
របស់ឪពុក[ទ] នៅក្នុងឯងគេបានបង្ខំស្រីដែលត្រូវញែកចេញ
ដោយមានរដូវ[ធ,ន] ១១ម្នាក់បានប្រព្រឹត្តការគួរស្អប់ខ្ពើម ជា
មួយនឹងប្រពន្ធរបស់អ្នកជិតខាងខ្លួន[ប] ១ទៀតបានធ្វើឱ្យកូន
ប្រសាស្រីខ្លួនមានសៅហ្មង[ផ] ដោយការអាស្រូវបារាយណ៍
ហើយម្នាក់ទៀតក្នុងឯងបានបង្ខូចប្អូនស្រី[ព] ដែលជាកូន
របស់ឪពុកខ្លួន[ភ] ១២នៅក្នុងឯងគេបានស៊ីសំណូក[ម] ដើម្បីនឹង
កំចាយឈាម ឯងបានយកទាំងការនិងកំរៃ[យ]ផង ហើយ
បានសង្កត់សង្កិនអ្នកជិតខាង[រ]ឯង ឱ្យបានចំណេញដោយ
ចិត្តលោភ ក៏បានភ្លេច[ល]អញទៅ នេះជាព្រះបន្ទូលនៃព្រះ
អម្ចាស់យេហូវ៉ា[វ] ។
១៣ដូច្នេះ មើល អញបានទះដៃ[ស] ដោយព្រោះកំរៃ
ទុច្ចរិតដែលឯងបាន[ហ]នោះ ហើយដោយព្រោះឈាម[ឡ]
ដែលបានខ្ចាយនៅកណ្តាលឯងផង[អ] ១៤តើចិត្តឯងនឹងធន់
នៅបាន[ក] ហើយដៃ[ខ]ឯងនឹងមានកំឡាំង នៅថ្ងៃដែលអញធ្វើ
ទោសដល់ឯងបានឬ អញ គឺព្រះយេហូវ៉ានេះ អញបាន
ចេញវាចាហើយ[គ] ក៏នឹងសំរេចតាមផង[ឃ] ១៥អញនឹងកំចាត់
កំចាយឯង នៅអស់ទាំងសាសន៍ ហើយបែងចែក[ង]ឯងទៅ
នៅអស់ទាំងស្រុក អញនឹងរំលីង[ច]សេចក្តីស្មោកគ្រោក
ចេញពីឯងទៅ[ឆ] ១៦ឯងនឹងត្រូវបន្ទាបបន្ថោក នៅចំពោះ
ភ្នែកនៃអស់ទាំងសាសន៍ នោះឯងនឹងដឹងថា អញនេះជា
ព្រះយេហូវ៉ាពិត ។
១៧ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា ១៨កូន
មនុស្សអើយ ពួកវង្សអ៊ីស្រាអែល បានត្រឡប់ជាអាចម៍
សំណល់[ជ]ដល់អញ គេសុទ្ធតែជាលង្ហិន ស៊ីវិឡាត ដែក និង
សំណល់នៅក្នុងបាវឡ[ឈ] គេជាអាចម៍ប្រាក់ទទេ[ញ] ១៩ហេតុ
នោះព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ដោយ
ព្រោះឯងរាល់គ្នាបានត្រឡប់ជាអាចម៍ប្រាក់ទាំងអស់គ្នាទៅ
ហើយ[ដ] នោះមើល អញនឹងប្រមូលឯងរាល់គ្នាទៅកណ្តាល
ក្រុងយេរូសាឡិម ២០ដូចជាគេប្រមូលប្រាក់ លង្ហិន ដែក
សំណ ហើយនឹងស៊ីវិឡាត ដាក់ក្នុងបាវឡ ដើម្បីសប់ភ្លើង
រំលាយទៅដែរ គឺយ៉ាងនោះដែលអញនឹងប្រមូលឯងរាល់
គ្នា ដោយសេចក្តីកំហឹង និងសេចក្តីឃោរឃៅរបស់អញ
គឺអញនឹងដាក់ឯងរាល់គ្នានៅទីនោះ ហើយរំលាយទៅ[ឋ]
២១អើ អញនឹងប្រមូលឯង ហើយផ្លុំរំលីង[ឌ]ឯង ដោយភ្លើង
នៃសេចក្តីក្រោធរបស់អញ នោះឯងរាល់គ្នានឹងត្រូវ
រលាយទៅ នៅកណ្តាលទីក្រុង[ឍ] ២២ប្រាក់ត្រូវរលាយទៅ[ណ]
ក្នុងបាវឡយ៉ាងណា នោះឯងរាល់គ្នានឹងត្រូវរលាយទៅ
នៅកណ្តាលនោះយ៉ាងនោះដែរ ដូច្នេះ ឯងរាល់គ្នានឹងដឹង
ថា អញគឺព្រះយេហូវ៉ានេះ អញបានចាក់សេចក្តីក្រោធ[ត]
របស់អញទៅលើឯងរាល់គ្នា[ថ] ។
២៣ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា ២៤កូន
មនុស្សអើយ ចូរប្រាប់ដល់ទីក្រុងថា ឯងជាស្រុកដែលមិន
បានជំរះសំអាតឡើយ ក៏គ្មានភ្លៀងធ្លាក់មកលើឯង ក្នុង
គ្រានៃសេចក្តីគ្នាន់ក្នាញ់ផង[ទ] ២៥ពួកហោរារបស់វា គេគិត

**២២:៦** ឈ អគ ១១:៦ ១៨:១០ ៣៣:២៥ **២២:៧** ញ ចទ ៥:១៦ មីក ៧:៦ ដ នក ២៣:៩ ឋ នក ២២:២១–២២ **២២:៨** ឌ នក ២០:៨ អគ ២៣:៣៨–៣៩ **២២:៩** ឍ លវ ១៩:១៦ ណ អស ៥៩:៣ អគ ១១:៦ ហស ៤:២ ៦:៩ ត អគ ១៨:១១ ថ អគ ២៣:២៩ ហស ៤:១០,១៤ **២២:១០** ទ លវ ១៨:៧ ធ លវ ១២:២ ន លវ ១៨:៨,១៩ **២២:១១** ប យរ ៥:៨ ផ លប ១១:៣១ លវ ១៨:១៥ ព លវ ១៨:៩ ២សយ ១៣:១៤ ភ អគ ១៨:៦ **២២:១២** ម នក ១៨:២១ ចទ ២៧:២៥ ទដ ២៦:១០ អស ៥:២៣ អម ៥:១២ មីក ៧:៣ យ អគ ១៨:៨ រ លវ ១៩:១៣ ល ទដ ១០៦:២១ អស ១៧:១០ ៥៧:១១ វ អគ ១១:៦ **២២:១៣** ស នក ២៤:១០ អគ ២១:១៧ ហ ខ.២៧ អស ៣៣:១៥ ឡ ខ.៣ អ អគ ៦:១១ **២២:១៤** ក ទដ ៧៦:៧ យអ ២:១១ ណហ ១:៦ មឡ ៣:២ ខ អគ ៧:១៧ គ អគ ២៤:១៤ ឃ អគ ១៧:២៤ **២២:១៥** ង លវ ២៦:៣៣ ចទ ៤:២៧ សក ៧:១៤ ច អគ ១៦:៤១ ឆ អគ ២៤:១១ **២២:១៨** ជ ទដ ១១៩:១១៩ ឈ អស ៤៨:១០ ញ យរ ៦:២៨–៣០ **២២:១៩** ដ ទដ ១១៩:១១៩ **២២:២០** ឋ ហស ៨:១០ មឡ ៣:២ **២២:២១** ឌ អស ៤០:៧ ហក ១:៩ ឍ ទដ ៦៨:២ អគ ២១:៣១ **២២:២២** ណ អស ១:២៥ ត អគ ៧:៨ ថ អស ៦៤:៧ **២២:២៤** ទ អគ ២៤:១៣

**២២:៧** *នៅក្នុងឯងគេបានមើលងាយទាំងឪពុកម្តាយផង* មើល មក ៧:៦ ចណុចទាំង២ គឺផ្ទុយគ្នាពីក្រិត្យវិន័យរបស់ព្រះ នៅក្នុង នក ២០:១២ (មើលការពន្យល់នៅទីនេះ) ។ *ពួកអ្នកដែលស្នាក់នៅ . . . ពួកកំព្រា . . . ស្ត្រីមេម៉ាយ* មើល នក ២២:២១–២៧ និងការពន្យល់ ចទ ១០:១៨ ១៦:១១ ១៤ ២៤:១៧ ២៧:១៩ ទដ ៦៨:៥–៦ ៨២:៣ អស ១:១៧ ២៣ យរ ៧:៦ ២២:៣ យក ១:៧) ។

**២២:៨** *ថ្ងៃឈប់សំរាក់* ជាថ្ងៃដែលត្រូវយកចិត្តទុកដាក់បំផុតនៅក្នុងព្រះគម្ពីរអេសេគាល (មើលការពន្យល់ ២០:១២) ។

**២២:៩** *គេបានស៊ីនៅលើភ្នំ* មើល ១៨:៦ និងការពន្យល់ ។ *គេបានប្រព្រឹត្តការអាស្រូវ បារាយណ៍* គេថ្វាយបង្គំព្រះតែសំបកក្រៅ ដោយចិត្តគេមិនជឿ (មើល ហស ៤:១៤ និងការពន្យល់) ។

**២២:១០** *គេបានបង្ខំស្រី* ។ ធៀបនឹង ១៨:៦ និងការពន្យល់ ។

**២២:១១** *ការគួរស្អប់ខ្ពើម* គ្រប់ទាំងអំពើបាបទាំងអស់ ដែលបានបញ្ជាក់នៅក្នុងខនេះ ជាពិសេសនោះដូចមានចែងនៅក្នុងក្រិត្យវិន័យ (លវ ១៨:៧–២០ ២០:១០–២១ ចទ ២២:២២–២៣ ២៧:២២) ។

**២២:១២** *ឯងបានយកទាំងការ និងកំរៃផង* មើល ១៨:៨ និងការពន្យល់ ។

**២២:១៣** *អញបានទះដៃ* ដោយសេចក្តីកំហឹង (មើល ២១:១៤,១៧) ។

**២២:១៧–២២** ទីក្រុងយេរូសាឡិមនឹងក្លាយទៅជា "ចង្ក្រាន" របស់ព្រះ ដែលទ្រង់នឹងរំលាយពួកគេ និងទីក្រុងដែលនៅមាន ដើម្បីសំអាត "ច្រេះ" ចេញឱ្យស្អាត (មើល ទដ ១២:៦ និងការពន្យល់ ។

គូរគ្នា[ធ]នៅកណ្ដាលនោះ ហាក់ដូចជាសិង្ហ[ន] ដែលគ្រហឹម
កំពុងហែករំពាស៊ី គេបានត្របាក់លេបព្រលឹងមនុស្ស[ប] គេ
យកទ្រព្យសម្បត្តិ និងរបស់មានដំឡៃទៅ ហើយគេធ្វើឱ្យ
មានពួកស្រីមេម៉ាយ[ផ]ជាច្រើននៅកណ្ដាលទីក្រុង ២៦ពួក
សង្ឃក៏បានធ្វើទទឹងនឹងក្រិត្យវិន័យ[ព]របស់អញ ព្រមទាំង
បង្អាប់របស់បរិសុទ្ធទាំងប៉ុន្មានរបស់អញ គេមិនបានចេះ
ញែករបស់បរិសុទ្ធចេញពីរបស់ធម្មតាទេ[ភ] ក៏មិនបាន
បង្ហាញឱ្យមនុស្សចេះសំគាល់របស់មិនស្អាត នឹងរបស់ស្អាត
ដែរ[ម] គេគេចភ្នែកចេញពីថ្ងៃឈប់សំរាករបស់អញ ហើយ
អញក៏ត្រូវអាប់ឱន[យ]នៅក្នុងពួកគេ[រ] ២៧ពួកចៅហ្វាយ[ល]នៅ
កណ្ដាលទីក្រុងប្រព្រឹត្តដូចជាសត្វស្វាន[វ] ដែលកំពុងតែហែក
រំពា គេប្រព្រឹត្តដូច្នោះ ដើម្បីនឹងកំចាយឈាម ហើយ
បំផ្លាញព្រលឹងមនុស្ស[ស] ប្រយោជន៍ឱ្យបានកំរៃទុច្ចរិត[ហ]
២៨ពួកហោរាបានបូកល្បាប់[ឡ]ឱ្យគេ ដោយឃើញការជាក់
ស្តែងជាសេចក្តីកំភូត[អ] ហើយទាយកុហកដល់គេថា ព្រះ
អម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ ក្នុងកាលដែលព្រះ
យេហូវ៉ាមិនបានមានបន្ទូលសោះ[ក] ២៩ពួកជននៅស្រុកធ្លាប់
សង្កត់សង្កិន ហើយប្លន់[ខ] អើ គេបៀតបៀនមនុស្សក្រីក្រ និង
ពួកកំសត់ទុគ៌ត ហើយបានសង្កត់សង្កិនមនុស្ស ដែលស្នាក់
នៅ[គ]ដោយឥតហេតុ[ឃ] ៣០អញបានស្វែងរកមនុស្សម្នាក់ក្នុង
ពួកគេ ដែលនឹងសង់កំផែង[ង]ឡើង ហើយឈរនៅចន្លោះ
បាក់បែកនៅមុខអញជំនួសគេ ដើម្បីឱ្យអញមិនបំផ្លាញស្រុក
គេឡើយ ប៉ុន្តែអញរកមិនបានអ្នកណាមួយសោះ[ច] ៣១ហេតុ
នោះបានជាអញចាក់សេចក្តីគ្នាន់ក្នាញ់របស់អញ ទៅលើ
គេ អញបានរំលីងគេ ដោយភ្លើងនៃសេចក្តីក្រោធរបស់
អញ[ឆ] ក៏បានទំលាក់[ជ]ផ្លូវរបស់គេទៅលើក្បាលគេវិញ នេះ
ជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ឈ]។

**២២:២៥** ធ យរ ១១:៩ ន ទដ ២២:១៣ ប ហស ៦:៩ ផ យរ១៥:៨ ១៨:២១ **២២:២៦** ព ហស ៩:៧–៨ សផ ៣:៤ មឡ ២:៧–៨ ភ អគ ៤២:២០ ៤៤:២៣ ម លវ ២០:២៥ យ លវ ១៨:២១ អគ ១៣:១៩ រ ខ.៨ ១សយ ២:១២–១៧ យរ ២:៨,២៦ ហក ២:១១–១៤ **២២:២៧** ល យរ ២៦:១០ សផ ៣:៣ វ មថ ៧:១៥ ស ខ.៣ អគ ១១:៦ ៣៣:២៥ ៣៤:២–៣ មីក ៣:២,១០ ហ ខ.១៣ លប ៣៧:២៤ អស ១:២៣ យរ ១២:២ ៥១:១៣ អគ ៣៣:៣១ **២២:២៨** ឡ អគ ១៣:១០ អ បទ ២:១៤ ៤:១៣ អគ ២១:១៩ ក អគ ១៣:២,៦–៧ **២២:២៩** ខ ទដ ៦២:១០ គ នក ២២:២១ ឃ អស ៥:៧ **២២:៣០** ង អគ ១៣:៥ ច ទដ ១០៦:២៣ អស ៦៤:៧ យរ ៥:១ **២២:៣១** ឆ នក ៣២:១០ អស ៣០:២៧ បទ ៤:១១ ជ អគ ១៦:៤៣ ឈ អគ ៧:៨–៩ រម ២:៨ **២៣:២** ក យរ ៣:៧ អគ ១៦:៤៥ **២៣:៣** ខ យស ២៤:១៤ គ លវ ១៧:៧ អស ១:២១ ឃ ទដ ២៥:៧ ង អគ ១៦:១៥ **២៣:៤** ច អគ ១៦:៤៦

## បងប្អូនស្រីពីរនាក់ដែលប្រព្រឹត្តកំផិត

**២៣** ១ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់ខ្ញុំម្តងទៀត
ថា ២កូនមនុស្សអើយ ពីដើមមានស្រី២នាក់ពោះ១នឹងគ្នា[ក]
៣ហើយគេបានធ្វើសំផឹងនៅស្រុកអេស៊ីព្ទ[ខ] អើ គេបានធ្វើ
សំផឹង[គ] ពីកាលនៅក្មេង[ឃ] នៅស្រុកនោះ មនុស្សបានចាប់
ដោះគេ នៅទីនោះបានអង្អែលដោះនៃវ័យក្រមុំរបស់គេ[ង]
៤ឯនាងទាំង២នោះ បងឈ្មោះថា អូហូឡា ហើយប្អូនឈ្មោះ
អូហូលីបា គេក៏ត្រឡប់ជារបស់ផងអញ ហើយបង្កើតបាន
កូនប្រុស និងកូនស្រី ចំណែកឈ្មោះគេ នោះអូហូឡា គឺជា
ក្រុងសាម៉ារី ហើយអូហូលីបា គឺជាក្រុងយេរូសាឡិម[ច]។
៥ឯអូហូឡា នាងក៏ធ្វើជាសំផឹង ក្នុងកាលដែលធ្វើជា
ប្រពន្ធរបស់អញ វាជាប់ចិត្តនឹងសហាយវា គឺនឹងសាសន៍

**២២:២៥** *ពួកចៅហ្វាយ* លោកអេសេគាល បាននិយាយដោយផ្តោតទៅលើ "ច្រេះ" នៅក្នុង ខ.១៨–២២ អ្នកដឹកនាំអ៊ីស្រាអែលទាំងអស់ ហើយពួកចៅហ្វាយ(នៅទីនេះ) សំដៅទៅលើសង្ឃ(ខ.២៦) មន្ត្រី(ខ.២៧) ហោរា (ខ.២៨) ប្រជាជន (ខ.២៩) ។ *ដូចជាសត្វស្វាន* ធៀបនឹង ខ.២៧ ១៣:៤ សផ ៣:៣)។

**២២:២៦** *គេមិនបានចេះញែករបស់បរិសុទ្ធចេញពីរបស់ធម្មតា* នេះជាការងារមួយដ៏សំខាន់ ក្នុងចំណោមភារកិច្ចការនានារបស់សង្ឃ (មើល ៤៤:២៣ ហើយមើលផងដែរ លវ ១០:១០) *ថ្ងៃឈប់សំរាក* មើលការពន្យល់ ខ.៨ ។ គេ *បង្អាប់ទីបរិសុទ្ធ* មើល លវ ១៨:២១ និងការពន្យល់ ។

**២២:២៨** *បូកល្បាប់* មើល ១៣:១០ និងការពន្យល់ ។

**២២:២៩** *ពួកជននៅស្រុក* មើល៧:២៧ និងការពន្យល់ ។

**២២:៣០** *អញបានស្វែងរកមនុស្សម្នាក់* ធៀបនឹង ១សយ ៥៩:១៦ ៦៣:៥ និងការពន្យល់ ។ *ឈរនៅចន្លោះបាក់បែកនៅមុខអញជំនួយគេ* មើល ១៣:៥ និងការពន្យល់ ។ នៅកន្លែងខ្លះបកប្រែថា ភារកិច្ចរបស់ហោរា គឺឈរនៅចន្លោះកណ្តាលរវាងព្រះ និងបណ្តាជន ដើម្បីទូលអង្វរដល់ទ្រង់ជំនួសរាស្ត្ររបស់ទ្រង់(មើល លក ២០:៧ ១សយ ៥៩:២៣ យរ ៣៧:៣ ៤២:២) ។ កន្លែងផ្សេងទៀតបកប្រែថា តួនាទីរបស់ហោរា គឺដើម្បីបង្រៀនដល់បណ្តាជន ជាពិសេសព្រះទ្រង់ត្រាសហៅហោរា ដើម្បីប្រាប់ដល់បណ្តាជនឱ្យប្រែចិត្ត មួយទៀតកិច្ចការរបស់ហោរា "ជាអ្នកចាំយាម" (៣:១៧–២១ ៣៣:១–៦) ។

**២២:៣១** *ក៏បានទំលាក់ផ្លូវរបស់គេទៅលើក្បាលគេវិញ* មើលការពន្យល់ ១៦:៤៣ ។

**២៣:១–៤៩** ពិពណ៌នាអំពីសេចក្តីបង្រៀនរបស់ព្រះដល់បណ្តាជន នូវអំពើបាបយ៉ាងក្រហមឆ្អៅរបស់ពួកអ៊ីស្រាអែល(ដូចគ្នានៅក្នុងជំពូក១៦) ការជំនុំជម្រះរបស់ព្រះទៅលើក្រុងយេរូសាឡិម និងស្រុកយូដា នៅក្នុងជំពូក១៣ (មើលការពន្យល់ ១៣:១–២៣ ១៨:១–៣២)។

**២៣:៤** *បង* មើល ១៦:៤៦ និងការពន្យល់ ។ *អូហូឡា* មានន័យថា "ទីជម្រករបស់នាង" ដោយសំដៅទៅការពិតដែលក្រុងសាម៉ារី មានទីកន្លែងបរិសុទ្ធ ហើយ *អូហូលីបា* មានន័យថា "ទីជម្រករបស់ខ្ញុំនៅក្នុងទ្រង់" ដោយសំដៅទៅទីកន្លែងបរិសុទ្ធ របស់ព្រះនៅក្នុងក្រុងយេរូសាឡិម ។ បងប្អូនស្រី២នាក់ មើល យរ ៣:៦–១២ និងការពន្យល់ ៣:៧ ។

**២៣:៥** *ស្រីសំផឹង* គឺជានិមិត្តរូប តំណាងពីសម្ព័ន្ធភាពនយោបាយរបស់អ៊ីស្រាអែល ជាមួយនិងពួកមានអំណាចនៃសាសន៍ដទៃ។ គេមិនត្រូវថ្វាយបង្គំរូបព្រះ ដូចជាក្នុងជំពូក១៦ (មើល នក ៣៤:១៥ និងការពន្យល់) ភាសាដែលបញ្ជាក់នៅក្នុងជំពូកនេះ បង្ហាញពីភាពខ្ញើមឆ្អើមរបស់ព្រះ និងលោកអេសេគាលចំពោះអ៊ីស្រាអែល ដែលគេលេងល្បែងនយោបាយអន្តរជាតិ

អាសស៊ើរ[ឆ] ជាអ្នកជិតខាងវា[ជ] ៦ជាពួកអ្នកដែលស្លៀកពាក់
ដោយសំពត់ពណ៌ខៀវ សុទ្ធតែជាចៅហ្វាយ ហើយជាអ្នក
គ្រប់គ្រង ជាពួកកំឡោះដែលចាប់ចិត្ត ហើយក៏ជិះសេះ
គ្រប់គ្នា ៧វាធ្វើសំផឹងនឹងគេ ដែលសុទ្ធតែជាមនុស្សជ្រើស
រើសក្នុងសាសន៍អាសស៊ើរ ហើយវាក៏ធ្វើឱ្យខ្លួនទៅជា
ស្មោកគ្រោក ដោយរូបព្រះរបស់អស់អ្នកដែលវាជាប់ចិត្ត
ស្រឡាញ់នោះ[ឈ] ៨វាមិនលះលែងការកំផិត ដែលវាបាន
ធ្វើតាំងពីនៅស្រុកអេស៊ីព្ទមកនោះទេ[ញ] ដ្បិតកាលវានៅ
ក្មេងនៅឡើយ នោះគេបានរួមដំណេកនឹងវា ហើយបាន
អង្អែលដោះនៃវ័យក្រមុំរបស់វា ព្រមទាំងចាក់ការកំផិត
របស់គេទៅលើវា[ដ] ៩ហេតុនោះ អញបានប្រគល់វាទៅ[ឋ]
ក្នុងកណ្តាប់ដៃនៃពួកសហាយវា[ឌ] គឺក្នុងកណ្តាប់ដៃនៃពួក
សាសន៍អាសស៊ើរ ដែលវាបានជាប់ចិត្តស្រឡាញ់នោះ[ឍ]
១០គេបានបើក[ណ]កេរខ្មាសរបស់វា ហើយចាប់យកកូនប្រុស
កូនស្រីរបស់វា ព្រមទាំងសំឡាប់ខ្លួនដោយដាវផង រួចវា
មានល្បីឈ្មោះ នៅក្នុងពួកស្រីៗ[ត] ដ្បិតគេបានសំរេចទោស[ថ]
ដល់វា[ទ] ។

១១ឯអូហូលីបា ជាប្អូន ក៏ឃើញដូច្នោះដែរ[ធ] ប៉ុន្តែបាន
ប្រព្រឹត្តខូចអាក្រក់ជាងទៅទៀត ដោយជាប់ចិត្តស្រឡាញ់
គេ ហើយដោយការសំផឹងរបស់វា ដែលលើសជាងការ
សំផឹងរបស់បងខ្លួន[ន] ១២វាជាប់ចិត្តស្រឡាញ់ពួកសាសន៍
អាសស៊ើរ ជាពួកចៅហ្វាយ គឺជាពួកអ្នកគ្រប់គ្រងដែលនៅ
ជិតខាងវា ជាពួកអ្នកដែលស្លៀកពាក់ដោយរុងរឿង ហើយ
ជិះសេះ សុទ្ធតែជាពួកកំឡោះយ៉ាងចាប់ចិត្ត[ប] ១៣អញក៏បាន
ឃើញថា វាត្រូវស្មោកគ្រោកហើយដែរ បងប្អូន២នាក់បាន
ដើរតាមផ្លូវតែ១[ផ] ១៤តែប្អូនបានចំរើនការសំផឹងរបស់ខ្លួន
ជាច្រើនឡើង ដ្បិតវាបានឃើញរូបមនុស្សដែលបានគូរ
នៅជញ្ជាំង[ព] គឺជារូបពួកសាសន៍ខាល់ដេ ដែលគូរដោយ
ពណ៌ក្រហម[ភ] ១៥មានទាំងខ្សែក្រវាត់[ម]នៅចង្កេះ ហើយ

**២៣:៥** ឆ ១ពវ ១៦:៧ ហស ៥:១៣ ជ ហស ៨:៩
**២៣:៧** ឈ អស ៥៧:៨ ហស ៥:៣ ៦:១០
**២៣:៨** ញ នក ៣២:៤ ដ អគ ១៦:១៥
**២៣:៩** ឋ ២ពវ ១៨:១១ ឌ យរ ៤:៣០ ឍ ហស ១១:៥
**២៣:១០** ណ ហស ២:១០ ត អគ ១៦:៤១ ថ យរ ៤២:១០ ទ អគ ១៦:៣៦
**២៣:១១** ធ យរ ៣:៧ ន យរ ៣:៨–១១ អគ ១៦:៥១
**២៣:១២** ប ២ពវ ១៦:៧–១៥ ២របា ២៨:១៦ អគ ១៦:១៥,២៨
**២៣:១៣** ផ ២ពវ ១៧:១៩ ហស ១២:២
**២៣:១៤** ព អគ ៨:១០ ភ យរ ២២:១៤ ណាហ ២:៣
**២៣:១៥** ម អស ៥:២៧
**២៣:១៦** យ អស ៥៧:៩ រ អគ ៦:៩
**២៣:១៧** ល យរ ៤០:៩ វ អគ ១៦:២៩

ក្បាលជួតដោយឈ្នួត មានរំភាយសំយុងចុះ គ្រប់គ្នាមាន
ភាពមើលទៅដូចជាកូនស្តេច តាមបែបពួកក្រុងបាប៊ីឡូន
ក្នុងស្រុកខាល់ដេ ជាស្រុកកំណើតរបស់គេ ១៦កាលវា
បានឃើញគេ នោះក៏ជាប់ចិត្តស្រឡាញ់ភ្លាម ហើយបាន
ចាត់ទូត[យ]ទៅឯគេ ក្នុងស្រុកខាល់ដេ[រ] ១៧នោះពួកក្រុង
បាប៊ីឡូន[ល]ក៏មកឯវា រួមដំណេកដោយស្រឡាញ់ គេក៏ធ្វើ
ឱ្យវាស្មោកគ្រោកដោយការកំផិតរបស់គេ វាបានសៅហ្មង
ដោយសារគេ រួចចិត្តក៏ណាយចេញពីគេវិញ[វ] ១៨គឺយ៉ាង
នោះដែលវាបានបើកអំពើកំផិតរបស់វា ហើយបើកកេរ
ខ្មាសឱ្យឃើញផង[ស] ដូច្នេះ ចិត្តអញក៏ជិនណាយ[ហ]ពីវា ដូច
ជាបានជិនណាយពីបងវាដែរ[ឡ] ១៩ប៉ុន្តែវាចេះតែចំរើនការ
សំផឹងរបស់វាឡើងទៀត ដោយរឭកពីកាលនៅក្មេងនៅ
ឡើយ ជាគ្រាដែលបានធ្វើសំផឹងនៅក្នុងស្រុកអេស៊ីព្ទនោះ
២០វាជាប់ចិត្តស្រឡាញ់សហាយវា ដែលមានសាច់ដូចជា
សាច់នៃសត្វលា ហើយទឹកកាមក៏ដូចជាទឹកកាមរបស់សេះ
២១គឺយ៉ាងនោះ ដែលឯងនឹកចាំពីអំពើអាស្រូវបារាយណ៍
ដែលប្រព្រឹត្តកាលពីនៅក្មេង ដោយពួកសាសន៍អេស៊ីព្ទ
បានចាប់ដោះឯង ដែលដោះឯងនៅជាក្រមុំផង[អ] ។

២២ហេតុនោះ ឱអូហូលីបាអើយ ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះថា មើល អញនឹងដាស់ពួកសហាយ
ឯង[ក] ដែលឯងបានណាយចិត្តពីគេនោះ ឱ្យមកទាស់នឹង
ឯង អញនឹងនាំគេមកទាស់នឹងឯងនៅគ្រប់ទិស[ខ] ២៣គឺជា
ពួកក្រុងបាប៊ីឡូន[គ] ពួកខាល់ដេទាំងប៉ុន្មាន[ឃ] ពួកពេកូឌ[ង] ពួក
សូអា និងពួកកូអា ព្រមទាំងពួកអាសស៊ើរជាមួយនឹងគេ
ដែរ ជាពួកកំឡោះគួរចាប់ចិត្ត ជាពួកចៅហ្វាយ ជាពួក
អ្នកគ្រប់គ្រងទាំងអស់គ្នា ព្រមទាំងពួកកូនស្តេច និងមនុស្ស

**២៣:១៨** ស អស ៥៧:៨ ហ ទដ ៧៨:៥៩ ១០៦:៤០ យរ ៦:៨ ឡ យរ ១២:៨ អម ៥:២១ **២៣:២១** អ អគ ១៦:២៦ **២៣:២២** ក យរ ៤:៣០ ខ អគ ១៦:៣៧ **២៣:២៣** គ ២ពវ ២០:១៤–១៨ យរ ៤០:៩ ឃ លប ១១:២៨ ង យរ ៥០:២១

ជាជាងដែលគេទុកចិត្តលើព្រះអម្ចាស់ ដើម្បីសន្តិសុខផ្ទាល់ខ្លួនរបស់គេ ។ ក្នុងករណីនេះ ការថ្វាយបង្គំរូបព្រះ គឺជាការកំផិតខាងសាសនា ដូចជា ។ *សាសន៍អាសស៊ើរ* មើល ២ពវ ១៥:១៩ និងការពន្យល់ ។

**២៣:៨** *នៅស្រុកអេស៊ីព្ទ* ធៀបនឹង ២០:៥–៨ អ៊ីស្រាអែលចូលទៅក្នុងប្រវត្តិសាស្ត្រមួយដែលគេលែងមានការស្មោះត្រង់ នៅពេលដែលគេចូលទៅដល់ទឹកដីអេស៊ីព្ទ មើល ចទ ១៧:៣ នក ១១:៥,១៨,២០ ១៤:២–៤ ២១:៥ ។

**២៣:១០** *គេបានបើកកេរខ្មាសរបស់វា* ការធ្លាក់ចុះរបស់សាសន៍សាម៉ារីចូលទៅក្នុងសាសន៍អាសស៊ើរ នៅក្នុងឆ្នាំ ៧២២–៧២១ មុន គ.ស ។

**២៣:១៤** *ដែលគូរដោយពណ៌ក្រហម* លោកយេរេមាតុបតែងលាបផ្ទះដោយពណ៌ក្រហម (មើល ២២:១៤) ។

**២៣:១៥** *ខ្សែក្រវាត់* ធៀបនឹង ១សយ ៥:២៧ ការហ៊ឹកហ្វឺនទាហានអាសស៊ើរ ។

**២៣:២០** *ទឹកកាមរបស់សេះ* មើលការពន្យល់ ១៦:២៦ ។

**២៣:២៣** *ពួកក្រុងបាប៊ីឡូន ពួកខាល់ដេ* ពួកគេស្គាល់គ្នាទៅវិញទៅមក (សូមមើល ១:៣ ១២:១៣) ។ ពួកគេល្បីឈ្មោះ (ដូចជានៅក្នុង ខ.១៥) ប្រហែលជាពួកខាល់ដេ ជាសាច់ញាតិពួកអ្នកចំណូលថ្មីរបស់សាសន៍ ពេកូឌ ពួកអារ៉ាប់ ដែលមានទីតាំងនៅឯប៉ែកខាងកើតនៃទីក្រុងបាប៊ីឡូន ។ *ពួកសូអា និងពួកកូអា* ដែលគេចងសម្ព័ន្ធភាពជាមួយនឹងពួកបាប៊ីឡូនកាលពីជិនាន់ដើម ។

មានឈ្មោះ ដែលសុទ្ធតែជិះសេះគ្រប់គ្នាផង[ច] ២៤គេនឹង
លើកគ្នាមកទាស់នឹងឯង ទាំងមានគ្រឿងសាស្ត្រាវុធ រទេះ
និងយន្តចំបាំង[ឆ] ព្រមទាំងនាំកងទ័ពមកជាច្រើន ពួកទាំង
នោះនឹងដំរៀបគ្នានៅជុំវិញឯង ទាំងកាន់ខែលធំខែលតូច
និងពាក់មួកសឹកផង រួចអញនឹងប្រគល់ការជំនុំជំរះ[ជ]ដល់
គេ នោះគេនឹងជំនុំជំរះឯងតាមច្បាប់របស់គេ ២៥អញនឹង
តាំងសេចក្ដីប្រចណ្ឌ[ឈ]របស់អញទាស់នឹងឯង ហើយគេនឹង
ប្រព្រឹត្តនឹងឯង ដោយសេចក្ដីឃោរឃៅ គេនឹងកាត់ច្រមុះ
កាត់ត្រចៀកឯងចេញ ហើយសំណល់របស់ឯងនឹងដួល
ដោយដាវ គេនឹងចាប់យកកូនប្រុសកូនស្រីរបស់ឯងទៅ[ញ]
ឯពួកឯងដែលនៅសល់ នោះនឹងត្រូវភ្លើងស៊ីបំផ្លាញបង់[ដ]
២៦គេនឹងបកយក[ឋ]សំលៀកបំពាក់ឯងចេញ ហើយយក
គ្រឿងលំអររបស់ឯងទៅដែរ[ឌ] ២៧គឺយ៉ាងនោះដែលអញ
នឹងបំបាត់[ឍ]អំពើអាស្រូវបារាយណ៍ពីឯងចេញ ព្រមទាំង
ការសំផឹងរបស់ឯង ដែលជាប់មកពីស្រុកអេស៊ីព្ទផង ឯង
នឹងមិនសំលៀងភ្នែកមើលទៅគេទៀតឡើយ ក៏មិនរឭក
ដល់ស្រុកអេស៊ីព្ទទៀតដែរ ២៨ដ្បិតព្រះអម្ចាស់យេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា មើល អញនឹងប្រគល់[ណ]ឯងទៅក្នុង
កណ្ដាប់ដៃនៃពួកអ្នកដែលឯងស្អប់ គឺទៅក្នុងកណ្ដាប់ដៃ
នៃពួកអ្នកដែលចិត្តឯងបានណាយចេញពីគេនោះ ២៩គេ
នឹងប្រព្រឹត្តនឹងឯងដោយចិត្តស្អប់ គេនឹងដកយកអស់ទាំង
ផលនៃការឯងទៅ ទុកឱ្យឯងនៅជាអាក្រាត[ត] ហើយខ្លួន
ទទេ នោះសេចក្ដីអាម៉ាសខ្មាសនៃការកំផិតរបស់ឯងនឹង
បានបើកនៅចំហ[ថ] ព្រមទាំងការអាស្រូវបារាណ៍[ទ] និងការ
សំផឹងរបស់ឯងផង[ធ]។

៣០ការទាំងនេះនឹងត្រូវធ្វើដល់ឯង ដោយព្រោះឯង
បានផិតតាមអស់ទាំងសាសន៍ដទៃ ហើយបានធ្វើឱ្យខ្លួន
ស្មោកគ្រោកដោយរូបព្រះរបស់គេ[ន] ៣១ឯងបានប្រព្រឹត្ត
តាមកិរិយារបស់បងស្រីឯង ហេតុនោះអញនឹងឱ្យពែង[ប]
របស់បងឯងទៅក្នុងដៃឯងដែរ[ផ] ៣២ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះថា ឯងនឹងត្រូវផឹកពីពែងរបស់បង
ស្រីឯង ជាពែងយ៉ាងជ្រៅ ហើយធំ ឯងនឹងត្រូវគេសើចឡក
ឡឺយ ហើយទុកជាទីមើលងាយ[ព] អើ ពែងនោះចំណុះជា
ច្រើន[ភ] ៣៣ឯងនឹងបានពេញដោយស្រវឹង ហើយទុក្ខព្រួយ
គឺជា ពែងនៃសេចក្ដីស្រឡាំងកាំង និងសេចក្ដីស្ងាត់ជ្រងំ ជា
ពែងរបស់សាម៉ារីបងស្រីឯង[ម] ៣៤ឯងនឹងត្រូវផឹកពីពែង
នោះ[យ] ព្រមទាំងសិរេងផង រួចនឹងកកេរបំណែក ហើយនឹង
ហែកដោះឯងទៅ ដ្បិតអញនេះបានចេញវាចាហើយ នេះ
ជាព្រះបន្ទូលនៃព្រះយេហូវ៉ា[រ] ៣៥ហេតុនោះព្រះអម្ចាស់
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះឯងបាន
ភ្លេច[ល]អញ ព្រមទាំងបោះបង់អញចោលទៅក្រោយខ្នងឯង[វ]
ដូច្នេះ នោះត្រូវឱ្យឯងរងទ្រាំ[ស]នឹងអំពើអាស្រូវបារាណ៍ និង
ការកំផិតរបស់ឯងចុះ ។

៣៦ព្រះយេហូវ៉ា ទ្រង់មានបន្ទូលនឹងខ្ញុំទៀតថា កូន
មនុស្សអើយ តើឯងចង់ជំនុំជំរះអូហូឡា និងអូហូលីបាឬអឺ
បើដូច្នេះ ចូររំឭក[ហ]ឱ្យនាងដឹងពីអំពើគួរស្អប់ខ្ពើមរបស់
នាងចុះ[ឡ] ៣៧ដ្បិតនាងបានប្រព្រឹត្តសេចក្ដីកំផិតហើយក៏មាន
ឈាមប្រឡាក់នៅដៃនាងដែរ នាងបានផិតទៅតាមរូបព្រះ
របស់ខ្លួន ហើយបានធ្វើឱ្យកូន ដែលនាងបង្កើតដល់អញ
ឆ្លងកាត់ភ្លើង ថ្វាយដល់រូបព្រះទាំងនោះ ឱ្យវាត្រូវឆេះទៅ[អ]
៣៨មួយទៀត នាងបានធ្វើការយ៉ាងនេះដល់អញ គឺបាន
ធ្វើឱ្យទីបរិសុទ្ធ[ក] របស់អញស្មោកគ្រោកទៅនៅថ្ងៃ១នោះ
ឯង ព្រមទាំងបង្អាប់ថ្ងៃឈប់សំរាករបស់អញផង[ខ] ៣៩ដ្បិត
កាលនាងបានសំឡាប់កូនរបស់ខ្លួន ថ្វាយដល់រូបព្រះទាំង
នោះ ហើយនៅថ្ងៃនោះឯង នាងក៏ចូលក្នុងទីបរិសុទ្ធរបស់

**២៣:២៣** ច ២ពវ ១៤:២ **២៣:២៤** ឆ យរ ៤៧:៣ អគ ២៦:៧,១០ ណាហ ២:៤ ជ យរ ៣៩:៥-៦ **២៣:២៥** ឈ ចទ ២៩:២០ ញ ខ.៤៧ អគ ២៤:២១ ដ យរ ១២:៩ អគ ១៦:៣៨ ២០:៤៧-៤៨ **២៣:២៦** ឋ យរ ១៣:២២ ឌ អស ៣:១៨-២៣ អគ ស១៦:៣៩ **២៣:២៧** ឍ អគ ១៦:៤១ **២៣:២៨** ណ យរ ៣៤:២០ **២៣:២៩** ត មីក ១:១១ ថ យរ ១៣:២៧ ទ អគ ២២:៩ ធ ចទ ២៨:៤៨ អគ ១៦:៣៦ **២៣:៣០** ន ទដ ១០៦:៣៧-៣៨ សផ ៣:១ **២៣:៣១** ប យរ ២៥:១៥ ផ ២ពវ ២១:១៣ **២៣:៣២** ព ទដ ៤៤:១៣ ហស ៧:១៦ ភ ទដ ៦០:៣ អស ៥១:១៧ យរ ២៥:១៥ **២៣:៣៣** ម យរ ២៥:១៥-១៦

អគ ១២:១៩ **២៣:៣៤** យ ទដ ១៦:៥ រ យរ ២៥:២៧ **២៣:៣៥** ល ចទ ៣២:១៨ អស ១៧:១០ វ ១ពវ ១៤:៩ ២របា ២៩:៦ ស អគ ១៦:៥២ **២៣:៣៦** ហ អគ ១៦:២ ឡ អស ៥៨:១ អគ ២២:២ មីក ៣:៨ **២៣:៣៧** អ អគ ១៦:៣៦ **២៣:៣៨** ក លវ ១៥:៣១ ខ នហ ១០:៣១

**២៣:២៤** *តាមច្បាប់របស់គេ* ដោយភាពឃោរឃៅ និងភាពខ្ពើមរអើម (មើល ខ.២៥)។

**២៣:២៥** *សេចក្ដីប្រចណ្ឌរបស់អញទាស់នឹងឯង* មើល ១៦:៣៨ មើលការពន្យល់ ១៥:៧ ២០:៤៧ ។

**២៣:២៧** *ស្រុកអេស៊ីព្ទ* មើលការពន្យល់ក្នុង ខ.៨ ។

**២៣:៣១** *ពែង* ពែងនោះពេញដោយក្រោធរបស់ព្រះ បើពួកគេផឹកដោយពែងនោះ គេនឹងស្លាប់ ដ្បិតគេពេញដោយរូបព្រះ មើល ទដ ១៦:៥ និងការពន្យល់ ៧៥:៨ អស ៥១:១៧ ២២ យរ ២៥:១៥ និងការពន្យល់ ៤៩:១២ បទ ៤:២១ អប ១៦ និងការពន្យល់ ហព ២:១៦ មថ ២០:២២ ២៦:៣៩ វវ ១៤:១០ និងការពន្យល់ ។

**២៣:៣៤** *ហែកដោះឯង* វាយដោះ និម្មិតសញ្ញាពីការយំសោក (មើល ២១:១២ មើលផងដែរ យរ ៣១:១៩ លក ២៣:៤៨ និងការពន្យល់ នៅត្រង់នេះអ្នកនិពន្ធចង់បញ្ជាក់ថា ការហែកដោះនោះ គឺហែកយ៉ាងខ្ទេចខ្ទី ដើម្បីឱ្យគេ ត្រូវតែស្វែងរកជំនួយសង្គ្រោះពីព្រះអម្ចាស់ នៅពេលដែលគេកំពុងតែរងទុក្ខឈឺចាប់នោះ។

**២៣:៣៥** *ឯងបានបំភ្លេចអញ* មើល ២២:១២ យរ ២:៣២ និងការពន្យល់ ។

**២៣:៣៧** *យកកូនទៅថ្វាយយញ្ញបូជាដល់រូបព្រះ* សូមមើលការពន្យល់ ១៦:២០ ។

**២៣:៣៨** *បានធ្វើឱ្យទីបរិសុទ្ធរបស់អញស្មោកគ្រោក* មើល ជំពូក ៨ ថ្ងៃបរិសុទ្ធ មើលការពន្យល់ ២២:៨ ។

អញ ដើម្បីនឹងបង្អាប់[គ]ទីនោះទៀត មើល នាងបានប្រព្រឹត្ត
យ៉ាង ដូច្នោះនៅកណ្ដាលវិហាររបស់អញ[ឃ] ៤០មួយទៀត
នាង បានចាត់ឱ្យទៅរកមនុស្សមកពីទីឆ្ងាយ[ង] ជាពួកអ្នក
ដែលបានចាត់ទូតទៅហៅ ហើយមើល ពួកនោះក៏មក
នាងបានងូតទឹក ផាត់រង្វង់ភ្នែក[ច] ហើយតែងខ្លួនដោយ
គ្រឿងលំអសំរាប់ទទួលគេ[ឆ] ៤១ហើយបានអង្គុយលើគ្រែដ៏
រុងរឿង[ជ] មានតុ[ឈ]រៀបជាស្រេចនៅពីមុខ ឯងក៏ដាក់
កំញាន[ញ] និងប្រេងរបស់អញលើតុនោះផង[ដ] ៤២នោះមាន
ឮសូរសំឡេងរបស់មនុស្សយ៉ាងសន្ធឹក ដែលនៅដោយឥត
កង្វល់[ឋ]ជាមួយនឹងនាង ក៏មានគេនាំពួកសេបា[ឌ]ពីទីរហោ-
ស្ថានមក ជាមួយនឹងមនុស្សកកកុញនោះ ពួកទាំងនោះ
បានបំពាក់កង[ឍ]នៅដៃនាង ហើយក្បាំងយ៉ាងល្អនៅលើ
ក្បាល[ណ]។

៤៣នោះខ្ញុំបាននឹកពីនាង ដែលធ្លាប់ប្រព្រឹត្តសេចក្ដីកំផិត
ជាយូរមកហើយថា ឥឡូវនេះ មុខជាគេនឹងសហាយ[ត]គ្នា
នឹងគ្នាហើយ ៤៤គេក៏ចូលទៅឯនាង ដូចជាចូលទៅឯស្រី
សំផឹង គឺយ៉ាងនោះដែលគេបានចូលទៅឯអូហូឡា និង
អូហូលីបា ជាស្រីឥតខ្មាសនោះ ៤៥ប៉ុន្តែនឹងមានមនុស្ស
សុចរិតជំនុំជំរះនាងទាំង២ តាមមាត្រាច្បាប់ដែលត្រូវខាង
ស្រីកំផិត ហើយតាមមាត្រាច្បាប់ត្រូវខាងស្រីដែលកំចាយ
ឈាម[ថ] ពីព្រោះនាងទាំង២ជាស្រីកំផិត ហើយដែលគេក៏
ប្រឡាក់ដោយឈាមផង[ទ] ៤៦ដ្បិតព្រះអម្ចាស់យេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា អញនឹងនាំមនុស្ស១ពួក[ធ]ឡើងមកទាស់
នឹងនាង ហើយនឹងប្រគល់នាងទៅគេ ឱ្យត្រូវបៀតបៀន
ហើយរឹបជាន់[ន] ៤៧ពួកមនុស្សទាំងនោះនឹងចោលនាងនឹងថ្ម
ហើយផ្តិលនាងដោយដាវ គេនឹងសំឡាប់កូនប្រុសកូនស្រី[ប]
របស់នាង ហើយដុត[ផ]ផ្ទះនាងចោល ៤៨គឺយ៉ាងនោះដែល
អញនឹងបំបាត់[ព]ការអាស្រូវបារាយណ៍ ពីស្រុកចេញដើម្បី
នឹងបង្រៀនពួកស្រីៗទាំងអស់ មិនឱ្យប្រព្រឹត្តតាមការ
អាស្រូវរបស់នាងតទៅ[ភ] ៤៩គេនឹងសងការអាស្រូវបារាយ-
ណ៍របស់នាងទៅលើនាងវិញ ហើយនាងនឹងត្រូវរងទ្រាំ
ទោសនៃការគោរពដល់រូបព្រះរបស់នាងដែរនោះ[ម] នាង
នឹងដឹងថា អញនេះជាព្រះអម្ចាស់យេហូវ៉ាពិត[យ]។

## ថ្លាង

**២៤** ១ លុះដល់ថ្ងៃ១០ ខែបុស្ស ឆ្នាំទី៩ នោះព្រះបន្ទូលនៃ
ព្រះយេហូវ៉ាក៏មកដល់ខ្ញុំទៀតថា[ក] ២កូនមនុស្ស អើយ ចូរ
កត់[ខ]ថ្ងៃនេះទុក គឺថ្ងៃនេះឯង ដ្បិតនៅថ្ងៃនេះ ស្តេចបាប៊ីឡូន
បានចូលទៅតនឹងក្រុងយេរូសាឡិមហើយ[គ] ៣ចូរពោល
ពាក្យប្រៀបប្រដូច [ឃ]ដល់ពួកវង្សរឹងចចេសនោះ[ង] ហើយ
ប្រាប់ថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរដាក់
ថ្លាង[ច]នៅលើភ្លើង ចូរដាក់ចុះ ហើយចាក់ទឹកផង ៤ចូរ
ប្រមូលដុំសាច់ គឺអស់ទាំងដុំល្អៗ និងភ្លៅ ហើយស្មាផង
ទៅកាក់ក្នុងថ្លាងនោះដែរ ត្រូវឱ្យបំពេញដោយឆ្អឹងយ៉ាង
សំរាំង[ឆ] ៥ត្រូវឱ្យរើសយកចៀមយ៉ាងសំរាំង[ជ]ហើយ ដុត

**២៣:៣៩** គ ២ពវ ២១:៤ ឃ យរ ៧:១០ អគ ២២:៨ **២៣:៤០** ង អស ៥៧:៩ ច ២ពវ ៩:៣០ ឆ យរ ៤:៣០ អគ ១៦:១៣–១៩ ហស ២:១៣ **២៣:៤១** ជ នអ ១:៦ សភ ៧:១៧ ឈ អស ៦៥:១១ អគ ៤១:២២ ៤៤:១៦ មឡ ១:៧,១២ ញ អស ៥៧:៩ ៦៥:៣ យរ ៤៤:៥ ដ ជន ១៨:១២ **២៣:៤២** ឋ ទដ ៧៣:៥ ឌ ២របា ៩:១ ឍ លប ២៤:៣០ ណ អគ ១៦:១១–១២ **២៣:៤៣** ត ខ.៣ **២៣:៤៥** ថ អគ ២២:៣ ទ លវ ២០:១០ អគ ១៦:៣៨ ហស ២:២ ៦:៥ **២៣:៤៦** ធ អគ ១៦:៤០ ន ចទ ២៨:២៥ យរ ២៥:៩ **២៣:៤៧** ប ខ.២៥ ផ ២របា ៣៦:១៩ យរ ៣៤:២២ ព ២របា ៣៦:១៧ **២៣:៤៨** ភ អគ ១៦:៤១ ម ២ពត ២:៦ **២៣:៤៩** យ អគ ២៤:១៣ រ អគ ៧:៤ ៩:១០ ១៦:៥៨ ២០:៣៨ **២៤:១** ក អគ ៨:១ ២៦:១ ២៩:១៧ **២៤:២** ខ អស ៣០:៨ ហប ២:២ គ ២ពវ ២៥:១ យរ ៣៩:១ **២៤:៣** ឃ អស ១:២ អគ ២:៣,៦ ង អគ ២០:៤៩ ច អគ ១១:៣ **២៤:៤** ឆ អគ ១១:៧ **២៤:៥** ជ អស ៣៤:១២ យរ ៥២:១០

**២៣:៤០** *នាងបានចាត់ឱ្យទៅរកមនុស្សមកពីទីឆ្ងាយជាពួកអ្នកដែលបានចាត់ទូតទៅហៅ* យោងតាមខនេះ ក្រុងយេរូសាឡិមកំពុងរៀបចំកិច្ចប្រជុំនៅចំពេលវេលារបស់ស្តេចសេដេគាល (យរ ២៧) ។ *នាង* ក្រុងយេរូសាឡិមបានផាត់រង្វង់ភ្នែក គូរផាត់ម្សៅលើភ្នែកដែលមើលទៅគួរឱ្យទាក់ទាញ ។

**២៣:៤១** *មានតុរៀបជាស្រេចនៅមុខ* សំរាប់ពិធីជប់លៀង (មើល ១សយ ២១:៥ និង សភ ៩:២) ។

**២៣:៤២** *ពួកសេបា* មនុស្សប្រុសមកពីសេបា ដែលមានទីតាំងនៅភាគខាងត្បូងនៃឧបទ្វីបអារ៉ាបីន ទីក្រុងយ៉េម៉ែន ( Modern Yemen ) ដែលគេបានស្គាល់ថាជាទីក្រុងពានិជ្ជកម្ម (មើល ២៧:២២ ៣៨:១៣ ១ពវ ១០:១ និងការពន្យល់ យប ១:១៥ និងការពន្យល់ ៦:១៩) ។

**២៤:១–១៤** សេចក្ដីផ្ដើមនៃសេចក្ដីទំនាយគឺនៅក្នុងជំពូក ១៣ (មើលការពន្យល់ ១៣:១–២៣) ចុងបញ្ចប់ការពណ៌នាក្រុងយេរូសាឡិម ប្រៀបដូចជាថ្លាងដែលកំពុងតែនៅលើភ្លើង និងពាក្យចុងក្រោយនិយាយពីសេចក្ដីទំនាយទី៧នៅក្នុងផ្នែកនេះ (មើល ១៨:៣០ ២៤:១៤ និងការពន្យល់)។

**២៤:១** *ថ្ងៃទី១០ . . . ខែទី១០ . . . ឆ្នាំទី៩* នៃរាជ្យស្ដេចសេដេគាល (២ពវ ២៥:១) នៅថ្ងៃទី១៥ ខែមករា ឆ្នាំ៥៨៨ មុន គ.ស ។ ២ឆ្នាំកន្លះក្រោយពីកាលបរិច្ឆេទ នៃសេចក្ដីទំនាយលើកមុន (មើល ២០:១)។ ឆ្នាំទី៤នៃរាជ្យស្ដេចសេដេគាល (មើល ១:២ ៨:១ ២០:១) ។

**២៤:២** *ចូរកត់ថ្ងៃនេះទុក . . . ដ្បិតនៅថ្ងៃនេះ* ព្រះទ្រង់បានបើកសំដែងឱ្យលោកអេសេគាល ឃើញនូវអ្វីដែលកើតឡើងនៅក្រុងយេរូសាឡិម។

**២៤:៣** *ពួកវង្សរឹងចចេស* ការជំនុំជម្រះនឹងកើតមានឡើងជាចុងក្រោយដូចជានៅក្នុងព្រះគម្ពីរអេសេគាល (មើល ២:៥,៦,៨ ៣:៩ ២៦–២៧ ១២:២–៣,២៥ ១៧:១២) ។ ការបះបោររបស់ពួកក្រុងយេរូសាឡិម នឹងត្រូវបំផ្លាញខ្ទេចខ្ទីយ៉ាងឆាប់បំផុត ។ *ពាក្យប្រៀបប្រដូច* ធៀបនឹង ១៧:២ ។ *ពាក្យថ្លាង* ត្រូវបានគេយកមកប្រើម្ដងទៀត ដូចជានៅក្នុង ១១:៣–១២។ ថ្លាងជានិមិត្តរូបពីក្រុងយេរូសាឡិម (ធៀបនឹង ១១:៣ និងការពន្យល់)។ នៅខាងក្រោមនេះប្រាប់ពីការចំអិនសាច់នៅក្នុងថ្លាង (ក្នុង ខ.៤–៥) ការដុតបំផ្លាញគ្រឿងស្មោកគ្រោក (ក្នុង ខ.៦–៨) ស្ងោរសាច់ឱ្យឆ្អិន (ក្នុង ខ.៩–១០) ដុតឱ្យឆេះអស់របស់ស្មោគគ្រោក ។

**២៤:៤** *គឺអស់ទាំងដុំល្អៗ* មនុស្សនៅក្រុងយេរូសាឡិម គេគិតថាគេបានទុកជីវិតឱ្យពួកអ្នកជាប់ជាឈ្លើយនៅក្នុងឆ្នាំ ៥៩៧ មុន គ.ស ដោយសារគេមានសេចក្ដីសប្បុរស (មើល ១១:៣ និងការពន្យល់) ។

ទាំងឆ្អឹងពីក្រោម ត្រូវធ្វើឱ្យពុះយ៉ាងខ្លាំង ឱ្យឆ្អឹងនៅក្នុង
ថ្លាងនោះបានឆ្អិន[ឈ]។
៦ហេតុនោះព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូល ដូច្នេះ
ថា វេទនា[ញ] ដល់ទីក្រុងដែលប្រឡាក់ដោយឈាម[ដ] គិតដល់
ថ្លាងដែលជាប់មានក្អែល ដែលក្អែលនោះមិនបានដុស
ចេញ ចូរយកសាច់ចេញដោយដុំៗ ឥតបោះឆ្នោត[ឋ]សោះ[ឌ]
៧ដ្បិតឈាមដែលបានកំចាយនោះ ក៏នៅកណ្ដាលទីក្រុង
នៅឡើយ វាបានដាក់ឈាមនោះនៅលើថ្មរលីង មិនបាន
ចាក់ទៅលើដី ដើម្បីនឹងគ្របបាំងដោយធូលីដីទេ[ឍ] ៨ជា
ការដែលបណ្ដាលឱ្យសេចក្ដីក្រោធ ឡើងមកសងសឹកនឹង
វា ដូច្នេះ អញបានដាក់ឈាមវាទៅលើថ្មរលីង ដើម្បីមិន
ឱ្យបានគ្របបាំងដែរ ៩ហេតុនោះ ព្រះអម្ចាស់យេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា វេទនាដល់ទីក្រុងដែលប្រឡាក់ដោយ
ឈាម អញនឹងបង្គរឧសឡើងយ៉ាងច្រើន ១០ចូរគរឧស
ឡើងជាច្រើន ដុតភ្លើងឱ្យយ៉ាងក្ដៅ ហើយស្ងោរសាច់ឱ្យ
ឆ្អិន រួចបង់គ្រឿងគ្រៅ ហើយដុតឆ្អឹងទៅ ១១បន្ទាប់នោះ
ត្រូវឱ្យយកថ្លាងទទេ ដាក់លើរងើកភ្លើងឱ្យក្ដៅ ហើយឱ្យ
លង្ហិនបានឆេះទៅ ដើម្បីឱ្យគ្រឿងស្មោកគ្រោបានរលាយ
ចេញ ហើយឱ្យក្អែលបានឆេះឱ្យសុស[ណ] ១២វាបាននឿយ
ហត់ដោយការឥតប្រយោជន៍ ប៉ុន្តែ ក្អែលយ៉ាងសំបើម
របស់វាមិនចេះបាត់ចេញទេ ត្រូវដុតក្នុងភ្លើងវិញ ១៣មាន
ការអាស្រូវបារាយណ៍ នៅក្នុងសេចក្ដីស្មោកគ្រោករបស់
ឯង ដ្បិតអញបានដុសជិរះឯង តែឯងមិនបានស្អាតទេ[ត]
ដូច្នេះ ឯងនឹងមិនបានស្អាតពីសេចក្ដីស្មោកគ្រោករបស់អញ
ឯងទៀតឡើយ ដរាបដល់អញឱ្យសេចក្ដីក្រោធរបស់អញ
ចំពោះឯងបានសំរាកវិញ[ថ] ១៤អញនេះ គឺយេហូវ៉ា បាន
ចេញវាចាហើយ[ទ] ការនេះនឹងកើតមក ហើយអញនឹងធ្វើ
ឱ្យសំរេចជាពិត[ធ] អញមិនព្រមដកថយ ឬត្រាប្រណីឡើយ[ន]
ក៏មិនដែលប្រែគំនិតដែរ[ប] គេនឹងជំនុំជំរះឯងតាមផ្លូវដែល
ឯងប្រព្រឹត្ត និងអំពើដែលឯងបានធ្វើវិញ[ផ] នេះជាព្រះបន្ទូល
នៃព្រះអម្ចាស់យេហូវ៉ា[ព]។

## ប្រពន្ធរបស់លោកអេសេគាលស្លាប់

១៥ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា ១៦កូន
មនុស្សអើយ មើល[ភ] អញនឹងដកយករបស់ដែលត្រូវចំណុច
ភ្នែកពីឯងចេញ[ម] ដោយអាសន្នរោគ តែមិនត្រូវឱ្យឯង
សោយសោក ឬយំយែកឡើយ ក៏មិនត្រូវស្រក់ទឹកភ្នែក
ដែរ[យ] ១៧ឯងនឹងដកដង្ហើមធំចុះ[រ] តែកុំឱ្យឮឱ្យសោះ កុំឱ្យ
យំសោកនឹងខ្មោចស្លាប់ឡើយ ត្រូវឱ្យរុំឈ្នួត[ល]ជាប់នៅលើ
ក្បាល ហើយពាក់ស្បែកជើងវិញ មិនត្រូវឱ្យបិទបាំងបបូរ

**២៤:៥** ឈ យរ ៥២:២៤-២៧ មីក ៣:២-៣ **២៤:៦** ញ អគ ១៦:២៣ ដ អគ ២២:២ ឋ យប ៦:២៧ យអ ៣:៣ អប ១:១១ ណហ ៣:១០ ឌ អគ ១១:១១ **២៤:៧** ឍ លវ ១៧:១៣ **២៤:១១** ណ យរ ២១:១០ **២៤:១៣** ត អស ២២:១៤ ថ យរ ៦:២៨ -៣០ បទ ១:៩ អគ ១៦:៤២ ២២:២៤ ២៣:៣៦-៤៩ ហស ៧:១ សក ៦:៨ **២៤:១៤** ទ អគ ២២:១៤ ធ ជន ១១:២៣ ន អគ ៨:១៨ ប យប ២៧:២២ ផ អគ ៣៦:១៩ សក ៨:១៤

ព អស ៣:១១ អគ ១៨:៣០ **២៤:១៦** ភ ទដ ៣៩:១០ ម ខ.២១ ទដ ៨៤:១ បទ ២:៤ យ យរ ១៣:១៧ ១៦:៥ ២២:១០ **២៤:១៧** រ ទដ ៣៩:៩ ល នក ២៨:៣៩ អស ៣:២០ វ អស ២០:២

**២៤:៥** *ដុត* ការដុតឧបករណ៍ដែលស្ដេចនេបូក្នេសាបានឡោមព័ទ្ធយកបាន។
**២៤:៦** *ទីក្រុងដែលប្រឡាក់ដោយឈាម* ផ្ទៀននឹងខ.៩ ២២:២-៣ ។ *ដុតឱ្យខ្លោច* ជានិមិត្តរូបពីស្ថានភាពមួយដែលទីក្រុងយេរូសាឡិម មិនអាចជួយរំដោះខ្លួនឯងបាន ។ *ឥតបោះឆ្នោតសោះ* បន្ទាប់ពីការឡោមព័ទ្ធក្រុងយេរូសាឡិមនៅឆ្នាំ៥៩៧ ប្រហែលជាពួកបាប៊ីឡូន ត្រូវដាក់ឱ្យចាំមើលពួកអ្នកដែលគេចាប់ជាឈ្លើយ នោះពួកគេគ្រប់គ្នាត្រូវទៅធ្វើការនោះ ។
**២៤:៧** *ឈាម . . . នៅលើថ្មរលីង* ក្រុងយេរូសាឡិមបានកំចាយឈាមនោះដោយឥតអៀនខ្មាស់ ដែលក្រុងនេះប្រព្រឹត្តដោយអយុតិធម៌ (ផ្ទៀបនឹង ១សយ ៣:៩)។ គេទុកឈាមនោះដោយចំហ ឥតគ្របបាំងឡើយ មើល លប ៤:១០ យប ១៦:១៨ និងការពន្យល់ ផ្ទៀបនឹង លវ ១៧:១៣-១៤ ។
**២៤:៨** *សេចក្ដីក្រោធ* សេចក្ដីក្រោធរបស់ព្រះ ចំពោះអ្វីដែលពួកក្រុងយេរូសាឡិមបានធ្វើ នោះគេនឹងបានទទួលលទ្ធផលពីការនោះវិញ (មើល ១៦:៤៣ និងការពន្យល់ ហើយមើលផងដែរ ១ពវ ៨:៣២ អស ៣:១ ផ្ទៀបនឹង នក ៤:២១ ២១:២៣-២៥ លវ ២៤:១៧-២២ ចទ ១៩:២១ និងការពន្យល់) ។
**២៤:១១** *ថ្លាងទទេ* ក្រុងយេរូសាឡិម នឹងគ្មានមនុស្សរស់នៅ ហើយស្ថិតនៅលើភ្លើង ហើយចុងក្រោយដើម្បីឱ្យក្រុងនេះញែកចេញជាបរិសុទ្ធ ។
**២៤:១៣** *ការអាស្រូវបារាយណ៍* មើល ១៦:១-៦៣, ២៣:១-៤៩ និងការពន្យល់ ។
**២៤:១៤** *ការនេះនឹងកើតមកពិត* មើល ៧:២-៣ និងការពន្យល់ក្នុងជំពូក ៧:១-២៧ *គេនឹងជំនុំជំរះឯងតាមផ្លូវដែលឯងប្រព្រឹត្ត* មើលការពន្យល់ក្នុង រម ២:១-១៦ ២:៦-៨ វវ ២០:១២ ។
**២៤:១៥-២៧** ខាងក្រោមនេះនិយាយផ្ដោតទៅលើសេចក្ដីទំនាយ នៃការជំនុំជម្រះរបស់ព្រះទៅលើពួកយូដា (១៣:១-២៤:១៤) សកម្មភាពរបស់លោកអេសេគាល អំពីសេចក្ដីស្លាប់ប្រពន្ធរបស់គាត់ ជាទីសំគាល់ពីការដែលពួកជាប់ជាឈ្លើយ នឹងប្រតិកម្មចំពោះការដួលរលំនៃក្រុងយេរូសាឡិមដូចជាទីសំគាល់ ដែលសំដែងឱ្យពួកជាប់ជាឈ្លើយនៅក្រុងយេរូសាឡិមបានឃើញ (មើល ១២:១-២៨ និងការពន្យល់ ។
**២៤:១៦** *មួយប៉ប្រិចភ្នែក* ជម្ងឺមួយចំនួនកើតឡើងយ៉ាងឆាប់រហ័សបំផុត ហើយវាអាចកើតឡើងឈានដល់កម្រិតមួយយ៉ាងធំ (មើល នក ៩:១៤ ជន ១៤:៣៧) ។ *ត្រូវចំណុចភ្នែក* ជាទីពេញចិត្ត (មើលក្នុងខ.២១,២៥) ការសន្មត់យ៉ាងច្បាស់ ដោយពោលទៅលើប្រពន្ធរបស់កូនមនុស្ស (ផ្ទៀបនឹង ពច ១៤:៣ "នាងជាទីពេញចិត្តរបស់ខ្ញុំ" នាងជាមនុស្សល្អនៅក្នុងកែវភ្នែករបស់ខ្ញុំ មើលផងដែរ បស ៨:១០) ។
**២៤:១៧** *រុំឈ្នួតជាប់នៅលើក្បាល* ជាធម្មតាពួកអ្នកកាន់ទុក្ខ ពេលដែលគេយំនោះគេយកឈ្នួតចេញ ហើយដាក់ធូលីដីនៅលើក្បាល (មើល យស ៧:៦ អស ៤:១២ និងការពន្យល់) ។ *ហើយពាក់ស្បែកជើងវិញ* ដើម្បីបង្ហាញគេពីការកាន់ទុក្ខ (មើល ២សយ ១៥:៣០ និងការពន្យល់)។ *គ្របមុខ* បង្ហាញ

មាត់ឯង[ស] ឬស៊ីអាហារធម្មតាទេ[ហ] ១៨ដូច្នេះ ខ្ញុំក៏និយាយ
ដល់បណ្ដាជននៅព្រឹកនោះ ហើយដល់ល្ងាចប្រពន្ធខ្ញុំស្លាប់
ទៅ រួចព្រឹកឡើងខ្ញុំបានធ្វើដូចជាទ្រង់បង្គាប់មក[ឡ]។
១៩បណ្ដាជនទាំងប៉ុន្មានក៏សួរខ្ញុំថា សូមប្រាប់យើង ពី
ការដែលអ្នកធ្វើទាំងនេះ តើមានន័យដូចម្ដេចដល់យើង[អ]
២០នោះខ្ញុំប្រាប់គេពីព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលបាន
មកដល់ខ្ញុំថា ២១ចូរប្រាប់ដល់ពួកវង្សអ៊ីស្រាអែលថា ព្រះ
អម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ មើល អញនឹង
បង្អាប់ទីបរិសុទ្ធ[ក]របស់អញ នឹងសេចក្ដីអំនួត[ខ]របស់អំណាច
ឯងរាល់គ្នា ហើយរបស់ដែលត្រូវចំណុចភ្នែកនៃឯង[គ] ព្រម
ទាំងសំណប់ចិត្តឯងរាល់គ្នាផង ឯពួកកូនប្រុស កូនស្រី[ឃ]
ដែលឯងបានទុកចោលឯណោះ នោះនឹងត្រូវដួលស្លាប់
ដោយដាវ[ង] ២២គ្រានោះអ្នករាល់គ្នានឹងធ្វើដូចជាខ្ញុំបានធ្វើ
នេះដែរ គឺអ្នករាល់គ្នានឹងមិនបិទបាំងបបូរមាត់[ច] ឬស៊ី
អាហារធម្មតាទេ[ឆ] ២៣ឯសំពត់ឈ្នួត[ជ]នឹងនៅជាប់លើក្បាល
ហើយស្បែកជើង[ឈ]នៅជាប់នឹងជើងដែរ អ្នករាល់គ្នានឹង
មិនសោយសោក[ញ] ឬយំយែកឡើយ គឺនឹងរោយរៀវទៅ[ដ]
ក្នុងអំពើទុច្ចរិតរបស់ខ្លួន ហើយនឹងថ្ងូរប្រទល់មុខគ្នានឹង
គ្នាវិញ[ឋ] ២៤អេសេគាល[ឌ]នឹងធ្វើជាទីសំគាល់[ឍ] ដល់ឯងរាល់
គ្នាយ៉ាង នោះឯងរាល់គ្នានឹងធ្វើតាម គ្រប់ទាំងការដែល
គាត់បានធ្វើនោះដែរ កាលណាការនោះកើតមក នោះឯង
រាល់គ្នានឹងដឹងថា អញនេះជាព្រះអម្ចាស់យេហូវ៉ាពិត ។
២៥ឯឯង កូនមនុស្សអើយ នៅថ្ងៃដែលអញនឹងដកយកទី
ពឹងពីគេចេញ ព្រមទាំងសេចក្ដីអំណរចំពោះសិរីល្អរបស់
គេ និងអ្វីៗ ដែលត្រូវចំណុចភ្នែក[ណ] ហើយសំណប់ចិត្តគេ
ផង[ត] គឺកូនប្រុសកូនស្រី[ថ]គេ ២៦នៅថ្ងៃនោះ ឯងអ្នកណា
ដែលរត់រួចបាន គេនឹងមកឯឯង[ទ] ដើម្បីនឹងប្រាប់ពីការ
នោះ ឱ្យឯងឮដោយត្រចៀក ២៧នៅថ្ងៃនោះ មាត់ឯងនឹង
បើកឡើងដល់អ្នកដែលរត់រួច ឯងនឹងអាចនិយាយបាន[ធ]
មិននៅតទៀតឡើយ គឺយ៉ាងនោះ ដែលឯងនឹងធ្វើជាទី
សំគាល់ដល់គេ ហើយគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ា
ពិត[ន] ។

**២៤:១៧** ស លវ ១៣:៤៥ ហ ខ. ២២ យរ ១៦:៧ **២៤:១៨** ឡ អក ១២:៧ **២៤:១៩** អ អក ១២:៩ ៣៧:១៨ **២៤:២១** ក លវ ២៦:៣១ អក ៧:២៤ ខ លវ ២៦:១៩ គ ខ. ១៦ ទដ ២៧:៤ ឃ អក ២៣:២៥ ង យរ ៧:១៤,១៥ ហស ៩:១២,១៦ មទ្ឋ ២:១២ **២៤:២២** ច លវ ១៣:៤៥ ឆ យរ ១៦:៧ **២៤:២៣** ជ នក ២៨:៣៩ អស ៣:២០ ឈ អស ២០:២ ញ នក ៣៣:៤ ដ លវ ២៦:១៦ ឋ ទដ ៧៨:៦៤ **២៤:២៤** ឌ អក ១:៣

## បទទំនាយទាស់នឹងកូនចៅអាំម៉ូន

**២៥** ១ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា ២កូន
មនុស្សអើយ ចូរដំរង់មុខឯងទៅខាង[ក]ពួកកូនចៅអាំម៉ូន[ខ]

ឍ អស ២០:៣ អក ១២:១១ **២៤:២៥** ណ បទ ២:៤ ត ទដ ២០:៤ ថ ចទ ២៨:៣២ យរ ១១:២២ **២៤:២៦** ទ ១សយ ៤:១២ យប ១:១៥–១៩ **២៤:២៧** ធ ដយ ១០:១៥ ន អក ៣:២៦ ៣៣:២២ **២៥:២** ក អក ១៣:១៧ ២៩:២ ខ អក ២១:២៨

ពីការខ្មាស់អៀន (មីក ៣:៧) ។ *ស៊ីអាហារអ្នកកាន់ទុក្ខ* អាហារសម្រាប់ពេលគេបញ្ចុះសព (មើល យរ ១៦:៧ និងការពន្យល់) ។

**២៤:១៨** *ហើយដល់ល្ងាចប្រពន្ធខ្ញុំស្លាប់ទៅ* នាងបានស្លាប់ចំពេលដែលព្រះវិហារត្រូវបានដុតបំផ្លាញ (នៅទី១៤ ខែសីហា ឆ្នាំ៥៨៦ គ.ស មើលក្នុង ខ.២៥–២៧ ២ពវ ២៥:៨ និងការពន្យល់ ហើយមើលផងដែរចំពោះសេចក្ដីផ្ដើម ពេលវេលា គោលបំណង និងសេចក្ដីសង្ខេបនៃមាតិការ)។

**២៤:១៩** *បណ្ដាជនទាំងប៉ុន្មានក៏សួរខ្ញុំថា* ជាលើកទី៣ បណ្ដាជនបានឆ្លើយតបចំពោះឥរិយាបទរបស់លោកអេសេគាល (មើល ១២:៩ ២១:៧ និងការពន្យល់) ។

**២៤:២១** *បង្អាប់ទីបរិសុទ្ធ* ដោយអនុញ្ញាតឱ្យស្ដេចនេបូក្នេសាដុតបំផ្លាញចោល ។

**២៤:២៤** *អេសេគាល* ព្រះមានបន្ទូលពីលោកអេសេគាល នៅក្នុងលក្ខណៈមនុស្សទី៣នៅកន្លែងមួយ អំពីឈ្មោះហោរ៉ា មានតែនៅក្នុងជំពូក១:៣ (មើលការពន្យល់នៅទីនោះ) ទីសំគាល់ មើល ខ.២៧ និងការពន្យល់នៅក្នុងជំពូក ១២:៦ )។

**២៤:២៦** *ដែលរត់រួចបាន* ការចាប់ជាឈ្លើយលើកដំបូងនៅឆ្នាំ ៥៨៦ មុន គ.ស ។ ការចាប់ផ្ដើម ការឡោមព័ទ្ធ (កើតមានឡើងនៅ ក្នុង ខ.១–២ ) ហើយនិងទីបញ្ចប់ (មើលការពន្យល់ក្នុងជំពូក ៣៣:២១) ។

**២៤:២៧** *នៅថ្ងៃនោះ* នៅពេលអ្នកដែលរត់រួច បានមកដល់ទីក្រុងយេរូសាឡិម (មើល ៣៣:២១ និងការពន្យល់) ។ *នោះពួកគេមិននៅស្ងៀមទៀតទេ* តែអ្នកនោះធ្វើគ ឱ្យនៅស្ងៀម តាំងពីការចាប់ផ្ដើមចំពោះព័ន្ធកិច្ចរបស់គាត់ (មើល ៣:២៦ និងការពន្យល់)។

**២៥:១–៣២:៣២** សេចក្ដីទំនាយទាស់ប្រឆាំងនឹងប្រជាជាតិ ជាទូទៅចំពោះសេចក្ដីទំនាយនៃព្រះបន្ទូលព្រះ ពីការជំនុំជម្រះទៅលើពួកអ៊ីស្រាអែល នោះកើតឡើងតាមសេចក្ដីទំនាយដែលបានទាយទុក ស្ដីពីការជំនុំជម្រះលើជនជាតិ នោះ(មើលការពន្យល់ យរ ៤៦:១–៥១:៦៤) ។ ការនេះបញ្ជាក់យ៉ាងច្បាស់ថា នៅថ្ងៃជំនុំជម្រះនឹងចាប់ផ្ដើមចេញពី "គ្រួសារព្រះ" (១ពត ៤:១៧) ប្រជាជាតិនេះ គេមិនអាចរត់រួចពីសេចក្ដីក្រោធរបស់ព្រះបានទេ ហើយការ ជំនុំជម្រះនេះជាសារមួយ អំពីសេចក្ដីសង្គ្រោះរបស់ព្រះ ចំពោះអ៊ីស្រាអែល (មើល ២៨:២៥–២៦ និងការពន្យល់)។ ភាពជោគជ័យរបស់ព្រះលើពួកខ្មាំងសត្រូវ បានបំផ្លាញខ្មាំងសត្រូវនៃរាស្ត្រទ្រង់ ឬទ្រង់ដាក់ទណ្ឌកម្មលើពួកសាសន៍ ដែលប្រព្រឹត្តយ៉ាងឃោរឃៅទៅលើរាស្ត្ររបស់ទ្រង់ ។ នៅក្នុងព្រះគម្ពីរអេសេគាល មានសេចក្ដីទំនាយ៧យ៉ាង (ទាំង៧នោះ គឺជា៧ផ្នែក) ដែលផ្នែកនិមួយៗ ចាប់ផ្ដើមដោយមានប្រយោគឃ្លាដូចជា "ព្រះបន្ទូលព្រះបានមកដល់ខ្ញុំ" មើលសេចក្ដីផ្ដើម គម្រោងមេរៀន) សេចក្ដីបង្រៀននៃ សេចក្ដីទំនាយនេះ ដូចជា "ដោយសារដែលគេបានប្រព្រឹត្តអំពើបាប "នោះ" នាំឱ្យមានការជំនុំជម្រះ" "ដោយដឹងថាអញគឺជាព្រះអម្ចាស់"(ឧទា. មើល ២៥:៣–៧) ។

**២៥:២** *ចូរតំរង់មុខ* មើលការពន្យល់ ២០:៤៦ *ពួកកូនចៅអាំម៉ូន* អាំម៉ូន (ជាផ្នែកមួយនៃពូជអំបូរយូដាសម័យថ្មី) ដែលឥឡូវនេះគេរស់នៅប៉ែកខាងកើតនៃអ៊ីស្រាអែល (មើល ២១:២០ និងការពន្យល់ ហើយមើលផងដែរ យរ ៩:២៦ ៤៩:១ អម ១:១៣–១៥ សផ ២:៨–១១) ។ ចំពោះសកម្មភាពខ្មាំង

ទាយពីដំណើរគេចុះ[គ] ៣ហើយប្រាប់ដល់ពួកកូនចៅអាំម៉ូន
ថា ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ាចុះព្រះអម្ចាស់
យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ ដោយព្រោះឯងបានថា
ហាស់ហា[ឃ] ទាស់នឹងទីបរិសុទ្ធរបស់អញ ក្នុងកាលដែល
ត្រូវបង្អាប់[ង]នោះ ហើយទាស់នឹងស្រុកអ៊ីស្រាអែលក្នុងកាល
ដែលត្រូវចោលស្ងាត់ ព្រមទាំងទាស់នឹងពួកវង្សយូដា ក្នុង
កាលដែលគេត្រូវដឹកនាំទៅជាឈ្លើយផង[ច] ៤ហេតុនោះ
មើល អញនឹងប្រគល់ឯងដល់ពួកកូនចៅស្រុកខាងកើត[ឆ]
ទុកជាកេរ្តិ៍អាករ គេនឹងតាំងបន្ទាយ[ជ] ហើយធ្វើទីលំនៅ
របស់គេនៅក្នុងឯង គេនឹងស៊ីផល ហើយផឹកទឹកដោះសត្វ
របស់ឯង[ឈ] ៥អញនឹងធ្វើឱ្យក្រុងរ៉ាបាត[ញ]ទៅជាក្រោល
សំរាប់សត្វអូដ្ឋ ហើយឱ្យស្រុកពួកកូនចៅអាំម៉ូនទៅជាទី
សំរាប់ឱ្យហ្វូងចៀមដេកនៅ[ដ] នោះឯងរាល់គ្នា នឹងដឹងថា
អញនេះជាព្រះយេហូវ៉ាពិត ៦ដ្បិតព្រះអម្ចាស់យេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា ដោយព្រោះឯងបានទះដៃ[ឋ] ហើយ
តន្រ្តំជើង ព្រមទាំងមានសេចក្តីរីករាយ ដោយគ្រប់ទាំង
សេចក្តីមើលងាយនៅក្នុងចិត្តឯង ចំពោះស្រុកអ៊ីស្រាអែល[ឌ]
៧ហេតុនោះមើល អញបានលូកដៃ[ឍ]ទៅលើឯងហើយ អញ
នឹងប្រគល់ឯងចេញ[ណ]ពីពួកសាសន៍ទាំងប៉ុន្មាន ហើយឱ្យឯង
វិនាសបាត់ពីអស់ទាំងប្រទេសទៅ អញនឹងបំផ្លាញ[ត]ឯងបង់
នោះឯងនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ថ] ។

**២៥:២** គ យរ ៤៩:១–៦
**២៥:៣** ឃ ទដ ៣៥:២១ អគ ២៦:២ ៣៦:២ ង សផ ២:៨ ច សភ ១៧:៥
**២៥:៤** ឆ លប ២៥:៦ ពច ៦:៣ ជ ជន ៣១:១០ ឈ ចទ ២៨:៣៣, ៥១ ពច ៦:៣៣
**២៥:៥** ញ ចទ ៣:១១ ដ អស ១៧:២
**២៥:៦** ឋ ជន ២៤:១០ ឌ អគ ៦:១១ អប ១:១២ សផ ២:៨
**២៥:៧** ឍ សផ ១:៤ ណ ជន ១៤:៣ ត អគ ២១:៣១ ថ ខ.១៣–១៤,១៧ អម ១:១៤–១៥
**២៥:៨** ទ លប ១៩:៣៧ ចទ ២៣:៦ អស ១៦:៦ ធ លប ១៤:៦

## សេចក្តីទំនាយទាស់នឹងពួកម៉ូអាប់

៨ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលថា ដោយព្រោះ
ស្រុកម៉ូអាប់[ទ] និងស្រុកសៀរ[ធ]ពោលថា មើល ពួកវង្សយូដា
គេក៏ដូចជាអស់ទាំងសាសន៍ដែរ ៩ហេតុនោះ មើល អញ
នឹងបើកស្រុកម៉ូអាប់ ឱ្យចំហខាងទីក្រុងទាំងប៉ុន្មានរបស់
គេ ដែលនៅក្បែរព្រំដែនគេ ជាទីរុងរឿងឧត្តមរបស់ស្រុក
នោះ គឺក្រុងបេត–យេស៊ីម៉ូត[ន] ក្រុងបាល–មេយ៉ូន[ប] និងក្រុង
គារយ៉ាថែម[ផ] ១០ដលក់ពួកកូនចៅនៅស្រុកខាងកើត ដើម្បី
ឱ្យគេបានទៅទាស់នឹងពួកកូនចៅអាំម៉ូន ហើយអញនឹងឱ្យ
ស្រុកនោះដល់គេ ទុកជាកេរ្តិ៍អាករ ដើម្បីនឹងបំបាត់សេចក្តី
នឹកចាំ[ព]ពីពួកកូនចៅអាំម៉ូន ពីកណ្តាលអស់ទាំងសាសន៍ទៅ
១១អញនឹងសំរេចតាមសេចក្តីយុត្តិធម៌ ដល់សាសន៍ម៉ូអាប់
នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ភ] ។

## សេចក្តីទំនាយទាស់នឹងពួកអេដំម

១២ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលថា ដោយព្រោះ
ពួកសាសន៍អេដំម[ម]បានប្រព្រឹត្តទាស់នឹងពួកវង្សយូដា ដោយ
ការសងសឹក ហើយមានទោសយ៉ាងធ្ងន់ ដោយការសងសឹក
តបនឹងគេដូច្នេះ ១៣ហេតុនោះ ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន

**២៥:៩** ន ជន ៣៣:៤៩ ប ជន ៣២:៣ ផ ជន ៣២:៣៧ យស ១៣:១៩ **២៥:១០** ព អគ ២១:៣២ **២៥:១១** ភ អស ១៥:៩ ១៦:១–១៤ យរ ៤៨:១ អម ២:១–៣ **២៥:១២** ម២សយ ៨:១៣–១៤ ២របា ២៨:១៧ អស ១១:១៤

សត្រូវពួកកូនចៅអាំម៉ូននៅក្នុងកំឡុងពេលនេះ និងពេលក្រោយទៀត សូមមើល ២ពរ ២៤:២ នហ ៤:៧) ។

**២៥:៣** *ហាស់ហា* ជាការសើចចំអកឱ្យ (ផ្ទៀបនឹង ២៦:២ ៣៦:២ ទដ ៣៥:២១–២៥) ។

**២៥:៤** *ពួកកូនចៅស្រុកខាងកើត* ប្រហែលជាពូជអំបូរ ដែលរស់នៅ វាល–រហោស្ថាន ស្រុកខាងកើតនៃពួកអាំម៉ូន ត្រង់ចំណុចនេះអាចសំដៅទៅលើស្តេចនៃប៊ូក្នេសា និងទាហានរបស់ទ្រង់ (មើល ២១:៣១) ។

**២៥:៥** *ក្រុងរ៉ាបាត* មើលការពន្យល់ ២១:២០ ។ *ក្រោល ... ដេកនៅ* ការពិពណ៌នាជាសាមញ្ញនៅសញ្ញាចាស់ អំពីការដែលគេបានបំផ្លាញទីក្រុង (មើល អស ៣៤:១៣–១៥ សផ ២:១៣–១៥)។ គេវិលត្រឡប់បែរទៅរកឯជីវិតចាស់ មុនពេលដែលទីក្រុងបានសាងសង់ឡើង ជាសេចក្តីវិនាសអន្តរាយ សម្រាប់ជីវិតរបស់គេ ។

**២៥:៦** *ឯងបានទះដៃ* មើល ៦:១១ និងការបន្យល់ ។

**២៥:៧** *អញបានលូកដៃទៅលើឯងហើយ* មើលការពន្យល់ ៦:១៤ ។ *អញនឹងប្រគល់ឯងទៅជារបឹបដល់សាសន៍ដទៃ* ផ្ទៀបនឹង ២៦:៥ ៣៤:២៨ ។ *អញនឹងកាត់ឯងចេញ* ផ្ទៀបនឹង ខ.១៦ ។

**២៥:៨** *ស្រុកម៉ូអាប់* ស្រុកនេះស្ថិតនៅប៉ែកខាងត្បូងនៃពួកអាំម៉ូន ខាងកើតនៃសមុទ្រស្លាប់ (មើល លប ១៩:៣៦–៣៨ និងការពន្យល់ អស ១៥–១៦ យរ ៤៨ អម ២:១–៣ សផ ២:៨–១១) ។ *ស្រុកសៀរ* ស្រុកអេដំម ជាស្រុកមួយស្ថិតនៅប៉ែកខាងត្បូងនៃស្រុកម៉ូអាប់ ហើយស្ថិតនៅប៉ែកខាងត្បូងនៃសមុទ្រស្លាប់ (មើលជំពូក ៣៥ ជាពិសេស ខ.១៥ ៣៦:៥ អស ៣៤:៥–១៧ ៦៣:១–៦ យរ ៤៩:៧–១១ អម ១:១១–១២) ។ *ដូចជាអស់ទាំងសាសន៍ដែរ* ពួកអ៊ីស្រាអែលចង់ធ្វើដូចជាសាសន៍ដ៏ទៃ (មើល ២០:៣២ និងការពន្យល់) នៅពេលដែលពួកសាសន៍ដទៃឃើញពួកយូដា ដែលគេកំពុងតែមានសេចក្តីរងគ្រោះ នោះពួកគេមានសេចក្តីភ័យខ្លាច ហើយគេក៏បរាជ័យនៅក្នុងការគោរពប្រតិបត្តិដល់ព្រះផងដែរ (ផ្ទៀបនឹង បទ ៤:១២) ។

**២៥:៩** *ស្រុកម៉ូអាប់* ជាដីខ្ពង់រាប មកពីខាងសមុទ្រស្លាប់ ដែលអាចមើលឃើញពីខាងក្រុងយេរូសាឡិមទៅ ។ *ក្រុងបេត–យេស៊ីម៉ូត* ជាស្រុកដែលនៅខាងក្នុងតំបន់ខ្ពង់រាបនៃស្រុកម៉ូអាប់ ។ *ក្រុងបាល–មេយ៉ូន* ជាក្រុងរបស់ពួកម៉ូអាប់ដ៏ធំ ដែលបានចារិកលើជញ្ជាំងវិមានរបស់មេសា ស្តេចម៉ូអាប់។ *ក្រុងគាយ៉ាថែម* ជាទីក្រុងមួយផងដែរ ដែលបានចរិកលើជញ្ជាំងវិមានរបស់មេសា ។ (ផ្ទៀបនឹង ២ពរ ៣:៤–៥ និងការពន្យល់ ២ពរ ១:១) ។

**២៥:១២** *ពួកសាសន៍អេដំម* មើលការពន្យល់ ខ.៨ (ស្រុកសៀរ) ។ *ការសងសឹក* មិនត្រូវធ្វើការសងសឹកទៅលើជនភាសខ្លួននៃសាសន៍យូដា ក្រោយឆ្នាំ៥៨៦ មុន គ.ស (មើល អប ខ.១១–១៤ និងការពន្យល់) ។

**២៥:១៣** *ស្រុកថេម៉ាន* ជាស្រុកមួយនៅជិតពេត្រា នៅចំកណ្តាលនៃស្រុកអេដំម (មើល យរ ៤៩:៧ ២០ អម ១:១២ អប ខ.៩ ហប និងការពន្យល់)។ *ដេដាន់* ជាទឹកដីរបស់ពួកកុលសម្ពន្ធ័ស្ថិតនៅប៉ែកខាងត្បូងនៃស្រុកអេដំម

បន្ទូលដូច្នេះថា អញនឹងលូកដៃ[យ]ទៅលើ ស្រុកអេដំមដែរ
ក៏នឹងកាត់ទាំងមនុស្សនិងសត្វចេញទៅផង[រ] ហើយនឹងធ្វើឱ្យ
ស្រុកនោះស្ងាត់ច្រៀប ចាប់តាំងពីក្រុងថេម៉ាន[ល] ទៅដល់
ដេដាន់[វ] គេនឹងដួលស្លាប់ដោយដាវ[ស] ១៤អញនឹងផ្តល់ការ
សងសឹករបស់អញ ទៅលើសាសន៍អេដំម ដោយសារដៃ
នៃអ៊ីស្រាអែល ជារាស្ត្រដែលនឹងធ្វើដល់សាសន៍អេដំម
តាមសេចក្តីកំហឹង[ហ] និងសេចក្តីក្រេវក្រោធរបស់អញ នោះ
គេនឹងស្គាល់សេចក្តីសងសឹករបស់អញ នេះជាព្រះបន្ទូលនៃ
ព្រះអម្ចាស់យេហូវ៉ា[ឡ]។

## សេចក្តីទំនាយទាស់នឹងពួកភីលីស្ទីន

១៥ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូល ដោយព្រោះ
សាសន៍ភីលីស្ទីន[អ]បានប្រព្រឹត្តដោយការសងសឹក គឺបានសង
សឹកតប ដោយសេចក្តីមើលងាយ[ក]នៅក្នុងចិត្តគេ ដើម្បីនឹង
បំផ្លាញ ដោយចងគំនុំជាប់តមកជានិច្ច[ខ] ១៦ហេតុនោះ
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មើល អញនឹង
លូកដៃទៅលើសាសន៍ភីលីស្ទីន[គ] អញនឹងកាត់ពួកកេរេធីម
ចេញ[ឃ] ព្រមទាំងបំផ្លាញសំណល់មនុស្ស ដែលនៅសល់តាម
ឆ្នេរសមុទ្រផង[ង] ១៧អញនឹងសំរេចការសងសឹក[ច] យ៉ាងធំ
ដល់គេ ដោយសេចក្តីផ្ទាញ់ផ្ទាល[ឆ]ដ៏ក្តៅក្រហាយ នោះគេ
នឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុងកាលដែលអញ
ទំលាក់សេចក្តីសងសឹកទៅលើគេ[ជ,ឈ]។

## សេចក្តីទំនាយទាស់នឹងពួកក្រុងទីរ៉ុស

**២៦** ១លុះដល់ថ្ងៃដើមខែនោះ ក្នុងឆ្នាំទី១១ នោះ
ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់ខ្ញុំថា[ក] ២កូនមនុស្ស
អើយ ដោយព្រោះក្រុងទីរ៉ុស[ខ] បានពោលទាស់នឹងក្រុង
យេរូសាឡិមថា ហាស់ហា[គ] ទីក្រុងដែលជាទ្វារនៃទាំង
សាសន៍ត្រូវបាក់បែក វាបានវិលមកឯអញហើយ ឥឡូវ

**២៥:១៣** យ នក ៧:៥ អគ ១៦:២៧ រ អគ ២៩:៨ ល លប ៣៦:១១,១៥,៣៤ វ យរ ៤៩:១០ អគ ១៤:១៧ **២៥:១៤** ស អគ ៣៥:១១ ហ ទដ ១៣៧:៧ អគ ៣២:២៩ ៣៥:២–៣ ៣៦:៥ អម ១:១១ អប ១:១,១០–១៦ មឡ ១:៤ **២៥:១៥** ឡ យស ១៣:៣ ២របា ២៨:១៨ អ ទដ ៧៣:៨ **២៥:១៦** ក ២របា ២៦:៦ អម ១:៨ ខ ១សយ ៣០:១៤ គ អគ ២០:៣៣ **២៥:១៧** ឃ ជន ៣១:៣ ង យរ ៤៤:១៣ ច នក ៦:២ ៨:២២ ឆ អស ១១:១៤ ជ អស ១៤:៣០ យរ ៤៧:៧ យអ ៣:៤ **២៦:១** ក អគ ២៤:១ ២៩:១ ៣០:២០ **២៦:២** ខ យស ១៩:២៩ ២សយ ៥:១១ គ អគ ២៥:៣

(មើល ២៧:២០ ៣៨:១៣ អស ២១:១៣ និងការពន្យល់ យរ ៤៩:៨)។

**២៥:១៥** *ភីលីស្ទីន* ជាស្រុកមួយនៃតំបន់ខ្ពង់រាប ដែលនៅជាប់ឆ្នេរសមុទ្រមេឌីទែរ៉ាណេ ស្ថិតនៅប៉ែកខាងលិចនៃស្រុកយូដា (មើល អស ៦:១៧ មើលការពន្យល់ លប ១០:១៤) វាបានគ្រប់គ្រងដោយពួកកាណាន រហូតដល់ពេលដែលស្តេចដាវីឌបានដណ្តើមយកជ័យជម្នះបាន ។ ចម្បាំងរបស់គេជាមួយអ៊ីស្រាអែលបានបន្តរហូតដល់ស្តេចនេប៊ូក្នេសា ចាប់ពួកគេទៅជាឈ្លើយ (មើល អស ១៤:២៩–៣១ យរ ៤៧ អម ១:៦–៨ សផ ២:៤–៧)។

**២៥:១៦** *ពួកកេរេធីម* ពួកនេះបានជាប់ទាក់ទងទៅនឹងពួកសាសន៍ភីលីស្ទីន (មើល អស ៣០:១៤ និងការពន្យល់ ២សយ ៨:១៨ ១៥:១៨ ២០:៧)។ *ឆ្នេរសមុទ្រ* ជាឆ្នេរសមុទ្រមេឌីទែរ៉ាណេ ។

**២៦:១–២៨:១៩** សេចក្តីទំនាយទាស់និងក្រុងទីរ៉ុសជាបន្តបន្ទាប់ វាគឺជាកំពង់ផែសមុទ្ររបស់ស្រុកភេនីស (នៅថ្ងៃបច្ចុប្បន្នហៅថាព្រៃល្បាណូន) ទីក្រុងទីរ៉ុសគឺជាដីកោះហើយក៏ជាប៉មបន្ទាយកងទ័ពដែលជាទីកន្លែងកោះដ៏សំខាន់ស្ថិតនៅលើទ្វីប ។ បន្ទាប់ពីការទទួលជ័យជម្នះរបស់ស្តេចនេប៊ូក្នេសានៅឯស្រុកកើកេមីសក្នុងឆ្នាំ៦០៥មុន គ.ស មក វាទីក្រុងមានអនុភាពដ៏ខ្ពង់ខ្ពស់ដែលត្រូវបានទទួលស្គាល់ក្នុងការគ្រងរាជ្យរបស់ស្តេចបាប៊ីឡូន ។ ប៉ុន្តែនៅក្នុងឆ្នាំ ៥៩៤ មុន គ.ស វាជាទីក្រុងដែលបានចងសម្ព័ន្ធភាពជាមួយរដ្ឋផ្សេងៗ ដកខ្លួនចេញ ពីនឹមត្រួតត្រារបស់ស្រុកបាប៊ីឡូន (យរ ២៧:៣ ៤៧:២)។ប្រវត្តិសាស្ត្រនៃពួកព្យុំកោបានទំនាក់ទំនងជាមួយស្តេចនេប៊ូក្នេសាដើម្បីដាក់ការឡោមព័ទ្ធទៅលើទីក្រុងទីរ៉ុសអស់រយៈពេល ១៥ឆ្នាំ (ធៀបនឹង ២៩:១៨ និងការពន្យល់) ។ ហើយការឡោមព័ទ្ធនោះនិងបានទទួលជ័យជម្នះ បន្ទាប់មកក៏បានតាំងស្តេចនោះឱ្យមានអំណាចនិងគ្រងរាជ្យលើទីក្រុងតែម្តង ។ ប៉ុន្តែ ទ្រង់មិនទទួលបានជ័យជម្នះក្នុងការបំផ្លាញទីក្រុងនោះឡើយ ។ ប៉មបន្ទាយនៃកោះនោះមិនបានលុកលុយ ឬរាតត្បាតទេរហូតមកដល់រាជ្យស្តេចអាឡិចសាន់ឌើរ ដែលទ្រង់បានដាក់ការឡោមព័ទ្ធមកលើទីក្រុងទីរ៉ុស ហើយបានសោយរាជ្យអស់រយៈពេល៧ខែនៅក្នុងឆ្នាំ ៣៣២ មុន គ.ស ។

**២៦:១** *លុះដល់ថ្ងៃដើមខែនោះ ក្នុងឆ្នាំទី ១១* គឺជាថ្ងៃទី ១៥ នៅក្នុងព្រះគម្ពីរ (សូមមើល ១:២ ៨:១ ២០:១ ២៤:១) ។ ដែលជាចំនួនខែនៃការខកខាន ។ ឆ្នាំដ៏ពេញលេញ គឺចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ ៥៨៧ មុន គ.ស ទៅដល់ថ្ងៃទី ១៣ ខែមេសា ឆ្នាំ ៥៨៦ មុន គ.ស ។ ដែលត្រូវជាថ្ងៃ បរិច្ឆេទនៃការឆ្នាំនៅសេចក្តីទំនាយនៅក្នុងឆ្នាំ ទី១១ ថ្ងៃទី ១៣ ខែគុម្ភៈ ឆ្នាំ ៥៨៦ មុន គ.ស ឬ នៅក្នុងឆ្នាំ ទី១២ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ៥៨៦ មុន គ.ស) ប៉ុន្តែមានបញ្ហាជាមួយកាលបរិច្ឆេទទាំងឡាយនោះ ។ នេះគឺជាសេចក្តីទំនាយរៀបរាប់របស់ទីក្រុងទីរ៉ុសដែលជាទីពេញចិត្តនៃការវិនាសមកលើក្រុងយេរូសាឡិម (ខ.២) ប៉ុន្តែក្រុងយេរូសាឡិមមិនបានរលំឡើយ រហូតដល់ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ៥៨៦ មុន គ.ស (សូមមើលការពន្យល់ ២ពវ ២៥:២–៣) ។ ហើយនិងមិនដែលធ្លាប់មានការឆេះបំផ្លាញដែររហូតដល់ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ៥៨៦ មុន គ.ស (សូមមើលការពន្យល់ ២ពវ ២៥:៨) ។ ពីរបីខែក្រោយមកពួកដែលនៅទីក្រុងទីរ៉ុសបានកំណត់កាលបរិច្ឆេទសម្រាប់ពិធីបុណ្យអបអរសាទរពីទីក្រុងយេរូសាឡិម ដែលប្រឈមមុខនិងការបំផ្លាញ "នៅសម័យនោះ បានដួលរលំនិងវិនាស" (ខ. ២) ។ ដើម្បីដោះស្រាយបញ្ហាជាច្រើននៅក្នុងការបកប្រែដោយមានជំនឿថា ការអាននៅក្នុងអត្ថបទដើមនៃព្រះគម្ពីរភាសារគឺជា "នៅក្នុងខែទី ១១ នៃឆ្នាំទី ១២ ត្រូវជាថ្ងៃទី១" ហើយដែលពាក្យថា" ខែទី ១២" គឺជាពាក្យប្រមាថដែលអ្នកចម្លងបានលុបចោល ។

**២៦:២** *ក្រុងទីរ៉ុស* ដ្បិតមានទំនាយជាច្រើនដែលទាយជំទាស់នឹងក្រុងទីរ៉ុស សូមមើល អស ២៣ យរ ២៥:២២ ៤៧:៤ យអ ៣:៤–៥ អម ១:៩–១០ សផ ៩:២–៤) ។ *ហាស់ហា* សូមមើលការពន្យល់នៅក្នុង ២៥:៣ ។ *ជាទ្វារនៃអស់ទាំងសាសន៍* ពីព្រោះវាគឺជាទីកន្លែងភូមិសាស្ត្រដ៏ល្អ ដែលជាទីកន្លែងនយោបាយដ៏សំខាន់ និងជាមជ្ឈមណ្ឌលច្បាប់ ហើយវាក៏ជាកន្លែងលេងកំសាន្ត និងជាកន្លែងពាណិជ្ជកម្មអន្តរជាតិផងដែរ (សូមមើល យរ ២៧) ។

នេះអញនឹងបានពោរពេញឡើង ដោយវាខូចបង់ ៣ហេតុ
នោះព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ម្នាល
ទីរ៉ុសអើយ អញទាស់នឹងឯង អញនឹងបណ្តាលឱ្យសាសន៍
ជាច្រើនឡើងមកទាស់នឹងឯង ដូចជាសមុទ្រ[ឃ]កំរើករលក
ឡើងដែរ ៤គេនឹងបំផ្លាញ[ង]កំផែងនៃក្រុងទីរ៉ុស[ច] ហើយនឹង
រំលំប៉មទាំងប៉ុន្មានផង អញនឹងគាស់យកទាំងធូលីដីចេញ
ទៅឱ្យទីក្រុងនោះនៅជាថ្មដារលីង ៥នោះនឹងបានជាកន្លែង
សំរាប់ហាលអួន[ឆ] នៅកណ្តាលសមុទ្រ[ជ] ដ្បិតអញបានចេញ
វាចាហើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ដូច្នេះ
ទីក្រុងនោះនឹងត្រឡប់ជារបឹប[ឈ]ដល់អស់ទាំងសាសន៍[ញ] ៦ឯ
កូនស្រីទាំងប៉ុន្មានរបស់វា ដែលនៅឯចំការ នឹងត្រូវស្លាប់
ដោយដាវ នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត។
៧ដ្បិត ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា
មើល អញនឹងនាំនេប៊ូក្នេសា[ដ] ស្តេចស្រុកបាប៊ីឡូន ជា
ស្តេចលើអស់ទាំងស្តេច[ឋ] មកពីទិសខាងជើង មានទាំងសេះ
រទេះចំបាំង[ឌ] ពលសេះ កងទ័ព និងមនុស្សសន្ធឹកផង ឱ្យ
ទាស់នឹងក្រុងទីរ៉ុស ៨វានឹងសំឡាប់កូនស្រីឯងទាំងប៉ុន្មាន
ដោយដាវនៅឯចំការ វានឹងធ្វើបន្ទាយ[ឍ] ហើយជីកស្នាម
ភ្លោះ[ណ] ព្រមទាំងលើកខែលទាស់នឹងឯង ៩វានឹងតាំងគ្រឿង
បុកទំលាយកំផែង ហើយនឹងរំលំប៉មរបស់ឯង ដោយ
ប្រដាប់របស់វា[ត] ១០សេះយ៉ាងសន្ធឹករបស់គេនឹងធ្វើឱ្យធូលី
ហុយឡើងគ្របលើឯង កំផែងរបស់ឯងនឹងញ័រ ដោយសូរ
សន្ធឹកនៃពលសេះរទេះ[ថ] និងយន្តចំបាំងទាំងប៉ុន្មានរបស់
គេ ក្នុងកាលដែលគេចូលទៅតាមទ្វារក្រុងរបស់ឯង ដូច
ជាចូលទៅក្នុងទីក្រុងណា ដែលគេបានរំលំកំផែងហើយ
១១អស់ទាំងផ្លូវរបស់ឯងនឹងត្រូវប៉ន់ទៅ ដោយក្រចកសេះ[ទ]
របស់គេ គេនឹងសំឡាប់ជនជាតិឯងដោយដាវ ឯអស់ទាំង
បង្គោលថ្ម[ធ]នៃកំឡាំងឯង និងត្រូវរំលំដល់ដី[ន] ១២គេនឹង
រឹបជាន់យកទ្រព្យសម្បត្តិរបស់ឯង ហើយដណ្តើមយកទំនិញ
ទាំងប៉ុន្មានផង គេនឹងបំបែករំលំកំផែង ហើយបំផ្លាញអស់
ទាំងផ្ទះ ជាទីរីករាយរបស់ឯង គេនឹងចាក់អស់ទាំងថ្ម និង
ឈើ ហើយធូលីដីរបស់ឯងទៅក្នុងទឹក[ប] ១៣អញនឹងធ្វើឱ្យ
បាត់[ផ]ឮសូរចំរៀងរបស់ឯង[ព] ហើយនឹងឥតមានឮសូរស៊ុង[ភ]
នៅក្នុងឯងទៀតឡើយ[ម] ១៤អញនឹងធ្វើឱ្យឯងទៅជាថ្មដា
រលីង ឯងនឹងបានជាកន្លែងសំរាប់ហាលអួន និងគ្មានអ្នក
ណាសង់ឡើងវិញ[យ] នៅជាដរាបតទៅ ដ្បិតគឺអញនេះជា
ព្រះយេហូវ៉ា បានចេញវាចាហើយ នេះជាព្រះបន្ទូលនៃ
ព្រះអម្ចាស់យេហូវ៉ា ។
១៥ព្រះអង្គយេហូវ៉ា ទ្រង់មានបន្ទូល ដល់ក្រុងទីរ៉ុស
ដូច្នេះថា ពិតប្រាកដអស់ទាំងកោះ[រ]នឹងញ័ររន្ធត់[ល] ដោយ
ឮសូរឯងដួល និងដំងូរ[វ]នៃមនុស្សដែលត្រូវរបួស ក្នុងកាល
ដែលសំរេចការសំឡេះយ៉ាងធំនៅកណ្តាលឯង ១៦គ្រា
នោះអស់ទាំងសេដ្ឋីជើងសមុទ្រ និងចុះពីទីថ្កល់របស់ខ្លួន
ដោយដោះសំលៀកបំពាក់ចេញ ហើយផ្លាស់អាវប៉ាក់[ស]គេ
នឹងប្រដាប់ខ្លួន[ហ]ដោយសេចក្តីញ័រខ្លាច ហើយគេនឹងអង្គុយ

**២៦:៣** ឃ ឧ.១៩ អស ៥:៣០ យរ ៥០:៤២ ៥១:៤២ **២៦:៤** ង អស ២៣:១,១១ ច អម ១:១០ **២៦:៥** ឆ អគ ២៧:៣២ ជ អគ ៤៧:១០ ឈ ជន ១៤:៣ អគ ២៩:១៩ ញ សក ៩:២–៤ **២៦:៧** ដ យរ ២៧:៦ ៣៩:១ ឋ អរ ៧:១២ ឌ អគ ២៣:២៤ ណហ ២:៣–៤ **២៦:៨** ឍ យរ ៦:៦ ណ យរ ៣៣:៤ **២៦:៩** ត អគ ២១:២២ **២៦:១០** ថ យរ ៤:១៣ ៤៦:៩ អគ ២៣:២៤ **២៦:១១** ទ អស ៥:២៨ ធ យរ ៤៣:១៣ ន អស ២៦:៥ **២៦:១២** ប អស ២៣:៨ យរ ៤:៧ អគ ២៧:៣–២៧ ២៨:៨ ហប ១:៨ **២៦:១៣** ផ យរ ៧:៣៤ ព អស ២៣:៧ ភ ទដ ១៣៧:២ អស ១៤:១១ ម យប ៣០:៣១ យរ ១៦:៩ ២៥:១០ វវ១៨:២២ **២៦:១៤** យ យប ១២:១៤ មឡ ១:៤ **២៦:១៥** រ អស ៤១:៥ អគ ២៧:៣៥ ល យរ ៤៩:២១ វ យប ២៤:១២ **២៦:១៦** ស នក ២៦:៣៦ ហ យប ៨:២២

**២៦:៣** *អញទាស់នឹងឯង* សូមមើលការពន្យល់នៅក្នុង ៥:៨ ។ *ដូចជាសមុទ្រកំរើករលកផងដែរ* នៅត្រង់នេះមានន័យថា ពួកទាហានជាច្រើនបានវាយប្រហាររាតត្បាតមកលើទីក្រុងទីរ៉ុសដែលប្រៀបប្រដូចទៅ នឹងរលកសមុទ្រ ធៀបនឹង អស ១៧:១២–១៣ ។

**២៦:៥** *របឹបដល់អស់ទាំងសាសន៍* ធៀបនឹង ២៥:៧ ៣៤:២៨ ។

**២៦:៦** *អញនេះជាព្រះយេហូវ៉ាពិត* សូមមើលពាក្យណែនាំដែលជាគោលរឿង ។

**២៦:៧** *ទិសខាងជើង* ស្តេចនេប៊ូក្នេសាបានគ្រប់គ្រងទិសខាងជើងដោយព្រោះតែទ្រង់បានចុះទៅឯទីក្រុងទីរ៉ុស ក្រោយមកដំណាក់កាលដំបូងទាហានរបស់ទ្រង់បានធ្វើដំណើរឡើងទៅឯទន្លេអឺប្រាត ដែលហាក់បីដូចជាដើរឆ្លងកាត់ជ្រលងភ្នំ និងទីរហោស្ថានអារ៉ាប់ប៉ុដើម្បីច្បាំងយកទីក្រុងនោះ (ធៀបនឹង យរ ១:១៣) ។ *អញនឹងនាំ* នៅវគ្គនេះគឺចង់ចង្អុលបង្ហាញច្បាស់ពីអំណាចរបស់ទ្រង់នៅលើគ្រប់ទាំងសាសន៍ (ធៀបនឹង ២៨:៧ ២៩:៨) ។ *នេប៊ូក្នេសា* គឺ ១/៤ បានបញ្ជាក់ពីឈ្មោះរបស់ទ្រង់នៅក្នុងព្រះគម្ពីរអេសេគាល (សូមមើល ២៩:១៨–១៩ ៣០:១០) ។ ស្តេចនេប៊ូក្នេសា បានគ្រប់គ្រងពីឆ្នាំ ៦០៥ ទៅដល់ ឆ្នាំ ៥៦២ មុន គ.ស ហើយឈ្មោះរបស់គាត់មានន័យថា "សូមព្រះណាប៊ូការពារកូនប្រុសរបស់ខ្ញុំផង ឬសូមព្រះណាប៊ូការពារទឹកដីរបស់ខ្ញុំផង" ហោរាយេរេមា និងហោរាអេសេគាល ទាំងពីរអ្នកបានប្រកាសថា នេះគឺជាស្តេចដែលមិនមានជំនឿលើព្រះ ប៉ុន្តែទ្រង់បានប្រើព្រះនាមព្រះដើម្បីធ្វើការងាររបស់ទ្រង់ (សូមមើល យរ ២៥:៩ និងការពន្យល់ ២៧:៦) ។

**២៦:៨** *បន្ទាយ* សូមមើលការពន្យល់នៅក្នុង ២៦:១–២៨:១៩ ។

**២៦:១៤** *គ្មានអ្នកណាសង់ឡើងវិញ* តាមរឿងដែលបានកើតឡើងគឺបន្ទាយនោះបានត្រូវបំផ្លាញដោយសារអធិរាជអាឡិចសាន់ឌើរ នៅក្នុងឆ្នាំ ៣៣២ មុន គ.ស (សូមមើលការពន្យល់នៅក្នុង អស ២៣:១) ។

**២៦:១៦** *អស់ទាំងសេដ្ឋីជើងសមុទ្រ* បានហៅស្តេចជាច្រើន មើលនៅក្នុង ២៧:៣៥ ពួកស្តេចទាំងអស់នោះប្រហែលជាដៃគូរធ្វើជំនួញជាមួយនិងទីក្រុងទីរ៉ុស ។ *ដោះសំលៀកបំពាក់ចេញ* តាមធម្មតាពួកគេបានហែកសំលៀកបំពាក់ដើម្បីកាន់ទុក្ខ (យប ២:១២) ព្រមទាំងស្លៀកសំពត់ធ្មៃ សូមមើលការប្រៀបធៀបជាមួយស្តេចនៃទីក្រុងនីនីវេ (យហ ៣:១៦) ។ *ប្រដាប់ខ្លួនដោយសេចក្តីភ័យខ្លាច* ពីព្រោះនយោបាយគ្រប់គ្រងប្រទេសពេញដោយភាពតក់ស្លុត គឺប្រៀបបីដូចជាកំរើករលកសមុទ្របានបក់ធ្លាក់មកលើទីក្រុង

នៅដីវិញ[ឬ] ដោយញាប់ញ័រជានិច្ច[អ] ព្រមទាំងមានសេចក្តី
ស្រឡាំងកាំង[ក] ដោយព្រោះឯងផង ១៧គេនឹងផ្តើមទួញ
ទំនួញពីឯង ដោយពាក្យថា ម្តេចក៏ឯងត្រូវបំផ្លាញយ៉ាងនេះ
ហ្ន៎ ឯងដែលជាទីលំនៅរបស់ពួកអ្នកដើរផ្លូវសមុទ្រ ជា
ទីក្រុងមានល្បីល្បាញ ដែលមានអំណាចខាងផ្លូវសមុទ្រ គឺ
ទាំងឯង និងពួកអ្នកនៅក្នុងឯងផង ជាពួកអ្នកដែលធ្វើឱ្យ
សេចក្តីស្ញែងខ្លាចរបស់ខ្លួននៅទីនោះអើយ[ខ] ១៨ឥឡូវនេះ
អស់ទាំងកោះនឹងញាប់ញ័រ[គ] នៅថ្ងៃដែលឯងដួលនោះ
អើយ អស់ទាំងកោះនៅសមុទ្រនឹងស្លុតចិត្ត ដោយឯងផុត
ទៅ[ឃ] ។

១៩ដ្បិតព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា
កាលណាអញបានធ្វើឱ្យឯងទៅជាទីក្រុងស្ងាត់ច្រៀប ដូច
ជាទីក្រុងណាដែលឥតមានមនុស្សនៅ កាលណាអញបាន
នាំទីជំរៅ[ង]មកលើឯង ហើយមានទឹកធំមកគ្របលើឯង
ហើយ[ច] ២០នោះអញនឹងទំលាក់ឯង ទៅជាមួយនឹងពួកអ្នក
ដែលចុះទៅក្នុងជង្ហុកធំ[ឆ] ដល់ពួកមនុស្សពីបុរាណ ហើយ
នឹងឱ្យឯងនៅទីចំរៅបំផុតនៃផែនដី ជាកន្លែងស្ងាត់ជ្រងំពី
យូរមកហើយ គឺឱ្យនៅជាមួយនឹងពួកអ្នកដែលចុះទៅក្នុង
ជង្ហុកធំ ដើម្បីមិនឱ្យមានអ្នកណានៅក្នុងឯងទៀតឡើយ តែ
អញនឹងបំរុងទុកសិរីល្អ សំរាប់ស្ថានរបស់មនុស្សរស់វិញ[ជ]
២១អញនឹងតាំងឯងជាសេចក្តីស្ញែងខ្លាច ហើយឱ្យលែង
មានទៀត[ឈ] នោះទោះបើគេស្វែងរកឯងក៏ដោយ គង់តែ
មិនដែលប្រទះឃើញទៀតឡើយ នេះជាព្រះបន្ទូលនៃព្រះ
អម្ចាស់យេហូវ៉ា[ញ] ។

## សេចក្តីទំនួញពីក្រុងទីរ៉ុស

**២៧** ១ព្រះបន្ទូល នៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំម្តងទៀត
ថា ២ឯងឯង កូនមនុស្សអើយ ចូរផ្តើមទួញទំនួញ[ក]ពីក្រុងទីរ៉ុស
៣ត្រូវឱ្យប្រាប់ដល់ក្រុងទីរ៉ុសថា[ខ] ម្នាលឯងដែលនៅត្រង់
ទ្វារសមុទ្រ[គ] ជាអ្នកជំនួញសំរាប់ជនជាតិនៅកោះជាច្រើន
អើយ ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ទីរ៉ុស
អើយ ឯងបានពោលថា អញមានលំអគ្រប់លក្ខណ៍ហើយ[ឃ]
៤ព្រំដែនរបស់ឯងនៅកណ្តាលសមុទ្រ ពួកអ្នកដែលបាន
សង់ឯង គេបានធ្វើឱ្យឯងមានលំអពេញខ្នាតហើយ[ង] ៥អស់
ទាំងក្តារឯងសុទ្ធតែជាឈើកកោះពីស្រុកសេនារ[ច] គេបាន
យកដើមតាត្រៅពីព្រៃល្បាណូនមក[ឆ] ធ្វើជាដងក្តោងសំរាប់
ឯង ៦អស់ទាំងដងចែវរបស់ឯង បានធ្វើពីឈើម៉ៃសាក់[ជ]
ស្រុកបាសាន គេបានធ្វើដើងម៉ាឯង ពីឈើគ្រញូង ពីកោះ
គីទីម[ឈ] ប្រដាប់ភ្លុក ៧ស្លាបក្តោងឯងធ្វើពីសំពត់ខ្លូតទេស[ញ]
យ៉ាងម៉ដ្តចំរុះ ដោយប៉ាក់មកពីស្រុកអេស៊ីព្ទ ដើម្បីនឹងទុកជា
ទង់ជ័យដល់ឯង ហើយមានសំពត់ពណ៌ខៀវ និងពណ៌
ស្វាយ[ដ] ពីកោះអេលីសា ធ្វើជាពិតាន[ឋ] ៨ពួកអ្នកនៅក្រុង
ស៊ីដូន និងអើវ៉ាឌ[ឌ] ជាអ្នកចែវរបស់ឯង ឱ ទីរ៉ុសអើយ ពួក
អ្នកប្រាជ្ញនៅក្នុងឯង គេជាមេដំរង់សំពៅ[ឍ] ៩ពួកអ្នកចាស់ៗ
និងពួកអ្នកប្រាជ្ញពីក្រុងកេបា[ណ] ក៏នៅក្នុងឯង ទុកជាអ្នកពារ

**២៦:១៦** ឡ យប ២:៨,១៣ អ ហស ១១:១០ ក លវ ២៦:៣២ អគ ៣២:១០ **២៦:១៧** ខ អគ ១៩:១ គ អស ១៤:១២ ៣២:២៤,៣០ **២៦:១៨** ឃ ទដ ៤៦:៦ យរ ៤៩:២១ ង អស ២៣:៥ ៤១:៥ អគ ២៧:៣៥ **២៦:១៩** ច លប ៧:១១ ឆ ខ.៣ អស ៨:៧–៨ **២៦:២០** ជ ជន ១៦:៣០ ទដ ២៨:១ ៨៨:៦ អគ ៣១:១៤ ៣២:១៨ អម ៩:២ យហ ២:២,៦ ឈ យប ២៨:១៣ អស ១៤:៩–១០ អគ **២៦:២១** ញ យរ ៥១:៦៤ ដយ ១១:១៩ ដ យរ ២០:៤ អគ ២៧:៣៦ ២៨:១៩ វវ ១៨:២១

**២៧:២** ក អគ ១៩:១ **២៧:៣** ខ ទដ ៨៣:៧ គ ខ.៣៣ ហស ៩:១៣ ឃ អស ២៣:៩ អគ ១៦:១៥ **២៧:៤** ង អគ ២៨:១២ **២៧:៥** ច ចទ ៣:៩ ឆ អស ២:១៣ **២៧:៦** ជ ជន ២១:៣៣ ទដ ២៩:៩ យរ ២២:២០ សក ១១:១២ ឈ លប ១០:៤ អស ២៣:១២ **២៧:៧** ញ នក ២៦:៣៦ អស ១៩:៩ ដ នក ២៥:៤ យរ ១០:១៩ ឋ លប ១០:៤ **២៧:៨** ឌ លប ១០:១៨ ឍ ១ពវ ៩:២៧ **២៧:៩** ណ យស ១៣:៥

យ៉ាងខ្លាំង(ធៀបនឹង ៧:២៧ ទដ ៣៥:២៦ ១០៩:២៩ និងការពន្យល់) ។

**២៦:១៧** *ទួញទំនួញ* សូមមើលការពន្យល់នៅក្នុង ១៩:១ ។

**២៦:២០** *ជង្ហុកធំ* គឺជាផ្នូរខ្មោច"ទីជំរៅបំផុតនៃផែនដី"(សូមមើលការពន្យល់នៅក្នុងទដ ៣០:១) ។ *ពួកមនុស្សពីបុរាណ* មនុស្សបុរាណទាំងនោះបានស្លាប់អស់ជាយូរលុងមកហើយ (សូមមើល ទដ ១៤:៣ បទ ៣:៦) ។ *មិនឱ្យមានអ្នកណានៅក្នុងឯងទៀតឡើយ តែអញនឹងបំរុងទុកសិរីល្អ សំរាប់ស្ថានមនុស្សរស់វិញ* គឺដូចដែលពួកអ៊ីស្រាអែលបានទូលសូម (សូមមើល ៣៧:១–១៤) ។

**២៦:២១** សូមមើល ២៧:៣៦ ២៨:១៩ ។

**២៧:២** *ទួញទំនួញ* សូមមើលការពន្យល់នៅក្នុង ១៩:១ ។

**២៧:៣** *អញមានលំអគ្រប់លក្ខណ៍ហើយ* សូមមើល ២៨:១២ និងការពន្យល់ធៀបនឹង ២៨:២ នៅត្រង់ឃ្លានេះគឺស្រដៀងនិងពាក្យថ្លែងពីសេចក្តីអំនួត ។ ចាប់តាំងពីគ្រានោះមកទីក្រុងទីរ៉ុសគឺត្រូវបានពិពណ៌នាថា ដូចជាទីក្រុងដែលមានមោទនភាព ។

**២៧:៤** *ឯងមានលំអពេញខ្នាតហើយ* សូមមើល ខ.១១ ។

**២៧:៥** *ស្រុកសេនារ* គឺពួកសាសន៍អាម៉ូរីគេឱ្យឈ្មោះថា ភ្នំហើម៉ូន ដែលជាជួរភ្នំព្រៃល្បាណូន និងដើមតាត្រៅ ។

**២៧:៦** *ស្រុកបាសាន* សូមមើលការពន្យល់នៅក្នុង ៣៩:១៨ ។ *ឈើគ្រញូង* នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរ ពាក្យឈើគ្រញូងមានន័យថា គីទីម ។

**២៧:៧** *កោះអេលីសា* គឺជាទីក្រុងមួយដែលស្ថិតនៅភាគខាងកើតនៃកោះគីប្រុស ដែលពីមុនឈ្មោះថា កោះគីទីម (សូមមើលការពន្យល់នៅក្នុង លប ១០:៤) ។

**២៧:៨** *ក្រុងស៊ីដូន* ជាទីក្រុងចំណាតដែលមានចម្ងាយ ៤០.២៥គីឡូម៉ែត្រស្ថិតនៅភាគខាងជើងនៃទីក្រុងទីរ៉ុស ដោយមានការប្រកួតប្រជែងខាងផ្នែកនយោបាយនិងជាកន្លែងសម្រាប់ធ្វើជំនួញពាណិជ្ជកម្មដ៏មានសារៈសំខាន់បំផុតនៅក្នុងទីក្រុងនោះ (សូមមើលការពន្យល់នៅក្នុង ២៨:២១) ។ *អើវ៉ាឌ* គឺជាទីក្រុងមួយទៀតរបស់សាសន៍ភីនីក (Phoenicien) ដែលជាដីកោះដែលជាឆ្នេរសមុទ្រមេឌីទែរ៉ាណេ ហើយស្ថិតនៅទិសខាងជើងទីក្រុងស៊ីដូន ។

**២៧:៩** *ក្រុងកេបាល* ដែលមានឈ្មោះថា ប៊ីប្លូស (Byblos) គឺជាទីក្រុងបុរាណមួយយ៉ាងសំខាន់ស្ថិតនៅតាមឆ្នេរសមុទ្រ នៅចន្លោះក្រុងស៊ីដូន និងក្រុងអើវ៉ាឌ (សូមមើលការពន្យល់ ១ពវ ៥:១៨) ។

ជ័រ ឯអស់ទាំងនាវានៅសមុទ្រ[ត] និងពួកជើងឈ្នួល ក៏នៅ
ក្នុងឯង ដើម្បីលក់ដូរទំនិញរបស់ឯង ១០មានសាសន៍ពើស៊ី[ថ]
សសន៍លូឌ[ទ] និងសាសន៍ពូត[ធ]នៅក្នុងកងទ័ពរបស់ឯង គឺជា
ពួកថ្មើកច្បាំងរបស់ឯង គេបានពាក់ព្យួរខែល[ន] ហើយនឹង
មួកសឹកនៅក្នុងឯង ក៏នាំឱ្យសេចក្តីលំអរបស់ឯងបានកាន់
តែរុងរឿងឡើង ១១ពួកក្រុងអើវ៉ាឌ ព្រមទាំងពួកកងទ័ព
របស់ឯងជាអ្នកការពារនៅលើកំផែងជុំវិញ ហើយមាន
មនុស្សក្លៀវក្លានៅក្នុងប៉មទាំងប៉ុន្មានរបស់ឯង គេបានពាក់
ព្យួរអស់ទាំងខែរបស់គេនៅជញ្ជាំងជុំវិញ ពួកនោះបានធ្វើ
ឱ្យសេចក្តីលំអរបស់ឯងបានពេញខ្នាត[ប] ។

១២ពួកស្រុកតើស៊ីស[ផ] ជាអ្នកលក់ដូរនឹងឯង ដោយព្រោះ
ឯងមានទ្រព្យសម្បត្តគ្រប់មុខជាបរិបូរ[ព] គេដូរប្រាក់ ដែក
ស៊ីវិឡាត និងសំណឱ្យបានទំនិញពីឯង ១៣ពួកយ៉ាវ៉ាន[ភ] ពួក
ទូបាល ហើយពួកមែសេក[ម]ជាអ្នកលក់ដូរនឹងឯង គេដូរខ្លួន
មនុស្ស[យ] ព្រមទាំងគ្រឿងប្រដាប់លង្ហិនឱ្យបាន ទំនិញរបស់
ឯង ១៤ឯពួកវង្សតូកាម៉ា[រ] គេដូរសេះជិះ សេះចំបាំង និង
លាកាត់ឱ្យបានទំនិញរបស់ឯង ១៥ពួកស្រុកដេដាន់[ល]ជាអ្នក
ជំនួញនឹងឯង ដែឯងបានលូកដូរនៅកោះជាច្រើន[វ] ហើយ
គេបានដឹកភ្លុក[ស] និងឈើគ្រញូងមកឱ្យឯងវិញ ១៦ស្រុកស៊ីរី[ហ]
ក៏ជាអ្នកលក់ដូរនឹងឯងដែរ ដោយព្រោះស្នា ដៃដ៏បរិបូរ
របស់ឯង គេបានដូរកែវមរកត[ឡ] សំពត់ពណ៌ស្វាយ សំពត់
ប៉ាក់ សំពត់ទេសឯកយ៉ាងម៉ដ្ត[អ] ផ្កាថ្ម[ក] និងត្បូងទទឹមឱ្យបាន
ទំនិញរបស់ឯង ១៧ស្រុកយូដា និងអ៊ីស្រាអែល គេជាអ្នកលក់
ដូរនឹងឯង គេយកស្រូវសាលី[ខ]ពី ស្រុកមីនីត[គ] បង្អែម ទឹកឃ្មុំ
និងប្រេង[ឃ] ហើយប្រទាលមុខសះ[ង] មកដូរទំនិញរបស់ឯង
១៨ពួកដាម៉ាស[ច]ក៏ជួញប្រែនឹងឯង ឱ្យបានស្នាដៃដ៏បរិបូរ
របស់ឯង ដោយព្រោះឯងមានទ្រព្យសម្បត្តគ្រប់មុខយ៉ាង
សន្ធឹក[ឆ] គេដូរដោយស្រាទំពាំងបាយជូរពីស្រុកហេលបូន
និងរោមចៀមស ១៩ពួកវេដាន់ និងយ៉ាវ៉ាន[ជ,ឈ] គេបានដូរ
អំបោះឱ្យបានទំនិញឯង មានទាំងដែកថែប កំញាន[ញ] និង
បួសកន្ទាយនៅក្នុងទំនិញរបស់ឯង ២០ស្រុកដេដាន់[ដ]ធ្វើជំនួញ

**២៧:៩** ត ទដ ១០៤:២៦ **២៧:១០** ថ ២របា ៣៦:២០ អរ ១:១ អគ ៣៨:៥ ដយ ៨:២០ ទ អស ៦៦:១៩ ធ លប ១០:៦ អគ ៣០:៥ ណហ ៣:៩ ន បស ៤:៤ **២៧:១១** ប ខ.២៧ **២៧:១២** ផ លប ១០:៤ ព ខ.១៨,៣៣ **២៧:១៣** ភ យអ ៣:៦ ម លប ១០:២ អស ៦៦:១៩ អគ ៣២:២៦ ៣៨:២ ៣៩:១ យ វវ ១៨:១៣ **២៧:១៤** រ លប ១០:៣ **២៧:១៥** ល លប ១០:៧ វ យរ ២៥:២២ ស ១ពវ ១០:២២ វវ ១៨:១២ **២៧:១៦** ហ ពច ១០:៦ អស ៧:១–៨ ឡ នក ២៨:១៨ ៣៩:១១ អគ ២៨:១៣ អ អគ ១៦:១០ ក យប ២៨:១៨ **២៧:១៧** ខ ១ពវ ៥:៩ គ ពវ ១១:៣៣ ឃ លប ៤៣:១១ ង កច ១២:២០ **២៧:១៨** ច លប ១៤:១៥ អគ ៤៧:១៦–១៨ ឆ ខ.១២ **២៧:១៩** ជ លប ១០:២ ឈ លប ១០:២៧ ញ នក ៣០:២៤ **២៧:២០** ដ លប ១០:៧

**២៧:១០** *សាសន៍ពើស៊ី* ឬ "សាសន៍ពេរ៉ស"(គ្មានការបញ្ជាក់អត្តញ្ញាណច្បាស់លាស់ឡើយ) ។ *សាសន៍លូឌ* គឺជាសាសន៍ដែលរស់នៅអាស៊ីមីន័រ ហើយសាសន៍លូឌនេះជាអ្នកថ្មើកចម្បាំង និងធ្វើជាទាហានស៊ីឈ្នួលឱ្យសាសន៍អេស៊ីព្ទ ។

*សាសន៍ពូត* គឺជាសាសន៍លីបយ៉ា (Libya) ដែលជាសាសន៍មួយរស់នៅក្នុងទ្វីបអាហ្វ្រិចខាងជើង និងនៅទិសខាងលិចនៃប្រទេសអេស៊ីព្ទ ។

*កងទ័ព* នៅវគ្គនេះចង់និយាយពីរូបភាពក៏ប៉ាល់ ដែលត្រូវបានគេបោះបង់ចោល ហើយបើតាមន័យប្រៀបធៀបគឺចង់សំដៅទៅលើទីក្រុងទីរ៉ុស (មើលការពន្យល់ ខ.១១) ។

**២៧:១១** *អើវ៉ាឌ* សូមមើលការពន្យល់ ខ.៨ ។

**២៧:១២** *ពួកស្រុកតើស៊ីស* តាមទំនាមទំលាប់ពួកតើស៊ីស គឺគេបានតាំងទីលំនៅតាមឆ្នេរសមុទ្រទិសខាងត្បូងនៃប្រទេសអេស្ប៉ាញ (Spain) សព្វថ្ងៃនេះ ប៉ុន្តែមាននៅតាមកោះសាឌីណាយ (Sardinai)ផងដែរ សូមមើល ១ពវ ១០:២២ យហ ១:៣ ដែលបានបញ្ជាក់ថា វាគឺខុសគ្នាឆ្ងាយពីពួកសាសន៍កាណាន សូមមើល ខ.១២–២៣ ។

**២៧:១៣** *ពួកទូបាល ហើយពួកមែសេក* ពួកសាសន៍ទាំងពីរនេះគឺស្ថិតនៅក្នុងអាស៊ីមីន័រ ។

**២៧:១២** *ពួកវង្សតូកាម៉ា* សព្វថ្ងៃគឺស្ថិតនៅក្នុងអាស៊ីមីន័រខាងកើត បច្ចុប្បន្ននេះគេហៅថា ជនជាតិអាម៉ានា (Armenai) (សូមមើល ៣៨:៦) ។

**២៧:១៥** *ពួកស្រុកដេដាន់* ជាកោះធំមួយនៅតាមឆ្នេរសមុទ្រអាស៊ីមីន័រដែលស្ថិតនៅទិសខាងត្បូងឆៀងខាងលិច(នីរតី) ហើយវាគឺជាច្រកផ្លូវទៅកោះអាហ្គេន (Aegean) វាក៏ជាកន្លែងមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់តាំងពីមុនមក(សូមមើល កច ២១:១) ។

**២៧:១៦** *ស្រុកស៊ីរី* ជាទីក្រុងទំនើបនៅក្នុងប្រទេសស៊ីរី (នៅ ខ.១៨ និងមើលការពន្យល់ ២៥:១២) ។

**២៧:១៧** *អ៊ីស្រាអែល គេជាអ្នកលក់ដូរនឹងឯង* ពួកគេបានអនុវត្តន៍នៅក្នុងសម័យមុនតាំងពីឆ្នាំ ៧២២–៧២១ មុន គ.ស ។ *ស្រុកមីនី* ជាក្រុងអាប់ម៉ូនដែលមានភាពល្បីល្បាញខាងស្រូវសាលីចំពោះទីក្រុងនោះ "ស្រូវសាលីពីក្រុងអាប់ម៉ូន"ជាស្រូវសាលីមានគុណភាពខ្ពស់ សម្រាប់យកមកធ្វើជាបង្អែម និងជាអាហារផ្សេងៗ ។ *ប្រេង* គឺជាជ័រ ឬខ្លាញ់ដែលបានមកពីរុក្ខជាតិមួយប្រភេទ (មើល លប ៣៧:២៥ និងការពន្យល់ យរ ៨:២២ ៤៦:១១) ។

**២៧:១៨** *ដាម៉ាស់* ជារាជ្យធានីរបស់ស៊ីរី (សូមមើលការពន្យល់ ខ.១៦ និងមើល អស ៧:៨) ។ *ស្រុកហេលបូន* ជាទីក្រុងមួយដែលស្ថិតនៅទិសខាងជើងទីក្រុងដាម៉ាស់ ហើយនៅមានមកដល់បច្ចុប្បន្ននេះ និងជាមជ្ឈមណ្ឌលផលិតស្រាទំពាំងបាយជូររហូតមកទល់សព្វថ្ងៃនេះ ។

**២៧:១៩** *ពួកវេដាន់* ដែលបានប្រើជាភាសាក្រិកមានន័យ ហូមែរ (Homer) ក្នុងព្រះគម្ពីរជាភាសាក្រិកពួកវេដាន់ឬហូមែរគឺជាអ្នកកវីនិពន្ធកំណាព្យ ។ មានការអានខ្លះ (គឺបានការបកប្រែព្រះគម្ពីរសញ្ញាចាស់ជាភាសាក្រិក ដែលគ្រីស្ទបរិស័ទក្រិកជំនាន់មុនបានបកប្រែព្រះគម្ពីរសញ្ញាចាស់) ។ ពួកវេដាន់ក៏ជាអ្នកធ្វើជំនួញ"ស្រាទំពាំងបាយជូរដែរ" "ចំពោះ" "*ពួកវេដាន់ និងយ៉ាវ៉ាន* គឺមកពីអ៊ូសាល សូមមើល លប ១០:២៧ ១របា ១:២១ ។ ពួកនេះប្រហែលសាសន៍ យ៉េមិន (Yemen) ដែលនៅចន្លោះតំបន់ហារ៉ាន (Haran) នឹងតំបន់ទីគ្រិស (Tgris) ។ *កំញាន* ប្រហាក់ប្រហែលនឹងដើមឈើម៉្យាងឈ្មោះឧបឈើយដែលមានពណ៌លឿងភ្លាវ សូមមើល នក ៣០:២៤ ។ ជារុក្ខជាតិមានក្លិនក្រអូប ។ *បួសកន្ទាយ* គឺជារុក្ខជាតិដែលមានក្លិនក្រអូប ។

នឹងឯង ដោយសំពត់មានដំឡៃសំរាប់ជិះសេះ ២១ស្រុក
អារ៉ាប់[ថ]ហើយពួកចៅហ្វាយនៅ ស្រុកកេដារ[ឌ]ទាំងប៉ុន្មាន
ជាអ្នកលក់ដូរនឹងឯង គេលក់កូនចៀម ចៀមឈ្មោល
និងពពែដល់ឯង ២២ពួកឈ្មួញពីស្រុកសេបា[ឍ] ហើយពីស្រុក
រ៉ាម៉ាជាអ្នកដូញប្រែនឹងឯង គេបានយកគ្រឿងម្ហូបយ៉ាង
វិសេស[ណ] ថ្មមានដំឡៃគ្រប់មុខ និងមាស[ត] ដូរនឹងទំនិញ
របស់ឯង ២៣ស្រុកខារ៉ាន[ថ] ស្រុកកាននេ និងស្រុកអេដែន[ទ]
ព្រមទាំងពួកឈ្មួញនៃស្រុកសេបា អាសស៊ើរ[ធ] និងគីលម៉ាឌ
ជាអ្នកដែលធ្វើជំនួញនឹងឯង ២៤ពួកទាំងនេះបានយកទំនិញ
យ៉ាងល្អ វេចដោយសំពត់ ពណ៌ខៀវហើយប៉ាក់ និង
សំលៀកបំពាក់ មានដំឡៃដាក់ចុះក្នុងហឹប ធ្វើពីឈើតាត្រៅ
ហើយចងដោយខ្សែមកលក់ដូរនឹងឯង ២៥អស់ទាំងនាវា
ស្រុកតើស៊ីស[ន] ជាពួកដឹកទំនិញឯង ឯងបានចំរើនជាពោរ
ពេញឡើង ហើយបានថ្កុំថ្កើងយ៉ាងក្រៃលែង នៅកណ្ដាល
សមុទ្រនោះ[ប] ។

២៦ពួកអ្នកចែវរបស់ឯង គេបាននាំឯងទៅក្នុងទឹកធំ
ខ្យល់ទីទិសខាងកើត[ផ]មានធ្វើឱ្យឯងបែកធ្លាយ នៅកណ្ដាល
សមុទ្រ ២៧អស់ទាំងទ្រព្យសម្បត្តិ[ព]នឹងរបស់លក់ដូរ ហើយ
ទំនិញរបស់ឯង ព្រមទាំងពួកជើងឈ្នួល ពួកនាយសំពៅ
ពួកបិទពារ និងពួកអ្នកលក់ដូរទំនិញរបស់ឯង ហើយពួក
ទាហានដែលនៅក្នុងឯង និងបណ្ដាជនទាំងប៉ុន្មានដែល
នៅកណ្ដាលឯង គេនឹងត្រូវលិចលង់នៅផ្ទៃសមុទ្រ[ភ] ក្នុង
ថ្ងៃដែលឯងត្រូវអន្តរាយនោះ ២៨កាលណាសូរសំរែកនៃ
ពួកនាយរបស់ឯងបានឮឡើង[ម] នោះដំបន់នៅជុំវិញនឹង
ញ័ររន្ធត់ដែរ ២៩ហើយពួកអ្នកចែវទាំងប៉ុន្មាន ពួកជើង
ឈ្នួល និងពួកនាយសំពៅតាមផ្លូវសមុទ្រ គេនឹងឡើងពី
នាវារបស់គេមកឈរនៅលើច្រាំង ៣០គេនឹងបន្លឺសំឡេង
ឡើងឱ្យឮគ្រប់លើឯង គេនឹងយំខ្សឹកខ្សួល ព្រមទាំងបាច
ធូលីដី[យ]ទៅលើក្បាល ហើយដេកននៀល[រ]នៅក្នុងផេះ[ល]
៣១គេនឹងកោរសក់[វ]ដោយព្រោះឯង ព្រមទាំងស្លៀកសំពត់
ធ្មៃ ហើយយំស្ដាយ[ស]ឯង ដោយចិត្តជូរចត់ ហើយដោយ
ទំនួញយ៉ាងខ្សឹកខ្សួល[ហ] ៣២កាលគេកំពុងតែទ្រហោយំ នោះ
គេនឹងចាប់ផ្ដើមទួញទំនួញ[ឡ]ដោយព្រោះឯង គេនឹងទួញថា
តើមានអ្នកណាដូចជាទីរ៉ុស ដែលត្រូវបំផ្លាញនៅកណ្ដាល
សមុទ្រដូច្នេះ[អ] ៣៣កាលទំនិញឯងបានចេញទៅតាមផ្លូវ
សមុទ្រ[ក] នោះឯងបានចំអែតដល់សាសន៍ជាច្រើន ឯងបាន
ធ្វើឱ្យពួកស្ដេចនៅផែនដីមានជាច្រើនឡើង ដោយសារ
ទ្រព្យសម្បត្តិ[ខ] និងទំនិញដ៏បរិបូររបស់ឯង ៣៤នៅគ្រាដែល
ឯងត្រូវសមុទ្របំបែកទំលាយនៅទីជំរៅទឹក នោះទំនិញឯង
ហើយពួកឯងទាំងប៉ុន្មាន បានធ្លាក់ទៅនៅកណ្ដាលឯងផង[គ]
៣៥អស់ពួកអ្នកនៅកោះទាំងប៉ុន្មាន[ឃ] មានសេចក្ដីអស្ចារ្យ[ង]
ពីដំណើរឯង ហើយពួកស្ដេចគេបានភ័យខ្លាចជាខ្លាំង ក៏
មានមុខស្រងូត[ច] ៣៦ពួកអ្នកជំនួញនៅអស់ទាំងសាសន៍ គេ
ធ្វើស៊ីសស៊ូសឱ្យឯង[ឆ] ឯងបានត្រឡប់ជាទីស្ញែងខ្លាច ហើយ

**២៧:២១** ថ ២របា ៩:១៤ ឌ លបា ២៥:១៣ អស ២១:១៧ **២៧:២២** ឍ លបា ១០:៧,២៨ ណ លបា ៤៣:១១ ត វវ ១៨:១២ **២៧:២៣** ថ លបា ១១:២៦ ទ អស ៣៧:១២ ធ លបា ១០:២២ ជន ២៤:២៤ **២៧:២៥** ន លបា ១០:៤ អស ២:១៦ ប វវ ១៨:៣ **២៧:២៦** ផ លបា ៤១:៦ យរ ១៨:១៧ **២៧:២៧** ព សភ ១១:៤ ភ អគ ២៨:៨ **២៧:២៨** ម យរ ៤៩:២១ **២៧:៣០** យ ហស ៧:៦ ២សយ ១:២ រ យរ ៦:២៦ ល វវ ១៨:១៨–១៩ **២៧:៣១** វ លវ ១៣:៤០ យប ១:២០ អស ៣:១៧ យរ ៤៨:៣៧ ស អស ១៦:៩ វវ ១៨:១៥ ហ នអ ៤:១ យប ៣:២០ អស ២២:១២ យរ ៦:២៦ បទ ២:១០ អគ ៧:១៨ **២៧:៣២** ឡ អគ ១៩:១ អ អស ២៣:១–៦ អគ ២៦:៥ **២៧:៣៣** ក ខ.៣ ខ ខ.១២ អគ ២៨:៤–៥ **២៧:៣៤** គ សក ៩:៤ **២៧:៣៥** ឃ អគ ២៦:១៥ ង លវ ២៦:៣២ យប ១៨:២០ ច អគ ២៦:១៧–១៨ ៣២:១០ **២៧:៣៦** ឆ យរ ១៩:៨ ៤៩:១៧ ៥០:១៣ សផ ២:១៥

**៧:២០** *ស្រុកដេដាន់* សូមមើលការពន្យល់ ២៥:១៣ ។

**២៧:២១** *ស្រុកអារ៉ាប់ ហើយ... ស្រុកកេដារ* ជាទូរទៅវគ្គនេះបានបង្ហាញពីទាហាននៃសាសន៍អាប់រ៉ាម ដែលធ្វើដំណើរឆ្លោះតម្រង់ទៅឯទីរហោស្ថានអារ៉ាប់ប៊ី ។ ចំពោះពួកសាសន៍ខាល់ដេ សូមមើល អស ២១:១៦ ហើយនិងការពន្យល់ ៤២:១១, ៦០:៧ យរ៤៩:២៨ ។

**២៧:២២** *ស្រុកសេបា* សូមមើលការពន្យល់ ២៣:៤២ ។ *ស្រុករ៉ាម៉ា* ជាទីក្រុងមួយដែលស្ថិតនៅក្នុងអារ៉ាប់ប៊ីភាគខាងត្បូង ។

**២៧:២៣** *ស្រុកខារ៉ាន* ជាទីក្រុងមួយស្ថិតនៅខាងកើតទីក្រុង កើរកេមីស (Carchemish) សព្វថ្ងៃនេះ ស្ថិតនៅទិសខាងកើតនៃប្រទេសទួរគី តាមដែលគេបានស្គាល់ទីក្រុងនេះពីបុរាណមក វាគឺជាទីក្រុងមួយដ៏ល្អប្រណិត ហើយជាកន្លែងសម្រាប់ធ្វើជំនួញនិងជាកន្លែងថ្វាយបង្គំដល់ព្រះចន្ទ័ដើម្បីលាងបាបរបស់ពួកគេផងដែរ ។ ទីក្រុងនោះបានផ្លាស់ប្ដូរពីអ័ប្រាហាំមកជាកាណានវិញ (មើល លប ១១:៣១ និងការពន្យល់ ១២:៤) ។ *កាននេ* ប្រហែលជាត្រូវបានផ្លាស់ប្ដូរទៅកន្លែងផ្សេងទៀតដែលគេសន្មត់ថា វាស្ថិតនៅក្នុងតំបន់មេសូប៉ូតាមា (Mesopotamia) ។ វាជាអត្តសញ្ញាណរបស់កាននេ (អស ១០:៩ អម ៦:២) ។ *ស្រុកអេដែន* គឺជាស្រុកហារ៉ានខាងត្បូងដែលបានកំណត់សម្គាល់និងជាការតភ្ជាប់ជាមួយរស្រុកហារ៉ាន សូមមើល ២ពវ ១៩:១២ ។ *អាសស៊ើរ* ជាទីក្រុងនៅក្នុងប្រទេសអាស៊ីរី (Assyria) ឬជាប្រជាជនអាស៊ីរី (Assyrians) ។ នៅត្រង់នេះប្រហែលជាទីក្រុងនីនីវេខាងត្បូងដែលត្រូវបានគេឱ្យឈ្មោះថាប្រទេស ។ *គីលម៉ាឌ* វាជាទីក្រុងមួយដែលស្ថិតនៅក្នុងតំបន់មេសូប៉ូតាមា ។

**២៧:២៥** *ស្រុកតើស៊ីស* សូមមើល ខ.១២ ។ នៅខនេះគឺបាននិយាយម្ដងទៀតក្នុងការធ្វើដំណើរតាមសមុទ្រ (សូមមើលការពន្យល់ ខ.៣,១០) ។

**២៧:២៦** *ខ្យល់ពីទិសខាងកើត* នៅត្រង់វគ្គនេះនិយាយពីគ្រោះមហន្តរាយនៅឯសមុទ្រ (សូមមើល ទដ ៤៨:៧ យរ ១៨:១៧) ហើយវាជានិមិត្តរូបនៃស្ដេចនេប៊ូក្នេសា (មើលនៅក្នុង ១៧:១០) ។

**២៧:៣០** *បាចធូលីដីទៅលើក្បាល* ចំពោះវគ្គនេះវាស្រដៀងនិង សូមមើល ២៦:១៦ ។ *ដេកននៀលនៅក្នុងផេះ* ធៀបនឹង មីក ១:១០ និងការពន្យល់ ។

**២៧:៣១** *គេនិងកោសក់ដោយសារឯង* ធៀបនឹង ៧:១៨ អស ១៥:២ ហើយនិងការពន្យល់ ២២:១២ ។ *ស្លៀកសំពត់ធ្មៃ* សូមមើលការពន្យល់ លប ៣៧:៣៤ វវ ១១:៣ ។

**២៧:៣៦** *ជាទីស្ញែងខ្លាច ហើយនិងលែងមានជាដរាបតទៅ* សូមមើល

នឹងដែលមានជាដរាបតទៅ[ជ] ។

## សេចក្ដីទំនាយទាស់នឹងស្ដេចក្រុងទីរ៉ុស

**២៨** ១ព្រះបន្ទូល នៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំម្ដងទៀតថា
២កូនមនុស្សអើយ[ក] ចូរប្រាប់ដល់ម្ចាស់ដ៏ធំនៃក្រុងទីរ៉ុស
ថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ដោយព្រោះ
ឯងកើតមានចិត្តធំ ហើយបានពោលថា អញជាព្រះអញ
អង្គុយលើបល្ល័ង្ក[ខ]របស់ព្រះនៅកណ្ដាលសមុទ្រ[គ] ប៉ុន្តែឯង
ជាមនុស្សទេ មិនមែនជាព្រះឡើយ ទោះបើឯងបានតាំង
ចិត្តដូចជាព្រះហឫទ័យព្រះក៏ដោយ[ឃ] ៣មើល ឯងមានប្រាជ្ញា
លើសជាងដានីយ៉ែលទៅទៀត[ង] គ្មានការសំងាត់ណាដែល
លាក់កំបាំងនឹងឯងសោះ ៤ឯងបានប្រមូលទ្រព្យសម្បត្តិ
ហើយបានមាសប្រាក់ដាក់ក្នុងឃ្លាំង ដោយប្រាជ្ញា និង
យោបល់របស់ឯង[ច] ៥ឯងបានចំរើនទ្រព្យសម្បត្តិដោយសារ
ប្រាជ្ញាដ៏ជ្រាជ្រៅរបស់ឯង និងការជំនួញ[ឆ]ផង ហើយចិត្ត
ឯងបានស្គយឡើង[ជ] ដោយព្រោះទ្រព្យសម្បត្តិរបស់ឯង[ឈ]
៦ហេតុនោះ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា
ដោយព្រោះឯងបានតាំងចិត្ត ឱ្យបានដូចជាព្រះហឫទ័យនៃ
ព្រះ ៧នោះមើលអញនឹងនាំសាសន៍ដទៃ គឺជាពួកអ្នកគួរ
ស្ញែងខ្លាច នៅកណ្ដាលគ្រប់ទាំងសាសន៍[ញ] មកលើឯង គេ
នឹងហូតដាវទៅទាស់នឹងលំអនៃប្រាជ្ញា[ដ]របស់ឯង ព្រមទាំង
បង្អាប់ស្មើរបស់ឯងផង[ឋ] ៨គេនឹងទំលាក់ឯង ទៅក្នុងជង្ហុក
ធំ[ឌ] ហើយឯងនឹងត្រូវស្លាប់ដូចជាពួកអ្នកដែល ត្រូវគេចាក់
សំឡាប់[ឍ] នៅកណ្ដាលសមុទ្រ[ណ] ៩នៅគ្រានោះ តើឯងនឹង
នៅតែពោល នៅមុខអ្នកដែលសំឡាប់ឯងថា អញជាព្រះ
ទៀតឬអី[ត] ប៉ុន្តែក៏នៅក្នុងកណ្ដាប់ដៃ នៃអ្នកដែលសំឡាប់ឯង
នោះឯងជាមនុស្សទេ មិនមែនជាព្រះឡើយ[ថ] ១០ឯងនឹងត្រូវ
ស្លាប់ ដូចជាពួកអ្នកមិនកាត់ស្បែកដែរ[ទ] គឺដោយដៃនៃពួក
សាសន៍ដទៃ ដ្បិតអញបានចេញវាចារួច ហើយនេះជាព្រះ
បន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ។
១១ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់ខ្ញុំទៀតថា
១២កូនមនុស្សអើយ ចូរផ្ដើមពាក្យទំនួញ[ធ]ពីដំណើរស្ដេច
ក្រុងទីរ៉ុស ហើយប្រាប់ថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ ឯងជាអ្នកបំពេញខ្នាត ដោយមានប្រាជ្ញាពោរ
ពេញ ហើយលំអគ្រប់លក្ខណ៍[ន] ១៣ពីដើមឯងបាននៅក្នុង
ច្បារអេដែន[ប]ជាសួនរបស់ព្រះ[ផ] ឯងបានប្រដាប់កាយ
ដោយត្បូងដ៏មានដំឡៃ[ព]គ្រប់មុខ គឺសាមសី ទោប៉ុត ពេជ្រ
បេរីលូនឹក្ស មណីជោតិ កណ្ដៀង មរកត បារកេត[ភ] ហើយ
និងមាស ឯក្រាប់នឹងខ្លុយរបស់ឯង នោះបានត្រៀមទុក
សំរាប់ឯងតាំងពីថ្ងៃដែលឯងកើតមក[ម] ១៤ឯងជាចេរូប៊ីន

**២៧:៣៦** ជ ទដ ៣៧:១០,៣៦ អគ ២៦:២១ **២៨:២** ក អស ១៣:១១ ខ អស ១៤:១៣ គ សផ ២:១៥ ឃ លប ៣:៥ ទដ ៩:២០ ៨២:៦-៧ អគ ១៦:៤៩ ២ធថ ២:៤ **២៨:៣** ង អគ ១៤:១៤ ដយ ១:២០-២៣,២៨ ៥:១១-១២ **២៨:៤** ច អស ១០:១៣ សក ៩:៣ **២៨:៥** ឆ អស ២៣:៨ ជ យប ៣១:២៥ ទដ ៥២:៧ ៦២:១០ ហស ១២:៨ ១៣:៣៦ ឈ យរ ៩:២៣ អគ ២៧:៣៣ **២៨:៧** ញ អគ ៣០:១១ ៣១:១២ ៣២:១២ ហប ១:១៦ ដ យរ ៩:២៣ ឋ អគ ៧:២៤ **២៨:៨** ឌ ទដ ៥៥:២៣ អគ ៣២:៣០ ឍ វវ ១៨:៧ ណ អគ ២៦:១២ ២៧:២៧ **២៨:៩** ត អស ៣១:៣ ថ អគ ១៦:៤៩ **២៨:១០** ទ ១សយ ១៤:៦ យរ ៩:២៦ អគ ៣២:១៩,២៤ **២៨:១២** ធ អគ ១៩:១ ន អគ ២៧:២-៤ **២៨:១៣** ប លប ២:៨ ផ អគ ៣១:៨-៩ ព វវ ១៧:៤ ភ អគ ២៧:១៦ ម អស ១៤:១១ វវ ២១:២០

២៦:២១ ២៨:១៩ និងមើលការពន្យល់ អស ២៣:១ ។
**២៨:២,៨** *នៅកណ្ដាលសមុទ្រ* នៅត្រង់វគ្គនេះនិយាយសង្កត់ធ្ងន់ថា ទីតាំងទីក្រុងទីរ៉ុសគឺជាបន្ទាយទ័ពនៅលើកោះមួយ ហើយមានកម្លាំងទ័ពដែលមានអំណាចគ្រប់គ្រងនៅក្នុងជំនួញតាមផ្លូវទឹក ។
**២៨:២** *ម្ចាស់ដ៏ធំរបស់ទីក្រុងទីរ៉ុស* ជាការបញ្ជាក់ទៅចំពោះទីក្រុងទីរ៉ុសនិងពីការគ្រប់គ្រងរបស់ស្ដេចអេតបាលទី២ ដែលជាស្ដេចនៃក្រុងទីរ៉ុស (សូមមើល ខ.១២) មិនអាចមានការភាន់ច្រឡំ និងស្ដេចអេតបាល ទី ១ឡើយ (សូម ១ពវ ១៦:៣១) ។ *មានចិត្តធំ* ធៀបនឹង ២៧:៣ ទដ ១១:២ និងការពន្យល់ ១៦:១៨ កិច្ចការ ១២:២១-២៣ ។ *អញជាព្រះ* ធៀបនឹងវគ្គនេះមានន័យថា គឺជាសេចក្ដីអំនួតរបស់ស្ដេចនៃទីក្រុងបាប៊ីឡូន មើលក្នុង អស ១៤:១២-១៥ ។
**២៨:៣** *ដានីយ៉ែល* សូមមើលការពន្យល់នៅក្នុង ១៤:៤ ។
**២៨:៧** *សាសន៍ដទៃ* គឺនិយាយអំពីពួកបាប៊ីឡូន សូមមើល ឃ្លាបន្ទាប់ ។
**២៨:៨** *ជង្ហុកធំ* ធៀបនឹង យប ៣៣:២២,២៤ មើលការពន្យល់ ២៦:២០ ។
**២៨:១០** *ពួកអ្នកមិនកាត់ស្បែក* នៅត្រង់ចំណុចនេះ គឺនិយាយសង្កត់ធ្ងន់ទៅលើមនុស្សកំរោល ឬមនុស្សអសីលធម៌ ។ ដូចជាពួកសាសន៍អ៊ីស្រាអែល និងពួកសាសន៍អេស៊ីព្ទបានអនុវត្តន៍ការកាត់ស្បែកនេះ (សូមមើល ៣១:១៨ ៣២:១៩) ។
**២៨:១២** *ពាក្យទំនួញ* សូមមើលការពន្យល់នៅក្នុង ១៩:១ ។
*ស្ដេចក្រុងទីរ៉ុស* ធៀបនឹង ខ.២ ប៉ុន្តែ សូមមើលការពន្យល់នៅក្នុង អស ១៤:១២-១៥ ។ *បំពេញខ្នាត* " ជាគំរូ" ការរស់នៅជាពន្លឺ " ជាត្រា"សូមមើលនៅក្នុង ហក ២:២៣ នៅត្រង់កន្លែងនេះ លោកសារូបាបិល គឺត្រូវបានព្រះទ្រង់ហៅមកធ្វើជាអ្នកបម្រើទ្រង់ ។ មានន័យថា"បោះត្រាដៅចំណាំ"ជាការកាត់ផ្ដាច់នៅការចំអកឡកឡឺយនៃហោរាអេសេគាល ដែលលោកបានពិពណ៌នាពីសេចក្ដីអំនួតរបស់ស្ដេចក្រុងទីរ៉ុស ដូចជាមនុស្សទីមួយដែលបានបង្កើតឡើង សម្រាប់ឆ្លុះបញ្ចាំងពីប្រាជ្ញា និងសោភណ័ភាពរបស់ទ្រង់ ។ *លំអរគ្រប់លក្ខណ៍* សូមមើល ២៧:៣ និងការពន្យល់ ។
**២៨:១៣** *ពីដើមឯងបាននៅក្នុងច្បារអេដែន* នៅត្រង់ចំណុចនេះ គឺនិយាយប្រៀបធៀបទៅនិងលោកអ័ដាម(លប ២:១៥) ។ ហោរាអេសេគាលគាត់បានបន្តដើម្បីប្រើនៅរូបភាពនៃការបង្កើតដែលបានបង្ហាញប្រាប់ពីការធ្លាក់ចុះនៃរាជរបស់ស្ដេចក្រុងទីរ៉ុស(សូមមើល ៣១:៩,១៦,១៨) ។ *ប្រដាប់កាយដោយត្បូងដំឡៃគ្រប់មុខ* ដែលមានការខុសផ្លែកពីជីវិតរបស់លោកអ័ដាម គឺខ្លួនរបស់លោកនៅជាអាក្រាត (សូមមើល លប ២:២៥) ។ ស្ដេចគឺបានបង្ហាញនូវការស្លៀកពាក់ជាសង្ឃដែលមានពន្លឺភ្លឺចាំង(ខ.១៤) ដើម្បីចាំយាមនៅដំណាក់បរិសុទ្ធរបស់ព្រះ ។ ត្បូងមានតម្លៃ ៩ ក្នុងចំណោមទាំង ១២ បានត្រូវបង្ហូចដោយសារសង្ឃ (នក ២៨:១៧-២០) ។ *បានត្រៀមទុកសំរាប់ឯង* ត្បិតគេគ្រប់គ្នាបានប្រដាប់កាយដោយត្បូងមានតម្លៃ ។ *តាំងពីថ្ងៃដែលឯងកើតមក* ធៀបនឹង ខ.១៥ លប ៥:២ ។

ដែលបានចាក់ប្រេងតាំងឡើង[យ]ជាអ្នកគ្របបាំង[រ] គឺអញបាន
តាំងឯងឡើង ឱ្យឯងបាននៅលើភ្នំបរិសុទ្ធរបស់ព្រះ ឯងក៏
បានដើរទៅមកនៅកណ្ដាលថ្មភ្លឺចាំង ១៥ចាប់តាំងពីថ្ងៃ
ដែលឯងកើតមក នោះឯងបានគ្រប់លក្ខណ៍ក្នុងគ្រប់ទាំង
ផ្លូវរបស់ឯង ដរាបដល់វេលា ដែលឃើញមានសេចក្ដី
ទុច្ចរិតនៅក្នុងឯង ១៦ដ្បិតដោយសារការជួញប្រែដ៏បរិបូរ
របស់ឯង នោះគេបានបំពេញឯងដោយសេចក្ដីច្រឡោត[ល]
ហើយឯងបានធ្វើបាប ហេតុនោះអញបានបោះចោល
ឯងចេញពីភ្នំនៃព្រះ ទុកដូចជារបស់អាប់ឱនទៅវិញ ឱ
ចេរូប៊ីនដែលគ្របបាំងអើយ[វ] អញបានបំផ្លាញឯង ចេញ
ពីកណ្ដាលថ្មភ្លឺចាំងនោះទៅ ១៧ចិត្តឯងបានស្គួយឡើង[ស]
ដោយព្រោះសេចក្ដីលំអរបស់ឯង ឯងបានបង្ខូចប្រាជ្ញាឯង
ដោយពន្លឺរស្មីរបស់ឯង អញបានបោះឯងចុះ ដល់ដីព្រម
ទាំងដាក់ឯងនៅមុខពួកស្ដេច ឱ្យគេបានពិចារណាឯង[ហ]
១៨ឯងបានបង្អាប់អស់ទាំងទីបរិសុទ្ធរបស់ឯង ដោយអំពើ
ទុច្ចរិតដ៏បរិបូររបស់ឯង ហើយដោយសេចក្ដីទុច្ចរិតនៃ
ការជួញប្រែរបស់ឯង ហេតុនោះអញបានធ្វើឱ្យមានភ្លើង[ឡ]
ចេញពីកណ្ដាលឯងមក ភ្លើងនោះបានឆេះបំផ្លាញឯង អញ
បានឱ្យឯងទៅជាផេះ[អ] នៅលើផែនដី នៅចំពោះភ្នែកនៃ
អស់អ្នកដែលឃើញឯង[ក] ១៩អស់អ្នកនៅគ្រប់ទាំងសាសន៍
ដែលស្គាល់ឯង គេនឹងស្រឡាំងកាំង[ខ]ទៅ ដោយព្រោះឯង
ឯងបានត្រឡប់ជាទីស្ញែងខ្លាច ហើយលែងមាននៅជាដរាប
តទៅ[គ] ។

**២៨:១៤** យ នក ៣០:២៦ ៤០:៩ រ នក ២៥:១៧–២០
**២៨:១៦** ល លប ៦:១១ ហប ២:១៧ វ លប ៣:២៤
**២៨:១៧** ស អស ១០:១២ អគ ១៦:៤៩ ៣១:១០ ហ អគ ១៩:១២
**២៨:១៨** ឡ អប ១:១៨ អ មឡ ៤:៣ ក សក ៩:២–៤
**២៨:១៩** ខ លវ ២៦:៣២ គ យរ ៥១:៦៤ អគ ២៦:២១
**២៨:២១** ឃ អគ ១៣:១៧ ង លប ១០:១៥ យរ ២៥:២២
**២៨:២២** ច អគ ៣៩:១៣ ឆ អគ ៣០:១៩ ជ លវ ១០:៣
**២៨:១៧** ឈ អគ ៥:១៧ ៣៨:២២
**២៨:២៤** ញ អស ៥:៦ អគ ២:៦
**២៨:២៥** ដ ទដ ១០៦:៤៧ យរ ៣២:៣៧ ឋ អស ១១:១២ ឌ អគ ២០:៤១ ឍ យរ ១២:១៥ ២៣:៨ អគ ១១:១៧ ៣៤:២៧ ៣៧:២៥

## សេចក្ដីទំនាយទាស់នឹងស៊ីដូន

២០រួចមកព្រះបន្ទូល នៃព្រះយេហូវ៉ា បានមកដល់ខ្ញុំថា
២១កូនមនុស្សអើយ ចូរតាំងមុខឯងត្រង់ទៅ[ឃ]ឯសីដូន[ង]
ហើយទាយទាស់នឹងទីក្រុងនោះថា ២២ព្រះអម្ចាស់យេហូវ៉ា
ទ្រង់ មានបន្ទូលដូច្នេះ ម្នាល សីដូនអើយ អញទាស់នឹងឯង
ហើយអញនឹងបានដំកើងឡើង[ច]នៅកណ្ដាលឯង នោះគេ
នឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុងកាលដែលអញ
បានសំរេចសេចក្ដីយុត្តិធម៌[ឆ]ដល់វា ហើយបានញែកជា
បរិសុទ្ធ[ជ]នៅក្នុងវាដែរ ២៣ពីព្រោះអញនឹងចាត់អាសន្ន
រោគទៅក្នុងវា និងឈាម ទៅនៅអស់ទាំងផ្លូវរបស់វាពួក
អ្នកដែលត្រូវរបួស និងដួលនៅកណ្ដាលវា ដោយមានដាវ
គ្របសង្កត់នៅគ្រប់ទិស នោះគេនឹងដឹងថា អញនេះជាព្រះ
យេហូវ៉ាពិត[ឈ] ២៤ដូច្នេះ នឹងលែងមានបន្លាចាក់ចុចដល់ពួក
វង្សអ៊ីស្រាអែល ឬបន្លាធ្វើទុក្ខ[ញ] នៅក្នុងសាសន៍ណានៅ
ព័ទ្ធជុំវិញ ដែលប្រព្រឹត្តនឹងគេដោយមើលងាយទៀតឡើយ
នោះគេនឹងដឹងថា អញនេះជាព្រះអម្ចាស់យេហូវ៉ាពិត ។
២៥ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា កាល
ណាអញបានប្រមូល[ដ]ពួកវង្សអ៊ីស្រាអែល មកពីគ្រប់សាសន៍
ដែលគេត្រូវខ្ចាត់ខ្ចាយទៅនោះ[ឋ] ហើយអញបានញែកជា
បរិសុទ្ធ[ឌ]នៅក្នុងពួកគេ ចំពោះភ្នែកនៃសាសន៍ដទៃ នោះគេ
នឹងអាស្រ័យនៅក្នុងស្រុករបស់ខ្លួន ដែលអញបានឱ្យដល់

**២៨:១៤** *ឯងជាចេរូប៊ីន* ធៀបនឹង ឧ.១៦ នៅក្នុងព្រះគម្ពីរលោកកុប្បត្តិមានដំណើររឿងពីចេរូប៊ីន(ជាពហុវចនៈ មានចំនួនច្រើន)ទីតាំងនៃចេរូប៊ីនគឺការពារសួនច្បារអេដែនបន្ទាប់ពីទ្រង់បានបណ្ដេញលោកអ័ដាម និងនាងអេវ៉ាចេញពីទីនោះមក (សូមមើល លប ៣:២៤ និងការពន្យល់) ។ *នៅលើភ្នំបរិសុទ្ធរបស់ព្រះ* ធៀបនឹង ឧ.១៦ ការនេះមិនបានឆ្លុះបញ្ចាំងអំពីសាច់រឿងនៅក្នុងព្រះគម្ពីរលោកកុប្បត្តិទេ សូមមើល អស ១៤:១៣ ដ្បិតអង្គុលីរបស់ទ្រង់បានសណ្ឋិតនៅលើភ្នំ ។ *ថ្មភ្លឺចាំង* ប្រដាប់កាយដោយត្បូងមានតម្លៃ (ឧ.១៣ ធៀបនឹង វវ ៤:១–៦ ២១:១៥–២១) ។

**២៨:១៥** *នោះឯងបានគ្រប់លក្ខណ៍. . .ដរាប* ដែលស្របនឹង លប ២–៣ គឺបានបញ្ជាក់ច្បាស់ (សូមមើល លប ៦:៩ និងការពន្យល់ ១៧:១) ។

**២៨:១៦** *ការជួញប្រែ... បានបំពេញឯងដោយសេចក្ដីច្រឡោត* អ្នកធំនៅទីក្រុងទីរ៉ុសពេញដោយសេចក្ដីច្រឡោត និងការប្រព្រឹត្តខុស ។

**២៨:១៧** *អញបានបោះឯងចុះដល់ដី* នៅត្រង់វគ្គនេះនិយាយពីព្រះទ្រង់បានបណ្ដេញចេញពីស្ថានសួគ៌ ។

**២៨:១៩** *បានត្រឡប់ជាទីស្ញែងខ្លាច ហើយលែងមាននៅជាដរាបតទៅ* សូមមើលការពន្យល់នៅក្នុង ២៧:៣៦ ។

**២៨:២១** *ចូរតាំងមុខឯង* សូមមើលការពន្យល់នៅក្នុង ២០:៤៦ ។ *សីដូន* សូមមើល ២៧:៨ និងការពន្យល់ នៅត្រង់នេះគឺមានតែមួយដងគត់ដែលបាននិយាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ បានបញ្ជាក់ពីស្រុកសីដូនគឺជាផ្នែកមួយនៃក្រុងទីរ៉ុស (ធៀបនឹង អស ២៣:១–៤ យរ ៤៧:៤ យអ ៣:៤ សក ៩:២) ។

**២៨:២២** *អញទាស់និងឯង* ការនេះអាចនឹងកើតឡើងដោយព្រោះស្រុក–សីដូនមានការទាក់ទងជាមួយក្រុងយេរូសាឡិម(យរ ២៧:៣ សូមមើលការពន្យល់ ៥:៨) ។ *អញនិងបានដំកើងឡើងនៅកណ្ដាលឯង* នៅត្រង់ឃ្លានេះ គឺ បង្ហាញពីសិរីល្អរបស់ព្រះអម្ចាស់ ដែលបម្រុងនឹងដាក់ទណ្ឌកម្មមកលើស្រុកសីដូន ។ *ញែកជាបរិសុទ្ធ* សូមមើល ឧ.២៥ លវ ១០:៣ និងការពន្យល់ ។

**២៨:២៤** *បន្លាធ្វើទុក្ខ* នេះគឺជាការបញ្ជាក់ពីកងទ័ពរបស់អ៊ីស្រាអែលដែលដូចជាបន្លា សូមមើល ជន ៣៣:៥៥ យស ២៣:១៣ ។

**២៨:២៥** *កាលណាអញបានប្រមូលពួកវង្សអ៊ីស្រាអែល* ទ្រង់បានសន្យាជាច្រើនដងនៅក្នុងព្រះគម្ពីរអេសេគាល (សូមមើល ១១:១៧ ២០:៣៤,៤១–៤២ ២៩:១៣ ៣៤:១៣ ៣៦:២៤ ៣៧:២១ ៣៨:៨ ៣៩:២៧ នហ ១:៩ សក ១០:៨,១០) ។ *យ៉ាកុប ជាបំរើអញ* ធៀបនឹង ៣៧:២៥ ។ ចំពោះសេចក្ដីសន្យា សូមមើល លប ២៨:១៣ ៣៥:១២ ទដ ១០៥:១០–១១) ។

យ៉ាកុប[ឍ]ជាអ្នកបំរើអញ ២៦គេក៏នឹងនៅក្នុងស្រុកនោះ
ដោយសុខសាន្ត[ណ] អើ គេនឹងសង់ផ្ទះ ព្រមទាំងដាំដំណាំ[ត]
ទំពាំងបាយជូរ នឹងអាស្រ័យនៅដោយសុខសាន្តផង ក្នុង
កាលដែលអញសំរេចសេចក្តីយុត្តិធម៌[ថ] ដល់ពួកអ្នកនៅ
ជុំវិញ ដែលបានប្រព្រឹត្តនឹងគេដោយសេចក្តីមើលងាយ
នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ា[ទ]គឺជាព្រះនៃ
គេពិត ។

**បទទំនាយទាស់នឹងនគរអេស៊ីព្ទ**

**២៩** ១នៅថ្ងៃ១២ ខែបុស្ស ឆ្នាំទី១០ នោះព្រះបន្ទូលនៃ
ព្រះយេហូវ៉ាបានមកដល់ខ្ញុំថា[ក] ២កូនមនុស្សអើយ ចូរតាំង
មុខទាស់នឹង[ខ]ផារ៉ោន ជាស្តេចក្រុងអេស៊ីព្ទ[គ] ហើយទាយ
ទាស់នឹងវា ព្រមទាំងស្រុកអេស៊ីព្ទទាំងមូលផងថា[ឃ] ៣ព្រះ
អម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ នែ ផារ៉ោន[ង] ជា
ស្តេចស្រុកអេស៊ីព្ទ ជាសត្វសំបើម[ច]ដែលដេកនៅកណ្តាល
ទន្លេរបស់ខ្លួនអើយ អញទាស់នឹងឯង ដ្បិតឯងជាទន្លេ[ឆ] នេះ
ជារបស់ផងអញ អញបានបង្កើតសំរាប់តែខ្លួនអញទេ ៤អញ
នឹងដាក់ទំពក់[ជ]នៅក្នុងមាត់ឯង ហើយនិងឱ្យត្រីនៅទន្លេឯង
មកភ្ជាប់ខ្លួននៅនឹងស្រកាឯង ក៏នឹងនាំឯងឡើង ចេញពី
កណ្តាលទន្លេឯងនោះ ដោយព្រោះត្រីទាំងប៉ុន្មាន ដែលនៅ
ទន្លេឯងជាប់នឹងស្រកាឯងមកផង[ឈ] ៥អញនឹងបោះឯង
ចោលក្នុងទីរហោស្ថាន គឺទាំងខ្លួនឯង និងត្រីទាំងអស់នៅ
ទន្លេឯងផង ឯងនឹងធ្លាក់ទៅនៅទីវាលទទេ ឥតដែលបាន
ប្រមូលផ្តុំគ្នា[ញ]ទៀតឡើយ អញបានឱ្យឯងទៅជាអាហារ
ដល់អស់ទាំងសត្វនៅដី និងសត្វហើរលើអាកាស[ដ] ៦នោះ
ពួកសាសន៍អេស៊ីព្ទទាំងអស់នឹងដឹងថា អញនេះជាព្រះ
យេហូវ៉ាពិត ពីព្រោះគេជាឈើច្រត់ធ្វើពីបបុស[ឋ] ដល់ពួក
វង្សអ៊ីស្រាអែល ៧កាលណាពួកអ៊ីស្រាអែលបានចាប់យក
កាន់ នោះឯងក៏បាក់បែកទៅ[ឌ] ហើយចាក់ហែកស្មាគេអស់
រលីង កាលគេច្រត់ពឹងមកលើឯង នោះឯងបានបាក់ទៅ
ធ្វើឱ្យថ្លស់ចង្កេះគេ[ឍ] ។
៨ហេតុនោះព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ
ថា មើល អញនឹងនាំដាវមកលើឯង ហើយនឹងកាត់ទាំង
មនុស្សនឹងសត្វចេញពីឯង[ណ] ៩នោះស្រុកអេស៊ីព្ទនឹងទៅជា
ទីចោលស្ងាត់ ហើយខូចបង់ ដូច្នេះ គេនឹងដឹងថា អញនេះ
ជាព្រះយេហូវ៉ាពិត ហើយដោយព្រោះវាបានពោលថា

**២៨:២៦** ណ លវ ២៥:១៨ ១ពវ ៤:២៥ យរ ១៧:២៥ ត ចទ ២០:៦ ថ ទដ ១៤៩ ទ អស ៦៥:២១ យរ ៣២:១៥ អគ ៣៨:៨ ៣៩:២៦–២៧ ហស ២:១៥ ១១:១១ អម ៩:១៤–១៥
**២៩:១** ក ខ.១៧ អគ ២៦:១
**២៩:២** ខ អគ ២៥:២ គ យរ ២៥:១៩ ឃ អស ១៩:១–១៧ យរ ៤៦:២ អគ ៣០:១–២៦ ៣១:១–១៨ ៣២:១–៣២
**២៩:៣** ង យរ ៤៤:៣០ ច ទដ ៦៨:៣០ ៧៤:១៣ អគ ៣២:២ ឆ យរ ៤៦:៨
**២៩:៤** ជ ២ពវ ១៩:២៨ យប ៤១:២
ឈ អគ ៣៨:៤ **២៩:៥** ញ យរ ៨:២ ដ យរ ៧:៣៣ ៣៤:២០ អគ ៣១:១៣ ៣២:៤–៦ ៣៩:៤ **២៩:៦** ឋ ២ពវ ១៨:២១ **២៩:៧** ឌ ២ពវ ១៨:២១ អស ៣៦:៦ ឍ យរ ១៧:៥ អគ ១៧:១៥–១៧ **២៩:៨** ណ អគ ២៥:១៣ ៣២:១១–១៣

**២៨:២៦** *និងអាស្រ័យនៅដោយសុខសាន្ត* នៅត្រង់ចំណុចនេះ គឺបញ្ជាក់ប្រាប់ពីលក្ខណៈជីវិត ដែលរស់នៅបានយូរអង្វែងតាមរយៈព្រះបន្ទូលសន្យា (សូម ៣៤:២៨ ៣៨:៨,១១,១៤ ៣៩:២៦ លវ ២៥:១៨–១៩ យរ ២៣:៦ ៣២:៣៧ ៣៣:១៦) ដែលបានទំនាក់ទំនងស្និទស្នាលជាមួយនិងសេចក្តីសន្យារបស់ព្រះ ។ "ការសម្រាក"(សូមមើល ចទ ៣:២០ និងការពន្យល់) ។ *សង់ផ្ទះ . . . ដំណាំទំពាំងបាយជូរ* នេះជាមូលដ្ឋានសំខាន់និងចាំបាច់បំផុតសម្រាប់ជីវិតដ៏ប្រសើរ (ធៀបនឹង អស ៦៥:២១ យរ ២៩:៥,២៨ អម ៩:១៤) ។

**២៩:១–៣២:៣២** សេចក្តីទំនាយចំនួនប្រាំពីរដងដែលថ្លែងទាស់និងស្រុកអេស៊ីព្ទជាបន្តបន្ទាប់ (ចំពោះកាលបរិច្ឆេទរបស់ពួកគេ សូមមើលការពន្យល់ខាងក្រោម) ។ នៅឆ្នាំក្រោយៗមកពួកគេបានចូលមកយ៉ាងច្រើនបំផុតក្នុងអំឡុងពេលនោះពួកអ្នកស្រុកអេស៊ីព្ទនិងស្តេចផារ៉ោន បាននាំយកដង្វាយដើម្បីធ្វើការលើកទឹកចិត្ត ទៅដល់ស្តេចសេដេគាជាប្រយោជន៍ដើម្បីធ្វើការបះបោរទាស់ប្រឆាំងជាមួយស្តេចនេប៊ូក្នេសា (សូមមើល ១៧:១៥ យរ ៣៧:៥–៨) ។

**២៩:១** *នៅថ្ងៃទី១២ ខែបុស្ស ឆ្នាំទី១០* នៅថ្ងៃទី៧ ខែ មករា ឆ្នាំ ៥៨៧ មុន គ.ស ដែលជាថ្ងៃកាលបរិច្ឆេទលើកទី៦ នៅក្នុងគ្រាហោរាអេសេគាល(សូមមើល ១:២ ៨:១ ២០:១ ២៤:១ ២៦:១)។ សេចក្តីទំនាយទាំងអស់ដែលថ្លែងទាស់និងស្រុកអេស៊ីព្ទសុទ្ធតែមានថ្ងៃកាលបរិច្ឆេទលើកតែសេចក្តីទំនាយមួយប៉ុណ្ណោះ(៣០:១) ។

**២៩:២** *ចូរតាំងមុខឯង* សូមមើលការពន្យល់នៅក្នុង ២០:៤៦ ។ *ផារ៉ោន* ឈ្មោះរបស់ទ្រង់ គឺផារ៉ោន–ហុបរ៉ាដែលទ្រង់ជាស្តេចនៃស្រុកអេស៊ីព្ទនៅឆ្នាំ ៥៨៩–៥៧០ មុន គ.ស (សូមមើល យរ ៤៤:៣០) ។

**២៩:៣** *អញទាស់និងឯង* សូមមើលការពន្យល់នៅក្នុង ៥:៨ ។ *ជាសត្វសំបើម* គឺដូចជាក្រពើ ដែលមាននៅទន្លេនីល (Nile) សូមមើលការពន្យល់ផ្សេងទៀតនៅ យប ៤១:១ ទដ ៧៤:១៣–១៤ អស ២៧:១ ។ *ទន្លេរបស់ខ្លួនអើយ* នៅត្រង់នេះគឺនិយាយពីដីសណ្តនៃទន្លេនីល នឹងដៃទន្លេទាំង ប៉ុន្មាន (ធៀបនឹង អស ៧:១៨ ១៩:៦ ៣៧:២៥) ។

**២៩:៤** *ដាក់ទំពក់* ធៀបនឹង ១៩:៤ ។ *ត្រីទាំងប៉ុន្មានដែលនៅទន្លេឯង* នៅត្រង់ឃ្លានេះមានន័យថា ពួកស្រុកអេស៊ីព្ទជាអ្នកស៊ីឈ្នួលក្នុងការធ្វើសង្គ្រាមបានច្បាំងដណ្តើមទឹកដីជាច្រើននៅយុគសម័យនោះ ។

**២៩:៥** *ជាអាហារដល់អស់ទាំងសត្វនៅដី* មានន័យថា ជាការបំផ្លិចបំផ្លាញយ៉ាងចម្លែកចំពោះសេចក្តីសង្ឃឹមរបស់ស្តេចផារ៉ោនដ៏សម្បើម សម្រាប់ជីវិតក្រោយពីស្លាប់ ដូចជានិមិត្តរូបដែលមានរាងជាប្រដាប់បួនជ្រុង និងសង្កត់ធ្ងន់ទៅលើស្រុកអេស៊ីព្ទ គឺជា" បញ្ជីនៃសេចក្តីស្លាប់" ។

**២៩:៦** *គេជាឈើច្រត់ធ្វើពីបបុស* គឺជាការប្រៀបធៀបនេះមាននៅក្នុងវគ្គមុនដែរ(សូមមើល អស ៣៦:៦ និងការពន្យល់) ។ ហុបរ៉ា នៅត្រង់នេះស្តេចហុបរ៉ាបានធ្វើសង្គ្រាមរយៈពេលខ្លី ប៉ុន្តែមិនបានទទួលជោគជ័យទេ ក្រោយមកពួកពលទ័ពរបស់ផារ៉ោននិងស្តេចបាប៊ីឡូន បានធ្វើការឡោមព័ទ្ធក្រុងយេរូសាឡិម(សូមមើល យរ ៣៧:១–១០) ។

**២៩:៨** *ដាវ* គឺបញ្ជាក់ពីព្រះអម្ចាស់ទ្រង់បានហូតដាវទៅលើស្តេចនេប៊ូក្នេសា (សូមមើល ៥:២ និងការពន្យល់) ។

ទន្លេ[ត]នេះជារបស់ផងអញ គឺអញបានបង្កើតឡើង[ថ] ១០ដូច្នេះ
មើល អញទាស់នឹងឯង[ទ] ហើយនឹងទន្លេទាំងប៉ុន្មានរបស់
ឯងផង អញនឹងធ្វើឱ្យស្រុកអេស៊ីព្ទ[ធ] ទៅជាទីខូចបង់អស់
រលីង ហើយចោលស្ងាត់[ន]នៅចាប់តាំងពីប៉មសីយេន[ប,ផ]
រហូតដល់ព្រំដែនស្រុកអេធីយ៉ូពី[ព] ១១នៅរវាង៤០ឆ្នាំនឹង
គ្មានជើងមនុស្សណា ឬជើងសត្វណាដើរកាត់ស្រុកនោះ
ឡើយ ក៏នឹងគ្មានអ្នកណាអាស្រ័យនៅផង[ភ] ១២អញនឹងធ្វើឱ្យ
ស្រុកអេស៊ីព្ទទៅជាទីស្ងាត់ច្រៀប[ម] នៅកណ្ដាលអស់ទាំង
ស្រុកស្ងាត់ជ្រងំ ហើយអស់ទាំងទីក្រុងនៃស្រុក នឹងនៅស្ងាត់
ច្រៀបអស់៤០ឆ្នាំ នៅកណ្ដាលអស់ទាំងទីក្រុងដែលខូច
បង់នោះ អញនឹងកំចាត់កំចាយពួកសាសន៍អេស៊ីព្ទឱ្យទៅ
នៅកណ្ដាលអស់ទាំងសាសន៍ ហើយបែងចែកគេទៅក្នុង
គ្រប់ទាំងស្រុក[យ]។

១៣ប៉ុន្តែ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា
លុះផុតពី៤០ឆ្នាំទៅ អញនឹងប្រមូលពួកសាសន៍អេស៊ីព្ទ
ពីគ្រប់ទាំងសាសន៍ដែលត្រូវខ្ចាត់ខ្ចាយទៅនោះ ១៤ក៏នឹង
នាំពួកអេស៊ីព្ទដែលនៅជាឈ្លើយឱ្យមកវិញ ហើយឱ្យគេ
ត្រឡប់ទៅនៅឯស្រុកប៉ាត្រូស[រ] ជាស្រុកកំណើតរបស់ផង
ខ្លួន គេនឹងបានជានគរយ៉ាងទាបថោក[ល]នៅទីនោះ[វ] ១៥នគរ
នោះនឹងបានទាបថោកជាអស់ទាំងនគរ ឥតដែលលើក
ខ្លួនឡើងខ្ពស់ជាងនគរផ្សេងៗឡើយ[ស] អញនឹងធ្វើឱ្យគេ
ថយតិចទៅ ដើម្បីមិនឱ្យគេគ្រប់គ្រងលើសាសន៍ដទៃទៀត
១៦នោះពួកវង្សអ៊ីស្រាអែលនឹងលែងទុកចិត្ត[ហ]នឹងគេតទៅ
ជាការដែលរំឭក[ឡ]ពីអំពើទុច្ចរិតរបស់ខ្លួន គ្រប់វេលាណា
ដែលងាកបែរមើលទៅឯគេ[អ] ដូច្នេះ គេនឹងដឹងថា អញ
នេះជាព្រះអម្ចាស់យេហូវ៉ាពិត[ក]។

១៧លុះដល់ថ្ងៃ១ ខែចេត្រ ឆ្នាំទី២៧ នោះព្រះបន្ទូលនៃ
ព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា[ខ] ១៨កូនមនុស្សអើយ នេប៊ូក្នេសា[គ]
ស្ដេចបាប៊ីឡូន បានឱ្យកងទ័ពរបស់ខ្លួន ធ្វើការងារបំរើ
យ៉ាងធំ ទាស់នឹងក្រុងទីរ៉ុស គ្រប់ទាំងក្បាលត្រូវទំពែក[ឃ]
ហើយគ្រប់ទាំងស្មាត្រូវរបក[ង] ប៉ុន្តែ ស្ដេចព្រមទាំងពួក
ពលទ័ពឥតមានកំរៃអ្វីពីក្រុងទីរ៉ុស ដោយការដែលខ្លួន
បានបំរើទាស់នឹងវានោះឡើយ ១៩ហេតុនោះព្រះអម្ចាស់
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មើល អញនឹងឱ្យស្រុក
អេស៊ីព្ទដល់នេប៊ូក្នេសា ជាស្ដេច[ច]បាប៊ីឡូន ស្ដេចនោះនឹង
ដឹកនាំពួកជនទាំងឡាយរបស់ស្រុកនោះ ទៅជាឈ្លើយ
ហើយយករបឹប[ឆ]និងរំពាផង នោះនឹងបានជាបំណាច់ដល់
ពួកកងទ័ពរបស់ខ្លួន[ជ] ២០ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល
ថា អញបានឱ្យស្រុកអេស៊ីព្ទ[ឈ]ដល់គេ ទុកជាបំណាច់នៃការ
ដែលគេបានបំរើនោះ ពីព្រោះគេបានធ្វើការនោះបំរើ
ដល់អញ[ញ]។

២១នៅថ្ងៃនោះ អញនឹងឱ្យស្នែង[ដ]១ប៉ិចឡើង ដល់ពួក
វង្សអ៊ីស្រាអែល ហើយអញនឹងបើកមាត់[ឋ]ឯង នៅកណ្ដាល
ពួកគេ នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ឌ]។

**បទទំនួញអំពីនគរអេស៊ីព្ទ**

**៣០** ១ព្រះបន្ទូល នៃព្រះយេហូវ៉ា បានមកដល់ខ្ញុំថា

**២៩:៩** ត យរ ៤៦:៨ ថ អគ ៣០:៧–៨,១៣–១៩ **២៩:១០** ទ យរ ២១:១៣ ធ នក ៣:២២ ន យរ ៤៦:១៩ ប នក ១៤:២ ផ អគ ៣០:៦ ព អស ១៨:១ អគ ៣០:៤ **២៩:១១** ភ អគ ៣២:១៣ **២៩:១២** ម អស ៣៤:១០ យ យរ ៤៦:១៩ អគ ៣០:៧,២៣,២៦ **២៩:១៤** រ អស ១១:១១ អគ ៣០:១៤ ល អគ ១៤:១៤ វ អស ១៩:២២ **២៩:១៥** ស សក ១០:១១ **២៩:១៦** ហ ២រប ៣២:១០ ឡ ជន ៥:១៥ អ បទ ៤:១៧

ក អស ២០:៥ ៣០:២ ហស ៨:១៣ **២៩:១៧** ខ ខ.១ អគ ២៤:១ ៣០:២០ ៤០:១ **២៩:១៨** គ យរ ២៧:៦ ៣៩:១

ឃ លវ ១៣:៤០ យប ១:២០ យរ ៤៨:៣៧ ង លប ៤៩:១៥ **២៩:១៩** ច អស ១៩:៤ ឆ អគ ២៦:៥ ជ យរ ៤៣:១០–១៣ អគ ៣០:៤,១០,២៤–២៥ ៣២:១១ **២៩:២០** ឈ អស ៤៣:៣ ញ អស ១០:៦–៧ ៤៥:១ យរ ២៥:៩ **២៩:២១** ដ ទដ ១៣២:១៧ លក ១:៦៩ ឋ អគ ៣៣:២២ ឌ អគ ៣:២៧

**២៩:១០** *សីយេន* សព្វថ្ងៃប្រហែលជាស្ថិតនៅភាគខាងត្បូងនៃប្រទេសអេស៊ីព្ទ(សូមមើល យរ ៤៤:១ និងការពន្យល់) ។ *ស្រុកអេធីយ៉ូពី* គឺជាទីក្រុងមួយដែលស្ថិនៅទិសខាងត្បូងប្រទេសអេស៊ីព្ទ"ពីសីយេនទៅអេយ៉ូពី" (សូមមើល ៣០:៦) ។ នៅត្រង់ចំណុចនេះទំនងជាចង់ចង្អុលបង្ហាញពីស្រុកអេស៊ីព្ទទាំងស្រុង ។ "ចាប់ពីដាន់ទៅដល់ បៀរ–សេបា"គឺជាទឹកដីរបស់អ៊ីស្រាអែលទាំងអស់ (សូមមើល ឧទាហរណ៍ ពច ២០:១ ១សយ ៣:២០ និងការពន្យល់ដទៃទៀត) ។

**២៩:១១** *នៅរវាង៤០ឆ្នាំ* នៅត្រង់ចំណុចនេះ ត្រូវបានគេប្រើដើម្បីបញ្ជាក់ប្រាប់ពីរយៈពេលដ៏យូរដែលពួកអ៊ីស្រាអែលឆ្លងកាត់នូវការដ៏លំបាក់នៅក្នុងទីរហោស្ថានអំលុងពេលនោះ(ធៀបនឹង ៤:៦) ។

**២៩:១៤** *ក៏នឹងនាំពួកអេស៊ីព្ទ* គឺនៅភាគខាងត្បូងនៃស្រុកអេស៊ីព្ទ (សូមមើល ៣០:១៤ អស ១១:១១ និងការពន្យល់ យរ ៤៤:១,១៥) ។

**២៩:១៧** នេះជាសេចក្ដីទំនាយជាលើកទីពីរដែលប្រឆាំងទាស់នឹងស្រុកអេស៊ីព្ទ (មើលការពន្យល់ ខ.១) ។ *លុះដល់ថ្ងៃទី១ ខែចេត្រឆ្នាំទី២៧* ដែលត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ ៥៧១ មុន គ.ស ។ នៅថ្ងៃទី៧មាននៅក្នុងព្រះគម្ពីរអេសេគាល (មើល ខ.១ ១:២ ៨:១ ២០:១ ២៤:១ ២៦:១) ។

**២៩:១៨** *បំរើយ៉ាងធំ* នៅត្រង់វគ្គនេះ គឺបញ្ជាក់ពីស្ដេចនេប៊ូនេសាបានឡោមព័ទ្ធទីក្រុងទីរ៉ុសអស់រយៈពេល១៥ឆ្នាំ ដែលចាប់តាំងពីឆ្នាំ ៥៨៦ ទៅដល់ ៥៧១មុន គ.ស(សូមមើល ២៦:៧–១៤) ។ *ព្រមទាំងក្បាលត្រូវទំពែក* នេះប្រហែលជាដោយសារពួកគេពាក់មួកធ្វើពីស្បែកសត្វ ។

**២៩:១៩** *មើលអញនឹងឱ្យ* នេះគឺជាអធិបតេយ្យភាពនៃព្រះដែលទ្រង់បានប្រកាសទាស់ប្រឆាំងមកលើប្រជាជាតិទាំងឡាយ ។

**២៩:២១** *អញនឹងឱ្យស្នែង១ប៉ិចឡើង* គឺបញ្ជាក់ពីការរស់ឡើងវិញ និងការមានកម្លាំងជាថ្មី ។ ដែលជាការចង្អុលបង្ហាញពីព្រះមែស៊ី(គឺប្រែថា ព្រះគ្រីស្ទ) ។ *អញនឹងបើកមាត់ឯង* នៅគ្រានោះហោរាអេសេគាលបានដូចជាមនុស្សគ តែគ្រាក្រោយមកព្រះបានបើកបបូរមាត់របស់គាត់ឡើងវិញ (សូមមើល ៣:២៦ ២៤:២៧) ហើយអណ្ដាតរបស់គេអាចនឹងកំរើកបានដែលដូចជាគិតទុកជាមុន នៅក្នុង ៣៣:២២ ។

**៣០:១** សេចក្ដីទំនាយជាលើកទីបី ដែលទាស់ប្រឆាំងនឹងស្រុកអេស៊ីព្ទ(សូមមើលការពន្យល់នៅក្នុង ២៩:១) ។ គ្មានការផ្ដល់កាលបរិច្ឆេទ ប៉ុន្តែវា

២កូនមនុស្សអើយ ចូរទៅប្រាប់ថា ព្រះអម្ចាស់យេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះ ចូរទ្រហោយំ[ក]ថា ថ្ងៃនោះវេទនាអីម្ល៉េះ
៣ដ្បិតថ្ងៃនោះជិតដល់ហើយ[ខ] គឺជាថ្ងៃនៃព្រះយេហូវ៉ា[គ] បាន
ចូលមកជិតហើយ ជាថ្ងៃមីរស្រទំ គឺជាពេលកំណត់នៃអស់
ទាំងសាសន៍ ៤នឹងមានដាវមកលើស្រុកអេស៊ីព្ទ[ឃ]ហើយ
សេចក្ដីតក់ស្លុតនៅក្នុងស្រុកអេធីយ៉ូពី[ង] គឺក្នុងកាលដែល
មនុស្សត្រូវរបួសដួលនៅក្នុងស្រុកអេស៊ីព្ទ គេនឹងដឹកនាំពួក
ជនទាំងឡាយរបស់វាចេញទៅ ហើយឫសវានឹងត្រូវ
បំផ្លាញបង់[ច] ៥ពួកសាសន៍អេធីយ៉ូពី សាសន៍ពូត[ឆ] សាសន៍
លូឌ និងអស់ទាំងសាសន៍លាយឡំគ្នា[ជ] ព្រមទាំងពួកគូប
ពួកកូនចៅ[ឈ]នៃស្រុកដែលជាមេត្រីមិត្រ គេនឹងដួលដោយ
ដាវទៅជាមួយគ្នា[ញ] ។

៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ឯពួកអ្នកដែល
ទប់ទល់ស្រុកអេស៊ីព្ទ គេនឹងដួលដែរ ហើយទាំងសេចក្ដី
ឆ្មើងឆ្មៃនៃអំណាចវា នឹងត្រូវបន្ទាបចុះផង គេនឹងដួល
ដោយដាវនៅក្នុងស្រុកនោះ ចាប់តាំងពីប៉មស៊ីយេនរហូត
ទៅ[ដ] នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ៧ហើយគេ
នឹងត្រូវស្ងាត់ច្រៀប នៅកណ្ដាលស្រុកទាំងប៉ុន្មាន ដែល
ត្រូវចោលស្ងាត់ អស់ទាំងទីក្រុងរបស់ស្រុកនោះ និងនៅ
ក្នុងពួកទីក្រុងទាំងប៉ុន្មានដែលត្រូវខូចបង់ដែរ[ឋ] ៨ដូច្នេះគេ
នឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត គឺក្នុងកាលដែល
អញបានបង្កាត់ភ្លើង[ឌ]នៅក្នុងស្រុកអេស៊ីព្ទ ហើយអស់អ្នក
ជំនួយរបស់វាបានត្រូវបំផ្លាញទៅ[ឍ] ៩នៅថ្ងៃនោះ ពួកទូត
នឹងចេញពីចំពោះអញ ជិះនាវាទៅបំភ័យដល់ពួកសាសន៍
អេធីយ៉ូពី[ណ] ដែលនៅដោយឥតកង្វល់[ត] នោះនឹងមានសេចក្ដី
តក់ស្លុតគ្របលើគេ ដូចជានៅថ្ងៃរបស់ស្រុកអេស៊ីព្ទដែរ
ដ្បិតមើលន៍ ថ្ងៃនោះមកហើយ[ថ] ។

១០ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា អញ
នឹងធ្វើឱ្យពួកជនទាំងឡាយនៃស្រុកអេស៊ីព្ទផុតទៅ ដោយ
ស្នារដៃនៃនេប៊ូក្នេសា[ទ] ជាស្ដេចបាប៊ីឡូន[ធ] ១១ស្ដេចនោះ
នឹងពួករាស្ត្រផង គឺជាពួកគួរស្ញែងខ្លាចនៅក្នុងអស់ទាំង
សាសន៍[ន] គេនឹងនាំគ្នាមកបំផ្លាញស្រុកអេស៊ីព្ទ ហើយនឹង
ហូតដាវទាស់នឹងស្រុកនោះ ព្រមទាំងបំពេញដោយសាក
សពនៃមនុស្សដែលគេសំឡាប់[ប] ១២អញនឹងពង្រីងអស់[ផ]
ទាំងទន្លេ[ព]ឱ្យរីងស្ងួតទៅ ហើយនឹងលក់ស្រុកនោះ ទៅក្នុង
កណ្ដាប់ដៃនៃមនុស្សអាក្រក់ ក៏នឹងធ្វើឱ្យស្រុកទៅជាស្ងាត់
ច្រៀប[ភ] ព្រមទាំងរបស់ដែលនៅក្នុងស្រុកនោះផង ដោយ
ស្នារដៃនៃពួកអ្នកដទៃ គឺអញនេះ ជាព្រះយេហូវ៉ា អញ
បានចេញវាចាហើយ ។

១៣ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា អញ
នឹងបំផ្លាញអស់ទាំងរូបព្រះ[ម] ហើយនឹងធ្វើឱ្យរូបទាំងអស់
ផុតបាត់ពីក្រុងណូពទៅ[យ] នោះនឹងលែងមានចៅហ្វាយណា
នៅស្រុកអេស៊ីព្ទទៀត[រ] អញនឹងឱ្យសេចក្ដីភ័យខ្លាច គ្រប
លើស្រុកអេស៊ីព្ទ ១៤ហើយនឹងឱ្យស្រុកប៉ាត្រូស នៅស្ងាត់

**៣០:២** ក អស ១៣:៦ យក ៥:១ **៣០:៣** ខ អគ ៧:៧ យអ ១:១៥ ២:១,១១ អប ១:១៥ គ ឧ.១៨ អគ ៧:១២,១៩ ៣២:៧ ៣៤:១២ **៣០:៤** ឃ យរ ២៥:១៩ ងយ ១១:៤៣ ង លប ១០:៦ អគ ២៩:១០ ច អគ ២៩:១៩ **៣០:៥** ឆ អគ ២៧:១០ ជ ២របា ៩:១៤ ឈ យរ ២៥:២០ ញ ណហ ៣:៩ **៣០:៦** ដ អគ ២៩:១០ **៣០:៧** ឋ អគ ២៩:១២ **៣០:៨** ឌ យរ ៤៩:២៧ អគ ៣៩:៦ អម ១:៤,៧,១០ ណហ ១:៦ ឍ អគ ២៩:៩ **៣០:៩** ណ លក ១០:៦ ត អស ២៣:៥ ថ អគ ៣២:៩–១០ សផ ២:១២

**៣០:១០** ទ យរ ៣៩:១ ធ អគ ២៩:១៩ **៣០:១១** ន អគ ២៨:៧ ប ខ.២៤–២៥ **៣០:១២** ផ អស១៩:៦ ព យរ ៤៦:៨ អគ ២៩:៩ ភ អគ ១៩:៧ **៣០:១៣** ម យរ ៤៣:១២ អគ ៦:៦ យ អស ១៩:១៣ រ សក ១០:១១

ប្រហែលជានៅចន្លោះរវាង ខែមករា និងខែមេសា ក្នុងឆ្នាំ ៥៨៧ មុន គ.ស ។ ការប្រៀបធៀបនឹង ២៩:១ និង ៣០:២០ ដែលទីក្រុងយេរូសាឡិម នៅក្រោមការឡោមព័ទ្ធក្នុងសម័យនោះ ។

**៣០:២–៣** *ថ្ងៃនោះ . . . គឺជាថ្ងៃនៃព្រះអម្ចាស់* ថ្ងៃនៃព្រះអម្ចាស់នឹងមកដល់នៅក្នុងការជំនុំជម្រះរបស់ទ្រង់(សូមមើល ៧:៧ និងការពន្យល់) ។ ការជំនុំជម្រះរបស់ស្រុកអេស៊ីព្ទគឺត្រូវបានប្រកាស ។

**៣០:៣** *ដ្បិតថ្ងៃនោះជិតដល់ហើយ* សូមមើល ៧:២–៣,៦ និងការពន្យល់នៅក្នុង ៧:១–២៧ ធៀបនឹង អស ១៣:៦ ។ *ថ្ងៃនៃព្រះយេហូវ៉ាបានចូលមកជិត* ធៀបនឹង យអ ២:២ សផ ។

**៣០:៤** *ដាវ* គឺបញ្ជាក់ថា ព្រះអម្ចាស់នឹងនាំដាវមកលើស្ដេចនេប៊ូក្នេសា ដើម្បីនឹងកាត់ទាំងមនុស្សនិងសត្វចេញពីឯង (សូមមើល ២៩:៨ និងការពន្យល់) ។

**៣០:៥** *សាសន៍ពូត សាសន៍អេធីយ៉ូពី* សាសន៍ទាំងពីរនេះគឺស្ថិតនៅអាហ្វ្រិកខាងជើង(សូមមើលការពន្យល់នៅក្នុង ២៧:១០) ។ *សាសន៍លូឌ* សូមមើល ២៧:១០ និងការពន្យល់ ។ សាសន៍អេធីយ៉ូពី នៅក្នុងព្រះគម្ពីរភាសាហេព្រើរ ហៅថា សាសន៍គូប ។ *ពួកកូនចៅនៃស្រុកដែលជាមេត្រីមិត្រ* នៅត្រង់វគ្គនេះ គឺជាការមើលឃើញយ៉ាងជាក់ស្ដែងពីការរស់នៅរបស់ពួកយូដានៅក្នុងស្រុកអេស៊ីព្ទ(សូមមើល យរ ៤៤ និងការពន្យល់នៅក្នុង ៤៤:១ ) ។

**៣០:៦** *ចាប់តាំងពីប៉មស៊ីយេន រហូតទៅ* សូមមើលការពន្យល់នៅក្នុង ២៩:១០ ។

**៣០:៨** *បង្កាត់ភ្លើង* សូមមើលការពន្យល់នៅក្នុង ២០:៤៧ ។

**៣០:៩** *ពួកទូត . . . ជិះនាវា* សូមមើល អស ១៨ ស្រដៀងនឹងសេចក្ដីទំនាយមកលើពួកសាសនន៍អេធីយ៉ូពី ដែលជាប់ទាក់ទងជាមួយនាវានៅទន្លេនីល ។

**៣០:១១** *គួរស្ញែងខ្លាចនៅក្នុងអស់ទាំងសាសន៍* ជាធម្មតានៅត្រង់ឃ្លានេះគឺបញ្ជាក់ពីពួកស្រុកបាប៊ីឡូន ដែលបានដឹងពីការកាចសាហាវ និងអំពើឃោរឃៅនៅចំពោះពួកគេ (សូមមើល ២ពរ ២៥:៧) ។

**៣០:១៣** *រូបព្រះ* សូមមើលការពន្យល់នៅក្នុង ៦:៤ ។ *ក្រុងណូព* គឺជាតំបន់មួយដែលមានចម្ងាយ២៤គីឡូម៉ែត្រស្ថិតនៅភាគខាងត្បូងនៃទីក្រុងកៃរ៉ូ Cairo) អតីតក្រុងណូពគឺជារាជធានីមួយរបស់ប្រទេសអេស៊ីព្ទ ដែលជាទីក្រុងធំជាងគេនៅក្នុងចំណោមទីក្រុងទាំងឡាយ ។ ឈ្មោះទីក្រុងទាំងឡាយគឺមិនបានបង្ហាញឱ្យដឹងពីភូមិសាស្ត្រទេ ប៉ុន្តែមានគំនូរមានលក្ខណៈជាអក្សរសាស្ត្រដែលបានប្រើនៅក្នុងរូបិយបណ៌ដើម្បីគូសបញ្ជាក់ពីព្រំដែននៃការធ្វើឱ្យវិនាស (ធៀបនឹង អស ១០:៩–១១ ២៧–៣២ មីក ១:១០–១៥ សផ ២:៤) ។ *ចៅហ្វាយ* នៅត្រង់នេះគឺបញ្ជាក់ពីស្ដេច ។

ច្រៀប[ល] ព្រមទាំងបង្កាត់ភ្លើងនៅស្រុកសូអាន[វ] ហើយ
សំរេចសេចក្ដីយុត្តិធម៌ដល់ក្រុងនរផង[ស] ១៥អញនឹងចាក់
សេចក្ដីឃោរឃៅរបស់អញទៅលើស្រុកសីន ជាទីមាំមួន
របស់ស្រុកអេស៊ីព្ទ ហើយនឹងកាត់ពួកបណ្ដាជនទីក្រុងនរ
ចេញ ១៦អញនឹងបង្កាត់ភ្លើង[ហ]នៅស្រុកអេស៊ីព្ទ ស្រុកសីននឹង
មានសេចក្ដីតក់ស្លុតយ៉ាងខ្លាំង ក្រុងនរនឹងត្រូវបាក់បែក
ហើយពួកខ្មាំងសត្រូវនឹងចូលក្រុងណូព[ឡ]ទាំងថ្ងៃ ១៧ពួក
កំឡោះៗ នៃក្រុងអាវេន[អ] និងក្រុងភី–បេសែតគេនឹង
ដួលចុះដោយដាវ ទីក្រុងទាំងនោះនឹងត្រូវដឹកនាំទៅជា
ឈ្លើយ ១៨នៅត្រង់ក្រុងតាហាពេនេស[ក] នោះថ្ងៃនឹងត្រូវ
ងងឹតក្នុងកាលដែល អញបំបាក់នឹមនៃស្រុកអេស៊ីព្ទនៅទី
នោះ[ខ] ហើយសេចក្ដីឆ្មើងឆ្មៃនៃអំណាចគេ នឹងផុតទៅ
ចំណែកស្រុកនោះ នឹងមានពពកគ្របបាំងពីលើ ហើយពួក
កូនស្រីទាំងប៉ុន្មាន នឹងត្រូវដឹកនាំទៅជាឈ្លើយ[គ] ១៩គឺយ៉ាង
ដូច្នោះដែលអញនឹងសំរេចសេចក្ដីយុត្តិធម៌[ឃ] ដល់ស្រុក
អេស៊ីព្ទ នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ។
២០លុះដល់ថ្ងៃ៧ ខែចេត្រ ឆ្នាំទី១១ នោះព្រះបន្ទូលនៃ
ព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា[ង] ២១កូនមនុស្សអើយ អញបាន
បំបាក់ដៃ[ច]ផារ៉ោន[ឆ] ជាស្ដេចស្រុកអេស៊ីព្ទ ក៏ឥតមានអ្នក
ណានឹងមើល[ជ] ដើម្បីនឹងលាបថ្នាំ ហើយរុំអបឱ្យមានកំឡាំង
អាចកាន់ដាវទៀតបានឡើយ ២២ហេតុនោះព្រះអម្ចាស់
យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា មើល អញទាស់នឹង
ផារ៉ោន ជាស្ដេចក្រុងអេស៊ីព្ទ[ឈ] អញនឹងបំបាក់ដៃវាទាំង
សងខាង គឺដៃដែលនៅមាំ និងដៃដែលបាក់ហើយ នោះផង
អញនឹងធ្វើឱ្យដាវធ្លាក់ចុះពីដៃវា[ញ] ២៣ហើយអញនឹងកំចាត់
កំចាយពួកសាសន៍អេស៊ីព្ទ ឱ្យទៅនៅកណ្ដាលអស់ទាំង
សាសន៍ ព្រមទាំងបែងចែកគេទៅក្នុងគ្រប់ទាំងស្រុក[ដ]
២៤អញនឹងចំរើនកំឡាំង[ឋ]ដៃនៃស្ដេចបាប៊ីឡូន ហើយដាក់
ដាវ[ឌ]អញទៅក្នុងដៃវា តែអញនឹងបំបាក់ដៃទាំង២របស់
ផារ៉ោនវិញ ដូច្នេះ វានឹងថ្ងូរ[ឍ]នៅមុខស្ដេចបាប៊ីឡូន ដោយ
ដំងូរនៃមនុស្សដែលត្រូវរបួសដល់ស្លាប់ ២៥អញនឹងជ្រោង
ដៃរបស់ស្ដេចស្រុកបាប៊ី–ឡូន តែដៃរបស់ផារ៉ោននឹងធ្លាក់
ចុះវិញ នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុង
កាលដែលអញដាក់ដាវ[ណ]របស់អញ ទៅក្នុងដៃរបស់ស្ដេច
បាប៊ីឡូន ហើយវាបានលូកដាវនោះ ទៅលើស្រុកអេស៊ីព្ទ[ត]
២៦អញនឹងកំចាត់កំចាយពួកសាសន៍អេស៊ីព្ទ ឱ្យទៅនៅ
កណ្ដាលអស់ទាំងសាសន៍ ព្រមទាំងបែងចែកគេ ឱ្យទៅនៅ
គ្រប់ទាំងស្រុក នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ា
ពិត[ថ] ។

## ដើមតាត្រៅនៅព្រៃល្បាណូន

**៣១** ១លុះដល់ថ្ងៃ១ ខែជេស្ឋ ឆ្នាំទី១១[ក] នោះព្រះបន្ទូល

**៣០:១៤** ល អគ ២៩:១៤ វ ជន ១៣:២២ ស យរ ៤៦:២៥ **៣០:១៦** ហ យស ៧:១៥ ឡ អស ១៩:១៣ **៣០:១៧** អ លប ៤១:៤៥ **៣០:១៨** ក យរ ៤៣:៧ ខ លវ ២៦:១៣ អស ៩:៤ គ ខ.៣ **៣០:១៩** ឃ អគ ២៨:២២ **៣០:២០** ង អគ ២៦:១ ២៩:១៧ ៣១:១ ៣២:១ **៣០:២១** ច យរ ៤៨:២៥ ឆ យរ ៤៤:៣០ ជ យរ ៣០:១៣ ៤៦:១១ **៣០:២២** ឈ លប ១៥:១៨ យរ ៤៦:២៥ ញ ទដ ៣៧:១៧ សក ១១:១៧ **៣០:២៣** ដ អគ ២៩:១២

**៣០:២៤** ឋ សក ១០:៦,១២ ១២:៥ ឌ អគ ២១:១៤ សផ ២:១២ ឍ យរ ៥១:៥២ **៣០:២៥** ណ ១របា ២១:១២ ត អស ១០:៥ ៤៥:១,៥ អគ ២៩:១៩ **៣០:២៦** ថ អគ ២៩:១២ **៣១:១** ក យរ ៥២:៥

**៣០:១៤** *ស្រុកប៉ាត្រូសនៅស្ងាត់ច្រៀប* សូមមើល ២៩:១៤ និងការពន្យល់ ។ *ស្រុកសូអាន* គឺជាទីក្រុងមួយដែលនៅភាគទិសឦសាន (ខាងជើងឆៀងខាងកើត) នៃប្រទេសអេស៊ីព្ទដែលជាដំបន់ដីសណ្ដ និងត្រូវបានគេហៅថាទីក្រុងរ៉ាមសេស (សូមមើល លប ៤៧:១១ និងការពន្យល់ នក ១:១១) ។ មិនតែប៉ុណ្ណោះគឺត្រូវបានគេហៅឈ្មោះទីក្រុងនោះទៀតថា ទីក្រុងអាវ៉ារិស ហើយនិង ទីក្រុងតានិសផងដែរ (Avaris and Tanis) (សូមមើល អស ១៩:១១,១៣ ៣០:៤ ហើយនិង ការពន្យល់ដទៃទៀត) ។ *ក្រុងនរ* វាជារាជធានីមួយដែលមានភាពល្បីល្បាញជាងគេនៃប្រទេសអេស៊ីព្ទហើយសព្វថ្ងៃនេះ មានឈ្មោះថា ទីក្រុងឡុកស៊ើរ ហើយនិង ក្រុងការណាក់ (Luxor and Karnak) ។

**៣០:១៥** *ស្រុកសីន* ស្រុកនេះគឺជាបន្ទាយទ័ពដែលនៅទិសបូព៌ា (ទិសខាងកើត) ស្ថិតនៅតាមដីសណ្ដនៃដងទន្លេរនីល ។

**៣០:១៧** *ក្រុងអាវេន* ឈ្មោះជាភាសាក្រិកមានន័យថា "ទីក្រុងព្រះអាទិត្យ" ជាតំបន់មួយដែលមានចម្ងាយប្រហែល៩គីឡូម៉ែត្រនៅទិសឦសាន (ខាងជើងឆៀងខាងកើត) ទីក្រុងកៃរ៉ូ(Cairo) ដែលជារាជធានីនៃប្រទេសអេស៊ីព្ទសព្វថ្ងៃនេះ ។ *ក្រុងភី–បេសែត* នៅសម័យមួយនោះវាគឺជារាជធានីដែលមិនសូវមានភាពល្បីល្បាញឡើយហើយក្រុងនោះស្ថិតនៅទិសខាងជើងនៃប្រទេសអេស៊ីព្ទ ជាតំបន់មួយមានចម្ងាយប្រហែល៦៤គីឡូម៉ែត្រ នៅទិសឦសាន (ខាងជើងឆៀងខាងកើត) នៃទីក្រុងកៃរ៉ូ (Cairo) ។

**៣០:១៨** *ងងឹត* ជាធម្មតានៅក្នុងព្រះគម្ពីរគឺជាពាក្យប្រៀបធៀប ដែលជាការរៀបរាប់ពីសេចក្ដីហិនវិនាស ឬបង្ហាញប្រាប់ពីសេចក្ដីស្លាប់ ។ *ក្រុងតាហាពេនេស* គឺជាក្រុងដែលស្ថិតនៅទិសឦសាន (ខាងជើងឆៀងខាងកើត) នៃប្រទេសអេស៊ីព្ទ ។ *ពពកគ្របបាំងពីលើ* សូមមើល ខ. ៣ និងការពន្យល់ ៣២:៧ ។

**៣០:២០** នេះជាសេចក្ដីទំនាយលើកទីបួនដែលទាស់ប្រឆាំងនឹងស្រុកអេស៊ីព្ទ (សូមមើលការពន្យល់នៅក្នុង ២៩:១) ។ *ថ្ងៃទី៧ ខែចេត្រ ឆ្នាំទី ១១* គឺត្រូវនឹងថ្ងៃទី ២៩ ខែមេសា ឆ្នាំ ៥៨៧ មុន គ.ស ត្រូវជាថ្ងៃទី ៨ ដែលបានចុះកាលបរិច្ឆេទនៅក្នុងព្រះគម្ពីរអេសេគាល (សូមមើល ១:២ ៨:១ ២០:១ ២៤:១ ២៦:១ ២៩:១,១៧) ។

**៣០:២១** *អញបានបំបាក់ដៃ* នៅត្រង់នេះជាការបញ្ជាក់សំដៅទៅលើស្ដេចផារ៉ោន–ហុបរ៉ាបានបរាជ័យដោយសារស្ដេចនេប៊ូក្នេសាច្បាំងឈ្នះនៅគ្រាយុគសម័យនោះ (សូមមើលការពន្យល់ ២៩:៦ យរ ៣៧:១០) ។

**៣០:២៤** *ដាក់ដាវអញទៅក្នុងដៃវា* សូមមើលការពន្យល់នៅក្នុង ២១:៣ ។

**៣០:២៥** *អញដាក់ដាវ* សូមមើល ៥:២ និងការពន្យល់ ។

**៣១:១** សេចក្ដីទំនាយទី៦ ជិទាស់ប្រឆាំងនឹងស្រុកអេស៊ីព្ទ (មើលការពន្យល់ ២៩:១) ។ *នៅថ្ងៃទី១ ខែជេស្ឋ ឆ្នាំទី១១* ត្រូវជាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ៥៨៧

នៃព្រះយេហូវ៉ាបានមកដល់ខ្ញុំថា[ខ] ២កូនមនុស្សអើយ ចូរ
ប្រាប់ដល់ផារ៉ោន ស្តេចស្រុកអេស៊ីព្ទ និងពួកកកកុញរបស់
វាថា ដែលឯងធំទាំងម្ល៉េះ នោះតើធៀបដូចជាអ្វី ៣មើលពី
ដើមពួកសាសន៍អាសសើរ[គ] គេជាដើមតាត្រៅនៅព្រៃ
ល្បាណូន[ឃ] មានមែកល្អ ហើយស៊ុបទ្រុបបាំងម្លប់ ក៏មាន
សណ្ឋានខ្ពស់ ហើយកំពូលនៅកណ្តាលមែកញឹកស្អិត[ង] ៤ទឹក[ច]
ទាំងឡាយបានចំរើនដើមនោះ ហើយទីជំរៅបានធ្វើឱ្យ
លូតឡើង ទន្លេទាំងប៉ុន្មានក៏ហូរព័ទ្ធជុំវិញកន្លែងរបស់វា
ព្រមទាំងបង្ហូរផ្លូវទឹក ទៅដល់គ្រប់ទាំងដើមឈើ នៅដីនោះ
ផង[ឆ] ៥ហេតុនោះបានជាវាលូតខ្ពស់ជាង[ជ]អស់ទាំងដើម
ឈើនៅផែនដី មែកវាចំរើនជាច្រើនឡើង ហើយក៏លូត
ចេញវែង ដោយមានទឹកជាច្រើន ក្នុងកាលដែលបែកមែក
ទាំងនោះ[ឈ] ៦អស់ទាំងសត្វហើរលើអាកាសបានធ្វើសំបុក
នៅមែកវា ហើយគ្រប់ទាំងសត្វនៅដីបានបង្កើត[ញ] កូននៅ
ក្រោមមែកវា ឯអស់ទាំងសាសន៍ធំៗ ក៏អាស្រ័យនៅក្រោម
ម្លប់វាដែរ[ដ] ៧យ៉ាងនោះវាបានល្អមើល ដោយព្រោះធំខ្ពស់
ហើយមានមែកវែង ដ្បិតឫសវានៅក្បែរទឹកជាច្រើន[ឋ]
៨អស់ទាំងដើមតាត្រៅ[ឌ] ដែលនៅសួនច្បារនៃព្រះ នឹងបិទ
បាំងមិនបាន ដើមកកោះទាំងប៉ុន្មានមិនប៉ុនមែកវា ហើយ
ដើមសុក្រ[ឍ]មក៏មិនស្មើនឹងមែកវាដែរ ឥតមានដើមឈើ
ណាមួយ ក្នុងសួនច្បារនៃព្រះ ដែលមានលំអដូចវាឡើយ[ណ]
៩អញបានធ្វើឱ្យវាល្អ ដោយមានមែកជាបរិបូរ ដល់ម្ល៉េះ
បានជាអស់ទាំងដើមឈើនៅអេដែន[ត] គឺនៅសួនច្បារនៃ
ព្រះបានច្រណែននឹងវា[ថ]។

១០ហេតុនោះ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូល
ដូច្នេះថា ដោយព្រោះឯងបានធំឡើងយ៉ាងខ្ពស់ ហើយ
មានកំពូលលូតឡើងនៅកណ្តាលមែកញឹកស្អិត ហើយ
មានចិត្តប៉ោងឡើង[ទ]ដោយសារកំពស់នោះ ១១នោះអញ
បានប្រគល់ទៅ ក្នុងកណ្តាប់ដៃនៃអ្នកដ៏ខ្លាំងពូកែរបស់អស់
ទាំងសាសន៍ អ្នកនោះនឹងប្រព្រឹត្តនឹងវា តាមអំពើអាក្រក់
របស់វា អញបានបណ្តេញវាចេញហើយ[ធ] ១២ពួកសាសន៍
ដទៃ ជាពួកគួរស្ញែងខ្លាចនៃអស់ទាំងសាសន៍[ន] បានកាត់វា
ចេញ ហើយបោះបង់ចោល មែកវាបានធ្លាក់នៅលើភ្នំ
ទាំងប៉ុន្មាន[ប] ហើយនៅអស់ទាំងច្រកភ្នំដែរ មែកវាទាំង
ប៉ុន្មានត្រូវបាក់តាមអស់ទាំងផ្លូវទឹកនៅស្រុកនោះ ហើយ
អស់ទាំងសាសន៍នៅផែនដីបានថយចុះពីម្លប់វា ទាំងចោល
វាទុកនៅ[ផ] ១៣ឯសត្វហើរលើអាកាស នឹងមកអាស្រ័យនៅ
លើបំណែក ហើយអស់ទាំងសត្វនៅដីនឹងមកអាស្រ័យ
នៅលើមែកវា[ព] ១៤ប្រយោជន៍មិនឱ្យអស់ទាំងដើមឈើ
ដែលដុះនៅក្បែរទឹកបានដំកើងខ្លួន ដោយមានកំពស់ ឬ
លូតកំពូលឡើងដល់ក្នុងមែកញឹកស្អិតឡើយ ហើយមិនឱ្យ
ដើមណាដែលបឺតទឹកបានឈរឡើង ដោយមានសណ្ឋាន
ខ្ពស់ដែរ ដ្បិតវាត្រូវប្រគល់[ភ]ដល់សេចក្តីស្លាប់ទាំងអស់[ម] គឺ
ដល់ទីទាបបំផុតក្នុងផែនដី ឱ្យនៅកណ្តាលពួកមនុស្សជាតិ
ជាមួយនឹងពួកមនុស្សដែលចុះទៅក្នុងជង្ហុកធំ[យ]។

១៥ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា នៅ
ថ្ងៃដែលវាចុះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះ
អញបានឱ្យគេយំសោក អញបានគ្របទីជំរៅដោយព្រោះ វា
ក៏បានបង្ខាំងទន្លេ ហើយទឹកធំបានឈប់ទ្រឹង អញបាន
ឱ្យព្រៃល្បាណូនយំសោកនឹងវា ហើយអស់ទាំងដើមឈេ
នៅផែនដី បានរោយរៀវទៅដោយព្រោះវា[រ] ១៦អញបាន
ធ្វើឱ្យអស់ទាំងសាសន៍ញាប់ញ័រ[ល] ដោយឮសូរវារលំ ក្នុង

**៣១:១** ខ អគ ៣០:២០ ៣២:១៧ **៣១:៣** គ យរ ៥០:១៨ ឃ ២ពវ ១៩:២៣ ហប ២:១៧ សក ១១:១ ង អស ១០:៣៤ អគ ១៩:១១ **៣១:៤** ច អគ ១៧:៧ ឆ ដយ ៤:១០ **៣១:៥** ជ ឌ.១០ ឈ ជន ២៤:៦ អគ ១៧:៥ **៣១:៦** ញ លប ៣១:៧–៩ ដ អគ ១៧:២៣ មថ ១៣:៣២ **៣១:៧** ឋ យប ១៤:៩ **៣១:៨** ឌ ទដ ៨០:១០ ឍ លប ៣០:៣៧ ណ លប ២:៨–៩ **៣១:៩** ត លប ២:៨ ថ លប ១៣:១០ អគ ២៨:១៣ **៣១:១០** ទ អស ២:១១ ១៤:១៣–១៤ អគ ២៨:១៧ **៣១:១១** ធ ដយ ៥:២០ **៣១:១២** ន អគ ២៨:៧ប អគ ៣២:៥ ៣៥:៨ ផ អគ ៣២:១១–១២ ដយ ៤:១៤ **៣១:១៣** ព អស ១៨:៦ អគ ២៩:៥ ៣២:៤ **៣១:១៤** ភ ទដ ៤៩:១៤ ម ទដ ៨២:៧ យ ជន ១៤:១១ ទដ ៦៣:៩ អគ ២៦:២០ ៣២:២៤ **៣១:១៥** រ ២សយ ១:២១ **៣១:១៦** ល យរ ៤៩:២១

មុន គ.ស ជាថ្ងៃទី៩ នៅជំនាន់ស្តេចសេដេគាល (មើល ១:២ ៨:១ ២០:១ ២៤:១ ២៦:១ ២៩:១,១៧ ៣០:២០)។

**៣១:៣** *ពួកសាសន៍អាសសើរ* ជាជនជាតិមួយយ៉ាងធំដែលបានដួលរលំនៅក្នុងឆ្នាំ៦០៩ មុន គ.ស។ ស្តេចផារ៉ោន–នេកោ និងកងទ័ពរបស់ទ្រង់បានធ្វើសមយុទ្ធនៅប៉ែកខាងជើង ដើម្បីជួយពួកសាសន៍អាសសើរ ដែលបាក់ទ័ពពីការវាយប្រហាររបស់ពួកបាប៊ីឡូន ។ ពួកគេបានបរាជ័យ ហើយពួកសាសន៍ អាសសើរបានផ្លងផុតពីប្រវត្តិសាស្ត្រនេះ ។ *ដើមតាត្រៅ* ជាការចាប់ផ្តើមប្រើពាក្យប្រៀបធៀបមួយផ្សេងទៀត (មើលនៅក្នុងព្រះ គម្ពីរអេសេគាល បានប្រើពាក្យប្រៀបធៀប អំពីដើមតាត្រៅនេះ នៅក្នុងជំពូក ១៧) ។ ព្រៃល្បាណូន ដែលគេស្គាល់វាថា ជាព្រៃដើមតាត្រៅ(មើលក្នុង ឌ.១៥–១៨ ពច ៩:១៥ ១ពវ ៤:៣៣ ៥:៦ ២ពវ ១៤:៩ អរ ៣:៧ ទដ ២៩:៥ ៩២:១២ ១០៤:១៦) ។

**៣១:៤** *ទឹក* ទឹកទន្លេហីដេកែល និងទឹកទន្លេអើប្រាត ឬ "ទីជម្រៅទឹក" (មើលការពន្យល់) ។

**៣១:៦** *សត្វហើរលើអាកាស* មើល ១៧:២៣ និងការពន្យល់ ។

**៣១:៨** *សួនច្បារនៃព្រះ* ធៀបនឹង ២៨:១៣ ។

**៣១:១១** *អ្នកដ៏ខ្លាំងពូកែរបស់អស់ទាំងសាសន៍* ប្រហែលជាពួកនាបូប៉ូឡាសា ឬអាចជាស្តេចនេប៊ូក្នេសា ។ *អំពើអាក្រក់របស់វា* សេចក្តីអំនួត (សូមមើល ឌ.១០ លប ១១:១–៨) ។

**៣១:១២** *ពួកគួរស្ញែងខ្លាច ជាពួកបាប៊ីឡូន* (មើលការពន្យល់ ៣០:១១) ។

**៣១:១៤** *ជង្ហុកធំ* ស្ថានឃុំព្រលឹងមនុស្សស្លាប់ "ដីនៅខាងក្រោម" (មើលការពន្យល់ ទដ ១០៩:២៩) ។

**៣១:១៥** *ទីជម្រៅទឹក* មើល ឌ.៤ និងការពន្យល់ ២៦:១៩ ។ *បានបង្ខាំង . . . យំ សោកនឹងវា* មើលការពន្យល់ ទដ ១០៩:១៩ ។

កាលដែលអញបានបោះវា ទៅក្នុងស្ថានឃុំព្រលឹងមនុស្ស
ស្លាប់ ជាមួយនឹងពួកអ្នកដែលចុះទៅក្នុងជង្ហុកធំ អស់ទាំង
ដើមឈើ[វ]នៅអេដែន[ស] និងដើមជ្រើសរើស ហើយល្អបំផុត
នៅព្រៃល្បាណូន គឺគ្រប់ទាំងដើមឈើដែលបឺតទឹក នោះ
មានសេចក្ដីក្សាន្តចិត្ត[ហ] នៅទីទាបបំផុតក្នុងផែនដី[ឡ] ១៧ពួក
ទាំងនោះក៏ចុះទៅឯស្ថានឃុំព្រលឹងមនុស្សស្លាប់ ជាមួយនឹង
វា ដល់ពួកអ្នកដែលត្រូវស្លាប់ដោយដាវ គឺជាពួកអ្នកជា
ដៃរបស់វា ដែលបានជ្រកក្រោមម្លប់របស់វា នៅកណ្ដាល
អស់ទាំងសាសន៍[អ]។
១៨ដូច្នេះ តើឯងប្រៀបផ្ទឹមនឹងសិរីល្អ ហើយសណ្ឋាន
ខ្ពស់របស់ដើមណា ក្នុងអស់ទាំងដើមឈើនៅអេដែននោះ
ទោះបើយ៉ាងណាក៏ដោយ គង់តែឯងនឹងត្រូវចុះទៅឯទីទាប
បំផុតក្នុងផែនដី ជាមួយនឹងពួកដើមឈើ ដែលនៅអេដែន
ទាំងប៉ុន្មានដែរ ឯងនឹងដេកនៅក្នុងពួកអ្នកដែលមិនកាត់
ស្បែក[ក] ជាមួយនឹងអស់អ្នកដែលត្រូវស្លាប់ដោយដាវ នេះ
ឯងគឺជាផារ៉ោន និងពួកកកកុញរបស់វាផង នេះជាព្រះ
បន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ។

## បទទំនួញអំពីស្ដេចផារ៉ោន

**៣២** ១លុះដល់ថ្ងៃទី១ខែផល្គុន ក្នុងទី១២ នោះព្រះបន្ទូល
នៃព្រះយេហូវ៉ាបានមកដល់ខ្ញុំថា[ក] ២កូនមនុស្ស អើយ ចូរ
ផ្ដើមពាក្យទំនួញ[ខ]ពីដំណើរផារ៉ោន ជាស្ដេចស្រុកអេស៊ីព្ទ
ហើយប្រាប់វាថា ពីដើមឯងប្រៀបដូចជាសិង្ហស្ទាវ[គ] របស់
សាសន៍ទាំងប៉ុន្មាន ហើយដូចជាសត្វសំបើម[ឃ]នៅក្នុង
សមុទ្រ[ង] ឯងបានធ្លាយចេញមកជាមួយនឹងទន្លេទាំងប៉ុន្មាន
របស់ឯង ហើយបានធ្វើឱ្យទឹកខ្វល់ឡើងដោយជើងឯង
ព្រមទាំងឱ្យទន្លេគេល្អទាំងអស់ផង[ច] ៣ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះថា អញនឹងលាតលប់អញគ្របលើ
ឯង ដោយសារហ្វូងមនុស្សយ៉ាងធំ គេនឹងទាញឯងឡើង
មកជាប់ក្នុងលប់របស់អញ[ឆ] ៤នោះអញនឹងទុកឯងចោល
នៅលើដីគោក អញនឹងបោះឯងចោលទៅលើទីវាលទទេ
ហើយនឹងឱ្យសត្វហើរលើអាកាសទាំងប៉ុន្មាន មកទំលើឯង
ក៏នឹងចំអែតសត្វនៅដីទាំងមូល ដោយសារឯងដែរ[ជ] ៥អញ
នឹងដាក់សាច់ឯងនៅលើភ្នំ ហើយបំពេញច្រកភ្នំ[ឈ]ទាំងអស់
ដោយគំនរសាកសពឯងដែរ ៦អញនឹងស្រោចផែនដី ជា
កន្លែងឯងហែលទឹកនោះ ដោយឈាម[ញ]របស់ឯង រហូត
ដល់អស់ទាំងភ្នំផង ហើយទាំងផ្លូវទឹកនឹងមានពេញដោយ
ឯងដែរ[ដ] ៧កាលណាអញពន្លត់ឯង នោះអញនឹងបាំងផ្ទៃ
មេឃ ហើយធ្វើឱ្យផ្កាយងងឹតទៅ អញនឹងបាំងថ្ងៃដោយ
ពពក ហើយខែនឹងលែងភ្លឺដែរ[ឋ] ៨ឯអស់ទាំងតួពន្លឺនៅលើ
មេឃ នោះអញនឹងធ្វើឱ្យងងឹតទៅ[ឌ]ដោយព្រោះឯង ព្រម
ទាំងគ្របស្រុកឯងដោយងងឹតផង[ឍ] នេះជាព្រះបន្ទូលនៃព្រះ
អម្ចាស់យេហូវ៉ា ៩អញនឹងបណ្ដាលឱ្យចិត្តនៃមនុស្សជាច្រើន
តក់ស្លុត ក្នុងកាលដែលអញនាំដំណឹង ពីការវិនាសរបស់
ឯង ទៅកណ្ដាលអស់ទាំងសាសន៍ គឺទៅក្នុងស្រុកទាំង

**៣១:១៦** វ អស ១៤:៨ ស លប ២:៨ ហ អគ ១៤:២២ ឡ អស ១៤:១៥ អគ ៣២:១៨
**៣១:១៧** អ ទដ ៩:១៧
**៣១:១៨** ក យរ ៩:២៦
**៣២:១** ក អគ ៣១:១ ៣៣:២១
**៣២:២** ខ ២សយ ១:១៧ ៣:៣៣ ២រប ៣៥:២៥ អគ ១៩:១ គ ២ពវ ២៤:១ ណហ ២:១១–១៣ ឃ យប ៣:៨ ទដ ៧៤:១៣ ង លប ១:២១ ច ខ.១៣ យប ៤១:៣១ អគ ២៩:៣ ៣៤:១៨
**៣២:៣** ឆ អគ ១២:១៣ ហប ១:១៥
**៣២:៤** ជ អស ១៨:៦ អគ ៣១:១២–១៣ ៣៩:៤–៥,១៧
**៣២:៥** ឈ អគ ៣១:១២
**៣២:៦** ញ អស ៣៤:៣ ដ អគ ២៩:៥
**៣២:៧** ឋ អស ១៣:១០ ៣៤:៤ អគ ៣០:៣ យអ ២:២,៣១ ៣:១៥ មថ ២៤:២៩ វវ ៨:១២ **៣២:៨** ឌ ទដ ១០២:២៦ ឍ យប ៩:៧ យរ ៤:២៣ យអ ២:១០

**៣១:១៦** *អស់ទាំងសាសន៍ញាប់ញ័រ* ដូចជាការដួលរលំនៃស្ដេចស្រុកទីរ៉ុស (មើលការពន្យល់ ២៧:៣៥ ២៨:១៩ ។ *មានសេចក្ដីក្សាន្តចិត្ត* កំលាំងនៃដើមទាំងនោះបាននៅជាមួយគេក្នុង "ស្ថានឃុំមនុស្សស្លាប់" ស្ថានមច្ចុរាជ (Sheol) ។

**៣១:១៧** *ពួកអ្នកដែលត្រូវស្លាប់ដោយដាវ* អស់អ្នកដែលគេបានសម្លាប់ទាំងនៅអាយុមិនទាន់គ្រប់ខែ ។

**៣១:១៨** *ឯង* ផារ៉ោន ស្ដេចស្រុកអេស៊ីព្ទ ។ គង់តែ*ឯង* វាបានកើតឡើងចំពោះផារ៉ោន ដូចជាបានកើតឡើងចំពោះពួកអាសសើរផងដែរ ។ *ពួកអ្នកមិនកាត់ស្បែក* មើលការពន្យល់ ២៨:១០ ។

**៣២:១** សេចក្ដីទំនាយលើកទី៦ទាស់ប្រឆាំងនឹងស្រុកអេស៊ីព្ទ (មើលការពន្យល់ ២៩:១) ។ *ថ្ងៃទី០១ ខែផល្គុន ក្នុងឆ្នាំទី១២* ត្រូវនឹងថ្ងៃទី០៣ ខែមិនា ឆ្នាំ ៥៨៥ មុន គ.ស ជាថ្ងៃទី១០ ក្នុងសម័យកាលស្ដេចហេសេគាល (មើល ១:២ ៨:១ ២៦:១ ២៩:១ ១៧ ៣០:២០ ៣១:១)។ បើសិនការបកប្រែថ្មី (ការបកប្រែភាសាក្រិករបស់គ្រីស្ទានជំនាន់មុននៅសញ្ញាចាស់) ("ឆ្នាំទី១១") ទៅតាមសម័យកាល តាមប្រភេទនៃសេចក្ដីទំនាយពីស្រុកអេស៊ីព្ទ នៅមាន (ហើយកាលបរិច្ឆេទត្រូវចំនឹងថ្ងៃទី១៣ ខែមិនា ឆ្នាំ៥៨៦) ធៀបនឹង ២៩:១ ៣០:២០ ៣១:១ មើល ខ.១៧ និងការពន្យល់ ។

**៣២:២** *ពាក្យទំនួញ* មើលការពន្យល់ ១៩:១ ។ *ឯងប្រៀបដូចជាសិង្ហស្ទាវរបស់សាសន៍ទាំងប៉ុន្មាន* ចង្អុលបង្ហាញពីភាពស្មោះត្រង់ និងសេចក្ដីថ្លៃថ្នូរ (មើល ១៩:១–៩) ហើយដូចជាសត្វសម្បើម មើល ២៩:៣ និងការពន្យល់ *ក្នុងសមុទ្រ . . . ទន្លេទាំងប៉ុន្មាន* ដៃទន្លេនីល (មើលការពន្យល់ ២៩:៣) ។

**៣២:៣** *អញនឹងលាតលប់អញ* នៅជំនាន់ដើម ស្ដេចសេដេគាបានលាលបទៅលើអស់អ្នកដែលព្រះបានបោះលប់របស់ទ្រង់ទៅលើគេ (មើល១២:១៣ ១៧:២០ ១៩:៨) ។

**៣២:៤** *អញនិងបោះឯងចោល* សកម្មភាពរបស់ព្រះនៅត្រង់នេះ គឺដូចគ្នាទៅអស់អ្នកដែលនៅក្នុងជីពូក ២៩:២–៩ ។

**៣២:៧–៨** ព្រះបន្ទូលព្រះនិយាយទាក់ទង់ទៅនឹងភាពងងឹត ដែលនឹងកើតមានឡើងនៅថ្ងៃនៃព្រះអម្ចាស់(មើល យអ ២:២ និងការពន្យល់ ខ.១០,៣១ ៣:១៥ អម ៥:១៨ និងការពន្យល់ សផ ១:១៥) ។

**៣២:៩** *ចិត្តនៃមនុស្សជាច្រើនតក់ស្លុត* ខនេះ និងខបន្ទាប់ប្រាប់ពីសេចក្ដីភ័យខ្លាចដែលនឹងកើតមានឡើង នៅពេលដែលអំណាចនៃលោកីយដួលចុះនោះ ហើយវានៅសល់តែសាសន៍ដែលទន់ខ្សោយប៉ុណ្ណោះ ធៀបនឹងឃ្លាមួយទៀតនិយាយថា សេចក្ដីភ័យខ្លាចរបស់គេ ដូចជាមាននៅជំនាន់នៃការដួលចុះរបស់ស្ដេចក្រុងទីរ៉ុស (២៦:១៦–១៨ ២៧:៣៥ ២៨:១៩) ។

ប៉ុន្មាន ដែលឯងមិនបានស្គាល់ឡើយ ១០អើ អញនឹងឲ្យជន
ជាតិជាច្រើន មានសេចក្ដីអស្ចារ្យពីដំណើរឯង ហើយស្តេច
របស់គេ នឹងភ័យខ្លាចជាខ្លាំង ដោយព្រោះឯង ក្នុងកាល
ដែលអញលើកដាវ[ណ]អញនៅមុខគេ គេនឹងញ័រញាក់ជា
និច្ច ដោយព្រោះជីវិតរៀងខ្លួន នៅថ្ងៃ[ត]ដែលឯងនឹងត្រូវ
ដួលនោះ[ថ] ។
១១ដ្បិតព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា
ដាវ[ទ]របស់ស្តេចបាប៊ីឡូន[ធ]នឹងមកលើឯង[ន] ១២អញនឹងធ្វើ
ឲ្យពួកកកកុញរបស់ឯងដួល ដោយដាវនៃពួកខ្លាំងពូកែ
គេសុទ្ធ តែជាមនុស្សគួរស្ញែងខ្លាច នៅក្នុងអស់ទាំង
សាសន៍[ប] គេនឹងធ្វើឲ្យសេចក្ដីឆ្មើងឆ្មៃ របស់ស្រុកអេស៊ីព្ទ
សូន្យបាត់ទៅ ហើយពួកកកកុញរបស់វានឹងត្រូវវិនាសទៅ
ដែរ[ផ] ១៣អញក៏នឹងបំផ្លាញសត្វទាំងប៉ុន្មាន របស់ស្រុកនោះ
នៅក្បែរផ្លូវទឹកជាច្រើន នោះជើងមនុស្ស និងជើងសត្វ និង
លែងធ្វើឲ្យទឹកនោះល្អក់ទៀត[ព] ១៤អញនឹងធ្វើឲ្យទឹកនោះ
ថ្លាវិញ ក៏នឹងឲ្យទន្លេទាំងប៉ុន្មានហូរដូចប្រេង នេះជាព្រះ
បន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ១៥កាលណាអញបានធ្វើឲ្យ
ស្រុកអេស៊ីព្ទ ទៅជាស្ងាត់ច្រៀប ហើយខូចបង់ ជាស្រុកខ្វះ
ខាតរបស់ដែលពីដើមមានជាបរិបូរ ហើយកាលណាអញ
បានវាយអស់អ្នកនៅស្រុកនោះ នោះគេនឹងដឹងថា អញនេះ
ជាព្រះយេហូវ៉ាពិត[ភ] ១៦នេះហើយជាពាក្យទំនួញ[ម] ដែលគេ
នឹងត្រូវទួញ ពួកកូនស្រីៗនៃអស់ទាំងសាសន៍ នឹងទួញទំនួញ
ដោយពាក្យនេះ គេនឹងទួញទំនួញនឹងស្រុកអេស៊ីព្ទ ហើយ
នឹងពួកកកកុញវា ដោយពាក្យនេះឯង នេះជាព្រះបន្ទូលនៃ
ព្រះអម្ចាស់យេហូវ៉ា ។
១៧នៅឆ្នាំ១២ដដែល ដល់ថ្ងៃ១៥ខែនោះ ព្រះបន្ទូលនៃ
ព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា[យ] ១៨កូនមនុស្សអើយ ចូរទ្រហោ
យំនឹងពួកកកកុញរបស់ស្រុកអេស៊ីព្ទចុះ ហើយបោះ[រ]គេចុះ
គឺវា និងពួកកូនស្រីៗរបស់សាសន៍ទាំងប៉ុន្មាន ដែលមានល្បី
ទៅក្នុងទីទាបជាងផែនដី ជាមួយនឹងពួកអ្នកដែលចុះទៅ
ក្នុងជង្ហុកធំ[ល] ១៩តើឯងមានលំអជាងអ្នកណា ចូរចុះទៅ
ហើយឲ្យដេកជាមួយនឹងពួកមិនកាត់ស្បែកចុះ[វ] ២០តែនឹង
ដួលនៅកណ្ដាលពួកអ្នក ដែលត្រូវស្លាប់ដោយដាវ វាត្រូវ
ប្រគល់ដល់ដាវហើយ ចូរអូស[ស]វាចេញទៅ ព្រមទាំងពួក
កកកុញរបស់វាផង[ហ] ២១ពួកមនុស្សថ្មើកច្បាំងដ៏ខ្លាំងពូកែ
គេនឹងនិយាយទៅកាន់វា ពីស្ថានឃុំព្រលឹងមនុស្សស្លាប់[ឡ]
ជាមួយនឹងពួកអ្នកដែលជួយវាដែរ គេបានចុះទៅហើយ
គេដេកស្ងួកនៅ គឺជាពួកមិនកាត់ស្បែក[អ] ដែលត្រូវស្លាប់
ដោយដាវ ។
២២អាសស៊ើរនៅទីនោះ ព្រមទាំងពួកវាផង ផ្នូរខ្មោច
របស់គេក៏នៅជុំវិញវា គេបានត្រូវដួលស្លាប់គ្រប់គ្នាដោយ
ដាវ ២៣ផ្នូរខ្មោចគេបានធ្វើនៅទីបំផុតនៃជង្ហុកធំ[ក] ហើយ
ពួកវាក៏នៅព័ទ្ធជុំវិញផ្នូរវា[ខ] គឺគ្រប់គ្នាបានត្រូវដួលស្លាប់
ដោយដាវ ជាពួកអ្នកដែលនាំឲ្យមានសេចក្ដីស្ញែងខ្លាច នៅ
ស្ថានរបស់មនុស្សរស់ ។
២៤នៅទីនោះក៏មានអេឡាំ[គ]ដែរ ព្រមទាំងពួកកកកុញ
របស់វា នៅជុំវិញផ្នូរខ្មោចវាផង គ្រប់គ្នាបានដួលស្លាប់
ដោយដាវ[ឃ] គេជាពួកអ្នកដែលនាំឲ្យមានសេចក្ដីស្ញែងខ្លាច
នៅស្ថានរបស់មនុស្សរស់[ង] គេបានចុះទៅដល់ទីទាបបំផុត
ក្នុងផែនដី ឥតដែលទទួលកាត់ស្បែក ក៏បានរងទ្រាំសេចក្ដី
ខ្មាសរបស់ខ្លួន ជាមួយនឹងពួកអ្នកដែលចុះទៅក្នុងជង្ហុកធំ[ច]
២៥គេបានតាំងដំណេករបស់វា នៅកណ្ដាលពួកមនុស្ស
ដែលត្រូវសំឡាប់ ជាមួយនឹងពួកកកកុញរបស់វាដែរ ផ្នូរ
របស់គេក៏នៅព័ទ្ធជុំវិញវា គ្រប់គ្នាជាមនុស្សដែលមិនបាន

**៣២:១០** ណ អស ៣០:៣២ ត យរ ៤៦:១០ ថ អគ ២៦:១៦ ២៧:៣៥ ៣០:៩ វវ ១៨:៩-១០ **៣២:១១** ទ អគ ២១:១៩ ធ អស ១៩:៤ យរ ៤៦:១៣ ន អគ ២៩:១៩ **៣២:១២** ប អគ ២៨:៧ ផ អគ ៣១:១១-១២ **៣២:១៣** ព ខ.២ អគ ២៩:៨,១១ **៣២:១៥** ភ នក ៧:៥ ១៤:៤,១៨ ទដ ១០៧:៣៣-៣៤ **៣២:១៦** ម លប ៥០:១០ អគ ១៩:១ **៣២:១៧** យ ខ.១ **៣២:១៨** រ យរ ១:១០ ល អគ ២៦:២០ ៣១:១៤,១៦ មីក ១:៨ **៣២:១៩** វ ខ.២៩-៣០ អគ ២៨:១០ **៣២:២០** ស ទដ ២៨:៣ ហ អគ ៣១:១៧-១៨ **៣២:២១** ឡ អស ១៤:៩ អ អគ ២៨:១០ **៣២:២៣** ក អស ១៤:១៥ ខ ណាហ ១:១៤ **៣២:២៤** គ លប ១០:២២ ឃ យរ ៤៩:៣៧ ង យប ២៨:១៣ ច អគ ២៦:២០

**៣២:១០** *ដាវអញ* មើល៥:២ និងការពន្យល់ ។
**៣២:១១** *ស្តេចក្រុងបាប៊ីឡូន* គឺជាស្តេចនេប៊ូក្នេសា (ធៀបនឹង ២១:១៩) ។
**៣២:១២** *គេសុទ្ធតែជាមនុស្សគួរស្ញែងខ្លាច នៅអស់ទាំងសាសន៍* ពួកបាប៊ីឡូនបាប៊ីឡូន (មើលការពន្យល់ ៣០:១១) ។ សេចក្ដីឆ្មើងឆ្មៃរបស់ស្រុកអេស៊ីព្ទ សេចក្ដីឆ្មើងឆ្មៃរបស់ពួកទាហានស្រុកអេស៊ីព្ទ (ពួកកកកុញរបស់វា) ធៀបនឹង អម ៦:៨ ។
**៣២:១៤** *ក៏នឹងឲ្យទន្លេទាំងប៉ុន្មានហូរដូចប្រេង* ផ្ទៃទឹកនោះនឹងហូរជារហូតដូចជាទឹករស់នៃជីវិត ។
**៣២:១៦** *ពួកកូនស្រីៗនៃអស់ទាំងសាសន៍* លោកីយនេះនឹងទួញទំនួញដោយសំលេងព្រមគ្នាតែមួយ (មើល យរ ៩:១៧-១៨ និងការពន្យល់) ។
**៣២:១៧** *សេចក្ដីទំនាយលើកទី៧ ទាយទាស់ប្រឆាំងនឹងស្រុកអេស៊ីព្ទ* (មើលការពន្យល់ ២៩:១) ។ *នៅឆ្នាំ១២ ដដែល ដល់ថ្ងៃ១៥* ខែនោះមិនមានព្រះបន្ទូលទេ (ដូចជានៅក្នុង ២៦:១ ៤០:១) ។ ពេញមួយឆ្នាំចំពោះកាលបរិច្ឆេទចាប់តាំងពី ថ្ងៃទី ១៣ ខែមេសា ឆ្នាំ៥៨៦ ដល់ថ្ងៃ ទី០១ ខែមេសា ឆ្នាំ៥៨៥ មុន គ.ស ។ ចំពោះកំណៃថ្មី ចាប់ផ្ដើមនៅខែទី១ គឺនៅថ្ងៃទី១៥ ហើយត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ៥៨៦ ។
**៣២:១៨** *ទីទាបជាងផែនដី* ដូចគ្នានិង "ស្ថានឃុំមនុស្សស្លាប់" រឺស្ថានមច្ចុរាជ (sheol) នៅក្នុង ៣១:១៥ ។ *ពួកកូនស្រីៗរបស់សាសន៍ទាំងប៉ុន្មាន* មើលការពន្យល់ក្នុង ខ.១៦ ។
**៣២:១៩** *ពួកមិនកាត់ស្បែក* មើលការពន្យល់ ២៨:១០ ។
**៣២:២៤** *អេឡាំ* ជាស្រុកមួយនៅទិសខាងកើតនៃប្រទេសអាសស៊ើរី ដែលសព្វថ្ងៃស្ថិតនៅឯប្រទេសអ៊ីរ៉ង់ (មើលការពន្យល់ អស ១១:១១) ។

ទទួលកាត់ស្បែក[ឆ] ហើយគេត្រូវស្លាប់ដោយដាវ ដ្បិតគេ
បានធ្វើឱ្យមានសេចក្ដីស្ញែងខ្លាច នៅក្នុងស្ថានរបស់មនុស្ស
រស់ គេបានរងទ្រាំសេចក្ដីខ្មាសរបស់ខ្លួន ជាមួយនឹងពួក
អ្នកដែលចុះទៅក្នុងជង្ហុកធំ គេបានដាក់វានៅកណ្ដាលពួក
មនុស្សដែលត្រូវសំឡាប់នោះ ។
២៦នៅទីនោះក៏មានមែសេក និងទូបាល[ជ] ព្រមទាំងពួក
កកកុញរបស់គេផង ផ្នូរខ្មោចរបស់គេនៅព័ទ្ធជុំវិញ គ្រប់
គ្នាជាមនុស្សដែលមិនទទួលកាត់ស្បែក ហើយត្រូវស្លាប់
ដោយដាវ ដ្បិតគេបានធ្វើឱ្យាមានសេចក្ដីស្ញែងខ្លាច នៅ
ស្ថានរបស់មនុស្សរស់ ២៧គេមិនបានដេកជាមួយនឹងមនុស្ស
ខ្លាំងពូកែ ដែលមិនទទួលកាត់ស្បែក[ឈ] ក្នុងពួកអ្នកដែល
ត្រូវសំឡាប់ ជាមនុស្សដែលបានចុះ ទៅឯស្ថានឃុំព្រលឹង
មនុស្សស្លាប់ ទាំងកាន់គ្រឿងចំបាំងរបស់គេ ព្រមទាំងដាក់
ដាវគេកើយក្បាល ហើយមានអំពើទុច្ចរិតរបស់ គេជាប់
នៅឆ្អឹងផងនោះទេ ដ្បិតគេជាទីស្ញែងខ្លាចដល់ពួក ខ្លាំង
ពូកែ នៅក្នុងស្ថានរបស់មនុស្សរស់ ២៨តែឯងនឹងត្រូវបាក់
បែក នៅក្នុងពួកដែលមិនទទួលកាត់ស្បែក ហើយនឹងដេក
នៅជាមួយនឹងពួកអ្នកដែលត្រូវស្លាប់ដោយដាវដែរ ។
២៩អេដុំម[ញ]ក៏នៅទីនោះ ព្រមទាំងពួកស្ដេចនឹងពួកចៅ
ហ្វាយវាផង ជាពួកអ្នកដែលទោះបើខ្លាំងពូកែក៏ដោយ គង់
តែត្រូវដេកនៅជាមួយនឹងពួកអ្នក ដែលស្លាប់ដោយដាវដែរ
គេត្រូវដេកនៅជាមួយនឹងពួក ដែលមិនទទួលកាត់ស្បែក
ហើយជាមួយនឹងពួកអ្នក ដែលចុះទៅក្នុងជង្ហុកធំ[ដ] ៣០ពួក
ចៅហ្វាយទាំងប៉ុន្មាននៃស្រុកខាងជើង[ឋ] ហើយពួកស៊ីដូន[ឌ]
ទាំងអស់នៅទីនោះដែរ ជាពួកអ្នកដែលចុះទៅជាមួយនឹង
មនុស្សដែលត្រូវសំឡាប់ គេត្រូវខ្មាសដោយព្រោះសេចក្ដី
ស្ញែងខ្លាចដែលគេបានបង្កើតឡើង ដោយកំឡាំងរបស់គេ
គេក៏ដេក ដោយឥតទទួលកាត់ស្បែក[ឍ] គឺដេកជាមួយនឹងពួក
មនុស្សដែលត្រូវស្លាប់ដោយដាវ គេរងទ្រាំសេចក្ដីខ្មាស
របស់ខ្លួន ជាមួយនឹងពួកអ្នកដែលចុះទៅក្នុងជង្ហុកធំ[ណ] ។
៣១ឯផារ៉ោននឹងឃើញគេដែរ ហើយនឹងមានសេចក្ដី
ក្សាន្តចិត្ត[ត] ពីដំណើរពួកកកកុញរបស់វា គឺផារ៉ោននោះឯង
និងពួកកងទ័ពរបស់វា ដែលត្រូវស្លាប់ដោយដាវផង នេះ
ជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ៣២ដ្បិតអញបានធ្វើ
ឱ្យសេចក្ដីស្ញែងខ្លាចរបស់អញ កើតឡើងនៅក្នុងស្ថានរបស់
មនុស្សរស់ ហើយនឹងត្រូវផ្ដេកនៅកណ្ដាលពួកអ្នក ដែល
មិនទទួលកាត់ស្បែក ជាមួយនឹងពួកអ្នកដែលត្រូវស្លាប់
ដោយដាវដែរ គឺផារ៉ោន[ថ]នោះឯង ព្រមទាំងពួកកកកុញ
របស់វាផង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ទ] ។

## លោកអេសេគាលដ៏ជាអ្នកចាំយាម

**៣៣** ១ព្រះបន្ទូល នៃព្រះយេហូវ៉ា បានមកដល់ខ្ញុំថា
២កូនមនុស្សអើយ ចូរប្រាប់ដល់ពួកកូនចៅសាសន៍ឯងថា
កាលណាអញនាំដាវ[ក]មកលើស្រុកណា ហើយបណ្ដាជន
នៅស្រុកនោះ រើសយកម្នាក់ពីក្នុងពួកគេ តាំងឡើងជាអ្នក
ចាំយាម[ខ] ៣បើអ្នកនោះឃើញដាវមកលើស្រុក ក៏ផ្លុំត្រែ[គ]
ដាស់បណ្ដាជន ៤ហើយមានអ្នកណាឮសូរត្រែ តែមិន
អើពើសោះ[ឃ] បើដាវមកពិត ហើយយកជីវិតគេទៅនោះ
ឈាមគេនឹងធ្លាក់ទៅលើក្បាលគេវិញ[ង] ៥ព្រោះបានឮសូរ
ត្រែ តែមិនអើពើសោះ ដូច្នេះ គេនឹងជាប់មានទោស
ចំពោះឈាមរបស់ខ្លួនវិញ[ច] ដ្បិតបើបានអើពើ នោះនឹងបាន
រួចជីវិតជាពិត[ឆ] ៦តែបើអ្នកចាំយាមឃើញដាវមក ហើយ
មិនផ្លុំត្រែឱ្យបណ្ដាជនបានដឹង រួចដាវក៏មកដល់ យកជីវិត
អ្នកណាចេញពីពួកគេទៅ អ្នកនោះនឹងត្រូវស្លាប់ទៅក្នុង
អំពើទុច្ចរិតរបស់ខ្លួន តែអញនឹងទារឈាមរបស់អ្នកនោះ

**៣២:២៥** ឆ អគ ២៨:១០ **៣២:២៦** ជ អគ ២៧:១៣ **៣២:២៧** ឈ អគ ២៨:១០ **៣២:២៩** ញ ទដ ១៣៧:៧ អស ៣៤:៥-១៥ យរ ៤៩:៧ អគ ៣៥:១៥ អប ១:១ ដ អគ ២៥:១២-១៤ **៣២:៣០** ឋ អស ១៤:៣១ យរ ២៥:២៦ អគ ៣៨:៦ ៣៩:២ ឌ លប ១០:១៥ យរ ២៥:១២ ឍ អគ ២៨:១០ ណ អគ ២៦:២០ ២៨:៨ **៣២:៣១** ត អគ ១៤:២២ **៣២:៣២** ថ យរ ៤៤:៣០ ទ យប ៣:១៤ **៣៣:២** ក លវ ២៦:២៥ យរ ១២:១២ ខ ១សយ ១៤:១៦ អស ២១:៦-៩ យរ ៥១:១២ **៣៣:៣** គ នក ២០:១៨ ជន ១០:១៧ ហស ៥:៨ ៨:១ **៣៣:៤** ឃ ២របា ២៥:១៦ ង លវ ២០:៩ យរ ៦:១៧ សក ១:៤ កច ១៨:៦ **៣៣:៥** ច លវ ២០:៩ ឆ នក ៩:២១

**៣២:២៦** *មែសេក និងទូបាល* ជាប្រជាជន និងទឹកដី ដែលស្ថិតអាស៊ី មានចំនួនតិចតួច (មើល ៣៨:២ និងការពន្យល់) ។

**៣២:២៩** *អេដុំម* មើលការពន្យល់ លក ៣៦:១,៨ និងមើល អស ៣៤:៥ អម ១:១១-១២ សេចក្ដីផ្ដើមក្នុងព្រះគម្ពីរអូបាឌា ការរួបរួម និងសាច់រឿង ។

**៣២:៣០** *ពួកស៊ីដូន* មើលការពន្យល់ ២៨:២១ ។

**៣៣:១-៤៨:៣៥** សេចក្ដីអធិប្បាយ និងសេចក្ដីទំនាយអំពីការលើកទឹកចិត្ត នៅពេលដែលទីក្រុងយេរូសាឡិមបានដួលរលំ ។ មានទាំងពាក្យព្រមាន និងការជំនុំជម្រះ (ឧទា. ៣៣:២៣-៣៣ ៣៤:១-១៩,៣៥) ។

**៣៣:១-២០** ចំណុចភ្ជាប់គ្នានៃអត្ថបទនេះ សំខាន់នៅត្រង់ការខុសគ្នារវាងសាច់រឿង ដូចជាលោកអេសេគាល ព្រះបានត្រាសហៅគាត់ឱ្យធ្វើជាអ្នក "ចាំយាម" សម្រាប់អ៊ីស្រាអែលជានិច្ច (មើល ៣:១៦-១៩ និងការពន្យល់ ៣:១៧) ។

**៣៣:២** *ពួកកូនចៅសាសន៍ឯង* ពួកកូនចៅអ៊ីស្រាអែលប្រុសៗ នៅពេលចាប់ជាឈ្លើយជាមួយលោកអេសេគាល ។ *ដាវ* ទាហានវាយលុក (ធៀបនឹង ៥:២ និងការពន្យល់) ។ *ហើយបណ្ដាជននៅស្រុកនោះ* មើលការពន្យល់ ៧:២៧ ។

**៣៣:៣** *ក៏ផ្លុំត្រែ* ជាឧបករណ៍ភ្លេងដែលធ្វើពីស្នែងចៀមឈ្មោល (មើលការពន្យល់ យស ៦:៤-៥) ។ ដែលគេប្រើវាសម្រាប់ការព្រមានអំពីគ្រោះថ្នាក់អ្វីមួយដែលអាចកើតមានឡើង (មើល នហ ៤:១៨-២០ យរ ៤:១៩ អម ៣:៦) ។

**៣៣:៤** *នោះឈាមគេនឹងធ្លាក់ទៅលើគេវិញ* មើលការពន្យល់ ១៨:១៣ ។

**៣៣:៦** *ឈាមរបស់អ្នកនោះ* ជីវិតរបស់គាត់មានឈាម នៅមានជីវិត (មើល

ពីដៃអ្នកចាំយាមវិញ[ជ]។
៧កូនមនុស្សអើយ គឺយ៉ាងនោះឯង ដែលអញបានតាំង
ឯងឡើង ឱ្យធ្វើជាអ្នកចាំយាម[ឈ] ដល់ពួកវង្សអ៊ីស្រាអែល
ដូច្នេះ ចូរស្តាប់ពាក្យពីមាត់អញ ហើយប្រកាសប្រាប់គេ
ឱ្យអញ[ញ] ៨កាលណាអញប្រាប់ដល់មនុស្សអាក្រក់ថា ឱ
មនុស្សអាក្រក់អើយ ឯងនឹងត្រូវស្លាប់ជាពិត[ដ] តែឯងមិន
ពន្យល់ប្រាប់មនុស្សអាក្រក់នោះ ឱ្យលះចោលផ្លូវរបស់ខ្លួន
ទេ ដូច្នេះមនុស្សអាក្រក់នោះ នឹងស្លាប់ក្នុងអំពើទុច្ចរិតរបស់
ខ្លួនមែន តែអញនឹងទារឈាមពីដៃឯងវិញ[ឋ] ៩ប៉ុន្តែ បើឯង
ពន្យល់ប្រាប់ដល់មនុស្សអាក្រក់ ពីផ្លូវរបស់វា ឱ្យបានលះ
ចោលផ្លូវនោះចេញ តែវាមិនបែរចេញពីផ្លូវរបស់ខ្លួន
សោះ[ឌ] នោះវានឹងស្លាប់ក្នុងអំពើទុច្ចរិតរបស់វា តែឯងបាន
ដោះខ្លួនឱ្យរួចវិញ[ឍ]។
១០ដូច្នេះ កូនមនុស្សអើយ ចូរប្រាប់ដល់ពួកវង្សអ៊ីស្រា–
អែលថា ឯងរាល់គ្នាពោលដូច្នេះថា អំពើរំលង និងអំពើ
បាបរបស់យើង គ្របសង្កត់លើយើងហើយ យើងកំពុងតែ
រោយរៀវទៅ[ណ] ក្នុងអំពើទាំងនោះ ដូច្នេះធ្វើដូចម្តេចឱ្យ
យើងរស់នៅបាន[ត] ១១ចូរប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ា
ទ្រង់ស្បថថា ដូចជាអញរស់នៅ នោះប្រាកដជាអញមិនរីក
រាយ ចំពោះសេចក្តីស្លាប់របស់មនុស្សអាក្រក់ឡើយ គឺចូល
ចិត្តឱ្យគេលះចោលផ្លូវរបស់ខ្លួន ហើយមានជីវិតរស់នៅ
វិញទេតើ[ថ] ចូរឱ្យឯងរាល់គ្នាបែរមក[ទ] ចូរបែរមកពីផ្លូវ
អាក្រក់របស់ខ្លួនចុះ ដ្បិតឱពួកវង្សអ៊ីស្រាអែលអើយ ហេតុអ្វី
បានជាចង់ស្លាប់[ធ] ១២ដូច្នេះ កូនមនុស្សអើយ ចូរប្រាប់ដល់
ពួកកូនចៅនៃសាសន៍ឯងថា[ន] សេចក្តីសុចរិតរបស់មនុស្ស
សុចរិត នឹងមិនដោះអ្នកនោះឱ្យរួច ក្នុងថ្ងៃដែលប្រព្រឹត្ត
អំពើរំលងវិញនោះឡើយ ហើយចំណែកអំពើអាក្រក់
របស់មនុស្សអាក្រក់វិញ គេមិនបានដួល ដោយព្រោះអំពើ
ទាំងនោះ ក្នុងថ្ងៃដែលប្រព្រឹត្តអំពើអាក្រក់របស់ខ្លួនទេ ឯ
មនុស្សសុចរិតវិញ ក៏មិនអាចនឹងរស់នៅ ដោយសារអំពើ
សុចរិតរបស់ខ្លួន ក្នុងថ្ងៃដែលប្រព្រឹត្តអំពើបាបវិញបាន
ដែរ[ប] ១៣កាលណាអញប្រាប់ដល់មនុស្សសុចរិតថា គេនឹង
រស់នៅជាពិត នោះបើគេពឹងដល់សេចក្តីសុចរិតរបស់ខ្លួន
ទៅប្រព្រឹត្តអំពើទុច្ចរិតវិញ នោះនឹងគ្មានអ្នកណានឹកចាំពី
អំពើសុចរិតទាំងប៉ុន្មានរបស់អ្នកនោះទេ គឺគេនឹងស្លាប់ទៅ
ក្នុងអំពើទុច្ចរិត ដែលខ្លួនបានប្រព្រឹត្តនោះវិញ[ផ] ១៤មួយ
ទៀត បើកាលណាអញប្រាប់ដល់មនុស្សអាក្រក់ថា ឯងនឹង
ត្រូវស្លាប់ជាពិត នោះបើគេបែរចេញពីអំពើបាបរបស់ខ្លួន
ទៅប្រព្រឹត្តសេចក្តីដែលទៀងត្រង់[ព] ហើយត្រឹមត្រូវវិញ ១៥គឺ
បើមនុស្សអាក្រក់នោះ នឹងប្រគល់របស់បញ្ចាំ[ភ]ដល់ម្ចាស់
វិញ ហើយប្រគល់របស់ដែលខ្លួនបានលួចទៅវិញដែរ[ម]
ព្រមទាំងដើរតាមអស់ទាំងច្បាប់នៃជីវិតនេះ ឥតប្រព្រឹត្ត
ទុច្ចរិតឡើយ នោះគេនឹងបានរស់នៅជាពិត ឥតត្រូវស្លាប់
ទេ[យ] ១៦ដូច្នេះ នឹងគ្មានអ្នកណានឹកចាំ ពីអំពើបាប[រ]ទាំង
ប៉ុន្មាន ដែលអ្នកនោះបានប្រព្រឹត្តឱ្យទាស់នឹងខ្លួនទៀតឡើយ
ដ្បិត គេបានប្រព្រឹត្តតាមសេចក្តីទៀតទ្រង់ត្រឹមត្រូវហើយ
គេនឹងរស់នៅជាពិត[ល]។
១៧ទោះបើយ៉ាងនោះ គង់តែពួកកូនចៅនៃសាសន៍ ឯង
តែងថា ផ្លូវរបស់ព្រះអម្ចាស់មិនស្មើទេ ចំណែកខាងគេ គឺ
ផ្លូវរបស់គេទេតើដែលមិនស្មើវិញ ១៨កាលណាមនុស្ស
សុចរិតបែរចេញពីសេចក្តីសុចរិតរបស់ខ្លួន ទៅប្រព្រឹត្ត
អំពើទុច្ចរិតវិញ[វ] នោះគេនឹងត្រូវស្លាប់ដោយព្រោះអំពើ
នោះឯង[ស] ១៩ហើយកាលណាមនុស្សអាក្រក់បែរចេញពី
សេចក្តីអាក្រក់របស់ខ្លួន ទៅប្រព្រឹត្តតាមសេចក្តីទៀងត្រង់
ហើយត្រឹមត្រូវវិញ នោះគេនឹងរស់នៅដោយសារអំពើ

**៣៣:៦** ជ អស ៥៦:១០–១១ អគ ៣:១៨
**៣៣:៧** ឈ អស ៥២:៨ ញ យរ ១:១៧ ២៦:២
**៣៣:៨** ដ ខ.១៤ ឋ អស ៣:១១ អគ ១៨:៤
**៣៣:៩** ឌ ទដ ៧:១២ ឍ អគ ៣:១៧–១៩
**៣៣:១០** ណ លវ ២៦:១៦ ត លវ ២៦:៣៩ អគ ៤:១៧
**៣៣:១១** ថ បទ ៣:៣៣ ទ ២របា ៣០:៩ អស ១៩:២២ យរ ៣:១២ ធ យរ ៤៤:៧–៨ អគ ១៨:២៣ ហស ១១:៨ យអ ២:១២ ១ធថ ២:៤
**៣៣:១២** ន ខ.២ ប ២របា ៧:១៤ អគ ៣:២០ ១៨:២១
**៣៣:១៣** ផ ហព ១០:៣៨ ២ពត ២:២០–២១
**៣៣:១៤** ព យរ ២២:៣
**៣៣:១៥** ភ នក ២២:២៦ ម នក ២២:១–៤ លវ ៦:២–៥ យ អស ៥៥:៧ យរ ១៨:៧–៨ លក ១៩:៨
**៣៣:១៦** រ យរ ៥០:២០ ល អស ៤៣:២៥
**៣៣:១៨** វ យរ ១៨:១០ ស អគ ៣:២០

លក ៩:៥ ៤២:២២ លវ ១៧:១១ និងការពន្យល់) ។

**៣៣:៧–៩** ធៀបនឹង ៣:១៧–១៩ ។

**៣៣:១០** *អំពើរំលង និងអំពើបាបរបស់យើង* នេះជាលើកទី១ដែលពួកជាប់ជាឈ្លើយបានភ្ញាក់ដឹងខ្លួនចំពោះអំពើបាបរបស់គេ ដ្បិតកាលពីមុន នោះពួកគេបានបន្ទោសអំពើបាបរបស់ឪពុកម្តាយគេ(១៨:២) ហើយគេបានបន្ទោសដល់ព្រះផងដែរ (១៨:១៩,២៥) ។

**៣៣:១១** *ដូចជាអញរស់នៅ* មើលការពន្យល់ ៥:១១ ។ *អញមិនរីករាយ* សំនួរនៅក្នុងនេះ ១៨:២៣ (មើលការពន្យល់នៅទីនេះ) ។ បំណងព្រះហឫទ័យ ជាមូលដ្ឋានរបស់ព្រះនៅពេលដែលទ្រង់បង្កើតរបស់សព្វសារពើរនោះគឺជីវិតមិនមែនសេចក្តីស្លាប់នោះទេ (មើលការពន្យល់ ១៦:៦) ។ *ឱ្យគេលះ ចោលផ្លូវរបស់ខ្លួន* នេះជាការត្រាសហៅលើកទី៣ ដើម្បីឱ្យគេប្រែចិត្ត (មើល ១៤:៦ ១៨:៣០) ។

**៣៣:១២–២០** ធៀបនឹង ១៨:២១–២៩ (មើលការពន្យល់នៅទីនោះ) ។

**៣៣:១៤** *ទៅប្រព្រឹត្តសេចក្តីទៀតត្រង់ ហើយត្រឹមត្រូវវិញ* មើលការពន្យល់ ១៨:៥ ទដ ១១៩:១២១ ។

**៣៣:១៥** *នឹងប្រគល់របស់បញ្ចាំដល់ម្ចាស់វិញ . . . ហើយបានប្រគល់របស់ដែល ខ្លួនបានលួច ទៅវិញដែរ* មើលការពន្យល់ ១៨:៧ ។ *ដើរតាមអស់ទាំងច្បាប់នៃជីវិតនេះ* គោលបំណងក្រិត្យវិន័យរបស់ព្រះ គឺចិញ្ចឹម និងការពារជីវិត (មើលការពន្យល់ ២០:១១) ។ *នោះគេនឹងបានរស់នៅជាពិត* ចូលដល់ផ្នែកនេះ គឺចម្លើយនៅក្នុងព្រះគម្ពីរអេសេគាល ចំពោះសំនួរនៃការអស់សង្ឃឹមមាននៅក្នុង ខ.១០ ។

**៣៣:១៧** *ផ្លូវរបស់ព្រះអម្ចាស់មិនស្មើទេ* មើលការពន្យល់ ១៨:២៥ ។

នោះឯង[ហ] ២០ប៉ុន្តែឯងរាល់គ្នាថា ផ្លូវរបស់ព្រះអម្ចាស់មិន
ស្មើទេឱពួកវង្សអ៊ីស្រាអែលអើយ អញនឹងជំនុំជំរះឯង
រាល់គ្នាតាមផ្លូវរបស់ឯងរៀងខ្លួន[ឡ]។

## អត្ថន័យនៃការដួលរលំនៃក្រុងយេរូសាឡិម

២១លុះដល់ថ្ងៃ៥ ខែបុស្ស ក្នុងឆ្នាំ១២ ដែលគេបានចាប់
យើងនាំទៅជាឈ្លើយ នោះមានម្នាក់ដែលរត់រួច[អ]ពីក្រុង
យេរូសឡិម បានមកដល់ខ្ញុំប្រាប់ថា គេចាប់ទីក្រុងបាន
ហើយ[ក] ២២រីឯនៅពេលល្ងាចមុនដែលអ្នករត់រួច នោះ
បានមកដល់ នោះព្រះហស្តនៃព្រះយេហូវ៉ាបានស្ថិតនៅ
លើខ្ញុំ[ខ] ទ្រង់ក៏បើកមាត់[គ]ខ្ញុំ ចាំតែអ្នកនោះមកដល់នៅពេល
ព្រឹក ដូច្នេះ មាត់ខ្ញុំបានបើកឡើង ហើយខ្ញុំមិននៅតទៀត
ទេ[ឃ]។

២៣គ្រានោះព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា
២៤កូនមនុស្សអើយ ពួកអ្នកដែលអាស្រ័យនៅអស់ទាំងទី
ខូចបង់[ង] ក្នុងស្រុកអ៊ីស្រាអែល គេថា លោកអ័ប្រាហាំជា
មនុស្សតែម្នាក់ទេ ហើយលោកបានទទួលស្រុកនេះទុកជា
មរដក ឯយើងរាល់គ្នាមានគ្នាច្រើន[ច] ស្រុកនេះក៏បាន
ប្រគល់មកយើងទុកជាមរដកដែរ[ឆ] ២៥ដូច្នេះ ចូរប្រាប់គេថា
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ឯងរាល់គ្នាស៊ី[ជ]
សាច់ដែលជាប់ទាំងឈាម[ឈ] ក៏ងើបភ្នែកទៅឯអស់ទាំង
រូបព្រះរបស់ឯងរាល់គ្នា ហើយកំចាយឈាមផង ដូច្នេះ តើ
ឯងរាល់គ្នានឹងបានស្រុកនេះឬ[ញ] ២៦ឯងរាល់គ្នាពឹងតែដាវ
របស់ឯង ក៏ប្រព្រឹត្តការគួរស្អប់ខ្ពើម[ដ] ហើយបង្ខូចប្រពន្ធ
របស់អ្នកជិតខាងឯងរៀងខ្លួន[ឋ] ដូច្នេះ តើឯងរាល់គ្នានឹង
បានស្រុកនេះឬ ២៧ត្រូវឱ្យឯងប្រាប់ដល់គេដូច្នេះថា ព្រះ
អម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូចជាអញរស់នៅ នោះ
ប្រាកដជាពួកអ្នក ដែលអាស្រ័យនៅអស់ទាំងទីខូចបង់នេះ
នឹងដួលដោយដាវ ហើយអ្នកណាដែលនៅឯទីវាលទទេ
អញនឹងប្រគល់ ដល់សត្វព្រៃឱ្យត្រូវហែកស៊ី ហើយពួកអ្នក
ដែលនៅក្នុងទីមាំមួន និងក្នុងរអាងភ្នំ គេនឹងស្លាប់ដោយ
អាសន្នរោគ[ឌ] ២៨អញនឹងធ្វើឱ្យស្រុកនេះស្ងាត់ជ្រងំ ហើយ
ជាទីស្រឡាំងកាំង នោះសេចក្តីឆ្មើងឆ្មៃនៃអំណាចវានឹង
ផុតទៅ ហើយភ្នំ[ឍ]ទាំងប៉ុន្មានរបស់ស្រុកអ៊ីស្រាអែលនឹង
ត្រូវចោលស្ងាត់នៅ ឥតមានអ្នកដើរកាត់ឡើយ[ណ] ២៩នោះ
គេនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុងកាលដែល
អញបានធ្វើឱ្យស្រុកនេះស្ងាត់ជ្រងំ[ត] ហើយជាទីស្រឡាំងកាំង
ដោយព្រោះអស់ទាំងអំពើគួរស្អប់ខ្ពើម ដែលគេបានប្រព្រឹត្ត
នោះ[ថ]។

៣០មួយទៀត កូនមនុស្សអើយ ពួកកូនចៅរបស់សាសន៍
ឯង គេនិយាយគ្នាពីឯងនៅក្បែរកំផែង ហើយនៅមាត់
ទ្វារផ្ទះ គេនិយាយគ្នា គឺគ្រប់គ្នានិយាយនឹងបងប្អូនខ្លួនថា
ចូរយើងទៅស្តាប់ព្រះបន្ទូល ដែលមកពីព្រះយេហូវ៉ាចុះ
៣១គេក៏មកឯឯង ដូចជាបណ្តាជនទាំងឡាយធ្លាប់មក ហើយ
គេអង្គុយនៅ[ទ]មុខឯង ដូចជារាស្ត្រអញក៏ស្តាប់អស់ទាំងពាក្យ

**៣៣:១៩** ហ ខ.១៤–១៥ **៣៣:២០** ឡ យប ៣៤:១១ **៣៣:២១** អ អគ ២៤:២៦ ក ២ពវ ២៥:៤,១០ យរ ៣៩:១–២ ៥២:៤–៧ អគ ៣២:១ **៣៣:២២** ខ អគ ១:៣ គ អគ ២៩:២១ លក ១:៦៤ ឃ អគ ៣:២៦–២៧ ២៤:២៧ **៣៣:២៤** ង អគ ៣៦:៤ ច ចទ ១:១០ ឆ អស ៥១:២ យរ ៤០:៧ អគ ១១:១៥ លក ៣:៨ កច ៧:៥ **៣៣:២៥** ជ យរ ៧:២១ ឈ លប ៩:៤ ញ យរ ៧:៩–១០ អគ ២២:៦,២៧ **៣៣:២៦** ដ យរ ៤១:៧ ឋ អគ ២២:១១ **៣៣:២៧** ឌ ១សយ ១៣:៦ អស ២:១៩ យរ ៤២:២២ អគ ៧:១៥ ១៤:២១

**៣៣:២៨** ឍ អស ៤១:១៥ ណ លប ៦:៧ យរ ៩:១០ **៣៣:២៩** ត លវ ២៦:៣៤ ថ យរ ១៨:១៦ ៤៤:២២ អគ ៣៦:៤ មីក ៧:១៣ **៣៣:៣១** ទ អគ ៨:១

**៣៣:២១–៣៣** នៅពេលដែលដំណឹងនៃការដួលរលំក្រុងយេរូសាឡិម បានឮដល់លោកអេសេគាល នោះគាត់បានពង្រើងស្មារតី ចំពោះពាក្យគាត់នៅកាលដើមថា "ទីបញ្ចប់"បានមកដល់ទីក្រុងនេះពិតប្រាកដហើយ ទោះបីជាគេនៅមានជីវិតរស់នៅក្តី នៅថ្ងៃហិនវិនាស នោះទីក្រុងនឹងត្រូវបំផ្លាញផងដែរ ( មើលការពន្យល់ ៧:១–២៧) ។

**៣៣:២១** *លុះដល់ថ្ងៃទី០៥ ខែបុស្ស ក្នុងឆ្នាំទី១២* គឺថ្ងៃទី០៨ ខែមករា ឆ្នាំ ៥៨៥ មុន គ.ស ។ ៥ខែមកក្រោយពេលព្រះវិហារក្រុងយេរូសាឡិម ត្រូវគេដុតបំផ្លាញនោះ មើលកាលបរិច្ឆេទនៅក្នុង ២ពវ ២៥:៨ ដែលរាប់តាមសម័យទំនើប គឺនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ៥៨៦ ។ ដំណើរនោះរវាងក្រុងយេរូសាឡិម និងក្រុងបាប៊ីឡូន គឺធ្វើឡើងនៅក្នុងរយៈ៤ខែម្តង(អរ ៧:៩) ។ *នោះមានម្នាក់ ដែលរត់* ការចាប់ជាឈ្លើយលើកទី១ នៅឆ្នាំ៥៨៦ (មើល ២៤:២៦ "បាន លួចរត់" មើលផងដែរការពន្យល់)។ គាត់បាន "រត់គេច" មានជីវិតរស់នៅពីគ្រោះថ្នាក់នៃក្រុងយេរូសាឡិម ។ *គេចាប់ទីក្រុងបានហើយ* សេចក្តីថ្លែងនេះ គ្រប់ទាំងសេចក្តីទំនាយលើកមុនរបស់លោកអេសេគាលបានសំរេច ហើយពិតជាត្រឹមត្រូវ ។ ព្រះបានចាត់បញ្ជូនគាត់ឱ្យទៅបំពេញបេសកកម្មជាថ្មី ជាអ្នកគង្វាលដែលកំសាន្តចិត្ត ។

**៣៣:២២** *ហើយខ្ញុំមិននៅគទៀតទេ* មើល ២៤:២៧ និងការពន្យល់ ។

**៣៣:២៤** *ពួកអ្នកដែលអាស្រ័យនៅអស់ទាំងទីខូច* ពួកអ្នកស្នាក់នៅក្រុងយេរូសាឡិមនោះ មិនមែនជាពួកអ្នកដែលគេចាប់ជាឈ្លើយ នៅក្នុងឆ្នាំ៥៨៦ មុន គ.សឡើយ ។ *លោកអ័ប្រាហាំជាមនុស្សតែ ម្នាក់គត . . . ឯយើងរាល់គ្នាមានគ្នាច្រើន* គេមានសេចក្តីអំនួត ថែមទាំងមិនប្រែចិត្តទៀតផង ហើយឃ្លានេះដូចគ្នាក្នុង ១១:១៥ (ធៀបនឹង លក ៣:៨) ។

**៣៣:២៥** *ឯងរាល់គ្នាស៊ីសាច់ដែលជាប់ទាំងឈាម* នេះគឺជាការហាមប្រាមនៅក្នុង លក ៩:៤ (មើលការពន្យល់នៅក្នុង លវ ១៧:១១)។ *ក៏ងើបភ្នែកទៅឯអស់ទាំងរូបព្រះរបស់ឯងរាល់គ្នា* មើលការពន្យល់ ១៨:១៦ ។

**៣៣:២៧** *ដូចជាអញរស់នៅ* មើលការពន្យល់ ៥:១១ ។ *ដាវ . . . សត្វព្រៃ . . . អាសន្ន* ធៀបនឹង គ្រោះចង្រៃទាំងបីនៅក្នុង ៥:១២ ៧:១៥ ១២:១៦ និងគ្រោះចង្រៃទាំងបីនៅក្នុង ១៤:១២–២១ (មើលការពន្យល់ ៥:២៦–១៧)។

**៣៣:២៩** *នោះគេដឹងថា អញនេះគឺជាព្រះអម្ចាស់ពិត* មើលសេចក្តីផ្តើមសាច់រឿង ។

**៣៣:៣០–៣៣** ពាក្យនេះនិយាយសំដៅទៅលើលោកអេសេគាល ប៉ុន្តែថែមទាំងមានការបន្ទោស និងការរំលឹកដាស់តឿន ចំពោះពួកអ្នកជាប់ជាឈ្លើយនៅតែមាននៅក្រុងយេរូសាឡិមនោះ ។

របស់ឯង តែមិនប្រព្រឹត្តតាមទេ ដ្បិតបបូរមាត់គេសំដែង
ចេញជាសេចក្ដីស្រឡាញ់យ៉ាងខ្លាំង[ធ] តែចិត្តគេដេញតាម
រកកំរៃដល់ខ្លួនវិញ[ន] ៣២ហើយមើល គេរាប់ឯងទុកដូចជា
បទចំរៀង[ប] ដ៏ពិរោះនៃមនុស្សមានសំឡេងល្អ ហើយចេះ
លេងភ្លេងយ៉ាងប្រសប់ប៉ុណ្ណោះ ដ្បិតគេស្ដាប់អស់ទាំង
ពាក្យរបស់ឯង ប៉ុន្តែមិនប្រព្រឹត្តតាមទេ[ផ] ៣៣កាលណាការ
នេះកើតមកហើយ (មើល ការនេះកំពុងតែមក ហើយ
មែន) នោះគេនឹងដឹងថា មានហោរាបាននៅក្នុងពួកគេជា
ពិត[ព]។

## ពួកអ្នកគង្វាល និងហ្វូងចៀម

**៣៤** ១ព្រះបន្ទូល នៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា ២កូន
មនុស្សអើយ ចូរទាយទាស់នឹងពួកអ្នកគង្វាលនៃសាសន៍
អ៊ីស្រាអែលចុះ ត្រូវឱ្យទាយប្រាប់គេ គឺពួកអ្នកគង្វាលនោះ
បានថា ព្រះអម្ចាស់យេហូវ៉ាមានបន្ទូលដូច្នេះ វេទនាដល់
ពួកអ្នកគង្វាលនៃសាសន៍អ៊ីស្រាអែល ដែលឃ្វាលតែខ្លួន
ឯង តើមិនត្រូវឱ្យពួកអ្នកគង្វាលនោះ ឃ្វាលហ្វូងចៀមវិញ
ទេឬអី[ក] ៣ឯងរាល់គ្នាស៊ីខ្លាញ់ ហើយស្លៀកពាក់ដោយសារ
រោមវា ក៏សំឡាប់សត្វបំប៉នដែរ តែមិនឃ្វាលហ្វូងទេ[ខ] ៤ឯង
រាល់គ្នាមិនបានចំរើនកំឡាំង ដល់សត្វណាដែលអន់កំឡាំង

**៣៣:៣១** ធ ទដ ១១៩:៣៦ ន ទដ ៧៨:៣៦–៣៧ អស ២៩:១៣ ៣៣:១៥ យរ ៣:១០ ៦:១៧ អគ ២២:២៧ មថ ១៣:២២ ១យហ ៣:១៨ **៣៣:៣២** ប ១ពវ ៤:៣២ ផ មក ៦:២០ **៣៣:៣៣** ព ១សយ ៣:២០ យរ ២៨:៩ អគ ២:៥ **៣៤:២** ក ទដ ៧៨:៧០–៧២ អស ៤០:១១ យរ ៣:១៥ ២៣:១ មីក ៣:១១ យហ ១០:១១ ២១:១៥–១៧ យដ ១:១២ **៣៤:៣** ខ អស ៥៦:១១ អគ ២២:២៧ អម ៦:៤ សក ១១:៥ **៣៤:៤** គ អស

ហើយណាដែលឈឺ នោះមិនបានមើលឱ្យជាទេ[គ] ណាដែល
បាក់ជើង ឯងមិនបានរុំអប[ឃ] ណាដែលត្រូវកំចាត់កំចាយ
នោះឯងមិនបានស្វែងរកដែរ គឺឯងរាល់គ្នាបានគ្រប់គ្រង
លើវា ដោយកំឡាំង ហើយតឹងរ៉ឹងវិញ[ង] ៥ដូច្នេះ វាត្រូវ
កំចាត់កំចាយទៅ ដោយព្រោះឥតមានអ្នកគង្វាល[ច] វាបាន
ត្រឡប់ជាអាហារដល់អស់ទាំងសត្វព្រៃ ហើយត្រូវខ្ចាត់
ខ្ចាយអស់ទៅ[ឆ] ៦ហ្វូងចៀមរបស់អញបានដើរចុះឡើង
នៅលើអស់ទាំងភ្នំធំ និងភ្នំតូចទាំងប៉ុន្មានផង[ជ] អើ ហ្វូង
ចៀមរបស់អញបានត្រូវចំចាត់កំចាយ[ឈ] នៅពេញពាសលើ
ផែនដី ឥតមានអ្នកណាទៅស៊ើបសួរ ឬស្វែងរកវាសោះ[ញ]។
៧ហេតុនោះពួកអ្នកគង្វាលរាល់គ្នាអើយ ចូរស្ដាប់
បន្ទូលនៃព្រះយេហូវ៉ាចុះ ៨ព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថ
ថា ដូចជាអញនឹងរស់នៅ ពិតប្រាកដជាដោយព្រោះហ្វូង
ចៀមអញបានទៅជារំពា[ដ] ហើយត្រឡប់ទៅជាអាហារដល់
អស់ទាំងសត្វព្រៃ[ឋ] ដោយឥតអ្នកគង្វាល ហើយដោយព្រោះ

៣:៧ ឃ អស ១:៦ ង ខ.១៦ លវ ២៥:៤៣ មីក ៣:៣ សក ១១:១៥–១៧ **៣៤:៥** ច ជន ២៧:១៧ ឆ ខ.២៨ អស ៥៦:៩ កច ២០:២៩ **៣៤:៦** ជ យរ ៥០:៦ ឈ លវ ២៦:៣៣ ទដ ៩៥:១០ យរ ១០:២១ ញ ២របា ១៨:១៦ ទដ ១៤២:៤ ហស ៧:១៣ មថ ៩:៣៦ ១៨:១២–១៣ លក ១៥:៥ ១ពត ២:២៥ **៣៤:៨** ដ ពច ២:១៤ ឋ អស ៥៦:៩

**៣៣:៣១** *ហើយគេអង្គុយនៅមុខឯង* ដូចជាពួកចាស់ទុំ (៨:១ ១៤:១)។ *ចិត្តគេដេញតាមរកកំរៃ* បណ្ដាជនគេរង់ចាំលោកអេសេគាល ដើម្បីប្រាប់គេនូវអ្វីដែលគេអាចរកប្រាក់ចំណេញដោយផ្ទាល់ខ្លួនបានពីស្ថានភាពនោះ ។ ពួកគេមិនចាប់អារម្មណ៍ ចំពោះអ្វីដែលព្រះទ្រង់បានរៀបចំសម្រាប់ពួកគេនោះឡើយ (ធៀបនឹង មថ ២០:២០–២៨) ។

**៣៣:៣២** *គេរាប់ឯងទុកដូចជាបទចម្រៀង* ដែលចង្អុលថាលោកអេសេគាលគាត់បានសូត្រសេចក្ដីទំនាយរបស់គាត់ (មើល ២ពវ ៣:១៥ អស ៥:១) ប៉ុន្តែលើសពីនេះទៀតនោះ ហោរាចូលចិត្តប្រើប្រាស់ជាពាក្យប្រៀបធៀប ។ *ដ្បិតគេស្ដាប់ . . . ប៉ុន្តែមិនប្រព្រឹត្តតាមទេ* មើល អស ២៩:១៣ និងការពន្យល់ មថ ២១:២៨–៣២ ធៀបនឹង យក ១:២២–២៥ ។

**៣៤:១–៣១** ព្រះអម្ចាស់ប្រទានដល់ពួកកូនចៅអ៊ីស្រាអែល ដែលគេចាប់ជាឈ្លើយ នូវព្រះបន្ទូលទ្រង់បន្តទៀតថា នៅថ្ងៃអនាគត នោះទ្រង់នឹងធ្វើជាអ្នកគង្វាលរបស់គេ ។ នៅក្នុងខ.១–១០ ទ្រង់បដិសេធន៍យ៉ាងដាច់ខាតថា ពួកអ៊ីសាអែលគ្មានតម្លៃ "អ្នកគង្វាល" នៅក្នុងខ ១១–១៦ ទ្រង់សន្យាថា ទ្រង់នឹងស្វែងរកចៀមដែលបានខ្ចាត់ខ្ចាយ នៅក្នុងខ ១៧–២២ ទ្រង់ប្រកាសថា ទ្រង់នឹងជំនុំជម្រះដល់ចៀមខ្លាំង ដែលជិះជាន់ដល់ចៀមទន់ខ្សោយ នៅក្នុងខ.២៣–២៤ ទ្រង់សន្យាថាទ្រង់នឹងញែកចៀមរបស់ទ្រង់ចេញ ដើម្បីគេឱ្យធ្វើជាអ្នកបម្រើទ្រង់ "ស្ដេចដាវីឌ" នៅក្នុងខ ២៥–៣១ ទ្រង់មានបន្ទូលយ៉ាងច្បាស់អំពី "ការតាំងសញ្ញានៃក្ដីសុខសាន្ត" ដែលទ្រង់នឹងរំដោះពួកអ៊ីស្រាអែលដោយប្រទានពរដល់គេវិញ ។

**៣៤:២** *អ្នកគង្វាល់នៃសាសន៍អ៊ីស្រាអែល* អស់អ្នកដែលបានទទួលឯកសិទ្ធិធ្វើជាអ្នកដឹកនាំ ជាពិសេសធ្វើជាអ្នកស្ដេច និងជាមន្ត្រី (មើល ២សយ ៧:៧ និងការពន្យល់ យរ ២៥:១៨–១៩) ថែមទាំងធ្វើជាហោរា និងជាសង្ឃ (មើល អស ៥៦:១១ យរ ២៣:៩–១១) ។ លោកអេសេគាល បានតែងតាំងឡើងឱ្យធ្វើជាចៅហ្វាយ និងជាសង្ឃ ហើយមានតួនាទីធ្វើជាហោរាផងដែរសម្រាប់ការបន្ទោសជាពិសេស (ជំពូក ២២) ព្រះបានត្រាសហៅគាត់ឱ្យធ្វើជាស្ដេច និងជាអ្នកគង្វាល ដែលមាននៅជិតទិសខាងកើត កាលពីជំនាន់បុរាណកាល (មើលការពន្យល់ ទដ ២៣:១) សម្រាប់ស្ដេចដាវីឌ ទ្រង់កើតចេញពីប្រភពជាអ្នកគង្វាល ហើយធ្វើជាអ្នកគង្វាល–ស្ដេច (សូមមើល ទដ ៧៨:៧០–៧១) សម្រាប់ការបន្ទោសដល់អ្នកគង្វាល (សូមធៀបនឹង យរ ២៣:១–៤) ។

**៣៤:៣** *ស៊ី . . . ស្លៀកពាក់ . . . សម្លាប់* អ្នកគង្វាលគេទទួលទោសតាមច្បាប់ចំពោះបទឧក្រិដ្ឋ ដែលគេបានធ្វើដោយគេមិនយកចិត្តទុកដាក់ថែរក្សាដល់ហ្វូងចៀម ។

**៣៤:៤** *ហើយណាដែលវង្វេងទៅ នោះក៏មិនបានស្វែងរកដែរ* (ធៀបនឹង យរ ៥០:៦ សក ១១:១៥–១៧ មថ ១៨:១២–១៤ លក ១៥:៤ ១៩:១០ ។

**៣៤:៥** *វាត្រូវកំចាត់កំចាយទៅ* ពាក្យនេះ លោកអេសេគាលបានប្រើដើម្បីពណ៌នាអំពីពួកអ៊ីស្រាអែល ដែលគេបានចាប់ទៅធ្វើជាឈ្លើយ និងដែលគេបានបែកខ្ចាត់ខ្ចាយនោះ (មើល ១១:១៦–១៧ ១២:១៥ ២០:២៣,៣៤ ៤១ ២២:១៥ ២៨:២៥) ។ *គ្មានអ្នកគង្វាល* មិនមានអ្នកគង្វាលពិតទេ (ធៀបនឹង មក ៦:៣៤) ។

**៣៤:៨** *ជាអាហារដល់អស់ទាំងសត្វព្រៃ* សត្រូវសាសន៍បរទេស ប៉ុន្តែមើល

អ្នកគង្វាលទាំងប៉ុន្មានរបស់អញ មិនបានស្វះស្វែងរកចៀម
អញ គឺបានឃ្វាលតែខ្លួនឯងវិញ ឥតឃ្វាលហ្វូងចៀមអញ
សោះ[ឱ] ៩ដូច្នេះ ពួកអ្នកគង្វាលអើយ ចូរស្ដាប់ព្រះបន្ទូលនៃ
ព្រះយេហូវ៉ាចុះ ១០ព្រះអម្ចាស់យេហូវ៉ាទ្រង់ មានបន្ទូល
ដូច្នេះថា មើល អញទាស់នឹង[ឍ]ពួកអ្នកគង្វាល ហើយអញនឹង
ទារចៀមអញពីដៃគេ ក៏នឹងឱ្យគេឈប់លែងឃ្វាលហ្វូង
ចៀមទៅ ពួកអ្នកគង្វាលនឹងមិនរកស៊ីចិញ្ចឹម ខ្លួនគេទៀត
ដែរ អញនឹងជួយ[ណ]ឱ្យចៀមអញរួចពីមាត់គេ ដើម្បីមិនឱ្យ
ធ្វើជាហារដល់គេឡើយ[ត]។

១១ដ្បិតព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា
មើល អញ គឺអញនេះហើយ នឹងស្វែងរកចៀម[ថ]របស់អញ
ទាំងស៊ើបសួរទាស់តែឃើញផង ១២ឯអ្នកគង្វាល[ទ]គេតែង
មើលហ្វូងចៀមខ្លួន នៅថ្ងៃដែលគេនៅជាមួយនឹងហ្វូង
ចៀមដែលខ្ចាត់ខ្ចាយជាយ៉ាងណា នោះអញនឹងថែមើល
ហ្វូងចៀមរបស់អញ ហើយជួយឱ្យវារួចចេញពីគ្រប់កន្លែង
ដែលវាត្រូវកំចាត់កំចាយនោះ នៅថ្ងៃដែលមេឃមីរស្រទំ
ហើយងងឹតយ៉ាងនោះដែរ[ធ] ១៣អញនឹងនាំវារាល់គ្នា ចេញ
ពីសាសន៍ទាំងប៉ុន្មាន ហើយប្រមូល[ន]វាពីគ្រប់ទាំងស្រុក រួច
នឹងនាំចូលទៅក្នុងស្រុករបស់វាវិញ[ប,ផ,ព,ភ] អញនឹងឃ្វាលវា
នៅលើភ្នំនៃស្រុកអ៊ីស្រាអែល ហើយតាមផ្លូវទឹក និងនៅ
គ្រប់ទាំងកន្លែង ដែលមានមនុស្សនៅក្នុងស្រុកនោះផង[ម,យ,រ]
១៤អញនឹងឃ្វាលវានៅទីវាលល្អ ហើយក្រោលវានឹងនៅ
លើភ្នំខ្ពស់ៗនៃស្រុកអ៊ីស្រាអែល[ល] នៅទីនោះវានឹងដេក
ចុះក្នុងក្រោលយ៉ាងល្អ ហើយនឹងរកស៊ីនៅវាលដ៏ល្អ[វ] នៅ
លើអស់ទាំងភ្នំនៃស្រុកអ៊ីស្រាអែលដែរ[ស] ១៥ខ្លួនអញនឹង

**៣៤:៨** ឱ យជ ១:១២
**៣៤:១០** ឍ យរ ២១:១៣ ណ ទដ ៧២:១៤ ត ១សយ ២:២៩–៣០ យរ ២៣:២ សក ១០:៣
**៣៤:១១** ថ ទដ ១១៩:១៧៦
**៣៤:១២** ទ អស ៤០:១១ យរ ៣០:១០ សក ១០:៣ លក ១៩:១០ ធ អគ ៣២:៧
**៣៤:១៣** ន លប ៤៨:២១ ចទ ៣០:៤ ប មីក ៤:៦ ផ អគ ១១:១៧ ព យរ ២៣:៨ ភ អស ៦៦:២០ ម អគ ២៨:២៥ ៣៦:២៤ យ យរ ៥០:១៩ រ យរ ២៣:៣
**៣៤:១៤** ល អគ ២០:៤០ វ ទដ ២៣:២ ៣៧:៣ ស អស ៦៥:១០ អគ ៣៦:២៩–៣០ ៣៧:២២ អម ៩:១៤ មីក ៧:១៤
**៣៤:១៥** ហ សផ ៣:១៣ ឡ ទដ ២៣:១–២

ធ្វើជាអ្នកគង្វាលដល់ហ្វូងចៀមរបស់អញ ហើយអញនឹង
ឱ្យវាដេកនៅ[ហ] នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ឡ]
១៦អញនឹងស្វែងរកសត្វណាដែលវង្វេងបាត់ ហើយនាំណា
ដែលត្រូវប្រដេញឱ្យមកវិញ សត្វណាដែលបាក់ជើង នោះ
អញនឹងរុំអប[អ]ឱ្យ ហើយអញនឹងចំរើនកំឡាំង ដល់ណា
ដែលឈឺ[ក] តែសត្វណាដែលធាត់ ហើយមានកំឡាំង នោះ
អញនឹងបំផ្លាញវាបង់[ខ] គឺអញនឹងឃ្វាលវា ដោយសេចក្ដី
វិនិច្ឆ័យវិញ[គ]។

១៧ឱហ្វូងរបស់អញអើយ ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលពីឯងដូច្នេះថា មើល អញនឹងជំនុំជំរះក្ដីរបស់ចៀម
នឹងចៀម ហើយរបស់ចៀមឈ្មោលនឹងពពែឈ្មោះផង[ឃ]
១៨ការដែលឯងរាល់គ្នាបានស៊ីស្មៅនៅទីវាលល្អ នោះតើ
ជាការតិចតួចដល់ឯងឬ[ង] បានជាឯងជាន់ឈ្លីស្មៅដែលនៅ
សល់ទៀត ហើយដែលឯងរាល់គ្នាបានផឹកទឹកថ្លានោះផង
ផង បានជាឯងទៅកកូរឡើងឱ្យល្អក់ដោយជើង ដូច្នេះ[ច]
១៩ចំណែកហ្វូងចៀមរបស់អញ វាត្រូវស៊ីស្មៅ ដែលឯង
រាល់គ្នាជាន់ឈ្លី ហើយផឹកទឹក ដែលឯងបានធ្វើឱ្យល្អក់នោះ
វិញ ។

២០ហេតុនោះព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដល់
វារាល់គ្នាថា មើល អញ គឺអញនេះហើយ នឹងជំនុំជំរះក្ដី
របស់ចៀមធាត់ និងចៀមស្គម[ឆ] ២១ពីព្រោះឯងរាល់គ្នា
តែងតែគះដោយចំហៀង ហើយនឹងស្មា ក៏ចុះអស់ទាំង

យរ ៣៣:១២ មីក ៥:៤ **៣៤:១៦** អ ទដ ១៤៧:៣ ក មីក ៤:៦ សផ ៣:១៩ ខ លក ១៩:១០ គ អស ១០:១៦ យរ ៣១:៨ លក ៥:៣២ **៣៤:១៧** ឃ មថ ២៥:៣២–៣៣ **៣៤:១៨** ង លប ៣០:១៥ ច អគ ៣២:២ **៣៤:២០** ឆ មថ ២៥:៣២

(ខ.២៨) គេធ្វើផ្ទុយពីនោះវិញ ។

**៣៤:១០** *មើលអញទាស់នឹងពួកគង្វាល* មើលការពន្យល់ ៥:៨ ។

**៣៤:១១** *មើលអញ គឺអញនេះហើយ នឹងស្វែងរកចៀមរបស់អញ ទាំងស៊ើបសួររកទាល់តែឃើញ* ទាក់ទងទៅនឹងអ្នកគង្វាលដែលគ្មានសេចក្ដីជំនឿ (មើលខ.១–១០) ព្រះអម្ចាស់ប្ដេជ្ញាថា ទ្រង់នឹងធ្វើជាអ្នកគង្វាលលើហ្វូងចៀមរបស់ទ្រង់ (មើល យរ ២៣:៣–៤)។

**៣៤:១២** *ពីគ្រប់កន្លែងដែលវាត្រូវកំចាត់កំចាយនោះ* ក្រុងបាប៊ីឡូនមិនមែនជាទីកន្លែងតែមួយគត ដែលពួកអ៊ីស្រាអែលបានទៅប៉ុណ្ណោះទេ (មើល យរ ៤៣:១–៧) ។ *នៅថ្ងៃនៃមេឃមីរស្រទំ* ថ្ងៃរបស់ព្រះអម្ចាស់ បានមកសណ្ឋិតលើអ៊ីស្រាអែល នៅពេលក្រុងយេរូសាឡិមដួលរលំនៅរដូវក្ដៅ នៅឆ្នាំ ៥៨៦ មុន គ.ស (មើល ៧:៧ ៣២:៧ និងការពន្យល់) ។

**៣៤:១៣** *អញនឹងនាំវារាល់គ្នា* ចេញពីសាសន៍ទាំងប៉ុន្មាន សេចក្ដីសន្យាពីការសាងសង់ឡើងវិញ បានចាប់ផ្ដើមនៅក្នុង ១១:១៧ និងការរំលឹកឡើងវិញនៅក្នុងជំពូក ២០:៣៤ ៤១–៤២ ២៨:២៥ រកការសង្កត់ន័យយ៉ាងពិសេសនៅក្នុងផ្នែកនេះ (ជំពូក ៣៣–៣៩) នៅក្នុងព្រះគម្ពីរអេសេគាល (មើល ៣៦:២៤–៣២ និងការពន្យល់ ៣៧:២១ ៣៨:៨ និងការពន្យល់ ៣៩:២៧) ។ *នៅលើភ្នំនៃស្រុកអ៊ីស្រាអែល* ប្រៀបធៀបទៅនឹងថ្មនៅក្នុង ៦:៣–៧ ទៅនឹងសេចក្ដីជំនុំជម្រះ (មើល ខ.១២) ភ្នំប្រហែលជាតំណាងពីទីកន្លែងនៃសេចក្ដីសង្គ្រោះ ។

**៣៤:១៤** *អញនឹងឃ្វាលវានៅទីវាលល្អ* សូមមើល អស ៤០:១១ យហ ១០:១១ ។

**៣៤:១៦** *ហើយអញនឹងចំរើនកំឡាំងដល់ណាដែលឈឺ* ដោយជួយថែបំប៉នដល់អស់ "ចៀម"ណាដែលត្រូវគេជិះជាន់ (មើលនៅក្នុងខ.១៧–២២)។

**៣៤:១៧** *ហើយរបស់ចៀមឈ្មោល និងពពែឈ្មោល* ពួកអ្នកកាន់អំណាច ហើយមានឥទ្ធិពល ដែលបានជិះជាន់លើពួកអ៊ីស្រាអែលក្រីក្រ នេះជាពាក្យបង្ហាញពីការយកចិត្តទុកដាក់ដូចគ្នា ចំពោះយុត្តិធម៌សង្គម ដែលឃើញមាននៅកន្លែងណាមួយក្នុងសេចក្ដីទំនាយនោះ (មើល អស ៣:១៣–១៥ ៥:៨ អម ៥:១២ ៦:១–៧ ហើយមើលផងដែរ មក ២:១–៥ និងការពន្យល់)។ ធៀបនឹង ទង្វើដែលគេប្រព្រឹត្តចំពោះពួកទាសករ ដែលលោកយេរេមាបានសង្កេតមើលឃើញបែបនោះ (យរ ៣៤:៨–១១)។

ចៀមខ្សោយដោយស្នែង[ជ] ដរាបដល់បានកំចាត់កំចាយគេទៅបាត់ ២២ដូច្នេះ អញនឹងជួយសង្គ្រោះហ្វូងចៀមរបស់អញ នោះវានឹងលែងបានជារំពាតទៅ ហើយអញនឹងជំនុំជំរះក្តីរបស់ចៀមនឹងចៀម[ឈ] ២៣អញនឹងតាំងអ្នកគង្វាលតែ១ ឱ្យថែមើលវា អ្នកនោះនឹងឃ្វាលវា គឺដាវីឌ ជាអ្នកបំរើរបស់អញ គាត់នឹងកៀងនាំ[ញ]វាទៅឱ្យស៊ី ហើយនឹងធ្វើជាអ្នកគង្វាលដល់ហ្វូង[ដ] ២៤នោះអញនេះ គឺយេហូវ៉ានឹងធ្វើជាព្រះនៃវាល់គ្នា[ឋ] ហើយដាវីឌ[ឌ] ជាអ្នកបំរើរបស់អញនឹងធ្វើជាចៅហ្វាយលើវា[ឍ] គឺអញនេះ ជាព្រះយេហូវ៉ា អញបានចេញវាចាហើយ[ណ]។

២៥អញនឹងតាំងសន្តិ[ត]សញ្ញា[ថ]នឹងវារាល់គ្នា ហើយនឹងធ្វើឱ្យសត្វកំណាច[ទ]ផុតចេញពីស្រុកវាទៅ ដូច្នេះ វានឹងអាស្រ័យនៅទីរហោស្ថានដោយសុខសាន្ត[ធ] ហើយដេកនៅក្នុងព្រៃផង ២៦អញនឹងធ្វើឱ្យ[ន]គេ ព្រមទាំងទីកន្លែងនៅជុំវិញភ្នំតូចរបស់អញ ជាទីឱ្យព្រះអញនឹងបង្អុរឱ្យភ្លៀងធ្លាក់មកតាមរដូវកាល[ប] នោះនឹងមានព្រះពរធ្លាក់មកមួយមេៗ[ផ] ២៧ដើមឈើនៅផែនដីនឹងបង្កើតផ្លែ[ព] ហើយដីនឹងបានផលចំរើន[ភ] វារាល់គ្នានៅក្នុងស្រុកខ្លួន ដោយសុខសាន្ត[ម] ហើយនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត ក្នុងកាលដែលអញបានបំបាក់នឹម[យ]ចេញពីវា ហើយបានជួយឱ្យវារួចពីកណ្តាប់ដៃនៃពួកអ្នកដែលចាប់វាទៅប្រើ[រ] ២៨នោះវារាល់គ្នានឹងមិនបានជារំពា ដល់អស់ទាំងសាសន៍តទៅ ហើយសត្វព្រៃនៅផែនដីក៏មិនហែកវាស៊ីដែរ គឺវានឹងនៅដោយសុខសាន្ត[ល] ឥតមានអ្នកណាបំភ័យឡើយ[វ] ២៩អញនឹងធ្វើឱ្យមានដំណាំ១កើតឡើងទុកជាល្បី[ស]ដល់វា នោះវារាល់គ្នានឹងមិនត្រូវសាបសូន្យទៅ ដោយអំណត់អត់[ហ]នៅក្នុងស្រុកឡើយ ក៏មិនត្រូវរងទ្រាំសេចក្តីខ្មាស[ឡ]នៃអស់ទាំងសាសន៍ទៀតដែរ[អ] ៣០នោះវារាល់គ្នានឹងដឹងថា អញដ៏ជាយេហូវ៉ា អញជាព្រះនៃវា ក៏នៅជាមួយផង ហើយថាវាដែលជាពួកវង្សអ៊ីស្រាអែល វាជារាស្ត្ររបស់អញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ក] ៣១ឯងរាល់គ្នាដែលជាហ្វូងចៀមរបស់អញ[ខ] គឺជាហ្វូងចៀមនៅទីឃ្វាលរបស់អញ[គ] ឯងរាល់គ្នាជាមនុស្ស ហើយអញជាព្រះនៃឯង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ។

**បទទំនាយទាស់នឹងស្រុកអេដំម**

**៣៥** ១ព្រះបន្ទូល នៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំម្តងទៀតថា

**៣៤:២១** ជ ចទ ៣៣:១៧ **៣៤:២២** ឈ ទដ ៧២:១២–១៤ យរ ២៣:២–៣ អគ ២០:៣៧–៣៨ **៣៤:២៣** ញ អស ៤០:១១ ដ អស ៣១:៤ មីក ៥:៤ **៣៤:២៤** ឋ អគ ៣៦:២៨ ឌ ទដ ៨៩:៤៩ ឍ អស ៥៣:៤ សក ១៣:៧ ណ យរ ២៣:៤–៥ ៣០:៩ ៣៣:១៤ យហ ១០:១៦ វវ ៧:១៧ **៣៤:២៥** ត ជន ២៥:១២ ថ អគ ១៦:៦២ ទ លវ ២៦:៦ ធ លវ ២៥:១៨ អស ១១:៦–៩ ហស ២:១៨ **៣៤:២៦** ន លប ១២:២ ប ទដ ៦៨:៩ យអ ២:២៣ ផ ចទ ១១:១៣–១៥ ២៨:១២ អស ៤៤:៣

**៣៤:២៧** ព ទដ ៧២:១៦ ភ យប ១៤:៩ ទដ ៦៧:៦ ម ជន ២៤:២១ យ លវ ២៦:១៣ រ យរ ៣០:៨ អគ ២០:៤២ ២៨:២៥ **៣៤:២៨** ល យរ ៣២:៣៧ វ យរ ៣០:១០ អគ ២៨:២៦ ៣៩:២៦ ហស ១១:១១ អម ៩:១៥ សផ ៣:១៣ សក ១៤:១១ **៣៤:២៩** ស អស ៤:២ ហ អគ ៣៦:២៩ ឡ ទដ ១៣៧:៣ អគ ៣៦:៦ យអ ២:១៩ អ អគ ៣៦:១៥ **៣៤:៣០** ក អគ ១៤:១១ ៣៧:២៧ **៣៤:៣១** ខ ទដ ២៨:៩ គ យរ ២៣:១

**៣៤:២៤** *ចៅហ្វាយ* ព្រះអម្ចាស់ទ្រង់ប្រកាសអំពីនគររបស់ទ្រង់នៅទីកន្លែងដែលទ្រង់គង់ធ្វើជាស្តេចនៅលើផែនដីនេះថា "ចៅហ្វាយ" (ធៀបនឹង ៣៧:២៥ ៤៤:៣ ៤៥:៧ ១៦–១៧ ៤៦:២–១៨ ៤៨:២១–២២)។

**៣៤:២៥** ***តាំងសន្តិសញ្ញានឹងវារាល់គ្នា*** ធៀបនឹង ៣៧:២៦ គ្រប់ទាំងគោលបំណងនៃការតាំងសញ្ញារបស់ផងព្រះ គឺសេចក្តីសុខសាន្ត (មើល លក ២៦:២៨–៣១ នក ២៥:១២ អស ៥៤:១០ មក ២:៥)។ ការតាំងសញ្ញានេះគឺជា ("ការតាំងសញ្ញាថ្មី" បានថ្លែងដោយលោកយេរេមា ៣១:៣១–៣៤) ក្រឡេកមើលទៅឯចំណុចចុងក្រោយ ព្រះគ្រីស្ទគឺជាអ្នកផ្តួចផ្តើមគំនិត (ភល ៤:៧) ហើយទ្រង់នៅតែរងចាំដើម្បីបំពេញសេចក្តីសន្យារបស់ទ្រង់ចុងក្រោយ។ "សេចក្តីសុខសាន្ត" ពាក្យហេព្រើរសាឡូម (Shalom) ដែលគេនឹងនឹកចាំ អំពីការស្អាងនៃភាពទំនាក់ទំនងរបស់គេជាមួយនឹងព្រះឡើងវិញ ដោយទ្រង់ប្រទានក្តីអំណរនៃជីវិត ធ្វើឱ្យគេបានពេញបរិបូរណ៍ និងសម្បូរសប្បាយរុងរឿង តាមរយៈព្រះពររបស់ទ្រង់ ។ នៅថ្ងៃជំនុំជម្រះរបស់ព្រះនោះនឹងគ្មានសេចក្តីភ័យខ្លាចណា មកបំភ័យយើងចំពោះ "សេចក្តីសុខសាន្ត" បានឡើយ (មើលការប្រៀបធៀបក្នុងខ ២៥–២៩ ជាមួយនឹង ៥:១៦–១៧ និងការពន្យល់)។ *ហើយដេកនៅក្នុងព្រៃផង* នោះសត្វចៀមវាតែងប្រឈមមុខនឹងគ្រោះថ្នាក់ដល់ជីវិត (មើល ទដ ១០៤:២០–២១ យរ ៥:៦)។

**៣៤:២៦** *បង្អុរឱ្យភ្លៀងធ្លាក់មកតាមរដូវកាល* សរទរដូវ (ចាប់ពីថ្ងៃទី២២ ខែកញ្ញា ដល់ថ្ងៃទី២១ ខែធ្នូ) ចាប់ផ្តើមនៅរដូវវស្សា និងនិទាឃរដូវ (រដូវស្លឹករំហើយ) រហូតដល់ចុងឆ្នាំ ។ ព្រះពររបស់ព្រះបានធ្លាក់មក ព្រះពរអំណាចនៃជីវិតដែលព្រះទ្រង់សន្យាសំរាប់រាស្ត្ររបស់ទ្រង់ តាមរយៈលោកអ័ប្រាហាំ (មើល លក ១២:១–៣) ដែលជានិម្មិតសញ្ញាពីភាពស្រស់បំព្រងនៃជីវិត ដោយទ្រង់ប្រទានឱ្យមានទឹកភ្លៀងធ្លាក់មក ។

**៣៤:២៧** *អញបានបំបាក់នឹមចេញពីវា* នឹមធ្វើឡើងពីឈើដែលមានខ្សែប្រឡៅ សម្រាប់ដាក់ខាងក្រោមកសត្វ ដើម្បីឱ្យវាទាញរទេះដើរទៅមុខបាន (មើល អស ៥៨:៦ ធៀបនឹង ៣០:១៨ លវ ២៦:១៣ យរ ២៧:២ ២៨:១០–១៣) ។ ជារូបភាពមួយ ដែលបង្ហាញពីការកៀបសង្កត់របស់បរទេស (សាសន៍ដទៃ) ។

**៣៤:២៩** *មិនត្រូវរងទ្រាំសេចក្តីខ្មាសនៃអស់ទាំងសាសន៍* (មើល ២២:៤) ។

**៣៤:៣០** *អញជាព្រះនៃវា . . . វាជារាស្ត្ររបស់អញ* ព្រះទ្រង់មានបន្ទូលពីការតាំងសញ្ញា (មើល ១១:២០ នក ៦:៧ ហស ១:៩ និងការពន្យល់) ។

**៣៥:១–១៥** ការស្អាងឡើងវិញចំពោះភាគីរបស់អ៊ីស្រាអែល ដូចជាព្រះអម្ចាស់ទ្រង់ស្អាងរាស្ត្ររបស់ទ្រង់ឡើងវិញ ចំពោះវិនាសកម្មដោយសារខ្មាំងសត្រូវរបស់គេ–នោះគឺពួកអេដំម (មើល ៣៦:៥)។ ដើម្បីឱ្យគេមានភាពទំនាក់ទំនងជាប្រវត្តិសាស្ត្រ រវាងអ៊ីស្រាអែល និងអេដំម (មើលការពន្យល់នៅក្នុង ខ.២,៥) គេប្រព្រឹត្តដោយគំនុំសងសឹកដល់ពួកយូដា ពីសំណាក់ពួកអេដំម នៅចំពេលដែលក្រុងយេរូសាឡិមដួលរលំ ហើយគេសមនឹងទទួលនូវការបន្ទោសនោះ (សូមមើល អស ៦៣:១–៦ និងការពន្យល់

²កូនមនុស្សអើយ ចូរតាំងមុខទាស់នឹងស្រុកភ្នំសៀរ[ក] ចូរ
ទាយទាស់នឹងវាថា ³ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូល
ដូច្នេះ នៃស្រុកភ្នំសៀរអើយ អញទាស់នឹងឯង អញនឹងលូក
ដៃ[ខ]អញទៅលើឯង ព្រមទាំងធ្វើឱ្យឯងទៅជាស្ងាត់ជ្រងំ
ហើយជាទីស្រឡាំងកាំង[គ] ⁴អញនឹងឱ្យទីក្រុងទាំងប៉ុន្មាន
របស់ឯងខូចបង់ទៅ[ឃ] ហើយឯងនឹងត្រូវចោលស្ងាត់ នោះ
ឯងនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ង] ⁵ពីព្រោះឯង
បានព្យាបាទជានិច្ច ក៏បានប្រគល់ពួកកូនចៅអ៊ីស្រាអែល
ដល់អំណាចនៃដាវ[ច] នៅថ្ងៃដែលគេមានសេចក្តីអន្តរាយ[ឆ]
គឺក្នុងកាលដែលសេចក្តីទុច្ចរិត បានដល់កំណត់ហើយ[ជ]
⁶ហេតុនោះព្រះអម្ចាស់យេហូវ៉ាទ្រង់ស្បថថា ដូចជាអញ
រស់នៅ ប្រាកដជាអញនឹងត្រៀមឯងទុក ដល់គ្រាខ្ចាយ
ឈាម[ឈ] ហើយឈាមនឹងដេញតាមឯងទៅ[ញ] ដោយព្រោះ
ឯងមិនបានស្អប់ឈាមទេ នោះឈាមនឹងដេញតាមឯងជា
ពិត ⁷គឺយ៉ាងនោះដែលអញនឹងធ្វើឱ្យភ្នំសៀរ ទៅជាទី
ស្រឡាំងកាំង ហើយឱ្យត្រូវស្ងាត់ជ្រងំ[ដ] ឯអស់អ្នកណា
ដែលដើរកាត់ស្រុកនោះ និងពួកអ្នកដែលត្រឡប់មកវិញ
នោះអញនឹងកាត់គេចេញ[ឋ] ⁸អញនឹងបំពេញអស់ទាំងភ្នំ
ដោយសាកសពនៃមនុស្សដែលត្រូវសំឡាប់ ពួកអ្នកដែល
ត្រូវស្លាប់ដោយដាវ គេនឹងដួលនៅលើភ្នំតូច នៅច្រកភ្នំ
ហើយនៅក្នុងផ្លូវទឹកទាំងប៉ុន្មានរបស់ឯង[ឌ] ⁹អញនឹងធ្វើឱ្យ
ឯងនៅស្ងាត់ច្រៀបជានិច្ចតទៅ[ឍ] ទីក្រុងទាំងប៉ុន្មានរបស់
ឯង នឹងគ្មានមនុស្សណានៅទៀតឡើយ នោះឯងរាល់គ្នា
នឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ណ]។
¹⁰ហេតុដោយព្រោះឯងបានថា សាសន៍ទាំង២នឹង
ស្រុកទាំង២នោះ នឹងបានជារបស់[ត]ផងអញ យើងនឹងជាប់
បានជារបស់ផងយើង ទោះបើព្រះយេហូវ៉ាទ្រង់គង់នៅទី
នោះក៏ដោយ ¹¹បានជាព្រះយេហូវ៉ាទ្រង់ស្បថថា ដូចជា
អញរស់នៅ ប្រាកដជាអញនឹងសំរេចតាមសេចក្តីកំហឹង[ថ]
របស់ឯង ហើយតាមសេចក្តីច្រណែនដែលឯងបានសំដែង
ចេញ ដោយចិត្តគុំគួនដល់គេ អញនឹងធ្វើឱ្យមនុស្សស្គាល់
អញនៅកណ្តាលពួកគេ ក្នុងកាលដែលអញជំនុំជំរះឯង[ទ]
¹²នោះឯងនឹងដឹងថា អញនេះគឺព្រះយេហូវ៉ាបានឮអស់
ទាំងពាក្យត្មះតិះដៀល ដែលឯងបានពោលទាស់នឹងភ្នំនៃ
ស្រុកអ៊ីស្រាអែលទាំងប៉ុន្មានថា ស្រុកគេត្រូវចោលស្ងាត់
ហើយ គឺបានប្រគល់មកឱ្យយើងត្របាក់លេប[ធ] ¹³តែឯង
រាល់គ្នាបានដំកើងខ្លួន[ន]ទាស់នឹងអញ ដោយសារមាត់ឯង
ព្រមទាំងចំរើនពាក្យរបស់ឯង ទាស់នឹងអញផង អញបាន
ឮហើយ[ប] ¹⁴ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
កាលណាផែនដីទាំងមូលបានរីករាយឡើង នោះអញនឹង
ធ្វើឱ្យឯងស្ងាត់ជ្រងំវិញ[ផ] ¹⁵ឯងបានអរសប្បាយ[ព]ពីដំណើរ
មរដកនៃពួកវង្សអ៊ីស្រាអែល ដោយព្រោះបានត្រូវចោល
ស្ងាត់ជាយ៉ាងណា នោះអញនឹងធ្វើដល់ឯងយ៉ាងនោះដែរ
ឱភ្នំសៀរ[ភ] និងស្រុកអេដំមទាំងមូល[ម] អើយ ឯងនឹងត្រូវ
ចោលស្ងាត់ នោះគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ា
ពិត ។

## សេចក្តីទំនាយដល់ភ្នំនៃស្រុកអ៊ីស្រាអែល

**៣៦** ¹កូនមនុស្សអើយ ចូរទាយដល់អស់ទាំងភ្នំនៃស្រុក
អ៊ីស្រាអែល[ក]ដែរថា ឱភ្នំអ៊ីស្រាអែលអើយ ចូរស្តាប់ព្រះ

**៣៥:២** ក លប ១៤:៦ **៣៥:៣** ខ យរ ៦:១២ គ អស ៣៤:១០ អគ ២៥:១២–១៤ **៣៥:៤** ឃ យរ ៤៤:២ ង ខ.៩ យរ ៤៩:១០ **៣៥:៥** ច ទដ ៦៣:១០ ឆ អប ១:១៣ ជ ទដ ១៣៧:៧ អគ ២១:២៩ **៣៥:៦** ឈ អស ៣៤:៣ ញ អស ៦៣:២–៦ **៣៥:៧** ដ យរ ៤៦:១៩ ឋ យរ ៤៩:១៧ **៣៥:៨** ឌ អគ ៣១:១២ **៣៥:៩** ឍ អប ១:១០ ណ អស ៣៤:៥–៦ យរ ៤៩:១៣ **៣៥:១០** ត ទដ ៨៣:១២ អគ ៣៦:២,៥ **៣៥:១១** ថ អគ ២៥:១៤ ទ ទដ ៩:១៦ អប ១:១៥ មថ ៧:២ **៣៥:១២** ធ យរ ៥១:៤៨ **៣៥:១៣** ន យរ ៤៩:១៦ ប ដយ ១១:៣៦ **៣៥:១៤** ផ យរ ៥១:៤៨ **៣៥:១៥** ព អគ ៣៦:៥ អប ១:១២ ភ ខ.៣ ម អស ៣៤:៥,១១ យរ ៥០:១១–១៣ បទ ៤:២១ អគ ៣២:២៩ **៣៦:១** ក អគ ១៧:២២

សេចក្តីផ្តើមព្រះគម្ពីរអូបាឌា ការរួបរួម និងសាច់រឿង ហើយមើលការពន្យល់ផងដែរនៅក្នុង អម ៩:១២ អប ៨) ។

**៣៥:៣** *អញទាស់នឹងឯង* (មើលការពន្យល់ ៥:៨) ។

**៣៥:៥** *ឯងបានព្យាបាទជានិច្ច* ផ្តើមឡើងដោយការឆបោករបស់លោកយ៉ាកុប ដែលដណ្តើមព្រះពរ ពីលោកអេសាវ(មើល លប ២៧ ជាពិសេស ខ.១៤) និងរហូតដល់ចុងក្រោយ (មើល នក ២០:១៤–២១ ២សយ ៨:១៣–១៤ ១ពវ ៩:២៦–២៨) ។ *នៅថ្ងៃដែលគេមានសេចក្តីអន្តរាយ* ពួកអេដំមបានលួចរបស់នៅក្រុងយេរូសាឡិមនៅក្នុងឆ្នាំ ៥៨៦ គ.ស (មើល អប ១១–១៤ និងការពន្យល់) ។

**៣៥:៦** *ដូចជាអញរស់នៅ* (មើលការពន្យល់ ៥:១១ ។ *គ្រាខ្ចាយឈាមហើយឈាមនឹងដេញឯងទៅ* ដោយភាពយុតិធម៌នោះគេត្រូវទទួលទោសវិញ យោងនៅក្នុង លប ៩:៦ (មើលការពន្យល់ក្នុងខនោះ) ។

**៣៥:៩** *ធ្វើឱ្យឯងនៅស្ងាត់ច្រៀបជានិច្ចតទៅ* នឹងមិនមានការស្ថាបនាឡើងវិញឡើយ ដូចជានៅស្រុកអេស៊ីព្ទ (មើល ២៩:១៣–១៦) ។ *ឯងរាល់គ្នានឹងដឹងថា អញនេះជាព្រះអម្ចាស់ពិត* មើលសេចក្តីផ្តើម សាច់រឿង ។

**៣៥:១០** *សាសន៍ទាំង២* គឺសាសន៍អ៊ីស្រាអែល និងសាសន៍យូដា *ទោះបើព្រះអម្ចាស់ទ្រង់គង់នៅទីនោះក៏ដោយ* (មើល ៤៨:៣៥ និងការពន្យល់)។

**៣៦:១–៣៨** ព្រះអម្ចាស់មានបន្ទូលដូច្នេះ ឈ្មោះរបស់ឯងត្រូវបានប្រមាថនិងជាទីឡកឡឺយដល់សំណល់នៃអស់ទាំងសាសន៍ ដែលនៅជុំវិញដើម្បីឱ្យគេបានដឹងថា អញនេះជាព្រះដ៏បរិសុទ្ធដែលបានបង្កើតមនុស្សមក មើល ខ. ១–១៥ ទ្រង់មានបន្ទូលដូច្នេះ ទីក្រុងនោះនឹងទៅជាទីចោលស្ងាត់ ។ (អស់ទាំងភ្នំតូចធំ) ជាការបង្ហាញពីភាពថ្កុំថ្កើង និងការរីកចម្រើនដែលជាព្រះពរសម្រាប់អ៊ីស្រាអែល ដូច្នេះពាក្យថា អស់ទាំងភ្នំតូចធំ គឺជាទីកន្លែងនៃការប្រទានពរចំពោះពួកអ៊ីស្រាអែល ។ ប៉ុន្តែទីកន្លែងនោះបានត្រឡប់ទៅជាទីបង្អាប់វិញ មើល ខ.១៦–៣៨ ។ ព្រះអម្ចាស់មានបន្ទូលថា នោះអញនឹងសម្អាតពីអស់ទាំងអំពើទុច្ចរិតរបស់ឯងចេញ នឹងសង់អស់ទាំងទីខូចបង់បាក់បែកឱ្យបានមាំមួនឡើងវិញ ហើយឱ្យមានមនុស្សអាស្រ័យនៅផង ដូច្នេះអស់ទាំងសាសន៍ដែលសល់នៅព័ទ្ធជុំវិញឯង គេនិងដឹងថា គឺអញជាព្រះដ៏បរិសុទ្ធ ។

បន្ទូលនៃព្រះយេហូវ៉ាចុះ ២ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះថា[ខ] ដោយព្រោះទាំងខ្មាំងសត្រូវបានពោល
ឡកឯងថាហាសហា[គ] ទីខ្ពស់ពីបុរាណទាំងនេះបាន[ឃ]ត្រឡប់
ជារបស់ផងយើងហើយ[ង] ៣ដូច្នេះចូរទាយប្រាប់ថា ព្រះ
អម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរទាយប្រាប់ថា
ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ដោយហេតុនេះ
គឺដោយព្រោះតែគេបានធ្វើឱ្យឯងនៅស្ងាត់ច្រៀប[ច] ព្រម
ទាំងលេបឯងចូលនៅគ្រប់ទិស ឱ្យឯងបានទៅជារបស់
សាសន៍ដែលនៅសល់ ហើយដោយព្រោះពួកអ្នកនិយាយ
ដើមបានចាប់តាំងនិយាយពីឯង ហើយជនទាំងឡាយ
និយាយអាក្រក់ពីឯងផង[ឆ] ៤ដូច្នេះ ឱភ្នំអ៊ីស្រាអែលអើយ
ចូរស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ាចុះ ព្រះអម្ចាស់
យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ ដល់អស់ទាំងភ្នំតូច ផ្លូវទឹក
និងច្រកភ្នំ[ជ] ព្រមទាំងទីខូចបង់[ឈ] និងទីក្រុងដែលគេចោល
ស្ងាត់[ញ] ជាទីដែលបានត្រឡប់ជារំពា ហើយជាទីឡកឡឺយ[ដ]
ដល់សំណល់នៃអស់ទាំងសាសន៍ដែលនៅព័ទ្ធជុំវិញ[ឋ] ៥គឺព្រះ
អម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា ឯសំណល់នៃអស់ទាំង
សាសន៍ ព្រមទាំងស្រុកអេដំមទាំងមូល ដែលបានដំរូវ
ស្រុកអញទុកជារបស់ផងគេ ដោយសេចក្តីអំណរអស់ពីចិត្ត
ទាំងមានចិត្តមើលងាយផង ដើម្បីនឹងបោះបង់ចោលចេញ
ទុកជារំពា[ឌ] នោះពិតប្រាកដជាអញបានតបនឹងគេ ដោយ
ភ្លើងនៃសេចក្តីប្រចណ្ឌរបស់អញ[ឍ] ៦ដូច្នេះ ចូរទាយ ពី
ដំណើរស្រុកអ៊ីស្រាអែល ហើយប្រាប់ដល់អស់ទាំងភ្នំធំ តូច
ផ្លូវទឹក និងច្រកភ្នំទាំងប៉ុន្មានថា ព្រះអម្ចាស់យេហូវ៉ា ទ្រង់
មានបន្ទូលដូច្នេះ មើល អញបាននិយាយ ដោយសេចក្តី
ប្រចណ្ឌ និងសេចក្តីក្រោធរបស់អញ ហើយដោយព្រោះ
ឯងរាល់គ្នា បានរងទ្រាំសេចក្តីខ្មាសរបស់សាសន៍ដទៃ[ណ]
៧ហេតុនោះព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលថា អញ
បានស្បថហើយ[ត]ថា ពិតប្រាកដជាសាសន៍ទាំងប៉ុន្មាន ដែល
នៅព័ទ្ធជុំវិញឯង គេនឹងត្រូវរងទ្រាំសេចក្តីខ្មាសរបស់ខ្លួន
គេវិញ[ថ] ។

៨តែចំណែកឯង ឱភ្នំអ៊ីស្រាអែលអើយ ឯងរាល់គ្នានឹង
បែកមែក ហើយបង្កើតផល[ទ]របស់ឯង ឱ្យអ៊ីស្រាអែលជា
រាស្ត្រអញ ពីព្រោះគេរៀបនឹងមកហើយ ៩ដ្បិតមើលអញ
កាន់ខាងឯង ហើយអញនឹងវិលមកឯងវិញ នោះនឹងមាន
គេភ្ជួររាល់ហើយសាបព្រោះឯងឡើង[ធ] ១០អញនឹងឱ្យ
មនុស្សចំរើនឡើងនៅក្នុងឯង គឺជាពួកវង្សអ៊ីស្រាអែល
ទាំងមូល ដូច្នេះទីក្រុងទាំងប៉ុន្មានរបស់ឯង នឹងមានមនុស្ស
នៅ ហើយអស់ទាំងទីខូចបង់[ន] នឹងបានសង់ឡើងវិញ[ប]
១១អញនឹងធ្វើឱ្យទាំងមនុស្សនិងសត្វផង បានចំរើនឡើង

**៣៦:២** ខ អគ ៦:២–៣ គ អគ ២៥:៣ ឃ ចទ ៣២:១៣ ង អគ ៣៥:១០ **៣៦:៣** ច អប ១:១៣ ឆ ទដ ៤៤:១៣–១៤ បទ ២:១៦ ៣:៦២ **៣៦:៤** ជ អគ ៦:៣ ឈ អគ ៣៣:២៤ ញ លវ ៦:៣ ដ យរ ២:២៦ ឋ ចទ ១១:១៣ ទដ ៧៩:៤ អគ ៣៣:២៨–២៩ **៣៦:៥** ឌ ចទ ២៩:២០ ឍ អស ៦៦:១៦ យរ ២៥:៣១ ៥០:១១ អគ ២៥:១២–១៤ ៣៥:១០,១៥ ៣៨:២២ យអ ៣:២,១៤ **៣៦:៦** ណ ទដ ១២៣:៣–៤ អគ ៣៤:២៩ **៣៦:៧** ត ជន ១៤:៣០ ថ យរ ២៥:៩

**៣៦:៨** ទ អស ៤:២ ២៧:៦ អគ ៤៧:១២ **៣៦:៩** ធ ខ.៣៤–៣៦ យរ ៣១:២៧ **៣៦:១០** ន អស ៤៩:៨ ប អស ៤៩:១៧–២៣ យរ ៣០:១៨

**៣៦:១–១៥** នៅត្រង់នេះព្រះបន្ទូលរបស់ព្រះមានការលើកទឹកចិត្ត ឱ្យពួកគេមានឋានៈស្មើគ្នា មើល ជំពូក៦ និង ខ.១–៧ ប្រកាសពីការជំនុំជម្រះនៃព្រះនឹងមកលើគ្រប់អស់ទាំងសាសន៍ ដោយសារការប្រមាថមើលងាយរបស់ពួកគេ បានពូនដូចជាគំនរនៅលើទឹកដីនៃប្រទេសអ៊ីស្រាអែល មើល ខ.៨–១៥ និងជាការប្រកាសពីការយាងត្រឡប់មកវិញ នូវភាពរុងរឿងរបស់ព្រះមកលើស្រុកអ៊ីស្រាអែល ។

**៣៦:២** *ដោយព្រោះខ្មាំងសត្រូវបានពោលឡកឱ្យឯងថា* សូមមើល ២៥:៣ ២៦:២ ។ *ហាសហា* សូមមើលការពន្យល់នៅក្នុង ២៥:៣ ។ *ទីខ្ពស់ពីបុរាណ* នៅត្រង់វគ្គនេះគឺជាទឹកដីសន្យាដែលពេលនោះបានសង់ឡើងទុកជាតំបន់នៅចន្លោះទន្លេយ័រដាន់ និងឆ្នេរសមុទ្រមេឌីទែរ៉ាណេសម្រាប់ធ្វើចំណុចកណ្តាលដ៏សំខាន់នៅយុគសម័យនោះ ។

**៣៦:៣** *បានទៅជារបស់សាសន៍* ពីអតីតកាលគ្រប់អស់ទាំងសាសន៍បានធ្វើសញ្ជ័យទៅលើផ្នែកផ្សេងៗនៃប្រទេសអ៊ីស្រាអែលរហូតដល់ទីបញ្ចប់ពួកគេបានទទួលការកាន់កាប់ទាំងស្រុង ។

**៣៦:៤** *អស់ទាំងភ្នំតូចភ្នំធំ ផ្លូវទឹក និងច្រកភ្នំ* សូមមើល ៦:៣ និងការពន្យល់នៅក្នុង ១:៥ ។

**៣៦:៥** *សំណល់នៃអស់ទាំងសាសន៍* ព្រះអម្ចាស់ផ្ទាល់ត្រូវបានគ្រប់អស់ទាំងសាសន៍ប្រមាថ និងចំអកឡកឡឺយ ។ ពីព្រោះពួកគេទាំងឡាយនោះបានរស់នៅលើទឹកដីដ៏វិសេសរបស់ទ្រង់ គឺជាទឹកដីដែលព្រះប្រទានឱ្យមកដល់ពួកគេ ។ ប៉ុន្តែពួកគេបានប្រព្រឹត្តនៅចំពោះទ្រង់ដោយការចំអកព្រមពេញទៅដោយការលួចប្លន់វិញ ។ *ស្រុកអេដំម* គឺពួកកម្លោះនៃស្រុកអេដំមបានត្រូវចេញទៅឈរទាស់ប្រឆាំងជាមួយនិងពួកអ៊ីស្រាអែលដោយចំណាយពេលវេលាអស់រយៈដ៏យូរលុង (សូមមើល ជំពូក ៣៥ ជាពិសេស សូមមើល ខ.២,៥ និងការពន្យល់ផ្សេងទៀត) ។

**៣៦:៦** *សេចក្តីប្រចណ្ឌ និងសេចក្តីក្រោធ* សូមមើល ១៦:៣៨ ហើយនិងការពន្យល់ ។

**៣៦:៧** *អញបានស្បថហើយថា* សូមមើល ២០:៥ ហើយនិងការពន្យល់ ។

**៣៦:៨** *បែកមែក ហើយនឹងបង្កើតផល* គឺជាសញ្ញាសម្គាល់នៃការលូតលាស់ (មើល ១៧:៨,២៣) ហើយបានបង្ហាញពីការសង់ឡើងវិញរបស់ទ្រង់ (សូមមើល លវ ២៦:៣–៥) ដែលមានការខុសប្លែកពីគ្នាជាមួយនិងការវិនាសហិនហោចរបស់ស្រុកអេដំម (មើលនៅក្នុង ៣៥:៣,៧,១៥ ។ *រៀបនឹងមកហើយ* នេះសំដៅទៅនឹងព្រឹត្តិការណ៍នៃថ្ងៃជំនុំជម្រះដែលត្រូវមកដល់យ៉ាងឆាប់រហ័ស ព្រមទាំងត្រូវបានប្រកាសនឹងបំបរបង់នៅវេលានោះ ។

**៣៦:៩** *អញ . . . នឹងវិលមកឯងវិញ* ធៀបនឹង លវ ២៦:៩ សម្រាប់នៅត្រង់វគ្គនេះគឺវាស្រដៀង និងដូចគ្នាជាមួយអនុប្រយោគដែលមាននៅក្នុងបរិបទមុន ។

**៣៦:១០** *ពួកវង្សអ៊ីស្រាអែលទាំមូល* សូមមើលនៅក្នុងជំពូក ៣៧:១៥–២៣ លោកហោរាអេសេគាលគាត់បាននិយាយពីការសាងសង់ឡើងវិញសម្រាប់ពួកអ៊ីស្រាដែលទាំងអស់ ។

**៣៦:១១** *គេនឹងចំរើនឡើង ហើយសាយគ្រាយចេញទៅ* នៅត្រង់នេះគឺដូច

នៅក្នុងឯង គេនឹងចំរើនឡើង[ផ] ហើយសាយក្រាយចេញ
ទៅ នោះអញនឹងឱ្យមានមនុស្ស[ព]អាស្រ័យនៅក្នុងឯង ដូច
យ៉ាងពីដើម[ភ] ហើយប្រព្រឹត្តនឹងឯង ដោយស្អាតជាងជាន់
ដើមទៅទៀត[ម] នោះឯងរាល់គ្នានឹងដឹងថា អញនេះជាព្រះ
យេហូវ៉ាពិត ១២អើ អញនឹងឱ្យមានមនុស្សដើរលើឯង គឺ
អ៊ីស្រាអែលជារាស្ត្ររបស់អញ គេនឹងបានឯងជារបស់ផង
គេ ហើយឯងនឹងបានជាមរដកដល់គេ[យ] នោះឯងនឹងមិន
ធ្វើឱ្យគេព្រាត់ប្រាសកូនទៀតឡើយ ១៣ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះគេនិយាយពីឯងថា
ឯងជាស្រុកដែលលេបមនុស្ស[រ]បាត់ ហើយបំរាលកូនរបស់
សាសន៍ឯង ១៤ដូច្នេះ ឯងនឹងលែងលេបមនុស្សបាត់តទៅ
ក៏មិនបំរាលកូនរបស់សាសន៍ឯងទៀតឡើយ នេះជាព្រះ
បន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ១៥អញក៏មិនឱ្យឯងឮពាក្យ
ត្មះតិះដៀលរបស់សាសន៍ដទៃទាំងប៉ុន្មានទៀតដែរ ឯង
មិនត្រូវរងទ្រាំសេចក្ដីប្រមាថមើលងាយរបស់គេតទៅ ឯង
នឹងមិនធ្វើជាហេតុ ឱ្យសាសន៍របស់ឯង ចំពប់ដួលទៀត
ឡើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ល] ។
១៦ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំម្តងទៀតថា
១៧កូនមនុស្សអើយ កាលពួកវង្សអ៊ីស្រាអែលបាននៅក្នុង
ស្រុករបស់ខ្លួន នោះគេបានបង្អាប់ស្រុកនោះ ដោយផ្លូវ
ប្រព្រឹត្ត និងកិរិយារបស់ខ្លួន ផ្លូវដែលគេប្រព្រឹត្តនៅមុខ អញ
ប្រៀបដូចជាសេចក្ដីស្មោកគ្រោក[វ] នៃស្រីដែលមាន រដូវ[ស]
១៨ហេតុនោះបានជាអញចាក់[ហ]សេចក្ដីក្រោធរបស់ អញ
ទៅលើគេ គឺដោយព្រោះឈាម ដែលគេបានកំចាយ
នៅក្នុងស្រុក ហើយដោយព្រោះគេបានបង្អាប់ស្រុក ដោយ
រូបព្រះរបស់គេ ១៩ដូច្នេះ អញបានកំចាត់កំចាយគេទៅ
នៅក្នុងអស់ទាំងសាសន៍ គេត្រូវបែងចែកទៅ[ឡ]នៅគ្រប់
ស្រុកផង អញបានជំនុំជំរះគេតាមផ្លូវគេប្រព្រឹត្ត និងតាម
កិរិយារបស់គេ[អ] ២០កាលគេបានចូលទៅឯសាសន៍ណា
ដែលគេត្រូវខ្ចាយទៅនោះ គេក៏បង្អាប់[ក]ឈ្មោះបរិសុទ្ធរបស់
អញទៀត ដោយមានមនុស្សថា ពួកនេះជាពួករបស់ព្រះ
យេហូវ៉ា គេបានចេញចាកពីស្រុករបស់ទ្រង់មក[ខ] ២១ប៉ុន្តែ
អញបានយល់ដល់ឈ្មោះបរិសុទ្ធរបស់អញ ដែលពួកវង្ស
អ៊ីស្រាអែលបានបង្អាប់ នៅកណ្តាលសាសន៍ទាំងប៉ុន្មាន
ដែលគេបានទៅដល់នោះ[គ] ។
២២ដូច្នេះ ចូរប្រាប់ដល់ពួកវង្សអ៊ីស្រាអែលថា ព្រះ
អម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ឱពួកវង្សអ៊ីស្រាអែល
អើយ អញមិនមែនធ្វើការនេះ ដោយយល់ដល់ឯងរាល់

**៣៦:១១** ផ លប ១:២ ព អស ៤៩:១៩ ភ មីក ៧:១៤ ម លវ ២៦:៩ យប ៤២:១៣ យរ ៣១:២៨ អគ ១៦:៥៥ សក ១០:៨ **៣៦:១២** យ អគ ៤៧:១៤,២២ **៣៦:១៣** រ ជន ១៣:៣២ **៣៦:១៥** ល ទដ ៨៩:៥០-៥១ អស ៥៤:៤ អគ ៣៤:២៩ **៣៦:១៧** វ លវ ៥:២ ១២:២ ស ទដ ១០៦:៣៧-៣៨ យរ ២:៧ **៣៦:១៨** ហ ២របា ៣៤:២១ **៣៦:១៩** ឡ ចទ ២៨:៦៤ អ លវ ១៨:២៤-២៨ អគ ៧:៨ ២៤:១៤ ៣៩:២៤

**៣៦:២០** ក លវ ១៨:២១ អគ ១៣:១៩ រម ២:២៤ ខ អស ៥២:៥ យរ ៣៣:២៤ អគ ១២:១៦ **៣៦:២១** គ ទដ ៧៤:១៨ អស ៤៨:៩

គ្នានិងការដែលព្រះទ្រង់បានប្រទានពរ ហើយបង្កើតកូនឱ្យចំរើនជាច្រើនឡើងនៅផែនដី (លប ១:២២,២៨ សូមមើល លប ៨:១៧ ៩:១,៧) ហើយក្រាក្រោយមកទៀតព្រះទ្រង់បានចុះការតាំងសញ្ញាប្រទានពរ (សូមមើល លប ១៧:៦ ៣៥:១១ ៤៨:៣-៤ នក ១:៧) ។ *នឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត* ព្រះបន្ទូលត្រង់នេះគឺបញ្ជាក់ពីការទទួលស្គាល់ពេញទីនៅក្នុងព្រះ គម្ពីរ ដើម្បីបង្ហាញពីសេចក្ដីប្រកាសរបស់ព្រះតាមរយៈការជំនុំជម្រះនៅចំណុចនេះជាការប្រកាសពីការបើកសម្ដែងរបស់ព្រះអង្គផ្ទាល់ (សូមមើល ៣៥:៩ ហើយនិងការពន្យល់) ។

**៣៦:១២** *ដើរលើឯង* អស់ទាំងភ្នំតូចភ្នំធំនៃប្រទេសអ៊ីស្រាអែលគឺនៅតែជាទីអាស្រ័យ ។ *នោះឯងនឹងមិនធ្វើឱ្យគេព្រាត់ប្រាស់កូនទៀតឡើយ* ភ្នំទាំងប៉ុន្មានគឺបានបង្ហាញពីភាពរីដើបរំជួលដូចជាការជំលៀសប្រជាជនដើម្បីនាំពួកគេទៅបំបរបង់ចោល ។ ការទាំងនេះគឺបានបញ្ជាក់ពីការពិតដែលបានកើតឡើងចំពោះសាសន៍ការណាន និងទីកន្លែងមជ្ឈមណ្ឌលសាសនារបស់ពួកគេនៅលើទឹកដីដែលបានសន្យា ។ (ទីខ្ពស់ទាំងឡាយ) ដែលបានដឹកនាំពួកអ៊ីស្រាអែលឱ្យវង្វេង ហើយបានធ្វើឱ្យសេចក្ដីក្រោធនៃព្រះធ្លាក់មកលើរាស្ត្ររបស់ទ្រង់ (សូមមើល ៦:៣ និងការពន្យល់) ។

**៣៦:១៦-២៣** ផ្លូវដែលគេប្រព្រឹត្តនៅមុខអញ ប្រៀបដូចជាសេចក្ដីស្មោកគ្រោក ដែលបានរីកខ្ចាត់ខ្ចាយដល់មនុស្ស ខ.១៦-២៣ ។ ដើម្បីជាការរំឭកដល់អ៊ីស្រាអែលឱ្យបានដឹងថា គ្រប់ទាំងសាសន៍គឺត្រូវបានបំបរបង់ចេញពីស្រុករបស់គេដោយព្រោះពួកគេមិនបានស្អាត ហើយនិងត្រូវសង់ឡើងវិញសម្រាប់ជាប្រយោជន៍នៅចំពោះព្រះនាមដ៏បរិសុទ្ធរបស់ព្រះ ខ.២៤-២៧ នេះជាការប្រកាសជាថ្មីនៃព្រះដល់ពួកអ៊ីស្រាអែល ដោយព្រោះពួកគេបានប្រព្រឹត្តសេចក្ដីស្មោកគ្រោកនៅចំពោះព្រះ ដែលជាការប្រកាសដ៏មានប្រសិទ្ធិភាពមកលើអ៊ីស្រាអែល (សូមមើល ខ.២៨-៣២) ហើយនិងមកលើគ្រប់ទាំងសាសន៍ (សូមមើល ខ.៣៣-៣៦) ខ.៣៧-៣៨ គឺជាការផ្ដល់នូវសេចក្ដីសង្ខេប ។

**៣៦:១៨** *ឈាមដែលគេបានកំចាយ... បានបង្អាប់ស្រុក ដោយរូបព្រះរបស់ពួកគេ* យោងតាមសេចក្ដីបញ្ជាក់សង្ខេប ចំពោះសង្គមអយុត្តិធម៌របស់អ៊ីស្រាអែលគឺ ដោយព្រោះពួកគេបានក្រាបថ្វាយបង្គំដល់ព្រះក្លែងក្លាយនិងគោរព ដល់សាសានាផ្សេងៗ (សូមមើល ២២:៣ និងការពន្យល់) ។ *រូបព្រះ* សូមមើលការពន្យល់នៅក្នុង ៦:៤ ។

**៣៦:២០** *គេត្រូវខ្ចាយទៅនោះ គេក៏បង្អាប់ឈ្មោះបរិសុទ្ធរបស់អញ* ដោយព្រោះអ៊ីស្រាអែលបានដាច់ឆ្ងាយពីស្រុករបស់អញ ដែលវាហាក់ដូចជាធ្វើដំណើរទៅកាន់សាសន៍នានាដែលអញមិនអាចការពារនិងរក្សាដល់ពួកគេបាន (សូមមើល ២០:៩ និងការពន្យល់ ធៀបនឹង ជន ១៤:១៥-១៦ ២ពវ ១៨:៣២-៣៥ ១៩:១០-១២) ។

**៣៦:២២** *ដោយយល់ដល់ឯងរាល់គ្នាទេ* មិនមែនដោយព្រោះព្រះមិនបានថែរក្សាចំពោះអ៊ីស្រាអែលនោះទេ ប៉ុន្តែដោយព្រោះពួកគេមិនសមនឹងទទួលនូវអ្វីដែលពួកគេបានប្រព្រឹត្ត (ធៀបនឹង ចទ ៩:៤-៦) ។ ដូចជាលោកហោរាអេសេគាលបានថ្លែងប្រកាស និងចែកចាយនៃព្រះគុណដ៏បរិសុទ្ធ

គ្នាទេ គឺដោយយល់ដល់ឈ្មោះបរិសុទ្ធរបស់អញវិញ[ឃ] ជា
ឈ្មោះដែលឯងរាល់គ្នាបានបង្អាប់[ង] នៅកណ្ដាលអស់ទាំង
សាសន៍ដែលឯងបានទៅដល់នោះ[ច] ២៣អញក៏នឹងញែក
ឈ្មោះដ៏ជាធំរបស់អញ[ឆ] ដែលត្រូវបង្អាប់[ជ]នៅកណ្ដាលអស់
ទាំងសាសន៍ គឺដែលឯងរាល់គ្នាបានបង្អាប់ នៅក្នុងពួក
គេ ចេញជាបរិសុទ្ធដែរ នោះពួកសាសន៍ដទៃនឹងដឹងថា
អញនេះជាព្រះយេហូវ៉ាពិត[ឈ] ក្នុងកាលដែលអញបានញែក
ជាបរិសុទ្ធ[ញ]ក្នុងពួកឯង នៅចំពោះភ្នែកគេ[ដ] នេះជាព្រះ
បន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ២៤ដ្បិតអញនឹងយកឯងរាល់
គ្នា ចេញពីអស់ទាំងសាសន៍ ហើយប្រមូលឯងពីគ្រប់ទាំង
ស្រុក នាំមកក្នុងស្រុកជារបស់ផងឯងរាល់គ្នាវិញ[ឋ] ២៥នោះ
អញនឹងប្រោះ[ឌ]ទឹកស្អាតទៅលើឯងរាល់គ្នា ដូច្នេះ ឯងនឹង
បានស្អាត អញនឹងជំរះ[ឍ]ឯងរាល់គ្នាឱ្យស្អាត ពីគ្រប់ទាំង
សេចក្ដីស្មោកគ្រោក[ណ] ហើយពីអស់ទាំងរូបព្រះរបស់ឯង
ផង[ត] ២៦អញនឹងឱ្យឯងមានចិត្តថ្មី[ថ] ហើយនឹងដាក់វិញ្ញាណថ្មី
នៅក្នុងឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្ម[ទ] ពីរូបសាច់
ឯងចេញ រួចនឹងឱ្យមានចិត្តជាសាច់វិញ[ធ] ២៧អញនឹងដាក់
វិញ្ញាណ[ន]របស់អញនៅក្នុងឯងរាល់គ្នា ហើយបណ្ដាលឱ្យ
ឯងរាល់គ្នាដើរតាមក្រិត្យក្រម[ប] ហើយរក្សាបញ្ញត្តច្បាប់
របស់អញ ព្រមទាំងប្រព្រឹតតាមផង[ផ] ២៨នោះឯងរាល់គ្នា
នឹងអាស្រ័យនៅក្នុងស្រុក ដែលអញបានឱ្យដល់ពួកឰយុកោ
ឯង ឯងរាល់គ្នានឹងធ្វើជារាស្ត្ររបស់អញ[ព] ហើយអញនឹង
បានជាព្រះដល់ឯង[ភ] ២៩អញនឹងជួយសង្គ្រោះឯងរាល់គ្នា
ឱ្យរួចពីអស់ទាំងសេចក្ដីសៅហ្មងរបស់ឯង អញនឹងបង្គាប់
ដល់ស្រូវ ឱ្យបានចំរើនឡើងជាបរិបូរ ឥតធ្វើឱ្យកើតមាន
អំណត់[ម]ទៀតឡើយ ៣០ក៏នឹងចំរើនផ្លែឈើ និងផលចំការ
ឡើងដែរ ដើម្បីមិនឱ្យឯងរាល់គ្នា ត្រូវពាក្យដំនៀលរបស់
សាសន៍ដទៃ ដោយព្រោះអំណត់អត់នោះតទៅ[យ] ៣១នោះ

**៣៦:២២** ឃ អស ៣៧:៣៥ អគ ២០:៤៤ ង រម ២:២៤ ច ចទ ៩:៥-៦ ទដ ១០៦:៨ អគ ២០:៩ **៣៦:២៣** ឆ ជន ៦:២៧ ជ អស ៣៧:២៣ ឈ ទដ ៤៦:១០ ញ អគ ២០:៤១ ដ ទដ ១២៦:២ អស ៥:១៦ **៣៦:២៤** ឋ អស ៤៣:៥-៦ អគ ៣៤:១៣ ៣៧:២១ **៣៦:២៥** ឌ លវ ១៤:៧ ១៦:១៤-១៥ ហាព ៩:១៣ ឍ ទដ ៥១:២,៧ ណ អគ ៦:២១ ត អស ២:១៨ យអ ៣:២១ សក ៣:៤ ១៣:២ កច ២២:១៦ **៣៦:២៦** ថ យរ ២៤:៧ ទ យរ ៥:៣ ធ ទដ ៥១:១០ អគ ១៨:៣១ ២កថ ៣:៣ **៣៦:២៧** ន អស ៤៤:៣ យអ ២:២៩ យហ ៣:៥ ប អគ ១៨:២១ ផ យរ ៥០:២០ ១ធថ ៤:៨ **៣៦:២៨** ព យរ ៣០:២២ ៣១:៣៣ ភ អគ ១១:១៧ ១៤:១១ ៣៤:២៤ ៣៧:១៤,២៧ សក ៨:៨ **៣៦:២៩** ម អគ ៣៤:២៩ **៣៦:៣០** យ លវ ២៦:៤-៥ អគ ៣៤:១៣-១៤ ហស ២:២១-២២

របស់ព្រះ ។ *ដោយយល់ដល់ឈ្មោះបរិសុទ្ធរបស់អញ* ហេតុផលទាំងនេះគឺបានផ្ដល់ការពន្យល់នៅក្នុងជំពូក ២០ ។ នៅត្រង់ឃ្លានេះគឺព្រះទ្រង់បានដកដៃចេញវិញ ដោយមិនបានដាក់ទណ្ឌកម្មទៅលើពួកគេទេ ហើយបានប្រព្រឹត្តដោយយល់នាមរបស់ទ្រង់ (សូមមើល ២០:៩,១៤,២២) នៅត្រង់ចំណុចនេះគឺជាហេតុផលដែលផ្ដល់ឱ្យនូវការសង់ឡើងវិញរបស់ព្រះអាទិករ ។

**៣៦:២៣** *នោះពួកសាសន៍ដទៃនឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត* គោលបំណងនិងផែនការណ៍នាគ្រាចុងក្រោយរបស់ទ្រង់ជាមួយនិងពួកអ៊ីស្រាអែលនោះគឺថា ពិភពលោកទាំងមូលនិងស្គាល់ព្រះដ៏ពិត (សូមមើល ៦:៧ និងការពន្យល់) ។ *អញបានញែកជាបរិសុទ្ធក្នុងពួកឯង សូមមើល លវ* ១០:៣ ហើយនិងការពន្យល់ ។

**៣៦:២៤-២៧** មានធាតុបួនយ៉ាងដែលបានសន្យានៅក្នុងការសាងសង់ឡើងវិញជាថ្មីគឺ ទី១ ការវិញត្រឡប់របស់ពួកជាឈ្លើយ (ខ.២៤) ទី២ ការលាងសម្អាតពីអំពើបាប (ខ.២៥) ទី៣ ប្រែចិត្តជាថ្មី (ខ.២៦) នឹងទី ៤ ការដែលអាចធ្វើបានដោយសារព្រះវិញ្ញាណនៃព្រះដើម្បីរស់នៅក្នុងផ្លូវរបស់ព្រះ (ខ.២៧) ។

**៣៦:២៥** *អញនឹងប្រោសទឹកស្អាត* ដ្បិតការប្រោសជាមួយនិងទឹកគឺដូចជាក្បួនដែលបញ្ជាក់ពីការសម្អាត សូមមើល នក ៣០:១៩-២០ លវ ១៤:៥១ ជន ១៩:១៨ ធៀបនឹង សផ ១៣:១ ហាព ១០:២២ ។ *អញនឹងជំរះឯងរាល់គ្នាឱ្យស្អាត* សូមមើល ខ.៣៣ ៣៧:២៣ យរ ៣៨:៨ ។ *អស់ទាំងរូបព្រះ* សូមមើលការពន្យល់នៅក្នុង ៦:៤ ។

**៣៦:២៦-២៧** នៅត្រង់វគ្គនេះគឺនិយាយពី "ការតាំងសញ្ញាថ្មី" (សូមមើល យរ ៣១:៣៣-៣៤ និងការពន្យល់ដទៃទៀត) ។

**៣៦:២៦** *មានចិត្តថ្មី* សូមមើលការពន្យល់នៅក្នុង ១១:១៩ ១៨:៣១ ។ *ដាក់វិញ្ញាណថ្មីនៅក្នុងឯង* គឺជាការបំផ្លាស់បំប្រែនៅក្នុងចិត្តគំនិតរបស់អ្នក មើលនៅក្នុង ១១:៩ ព្រះអម្ចាស់បានប្រកាសថា ទ្រង់នឹងនាំមកនូវការផ្លាស់ប្រែ មើល ១៨:៣១ សូមមើលការពន្យល់ដែលមាននៅទីនេះគឺ ព្រះទ្រង់បានត្រាសហៅប្រជារាស្ត្ររបស់ទ្រង់មកដើម្បីឱ្យពួកគេប្រែចិត្ត ។ ហើយអ្វីដែលព្រះទ្រង់ត្រូវការធ្វើគឺទ្រង់តែងតែជាជំនួយដល់រាស្ត្ររបស់ទ្រង់ជានិច្ច ។ *រូបសាច់ឯង* នៅត្រង់នេះគឺនិយាយពីសាច់ឈាម មើលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលជាញឹកញាប់បញ្ជាក់បង្ហាញពីសញ្ញានៃសេចក្ដីកំសោយនឹងភាពមិនរឹងមាំខាងសេចក្ដីជំនឿ (អស ៣១:៣) ។ ចំណែកនៅក្នុងព្រះគម្ពីរសញ្ញាថ្មីសាច់ឈាមជារឿយៗគឺបានបញ្ជាក់បង្ហាញពីជីវិតពេញដោយអំពើបាបដែលជាការទាស់ប្រឆាំងជាមួយនិងព្រះ (ដូចមាននៅក្នុង រម ៥:៨) ។

**៣៦:២៧** *អញនឹងដាក់វិញ្ញាណរបស់អញ* នៅត្រង់ឃ្លានេះមានន័យថា ព្រះបានចាក់វិញ្ញាណបរិសុទ្ធរបស់ទ្រង់ដើម្បីឱ្យមនុស្សមានអំណាចដោយសារព្រះវិញ្ញាណប្រយោជន៍ និងសម្រេចដល់ការងាររបស់ទ្រង់ (សូមមើល ៣៧:១៤ និងការពន្យល់នៅក្នុង ២:២) ។ នៅ ខ.២៥-២៧ គឺបានស្របគ្នាទៅនឹង ទដ ៥១:៧-១១ (សូមមើលការពន្យល់ផ្សេងទៀត) ។

**៣៦:២៨-៣២** លទ្ធផលទាំងឡាយរបស់អ៊ីស្រាអែលដែលបានចាប់ផ្ដើមជាថ្មីនៅត្រង់នេះ គឺបានបង្ហាញពីការសាងសង់ឡើងវិញដើម្បីបញ្ជាក់ប្រាប់ពីការរីកចម្រើននិងភាពថ្កុំថ្កើងនៃប្រទេសអ៊ីស្រាអែល (ខ.២៨-៣០) ដែលស៊ីជម្រៅខាងវិញ្ញាណនៃសេចក្ដីខ្មាសសម្រាប់អំពើបាបរបស់ពួកគេ (ខ.៣១:៣២) ។

**៣៦:២៨** *រាស្ត្ររបស់អញ ហើយអញនឹងបានជាព្រះដល់ឯង* នៅត្រង់វគ្គនេះព្រះអម្ចាស់យេហូវ៉ាគឺជាព្រះនៃគ្រប់ទាំងសាសន៍និងគ្រប់ភាសា (សូមមើល ១១:២០ និងការពន្យល់) ។

**៣៦:២៩** *រួចពីអស់ទាំងសេចក្ដីសៅហ្មងរបស់ឯង* នៅត្រង់ចំណុចនេះគឺព្រះទ្រង់ឱ្យពួកអ៊ីស្រាអែលងាកបែរចេញពីការថ្វាយបង្គំរូបព្រះក្លែងក្លាយនិងគេចចេញពីសីលធម៌ដ៏អាក្រក់របស់ពួកគេ (សូមមើល ខ.២៥ ៣៧:២៣) ។

**៣៦:៣០** *ពាក្យដំនៀល* ដូចមាននៅ ខ.១៥ ។

ឯងរាល់គ្នានឹងនឹកចាំពីកិរិយាអាក្រក់របស់ឯង ហើយពី
អំពើដែលឯងរាល់គ្នាប្រព្រឹត្តមិនល្អផង ដូច្នេះ ឯងរាល់គ្នា
នឹងមើលខ្លួនដោយខ្ពើមឆ្អើម ដោយព្រោះអំពើទុច្ចរិត និង
អំពើគួរស្អប់ខ្ពើមរបស់ឯង[វ] ។
[៣២]ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលថា ត្រូវឱ្យឯង
រាល់គ្នាដឹងថា មិនមែនដោយយល់ដល់ឯងរាល់គ្នា ដែល
អញធ្វើដូច្នេះទេ ឱពួកវង្សអ៊ីស្រាអែលអើយ ចូរឱ្យមាន
សេចក្តីខ្មាស[ល] ហើយជ្រប់មុខ ដោយព្រោះកិរិយារបស់ឯង
ចុះ[វ] [៣៣]ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា នៅ
ថ្ងៃដែលអញជំរះ[ស]ឯងរាល់គ្នា ឱ្យស្អាតពីអស់ទាំងអំពើ
ទុច្ចរិតរបស់ឯងចេញ នោះអញនឹងឱ្យអស់ទាំងទីក្រុងរបស់
ឯង មានមនុស្សអាស្រ័យនៅវិញ ហើយឱ្យអស់ទាំងទីខូច
បង់[ហ]បានសង់ឡើង[ឡ] [៣៤]ឯស្រុកដែលបាននៅស្ងាត់នឹង
មានភ្ជួររាស់ ជាស្រុកដែលពីដើមនៅស្ងាត់ច្រៀប ចំពោះ
ភ្នែកនៃអស់អ្នកដែលដើរកាត់នោះ [៣៥]ហើយគេនឹងពោល
ថា ស្រុកនេះដែលត្រូវចោលស្ងាត់ បានត្រឡប់ដូចជាសួន
ច្បារអេដែនវិញ[អ] ហើយទីក្រុងទាំងប៉ុន្មានដែលត្រូវខូចបង់
ចោលស្ងាត់ ហើយបាក់បែក ក៏បានមាំមួនឡើង ហើយ
មានមនុស្សអាស្រ័យនៅផង[ក] [៣៦]ដូច្នេះ អស់ទាំងសាសន៍
ដែលសល់នៅព័ទ្ធជុំវិញឯង គេនឹងដឹងថា គឺអញជាព្រះ
យេហូវ៉ានេះ អញបានសង់ទីបំផ្លាញនោះឡើយ ហើយ
សាបព្រោះកន្លែងដែលចោលស្ងាត់វិញ គឺអញជាយេហូវ៉ា
នេះ អញបានចេញវាចាហើយ ក៏នឹងសំរេចតាមផង[ខ] ។
[៣៧]ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា មួយទៀត
អញនឹងបើកឱ្យពួកវង្សអ៊ីស្រាអែល បានសួរ[គ]អញពីដំណើរ
នោះឯង ដើម្បីឱ្យអញបានសំរេចការនោះដល់គេ គឺអញ
នឹងឱ្យគេចំរើនគ្នាជាច្រើនឡើង ដូចជាហ្វូងចៀម[ឃ] [៣៨]អស់
ទាំងទីក្រុងខូចបង់ នឹងបានពេញដោយហ្វូងមនុស្ស ប្រៀប
ដូចជាហ្វូងចៀមដែលញែកជាបរិសុទ្ធ[ង] គឺដូចជាហ្វូងចៀម
នៅក្រុងយេរូសាឡិម ក្នុងថ្ងៃបុណ្យមានកំណត់ នោះគេ
នឹងដឹងថា អញនេះជាព្រះយេហូវ៉ាពិត[ច] ។

**៣៦:៣១** វ អស ៦:៥ យរ ៣១:១៩ អគ ៦:៩
**៣៦:៣២** ល អគ ១៦:៦៣ វ ចទ ៩:៥
**៣៦:៣៣** ស លវ ១៦:៣០ ហ លវ ២៦:៣១ ឡ អស ៤៩:៨
**៣៦:៣៥** អ លប ២:៨ ក អម ៩:១៤
**៣៦:៣៦** ខ យរ ៤២:១០ អគ ១៧:២២ ៣៧:១៤ ៣៩:២៧–២៨
**៣៦:៣៧** គ សក ១០:៦ ១៣:៩ ឃ ទដ ១០២:១៧ យរ ២៩:១២–១៤
**៣៦:៣៨** ង ១ពវ ៨:៦៣ ២រប ៣៥:៧–៩ ច នក ៦:២
**៣៧:១** ក អគ ១:៣ ខ អគ ១១:២៤

## ច្រកភ្នំនៃឆ្អឹងស្ងួត

**៣៧** [១]ព្រះហស្តនៃព្រះយេហូវ៉ា បានសណ្ឋិតលើខ្លួន[ក]
ហើយទ្រង់នាំយកខ្ញុំ ដោយព្រោះវិញ្ញាណ[ខ]នៃព្រះយេហូវ៉ា
ទៅដាក់ចុះនៅកណ្តាលច្រកភ្នំ១[គ] ដែលពេញដោយឆ្អឹង
ខ្មោច[ឃ] [២]ទ្រង់ឱ្យខ្ញុំដើរក្បែរឆ្អឹងទាំងនោះនៅព័ទ្ធជុំវិញ ខ្ញុំក៏
ឃើញថា នៅវាលច្រកនោះមានឆ្អឹងយ៉ាងសន្ធឹក ហើយថា

លក ៤:១ កច ៨:៣៩ គ យរ ៧:៣២ ឃ យរ ៨:២ អគ ៤០:១

**៣៦:៣១** *នោះឯងរាល់គ្នានឹងនឹកចាំ* នៅត្រង់ចំនុចនេះជាការបង្ហាញពីការដឹកនាំនៃពួកអ៊ីស្រាអែល គឺគ្មានព្រះគុណនៃព្រះក្នុងការដឹកនាំឡើយ នេះជាការរំឭក ដើម្បីបញ្ជាក់ពីការស្តាយក្រោយដែលពួកគេបានប្រព្រឹត្តកន្លងមក (ធៀបនឹង ៦:៩ ១៦:៦៣ ២០:៤៣ ទដ ១៣:៤) ។

**៣៦:៣២** *មិនមែនដោយយល់ដល់ឯងរាល់គ្នា* សូមមើលការពន្យល់នៅក្នុង ខ.២២ ។

**៣៦:៣៣–៣៦** ប្រឆាំងនឹងការសង់ឡើងវិញរបស់ពួកអ៊ីស្រាអែលនិងមនុស្សជាតិនៅលើអស់ទាំងសាសន៍ ។

**៣៦:៣៣** *នៅថ្ងៃ* គឺជាការទាក់ទងគ្នា ទានឹងសេចក្តីសន្យាពីការសម្អាត (ខ.២៤–៣២) ហើយនិងសេចក្តីសន្យាឱ្យមានមនុស្សអាស្រ័យនៅវិញដូចដើមវិញ (ខ.៣៣–៣៦) ។

**៣៦:៣៥** *សួនច្បារអេដែន* ធៀបនឹង ២៨:១៣ ៣១:៩ ។ *ក៏បានមាំមួនឡើង* ដែលមានការផ្ទុយគ្នានៅក្នុង ៣៨:១១ ។

**៣៦:៣៦** *អស់ទាំងសាសន៍ . . . នឹងដឹងថា* សូមមើលការពន្យល់នៅក្នុង ខ.២៣ ។

**៣៦:៣៧–៣៨** នៅក្នុងសេចក្តីសង្ខេប គឺពួកអ៊ីស្រាអែលទាំងអស់បានឈរជាមួយនឹងព្រះដើម្បីសង់ទីខូចបង់ឡើងវិញ ។

**៣៦:៣៧** *បានសំរេចការនោះ* គឺជាអនុញ្ញាតិឱ្យគ្រប់គ្នាបានទូលអង្វរចូលមកចំពោះព្រះសារជាថ្មី ។ ហើយព្រះទ្រង់មិនបានបដិសេធចំពោះការទូលអង្វររបស់ពួកអ៊ីស្រាអែលឡើយ នៅពេលណាដែលពួកគេបានទូលសូម នោះព្រះទ្រង់នឹងឆ្លើយតបមកយ៉ាងឆាប់រហ័សបំផុត (ធៀបនឹង១៤:៣ ២០:៣,៣១) ។

**៣៦:៣៨** *ដូចជាហ្វូងចៀមដែលញែកជាបរិសុទ្ធ* សូមមើល ១ពវ ៨:៦៣ ១រប ២៩:២១ ២រប ៣៥:៧ នេះជាការប្រៀបធៀប ។

**៣៧:១–២៨** ទោះបីយ៉ាងណាគឺហោរាអេសេគាលបានទទួលនូវទស្សនះមួយយ៉ាងសំខាន់ ប៉ុន្តែវាជាការចម្លែកដែលគ្មានចុះថ្ងៃខែ យ៉ាងណាក៏ដោយ វាត្រូវតែបានមកដល់ហោរាអេសេគាលប្រហែលនៅឆ្នាំបន្ទាប់ ៥៨៦ មុន គ.ស ។ វាជានិមិត្តរូបពីទស្សនៈដែលបានផ្តល់មកឱ្យលោកអេសេគាល (ខ.១–១៥) យោងទៅតាមសញ្ញាសម្គាល់នៃសកម្មភាពដែលហោរាអេសេគាលគឺជាការបង្ហាត់បង្រៀនដើម្បីសម្តែង (ខ.១៦–២៨) ។ ចំណុចទាំងពីរនេះគឺនិយាយពីរការសង់ឡើងវិញរបស់ពួកអ៊ីស្រាអែល ដែលជាចំកណ្តាលនៃគោលរឿង ជំពូក ៣៤–៣៦ ។

**៣៧:១** *ព្រះហស្តនៃព្រះយេហូវ៉ា* សូមមើលការពន្យល់ ១:៣ ។ *នាំយកខ្ញុំដោយព្រះវិញ្ញាណ* សូមមើល ៣:១២ និងការពន្យល់ ។ *ច្រកភ្នំ* នៅក្នុងព្រះគម្ពីរហេព្រើរពាក្យនេះមានន័យដូចគ្នាដែលបានបកប្រែថា "វាលរាប" មើលក្នុង ៣:២២–២៣ ៨:៤ ។ ឥឡូវនេះហោរាអេសេគាលបានទទួលសារនៃសេចក្តីសង្ឃឹម នៅពេលមុនដែលគាត់បានឮព្រះបន្ទូលនៃព្រះពីការជំនុំជម្រះ ។ *ឆ្អឹងខ្មោច* មើល ខ.១១ គឺបានបកស្រាយពីនិមិត្តសញ្ញាការជាក់ស្តែងនៃពួកអ៊ីស្រាអែលដែលគ្មានសេចក្តីសង្ឃឹមជាស្ថានភាពក្នុងការនិរទេស ។

**៣៧:២** *មានឆ្អឹងយ៉ាងសន្ធឹក* នៅត្រង់ចំណុចនេះគឺជានិមិត្តសញ្ញាមួយដែលបានបញ្ជាក់បង្ហាញពីសង្គមទាំងមូលត្រូវបានបំបរបង់ឬក៏ត្រូវបានគេនិរទេស ។ *ស្ងួតហែង* ចំណុចនេះគឺបញ្ជាក់ពីការស្លាប់នៃមនុស្សអស់រយះពេលយ៉ាងយូរទោះនៅឆ្ងាយ ឬនៅឯណាក៏ដោយដល់ថ្ងៃមួយនោះនឹងរស់

ស្ងួតហែងណាស់ផង ៣រួចទ្រង់មានបន្ទូលសួរខ្ញុំថា កូន
មនុស្សអើយ តើឆ្អឹងទាំងនេះនឹងរស់ឡើងបានឬ ខ្ញុំក៏ទូល
ឆ្លើយថា ឱព្រះអម្ចាស់យេហូវ៉ាអើយ ទ្រង់ជ្រាបហើយ[ង]
៤ទ្រង់មានបន្ទូលមកខ្ញុំទៀតថា ចូរទាយពីដំណើរឆ្អឹងទាំង
នេះ ហើយប្រាប់ថា ឱឆ្អឹងស្ងួតហែងទាំងឡាយអើយ ចូរ
ស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ[ច] ៥ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដល់ឆ្អឹងទាំងទាំងនេះដូច្នេះថា មើលអញនឹង
ឱ្យមានខ្យល់ដង្ហើមចូលទៅក្នុងឯងរាល់គ្នា ហើយឯងនឹង
មានជីវិតឡើង[ឆ] ៦អញនឹងដាក់ឱ្យមានសរសៃ ហើយធ្វើ
ឱ្យមានសាច់ដុះលើឯងរាល់គ្នា រួចនឹងគ្របរុំដោយស្បែក
ព្រមទាំងបញ្ចូលខ្យល់ដង្ហើមទៅក្នុងឯងរាល់គ្នាផង នោះ
ឯងរាល់គ្នានឹងមានជីវិតឡើង ដូច្នេះ ឯងរាល់គ្នានឹងដឹងថា
អញនេះជាព្រះយេហូវ៉ាពិត[ជ]។

៧ដូច្នេះ ខ្ញុំក៏ទាយដូចជាទ្រង់បង្គាប់មក ហើយកំពុង
ដែលខ្ញុំទាយ នោះមានឮសូរក្រិកៗ ហើយមើល ឆ្អឹង ទាំង
នោះបានកំរើក ក៏ផ្ដុំជាប់គ្នា ឆ្អឹង១ភ្ជាប់ត្រង់កន្លែងរបស់ខ្លួន
៨កាលខ្ញុំកំពុងតែមើល នោះឃើញមានសរសៃ នឹងសាច់
កើងឡើងនៅឆ្អឹងទាំងនោះ រួចមានស្បែករុំគ្របទៀត តែ
ឥតមានខ្យល់ដង្ហើមនៅក្នុងវាទេ ៩នោះទ្រង់មាន បន្ទូលមក
ខ្ញុំថា ចូរទាយ ហើយប្រាប់ដល់ខ្យល់[ឈ] ឱកូនមនុស្សអើយ
ចូរទាយចុះ ត្រូវប្រាប់ដល់ខ្យល់ថា ព្រះអម្ចាស់យេហូវ៉ា
ទ្រង់មានបន្ទូលដូច្នេះ ឱខ្យល់ដង្ហើម ចូរមកពីខ្យល់ទាំង៤
ទិស[ញ] ផ្លុំលើខ្មោចស្លាប់ទាំងនេះ ឱ្យមានជីវិតរស់ឡើង
១០ដូច្នេះ ខ្ញុំក៏ទាយដូចជាទ្រង់បង្គាប់មក[ដ] រួចខ្យល់ដង្ហើមក៏
ចូលទៅក្នុងសពទាំងនោះ ហើយវាក៏រស់ឡើង បានទាំង
ឈរឡើងជាកងទ័ពយ៉ាងធំក្រៃលែង[ឋ]។

១១រួចទ្រង់មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ ឆ្អឹង
ទាំងនេះជាពួកវង្សអ៊ីស្រាអែលទាំងមូល មើល គេនិយាយ
ថា ឆ្អឹងយើងរាល់គ្នាស្ងួតហែងហើយ ទីសង្ឃឹមរបស់
យើងក៏បាត់អស់ទៅ យើងរាល់គ្នាត្រូវកាត់ចេញស្រឡះផង[ឌ]
១២ដូច្នេះ ចូរទាយប្រាប់គេថាព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូលដូច្នេះ ម្នាលរាស្ត្រអញអើយ អញនឹងបើកផ្នូរខ្មោច
របស់ឯងរាល់គ្នា ហើយនឹងធ្វើឱ្យឯងរាល់គ្នាឡើងចេញពី
ផ្នូរមក រួចនឹងនាំឯងឱ្យចូលទៅក្នុងស្រុកអ៊ីស្រាអែលវិញ[ឍ]
១៣ឱរាស្ត្រអញអើយ ឯងរាល់គ្នានឹងដឹងថា អញនេះជា
ព្រះយេហូវ៉ាពិត[ណ] ក្នុងកាលដែលអញបើកផ្នូររបស់ឯង ឱ្យ
ឯងបានឡើងចេញពីនោះមក[ត] ១៤គ្រានោះ អញនឹងដាក់
វិញ្ញាណ[ថ]អញនៅក្នុងឯងរាល់គ្នា ឯងនឹងមានជីវិតរស់ឡើង
ហើយអញនឹងតាំង[ទ]ឯង ឱ្យអាស្រ័យនៅ ក្នុងស្រុកដែលជា
របស់ផងឯង នោះឯងរាល់គ្នានឹងដឹងថា គឺអញជាព្រះ
យេហូវ៉ានេះ បានចេញវាចាហើយ ក៏បានសំរេចតាមផង
នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ធ]។

## ជាតិមួយនៅក្រោមស្តេចមួយអង្គ

១៥ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំម្តងទៀតថា
១៦កូនមនុស្សអើយ ចូរយកបន្ទះឈើ១ មកសរសេរចុះថា
សំរាប់ពួកយូដា និងពួកកូនចៅអ៊ីស្រាអែល[ន] ជាភឿនមិត្រ
របស់គេ[ប] រួចយកបន្ទះឈើ១ទៀតសរសេរថា សំរាប់ពួក

**៣៧:៣** ង ចទ ៣២:៣៩ ១សយ ២:៦ អស ២៦:១៩ ១កថ ១៥:៣៥ **៣៧:៤** ច យរ ២២:២៩ **៣៧:៥** ឆ លប ២:៧ ទដ ១០៤:២៩–៣០ វវ ១១:១១ **៣៧:៦** ជ នក ៦:២ អគ ៣៨:២៣ **៣៧:៩** ឈ ខ.១៤ ទដ ១០៤:៣០ អស ៣២:១៥ អគ ៣៩:២៩ សក ១២:១០ ញ យរ ៤៩:៣៦ ដយ ៧:២ ៨:៨ ១១:៤ សក ២:៦ ៦:៥ វវ ៧:១ **៣៧:១០** ដ អគ ១២:៧ ឋ វវ ១១:១១ **៣៧:១១** ឌ យប ១៧:១៥ បទ ៣:៥៤ **៣៧:១២** ឍ ខ.២១ ចទ ៣២:៣៩ ១សយ ២:៦ អស ២៦:១៩ យរ ២៩:១៤ ហស ១៣:១៤ អម ៩:១៤–១៥ សផ ៣:២០ សក ៨:៨ **៣៧:១៣** ណ នក ៦:២ ត អគ ១៧:២៤ ហស ១៣:១៤ **៣៧:១៤** ថ ខ.៩ អស ១១:២ យអ ២:២៨–២៩ ទ យរ ៤៣:២ ធ អគ ៣៦:២៧–២៨,៣៦ វវ ១១:១១ **៣៧:១៦** ន ១ពវ ១២:២០ ២របា ១០:១៧–១៩ ប ជន ១៧:២–៣ ២របា ១៥:៩

ឡើវិញ (១ពវ ១៧:១៧–២៤ ២ពវ ៤:១៨–៣៧ ប៉ុន្តែ សូមមើល ២ពវ ១៣:២១) ។

**៣៧:៤** *ចូរទាយពីដំណើរឆ្អឹងទាំងនេះ* ហោរាអេសេគាលបានធ្វើការទស្សន៍ទាយដើម្បីប្រឆាំងទាស់និងការគ្មានជីវិត (អស់ទាំងភ្នំ មើល ៦:២ ៣៦:១ អស់ទាំងព្រៃ មើល ២០:៤៧) ។ ឥឡូវនេះគាត់ទស្សន៍ទាយពីអស់ទាំងឆ្អឹង ដែលគ្មានជីវិត ហើយនិងពី "ដង្ហើម"(ខ.៩) ធៀបនឹង យហ ៥:២៥ និងការពន្យល់ ។

**៣៧:៦** *សរសៃ . . . សាច់ . . . ស្បែក . . . ដង្ហើម* នៅត្រង់ចំណុចនេះគឺនិយាយអំពីតួរមានជីវិតបួនរូប ដែលមាននៅក្នុងព្រះគម្ពីរអេសេគាល (សូមមើលការពន្យល់ ១:១៥) ។

**៣៧:៨** *តែឥតមានខ្យល់ដង្ហើម* គឺបង្ហាញពីព្រះទ្រង់ដ៏ជាព្រះយកធូលីដីមកសូន្យធ្វើជាមនុស្ស ហើយទ្រង់ក៏ផ្លុំខ្យល់ដង្ហើមទៅក្នុងអ័ដាម លប ២៧ ។

**៣៧:៩** *ខ្យល់ដង្ហើម* សូមមើលការពន្យល ១:៥ ។ *ខ្មោចស្លាប់* អ្វីដែលហោរាអេសេគាលបានឃើញគឺជាសមភូមិ ឬវាលចម្បាំងមួយដែលបានរាចសាចពេញដោយឆ្អឹងជាច្រើនដែលបានរលំចុះ (សូមមើល ខ.១០) ។

**៣៧:១១** *ឆ្អឹងយើងរាល់គ្នា . . . ត្រូវកាត់ចេញ* នៅត្រង់វគ្គនេះគឺនិយាយអំពីសម្លេងនៃវិញ្ញាណទាំងឡាយបានថ្ងូរបញ្ជាក់ពីភាពអស់សង្ឃឹម ។

**៣៧:១២** *ផ្នូរខ្មោច* គឺជានិមិត្តរូបនៃការផ្លាស់ប្តូរមួយដែលមានឆ្អឹងខ្មោចជាច្រើនរាចសាចនៅលើវាលចម្បាំង(សូមមើលការពន្យល់ ខ.៩) នៅទីនោះមានកន្លែងបញ្ចុះសពនៅទីស្មសានហើយបានបិទត្រានៅលើផ្នូរខ្មោចទាំងឡាយនោះ ។

**៣៧:១៤** *អញនឹងដាក់វិញ្ញាណអញនៅក្នុងឯងរាល់គ្នា* សូមមើល ៣៦:២៧ និងការពន្យល់ ។ *អញនឹងតាំងឯង ឱ្យអាស្រ័យនៅ ក្នុងស្រុកដែលជារបស់ផងឯង* ព្រះបន្ទូលរបស់ព្រះអម្ចាស់មានបន្ទូលជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះអម្ចាស់គឺមិនបានមានបន្ទូលនៅត្រង់កន្លែងនេះទេអំពីរដំណើរនៃការរស់ឡើងវិញពីសេចក្តីស្លាប់ ប៉ុន្តែប្រជាជាតិអ៊ីស្រាអែលនិងបានសង់ឡើងវិញ ។

**៣៧:១៦** *ចូរយកបន្ទះឈើ ១* នេះគឺជានិមិត្តសញ្ញាចុងក្រោយរបស់ហោរាអេសេគាល ដែលជាកិច្ចការជាប់ទាក់ទងជាមួយសម្ភារៈនឹងបានជាទីសម្គាល់ដល់ពួកវង្សអ៊ីស្រាអែល(ធៀបនឹង ៤:១,៣,៩ ៥:១) ។ *សរសេរចុះ* សូម

យ៉ូសែប ជាឈើរបស់ពួកអេប្រាអិមនឹងពួកវង្សអ៊ីស្រាអែល
ជាភឿនមិត្ររបស់គេ ១៧រួចភ្ជាប់គ្នាទាំង២នោះធ្វើជាបន្ទះ
តែ១ ដើម្បីឱ្យបានជាប់ជាមួយគ្នានៅដៃឯង[ផ] ១៨កាល
ណាពួកកូនចៅសាសន៍ឯងនឹងសួរដល់ឯងថា សូមប្រាប់
ឱ្យយើងដឹងជាឈើទាំង២ នេះមានន័យដូចម្តេច[ព] ១៩នោះ
ត្រូវឱ្យប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ
មើល អញនឹងយកបន្ទះឈើរបស់ពួកយ៉ូសែប ដែលនៅ
ដៃអេប្រាអិម និងពូជអំបូរអ៊ីស្រាអែលទាំងប៉ុន្មាន ដែលជា
ភឿនមិត្ររបស់គេ ដាក់ភ្ជាប់ជាមួយនឹងបន្ទះឈើ១នោះ
ដែលជារបស់ពួកយូដា ឱ្យបានជាប់ជាបន្ទះតែ១វិញ រួច
វានឹងបានជាប់តែ១នៅក្នុងដៃអញ[ភ] ២០ឈើទាំង២ដែល
ឯងបានសរសេរចុះនោះ នឹងបាននៅក្នុងដៃឯងចំពោះ
ភ្នែកគេ ២១ចូរប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មាន
បន្ទូល ដូច្នេះ មើល អញនឹងយកពួកកូនចៅអ៊ីស្រាអែល
ចេញ ពីអស់ទាំងសាសន៍ដែលគេបានទៅនោះ ហើយ
ប្រមូលមកពីគ្រប់ទិស នាំចូលទៅក្នុងស្រុករបស់ផងខ្លួន[ម]
២២អញនឹងធ្វើឱ្យគេរួមគ្នាជានគរតែ១ នៅក្នុងស្រុកនោះ
គឺនៅលើអស់ទាំងភ្នំនៃស្រុកអ៊ីស្រាអែល[យ] នោះនឹងមាន
ស្តេចតែ១អង្គគង់ធ្វើស្តេចលើគេគ្រប់គ្នា គេនឹងលែងធ្វើ
ជានគរ២តទៅ ឥតដែបែកទៅជានគរ២ទៀតឡើយ[រ] ២៣ក៏
មិនធ្វើឱ្យខ្លួនស្មោកគ្រោក[ល] ដោយគោរពដល់រូបព្រះ ឬ
ដោយរបស់គួរស្អប់ខ្ពើម ឬដោយអំពើរំលងរបស់ខ្លួនទៀត
ដែរ អញនឹងជួយសង្គ្រោះគេ ឱ្យរួចពីគ្រប់ទាំងទីអាស្រ័យ
នៅរបស់គេ ជាកន្លែងដែលគេបានធ្វើបាបនោះ[វ] ហើយ
អញនឹងជំរះគេឱ្យស្អាតវិញយ៉ាងនោះ គេនឹងបានជារាស្ត្រ
របស់អញ ហើយអញនឹងធ្វើជាព្រះដល់គេ[ស]។

២៤នោះដាវីឌ[ហ] ជាអ្នកបំរើរបស់អញ នឹងធ្វើជាស្តេច[ឡ]
លើគេ ហើយគេទាំងអស់គ្នានឹងមានអ្នកគង្វាលតែ១[អ] គេ
នឹងដើរតាមក្រិត្យក្រមរបស់អញ ហើយរក្សាបញ្ញត្តច្បាប់
ទាំងប៉ុន្មានរបស់អញ ព្រមទាំងប្រព្រឹត្តតាមផង[ក] ២៥គេនឹង
អាស្រ័យនៅក្នុងស្រុកដែលអញបានឱ្យដល់យ៉ាកុប ជាអ្នក
បំរើអញ ជាស្រុកដែលពួកឰយុកោរបស់ឯងរាល់គ្នាបាន
អាស្រ័យនៅដែរ[ខ] នោះទាំងខ្លួនគេ និងកូនចៅរបស់គេ នឹង
នៅជាប់ក្នុងស្រុកនោះជាដរាបតទៅ[គ] ហើយដាវីឌ ជាអ្នក
បំរើអញ និងធ្វើជាចៅហ្វាយលើគេ ជារៀងដរាបតទៅ[ឃ]
២៦មួយទៀត អញនឹងតាំងសន្តិសញ្ញា[ង]នឹងគេ សញ្ញានោះ
នឹងនៅជាប់នឹងគេអស់កល្បជានិច្ច[ច] អញនឹងតាំងគេឡើង

**៣៧:១៧** ផ ខ.២៤ អស ១១:១៣ យរ ៥០:៤ ហស ១:១១ **៣៧:១៨** ព អគ ២៤:១៩ **៣៧:១៩** ភ សក ១០:៦ **៣៧:២១** ម ខ.១២ អស ៤៣:៥–៦ អគ ២០:៤២ ៣៩:២៧ មីក ៤:៦ **៣៧:២២** យ អគ ១៧:២២ ៣៤:១៣–១៤ រ អស ១១:១៣ យរ ៣៣:៣៤ ៥០:៤ ហស ១:១១ **៣៧:២៣** ល អគ ៤៣:៧ វ យរ ៧:២៤ ស អគ ១១:១៨ ៣៦:២៨ ណហ ២:២ **៣៧:២៤** ហ អស ៥៥:៤ ហស ៣:៥ ឡ ១សយ ១៣:១៤ អស ៣២:១ អ សក ១៣:៧ ក ទដ ៧៨:៧០–៧១ យរ ៣០:២១ អគ ២១:២៧ **៣៧:២៥** ខ អគ ២៨:២៥ គ អរ ៩:១២ អម ៩:១៥ ឃ ទដ ៨៩:៣–៤ អស ១១:១ អគ ៣៤:២៣–២៤ **៣៧:២៦** ង ជន ២៥:១២ ច លប ៩:១៦ ចទ ២៩: ១៤ ហព ១៣:២០

សូមមើល សក ១១:៧ នឹងបានឃើញនូវគន្លឹះផ្សេងទៀតនៅក្នុងព្រះគម្ពីរអេសេគាល ។

**៣៧:១៨** *សូមប្រាប់យើង . . .* នៅត្រង់ចំណុចនេះគឺបញ្ជាក់ប្រាប់ពីនិមិត្តសញ្ញានៃការជោគជ័យដែលមនុស្សគ្រប់គ្នាប្រាថ្នាចង់បានចង់ឃើញ (សូមមើល ១២:៩ ២១:៧ ២៤:១៩) ។

**៣៧:១៩** *រួចវានឹងបានជាប់តែ១នៅក្នុងដៃអញ* ព្រះអម្ចាស់នឹងចម្លងនូវនិមិត្តសញ្ញារបស់អេសេគាលដែលថា នឹងមានស្តេចតែមួយអង្គបានធ្វើជាស្តេចលើគេគ្រប់គ្នា គេនឹងលែងធ្វើជានគរពីរតទៅ ឥតដែលបែកទៅជានគរពីរទៀតឡើយ វគឺចាប់តាំងពីគ្រាស្តេចសាឡូម៉ូនសុគត់មកម្លេះ (មើល ១ពវ ១២) ។ ចំពោះនិមិត្តសញ្ញានេះ គឺជាសេចក្តីទំនាយអំពីអ៊ីស្រាអែល មើល ៣៣:២៣,២៩ យរ ៣:១៨ ២៣:៥–៦ ហស ១:១១ អម ៩:១១ ។

**៣៧:២២** *អស់ទាំងភ្នំនៃស្រុកអ៊ីស្រាអែល* មើល ៦:២–៣ ៣៤:១៣ ៣៦:១ ។ *ស្តេចតែ១អង្គ* ចំណុចនេះពាក្យស្តេចតែមួយអង្គ គឺមានតែមួយគត់នៅក្នុង ខ.២៤ នេះជាពាក្យស្តេចបានបញ្ជាក់អំពីស្តេច ដាវីឌនឹងធ្វើជាស្តេចលើពួកអ៊ីស្រាអែល ហើយស្តេចគឺជាអ្នកគ្រប់គ្រងនៅលើនគរ ។ ជាញឹកញាប់ស្តេចឬព្រះអម្ចាស់ គឺមានប្រើនៅក្នុង (មើលការពន្យល់ ៣៤:២៤) ដូចជាក្នុង ខ.២៥ ។ មើល ៧:២៧ និងការពន្យល់, និងមើល ៤៤:៣ ៤៥:៧–៩ និងជារឿយៗនៅក្នុងជំពូកផ្សេងទៀត ៤៥–៤៨ នៅដែលគ្រប់គ្រងនៅក្នុងឧត្តមគតិ គឺជានិច្ចជាកាលតែងតែសំដៅទៅលើ "ព្រះអម្ចាស់" ។

**៣៧:២៣** *រូបព្រះ* គឺជាការថ្វាយបង្គំដល់ព្រះក្លែងក្លាយដែលជាការប្រព្រឹត្តខុសនិងជាទីស្អប់ខ្ពើមនៅចំពោះព្រះ (សូមមើលការពន្យល់ ៦:៤) ។ *ប្រព្រឹត្តអំពើបាប* ធៀបនឹង ២:១៩ ៣:២២ ។ *ជំរះគេឱ្យស្អាត* ធៀបនឹង ៣៦:២៥ ប្រជារាស្ត្ររបស់ទ្រង់នឹងបានជម្រះឱ្យស្អាត ។ *រាស្ត្ររបស់អញ . . . ធ្វើជាព្រះដល់គេ* សូមមើល ១១:២០ និងការពន្យល់ ។

**៣៧:២៤–២៦** នៅក្នុងខព្រះគម្ពីរទាំងនេះបានបង្ហាញពីការរំឮកឡើងវិញដែលជាការតាំងសញ្ញានៃកិច្ចព្រមព្រៀង (ខ.២៤) ដូចជាសេចក្តីតាំងសញ្ញានៅលើភ្នំស៊ីណាយ (ខ.២៤) និងសេចក្តីតាំងសញ្ញាចំពោះលោកអ័ប្រាហាំ (ខ.២៥) ដែលទាំងអស់នេះ គឺជាសេចក្តីតាំងសញ្ញានៃសន្តិភាព (ខ. ២៦) ។

**៣៧:២៤** *នោះដាវីឌ ជាអ្នកបំរើរបស់អញ* ដូចនៅក្នុង ៣៤:២៣ (សូមមើលការពន្យល់ដែលមាននៅទីនោះ) ព្រះមែស៊ីនឹងមកគ្រងរាជ្យគឺជាពូជល្អួងនៃស្តេចដាវីឌពីព្រោះគាត់នឹងកូនចៅរបស់ស្តេចដាវីឌនឹងសម្រេចចំពោះអ៊ីស្រាអែលដែលស្តេចដាវីឌបានលើកលែងជាច្រើន ។ *ស្តេច* សូមមើលការពន្យល់ ខ.២២ ។ *អ្នកគង្វាល* ដូចមាននៅក្នុង ៣៤:២៣ ការគ្រប់គ្រងនឹងមកដល់ដូចជាអ្នកគង្វាលដែលថែរក្សាហ្វូងចៀមរបស់ទ្រង់ (ធៀបនឹង ១០ នឹងចំណុចពិសេសនៅ ខ.១៦ ។

**៣៧:២៥** *យ៉ាកុប ជាអ្នកបំរើដល់អញ* សូមមើល ២៨:២៥ និងការ ពន្យល់ ។

**៣៧:២៦** *តាំងសន្តិសញ្ញា* សូមមើល ៣៤:២៥ និងការពន្យល់ ។ *សញ្ញានោះនឹងនៅជាប់នឹងគេអស់កល្បជានិច្ច* សូមមើលការពន្យល់ ១៦:៥៩–៦៣ ។ នៅត្រង់ឃ្លានេះមានការនិយាយឡើង១៦ដង នៅក្នុងព្រះគម្ពីរសញ្ញាចាស់

ហើយចំរើនគេ ឱ្យមានគ្នាច្រើន[ឆ] ព្រមទាំងដាក់ទីបរិសុទ្ធ
របស់អញ នៅកណ្ដាលគេ[ជ] ឱ្យនៅអស់កល្បជានិច្ច[ឈ] ២៧ព្រះ
វិហាររបស់អញ នឹងនៅ[ញ]ជាមួយនឹងគេដែរ អញក៏នឹង
ធ្វើជាព្រះដល់គេ ហើយគេនឹងបានជារាស្ត្ររបស់អញ[ដ]
២៨នោះអស់ទាំងសាសន៍នឹងដឹងថា អញនេះជាព្រះយេហូវ៉ា
ដែលញែកពួកអ៊ីស្រាអែលចេញជាបរិសុទ្ធ[ឋ] គឺក្នុងកាល
ដែលទីបរិសុទ្ធរបស់អញបានតាំងនៅកណ្ដាលគេ ឱ្យបាន
នៅអស់កល្បជានិច្ច[ឌ]។

## សេចក្ដីទំនាយទាស់នឹងសាសន៍កុក

**៣៨** ១ ព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា ២កូន
មនុស្សអើយ ចូរតាំងមុខនៅខាងកុប[ក]នៃស្រុកម៉ាកុក[ខ] ជា
ចៅហ្វាយនៃពួករ៉ុស ពួកមែសេក និងពួកទូបាល[គ] ត្រូវឱ្យ
ទាយទាស់នឹងវាថា ៣ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល
ដូច្នេះ ម្នាលកុក ជាចៅហ្វាយនៃពួករ៉ុស ពួកមែសេក និង
ពួកទូលបាលអើយ មើល អញទាស់នឹងឯង[ឃ] ៤អញនឹងធ្វើ
ឱ្យឯងបែរមក អញនឹងដាក់ទំពក់[ង]នៅថ្គាមឯង ហើយនឹង
នាំឯងចេញមក ព្រមទាំងពលទ័ពឯងទាំងប៉ុន្មាន ទាំង សេះ
និងពលសេះផង គ្រប់គ្នាស្លៀកពាក់ជាគ្រឿងសឹក សព្វគ្រប់

**៣៧:២៦** ឆ យរ ៣០:១៩ ជ លវ ២៦:១១ ឈ អគ ១៦:៦២ **៣៧:២៧** ញ លវ ២៦:១១ ដ អគ ៣៤:៣០ ៣៦:២៨ ២កថ ៦:១៦ **៣៧:២៨** ឋ នក ៣១:១៣ ឌ ហេស ១:១០–១១ ឍ អគ ៤៣:៩ សផ ៣:១៥ **៣៨:២** ក ខ.១៤ អគ ៣៩:១១ ខ លប ១០:២ គ អគ ២៧:១៣ **៣៨:៣** ឃ អគ ៣៩:១ ៣៨:៤ ង ២ពវ ១៩:២៨

សេចក្ដីយោងនៅក្នុងគ្រានោះគឺជាសេចក្ដីសញ្ញាដែលទ្រង់បានតាំងសញ្ញាជាមួយនឹងលោកណូអេ(លប ៩:១៦) ។ សេចក្ដីតាំងសញ្ញាជាមួយអ័ប្រាហាំ (លប ១៧:៧,១៣,១៩) ។ សេចក្ដីតាំងសញ្ញាជាមួយនឹងស្ដេចដាវីឌ(២សយ ២៣:៥) ។ ការតាំងសញ្ញាថ្មី(យរ ៣២:៤០ ធៀបនឹង ។ សេចក្ដីតាំងសញ្ញាជាមួយនឹងលោកភីនេហាស(ជន ២៥:១២–១៣) ។ *ទីបរិសុទ្ធរបស់អញបានតាំងនៅកណ្ដាលគេ* គឺជាការងាររបស់ទ្រង់ដែលទ្រង់បានធ្វើពីមុនមក ។ នេះជាព្រះបន្ទូលដែលបានលើកតម្កើងក្នុងការបើកសម្ដែងរបស់ហោរាអេសេគាលនៅពេលអនាគតទីបសរិសុទ្ធនឹងបានសង់ឡើងវិញដែលជាទីតាំងកណ្ដាល(ជំពូក ៤០–៤៨) សូមមើល ខ.២៧–២៨ ។

**៣៨:១–៣៩:២៩** គឺជាចម្បាំងដ៏ធំមួយនឹងកើតឡើងនៅសម័យនោះ នៅគ្រានោះអ៊ីស្រាអែលនឹងសាងសង់ឡើងវិញក្នុងពេលអនាគត ដែលស្ថិតក្រោមការឡោមព័ទ្ធរបស់វង្សស្ដេចដាវីឌ (ជំពូក ៣៧) ។ នឹងមានគ្រូមន្តអាគមគាថាដែលជាអំណាចរបស់លោកិយយ៉ាងសន្ធឹក មកកកកុញគ្នាដើម្បីនឹងបំផ្លាញនគររបស់នៃព្រះ ។ នៅពេលនោះ មានពលទ័ពជាច្រើននឹងឡើងមកប្រឆាំងជាមួយក្រុងយេរូសាឡិម ទីបំផុតនឹងមានសាកសពជាច្រើនបានស្លាប់ ។ សាកសពទាំងនោះរាចសាចនៅពាសពេញទីវាលនៃទឹកដីសន្យា នឹងក្លាយទៅជាទីស្មរសាននៃអស់ទាំងខ្មាំងសត្រូវ ដែលបានរាតត្បាតឈ្លានពាន(ធៀបនឹង ជំពូក ៣៩) ។ មានទំនាយបីដងដែលទាស់នឹងសាសន៍កុក(កុកជាកូនប្រុសរបស់លោកយ៉ូអែល (៣៨:១–១៣,១៤ ២៣ ៣៩:១–១៦) គឺជាការពិពណ៌នាពីការស៊ីលៀងយ៉ាងធំនៅចំពោះខ្មាំងសត្រូវដែលជាអ្នកចម្បាំងដោយបានរៀបរាប់ នៅក្នុងវគ្គមុនពីការថ្វាយយញ្ញបូជានៃសត្វទាំងឡាយ(៣៩:១៧–២០) ។ ជាការបញ្ចប់នៃព្រះបន្ទូលនៅលើកទីពីរ គឺជាចម្បាំងដ៏ធំនៅក្នុងអត្ថបទនេះ តែព្រះគឺជាផ្លូវក្នុងការបំបរបង់ និងសង់ឡើងនៃពួកអ៊ីស្រាអែល ។ (១).នៅគ្រប់ទាំងសាសន៍នឹងដឹងថា អ៊ីស្រាអែលនឹងត្រូវបានបំបរបង់ មិនមែនដោយសារព្រះអសមត្ថភាពនឹងការពារដល់ពួកគេមិនបាននោះឡើយ ប៉ុន្តែពួកគេបានទទួលទណ្ឌកម្មនេះដោយសារគេពុំមានជំនឿចំពោះទ្រង់(៣៩:២១–២៤) ។ (២).អ៊ីស្រាអែលនឹងបានសង់ឡើងវិញ ដែលពួកគេបានទទួលទណ្ឌកម្មពីមុនមក ដើម្បីនឹងបង្ហាញដល់គ្រប់ទាំងសាសន៍ដឹងថា ព្រះនៃសាសន៍អ៊ីស្រាអែលគឺជាព្រះពិត និងបរិសុទ្ធ (៣៩:២៥–២៩) ។

**៣៨:១** នេះគឺជាសេចក្ដីថ្លែងដែលបានរំឭកឡើងវិញ ចំពោះការទទួលនូវព្រះបន្ទូលរបស់ទ្រង់ ដោយឈរលើការណែនាំក្នុងជំពូក ៣៨–៣៩ ។

**៣៨:២** *កូនមនុស្សអើយ* សូមមើលការពន្យល់ ២:១ ។ *ចូរតាំងមុខ* សូមមើលការពន្យល់ ២០:៤៦ ។ កុក គឺជាកូនប្រុសរបស់លោកយ៉ូអែល គាត់ជាពិតជាអ្នកដឹកនាំ ឬជាឈ្មោះរបស់ស្ដេចដែលមានបង្ហាញប្រាប់តែមួយគត់នៅក្នុងជំពូក ៣៨–៣៩ *វវ* ២០:៨ ។ មានការបង្ហាញពីអត្តសញ្ញាណហើយគួរឱ្យកត់សម្គាល់នោះគឺ ជីគ (Gyges) ជាស្ដេចស្រុកលីឌា(៦៦០ឆ្នាំមុន គស) ឈ្មោះនេះអាចជាអាថ៌កំបាំង ដែលជាលក្ខណៈខ្មាំងសត្រូវរបស់ព្រះ ។ *នៃស្រុកម៉ាកុក* នៅក្នុង លប ១០:២ ១របា ១:៥ ម៉ាកុកគឺជាកូនប្រុសមួយក្នុងចំណោមកូនប្រុសរបស់លោកយ៉ាផែត ដែលជាឈ្មោះរបស់មនុស្សមួយ ។ ក្នុងព្រះគម្ពីរអេសេគាល ៣៩:៦ វាបានបង្ហាញពីមនុស្សម្នាក់ ប៉ុន្តែតាំងពីបុព្វបទ គឺម៉ា–កែន ដែលមានន័យថា " ទីកន្លែង " ម៉ាកុកដែលបង្ហាញប្រាប់នៅត្រង់នេះ ប្រហែលជាមានអត្ថន័យថា"ស្រុកកុក" ។ សាសន៍អ៊ីស្រាអែលបានទទួលបទពិសោធន៍ពីការចំបាំងជាមួយពួកហាំ និងពួកសិមនៅពេលអនាគត់ ពួកគេនឹងព្រួតដៃគ្នាដើម្បីមកច្បាំងនឹងសាសន៍អ៊ីស្រាអែលនៅតំបន់ជុំវិញ ។ ពួកគេនិងបន្ថែមចំនួនអ្នកដឹកនាំពិតប្រាកដនៃចំនួនមនុស្សដែលមកពីពួកយ៉ាផែត ដើម្បីច្បាំងជាមួយអ៊ីស្រាអែល(ធៀបនឹង លប ១០) ។*ចៅហ្វាយ* គឺជាមេបញ្ជាការកងទ័ព នៅក្នុងអត្ថបទអ៊ិនអាយវី ( NIV ) ដែលអាចប្រែថា"ចៅហ្វាយនៃពួករ៉ុស" ហើយប្រហែលជាត្រឹមត្រូវ ។ រ៉ុសប្រហែលគឺជាឈ្មោះដែលគ្មានមនុស្សណាស្គាល់ឬពីទីកន្លែងពិតប្រាកដនោះឡើយ ។ អត្តសញ្ញាណរបស់វាដូចជាពួករ៉ុស្ស៊ី គឺដែលមិនគួរឱ្យជឿ ហើយនៅក្នុងករណីខ្លះមិនអាចបញ្ជាក់ពីភស្តុតាងបានឡើយ ។ *ពួកមែសេក និងពួកទូបាល* ពួកទាំងនេះគឺជាកូនប្រុសរបស់យ៉ាផែត(សូមមើល លប ១០:២ និងការពន្យល់ ១របា ១:៥)គឺប្រហែលជាពួកគេស្ថិតនៅតំបន់ភាគខាងកើតអាស៊ីម៉ីនើរ ( Asia Minor ) (ធៀបនឹង ២៧:១៣ ៣២:២៦ ។ ពួកគេទាំងនេះគឺជា មនុស្សដែលស្ថិតនៅដែនដីភាគខាងជើងរបស់អ៊ីស្រាអែល (ធៀបនឹង ខ. ៦,១៥ ៣៩:២ ) ។ គឺដូចនៅថ្ងៃនៃពួកសាសន៍អាស៊ើរី នឹងពួកសាសន៍បាប៊ីឡូន ដែលមានការចងសម្ព័ន្ធយ៉ាងសំខាន់ ហើយពួកទាំងនោះនឹងមកពីភាគខាងជើង ។

**៣៨:៣** *អញទាស់និងឯង* (សូមមើលការពន្យល់ ៥:៨) ។

**៣៨:៤** *អញនឹងធ្វើឱ្យឯងបែរមក* នៅត្រង់វគ្គនេះបានបញ្ជាក់នៅការពិតថាព្រះទ្រង់គឺនៅក្នុងការបំពេញ និងត្រួតត្រាលើគ្រប់របស់ទាំងអស់ គឺដើម្បីឱ្យពួកគេបានបែរមករកទ្រង់វិញ ។ *អញនឹងដាក់ទំពក់នៅថ្គាមឯង* ដូចជាបានធ្វើជាមួយស្ដេចផារ៉ោន នៅក្នុង ២៩:៤ ។ កុក គឺប្រៀបប្រដូចទៅនិងសត្វសា

ជាកងទ័ពយ៉ាងធំ មានទាំងខែលធំ ខែលតូច ហើយកាន់
ដាវគ្រប់គ្នាផង[ច] ៥មានសាសន៍ពើស៊ី សាសន៍គូស[ឆ] និង
សាសន៍ពូត[ជ]មកជាមួយគ្នា គ្រប់គ្នាមានខែល ហើយមួកដែក
៦ហើយមានទាស់ទាំងសាសន៍កូមើរ[ឈ] និងពួកកកកុញទាំង
ប៉ុន្មានរបស់គេ ក៏មានពួកវង្សតូកាម៉ា[ញ] ពីស្រុកខាងជើង
បំផុត[ដ] និងពួកកកកុញទាំងអស់របស់គេ គឺមានសាសន៍ជា
ច្រើនមកជាមួយនឹងឯងផង ។
៧ចូរឱ្យឯងបានរៀបចំខ្លួនជាស្រេចចុះ[ឋ] អើ ចូររៀបចំ
ឡើង គឺទាំងឯងនឹងបណ្តាកងទ័ពទាំងប៉ុន្មាន ដែលបាន
មូលមកឯឯង ហើយឱ្យឯងធ្វើជាមេទ័ពដល់គេចុះ ៨ក្រោយ
យូរថ្ងៃទៅ[ឌ] នោះឯងនឹងបានតាំងឡើង ឯងដល់ជាន់ក្រោយ
បង្អស់ នោះឯងនឹងចូលទៅក្នុងស្រុក ដែលបានប្រោសឱ្យ
រួចពីដាវមកវិញ គឺដែលបានប្រមូលចេញរួច ពីសាសន៍ជា
ច្រើន[ឍ] មកនៅលើអស់ទាំងភ្នំនៃស្រុកអ៊ីស្រាអែល ជាស្រុក
ត្រូវខូចបង់នៅជានិច្ច តែបាននាំចេញពីគ្រប់សាសន៍ នោះ
គេនឹងអាស្រ័យនៅដោយសុខសាន្តទាំងអស់គ្នា[ណ] ៩ឯងនឹង
ឡើងមក គឺនឹងមកដូចជាខ្យល់ព្យុះ[ត] ហើយឯងនិងពួក
កកកុញទាំងប៉ុន្មានរបស់ឯង ព្រមទាំងសាសន៍ជាច្រើន
ដែលមកជាមួយ នឹងបានដូចជាពពក[ថ]គ្របលើស្រុក[ទ] ។

**៣៨:៤** ច អស ៤៣:១៧ អក ២៩:៤ ៣៩:២ ដយ ១១:៤០
**៣៨:៥** ឆ លប ១០:៦ ជ លប ១០:៦ អក ២៧:១០
**៣៨:៦** ឈ លប ១០:២ ញ លប ១០:៣ ដ អក ៣២:៣០
**៣៨:៧** ឋ អស ៨:៩
**៣៨:៨** ឌ អស ២៤:២២ ឍ អស ១១:១១ ណ ខ.១៤ យរ ២៣:៦ អក ២៨:២៦ យអ ៣:១
**៣៨:៩** ត អស ២៥:៤ ២៨:២ ថ ខ.១៦ យរ ៤:១៣ យអ ២:២ ទ វវ ២០:៨
**៣៨:១០** ធ យរ ១៧:១០ ន ទដ ៣៦:៤ មីក ២:១
**៣៨:១១** ប លប

១០ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលថា នៅថ្ងៃនោះ
នឹងមានគមនិតកើតឡើងក្នុងចិត្តឯង[ធ] ហើយឯងនឹងបង្កើត
កិច្ចកលអាក្រក់[ន] ១១ឯងនឹងថា អញនឹងឡើងទៅឯស្រុក
ដែលនៅចំហ អញនឹងទៅឯពួកមនុស្ស ដែលនៅដោយឥត
កង្វល់[ប] ហើយដោយសុខសាន្ត ដែលទាំងអស់គ្នានៅដោយ
ឥតមានកំផែង ឬទ្វារ ឬរនុកឡើយ[ផ] ១២ដើម្បីនឹងចាប់យក
របឹបនឹងទំពា ហើយត្រឡប់ដៃទៅទាស់នឹងទីខូចបង់ ដែល
មានមនុស្សអាស្រ័យនៅឡើងវិញ ហើយទាស់នឹងបណ្តា
មនុស្ស ដែលបានប្រមូលចេញពីគ្រប់ទាំងសាសន៍ ជាពួក
អ្នកដែលចំរើនបានហ្វូងសត្វ និងទ្រព្យសម្បត្តិ ក៏នៅចំ
កណ្តាលផែនដី ១៣ឯពួកសេបា[ព] ពួកដេដាន់[ភ] ពួកជំនួញ
របស់ស្រុកតើស៊ីស[ម] ព្រមទាំងសិង្ហស្ទាវទាំងប៉ុន្មានរបស់
ពួកទាំងនោះ គេនឹងសួរមកឯងថា តើលោកមកចាប់យក
របឹបឬ តើបានប្រមូលពួកទាំងប៉ុន្មានរបស់លោក ដើម្បី
នឹងចាប់យករំពាឬ តើចង់ដឹកយកប្រាក់ និងមាសហើយ
នាំហ្វូងសត្វ និងទ្រព្យសម្បត្តទៅឬ គឺចង់ប្លន់យករបឹប
យ៉ាងច្រើនឬអី[យ] ។

៣៤:២៥ ផ យរ ៤៩:៣១ សក ២:៤ **៣៨:១៣** ព លប ១០:៧ ភ លប ២៥:៣ ម លប ១០:៤ យ អស ១០:៦ ៣៣:២៣ យរ ១៥:១៣

ហារដែលប្រឆាំងជាមួយនឹងព្រះ ។

**៣៨:៥** *សាសន៍គូស* គឺជាការឈ្លានពានរបស់កងទ័ពដែលមកពីភាគខាងជើង (សូមមើល ខ.២ និងការពន្យល់) គឺពួកគេបានចូលរួមដោយកងទ័ពមកពីភាគខាងត្បូង ។

*សាសន៍ពូត* គឺជាពួសាសន៍លីប៊ី (សូមមើល ២រប ១២:៣ ។

**៣៨:៦** *សាសន៍កូមើរ* គឺជាសាសន៍ដទៃផ្សេងទៀតដែលបាន ចងសម្ព័ន្ធមិត្រជាមួយនិងសាសន៍កុកភាគខាងជើង (សូមមើលការពន្យល់ ខ.២) ។ មើលការបញ្ជាក់នៅក្នុង លប ១០:៣ ១រប ១:៦ គឺដូចជាកូនប្រុសមួយក្នុងចំណោមកូនរបស់លោកយ៉ាផែត ។ យោងតាមពុំមានប្រភពនៃព្រះគម្ពីរបញ្ជាក់ច្បាស់លាស់មនុស្សទាំងនេះ គឺប្រហែលមកពីទីដាច់ស្រយាលទិសខាងជើងនៃសមុទ្រខ្មៅ ។ *ពួកវង្សតូកាម៉ា* សូមមើលការពន្យល់នៅ ២៧:១៤ យោងទៅនិង លប ១០:៣ និង ១រប ១:៦ តូកាម៉ា គឺជាកូនមួយនៅក្នុងចំណោមកូនរបស់លោកកូមើរ ។

**៣៨:៨** *ក្រោយយូរថ្ងៃទៅ . . . ដល់ជាន់ក្រោយបង្អស់* បន្ទាប់ពីព្រឹត្តិការណ៍ទាំងឡាយរបស់អ៊ីស្រាអែលដែលបានសាងសង់ឡើងវិញ គឺបានពិពណ៌នានៅក្នុង ជំពូក ៣៤–៣៧ មានការបញ្ជាក់យ៉ាងគ្រប់គ្រាន់ ។

**៣៨:៩** *ដូចជាពពក* នៅត្រង់វគ្គនេះហោរាយេរេមា បានពិពណ៌នាពីការវាយលុករាតត្បាតមកពីទិសខាងជើង នៅក្នុង យរ ៤:១៣ ។

**៣៨:១០** *នៅថ្ងៃនោះ* នៅត្រង់វគ្គនេះគឺជាការថ្លែងដែលទាយទុកជាមុន ក្នុងការសរសេរ ដូចជាពពកនៅត្រង់នេះបានបង្ហាញប្រាប់ថា នៅថ្ងៃមួយសាសន៍កុកនឹងវាយលុករាតត្បាតមកលើអ៊ីស្រាអែល ដែលប្រៀបដូចជាពពកមកគ្របពីលើ ។ *នឹងមានគំនិតកើតឡើងក្នុងចិត្តឯង* នៅត្រង់ចំណុចនេះ គឺនិយាយពីគំនិតដើមដែលល្អឥតខ្ចោះ ជាការដែលមិនអាចគិតស្មានដល់ថានឹងកើតឡើងយ៉ាងដូច្នេះ (ខ.៤) ។ វាជាការស្របគ្នាជាមួយនឹងបទគម្ពីរដោយសារសកម្មភាពរបស់មនុស្ស(ធៀបនឹង ចទ ៣១:៣ អស ១០:៦–៧) ។ *កិច្ចការអាក្រក់* គឺជាដំណើរនៃការវាយលុកឆ្មក់ចូល ដើម្បីរឹបអូសចាប់យករបឹបនិងរបស់ (សូមមើល ខ.១២) ។

**៣៨:១១** *ស្រុកដែលនៅចំហរ* នៅត្រង់វគ្គនេះ និយាយអំពីស្រុកដែលពេញដោយសុភមង្គល នឹងសន្តិភាព ។ នៅពេលអនាគត់នឹងមិនត្រូវការកំផែងទៀតឡើយ ពីព្រោះព្រះទ្រង់នឹងបានជាកំផែងភ្លើងដល់ស្រុកនោះនៅព័ទ្ធជុំវិញ ហើយនឹងជាសិរីល្អនៅកណ្តាលស្រុកនោះដែរ (សក ២:៤–៥) ។ ដូចជាព្រះអម្ចាស់ គឺព្រះទ្រង់មានលក្ខណៈគ្រប់គ្រាន់ក្នុងការការពារ (ធៀបនឹង ៣៦:៣៥–៣៦ ។

**៣៨:១២** *កណ្តាលផែនដី* ពាក្យនេះ នៅក្នុងព្រះគម្ពីរជាភាសាហេព្រើរគឺ "កណ្តាល"មានន័យថា "ផ្ចិត" ដែលជាសញ្ញាសម្គាល់ពីជំនឿដែលពួកអ៊ីស្រាអែលបានមានទំនាក់ទំនងផ្សាភ្ជាប់ជាមួយព្រះនិងមនុស្ស(នឹងបានឃើញនៅក្នុង ៥:៥ ។ ព្រោះនៅក្នុងព្រះគម្ពីរភាសាហេព្រើរ "ស្រុក"មានន័យថា "ផែនដី" តាមវិជ្ជាសិក្សាអំពីព្រះ ពាក្យទាំងពីរនេះគឺមានអត្ថន័យថាក្រុងយេរូសាឡិមជាចំណុចកណ្តាលនៃទឹកដីអ៊ីស្រាអែល និងជាចំណុចកណ្តាលនៃពិភពលោក ។

**៣៨:១៣** *ពួកសេបា* គឺពួកគេរស់នៅ ទិសខាងត្បូងឆៀងខាងលិច (និរតី) ដែលស្ថិតនៅឧបទ្វីបអារ៉ាប់ (ជាប្រទេសយេមិន សព្វថ្ងៃនេះ) (Yemen) ដែលគេបានដឹងថា ជាតំបន់ពាណិជ្ជកម្ម (យប ៦:១៦ សូមមើល ២៣:៤២ ២៧:២២ លប ១០:២៨ និងការពន្យល់) ។ *ពួកដេដាន់* សូមមើលការ

១៤ដូច្នេះ កូនមនុស្សអើយ ចូរទាយចុះ ហើយប្រាប់
កុកថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ នៅថ្ងៃ
នោះ កាលណាអ៊ីស្រាអែល ជារាស្ត្រអញ បាននៅដោយ
សុខសាន្ត[រ] នោះតើឯងមិនបានដឹងទេឬ ១៥ឯងនឹងចេញ
ពីកន្លែងរបស់ឯង គឺពីស្រុកខាងជើងបំផុតមក[ល] មានទាំង
សាសន៍ជាច្រើនមកជាមួយនឹងឯងផង ជាពួកកងយ៉ាង
សន្ធឹក ហើយជាពលទ័ពខ្លាំងពូកែ[វ] ដែលសុទ្ធតែជិះសេះ
គ្រប់ៗគ្នា ១៦ឯងនឹងឡើងមកទាស់នឹងអ៊ីស្រាអែល ជារាស្ត្រ
អញ ដូចជាពពក[ស]ដែលគ្របស្រុក[ហ] គឺនៅជាន់ក្រោយបង្អស់
អញនឹងនាំឯងមកទាស់នឹងស្រុកអញ ដើម្បីឱ្យអស់ទាំង
សាសន៍បានស្គាល់អញ ឱកុកអើយ គឺក្នុងកាលដែលអញ
បានតាំងជាបរិសុទ្ធ[ឡ] នៅក្នុងឯងចំពោះភ្នែកគេ[អ]។
១៧ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលថា តើឯងឬ
អីដែលអញ បាននិយាយកាលពីដើម ដោយសារពួកអ្នក
បំរើអញ គឺជាពួកហោរានៃសាសន៍អ៊ីស្រាអែល នៅ
ជាន់នោះ ដែលបានទាយជាយូរឆ្នាំមក ដោយថាអញនឹងនាំ
ឯងមកទាស់នឹងគេនោះ ១៨ព្រះអម្ចាស់យេហូវ៉ា ទ្រង់មាន
បន្ទូលថា នៅគ្រានោះកាលណាកុក បានមកទាស់នឹងស្រុក
អ៊ីស្រាអែល នោះសេចក្ដីក្រោធរបស់អញនឹងឆួលឡើង
នៅច្រមុះអញ ១៩ដ្បិតគឺដោយសេចក្ដីប្រចណ្ឌរបស់អញ
នឹងភ្លើងនៃសេចក្ដីក្រោធរបស់អញ ដែលអញបានថា ពិត
ប្រាកដជានៅថ្ងៃនោះ នឹងមានការកក្រើករំពើក[ក] ជាខ្លាំង
នៅក្នុងស្រុកអ៊ីស្រាអែល[ខ] ២០ដល់ម៉្លេះបានជា ទាំងត្រីសមុទ្រ
និងសត្វហើរលើអាកាស សត្វព្រៃ និងសត្វលូនវារ នៅដី
ហើយគ្រប់ទាំងមនុស្សនៅផែនដី នឹងញាប់ញ័រ[គ]នៅចំពោះ
អញ ឯភ្នំទាំងប៉ុន្មាននឹងរលំចុះ[ឃ] ចំរែះ ភ្នំនឹងបាក់ធ្លាក់
មក[ង] ហើយអស់ទាំងកំផែងនឹងដួលដល់ដី[ច] ២១ព្រះអម្ចាស់
យេហូវ៉ាទ្រង់មានបន្ទូលថា អញនឹងហៅដល់អស់ទាំងភ្នំ
របស់អញឱ្យមានដាវ[ឆ]មកទាស់នឹងវា នោះដាវរបស់មនុស្ស
ទាំងឡាយ នឹងបានទាស់នឹងបងប្អូនខ្លួន[ជ] ២២អញនឹងសំរេច
ទោស[ឈ]ដល់វា ដោយអាសន្នរោគ និងឈាម[ញ] អញនឹង
បង្អុរភ្លៀងរំលា ព្រមទាំព្រឹលយ៉ាងធំ[ដ] និងភ្លើង ហើយ
ស្ពាន់ធ័រមកលើវា[ឋ] និងពួកកកកុញរបស់វា ហើយលើ
បណ្ដាសាសន៍ជាច្រើន ដែលមកជាមួយផង[ឌ] ២៣អញនឹង
ដំកើងខ្លួនអញ ហើយតាំងខ្លួនអញជាបរិសុទ្ធ ព្រមទាំងធ្វើឱ្យ
សាសន៍ជាច្រើន ស្គាល់អញចំពោះភ្នែកផង នោះគេនឹងដឹង
ថា អញនេះជាព្រះយេហូវ៉ាពិត[ឍ]។

**៣៩** ១ដូច្នេះ កូនមនុស្សអើយ ចូរទាយទាស់នឹងកុក[ក]
ហើយប្រាប់ថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូល ដូច្នេះ
ម្នាលកុក ជាចៅហ្វាយនៃពួករ៉ុស ពួកមេសេក[ខ] និងពួក
ទូលបាល អើយ[គ] អញទាស់នឹងឯង ២អញនឹងធ្វើឱ្យឯង
បែរមក ហើយនាំឯងទៅមុខ ក៏នឹងបណ្ដាលឱ្យឯងឡើង
មកពីស្រុកខាងជើងបំផុត[ឃ] ព្រមទាំងនាំឯងមកលើភ្នំទាំង
ប៉ុន្មានរបស់ស្រុកអ៊ីស្រាអែល[ង] ៣អញនឹងវាយធ្នូ[ច]ចេញពីដៃ
ឆ្វេងរបស់ឯង ហើយនឹងធ្វើឱ្យព្រួញ[ឆ]ធ្លាក់ចេញពីដៃស្តាំឯង
៤ឯងនឹងដួលនៅលើអស់ទាំងភ្នំរបស់ស្រុកអ៊ីស្រាអែល គឺ

**៣៨:១៤** រ ខ.៨ លវ ២៥:១៨ យរ ១៦:១៥ សក ២:៥ **៣៨:១៥** ល អគ ៣២:៣០ វ អគ ៣៩:២ វវ ២០:៨ **៣៨:១៦** ស ខ.៩ ហ យអ ៣:១១ ឡ លវ ១០:៣ អ អស ២៩:២៣ អគ ៣៩:២១ **៣៨:១៩** ក អស ២៤:១៨ យអ ២:១០ ៣:១៦ វវ ៦:១២ ខ ទដ ១៨:៧ អគ ៥:១៣ ហក ២:៦,២១ **៣៨:២០** គ នក ១៥:១៤ ឃ អស ៤២:១៥ ង យប ១៤:១៨ ច ទដ ៧៦:៨ ហស ៤:៣ ណហ ១:៥ **៣៨:២១** ឆ អស ៦៦:១៦ យរ ២៥:២៩ ជ ១សយ ១៤:២០ ២រប ២០:២៣ ហក ២:២២ **៣៨:២២** ឈ អស ៦៦:១៦ យរ ២៥:២៩ ញ យរ ២៥:៣១ អគ ៣៦:៥ ដ អគ ១៤:១៩ ២៨:២៣ ឋ នក ៩:១៨ ឌ ទដ ១៨:១២ វវ ១៦:២១ ឍ លប ១៩:២៤ វវ ៩:១៧ ណ អគ ១៣:១១ **៣៨:២៣** ត អគ ២០:៤២ ៣៦:២៣ ៣៧:៦ **៣៩:១** ក វវ ២០:៨ ខ លប ១០:២ គ អគ ២៧:១៣ ៣៨:២,៣ **៣៩:២** ឃ អគ ៣២:៣០ ង អគ ៣៨:៤,១៥ **៣៩:៣** ច ហស ១:៥ អម ២:១៥ ឆ ទដ ៧៦:៣

ពន្យល់ ២៥:១៣ ។ *ស្រុកតើស៊ីស* សូមមើលការពន្យល់ ២៧:១២ ។
**៣៨:១៦** *តាំងជាបរិសុទ្ធ នៅក្នុងឯង* សូមមើល លវ ១០:៣ និងការពន្យល់ ។
**៣៨:១៧** *តើឯងឬអី ដែលអញបាននិយាយកាលពីដើម . . .* នៅត្រង់ឃ្លានេះ គឺប្រហែលទូទៅជាសេចក្ដីបញ្ជាក់ទៅលើទំនាយទាំងឡាយពីមុនមកនៃការជំនុំជម្រះដ៏បរិសុទ្ធរបស់ព្រះទៅលើជាតិសាសន៍នានា ដែលបានទាស់ប្រឆាំងជាមួយព្រះនិងប្រជារាស្ត្ររបស់ទ្រង់ ។
**៣៨:១៩** *ការកក្រើករំពើក* នៅត្រង់វគ្គនេះ គឺជាសញ្ញាសម្គាល់ដែលបង្ហាញពីអនុភាព និងភាពខ្លាំងពូកែរបស់ទ្រង់ ដែលទ្រង់នឹងយាងមកដើម្បីស្រោចមកលើកងទ័ពយ៉ាងសម្បើមក្នុងការវាយលុកឈ្លានពានទឹកដីរបស់ទ្រង់ ។
**៣៨:២០** មួយភាគបួននៅក្នុងបញ្ជីឈ្មោះគ្រប់ទាំងសត្វនៅលើផែនដី គឺបានបង្ហាញប្រាប់ពីធម្មជាតិទាំងអស់ (សូមមើលការពន្យល់ ១:៥ ធៀបនឹង លប ៩:២ ១ពវ ៤:៣៣ យប ១២:៧–៨ ប្រហាក់ប្រហែលស្រដៀងនឹងបញ្ជីឈ្មោះទាំងឡាយ) ។
**៣៨:២១** *អញនឹងហៅ ដល់អស់ទាំងភ្នំរបស់អញឱ្យមានដាវ* ដាវរបស់ព្រះនឹងជំនុំជម្រះ (សូមមើល ៥:២ និងការពន្យល់) ។ *ដាវរបស់មនុស្សទាំងឡាយ នឹងបានទាស់នឹងបងប្អូនខ្លួន* នៅត្រង់ឃ្លានេះ នៅគ្រានោះសត្រូវរបស់ពួកអ៊ីស្រាអែល គេនឹងព្រួតគ្នាបំផ្លាញគ្នាទៅវិញទៅមក ដូចជាទាហានទាំងឡាយ ដែលបានប្រយុទ្ធជាមួយពួកយូដា នៅក្នុងគ្រាស្ដេចយ៉ូសាផាតសោយរាជ្យ (២រប ២០:២២–២៣) ។
**៣៨:២២** បញ្ជីសស្ត្រាវុធដ៏បរិសុទ្ធទាំងឡាយដែលបង្ហាញថា ព្រះទ្រង់ធ្វើអន្តរាគមន៍ដោយផ្ទាល់ ដែលគ្មានប្រយោជន៍នឹងជួយដល់កងទ័ពនៅលោកិយនេះបានឡើយ ។
**៣៩:១–៦** ព្រឹត្តិការណ៍សំខាន់ៗដដែលដូចដែលមាននៅក្នុងជំពូក ៣៨ គឺបានរៀបរាប់លំអិតជាថ្មីខ្លះៗបន្ថែមទៀត ។
**៣៩:១** *ម្នាលកុក ជាចៅហ្វាយនៃពួករ៉ុស ពួកមេសេក* សូមមើលការពន្យល់ ៣៨:២ ។
**៣៩:២** *មកពីស្រុកខាងជើងបំផុត* ដូចមាននៅក្នុង ៣៨:៦,១៥ ។
**៣៩:៣** *ធ្នូ* ធៀបនឹង យរ ៦:២៣ ព្រះអម្ចាស់ទ្រង់នឹងដកអាវុធពីខ្នាំងសត្រូវរបស់ពួកអ៊ីស្រាអែលចេញ ដែលពីមុនពួកគេអាចបាញ់ព្រួញ ។
**៣៩:៤** *សត្វហើរផ្សេងៗដែលស៊ីគំរង់* បានពង្រីកគោលរឿង ខ.១៧–២០ ។

ទាំងឯង និងពួកកកកុញរបស់ឯង ហើយសាសន៍ទាំងប៉ុន្មាន
ដែលនៅជាមួយផង អញនឹងប្រគល់ឯងដល់សត្វហើរ[ជ]
ផ្សេងៗដែលស៊ីគិរង់ ហើយដល់សត្វព្រៃឱ្យវាស៊ីទៅ[ឈ] ៥ឯង
នឹងដួលនៅទីវាលទទេ ដ្បិតអញបានចេញវាចាហើយ នេះ
ជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ញ] ៦អញនឹងចាត់ភ្លើង[ដ]
ទៅលើស្រុកម៉ាកុក[ឋ] ហើយលើពួកអ្នកដែលអាស្រ័យនៅ
ដោយសុខសាន្តនៅកោះទាំងឡាយ[ឌ] នោះគេនឹងដឹង[ឍ]ថា
អញនេះជាព្រះយេហូវ៉ាពិត ៧អញនឹងឱ្យមនុស្សស្គាល់
ឈ្មោះដ៏បរិសុទ្ធរបស់អញ នៅកណ្ដាលពួក អ៊ីស្រាអែលជា
រាស្ត្រអញ ក៏មិនឱ្យឈ្មោះបរិសុទ្ធរបស់អញ ត្រូវបង្អាប់
ទៀត[ណ] ដូច្នេះ អស់ទាំងសាសន៍នឹងដឹង[ត]ថា អញជាព្រះ
យេហូវ៉ា គឺព្រះដ៏បរិសុទ្ធនៅក្នុងពួកអ៊ីស្រាអែល[ថ] ៨ព្រះ
អម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា មើល ការនោះកំពុងតែ
មក ហើយនឹងបានសំរេចជាពិត នេះហើយជាថ្ងៃ[ទ] ដែល
អញបានប្រាប់នោះ ៩ឯពួកអ្នកដែលនៅអស់ទាំងពី ក្រុងនៃ
ស្រុកអ៊ីស្រាអែល គេនឹងចេញទៅប្រមូលគ្រឿងសាស្ត្រា
វុធដុតចោល គឺទាំងខែលតូច ខែលធំ ទាំងធ្នូ និងព្រួញ[ធ]
ដែលពួយ និងលំពែងផង គេនឹងដុតគ្រឿងទាំង នោះអស់
៧ឆ្នាំ[ន] ១០ឥតត្រូវការរើសរំកាច់ឈើនៅទីវាល ឬកាប់ឧស
នៅក្នុងព្រៃលើយ ដ្បិតគេនឹងប្រើគ្រឿងទាំង នោះសំរាប់
ដុតវិញ ហើយគេនឹងរឹបជាន់ ពួកអ្នកដែលបានរឹបជាន់[ប]ខ្លួន
ព្រមទាំងប្លន់ពួកអ្នកដែលបានប្លន់ខ្លួនដែរ នេះជាព្រះបន្ទូល
នៃព្រះអម្ចាស់យេហូវ៉ា[ផ] ។
១១គ្រានោះ អញនឹងឱ្យកន្លែង១ដល់ពួកកុក សំរាប់ជាទី
កប់ខ្មោចនៅក្នុងស្រុកអ៊ីស្រាអែល គឺជាច្រកភ្នំដែលមនុស្ស
ដើរកាត់ ទៅខាងកើតសមុទ្រ ច្រកនោះនឹងបិទខ្ទប់ពួក
អ្នកដើរកាត់ ហើយនៅទីនោះ គេនឹងកប់[ព]សាកសពនៃ កុក
និងពួកកកកុញរបស់វា គេនឹងហៅស្រុកភ្នំនោះថា ហាមុន–
កុក[ភ] ១២ពួកវង្សអ៊ីស្រាអែលនឹងកប់ខ្មោចអ្នកទាំងនោះអស់
៧ខែ ទើបបានហើយ ដើម្បីនឹងសំអាតស្រុក[ម] ១៣អើ មនុស្ស
ទាំងនៅស្រុកនោះនឹងធ្វើការកប់សពគេ ហើយការនោះ
នឹងបានជាល្បីដល់គេ ក្នុងថ្ងៃដែលអញបានដំកើងឡើង[យ]
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ១៤គេនឹងជំរូវទុក
មនុស្ស១ពួក ដែលត្រូវធ្វើការនោះជានិច្ច ឱ្យបានដើរចុះ
ឡើងក្នុងស្រុក ជាមួយនឹងពួកអ្នកដែល ដើរដំណើរទៅមក
ដើម្បីនឹងកប់សពដែលសល់នៅលើដី ប្រយោជន៍នឹងសំអាត
ស្រុកទៅ ក្រោយ៧ខែ នោះគេនឹងដើរទៅមក មើល បើ
ឃើញឆ្អឹងខ្មោចមនុស្សណា នោះគេនឹងតាំងទីសំគាល់១
នៅជិតខាង ទាស់នឹងពួកកប់ខ្មោចបានមកកប់ ចោលនៅ
ក្នុងច្រកភ្នំហាមុន–កុកទាំងអស់ទៅ ១៦ហើយទីក្រុង១ នឹង
មានឈ្មោះហៅថា ហាម៉ូណា គឺយ៉ានោះដែលគេនឹង
សំអាតស្រុក ។
១៧ឯឯង កូនមនុស្សអើយ ព្រះអម្ចាស់យេហូវ៉ាទ្រង់
មានបន្ទូលថា ចូរប្រាប់ដល់សត្វស្លាប[រ]គ្រប់យ៉ាង និងដល់
អស់ទាំងសត្វព្រៃនៅផែនដីថា ចូរមូលគ្នាមក ចូរប្រជុំ
គ្នាពីគ្រប់ទិស មកឯយញ្ញបូជារបស់អញ ដែលអញធ្វើ
សំរាប់ឯងរាល់គ្នា ជាសញ្ញបូជាយ៉ាងធំ នៅលើអស់ទាំង
ភ្នំស្រុកអ៊ីស្រាអែល ដើម្បីឱ្យឯងបានស៊ីសាច់ ហើយផឹក
ឈាម[ល] ១៨ឯងរាល់គ្នានឹងស៊ីសាច់របស់មនុស្សខ្លាំងពូកែ
ហើយផឹកឈាមរបស់ពួកចៅហ្វាយនៅផែនដី ទាំងចៀម

**៣៩:៤** ជ លប ៤០:១៩ ឈ ខ.១៧–២០ យរ ២៥:៣៣ អគ ២៩:៥ ៣៣:២៧
**៣៩:៥** ញ អគ ៣២:៤
**៣៩:៦** ដ អគ ៣០:៨ វវ ២០:៩ ឋ លប ១០:២ ឌ យរ ២៥:២២ ឍ នក ៦:៧
**៣៩:៧** ណ នក ២០:៧ អគ ១៣:១៩ ត អស ៤៩:២៦ ថ អស ១២:៦ ៥៤:៥ អគ ២០:៩ ៣៦:១៦,២៣
**៣៩:៨** ទ អគ ៧:៦
**៣៩:៩** ធ ទដ ៧៦:៣ ន ទដ ៤៦:៩
**៣៩:១០** ប នក ៣:២២ ផ អស ១៤:២ ៣៣:១ ហប ២:៨
**៣៩:១១** ព អស ៣៤:៣ ភ អគ ៣៨:២
**៣៩:១២** ម ចទ ២១:២៣
**៣៩:១៣** យ អគ ២៨:២២
**៣៩:១៧** រ យប ១៥:២៣ ល អគ ៣២:៤

**៣៩:៦** *អញនឹងចាត់ភ្លើង* សូមមើល ២០:៤៧ និងការពន្យល់ ។
**៣៩:៧** *ឱ្យមនុស្សស្គាល់ឈ្មោះដ៏បរិសុទ្ធរបស់អញ* សូមមើល លវ ១៨:២១ និងការពន្យល់ ។ *ជាព្រះដ៏បរិសុទ្ធ* សូមមើល លវ ១១:៤៤ និងការពន្យល់ ។
**៣៩:៩** *៧* គឺជានិមិត្តសញ្ញាពីចំនួនលេខនៃការប្រកាសជាទ្រង់ទ្រាយខ្នាតដ៏ធំចំពោះការវាយលុកឃ្លានពានរបស់កងទ័ពទាំងឡាយ រហូតដល់ទីបញ្ចប់ក្នុងការប្រយុទ្ធចម្បាំងដ៏ធំ ដើម្បីប្រឆាំងទាស់ជាមួយនិងប្រជារាស្ត្ររបស់ព្រះ ។
**៣៩:១២** *៧* សូមមើល ខ.៩ និងការពន្យល់ ។ *សំអាតស្រុក* នៅត្រង់វគ្គ នេះ សម្អាតស្រុកគឺជាពិធីបុណ្យបរិសុទ្ធ ដើម្បីនិងសម្អាតឱ្យបានបរិសុទ្ធនៅចំពោះព្រះ ហើយគឺជាផ្នែកដ៏សំខាន់នៅក្នុងវិជ្ជាសិក្សាអំពីព្រះ (សូមមើល ២២:២៦ ២៤:១៣ ៣៦:២៥,៣៣ ៣៧:២៣) ។ និងជាពិសេសគឺសម្អាតគ្រប់ទាំងខ្លួនប្រាណណាដែលមិនស្អាត (សូមមើល លវ ៥:២ ២១:១,១១ ២២:៤ ជន ៥:២ ៦:៦–១២ ១៩:១៦ ៣១:១៩) ។
**៣៩:១៣** *មនុស្សទាំងអស់នៅស្រុក* សូមមើល ៧:២៧ និងការពន្យល់ ។
**៣៩:១៤** *នឹងជំរូវទុកមនុស្ស១ពួក ដែលត្រូវធ្វើការនោះជានិច្ច* នៅកំឡុងពេល៧ខែ បន្ទាប់ បានសង្កេតឃើញការបញ្ចុះសាកសពមនុស្សទាំងអស់ ជាពិសេសក្រុមកងទ័ពជាច្រើនក្រុមនឹងបានស៊ីឈ្នួលពេញពេល ដើម្បីទទួលការធានាក្នុងការសម្អាតស្រុក ដោយបានធ្វើទីនោះទុកជាទីកន្លែងកប់សាកសពនិងឆ្អឹងមនុស្សទាំងឡាយ ដែលអាចមានការខកខាន ។ សរុបសេចក្ដីមកពិធីសម្អាតបរិសុទ្ធ គឺជាបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ ។
**៣៩:១៧–២០** ខព្រះគម្ពីរទាំងឡាយនេះមានជាប់ទំនាក់ទំនង និងជាការថ្លែងឡើងវិញនៅ ខ.៩–១៦ បានបញ្ជាក់ពីការស៊ីឈ្នួលដែលមានតួលេខនៃចំនួនខុសគ្នា (សូមមើល អស ៣៤:៦ និងការពន្យល់ យរ ៤៦:១០ សផ ១:៧) ។ ដែលជាការប្រៀបធៀបនិងពិធីថ្វាយញ្ញបូជា ជាការណែនាំដាស់តឿន ដើម្បីញែកចេញជាបរិសុទ្ធ ដូចដែលព្រះអម្ចាស់ានជិនុំជម្រះជាមួយនិងទីក្រុងយេរីខូរ (សូមមើល យស ៦:១៧) ។
**៣៩:១៨** *ឯងរាល់គ្នានឹងស៊ីសាច់របស់មនុស្សខ្លាំពូកែ* គឺជាការរៀបរាប់ពីសត្វស្លាបដែលហើរលើអាកាស នឹងមកប្រជុំពីគ្រប់ទិសទីដើម្បីនឹងស៊ីសាច់ហុតឈាមរបស់ពួកស្ដេច ពួកមេទ័ព ពួកមនុស្សខ្លាំងពូកែ និងសាច់នៃមនុស្សទាំងអស់ ទុកជាចំណីនិងជាវិពាររបស់សត្វទាំងនោះ (សូមមើលមើលការ

ឈ្មោល កូនចៀម ពពែ និងគោផង សុទ្ធតែជាសត្វបំប៉ន
ពីស្រុកបាសាន[រ] ១៩ឯងរាល់គ្នានឹងស៊ីខ្លាញ់ទាល់តែឆ្អែត
ហើយផឹកឈាម ទាស់តែស្រវឹង ដោយសារយញ្ញបូជា[ស]
ដែលអញធ្វើសំរាប់ឯង ២០នៅតុអញ ឯងរាល់គ្នានឹងបាន
ឆ្អែតដោយសាច់សេះ ពួករទេះចំបាំង ពួកមនុស្សខ្លាំងពូកែ
និងពួកទាហានទាំងប៉ុន្មានដែរ នេះជាព្រះបន្ទូលនៃព្រះ
អម្ចាស់យេហូវ៉ា[ហ]។
២១អញនឹងតាំងសិរីល្អរបស់អញ នៅកណ្ដាលអស់ទាំង
សាសន៍ ហើយអស់ទាំងសាសន៍នឹងឃើញសេចក្ដីយុត្តិធម៌
របស់អញ ដែលបានសំរេចនោះ នឹងដៃអញដែលបានដាក់
លើគេ[ឡ] ២២យ៉ាងនោះពួកវង្សអ៊ីស្រាអែលនឹងដឹងថា អញ
នេះជាព្រះយេហូវ៉ា គឺជាព្រះនៃគេ តាំងតែពីថ្ងៃនោះតទៅ
២៣ឯពួកសាសន៍ដទៃ គេនឹងដឹងថា ពួកវង្សអ៊ីស្រាអែលបាន
ត្រូវដឹកនាំទៅជាឈ្លើយ ដោយព្រោះអំពើទុច្ចរិតរបស់
ខ្លួនដោយព្រោះគេប្រព្រឹត្តរំលងទាស់នឹងអញ ហើយបាន
ជាអញគេចមុខចេញពីគេ ដោយហេតុនោះបានជាអញ
ប្រគល់គេ ទៅក្នុងកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ ហើយគេ
ត្រូវដួលដោយដាវទាំងអស់គ្នា[អ] ២៤អញបានធ្វើដល់គេតាម
សេចក្ដីស្មោកគ្រោក និងអំពើរំលងរបស់គេព្រមទាំងគេច
មុខចេញពីគេផង[ក]។
២៥ហេតុនោះ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូល
ដូច្នេះថា ឥឡូវនេះ អញនឹងនាំពួកយ៉ាកុបដែលនៅជា
ឈ្លើយ[ខ]ឲ្យមកវិញ ហើយនឹងមានសេចក្ដីអាណិតមេត្តា[គ] ដល់
ពួកវង្សអ៊ីស្រាអែលទាំងមូល ហើយនឹងមានសេចក្ដីប្រចណ្ឌ
ដោយយល់ដល់ឈ្មោះបរិសុទ្ធរបស់អញ[ឃ] ២៦ឯក្រោយ
ដែលគេបានរងទ្រាំសេចក្ដីខ្មាស និងគ្រប់ទាំងអំពើរំលង
ដែលគេបានប្រព្រឹត្តទាស់នឹងអញ ក្នុងគ្រាដែលគេនៅក្នុង
ស្រុកខ្លួន ដោយសុខសាន្ត[ង] ឥតមានអ្នកណាបំភ័យឡើយ[ច]
២៧គឺក្នុងកាលដែលអញបាននាំគេចេញ ពីអស់ទាំងសាសន៍
មកវិញ ហើយប្រមូលគេ ពីគ្រប់ទាំងស្រុករបស់ខ្មាំងសត្រូវ
គេ ព្រមទាំងតាំងខ្លួនអញជាបរិសុទ្ធ នៅក្នុងពួកគេ ចំពោះ
ភ្នែកសាសន៍ជាច្រើន[ឆ] ២៨ហើយគេនឹងដឹងថា អញនេះជា
ព្រះយេហូវ៉ា គឺព្រះនៃគេ ដោយអញ បានធ្វើឲ្យគេទៅជា
ឈ្លើយ នៅកណ្ដាលអស់ទាំងសាសន៍ រួចបានប្រមូលគេ[ជ]
មកក្នុងស្រុករបស់ខ្លួនគេវិញ ឥតទុកអ្នកណាមួយឲ្យនៅសល់
ក្នុងស្រុកទាំងនោះទៀត[ឈ] ២៩អញក៏នឹងមិនគេចមុខ[ញ]ពីគេ

**៣៩:១៨** រ ទដ ២២:១២ យរ ៥១:៤០ **៣៩:១៩** ស លវ ៣:៩ **៣៩:២០** ហ អស ៥៦:៩ យរ ១២:៩ វវ ១៩:១៧-១៨ **៣៩:២១** ឡ នក ៩:១៦ អស ៣៧:២០ អគ ៣៨:១៦ **៣៩:២៣** អ អស ១:១៥ ៥៩:២ យរ ២២:៨-៩ ៤៤:២៣ **៣៩:២៤** ក ២ពវ ១៧:២៣ យរ ២:១៧ ,១៩ ៤:១៨ អគ ៧:២២ ដយ ៩:៧ **៣៩:២៥** ខ យរ ៣៣:៧ គ យរ ៣០:១៨ ឃ អស ២៧:១២-១៣ អគ ១៦:៥៣ **៣៩:២៦** ង ១ពវ ៤:២៥ យរ ៣២:៣៧ អគ ៣៨:៨ ច អស ១៧:២ អគ ៣៤:២៨ មីក ៤:៤ **៣៩:២៧** ឆ អគ ៣៧:២១ **៣៩:២៨** ជ ទដ ១៤៧:២ ឈ អគ ៣៦:២៣,២៦ **៣៩:២៩** ញ ចទ ៣១:១៧

ពន្យល់ពីមុន និង វវ ១៩:១៧-២១) ។ *ទាំងចៀមឈ្មោល កូនចៀម ពពែ និងគោ* គ្រប់ទាំងរូបកាយនឹងបានជាយញ្ញបូជាគឺប្រៀបដូចជាសត្វទាំងឡាយ ដែលបានប្រើសម្រាប់ថ្វាយយញ្ញបូជាទៅចំពោះព្រះនៅយុគសម័យនោះ ។ *ស្រុកបាសាន* គឺជាស្រុកសម្បូរទៅដោយវាលស្មៅ និងស្ថិតនៅខាងកើតសមុទ្រកាលីឡេ ដែលគេបានស្គាល់ថា ជាស្រុកដ៏ល្អប្រណិត និងសម្បូរទៅដោយសត្វពាហនៈ ដូចជា គោ ក្របី សេះ ចៀម ពពែ (សូមមើល ចទ ៣២:១៤ ទដ ២២:១២ អម ៤:១) និងមានសម្បូរទៅដោយដើមឈើម៉ៃសាក់ជាច្រើន (២៧:៦ អស ២:១៣) ។

**៣៩:១៩** *ស៊ីខ្លាញ់ . . . ផឹកឈាម* ជាការចង្អុរបង្ហាញថា ខ្លាញ់ និង ឈាមទាំងនេះ គឺជាយញ្ញបូជាសម្រាប់ថ្វាយដល់ព្រះអម្ចាស់ នៅក្នុងនោះ ខ្លាញ់ និង ឈាមជាធម្មតាបានរក្សាទុកសម្រាប់ព្រះ (សូមមើល ៤៤:១៥ សូមមើលផងដែរ លវ ៣:១៦ ១សយ ២:១៥ អស ៣៤:៦ និងការពន្យល់ ។

**៣៩:២០** *នៅតុអញ* ជាការថ្វាដង្វាយនៅលើអាសនា សូមមើល ៤០:៣៨-៤៣ និង ៤១:២២ សម្រាប់ជាការពិពណ៌នានៃតុទាំងឡាយនៅក្នុងព្រះវិហារថ្មី ។

**៣៩:២១** *សិរីល្អរបស់អញ* ជាការបង្ហាញនូវការបើកសម្ដែងនៅក្នុងព្រះបន្ទូល (សូមមើលការពន្យល់ ១:២៨) ។ សិរីល្អរបស់អញនៅត្រង់នេះ គឺជាការបើកសម្ដែងពីសិទ្ធិអំណាចបរិសុទ្ធនៃព្រះ ដែលមកសណ្ឋិតលើប្រជារាស្ត្ររបស់ទ្រង់ ។

**៣៩:២២-២៣** *ពួកវង្សអ៊ីស្រាអែលនឹងដឹងថា . . . ឯពួកសាសន៍ដទៃ គេនឹងដឹងថា* ដូចជាព្រះបានធ្វើដោយព្រះអង្គទ្រង់ ដើម្បីឲ្យពួកអ៊ីស្រាអែលនិងគ្រប់សាសន៍ដទៃបានដឹងតាមរយៈការសង្គ្រោះរបស់ទ្រង់ នៅក្នុងកិច្ចការទាំងឡាយនៃពួកអ៊ីស្រាអែល (សូមមើល នក ៦:៧ ៧:៥,១៧ ១០:២ ១៤:១៨ ១៦:៦-៧,១២ យស ៣:១០ ៤:២៤ ធៀបនឹង យស ២:៩-១១ ៥:១) ។ ឥឡូវនេះពួកអ៊ីស្រាអែល និងពួកសាសន៍ដទៃនឹងបានឃើញ នៅការងាររបស់ទ្រង់គឺទ្រង់ជំនុំជម្រះដោយសុចរិត ដើម្បីនឹងអត់ទោសបាបដល់ពួកគេ ដែលជាប្រជារាស្ត្រនៃព្រះ (សូមមើល ខ. ២៧ ៦:៧ និងការពន្យល់) ។

**៣៩:២៣** *អញគេចមុខចេញ* គឺជាសម្ដែងចេញពីក្ដីបរិសុទ្ធរបស់ទ្រង់មិនពេញព្រះហឫទ័យ ចំពោះពួកអ្នកដែលបានប្រព្រឹត្តសេចក្ដីអាក្រក់ឡើយ (សូមមើល ទដ ១៣:១ និងការពន្យល់ ៣០:៧ អស ៥៤:៨ ៥៧:១៧) ។

**៣៩:២៤** *អំពើរំលងរបស់គេ ព្រមទាំងគេចមុខចេញពីគេផង* បានសរសេរចេញយ៉ាងពិសេសនៅក្នុងជំពូក ២២ ប៉ុន្តែមានការរៀបរាប់លំអិតនៅក្នុងជំពូក ៦-២៤ ផងដែរ ។

**៣៩:២៥** *ពួកយ៉ាកុប* គឺជាជាតិសាសន៍របស់អ៊ីស្រាអែល ដូចនៅក្នុង ២០:៥ ។ *ឈ្មោះបរិសុទ្ធរបស់អញ* សូមមើល ២០:៩ និងការពន្យល់ ។

**៣៩:២៦** *ឯក្រោយដែលគេបានរងទ្រាំសេចក្ដីខ្មាស* ការចងចាំនៅសេចក្ដីខ្មាស ដែលមានពីមុនមក (៦:៩ ២០:៤៣ ៣៦:៣១) គឺត្រូវបានបំបាត់ចោល ។

**៣៩:២៧** *តាំងខ្លួនអញជាបរិសុទ្ធ នៅក្នុងពួកគេ* នៅឃ្លានេះបានបញ្ជាក់ថា ព្រះទ្រង់នឹងបើកសម្ដែងដោយសារព្រះអង្គទ្រង់ផ្ទាល់សាជាថ្មី នៅក្នុងសង់ប្រជារាស្ត្ររបស់ព្រះអង្គឡើងវិញ (សូមមើល លវ ១០:៣ និងការពន្យល់) ។

**៣៩:២៨** *ហើយគេនឹងដឹងថា អញនេះជាព្រះយេហូវ៉ា* សូមមើលការពន្យល់ ខ.២២-២៣ ។

**៣៩:២៩** *ដ្បិតអញបានចាក់វិញ្ញាណអញ* ព្រះវិញ្ញាណ គឺជាអំណោយទាន

ទៀតដែរ ដ្បិតអញបានចាក់វិញ្ញាណ[ដ] អញទៅលើពួក
វង្សអ៊ីស្រាអែលហើយ នេះជាព្រះបន្ទូល នៃព្រះអម្ចាស់
យេហូវ៉ា[ឋ]។

## ទីកន្លែងថ្មីរបស់ព្រះវិហារ

**៤០** ១ នៅឆ្នាំ២៥ ដែលយើងរាល់គ្នា នៅជាឈ្លើយ
លុះដល់ដល់ថ្ងៃ១០ខែដើមឆ្នាំ គឺក្នុងឆ្នាំទី១៤ តាំងពីទីក្រុង[ក]
ត្រូវគេវាយមក នៅថ្ងៃនោះឯង ព្រះហស្តនៃព្រះយេហូវ៉ា
បានសណ្ឋិតនៅលើខ្ញុំ[ខ] ហើយទ្រង់នាំខ្ញុំទៅទីនោះ ២ទ្រង់
បាននាំខ្ញុំទៅក្នុងអ៊ីស្រាអែល ដោយការជាក់ស្តែង[គ]របស់
ព្រះ ហើយបានដាក់ខ្ញុំចុះលើភ្នំ១យ៉ាងខ្ពស់[ឃ] ដែលនៅភ្នំ
នោះ មានសណ្ឋានដូចជាទីក្រុង នៅប៉ែកខាងត្បូង ៣ទ្រង់នាំ
ខ្ញុំទៅឯទីនោះ ខ្ញុំក៏ឃើញមានមនុស្សម្នាក់មានភាពដូចជា
លង្ហិន[ង] ដែលកាន់ខ្សែខ្លូតទេសនៅដៃ និងបបុស[ច] សំរាប់
វាស់ផង លោកឈរនៅក្នុងទ្វារ ៤មនុស្សនោះក៏និយាយ
មកខ្ញុំថា កូនមនុស្សអើយ ចូរពិនិត្យដោយភ្នែក ហើយស្តាប់
ដោយត្រចៀកចុះ រួចយកចិត្តទុកដាក់នឹងគ្រប់ទាំងអស់
ដែលអញបង្ហាញដល់ឯង[ឆ] ដ្បិតបាននាំឯងមក នៅទីនេះ
ប្រយោជន៍ឱ្យអញបានបង្ហាញទាំងអស់នេះដល់ ឯងហើយ
ដូច្នេះ ចូរប្រាប់[ជ]ទាំងអស់ដែលឯងឃើញ ដល់ពួកវង្ស
អ៊ីស្រាអែលផង[ឈ]។

## ទ្វារខាងក្រៅចេញទៅទីលានខាងក្រៅ

៥នោះក៏ឃើញមានកំផែង នៅព័ទ្ធជុំវិញ ខាងក្រៅនៃ
ព្រះវិហារ ហើយនៅដៃមនុស្សនោះ មានបបុសសំរាប់វាស់
ប្រវែង៦ហត្ថ ដែលក្នុង១ហត្ថនោះ ត្រូវជាហត្ថ១ទះ ដូច្នេះ
លោកក៏វាស់[ញ]កំរាស់កំផែងនោះ ត្រូវជា១ខ្នាតបបុស
ហើយកំពស់ក៏១ខ្នាតនោះដែរ ៦រួចលោកទៅដល់ទ្វារ
ដែលបើក ទៅទិសខាងកើត[ដ]ក៏ឡើងជណ្តើរទ្វារនោះទៅ

**៣៩:២៩** ដ អស ១១:២ អគ ៣៧:៩ កច ២:១៧ ឋ អគ ១៦:៤២
**៤០:១** ក ២ពវ ២៥:៧ យរ ៣៩:១–១០ ៥២:៤–១១ ខ អគ ១:៣ ២៩:១៧
**៤០:២** គ នក ២៤:១០ ដយ ៧:១,៧ ឃ យរ ៣១:១២ អគ ១៧:២២ វវ ២១:១០
**៤០:៣** ង អគ ១:៧ វវ ១:១៥ ច អគ ៤៧:៣ សក ២:១–២ វវ ១១:១ ២១:១៥
**៤០:៤** ឆ ចទ ៦:៦ ជ រយ ២៦:២
ឈ អគ ៤៤:៥ **៤០:៥** ញ អគ ៤២:២០ **៤០:៦** ដ អគ ៨:១៦

របស់ព្រះ ដែលព្រះទ្រង់ប្រទានឱ្យដល់កូនរទ្រង់ ដើម្បីជាជំនួយ (សូមមើល ៣៦:២៧ ៣៧:១៤ សូមមើលការពន្យល់ ២:២ យអ ២:២៨) ផងដែរ។

**៤០:១–៤៨:៣៥** ការសង់ឡើងវិញរបស់ពួកអ៊ីស្រាអែល គឺដូចជាត្រូវបានសម្អាតសាជាថ្មី និងជាមនុស្សដែលព្រះទ្រង់បានត្រាស់ហៅជាបរិសុទ្ធ ដើម្បីនឹងសម្អាតទឹកដី និងជារបៀបថ្មីមួយដែលប្រជាជនទាំងនោះ គឺជាប្រជារាស្ត្ររបស់ទ្រង់ ។ ទាំងនេះ គឺជាប្រធានបទនៅក្នុងទស្សនះចុងក្រោយរបស់ហោរាអេសេគាល ដែលជាការបង្ហាញនូវរូបភាពនិងគំនិតថ្មី នៅការរៀបចំដើម្បីចូលទៅទឹកដីថ្មី ។ ការនេះសម្រាប់គម្រោងជាមូលដ្ឋាននៃទស្សនះនិងប្រធានបទផ្សេងៗសូមមើលសេចក្តីផ្តើម ។ គម្រោងសង្ខបខាងក្រោម "ការរៀបចំថ្មីជាការសម្អាតពួកអ៊ីស្រាអែល" ក៏ដូចជាសេចក្តីសង្ខេប(សេចក្តីសង្ខេប) ការពន្យល់ខាងក្រោម ។

**៤០:១–៤៧** ខគម្ពីរទាំងនេះ គឺបានរៀបរាប់ពីការសង់ឡើងវិញនៃបរិវេណព្រះវិហារ ។

**៤០:១** *នៅឆ្នាំ ២៥ . . .លុះដល់ថ្ងៃ ១០ ខែដើមឆ្នាំ* គឺត្រូវជាថ្ងៃទី២៨ ខែមេសា នៅឆ្នាំ ៥៧៣ មុន គ.ស ។ *យើងរាល់គ្នានៅជាឈ្លើយ* កាលបរិច្ឆេទទាំងអស់នៅក្នុងព្រះគម្ពីរអេសេគាល បើតាមការនឹកស្មានពីឆ្នាំ ៥៩៧ មុន គ.ស គឺជាការនៅជាឈ្លើយ ប៉ុន្តែមានការបង្ហាញតែម្តងគត់នៅក្នុង ៣៣:២១ គឺជាការនៅជាឈ្លើយដោយបានបញ្ជាក់យ៉ាងច្បាស់អំពីការបំបរបង់នេះ (សូមមើល ១:២) ។ *ដើមឆ្នាំ* នៅក្នុងព្រះគម្ពីរភាសារហេព្រើហៅថា រ៉ុសហាសាណា (Rosh Hashanah) ដែលជាពិធីបុណ្យចូលឆ្នាំថ្មីនៃពួកសាសន៍យូដា ។ វាគឺជាពិធីបុណ្យដែលបានកើតឡើងតាំងពីយូរយារណាស់មកហើយ នៅក្នុងរដូវភ្លៀងធ្លាក់(គេប្រារព្ធពិធីនេះ នៅក្នុងខែ កញ្ញា ឬ ខែតុលា ក៏បាន) ។ ប៉ុន្តែ នៅគ្រាព្រះគម្ពីរអេសេគាលទាំងមូល គឺបានប្រើខុសគ្នានិងទំនៀមទម្លាប់នៃសាសនាពីបុរាណនៅក្នុងប្រតិទិន គឺគេប្រារព្ធពិធីនេះឡើនៅរដូវលំហើយ ដូចជាកាលបរិច្ឆេទផ្តល់ឱ្យនៅខាងលើ គឺជាការត្រឹមត្រូវ(សូមមើលការពន្យល់ លវ ២៣:២៤) ។ *ព្រះហស្តនៃព្រះយេហូវ៉ា បានសណ្ឋិតលើខ្ញុំ* សូមមើលការពន្យល់ ១:៣ ។

**៤០:២** *ការជាក់ស្តែងរបស់ព្រះ* មានការបង្ហាញនៅការជាក់ស្តែងសំខាន់បីនៅក្នុងព្រះគម្ពីរអេសេគាល(សូមមើល ១:១ ៨:៣) ។ *លើភ្នំ ១ យ៉ាងខ្ពស់* សំដៅទៅលើភ្នំស៊ីយ៉ូន ហើយភ្នំនេះមានកំពស់ខ្ពស់លើសអស់ទាំងភ្នំ គឺជាភ្នំដ៏អស្ចារ្យដូចដែលបានទទួលការបើកសម្តែង និងទាយទុកជាមុន (១៧:២២ អស ២:២ មីក ៤:១ សក ១៤:១០) ។ កំពស់ខ្ពស់នៅត្រង់នេះមានន័យសំខាន់ គឺទីនោះដូចជាផែនដី ដែលជាទីកន្លែងរបស់ព្រះអម្ចាស់គង់នៅ និងគ្រង រាជ្យ ។ *នៅប៉ែកខាងត្បូង* ជាតំបន់ទីក្រុងដែលស្ថិតនៅទិសខាងត្បូងតាម ជម្រាលភ្នំឆ្ពោះទៅកាន់ទិសខាងជើង(ធៀបនឹង ទដ ៤៨ សូមមើល ទដ ៤៨:២ និងការពន្យល់) ។

**៤០:៣** *ដូចជាលង្ហិន* គឺជាការចង្អុរបង្ហាញពីមនុស្ស ។ *នៅក្នុងទ្វារ* តាមការប៉ាន់ស្មានវាជាទីលានខាងក្រៅ(សូមមើល ខ. ១៧–១៩) ។ *ខ្សែខ្លូតទេស* វាជារង្វាស់វែងដែលបានប្រើសម្រាប់ការវាស់វែងអ្វីមួយ មើលនៅក្នុង ៤៧:៣ ។ *បបុសសំរាប់វាស់* វាជាខ្នាតរង្វាស់ខ្លីជាងខ្សែខ្លូតទេសដែលគេបានប្រើសម្រាប់វាស់វែង ប្រហែលមានប្រវែង ៣ ម៉ែត្រ ។

**៤០:៥** *មានកំផែង នៅព័ទ្ធជុំវិញ ខាងក្រៅនៃព្រះវិហារ* គឺជាការបែងចែកទីសក្ការៈបូជាពីអាណាចក្រនោះ ។ *ប្រវែង ៦ ហត្ថ* លោកហោរាអេសេគាលបានប្រើរង្វាស់ហត្ថវែង ហើយក្នុង១ហត្ថវែង ប្រហែលមានប្រវែង ៥៣.៣៤ សង់ទីម៉ែត្រ ដែលជារង្វាស់ហត្ថពីបុរាណ ។ ហោរាអេសេគាលបានប្រើខ្នាតរង្វាស់ថ្មីនេះនៅក្នុងសហគមន(សូមមើល ២របា ៣:៣) ។

**៤០:៦** *ទ្វារដែលបើកទៅទិសខាងកើត* គឺជាទ្វារទីលានខាងក្រៅ ដែលមានទ្វារបី (ទ្វារខាងកើត ទ្វារខាងជើង និងទ្វារខាងត្បូង) នេះជាទ្វារទីលានខាងក្រៅ គឺប្រហាក់ប្រហែលទៅនិងទ្វារបីដែលស្ថិតនៅទីលានខាងក្នុងដែរ (ខ.៣២) ។ ចំនួន ៦ ហត្ថ គឺជាបន្ទប់យាមតូចៗ( បន្ទប់និមួយៗមានមាត់ទ្វារបី) ហើយនិងមានដំបូលសម្រាប់ជាផ្លូវដើរ (ខ.៨–៩) ដោយប្រៀបធៀបបានទៅនិងគម្រោងទ្វារទាំងឡាយ ដែលនៅតែរកឃើញជាបន្តបន្ទាប់ទៀតនៅឯស្រុកមេគីដោ ក្រុងកេស៊ើរ និង ក្រុងហាសោរ នៅគ្រាស្តេចសាឡូម៉ូន (សូមមើល ១ពវ ៩:១៥) ។ សន្តិសុខទាំងឡាយនោះ បានហាមឃាត់មិន

វាស់ទទឹង មាត់ទ្វារបាន១ខ្នាត ហើយទទឹង១ទៀតក៏បាន
១ខ្នាតដូចគ្នា [៧]គ្រប់ទាំងបន្ទប់[ឋ] មានបណ្ដោយ១ខ្នាត និង
ទទឹង១ខ្នាត ឯប្រឡោះកណ្ដាលបន្ទប់ទាំងនោះ មាន៥ហត្ថ
ហើយមាត់ទ្វារបាំងសាចនៃទ្វារខាងក្នុង ក៏១ខ្នាតដែរ
[៨]លោកក៏វាស់បាំងសាច់ទ្វារខាងក្នុងបាន១ខ្នាត [៩]រួចលោក
វាស់បាំង សាច់បាន៨ហត្ថ ហើយសសរបាំងសាចនោះបាន
២ហត្ថ ឯបាំងសាចនៃទ្វារកំផែងនោះនៅខាងក្នុង [១០]បន្ទប់
ទាំងប៉ុន្មានរបស់ទ្វារខាងកើតនោះ មាន៣ខាងនេះ ហើយ
៣ខាងនោះ គ្រប់ទាំង៣មានទំហំដូចគ្នា ហើយសសរខាង
នេះ និងនៅខាងនោះ ក៏មានទំហំដូចគ្នា ដែរ [១១]លោកក៏
វាស់ទទឹងនៃផ្លូវចូលតាមទ្វារ កំផែងបាន ១០ហត្ថ ហើយ
បណ្ដោយបាន ១៣ហត្ថ [១២]ក៏មានរបង១ហត្ថ នៅពីមុខបន្ទប់
នីមួយៗ ទាំងខាងនេះនឹងខាងនោះផង បន្ទប់ទាំងនោះ
មានទំហំ៦ហត្ថ៤ជ្រុងស្មើ [១៣]លោកក៏វាស់ ទ្វារពីដំបូល
បន្ទប់១ ដល់ដំបូលបន្ទប់ម្ខាង បានទទឹង២៥ ហត្ថ មានទ្វារ
ទល់មុខនឹងទ្វារ [១៤]លោកក៏ធ្វើសសរបាន ៦០ហត្ថ ហើយ
ទីលានក៏ត្រឹមសសរទាំងនោះ នៅព័ទ្ធជុំ វិញទ្វារកំផែង[ឌ]
[១៥]ចាប់តាំងពីមុខទ្វារកំផែងត្រង់ផ្លូវចូល រហូតដល់មុខ
បាំង សាចខាងក្នុងនៃទ្វារ នោះបាន៥០ហត្ថ [១៦]បន្ទប់ទាំង
នោះមានបង្អួចបិទព្រមទាំងនៅសសរខាងក្នុងទ្វារកំផែង
ព័ទ្ធ ជុំវិញ ហើយនៅក្នុងខ្លោងទ្វារផងមានបង្អួចនៅព័ទ្ធ
ជុំវិញ ខាងក្នុង ហើយនៅសសរនីមួយៗ មានឆ្លាក់ ជាដើម
លម៉ើ[ឍ]។

## ទីលានខាងក្រៅ

[១៧]រួចលោកនាំខ្ញុំទៅឯទីលានខាងក្រៅ[ណ] នោះឃើញ
មានបន្ទប់ ហើយកំរាលថ្មដែលធ្វើសំរាប់ទីលាននៅជុំវិញ
គឺមានបន្ទប់[ត]៣០ នៅលើកំរាលថ្មនោះ[ថ] [១៨]កំរាលថ្មនោះ
ក៏នៅក្បែរទ្វារ ត្រូវនឹងប្រវែងទ្វារ នោះជាកំរាលថ្មជាន់
ក្រោម [១៩]រួចលោកវាស់ទទឹងទីលានពីខាងក្រៅ ចាប់
តាំងពីមុខទ្វារកំផែងខាងក្រោម រហូតដល់មុខទីលានខាង
ក្នុង[ទ] បាន១០០ហត្ថ[ធ] ទាំងខាងកើតនឹងខាងជើងផង ។

## ទ្វារខាងជើង

[២០]លោកក៏វាស់បណ្ដោយ និងទទឹងនៃទ្វារកំផែងរបស់
ទីលានខាងក្រៅ ដែលបើកទៅខាងជើង [២១]ហើយមាន
បន្ទប់[ន]៣ខាងនេះ និង៣ខាងនោះដែរ ឯសសរនិងខ្លោង
ទ្វារ[ប]នោះ ក៏មានទំហំត្រូវគ្នានឹងទ្វារទី១ គឺបណ្ដោយ៥០
ហត្ថ ទទឹង២៥ហ្ថ [២២]អស់ទាំងបង្អួច និងខ្លោងទ្វារ[ផ] ហើយ
ក្បាច់ដើមលម៉ើ ក៏មានទំហំដូចជាទ្វារកំផែង ដែលបើក
ទៅទិសខាងកើត មានជណ្ដើរ៧ថ្នាក់ឡើងទៅ ដល់ទ្វារ
នោះ រួចមានខ្លោងទ្វារពីមុខដែរ[ព] [២៣]ក៏មានទ្វារចូលទៅ
ក្នុងទីលានខាងក្នុង ដែលប្រទល់មុខនឹងទ្វារនោះ ទាំងខាង
ជើង និងខាងកើតផង រួចលោកវាស់ពីទ្វារ១ ទៅទ្វារ១
ទៀតបាន១០០ហត្ថ[ភ]។

## ទ្វារខាងត្បូង

[២៤]លោកក៏នាំខ្ញុំទៅខាងត្បូង នោះឃើញមានទ្វារ១
ដែលបើកទៅទិសខាងត្បូងដែរ លោកវាស់សសរ និង
ខ្លោងទ្វារទាំងនោះ ក៏ត្រូវនឹងទំហំ[ម]ទាំងនោះ [២៥]ក៏មាន
បង្អួចនៅទីនោះ ហើយនៅខ្លោងទ្វារទ័ទ្ធជុំវិញ ដូចជាបង្អួច
ពីមុន ទ្វារនោះបណ្ដោយបាន៥០ហត្ថ ហើយទទឹង[យ]២៥ហត្ថ
[២៦]ក៏មានជណ្ដើរ៧ថ្នាក់ឡើងទៅដល់ទ្វារ និងខ្លោងទ្វារពី
មុខនោះដែរ នៅសសរទាំងសងខាង មានក្បាច់ដើមលម៉ើ
១ខាងនេះ ហើយ១ខាងនោះ[រ] [២៧]ក៏មានទ្វារ១បើកទៅក្នុង
ទីលានខាងក្នុង[ល] ដែលនៅទិសខាងត្បូង ហើយលោកវាស់
ពីទ្វារកំផែង១ទៅដល់ទ្វារកំផែង១ទៀត ខាងត្បូងនោះ

**៤០:៧** ថ ខ.៣៦
**៤០:១៤** ឌ នក ២៧:៩
**៤០:១៦** ឍ ខ.២១-២២ ២រប ៣:៥ អគ ៤១:២៦
**៤០:១៧** ណ វវ ១១:២ ត អគ ៤១:៦ ថ អគ ៤២:១
**៤០:១៩** ទ អគ ៤៦:១ ធ ខ.២៣,២៧
**៤០:២១** ន ខ.៧ ប ខ.៣០
**៤០:២២** ផ ខ.៤៩ ព ខ.១៦,២៦
**៤០:២៣** ភ ខ.១៩
**៤០:២៤** ម ខ.៣២,៣៥
**៤០:២៥** យ ខ.៣៣
**៤០:២៦** រ ខ.២២
**៤០:២៧** ល ខ.៣២

អនុញ្ញាតឱ្យមនុស្សគ្រប់គ្នាអាចចូលទៅ ក្នុងប្រឡោះទៅកាន់តំបន់នៃព្រះវិហារនោះបានឡើយ(សូមមើល អរ ២:២៦) ។ *ឡើងជណ្ដើរទ្វារនោះ* គឺជាជណ្ដើរបីថ្នាក់ដំបូងឆ្ពោះទៅកាន់ព្រះវិហារ ជណ្ដើរទីមួយមាន ប្រាំពីថ្នាក់ (ខ.២២) និងជណ្ដើរបន្ទាប់មួយទៀត (ទៅកាន់ទីលានខាងក្នុង) មានប្រាំបីជាន់(ខ.៣១) ហើយនិងជណ្ដើរទៅកាន់(ព្រះវិហារ) ចុង ក្រោយបង្អស់មានដប់ថ្នាក់ (ខ.៤៩ សូមមើលការពន្យល់) ។

**៤០:៩** *បាំងសាចនៃទ្វារកំផែងនោះនៅខាងក្នុង* ជាទីតាំងខាងក្រោយនៃបាំងសាចទ្វារទីលានខាងក្នុង ដែលស្ថិតនៅប្រទល់មុខផ្លូវនៃព្រះវិហារ (ខ.៣៤) ។

**៤០:១០** *មាន៣ខាងនេះ* ជាបន្ទប់តូចៗសម្រាប់អ្នកយាម ដែលមានចែងនៅក្នុង ខ.៧ ។

**៤០:១៦** *ដើមលម៉ើ* ដូចជានៅក្នុងព្រះវិហាររបស់ស្ដេចសាឡូម៉ូន(សូមមើល ១ពវ ៦:២៩ និងការពន្យល់ ៣២,៣៥) ។

**៤០:១៧** *មានបន្ទប់៣០* ទីកន្លែងពិតប្រាកដនៃបន្ទប់ទាំងអស់នេះ គឺមិនត្រូវបានគេផ្ដល់ឱ្យប្រើប្រាស់ទេ ។ ប្រហែលជាពួកគេបានបម្រុងទុកនៅបន្ទប់ទាំង ឡាយនេះសម្រាប់ឱ្យមនុស្សប្រើប្រាស់ (សូមមើល យរ ៣៥:២ និងការពន្យល់ ខ.៤) ។

**៤០:១៩** *១០០ហត្ថ* ប្រហែលជាមានប្រវែង ៥១ម៉ែត្រ (សូមមើលការពន្យល់ ខ.៥) ដែលបានបំបែកគ្នាពីជញ្ជាំងខាងក្រៅ ទៅជញ្ជាំងខាងក្នុង គឺស្ថិតនៅទទឹងនៃទីលានខាងក្នុង ។

**៤០:២០** *បែកទៅទិសខាងជើង* ទ្វារទាំងពីរនេះ គឺបែរទៅរកទ្វារនៅទិសខាងត្បូង (ខ.១៤) ទ្វារនេះមានសណ្ឋានដូចគ្នាបេះបិទ និងទ្វារដែលស្ថិតនៅទិសខាងកើត(សូមមើលការពន្យល់នៅ ខ.៦) ។

**៤០:២២** *ជណ្ដើរ៧ថ្នាក់* សូមមើលការពន្យល់ ខ.៦ ។

បាន១០០ហត្ថ[វ] ។

## ទ្វារចូលទៅក្នុងទីលានខាងក្នុង

២៨ រួចលោកនាំខ្ញុំទៅដល់ទីលានខាងក្នុង ក្បែរទ្វារ
កំផែងខាងត្បូង លោកវាស់ទ្វារខាងត្បូង ក៏ត្រូវនឹងទំហំ[ស]
ទាំងនោះ ២៩ ឯបន្ទប់[ហ]ទាំងប៉ុន្មាន និងសសរ ហើយខ្លោង
ទ្វារ នោះមានទំហំដូចគ្នាដែរ មានបង្អួចនៅទីនោះ ហើយ
នៅខ្លោងទ្វារព័ទ្ធជុំវិញ ទ្វារនោះក៏បណ្តោយ៥០ហត្ថ និង
ទទឹង២៥ហត្ថដូចគ្នា[ឡ] ៣០ ហើយមានខ្លោងទ្វារ[អ]នៅជុំវិញ
បណ្តោយ២៥ហត្ថ និងទទឹង៥ហត្ថ ៣១ ខ្លោងទ្វារ[ក]ទាំង
នោះក៏បែរទៅខាងទីលានខាងក្រៅ ហើយមានក្បាច់ដើម
លម៉ើ នៅសសរទាំងប៉ុន្មាន ឯជណ្តើរឡើងទៅឯទ្វារនោះ
មាន៨ថ្នាក់វិញ[ខ] ។

៣២ បន្ទាប់មកលោកនាំខ្ញុំទៅឯទីលានខាងក្នុង ដែល
នៅទិសខាកើត លោកក៏វាស់[គ]ទ្វារនោះមានទំហំត្រូវគ្នាដែរ
៣៣ ឯបន្ទប់[ឃ]ទាំងប៉ុន្មាន និងសសរ ហើយខ្លោងទ្វារ ក៏ត្រូវ
តាមទំហំទាំងនោះទៀត មានទាំងបង្អួចនៅទីនោះ ហើយ
នៅខ្លោងទ្វារព័ទ្ធជុំវិញ ទ្វារនោះក៏មានបណ្តោយ៥០ហត្ថ
ទទឹង២៥ហត្ថ ៣៤ ឯខ្លោងទ្វារ[ង]ក៏បែរទៅឯទីលានខាងក្រៅ
មានក្បាច់ដើមលម៉ើ នៅសសរសងខាង ខាងឯជណ្តើរ
ដែលឡើងទៅ ឯទ្វារនោះមាន៨ថ្នាក់ដែរ ។

៣៥ រួចលោកនាំខ្ញុំទៅឯទ្វារទិសខាងជើង[ច] ក៏វាស់ទ្វារ
នោះ មានទំហំ[ឆ]ត្រូវគ្នាដែរ ៣៦ បន្ទប់[ជ]ទាំងប៉ុន្មាន និងសសរ
ហើយខ្លោងទ្វារផង ក៏មានបង្អួចនៅជុំវិញ ទ្វារនោះ
បណ្តោយ៥០ហត្ថ ទទឹង២៥ហត្ថដូចគ្នា ៣៧ សសរ[ឈ]ទាំង
ប៉ុន្មានក៏បែរទៅឯទីលានខាងក្រៅ ហើយមានក្បាច់ដើម
លម៉ើលទាំងសងខាង ឯជណ្តើរដែលឡើងទៅឯទ្វារនោះ
ក៏មាន៨ថ្នាក់ដែរ[ញ] ។

**៤០:២៧** វ ខ.១៩
**៤០:២៨** ស ខ.៣៥
**៤០:២៩** ហ ខ.៧
ឡ ខ.២៥
**៤០:៣០** អ ខ.២១
**៤០:៣១** ក ខ.២២
ខ ខ.៣៤,៣៧
**៤០:៣២** គ ខ.២៤
**៤០:៣៣** ឃ ខ.៧
**៤០:៣៤** ង ខ.២២
**៤០:៣៥** ច អក ៤៤:៤ ៤៧:២
ឆ ខ.២៤
**៤០:៣៦** ជ ខ.៧
**៤០:៣៧** ឈ ខ.២២
ញ ខ.៣៤
**៤០:៣៨** ដ ២របា ៤:៦ អក ៤២:១៣
**៤០:៣៩** ឋ អក ៤៦:២ ឌ លវ ៤:៣,២៨ ឍ លវ ៧:១ ណ ខ.៤២
**៤០:៤២** ត នក ២០:២៥ ថ ខ.៣៩
**៤០:៤៥** ទ ១របា ៩:២៣
**៤០:៤៦** ធ អក ៤២:១៣ ន ជន ១៨:៥ ប ២សយ ៨:១៧ អរ ៧:២ ផ ជន ១៦:៥ អក ៤៣:១៩ ៤៤:១៥ ៤៥:៤ ៤៨:១១

## បន្ទប់សម្រាប់រៀបចំយញ្ញបូជា

៣៨ មានបន្ទប់១ ដែលមានទ្វារក្បែរសសរ នៅត្រង់ទ្វារ
កំផែង គឺជាទីនោះដែលគេលាងដង្វាយដុត[ដ] ៣៩ ហើយ
នៅបាំងសាចនៃទ្វារកំផែង មានតុ២នៅខាងនេះហើយ
២ខាងនោះ សំរាប់នឹងសំឡាប់ដង្វាយដុត[ឋ] យញ្ញបូជាលោះ
បាប[ឌ] និងយញ្ញបូជា[ឍ] ដែលថ្វាយដោយព្រោះការរំលង[ណ]
៤០ ឯខាងក្រៅ ដែលឡើងទៅឯផ្លូវចូលទ្វារកំផែងទិសខាង
ជើង នោះមានតុ២ម្ខាង ហើយ២ម្ខាងទៀតរបស់បាំង
សាចនៃទ្វារកំផែងនោះ ៤១ មានតុ៤ខាងនេះ ហើយ៤ខាង
នោះ ដែលនៅខាងៗនៃទ្វារកំផែង គឺទាំងអស់មានតុ៨
សំរាប់នឹងសំឡាប់យញ្ញបូជា ៤២ ក៏មានតុ៤ដាប់ពីថ្ម[ត] ប្រវែង
១ហត្ថកន្លះ ទទឹង១ហត្ថកន្លះ ហើយកំពស់១ហត្ថ សំរាប់
ដង្វាយដុត និងយញ្ញបូជានោះ[ថ] ៤៣ ហើយមានទំពក់ប្រវែង
១ទះ ភ្ជាប់នឹងជញ្ជាំងវិញ ឯសាច់នៃដង្វាយក៏នៅលើតុទាំង
នោះ ។

## បន្ទប់សម្រាប់ពួកសង្ឃ

៤៤ នៅខាងក្រៅនៃទ្វារខាងក្នុង នោះមានបន្ទប់សំរាប់
ពួកចំរៀង នៅក្នុងទីលានខាងក្នុង ដែលនៅត្រង់ទ្វារទិស
ខាងជើង ឯបន្ទប់ទាំងនោះបើកទៅខាងត្បូង ហើយមាន
១ទៀត នៅត្រង់ទ្វារខាងកើត ដែលបើកទៅទិសខាង
ជើង ៤៥ លោកក៏ប្រាប់ខ្ញុំថា បន្ទប់១នេះដែលបើកទៅខាង
ត្បូងនោះសំរាប់ពួកសង្ឃ ដែលរក្សាបញ្ញើនៃព្រះវិហារ[ទ]
៤៦ ហើយបន្ទប់១ដែលបើកទៅខាងជើង[ធ] នោះសំរាប់ពួក
សង្ឃដែលរក្សាបញ្ញើនៃអាសនា[ន] ឯពួកទាំងនោះ គឺជាកូន
ចៅរបស់សាដុក[ប] ក្នុងពួកកូនចៅលេវី ដែលចូលទៅជិត
ព្រះយេហូវ៉ា ដើម្បីធ្វើការងារថ្វាយទ្រង់[ផ] ៤៧ លោកក៏វាស់
ទីលានបានប្រវែង១០០ហត្ថ ទទឹង១០០ហត្ថ ៤ជ្រុងស្មើ

**៤០:២៨** *កំផែងខាងត្បូង* ជាជញ្ជាំងនៃផ្នែកខាងក្នុង ដែលមិនមានការរៀបរាប់អំពីវាឱ្យបានច្បាស់លាស់ឡើយ ប៉ុន្តែវាត្រូវតែបានទទួលនូវការកាន់កាប់ នៃកំផែងនោះ ។ វាបានដូចជារង្វាស់ខ្នាតផ្សេងៗទៀត នៅក្នុងជញ្ជាំងនៃផ្នែកខាងក្រៅទាំងពីរនោះ (សូមមើលការពន្យល់ ខ.៦) ។

**៤០:៣៤** *មាន៨ថ្នាក់* សូមមើលការពន្យល់ ខ. ៦ ។

**៤០:៣៨** *មានទ្វារក្បែរសសរ នៅត្រង់ទ្វារកំផែង* វាជាដំបូលផ្លូវដើរនៅត្រង់ទ្វារកំផែង គឺនៅជ្រុងខាងក្រៅទីលានទល់មុខនិងផ្លូវទៅកាន់ព្រះវិហារ ។ *លាង* គឺជាការលាងសម្អាតនៅអាការៈខាងក្នុង និងជើងទាំងប៉ុន្មាននោះត្រូវលាងសម្អាតនិងទឹក រួចហើយត្រូវយកវាដាក់ដុតនៅលើអាសនា ដើម្បីទុកជាដង្វាយដុតថ្វាយដល់ព្រះយេហូវ៉ា (លវ ១: ៩) ។

**៤០:៣៩** *ដង្វាយដុត* វាប្រហែលជាពិធីមួយប្រភេទដែលមានតាំងពីសម័យបុរាណមកម្ល៉េះ ចំពោះការថ្វាយដង្វាយដុតទុកជាយញ្ញបូជាថ្វាយដល់ព្រះ ។ នៅក្នុងពិធីដង្វាយដុត គឺពួកសង្ឃតែងតែយកសត្វទាំងមូលទៅដុតនៅលើអាសនា ដើម្បីទុកជាដង្វាយថ្វាយដល់ព្រះ (សូមមើលការពន្យល់ លវ ១:៣) ។
*យញ្ញបូជាលោះបាប និងយញ្ញបូជា* បាននិយាយនៅក្នុង លវ ៤–៧ (មើលការពន្យល់នៅក្នុងវគ្គនេះ) ។ គឺជាដង្វាយមេត្រីភាពដែលបានប្រារព្ធធ្វើឡើងយ៉ាងអឺកធឹកដ៏សម្បើម ដោយពួកគេបានអវត្តមាននៅក្នុងបញ្ជីនេះ (សូមមើល ៤៣:២៧ ៤៥:១៧ ៤៦:២,១២) ។

**៤០:៤៦** *កូនចៅរបស់សាដុក* មានការបែងចែកខុសគ្នារវាងកូនចៅរបស់សាដុក និងកូនចៅរបស់ពួកលេវី សូមមើលការការនិយាយទាំងស្រុងនៅក្នុងការពន្យល់ ៤៤:១៥–៣១ ។

**៤០:៤៧** *អាសនា* បាននិយាយនៅក្នុង ៤៣:១៣–១៧ (សូមមើលការពន្យល់នៅក្នុងវគ្គនេះ) ។

ហើយអាសនានៅពីមុខព្រះវិហារ[ព]។

## ព្រះវិហារ

48រួចលោកនាំខ្ញុំទៅឯបាំងសាចនៃព្រះវិហារ[ភ] លោក
វាស់សសរបាំងសាចនោះ បាន៥ហត្ថខាងលើនេះ និង៥
ហត្ថខាងនោះ ហើយទទឹងទ្វារនោះបាន៥ហត្ថខាងនេះ
និង៣ហត្ថខាងនោះ 49ប្រវែងរបស់បាំងសាច[ម]នោះ មាន
២០ហត្ថ និងទទឹង១១ហត្ថ ហើយគេឡើងទៅឯបាំងសាច
នោះ ដោយថ្នាក់ជណ្ដើរ ក៏មានបង្គោល[យ]នៅក្បែរសសរ
ទាំងនោះ ១ខាងនេះ ហើយ១ខាងនោះ ។

**៤១** 1រួចលោក នាំខ្ញុំទៅឯព្រះវិហារ[ក] ក៏វាស់សសរ
បានទទឹង៦ហត្ថខាងនេះ ហើយ៦ហត្ថខាងនោះ ដែល
ស្មើនឹងទទឹងរោងឧបោសថ 2ហើយផ្លូវចូល នោះទទឹង
១០ហត្ថ ឯផ្ទាំងទ្វារម្ខាង នោះ៥ហត្ថ ហើយម្ខាងទៀត
ក៏៥ហត្ថ ឯបណ្ដោយព្រះវិហារ លោកវាស់បាន៤០ហត្ថ
ហើយទទឹង២០ហត្ថ[ខ] 3រួចលោកក៏ចូលទៅខាងក្នុង វាស់
ក្របទ្វារទាំងសងខាងបាន២ហត្ថ 4លោកវាស់បណ្ដោយទី
នោះបាន២០ហត្ថ ហើយទទឹងបាន២០ហត្ថ នៅខាងមុខ
ព្រះវិហារ[គ] រួចលោកប្រាប់មកខ្ញុំថា ទីនេះជាទីបរិសុទ្ធ
បំផុត[ឃ]។

5រួចមកលោកវាស់ជញ្ជាំងនៃព្រះវិហារ មាន៦ហត្ថ
ហើយទទឹងគ្រប់ទាំងបន្ទប់ នៅខាងជុំវិញព្រះវិហារ នោះ
បាន៤ហត្ថគ្រប់ទាំងអស់ 6បន្ទប់ទាំងនោះមាន៣ជាន់ គឺ
បន្ទប់១នៅលើ១ទៀត ទាំងអស់មាន៣០[ង]បន្ទប់ ក៏តជាប់ពី
ជញ្ជាំងព្រះវិហារ សំរាប់ជាបន្ទប់នៅព័ទ្ធជុំវិញដើម្បីឱ្យ
បានជាប់នឹងជញ្ជាំងនោះ តែមិនឱ្យស៊កចូលទៅក្នុងជញ្ជាំង
ព្រះវិហារទេ[ច] 7ហើយបន្ទប់ទាំងនោះបានកាន់តែធំជា
លំដាប់ តាមដែលឡើងខ្ពស់ទៅព័ទ្ធជុំវិញព្រះវិហារ ដ្បិត
ផ្លូវដែលព័ទ្ធជុំវិញព្រះវិហារ បានឡើងកាន់តែខ្ពស់ទៅ តែ
ទទឹងព្រះវិហារនៅដូចគ្នាទៅខាងលើ ហេតុនោះ បន្ទប់
បានកាន់តែធំទូលាយទៅខាងលើយ៉ាងនោះ ចេញពី[ឆ]បន្ទប់
ជាន់ក្រោមឡើង ទៅឯបន្ទប់ជាន់លើ ដោយផ្លូវកណ្ដាល
8ខ្ញុំក៏ពិចារណាមើលកំពស់ព្រះវិហារនៅព័ទ្ធជុំវិញ ឃើញ
ថា ជើងជញ្ជាំងបន្ទប់ទាំងនោះបានខ្ពស់ពេញ១ខ្នាតបបុស
គឺ៦ហត្ថធំ 9ឯកំរាស់នៃជញ្ជាំងខាងក្រៅរបស់បន្ទប់ទាំង
នោះ បាន៥ហត្ថ ហើយប្រឡោះដែលសល់ នោះសំរាប់
បន្ទប់ខាងៗរបស់ព្រះវិហារ 10ហើយនៅកណ្ដាលបន្ទប់
ទាំងនោះ មានប្រឡោះទទឹង២០ហត្ថនៅព័ទ្ធជុំវិញព្រះ
វិហារ 11ឯទ្វារនៃបន្ទប់ទាំងនោះ ក៏បើកទៅខាងកន្លែង
ដែលសល់នោះ គឺមានទ្វារ១បើកទៅខាងជើង ហើយ១
ទៀតបើកទៅខាងត្បូង ហើយមានប្រឡោះសល់នៅព័ទ្ធ
ជុំវិញទទឹង៥ហត្ថ ។

12ឯមន្ទីរដែលនៅខាងមុខទីលានទទេ គឺនៅខាងលិច
នោះទទឹង៧០ហត្ថ បណ្ដោយ៩០ហត្ថ ហើយជញ្ជាំងមន្ទីរ
នៅព័ទ្ធជុំវិញ មានកំពស់៥ហត្ថ 13ដូច្នេះ លោកក៏វាស់ព្រះ
វិហារបាន១០០ហត្ថ ហើយទីលានទទេ និងមន្ទីរនោះ
ព្រមទាំងជញ្ជាំងផង នោះមានបណ្ដោយ១០០ហត្ថ 14ឯ
ទទឹងខាងមុខព្រះវិហារ និងទីលានទទេ នៅខាងកើត
នោះក៏មាន១០០ហត្ថ[ជ]។

15លោកក៏វាស់ប្រវែងនៃមន្ទីរ នៅមុខទីលានទទេ
ដែលនៅខាងក្រោយនោះ ព្រមទាំងរានហាលទាំងសង
ខាងបាន១០០ហត្ថ ហើយទាំងព្រះវិហារខាងក្នុង និងបាំង
សាច[ឈ]នៃទីលានផង 16អស់ទាំងទ្វារនឹងបង្អួច[ញ]បិទ ហើយ

**៤០:៤៧** ព អក ៤១:១៣-១៤
**៤០:៤៨** ភ ១ពវ ៦:២
**៤០:៤៩** ម ខ.២២ ១ពវ ៦:៣ យ ១ពវ ៧:១៥
**៤១:១** ក ខ.២៣
**៤១:២** ខ ២រប ៣:៣
**៤១:៤** គ ១ពវ ៦:២០ ឃ អក ២៦:៣៣ ហព ៩:៣-៨
**៤១:៦** ង អក ៤០:១៧ ច ១ពវ ៦:៦
**៤១:៧** ឆ ១ពវ ៦:៨
**៤១:១៤** ជ អក ៤០:៤៧
**៤១:១៥** ឈ អក ៤២:៣
**៤១:១៦** ញ ១ពវ ៦:៤

**៤០:៤៨-៤២:២០** ខគម្ពីរទាំងនេះ គឺជាការរៀបរាប់អំពីព្រះវិហារថ្មី ។

**៤០:៤៨** *សសរបាំងសាច* សសរទាំងនេះប្រហាក់ប្រហែលនិង សសរបាំងសាចនៅក្នុងព្រះវិហារនៃស្តេចសាឡូម៉ូនដែរ ប៉ុន្តែ វាមានទំហំក្រាស់ជាងបន្តិច(សូមមើល ១ពវ ៦:៣) ។

**៤០:៤៩** *បង្គោល* ត្រូវបានគេហៅថា យ៉ាគីន (Jakin) និង (Boaz) ដែលមាននៅក្នុងព្រះវិហារនៃជំនាន់ស្តេចសាឡូម៉ូន(សូមមើល ១ពវ ៧:២១) ។

**៤១:១** *រោងឧបោសថ* នៅចំកណ្តាលព្រះវិហារ មានបន្ទប់៣ធំៗនៅក្នុងព្រះវិហារ (សូមមើល ១ពវ ៦:៣-៥ ដែលទីកន្លែងហៅថា សាលប្រជុំយ៉ាងសំខាន់) ។ *រោងឧបោសថ* គឺមានលក្ខណៈដូចជាដំណាក់របស់ស្តេចសាឡូមូន (មើល ១ពវ ៦:១៧)។

**៤១:៣** *រួចលោកក៏ចូលទៅខាងក្នុង* មានតែទេវតាមួយគតដែលអាចចូលទៅទីកន្លែងនោះបាន លោកអេសេគាលមិនអាចចូលទៅទីកន្លែងបរិសុទ្ធបំផុតបានឡើយ (លវ ១៦) ជាកន្លែងដែលហាមប្រាមសម្រាប់អ្នកផ្សេង ប៉ុន្តែលើកលែងតែសម្តេចសង្ឃមួយប៉ុណ្ណោះ ដែលអាចចូលទៅទីនោះបានក្នុងរយៈពេល១ឆ្នាំម្តង (មើល ហព ៩:៧ និងការពន្យល់)។ ផ្លូវចូលក៏៦ហត្ថ សូមកត់ចំណាំថា ផ្លូវចូលតាមទ្វារដែលបើកចំហរ គឺតូចចង្អៀត ចូលទៅដល់ទីកន្លែងរោងឧបោសថនោះ (៤០:៤៨ មាន១៤ហត្ថ ៤១:២ មាន១០ហត្ថ ហើយនៅទីនេះមាន ៦ហត្ថ) ។

**៤១:៤** *ទីនេះជាទីបរិសុទ្ធបំផុត* (មើលការពន្យល់ នក ២៦:៣១-៣៥ ២៧:១២-១៣ ១ពវ ៦:២ ២៣ ២រប ៣:៨ អរ ៦:១៥ ទដ ២៨:២ មថ ២៧:៥១ ហព ៨:២ ១០:១៩-២០) ។

**៤១:៦** *ទាំងអស់មាន៣០បន្ទប់* បន្ទប់ទាំង៩០នេះ ប្រហែលជាបន្ទប់សម្រាប់ដាក់តង្វាយរបស់សង្ឃ អាចជាទីកន្លែងសម្រាប់ដាក់ដង្វាយ (មើល មឡ ៣:១០ និង ការពន្យល់) ។

**៤១:១៣** *វាស់បាន១០០ហត្ថ* មានកំពស់សមមាត្រ១០០ហត្ថ គឺល្អឥតខ្ចោះ ។

**៤១១៦** *បានស្រោបឈើនៅជុំវិញ* ដូចជាដំណាក់របស់ស្តេចសាឡូម៉ូន ។

រានហាលនៅជុំវិញទាំង៣ជាន់ ដែលប្រទល់មុខនឹងមាត់
ទ្វារ បានស្រោបដោយឈើនៅជុំវិញ ចាប់តាំងពីដីឡើង
ទៅដល់បង្អួច(រីឯបង្អួចទាំងនោះ សុទ្ធតែគ្របបិទ)[ដ] ១៧ទៅ
ដល់ខាងលើទ្វារ រហូតដល់ក្នុងព្រះវិហារ ហើយខាងក្រៅ
ព្រមទាំងកំផែងនៅជុំវិញ ទាំងក្នុង ទាំងក្រៅ ក៏ធ្វើតាម
ទំហំផង ១៨នោះសុទ្ធតែធ្វើដោយមានក្បាច់[ឋ] ជាចេរូប៊ីន[ឌ]
និងដើមលម៉ើ[ឍ] មានដើមលម៉ើ១ នៅជាកណ្ដាល ចេរូប៊ីន
និងចេរូប៊ីន ហើយចេរូប៊ីនទាំងនោះសុទ្ធ តែមានមុខ២
រៀងខ្លួន[ណ] ១៩បានជាមានមុខមនុស្សបែរទៅ ខាងដើម
លម៉ើម្ខាង ហើយមុខសិង្ហស្ទាវបែរទៅខាងដើម លម៉ើ
ម្ខាងទៀត គឺបានធ្វើយ៉ាងនោះក្នុងព្រះវិហារនៅព័ទ្ធជុំវិញ[ត]
២០គេបាន ធ្វើចេរូប៊ីននឹងដើមលម៉ើចាប់តាំងពីដីរហូត
ទៅដល់ខាង លើទ្វារជញ្ជាំងរបស់ព្រះវិហារបានធ្វើយ៉ាង
នោះ ។

២១ឯក្របទ្វារនៃព្រះវិហារ[ថ] មាន៤ជ្រុងស្មើ ហើយ
ខាងមុខនៃទីបរិសុទ្ធ មានសណ្ឋានមើលទៅដូចជា ២២ឯ
អាសនា[ទ]បានធ្វើពីឈើ កំពស់៣ហត្ថ ប្រវែង២ហត្ថ ឯ
ជ្រុងនិងបណ្ដោយ ហើយខាងៗអាសនានោះ សុទ្ធតែជា
ឈើទាំងអស់ ហើយលោកនិយាយមកខ្ញុំថា នេះជាតុ[ធ]ដែល
នៅចំពោះព្រះយេហូវ៉ា ២៣ឯព្រះវិហារ[ន] និងទីបរិសុទ្ធ
មានទ្វារ២[ប] ២៤ចំណែកទ្វារទាំងនោះមាន២ផ្ទាំង[ផ]ហើយ
ទ្វារ ១ទៀតក៏មាន២ផ្ទាំងដែរ ២៥នៅផ្ទាំងទ្វារទាំងនោះ គឺ
ជាទ្វារនៃព្រះវិហារ មានឆ្លាក់ជារូបប៊ីន នឹងដើមលម៉ើ ដូច
ជាបានធ្វើនៅជញ្ជាំងដែរ ហើយនៅបាំងសាចខាងក្រៅ
មានក្រាលក្តារ ២៦ក៏មានបង្អួចបិទនឹងក្បាច់ជាដើមលម៉ើ
ទាំងសងខាងបាំងសាច អស់ទាំងបន្ទប់ខាងៗនៃព្រះវិហារ
និងកំរាលក្តារក៏យ៉ាងនោះទាំងអស់[ព] ។

## បន្ទប់សម្រាប់ពួកសង្ឃ

៤២ ១រួចលោកក៏នាំខ្ញុំ ចេញទៅឯទីលានខាងក្រៅ តាម
ផ្លូវទៅឯទិសខាងជើង លោកនាំខ្ញុំទៅបន្ទប់[ក]ដែលនៅមុខ
ទីលាន[ខ]ទទេ ដែលនៅខាងជើងប្រទល់មុខនឹងមន្ទីរ[គ] ២ខាង
មុខនោះ ជាកន្លែងមានទ្វារខាងជើង នោះប្រវែង ១០០
ហត្ថ ទទឹង៥០ហត្ថ ៣ប្រទល់នឹងទីលានខាងក្នុង ដែលវាស់
បាន២០ហត្ថ ហើយទល់មុខនឹងកំរាលថ្មនៅទីលានខាង
ក្រៅ នោះមានរានហាល[ឃ]៣ជាន់[ង] ៤នៅពីមុខបន្ទប់ទាំង
ប៉ុន្មាន នោះមានទីដើរ ទទឹង១០ហត្ថខាងក្នុង ក៏មានផ្លូវ១
ហត្ថចូលតាមទ្វារបន្ទប់ទាំងនោះ ដែលបើកទៅទិសខាង
ជើង[ច] ៥រីឯបន្ទប់ខាងលើសុទ្ធតែខ្លីជាង ពីព្រោះរានហាល
កាត់ចេញពីបន្ទប់ទាំងនោះ ជាជាងបន្ទប់ ជាន់ក្រោម និង
បន្ទប់ជាន់កណ្ដាលនៃមន្ទីរនោះ ៦ដ្បិត មាន៣ជាន់ តែឥត
មានសសរ ដូចជាសសរទីលានទេ ហេតុនោះបានជាជាន់
លើត្រូវចង្អៀតជាងជាន់ក្រោម និងជាន់កណ្ដាល រាប់ពីដី
ឡើង ៧ឯជញ្ជាំងខាងក្រៅ ដែលទល់មុខនឹងបន្ទប់ទាំងនោះ
ខាងឯទីលានខាងក្រៅ ពីមុខបន្ទប់ នោះបណ្ដោយ៥០ ហត្ថ
៨ដ្បិតបន្ទប់ទាំងនោះ ដែលនៅទីលានខាងក្រៅ មាន
បណ្ដោយ៥០ហត្ថ ហើយមើល នៅមុខព្រះវិហារនោះមាន
១០០ហត្ថ ៩ហើយនៅក្រោមបន្ទប់ទាំងនោះ មានផ្លូវចូល[ឆ]
ពីខាងកើត តាមដែលអ្នកណាចូលមកពីទីលានខាងក្រៅ ។

១០នៅក្នុងកំរាស់កំផែងទីលានខាងកើត ប្រទល់មុខនិង
ទីលាន[ជ]ទទេ ហើយពីមុខមន្ទីរ នោះមានបន្ទប់ដែរ[ឈ] ១១ឯ
ទីដើរនៅមុខបន្ទប់ទាំងនោះ មើលទៅដូចទីដើរនៃបន្ទប់
ដែលនៅខាងជើងដែរ មានបណ្ដោយ និងទទឹងស្មើគ្នា
ហើយអស់ទាំងផ្លូវចេញពីបន្ទប់ទាំងនោះ ក៏ត្រូវតាមរបៀប
ហើយតាមទ្វារបន្ទប់មុននោះដែរ ១២ហើយតាមរបៀបនៃ
ទ្វាររបស់បន្ទប់នៅខាងត្បូង នោះក៏មានទ្វារ១នៅក្បាល ផ្លូវ
គឺជាផ្លូវដែលចេញទៅចំពីមុខកំផែងទិសខាងកើត តាម
ដែលអ្នកណាចូលទៅឯបន្ទប់ទាំងនោះ ។

១៣រួចលោកនិយាយមកខ្ញុំថា បន្ទប់ទាំងប៉ុន្មាន នៅខាង

**៤១:១៦** ដ ខ.២៥–២៦ ១ពរ ៦:១៥ អគ ៤២:៣
**៤១:១៨** ឋ ១ពរ ៦:១៨ ឌ នក ៣៧:៧ ២របា ៣:៧ ឍ ១ពរ ៦:២៩ ៧:៣៦ ណ អគ ១០:២១
**៤១:១៩** ត អគ ១០:១៤
**៤១:២១** ថ ខ.១
**៤១:២២** ទ នក ៣០:១ ធ នក ២៥:២៣ អគ ២៣:៤១
**៤១:២៣** ន ខ.១ ប ១ពរ ៦:៣២
**៤១:២៤** ផ ១ពរ ៦:៣៤
**៤១:២៦** ព ខ.១៥–១៦ អគ ៤០:១៦
**៤២:១** ក ខ.១៣ ខ នក ២៧:៩ អគ ៤១:១២–១៤ គ អគ ៤០:១៧
**៤២:៣** ឃ អគ ៤១:១៥ ង អគ ៤១:១៦
**៤២:៤** ច អគ ៤៦:១៩
**៤២:៩** ឆ អគ ៤៤:៥ ៤៦:១៩
**៤២:១០** ជ អគ ៤១:១២–១៤ ឈ ខ.១

**៤១:១៨** *ក្បាច់ជាចេរូប៊ីន* ដែលបម្រើដូចជាអ្នកចាំយាម (ផ្ទៀបនឹង លក ៣:២៤ និងការពន្យល់ ដែលឈទល់មុខគ្នា ដូចជាបានបញ្ជាក់នៅក្នុងជំពូក ១០ (មើលការពន្យល់ ១:៥ មានមុខ២ គឺមុខមនុស្ស១ និងមុខសត្វសិង្ហ១ (មើល ១ពរ ៦:២៩,៣២,៣៥) ។

**៤១:២២** *ឯអាសនាបានធ្វើពីឈើ* ជាអាសនា១យ៉ាងធំ បញ្ឈរនៅខាងក្រៅព្រះវិហារ (មើល ៤៣:១៣–១៧) ហើយអាសនាតូច (មានទទឹង ៣.៥ និងមានរាងជាការេ កំពស់៥ហត្ថ) ដែលបញ្ឈរនៅខាងក្រៅទីបរិសុទ្ធបំផុត គេដាក់តុ១នៅខាងក្រៅសម្រាប់ដាក់នំបុ័ងនៅពីលើ (មើល នក ២៥:៣០ លវ ២៤:៥–៩ ១ពរ ៧:៤៨ និងការពន្យល់)។ ហើយលោកអេសេកាល មិន មិនបញ្ជាក់ទៅលើអាសសនា ដែលមានទៀន និងជើងចង្កៀង ដូចជាបានរកឃើញនៅក្នុងព្រះវិហាររបស់ស្តេចសាឡូម៉ូន និងនៅក្នុងរោងឧបោសថនៅពីខាងមុខនោះទេ ។ មិនរាប់បញ្ចូល "សមុទ្រ" (មើល ១ពរ ៧:២៣) និងទូកនៃការតាំងសញ្ញា (មើលការពន្យល់ អរ ៦:១៥) ។

**៤១:២៣** *មានទ្វារ២* ទ្វារនោះអាចបត់បាន ដ្បិតអ្នកចូលតាមទ្វារនោះគឺតូចចង្អៀត ។

**៤២:១** *បន្ទប់ដែលនៅនៅមុខទីលានទទេ* ទីកន្លែងនោះដូចជាបានរៀបរាប់នៅក្នុង ខ.១៣–១៤ វាមិនដូចគ្នានឹងព្រះវិហាររបស់ស្តេចសាឡូម៉ូននោះទេ ដូចជាបានរៀបរាប់នៅក្នុង ១ពរជំពូក ៦ ។

**៤២:១៣** *ជាកន្លែងនៃពួកសង្ឃដែលចូលទៅជិតព្រះយេហូវ៉ា* កូនរបស់សាដុក (មើល ៤០:៦ និងការពន្យល់ក្នុង ៤៤:១៥) ។ *គេបរិភោគរបស់*

ជើង[ញ] ហើយខាងត្បូង[ដ] ដែលនៅមុខទីលាន[ឋ]ទទេ នោះ
ជាបន្ទប់បរិសុទ្ធ ជាកន្លែងនៃពួកសង្ឃដែលចូលទៅជិត
ព្រះយេហូវ៉ា គេបរិភោគរបស់បរិសុទ្ធបំផុត គឺនៅទីនោះ
ដែលគេត្រូវដាក់របស់បរិសុទ្ធបំផុត ជាដង្វាយម្សៅ[ឌ] ដង្វាយ
លោះបាប[ឍ] និងដង្វាយដែលថ្វាយដោយព្រោះការរំលង[ណ]
ផង ដ្បិតទីនោះជាទីបរិសុទ្ធ[ត] ១៤កាលណាពួកសង្ឃចូលទៅ
នោះគេមិនត្រូវចេញ ពីទីបរិសុទ្ធ ទៅឯទីលានខាងក្រៅ
ឡើយ គឺគេត្រូវទុកសំលៀកបំពាក់[ថ] ដែលគេស្លៀកពាក់
កំពុង ដែលធ្វើការងារនៅទីនោះវិញ ពីព្រោះសំលៀក
បំពាក់ទាំងនោះសុទ្ធតែបរិសុទ្ធ ហើយគេត្រូវតែងខ្លួន
ដោយសំលៀកបំពាក់ផ្សេងទៀត រួចនឹងចូលទៅឯចំណែក
របស់ផងបណ្ដាជនបាន[ទ]។
១៥កាលលោកបានវាស់ព្រះវិហារ ខាងក្នុងរួចហើយ
នោះក៏នាំខ្ញុំចេញទៅតាមផ្លូវនៃទ្វារកំផែង ដែលបើកទៅ
ទិសខាងកើត[ធ] រួចក៏វាស់កំផែងព័ទ្ធជុំវិញ ១៦លោកវាស់
ចំហៀងខាងកើត ដោយខ្នាតបបុសបាន៥០០ខ្នាត គឺបាន
វាស់ដោយខ្នាតបបុសនៅព័ទ្ធជុំវិញ ១៧លោកវាស់ចំហៀង
ខាងជើង ដោយខ្នាតបបុស នោះបាន៥០០ខ្នាតជុំវិញ
១៨លោកក៏វាស់ចំហៀងខាងត្បូង ដោយខ្នាតបបុសនោះ
បាន៥០០ខ្នាត ១៩រួចលោកត្រឡប់ទៅខាងលិច វាស់ដោយ
ខ្នាតបបុសបាន៥០០ខ្នាត ២០គឺលោកបានវាស់[ន]ចំហៀង[ប]
ទាំង៤ មានកំផែងព័ទ្ធជុំវិញ[ផ] បណ្ដោយ៥០០ ទទឹង៥០០[ព]
ដើម្បីនឹងញែករបស់ដែលបរិសុទ្ធ ចេញពីរបស់ដែលមិន
បរិសុទ្ធ[ភ]។

## សិរីល្អវិលត្រឡប់មកឯព្រះវិហារវិញ

**៤៣** ១បន្ទាប់មក លោកនាំខ្ញុំទៅឯទ្វារកំផែង គឺជាទ្វារ
ដែលបើកទៅទិសខាងកើត[ក] ២ហើយមើល សិរីល្អរបស់
ព្រះនៃសាសន៍អ៊ីស្រាអែល ក៏មកតាមផ្លូវពីទិសខាងកើត
ព្រះសូរសៀងទ្រង់ឮដូចជាសូរនៃទឹកច្រើន[ខ] ហើយផែនដី
បានភ្លឺ ដោយសារសិរីល្អរបស់ទ្រង់[គ] ៣នោះក៏ដូចជាការ
ជាក់ស្តែង ដែលលេចមកឱ្យខ្ញុំឃើញ គឺដូចជាការជាក់
ស្តែងដែលខ្ញុំបានឃើញ ក្នុងកាលដែលខ្ញុំមក ដើម្បីបំផ្លាញ
ទីក្រុង ការជាក់ស្តែងទាំងនោះ ដូចជាការជាក់ស្តែងដែល
ខ្ញុំបានឃើញ នៅក្បែរទន្លេកេបារដែរ ដូច្នេះ ខ្ញុំក៏ដួលផ្កាប់
មុខចុះ ៤នោះសិរីល្អ[ឃ]នៃព្រះយេហូវ៉ាក៏ចូលទៅ ក្នុងព្រះ
វិហារ តាមផ្លូវនៃទ្វារកំផែង ដែលបើកទៅទិសខាងកើត[ង]
៥រួចព្រះវិញ្ញាណ[ច]ទ្រង់លើកខ្ញុំឡើង[ឆ]នាំទៅឯទីលាន ខាង
ក្នុង ហើយមើល សិរីល្អ[ជ]នៃព្រះយេហូវ៉ាបាននៅពេញ
ក្នុងព្រះវិហារ[ឈ]។
៦ខ្ញុំក៏ឮព្រះមានបន្ទូលមកខ្ញុំ ពីក្នុងព្រះវិហារ មានទាំង
មនុស្សនោះឈរនៅក្បែរខ្ញុំដែរ ៧នោះទ្រង់មានបន្ទូលមក
ខ្ញុំថា កូនមនុស្សអើយ នេះជាទីកន្លែងនៃបល្ល័ង្ក[ញ]អញ ហើយ

**៤២:១៣** ញ អគ ៤០:៤៦ ដ ខ.១ ឋ អគ ៤១:១២–១៤ ឌ យរ ៤១:៥ ឍ លវ ១០:១៧ ណ លវ ១៤:១៣ ត នក ២៩:៣១ លវ ៦:២៩ ៧:៦ ១០:១២–១៣ ជន ១៨:៩–១០ **៤២:១៤** ថ លវ ១៦:២៣ អគ ៤៤:១៩ ទ នក ២៩:៩ លវ ៨:៧–៩ **៤២:១៥** ធ អគ ៤៣:១ **៤២:២០** ន អគ ៤០:៥ ប អគ ៤៣:១២ ផ សក ២:៥ ព អគ ៤៥:២ វវ ២១:១៦ ភ អគ ២២:២៦ **៤៣:១** ក ១របា ៩:១៨ អគ ៨:១៦ ៤២:១៥ ៤៤:១ **៤៣:២** ខ ទដ ១៨:៤ វវ ១:១៥ គ អស ៦:៣ វវ ១៨:១ ២១:១១

**៤៣:៤** ឃ អគ ១:២៨ ង អគ ១០:១៩ ៤៤:២ **៤៣:៥** ច អគ ១១:២៤ ឆ អគ ៣:១២ ជ នក ១៦:៧ ឈ អស ៦:៤ **៤៣:៦** ញ យរ ៣:១៧

*បរិសុទ្ធបំផុត* ពួកសង្ឃជាធម្មតា បានទទួលយញ្ញបូជា១ចំនែក ដើម្បីបរិភោគ (មើល លវ ២:៣ ៥:១៣ ៦:១៦ ២៦ ២៩ ៧:៦,១០) ។ *ដ្បិតទីនោះជាទីបរិសុទ្ធបំផុត* (មើលការពន្យល់ លវ ១១:៤៤ មើលផងដែរសេចក្តីផ្តើមនៅក្នុងព្រះគម្ពីរ លេវី សាច់រឿងដែលនិយាយពីការសិក្សាអំពីព្រះ) ។

**៤២:២០** *បណ្ដោយ៥០០ហត្ថ ទទឹង៥០០ហត្ថ* ទីធ្លាព្រះវិហារនោះគឺ សមាមាត្រគ្នា ។

**៤៣:១–១២** សិរីរុងរឿងរបស់ព្រះយាងវិលត្រឡប់ទៅក្នុងព្រះវិហារថ្មី ។

**៤៣:២** *មើលសិរីល្អរបស់ព្រះ* ទីកន្លែងដ៏ខ្ពស់បំផុតនៅក្នុងជំពូក ៤០–៤៨ ព្រះវិហារដែលបានរៀបចំនៅពេលនេះ ដើម្បីទុកពេលមានកម្មវិធីសម្តែងអ្វីមួយ ។ *មកពីទិសខាងកើត* ជាទិសដែលលោកអេសេគាលបានឃើញព្រះទ្រង់យាងចេញ (មើល ១១:២៣ និងការពន្យល់)។ នៅក្នុងព្រះគម្ពីរ អេសេគាល សិរីល្អរបស់ព្រះ គឺតែងតែចែងជះសិរីរុងរឿង (មើល ខ.៤–៥ ៣:២៣ ៩:៣ ១០:៤ ៨ ៤៤:៤)។ *ព្រះសូរសៀងទ្រង់ឮដូចជាសូរនៃទឹក* ច្រើន លោកអេសេគាលគាត់មានបទពិសោធន៍ ដោយគាត់បានឮព្រះសូរសៀងរបស់ព្រះ នៅពេលគាត់ឃើញការជាក់ស្តែងរបស់ទ្រង់ ជាពាក្យប្រៀបធៀប (មើល ១:២៤ វវ ១:១៥ ១៤:២ ១៩:៦) ។ *ហើយផែនដីបានភ្លឺ ដោយសារសិរីល្អរបស់ទ្រង់* សិរីល្អរបស់ព្រះនោះអាចមើលឃើញ ហើយត្រូវបានពណ៌នាថាដូចជាពន្លឺភ្លឺយ៉ាងខ្លាំង (សូមមើល ១០:៤ លក ២:៩ វវ ២១:១១, ២៣) ។

**៤៣:៣** *នោះក៏ដូចជាការជាក់ស្តែង* ដែលលេចមកឱ្យខ្ញុំឃើញ តែវាមានលក្ខណៈខុសគ្នា មិនមានសត្វ រីកង់ដែលបានលើកមកបញ្ជាក់នៅទីនេះ *ដើម្បីបំផ្លាញទីក្រុង* មើលជំពូក៩ *ទន្លេកេបារ* (មើល១:១ និងការពន្យល់) ។ *ខ្ញុំក៏ដួលផ្កាប់មុខចុះ* (មើល ១:២៨ ៣:២៣ ៩:៨ ១១:១៣ ៤៤:៤)។

**៤៣:៤** *តាមផ្លូវនៃទ្វារកំផែងដែលបើកទៅទិសខាងកើត* (មើលការពន្យល់ ខ.២)។

**៤៣:៥** *រួចព្រះវិញ្ញាណទ្រង់លើកខ្ញុំឡើង* ដែលទ្រង់យាងមកជិត ទ្រង់យាងមកដែលមានទេវតាហែហមមកជាមួយ។ លោកអេសេគាលបានដើរចូលទៅទីកន្លែងកាត់ក្តីខាងក្នុង តែមិនបានចូលទៅខាងក្នុងព្រះវិហារនោះទេ (ធៀបនឹង ៣:១២ និងការពន្យល់) ។ *បាននៅពេញក្នុងព្រះវិហារ* ដូចជានៅពេល ដែលរៀបចំពិធីអរព្រះគុណនៅក្នុងព្រះវិហាររបស់ស្តេចសាឡូម៉ូន (១ពវ ៨:១០–១១ មើលការពន្យល់ នក ៤០:៣៤ ១ពវ ៨:១០ ធៀបនឹង អស ៦:៤) ។

**៤៣:៦** *អង្គទ្រង់* ព្រះជាម្ចាស់ សំលេងទ្រង់ដូចជាខ្យល់គួរឱ្យស្ញែងខ្លាច ។

**៤៣:៧** *នេះជាទីកន្លែងនៃបល្ល័ង្ករបស់អញ* (មើល អស ៤:៤ ទដ ៤៧:៨ និងការពន្យល់) ។ *ហើយជាទីសម្រាប់បាតជើងរបស់អញ* (មើល ១របា ២៨:២ ទដ ៩៩:៥ និងការពន្យល់ ១៣២:៧ អស ៦០:១៣ និងការពន្យល់ បទ ២:១)។

ជាទីសំរាប់បាត់ជើងអញ គឺជាកន្លែងដែលអញនឹងនៅ
កណ្តាលពួកកូនចៅអ៊ីស្រាអែលជាដរាបតទៅ ហើយពួក
វង្សអ៊ីស្រាអែល នឹងមិនដែលបង្អាប់[ដ]ឈ្មោះបរិសុទ្ធរបស់
អញទៀត ទោះទាំងខ្លួនគេ និងពួកស្តេចគេផង ដោយការ
កំផិតរបស់គេ ឬដោយសាកសពនៃស្តេចគេ ដែលបាន
ដំកល់ទុក[ឋ] ៨ឬដោយគេធ្វើមាត់ទ្វារគេ ក្បែរមាត់ទ្វាររបស់
អញ និងក្របទ្វារគេ ផ្ទាប់នឹងក្របទ្វាររបស់អញ ឱ្យមាន
តែជញ្ជាំងនៅកណ្តាលអញនឹងគេ ហើយគេបានបង្អាប់
ឈ្មោះបរិសុទ្ធរបស់អញ ដោយអំពើដ៏គួរស្អប់ខ្ពើម ដែល
គេបានប្រព្រឹត្ត ដោយហេតុនោះ បានជាអញធ្វើឱ្យគេសាប
សូន្យទៅ ដោយសេចក្តីកំហឹងរបស់អញ ៩ឥឡូវនេះ ត្រូវ
ឱ្យគេលះចោលការកំផិត និងសាកសពនៃស្តេចគេចេញ
ឆ្ងាយពីអញទៅ នោះអញនឹងនៅកណ្តាលពួកគេជាដរាប
រៀងតទៅ[ឌ]។
១០ឯឯង កូនមនុស្សអើយ ចូរបង្ហាញព្រះវិហារនេះ
ដល់ពួកវង្សអ៊ីស្រាអែលចុះ ដើម្បីឱ្យគេមានសេចក្តីខ្មាស[ឍ]
ចំពោះអំពើទុច្ចរិតរបស់គេ ហើយឱ្យគេវាស់គំរូផង ១១បើ
គេមានសេចក្តីខ្មាស ចំពោះការទាំងប៉ុន្មានដែលគេប្រព្រឹត្ត
នោះត្រូវឱ្យគេស្គាល់រាង និងបែបផែននៃព្រះវិហារ ព្រម
ទាំងផ្លូវចេញចូល និងសណ្ឋានគ្រប់យ៉ាង ហើយក្រឹត្យ
ក្រមគ្រប់ចំពូក នូវអស់ទាំងបញ្ញត្តច្បាប់នៃព្រះវិហារផង
ចូរកត់ទុកទាំងអស់នៅចំពោះភ្នែកគេ ដើម្បីឱ្យគេបានរក្សា
ទុកនូវសណ្ឋានគ្រប់យ៉ាង និងក្រឹត្យក្រមទាំងប៉ុន្មាន ព្រម
ទាំងធ្វើតាមផង[ណ] ១២នេះហើយជាច្បាប់នៃព្រះវិហារនៅ
លើកំពូលភ្នំនោះ ហើយតាមព្រំនៅជុំវិញទាំងអស់នោះ[ត]
ត្រូវជាទីបរិសុទ្ធ[ថ] មើលនេះឯងជាច្បាប់នៃព្រះវិហារ ។

## អាសនា

១៣នេះជាទំហំនៃអាសនា[ទ] ដែលវាស់តាមហត្ថ គឺហត្ថ
ធំដែលត្រូវជា១ហត្ថ១ទះ បាតនៃអាសនាបាន១ហត្ថ ទទឹង១
ហត្ថ ហើយកែមនៅជុំវិញហាម បាន១ចំអាម នោះជាជើង
នៃអាសនា ១៤ពីបាតដែលនៅលើដីឡើង ទៅដល់គន្ទាក់
ខាងក្រោម នោះមាន២ហត្ថ និងទទឹង១ហត្ថ ហើយតាំង
ពីគន្ទាក់ក្រោម ឡើងទៅដល់គន្ទាក់ខាងលើ នោះមាន៤
ហត្ថនឹងទទឹង១ហត្ថ ១៥ឯប្រទាស អាសនា[ធ] នោះមាន៤ហត្ថ
ហើយមានស្នែង[ន]៤ចេញពី អាសនាឡើងទៅ ១៦ឯប្រទាស
អាសនា នោះបណ្តោយ ១២ហត្ថ ទទឹង១២ហត្ថ ៤ជ្រុងស្មើ[ប]
១៧ហើយគន្ទាក់[ផ] ប្រវែង១៤ហត្ថ ទទឹង១៤ហត្ថ ទាំង៤ជ្រុង
ក៏មានកែម នៅព័ទ្ធជុំវិញកន្លះហត្ថ ហើយបាតក៏១ហត្ថ
ទាំង៤ជ្រុង ឯជណ្តើរ[ព]នោះ បែរមុខទៅទិសខាងកើត[ភ]។
១៨រួចលោកនិយាយមកខ្ញុំថា កូនមនុស្សអើយ ព្រះ

**៤៣:៧** ដ អគ ៣៧:២៣ ឋ លវ ២៦:៣០ អគ ២០:២៩,៣៩
**៤៣:៩** ឌ អគ ៣៧:២៦-២៨
**៤៣:១០** ឍ អគ ១៦:៦១
**៤៣:១១** ណ អគ ៤៤:៥
**៤៣:១២** ត អគ ៤២:២០ ថ អគ ១៧:២២
**៤៣:១៣** ទ នក ២០:២៤ ២រប ៤:១
**៤៣:១៥** ធ អស ២៩:២ ន នក ២៧:២
**៤៣:១៦** ប វវ ២១:១៦
**៤៣:១៧** ផ ខ.២០ អគ ៤៥:១៩ ព នក ២០:២៦ ភ នក ២៧:១

*អញនឹងនៅកណ្តាលពួកកូនចៅអ៊ីស្រាអែលដរាបតទៅ* ការរំលឹកពីសេចក្តីសន្យារ ៣៧:២៦-២៨ (មើល ខ.៩ ១ពវ ៦:១៣ សក ២:១១) ។ មិនដែលបង្អាប់ឈ្មោះបរិសុទ្ធរបស់អញទៀត(មើល លវ ១៨:២១ និងការពន្យល់) ។ *ដោយការកំផិតរបស់គេ* (មើលការពន្យល់ នក ៣៤:១៥ *ដែលបានដំកល់ទុក* នៅក្នុងខនេះចង្អុលបង្ហាញទៅលើរូបសំណាក់ រឺ វិមានរឹថ្មររបស់ស្តេច កាលពីជំនាន់អតីតកាល ដែលមានស្តេចរបស់យូដា១៤អង្គបានបញ្ចុះនៅក្រុងយេរូសាឡិមនៅជិត (នៅជិតលោកអេសេគាល) ព្រះវិហារ (មើល ២ពវ ២១:១៨,២៦ ២៣:៣០) ។

**៤៣:៨** *មាត់ទ្វារគេ ក្បែរមាត់ទ្វាររបស់អញ* ព្រះវិហាររបស់ស្តេចសាឡូម៉ូនគឺនៅព័ទ្ធជុំវិញអាគារនៃដំណាក់របស់ទ្រង់ជាច្រើន (មើល ១ពវ ៧:១-១២ ភាពខុសគ្នាររវាងព្រះវិហារដ៏បរិសុទ្ធរបស់ព្រះ និងលោកីយនេះដែលជាគំនិតសំខាន់នៅក្នុងព្រះគម្ពីរអេសេគាល (មើល ខ.១២ ៤៤:២៣) ។ *នោះអញ ធ្វើឱ្យគេសាបសូន្យទៅ* ដូចជានៅក្នុងព្រះគម្ពីរអេសេគាល ភាពខុសគ្នានេះ មកពីរាស្ត្រ និងស្តេចគេធ្វើនូវទង្វើដែលខុសគ្នា (មើល ៥:១១ ១៨:១០-១២ និងជាពិសេស ២២:១-១៥) ។

**៤៣:១២** *នេះហើយជាច្បាប់* សំដៅលើមាតិការនៅក្នុងជំពូក ៤០-៤២ ។

**៤៣:១៣-២៧** ការសាងសងអាសនាមួយយ៉ាងល្អ ។

**៤៣:១៣** *អាសនា* និយាយពោលនៅក្នុង ៤០:៤៧ ហើយនៅទីនេះត្រូវបានពណ៌នាយ៉ាងលំអិត ទោះបីសម្ភារៈនោះមិនបានលើកមកបញ្ជាក់ក្តី ដែលថ្មនោះត្រូវបានគេយកវាមកប្រើប្រាស់ (មើល នក ២០:២៤-២៦) ដែលអាសនានោះគេធ្វើឡើងពីដី ប៉ុន្តែអាសនាដែលធ្វើឡើងពីថ្មវិញ ត្រូវបានហាមប្រាមមិនឱ្យធ្វើ (មើលការពន្យល់ ២០:២៤-២៥)។ អាសនារបស់ស្តេចសាឡូម៉ូនមានពណ៌ទង់ដែង (១ ពវ ៨:៦៤) ។ អាសនារបស់លោកអេសេគាល នោះគឺធំជាងអាសនារបស់ស្តេចសាឡូម៉ូន រហូតដល់មានកំពស់២០ហត្ថ (រួមទាំងស្នែងសត្វ នៅក្នុងខ.១៥) ដែលទទឹងកំរាស់៣តឹក វាដូចពីរ៉ាមីតរបស់ស្រុកអេស៊ីព្ទ ឬកំផែងរបស់ពួកបាប៊ីឡូន "ជើងខាងក្រោមលយចេញទៅក្រៅបន្តិច "(ខ.១៤) មានកំពស់២ហត្ថ "ខាងលើមានទំហំ" (ខ.១៤) មានកំពស់៤ហត្ថ ហើយ "អាសនាធ្វើពីដី"(ខ.១៥)មានកំពស់៤ហត្ថ ។

**៤៣:១៥** *ប្រទាសអាសនា* ចំពោះពាក្យនេះនៅក្នុងភាសាហេព្រើរ គឺមាននៅនៅក្នុងសញ្ញាចាស់ ហើយវាមានន័យថា "ភ្នំរបស់ព្រះ" ឬ"សឹង្ហរបស់ព្រះ" ដែលប្តូរមកពីពាក្យមួយនៅក្នុង (មើល អស ២៩:១-២,៧ និងការពន្យល់) ។ *មានស្នែង៤* ដែលធ្វើយ៉ាងរឹងនៃជ្រុងទាំង៤នោះចេញពីប្រទាសនោះឡើងទៅ ។ កាលនៅជំនាន់ដើម អាសនានោះគេធ្វើឡើងជាជម្រក សម្រាប់ជនជាប់ទោទ ធ្វើការកែប្រែខ្លួនគេនៅថ្ងៃចុងក្រោយ (មើល នក ២១:១២-១៤ ១ពវ ១:៥០-៥១ ២:២៨-២៩) ។

**៤៣:១៧** *ជណ្តើរអាសនានោះ* ត្រូវហាមឃាត នៅ នក ២០:២៦ វាតម្រូវទៅតាមទំហំនៃអាសនានោះ (មើលការពន្យល់ ខ.១៣) ។

**៣២:១៨** *ដើម្បីនឹងថ្វាយដង្វាយដុត* (មើលការពន្យល់ ៤០:៣៩) ហើយប្រោះឈាមលើអាសនានោះ (មើល នក ២៩:១៦ លវ ៤:៦ ៥:៩) ។

អម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ នេះជាច្បាប់សំរាប់
អាសនា នៅវេលាណាដែលគេនឹងតាំងឡើង ដើម្បីនឹង
ថ្វាយដង្វាយដុត[ម] ហើយប្រោះឈាម[យ]ទៅលើអាសនានោះ
១៩ ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថាត្រូវឱ្យឯងបានគោ
ឈ្មោលស្ទាវ១[រ] សំរាប់ជាដង្វាយលោះបាប ដល់ពួកលេវី
ដែលជាសង្ឃ ក្នុងពូជពង្សសាដុក[ល] ជាអ្នកដែលចូលមក
ជិត[វ] ដើម្បីនឹងធ្វើការងារដល់អញ ២០ ត្រូវឱ្យឯងយកឈាម
នៃយញ្ញបូជាទៅប្រឡាក់ នៅស្នែងអាសនា[ស]ទាំង៤ និងនៅ
គន្លាក់ទាំង៤ជ្រុង[ហ] ហើយនៅគែមព័ទ្ធជុំវិញដែរ គឺយ៉ាង
នោះដែលឯងត្រូវសំអាត ហើយថ្វាយដង្វាយឱ្យធួននឹង
អាសនា[ឡ] ២១ ត្រូវឱ្យឯងយកគោឈ្មោលដែលសំរាប់ជា
ដង្វាយលោះបាបដែរ ហើយត្រូវដុតនៅកន្លែងសំរាប់ការ
នោះ នៅក្នុងព្រះវិហារខាងក្រៅទីបរិសុទ្ធ[អ] ២២ លុះដល់ថ្ងៃ
ទី២ ត្រូវឱ្យឯងថ្វាយពពែឈ្មោលឥតខ្ចោះ សំរាប់ជា
ដង្វាយលោះបាប ហើយគេនឹងសំអាតអាសនា ដូចជាបាន
សំអាតដោយគោឈ្មោលនោះដែរ ២៣ កាលណាឯងបាន
សំអាតអាសនារួចហើយ នោះត្រូវឱ្យឯងថ្វាយគោឈ្មោល
ស្ទាវ១ឥតខ្ចោះ និងចៀមឈ្មោល១ឥតខ្ចោះ ពីហ្វូងចៀម
ទៀត[ក] ២៤ ត្រូវឱ្យឯងនាំសត្វទាំង២នោះមកនៅ ចំពោះព្រះ
យេហូវ៉ា រួចត្រូវឱ្យពួកសង្ឃបាចអំបិល[ខ]ទៅលើ ហើយ
ថ្វាយជាដង្វាយដុតដល់ព្រះយេហូវ៉ា ២៥ នៅរវាង៧ថ្ងៃ[គ]
នោះត្រូវឱ្យឯងរៀបពពែឈ្មោល១ សំរាប់ជាដង្វាយលោះ
បាបរាល់ៗថ្ងៃ គេត្រូវរៀបគោឈ្មោលស្ទាវ១ និងចៀម
ឈ្មោលឥតខ្ចោះ១[ឃ] ពីហ្វូងសត្វដែរ ២៦ នៅគំរប់៧ត្រូវឱ្យ
គេថ្វាយដង្វាយឱ្យធួននឹងអាសនា ហើយញែកចេញជា
បរិសុទ្ធ គឺយ៉ាងនោះដែលគេត្រូវឆ្លងអាសនា ២៧ កាល
ណាគេបានសំរេចកំណត់ថ្ងៃទាំងនោះហើយ លុះដល់ថ្ងៃ[ង]
ទី៨ ហើយតទៅមុខ នោះត្រូវឱ្យពួកសង្ឃថ្វាយដង្វាយដុត[ច]
និងដង្វាយមេត្រី[ឆ]របស់ឯងរាល់គ្នា នៅលើអាសនានោះ
យ៉ាងនោះ អញនឹងទទួលឯងរាល់គ្នា នេះជាព្រះបន្ទូលនៃ
ព្រះអម្ចាស់យេហូវ៉ា ។

## ពួកចៅហ្វាយ ពួកលេវី និងពួកសង្ឃ

**៤៤** ១ រួចលោកនាំខ្ញុំ វិលទៅតាមផ្លូវនៃទ្វារខាងក្រៅ
របស់ទីបរិសុទ្ធ ដែលបើកទៅទិសខាងកើត[ក] ទ្វារនោះបិទ
នៅ ២ ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកខ្ញុំថា ទ្វារនេះត្រូវ
នៅជាបិទ ឥតបើកឡើយ ក៏មិនត្រូវឱ្យមនុស្សណាចូល
តាមទ្វារនេះដែរ[ខ] ដ្បិតព្រះយេហូវ៉ា ជាព្រះនៃសាសន៍
អ៊ីស្រាអែល ទ្រង់បានយាងតាមទ្វារនេះហើយ ហេតុ
នោះនឹងត្រូវបិទនៅ ៣ ឯព្រះអម្ចាស់ដ៏ឧត្តម ទ្រង់នឹងគង់
នៅទីនោះទុកជាព្រះអម្ចាស់ ដើម្បីនឹងសោយព្រះស្ងោយ
នៅចំពោះ[គ]ព្រះយេហូវ៉ា ទ្រង់នឹងយាងចូលតាមផ្លូវបាំង
សាចនៃទ្វារកំផែង ហើយនឹងយាងចេញទៅវិញតាមផ្លូវ
ដដែល[ឃ] ។
៤ បន្ទាប់មក លោកនឹងនាំខ្ញុំទៅតាមផ្លូវនៃទ្វារខាងជើង[ង]
ពីមុខព្រះវិហារ នោះខ្ញុំក្រឡេកមើលទៅឃើញសិរីល្អនៃ
ព្រះយេហូវ៉ា នៅពេញក្នុងព្រះវិហារ[ច]របស់ព្រះយេហូវ៉ា
រួចខ្ញុំដួលផ្កាប់មុខចុះ[ឆ] ៥ ព្រះយេហូវ៉ាទ្រង់មានបន្ទូលមក

**៤៣:១៨** ម កន ៤០:២០ យ លវ ១:៥,១១ ហេព ៩:២១-២២ ១៧:២២
**៤៣:១៩** រ លវ ៤:៣ ល ២សយ ៨:១៧ អគ ៧:២ វ ជន ១៦:៤០ អគ ៤០:៦
**៤៣:២០** ស លវ ៤:៧ ហ ខ.១៧ ឡ លវ ១៦:១៩
**៤៣:២១** អ នក ២៩:១៤ ហេព ១៣:១១
**៤៣:២៣** ក នក ២៩:១ លវ ២២:២០
**៤៣:២៤** ខ លវ ២:១៣ មក ៩:៤៩-៥០
**៤៣:២៥** គ លវ ៨:៣៣ ឃ នក ២៩:៣៧
**៤៣:២៧** ង លវ ៩:១ ច អស ៦០:៧ ឆ នក ៣២:៦ លវ ១៧:៥
**៤៤:១** ក អគ ៤៣:១
**៤៤:២** ខ អគ ៤៣:៤-៥
**៤៤:៣** គ នក ២៤:៩-១១ ឃ អគ អគ ៤៦:២,៩
**៤៤:៤** ង អគ ៤០:៣៥ ច អស ៦:៤ អគ ១០:៤ វវ ១៥:៨ ឆ ដយ ៨:១៧

**៤៣:១៩** *សំរាប់ជាដង្វាយលោះបាប* ដើម្បីនឹងសម្អាតអាសនាពីភាពកខ្វក់ដែលជាអំពើបាបរបស់មនុស្ស (មើលការពន្យល់ ៤០:៣៩) ។ *ក្នុងពូជពង្សសាដុក* (មើលការពន្យល់ ៤៤:១៥) ។

**៤៣:២១** *នៅក្នុងវិហារខាងក្រៅទីបរិសុទ្ធ* ដូចជាបទបញ្ញត្តិមួយនៅក្នុង នក ២៩:១៤ លវ ៤:១២,២១ ៨:១៧ ៩:១១ ១៦:២៧ ។ សកម្មភាពនេះ ទាយទុកទីទិដ្ឋភាពមួយអំពីយញ្ញបូជារបស់ព្រះគ្រីស្ទ (មើល ហេព ១៣:១១-១៣ និងការពន្យល់) ។

**៤៣:២២** *ពពែឈ្មោលឥតខ្ចោះ* ប្រោះឈាមលើអាសនានោះ (មើល ខ.២០) ។

**៤៣:២៧** *ដង្វាយមេត្រីរបស់ឯងរាល់គ្នា* ពិធីសម្ពន្ធវង់បរិសុទ្ធនេះធ្វើឡើងនៅក្នុងរយៈពេល៧ថ្ងៃបន្ទាប់ ដោយការថ្វាយដង្វាយដុត និងដង្វាយលោះបាប ទីអាសនាបានរៀបចំជាស្រេច សម្រាប់រៀបចំពិធីថ្វាយដង្វាយមេត្រីនៅពេលដែលបណ្ដាជនគេចូលរួមបរិភោគដង្វាយនោះ (មើលការពន្យល់ លវ ៣:១) ។

**៤៤:១-៣១** ការស្អាងគ្រួសារសង្ឃឡើងវិញ ។

**៤៤:២** *ទ្វារនេះត្រូវនៅជាបិទ ឥតបើកឡើយ* ហេតុផលនៅទីនេះ គឺមានន័យថាព្រះទ្រង់បានយាងចូលតាមទ្វារខាងកើត (សូមមើល ៤៣:១-២) ដូចនេះទីនោះត្រូវបរិសុទ្ធ នេះគឺទាក់ទង់នឹងហេតុផលដែលព្រះមិនដែលបានយាងចេញតាមទ្វារនោះទេ (សូមមើល ១០:១៩ ១១:២៣) ហើយដែលមនុស្សគេមិនត្រូវថ្វាយបង្គំដល់ព្រះអាទិត្យឡើយ (សូមមើល ៨:១៦) ។ សព្វថ្ងៃនេះទ្វារទិសខាងកើត (មានឈ្មោះថា ទ្វារមាស) ជាកន្លែងគោរពបូជារបស់ពួកម៉ូស្លិម ហារ៉ាម អ៊ិសហ្សារ៉ុស (Haram esh-Sharif) នៅក្នុងក្រុងយេរូសាឡិម ហើយចុងក្រោយនោះវាអាចក្លាយទៅជាទីន្លែងសាសនារបស់គេ ។

**៤៤:៣** *ព្រះអម្ចាស់ដ៏ឧត្តម* ការបញ្ជាក់ពីព្រះអម្ចាស់មាននៅក្នុងជំពូក ៤០-៤៨ (មើល ៣៤:២៤ និងការពន្យល់) ។ ដើម្បីនឹងសោយព្រះស្ងោយ ប្រហែលនេះជាផ្នែកមួយនៃដង្វាយមេត្រីរបស់ទ្រង់ (មើល លវ ៧:១៥ ចទ ១២:៧ មើលផងដែរ អគ ៤៣:២៧ និងការពន្យល់) ។ នេះគឺជាការផ្ដល់កិត្តិយសដល់ព្រះអម្ចាស់ វាគឺសំខាន់ណាស់ដែលគ្មានពិធីណាដែលបានផ្ដល់កិត្តិយសដូចជាពិធីនេះឡើយ នេះគឺសម្រាប់តែសង្ឃតែប៉ុណ្ណោះ (មើល ២របា ២៦:១៦-២០) ។ *ទ្រង់នឹងយាងចូលតាមផ្លូវបាំងសាចនៃទ្វារកំផែង* តាមផ្លូវទីលានកាត់ក្ដីខាងក្នុង ។

ខ្ញុំថា កូនមនុស្សអើយ ចូរផ្ចង់ចិត្តចុះ ត្រូវឱ្យមើលដោយភ្នែក
ហើយស្ដាប់ដោយត្រចៀក តាមគ្រប់ទាំងសេចក្ដីដែលអញ
និយាយ ពីដំណើររបៀបទាំងប៉ុន្មាន ក្នុងព្រះវិហារនៃព្រះ
យេហូវ៉ា ហើយពីអស់ទាំងច្បាប់ផង ហើយផ្ចង់ចិត្តចំពោះ
ផ្លូវចូល[ជ]ព្រះវិហារ និងអស់ទាំងផ្លូវចេញពីទីបរិសុទ្ធផង[ឈ]
៦ រួចត្រូវឱ្យឯងប្រាប់ដល់ពួករឹងចចេស គឺដល់ពួកវង្ស[ញ]
អ៊ីស្រាអែលថា ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ
ឱពួកវង្សអ៊ីស្រាអែលអើយ ត្រូវឱ្យការគួរស្អប់ខ្ពើមរបស់
ឯងបានល្មមដល់ឯងប៉ុណ្ណឹងចុះ ៧ គឺជាការដែលឯងរាល់គ្នា
បាននាំពួកសាសន៍ដទៃ ជាមនុស្សដែលមិនទទួលកាត់ស្បែក
ខាងចិត្ត[ដ] ហើយខាងរូបសាច់ផង ឱ្យចូលមកនៅក្នុងទី
បរិសុទ្ធរបស់អញ ដើម្បីនឹងបង្អាប់ទីលំនៅរបស់អញ ក្នុង
កាលដែលឯងរាល់គ្នាបានថ្វាយនំបុ័ងរបស់អញ ព្រមទាំង
ខ្លាញ់ និងឈាមផង ហើយបានផ្តាច់សេចក្ដីសញ្ញារបស់
អញ ដោយអស់ទាំងអំពើគួរស្អប់ខ្ពើម ដែលឯងប្រព្រឹត្ត
នោះ[ឋ] ៨ ហើយឯងរាល់គ្នាមិនបានរក្សាបញ្ញើ នៃរបស់
បរិសុទ្ធដែលអញផ្ញើទុកនឹងឯង គឺបានតាំងគេឱ្យរក្សាបញ្ញើ
របស់អញនៅទីបរិសុទ្ធតាមអំពើចិត្តឯងវិញ[ឌ]។
៩ ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា មិនត្រូវ
ឱ្យមានសាសន៍ដទៃណាមួយ ក្នុងពួកសាសន៍ដទៃ ដែលនៅ
កណ្ដាលពួកកូនចៅអ៊ីស្រាអែល ជាអ្នកដែលមិនទទួលកាត់
ស្បែកខាងចិត្ត និងខាងរូបសាច់ផង បានចូលទៅក្នុង
ទីបរិសុទ្ធរបស់អញឡើយ[ឍ] ១០ ឯពួកលេវីដែលបានឃ្លាត
ឆ្ងាយពីអញ ក្នុងកាលដែលពួកអ៊ីស្រាអែល វង្វេងចេញ[ណ]
គឺដែលគេបានលះចោលអញ ទៅតាមរូបព្រះទាំងប៉ុន្មាន
របស់គេ គេនឹងត្រូវរងទ្រាំងសេចក្ដីទុច្ចរិតរបស់ខ្លួន[ត]
១១ ប៉ុន្តែគេនឹងបានជាអ្នកធ្វើការងារ នៅក្នុងទីបរិសុទ្ធរបស់
អញ ព្រមទាំងមានអំណាចត្រួតត្រានៅអស់ទាំងទ្វារនៃព្រះ
វិហារ ហើយទាំងធ្វើការងារក្នុងព្រះវិហារផង គេត្រូវ
សំឡាប់ដង្វាយដុត[ថ] និងយញ្ញបូជាសំរាប់បណ្ដាជន ហើយ
ត្រូវឱ្យគេឈរនៅមុខបណ្ដាជន ដើម្បីធ្វើការងារជំនួស[ទ]
១២ ហេតុដោយព្រោះគេបានធ្វើការងារឱ្យ នៅចំពោះរូប
ព្រះរបស់គេ ហើយបានត្រឡប់ជាសេចក្ដីទុច្ចរិត ដែល
នាំឱ្យពួកវង្សអ៊ីស្រាអែលចំពប់ដួល[ធ] បានជាព្រះអម្ចាស់
យេហូវ៉ា ទ្រង់មានបន្ទូលថា អញបានលើកដៃ[ន]ទាស់នឹងគេ
ហើយគេនឹងត្រូវរងទ្រាំសេចក្ដីទុច្ចរិតរបស់ខ្លួន[ប] ១៣ គេមិន
ត្រូវចូលមកជិតអញ ដើម្បីធ្វើការងារជាសង្ឃដល់អញ ឬ
ចូលទៅជិតរបស់បរិសុទ្ធណាមួយ ក្នុងអស់ទាំងវត្ថុបរិសុទ្ធ
បំផុតរបស់អញឡើយ គឺគេត្រូវរងទ្រាំងសេចក្ដីខ្មាស[ផ]របស់
ខ្លួន និងអំពើគួរស្អប់ខ្ពើមដែលគេបានប្រព្រឹត្តនោះ[ព] ១៤ ប៉ុន្តែ
អញនឹងតាំងគេជាអ្នករក្សាបញ្ញើនៃព្រះវិហារ សំរាប់គ្រប់
ការងារទាំងនោះ និងគ្រប់ទាំងការដែលត្រូវធ្វើ ក្នុងទី
នោះដែរ[ភ]។
១៥ ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ឯពួក
លេវីដែលជាសង្ឃជាកូនសាដុក[ម] ដែលបានរក្សាបញ្ញើទី
បរិសុទ្ធរបស់អញ នៅវេលាដែលពួកកូនចៅអ៊ីស្រាអែល
បានវង្វេងចាកចេញពីអញពួកនោះ នឹងចូលមកជិតអញ

**៤៤:៥** ជ អគ ៣:៩ ឈ អគ ៤០:៤ ៤៣:១០–១១
**៤៤:៦** ញ អគ ៣:៩
**៤៤:៧** ដ លវ ២៦:៤១ ឋ លប ១៧:១៤ នក ១២:៤៨ លវ ២២:២៥
**៤៤:៨** ឌ លវ ២២:២ ជន ១៨:៧
**៤៤:៩** ឍ យអ ៣:១៧ សក ១៤:២១
**៤៤:១០** ណ ទដ ៩៥:១០ ត ជន ១៨:២៣
**៤៤:១១** ថ ២របា ២៩:៣៤ ទ ជន ៣:៥–៣៧ ១៦:៩ ១របា ២៦:១២–១៩
**៤៤:១២** ធ យរ ១៨:១៥ ន ទដ ១០៦:២៦ ប ២ពវ ១៦:១០–១៦ យរ ១៤:១០
**៤៤:១៣** ផ អគ ១៦:៦១ ព ជន ១៨:៣
**៤៤:១៤** ភ ១សយ ២:៣៦ ២ពវ ២៣:៩ ១របា ២៣:២៨–៣២
**៤៤:១៥** ម ២សយ ៨:១៧ អគ ៧:២

**៤៤:៧** *ជាមនុស្សដែលមិនទទួលកាត់ស្បែកខាងចិត្ត* ដែលគេមិនធ្វើតាមខាងវិញ្ញាណនោះឡើយ ។

**៤៤:៩** *មិនត្រូវសាសន៍ដទៃណាមួយ ក្នុងពួកសាសន៍ដទៃ . . . ជាអ្នកមិនទទួលការកាត់ស្បែកខាងចិត្ត និងរូបសាច់ផង បានចូលទៅក្នុងទីបរិសុទ្ធរបស់អញឡើយ* លោកនេហេមាបានពង្រឹងចិត្តរបស់ខ្លួនចំពោះលក្ខខ័ណ្ឌនេះ នៅពេលដែលគាត់បានបណ្ដេញថូប៊ីយ៉ា (នហ ១៣:៨) ដែលជាសាសន៍អាំម៉ូនចេញ(មើល នហ ២:១០ ចទ ២៣:៣) ។ ទោះជាយ៉ាងណាក្ដី សាសន៍ដទៃនោះ គេនៅតែរស់នៅជាមួយពួកអ៊ីស្រាអែល (មើល ៤៧:២២) ។

**៤៤:១០** *ឯពួកលេវី* សមាជិកខ្លះរបស់ពូជអំបូរលេវីបានបំរើការងារជាសង្ឃ (មើល ចទ ៣៣:៨–១១ ពច ១៧:១៣) ។ *ក្នុងកាលដែលពួកអ៊ីស្រាអែលវង្វេងចេញ* ខនេះគឺសំដៅសំខាន់ទៅលើរបបមួយ ជាពិសេសនៅឆ្នាំចុងក្រោយ នៅពេលដែលលោកអេសេគាល បានរិះគន់ទៅលើបណ្ដាជន ដែលគេគោរពថ្វាយបង្គំដល់រូបព្រះ (មើល ៦:៣–៦ ១៤:៣–១១ ១៦:១៨–២១ ២៣:៣៦–៤៩ ៣៦:១៧–១៨ ៣៧:២៣) ។

**៤៤:១១** *ហើយត្រូវឱ្យគេឈរនៅមុខបណ្ដាជន* ធៀបនឹង ត្រូវឱ្យគេឈរនៅមុខព្រះអម្ចាស់ (មើល ខ.១៥) ពួកលេវីត្រូវមានឥរិយាបទមួយ ដែលគួរឱ្យគោរព ។

**៤៤:១២** *អញបានលើកដៃ* (មើល ២០:៥ និងការពន្យល់) ។

**៤៤:១៥** *សាដុក* មានពូជពង្សមកពីពូជអំបូលេវីទៅគ្រួសារអើរ៉ុន តាមរយៈលោកអេលាសារ ជាកូនប្រុសរបស់អើរ៉ុន (១របា ៦:៥០–៥៣)។ គាត់បានបម្រើការងារជាសង្ឃ ក្រោមការគ្រប់គ្រងរបស់ស្ដេចដាវីឌ ជាមួយនិងលោកអ័បៀថើរ (មើល ២សយ ៨:១៧ និងការពន្យល់ ១៥:២៤–២៩ ២០:២៥) ។ គាត់បានគាំទ្រដល់ស្ដេចសាឡូម៉ូន (ជាអ្នកដែលប្រឆាំងចំពោះអ័បៀថើរ ដែលជាអ្នកបានសន្យាជាមួយអ័ដូនីយ៉ា) ហើយជាអ្នកដែលបានរំដោះខ្លួនឯង និងពូជពង្សរបស់គាត់ ដោយទទួលបាននូវឯកសិទ្ធិ ជាអ្នកបម្រើព្រះនៅក្នុងព្រះវិហារក្រុងយេរូសាឡិម (មើល ១ពវ ១)។ ក្រោយមកកូនចៅរបស់សាដុកបានផ្លាស់ប្ដូរទីកន្លែង ហើយពួកគេស្មោះត្រង់ជាមួយគាត់ ។ *ដែលបានរក្សាបញ្ញើទីបរិសុទ្ធរបស់អញ* លោកអេសេគាលមិនបាននិយាយអ្វីដែលផ្ទុយនៅក្នុងសេចក្ដីទំនាយអំពីការជំនុំជម្រះឡើយ (មើល ៧:២៦ ២២:២៦ និងជំពូក៨)។ នៅក្នុងជំពូក ៤០–៤៨ គេរៀបចំពិធីនោះឱ្យសមរម្យបំផុត ។ ទោះជាយ៉ាងណាក្ដី កូនចៅរបស់សាដុក បានទទួលនូវការរាប់អានដ៏ពិសេស ដោយសារគេមាន សេចក្ដីស្មោះត្រង់ ។ *ដើម្បីនឹង*

ដើម្បីនឹងធ្វើការងារដល់អញវិញ ព្រមទាំងឈរនៅមុខ
អញ ដើម្បីថ្វាយខ្លាញ់[យ]នឹងឈាមផង[រ] ១៦ គេនឹងចូលមកក្នុង
ទីបរិសុទ្ធរបស់អញ ក៏ចូលមកជិតតុ[ល]របស់អញ ដើម្បី
នឹងធ្វើការងារដល់អញ ព្រមទាំងរក្សាបញ្ញើរបស់អញ
ផង[វ] ១៧ កាលណាគេចូលទៅតាមទ្វារកំផែងទីលានខាងក្នុង
នោះគេនឹងត្រូវស្លៀកពាក់ ដោយសំពត់ទេសឯក[ស]ឥតមាន
ស្លៀកពាក់អ្វី ធ្វើពីរោមចៀម កំពុងដែលគេធ្វើការងារ
នៅខាងក្នុងទ្វារ ទីលានខាងក្នុង ហើយក្នុងព្រះវិហារឡើយ
១៨ គេត្រូវជួតឈ្នួត[ហ]ធ្វើពីសំពត់ទេសឯក នៅលើក្បាល
ហើយស្លៀក ខោស្នាប់ភ្លៅ[ឡ]ទេសឯកដែរ គេមិនត្រូវក្រវាត់
ខ្លួន ដោយអ្វីដែលនាំឱ្យបែកញើសទេ[អ] ១៩ រួចកាលណាគេ
ចេញទៅឯទីលានខាងក្រៅ គឺទៅឯបណ្ដាជនដែលនៅ
ទីលានខាងក្រៅ នោះគេត្រូវដោះសំលៀកបំពាក់ ដែលគេ
ស្លៀកពាក់ សំរាប់ធ្វើការងារ ចេញដាក់ទុកក្នុងបន្ទប់
បរិសុទ្ធទាំងប៉ុន្មាន ហើយត្រូវស្លៀកពាក់ផ្សេងវិញ ដើម្បី
មិនឱ្យគេញែក[ក]បណ្ដាជនចេញជាបរិសុទ្ធ ដោយសារ
សំលៀកបំពាក់របស់គេ[ខ] ២០ គេក៏មិនត្រូវកោរ[គ]សក់ ឬទុក
ឱ្យសក់ដុះវែងដែរ គេនឹងគ្រាន់តែកាត់ដិរីមប៉ុណ្ណោះ[ឃ]
២១ មិនត្រូវឱ្យសង្ឃណាមួយផឹកស្រាទំពាំងបាយជូរ ក្នុងកាល
ដែលចូលទៅក្នុងទីលានខាងក្នុងឡើយ[ង] ២២ ក៏មិនត្រូវយក
ស្រីមេម៉ាយ ឬស្រីប្ដីលែង ធ្វើជាប្រពន្ធខ្លួនដែរ គឺត្រូវយក
តែស្រីក្រមុំក្នុងពូជវង្សអ៊ីស្រាអែល ឬស្រីមេម៉ាយណា
ដែលជាប្រពន្ធរបស់សង្ឃពីកាលដើមប៉ុណ្ណោះ[ច] ២៣ គេ
ត្រូវបង្រៀនរាស្ត្រឱ្យចេះសំគាល់របស់បរិសុទ្ធ និងរបស់
ធម្មតា[ឆ] ហើយឱ្យគេមើលដឹងរបស់ស្អាត និងរបស់ដែលមិន
ស្អាត[ជ] ២៤ ឯក្នុងរឿងទាស់ទែងគ្នា នោះត្រូវឱ្យគេឈរជំនុំ
ជំរះ[ឈ]សេចក្ដីត្រូវឱ្យគេជំនុំជំរះ ការណ៍នោះ តាមសេចក្ដី
យុត្តិធម៌របស់អញ ព្រមទាំងរក្សាអស់ទាំងក្រិត្យក្រម និង
បញ្ញត្តច្បាប់របស់អញ នៅអស់ទាំងបុណ្យមានកំណត់របស់
អញផង[ញ] ហើយត្រូវឱ្យគេរក្សាថ្ងៃឈប់សំរាករបស់អញ
ទុកជាទីបរិសុទ្ធដែរ[ដ] ២៥ មិនត្រូវឱ្យគេចូលទៅជិតខ្មោច
ស្លាប់ណា ឱ្យខ្លួនត្រូវសៅហ្មងឡើយ វៀរតែខ្មោចឪពុក
ម្តាយ កូនប្រុសឬកូនស្រី បងប្អូនប្រុសឬប្អូនស្រី ដែលមិន
ទាន់មានប្តីនៅឡើយ នោះគេនឹងឱ្យខ្លួនសៅហ្មង ដោយ
ព្រោះខ្មោចអ្នកទាំងនោះបាន[ឋ] ២៦ រួចកាលណាបានសំអាត
ខ្លួនវិញហើយ នោះត្រូវរាប់៧ថ្ងៃដល់សង្ឃនោះ[ឌ] ២៧ លុះ
ដល់ថ្ងៃដែលចូលទៅក្នុងទីលានខាងក្នុង នៃទីបរិសុទ្ធដើម្បី
នឹងធ្វើការងារក្នុងទីបរិសុទ្ធ[ឍ] នោះត្រូវថ្វាយដង្វាយ[ណ]លោះ
បាបរបស់ខ្លួន នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា ។
២៨ ត្រូវឱ្យកេមរដកដែរ គឺអញជាមរដក[ត]របស់គេ ឯង
រាល់គ្នា មិនត្រូវឱ្យគេមានកេរ្តិ៍អាករ នៅក្នុងស្រុកអ៊ីស្រា–
អែលឡើយ ដ្បិតអញ ជាកេរ្តិ៍អាកររបស់គេហើយ ២៩ គេ
នឹងស៊ី[ថ]ដង្វាយម្សៅ ដង្វាយលោះបាប និងដង្វាយដែល
ថ្វាយដោយព្រោះការរំលង ហើយគ្រប់របស់ទាំងអស់
ដែលបានថ្វាយដាច់ដល់ព្រះ[ទ] នៅក្នុងពួកអ៊ីស្រាអែល នោះ
នឹងបានជារបស់ផងគេទាំងអស់[ធ] ៣០ ឯចំណែកដំបូង[ន] ពីផល

**៤៤:១៥** យ នក ២៩:១៣ រ យរ ៣៣:១៨ អគ ៤០:៤៦ សក ៣:៧ **៤៤:១៦** ល អគ ៤១:២ វ លវ ៣:១៦–១៧ ១៧:៥–៦ ជន ១៨:៥ ១សយ ២:៣៥ សក ៣:៧ **៤៤:១៧** ស វវ ១៩:៨ **៤៤:១៨** ហ នក ២៨:៤២ អស ៣:២០ ឡ នក ២៨:៤២ អ លវ ១៦:៤ **៤៤:១៩** ក លវ ៦:២៧ ខ នក ៣៩:២៧–២៩ លវ ៦:១០–១១ អគ ៤២:១៤ **៤៤:២០** គ អគ ៥:១ ឃ លវ ២១:៥ ជន ៦:៥ **៤៤:២១** ង លវ ១០:៩ **៤៤:២២** ច លវ ២១:៧ **៤៤:២៣** ឆ អគ ២២:២៦ ជ លប ៧:២ លវ ១៣:៥០ ១៥:៣១ យរ ១៥:១៩ ហក ២:១១–១៣

**៤៤:២៤** ឈ ចទ ១៧:៨–៩ ១៩:១៧ ២១:៥ ១របា ២៣:៤ ញ លវ ២៣:២ ដ ២របា ១៩:៨ **៤៤:២៥** ឋ លវ ២១:១–៤ **៤៤:២៦** ឌ ជន ១៩:៤ **៤៤:២៧** ឍ ជន ៣:៣៨ ណ លវ ៤:២៨ ជន ៦:១១ **៤៤:២៨** ត ជន ១៨:២០ ចទ ១៨:១–២ យស ១៣:៣៣ **៤៤:២៩** ថ លវ ៦:១៦ ទ លវ ២៧:២១ ធ ជន ១៨:៩,១៤ យស ១៣:១៤ **៤៤:៣០** ន ១៨:១២–១៣ ២របា ៣១:៥

*ថ្វាយខ្លាញ់ និងឈាមផង* (មើល ៣៩:១៩ និងការពន្យល់) ។

**៤៤:១៦** *គេនឹងចូលមកក្នុង* នេះគឺជាការលើកដំកើងដល់សង្ឃនៃពួកកូនចៅសាដុក ហើយមិនបានលើកដំកើងដល់ពួកលេវី ដោយគេលែងជាអ្នកបរិសុទ្ធទៀតឡើយ សាច់រឿងដ៏សំខាន់ នៅក្នុងជំពូក ៤០–៤៨ ។ ជិតតុរបស់អញ តុនោះគេរៀបចំសម្រាប់ដាក់នំប៉័ង (មើល ៤១:២២ និងការពន្យល់) រឺអាសនា ធំនោះជាទីកន្លែងសម្រាប់លាងព្រះអម្ចាស់ (ខ.១៧)។

**៤៤:១៧** *សំពត់ទេសឯក* មានពណ៌ស្រស់ជាងរោមចៀម (មើល ខ.១៨) ។

**៤៤:១៨** *ឈ្នួត* លោកអេសេគាលបានពាក់ឈ្នួតនោះ (មើល ២៤:១៧) ។

**៤៤:១៩** *នោះគេត្រូវដោះសំលៀកបំពាក់* នៅក្នុងលក្ខណៈមួយ ឱ្យគេបានបរិសុទ្ធ ។

**៤៤:២០** *គេមិនត្រូវកោរសក់* ពីព្រោះវាគឺជាការកាន់ទុក្ខមួយ ដែលធ្វើឱ្យអ្នកកាន់ទុក្ខមិនបរិសុទ្ធ (មើល ៧:១៨ លវ ២១:១–៥ ឬទុកឱ្យសក់ដុះវែងដែរ។ ពីព្រោះវាគឺជាបញ្ជាក់ពីសេចក្ដីសន្យាដែលការពារពួកសង្ឃពីការ ដែលគេបម្រើព្រះនោះ (មើល ជន ៦:៥ កច ២១:២៣–២៦) ។

**៤៤:២៣** *ឱ្យចេះសំគាល់របស់បរិសុទ្ធ និងរបស់ធម្មតា* នេះការការយកចិត្តទុកដាក់មួយដ៏សំខាន់របស់លោកអេសេគាល ។ នេះជាភារកិច្ចដ៏សំខាន់នៃការប្រកាសបំណងព្រះហឫទ័យរបស់ព្រះ សម្គាល់ទៅលើម្ហូបណាដែលស្អាត ហើយម្ហូបណាដែលមិនស្អាត ដែលគេត្រូវរៀបចំនូវយញ្ញបូជាដែលបរិសុទ្ធ (មើល មីក ៣:១១) រឺមិនត្រូវធ្វើឱ្យតែបាននោះទេ (មើល យរ ២:៨ អគ ២២:២៦ និងការពន្យល់) មើល ហក ២:១០–១៣ ជាឧទាហរណ៍វិជ្ជមាន ។ *ហើយគេមើលដឹងរបស់ស្អាត និងរបស់ដែលមិនស្អាត* (មើល លវ ១១ ចទ ១៤:៣–២១ និងការពន្យល់)។

**៤៤:២៤** *នោះត្រូវឱ្យគេឈរជំនុំជម្រះសេចក្ដី* នេះជាមុខងារមួយរបស់សង្ឃនៅក្នុងមុខងាររបស់គេជាច្រើនទៀត នៅថ្ងៃជំនាន់ដើម (មើលការពន្យល់ ១សយ ៤:១៨ និងមើលផងដែរ ១៩:៨–១១) ។

**៤៤:២៥** *ខ្មោចស្លាប់* ទាក់ទងជាមួយនឹងខ្មោចពេលដែលមនុស្សគេរៀបចំពិធីសពនោះ (មើល លវ ២១:១–៣ ហក ២:១៣) ។

**៤៤:២៨** *មិនត្រូវឱ្យគេមានកេរ្តិ៍អាករ* ឃ្លានេះមានន័យថាសង្ឃមិនអនុញ្ញាត្តឱ្យមានដីជារបស់កម្មសិទ្ធផ្ទាល់ខ្លួនឡើយ (មើល នហ ១៨:២០,២៣–២៤ ចទ ១០:៩ យស ១៣:១៤,៣៣ ១៨:៧) ។

ដំបូងគ្រប់យ៉ាង និងអស់ទាំងដង្វាយដែលថ្វាយ ដោយលើក
ចុះឡើងគ្រប់មុខ ពីអស់ទាំងដង្វាយលើកចុះ ឡើងរបស់ឯង
រាល់គ្នា នោះសុទ្ធតែជារបស់ផងពួកសង្ឃ ឯងរាល់គ្នាក៏
ត្រូវឱ្យម្សៅដំបូងរបស់ឯង[ប] ដល់ពួកសង្ឃដែរ ដើម្បីឱ្យបាន
ព្រះពរ[ផ]ស្ថិតលើផ្ទះឯង[ព] ៣១ពួកសង្ឃមិនត្រូវស៊ីអ្វីដែល
ស្លាប់[ភ]ដោយខ្លួនឯង ឬដែលសត្វណាបានហែកហួរ ទោះ
បើជាសត្វហើរ ឬសត្វជើង៤ក្តី[ម]។

## ការបែងចែកទឹកដី

**៤៥** ១មួយទៀត កាលណាឯងរាល់គ្នា បានឆ្នោតចែក
ស្រុកជាមរដក[ក] នោះត្រូវឱ្យថ្វាយដង្វាយ១ដល់ព្រះយេហូវ៉ា
ជាចំណែកបរិសុទ្ធនៃស្រុកនោះ[ខ] បណ្តោយត្រូវជា ម៉ឺន៥
ពាន់ខ្នាត ហើយទទឹង១ម៉ឺនខ្នាត ដីនោះត្រូវតែបានបរិសុទ្ធ
នៅគ្រប់ក្នុងព្រំដែនជុំវិញ ២ក្នុងដីនោះត្រូវឱ្យមានកន្លែង
សំរាប់ទីបរិសុទ្ធ ប្រវែង៥០០[គ] និងទទឹង៥០០ គឺ៤ជ្រុងស្មើ
ថែមទាំង៥០ហត្ថ នៅព័ទ្ធជុំវិញសំរាប់ជា វាលទំនេរ ៣ត្រូវ
ឱ្យយករង្វាស់ដដែល ដើម្បីវាស់ដីម្តុំ បណ្តោយ២ម៉ឺន៥ពាន់
ហើយទទឹង១ម៉ឺន ឯទីបរិសុទ្ធ ដែលជាបរិសុទ្ធបំផុត នោះ
នឹងនៅក្នុងដីម្តុំនោះ ៤នេះជាចំណែកដីដែលបរិសុទ្ធ ត្រូវ
ទុកសំរាប់ពួកសង្ឃ[ឃ] ជាពួកអ្នកដែលធ្វើការងារក្នុងទី
បរិសុទ្ធ ហើយចូលមកជិត ដើម្បីធ្វើការងារថ្វាយព្រះ
យេហូវ៉ា ដីនោះនឹងត្រូវទុកសំរាប់ជាទីសង់ផ្ទះរបស់គេ
ហើយជាកន្លែងបរិសុទ្ធសំរាប់ទីបរិសុទ្ធ[ង] ៥ហើយត្រូវមានដី
បណ្តោយ២ម៉ឺន៥ពាន់ និងទទឹង១ម៉ឺន សំរាប់ពួកលេវី ជា
ពួកអ្នកដែលធ្វើការងារក្នុងព្រះវិហារ ទុកសំរាប់ជាកេរ្តិ៍
អាករដល់គេ ឱ្យគេបានទីក្រុងអាស្រ័យនៅ[ច] ៦ហើយត្រូវឱ្យ
ឯងរាល់គ្នាដំរូវទុកដីរបស់ផងទីក្រុង ទទឹង៥ពាន់ បណ្តោយ
២ម៉ឺន៥ពាន់ ទន្ទឹមនឹងដីបរិសុទ្ធ ដែលបានថ្វាយដល់ព្រះ
ហើយ នោះនឹងបានសំរាប់ពួកវង្សអ៊ីស្រាអែលទាំងអស់
គ្នា[ឆ] ៧ត្រូវឱ្យមាន១ចំណែកសំរាប់ចៅហ្វាយ នៅទាំងសង
ខាងនៃដីបរិសុទ្ធ ដែលបានថ្វាយដល់ព្រះនោះ និងដីរបស់
ផងទីក្រុង គឺខាងមុខដីជាដង្វាយបរិសុទ្ធ និងដីរបស់ទីក្រុង
នោះ តាំងពីព្រំខាងលិច ចេញទៅខាងលិច ហើយពីព្រំ
ខាងកើតចេញទៅខាងកើត ហើយប្រវែងដីនោះនឹងត្រូវ
បានស្មើនឹងដី១ចំណែក ចាប់តាំងពីព្រំស្រុកខាងលិច ទៅ
ដល់ព្រំស្រុកខាងកើត[ជ] ៨នោះនឹងបានជាដីរបស់ផងលោក
ទុកជាកេរ្តិ៍អាករ នៅក្នុងស្រុកអ៊ីស្រាអែល អស់ទាំងចៅ
ហ្វាយរបស់អញ នឹងមិនសង្កត់សង្កិនរាស្ត្រអញទៀតឡើយ
គឺនឹងចែកស្រុកនោះដល់ពួកវង្សអ៊ីស្រាអែល តាមពូជអំបូរ
របស់គេ[ឈ]។

៩ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ឱពួក
ចៅហ្វាយនៃសាសន៍អ៊ីស្រាអែលអើយ ល្មមហើយ ចូរលះ
បង់សេចក្តីច្រឡោត និងការរឹបជាន់[ញ]ចេញ ហើយសំរេច

**៤៤:៣០** ប ជន ១៥:១៨–២១ ផ លវ ២៥:២១
ព ២រប ៣១:១០ នហ ១០:៣៥–៣៧
**៤៤:៣១** ភ លវ ១១:៣៩ ម នក ២២:៣១ លវ ១១:៤០
**៤៥:១** ក ជន ៣៤:១៣ ខ អគ ៤៨:៨–៩,២៩
**៤៥:២** គ អគ ៤២:២០
**៤៥:៤** ឃ អគ ៤០:៤៦
ង អគ ៤៨:១០–១១
**៤៥:៥** ច អគ ៤៨:១៣
**៤៥:៦** ឆ អគ ៤៨:១៥–១៨
**៤៥:៧** ជ អគ ៤៨:២១
**៤៥:៨** ឈ ជន ២៦:៥៣ អគ ៤៦:១៨
**៤៥:៩** ញ ទដ ១២:៥

**៤៤:៣១** *អ្វីដែលស្លាប់ដោយខ្លួនឯង* ពួកអ៊ីស្រាអែលបានអនុវត្ត ចំពោះលក្ខខ័ណ្ឌនេះទាំងអស់គ្នា ដោយយោងទៅលើខព្រះគម្ពីរ លវ ៧:២៤)។

**៤៥:១–៤៦:២៤** ការពណ៌នាអំពីគំនិតយ៉ាងល្អ ចំពោះការស្អាងដល់ពួកអ៊ីស្រាអែលឡើងវិញ ដែលគេបានគោរពដល់ព្រះ ។

**៤៥:១** *កាលណាឯងរាល់គ្នាចាប់ឆ្នោតចែកស្រុកជាមរដក* គេបានគិតថា គេនឹងទទួលយកទឹកដីដែលគេបានបែងចែកគ្នា ។ *នោះត្រូវឱ្យថ្វាយដង្វាយ១ដល់ព្រះអម្ចាស់* ផ្ទៃដីនោះគឺ៤ជ្រុងស្មើ ហើយនៅផ្នែកកណ្តាលនៃចំណុចនោះ គឺញែកទុកសម្រាប់ព្រះអម្ចាស់ ដែលមានប្រវែង២ម៉ឺន និងទទឹង៥ពាន់ (ខ.៦) ប្រវែងនោះគឺ៤ជ្រុងស្មើល្អឥតខ្ចោះ ។ *ដីនោះត្រូវតែបរិសុទ្ធ នៅគ្រប់ក្នុងព្រំដែនជុំវិញ* ដីនោះញែកសម្រាប់ព្រះអម្ចាស់ មិនត្រូវទុកដល់ពួកអំបូណាមួយឡើយ ។

**៤៥:២** *ប្រវែង៥០០ និងទទឹង៥០០ គឺ៤ជ្រុងស្មើ* ផ្ទៃដីនៃព្រះវិហារនោះ បានពិភាក្សានៅក្នុង ៤២:១៦–២០ ។ *សម្រាប់ជាវាលទំនេរ* ដីមួយក្បាលដែលបានច្បាំងយកបាននោះ ទុកជាទីកន្លែងបែងចែក សម្រាប់ដីដែលបរិសុទ្ធ និងដីដែលមិនបរិសុទ្ធ ហើយព្រំដែនដីទាំងនោះ ត្រូវតែបរិសុទ្ធ (មើល ៤២:២០)។

**៤៥:៣** *ដើម្បីនឹងវាស់ដី* ដីនៅចំកណ្តាលដែលមាន៤ជ្រុងស្មើ ជាដីបរិសុទ្ធជាពិសេសសម្រាប់ព្រះវិហារ ។

**៤៥:៤** *នេះជាដីបរិសុទ្ធ ទុកសម្រាប់សង្ឃ* ដែលសង្ឃមិនត្រូវយកធ្វើជា របស់ផ្ទាល់ខ្លួនឡើយ តែសម្រាប់តែការស្នាក់នៅប៉ុណ្ណោះ (មើល ៤៤:២៨)។

**៤៥:៥** *ដីនោះសម្រាប់ពួកលេវី* ដីនៅទីនោះត្រូវមានទំហំស្មើគ្នា ចាប់ពីទិសខាងជើងទៅ គឺសម្រាប់ពួកលេវីរស់នៅ ទោះដីនៅទីនោះជាទីកន្លែងបរិសុទ្ធក្តី ហើយពួកលេវីជាជាអ្នកប្រឆាំងជាមួយនឹងពួកកូនចៅសាដុកដែលជាសង្ឃនោះ ហើគេអាចកាន់កាប់ទឹកដីនោះ ជាកម្មសិទ្ធិរបស់គេបាន។

**៤៥:៦** *ទីក្រុង* ជាទីធ្លាដែលជាទីកន្លែងចាស់របស់ក្រុងយេរូសាឡិម ហើយមិនមែនជាទីក្រុងថ្មីបរិសុទ្ធទេ តែវាជាទីក្រុងដែលនៅជិតនឹងព្រះវិហារ ដែលទទឹងមាន៥ពាន់ ជាដីមួយដែលនៅឆ្ងាយពីទីក្រុង ដោយមានទំហំ៤ជ្រុងស្មើគ្នា ។ *ដីនោះនឹងបានសម្រាប់ពួកវង្សអ៊ីស្រាអែលទាំងអស់គ្នា* ដីនោះមិនមែនសម្រាប់ពូជអំបូរណាឡើយ ឬសម្រាប់អ្នកណាដូចជានៅថ្ងៃនៃជំនាន់ដើមឡើយ ។

**៤៥:៧** *ត្រូវឱ្យមាន១ចំណែកសម្រាប់ចៅហ្វាយ* ចំណែកទឹកដីដែលបានច្បាំងយកបាន នៅក្នុងខបន្ទាប់ទៀត (ធៀននឹង ៤៦:១៨) ការបែងចែកទឹកដីដោយយុតិធម៌ ហើយពួកចៅហ្វាយមិនត្រូវលោភលន់នោះឡើយ ដូចជាលោកអាហាប់ (មើល ១ពវ ២១)។ ពួកចៅហ្វាយគឺទទួលខុសត្រូវផងដែរ ចំពោះដង្វាយជាច្រើននោះ (មើល ខ.១៧)។

**៤៥:៩** *ឱពួកចៅហ្វាយនៃសាសន៍អ៊ីស្រាអែលអើយ* ព្រះបន្ទូលនៅត្រង់ខនេះ គឺនិយាយសំដៅលើសេចក្តីអធិប្បាយរបស់លោកអេសេគាល ដែលគាត់បានថ្លែងមុនឆ្នាំ ៥៨៦ គ.ស (មើល ២២:៦)។ ហើយសំរេចសេចក្តីយុតិធម៌ និង

តាមសេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិតចុះ[ដ] ត្រូវឱ្យដក
លែងការស៊ីបំបាត់រាស្ត្រអញចេញ នេះជាព្រះបន្ទូលនៃ
ព្រះអម្ចាស់យេហូវ៉ា ១០ត្រូវឱ្យមានជញ្ជីងត្រឹមត្រូវ[ឋ] និង
អេផា[ឌ] ហើយបាថពេញខ្នាតដែរ ១១ឯអេផានិងបាថ[ឍ]នោះ
ត្រូវមានចំណុះស្មើគ្នា ដើម្បីឱ្យបាថ១នោះ ត្រូវជា១ភាគ
ក្នុង១០ ក្នុង១ហូមើរដូចគ្នា រង្វាស់នោះរាប់តាមហូមើរ
១២ឯប្រាក់សេកិល នោះត្រូវជា២០គេរ៉ា[ណ] ហើយ១ម៉ានេ
របស់ឯងត្រូវនឹង២០ នឹង២៥ ហើយ១៥សេកិល ។

## ដង្វាយ និងថ្ងៃបុណ្យ

១៣នេះជាដង្វាយដែលឯងរាល់គ្នាត្រូវថ្វាយ គឺក្នុងស្រូវ
ភោជ្ជសាលី១ហូមើរ ត្រូវថ្វាយ១ភាគក្នុង៦ ក្នុង១អេផា
ហើយក្នុងស្រូវឱក១ហូមើរ ត្រូវថ្វាយ១ភាគក្នុង៦ ក្នុង១
អេផាដែរ ១៤ឯកំណត់ប្រេងដែលត្រូវថ្វាយក្នុងប្រេង១ បាថ
នោះគឺក្នុង១គ័រ ត្រូវថ្វាយ១ភាគក្នុង៥ក្នុង ១បាថ ឯ១គ័រ
នោះស្មើនឹង១ហូមើរ គឺត្រូវជា១០បាថ ដ្បិត១០បាថត្រូវជា
១ហូមើរដែរ ១៥ឯហ្វូងចៀម នោះត្រូវយក១ក្នុង២០០ ដែល
រកស៊ីនៅវាលស្មៅយ៉ាងល្អនៅ ស្រុកអ៊ីស្រាអែលមកថ្វាយ
ព្រមទាំងដង្វាយម្សៅ ដង្វាយដុត[ត] និងដង្វាយមេត្រី ដើម្បីឱ្យ
បានធួន[ថ]នឹងគេ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា
១៦បណ្ដាជនទាំងឡាយនៅក្នុងស្រុក ត្រូវច្រាក់គ្នាថ្វាយ
ដង្វាយនេះសំរាប់ចៅហ្វាយនៃសាសន៍អ៊ីស្រាអែល ១៧ឯ
ដង្វាយដុត ដង្វាយម្សៅ និងដង្វាយច្រួច នៅថ្ងៃបុណ្យ នៅ
ថ្ងៃដើមខែ[ទ] ហើយនៅថ្ងៃឈប់សំរាក[ធ] គឺនៅគ្រប់ទាំង
បុណ្យមានកំណត់របស់ពួកវង្សអ៊ីស្រាអែល នោះស្រេចនៅ
លើចៅហ្វាយវិញ លោកត្រូវរៀបចំដង្វាយសំរាប់លោះ
បាប ដង្វាយម្សៅ ដង្វាយ ដុត និងដង្វាយមេត្រី ដើម្បីឱ្យបាន
ធួននឹងពួកវង្សសាសន៍អ៊ីស្រាអែល[ន] ។
១៨ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា លុះ
ដល់ថ្ងៃទី១ ក្នុងខែដំបូង[ប] នោះត្រូវឱ្យឯងយកគោឈ្មោល
ស្ទាវ១ឥតខ្ចោះ[ផ] ហើយត្រូវសំអាតទីបរិសុទ្ធ[ព] ១៩ឯសង្ឃ
ត្រូវយកឈាមដង្វាយលោះបាបនោះ ទៅប្រឡាក់នៅក្រប
ទ្វារព្រះវិហារ ហើយនៅគន្លាក់[ភ]នៃអាសនាទាំង៤ជ្រុងព្រម
ទាំងនៅក្របទ្វារកំផែងនៃទីលានខាងក្នុងផង[ម] ២០ហើយ
នៅថ្ងៃទី៧ខែនោះ ត្រូវធ្វើដូចគ្នាទៀត សំរាប់អស់អ្នក
ណាដែលវង្វេងចេញ[យ] ហើយសំរាប់អ្នកណាដែលខ្លៅល្ងង់
ដែរ យ៉ាងនោះឯងនឹងបានធួននឹងព្រះវិហារ ។
២១លុះដល់ថ្ងៃ១៤ក្នុងខែដំបូង នោះត្រូវឱ្យឯងរាល់គ្នា
ធ្វើបុណ្យរំលង[រ] ជាបុណ្យដែលត្រូវធ្វើអស់៧ថ្ងៃហើយត្រូវ
ស៊ីតែនំបុ័ងឥតដំបែម្យ៉ាង ២២នៅថ្ងៃនោះចៅហ្វាយត្រូវ
រៀបចំគោឈ្មោល១ ទុកជាដង្វាយលោះបាប សំរាប់ខ្លួន
លោក និងបណ្ដាជននៅក្នុងស្រុកដែរ[ល] ២៣ហើយក្នុងរវាង
៧ថ្ងៃនៃបុណ្យ នោះលោកត្រូវរៀបចំដង្វាយដុតថ្វាយព្រះ
យេហូវ៉ា គឺគោឈ្មោល៧ និងចៀមឈ្មោល[វ]៧ ឥតខ្ចោះ
រាល់ៗថ្ងៃគ្រប់៧ថ្ងៃនោះ ព្រមទាំងពពែឈ្មោល១រាល់ថ្ងៃ
ដែរ ទុកជាដង្វាយលោះបាប[ស] ២៤ក៏ត្រូវរៀបដង្វាយម្សៅ[ហ]
ដែរ គឺត្រូវយក១ថាំងសំរាប់គោ១ និង១ថាំងសំរាប់ចៀម
ឈ្មោល១ ហើយប្រេង៨កំប៉ុងសំរាប់ម្សៅ១ថាំង[ឡ] ២៥ដល់
ថ្ងៃ១៥ខែអស្សុជ ក្នុងពេលបុណ្យនោះ[អ] លោកត្រូវធ្វើ

**៤៥:៩** ដ យរ ២២:៣ សក ៧:៩–១០ ៨:១៦ **៤៥:១០** ឋ ចទ ២៥:១៥ សភ ១១:១ អម ៨:៤–៦ មីក ៦:១០–១១ ឌ លវ ១៩:៣៦ **៤៥:១១** ឍ អស ៥:១០ **៤៥:១២** ណ នក ៣០:១៣ លវ ២៧:២៥ ជន ៣:៤៧ **៤៥:១៥** ត លវ ១:៤ ថ លវ ៦:៣០ **៤៥:១៧** ទ ជន ១០:១០ ធ លវ ២៣:៣៨ អស ៦៦:២៣ ន ១ពវ ៨:៦២ ២របា ៣១:៣ អគ ៤៦:៤–១២ **៤៥:១៨** ប នក ១២:២ ផ លវ ២២:២០ ហព ៩:១៤ ព លវ ១៦:១៦,៣៣ **៤៥:១៩** ភ អគ ៤៣:១៧ ម លវ ១៦:១៨–១៩ **៤៥:២០** យ លវ ៤:២៧ **៤៥:២១** រ នក ១២:១១ **៤៥:២២** ល លវ ៤:១៤ **៤៥:២៣** វ ជន ២២:៤០ យប ៤២:៨ ស ជន ២៨:១៦–២៥ **៤៥:២៤** ហ ជន ២៨:១២–១៣ ឡ អគ ៤៦:៥–៧ **៤៥:២៥** អ ចទ ១៦:១៣

សេចក្ដីសុចរិតចុះ (មើលការពន្យល់ ៣៣:១៤) ។

**៤៥:១០** *ត្រូវឱ្យមានជញ្ជីងត្រឹមត្រូវ* ពួកអ៊ីស្រាអែលមិនត្រូវធ្វើអ្វីទៅតាមសេដ្ឋកិច្ចដែលប្រែប្រួល ដូចជានៅកាលពីជំនាន់មុនឡើយ ។ នៅសម័យជំនាន់សញ្ញាចាស់ តែងតែព្រមានប្រឆាំង ចំពោះការបោកប្រាស់ នៅពេលដែលវាស់ និងថ្លឹងជញ្ជីងមិនត្រឹមត្រូវ (មើល លវ ១៩:៣៥ និងការពន្យល់ ចទ ២៥:១៣–១៦ មីក ៦:១០–១២) ។

**៤៥:១១** *ត្រូវមានចំណុះស្មើគ្នា* ទោះបីជាកញ្ចេះនោះតូចជាងគ្នាបន្តិចក្ដី។ *១ហូមើរ* ស្មើនឹង៦កញ្ចេ ។

**៤៥:១៣** *ដង្វាយ* ដង្វាយដែលបានបែងចែកដល់ពួកចៅហ្វាយ ជាដង្វាយដែលបានមកពីសង្ឃ(៤៤:៣០)។ ពួកចៅហ្វាយគេប្រើប្រាស់ដង្វាយនេះមួយផ្នែក ក្នុងការថ្វាយដល់ព្រះអម្ចាស់ (មើល ខ.១៦) ។

**៤៥:១៥** *ដើម្បីឱ្យធួននឹងគេ* (មើលការពន្យល់ នក ២៥:១៧ លវ ១៦:២០–២២ ១៧:១១ រម ៣:២៥) ។

**៤៥:១៦** *បណ្ដាជនទាំងឡាយនៅក្នុងស្រុក* (មើល ខ.២២ ៧:២៧ និងការពន្យល់) ។

**៤៥:១៧** ដង្វាយច្រួច ជាធម្មតាស្រាគឺមានន័យ (មើល នក ១៥:៥ ហស ៩:៤ ប៉ុន្តែស្រា និងប្រេងក៏មិនបានលើកយកមកនិយាយនៅទីនេះទេដែរ (មើល ខ.១៤,២៤) ។

**៤៥:១៨–៤៦:២៤** ចូលដល់ផ្នែកនេះ វាមានការផ្លាស់ប្ដូរជាច្រើនពីសៀវភៅក្រិត្យវិន័យ ដែលគ្រូខាងក្រិត្យវិន័យបានព្យាយាម ដើម្បីផ្សះផ្សារគេ ។ ឧទាហរណ៍អំពីការបែកចែកនៅក្នុង ៤៥:១៨ សំរាប់ពិធីញែកជាបរិសុទ្ធប្រចាំឆ្នាំរបស់ព្រះវិហារ ដែលមិនបានគិតដល់ថ្ងៃ ដែលគេទទួលទោសនោះនៅក្នុង លវ ១៦ ។

**៤៥:១៩** *សង្ឃ* សម្ដេចសង្ឃ ។

**៤៥:២០** *សម្រាប់អស់អ្នកណាដែលវង្វេងចេញ ហើយសម្រាប់អ្នកណាដែលខ្លៅល្ងង់ដែរ* មើល ជន ១៥:២២–៣០ និងការពន្យល់)។

**៤៥:២២** ទុកជាដង្វាយលោះបាប មើលការពន្យល់ ៤០:៣៩ ។

**៤៥:២៥** *នៅខែអស្សុជ ក្នុងពេលបុណ្យនោះ* លោកត្រូវធ្វើដូច្នេះទៀតគ្រប់ទាំង៧ថ្ងៃ នៅក្នុងការគោរពខ្លះ ពិធីបុណ្យដ៏សំខាន់បំផុត ឈ្មោះថាពិធីបុណ្យប្រមូលផល (មើល នក ២៣:១៦ ៣៤:២២) និងពិធីបុណ្យនៃរោងឧបោសថ

ដូច្នោះទៀតគ្រប់ទាំង៧ថ្ងៃ តាមរបៀបដង្វាយលោះបាប
ដង្វាយដុត ដង្វាយម្សៅ និងដង្វាយប្រេងដែរ[ក]។

**៤៦** ១ ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ទ្វារ
កំផែងនៃទីលានខាងក្នុង[ក] ដែលបើកទៅទិសខាងកើត[ខ]
នោះត្រូវបិទ នៅក្នុងរវាង៦ថ្ងៃដែលធ្វើការ តែដល់ថ្ងៃ
ឈប់សំរាកនោះត្រូវបើកវិញ ព្រមទាំងនៅថ្ងៃចូលខែ[គ]ដែរ
២ឯចៅហ្វាយលោក នឹងចូលតាមផ្លូវបាំងសាច នៃទ្វារ
កំផែងខាងក្រៅ ហើយនឹងឈរនៅជិតបង្គោល[ឃ]ទ្វារ ពួក
សង្ឃនឹងរៀបដង្វាយដុត[ង] និងដង្វាយមេត្រីរបស់លោក
ហើយលោកនឹងថ្វាយបង្គំនៅត្រង់ទ្វារនោះ រួចលោកនឹង
ចេញទៅវិញ តែទ្វារនោះមិនត្រូវបិទដរាបដល់ល្ងាច[ច]
៣ឯបណ្តាជននៅក្នុងស្រុក គេនឹងថ្វាយបង្គំដល់ព្រះយេហូវ៉ា
នៅមាត់ទ្វារនោះ[ឆ] រាល់ថ្ងៃឈប់សំរាក[ជ] និងថ្ងៃចូល
ខែដែរ ៤ឯដង្វាយដុត ដែលចៅហ្វាយត្រូវថ្វាយដល់ព្រះ
យេហូវ៉ា នៅថ្ងៃឈប់សំរាក នោះគឺកូនចៀម៦ឥតខ្ចោះ
និងចៀមឈ្មោល១ឥតខ្ចោះ ៥ហើយដង្វាយម្សៅត្រូវជា១
ថាំង សំរាប់ចៀមឈ្មោលនោះ ហើយដង្វាយម្សៅដែល
សំរាប់កូនចៀមទាំងនោះ ត្រូវតាមដែលលោកអាចនឹង
ថ្វាយបាន ព្រមទាំងប្រេង៨កំប៉ុងសំរាប់ម្សៅ១ថាំងផង[ឈ]។
៦លុះដល់ថ្ងៃចូលខែ[ញ] ត្រូវថ្វាយគោឈ្មោលស្ទាវ១ ឥត
ខ្ចោះ កូនចៀម៦ និងចៀមឈ្មោល១ សុទ្ធតែឥតខ្ចោះទាំង
អស់[ដ] ៧លោកក៏ត្រូវរៀបដង្វាយម្សៅ១ថាំង សំរាប់គោ
ឈ្មោល និង១ថាំងសំរាប់ចៀមឈ្មោលនោះ តែឯកូន
ចៀមវិញ នោះត្រូវតាមដែលលោកអាចនឹងថ្វាយបាន ព្រម
ទាំងប្រេង៨កំប៉ុងសំរាប់ម្សៅ១ថាំងផង[ឋ] ៨កាលណាចៅ
ហ្វាយចូល នោះលោកត្រូវចូលតាមផ្លូវបាំងសាច[ឌ]នៃទ្វារ
កំផែង ហើយក៏ត្រូវចេញទៅវិញ តាមផ្លូវដដែលដែរ[ឍ]។
៩ប៉ុន្តែកាលណាពួកជនក្នុងស្រុកចូលមក នៅចំពោះ
ព្រះយេហូវ៉ា នៅវេលាថ្ងៃបុណ្យមានកំណត់[ណ] នោះអ្នកណា
ដែលចូលតាមផ្លូវទ្វារទិសខាងជើង ដើម្បីនឹងថ្វាយបង្គំ
ត្រូវតែចេញទៅតាមផ្លូវនៃទ្វារខាងត្បូងវិញ ហើយអ្នកណា
ដែលចូលតាមផ្លូវទ្វារទិសខាងត្បូង នោះត្រូវតែចេញតាម
ផ្លូវទ្វារខាងជើងទៅ គេមិនត្រូវវិលទៅវិញ តាមផ្លូវនៃទ្វារ
ដែលគេបានចូលនោះឡើយ គឺត្រូវចេញទៅតាមផ្លូវត្រង់
ខាងមុខជារហូតទៅ ១០ហើយកាលណាគេចូលទៅ នោះ
ចៅហ្វាយនឹងចូលទៅនៅកណ្តាលពួកគេ រួចកាលណា
គេចេញទៅ នោះនឹងចេញទៅជាមួយគ្នាដែរ[ត]។
១១រីឯនៅថ្ងៃបុណ្យ និងបុណ្យមានកំណត់ នោះត្រូវ
ថ្វាយដង្វាយម្សៅ ជា១ថាំងសំរាប់គោឈ្មោល១ និង១ថាំង
សំរាប់ចៀមឈ្មោល១ ហើយត្រង់កូនចៀមទាំងប៉ុន្មាន
នោះត្រូវតាមតែលោកអាចនឹងថ្វាយបាន ហើយប្រេងត្រូវ
ជា៨កំប៉ុងសំរាប់ម្សៅ១ថាំង[ថ] ១២កាលណាចៅហ្វាយនឹង
ថ្វាយ[ទ]ដង្វាយស្ម័គ្រពីចិត្ត[ធ] ជាដង្វាយដុត ឬដង្វាយមេត្រី ទុក
ជាដង្វាយថ្វាយដល់ព្រះយេហូវ៉ាស្ម័គ្រពីចិត្ត នោះត្រូវឱ្យគេ
បើកទ្វារខាងកើតនោះ ជូនលោក រួចលោកនឹងរៀប
ដង្វាយដុតនឹងដង្វាយមេត្រីរបស់លោក ដូចជាធ្លាប់ធ្វើនៅ
ថ្ងៃ ឈប់សំរាកដែរ ស្រេចហើយ លោកនឹងចេញទៅ លុះ
លោកបានចេញទៅហើយ នោះគេនឹងបិទទ្វារវិញ[ន]។
១៣រាល់តែថ្ងៃ ត្រូវឱ្យរៀបកូនចៀម១ឥតខ្ចោះ អាយុ
១ខួប ទុកជាដង្វាយដុតថ្វាយដល់ព្រះយេហូវ៉ា ត្រូវថ្វាយ

**៤៥:២៥** ក លវ ២៣:៣៤-៤៥,ជន ២៩:១២-៣៨
**៤៦:១** ក អគ ៤០:១៩ ខ ១របា ២៣:៣៤-៤៣ គ ខ.៦ អស ៦៦:២៣
**៤៦:២** ឃ ខ.៨ ង អគ ៤០:៣៩ ច ខ.១២ អគ ៤៤:៣
**៤៦:៣** ឆ លក ១:១០ ជ អស ៦៦:២៣
**៤៦:៥** ឈ ខ.១១
**៤៦:៦** ញ ខ.១ ជន ១០:១០ ដ លវ ២២:២០
**៤៦:៧** ឋ អគ ៤៥:២៤
**៤៦:៨** ឌ ខ.២ ឍ អគ ៤៤:៣
**៤៦:៩** ណ នក ២៣:១៤ ៣៤:២០
**៤៦:១០** ត ២សយ ៦:១៤-១៥ ទដ ៤២:៤
**៤៦:១១** ថ ខ.៥
**៤៦:១២** ទ អគ ៤៥:១៧ ធ លវ ៧:១៦ ន ខ.២

(មើល ចទ ១៦:១៦ និងការពន្យល់ សក ១៤:១៦)។
**៤៦:១** *ទ្វារកំផែងនៃទីលានខាងក្នុង* នៅពេលដែលទ្វារខាងកើតនៃទីលានខាងក្រៅ គឺតែងតែបិទជានិច្ច (៤៤:២) ហើយទ្វារខាងកើតនៃទីលានខាងក្នុងនឹងត្រូវបើកនៅថ្ងៃបុណ្យនានា ។
**៤៦:២** *លោកនឹងចូលតាមផ្លូវបាំងសាចនៃទ្វារកំផែងខាងក្រៅ* ផ្លូវបាំងសាចនៃទ្វារទីលានខាងក្នុង ទល់មុខនឹងទីខាងក្រៅ ហើយនឹងឈរនៅជិតបង្គោលទ្វារ ទីនោះត្រូវតែសម្អាតឱ្យបានល្អ (មើល ៤៥:១៩) នៅទីនោះដែលពួកចៅហ្វាយ អាចពិនិត្យមើលយញ្ញបូជាដែលគេដុតនៅទីអាសនាធំ នៅទីលានខាងក្នុង ហើយពួកគេក៏មិនអនុញ្ញាតឱ្យចូលទៅទីលានខាងក្នុងឡើយ ។
**៤៦:៣** *ឯបណ្តាជននៅក្នុងស្រុក* (មើលការពន្យល់ ៧:២៧ នៅមាត់ទ្វារនោះ រាល់ថ្ងៃឈប់សំរាក ប៉ុន្តែវានៅខាងក្នុងទីលានខាងក្រៅ ។
**៤៦:៤** *នោះគឺកូនចៀម៦ឥតខ្ចោះ និងចៀមឈ្មោល១ឥតខ្ចោះ* នេះជាឧទាហរណ៍មួយផ្សេងទៀត ពីភាពខុសគ្នាក្នុងសៀវភៅក្រិត្យវិន័យ (មើលការពន្យល់ ៤៥:១៨-៤៦:២៤)។ នក ២៨:៩ ដែលត្រូវមានកូនចៀម២ឥតខ្ចោះ ហើយគ្មានចៀមឈ្មោលទេនៅថ្ងៃឈប់សំរាក។
**៤៦:៥** *ដង្វាយម្សៅ១ថាំង* ដែលផ្ទុយគ្នានៅក្នុង នក ២៨:១១ ។
**៤៦:៦** *លុះដល់ថ្ងៃចូលខែ* នៅថ្ងៃទី១នៃដើមខែ ដែលផ្ទុយគ្នាពីអ្វីតំរូវនៅក្នុង (នក ២៨:១១) ។
**៤៦:៧** *លោកត្រូវរៀបដង្វាយម្សៅ១ថាំង* ខុសគ្នានៅក្នុង នក ២៨:១២ ។
**៤៦:៩** *នោះអ្នកណាដែលចូលតាមផ្លូវទ្វារទិសខាងជើង* ខនេះបង្ហាញពីការគ្រប់គ្រងដល់ហ្វូងមនុស្ស ដូចនេះនៅថ្ងៃនៃសករាជថ្មី នឹងឃើញហ្វូងមនុស្សនៅក្នុងព្រះវិហារនៅថ្ងៃបុណ្យនោះ។
**៤៦:១២** *នឹងថ្វាយដង្វាយស្ម័គ្រពីចិត្ត* នៅខាងលើ និងទៅមុខនោះពួកចៅហ្វាយត្រូវចេះថ្វាយដង្វាយ ។
**៤៦:១៣** *រាល់តែព្រឹកជានិច្ច* ធៀបនៅក្នុង នក ២៨:៣-៨ ជារៀងរាល់ថ្ងៃ ត្រូវថ្វាយដង្វាយកូនចៀមម្តង១ នៅពេលព្រឹក១ និងពេលល្ងាច១ (មើល ១របា ១៦:៤០ ២របា ១៣:១១ ៣១:៣)។ ចំពោះទំនៀមទម្លាប់ខុសគ្នាបង្ហាញនៅក្នុង ២ពវ ១៦:១៥ នោះត្រូវថ្វាយដង្វាយដុតនៅពេលព្រឹកម្តង និង

ដង្វាយនេះរាល់តែព្រឹក[ប]ជានិច្ច[ផ] ១៤ហើយរាល់តែព្រឹក ត្រូវ
រៀបដង្វាយម្សៅជាមួយផង គឺជាម្សៅ១ភាគក្នុង៦ក្នុង១
ថាំង និងប្រេង[ព]១ភាគក្នុង៣ក្នុង១ហ៊ីន ដើម្បីលាយនឹង
ម្សៅយ៉ាងម៉ដ្តនោះ ជាដង្វាយម្សៅដែលថ្វាយដល់ព្រះ
យេហូវ៉ាជានិច្ច តាមច្បាប់ដ៏នៅជាដរាបតទៅ[ភ] ១៥គឺយ៉ាង
នោះដែលគេត្រូវរៀបចំកូនចៀម ដង្វាយម្សៅ និងប្រេង
រាល់[ម]តែព្រឹក ទុកជាដង្វាយដុតជានិច្ច[យ]។

១៦ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា បើ
សិនជាចៅហ្វាយនឹងចែកអំណោយអ្វី ឱ្យដល់កូនខ្លួនណា
មួយ នោះនឹងបានជាមរដករបស់កូននោះ ហើយនឹងបាន
ជារបស់កូននោះតទៅ ទុកជារបស់ផងគេ ដែលគេទទួល
ជាមរដក[រ] ១៧តែបើលោកចែកអំណោយអ្វីពីមរដករបស់
លោក ឱ្យដល់បាវរបស់ខ្លួនណាមួយវិញ នោះនឹងបាន
ជារបស់ផងបាវនោះ ដរាបដល់ឆ្នាំដែលត្រូវលែងចេញ[ល]
រួចនឹងត្រឡប់មកជារបស់ចៅហ្វាយវិញ មានតែពួកកូន
លោកប៉ុណ្ណោះទេ ដែលអាចនឹងទទួលមរដករបស់លោក
បាន ១៨មួយទៀត ចៅហ្វាយនោះមិនត្រូវដណ្តើមយក[វ]អ្វី
ពីមរដក[ស]របស់បណ្តាជន ហើយបណ្តេញគេចេញពីកេរ្តិ៍
អាកររបស់គេឡើយ លោកត្រូវចែកតែរបស់ទ្រព្យខ្លួន ឱ្យ
ដល់កូន ទុកជាមរដកប៉ុណ្ណោះ ដើម្បីមិនឱ្យរាស្ត្ររបស់
អញត្រូវខ្ចាត់ខ្ចាយ ពីកេរ្តិ៍អាកររបស់គេរៀងខ្លួនឡើយ ។

១៩បន្ទាប់នោះ លោកនាំខ្ញុំទៅតាមផ្លូវចូល[ហ] ក្បែរទ្វារ
កំផែង ទៅក្នុងបន្ទប់បរិសុទ្ធរបស់ពួកសង្ឃ ដែលបើកទៅ
ទិសខាងជើង[ឡ] នោះឃើញមានកន្លែង១នៅចុងបន្ទប់នោះ
ខាងលិច ២០លោកក៏ប្រាប់ខ្ញុំថា នេះជាកន្លែងដែលពួក
សង្ឃត្រូវសោរដង្វាយ ដែលថ្វាយដោយព្រោះការរំលង
និងដង្វាយលោះបាប ព្រមទាំងចំអិនដង្វាយម្សៅ ដើម្បី
មិនឱ្យត្រូវយករបស់ទាំងនោះ ចេញទៅឯទីលានខាងក្រៅ
ឡើយ ក្រែងបានញែក[អ]បណ្តាជនចេញជាបរិសុទ្ធដល់ព្រះ
ដែរ[ក] ២១រួចលោកនាំខ្ញុំចេញទៅឯទីលានខាងក្រៅ ឱ្យខ្ញុំ
ដើរទៅតាមទាំង៤ជ្រុងទីលាននោះ នោះឃើញមានទី
លានមួយៗនៅគ្រប់ទាំងជ្រុងទីលាននោះ ២២គឺនៅជ្រុង
ទាំង៤នៃទីលាន មានទីលានរាំងបាំងជាប់តពីទីលានធំ
បណ្តោយ៤០ហត្ថ ទទឹង៣០ហត្ថ ទីលាននៅជ្រុងទាំង៤នោះ
មានទំហំប៉ុនគ្នា ២៣មានជញ្ជាំងនៅជុំវិញទីលានទាំងនោះ
ហើយនៅទីលានទាំង៤ មានកន្លែងនៅ ជាប់នឹងជញ្ជាំង
ជុំវិញសំរាប់សោរ ២៤លោកប្រាប់ខ្ញុំថា នេះជាកន្លែង
សំរាប់ស្ងោរសាច់ ជាទីដែលពួកអ្នកធ្វើការងារក្នុងព្រះ
វិហារត្រូវសោរគ្រឿងយញ្ញបូជារបស់បណ្តាជន ។

## ទន្លេដែលហូរចេញពីព្រះវិហារ

**៤៧** ១រួចលោកនាំខ្ញុំ វិលទៅឯទ្វារនៃព្រះវិហារវិញ
នោះឃើញមានទឹក[ក]ចេញ ពីក្រោមមាត់ទ្វារនៃព្រះវិហារ
ខាងកើត ដ្បិតមុខព្រះវិហារបែរទៅទិសខាងកើត ហើយ
ទឹកនោះហូរមកពីក្រោម ពីខាងស្តាំនៃព្រះវិហារគឺពីខាង
ត្បូងអាសនា[ខ] ២រួចលោកនាំខ្ញុំចេញទៅតាមផ្លូវនៃទ្វារ
កំផែងខាងជើង[គ] ហើយនាំវាងទៅតាមផ្លូវខាងក្រៅរហូត
ដល់ទ្វារកំផែងខាងក្រៅ ដែលបើកទៅខាងកើតនោះ
ឃើញមានទឹកហូរចេញមកខាងស្តាំ ៣លុះបានចេញទៅ
ខាងកើត មនុស្សនោះក៏វាស់១ពាន់ហត្ថដោយខ្សែ[ឃ] ដែល
កាន់នៅដៃ នោះលោកឱ្យខ្ញុំលុយកាត់ទឹក ឯទឹកនោះបាន
ត្រឹមភ្នែកគោរ ៤លោកក៏វាស់១ពាន់ហត្ថទៀតរួចឱ្យខ្ញុំ លុយ
កាត់ទៅ ទឹកត្រង់នោះបានត្រឹមក្បាលជង្គង់ រួចលោក
វាស់១ពាន់ហត្ថទៀត ក៏ឱ្យខ្ញុំលុយកាត់ទៅ ទ្រង់នោះទឹក
បានដល់ត្រឹមចង្កេះ ៥ក្រោយនោះលោកវាស់១ពាន់ហត្ថ
ទៀត នោះមានទន្លេ[ង]ដែលខ្ញុំលុយកាត់មិនបាន ដ្បិតទឹក

**៤៦:១៣** ប ទដ ៥:៣ ផ នក ២៩:៣៨ ជន ២៨:៣
**៤៦:១៤** ព ជន ១៥:៦ ភ ដយ ៨:១១
**៤៦:១៥** ម នក ២៩:៤២ យ នក ២៩:៣៨ ជន ២៨:៥–៦
**៤៦:១៦** រ ២របា ២១:៣
**៤៦:១៧** ល លវ ២៥:១០
**៤៦:១៨** វ ១សយ ៨:១៤ ស លវ ២៥:២៣ អគ ៤៥:៨ មីក ២:១–២
**៤៦:១៩** ហ អគ ៤២:៩ ឡ អគ ៤២:៤
**៤៦:២០** អ លវ ៦:២៧ ក ខ.២៤ សក ១៤:២០
**៤៧:១** ក អស ៥៥:១ ខ ទដ ៤៦:៤ យអ ៣:១៨ វវ ២២:១
**៤៧:២** គ អគ ៤០:៥
**៤៧:៣** ឃ អគ ៤០:៣
**៤៧:៥** ង លប ២:១០

ពេលល្ងាចម្តង ។

**៤៦:១៤** *គឺជាម្សៅ១ភាគក្នុង៦ ក្នុង១ថាំង និងប្រេង១ភាគក្នុង១ហ៊ីន* ដែលផ្ទុយគ្នានៅក្នុង នក ២៨:៥ ។

**៤៦:១៦** *នឹងបានជាមរដករបស់កូននោះ* លោកអេសេគាលបង្ហាញនៅក្នុងរូបភាពមួយក្នុងការគ្រប់គ្រងតាមពូជអំបូរ ។

**៤៦:១៧** *ដរាបដល់ឆ្នាំដែលត្រូវលែងចេញ* ជាឆ្នាំសោមន្ស ជាឆ្នាំដែលបានរៀបចំឡើងជារៀងរាល់៥០ឆ្នាំម្តង (មើល លវ ២៥:៨–១៥ ជាពិសេសនៅក្នុង ខ.១៣) ។

**៤៦:១៨** *ចៅហ្វាយនោះមិនត្រូវដណ្តើមយកអ្វី* (មើលការពន្យល់ ៤៥:៧) ។

**៤៦:១៩–២៤** បន្ទប់នោះត្រូវបរិសុទ្ធ ដូចជាទីកន្លែងបន្ទប់របស់សង្ឃ ៤២:១៣–១៤ ។ ចំពោះការបែងចែកនោះ វាត្រូវទៅនឹងច្បាប់ខាងក្រិត្យវិន័យ ។ ហើយទីកន្លែងរបស់សង្ឃនោះ ត្រូវញែកទុកសម្រាប់សង្ឃ ពីទីកន្លែងធ្វើម្ហូបរបស់ពួកលេវី (មើល ខ.១៩–២០ ២១–២៤)។

**៤៧:១–១២** ទន្លេជីវិតហូរចេញពីព្រះវិហារ ។

**៤៧:១** *លោក* ទេវតាជាអ្នកនាំផ្លូវ ដែលជាអ្នកលេចបង្ហាញនៅពេលលើកមុន និងទស្សនៈវិស័យរបស់លោកអេសេគាល អំពីព្រះវិហារថ្មី (៤០:៣) ។ *ទ្វារនៃព្រះវិហារ* លោកអេសេគាលបានឈរនៅទីលានខាងក្នុង ។ *ទឹក* នៅក្នុងផ្នែកនេះ (ខ.១–១២) ទីនេះបង្ហាញយ៉ាងច្បាស់អំពីទឹក ដែលអាចប្រោសឱ្យជា ទឹកផ្តល់ឱ្យ (មើល ទដ ៣៦:៨ ៤៦:៤ និងការពន្យល់ មើលផងដែរ អយ ៣:១៨ សក ១៣:១ ១៤:៨ វវ ២២:១–២) ។ នៅក្នុងប្រវត្តិដើមនិយាយពីទឹកដែលហូរមកពីសួនច្បារអេដែន (មើល ២:១០) ។

**៤៧:២** *នាំខ្ញុំចេញទៅតាមផ្លូវនៃទ្វារកំផែងខាងជើង* ដោយសារទ្វារខាងកើតបានបិទ (មើល ៤៤:២) ។

**៤៧:៥** *លោកវាស់១ពាន់ហត្ថទៀត* លោកបានវាស់សរុប៤ហត្ថ (មើលការ

បានខ្ពស់ឡើង ជាទឹកដែលល្មមហែលបាន គឺជាទន្លេដែល
លុយពុំបានទេ[ច]។
៦នោះលោកសួរមកខ្ញុំថា កូនមនុស្សអើយ តើបាន
ឃើញហើយឬរួចលោកនាំខ្ញុំឱ្យត្រឡប់ទៅឯមាត់ទន្លេនោះ
វិញ ៧កាលខ្ញុំបានត្រឡប់ទៅដល់ហើយ នោះឃើញតាម
មាត់ទន្លេ មានដើមឈើជាច្រើន ទាំងខាងនេះនឹងខាង
នោះផង[ឆ] ៨លោកក៏ប្រាប់ខ្ញុំថា ទឹកនេះហូរចេញទៅទិស
ខាងកើតធ្លាក់ចុះទៅដល់ស្រុកវាល រួចនឹងហូរធ្លាក់ទៅឯ
សមុទ្រ លុះហូរធ្លាក់ទៅក្នុងសមុទ្រហើយ[ជ] នោះទឹកសមុទ្រ
នឹងទៅជាល្អវិញ[ឈ] ៩ហើយគ្រប់ទាំងសត្វមានជីវិត ដែល
រវើកនៅគ្រប់កន្លែងណាដែលទន្លេនោះហូរ នឹងបានរស់
នៅ ក៏នឹងមានត្រីមយ៉ាងសន្ធឹក ដោយព្រោះទឹកទាំងនេះ
បានហូរទៅដល់ទីនោះ ហើយទឹកសមុទ្រនោះនឹងបានល្អ
ឯកន្លែងណាដែលទឹកទន្លេនេះហូរទៅដល់ នោះគ្រប់ទាំង
អស់នឹងរស់នៅ[ញ] ១០ពួកនេសាទត្រី[ដ]នឹងឈរនៅមាត់ទឹក
នោះ ចាប់តាំងពីអេន-កេឌី[ឋ] រហូតដល់អេន-អេកលែមទី
នោះនឹងបានជាទីសំរាប់បង់សំណាញ់[ឌ] ឯត្រីនៅក្នុងទឹក
នោះ នឹងមានយ៉ាងសន្ធឹកគ្រប់បែបតាមពូជ[ឍ] ដូចជាត្រីនៅ
ក្នុងសមុទ្រធំដែរ[ណ] ១១តែទីល្បាប់ នឹងបឹងនៅទីនោះនឹងមិន
បានសាបល្អវិញទេ កន្លែងទាំងនោះនឹងបានទុកសំរាប់ធ្វើ
អំបិលវិញ[ត] ១២ឯតាមមាត់ច្រាំងទាំងសងខាងទន្លេនោះ[ថ]
នឹងមានដុះដើមឈើគ្រប់យ៉ាង សំរាប់ជាអាហារជាដើម
ដែលស្លឹកមិនស្រពោនឡើយ ហើយមិនដែលខានមានផ្លែ[ទ]
ដែរ គឺនឹងកើតផ្លែថ្មីរាល់តែខែ ពីព្រោះទឹកនោះចេញពីទី
បរិសុទ្ធ[ធ]មក ហើយផ្លែឈើទាំងនោះ នឹងបានសំរាប់ជា
អាហារ ឯស្លឹកក៏សំរាប់នឹងកែរោគឱ្យជាដែរ[ន]។

## ព្រំស្រុក

១៣ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា នេះ
ជាព្រំ[ប]ស្រុក ដែលឯងរាល់គ្នានឹងចែកទុកជាមរដក តាម
ពូជអំបូរសាសន៍អ៊ីស្រាអែលទាំង១២ ឯពួកយ៉ូសែប នឹង
ត្រូវបាន២ចំណែក[ផ] ១៤ឯរាល់គ្នានឹងបានស្រុកទុកជា
មរដកស្មើគ្នាទាំងអស់ ដ្បិតអញបានស្បថនឹងឱ្យស្រុកនេះ
ដល់ពួកព្ធយុកោឯងរាល់គ្នាហើយ ដូច្នេះស្រុកនេះនឹងបាន
បន្តដល់ឯងរាល់គ្នា ទុកជាមរដកដែរ[ព] ១៥នេះជាព្រំស្រុក[ភ]
គឺខាងជើងនោះ ចាប់ផ្តើមពីសមុទ្រ[ម]ធំ តាមផ្លូវ[យ]ក្រុង

**៤៧:៥** ច អស ១១:៩ ហព ២:១៤ **៤៧:៧** ឆ ខ.១២ វវ ២២:២ **៤៧:៨** ជ ចទ ១:១ ៣:១៧ ឈ អស ៤១:១៨ **៤៧:៩** ញ អស ១២:៣ ៥៥:១ យហ ៤:១៤ ៧:៣៧-៣៨ **៤៧:១០** ដ អស ១៩:៨ មថ ៤:១៩ ឋ យស ១៥:៦២ ឌ អគ ២៦:៥ ឍ ទដ ១០៤:២៥ មថ ១៣:៤៧ ណ ជន ៣៤:៦ **៤៧:១១** ត ចទ ២៩:២៣ **៤៧:១២** ថ ខ.៧ វវ ២២:២ ទ ទដ ១:៣ ធ អស ៥៥:១ ន លប ២:៩ យរ ១៧:៨ អគ ៣៦:៨ **៤៧:១៣** ប ជន ៣៤:២-១២ ផ លប ៤៨:១៦ ៤៩:២៦ **៤៧:១៤** ព លប ១២:៧ ចទ ១:៨ អគ ៣៦:១២ **៤៧:១៥** ភ ជន ៣៤:២ ម ខ.១៩ ជន ៣៤:៦ យ អគ ៤៨:១

ពន្យល់ ១:៥) ។ នោះមានទន្លេដែលខ្ញុំលុយកាត់មិនបាន ជាការអស្ចារ្យតែទឹកនោះមិនសូវហូរខ្លាំង ដែលល្មមអាចហែលបាន ។

**៤៧:៧** *មានដើមឈើជាច្រើន* ដើមឈើនៅសួនអេដែន អាចអង្គុយសំណេះសំណាលបាន (មើល លក ២:៩) ។

**៤៧:៨** *ទឹកនេះហូរចេញទៅទិសខាងកើត* ធៀបនៅក្នុង សក ១៤:៨ ។ *ស្រុកវាល* ជាតំបន់រីងទឹក នៅចន្លោះក្រុងយេរូសាឡិម និងសមុទ្រស្លាប់ (មើលការពន្យល់) ។ សមុទ្រ ជាទូទៅមានន័យលើសមុទ្រមេឌីទែរ៉ាណេ ប៉ុន្តែនៅទីនេះ គឺសំដៅលើសមុទ្រស្លាប់ (មើលការពន្យល់) ។ *នឹងទៅជាល្អឡើងវិញ* ភាសាហេព្រើរនិយាយក្នុងន័យប្រៀបធៀបថា "នឹងទៅជា ជាសះស្បើយឡើងវិញ" ទឹកសមុទ្រនោះគឺប្រៃ(២៥ភាគរយ) នៅក្នុងរូបកាយ នៅលើលោកនេះ ទឹកជួយទ្រទ្រង់ដល់ជីវិត ហើយវានាំមានជីវិតដ៏ពេញបរិបូរណ៍ ដែលចង្អុលបង្ហាញពីអំណាចដ៏អស្ចារ្យ ជា" ទឹកទន្លេនៃជីវិត"(វវ ២២:១)។

**៤៧:៩** *ហើយគ្រប់ទាំងសត្វមានជីវិត* មាននៅក្នុង លក ១:២០-២១ ចង្អុលបង្ហាញពីការបង្កបង្កើតជាថ្មី ។

**៤៧:១០** *អេន-កេឌី* មានន័យថា "រដូវនៃសត្វពពែ" រដូវលូតលាស់ខ្លាំងនៅចំកណ្ដាលផ្លូវ តាមបណ្ដោយផ្លូវទៅភាគខាងលិចនៃសមុទ្រស្លាប់ ។ *អេ-អេកលែម* មានន័យថា"រដូវនៃគោ២" វាប្រហែលជា អេន ហ្វេស្កា (Ain Feshka) នៅឯភាគខាងជើង កាច់ជ្រុងនឹងសមុទ្រស្លាប់ អ្នកខ្លះគិតថាវាមានទីតាំងនៅលីបង់ខាងកើត ។ *សមុទ្រធំ* (មើលការពន្យល់) ។

**៤៧:១១** *កន្លែងនោះនឹងបានទុកសម្រាប់ធ្វើអំបិលវិញ* ប្រហែលជាគេចែកអំបិលនៅពេលដែលថ្វាយយញ្ញបូជា (៤៣:២៤) ។

**៤៧:១២** *គឺនឹងកើតផ្លែថ្មីរាល់តែខែ* ជាការអស្ចារ្យអំពីសេចក្ដីសន្យា នៅក្នុង ៣៤:២៧ ៣៦:៣០ (មើល អម ៩:១៣ ធៀបនឹង វវ ២២:២) ។

**៤៧:១៣-២៣** ដែនដីនៃទឹកដីថ្មី (មើលផែនទីនៅទំព័រ ១៣១៥) ។

**៤៧:១៣** *ឯពួកយ៉ូសែបនឹងត្រូវបាន២ចំណែក* ឯពួកលេវីមិនត្រូវបានទទួលចំណែកអ្វីឡើយ (មើល ៤៤:២៨) ឯពួកអេប្រាអិម ពួកម៉ាន៉ាសេ និងកូនចិញ្ចឹមរបស់លោកយ៉ូសែប២នាក់ ហើយម្នាក់ៗនឹងទទួលបាននូវចំណែកនោះផងដែរ (មើល ៤៨:៤-៥) ។

**៤៧:១៤** *ដ្បិតអញបានស្បថ* ដោយយោងលើការតាំងសញ្ញាដែលព្រះទ្រង់បានធ្វើជាមួយលោកអាប់រ៉ាម (មើល លក ១៥:៩-២១ និងការពន្យល់ អគ ២០:៥, ៣៦:២៨)។ *នឹងឱ្យស្រុកនេះ* (មើល ២០:៥ និងការពន្យល់) ។

**៤៧:១៥** *នេះគឺជាព្រំស្រុក* ប្រហែលជាព្រំស្រុករបស់អ៊ីស្រាអែលនៅជំនាន់ស្ដេចដាវីឌ និងស្ដេចសាឡូម៉ូន លើកលែងតែ អ្នករស់នៅតាមដងទន្លេយ័រដាន់ (មើល ខ.១៨) ដែលមិនមែននៅក្នុងព្រំស្រុកនៃទឹកដីយ័រដាន់ឡើយ ការបញ្ជាក់ពីព្រំស្រុកនោះវាដូចគ្នានៅក្នុង (នក ៣៤:១-១២) ។ *តាមផ្លូវក្រុងហេតឡុន* តាមឆ្នេរសមុទ្រមេឌីទែរ៉ាណេ ហើយសព្វថ្ងៃនេះនៅក្នុងលេបាណន។ *ក្រុងឡេបូ ហាម៉ាត* (មើលការពន្យល់) ។ ឡេបូ ទោះជាយ៉ាងណាក្តីនោះប្រហែលជាវាមិនមានន័យថា "ផ្លូវចូល" នោះទេ ប៉ុន្តែវាត្រូវបានគេចំណាំថាជា ឡេបវេដ៏ទំនើប ហើយវាមានចង្ងាយប្រហែល១៥ម៉ាយពីទិសឦសាន នៃក្រុងប្អាឡែក និង២០ម៉ាយ នៅទិសនិរតី នៃក្រុងកាដេសនៅទន្លេហូរ៉ុន នៅជិតរីបឡា។ នៅពេលមួយ ឡេបូ ត្រូវគេធ្វើឡើងសម្រាប់ជាបន្ទាយចាំយាម តាមផ្លូវភាគខាងត្បូង ទៅហាម៉ាត ប្រហែលជាឃ្លានោះត្រូវបានគេបកប្រែថា "ឡេបូ ហាម៉ាត" វាត្រូវបានគេប្រើជារឿយៗនៅក្នុងព្រះគម្ពីរថាជាព្រំដែនរបស់អ៊ីស្រាអែល (មើល ខ.២០ ៤៨:១ ជន ១៣:២១

ហេតឡូន រហូតដល់ផ្លូវចូលក្រុងសេដាត់ ១៦ក្រុងហាម៉ាត
ក្រុងបេរ៉ូថា[រ] ក្រុងស៊ីបរ៉ែប ដែលនៅកណ្ដាលដែនស្រុក
ដាម៉ាស និងស្រុកហាម៉ាត[ល] ហើយហាសា–ហាទីកុន ដែល
នៅក្បែរព្រំស្រុកហាវរ៉ុន ១៧ដូច្នេះ ព្រំស្រុកនឹងចាប់តាំងពី
សមុទ្រ គឺហាសា–អេណាន រហូតដល់ស្រុកដាម៉ាស ឯ
ខាងជើង នោះជាព្រំស្រុកហាម៉ាត នេះហើយជាព្រំដែន
ខាងជើង[វ] ១៨ឯខាងកើត នោះត្រូវឱ្យវាស់តាមទន្លេយ័រដាន់
នៅជាកណ្ដាលស្រុកហាវរ៉ុន ស្រុកដាម៉ាស និងស្រុក
កាឡាត ម្ខាង និងស្រុកអ៊ីស្រាអែលម្ខាង ចាប់តាំងពីព្រំស្រុក
ខាងជើង រហូតដល់សមុទ្រខាងកើត នេះហើយជាព្រំដែន
ខាងកើត[ស] ១៩ឯខាងត្បូងនោះចាប់តាំងពីស្រុកតាម៉ារ រហូត
ដល់ទឹកមេរីបា–កាដេស[ហ] តាមជ្រោះទឹក[ឡ]ទៅដល់សមុទ្រ
ធំ[អ] នេះជាព្រំដែនខាងត្បូង ២០ហើយខាងលិច នោះគឺជា
សមុទ្រធំ ចាប់តាំងពីព្រំដែនខាងត្បូងទៅ ត្រឹមទល់ដែន
និងទ្វារស្រុកហាម៉ាត[ក] នេះជាព្រំដែនខាងលិច[ខ]។
២១ត្រូវឱ្យឯងរាល់គ្នាចែកស្រុកនេះ ដល់គ្នាតាមពូជ
អំបូរទាំងប៉ុន្មាននៃសាសន៍អ៊ីស្រាអែល ២២ត្រូវឱ្យចែកគ្នា
ដោយចាប់ឆ្នោត ទុកជាមរដក[គ]សំរាប់ឯងរាល់គ្នា ហើយ
សំរាប់ពួកសាសន៍ដទៃ[ឃ] ដែលអាស្រ័យនៅកណ្ដាលឯង

**៤៧:១៦** រ ២សយ ៨:៨ ល ១៣:២១ យរ ៤៩:២៣ អគ ៤៨:១ **៤៧:១៧** វ អគ ២៧:១៨ **៤៧:១៨** ស អគ ២៧:១៨ **៤៧:១៩** ហ ចទ ៣២:៥១ ឡ លប ១៥:១៨ អស ២៧:១២ អ ខ.១៥ អគ ៤៨:២៨ **៤៧:២០** ក ជន ១៣:២១ អគ ៤៨:១ ខ ជន ៣៤:៦ **៤៧:២២** គ អគ ៣៦:១២ ឃ ចទ ២៤:១៩ អស ១៤:១ មឡ ៣:៥ ង លវ ២៤:២២ ជន ១៥:២៩ ២៦:៥៥–៥៦ អស ៥៦:៦–៧ រម ១០:១២ អភ ២:១២–១៦ ៣:៦

រាល់គ្នា ជាពួកអ្នកដែលនឹងបង្កើតកូន នៅកណ្ដាលឯង
ដែរ អ្នកទាំងនោះនឹងបានដូចអ្នក ដែលកើតនៅក្នុងស្រុក
អ៊ីស្រាអែលដល់ឯងរាល់គ្នា គេនឹងបានមរដកនៅក្នុង
ពូជអំបូរទាំងប៉ុន្មាននៃអ៊ីស្រាអែល ជាមួយនឹងឯងរាល់គ្នា
ដែរ[ង] ២៣ឯសាសន៍ដទៃទាំងនោះអាស្រ័យនៅក្នុងពូជអំបូរ
ណា នោះត្រូវឱ្យឯងរាល់គ្នាចែក ឱ្យមានមរដកនៅទីនោះ
ឯង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា[ច]។

## ការបែងចែកទឹកដី

**៤៨** ១នេះជាចំណែកតាមឈ្មោះនៃពូជអំបូរនីមួយៗ ចាប់
តាំងពីចុងស្រុកខាងជើងតាមផ្លូវហេតឡូន[ក] រហូតដល់ទ្វារ
ស្រុកហាម៉ាត[ខ] និងហាសា–អេណាន ត្រង់ព្រំដែនស្រុក
ដាម៉ាស នៅខាងជើងជិតស្រុកហាម៉ាត នោះមាន ចំណែក
១ សំរាប់ពូជអំបូរដាន់[គ] ដ្បិតគេនឹងមានចំណែក ស្រុកចាប់
តាំងពីខាងកើត រហូតដល់ខាងលិច ២ហើយតាមព្រំស្រុក
របស់ដាន់ចាប់តាំងពីខាងកើតរហូតដល់ខាងលិច នោះ
មានចំណែក១សំរាប់ពូជអំបូរអេស៊ើរ[ឃ] ៣ហើយ តាមព្រំ
ស្រុករបស់អេស៊ើរ ចាប់តាំងពីខាងកើតរហូតដល់ខាង

កល ៣:១១ **៤៧:២៣** ច ចទ ១០:១៩ **៤៨:១** ក អគ ៤៧:២០ ខ អគ ៤៧:១៥–១៧ គ លប ៣០:៦ **៤៨:២** ឃ យស ១៩:២៤–៣១

៣៤:៨ យស១៣:៥ ១ពវ ៨:៦៥ ២ពវ ១៤:២៥ អម ៦:១៤)។ *សេដាត់* មានបញ្ជាក់នៅក្នុង ជន ៣៤:៨ ប៉ុន្តែអ្នកប្រាជ្ញផ្សេងទៀតដែលគេមិនបានស្គាល់។

**៤៧:១៦** *ក្រុងបេរ៉ូថា* ប្រហែលជាគេបានចំណាំវាថាជា បេរ៉ូថៃ នៅក្នុង ២សយ ៨:៨ ប៉ុន្តែគេមិនបានស្គាល់វាទេ ។ *ក្រុងស៊ីបរ៉ែម* មាននៅទីកន្លែង១ដែលគេមិនស្គាល់ ប្រហែលជាក្រុងសេផាវែម នៅក្នុង ២ពវ ១៧:២៤ ១៨:៣៤ ។ *ស្រុកដាម៉ាស* ជាទីក្រុងរបស់អារ៉ាម (ស៊ីរ៉ា) ដោយយោងតាមខ ១៧ គឺរួមបញ្ចូលទាំងអ៊ីស្រាអែល ។ *ហាម៉ាត* ជាទីក្រុង១មានចម្ងាយប្រហែល១២០ម៉ាយ នៅភាគខាងជើង នៃស្រុកដាម៉ាស នៅជាប់នឹងទន្លេហូរ៉ុន ។ *ហាសា–ហាទីកុន* មានន័យថា "ជាទីកន្លែងមួយដែលគេបានឡោមព័ទ្ធនៅចំកណ្ដាល" វាមានទីតាំងនៅកន្លែង១ដែលគេមិនបានស្គាល់ ប៉ុន្តែវាវាអាចដូចគ្នានឹង ហាសា–ណាន (នៅក្នុង ខ.១៧) ។

**៤៧:១៩** *សមុទ្រខាងកើត* សមុទ្រស្លាប់ (មើល យអ ២:២០ អគ ១៤:៨) ។ *តាម៉ារ* មានន័យថា"ទីកន្លែង" ត្នោត (មើល ខ.១៩ ៤៨:២៨) បានបញ្ជាក់នៅក្នុង លក ១៤:៧ (ហាសាសុន–តាម៉ារ) និង ១ពវ ៩:១៨ (មើលការពន្យល់ និងការបញ្ជាក់អំពី អេន កេឌី (មើលការពន្យល់នៅ ខ.១០) នៅក្នុង ២របា ២០:២ ។

**៤៧:១៩** *ទឹកមេរីបា–កាដេស* ជាស្រុកមួយ ដែលមានចម្ងាយប្រហែល ៥០ម៉ាយ នៅខាងកើតនៃស្រុកបៀរសេបា ត្រូវគេចំណាំថា កាដេស បានៀ នៅក្នុង នក ៣៤:៤ *តាមជ្រោះទឹកទៅដល់សមុទ្រធំ* ទឹកជ្រោះ–អារីស ជាទឹកជ្រោះ១យ៉ាងជ្រៅ ហូរកាត់តាមរដូវកាល ដែលហូរចេញពីភ្នំស៊ីណៃខាងជើង–ទិសពាយព្យ រហូតទៅដល់សមុទ្រមេឌីទែរ៉ាណេ មានចម្ងាយ៥០ ម៉ាយនៅខាងលិចក្រុងកាហ្សា ។ វាត្រូវបានគេកត់ចំណាំថា ជាទីកន្លែង១ដែលនៅឆ្ងាយបំផុត ក្នុងជំនាន់រាជ្យស្ដេចសាឡូម៉ូន (មើល ១ពវ ៨:៦៥)។

**៤៧:២២** *អ្នកទាំងនោះនឹងបានដូចអ្នកដែលកើតនៅក្នុងស្រុកអ៊ីស្រាអែល* ជាការល្អដែលមានការបែកចែកមរដកទុកជាមុន មើល ១៤:៧ វាបានឆ្លុះបញ្ចាំងចំពោះភាពសាកលដូចគ្នា ដែលរកឃើញមាននៅក្នុងសេចក្ដីទំនាយក្នុង អស ៥៦:៣–៨ (មើលការពន្យល់) ។

៤៨:១–២៩ ការបែងចែងទឹកដីតាមលំដាប់លំដោយ (មើលផែនទីទំព័រ ១៣១៥) ។

**៤៨:១** *ពូជអំបូរដាន់* គេបានកាន់កាប់ទឹកដី ហើយតាំងទីលំនៅ ជាប្រវត្តិសាស្ត្រ គេជាពូជអំបូរ ដែលតាំងលំនៅ នៅឆ្ងាយជាងគេ(មើលឃ្លា"ពីពូជអំបូរដាន់ ទៅដល់ពូជអំបូរបៀសេបា" ការបែងចែកទឹកដី ចាប់តាំងពីព្រំស្រុកខាងជើង ដល់ស្រុកខាងត្បូង ឧទាហរណ៍នៅក្នុង ពច ២០:១ ១សយ ៣:២០) ។ ពូជអំបូរដាន់ បានកើតមកធ្វើជាអ្នកបម្រើដល់នាងរ៉ាដែលឈ្មោះថាប៊ីហា (មើល លក ៣៥:២៥) ។ *ផ្លូវហេតឡូន រហូតដល់ទ្វារស្រុកឡេបូ–ហាម៉ាត* (មើលការពន្យល់ ៤៧:១៥) ហាសា–អេណាន មើលការពន្យល់ ៤៧:១៦ ។

**៤៨:២** *ពូជអំបូរអេស៊ើរ* កើតមកធ្វើជាអ្នកបម្រើនាងឡេអា ឈ្មោះស៊ុលផា (មើល លក ៣៥:២៦)។ ពួជអំបូរនោះចាប់ពីពូជអ្នកបម្រើ ដែលនៅឆ្ងាយជាងគេចាប់តាំងពីរោងឧបោសថ (មើលចាប់ពីព្រំស្រុករបស់ដាន់ នៅក្នុង ខ.១ ព្រំស្រុកណែបថាលី ក្នុង ខ.៣ ព្រំស្រុកកាឌ់) ។

**៤៨:៣** *ពូជអំបូរណែបថាលី* កើតមកធ្វើជាអ្នកបម្រើរបស់ប៊ីលហា (មើល

លិច នោះមានចំណែក១សំរាប់ពូជអំបូរណែបថាលី[ង]
៤ហើយតាមព្រំស្រុករបស់ណែបថាលី ចាប់តាំងពីខាង
កើត រហូតដល់ខាងលិច នោះមានចំណែក១សំរាប់ពូជ
អំបូរម៉ាន៉ាសេ[ច] ៥ហើយតាមព្រំស្រុករបស់ម៉ាន៉ាសេ[ឆ] ចាប់
តាំងពីខាងកើត រហូតដល់ខាងលិច[ជ] នោះមានចំណែក១
សំរាប់ពូជអំបូរអេប្រាអិម[ឈ] ៦ហើយតាមព្រំស្រុកអេប្រាអិម
ចាប់តាំងពីខាងកើត រហូតដល់ខាងលិចនោះមានចំណែក
សំរាប់ពូជអំបូររូបេន[ញ] ៧ហើយតាមព្រំស្រុករបស់រូបេន
ចាប់តាំងពីខាងកើត រហូតដល់ខាងលិចនោះមានចំណែក
១សំរាប់ពូជអំបូរយូដា[ដ]។
៨តាមព្រំស្រុកយូដា ចាប់តាំងពីខាងកើតរហូតដល់ខាង
លិច នោះជាដង្វាយដែលឯងរាល់គ្នាត្រូវថ្វាយវិញ គឺទទឹង
២ម៉ឺន៥ពាន់ខ្នាត ហើយបណ្តោយក៏ប៉ុននឹងចំណែកស្រុកឯ
ទៀត គឺចាប់តាំងពីខាងកើត រហូតដល់ខាងលិច ឯទី
បរិសុទ្ធ និងនៅកណ្តាលនោះ[ឋ] ៩ចំណែកដង្វាយដែល
ឯងរាល់គ្នាត្រូវថ្វាយដល់ព្រះយេហូវ៉ា នោះត្រូវបណ្តោយ
២ម៉ឺន៥ពាន់ខ្នាត និងទទឹង១ម៉ឺនខ្នាត[ឌ] ១០ដង្វាយបរិសុទ្ធ នេះ
ត្រូវបានសំរាប់ពួកសង្ឃ ឯខាងជើងនោះ បណ្តោយ ២ម៉ឺន
៥ពាន់ខ្នាត ហើយខាងលិច មានទទឹងជា១ម៉ឺន ខ្នាតខាង
កើត ទទឹង១ម៉ឺនខ្នាត ហើយខាងត្បូងបណ្តោយ ២ម៉ឺន៥
ពាន់ខ្នាត ឯទីបរិសុទ្ធរបស់ព្រះយេហូវ៉ា នឹងនៅកណ្តាល
នោះ[ឍ] ១១ដីនោះនឹងទុកសំរាប់ពួកសង្ឃ ជាកូនចៅសាដុក[ណ]
ដែលបានញែកជាបរិសុទ្ធ ហើយក៏រក្សាបញ្ញើរបស់អញ[ត]
ឥតវង្វេងចេញ ក្នុងកាលដែលពួកកូនចៅអ៊ីស្រាអែល
បានវង្វេងដូចជាពួកលេវីបានវង្វេងនោះឡើយ[ថ] ១២នេះនឹង
បានជាដង្វងាយបរិសុទ្ធសំរាប់ពួកសង្ឃ ជាដង្វាយលើក
ចេញពីចំណែកដី ដែលគេបានថ្វាយនោះ ទុកជារបស់
បរិសុទ្ធបំផុត ក្បែរព្រំដែននៃពួកលេវី ។
១៣ឯប្រទល់នឹងស្រុករបស់ពួកសង្ឃ នោះពួកលេវី ត្រូវ

**៤៨:៣** ង ១៩:៣២–៣៩
**៤៨:៤** ច យស ១៧:១–១១
**៤៨:៥** ឆ យស ១៧:១៧ ជ យស ១៧:៧–១០
ឈ យស ១៦:៥–៩
**៤៨:៦** ញ យស ១៣:១៥–២១
**៤៨:៧** ដ យស ១៥:១–៦៣
**៤៨:៨** ឋ ខ.២១
**៤៨:៩** ឌ អក ៤៥:១
**៤៨:១០** ឍ ខ.២១ អក ៤៥:៣–៤
**៤៨:១១** ណ ២សយ ៨:៣៥ ត លវ ៨:៣៥ ថ អក ១៤:១១ ៤៤:១៥
**៤៨:១៣** ទ អក ៤៥:៥
**៤៨:១៤** ធ លវ ២៥:៣៤ ២៧:១០,២៨
**៤៨:១៦** ន វវ ២១:១៦
**៤៨:១៨** ប អក ៤៥:៦

មានដីបណ្តោយ២ម៉ឺន៥ពាន់ខ្នាត ហើយទទឹង១ម៉ឺនខ្នាត គឺ
២ម៉ឺន៥ពាន់ខ្នាត តាមបណ្តោយរហូត ហើយ១ម៉ឺនតាម
ទទឹងរហូត[ទ] ១៤មិនត្រូវឱ្យគេលក់អ្វីពីនោះឡើយ ក៏មិនត្រូវ
ប្តូរ ឬបញ្ជូនផលដំបូងចេញទៅឯណាដែរ ដ្បិត ផលនោះ
ជារបស់បរិសុទ្ធដល់ព្រះយេហូវ៉ា[ធ]។
១៥ឯដី៥ពាន់ខ្នាតដែលសល់នៅ តាមទទឹងដែលនៅ
ខាងមុខចំណែក២ម៉ឺន៥ពាន់ខ្នាត នោះសំរាប់ប្រើជុំគ្នា
សំរាប់ជាទីក្រុង ឱ្យធ្វើទីលំនៅ ហើយសំរាប់ជាដីទំនេរ ឯ
ទីក្រុង ត្រូវនៅកណ្តាលនោះ ១៦ហើយទំហំទីក្រុងនោះ គឺ
ខាជើង ត្រូវជា៤៥០០ខ្នាត ខាងត្បូង៤៥០០ខ្នាត ខាង
កើត៤៥០០ខ្នាត ហើយខាងលិច៤៥០០ខ្នាតដែរ[ន] ១៧ទី
ក្រុងនោះត្រូវមានដីទំនេរនៅជុំវិញ គឺខាងជើង ត្រូវមាន
២៥០ខ្នាត ខាងត្បូង២៥ខ្នាត ខាងកើត២៥០ខ្នាត និង
ខាងលិច២៥០ខ្នាតដែរ ១៨ហើយដីដែលសល់នៅតាម
បណ្តោយ ដែលជាប់តពីដីបរិសុទ្ធ នោះខាងកើតត្រូវជា
១ម៉ឺនខ្នាត ហើយខាងលិច១ម៉ឺនខ្នាត នោះជាដីជាប់តពីដី
បរិសុទ្ធ ឯផលចំរើនពីដីនោះ នឹងបានសំរាប់ជាអាហារ
ដល់ពួកអ្នកដែលរកស៊ីនៅក្នុងទីក្រុង[ប] ១៩ពួកអ្នកដែលរក
ស៊ីធ្វើការ នៅក្នុងទីក្រុងពីគ្រប់ទាំងពូជអំបូរអ៊ីស្រាអែល
គេនឹងភ្ជួររាស់ដីនោះ ២០ដីដែលថ្វាយជាដង្វាយនោះ ទាំង
អស់បណ្តោយត្រូវជា២ម៉ឺន៥ពាន់ខ្នាត ហើយទទឹង២ម៉ឺន
៥ពាន់ខ្នាត ត្រូវឱ្យឯងរាល់គ្នាថ្វាយដីបរិសុទ្ធនេះ៤ជ្រុង
ស្មើ ព្រមទាំងមានកន្លែងសំរាប់ទីក្រុងផង ។
២១ឯដីដែលសល់នៅ នោះនឹងបានសំរាប់ចៅហ្វាយ
គឺនៅទាំងសងខាងដីបរិសុទ្ធនោះ និងកន្លែងសំរាប់ទីក្រុង
ដែលនៅខាងមុខដីបរិសុទ្ធទាំង២ម៉ឺន៥ពាន់ខ្នាត ចេញ
ទៅឯព្រំស្រុកខាងកើត ហើយនៅមុខ២ម៉ឺន៥ពាន់ខ្នាត
ចេញទៅឯព្រំស្រុកខាងលិច ឱ្យប៉ុនស្មើនឹងចំណែកដីឯ
ទៀត នោះនឹងបានទុកសំរាប់ចៅហ្វាយ ហើយដីបរិសុទ្ធ

ការពន្យល់ ខ.២)។
**៤៨:៤** *ពូជអំបូរម៉ាន៉ាសេ* មើលការពន្យល់ ៤៧:១៣ ។
**៤៨:៥** *ពូជអំបូរអេប្រាអិម* មើលការពន្យល់ ៤៧:១៣ ។
**៤៨:៦** *ពូជអំបូររូបេន* ជាកូនច្បងរបស់នាងលេអា (មើល លក ២៩:៣១)។
**៤៨:៧** *ពូជអំបូរយូដា* ជាកូនប្រុសរបស់នាងលេអា (មើល លក ៣៥:២៣) គាត់មានទីកន្លែង១ ដែលមានការល្បីឈ្មោះបំផុត គាត់បានទទួលចំណែកព្រំស្រុកកណ្តាល ដែលជាទីបរិសុទ្ធ (ខ.៨) ពីព្រោះពូជអំបូររបស់គាត់ត្រូវបានផ្តល់ឱ្យតាមសេចក្តីសន្យារបស់ព្រះមេស៊ី (មើល លក ៤៨:៨–១៣ និង ការពន្យល់ ៤៩:៨) ។
**៤៨:៨–២២** ការពង្រីកទឹកដី នៅក្នុង ៤៥:១–៨ (មើលការពន្យល់)។
**៤៨:៩** ទទឹង១ម៉ឺនខ្នាត ទទឹងនោះជាទីកន្លែង១សំរាប់ធ្វើការគោរពបូជា ដែលមានទំហំប្រវែង ២ម៉ឺនហត្ថ (មើល ៤៥:១) ខនេះគឺសំដៅទៅលើទីកន្លែងរបស់ពួកសង្ឃ ឬពួកលេវី ។
**៤៨:១១** *កូនចៅសាដុក ដែលបានញែកជាបរិសុទ្ធ* សូមមើលការពន្យល់ ៤៤:១៥ ។
**៤៨:១៤** *មិនត្រូវឱ្យគេលក់អ្វីពីនោះឡើយ ក៏មិនត្រូវប្តូរ* ព្រោះថាព្រះអម្ចាស់មិនចង់ឱ្យធ្វើដូច្នោះ វាមិនមែនជាជាគោលដៅដើម្បីធ្វើពានិជ្ជកម្មឡើយ ។
**៤៨:១៩** *ពីគ្រប់ទាំងពូជអំបូរអ៊ីស្រាអែល* ទីកន្លែងសំរាប់ថ្វាយយញ្ញបូជាជាទ្រព្យសម្បត្តិរបស់ជាតិ មិនមែនជាកម្មសិទ្ធិ ជាឯកជនរបស់ពួកចៅហ្វាយណាឡើយ ។

ដែលបានថ្វាយនឹងទីបរិសុទ្ធរបស់ព្រះវិហារ នោះត្រូវនៅ
កណ្តាលនោះ[ផ] ២២ដូច្នេះ ដីដែលត្រូវទុកសំរាប់ចៅហ្វាយ
នោះជាដីដែលជាប់តពីដីរបស់ពួកលេវី ហើយពីដីសំរាប់
ទីក្រុង គឺទាំងអស់ដែលនៅកណ្តាលព្រំស្រុកយូដា និងព្រំ
ស្រុកបេនយ៉ាមីន នោះត្រូវទុកសំរាប់ចៅហ្វាយ ។
២៣រីឯពូជអំបូរឯទៀត ចាប់តាំងពីខាងកើតរហូតដល់
ខាងលិច នោះមានចំណែក១សំរាប់ពូជអំបូរបេនយ៉ាមីន[ព]
២៤ហើយតាមព្រំស្រុករបស់បេនយ៉ាមីន ចាប់តាំងពីខាង
កើតរហូតដល់ខាងលិច នោះមានចំណែក១សំរាប់ពូជ
អំបូស៊ីម្មាន[ភ] ២៥ហើយតាមព្រំស្រុករបស់ស៊ីម្មាន ចាប់
តាំងពីខាងកើត រហូតដល់ខាងលិច នោះមានចំណែក១
សំរាប់ពូជអំបូរស៊ីសាខារ[ម] ២៦ហើយតាមព្រំស្រុករបស់ពួក
អ៊ីសាសាខារចាប់តាំងពីខាងកើតរហូតដល់ខាងលិច នោះ
មានចំណែក១សំរាប់ពូជអំបូរសាប់យូល៉ូន[យ] ២៧ហើយ
តាមព្រំស្រុករបស់សាប់យូល៉ូន ចាប់តាំងពីខាងកើតរហូត
ដល់ខាងលិច នោះមានចំណែក១សំរាប់ពូជអំបូរកាឌ់[រ]
២៨ហើយតាមព្រំស្រុករបស់កាឌ់ខាងត្បូងបំផុត នោះព្រំ
ស្រុកគេ ត្រូវចាប់តាំងពីក្រុងតាម៉ារ[ល] ទៅដល់ទឹកមេរីបា–
កាដេស តាមជ្រោះទឹក រហូតដល់សមុទ្រធំ[វ] ២៩នេះជា
ស្រុកដែលឯងរាល់គ្នាត្រូវចាប់ឆ្នោត បែងចែកដល់ពូជ
អំបូរទាំងប៉ុន្មានរបស់អ៊ីស្រាអែលទុកជាមរដក នេះជា
ចំណែករបស់គេនីមួយៗ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់
យេហូវ៉ា[ស]។

## ទ្វារទាំងឡាយនៃក្រុង

៣០ឯព្រំខណ្ឌនៃទីក្រុងនោះ គឺខាងជើងមាន៤៥០០ខ្នាត
តាមរង្វាស់ ៣១ហើយទ្វារទាំងប៉ុន្មាននៃទីក្រុង នឹងមាន
ឈ្មោះ តាមឈ្មោះអស់ទាំងពូជអំបូរសាសន៍អ៊ីស្រាអែល
ខាងជើងនឹងមានទ្វារ៣គឺទ្វាររូបេន១ ទ្វារយូដា១ និងទ្វារ
លេវី១ ៣២នៅខាងកើតមាន៤៥០០ខ្នាត ហើយទ្វារ៣ គឺ
ទ្វារយ៉ូសែប១ទ្វារបេនយ៉ាមីន១ និងទ្វារដាន់១ ៣៣នៅ
ខាងត្បូងមាន៤៥០០ខ្នាត ហើយទ្វារ៣ គឺទ្វារស៊ីម្មាន១ទ្វារ
អ៊ីសាខារ១ និងទ្វារសាប់យូល៉ូន១ ៣៤នៅខាងលិចមាន
៤៥០០ខ្នាតហើយទ្វារ៣គឺទ្វារកាឌ់១ ទ្វារអេស៊ើ១ និង
ទ្វារណែបថាលី១[ហ] ៣៥ឯព័ទ្ធជុំវិញទីក្រុងនោះត្រូវជា១ម៉ឺន
៨ពាន់ខ្នាតហើយតាំងពីថ្ងៃនោះតទៅ ទីក្រុងនោះត្រូវមាន
ឈ្មោះថា "ព្រះយេហូវ៉ាទ្រង់គង់នៅទីនេះ"[ឡ]។/

**៤៨:២១** ផ ខ.៨,១០ អគ ៤៥:៧
**៤៨:២៣** ព យស ១៨:១១–២៨
**៤៨:២៤** ភ យស ២៩:៣៣ យស ១៩:១–៩
**៤៨:២៥** ម យស ១៩:១៧–២៣
**៤៨:២៦** យ យស ១៩:១០–១៦
**៤៨:២៧** រ យស ១៣:២៤–២៨
**៤៨:២៨** ល លប ១៤:៧ វ ជន ៣៤:៦ អគ ៤៧:១៩
**៤៨:២៩** ស អគ ៤៥:១
**៤៨:៣៤** ហ ២រប ៤:៤ វវ ២១:១២–១៣
**៤៨:៣៥** ឡ អស ១២:៦ ២៤:២៣ យរ ៣:១៧ ១៤:៩ ៣៣:១៦ យអ ៣:២១ វវ ៣:១២ ២១:៣

**៤៨:២៣** *ពូជអំបូរបេនយ៉ាមីន* ជាកូនប្រុសរបស់នាងរ៉ាជែល (មើល លក ៣៥:២៤) ។

**៤៨:២៤** *ពូជអំបូរស៊ីម្មាន* ជាកូនប្រុសរបស់នាងលេអា (មើល លក ៣៥:២៣) ។

**៤៨:២៥** *ពូជអំបូរអ៊ីសាខារ* ជាកូនប្រុសរបស់នាងលេអា (មើល លក ៣៥:២៣) ។

**៤៨:២៦** *ពូជអំបូរសាប់យូល៉ូន* ជាកូនប្រុសរបស់នាងលេអា (មើល លក ៣៥:២៣) ។

**៤៨:២៧** *ពូជអំបូរកាឌ់* កូនប្រុសរបស់នាងស៊ីលផា ជាអ្នកបម្រើស្រីរបស់នាងលេអា (មើលការពន្យល់ ខ.២) ។

**៤៨:២៨** *ក្រុងតាម៉ារ* មើលការពន្យល់ ៤៧:១៨ *ទឹកមេរីបា–កាដេស* មើលការពន្យល់ ៤៧:១៩ ទឹកសមុទ្រធំ មើលការពន្យល់ ៤៧:១៩ ។

**៤៨:៣០–៣៥** ទ្វារទាំង១២ នៃទីក្រុងថ្មីរបស់ក្រុងយេរូសាឡិម ។

**៤៨:៣១** *ទ្វាររូបេន១ ទ្វារយូដា១ និងទ្វារលេវី១* រូបេន (តំណាងឱ្យកូនច្បង) យូដា (ពូជអំបូរមេស៊ី) ហើយលេវី (ពូជអំបូរសង្ឃ) ដែលមានទ្វាររួមគ្នានៅខាងជើង ។ យ៉ូសែប (ខ.៣២) តំណាងឱ្យពូជអំបូរអេប្រាអិម និងពូជអំបូរម៉ាន៉ាសេ (មើលការពន្យល់ ៤៧:១៣) ដើម្បីនឹងរក្សាទ្វារទាំង១២ ។ សម្រាប់ទ្វារ ធៀបនឹង នៅក្នុង វវ ២១:១២–១៤ ។

**៤៨:៣៥** *ព្រះអម្ចាស់ទ្រង់គង់នៅទីនេះ* ព្រះបន្ទូលយ៉ាងខ្លាំងដែលផ្តោតទៅលើទីក្រុងបរិសុទ្ធ ។ ពាក្យហេព្រើរសម្រាប់ឃ្លានេះគឺ ព្រះយេហូវ៉ា (Yahweh) សាំម៉ា ហើយអាចប្រហែលជាមានន័យថា យេរូសាឡិម (Yerushalayim) ការបញ្ចេញសំលេងជាពាក្យហេព្រើរថាក្រុងយេរូសា–ឡិមញ ។ សម្រាប់ឈ្មោះផ្សេងទៀតនៃក្រុងយេរូសាឡិម មើល ២៣:៤ អស ១:២៦ ៦០:១៤ ៦២:២–៤ យរ ៣:១៧ ៣៣:១៦ អគ ៨:៣ ព្រះគម្ពីរយ៉ូអែលនៅទីបញ្ចប់គឺដូចគ្នា (មើលការពន្យល់ក្នុង យអ ៣:២១) ។

# ព្រះគម្ពីរដានីយ៉ែល

## សេចក្តីផ្តើម

### អ្នកនិពន្ធ និងកាលបរិច្ឆេទ និងប្រភព

តាមបទគម្ពីរនៅក្នុងព្រះគម្ពីរនេះ គេអាចសន្និដ្ឋានបានថា លោកដានីយ៉ែលគឺជាអ្នកនិពន្ធព្រះគម្ពីរនេះ (មើល ៩:២ ១០:២)។ ព្រះយេស៊ូវទ្រង់បានមានបន្ទូលអំពី "សេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញ" ដែលជាបទទំនាយរបស់លោកដានីយ៉ែលនៅក្នុង ៩:២៧ (មើលការពន្យល់ខនេះ) ១១:៣១ និង ១២:១១ ។ គេជឿថា ព្រះគម្ពីរនេះបាននិពន្ធចប់សព្វគ្រប់ ប្រហែលជានៅក្នុងឆ្នាំ ៥៣០ មុន គ.ស គឺនៅក្រោយដែលស្តេចស៊ីរ៉ូសដ៏អស្ចារ្យ (Cyrus the Great) នៃចក្រភពពើស៊ី បានឈ្លានពាន ហើយកាន់កាប់ទីក្រុងបាប៊ីឡូននៅ ឆ្នាំ ៥៣៩ មុន គ.ស ។

មនុស្សជាច្រើនបានមានទស្សនៈថា ព្រះគម្ពីរដានីយ៉ែលគឺជាសៀវភៅរឿងប្រឌិត ដោយពួកគេសម្អាងទៅលើការសន្និដ្ឋានតាមបែបទស្សនវិជ្ជាសម័យទំនើបដែលថា ការថ្លែងទំនាយអំពីអនាគតដ៏យូរអង្វែង ដោយនិយាយអំពីសម័យមួយទៅសម័យមួយទៀតបែបនេះ គឺជារឿងដែលមិនអាចធ្វើទៅបានទេ ។ ដូចនេះពួកគេអះអាងថា ព្រះគម្ពីរដានីយ៉ែលប្រាកដជាត្រូវបាននិពន្ធនៅក្រោយសម័យម៉ាកាប៊ី (សតវត្សទី២ មុន គ.ស) គឺបន្ទាប់ពីបទទំនាយបានសម្រេចហើយ ។ ប៉ុន្តែមានភស្តុតាងជាច្រើនដែលបង្ហាញថា ទស្សនៈនេះពិតជាមិនត្រឹមត្រូវឡើយ:

១).បើព្រះគម្ពីរនេះត្រូវបាននិពន្ធនៅក្រោយសម័យម៉ាកាប៊ីមែន នោះតាមធម្មតា អ្នកនិពន្ធប្រាកដជានិយាយអំពីចក្រភពទាំងបួននៅក្នុងជំពូក ២ និង ៧ ដោយសំដៅទៅលើចក្រភពបាប៊ីឡូន មេឌី ពើស៊ី និងក្រិក ។ ប៉ុន្តែ អ្នកនិពន្ធមិនបានសរសេរដូចនោះទេ គឺលោកបាននិយាយអំពីចក្រភព "មេឌី និងពើស៊ី" (៥:២៨ និងការពន្យល់) ដោយដាក់ចក្រភពទាំងពីរនៅក្នុងលំដាប់ទីពីរ នៃចក្រភពទាំងបួន (២:៣២ –៤៣ និងការពន្យល់) ដូចនេះ អ្នកនិពន្ធបានបញ្ជាក់យ៉ាងច្បាស់ថា ចក្រភពទាំងបួន គឺបាប៊ីឡូន មេដូ–ពើស៊ី ក្រិក និងរ៉ូម៉ាំង ។

២).តាមរយៈការសិក្សាអំពីភាសាដែលប្រើនៅក្នុងការសរសេរព្រះគម្ពីរនេះ គេអាចសន្និដ្ឋានបានថា ព្រះគម្ពីរនេះត្រូវបាននិពន្ធនៅ មុនសតវត្សទី២មុន គ.ស ។ ភស្តុតាងផ្នែកអក្សរសាស្ត្រ នៅក្នុងក្រាំងសមុទ្រស្លាប់ (ដែលជាប្រភពនៃគម្ពីរស្នាដៃអក្សរសាស្ត្រជាភាសាហេព្រើរ និងអើរ៉ាម នៅសតវត្សទី៣ និងទី២ មុនគ.ស) បានបង្ហាញថា អត្ថបទនៅក្នុងព្រះគម្ពីរដានីយ៉ែលដែលជំពូកខ្លះសរសេរជា ភាសាហេព្រើរ និងខ្លះទៀតជាភាសាអើរ៉ាម គឺត្រូវបាននិពន្ធឡើងនៅមុនសតវត្សទី ២ មុនគ.ស ។ ជាងនេះទៅទៀត ពាក្យជាភាសាពើស៊ី និងក្រិក នៅក្នុងព្រះគម្ពីរដានីយ៉ែល ក៏ជាពាក្យដែលគេប្រើនៅសម័យនោះផងដែរ ។ ពាក្យបច្ចេកទេសមួយចំនួននៅក្នុងជំពូក៣ គឺមិនត្រូវ បានគេប្រើទៀតទេ នៅក្នុងសតវត្សទី២ មុនគ.ស ។

៣).មានសេចក្តីទំនាយជាច្រើននៅក្នុងព្រះគម្ពីរដានីយ៉ែលដែលមិនទាន់បានសម្រេចនៅសតវត្សទីពីរមុនគ.សនៅឡើយ ដូចនេះគេមិនអាចបដិសេធសេចក្តីទំនាយនោះបានឡើយ ។ និមិត្តរូបដែលទាក់ទងនឹងចក្រភពទីបួន គឺជាសេចក្តីទំនាយដែលត្រូវនឹងលក្ខណៈចក្រភពរ៉ូម៉ាំងដែលមិនអាចប្រកែកបាន (មើល ២:៣៣ ៧:៧,១៩) ដែលចាប់ផ្តើមគ្រប់គ្រងទឹកដីស៊ីរី និងប៉ាលេស្ទីននៅឆ្នាំ ៦៣ មុនគ.ស ។ ជាពិសេសនៅក្នុងសេចក្តីទំនាយនោះ គេអាចកាត់ស្រាយសេចក្តីទំនាយអំពីការយាងមកនៃ "អ្នកដែលបានចាក់ប្រេងតាំង" ដែលកើតឡើងប្រហែលជា ៤៨៣ ឆ្នាំបន្ទាប់ពីការ "ចេញបញ្ជាឱ្យសង់ទីក្រុងយេរូសាឡិមឡើងវិញ" (៩:២៥ និងការពន្យល់ ៩:២៥–២៧) រហូតដល់ការចាប់ផ្តើមព្រះរាជកិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ ។

ដូចនេះ តាមភស្តុតាងខាងលើ ការចោទប្រកាន់ថា ព្រះគម្ពីរនេះត្រូវបានសរសេរនៅសតវត្សទីពីរមុនគ.ស គឺជាការមិនត្រឹមត្រូវទេ ហើយការដែលលោកដានីយ៉ែលជាអ្នកនិពន្ធ ក៏គេមិនអាចបដិសេធបានដែរ ។

### ខ្លឹមសារផ្នែកវិជ្ជាអំពីព្រះ

ខ្លឹមសារផ្នែកវិជ្ជាអំពីព្រះនៃព្រះគម្ពីរនេះ គឺត្រូវបានសង្ខេបនៅក្នុង ៤:១៧ ៥:១២ : "ព្រះដ៏ខ្ពស់បំផុតទ្រង់គ្រប់គ្រងលើរាជ្យរបស់មនុស្ស"។ សេចក្តីទំនាយរបស់លោកដានីយ៉ែលតែងតែបង្ហាញថា ព្រះទ្រង់តែងមានជ័យជម្នះជានិច្ច (៧:១១,២៦–២៧ ៨:២៥ ៩:២៧)។ ចំណុចសំខាន់បំផុតនៃការដឹកនាំរបស់ទ្រង់គឺត្រូវបានពិពណ៌នានៅក្នុងព្រះគម្ពីរវិវរណៈ "នគរទាំងប៉ុន្មាននៅលើលោកីយបានត្រឡប់ជានគររបស់ព្រះអម្ចាស់នៃយើងរាល់គ្នា និងជារបស់ផងព្រះគ្រីស្ទនៃទ្រង់ហើយ ទ្រង់នឹងសោយរាជ្យនៅអស់កល្បជានិច្ចរៀងរាបតទៅ" (វវ ១១:១៥ មើល ដយ ២:៤៤ ៧:២៧ និងការពន្យល់)។

**ទម្រង់អក្សរសាស្ត្រ**

ព្រះគម្ពីរនេះគឺជាព្រះគម្ពីរអត្ថាធិប្បាយបែបប្រវត្តិសាស្ត្រ (មាននៅក្នុងជំពូក ១–៦) និងព្រះគម្ពីរហោរា ("បើកសម្ដែង", មានជាពិសេសនៅក្នុងជំពូក ៧–១២)។ ព្រះគម្ពីរមានលក្ខណៈជាព្រះគម្ពីរហោរា ដែលលើកឡើងអំពី និមិត្តរូប បទទំនាយ ហើយត្រូវបាននិពន្ធឡើងនៅក្នុងអំឡុងពេលនៃការគៀបសង្កត់ និងនិយាយទាក់ទងនឹងការជំនុំជម្រះ ។ ព្រះគម្ពីរហោរាគឺជាស្នាដៃអក្សរសាស្ត្រដែលមានការលើកទឹកចិត្តដល់រាស្ត្ររបស់ព្រះ (មើលសេចក្ដីផ្ដើមព្រះគម្ពីរសាការីត្រង់ចំណុច ទម្រង់ និងខ្លឹមសារអក្សរសាស្ត្រ និងសេចក្ដីផ្ដើមព្រះគម្ពីរវិវរណៈត្រង់ចំណុចទម្រង់អក្សរសាស្ត្រ)។ ចំពោះការប្រើលេខនៅក្នុងការថ្លែងទំនាយ សូមមើលសេចក្ដីផ្ដើមព្រះគម្ពីរវិវរណៈត្រង់លក្ខណៈពិសេស ។

**គម្រោងសង្ខេប**

I. សេចក្ដីផ្ដើមៈ សង្គមបរិយាកាស (ជំពូក១, សរសេរជាភាសាហេព្រើរ)
- ក. សេចក្ដីផ្ដើមផ្នែកប្រវត្តិសាស្ត្រ (១:១–២)
- ខ. ការជាប់ជាឈ្លើយរបស់លោកដានីយ៉ែល និងមិត្តភ័ក្ដ (១:៣–៧)
- គ. ពួកក្មេងប្រុសៗមានភាពស្មោះត្រង់ (១:៨–១៦)
- ឃ. ពួកខ្មេងប្រុសៗត្រូវតម្លើងឱ្យកាន់មុខដំណែងខ្ពស់ (១:១៧–២១)

II. ជោគវាសនានៃនគរនៃលោកិយ (ជំពូក ២–៧, សរសេរជាភាសាអើរ៉ាមចាប់ពី ២:៤ខ)
- ក. សុបិន្តរបស់ស្ដេចនេប៊ូក្នេសាអំពីរូបចម្លាក់ធំមួយ (ជំពូក ២)
- ខ. ស្ដេចនេប៊ូក្នេសាធ្វើរូបមាស និងដាក់បញ្ជាឱ្យថ្វាយបង្គំរូបនោះ (ជំពូក ៣)
- គ. សុបិន្តរបស់ស្ដេចនេប៊ូក្នេសាអំពីដើមឈើធំអស្ចារ្យ (ជំពូក ៤)
- ឃ. ការដួលរលំរបស់ស្ដេចបេលសាសារ និងរបស់ចក្រភពបាប៊ីឡូន (ជំពូក ៥)
- ង. ការដោះលែងលោកដានីយ៉ែលពីរូងសឹង្ហ (ជំពូក ៦)
- ច. សុបិន្តរបស់លោកដានីយ៉ែលអំពីសត្វសាហាវទាំងបួន (ជំពូក ៧)

III. ជោគវាសនានៃនគរអ៊ីស្រាអែល (ជំពូក ៨–១២, សរសេរជាភាសាហេព្រើរ)
- ក. បទទំនាយរបស់លោកដានីយ៉ែលអំពីសត្វចៀមឈ្មោល និងពពែ (ជំពូក ៨)
- ខ. សេចក្ដីអធិស្ឋានរបស់លោកដានីយ៉ែល និងបទទំនាយរបស់គាត់អំពី "អាទិត្យ"ទាំង៧០ (ជំពូក ៩)
- គ. បទទំនាយរបស់លោកដានីយ៉ែលអំពីអនាគតរបស់អ៊ីស្រាអែល (ជំពូក ១០–១២)
  - ១. បទទំនាយអំពីការដែលត្រូវមក (១០:១–៣)
  - ២. ការបើកសំដែងពីទេវតានាំព្រះរាជសារ (១០:៤–១១:១)
  - ៣. បទទំនាយអំពីចក្រភពពើស៊ី និងក្រិក (១១:២–៤)
  - ៤. បទទំនាយអំពីទឹកដីអេស៊ីព្ទ និងស៊ីរី (១១:៥–៣៥)
  - ៥. បទទំនាយអំពីពួកទទឹងព្រះគ្រីស្ទ (១១:៣៦–៤៥)
  - ៦. សេចក្ដីទុក្ខ និងការរំដោះ (១២:១)
  - ៧. ការរស់ឡើងវិញទាំងពីរ (១២:២–៣)
  - ៨. ការបង្គាប់ដល់លោកដានីយ៉ែល (១២:៤)
  - ៩. ការសន្និដ្ឋាន (១២:៥–១៣)

## លោកដានីយ៉ែលទទួលការហ្វឹកហាត់នៅក្រុងបាប៊ីឡូន

**១** ១ នៅឆ្នាំទី៣ ក្នុងរាជ្យយេហូយ៉ាគីម[ក] ជាស្តេចយូដា
នោះនេប៊ូក្នេសា[ខ] ជាស្តេចបាប៊ីឡូន[គ] ទ្រង់មកឡោមព័ទ្ធ
ច្បាំងនឹងក្រុងយេរូសាឡិម[ឃ] ២ នោះព្រះអម្ចាស់ទ្រង់ប្រគល់
យេហូយ៉ាគីម ជាស្តេចយូដាទៅក្នុងកណ្តាប់នៃនេប៊ូក្នេសា
ព្រមទាំងគ្រឿងប្រដាប់១ភាគ ដែលនៅក្នុងព្រះវិហារនៃ
ព្រះផង ហើយទ្រង់ក៏ដឹកនាំ[ង]ទៅឯស្រុកស៊ីណើរ ដាក់ក្នុង
វិហាររបស់ព្រះនៃទ្រង់ គឺបាននាំយកគ្រឿងប្រដាប់ទាំង
នោះទៅក្នុងឃ្លាំងរបស់ព្រះនៃខ្លួន[ច] ៣ ស្តេចទ្រង់មានបន្ទូល
បង្គាប់ដល់អាសផ្នាស ជានាយលើពួកកំរៀវរបស់ទ្រង់ ឱ្យ
នាំពូជស្តេច និងពួកមានត្រកូលខ្ពស់ ក្នុងពួកកូនចៅអ៊ីស្រា
អែលចូលមក[ឆ] ៤ គឺជាមនុស្សកំឡោះៗដែលឥតមាន ខ្ចោះអ្វី
សោះ ជាអ្នកដែលមានរូបរាងល្អ[ជ] ហើយចេះស្ទាត់ក្នុងគ្រប់
ទាំងចំណេះ[ឈ] ឆាប់យល់ខាងសេចក្តីជ្រៅជ្រះ មានគំនិត
វាងវៃ និងអស់អ្នកដែលមានដំរិះ អាចធ្វើការងារក្នុង
ដំណាក់ស្តេចបាន ក៏ប្រាប់ឱ្យលោកបង្រៀនគេតាមវិជ្ជា
និងភាសា[ញ]របស់សាសន៍ខាល់ដេ ៥ ស្តេចទ្រង់ក៏ដំរូវឱ្យមាន
ចំណែកអាហារហ្លួងចែកដល់គេជារាល់ថ្ងៃ ព្រមទាំងស្រា
ទំពាំងបាយជូរ[ដ]ដែលទ្រង់ធ្លាប់សោយផង[ឋ] ហើយឱ្យចិញ្ចឹម
គេយ៉ាងដូច្នោះគ្រប់៣ឆ្នាំ[ឌ] ដើម្បីកាលណាសំរេចពេល
កំណត់ហើយ នោះឱ្យគេបានធ្វើការងារនៅចំពោះស្តេច[ឍ]
៦ រីឯក្នុងពួកអ្នកទាំងប៉ុន្មាននោះ មានពួកយូដាខ្លះ គឺមាន
ដានីយ៉ែល១[ណ] ហាណានា១ មីសាអែល១ និងអ័សារា១[ត]
៧ ឯចៅហ្វាលើពួកកំរៀវ លោកឱ្យមានឈ្មោះផ្សេងវិញ
គឺលោកឱ្យដានីយ៉ែលមានឈ្មោះថា បេលថិស្សាសារ[ថ] ឱ្យ
ហាណានាមានឈ្មោះថា សាដ្រាក់ ឱ្យមីសាអែលមាន
ឈ្មោះថា ម៉ែសាក់ ហើយក៏ឱ្យអ័សារាមានឈ្មោះថា
អ័បេឌ-នេកោ[ទ]។

៨ ប៉ុន្តែដានីយ៉ែលបានសំរេចក្នុងចិត្តថា មិនព្រមឱ្យខ្លួន
សៅហ្មង[ធ] ដោយអាហាររបស់ស្តេច ឬដោយស្រាទំពាំង
បាយជូរដែលទ្រង់ធ្លាប់សោយឡើង បានជាលោកសូមដល់
ចៅហ្វាយលើពួកកំរៀវ ដើម្បីមិនឱ្យខ្លួនត្រូវសៅហ្មងទៅ

**១:១** ក យរ ៤៦:២ ខ ២ពវ ២៤:១ យរ ២៨:១៤ គ យរ ៥០:១ ឃ ២ពវ ២៤:១ ២រប ៣៦:៦ យរ ៣៥:១១ **១:២** ង ២ពវ ២៤:១៣ ច ២រប ៣៦:៧ យរ ២៧:១៩-២០ សក ៥:៥-១១ **១:៣** ឆ ២ពវ ២០:១៨ ២៤:១៥ អស ៣៩:៧ **១:៤** ជ លប ៣៩:៦ ឈ ខ.១៧ ញ អរ ៤:៧ **១:៥** ដ ខ.៨,១០ ឋ នអ ២:៩ ឌ ខ.១៨ ឍ ខ.១៩ នអ ២:៥-៦ **១:៦** ណ អគ ១៤:១៤ ត ដយ ២:១៧,២៥ **១:៧** ថ ដយ ២:២៦ ៤:៨ ៥:១២ ១០:១ ទ អស ៣៩:៧ ដយ ២:៤៩ ៣:១២ **១:៨** ធ អគ ៤:១៣-១៤

**១:១** *នៅឆ្នាំទី៣* តាមក្បួនរបស់ពួកបាប៊ីឡូននៅក្នុងការរាប់ឆ្នាំនៃការគ្រប់គ្រងរបស់ស្តេច ឆ្នាំទីបីក្នុងរាជ្យយេហូយ៉ាគីមគឺត្រូវជាឆ្នាំ ៦០៥ មុនគ.ស គឺរយៈពេលនៃការសោយរាជ្យនៃស្តេចនេះត្រូវរាប់ចាប់ពីថ្ងៃចូលឆ្នាំថ្មី ដែលស្ថិតនៅក្រោយពេលសោយរាជ្យរបស់ស្តេចនេះនៅឆ្នាំ ៦០៨ មុនគ.ស ប៉ុន្តែតាមក្បួនដែលគេប្រើនៅស្រុកយូដា គេកំណត់យកឆ្នាំឡើងសោយរាជ្យ ជាឆ្នាំទីមួយនៃរជ្ជកាល មានន័យថាតាមក្បួននេះ ឆ្នាំនោះគឺជាឆ្នាំទីបួននៃរាជ្យស្តេចយេហូយ៉ាគីម (យរ ២៥:១ ៤៦:២ និងការពន្យល់) ។ *យេហូយ៉ាគីម ជាស្តេចយូដា* មើល ២ពវ ២៣:៣៤ ២រប ៣៦:៥-៨ និងការពន្យល់ ។ *នេប៊ូក្នេសា ជាស្តេចបាប៊ីឡូន* ឆ្នាំ ៦០៥ មុនគ.ស ក៏ជាឆ្នាំទីមួយ របស់ស្តេចអង្គនេះផងដែរ (យរ ២៥:១ ២ពវ ២៤:១ និងការពន្យល់) ។

**១:២** *ដឹកនាំ* ពួកសាសន៍យូដាត្រូវនិរទេសទៅស្រុកបាប៊ីឡូន ពីព្រោះពួកគេមិនស្តាប់បង្គាប់ព្រះបន្ទូលព្រះ ដោយមិនកាន់តាមសេចក្តីសញ្ញា មិនគោរពឆ្នាំឈប់សម្រាក និងថ្វាយបង្គំរូបព្រះ (មើល លវ ២៥:៤ និងការពន្យល់ ២៦:២៧-៣៥ ចទ ២៨:១៥-៦៨ ២ពវ ២៥:១ និងការពន្យល់ ២រប ៣៦:២០-២១ និងការពន្យល់)។ ការនិរទេសលើកទីមួយ (ឆ្នាំ ៦០៥ មុនគ.ស) រួមមានលោកដានីយ៉ែលផងដែរ ហើយលើកទីពីរ (ឆ្នាំ ៥៩៧ មុនគ.ស) រួមមានលោកអេសេគាល ។ ការនិទេសលើកទីបីកើតឡើងនៅក្នុងឆ្នាំ ៥៨៦ មុនគ.ស នៅពេលដែលចក្រភពបាប៊ីឡូនបំផ្លាញទីក្រុងយេរូសាឡិម និងព្រះវិហារស្តេចសាឡូម៉ូន ។ *ព្រះនៃខ្លួន* គឺព្រះម៉ាឌូក (Marduk, មើលការពន្យល់ អស ៤៥:៤) ។

**១:៤** *វិជ្ជា និងភាសារបស់សាសន៍ខាល់ដេ* គឺរួមមានស្នាដៃអក្សរសាស្ត្រដែលគេចារនៅលើបន្ទះដីឥដ្ឋជាភាសាស៊ូម៉េរ (Sumerian) និងអ័កខេដ (Akkadian) របស់ចក្រភពបាប៊ីឡូន ដែលមានប្រព័ន្ធនៃការសរសេរដែលមានព្យាង្គស្មុគស្មាញ ។ ប៉ុន្តែ ភាសាដែលគេប្រើនៅក្នុងការប្រាស្រ័យទាក់ទងធម្មតានៅក្នុងចក្រភពបាប៊ីឡូន ដែលមានចំរុះជាតិសាសន៍ គឺភាសាអើរ៉ាម ដែលគេអាចសរសេរដោយប្រើព្យញ្ជនៈដែលងាយស្រួលរៀន (មើល ២:៤ និងការពន្យល់)។

**១:៦** *ដានីយ៉ែល* មានន័យថា "ព្រះទ្រង់ជាអ្នកជំនុំជម្រះ (របស់ខ្ញុំ)"។ *ហាណានា* មានន័យថា "ព្រះទ្រង់ផ្តល់ព្រះគុណ"។ *មីសាអែល* មានន័យថា "តើអ្នកណាដែលដូចព្រះ?"។ *អ័សារា* មានន័យថា "ព្រះអម្ចាស់ទ្រង់ជួយ"។

**១:៧** *លោកឱ្យមានឈ្មោះផ្សេងវិញ* ដើម្បីបញ្ជាក់ថា ពួកគេត្រូវស្ថិតនៅក្រោមអំណាចរបស់ស្តេចនេប៊ូក្នេសាហើយ (មើល លប ១៧:៥ ៤១:៤៥ ២ពវ ២៣:៣៤ ២៤:១៧ និងការពន្យល់) ។ *បេលថិស្សាសារ* ពាក្យនេះជាភាសាបាប៊ីឡូនប្រហែលជាមានន័យថា "ព្រះបាល (គឺព្រះម៉ាឌូក) ការពារជីវិតគាត់"។ *សាដ្រាក់* ប្រហែលជាមានន័យថា "ព្រះរាជបញ្ជារបស់ព្រះអ័គូ (Aku, ព្រះនៃដួងច័ន្ទរបស់សាសន៍ស៊ូម៉េរ)" ។ *ម៉ែសាក់* ប្រហែលជាមានន័យថា "តើអ្នកណាដូចព្រះអ័គូ"។ *អ័បេឌ-នេកោ* មានន័យថា "អ្នកបម្រើរបស់ស្តេចនេប៊ូក្នេសា"។

**១:៨** *អាហាររបស់ស្តេច ឬស្រាទំពាំងបាយជូរ* ពួកសាសន៍អ៊ីស្រាអែលបានចាត់ទុកអាហារដែលបានពីលើតុស្តេចនេប៊ូក្នេសាថាមិនស្អាត ពីព្រោះចំណែកទីមួយនៃអាហារនោះគឺជាដង្វាយសម្រាប់រូបព្រះ ។ ស្រាទំពាំងបាយជូរមួយភាគត្រូវច្រួចលើអាសនារបស់សាសន៍ដទៃ ។ ពួកគេបានប្រើសត្វដែលរាប់ជាមិនស្អាតតាមក្រឹត្យវិន័យ ហើយមិនបានសម្លាប់ ឬរៀបចំតាមក្រឹត្យវិន័យព្រះទេ ។ *សូម... ដើម្បីមិនឱ្យខ្លួនត្រូវសៅហ្មង* នៅត្រង់ចំណុចនេះ លោកដានីយ៉ែលបានបង្ហាញអំពីការឈរមាំនៅក្នុងសេចក្តីជំនឿ ដោយសេចក្តីក្លាហាន ។

9 ព្រះទ្រង់ក៏ធ្វើឱ្យដានីយ៉ែលបានប្រកបដោយ សេចក្ដីសប្បុ-
រស[ន] និងសេចក្ដីស្រឡាញ់[ប]របស់ចៅហ្វាយនោះ 10 ឯ
ចៅហ្វាយលើពួកកំរៀវនោះក៏និយាយនឹងដានីយ៉ែលថា
យើងខ្លាចព្រះករុណា ជាព្រះអម្ចាស់នៃយើង ដែលទ្រង់
បានដំរូវអាហារ និងគ្រឿងផឹក[ផ]ដល់អ្នកណាស់ ចង់ឱ្យទ្រង់
ទតឃើញមុខអ្នករាល់គ្នាបានអាក្រក់ជាងពួកកំឡោះៗ
ស្រករនឹងឯងធ្វើអី យ៉ាងនោះអ្នកនឹងធ្វើឱ្យយើងប្រថុយ
ក្បាលចំពោះស្តេចហើយ 11 នោះដានីយ៉ែលនិយាយដល់
អ្នកដំរួត ដែលចៅហ្វាយពួកកំរៀវបានតាំងឱ្យត្រួតលើ
ដានីយ៉ែល ហាណានា មីសាអែល និងអ័សារាថា 12 សូម
ល្បងល[ព]យើងខ្ញុំ ជាអ្នកបំរើលោកបាន១០ថ្ងៃ មើលសូមឱ្យ
គេឱ្យយើងខ្ញុំរាល់គ្នាទទួលទានតែបន្លែ ហើយផឹកទឹក
ប៉ុណ្ណោះចុះ 13 រួចសូមលោកមើលមុខយើងខ្ញុំ ផ្ទឹមនឹងមុខ
ពួកកំឡោះៗ ដែលបរិភោគអាហាររបស់ស្តេច ក៏សូម
លោកប្រព្រឹត្តនឹងយើងខ្ញុំតាមដែលលោកឃើញចុះ[ភ]។
14 ដូច្នេះ លោកក៏ស្តាប់តាមគេក្នុងដំណើរនោះ ក៏
ល្បងល[ម]គេមើលអស់១០ថ្ងៃ 15 លុះដល់ផុត១០ថ្ងៃទៅ នោះ
មុខគេបានស្រស់ជាង ហើយគេមានសាច់ល្អជាងពួក
កំឡោះៗ ដែលបរិភោគអាហាររបស់ស្តេចទៅទៀត[យ]
16 ដូច្នេះអ្នកដំរួតក៏ដកយកអាហារ នឹងស្រាទំពាំងបាយជូរ
ដែលសំរាប់ឱ្យគេផឹកចេញទៅ ហើយបានឱ្យតែបន្លែដល់
គេវិញ[រ]។
17 រីឯមនុស្សកំឡោះទាំង៤នាក់នេះ ព្រះទ្រង់ប្រទាន
ឱ្យគេមានដំរិះ[ល]ហើយឱ្យបានឆ្លៀវឆ្លាតក្នុងគ្រប់ទាំងចំណេះ
និងប្រាជ្ញា[វ] ឯដានីយ៉ែល លោកក៏មានយោបល់ក្នុងអស់
ទាំងការជាក់ស្តែង និងការយល់សប្តិផង[ស] 18 លុះដល់
កំណត់ពេល ដែលស្តេចបានបង្គាប់ឱ្យនាំគេចូលមក នោះ
ចៅហ្វាយលើពួកកំរៀវ ក៏នាំគេចូលទៅគាល់នេប៊ូក្នេសា[ហ]
19 ស្តេចទ្រង់ក៏មានបន្ទូលសន្ទនានឹងគេ ហើយក្នុងពួក
អ្នកទាំងនោះ ឥតឃើញមានអ្នកណាដូចជាដានីយ៉ែល
ហាណានា មីសាអែល និងអ័សារាឡើយ ដូច្នេះ អ្នកទាំង
នោះបានធ្វើការងារ នៅចំពោះស្តេចទៅ[ឡ] 20 ហើយក្នុង
គ្រប់ទាំងរឿងខាងឯប្រាជ្ញា និងយោបល់ ដែលស្តេចទ្រង់
សួរដល់គេ នោះក៏ឃើញថា គេវិសេសជាងអស់ទាំងពួក
គ្រូមន្តអាគម[អ] ហើយនឹងគ្រូអង្គុយធម៌ ដែលនៅគ្រប់ក្នុង
អាណាខេត្តទ្រង់១ជា១០ស្ទួន[ក] 21 ហើយដានីយ៉ែលក៏នៅ
រៀងតទៅ ដរាបដល់ឆ្នាំទី១ក្នុងរាជ្យស្តេចស៊ីរូស[ខ]។

## សុបិន្តរបស់ស្តេចនេប៊ូក្នេសា

**២** 1 នៅក្នុងឆ្នាំទី២ នៃរាជ្យនេប៊ូក្នេសា នោះទ្រង់បាន
សុបិននិមិត្ត[ក] ហើយមានវិញ្ញាណវឹងស៊ុង[ខ] បានជាទ្រង់ផ្ទំ
មិនលក់ឡើយ[គ] 2 រួចស្តេចទ្រង់បង្គាប់ឱ្យហៅពួកគ្រូមន្ត
អាគម[ឃ] គ្រូអង្គុយធម៌[ង] និងគ្រូអាបធ្មប់[ច] ព្រមទាំងពួក
ខាល់ដេ ឱ្យមកកាត់ស្រាយសប្តិនោះថ្វាយទ្រង់[ឆ] គេក៏ចូល
មកឈរនៅចំពោះស្តេច 3 រួចស្តេចទ្រង់មានបន្ទូលនឹងគេ
ថា អញបានយល់សប្តិ ហើយមានវិញ្ញាណវឹងស៊ុង[ជ] ដោយ
ចង់ដឹងន័យក្នុងសប្តិនោះ 4 ដូច្នេះពួកខាល់ដេ គេទូលឆ្លើយ
ដល់ស្តេច ជាភាសាអារ៉ាម[ឈ]ថា បពិត្រព្រះករុណា សូមឱ្យ
ទ្រង់មានព្រះជន្មតរៀង[ញ]ទៅ សូមទ្រង់មានបន្ទូលប្រាប់

**១:៩** ន លប ៣៩:២១ សផ ១៦:៧ ប ១ពវ ៨:៥០
**១:១០** ផ ខ.៥
**១:១២** ព វវ ២:១០
**១:១៣** ភ ខ.១៦
**១:១៤** ម វវ ២:១០
**១:១៥** យ នក ២៣:២៥
**១:១៦** រ ខ.១២–១៣
**១:១៧** ល យប ១២:១៣ វ ដយ ២:២៣ កល ១:៩ យក ១:៥ ស ដយ ២:១៩,៣០ ៥:១០ ៧:១ ៨:១
**១:១៨** ហ ខ.៥
**១:១៩** ឡ លប ៤១:៤៦
**១:២០** អ លប ៤១:៨ ក ១ពវ ៤:៣០ នអ ២:១៥ អគ ២៨:៣ ដយ ២:១៣,២៨ ៤:១៨ ៦:៣
**១:២១** ខ ២របា ៣៦:២២ ដយ ៦:២៨ ១០:១
**២:១** ក ខ.៣ លប ២០:៣ យប ៣៣:១៥,១៨ ដយ ៤:៥ ខ លប ៤១:៨ គ នអ ៦:១
**២:២** ឃ លប ៤១:៨ ង នក ៧:១១ យរ ២៧:៩ ច ខ.១០ អស ១៩:៣ ៤៤:២៥ ឆ ដយ ៤:៦ **២:៣** ជ ដយ ៤:៥ **២:៤** ឈ អរ ៤:៧ ញ នហ ២:៣

**១:៩** *ព្រះក៏ធ្វើឱ្យដានីយ៉ែលបានប្រកបដោយសេចក្ដីសប្បុរស និងសេចក្ដីស្រឡាញ់របស់ចៅហ្វាយនោះ* របៀបនៃការធ្វើការរបស់លោកដានីយ៉ែល និងលោកយ៉ូសែប មានលក្ខណៈស្រដៀងគ្នាជាច្រើន (លប ៣៩–៤១)។

**១:១២** *សូមល្បងលយើងខ្ញុំ ជាអ្នកបំរើលោក* លោកដានីយែលប្រើវិធីដោះស្រាយបញ្ហាបានយ៉ាងល្អ ដោយសូមពីចៅហ្វាយរបស់គាត់នូវជម្រើសមួយជាជាងធ្វើការបះបោរប្រឆាំង ។ *១០ថ្ងៃ* ជាញឹកញាប់ពាក្យនេះគឺជានិមិត្តរូបនៃភាពពេញលេញ ។

**១:១៧** ព្រះអម្ចាស់បានជួយដល់លោកដានីយ៉ែល និងមិត្រភ័ក្ត្ររបស់លោកឱ្យមានចំណេះអាចកាត់ស្រាយសប្តិបាន ។ ការកាត់ស្រាយ និងការថ្លែងទំនាយរបស់ពួកគេ (២:២–១១ ៤:៦–៧) បានធ្វើឱ្យចំណេះរបស់សាសន៍ដទៃទៅជាគ្មានតម្លៃវិញ ។ បើគ្មានការបើកសម្តែងជាពិសេសរបស់ព្រះអម្ចាស់ទេ (២:១៧–២៨) នោះលោកដានីយ៉ែលមិនអាចធ្វើការកាត់ស្រាយបានយ៉ាងត្រឹមត្រូវទេ។

**១:២០** *១ ជា ១០ ស្ទួន* មើលការពន្យល់ ខ.១២ ។ *ពួកគ្រូមន្តអាគម* មើលការពន្យល់ លប ៤:១៨ ។

**១:២១** *នៅរៀងតទៅ* គឺនៅតំបន់បាប៊ីឡូន ។ *ឆ្នាំទី១ក្នុងរាជ្យស្តេចស៊ីរូស* គឺនៅក្នុងឆ្នាំទី១ នៃការគ្រប់គ្រងចក្រភពបាប៊ីឡូន (ឆ្នាំ ៥៣៩ មុនគ.ស)។ លោកដានីយ៉ែលបានចំណាយពេលប្រហែល ៧០ ឆ្នាំ ហើយនៅតែមានជីវិតរស់នៅក្នុងឆ្នាំ ៥៣៧ មុនគ.ស (១០:១) ដូចនេះ លោកបានឃើញដំណើរវិលត្រឡប់ទៅស្រុកយូដាវិញ នៃពួកដែលត្រូវគេនិរទេសជាឈ្លើយនៅតំបន់បាប៊ីឡូន ។

**២:១** *ឆ្នាំទី ២ នៃរាជ្យនេប៊ូក្នេសា* គឺត្រូវជាឆ្នាំ ៦០៤ មុនគ.ស (មើល ១:១ និងការពន្យល់)។ *ទ្រង់ផ្ទំមិនលក់ឡើយ* មើល ៦:១៨, នអ ៦:១ និងការពន្យល់ ។

**២:២** *ពួកគ្រូមន្តអាគម គ្រូអង្គុយធម៌ និងគ្រូអាបធ្មប់* មើល ចទ ១៨:៩–១៤ និងការពន្យល់ ១៨:៩ ។

**២:៤** *អារ៉ាម* ដោយសារពួកតារាសាស្ត្រទាំងនោះមានប្រវត្តិផ្សេងៗពីគ្នា ពួកគេធ្វើការទំនាក់ទំនងជាភាសាអារ៉ាម ដែលភាសានេះគេគ្រប់គ្នាអាចយល់បាន ។ ចាប់តាំងពីខនេះរហូតដល់ជំពូក៧ អ្នកនិពន្ធបានធ្វើការរៀបរាប់ដោយប្រើភាសាអារ៉ាម ។ ទាំងប្រាំមួយជំពូកនេះនិយាយអំពីបញ្ហាដែល

សុបិននោះមកយើងខ្ញុំ ជាបាវបំរើចុះ នោះយើងខ្ញុំនឹងកាត់
ស្រាយថ្វាយទ្រង់ជ្រាប ៥តែស្តេច ទ្រង់មានបន្ទូលដល់ពួក
ខាល់ដេថា សេចក្តីនោះយើងបានភ្លេចទៅហើយ[ដ] បើអ្នក
រាល់គ្នាមិនប្រាប់ឱ្យយើងដឹងសប្តិនោះ ហើយកាត់ស្រាយ
ផង នោះអ្នករាល់គ្នានឹងត្រូវកាប់ជាដុំៗ[ឋ] ហើយផ្ទះរបស់
អ្នករាល់គ្នានឹងទៅជាកន្លែងសំរាប់បន្ទោលាមក[ឌ] ៦តែបើ
អ្នករាល់គ្នាប្រាប់សប្តិនោះ ព្រមទាំងកាត់ស្រាយផង នោះ
អ្នករាល់គ្នានឹងបានអំណោយទាន និងរង្វាន់ ហើយកិត្តិយស
ពីយើងវិញ[ឍ] ដូច្នេះចូរប្រាប់ពន្យល់សប្តិនោះដល់យើង
ហើយកាត់ស្រាយទៅចុះ ៧គេទូលឆ្លើយម្តងទៀតថា សូម
តែឱ្យព្រះករុណាមានបន្ទូលប្រាប់សប្តិនោះដល់យើងខ្ញុំ ជា
បាវបំរើទ្រង់ នោះយើងខ្ញុំនឹងកាត់ស្រាយថ្វាយទ្រង់ជ្រាប
៨ស្តេចទ្រង់តបឡើងថា យើងបានដឹងពិតប្រាកដថា អ្នក
រាល់គ្នានឹងចង់បានពេលវេលា ដោយឃើញថា យើងបាន
ភ្លេចសេចក្តីទៅហើយ ៩បើសិនជាអ្នករាល់គ្នាមិនប្រាប់
សប្តិនោះដល់យើងទេ នោះមានទោស[ណ]តែ១ប៉ុណ្ណោះ
សំរាប់អ្នកទាំងអស់គ្នា ដ្បិតអ្នករាល់គ្នាបានបង្កើតពាក្យ
ភូតភរ ហើយឆបោកសំរាប់ឆ្លើយមកយើង ចាំទំរាំតែគ្រា
នេះ បានផ្លាស់ប្រែទៅ ដូច្នេះ ចូរប្រាប់សប្តិនោះដល់យើង
នោះយើងនឹងដឹងថា អ្នករាល់គ្នាអាចនឹងកាត់ស្រាយបាន
មែន[ត] ១០តែពួកខាល់ដេ[ថ] គេទូលឆ្លើយនៅចំពោះស្តេចថា
គ្មានមនុស្សណាមួយនៅលើផែនដីនេះ ដែលអាចនឹង
បង្ហាញដំណើរនៃព្រះករុណាបានទេ ក៏មិនដែលមានស្តេច
ណា ទោះបើធំ ហើយមានអំណាចយ៉ាងណាក៏ដោយ ដែល
បានបង្គាប់ការយ៉ាងនេះដល់ពួកគ្រូមន្តអាគម គ្រូ អង្គុយធម៌
ឬដល់ពួកខាល់ដេណាៗឡើយ[ទ] ១១ការដែលព្រះករុណា
ទ្រង់បង្គាប់នេះ ជាការកម្រមានណាស់ គ្មានអ្នកណាអាច
នឹងបង្ហាញដំណើរនេះដល់ព្រះករុណាបានទេ មានតែពួក
ព្រះ[ធ]ដែលមិនស្ថិតនៅក្នុងសាច់ឈាមវិញប៉ុណ្ណោះ ១២ហេតុ
ដូច្នេះស្តេចទ្រង់ក៏ខ្ញាល់ ហើយមានសេចក្តីក្រេវក្រោធ
យ៉ាងក្រៃលែង[ន] ក៏បង្គាប់ឱ្យបំផ្លាញ[ប]ពួកអ្នកប្រាជ្ញទាំងអស់
ដែលនៅក្រុងបាប៊ីឡូនទៅ ១៣យ៉ាងនោះមានព្រះរាជឱង្ការ
ចេញទៅ បង្គាប់ឱ្យសំឡាប់ពួកអ្នកប្រាជ្ញបង់ ហើយគេក៏រក
ដានីយ៉ែល និងពួកគូកនលោកដើម្បីយកទៅសំឡាប់ដែរ[ផ]។
១៤គ្រានោះ ដានីយ៉ែលឆ្លើយដោយវាងវៃ ហើយឆ្លៀវ
ឆ្លាតដល់អើយ៉ុក ជាមេកងទ័ពរក្សាអង្គ ដែលបានចេញទៅ
ដើម្បីសំឡាប់ពួកអ្នកប្រាជ្ញដែលនៅក្រុងបាប៊ីឡូន ១៥លោក
សួរដល់អើយ៉ុក ជាមេកងទ័ពរក្សាអង្គថា ហេតុអ្វីបានជា
ព្រះរាជឱង្ការនៃស្តេចប្រថំអីម្ល៉េះ នោះអើយ៉ុកក៏ពន្យល់
ប្រាប់ដានីយ៉ែល ១៦រួចដានីយ៉ែលចូលទៅគាល់ស្តេច ទូល
សូមឱ្យបានឱកាសបន្តិច នោះនឹងកាត់ស្រាយថ្វាយទ្រង់ជ្រាប
១៧នោះដានីយ៉ែលក៏វិលទៅឯផ្ទះប្រាប់រឿងនោះដល់
ហាណានា មីសាអែល និងអ័សារាជាគូកនរបស់លោក[ព]
១៨ដើម្បីឱ្យគេបានទូលសូមដល់ព្រះនៃស្ថានសួគ៌[ភ] ឱ្យទ្រង់
បានប្រោសមេត្តា[ម]ដល់គេ ពីដំណើរសេចក្តីអាថ៌កំបាំង
នោះ[យ] ប្រយោជន៍ឱ្យដានីយ៉ែលនឹងគូកនលោកមិនត្រូវវិនា–
សជាមួយនឹងពួកអ្នកប្រាជ្ញឯទៀត ដែលនៅក្រុងបាប៊ីឡូន
ឡើយ ១៩ដូច្នេះសេចក្តីអាថ៌កំបាំង[រ]នោះបានសំដែងមកឱ្យ
ដានីយ៉ែលឃើញ ក្នុងការជាក់ស្តែង[ល] នៅវេលាយប់នោះ
លោកក្រាបថ្វាយបង្គំដល់ព្រះនៃស្ថានសួគ៌[វ] ២០ហើយទូល
ថាសូមឱ្យព្រះនាមនៃព្រះបានប្រកបដោយព្រះពរ នៅអស់
កល្បតរៀងទៅ[ស] ដ្បិតប្រាជ្ញា និងតេជានុភាព[ហ]ជារបស់
ផងទ្រង់ ២១គឺទ្រង់ដែលបំផ្លាស់បំប្រែពេលកំណត់ និងរដូវ
កាល[ឡ] ទ្រង់ដកស្តេច[អ]ចេញ ហើយក៏តាំងស្តេចឡើង[ក] ទ្រង់
ប្រទានប្រាជ្ញា[ខ]ដល់ពួកអ្នកប្រាជ្ញ និងចំណេះដល់អស់អ្នក

**២:៥** ដ លប ៤១:៣២ ឋ ខ.១២ ឌ អរ ៦:១១ ដយ ៣:២៩
**២:៦** ឍ ខ.៤៨ ដយ ៥:៧,១៦
**២:៩** ណ នអ ៤:១១ ត អស ៤១:២២–២៤
**២:១០** ថ ខ.២ ដយ ៣:៨ ៤:៧ ទ ខ.២៧ ដយ ៥:៨
**២:១១** ធ លប ៤១:៣៨
**២:១២** ន ដយ ៣:១៣,១៩ ប ខ.៥
**២:១៣** ផ ដយ ១:២០ ៥:១៩
**២:១៧** ព ដយ ១:៦
**២:១៨** ភ អរ ១:២ នហ ១:៤ យហ ១:៩ វវ ១១:១៣ ម អស ៣៧:៤ យ ខ.២៣ យរ ៣៣:៣
**២:១៩** រ ខ.២៨ ល យប ៣៣:១៥ ដយ ១:១៧ វ យស ២២:៣៣
**២:២០** ស ទដ ១១៣:២ ១៤៥:១–២ ហ យប ៩:៤ យរ ៣២:១៩
**២:២១** ឡ ដយ ៧:២៥ អ ដយ ៤:១៧ ក យប ១២:១៩ ទដ ៧៥:៦–៧
រម ១៣:១ ខ ទដ ១១៩:៣៤ យក ១:៥

សំខាន់ចំពោះសាសន៍ដទៃនៅក្នុងតំបន់មជ្ឈឹមបូព៌ា ហើយត្រូវបានសរសេរជាភាសាដែលពួកគេគ្រប់គ្នាសុទ្ធតែអាចយល់ ។ ប៉ុន្តែ ជំពូកទាំងប្រាំចុងក្រោយ(៨–១២)ត្រូវបានសរសេរជាភាសាហេព្រើរវិញ ព្រោះជាវគ្គដែលនិយាយអំពីបញ្ហាពិសេសរបស់ពួករាស្ត្រជ្រើសតាំង ។

**២:៥** មើល ៣:២៩ ។

**២:១០** *គ្មានមនុស្សណាមួយនៅលើផែនដីនេះ ដែលអាចនឹងបង្ហាញដំណើរនៃព្រះករុណាបានទេ* ប៉ុន្តែ "ព្រះដែលគង់នៅស្ថានសួគ៌" ទ្រង់អាចធ្វើបាន (ដោយប្រើលោកដានីយ៉ែល, មើល ២៧–២៨)។

**២:១១** *មិនស្ថិតនៅក្នុងសាច់ឈាមវិញ* គឺមានន័យថា មនុស្សមិនអាចចូលទៅដល់ព្រះទាំងនោះបានដោយស្រួលឡើយ ។

**២:១៤** *អើយ៉ុក* ឈ្មោះនេះក៏ជាឈ្មោះរបស់ស្តេចនៃតំបន់មេសូប៉ូតាមា ដែលបានរស់នៅកាលពីសតវត្សមុន ។

**២:១៨** *ព្រះនៃស្ថានសួគ៌* នៅក្នុងភាសាពើស៊ី ពាក្យនេះគឺប្រើសម្រាប់ហៅព្រះមួយអង្គដែលគង់នៅស្ថានខ្ពស់បំផុត(មើលការពន្យល់ អរ ១:២) ហើយនៅក្នុងខនេះគឺប្រើសំដៅទៅលើព្រះយេហូវ៉ាដែលជាព្រះនៃអ៊ីស្រាអែល ។ *សេចក្តីអាថ៌កំបាំង* គឺជាពាក្យគន្លឹះនៅក្នុងព្រះគម្ពីរដានីយ៉ែល(ខ.១៩,២៧–៣១,៤៧ ៤:៩)។ ពាក្យនេះនៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺប្រើសំដៅទៅលើបំណងព្រះហឫទ័យរបស់ព្រះ ដែលមានតែពួកហោរា និងពួក សិស្សដែលទ្រង់ជ្រើសរើសប៉ុណ្ណោះ ដែលទ្រង់បើកសំដែងឱ្យដឹង(មើលការពន្យល់ រម ១១:២៥ វវ ១០:៧)។

**២:២១** *ទ្រង់ប្រទានប្រាជ្ញា . . . ដល់អស់អ្នកដែលមានយោបល់* មើល សភ ១:២–៥ និងការពន្យល់ ១:២ ។

ដែលមានយោបល់[គ] ២២ទ្រង់ក៏សំដែងឱ្យឃើញអស់ទាំង
សេចក្តីជ្រាលជ្រៅ ហើយលាក់កំបាំង[ឃ] ទ្រង់ជ្រាបសេចក្តី
ដែលនៅទីងងឹត[ង] ហើយមានពន្លឺ[ច]នៅជាមួយនឹងទ្រង់ ២៣ឱ
ព្រះនៃពួកព្ធយុកោទូលបង្គំ[ឆ]អើយ ទូលបង្គំអរព្រះគុណ
ហើយក៏សរសើរដល់ទ្រង់ ពីព្រោះទ្រង់បានប្រោសឱ្យទូល
បង្គំមានប្រាជ្ញា[ជ] និងអំណាច ហើយឥឡូវនេះទ្រង់បាន
សំដែងឱ្យទូលបង្គំដឹងសេចក្តី ដែលយើងខ្ញុំបានសូមពីទ្រង់
ដ្បិតទ្រង់បានសំដែង ឱ្យយើងខ្ញុំស្គាល់រឿងរ៉ាវរបស់ស្តេច[ឈ]

## លោកដានីយ៉ែលកាត់ស្រាយសុបិន្តនោះ

២៤ដូច្នេះ ដានីយ៉ែលក៏ចូលទៅឯអើយ៉ុក[ញ] ជាអ្នកដែល
ស្តេចបានបង្គាប់ឱ្យបំផ្លាញពួកអ្នកប្រាជ្ញ នៅក្រុងបាប៊ីឡូន
បង់ នោះគឺបានទៅនិយាយដូច្នេះថា សូមកុំបំផ្លាញពួក អ្នក
ប្រាជ្ញ នៅក្រុងបាប៊ីឡូនឡើយ សូមនាំខ្ញុំចូលទៅ គាល់ដល់
ស្តេចចុះ នោះខ្ញុំនឹងកាត់ស្រាយសេចក្តីថ្វាយទ្រង់ជ្រាបវិញ។
២៥ដូច្នេះអើយ៉ុកក៏នាំដានីយ៉ែលចូលទៅចំពោះស្តេច
ដោយប្រញាប់ប្រញាល់ ហើយទូលថា ទូលបង្គំរកបាន
មនុស្សម្នាក់ ក្នុងកូនចៅនៃពួកឈ្លើយ[ដ] ជាសាសន៍យូដា[ឋ]
ដែលនឹងកាត់ស្រាយសេចក្តី ថ្វាយព្រះករុណាឱ្យទ្រង់ជ្រាប
បាន ២៦ស្តេចទ្រង់មានបន្ទូលសួរដានីយ៉ែល ដែលលោក
មានឈ្មោះជា បេលថិស្សាសារ[ឌ] ថា តើអ្នកអាចនឹងប្រាប់
សប្តិ ដែលយើងបានឃើញនោះ ហើយកាត់ស្រាយឱ្យ
យើងផងបានឬ ២៧នោះដានីយ៉ែលក៏ទូលនៅចំពោះស្តេច
ថា សេចក្តីអាថ៌កំបាំងដែលព្រះករុណាបានបង្គាប់មកនោះ
គ្មានពួកអ្នកប្រាជ្ញ ពួកគ្រូអាបធ្មប់ ពួកគ្រូអង្គុយធម៌ ឬគ្រូ
ទាយណា ដែលអាចនឹងកាត់ស្រាយថ្វាយព្រះករុណាបាន
ទេ[ឍ] ២៨តែមានព្រះ១អង្គ ដែលគង់នៅស្ថានសួគ៌ ទ្រង់
សំដែងឱ្យយល់សេចក្តីអាថ៌កំបាំងបាន[ណ] ហើយទ្រង់បាន
សំដែងឱ្យព្រះករុណានេប៊ូក្នេសាបានជ្រាបពីការដែលត្រូវ
កើតមកនៅថ្ងៃក្រោយ[ត] សុបិនរបស់ទ្រង់ និងការជាក់
ស្តែង ដែលទ្រង់បានឃើញ[ថ]កំពុងផ្ទំលក់[ទ] គឺយ៉ាងនេះ[ធ] ២៩ឯ
ត្រង់ទ្រង់ ឱព្រះករុណាអើយ ទ្រង់កើតមានគំនិត កាលទ្រង់
កំពុងផ្ទំនៅលើព្រះក្រឡាបន្ទំ ពីការដែលត្រូវកើតមកនៅ
ខាងមុខ ហើយព្រះដែលទ្រង់សំដែងឱ្យបានយល់ការអាថ៌
កំបាំង ទ្រង់បានធ្វើឱ្យព្រះករុណាជ្រាបពីការដែលត្រូវមក
ដល់[ន] ៣០តែចំណែកទូលបង្គំ ការអាថ៌កំបាំងនេះបានសំដែង
មក[ប]ឱ្យទូលបង្គំយល់ មិនមែនដោយព្រោះទូលបង្គំមាន
ប្រាជ្ញា លើសជាមនុស្សណាទៀតទេ គឺដើម្បីឱ្យសេចក្តី
សំរាយនោះ បានសំដែងមកឱ្យទ្រង់បានជ្រាបវិញ ហើយឱ្យ
ទ្រង់ព្រះករុណា បានជ្រាបអស់ទាំងគំនិតដែលទ្រង់បានគិត
នៅក្នុងព្រះទ័យប៉ុណ្ណោះ ។
៣១បពិត្រព្រះករុណាទ្រង់បានទតឃើញរូប១យ៉ាងធំ
រូបនោះដែលធំសំបើម ហើយភ្លឺយ៉ាងអស្ចារ្យ[ផ] ក៏ឈរនៅ
ចំពោះទ្រង់ មានភាពគួរស្ញែងខ្លាច[ព] ៣២ឯក្បាលរបស់រូប
នោះ ជាមាសយ៉ាងល្អ ដើមទ្រូងនឹងដៃជាប្រាក់ ពោះនឹង
ភ្លៅជាលង្ហិន ៣៣ជើងជាដែក ហើយប្រអប់ជើងជាដែក
លាយនឹងដីឥដ្ឋ ៣៤ទ្រង់បានទតឃើញ ដរាបដល់មានថ្ម១
ដាប់ផ្តាច់ចេញ ឥតដៃអ្នកណាធ្វើ[ភ] មកទង្គិចត្រូវរូបនោះ
ត្រង់ប្រអប់ជើង ដែលធ្វើពីដែកនិងដីឥដ្ឋ ក៏បាក់បំបែក[ម]
ខ្ទេចខ្ទីទៅ[យ] ៣៥រួចទាំងដែក ដីឥដ្ឋ លង្ហិន ប្រាក់ ហើយនឹង
មាស ក៏ត្រូវបែកបាក់ខ្ទេចខ្ទីទាំងអស់ ហើយត្រឡប់ដូចជា
អង្កាមនៅលានស្រូវខែប្រាំង រួចខ្យល់បក់ផាត់យកទៅ
បាត់[រ] ឥតដែលឃើញផង់ណារបស់រូបនោះទៀតឡើយ ឯ
ថ្មដែលទង្គិចនឹងរូបនោះ ក៏ត្រឡប់ទៅជាភ្នំយ៉ាងធំ[ល]នៅ
ពេញផែនដីទាំងដុំមូល[វ] ។
៣៦សេចក្តីនេះហើយ ជាសុបិនរបស់ទ្រង់ព្រះករុណា
ឥឡូវនេះ យើងខ្ញុំនឹងកាត់ស្រាយ ថ្វាយព្រះករុណាជ្រាប[ស]

**២:២១** គ ២សយ ១៤:១៧ **២:២២** ឃ លប ៤០:៨ យប ១២:២២ ដយ ៥:១១ ១កថ ២:១០ ង យប ១២:២២ ទដ ១៣៩:១១–១២ យរ ២៣:២៤ ហព ៤:១៣ ច អស ៤៥:៧ យក ១:១៧ **២:២៣** ឆ លប ៣១:៥ នក ៣:១៥ ជ ដយ ១:១៧ ឈ អក ២៨:៣ **២:២៤** ញ ខ.១៤ **២:២៥** ដ ចទ ២១:១០ ឋ ដយ ១:៦ ៥:១៣ ៦:១៣ **២:២៦** ឌ ដយ ១:៧ **២:២៧** ឍ ខ.១០ លប ៤១:៨ **២:២៨** ណ លប ៤០:៨ យរ ១០:៧ អម ៤:១៣ ត លប ៤៩:១ ដយ ១០:១៤ មថ ២៤:៦ វវ ១:១ ២២:៦ ថ ដយ ៤:៥ ទ ទដ ៤:៤ ធ អក ២៨:៣ ដយ ១:២០ **២:២៩** ន លប ៤១:២៥ **២:៣០** ប អស ៤៥:៣ ដយ ១:១៧ អម ៤:១៣ **២:៣១** ផ ហព ១:៧ ព អស ២៥:៣–៥ **២:៣៤** ភ យប ១២:១៩ សក ៤:៦ ម យប ៣៤:២៤ យ ខ.៤៤–៤៥ ទដ ២:៩ អស ៦០:១២ ដយ ៨:២៥ **២:៣៥** រ ទដ ១:៤ ៣៧:១០ អស ១៧:១៣ ៤១:១៥–១៦ ល អស ២:៣ មីក ៤:១ វ សក ១២:៣ **២:៣៦** ស លប ៤០:១២

**២:២២** *មានពន្លឺនៅជាមួយនឹងទ្រង់* មើល សភ ៣៦:៩ និងការពន្យល់ ។
**២:២៩** *ទ្រង់សំដែងឱ្យបានយល់ការអាថ៌កំបាំង* មើល ខ.៤៧ ។
**២:៣២–៤៣** ក្បាលដែលធ្វើអំពីមាសគឺជាតំណាងឱ្យចក្រភពបាប៊ីឡូនថ្មី (ខ.៣៨ មើល យរ ៥១:៧ និងការពន្យល់)។ ដើមទ្រូង និងដៃដែលធ្វើអំពីប្រាក់គឺជាតំណាង ឱ្យចក្រភព មីដូ–ពើស៊ី ដែលបង្កើតឡើងដោយស្តេចស៊ីរ៉ូស នៅក្នុងឆ្នាំ ៥៣៩ មុនគ.ស(គឺជាឆ្នាំនៃការដួលរលំនៃចក្រភពបាប៊ីឡូន) ពោះនឹងភ្លៅជាលង្ហិនគឺតំណាងឱ្យចក្រភពក្រិចដែលស្តេចអ័ឡេចក្សានឌ័របង្កើតឡើងនៅឆ្នាំ ៣៣០ មុនគ.ស ជើងនិងប្រអប់ជើងដែលធ្វើអំពីដែក គឺជាតំណាងឱ្យចក្រភពរ៉ូម៉ាំង ។ អ្នកខ្លះយល់ថា ម្រាមជើង(ខ.៤១) គឺជាតំណាងឱ្យរដ្ឋដែលចងសម្ព័ន្ធគ្នាជាច្រើន ដែលធ្លាប់ជារដ្ឋចំណុះឱ្យចក្រភពរ៉ូម៉ាំងនៅសម័យក្រោយមកទៀត ។ ការរៀបរាប់អំពីតម្លៃនៃលោហៈចុះពីមាសមកប្រាក់ មកលង្ហិន ហើយមកដែក គឺជាតំណាងឱ្យការចុះខ្សោយនៃអំណាច និងភាពថ្កុំថ្កើង(ខ.៣៩)នៃអ្នកដឹកនាំនៃចក្រភពនីមួយៗ គឺពីការប្រើអំណាចផ្តាច់ការរបស់ស្តេចនេប៊ូក្នេសារ ទៅការប្រើប្រព័ន្ធប្រជាធិប្បតេយ្យ ដែលមានព្រឹទ្ធសភា និងសភារ៉ូម៉ាំង ។ លោហៈនីមួយៗក៏ជាតំណាងឱ្យកម្រិតនៃភាពស្វិតស្វាញ និងអត់ធន់ផងដែរ គឺមានន័យថា ចក្រភពដែលនៅបន្ទាប់ គឺមានការដឹកនាំដែលយូរជាងចក្រភពមុនៗ ។
**២:៣៣** *ជាដែកលាយនឹងដីឥដ្ឋ* "មានន័យថាមានផ្នែកខ្លះរឹង ហើយផ្នែកខ្លះទៀតស្រួយ" (ខ.៤២)។
**២:៣៥** *ត្រូវបែកបាក់ខ្ទេចខ្ទីទាំងអស់* មើល លក ២០:១៨ និងការពន្យល់ ។

៣៧បពិត្រព្រះករុណា ទ្រង់ជាស្ដេចលើអស់ទាំងស្ដេច[ហ] គឺជា
ស្ដេចដែលព្រះនៃស្ថានសួគ៌ ទ្រង់បានប្រទានឱ្យមានរាជ្យ[ឡ]
ព្រះចេស្ដា ឥទ្ធិឫទ្ធិ និងសិរីល្អទាំងនេះ ៣៨ហើយកន្លែង
ណាដែលមានមនុស្សជាតិអាស្រ័យនៅ នោះព្រះទ្រង់បាន
ប្រទានទាំងសត្វនៅដី និងសត្វហើរលើអាកាស មកក្នុង
ព្រះហស្តទ្រង់ ព្រមទាំងតាំងទ្រង់ឱ្យគ្រប់គ្រងលើទាំងអស់
ផង[អ] គឺទ្រង់ដែលជាក្បាលមាសនោះ ៣៩តពីទ្រង់ទៅ
នោះនឹងមាននគរ១ទៀតកើតឡើង ដែលថោកជាងទ្រង់
រួចនឹងមាននគរ១ទៀត មាននគរទី៣ ដែលជាលង្ហិន នគរ
នោះនឹងមានអំណាចគ្រប់គ្រងលើផែនដីទាំងមូល[ក] ៤០ឯ
នគរទី៤នឹងមានកំឡាំងដូចដែក ដ្បិតដែលដែកបំបាក់
បំបែកឱ្យខ្ទេចខ្ទី ហើយក៏កំរាបទាំងអស់ជាយ៉ាងណា នគរ
នោះក៏នឹងបំបែកបំបាក់ឱ្យខ្ទេចខ្ទី ហើយកិនល្អិតយ៉ាងនោះ
ដែរ គឺដូចជាដែក ដែលបំបាក់បំបែករបស់ទាំងនោះឯង[ខ]
៤១ហើយដែលទ្រង់បានឃើញប្រអប់ជើង និងម្រាមជើង
នោះមាន១ចំណែកជាដីរបស់ជាងស្មូន ហើយ១ចំណែក
ទៀតជាដែកវិញ នោះគឺថា នគរនោះនឹងញែកបែកគ្នា តែ
ក្នុងនគរនោះ និងមានកំឡាំងដូចជាដែក ដ្បិតទ្រង់បាន
ឃើញដែកលាយនឹងដីស្អិតនោះ ៤២ហើយដែលម្រាមជើង
ជាដែក និងជាដីឥដ្ឋ លាយគ្នាជាយ៉ាងណា នគរនោះ នឹង
មានកំឡាំង១ចំណែក ហើយស្រួយ១ចំណែកយ៉ាងនោះដែរ
៤៣ហើយដែលទ្រង់បានឃើញដែកលាយនឹងដីស្អិតជាយ៉ាង
ណា នោះគឺគេនឹងលាយខ្លួននឹងអស់ទាំងពូជមនុស្សផង
យ៉ាងនោះដែរ តែគេនឹងមិននៅជាប់ជិតគ្នានឹងគ្នាទេ ដូច
ជាដែកដែលមិនលាយជាប់នឹងដីដែរ ៤៤រីឯនៅគ្រានៃស្ដេច
ទាំងនោះ ព្រះនៃស្ថានសួគ៌ទ្រង់នឹងតាំងនគរ១ឡើង ដែល
មិនត្រូវបំផ្លាញឡើយ ហើយអំណាចហ្លួងក៏មិនត្រូវផ្ទេរ
ដល់សាសន៍ដទៃណាដែរ គឺនឹងបំបាក់បំបែក ហើយលេប
បំបាត់[គ]នគរទាំងនោះវិញ[ឃ] នគរនោះនឹងស្ថិតស្ថេរនៅអស់
កល្បជានិច្ច[ង] ៤៥គឺដូចជាទ្រង់បានឃើញថ្ម[ច]នោះ ដាប់ផ្ដាច់
ចេញពីភ្នំឥតមានដៃអ្នកណាធ្វើ[ឆ] ហើយថ្មនោះបានបំបាក់
បំបែកទាំងដែក លង្ហិន ដីឥដ្ឋ ប្រាក់នឹងមាសនោះហើយ គឺ
ព្រះដ៏ជាធំ ទ្រង់បានសំដែងឱ្យព្រះករុណាជ្រាបពីការដែល
ត្រូវមកនៅខាងមុខ[ជ] សុបិននេះជា ប្រាកដហើយ[ឈ]ឯសេចក្ដី
សំរាយក៏ជាពិតដែរ ។

៤៦ដូច្នេះ ស្ដេចនេប៊ូក្នេសា ទ្រង់ក្រាបផ្កាប់ព្រះភក្ត្រ[ញ]
ថ្វាយបង្គំដល់ដានីយ៉ែល ក៏បង្គាប់ឱ្យគេយកគ្រឿងបូជា[ដ]
និងគ្រឿងក្រអូបមកគោរពដល់លោក ៤៧ស្ដេចទ្រង់មាន
បន្ទូលនឹងដានីយ៉ែលថា ពិតប្រាកដជាព្រះនៃអ្នកជាព្រះលើ
អស់ទាំងព្រះហើយ[ឋ] ទ្រង់ជាព្រះអម្ចាស់លើអស់ទាំងស្ដេច[ឌ]
គឺជាព្រះដែលសំដែងឱ្យយល់សេចក្ដីអាថ៌កំបាំង[ឍ] ពីព្រោះ
ឃើញថា អ្នកអាចនឹងសំដែង ឱ្យយល់សេចក្ដីអាថ៌កំបាំង
នេះបាន[ណ] ៤៨នោះស្ដេចទ្រង់ក៏តាំងដានីយ៉ែលឡើងជាធំ[ត]
ទ្រង់ប្រទានអំណោយទានយ៉ាងវិសេសជាច្រើនដល់លោក
ព្រមទាំងតាំងលោក ឱ្យត្រួតលើខេត្តបាប៊ីឡូនទាំងមូល
ហើយឱ្យបានជាអធិបតី លើពួកអ្នកប្រាជ្ញទាំងប៉ុន្មាន នៅ
ក្រុងបាប៊ីឡូនផង[ថ] ៤៩ឯដានីយ៉ែល លោកសូមដល់ស្ដេច
ហើយទ្រង់ក៏តាំងសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ
ឡើងជាអ្នកត្រួតលើក្រសួងការទាំងពួង នៅខេត្តបាប៊ីឡូន[ទ]
តែដានីយ៉ែលលោកនៅក្នុងព្រះរាជវាំងវិញ[ធ]។

## រូបមាស និងគុកភ្លើង

៣ ១រីឯស្ដេចនេប៊ូក្នេសា ទ្រង់ធ្វើរូប[ក]មាស១ មានកំពស់
៦០ហត្ថ ទទឹង៦ហត្ថ ទ្រង់បញ្ឈររូបនោះនៅវាលឌូរ៉ា ក្នុង
ខេត្តបាប៊ីឡូន ២រួចស្ដេចនេប៊ូក្នេសាទ្រង់ចាត់ឱ្យទៅប្រមូល
ពួកចៅហ្វាយខេត្ត[ខ] ពួកភូឈ្មួយ ពួកចៅហ្វាយស្រុក ពួកចៅ

**២:៣៧** ហ អរ ៧:១២ ឡ យរ ២៧:៧ ដយ ៤:២៦ **២:៣៨** អ យរ ២៧:៦ ដយ ៤:២១-២២ ៥:១៨ **២:៣៩** ក ដយ ៧:៥ **២:៤០** ខ ដយ ៧:៧,២៣ **២:៤៤** គ លប ២៧:២៩ ទដ ២:៩ ១១០:៥ មថ ២១:៤៣-៤៤ ១កថ ១៥:២៤ ឃ ១សយ ៩:២០ ហក ២:២២ ង ទដ ១៤៥:១៣ អស ៩:៧ ដយ ៤:៣៤ ៦:២៦ ៧:១៤,២៧ អប ១:២១ មីក ៤:៧,១៣ លក ១:៣៣ វវ ១១:១៥ **២:៤៥** ច អស ២៨:១៦ ឆ ដយ ៨:២៥ ជ លប ៤១:២៥ ឈ វវ ២២:៦ **២:៤៦** ញ ដយ ៨:១៧ កច ១០:២៥ ដ កច ១៤:១៣ **២:៤៧** ឋ ចទ ១០:១៧ ដយ ១១:៣៦ ឌ ចទ ៤:២៥ ១ធថ ៦:១៥ ឍ ខ.២២,២៨ ណ ដយ ៤:៩ ១កថ ១៤:២៥ **២:៤៨** ត ២ពវ ២៥:២៨ ថ ខ.៦ នអ ៨:២ ដយ ១:២០ ៤:៩ ៥:១១ ៨:២៧ **២:៤៩** ទ ចទ ១:៧ ៣:៣០ ធ ចទ ៦:២ **៣:១** ក ខ.១៤ អស ៤៦:៦ យរ ១៦:២០ ហព ២:១៩ **៣:២** ខ នអ ១:១

**២:៣៧** *ស្ដេចលើអស់ទាំងស្ដេច* មានន័យថា ជាស្ដេចដែលមានអំណាចជាងគេ(ធៀបនឹង ខ.៤៧ អរ ៧:១២ និងការពន្យល់ ១ធថ ៦:១៥ វវ ១៧:១៤ និងការពន្យល់, ១៩:១៦)។

**២:៤៤** ចក្រភពទីប្រាំគឺជានគរព្រះ ដែលស្ថិតនៅអស់កល្បជានិច្ច (មើល វវ ១១:១៥) ដែលសាងឡើងនៅលើសំណល់បាក់បែកនៃចក្រភពទាំងឡាយរបស់លោកិយនេះ ។ អំណាចរបស់នគរនេះនឹងពង្រីកធំឡើងពេញ"ផែនដី" (ខ.៣៥) ហើយនៅទីបញ្ចប់ នគរនេះនឹងពង្រីកពេញ "ផ្ទៃមេឃ និងផែនដីថ្មី"(វវ ២១:១) ។

**២:៤៦** *គ្រឿងបូជា . . . មកគោរពដល់លោក* គឺធ្វើដូចជាថ្វាយដល់ព្រះ (ធៀបនឹង កច ១៤:១២ និងការពន្យល់) ។

**២:៤៨** ធៀបនឹងរឿងរបស់លោកយ៉ូសែប (លប ៤១:៤១-៤៣) ។

**២:៤៩** នៅត្រង់ចំណុចនេះ លោកដានីយ៉ែលបានស្នើរសូមឱ្យមានការចែកអំណាចរដ្ឋបាលជាមួយនឹងមិត្តភ័ក្ត្រទាំងបីនាក់របស់គាត់ ដែលជាសាសន៍យូដា ។

**៣:១** *រូបមាស* រូបប្រភេទនេះមានមាឌធំ ហើយគេស្រោបវាដោយមាស គឺមិនមែនជារូបមាសតាន់នោះទេ ។ *កំពស់ ៦០ ហត្ថ* គឺជាកំពស់ដែលគេគិតតាំងទម្រជើងផង(ធៀបនឹង នអ ៥:១៤ និងការពន្យល់)។ *វាលឌូរ៉ា* គឺជាទីកន្លែងដែលមានទួលជាច្រើន(ស្ថិតនៅចម្ងាយប្រហែលពីរបីគីឡូម៉ែតពីចក្រភពបាប៊ីឡូន) ឬជានាមដែលមានន័យថា "មានកំផែងជុំជិត" ។

**៣:២** ពួកមន្ត្រីទាំងប្រាំពីរថ្នាក់ត្រូវធ្វើសច្ចាប្រណិធានចំពោះរូបព្រះ ដើម្បី

ក្រុម ពួកមេឃ្លាំង ពួកបាទ្បាត់ ពួកនាយក នគរបាល និង
អស់ទាំងពួកមន្ត្រីខេត្តទាំងប៉ុន្មាន[គ] ឱ្យគេមូល គ្នាមកឯបុណ្យ
ឆ្លងរូប ដែលស្តេចនេប៊ូក្នេសាតាំងឡើងនោះ ៣ដូច្នេះពួក
ចៅថ្វាយខេត្ត ពួកភូឈួយ ពួកចៅហ្វាយស្រុក ពួកចៅក្រម
ពួកមេឃ្លាំង ពួកបាទ្បាត់ ពួកនាយក នគរបាលនិងអស់ទាំង
ពួកមន្ត្រីខេត្ត ក៏មូលគ្នាមកឯបុណ្យឆ្លងរូបនោះ ដែលស្តេច
នេប៊ូក្នេសាតាំងឡើងគេក៏ឈរនៅ ចំពោះរូបដែលទ្រង់
តាំងទុកនោះ ៤រួចមានអ្នកស្រែកប៉ាវប្រកាស ជាសំឡេង
យ៉ាងខ្លាំងថា ម្នាលជនទាំងឡាយ ព្រមទាំងសាសន៍ដទៃ និង
មនុស្សគ្រប់ភាសាអើយ មានសេចក្តីបង្គាប់ដល់អ្នករាល់គ្នា
ដូច្នេះថា[ឃ] ៥វេលាណាដែល អ្នករាល់គ្នាឮសូរត្រែ ខ្លុយ
ស៊ុង ចាប៉ី ពិណ[ង] និងប៉ី ហើយ ដន្ត្រីគ្រប់យ៉ាង នោះត្រូវ
ក្រាបថ្វាយបង្គំដល់រូប[ច]មាស ដែលព្រះករុណាទ្រង់បាន
តាំងឡើងទៅ[ឆ] ៦បើអ្នកណាមិនក្រាបថ្វាយបង្គំទេ នោះនឹង
ត្រូវបោះទៅកណ្តាលគុកភ្លើង ដែលកំពុងឆេះយ៉ាងសន្ធៅ
នៅវេលានោះឯង[ជ] ៧ដូច្នេះ នៅវេលានោះ កាលជនទាំង
ឡាយបានឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងដន្ត្រីគ្រប់
យ៉ាងហើយ នោះជនទាំងឡាយ ព្រមទាំងសាសន៍ដទៃនិង
មនុស្សគ្រប់ភាសាផង ក៏ក្រាបថ្វាយបង្គំដល់រូបមាស ដែល
ស្តេចនេប៊ូក្នេសាបានតាំងទុកនោះ[ឈ]។
៨នៅគ្រានោះ មានពួកខាល់ដេ[ញ]ខ្លះចូលទៅជិតប្តឹងពី
ពួកសាសន៍យូដា ៩គេទូលដល់ស្តេចនេប៊ូក្នេសាថា បពិត្រ
ព្រះករុណា សូមឱ្យទ្រង់មានព្រះជន្មតរៀងទៅ[ដ] ១០បពិត្រ
ព្រះករុណា ទ្រង់បានចេញព្រះរាជបង្គាប់ថា[ឋ] អស់មនុស្ស
ណាដែលឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ ប៉ី និងដន្ត្រីគ្រប់
យ៉ាង នោះត្រូវតែក្រាបថ្វាយបង្គំដល់រូបមាសនេះ[ឌ] ១១ហើយ
ថា បើអ្នកណាមិនក្រាបថ្វាយបង្គំទេ នោះត្រូវបោះទៅក្នុង
គុកភ្លើងដែលឆេះយ៉ាងសន្ធៅ ១២រីឯពួកអ្នកដែលទ្រង់បាន
តាំងឡើង លើក្រសួងការខេត្តបាប៊ីឡូន នោះមានពួក
សាសន៍យូដាខ្លះ គឺសាដ្រាក់ មែសាក់ នឹង អ័បេឌ–នេកោ[ឍ]
ទាំង៣នាក់នោះ បពិត្រព្រះករុណា គេមិនបានស្តាប់បង្គាប់
ទ្រង់ទេ[ណ] គេក៏មិនទាំងគោរពប្រតិបត្តិដល់ ព្រះនៃទ្រង់ ឬ
ថ្វាយបង្គំដល់រូបមាស ដែលទ្រង់បានតាំងឡើងនោះដែរ[ត]។
១៣ហេតុនោះនេប៊ូក្នេសាទ្រង់មានសេចក្តីក្រោធ[ថ] និង
សេចក្តីឃោរឃៅយ៉ាងក្រៃលែងក៏បង្គាប់ឱ្យគេនាំសាដ្រាក់
មែសាក់ និងអ័បេឌ–នេកោមក ដូច្នេះ គេក៏នាំអ្នកទាំង៣
នោះចូលមកនៅចំពោះស្តេច ១៤នេប៊ូក្នេសា ទ្រង់មានបន្ទូល
សួរគេថា ម្នាល សាដ្រាក់ មែសាក់ និងអ័បេឌ–នេកោ តើ
ដោយបំណងចិត្តឬ ដែលឯងរាល់គ្នាមិនគោរព ដល់ព្រះនៃ
យើង[ទ] ឬថ្វាយបង្គំដល់រូប[ធ]មាសដែលយើងបាន តាំងឡើង
ហើយនោះ ១៥ឥឡូវនេះ បើឯងរាល់គ្នាប្រុងប្រៀបក្នុង
វេលាណាដែលឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ ប៉ី និង
ដន្ត្រីគ្រប់យ៉ាង ឱ្យបានក្រាបថ្វាយបង្គំដល់រូបមាសដែល
យើងបានធ្វើនេះ នោះបានហើយ តែបើមិនថ្វាយបង្គំទេ
នោះនឹងត្រូវបោះឯងទៅក្នុងគុកភ្លើង ដែលឆេះយ៉ាងសន្ធៅ
នៅវេលានោះឯង តើមានព្រះឯណា[ន] ដែលអាចនឹងដោះ[ប]
ឯងរាល់គ្នា ឱ្យរួចពីកណ្តាប់ដៃយើងបាន ១៦តែសាដ្រាក់
មែសាក់ និងអ័បេឌ–នេកោ[ផ]ទូលឆ្លើយដល់ស្តេចថា បពិត្រ
ព្រះរាជនេប៊ូក្នេសា យើងខ្ញុំមិនចាំបាច់ទូលឆ្លើយដល់ទ្រង់
ពីដំណើរនេះទេ ១៧បើជាយ៉ាងនោះមែន នោះព្រះនៃ
យើងខ្ញុំ ដែលយើងខ្ញុំគោរពប្រតិបត្តិតាម ទ្រង់អាចនឹងជួយ[ព]
ឱ្យយើងខ្ញុំរួចពីគុកភ្លើង ដែលឆេះយ៉ាងសន្ធៅបានហើយ
បពិត្រព្រះករុណា ព្រះអង្គនោះក៏នឹងជួយ[ភ]ឱ្យយើងខ្ញុំរួចពី
ព្រះហស្តទ្រង់ដែរ ១៨តែបើមិនជួយទេនោះសូមឱ្យទ្រង់ព្រះ
ករុណាជ្រាបថា យើងខ្ញុំមិនព្រមគោរពតាមព្រះរបស់ទ្រង់
ឡើយក៏ មិនព្រមថ្វាយបង្គំ ដល់រូបមាសដែលទ្រង់បានតាំង

**៣:២** គ ឌ.២៧ ដយ ៦:៧
**៣:៤** ឃ ដយ ៤:១ ៦:២៥ វវ ១០:១១
**៣:៥** ង លប ៤:២១ ច វវ ១៣:១២ ឆ ឌ.១០,១៥
**៣:៦** ជ ឌ.១១,១៥,២១ យរ ២៩:២២ ដយ ៥:១៩ ៦:៧ មថ ១៣:៤២,៥០ វវ ១៣:១៥
**៣:៧** ឈ ឌ.៥
**៣:៨** ញ អស ១៩:៣ ដយ ២:១០
**៣:៩** ដ នហ ២:៣ ដយ ៥:១០ ៦:៦
**៣:១០** ឋ ដយ ៦:១២ ឌ ឌ.៤–៦
**៣:១២** ឍ ដយ ២:៤៩ ណ ដយ ៦:១៣ ត នអ ៣:៣
**៣:១៣** ថ ដយ ២:១២
**៣:១៤** ទ អស ៤៦:១ យរ ៥០:២ ធ ឌ.១
**៣:១៥** ន អស ៣៦:១៨–២០ ប ២របា ៣២:១៥
**៣:១៦** ផ ដយ ១:៧
**៣:១៧** ព លប ៤៨:១៦ ទដ ១៨:៤៨ ២៧:១–២ ភ យប ៥:១៩ យរ ១:៨ ដយ ៦:២០

បញ្ជាក់អំពីភាពស្មោះស្ម័គ្រចំពោះចក្រភពថ្មីដែលបានបង្កើតឡើង ។ រូបព្រះនោះប្រហែលជារូបតំណាងឱ្យរូបព្រះនេប៊ូ ដែលឈ្មោះព្រះនេះគឺជាលំនាំរបស់ឈ្មោះស្តេចនេប៊ូក្នេសា (មើលការពន្យល់ ២ពវ ២៤:១) ។

**៣:៤** *គ្រប់ភាសា* ទីក្រុងបាប៊ីឡូនរបស់ស្តេចនេប៊ូក្នេសាបានក្លាយជាទីក្រុងដែលមានចំរុះជាតិសាសន៍ (មើល ឌ.៧) ។

**៣:៥** សិលាចារិករបស់សាសន៍អាសស៊ើរមានសរសេរអំពីអ្នកភ្លេង និងគ្រឿងភ្លេងរបស់សាសន៍ក្រិក នៅមុនសម័យស្តេចនេប៊ូក្នេសា ។ *ត្រូវក្រាបថ្វាយបង្គំដល់រូបមាស* មើល នក ២០:៤–៥ និងការពន្យល់ ២០:៤ ។

**៣:១២** *គេមិនបានស្តាប់បង្គាប់ទ្រង់ទេ គេក៏មិនទាំងគោរពប្រតិបត្តិដល់ព្រះនៃទ្រង់* ពីព្រោះពួកគេស្តាប់បង្គាប់តាមព្រះបន្ទូលព្រះ (នក ២០:៣–៥) ជាជាងពាក្យរបស់ស្តេច ។

**៣:១៥** *តើមានព្រះឯណា ដែលអាចនឹងដោះឯងរាល់គ្នា ឱ្យរួចពីកណ្តាប់ដៃយើងបាន* ការប្រើពាក្យដូចនេះ គឺជាបង្ហាញអំពីលក្ខណៈសម្បត្តិរបស់អ្នកដឹកនាំដែលមានអំណួត នៅក្នុងតំបន់មេសូប៉ូតាមា (មើល អស ៣៦:១៨–២០ និងការពន្យល់) ។

**៣:១៧** មើល ឌ.២៦–២៧ ហព ១១:៣៤ និងការពន្យល់ ។ *ព្រះអង្គនោះក៏នឹងជួយឱ្យយើងរួចពីព្រះហស្តទ្រង់* ចំពោះការដែលព្រះទ្រង់ "អាច" នឹងធ្វើ សូមមើលឧទាហរណ៍នៅក្នុង ៤:៣៧ ៦:១៩–២២ (ធៀបនឹង រម ១១:២៣ ២កថ ៩:៨ ហព ៧:២៥ យដ ២៤–២៥ និងការពន្យល់) ។

**៣:១៨** *តែបើមិនជួយទេ* គឺមានន័យថា ពួកគេនៅតែដាក់សេចក្តីជំនឿរបស់ពួកគេទាំងស្រុងទៅលើព្រះហឫទ័យទ្រង់ ទោះបីជាទ្រង់សម្រេចថាជួយ (ឌ.១៧) ឬមិនជួយពួកគេក៏ដោយ ។

ឡើងនោះដែរ[ម]។
១៩នោះនេប៊ូក្នេសា ទ្រង់មានពេញដោយសេចក្ដីឃោរឃៅ
ព្រះភក្ត្រទ្រង់ក៏ផ្លាស់ប្រែទៅ ទាស់នឹងសាដ្រាក់ មែសាក់
និងអ័បេឌ-នេកោ ទ្រង់ក៏បង្គាប់ឱ្យគេដុតគុកភ្លើងឱ្យក្ដៅ
ជាងធម្មតា១ជា៧[យ] ២០រួចទ្រង់បង្គាប់ដល់មនុស្សខ្លាំងពូកែ
ខ្លះក្នុងទ័ពទ្រង់ ឱ្យគេចងសាដ្រាក់ មែសាក់ និងអ័បេឌ-
នេកោ[រ] បោះទៅក្នុងគុកភ្លើងដែលឆេះយ៉ាងសន្ធៅនោះ
២១ដូច្នេះ គេក៏ចងអ្នកទាំងនោះភ្ជាប់ទាំងខោ ទាំងអាវ
និងឈ្នួត ព្រមទាំងសំលៀកបំពាក់ទៀតផង បោះចុះក្នុងគុក
ភ្លើងដែលឆេះយ៉ាងសន្ធៅទៅ ២២ហេតុនោះដោយព្រោះ
បង្គាប់ស្ដេចក៏តឹងរឹងណាស់ ហើយគុកភ្លើងបានក្ដៅយ៉ាង
ក្រៃលែង បានជាអណ្ដាតភ្លើងឆេះសំឡាប់ពួកអ្នកដែលបាន
លើកបោះសាដ្រាក់ មែសាក់ និងអ័បេឌ-នេកោទៅនោះ[ល]
២៣ចំណែកអ្នកទាំង៣នោះ គឺសាដ្រាក់ មែសាក់ និងអ័បេឌ-
នេកោ គេធ្លាក់ទៅកណ្ដាលគុកភ្លើង ដែលឆេះយ៉ាងសន្ធៅ
ទាំងជាប់ចំណងផង ។
២៤ខណនោះ ស្ដេចនេប៊ូក្នេសាទ្រង់មានសេចក្ដីស្រឡាំង
កាំង ហើយក៏ក្រោកឡើងជាប្រញាប់ មានបន្ទូលនឹងពួក
ជំនិតរបស់ទ្រង់ថា តើមិនមែន៣នាក់ដែលយើង បោះទៅ
ក្នុងភ្លើងទាំងជាប់ចំណងផងទេឬអី គេក៏ទូលតបថា បពិត្រ
ព្រះករុណាអើយ ពិតហើយដូច្នោះ ២៥រួចទ្រង់មានបន្ទូល
ថា មើល យើងឃើញ៤នាក់ឥតជាប់ចំណងសោះ កំពុងដើរ
នៅកណ្ដាលភ្លើង ឥតមានអ្វីសោះ ឯអ្នកទី៤ក៏មានភាពដូច
ជាកូនព្រះ ២៦នោះនេប៊ូក្នេសាក៏ចូលទៅជិតមាត់គុកភ្លើង
ដែលឆេះយ៉ាងសន្ធៅនោះ មានបន្ទូលថា ឱសា-ដ្រាក់
មែសាក់ និងអ័បេឌ-នេកោ ជាអ្នកគោរពដល់ព្រះដ៏ខ្ពស់
បំផុតអើយ[វ] សូមចេញមក ហើយមកឯណេះចុះ ដូច្នេះ
សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ក៏ចេញពីកណ្ដាល
ភ្លើងមក ២៧រួចពួកចៅហ្វាយខេត្ត ពួកភូឈួយ ពួកចៅ
ហ្វាយស្រុក និងពួកជំនិត[ស]របស់ស្ដេចដែលបានប្រជុំគ្នា[ហ]
គេក៏ ឃើញមនុស្សទាំងនោះដែលភ្លើង[ឡ]គ្មានអំណាចលើ
ខ្លួនគេសោះ សក់ក្បាលគេក៏មិនបានទាំងរួញដែរ ឯខោ
អាវមិនបានឆេះ ក៏ឥតមានក្លិនឈ្ងៀមនៅជាប់នឹងគេផង។
២៨នេប៊ូក្នេសា ទ្រង់មានបន្ទូលថា សូមឱ្យព្រះនៃសាដ្រាក់
មែសាក់ និងអ័បេឌ-នេកោ បានប្រកបដោយព្រះពរជា
ព្រះដែលទ្រង់បានចាត់ទេវតារបស់ទ្រង់[អ] ឱ្យមកប្រោស[ក]ពួក
បំរើទ្រង់ ដែលទុកចិត្ត[ខ]ដល់ទ្រង់ ឱ្យរួច គេបានរំលងនឹង
បង្គាប់នៃស្ដេច ព្រមទាំងប្រថុយខ្លួនគេ ដើម្បីមិនឱ្យគោរព
ឬថ្វាយបង្គំដល់ព្រះឯណាក្រៅពីព្រះរបស់ខ្លួនឡើយ[គ]
២៩ដូច្នេះ យើងចេញព្រះរាជបំរាម[ឃ]ដល់បណ្ដាជនទាំង
ឡាយ ព្រមទាំងសាសន៍ដទៃ និងមនុស្សគ្រប់ភាសាថា
បើអ្នកណានិយាយបង្អុសពីព្រះនៃសាដ្រាក់ មែសាក់ និង
អ័បេឌ-នេកោ នោះនឹងត្រូវកាប់ដាច់ជាដុំៗ ហើយផ្ទះគេ
នឹងត្រូវទុកជាទីបន្ទោលបង់លាមក[ង] ពីព្រោះគ្មានព្រះឯ
ណាទៀតដែលអាចនឹងជួយ[ច]ឱ្យរួចយ៉ាងដូច្នេះបានឡើយ
៣០រួចមកស្ដេចទ្រង់ក៏ដំឡើងងារដល់សាដ្រាក់ មែសាក់
និងអ័បេឌ-នេកោ នៅក្នុងខេត្តបាប៊ីឡូន[ឆ]។

## ស្ដេចនេប៊ូក្នេសាសុបិន្តឃើញដើមឈើមួយដើម

**៤** ១ស្ដេចនេប៊ូក្នេសា ទ្រង់ប្រកាសដល់បណ្ដាជនទាំង
ឡាយ ព្រមទាំងសាសន៍ដទៃ និងមនុស្សគ្រប់ភាសា[ក]ដែល
នៅលើផែនដីទាំងមូលថា សូមឱ្យអ្នករាល់គ្នាបានប្រកប
ដោយសេចក្ដីសុខ កាន់តែច្រើនឡើងចុះ[ខ] ២យើងបាន
ឃើញថាគួរនឹងបង្ហាញអស់ទាំងទីសំគាល់[គ] និងការអស្ចារ្យ
ដែលព្រះដ៏ខ្ពស់បំផុត[ឃ]បានប្រោសដល់យើង ៣ទីសំគាល់
របស់ទ្រង់ធំណាស់ហ្ន៎ ហើយការអស្ចារ្យរបស់ទ្រង់ក៏មាន
អានុភាពណាស់ដែរ[ង] រាជ្យទ្រង់ជារាជ្យដ៏ស្ថិតស្ថេរនៅអស់
កល្បជានិច្ច ហើយអំណាចគ្រប់គ្រងរបស់ទ្រង់ក៏នៅ[ច]គ្រប់
ទាំងដំណមនុស្សតរៀងទៅ ។

**៣:១៨** ម ខ.២៨ នក ១:១៧ យស ២៤:១៥
**៣:១៩** យ លប ២៦:១៨-២៨
**៣:២០** រ ដយ ១:៧
**៣:២២** ល ដយ ១:៧
**៣:២៦** វ ដយ ៤:២,៣៤
**៣:២៧** ស ខ.២ ដយ ៦:៧ ហ ទដ ៩១:៣-១១ អស ៤៣:២ ហព ១១:៣២-៣៤ ឡ ដយ ៦:២៣
**៣:២៨** អ ទដ ៣៤:៧ ដយ ៦:២២ កច ៥:១៩ ក ទដ ៩៧:១០ កច ១២:១១ ខ ចទ ៣១:២០ យប ១៣:១៥ ទដ ២៦:១ ៨៤:១២ គ ខ.១៨
**៣:២៩** ឃ ដយ ៦:២៦ ង អរ ៦:១១ ច ដយ ៦:២៧
**៣:៣០** ឆ ដយ ២:៤៩
**៤:១** ក ដយ ៣:៤ ខ ដយ ៦:២៥
**៤:២** គ ទដ ៧៤:៩ ឃ ដយ ៣:២៦
**៤:៣** ង ទដ ១០៥:២៧ ដយ ៦:២៧ ច ដយ ២:៤៤

**៣:១៩** *ក្ដៅជាងធម្មតា១ជា៧* ពាក្យនេះប្រហែលជាន័យធៀបរបស់ពាក្យ "ក្ដៅបំផុត" ("៧" គឺសំដៅទៅលើភាពពេញលេញ)។

**៣:២៥** មើល ទដ ៩១:៩-១២ ។ *កូនព្រះ* នៅត្រង់ចំណុចនេះ ស្ដេចនេប៊ូ-ក្នេសា គឺកំពុងតែនិយាយតាមរបៀបសាសន៍ដទៃ ដែលពួកគេជឿលើព្រះច្រើនអង្គ ហើយជឿថាអ្នកដែលនៅក្នុងភ្លើងនោះជាពួកកូនព្រះ ("ទេវតា" ខ.២៨) ដែលព្រះដ៏មានអំណាចរបស់ពួកយូដាបានបញ្ជូនមក (សូមមើល ៦:២២) ។

**៣:២៦** *ព្រះដ៏ខ្ពស់បំផុត* នៅមុននោះបន្តិច ស្ដេចនេប៊ូក្នេសាបានទទួលស្គាល់ថា ព្រះរបស់លោកដានីយ៉ែលជា"ព្រះលើអស់ទាំងព្រះ ហើយជាព្រះអម្ចាស់លើអស់ទាំងស្ដេច" (២:៤៧)។

**៣:២៨** *ពួកបំរើទ្រង់ ដែលទុកចិត្តដល់ទ្រង់* មើល ៦:២៣ និងការពន្យល់, ទដ ១១,១៦,២៣,៣១,៥២, សភ ៣:៥ និងការពន្យល់ ។

**៣:២៩** មើល ២:៥ ។ *គ្មានព្រះឯណាទៀត ដែលអាចនឹងជួយ* មើល អស ៤០:១៨-២០ ៤១:២៤ ៤៤:១៧ និងការពន្យល់(ធៀបនឹង យហ ១៤:៦ និងការពន្យល់)។

**៤:១-៣** ស្ដេចនេប៊ូក្នេសាធ្វើសេចក្ដីសន្និដ្ឋាននៅក្នុងវគ្គនេះ បន្ទាប់ពីទទួលបទពិសោធន៍នៅក្នុង ខ.៤-៣៣ ។ ភាសាដែលស្ដេចនេះប្រើនៅក្នុងវគ្គនេះគឺឆ្លុះបញ្ចាំងអំពីឥទ្ធិពលរបស់លោកដានីយ៉ែល ។

**៤:៣** *រាជ្យទ្រង់ . . . គ្រប់ទាំងដំណមនុស្សតរៀងទៅ* មើល ខ.៣៤ និងការពន្យល់ ។

៤យើង នេប៊ូក្នេសាកំពុងនៅជាសុខ[ឆ] នៅក្នុងដំណាក់
របស់យើង ហើយកំពុងចំរើននៅក្នុងព្រះរាជវាំង ៥នោះ
យើងឃើញ[ជ] និមិត្តដែលនាំឱ្យតក់ស្លុត ហើយគំនិតដែល
យើងគិតនៅលើដំណេក[ឈ] និងការជាក់ស្តែងនៅក្នុងខួរ[ញ] ក៏
នាំឱ្យយើងបារម្ភព្រួយទៅ[ដ] ៦ដូច្នេះ យើងបានចេញបង្គាប់
ឱ្យនាំអស់ទាំងអ្នកប្រាជ្ញក្នុងក្រុងបាប៊ីឡូន មកចំពោះយើង
ដើម្បីឱ្យគេបានកាត់ស្រាយន័យ[ឋ]សុបិននិមិត្តនោះ ឱ្យយើង
ដឹង ៧នោះពួកគ្រូមន្តអាគម[ឌ] គ្រូអង្គុយធមិ៍ ពួកខាល់ដេ
និងពួកគ្រូទាយ[ឍ]ក៏មក ហើយយើងបានប្រាប់សុបិននោះដល់
គេតែគេមិនបានកាត់ស្រាយឱ្យយើងយល់ន័យសោះ[ណ] ៨លុះ
ក្រោយមក ដានីយ៉ែល ដែលមានឈ្មោះបេលថិស្សាសារ[ត]
តាមព្រះនាមព្រះនៃយើង បានចូលមកចំពោះយើង ជាអ្នក
ដែលមានវិញ្ញាណរបស់ព្រះដ៏បរិសុទ្ធ[ថ] សណ្ឋិតនៅលើខ្លួន
យើងក៏ប្រាប់សុបិននោះដល់គាត់ថា ៩ឱបេលថិស្សាសារ
ជាមេ[ទ]នៃពួកគ្រូមន្តអាគមអើយ ដោយព្រោះយើងដឹងថា
មានវិញ្ញាណនៃព្រះដ៏បរិសុទ្ធ[ធ]សណ្ឋិតលើអ្នក ហើយថាគ្មាន
ការអាថ៌កំបាំងណា ដែលធ្វើឱ្យអ្នកពិបាកចិត្តឡើយ បាន
ជាយើងសូមឱ្យអ្នកប្រាប់ពីការជាក់ស្តែង ដែលយើងបាន
ឃើញក្នុងសុបិន ហើយកាត់ស្រាយឱ្យយើងផង ១០ឯការ
ជាក់ស្តែងដែលយើងឃើញក្នុងខួរនៅលើដំណេក[ន] នោះគឺ
យើងឃើញថា មានដើមឈើ១មានកំពស់យ៉ាងក្រៃលែង
នៅកណ្តាលផែនដី[ប] ១១ដើមនោះបានដុះធំឡើង ហើយក៏
មាំ ឯកំពូលបានលូតដល់ទល់នឹងផ្ទៃមេឃ ហើយក៏មើល
វាឃើញ រហូតដល់ចុងផែនដីបំផុត[ផ] ១២ស្លឹកដើមនោះល្អ
មើល ហើយផ្លែក៏មានច្រើន ទុកជាអាហារសំរាប់គ្រប់ទាំង
អស់ ឯសត្វនៅផែនដីបានមកជ្រកនៅក្រោមម្លប់ និងសត្វ
ហើរលើអាកាសក៏ទំនៅលើមែក[ព] គ្រប់ទាំងសាច់បានអា–
ហារចិញ្ចឹមខ្លួនពីនោះមក ១៣ក្នុងការជាក់ស្តែងនៅលើ
ដំណេកនោះ[ភ] យើងបានឃើញក្នុងខួរថា មានពួកពិនិត្យត្រួត
មើល១រូប និងពួកបរិសុទ្ធ១[ម] ចុះពីស្ថានសួគ៌មក ១៤ក៏បន្លឺ
ឡើងជាខ្លាំងថា ចូរកាប់ដើមឈើ[យ]នេះចុះ ត្រូវឱ្យកាប់ផ្តាច់
មែកចេញ ព្រមទាំងអង្រួនជំរុះស្លឹក ហើយកំចាត់កំចាយ
ផល ត្រូវឱ្យសត្វទាំងប៉ុន្មានចេញពីក្រោម ហើយសត្វស្លាប
ពីមែកវាទៅ[រ] ១៥ប៉ុន្តែត្រូវឱ្យទុកគល់និងឫសនៅជាប់ក្នុងដី
ចុះ មានទាំងវ័ណ្ឌដែក និងលង្ហិនព័ទ្ធជុំវិញនៅក្នុងស្មៅខ្ចី
នៅវាលដែរ ហើយត្រូវឱ្យបានទទឹកដោយសន្សើមពីលើ
មេឃ ព្រមទាំងឱ្យមានចំណែកនៅក្នុងស្មៅនៃផែនដី ជា
មួយនឹងអស់ទាំងសត្វផង ១៦ត្រូវឱ្យចិត្តវាបានផ្លាស់ប្រែពី
សណ្ឋានចិត្តមនុស្ស ឱ្យទៅជាចិត្តរបស់សត្វវិញ រួចឱ្យ
នៅយ៉ាងនោះ ដរាបដល់កន្លងទៅអស់៧ខួប[ល] ១៧ទោស
នេះ គឺជាពួកពិនិត្យត្រួតមើលដែលកាត់ឱ្យ ហើយសេចក្តី
នេះក៏តាមបង្គាប់នៃពួកបរិសុទ្ធ ប្រយោជន៍ឱ្យមនុស្សដែល
នៅរស់បានដឹងថា ព្រះដ៏ខ្ពស់បំផុត[វ] ទ្រង់គ្រប់គ្រងលើរាជ្យ
របស់មនុស្ស[ស] ក៏ប្រគល់ដល់អ្នកណាតាមព្រះហទ័យ ព្រម
ទាំងតាំងមនុស្សសណ្ឋានទាបថោកបំផុត[ហ] ឡើង ឱ្យគ្រប់គ្រង
ផង ១៨យើងនេះ ជាស្តេចនេប៊ូក្នេសា បានឃើញសុបិន
នេះ ដូច្នេះ ឱបេលថិស្សាសារអើយ ចូរកាត់ស្រាយទៅ
ពីព្រោះអស់ទាំងពួកអ្នកប្រាជ្ញក្នុងនគរយើង មិនអាចនឹង
កាត់ស្រាយឱ្យយើងបានយល់ទេ[ឡ] តែអ្នកអាច[អ]ស្រាយបាន
វិញ ដ្បិតវិញ្ញាណរបស់ព្រះដ៏បរិសុទ្ធ[ក]សណ្ឋិតនៅលើអ្នក[ខ] ។

## លោកដានីយ៉ែលកាត់ស្រាយសុបិន្តនោះ

១៩លំដាប់នោះ ដានីយ៉ែល ដែលមានឈ្មោះថា
បេលថិស្សាសារ លោកត្រូវងឿងនៅ១សំទុះ ហើយគំនិត

**៤:៤** ឆ ទដ ៣០:៦ អស ៣២:៩ **៤:៥** ជ ដយ ២:១ ឈ ទដ ៤:៤ ញ ដយ ២:២៨ ដ .១៩ លប ៤១:៨ យប ៣:២៦ ដយ ២:៣ ៥:៦ **៤:៦** ឋ ដយ ២:២ **៤:៧** ឌ លប ៤១:៨ ឍ អស ៤៤:២៥ ដយ ២:២ ណ ដយ ២:១០ **៤:៨** ត ដយ ១:៧ ថ លប ៤១:៣៨ **៤:៩** ទ ដយ ២:៤៨ ធ ដយ ៥:១១–១២ **៤:១០** ន ខ.៥ ទដ ៤:៤ ប អគ ៣១:៣–៤ **៤:១១** ផ អគ ១៩:១១ ៣១:៥ **៤:១២** ព អគ ១៧:២៣ មថ ១៣:៣២ **៤:១៣** ភ ខ.១០ ដយ ៧:១ ម ខ.២៣ ចទ ៣៣:២ **៤:១៤** យ យប ២៤:២០ រ អគ ៣១:១២ មថ ៣:១០ **៤:១៦** ល ខ.២៣,៣២ **៤:១៧** វ ខ.២,២៥ ទដ ៨៣:១៨ ស ទដ ១០៣:១៩ យរ ២៧:៥–៧ ដយ ២:២១ ៥:១៨–២១ រម ១៣:១ ហ ដយ ១១:២១ មថ ២៣:១២ **៤:១៨** ឡ លប ៤១:៨ ដយ ៥:៨,១៥ អ លប ៤១:១៥ ក លប ៤១:៣៨ ខ ខ.៧–៩ ដយ ១:២០

**៤:៨** *តាមព្រះនាមព្រះនៃយើង* មើលការពន្យល់ ១:៧ ។ ពាក្យថា បេល ("ព្រះអម្ចាស់") ដែលមាននៅក្នុងឈ្មោះបេលថិស្សាសារ គឺជាងាររបស់ព្រះម៉ាឌុក នៃចក្រភពបាប៊ីឡូន ។

**៤:៩** *មេនៃពួកគ្រូមន្តអាគម* មើល ២:៤៨ ។

**៤:១០** *ដើមឈើ* ពាក្យនេះមានការបកប្រែនៅក្នុង ខ.២២ ។

**៤:១១** *បានដុះធំឡើង ហើយក៏មាំ* សិលាចារិកនៅក្នុងអាគាររបស់ស្តេចនេប៊ូក្នេសាបានប្រៀបប្រដូចចក្រភពបាប៊ីឡូនទៅនឹងដើមឈើមួយដើមដែលដុះឡើង(ធៀបនឹង ខ.២២) ។ *ឯកំពូលបានលូតដល់ទល់នឹងផ្ទៃមេឃ* ពាក្យនេះគេច្រើនប្រើនៅក្នុងការនិយាយអំពីកំពូលព្រះវិហារ របស់សាសន៍នៃតំបន់មេសូប៉ូតាមា(មើល លប ១១:៤ និងការពន្យល់) ។

**៤:១៣** *ពួកត្រួតពិនិត្យមើល* គឺទេវតា មើល ខ.១៧ និង ២៣ ផងដែរ ។

**៤:១៥** *ត្រូវឱ្យទុកគល់ . . . នៅជាប់* នៅត្រង់ចំណុចនេះគឺចង់បញ្ជាក់ថាដើមឈើនឹងបន្តជីវិតរបស់វា (មើល ខ.២៦) ។

**៤:១៦** *៧* លេខនេះគឺប្រើដើម្បីបញ្ជាក់អំពីភាពពេញលេញ(ឧ.រង្វាស់ដែលគ្រប់)។ *ខួប* ឬឆ្នាំ ។ មើល ខ.២៣,២៥ និង ៣២ ផងដែរ ។ ឬម្យ៉ាងទៀតពាក្យខួបនៅត្រង់ចំណុចនេះ អាចសំដៅទៅលើរយៈពេលដែលមិនកំណត់ ។

**៤:១៧** *ពួកត្រួតពិនិត្យមើល* គឺជាភ្នាក់ងាររបស់ព្រះ ដែលទ្រង់ជាប្រភពនៃ"ការសម្រេចទោស"(មើលខ.២៤)។ *ព្រះដ៏ខ្ពស់បំផុតទ្រង់គ្រប់គ្រងលើរាជ្យរបស់មនុស្ស* មើលសេចក្តីផ្តើមត្រង់ខ្លឹមសារខាងវិជ្ជាសិក្សាអំពីព្រះ ។

**៤:១៩** *ដានីយ៉ែល . . . ត្រូវងឿងនៅ១សំទុះ* លោកដានីយ៉ែលត្រូវងឿងមួយសំទុះ ដើម្បីត្រៀមខ្លួនធ្វើការកាត់ស្រាយ ឱ្យបានត្រឹមត្រូវ ។ *បពិត្រព្រះអម្ចាស់ . . . ពួកសត្រូវរបស់ទ្រង់ដែរ* នៅត្រង់ចំណុចនេះលោកដានីយ៉ែល

របស់លោកក៏នាំឱ្យបារម្ភព្រួយ[ក] តែស្ដេចទ្រង់មានបន្ទូលថា
បេលថិស្សាសារអើយ កុំឱ្យសុបិននេះ ឬសេចក្ដីសំរាយ
បាននាំឱ្យអ្នកបារម្ភព្រួយឡើយ[ខ] នោះបេលថិស្សាសារទូល
តបថា បពិត្រព្រះអម្ចាស់ជីវិតនៃទូលបង្គំ សូមឱ្យសុបិននេះ
បានកើតដល់ពួកអ្នកដែលស្អប់ទ្រង់វិញចុះ ហើយសេចក្ដី
សំរាយបានដល់ពួកសត្រូវរបស់ទ្រង់ដែរ ២០ឯដើមឈើ
ដែលទ្រង់ទតឃើញថាបានដុះ ហើយក៏មាំនោះដែលមាន
កំពូលលូតឡើង ទល់នឹងផ្ទៃមេឃ ហើយ មើលវាឃើញ
រហូតដល់គ្រប់ទីនៅផែនដី ២១ជាដើមឈើមានស្លឹកល្អ
មើល ហើយផលក៏មានច្រើន ទុកសំរាប់ជាអាហារ ដល់
គ្រប់ទាំងអស់ ដែលសត្វនៅផែនដីបានជ្រកក្រោម ហើយ
សត្វហើរលើអាកាសក៏ធ្វើសំបុកនៅ[ង] ២២បពិត្រព្រះករុណា
ដើមឈើនោះគឺជាអង្គទ្រង់[ច]ដែលបានឡើងជាធំ ហើយមាន
អានុភាព ដ្បិតភាពធំរបស់ទ្រង់បានលូតឡើងរហូតដល់
ផ្ទៃមេឃ ហើយអំណាចគ្រប់គ្រងរបស់ទ្រង់ក៏ដល់ចុង
ផែនដីបំផុតដែរ[ឆ] ២៣ហើយដំណើរដែលព្រះករុណាបាន
ឃើញពួកពិនិត្យត្រួតមើល១រូប និងពួកបរិសុទ្ធ១[ជ]ចុះមកពី
ស្ថានសួគ៌និយាយថា ចូរកាប់ដើមឈើនេះចុះ ហើយ
បំផ្លាញទៅ តែត្រូវទុកគល់ និងឫសជាប់នៅក្នុងដី មាន
ទាំងវ័ណ្ឌដែក និងលង្ហិនជុំវិញ នៅកណ្ដាលស្មៅនៅ វាល
ហើយត្រូវឱ្យបានទទឹក ដោយសន្សើមពីលើមេឃ ព្រមទាំង
ឱ្យមានចំណែក ជាមួយនឹងអស់ទាំងសត្វ នៅផែនដីទាល់តែ
បានកន្លងអស់៧ខួបទៅ[ឈ,ញ] ២៤បពិត្រព្រះករុណា នេះជា
សេចក្ដីសំរាយ ហើយគឺជាបង្គាប់ដែលមក[ដ] ពីព្រះដ៏ខ្ពស់
បំផុត ជាការដែលត្រូវមកដល់ទ្រង់ព្រះករុណាជាព្រះ
អម្ចាស់ជីវិតនៃទូលបង្គំ ២៥គឺថាទ្រង់នឹងត្រូវបណ្ដេញចេញ
ពីមនុស្សលោកទៅ ហើយទ្រង់នឹងមានទីលំនៅជាមួយនឹង
អស់ទាំងសត្វនៅផែនដី ឱ្យទ្រង់បានសោយស្មៅ ដូចជាគោ
ទ្រង់នឹងត្រូវទទឹក[ឋ] ដោយសន្សើមពីលើមេឃ ដរាបដល់
បានកន្លងអស់៧ខួប ទាល់តែទ្រង់បានជ្រាបថា ព្រះដ៏ខ្ពស់
បំផុត[ឌ]ទ្រង់គ្រប់គ្រងលើរាជ្យរបស់មនុស្ស ហើយក៏ប្រទាន
ដល់អ្នកណាតាមព្រះទ័យ[ឍ] ២៦ឯដំណើរដែលគេបានបង្គាប់
ឱ្យទុកគល់និងឫសនៃដើមនោះ[ណ]ឱ្យនៅ នោះគឺថា រាជ្យទ្រង់
នឹងបានទុកនៅសំរាប់កាលណាទ្រង់បានជ្រាបថា ស្ថានសួគ៌
មានអំណាចគ្រប់គ្រង[ត] ២៧ដូច្នេះ ឱព្រះករុណាអើយ សូមឱ្យ
ទ្រង់បានរាប់សេចក្ដីទូន្មានរបស់ទូលបង្គំ ជាគួរទទួលចុះ
សូមឱ្យទ្រង់ផ្ដាច់អំពើបាបរបស់ទ្រង់ចេញ ដោយប្រព្រឹត្ត
សេចក្ដីសុចរិតវិញ ហើយផ្ដាច់អំពើទុច្ចរិតរបស់ទ្រង់ចេញ
ផង ដោយសំដែងសេចក្ដីមេត្តាករុណាដល់ពួកក្រីក្រ[ថ] ក្រែង
នឹងមានសេចក្ដីសុខ[ទ]ជាអង្វែងតទៅ[ធ]។

## សុបិន្តនោះក្លាយជាការពិត

២៨ការទាំងនោះក៏កើត[ន]ដល់ស្ដេចនេប៊ូក្នេសា ២៩លុះ
កន្លងបាន១២ខែហើយ នោះទ្រង់កំពុងយាងក្នុងព្រះរាជ
វាំងនៅក្រុងបាប៊ីឡូន ៣០ខណនោះស្ដេចទ្រង់មានបន្ទូលថា
នេះតើមិនមែនជាក្រុងបាប៊ីឡូនដ៏ធំ ដែលអញបានស្អាងទុក
ជាព្រះរាជស្ថាន ដោយអានុភាពនៃអំណាច[ប]របស់អញ
ហើយសំរាប់ជាសិរីល្អ នៃឥទ្ធានុភាពរបស់អញទេឬ[ផ]
៣១កាលស្ដេចកំពុងតែមានបន្ទូលពាក្យទាំងនោះនៅឡើយ
នោះមានឮសំឡេងធ្លាក់មកពីលើមេឃថា ម្នាលស្ដេច
នេប៊ូក្នេសាអើយ មានសេចក្ដីប្រាប់ដល់ឯងហើយ ថារាជ្យ
បានផុតចេញពីឯងហើយ[ព] ៣២ឯងនឹងត្រូវបណ្ដេញចេញពី
ពួកមនុស្សលោកទៅ ឯងនឹងមានទីលំនៅជាមួយនឹងពួកសត្វ
នៅផែនដី ឱ្យបានស៊ីស្មៅដូចជាគោ ដរាបដល់បានកន្លងទៅ
អស់៧ខួប ទាល់តែឯងបានដឹងថា ព្រះដ៏ខ្ពស់បំផុតទ្រង់គ្រប់
គ្រងលើរាជ្យរបស់មនុស្ស ហើយក៏ប្រទានដល់អ្នកណា តាម
ព្រះហឫទ័យ[ភ] ៣៣នៅវេលានោះឯង ពាក្យនោះបានសំរេច
ដល់នេប៊ូក្នេសា គឺទ្រង់ត្រូវបណ្ដេញ ចេញពីពួកមនុស្ស

**៤:១៩** ក ខ.៥ លប ៤១:៨ ដយ ៧:១៥,២៨ ៨:២៧ ១០:១៦–១៧ ខ លប ៤០:១២ **៤:២១** ង អគ ៣១:៦ **៤:២២** ច ២សយ ១២:៧ ឆ យរ ២៧:៧ ដយ ៥:១៨–១៩ **៤:២៣** ជ ខ.១៣ ដយ ៨:១៣ ឈ ដយ ៥:២១ ញ អគ ៣១:៣–៤ **៤:២៤** ដ យប ៤០:១២ ទដ ១០៧:៤០ យរ ៤០:២ **៤:២៥** ឋ យប ២៤:៨ ឌ ខ.១៧ ឍ យរ ២៧:៥ ដយ ២:៤៧ ៥:២១ **៤:២៦** ណ ខ.១៥ ត ដយ ២:៣៧ **៤:២៧** ថ អស ៥៥:៦–៧ ទ យរ ២៩:៧ ធ ចទ ២៤:១៣ ១ពវ ២១:២៩ ទដ ៤១:៣ សភ ២៨:១៣ អគ ១៨:២២ **៤:២៨** ន ជន ២៣:១៩ **៤:៣០** ប អស ១៣:១៩ ផ អស ១០:១៣ ៣៧:២៤–២៥ ដយ ៥:២០ ហព ១:១១ ២:៤ **៤:៣១** ព ២សយ ២២:២៨ ដយ ៥:២០ **៤:៣២** ភ យប ៩:១២

ទូលឱ្យស្ដេចទ្រង់ត្រៀមខ្លួនសម្រាប់ការអាក្រក់បំផុតដែលនឹងកើតឡើង ។

**៤:២២** *បពិត្រព្រះករុណា ដើមឈើនោះ* ធៀបនឹង ២:៣៧–៣៨ ។ *អំណាចគ្រប់គ្រងរបស់ទ្រង់ក៏ដល់ចុងផែនដីបំផុត* នៅសម័យនោះ ចក្រភពរបស់ស្ដេចនេប៊ូក្នេសាគឺ ធំ ហើយខ្លាំងជាងគេ ។

**៤:២៥** *ទ្រង់បានសោយស្មៅដូចគោ* នៅត្រង់ចំណុចនេះស្ដេចនេប៊ូក្នេសាត្រូវមានជម្ងឺសរសៃប្រសាទ (មើល ខ.៣៤) ម្យ៉ាង ដែលធ្វើឱ្យទ្រង់មានទម្លាប់ស៊ីស្មៅដូចគោ (ខ.៣៣) ។ *ជ្រាបថា ព្រះដ៏ខ្ពស់បំផុតទ្រង់គ្រប់គ្រងលើរាជ្យរបស់មនុស្ស* ការនេះនឹងកើតឡើងចំពោះទ្រង់ក្នុងពេលដ៏ខ្លីខាងមុខ ទុកដូចជាមេរៀន (ធៀប ខ.៣០ ជាមួយនឹង ខ.៣៧) ។

**៤:២៦** *ស្ថានសួគ៌* ពាក្យនេះពួកសាសន៍យូដាប្រើដើម្បីនិយាយសំដៅទៅលើព្រះ ហើយនៅក្នុងសញ្ញាថ្មី ព្រះយេស៊ូវទ្រង់ប្រើពាក្យ "នគរស្ថានសួគ៌" (ធៀបឧទាហរណ៍ក្នុង មថ ៥:៣ ជាមួយនឹង លក ៦:២០) ។

**៤:២៨** *ការទាំងនេះ* គឺដោយសារតែស្ដេចនេប៊ូក្នេសាមិនធ្វើតាម ការឱ្យយោបលរបស់លោកដានីយ៉ែល (ខ.២៧) ។

**៤:៣០** *ក្រុងបាប៊ីឡូនដ៏ធំ* ទីក្រុងដ៏ធំនេះគឺជាមានទៅដោយ កំផែងទីក្រុង ព្រះវិហារ និងសួនច្បារជាច្រើន (មើលការពន្យល់ អស ១៣:១៩) ។

**៤:៣១** *កំពុងតែមានបន្ទូលពាក្យទាំងនោះនៅឡើយ* មើល លក ១២:១៩–២០ ។

**៤:៣៣** *ពាក្យនោះបានសំរេច* មើល សភ ១១:២ និងការពន្យល់, ១៦:១៨ ។ *ត្រូវបណ្ដេញ* អាចត្រូវបណ្ដេញឱ្យទៅសួនច្បារាជវាំង ។ ទីប្រឹក្សារបស់ទ្រង់

លោក ហើយក៏សោយស្មៅដូចជាគោ អង្គទ្រង់ត្រូវទទឹក[ម]
ដោយសន្សើមពីលើមេឃ ទាល់តែព្រះកេសទ្រង់បានដុះ
វែង ដូចជាស្លាបឥន្ទ្រី ហើយនខាទ្រង់ ក៏ដូចជាក្រចកនៃ
សត្វស្លាប[យ]។
៣៤ លុះដល់ផុតពេលកំណត់ហើយ នោះនេប៊ូក្នេសា
យើងបានងើបភ្នែកឡើងទៅលើមេឃ ហើយសតិស្មារតី[រ]ក៏
ត្រឡប់មកឯយើងវិញ រួចយើងបានក្រាបថ្វាយបង្គំដល់
ព្រះដ៏ខ្ពស់បំផុត ព្រមទាំងសរសើរ ហើយលើកដំកើងព្រះ
ដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ចផង[ល] ដោយព្រោះ
អំណាចគ្រប់គ្រង[វ]របស់ទ្រង់ស្ថិតស្ថេរនៅជាដរាប ហើយ
រាជ្យទ្រង់ក៏នៅអស់ទាំងដំណមនុស្សតរៀងទៅ[ស] ៣៥ ឯអស់
ទាំងមនុស្សលោកក៏រាប់ទុកជាឥតការទទេ[ហ] ទ្រង់ធ្វើតាមតែ
ព្រះហឫទ័យ[ឡ]ក្នុងពួកពលបរិវារនៃស្ថានសួគ៌ ហើយនៅ
កណ្ដាលពួកមនុស្សលោកផង ឥតមានអ្នកណាអាចនឹង
ឃាត់ទប់[អ]ព្រះហស្តទ្រង់[ក] ឬនឹងទូលសួរទ្រង់ថា ទ្រង់ធ្វើអ្វី
ដូច្នេះបានឡើយ[ខ] ៣៦ នៅវេលានោះឯង សតិស្មារតីរបស់
យើងក៏ត្រឡប់មកវិញ ឯសិរីល្អនៃរាជ្យយើង ហើយនឹង
ឥទ្ធានុភាព ព្រមទាំងរស្មីពន្លឺ ក៏មកឯយើងវិញដែរ[គ] ពួក
ប្រឹក្សា និងពួកសេនាបតី គេមករកយើង គឺយើងបានតាំង
ឡើងនៅក្នុងរាជ្យរបស់យើងវិញ ហើយអំណាចយើងក៏
កាន់តែធំថែមឡើង ៣៧ ឥឡូវនេះ នេប៊ូក្នេសា យើងក៏
សរសើរ[ឃ] ហើយលើកដំកើង[ង] ព្រមទាំងពណ៌នាគុណដល់
មហាក្សត្រនៃស្ថានសួគ៌ ដ្បិតអស់ទាំងការនៃទ្រង់សុទ្ធតែ
ពិតត្រង់[ច] ហើយផ្លូវប្រព្រឹត្តទាំងប៉ុន្មានរបស់ទ្រង់ក៏យុត្តិធម៌
ដែរ ទ្រង់អាចនឹងបន្ទាបអស់អ្នកដែលប្រព្រឹត្តដោយចិត្តធំ[ឆ]
ទៅ[ជ]។

**៤:៣៣** ម យប ២៤:៨ យ ដយ ៥:២០–២១ **៤:៣៤** រ យប ១២:២០ ល ដយ ១២:៧ វ អស ៣៧:១៦ ស ទដ ១៤៥:១៣ ដយ ២:៤៤ ៥:២១ ៦:២៦ លក ១:៣៣ **៤:៣៥** ហ អស ៤០:១៧ ឡ ចទ ២១:៨ ទដ ១១៥:៣ ១៣៥:៦ យហ ១:១៤ អ អស ១៤:២៧ ក ចទ ៣២:៣៩ ខ យប ៩:៤ អស ១៤:២៤ ៤៥:៩ ដយ ៥:២១ រម ៩:២០ **៤:៣៦** គ សភ ២២:៤ ដយ ៥:១៨ **៤:៣៧** ឃ នក ១៥:២ ង ទដ ៣៤:៣ ច ចទ ៣២:៤ ទដ ៣៣:៤–៥ ឆ ទដ ១៨:២៧ ១១៩:២១ ជ យប ៣១:៤ ៤០:១១–២១ អស ១៣:១១ ដយ ៥:២០,២៣ មថ ២៣:១២

**៥:១** ក ខ.៣០ ដយ ៧:១ ៨:១ ខ ១ពវ ៣:១៥ គ យរ

## សំណេរនៅលើជញ្ជាំង

**៥** ១ ស្ដេចបេលសាសារ[ក] ទ្រង់ជប់លៀងយ៉ាងធំ[ខ] ដល់
ពួកសេនាបតី[គ]របស់ទ្រង់១ពាន់នាក់ ហើយក៏សោយស្រា
ទំពាំងបាយជូរ នៅចំពោះអ្នកទាំង១ពាន់នោះ ២ កាល
បេលសាសារកំពុងតែភ្លក់[ឃ]ស្រាទំពាំងបាយជូរ នោះទ្រង់ក៏
បង្គាប់ឱ្យគេយកពែងមាស ពែងប្រាក់[ង] ដែលនេប៊ូក្នេសា
ជា បិតាទ្រង់ បានប្រមូលយកពីព្រះវិហារ ដែលនៅក្រុង
យេរូសាឡិមមក សំរាប់ឱ្យស្ដេច និងពួកសេនាបតីរបស់
ទ្រង់ ព្រមទាំងពួកភរិយា[ច] ហើយពួកស្រីអ្នកម្នាងរបស់គេ
ទាំងអស់គ្នាបានផឹក[ឆ] ៣ ដូច្នេះ គេក៏យកពែងមាស ដែលបាន
ប្រមូលយកពីទីបរិសុទ្ធក្នុងព្រះវិហារនៃព្រះ ដែលនៅក្រុង
យេរូសាឡិមមកថ្វាយ រួចស្ដេច និងពួកសេនាបតីរបស់
ទ្រង់ ព្រមទាំងពួកភរិយា និងពួកស្រីអ្នកម្នាងទាំងប៉ុន្មាន
ក៏ផឹកពីពែងទាំងនោះ ៤ គេបានផឹកស្រាបណ្ដើរ ហើយ
សរសើរដល់អស់ទាំងព្រះបណ្ដើរ[ជ] ជាព្រះធ្វើពីមាស ប្រាក់
លង្ហិន ដែក ឈើ និងថ្ម[ឈ]។
៥ នៅវេលានោះឯង មានម្រាមដៃនៃមនុស្ស លេច
ចេញមក សរសេរនៅជញ្ជាំងនៃព្រះរាជដំណាក់ ប្រទល់
មុខនឹងជើងចង្កៀង ស្ដេចទ្រង់ក៏ឃើញចំណែកដៃដែល
សរសេរនោះ ៦ ដូច្នេះ ព្រះភក្ត្របំព្រងនៃស្ដេចក៏ផ្លាស់ប្រែ
ទៅ[ញ] ហើយគំនិតទ្រង់ក៏នាំឱ្យបារម្ភព្រួយវិញ[ដ] កំឡាំងទ្រង់
ក៏ល្ហើយទៅ[ឋ] ហើយព្រះជង្ឃទ្រង់ប្រជុំគ្នា[ឌ] ៧ ស្ដេចទ្រង់
ស្រែកយ៉ាងខ្លាំង បង្គាប់ឱ្យនាំពួកអាបធ្មប់[ឍ] និងពួក

៥០:៣៥ **៥:២** ឃ អស ២១:៥ ង ២ពវ ២៤:១៣ ២របា ៣៦:១០ យរ ៥២:១៩ ច នអ ២:១៤ ឆ នអ ១:៧ ដយ ១:២ **៥:៤** ជ ពច ១៦:២៤ ឈ នអ ១:១០ ទដ ១៣៥:១៥–១៨ ហព ២:១៩ វវ ៩:២០ **៥:៦** ញ យប ៤:១៥ ដ ដយ ៤:៥ ឋ អស ៧:២ ឌ ទដ ២២:១៤ អគ ៧:១៧ **៥:៧** ឍ លប ៤១:៨

ប្រហែលមានលោកដានីយ៉ែលជាអ្នកដឹកនាំ (មើល ២:៤៨–៤៩) ហើយអាច
ដឹកនាំនគរយ៉ាងមានប្រសិទ្ធិភាព ។
**៤:៣៤** *ដល់ផុតពេលកំណត់ហើយ* ប្រហែលជាមានរយៈពេល៦ឆ្នាំ (មើល ខ.១៦ និងការពន្យល់) ។ *អំណាចគ្រប់គ្រងរបស់ទ្រង់ . . . នៅអស់ទាំងដំណមនុស្សតរៀងទៅ* នៅត្រង់ចំណុចនេះ ស្ដេចនេប៊ូក្នេសាបានវិលមកកាន់អំណាច ដែលទ្រង់មានកាលពីមុនវិញ (មើល ខ.៣ និង ៦:២៦ ៧:១៤) ។
**៤:៣៥** មើល ទដ ១១៥:៣ និងការពន្យល់ ។
**៤:៣៦** ធៀបនឹង យប ៤២:១០,១២ ។
**៤:៣៧** *អស់ទាំងការនៃទ្រង់សុទ្ធតែពិតត្រង់ . . . យុត្តិធម៌ដែរ* មើលការពន្យល់ អគ ១៨:២៥ ។ *ទ្រង់អាចនឹងបន្ទាបអស់អ្នកដែលប្រព្រឹត្តដោយចិត្តធំទៅ* មើល សភ ៣:៣៤ យក ៤:៦,១០ ១ពត ៥:៥–៦ ។
**៥:១–៤** ពិធីជប់លៀងផឹកស៊ីដ៏ហួសហេតុនេះ គឺជាភាពអឹងកង ហើយប្រមាថដល់ព្រះនាមព្រះ ។ ប្រវត្តិវិទូក្រិកដូចជាលោកហេរ៉ូដូទូស (Herodotus) និងសេណូហ្វុន (Xenophon) ក៏បានកត់ត្រាអំពីព្រឹត្តិការណ៍ដូចនេះផងដែរ ។
**៥:១** *ស្ដេច* ស្ដេចបេលសាសារ (មានន័យថា "ព្រះបេលការពារស្ដេច") គឺជាបុត្រ និងអ្នកដឹកនាំជាតំណាងរបស់ស្ដេចណាបូនីដូស (Nabonidus) ។ គេហៅស្ដេចនេះថា "ព្រះរាជបុត្រ" របស់ស្ដេច នេប៊ូក្នេសា (ខ.២២) ប៉ុន្តែពាក្យនេះជាភាសាអារ៉ាមក៏អាចមានន័យថា "ចៅ" ឬ "កូនចៅ" ឬក៏ "អ្នកស្នងរាជ្យ" ។ មើល ខ.១០ ។
**៥:២** *ពែងមាស . . . ដែលនេប៊ូក្នេសា . . . បានប្រមូលយកពីព្រះវិហារ* ការនេះបានកើតឡើងនៅក្នុងឆ្នាំទីប្រាំបីនៃរាជ្យរបស់ទ្រង់ (ឆ្នាំ ៥៩៧ មុនគ.ស, មើល ១ពវ ២៤:១២–១៣ និងការពន្យល់ ២៤:១២) ។
**៥:៥** *នៅវេលានោះឯង* មើល ៤:៣១ សភ ២៩:១, ១ថន ៥:៣ និងការពន្យល់ ។
**៥:៧** *អ្នកគ្រប់គ្រងទី ៣ ក្នុងនគរ* ស្ដេចណាប៊ូនីដូស (Nabonidus) គឺទី១ ហើយស្ដេចបេលសាសារទី ២ ។

ខាល់ដេ[ណ] ហើយពួកគ្រូទាយ[ត]មក រួចស្ដេចទ្រង់មានបន្ទូល
នឹងពួកអ្នកប្រាជ្ញ[ថ] ដែលនៅក្រុងបាបីឡូនថា អ្នកណាដែល
អានមើល អក្សរនេះ ហើយស្រាយន័យឱ្យយើងផង អ្នក
នោះនឹងបានស្លៀកពាក់សំពត់ពណ៌ស្វាយ ហើយនឹងមាន
ខ្សែមាសពាក់នៅក[ទ] ក៏នឹងបានតាំងឡើងជាអ្នកគ្រប់គ្រង
ទី៣[ធ]ក្នុងនគរ[ន] ៨ខណៈនោះ អស់ទាំងពួកអ្នកប្រាជ្ញ[ប]របស់
ស្ដេចក៏ចូលមក តែគេមើលអក្សរនោះមិនបានឡើយ ក៏មិន
អាចនឹងស្រាយន័យថ្វាយស្ដេចបានដែរ[ផ] ៩ដូច្នេះ បេលសា–
សារ ទ្រង់មានព្រះទ័យវិតក្កជាខ្លាំង[ព] ហើយព្រះភក្ត្រទ្រង់
ក៏ស្លុតទៅ ឯពួកសេនាបតីរបស់ទ្រង់គេក៏ទាល់គំនិតដែរ ។
១០រីឯអគ្គមហេសី ព្រះនាងក៏យាងចូលទៅក្នុងរោង
លៀង ដោយឮព្រះបន្ទូលនៃស្ដេច និងពួកសេនាបតីរបស់
ទ្រង់ ព្រះនាងទូលដល់ស្ដេចថា បពិត្រព្រះករុណា សូម
ទ្រង់មានព្រះជន្មចំរើននៅជាយឺនយូរ[ភ] សូមកុំឱ្យគំនិតទ្រង់
នាំឱ្យមានព្រះទ័យវិតក្កឡើយ ក៏កុំឱ្យព្រះភក្ត្រទ្រង់ផ្លាស់
ប្រែទៅដូច្នេះដែរ ១១ដ្បិតនៅក្នុងនគរទ្រង់ មានមនុស្ស
ម្នាក់ឈ្មោះដានីយ៉ែល ជាអ្នកដែលមានវិញ្ញាណនៃព្រះដ៏
បរិសុទ្ធ[ម]សណ្ឋិតនៅ ហើយនៅក្នុរាជ្យនៃព្រះបិតាទ្រង់
នោះឃើញមានពន្លឺ និងយោបល់ ព្រមទាំងប្រាជ្ញា[យ] ដូចជា
ប្រាជ្ញារបស់ពួកព្រះនៅក្នុងអ្នកនោះ[រ] រីឯស្ដេចនេប៊ូក្នេសា
បិតាទ្រង់ ក៏បានតាំងអ្នកនោះឡើង ជាអធិបតីលើពួកគ្រូ
មន្តអាគម គ្រូអង្គុយធម៌ ពួកខាល់ដេ និងពួកគ្រូទាយ
អើ គឺជាស្ដេច ជាបិតាទ្រង់នោះឯងដែលតាំងគេ[ល] ១២ពី
ព្រោះឃើញថា មានវិញ្ញាណយ៉ាងវិសេស មានដំរិះ និង
យោបល់ ក៏មានចំណេះចេះកាត់ស្រាយសប្តិ និងដោះ
ស្រាយប្រស្នា[វ] ហើយកែសេចក្ដីដ៏ជ្រាលជ្រៅ[ស] នៅក្នុងខ្លួន
អ្នកនោះដែលស្ដេចទ្រង់ប្រទានឈ្មោះថា បេលថិស្សា–
សារ[ហ] ដូច្នេះ សូមឱ្យគេហៅដានីយ៉ែលនោះមកឥឡូវ
លោកនឹងបកប្រែសេចក្ដីថ្វាយទ្រង់[ឡ] ។
១៣ដូច្នេះ គេក៏នាំដានីយ៉ែលចូលមក ចំពោះស្ដេច
ហើយស្ដេចទ្រង់មានបន្ទូលទៅដានីយ៉ែលថា តើលោក
ជាឈ្មោះដានីយ៉ែលនោះ នៅក្នុងពួកឈ្លើយសាសន៍យូដា
ដែលស្ដេច ជាបិតាយើង បានដឹកនាំចេញពីស្រុកយូដាមក
ឬអី[អ] ១៤យើងបានឮនិយាយពីលោកថា មានវិញ្ញាណនៃ
ពួកព្រះ[ក]សណ្ឋិតលើលោក ហើយថាមានពន្លឺ យោបល់
និងប្រាជ្ញាស្រួចស្រាល់នៅក្នុងខ្លួនលោក[ខ] ១៥រីឯពួកអ្នក
ប្រាជ្ញ និងពួកគ្រូអង្គុយធម៌បានចូលមកចំពោះយើង ដើម្បី
ឱ្យបានអានមើលអក្សរនេះ ហើយនឹងប្រែន័យសេចក្ដីមក
ឱ្យស្ដាប់បាន តែគេមិនអាចនឹងប្រែបានទេ[គ] ១៦ប៉ុន្តែ
ចំណែកលោក យើងបានឮថា លោកប៉ិនប្រសប់នឹងប្រែ
សេចក្ដី ហើយកែន័យដ៏ជ្រាលជ្រៅបាន[ឃ] ឥឡូវនេះ បើ
លោកអាចនឹងមើលអក្សរនេះ ហើយប្រែន័យសេចក្ដីឱ្យ
យើងស្ដាប់បាន នោះលោកនឹងបានស្លៀកពាក់សំពត់
ពណ៌ស្វាយ ហើយមានខ្សែមាសពាក់នៅកផង[ង] ក៏នឹង
បានតាំងឡើងជាអ្នកគ្រប់គ្រងទី៣ក្នុងនគរ[ច] ។
១៧នោះដានីយ៉ែល លោកទូលតបនឹងស្ដេចថា ឯ
អំណោយទានរបស់ព្រះករុណា សូមទុកសំរាប់ព្រះអង្គ
ទ្រង់ហើយសូមប្រទានរង្វាន់ដល់អ្នកដទៃទៀតចុះ[ឆ] ប៉ុន្តែ
ចំណែកទូលបង្គំៗនឹងអានមើលអក្សរនេះ ថ្វាយទ្រង់ព្រះ
ករុណា ហើយនឹងបកប្រែថ្វាយទ្រង់ជ្រាបផង ១៨បពិត្រព្រះ
រាជា ព្រះដ៏ខ្ពស់បំផុតទ្រង់បានប្រទានរាជ្យ អំណាច សិរីល្អ
និងឥទ្ធានុភាពដល់នេប៊ូក្នេសា[ជ]ជាព្រះបិតាទ្រង់[ឈ] ១៩បណ្ដា
ជនទាំងឡាយ និងគ្រប់សាសន៍ គ្រប់ភាសាក៏ញាប់ញ័រ
ហើយកោតខ្លាចចំពោះទ្រង់ ដោយព្រោះអំណាច ដែល
ព្រះបានប្រទាននោះ អ្នកណាដែលទ្រង់ចង់សំឡាប់ នោះ
ក៏សំឡាប់ទៅ[ញ] ហើយអ្នកណាដែលចង់ទុកឱ្យរស់នៅ នោះ
ក៏ទុកតាម ព្រះទ័យ ឯអ្នកណាដែលទ្រង់ចង់តាំងឡើង នោះ
ក៏តាំង ហើយអ្នកណាដែលទ្រង់ចង់ទំលាក់ចុះ នោះក៏ទំលាក់
ទៅ[ដ] ២០តែកាលព្រះទ័យទ្រង់បានប៉ោងឡើង ត្រឡប់ជា
រឹងត្អឹង ដល់ម្ល៉េះបានជាទ្រង់ប្រព្រឹត្ត ដោយសេចក្ដីអំនួត[ឋ]
នោះទ្រង់ ត្រូវទំលាក់ចុះពីបល្ល័ង្ករាជ្យ[ឪ]របស់ទ្រង់ ហើយគេ
ក៏ដក[ឍ]កិត្តិយសរបស់ទ្រង់ចេញ[ណ] ២១ទ្រង់ត្រូវបណ្ដេញពីពួក
មនុស្សទៅ ហើយព្រះទ័យទ្រង់បានត្រឡប់ទៅ ដូចជាចិត្ត
របស់សត្វវិញ ទ្រង់មានទីលំនៅជាមួយនឹងលាព្រៃ ក៏សោយ

**៥:៧** ណ អស ១៩:៣
ត អស ៤៤:២៥
ថ យរ ៥០:៣៥
ដយ ៤:៦–៧
ទ លប ៤១:៤២
ធ នអ ១០:៣ ន ដយ
២:៥–៦,៤៨
**៥:៨** ប នក ៨:១៨
ផ ដយ ២:១០,២៧
៤:១៨
**៥:៩** ព ទដ ៤៨:៥
អស ២១:៤
**៥:១០** ភ នហ ២:៣
ដយ ៣:៩
**៥:១១** ម លប
៣១:៣៨ យ ឧ.១៤
ដយ ១:១៧ រ ដយ
២:២២ ល ដយ
២:៤៧–៤៨
**៥:១២** វ ជន ១២:៨
ស ឧ.១៤–១៦ ដយ
៦:៣ ហ ដយ ១:៧
ឡ អគ ២៨:៣
**៥:១៣** អ នអ ២:៥–
៦ ដយ ៦:១៣
**៥:១៤** ក លប
៤១:៣៨ ខ ដយ
២:២២
**៥:១៥** គ ដយ ៤:១៨
**៥:១៦** ឃ លប
៤១:១៥ ង លប
៤១:៤២ ច នអ ៥:៣
ដយ ២:៦
**៥:១៧** ឆ ២ពវ
៥:១៦
**៥:១៨** ជ យរ
២៨:១៤ ឈ យរ
២៧:៧ ដយ
២:៣៧–៣៨ ៤:៣៦
**៥:១៩** ញ ដយ
២:១២–១៣ ៣:៦
ដ ដយ ៤:២២
**៥:២០** ឋ ដយ
៤:៣០ ឱ យរ ៤៣:១០ ឍ យរ ១៣:១៨ ដយ ៤:៣១ ណ យប ៤០:១២ អស
១៤:១៣–១៥ អគ ៣១:១០–១១ ដយ ៨:៨

**៥:១០** *អគ្គមហេសី* អាចជា (១).មហេសីរបស់ស្ដេចនេប៊ូក្នេសា ឬ (២).បុត្រី
របស់ស្ដេចនេប៊ូក្នេសា និងមហេសីរបស់ស្ដេចណាប៊ូនីដូស (Nabonidus )
ឬក៏ (៣).ជាមហេសីរបស់ណាប៊ូនីដូស ប៉ុន្តែ មិនមែនជាបុត្រីរបស់ស្ដេច
នេប៊ូក្នេសា ។
**៥:១១** *នៅក្នុងរាជ្យនៃព្រះបិតាទ្រង់* នៅពេលនោះគឺស្ថិតនៅក្នុងឆ្នាំ ៥៣៩
មុនគ.ស ហើយស្ដេចនេប៊ូក្នេសាសុគតនៅក្នុងឆ្នាំ ៥៦២ ។
**៥:១៦** *អ្នកគ្រប់គ្រងទី ៣* មើល ឧ.៧ និងការពន្យល់ ។
**៥:១៧** *អំណោយទានរបស់ព្រះករុណា សូមទុកសំរាប់ព្រះអង្គទ្រង់* មើល
លប ១៤:២៣, ២ពវ ៥:១៦ និងការពន្យល់ ។
**៥:២១** *ទ្រង់ត្រូវ . . . ដូចជាចិត្តរបស់សត្វ* មើល ៤:២៥ និងការពន្យល់ ។
*ដរាបដល់ទ្រង់បានជ្រាប* មើលការពន្យល់ ៤:២៥ ។ *ព្រះដ៏ខ្ពស់បំផុតទ្រង់
គ្រប់គ្រងលើរាជ្យរបស់មនុស្ស* មើលសេចក្ដីផ្ដើម ត្រង់ចំណុច ខ្លឹមសារខាង

ស្មៅដូចជាគោ ហើយត្រូវទទឹកដោយសន្សើមពីលើមេឃ
ដរាបដល់ទ្រង់បានជ្រាបថា ព្រះដ៏ខ្ពស់បំផុតទ្រង់គ្រប់គ្រង
លើរាជ្យរបស់មនុស្ស[ត] ហើយថា ទ្រង់តាំងអ្នកណាឡើង
ឱ្យគ្រប់គ្រងនោះក៏តាមព្រះហឫទ័យ[ថ] ២២តែទ្រង់ដែលជា
ព្រះរាជបុត្រ ឱបេលសាសារអើយ ទោះបើទ្រង់បានជ្រាប
រឿងទាំងនោះហើយក៏ដោយ គង់តែទ្រង់មិនបានបន្ទាប[ទ]
ព្រះទ័យដែរ ២៣គឺទ្រង់បានលើកអង្គទ្រង់ឡើង ទាស់នឹង[ធ]
ព្រះអម្ចាស់នៃស្ថានសួគ៌វិញ ហើយគេបាននាំយកពែង
របស់ព្រះវិហារនៃព្រះមកចំពោះទ្រង់ ឯទ្រង់នឹងអស់ពួក
សេនាបតីរបស់ទ្រង់ ព្រមទាំងភរិយា[ន] និងពួកស្រីអ្នកម្នាង
ទាំងអស់គ្នា បានផឹកស្រាទំពាំងបាយជូរពីពែងទាំងនោះ
ក៏បានសរសើរដល់អស់ទាំងព្រះ ដែលធ្វើពីប្រាក់ មាស
លង្ហិន ដែក ឈើ នឹងថ្ម ដែលមើលមិនឃើញ ស្តាប់ មិនឮ
ក៏មិនដឹងអ្វីសោះ[ប] តែចំណែកព្រះដែលក្តាប់ ដង្ហើមជីវិត[ផ]
ព្រះករុណានៅក្នុងព្រះហស្ត ហើយអស់ទាំងផ្លូវរបស់
ព្រះករុណាជារបស់ផងព្រះនោះដែរ នោះព្រះករុណាមិន
បានលើកដំកើងព្រះអង្គនោះសោះ[ព] ២៤យ៉ាងនោះបានជា
ចាត់ប្រើចំណែកដៃនេះពីចំពោះព្រះមក ហើយមានកត់
អក្សរនេះទុកនៅ ២៥ឯពាក្យដែលបានសរសេរនោះ គឺថា
"មេនេ មេនេ ទេកិលអ៊ូផារសិន" ២៦ហើយនេះជាសេចក្តី
បកប្រែនៃពាក្យទាំងនោះ "មេនេ"ប្រែថា ព្រះបានរាប់
ថ្ងៃ[ភ]នៃរាជ្យទ្រង់ ហើយបានធ្វើឱ្យផុតទៅ[ម] ២៧"ទេកិល"
ប្រែថា ទ្រង់បានត្រូវថ្លឹងនៅជញ្ជីង[យ] ឃើញថាខ្វះខាត[រ]
២៨ឯ"ពេរេស"នោះប្រែថា នគររបស់ទ្រង់ត្រូវបែងចែក
ឱ្យដល់ពួកសាសន៍មេឌី[ល] និងសាសន៍ពើស៊ីហើយ[វ] ។
២៩នោះបេលសាសារទ្រង់ក៏ចេញបង្គាប់ ហើយគេ
បំពាក់ដានីយ៉ែលដោយសំពត់ពណ៌ស្វាយ ព្រមទាំងខ្សែ
មាសនៅកផង[ស] រួចក៏ប្រកាសប្រាប់ពីដំណើរលោកថា ត្រូវ
បានជាអ្នកគ្រប់គ្រងទី៣ក្នុងនគរ[ហ] ៣០នៅយប់នោះឯង
បេលសាសារ[ឡ] ជាស្តេច[អ]សាសន៍ខាល់ដេទ្រង់ត្រូវគេធ្វើ
គុត[ក] ៣១ហើយដារីយុស[ខ] ជាសាសន៍មេឌី[គ] ដែលមានព្រះជន្ម
ប្រមាណ៦២ឆ្នាំហើយ ក៏ទទួលគ្រងរាជ្យឡើង ។

## លោកដានីយ៉ែលនៅក្នុងរូងសិង្ហ

**៦** ១ឯដារីយុស[ក]ទ្រង់សព្វព្រះទ័យនឹងតាំងចៅហ្វាយខេត្ត[ខ]
១២០នាក់ឡើង ឱ្យត្រួតត្រាលើនគរ ជាពួកអ្នកដែលត្រូវ
ផ្សាយចេញទៅនៅពេញក្នុងនគរទាំងមូល ២ហើយឱ្យមាន
អធិបតី៣នាក់ត្រួតលើចៅហ្វាយទាំងនោះ ដើម្បីឱ្យគេរាប់
រៀបប្រាប់[គ]ដល់ពួក៣នាក់នោះ ប្រយោជន៍មិនឱ្យស្តេចត្រូវ
ខ្វះខាតអ្វីឡើយ ឯដានីយ៉ែល[ឃ] លោកក៏នៅក្នុងពួកអធិបតី
នោះដែរ ៣រួចមកដានីយ៉ែលបានត្រឡប់ជាកំពូលលើ
ពួកអធិបតី និងពួកចៅហ្វាយទាំងប៉ុន្មាន ដ្បិតលោកមាន
វិញ្ញាណយ៉ាងស្រួចស្រាល់ ហើយស្តេចទ្រង់គិតនឹងតាំង
លោកឱ្យត្រួតលើនគរទាំងមូល[ង]។
៤ដូច្នេះពួកអធិបតី និងពួកចៅហ្វាយក៏ស្វែងរកហេតុ[ច]
ពីដំណើររាជការផែនដី ឱ្យទាស់នឹងដានីយ៉ែល តែគេរក
ឱកាស ឬកំហុសអ្វីមិនបានឡើយ ក៏មិនឃើញមានថ្លស់
ធ្លោយ ឬទោសទាស់អ្វីដែរ ពីព្រោះលោកជាមនុស្សស្មោះ
ត្រង់ ៥ដូច្នេះ ពួកអ្នកទាំងនោះប្រឹក្សាគ្នាថា យើងនឹងរក
ឱកាសទាស់នឹងឈ្មោះដានីយ៉ែលនេះមិនបានឡើយ វៀរ
តែរកបានខាងឯក្រិត្យវិន័យរបស់ព្រះនៃវាប៉ុណ្ណោះ[ឆ] ៦ពួក

គ អស ១៣:៣ **៦:១** ក ដយ ៥:៣១ ខ នអ ១:១ **៦:២** គ អរ ៤:២២ ឃ ដយ ២:៤៨–៤៩ **៦:៣** ង លប ៤១:៤១ នអ ១០:៣ ដយ ១:២០ ៥:១២–១៤ **៦:៤** ច យរ ២០:១០ **៦:៥** ឆ កច ២៤:១៣–១៦

**៥:២១** ត អគ ១៧:២៤ ថ ដយ ៤:១៦–១៧,៣៥
**៥:២២** ទ នក ១០:៣
**៥:២៣** ធ អស ១៤:១៣ យរ ៥០:២៩ ន យរ ៤៤:៩ ប ទដ ១១៥:៤–៨ ហព ២:១៩ វវ ៩:២០ ផ យប ១២:១០ កច ១៧:២៨ ព យប ៣១:៤ អស ១៣:១១ យរ ១០:២៣ ៤៨:២៦
**៥:២៦** ភ យរ ២៧:៧ ម អស ១៣:៦
**៥:២៧** យ យប ៦:២ រ ទដ ៦២:៩
**៥:២៨** ល អស ១៣:១៧ វ យរ ២៧:៧ ៥០:៤១–៤៣ ដយ ៦:២៨
**៥:២៩** ស លប ៤១:៤២ ហ ដយ ២:៦
**៥:៣០** ឡ ខ.១ អ យ ៥០:៣៥ ក អស ២១:៩ យរ ៥១:៣១
**៥:៣១** ខ យរ ៥០:៤១ ដយ ៦:១ ៩:១ ១១:១

របស់ព្រះវិហារនៃព្រះមកប្រើ(ខ.២៣ក) ហើយ (៣).ទ្រង់បានសរសើរតម្កើងដល់រូបព្រះ ដែលជាការមិនលើកតម្កើងព្រះនាមព្រះ (ខ.២៣) ។

**៥:២៣** ការនិយាយអំពីភាពផ្ទុយគ្នារវាងព្រះក្លែងក្លាយនៃជាតិសាសន៍ទាំងឡាយ និងព្រះពិតតែមួយ គឺជាខ្លឹមសារសំខាន់នៅក្នុងព្រះគម្ពីរហោរា(មើលឧទាហរណ៍នៅក្នុង ៣:២៩ និងការពន្យល់, អស ៤១:៥–១០ ៤៤:៦–២៣ យរ ១០:១–១៦ អគ ៨–៩ ហស ១៣:១–៨ ហព ២:១៨–២០ និង ទដ ១១៥:២–៨ ១៣៥:១៥–១៨) ។

**៥:២៤** *ចាត់ប្រើចំណែកដៃនេះ* នៅចុងបញ្ចប់នៃការបកស្រាយថ្វាយស្តេច លោកដានីយ៉ែលបានទូលឱ្យស្តេចបានជ្រាបថា ព្រះទ្រង់ជាប្រភពនៃអក្សរដែលសរសេរដោយដៃនោះ ។

**៥:២៧** *ត្រូវថ្លឹងនៅជញ្ជីង* គឺថ្លឹងតាមមាត្រដ្ឋានរបស់ព្រះ(មើល ៣១:៦ និងការពន្យល់, ទដ ៦២:៩)។

**៥:២៨** *ត្រូវបែងចែក... សាសន៍ពើស៊ី* ពាក្យពើស៊ីគឺមានន័យថា ត្រូវបានបែងចែក ។ *ពួកសាសន៍មេឌី និងសាសន៍ពើស៊ី* គឺជានគរទីពីរដែលមាននិយាយនៅក្នុងបទទំនាយនៅក្នុងជំពូក ២ (មើលសេចក្តីផ្តើមត្រង់ចំណុចអ្នកនិពន្ធ កាលបរិច្ឆេទ និងភាពជាក់លាក់) ។

**៥:២៩** *ខ្សែមាសនៅកផង* គឺជានិមិត្តរូបនៃអំណាច (មើល លប ៤១:៤២ និងការពន្យល់) ។

**៥:៣០** *នៅយប់នោះឯង* មើល សភ ៦:១៥ និងការពន្យល់, លក ១២:២០ ។

**៥:៣១** *ដារីយុស ជាសាសន៍មេឌី* ឈ្មោះម្យ៉ាងទៀតប្រហែលជា គូបារូ (Gubaru) ដែលតាមសិលាចារិករបស់ចក្រភពបាប៊ីឡូន គឺជាអ្នកដែលស្តេចស៊ីរូសបានចាត់ ឱ្យគ្រប់គ្រងទឹកដីដែលបានដណ្តើមកាន់កាប់ថ្មីៗ ។ ឬម្យ៉ាងទៀតពាក្យ "ដារីយុស ជាសាសន៍មេឌី" អាចជាឈ្មោះរាជបល្ល័ង្ករបស់ស្តេចស៊ីរូសនៅចក្រភពបាប៊ីឡូន(មើល ១របៈ ៥:២៦ និងការពន្យល់)។ *ទទួលគ្រងរាជ្យឡើង* នៅឆ្នាំ ៥៣៩ មុនគ.ស "ក្បាលមាស"(២:៣៨)លែងមានតទៅទៀត ដូចដែលបានទាយទុកនៅក្នុង ២:៣៩ ។

អធិបតី និងពួកចៅហ្វាយទាំងនោះ ក៏នាំគ្នាចូលទៅគាល់
ស្តេច ទូលដូច្នេះថា បពិត្រព្រះរាជាដារីយុស សូមឱ្យទ្រង់
បានប្រកបដោយព្រះជន្មចំរើនជាយឺនយូរតទៅ[ជ] ៧ពួក
អធិបតីក្នុងនគរ ពួកចៅហ្វាយខេត្ត ពួកភូឈួយ ពួក
បាឡាត់ និងពួកចៅហ្វាស្រុក[ឈ] បានជំនុំព្រមគ្នា ចង់តាំង
ព្រះរាជឱង្ការ១ច្បាប់ គឺជាសេចក្តីបំរាមយ៉ាងតឹងរឹងថា
បើអ្នកណានឹងសូមអ្វីពីព្រះណាឬពីមនុស្សណាក៏ដោយ វៀរ
តែសូមពីព្រះរាជាក្នុងរវាង៣០ថ្ងៃ នោះនឹងត្រូវបោះចោល
ទៅក្នុងរូងសិង្ហ[ញ] ៨បពិត្រព្រះរាជា ដូច្នេះសូមទ្រង់តាំង
ច្បាប់ហើយចុះហត្ថលេខានៅច្បាប់នោះ ប្រយោជន៍មិនឱ្យ
ផ្លាស់ប្រែបាន តាមរបៀបច្បាប់នៃសាសន៍មេឌី និងសាសន៍
ពើស៊ី ដែលនឹងផ្លាស់ប្តូរមិនបានឡើយ[ដ] ៩ដូច្នេះស្តេច
ដារីយុសទ្រង់ក៏ចុះហត្ថលេខា នៅសំបុត្រជាសេចក្តីបំរាម
នោះ ។

១០កាលដានីយែលបានដឹងថា សំបុត្រនោះបានចុះ
ហត្ថលេខាហើយ នោះលោកក៏ចូលទៅក្នុងផ្ទះរបស់លោក
(រីឯបង្អួចនៃបន្ទប់របស់ លោកខាង[ឋ]ក្រុងយេរូសាឡិមក៏
នៅចំហ) លោកលុតជង្គង់[ឌ]ចុះអធិស្ឋាន ហើយអរព្រះគុណ
ដល់ព្រះរបស់លោក១ថ្ងៃ៣ដង ដូចជាកាលពីមុន[ឍ] ១១ឯ
ពួកអ្នកទាំងនោះ គេក៏មូលគ្នាមកឃើញដានីយ៉ែលកំពុង
តែអធិស្ឋាន ទូលអង្វរនៅចំពោះព្រះនៃលោក[ណ] ១២រួចគេ
ក៏ចូលទៅជិតទូលនឹងស្តេច ពីដំណើរពាក្យបំរាមរបស់
ទ្រង់ថា ទ្រង់បានចុះហត្ថលេខា នៅច្បាប់បំរាប់ហើយថា
បើអ្នកណានឹងសូមអ្វីពីព្រះណា ឬពីមនុស្សណាក៏ដោយ
លើកតែសូមពីព្រះរាជា ក្នុងរវាង៣០ថ្ងៃ នោះនឹងត្រូវបោះ
ចោលទៅក្នុងរូងសិង្ហមែនឬមិនមែន ស្តេចទ្រង់មានបន្ទូល
តបថា សេចក្តីនោះពិតមែនហើយ តាមរបៀបច្បាប់នៃ
សាសន៍មេឌី និងសសន៍ពើស៊ី ដែលនឹងផ្លាស់ប្តូរមិនបាន
ឡើយ[ត] ១៣នោះគេក៏ទូលដល់ស្តេចថា ឈ្មោះដានីយ៉ែល
នោះ ដែលជាពួកឈ្លើយសាសន៍យូដា[ថ] មិនអើពើ[ទ]ចំពោះ
ទ្រង់ទេ ឱព្រះករុណាអើយ ក៏មិនយកចិត្តទុកដាក់នឹងច្បាប់
បំរាម ដែលទ្រង់បានចុះហត្ថលេខាហើយ នោះដែរ គឺចេះ
តែអធិស្ឋាន សូម១ថ្ងៃ៣ដងវិញ ១៤កាលស្តេចបានឮពាក្យ
ទាំងនោះ ទ្រង់ក៏ទោមនស្សជាខ្លាំង[ធ] ហើយតាំងព្រះទ័យ
នឹងរកដោះដានីយ៉ែលឱ្យរួច ទ្រង់ខំរកផ្លូវជួយឱ្យលោក រួច
ដរាបដល់ថ្ងៃលិច ១៥ខណនោះពួកអ្នកទាំងនោះក៏មូលគ្នា
មកឯស្តេចទូលថា បពិត្រព្រះរាជា សូមទ្រង់ជ្រាបថា តាម
ច្បាប់នៃសោសន៍មេឌី នឹងសាសន៍ពើស៊ី ច្បាប់ណា ឬបំរាម
ណា ដែលស្តេចបានតាំងទុកហើយ នោះនឹងផ្លាស់ប្តូរមិន
បានឡើយ[ន] ។

១៦ដូច្នេះ ស្តេចទ្រង់ក៏ចេញបង្គាប់ ហើយគេនាំយក
ដានីយ៉ែលទៅបោះចុះក្នុងរូងសត្វសិង្ហទៅ[ប] ស្តេចទ្រង់មាន
បន្ទូលដល់ដានីយ៉ែលថា ព្រះនៃអ្នកដែលអ្នកគោរពជានិច្ច
ទ្រង់នឹងជួយសង្គ្រោះ[ផ]អ្នកជាពិត ១៧គេក៏យកថ្ម១មកបិទ
សន្ធប់មាត់រូង ស្តេចទ្រង់ក៏ប្រថាប់ត្រា[ព]ព្រះទំរង់ ហើយនឹង
ចិញ្ចៀនត្រារបស់សេនាបតីទ្រង់ផង ដើម្បីមិនឱ្យមានអ្វី
ផ្លាស់ប្តូរពីដំណើរដានីយ៉ែលឡើយ ១៨រួចទ្រង់វិលទៅឯ
ព្រះរាជវាំងវិញ ក៏អត់ព្រះស្ងោយ[ភ]អស់១យប់នោះ ពួក
មហោរីមិនបានប្រគំថ្វាយទ្រង់ទេឯទ្រង់ក៏ផ្ទំមិនលក់ដែរ[ម] ។

១៩ស្តេចទ្រង់តើនឡើងពីព្រលឹមស្រាង យាងទៅឯរូង
សិង្ហជាប្រញាប់ ២០កាលជិតដល់រូងហើយ នោះទ្រង់
ស្រែកហៅដានីយ៉ែល ដោយសំឡេងយ៉ាងកណ្តុក សួរថា
ឱដានីយ៉ែល ជាអ្នកបំរើនៃព្រះដ៏មានព្រះជន្មរស់អើយ តើ
ព្រះនៃអ្នក ដែលអ្នកគោរពជានិច្ចនោះ ទ្រង់អាចនឹងជួយ
ឱ្យអ្នករួចពីសិង្ហបានឬទេ[យ] ២១នោះដានីយ៉ែលលោកទូល
តបថាបពិត្រព្រះករុណា សូមទ្រង់បានប្រកបដោយព្រះជន្ម
ចំរើនជាយឺនយូរចុះ[រ] ២២ព្រះនៃទូលបង្គំទ្រង់បានចាត់
ទេវតារបស់ទ្រង់[ល] ឱ្យមកបិទមាត់សិង្ហទាំងអស់[វ] វាមិនបាន
ប្រទូស្តដល់ទូលបង្គំទេ ពីព្រោះនៅចំពោះព្រះ នោះមិន
ឃើញជាទូលបង្គំមានទោសអ្វីឡើយ[ស] ហើយបពិត្រព្រះ
ករុណា នៅចំពោះទ្រង់ ទូលបង្គំក៏មិនបានធ្វើខុសអ្វីដែរ

**៦:៦** ជ នហ ២:៣
**៦:៧** ឈ ដយ ៣:២
ញ ទដ ៥៩:៣
៦៤:២–៦ ដយ ៣:៦
**៦:៨** ដ នអ ១:១៩
**៦:១០** ឋ ១ពវ
៨:២៩ ឌ ទដ ៩៥:៦
ឍ មថ ៦:៦ កច
៥:២៩
**៦:១១** ណ ១ពវ
៨:៤៨–៥០ ទដ
៥៥:១៧ ១ថន
៥:១៧–១៨
**៦:១២** ត នអ ១:១៩
ដយ ៣:៨–១២
**៦:១៣** ថ អក
១៤:១៤ ដយ ២:២៥
ទ នអ ៣:៨
**៦:១៤** ធ មក ៦:២៦
**៦:១៥** ន នអ ៨:៨
**៦:១៦** ប ឧ.៧
ផ យប ៥:១៩ ទដ
៣៧:៣៩–៤០
៩៧:១០
**៦:១៧** ព មថ
២៧:៦៦
**៦:១៨** ភ ២សយ
១២:១៧ ដយ ១០:៣
ម នអ ៦:១
**៦:២០** យ ដយ
៣:១៧
**៦:២១** រ នហ ២:៣
ដយ ៣:៩
**៦:២២** ល លប
៣២:១ ដយ ៣:២៨
វ ឧ.២៧ ទដ ៩១:១១–១៣ ហព ១១:៣៣ ស កច ១២:១១ ២ធថ ៤:១៧

**៦:៧** ពួកអ្នកផ្សំគំនិតទាំងនោះបាននិយាយកុហកថា ពួកអ្នកធ្វើការរដ្ឋបាលទាំងអស់សុទ្ធតែគាំទ្រ សេចក្តីសំណើរឱ្យចេញច្បាប់នោះ ពីព្រោះពួកគេជឿថា លោកដានីយ៉ែល(ដែលមិនបានដឹងអំពីសំណើរនោះទាល់តែសោះ) គឺជាអ្នកនាំមុខគេនៅក្នុងចំណោមអ្នករដ្ឋបាលទាំងបីនាក់នោះ ។ *រូងសិង្ហ* គឺជារូងដែលមានច្រកចូលខាងលើតូចមួយ(ខ.១៧) ហើយអ្នកទោសដែលគេបានទំលាក់ចូលទៅ គឺមិនអាចគេចចេញមកក្រៅបានទេ ។

**៦:៨,១២** *ច្បាប់នៃសាសន៍មេឌី និងសាសន៍ពើស៊ី ដែលនឹងផ្លាស់ប្តូរមិនបាន* មើលការពន្យល់ នអ ១:១៩, ៨:៨ ។

**៦:១០** *ខាងក្រុងយេរូសាឡិម* មើល របា ៦:៣៨–៣៩ ។ *១ ថ្ងៃ ៣ ដង* ធៀបនឹង ទដ ៥៥:១៧ ។ *អធិស្ឋាន . . . ដូចជាកាលពីមុន* ការគំរាមនៃសេចក្តីស្លាប់មិនអាចធ្វើឱ្យលោកដានីយ៉ែលបញ្ឈប់ការអធិស្ឋានជាធម្មតាបានទេ ។

**៦:១៣** *មិនអើពើចំពោះទ្រង់ទេ* មើល ខ.២២,២៤ ។

**៦:១៦** *ដែលអ្នកគោរពជានិច្ច* មើល ១កថ ១៥:៥៨ និងការពន្យល់ ។

**៦:១៨** *ទ្រង់ក៏ផ្ទំមិនលក់ដែរ* មើល ២:១ នអ ៦:១ និងការពន្យល់ ។

**៦:២០** *តើព្រះនៃអ្នក . . . អាចនឹងជួយឱ្យអ្នក . . . ឬទេ* មើល ៣:១៧ និងការពន្យល់ ។

២៣ដូច្នេះស្ដេចទ្រង់មានព្រះទ័យរីករាយក្រៃលែង ក៏ចេញ
បង្គាប់ឱ្យយោងយកដានីយ៉ែលចេញពីរូងមក គេក៏យោង
យកដានីយ៉ែលចេញមក ហើយឥតឃើញមានរបួស[ហ]ណា
នៅខ្លួនលោកឡើយ ពីព្រោះលោកបានទុកចិត្ត[ឡ]នឹងព្រះនៃ
លោក ។
២៤រួចស្ដេចទ្រង់ចេញបង្គាប់ ហើយគេក៏នាំពួកអ្នក
ដែលប្ដឹងចោទដានីយ៉ែល មកបោះគេទៅក្នុងរូងសិង្ហវិញ[អ]
គឺទាំងខ្លួនគេ និងប្រពន្ធកូនគេផង[ក] ហើយសិង្ហទាំងឡាយ
ក៏មានអំណាចលើគេ បានទាំងបំបាក់ឆ្អឹងគេឱ្យខ្ទេចខ្ទីទៅ
មុនដែលគេធ្លាក់ទៅដល់បាតរូងផង[ខ] ។
២៥រួចមក ស្ដេចដារីយុស ទ្រង់ចេញព្រះរាជសាសន៍
ផ្ញើដល់បណ្ដាជនទាំងឡាយ ព្រមទាំងសាសន៍ដទៃ និង
មនុស្សគ្រប់ភាសា[គ]ដែលនៅលើផែនដីទាំងមូលថា សូមឱ្យ
សេចក្ដីសុខបានចំរើនដល់អ្នករាល់គ្នាចុះ[ឃ] ២៦យើងចេញ
បង្គាប់ឱ្យមនុស្សទាំងឡាយ នៅពេញក្នុងអាណាចក្ររបស់
យើង បានញាប់ញ័រហើយកោតខ្លាច[ង] នៅចំពោះព្រះនៃ
ដានីយ៉ែល[ច] ដ្បិតទ្រង់ជាព្រះដ៏មានព្រះជន្មរស់នៅ[ឆ] ក៏ស្ថិត
ស្ថេរនៅអស់កល្បរៀងតទៅ[ជ] រាជ្យទ្រង់នឹងមិនត្រូវបំផ្លាញ
ឡើយ ហើយអំណាចគ្រប់គ្រងរបស់ទ្រង់ និងនៅជាប់
ដរាបដល់ចុងបំផុត[ឈ] ២៧ទ្រង់ប្រោសឱ្យរួច ហើយក៏ជួយ
សង្គ្រោះ[ញ] ទ្រង់ធ្វើទីសំគាល់ និងការអស្ចារ្យ[ដ]នៅស្ថានសួគ៌
ហើយនៅផែនដី គឺទ្រង់ដែលបានប្រោសឱ្យដានីយ៉ែល
រួចពីអំណាចសិង្ហ[ឋ] ។
២៨យ៉ាងនោះ ដានីយ៉ែលនេះ ក៏ចំរើនឡើងនៅក្នុង
រាជ្យរបស់ដារីយុសហើយក្នុងរាជ្យរបស់ស៊ីរូស[ឌ] ជាសាសន៍
ពើស៊ីដែរ[ឍ] ។

**៦:២៣** ហ ដយ ៣:២៧ ឡ ១រប ៥:២០ អស ១២:២ **៦:២៤** អ ចទ ១៩:១៨–១៩ នអ ៧:៩–១០ ទដ ៥៤:៥ ក ចទ ២៤:១៦ ២ពវ ១៤:៦ ខ អស ៣៨:១៣ **៦:២៥** គ ដយ ៣:៤ ឃ ដយ ៤:១ **៦:២៦** ង ទដ ៥:៧ ច នអ ៨:១៧ ទដ ៩៩:១–៣ ដយ ៣:២៩ ឆ យស ២:១១ ៣:១០ ជ យរ ១០:១០ ដយ ១២:៧ វវ ១:១៨ ឈ ដយ ២:៤៤ **៦:២៧** ញ ដយ ៣:២៩ ដ ដយ ៤:៣ ឋ ខ.២២ **៦:២៨** ឌ ២រប ៣៦:២២ ដយ ១:២១ ឍ ដយ ៥:២៨ **៧:១** ក ដយ ៥:១ ខ អគ ៤០:២ គ ដយ ១:១៧ ឃ ទដ ៤:៤ ដយ ៤:១៣ ង យរ ៣៦:៤ **៧:២** ច អគ ៣៧:៩ ដយ ៨:៨ ១១:៤

## លោកដានីយ៉ែលសុបិន្តឃើញសត្វសាហាវទាំងបួន

**៧** ១នៅក្នុងឆ្នាំដំបូង នៃបេសាសារ[ក] ជាស្ដេចក្រុង
បាប៊ីឡូន នោះដានីយ៉ែលលោកយល់សប្ដិ ហើយឃើញ
ការជាក់ស្ដែង[ខ]នៅក្នុងខួរ[គ] កំពុងដេកលើដំណេក[ឃ] រួចក៏
កាត់[ង]សប្ដិនោះទុក ហើយប្រាប់ដោយសង្ខេបតាមសេចក្ដី
ដែលសំខាន់ៗ ២ដានីយ៉ែលលោកបរិយាយថា ខ្ញុំបានឃើញ
ការជាក់ស្ដែងនៅពេលយប់ដូច្នេះ ខ្យល់ទាំង៤នៅលើ
អាកាស[ច]ធ្លាក់ចុះមកលើមហាសមុទ្រ ៣រួចមានសត្វធំ៤[ឆ]
ឡើងចេញពីសមុទ្រមក មានសណ្ឋានផ្សេងៗគ្នា ៤សត្វទី១
ដូចជាសិង្ហ[ជ] ហើយមានស្លាបជាស្លាបឥន្ទ្រី[ឈ] ខ្ញុំបានគន់
មើលដរាបដល់ចំអេងស្លាបវាត្រូវដកចេញ ហើយវាត្រូវ
លើកឡើងផុតពីដី ក៏ដាក់ឱ្យឈរជើង២ដូចជាមនុស្ស ហើយ
បានឱ្យវាមានចិត្តរបស់មនុស្សដែរ ៥រួចឃើញសត្វ១ទៀត
ជាសត្វទី២ មានសណ្ឋានជាខ្លាឃ្មុំ ក៏ឈរចំខែងពាំឆ្អឹងជំនីរ
៣នៅក្នុងមាត់ខាំដោយធ្មេញ ហើយមានគេប្រាប់ដល់វាថា
ចូរក្រោកឡើង ហើយត្របាក់ស៊ីសាច់ឱ្យច្រើនៗទៅ[ញ]
៦ក្រោយមក ខ្ញុំគន់មើលទៅឃើញសត្វ១ទៀត មានសណ្ឋាន
ជាខ្លារខិន[ដ] ឯនៅលើខ្នងវាមានស្លាប៤នៃសត្វហើរ ក៏មាន
ក្បាល៤ដែរ ហើយមានអំណាចគ្រប់គ្រងប្រគល់ដល់វា
៧លំដាប់នោះ ក្នុងការជាក់ស្ដែង[ឋ]ពេលយប់ ខ្ញុំក៏ឃើញសត្វ
ទី៤ដែលគួរស្ញែម គួរស្ញែងខ្លាច ហើយមានកំឡាំងយ៉ាង

វវ ៧:១ **៧:៣** ឆ វវ ១៣:១ **៧:៤** ជ ២ពវ ២៤:១ ទដ ៧:២ យរ ៤:៧ វវ ១៣:២ ឈ អគ ១៧:៣ **៧:៥** ញ ដយ ២:៣៩ **៧:៦** ដ វវ ១៣:២ **៧:៧** ឋ អគ ៤០:២

**៦:២៣** *ឥតឃើញមានរបួសណានៅខ្លួនលោក* មើល ៣:២៧ ។ *លោកបានទុកចិត្តនឹងព្រះនៃខ្លួន* សត្វសិង្ហទាំងនោះមានការស្រេកឃ្លានយ៉ាងខ្លាំង (ខ.២៤) ប៉ុន្តែព្រះអម្ចាស់ទ្រង់នៅតែអាចជួយដល់ជីវិតលោកដានីយ៉ែលដែលមានជំនឿលើទ្រង់(មើល ៣:៨ និងការពន្យល់) ។

**៦:២៤** *គឺទាំងខ្លួនគេ និងប្រពន្ធកូនគេផង* ការកាត់ទោសនេះគឺតាមប្រពៃណីយរបស់សាសន៍ពើស៊ី (ធៀបនឹង យស ៧:២៤ និងការពន្យល់) ។

**៧:១** *នៅក្នុងឆ្នាំដំបូង នៃបេលសាសារ* ប្រហែលនៅឆ្នាំ ៥៥៣ មុនគ.ស ។ ហេតុការណ៍នៅក្នុងជំពូក ៧ កើតឡើងមុនឆ្នាំជំពូក ៥ ។

**៧:២** *មហាសមុទ្រ* គឺសំដៅទៅលើ ពិភពលោកដែលមានទៅដោយនគរ និងជាតិសាសន៍ជាច្រើន(មើល ខ.៣,១៧) ។

**៧:៤–៧** សត្វសិង្ហដែលមានស្លាបឥន្ទ្រីគឺជា និមិត្តរូបតំណាងឱ្យចក្រភពបាប៊ីឡូនថ្មី(មើល លប ៣:២៤ និងការពន្យល់) ។ នៅក្នុងផ្នែកផ្សេងទៀតនៃ ខ.៤ ប្រហែលជាឆ្លុះបញ្ចាំងអំពីការបន្ទាបខ្លួនរបស់ស្ដេចនេប៊ូក្នេសា ដូចដែលបាននិយាយនៅក្នុងជំពូក ៤ ។ សត្វខ្លាឃ្មុំ(ខ.៥) "ដែលពាំឆ្អឹងជំនីរ" គឺសំដៅទៅលើ អំណាចដ៏ខ្លាំងរបស់សាសន៍ពើស៊ី នៅក្នុងសម្ព័ន្ធមិត្រមេដូ–ពើស៊ី (Medo-Persia) ។ ឆ្អឹងជំនីរទាំងបីនោះអាចសំដៅទៅលើការកាន់កាប់ទឹកដីសំខាន់ៗបីគឺ ទឹកដីលីឌា(ឆ្នាំ ៥៤៦ មុនគ.ស) បាប៊ីឡូន(ឆ្នាំ ៥៣៩ មុនគ.ស) និងអេស៊ីព្ទ(ឆ្នាំ ៥២៥ មុនគ.ស)។ ខ្លារខិនដែលមានស្លាបបួន(ខ.៦) គឺជានិមិត្តរូបនៃការធ្វើសង្គ្រាមវាយកាន់កាប់ដ៏ឆាប់រហ័សរបស់ស្ដេចអ័រឡេចក្សានឌ័រ (ឆ្នាំ ៣៣៤–៣៣០ មុនគ.ស) ហើយក្បាលទាំងបួនគឺសំដៅទៅលើការបែងចែកទឹកដីរបស់ទ្រង់បន្ទាប់ពីចក្រភពរបស់ទ្រង់ត្រូវដួលរលំបន្ទាប់ពីការសុគតរបស់ទ្រង់នៅឆ្នាំ ៣២៣ មុនគ.ស(មើល ៨:២២) ដែលទឹកដីទាំងនោះមានដូចជា ទឹកដីម៉ាសេដូន ដែលត្រូវគ្រប់គ្រងដោយស្ដេចអង់ទីប៉ាទ័រ (Antipater) ទឹកដីក្រិកដែលត្រូវគ្រប់គ្រងដោយ ស្ដេចកាស–សានឌ័រ (Cassander) ទឹកដីស៊ីរី ដែលត្រូវគ្រប់គ្រងដោយស្ដេចសេលើស៊ីឌទី១(Seleucid I) ទឹកដីបរិសុទ្ធ និងទឹកដីអេស៊ីព្ទដែលគ្រប់គ្រងដោយស្ដេចផ្ដោលេមី ទី១ (Ptolemy I) ។ សត្វសាហាវទី៤ (ខ.៧) ដែលមានអំណាចពិបាកទប់ទល់ខ្លាំងជាង ចក្រភពមុនៗ គឺសំដៅទៅលើចក្រភពរ៉ូម៉ាំង(ធៀប ១១:៣០ និងការពន្យល់) ។ ស្នែងទាំងដប់របស់វាគឺសំដៅទៅលើម្រាមទាំងដប់ដែលមាននិយាយក្នុង ២:៤១–៤២ (មើលការពន្យល់ ២:៣២–៤៣) ។

ក្រែលែង មានធ្មេញដែក[ឱ]ធំៗវា ត្របាក់លេបលំអិតកំទេច
ហើយជាន់ឈ្លី[ឲ]សំណល់[ណ] ដោយជើងសត្វនោះ ផ្សេងពី
អស់ទាំងសត្វដែលមកជាមុននោះ ក៏មានស្នែង១០[ត] ៨ខ្ញុំបាន
ពិចារណាមើលស្នែងទាំងនោះ ក៏ឃើញមានស្នែង១ទៀត
ជាស្នែងតូច[ថ] ដុះឡើងនៅជាកណ្ដាល នៅមុខវាស្នែង
ចាស់៣ត្រូវរដកចេញទាំងឫស ហើយឃើញថា ស្នែង១
នោះមានភ្នែក ដូចជាភ្នែកនៃមនុស្ស[ទ] ក៏មានមាត់កំពុង
តែពោលយ៉ាងធំ[ធ]។

៩ខ្ញុំក៏គន់មើល ទាល់តែមានគេយកបល្ល័ង្ក មកតាំង
ហើយព្រះដ៏មានព្រះជន្មពីចាស់បុរាណ[ន]ទ្រង់ក៏គង់លើ[ប] ព្រះ
ពស្ត្រទ្រង់សស្គុសដូចហិមៈ[ផ] ហើយព្រះកេសនៅព្រះសិរ
ទ្រង់ ក៏សដូចរោមចៀមយ៉ាងស្អាត[ព] ឯបល្ល័ង្កទ្រង់នោះ
សុទ្ធតែជាអណ្ដាតភ្លើង ហើយកង់[ភ]នៃបល្ល័ង្កនោះ ក៏ជា
ភ្លើងឆេះដែរ ១០មានដូចជាភ្លើង[ម]ហូរចេញពីចំពោះទ្រង់[យ]
មកមានទាំងពាន់ទាំងពាន់ដែលគោរពដល់ទ្រង់ ហើយ
ទាំងម៉ឺនទាំងសែនក៏ឈរនៅចំពោះទ្រង់ នោះការវិនិច្ឆ័យ
បានរៀបចំជាស្រេច ឯបញ្ជីទាំងប៉ុន្មាន[រ]បានបើកឡើង
ហើយ ១១ខណៈនោះ ខ្ញុំបានគន់មើល ដោយព្រោះសំឡេង
របស់ស្នែង១ ដែលពោលយ៉ាងធំ[ល]នោះ ក៏មើលដរាបដល់
សត្វនោះត្រូវសំឡាប់បង់ ហើយខ្មោចវាត្រូវបំផ្លាញ ព្រម
ទាំងប្រគល់ដល់ភ្លើងឱ្យឆេះផង[វ] ១២រីឯសត្វឯទៀតទាំង
នោះអំណាចគ្រប់គ្រងរបស់វាត្រូវដកចេញ តែជីវិតវា
បានតទៅអស់១ពេលដល់កំណត់ ។

១៣ខ្ញុំក៏ឃើញ ក្នុងការជាក់ស្ដែងពេលយប់នោះ មាន១
អង្គដូចជាមនុស្សជាតិ[ស]ទ្រង់យាងមក[ហ]ក្នុងពពកឮដ៏អាកាស[ឡ]
ទ្រង់យាងមកឯព្រះដ៏មានព្រះជន្មពីបុរាណនោះហើយមាន
គេនាំចូលទៅចំពោះព្រះអង្គ ១៤នោះបានប្រទានឱ្យទ្រង់
មានអំណាចគ្រប់គ្រង[អ] និងសិរីល្អ ព្រមទាំងឱ្យមានរាជ្យផង
ដើម្បីឱ្យបណ្ដាជនទាំងឡាយ សាសន៍ដទៃ និងមនុស្សគ្រប់
ភាសា បានគោរពដល់ទ្រង់[ក] ឯអំណាចគ្រប់គ្រងរបស់ ទ្រង់
នោះក៏ស្ថិតស្ថេរនៅអស់កល្ប ឥតដែលកន្លងបាត់ឡើយ
ហើយរាជ្យ[ខ]របស់ទ្រង់នឹងបំផ្លាញមិនបានផង[គ]។

## ការកាត់ស្រាយសុបិន្ត

១៥ឯខ្ញុំ ដានីយ៉ែល ចិត្តខ្ញុំកើតមានសេចក្ដីតប់ប្រមល់
នៅក្នុងខ្លួន ហើយការជាក់ស្ដែងក្នុងខួរខ្ញុំ ក៏នាំឱ្យខ្ញុំវិតក្ក
ព្រួយ[ឃ] ១៦ខ្ញុំក៏អែបចូលទៅជិតម្នាក់ដែលឈរនៅទីនោះ
សួរន័យដ៏ពិតរបស់ការទាំងនោះ អ្នកនោះក៏ប្រាប់ដល់ខ្ញុំ
ព្រមទាំងទំលាយន័យសេចក្ដី[ង]ឱ្យខ្ញុំយល់ផង ១៧ឯសត្វធំ
ទាំង៤នោះ គឺស្ដេច៤អង្គដែលនឹងកើតឡើងនៅផែនដី
១៨តែពួកបរិសុទ្ធ[ច]របស់ព្រះដ៏ខ្ពស់បំផុត គេនឹងទទួលរាជ្យ[ឆ]
ហើយនឹងបានរាជ្យនោះជារបស់ផងខ្លួនជានិច្ច គឺអស់
កល្បតទៅ[ជ] ១៩នោះខ្ញុំចង់ដឹងន័យពិត ពីសត្វទី៤ដែល
ផ្សេងពីសត្វឯទៀតនោះ ជាសត្វដែលគួរស្ញែងខ្លាចជាខ្លាំង
មានធ្មេញដែក នឹងក្រចកលង្ហិន ដែលត្របាក់លេប លំអិត
កំទេច ហើយជាន់ឈ្លីសំណល់ដោយជើង ២០ក៏ចង់ដឹង
ពីដំណើរស្នែង[ឈ]១០ នៅលើក្បាលវា និងពីស្នែង១នោះ

**៧:៧** ឱ ដយ ២:៤០ ឲ ដយ ៨:១០ ណ ដយ ៨:៧ ត វវ ១២:៣ **៧:៨** ថ ដយ ៨:៩ ទ វវ ៩:៧ ធ ទដ ១២:៣ វវ ១៣:៥–៦ **៧:៩** ន ខ.២២ ប ១ពវ ២២:១៩ ២របា ១៨:១៨ មថ ១៩:២៨ វវ ៤:២ ២០:៤ ផ មថ ២៨:៣ ព វវ ១:១៤ ភ អគ ១:១៥ ១០:៦ **៧:១០** ម ទដ ៥០:៣ ៩៧:៣ អស ៣០:២៧ យ ចទ ៣៣:២ ទដ ៦៨:១៧ យដ ១:១៤ វវ ៥:១១ រ នក ៣២:៣២ ទដ ៥៦:៨ វវ ២០:១១–១៥ **៧:១១** ល វវ ១៣:៤–៦ វ វវ ១៩:២០ **៧:១៣** ស អគ ១:៥ ២:១ មថ ៨:២០ វវ ១:១៣ ១៤:១៤ ហ អស ១៣:៦ សផ ១:១៤ មឡ ៣:២ ៤:១ ឡ ចទ ៣៣:២៦ វវ ១:៧

**៧:១៤** អ មថ ២៨:១៨ ក ទដ ៧២:១១ ១០២:២២ ខ អស ១៦:៥ គ ដយ ២:៤៤ ហព ១២:២៨ វវ ១១:១៥ **៧:១៥** ឃ យប ៤:១៥ ដយ ៤:១៩ **៧:១៦** ង ដយ ៨:១៦ ៩:២២ សក ១:៩ **៧:១៨** ច ទដ ១៦:៣ ឆ ទដ ៤៩:១៤ ជ អស ៦០:១២–១៤ លក ១២:៣២ ហព ១២:២៨ វវ ២:២៦ ២០:៤ **៧:២០** ឈ វវ ១៧:១២

**៧:៧** *ដែក* មើល ២:៤០–៤៣ និងការពន្យល់ ២:៣២–៤៣ ។ *ស្នែង១០* នៅត្រង់ចំណុចនេះ គឺបង្ហាញអំពីអំណាចរបស់សត្វសាហាវនោះ (មើលការពន្យល់ ១:១២) ។

**៧:៨** *ស្នែងមួយទៀត ជាស្នែងតូច* គឺសំដៅទៅលើពួកទទឹងនឹងព្រះគ្រីស្ទ ឬអំណាចលោកិយ ដែលមាននៅក្នុងលក្ខណៈរបស់ពួកទទឹងនឹងព្រះគ្រីស្ទ ។ *មាត់កំពុងតែពោលយ៉ាងធំ* មើល ១១:៣៦ ២ថន ២:៤ និងការពន្យល់ ។ វវ ១៣:៥–៦ ។

**៧:៩** *ពីចាស់បុរាណ* គឺសំដៅទៅលើព្រះ ។ *ព្រះកេសនៅព្រះសិរទ្រង់ក៏សដូចរោមចៀមយ៉ាងស្អាត* មើល វវ ១:១៤ និងការពន្យល់ ។ *បល្ល័ង្កទ្រង់ . . . កង់* អរ ២:១៥–២១, ២៦–២៧ ។

**៧:១០** *ទាំងពាន់ . . . ទាំងម៉ឺន* សូមមើល ១សយ ១៨:៧ និងការពន្យល់ ។ *ការវិនិច្ឆ័យបានរៀបចំ . . . បញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ* លោកយ៉ូហានក៏បាននិយាយអំពីការជំនុំជម្រះបែបដូច្នេះដែរ ដែលមាននៅក្នុង វវ ២០:១២ ។

**៧:១៣** *ដូចជាមនុស្សជាតិ* មើល មក ៨:៣១ និងការពន្យល់, វវ ១:១៣ ។ នៅត្រង់ចំណុចនេះគឺសំដៅទៅលើ ព្រះមែស៊ីដែលជា កូនមនុស្ស ហើយពាក្យកូនមនុស្សនេះព្រះយេស៊ូវទ្រង់បានប្រើសម្រាប់អង្គទ្រង់ ។ ទ្រង់នឹងឡើងគ្រងរាជ្យ ជាអ្នកដឹកនាំលោកិយទាំងមូល (ដែលពីមុនត្រូវនគរទាំងបួនគ្រប់គ្រង ដោយមិនត្រឹមត្រូវ ហើយប្រឆាំងនឹងនគរព្រះ) ហើយនគររបស់ទ្រង់ "នឹងបំផ្លាញមិនបានឡើយ" (ខ.១៤) ទោះជានៅក្នុងលោកិយ ឬនៅស្ថានសួគ៌ក៏ដោយ ។ *យាងមកក្នុងពពកឮដ៏អាកាស* មើល មក ១៤:៦២ និងការពន្យល់, វវ ១:៧ ។

**៧:១៦** *ម្នាក់ដែលឈរនៅទីនោះ* គឺទេវតា ។

**៧:១៧** *ស្ដេចបួនអង្គ* មើល ខ.៣៨–៤០ និងការពន្យល់ ២:៣២–៤៣ ។ *ផែនដី* គឺសំដៅទៅលើលោកិយដែលមានទៅដោយប្រទេស និងជាតិសាសន៍ជាច្រើន ហើយនៅក្នុង ខ.២–៣ ប្រើពាក្យ "មហាសមុទ្រ"។

**៧:១៨** *ពួកបរិសុទ្ធ* ឯកសិទ្ធិពិសេសនិងខ្ពង់ខ្ពស់ នឹងមានសម្រាប់អ្នកដើរតាមព្រះគ្រីស្ទ នៅក្នុងនគរនៃព្រះមែស៊ី (មើល មថ ១៩:២៨–២៩ និងមើល លក ២២:២៩–៣០ វវ ១:៦ ២០:២–៦ និងការពន្យល់)។ *នឹងទទួលរាជ្យ* មើល ខ.២២,២៧ និងការពន្យល់ ។

ដែលដុះឡើងជាខាងក្រោយ ហើយមានស្នែង៣មុនដួល
នៅមុខវា គឺជាស្នែង១នោះដែលមានភ្នែក និងមាត់ពោល
យ៉ាងធំ ហើយឫកពាក៏មាំជាងស្នែងឯទៀត[ញ] ២១ខ្ញុំគន់
មើលទៅ ឃើញស្នែងនោះឯង បានច្បាំងនឹងពួកបរិសុទ្ធ
ហើយក៏ឈ្នះផង[ដ] ២២ដរាបដល់ព្រះដ៏មានព្រះជន្មពីបុរាណ
បានយាងមក នោះការវិនិច្ឆ័យបានប្រគល់ដល់ពួកបរិសុទ្ធ
របស់ព្រះដ៏ខ្ពស់បំផុត ហើយកំណត់ក៏មកដល់ ដែលពួក
បរិសុទ្ធត្រូវបានរាជ្យជារបស់ផងខ្លួន[ឋ] ។
២៣អ្នកនោះក៏ប្រាប់ថា សត្វទាំង៤នោះ គឺជានគរទី៤
នៅលើផែនដី ដែលនឹងត្រូវជាផ្សេងពីអស់ទាំងនគរ ហើយ
នឹងត្របាក់លេបផែនដីទាំងមូល ក៏នឹងជាន់ពង្រាបដោយ
ជើង ព្រមទាំងលំអិតកំទេចផង[ឌ] ២៤ឯស្នែងទាំង១០នោះ[ឍ]
គឺនឹងមានស្តេច១០អង្គកើតឡើងពីនគរនោះ ហើយក្រោយ
មកនឹងមាន១ទៀតកើតឡើង ដែលនឹងប្លែកពីស្តេចមុនៗ
ក៏នឹងទំលាក់ស្តេច៣អង្គនោះចុះ ២៥ស្តេចនោះនឹងពោល
ពាក្យទាស់នឹងព្រះដ៏ខ្ពស់បំផុត[ណ] ហើយនឹងធ្វើទុក្ខបៀតបៀន
ដល់ពួកបរិសុទ្ធ[ត]នៃព្រះដ៏ខ្ពស់បំផុតដែរ ព្រមទាំងគិតបំផ្លាស់
ពេលកំណត់[ថ] និងច្បាប់ផង ហើយគេនឹងត្រូវប្រគល់ទៅក្នុង
កណ្តាប់ដៃនៃស្តេចនោះ នៅ១ខួប២ខួបហើយកន្លះខួប[ទ]
២៦ប៉ុន្តែការវិនិច្ឆ័យនឹងបានរៀបចំជាស្រេច ហើយគេនឹង
ដកអំណាចវាចេញ ឱ្យត្រូវបំផ្លាញ[ធ] ហើយសាបសូន្យទៅ
ដរាបដល់ចុងបំផុត ២៧នោះរាជ្យ និងអំណាចគ្រប់គ្រង
ព្រមទាំងភាពរុងរឿងឧត្តមនៃអស់ទាំងនគរ[ន]នៅក្រោម
មេឃទាំងមូល និងបានប្រគល់ ដល់បណ្តាជន ជាពួក
បរិសុទ្ធ[ប]នៃព្រះដ៏ខ្ពស់បំផុត[ផ] រាជ្យរបស់ទ្រង់ស្ថិតស្ថេរនៅ
អស់កល្បជានិច្ច[ព] ហើយគ្រប់ទាំងអំណាចគ្រប់គ្រងនឹងត្រូវ
គោរព[ភ]ដល់ទ្រង់ ហើយស្តាប់បង្គាប់ផង ២៨ដំណើរនោះ
បានចប់ត្រឹមប៉ុណ្ណោះ ចំណែកខ្ញុំ ដានីយ៉ែល គំនិតខ្ញុំ[ម]បាននាំ
ឱ្យខ្ញុំវិតក្កព្រួយជាខ្លាំង[យ] ភាពខ្ញុំក៏ផ្លាស់ប្រែទៅ[រ] តែខ្ញុំបាន
ទុកដំណើរនោះនៅតែក្នុងចិត្តទេ ។

## លោកដានីយ៉ែលឃើញចៀមឈ្មោល១ និងពពែ១

**៨** ១នៅឆ្នាំទី៣ ក្នុងរាជ្យនៃស្តេចបេលសាសារ[ក] នោះមាន
ការជាក់ស្តែងលេចមក ឱ្យដានីយ៉ែលខ្ញុំឃើញ[ខ] គឺក្រោយ
ការជាក់ស្តែង១ដែលខ្ញុំបានឃើញពីមុននោះ ២រីឯកាលខ្ញុំ
ឃើញការជាក់ស្តែង១នេះ នោះខ្ញុំនៅក្នុងព្រះរាជវាំងត្រង់
ក្រុងស៊ូសាន[គ]ក្នុងខេត្តអេឡាំ[ឃ] តែក្នុងការជាក់ស្តែងនោះ ខ្ញុំ
ឃើញថា ខ្ញុំនៅឯមាត់ទន្លេអ៊ូឡាយវិញ ៣ខណនោះ ខ្ញុំបាន
ងើបភ្នែកឡើង[ង] មើលទៅឃើញមានចៀមឈ្មោល១[ច]ឈរ
នៅក្បែរទន្លេ វាមានស្នែង២ ហើយស្នែងទាំង២ក៏វែង
មានតែ១វែងជាង ឯស្នែង១ដែលវែងជាង បានដុះឡើងជា
ខាងក្រោយ ៤ខ្ញុំក៏ឃើញចៀមឈ្មោលនោះកំពុងតែទន្រ្ទាន
ទៅទិសខាងលិច ទិសខាងជើង និងទិសខាងត្បូង ឥតមាន
សត្វណាមួយអាចនឹងទប់ទល់បានឡើយ ក៏គ្មានណាអាច
នឹងជួយ ឱ្យរួចពីកណ្តាប់ដៃវាបានដែរ[ឆ] គឺវាបានធ្វើតាម
តែអំពើចិត្ត[ជ] ហើយក៏ដំកើងខ្លួនឡើងផង ។
៥កាលខ្ញុំកំពុងតែពិចារណា នោះឃើញមានពពែ
ឈ្មោល១មកពីទិសខាងលិច ហោះពេញលើផែនដីទាំង
ដុំមូល ឥតពាល់ប៉ះនឹងដីឡើយ ពពែនោះមានស្នែង១
នៅកណ្តាលភ្នែកទាំង២ ជាស្នែងគួរពិចពិលមើល ៦វាក៏
មកដល់ចៀមឈ្មោលមានស្នែង២ ដែលខ្ញុំឃើញឈរនៅ
ក្បែរទន្លេនោះ ក៏ស្ទុះទៅលើ ដោយសេចក្តីឃោរឃៅនៃ
កំឡាំងវា ៧ខ្ញុំឃើញវាចូលទៅជិតចៀមឈ្មោល មាន

**៧:២០** ញ វវ ១៣:៥-៦ **៧:២១** ដ វវ ១៣:៧ **៧:២២** ឋ មក ៨:៣៥ **៧:២៣** ឌ ដយ ២:៤០ **៧:២៤** ឍ វវ ១៧:១២ **៧:២៥** ណ អស ៣៧:២៣ ដយ ១១:៣៦ ត វវ ១៦:៦ ថ ដយ ២:២១ មក ១:១៥ លក ២១:៨ កច ១:៦-៧ ទ ដយ ៨:២៤ ១២:៧ វវ ១១:២ **៧:២៦** ធ វវ ១៩:២០ **៧:២៧** ន អស ១៤:២ ប ១កថ ៦:២ ផ លប ១៤:១៨ ព ២សយ ៧:១៣ ទដ ១៤៥:១៣ ដយ ២:៤៤ ៤:៣៤ លក ១:៣៣ វវ ១១:១៥ ២២:៥ ភ ទដ ២២:២៧ ៧២:១១ ៨៦:៩ **៧:២៨** ម ទដ ១៣:២ យ អស ២១:៣ ដយ ៤:១៩ រ យប ៤:១៥ **៨:១** ក ដយ ៥:១ ខ ដយ ១:១៧ **៨:២** គ អរ ៤:៩ នអ ២:៨ ឃ លប ១០:២២ **៨:៣** ង ដយ ១០:៥ ច វវ ១៣:១១ **៨:៤** ឆ អស ៤១:៣ ជ ដយ ១១:៣,១៦

**៧:២៤** *ស្តេច១០អង្គ* គ្រប់ទាំងអំណាចនយោបាយ(មើលការពន្យល់ ១:១២, មើល វវ ១៧:១២-១៤)ដែលនឹងលេចឡើងពីនគរទីបួន ប៉ុន្តែមិនមែនសុទ្ធតែលិចឡើងក្នុងពេលដំណាលគ្នាទេ(មើល ២:៤៤ និងការពន្យល់)។ *ស្តេច៣អង្គ* គឺស្តេចមួយចំនួននៅក្នុងចំណោមស្តេចទាំង១០អង្គ ។ ពាក្យថា ៣ គឺបញ្ជាក់អំពីចំនួនបន្តិចបន្តួច ហើយមិនច្បាស់លាស់(មើល នក ៣:១៨ និងការពន្យល់) ។

**៧:២៥** *ស្តេចនោះ* មើល ខ.៨ និងការពន្យល់ ។ *នៅ១ខួប២ខួប ហើយកន្លះខួប* គឺមានន័យថា នៅ ១ ឆ្នាំ ២ ឆ្នាំ ហើយកន្លះឆ្នាំ ។

**៧:២៧** *ប្រគល់ ដល់បណ្តាជន ជាពួកបរិសុទ្ធ* គឺដើម្បីជាប្រយោជន៍ដល់ពួកគេ ។ ព្រះ និងព្រះមែស៊ីទ្រង់នឹងសោយរាជ្យ(មើល វវ ១៨-២២)។

**៨:១-១២:១៣** ជំពូកទាំងនេះ គឺត្រូវបានសរសេរជាភាសាហេព្រើរ (មើលការពន្យល់ ២:៤)។

**៨:១** *ឆ្នាំទី៣* គឺប្រហែលជានៅឆ្នាំ ៥៥១ មុនគ.ស ។ ហេតុការណ៍ដែលនិយាយនៅក្នុង ជំពូក ៨ គឺបានកើតឡើងមុន ជំពូក ៥ ។ *គឺក្រោយការជាក់ស្តែង១ ដែលខ្ញុំបានឃើញពីមុន* គឺពីឆ្នាំមុន(មើល ៧:១ និងការពន្យល់)។

**៨:២** *ព្រះរាជវាំងត្រង់ក្រុងស៊ូសាន ក្នុងខេត្តអេឡាំ* មើលការពន្យល់ អរ ៤:៩ នអ ១:២ ។

**៨:៣** ចៀមឈ្មោលនោះគឺជាតំណាងឱ្យ ចក្រភពមេដូ-ពើស៊ី (Medo-Persia,ខ.២០)។ ស្នែងដែលវែងជាងមួយគូរនោះ គឺឆ្លុះបញ្ចាំងអំពីអំណាចរបស់ចក្រភពពើស៊ី ជាអំណាចដែលខ្លាំងជាងគេនៅសម័យនោះ (មើល ៧:៥ និងការពន្យល់ ៧:៤-៧)។

**៨:៥** សត្វពពែឈ្មោលនោះគឺសំដៅទៅលើចក្រភពក្រិក ហើយ"ស្នែងគួរពិចពិលរមិលមើល" គឺជាស្តេចអ័ឡេចក្សាន្តឌ័រ ដែលទ្រង់ "ជាស្តេចដើមដំបូង" (ខ.២១)។

សេចក្ដីមួម៉ោដាលឡើង ក៏ជល់ចៀមនោះ បំបាក់ស្នែង
ទាំង២ទៅ ចៀមនោះមិនអាចនឹងឈរនៅមុខវាបានទេ
គឺត្រូវដួលចុះដល់ដី ហើយពពែបានជាន់ឈ្លីទៅ[ឈ] ឥតមាន
អ្នកណាមួយអាចនឹងជួយចៀមឱ្យរួចបានឡើយ[ញ] 8ពពែ
ឈ្មោលនោះក៏ដំកើងខ្លួនយ៉ាងក្រៃលែង កាលបានមាន
កំឡាំងហើយ នោះស្នែងធំត្រូវបាក់ទៅ[ដ] រួចមានស្នែង៤
គួរពិចពិលមើល បានដុះឡើងជំនួស ស្នែងទាំងនោះ
កន្ទែកទៅទិសទាំង៤[ឋ] ។
9រួចមកមានស្នែង១តូច[ឌ]ដុះចេញពីស្នែង១នោះ ក៏ធំ
ឡើងយ៉ាងក្រៃលែង មានអំណាចទៅទិសខាងត្បូង ទិស
ខាងកើត និងខាងស្រុកដ៏ឧត្ដមដែរ[ឍ] 10វាក៏លើកខ្លួនឡើង
រហូតដល់[ណ]ពួកពលបរិវារនៅលើមេឃ ហើយក៏ទំលាក់
ពួកនោះខ្លះ និងផ្កាយខ្លះចុះមកដល់ដី[ត] រួចជាន់ឈ្លីដោយ
ជើង[ថ] 11អើ វាដំកើងខ្លួនឡើង រហូតដល់អ្នកជាកំពូល
បណ្ដាច់[ទ] នៃពួកពលបរិវារ[ធ]ផង ក៏លើកចោលការថ្វាយ
ដង្វាយដុត ដែលត្រូវថ្វាយជានិច្ច[ន]ពីទ្រង់ចេញ ព្រមទាំងធ្វើ
ឱ្យទីបរិសុទ្ធរបស់ទ្រង់អាប់ឱនទៅ[ប] 12ឯពួកពលបរិវារក៏
ត្រូវប្រគល់ទៅព្រមគ្នានឹងការថ្វាយដង្វាយដុតជានិច្ច ដោយ
ព្រោះអំពើរំលង វាបានបោះចោលសេចក្ដីពិតចុះដល់ដី ក៏
ធ្វើតាមតែអំពើចិត្ត ហើយបានចំរើនផង[ផ] 13លំដាប់នោះ
ខ្ញុំឮអ្នកបរិសុទ្ធម្នាក់[ព]កំពុងតែនិយាយ ហើយមានអ្នកបរិសុទ្ធ
១ទៀតសួរដល់អ្នកដែលនិយាយនោះថា តើដល់កាលណា
ទើបបានសំរេចការជាក់ស្ដែង[ភ] ពីការថ្វាយដង្វាយ ដុតជា
និច្ច និងពីអំពើរំលងដែលធ្វើឱ្យខូចបង់នោះ ដើម្បីនឹង
ប្រគល់ទីបរិសុទ្ធ ហើយនឹងពួកពលបរិវារឱ្យត្រូវជាន់ឈ្លី[ម]
ទៅ 14អ្នកនោះក៏ប្រាប់មកខ្ញុំថា គឺដរាបដល់បានកន្លង
២៣00ព្រឹក និងល្ងាចទៅ នោះទើបទីបរិសុទ្ធនឹងបានស្អាត
ឡើងវិញ[យ] ។

## ការកាត់ស្រាយការជាក់ស្ដែងដែលបានឃើញនោះ

15កាលខ្ញុំ គឺដានីយ៉ែលខ្ញុំនេះ បានឃើញការជាក់ស្ដែង
នោះហើយ[រ] ខ្ញុំក៏រកចង់យល់ន័យ នោះឃើញមានភាព
ដូចជាមនុស្សឈរនៅមុខខ្ញុំ[ល] 16ហើយខ្ញុំឮសំឡេងមនុស្សពី
កណ្ដាលទន្លេអ៊ូឡាយ[វ] ហៅមកថា កាព្រីយ៉ែល អើយ[ស]
ចូរឱ្យមនុស្សនេះយល់ការជាក់ស្ដែងចុះ[ហ] 17ដូច្នេះ លោក
ក៏ចូលមកជិតកន្លែងដែលខ្ញុំឈរនៅ កាលលោកមកដល់
ហើយ នោះខ្ញុំភ័យញ័រ ក៏ទំលាក់ខ្លួនផ្កាប់មុខចុះ[ឡ] តែលោក
និយាមកខ្ញុំថា កូនមនុស្សអើយ ចូរយល់ចុះ ដ្បិតការជាក់
ស្ដែងនេះសំរាប់គ្រាខាងចុងបំផុត[អ] 18កាលលោកកំពុង

**៨:៧** ឈ ដយ ៧:៧ ញ ដយ ១១:១១,១៦ **៨:៨** ដ ២របា ២៦:១៦–២១ ដយ ៥:២០ ឋ ដយ ៧:២ វវ ៧:១ **៨:៩** ឌ ដយ ៧:៨ ឍ អក ២០:៦ ដយ ១១:១៦ **៨:១០** ណ អស ១៤:១៣ ត វវ ៨:១០ ១២:៤ ថ ដយ ៧:៧ **៨:១១** ទ ខ.២៥ ធ ដយ ១១:៣៦–៣៧ ន អក ៤៦:១៣–១៤ ប ដយ ១១:៣១ ១២:១១ **៨:១២** ផ អស ៤៨:១ **៨:១៣** ព ចទ ៣៣:២ ដយ ៤:២៣ ភ ដយ ១២:៦ ម អស ២៨:១៨ លក ២១:២៤ វវ ១១:២ **៨:១៤** យ ដយ ១២:១១–១២ **៨:១៥** រ ខ.១ ល អក ២:១ ដយ ១០:១៦–១៨ **៨:១៦** វ ខ.២ ស ដយ ៩:២១ លក ១:១៩ ហ ដយ ៧:១៦ **៨:១៧** ឡ អក ១:២៨ ៤៤:៤ ដយ ២:៤៦ វវ ១:១៧ អ ខ.១៩ហាព ២:៣

**៨:៧** *បំបាក់ស្នែងទាំង២ទៅ* គឺចក្រភពក្រិកបានបំផ្លាញចក្រភព មេដូ–ពើស៊ី (Medo-Persia) ។

**៨:៨** *ស្នែងធំត្រូវបាក់* គឺនៅពេលដែលស្ដេចអ័ឡេចក្សាន្ដឌ័រត្រូវសុគត នៅពេលអំណាចរបស់ទ្រង់បានឡើងដល់ថ្នាក់កំពូល (ឆ្នាំ ៣២៣ មុនគ.ស.) ។ *ស្នែង៤គួរពិចពិលមើល* ស្នែងទាំងបួន និង "ក្បាលទាំងបួន" នៅក្នុង ៧:៦ គឺស្មើគ្នា (មើលការពន្យល់ ៧:៤–៧) ។

**៨:៩–១២** "ស្នែង១តូច" (ខ.៩) ស្នែងនេះមិនដុះចេញពីស្នែងទាំងដប់របស់ចក្រភពទីបួននោះទេ (ដូចដែលនិយាយនៅក្នុង ៧:៨) ប៉ុន្ដែ គឺចេញពីស្នែងមួយក្នុងចំណោមស្នែងទាំងបួនរបស់ចក្រភពទីបី ។ "ស្នែងតូចមួយ"នោះ គឺជាស្ដេច អាន់ទីយ៉ូកូស ទីបួន នៃអេពីផានេស (Antiochus of Epiphanes) ស្ដេចនេះបានព្យាយាមយ៉ាងមុះមុតនៅក្នុងការបំផ្លាញជំនឿរបស់ពួកសាសន៍យូដា នៅក្នុងរយះពេលបួនឆ្នាំចុងក្រោយ នៃការកាន់អំណាចរបស់ខ្លួន (ឆ្នាំ ១៦៨–១៦៤ មុនគ.ស) ។ ស្ដេចអង្គនេះគឺមិនខុសពីសត្វសាហាវនៅថ្ងៃចុងក្រោយទេ (ពួកទទឹងព្រះគ្រីស្ទ) ដែលនៅក្នុង ៧:៨ គឺជាស្នែង"តូច"។ ស្ដេចអាន់ទីយ៉ូកូសបានពង្វាតទឹកដីកាន់កាប់នគរអ៊ីស្រាអែល ដែលជា "ស្រុកដ៏ឧត្ដម" (ខ.៩, មើល យរ ៣:១៩ និងការពន្យល់) ហើយបានយកឈ្នះលើអ្នកកោតខ្លាចព្រះនៅក្នុងនគរនោះ ហើយពួកគេជាច្រើននាក់បានស្លាប់ដើម្បីសេចក្ដីជំនឿរបស់ពួកគេ (ខ.១០ បាននិយាយអំពី "ពួកពលបរិវារនៅលើមេឃ" សំដៅទៅលើអ្នកទាំងនោះ, មើល ខ.១២) ។ បន្ទាប់មកស្ដេចអង្គនេះក៏បានតាំងខ្លួនឡើងស្មើនឹងព្រះ ("អ្នកជាកំពូលបណ្ដាច់នៃពួកពលបរិវារ" ខ.១០) ហើយបញ្ជាឱ្យបញ្ឈប់ការថ្វាយដង្វាយទៅព្រះជាប្រចាំថ្ងៃ ។ ប៉ុន្ដែក្រោយមក កងទ័ពរបស់លោក យ៉ូដាស ម៉ាកាប៊ី (Judas Machabee) បានរំដោះបានទីក្រុងយេរូសាឡិមមកវិញ ហើយបានចាប់ផ្ដើមបើកព្រះវិហារឡើងវិញ (ខ.១៤) ថ្វាយដល់ព្រះអម្ចាស់ (នៅខែធ្នូ ឆ្នាំ ១៦៥ មុនគ.ស) ដែលការនេះគឺជាប្រភពនៃពិធីបុណ្យហានូកាហ៍ (Feast of Hanukah, មើល យហ ១0:២២ និងការពន្យល់) ដែលសាសន៍យូដានៅតែប្រារព្ធធ្វើរហូតមកដល់សព្វថ្ងៃ ។

**៨:១៣** *អ្នកបរិសុទ្ធម្នាក់* គឺទេវតា ។

**៨:១៤** មានការថ្វាយដង្វាយពីរដងក្នុងមួយថ្ងៃ សម្រាប់ធ្វើជាយញ្ញបូជាជារៀងរាល់ថ្ងៃ (សូមមើល ៩:២១ នក ២៩:៣៨–៣៩ និងការពន្យល់) ជាតំណាងឱ្យការលោះបាបដល់សាសន៍អ៊ីស្រាអែលទាំងមូល ។ ចំនួន "២៣00ព្រឹក និងល្ងាច"ប្រហែលជាសំដៅទៅលើចំនួននៃយញ្ញបូជា ដែលត្រូវថ្វាយពីរដង ក្នុងមួយថ្ងៃជារៀងរាល់ថ្ងៃ អស់រយះពេល ១១៥0ថ្ងៃ ដែលជាចន្លោះពេល នៃការបង្អាប់អាសនានៃព្រះអម្ចាស់ ដោយស្ដេចអាន់ទីយ៉ូកូស និងការស្អាងអាសនាឡើងវិញ ដោយលោកយ៉ូដាស ម៉ាកាប៊ី នៅឆ្នាំ ១៦៥ មុនគ.ស ។

**៨:១៦** *កាព្រីយ៉ែល* គឺជាឈ្មោះមហាទេវតា (មើល លក ១:១៩ និងការពន្យល់) ។

**៨:១៧** *កូនមនុស្សអើយ* គឺខុសពី "១អង្គដូចមនុស្សជាតិ" នៅក្នុង ៧:១៣ (មើលការពន្យល់ក្នុងខនេះ និងការពន្យល់ អក ២:១) ។

និយាយមកខ្ញុំ នោះខ្ញុំក៏លង់ស្មារតីទៅ មានមុខផ្កាប់ដល់ដី[ក]
តែលោកពាល់ខ្ញុំធ្វើឱ្យខ្ញុំឈរឡើង[ខ] ១៩ក៏ប្រាប់ខ្ញុំថា នែ អញ
នឹងឱ្យឯងដឹង ពីការដែលត្រូវមកក្នុង ពេលចុងបំផុតនៃ
សេចក្ដីក្នាន់ក្នាញ់[គ] ដ្បិតការជាក់ស្ដែងនេះ សំដៅទៅគ្រា[ឃ]
ចុងបំផុត[ង] ២០ឯចៀមឈ្មោលមានស្នែង២ ដែលឯងបាន
ឃើញ នោះគឺជាស្ដេចសាសន៍មេឌី និងស្ដេចសាសន៍ពើស៊ី[ច]
២១ហើយពពែឈ្មោលរោមស្រមូវ នោះគឺជាស្ដេចសាសន៍
ក្រេកវិញ[ឆ] ចំណែកស្នែង១ធំដែល នៅជាកណ្ដាលភ្នែក
ទាំង២នោះ គឺជាស្ដេចដើមដំបូង[ជ] ២២ឯដំណើរដែលស្នែង
នោះត្រូវបាក់ ហើយមានស្នែង៤ ដុះឡើងជំនួស នោះគឺជា
នគរ៤ ដែលនឹងកើតឡើង ពីសាសន៍នោះ តែមិនមែនមាន
អំណាចដូចស្ដេចដើមនោះទេ ២៣លុះដល់គ្រាក្រោយបង្អស់
នៃនគរទាំងនោះ ក្នុងកាលដែលពួកអ្នកប្រព្រឹត្តរំលងបាន
គ្រប់ចំនួនហើយ នោះនឹងមានស្ដេច១កើតឡើង ដែលមាន
ទឹកមុខសាហាវ ជាអ្នកយល់ក្នុងប្រស្នា ២៤ស្ដេចនោះនឹង
មានអំណាចយ៉ាងខ្លាំងក្រៃលែង តែមិនមែនដោយអំណាច
របស់ខ្លួនទេ វានឹងបំផ្លាញយ៉ាងអស្ចារ្យ ក៏នឹងធ្វើកើតការ
ទាំងអស់ដែលគិតធ្វើ វានឹងបំផ្លាញទាំងពួកខ្លាំងពូកែ និងពួក
បរិសុទ្ធបង់[ឈ] ២៥ហើយដោយគំនិតវាងវៃរបស់វា នោះវា
នឹងធ្វើឱ្យកលឧបាយ[ញ]បានប្រយោជន៍នៅដៃខ្លួន រួចនឹងមាន
ចិត្តលើកដំកើងខ្លួន ព្រមទាំងបំផ្លាញមនុស្សយ៉ាងច្រើន
ដែលនៅដោយសុខស្រួល សូម្បីតែព្រះអម្ចាស់ លើអស់ទាំង
ព្រះអម្ចាស់[ដ] គង់តែវានឹងហ៊ានឈរទទឹងទាស់ដែរ តែវា
នឹងត្រូវបាក់បែកទៅ ឥតមានដៃអ្នកណាធ្វើឡើយ[ឋ] ២៦ឯការ
ជាក់ស្ដែងពីព្រឹកនឹងល្ងាចទាំងប៉ុន្មាន ដែលបានប្រាប់មក
នោះជាសេចក្ដីពិតហើយ[ឌ] ប៉ុន្តែត្រូវឱ្យឯងបំបិទ[ឍ]ការជាក់
ស្ដែងនេះទុកនៅ ដ្បិតគឺសំរាប់ពេលទៅមុខជាយូរលង់[ណ]
២៧នោះខ្ញុំដានីយ៉ែល ក៏ខ្សោះល្វើយ ហើយឈឺ[ត]នៅបួនដប់
ថ្ងៃ រួចខ្ញុំក្រោកឡើងទៅទទួលការរបស់ស្ដេចវិញ[ថ] ខ្ញុំក៏
អស្ចារ្យក្នុងចិត្ត[ទ]ពីដំណើរការជាក់ស្ដែងនោះ ប៉ុន្តែគ្មានអ្នក
ណាយល់សោះ ។

**៨:១៨** ក ដយ ១០:៩ ខ អក ២:២ ដយ ១០:១៦–១៨ សក ៤:១ **៨:១៩** គ អស ១០:២៥ ឃ ទដ ១០២:១៣ ង ហព ២:៣ **៨:២០** ច អគ ២៧:១០ **៨:២១** ឆ ដយ ១០:២០ ជ ដយ ១១:៣ **៨:២៤** ឈ ដយ ៧:២៥ ១១:៣៦ **៨:២៥** ញ ដយ ១១:២៣ ដ ដយ ១១:៣៦ ឋ ដយ ២:៣៤ ១១:២១ **៨:២៦** ឌ ដយ ១០:១ ឍ អស ៨:១៦ ២៩:១១ វវ ១០:៤ ២២:១០ ណ ដយ ១០:១៤ **៨:២៧** ត ដយ ១០:៨ ថ ដយ ២:៤៨ ទ អស ២១:៣ ដយ ៤:១៩ **៩:១** ក ដយ ៥:៣១ ខ អរ ៤:៦ **៩:២** គ ២របា ៣៦:២១ យរ ២៩:១០ សក ១:១២ ៧:៥

## សេចក្ដីអធិស្ឋានរបស់លោកដានីយ៉ែល

**៩** ១នៅឆ្នាំដំបូង ក្នុងរាជ្យនៃដារីយុស[ក] ព្រះរាជបុត្រា
អ័ហាស៊ូរុស[ខ] ជាពូជពង្សសាសន៍មេឌី ដែលគេបានតាំង
ឡើងជាស្ដេច ឱ្យគ្រប់គ្រងលើអាណាខេត្តរបស់សាសន៍
ខាល់ដេ ២គឺក្នុងឆ្នាំដំបូងនៃរាជ្យទ្រង់ នោះខ្ញុំ ដានីយ៉ែល
បានមើលគម្ពីរ ត្រង់កន្លែងដែលព្រះបន្ទូលនៃព្រះយេហូវ៉ា
បានមកដល់ហោរាយេរេមាពីចំនួនឆ្នាំដែលត្រូវកន្លងទៅ
ដើម្បីនឹងសំរេចការខូចបង់នៃក្រុងយេរូសាឡិម គឺគ្រប់
៧០[គ]ឆ្នាំ ៣នោះខ្ញុំបានតាំងចិត្តចំពោះព្រះដ៏ជាព្រះអម្ចាស់
ដើម្បីរកអធិស្ឋាន ហើយទូលអង្វរ ព្រមទាំងតមអត់[ឃ] ស្លៀក
សំពត់ធ្មៃ ហើយព្រលាំងផេះផង[ង] ៤ខ្ញុំបានអធិស្ឋានដល់
ព្រះយេហូវ៉ា ជាព្រះនៃខ្ញុំ ក៏លន់តួ[ច] ដោយពាក្យថា ឱព្រះ
អម្ចាស់ជាព្រះដ៏ធំ ហើយគួរស្ញែងខ្លាច[ឆ] ជាព្រះដែលរក្សា
សេចក្ដីសញ្ញា និងសេចក្ដីសប្បុរស[ជ] ចំពោះអស់អ្នក ដែល
ស្រឡាញ់ដល់ទ្រង់ ហើយកាន់តាមបញ្ញត្តទ្រង់អើយ ៥យើង
ខ្ញុំរាល់គ្នាបានធ្វើបាប[ឈ] បានប្រព្រឹត្តក្រវិចក្រវៀន[ញ] គឺបាន
ប្រព្រឹត្តអាក្រក់ហើយបះបោរ ព្រមទាំងងាកបែរចេញ[ដ]ពី

**៩:៣** ឃ ២របា ២០:៣ ង ២សយ ១៣:១៩ នហ ១:៤ យរ ២៩:១២ ដយ ១០:១២ យហ ៣:៦ **៩:៤** ច ១ពវ ៨:៣០ ឆ ចទ ៧:២១ ជ ចទ ៧:៩ ១ពវ ៨:២៣ **៩:៥** ឈ យរ ៨:១៤ ញ ទដ ១០៦:៦ ដ អស ៥៣:៦

**៨:២១** មើល ២.៥ និងការពន្យល់ ។

**៨:២២** មើល ២.៨ និងការពន្យល់ ។

**៨:២៣–២៥** វគ្គនេះគឺជាការពិពណ៌នាអំពី ស្ដេចអាន់ទីយ៉ូកូសទីបួន និងការឡើងកាន់អំណាចរបស់ស្ដេចនេះ ដោយប្រើផែនការអាក្រក់ និងការបោកបញ្ឆោត (ស្ដេចនេះមិនមែនជាអ្នកស្នងរាជ្យដ៏ត្រឹមត្រូវរបស់រាជវង្សសេលេ–ឡើស៊ីដទេ) ។

**៨:២៥** *មានចិត្តលើកដំកើងខ្លួន* ស្ដេចអាន់ទីយ៉ូកូសទីបួន បានហៅខ្លួនឯងថា អេពីផានេស (មានន័យថា "ព្រះទ្រង់បើកសម្ដែងច្បាស់") ។ *ព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់* គឺសំដៅទៅលើព្រះ ។ *ត្រូវបាក់បែកទៅ ឥតមានដៃអ្នកណាធ្វើឡើយ* ស្ដេចអាន់ទីយ៉ូកូសបានស្លាប់នៅឆ្នាំ ១៦៤ មុនគ.ស នៅតំបន់តាបេ (Tabae) នៅក្នុងចក្រភពពើស៊ី ដោយសារជម្ងឺ ឬគ្រោះថ្នាក់ ដែលជាការបំផ្លាញមកពីព្រះអម្ចាស់ ។

**៨:២៦** *ការជាក់ស្ដែងពីព្រឹកនិងល្ងាច* មើល ៤.១៤ និងការពន្យល់ ។

**៩:១** *នៅឆ្នាំដំបូង* ឆ្នាំ ៥៣៩ ដល់ ៥៣៨ មុនគ.ស ។ *ដារីយុស . . . សាសន៍មេឌី* មើល ៥:៣១ និងការពន្យល់ ។ *អ័ហាស៊ូរុស* ស្ដេចអង្គនេះ និងស្ដេចអ័ហាស៊ូរុសនៅក្នុងព្រះគម្ពីរនាងអេសធើរ គឺមិនមែនជាមនុស្សតែមួយទេ ។

**៩:២** *ហោរាយេរេមា . . . គឺគ្រប់ ៧០ ឆ្នាំ* មើលការពន្យល់ យរ ២៥:១១–១២ ។

**៩:៣–១៩** សេចក្ដីអធិស្ឋានរបស់លោកដានីយ៉ែល បង្ហាញអំពីការបន្ទាប់ខ្លួន (ខ.៣) ការថ្វាយបង្គំ (ខ.៤) ការលន់តួបាប (ខ.៥–១៥) និងការទូលអង្វរ (ខ.១៦–១៩) ។ មើលការអធិស្ឋានស្រដៀងគ្នានៅក្នុង អរ ៩:៥–១៥ នហ ៩:៥–៣៧ (មើលការពន្យល់) ។

**៩:៣** *សំពត់ធ្មៃ . . . ផេះ* មើលការពន្យល់ លប ៣៧:៣៤ វវ ១១:៣ ។

**៩:៤** *ជាព្រះដែលរក្សាសេចក្ដីសញ្ញា* មើល ចទ ៧:៩,១២ និងការពន្យល់ ។ *អស់អ្នកដែលស្រឡាញ់ដល់ទ្រង់ ហើយកាន់តាមបញ្ញត្តទ្រង់* មើល នហ ១:៥ ធៀបនឹង នក ២០:៦ និងការពន្យល់ ។

ក្រិត្យក្រម និងបញ្ញត្តិច្បាប់របស់ទ្រង់ផង[ឋ] ៦ក៏មិនស្តាប់[ឌ]
តាមពួកហោរា[ឍ] ជាអ្នកបំរើរបស់ទ្រង់ ដែលបានទាយដល់
ពួកស្តេច ពួកចៅហ្វាយ ពួកព្ធយុកោរបស់យើងខ្ញុំ[ណ] និង
បណ្តាជនក្នុងស្រុក ដោយនូវព្រះនាមទ្រង់ដែរ ៧ឱព្រះ
អម្ចាស់អើយ សេចក្តីសុចរិត[ត]ជារបស់ផងទ្រង់ហើយ តែ
ខាងយើងខ្ញុំ មានតែសេចក្តីជ្រប់មុខ[ថ]វិញ ដូចជាសព្វថ្ងៃ
នេះ គឺទាំងពួកមនុស្សនៅស្រុកយូដា ពួកអ្នកនៅក្រុង
យេរូសាឡិម និងសាសន៍អ៊ីស្រាអែលទាំងអស់គ្នា ដែល
នៅជិតនៅឆ្ងាយ នៅក្នុងអស់ទាំងប្រទេសដែលទ្រង់បាន
បណ្តេញ[ទ]គេ ដោយព្រោះអំពើរំលង[ធ] ដែលគេបានប្រព្រឹត្ត
ទាស់នឹងទ្រង់ផង[ន] ៨ឱព្រះអម្ចាស់អើយ សេចក្តីជ្រប់មុខ
ជារបស់ផងយើងខ្ញុំហើយ គឺរបស់ពួកស្តេច ពួកចៅហ្វាយ
និងពួកព្ធយុកោនៃយើងខ្ញុំ ពីព្រោះយើងខ្ញុំបានធ្វើបាបនឹង
ទ្រង់[ប] ៩ឯសេចក្តីមេត្តាករុណា និងសេចក្តីអត់ទោសនោះ[ផ]
ជារបស់ផងព្រះដ៏ជាព្រះអម្ចាស់នៃយើងខ្ញុំវិញ ទោះបើ
យើងខ្ញុំបានបះបោរនឹងទ្រង់ក៏ដោយ[ព] ១០យើងខ្ញុំក៏មិនបាន
ស្តាប់តាមព្រះបន្ទូលរបស់ព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំ
ដើម្បីនឹងដើរតាមក្រិត្យវិន័យរបស់ទ្រង់ ដែលទ្រង់បានតាំង
នៅមុខយើងខ្ញុំ ដោយសារពួកហោរា ជាអ្នកបំរើទ្រង់ដែរ[ភ]
១១អើ ពួកអ៊ីស្រាអែលទាំងអស់គ្នាបានរំលង[ម]ចំពោះក្រិត្យ
វិន័យ[យ]របស់ទ្រង់ហើយ ក៏បែរចេញ ដើម្បីមិនឱ្យត្រូវស្តាប់
តាមព្រះបន្ទូលទ្រង់ឡើយ ហេតុនោះសេចក្តីបណ្តាសា[រ]នេះ
ត្រូវចាក់មកលើយើងខ្ញុំ ព្រមទាំងសេចក្តីសម្បថដែលបាន
កត់ទុក នៅក្នុងក្រិត្យវិន័យ[ល]របស់លោកម៉ូសេ ជាអ្នកបំរើនៃ
ព្រះដែរ ពីព្រោះយើងខ្ញុំបានធ្វើបាប[វ]ចំពោះទ្រង់ ១២ហើយ
ទ្រង់បានសំរេច[ស]បញ្ជាក់ព្រះបន្ទូល ដែលទ្រង់មានបន្ទូល
ទាស់នឹងយើងខ្ញុំ ហើយទាស់នឹងពួកចៅក្រម ដែលជិនុំជិរះ
យើងខ្ញុំ ដោយបាននាំសេចក្តីអាក្រក់យ៉ាងធំនេះមកលើ
យើងខ្ញុំ[ហ] ដ្បិតនៅក្រោមមេឃទាំងមូល មិនដែលកើតមាន
ការអ្វី ដូចជា[ឡ]បានកើតដល់ក្រុងយេរូសាឡិមនោះឡើយ[អ]។
១៣សេចក្តីអាក្រក់ទាំងប៉ុន្មាននេះ បានមកលើយើងខ្ញុំ
ដូចជាបានចែងទុកមក នៅក្នុងក្រិត្យវិន័យរបស់លោកម៉ូ
សេហើយ ប៉ុន្តែយើងខ្ញុំមិនបានទូលអង្វរស្វែងរកព្រះគុណ
របស់ព្រះយេហូវ៉ា[ក] ជាព្រះនៃយើងខ្ញុំ ដើម្បីនឹងបែរចេញ
ពីអំពើទុច្ចរិតរបស់យើងខ្ញុំ ឱ្យមានគំនិតវាងវៃ ក្នុងសេចក្តី
ពិតរបស់ទ្រង់វិញនោះឡើយ[ខ] ១៤ហេតុនោះបានជាព្រះ
យេហូវ៉ាទ្រង់បានរវាំងមើលអំពើអាក្រក់នោះ[គ] ក៏បាន
ទំលាក់មកលើយើងខ្ញុំវិញ ដ្បិតព្រះយេហូវ៉ា ជាព្រះនៃយើង
ខ្ញុំទ្រង់សុចរិតក្នុងគ្រប់ទាំងការដែលទ្រង់ធ្វើ[ឃ] តែយើងខ្ញុំមិន
បានស្តាប់តាមព្រះបន្ទូលទ្រង់ឡើយ[ង] ១៥ឥឡូវនេះ ឱព្រះ
អម្ចាស់ ជាព្រះនៃយើងខ្ញុំ ដែលបាននាំរាស្ត្ររបស់ទ្រង់
ចេញពីស្រុកអេស៊ីព្ទ ដោយព្រះហស្តខ្លាំងពូកែ[ច] ហើយ
បានល្បីព្រះនាមខ្ចរខ្ចាយ[ឆ] ដូចជាសព្វថ្ងៃនេះអើយ យើង
ខ្ញុំបានធ្វើបាប ក៏បានប្រព្រឹត្តអំពើអាក្រក់ផង ១៦ឱព្រះ
អម្ចាស់អើយ តាមគ្រប់ទាំងសេចក្តីសុចរិតរបស់ទ្រង់[ជ] នោះ
សូមឱ្យសេចក្តីខ្ញាល់ និងសេចក្តីក្រោធ[ឈ]របស់ទ្រង់ បានបែរ
ចេញ[ញ]ពីក្រុងយេរូសាឡិម[ដ] គឺជាភ្នំបរិសុទ្ធរបស់ទ្រង់ទៅ[ឋ]
ដ្បិត ក្រុងយេរូសាឡិម និងពួករាស្ត្ររបស់ទ្រង់បានត្រឡប់
ជាទីត្មះតិះដៀល[ឌ]ដល់មនុស្សទាំងអស់ដែលនៅព័ទ្ធជុំវិញ
យើងខ្ញុំ គឺដោយព្រោះតែអំពើបាបរបស់យើងខ្ញុំ ហើយនឹង
អំពើទុច្ចរិតរបស់ពួកព្ធយុកោយើងខ្ញុំទេ ១៧ដូច្នេះ ឱព្រះនៃ
យើងខ្ញុំអើយ សូមទ្រង់ស្តាប់តាមសេចក្តីអធិស្ឋាន និង ពាក្យ
ទូលអង្វររបស់អ្នកបំរើទ្រង់ ហើយសូមធ្វើឱ្យព្រះភក្ត្រ ទ្រង់
ភ្លឺ[ឍ]មកលើទីបរិសុទ្ធរបស់ទ្រង់ ដែលនៅស្ងាត់ច្រៀបចុះ
គឺដោយយល់ដល់ព្រះអម្ចាស់ ១៨ឱព្រះនៃទូលបង្គំអើយ
សូមផ្ទៀងព្រះកាណ៌[ណ]មកស្តាប់[ត] សូមបើកព្រះនេត្រទ្រង់ទត
មើល[ថ] សេចក្តីខូចបង់របស់យើងខ្ញុំ និងទីក្រុងដែលបាន
ហៅតាមព្រះនាមទ្រង់[ទ] ដ្បិតយើងខ្ញុំមិនមែនទូលអង្វរដល់
ទ្រង់ ដោយព្រោះយើងខ្ញុំមានសេចក្តីសុចរិតទេ គឺដោយ

**៩:៥** ឋ ខ.១១ បទ ១:២០ ៣:៤២ **៩:៦** ឌ ២ពវ ១៨:១២ ឍ ២ពវ ៣៦:១៦ យរ ៤៤:៥ យក ៥:១០ វវ ១០:៧ ណ ២រប ២៩:៦ **៩:៧** ត អរ ៩:១៥ អស ៤២:៦ ថ អរ ៩:៧ ទដ ៤៤:១៥ ទ ចទ ៤:២៧ អម ៩:៩ ធ ចទ ៧:៣ ន យរ ៣:២៥ ២៤:៩ អក ៣៩:២៣–២៤ **៩:៨** ប នហ ៩:៣៣ យរ ១៤:២០ អក ១៦:៦៣ **៩:៩** ផ នក ៣៤:៧ ២រប ២៤:១៤ យរ ៤២:១២ ព នហ ៩:១៧ យរ ១៤:៧ **៩:១០** ភ ២ពវ ១៧:១៣–១៥ ១៨:១២ វវ ១០:៧ **៩:១១** ម យរ ២:២៩ យ ២ពវ ២២:១៦ រ ចទ ១១:២៦ ១៣:១៥ ២៨:១៥ ល ២ពវ ១៧:២៣ វ អស ១:៤–៦ យរ ៨:៥–១០ **៩:១២** ស អស ៤៤:២៦ សក ១:៦ ហ យរ ៤៤:២៣ ឡ យរ ៣០:៧ អ យរ ៤៤:២–៦ អក ៥:៩ ដយ ១២:១ យអ ២:២ សក ៧:១២ **៩:១៣** ក ចទ ៤:២៩ អស ៣១:១ ខ អស ៩:១៣ យរ ២:៣០ **៩:១៤** គ យរ ១៨:៨

៤៤:២៧ ឃ លប ១៨:២៥ ២រប ១២:៦ យរ ១២:១ ង នហ ៩:៣៣ យរ ៣២:២៣ ៤០:៣ **៩:១៥** ច នក ៣:២០ យរ ៣២:២១ ឆ នហ ៩:១០ **៩:១៦** ជ ពច ៥:១១ ទដ ៣១:១ ឈ ទដ ៨៥:៣ ញ អស ៥:២៥ ដ យរ ៣២:៣២ ឋ នក ១៥:១៧ ទដ ៤៨:១ ឌ ទដ ៣៩:៨ អក ៥:១៤ **៩:១៧** ឍ ជន ៦:២៤–២៦ ទដ ៨០:១៩ **៩:១៨** ណ ទដ ៥:១ ត ទដ ១១៦:១ ថ ទដ ៨០:១៤ ទ ចទ ២៨:១០ អស ៣៧:១៧ យរ ៧:១០–១២ ២៥:២៩

**៩:៦** *អ្នកបំរើរបស់ទ្រង់ ដែលបានទាយ* មើល ខ.១០ និង យរ ៧:២៥ សក ១:៦ និងការពន្យល់ ។

**៩:៧** *ទ្រង់បានបណ្តេញគេ ដោយព្រោះអំពើរំលង* មើល ២ពវ ១៧:៧–២៣ និងការពន្យល់, ២រប ៣៦:១៥–២០ ។

**៩:១១** *សេចក្តីបណ្តាសា... ដែលបានកត់ទុក នៅក្នុងក្រិត្យវិន័យ* មើល លវ ២៦:៣៣ ចទ ២៨:៦៤ និងការពន្យល់ ។

**៩:១៤** *ព្រះនៃយើងខ្ញុំទ្រង់សុចរិត* មើល ទដ ៤:១ យរ ១២:១ និងការពន្យល់ ។

**៩:១៨** *ទីក្រុងដែលបានហៅតាមព្រះនាមទ្រង់* គឺទីក្រុងយេរូសាឡិម (១ពវ ១១:៣៦, ធៀបនឹង ទដ ១៣២:១៣ និងការពន្យល់, មើល យរ ២៥:២៩ និងការពន្យល់)។ *ព្រះនាម* មើល ចទ ១២:៥ និងការពន្យល់ ។ *គឺដោយព្រោះតែសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់វិញ* ព្រះទ្រង់ឆ្លើយតបនឹងសេចក្តីអធិស្ឋានរបស់យើងដោយសេចក្តីមេត្តាករុណារបស់ទ្រង់ គឺមិនមែនដោយការដែលយើងធ្វើទេ ។

ព្រោះតែសេចក្ដីមេត្តាករុណាដ៏ធំរបស់ទ្រង់វិញ[ធ] ១៩ឱព្រះ
អម្ចាស់អើយ សូមទ្រង់ព្រះសណ្ដាប់ ឱព្រះអម្ចាស់អើយ សូម
ទ្រង់អត់ទោស[ន] ឱព្រះអម្ចាស់អើយ សូមទ្រង់ស្ដាប់ ហើយ
ប្រោសមេត្តាផង ឱព្រះនៃទូលបង្គំអើយ សូមកុំបង្អង់
ឡើយ ដោយយល់ដល់អង្គទ្រង់[ប] ដ្បិតទីក្រុងនៃទ្រង់ និង
រាស្ត្ររបស់ទ្រង់ បានហៅតាមព្រះនាមទ្រង់ហើយ ។

## ប្រាំពីរសប្ដាហ៍

២០កាលខ្ញុំកំពុងតែទូលដល់ព្រះយេហូវ៉ា ជាព្រះនៃខ្ញុំ
ព្រមទាំងអធិស្ឋាន និងលន់តួ[ផ]បាបរបស់ខ្លួនខ្ញុំ ហើយបាប
របស់ពួកអ៊ីស្រាអែលជាសាសន៍នៃខ្ញុំ ទាំងទូលអង្វរឱ្យភ្នំ
បរិសុទ្ធរបស់ព្រះនៃខ្ញុំផង[ព] ២១អើ កំពុងដែលខ្ញុំអធិស្ឋាន
នៅឡើយ នោះលោកដែលនាមជា កាព្រីយ៉ែល[ភ] ជាអ្នក
ដែលខ្ញុំបានឃើញក្នុងការជាក់ស្ដែងមុនដំបូង លោកហោះ
យ៉ាងលឿន ចូលមកឯខ្ញុំ ក្នុងរវាងពេលថ្វាយដង្វាយល្ងាច[ម]
២២ហើយក៏ប្រាប់ខ្ញុំ ព្រមទាំងសន្ទនានឹងខ្ញុំថា ដានីយ៉ែល
អើយ យើងបានចេញមកឥឡូវ ដើម្បីនឹងឱ្យអ្នកមានប្រាជ្ញា
ហើយនិងយោបល់[យ] ២៣កាលអ្នកទើបនឹងចាប់តាំង
អធិស្ឋាន[រ] នោះមានចេញបង្គាប់ស្រេចហើយ រួចយើងបាន
ចេញមក ដើម្បីនឹងប្រាប់ដល់អ្នក ដ្បិតអ្នកជាមនុស្សសំណប់
យ៉ាងសំខាន់[ល] ដូច្នេះ ចូរពិចារណាសេចក្ដីនេះ ហើយយល់
ការជាក់ស្ដែងចុះ[វ] ។
២៤គ្រប់៧០អាទិត្យបានកំណត់ដល់សាសន៍ឯង នឹងដល់
ទីក្រុងបរិសុទ្ធរបស់ឯង[ស] ដើម្បីនឹងរំលត់បំបាត់អំពើរំលង
នឹងធ្វើឱ្យអំពើបាបផុតទៅ ហើយឱ្យបានធួន[ហ]នឹងអំពើ
ទុច្ចរិត ព្រមទាំងនាំសេចក្ដីដ៏នៅអស់កល្បជានិច្ច[ឡ] ចូលមក
និងបិទត្រាការជាក់ស្ដែង និងសេចក្ដីទំនាយ ហើយនិងចាក់
ប្រេងតាំងអ្នកដ៏បរិសុទ្ធបំផុតឡើង ២៥ដូច្នេះ ត្រូវឱ្យដឹង
ហើយយល់ថា ចាប់តាំងពីចេញបង្គាប់ឱ្យតាំង ក្រុងយេរូ–
សាឡិម ហើយសង់ឡើងវិញ[អ] ដរាបដល់គ្រាអ្នក ដែលចាក់
ប្រេងតាំងនោះ[ក] គឺជាអ្នកដែលជាកំពូល[ខ]បណ្ដាច់ នោះត្រូវ
ជាចំនួន៧អាទិត្យ និង៦២អាទិត្យ រួចនៅគ្រាជ្រួលច្រាល់
នោះទីក្រុងនឹងបានសង់ឡើងវិញ មានទាំងផ្លូវថ្លា និងកំផែង
ផង[គ] ២៦លុះក្រោយពី៦២អាទិត្យនោះទៅ នោះអ្នកដែល
បានចាក់ប្រេងតាំងឡើង នឹងត្រូវផ្ដាច់ចេញវិញ[ឃ] ឥតមាន
ទាក់ទងនឹងអ្វីឡើយ រួចបណ្ដាទ័ពរបស់ចៅហ្វាយ១ដែល
នឹងមក គេនឹងបំផ្លាញទីក្រុង និងទីបរិសុទ្ធបង់ ឯចុងបំផុត
នៃការនោះនឹងបានដូចជាជំនន់ទឹក[ង] ក៏នឹងមានចំបាំង
ដរាបដល់ចុង ហើយបានសំរេចឱ្យមានការលាញបំផ្លាញ[ច]
ដែរ[ឆ] ២៧ចៅហ្វាយនោះនឹងតាំងសញ្ញាយ៉ាងមុឹងម៉ាត់នឹង
មនុស្សជាច្រើននៅរវាង១អាទិត្យ តែដល់ពាក់កណ្ដាល
អាទិត្យនោះ និងធ្វើឱ្យការថ្វាយយញ្ញបូជា និងដង្វាយឈប់
ទៅ ហើយនៅក្នុងព្រះវិហារ នឹងមានធ្វើការគួរស្អប់ខ្ពើម

**៩:១៨** ធ លក ១៨:១៣
**៩:១៩** ន ទដ ៤៤:២៣ ប ១សយ ១២:២២
**៩:២០** ផ អរ ១០:១ ព ខ.៣ ទដ ១៤៥:១៨ អស ៥៨:៩
**៩:២១** ភ ដយ ៨:១៦ លក ១:១៩ ម នក ២៩:៣៩
**៩:២២** យ ដយ ៧:១៦ ១០:១៤ អម ៣:៧
**៩:២៣** រ អស ៦៥:២៤ ល ដយ ១០:១៩ លក ១:២៨ វ ដយ ១០:១១–១២ មថ ២៤:១៥
**៩:២៤** ស អស ១:២៦ ហ អស ៥៣:១០ ឡ អស ៥៦:១ ហព ៩:១២
**៩:២៥** អ អរ ៤:២៤ ៦:១៥ ក មថ ១:១៧ យហ ៤:២៥ ខ ១សយ ១៣:១៤ គ អរ ៣:៣
**៩:២៦** ឃ អស ៥៣:៨ មថ ១៦:២១ ង អស ២៨:២ ដយ ១១:១០ ណាហ ១:៨ ច ទដ ៤៦:៨
ឆ អស ៦១:១ អគ ៤:៥–៦ ហក ២:២៣ សក ៤:១៤

**៩:២០** *កាលខ្ញុំកំពុងតែទូល* មើល អស ៦៥:២៤ ។ *ភ្នំបរិសុទ្ធ* គឺភ្នំស៊ីយ៉ូន (មើល ទដ ២:៦ និងការពន្យល់) ។

**៩:២១** *ការព្រីយ៉ែល* មើល ៨:១៦ និងការពន្យល់ ។ *ពេលថ្វាយដង្វាយល្ងាច* មើលការពន្យល់ ទដ ១៤១:២ ។

**៩:២៤** គោលបំណងទាំងប្រាំមួយដែលមាននៅក្នុងខនេះគឺត្រូវព្រះមែស៊ីទ្រង់សម្រេច ។ អ្នកខ្លះជឿថា គោលបំណងទាំងបីចុងក្រោយគឺត្រូវបានសម្រេចដោយការសុគត និងការមានព្រះជន្មឡើងវិញរបស់ព្រះគ្រីស្ទ តែអ្នកខ្លះជឿថា ការនេះត្រូវសម្រេចដោយព្រះមែស៊ីទ្រង់នាំសេចក្ដីសុចរិតដ៏នៅអស់កល្បជានិច្ចចូលមក បិតត្រាការជាក់ស្ដែង និងសេចក្ដីទំនាយ ហើយនឹងចាក់ប្រេងតាំងអ្នកដ៏បរិសុទ្ធបំផុតឡើង ។

**៩:២៥–២៧** ចាប់តាំងពីពេលចេញព្រះរាជក្រឹត្យឱ្យសង់ទីក្រុងយេរូសាឡិមឡើងវិញ (ខ.២៥) រហូតដល់ការយាងមកនៃព្រះមែស៊ី គឺមានរយៈពេល ៤៨៣ ឆ្នាំ (មើលការពន្យល់ អរ ៧:១១) ។ ចំនួន "៧" គឺអាចសំដៅទៅលើរយៈពេលនៃការស្ដារទីក្រុងយេរូសាឡិមឡើងវិញដោយចប់សព្វគ្រប់ (ព្រះគម្ពីរអែសរ៉ា និងនេហេមាក៏បាននិយាយអំពីការសាងទីក្រុងនេះផងដែរ) ហើយចំនួន "៦២" គឺជារយៈពេលដែលរាប់ចាប់ការស្ដារឡើងវិញនោះ និងការដែលព្រះមែស៊ីទ្រង់យាងមកនគរអ៊ីស្រាអែល ។ ចំនួន១អាទិត្យនៅក្នុង ខ.២៧ គឺសំដៅទៅលើ ចំនួន "៧" ចុងក្រោយ (គឺចំនួនទី៧០) ដែលទាក់ទងនឹងបទទំនាយអំពីការបំផ្លាញទីក្រុងយេរូសាឡិមដោយ "បណ្ដាទ័ពរបស់ចៅហ្វាយ១ដែលនឹងមក" (គឺមេទ័ពឈ្មោះទីតុស នៅឆ្នាំ ៧០ នៃគ្រីស្ទសករាជ) ។ នៅក្នុងឆ្នាំទី ៧០ ស្នែងតូច ឬសត្វសាហាវ (ពួកទទឹងព្រះគ្រីស្ទ) នៃថ្ងៃចុងក្រោយ (នៅក្នុងវគ្គនេះគឺសំដៅទៅលើអ្នកដែលនាំឱ្យមាន "សេចក្ដីគួរស្អប់ខ្ពើមដែលនាំឱ្យបង្ខូចបំផ្លាញ" ហើយជាពួកទទឹងព្រះគ្រីស្ទ ដូចលោកទីតុសដែលជាមេទ័ពរ៉ូម៉ាំង, មើល វវ ១៣:១–៨ និងការពន្យល់) នឹងធ្វើសេចក្ដីសញ្ញាដែលមានរយៈពេលប្រាំពីរឆ្នាំ ជាមួយនឹងសាសន៍យូដា ប៉ុន្ដែ បានបំពានសេចក្ដីសញ្ញានៅពាក់កណ្ដាលទី (មើលការពន្យល់ ខ.២៧ ផងដែរ) ។ ការផ្ដាច់ចេញអ្នកដែលបានចាក់ប្រេងតាំង (ខ.២៦) គឺសំដៅទៅលើការឆ្កាងព្រះគ្រីស្ទ ។

**៩:២៧** *ចៅហ្វាយនោះនឹងតាំងសញ្ញាយ៉ាងមុឹងម៉ាត់ . . . នឹងធ្វើឱ្យការថ្វាយយញ្ញបូជា និងដង្វាយឈប់ទៅ* អ្នកខ្លះយល់ថា ត្រង់ចំណុចនេះគឺសំដៅទៅលើព្រះមែស៊ី ("អ្នកដែលបានទទួលការចាក់ប្រេងតាំង", ខ.២៦) ដែលទ្រង់តាំងសញ្ញាថ្មី និងបញ្ចប់ប្រពៃណីយថ្វាយដង្វាយតាមសញ្ញាចាស់ ។ អ្នកខ្លះទៀតយល់ថា ត្រង់ចំណុចនេះគឺសំដៅទៅលើពួកទទឹងព្រះគ្រីស្ទ ("ចៅហ្វាយដែលត្រូវមក", ខ.២៦) ដែលតាំងសញ្ញាជាមួយនឹងពួកសាសន៍យូដានៅក្នុងពេលអនាគត ហើយបំផ្លាញប្រពៃណីយថ្វាយដង្វាយរបស់ពួកគេ ។ *ការគួរស្អប់ខ្ពើមដែលនឹងបង្ខូចបំផ្លាញ* មើលការពន្យល់ ១១:៣១ ។

ដែលនឹងបង្ខូចបំផ្លាញ ក៏នឹងមានសេចក្តីក្រោធ ចាក់ទៅលើ
ទីខូចបង់នោះ[ជ] ដរាបដល់ចុងបំផុត ជាវេលាដែលបាន
កំណត់ទុកហើយ ។

## លោកដានីយ៉ែលមើលឃើញមនុស្សប្រុសម្នាក់

**១០** ១ នៅឆ្នាំទី៣ ក្នុងរាជ្យនៃស៊ីរូស[ក] ជាស្តេចពើស៊ីនោះ
មានការ១បើកសំដែងឱ្យដានីយ៉ែល ដែលលោកមាន
ឈ្មោះថា បេលថិស្សាសារ[ខ] ឃើញការនោះក៏ពិតប្រាកដ[គ]
គឺជាការសង្គ្រាមយ៉ាងធំ លោកក៏ពិចារណាដំណើរនោះ
ហើយបានយល់ចំពោះការជាក់ស្តែង ២ នៅគ្រានោះ ខ្ញុំ
ដានីយ៉ែល ខ្ញុំមានសេចក្តីទុក្ខព្រួយ[ឃ]នៅពេញ៣អាទិត្យ ៣ ខ្ញុំ
មិនបានទទួលទានអ្វីដែលត្រូវចំណុចចិត្ត ក៏មិនមានសាច់ ឬ
ស្រាទំពាំងបាយជូរ ចូលមកក្នុងមាត់ខ្ញុំឡើយ[ង] ខ្ញុំក៏មិនបាន
អប់ខ្លួនដែរ ដរាបដល់ផុត៣អាទិត្យនោះទៅ ៤ លុះដល់ថ្ងៃ
២៤ខែចេត្រ កាលខ្ញុំនៅមាត់ទន្លេធំ[ច] គឺជាទន្លេ ហ៊ីដេកែល[ឆ]
៥ នោះខ្ញុំបានងើបភ្នែកមើល[ជ]ទៅ ឃើញមានមនុស្សម្នាក់
ស្លៀកពាក់ដោយសំពត់ទេសឯក[ឈ] ហើយក្រវាត់ចង្កេះ
ដោយមាសសុទ្ធ[ញ]ពីស្រុកអ៊ូផាស ៦ រូបកាយរបស់អ្នកនោះ
មើលទៅដូចជាត្បូងបេរីល[ដ] ហើយមុខមានភាពដូចជាផ្លេក
បន្ទោរ[ឋ] ឯភ្នែកក៏ដូចជាចន្លុះដែលឆេះ[ឌ] ដៃនិងជើងដូចជា
លង្ហិនខាត់យ៉ាងភ្លឺ[ឍ] ហើយសូរសំឡេង[ណ]របស់អ្នកនោះ ដូច
ជាសូរនៃជំនុំមនុស្សយ៉ាងធំ ៧ គឺខ្ញុំ ដានីយ៉ែលតែឯង ដែល
ឃើញការជាក់ស្តែងនោះ ពួកអ្នកដែលនៅជាមួយនឹងខ្ញុំ
ឥតបានឃើញទេ[ត] តែគេកើតមានសេចក្តីភ័យញ័រជាខ្លាំង
ហើយក៏រត់ទៅពួនខ្លួន ៨ ដូច្នេះ ខ្ញុំត្រូវចោលឱ្យនៅតែឯង[ថ]
ខ្ញុំក៏ឃើញការជាក់ស្តែងយ៉ាងធំនោះ ហើយបានខ្សោះ
ល្វើយទៅ[ទ] ទឹកមុខខ្ញុំក៏ផ្លាស់ប្រែទៅជាស្លេកស្លាំង[ធ] ហើយ
ខ្ញុំឥតមានកំឡាំងនៅសល់ឡើយ[ន] ៩ ប៉ុន្តែខ្ញុំឮសំឡេងនៃ
ពាក្យរបស់អ្នកនោះបាន កាលខ្ញុំបានឮសំឡេងនៃពាក្យ
នោះរួចហើយ នោះខ្ញុំក៏លង់ស្មារតីទៅ មានមុខផ្កាប់ចុះ
ដល់ដី[ប] ។
១០ នោះមានដៃ១ពាល់ខ្ញុំ[ផ] ឱ្យខ្ញុំញ័រងើបឡើង ដោយ
ជង្គង់ និងបាតដៃ[ព] ១១ រួចក៏ពោលមកខ្ញុំថា ឱដានីយ៉ែល

**៩:២៧** ជ អស ១០:២២
**១០:១** ក ដយ ១:២១ ខ ដយ ១:៧ គ ដយ ៨:២៦
**១០:២** ឃ អរ ៩:៤
**១០:៣** ង ដយ ៦:១៨
**១០:៤** ច ដយ ១២:៥ ឆ លប ២:១៤
**១០:៥** ជ ដយ ៨:៣ ឈ អគ ៩:២ វវ ១៥:៦ ញ យរ ១០:៩
**១០:៦** ដ នក ២៨:២០ ឋ មថ ១៧:២ ២៨:៣ ឌ យប ៤១:១៩ វវ ១៩:១២ ឍ អគ ១:៧ វវ ១:១៥ ណ អគ ១:២៤
**១០:៧** ត ២ពវ ៦:១៧–២០ កច ៩:៧
**១០:៨** ថ លប ៣២:២៤ ទ យប ៤:១៤ ដយ ៨:២៧ ធ យប ៤:១៥ ន ហព ៣:១៦
**១០:៩** ប ដយ ៨:១៨ មថ ១៧:៦
**១០:១០** ផ យរ ១:៩ ព វវ ១:១៧
**១០:១១** ភ លប ៦:៩ ដយ ៩:២៣ ម អគ ២:១
**១០:១២** យ មថ ១៤:២៧ រ លវ ១៦:៣១ ដយ ៩:៣ ល អស ៦៥:២៤ វ ដយ ៩:២០
**១០:១៣** ស អស ២៤:២១ ហ ខ.២១ ដយ ១២:១ យដ ១:៩

ជាអ្នកសំណប់យ៉ាងសំខាន់អើយ[ភ] ចូរយល់ពាក្យ ដែល
យើងប្រាប់អ្នក ហើយឈរឱ្យត្រង់ឡើងចុះ[ម] ពីព្រោះយើង
ត្រូវចាត់មកឯអ្នក កាលលោកបានពោលពាក្យទាំងនោះ
មកខ្ញុំហើយ នោះខ្ញុំក៏ឈរនៅទាំងញាប់ញ័រ ១២ រួចលោក
ប្រាប់ខ្ញុំថា ដានីយ៉ែលអើយ កុំឱ្យខ្លាចឡើយ[យ] ដ្បិតចាប់
តាំងពីថ្ងៃមុនដំបូង ដែលអ្នកបានតាំងចិត្តរកយល់ ហើយ
បន្ទាបខ្លួនចុះ[រ] នៅចំពោះព្រះនៃអ្នក នោះពាក្យ[ល]របស់អ្នកក៏
បានឮហើយ រួចយើងក៏បានមក ដោយព្រោះពាក្យនោះ[វ]
១៣ ប៉ុន្តែម្ចាស់[ស]ដ៏ធំនៃនគរពើស៊ីបានឃាត់យើងអស់២១ថ្ងៃ
តែមើល មីកែល[ហ] ជាពួកមហាទេវតា១បានមកជួយយើង
យ៉ាងនោះ យើងបាននៅទីនោះជាមួយនឹងពួកស្តេចពើស៊ី
ទៅ ១៤ ឥឡូវនេះបានមក ដើម្បីឱ្យអ្នកយល់[ឡ]ពីការដែល
ត្រូវកើតដល់សាសន៍អ្នក នៅគ្រាក្រោយបង្អស់[អ] ដ្បិតការ
ជាក់ស្តែងនេះសំដៅដល់យូរថ្ងៃទៅខាងមុខ[ក] ១៥ លុះកាល
លោកបាននិយាយមកខ្ញុំ តាមសេចក្តីទាំងនោះរួចហើយ
នោះខ្ញុំក៏ឱនមុខមើលទៅដី ហើយបានគនៅ[ខ] ១៦ នោះ
ឃើញមានម្នាក់មានភាពដូចជាមនុស្សជាតិ មកពាល់បបូរ
មាត់ខ្ញុំ[គ] រួចខ្ញុំហាមាត់និយាយដល់លោក ដែលឈរនៅ
មុខខ្ញុំថា ឱលោកម្ចាស់អើយ សេចក្តីបារម្ភព្រួយ[ឃ]បានចាប់
ខ្ញុំ ដោយព្រោះឃើញការជាក់ស្តែងនេះ ហើយខ្ញុំឥតមាន
កំឡាំងទៀតសោះ ១៧ ដ្បិតធ្វើដូចម្តេចឱ្យខ្ញុំ ជាបាវបំរើ
របស់លោកម្ចាស់ ហ៊ាននិយាយនឹងលោកបាន ពីព្រោះ
ចំណែកខ្ញុំ ស្រាប់តែគ្មានកំឡាំងនៅក្នុងខ្លួនទៀតសោះ
ក៏គ្មានដង្ហើមសល់នៅដែរ[ង] ។
១៨ រួចមកមានម្នាក់មានភាពដូចជាមនុស្សជាតិ បាន
ពាល់[ច]ខ្ញុំទៀត ហើយក៏ចំរើនកំឡាំងដល់ខ្ញុំ[ឆ] ១៩ រួចប្រាប់ខ្ញុំ
ថា ឱអ្នកសំណប់យ៉ាងសំខាន់អើយ[ជ] កុំឱ្យខ្លាចឡើយ សូមឱ្យ
បានប្រកបដោយសេចក្តីសុខចុះ[ឈ] ចូរឱ្យមានកំឡាំងឡើង[ញ]
អើ ចូរមានកំឡាំងឡើង កាលលោកបានពោលនឹងខ្ញុំហើយ

**១០:១៤** ឡ ដយ ៩:២២ អ អគ ១២:២៧ ក ដយ ២:២៨ ៨:២៦ ហព ២:៣
**១០:១៥** ខ អគ ២៤:២៧ លក ១:២០ **១០:១៦** គ អស ៦:៧ យរ ១:៩ ដយ ៨:១៥–១៨ ឃ អស ២១:៣ **១០:១៧** ង ដយ ៤:១៩ **១០:១៨** ច ខ.១៦ ឆ ដយ ៨:១៨ **១០:១៩** ជ ដយ ៩:២៣ ឈ ពច ៦:២៣ អស ៣៥:៤ ញ យស ១:៩

**១០:១** *នៅឆ្នាំទី៣ ក្នុងរាជ្យនៃស៊ីរូស* គឺនៅឆ្នាំ ៥៣៧ មុនគ.ស ។ ឆ្នាំនោះ គឺជាឆ្នាំទីបីបន្ទាប់ពីស្តេចនេះកាន់កាប់ចក្រភពបាប៊ីឡូននៅឆ្នាំ ៥៣៩ មុន គ.ស (មើលការពន្យល់ ១:១) ។

**១០:៣** មើល ១:៨–១៦ និងការពន្យល់ ១:៨ ។

**១០:៥–៦** មើល ៧:៩ វវ ១:១២–១៦ និងការពន្យល់ ។

**១០:៧** ធៀបនឹង កច ៩:៧ ។

**១០:១៣** *ពួកស្តេចពើស៊ី* ប្រហែលជាសំដៅទៅលើ វិញ្ញាណអាក្រក់ដែលមានឥទ្ធិពលលើរបបគ្រប់គ្រងរបស់ចក្រភពពើស៊ី ដើម្បីបម្រើប្រយោជន៍អារក្សសាតាំង (មើល ខ.២០ ផងដែរ) ។ ការតស៊ូប្រឆាំងរបស់វាត្រូវបង្ក្រាបដោយមហាទេវតាមីកែល ដែលជា "អ្នកការពារដ៏អស្ចារ្យ" របស់រាស្ត្រនៃព្រះ (១២:១) ។

**១០:១៤** *ការដែលត្រូវកើតដល់សាសន៍អ្នក* មើលជំពូក ១១–១២ ។

**១០:១៦** *ពាល់បបូរមាត់ខ្ញុំ រួចខ្ញុំហាមាត់និយាយដល់លោក* មើល អស ៦:៧, យរ ១:៩ និងការពន្យល់ ។

នោះខ្ញុំក៏មានកំឡាំងឡើង ហើយខ្ញុំនិយាយថា សូមឱ្យលោក
ម្ចាស់មានប្រសាសន៍មកចុះ ពីព្រោះលោកបានចំរើន
កំឡាំងដល់ខ្ញុំហើយ[ដ] ២០លោកតបមកថា តើអ្នកដឹងជាយើង
មកឯអ្នក ដោយហេតុអ្វីឬទេ តែឥឡូវ នេះយើងត្រូវត្រឡប់
ទៅ តយុទ្ធនឹងម្ចាស់ដ៏ធំនៃនគរពើស៊ី កាលយើងបានចេញ
ទៅផុតហើយ នោះម្ចាស់ដ៏ធំនៃនគរក្រេក[ឋ]នឹងមកដល់
២១ប៉ុន្តែ យើងនឹងប្រាប់អ្នកពីសេចក្ដី ដែលកត់ទុកក្នុងគម្ពីរ
ដ៏ពិត[ឌ] គ្មានអ្នកណាជួយខាងយើង ក្នុងដំណើរការទាំងនេះ
ឡើយ មានតែមីកែល ជាទេវតារបស់អ្នកប៉ុណ្ណោះ[ឍ]។

**១១** ១ឯយើង នៅឆ្នាំដំបូងក្នុងរាជ្យនៃដារីយុស[ក] ជា
សាសន៍មេឌី នោះយើងបានឈរជាមួយ ដើម្បីចំរើនកំឡាំង
ហើយទប់ទល់ស្ដេច ។

### ពួកស្ដេចនគរខាងត្បូង និងខាងជើង

២ឥឡូវនេះ យើងនឹងសំដែងឱ្យអ្នកឃើញសេចក្ដីពិត[ខ]
មើល ត្រូវមានស្ដេចសាសន៍ពើស៊ី៣អង្គទៀតសោយរាជ្យ
ឡើង រួចស្ដេចទី៤នឹងមានព្រះរាជ្យទ្រព្យច្រើនក្រៃលែង
ជាជាងគេទាំងអស់ កាលណាបានចំរើនកំឡាំង ដោយសារ
ព្រះរាជទ្រព្យទាំងនោះហើយ នោះទ្រង់នឹងលើកមនុស្ស
ទាំងអស់ឡើង ទាស់នឹងអាណាចក្ររបស់សាសន៍ក្រេក[គ]
៣គ្រានោះ នឹងមានស្ដេច១ខ្លាំងពូកែសោយរាជ្យឡើង ជា
ស្ដេចដែលនឹងគ្រប់គ្រង ដោយអំណាចយ៉ាងខ្លាំង ហើយ
នឹងធ្វើតាមតែបំណងព្រះទ័យ[ឃ] ៤កាលណាស្ដេចនោះបាន
សោយរាជ្យឡើងហើយ នោះនគរទ្រង់នឹងត្រូវបែកខ្ញែក
ហើយបែងចែកទៅឯខ្យល់លើអាកាសទាំង៤ទិស[ង] តែមិន
មែនចែកឱ្យដល់ពូជពង្សនៃស្ដេចនគរនោះទេ ក៏មិនមែន
ដោយមានអំណាចដូចជាស្ដេចនោះធ្លាប់គ្រប់គ្រងដែរ ដ្បិត
នគរនោះនឹងត្រូវច្រៀកចេញ[ច]ចែកដល់មនុស្សដទៃវិញ ។
៥ឯស្ដេចខាងត្បូង និងមានកំឡាំង តែមេទ័ពម្នាក់
របស់ទ្រង់នឹងមានកំឡាំងច្រើនលើសជាង ហើយនឹងមាន
អំណាចសោយរាជ្យ ឯអំណាចគ្រប់គ្រងរបស់អ្នកនោះនឹង
បានធំទូលាយ ៦ដល់ក្រោយបួនដប់ឆ្នាំទៅ នោះគេនឹង
ចងសម្ពន្ធមិត្រនឹងគ្នាវិញ ដោយព្រះរាជបុត្រីនៃស្ដេចខាង
ត្បូងបានទៅឯស្ដេចខាងជើង ដើម្បីតាំងសញ្ញានឹងគ្នា តែ
នាងនឹងមិនមានអំណាចនៅជាយូរទេ ហើយបិតានាងក៏
មិនជាប់នៅ ឬកន្សែវង្សរបស់ទ្រង់ផង គឺនាងនឹងត្រូវលើក
ចោល ព្រមទាំងពួកអ្នកដែលបាននាំនាង និងកូនដែលនាង
បង្កើត ហើយអ្នកដែលបានគាំពានាងក្នុងគ្រានោះដែរ ។
៧តែនឹងមានលំពង់១ពន្លកចេញពីវង្សនាង សោយ
រាជ្យឡើងចំនួសបិតា ស្ដេចនោះនឹងទៅច្បាំងនឹងពលទ័ព
នៃស្ដេចខាងជើង[ឆ] ហើយនឹងចូលទៅក្នុងបន្ទាយរបស់គេ

**១០:១៩** ដ អស ៦:១-៨
**១០:២០** ឋ ដយ ៨:២១ ១១:២
**១០:២១** ឌ ដយ ១១:២ ឍ ខ.១៣ យដ ១:៩
**១១:១** ក ដយ ៥:៣១
**១១:២** ខ ដយ ១០:២១ គ ដយ ១០:២០
**១១:៣** ឃ ដយ ៨:៤,២១
**១១:៤** ង ដយ ៧:២ ៨:២២ ច យរ ៤២:១០
**១១:៧** ឆ ខ.៦

**១០:២០** *ម្ចាស់ដ៏ធំនៃនគរក្រេក* មើលការពន្យល់ ខ.១៣ ។ អំណាចខាងឯវិញ្ញាណមួយនេះនឹងត្រូវប្រឆាំងផងដែរ ។
**១០:២១** *គម្ពីរដ៏ពិត* មើល ១២:១ ។ ត្រង់ចំណុចនេះប្រហែលជាសំដៅទៅលើព្រះគម្ពីរដែលព្រះទ្រង់កត់ត្រាអំពីដោគវាសនារបស់មនុស្សគ្រប់គ្នា (មើល នក ៣២:៣២ ទដ ៦៩:២៨ និងការពន្យល់) ។
**១១:១** *ដារីយុស ជាសាសន៍មេឌី* មើលការពន្យល់ ៥:៣១ ។
**១១:២** *ស្ដេចសាសន៍ពើស៊ី៣អង្គទៀត* គឺស្ដេច ខាមប៊ីសេស (Cambyses, ឆ្នាំ ៥៣០-៥២២ មុនគ.ស) ស្ដេច ស៊ីដូ-ស្មើរឌីស (Pseudo-Smerdis) ឬ គោមាតា (Gaumata, ឆ្នាំ ៥២២ មុនគ.ស) និងស្ដេច ដារីយ៉ុសទីមួយ (Darius I, ឆ្នាំ ៥២២-៤៨៦ មុនគ.ស) ។ *ទី៤* គឺស្ដេចអ័ហាស៊្វេរុស ទី១ (ឆ្នាំ៤៨៦-៤៦៥ មុនគ.ស, មើលការពន្យល់ នអ ១:១) ដែលបានប៉ុនប៉ងវាយកាន់កាប់ចក្រភពក្រិកនៅឆ្នាំ ៤៨០ មុនគ.ស ។
**១១:៣** *ស្ដេច១ខ្លាំងពូកែ* គឺស្ដេចអ័ឡេចក្សាន់ឌ័រ (ឆ្នាំ ៣៣៦-៣២៣ មុនគ.ស) ។
**១១:៤** *ខ្យល់លើអាកាសទាំង៤ទិស* មើល ៧:២-៣ និងការពន្យល់ ៧:៤-៧ (ក្បាលបួន) ។
**១១:៥** *ស្ដេចខាងត្បូង* គឺស្ដេចផ្ទោលេមី ទីមួយ សូទ័រ (Ptolemy I Soter, ៣២៣-២៨៥ មុន គ.ស) នៃនគរអេស៊ីព្ទ ។ *មេទ័ពម្នាក់របស់ទ្រង់* គឺមានឈ្មោះសេលើកូស ទីមួយ នីកាទ័រ (Seleucus I Nicator, ឆ្នាំ ៣១១-២៨០ មុនគ.ស) ។ *អំណាច គ្រប់គ្រងរបស់អ្នកនោះ* គឺជាអំណាចគ្រប់គ្រងដែលចាប់ផ្ដើមពីចក្រភពបាប៊ីឡូន ដែលស្ដេចអង្គនេះនឹងពង្រីកដោយកាន់កាប់ទឹកដីខាងកើត និងខាងលិចបន្ថែមទៀត ។
**១១:៦** *ព្រះរាជបុត្រីនៃស្ដេចខាងត្បូង* គឺមានព្រះនាមថា បេរេណាយស៍ (Berenice) ដែលជាបុត្រីរបស់ស្ដេចផ្ទោលេមី ទីពីរ ភីឡាឌែលភ័ស (Ptolemy II Philadelpus, ឆ្នាំ ២៨៥-២៤៦ មុនគ.ស) នៃនគរអេស៊ីព្ទ ។ *ស្ដេចខាងជើង* គឺស្ដេចអាន់ទីយ៉ូកូស ទីពីរ ដេអូស (Antiochus II Theos, ឆ្នាំ ២៦១-២៤៦ មុនគ.ស) នៃនគរស៊ីរី ។ *សម្ពន្ធមិត្រនឹងគ្នា* គឺជាសម្ព័ន្ធមិត្រដែលបង្កើតឡើយដោយការអភិសេកព្រះនាងបេរេណាយស៍ ជាមួយនឹងស្ដេចអាន់ទីយ៉ូកូស ។ *នាងនឹងមិនមានអំណាចនៅជាយូទេ ហើយបិតានាងក៏មិនជាប់នៅ* នៅត្រង់ចំណុចនេះ អតីតមហេសីរបស់ស្ដេចផ្ទោលេមី ព្រះនាមឡាអូឌីស៍ (Laodice) បានរៀបគម្រោងធ្វើគុតព្រះនាងបេរេណាយស៍ និងស្ដេចអាទីយ៉ូកូស។ *បិតានាង* ព្រះនាងបេរេណាយស៍ ព្រមទាំងព្រះបិតាបានស្លាប់ ប្រហែលជាក្នុងពេលដំណាលគ្នា ។
**១១:៧** *លំពង់១ពន្លកចេញពីវង្សនាង* ព្រះរាមរបស់ព្រះនាងបេរេណាយស៍ គឺផ្ទោលេមី ទី៣ អើហ្គេតេស (ឆ្នាំ ២៤៦-២២១ មុនគ.ស) នៃនគរអេស៊ីព្ទ បានរួមគំនិតគ្នាជាមួយនឹងព្រះនាងឡាអូឌីស៍ ។ *ស្ដេចខាងជើង* គឺស្ដេច សេលើកូស ទី២ កាលីនីកូស ( (Seleucus III Calinicus, ២៤៦-២២១ មុនគ.ស) នៃនគរស៊ីរី ។ *បន្ទាយរបស់គេ* អាចជា (១).សេលើស៊ា (មើល កច ១៣:៤ និងការពន្យល់) ដែលជាកំពង់ផែនៃក្រុងអាន់ទីយ៉ូក ។ ឬជា (២).ទីក្រុងអាន់ទីយ៉ូក ។

ក៏តយុទ្ធនឹងគេព្រមទាំងឈ្នះផង ៨រួចនឹងកៀរយកអស់
ទាំងព្រះ និងរូបសិតរបស់គេ[ជ] ព្រមទាំងប្រដាប់ធ្វើពីប្រាក់
និងមាសដ៏មានដំឡៃនាំទៅស្រុកអេស៊ីព្ទ[ឈ] បន្ទាប់នោះនឹង
ខានទៅច្បាំងនឹងស្តេចខាងជើងជាយូរឆ្នាំ ៩ឯស្តេចខាង
ជើង នោះនឹងទន្ទ្រានចូលក្នុងព្រំដែនរបស់ស្តេចខាងត្បូង
តែនឹងត្រូវត្រឡប់ទៅឯស្រុកកំណើតរបស់ខ្លួនវិញ ។
១០រួចមកពួកកូនចៅរបស់ស្តេចនោះនឹងធ្វើចំបាំង គឺ
នឹងប្រមូលកងទ័ពយ៉ាងធំជាច្រើន កងទ័ពនោះនឹងចេញ
ទៅសាយពេញពាស[ញ] ហើយដើរកាត់ស្រុកទោច្បាំង រហូត
ដល់បន្ទាយរបស់គេ ១១គ្រានោះ ស្តេចខាងត្បូងនឹងមាន
សេចក្តីក្រេវក្រោធឆុរឆេវឡើង ចេញទៅតយុទ្ធនឹងស្តេច
ខាងជើង គឺនឹងដំរៀបពលទ័ពយ៉ាងសន្ធឹក ហើយពលទ័ព
របស់គេ នឹងត្រូវប្រគល់មកក្នុងកណ្តាប់ដៃនៃស្តេចខាង
ត្បូង[ដ] ១២កាលណាបានឈ្នះពលទ័ពរបស់គេហើយ នោះ
ទ្រង់នឹងមានព្រះទ័យប៉ោងឡើង រួចទ្រង់នឹងសំឡាប់ពួកគេ
ទាំងម៉ឺនៗ តែតទៅនឹងឈ្នះមិនបានទេ ១៣ដ្បិតស្តេចខាង
ជើងនឹងវិលត្រឡប់មកវិញ នាំទាំងពលទ័ពយ៉ាងសន្ធឹក
លើសជាងជាន់មុនទៅទៀត ហើយក្រោយបន្តិចទៅ គឺ
ក្រោយប្រមាណប៉ុន្មានឆ្នាំទៅមុខ ទ្រង់នឹងនាំពលទ័ពយ៉ាង
ធំ និងគ្រឿងចំបាំងយ៉ាងសន្ធឹកមក ១៤នៅគ្រានោះនឹងមាន
មនុស្សជាច្រើនតាំងខ្លួនឡើង ទាស់នឹងស្តេចខាងត្បូងឯក្នុង
សាសន៍របស់អ្នក ក៏នឹងមានពួកមនុស្សច្រឡោតខ្លះលើក
ខ្លួនឡើងដែរ ដើម្បីនឹងសំរេចការជាក់ស្តែងនេះ តែ
គេនឹងត្រូវដួលចុះទេ ១៥យ៉ាងនោះ ស្តេចខាងជើងនឹងមក
ដីកស្នាមភ្លោះ[ឋ] ហើយចាប់យកបានទីក្រុងដែលមានគ្រឿង
ការពារជាបរិបូរឯពលទ័ពរបស់ស្រុកខាងត្បូងនឹងធន់នៅ
មិនបាន ព្រមទាំងពលជ្រើសរើសរបស់ស្តេចនោះផង ក៏
នឹងគ្មានកំឡាំងល្មមទប់ទល់ឡើយ ១៦គឺស្តេចដែលលុក
ចូលមកច្បាំងនោះ នឹងធ្វើតាមតែអំពើចិត្ត[ឌ] ឥតមានអ្នក
ណាអាចនឹងឈរនៅមុខទ្រង់បានឡើយ[ឍ] ទ្រង់នឹងឈរនៅ
ក្នុងស្រុកដ៏ឧត្តម ទាំងមានអំណាចបំផ្លាញនៅក្នុងកណ្តាប់
ដៃផង[ណ] ១៧ហើយទ្រង់នឹងមានកំណិតគិតនាំកំឡាំងនៃរាជ្យ
ទ្រង់ទាំងអស់មកទៀត តែទ្រង់បែរជាតាំងស្ពានមេត្រីវិញ
ហើយក៏សំរេចតាមនោះ រួចលើកបុត្រីខ្លួន ឱ្យដល់ស្តេច
ខាងត្បូង ដើម្បីនឹងគិតបំផ្លាញទ្រង់ តែនាងមិនចូលគំនិត
ឬសំរេច[ត]តាមបំណងបិតាឡើយ ១៨ក្រោយនោះមកទ្រង់
នឹងបែរព្រះភក្ត្រទៅខាងកោះសមុទ្រ[ថ]ទាំងប៉ុន្មាន ហើយ
នឹងចាប់យកបានជាច្រើនដែរ តែនឹងមានមេទ័ព១ក៏ចាត់
សេចក្តីអាម៉ាស់ខ្មាស ចំពោះស្តេចនោះចេញ អើមួយ
ទៀតនឹងទំលាក់សេចក្តីអាម៉ាស់ខ្មាសនោះទៅលើទ្រង់វិញ[ទ]
១៩នោះទ្រង់នឹងបែរមុខទៅឯបន្ទាយនៅក្នុងស្រុករបស់ខ្លួន
តែទ្រង់នឹងចំពប់ដួល[ធ]ឥតមានអ្នកណាឃើញទៀតឡើយ[ន] ។
២០បន្ទាប់នោះមក នឹងមានស្តេច១សោយរាជ្យឡើង

**១១:៨** ជ អស ៣៧:១៩ ៤៦:១-២ ឈ យរ ៤៣:១២
**១១:១០** ញ អស ៨:៨ យរ ៤៦:៨ ដយ ៩:២៦
**១១:១១** ដ ដយ ៨:៧-៨
**១១:១៥** ឋ អគ ៤:២
**១១:១៦** ឌ ដយ ៨:៤ ឍ យស ១:៥ ដយ ៨:៧ ណ ដយ ៨:៩
**១១:១៧** ត ទដ ២០:៤
**១១:១៨** ថ អស ៦៦:១៩ យរ ២៥:២២ ទ ហស ១២:១៤
**១១:១៩** ធ ទដ ២៧:២ ៤៦:២ ន ទដ ៣៧:៣៦ អគ ២៦:២១

**១១:៨** *ព្រះ និងរូបសិតរបស់គេ* គឺរូបព្រះរបស់សាសន៍ស៊ីរី និងរូបព្រះរបស់អេស៊ីព្ទដែលចក្រភពពើស៊ីរឹបអូស បន្ទាប់ពីបានវាយ និងកាន់កាប់នគរអេស៊ីព្ទ នៅឆ្នាំ ៥២៥ មុនគ.ស ។

**១១:១០** *ពួកកូនចៅរបស់ស្តេចនោះ* គឺស្តេចសេលើកូស ទី៣ សេរ៉ូណូស (Seleucus III Ceraunus, ឆ្នាំ ២២៦-២២៣ មុនគ.ស) និង អាន់ទីយ៉ូកូស ទី៣ (Antiochus III, ឆ្នាំ ២៣៣-១៨៧ មុនគ.ស) ពួកបុត្រារបស់ស្តេចសេលើកូស ទី២ (Seleucus II) ។ *បន្ទាយរបស់គេ* គឺបន្ទាយព័ទរបស់ស្តេចផ្តោលេមី នៅក្រុងរ៉ាហ្វៀ (នៅភាគនិរតីនៃតំបន់កាសា) ។

**១១:១១** *ស្តេចខាងត្បូង* គឺស្តេចផ្តោលេមី ទី៤ ភីឡូផាទ័រ (២២១-២០៣ មុនគ.ស) នៃនគរអេស៊ីព្ទ ។ *ស្តេចខាងជើង* អានទីយ៉ូកូស ទី៣ ។ *ប្រគល់មកក្នុងកណ្តាប់ដៃ* គឺនៅត្រង់តំបន់រ៉ាហ្វៀ នៅឆ្នាំ ២១៧ មុនគ.ស ។

**១១:១២** *សំឡាប់ពួកគេទាំងម៉ឺនៗ* តាមប្រវត្តិវិទូក្រិក គឺលោកប៉ូលីបីយ៉ូស (Polybius) ទ័ពថ្មើរជើងរបស់ស្តេចអាន់ទីយ៉ូកូសត្រូវបាត់បង់ជីវិតអស់មួយម៉ឺននាក់ នៅតំបន់រ៉ាហ្វៀ ។

**១១:១៤** *ស្តេចខាងត្បូង* គឺស្តេចផ្តោលេមី ទី៥ អេពីផានេស (Ptolemy V Epiphanes, ឆ្នាំ ២០៣-១៨១ មុនគ.ស) នៃនគរអេស៊ីព្ទ ។ *ក្នុងសាសន៍របស់អ្នក ក៏នឹងមានពួកមនុស្សច្រឡោតខ្លះ* គឺពួកសាសន៍យូដាដែលចូលរួមក្នុងកងកម្លាំងរបស់ស្តេចអាន់ទីយ៉ូកូស ។ *តែនឹងត្រូវដួលចុះទេ* មេទ័ពរបស់ស្តេចផ្តោលេមី ឈ្មោះ ស្កូផាស (Scopas) បានបង្ក្រាបការបះបោរនៅឆ្នាំ ២០០ មុនគ.ស ។

**១១:១៥** *ទីក្រុងដែលមានគ្រឿងការពារជាបរិបូរ* គឺកំពុងផែស៊ីដូននៅសមុទ្រមេឌីទែរ៉ាណេ ។

**១១:១៦** *ស្តេចដែលលុកចូលមកច្បាំង* គឺស្តេចអាន់ទីយ៉ូកូស ដែលកាន់កាប់ទឹកដីបរិសុទ្ធនៅឆ្នាំ ១៩៧ មុនគ.ស ។ *ស្រុកដ៏ឧត្តម* មើលការពន្យល់ ៨:៩-១២ ។

**១១:១៧** *រួចលើកបុត្រីខ្លួន ឱ្យ* ស្តេចអាន់ទីយ៉ូកូសបានលើកបុត្រី គឺព្រះនាងក្លេអូប៉ាត្រា ទី១ ឱ្យដល់ស្តេចផ្តោលេមី ទី៥ នៅឆ្នាំ ១៩៤ មុនគ.ស ។

**១១:១៨** *ទ្រង់* គឺស្តេចអាន់ទីយ៉ូកូស ។ *កោះសមុទ្រ* គឺតំបន់អាស៊ីមីន័រ (Asia Minor) ហើយប្រហែលជារួមទាំងដីគោកនៃនគរក្រិកផងដែរ ។ *មេទ័ព* គឺសាសន៍រ៉ូម៉ាំង ឈ្មោះ លូសៀស កូនេលៀស ស្គីភីអូ អាស៊ីអាទីកូស (Lucius Cornelius Scipio Asiaticus) ដែលបានវាយឈ្នះស្តេចអាន់ទីយ៉ូកូសនៅតំបន់ម៉ាញេស៊ី (Magnesia) នៅអាស៊ីម៉ាន័រ នៅឆ្នាំ ១៩០ មុនគ.ស ។

**១១:១៩** *ចំពប់ដួល* ស្តេចអាន់ទីយ៉ូកូសត្រូវសុគតនៅឆ្នាំ ១៨៧ មុនគ.ស នៅក្នុងពេលព្យាយាមវាយលុកលុយព្រះវិហារមួយនៅក្នុងខេត្តអេលីម៉ាអ៊ីស (Elymais) ។

**១១:២០** *ស្តេច ១ សោយរាជ្យឡើងជំនួស* គឺសេលើកូស ទី៤ ភីឡូប៉ាទ័រ

ជំនួស ជាអ្នកដែលនឹងចាត់ភ្នាក់ងារ ឱ្យដើរកាត់ស្រុករុង
រឿងក្នុងនគរ ដើម្បីរ៉ឹងទារសួយ[ប] តែក្រោយមកមិនយូរថ្ងៃ
ស្ដេចនោះនឹងត្រូវបំផ្លាញទៅ មិនមែនក្នុងការកំហឹង ឬ
ការសង្គ្រាមនោះទេ ២១រួចនឹងមានម្នាក់ដែលគួរស្អប់ខ្ពើម[ផ]
តាំងខ្លួនឡើងជំនួសទ្រង់ ឥតមានអ្នកណាប្រគល់រាជសក្តិ
ដល់អ្នកនោះឡើយ[ព] គឺនឹងចូលមកក្នុងគ្រាសុខសាន្ត ដែង
យករាជ្យដោយសេចក្តីបញ្ចើចវិញ ២២ឯពលទ័ពក៏មានជ័យ
នឹងត្រូវចុះចាញ់[ភ] នៅចំពោះអ្នកនោះហើយនឹងត្រូវបាក់
បែកអស់ទៅ អើ ទោះទាំងសំដេចសង្ឃនៃសេចក្តីសញ្ញា
ផង[ម] ២៣ក្រោយដែលគេបានតាំងសញ្ញានឹងអ្នកនោះហើយ
នោះ វានឹងប្រព្រឹត្តដោយឧបាយ[យ] ដ្បិតនឹងឡើងមក
ហើយនឹងមានកំឡាំងឡើង ដោយមានគ្នាតែបន្តិចបណ្ដោះ
២៤គឺនៅក្នុងនៅក្នុងគ្រាសុខសាន្តដែលវានឹងឡើងមកឯ
កន្លែងដ៏ល្អបំផុតក្នុងដែនខេត្ត ហើយវានឹងធ្វើការដែលពួក
ឰយុកោវាត។មកមិនដែលធ្វើឡើយគឺវានឹងយករបឹបនឹង
របស់ដែលប្លន់បានហើយទ្រព្យសម្បត្តិផ្សេង។កំចាយដល់
គេ[រ] អើវានឹងបង្កើតកិច្ចកលរបស់វា ទាស់នឹងទីមាំមួន នៅ
រវាង១ពេល ២៥វានឹងដាស់កំឡាំង និងសេចក្តីអង់អាច
របស់វាឡើងទាស់នឹងស្តេចខាងត្បូងដោយមានពលទ័ព
យ៉ាងសន្ធឹកហើយស្តេចខាងត្បូងនឹងមកច្បាំងនឹងវាមាន
ពលទ័ពយ៉ាងសន្ធឹកហើយខ្លាំងពូកែផង តែនឹងទប់ទល់មិន
បានទេ ពីព្រោះនឹងមានគេបង្កើតកិច្ចកលទាស់នឹងទ្រង់
២៦អើ អ្នក១ដែលធ្លាប់ស៊ីចំណីរបស់ទ្រង់នឹងបំផ្លាញទ្រង់
បង់ ហើយកងទ័ពរបស់ទ្រង់នឹងបែកខ្ចែករត់ទៅតែពាស
ក៏នឹងមានជាច្រើនដួលស្លាប់ដែរ ២៧ឯស្តេចទាំង២អង្គ
នេះ គេនឹងមានចិត្តរិះរកធ្វើតែការកំណាចទទេ[ល] គេនឹង
កុហក[វ]ដល់គ្នានឹងគ្នា ក្នុងពេលកំពុងអង្គុយនៅតុជាមួយគ្នា
ផង តែការនោះនឹងមិនចំរើនដល់គេឡើយ ដ្បិតវេលាចុង
បំផុតនឹងមកក្នុងពេលកំណត់ទេ[ស]។

២៨គ្រានោះ វានឹងវិលទៅឯស្រុករបស់ខ្លួនវិញ នាំ
ទាំងទ្រព្យសម្បត្តិជាច្រើនទៅផង រួចវានឹងកើតមានចិត្ត
ទាស់ទទឹងនឹងសេចក្តីសញ្ញាដ៏បរិសុទ្ធ ហើយនឹងធ្វើតាម
តែបំណងចិត្ត រួចវិលទៅឯស្រុករបស់ខ្លួនវិញ ២៩លុះដល់
វេលាកំណត់ វានឹងត្រឡប់មកចូលក្នុងស្រុកខាងត្បូងទៀត
តែជាន់ក្រោយនេះនឹងមិនបានដូចជាជាន់មុនទេ ៣០ពីព្រោះ
អស់ទាំងនាវា ពីស្រុកគីទីម[ហ] នឹងមកទាស់នឹងវា ដូច្នេះវា
នឹងធ្លាក់ចិត្ត[ឡ] ហើយវិលទៅវិញ ដោយមានសេចក្តីគ្នាន់
ក្នាញ់[អ]ទាស់នឹងសេចក្តីសញ្ញាដ៏បរិសុទ្ធ ហើយនឹងធ្វើតាម
តែអំពើចិត្ត គឺវានឹងត្រឡប់មកវិញ ហើយរួមគំនិតនឹង
ពួកអ្នកដែលក្បត់សេចក្តីសញ្ញាដ៏បរិសុទ្ធនោះ ៣១គ្រានោះ
ពលទ័ពនឹងត្រូវខាងវា ហើយគេនឹងបង្អាប់ទីបរិសុទ្ធ គឺជា
ទីមាំមួន ព្រមទាំងបញ្ឈប់បំបាត់ការថ្វាយដង្វាយជានិច្ច
ចេញ[ក] ហើយតាំងសេចក្តីគួរស្អប់ខ្ពើមដែលនាំឱ្យបង្ខូច
បំផ្លាញឡើង[ខ] ៣២ឯពួកអ្នកដែលប្រព្រឹត្តអាក្រក់ទាស់នឹង
សេចក្តីសញ្ញា នោះវានឹងនាំបង្ខូចចិត្តគេ ដោយពាក្យ
បញ្ចើច តែចំណែកពួកអ្នកទាំងប៉ុន្មានដែលស្គាល់ព្រះនៃ

**១១:២០** ប អស ៦០:១៧
**១១:២១** ផ ដយ ៤:១៧ ព ដយ ៨:២៥
**១១:២២** ភ អស ២៨:១៥ ម ដយ ៨:១០–១១
**១១:២៣** យ ដយ ៨:២៥
**១១:២៤** រ នហ ៩:២៥
**១១:២៧** ល ទដ ៦៤:៦ វ ទដ ១២:២ យរ ៩:៥ ស ហព ២:៣
**១១:៣០** ហ លប ១០:៤ ឡ ១សយ ១៧:៣២ អ យប ១៥:១៣
**១១:៣១** ក ហស ៣:៤ ខ យរ ១៩:៤ ដយ ៨:១១–១៣ ៩:២៧ មថ ២៤:១៥ មក ១៣:១៤

(Seleucus IV Philopator, ឆ្នាំ ១៨៧–១៧៥ មុនគ.ស) ដែលត្រូវជាបុត្រា និងអ្នកស្នងរាជ្យរបស់ស្តេចអាន់ទីយ៉ូកូស ។ *អ្នក... រ៉ឹងទារសួយ* គឺរដ្ឋមន្ត្រីហិរញ្ញវត្ថុរបស់ស្តេចសេលើកូស ឈ្មោះ ហេលីអូដូរ៉ូស (Heliodorus) ។ *ស្តេចនោះនឹងត្រូវបំផ្លាញទៅ* ស្តេចសេលើកូស គឺជាជនរងគ្រោះ ដោយសារគម្រោងអាក្រក់របស់ហេលីអូដូរ៉ូស (Heliodorus) ។

**១១:២១** *ម្នាក់ដែលគួរស្អប់ខ្ពើម* គឺប្អូនប្រុសរបស់ស្តេចសេលើកូស ឈ្មោះ អាន់ទីយ៉ូកូស ទី៤ អេពីផានេស (Antiochus IV Ephipanes, ឆ្នាំ ១៧៥–១៦៤ មុនគ.ស)។ *ឥតមានអ្នកណាប្រគល់រាជសក្តិ* ស្តេចអាន់ទីយ៉ូកូសបានដណ្តើមអំណាច ពីអ្នកស្នងរាជដែលនៅវ័យក្មេងនៅឡើយ គឺបុត្រារបស់ស្តេចសេលើកូស (ក្រោយមកត្រូវហៅថា ឌីមេទ្រីស ទី១ វិញ, Demetrius I)។ *ចូលមក* គឺចូលឈ្លានពានតំបន់ ស៊ីរ៉ូ–ប៉ាលេស្ទីន (Syro-Palestine)។

**១១:២២** *សំដេចសង្ឃនៃសេចក្តីសញ្ញា* គឺសម្តេចសង្ឃឈ្មោះ អូនីអាស ទី៣ (Onias III) ដែលគេធ្វើឃាតនៅឆ្នាំ ១៧០ មុនគ.ស ។

**១១:២៣** *អ្នកនោះ* អាន់ទីយ៉ូក ។

**១១:២៤** *កន្លែងដ៏ល្អបំផុត* គឺសំដៅទៅលើ ទឹកដីបរិសុទ្ធ ឬនគរ អេស៊ីព្ទ ។ *ទីមាំមួន* គឺនៅក្នុងនគរ អេស៊ីព្ទ ។

**១១:២៥** *ស្តេចខាងត្បូង* គឺស្តេចផ្តោលេមី ទី៦ ។

**១១:២៦** *កងទ័ពរបស់ទ្រង់* គឺកងទ័ពរបស់ស្តេចផ្តោលេមី ។

**១១:២៧** *ស្តេចទាំង ២ អង្គ* គឺស្តេចអាន់ទីយ៉ូកូស និងផ្តោលេមី ដែលស្តេចផ្តោលេមីត្រូវរស់នៅក្នុងមន្ទីឃុំឃាំងរបស់ស្តេចអាន់ទីយ៉ូកូស ។

**១១:២៨** *ទាស់ទទឹងនឹងសញ្ញាដ៏បរិសុទ្ធ* នៅក្នុងឆ្នាំ ១៦៩ មុនគ.ស ស្តេចអាន់ទីយ៉ូកូសបានវាយចូលលុកលុយព្រះវិហារនៃទីក្រុងយេរូសាឡិម បានសង់បន្ទាយទ័ពនៅទីនោះ ហើយសម្លាប់រង្គាលសាសន៍យូដាជាច្រើននាក់នៅក្នុងក្រុងនោះ ។

**១១:៣០** *អស់ទាំងនាវា ពីស្រុកគីទីម* គឺកងទ័ពជើងទឹករបស់ពួករ៉ូម៉ាំង ដែលដឹកនាំដោយ លោកប៉ូពីលីអ័ស លាណាស (Popilius Laenas)។ *ពួកអ្នកដែលក្បត់សេចក្តីសញ្ញាដ៏បរិសុទ្ធ* គឺសាសន៍យូដាដែលផ្លាស់ប្តូរជំនឿ (មើល ខ.៣២) ។

**១១:៣១** *សេចក្តីគួរស្អប់ខ្ពើមដែលនាំឱ្យបង្ខូចបំផ្លាញ* មើល ៩:២៧ ១២:១១ គឺសំដៅទៅលើ អាសនាសម្រាប់ព្រះសាសន៍ដទៃ ឈ្មោះ ហ្សីស អូឡាំពីយ៉ូស (Zeus Olympius) ដែលស្តេចអាន់ទីយ៉ូកូស អេពីផានេស (Antiochus Epiphanes) ឱ្យគេសង់នៅឆ្នាំ ១៦៨ មុនគ.ស ។ សេចក្តីដែលគួរស្អប់ខ្ពើមនេះ គឺត្រូវនឹងសេចក្តីទំនាយដែលព្រះយេស៊ូវទ្រង់បានថ្លែង (មើល មថ ២៤:១៥ លក ២១:២០ និងការពន្យល់) ។

ខ្លួនគេនឹងមានចិត្តរឹងប៉ឹង[គ] ហើយនឹងប្រតិបត្តិតទៅ ៣៣ពួក
អ្នកដែលមានប្រាជ្ញាក្នុងបណ្ដាជន គេនឹងបង្រៀន[ឃ]មនុស្ស
ជាច្រើន ប៉ុន្តែគេនឹងត្រូវដួលដោយដាវនឹងភ្លើងព្រមទាំង
ត្រូវដឹកទៅជាឈ្លើយ ហើយត្រូវគេរឹបជាន់ជាយូរថ្ងៃផង[ង]
៣៤រីឯកាលណាគេត្រូវដួល នោះគេនឹងមានសេចក្ដីជំនួយ
បន្តិចដែរ ក៏នឹងមានមនុស្សជាច្រើនចូលខាងគេ ដោយ
ចិត្តក្រឡេចក្រឡុច[ច] ៣៥ឯពួកគេដែលមានប្រាជ្ញា នឹងមាន
ខ្លះដួលចុះ ដើម្បីឱ្យបានសំរង[ឆ] ហើយសំអាតពួកគេ ព្រម
ទាំងឱ្យគេបានស្គុស ដរាបដល់វេលាចុងបំផុត ដ្បិតការ
ទាំងនេះនឹងមកក្នុងពេលកំណត់ទេ ។

## ស្ដេចដែលតម្កើងខ្លួនឡើង

៣៦ស្ដេចនោះនឹងធ្វើតាមតែអំពើចិត្ត ក៏នឹងដំកើងខ្លួន[ជ]
ហើយលើកខ្លួនខ្ពស់ជាងអស់ទាំងព្រះ វានឹងពោលយ៉ាង
អស្ចារ្យ[ឈ]ទាស់នឹងព្រះនៃអស់ទាំងព្រះ[ញ] វានឹងចេះតែចំរើន
ដរាបដល់សេចក្ដីក្នាន់ក្នាញ់[ដ]បានសំរេច ដ្បិតការដែលបាន
សំរេចនឹងធ្វើហើយនោះត្រូវធ្វើទៅ[ឋ] ៣៧វានឹងមិនយកចិត្ត
ទុកដាក់ចំពោះព្រះនៃពួកឰយុកោវា ឬចំពោះបំណងចិត្ត
របស់ពួកស្រីៗទេ ក៏មិនកោតខ្លាចដល់ព្រះណាផង ដ្បិត
វានឹងដំកើងខ្លួនជាធំលើសជាងទាំងអស់ ៣៨ទោះបើយ៉ាង
នោះ គង់តែវានឹងគោរពតាមព្រះនៃបន្ទាយដែរ ហើយ
ឯព្រះ១ដែលពួកឰយុកោវាមិនបានស្គាល់សោះ នោះវា
នឹងគោរពដោយមាស ប្រាក់ នឹងត្បូងមានដំឡៃ ហើយ
នឹងរបស់ថ្លៃវិសេស ៣៩គឺដោយព្រះដទៃនោះ ដែលវានឹង
ឈ្នះទីមាំមួនរបស់សាសន៍ផ្សេងៗ ឯអ្នកណាដែលនឹង
យល់ខាងខ្លួន នោះវានឹងលើកឱ្យមានសក្តិយសជាធំឡើង
ហើយនឹងតាំងឱ្យគេគ្រប់គ្រងលើមនុស្សជាច្រើន ព្រមទាំង
ចែកឱ្យដល់គេទុកជារង្វាន់ផង ។

៤០លុះដល់គ្រាចុងបំផុត នោះស្ដេចខាងត្បូង[ឌ]នឹងត
យុទ្ធនឹងវា តែស្ដេចខាងជើងនឹងមកទាស់នឹងទ្រង់ដូចជា
ខ្យល់កួច[ឍ] មានទាំងរទេះចំបាំង ពលសេះ និងនាវា
ជាច្រើន វានឹងលុកចូលក្នុងប្រទេសដទៃទាំងប៉ុន្មាន ទាំង
សាយចេញដូចជាទឹកជន់[ណ] រួចបង្ហួសទៅ ៤១វានឹងចូលទៅ
ក្នុងស្រុកឧត្តមដែរ[ត] ហើយមនុស្សជាច្រើននឹងត្រូវផ្ដួលចុះ
តែសាសន៍ទាំងនេះ នឹងបានរួចពីកណ្ដាប់ដៃវា គឺអេដំម[ថ]
ម៉ូអាប់[ទ] នឹងពួកសំខាន់ក្នុងពួកកូនចៅអាំម៉ូន ៤២វានឹង
លូកដៃទៅលើប្រទេសទាំងអស់ ហើយស្រុកអេស៊ីព្ទក៏មិន
បានរួចដែរ ៤៣គឺវានឹងគ្រប់គ្រងលើអស់ទាំងមាសនិង
ប្រាក់ជាព្រះរាជទ្រព្យ នឹងលើគ្រប់ទាំងរបស់មានដំឡៃនៅ
ស្រុកអេស៊ីព្ទ[ធ] ឯពួកសាសន៍លីប៊ី[ន] និងសាសន៍អេធីយ៉ូពី គេ
នឹងជាប់តាមដានជើងវា ៤៤តែដំណឹងដែលនឹងចេញពី
ស្រុកខាងកើត ហើយពីខាងជើង នឹងនាំឱ្យវាវិតក្កព្រួយ
ដូច្នេះវានឹងចេញទៅ ដោយសេចក្ដីក្រេវក្រោធយ៉ាងខ្លាំង
ដើម្បីនឹងបំផ្លាញ ហើយរំលាងមនុស្សជាច្រើនបង់ ៤៥វា
នឹងដំឡើងអស់ទាំងពន្លានៃព្រះរាជស្ថាន នៅជាកណ្ដាល
សមុទ្រ ហើយនិងភ្នំបរិសុទ្ធដ៏ឧត្ដម[ប] ប៉ុន្តែវានឹងមកដល់
ចុងបំផុតរបស់វា ឥតមានអ្នកណាជួយឡើយ ។

## គ្រាចុងក្រោយ

**១២** ១នៅគ្រានោះ មីកែល[ក] ជាមហាទេវតាដែលដំណាង

**១១:៣២** គ មីក ៥:៧–៩
**១១:៣៣** ឃ ដយ ១២:៣ មឡ ២:៧ ង មថ ១៤:៩ យហ ១៦:២ ហព ១១:៣២–៣៨
**១១:៣៤** ច មថ ៧:១៥ រម ១៦:១៩
**១១:៣៥** ឆ យបប ២៨:១ ទដ ៧៨:៣៨ អស ៤៨:១០ ដយ ១២:១០ សក ១៣:៩ យហ ១៥:២
**១១:៣៦** ជ យដ ១:១៦ ឈ វវ ១៣:៥–៦ ញ ចទ ១០:១៧ អស ១៤:១៣–១៤ ដយ ៧:២៥ ៨:១១–១២,២៥ ២ថន ២:៤ ដ អស ១០:២៥ ២៦:២០ ឋ អគ ៣៥:១៣ ដយ ៨:២៤
**១១:៤០** ឌ អស ២១:១ ឍ អស ៥:២៨ ណ អស ៨:៧ អគ ៣៨:៤
**១១:៤១** ត អគ ២០:៦ មឡ ៣:១២ ថ អស ១១:១៤ ទ យរ ៤៨:៤៧
**១១:៤៣** ធ អគ ៣០:៤ ន ២របា ១២:៣ ណហ ៣:៩ **១១:៤៥** ប អស ២:២,៤ ដយ ៨:៩
**១២:១** ក ដយ ១០:១៣ យដ ១:៩

**១១:៣៣** *ពួកអ្នកដែលមានប្រាជ្ញា* គឺអ្នកដឹកនាំសាសន៍យូដាដែលកោតខ្លាចព្រះ ដែលដឹងនាំចលនាតស៊ូ ហើយគេហៅពួកអ្នកទាំងនោះម្យ៉ាងទៀតថា ហាស៊ីឌីម (Hasidim) ។ *ត្រូវដួលដោយដាវ និងភ្លើង ព្រមទាំងដឹកទៅជាឈ្លើយ ហើយត្រូវរឹបជាន់ជាយូរថ្ងៃផង* មើល ហព ១១:៣៦–៣៨ ។
**១១:៣៤** *សេចក្ដីជំនួយបន្តិចដែរ* គឺជាជ័យជម្នះនៅពេលដំបូង ដោយការធ្វើសង្គ្រាមវាយឈ្លប (ឆ្នាំ ១៦៨ មុនគ.ស) ដែលមានប្រភពនៅតំបន់ម៉ូឌេអ៊ីន (Modein) ដែលស្ថិតនៅភាគពាយព្យ និងចម្ងាយ ២៧,៣ គីឡូម៉ែត្រ ពីទីក្រុងយេរូសាឡិម ។ លោកម៉ាតាធាស (Mattathias) និងកូនប្រុសឈ្មោះយូដាស ម៉ាកាប៊ីស (Judas Maccabeus) គឺជាអ្នកដឹកនាំចលនាតស៊ូនេះ ។ នៅខែធ្នូ ឆ្នាំ ១៦៥ មុនគ.ស គេបានចាប់ផ្ដើមសម្អាតឱ្យប្រើអាសនានៃព្រះវិហារឡើងវិញ ។
**១១:៣៥** *វេលាចុងបំផុត* មើល ខ.៤០ ១២:៤,៩ ។ នៅត្រង់ចំណុចនេះ លោកដានីយ៉ែលបញ្ចប់ការថ្លែងទំនាយអំពីស្ដេចអាន់ទីយ៉ូកូស អេពីផានេស (Antiochus Epiphanes) ហើយចាប់ផ្ដើមថ្លែងទំនាយអំពីការដែលត្រូវកើតឡើងនៅក្នុងពេលដ៏យូរខាងមុខវិញម្ដង ។
**១១:៣៦** ចាប់ពីខនេះរហូតដល់ចុងបញ្ចប់នៃជំពូក១១ គឺជាការថ្លែងទំនាយអំពីពួកទទឹងព្រះគ្រីស្ទ (មើលការពន្យល់ ៧:៨ ៩:២៧) ។ ហើយសេចក្ដីលម្អិតនៃវគ្គនេះ គឺមិនបាននិយាយអំពីស្ដេចអាន់ទីយ៉ូកូស អេពីផានេសទេ ។ មើល ២ថន ២:៣–៤ និងការពន្យល់, ធៀប វវ ១៣:៥–៨ ។
**១១:៣៧** *មិនយកចិត្តទុកដាក់ . . . ចំពោះបំណងចិត្តរបស់ពួកស្រីៗ* តាមធម្មតា គឺសំដៅទៅលើព្រះថាមូស (មើល អគ ៨:១៤ និងការពន្យល់) ឬព្រះមែស៊ី (មើល ហក ២:៧ និងការពន្យល់) ។
**១១:៤០–៤៥** នៅក្នុងវគ្គនេះ គឺនិយាយអំពីជម្លោះវាយ ពួកទទឹងនឹងព្រះគ្រីស្ទ និងសត្រូវផ្នែកនយោបាយរបស់ពួកគេ ។ ពួកទទឹងព្រះគ្រីស្ទនោះនឹងត្រូវដល់ទីបញ្ចប់របស់ខ្លួននៅ "ភ្នំបរិសុទ្ធដ៏ឧត្តម្ភ" (ខ.៤៥) ដែលជាទួលព្រះវិហារទីក្រុងយេរូសាឡិម ដែលការនេះប្រហែលជាជាប់ទាក់ទងនឹងសង្គ្រាមអើម៉ាគេដូន (វវ ១៦:១៣–១៦) ។
**១១:៤១** *ស្រុកឧត្តម* មើលការពន្យល់ ៨:៩–១២ ។

ពួកកូនចៅរបស់សាសន៍អ្នក លោកនឹងឈរឡើង ក៏នឹង
មានគ្រាវេទនាជាខ្លាំង[ខ] ដល់ម្ល៉េះបានជាចាប់តាំងពីមាន
នគរដរាបដល់វេលានោះឯង នោះមិនដែលកើតមានយ៉ាង
ដូច្នោះឡើយ ហើយនៅគ្រានោះ សាសន៍អ្នកនឹងបាន
ប្រោសឱ្យរួច[គ] គឺអស់អ្នកណាដែលមានកត់ទុកក្នុងបញ្ជី[ឃ]
២ហើយពួកអ្នកដែលដេកលក់នៅក្នុងធូលីដី និងភ្ញាក់ឡើង
វិញជាច្រើន[ង] គឺខ្លះឱ្យបានជីវិតរស់នៅអស់កល្បជានិច្ច
និងខ្លះឱ្យបានសេចក្តីអាម៉ាស់ខ្មាស ហើយឱ្យបានជាទីខ្ពើម
ឆ្អើមនៅអស់កល្បជានិច្ចវិញ[ច] ៣ឯពួកអ្នកដែលមានប្រាជ្ញា[ឆ]
គេនឹងភ្លឺ[ជ]ដូចជារស្មីនៃផ្ទៃមេឃ ហើយពួកអ្នកដែលទាញ
នាំមនុស្សជាច្រើនឱ្យវិលមកឯសេចក្តីសុចរិត[ឈ] នោះនឹងភ្លឺ
ដូចជាអស់ទាំងផ្កាយនៅជាដរាបតទៅ[ញ] ៤តែចំណែកអ្នក ឱ
ដានីយ៉ែលអើយ ចូរបិទបាំងពាក្យទាំងនេះ ហើយបិទត្រា[ដ]
សៀវភៅនេះទុកដរាបដល់គ្រាចុងបំផុតចុះ[ឋ] មនុស្សជា
ច្រើននឹងខំរក[ឌ]យល់ហើយចំណេះនឹងបានចំរើនឡើង ។
៥គ្រានោះ ខ្ញុំដានីយ៉ែលក៏មើលទៅឃើញមាន២នាក់
ទៀតឈរនៅ ១ត្រើយទន្លេខាងអាយ ហើយ១ត្រើយ ទន្លេ
ខាងនាយ[ឍ] ៦ម្នាក់ក៏និយាយាដល់មនុស្សស្លៀកពាក់សំពត់
ទេសឯក[ណ] ដែលនៅពីលើទឹកទន្លេថា តើកាលណាបាន
ដល់ចុងបំផុតនៃការអស្ចារ្យទាំងនេះ[ត] ៧ខ្ញុំក៏ឮមនុស្សដែល
ស្លៀកពាក់សំពត់ទេសឯក ដែលនៅពីលើទឹកទន្លេនោះ ក្នុង
កាលដែលលោកបានលើកដៃទាំងស្តាំ[ថ]ទាំងឆ្វេងទៅឯលើ
ស្បថដោយនូវព្រះអង្គដែលមានព្រះជន្មរស់នៅអស់កល្ប
ជានិច្ច[ទ]ថា ការនេះនឹងមាននៅអស់១ខួប ២ខួប ហើយកន្លះ
ខួប[ធ] ហើយកាលណាគេបានបង្ហើយការបំបែក កំទេច
កំណាចរបស់ជនជាតិបរិសុទ្ធ[ន]រួចជាស្រេច នោះការទាំង
នេះនឹងបានសំរេចដែរ[ប] ៨ខ្ញុំបានឮ តែមិនបានយល់សោះ
ដូច្នេះ ខ្ញុំសួរថា ឱលោកម្ចាស់អើយ តើចុងបំផុត នៃការ
ទាំងនេះនឹងបានយ៉ាងណាទៅ ៩តែលោកតបថា ដានីយ៉ែល
អើយ ចូរទៅចុះ ដ្បិតសេចក្តីទាំងនេះត្រូវបិទ បាំងហើយ
បិទត្រា[ផ]ទុកដរាបដល់គ្រាចុងបំផុត[ព] ១០មនុស្សជាច្រើននឹង
សំអាត ហើយជំរះខ្លួនឱ្យសស្គុស រួចនឹងបានសំរងជា
ស្រេច[ភ] ឯពួកមនុស្សអាក្រក់ គេនឹងចេះតែប្រព្រឹត្តអំពើ
អាក្រក់តទៅ[ម] តែគ្មានមនុស្សអាក្រក់ណាមួយនឹងបានយល់
ទេ ចំណែកឯពួកអ្នកមានប្រាជ្ញា គេនឹងយល់ឃើញ[យ] ១១រីឯ
ពេលចាប់តាំងពីការថ្វាយដង្វាយ[រ]ជានិច្ចត្រូវបញ្ឈប់បំបាត់
ទៅ ហើយរបស់គួរស្អប់ខ្ពើម ដែលនាំឱ្យបង្ខូចបំផ្លាញ[ល]
បានតាំងឡើង នោះត្រូវមាន១២៩០ថ្ងៃ[វ] ១២មាន ពរហើយ
អ្នកណាដែលរង់ចាំ[ស] ទំរាំដល់គ្រា១៣៣៥ថ្ងៃ[ហ] ១៣ត្រូវឱ្យ
អ្នកទៅតាមផ្លូវរបស់អ្នកចុះ ដរាបដល់ចុងបំផុត[ឡ] ដ្បិតអ្នក
នឹងត្រូវសំរាកទៅ[អ] តែនឹងបានឈរឡើងវិញ ដើម្បីទទួល
ចំណែករបស់អ្នកនៅគ្រាចុងបំផុត[ក,ខ] ។/

**១២:១** ខ ដយ ៩:១២ មថ ២៤:២១ មក ១៣:១៩ វវ ១៦:១៨ គ យរ ៣០:៧ ឃ នក ៣២:៣២ ទដ ៥៦:៨ យរ ១៧:១៣ លក ១០:២០ **១២:២** ង យហ ១១:២៤ ច អស ២៦:១៩ មថ ២៥:៤៦ **១២:៣** ឆ ដយ ១១:៣៣ ជ មថ ១៣:៤៣ យហ ៥:៣៥ ភល ២:១៥ ឈ អស ៦:៧ ញ សភ ៤:១៨ ១កថ ១៥:៤២ **១២:៤** ដ អស ៨:១៦ ឋ ខ.៩,១៣ វវ ២០:១០ ឌ យរ ៥:១ **១២:៥** ឍ ដយ ១០:៤ **១២:៦** ណ អគ ៩:២ ត ដយ ៨:១៣ **១២:៧** ថ លប ១៤:២២ ទ ដយ ៦:២៦ វវ ១០:៥–៦ ធ ដយ ៧:២៥ វវ ១១:២ ន ដយ ៨:២៤ ប លក ២១:២៤ វវ ១០:៧

**១២:៩** ផ អស ២៩:១១ ព ខ.៤ **១២:១០** ភ អស ១:២៥ ដយ ១១:៣៥ ម អស ៣២:៧ វវ ២២:១១ យ ហស ១៤:៩ **១២:១១** រ នក ២៩:៣៨ ល ដយ ៨:១១ ៩:២៧ មថ ២៤:១៥ មក ១៣:១៤ វ វវ ១១:២ **១២:១២** ស អស ៣០:១៨ ហ អគ ៤:៥–៦ ដយ ៨:១៤ **១២:១៣** ឡ ខ.៤ អ អស ៥៧:២ ក ទដ ១៦:៥ វវ ១៤:១៣ ខ មថ ១០:២២ យក ១:១២

**១២:១** *មីកែល* មើលការពន្យល់ ១០:១៣ ។ *គ្រាវេទនាជាខ្លាំង* យរ ៣០:៧ មថ ២៤:២១ និងការពន្យល់, ធៀបនឹង វវ ១៦:១៨ ។ *បញ្ជី* មើល ១០:២១ ទដ ៩:៥ ៥១:១ ៦៩:២៨ និងការពន្យល់ ។

**១២:២** *ពួកអ្នកដែលដេកលក់នៅក្នុងធូលីដី នឹងភ្ញាក់ឡើងវិញជាច្រើន* គឺមានន័យថា ពួកគេនឹងរស់ឡើងវិញ(មើល អស ២៦:១៩ និងការពន្យល់)។ *ខ្លះឱ្យបានជីវិតរស់នៅអស់កល្បជានិច្ច និងខ្លះឱ្យបានសេចក្តីអាម៉ាស់ខ្មាស់* នៅត្រង់ចំណុចនេះ គឺនិយាយសំដៅទៅលើការរស់ឡើងវិញទាំងពួកសុច្ចរិត និងពួកទុច្ចរិត ។ មើល យហ ៥:២៤–២៩ និងការពន្យល់ ។ *ជីវិតរស់នៅអស់កល្បជានិច្ច* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានតែខនេះប៉ុណ្ណោះដែលប្រើពាក្យនេះ ។

**១២:៥** *២នាក់ទៀត* នៅក្នុងការធ្វើសម្បថ គឺតម្រូវឱ្យមានស្មរបន្ទាល់យ៉ាងតិចបំផុតពីរនាក់ ។

**១២:៧** *១ខួប ២ខួប ហើយកន្លះខួប* ឬអាចនិយាយបានម្យ៉ាងទៀតថា ១ឆ្នាំ ២ឆ្នាំ ហើយកន្លះឆ្នាំ ។ ធៀបនឹង ៧:២៥ ។

**១២:១១–១២** វគ្គនេះគឺនិយាយសំដៅទៅលើ (១).ទំហំនៃការធ្វើទុក្ខបៀតបៀនរបស់ស្តេចអាន់ទីយ៉ូកូស អេពីផានេស(មើល ៨:១៤ ១១:២៨ និងការពន្យល់) ឬ(២).ការធ្វើទុក្ខបៀបបៀននៅគ្រាចុងក្រោយ ។

**១២:១១** *ការថ្វាយដង្វាយជានិច្ច ត្រូវបញ្ឈប់បំបាត់ទៅ ហើយរបស់គួរស្អប់ខ្ពើម ដែលនាំឱ្យបង្ខូចបំផ្លាញបានតាំងឡើង* មើល ១១:៣១ និងការពន្យល់

**១២:១៣** *សំរាក* គឺមានន័យថា ស្លាប់(មើល យប ៣:១៧)។

# ព្រះគម្ពីរហូសេ

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ និងកាលបរិច្ឆេទ

លោកហូសេគឺជាកូនរបស់លោកបេអេរី ។ លោកហូសេបានថ្លែងទំនាយនៅក្នុងពាក់កណ្ដាលនៃសតវត្សទី៨ មុនគ.ស គឺលោកបានចាប់ផ្ដើមការងារបម្រើព្រះនៅក្នុងអំឡុងពេលជាមួយ ឬនៅក្រោយពេលបម្រើព្រះរបស់លោកអេម៉ុសបន្តិច ។ លោកអេម៉ុសបានធ្វើការព្រមានពួកអ៊ីស្រាអែលអំពីការជំនុំជម្រះរបស់ព្រះអម្ចាស់ ដែលនឹងបញ្ជូនពួកគេទៅក្នុងដៃនៃខ្មាំងសត្រូវ តែលោកអេម៉ុសមិនបានឱ្យដឹងថាពួកខ្មាំងសត្រូវនោះជាពួកណាទេ ។ ចំណែកលោកហូសេវិញបានបញ្ជាក់ថា ពួកខ្មាំងសត្រូវនោះគឺជាសាសន៍អាសស៊ើរ (៧:១១ ៨:៩ ១០:៦ ១១:១១)។ ក្រៅពីព្រះគម្ពីរបរិសុទ្ធ គេស្ទើរតែមិនអាចរកបាននូវឯកសារទាក់ទងនឹងលោកហូសេ តែទោះជាយ៉ាងណាក៏ដោយ ដោយសម្អាងទៅលើការថ្លែងទំនាយនៅក្នុងរាជ្យស្ដេចជាច្រើនអង្គ នៅក្នុង១:១ នោះលោកហូសេប្រាកដជាបានថ្លែងទំនាយអស់រយៈពេលយ៉ាងហោចណាស់៣៨ឆ្នាំ ។ លោកហូសេស្ថិតនៅក្នុងចំណោមហោរាដែលនិពន្ធព្រះគម្ពីរ ដែលមកពីនគរខាងជើង(អ៊ីស្រាអែល) ហើយបទទំនាយរបស់លោកគឺថ្លែងទៅកាន់នគរនោះដោយផ្ទាល់តែម្ដង ។ ប៉ុន្តែ ដោយសារគេអាចដឹងអំពីកាលបរិច្ឆេទនៃការងារបម្រើព្រះរបស់លោកហូសេ ដោយយោងទៅតាមរជ្ជកាលរបស់ពួកស្ដេចស្រុកយូដា នោះគេជឿថា ព្រះគម្ពីរនេះត្រូវបាននិពន្ធឡើងនៅក្នុងស្រុកយូដា នៅក្រោយពេលរាជធានីសាម៉ារីនៃនគរខាងជើងត្រូវដួលរលំ(ឆ្នាំ ៧២២ ដល់ ៧២១ មុនគ.ស) ហើយគេសម្អាងការនេះទៅលើការនិយាយអំពីស្រុកយូដាជាច្រើនដងនៅក្នុងព្រះគម្ពីរនេះទាំងមូល(១:៧,១១ ៤:១៥ ៥:៥,១០,១២-១៣ ៦:៤,១១ ១០:១១ ១១:១២ ១២:២)។ គេមិនដឹងថាតើលោកហូសេជាអ្នកនិពន្ធព្រះគម្ពីរនេះឬយ៉ាណាទេ ។ ព្រះគម្ពីរហូសេស្ថិតនៅក្នុងលំដាប់ទីមួយនៃក្រុមព្រះគម្ពីរហោរាតូច(ឈ្មោះហោរាតូចគឺសំដៅទៅលើភាពខ្លីនៃព្រះគម្ពីរហោរាទាំង១២ បើប្រៀបធៀបជាមួយនឹងព្រះគម្ពីរ អេសាយ យេរេមា និងអេសេគាល)។

### ប្រវត្តិ

លោកហូសេរស់នៅក្នុងសម័យអន្តរាយចុងក្រោយនៃនគរខាងជើង ដែលនៅក្នុងនោះមានស្ដេចប្រាំមួយអង្គ(បន្ទាប់ពីរាជ្យស្ដេចយេរ៉ូបោមទីពីរ)បានឡើងសោយរាជ្យជាបន្តបន្ទាប់ក្នុងរយៈពេល២៥ឆ្នាំ(២ពវ ១៥:៨-១៧:៦)។ ស្ដេចបួនអង្គ(ស្ដេចសាការី ស៊ីលិម ពេកាហ៊ា ពេកា)ត្រូវគេធ្វើគុតដណ្ដើមរាជ្យនៅពេលកំពុងកាន់អំណាច មានមួយអង្គ(ហូស៊ា)ដែលត្រូវគេចាប់ខ្លួននៅក្នុងសង្គ្រាម ហើយមានតែមួយអង្គប៉ុណ្ណោះ(មណាហិម)ដែលចុះចេញពីបល្ល័ង្ក ដោយមានកូនស្នងរាជ្យ ។ ព្រះទ្រង់ប្រទានពួកអ៊ីស្រាអែលឱ្យមានពួកស្ដេចទាំងនេះដោយ "សេចក្ដីកំហឹង" ដកយកចេញពីពួកគេវិញដោយ "សេចក្ដីក្រោធ"(១៣:១១) ហើយពួកស្ដេចទាំងនេះនឹងត្រូវអណ្ដែតដូចជា "ពពុះនៅលើទឹក"(១០:៧)។ មានការកំចាយឈាមមួយ បន្តពីការកំចាយឈាមមួយទៀត(៤:២)។ ចក្រភពអាសស៊ើរបានធ្វើការពង្វាតទឹកដីទៅតំបន់ខាងលិច ស្ដេចមណាហិមបានព្រមនៅក្រោមចំណុះ ហើយបង់សួយសារអាករ(២ពវ ១៥:១៩-២០)។ ប៉ុន្តែមិនយូរប៉ុន្មាន នៅក្នុងឆ្នាំ ៧៣៣ មុនគ.ស នគរអ៊ីស្រាអែលត្រូវចក្រភពអាសស៊ើរពុះចែក ដោយសារតែគម្រោងរបស់ស្ដេចពេកា(ស្ដេចនេះបានធ្វើគុតស្ដេចពេកាហ៊ាដើម្បីគ្រប់គ្រងអ៊ីស្រាអែល ដែលស្ដេចពេកាហ៊ាជាកូន និងជាអ្នកស្នងរាជ្យរបស់ស្ដេចមណាហិម)។ ស្ដេចអ៊ីស្រាអែលនៅសល់តែទឹកដីអេប្រាអ៊ីម និងម៉ានាសេភាគខាងលិចប៉ុណ្ណោះសម្រាប់គ្រប់គ្រង ។ ក្រោយមកទៀត ដោយសារតែភាពមិនស្មោះត្រង់របស់ស្ដេចហូស៊ា(អ្នកស្នងរាជ្យស្ដេចពេកា) ទីក្រុងសាម៉ារីត្រូវគេកាន់កាប់ ហើយអ្នករស់នៅក្នុងក្រុងនោះត្រូវនិរទេសនៅឆ្នាំ ៧២២-៧២១ មុនគ.ស ធ្វើឱ្យនគរខាងជើងត្រូវបាត់បង់ ។

### ខ្លឹមសារនិងការបង្រៀនផ្នែកវិជ្ជាអំពីព្រះ

ផ្នែកទីមួយនៃព្រះគម្ពីរនេះ(ជំពូក ១-៣)បានរៀបរាប់អំពីជីវិតគ្រួសាររបស់លោកហូសេ ដែលជានិមិត្តរូប(គឺស្រដៀងគ្នានឹងការនិយាយជានិមិត្តរូបនូវជីវិតរបស់លោកអេសាយ យេរេមា និងអេសេគាលផងដែរ)ដែលលោកហូសេត្រូវប្រើនៅក្នុងការនាំព្រះបន្ទូលពីព្រះអម្ចាស់មកប្រកាសប្រាប់ដល់រាស្ត្ររបស់ទ្រង់ ។ ព្រះអម្ចាស់ទ្រង់បានបង្គាប់លោកហូសេឱ្យរៀបការជាមួយនឹងស្ត្រីផិតក្បត់ម្នាក់ឈ្មោះកូមេរ ហើយពួកគេមានកូនបីនាក់ ដែលឈ្មោះរបស់ពួកគេម្នាក់ៗគឺជានិមិត្តរូបតំណាងឱ្យព្រះបន្ទូលអំពីការអាក្រក់ដែលនឹងកើតឡើង ។ ជំពូកទីពីរនិយាយអំពីទំនាក់ទំនងរវាងលោកហូសេ និងនាងកូមេរ និងអំពីនិមិត្តរូបនៃទំនាក់ទំនងនេះដែលតំណាងឱ្យទំនាក់ទំនងរវាងព្រះ និងពួកអ៊ីស្រាអែល ។ មានការប្រាប់ឱ្យកូនៗរបស់លោកហូសេបណ្ដេញម្ដាយដែលមិនស្មោះត្រង់នោះចេញពីផ្ទះ ប៉ុន្តែមិនមែនដើម្បីកំចាត់នាងចោលទេ គឺដើម្បីកែប្រែនាងឡើងវិញ ។ ព្រះអម្ចាស់ទ្រង់បង្គាប់ឱ្យលោកហោរាហូសេបន្តស្រឡាញ់នាង និងនាំនាងមកវិញ ហើយទុក

ឱ្យនាងនៅតែឯងមួយរយៈ (ជំពូក ៣) ។ ការនេះគឺតំណាងឱ្យទំនាក់ទំនងរបស់ព្រះអម្ចាស់នឹងពួកអ៊ីស្រាអែល (ធៀបនឹង ២:៤,៩,១៨) ដែលមិនស្មោះត្រង់ចំពោះទ្រង់ដោយថ្វាយបង្គំព្រះរបស់សាសន៍កាណាន ដោយចាត់ទុកជាប្រភពនៃអ្វីៗទាំងអស់របស់ពួកគេ ។ ពួកសាសន៍អ៊ីស្រាអែលត្រូវឆ្លងកាត់រយៈពេលនៃការនិរទេស (ធៀបនឹង ៧:១៦ ៩:៣,៦,១៧ ១១:៥) ។ ប៉ុន្តែព្រះអម្ចាស់ទ្រង់នៅតែស្រឡាញ់រាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ ហើយទ្រង់សព្វព្រះទ័យនឹងឱ្យពួកគេវិលមកវិញ គឺដូចដែលលោកហូសេបាននាំនាងកូមើរមកវិញអញ្ចឹងដែរ ។ ការវិលមកវិញនោះគឺត្រូវបានរៀបរាប់ដោយប្រើរូបារម្មណ៍ ដែលរំឭកអំពីការនិរទេសពីស្រុកអេស៊ីព្ទ និងការចូលមករស់នៅក្នុងទឹកដីកាណាន (ធៀបនឹង ១:១១ ២:១៤-២៣ ៣:៥ ១១:១០-១១ ១៤:៤-៧) ។ តាមព្រះគម្ពីរនេះ បទពិសោធន៍ដែលពួកអ៊ីស្រាអែលមានជាមួយនឹងព្រះអម្ចាស់ គឺជាគំរូ ឬវិធីនៃការដោះស្រាយរបស់ព្រះអម្ចាស់ជាមួយនឹងរាស្ត្ររបស់ទ្រង់ ។

ផ្នែកទីពីរនៃព្រះគម្ពីរនេះ (ជំពូកទី៤-១៤) និយាយលម្អិតអំពីទំនាក់ទំនងរបស់ពួកអ៊ីស្រាអែលជាមួយនឹងសាសនារបស់ពួកកាណាន ដែលបង្កប់ទៅដោយវិជ្ជាអំពីព្រះជាច្រើន ។ ព្រះគម្ពីរហូសេនិយាយពីការប្រកាសឱ្យប្រែចិត្ត ដូចព្រះគម្ពីរហោរាដទៃទៀតដែរ ។ ដើម្បីជៀសចេញពីសេចក្តីវិនាស ពួកអ៊ីស្រាអែលត្រូវឈប់ថ្វាយបង្គំរូបព្រះ ហើយវិលមកព្រះអម្ចាស់វិញ (ជំពូក ៦,១៤) ។ តាមពត៌មានដែលប្រមូលបានពីការរកឃើញសិលាចារឹក/សំភារៈនៅតំបន់ អ៊ូការីត (Ugarit, មានប្រវត្តិពីសតវត្សទី ១៥ មុនគ.ស) បាននាំឱ្យយើងអាចដឹងកាន់តែច្បាស់អំពីសកម្មភាពនៅក្នុងជំនឿសាសនា ដែលលោកហូសេប្រឆាំងនៅសម័យនោះ ។

ព្រះគម្ពីរហូសេបានបង្ហាញថា ការមិនទទួលស្គាល់ព្រះអម្ចាស់ (៤:១,៦ ៨:២-៣ ១៣:៤) គឺជាបញ្ហាជាចំបងរបស់ពួកអ៊ីស្រាអែល ។ ព្រះអម្ចាស់ទ្រង់រាប់រកពួកអ៊ីស្រាអែលដោយសេចក្តីស្រឡាញ់ (២:១៩ ៤:១ ៦:៦ ១០:១២ ១២:៦) ។ ទំនាក់ទំនងស្និទ្ធស្នាលរបស់ព្រះអម្ចាស់ ជាមួយនឹងរាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ គឺត្រូវបានបកស្រាយនៅក្នុងផ្នែកទីមួយនៃព្រះគម្ពីរនេះ ដោយការលើកឡើងអំពីទំនាក់ទំនងប្តី និងប្រពន្ធ ហើយបកស្រាយបន្ថែមនៅក្នុងផ្នែកផ្សេងទៀត ដោយលើកឡើងអំពីទំនាក់ទំនងឪពុក និងកូន (១១:១-៤) ។ ការមិនស្មោះត្រង់នឹងព្រះអម្ចាស់គឺជាការផិតក្បត់ខាងវិញ្ញាណ (៤:១៣-១៤ ៥:៤ ៩:១ ធៀបនឹង យរ ៣ មើលការពន្យល់ នក ៣៤:១៥) ។ ពួកអ៊ីស្រាអែលបានបែរទៅរកការថ្វាយបង្គំរូបព្រះបាល ហើយធ្វើយញ្ញបូជានៅទីកន្លែងខ្ពស់របស់សាសន៍ដទៃ ដែលរួមមានការចងសម្ព័ន្ធជាមួយនឹងពួកស្រីសំផឹងនៅទីកន្លែងថ្វាយយញ្ញបូជានោះ (៤:១៤) និងថ្វាយបង្គំរូបកូនគោនៅក្រុងសាម៉ារីផងដែរ (៨:៥ ១០:៥-៦ ១៣:២) ។ មានការរៀបគម្រោងការណ៍អាក្រក់ (៥:១៣ ៧:៨-១១) និងសំភារៈនិយមនៅក្នុងទំនាក់ទំនងអន្តរជាតិផងដែរ ។ ព្រះគម្ពីរនេះនិយាយអំពីការជំនុំជម្រះរបស់ព្រះ និងប្រើពាក្យធ្ងន់ៗនៅក្នុងការប្រកាសអំពីការជំនុំជម្រះដែលមិនអាចជៀសរួច ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គោលបំណងសំខាន់នៃព្រះគម្ពីរនេះគឺដើម្បីប្រកាសអំពីការអាណិតអាសូររបស់ព្រះ និងសេចក្តីស្រឡាញ់តាមសេចក្តីសញ្ញា ដែលជាហេតុនាំឱ្យទ្រង់មិនអាចបោះបង់ពួកអ៊ីស្រាអែលចោលបាន ។

### គម្រោងសង្ខេប

I. សេចក្តីផ្តើម (១:១)

II. ប្រពន្ធដែលមិនស្មោះត្រង់ និងប្តីដែលស្មោះត្រង់ (១:២-៣:៥)
- ក. កូនៗដែលជាសញ្ញា (១:២-២:១)
- ខ. ប្រពន្ធដែលមិនស្មោះត្រង់ (២:២-២៣)
  - ១. ការជំនុំជម្រះរបស់ព្រះអម្ចាស់មកលើពួកអ៊ីស្រាអែល (២:២-១៣)
  - ២. ការស្តារពួកអ៊ីស្រាអែលឡើងវិញ (២:១៤-២៣)
  - ៣. ប្តីដែលស្មោះត្រង់ (ជំពូក ៣)

III. សាសន៍ដែលមិនស្មោះត្រង់ និងព្រះដែលស្មោះត្រង់ (ជំពូក ៤-១៤)
- ក. ភាពមិនស្មោះត្រង់របស់អ៊ីស្រាអែល (៤:១-៦:៣)
  - ១. ជាចោទប្រកាន់អំពីរឿងជាទូទៅ (៤:១-៣)
  - ២. ការប្រកាសអំពីមូលហេតុ និងបកស្រាយអំពីលទ្ធផល (៤:៤-១៩)
  - ៣. ព្រះបន្ទូលពិសេសសម្រាប់បណ្តាជន និងអ្នកដឹកនាំ (ជំពូក ៥)
  - ៤. ការអង្វររបស់បណ្តាជនដោយទុក្ខព្រួយ (៦:១-៣)
- ខ. ការជំនុំជម្រះអ៊ីស្រាអែល (៦:៤-១០:១៥)

១. ការលើកឡើងអំពីរឿងក្តី (៦:៤–៧:១៦)

២. ការប្រកាសអំពីការជំនុំជម្រះ (ជំពូក ៨–៩)

៣. ការសង្ខេប និងការប្រកាសឱ្យប្រែចិត្ត (៣:១–១៦)

គ. សេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ដែលប្រកបដោយភាពស្មោះត្រង់ (ជំពូក ១១–១៤)

១. សេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ក្នុងលក្ខណៈជាឪពុក (១១:១–១១)

២. ការជំនុំជម្រះពួកអ៊ីស្រាអែលពីបទមិនមានភាពស្មោះត្រង់ (១១:១២–១៣:១៦)

៣. ការស្តារអ៊ីស្រាអែលឡើងវិញ បន្ទាប់ពីពួកគេបានប្រែចិត្ត (ជំពូក ១៤)

**១** ១ នេះជាព្រះបន្ទូល នៃព្រះយេហូវ៉ា ដែលមក[ក]ដល់ហូសេ
ជាកូនបេអេរី នៅក្នុងរាជ្យអូសៀស[ខ] យ៉ូថាម[គ] អេហាស[ឃ] និង
ហេសេគា[ង] ជាស្ដេចស្រុកយូដា[ច] ហើយក្នុងគ្រាដែល
យេរ៉ូបោម[ឆ] ជាកូនយ៉ូអាស បានធ្វើជាស្ដេចលើស្រុក
អ៊ីស្រាអែល[ជ]។

## ប្រពន្ធ និងកូនរបស់លោកហូសេ

២កាលព្រះយេហូវ៉ាទ្រង់ចាប់ផ្ដើមមានបន្ទូល ដោយ
សារហូសេជាមុនដំបូង នោះទ្រង់មានបន្ទូលប្រាប់គាត់ថា
ចូរឯងទៅយកស្រីដែលធ្លាប់ប្រព្រឹត្តជាសំផឹង[ឈ] នាំមកនៅ
ជាមួយគ្នា ហើយបង្កើតកូនសហាយចុះ ដ្បិតស្រុកនេះតែង
ប្រព្រឹត្តការកំផិត[ញ] ចេញពីព្រះយេហូវ៉ាយ៉ាងខ្លាំង ៣ដូច្នេះ
លោកក៏ទៅយកនាងកូមើរ[ដ]ជាកូនឌីប្លែម ហើយនាងមាន
ទំងន់បង្កើតបានកូនប្រុស១ឱ្យលោក ៤ព្រះយេហូវ៉ាទ្រង់
បង្គាប់លោកថា ចូរឱ្យឈ្មោះថា "យេសរាល"ទៅ[ឋ] ដ្បិត
នៅតែបន្តិចទៀត អញនឹងសងសឹកដល់ពួកវង្សយេហ៊ូវ
ដោយព្រោះឈាមយេសរាលនោះហើយ ក៏នឹងធ្វើឱ្យរាជ្យ
នៃពួកវង្សអ៊ីស្រាអែលផុតទៅដែរ ៥នៅគ្រានោះ អញនឹង
បំបាក់ធ្នូរបស់ពួកអ៊ីស្រាអែល នៅក្នុងច្រកភ្នំយេសរាល[ឌ]
៦នាង[ឍ]មានទំងន់ម្ដងទៀត ហើយបង្កើតបានកូនស្រី១នោះ
ព្រះទ្រង់បង្គាប់លោកថា ចូរឱ្យឈ្មោះថា «ឡូ-រូហាម៉ា»[ណ]
ចុះដ្បិតអញនឹងមិនអាណិតមេត្តា ដល់ជនួរវង្សអ៊ីស្រាអែល[ត]
ដើម្បីនឹងអត់ទោសដល់គេតទៅទៀតឡើយ ៧តែអញនឹង
អាណិតមេត្តាដល់ពួកវង្សយូដា ហើយនឹងជួយសង្គ្រោះគេ
មិនមែនជាធ្នូ[ថ] ដាវ ការតស៊ូ សេះ ឬពលសេះទេ គឺ
នឹងជួយសង្គ្រោះគេ ដោយសារព្រះយេហូវ៉ា ជាព្រះនៃគេ
វិញ[ទ] ៨រីឯកាលនាងបានផ្ដាច់ដោះឡូ-រូហាម៉ាហើយ[ធ] នាង
ក៏មានទំងន់ទៀតបង្កើតបានកូនប្រុស១ ៩ព្រះទ្រង់បង្គាប់ ថា
ចូរឱ្យឈ្មោះថា «ឡូ-អាំមី»ចុះ ដ្បិនឯងរាល់គ្នាមិនមែន
ជារាស្ត្ររបស់អញទេ អញក៏មិនព្រមធ្វើជាព្រះរបស់ឯង
ដែរ[ន] ។

**១:១** ក យរ ១:២ ខ ២ពវ ១៤:២១ គ ១រប ៣:១២ ឃ ១រប ៣:១៣ ង ១រប ៣:១៣ ច អស ១:១ មីក ១:១ ឆ ២ពវ ១៣:១៣ ជ អម ១:១ **១:២** ឈ យរ ៣:១ ហស ២:២,៥ ៣:១ ញ ចទ ៣១:១៦ យរ ៣:១៤ អគ ២៣:៣-២១ ហស ៥:៣ **១:៣** ដ ខ.៦ **១:៤** ឋ ខ.១១ ១សយ ២៩:១ ១ពវ ១៨:៤៥ ២ពវ ១០:១-១៤ ហស ២:២២ **១:៥** ឌ យស ១៥:៥៦ ១សយ ២៩:១ ២ពវ ១៥:២៩ **១:៦** ឍ ខ.៣ ណ ខ.៨ ហស ២:២៣ ត ហស ២:៤ **១:៧** ថ ទដ ៤៤:៦ ទ សក ៤:៦ **១:៨** ធ ខ.៦ **១:៩** ន ខ.១០ អគ ១១:១៩-២០ ១ពវ ២:១០

**១:១** *ព្រះបន្ទូល នៃព្រះយេហូវ៉ា* លោកហូសេផ្ដើមដោយពាក្យនេះ គឺដើម្បីបញ្ជាក់ពីអំណាចនៃពាក្យដែលលោកសរសេរ គឺដូចលោកហោរាយេរេមា (១:២,៤) លោកអេសេគាល (១:៣) លោកយ៉ូអែល (១:១) លោកយ៉ូណាស (១:១ ៣:១) លោកមីកា (១:១) លោកសេផានា(១:១) លោកហាកាយ(១:១,៣ ២:១,១០,២០) លោកសាការី(១:១, ៧ ៩:១ ១២:១) និងលោកម៉ាឡាគី(១:១) ។ *ហូសេ* មានន័យថា "សេចក្ដីសង្គ្រោះ" ។ *អូសៀស* សោយរាជ្យពីឆ្នាំ ៧៩២-៧៤០ មុនគ.ស ។ *យ៉ូថាម* សោយរាជ្យពីឆ្នាំ ៧៥០-៧៣២ មុនគ.ស ។ *ហេសេគា* សោយរាជ្យពីឆ្នាំ ៧២៩-៦៨៦ មុនគ.ស ។ ស្ដេចខ្លះសោយរាជ្យក្នុងពេលដំណាលគ្នា ស្ដេចអេហាស និងស្ដេចហេសេគាបានសោយរាជ្យរួមគ្នាអស់ពេលដ៏យូរជាងគេ(ការពន្យល់ អស ៣៦:១) ។ *យេរ៉ូបោម* គឺយេរ៉ូបោមទី២ សោយរាជ្យពីឆ្នាំ ៧៩៣-៧៥៣ មុនគ.ស ។ លោកហូសេរស់នៅក្នុងជំនាន់ជាមួយនឹងលោកអេសាយ លោកអេម៉ុស និងលោកមីកា (មើលខដំបូងនៅក្នុងបទទំនាយរបស់ពួកគេ) ។

**១:២** *យកស្រីដែលធ្លាប់ប្រព្រឹត្តជាសំផឹង* មើលសេចក្ដីផ្ដើមត្រង់ចំណុចបញ្ហាពិសេស ។ *ការកំផិត* គឺជាអំពីបាបដ៏ធំ ដែលព្រះអម្ចាស់បានចោទប្រកាន់ពួកអ៊ីស្រាអែលតាមរយៈលោកហូសេ ។

**១:៣** *នាងកូមើរ* ឈ្មោះនោះមាននិយាយតែនៅក្នុងព្រះគម្ពីរនេះប៉ុណ្ណោះ ។ *លោក* ការមិនប្រើពាក្យនេះម្ដងទៀតនៅក្នុង ខ.៦,៩ បង្ហាញថា លោកហូសេមិនមែនជាឪពុករបស់កូនពីរនាក់ទៀតដែលនាងកូមើរបង្កើតក្រោយមកទៀតនោះឡើយ ។

**១:៤** *យេសរាល* មានន័យថា "ព្រះទ្រង់កំចាត់កំចាយ" នៅក្នុងខនេះ ឈ្មោះនេះត្រូវបានប្រើដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់អំពីការប្រកាសអំពីការជំនុំជម្រះរាជ្យវង្សដែលកំពុងកាន់កាប់អំណាច(ការពន្យល់ ខ.១១ ២:២២) ។ ស្ដេចយេរ៉ូបោមទី២ស្ថិតនៅក្នុងរាជ្យវង្សនៃស្ដេចយេហ៊ូ (សោយរាជ្យពីឆ្នាំ ៨៤១-៨១៤ មុនគ.ស) ដែលបានបង្កើតឡើងនៅទីក្រុងយេសរាល ដោយផ្ដួលរំលំស្ដេចយ៉ូរ៉ាមបុត្រាស្ដេចអ័ហាប់ (មើល ២ពវ ៩:១៤-២៩ ១ពវ ១៩:១៦-១៧ និងការពន្យល់) ។ រាជ្យវង្សនៃស្ដេចយេហ៊ូត្រូវបញ្ចប់នៅពេលស្ដេចសាការីត្រូវគេធ្វើឃាតនៅឆ្នាំ ៧៥៣ មុនគ.ស(២ពវ ១៥:៨-១០) ។

**១:៥** *ធ្នូរបស់ពួកអ៊ីស្រាអែល* កំឡាំងទ័ពរបស់អ៊ីស្រាអែលត្រូវបានបំបាក់នៅក្នុងឆ្នាំ ៧២៥ មុនគ.ស ហើយទីក្រុងសាម៉ារីបានទប់ទល់នឹងការលោមព័ទ្ធបានយូរជាងបីឆ្នាំ(មើល ២ពវ ១៧:៥-៦ និងការពន្យល់) ។ *ច្រកភ្នំយេសរាល* ស្ថិតនៅភាគខាងកើតនៃច្រកភ្នំមេគីដោ ហើយបានផ្ដល់ច្រកផ្លូវតែមួយ ដែលគេអាចធ្វើដំណើរពីជើងទៅត្បូងទៅប្រទេសអ៊ីស្រាអែលកាត់តាមជួរភ្នំ១ ដូចនេះច្រកភ្នំនេះគឺជាកន្លែងសមរភូមិដ៏ខ្លាំងមួយនៅសម័យបុរាណ ។

**១:៦** *ឡូ-រូហាម៉ា* ឈ្មោះនេះតំណាងឱ្យសេចក្ដីស្រឡាញ់ដែលព្រះទ្រង់បានផ្ដល់ឱ្យដល់អ៊ីស្រាអែល (មើល នក ៣៣:១៩ ចទ ៧:៦-៨)កាលពីមុន(មើល នក ៣៣:១៩ ចទ ៧:៦-៨ និងការពន្យល់ ៧:៨) ប៉ុន្តែពេលក្រោយមកទៀតទ្រង់បានសន្យាប្រទានដល់ពួកគេម្ដងទៀត(មើល ២:២៣ និងការពន្យល់) ។

**១:៧** *តែ* មើល ខ.១០ និងការពន្យល់ ។ *ពួកវង្សយូដា . . . ជួយសង្គ្រោះគេ* ព្រះអម្ចាស់បានជួយសង្គ្រោះពួកគេឱ្យរួចពីសាសន៍អាសស៊ើរនៅក្នុងឆ្នាំ ៧២២-៧២១ មុនគ.ស ហើយម្ដងទៀតនៅក្នុងឆ្នាំ ៧០១ មុនគ.ស(មើល ២ពវ ១៩:៣២-៣៦) ។

**១:៩** *ឡូ-អាំមី* ឈ្មោះនេះតំណាងឱ្យការបែកបាក់នៃទំនាក់ទំនងរវាងព្រះអម្ចាស់ និងអ៊ីស្រាអែល ដោយការតាំងសេចក្ដីសញ្ញា (មើល នក ៦:៧ យរ ៧:២៣ និងការពន្យល់)តែទោះជាយ៉ាងណាក៏ដោយទំនាក់ទំនងនេះបានស្អាងឡើងជាថ្មីវិញ(មើល ២:២៣ និងការពន្យល់)។ ការព្រមានកាន់តែធ្ងន់ធ្ងរ ដោយត្រូវព្រមានចាប់ពីកូនទីមួយរហូតដល់កូនទីបី ។

១០ ប៉ុន្តែពួកកូនចៅអ៊ីស្រាអែលនឹងមានចំនួនដូចជាខ្សាច់
នៅសមុទ្រ ដែលនឹងវាល់ ឬរាប់មិនបានឡើយ[ប] រួចក្រោយ
មក នឹងកើតមានដូច្នេះ គឺពាក្យដែលបានពោលទុកថា ឯង
រាល់គ្នាមិនមែនជារាស្ត្រអញទេ នោះនឹងផ្លាស់ទៅជាថា
ឯងរាល់គ្នាជាកូននៃព្រះដ៏មានព្រះជន្មរស់នៅវិញ[ផ,ព] ១១ គ្រា
នោះ ពួកកូនចៅយូដា និងពួកកូនចៅអ៊ីស្រាអែល និងបាន
រួបរួមគ្នា[ភ] ក៏នឹងតាំងឱ្យមានអ្នកជាប្រមុខតែ១[ម] លើពួកខ្លួន
ហើយនឹងឡើងចេញពីស្រុកទៅ[យ] ដ្បិតថ្ងៃនៃយេសរាលនឹង
បានជាថ្ងៃយ៉ាងសំបើម[រ] ។

**២** ១ ចូរប្រាប់ដល់ពួកបងប្អូនប្រុសរបស់ឯងថា "អាំមី"
ហើយដល់បងប្អូនស្រីថា «រូហាម៉ា»ចុះ[ក] ។

## សាសន៍អ៊ីស្រាអែលត្រូវទទួលទោស និងការស្តារឡើងវិញ

២ ចូរស្តីប្រដៅដល់ម្តាយឯង[ខ] ចូរស្តីប្រដៅចុះ ដ្បិត នាង
មិនមែនជាប្រពន្ធអញទេ អញក៏មិនមែនជាប្តីនាងដែរ ត្រូវ
ឱ្យនាងលះចោលការកំផិត[គ]ពីមុខនាងចេញ ហើយការ
កន្លងបវេណីពីកណ្តាលទ្រូងនាងទៅ ៣ ក្រែងអញសំរាត[ឃ]
ឱ្យនាងនៅខ្លួនទទេ ហើយធ្វើឱ្យត្រឡប់ដូចជានៅថ្ងៃដែល
កើតមកវិញ[ង] ឱ្យនាងបានដូចជាទីរហោស្ថាន គឺដូចជាដី
ហួតហែង[ច] ព្រមទាំងសំឡាប់នាងដោយខះស្រេកផង ៤ អើ
អញនឹងមិនអាណិតមេត្តាដល់ទាំងកូននាងដែរ[ឆ] ពីព្រោះវា
សុទ្ធតែជាកូនសហាយ[ជ] ៥ ដ្បិតម្តាយវាបានប្រព្រឹត្តការកំផិត
គឺអ្នកដែលបានឱ្យវាកើតឡើង បានប្រព្រឹត្តអំពើគួរខ្មាស
ហើយ ដ្បិតនាងបានថា អញនឹងទៅតាមពួកសហាយ[ឈ] អញ
ជាអ្នកដែលតែងឱ្យនំបុ័ងនឹងទឹកមកអញ ព្រមទាំង រោម
ចៀម ខ្លូតទេស ប្រេង និងគ្រឿងផឹកផង[ញ] ៦ ដូច្នេះ
មើលអញនឹងស្រាស់ផ្លូវនាងដោយបន្លា ហើយធ្វើកំផែង
ផង ដើម្បីមិនឱ្យនាងស្គាល់ផ្លូវខ្លួនទៀត[ដ] ៧ នាងនឹងទៅតាម
ពួកសហាយរបស់ខ្លួន តែនឹងមិនទាន់ឡើយ នាងនឹងស្វែង
រកគេ[ឋ] តែនឹងមិនប្រទះសោះ នោះនាងនឹងសំរេចថា អញ
នឹងវិលទៅឯប្តី[ឍ]ដើមវិញ[ឍ] ដ្បិតនៅគ្រាមុននោះ អញបាន
ស្រួលជាង[ណ]សព្វថ្ងៃនេះ ។

៨ នាងមិនបានដឹង[ត]ថា គឺអញនេះដែលតែងតែឱ្យស្រូវ
ទឹកទំពាំងបាយជូរ និងប្រេងដល់នាង[ថ] ព្រមទាំងចំរើន
ប្រាក់នឹងមាស[ទ]ដល់នាង ដែលគេបានប្រើសំរាប់គោរពដល់

**១:១០** ប លប ២២:១៧ យរ ៣៣:២២ ផ ខ.៩ ហស ២:២៣ រម ៩:២៦ ព យស ៣:១០ **១:១១** ភ អស ១១:១២,១៣ ម យរ ២៣:៥–៨ ៣០:៩ យ អគ ៣៧:១៥–២៨ រ ខ.៤ **២:១** ក ខ.២៣ ១ពត ២:១០ **២:២** ខ ខ.៥ អស ៥០:១ ហស ១:២ ៤:៥ គ អស ១:២១ អគ ២៣:៤៥ **២:៣** ឃ អគ ១៦:៣៧ ង អគ ១៦:៤,២២ ច អស ៣២:១៣–១៤ **២:៤** ឆ អគ ៨:១៨ ហស ១:៦ ជ ហស ៥:៧ **២:៥** ឈ យរ ៣:៦ ហស ១:២ ញ យរ ៤៤:១៧–១៨ **២:៦** ដ យប ៣:២៣ ១៩:៨ បទ ៣:៩ **២:៧** ឋ ហស ៥:១៣ ឍ អស ៥៤:៥ ឍ យរ ២:២ ៣:១ ណ អគ ១៦:៨ **២:៨** ត អស ១:៣ ថ ជន ១៨:១២ ទ ចទ ៨:១៨

**១:១០** ខនេះមានដកស្រង់នៅក្នុង រម ៩:២៦ ១ពរ ២:១០ (មើលការពន្យល់) ហើយត្រូវបានប្រើនៅក្នុងការបម្រើព្រះ នៅក្នុងចំណោមសាសន៍ដទៃ ។ *ប៉ុន្តែ* ការដាក់ទោសដែលបានគម្រាមនោះ (ខ.៤–៦,៩) និងមិនមានរយៈពេលជារៀងរហូតនោះទេ ព្រោះរយៈពេលនៃព្រះពរនឹងមកបន្ត ។ *ខ្សាច់នៅសមុទ្រ* សូមមើលព្រះបន្ទូលសន្យាដែលព្រះទ្រង់មាននឹងលោកអ័ប្រាហាំ និងលោកយ៉ាកុប (លប ២២:១៧ ៣២:១២ ធៀបនឹង យរ ៣៣:២២ និងការពន្យល់ ហព ១១:១២) ។ *កូន* គឺផ្ទុយពី "កូននៃភាពមិនស្មោះត្រង់ ឬកំផិត" (ខ.២ ២:៤) ។ *ព្រះដ៏មានព្រះជន្មរស់នៅ* គឺផ្ទុយនឹងរូបព្រះ "ដែលមិនមែនជាព្រះ" (ចទ ៣២:១៧) ។

**១:១១** *រួបរួមគ្នា* សាសន៍អ៊ីស្រាអែល និងសាសន៍យូដាក្លាយជាជាតិសាសន៍តែមួយឡើងវិញ ។ *ឡើងចេញពីស្រុក* អាចជាស្រុកដែលត្រូវនិរទេសទៅ (ធៀបនឹង នក ១:១០) ។ តាមការកាត់ស្រាយម្យ៉ាងទៀត គឺថាពួកគេនឹងដុះឡើងពីដីដូចជារុក្ខជាតិ ។ *យេសរាល* នៅត្រង់ចំនុចនេះអត្ថន័យនៃពាក្យនេះដែលមានន័យថា "ព្រះទ្រង់កំចាត់កំចាយ" (មើលការពន្យល់ ខ.៤) គឺសំដៅទៅលើការធ្លាក់ព្រឹល ឬការដាំដុះ (មើល ២:២១–២៣ និងការពន្យល់) ។

**២:១** *"អាំមី"...."រូហាម៉ា"* ត្រង់ចំណុចនេះ ភាពអវិជ្ជមានដែលទាក់ទងនឹងឈ្មោះរបស់កូនរបស់លោកហូសេត្រូវជម្រុះចោល ។

**២:២** *មិនមែនជាប្រពន្ធអញទេ* អាពាហ៍ពិពាហ៍ត្រូវបាក់បែកដោយសារភាពមិនស្មោះត្រង់ ប៉ុន្តែ ត្រូវស្វែងរកការបង្រួបបង្រួមឡើងវិញ គឺមិនមែនការលែងលះឡើយ (ធៀបនឹង ខ.៧–១៥) ។

**២:៣** *សំរាតឱ្យនាង* ប្តីជាអ្នកផ្គត់ផ្គង់សំលៀកបំពាក់ដល់ប្រពន្ធ (មើល នក ២១:១០ អគ ១៦:១០) ហើយនៅក្នុងខនេះប្តីត្រូវបកអាក្រាតអំពីភាពមិនស្មោះត្រង់របស់នាង (មើល យរ ១៣:២៦ អគ ១៦:៣៩) ។ *ត្រឡប់ដូចជានៅថ្ងៃដែលកើតមក* គឺដូចអ៊ីស្រាអែលកាលព្រះអម្ចាស់បានរំដោះពួកគេពីស្រុកអេស៊ីព្ទ ពីភាពជាទាសករ តាំងពីពួកគេនៅបាតដៃទទេ (ធៀបនឹង អគ ១៦:៤–៨ ណាហ ៣:៥) ។

**២:៤** *កូនសាហាយ* មើល ១:២ និងការពន្យល់ ។ នៅត្រង់ចំណុចនេះគឺផ្ទុយនឹង "កូននៃព្រះដ៏មានព្រះជន្មរស់នៅ" (១:១០ ធៀបនឹង ១១:១) ។

**២:៥** *នឹងទៅតាម* គឺប្រពន្ធរបស់លោកហូសេកំពុងទៅតាមប្រុសផ្សេង (មើល ខ.១៣ យរ ៣:២ អគ ១៦:៣៣–៣៤) ។ *ពួកសហាយ* មើល ខ.៧,១០ ត្រង់ចំណុចនេះគឺសំដៅទៅលើការថ្វាយបង្គំព្រះរបស់សាសន៍កាណាន (ដូចជាព្រះបាលជាដើម) ដែលពួកអ្នកថ្វាយបង្គំនោះរំពឹងថានឹងបានទទួលជីជាតិសម្រាប់ដំណាំ កសិកម្មរបស់ខ្លួន (មើលការពន្យល់ នក ៣៤:១៥) ។ *រោមចៀម ខ្លូតទេស ប្រេង និងគ្រឿងផឹក* គឺជារបស់ផលិតផលកសិកម្មរបស់ទឹកដីបរិសុទ្ធ ។ ពួកអ៊ីស្រាអែលមិនបានស្គាល់អំពីប្រភពពិតប្រាកដនៃព្រះពរដែលពួកគេបានទទួលទេ ។

**២:៦** *ស្រាស់ផ្លូវនាង . . . ធ្វើកំផែងផង* ព្រះអម្ចាស់ទ្រង់នឹងដាក់អ៊ីស្រាអែលឱ្យនៅឆ្ងាយពីគេ ជាជាងដាក់ទោសឱ្យពួកគេស្លាប់ (ធៀបនឹង ចទ ២២:២១ អគ ១៦:៣៩–៤០ ២៣:៤៧ ណាហ ៣:៥–៧) ។

**២:៧** *នឹងស្វែងរក* មើល ៥:៦,១៥ ។ *តែមិនប្រទះសោះ* មើល ៥:៦ និងការពន្យល់ ។ *នឹងវិលទៅ . . . វិញ* នៅក្នុងភាសាហេព្រើ ឃ្លានេះគឺច្រើនតែមានន័យថា "ប្រែចិត្ត"។ *ប្តីដើម* គឺព្រះអម្ចាស់ ។

**២:៨** *នាងមិនបានដឹង* ពួកសាសន៍កាណានជឿថា ព្រះបាលជាអ្នកផ្គត់ផ្គង់ "ស្រូវ ទឹកទំពាំងបាយជូរ និងប្រេង"ដល់ពួកគេ (មើល ចទ ៧:១៣ យអ

ព្រះបាលនោះផងទេ[ធ] ៨ដូច្នេះ អញនឹងដកយកស្រូវ[ន]របស់
អញនៅរដូវចំរូត និងទឹកទំពាំងបាយជូរ[ប]របស់អញមកវិញ
នៅក្នុងរដូវបេះផ្លែ ហើយអញនឹងកញ្ឆក់យករោមចៀមនឹង
ខ្លូតទេសរបស់អញ ដែលសំរាប់ហ៊ុំកេរខ្មាសនាងមកវិញ
ដែរ ១០ឥឡូវនេះអញនឹងបើក[ផ]សេចក្តីអាមាស់ខ្មាសនាងឱ្យ
ពួកសហាយនាងបានឃើញ[ព] ឥតមានអ្នកណាដោះនាងឱ្យ
រួចពីកណ្តាប់ដៃអញបានឡើយ[ភ] ១១ក៏នឹងបំបាត់[ម]សណ្ឋាន
រីករាយរបស់នាង[យ] ព្រមទាំងបុណ្យសម្ពោធ បុណ្យថ្ងៃចូល
ខែ ថ្ងៃឈប់សំរាក ហើយអស់ទាំងជំនុំមុតមាំរបស់នាងផង[រ]
១២អញនឹងបំផ្លាញដើមទំពាំងបាយជូរ[ល] និងដើមល្វារបស់
នាង[វ]ដែលនាងធ្លាប់ពោលថា របស់ទាំងនេះជាឈ្នួល
ដែលសហាយនាងបានឱ្យ[ស] តែអញនឹងធ្វើឱ្យត្រឡប់ទៅជា
ព្រៃវិញ[ហ] ឯសត្វព្រៃ នឹងស៊ីអស់ទៅ[ឡ] ១៣អញនឹងទំលាក់អស់
ទាំងថ្ងៃ ដែលនាងបានដុតកំញាន[អ]ថ្វាយដល់ព្រះបាលទៅ[ក]
លើនាងវិញ គឺជាពេលដែលនាងបានធ្លាប់តែងខ្លួនដោយ
ទំហូ និងគ្រឿងលំអផ្សេងៗរបស់នាង[ខ] ទៅតាមសហាយ[គ]
ទាំងភ្លេចអញផង[ឃ] នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ង]។

១៤ដោយហេតុនោះ មើល អញនឹងប្រលោមនាំនាងទៅ
ឯទីរហោស្ថាន[ច] ហើយនិយាយសំរេចចិត្តនាង ១៥នៅទី
នោះ អញនឹងប្រគល់ចំការទំពាំងបាយជូររបស់នាងដល់
នាងវិញ ព្រមទាំងច្រកភ្នំអាកោរ[ឆ] ទុកជាទ្វារនៃទីសង្ឃឹម
ហើយនៅទីនោះនាងនឹងឆ្លើយតប[ជ]ដល់អញ ដូចកាលនៅ
វ័យក្មេង[ឈ] នឹងដូចនៅថ្ងៃដែលឡើងចេញពីស្រុកអេស៊ីព្ទ
មក[ញ] ១៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅថ្ងៃនោះនាង
នឹងហៅអញថា "អ្នកប្តី"អើយ[ដ] មិនមែនហៅថា "លោក
ម្ចាស់"ទៀតឡើយ ១៧ដ្បិតអញនឹងដកអស់ទាំងឈ្មោះនៃ
ព្រះបាលចេញពីមាត់នាង[ឋ] នោះអញនឹងលែងនឹកដើមពី
ឈ្មោះព្រះទាំងនោះទៀត[ឌ] ១៨នៅថ្ងៃនោះអញក៏នឹងតាំង
សញ្ញាឱ្យគេ ជាមួយនឹងសត្វនៅផែនដី នឹងសត្វហើរលើ
អាកាស ហើយសត្វលូនវារនៅដីផង[ឍ]អញនឹងបំបាក់ធ្នូ និង

**២:៨** ធ ខ.១៣ អក ១៦:១៥–១៩ ហស ៨:៤ **២:៩** ន ហស ៨:៧ ប ហស ៩:២ **២:១០** ផ អក ២៣:១០ ព យរ ១៣:២៦ ភ អក ១៦:៣៧ **២:១១** ម យរ ៧:៣៤ យ អស ២៤:៨ រ អស ១:១៤ យរ ១៦:៩ ហស ៣:៤ ៩:៥ អម ៥:២១ ៨:១០ **២:១២** ល អស ៧:២៣ យរ ៨:១៣ វ យរ ៥:១៧ ស យរ ៣:១ ហ អស ៥:៦ ឡ ហស ៥:៧ ១៣:៨ **២:១៣** អ អស ៦៥:៧ ក ខ.៨ យរ ៧:៩ ហស ១១:២ ខ អក ១៦:១៧ ២៣:៤០ គ ហស ៤:១៣ ឃ ហស ៤:៦ ៨:១៤ ១៣:៦ ង យរ ៤៤:១៧ ហស ១៣:១ **២:១៤** ច អក ១៩:១៣ **២:១៥** ឆ យស ៧:២៤,២៦ ជ នក ១៥:១–១៨ ឈ យរ ២:២ អក ១៦:២២ ញ អក ២៨:២៦ ហស ១២:៩ **២:១៦** ដ អស ៥៤:៥ **២:១៧** ឋ នក ២៣:១៣ ទដ ១៦:៤ ឌ យស ២៣:៧ សក ១៣:២ **២:១៨** ឍ យប ៥:២២

១:១០ ហក ១:១១ និងការពន្យល់)។ *ប្រាក់និងមាស* គឺប្រើសម្រាប់សង់រូបព្រះ(មើល ៨:៤ ១៣:២)។ *ព្រះបាល* គឺជាព្រះរបស់ពួកកាណាន ដែលពួកគេជឿថា ជាព្រះដែលគ្រប់គ្រងលើអាកាសធាតុ ដីជាតិនៃដំណាំ សត្វ និងមនុស្ស(មើលការពន្យល់ ពច ២:១៣)។

**២:៩** *ដកយក* ព្រះអម្ចាស់ទ្រង់ធ្វើឱ្យពួកគេបានដឹងអំពីប្រភពពិតប្រាកដនៃព្រះពរ ដោយធ្វើឱ្យដំណាំ និងហ្វូងសត្វរបស់ពួកគេមិនអាចបង្កើតផលបាន។

**២:១០** *បើកសេចក្តីអាមាស់ខ្មាសនាង* គឺបើកសេចក្តីអាមាស់របស់ប្រពន្ធដែលមិនស្មោះត្រង់ម្នាក់នោះនៅទីសាធារណៈ(មើល បទ ១:៨ អក ១៦:៣៧ ២៣:២៩)។

**២:១១** *បំបាត់សណ្ឋានរីករាយ* នៅពេលដែលពួកអ៊ីស្រាអែលត្រូវបាននិរទេស បុណ្យដ៏សប្បាយរីករាយរបស់ពួកគេនឹងលែងមានតទៅទៀត ។ *បុណ្យសម្ពោធ* មើល នក ២៣:១៤–១៧ ចទ ១៦:១៦ និងការពន្យល់ ។ *បុណ្យថ្ងៃចូលខែ* មើល ២ពវ ៤:២៣ អស ១:១៤ អម ៨:៥ និងពន្យល់ ។ *ថ្ងៃឈប់សំរាក* មើល នក ២០:៨–១១ ។

**២:១២** *ជាឈ្នួលដែលសហាយនាងបានឱ្យ* គឺជាថ្លៃឈ្នួលសម្រាប់ស្រីរកស៊ីផ្លូវភេទ(មើល ខ.៥ ៩:១ ចទ ២៣:១៨ អគ ១៦:៣៣ មីក ១:៧)។ ពួកអ៊ីស្រាអែលជឿថា ផលកសិកម្មរបស់ពួកគេគឺបានមកពីព្រះក្លែងក្លាយដែលពួកគេថ្វាយបង្គំ មិនមែនមកពីព្រះអម្ចាស់ទេ (មើល ចទ ១១:១៣–១៤)។

**២:១៣** *ថ្ងៃ* គឺថ្ងៃបុណ្យ ។ *ព្រះបាល* មើល ខ.១៧ ១១:២ ។ នៅត្រង់ចំណុចនេះលោកហូសេប្រើពាក្យព្រះបាលសំដៅទៅលើរូបព្រះដែលគេដាក់នៅក្នុងកន្លែងថ្វាយបង្គំជាច្រើន (មើល ពច ២:១១–១៣ និងការពន្យល់ យរ ២:២៣,២៨ និងការពន្យល់, ៩:១៤) ។ *ទៅតាម* មើលការពន្យល់ ខ.៥ ។ *ភ្លេច* គឺផ្ទុយនឹងពាក្យ "ទទួលស្គាល់"(មើលការពន្យល់ ខ.២០) នៅក្នុងព្រះគម្ពីរហូសេ(មើល ១៣:៤–៦ និងការពន្យល់ ១៣:៦, និងការពន្យល់ ១សយ ១២:៩)។

**២:១៤** *ទៅឯទីរហោស្ថាន* គឺដើម្បីចាប់ផ្តើមទំនាក់ទំនងឡើងវិញ(មើល ខ.១៩–២០)។ ត្រង់ចំណុចនេះគឺសំដៅទៅលើសម័យដែលពួកអ៊ីស្រាអែលត្រូវវិលវល់នៅទីរហោស្ថាន គឺនៅមុនពេលដែលពួកគេត្រូវល្បួងរបស់ព្រះបាលនៅស្រុកកាណាន ។ *និយាយសំរេចចិត្ត* គឺនិយាយបញ្ជាក់សារជាថ្មីលើកទឹកចិត្ត និងកម្សាន្តចិត្ត(ធៀបនឹង លប ៣៤:៣ រម ២:១៣ អស ៤០:២)។ ព្រះទ្រង់នៅតែបន្តបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ជានិច្ច ទោះជាស្ថិតក្នុងពេលជំនុំជម្រះក៏ដោយ ។

**២:១៥** *ច្រកភ្នំអាកោរ* គឺនៅក្បែរក្រុងយេរីខូ(មើល យស ៧:២៤,២៦ អស ៦៥:១០)។ លោកហូសេបាននិយាយជាពាក្យផ្ទុយអំពីន័យឈ្មោះកូនរបស់គាត់ ហើយនៅក្នុងខនេះគាត់ក៏បាននិយាយជាពាក្យផ្ទុយអំពីន័យឈ្មោះច្រកភ្នំអាកោរ ដែលជាកន្លែងដែលព្រះទ្រង់ជំនុំជម្រះរាស្ត្ររបស់ទ្រង់ជាលើកទីមួយនៅក្នុងទឹកដីសន្យា ហើយច្រកភ្នំនេះត្រូវក្លាយជានិមិត្តសញ្ញានៃឱកាសថ្មី ។

**២:១៦–១៧** *អ្នកប្តី . . . លោកម្ចាស់ . . . ព្រះបាល* គឺជាការលេងពាក្យ ។ ពាក្យប្តីជាភាសាហេព្រើមានការសរសេរ និងបញ្ចេញសម្លេងដូចពាក្យ "បាល"(ព្រះបាល)។ ការប្រើពាក្យនេះសំដៅទៅលើព្រះបាលគឺមានន័យថា មានការប្រឆាំងយ៉ាងខ្លាំងចំពោះការថ្វាយបង្គំព្រះបាល ។

**២:១៨** *តាំងសញ្ញាឱ្យគេ* មើល ៦:៧ ៨:១ ។ សត្វដែលបំផ្លាញ នៅក្នុង ខ.១២ ក៏ដូចជាសត្វស្លាប និងសត្វល្អិត នឹងមិនគំរាមកំហែងជីវិតទៀតទេ ។ ធម្មជាតិ និងប្រវត្តិសាស្ត្របានរួមផ្សំគ្នានៅក្នុងរូបភាពនៃសន្តិភាព (មើល អស ១១:៦–៩ និងការពន្យល់, ៦៥:២៥)។ *ដី* គឺប្រទេសអ៊ីស្រាអែល (មើល ១:២ ៤:១,៣ ៩:៣ និងការពន្យល់ ១០:១)។ *បានដេកទៅដោយសុខសាន្ត* មើល យរ ៣៣:១៦ អគ ៣៤:២៤–២៨ ។

ដាវ ហើយធ្វើឱ្យការសង្គ្រាមបាត់ចេញពីស្រុកទៅ[ណ] ឱ្យគេ
បានដេកទៅដោយសុខសាន្ត[ត] ១៩នោះអញនឹងដណ្តឹង[ថ]នាង
សំរាប់អញ ទុកជាដរាបតទៅ អើ អញនឹងដណ្តឹងនាង
សំរាប់អញ ដោយសេចក្តីសុចរិត សេចក្តីយុត្តិធម៌[ទ] សេចក្តី
សប្បុរស[ធ] និងសេចក្តីមេត្តាករុណា ២០ក៏នឹងដណ្តឹងនាង
សំរាប់អញដោយ សេចក្តីស្មោះត្រង់ផង នោះនាងនឹងបាន
ស្គាល់[ន]ព្រះយេហូវ៉ា[ប]។
២១ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា នៅថ្ងៃនោះអញនឹង
ឆ្លើយតប គឺអញនឹងតប[ផ]នឹងផ្ទៃមេឃ ហើយផ្ទៃមេឃនឹង
តបដល់ផែនដី ២២ដីនឹងតបដល់ស្រូវ ទឹកទំពាំង បាយជូរ
ហើយនិងប្រេង[ព] របស់ទាំងនោះក៏នឹងតបដល់ យេសរាល
ដែរ[ភ] ២៣អញនឹងសាបព្រោះ[ម]ពូជនាងនៅលើផែនដី
សំរាប់អញ រួចអញនឹងអាណិតមេត្តាដល់ពួកឡូ-រូហាម៉ា[យ]
ហើយនឹងនិយាយដល់ពួកឡូ-អាំមីថា ឯងជារាស្ត្ររបស់
អញ[រ] នោះគេនឹងឆ្លើយតបថា ទ្រង់ជាព្រះនៃយើងខ្ញុំ[ល]។

**២:១៨** ណ ទដ ៤៦:៩ អស ២:៤ សក ៩:១០ ត យប ៥:២៣ យរ ២៣:៦ អគ ៣៤:២៥
**២:១៩** ថ អស ៦២:៤ ២កថ ១១:២ ទ អស ១:២៧ ធ អស ៥៤:៨
**២:២០** ន យរ ៣១:៣៤ ហស ៤:១ ៦:៦ ១៣:៤ ប អគ ១៦:៨
**២:២១** ផ អស ៥៥:១០ សក ៨:១២ មឡ ៣:១០-១១
**២:២២** ព យរ ៣១:១២ ហស ១៤:៧ យអ ២:១៩

## ការផ្សះផ្សារបស់លោកហូសេជាមួយនឹងប្រពន្ធ

**៣** ១រួចព្រះយេហូវ៉ា ទ្រង់មានបន្ទូលមកខ្ញុំថា ចូរឱ្យឯង
ទៅស្រឡាញ់ស្រីមួយទៀតចុះ គឺជាស្រីដែលមានអ្នកដទៃ
ស្រឡាញ់ហើយ ក៏ជាស្រីសំផឹងផង[ក] ដូចជាព្រះយេហូវ៉ា
ទ្រង់ក៏ស្រឡាញ់ ដល់ពួកកូនចៅអ៊ីស្រាអែលដែរ ទោះបើ
គេបែរទៅប្រព្រឹត្តតាមព្រះដទៃ ហើយគេចូលចិត្តនឹងផែន
ទំពាំងបាយជូរក៏ដោយ[ខ] ២ដូច្នេះ ខ្ញុំក៏ទិញនាងមកសំរាប់
ខ្លួន ដោយប្រាក់១៥ដួង នឹងស្រូវឱក១ថាំងកន្លះ ៣រួចខ្ញុំ
និយាយនឹងនាងថា ត្រូវឱ្យឯងនៅសំរាប់អញ ជាយូរលង់
មិនត្រូវឱ្យក្បត់អញ ឬទៅជាប្រពន្ធរបស់អ្នកដទៃណាឡើយ
អញក៏នឹងប្រព្រឹត្តចំពោះឯងដូច្នេះដែរ ៤នេះពីព្រោះពួក
កូនអ៊ីស្រាអែលនឹងនៅឥតមានស្តេច ឬចៅហ្វាយ[គ]ឥតការ

ភ អគ ៣៦:២៩-៣០ ហស ១:៤ **២:២៣** ម យរ ៣១:២៧ យ ហស ១:៦ រ ខ.១ អស ១៩:២៥ ហស ១:១០ យរ ២៩:១២ រម ៩:២៥ ១ពត ២:១០ **៣:១** ក ហស ១:២ ខ ២សយ ៦:១៩ **៣:៤** គ ហស ១៣:១១

**២:១៩-២០** សេចក្តីសំខាន់ៗទាំងប្រាំនេះមានភាពចាំបាច់នៅក្នុងការចងស្ពានមេត្រីនៅក្នុងអាពាហ៍ពិពាហ៍ គឺជាបណ្ណាការដែលប្រសើរជាងលុយបណ្ណាការសម្រាប់កូនក្រមុំទៅទៀត (មើល នក ២២:១៦ ១សយ ១៨:២៥ និងការពន្យល់)។

**២:១៩** *សេចក្តីសុចរិត* មើល ១០:១២ ទដ ៤:១ យរ ២៣:៦ និងការពន្យល់។ *សេចក្តីយុត្តិធម៌* មើល អម ៥:២៤ និងការពន្យល់ ។ *សេចក្តីសប្បុរស* មើល ៤:១ ៦:៤ ១០:១២ និងការពន្យល់, ១២:៦ ។ *សេចក្តីមេត្តាករុណា* មើល ១:៦ និងការពន្យល់ ។ ពាក្យ "ឡូ-រហាម៉ា"មានន័យថា "មិនអាណិតមេត្តា" (ធៀបនឹង ទដ ៥១:១ ១០៣:៣-១៤)។

**២:២០** *សេចក្តីស្មោះត្រង់* គឺមានន័យថា អាចពឹងពាក់បាន(ចទ ៣២:៤ ទដ ៨៨:១១)។ *នឹងបានស្គាល់* គឺជាការទទួលស្គាល់អ្នកដែលបានតាំងសញ្ញាជាមួយគ្នា(មើល ៦:៣ និងការពន្យល់ ៨:២ ១៣:៤)។

**២:២១** *ឆ្លើយតប* ស្ត្រីនោះ(អ៊ីស្រាអែល)បានឆ្លើយតបចំពោះការស្នើរបស់ព្រះអម្ចាស់ ហើយឥឡូវនេះព្រះទ្រង់ឆ្លើយតបចំពោះអាកប្បកិរិយារបស់នាងវិញផងដែរ ។ ហើយដីបានឆ្លើយតប ដោយប្រែក្លាយជាមានជីជាតិ (មើល ខ.២១-២២)។

**២:២២** *យេសរាល* នៅក្នុងខនេះ ពាក្យនេះមានន័យថា "រុក្ខជាតិរបស់ព្រះអម្ចាស់"(មើល ១:៤,១១ និងការពន្យល់)។ ការគំរាមដែលមានឈ្មោះកូនរបស់លោកហូសេជាតំណាង បានប្រែក្លាយជាព្រះពរវិញ (មើល ១:១០ និងការពន្យល់) ។ ពាក្យដំបូងដែលត្រូវប្រើនៅក្នុងការតាំងសេចក្តីសញ្ញាគឺ "អញនឹងធ្វើជាព្រះដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងធ្វើជារាស្ត្រអញ" (យរ ៧:២៣, មើលការពន្យល់ នក ៦:៧ សក ៨:៨)។

**២:២៣** *ទ្រង់ជាព្រះនៃយើងខ្ញុំ* ត្រង់ចំណុចនេះ ពួកគេបានឆ្លើយតបចំពោះព្រះគុណនៃព្រះ ។ ផ្នែកខ្លះនៃខនេះត្រូវបានដងស្រង់នៅក្នុង រម ៩:២៥ ១ពត ២:១០ ហើយប្រើចំពោះសាសន៍ដទៃដែលចូលមកក្នុងពួកជំនុំ ។

**៣:១** *មានបន្ទូលមកខ្ញុំថា* ជំពូក៣ត្រូវបានរៀបរាប់ដោយប្រើសព្វនាមទីមួយ ហើយជំពូក១ត្រូវបានរៀបរាប់ដោយប្រើសព្វនាមទីបី ។ *ចូរឱ្យឯងទៅស្រឡាញ់ស្រីមួយទៀតចុះ* សេចក្តីស្រឡាញ់ដែលលោកហូសេមានចំពោះនាងកូមើរដែលមានចិត្តមិនស្មោះត្រង់ គឺបានបង្ហាញអំពីសេចក្តីស្រឡាញ់ដែលព្រះទ្រង់មានចំពោះសាសន៍អ៊ីស្រាអែលដែលស្មោះត្រង់ ។ ខ្លឹមសារសំខាន់បំផុតនៃព្រះគម្ពីរនេះគឺសេចក្តីស្រឡាញ់ដែលព្រះទ្រង់មានចំពោះអ៊ីស្រាអែល(មើល ១១:១ និងការពន្យល់, ១៤:៤) ។ *ព្រះដទៃ* មើល នក ២០:៣ ចទ ៣១:២០ ។ *ផែនទំពាំងបាយជូរ* គឺជាដង្វាយដែលពួកគេថ្វាយទៅព្រះបាល នៅក្នុងពិធីបុណ្យអរព្រះគុណសម្រាប់ការប្រមូលផល ។

**៣:២** មានភស្តុតាងបញ្ជាក់ថា នាងកូមើរបានធ្លាក់ខ្លួនជាទាសករ ហើយលោកហូសេបានលោះនាង ។ *១៥ដួង* គឺត្រូវជាពាក់កណ្តាលនៃតម្លៃខ្លួនធម្មតារបស់ទាសករម្នាក់(នក ២១:៣២ និងការពន្យល់) ឬតម្លៃលោះខ្លួននៅក្នុងការធ្វើបំណន់(លវ ២៧:៤) ។ *ថាំង* មានចំណុះប្រហែល ៣៣០ លីត្រ ។ នៅក្នុងខនេះយើងឃើញថា លោកហូសេបានលោះនាងដោយតម្លៃពាក់កណ្តាលជាប្រាក់១៥ដួង ហើយពាក់កណ្តាលជាស្រូវឱក១ថាំងកន្លះដែលសរុបមកត្រូវជាប្រាក់៣០ដួង ។

**៣:៣-៥** វគ្គនេះគឺបង្ហាញពីរូបភាពនៃការនិរទេសខ្លួន និងការវិលត្រឡប់មកវិញ ។

**៣:៣** *ជាយូរលង់* ប៉ុន្តែមិនមែនជារៀងរហូតទេ ព្រោះនឹងមានពេល "ក្រោយនោះ"(មើល ខ.៥) និងអនាគត (សូមមើល យរ ២៩:១១) ។ *នៅសំរាប់អញ* ត្រង់ចំណុចនេះ គឺសំដៅទៅលើរយៈពេលនៅឯកោ (សូមមើល ២:៦ និងការពន្យល់) គឺអាចប្រៀបធៀបនឹងការនិទេសរបស់អ៊ីស្រាអែល ។

**៣:៤** *ស្តេច* មើល ១:៤ ៥:១ ៨:៤,១០ ១០:១៥ ១៣:១០-១១ ។ *ចៅហ្វាយ* មើល ៧:៣,៥ ៨:៤ ១៣:១០ ។ *ឥតការថ្វាយយញ្ញបូជា* មើល ៦:៦ ៨:១១, ១៣ ។ *បង្គោលគោរព* មើល ១០:១-២ ១ពវ ១៤:២៣ និងការពន្យល់ ២ពវ ១០:១៧ មីក ៥:១៣ ។ *អេផូឌ* នៅត្រង់ចំណុចនេះ គឺសំដៅទៅលើរូបដែលជាប់ទាក់ទងនឹងរូបព្រះ(មើល ពច ៨:២៧ ១៧:៥ និងការពន្យល់)។ *រូបព្រះ* មើល លប ៣១:៣០ ១សយ ១៩:១៣,១៦ ។

ថ្វាយយញ្ញបូជា[ឃ] ឬបង្គោលគោរព[ង] ឥតអេផូឌ[ច] ឬរូបព្រះ
ជាយូរអង្វែង[ឆ] ៥ក្រោយនោះ ពួកកូនចៅអ៊ីស្រាអែលនឹង
វិលមកវិញ ហើយនឹងស្វែងរក[ជ]ព្រះយេហូវ៉ា ជាព្រះនៃគេ
និងដាវីឌ ជាស្តេចរបស់គេ[ឈ] នៅជាន់ក្រោយបង្អស់ គេនឹង
មកពឹងជ្រកនឹងព្រះយេហូវ៉ា ហើយនឹងសេចក្ដីសប្បុរសនៃ
ទ្រង់ ដោយញាប់ញ័រ[ញ,ដ]។

## រឿងក្ដីទាស់នឹងពួកអ៊ីស្រាអែល

**៤** ១ឱពួកកូនចៅអ៊ីស្រាអែលអើយ ចូរស្ដាប់ព្រះបន្ទូល
នៃព្រះយេហូវ៉ាចុះ ដ្បិតព្រះយេហូវ៉ាទ្រង់មានរឿង[ក]នឹងពួក
អ្នកស្រុកនេះ[ខ] ពីព្រោះគ្មានសេចក្ដីពិត[គ] ឬសេចក្ដីសប្បុរស
ក៏ឥតមានអ្នកណាស្គាល់ព្រះ[ឃ]នៅក្នុងស្រុកនេះឡើយ[ង] ២មាន
សុទ្ធតែការប្រទេសផ្ដាសា ភូតកុហក[ច] កាប់សំឡាប់[ឆ] លួច
ប្លន់[ជ] ហើយផិតគ្នាទទេ[ឈ] គេរឹបជាន់ ហើយកំចាយឈាម
តៗគ្នា[ញ] ៣ហេតុនោះ ស្រុកនេះនឹងត្រូវសោយសោក[ដ] ហើយ
អស់អ្នកដែលនៅក្នុងស្រុក គេនឹងល្វើយទៅ[ឋ] ព្រមទាំងសត្វ
នៅដី នឹងសត្វហើរលើអាកាសផង អើ ទាំងត្រីនៅសមុទ្រ
ក៏ត្រូវដកចេញដែរ[ឌ] ៤ប៉ុន្តែមិនត្រូវឱ្យអ្នកណាតតាំងឬស្តី
បន្ទោសអ្នកណាឡើយ ដ្បិតជនជាតិឯងប្រៀបដូចជាមនុស្ស
ដែលតតាំងនឹងសង្ឃ[ឍ] ៥ហេតុនោះ ឯងនឹងត្រូវចំពប់[ណ] ទាំង
ថ្ងៃ ហើយហោរានឹងចំពប់ជាមួយនឹងឯង នៅពេលយប់
ដែរ អញនឹងបំផ្លាញទាំងម្ដាយឯងផង[ត]។
៦រាស្ត្រអញ គេត្រូវបំផ្លាញទៅ ដោយខ្វះខាតដំរិះ[ថ] ដូច្នេះ
ដោយព្រោះឯងមិនព្រមទទួលដំរិះ បានជាអញក៏នឹងបោះ
បង់ចោលឯង មិនឱ្យធ្វើជាសង្ឃដល់អញទៀតដែរ ហើយ
ដោយហេតុ ដែលឯងបានភ្លេចច្បាប់[ទ]របស់ព្រះនៃឯង
នោះអញក៏នឹងភ្លេចកូនចៅរបស់ឯងដូចគ្នា ៧វារាល់គ្នា
មានចំនួនច្រើនឡើងប៉ុណ្ណា នោះក៏បានធ្វើបាបនឹងអញជា

**៣:៤** ឃ ដយ ១១:៣១ ហស ២:១១ ង ហស ១០:១ ច នក ២៥:៧ ឆ ពជ ១៧:៥–៦ ១៨:១៤–១៧ បទ ២:៩ សក ១០:២ **៣:៥** ជ ចទ ៤:២៩ អស ៩:១៣ ១០:២០ ហស ៥:១៥ មីក ៤:១–២ ឈ ១សយ ១៣:១៤ ញ ទដ ១៨:៤៥ ដ ចទ ៤:៣០ យរ ៥០:៤–៥ ហស ១១:១០ **៤:១** ក យប ១០:២ យរ ២:៩ ខ យអ ១:២,១៤ គ សភ ២៤:២ ឃ សភ ១០:២១ អស ១:៣ យរ ៧:២៨ ហស ២:២០ ង យរ ៥១:៥ **៤:២** ច អស ៥៩:៣ ហស ៧:៣ ១០:៤ ១១:១២ ឆ ហស ៥:២ ៦:៩ ជ ហស ៧:១ ឈ យរ ៩:២ ញ ២ពវ ២១:១៦ អស ១:១៥ អគ ២២:២,៩ ហស ៥:២ ១០:១៣ **៤:៣** ដ យរ ៤:២៨ ឋ អស ១៥:៦ ៣៣:៩ ឌ យរ ៤:២៥ ៩:១០ អគ ៣៨:២០ សផ ១:៣ **៤:៤** ឍ ចទ ១៧:១២ អគ ៣:២៦ **៤:៥** ណ អគ ៧:១៩ ១៤:៧ ត ហស ២:២ **៤:៦** ថ សភ ១០:២១ ទ ហស ៨:១,១២

**៣:៥** *វិលមកវិញ* លោកហូសេបានប្រើពាក្យនេះជាច្រើនដងនៅក្នុងព្រះគម្ពីរនេះ(មើល ២:៧ ៥:៤ ៦:១ ៧:១០ ១១:៥ ១២:៦ ១៤:១–២)។ *ស្វែងរក* គឺជាការប្រែចិត្ត(មើល ៥:១៥) ហើយលះចោលការបះបោរដែលរឹងចចេស(៧:១០)។ *ព្រះយេហូវ៉ា ជាព្រះនៃគេ* មើល ១២:៩ ១៣:៤ យរ ៥០:៤ ។ *ដាវីឌ ជាស្តេចរបស់គេ* គេសំដៅទៅលើស្ដេចដ៏ជាព្រះមែស៊ីដែលប្រសូត្រចេញពីវង្សស្ដេចដាវីឌ(មើល យរ ៣០:៩ អគ ៣៤:២៤ និងការពន្យល់)។ បន្ទាប់ពីស្ដេចសាឡូម៉ូនសុគត នគរអ៊ីស្រាអែល(នគរខាងជើង) បានបោះបង់ចោលវង្សស្ដេចដាវីឌ ។ *នៅជាន់ក្រោយបង្អស់* តាមព្រះគម្ពីរភាសាហេព្រើ ពាក្យនេះមានប្រើ១៣ដងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលជួនកាលមានន័យថា ពេលអនាគត("ជាន់ក្រោយ" លប ៤៩:១) ប៉ុន្តែភាគច្រើនដូចនៅក្នុងព្រះគម្ពីរនេះ គឺសំដៅទៅលើសម័យនៃព្រះមែស៊ី ("ក្រោយគ្រានោះ"យអ ២:២៨ ធៀបនឹង កច ២:១៧ ហព ១:២)។ *សេចក្ដីសប្បុរសនៃទ្រង់* គឺការប្រទានមកវិញនូវដំណាំទំពាំងបាយជូរ និងអូលីវដែលទ្រង់បានដកចេញពីពួកគេ(មើល ២:១២) និងប្រទាននូវគ្រប់ទាំងអ្វីៗដែលជាការប្រទានរបស់ទ្រង់ (ធៀបនឹង យរ ៣១:១២–១៤) ។

**៤:១–១៤:៩** វគ្គនេះនិយាយអំពី ការទាក់ទងរបស់អ៊ីស្រាអែលជាមួយនឹងសាសនានៅស្រុកកាណាន ដែលជាអំពើបាប និងលក្ខណៈនៅក្នុងទំនាក់ទំនងអន្តរជាតិរបស់អ៊ីស្រាអែល ។

**៤:១** *ព្រះបន្ទូលនៃព្រះយេហូវ៉ា* ក្នុងនាមជាអ្នកនាំព្រះរាជសាររបស់ព្រះ លោកហូសេបានធ្វើការចោទប្រកាន់ទៅលើសាសន៍អ៊ីស្រាអែលដែលមិនស្មោះត្រង់ និងធ្វើខុសនឹងសេចក្ដីសញ្ញា(ធៀបនឹង ខ.៤ ១២:២ អស ៣:១៣ យរ ២:៩ មីក ៦:២)។ *សេចក្ដីពិត* គឺសេចក្ដីស្មោះត្រង់(មើល ២:២០ និងការពន្យល់)នឹងព្រះអម្ចាស់ដែលបានតាំងសញ្ញាជាមួយពួកគេ(យស ២៤:១៤) និងជាការដោះស្រាយដ៏ត្រឹមត្រូវរបស់ពួកគេជាមួយនឹងអ្នកដទៃ (ធៀបនឹង សភ ៣:៣) ។

**៤:២** *ប្រទេចផ្ដាសា . . . ផិតគ្នា* អំពីបាបដែលមានរៀបរាប់នៅក្នុងខនេះ (ធៀបនឹង យរ ៧:៩)គឺជាអំពើរំលងក្រឹត្យវិន័យជាច្រើននៅក្នុងចំណោមក្រឹត្យវិន័យទាំងដប់ប្រការ(មើល នក ២០:១៣–១៦ និងការពន្យល់ ២០:១–២)។ *កំចាយឈាម* ការនេះគឺរួមមាន (១). ឃាតកម្ម(មើល ៦:៨–៩) (២). ការលួចធ្វើឃាត បន្ទាប់ពីស្ដេចយេរ៉ូបោមទីពីរបានស្លាប់ និងនៅក្នុងពេលដែលស្ដេចបីអង្គបានសោយរាជ្យនៅក្នុងរយៈពេល១ឆ្នាំ (២ពវ ១៥:១០–១៤) និង(៣). ការយកមនុស្សធ្វើយញ្ញបូជា (ទដ ១០៦:៣៨ អគ ១៦:២០–២១ ២៣:៣៧) ។ នៅពេលដែលពួកគេមិនស្គាល់ព្រះអម្ចាស់ទេ (ខ.១) នោះអំពើសុចរិតក៏មិនមានដែរ ។

**៤:៤–៩** វគ្គនេះគឺជាពាក្យបណ្ដឹងទាស់នឹងពួកសង្ឃ ដែលមាននាទីកាន់តាមក្រឹត្យវិន័យ និងនាំឱ្យគេកាន់តាមក្រឹត្យវិន័យ(មើល លវ ១០:១១ ចទ ៣១:៩–១៣ ៣៣:១០ ២រប ១៧:៨–៩ អរ ៧:៦,១០ យរ ១៨:១៨ អគ ៧:២៦ និងការពន្យល់ សផ ៣:៤ ហក ២:១១ មឡ ២:៧–៩)។ លោកហូសេបានព្រមានមិនឱ្យពួកសង្ឃចោទបណ្ដាជន នៅក្នុងរឿងដែលព្រះអម្ចាស់ជំនុំជម្រះជាតិសាសន៍អ៊ីស្រាអែលទាំងមូលនោះទេ ពីព្រោះពួកគេក៏មានកំហុស ហើយបណ្ដាជនក៏អាចចោទប្រកាន់ពួកគេបានដែរ គឺដូចជាដែលលោកហូសេបានធ្វើរួចហើយ(មើល ខ.៩ ធៀបនឹង អស ២៨:៧ យរ ២:២៦ ៤:៩ ២៣:១១)

**៤:៥** *ត្រូវចំពប់* គឺត្រូវជួបនឹងមហន្តរាយ(មើល ៥:៥)។ *ហោរា* មើល មីក ២:៦,១១ ៣:៥–៧ ។ *ម្ដាយឯង* គឺប្រទេសជាតិ(មើល ២:២,៥ អស ៥០:១)

**៤:៦** *រាស្ត្រអញ* គឺអ៊ីស្រាអែល(មើល ខ.៨,១២ ២:១,២៣ ៦:១១ ១១:៧ មីក ៦:៣,៥)។ *ត្រូវបំផ្លាញទៅ ដោយខ្វះខាតដំរិះ* នៅត្រង់ចំណុចនេះពួកសង្ឃមិនបានបង្រៀនព្រះបន្ទូលដល់បណ្ដាជនទេ ។ *មិនព្រមទទួលដំរិះ . . . មិនឱ្យធ្វើជាសង្ឃ* គឺជាការដាក់ទោស ។ *ច្បាប់របស់ព្រះ* គឺជាប្រភពនៃជីវិតរបស់ប្រទេសអ៊ីស្រាអែល(មើល ចទ ៣០:២០ និងការពន្យល់) ដែលពួកសង្ឃត្រូវធ្វើការពង្រឹងការអនុវត្តន៍ច្បាប់នោះដោយចិត្តស្មោះត្រង់ ។

ច្រើនប៉ុណ្ណោះដែរ ដូច្នេះអញនឹងបំផ្លាស់កិត្តិសព្ទ[ធ]របស់គេ
ឱ្យទៅជាសេចក្តីអាម៉ាស់ខ្មាសវិញ[ន] ៨គេចិញ្ចឹមជីវិត ដោយ
អំពើបាបរបស់រាស្ត្រអញ ក៏តាំងចិត្តចំពោះអំពើទុច្ចរិត
របស់វារាល់គ្នា[ប] ៩នៅគ្រានោះ បណ្តាជនជាយ៉ាងណា
សង្ឃ[ផ]ក៏នឹងយ៉ាងនោះដែរ ហើយអញនឹងធ្វើទោសគេ
ដោយព្រោះអំពើប្រព្រឹត្តរបស់គេ ព្រមទាំងសងដល់គេ
តាមកិរិយារបស់គេផង[ព] ១០នោះគេនឹងស៊ីតែមិនបានឆ្អែត[ភ]
ទេ ក៏នឹងប្រព្រឹត្តសេចក្តីកំផិត[ម] តែឥតបានចំរើនគ្នាដែរ
គឺដោយ ព្រោះគេបានលែងប្រយ័ត្ន[យ]ចំពោះយេហូវ៉ាទៅ។
១១ឯការកំផិត[រ] ស្រាទំពាំងបាយជូរ[ល] និងទឹកទំពាំងបាយ
ជូរថ្មី នោះរមែងដកយោបល់ចេញ[វ] ១២រាស្ត្រអញ គេសូម
សេចក្តីប្រឹក្សាចំពោះដុំឈើ[ស] គឺជាឈើផ្សងរបស់គេ[ហ] ដែល
ឱ្យគេយល់វិញ ដ្បិតនិស្ស័យនៃការកំផិត[ឡ]បានឱ្យគេប្រព្រឹត្ត
កន្លង[អ] គេបានប្រព្រឹត្តការកំផិត ដោយក្បត់[ក]ចំពោះ ព្រះ
របស់ខ្លួនហើយ ១៣គេថ្វាយយញ្ញបូជានៅលើកំពូល ភ្នំទាំង
ប៉ុន្មាន ក៏ដុតកំញានៅលើភ្នំតូច នៅក្រោមដើម ម៉ៃសាក់[ខ]
ដើមរលួស នឹងដើមពោធិ៍ទាំងអស់ដែរ ពីព្រោះដើមទាំង
នោះមានម្លប់ល្អ[គ] គឺហេតុនោះបានជាកូនស្រីរបស់ឯងរាល់
គ្នាបានកន្លងបវេណី[ឃ] ហើយអស់ទាំងប្រពន្ធថ្មោងថ្មីក្នុងពួក
ឯងរាល់គ្នាក៏ប្រព្រឹត្តកំផិតដែរ[ង] ១៤អញនឹងមិនធ្វើទោស
ដល់កូនស្រីរបស់ឯង ក្នុងកាលដែលប្រព្រឹត្តកន្លងបវេណី
ឬដល់ប្រពន្ធថ្មោងថ្មី ក្នុងកាលដែលប្រព្រឹត្តកំផិត នោះទេ
ដ្បិតពួកប្រុសៗក៏ដកខ្លួនទៅដោយឡែក ជាមួយនឹងពួក
សំផឹងដែរ[ច] គេថ្វាយយញ្ញបូជាជាមួយនឹងពួកកំផិត[ឆ] ដូច្នេះ
ជនទាំងឡាយដែលឥតមានយោបល់[ជ]នេះ គេនឹងត្រូវវិនាស
បង់[ឈ]។
១៥ឱអ៊ីស្រាអែលអើយ ទោះបើឯងប្រព្រឹត្តការកំផិត ក៏
មែនហើយ ប៉ុន្តែមិនត្រូវឱ្យយូដាទៅជាមានទោសឡើយ កុំ
ឱ្យឯងឡើងមកឯគីលកាល[ញ] ក៏កុំឱ្យឯងឡើងទៅឯបេត–
អាវេន[ដ] ឬស្បថថា "ដូចជាព្រះយេហូវ៉ាទ្រង់មានព្រះជន្ម

**៤:៧** ធ ហាព ២:១៦ ន ហស ៩:១១ ១០:១,៦ ១៣:៦ **៤:៨** ប អស ៥៦:១១ ហស ១៤:១ មីក ៣:១១ **៤:៩** ផ អស ២៤:២ ព យរ ៥:៣១ ហស ៨:១៣ ៩:៩,១៥ ១០:១០ ១២:២ **៤:១០** ភ លវ ២៦:២៦ អស ៥៥:២ មីក ៦:១៤ ម អគ ២២:៩ យ ហស ៧:១៤ ៩:១៧ **៤:១១** រ ខ.១៤ ហស ៥:៤ ល លវ ១០:៩ ១សយ ២៥:៣៦ វ សភ ២០:១ **៤:១២** ស យរ ២:២៧ ហ ហាព ២:១៩ ឡ ជន ១៥:៣៩ អ អស ៤៤:២០ ក ទដ ៧៣:២៧ **៤:១៣** ខ អស ១:២៩ គ យរ ៣:៦ ហស ១០:៨ ១១:២ ឃ យរ ២:២០ អម ៧:១៧ ង ហស ២:១៣ **៤:១៤** ច ខ.១១ ឆ លប ៣៨:២១ ហស ៩:១០ ជ សភ ១០:២១ ឈ ខ.១៩ **៤:១៥** ញ ហស ៩:១៥ ១២:១១ អម ៤:៤ ៥:៥ ដ យស ៧:២ ហស ៥:៨

**៤:៧** *កិត្តិសព្ទរបស់គេ* ព្រះទ្រង់ជាកិត្តិសព្ទរបស់ពួកគេ(មើល ទដ ១០៦:២០ និងការពន្យល់)។

**៤:៨** *ចិញ្ចឹមជីវិតដោយអំពើបាប* ពួកសង្ឃបានបរិភោគយញ្ញបូជាយ៉ាងស្រេកឃ្លាន(មើល ១សយ ២:១៣–១៧ និងការពន្យល់) ហើយបានទទួលផលចំណេញពីការបន្តធ្វើអំពីបាប ជាជាងពីការព្យាបាលអំពើបាបនោះ (មើល ៨:១៣ និងការពន្យល់)។

**៤:៩** *បណ្តាជនជាយ៉ាងណា សង្ឃក៏នឹងយ៉ាងនោះដែរ* មានន័យថា គ្រប់គ្នានឹងត្រូវទទួលការជំនុំជម្រះចំពោះអំពើបាបរបស់ពួកគេ ហើយគ្មានអ្នកណាម្នាក់អាចរួចខ្លួនឡើយ ។

**៤:១០** *ស៊ីតែមិនបានឆ្អែតទេ* នៅត្រង់ចំណុចនេះ ទោសដែលត្រូវទទួល(គឺ "បណ្តាសាផលដំណាំ" មើលការពន្យល់ ហាក ១:៦)គឺសក្តិសមនឹងអំពើបាបដែលបានប្រព្រឹត្ត ។ *សេចក្តីកំផិត* មើល ខ.១២,១៨ ២:៤ ៦:១០ ៩:១ ពច ២:១៧ និងការពន្យល់, ទដ ១០៦:៣៩ ។ ពួកគេមិនបានថ្វាយខ្លួនពួកគេដល់ព្រះអម្ចាស់ទេ ប៉ុន្តែ បែរជាប្រគល់ខ្លួនពួកគេទៅក្នុងអំពើកំផិតវិញ(ខ.១១–១៥ និងការពន្យល់ លប ២០:៩ នក ៣៤:១៥ ទដ ៧៣:២៧) ។

**៤:១១** *ស្រាទំពាំងបាយជូរ* មើល ៧:៥ ។ *ថ្មី* មើល ២:៨–៩,២២ ៧:១៤ ៩:២ ។

**៤:១២** *ដុំឈើ* គឺជារូបព្រះ(មើល យរ ២:២៧ ១០:៨ ហាព ២:១៩) ។ *ឈើផ្សង* គឺអាចជារូបព្រះធ្វើអំពីឈើ ឬឈើរបស់ពួកគ្រូទាយដែលមានរាងដូចរំពាត់ ។ *និស្ស័យនៃការកំផិត* មើល ៥:៤ ។

**៤:១៣** *កំពូលភ្នំ* តាមធម្មតា គឺជាទីកន្លែងដែលសាសន៍ដទៃជ្រើសរើសជាកន្លែងតាំងអាសនា(មើល ១០:៨ ចទ ១២:២ ១ពវ ៣:២ និងការពន្យល់ យរ ២:២០ ៣:៦)។ តាមអក្សរចារិកនៅលើបន្ទះដីឥដ្ឋ ពួកសាសន៍កាណានបានធ្វើពិធីបុណ្យសូមដីជាតិសម្រាប់ផលដំណាំនៅលើកំពូលភ្នំ ។ *ម៉ៃសាក់ . . . ដើមពោធិ៍* គឺដើមឈើសម្បូរម្លប់ ។ *កន្លងបវេណី* នៅក្នុងពិធីបុណ្យសូមដីជាតិសម្រាប់ផលដំណាំរបស់ពួកកាណាន មានសកម្មភាពផ្លូវភេទ(ខ.១៤) ដែលនាំឱ្យខូចដល់សីលធម៌ជាទូទៅ ។

**៤:១៤** *មិនធ្វើទោស* ត្រង់ចំណុចនេះមានន័យថា ពួកប្រុសៗនឹងកាត់ទោសកូនស្រី ឬប្រពន្ធខ្លួន ដោយសារអំពើអសីលធម៌ ប៉ុន្តែ ព្រះអម្ចាស់ទ្រង់មិនរួមចំណែក នៅក្នុងការកាត់ទោសដែលធ្វើដោយពួកមនុស្សមានពុតទាំងនោះទេ។ *ពួកកំផិត* គឺសំដៅទៅលើពួកស្ត្រីបម្រើផ្លូវភេទដល់ពួកប្រុសៗនៅកន្លែងថ្វាយដង្វាយ ហើយសកម្មភាពផ្លូវភេទនោះគឺជាផ្នែកមួយនៃពិធីបុណ្យនៅក្នុងសាសនារបស់ពួកគេ(ធៀបនឹង លប ៣៨:២១ និងការពន្យល់, ចទ ២៣:១៨)។ *ឥតមានយោបល់* គឺខុសពីសេចក្តីក្នុង ១៤:៩ ។

**៤:១៥** *ប្រព្រឹត្តកន្លងបវេណី* មើលការពន្យល់ លប ២០:៩ នក ៣៤:១៥ ។ *យូដា* មើលសេចក្តីផ្តើមត្រង់ចំណុច អ្នកនិពន្ធ និងកាលបរិច្ឆេទ ។ *មានទោស* មើល ១០:២ ១៣:១ ។ *កុំឱ្យឯងឡើងទៅ* គឺសំដៅទៅលើប្រទេសទាំងមូល ។ *គីលកាល* នៅក្បែរក្រុងយេរីខូ(មើល ២:១៥ ១២:១១ យស ៤:១៩ ១សយ ១១:១៤ និងការពន្យល់)និងជាកន្លែងដែលពួកអ៊ីស្រាអែលបានសង់ទីកន្លែងសម្រាប់សាសនា ។ *បេត–អាវេន* គឺជាឈ្មោះដែលត្រូវបានប្តូរពីឈ្មោះក្រុងបែតអែល(មើល ៥:៨) ជាកន្លែងមួយនៅក្នុងចំណោមកន្លែងថ្វាយបង្គំសំខាន់ៗទាំងពីរកន្លែងដែលស្តេចយេរ៉ូបោមទី១បានបង្កើត (មើល ១ពវ ១២:២៩ និងការពន្យល់)។ *ដូចជាព្រះយេហូវ៉ាទ្រង់មានព្រះជន្មរស់នៅ* ឃ្លានេះប្រើនៅក្នុងសម្បថ (មើល លប ៤២:១៥ និងការពន្យល់ ពច ៨:១៩ នរ ៣:១៣ ១សយ ១៤:៣៩ ២៦:១០,១៦ យរ ៤:២ ៣៨:១៦) ។ ទោះបីជាឃ្លានេះនិយាយអំពីព្រះដ៏ពិតក៏ដោយ(ចទ ៦:១៣ ១០:២០ ធៀបនឹង យស ២៣:៧) ក៏នៅក្នុងខនេះ មិនមានការអនុញ្ញាតិឱ្យប្រើដោយភាពពុតត្បុត ដោយធ្វើហាក់ដូចជាពួកគេពិតជាគោរពដល់ព្រះនាមទ្រង់មែននោះទេ

រស់នៅ"[ឋ] នោះដែរ ១៦ដ្បិតអ៊ីស្រាអែលបានប្រព្រឹត្តដោយ
រឹងចចេស[ឌ] ដូចជាគោក្រមុំក្រាញ[ឍ] ឥឡូវនេះ តើព្រះ
យេហូវ៉ា ទ្រង់ត្រូវឃ្វាលគេ ដូចជាកូនចៀម[ណ] នៅទីវាល
ធំទូលាយឬអី ១៧ឯអេប្រាអិមវាភ្ជាប់ខ្លួនតាមរូបព្រះហើយ
តាមតែវាចុះ ១៨គ្រឿងផឹករបស់គេបានទៅជាជូរហើយ គេ
ប្រព្រឹត្តសេចក្ដីកំផិតជានិច្ច ឯពួកគ្រប់គ្រងលើគេក៏គាប់ចិត្ត
ចំពោះតែអំពើគួរខ្មាស ១៩ខ្យល់[ត]បានក្ដោបគេដោយស្លាប
គេនឹងត្រូវមានសេចក្ដីខ្មាស ដោយព្រោះយញ្ញបូជាទាំង
ប៉ុន្មានរបស់ខ្លួន[ថ] ។

## ការជំនុំជម្រះសាសន៍អ៊ីស្រាអែល

**៥** ១ឱពួកសង្ឃអើយ ចូរស្ដាប់សេចក្ដីនេះ ឱពួកវង្ស
អ៊ីស្រាអែលអើយ ចូរស្ដាប់ចុះ ឯពូជពង្សនៃស្ដេចអើយ
ចូរផ្ទៀងត្រចៀកដែរ ដ្បិតសេចក្ដីយុត្តិធម៌[ក]កំពុងតែកាត់
ទោសដល់ឯងរាល់គ្នាហើយ ពីព្រោះឯងជាអន្ទាក់[ខ]នៅត្រង់
មីសប៉ា ហើយជាមង[គ]លាតទៅលើភ្នំតាបោរ ២ពួកក្បត់
បានផុងយ៉ាងជ្រៅ ចុះក្នុងការសំឡាប់សត្វថ្វាយដល់រូបព្រះ[ឃ]
ទោះបើអញបានធ្វើជាអ្នកបន្ទោស ដល់គេគ្រប់គ្នាក៏ដោយ[ង]
៣អញស្គាល់អេប្រាអិមហើយ ឯអ៊ីស្រាអែលក៏មិនកំបាំង[ច]
ពីអញដែរ ដ្បិតឥឡូវនេះ ឱអេប្រាអិមអើយ ឯងបាន
ប្រព្រឹត្តសេចក្ដីកំផិត ហើយអ៊ីស្រាអែលក៏ស្មោកគ្រោកដូច
គ្នា[ឆ] ៤ការប្រព្រឹត្តរបស់គេមិនបើកឱ្យគេវិលមក[ជ]ឯព្រះនៃ
គេវិញបានទេ ដ្បិតនិស្ស័យកំផិត[ឈ]នៅក្នុងគេហើយ គេមិន
បានស្គាល់[ញ]ព្រះយេហូវ៉ាសោះ ៥សេចក្ដីអំនួតរបស់ពួក
អ៊ីស្រាអែលតែងធ្វើបន្ទាល់[ដ]ទាស់នឹងគេ ហេតុនោះបានជា
អ៊ីស្រាអែល ហើយអេប្រាអិម និងត្រូវចំពប់ដួលចុះ[ឋ] ក្នុង
អំពើទុច្ចរិតរបស់ខ្លួន ឯយូដាក៏នឹងចំពប់ដួលចុះជាមួយនឹង
គេដែរ[ឌ] ៦គេនឹងនាំទាំងហ្វូងសត្វធំតូច ទៅស្វែងរកព្រះ
យេហូវ៉ា[ឍ] តែនឹងមិនប្រទះឃើញទ្រង់ទេ ដ្បិតទ្រង់បានថយ
ចេញ[ណ]ពីគេហើយ ៧គេបានប្រព្រឹត្តការកំបត់[ត]ចំពោះ

**៤:១៥** ឋ យរ ៤:២
**៤:១៦** ឌ នក ៣២:៩ ឍ យរ ៣១:១៨ ណ អស ៥:១៧ ៧:២៥
**៤:១៩** ត ហស ១២:១ ១៣:១៥ ថ ២.១៣–១៤ អស ១:២៩
**៥:១** ក យប ១០:២ ខ ហស ៦:៩ ៩:៨ គ យរ ៥:២៦
**៥:២** ឃ ហស ៤:២ ង ហស ៩:១៥
**៥:៣** ច អម ៥:១២ ឆ អក ២៣:៧ ហស ១:២ ៦:១០
**៥:៤** ជ ហស ៧:១០ ឈ ហស ៤:១១ ញ យរ ៤:២២ ហស ៤:៦
**៥:៥** ដ អស ៣:៩ យរ ២:១៩ ហស ៧:១០ ឋ អក ១៤:៧ ឌ ហស ១៤:១
**៥:៦** ឍ មីក ៦:៦–៧ ណ សភ ១:២៨ អស ១:១៥ អក ៨:៦ មឡ ១:១០
**៥:៧** ត អស ២៤:១៦ ហស ៦:៧

(មើល យរ ៥:២ និងការពន្យល់) ។

**៤:១៦** *រឹងចចេស* មើល នហ ៩:២៩ សក ៧:១១ ។ *គោក្រមុំក្រាញ* មើល យរ ២:២០ ៣១:១៨ និងការពន្យល់ ។ ត្រង់ចំណុចនេះ គឺបង្ហាញអំពីការមិនស្ដាប់បង្គាប់របស់អ៊ីស្រាអែល (ហស ១០:១១ ធៀបនឹង ១១:៤) ។

**៤:១៧** *អេប្រាអិម* គឺជាពូជអំបូរដែលធំជាងគេបំផុតរបស់អ៊ីស្រាអែល (មើលការពន្យល់ ៩:១១ ១៣:១) ហើយឈ្មោះនៃពូជអំបូរនេះត្រូវបានប្រើសំដៅទៅលើនគរខាងជើងទាំងមូល ។ *រូបព្រះ* គឺជារូបចម្លាក់កូនគោធ្វើពីមាស(មើល ៨:៥ និងការពន្យល់) និងជារូបព្រះបាល(មើល ២:៨,១៣ និងការពន្យល់)។ *តាមតែវាចុះ* មានន័យថា មិនអាចធ្វើអ្វីមួយ ដែលជួយដល់វាបាននោះទេ (មើល ២សយ ១៦:១១ ២ពវ ២៣:១៨) ។

**៤:១៩** *ខ្យល់បានក្ដោបគេដោយស្លាប* គឺជាន័យធៀបអំពីអំពើហឹង្សាដែលនឹងនាំឱ្យពួកគេត្រូវនិរទេស (មើល ១៣:៣ នរ ១:២២ ទដ ១:៤ និងការពន្យល់)។ ដោយសារនៅក្នុងភាសាហេព្រើ ពាក្យ "ខ្យល់" និង "វិញ្ញាណ" គឺតែមួយ ដូចនេះពាក្យខ្យល់ក្នុងខនេះអាចសំដៅទៅលើ "វិញ្ញាណនៃពេស្យាចារ"(មើល ៥.១២ និងការពន្យល់) ។ *សេចក្ដីខ្មាស* ពួកគេសង្ឃឹមថា ការដែលពួកគេធ្វើយញ្ញបូជាអាចជួយឱ្យពួកគេចម្រើនឡើង ប៉ុន្តែដោយសារការថ្វាយបង្គំរូបព្រះ ព្រះទ្រង់នឹងឱ្យពួកគេទទួលនូវការជំនុំជម្រះដែលនឹងធ្វើឱ្យពួកគេត្រូវមានសេចក្ដីខ្មាសនៅក្នុងចំណោមជាតិសាសន៍ទាំងឡាយ(មើល ១០:៦)។

**៥:១** *ពួកសង្ឃ . . . ពួកវង្សអ៊ីស្រាអែល . . . ពូជពង្សនៃស្ដេចអើយ* មនុស្សទាំងបីក្រុមនេះត្រូវទទួលខុសត្រូវនៅក្នុងការការពារយុត្តិធម៌ ប៉ុន្តែ ពួកគេមិនបានធ្វើឱ្យបានត្រឹមត្រូវទេ ។ *អន្ទាក់ . . . មងលាត* គឺជាឧបករណ៍ចាប់សត្វ ហើយខនេះបាននិយាយអំពីឧបករណ៍ទាំងនេះធៀបនឹងអ្នកដែលប្រើទាញយកប្រយោជន៍ពីអ្នកស្លូតត្រង់យ៉ាងព្រៃផ្សៃ ដោយប្រើច្បាប់ និងសេដ្ឋកិច្ចជាកលល្បិច(មើល យប ១៨:៨–១០ ទដ ១៤០:៥ សភ ២៩:៥–៦ បទ ១:១៣)។ *មីសប៉ា* គឺអាចជា(១).តំបន់ដែលនៅស្រុកកាឡាត ខាងកើតទន្លេយ័រដាន់(លប ៣១:៤៣–៤៩) ឬជា(២).តំបន់នៅបេនយ៉ាមីន(១សយ ៧:៥ និងការពន្យល់) ។ *ភ្នំតាបោរ* គឺជាភ្នំដែលនៅតំបន់ចុងអាគ្នេយ៍នៃច្រកភ្នំយេសរាល ។ ខនេះប្រាកដជានិយាយអំពីភ្នំតាបោរសំដៅទៅលើហេតុការណ៍ដ៏ល្បីមួយ ដែលបង្ហាញអំពីអំពើពុករលួយរបស់អ៊ីស្រាអែល ។

**៥:២** *បន្ទោស* គឺជាពាក្យដ៏សំខាន់ ដែលប្រើនៅក្នុងបទទំនាយអំពីការដែលព្រះអម្ចាស់កែរតម្រង់រាស្ត្ររបស់ទ្រង់(មើល អស ២៦:១៦ យរ ២:៣០ ៥:៣ ៧:២៨)។

**៥:៤** *ការប្រព្រឹត្តរបស់គេ* មើល ៤:៩ ៧:២ ៩:១៥ ១២:២ ។ ការដែលនៅតែចចេសប្រព្រឹត្តបាបអាចនាំឱ្យពិបាកប្រែចិត្ត(យរ ១៣:២៣ យហ ៨:៣៤ រម ៦:៦,១៦)។ *និស្ស័យកំផិត* មើល ៤:១២ និងការពន្យល់ ។ *មិនបានស្គាល់* មើល ៤:៦ អស ១:៣ និងការពន្យល់ ។

**៥:៥** *សេចក្ដីអំនួត* គឺការរឹងចចេសបះបោរទាស់នឹងព្រះអម្ចាស់(មើល ចទ ១:៤៣ ១សយ ១៥:២៣ នហ ៩:១៦ យប ៣៥:១២ ទដ ១០:២ អក ១៦:៥៦–៥៧)។ *ធ្វើបន្ទាល់* គឺធ្វើបន្ទាល់តាមរយៈការចោទប្រកាន់របស់ព្រះអម្ចាស់ចំពោះរាស្ត្រទ្រង់(មើល ៤:១ និងការពន្យល់)។ *ចំពប់ដួល* មើល ៤:៥ និងការពន្យល់ ។ *យូដា* មើលសេចក្ដីផ្ដើមត្រង់ចំណុច អ្នកនិពន្ធ និងកាលបរិច្ឆេទ ។

**៥:៦** *ទៅស្វែងរកព្រះយេហូវ៉ា* គឺដោយចូលទៅចំពោះទ្រង់ដោយការអធិស្ឋាន និងថ្វាយយញ្ញបូជា(មើល ៣:៥ និងការពន្យល់, អម ៥:៤–៥)។ *មិនប្រទះឃើញទ្រង់ទេ* ការថ្វាយយញ្ញបូជានៅក្នុងស្ថានភាពបែបនេះគឺគ្មានប្រយោជន៍ទេ(មើល ២:៧ ធៀបនឹង អស ១:១០–១៥ អម ៥:២១–២៤ មីក ៦:៦–៨)។ អោយតែពួកអ៊ីស្រាអែលបែរមករកទ្រង់វិញ ដោយចិត្តស្មោះត្រង់ នោះពួកគេនឹងអាច"ស្វែងរកទ្រង់ឃើញ" (មើល ៦.១៥ ៣:៥ ចទ ៤:២៩–៣១ យរ ២៩:១៣)។

ព្រះយេហូវ៉ា ដ្បិតគេបានបង្កើតកូនកំផិត[ច]ឡើង ដូច្នេះដល់
ចូលខែថ្មី[ទ]គេនឹងត្រូវវិនាស[ធ]ទៅ ព្រមទាំងស្រែចំការរបស់
គេផង។

៨ចូរផ្លុំស្នែង[ន] នៅត្រង់គីបៀរ[ប] ហើយផ្លុំត្រែនៅត្រង់
រ៉ាម៉ាចុះ[ផ] ចូរធ្វើសូរជាគ្រឿងសំគាល់ឡើងនៅត្រង់បេត–
អាវេនថា[ព] ឱបេនយ៉ាមីនអើយ ន៎ គេមកខាងក្រោយឯង
ហើយ ៩នៅថ្ងៃដែលត្រូវបន្ទោសនោះ[ភ] អេប្រាអិមនឹង
ត្រឡប់ទៅជាទីខូចបង់[ម]នៅកណ្ដាលអស់ទាំងពូជអំបូរនៃ
អ៊ីស្រាអែល អញបានឱ្យដឹងដំណឹងពីការដែលត្រូវកើតមក
ជាមិនខាន[យ] ១០ពួកចៅហ្វាយរបស់យូដា ប្រៀបដូចជា
មនុស្សដែលដកព្រំខ័ណ្ឌចោល[រ] ដូច្នេះអញនឹងចាក់សេចក្ដី
ក្រោធ[ល]របស់អញទៅលើគេដូចជាទឹក ១១អេប្រាអិមត្រូវ
សង្កត់សង្កិន គឺត្រូវកិនកំទេចក្នុងការវិនិច្ឆ័យ ពីព្រោះគេ
បានស្ម័គ្រចិត្តដើរតាមបង្គាប់របស់មនុស្ស[វ] ១២ដូច្នេះអញ
នឹងបានដូចជាដង្កូវកាត់[ស] ដល់ពួកអេប្រាអិម ហើយដូចជា
សេចក្ដីពុកផុយ[ហ]ដល់ពួកវង្សយូដា ១៣កាលអេប្រាអិម[ឡ]បាន
ដឹងអាការៈរោគរបស់ខ្លួន ហើយយូដាបានឃើញរបួស
របស់ខ្លួន នោះអេប្រាអិមក៏ទៅឯស្រុកអាសស៊ើរ[អ] ហើយ
ចាត់គេទៅឯស្ដេចយ៉ារេប[ក] តែគេមិនអាចនឹងរំងាប់រោគ[ខ]
ឯងឬមើលរបួសឱ្យឯងសះបានឡើយ[គ] ១៤ដ្បិតអញនឹងបានដូច
ជាលង្ហិនដល់ពួកអេប្រាអិម ហើយដូចសិង្ហស្ទាវ[ឃ]ដល់ពួក
វង្សយូដា អញ គឺអញនេះហើយ នឹងហែកគេ[ង] រួចចេញ
ទៅបាត់ អញនឹងពាំយកគេទៅ ឥតមានអ្នកណាជួយឱ្យ
រួចបានឡើយ[ច] ១៥អញនឹងវិលត្រឡប់ទៅឯទីកន្លែងរបស់
អញ[ឆ] ទាល់តែគេបានទទួលស្គាល់ទោសរបស់ខ្លួន[ជ] ហើយ
ស្វែងរកមុខអញវិញ[ឈ] កាលណាគេមានសេចក្ដីវេទនា[ញ]
នោះ គេនឹងស្វែងរកអញយ៉ាងស្រវ៉ាស្រទេញ[ដ] ។

## ពួកអ៊ីស្រាអែលមិនព្រមប្រែចិត្ត

**៦** ១ចូរមក យើងវិលត្រឡប់[ក]ទៅឯព្រះយេហូវ៉ាចុះ ដ្បិត
ទ្រង់បានហែកហួរយើងហើយ[ខ] ទ្រង់ក៏នឹងប្រោសឱ្យជាផង[គ]
ទ្រង់បានវាយឱ្យរបួស ហើយទ្រង់នឹងរុំបិទវិញ[ឃ] ២នៅតែ
២ថ្ងៃ នោះទ្រង់នឹងប្រោសឱ្យយើងរាល់គ្នាបានរស់ហើយ[ង]

**៥:៧** ច ហស ២:៤ ទ អស ១:១៤ ធ ហស ២:១១–១២ **៥:៨** ន ជន ១០:២ យរ ៤:២១ អគ ៣៣:៣ ប ពច ១៩:១២ ហស ៩:៩ ១០:៩ ផ អស ១០:២៩ ព យស ៧:២ ហស ៤:១៥ ១០:៥ **៥:៩** ភ អស ៣៧:៣ ហស ៩:១១–១៧ ម អស ៧:១៦ យ អស ៤៦:១០ សក ១:៦ **៥:១០** រ ចទ ១៩:១៤ **៥:១០** ល អគ ៧:៨ **៥:១១** វ ហស ៩:១៦ មីក ៦:១៦ **៥:១២** ស យប ១៣:២៨ អស ៥១:៨ ហ យប ១៨:១៦ **៥:១៣** ឡ អស ៧:១៦ អ អគ ២៣:៥ ហស ៧:១១ ៨:៩

១២:១ ក បទ ៥:៦ ហស ៧:៨ ១០:៦ ខ អស ៣:៧ ហស ១៤:៣ គ ហស ២:៧ **៥:១៤** ឃ យប ១០:១៦ យរ ៤:៧ អម ៣:៤ ង ហស ៦:១ ច ចទ ៣២:៣៩ មីក ៥:៨ **៥:១៥** ឆ បអស ១៨:៤ ជ លប ២៥:៤០ ឈ ជន ២១:៧ ទដ ២៤:៦ ហស ៣:៥ ញ ទដ ៥០:១៥ យរ ២:២៧ ដ អស ៦៤:៩ អក ២០:៤៣ **៦:១** ក អស ១០:២០ ១៩:២០ ខ យប ១៦:៩ បទ ៣:១១ ហស ៥:១៤ គ ជន ១២:១៣ យរ ៣:២២ ឃ ចទ៣២:៣៩ យប ៥:១៨ យរ ៣០:១៧ ហស ១៤:៤ ង ទដ ៣០:៥ ៨០:១៨

**៥:៧** *ការកំបត់* មើល ១:២ និងការពន្យល់ ។ *ខែថ្មី* តាមធម្មតា ពេលនោះគឺជាថ្ងៃបុណ្យ(មើលឧទាហរណ៍នៅក្នុង ២:១១ ១សយ ២០:៥ និងការពន្យល់ អម ៨:៥ កល ២:១៦) ប៉ុន្ដែនៅក្នុងខនេះគឺជាពេលជិនុំជម្រះ ។ ឬមានន័យម្យ៉ាងទៀតថា រយៈពេលមួយខែគឺគ្រប់គ្រាន់ល្មមសម្រាប់ការដាក់ទោសពួកគេ ។

**៥:៨** នៅក្នុងចំណុចនេះ អ្នកកាត់ស្រាយខ្លះយល់ឃើញថា បទទំនាយនៅក្នុងជំពូក ៤–៥ មានការទាក់ទងនឹងសង្គ្រាមរវាងពួកអ៊ើរ៉ាម(ស៊ីរី) និងពួកអេប្រាអិម(អ៊ីស្រាអែល) (មើល ២ពវ ១៦:៥–៩ អស ៧:១–៩ និងការពន្យល់)។ *ផ្លុំត្រែ* គឺធ្វើពីស្នែងចៀមឈ្មោល ហើយនៅក្នុងខនេះបានបន្លឺសម្លេងប្រកាសអាសន្នអំពីកងទ័ពសត្រូវដែលកំពុងតែធ្វើដំណើរសំដៅមក (មើល ៨:១ យអ ២:១ និងការពន្យល់, អម ៣:៦)។ *គីបៀរ* ជាក្រុងដែលស្ថិតនៅខាងជើងទីក្រុងយេរូសាឡិម ចម្ងាយប្រហែល ៣,២ គីឡូម៉ែត្រ ។ *រ៉ាម៉ា* ស្ថិតនៅខាងជើងក្រុងគីបៀរ ។ *បេតអាវេន* ការពន្យល់ ៤:១៥ ។ *ឱបេនយ៉ាមីនអើយ ន៎ គេមកខាងក្រោយឯងហើយ* ប្រហែលជាសម្រែកឱ្យចាប់ផ្ដើមប្រយុទ្ធ របស់ពួកបេនយ៉ាមីន ។

**៥:៩** *នឹងត្រឡប់ទៅជាទីខូចបង់* មើល យរ ២៥:១១,៣៨ ។

**៥:១០** *ដកព្រំខ័ណ្ឌចោល* ពួកយូដាបានរឹមអូសទឹកដីពួកអ៊ីស្រាអែល(១ពវ ១៥:១៦–២២ មើល ចទ ១៩:១៤ និងការពន្យល់ ២៧:១៧ សភ ១៥:២៥ និងការពន្យល់, ២៣:១០ អស ៥:៨ មីក ២:២) ។ *សេចក្ដីក្រោធរបស់អញ* មើល ១៣:១១ ។

**៥:១២** *ដង្កូវ . . . សេចក្ដីពុកផុយ* មានន័យថា ពួកគេទាំងពីរក្រុមនឹងត្រូវទទួលរងការបំផ្លាញ (មើល យប ១៣:២៨)។

**៥:១៣** *អាការៈរោគ . . . របួស* គឺជាពាក្យប្រៀបប្រដូចទៅនឹងរបួសរបស់ជាតិទាំងមូល ដែលពួកអ៊ីស្រាអែល និងយូដាបានទទួលរងពីខ្មាំងសត្រូវរបស់ពួកគេ(មើល អស ១:៥–៦ ១៧:១១ យរ ១៥:១៨ ៣០:១២–១៥)។ *ទៅឯស្រុកអាសស៊ើរ* ក្នុងកំណត់ត្រាជាប្រវត្តិសាស្ត្ររបស់សាសន៍អាសស៊ើរ ស្ដេចនេហេមា និងហូស៊ារបស់ពួកអ៊ីស្រាអែលបាននាំសួយសារអាករដល់ស្ដេចទិកឡាថ–ភីលេស៊ើ ទី៣(ផ្ទៀបនឹង ២ពវ ១៥:១៩–២០ ១៧:៣)។ *មិនអាចនឹងរំងាប់រោគ* មានន័យថា ការចងសម្ព័ន្ធមិត្រជាមួយគ្នានោះគឺគ្មានប្រយោជន៍ទេ ។

**៥:១៤** *សិង្ហ* មើល ១៣:៧ អម ១:២ និងការពន្យល់, ៣:៨ ។ ព្រះអម្ចាស់ទ្រង់អាចប្រើឱ្យមនុស្សធ្វើការថ្វាយទ្រង់(មើល អស ១០:៥ និងការពន្យល់) ប៉ុន្ដែទ្រង់នឹងមានការទទួលខុសត្រូវនៅក្នុងការដាក់ទោសអ៊ីស្រាអែល ដែលពួកគេមិនអាចគេរួច(មើល អស ៥:២៩ ៤២:២២ អម ៩:១–៤)។

**៥:១៥** *វិលត្រឡប់ទៅឯទីកន្លែងរបស់អញ* នៅត្រង់ចំណុចនេះព្រះអម្ចាស់ទ្រង់គំរាមថា ទ្រង់នឹងដកព្រះវត្តមានចេញពីអ៊ីស្រាអែលរហូតដល់ពួកគេពិតជាប្រែចិត្តឡើងវិញមែន នៅពេលដែលពួកគេមិនអាចសង្ឃឹមលើអ្វីទៀត ហើយការនេះគឺជាមូលដ្ឋានគ្រឹះនៃខ្លឹមសារបន្ទាប់ទៀតនៅក្នុងបទទំនាយរបស់លោកហោរា ។

**៦:១** *ចូរមក យើងវិលត្រឡប់* ពាក្យនេះគឺជាសំណើរឱ្យប្រែចិត្ត (ដោយប្រើឃ្លានៅក្នុង ៥:១៣–១៥) ដែលនៅក្នុងនោះ ពួកអ៊ីស្រាអែលបានទទួលស្គាល់ថា ព្រះទ្រង់ជាគ្រូពេទ្យដ៏ពិត (ផ្ទៀប ៧:១) ហើយពួកអាសស៊ើរមិនអាចព្យាបាលបានទេ(ផ្ទៀបនឹង ៥:១៣) ។

**៦:២** *២ថ្ងៃ . . . ថ្ងៃទី៣* គឺជារយៈពេលដ៏ខ្លី ។ នៅត្រង់ចំណុចនេះ ពួក

លុះដល់ថ្ងៃទី៣[ច] ទ្រង់នឹងឱ្យយើងក្រោកឡើង[ឆ] នោះយើង
នឹងរស់នៅចំពោះព្រះភក្ត្រទ្រង់ ៣ចូរឱ្យយើងបានស្គាល់
ព្រះយេហូវ៉ាចុះ ហើយមានព្យាយាមនឹងស្គាល់ទ្រង់តទៅ ឯ
ដំណើរដែលទ្រង់យាងចេញមក នោះទៀងដូចជាអរុណ
រះ[ជ] ហើយទ្រង់នឹងយាងមកឯយើងរាល់គ្នា ដូចជាទឹកភ្លៀង
គឺដូចជាភ្លៀងចុងរដូវ ដែលតែងតែស្រោចស្រពផែនដី[ឈ] ។
៤ឱអេប្រាអិមអើយ[ញ] តើគួរឱ្យអញប្រោសដល់ឯងជា
យ៉ាងណា ឱយូដាអើយ តើគួរឱ្យអញប្រោសដល់ឯងជា
យ៉ាងណា ដ្បិតសេចក្ដីសប្បុរសរបស់ឯង នោះប្រៀបដូច
ជាពពកនៅពេលព្រលឹម ហើយដូចជាទឹកសន្សើមដែល
បាត់ទៅយ៉ាងបន្ទាន់[ឌ] ៥ដោយហេតុនោះ អញបានកាប់ គេ
ដោយសារពួកហោរ៉ា ហើយបានសំឡាប់គេ ដោយពាក្យ
ពីមាត់អញ[ឍ] ឯសេចក្ដីវិនិច្ឆ័យរបស់អញ នោះប្រៀប ដូច
ជាពន្លឺដែលចាំងមក[ណ] ៦ដ្បិតអញពេញចិត្តចំពោះសេចក្ដី
សប្បុរស មិនមែនចំពោះយញ្ញបូជាទេ[ត] ហើយពេញចិត្ត
ចំពោះការស្គាល់[ថ]ព្រះ ជាជាងការថ្វាយដង្វាយដុតទៅ
ទៀត[ទ] ៧ប៉ុន្តែគេបានប្រព្រឹត្តដូចជាមនុស្សល្មើស គឺបានកន្លង
នឹងសេចក្ដីសញ្ញា[ធ] គេបានក្បត់[ន]នឹងអញ ក្នុងសេចក្ដីនោះ
ឯង ៨កាឡាតជាទីក្រុងរបស់ពួកអ្នកដែលប្រព្រឹត្តអំពើ
ទុច្ចរិត[ប] គឺត្រូវប្រឡាក់ដោយឈាមហើយ ៩ពួកចោរឃ្លាំ
ចាំប្លន់មនុស្សជាយ៉ាងណា[ផ] ពួកសង្ឃក៏កាប់សំឡាប់[ព]មនុស្ស
តាម ផ្លូវទៅឯស៊ីគែមដូច្នោះដែរ អើ គេបានប្រព្រឹត្តបទដ៏
អាក្រក់ណាស់ផង[ភ] ១០អញបានឃើញការយ៉ាងសំបើម[ម]
នៅក្នុងពួកវង្សអ៊ីស្រាអែល គឺមានការកំផិតរបស់ពួក
អេប្រាអិម ឯអ៊ីស្រាអែលក៏បានស្មោកគ្រោកដែរ[យ] ១១មួយ
ទៀតឱយូដា អើយ មានការចំរូតដំរូវ[រ]មកលើឯងដែរ ក្នុង
កាលដែល អញនាំពួកឈ្លើយ[ល]ក្នុងរាស្ត្រអញឱ្យមកវិញ ។

៧ ១កាលអញ ចង់ប្រោសពួកអ៊ីស្រាអែលឱ្យជានោះ
សេចក្ដីទុច្ចរិតរបស់អេប្រាអិម និងអំពើអាក្រក់របស់
សាម៉ារីបានលេចមកឱ្យឃើញ[ក] ដ្បិតគេបានប្រព្រឹត្តសេចក្ដី
កំភូត[ខ] មានចោរលួចចូលមកនៅខាងក្នុង[គ] ហើយមាន
ចោរប្លន់រឹបជាន់ខាងក្រៅ[ឃ] ២គេក៏មិនពិចារណាក្នុងចិត្តថា

**៦:២** ច មថ ១៦:២១ ឆ ទដ ៧១:២០ **៦:៣** ជ យប ៤:៣ យអ ២:២៣ ឈ ទដ ៧២:៦ ហស ១១:១០ ១២:៦ **៦:៤** ញ ហស ១១:៨ ដ ហស ៧:១ ១៣:៣ **៦:៥** ឋ យរ ១:៩–១០ ៥:១៤ ២៣:២៩ ឌ ហព ៤:១២ **៦:៦** ឍ ១សយ ១៥:២២ អស ១:១១ មថ ៩:១៣ ១២:៧ មក ១២:៣៣ ណ យរ ៤:២២ ហស ២:២០ ត ទដ ៤០:៦ មីក ៦:៨ **៦:៧** ថ លប ៩:១១ យរ ១១:១០ ហស ៨:១ ទ ហស ៥:៧ **៦:៨** ធ ហស ១២:១១

**៦:៩** ន ទដ ១០:៨ ប ហស ៤:២ ផ យរ ៥:៣០–៣១ ៧:៩–១០ អគ ២២:៩ ហស ៥:១ ៧:១ **៦:១០** ព យរ ៥:៣០ ភ យរ ២៣:១៤ អគ ២៣:៧ ហស ៥:៣ **៧:១** ក អគ ២៤:១៣ ហស ៦:៤ ខ .១៣ គ នក ២២:២ ហស ៤:២ ឃ ហស ៦:៩ ១២:១

អ៊ីស្រាអែលស្មានថា សេចក្ដីក្រោធរបស់ព្រះគឺគ្រាន់តែបណ្ដោះអាសន្នទេ ។

**៦:៣** *បានស្គាល់ព្រះ* គឺជាពាក្យជាគន្លឹះនៃព្រះគម្ពីរហូសេ (មើល ខ.៦ ២:២០ និងការពន្យល់, ៤:១,៦ ៥:៤) ។ *ដូចជាទឹកភ្លៀង . . . ភ្លៀងចុងរដូវ* ពួកអ៊ីស្រាអែលជឿថា ដរាបណាភ្លៀងនៅតែធ្លាក់តាមរដូវ សេចក្ដីសប្បុរសរបស់ទ្រង់នឹងត្រឡប់មករកពួកគេវិញ ហើយស្អាងពួកគេឡើងវិញ ។

**៦:៤** *តើគួរឱ្យអញប្រោសដល់ឯងជាយ៉ាងណា* មើល អស ៥:៤ ។ ព្រះអម្ចាស់ទ្រង់ជ្រាបអំពីការប្រែចិត្តមិនច្បាស់លាស់របស់ពួកអ៊ីស្រាអែល ។ *អេប្រាអិម* មើលការពន្យល់ ៤:១៧ ។ *យូដា* មើលសេចក្ដីផ្ដើមត្រង់ចំណុចអ្នកនិពន្ធ និងកាលបរិច្ឆេទ ។ *សេចក្ដីសប្បុរស* មើល ២:១៩ និងការពន្យល់ ខ.៦ ។ *ពពកនៅពេលព្រលឹម . . . ទឹកសន្សើមដែលបាត់ទៅយ៉ាងបន្ទាន់* គឺជាការប្រៀបប្រដូចអំពីភាពបណ្ដោះអាសន្ន មិនស្ថិតស្ថេរ ។

**៦:៥** *ពួកហោរ៉ា* នៅត្រង់ចំណុចនេះ អ្នកនាំព្រះរាជសាររបស់ព្រះអម្ចាស់បានប្រកាសអំពីអំពើបាបរបស់រាស្ត្រទ្រង់ ។ *ពាក្យពីមាត់* គឺជាពាក្យសម្រេចទោសដែលថ្លែងដោយពួកហោរ៉ាដ៏ស្មោះត្រង់របស់ទ្រង់ (មើល យរ ១:៩ ១៥:១៩ និងការពន្យល់) ។

**៦:៦** *សេចក្ដីសប្បុរស* ពាក្យនេះជាភាសាហេព្រើគឺ "*ខេសេឌ*" (Checed) គឺប្រើសំដៅទៅលើការប្រព្រឹត្តដ៏ត្រឹមត្រូវចំពោះអ្នកដទៃ ឬសេចក្ដីស្មោះត្រង់ចំពោះព្រះអម្ចាស់ ឬក៏សំដៅទៅលើសេចក្ដីទាំងពីរ ដែលជាអ្វីដែលព្រះអម្ចាស់ទ្រង់តម្រូវឱ្យរាស្ត្រទ្រង់មាន ។ នៅក្នុងខនេះ ប្រហែលជាសំដៅទៅលើន័យទាំងពីរ ។ *មិនមែនចំពោះយញ្ញបូជាទេ* ព្រះអម្ចាស់ទ្រង់មិនសព្វព្រះទ័យនឹងទទួលយញ្ញ បូជាដែលថ្វាយដោយមិនស្មោះត្រង់នោះទេ (មើល ១សយ ១៥:២២–២៣ អស ១:១១–១៥ យរ ៧:២១–២៣ អម ៥:២១–២៤ មីក ៦:៦–៨ មថ ៩:១៣ ១២:៧) ។ *ការស្គាល់ព្រះ* មើល ខ.៣ ២:២០ និងការពន្យល់ ។

**៦:៧** *កន្លងនឹងសេចក្ដីសញ្ញា* មើល ៨:១ យស ៧:១១ ។

**៦:៨** *កាឡាត* មើល ១២:១១ ពច ១០:១៧ ១២:៧ ។ *ប្រឡាក់ដោយឈាម* ត្រង់ចំណុចនេះលោកហូសេប្រហែលជានិយាយសំដៅទៅលើហេតុការណ៍ដែលបានកើតឡើងនៅសម័យក្រោយព្រឹត្តការណ៍នៃការបង្ហូរឈាមនៅក្នុង ពច ១២:១–៦ ដែលនៅក្នុងនោះ លោកពេកាបានធ្វើការបះបោរប្រឆាំងនឹងស្ដេចពេកាហ៊ា (មើល ២ពវ ១៥:២៥) ។

**៦:៩** *ស៊ីគែម* មើល លប ៣៣:១៨ និងការពន្យល់ ។

**៦:១០** *ការកំផិត* មើលការពន្យល់ ៤:១០ ។

**៦:១១** *ការចំរូត* គឺជាពាក្យប្រៀបប្រដូចនឹងការជំនុំជម្រះរបស់ព្រះ (មើល ៨:៧ ១០:១២–១៣ យរ ៥១:៣៣ មថ ១៣:៣០,៣៩–៤២ វវ ១៤:១៥) ។ *នាំពួកឈ្លើយក្នុងរាស្ត្រអញឱ្យមកវិញ* ឃ្លានេះមានន័យស្រដៀងគ្នានឹងពាក្យ "ប្រោសឱ្យជា" (៧:១) ហើយសំដៅទៅលើការស្អាងជាតិសាសន៍ដែលមានរបួសឡើងវិញ (មើល យអ ៣:១ សផ ៣:២០) ។

**៧:១** *ប្រោស* មើល ៥:១៣ ៦:១ ១១:៣ ១៤:៤ យរ ៥១:៨–៩ ។ *អំពើទុច្ចរិត* មើល ៤:៨ ៥:៥ ៨:១៣ ។ *អេប្រាអិម* មើលការពន្យល់ ៤:១៧ ។ *លេចមកឱ្យឃើញ* មានន័យថា ព្រះអម្ចាស់ទ្រង់ទតឃើញពួកគេ ។ *អំពើអាក្រក់* មើល ខ.៣ ។ *សាម៉ារី* គឺជាឈ្មោះម្យ៉ាងទៀតរបស់នគរខាងជើង ហើយដែលស្ដេចអំរីបានដាក់ឈ្មោះរាជធានីថាសាម៉ារី (១ពវ ១៦:២៤ និងការពន្យល់) ។ *សេចក្ដីកំភូត* មើល យរ ៦:១៣ ៨:១០ ។ ពាក្យនេះប្រហែលជាសំដៅទៅលើការធ្វើពុតជាប្រែចិត្ត និងការចងសម្ព័ន្ធមិត្តជាមួយនឹងបរទេសដោយចិត្តមិនស្មោះត្រង់ ។ *ចោរលួច* មើល ៤:២ ។ *ចោរប្លន់* មើល ៦:៩ លប ៤៩:១៩ យរ ១៨:២២ ។

អញនឹកចាំ[ង]អស់ទាំងអំពើអាក្រក់របស់គេនោះទេ[ច] ឥឡូវ
នេះអំពើរបស់គេបានឡោមព័ទ្ធគេហើយ[ឆ] ក៏នៅចំពោះ
មុខអញផង ៣គេនាំឱ្យស្ដេចបានរីករាយ ដោយអំពើរ
អាក្រក់របស់ខ្លួន ហើយពួកចៅហ្វាយផង ដោយសេចក្ដីភូត
ភររបស់ខ្លួនដែរ[ជ] ៤គេសុទ្ធតែជាពួកកំផិតទទេ[ឈ] គេប្រៀប
ដូចជាឡ ដែលអ្នកធ្វើនំបុ័ងបានដុតឱ្យក្ដៅហើយ គាត់លែង
វាចភ្លើងចាប់តាំងពីវេលាដែលច្របាច់ម្សៅ ដរាបដល់
បានដោរឡើង ៥នៅថ្ងៃបុណ្យចំរើនព្រះជន្មស្ដេចនៃយើង
រាល់គ្នានោះពួកចៅហ្វាយបានធ្វើឱ្យខ្លួនឈឺ ដោយកំដៅនៃ
ស្រាទំពាំងបាយជូរ[ញ] ស្ដេចក៏ចូលដៃទៅជាមួយនឹងពួក
ឡកឡឺយ[ដ] ៦ដ្បិតគេបានរៀបចំចិត្តដូចជាឡហើយ[ឋ] កំពុង
ដែលគេចាំយាម នោះអ្នកដុតនំបុ័ងរបស់គេក៏ដេកលក់ទាល់
ភ្លឺ លុះព្រឹកហើយ ឡនោះក៏ឆេះឆ្លោឡើង ៧គេសុទ្ធតែក្ដៅ
ដូចជាឡ គេឆេះបន្សុសពួកចៅក្រមគេទៅ ឯពួកស្ដេច
របស់គេក៏បានដួលអស់ហើយ[ឌ] ក្នុងពួកគេឥតមានអ្នកណា
មួយដែលអំពាវនាវ[ឍ]ដល់អញឡើយ ។
៨ចំណែកអេប្រាអិម គាត់លាយខ្លួន[ណ]នឹងសាសន៍ដទៃ

**៧:២** ង យរ ១៤:១០ ៤៤:២១ ហស ៨:១៣ ច យប ៣៥:១៥ ហស ៩:១៥ ឆ យរ ២:១៩ ៤:១៨ **៧:៣** ជ យរ ២៨:១–៤ ហស ៤:២ ១០:១៣ មីក ៧:៣ **៧:៤** ឈ យរ ៩:២ **៧:៥** ញ អស ២៨:១,៧ ដ ទដ ១:១ **៧:៦** ឋ ទដ ២១:៩ **៧:៧** ឌ ហស ១៣:១០ ឍ ខ.១៦ ទដ ១៤:៤ អស ៩:១៣ សផ ១:៦ **៧:៨** ណ ខ.១១ ទដ ១០៦:៣៥ ហស ៥:១៣ **៧:៩** ត អស ១:៧ ហស ៨:៧

អេប្រាអិមជានំ ដែលមិនបានប្រែ ៩ពួកដទៃបានបង្ហិន
កំឡាំងគាត់ទៅ[ត] តែគាត់មិនដឹងខ្លួនទេ អើ មានសក់ស្កូវ
ល្បាយនៅលើក្បាល តែគាត់ឥតដឹងសោះ ១០ហើយសេចក្ដី
អំនួតរបស់អ៊ីស្រាអែល ក៏តែងតែធ្វើបន្ទាល់ ទាស់នឹងគាត់[ថ]
ទោះបើកើតមានដូច្នោះក៏ដោយ គង់តែគេមិនបានវិល
ត្រឡប់[ទ]មកឯព្រះយេហូវ៉ា ជាព្រះនៃខ្លួនទេ ក៏មិនបានស្វែង
រក[ធ]ទ្រង់ផង ១១អេប្រាអិមក៏ដូចជាព្រាបអាប់ឥត ប្រាជ្ញា[ន]
ហើយឥតយោបល់ គេហៅរកសាសន៍អេស៊ីព្ទ[ប] តែគេទៅ
ឯស្រុកអាសស៊ើរវិញ[ផ] ១២កាលណាគេទៅ នោះអញនឹង
លាតមង[ព]អញគ្របលើគេ អញនឹងទំលាក់គេចុះមក ដូចជា
សត្វហើរលើអាកាស ក៏នឹងវាយផ្ចាលគេ ដូចជាពួកជំនុំគេ
បានឮហើយ ១៣វេទនា[ភ]ដល់គេ ដ្បិតគេបានសាត់ព្រាត់
ឆ្ងាយ[ម]ពីអញ សូមឱ្យគេត្រូវបំផ្លាញចុះ ដ្បិតគេបានរំលង
ទាស់នឹងអញហើយ ទោះបើអញចង់លោះគេក៏ដោយ គង់

**៧:១០** ថ ហស ៥:៥ ទ ហស ៥:៤ ធ ខ.១៤ អស ៩:១៣ **៧:១១** ន លប ៨:៨ ប ខ.១៦ ហស ៩:៦ ផ ខ.៨ យរ ២:១៨ បទ ៥:៦ ហស ៩:៣ ១២:១ **៧:១២** ព អគ ១២:១៣ ៣២:៣ **៧:១៣** ភ ហស ៩:១២ ម យរ ១៤:១០ អគ ៣៤:៤–៦ ហស ៩:១៧

**៧:២** មើល ទដ ៩០:៨ និងការពន្យល់ ។ *អញនឹកចាំ* ព្រះទ្រង់ជ្រាបគ្រប់ការទាំងអស់ដែលកើតឡើង គឺមិនដូចជាការគិតរបស់ពួកមនុស្សអាក្រក់នោះទេ (មើល ទដ ១០:៦,១១ និងការពន្យល់) ។

**៧:៣** *នាំឱ្យស្ដេចបានរីករាយ* ត្រង់ចំណុចនេះ ប្រហែលជាជាប់ទាក់ទងនឹងការបះបោរនៅក្នុងព្រះរាជវាំង (មើល ២ពវ ១៥:៨–៣០) ។ នៅក្នុងព្រឹត្តិការណ៍នោះ ពួកគេបង្ករបរិយាកាសកម្សាន្តរីករាយ និងលួងលោមស្ដេច និងពួកកូនស្ដេច ដោយរៀបគម្រោងការណ៍ចាក់សម្លាប់ពីខាងក្រោយខ្នង (ខ.៦–៧ និងការពន្យល់ ខ.៧) ។ *សេចក្ដីភូតភរ* មើល ១១:១២ ទដ ១០:៧ និងការពន្យល់, ណាហ ៣:១ ។

**៧:៤** *ពួកកំផិត* មើលការពន្យល់ ៤:១៥ ។ *ភ្លើង* គឺជាពាក្យប្រៀបប្រដូចទៅនឹងល្បិចនយោបាយ (មើល ខ.៦–៧) ។ គេដុតភ្លើងទុករហូតដល់ពេលដែលអាចប្រើបាន ហើយភ្លើងនឹងផ្ទុះឡើង ។ *អ្នកធ្វើនុំបុ័ង* ប្រហែលជាសំដៅទៅលើមេផ្សំគំនឹត ។

**៧:៥** *ថ្ងៃបុណ្យចំរើនព្រះជន្មស្ដេច* ត្រង់ចំណុចនេះប្រហែលជាសំដៅទៅលើការឡើងសោយរាជ្យ ឬបុណ្យចម្រើនព្រះជន្មរបស់ស្ដេច ដែលមានការផឹកស្រាស្រវឹងយ៉ាងគ្រឹកគ្រេង ។ ស្ដេចអេឡាបានស្លាប់ដោយសារស្រវឹងស្រា (មើល ១ពវ ១៦:៩ និងការពន្យល់) ។ *ពួកឡកឡឺយ* មើល សភ ១:២២ និងការពន្យល់ ។ លោកអេសាយ (២៨:១–៨,១៤) បានថ្កោលទោសពួកអ៊ីស្រាអែលចំពោះការស្រវឹងស្រា និងការល្មោភស៊ី ។

**៧:៦** ពួកគេរក្សាការសម្ងាត់មិនឱ្យគេដឹងអំពីគម្រោងអាក្រក់របស់ពួកគេរហូតដល់ពេលដ៏សមរម្យមួយ ។

**៧:៧** *ពួកចៅក្រម . . . ពួកស្ដេច* នៅក្នុងអំឡុងពេល២០ឆ្នាំ ស្ដេចចំនួនបួនអង្គត្រូវគេធ្វើឃាត ដែលក្នុងចំណោមនោះស្ដេចសាការី និងស្ដេចសាលូម (២ពវ ១៥:១០–១៤) ។ *ឥតមានអ្នកណាមួយដែលអំពាវនាវដល់អញ* គឺដោយសារតែពួកគេមានភាពអាម៉ាស់ ។

**៧:៨** *លាយខ្លួននឹងសាសន៍ដទៃ* មើល ខ.១១ និងការពន្យល់ ។ *នំដែលមិនបានប្រែ* គឺជាពាក្យប្រៀបធៀបនឹងការធ្វើគោលនយោបាយដោយគ្មានប្រាជ្ញា ។ នុំដែលដុតនៅលើថ្មក្ដៅ (ធៀបនឹង ១ពវ ១៩:៦) មិនបានត្រឹមត្រូវ ត្រូវខ្លោចនៅផ្នែកខាងក្រោម ហើយឆៅនៅផ្នែកខាងលើ ។

**៧:៩** *ពួកដទៃបានបង្ហិនកំឡាំងគាត់* ការបង់សួយសារអាករឱ្យចក្រភពអាសស៊ើរ (២ពវ ១៥:១៩–២០) និងដល់ប្រទេសអេស៊ីព្ទ (ខ.១១) បានធ្វើឱ្យប្រទេសជាតិចុះខ្សោយផ្នែកសេដ្ឋកិច្ច ។ *សក់ស្កូវ* គាត់បានចាស់មុនអាយុ ហើយធ្វើដឹងមិនឮចំពោះសញ្ញាប្រកាសអាសន្ន ។

**៧:១០** *វិលត្រឡប់មក* មើល ៣:៥ ៥:៤ អម ៤:៦–១១ ។ *ស្វែងរកទ្រង់* មើល ៣:៥ ៥:៦,១៥ និងការពន្យល់ ។

**៧:១១** *ព្រាប* មើល ១១:១១ និងការពន្យល់ ដែលនិយាយអំពីរូបភាពខុសគ្នា មើលការពន្យល់ ទដ ៦៨:១៣ ។ *ឥតយោបល់* មើល យរ ៥:២១ ។ ស្ដេចមហាណិមបានចុះចូលនឹងចក្រភពអាសស៊ើរ (២ពវ ១៥:១៩–២០) ហើយស្ដេចហូសេ៊ាបានប្រែប្តូរនៅក្នុងការចុះចូលនឹងចក្រភពអាសស៊ើរ និងប្រទេសអេស៊ីព្ទ (២ពវ ១៧:៣–៤) ។

**៧:១២** *មងអញ* ព្រះទ្រង់ជាអ្នកប្រមាញ់ ហើយសាសន៍ដទៃមិនមែនជាអ្នកប្រមាញ់ទេ ដូចនេះសាសន៍អ៊ីស្រាអែលប្រាកដជាត្រូវជាប់ខ្លួនគេចទៅណាមិនរួច ។

**៧:១៣** *វេទនា* ជាញឹកញាប់ ពាក្យនេះប្រើនៅក្នុងការប្រកាសអំពីការជំនុំជម្រះដែលត្រូវមកដល់ (មើល ៩:១២) ។ *ត្រូវបំផ្លាញ* មើល ៩:៦ អស ១៣:៦ ។ *លោះ* មើល ១៣:១៤ ។ ពាក្យនេះក៏មានប្រើផងដែរនៅក្នុងការរំដោះពីប្រទេសអេស៊ីព្ទ (មើល នក ៦:៦ មីក ៦:៤) ។ *ពាក្យភូតភរ* ត្រង់នេះអាចសំដៅទៅលើការទទួលស្គាល់ថា ភាពសម្បូររុងរឿង និងជោគវាសនា

តែគេបានពោលពាក្យភូតភរ[យ]ទាស់នឹងអញដែរ[រ] ១៤គេមិន
បានអំពាវនាវដល់អញ ដោយស្មោះពីចិត្តទេ[ល] គឺបានស្រែក
ទ្រហោនៅលើដំណេកគេវិញ គេប្រជុំគ្នាឱ្យបានស្រូវនឹង
ទឹកទំពាំងបាយជូរ[វ] តែគេបះបោរនឹងអញវិញ[ស] ១៥ទោះបើ
អញបានវាយផ្ចាល ឬចំរើនកំឡាំង[ហ]ដៃគេក្តី គង់តែគេ
បង្កើតការកំណាច[ឡ]ទាស់នឹងអញដែរ ១៦គេត្រឡប់មក តែ
មិនមែនមកឯព្រះដ៏ខ្ពស់បំផុតទេ[អ] គេប្រៀបដូចជាធ្នូដែល
បាញ់ទៅមិនត្រង់[ក] ពួកចៅហ្វាយរបស់គេ និងត្រូវដួល
ដោយដាវ ដោយព្រោះមោហ៍[ខ]គ្រប់នៃអណ្តាតរបស់ខ្លួន
នេះឯងនឹងបានជាទីមើលងាយ[គ]ដល់គេ នៅក្នុងស្រុក
អេស៊ីព្ទ[ឃ] ។

## ពួកអ៊ីស្រាអែលត្រូវទទួលផលជាខ្យល់គួច

៨ ១ចូរផ្អឹបត្រែ[ក]នៅមាត់ឯងចុះ គេមកទាស់នឹងលំនៅនៃ
ព្រះយេហូវ៉ា ដូចជាឥន្ទ្រី[ខ] ពីព្រោះអ៊ីស្រាអែលបានក្បត់
សញ្ញា[គ]របស់អញ ហើយបានរំលងច្បាប់អញផង[ឃ] ២គេនឹង
អំពាវនាវមករកអញថា ឱព្រះនៃខ្ញុំអើយ អ៊ីស្រាអែលយើង
ស្គាល់ទ្រង់ដែរ ៣តែអ៊ីស្រាអែលបានលះបង់ចោលសេចក្តី
ដែលល្អហើយ ពួកខ្មាំងសត្រូវនឹងដេញតាមគេ[ង] ៤គេបាន
តាំងស្តេចផ្សេងៗឡើង តែមិនមែនដោយសារអញទេ ក៏
បានតាំងចៅហ្វាយឡើង តែអញមិនបានដឹងឡើយ[ច] គេ
បានយកប្រាក់ និងមាសរបស់ខ្លួនធ្វើជារូបព្រះ[ឆ] ជាការ
ដែលនាំឱ្យគេត្រូវកាត់ចេញ ៥ឱសាម៉ារីអើយ[ជ] រូបកូនគោ
របស់ឯងបានត្រូវចោលចេញហើយ សេចក្តីកំហឹងរបស់
អញបានឆួលឡើងទាស់នឹងវា តើដល់កាលណាទើបគេ
ជ្រះស្អាតវិញ[ឈ] ៦ដ្បិតរូបកូនគោនោះកើតនៅស្រុកអ៊ីស្រា
អែល គឺពួកជាងដែលបង្កើតវាឡើង វាមិនមែនជាព្រះទេ[ញ]
អើ រូបកូនគោ[ដ]របស់សាម៉ារី និងត្រូវបំបែកខ្ទេចខ្ទីទៅ[ឋ]
៧ដ្បិត គេបានសាបព្រោះជាខ្យល់ ហើយនឹងច្រូតកាត់បាន
ជាខ្យល់គួចវិញ[ឌ] ឥតមានដើមស្រូវសោះ ក៏គ្មានគ្រាប់ល្មម
នឹងកិនធ្វើជាម្សៅបានផង[ឍ] ឬបើកើតមានផលដែរ នោះ

**៧:១៣** យ ទដ ១១៦:១១ រ ខ.១ យរ ៥១:៩ មថ ២៣:៣៧ **៧:១៤** ល យរ ៣:១០ វ អម ២:៨ ស ខ.១០ ហស ៤:១០ ៩:១ ១៣:១៦ **៧:១៥** ហ ហស ១១:៣ ឡ ទដ ២:១ ១៤០:២ ណាហ ១:៩,១១ **៧:១៦** អ ខ.៧ ក ទដ ៧៨:៩,៥៧ ខ មឡ ៣:១៤ គ អគ ២៣:៣២ ឃ ខ.១១ ហស ៩:៣ ១១:៥ **៨:១** ក ជន ១០:២ អគ ៣៣:៣ ខ ចទ ២៨:៤៩ យរ ៤:១៣ គ យរ ១១:១០ ឃ ហស ៤:៦ ៦:៧

**៨:៣** ង មថ ៧:២៣ ទត ១:១៦ **៨:៤** ច ហស ៧:៩ ១៣:១០ ឆ ហស ២:៨ ១៣:១–២ **៨:៥** ជ ខ.៦ ហស ១០:៥ ឈ យរ ១៣:២៧ **៨:៦** ញ យរ ១៦:២០ ហស ១៤:៣ ដ នក ៣២:៤ ឋ ខ.៥ **៨:៧** ឌ យប ៤:៨ សភ ២២:៨ អស ៦៦:១៥ ហស ១០:១២–១៣ ណាហ ១:៣ កទ ៦:៨ ឍ ចទ ២៨:៣៨ អស ១៧:១១ ហស ៩:១៦

ជាការកំណត់របស់ព្រះសាសន៍ដទៃ ហើយមិនមែនជាការកំណត់របស់ព្រះអម្ចាស់ ។

**៧:១៤** *ស្រែកទ្រហោ* មើល យអ ១:១៣ ។ *គេប្រជុំគ្នា* ប្រៀបធៀបនឹង លវ ១៩:២៨ ២១:៥ និងការពន្យល់ ។ *ស្រូវ និងទំពាំងបាយជូរ* មើល ២:៨,២២ ៩:១–២ ។

**៧:១៥** *អញបានវាយផ្ចាល* គឺវាយផ្ចាលដូចជាកូន (មើល ១១:៣ និងការពន្យល់) ឬប្រហែលជាដូចជាកងទ័ព ។ *ចំរើនកំឡាំងដៃគេ* មើល អគ ៣០:២៤–២៥ ។

**៧:១៦** *ព្រះដ៏ខ្ពស់បំផុត* មើល ១១:៧ ចទ ៣២:៨ និងការពន្យល់ ។ *ធ្នូដែលបាញ់ទៅមិនត្រង់* មើល ទដ ៧៨:៥៧ ។ ព្រួញបានបាញ់ខុសគោលដៅ គឺដូចសាសន៍អ៊ីស្រាអែលដែលបានធ្វើខុសគោលដៅ ។ *ជាទីមើលងាយ* ប្រទេសអេស៊ីព្ទនឹងខានមិនបានជួយដល់អ៊ីស្រាអែល ហើយពួកគេនឹងចាត់ទុកថាអំណាចរបស់ព្រះមិនសំខាន់ (ចទ ៩:២៨) ។ *ស្រុកអេស៊ីព្ទ* មើល ៨:១៣ ១១:៥ និងការពន្យល់ ។ មានអ្នកខ្លះដែលជាប់ជាឈ្លើយ ត្រូវបានបញ្ជូនទៅស្រុកអេស៊ីព្ទ (២ពវ ២៣:៣៤ យរ ២២:១១–១៤) ហើយអ្នកខ្លះ ទៀតដែលមិនមែនជាឈ្លើយបានទៅដោយខ្លួនឯង(២ពវ ២៥:២៦ យរ ៤២–៤៤) ។ ការវិលត្រឡប់ពីស្រុកអេស៊ីព្ទវិញមាននិយាយជាទំនាយនៅក្នុង ១១:១១ អស ១១:១១ ២៧:១៣ សក ១០:១០ ។

**៨:១** *ផ្អឹបត្រែ* មើល ៥:៨ និងការពន្យល់ ។ *ឯង* គឺសំដៅទៅលើលោកហូសេ ។ *ឥន្ទ្រី* ឬ "ត្មាត" គឺសំដៅទៅលើចក្រភពអាសស៊ើរ ។ *លំនៅនៃព្រះយេហូវ៉ា* គឺទឹកដីអ៊ីស្រាអែល ហើយមិនគ្រាន់តែជាព្រះវិហារប៉ុណ្ណោះទេ (មើល ៩:១៥ និងការពន្យល់ ធៀបនឹង នក ១៥:១៧) ។

**៨:២** *យើងស្គាល់ទ្រង់ដែរ* មើល ២:២០ ៦:៣ និងការពន្យល់ ។ ពួកគេស្គាល់ព្រះ ប៉ុន្តែ ការថ្វាយបង្គំរបស់ពួកគេមានពេញដោយភាពពុករលួយ ដោយសារពួកគេយកលំនាំតាមជំនឿ និងការអនុវត្តន៍របស់សាសន៍ដទៃ ដូចដែលមាននិយាយនៅ ខ.៣–៦ (មើល អម ២:៤,៧–៨ ៣:១៤ ៥:២៦) ។

**៨:៣** *ពួកខ្មាំងសត្រូវ* គឺចក្រភពអាសស៊ើរ ។

**៨:៤** *តាំងស្តេចផ្សេងៗ* បន្ទាប់ពីរាជ្យស្តេចយេរ៉ូបោមទីពីរ គឺមានស្តេចប្រាំអង្គដែលដឹកនាំនគរអ៊ីស្រាអែលនៅក្នុងរយៈពេល ១៣ឆ្នាំ (២ពវ ១៥:៨–៣០) ដែលនៅក្នុងចំណោមនោះ មានបីអង្គដែលបានឡើងសោយរាជ្យដោយការប្រើហិង្សាដណ្តើមរាជ្យបល្ល័ង្ក(មើល ៧:៧ និងការពន្យល់)។

**៨:៥** *រូបកូនគោ* មើល ១០:៥ ១៣:២ ។ ស្តេចយេរ៉ូបោមទីមួយ (ឆ្នាំ ៩៣០–៩០៩ មុនគ.ស.)បានសង់រូបកូនគោមាសពីរ មួយដាក់នៅក្រុងបេត–អែល និងមួយទៀតនៅក្រុងដាន់ ហើយនិយាយថា "មើល នេះនែ ព្រះរបស់ឯង" (១ពវ ១២:២៨–៣៣ និងការពន្យល់ ១២:២៨) ។ *សាម៉ារី* មើលការពន្យល់ ៧:១ ។

**៨:៦** *ពួកជាងដែលបង្កើតវាឡើង* ចំពោះបទទំនាយអំពីការថ្វាយបង្គំរូបព្រះ មើល អស ៤០:២០ ៤១:២២–២៤ ៤៤:៩–២០ និងមើល ទដ ១១៥:៤–៨ និងការពន្យល់ ។ អ្នកដឹកនាំអ៊ីស្រាអែល(នក ៣២:៤) និងយេរ៉ូបោមទីមួយបាននិយាយថា "នេះនែ ព្រះរបស់ឯង" ប៉ុន្តែលោកហូសេបានបដិសេធថា "មិនមែនជាព្រះទេ"។

**៨:៧** *សាបព្រោះ . . . ខ្យល់គួច* គឺជាសុភាសិតដែលនិយាយអំពីលទ្ធផលនៃការធ្វើអាក្រក់(មើល ១០:១៣ យប ៤:៨ ទដ ១២៦:៥–៦ សភ ១១:១៨ ២២:៨ ២កថ ៩:៦ កទ ៦:៧)។ ពួកសាសន៍អ៊ីស្រាអែលបានសាបព្រោះនូវខ្យល់នៃការថ្វាយបង្គំរូបព្រះ ហើយបានច្រូតកាត់ទទួលផលនៃខ្យល់គួចនៃចក្រភពអាសស៊ើរ ។ *មនុស្សដទៃ* គឺសាសន៍អាសស៊ើរ ។

មនុស្សដទៃនឹងលេបបាត់ទៅ[ណ] ។
៨អ៊ីស្រាអែលត្រូវលេបបាត់ហើយ[ត] ឥឡូវនេះ គេនៅ
កណ្ដាលពួកសាសន៍ទាំងប៉ុន្មានទុកដូចជាភាជនៈ ដែលឥត
មានអ្នកណាចូលចិត្តសោះ[ថ] ៩ដ្បិតគេបានឡើងទៅឯស្រុក
អាសស៊ើរ[ទ] ដូចជាលាព្រៃ[ធ]ដែលនៅតែឯង អេប្រាអិមបាន
ជួលពួកសហាយ[ន] ១០អើ ទោះបើគេជូនសំណូកដល់សាសន៍
ដទៃក៏ដោយ គង់តែអញនឹងប្រមូលពួកទាំងនោះមកដែរ[ប]
ហើយគេនឹងត្រូវអន់ថយទៅ[ផ] ដោយព្រោះបន្ទុករបស់
ស្ដេចនៃអស់ទាំងព្រះអម្ចាស់ ។
១១ហេតុដោយព្រោះអេប្រាអិមបានចំរើនអាសនាជា
ច្រើនឡើងសំរាប់ធ្វើបាប បានជាគេរាប់អាសនាទាំងអស់
ទុកជាទីសំរាប់ធ្វើបាបដែរ[ព] ១២ទោះបើអញកត់ទុកអស់ទាំង
មាត្រាក្នុងច្បាប់របស់អញក៏ដោយ គង់តែគេនឹងប្រកាន់ថា
ជាច្បាប់ដទៃវិញ[ភ] ១៣ឯខាងយញ្ញបូជា ជាដង្វាយដែលត្រូវ
ថ្វាយដល់អញ នោះគេសំឡាប់សត្វទៅ ដើម្បីតែស៊ី[ម]សាច់
ប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់មិនទទួលទេ[យ] ទ្រង់នឹងនឹកចាំ[រ]
ពីអំពើទុច្ចរិតរបស់គេឥឡូវ ហើយតបស្នងនឹងអំពើបាប[ល]
របស់គេ ឯគេ នឹងត្រូវវិលទៅឯស្រុកអេស៊ីព្ទទាំងអស់វិញ[វ]

**៨:៧** ណ ហស ២:៩
**៨:៨** ត យរ ៥១:៣៤
ថ យរ ២២:២៨
**៨:៩** ទ យរ ២:១៨
ធ លប ១៦:១២
ន យរ ២២:២០ អគ
២៣:៥ ហស ៥:១៣
**៨:១០** ប អគ
១៦:៣៧ ២:២០
ផ យរ ៤២:២
**៨:១១** ព ហស
១០:១ ១២:១១
**៨:១២** ភ ខ.១
**៨:១៣** ម យរ
៧:២១ យ យរ
៦:២០ ហស ៩:៤
រ ហស ៧:២ ៩:៩
អម ៨:៧ ល ហស
៤:៩ វ ហស ៩:៣,៦
**៨:១៤** ស ចទ
៣២:១៨ អស
១៧:១០ ហស ២:១៣
ហ ទដ ៩៥:៦ ឡ

១៤ពីព្រោះអ៊ីស្រាអែលបានភ្លេច[ស] ព្រះដែលបង្កើតខ្លួនទៅ[ហ]
ក៏ស្អាងវិហារផ្សេងៗឡើង ហើយពួកយូដាបានសង់ទីក្រុង
មានបន្ទាយកាន់តែច្រើន តែអញនឹងចាត់ភ្លើងទៅលើទី
ក្រុងទាំងប៉ុន្មានរបស់គេ ភ្លើងនោះនឹងឆេះបន្សុសអស់ទាំង
ដំណាក់របស់គេទៅ[ឡ] ។

## ការដាក់ទោសពួកអ៊ីស្រាអែល

**៩** ១ឱអ៊ីស្រាអែលអើយ កុំឲ្យរីករាយ[ក]ដោយចិត្តអំណរ ដូច
ជាអស់ទាំងសាសន៍ឡើយ ដ្បិតឯងបានប្រព្រឹត្តសេចក្ដីកំផិត[ខ]
ចាកចេញ[គ]ពីព្រះរបស់ឯងហើយ ឯងពេញចិត្តនឹងទទួល
រង្វាន់ នៅគ្រប់ទាំងទីលានស្រូវ ២ដូច្នេះ ទីលានស្រូវ និង
ធុងជាន់ផ្លែទំពាំងបាយជូរ នឹងមិនចិញ្ចឹមគេទៀត ហើយទឹក
ទំពាំងបាយជូរ[ឃ]នឹងខានមានទៅ ៣គេនឹងលែង អាស្រ័យ[ង]
នៅក្នុងស្រុករបស់ព្រះយេហូវ៉ា ឯអេប្រាអិមនឹងត្រឡប់ទៅ
ឯស្រុកអេស៊ីព្ទ[ច] ហើយគេនឹងស៊ីអាហារដែលស្មោគគ្រោក
នៅក្នុងស្រុកអាសស៊ើរ[ឆ] ៤គេនឹងលែងច្រួចស្រាទំពាំង

យរ ៥:១៧ ១៧:២៧ អម ២:៥ **៩:១** ក អស ២២:១២–១៣ ខ លប ៣០:១៥ គ ទដ ៧៣:២៧ អស ២៤:១៦ ហស ៧:១៤ ១០:៥ **៩:២** ឃ អស ២៤:៧ ហស ២:៩ យអ ១:១០ **៩:៣** ង លវ ២៥:២៣ ច ហស ៧:១៦ ៨:១៣ ឆ អគ ៤:១៣ ហស ៧:១១ ១០:៥ អម ៧:១៧

**៨:៨** ព្រះអម្ចាស់បានជ្រើសរើសអ៊ីស្រាអែលជារាស្ត្ររបស់ទ្រង់(មើល នក ១៩:៥, អម ៣:២ និងការពន្យល់) ប៉ុន្តែ ដោយសារពួកគេប្រព្រឹត្តតាមសាសន៍ដទៃ ពួកគេត្រូវបាត់បង់អត្តសញ្ញាណ ពិសេសរបស់ខ្លួន ហើយត្រូវក្លាយជា "គ្មានតម្លៃ"សម្រាប់ព្រះអម្ចាស់ ។

**៨:៩** *លាព្រៃដែលនៅតែឯង* មើល យរ ២:២៥ និងការពន្យល់។ *អេប្រាអិម* មើលការពន្យល់ ៤:១៧ ។ *ជួលពួកសហាយ* គឺបង់ថ្លៃការពារដល់ពួកសាសន៍អាសស៊ើរ(មើល ៩:១ និងការពន្យល់) ។ ស្ដេចមណាហិម (២ពវ ១៥:១៩) និងស្ដេចហូសេ៊ានៃនគរអ៊ីស្រាអែលបានបង់សួយសារអាករដល់ចក្រភពអាសស៊ើរ ។

**៨:១០** ទោះបីជាអ៊ីស្រាអែលបង់សួយសារអាករដល់ចក្រភពអាសស៊ើរក៏ដោយ ក៏ពួកគេមិនអាចទទួលបាននូវសន្តិសុខដែរ ព្រោះព្រះទ្រង់នឹងជំនុំជម្រះពួកគេតាមរយៈស្ដេចអាសស៊ើរ ។ នៅត្រង់ចំណុចនេះ សត្រូវរបស់អ៊ីស្រាអែលគឺព្រះអម្ចាស់ទេ (មើល ២:៨–១៣ ៧:១២ និងការពន្យល់) ។

**៨:១៣** *ខាងឯយញ្ញបូជា* មើល ខ.២ និងការពន្យល់ ។ *ស៊ីសាច់* នៅត្រង់ចំនុចនេះ ផ្នែកខ្លះនៃយញ្ញបូជាត្រូវអ្នកថ្វាយយញ្ញបូជា និងពួកសង្ឃបរិភោគ (មើល លវ ៧:១១–១៨,២៨–៣៦ ចទ ១២:៧ យរ ៧:២១) ។ *មិនទទួលទេ* មើល ៦:៦ និងការពន្យល់ ។ *អេស៊ីព្ទ* ពួកសាសន៍អ៊ីស្រាអែលដែលបានទុកចិត្តលើនគរអេស៊ីព្ទ និងចក្រភពអាសស៊ើរ ត្រូវត្រឡប់ទៅ "នគរអេស៊ីព្ទ" វិញ ក្នុងសភាពជាប់ជាឈ្លើយនៅក្នុងទឹកដីសាសន៍ដទៃ ជាពិសេសសាសន៍អាសស៊ើរ (មើល ៩:៣) ។ មើលការពន្យល់ ៧:១៦ ។

**៨:១៤** *អ៊ីស្រាអែលបានភ្លេច* ការនេះជាមូលហេតុនៃគ្រប់ទាំងបញ្ហាដែលពួកគេមាន(មើល ២:១៣ និងការពន្យល់, ធៀបនឹង ពច ២:១០) ។ *ស្អាងវិហារផ្សេងៗឡើង សង់ទីក្រុងមានបន្ទាយកាន់តែច្រើន* ត្រង់ចំណុចនេះ ពួកអ៊ីស្រាអែលមិនមានការទុកចិត្តលើព្រះដែលបង្កើតខ្លួនទេ ប៉ុន្តែបានទុកចិត្តលើអ្វីដែលខ្លួនអាចធ្វើបានទៅវិញ ។ *យូដា* មើលសេចក្ដីផ្ដើមត្រង់ចំណុចអ្នកនិពន្ធ និងកាលបរិច្ឆេទ ។ *ភ្លើងនោះនឹងឆេះបន្សុស* មើល អម ១:៤ និងការពន្យល់ ។

**៩:១** ខនេះគឺជាការចាប់ផ្ដើមវគ្គថ្មីមួយទៀតដែលប្រហែលជាការប្រកាសនៅក្នុងបុណ្យច្រូតកាត់មួយ ដូចជាបុណ្យបារាំជាដើម(លវ ២៣:៣៣–៤៣ ចទ ១៦:១៣–១៥)។ *សេចក្ដីកំផិត* មើល ១:២ ២:២–៥ និងការពន្យល់ ។ *រង្វាន់* មើល ២:១២ និងការពន្យល់ ។ គឺជារង្វាន់ដែលបានពីការកំផិតខាងវិញ្ញាណ(មើល ២:១២ និងការពន្យល់)។ *នៅគ្រប់ទាំងទីលានស្រូវ* ទីលានស្រូវ នៅក្នុងពេលបញ្ជាន់ស្រូវគឺជាទីកន្លែងរបស់មនុស្សប្រុស ពួកគេស៊ីលាងនៅថ្ងៃបង្ហើយ ហើយត្រូវនៅយាមស្រូវពេញមួយយប់(មើល នរ ៣:២–៣ និងការពន្យល់) ដូចនេះតាមធម្មតា ពួកស្រីសំផឹងគឺជាភ្ញៀវដែលមករកស៊ីនៅទីកន្លែងនោះ ។

**៩:៣** *ស្រុករបស់ព្រះយេហូវ៉ា* គឺទឹកដីសន្យា ដែលព្រះអម្ចាស់ប្រកាសថាជារបស់ទ្រង់(មើល លវ ២៥:២៣ យស ២២:១៩ និងការពន្យល់, យរ ២:៧ អគ ៣៨:១៦ យអ ១:៦)។ *អេប្រាអិម* មើលការពន្យល់ ៤:១៧ ។ *ស្រុកអេស៊ីព្ទ . . . ស្រុកអាសស៊ើរ* ពួកអ៊ីស្រាអែលបានទទួលការគម្រាមកំហែងអំពីការនិរទេសទៅកាន់ទឹកដីដែលពួកគេត្រូវពឹងផ្អែក គឺកន្លែងដែលពួកគេមិនមានព្រះវិហារសម្រាប់ថ្វាយយញ្ញបូជាបាន(មើល ៧:១៦ ៨:១៣ និងការពន្យល់) ។ *ដែលស្មោគគ្រោក* ទឹកដីសាសន៍ដទៃគឺជាកន្លែងស្មោគគ្រោក (មើល អម ៧:១៧) ។ ដំណាំដែលលូតលាស់ និងទទួលផលនៅក្នុងទឹកដីនោះគឺជារបស់មិនស្អាត ដោយសារជាផលដែលទទួលបាន ដោយការដឹងគុណដល់ព្រះសាសន៍ដទៃ(មើល ២:៥ និងការពន្យល់, អគ ៤:១៣)។

បាយជូរ[ជ]ថ្វាយដល់ព្រះយេហូវ៉ា ក៏មិនបានជាទីគាប់ព្រះ
ហឫទ័យ[ឈ]ដល់ទ្រង់ដែរ អស់ទាំងយញ្ញបូជារបស់គេនឹង
បានដូចជានំបុ័ងរបស់អ្នកកាន់ទុក្ខដល់គេវិញ[ញ] អស់អ្នកណា
ដែលស៊ីទៅ នឹងត្រូវស្មោកគ្រោកហើយ[ដ] នំបុ័ងរបស់គេ
នឹងបានសំរាប់តែចំអែតពោះគេប៉ុណ្ណោះ គឺនឹងមិនដែល
ចូលទៅក្នុងព្រះវិហារនៃព្រះយេហូវ៉ាឡើយ[ឋ] ៥នៅថ្ងៃជំនុំ
មុតមាំ ហើយនៅថ្ងៃបុណ្យនៃព្រះយេហូវ៉ា នោះ[ឌ]តើឯង
រាល់គ្នានឹងធ្វើដូចម្តេច[ឍ] ៦ដ្បិតមើល គេបានចេញទៅ រួចពី
ការបំផ្លាញហើយតែសាសន៍អេស៊ីព្ទនឹងកៀរប្រមូល គេ
ទុក[ណ]ក្រុងណូព[ត]នឹងកប់ខ្មោចគេ[ថ] ឯគ្រឿងប្រាក់[ទ]ដែលគាប់
ចិត្តគេ នោះនឹងទៅជារបស់ដើមកន្ទេចអាលវិញ ហើយ
បន្លា[ធ]នឹងដុះក្នុងទីលំនៅរបស់គេ ៧គ្រាស្នងទោស[ន]បានមក
ដល់ គឺគ្រាសងសំណងដល់គេបានមកហើយ ពួកអ៊ីស្រា
អែលនឹង ដឹងដែរ[ប]ឯហោរាគេឆ្កួត ហើយមនុស្សដែលមាន
និស្ស័យខាងវិញ្ញាណក៏លីលា តែដោយព្រោះអំពើទុច្ចរិត[ផ]ដ៏
បរិបូណ៌របស់ឯង[ព] នឹងសេចក្តីសំអប់ដ៏ជាខ្លាំង[ភ] ៨អ្នកចាំ
យាមរបស់អេប្រាអិមបាននៅជាមួយនឹងព្រះនៃខ្ញុំ តែពួក
ហោរាសុទ្ធតែជាលប់[ម] សំរាប់ចាប់សត្វ នៅគ្រប់ទាំងផ្លូវ
របស់គេ ហើយជាសេចក្តីសំអប់នៅក្នុងព្រះវិហាររបស់
ព្រះនៃខ្លួន[យ] ៩គេបានបង្ខូចចិត្តគេទៅយ៉ាងជ្រៅ[រ] ដូចកាល
នៅគ្រាគីបៀរ[ល]ទ្រង់នឹងនឹកចាំ[វ]ពីអំពើទុច្ចរិតរបស់គេ
ហើយនឹងតបស្នងចំពោះបាបគេដែរ[ស]។
១០អញបានប្រទះនឹងអ៊ីស្រាអែល ដូចជាប្រទះនឹងផ្លែ
ទំពាំងបាយជូរនៅក្នុងទីរហោស្ថាន អញបានឃើញពួក
ឰយុកោឯងរាល់គ្នា ដូចជាផ្លែ[ហ]នៅដើមល្វា[ឡ]ដែលទុំមុនគេ
នៅរដូវជាដំបូង តែគេបានទៅដល់បាល-ពេអរ[អ] ហើយ
បានថ្វាយខ្លួនដល់រូបព្រះគួរខ្មាស[ក] ក៏ត្រឡប់ជាគួរខ្ពើមឆ្អើម
ដូចជារបស់ដែលគេស្រឡាញ់នោះ ១១ចំណែកអេប្រាអិម
សិរីល្អ[ខ]របស់គេនឹងហើរបាត់ទៅដូចជាសត្វស្លាប[គ] និងឥត
មានការសំរាល ឬមានទំងន់ ឬការចាប់ទំផ្ទៃទៀតឡើង[ឃ]
១២ហើយទោះបើគេបីបាច់ចិញ្ចឹមកូនឱ្យធំឡើង គង់តែអញ
នឹងបង្អត់[ង]ទៅ ឱ្យឥតមានមនុស្សណានៅសល់សោះ អើ

**៩:៤** ជ យអ ១:៩,១៣ ២:១៤ ឈ ហស ៨:១៣ ញ យរ ១៦:៧ ដ ចទ ២៦:១៤ ហក ២:១៣–១៤ ឋ អគ ៤:១៣–១៤ **៩:៥** ឌ អស ១០:៣ យរ ៥:១៣ ឍ ហស ២:១១ **៩:៦** ណ ហស ៧:១១ ៨:១៣ ត អស ១៩:១៣ ថ យរ ៤២:២២ ទ សផ ១:១១ ធ អស ៥:៦ ហស ១០:៨ **៩:៧** ន អស ៣៤:៨ យរ ១០:១៥ មីក ៧:៤ លក ២១:២២ ប យប ៣១:១៤ ផ យរ ១៦:១៨ ព ១សយ ១០:១១ អស ៤៤:២៥ បទ ២:១៤ អគ ១៤:៩–១០ ភ យរ ២៩:២៦ ហស ១៤:១ **៩:៨** ម ហស ៥:១ យ អគ ២២:២៦ **៩:៩** រ សផ ៣:៧ ល ពច ១៩:១៦–៣០ ហស ៥:៨ វ ហស ៨:១៣ ស ហស ៤:៩ **៩:១០** ហ បស ២:១៣ ឡ អស ២៨:៤ អ ជន ២៥:១–៥ ទដ ១០៦:២៨–២៩ ក យរ ១១:១៣ ហស ៤:១៤ **៩:១១** ខ អស ១៧:៣ គ ហស ៤:៧ ១០:៥ ឃ ខ.១៤ **៩:១២** ង ខ.១៦ អក ២៤:២១ ច ហស ៧:១៣

**៩:៤** *នំបុ័ងរបស់អ្នកកាន់ទុក្ខ* គឺជារបស់មិនស្អាត ដូចជានំបុ័ងនៅក្នុងផ្ទះដែលមានមនុស្សស្លាប់ (មើល ជន ១៩:១៤ និងការពន្យល់, ចទ ២៦:១៤ យរ ១៦:៧)។ អ្នកដែលប៉ះពាល់របស់នោះ ត្រូវក្លាយជាមិនស្អាតតាមក្រឹត្យវិន័យ *ចូលទៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា* ដោយស្ថិតនៅក្នុងការនិរទេស ពួកអ៊ីស្រាអែលនឹងមិនមានទីកន្លែង(សូម្បីតែកន្លែងដែលស្តេចរេហូបោមទីមួយបានសង់ឡើង,១ពវ ១២:២៨–៣៣)សម្រាប់ថ្វាយយញ្ញបូជា ឬធ្វើបុណ្យតាមជំនឿ(ខ.៥)។

**៩:៥** *ថ្ងៃជំនុំមុតមាំ . . . ថ្ងៃបុណ្យនៃព្រះយេហូវ៉ា* មើល ២:១១ និងការពន្យល់ ។

**៩:៦** *អេស៊ីព្ទ* មើល ៧:១៦ ៨:១៣ ១១:៥ និងការពន្យល់ ។ *ក្រុងណូព* គឺជាទីក្រុងមួយនៅក្នុងតំបន់អេស៊ីព្ទក្រោម(ភាគខាងជើង) ។ *ដើមកន្ទេចអាលវិញ ហើយបន្លា* សូមធៀបនឹង ការគម្រាមកំហែងស្រដៀងគ្នាចំពោះស្រុកអេដំម(អស ៣៤:១៣) ។

**៩:៧** *មនុស្សដែលមាននិស្ស័យខាងវិញ្ញាណ* មើល មីក ៣:៨ និងការពន្យល់។ *លីលា* មើល ២ពវ ៩:១១ យរ ២៩:២៦ និងការពន្យល់, ធៀបនឹង ១សយ ២១:១៥ ។

**៩:៨** *អ្នកចាំយាម* មើល អគ ៣:១៧ ហព ២:១ និងការពន្យល់ ។ *លប់ . . . សេចក្តីសំអប់* នៅត្រង់ចំណុចនេះ ពួកអ៊ីស្រាអែលបានបង្ហាញតែការជិទាស់ប៉ុណ្ណោះ ចំពោះអ្នកចាំយាម(ហោរាដ៏ត្រឹមត្រូវ) ដែលព្រះទ្រង់បានចាត់ឱ្យមកព្រមានដល់រាស្ត្ររបស់ទ្រង់អំពីគ្រោះថ្នាក់ដ៏ធំដែលជាការគម្រាមកំហែង (មើល យរ ១:១៩ ១១:១៩ ១៥:១០ អម ៧:១០–១៣) ។

**៩:៩** *អំពើទុច្ចរិត* ពាក្យនេះគឺប្រើចំពោះពួកសាសន៍អ៊ីស្រាអែលដែលថ្វាយបង្គំរូបកូនគោមាស(មើល នក ៣២:៧ និងការពន្យល់, ចទ ៩:១២)។ *កាលនៅគ្រាគីបៀរ* គឺសំដៅទៅលើអំពើពុករលួយរបស់ពួកបេនយ៉ាមីន ដែលមានរៀបរាប់នៅក្នុង ពច ១៩–២១ ។ *ទ្រង់នឹងនឹកចាំ* ព្រះទ្រង់នឹកចាំអំពីអំពើរបាបដែលមិនបានប្រែចិត្ត ហើយទ្រង់ក៏នឹកចាំផងដែរអំពីបាបជារួមដែលពួកគេធ្វើនៅក្នុងជំនាន់របស់ពួកគេ(មើល ១៣:១២) ។

**៩:១០** *អញបានប្រទះនឹងអ៊ីស្រាអែល . . . អញបានឃើញពួកឰយុកោឯង* ទំនាក់ទំនងតាមសម្ព័ន្ធមេត្រីគឺមានប្រភពនៅ "វាលរហោស្ថាន" (មើល ២:១៤–១៥ និងការពន្យល់ ២:១៤ ១៣:៥ ចទ ៣២:១០)។ *ទំពាំងបាយជូរ . . . ផ្លែនៅដើមល្វា* គឺជាអាហារឆ្ងាញ់ពិសារមួយបែប(មើល បស ២:១៣ អស ២៨:៤ មីក ៧:១)។ ការប្រើរូបបារម្មណ៍នៅត្រង់ចំណុចនេះគឺដើម្បីបង្ហាញអំពីសេចក្តីអំណរ របស់ព្រះអម្ចាស់ចំពោះអ៊ីស្រាអែលបានប្តេជ្ញានៅក្នុងការតាំងសញ្ញាជាមួយនឹងទ្រង់នៅភ្នំស៊ីណាយ ។ *បាល–ពេអរ* ពេអរគឺជាឈ្មោះភ្នំមួយ (ជន ២៣:២៨) ។ "បាល–ពេអរ" គឺសំដៅទៅលើព្រះនៃភ្នំពេអរ (ជន ២៥:១–៣) ហើយនៅក្នុងខនេះគឺប្រើសំដៅទៅលើបេតពេអរ ដែលមានន័យថា "ទីបរិសុទ្ធនៃភ្នំពេអរ" (មើល ចទ ៣:២៩ និងការពន្យល់, ៤:៣,៤៦ យស ១៣:២០) ។ នៅត្រង់ចំណុចនេះ លោកហូសេប្រើពាក្យនេះសំដៅទៅលើហេតុការណ៍ដែលកើតឡើងនៅក្នុង ជន ២៥ ។ *រូបព្រះគួរខ្មាស* មើល ពច ៦:៣២, យរ ២:២៦ និងការពន្យល់ ។ *ត្រឡប់ជាគួរខ្ពើមឆ្អើម* មើល អស ៥:២,៤,៧ ។

**៩:១១** *អេប្រាអិម សិរីល្អរបស់គេ* គឺសំដៅទៅលើចំនួនប្រជាជនដ៏ច្រើន និងភាពសម្បូររុងរឿងរបស់ពួកគេ ។ ទោសគឺត្រូវទទួលសមនឹងអំពើបាបដែលបានប្រព្រឹត្ត ។ ពេស្យាចារមិននាំមកនូវភាពរីកចម្រើនទេ (មើល ៤:១០ ២:១៧ និងការពន្យល់) ។ *ហើរបាត់ទៅដូចជាសត្វស្លាប* គឺទៅបាត់លែងត្រឡប់មកវិញ (មើល សភ ២៣:៥) ។

វេទនា[ច]ដល់គេដែរ ក្នុងកាលដែលអញចាកចេញពីគេទៅ[ឆ]
១៣ឯអេប្រាអិម[ជ]បានតាំងនៅក្នុងទីគាប់ចិត្ត[ឈ] ដូចជាអញ
បានឃើញក្រុងទីរ៉ុសដែរ ប៉ុន្តែអេប្រាអិមនឹងត្រូវនាំកូនខ្លួន
ចេញមកឱ្យអ្នកដែលកាប់សំឡាប់វិញ[ញ] ១៤ឱព្រះយេហូវ៉ា
អើយសូមប្រទានដល់គេ តែត្រូវប្រទានអ្វី គឺត្រូវឱ្យគេមាន
ផ្ទៃដែលរលូតកូនហើយដោះរីងស្ងួត[ដ] ១៥អស់ទាំងអំពើ
អាក្រក់របស់គេសុទ្ធតែនៅត្រង់គីលកាល[ឋ] ដ្បិតគឺនៅទីនោះ
ដែលអញបានស្អប់ គេអញនឹងបណ្តេញគេចេញពីព្រះ
វិហាររបស់អញ ដោយព្រោះសេចក្តីអាក្រក់នៃការដែល
គេធ្វើ[ឌ] អញនឹងមិនស្រឡាញ់គេតទៅទៀត[ឍ] ពួកចៅហ្វាយ
របស់គេសុទ្ធតែជាមនុស្សបះបោរ[ណ] ១៦អេប្រាអិម[ត]ត្រូវវាយ
ហើយឫសរបស់គេបានក្រៀមទៅ គេនឹងមិនបង្កើតផល
ទៀតឡើយ[ថ] អើ ទោះបើគេបង្កើតកូនបានដែរ គង់តែអញ
នឹងសំឡាប់[ទ]កូនសំឡាញ់ ដែលចេញពីផ្ទៃគេមក ១៧ព្រះនៃខ្ញុំ
ទ្រង់នឹងបោះគេចោល[ធ] ពីព្រោះគេមិនបានស្តាប់តាម[ន]ទ្រង់
នោះគេនឹងបានជាមនុស្សសាត់អណ្តែត នៅកណ្តាលអស់
ទាំងសាសន៍[ប] ។

**១០** ១អ៊ីស្រាអែលជាដើមទំពាំងបាយជូរទ្រប់ទ្រល់[ក] ដែល
កើតមានផ្លែ គេមានផលកាន់តែច្រើនឡើងយ៉ាងណា នោះ
ក៏ចំរើនអាសនារបស់ខ្លួនជាច្រើនឡើងយ៉ាងនោះដែរ[ខ]
ហើយស្រុកគេបានល្អយ៉ាងណា[គ] នោះគេបានធ្វើបង្គោល
គោរពឱ្យល្អយ៉ាងនោះដែរ[ឃ] ២ចិត្តគេចែកជាពីរ[ង]ហើយ
គេនឹងត្រូវឃើញថាមានទោសឥឡូវ[ច] ទ្រង់នឹងវាយអស់ទាំង
អសនារបស់គេ[ឆ] ហើយបំផ្លាញបង្គោលគោរពរបស់គេ
បង់[ជ] ៣ឥឡូវនេះ ពិតប្រាកដជាគេនឹងពោលថា យើងគ្មាន
ស្តេចទេ ដ្បិតយើងមិនបានកោតខ្លាចដល់ព្រះយេហូវ៉ា តែ
បើមានស្តេចវិញ តើនឹងមានប្រយោជន៍អ្វីដល់យើង ។
៤គេពោលចេញតែពាក្យប៉ុណ្ណោះ ដោយស្បថកុហក[ឈ]
ក្នុងការតាំងសញ្ញាគ្នា[ញ] ហេតុនោះមានការវិនិច្ឆ័យដុះឡើង
ដូចជាដើមពុល[ដ] តាមគន្លងក្នុងចំការ ៥ឯពួកអ្នកនៅក្រុង
សាម៉ារីគេនឹងភ័យស្លុតពីដំណើររូបកូនគោ[ឋ]ដែលនៅបេត
–អាវេន[ឌ] ដ្បិតពួកជនទាំងឡាយនឹងសោយសោកព្រោះរូប
នោះ ព្រមទាំងពួកសង្ឃ[ឍ]ដែលបានយករូបនោះជាទីរីក
រាយចិត្តផង ពីព្រោះសិរីល្អរបស់រូបនោះបានចាត់ទៅ
ហើយ[ណ] ៦គេនឹងដឹកនាំទៅស្រុកអាសស៊ើរ[ត] ទុកជាដង្វាយ
ថ្វាយ[ថ]ដល់ស្តេចយ៉ារេប[ទ] អេប្រាអិមនឹងទទួលតែសេចក្តី
អាម៉ាស់ខ្មាស[ធ] ហើយអ៊ីស្រាអែលនឹងត្រូវខ្មាស[ន]ចំពោះ
សេចក្តីប្រឹក្សារបស់ខ្លួន ៧ចំណែកក្រុងសាម៉ារី ស្តេចគេបាន
សូន្យបាត់[ប] ដូចជាពពុះនៅលើទឹក ៨ឯទីខ្ពស់ទាំងប៉ុន្មាន[ផ]នៃ

**៩:១២** ឆ ចទ ៣១:១៧ **៩:១៣** ជ ទដ ៧៨:៦៧ ឈ អក ២៧:៣ ញ យប ១៥:២២ បទ ២:២២ **៩:១៤** ដ ខ.១១ លក ២៣:២៩ **៩:១៥** ឋ ហស ៤:១៥ ឌ ហស ៧:២ ឍ យរ ១២:៨ ណ អស ១:២៣ ហស ៤:៩ ៥:២ **៩:១៦** ត ហស ៥:១១ ថ យប ១៥:៣២ ហស ៨:៧ ទ ខ.១២ **៩:១៧** ធ យរ ៦:៣០ ន ហស ៤:១១ ប ចទ ២៨:៦៥ ហស ៧:១៣ **១០:១** ក អក ១៥:២ ខ ១ពវ ១៤:២៣ គ ហស ១៣:១៥ ឃ ហស ៣:៤ ៤:៧ ៨:១១ ១២:១១ **១០:២** ង ១ពវ ១៨:២១ ច ហស ១៣:១៦ ឆ ខ.៨ ជ មីក ៥:១៣

**១០:៤** ឈ ហស ៤:២ ញ អក ១៧:១៩ អម ៥:៧ ដ អម ៦:១២ **១០:៥** ឋ នក ៣២:៤ អស ៤៤:១៧–២០ ឌ ខ.៨ ហស ៥:៨ ឍ ២ពវ ២៣:៥ សផ ១:៤ ណ ពច ១៨:១៧–១៨ ហស ៨:៥ ៩:១,៣,១១ **១០:៦** ត ២ពវ ១៦:៧ ហស ១១:៥ ថ ពច ៣:១៥ ទ ហស ៥:១៣ ធ អស ៣០:៣ ហស ៤:៧ ន យរ ៤៨:១៣ **១០:៧** ប ខ.១៥ ហស ១៣:១១ **១០:៨** ផ អក ៦:៦

**៩:១២** *វេទនា* មើល ៧:១៣ និងការពន្យល់ ។

**៩:១៣** *ក្រុងទីរ៉ុស* គេស្គាល់ទីក្រុងនេះថា សម្បូរទៅដោយទ្រព្យសម្បត្តិ មានបរិស្ថាន និងសន្តិសុខជាទីគាប់ចិត្ត (មើល អគ ២៧:៣–២៥) ។

**៩:១៤** លោកហូសេមិនបានអធិស្ឋាន ដោយចិត្តដែលកាត់ទោសអ៊ីស្រាអែល ដោយការស្អប់នោះទេ ប៉ុន្តែ គឺដោយសារលោកមានចំណែកនៅក្នុងសេចក្តីក្រោធរបស់ព្រះអម្ចាស់ចំពោះអំពើបាបរបស់ពួកគេ ។

**៩:១៥** *គីលកាល* មើលការពន្យល់ ៤:១៥ ។ *បណ្តេញគេចេញពីព្រះវិហាររបស់អញ* ព្រះអម្ចាស់ទ្រង់បណ្តេញពួកគេចេញពីផ្ទះ និងទឹកដីរបស់ទ្រង់ ដូចជាប្តីបណ្តេញប្រពន្ធដែលផិតក្បត់ចេញពីផ្ទះ (មើល ៨:១ និងការពន្យល់) ។ *អញនឹងមិនស្រឡាញ់គេតទៅទៀត* គឺដោយសារតែអំពើបាបរបស់ពួកគេ ។ ប៉ុន្តែនៅពេលដែលពួកគេប្រែចិត្ត ហើយទូលសូមឱ្យព្រះអម្ចាស់អត់ទោសបាបដល់ពួកគេ (មើល ១៤:១–២ និងការពន្យល់) នោះទ្រង់នឹង "ស្រឡាញ់ពួកគេជាធម្មតាវិញ" (១៤:៤) ។

**៩:១៧** *ព្រះនៃខ្ញុំ* គឺជាពាក្យដែលលោកហូសេប្រើតែម្នាក់ឯង ព្រោះព្រះអម្ចាស់ទ្រង់មិនមែនជាព្រះរបស់ពួកគេទៀតទេ ។ *មិនបានស្តាប់តាម* មើល ៤:៦ ២ពវ ១៧:២០ ។ *សាត់អណ្តែត* គឺដូចជាលោកកាអ៊ីន (មើល លប ៤:១២–១៦) ។

**១០:១** *អ៊ីស្រាអែល* គឺសំដៅទៅលើនគរអ៊ីស្រាអែល ។ *ដើមទំពាំងបាយជូរ* ជាញឹកញាប់ពាក្យនេះសំដៅទៅលើសាសន៍អ៊ីស្រាអែល (មើល ទដ ៨០:៨–១៦ និងការពន្យល់) ។ *មានផលកាន់តែច្រើនឡើង* ប្រហែលជាសំដៅទៅលើភាពសម្បូរុងរឿងនៅក្នុងរាជ្យកាលស្តេចយេរ៉ូបោមទីពីរ (ឆ្នាំ៧៩៣–៧៥៣ មុនគ.ស) ។ *បង្គោលគោរព* មើល ៣:៤ និងការពន្យល់ ។

**១០:២** *ចិត្តគេចែកជាពីរ* មើល យរ ១៧:៩ និងការពន្យល់ ។ កាលពីមុនពួកអ៊ីស្រាអែលបានស្រែកអំពាវនាវដល់ព្រះ ប៉ុន្តែ នៅពេលនេះពួកគេមិនគោរពដល់ទ្រង់ ដោយថ្វាយបង្គំព្រះរបស់សាសន៍ដទៃ (មើល ៨:២ និងការពន្យល់) ។

**១០:៣** *យើងគ្មានស្តេចទេ* ការនេះនឹងកើតឡើងចំពោះពួកគេក្នុងពេលឆាប់ៗខាងមុខ នៅពេលដែលពួកសាសន៍អាសស៊ើរបានបំផ្លាញនគររបស់ពួកគេ ។

**១០:៤** *គេពោលចេញតែពាក្យប៉ុណ្ណោះ* ពួកស្តេចចុងក្រោយរបស់ពួកអ៊ីស្រាអែល គឺល្បីឈ្មោះខាងអំពើពុករលួយ និងការកុហកបោកប្រាស ។

**១០:៥** *ក្រុងសាម៉ារី* គឺជារាជធានីរបស់អ៊ីស្រាអែល (មើលការពន្យល់ ៧:១) ។ *រូបកូនគោដែលនៅបេត–អាវេន* គឺរូបព្រះដែលស្តេចយេរ៉ូបោមទីមួយបានដំកល់នៅក្រុងបេតអែល (មើល៨:៥ និងការពន្យល់) ។

**១០:៦** *ទុកជាដង្វាយថ្វាយដល់ស្តេច* មើល ៥:១៣ និងការពន្យល់ ។ *អេប្រា–អិម* មើលការពន្យល់ ៤:១៧ ។

ក្រុងអាវេន គឺជាអំពើបាប[ព]របស់ពួកអ៊ីស្រាអែល នោះនឹង
ត្រូវបំផ្លាញ ហើយមានបន្លា[ភ]និងអញ្ចាញដុះឡើង នៅលើ
អាសនារបស់គេ[ម] ហើយគេនឹងនិយាយដល់ភ្នំធំទាំងប៉ុន្មាន
ថា ចូរគ្របបាំងយើងរាល់គ្នាចុះ[យ] ហើយដល់ភ្នំតូចទាំង
ប៉ុន្មានថា ចូរធ្លាក់មកលើយើងចុះ[រ]។
៩ឱអ៊ីស្រាអែលអើយ ឯងបានប្រព្រឹត្តអំពើបាប[ល]ចាប់
តាំងពីគ្រាក្រុងគីបៀររៀងមក[វ] នៅទីនោះគេបានឈរនឹង
នៅ នៅត្រង់គីបៀរនោះ ចំបាំងទាស់នឹងមនុស្សទុច្ចរិត
មិនទាន់មកលើគេនៅឡើយ ១០កាលណាអញពេញចិត្ត
នោះអញនឹងវាយផ្ចាល[ស]គេ ហើយជនជាតិទាំងប៉ុន្មាននឹង
មូលគ្នាទាស់នឹងគេ ក្នុងកាលដែលគេបានទឹមនឹមជាមួយ
នឹងអំពើបាបរបស់គេទាំង២នោះ ១១អេប្រាអិមជាគោ
ក្រមុំថ្មឹកហើយ ដែលចូលចិត្តបញ្ជាន់ស្រូវ តែអញបាន
បំពាក់នឹម[ហ]ទៅលើកដ៏ល្អរបស់គេ អញនឹងឱ្យម្នាក់ជិះលើ
អេប្រាអិម ឯយូដាគេនឹងភ្ជួរ ហើយយ៉ាកុបនឹងរាស់ ។
១២ចូរសាបព្រោះ[ឡ]សំរាប់ខ្លួនដោយសុចរិត[អ] ហើយច្រូត
កាត់ដោយសេចក្ដីសប្បុរស ចូរកំសុលដីរបស់ឯងរាល់គ្នា
ឡើង[ក] ដ្បិតដល់ពេលដែលគួរស្វែងរក[ខ]ព្រះយេហូវ៉ាទាល់
តែទ្រង់យាងមកបង្អុរ ឱ្យភ្លៀងជាសេចក្ដីសុចរិត[គ]មកលើ
ឯងរាល់គ្នា ១៣ឯងរាល់គ្នាបានភ្ជួរជាអំពើអាក្រក់ ហើយ
បានច្រូតកាត់ជាសេចក្ដីទុច្ចរិត[ឃ] ឯងរាល់គ្នាបានស៊ីផលនៃ
ការកុហកហើយ[ង] ដ្បិតឯងបានទុកចិត្តនឹងផ្លូវរបស់ខ្លួន
ហើយនិងចំនួនច្រើននៃមនុស្សខ្លាំងពូកែរបស់ឯង[ច] ១៤ហេតុ
នោះនឹងមានការជ្រួលច្រើមកើតឡើងក្នុងជនជាតិឯង អស់
ទាំងបន្ទាយរបស់ឯងនឹងត្រូវបំផ្លាញ[ឆ] ដូចជាស្ដេចសាល-
ម៉ាន[ជ]បានបំផ្លាញក្រុងបេត-អើបេលក្នុងថ្ងៃចំបាំង នៅគ្រា
នោះ ទាំងម្ដាយនឹងកូនផង ក៏ត្រូវបោកខ្ទេចខ្ទីជាមួយគ្នា[ឈ]
១៥ឯបេត-អែលនឹងនាំឱ្យឯងបានដូច្នោះដែរ ដោយព្រោះ
អំពើអាក្រក់ដ៏ធំក្រៃលែងរបស់ឯង គឺនៅពេលព្រលឹម
ស្រាង នោះស្ដេចអ៊ីស្រាអែលនឹងត្រូវផ្ដាច់ចេញអស់ទៅ[ញ]។

## សេចក្ដីស្រឡាញ់របស់ព្រះចំពោះពួកអ៊ីស្រាអែល

**១១** ១ក្នុងគ្រាដែល អ៊ីស្រាអែល នៅក្មេងនៅឡើយ[ក]
នោះអញបានស្រឡាញ់[ខ]វា ក៏បានហៅកូនអញចេញពីស្រុក

**១០:៨** ព ខ.៥ ១ពវ ១២:២៨-៣០ ហស ៤:១៣ ភ ហស ៩:៦ ម ខ.២ អស ៣២:១៣ យ យប ៣០:៦ អម ៣:១៤-១៥ រ អម ៧:៩ លក ២៣:៣០ វវ ៦:១៦ **១០:៩** ល យស ៧:១១ វ ហស ៥:៨ **១០:១០** ស អគ ៥:១៣ ហស ៤:៩ **១០:១១** ហ យរ ១៥:១២ ៣១:១៨ **១០:១២** ឡ សស ១១:១ អ សភ ១១:១៨ យក ៣:១៨ ក យរ ៤:៣ ខ អស ១៩:២២ ហស ១២:៦ គ អស ៤៥:៨ **១០:១៣** ឃ យប ៤:៨ ហស ៧:៣ ១១:១២ កទ ៦:៧-៨ ង សភ ១១:១៨ ហស ៨:៧ ច ទដ ៣៣:១៦ **១០:១៤** ឆ អស ១៧:៣ មីក ៥:១១ ជ ២ពវ ១៧:៣ ឈ អស ១៣:១៦ ហស ១៣:១៦ **១០:១៥** ញ ខ.៧ **១១:១** ក យរ ២:២ អគ ១៦:២២ ខ ចទ ៤:៣៧

**១០:៨** *ទីខ្ពស់* មើល ៤:១៣-១៤ និងការពន្យល់ ៤:១៣ ។ *ចូរគ្របបាំងយើងរាល់គ្នាចុះ... ចូរធ្លាក់មកលើយើងចុះ* ព្រះយេស៊ូវទ្រង់បានមានបន្ទូលអំពីការនេះ (មើល លក ២៣:៣០) ហើយការនេះបានបើកសំដែងនៅក្នុង វវ ៦:១៦ ។
**១០:៩** *ក្រុងគីបៀរ* មើល ៩:៩ និងការពន្យល់ ។ សង្គ្រាម និងការជាប់ជាឈ្លើយនឹងធ្លាក់មកលើអ៊ីស្រាអែល ដូចជាសង្គ្រាមដែលកើតឡើងចំពោះក្រុងគីបៀរដែរ ។
**១០:១១** *គោក្រមុំថ្មឹក* រហូតមកដល់ពេលនេះ ស្រុកអេប្រាអឹម (អ៊ីស្រាអែល) មានការស្កប់ស្កល់ចិត្តដូចជាគោក្រមុំដែលស៊ីនៅពេលបញ្ជាន់ស្រូវ ។ ប៉ុន្តែព្រះទ្រង់នឹងធ្វើឱ្យពួកអ៊ីស្រាអែល (នៅក្នុងខនេះគឺត្រូវបានហៅថា អេប្រាអិម និងយ៉ាកុប) និងយូដាធ្វើការធ្ងន់ៗ ដូចជាភ្ជួររាស់ ដោយស្ថិតនៅក្រោមនឹមជាការប្រៀបធៀបទៅនឹងការត្រឡប់ជាឈ្លើយ របស់ចក្រភពអាសស៊ើរ និងបាប៊ីឡូន ។ *យូដា* មើលសេចក្ដីផ្ដើមត្រង់ចំនុចអ្នកនិពន្ធ និងកាលបរិច្ឆេទ
**១០:១២** *ច្រូតកាត់ដោយសេចក្ដីសប្បុរស* ព្រះអម្ចាស់ទ្រង់នឹងប្រទានពរដល់ពួកអ៊ីស្រាអែល ឱ្យតែពួកគេនៅតែធ្វើការអ្វីដែលត្រឹមត្រូវ (ដោយសេចក្ដីស្រឡាញ់, មើលការពន្យល់ ៦:៦) ។ *ចូរកំសុលដីរបស់ឯងរាល់គ្នា* មានន័យថា ចូរឈប់មិនបង្កើតផលផ្លែ ហើយប្រែចិត្តឡើង ដោយចាប់ផ្ដើមជាថ្មីយ៉ាងឆាប់ ហើយបង្កើតផលផ្លែឡើង ។ *សេចក្ដីសុចរិត* ព្រះទ្រង់បានប្រទានពរនៅក្នុងការតាំងសេចក្ដីសញ្ញារបស់ទ្រង់ ដោយនឹងបង្អុរភ្លៀងមកលើពួកគេដោយសេចក្ដីសុចរិត បើសិនជាពួកគេមានសេចក្ដីស្មោះត្រង់នឹងទ្រង់ដោយសេចក្ដីសុចរិត ដែលទ្រង់ជាព្រះអម្ចាស់របស់ពួកគេតាមសេចក្ដីសញ្ញា ។
**១០:១៣** *ការកុហក* ត្រង់ចំណុចនេះ ពួកអ៊ីស្រាអែលគឺជាពួកកុហក ហើយរស់នៅដោយសារការកុហក (មើល ខ.៤ ៧:៣ ១១:១២ ១២:១ ប្រៀបធៀបនឹង ១យហ ១:៦) ។
**១០:១៤** *ស្ដេចសាលម៉ានបានបំផ្លាញក្រុងបេត-អើបេល* ឈ្មោះស្ដេចសាលម៉ានអាចជាឈ្មោះហៅកាត់ពីឈ្មោះដើមថា សាលម៉ានេសេ ទី៥ ជាស្ដេចដែលបានធ្វើសង្គ្រាមលោមព័ទ្ធស្រុកសាម៉ារីនៅឆ្នាំ ៧២៥ មុនគ.ស (មើល ២ពវ ១៧:៣-៥) ។ ភាពសាហាវព្រៃផ្សៃដែលកើតឡើងចំពោះប្រជាជន គឺជារឿងធម្មតានៅក្នុងសង្គ្រាមសម័យបុរាណ (មើល ៩:១៣ ១៣:១៦ មើល ទដ ១៣៧:៩ និងការពន្យល់) ។
**១០:១៥** *បេត-អែល* មើល ខ.៨, ១២:៤ និងការពន្យល់ ។
**១១:១** ខនេះគឺជាការរំឭកជាលើកទីបីអំពីប្រវត្តិសាស្ត្រ (មើល ៩:១០ ១០:៩) ដែលនិយាយអំពីជម្រើសដែលព្រះអម្ចាស់ទ្រង់មានចំពោះអ៊ីស្រាអែលនៅស្រុកអេស៊ីព្ទ ដែលការដែលទ្រង់នាំពួកគេចេញពីស្រុកនោះមក (ធៀបនឹង ១២:៩ ១៣:៤) បាននាំឱ្យពួកគេមានកំណើតជាជនគរមួយ ។ ប៉ុន្តែនៅពេលនេះ ពួកអ៊ីស្រាអែលបានឆ្លើយតបនឹងព្រះអម្ចាស់វិញ ដោយធ្វើខ្លួនដូចជាកូនដែលមិនស្ដាប់បង្គាប់ ជាជាងធ្វើជាប្រពន្ធដែលមិនស្មោះត្រង់ (ជំពូក ១-៣) ។ នៅក្នុងបទគម្ពីរផ្សេងទៀតបាននិយាយអំពីអ៊ីស្រាអែល ក្នុងនាមជា "កូនរបស់ព្រះ" (មើល នក ៤:២២-២៣ និងការពន្យល់, អស ១:២,៤) ។ ចំពោះការដែលព្រះអម្ចាស់ធ្វើជាឪពុករបស់ពួកអ៊ីស្រាអែល មើល ចទ ៣២:៦ អស ៦៣:១៦ ៦៤:៨ ។ លោកហូសេបានដឹងថា សេចក្ដីស្រឡាញ់របស់ព្រះគឺជាមូលហេតុចំបងដែលទ្រង់បានរើសពួកគេ (មើល ៣:១ និងការពន្យល់) ។ ព្រះគម្ពីរម៉ាថាយបានបង្ហាញថា ដំណើរវិលត្រឡប់របស់ព្រះយេស៊ូវពីស្រុកអេស៊ីព្ទ គឺជានិមិត្តសញ្ញានៃការសម្រេចព្រះបន្ទូលសន្យារំដោះអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ (សូមមើល ម៉ាថាយ ២:១៥ និងការពន្យល់) ។

អេស៊ីព្ទមក[គ] ២ពួកហោរាបានហៅគេជាច្រើនដងប៉ុណ្ណា
នោះគេបានឃ្លាតឆ្ងាយទៅប៉ុណ្ណោះឯង[ឃ] គេបានថ្វាយយញ្ញ
បូជាដល់អស់ទាំងព្រះបាល[ង] ព្រមទាំងដុតកំញ៉ានថ្វាយដល់
រូបឆ្លាក់ផង[ច] ៣ប៉ុន្តែគឺអញដែលបង្ហាត់ឱ្យអេប្រាអិមចេះដើរ
ក៏បានបីគេ[ឆ] តែគេមិនបានដឹងថា គឺអញដែលមើលគេឱ្យ
ជា[ជ]ទេ ៤អញបានទាញនាំគេដោយខ្សែជាសេចក្តីទទួច
របស់មនុស្ស គឺដោយចំណងនៃសេចក្តីស្រឡាញ់[ឈ] អញ
បានធ្វើដល់គេ ដូចជាអ្នកដែលលើកបង្ហើបនឹម[ញ] នៅកគោ
ហើយដាក់ស្មៅនៅ[ដ]មុខវា[ឋ] ។
៥គេនឹងមិនវិលទៅឯស្រុកអេស៊ីព្ទ[ឌ]វិញឡើយ គឺអ្នកស្រុក
អាសស៊ើរ[ឍ]នឹងធ្វើជាស្តេចលើគេ ពីព្រោះគេមិនព្រម
ត្រឡប់មកឯអញទេ[ណ] ៦ដូច្នេះ ដាវ[ត]នឹងធ្លាក់មកលើទីក្រុង
របស់គេ ព្រមទាំងបំផ្លាញអ្នកដ៏ជាកំពូល[ថ]អស់ទៅ ហើយ
លេបពួកគេបាត់ផង ដោយព្រោះការប្រឹក្សារបស់ខ្លួនគេ
៧រាស្ត្ររបស់អញ គេតែងតែរាថយចេញ[ទ]ពីអញ[ធ] ទោះបើ
មានអ្នកណាហៅគេមកឯព្រះដ៏ខ្ពស់បំផុតក៏ដោយ គង់តែ
ឥតមានអ្នកណាមួយព្រមដំកើងទ្រង់ឡើង ។
៨ឱអេប្រាអិមអើយ ធ្វើដូចម្តេចឱ្យអញចោលឯង[ន] បាន
ឱអ៊ីស្រាអែលអើយ[ប] ធ្វើដូចម្តេចឱ្យអញលះបង់ឯងបាន
អញនឹងធ្វើដល់ឯង ដូចជាបានធ្វើដល់ក្រុងអាត់ម៉ាយ៉ាង
ណាបាន ឬប្រព្រឹត្តនឹងឯង ដូចជាបានប្រព្រឹត្តនឹងសេបោដូច
ម្តេចបាន[ផ] ចិត្តរបស់អញបានប្រែប្រួលនៅក្នុងខ្លួន សេចក្តី
អាណិតអាសូរ[ព]របស់អញបានរំជួលឡើងជាមួយគ្នា[ភ] ៩អញ
នឹងមិនសំរេចតាមសេចក្តីកំហឹងដ៏សហ័សរបស់អញទេ[ម] ក៏
មិនវិលមកបំផ្លាញ[យ]អេប្រាអិមដែរ ដ្បិត អញនេះជាព្រះ មិន
មែនជាមនុស្ស[រ]ទេ គឺជាព្រះដ៏បរិសុទ្ធ[ល] នៅកណ្តាលឯង
រាល់គ្នា អញនឹងមិនមកដោយសេចក្តីក្រោធឡើយ ១០គេ
នឹងដើរជាប់តាមព្រះយេហូវ៉ា ទ្រង់នឹងបញ្ចេញព្រះសូរ
សៀង[វ]ដូចជាសិង្ហ[ស] កាលណាទ្រង់បញ្ចេញ ព្រះសូរសៀង
នោះពួកកូននឹងរត់មកពីទិសខាងលិចទាំងញាប់ញ័រ[ហ,ឡ]
១១គេនឹងមកទាំងញាប់ញ័រដូចជាសត្វហើរមក ពីស្រុកអេ-
ស៊ីព្ទ ហើយមកពីស្រុកអាសស៊ើរដូចជាព្រាប[អ,ក] នោះនឹង
ឱ្យគេអាស្រ័យនៅក្នុងផ្ទះរបស់ខ្លួន[ខ] នេះជាព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ។

**១១:១** គ នក ៤:២២ ហស ១២:៩,១៣ ១៣:៤ មថ ២:១៥ **១១:២** ឃ ខ.៧ ង ហស ២:១៣ ច ២ពវ ១៧:១៥ អស ៦៥:៧ យរ ១៨:១៥ ហស ៤:១៣ ១៣:១ **១១:៣** ឆ ចទ ១:៣១ ៣២:១១ ហស ៧:១៥ ជ នក ១៥:២៦ យរ ៣០:១៧ **១១:៤** ឈ យរ ៣១:២–៣ ញ លវ ២៦:១៣ ដ នក ១៦:៣២ ទដ ៧៨:២៥ ឋ យរ ៣១:២០ **១១:៥** ឌ ហស ៧:១៦ ឍ ហស ១០:៦ ណ នក ១៣:១៧ **១១:៦** ត ហស ១៣:១៦ ថ បទ ២:៩

**១១:៧** ទ អស ២៦:១០ ធ ខ.២ យរ ៣:៦–៧ ៨:៥ **១១:៨** ន យរ ៧:២៩ ប ហស ៦:៤ ផ លប ១៤:៨ បទ ៣:៣២ ព ១ពវ ៣:២៦ ទដ ២៥:៦ ភ អគ ៣៣:១១ អម ៧:៣ **១១:៩** ម ចទ ១៣:១៧ យរ ១៨:៨ ៣០:១១ យ បទ ៣:២២ មឡ ៣:៦ រ ជន ២៣:១៩ ល ២ពវ ១៩:២២ អស ៣១:១ **១១:១០** វ អស ៤២:១៣ ស អស ៣១:៤ ហ ទដ ១៨:៤៥ ឡ ហស ៣:៥ ៦:១–៣ **១១:១១** អ លប ៨:៨ ក អស ១១:១១ ខ អគ ២៨:២៦ ៣៤:២៥–២៨

**១១:២** *ព្រះបាល* មើល ២:១៣ និងការពន្យល់ ។ *រូបឆ្លាក់* មើល ចទ ៧:២៥ ។

**១១:៣** *អេប្រាអឹម* មើលការពន្យល់ ៤:១៧ ។ *ដើរ* ត្រង់ចំណុចនេះ គឺបានបង្ហាញពីរូបភាពដ៏ទន់ភ្លន់បំផុតនៃការដែលឪពុកបង្រៀនកូនរបស់ខ្លួនឱ្យចេះដើរ ។ *មិនបានដឹង* មើល ២:៥–៨ និងការពន្យល់ ២:៨ ។ *មើលគេឱ្យជា* មើល ៥:១៣ ៦:១ និងការពន្យល់, ៧:១ ។

**១១:៤** នៅក្នុងខនេះហាក់ដូចជានិយាយប្រៀបធៀបទៅនឹងកសិករដែលមើលថែរសត្វពាហនៈរបស់ខ្លួន ។ តាមការកាត់ស្រាយម្យ៉ាងទៀត នៅក្នុងខនេះគឺជាការនិយាយប្រៀបធៀបទៅនឹងឪពុកដែលលើកកូនប្រុសរបស់ខ្លួនឡើង ។ *ដាក់ស្មៅនៅមុខវា* ព្រះអម្ចាស់ទ្រង់បានប្រទាននូវអាហារដោយការអស្ចារ្យនៅក្នុងទីរហោស្ថាន (មើល នក ១៦ ចទ ៨:១៦) ។

**១១:៥** *ស្រុកអេស៊ីព្ទ . . . អាសស៊ើរ* មើល ៨:១៣ ៩:៣ និងការពន្យល់ ។ សម្លេងដ៏ស្រទន់ (ខ.១–៤) ត្រូវប្រែក្លាយជាសម្លេងគម្រាមនិរទេសទៅប្រទេសទាំងពីរ ។ ការនេះមានន័យថា ជាតិសាសន៍ដែលព្រះអម្ចាស់បានរំដោះពីប្រទេសអេស៊ីព្ទត្រូវត្រឡប់ទៅវិញ ដោយសារពួកគេមិនស្មោះត្រង់ចំពោះអ្នកដែលបានរំដោះពួកគេ ។

**១១:៧** *ព្រះដ៏ខ្ពស់បំផុត* មើល ៧:១៦ និងការពន្យល់ ។

**១១:៨** កូនដែលក្បាលរឹងត្រូវទទួលទោសចោលនឹងដុំថ្មសម្លាប់ (ចទ ២១:១៨–២១) ប៉ុន្តែ សេចក្តីអាណិតអាសូររបស់ព្រះអម្ចាស់បានធ្វើឱ្យទ្រង់ដកសេចក្តីក្រោធរបស់ទ្រង់ចេញ ហើយទ្រង់បដិសេធមិនព្រមបំផ្លាញពួកអេប្រាអិម (អ៊ីស្រាអែល) ។ *ក្រុងអាត់ម៉ា . . . សេបោ* គឺជាក្រុងនៃវាលទំនាប (មើល លប ១០:១៩ និងការពន្យល់, ១៤:២,៨) ដែលត្រូវដួលរលំ នៅពេលដែលក្រុងសូដំមត្រូវបានបំផ្លាញ (លប ១៩:២៤–២៥ ចទ ២៩:២៣ យរ ៤៩:១៨) ហើយជានិមត្តរូបនៃការបំផ្លិចបំផ្លាញទាំងស្រុង (មើល អម ៤:១១ និងការពន្យល់) ។

**១១:៩** *អញនេះជាព្រះ មិនមែនជាមនុស្សទេ* នៅត្រង់ចំនុចនេះ ព្រះទ្រង់មានសេចក្តីស្រឡាញ់ពិតចំពោះអ៊ីស្រាអែល (មើល ខ.១–៤ ១សយ ១៥:២៩ មឡ ៣:៦) ។ សាសន៍អ៊ីស្រាអែលត្រូវទទួលទោស ប៉ុន្តែមិនមែនការបំផ្លាញនោះទេ ។ *ព្រះដ៏បរិសុទ្ធនៅកណ្តាលឯងរាល់គ្នា* ព្រះអម្ចាស់ទ្រង់បង្ហាញសេចក្តីបរិសុទ្ធរបស់ទ្រង់នៅក្នុងព្រះគម្ពីរហូសេនៅក្នុងខនេះ និងក្នុង ខ.១២ (មើលការពន្យល់ នក ៣:៥ លវ ១១:៤៤) ។

**១១:១០** នៅត្រង់ចំណុចនេះ គឺនិយាយអំពីការវិលត្រឡប់ពីការនិរទេសមកវិញ ។ *ព្រះសូរសៀងដូចជាសិង្ហ* នៅត្រង់ចំណុចនេះព្រះសូរសៀងរបស់ទ្រង់មិនមែនជាការគំរាមកំហែងថានឹងបំផ្លាញទេ (ធៀបនឹង ៥:១៤ ១៣:៧) ប៉ុន្តែព្រះសូរសៀងរបស់ទ្រង់នៅពេលនេះ គឺជាសញ្ញាដ៏ច្បាស់មួយដែលបញ្ជាក់ពីការវិលត្រឡប់ពីការនិរទេសមកវិញ ។ *ពីទិសខាងលិច* គឺជាមកពីកោះ និងតំបន់ឆ្នេរសមុទ្រមេឌីទែរ៉ានេ ។

**១១:១១** *មកពីស្រុកអេស៊ីព្ទ . . . ស្រុកអាសស៊ើរ* មើល ៧:១៦ និងការពន្យល់, ៩:៣ ។ *ដូចជាសត្វហើរ . . . ដូចជាព្រាប* គឺបង្ហាញអំពីការវិលមកវិញដែលកើតឡើងយ៉ាងលឿន (ធៀបនឹង អស ៦០:៨) ហើយពាក្យនេះមិនមែនជាការបន្ទាបពួកគេឱ្យស្មើនឹងសត្វ ដូចបានដែលនិយាយក្នុងខខាងដើមថា ជាប្រៀបអាប់អោននោះទេ (៧:១១) ។

## អំពើបាបរបស់ពួកអ៊ីស្រាអែល

**១២** ១អេប្រាអិមតែងឡោមព័ទ្ធអញ ដោយសេចក្ដីភូត
ភរ[ក] ហើយពួកវង្សអ៊ីស្រាអែល ដោយសេចក្ដីឆបោកដែរ
ឯយូដា គេនៅតែមានអំណាចចំពោះព្រះនៅឡើយ ក៏
ស្មោះត្រង់[ខ]ចំពោះព្រះដ៏បរិសុទ្ធដែរ[គ] ២អេប្រាអិម[ឃ]ចិញ្ចឹម
ខ្លួនដោយខ្យល់ទទេ[ង]ក៏ដេញតាមខ្យល់ពីទិសខាងកើត គេ
ចំរើនសេចក្ដីភូតភរនឹងការខូចបង់ជានិច្ច[ច] គេតាំងសញ្ញា
នឹងស្រុកអាសស៊ើរ[ឆ] ហើយបញ្ជូនប្រេងទៅឯស្រុកអេស៊ីព្ទ[ជ]
៣ព្រះយេហូវ៉ាទ្រង់មានរឿង[ឈ]នឹងយូដាដែរ[ញ] ក៏នឹងធ្វើ
ទោស[ដ]ដល់យ៉ាកុបតាមអំពើប្រព្រឹត្តរបស់គេ ព្រមទាំងសង
គេតាមកិរិយារបស់គេផង[ឋ] ៤កាលនៅក្នុងផ្ទៃនៅឡើយ
នោះ យ៉ាកុបបានចាប់កែងជើងរបស់បង[ឌ] លុះដល់មាន
វ័យពេញកំឡាំងហើយ នោះក៏មានអំណាច[ឍ]នៅ ចំពោះ
ព្រះដែរ ៥អើ ក៏មានអំណាចលើទេវតា ហើយលោកបាន
ឈ្នះផង លោកបានយំ ហើយអង្វរដល់ទ្រង់ ក៏ប្រទះឃើញ
នៅត្រង់បេត-អែល[ណ]នៅទីនោះទ្រង់ក៏មានបន្ទូលមក
យើងរាល់គ្នា ៦គឺព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ
"យេហូវ៉ា" នេះ ជានាម[ត]ដ៏ជាទីរំឭកពីទ្រង់ ៧ដូច្នេះ ចូរវិល
មក[ថ]ឯព្រះនៃឯងវិញចុះ ចូរកាន់តាមសេចក្ដីសប្បុរស និង
សេចក្ដីយុត្តិធម៌[ទ] ព្រមទាំងរង់ចាំព្រះនៃឯងជានិច្ចផង[ធ]។
៨ពួកឈ្មួញគេតើហ្ន៎ មានជញ្ជីងមិនត្រឹមត្រូវកាន់នៅ
ដៃ[ន] ក៏ចូលចិត្តនឹងការកោងបំបាត់ផង ៩អេប្រាអិមពោល
ថា[ប] អញបានត្រឡប់ជាអ្នកស្តុកស្តម្ភហើយ អញរកបាន
ទ្រព្យសម្បត្តយ៉ាងច្រើន[ផ] តែក្នុងការទាំងប៉ុន្មានរបស់អញ
នោះនឹងឥតមានអ្នកណាឃើញអំពើទុច្ចរិត ឬអំពើបាប
ណាឡើយ ១០ប៉ុន្តែអញនេះជាព្រះយេហូវ៉ា គឺជាព្រះនៃ
ឯង ចាប់តាំងពីនៅស្រុកអេស៊ីព្ទមក[ព] អញនឹងធ្វើឱ្យឯងបាន
នៅក្នុងបារាំ[ភ]ម្តងទៀត ដូចនៅគ្រាបុណ្យមុតមាំ ១១អញ
បាននិយាយដោយសារពួកហោរា ហើយបានចំរើនការ
ជាក់ស្តែងឡើង ក៏បានប្រើសេចក្ដីប្រៀបធៀប[ម] ដោយសារ

**១២:១** ក ហស ៤:២ ខ ចទ ៧:៩ គ ហស ១០:១៤ **១២:២** ឃ ទដ ៧៨:៦៧ ង លប ៤១:៦ អគ ១៧:១០ ច ហស ៤:១៩ ៧:១ ឆ ហស ៥:១៣ ៧:១១ ជ ២ពវ ១៧:៤ **១២:៣** ឈ យប ១០:២ មីក ៦:២ ញ អម ២:៤ ដ នក ៣២:៣៤ ឋ ហស ៤:៩ ៩:១៥ **១២:៤** ឌ លប ២៥:២៦ ឍ លប ៣២:២៤-២៩ **១២:៥** ណ លប ១២:៨ ៣៥:១៥ **១២:៦** ត នក ៣:១៥ **១២:៧** ថ អស ១៩:២២ យរ ៤:១ យអ ២:១២ ទ ទដ ១០៦:៣ យរ ២២:៣ ធ អគ ១៨:៣០ ហស ៦:១-៣ ១០:១២ មីក ៧:៧ **១២:៨** ន លវ ១៩:៣៦ អម ៨:៥ **១២:៩** ប អគ ២៨:៥ ផ ទដ ៦២:១០ វវ ៣:១៧ **១២:១០** ព លវ ២៣:៤៣ ហស ២:១៥ ១១:១ ភ នហ ៨:១៧ **១២:១១** ម ពច ១៤:១២ អគ ២០:៤៩ យ ២ពវ ១៧:១៣

**១២:១** *សេចក្ដីភូតភរ . . . សេចក្ដីឆបោក* មើល ១០:១៣ និងការពន្យល់ *យូដា* មើលសេចក្ដីផ្ដើមត្រង់ចំណុច អ្នកនិពន្ធ និងកាលបរិច្ឆេទ ។ *នៅតែមានអំណាចចំពោះព្រះ* មើល យរ ២:៣១ ។ *ព្រះដ៏បរិសុទ្ធ* មើល ខ.៩ និងការពន្យល់ ។

**១២:២** *អេប្រាអិម* មើលការពន្យល់ ៤:១៧ ។ *ខ្យល់* មើល ៨:៧ សស ១:១៤ ។ *ខ្យល់ពីទិសខាងកើត* មើល ១៣:១៥ យប ១៥:២ យរ ១៨:១៧ ។ ការដេញតាមខ្យល់គឺជានិមិត្តរូបនៃគោលនយោបាយក្រៅប្រទេសរបស់អ៊ីស្រាអែល ដែលម្តងឃ្លោងទៅខាងនគរអេស៊ីព្ទ(២ពវ ១៧:៤ អស ៣០:៦-៧) ហើយម្តងឃ្លោងទៅខាងចក្រភពអាសស៊ើរ (មើល ៥:១៣ ៧:១១ ៨:៩ និងការពន្យល់ ២ពវ ១៧:៣)។

**១២:៣** *មានរឿងនឹងយូដា* មើល ៤:១ និងការពន្យល់ ។ *យូដា* មើលការពន្យល់ត្រង់ចំនុចអ្នកនិពន្ធ និងកាលបរិច្ឆេទ ។ *យ៉ាកុប* គឺអ៊ីស្រាអែល(មើល ១០:១១)។ ព្រះអម្ចាស់ទ្រង់មានបន្ទូលអំពីនគរទាំងពីរ ដែលជាកូនចៅជំនាន់ក្រោយរបស់លោកឪពុកយ៉ាកុប ។ ប៉ុន្តែពួកគេបានខំរស់នៅដើម្បីភាពប្រសើររបស់នាមលោកយ៉ាកុប ដោយសេចក្ដីកុហកបោកប្រាសរបស់ពួកគេ ។

**១២:៤** *នៅក្នុងផ្ទៃ* មើល លប ២៥:២៦ ២៧:៣៦ និងការពន្យល់ ។ *ចាប់កែងជើងរបស់បង* នៅត្រង់ចំណុចនេះ រាស្ត្ររបស់ព្រះកំពុងឆ្លងកាត់បទពិសោធន៍របស់លោកឪពុកយ៉ាកុប ហើយត្រូវវិលត្រឡប់ទៅរកព្រះអម្ចាស់វិញ គឺដូចលោកយ៉ាកុបវិលត្រឡប់ទៅឯក្រុងបេត-អែលដែរ (លប ៣៥:១-១៥) ។

**១២:៥** *មានអំណាចលើទេវតា* មើល លប ៣២:២២-២៨ ។ *បេត-អែល* មើល លប ២៨:១២-១៩ ៣៥:១-១៥ ។ នៅក្នុងសម័យលោកហូសេ ក្រុបបេត-អែល គឺជាទីកន្លែងបរិសុទ្ធដែលសំខាន់ជាងគេបំផុតនៅក្នុងនគរខាងជើង(ធៀបនឹង អម ៧:១៣)។

**១២:៧** *សេចក្ដីសប្បុរស* មើល ៦:៦ និងការពន្យល់ ។ *សេចក្ដីយុត្តិធម៌* មើល អម ៥:២៤ មីក ៦:៨ និងការពន្យល់ ។

**១២:៨** *ពួកឈ្មួញ* នៅក្នុងខ.២ លោកហូសេបានលេងន័យពាក្យ របស់ឈ្មោះលោកយ៉ាកុប ហើយនៅក្នុងខនេះ លោកលោកន័យពាក្យឈ្មោះរបស់ទឹកដីកាណាន(ពាក្យ"ពួកឈ្មួញ" នៅក្នុងភាសាហេព្រើមានសម្លេងដូចពាក្យកាណាន) ដើម្បីបញ្ជាក់ថា ពួកអ៊ីស្រាអែលមិនល្អជាងពួកកាណានទេ(មើលការពន្យល់ សក ១៤:២១)។ *ជញ្ជីងមិនត្រឹមត្រូវ* មើល លវ ១៩:៣៥, សភ ១១:១ និងការពន្យល់ ។

**១២:៩** *អញបានត្រឡប់ជាអ្នកស្តុកស្តម្ភ* ដោយសារពួកគេមានស្តុកស្តម្ភ ដូចនេះពួកគេយកទ្រព្យសម្បត្តិជាទីអាង(ធៀបនឹង ១០:១៣ ចទ ៣២:១៥-១៨ លក ១២:១៩ វវ ៣:១៧)។ *ឥតមានអ្នកណាឃើញអំពើទុច្ចរិត ឬអំពើបាបណាឡើយ* ពួកអេប្រាអិម (អ៊ីស្រាអែល) ជឿជាក់ថា ភាពពុតត្បុត (មើល ១០:១៣ និងការពន្យល់) របស់ពួកគេនឹងត្រូវលាក់ជិត ដូចពួកឈ្មួញទុច្ចរិតដែរ ។

**១២:១០** *អញនេះជាព្រះយេហូវ៉ា* មើល ១៣:៤ នក ២០:២ និងពន្យល់ ។ *បារាំ* ត្រង់ចំណុចនេះ គឺជាការរំឭកអំពីការធ្វើដំណើរតាមវាលរហោស្ថានកាលពីយូរណាស់មកហើយ(ធៀបនឹង ២:១៤-១៥)។ *គ្រាបុណ្យមុតមាំ* ប្រហែលជាបុណ្យបារាំ (មើល លវ ២៣:៣៣-៤៣ និងការពន្យល់ ២៣:៤២) ដែលជាការរំឭកអំពីការធ្វើដំណើរតាមវាលរហោស្ថាន ។

**១២:១១** *និយាយដោយសារពួកហោរា* មើល ៦:៥, អម ២:១១ និងការពន្យល់, ហព ១:១ ។ មានការព្រមានជាច្រើនដងមកហើយ ។ *ការជាក់ស្តែង* គឺការបើកសំដែងឱ្យឃើញ(មើល ជន ១២:៦-៨ និងការពន្យល់, អម ១:១)។ *សេចក្ដីប្រៀបធៀប* គឺជាពាក្យដែលបង្កប់ព្រះបន្ទូលព្រមាន (មើល

ដៃនៃពួកហោរាដែរ[យ] ១២ឯស្រុកកាឡាតគេអាក្រក់ទទេ[រ] ក៏
សុទ្ធតែឥតប្រយោជន៍ទាំងអស់ នៅត្រង់គីលកាល[ល] គេ
ថ្វាយគោជាយញ្ញបូជា អស់ទាំងអាសនារបស់គេ ប្រៀប
ដូចជាដុំដី នៅក្នុងគន្លងស្រែចំការ[វ] ១៣ចំណែកឯយ៉ាកុប
លោកបានរត់ទៅដល់ស្រុកអើរ៉ាម[ស] អ៊ីស្រាអែលបានបំរើ
គេ ឱ្យបានប្រពន្ធ គឺបានធ្វើជាអ្នកគង្វាលឃ្វាលហ្វូងចៀម
ឱ្យបានប្រពន្ធនោះ[ហ] ១៤ហើយដោយសារហោរាម្នាក់នោះ
ព្រះយេហូវ៉ាទ្រង់បាននាំពួកអ៊ីស្រាអែល ឡើងចេញពីស្រុក
អេស៊ីព្ទ[ឡ] ព្រមទាំងការពារ ដោយសារហោរាដែរ[អ] ១៥តែ
អេប្រាអិមបានបណ្តាល ឱ្យមានសេចក្តីខ្ញាល់យ៉ាគ្រោត
គ្រាត ហេតុនោះឈាមរបស់គេ[ក] នឹងនៅជាប់លើខ្លួនគេ
ហើយព្រះអម្ចាស់ទ្រង់នឹងតបស្នងសេចក្តីដំនៀលរបស់គេ
ទៅលើគេវិញ[ខ] ។

## សេចក្តីក្រោធរបស់ព្រះអម្ចាស់ចំពោះពួកអ៊ីស្រាអែល

**១៣** ១ពីដើមអេប្រាអិមពោលឡើងកាលណា នោះ
មនុស្សក៏រន្ធត់ញាប់ញ័រ[ក] គេបានដំកើងខ្លួនឡើង[ខ] ក្នុងពួក
អ៊ីស្រាអែល តែកាលគេមានទោស ពីដំណើរព្រះបាល[គ]
នោះគេត្រូវស្លាប់វិញ ២ហើយឥឡូវនេះ គេធ្វើបាបរឹតតែ
ច្រើនឡើងជានិច្ច គេបានយកប្រាក់របស់គេសិតធ្វើ[យ]ជា
រូប[ង] គឺជារូបព្រះតាមយោបល់របស់ខ្លួន សុទ្ធតែជាស្នាដៃ
នៃពួកជាង[ច] ហើយគេប្រកាសពីរូបទាំងនោះថា ចូរឱ្យអស់
អ្នកដែលថ្វាយយញ្ញបូជា មកថើប[ឆ]រូបកូនគោនេះចុះ[ជ]
៣ហេតុដូច្នោះគេនឹងបានដូចជាពពកនៅពេលព្រលឹម
ហើយដូចជាទឹកសន្សើមដែលសូន្យបាត់យ៉ាងបន្ទាន់[ឈ] គឺដូច
ជាអង្កាម[ញ] ដែលខ្យល់កួចផាត់ចេញពីលានស្រូវ[ដ] ហើយដូច
ជាផ្សែង[ឋ] ដែលហុយចេញពីជើងក្រាន ។
៤ទោះបើយ៉ាងនោះក៏ដោយ គង់តែអញ គឺព្រះយេហូវ៉ា
អញ ជាព្រះនៃឯង ចាប់តាំងពីស្រុកអេស៊ីព្ទមកហើយ[ឌ] មិន
ត្រូវឱ្យឯងស្គាល់[ឍ]ព្រះឯណាទៀត ក្រៅពីអញឡើយ[ណ] ក្រៅ
ពីអញគ្មានព្រះអង្គសង្គ្រោះ[ត]ណាមួយសោះ ៥អញបាន

**១២:១១** យ យរ ៧:២៥
**១២:១២** រ ហស ៦:៨ ល ហស ៤:១៥ វ ហស ៨:១១
**១២:១៣** ស លប ២៨:៥ ហ លប ២៩:១៨
**១២:១៤** ក អគ ១៨:១៣ ខ ដយ ១១:១៨
**១៣:១** ក ពច ១២:១ ខ ពច ៨:១ គ ហស ១១:២
**១៣:២** យ យរ ៤៤:៨ ង អស ៤៦:៦ យរ ១០:៤ ច ហស ១៤:៣ ឆ ១ពវ ១៩:១៨ ជ អស ៤៤:១៧–២០ ហស ៨:៤
**១៣:៣** ឈ ហស ៦:៤ ញ យប ១៣:២៥ ទដ ១:៤ អស ១៧:១៣ ដ ដយ ២:៣៥ ឋ ទដ ៦៨:២
**១៣:៤** ឌ យរ ២:៦ ហស ១២:៩ ឍ ហស ២:២០ ណ នក ២០:៣ ត ចទ ២៨:២៩ ទដ ១៨:៤៦ អស ៤៣:១១ ៤៥:២១–២២

២សយ ១២:១–៤ ទដ ៧៨:២ អស ៥:១–៧ អគ ១៧:២ ២៤:៣) ។

**១២:១២** *ស្រុកកាឡាតគេអាក្រក់* មើល ៦:៨–៩ និងការពន្យល់ ។ ស្រុកកាឡាតត្រូវចក្រភពអាសស៊ើរវាយកាន់កាប់ពីឆ្នាំ ៧៣៤ ដល់ ៧៣២ មុន គ.ស(២ពវ ១៥:២៩) ។ *គីលកាល* មើល ៤:១៥ និងការពន្យល់ ។ អាសនារបស់ពួកគេនឹងមិនអាចផ្តល់ឱ្យពួកគេនូវភាពសុខសាន្តទេ ហើយអាសនានោះនឹងត្រូវបំផ្លាញ ។ *នៅក្នុងគន្លងស្រែចំការ* នៅត្រង់ចំណុចនេះ ពួកអ៊ីស្រាអែលដែលជាអ្នកស្រែប្រមូលជាគំនរនូវដុំថ្ម ដែលមាននៅក្នុងស្រែ ។

**១២:១៣** លោកយ៉ាកុបរត់គេចពីលោកអេសាវទៅដល់ស្រុកអ៊ើរ៉ាម(លប ២៨:២,៥) បានបម្រើលោកឡាបានអស់រយៈពេលប្រាំឆ្នាំសម្រាប់ប្រពន្ធនីមួយៗ(លប ២៩:២០–២៨) ហើយបន្តបម្រើប្រាំមួយឆ្នាំទៀតជាអ្នកគង្វាលរបស់លោកឡាបាន(លប ៣០:៣១ ៣១:៤១) ។

**១២:១៤** *ហោរា* គឺលោកម៉ូសេ(ធៀបនឹង ជន ១២:៦–៨ ចទ ១៨:១៥ ៣៤:១០)។ *ការពារ* ព្រះអម្ចាស់ទ្រង់ការពារពួកអ៊ីស្រាអែលនៅពេលដែលពួកគេរិលវល់នៅក្នុងវាលរហោស្ថាន ហើយលោកយ៉ាកុបមើលថែរហ្វូងសត្វរបស់លោកឡាបាន ។ ការដឹកនាំរបស់លោកម៉ូសេនៅសម័យមុន មានលក្ខណៈផ្ទុយពីការបដិសេធរបស់ពួកអ៊ីស្រាអែល ចំពោះពួកហោរានៅក្នុងសម័យលោកហូសេ(ធៀបនឹង ៤:៥ ៦:៥ ៩:៧) ។

**១២:១៥** *អេប្រាអឹមបានបណ្តាល* នៅត្រង់ចំណុចនេះ ពួកគេនៅតែបណ្តាលឱ្យទ្រង់ខ្ញាល់ ទោះបីជាទ្រង់បានព្រមានពួកគេហើយក៏ដោយ ។ *ឈាមរបស់គេ* ធៀបនឹង ១:៤ ៤:២ ៥:២ ៦:៨ ។ នៅត្រង់ចំណុចនេះគឺសំដៅទៅលើអំពើហិង្សាដែលពួកគេប្រព្រឹត្តចំពោះអ្នកដទៃ ដែលរួមមានការធ្វើយញ្ញបូជាមនុស្សផងដែរ (មើល ១៣:២ និងការពន្យល់) ។ នៅក្នុងបទគម្ពីរក្រឹត្យវិន័យដែលនិយាយអំពីទោសកំហុស ដូចនៅក្នុង លវ ២០:១១–២៧ "ឈាមរបស់គេនឹងធ្លាក់មកលើខ្លួនគេវិញ"។ លោកហោរាហូសេបានបង្ហាញអំពីភាពខុសគ្នារវាងការការពាររបស់ព្រះកាលពីមុន និងសេចក្តីក្រោធដែលទ្រង់មាននៅក្នុងពេលបច្ចុប្បន្ន ដែលនឹងនាំមកនូវការជំនុំជម្រះ ។ *តបស្នង* មើល អស ៦៥:៧ ។

**១៣:១** *អេប្រាអឹមពោលឡើង* គឺនិយាយតាមពរដែលលោកយ៉ាកុបឱ្យ (លប ៤៨:១០–២០) ពួកអេប្រាអិមបានក្លាយជាពូជអំបូរដែលមានអំណាច (ពច ៨:១–៣ ១២:១–៦ ១សយ ១:១–៤) ហើយមានអ្នកដឹកនាំខ្លាំងពូកែដែលកើតចេញពីពូជអំបូរនេះ ដូចជាលោកយ៉ូស្វេ (ជន ១៣:៨,១៦ យស ២៤:២៩–៣០) និងយេរ៉ូបោមទីមួយ(១ពវ ១១:២៦ ១២:២០) ។ *អេប្រាអឹម* មើលការពន្យល់ ៤:១៧ ។ *ពួកអ៊ីស្រាអែល* គឺសំដៅទៅលើពូជអំបូរទាំង ១២ ។ *ត្រូវស្លាប់* ឈ្នួលនៃអំពើបាបគឺសេចក្តីស្លាប់ (ធៀបនឹង រម ៦:២៣) ហើយជាតិសាសន៍នេះត្រូវនៅជៀកនឹងទីបញ្ចប់ ។

**១៣:២** *រូប* មើល ៤:១២ ៨:៥–៦ និងការពន្យល់, ១១:២ ។ *យញ្ញបូជា* មើល លវ ១៨:២១ ២ពវ ១៦:១៣ ១៧:១៧ ២៣:១០ យរ ៧:៣១ និងការពន្យល់, អគ ២០:២៦ មីក ៦:៧ និងការពន្យល់ ១ពវ ១២:២៦–៣៣ ។ *ថើប* គឺដើម្បីបង្ហាញអំពីការថ្វាយបង្គំជាសាធារណៈ (មើល ទដ ២:១២ និងការពន្យល់)។ *រូបកូនគោ* មើល ៨:៥ និងការពន្យល់, ១០:៥ ។

**១៣:៣** ពួកអេប្រាអឹមគឺប្រៀបបាននឹង "ពពក" និង "ទឹកសន្សើម"(មើល ៦:៤) "ចំបើង"(មើល ទដ ១:៤ និងការពន្យល់, ៣៥:៥ អស ១៧:១៣ ២៩:៥ សផ ២:២) និង "ផ្សែង"(មើល ទដ ៣៧:២០ ៦៨:២ អស ៥១:៦) ដែលជាតិសាសន៍របស់គេនឹងត្រូវវិនាសទៅក្នុងពេលដ៏ខ្លី ។

**១៣:៤** *អញជាព្រះនៃឯង* មើល ១២:៩ នក ២០:២ និងការពន្យល់ ។ ព្រះបន្ទូលទ្រង់នៅត្រង់ចំណុចនេះគឺផ្ទុយនឹងការប្រកាសរបស់ស្តេចរេហូបោម ដែលថា "មើល នេះនៃ ព្រះរបស់ឯង"(១ពវ ១២:២៨)។ *ស្គាល់ព្រះ* មើល ២:២០ ៦:៣ និងការពន្យល់ ។

ស្គាល់ឯង កាលនៅទីរហោស្ថាន[ថ] គឺនៅទីហួតហែង ៦ឯង
បានឆ្អែត តាមសណ្ឋាននៃទីឃ្វាលរបស់ឯង លុះបានឆ្អែត
ហើយ នោះឯងកើតមានចិត្តប៉ោងឡើង[ទ] គឺហេតុនោះ
បានជាឯងភ្លេច[ធ]អញទៅ[ន] ៧ដូច្នេះ អញដូចជាសិង្ហដល់ឯង[ប]
អញនឹងលបចាំតាមផ្លូវដូចជាខ្លារខិន ៨អញនឹងសង្គ្រុប
ចូលទៅលើឯង ដូចជាខ្លាឃ្មុំដែលត្រូវព្រាត់ពីកូន[ផ] គឺអញ
នឹងហែកស្រោមបេះដូងឯងចេញ នៅទីនោះនឹងត្របាក់ស៊ី
ឯងទៅ ដូចជាសិង្ហញី[ព] ឯសត្វព្រៃនឹងហែកឯងដែរ[ភ]។
៩ឱអ៊ីស្រាអែលអើយ សេចក្ដីដែលនាំឱ្យឯងត្រូវវិនាស នោះ
គឺជាដំណើរដែលទាស់ទទឹងនឹងអញ[ម] គឺទាស់នឹងអ្នកដែល
ជួយសង្គ្រោះឯង[យ] ១០ឥឡូវនេះ ស្ដេចឯងនៅឯណា[រ] ដើម្បី
ឱ្យគេបានជួយសង្គ្រោះឯង នៅគ្រប់ទាំងទីក្រុងរបស់ឯង
ផង និងពួកចៅក្រមរបស់ឯង ដែលឯងបានសូមគេថា
សូមឱ្យយើងមានស្ដេច និងពួកចៅហ្វាយចុះ[ល] ១១អញបាន
ឱ្យឯងមានស្ដេច[វ] ដោយសេចក្ដីកំហឹងរបស់អញ ក៏បាន
ដកស្ដេចនោះចេញ[ស] ដោយសេចក្ដីក្រោធរបស់អញដែរ
១២សេចក្ដីទុច្ចរិតរបស់អេប្រាអិមបានខ្ចប់ទុក ហើយឯអំពើ
បាបរបស់គេក៏បានសន្សំទុកដែរ[ហ] ១៣គេនឹងកើតមាន
សេចក្ដីឈឺចាប់ ដូចជាស្រីកំពុងឈឺនឹងសំរាលកូន[ឡ] គេជា
កូនដែលអាប់ឥតប្រាជ្ញា ដ្បិតដល់កំណត់ហើយ[អ] នោះមិនគួរ
ឱ្យនៅជាយូរក្នុងទីសំរាលកូនឡើយ[ក] ១៤អញនឹងដោះគេឱ្យ
រួចពីកណ្ដាប់ដៃនៃស្ថានឃុំព្រលឹងមនុស្ស ស្លាប់[ខ]ក៏នឹងលោះ
គេ ឱ្យរួចពីសេចក្ដីស្លាប់ដែរ[គ] សេចក្ដីស្លាប់អើយ ទុក្ខវេទនា
របស់ឯងនៅឯណា ឱស្ថានឃុំព្រលឹងមនុស្សស្លាប់អើយ
អំណាចបំផ្លាញរបស់ឯង[ឃ]តើនៅឯណា ឯសេចក្ដីឈឺចិត្ត
ខ្មាសបាប នឹងបានកំបាំងពីភ្នែកអញ ។
១៥ទោះបើគេកើតផលជាបរិបូរ[ង] នៅក្នុងពួកបងប្អូន
ក៏ដោយគង់តែនឹងមានខ្យល់[ច]ពីទិសខាងកើតបក់មក គឺជា
ខ្យល់នៃព្រះយេហូវ៉ា ដែលបក់មកពីទីរហោស្ថានដែរនោះ
ក្បាលទឹកគេនឹងរីងស្ងួត[ឆ] ហើយរន្ធទឹករបស់គេនឹងហួត
ហែងទៅ ខ្យល់នោះនឹងធ្វើ[ជ]ទ្រព្យសម្បត្តិសម្បត្តិ ជាភាជនៈ
ដ៏មានដំឡៃគ្រប់មុខបានទៅជាបរបឹបទាំងអស់ ១៦ឯសាម៉ា–
រី[ឈ]នឹងត្រូវរងទ្រាំទោសរបស់ខ្លួន[ញ]ពីព្រោះបានបះបោរ[ដ]

**១៣:៥** ថ ចទ ១:១៩ **១៣:៦** ទ អក ២៨:៥ ធ ចទ ៣២:១៨ អស ១៧:១០ ន ចទ ៣២:១២–១៥ សភ ៣០:៧–៩ យរ ៥:៧ ហស ២:១៣ ៤:៧ **១៣:៧** ប យប ១០:១៦ យរ ៤:៧ **១៣:៨** ផ ២សយ ១៧:៨ ព ២សយ ១៧:៣៤ ទដ ១៧:១២ ភ ទដ ៥០:២២ បទ ៣:១០ ហស ២:១២ **១៣:៩** ម យរ ២:១៧–១៩ យ ចទ ៣៣:២៩ **១៣:១០** រ ២ពរ ១៧:៤ ហស ៧:៧ ល ១សយ ៨:៦ ហស ៨:៤ **១៣:១១** វ ជន ១១:២០ ស យស ២៤:២០ ១សយ ១៣:១៤ ១ពរ ១៤:១០ ហស ៣:៤ ១០:៧ **១៣:១២** ហ ចទ ៣២:៣៤ **១៣:១៣** ឡ អស ១៣:៨ មីក ៤:៩–១០ អ ២ពរ ១៩:៣ ក អស ៦៦:៩ **១៣:១៤** ខ ទដ ១៦:១០ ៤៩:១៥ អគ ៣៧:១២–១៣ គ អស ២៥:៨ ឃ ១កថ ១៥:៥៥ **១៣:១៥** ង ហស ១០:១ ច យប ១:១៩ អគ ១៩:១២ ហស ៤:១៩ ឆ យរ ៥១:៣៦ ជ យរ ២០:៥ **១៣:១៦** ឈ ២ពរ ១៧:៥ ញ ហស ១០:២ ដ ហស ៧:១៤

**១៣:៥** *ទីរហោស្ថាន* មើល ២:១៤ ៩:១០ និងការពន្យល់ ។
**១៣:៦** *ឆ្អែត* មើល ចទ ៦:១១–១២ ៨:១០–១៤ ១១:១៥ ។ *ភ្លេចអញ* មើល ២:១៣ ចទ ៦:១០–១២ និងការពន្យល់, ៨:១១,១៤,១៩ ៣២:១៨ ។
**១៣:៧–៨** នៅក្នុងវគ្គមុន ព្រះអម្ចាស់ទ្រង់ជាអ្នកគង្វាល(៤:១៦) ប៉ុន្តែក្នុងវគ្គនេះទ្រង់នឹងធ្វើការវាយប្រហារដូចជាសត្វសិង្ហ ដែលហែកហួរហ្វូងសត្វ ។
**១៣:៧** *សិង្ហ* មើល ៥:១៤ និងការពន្យល់ ។ *ខ្លារខិន* មើល យរ ៥:៦ វវ ១៣:២ ។
**១៣:៨** *ខ្លាឃ្មុំដែលត្រូវព្រាត់ពីកូន* មើល ២សយ ១៧:៨ សភ ១៧:១២ និងការពន្យល់ ។
**១៣:៩** *អ្នកជួយសង្គ្រោះ* មើល ទដ ១០:១៤ ៣០:១០ ៥៤:៤ ។
**១៣:១០** *ស្ដេចឯងនៅឯណា . . .* ត្រង់ចំណុចនេះគឺមានន័យថា ជំនួយគឺមកអំពីព្រះអម្ចាស់(ទដ ១២១:២) មិនមែនមកពីស្ដេចទេ ។ លោកហូសេហាក់ដូចជានិយាយពន្លយពាក្យអំពីការធ្វើឃាតនៅក្នុងរាជវង្ស នៅក្នុងសម័យរបស់គាត់(មើល ៧:៧ ៨:៤ និងការពន្យល់) ។ *សូមឱ្យយើងមានស្ដេច* នៅក្នុងសម័យលោកសាំយូអែល ពួកអ៊ីស្រាអែលទាំងអស់បាននាំគ្នាសូមឱ្យមានស្ដេចគ្រប់គ្រងពួកគេ(មើល ១សយ ៨:៥ និងការពន្យល់) ប៉ុន្តែ នៅក្នុងខនេះ ពួកគេសូមឱ្យមានស្ដេចគ្រប់គ្រងតែនៅក្នុងនគរខាងជើងប៉ុណ្ណោះ ។ ពួកអ៊ីស្រាអែលបានជ្រើសរើសយេរ៉ូបោមទីមួយ តាមការនិយមជ្រើសរើសអ្នកស្នងរាជ្យក្នុងត្រកូលស្ដេចដាវីឌ ។
**១៣:១១** នៅក្នុងខនេះគឺនិយាយសំដៅទៅលើពួកស្ដេចនៃនគរខាងជើងរបស់អ៊ីស្រាអែល ។
**១៣:១២** មើល ៩:៩ និងការពន្យល់, យប ១៤:១៧ ។ *អំពើបាបរបស់គេក៏បានសន្សំទុក* មើល ៧:២ និងការពន្យល់, ចទ ៣២:៣៤ ។
**១៣:១៣** *សេចក្ដីឈឺចាប់ ដូចជាស្រីកំពុងឈឺនឹងសំរាល* ស្ថានភាពអស់សង្ឃឹមរបស់ពួកគេ គឺប្រៀបបានទៅនឹងស្ថានភាពសម្រាលកូនរបស់ស្ត្រី (មើល អស ១៣:៨ និងការពន្យល់, ២១:៣ មីក ៤:៩–១០ មថ ២៤:៨) ដែលបង្កើតកូនមិនរួច(មើល ២ពរ ១៩:៣) ហើយត្រូវបាត់បង់ជីវិតនៅក្នុងស្ថានភាពនោះ ។
**១៣:១៤** *អញនឹងដោះគេ* គឺជាសេចក្ដីសន្យាថា នឹងលោះពីសេចក្ដីស្លាប់ ។ *ឱសេចក្ដីស្លាប់អើយ . . . នៅឯណា* នៅត្រង់ចំណុចនេះ គឺសំដៅទៅលើការស្លាប់របស់ជាតិសាសន៍មួយ(មើលការពន្យល់ ខ.១)។ លោកសាវ័កប៉ុលបានប្រើបទគម្ពីរនេះ នៅក្នុងសេចក្ដីបង្រៀនអំពីការរស់ឡើងវិញ(១កថ ១៥:៥៥)។ *ស្ថានឃុំព្រលឹងមនុស្សស្លាប់* មើល យប ៣:១៣–១៩ អស ១៤:៩–១០, មើលការពន្យល់ លប ៣៧:៣៥ ។
**១៣:១៥** *កើតផលជាបរិបូរ* គឺជាការលេងពាក្យចំពោះអត្ថន័យរបស់ពាក្យអេប្រាអិមដែលមានន័យថា "កើតផលជាបរិបូរ"។ ខ្យល់ពីទិសខាងកើតដែលនាំមកនូវភាពរាំងស្ងួត(មើល ១២:១ លប ៤១:៧ និងការពន្យល់, យប ១:១៩ អស ២៧:៨ យរ ៤:១១ ១៣:២៤ ១៨:១៧) គឺជាពាក្យប្រៀបប្រដូចទៅនឹងចក្រភពអាសស៊ើរ ដែលជាឧបករណ៍របស់ព្រះអម្ចាស់(មើល អស ១០:៥ និងការពន្យល់)។ ចក្រភពអាសស៊ើរបានធ្វើការឈ្លានពាននគរខាងជើងនៅឆ្នាំ ៧៣៤ មុនគ.ស បន្ទាប់មក បានបំផ្លាញ ហើយនិរទេសប្រជាជនក្នុងនគរនោះនៅឆ្នាំ ៧២២–៧២១ មុនគ.ស ។ *ទ្រព្យសម្បត្តិ* ណាហ ២:៩ ។

នឹងព្រះនៃខ្លួនគេនឹងដួលស្លាប់ដោយដាវ[ឋ]កូនខ្ចីរបស់គេនឹង
ត្រូវបោកខ្ទេចខ្ទី[ឌ] ហើយពួកស្រីៗ[ឍ]ដែលមានទំងន់នឹងត្រូវ
វះពោះចោល ។

## ការប្រែចិត្តដែលនាំមកនូវព្រះពរ

**១៤** ១ឱអ៊ីស្រាអែលអើយ ចូរវិលមក[ក]ឯព្រះយេហូវ៉ា
ជាព្រះនៃឯងវិញចុះ ដ្បិតឯងបានភ្លាត់ដួលទៅ[ខ] ដោយអំពើ
ទុច្ចរិតរបស់ឯង[គ] ២ចូរប្រុងប្រៀងពាក្យសំដី ហើយវិលមក
ឯព្រះយេហូវ៉ាចុះ ត្រូវឱ្យទូលដល់ទ្រង់ថា សូមលើក[ឃ]អស់
ទាំងអំពើទុច្ចរិតចោលចេញ ហើយទទួលយើងខ្ញុំដោយ
ព្រះគុណ[ង] យ៉ាងនោះយើងខ្ញុំនឹងថ្វាយដង្វាយនៃបបូរមាត់
យើងខ្ញុំ ជំនួសគោឈ្មោលដែលសំរាប់យញ្ញបូជា[ច] ៣ស្រុក
អាសស៊ើរនឹងជួយសង្គ្រោះយើងខ្ញុំមិនបាន[ឆ] យើងខ្ញុំមិន
ព្រមជិះសេះទេ[ជ] ក៏មិនពោលដល់ស្នាដៃរបស់យើងខ្ញុំទៀត
ថា[ឈ] លោកជាព្រះនៃខ្ញុំដែរ[ញ] ដ្បិតនៅក្នុងទ្រង់ ទើបពួកកូន
កំព្រា[ដ]រកបានសេចក្ដីមេត្តាករុណាវិញ ។
៤អញនឹងកែ[ឋ]ការរាថយរបស់គេឱ្យជា[ឌ] ហើយអញនឹង
ស្រឡាញ់គេស្ម័គ្រពីចិត្ត[ឍ] ដ្បិតសេចក្ដីកំហឹងរបស់អញបាន
បែរចេញ[ណ]ពីគេហើយ ៥អញនឹងបានដូចជាទឹកសន្សើម[ត]
ដល់អ៊ីស្រាអែល គេនឹងផ្កាឡើងដូចជាផ្កាច័ន្ទ[ថ] ហើយចាក់
ឫស[ទ]ទៅ ដូចជាព្រៃល្បាណូ[ធ] ៦មែកគេនឹងត្រសាយចេញ
ទៅ ឯលំអរបស់គេ នឹងបានដូចជាដើមអូលីវ[ន] ហើយនឹង
មានក្លិនដូចជាព្រៃល្បាណូន[ប] ៧ពួកអ្នកដែលធ្លាប់នៅក្រោម
ម្លប់[ផ] គេនឹងវិលមកវិញ ហើយនឹងលាស់ឡើងថ្មី[ព]ដូចជា
សំទូង ព្រមទាំងចេញផ្កា ដូចជាដើមទំពាំងបាយជូរ[ភ]ដែល
មានក្លិន ដូចជាស្រាទំពាំងបាយជូរ មកពីភ្នំល្បាណូន[ម]
៨អេប្រាអិមនឹងពោលថា តើខ្ញុំត្រូវការអ្វីចំពោះរូបព្រះទៀត
នោះ[យ] អញបានតបឆ្លើយហើយនឹងត្រួតត្រាមើលគេ អញ
ប្រៀបដូចជាដើមកោះ[រ]ខៀវខ្ចី ឯងនឹងរកបានផលរបស់
ឯងពីអញ ។
៩តើមានអ្នកណា ដែលមានប្រាជ្ញា[ល] ឱ្យយល់សេចក្ដីទាំង
នេះបាន ឬមានគំនិតវាងវៃឱ្យបានស្គាល់សេចក្ដីទាំងនេះ
ផង[វ] ដ្បិតអស់ទាំងផ្លូវរបស់ព្រះយេហូវ៉ាសុទ្ធតែទៀងត្រង់[ស]
ពួកអ្នកសុចរិតនឹងដើរ[ហ]ក្នុងផ្លូវទាំងនោះ តែមនុស្សទុច្ចរិត
នឹងចំពប់ដួលក្នុងផ្លូវនោះវិញ ។/

**១៣:១៦** ឋ ហស ១១:៦ ឌ ២ពវ ៨:១២ ហស ១០:១៤ ឍ ២ពវ ១៥:១៦ អស ១៣:១៦ អម ១:១៣ **១៤:១** ក អស ១៩:២២ យរ ៣:១២ ខ ហស ៥:៥ ៩:៧ គ ហស ៤:៨ **១៤:២** ឃ នក ៣៤:៩ ង ទដ ៥១:១៦–១៧ មីក ៧:១៨–១៩ ច ហព ១៣:១៥ **១៤:៣** ឆ ហស ៥:១៣ ជ ទដ ៣៣:១៧ អស ៣១:១ មីក ៥:១០ ឈ ខ.២៨ ហស ១៣:២ ញ ហស ៨:៦ ដ ទដ ១០:១៤ ៦៨:៥ យរ ៤៩:១១ **១៤:៤** ឋ អស ៣០:២៦ ហស ៦:១ ឌ យរ ២:១៩ ឍ អស ៥៥:១ យរ ៣១:២០ សផ ៣:១៧ ណ យប ១៣:១៦ **១៤:៥** ត លប ២៧:២៨ អស ១៨:៤ ថ បស ២:១ ទ យប ២៩:១៩ ធ អស ៣៥:២ **១៤:៦** ន ទដ ៥២:៨ យរ ១១:១៦ ប ទដ ៩២:១២ បស ៤:១១ **១៤:៧** ផ ទដ ៩១:១–៤ ព លប ៤០:១០ ភ ហស ២:២២ ម អគ ១៧:២៣ **១៤:៨** យ ខ.៣ រ អស ៣៧:២៤ **១៤:៩** ល ទដ ១០៧:៤៣ វ សភ ១០:២៩ អស ១:២៨ ដយ ១២:១០ ស ទដ ១១១:៧–៨ សផ ៣:៥ កច ១៣:១០ ហ អស ២៦:៧

**១៣:១៦** *សាម៉ារី* មើល ៧:១ និងការពន្យល់, ៨:៥–៦ ១០:៥,៧ នៅក្នុងខនេះ ទីក្រុងសាម៉ារីគឺសំដៅទៅលើនគរខាងជើង ។ *បះបោរនឹង* មើល ទដ ៥:១០ អស ១:២ និងការពន្យល់, អគ ២០:៨,១៣,២១ ។ *កូនខ្ចី . . . ពួកស្រីៗ* ចំពោះអំពើព្រៃផ្សៃមកលើស្ត្រី និងកុមារ មើល ១០:១៤ ទដ ១៣៧:៩ និងការពន្យល់ ។

**១៤:១** *វិលមក* ពាក្យនេះគឺជាការប្រកាសមួយទៀត ឱ្យប្រែចិត្ត(មើល ១០:១២ ១២:៦)។ ការប្រែចិត្តនេះគឺត្រូវធ្វើឡើងដោយចិត្តស្មោះត្រង់ ដើម្បីឱ្យពួកគេអាចទទួលនូវការឆ្លើយតបតាមព្រះគុណរបស់ទ្រង់ ដែលមាននៅក្នុងសេចក្ដីសន្យានៅក្នុង ខ.៤–៨ (ធៀបនឹង ទដ ១៣០:៧–៨ អស ៥៥:៦–៧) ។

**១៤:២** *ប្រុងប្រៀបពាក្យសំដី* គ្មាននរណាម្នាក់អាចចូលមកចំពោះអម្ចាស់ដោយដៃទទេឡើយ(នក ២៣:១៥ ៣៤:២០) ប៉ុន្តែ ការថ្វាយយញ្ញបូជាសត្វនឹងមិនមានលក្ខណៈគ្រប់គ្រាន់ឡើយ គឺមានតែពាក្យលន់តួបាបដ៏ពិតប៉ុណ្ណោះដែលមានលក្ខណៈគ្រប់គ្រាន់ ។ *ដង្វាយនៃបបូរមាត់* គឺជាដង្វាយអរព្រះគុណដល់ព្រះអម្ចាស់(មើល ហព ១៣:១៥)។

**១៤:៣** *ស្នាដៃរបស់យើងខ្ញុំ* គឺសំដៅទៅលើរូបព្រះ(មើល ខ.៨ ១៣:២ និងការពន្យល់)។ *ពួកកូនកំព្រា* គឺសំដៅទៅលើសាសន៍អ៊ីស្រាអែលដែលបានប្រែចិត្តហើយ(មើល ទដ ១០:១៤ ៦៨:៥ បទ ៥:៣)។ *សេចក្ដីមេត្តាករុណា* ធៀបនឹងឈ្មោះក្មេង "ឡូ–រូហាម៉ា" (មើល ១:៦ និងការពន្យល់, ២:១, ២៣) ។

**១៤:៤** *កែ . . . ឱ្យជា* មើល ១១:៣ និងការពន្យល់ ។ *ការរាថាយ* មើល ១១:៧ ។ *ស្រឡាញ់គេស្ម័គ្រពីចិត្ត* ធៀបនឹង ៩:១៥ និងការពន្យល់ ។ *ស្រឡាញ់* មើល ៣:១ ១១:១ និងការពន្យល់ ។ *សេចក្ដីកំហឹង . . . បែរចេញ* គឺខុសពីកំហឹងឆាបឆេះដែលនាំមកនូវសេចក្ដីហិនវិនាស(មើល ៨:៥)។

**១៤:៥** *ទឹកសន្សើម* នៅត្រង់ចំណុចនេះគឺមិនសំដៅទៅលើភាពមិនស្ថិតស្ថេរនោះទេ(ធៀបនឹង ៦:៤ ១៣:៣) ប៉ុន្តែ គឺសំដៅទៅលើព្រះពររបស់ព្រះ (មើល ចទ ៣៣:១៣ មីក ៥:៧ និងការពន្យល់)។ *ព្រៃល្បាណូន* មើលការពន្យល់ ពច ៩:១៥ ១ពវ ៥:៦ អស ៩:១០ ។ *ព្រៃ* មើល ទដ ៨០:៨–១១ ។ *ល្បាណូន* មើល ទដ ១០៤:១៦–១៨ និងការពន្យល់ ។

**១៤:៧** *ម្លប់* គឺការការពារ (មើល ពច ៩:១៥ និងការពន្យល់ បស ២:៣ អគ ៣១:៦)។ *ដើមទំពាំងបាយជូ* មើល ១០:១ ទដ ៨០:៨–១៦ និងការពន្យល់ ។

**១៤:៨** *អេប្រាអិម* មើលការពន្យល់ ៤:១៧ ។ *ដើម* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានតែនៅក្នុងខនេះប៉ុណ្ណោះ ដែលព្រះអម្ចាស់ទ្រង់ប្រៀបធៀបពួកអេប្រាអិមទៅនឹងដើមឈើ ។ មើល អគ ៣១:៣–៧ ដយ ៤:១២ ។ *ផល* ពួកអេប្រាអិម(មានន័យថា "មានផលផ្លែ" មើល លប ៤១:៥២ និងការពន្យល់) ទទួលផលផ្លែរបស់ពួកគេពីព្រះអម្ចាស់(ធៀបនឹង ២:៨)។

**១៤:៩** *ផ្លូវរបស់ព្រះយេហូវ៉ា* មើល ទដ ១៨:២១ ២៥:៤ និងការពន្យល់ ។ នៅចុងបញ្ចប់នេះ លោកហូសេបានផ្ដល់ឱ្យអ្នកអាននូវជម្រើសពីរគឺ ការដើរ ឬជំពប់ដួល(ធៀបនឹង ៤:៥ ៥:៥) មានន័យថា ត្រូវជ្រើសរើស ការស្ដាប់បង្គាប់ ឬការបះបោរ ។

# ព្រះគម្ពីរយ៉ូអែល

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានមនុស្ស១២នាក់ដែលមានឈ្មោះយ៉ូអែលដែរ ប៉ុន្តែ ពួកគេមិនអាចជាលោកយ៉ូអែលទេ ។ មានតែព្រះគម្ពីរយ៉ូអែល និងកិច្ចការ ទេ ដែលបាននិយាយបញ្ជាក់អំពីលោកហោរាយ៉ូអែល (កថ ២:១៦) ។ មានរឿងព្រេងដែលនិយាយអំពីលោកយ៉ូអែល ប៉ុន្តែមិនមែនជារឿងនៅក្នុងព្រះគម្ពីរដែលអាចជឿទុកចិត្តបាននោះទេ ។ ឪពុករបស់លោកយ៉ូអែល គឺលោកពេធូអែល (១:១) ហើយគេមិនស្គាល់ថាគាត់ជានរណាទេ ។ ដោយសារលោកយ៉ូអែលនិយាយផ្ដោតទៅលើស្រុកយូដា និងទីក្រុងយេរូសាឡិម (មើល ២:៣២ ៣:១,៦,៨,១៦-២០) ដូចនេះ លោកយ៉ូអែលទំនងជារស់នៅក្នុងតំបន់នោះដែរ ។ មើលការពន្យល់ ១:១ ។

### កាលបរិច្ឆេទ

ព្រះគម្ពីរនេះមិនបានប្រាប់អំពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទេ ។ មានអ្នកកាត់ស្រាយជាច្រើនបានកំណត់កាលបរិច្ឆេទនៃព្រះគម្ពីរនេះថា នៅចន្លោះសតវត្សរ៍ទី៧ និងដើមសតវត្សរ៍ទី៥នៃគ្រីស្ទសករាជ ។ ទោះជាយ៉ាងណាក៏ដោយបញ្ហាកាលបរិច្ឆេទមិនមានអ្វីប៉ះពាល់ដល់ពាក្យដែលគាត់ត្រូវសរសេរនោះឡើយ ។

ព្រះគម្ពីរយ៉ូអែលមានលក្ខណៈអក្សរសាស្ត្រស្របគ្នានឹងព្រះគម្ពីរអេម៉ុស មីកា សេផានា យេរេមា និងអេសេគាល ។ អ្នកខ្លះបានអះអាងថា ពួកហោរាបានខ្ចីពាក្យពីគ្នាទៅវិញទៅមក អ្នកខ្លះទៀតជឿថា ពួកហោរាបាននិយាយតាមប្រពៃណីនៃការប្រើអក្សរសាស្ត្រនៅក្នុងជំនឿរបស់ខ្លួន និងជំនឿរបស់អ្នកអាន ។

### ព្រះរាជសារខាងវិជ្ជាអំពីព្រះ

លោកយ៉ូអែលបានមើលឃើញអំពីសេចក្ដីវេទនាដែលកើតឡើងពីហ្វូងកណ្ដូបដ៏ច្រើនមហិមា និងគ្រោះរាំងស្ងួត ដែលបានបំផ្លាញស្រុកយូដា ដែលជាសញ្ញាប្រកាសអំពី "ថ្ងៃដ៏អស្ចារ្យ និងធ្ងន់ធ្ងរនៃព្រះអម្ចាស់" (២:៣១) ។ (ហ្វូងកណ្ដូបនៅក្នុង ១:៤ ២:២៥ គឺជាហ្វូងសត្វល្អិតពិត។ គឺមិនមែនជាចក្រភពបាប៊ីឡូន ពើរស៊ី ក្រិច និងរ៉ូម៉ាំង តាមន័យធៀប ដូចដែលអ្នកខ្លះបានកាត់ស្រាយនោះឡើយ) ។ ដោយត្រូវប្រឈមមុខនឹងវិបត្តិដ៏ធ្ងន់ធ្ងរនេះ លោកយ៉ូអែលបានប្រកាសប្រាប់ឱ្យគ្រប់គ្នាប្រែចិត្ត គឺទាំងមនុស្សចាស់ ក្មេង (១:២-៣) អ្នកប្រមឹក (១:៥) កសិករ (១:១១) និងពួកសង្ឃ (១:១៣) ។ លោកយ៉ូអែលពិពណ៌នាអំពីហ្វូងកណ្ដូបថាជា កងទ័ពនៃព្រះអម្ចាស់ ហើយការមកនៃហ្វូងកណ្ដូបគឺជាការដាស់រំឭកឱ្យដឹងថាថ្ងៃនៃព្រះអម្ចាស់ជិតដល់ហើយ ។ ថ្ងៃនោះមិនមែនគ្រាន់តែជាថ្ងៃជំនុំជម្រះជាតិសាសន៍ទាំងឡាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាថ្ងៃរំដោះ និងប្រទានពរដល់អ៊ីស្រាអែលផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ លោកយ៉ូអែលបានពិពណ៌នាដូចលោកអេសាយ (២:១០-២១) យេរេមា (៤:៥-៩) អេម៉ុស (៥:១៨-២០) និងសេផានា (១:៧-១៨) ថា ជាថ្ងៃដាក់ទោសដល់សាសន៍អ៊ីស្រាអែល ដោយសាភាពមិនស្មោះផងដែរ ។ ការស្អាងឡើងវិញ និងប្រពរនឹងមកដល់ ទាល់តែព្រះទ្រង់បានជំនុំជម្រះ ហើយពួកគេបានប្រែចិត្តហើយ ។

### គម្រោងសង្ខេប

I. ចំណងជើង (១:១)

II. ស្រុកយូដាជួបវិបត្តិដែលប្រាប់ជាមុនអំពីថ្ងៃនៃព្រះអម្ចាស់ (១:២-២:១៧)

- ក. ការប្រកាសហៅឱ្យមកទួញសោក និងអធិស្ឋាន (១:២-១៤)
- ខ. ការប្រកាសអំពីថ្ងៃនៃព្រះអម្ចាស់ (១:១៥-២:១១)
- គ. ការប្រកាសហៅឱ្យប្រែចិត្ត និងអធិស្ឋាន (២:១២-១៧)

III. ស្រុកយូដាទទួលការធានាថា នឹងបានទទួលសេចក្ដីសង្គ្រោះនៅថ្ងៃនៃព្រះអម្ចាស់ (២:១៨-៣:២១)

- ក. ព្រះអម្ចាស់ស្អាងសាសន៍យូដាឡើងវិញ (២:១៨-២៧)

ខ. ព្រះអម្ចាស់សម្អាតរាស្ត្រទ្រង់ជាថ្មី (២:២៨–៣២)

គ. ការមកដល់នៃថ្ងៃនៃព្រះអម្ចាស់ (ជំពូក ៣)

១. ជាតិសាសន៍ទាំងឡាយត្រូវទទួលការជំនុំជម្រះ (៣:១–១៦)

២. រាស្ត្ររបស់ព្រះទទួលព្រះពរ (៣:១៧–២១)

**១** ១នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលបានមក[ក]ដល់
យ៉ូអែល[ខ] ជាកូនពេធូអែល ។

## ការវាយលុករបស់ហ្វូងកណ្ដូប

២ឱពួកចាស់ព្រឹទ្ធាចារ្យទាំងឡាយអើយ[គ] ចូរស្ដាប់ចុះ[ឃ]
ឱពួកអ្នកស្រុកអើយ[ង] ចូរផ្ទៀងត្រចៀកដែរ ការយ៉ាងនេះ
ដែលកើតមានក្នុងគ្រារបស់អ្នករាល់គ្នា ឬក្នុងជំនាន់នៃ
ឪពុកអ្នករាល់គ្នាដែរឬ[ច]
៣ចូរប្រាប់ដល់កូនអ្នករាល់គ្នា
ចុះ[ឆ]ហើយឱ្យកូនប្រាប់ដល់ចៅ រួចឱ្យចៅប្រាប់ដល់ដំណ
ទៅមុខទៀតៗទៅ[ជ]
៤គឺថា របស់អ្វីដែលសល់ពីក្រា នោះ
កណ្ដូប[ឈ]បានស៊ី ហើយអ្វីដែលសល់ពីកណ្ដូប នោះចង្រិត
បានកាត់ រួចអ្វីដែលសល់[ញ]ពីចង្រិត នោះដង្កូវបានស៊ីទៅ[ដ]។
៥ម្នាលពួកប្រមឹក ចូរភ្ញាក់ឡើង ហើយយំចុះ ឱពួក
អ្នកដែលបានធ្លាប់ផឹកស្រាទំពាំងបាយជូរអើយ[ឋ] ចូរទ្រហោ
យំចុះដោយនឹកស្ដាយទឹកទំពាំងបាយជូរផ្អែម ដ្បិតត្រូវដាច់[ឌ]
ពីមាត់អ្នករាល់គ្នាហើយ
៦ពីព្រោះមានជាតិ១ឡើងមកលើ
ស្រុកអញ ជាជាតិខ្លាំងពូកែ[ឍ] ហើយមានច្រើនឥតគណនា
វាមានធ្មេញដូចជាធ្មេញសិង្ហ មានថ្គាម[ណ]ជារបស់សិង្ហញី
៧វាបានបំផ្លាញ[ត]ដើមទំពាំងបាយជូររបស់អញ ក៏បានស៊ី
សំបកដើមល្វារបស់អញ[ថ] ព្រមទាំងឱ្យនៅរលីងផង គឺបាន
ធ្វើឱ្យមែកទាំងអស់ទៅជាទទេ ។
៨ចូរសោកពិលាប ដូចជាស្រីក្រមុំដែលស្លៀកពាក់
សំពត់ធ្មៃ[ទ]កាន់ទុក្ខប្ដីដែលដណ្ដឹងនាងពីកាលនៅក្មេង
៩ឯ
ដង្វាយម្សៅ និងដង្វាយច្រួច[ធ] នោះបានផ្ដាច់ចេញពីព្រះ
វិហារនៃព្រះយេហូវ៉ាហើយ ពួកសង្ឃដែលធ្វើការងារ
ថ្វាយព្រះយេហូវ៉ា គេយំសោក[ន]
១០ស្រែចំការត្រូវខូចបង់
ហើយស្រុកកំពុងសោយសោក ដ្បិតស្រូវត្រូវបំផ្លាញហើយ
ទឹកទំពាំងបាយជូរថ្មី[ប]បានហួតរីង[ផ] ឯប្រេងក៏ខះទៅ[ព]
១១ឱ
ពួកអ្នកធ្វើស្រែចំការអើយ[ភ] ចូរស្រឡាំងកាំងនៅ ហើយ
ពួកអ្នកដែលរក្សាចំការទំពាំងបាយជូរអើយ ចូរទ្រហោយំ
ចុះ ដោយព្រោះស្រូវសាលី និងស្រូវឱក[ម] ដ្បិតចំរូតនៅស្រែ
ចំការខូចអស់ហើយ[យ]
១២ដើមទំពាំងបាយជូរបាននស្វិត
ក្រៀម[រ] ហើយដើមល្វាក៏រោយរៀវចុះ ឯដើមទទឹម[ល]

**១:១** ក យរ ១:២
ខ កច ២:១៦
**១:២** គ ហស ៥:១
ឃ យអ ២:១៦
ង ហស ៤:១
ច យអ ២:២
**១:៣** ឆ នក ១០:២
ជ ទដ ៧១:១៨
**១:៤** ឈ នក ១០:១៤
ញ នក ១០:៥
ដ នក ១០:១៥
ចទ ២៨:៣៩ អម
៧:១ ណហ ៣:១៥
**១:៥** ឋ យអ ៣:៣
ឌ អស ២៤:៧
**១:៦** ឍ ទដ
១០៥:៣៤ យអ
២:២,១១,២៥
ណ វវ ៩:៨
**១:៧** ត អស ៥:៦
ថ អម ៤:៩
**១:៨** ទ ខ.១៣ អស
២២:១២ អម
៨:១០ **១:៩** ធ ហស ៩:៤ ន អស ២២:១២ **១:១០** ប ហស ៩:២ ផ អស ៥:៦
២៤:៤ យរ ៣:៣ ព ជន ១៨:១២ **១:១១** ភ យប ៦:២០ អម ៥:១៦ ម នក
៩:៣១ យ អស ១៧:១១ **១:១២** រ អស ១៥:៦ ល នក ២៨:៣៣

**១:១** *ព្រះបន្ទូលនៃព្រះយេហូវ៉ា* មើល ហស ១:១ និងការពន្យល់ ។ *យ៉ូអែល* ឈ្មោះនេះមានន័យថា "ព្រះអម្ចាស់ទ្រង់ជាព្រះ"។ សូមផ្ទៀបនឹងឈ្មោះលោកអេលីយ៉ា ដែលមានន័យថា "ព្រះ (នៃខ្ញុំ) ទ្រង់ជាព្រះអម្ចាស់"។

**១:២** *ពួកចាស់ព្រឹទ្ធាចារ្យទាំងឡាយអើយ* គឺសំដៅទៅលើពួកចាស់ទុំក្នុងសហគមន៍ ឬពួកមន្ត្រីដែលគេស្គាល់ (មើល ខ.១៤ ២:១៦,២៨ មើលការពន្យល់ នក ៣:១៦) ។

**១:៤** *កណ្ដូប . . ចង្រិត . . ដង្កូវ* មើល ២:២៥, នក ១០:៤ និងការពន្យល់។

**១:៥** *ពួកប្រមឹក* លោកយ៉ូអែលប្រកាសឱ្យប្រែចិត្ត ប៉ុន្តែ នៅក្នុងព្រះគម្ពីរនេះ អំពើបាបដែលលោកសង្កត់ធ្ងន់គឺការប្រមឹកស្រា ។ ការប្រមឹកស្រានេះគឺបង្ហាញអំពីការខំដេញតាមការរស់នៅដែលបណ្ដោយខ្លួនហួសហេតុ (ផ្ទៀបនឹង អស ២៨:៧–៨ អម ៤:១) របស់ពួកអ្នកដែលឱ្យតម្លៃទៅលើសំភារៈខ្លាំងជាងព្រះលឹងវិញ្ញាណ ។ *យំ* ត្រង់ចំណុចនេះលោកយ៉ូអែលប្រកាសដល់ផ្នែកផ្សេងៗនៅក្នុងសហគមន៍ (ពួកប្រមឹកគឺសំដៅទៅលើ មនុស្សទូទៅ, ខ.៨ ពួកអ្នកធ្វើស្រែចំការ, ខ.១១ ពួកអ្នកធ្វើការនៅចំពោះអាសនា ខ.១៣) ឱ្យយំសោក ។ ហ្វូងកណ្ដូបបានស៊ីបំផ្លាញចំការទំពាំងបាយជូរ ធ្វើឱ្យពួកប្រមឹកបាត់បង់ប្រភពស្រាទំពាំងបាយជូរ ។

**១:៦** ខនេះបានប្រៀបប្រដូចហ្វូងកណ្ដូបទៅនឹងជាតិសាសន៍មួយ ។ ផ្ទៀបនឹងសត្វស្រមោច និងទន្សាយថ្ម នៅក្នុង សភ ៣០:២៥–២៦ ដែលពាក្យ "សត្វ" នៅក្នុងភាសាហេព្រើមានន័យត្រង់ថា "មនុស្ស"។ នៅក្នុងបទគម្ពីរផ្សេងទៀតហ្វូងកណ្ដូបត្រូវបានហៅថា "កងទ័ព" របស់ព្រះអម្ចាស់ (២:១១,២៥) ។ ការប្រៀបផ្ទៀបនេះគឺ ដោយសារហ្វូងកណ្ដូបមានចំនួនច្រើន ហើយជាការធម្មតានៅក្នុងព្រះគម្ពីរសញ្ញាចាស់ (មើល ពច ៦:៥ និងការពន្យល់ យរ ៤៦:២៣ ៥១:១៤,២៧ ណហ ៣:១៥) ។ *ច្រើនឥតគណនា* ពាក្យនេះត្រូវបានប្រើផងដែរនៅក្នុងការពិណ៌នាអំពីហ្វូងកណ្ដូបនៅក្នុងសេចក្ដីវេទនានៅស្រុកអេស៊ីព្ទ (មើល ទដ ១០៥:៣៤ នក ១០:៤–៦,១២–១៥) ។ *ធ្មេញ* ព្រះគម្ពីរ វវ ៩:៨ បាននិយាយឆ្លុះបញ្ចាំងអំពីការដែលលោកយ៉ូអែលប្រៀបផ្ទៀបធ្មេញរបស់ហ្វូងកណ្ដូបទៅនឹងធ្មេញសត្វតោ ។

**១:៧** *របស់អញ* ការដែលប្រើពាក្យសព្វនាមកម្មសិទ្ធិនៅក្នុងខនេះ និងក្នុងខដទៃទៀត (ខ.៦,១៣–១៤ ២:១,១៣–១៤,១៧–១៨,២៣,២៦–២៧ ៣:២,៥,១៧) បានផ្ដល់នូវតំរុយនៃសេចក្ដីសង្ឃឹម ព្រោះពាក្យនេះបង្ហាញថា ពួកគេគឺជារាស្ត្ររបស់ព្រះអម្ចាស់ (ផ្ទៀបនឹង យស ២២:១៩) ។

**១:៨** *ស្រីក្រមុំ* ត្រង់ចំណុចនេះគឺនិយាយអំពីអ្នកនៅក្នុងសហគមន៍ ។ នៅក្នុងប្រពៃណីអ៊ីស្រាអែល នៅពេលដែលស្ត្រីម្នាក់ត្រូវបានបម្រុងទុកធ្វើជាប្រពន្ធរបស់បុរសណាម្នាក់ នោះគេហៅបុរសនោះថាជា ប្ដីរបស់នាង ហើយនាងជាប្រពន្ធរបស់គាត់ ទោះបីជាពួកគេមិនទាន់បានរៀបការក៏ដោយ (មើល ចទ ២២:២៣–២៤) ។ ក្នុងខនេះ គឺសំដៅទៅលើស្រីក្រមុំដែលត្រូវបានបំរុងទុកឱ្យបុរសម្នាក់ ប៉ុន្តែ បុរសនេះបានស្លាប់មុនពេលរៀបការ ។ *សំពត់ធ្មៃ* មើល ខ.១៣ លប ៣៧:៣៤ វវ ១១:៣ និងការពន្យល់ ។

**១:៩** *ដង្វាយ* មើល ខ.១៣ ២:១៤ ។ ហ្វូងកណ្ដូបបានបំផ្លាញ ដោយគ្មានបន្សល់ទុកអ្វីសម្រាប់ថ្វាយជាដង្វាយ ។ ដង្វាយម្សៅ (លវ ២:១–២) និងដង្វាយច្រួច ដែលកើតពីផលទំពាំងបាយជូរ (លវ ២៣:១៣) គឺជាផ្នែកនៃការថ្វាយដង្វាយប្រចាំថ្ងៃ (នក ២៩:៤០ ជន ២៨:៥–៨) ។

**១:១០** *ហួតរីង* ភាពរាំងស្ងួតបានធ្វើឱ្យវិនាសសកម្ម ដែលបង្ករដោយពពួកហ្វូងកណ្ដូបកាន់តែអាក្រក់ឡើង ។ *ស្រូវ . . . ទឹកទំពាំងបាយជូរថ្មី . . . ប្រេង* វាគឺជាផលិតផលកសិកម្មសំខាន់ៗទាំងបីប្រភេទនានៃសម័យនោះ (មើល ២:១៩) ។

ដើមលម៉ើ និងដើមសារី គឺអស់ទាំងដើមឈើនៅចំការបាន
ស្វិតក្រៀមទៅ[វ] អើ សេចក្តីអំណរក៏បានរៀវបាត់ពីមនុស្ស
លោកដែរ ។

## ការព្រាសហៅឱ្យប្រែចិត្ត

១៣ឱពួកសង្ឃអើយ ចូរក្រវាត់ខ្លួនឡើង[ស] ហើយទួញ
យំចុះ ឱពួកអ្នកដែលធ្វើការងារ[ហ]ចំពោះអាសនាអើយ ចូរ
ទ្រហោយំទៅ ឱពួកដែលធ្វើការងារថ្វាយព្រះ នៃខ្ញុំអើយ
ចូរមកដេកគ្រលុំខ្លួនដោយសំពត់ធ្មៃអស់១យប់ ចុះដ្បិត
ដង្វាយម្សៅ និងដង្វាយច្រួច[ឡ] ត្រូវឃាំងនៅ មិនឱ្យ
ចូលក្នុងព្រះវិហារនៃព្រះរបស់អ្នករាល់គ្នាឡើយ ១៤ចូរ
ញែកពេលចេញ ដើម្បីតមអត់[អ] ចូរប្រកាសឱ្យមានជំនុំមុត
មាំ ត្រូវឱ្យប្រមូលពួកចាស់ៗ និងពួកអ្នកស្រុក[ក]ទាំងអស់ឱ្យ
មកឯព្រះវិហារនៃព្រះយេហូវ៉ា ជាព្រះរបស់អ្នករាល់គ្នា
រួចអំពាវនាវ[ខ]ដល់ព្រះយេហូវ៉ាទៅ[គ] ។
១៥វរហើយថ្ងៃនោះ[ឃ] ដ្បិតថ្ងៃនៃព្រះយេហូវ៉ា[ង]ជិតដល់
ហើយ ថ្ងៃនោះនឹងមកដូចជាការបំផ្លាញពីព្រះដ៏មានគ្រប់
ព្រះចេស្តា[ច] ១៦ឯអាហារតើមិនបានដាច់ចេញ[ឆ]ពីចំពោះ

**១:១២** វ អស ១៦:៨ ហាក ២:១៩ **១:១៣** ស លប ៣៧:៣៤ យរ ៤:៨ ហ យអ ២:១៧ ឡ ខ.៩ ហស ៩:៤ យអ ២:១៤ **១:១៤** អ ២របា ២០:៣ ក ហស ៤:១ ខ យហ ៣:៨ គ ២របា ២០:៤ **១:១៥** ឃ អស ២:១២ យរ ៣០:៧ ៤៦:១០ អគ ៣០:៣ មឡ ៤:៥ ង យអ ២:១,១១,៣១ ៣:១៤ អម ៥:១៨ សផ ១:១៤ សក ១៤:១ ច លប ១៧:១ **១:១៦** ឆ អស ៣:៧ ជ ទដ ៥១:៨ ឈ ចទ ១២:៧ **១:១៧** ញ អស

ភ្នែកយើង ព្រមទាំងសេចក្តីអំណរ និងសេចក្តីរីករាយ[ជ]
ពីព្រះវិហាររបស់ព្រះ[ឈ]នៃយើងផងទេឬអី ១៧ឯពូជពង្រោះ
ក៏ពុករលួយនៅក្រោមបំណែកដី[ញ] ជង្រុកទាំងប៉ុន្មានក៏នៅ
ទទេ ហើយក្រង់ស្រូវក៏រលំអស់ហើយ ពីព្រោះស្រូវបានស្វិត
ក្រៀមទៅ ១៨អើហ្ន៎ សត្វតាំងប៉ុន្មានស្រែកយំស៊ាន ហ្វូងគោ
ត្រូវស្រឡាំងកាំង ដ្បិតគ្មានទីកគង្វាលរកស៊ីសោះ[ដ] អើទាំង
ហ្វូងចៀមក៏ត្រូវវិនាសដែរ[ឋ] ១៩ឱព្រះយេហូវ៉ាអើយ ទូល
បង្គំអំពាវនាវដល់ទ្រង់[ឌ] ដ្បិតភ្លើង[ឍ]បានឆេះវាលស្មៅនៅ
ទីរហោស្ថាន[ណ] ហើយអណ្តាតភ្លើងបានឆេះទាំងអស់ទាំង
ដើមឈើនៅវាលដែរ ២០អើ សត្វនៅដីទាំងប៉ុន្មានក៏ដង្ហក់
រកទ្រង់[ត] ពីព្រោះអស់ទាំងជ្រោះទឹកបានរីងស្ងួតទៅ[ថ] ភ្លើង
ក៏បានឆេះវាលស្មៅនៅទីរទីរហោស្ថានអស់ហើយ[ទ] ។

## ទ័ពហ្វូងកណ្តូប

**២** ១ចូរផ្លុំត្រែ[ក]ឡើងនៅក្រុងស៊ីយ៉ូន[ខ] ហើយធ្វើសូរសញ្ញា
នៅភ្នំបរិសុទ្ធរបស់អញ[គ] ត្រូវឱ្យអ្នកស្រុកទាំងអស់ញាប់ញ័រ

១៧:១០–១១ **១:១៨** ដ លប ៤៧:៤ ឋ យរ ៩:១០ **១:១៩** ឌ ទដ ៥០:១៥ ឍ ទដ ៩៧:៣ អម ៧:៤ ណ យរ ៩:១០ **១:២០** ត ទដ ៤២:១ ១០៤:២១ ថ ១ពវ ១៧:៧ ទ យអ ២:២២ **២:១** ក ជន ១០:២,៧ ខ ខ.១៥ គ នក ១៥:១៧

**១:១៣** *ព្រះនៃខ្ញុំ . . . ព្រះរបស់អ្នករាល់គ្នា* មើលការពន្យល់ ខ.៧ ។ *ដង្វាយម្សៅ និងដង្វាយច្រួច* មើលការពន្យល់ ខ.៩ ។

**១:១៤** *តមអត់ . . . ជំនុំមុតមាំ* មើល ២:១៥ ។ ការតមអត់គឺចាំបាច់ត្រូវធ្វើនៅថ្ងៃលោះបាប ហើយត្រូវធ្វើនៅថ្ងៃមានហន្តរាយ (មើល ពច ២០:២៦ ២សយ ១២:១៦ អគ ៤:៣,១៦ យរ ១៤:១២ យហ ៣:៤–៥ សក ៧:៣) ហើយគឺជាសញ្ញាបង្ហាញអំពីការសោកស្តាយចំពោះអំពើបាប និងជាសញ្ញានៃការបន្ទាបខ្លួន ។ ព្រះគម្ពីរបានបដិសេធការបង្ហាញនូវអាការៈខាងក្រៅដែលមិនឆ្លុះបញ្ចាំងឱ្យឃើញនូវជំនឿនៅក្នុងចិត្ត (មើល មថ ៦:១–៨,១៦–១៨ ២៣:១–៣៦) ។ *ពួកចាស់ៗ* មើលការពន្យល់ ខ.២, នក ៣:១៦ ២សយ ៣:១៧ ។

**១:១៥** *ថ្ងៃនៃព្រះយេហូវ៉ា* មើលការពន្យល់ អម ៥:១៨ ។ ឃ្លានេះមានប្រើប្រាំដងនៅក្នុងព្រះគម្ពីរយ៉ូអែល ហើយជាខ្លឹមសារសំខាន់នៃព្រះគម្ពីរនេះ (២:១,១១,៣១ ៣:១៤) ។ ពួកហោរាប្រាំរូបផ្សេងទៀតក៏បានប្រើពាក្យនេះដែរ ដូចជាលោកអេសាយ(អស ១៣:៦,៩) អេសេគាល(អគ ១៣:៥ ៣០:៣) អេម៉ុស(អម ៥:១៨,២០) អូបាឌា(អប ១៥) សេផានា(១:៧,១៤) និងម៉ាឡាគី(៤:៥) ហើយប្រើពាក្យដែលមានន័យដូចគ្នា នៅក្នុង សក ១៤:១ ជួនកាលប្រើជាទម្រង់ខ្លីដូចជា "ថ្ងៃនោះ" ដែលពាក្យនេះជាញឹកញាប់សំដៅទៅលើ ការធ្វើអន្តរាគមន៍របស់ព្រះអម្ចាស់នៅក្នុងប្រវត្តិសាស្ត្រ ដោយការចូលលុកលុយនៃហ្វូងកណ្តូបនៅក្នុងព្រះគម្ពីរយ៉ូអែល ឬនៅក្នុងសង្គ្រាមកាកេមីស(Cachemish) ក្នុងឆ្នាំ ៦០៥ មុនគ.ស.(មើល យរ ៤៦:២,១០) ។ ពាក្យនេះក៏អាចសំដៅទៅលើការយាងមកវិញនៃព្រះគ្រីស្ទដើម្បីបញ្ចប់ប្រវត្តិសាស្ត្រ(មើល មឡ ៤:៥ ១កថ ៥:៥ ២កថ ១:១៤ ១ថន ៥:២ និងការពន្យល់, ២ពវ ៣:១០) ។ នៅពេលដែលឃ្លានេះមិនបានប្រើសំដៅទៅលើការជំនុំជម្រះនៃព្រះនៅក្នុងប្រវត្តិសាស្ត្រទេ នោះឃ្លានេះត្រូវប្រើសំដៅទៅលើថ្ងៃចុងក្រោយនៃព្រះអម្ចាស់ ដែលជាទូទៅមានន័យពីរយ៉ាងគឺ (១).ព្រះអម្ចាស់មានជ័យជម្នះលើខ្មាំងសត្រូវរបស់ទ្រង់ ហើយជំនុំជម្រះពួកគេ (២).ការប្រទាននូវការសម្រាក(សេចក្តីសុខ) និងព្រះពរដល់រាស្ត្ររបស់ទ្រង់ ។ *ការបំផ្លាញ . . . គ្រប់ព្រះចេស្តា* មើល អស ១៣:៦ និងការពន្យល់ ។

**១:១៨** ធៀបនឹងការពិពណ៌នាអំពីភាពរាំងស្ងួតនៅក្នុង យរ ១៤:៥–៦ ។ *ស្រែកយំស៊ាន* ព្រះគម្ពីរភាសារហេព្រើប្រើពាក្យយ៉ាងដូចនេះ សំដៅទៅលើការយំស្រែករបស់អ៊ីស្រាអែលនៅស្រុកអេស៊ីព្ទ(នក ២:២៣) និងការយំស្រែករបស់សាសន៍ដទៃទៀតដែលជួបវិបត្តិ (សភ ២៩:២ អស ២៤:៧ បទ ១:៤,៨,១១,២១ អគ ៩:៤ ២១:១២) ។ *ត្រូវស្រឡាំងកាំង* ព្រះគម្ពីរភាសារហេព្រើប្រើពាក្យដែលមានន័យដូចនេះ សម្រាប់បកស្រាយអំពីការវិលវល់របស់អ៊ីស្រាអែលនៅក្នុងវាលរហោស្ថាន (នក ១៤:៣) ។ *ទាំងហ្វូងចៀម* ហ្វូងចៀមនឹងត្រូវរងគ្រោះចុងក្រោយគេ ដោយសារពួកវាអាចជីកឫសស្មៅពីក្នុងដីស៊ីបាន ។

**១:១៩–២០** *ភ្លើង* ទោះបីជាវគ្គផ្សេងទៀតបានប្រៀបធៀបការបំផ្លាញរបស់ហ្វូងកណ្តូប ទៅនឹងការបំផ្លាញរបស់ភ្លើង(មើល ២:៣) ក៏នៅក្នុងវគ្គនេះលោកយ៉ូអែលប្រហែលជាកំពុងពិពណ៌នាអំពីវិនាសកម្មដែលកើតឡើងពីភាពរាំងស្ងួត ។ នៅក្នុងករណីទាំងពីរនេះ លោកយ៉ូអែលចង់បង្ហាញថាភ្លើងនោះជាភ្លើងនៃសេចក្តីជំនុំជម្រះនៃព្រះ(មើល ឧទាហរណ៍ យរ ៤:៤ ១៥:១៤ ១៧:២៧ និងការពន្យល់ អគ ៥:៤ ១៥:៦–៧ និងការពន្យល់ ១៥:៧ ២០:៤៧ ២១:៣២ ហស ៨:១៤ អម ១:៤ និងការពន្យល់) ។

**២:១** *ត្រែ* មើល ខ.១៥ ។ គេធ្វើត្រែនេះ អំពីស្នែងចៀម ឬគោ ។ គេប្រើវាជាសញ្ញាប្រកាសអាសន្ន(មើល យរ ៤:៥ អគ ៣៣:៣ និងការពន្យល់) ។

ពីព្រោះថ្ងៃនៃព្រះយេហូវ៉ា[ឃ]កំពុងតែមក ក៏ជិតដល់ហើយ[ង]
២គឺជាថ្ងៃងងឹត[ច] ហើយមីរស្រទំ[ឆ,ជ] ជាថ្ងៃមានពពក[ឈ]
ហើយងងឹតយ៉ាងក្រាស់[ញ] មានជាតិ១ធំ ហើយខ្លាំងពូកែ[ដ]មក
ដូចជាពន្លឺ នៅពេលបំព្រាងលាតផ្សាយទៅនៅលើភ្នំ មិន
ដែលមានឱ្យដូចឡើយ[ឋ] ហើយក្រោយគេតទៅ ក៏មិនត្រូវ
មានយ៉ាងនោះដែរ ដរាបដល់ច្រើនដំណមនុស្សរៀងទៅ
៣មានភ្លើង[ឌ]ឆេះបន្សុសពីមុខគេ ហើយខាងក្រោយគេក៏មាន
អណ្តាតភ្លើងឆេះដែរ នៅមុខគេ ផែនដីប្រៀបដូចជាសួន
ច្បារអេដែន[ឍ] តែខាងក្រោយគេ នោះបានដូចជាទីរហោ
ស្ថានដ៏ស្ងាត់ច្រៀប[ណ]វិញ ឥតមានអ្វីរួចពីគេឡើយ។
៤ភាពរូបរបស់គេមើលទៅដូចជាសេះ[ត] គេក៏រត់ដូច
ជាសេះចំបាំងដែរ ៥គេកញ្ជ្រោលព្ធសន្ទឹក ដូចជារទេះ[ថ]
ចំបាំងនៅលើកំពូលភ្នំទាំងប៉ុន្មាន គឺដូចជាសន្ធឹកអណ្តាត
ភ្លើង[ទ]ដែលឆេះជញ្ជ្រាំង ហើយដូចជាកងទ័ពយ៉ាងខ្លាំង
ពូកែដែលដំរៀបគ្នាប្រុងចូលច្បាំង ៦អស់ទាំងសាសន៍មាន
សេចក្តីបារម្ភព្រួយនៅមុខគេ[ធ] មុខមនុស្សទាំងអស់ក៏ស្លេក
ស្លាំងទៅ[ន] ៧គេរត់ដូចជាមនុស្សខ្លាំងពូកែ[ប] ក៏ឡើងកំផែង
ដូចជាមនុស្សថ្មីកច្បាំង គ្រប់គ្នាដើរត្រង់ទៅខាងមុខ[ផ] ឥត
មានណារាបែក[ព]ឡើយ ៨ក៏គ្មានណាមួយប្រជ្រៀតគ្នានឹងគ្នា
ដែរ គឺទាំងអស់ដើរតាមផ្លូវរៀងខ្លួន គេទំលុះទំលាយ
គ្រឿងសាស្ត្រាវុធឥតរុញរាថយក្រោយឡើយ ៩គេផ្សាយ
ទៅពេញក្នុងទីក្រុង ក៏រត់នៅលើកំផែង ហើយឡើងទៅលើ
ផ្ទះទាំងប៉ុន្មាន[ភ] គេចូលតាមបង្អួចដូចជាចោរ[ម] ១០ផែនដីក៏
កក្រើកនៅមុខគេ[យ] ឯផ្ទៃមេឃក៏ញ័ររន្ធត់[រ] ព្រះអាទិត្យនឹង
ព្រះចន្ទក៏ងងឹត[ល] ហើយផ្កាយទាំងប៉ុន្មានលែងភ្លឺទៅ[វ] ១១ព្រះ
យេហូវ៉ា[ស] ទ្រង់បញ្ចេញព្រះសូរសៀង[ហ] នៅមុខពលទ័ព
របស់ទ្រង់[ឡ] ដ្បិតទីបោះទ័ពរបស់ទ្រង់ធំណាស់ ពីព្រោះអ្នក
ដែលធ្វើសំរេចតាមព្រះបន្ទូលទ្រង់ នោះមានកំឡាំងខ្លាំង
ដ្បិតថ្ងៃនៃព្រះយេហូវ៉ាធំក្រៃលែង[អ] ហើយគួរស្ញែងខ្លាច

**២:១** ឃ យអ ១:១៥ សផ ១:១៤–១៦ ង អគ ១២:២៣ ៣០:៣ អប ១:១៥ **២:២** ច ខ.១០,៣១ យប ៩:៧ អស ៨:២២ ១៣:១០ អម ៥:១៨ ឆ ដយ ៩:១២ មថ ២៤:២១ ជ អគ ៣៤:១២ ឈ អគ ៣៨:៩ ញ សផ ១:១៥ វវ ៩:២ ដ យអ ១:៦ ឋ យអ ១:២ **២:៣** ឌ ទដ ៩៧:៣ អស ១:៣១ ឍ លប ២:៨ ណ នក ១០:១២–១៥ ទដ ១០៥:៣៤–៣៥ អស ១៣:១៧ **២:៤** ត វវ ៩:៧ **២:៥** ថ វវ ៩:៧ ទ អស ៥:២៤ ៣០:៣០ **២:៦** ធ អស ១៣:៨ ន អស ២៩:២២ **២:៧** ប យប ១៦:១៤ **២:៩** ភ នក ១០:៦ ម យរ ៩:២១ **២:១០** យ ទដ ១៨:៧ ណាហ ១:៥ រ អគ ៣៨:១៩ ល ខ.២ អស ៥:៣០ មថ ២៣:២៩ មក ១៣:២៤ វវ ៩:២ វ យប ៩:៧ ទដ ១០២:២៦ អស ១៣:១០ អគ ៣២:៨ **២:១១** ស អស ២:១២ អគ ៣០:៣ យអ ១:១៥ អប ១:១៥ ហ ទដ ២៩:៣ ឡ ខ.២,២៥

សម្លេងរបស់វាអាចធ្វើឱ្យមនុស្សភ័យញ័រ (មើល អម ៣:៦)។ *ក្រុងស៊ីយ៉ូន* មើល ខ.១៥ ៣:១៧,២១ ។ នៅក្នុងខនេះគឺសំដៅទៅលើទីក្រុងយេរូសាឡិម ដែលជារាជធានី ។ *ថ្ងៃនៃព្រះយេហូវ៉ា* មើល ១:១៥ អស ២:១១,១៧,២០ និងការពន្យល់ ។

**២:២** *ថ្ងៃងងឹត* ព្រះគម្ពីរហោរាប្រើពាក្យនេះប្រៀបប្រដូចទៅនឹងថ្ងៃនៃព្រះអម្ចាស់ (មើល អម ៥:១៨ និងការពន្យល់ សផ ១:១៥) ហើយជាពាក្យប្រៀបធៀបទៅនឹងភ័យវិបត្តិ និងការរងទុក្ខ (មើល អស ៥០:៣ ៥៩:៩ យរ ២:៦ ១៣:១៦ បទ ៣:៦ អគ ៣៤:១២ និងការពន្យល់)។ *ពន្លឺនៅពេលបំព្រាង* តាមធម្មតាពាក្យនេះប្រើដើម្បីបង្ហាញអំពីការធូរស្រាលអំពីទុក្ខព្រួយ ឬភាពងងឹត មានន័យថាជាចុងបញ្ចប់នៃភាពងងឹត (ធៀបនឹង អស ៨:២០ ៥៨:៨)។ ទោះជាយ៉ាងណាក៏ដោយ នៅត្រង់ចំណុចនេះគឺជាការប្រៀបធៀបអំពីការដែលហ្វូងកណ្តូបយ៉ាងច្រើនឥតគណនាដែលហើរកាត់ទឹកដីដូចពន្លឺថ្ងៃដែលរះកាត់ទឹកដីចាប់ពីទិសខាងកើត ហើយគ្របដណ្តប់ទឹកដីនោះទាំងមូលតែម្តង

**២:៣–១១** វគ្គនេះសរសេរជាបទកំណាព្យ ដែលនិយាយអំពីសង្គ្រាម (មើល ណាហ ៣:១–៣)។

**២:៣** *ពីមុខគេ* ដើម្បីនិយាយសង្កត់ធ្ងន់លោកយ៉ូអែលបានប្រើពាក្យនេះចំនួនបីដង (ពីដងនៅក្នុងខ.៣ ហើយម្តងទៀតនៅក្នុង ខ.១០) ពាក្យ "ក្រោយគេ" ពីដង (ខ.៣) ហើយ "នៅមុខគេ" មួយដង (ខ.៦)។ *ភ្លើង* មើលការពន្យល់ ១:១៩–២០ ។ *ច្បារអេដែន* មើល លប ២:៨,១៥ (គឺសួនច្បារដែលមិនទាន់មានអំពើបាបចូលមកដល់) លប ១៣:១០ (ច្រកទន្លេយ័រដាន់ មុនពេលនៃការបំផ្លាញទីក្រុងសូដំម) និង អស ៥១:៣ អគ ៣១:៨–៩,១៦,១៨ ៣៦:៣៥ (ខទាំងនេះពិពណ៌នាអំពីវាលរហោស្ថាន ដែលប្រែក្លាយជាដូចសួនច្បារអេដែន) ។

**២:៤** *សេះ* ព្រះគម្ពីរយ៉ូបបានប្រៀបធៀបសត្វសេះទៅនឹងហ្វូងកណ្តូប (យប ៣៩:១៩–២០) ដោយឡែក ព្រះគម្ពីរយ៉ូអែលប្រៀបធៀបបញ្ច្រាសវិញ ។

**២:៥** ទោះបីជាភ្នំអាចជាឧបសគ្គសម្រាប់សេះ និងរទេះសេះក៏ដោយ ក៏មិនអាចឃាត់ឃាំងហ្វូងកណ្តូបបានដែរ ។

**២:៦** *នៅមុខគេ* ពាក្យនេះមានន័យដូចពាក្យ "ពីមុខគេ" (ខ.៣,១០)។ *មានសេចក្តីបារម្ភព្រួយ* គឺដោយសារតែភាពអត់ឃ្លានដែលបង្ករដោយហ្វូងកណ្តូប ។

**២:៩** *ឡើងទៅលើផ្ទះ* គឺដូចសេចក្តីវេទនានៃកណ្តូបនៅប្រទេសអេស៊ីព្ទ (នក ១០:៦) ។ បង្អួចដែលមានតែចម្រឹង តែគ្មានកញ្ចក់មិនអាចទប់ទល់នឹងពួកវាបានឡើយ ។

**២:១០** *ផែនដីក៏កក្រើក* មើល ទដ ៦៨:៨ អស ២៤:១៨–២០ យរ ៤:២៤ អម ៨:៨ ណាហ ១:៥ ។ *ផ្ទៃមេឃក៏ញ័ររន្ធត់* មើល ២សយ ២២:៨ អស ១៣:១៣ ហាក ២:៦,២១ ហព ១២:២៦–២៨ ។ *ងងឹត* ត្រង់ចំណុចនេះលោកយ៉ូអែលបាននិយាយភ្ជាប់ការជំនុំជម្រះរបស់ព្រះអម្ចាស់តាមរយៈហ្វូងកណ្តូប ជាមួយនឹងបាតុភូតធម្មជាតិដែលនឹងកើតឡើងនៅថ្ងៃនៃព្រះអម្ចាស់ ។

**២:១១** លោកអេសាយបានមើលឃើញចក្រភពអាសស៊ើរ (មើល អស ១០:៥ និងការពន្យល់) ហើយលោកយេរេមាបានមើលឃើញចក្រភពបាប៊ីឡូន (យរ ២៥:៩ ៤៣:១០) ដូចជាអាវុធរបស់ព្រះអម្ចាស់ ដូចនេះលោកយ៉ូអែលបានមើលឃើញហ្វូងកណ្តូបជាកងទ័ពរបស់ទ្រង់ (ធៀបនឹង យស ៥:១៤ ទដ ៦៨:១៧ ហព ៣:៨–៩) គឺជាកងទ័ពនៃព្រះអម្ចាស់ដែលទ្រង់នឹងយាងមកជាមួយមកទាស់នឹងសត្រូវរបស់ទ្រង់នៅថ្ងៃនៃព្រះអម្ចាស់ (មើល ៣:៩–១១ និងការពន្យល់)។ បទគម្ពីរនេះមានន័យដូច សផ ១:១៤ (ធៀបនឹង ខ.៣១ ៣:១៤ មឡ ៤:១,៥)។ *បញ្ចេញព្រះសូរសៀង* មើល ៣:១៦ និងការពន្យល់ ។ *ធំណាស់... គួរស្ញែងខ្លាច* មើល ចទ ៧:២១ ១០:២១ ទដ ១០៦:២១–២២។ ជាញឹកញាប់ពាក្យនេះប្រើសម្រាប់ពិពណ៌នាថ្ងៃនៃព្រះអម្ចាស់ (មើល ខ.៣១

ណាស់ តើអ្នកណាអាចនឹងធន់នៅបាន[ក]។

## ចូរបញ្ឈឺចិត្តខ្លួនឯង

១២ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា ទោះបីយ៉ាង នោះក៏
ដោយ ចូរឱ្យឯងរាល់គ្នាវិលមក[ខ]ឯអញ ឱ្យអស់អំពីចិត្ត[គ]
ដោយតមអត់ ហើយយំពិលាប ព្រមទាំងសៅសោក ឥឡូវ
នេះចុះ ១៣មិនត្រូវឱ្យហែកអាវខ្លួនទេ គឺត្រូវហែកចិត្ត[ឃ]វិញ[ង]
ហើយវិលមក[ច]ឯព្រះយេហូវ៉ា ជាព្រះនៃឯងចុះ ដ្បិតទ្រង់
ប្រកបដោយព្រះគុណ និងសេចក្តីមេត្តាករុណា[ឆ] ទ្រង់យឺត
និងខ្ញាល់ ហើយក៏មានសេចក្តីសប្បុរសជាបរិបូរ[ជ] ទ្រង់មាន
ព្រះហឫទ័យស្តាយដោយត្រូវវាយផ្ចាលគេដែរ[ឈ] ១៤ឯទ្រង់
ប្រហែលនឹងបែរ[ញ] ជាមានព្រះហឫទ័យស្តាយ[ដ] ក្នុងគ្រានេះ
ទេដឹង ហើយខាងក្រោយទ្រង់នឹងឱ្យមានព្រះពរ[ឋ]ដែរ
គឺឱ្យមានដង្វាយម្សៅ និងដង្វាយច្រួច[ឌ] សំរាប់ថ្វាយដល់
ព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នាផង។

១៥ចូរផ្លុំត្រែឡើង[ឍ]នៅក្រុងស៊ីយ៉ូន[ណ] ចូរញែកពេលចេញ
សំរាប់តមអត់[ត] ចូរប្រកាសឱ្យមានជំនុំមុតមាំចុះ[ថ] ១៦ត្រូវឱ្យ
ប្រមូលពួកជន ហើយញែកពួកជំនុំចេញជាបរិសុទ្ធ[ទ] ចូរ
ប្រជុំពួកចាស់ៗ[ធ] ហើយប្រមូលកូនក្មេង និងកូនដែលនៅ
បៅដោះ ត្រូវឱ្យប្តីថ្មោងថ្មី[ន]ចេញពីបន្ទប់មក ហើយប្រពន្ធ
ថ្មោងថ្មីចេញពីក្នុងវាំងននដែរ ១៧ត្រូវឱ្យពួកសង្ឃ ជា
ពួកអ្នកធ្វើការងារ[ប]ថ្វាយព្រះយេហូវ៉ា បានយំ[ផ]នៅត្រង់
កណ្តាល បាំងសាច និងអាសនា[ព] ត្រូវឱ្យគេទូលថា ឱព្រះ
យេហូវ៉ា អើយ សូមទ្រង់មេត្តាប្រណីដល់រាស្ត្រទ្រង់ផង
សូមកុំប្រគល់មរដករបស់ទ្រង់ទៅ ឱ្យត្រូវគេត្មះតិះដៀល[ភ]
ឱ្យពួកសាសន៍ដទៃបានគ្រប់គ្រងលើ[ម]គេឡើយ តើមានទំនង
អ្វីឱ្យ គេបានសួរនៅកណ្តាលអស់ទាំងសាសន៍ថា តើព្រះ
របស់គេនៅឯណា[យ]។

## ចម្លើយរបស់ព្រះអម្ចាស់

១៨នៅគ្រានោះ ព្រះយេហូវ៉ា ទ្រង់មានសេចក្តីប្រចណ្ឌ[រ]
ចំពោះស្រុករបស់ទ្រង់ ក៏មានសេចក្តីអាណិតមេត្តា[ល]ដល់
រាស្ត្រទ្រង់ ១៩ដូច្នេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលតបនឹង
រាស្ត្រទ្រង់ថា នែអញនឹងផ្ញើស្រូវ ទឹកទំពាំងបាយជូរ[វ]ថ្មី និង
ប្រេងដល់ឯងរាល់គ្នា[ស] ហើយឯងរាល់គ្នានឹងបានស្កប់ចិត្ត[ហ]
អញនឹងមិនធ្វើឱ្យឯងជាទីត្មះតិះដៀល[ឡ] នៅកណ្តាលអស់
ទាំងសាសន៍ទៀតឡើយ ២០គឺអញនឹងកំចាត់ពលទ័ព[អ]ពីទិស
ខាងជើងឱ្យឆ្ងាយចេញពីឯងទៅ ហើយបណ្តេញគេទៅឯ
ស្រុក១ដែលហួតហែង ហើយស្ងាត់ច្រៀប មានក្បាលទ័ព

**២:១១** អ សផ ១:១៤ ក អគ ២២:១៤ សផ ២:១១ វវ ៦:១៧ **២:១២** ខ ចទ ៣:៤០ អគ ៣៣:១១ ហស ១២:៦ គ ១សយ ៧:៣ **២:១៣** ឃ ទដ ៥១:១៧ អស ៥៧:១៦ ង លប ៣៧:២៩ ជន ១៤:៦ យប ១:២០ ច អស ១៩:២២ ឆ ចទ ៤:៣១ ជ នក ៣៤:៦ ទដ ៨៦:៥,១៥ ឈ យរ ១៨:៨ យហ ៤:២ **២:១៤** ញ យរ ២៦:៣ យហ ៣:៩ ដ អម ៥:១៥ យហ ១:៦ ឋ យរ ៣១:១៤ ហាក ២:១៩ សក ៨:១៣ មឡ ៣:១០ ឌ យអ ១:១៣ **២:១៥** ឍ ជន ១០:២ ណ ខ.១ ត ២របា ២០:៣ យរ ៣៦:៩ ថ នក ៣២:៥ ជន ១០:៣ **២:១៦** ទ នក ១៩:១០,២២ ធ យអ១:២ ន ទដ ១៩:៥ **២:១៧** ប យអ ១:១៣ ផ អស ២២:១២ ព អគ ៨:១៦ មថ ២៣:៣៥ ភ ចទ ៩:២៦-២៩ ទដ ៤៤:១៣ ម ១ពវ ៩:៧ យប ១៧:៦ យ ទដ ៤២:៣ **២:១៨** រ អស ២៦:១១ សក ១:១៤ ៨:២ ល ទដ ៧២:១៣ **២:១៩** វ ទដ ៤:៧ ស យរ ៣១:១២ ហ លវ ២៦:៥ ឡ អគ ៣៤:២៩ **២:២០** អ យរ ១:១៤-១៥

មឡ ៤:៥)។ *តើអ្នកណាអាចនឹងធន់នៅបាន* មើល ណហ ១:៦ និងការពន្យល់, មឡ ៣:២ វវ ៦:១៧ ។ មានន័យថា ពួកគេមិនអាចគេចបានទេ គឺមានតែងាកបែរមកឯព្រះអម្ចាស់វិញប៉ុណ្ណោះ ។

**២:១២-១៧** ផ្នែកពាក់កណ្តាលដំបូងនៃព្រះគម្ពីរនេះបញ្ចប់ ដោយការត្រាសហៅឱ្យលន់តួបាប("វិលមកវិញ" ខ.១២-១៣ មើល ហស ១៤:១ និងការពន្យល់) ហើយអធិស្ឋាន(ខ.១៧) ដោយវគ្គនេះចាប់ផ្តើមដោយការត្រាសហៅឱ្យទួញសោក និងអធិស្ឋាន(១:២-១៤)។

**២:១៣** *ត្រូវហែកចិត្ត* មើល ទដ ៥១:១៧ និងការពន្យល់ ។ *ប្រកបដោយព្រះគុណ . . . សេចក្តីសប្បុរសជាបរិបូរ* គឺជាការរំឭកឡើងវិញអំពីលក្ខណៈសម្បត្តិរបស់ព្រះ នៅក្នុង នក ៣៤:៦-៧ ដែលប្រៀបបានទៅនឹងសរសៃអម្បោះដែលចងភ្ជាប់ពេញព្រះគម្ពីរសញ្ញាចាស់(មើលការពន្យល់ នក ៣៤:៦-៧ និង ចទ ៤:៣១ មីក ៧:១៨)។

**២:១៤** *ដង្វាយម្សៅ និងដង្វាយច្រួច* មើលការពន្យល់ ១:៩ ។

**២:១៥** *ផ្លុំត្រែ* មិនមែនជាការផ្លុំត្រែហៅឱ្យមកយំសោកដូចនៅក្នុង ខ.១ នោះទេ ប៉ុន្តែ គឺជាការផ្លុំហៅឱ្យមកជួបជុំគ្នាតាមពិធីបុណ្យ(មើល លវ ២៣:២៤ ២៥:៩ ជន ១០:១០ យស ៦:៤-៥ ២ពវ ១៥:១៤ ទដ ៩៨:៦ និងការពន្យល់)។ *តមអត់ . . . ជំនុំមុតមាំ* មើលការពន្យល់ ១:១៤ ។

**២:១៦** ការហៅឱ្យមកយំសោកនៅក្នុងជំពូក ១ គឺជាការហៅគ្រប់ក្រុមទាំងអស់នៅក្នុងសហគមន៍ដោយគ្មានលើកលែងក្រុមណាមួយទេ ។ *ពួកជំនុំ* មើល ជន ១៦:៣ ២របា ៣០:២,៤,២៣-២៥ មីក ២:៥ ។ *ពួកចាស់ៗ* មើលការពន្យល់ ១:២ ។ *វាំងនន* គឺជាទីកន្លែងប្រារព្ធពិធីរៀបការ ។

**២:១៧** *មរដករបស់ទ្រង់* ពួកអ៊ីស្រាអែលគឺជាសម្បត្តិពិសេសរបស់ព្រះ (មើល នក ៣៤:៩ យរ ៣:១៩ និងការពន្យល់)។ ពួកយូដាត្រូវទូលអង្វរដល់ព្រះអម្ចាស់(នក ៣២:១២ ជន ១៤:១៣ យស ៧:៩ និងការពន្យល់)។ *ត្មះតិះដៀល* មើលការពន្យល់ ១ពវ ៩:៧ ។ *តើព្រះរបស់គេនៅឯណា* គឺជាពាក្យចម្អក ឬបញ្ឈឺ(មើល ទដ ៣:២ ១០:១១ ១១៥:២ និងការពន្យល់)។

**២:១៨** នៅក្នុងវគ្គនេះលោកយ៉ូអែលបានចាប់ផ្តើមវគ្គថ្មីមួយទៀត ដោយឈប់និយាយអំពីសេចក្តីហិនវិនាស ដែលបង្ករឡើងដោយហ្វូងកណ្តូប ហើយចាប់ផ្តើមនិយាយអំពីព្រះពរដែលព្រះទ្រង់នឹងប្រទានដល់រាស្ត្រទ្រង់ដែលប្រែរចិត្ត ។ *សេចក្តីប្រចណ្ឌ* មើលការពន្យល់ នក ២០:៥ ។ ព្រះអម្ចាស់ទ្រង់នឹងឆ្លើយតបចំពោះសេចក្តីអធិស្ឋាននៃខ.១៧ ហើយទ្រង់ការពារព្រះនាមទ្រង់ ហើយមានសេចក្តីអាណិតដល់រាស្ត្រទ្រង់ ។

**២:១៩** *ស្រូវ ទឹកទំពាំងបាយជូរថ្មី និងប្រេង* មើលការពន្យល់ ១:១០ ។

**២:២០** *ពលទ័ពពីទិសខាងជើង* កងទ័ពសម័យនោះ មិនធ្វើការឈ្លានពានពីសមុទ្រ និងដោយកាត់តាមវាលរហោស្ថានទេ ដូចនេះតាមទីតាំងភូមិសាស្ត្រតំបន់កាណានងាយនឹងត្រូវទទួលការឈ្លានពានពីនៅតំបន់ខាងត្បូង(សាសន៍អេស៊ីព្ទ) និងពីខាងជើង(សាសន៍អាសស៊ើរ និងបាប៊ីឡូន)។ នៅក្នុងខនេះហ្វូងកណ្តូបគឺប្រៀបបានទៅនឹងកងទ័ពដ៏សម្បើម ដែលអ៊ីស្រាអែលភ័យខ្លាច

បែរទៅឯសមុទ្រខាងកើត[ក] ហើយកន្ទុយទ័ពនៅឯសមុទ្រ
ខាងលិច ហើយក្លិនស្អុយ[ខ]របស់គេនឹងសាបឡើង ព្រមទាំង
ក្លិនគំរង់ផង ពីព្រោះគេបានធ្វើការយ៉ាងសំបើម ។
២១ឱស្រុកអើយ កុំឱ្យភ័យឡើយ[គ] ចូរមានសេចក្ដីត្រេក
អរ ហើយរីករាយឡើង[ឃ] ដ្បិតព្រះយេហូវ៉ាទ្រង់បានធ្វើការ
យ៉ាងសំបើមដែរ[ង] ២២ម្នាលសត្វនៅផែនដីទាំងឡាយកុំ
ខ្លាចអ្វី ដ្បិតវាលស្មៅនៅទីរហោស្ថានកំពុងលូតលាស់
ឡើង[ច] ហើយដើមឈើទាំងប៉ុន្មានក៏កើតផល ឯដើមល្វា[ឆ]
និងដើមទំពាំងបាយជូរ[ជ]កំពុងតែបញ្ចេញសម្បត្តិវា[ឈ]
២៣ដូច្នេះ ពួកកូនស្រុកក្រុងស៊ីយ៉ូនអើយ ចូរអរសប្បាយ
ឡើង[ញ] ចូរមានសេចក្ដីរីករាយក្នុងព្រះយេហូវ៉ាជាព្រះនៃ
ឯងចុះ ពីព្រោះទ្រង់ប្រទានភ្លៀងដំបូងមកតាមខ្នាតត្រឹម
ត្រូវ[ដ] ទ្រង់បង្អុរឱ្យភ្លៀងធ្លាក់ចុះ សំរាប់ឯងរាល់គ្នា[ឋ] គឺជា
ភ្លៀងដើម[ឌ]ចុងរដូវ[ឍ] ដូចកាលមុន ២៤អស់ទាំងទីលាននឹង
បានពេញដោយស្រូវសាលី ហើយធុងទាំងប៉ុន្មាននឹងពេញ
ព្រៀប[ណ] ទៅដោយទឹកទំពាំងបាយជូរ[ត]និងប្រេង ២៥អញនឹង
សងបំពេញឆ្នាំទាំងប៉ុន្មាន ដែលត្រូវស៊ីបង្ខូច[ថ]ដោយកណ្តូប[ទ]
ចង្រិត ដង្កូវ និងក្រា គឺជាកងទ័ពធំ[ធ]របស់អញ ដែលអញ
បានចាត់ប្រើមកកណ្ដាលឯងរាល់គ្នានោះ ២៦ឯងរាល់គ្នា
នឹងបានស៊ីជាបរិបូរ ហើយបានឆ្អែតផង[ន] ក៏នឹងសរសើរ[ប]
ដល់ព្រះនាមព្រះយេហូវ៉ា ជាព្រះនៃឯងរាល់គ្នា ដែលទ្រង់
បានប្រព្រឹត្តនឹងឯងយ៉ាងអស្ចារ្យ[ផ] រួចរាស្ត្រអញនឹងមិនត្រូវ
មានសេចក្ដីខ្មាសទៀតឡើយ[ព] ២៧នោះឯងរាល់គ្នានឹងដឹង[ភ]
ថា អញស្ថិតនៅកណ្ដាលសាសន៍អ៊ីស្រាអែល ហើយថាអញ
នេះ គឺយេហូវ៉ា[ម] ជាព្រះនៃឯងរាល់គ្នា ឥតមានព្រះណា
ដទៃទៀត យ៉ាងនោះ រាស្ត្រអញនឹងមិនត្រូវមានសេចក្ដី
ខ្មាសទៀតឡើយ[យ] ។

## ថ្ងៃនៃព្រះអម្ចាស់

២៨ក្រោយគ្រានោះ អញនឹងចាក់វិញ្ញាណ[រ]របស់អញ ទៅ
លើគ្រប់ទាំងមនុស្ស[ល] នោះកូនប្រុសស្រីរបស់ឯងនឹងទាយ[វ]
ពួកចាស់ៗរបស់ឯងនឹងយល់សប្តិឃើញ[ស] ហើយពួកកំឡោះ
ៗរបស់ឯងនឹងឃើញការជាក់ស្តែង ២៩នៅគ្រានោះ អញ
នឹងចាក់វិញ្ញាណរបស់អញ ទៅលើទាំងពួកទាសាទាសី[ហ]
ដែរ[ឡ] ៣០អញនឹងសំដែងការអស្ចារ្យនៅលើមេឃ[អ] ហើយ
នៅផែនដីផង[ក] គឺជាឈាម និងភ្លើង ហើយនិងកំសួលផ្សែង

**២:២០** ក សក ១៤:៨ ខ អស ៣៤:៣ **២:២១** គ អស ២៩:២២ ៥៤:៤ សផ ៣:១៦-១៧ ឃ ទដ ៩:២ ង ទដ ១២៦:៣ អស ២៥:១ **២:២២** ច ទដ ៦៥:១២ ឆ ១ពវ ៤:២៥ ជ ជន ១៦:១៤ ឈ យអ ១:១៨-២០ សក ៨:១២ **២:២៣** ញ ទដ ៣៣:២១ ៩៧:១២ ១៤៩:២ អស ១២:៦ ៤១:១៦ ៦៦:១៤ ហាព ៣:១៨ សក ១០:៧ ដ អស ៤៥:៨ ឋ យប ៣៦:២៨ អគ ៣៤:២៦ ឌ ទដ ៨៤:៦ ឍ លប ២៦:៤ ទដ ១៣៥:៧ យក ៥:៧ **២:២៤** ណ លវ ២៦:១០ មឡ ៣:១០ ត សភ ៣:១០ យអ ៣:១៨ អម ៩:១៣ **២:២៥** ថ ចទ ២៨:៣៩ ទ នក ១០:១៤ អម ៤:៩ ធ យអ ១:៦ **២:២៦** ន លវ ២៦:៥ ប លវ ២៣:៤០ អស ៦២:៩ ផ ទដ ១២៦:៣ អស ២៥:១ ព អស ២៩:២២ **២:២៧** ភ នក ៦:៧ ម នក ៦:២ អស ៤៤:៨ យអ ៣:១៧ យ អស ៤៥:១៧ ៥៤:៤ សផ ៣:១១ **២:២៨** រ អស ១១:២ ៤៤:៣ ល ជន ១១:១៧ មក ១:៨ កទ ៣:១៤ វ ១សយ ១៩:២០ ស យរ ២៣:២៥ **២:២៩** ហ ១កថ ១២:១៣ កទ ៣:២៨ ឡ អគ ៣៦:២៧ **២:៣០** អ ខ.២ អស ២២:៥ យរ ៤:២៣ មថ ២៤:២៩ ក យអ ១:១៥ អប ១:១៥ មឡ ៣:២ ៤:១,៥

បំផុត ។ *ក្លិនស្អុយ* ពីព្រោះហ្វូងកណ្តូបត្រូវស្លាប់ហើយ ។

**២:២១-២៣** មានការត្រាសហៅជាច្រើនដងឱ្យមកយំសោក (១:៥,៨,១១,១៣) ដូចនេះមានការត្រាសហៅជាច្រើនដងឱ្យមានអំណរអរសប្បាយ គឺជាការត្រាសហៅទឹកដី (ខ.២១) សត្វព្រៃ (ខ.២២) និងមនុស្ស (ខ.២៣) ឱ្យមានអំណរនឹងរង្វាន់ដែលព្រះអម្ចាស់នឹងប្រទានឱ្យ ។

**២:២២** នៅត្រង់ចំណុចហ្វូងសត្វព្រៃបានរកឃើញវាលស្មៅដ៏ធំល្វឹងល្វើយ (ធៀបនឹង ១:១៩-២០) ។ ទីកន្លែងដែលហ្វូងកណ្តូប និងភាពរាំងស្ងួតបានបំផ្លាញរុក្ខជាតិដុះនៅទីនោះ (មើល ១:៧,១២,១៩) ឥឡូវត្រូវប្រែជាកើតផលច្រើនវិញ ។

**២:២៤** *ទីលាន* មើលការពន្យល់ រម ១:២២ ។ *ធុង* មើលការពន្យល់ ហក ២:១៦ ។

**២:២៥** មើល ១:៤ និងការពន្យល់ ។

**២:២៦** *យ៉ាងអស្ចារ្យ* ព្រះទ្រង់បានធ្វើការអស្ចារ្យដល់រាស្ត្រទ្រង់កាលពួកគេនៅស្រុកអេស៊ីព្ទ (មើល នក ៣:២០ និងការពន្យល់, ៧:៣) ហើយនៅក្នុងខនេះ ទ្រង់ធ្វើការអស្ចារ្យ នៅក្នុងការស្អាងឡើងវិញ នូវទឹកដីរបស់ពួកគេដែលទទួលរងការបំផ្លាញ ។

**២:២៧** *សាសន៍អ៊ីស្រាអែល* ប្រហែលជាសំដៅទៅលើរាស្ត្រទាំងអស់របស់ព្រះ ដោយមិនបែងចែកខាងជើង ឬខាងត្បូង ដូចមាននិយាយនៅក្នុង ៣:២,១៦ ។ *ជាព្រះនៃឯងរាល់គ្នា* ឃ្លានេះរំឭកឡើងវិញនូវសេចក្ដីសញ្ញាដែលព្រះអម្ចាស់បានតាំងនៅភ្នំស៊ីណាយ (នក ២០:២ និងការពន្យល់) ។ *ឥតមានព្រះណាដទៃទៀត* មើលការពន្យល់ ចទ ៤:៣៥ ។

**២:២៨-៣២** លោកសាវកពេត្រុសបានដកស្រង់វគ្គនេះនៅក្នុងថ្ងៃបុណ្យទី៥០ (កថ ២:១៦-២១) ។

**២:២៨** *ក្រោយគ្រានោះ* មានន័យថា នៅក្នុងគ្រានៃព្រះមែស៊ី ។ *ចាក់វិញ្ញាណរបស់អញ* មើល ខ.២៩ អស ៣២:១៥ ៤៤:៣ អគ ៣៩:២៩ និងការពន្យល់, សក ១២:១០-១៣:១ ។ *គ្រប់ទាំងមនុស្ស* ទាំងអស់គ្នានឹងចូលរួមដោយមិនប្រកាន់ភេទ អាយុ ឬឋានៈឡើយ ហើយសេចក្ដីប្រាថ្នារបស់លោកម៉ូសេ (ជន ១១:២៩ និងការពន្យល់) និងបានសម្រេច (ធៀបនឹង កទ ៣:២៨) ។ លោកពេត្រុសបានប្រើពាក្យ "គ្រប់ទាំងមនុស្ស" នៅក្នុងខនេះ និងពាក្យ "អស់អ្នកណា" នៅក្នុងខ.៣២ សំដៅទៅលើពួកសាសន៍ដទៃផងដែរ ("អស់អ្នកដែលនៅឆ្ងាយដែរ", កថ ២:៣៩ មើលការពន្យល់ កថ ២:១៧) ដែលនឹងមិនត្រូវបានបដិសេធចេញពីការរំដោះនៃព្រះវិញ្ញាណ (ធៀបនឹង រម ១១:១១-២៤) ។ *ទាយ . . . យល់សប្តិឃើញ . . . ឃើញការជាក់ស្តែង* មើល ជន ១២:៦ ។

**២:៣០-៣១** នៅក្នុងវគ្គនេះនិយាយអំពីព្រឹត្តិការណ៍ដែលទាក់ទងនឹងសាកលលោក ដែលជាញឹកញាប់ព្រឹត្តិការណ៍ទាំងនេះជាប់ទាក់ទងនឹងថ្ងៃនៃព្រះអម្ចាស់ (មើល អស ១៣:៩-១០,១៣ ៣៤:៤ មថ ២៤:២៩ វវ ៦:១២-១៣ ៨:៨-៩ ៩:១-១៩ ១៤:១៤-២០ ១៦:៤,៨-៩) ។

**២:៣០** *ឈាម* កើតឡើងពីសង្គ្រាម ។ *ភ្លើង . . . ហើយនិងកំសួលផ្សែង* ជាសញ្ញាបញ្ជាក់ពីព្រះវត្តមានរបស់ព្រះ (មើល លប ១៥:១៧ និងការពន្យល់) ។

៣១ព្រះអាទិត្យនឹងប្រែទៅជាងងឹត[ខ] ហើយព្រះចន្ទនឹងទៅជា
ឈាម មុនដែលថ្ងៃធំ គួរស្ញែងខ្លាចរបស់ព្រះយេហូវ៉ាបាន
មកដល់[គ] ៣២នោះអស់អ្នកណាដែលអំពាវនាវដល់ព្រះនាម
ព្រះយេហូវ៉ា[ឃ]នឹងបានប្រោសឱ្យរួច[ង] ដ្បិតនៅភ្នំស៊ីយ៉ូន[ច]
ហើយនៅក្រុងយេរូសាឡិម នោះនឹងមានសេចក្ដីសង្គ្រោះ[ឆ]
ដូចជាព្រះយេហូវ៉ា ទ្រង់បានមានបន្ទូលទុកហើយក្នុងពួក
មនុស្សដែលសល់នៅ[ជ] និងមានអ្នកខ្លះដែលព្រះយេហូវ៉ា
ទ្រង់នឹងហៅផង[ឈ]។

## នគរដែលត្រូវជំនុំជម្រះ

**៣** ១ដ្បិតមើល នៅគ្រានោះ គឺនៅវេលានោះឯង កាល
អញបាននាំពួកយូដា[ក] ហើយពួកក្រុងយេរូសាឡិម ដែល
ជាប់ជាឈ្លើយមកវិញ[ខ] ២នោះអញនឹងប្រមូល[គ]សាសន៍ទាំង
អស់នាំគេចុះទៅក្នុងច្រកភ្នំយេហូសាផាត[ឃ] នៅទីនោះអញ
នឹងសំរេចតាមសេចក្ដីយុត្តិធម៌[ង]ដល់គេ ដោយព្រោះរាស្ត្រ
អញ គឺអ៊ីស្រាអែលជាមរដករបស់អញ ដែលគេកំចាត់
កំចាយ[ច]ទៅនៅអស់ទាំងសាសន៍ ព្រមទាំងបែងចែកស្រុក
របស់អញផង ៣គេបានបោះឆ្នោត[ឆ]ឱ្យបានរាស្ត្រអញ
គេបានដូរកូនប្រុស១ឱ្យបានស្រីសំផឹងវិញ ហើយបាន
លក់កូនស្រី១ឱ្យបានស្រាទំពាំងបាយជូរ[ជ]សំរាប់ផឹក ៤ម្នាល
ក្រុងទីរ៉ូស ក្រុងស៊ីដូន[ឈ] និងក្រវល់ស្រុកភីលីស្ទីនអើយ[ញ] តើ
ឯងមានការអ្វីនឹងអញ តើឯងរាល់គ្នាគិតសងបំណាច់ដល់
អញឬ បើឯងរាល់គ្នាសងអញ នោះអញនឹងទំលាក់ទៅ
លើក្បាលឯងវិញភ្លាម១រំពេច[ដ] ៥ពីព្រោះឯងរាល់គ្នាបាន
យកប្រាក់នឹងមាសរបស់អញ ដឹកនាំប្រដាប់វិសេសរបស់
អញ ទៅទុកនៅក្នុងវិហាររបស់ឯង[ឋ] ៦ក៏បានលក់ពួកកូន
ចៅយូដា និងកូនចៅក្រុងយេរូសាឡិម ឱ្យដល់ពួកសាសន៍
ក្រេក[ឌ] ឱ្យគេបាននាំយកទៅឯទីឆ្ងាយពីដែនស្រុករបស់ខ្លួន
៧មើល អញនឹងដាស់គេឡើង ឱ្យចេញពីទីកន្លែង ដែល
ឯងបានលក់គេទៅនៅនោះ[ឍ] ហើយនិងសង[ណ]អំពើនោះ
ទៅលើក្បាលរបស់ឯងរាល់គ្នាវិញ ៨អញនឹងលក់កូនប្រុស[ត]
កូនស្រីរបស់ឯងរាល់គ្នា ទៅក្នុងកណ្ដាប់ដៃ នៃពួកកូនចៅ

**២:៣១** ខ ខ.២ អស ២២:៥ យរ ៤:២៣ មថ ២៤:២៩ គ យអ ១:១៥ អប ១:១៥ មឡ ៣:២ ៤:១,៥ **២:៣២** ឃ លប ៤:២៦ ទដ ១០៥:១ ង ទដ ១០៦:៨ កច ២:១៧-២១ រម ១០:១៣ ច អស ៤៦:១៣ ឆ អប ១:១៧ ជ អស ១:៩ ១១:១១ មីក ៤:៧ ៧:១៨ រម ៩:២៧ ឈ កច ២:៣៩ **៣:១** ក យរ ៤០:៥ ខ ចទ ៣០:៣ យរ ១៦:១៥ អគ ៣៨:៨ សផ ៣:២០ **៣:២** គ សផ ៣:៨ ឃ ខ.១២ អស ២២:១ ង អស ១៣:៩ យរ ២:៣៥ អគ ៣៦:៥ ច លប ១១:៤ លវ ២៦:៣៣ **៣:៣** ឆ យប ៦:២៧ អគ ២៤:៦ ជ យអ ១:៥ អម ២:៦ **៣:៤** ឈ លប ១០:១៥ មថ ១១:២១ ញ ទដ ៨៧:៤ អស ១៤:២៩-៣១ យរ ៤៧:១-៧ ដ លវ ២៦:២៨ អស ៣៤:៨ អគ ២៥:១៥-១៧ សក ៩:៥-៧ **៣:៥** ឋ ១ពវ ១៥:១៨ ២របា ២១:១៦-១៧ **៣:៦** ឌ អគ ២៧:១៣ សក ៩:១៣ **៣:៧** ឍ អស ៤៣:៥-៦ យរ ២៣:៨ ណ អស ៦៦:៦ **៣:៨** ត អស ៦០:១៤

**២:៣១** *ងងឹត* មើល ខ.២ និងការពន្យល់ ។ *ឈាម* ព្រះច័ន្ទនឹងប្រែជាមានពណ៌ក្រហមដូចឈាម ។ *ថ្ងៃធំគួរស្ញែងខ្លាចរបស់ព្រះយេហូវ៉ា* មើល ខ.១១ ១:១៥ និងការពន្យល់ ។

**២:៣២** *អំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា* គឺដោយថ្វាយបង្គំព្រះ និងអធិស្ឋានដល់ទ្រង់(មើល លប ៤:២៦ ១២:៨ ទដ ១១៦:៤)។ *ប្រោសឱ្យរួច* គឺប្រោសឱ្យរួចពីសេចក្ដីក្រោធនៃសេចក្ដីជំនុំជម្រះរបស់ព្រះ(មើល មថ ២៤:១៣)។ *ដូចជាព្រះយេហូវ៉ាទ្រង់បានមានបន្ទូលទុក* ត្រង់ចំនុចនេះប្រហែលជាលោកយ៉ូអែលកំពុងរំឭកឡើងវិញនូវសេចក្ដីសញ្ញាដែលព្រះអម្ចាស់បានតាំងជាមួយនឹងស្ដេចដាវីឌ(មើល ២សយ ៧ ទដ ១៣២:១១-១៨)។ *ពួកមនុស្សដែលនៅសល់* មើល សក ១៣:៨-៩ និងការពន្យល់ ១៤:២ ។

**៣:១** *នៅគ្រានោះ* គឺនៅគ្រាប្រោសលោះសាសន៍អ៊ីស្រាអែលជាលើកចុងក្រោយ(មើល ខ.១៨ និងការពន្យល់)។ *នាំ . . . មកវិញ* មើល ខ.៦-៧ និងការពន្យល់ យរ ២៩:១៤ ។

**៣:២** *ច្រកភ្នំយេហូសាផាត* មើល ខ.១២ ។ ក្នុង ខ.១៤ គេហៅច្រកភ្នំនេះថា "ច្រកភ្នំនៃការសម្រេចទោស"។ ឈ្មោះច្រកភ្នំនេះហាក់ដូចជាឈ្មោះជានិមិត្តរូបឱ្យច្រកភ្នំនៅក្បែរទីក្រុងយេរូសាឡិម ហើយនៅក្នុងខនេះ ច្រកភ្នំនេះគឺជាកន្លែងព្រះអម្ចាស់ជំនុំជម្រះជាតិសាសន៍ជាច្រើនដែលបានរួមគ្នាទាស់នឹងទីក្រុងយេរូសាឡិម (ធៀបនឹង សក ៦:១ និងការពន្យល់) ។ នៅកន្លែងនោះ ស្ដេចយេហូសាផាតបានមើលឃើញផ្ទាល់ភ្នែក នូវជ័យជម្នះមួយក្នុងចំណោមជ័យជម្នះជាប្រវត្តិសាស្ត្រ ដែលព្រះអម្ចាស់មានលើពួកសាសន៍ដទៃ (មើល ២របា ២០:១-៣០) ។ *មរដករបស់អញ* មើលការពន្យល់ ២:១៧ ។ នៅក្នុងវគ្គនៃ ខ.២-៣,៥ ព្រះអម្ចាស់ទ្រង់ប្រើពាក្យ "របស់អញ" ដើម្បីសង្កត់ធ្ងន់ទៅលើទំនាក់ទំនងដែលទ្រង់បានតាំងសញ្ញាជាមួយនឹងអ៊ីស្រាអែល ។ *អ៊ីស្រាអែល* មើលការពន្យល់ ២:២៧ ។

**៣:៣** *បោះឆ្នោតឱ្យបានរាស្ត្រអញ* ការនេះបានកើតឡើងចំពោះប្រទេសយូដា នៅក្នុងសម័យចាប់ជាឈ្លើយ(ឆ្នាំ ៥៨៦ មុនគ.ស) ហើយការនេះបានបញ្ជាក់នៅក្នុង អប ១១ ។ ពួកខ្មាំងសត្រូវបានចាប់ទុកអ៊ីស្រាអែលថា គ្រាន់តែជារបស់កម្មសិទ្ធិធម្មតា ដែលគេអាចយកមកជួញដូរដើម្បីឱ្យបានសប្បាយនឹងស្រីសំផឹង និងស្រា ។

**៣:៤-៨** នៅក្នុង ខ.១-៣ និង ខ.៩-៦ ព្រះទ្រង់ប្រកាសអំពីសេចក្ដីជំនុំជម្រះសាសន៍ដែលទាស់នឹងសាសន៍អ៊ីស្រាអែល ប៉ុន្តែនៅក្នុងវគ្គនេះ ទ្រង់ប្រកាសដោយបញ្ចេញឈ្មោះដោយផ្ទាល់តែម្ដង ។

**៣:៤** *ក្រុងទីរ៉ូស ក្រុងស៊ីដូន . . . ស្រុកភីលីស្ទីន* ពួកក្រុងទីរ៉ូស និងពួកស្រុកភីលីស្ទីនបានលក់សាសន៍អ៊ីស្រាអែលជាទាសករ (មើល អម ១:៦,៩ និងការពន្យល់) ហើយជាញឹកញាប់សាសន៍ភីលីស្ទីនបានវាយចូលលុកលុយប្រទេសអ៊ីស្រាអែល (មើល ពច ១៣:១ ១សយ ៥:១ ២របា ២១:១៦-១៧ អគ ២៥:១៥-១៧ និងការពន្យល់ ២៥:១៥)។ ព្រះទ្រង់បានដាក់ទោសពួកគេដោយបណ្ដោយឱ្យទីក្រុងស៊ីដូនត្រូវទទួលរងការបំផ្លាញ និងប្រជាជននៃក្រុងនេះជាច្រើនត្រូវស្ដេចអើថាសើកសេសទី៣ ចាប់ជាទាសករ នៅឆ្នាំប្រហែល ៣៤៥ មុនគ.ស ហើយទ្រង់បានបណ្ដោយឱ្យពួកក្រិចកាន់កាប់ទីក្រុងទីរ៉ូស (ក្រោមការដឹកនាំរបស់ស្ដេចអ័ឡេក្សាន់ឌ័រ) នៅឆ្នាំ ៣៣២ មុនគ.ស.។ *ទំលាក់ទៅលើក្បាលឯងវិញភ្លាម* មើល ខ.៧ អគ ១៦:៤៣ និងការពន្យល់ ។

**៣:៦** ពួកសាសន៍ក្រិចធ្វើជំនួញជាមួយនឹងពួកសាសន៍ភេនីសចាប់តាំងពីដើមឆ្នាំ៨០០ មុនគ.ស ។

**៣:៨** *ពួកសេបា* មើល យប ១:១៥ និងការពន្យល់ ។ គឺជាសាសន៍ដែលមកពី

យូដាវិញ[ថ] ពួកនោះនឹងលក់វាទៅឱ្យពួកសេបា[ទ] គឺដល់
សាសន៍១ដែលនៅឆ្ងាយ ដ្បិតព្រះយេហូវ៉ាទ្រង់បានចេញ
វាចាហើយ[ធ]។
៩ចូរប្រកាសប្រាប់សេចក្ដីនេះ នៅកណ្ដាល០អស់ទាំង
សាសន៍ថា ចូរត្រៀមគ្នាសំរាប់ចូលច្បាំង[ន] ត្រូវឱ្យដាស់ពួក
ខ្លាំងពូកែឡើង[ប] ចូរឱ្យអស់ទាំងមនុស្សថ្មើរចំបាំងចូលមកជិត
ហើយឡើងមកចុះ ១០ចូរដំដែកផាលរបស់ឯងរាល់គ្នាធ្វើ
ជាដាវ ហើយដង្កាវ[ផ]របស់ឯងធ្វើជាលំពែងទៅ[ព] ត្រូវឱ្យអ្នក
ខ្សោយ[ភ]ពោលថា ខ្ញុំមានកំឡាំងដែរ[ម] ១១ម្នាល សាសន៍
ទាំងឡាយដែលនៅព័ទ្ធជុំវិញអើយ ចូរប្រញាប់មកប្រជុំគ្នា
ចុះ[យ] ឱព្រះយេហូវ៉ាអើយ សូមទ្រង់ឱ្យពួកខ្លាំងពូកែរបស់
ទ្រង់ចុះទៅឯទីនោះដែរ[រ] ១២ត្រូវឱ្យសាសន៍ទាំងប៉ុន្មានភ្ញាក់
ឡើង ហើយមកឯច្រកភ្នំយេហូសាផាត[ល] ដ្បិតនៅទីនោះ
អញនឹងអង្គុយជំនុំជំរះ[វ]អស់ទាំងសាសន៍ ដែលនៅព័ទ្ធជុំវិញ
១៣ចូរលូកកណ្ដៀវ[ស]ទៅ ដ្បិតចំរូត[ហ]ទុំហើយចូរមកជាន់ផ្លែ
ចុះ[ឡ] ដ្បិតធុងសំរាប់ជាន់[អ] បានពោរពេញធុងរងទឹកទាំង
ប៉ុន្មាន ក៏ពេញហៀរហើយ ពីព្រោះអំពើអាក្រក់របស់គេ
សំបើមណាស់ ។
១៤មានមនុស្សទាំងហ្វូង[ក] អើ មានទាំងហ្វូងនៅច្រកភ្នំ[ខ]នៃ
ការសំរេចទោស ដ្បិតថ្ងៃនៃព្រះយេហូវ៉ា[គ]ជិតដល់ហើយ
នៅក្នុងច្រកភ្នំនៃការសំរេចទោស[ឃ] ១៥ព្រះអាទិត្យនឹងព្រះ
ច័ន្ទក៏ងងឹតទៅ ហើយផ្កាយទាំងប៉ុន្មានបានលែងភ្លឺទៅ[ង]
១៦ព្រះយេហូវ៉ានឹងស្រែកគ្រហឹម[ច]ពីស៊ីយ៉ូនមក ហើយ
បញ្ចេញព្រះសៀងពីក្រុងយេរូសាឡិម[ឆ] នោះទាំងផ្ទៃមេឃ
ហើយផែនដីនឹងកក្រើករំពើកទៅ[ជ] តែព្រះយេហូវ៉ានឹងធ្វើ
ជាទីពំនាក់[ឈ]ដល់រាស្ត្រទ្រង់ ហើយជាទីមាំមួន[ញ] ដល់ពួកកូន
ចៅអ៊ីស្រាអែល ។

## ព្រះពរសម្រាប់រាស្ត្ររបស់ព្រះ

១៧យ៉ាងនោះឯងរាល់គ្នានឹងដឹង[ដ]ថា អញនេះជាព្រះ

**៣:៨** ថ អស ១៤:២ ទ លប ១០:៧ ២របា ៩:១ ធ អស ២៣:១ យរ ៣០:៦ **៣:៩** ន អស ៨:៩ ប យរ ៤៦:៤ **៣:១០** ផ អស ២:៤ ព ជន ២៥:៧ ភ សក ១២:៨ ម យស ១:៦ **៣:១១** យ អគ ៣៨:១៥–១៦ សផ ៣:៨ រ អស ១៣:៣ **៣:១២** ល ខ.២ វ ទដ ៨២:១ អស ២:៤ **៣:១៣** ស មក ៤:២៩ ហ អស ១៧:៥ ហស ៦:១១ មថ ១៣:៣៩ វវ ១៤:១៥–១៩ ឡ យរ ២៥:៣០

អ ពច ៦:១១ វវ ១៤:២០ **៣:១៤** ក អស ១៣:៤ ខ អស ២២:១ គ អស ៣៤:២–៨ យអ ១:១៥ សផ ១:៧ ឃ អស ២:៤ អគ ៣៦:៥ **៣:១៥** ង យប ៩:៧ អគ ៣២:៧ **៣:១៦** ច អស ៤២:១៣ ឆ អម ១:២ ជ ពច ៥:៤ អស ១៤:១៦ អគ ៣៨:១៩ ឈ ទដ ៤៦:១ អស ២៥:៤ សក ១២:៨ ញ ២សយ ២២:៣ យរ ១៦:១៩ សក ៩:១២ **៣:១៧** ដ នក ៦:៧

ស្រុកសេបា ជាស្រុកដែលមានម្ចាស់ក្សត្រីមួយអង្គធ្វើដំណើរមកជួបស្ដេចសាឡូម៉ូន(១ពវ ១០:១–១៣ និងការពន្យល់ ១០:១) ។ *ដែលនៅឆ្ងាយ* គឺស្ថិតនៅភូមិភាគខាងត្បូងរបស់ឧបទ្វីបអារ៉ាប់ (ប្រទេសយេមែនសព្វថ្ងៃ) ។

**៣:៩–២១** នៅក្នុង ខ.៩–១១ លោកយ៉ូអែលជាអ្នកនិយាយ, នៅក្នុង ខ.១២–១៣ ព្រះទ្រង់មានបន្ទូល, នៅក្នុង ខ.១៤–១៦ លោកយ៉ូអែលនិយាយ ហើយនៅក្នុង ខ.១៧–២១ ព្រះទ្រង់មានបន្ទូល ។ នៅពេលលោកយ៉ូអែលនិយាយ លោកនិយាយក្នុងនាមជាអ្នកនាំពាក្យរបស់ព្រះអម្ចាស់ ដែលទ្រង់បានចាត់ឱ្យលោកធ្វើជាហោរា ។

**៣:៩–១១** លោកយ៉ូអែលបានបង្គាប់ឱ្យសាសន៍ទាំងនោះប្រកាសអាសន្នត្រៀមខ្លួនធ្វើសង្គ្រាម ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងមកទាស់នឹងពួកគេដោយកងទ័ពស្ថានសួគ៌ដែលពួកគេមិនអាចយកឈ្នះបាន ហើយទ្រង់នឹងជំនុំជម្រះពួកគេ(ធៀបនឹង អគ ៣៨–៣៩ វវ ១៩)។

**៣:១០** ផ្នែកដំបូងនៃខនេះនិយាយផ្ទុយនឹង អស ២:៤ (មើលការពន្យល់ក្នុងខនេះ) និង មីក ៤:៣ ដែលខទាំងនេះនិយាយអំពីភាពសុខសាន្តដែលកើតឡើងពីការគ្រប់គ្រងរបស់ព្រះ ។ នៅក្នុងខនេះ ព្រះអម្ចាស់ប្រកាសហៅឱ្យសត្រូវរបស់ទ្រង់ចូលមកប្រឈមមុខនឹងទ្រង់ជាលើកចុងក្រោយ ។ *ដែកផាល* មើលការពន្យល់ អស ២:៤ ។

**៣:១១** *មកប្រជុំគ្នា* គឺនៅច្រកភ្នំយេហូសាផាត ដើម្បីទទួលការជំនុំជម្រះ (ខ.២,១២)។

**៣:១៣** វិនាសកម្មនៃស្រុកយូដាដែលកើតឡើងពីកងទ័ពហ្វូងកណ្ដូបនៃព្រះអម្ចាស់(មើល ២:៣–១១ និងការពន្យល់ ២:១១) បានធ្វើឱ្យការច្រូតកាត់មិនអាចកើតមានទៀត(២:៣) ។ ប៉ុន្តែ ការច្រូតកាត់នឹងត្រូវមានឡើងវិញ (២:១៩,២២,២៤,២៦) ។ នៅថ្ងៃនៃព្រះអម្ចាស់ ក៏នឹងមានការច្រូតកាត់ផងដែរ គឺការច្រូតកាត់ដោយការជំនុំជម្រះរបស់ព្រះអម្ចាស់មកលើជាតិសាសន៍វគ្គនៃបទគម្ពីរ វវ ១៤:១៤–២០ បានបង្ហាញយ៉ាងច្បាស់នូវរូបភាពនៃការជំនុំជម្រះនេះ(មើលការពន្យល់ វវ ១៤:១៥,១៨–២០) ។ *ធុងទឹក* មើល ២:២៤ និងការពន្យល់ ។

**៣:១៤** *ច្រកភ្នំនៃការសំរេចទោស* គឺច្រកភ្នំនៃស្ដេចយេហូសាផាត(ការជំនុំជម្រះ)ដែលមាននិយាយនៅក្នុង ខ.២,១២ ។ "ស្ដេចយេហូសាផាត" បាននិយាយអំពីតួនាទីនៃព្រះអម្ចាស់ជាចៅក្រមជំនុំជម្រះ (មើលការពន្យល់ ខ.២) ។ ខនេះបានបញ្ជាក់ថា ច្រកភ្នំនេះគឺជាទីកន្លែងដែលព្រះអម្ចាស់សម្រេចដាក់ទោស ។ *ថ្ងៃនៃព្រះអម្ចាស់* មើល ១:១៥ និងការពន្យល់ ។

**៣:១៥** មើល ២:១០ និងការពន្យល់ ។

**៣:១៦** *ស្រែកគ្រហឹម* មានន័យថា ព្រះអម្ចាស់ទ្រង់នឹងបំផ្លាញជាតិសាសន៍ទាំងឡាយដូចជាសត្វសឹង្ហ ។ ពីរបន្ទាត់ដំបូងនៃខនេះ គឺនិយាយដូចនៅក្នុង អម ១:២(មើលការពន្យល់ ខនេះ និងមើល យរ ២៥:៣០) ។ *ពីស៊ីយ៉ូន* មើលការពន្យល់ អម ១:២ ។ *ព្រះសៀង* ព្រះទ្រង់បញ្ចេញព្រះសៀងដូចជាផ្គរលាន់ នៅក្នុងការដឹកនាំទ័ពទ្រង់ទាស់នឹងទីក្រុងយេរូសាឡិម(២:១១) ហើយទ្រង់នឹងបញ្ចេញព្រះសៀងទាស់នឹងខ្មាំងសត្រូវរបស់ទីក្រុងយេរូសាឡិម ចេញពីរាជធានីរបស់ទ្រង់មក ជាកន្លែងដែលទ្រង់គ្រប់គ្រង"មរតក"របស់ទ្រង់(មើល ខ.១៧ អម ១:២) ។ *ទាំងផ្ទៃមេឃ ហើយផែនដីនឹងកក្រើករំពើក* មើល ២:១០ និងការពន្យល់ ។ *អ៊ីស្រាអែល* មើលការពន្យល់ ២:២៧ ។

**៣:១៧–២១** ព្រះទ្រង់ប្រទានពរដល់រាស្ត្រទ្រង់ ដោយវិធីពីរបែបៈ តាមបែបអវិជ្ជមាន ដោយបំផ្លាញខ្មាំងសត្រូវរបស់ពួកគេ ហើយតាមបែបវិជ្ជមានដោយប្រទានពួកគេនូវរបស់ល្អ ។

**៣:១៧** *គង់នៅស៊ីយ៉ូន* ព្រះអម្ចាស់ទ្រង់នឹងគង់នៅជាមួយពួកគេ(មើល ខ.២១) ។ ការនេះមាននិយាយនៅក្នុង ២:២៧ ទដ ៤៦:៤(ធៀបនឹង វវ ២១:៣) ។ ទីក្រុងដែលបានប្រែជាមិនបរិសុទ្ធ និងងាយទទួលរងការបំផ្លាញ

យេហូវ៉ាគឺជាព្រះនៃឯងរាល់គ្នា[ឋ] ដែលគង់នៅស៊ីយ៉ូន[ឌ] ជា
ភ្នំបរិសុទ្ធរបស់អញ[ឍ] គ្រានោះក្រុងយេរូសាឡិម នឹងបាន
បរិសុទ្ធ[ណ] ឥតមានអ្នកដទៃណាដើរកាត់ទៀតឡើយ[ត] ។
១៨នៅគ្រានោះ អស់ទាំងភ្នំធំ នឹងស្រក់ទឹកទំពាំងបាយ
ជូរ[ថ]ផ្អែមមក ហើយអស់ទាំងភ្នំតូចនឹងហូរដោយទឹកដោះ[ទ]
អស់ទាំងជ្រោះនៅស្រុកយូដានឹងមានទឹកហូរ[ធ] ហើយនិង
មានក្បាលទឹក១ ហូរចេញពីព្រះវិហារនៃព្រះយេហូវ៉ាមក[ន]
ស្រោចស្រពច្រកភ្នំសិទីម[ប] ១៩ស្រុកអេស៊ីព្ទ[ផ]នឹងត្រូវស្ងាត់
ច្រៀប ហើយស្រុកអេដំម[ព]នឹងទៅជាទីរហោស្ថាន ដោយ
ព្រោះការច្រឡោត[ភ]ដែលបានធ្វើដល់ពួកកូនចៅយូដា ដ្បិត
គេបានកំចាយឈាមឥតទោសនៅក្នុងស្រុកគេ ២០ប៉ុន្តែ
យូដានឹងស្ថិតស្ថេរនៅជាដរាប[ម] ហើយក្រុងយេរូសាឡិម
ដែរ នៅអស់ទាំងដំណតរៀងទៅ ២១អញនឹងលុបទោស
គេចេញ[យ] គឺទោសដែលមិនទាន់បានលុបចេញ[រ]នៅឡើយ
ពីព្រោះព្រះយេហូវ៉ាទ្រង់គង់នៅក្រុងស៊ីយ៉ូន[ល] ។/

**៣:១៧** ឋ យអ ២:២៧ ឌ ទដ ៧៤:២ អស ៤:៣ ឍ ទដ ២:៦ អស ២:២ អក ១៧:២២ ណ យរ ៣១:៤០ ត អស ៥២:១ អក ៤៤:៩ សក ៩:៨ **៣:១៨** ថ យអ ២:២៤ ទ នក ៣:៨ បស ៥:១ ធ អស ៣០:២៥ ៣៥:៦ ៤៤:៣ ន វវ ២២:១-២ ប ជន ២៥:១ អស ២៥:៦ យរ ៣១:១២ អក ៤៧:១ អម ៩:១៣ **៣:១៩** ផ អស ១៩:១ ព អស ១១:១៤ ៣៤:១១ ភ យរ ៥១:៣៥ អប ១:១០ **៣:២០** ម អរ ៩:១២ អម ៩:១៥ **៣:២១** យ អស ១:១៥ រ អក ៣៦:២៥ ល ទដ ៧៤:២ អស ៥៩:២០ អក ៤៨:៣៥ សក ៩:៣

នឹងបានទទួលព្រះពរពីព្រះអម្ចាស់ ដោយទ្រង់នឹងគង់នៅជាមួយពួកគេ (មើល ខ.២១ និងការពន្យល់ វវ ២១) ។ ដោយសារព្រះវត្តមានទ្រង់ ពួកគេបានប្រែជាបរិសុទ្ធ ហើយមិនអាចមិនបំផ្លាញបានឡើយ (មើល សក ១៤:២១ និងការពន្យល់) ។ *ស៊ីយ៉ូន* មើល ២:១ និងការពន្យល់ ។

**៣:១៨** *នៅគ្រានោះ* នៅក្នុងខនេះ គឺនិយាយផ្ទុយស្រឡះពីគ្រោះរាំងស្ងួតនៅក្នុង ១:១០ (មើល អម ៩:១៣) ។ *អស់ទាំងភ្នំធំ . . . ភ្នំតូច* មើល ទដ ១០៤:១៣-១៥ ហក ១:១១ និងការពន្យល់ ។ *ក្បាលទឹក១ ហូរចេញពីព្រះវិហារនៃព្រះយេហូវ៉ា* គឺហូរចេញពីព្រះវត្តមានព្រះ ទឹកនៃព្រះពរនឹងលាងសម្អាតរាស្ត្ររបស់ទ្រង់ ហើយធ្វើឱ្យទីកន្លែងរបស់ពួកគេសម្បូរសប្បាយ (មើល ទដ ៣៦:៨ ៤៦:៤ និងការពន្យល់, ៨៧:៧ អក ៤៧:១-១២ និង វវ ២២:១-២) ។ *ច្រកភ្នំសិទីម* មើល នក ២៥:៥ និងការពន្យល់ ។ គឺជាតំបន់វាលរហោស្ថានដែលសម្បូរទឹក ។

**៣:១៩** *ស្រុកអេស៊ីព្ទ . . . ស្រុកអេដំម* គឺជាសត្រូវចាស់របស់អ៊ីស្រាអែល គឺជាតំណាងឱ្យអស់ទាំងសាសន៍ដែលជាខ្មាំងសត្រូវរាស្ត្ររបស់ព្រះ (មើលការពន្យល់ អក ៣៥:១-១៥ សក ១០:១០) ។ *ស្ងាត់ច្រៀប . . . ទីរហោស្ថាន* គឺជាន័យធៀបអំពីការដកយកចេញនូវគ្រប់ទាំងព្រះពរដែលទ្រទ្រង់ជីវិតរស់នៅ ហើយបង្ហាញអំពីភាពខុសគ្នារវាងរាស្ត្ររបស់ព្រះ និងខ្មាំងសត្រូវនៃនគរព្រះ ។ ការនិយាយអំពីទីរហោស្ថានស្ងាត់ច្រៀបនេះក៏ជាការរំឭកផងដែរអំពីការពិពណ៌នាកាលពីមុនអំពីស្រុកយូដា (២:៣) ។

**៣:២០** *នឹងស្ថិតស្ថេរនៅជាដរាប* នៅពេលដែលការជំនុំជម្រះ និងការប្រោសលោះរបស់ព្រះត្រូវបានធ្វើឡើងហើយ នគររបស់ទ្រង់ និងស្ថិតស្ថេរនៅ និងរុងរឿងអស់កល្បជានិច្ច ។

**៣:២១** ព្រះគម្ពីរដែលនិយាយអំពីការជំនុំជម្រះនេះបានបញ្ចប់ទៅវិញដោយព្រះបន្ទូលសន្យា និងលើកទឹកចិត្តថា "ព្រះយេហូវ៉ាទ្រង់គង់នៅក្រុងស៊ីយ៉ូន" ដូចនេះ ការដែលជឿលើទ្រង់ និងនៅជាប់ជាមួយនឹងទ្រង់ គឺជាការដែលត្រឹមត្រូវជានិច្ច ។ ព្រះគម្ពីរអេសេគាលមានការបញ្ចប់ស្រដៀងគ្នានឹងព្រះគម្ពីរនេះផងដែរ (មើលការពន្យល់ អក ៤៨:៣៥) ។

# ព្រះគម្ពីរអេម៉ុស

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ

លោកអេម៉ុសជាអ្នកមកពីក្រុងត្កូអា (១:១) ដែលជាក្រុងតូចមួយនៅស្រុកយូដា ស្ថិតនៅចម្ងាយប្រហែល ៩,៦ គីឡូម៉ែត្រ ពីភូមិបេថ្លេហិម និងមានចម្ងាយ ១៧,៦ គីឡូម៉ែត្រ ពីក្រុងយេរូសាឡិម ។ លោកមិនមែនជាអ្នកធ្វើការរាជការដូចលោកអេសាយ ឬកើតនៅក្នុងត្រកូលពួកសង្ឃ ដូចលោកយេរេមា និងអេសេគាលទេ ។ គឺលោករកស៊ីចិញ្ចឹមជីវិតដោយការគង្វាលគោ និងបេះផ្លែដើមឧទុម្ពរ (១:១ ៧:១៤–១៥)។ គេមិនទាន់ដឹងច្បាស់ទេ ថាតើលោកអេម៉ុសជាម្ចាស់ហ្វូងគោ និងម្ចាស់ចម្ការដើមឧទុម្ពរ ឬគ្រាន់តែជាអ្នកស៊ីឈ្នួល ។ លោកអេម៉ុសមានជំនាញនៅក្នុងការនិយាយ ហើយពូកែខាងចំណេះដឹងទូទៅអំពីប្រវត្តិសាស្ត្រ និងពិភពលោក ដូចនេះលោក មិនមែនជាអ្នកស្រែដែលគ្មានចំណេះដឹងនោះទេ ។ ទោះបីជាផ្ទះរបស់លោកនៅប្រទេសយូដាក៏ដោយ ព្រះបានចាត់ឱ្យលោកទៅប្រកាសការជំនុំជម្រះរបស់ទ្រង់ដល់នគរខាងជើង(អ៊ីស្រាអែល)។ លោកប្រហែលជាបានធ្វើការបម្រើព្រះ ភាគច្រើននៅក្រុងបេត–អែល(៧:១០–១៣ ១ពវ ១២:២៨–៣០ និងការពន្យល់) ដែលគេចាត់ទុកជាកន្លែងបរិសុទ្ធ ដែលពួកវណ្ណៈថ្នាក់ខ្ពស់នៅនគរខាងជើងថ្វាយបង្គំ ។

នៅក្នុងព្រះគម្ពីរនេះ លោកអេម៉ុសបានរៀបចំសេចក្ដីទំនាយជាច្រើនរបស់លោក យ៉ាងប្រុងប្រយ័ត្ន ឱ្យមានលក្ខណៈជាបទទំនាយតែមួយ ។ លោកអេម៉ុសបានរៀបចំពាក្យនិយាយតាមលំដាប់លំដោយ ហើយព្រះគម្ពីរនេះគឺជាព្រះរាជសារសម្រាប់ជនជាតិអ៊ីស្រាអែលគ្រប់រូប(គឺទាំងអ្នកនៅប្រទេសយូដា និងទីក្រុងយេរូសាឡិមផងដែរ)។

### កាលបរិច្ឆេទ និងស្ថានភាពប្រវត្តិសាស្ត្រ

តាមខដំបូងនៃព្រះគម្ពីរអេម៉ុស លោកអេម៉ុសថ្លែងទំនាយនៅក្នុងរាជ្យស្ដេចអូសៀស ជាស្ដេចយូដា(៧៩២–៧៤០ មុនគ.ស.) និងស្ដេចយេរ៉ូបោម ជាស្ដេចអ៊ីស្រាអែល(៧៩៣–៧៥៣ មុនគ.ស.)។ ផ្នែកសំខាន់នៃការងារបម្រើព្រះរបស់លោកប្រហែលជាស្ថិតនៅចន្លោះឆ្នាំ ៧៦០–៧៥០ មុនគ.ស.។ នគរទាំងពីរកំពុងតែមានភាពសម្បូរសប្បាយ ហើយបានឈានទៅដល់អំណាចនយោបាយ និងកម្លាំងទ័ពថ្មី (ធៀបនឹង ២ពវ ១៤:២៣–១៥:៧ ២របា ២៦)។ សម័យនោះក៏ជាសម័យថ្វាយបង្គំរូបព្រះ ល្ងក់វង្វេងនឹងភាពហ៊ឺហារ អសីលធម៌ ពុករលួយនៅក្នុងស្ថាប័នយុត្តិធម៌ និងគាបសង្កត់អ្នកក្រ ។ ដោយសារការអាក្រក់ទាំងអស់នោះ ព្រះទ្រង់នឹងបណ្ដោយឱ្យចក្រភពអាសស៊ើរកាន់កាប់នគរខាងជើង ដោយដាក់ជាឈ្លើយក្នុងពេលដ៏ខ្លីខាងមុខ(ឆ្នាំ ៧២២ –៧២១ មុនគ.ស.)។

នៅសម័យនោះ ប្រទេសអ៊ីស្រាអែលកំពុងតែមានស្ថេរភាពផ្នែកនយោបាយ និងមានភាពស្ពប់ស្គល់ខាងវិញ្ញាណ ។ កាលពី ៤០ ឆ្នាំមុន នៅទីបញ្ចប់នៃការងារបម្រើព្រះរបស់លោកអេលីសេ លោកបានថ្លែងទំនាយអំពីការចាប់ផ្ដើមមានអំណាចឡើងវិញរបស់អ៊ីស្រាអែល(២ពវ ១៣:១៧–១៩) ហើយមុនសម័យនោះបន្តិចលោកយ៉ូណាសបានថ្លែងទំនាយអំពីការស្អាងឡើងវិញនូវភាពរុងរឿងដែលមិនធ្លាប់មានចាប់តាំងពីក្រោយសម័យស្ដេចសាឡូម៉ូន(២ពវ ១៤:២៥)។ ដូចនេះ ប្រទេសអ៊ីស្រាអែលនៅតែយល់ថា ខ្លួនជារាស្ត្ររើសតាំងពិសេសរបស់ព្រះ ។ ប៉ុន្តែ ភាពសម្បូរសប្បាយបានបង្ករឱ្យអ៊ីស្រាអែលមានភាពពុករលួយខាងជំនឿ និងសីលធម៌កាន់តែខ្លាំង ។ ព្រះទ្រង់បានបំភ្លេចការកាត់ទោសរបស់ទ្រង់កាលពីមុនដោយសារភាពមិនស្មោះត្រង់របស់ពួកគេ ហើយទ្រង់បញ្ឈប់ការអត់ធ្មត់របស់ទ្រង់ ដោយបញ្ជូនលោកអេម៉ុសឱ្យប្រកាសសេចក្ដីទំនាយ ។

ដោយសារលោកអេម៉ុសរស់នៅក្នុងសម័យតែមួយជាមួយនឹងលោកហូសេ និងយ៉ូណាស សូមមើលសេចក្ដីផ្ដើមនៃព្រះគម្ពីរទាំងពីរ ។

### ខ្លឹមសារ និងព្រះរាជសារខាងវិជ្ជាអំពីព្រះ

ខ្លឹមសារសំខាន់នៃព្រះគម្ពីរនេះគឺមាននៅក្នុង ៥:២៤ ដែលទាមទារឱ្យមានយុត្តិធម៌ក្នុងសង្គម ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវការមានជំនឿដ៏ពិត ។ លោកអេម៉ុសមានភាពមាំមួន និងខ្លាំងពូកែនៅក្នុងការនាំព្រះរាជសារ ដើម្បីស្វែងរកយុត្តិធម៌ និងសេចក្ដីសុចរិត ហើយលោកហូសេនិយាយសង្កត់ធ្ងន់ទៅលើ សេចក្ដីស្រឡាញ់ ព្រះគុណ សេចក្ដីមេត្តាករុណា និងសេចក្ដីសុចរិតរបស់ព្រះ ។ លោកអេម៉ុសប្រកាសថា ព្រះអម្ចាស់ទ្រង់នឹងជំនុំជម្រះរាស្ត្ររបស់ទ្រង់ ដោយសារភាពមិនស្មោះត្រង់ ការមិនស្ដាប់បង្គាប់ និងការរំលងសេចក្ដីសញ្ញា ។ ទោះបីជាព្រះអម្ចាស់បានជ្រើសរើសពួកគេជាពិសេស ហើយផ្ដល់នូវសេចក្ដីមេត្តាករុណាដល់ពួកគេនៅក្នុងពេលរំដោះពួកគេពីស្រុកអេស៊ីព្ទ និងពេលចូលកាន់កាប់ទឹកដីសន្យា ហើយនៅក្នុងសម័យស្ដេចដាវីឌ និងសាឡូម៉ូន រាស្ត្ររបស់ទ្រង់បានធ្វើខុសនឹងទ្រង់ម្ដងហើយ

ដោយមិនបានគោរព និងស្តាប់បង្គាប់ទ្រង់ ។ ទីបរិសុទ្ធនៃក្រុងបេត-អែល និងកន្លែងថ្វាយបង្គំដទៃទៀតត្រូវក្លាយជាកន្លែងថ្វាយបង្គំបែបសាសន៍ដទៃ ហើយពួកអ៊ីស្រាអែលមានទស្សនៈបែបលោកិយចំពោះពិធីបុណ្យដែលព្រះបានបង្គាប់ ។ ពួកគេយល់ថា ការធ្វើពិធីបុណ្យជាការបង្គាប់របស់ព្រះ ហើយឱ្យតែបានធ្វើបង្គ្រប់កិច្ចហើយ ពួកគេអាចធ្វើអ្វីក៏បានតាមចិត្ត ហើយការនេះគឺជំនឿបែបសាសន៍ដទៃ ។ ដោយសារពួកគេមិនខិតខំកាន់តាមក្រឹត្យវិន័យ ពួកគេគ្មានមូលដ្ឋានគ្រឹះនៃការប្រព្រឹត្តដែលត្រឹមត្រូវ ។ លោកអេម៉ុសបានធ្វើការថ្កោលទោសចំពោះអស់អ្នកដែលធ្វើឱ្យខ្លួនមានអំណាច ឬមានទ្រព្យសម្បត្តិដោយធ្វើអាក្រក់មកលើអ្នកដទៃ ។ ពួកអ្នកដែលមានផ្ទះសម្រាប់រដូវរងារ និងរដូវក្តៅ(៣:១៥) មានគ្រឿងសង្ហារឹមថ្លៃៗ និងរបស់មានតម្លៃជាច្រើនទៀតដោយការបោកប្រាស បង្វែរសេចក្តីយុត្តិធម៌ និងជិះជាន់សេចក្តីយុត្តិធម៌ នឹងត្រូវបាត់បង់អ្វីៗទាំងអស់ដែលពួកគេមាន ។

ការជំនុំជម្រះរបស់ព្រះអម្ចាស់ដែលត្រូវមកដល់ក្នុងពេលដ៏ខ្លីខាងមុខនោះ នឹងមិនជាការវាយផ្ចាលធម្មតា ដើម្បីគ្រាន់តែព្រមានអ៊ីស្រាអែលប៉ុណ្ណោះទេ(ដូចការជំនុំជម្រះមុនៗ មើល ៤:៦-១១ និងការពន្យល់) ប៉ុន្តែ គឺជាការបំផ្លិចបំផ្លាញពួកគេស្ទើរគ្មានសល់ ។ ការដែលមិននឹកស្មានដល់នឹងកើតឡើងក្នុងពេលឆាប់ៗនោះគឺ ព្រះទ្រង់នឹងដករំលើងឫសរបស់រាស្ត្រទ្រង់ ដោយបញ្ជូនពួកគេទៅក្នុងដៃសាសន៍ដទៃ ពីព្រោះពួកគេមិនស្មោះត្រង់នៅក្នុងការញែកខ្លួនពួកគេជាបរិសុទ្ធសម្រាប់ការដឹកនាំរបស់ព្រះអម្ចាស់ ។ ទោះជាយ៉ាងនេះក៏ដោយ ឱ្យតែពួកគេប្រែចិត្ត ពួកគេអាចនៅមានសង្ឃឹមថា "ព្រះដ៏មានគ្រប់ព្រះចេស្តា(នឹង)មានសេចក្តីមេត្តាដល់ពួកសំណល់"(៥:១៥ មើល ៥:៤-៦,១៤)។ តាមការពិត ព្រះអម្ចាស់ទ្រង់បានរៀបចំអនាគតដ៏រុងរឿងសម្រាប់រាស្ត្ររបស់ទ្រង់ គឺមិនប្រទានតែសេចក្តីជំនុំជម្រះប៉ុណ្ណោះទេ ។ ពួកវង្សហ្លួងដាវីឌនឹងបានគ្រប់គ្រងអ៊ីស្រាអែលសាជាថ្មីម្តងទៀត ហើយថែមទាំងពង្រីកការគ្រប់គ្រងមកលើសាសន៍ដទៃថែមទៀត ហើយអ៊ីស្រាអែលនឹងបានសុខសាន្តនៅក្នុងទឹកដីសន្យា ដោយមានពិធីជប់លៀងដោយស្រាទំពាំងបាយជូរ និងផ្លែឈើ(៩:១១-១៥)។ ព្រះនៃអ៊ីស្រាអែល ដែលជាម្ចាស់នៃប្រវត្តិសាស្ត្រ នឹងមិនបោះបង់ចោលរាស្ត្រជ្រើសតាំង ឬផែនការសង្គ្រោះរបស់ទ្រង់ទេ ។

ព្រះដែលលោកអេម៉ុសបម្រើ មិនមែនគ្រាន់តែជាព្រះរបស់អ៊ីស្រាអែលប៉ុណ្ណោះទេ ។ ព្រះទ្រង់ក៏បានប្រើសាសន៍មួយឱ្យទាស់នឹងសាសន៍មួយ ដើម្បីឱ្យព្រះហឫទ័យទ្រង់បានសម្រេច(៦:១៤) ។ ទ្រង់ជាមហាក្សត្រដ៏អស្ចារ្យដែលគ្រប់គ្រងសាកលលោកទាំងមូល(៤:១៣ ៥:៨ ៩:៥-៦)។ ដោយសារទ្រង់មានអំណាចគ្រប់គ្រងលើអ្វីៗទាំងអស់ ព្រះនៃអ៊ីស្រាអែលទ្រង់ជាម្ចាស់នៃប្រវត្តិសាស្ត្រ និងជោគវាសនានៃមនុស្សគ្រប់រូប និងលោកិយដែលនៅក្នុងព្រះហស្តទ្រង់ ។ អ៊ីស្រាអែលមិនគ្រាន់តែត្រូវដឹងថា ទ្រង់ជាព្រះនៃអនាគតរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវដឹងថា ទ្រង់ជាម្ចាស់លើគ្រប់ទាំងអស់ផងដែរ ហើយត្រូវដឹងថា ទ្រង់មានគោលបំណង និងការគិតគូរហួសពីព្រំដែនរបស់អ៊ីស្រាអែលទៅទៀត ។ អ៊ីស្រាអែលគ្រាន់តែជារាស្ត្រជ្រើសតាំងរបស់ព្រះ ប៉ុន្តែមិនមែនមានសិទ្ធដាច់មុខនៅក្នុងការធ្វើជារាស្ត្ររបស់ព្រះនោះទេ ។ ពួកគេត្រូវចងចាំ មិនគ្រាន់តែការប្តូផ្តាច់របស់ទ្រង់នៅក្នុងការតាំងសេចក្តីសញ្ញាជាមួយនឹងពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវចងចាំការតព្វកិច្ចដែលពួកគេត្រូវមាននៅក្នុងសេចក្តីសញ្ញា (មើលសេចក្តីទំនាយរបស់លោកយ៉ូណាសជាបន្ថែមទៀត)។

**គម្រោងសង្ខេប**

I. ពាក្យលំនាំ(១:១)

II. សេចក្តីផ្តើមនៃព្រះគម្ពីរអេម៉ុស(១:២)

III. សេចក្តីទំនាយទាស់នឹងប្រទេសយូដា និងប្រទេសអ៊ីស្រាអែល(១:៣-២:១៦)

- ក. ការជំនុំជម្រះប្រទេសស៊ីរី (១:៣-៥)
- ខ. ការជំនុំជម្រះប្រទេសភីលីស្ទីន(១:៦-៨)
- គ. ការជំនុំជម្រះប្រទេសភីនីក(១:៩-១០)
- ឃ. ការជំនុំជម្រះប្រទេសអេដំម(១:១១-១២)
- ង. ការជំនុំជម្រះប្រទេសអាំម៉ូន(១:១៣-១៥)
- ច. ការជំនុំជម្រះប្រទេសម៉ូអាប់(២:១-៣)
- ឆ. ការជំនុំជម្រះប្រទេសយូដា(២:៤-៥)
- ជ. ការជំនុំជម្រះប្រទេសអ៊ីស្រាអែល(២:៦-១៦)
  - ១. ការគៀបសង្កត់អ្នកក្រដោយគ្មានអាណិតអាសូរ (២:៦-៧ក)
  - ២. ការប្រព្រឹត្តស្មោកគ្រោកដោយមិនគោរពដល់ជំនឿ(២:៧ខ-៨)
  - ៣. ការធ្វើផ្ទុយរបស់ពួកអ៊ីស្រាអែល(២:៩-១២)

៤. ប្រព័ន្ធនៃការគាបសង្កត់នឹងត្រូវរលាយ (២:១៣–១៦)

IV. សេចក្តីទំនាយទាស់នឹងអ៊ីស្រាអែល (៣:១–៥:១៧)

ក. ការជំនុំជម្រះរាស្ត្រជ្រើសតាំង (ជំពូក ៣)

១. ការប្រកាសពីការជំនុំជម្រះ (៣:១–២)

២. ការប្រកាសដែលមានយុត្តិធម៌ (៣:៣–៨)

៣. ការជំនុំជម្រះដែលមានយុត្តិធម៌ (៣:៩–១៥)

ខ. ការជំនុំជម្រះលើរាស្ត្រដែលមិនប្រែចិត្ត (ជំពូក ៤)

១. ការជំនុំជម្រះពួកគាបសង្កត់អ្នកក្រ (៤:១–៣)

២. ការក្លែងការរស់នៅតាមជំនឿ (៤:៤–៥)

៣. មហន្តរាយកាលពីមុន មិនបាននាំឱ្យមានការប្រែចិត្ត (៤:៦–១១)

៤. គ្មានសេចក្តីសង្ឃឹមសម្រាប់ពួកមនុស្សចិត្តរឹង (៤:១២–១៣)

គ. ការជំនុំជម្រះរាស្ត្រដែលធ្វើអំពើអយុត្តិធម៌ (៥:១–១៧)

១. ការទួញសោកនឹងការស្លាប់ (៥:១–៣)

២. ការលើកទឹកចិត្តឱ្យស្វែងរកការរស់នៅ (៥:៤–៦)

៣. ពាក្យបណ្តឹងចំពោះអំពើអយុត្តិធម៌ (៥:៧–១៣)

៤. ការលើកទឹកចិត្តឱ្យស្វែងរកការរស់នៅ (៥:១៤–១៥)

៥. ភាពសម្បូរសប្បាយនឹងប្រែក្លាយជាការសោកសង្រេង (៥:១៦–១៧)

V. ការប្រកាសពីការនិរទេស (៥:១៨–៦:១៤)

ក. សេចក្តីវេទនាដែលនឹងកើតឡើងដល់អ៊ីស្រាអែលដោយសារការក្បត់ជំនឿ (៥:១៨–២៧)

ខ. សេចក្តីវេទនាដែលនឹងកើតឡើងដល់អ៊ីស្រាអែលដោយសារអំនួតនឹងការស្កប់ស្កល់ចិត្ត (៦:១–៧)

គ. ការស្បថថានឹងជំនុំជម្រះសាសន៍ដែលមានអំនួត និងអយុត្តិធម៌ (៦:៨–១៤)

VI. ការបើកសំដែងឱ្យឃើញការជំនុំជម្រះ (៧:១–៩:១០)

ក. ការជំនុំជម្រះដែលមានការបន្ធូរបន្ថយ (៧:១–៦)

១. ហ្វូងកណ្តូប (៧:១–៣)

២. ភ្លើងឆេះបំផ្លាញ (៧:៤–៦)

ខ. ការជំនុំជម្រះដោយគ្មានការបន្ធូរបន្ថយ (៧:១០–១៧)

១. កូនតឹង (៧:៧–១៧)

១.១ ការបើកសំដែង (៧:៧–៩)

១.២ លោកអេម៉ុសទទួលការជំរុញ និងគ្មានទោស (៧:១០–១៧)

២. កំប្រោងដាក់ផ្លែឈើទុំ (ជំពូក ៨)

២.១ ការបើកសំដែង (៨:១–៣)

២.២ ការពន្យល់អំពីការបើកសម្តែង (៨:៤–១៤)

៣. ព្រះអម្ចាស់ឈរនៅក្បែរអាសនា (៩:១–១០)

៣.១ ការបើកសំដែង (៩:១–៤)

៣.២ ការពន្យល់អំពីការបើកសម្តែង (៩:៥–១០)

VII. អនាគតនៃព្រះពររបស់អ៊ីស្រាអែលដែលព្រះអម្ចាស់បានស្អាងឡើងវិញហើយ (៩:១១–១៥)

ក. ការបំផ្លាសបំប្រែនៃវង្សស្តេចដាវីឌ (៩:១១–១២)

ខ. ការស្អាងអ៊ីស្រាអែលឡើងវិញ ដើម្បីឱ្យបានទទួលទឹកដីសន្យានៃសួនច្បារអេដែន (៩:១៣–១៥)

# ១

១ នេះជាពាក្យរបស់អេម៉ុស ជាម្នាក់ក្នុងពួកគង្វាលនៅ
ត្កូអា[ក] គឺជាសេចក្ដីដែលគាត់បានឃើញ ពីដំណើរពួក
អ៊ីស្រាអែលនៅក្នុងរាជ្យនៃអូសៀស[ខ] ជាស្ដេចយូដា ហើយ
ក្នុងរាជ្យនៃយេរ៉ូបោម[គ] ជាបុត្រយ៉ូអាស ស្ដេចអ៊ីស្រាអែល[ឃ]
គឺ២ឆ្នាំមុនកក្រើកដី[ង]។
២ គាត់ពោលថា ព្រះយេហូវ៉ាទ្រង់នឹងស្រែកគ្រហឹម[ច] ពី
ស៊ីយ៉ូន ហើយបញ្ចេញព្រះសូរសៀង[ឆ]ពីក្រុងយេរូសាឡិម[ជ]
មក នោះទីវាលស្មៅរបស់ពួកអ្នកគង្វាលនឹងសៅសោក
ហើយកំពូលភ្នំកើមែល[ឈ]នឹងហែងទៅ[ញ]។

**១:១** ក ២សយ ១៤:២ ខ ២ពវ ១៤:២១ ២របា ២៦:២៣ គ ២ពវ ១៤:២៣ ឃ សហ ១:១ ង សក ១៤:៥ **១:២** ច អស ៤២:១៣ ឆ ទដ ២៩:៣ ជ យអ ៣:១៦ ឈ អម ៩:៣ ញ យរ ១២:៤ **១:៣** ដ អស ៧:៨

## ការជំនុំជម្រះនគរជិតខាងរបស់អ៊ីស្រាអែល

៣ ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះ
អំពើរំលងទាំង៣របស់ក្រុងដាម៉ាស[ដ] អើ ដោយព្រោះ៤ផង
នោះអញនឹងមិនព្រមលើកទោសគេចោលឡើយ[ឋ] ពីព្រោះ
គេបានបញ្ជាន់ស្រុកកាឡាត ដោយគ្រឿងបញ្ជាន់ធ្វើពីដែក
៤ អញនឹងចាត់ប្រើភ្លើង[ឌ] ឱ្យចូលទៅក្នុងផ្ទះរបស់ហាសែល[ឍ]
ភ្លើងនេះនឹងឆេះដំណាក់[ណ]របស់បេន–ហាដាឌទៅ[ត]
៥ អញ

៨:៤ ១៧:១–៣ ឋ ខ.៦,៩,១១,១៣ អម ២:៦ **១:៤** ឌ យរ ៤៩:២៧ អគ ៣០:៨ ឍ ១ពវ ១៨:១៧ ២ពវ ៨:៧–១៥ ណ យរ ១៧:២៧ ត ១ពវ ២០:១ ២ពវ ៦:២៤ យរ ៤៩:២៣–២៧

**១:១** *អេម៉ុស* ឈ្មោះនេះប្រហែលជាទម្រង់ខ្លីនៃឈ្មោះ "អ័ម៉ាស៊ីយ៉ា" (២របា ១៧:១៦) ដែលមានន័យថា "ព្រះអម្ចាស់ទ្រង់ទ្រ" ឬ "ព្រះអម្ចាស់ទ្រង់រក្សា"។ *ពួកគង្វាល* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពាក្យនេះនៅក្នុងបទគម្ពីរផ្សេងទៀត គឺប្រើសំដៅទៅលើស្ដេចនៃសាសន៍ម៉ូអាប់(២ពវ ៣:៤ ដែលប្រែមកថា "ចិញ្ចឹមចៀម") ។ ធៀបនឹង ៧:១៤ ដែលប្រើពាក្យផ្សេងទៀត ។ លោកអេម៉ុសមិនមានអាជីពជាហោរាទេ គឺលោកមានការងារផ្សេងក្រៅពីកិច្ចការខាងសេចក្ដីជំនឿ ។ *ត្កូអា* មើលសេចក្ដីផ្ដើមត្រង់អ្នកនិពន្ធ ។ *បានឃើញ* គឺឃើញ ដោយការបើកសម្ដែងដែលមកពីព្រះ ។ *អូសៀស* មើលសេចក្ដីផ្ដើមត្រង់កាលបរិច្ឆេទ និងស្ថានភាពប្រវត្តិសាស្ត្រ និងការពន្យល់ អស ៦:១ ។ *យេរ៉ូបោម* មើលសេចក្ដីផ្ដើមត្រង់កាលបរិច្ឆេទ និងស្ថានភាពប្រវត្តិសាស្ត្រ ។ *កក្រើកដី* មានភស្តុតាងបញ្ជាក់ថា ការកក្រើកដីដ៏ខ្លាំងមួយដែលគេចងចាំអស់ពេលដ៏យូរ ហើយប្រហែលជាការកក្រើកដីដែលបញ្ជាក់នៅក្នុង សក ១៤:៥ ។ តាមការសិក្សាបុរាណវត្ថុវិទ្យាថ្មីៗនេះ ការកក្រើកដីដ៏ខ្លាំងនោះបានកើតឡើងប្រហែលឆ្នាំ ៧៥០ មុនគ.ស. ។ អ្នកនិពន្ធបានលើកយកការកក្រើដីមកនិយាយ ដើម្បីបង្ហាញថា នោះគឺជាការជំនុំជម្រះដែលកើតឡើងតាមបទទំនាយ ។

**១:២** គឺជាខគន្លឹះនៃព្រះគម្ពីរនេះ ដែលជាការប្រកាសរបស់លោកអេម៉ុសអំពីហេតុការអាក្រក់ដែលត្រូវកើតឡើង ។ *ស្រែកគ្រហឹម* ព្រះអម្ចាស់បានចាត់លោកអេម៉ុសដែលជាអ្នកគង្វាល ឱ្យទៅព្រមានដល់សាសន៍អ៊ីស្រាអែលថា លោកបានឮសម្រែកតោគ្រហឹម ហើយតោនោះគឺជាព្រះអម្ចាស់ ដែលទ្រង់គ្រាន់តែចង់ធ្វើជាអ្នកគង្វាលសាសន៍អ៊ីស្រាអែល ។ ចំពោះការនិយាយប្រៀបធៀបដូចនេះនៅក្នុងបរិបទផ្សេងទៀត មើល យរ ២៥:៣០ យអ ៣:១៦ ។ *ពីស៊ីយ៉ូន* ព្រះអម្ចាស់ទ្រង់សាងរាជបល្ល័ង្ករបស់ទ្រង់នៅលើលោកិយ នៅក្រុងយេរូសាឡិម នៅក្នុងចំណោមរាស្ត្រពិសេសរបស់ទ្រង់ ហើយទ្រង់ប្រកាសសេចក្ដីជំនុំជម្រះពួកគេ និងសាសន៍ដទៃ ពីទីកន្លែងនោះទៅ ។ *ទីវាលស្មៅ . . . កំពូលភ្នំកើមែល* មើល ៩:៣ ។ សេចក្ដីជំនុំជម្រះនៃព្រះអម្ចាស់នឹងបានដូចជាភាពរាំងស្ងួតយ៉ាងខ្លាំង ដែលបំផ្លាញទីកដីទាំងស្រុង ចាប់ពីកន្លែងទាប និងស្ងួតបំផុត ដល់ទីកន្លែងខ្ពស់ និងពណ៌បៃតងបំផុត

**១:៣–២:១៦** វគ្គនេះនិយាយអំពីបទទំនាយជាបន្តបន្ទាប់ ដែលថ្លែងទាស់នឹងសាសន៍ជាច្រើន ចំពោះវគ្គដែលស្របនឹងវគ្គនេះ មើល អស ១៣:១–២៣:១៨ និងការពន្យល់ ។ បន្ទាប់ពីប្រកាសអំពីការជំនុំជម្រះ(ការជំនុំជម្រះដែលធ្វើឱ្យសាសន៍អ៊ីស្រាអែលអរសប្បាយ) ប្រទេសជិតខាងអ៊ីស្រាអែលចំពោះអំពើអាក្រក់ផ្សេងៗរបស់ពួកគេ លោកអេម៉ុសប្រកាសអំពីការថ្កោលទោសរបស់ព្រះអម្ចាស់ចំពោះនគរទាំងពីររបស់ទ្រង់ ដែលបានប្រមាថដល់ក្រឹត្យវិន័យទ្រង់ ។ ការដែលទ្រង់បានរាយបញ្ជីអំពើបាបរបស់អ៊ីស្រាអែលនៅក្នុងពាក្យបណ្ដឹង ដូចគ្នានឹងពាក្យបណ្ដឹងដែលទ្រង់ប្រើចំពោះសាសន៍ដទៃ គឺជាការបង្ហាញអំពីអំពើបាប ដែលសាសន៍អ៊ីស្រាអែលប្រព្រឹត្តជាមួយនឹងប្រទេសជិតខាង ។

**១:៣** *ទ្រង់មានបន្ទូលដូច្នេះថា* មើល ខ.៦,៩,១១,១៣ ២:១,៤,៦ ។ ក្នុងនាមជាអ្នកនាំព្រះបន្ទូលព្រះអម្ចាស់ លោកអេម៉ុសថ្លែងទំនាយតាមរបៀបអ្នកនាំសារ ដោយបញ្ជាក់អំពីប្រភពច្បាស់លាស់នៃបទទំនាយ ។ *ដោយព្រោះអំពើរំលងទាំង៣ . . . ៤ផង* មានន័យថា ដោយព្រោះអំពើបាបដែលបានធ្វើជាច្រើន ជាពិសេសអំពើបាបមួយដែលបានបញ្ជាក់ ។ មើល ខ.៦,៩,១១,១៣ ២:១,៤,៦ ។ ចំពោះការរៀបរាប់ដោយប្រើលេខស្រដៀងគ្នានឹងខនេះសូមមើល យប ៥:១៩ សភ ៦:១៦ មីក ៥:៥ និងការពន្យល់ ។ *ក្រុងដាម៉ាស* ជារាជធានីនៃប្រទេសស៊ីរី នៅភាគខាងជើងនៃប្រទេសអ៊ីស្រាអែល (មើលការពន្យល់ អស ១៧:១) ហើយជាសត្រូវជានិរន្ត នៅសម័យនោះ ។ ទោសនៃទីក្រុងនេះគឺ អំពើយុងឃ្នងដែលប្រព្រឹត្តមកលើប្រជាជននៃទឹកដីដែលខ្លួនបានកាន់កាប់ នៅក្រុងកាឡាត ជាទឹកដីរបស់អ៊ីស្រាអែល ដែលនៅខាងកើតស្រុកកាលីឡេ ។ *អញនឹងមិនព្រមលើកទោសគេចោលឡើយ* មើល អស ៩:១២,១៧,២១ និងការពន្យល់, យរ ២៣:២០ ។ *បញ្ជាន់ . . . គ្រឿងបញ្ជាន់ធ្វើពីដែក* ធៀបនឹង យប ៤១:៣០ អស ២៨:២៧ ៤១:១៥ ហាព ៣:១២ មើល ២ពវ ១៣:៧ និងការពន្យល់ រម ១:២២ ។

**១:៤** *ភ្លើង . . . នឹងឆេះ* មើល ខ.៧,១០,១២,១៤ ២:២,៥ ។ ឃ្លានេះគឺជាការពិពណ៌នាអំពីការគំរាមកំហែងនៃការជំនុំជម្រះនៃព្រះអម្ចាស់ ដែលតាមធម្មតាទ្រង់នាំឱ្យមាននូវសង្គ្រាមបំផ្លិចបំផ្លាញ ដោយដុតបំផ្លាញទីក្រុងសំខាន់ៗ និងបន្ទាយទាហាន (មើល យរ ១៧:២៧ និងការពន្យល់, ហស ៨:១៤) ។ *ហាសែល* គឺជាស្ដេចនៃក្រុងដាមាស និងជាអ្នកបង្កើតខ្សែរាជវង្សថ្មី (មើល ២ពវ ៨:៧–១៥ និងការពន្យល់ ៨:១៥) ។ *ដំណាក់* មើល ខ.៧,១០,១២,១៤ ២:២,៥ ។ ពាក្យនេះមិនគ្រាន់តែប្រើសំដៅទៅលើរាជដំណាក់របស់ពួកស្ដេចដែលមានសណ្ឋានដូចបន្ទាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំដៅទៅលើបន្ទាយទាហានផងដែរ ។ *បេន–ហាដាឌ* គឺជាកូនរបស់ស្ដេចហាសែល (មើល ២ពវ ១៣:៣ និងការពន្យល់) និងស្ដេចមួយអង្គទៀតដែលមានឈ្មោះដូចនេះដែរ (ធៀបនឹង ២ពវ ៨:១៤–១៥) ។

**១:៥** *ពួកអ្នក* មើល ខ.៨ គឺសំដៅទៅលើ "ពួកអ្នកដែលអង្គុយលើបល្ល័ង្ក"។ *ច្រកភ្នំអាវេន* អាចជាច្រកភ្នំ "បេកា" (Beqaa) ដែលស្ថិតនៅចន្លោះភ្នំនៃ

នឹងបំបាក់រនុកទ្វារ[ថ]របស់ក្រុងដាម៉ាស ហើយកាត់ពួកអ្នក
នៅច្រកភ្នំអាវេនចេញ ព្រមទាំងអ្នកដែលកាន់ដំបងរាជ្យ
របស់បេត–អេដែនផង[ទ] នោះពួកសាសន៍ស៊ីរីនឹងត្រូវទៅ
ជាឈ្លើយដល់ស្រុកគារ[ធ]នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ន]។
៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះ
អំពើរំលងទាំង៣របស់ក្រុងកាសា[ប]ហើយដោយព្រោះ៤ផង
នោះអញនឹងមិនព្រមលើកទោសគេចោលឡើយ[ផ] ពីព្រោះ
គេបានកៀរយកពួកឈ្លើយទាំងអស់ ដើម្បីប្រគល់ដល់
សាសន៍អេដុំម[ព] ៧អញនឹងចាត់ប្រើភ្លើងឱ្យទៅលើកំផែង
នៃក្រុងកាសា ភ្លើងនោះនឹងឆេះដំណាក់របស់គេអស់ទៅ
៨អញនឹងកាត់ពួកអ្នកនៅក្រុងអាសដូឌចេញ[ភ] ព្រមទាំងអ្នក
ដែលកាន់ដំបងរាជ្យនៃក្រុងអាសកាឡូនផង អញក៏នឹង
បែរដៃ[ម]ទៅទាស់នឹងក្រុងអេក្រុនដែរ នោះសំណល់នៃពួក
ភីលីស្ទីន[យ]នឹងត្រូវវិនាសបង់[រ] នេះជាព្រះបន្ទូលនៃព្រះ
អម្ចាស់យេហូវ៉ា[ល] ។
៩ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះ
អំពើរំលងទាំង៣របស់ក្រុងទីរ៉ុស[វ] អើ ដោយព្រោះ៤ផង
នោះអញនឹងមិនព្រមលើកទោសគេចោលឡើយ[ស] ពីព្រោះ
គេបានប្រគល់ពួកឈ្លើយទាំងអស់ដល់សាសន៍អេដុំម ឥត

**១:៥** ថ យរ ៥១:៣០ ទ អស ៣៧:១២ ធ ២ពវ ១៦:៩ អស ២២:៦ សក ៩:១ ន អស ៧:១៦ យរ ៤៩:២៧ **១:៦** ប លប ១០:១៩ ១សយ ៦:១៧ សផ ២:៤ ផ ខ.៣ ព លប ១៤:៦ អប ១:១១ **១:៨** ភ ២របស ២៦:៦ ម ទដ ៨១:១៤ យ អគ ២៥:១៦ រ អស ៣៤:៨ ល អស ១៤:២៨–៣២ សផ ២:៤–៧ **១:៩** វ ១ពវ ៥:១ ៩:១១–១៤ យរ ២៥:២២ យអ ៣:៤ មថ ១១:២១ ស ខ.៣ ហ ១ពវ ៥:១២ **១:១០** ឡ អស ២៣:១–១៨ ៣៤:៨

នឹកចាំសេចក្ដីសញ្ញាជាបងប្អូននឹងគ្នាសោះ[ហ] ១០អញនឹង
ចាត់ប្រើភ្លើង ឱ្យទៅលើកំផែងនៃក្រុងទីរ៉ុស ភ្លើងនោះ
នឹងឆេះដំណាក់របស់គេអស់ទៅ[ឡ]។
១១ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះ
អំពើរំលងទាំង៣របស់សាសន៍អេដុំម[អ] អើ ដោយព្រោះ
៤ផង នោះអញនឹងមិនព្រមលើកទោសគេចោលឡើយ
ពីព្រោះគេបានកាន់ដាវ[ក] ដេញតាមបងប្អូនខ្លួន ព្រមទាំង
សង្កត់រំលត់សេចក្ដីមេត្តាប្រណីរបស់ខ្លួនផង ឯសេចក្ដី
កំហឹងរបស់គេបានចេះតែហែកហួរជានិច្ច ក៏រក្សាសេចក្ដី
ក្រោធ ទុកនៅជាដរាប[ខ] ១២អញនឹងចាត់ប្រើភ្លើងឱ្យទៅលើ
ក្រុងថេម៉ាន[គ] ភ្លើងនោះនឹងឆេះដំណាក់របស់ក្រុងបុសរ៉ា
អស់ទៅ[ឃ]។
១៣ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះ
អំពើរំលងទាំង៣របស់ពួកកូនចៅអាំម៉ូន[ង] អើ ដោយព្រោះ
៤ផង នោះអញនឹងមិនព្រមលើកទោសគេចោលឡើយ

យរ ៤៧:៤ អគ ២៦:២–៤ សក ៩:១–៤ **១:១១** អ ជន ២០:១៤–២១ ២របស ២៨:១៧ ទដ ៨៣:៦ ក ទដ ៦៣:១០ ខ អគ ២៥:១២–១៤ សក ១:១៥ **១:១២** គ លប ៣៦:១១,១៥ ឃ អស ៣៤:៥ ៦៣:១–៦ យរ ២៥:២១ អគ ២៥:១២–១៤ ៣៥:១–១៥ អប ១:១ មឡ ១:២–៥ **១:១៣** ង លប ១៩:៣៨ អគ ២១:២៨

ប្រទេសល្បាណូន និងភ្នំនៃខ្មាំងសត្រូវនៃប្រទេសនេះ ប៉ុន្តែអាចសំដៅទៅលើជ្រលងទន្លេ និងជាទីតាំងនៃទីក្រុងដាម៉ាស(ការពន្យល់ ២ពវ ៥:១២) គេហៅជ្រលងទន្លេនេះថា "ជ្រលងនៃសេចក្ដីទុច្ចរិត"។ *បេត–អេដែន* ប្រហែលជាទីក្រុងដាម៉ាស ដែលជាទីកន្លែងសួនច្បារនៃតំបន់នេះ ។ *ពួកសាសន៍ស៊ីរី* មើលការពន្យល់ ចទ ២៦:៥ ។ *ស្រុកគារ* គេមិនទាន់ស្គាល់កន្លែងនេះនៅឡើយទេ ។ អាចជាកន្លែងជិតខាងនៃតំបន់អេឡាម(មើល ២ពវ ១៦:៩ និងការពន្យល់) ។

**១:៦** *ក្រុងកាសា* គឺជាទីក្រុងមួយក្នុងចំណោមទីក្រុងសំខាន់ៗទាំងប្រាំរបស់សាសន៍ភីលីស្ទីន គឺជាទីកន្លែងការពារច្រកចូលទឹកដីកាណានពីប្រទេសអេស៊ីព្ទ ។ *ពួកឈ្លើយទាំងអស់* មើល ខ.៩ ។ គឺមិនគ្រាន់តែជាពួកទាហានដែលចាប់បាននៅក្នុងសង្គ្រាមប៉ុណ្ណោះទេ ។ ប្រហែលជាសំដៅទៅលើពួកអ្នករស់នៅភូមិទាំងឡាយដែលតំបន់ខាងត្បូងនៃស្រុកយូដា ដែលនៅតាមផ្លូវពាណិជ្ជកម្មពីប្រទេសអេដុំមទៅទីក្រុងកាសា ។ *ដល់សាសន៍អេដុំម* មើល ខ.៩ ។ នៅត្រង់ចំណុចនេះ ពួកគេជួញដូរមនុស្សដូចហ្វូងគោទៅប្រទេសផ្សេងទៀត ។

**១:៨** *ក្រុងអាសដូឌ . . . ក្រុងអាសកាឡូន . . . ក្រុងអេក្រុន* គឺជាទីក្រុងសំខាន់ៗបីទៀតរបស់សាសន៍ភីលីស្ទីន (មើលការពន្យល់ ខ.៦)។ ទីក្រុងកាថគឺជាទីក្រុងទីប្រាំ (ធៀបនឹង ៦:២) ប្រហែលជាត្រូវស្ដេចអូសៀសវាយកាន់កាប់ (មើល ២របស ២៦:៦) ។ *វិនាសបង់* មានន័យថា និងមិនមាននៅសល់ពួកសំណល់ទេ ។ ប្រទេសភីលីស្ទីននឹងត្រូវបំផ្លាញដោយស្ដេចនៃប៊ូក្អេសានៅទីបញ្ចប់ ។

**១:៩** *ក្រុងទីរ៉ុស* គឺជាទីក្រុងជំនួញ ដែលបានចងសម្ព័ន្ធមិត្រជាមួយនឹងសាសន៍អ៊ីស្រាអែល នៅក្នុង "សន្ធិសញ្ញាបងប្អូន" នៅរាជ្យស្ដេចដាវីឌ(១ពវ ៥:១) ហើយម្តងទៀតនៅក្នុងរាជ្យនៃស្ដេចសាឡូម៉ូន(១ពវ ៥:១២) ហើយក្រោយមកទៀតនៅក្នុងរាជ្យស្ដេចអ័ហាប់ ដែលមានឪពុកក្មេកជាអ្នកដឹកនាំទីក្រុងទីរ៉ុស និងស៊ីដូន(១ពវ ១៦:៣០–៣១)។ *ប្រគល់ពួកឈ្លើយ* ការនេះគឺដូចជាទង្វើអាក្រក់របស់ពួកភីលីស្ទីន(ខ.៦)។

**១:១០** *កំផែងក្រុង* ទីក្រុងទីរ៉ុសគឺកោះដែលមិនអាចវាយបំបែកបាន ហើយមានអំនួតនឹងសន្តិសុខរបស់ខ្លួន(ធៀបនឹង អគ ២៦:១–២៨:១៩)។

**១:១១** *សាសន៍អេដុំម* សាសន៍នេះជាកូនចៅរបស់លោកអេសាវ(លប ៣៦ ២៥:២៣–៣០ ២៧:៣៩–៤០ និង ២៥:២៥)។ *បងប្អូន* គឺសាសន៍អ៊ីស្រាអែល (មើល អប ៨–១០ និងការពន្យល់ អប ១០)។ ក្នុងខនេះប្រហែលជាសំដៅទៅលើ "បងប្អូន"ដែលចុះសេចក្ដីសញ្ញានឹងគ្នា(មើលការពន្យល់ ខ.៩)។ កំហុសរបស់សាសន៍អេដុំម គឺការបំពានទំនាក់ទំនងនេះដោយការធ្វើជាសត្រូវនឹងសាសន៍អ៊ីស្រាអែលមិនឈប់ឈរ ។

**១:១២** *ក្រុងថេម៉ាន . . . ក្រុងបុសរ៉ា* គឺជាទីក្រុងសំខាន់ៗរបស់ប្រទេសអេដុំម គេយល់ថា ក្រុងថេម៉ានមានទីតាំងនៅក្បែរទីក្រុងពេត្រា(មើលការពន្យល់ អប ៩) ហើយក្រុងបុសរ៉ាគឺជាទីក្រុងប៊ូសេរ៉ា(Buseirah) ដែលមានចម្ងាយប្រហែល ៦០ គីឡូម៉ែត្រ នៅភាគខាងជើង ។ ដោយត្រូវទទួលរងការបំផ្លិចបំផ្លាញ សាសន៍អេដុំមនឹងត្រូវបាត់បង់សមត្ថភាពបន្តសង្គ្រាម ។

**១:១៣** *ពួកកូនចៅអាំម៉ូន* សេចក្ដីជំនុំជម្រះនឹងផ្ដោតទៅលើទីក្រុងរ៉ាបាត (ខ.១៤ និងការពន្យល់ ចទ ៣:១១) ដែលសព្វថ្ងៃគេហៅថាទីក្រុងអាំម៉ាន (Amman)។ សេចក្ដីលោភលន់ស្រេកឃ្លានទឹកដីបាននាំឱ្យមានអំពើប្រល័យពូជសាសន៍យ៉ាងសាហាវព្រៃផ្សៃ ដែលត្រូវទទួលជំនុំជម្រះដោយសម្រេក

ពីព្រោះគេបានវះពោះរបស់ពួកស្រីៗ[ច] ដែលមានទំងន់នៅ
ស្រុកកាឡាត ដើម្បីឱ្យបានវាតព្រំស្រុករបស់ខ្លួនឱ្យធំឡើង
១៤អញនឹងបង្កាត់ភ្លើងនៅលើកំផែងនៃក្រុងរ៉ាបាត[ឆ] ភ្លើង
នោះនឹងឆេះ[ជ]ដំណាក់របស់គេអស់ទៅ ដោយសូរស្រែក
ហ៊ោ[ឈ]ក្នុងថ្ងៃសង្គ្រាម និងដោយព្យុះសង្ឃរា ក្នុងថ្ងៃដែល
មានខ្យល់កំបុតត្បូង[ញ] ១៥នោះស្តេចរបស់គេនឹងត្រូវចាប់
ទៅជាឈ្លើយ ព្រមទាំងពួកចៅហ្វាយរបស់គេផង[ដ] នេះ
ជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ឋ]។

**២** ១ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះ
អំពើរំលងទាំង៣របស់សាសន៍ម៉ូអាប់[ក] អើ ដោយព្រោះ៤
ផង នោះអញនឹងមិនព្រមលើកទោសគេចោលឡើយ ពី
ព្រោះគេបានដុតឆ្អឹងរបស់ស្តេចអេដំម ធ្វើជាកំបោរ[ខ]
២អញ នឹងចាត់ប្រើភ្លើងឱ្យទៅលើម៉ូអាប់ ភ្លើងនោះនឹង
ឆេះដំណាក់នៅក្រុងកេរីយ៉ុតអស់ទៅ[គ] ហើយម៉ូអាប់នឹង
ស្លាប់ទៅដោយសូរគ្រាំគ្រេង ដោយសំរែក[ឃ]ឮលាន់ និង
សូរផ្លុំត្រែ[ង] ៣អញនឹងកាត់ចៅក្រម[ច]ពីកណ្តាលគេចេញព្រម
ទាំងសំឡាប់ពួក ចៅហ្វាយទាំងប៉ុន្មានជាមួយនឹងគេដែរ[ឆ]
នេះជាព្រះបន្ទូល នៃព្រះយេហូវ៉ា[ជ]។

៤ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ដោយព្រោះ
អំពើរំលងទាំង៣របស់ពួកយូដា[ឈ] អើ ដោយព្រោះ៤ផង

**១:១៣** ច លប ៣៤:២៩ ២ពវ ៨:១២ ហស ១៣:១៦
**១:១៤** ឆ ចទ ៣:១១ ជ អស ៣០:៣០ ឈ យប ៣៩:២៥ ញ យរ ២៣:១៩
**១:១៥** ដ យរ ២៥:២១ ឋ ១របា ២០:១ យរ ៤៩:១ អគ ២១:២៨–៣២ ២៥:២–៧
**២:១** ក អស ១៦:៦ ខ អស ៣៣:១២
**២:២** គ យរ ៤៨:២៤ ឃ យប ៣៩:២៥ ង យស ៦:២០
**២:៣** ច ទដ ២:១០ ឆ អស ៤០:២៣ ជ អស ១៥:១–៩ ១៦:១–១៤ ២៥:១០ យរ ៤៨:១ អគ ២៥:៨–១១ សផ ២:៨–៩
**២:៤** ឈ ២ពវ

នោះអញនឹងមិនព្រមលើកទោសគេចោលឡើយ ពីព្រោះ
គេបានបោះបង់ចោលក្រិត្យវិន័យ[ញ]របស់ព្រះយេហូវ៉ា ហើយ
មិនបានកាន់តាមបញ្ញត្តិច្បាប់[ដ]របស់ទ្រង់សោះ ឯរបស់
កំភូត[ឋ] ដែលពួកឰយុកោគេបានគោរពតាម[ឌ] នោះបានធ្វើ
ឱ្យគេវង្វេង[ឍ]ចេញ ៥អញនឹងចាត់ប្រើភ្លើង[ណ]ឱ្យទៅលើពួក
យូដា ភ្លើងនោះនឹងឆេះដំណាក់[ត]នៅក្រុងយេរូសាឡិមអស់
ទៅ[ថ]។

## ការជំនុំជម្រះនគរអ៊ីស្រាអែល

៦ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា ដោយព្រោះអំពើ
រំលងទាំង៣របស់ពួកអ៊ីស្រាអែល អើ ដោយព្រោះ ៤ផង
នោះអញនឹងមិនព្រមលើកទោសគេចោលឡើយ[ទ] ពីព្រោះ
គេបានលក់មនុស្សសុចរិត ឱ្យបានប្រាក់ ហើយមនុស្សកំសត់
ទុគ៌តផង ឱ្យបានស្បែកជើង១សំរាប់[ធ] ៧សូម្បីតែធូលីដីដែល
នៅលើក្បាលមនុស្សកំសត់ទុគ៌តនោះ គេក៏ដង្ហក់ចង់បាន
ដែរ ហើយគេបង្វែរផ្លូវរបស់មនុស្សរាបទាប ឯទាំងកូននឹង
ឪពុកក៏ចូលទៅឯស្រីក្រមុំតែ១ ជាការដែល បង្អាប់ដល់នាម

១៧:១៩ ហស ១២:២ ញ យរ ៦:១៩ ដ អគ ២០:២៤ ឋ នក ៣៤:១៥ ចទ ៣១:២០ ទដ ៤:២ ឌ ២ពវ ២២:១៣ ឍ អស ៩:១៦ **២:៥** ណ ២ពវ ២៥:៩ ២របា ៣៦:១៩ ត អម ៣:១១ ថ យរ ១៧:២៧ ហស ៨:១៤ **២:៦** ទ អម ១:៣ ធ យអ ៣:៣ អម ៨:៦

ច្រូលច្របល់នៃហ្វូងមនុស្ស និងធម្មជាតិ ហើយនឹងគ្មានអ្នកដឹកនាំប្រទេស ដើម្បីនឹងបន្តអំពើនោះតទៅទៀត (មើល ១ពវ ៨:១២ និងការពន្យល់) ។
**១:១៤** បទទំនាយក្នុងខនេះត្រូវបានសំរេចដោយចក្រភពអាសស៊ើរ ។
**១:១៥** *ស្តេចរបស់គេ* មើល យរ ៤៩:៣ និងការពន្យល់ ៤៩:១ ។
**២:១** *សាសន៍ម៉ូអាប់* មានទីតាំងនៅភាគខាងកើតនៃសមុទ្រស្លាប់(មើលការពន្យល់ អស ១៥:១)។ *ដុតឆ្អឹងរបស់ស្តេចអេដំម ធ្វើជាកំបោរ* គឺមានន័យថា សូម្បីតែកន្លែងកប់សពក៏គ្មានដែរ ។
**២:២** *ក្រុងកេរីយ៉ុត* ប្រហែលជានាមពហុវចនៈ ដែលមានន័យថា "ទីក្រុង" ឬជាឈ្មោះរបស់ទីក្រុងសំខាន់មួយ(មើល យរ ៤៨:២៤) និងជាទីសក្ការៈរបស់ព្រះកេម៉ូស ដែលជាព្រះរបស់សាសន៍ម៉ូអាប់(មើល ១ពវ ១១:៧,៣៣)
**២:៤** *បោះបង់ចោលក្រិត្យវន័យ* អំពើបាបរបស់សាសន៍យូដាគឺខុសពីអំពើបាបរបស់សាសន៍ដទៃ ។ ពួកសាសន៍ដទៃបានធ្វើអំពើបាបតែពួកគេមិនបានស្គាល់ក្រឹត្យវិន័យព្រះទេ ប៉ុន្តែសាសន៍យូដាបានធ្វើខុសនឹងក្រឹត្យវិន័យដែលព្រះបានប្រទានដល់ពួកគេ ។ អំពើបាបទាំងនោះប្រហែលជាមាននៅក្នុងពាក្យបណ្តឹងនៃព្រះអម្ចាស់ ទាស់នឹងសាសន៍អ៊ីស្រាអែល ។
**២:៥** *ភ្លើង . . . ឆេះដំណាក់* មើល ១:៤ និងការពន្យល់ ។ ព្រះអម្ចាស់នឹងជំនុំជម្រះស្រុកយូដា ដូចស្រុកស៊ីរី(១:៤) ភីលីស្ទីន(១:៧) ភីនិក (១:១០) អេដំម(១:១២) អាំម៉ូន(១:១៤) និងម៉ូអាប់(២:២) ដោយត្រូវបាត់បង់ការការពារ និងទ្រព្យសម្បត្តិ ដែលពួកគេបានជឿទុកចិត្ត ។
**២:៦** អំពើបាបរបស់សាសន៍អ៊ីស្រាអែល បានបង្ហាញអំពីការធ្លាក់ចុះនៃសីលធម៌ជាទូទៅនៃសាសន៍នេះ ។ *មនុស្សសុចរិត* គឺពួកអ្នកដែលមិនជាប់បំណុលអ្វី ហើយគ្មានហេតុផល ឬច្បាប់អ្វីត្រូវយកទៅលក់ជាទាសករ (ធៀបនឹង លប ២៥:៣៩–៤៣)។ ឬម្យ៉ាងទៀត ពាក្យ"មនុស្សសុចរិត"នៅក្នុងខនេះអាច សំដៅទៅលើ "អ្នកក្រ"(ខ.៧ ធៀបនឹង ៥:១២ ៨:៦) ដែលផ្ទុយពីពួកមនុស្សទុច្ចរិត ដែលមានអំណាច និងទ្រព្យសម្បត្តិ(មើល ៤:១–៥ ៦:១–៧)។ *មនុស្សកំសត់* ព្រះអម្ចាស់ទ្រង់បានបង្គាប់ឱ្យជួយដល់ពួកគេ(មើល ចទ ១៥:៧–១១ និងការពន្យល់ ១៥:១១) ប៉ុន្តែ ពួកគេបែរជាត្រូវបានលក់ដោយសារមិនអាចសងបំណុល(ប្រហែលបំណុលតែបន្តិចបន្តួច) ហើយពួកគេត្រូវបានគេទិញដោយស្បែកជើងតែមួយសម្រាប់(មើល ៨:៦)។
**២:៧** *ដង្ហក់ចង់បាន* មើល ៥:១១ ៨:៤ ។ *មនុស្សកំសត់ទុគ៌គត . . . មនុស្សរាបទាប* គឺជាពួកអ្នកដែលត្រូវទទួលការយកចិត្តទុកដាក់ និងការការពារ ពីអំពើអយុត្តិធម៌ ដូចដែលមានបង្គាប់យ៉ាងច្បាស់នៅក្នុងក្រឹត្យវិន័យនៃសាសន៍អ៊ីស្រាអែល(នក ២៣:៦–៨) ហើយនៅតំបន់មជ្ឈឹមបូព៌ាសម័យដើម ពួកស្តេចជាច្រើនក៏ទទួលការជំរុញឱ្យការពារពួកគេផងដែរ ។ *កូននឹងឪពុកក៏ចូលទៅឯស្រីក្រមុំតែ១* គេមិនដឹងច្បាស់ថាតើស្រីក្រមុំនៅក្នុងខនេះ ជាអ្នកបម្រើក្នុងផ្ទះ(នៅក្នុងខនេះ ឪពុកនិងកូនប្រុសបានយកអ្នកបម្រើក្នុងផ្ទះ ធ្វើជាស្រីសំផឹងក្នុងផ្ទះ)ឬយ៉ាងណានោះទេ ។ ទោះជាក្នុងករណីណាក៏ដោយ ក្រឹត្យវិន័យបានតម្រូវមកថា បុរសដែលមានទំនាក់ទំនងផ្លូវភេទជាមួយនឹងស្រីក្រមុំណាម្នាក់ ត្រូវរៀបការជាមួយនឹងនាង(នក ២២:១៦ ចទ ២២:២៨–២៩) ។ ការដែលឪពុក និងកូនប្រុសមានទំនាក់ទំនងផ្លូវភេទជាមួយនឹងស្រីក្រមុំ

បរិសុទ្ធរបស់អញ[ន] [៨]គេក្រាលសំលៀកបំពាក់ ដែលបាន
ទទួលបញ្ចាំ ដេកចុះនៅក្បែរគ្រប់ទាំងអាសនា[ប] ហើយនៅ
ក្នុងវិហាររបស់ព្រះនៃគេ នោះគេផឹកស្រាទំពាំងបាយជូរ[ផ]
របស់ពួកអ្នក ដែលខ្លួនបានពិន័យលក់ហើយដែរ[ព]។
[៩]ប៉ុន្តែឯអញៗបានបំផ្លាញសាសន៍អាម៉ូរី[ភ] ដែលមាន
កំពស់ដូចដើមតាត្រៅ ហើយមានកំឡាំង[ម] ដូចជាដើម
ម៉ៃសាក់ចេញពីមុខឯងទៅ[យ] គឺអញបានបំផ្លាញទាំងផលគេ
ខាងលើ និងឫសគេ[រ]នៅក្រោមផង [១០]អញក៏បាននាំឯង
រាល់គ្នាឡើងចេញពីស្រុកអេស៊ីព្ទមក[ល] គឺបាននាំមុខ[វ]ឯង
នៅក្នុងទីរហោស្ថានអស់៤០ឆ្នាំ[ស] ឲ្យបានចាប់យកស្រុក
របស់សាសន៍អាម៉ូរី ទុកជាកេរ្តិ៍អាករ[ហ] [១១]អញបានតាំងពួក
កូនចៅខ្លះរបស់ឯងរាល់គ្នាឡើងធ្វើជាហោរា[ឡ] និងពួក
កំឡោះខ្លះរបស់ឯងធ្វើជាពួកណាសារីត[អ] ព្រះយេហូវ៉ាទ្រង់
សួរថា ឱពួកកូនចៅអ៊ីស្រាអែលអើយ តើមិនមែនដូច្នោះ ឬ
[១២]ប៉ុន្តែឯងរាល់គ្នាឲ្យពួកណាសារីតផឹកស្រាទំពាំងបាយជូរ
វិញហើយបានហាមដល់ពួកហោរាថាកុំឲ្យទាយឡើយ[ក]។
[១៣]មើល អញនឹងកិនឯងរាល់គ្នា នៅទីកន្លែងរបស់
ឯង ដូចជារទេះដែលពេញដោយកណ្តាប់តែងកិនដីដែរ[ខ]

**២:៧** ន លវ ១៨:២១ អម ៥:១១–១២ ៨:៤ **២:៨** ប នក ២២:២៦ ចទ ២៤:១២–១៣ ផ ហស ៧:១៤ អម ៤:១ ៦:៦ ព ហព ២:៦ **២:៩** ភ ជន ២១:២៣–២៦ យស ១០:១២ ម អស ១០:៣៣ យ ទជ ២៩:៩ រ ២ពវ ១៩:៣០ យប ១៨:១៦ អគ ១៧:៩ **២:១០** ល នក ៦:៦ ២០:២ អម ៣:១ វ ចទ ៨:២ ស ចទ ២:៧ ហ នក ៣:៨ ជន ២១:២៥ យស ១៣:៤ អម ៩:៧

[១៤]នោះអំណាចរត់រួច និងបាត់ចេញពីមនុស្សល្បឿន[គ] ឯ
មនុស្សមានកំឡាំង[ឃ] ក៏មិនបានចំរើនកំឡាំងរបស់ខ្លួនដែរ
ហើយមនុស្សពូកែនឹងដោះខ្លួនឲ្យរួចមិនបាន[ង] [១៥]អ្នកណា
ដែលកាន់ធ្នូ[ច]នឹងមិនអាចឈរនៅបាន ឯអ្នកដែលមានថ្មើ
ជើង នោះមិនបានរួចដែរ ហើយអ្នកដែលជិះសេះ[ឆ] នឹង
មិនដោះខ្លួនឲ្យរួចបានឡើយ[ជ] [១៦]ចំណែកអ្នកដែលមាន
ចិត្តក្លាហានក្នុងពួកខ្លាំងពូកែ[ឈ] គេនឹងរត់ទៅទាំងខ្លួនអា
ក្រាតក្នុងថ្ងៃនោះ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។

## សួរបន្ទាល់ទាស់នឹងនគរអ៊ីស្រាអែល

៣ [១]ឱពួកកូនចៅអ៊ីស្រាអែលអើយ ចូរស្តាប់ព្រះបន្ទូលនេះ
ដែលព្រះយេហូវ៉ាបានមានបន្ទូលទាស់នឹងឯងរាល់គ្នា[ក] គឺ
ទាស់នឹងគ្រួទាំងមូលដែលអញបាននាំឡើងចេញពីស្រុក
អេស៊ីព្ទមកគឺថា[ខ] [២]ក្នុងអស់ទាំងគ្រួនៅផែនដីអញបានស្គាល់

**២:១១** ឡ ចទ ១៨:១៨ យរ ៧:២៥ អ ពច ១៣:៥ **២:១២** ក អស ៣០:១០ យរ ១១:២១ អម ៧:១២–១៣ មីក ២:៦ **២:១៣** ខ អម ៧:១៦–១៧ **២:១៤** គ យបប ១១:២០ ឃ ១ពវ ២០:១១ ង ទជ ៣៣:១៦ អស ៣០:១៦–១៧ **២:១៥** ច អគ ៣៩:៣ ឆ នក ១៥:២១ សក ១០:៥ ជ សស ៩:១១ **២:១៦** ឈ យរ ៤៨:៤១ **៣:១** ក សជ ២:៥ ខ អម ២:១០

ឬស្ត្រីតែមួយ គឺត្រូវហាមឃាត់ដាច់ខាត (លវ ១៨:៧–៨,១៥ ២០:១១–១២)។ *បង្អាប់ដល់នាមបរិសុទ្ធរបស់អញ* ធៀបនឹង លវ ១៨:២១ និងការពន្យល់ ១៩:១២ ២០:៣ ២១:៦ ២២:២,៣២ ។ មើល យរ ៣៤:១៦ អគ ២០:៩ និងការពន្យល់ ៣៦:២០–២៣ ៣៩:៧ ។

**២:៨** *សំលៀកបំពាក់ ដែលបានទទួលបញ្ចាំ* ក្រឹត្យវិន័យបានហាមឃាត់ការទទួលបញ្ចាំសំលៀកបំពាក់រហូតដល់ពេលយប់ (នក ២២:២៦–២៧ និងការពន្យល់ ចទ ២៤:១២–១៣) និងការទទួលបញ្ចាំសំលៀកបំពាក់ស្ត្រីមេម៉ាយ (ចទ ២៤:១៧)។ *ពិន័យលក់* គឺពិន័យឲ្យសងចំពោះការខូចខាត ។ នៅត្រង់ចំណុចនេះប្រហែលជាសំដៅទៅលើការពិន័យដែលមិនត្រូវ ។ *នៅក្បែរគ្រប់ទាំងអាសនា ហើយនៅក្នុងវិហាររបស់ព្រះនៃគេ* ពួកសាសន៍អ៊ីស្រាអែលដែលរំលងក្រឹត្យវិន័យដែលការពារអ្នកទន់ខ្សោយ បានទាញយកផលដោយឥតខ្មាសពីទីកន្លែងជាច្រើន សូម្បីតែកន្លែងដែលរាប់ជាទីបរិសុទ្ធក៏ដោយ ។

**២:៩** *អញៗបានបំផ្លាញ* សាសន៍អ៊ីស្រាអែលមិនគ្រាន់តែបានទទួលក្រឹត្យវិន័យពីព្រះអម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានទទួលជំនួយពីទ្រង់ថែមទៀតផង ។ *សាសន៍អាម៉ូរី* នៅត្រង់ចំណុចនេះគឺសំដៅទៅលើអស់អ្នកដែលរស់នៅក្នុងស្រុកកាណាន (មើលការពន្យល់ លប ១០:១៦ ១៥:១៦ ពច ៦:១០)។ *មានកំពស់ . . . មានកំឡាំង* ចំនួនប្រជាជន ឬកម្លាំងទ័ពកាណានមិនអាចទប់ទល់នឹងជ័យជម្នះនៃព្រះអម្ចាស់បានទេ (មើល យស ១០:៥,១២–១៣)។ *ផលគេខាងលើ និងឫសគេនៅខាងក្រោម* មានន័យថា ទាំងស្រុង ។

**២:១០** *អញក៏បាននាំឯងរាល់គ្នាឡើងចេញ* មើល ៣:១ និង នក ២០:២ និងការពន្យល់ ។ ព្រះអម្ចាស់បានប្រទានព្រះពរដល់អ៊ីស្រាអែលកាលពីមុន ហើយដោយសារពួកគេប្រព្រឹត្តខុស ព្រះអម្ចាស់ទ្រង់បានធ្វើពាក្យចោទប្រកាន់ពួកគេ ។

**២:១១** *អញបានតាំង . . . ជាហោរា និង . . . ជាពួកណាសារីត* ពួកហោរាគឺជាអ្នកនាំសារដ៏ស្មោះត្រង់របស់ព្រះអម្ចាស់ (មើល ចទ ១៨:១៥–២០ និងការពន្យល់ ១៨:១៥) និងពួកណាសារីត គឺជាពួកដែលលះបង់ខ្លួនជាពិសេសថ្វាយដល់ព្រះ (មើល ជន ៦:១–២១ និងការពន្យល់ ៦:២ ពច ១៣:៥ និងការពន្យល់) ហើយពួកគេគឺជាអំណោយដ៏ពិសេសពីព្រះអម្ចាស់ ។ ពួកគេស្ថិតនៅក្រៅការងារពួកសង្ឃ ហើយព្រះអម្ចាស់ទ្រង់ប្រើពួកគេ ឲ្យនាំសារទ្រង់ និងរស់នៅជាគំរូ ដើម្បីត្រាស់ហៅរាស្ត្រទ្រង់ឲ្យមានភាពស្មោះត្រង់ ។

**២:១២** *ប៉ុន្តែ ឯងរាល់គ្នា* ពួកសាសន៍អ៊ីស្រាអែលបានប្រើពាក្យប្រមាថមើលងាយដល់អ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះ ដូចនេះពួកគេកំពុងបង្ហាញពីចិត្តដ៏ស្មោកគ្រោក ចំពោះព្រះរាជកិច្ចដែលទ្រង់ធ្វើនៅក្នុងចំណោមពួកគេ (ធៀបនឹង ៧:១៦)។

**២:១៣** រទេះដែលមានផ្ទុកពីលើ កិនបំផ្លាញរបស់អ្វីដែលធ្លាក់នៅពីក្រោមកង់របស់វា ។

**២:១៤–១៦** អ្នកដែលទុកចិត្តថា ខ្លួនអាចឈរមាំមួន ឬគេចខ្លួនបាន នឹងមិនអាចជួយសង្គ្រោះខ្លួនឯងបានទេ ។

**២:១៦** *នៅថ្ងៃនោះ* គឺនៅថ្ងៃដែលព្រះអម្ចាស់ទ្រង់នឹងយាងមកជំនុំជម្រះ (មើល ៥:១៨ យអ ១:១៥ និងការពន្យល់) ដូចដែលទ្រង់បានធ្វើដោយបញ្ជូនចក្រភពអាសស៊ើរឲ្យឈ្លានពាន ដណ្តើមយកទឹកដីនគរខាងជើង ។

**៣:១–៥:១៧** វគ្គនេះគឺជាបទទំនាយដែលនិយាយសង្កត់ធ្ងន់អំពីការជំនុំជម្រះដែលព្រះអម្ចាស់ទ្រង់ប្រាកដជាធ្វើចំពោះសាសន៍អ៊ីស្រាអែល ។

**៣:១** *ចូរស្តាប់ព្រះបន្ទូល* មើល ៤:១ ៥:១ ។ ព្រះអម្ចាស់ទ្រង់ត្រាស់ហៅរាស្ត្ររបស់ទ្រង់ឲ្យសារភាពអំពើបាបរបស់ពួកគេ ។

តែ[គ]ឯងរាល់គ្នាទេ ដូច្នេះ អញនឹងធ្វើទោស[ឃ]ដល់ឯងរាល់
គ្នា ដោយព្រោះអំពើទុច្ចរិតទាំងប៉ុន្មានរបស់ឯង[ង] ៣បើ
មនុស្ស២នាក់មិនព្រមចិត្តគ្នា នោះតើនឹងដើរជា១គ្នាបានឬ
៤ឯសិង្ហ និងស្រែកគ្រហឹម[ច]នៅក្នុងព្រៃ ក្នុងកាលដែលមិន
ទាន់ចាប់រំពាឬ[ឆ] បើសិង្ហស្ទាវមិនបានចាប់អ្វីសោះ តើនឹង
ស្រែកនៅក្នុងរូងវាដែរឬ ៥នៅកន្លែងដែលឥតមានដាក់
ខ្សែរូត នោះសត្វហើរអាចនឹងធ្លាក់ទៅជាប់ក្នុងអន្ទាក់[ជ] បាន
ឬ តើអន្ទាក់នឹងវាត់ឡើងពីដី ឥតមានជាប់អ្វីឬទេ ៦តើនឹងផ្លុំ
ត្រែ[ឈ]នៅក្នុងក្រុង ឥតធ្វើឱ្យបណ្ដាជនក្ដុកចិត្តបាន ឬតើនឹង
មានអន្តរាយ[ញ]កើតដល់ទីក្រុងណា ឥតព្រះយេហូវ៉ាធ្វើដែរ
ឬទេ[ដ] ៧ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់នឹងមិនធ្វើអ្វី ដូច្នោះ
ឡើយ លើកតែទ្រង់សំដែង ឱ្យពួកហោរា ជាអ្នកបំរើទ្រង់
ឃើញគំនិតលាក់កំបាំង[ឋ]របស់ទ្រង់ផង[ឌ] ៨រីឯសិង្ហ[ឍ]បាន
ស្រែកគ្រហឹមហើយ[ណ] តើមានអ្នកណាដែលមិនព្រម ខ្លាច
ព្រះអម្ចាស់យេហូវ៉ា ទ្រង់បានចេញវាចាហើយ តើមានអ្នក
ណានឹងទប់មិនទាយបានឬ[ត]។

៩ចូរប្រកាសប្រាប់នៅក្នុងដំណាក់ នៅក្រុងអាសដូឌ[ថ]
ហើយក្នុងដំណាក់នៅស្រុកអេស៊ីព្ទផងថា ចូរមូលគ្នាមក
នៅលើអស់ទាំងភ្នំរបស់ស្រុកសាម៉ារី[ទ]ពិចារណាមើលការ
កោលាហលយ៉ាងធំ និងការសង្កត់សង្កិនដែលកើតមាន
នៅកណ្ដាលស្រុកនោះចុះ ១០ដ្បិតព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា គេមិនចេះប្រព្រឹត្តត្រឹមត្រូវទេ[ធ] គេជាពួកអ្នកដែល
សន្សំទុកនូវសេចក្ដីច្រឡោត និងការរឹបជាន់[ន]នៅក្នុងអស់
ទាំងដំណាក់[ប]របស់គេ ១១ហេតុនោះបានជាព្រះអម្ចាស់
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា និងមានខ្មាំងសត្រូវឡោម
ព័ទ្ធស្រុក វានឹងនាំឱ្យកំឡាំងឯងអន់ថយចុះ នោះអស់ទាំង
ដំណាក់របស់ឯងនឹងត្រូវរឹបជាន់វិញ[ផ] ១២ព្រះយេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះថា អ្នកគង្វាលដោះជើង២ នឹងត្រចៀក
១កំណាត់ ចេញពីមាត់សិង្ហ[ព]យ៉ាងណា នោះពួកកូនចៅ
អ៊ីស្រាអែលដែលអង្គុយនៅទីកៀនដំណេក ហើយលើ
ខ្នើយកំណល់ធ្វើពីសូត្រ នៅក្នុងក្រុងសាម៉ារី នឹងបាន
ដោះឱ្យរួចយ៉ាងនោះដែរ[ភ]។

១៣ព្រះអម្ចាស់យេហូវ៉ា ជាព្រះនៃពួកពលបរិវារទ្រង់
មានបន្ទូលថា ចូរស្តាប់ចុះ ហើយធ្វើបន្ទាល់[ម]ទាស់នឹងពួក
វង្សយ៉ាកុប ១៤ដ្បិតនៅថ្ងៃដែលអញទំលាក់អំពើរំលង[យ]
របស់អ៊ីស្រាអែលទៅលើគេវិញ នោះអញនឹងធ្វើទោស

**៣:២** គ នក ១៩:៦ ចទ ៧:៦ លក ១២:៤៧ ឃ ខ.១៤ ង យរ ១៤:១០ មីក ២:៣ ១ពត ៤:១៧ **៣:៤** ច អស ៤២:១៣ ឆ ទដ ១០៤:២១ ហស ៥:១៤ **៣:៥** ជ ទដ ១១៩:១១០ **៣:៦** ឈ ជន ១០:២ យប ៣៩:២៤ យរ ៤:២១ ញ អស ៣១:២ ដ អស ១៤:២៤–២៧ **៣:៧** ឋ លប ១៨:១៧ ១សយ ៣:៧ ដយ ៩:២២ យហ ១៥:១៥ វវ ១០:៧ ឌ យរ ២៣:២២ **៣:៨** ឍ អស ៣១:៤ ណ អស ៤២:១៣ ត យរ ២០:៩ យហ ១:១–៣ ៣:១–៣ កច ៤:២០ **៣:៩** ថ យស ១៣:៣ ២រប ២៦:៦ ទ អម ៤:១ ៦:១ **៣:១០** ធ អម ៥:៧ ៦:១២ ន ហាព ២:៨ ប ទដ ៣៦:៣ មីក ៦:១០ សផ ១:៩ **៣:១១** ផ អម ២:៥ ៦:១៤ **៣:១២** ព ១សយ ១៧:៣៤ ភ នអ ១:៦ អម ៦:៤ **៣:១៣** ម អគ ២:៧ **៣:១៤** យ ខ.២ លវ ២៦:១៨

**៣:២** *តែឯងរាល់គ្នាទេ* កម្លាំង និងភាពសម្បូរសប្បាយដែលពួកអ៊ីស្រាអែលមាននៅពេលនេះ បាននាំឱ្យពួកគេមានការពេញចិត្តនឹងអភ័យឯកសិទ្ធិជារាស្ត្រជ្រើសតាំងនៃព្រះ ។ ប៉ុន្តែ ពួកគេបានបំភ្លេចចោលការទទួលខុសត្រូវដែលពួកគេបានទទួលពីអភ័យឯកសិទ្ធិនេះ ។

**៣:៣–៦** វគ្គនេះគឺជាសំណួរប្រៀបធៀប ដែលលោកអេម៉ុសប្រើដើម្បីបន្តពាក្យក្នុង វគ្គ ៧–៨ ដើម្បីពន្យល់ពីមូលហេតុដែលលោកត្រូវប្រើពាក្យគួរឱ្យភ័យខ្លាចនេះ ។ លោកបានប្រើពាក្យនិយាយអំពីហេតុ និងផល ហើយធ្វើការប្រៀបធៀបដោយនិយាយអំពីសកម្មភាពនៅក្នុងជីវិតពិត និងអំពីការអស្ចារ្យដែលព្រះទ្រង់ធ្វើ(ខ.៦) ។

**៣:៧** *ពួកហោរា ជាអ្នកបំរើទ្រង់* មើល យរ ៧:២៥ សក ១:៦ និងការពន្យល់ ។

**៣:៨** *សិង្ហបានស្រែកគ្រហឹម* មើល ១:២ និងការពន្យល់ ។ *តើមានអ្នកនានឹងទប់មិនទាយបានឬ* លោកអេម៉ុសត្រូវតែថ្លែងទំនាយ ពីព្រោះព្រះអម្ចាស់បានមានបន្ទូលមកកាន់គាត់ហើយ ។

**៣:៩** ពួកអ្នកមានទ្រព្យសម្បត្តិ និងពួកអ្នកមានអំណាច នៅស្រុកភីលីស្ទីន និងអេស៊ីព្ទ បានឮការប្រកាសប្រាប់ឱ្យធ្វើជាសាក្សីនៃពាក្យបណ្ដឹងនៃព្រះអម្ចាស់ទាស់នឹងពួកអ្នកដែលប្រមូលទ្រព្យទុកនៅក្នុងទីមាំមួននៃស្រុកសាម៉ារី ដោយការអាក្រក់(មើល ខ.១៥)។ *ដំណាក់* មើលការពន្យល់ ១:៤ ។ *ការកោ–លាហលយ៉ាងធំ* គឺកើតឡើងពីអំពើហឹង្សា ដែលបណ្ដាលមកពីការកាន់អំណាចដោយភាពអាត្មានិយម ដោយមិនប្រកាន់យកនូវយុត្តិធម៌តាមក្រឹត្យវិន័យព្រះ ។

**៣:១០** *ពួកអ្នកដែលសន្សំទុក* ធៀបនឹង ២:៦–៨ ។ នៅក្នុងខជាបន្តបន្ទាប់ ព្រះអម្ចាស់ទ្រង់ប្រកាសជំនុំជម្រះពួកសាសន៍អ៊ីស្រាអែល ដែលជាអ្នកមានដែលរកទ្រព្យបានដោយការគៀបសង្កត់ និងឆក់ប្លន់ (សូមធៀបនឹង ហប ២:៦–១១) ។

**៣:១១** *ខ្មាំងសត្រូវ* គឺពួកសាសន៍អាសស៊ើរ ។ *ដំណាក់របស់ឯងនឹងត្រូវរឹបជាន់* គឺសំដៅទៅលើពួកអ្នកមាននៅស្រុកសាម៉ារី ដែលមានភាពលោភលន់

**៣:១២** *អ្នកគង្វាលដោះជើង២* ពាក្យនេះប្រើដើម្បីប្រាប់ដល់ម្ចាស់ចៀមថា ចៀមរបស់ខ្លួនត្រូវបានសត្វព្រៃស៊ីហើយ គឺមិនមែនត្រូវពួកគង្វាលលួចទេ ។ *នឹងបានដោះឱ្យរួច* អ្នកដែលគេចផុតពីសេចក្ដីស្លាប់ គឺជាពួកសំណល់ដែលទទួលរងគ្រោះថ្នាក់យ៉ាងដំណំ ។ ជាតិសាសន៍ដូចនោះនឹងត្រូវទទួលរងលើសពីការរបួស គឺនឹងត្រូវទទួលរងការបំផ្លាញ ។ *ពួកកូនចៅអ៊ីស្រា–អែលដែលអង្គុយ* គឺអង្គុយយ៉ាងខ្ជិលនៅលើគំនរទ្រព្យសម្បត្តិ(មើល ៦:៤)។

**៣:១៣** *ស្តាប់ . . . ធ្វើបន្ទាល់* ពាក្យនេះគឺនិយាយទៅកាន់ពួកអ្នកដែលបានទទួលការប្រកាសហៅនៅក្នុង ខ.៩ ។ ពួកអ្នកមាន និងអ្នកមានអំណាចនៅប្រទេសភីលីស្ទីន និងអេស៊ីព្ទបានទទួលការប្រកាសហៅឱ្យមកស្ដាប់នូវពាក្យបណ្ដឹងនៃព្រះអម្ចាស់ទាស់នឹងពួកអ្នកមាន និងអ្នកមានអំណាចនៅស្រុកសាម៉ារី និងដើម្បីឱ្យពួកគេធ្វើជាសាក្សីចំពោះសេចក្ដីពិតនៃពាក្យបណ្ដឹង និងភាពពិតប្រាកដនៃការជំនុំជម្រះរបស់ទ្រង់ ។

**៣:១៤** *អាសនានៃបេត–អែល* អំពើបាបនៃសាសន៍អ៊ីស្រាអែលបានមានប្រភពពីអាសនាក្លែងក្លាយដែលស្តេចយេរ៉ូបោមទីមួយ បានសង់នៅស្រុកបេតអែល(១ពវ ១២:២៦–៣៣)។ *ស្នែងអាសនា* ត្រង់ចំណុចនេះមានន័យ

ដល់អាសនានៃបេត-អែលទាំងប៉ុន្មានដែរ[រ] ស្នែង[ល]អាសនា
ទាំងនោះនឹងត្រូវកាត់ចេញឱ្យធ្លាក់ដល់ដី ១៥អញនឹងវាយ
បំផ្លាញអស់ទាំងផ្ទះ[វ]សំរាប់រដូវរងា និងផ្ទះសំរាប់រដូវ
ក្តៅ[ស]ផងឯដំណាក់ភ្លុក[ហ]នឹងត្រូវវិនាសទៅ ហើយផ្ទះធំៗ
ទាំងប៉ុន្មាន[ឡ]នឹងត្រូវសូន្យបាត់[អ]នេះ ជាព្រះបន្ទូលនៃព្រះ
យេហូវ៉ា[ក] ។

## ពួកអ៊ីស្រាអែលនៅតែមិនទាន់បែរមកឯព្រះវិញ

**៤** ១ឱពួកគោពីស្រុកបាសាន[ក]អើយ ចូរស្តាប់ពាក្យនេះ
ចុះ ឯងរាល់គ្នាដែលនៅលើភ្នំសាម៉ារី[ខ] កំពុងសង្កត់សង្កិន
ពួកក្រីក្រ[គ] ហើយជាន់ឈ្លីពួកកំសត់ទុគ៌ត[ឃ] ឯងនិយាយដល់
ចៅហ្វាយរបស់ខ្លួនថា[ង] ចូរនាំយកមកឱ្យយើងបានផឹកជា
មួយគ្នា[ច] ២ព្រះអម្ចាស់យេហូវ៉ាទ្រង់បានស្បថដោយសេចក្តី
បរិសុទ្ធរបស់ទ្រង់ថា ចាំមើលចុះ នឹងមានគ្រា[ឆ]មកលើឯង
រាល់គ្នា ជាគ្រាដែលគេនឹងដឹកអូសនាំឯងរាល់គ្នាចេញទៅ[ជ]
ដោយសារទំពក់[ឈ] នឹងសំណល់នៃឯងរាល់គ្នាដោយស្ទូច
៣នោះឯងរាល់គ្នានឹងចេញតាមចន្លោះកំផែងបែកបាក់[ញ]
ត្រង់ទៅខាងមុខរៀងខ្លួន ហើយឯងរាល់គ្នានឹងត្រូវបោះ
ទៅក្នុងបន្ទាយ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
៤ឱពួកកូនចៅអ៊ីស្រាអែលអើយ ចូរមកឯបេត-អែល[ដ]
ហើយប្រព្រឹត្តអំពើរំលងចុះ ក៏មកឯគីលកាល[ឋ]ដែរ ហើយ
ចំរើនអំពើរំលងជាច្រើនឡើង ចូរនាំយកយញ្ញបូជារបស់
ឯងមករាល់តែព្រឹក[ឌ] ហើយដង្វាយ១ភាគក្នុង១០[ឍ]របស់ឯង
រាល់តែ៣ថ្ងៃ[ណ] ៥ត្រូវឱ្យបូជាថ្វាយនំបុ័ង ដែលមានដំបែរ[ត]
ទុកជាដង្វាយអរព្រះគុណ ហើយប្រកាសប្រាប់យ៉ាងច្បាស់
ឱ្យបានថ្វាយដង្វាយស្មគ្រពីចិត្ត[ថ] ដ្បិតឯងរាល់គ្នាគាប់ចិត្ត
យ៉ាងនោះហើយ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់យេហូវ៉ា។
៦ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា អញក៏ឱ្យឯងរាល់គ្នា
មានធ្មេញស្អាត នៅគ្រប់ទាំងទីក្រុងរបស់ឯង ហើយឱ្យខ្វះ
ខាតអាហារនៅគ្រប់ទីកន្លែងរបស់ឯង[ទ] ទោះបើយ៉ាងនោះ

**៣:១៤** រ លប ១២:៨ អម ៥:៥-៦ ល នក ២៧:២ **៣:១៥** វ យរ ៣៦:២២ ស ពច ៣:២០ ហ ១ពវ ២២:៣៩ ឡ អម ៥:១១ ៦:១១ អ អស ៣៤:៥ ក ហស ១០:៥-៨, ១៤-១៥ **៤:១** ក ទដ ២២:១២ ខ អម ៣:៩ គ អស ៥៨:៦ អគ ១៨:១២ ឃ ចទ ២៤:១៤ ង យរ ៤៤:១៩ ច អម ២:៨ ៥:១១ ៨:៦ **៤:២** ឆ យរ ៣១:៣១ ជ អម ៦:៨ ឈ ២ពវ ១៩:២៨ ២របា ៣៣:១១ អស ១៩:៨ **៤:៣** ញ អគ ១២:៥ **៤:៤** ដ យស ៧:២ ឋ ហស ៤:១៥ ឌ ជន ២៨:៣ ឍ ចទ ១៤:២៨ ណ អគ ២០:៣៩ អម ៥:២១-២២ **៤:៥** ត លវ ៧:១៣ ថ លវ ២២:១៨-២១ **៤:៦** ទ អស ៣:១ ៩:១៣ យរ ៥:៣ ហក ២:១៧

ថា សូម្បីតែកន្លែងជ្រកកោនសម្រាប់ពួកជាប់ទោសនៅស្រុកអ៊ីស្រាអែលក៏គ្មានដែរ (ប្រៀបធៀបនឹង ១ពវ ១:៥០-៥៣) ។

**៣:១៥** *ផ្ទះសំរាប់រដូវរងា និងផ្ទះសំរាប់រដូវក្តៅ* ធៀបនឹង ៦:១១ ។ ត្រង់ចំណុចនេះ មានន័យថា ទ្រព្យសម្បត្តិមានតម្លៃនឹងមិនមានប្រយោជន៍ដល់ម្ចាស់វាទៀតឡើយ នៅពេលដែលថ្ងៃជំនុំជម្រះនៃព្រះអម្ចាស់មកដល់ ហើយរបស់ដែលនាំចូលពីបរទេសដូចជា គ្រឿងតុបតែង ចម្លាក់ និងគ្រឿងភ្លុក (ធៀបនឹង ៦:៤) ក៏មិនមានប្រយោជន៍ដែរ ។ គេបានរកឃើញគ្រឿងចម្លាក់ដូចនោះ នៅក្នុងដំណាក់ពួកស្តេចនៅស្រុកសាម៉ារី និងទីក្រុងដទៃទៀត (មើល ១ពវ ២២:៣៩ និងការពន្យល់) ។

**៤:១** *ពួកគោពីស្រុកបាសាន* នៅត្រង់ចំណុចនេះ គឺជាការប្រដូចស្ត្រីវណ្ណៈជាន់ខ្ពស់ទៅនឹងពូជសត្វដែលល្អបំផុតនៅក្នុងហ្វូង នៅក្នុងតំបន់កាណានសម័យដើម ដែលគេចិញ្ចឹមបំប៉ន នៅវាលស្មៅនៅតំបន់យ័រដាន់ (មើល ទដ ២២:១២ អគ ៣៩:១៨ និងការពន្យល់) ។ *ចូរស្តាប់ពាក្យនេះ* មើលការពន្យល់ ៣:១ ។ *ភ្នំសាម៉ារី* មើល ៦:១ និងការពន្យល់ ។

**៤:២** *ព្រះអម្ចាស់យេហូវ៉ាទ្រង់បានស្បថ* ត្រង់នេះគឺនិយាយសង្កត់ធ្ងន់ពីភាពឱឡារិកនៃស្ថានភាព និងភាពពិតប្រាកដនៃហេតុការណ៍ ។ *ដោយសេចក្តីបរិសុទ្ធរបស់ទ្រង់* គឺផ្ទុយពីពួកអ៊ីស្រាអែលដែលពេញដោយអំពើបាប ។ ត្រង់ចំណុនេះគឺជាការរំឭកដល់ពួកគេឱ្យបានដឹងថាតើពួកគេនឹងមានសភាពយ៉ាងណា (មើល នក ១៩:៦ និងការពន្យល់) បើពួកគេបានកាន់តាមសេចក្តីសញ្ញាដោយស្មោះត្រង់ ដូចដែលព្រះអម្ចាស់ទ្រង់ស្មោះត្រង់ដែរ ។ *ទំពក់* តាមរូបចម្លាក់របស់ពួកសាសន៍អាសស៊ើរ ពួកអ្នកទោសសង្គ្រាមត្រូវបានដឹកដោយខ្សែព្រួរដែលភ្ជាប់ដោយទំពក់ដែលចោះជាប់នឹងច្រមុះ ឬបបូរមាត់ក្រោម (មើល ២ពវ ១៩:២៨ និងការពន្យល់ ២របា ៣៣:១១ អគ ១៩:៤,៩ ហព ១:១៥) ។

**៤:៣** *តាមចន្លោះកំផែងបែកបាក់* ធៀបនឹង ២ពវ ១៧:៥ អគ ១៣:៥ ។

**៤:៤** *បេត-អែល . . . គីលកាល* ទីក្រុងទាំងនេះមានភាពសំខាន់នៅក្នុងប្រវត្តិសាស្ត្រ ដោយសាជាកន្លែងរំឭកដល់ជំនួយរបស់ព្រះអម្ចាស់ (លប ៣៥:១-១៥ យស ៤:២០-២៤) ហើយជាកន្លែងដែលគេនិយមទៅថ្វាយបង្គំព្រះនៅជំនាន់លោកអេម៉ុស (៥:៥ មើល ហស ៤:១៥ ១២:៤ និងការពន្យល់) ។ *នាំយកយញ្ញបូជារបស់ឯងមករាល់តែព្រឹក* មើល នក ២៩:៣៨-៤១ ។ *ដង្វាយ១ភាគក្នុង១០* ប្រហែលជាដង្វាយមួយភាគក្នុងដប់ពិសេសដែលត្រូវនាំយកមក "រៀងរាល់បីឆ្នាំម្តង" (ចទ ១៤:២៨ ២៦:១២) ។ *ថ្ងៃ* ពាក្យ "ថ្ងៃ" នៅក្នុងភាសាហេព្រើជួនកាលមានន័យថា "ឆ្នាំ" ។

**៤:៥** *នំបុ័ង ដែលមានដំបែរ* ការដុតនំបុ័ងមានដំបែរនៅក្នុងយញ្ញបូជាគឺជាការហាមឃាត់ដាច់ខាត (មើល លវ ២:១១ ៦:១៧) ។ នៅក្នុងចំណុចនេះមានន័យពីរយ៉ាង គឺលោកអេម៉ុសស្តីបន្ទោសពួកអ៊ីស្រាអែល ចំពោះការរំលងក្រឹត្យវិន័យដោយចេតនា ឬគាត់និយាយអំពីការដុតយញ្ញបូជាជាទូទៅដោយប្រើដង្វាយមិនសមរម្យ ។ គេអាចយកនំបុ័ងឥតដំបែរមកថ្វាយជាមួយនឹងដង្វាយមេត្រីភាព (មើល លវ ៧:១៣) ។ *ឯងរាល់គ្នាគាប់ចិត្តយ៉ាងនោះហើយ* ពួកគេស្រឡាញ់បែបបទ និងការធ្វើពិធីបុណ្យក្នុងជំនឿ ប៉ុន្តែពួកគេមិនស្រឡាញ់នូវអ្វីដែលព្រះអម្ចាស់ទ្រង់ស្រឡាញ់ ដែលមានដូចជា សេចក្តីល្អ សេចក្តីមេត្តា ចិត្តសប្បុរស និងយុត្តធម៌ (មើល ៥:១៥ អស ៥:៧ ៦១:៨ ហស ៦:៦ និងការពន្យល់, មីក ៦:៨) ។

**៤:៦-១១** កាលពីមុន ព្រះទ្រង់បានប្រើគ្រោះធម្មជាតិ ដើម្បីធ្វើការលត់ដំ និងព្រមានរាស្ត្ររបស់ទ្រង់ ប៉ុន្តែពួកគេបានភ្លេចនូវមេរៀនទាំងនោះ យ៉ាងឆាប់ (ធៀបនឹងបណ្តាសានៃសេចក្តីសញ្ញានៅក្នុង ចទ ២៨:២២-២៤,៣៩-៤០,៤២,៤៨,៥៦-៥៧) ។

**៤:៦** *អញ* មានន័យថា ព្រឹត្តិការណ៍ទាំងអស់នោះមិនគ្រាន់តែជាគ្រោះធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែ គឺជាការដែលព្រះទ្រង់បានធ្វើដោយផ្ទាល់ (៣:៦) ។ *គង់តែឯងមិនបានវិលត្រឡប់មកឯអញដែរ* គឺជាការចោទប្រកាន់ម្តងទៀត

គង់តែឯងមិនបានវិលត្រឡប់មកឯអញដែរ ៧អញបាន
ទាំងបិទទប់[ធ]មិនបង្អុរភ្លៀងដល់ឯងរាល់គ្នា ក្នុងកាលដែល
នៅខ្វះតែ៣ខែនឹងដល់រដូវចំរូតហើយផង អញបានឱ្យ
ភ្លៀងធ្លាក់ទៅលើទីក្រុង១ ហើយមិនឱ្យធ្លាក់ទៅលើទីក្រុង
១ទៀត[ន] ស្រែ១មានភ្លៀងធ្លាក់ ហើយ១ទៀតដែលឥតមាន
ក៏ស្វិតក្រៀមទៅ ៨បានជាទីក្រុង២ឬ៣ក៏ដើរចច្រប់ទៅឯ
ទីក្រុង១ ដើម្បីផឹកទឹក[ប] តែមិនបានឆ្អែត[ផ]ឡើយ ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា[ព] ទោះបើយ៉ាងនោះក៏ដោយ
គង់តែឯងរាល់គ្នាមិនបានវិល[ភ]មកឯអញវិញដែរ ៩អញ
បានវាយផ្ចាលឯងរាល់គ្នា ដោយស្រូវស្កក ហើយក្រាចាប់[ម]
ឯអស់ទាំងសួន និងចំការទំពាំងបាយជូរ ព្រមទាំងដើម
ល្វានឹងដើមអូលីវដ៏បរិបូររបស់ឯងរាល់គ្នា[យ] នោះដង្កូវ[រ]
បានស៊ីបំផ្លាញអស់ទៅ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ទោះ
បើយ៉ាងនោះក៏ដោយ គង់តែឯងរាល់គ្នាមិនបានវិលមក[ល]ឯ
អញវិញដែរ ១០អញបានចាត់ប្រើអសន្នរោគ[វ]ឱ្យមកនៅ
កណ្តាលឯងរាល់គ្នា បែបដូចជានៅស្រុកអេស៊ីព្ទ[ស] អញ
បានប្រហារជីវិតពួកកំឡោះៗ[ហ]របស់ឯងរាល់គ្នាដោយដាវ
ហើយបានដឹកសេះទាំងប៉ុន្មានរបស់ឯងទៅបាត់ ព្រមទាំង
ធ្វើឱ្យក្លិនស្អុយ[ឡ]ពីទីបោះទ័ពរបស់ឯង បានសាយឡើងដល់
ច្រមុះរបស់ឯងផង ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា[អ] ទោះ
បើយ៉ាងនោះក៏ដោយ គង់តែឯងរាល់គ្នាមិនបានវិលមកឯ
អញវិញដែរ[ក] ១១អញបានបំផ្លាញនៅកណ្តាលពួកឯងរាល់
គ្នា ដូចកាលព្រះទ្រង់បានបំផ្លាញក្រុងសូដុំម និងក្រុងកូម៉ូរ៉ា[ខ]
ហើយឯងរាល់គ្នាបានដូចជាអង្កត់ឧស[គ] ដែលគេកន្ត្រាក់
រោចចេញពីភ្លើង តែព្រះយេហូវ៉ាទ្រង់មានបន្ទូលថា[ឃ]ទោះ
បើយ៉ាងនោះក៏ដោយ គង់តែឯងរាល់គ្នាមិនបានវិលមកឯ
អញវិញដែរ ។
១២ហេតុនោះ ឱអ៊ីស្រាអែលអើយ អញនឹងប្រព្រឹត្ត
នឹងឯងរាល់គ្នាយ៉ាងនោះតទៅ ហើយដោយព្រោះអញ នឹង
ប្រព្រឹត្តយ៉ាំនោះដល់ឯង បានជា ឱអ៊ីស្រាអែលអើយ
ចូររៀបចំ ដើម្បីជួបនឹងព្រះនៃខ្លួនចុះ ១៣ដ្បិតមើល ព្រះ
ដែលទ្រង់សូនធ្វើភ្នំទាំងប៉ុន្មាន[ង] ក៏បង្កើតខ្យល់[ច] ហើយថ្លែង
ប្រាប់ដល់មនុស្សអំពីគំនិត[ឆ]ដែលនៅក្នុងខ្លួនគេ ព្រមទាំង
ធ្វើឱ្យពេលព្រឹកព្រហាមទៅជាងងឹត ហើយយាងលើទីខ្ពស់
ទាំងប៉ុន្មាននៃផែនដីផង[ជ] ព្រះនាមរបស់ទ្រង់គឺ "យេហូវ៉ា
ជាព្រះនៃពួកពលបរិវារ"[ឈ]។

### ទំនុកពាក្យទំនួញ និងការត្រាស់ហៅឱ្យប្រែចិត្ត

**៥** ១ឱពួកវង្សអ៊ីស្រាអែលអើយ ចូរស្តាប់ពាក្យដែល អញ
តាំងឡើងនេះ ទុកសំរាប់ជាពាក្យទំនួញ[ក]ពីឯងរាល់គ្នាចុះ
២នាងព្រហ្មចារី[ខ] គឺនគរអ៊ីស្រាអែលបានដួលចុះហើយ
និងក្រោកឡើវិញមិនបានឡើយ នាងដេកត្រមោចនៅ
លើដីខ្លួន គ្មានអ្នកណានឹងលើកឡើងវិញសោះ[គ] ៣ដ្បិត
ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា ទីក្រុងណា
ដែលលើកទ័ព១ពាន់ចេញទៅ នោះនឹងសល់នៅតែ១រយ
វិញ ហើយទីក្រុងដែលមាន១រយចេញទៅ នោះនឹងសល់
នៅតែ១០ដល់ពួកវង្សអ៊ីស្រាអែលទេ[ឃ]។
៤ដ្បិតព្រះយេហូវ៉ា ទ្រង់មានបន្ទូលដល់ពួកវង្សអ៊ីស្រា
អែលដូច្នេះថា ចូរស្វែងរក[ង]អញ នោះឯងរាល់គ្នានឹងរស់

**៤:៧** ធ យរ ៣:៣ សក ១៤:១៧ ន នក ៩:៤,២៦ ចទ ១១:១៧ ២រប ៧:១៣ អស ៥:៦ **៤:៨** ប អគ ៤:១៦–១៧ ផ ហក ១:៦ ព យប ៣៦:៣១ យរ ១៤:៤ ភ យរ ៣:៧ **៤:៩** ម ចទ ២៨:២២ យ យអ ១:៧ រ នក ១០:១៣ យអ ២:២៥ ល អស ៩:១៣ យរ ៣:១០ **៤:១០** វ នក ៩:៣ ស នក ១១:៥ ហ អស ៩:១៧ ឡ អស ៣៤:៣ អ អស ៩:១៣ ក ចទ ២៨:២១ **៤:១១** ខ លប ១៩:២៤ យរ ២៣:១៤ គ អស ៧:៤ យដ ១:២៣ ឃ យប ៣៦:១៣ **៤:១៣** ង ទដ ៦៥:៦ ច ទដ ១៣៥:៧ ឆ ដយ ២:២៨ ជ មីក ១:៣ ឈ អស ៤៧:៤ អម ៥:៨,២៧ ៩:៦ **៥:១** ក យរ ៤:៨ អគ ១៩:១

**៥:២** ខ ២ពវ ១៩:២១ យរ ១៤:១៧ គ យរ ៥០:៣២ អម ៨:១៤ **៥:៣** ឃ អស ៦:១៣ អម ៦:៩ **៥:៤** ង ចទ ៤:២៩

ដែលដូចជាការចុងចួនគ្នាពី ខ.៨–១១ ។

**៤:៧–៨** នៅក្នុងវគ្គនេះ ការខ្វះខាតទឹកភ្លៀងចំនួនបីខែមុននឹងរដូវចម្រូតមកដល់ នាំឱ្យគ្រាប់ពូជមិនអាចលូតលាស់ពេញលេញបាន ។

**៤:៩** *ដោយស្រូវស្កក និងក្រាចាប់* មើល ហក ២:១៧ និងការពន្យល់ ។ *ដង្កូវ* មើល នក ១០:១៤ និងការពន្យល់ ។

**៤:១០** *អសន្នរោគ . . . ដូច . . . នៅស្រុកអេស៊ីព្ទ* មើល នក ៧:១៤–១២:៣០

**៤:១១** *ក្រុងសូដុំម និងក្រុងកូម៉ូរ៉ា* គឺជាឧទាហរណ៍នៃការបំផ្លាញទាំងស្រុងការដែលព្រះទ្រង់ជំនុំជម្រះទីក្រុងទាំងពីរ (មើល លប ១៩:២៤–២៥) បានក្លាយទៅជាសុភាសិត (មើល ចទ ២៩:២៣ អស ១:៩ ១៣:១៩ មើល យរ ៤៩:១៨ សផ ២:៩ និងការពន្យល់) ។ *គេកន្ត្រាក់រោចចេញពីភ្លើង* មានន័យថា បានសង្គ្រោះដោយសារតែព្រះគុណនៃព្រះប៉ុណ្ណោះ (មើល សក ៣:២ និងការពន្យល់) ។

**៤:១២** *ចូររៀបចំ ដើម្បីជួបនឹងព្រះនៃខ្លួន* សាសន៍អ៊ីស្រាអែលត្រូវទទួលរងការបំផ្លាញពីសាសន៍អាសស៊ើរ ដែលបានធ្វើឱ្យពួកគេលុតជង្គង់ ហើយនិងបានជួបនឹងព្រះនៃខ្លួនដែលបានតាំងសញ្ញានៅភ្នំស៊ីណាយ ហើយនៅពេលនេះពួកគេត្រូវធ្វើខុសយ៉ាងធ្ងន់ ។

**៤:១៣** មើលការពន្យល់ ៥:៨–៩ ។ ព្រះទ្រង់មានគ្រប់អំណាចព្រះចេស្តា ដូចនេះទ្រង់មិនពិបាកអ្វីនៅក្នុងការជំនុំជម្រះពួកគេដូចដែលបានប្រកាសនៅក្នុង ខ.១២ ទេ ។

**៥:១** *ចូរស្តាប់ពាក្យ* មើលការពន្យល់ ៣:១ ។ *ពាក្យទំនួញ* លោកអេម៉ុសបានប្រើពាក្យទំនួញ ហាក់ដូចជាប្រទេសអ៊ីស្រាអែលបានស្លាប់ទៅហើយ ។

**៥:២** *នាងព្រហ្មចារី* គឺនគរអ៊ីស្រាអែល (ការពន្យល់ ២ពវ ១៩:២១)។ *ត្រមោច* គឺត្រូវទុកចោល ដូចសាកសពនៅកណ្តាលវាល(មើល យរ ៨:២ ៩:២២) ។

**៥:៣** *ទីក្រុង . . . ទីក្រុង* តាមព្រះគម្ពីរភាសារហេព្រើ ទីក្រុងទាំងពីរគឺទីក្រុងធំៗ និងក្រុងតូចៗ ដែលសុទ្ធតែត្រូវទទួលរងគ្រោះ ។

**៥:៤** *ស្វែងរកអញ នោះឯងរាល់គ្នានឹងរស់នៅ* ការត្រាស់ហៅដោយព្រះគុណមាននិយាយម្តងទៀតនៅក្នុង ខ.៦ និង ខ.១៤ ។ បើរាស្ត្រអ៊ីស្រាអែល (ឬយ៉ាងហោចណាស់ "ពួកសំណល់" ខ.១៥) ស្វែងរកព្រះអម្ចាស់ នោះពួកគេនឹងបានគេចផុតពីការស្លាប់ដោយអំពើហឹង្សាដែលលោកអេម៉ុសបានថ្លែង

នៅ[ច] ៥កុំឱ្យរកដល់បេត–អែល ឬចូលទៅក្នុងគីលកាល
ឡើយ[ឆ] ក៏កុំឱ្យរំលងទៅដល់បៀរ–សេបាដែរ[ជ] ពីព្រោះ
គីលកាលនឹងត្រូវទៅជាឈ្លើយពិត ហើយបេត–អែលនឹង
ត្រូវសូន្យបាត់ទៅ[ឈ] ៦ចូរស្វែងរក[ញ]ព្រះយេហូវ៉ាវិញ នោះ
ឯងរាល់គ្នានឹងរស់នៅ[ដ] ក្រែងទ្រង់កាត់ឆេះឡើង ដូចជា
ភ្លើងនៅក្នុងវង្សយ៉ូសែប[ឋ] ហើយបញ្ឆេះអស់រលីងទៅ ឥត
មានអ្នកណានៅបេត–អែល[ឌ]ដែលអាចនឹងពន្លត់បាន
ឡើយ[ឍ] ៧ម្នាលឯងរាល់គ្នាដែលបំផ្លាស់បំប្រែសេចក្ដីយុត្តិ–
ធម៌ឱ្យទៅជាស្លែង[ណ] ហើយបោះសេចក្ដីសុចរិត[ត]ចុះដល់ដី[ថ]
៨ចូរស្វែងរកព្រះដែលទ្រង់បានបង្កើតផ្កាយកូនមាន់ និង
ផ្កាយនាយព្រាន[ទ] ក៏ធ្វើឱ្យម្លប់នៃសេចក្ដីស្លាប់ប្រែទៅជា
ព្រលឹមស្រាង[ធ] ហើយឱ្យថ្ងៃត្រឡប់ទៅជាយប់វិញ[ន] ព្រម
ទាំងហៅសមុទ្រមក រួចចាក់ទៅលើផែនដីព្រះនាមទ្រង់[ប]
គឺព្រះយេហូវ៉ា ៩ទ្រង់នាំការបំផ្លាញមកលើមនុស្សខ្លាំងពូកែ
ភ្លាម១រំពេច ដល់ម្ល៉េះបានជាទាំងបន្ទាយក៏ត្រូវបំផ្លាញ
ផង[ផ]។
១០គេរមែងស្អប់អ្នក ដែលបន្ទោសនៅត្រង់ទ្វារក្រុង[ព]
ហើយក៏តែងតែខ្ពើមអ្នក ដែលពោលសេចក្ដីទៀងត្រង់ផង[ភ]
១១ដូច្នេះ ដោយព្រោះឯងរាល់គ្នាតែងញាំញីពួកក្រ[ម] ហើយ
រឹបយកស្រូវពីគេ បានជាឯងរាល់គ្នានឹងសង់ផ្ទះដោយថ្ម
ដាប់[យ] តែមិនបានអាស្រ័យនៅក្នុងផ្ទះនោះទេ[រ] ឯងរាល់គ្នា
នឹងដាំចំការទំពាំងបាយជូរដ៏គាប់ចិត្ត តែមិនបានផឹកស្រា
ទំពាំងបាយជូរពីនោះឡើយ[ល] ១២ដ្បិតអញដឹងហើយថា
អំពើរំលងរបស់ឯងរាល់គ្នាមានសន្ធឹកណាស់ ហើយអំពើ
បាបរបស់ឯងរាល់គ្នាក៏មានទំងន់ពេកផង[វ] គឺឯងរាល់គ្នា
ហើយ ជាពួកអ្នកដែលបៀតបៀនមនុស្សសុចរិត ហើយ
ស៊ីសំណូក[ស] ព្រមទាំងបង្វែរមនុស្សកំសត់ទុគ៌ត[ហ]មិនឱ្យបាន
សំរេចតាមអំណាច្បាប់[ឡ] ១៣ហេតុនោះ មនុស្សដែលមាន
គំនិតវាងវៃ និងស្ងៀមនៅ[អ] ក្នុងគ្រាយ៉ាងនេះ ដ្បិតជាគ្រា
អាក្រក់ហើយ[ក]។

**៥:៤** ច ចទ ៣២:៤៦–៤៧ អស ៥៥:៣ យរ ២៩:១៣ អគ ១៨:៩ **៥:៥** ឆ ១សយ ១១:១៤ ហស ៤:១៥ ជ លប ២១:៣១ អម ៨:១៤ ឈ ១សយ ៧:១៦ ៨:២ **៥:៦** ញ ទដ ២២:២៦ ១០៥:៤ អស ៣១:១ ៥៥:៦ សផ ២:៣ ដ ខ.១៤ លវ ១៨:៥ ឋ ចទ ៤:២៤ ឌ អម ៣:១៤ ឍ យរ ៤:៤ **៥:៧** ណ អស ៥:២០ អម ៦:១២ ត អម ៣:១០ ថ ហស ១០:៤ **៥:៨** ទ លប ១:១៦ យប ៣៨:៣១ ធ យប ៣៨:១២ អស ៤២:១៦ ន ទដ ១០៤:២០ អម ៨:៩ ប ទដ ១០៤:៦–៩ យរ ១៦:២១ អម ៤:៣១ **៥:៩** ផ មីក ៥:១១**៥:១០** ព អស ២៩:២១ ភ ១ពវ ២២:៨ កទ ៤:១៦**៥:១១** ម អម ៨:៦ យ អម ៣:១៥ រ ចទ ២៨:៣០ មីក ១:៦ ល ពច ៩:២៧ អម ៤:១ ៩:១៤មីក ៦:១៥ សផ ១:១៣ **៥:១២** វ ហស ៥:៣ ស យប ៣៦:១៨ អស ១:២៣ អគ ២២:១២ ហ យរ ៥:២៨ ឡ យប ៥:៤ អស ៥:២៣ អម ២:៦–៧ **៥:១៣** អ នអ ៤:១៤ ក មីក ២:៣

ទំនាយជាពាក្យទំនួញ(មើល សផ ២:៣ និងការពន្យល់) ។
**៥:៥** *បេត–អែល . . . គីលកាល* មើលការពន្យល់ ៤:៤ ។ *បៀរ–សេបា* ស្ថិតនៅភាគខាងត្បូងនៃស្រុកយូដា ហើយត្រូវក្លាយជាកន្លែងដែលគេធ្វើដំណើរពីចម្ងាយមកថ្វាយបង្គំរូបព្រះ(មើល ៨:១៤)។ គ្រប់ទាំងកន្លែងដែលធ្វើឱ្យខូចដល់ការថ្វាយបង្គំព្រះនឹងត្រូវទទួលរងការបំផ្លាញ ។
**៥:៦** កន្លែងថ្វាយបង្គំរូបព្រះត្រូវបានបំផ្លាញ ប៉ុន្តែបើប្រទេសអ៊ីស្រាអែលបែរមករកព្រះវិញ នោះជាតិសាសន៍អ៊ីស្រាអែលនឹងមានសង្ឃឹមឡើងវិញ បើមិនដូច្នោះទេ ប្រជាជនក៏នឹងត្រូវទទួលរងការបំផ្លាញផងដែរ ។ *ស្វែងរក . . . រស់នៅ* មើល ខ.៤ និងការពន្យល់ ។ *វង្សយ៉ូសែប* គឺនគរខាងជើងនៃអ៊ីស្រាអែល ដែលគ្រប់គ្រងដោយពូជអំបូរអេប្រាអិម ដែលជាកូនចៅរបស់លោកយ៉ូសែប(មើល ខ.១៥ ៦:៦ ហស ៤:៧ និងការពន្យល់)។ *បេត–អែល* គឺជាមជ្ឈមណ្ឌលនៃជំនឿរបស់នគរខាងជើង(មើល ៣:១៤ ៤:៤ ៧:១៣ ហស ១២:៤ និងការពន្យល់)។ ព្រះដែលពួកអ៊ីស្រាអែលថ្វាយបង្គំនៅកន្លែងនោះនឹងគ្មានអំណាចអ្វីនៅក្នុងការជួយសង្គ្រោះទីកន្លែងនោះបានទេ នៅពេលដែលព្រះទ្រង់ជំនុំជម្រះ ។
**៥:៧** *បំផ្លាស់បំប្រែសេចក្ដីយុត្តិធម៌ ឱ្យទៅជាស្លែង* ពួកគេបានធ្វើឱ្យខូចដល់ទម្រង់ការ និងស្ថាប័នយុត្តិធម៌ (តុលាការ) ។ ការធ្វើឱ្យខូចសណ្ដាប់ធ្នាប់ដែលព្រះទ្រង់ប្រទានគឺជារឿងដែលកើតឡើងដោយជៀសមិនផុត នៅក្នុងសង្គមដែលមិនកាន់តាមក្រឹត្យវិន័យរបស់ទ្រង់ ហើយធ្វើឱ្យអាប់អោនដល់ជំនឿដែលត្រឹមត្រូវ(មើល ៦:១២ និងការពន្យល់) ។
**៥:៨–៩** វគ្គនេះគឺជាបទទំនុកតម្កើងខ្លីមួយ ដូចនៅក្នុង ៤:១៣ (មើល ៩:៥–៦ និងការពន្យល់)។ នៅក្នុងវគ្គនេះ លោកអេម៉ុសលើកឡើងអំពីភាពផ្ទុយគ្នារវាង "ម្នាលឯងរាល់គ្នាដែលបំប្រែ" សេចក្ដីល្អ ឱ្យទៅជាអាក្រក់ (ខ.៧) និងអ្នក"ដែលបំប្រែ"យប់ទៅជាថ្ងៃ ហើយគ្រប់គ្រងសណ្ដាប់ធ្នាប់នៃសកលលោក ហើយមានអំណាចរំលាយជញ្ជាំងដែលរាស្ត្ររបស់ទ្រង់លាក់ពីខាងក្រោយ ។
**៥:៨** *ផ្កាយកូនមាន់* គឺជាក្រុមផ្កាយទាំងប្រាំពីរ (មើលការពន្យល់ យប ៩:៩)។ *ម្លប់នៃសេចក្ដីស្លាប់ប្រែទៅជាព្រលឹម . . . ថ្ងៃត្រឡប់ទៅជាយប់វិញ* គឺជាការបន្តគ្នានៃថ្ងៃនិងយប់តាមលំដាប់លំដោយ (មើល លប ៨:២២ យរ ៣១:៣៥)។ *ទឹកសមុទ្រ* គឺជាទឹកដែលធំមហាសាល (មើល ៩:៦ លប ១:៧ និងការពន្យល់ ទដ ៣៦:៨ ៤២:៧ ១០៤:៣) ឬទឹកដែលហួតចេញពីសមុទ្រហើយកជាទឹកភ្លៀង ។ *ព្រះនាមទ្រង់ គឺព្រះយេហូវ៉ា* គឺជាពាក្យដែលមាននិយាយបីដងនៅក្នុងព្រះគម្ពីរនេះ និងជាលើកទីពីរ(ចំពោះការនិយាយពីរដងទៀតមើលនៅក្នុង ៤:១៣ និង ៩:៦) ។
**៥:១០** ខនេះបន្តអត្ថបទជាកំណាព្យដែលចាប់ផ្ដើមនៅក្នុង ខ.៧។ បទកំណាព្យនេះមានបន្ត និងបញ្ចប់នៅក្នុងវគ្គ ខ.១២ខ–១៣ ដែលប្រើសព្វនាមទីបី ហើយវគ្គខាងមុខ (ខ.១១–១២ក) ប្រើសព្វនាមទី២ ។ ការចោទប្រកាន់នៅក្នុង ខ.៧,១០,១២ខ–១៣ មានលក្ខណៈពិពណ៌នាជាង ហើយវគ្គ ខ.១១–១២ក មានលក្ខណៈផ្ទាល់ជាង ។
**៥:១១** *ញាំញីពួកក្រ* គឺជាការនិយាយម្ដងទៀតអំពីពាក្យចោទប្រកាន់ដំបូងចំពោះពួកអ៊ីស្រាអែល(២:៧)។ *បានជាឯងរាល់គ្នានឹងសង់ផ្ទះ* ព្រះអម្ចាស់ទ្រង់នឹងដកយកចេញពី ពួកគេនូវរបស់ទ្រព្យមានតម្លៃដែលរកបានដោយអំពើអាក្រក់ ។ ភាពមានបានរបស់ពួកគេនឹងត្រឡប់ជាការទួញសោក(មើលបណ្ដាសានៃសេចក្ដីសញ្ញានៅក្នុង ចទ ២៨:៣០,៣៨–៤០)។
**៥:១៣** *មនុស្សដែលមានគំនិតវាងវៃ* គឺមិនមែនមនុស្សដែលមិនអាចកែប្រែបញ្ហានៅពេលបច្ចុប្បន្នបាន ដូចនេះគ្រាន់តែរង់ចាំថ្ងៃជំនុំជម្រះនៅពេល

១៤ចូរស្វែងរកសេចក្ដីល្អ កុំរកសេចក្ដីអាក្រក់ឡើយ
ដើម្បីឱ្យឯងរាល់គ្នាបានរស់នៅ[ខ] យ៉ាងនោះព្រះយេហូវ៉ា ជា
ព្រះនៃពួកពលបរិវារ ទ្រង់នឹងគង់នៅជាមួយនឹងឯងជា
ពិតដូចជាឯងធ្លាប់ថាហើយ ១៥ចូរស្អប់អំពើអាក្រក់[គ] ហើយ
ស្រឡាញ់អំពើល្អវិញ[ឃ] ចូរតាំងឱ្យមានសេចក្ដីយុត្តិធម៌នៅ
ត្រង់ទ្វារក្រុងចុះ[ង] នោះប្រហែលជា[ច]ព្រះយេហូវ៉ា ជាព្រះ
នៃពួកពលបរិវារ ទ្រង់នឹងប្រព្រឹត្តដល់សំណល់[ឆ]នៃពួក
យ៉ូសែប ដោយករុណាគុណ[ជ]ទេដឹង ។
១៦ហេតុនោះព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ
គឺជាព្រះអម្ចាស់ ទ្រង់មានបន្ទូលដូច្នេះថា មនុស្សនឹងទ្រហោ
យំនៅគ្រប់ទាំងផ្លូវធ្លា ហើយនៅគ្រប់ទាំងផ្លូវ[ឈ]គេនឹងថា
វរហើយ វរហើយ[ញ] គេនឹងហៅពួកអ្នកស្រែចំការ[ដ]ឱ្យមក
សោយសោក ហើយពួកអ្នកដែលប្រសប់ទួញទំនួញ ឱ្យ
មកទ្រហោយំ ១៧នៅគ្រប់ទាំងចំការទំពាំងបាយជូរ គេ
នឹងទ្រហោយំ[ឋ]ដែរ ដ្បិតអញនឹងដើរកាត់[ឌ]កណ្ដាលឯងរាល់
គ្នា នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ឍ] ។

## ថ្ងៃនៃព្រះអម្ចាស់

១៨វេទនាដល់ឯងរាល់គ្នា ដែលសង្វាតចង់បានថ្ងៃនៃ
ព្រះយេហូវ៉ា[ណ] តើចង់បានថ្ងៃនៃព្រះយេហូវ៉ាធ្វើអី[ត] ថ្ងៃ
នោះជាថ្ងៃងងឹត[ថ]មិនមែនភ្លឺទេ[ទ] ១៩ហាក់ដូចជាមនុស្សដែរ
រត់រួចពីសិង្ហ ហើយលោតែប្រទះនឹងខ្លាឃ្មុំ[ធ] ឬដូចជាអ្នក
ណា ដែលចូលទៅក្នុងផ្ទះ ច្រត់ដៃនៅជញ្ជាំង រួចមានពស់
ចឹក[ន] ២០ឯថ្ងៃនៃព្រះយេហូវ៉ា តើមិនមែនជាថ្ងៃងងឹត[ប] ឥត
មានពន្លឺជាពិត គឺជាថ្ងៃងងឹតសូន្យសុង ឥតមានពន្លឺបន្តិច
សោះទេឬអី[ផ] ។
២១អញស្អប់[ព] អញខ្ពើមបុណ្យទាំងប៉ុន្មានរបស់ឯងរាល់
គ្នា[ភ] ហើយអញនឹងមិនរីករាយ ចំពោះជំនុំមុតមាំរបស់
ឯងរាល់គ្នាទេ[ម] ២២អើ ទោះបើឯងរាល់គ្នាថ្វាយយញ្ញបូជា[យ]
និងដង្វាយម្សៅរបស់ឯងដល់អញ គង់តែអញមិនព្រមទទួល
ដែរ[រ,ល] អញក៏មិនព្រមអើពើនឹងសត្វធាត់ៗ ដែលឯងរាល់
គ្នាថ្វាយជាដង្វាយមេត្រីឡើយ[វ,ស] ២៣ចូរដកសូរទំនាស់នៃ
ចំរៀងរបស់ឯងរាល់គ្នាចេញពីអញទៅ ដ្បិតអញមិន
ព្រមស្តាប់សូរដន្ត្រីនៃពិណរបស់ឯងទេ[ហ] ២៤តែត្រូវឱ្យមាន

**៥:១៤** ខ ខ.៦
**៥:១៥** គ ទដ ៥២:៣ ៩៧:១០ រម ១២:៩ ឃ លប ១៨:២៥ ង អស ១:១៧ ២៩:២១ សក ៨:១៦ ច យរ ៣៦:៣ ឆ មីក ៥:៧,៨ ៧:១៨ ជ យអ ២:១៤
**៥:១៦** ឈ យរ ៧:៣៤ ញ យរ ៩:១៧ អម ៨:៣ សផ ១:១០ ដ យអ ១:១១
**៥:១៧** ឋ នក ១១:៦ ឌ នក ១២:១២ ឍ អស ១៦:១០ យរ ៤៨:៣៣
**៥:១៨** ណ អស ២:១២ យអ ១:១៥ ត យរ ៣០:៥ ថ ១សយ ២:៩ យអ ២:២ ទ យប ២០:២៨ អស ៥:១៩,៣០ យរ ៣០:៧
**៥:១៩** ធ បទ៣:១០ ន ចទ ៣២:២៤ យប ២០:២៤ សស ១០:៨ អស ២៤:១៧–១៨ យរ ១៥:២–៣ ៤៨:៤៤ **៥:២០** ប ១សយ ២:៩ ផ អស ១៣:១០ អគ ៧:៧ អប ១:១៥ សផ ១:១៥ **៥:២១** ព យរ ៤៤:៤ ភ លវ ២៦:៣១ ហស ២:១១ ម អគ ២៣:១៨ **៥:២២** យ លវ ២៦:៣១ រ យរ ៧:២១ ល ទដ ៤០:៦ វ យរ ១៤:១២ អម ៤:៤ មីក ៦:៦–៧ ស អស ១:១១–១៦ ៦៦:៣ **៥:២៣** ហ អម ៦:៥

ខាងមុខប៉ុណ្ណោះ ។
**៥:១៤** *ចូរស្វែងរកសេចក្ដីល្អ* ធៀបនឹងពាក្យ "ចូរស្វែងរកអញ" (ខ.៤ មើលការពន្យល់ និង អស ១:១៦–១៧ និងការពន្យល់ ១:១៧) ។ *ដើម្បីឱ្យឯងរាល់គ្នាបានរស់នៅ* គោលបំណងនៃការស្វែងរកបានបង្ហាញផងដែរនៅក្នុង ខ.៤,៦ ។ *នៅជាមួយនឹងឯង* គឺនៅជាមួយដើម្បីផ្ដល់ជាសន្តិសុខ និងប្រភពនៃព្រះពរ ។
**៥:១៥** *ប្រហែលជា* ពាក្យនេះប្រើដើម្បីសង្កត់ធ្ងន់អំពីគ្រោះថ្នាក់នៃការស្មានអំពីព្រះគុណនៃព្រះ ។ *សំណល់* មានន័យថា មានអ្នកដែលគេចផុតពីស្លាប់ ទោះបីជាប្រទេសជាតិទាំងមូលត្រូវវិនាសក៏ដោយ ។ *យ៉ូសែប* មើលការពន្យល់ ខ.៦ ។
**៥:១៦–១៧** វគ្គនេះចាប់ផ្ដើមនិយាយម្ដងទៀតអំពីពាក្យសោកសង្រេង (ខ.១–២) ។ *ផ្លូវធ្លា . . . គ្រប់ទាំងផ្លូវ . . . ពួកអ្នកស្រែចំការ . . . ចំការទំពាំងបាយជូរ* មានន័យថា គ្រប់គ្នានឹងទទួលផលប៉ះពាល់ពីការជំនុំជម្រះរបស់ព្រះ ។ សូម្បីតែពួកអ្នកស្រែចំការដែលរវល់នឹងស្រែចំការក៏ត្រូវចូលរួមទួញសោកជាមួយពួកស៊ីឈ្នួលយំសោកដែរ នៅក្នុងវគ្គដែលនិយាយអំពីការសោកសង្រេងនេះ ហើយការទួញសោកនឹងកើតមានចាប់ពីទីក្រុង រហូតដល់ស្រែចំការ (មើល យអ ១:៥ និងការពន្យល់) ។ នៅពេលដែលព្រះអម្ចាស់ទ្រង់ "យាងកាត់" (ដូចកាលនៅស្រុកអេស៊ីព្ទ នក ១២:១២) ពួកមិនបរិសុទ្ធ និងមិនយុត្តិធម៌នឹងទទួលជំនុំជម្រះដោយជៀសមិនផុត (ធៀបនឹង អស ៦:៥) ។
**៥:១៨** *ថ្ងៃនៃព្រះយេហូវ៉ា* គឺជាថ្ងៃដែលព្រះអម្ចាស់ទ្រង់នឹងបង្ហាញអង្គទ្រង់ជាអ្នកមានជ័យជម្នះលើលោកិយ (មើលការពន្យល់ ៨:៩ អស ២:១១,១៧,២០ យអ ១:១៥) ។ ពួកសាសន៍អ៊ីស្រាអែលរំពឹងថា នឹងត្រូវបានតម្កើងឡើងជារាស្ត្ររបស់ព្រះ ហើយពួកគេចង់ឱ្យថ្ងៃនោះមកដល់ខ្លាំងណាស់ ។ លោកអេម៉ុសបានព្រមានថា ថ្ងៃនោះនឹងមកដល់ប៉ុន្តែមិនដូចដែលពួកសាសន៍អ៊ីស្រាអែលបានរំពឹងទុកនោះទេ គឺថាថ្ងៃនោះនឹងជាថ្ងៃនៃ "សេចក្ដីងងឹតប៉ុន្តែមិនមែនពន្លឺ" (ខ.២០ មើល ៨:៩ និងការពន្យល់) សម្រាប់ពួកគេទេ ពីព្រោះពួកគេមិនបានស្មោះត្រង់នឹងព្រះអម្ចាស់ ។ (ធៀបនឹង "ថ្ងៃនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ" និង ១កថ ១:៨ ៣:១២–១៥ ៥:៥ ២កថ ១:១៤ ភល ១:៦,១០ ២:១៦) ។ លោកអេម៉ុសនិយាយអំពីការជំនុំជម្រះសាសន៍អ៊ីស្រាអែល ដែលជិតមកដល់ និងពិតប្រាកដ គឺមិនសំដៅទៅលើការជំនុំជម្រះថ្ងៃចុងក្រោយ ។
**៥:១៩–២០** វគ្គនេះបង្ហាញពីរូបភាពពីរយ៉ាង (ខ.១៩) ដែលបញ្ជាក់ថា ថ្ងៃជំនុំជម្រះរបស់ព្រះអម្ចាស់នឹងប្រាកដជាមកដល់ ។
**៥:២១–២៧** ក្នុងវគ្គនេះ ព្រះអម្ចាស់ទ្រង់លើកឡើងម្ដងទៀតអំពីការចោទប្រកាន់ពួកអ៊ីស្រាអែលអំពីភាពមិនស្មោះត្រង់ ។
**៥:២១–២៣** ខទាំងបីនៅក្នុងវគ្គនេះ គឺជាការសង្ខេប និងបដិសេធន៍ការថ្វាយបង្គំរបស់ពួកអ៊ីស្រាអែលនៅពេលនោះ ។ ជំនឿរបស់ពួកគេមិនខុសឆ្គងទេ ប៉ុន្តែគឺពួកគេដែលជាអ្នកថ្វាយបង្គំ និងរបៀបដែលពួកគេថ្វាយបង្គំដែលខុសឆ្គង ។ ពួកគេមិនមានសម្អាងអ្វីនៅក្នុងការចូលក្នុងវត្តមានព្រះទេ ពីព្រោះការប្រព្រឹត្តរបស់ពួកគេបានឆ្លុះបញ្ចាំងអំពីការមិនស្តាប់បង្គាប់ក្រឹត្យវិន័យរបស់ទ្រង់ (មើល អស ១:១១–១៥ និងការពន្យល់) ។
**៥:២៤** *សេចក្ដីយុត្តិធម៌ . . . សេចក្ដីសុចរិត* គឺជាចាំបាច់ត្រូវមានដើម្បីឱ្យព្រះ

សេចក្ដីយុត្តិធម៌[ឡ]ហូរមកដូចជាទឹក ហើយសេចក្ដីសុចរិត[អ] ដូចជាទន្លេធំវិញ[ក]។

២៥ឱពួកវង្សអ៊ីស្រាអែលអើយ ឯយញ្ញបូជា[ខ] និងដង្វាយម្សៅ ដែលឯងរាល់គ្នាបានថ្វាយនៅទីរហោស្ថាន ក្នុងរវាង ៤០ឆ្នាំ[គ]នោះ តើបានថ្វាយដល់អញពិតឬ ២៦អើ ឯងរាល់គ្នាបានលីសែងបារាំនៃម៉ូឡុក ជាព្រះរបស់ឯងនឹងភីយុន ជារូបព្រះរបស់ឯង[ឃ] ព្រមទាំងផ្កាយរបស់ព្រះដែលឯងរាល់គ្នា បានធ្វើសំរាប់ខ្លួនវិញ ២៧ដូច្នេះ ព្រះយេហូវ៉ាដែលទ្រង់ព្រះនាមជាព្រះនៃពួកពលបរិវារ ទ្រង់មានបន្ទូលថា អញនឹងឱ្យឯងរាល់គ្នាត្រូវទៅជាឈ្លើយ[ង]ខាងនាយក្រុងដាម៉ាស[ច]

## វេទនាដល់ពួកអ្នកដែលនៅជាឥតកង្វល់

**៦** ១វេទនាដល់ពួកអ្នក[ក] ដែលនៅជាឥតកង្វល់[ខ] ក្នុងក្រុងស៊ីយ៉ូន ហើយដល់ពួកអ្នកដែលនៅ ដោយសុខសាន្ត[គ]លើភ្នំសាម៉ារីផង[ឃ] គឺជាពួកប្រធានក្នុងពួកអ្នកមុខនៃអស់ទាំងសាសន៍ ដែលពួកវង្សអ៊ីស្រាអែលបានមកដល់គេ[ង] ២ចូរទៅឯក្រុងកាលនេ[ច] ហើយពិចារណាមើលចុះ ពីនោះឱ្យទៅដល់ហាម៉ាត[ឆ] ជាក្រុងធំ រួចចុះទៅឯក្រុងកាថ[ជ]របស់សាសន៍ភីលីស្ទីន តើទីក្រុងទាំងនោះវិសេសជាង[ឈ]នគរទាំងនេះឬ ឯព្រំស្រុករបស់គេ តើធំជាងព្រំស្រុករបស់ឯងរាល់គ្នាឬទេ ៣ឯងរាល់គ្នាគិតបន្ថយថ្ងៃអាក្រក់ឱ្យឆ្ងាយចេញ ហើយបង្ខិតទីស្ដីការនៃសេចក្ដីច្រឡោត ឱ្យចូលមកជិតវិញ[ញ] ៤ក៏ដេកលើគ្រែភ្លុក ហើយមិតពត់ខ្លួននៅលើដំណេកព្រម[ដ] ទាំងស៊ីកូនចៀមពីហ្វូងសត្វ និងកូនគោដែលបង្ខាំងទុក[ឋ] ៥ជាអ្នកដែលច្រៀងរឡៃរឡាតាមពិណ[ឌ] ហើយបង្កើតគ្រឿងភ្លេងសំរាប់ខ្លួនដូចដាវីឌ[ឍ] ៦ក៏ផឹកស្រាទំពាំងបាយជូរ[ណ] ដោយចានគោម ហើយបំព្រំខ្លួនដោយប្រេងយ៉ាងវិសេស តែឥតមានចិត្តព្រួយ[ត]ចំពោះការវេទនារបស់យ៉ូសែបទេ[ថ]។

៧ដូច្នេះពួកអ្នកទាំងនោះនឹងត្រូវចាប់នាំទៅជាឈ្លើយ[ទ] ជាមួយនឹងពួកអ្នកដែលទៅជាឈ្លើយជាមុនដំបូង នោះការលេងសប្បាយរបស់ពួកអ្នក ដែលមិនពត់ខ្លួន និងសូន្យបាត់ទៅ[ធ]។

## ព្រះអម្ចាស់ទ្រង់ខ្ពើមសេចក្ដីអំណួតរបស់អ៊ីស្រាអែល

៨ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ ទ្រង់មានបន្ទូលថា ព្រះអម្ចាស់យេហូវ៉ាទ្រង់បានស្បថដោយអង្គទ្រង់[ន]ថា អញខ្ពើម[ប]សេចក្ដីមានះរបស់យ៉ាកុប[ផ] ក៏ស្អប់ដំណាក់ទាំងប៉ុន្មានរបស់គេដែរ[ព] ដូច្នេះ អញនឹងប្រគល់[ភ] ទាំងទីក្រុងនឹង

**៥:២៤** ឡ យរ ២២:៣ អ អស ៤៥:៨ ក មីក ៦:៨ **៥:២៥** ខ អស ៤៣:២៣ គ នក ១៦:៣៥ **៥:២៦** ឃ អក ១៨:៦ ២០:១៦ **៥:២៧** ង អម ៦:៧ ៧:១១,១៧ មីក ១:១៦ ច ចទ ៣២:១៧–១៩ យរ ៣៨:១៧ អម ៤:១៣ កច ៧:៤២–៤៣ **៦:១** ក លក ៦:២៤ ខ សផ ១:១២ គ យប ២៤:២៣ ឃ អម ៣:៩ ង អស ៣២:៩–១១ **៦:២** ច លប ១០:១០ ឆ ២ពវ ១៧:២៤ យរ ៤៩:២៣ ជ យស ១១:២២ ២រប ២៦:៦ ឈ ណាហ ៣:៨ **៦:៣** ញ អស ៥៦:១២ អគ ១២:២២ អម ៩:១០ **៦:៤** ដ នអ ១:៦ សភ ៧:១៧ ឋ អស ១:១១ អគ ៣៤:២–៣ អម ៣:១២ **៦:៥** ឌ ទដ ១៣៧:២ អស ១៤:១១ អម ៥:២៣ ឍ ១រប ១៥:១៦ **៦:៦** ណ អស ២៨:១ អម ២:៨ ត អគ ៩:៤ ថ អគ ១៦:៤៩ **៦:៧** ទ អម ៥:២៧ ធ យរ ១៦:៩ បទ ៤:៥ **៦:៨** ន លប ២២:១៦ ហព ៦:១៣ ប លវ ២៦:៣០ ផ ទដ ៤៧:៤ ព យរ ១២:៨ ភ អម ៤:២

ទ្រង់ទទួលស្គាល់(មើល មីក ៦:៨ និងការពន្យល់) ប៉ុន្តែពួកអ៊ីស្រាអែលបានបដិសេធ និងមើលងាយដល់ការសំខាន់ៗទាំងនេះ (ធៀបនឹង ខ.៧,១០, ១២ខ)។ *ដូចជាទឹក . . . ទន្លេធំវិញ* គឺផ្ទុយពីបាតអូរដែលរាំងស្ងួតជាច្រើនដង(មើល យរ ១៥:១៨ និងការពន្យល់) ។ នៅក្នុងខនេះ មានការប្រៀបធៀបថា នៅទីណាដែលមានទឹក ជីវិតសត្វ និងរុក្ខជាតិមានការចម្រើនលូតលាស់ ដូចនេះ នៅកន្លែងដែលមានយុត្តិធម៌ និងសេចក្ដីសុចរិត ជីវិតមនុស្សនឹងមានការចម្រើនរុងរឿង ។

**៥:២៥** ទំនាក់ទំនងដ៏ត្រឹមត្រូវរវាងអ៊ីស្រាអែល និងព្រះអម្ចាស់មិនអាចបង្កើតឡើងដោយការថ្វាយយញ្ញបូជាបានឡើយ ពីព្រោះពួកគេត្រូវស្ដាប់បង្គាប់ព្រះអម្ចាស់ (មើល ១សយ ១៥:២២ និងការពន្យល់ ធៀបនឹង រម ១:៥) ។ *នៅទីរហោស្ថានក្នុងរវាង៤០ឆ្នាំ* មើល ជន ១៤:៣២–៣៥ និងការពន្យល់ ១៤:៣៤ ។

**៥:២៦** ខនេះនិយាយអំពីការថ្វាយបង្គំរូបព្រះរបស់ពួកអ៊ីស្រាអែល ប៉ុន្តែមិនបានបញ្ជាក់ច្បាស់ថា តើជាការថ្វាយបង្គំដែលពួកគេធ្វើទីរហោស្ថានជាយូរមកហើយ ឬនៅក្នុងទឹកដីសន្យានៅសម័យនោះ ។

**៥:២៧** ការកាត់ទោសក្នុងខនេះគឺជាលើកចុងក្រោយ ដោយនិរទេសពួកគេពីទឹកដីដែលព្រះប្រទាន ទៅទីដាច់ស្រយាលនៅក្នុងស្រុកបរទេស ។

**៦:១** *ក្នុងក្រុងស៊ីយ៉ូន . . . លើភ្នំសាម៉ារី* ទោះបីជាលោកអេម៉ុសនិយាយបន្ទោសទៅកាន់ប្រទេសអ៊ីស្រាអែលក៏ដោយ ក៏ប្រទេសយូដា និងក្រុងយេរូសាឡិម(ស៊ីយ៉ូន)សមនឹងទទួលការស្ដីបន្ទោសនោះផងដែរ (ធៀបនឹង ២:៤–៥) ព្រោះអ៊ីស្រាអែលគឺរួមមានពូជអំបូរទាំង១២ ។ *ភ្នំសាម៉ារី* មើល ៤:១ ។ សាម៉ារីគឺជារាជធានីនៃប្រទេសអ៊ីស្រាអែល ដែលបង្កើតឡើងដោយស្ដេចអំរី មានទីតាំងនៅលើទួលដ៏ខ្ពស់មួយដែលមានការការពារមាំមួន (មើល ១ពវ ១៦:២៤ និងការពន្យល់) ។

**៦:២** ក្រុងកាលនេ និងក្រុងហាម៉ាតប្រហែលជាត្រូវដួលចុះនៅក្នុងការដឹកនាំធ្វើសង្គ្រាមរបស់ស្ដេចយេរ៉ូបោមទី២ (មើល ២ពវ ១៤:២៥,២៨ និងការពន្យល់) ហើយកំផែងក្រុងកាថប្រហែលជាត្រូវបានផ្ដួលរំលំដោយស្ដេចអ៊ូសៀស(២ពវ ២៦:៦) ។

**៦:៣** *ថ្ងៃអាក្រក់* មើលការពន្យល់ ៥:១៨ ។

**៦:៤** *ដេក . . . ពត់ខ្លួននៅលើដំណេក* មើល ៣:១២ និងការពន្យល់ ។ *ភ្លុក* មើល ៣:១៥ និងការពន្យល់ ។

**៦:៥** *ដូចដាវីឌ* មើល ១សយ ១៦:១៥–២៣ ២សយ ២៣:១ ។

**៦:៦** *ដោយចានគោម* មានន័យថា មានពេញដោយការខ្ជះខ្ជាយ និងល្មោភផឹកស៊ីជ្រុល ។ *យ៉ូសែប* មើលការពន្យល់ ៥:៦ ។

**៦:៨** *ស្បថដោយអង្គទ្រង់* មើលការពន្យល់ លប ២២:១៦ ហព ៦:១៣ ។ ចំពោះការមានបន្ទូលជាពាក្យសម្បថនេះ គឺជាការប្រកាសប្រាប់ថា ទ្រង់បានសម្រេចទោសជាការបញ្ចប់ ។ *សេចក្ដីមានះរបស់យ៉ាកុប* គឺជាទីមាំមួនមួយដែលធ្វើឱ្យមនុស្សភាគច្រើនមានសេចក្ដីអំនួត ("គឺបន្ទាយទាហាន" ធៀបនឹង អគ ៣២:១២ និងការពន្យល់) ។ *ដំណាក់ទាំងប៉ុន្មាន* មើលការពន្យល់ ១:៤ ។

របស់ទាំងអស់ ដែលនៅក្នុងទីនេះទៅផង[ម] ៩គ្រានោះបើ
សិនជាមានមនុស្ស១០[យ]នាក់សល់នៅក្នុងផ្ទះ១ គេនឹងត្រូវ
ស្លាប់ទាំងអស់ទៅ ១០ហើយកាលណាញាតិសន្តានជិតដិត
ដែលគេបានដំរូវឱ្យត្រូវដុតខ្មោច[រ]បានលើកសពគេ នាំ
ចេញឱ្យផុតពីផ្ទះទៅ រួចសួរដល់អ្នកណាដែលនៅខាងក្នុង
ថា តើមានសល់នៅទៀតជាមួយនឹងឯងឬទេ អ្នកនោះនឹង
ឆ្លើយថា ឥតមានទេ នោះគេនឹងហាមថា កុំមាត់ឡើយ[ល]
ដ្បិតយើងគ្មាន ច្បាប់នឹងចេញព្រះនាមនៃព្រះយេហូវ៉ាទេ
១១ដ្បិតមើល ព្រះយេហូវ៉ាទ្រង់ចេញបង្គាប់ វេលាណា
នោះផ្ទះធំនឹងត្រូវវាយ[វ]ឱ្យប្រេះឆា ហើយផ្ទះ[ស]តូចផងឱ្យត្រូវ
បែកបាក់[ហ]។
១២ម្នាល ឯងរាល់គ្នា ដែលរីករាយក្នុងសេចក្ដីសោះ
សូន្យ ឯងថា យើងបានអំណាចឡើង ដោយសារកំឡាំង
របស់ខ្លួនយើងទេតើ[ឡ] ១៣ចុះសេះនឹងបោលនៅលើថ្មដែរ
ឬតើមនុស្សនឹងភ្ជួរនៅទីនោះដោយគោឬ បានជាឯងរាល់
គ្នាបានបំផ្លាស់បំប្រែសេចក្ដីយុត្តិធម៌ឱ្យទៅជាពិស[អ] ហើយឱ្យ
ផលនៃសេចក្ដីសុចរិត[ក] បានប្រែត្រឡប់ជាស្លែងវិញដូច្នេះ[ខ]
១៤ដ្បិតមើល ព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ ទ្រង់
មានបន្ទូលថា ឱពួកវង្សអ៊ីស្រាអែលអើយ អញនឹងញុាំង
សាសន៍[គ]១ឱ្យមកទាស់នឹងឯង គេនឹងធ្វើទុក្ខឯងរាល់គ្នាចាប់
តាំងពីទ្វារចូលស្រុកហាម៉ាត[ឃ] រហូតដល់ជ្រោះទឹកនៅស្រុក

**៦:៨** ម លវ ២៦:១៩ ចទ ៣២:១៩
**៦:៩** យ អម ៥:៣
**៦:១០** រ ១សយ ៣១:១២ ល អម ៨:៣
**៦:១១** វ អស ៣៤:៥ ស អម ៣:១៥ ហ អស ៥៥:១១
**៦:១២** ឡ យប ៨:១៥ អស ២៨:១៤–១៥
**៦:១៣** អ ហស ១០:៤ ក អម ៣:១០ ខ អស ១:២១ អម ៥:៧
**៦:១៤** គ យរ ៥:១៥ ឃ ជន ១៣:២១ ង អម ៣:១១
**៧:១** ក ខ.៧ អម ៨:១ ខ ទដ ៧៨:៤៦ យរ ៥១:១៤ យអ ១:៤
**៧:២** គ នក ១០:១៥ ឃ អស ៣៧:៤ ង អគ ១១:១៣ អម ៤:៩

វ៉ាល[ង]។

## កណ្ដូប ភ្លើង និងខ្សែកូនតឹង

៧ ១គឺការយ៉ាងនោះ ដែលព្រះអម្ចាស់យេហូវ៉ាទ្រង់បាន
បង្ហាញដល់ខ្ញុំ[ក] ហើយមើល ទ្រង់ក៏បង្កើតកណ្ដូប[ខ]នៅវេលា
ដែលស្មៅកំពុងលាស់ឡើងជាថ្មី គឺកាលស្មៅកំពុងលាស់
ឡើង ក្រោយដែលបានច្រូតម្ដងថ្វាយស្ដេចហើយ ២រួច
កាលកណ្ដូបទាំងនោះបានស៊ីស្មៅ នៅក្នុងស្រុកអស់ទៅ[គ]
នោះខ្ញុំក៏ទូលថា ឱព្រះអម្ចាស់យេហូវ៉ាអើយ ទូលបង្គំទូល
អង្វរសូមឱ្យទ្រង់អត់ទោស ធ្វើដូចម្ដេចឱ្យពួកយ៉ាកុបស្ថិត
ស្ថេរនៅបាន[ឃ] ដ្បិតគេជាពួកតិចតួចទេ[ង] ៣ដូច្នេះ ព្រះ
យេហូវ៉ាក៏ប្រែព្រះហឫទ័យពីដំណើរនោះ[ច] ដោយបន្ទូលថា
ការនេះមិនត្រូវធ្វើឡើយ[ឆ]។
៤ព្រះអម្ចាស់យេហូវ៉ាទ្រង់ក៏បង្ហាញការយ៉ាងនេះទៀត
ដល់ខ្ញុំ មើល ព្រះអម្ចាស់យេហូវ៉ាទ្រង់ប្រកាសប្រាប់ឱ្យមាន
ការផ្ចាញ់ផ្ចាលដោយភ្លើង[ជ] នោះភ្លើងក៏ឆេះទាំងទីជំរៅដ៏
ធំក៏បំរុងនឹងស៊ី[ឈ]ស្រុកទាំងមូលផង ៥ខណនោះ ខ្ញុំទូលថា ឱ
ព្រះអម្ចាស់យេហូវ៉ាអើយ ទូលបង្គំទូលអង្វរសូមឱ្យទ្រង់
ឈប់ ធ្វើដូចម្ដេចឱ្យយ៉ាកុបស្ថិតស្ថេរនៅបាន ដ្បិត គេជាពួក
តិចតួចទេ[ញ] ៦ដូច្នេះ ព្រះយេហូវ៉ាក៏ប្រែព្រះហឫទ័យពី

**៧:៣** ច នក ៣២:១៤ ចទ ៣២:៣៦ យរ ១៨:៨ ២៦:១៩ ឆ ហស ១១:៨ **៧:៤** ជ អស ៦០:១៦ យអ ១:១៩ ឈ ចទ ៣២:២២ **៧:៥** ញ ខ.១–២ យអ ២:១៧

**៦:១០–១១** វគ្គនេះនិយាយអំពីព្រឹត្តិការណ៍ដ៏គួរឱ្យភ័យខ្លាច ដែលអ្នកនៅរស់ត្រូវភ័យខ្លាចញាប់ញ័រនៅក្នុងផ្ទះ ហើយញាតិសណ្ដានរបស់ពួកគេបានហាមមិនឱ្យពួក គេអធិស្ឋានទៅរកព្រះអម្ចាស់ព្រោះសេចក្ដីក្រោធរបស់ទ្រង់បានធ្លាក់មកលើទីក្រុងហើយ ។

**៦:១០** *ដុតខ្មោច* ប្រហែលជាសំដៅទៅលើការបូជាភ្លើង ដើម្បីធ្វើការគោរពដល់អ្នកស្លាប់ (មើល យរ ៣៤:៥ និងការពន្យល់) ។ ជាទូទៅ គេមិនប្រារព្ធធ្វើពិធីបូជាសពទេ ដោយការនេះគេធ្វើចំពោះតែអ្នកដែលប្រព្រឹត្តខុសធ្ងន់ (មើល លប ៣៨:២៤ លវ ២០:១៤ ២១:៩ យស ៧:១៥,២៥ ១សយ ៣១:១២ និងការពន្យល់) ។

**៦:១១** *ផ្ទះធំ . . . ផ្ទះតូច* ប្រៀបធៀបនឹង "ផ្ទះសម្រាប់រដូវរងា" និង "ផ្ទះសម្រាប់រដូវក្ដៅ" នៅក្នុង ៣:១៥ ។

**៦:១៣** *ភ្ជួរនៅទីនោះដោយគោឬ* ឃ្លានេះនៅក្នុងព្រះគម្ពីរភាសាហេព្រើអាចបកប្រែថា "ភ្ជួរសមុទ្រដោយប្រើគោ" ។ មានន័យថា ការដែលពួកអ៊ីស្រាអែលបានបង្វែរសេចក្ដីយុត្តិធម៌ នោះគឺជាការខុសឆ្គងដែលសូម្បីតែមនុស្សសាមញ្ញក៏អាចប្រើប្រាជ្ញាមើលដឹងដែរ ។ សូមមើល ៥:៧ និងការពន្យល់ ។

**៦:១៤** *សាសន៍១* គឺសាសន៍អាសស៊ើរ ។ *ពីទ្វារចូលស្រុកហាម៉ាត រហូតដល់ជ្រោះទឹកនៅស្រុកវ៉ាល* គឺចាប់ពី ទន្លេអូរ៉ុនទេស (Orontes) នៅតំបន់ខាងជើងនៃប្រទេសល្បាណូន រហូតដល់សមុទ្រស្លាប់ គឺមានន័យថា ទឹកដីទាំងមូលនៃស្រុកអ៊ីស្រាអែល (មើល ២ពវ ១៤:២៥) ។

**៧:១** *បង្ហាញដល់ខ្ញុំ* គឺបានឃើញ និងស្ដាប់ (សូមមើល ខ.៤,៧ ៨:១ យរ ១:១១ និងការពន្យល់ ធៀបនឹង អម ៩:១) ។ *កណ្ដូប* សូមមើល ៤:៩ នក ១០:៤ និងការពន្យល់ ។ *ច្រូតម្ដងថ្វាយស្ដេច* ប្រហែលជាថ្វាយជាពន្ធដាដល់ស្ដេច ។

**៧:២** មើល ខ.៥ ។ *ធ្វើដូចម្ដេច . . . . ស្ថិតស្ថេរនៅបាន* ការអត់ឃ្លានយ៉ាងខ្លាំងនឹងកើតឡើងចំពោះពួកគេគ្រប់គ្នា ។ *យ៉ាកុប* គឺអ៊ីស្រាអែល ។ *ពួកតិចតួច* គឺមានន័យថា គ្មានកម្លាំងនឹងទប់ទល់នឹងគ្រោះមហន្តរាយនោះបានទេ ។ លោកអេម៉ុសមិនបានលើកឡើងអំពីសេចក្ដីសញ្ញាដែលព្រះអម្ចាស់បានតាំងជាមួយនឹងអ៊ីស្រាអែល ប្រហែលមកពីភាពមិនស្មោះត្រង់របស់អ៊ីស្រាអែលបានធ្វើឱ្យពួកគេអស់សិទ្ធិនៅក្នុងការលើកឡើងអំពីសេចក្ដីសញ្ញានោះ ។

**៧:៣** មើល ខ.៦ ។ *ព្រះយេហូវ៉ាក៏ប្រែព្រះហឫទ័យ* គឺដើម្បីឆ្លើយតបចំពោះការទូលអង្វររបស់លោកហោរា (មើល លប ២០:៧) ប៉ុន្តែទ្រង់មិនបានប្រទានការអត់ទោសទេ ។

**៧:៤** *ទីជំរៅដ៏ធំ* ប្រហែលសំដៅទៅលើ សមុទ្រមេឌីទែរ៉ាណេ ។ *ស្រុក* ប្រហែលសំដៅទៅលើទឹកដីសន្យា ឬគ្រប់ទាំងអ្វីៗដែលលូតលាស់នៅលើទឹកដីនោះ (ធៀបនឹង យអ ១:១៩) ។

**៧:៥** មើលការពន្យល់ ខ.២ ។

**៧:៦** មើលការពន្យល់ ខ.៣ ។

ដំណើរនោះ[ដ]ដោយបន្ទូលថា ការនេះក៏មិនត្រូវធ្វើដែរ[ឋ]។
៧ រួចទ្រង់ក៏បង្ហាញខ្ញុំដូច្នេះ មើល ព្រះអម្ចាស់យេហូវ៉ា
ទ្រង់ឈរលើកកំផែង ដែលធ្វើដំរង់ដោយកូនតឹង ទ្រង់ក៏
កាន់ខ្សែកូនតឹង១នៅព្រះហស្តដែរ ៨ ហើយព្រះយេហូវ៉ា
ទ្រង់មានបន្ទូលសួរខ្ញុំថា អេម៉ុសអើយ[ឍ] តើឯងឃើញអ្វី[ឍ] ខ្ញុំ
ទូលតបថា ឃើញខ្សែកូនតឹង[ណ] រួចព្រះអម្ចាស់មានបន្ទូលថា
មើល អញនឹងឱ្យមានខ្សែកូនតឹងនៅកណ្ដាលពួកអ៊ីស្រា
អែលជារាស្ត្រអញ នោះអញនឹងមិនដើរបង្ហួសពីគេទៀត
ឡើយ[ត] ៩ អស់ទាំងទីខ្ពស់[ថ]របស់អ៊ីសាកនឹងត្រូវខូចបង់ ឯទី
គោរពទាំងប៉ុន្មាន[ទ]របស់អ៊ីស្រាអែល និងត្រូវបំផ្លាញទៅ
អញក៏នឹងក្រោកឡើង ទាស់នឹងពួកវង្សយេរ៉ូបោម[ធ] ដោយ
ដាវដែរ ។

## លោកអេម៉ុស និងអ័ម៉ាស៊ា

១០ នោះអ័ម៉ាស៊ា ជាសង្ឃនៅត្រង់បេត-អែល[ន]ក៏ចាត់ឱ្យ
ទៅឯយេរ៉ូបោម[ប] ជាស្តេចអ៊ីស្រាអែលទូលថា អេម៉ុស
កំពុងបង្កើតការក្បត់[ផ]ចំពោះទ្រង់ នៅកណ្ដាលពួកវង្ស
អ៊ីស្រាអែល ប្រទេសនេះនឹងទ្រាំនៅចំពោះពាក្យទាំងប៉ុន្មាន
របស់វាមិនបានទេ[ព] ១១ ដ្បិតវានិយាយដូច្នេះថា យេរ៉ូបោម
នឹងត្រូវស្លាប់ដោយដាវ ហើយសាសន៍អ៊ីស្រាអែលនឹងត្រូវ
ដឹកនាំចេញពីស្រុករបស់ខ្លួនទៅជាឈ្លើយ[ភ]ជាមិនខាន[ម]
១២ រួចអ័ម៉ាស៊ាក៏ប្រាប់ដល់អេម៉ុសថា ឱអ្នកមើលឆុតអើយ[យ]
ចូរកត់ទៅឯស្រុកយូដា ហើយរកស៊ីដោយទាយនៅស្រុក
នោះវិញចុះ[រ] ១៣ កុំឱ្យទាយនៅត្រង់បេត-អែលទៀតឡើយ[ល]
ដ្បិតនេះជាទីគោរពរបស់ស្តេច ហើយជាដំណាក់ហ្លួង[វ]ផង[ស]
១៤ នោះអេម៉ុស ឆ្លើយតបដល់អ័ម៉ាស៊ាថា ខ្ញុំពីដើមមិន
មែនជាហោរាទេ ក៏មិនមែនជាកូនរបស់ហោរា[ហ]ដែរ គឺ
ជាអ្នកគង្វាលសត្វ ហើយជាអ្នកបេះផ្លែឧទុម្ពរវិញ[ឡ] ១៥ តែ
ព្រះយេហូវ៉ាទ្រង់បានយកខ្ញុំចេញពីការឃ្វាលហ្វូងចៀម[អ] ក៏
បានបង្គាប់ខ្ញុំថា ចូរទៅ[ក]ទាយ[ខ]ដល់អ៊ីស្រាអែល ជារាស្ត្រ

**៧:៦** ដ នក ៣២:១៤ យរ ១៨:៨ យហ ៣:១០ ឋ យរ ៤២:១០ អគ ៩:៨ **៧:៨** ឌ អម ៨:២ ឍ យរ ១:១១,១៣ ណ ២ពវ ២១:១៣ ត យរ ១៥:៦ អគ ៧:២-៩ **៧:៩** ថ លវ ២៦:៣០ ទ លវ ២៦:៣១ ធ ១ពវ ១៣:៣៤ ២ពវ ១៥:៩ អស ៦៣:១៨ ហស ១០:៨ **៧:១០** ន យស ៧:២ ប ២ពវ ១៤:២៣ ផ យរ ៣៨:៤ ព ២ពវ ១៤:២៤ យរ ២៦:៨-១១ **៧:១១** ភ អម ៥:២៧ ម យរ ៣៦:១៦ **៧:១២** យ ១សយ ៩:៩ រ មថ ៨:៣៤ **៧:១៣** ល យស ៧:២ ១ពវ ១២:២៩ វ យរ ៣៦:៥ ស យរ ២០:២ អម ២:១២ កច ៤:១៨ **៧:១៤** ហ ១សយ ១០:៥ ២ពវ ២:៥ ៤:៣៨ សក ១៣:៥ ឡ ១ពវ ១០:២៧ អស ៩:១០ **៧:១៥** អ លប ៣៧:២ ២សយ ៧:៨ ក អស ៦:៩ ខ យរ ២៦:១២ គ យរ ៧:១-២ អគ ២:៣-៤

**៧:៧** អ៊ីស្រាអែលប្រៀបបានទៅនឹងជញ្ជាំងដែលបានសង់យ៉ាង "ត្រឹមត្រូវតាមរង្វាស់កូនតឹង" មានន័យថា អ៊ីស្រាអែលគួរតែមានលក្ខណៈ តាមការអ្វីដែលព្រះអម្ចាស់ទ្រង់បានធ្វើសម្រាប់ពួកគេ ។

**៧:៨-៩** នៅក្នុងវគ្គ ៦.១-៦ ព្រះទ្រង់ប្រកាសអំពីការជំនុំជម្រះឱ្យទទួលរងការបំផ្លាញទាំងស្រុង ប៉ុន្តែទ្រង់បន្ថយទម្ងន់នៃទោសនោះ ដោយសារលោកអេម៉ុសអធិស្ឋានទូលអង្វរ ទោះបីជាទ្រង់មិនបានសន្យាអត់ទោសឱ្យក៏ដោយ។ នៅក្នុងវគ្គនេះ ព្រះទ្រង់លែងស្តាប់ការទូលអង្វរនោះទៀតឡើយ (មើល យរ ៧:១៦ ១៥:១ និងការពន្យល់) ។

**៧:៨** *តើឯងឃើញអ្វី...* មើលការពន្យល់ យរ ១:១១ ។ *ខ្សែកូនតឹង* ព្រះ "សាង"(៦.៧) រាស្ត្ររបស់ទ្រង់ឡើង ដោយរង្វាស់ដែលទ្រង់បានកំណត់ ។ ទ្រង់សព្វព្រះទ័យឱ្យពួកគេមានភាពត្រឹមត្រូវតាមរង្វាស់នោះ ប៉ុន្តែពួកគេបានត្រឹមត្រូវតាមរង្វាស់ខ្សែកូនតឹងនោះទេ នៅពេលដែលវាស់មើល(មើល ២ពវ ២១:១៣ និងការពន្យល់) ។ *រាស្ត្រអញ* គឺជាលើកទីមួយដែលព្រះអម្ចាស់ទ្រង់ហៅអ៊ីស្រាអែលថា "រាស្ត្រអញ" នៅក្នុងព្រះគម្ពីរនេះ(មើល ៦.១៥ ៨:២ ៩:១០,១៤ និងការពន្យល់ នក ១៧:៤)។ *អញនឹងមិនដើរបង្ហួសពីគេទៀតឡើយ* មើល ៨:២ ធៀបនឹង ៩:១-៤ ។

**៧:៩** *ទីខ្ពស់...ទីគោរព...ពួកវង្ស* គឺជាមជ្ឈមណ្ឌលនៃភាពកំពុតខាងជំនឿ និងនយោបាយ និងសេចក្តីអំនួតខាងឯសេចក្តីសុចរិត ដែលព្រះទ្រង់នឹងរំលំ ។ *អ៊ីសាក់* ជាឪពុករបស់លោកយ៉ាកុប(អ៊ីស្រាអែល) ។ ការប្រើពាក្យនេះគឺជារបៀបនិយាយសំដៅទៅលើអ៊ីស្រាអែល នៅក្នុងព្រះគម្ពីរអេម៉ុស(មើល ៦.១៦)។ *យេរ៉ូបោម* បទទំនាយនៃជំពូក ១-៦ គឺនិយាយទៅកាន់ពួកអ្នកដឹកនាំអ៊ីស្រាអែល និងសាម៉ារីទាំងអស់ ហើយនៅក្នុង៦នេះលោកអេម៉ុសនិយាយបញ្ចេញឈ្មោះស្តេចយេរ៉ូបោមទី២ ។

**៧:១១** ពាក្យរបស់លោកអ័ម៉ាស៊ាបានសង្ខេបពាក្យនៃលោកអេម៉ុស (មើលការពន្យល់ ៦.១៧) ។ *យេរ៉ូបោម* នៅត្រង់ចំណុចនេះ ឈ្មោះស្តេចយេរ៉ូបោមគឺជាតំណាងឱ្យរាជ្យវង្សរបស់ស្តេចនេះទាំងមូល ។ *និងត្រូវស្លាប់* ស្តេចយេរ៉ូបោមត្រូវស្លាប់ដោយការចាស់ជរា (២ពវ ១៤:២៩) ប៉ុន្តែបុត្រារបស់ទ្រង់ គឺសាការីដែលជាស្តេចស្នងរាជ្យ (២ពវ ១៥:៨) ត្រូវគេធ្វើឃាត (២ពវ ១៥:១០) ។

**៧:១២** *ចូររត់ទៅឯស្រុកយូដា ហើយរកស៊ីដោយទាយនៅស្រុកនោះវិញចុះ* មានន័យថា ដេញឱ្យទៅស្រុកកំណើតរបស់លោកអេម៉ុសវិញ (មើលសេចក្តីផ្តើមត្រង់ចំណុចអ្នកនិពន្ធ) ។ ពីព្រោះចង់មានន័យថា ឯងគ្មានកិច្ចការអ្វី ឬត្រូវធ្វើឈរនៅកណ្ដាលពួកយើងទេ ។

**៧:១៣** *ទីគោរពរបស់ស្តេច* លោកអ័ម៉ាស៊ាបម្រើស្តេចនៅប្រទេសសាម៉ារី គឺមិនមែនបម្រើស្តេចដែលគង់នៅស្ថានសួគ៌របស់អ៊ីស្រាអែលទេ ដូចនេះគាត់មិនព្រមឱ្យលោកហោរាថ្លែងពាក្យទាស់នឹងស្តេចយេរ៉ូបោម ឬទាស់នឹងនគរសាម៉ារី នៅក្នុងដំណាក់របស់ទ្រង់បានទេ ។

**៧:១៤** *មិនមែនជាហោរាទេ ក៏មិនមែនជាកូនរបស់ហោរាដែរ* លោកអេម៉ុសបានបដិសេធមិនទាក់ទងជាមួយនឹងពួកហោរាទាំងនោះ និងសិស្សរបស់ពួកគេទេ(មើលការពន្យល់ ១ពវ ២០:៣៥) ។ គ្មាននរណាជួលលោកអេម៉ុសឱ្យមកប្រកាសពីសេចក្តីជំនុំជម្រះដល់ស្តេចយេរ៉ូបោមនិងអ៊ីស្រាអែលទេ ។ *អ្នកគង្វាលសត្វ* មើលការពន្យល់ ១:១ តាមព្រះគម្ពីរភាសាហេព្រើ នៅត្រង់ចំណុចនេះ គឺសំដៅទៅលើអ្នកគង្វាលសត្វគោ ដូចនេះលោកអេម៉ុសអាចជាអ្នកគង្វាលសត្វគោ ។ *ផ្លែឧទុម្ពរ* គឺសំដៅទៅលើជាប្រភេទដើមឈើម្យ៉ាងដែលចេញផ្លែដូចដើមល្វា ប៉ុន្តែមានដើមតូចជាង ហើយគុណភាពអន់ជាង ។

**៧:១៥** *ឃ្វាល* មើល ២សយ ៧:៨ ។ នៅត្រង់ចំណុចនេះ ព្រះគម្ពីរភាសាហេព្រើរសង្កត់ន័យទៅលើទីកន្លែងរបស់អ្នកគង្វាល ជាជាងទៅលើការងារដែលគាត់ធ្វើ ។ *ចូរទៅ* លោកអេម៉ុសនៅស្រុកបេត-អែល ពីព្រោះព្រះបានបញ្ជូនគាត់ឱ្យទៅថ្លែងទំនាយនៅទីនោះ ។

អញចុះ[គ] ១៦ដូច្នេះចូរលោកស្តាប់[ឃ]ព្រះបន្ទូលនៃព្រះយេហូ
វ៉ាឥឡូវចុះ លោកប្រាប់ខ្ញុំថាកុំឱ្យទាយទាស់នឹង[ង]អ៊ីស្រាអែល
ឱ្យសោះ ក៏កុំឱ្យបញ្ចេញពាក្យណាទាស់នឹងពួកវង្សអ៊ីសាក់
ដែរ ១៧ហេតុនោះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា
ប្រពន្ធលោកនឹងទៅជាស្រីសំផឹង[ច]នៅក្នុងទីក្រុង ហើយ
កូនប្រុសកូនស្រីរបស់លោកនឹងត្រូវដួលដោយដាវ ស្រុក
របស់លោកនឹងត្រូវវាស់ចែកដោយខ្សែ ឯខ្លួនលោក និង
ត្រូវស្លាប់នៅស្រុក១ដែលស្មោកគ្រោក ហើយសាសន៍
អ៊ីស្រាអែលនឹងត្រូវគេដឹកនាំចេញពីស្រុករបស់ខ្លួន ទៅជា
ឈ្លើយ[ឆ] ជាមិនខាន[ជ]។

## កំប្រោងផ្លែឈើទុំ

**៨** ១ព្រះអម្ចាស់យេហូវ៉ា ទ្រង់ក៏បង្ហាញខ្ញុំដូច្នេះ[ក] មើល
មានកំប្រោង១ពេញដោយផ្លែរដូវក្តៅ ២ហើយទ្រង់មាន
បន្ទូលសួរខ្ញុំថា អេម៉ុសអើយ[ខ] ឯងឃើញអ្វី[គ] នោះខ្ញុំទូល
ឆ្លើយថា ឃើញកំប្រោង[ឃ]ពេញដោយផ្លែរដូវក្តៅ រួចព្រះ
យេហូវ៉ាទ្រង់ប្រាប់ខ្ញុំថា ចុងបំផុតបានមកដល់អ៊ីស្រាអែល
ជារាស្ត្រអញហើយ អញនឹងមិនដើរបង្ហួសគេទៅទៀត
ឡើយ[ង] ៣ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលថា នៅថ្ងៃ
នោះបទចំរៀងដែលច្រៀងនៅក្នុងព្រះវិហារ និងត្រឡប់
ជាសំរែកទ្រហោយំវិញ[ច] និងមានសាកសពយ៉ាងសន្ធឹកនៅ
គ្រប់ទីកន្លែង គេនឹងបោះសពទាំងនោះចេញដោយស្ងៀម
ស្ងាត់[ឆ]។
៤ម្នាល ពួកអ្នកដែលចង់លេបមនុស្សកំសត់ទុគ៌តទៅ
ដើម្បីនឹងធ្វើឱ្យមនុស្សក្រីក្រ[ជ]នៅក្នុងស្រុកបាត់ចេញ[ឈ] ៥ដោយ
ពាក្យថា តើដល់កាលណាបានផុតពីថ្ងៃបុណ្យចូលខែ[ញ]ទៅ
ដើម្បីឱ្យយើងបានលក់ស្រូវ ហើយនឹងថ្ងៃឈប់សំរាកដែរ
ដើម្បីឱ្យយើងបានដាក់លក់[ដ]ភោជ្ជសាលី[ឋ] ព្រមទាំងធ្វើ
បង្រួមរង្វាល់ហើយដំឡើងថ្លៃ រួចឆបំបាត់[ឌ]ដោយជញ្ជីង
មិនត្រឹមត្រូវ[ឍ] ៦ប្រយោជន៍ឱ្យបានទិញមនុស្សក្រីក្រ[ណ] ដោយ
ប្រាក់ និងមនុស្សកំសត់ទុគ៌ត ដោយស្បែកជើង១ សំរាប់
ព្រមទាំងលក់សំដីស្រូវផង ចូរស្តាប់សេចក្តីនេះចុះ[ត] ៧ព្រះ
យេហូវ៉ា ទ្រង់បានស្បថដោយសិរីល្អនៃយ៉ាកុបថា[ថ] ពិត
ប្រាកដជា អញនឹងមិនដែលភ្លេច[ទ]អំពើរបស់គេណា១
ឡើយ[ធ] ៨ដោយហេតុទាំងនោះ តើស្រុកមិនញាប់ញ័រ[ន]ទេឬ
អី ហើយគ្រប់ទាំងមនុស្សនៅក្នុងស្រុក តើមិនសោយសោក
ទេឬ អើ ស្រុកនេះទាំងមូលនឹងឡើងលិចដូចជាទន្លេធំ និង
ចំរើនដី ហើយស្រោចស្រព រួចស្រកទៅវិញ ដូចជាទន្លេនៃ
ស្រុកអេស៊ីព្ទ[ប] ៩ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា នៅ
ថ្ងៃនោះ អញនឹងធ្វើឱ្យព្រះអាទិត្យលិចទៅនៅពេលថ្ងៃត្រង់

**៧:១៦** ឃ យរ ២២:២ ង អគ ២០:៤៦ មីក ២:៦ **៧:១៧** ច ហស ៤:១៣ ឆ អម ៥:២៧ ជ ២ពវ ១៧:៦ អគ ៤:១៣ ហស ៩:៣ អម ២:១២–១៣ **៨:១** ក អម ៧:១ **៨:២** ខ អម ៧:៨ គ យរ ១:១៣ ២៤:៣ ឃ លប ៤០:១៦ ង បទ ៤:១៨ អគ ៧:២–៩ **៨:៣** ច អម ៥:១៦ ឆ អម ៦:១០ **៨:៤** ជ សភ ៣០:១៤ ឈ យប ២០:១៩ ទដ ១៤:៤ អម ២:៧ **៨:៥** ញ ជន ១០:១០ ដ អស ៥៨:១៣ ឋ នហ ១០:៣១ ឌ លប ៣១:៧ ឍ ចទ ២៥:១៥ ២ពវ ៤:២៣ នហ ១៣:១៥–១៦ អគ ៤៥:១០–១២ ហស ១២:៧ មីក ៦:១០–១១ សក ៥:៦ **៨:៦** ណ អម ៥:១១ ត អម ២:៦ ៤:១ **៨:៧** ថ ទដ ៤៧:៤ ទ ហស ៨:១៣ ធ យប ៣៥:១៥ **៨:៨** ន យប ៩:៦ យរ ៥១:២៩ ប ទដ ១៨:៧ យរ ៤៦:៨ អម ៩:៥

**៧:១៦** *កុំឱ្យទាយ* ធៀបនឹង ២:១២ ។

**៧:១៧** ក្នុងខនេះ លោកអេម៉ុសបានបែរមកថ្កោលទោលពួកសង្ឃម្នាក់នោះដោយចំពោះវិញម្តង ។ *ស្រីសំផឹង* នៅពេលដែលលោកអ័ម៉ាស៊ាត្រូវបាននិរទេសខ្លួន កូនប្រុសស្រីរបស់គាត់ត្រូវគេសម្លាប់ ទ្រព្យសម្បត្តិត្រូវបាត់បង់ ហើយប្រពន្ធរបស់គាត់ត្រូវធ្លាក់ខ្លួនធ្វើជាស្រីសំផឹងដើម្បីចិញ្ចឹមជីវិត ។ *ស្រុករបស់លោក* ទ្រព្យសម្បត្តិឯកជនរបស់លោកអ័ម៉ាស៊ានឹងត្រូវអ្នកដទៃចែកគ្នា *នៅស្រុក១* គឺនៅស្រុកដែលឋានៈជាសង្ឃរបស់គាត់ត្រូវបន្ទាបន្ថោកវិញ ។ *ហើយសាសន៍អ៊ីស្រាអែល . . . ស្រុករស់ខ្លួន* នៅត្រង់ចំណុចនេះ លោកអេម៉ុសបានលើកមកនិយាយឡើងវិញនូវពាក្យដែលលោកអ័ម៉ាស៊ាសង្ខេបសាររបស់លោកអេម៉ុស(ខ.១១) ។

**៨:១** *ទ្រង់បង្ហាញខ្ញុំ* មើលការពន្យល់ ៧:១ ។

**៨:២** *ឯងឃើញអ្វី . . .* មើល ៧:៨ និងការពន្យល់ ។ *ផ្លែរដូវក្តៅ . . . ចុងបំផុត* មានន័យថា ដល់ពេលដែលត្រូវវាយសាសន៍អ៊ីស្រាអែល ។ *រាស្ត្រអញ* មើល ៧:៨ និងការពន្យល់ ។ *មិនដើរបង្ហួសគេទៅទៀត* មើល ៧:៨ ។

**៨:៣** *នៅថ្ងៃនោះ* មើល ៥:១៨ និងការពន្យល់ ។ *សំរែកទ្រហោយំ . . . ស្ងៀមស្ងាត់* នៅក្នុងរដូវចម្រូតនេះ និងគ្មានចំរៀងអរព្រះគុណទៀតឡើយ (ខុសពី លវ ២៣:៣៩–៤១) ប៉ុន្តែ មានតែភាពស្ងៀមស្ងាត់នៅចំពោះមុខនៃការជំនុំជម្រះរបស់ព្រះ(មើលការពន្យល់ ហព ២:២០) ។

**៨:៤** *ចង់លេប* មើល ៥:១១ និងការពន្យល់ ។

**៨:៥** *ថ្ងៃបុណ្យចូលខែ . . . ថ្ងៃឈប់សំរាក* គឺជាថ្ងៃបុណ្យជាផ្លូវការ ជាពេលដែលការរកស៊ីត្រូវផ្អាកសិន (មើល ជន ២៨:៩–១៥ ២ពវ ៤:២៣ និងការពន្យល់) ។ *ធ្វើបង្រួមរង្វាល់ ហើយដំឡើងថ្លៃ . . . ជញ្ជីងមិនត្រឹមត្រូវ* មើល លវ ១៩:៣៥ សភ ១១:១ និងការពន្យល់ ហស ១២:៧ ។

**៨:៦** មើលការពន្យល់ ២:៦ ។

**៨:៧** *ព្រះយេហូវ៉ាទ្រង់បានស្បថដោយសិរីល្អនៃយ៉ាកុប* មានន័យថា ទ្រង់ស្បថដោយនូវអង្គទ្រង់ ។ នៅក្នុង ៦:៨ លោកអេម៉ុសប្រើពាក្យសេចក្តីមានះរបស់យ៉ាកុប សំដៅទៅលើបន្ទាយទាហានរបស់ពួកអ៊ីស្រាអែល ។

**៨:៨** មើល ៩:៥ ។ *ឡើងលិចដូចជាទន្លេធំ* ទន្លេធំនេះគឺសំដៅទៅលើទន្លេនីលប្រទេសអេស៊ីព្ទ ។ ដោយសារតែភ្លៀងធ្លាក់ខ្លាំងប្រចាំរដូវ នៅប្រទេសអេធ្យូពី កំណើនប្រចាំឆ្នាំនៃទឹកទន្លេនីលនៅប្រទេសអេស៊ីព្ទ ត្រូវកើនឡើងដល់ប្រហែល ៧,៦ ម៉ែត្រ ធ្វើឱ្យជន់លិចតំបន់ជ្រលងភ្នំទាំងមូល លើកលែងតែទីក្រុង និងភូមិដែលស្ថិតនៅតំបន់ខ្ពស់ជាងទឹកជំនន់ ។ ទឹកទន្លេនេះបានហូរនាំដីល្បាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ សម្រាប់តំបន់នោះ ។

**៨:៩** *នៅថ្ងៃនោះ* មើល ៥:១៨ និងការពន្យល់ ។ *ឱ្យផែនដីបានទៅជាងងឹត* ដូចនៅក្នុងបទគម្ពីរផ្សេងទៀតដែរ "ថ្ងៃនៃព្រះអម្ចាស់"លោកិយនឹងត្រូវបំផ្លាញ ហើយពន្លឺនឹងក្លាយជាងងឹត(មើល ៥:១៨,២០ អស ១៣:១០ ២៤:២៣ ៣៤:៤ ៥០:៣ អគ ៣២:៧–៨ យអ ២:២,១០,៣១ និងការពន្យល់ ២:២ មីក ៣:៦ សផ ១:១៥ វវ ៦:១២) ដែលហាក់ដូចជា អ្វីដែលបានបង្កើតត្រូវ

ឱ្យ ផែនដីបានទៅជាងងឹត កំពុងដែលមេឃនៅស្រឡះផង[ផ]
១០អញនឹងធ្វើឱ្យបុណ្យ[ព]ទាំងប៉ុន្មានរបស់ឯងរាល់គ្នាទៅជា
ការយំសោក ហើយឱ្យបទចំរៀងរបស់ឯងរាល់គ្នាទៅជា
ពាក្យទំនួញវិញ[ភ] អញនឹងធ្វើឱ្យគ្រប់ទាំងចង្កេះបានស្លៀក
ដោយសំពត់ធ្មៃ[ម] ហើយគ្រប់[យ]ទាំងក្បាលបានត្រងោលផង
អញនឹងធ្វើឱ្យមានការយំសោក ដូចជាការយំសោកនឹងកូន
តែមួយ[រ] ឯចុងបំផុតនៃការនោះនឹងត្រូវជាថ្ងៃយ៉ាងល្វីង[ល]។
១១ព្រះអម្ចាស់យេហូវ៉ាទ្រង់មានបន្ទូលថា មើល មានគ្រា
មក[វ] ដែលអញនឹងចាត់ប្រើអំណត់មកក្នុងស្រុក មិនមែនជា
អំណត់ដែលអត់អាហារ[ស] ឬដែលស្រេកទឹកទេ គឺជាអំណត់
ខាងឯការឮព្រះបន្ទូលនៃព្រះយេហូវ៉ាវិញ[ហ] ១២គេនឹងដើរ
ចុះឡើងពីសមុទ្រម្ខាងទៅសមុទ្រម្ខាង ហើយពីទិសខាង
ជើងរហូតដល់ទិសខាងកើត គេនឹងរត់ច្រវាត់ខំរកព្រះ
បន្ទូលនៃព្រះយេហូវ៉ាតែនឹងមិនប្រទះឡើយ[ឡ] ១៣នៅថ្ងៃ
នោះ ពួកក្រមុំៗយ៉ាងល្អ និងពួកកំឡោះៗ[អ]នឹងល្វើយទៅ
ដោយស្រេក[ក] ១៤ពួកអ្នកដែលស្បថដោយអំពើបាបរបស់
សាម៉ារី[ខ] ដោយថា "ដូចជាព្រះឯងរស់នៅ ឱដាន់អើយ"[គ]
ហើយថា "ដូចជាផ្លូវប្រព្រឹត្តនៃបៀរ-សេបា[ឃ]បានរស់នៅ"
ដែរ ពួកទាំងនោះនឹងដួល[ង] ឥតក្រោកឡើងវិញឡើយ[ច]។

**៨:៩** ផ យប ៥:១៤ អស ៥៩:៩-១០ យរ ១៣:១៦ ១៥:៩ អគ ៣២:៧ អម ៥:៨ មីក ៣:៦ មថ ២៧:៤៥ មក ១៥:៣៣ លក ២៣:៤៤-៤៥ **៨:១០** ព លវ ២៦:៣១ ភ បទ ៥:១៥ ហស ២:១១ ម យអ ១:៨ យ លវ ១៣:៤០ អស ៣:១៧ រ លប ២១:១៦ ល យរ ២:១៩ អគ ៧:១៨ **៨:១១** វ យរ ៣០:៣ ៣១:២៧ ស អស ៣០:២០ ហ ១សយ ៣:១ ២៨:៦ ២របា ១៥:៣ **៨:១២** ឡ អគ ២០:៣,៣១ **៨:១៣** អ អស ៩:១៧ ក អស ៤១:១៧

## សាសន៍អ៊ីស្រាអែលនឹងទទួលរងការបំផ្លាញ

**៩** ១ខ្ញុំក៏ឃើញព្រះអម្ចាស់ទ្រង់ឈរក្បែរអាសនា ហើយ
ទ្រង់បង្គាប់ថា ចូរវាយក្បាលសសរឱ្យជើងត្រូវញ័រ ហើយ
បំបែកនៅលើក្បាល[ក]របស់មនុស្សទាំងអស់ រួចពួកអ្នកដែល
សល់ អញនឹងប្រហារដោយដាវ ឥតមានអ្នកណា១ដែល
រត់ទៅបាន ឬអ្នកណាដែលនឹងរួចឡើយ[ខ] ២ទោះបើគេ
ជីកទំលុះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ក៏ដោយ[គ] គង់
តែដៃអញនឹងចាប់គេមកពីទីនោះដែរ ហើយទោះបើគេ
ប្រឹងឡើងទៅដល់ស្ថានសួគ៌[ឃ] គង់តែអញនឹងនាំគេចុះពី
នោះមកវិញ[ង] ៣ទោះបើគេពួនខ្លួននៅលើកំពូលភ្នំកើមែល
ក៏ដោយ[ច] គង់តែអញនឹងរកគេ ហើយចាប់នាំចេញពីទី
នោះ[ឆ]មក ទោះបើបានលាក់កំបាំងពីភ្នែកអញនៅទីបាតាល
នៃសមុទ្រក៏ដោយ[ជ] គង់តែអញនឹងបង្គាប់ដល់នាគ[ឈ] ហើយ
វានឹងចឹកគេនៅទីនោះ[ញ,ដ] ៤ទោះបើគេត្រូវចាប់ទៅជា
ឈ្លើយ នៅពីមុខខ្មាំងសត្រូវ គង់តែអញនឹងបង្គាប់ដល់ដាវ[ឋ]

ហស ២:៣ **៨:១៤** ខ មីក ១:៥ គ ១ពវ ១២:២៩ ឃ អម ៥:៥ ង ទដ ៤៦:២ ច អម ៥:២ **៩:១** ក ទដ ៦៨:២១ ខ យរ ១១:១១ **៩:២** គ យប ៧:៩ អគ ២៦:២០ ឃ យរ ៥១:៥៣ ង អប ១:៤ **៩:៣** ច អម ១:២ ឆ ទដ ១៣៩:៨-១០ ជ ទដ ៦៨:២២ ឈ អស ២៧:១ ញ យរ ១៦:១៦-១៧ ដ លប ៤៩:១៧ យប ១១:២០ **៩:៤** ឋ លវ ២៦:៣៣ អគ ៥:១២

បំផ្លាញចោល (មើល យរ ៤:២៣ និងការពន្យល់) ។

**៨:១០** *ការយំសោក* មើលការរៀបរាប់របស់ស្ដេចដាវីឌអំពីការយំសោក (២សយ ១៨:៣៣) ។ *ស្លៀកសំពត់ធ្មៃ . . . ក្បាលបានត្រងោល* គឺជាសញ្ញាបញ្ជាក់អំពីការទួញសោក (មើល លប ៣៧:៣៤ អស ១៥:២-៣ និងាការពន្យល់) ។ *កូនតែមួយ* អនាគតនៃគ្រួសារត្រូវរំពឹងទៅលើកូនតែមួយនេះ (ធៀបនឹង ២សយ ១៨:១៨) ។ *ថ្ងៃយ៉ាងល្វីង* គឺផ្ទុយពី "ថ្ងៃសប្បាយ"(នអ ៩:២២) ។

**៨:១១** *គ្រាមក* គឺគ្រាជំនុំជម្រះដែលត្រូវមកដល់ ។ *អំណត់ខាងឯការឮព្រះបន្ទូលនៃព្រះយេហូវ៉ា* នៅពេលដែលជួបមហាទុក្ខ ពួកអ៊ីស្រាអែលបានបែរមកឯព្រះអម្ចាស់វិញ ដោយរំពឹងថានឹងឮពួកហោរាថ្លែងពាក្យនៃសេចក្ដីសង្ឃឹម ឬណែនាំ(មើលឧទាហរណ៍ក្នុង ២ពវ ១៩:១-៤,១៤-១៥ ២២:១៣-១៤ យរ ២១:១-២ អគ ១៤:៧) ប៉ុន្តែ នៅពេលដែលការជំនុំជម្រះត្រូវមកដល់ទ្រង់នឹងឆ្លើយតបនឹងការអំពាវនាវរបស់ពួកគេដោយភាពស្ងៀមស្ងាត់យ៉ាងខ្លាំង(មើល អគ ៧:២៦ និងការពន្យល់, ២០:១-៣ មីក ៣:៤,៧)។

**៨:១២** *ពីសមុទ្រម្ខាងទៅសមុទ្រម្ខាង ហើយពីទិសខាងជើងរហូតដល់ទិសខាងកើត* គឺពេញទូទាំងទឹកដីអ៊ីស្រាអែល ចាប់ពីសមុទ្រមេឌីទែរ៉ានេ ដល់សមុទ្រស្លាប់ ហើយរួមទាំងតំបន់យ័រដាន់ផងដែរ ។

**៨:១៣** *ស្រេក* គឺស្រេកទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ។ កម្លាំងរបស់ពួកគេត្រូវស្រុតចុះ ហើយសូម្បីតែ "មនុស្សស្រីក្មេងដែលគួឱ្យស្រឡាញ់ និងមនុស្សប្រុសដែលខ្លាំងរបស់ពួកគេ"នឹងត្រូវងងឹតមុខដួល ហើយប្រែជាគ្មានប្រយោជន៍ ។

**៨:១៤** *ពួកអ្នកដែលស្បថ* គឺដែលស្បថដោយឈ្មោះព្រះផ្សេងៗរបស់ពួកគេ គឺជាព្រះក្លែងក្លាយដែលពួកគេជឿ មិនមែនជាព្រះអម្ចាស់ឡើង ។ *សាម៉ារី* មើលការពន្យល់ ៦:១ ។ *ដាន់ . . . បៀរ-សេបា* គេមិនគ្រាន់តែស្គាល់ថាជាទីក្រុងព្រំខ័ណ្ឌនៅភាគខាងជើង និងខាងត្បូងនៃអ៊ីស្រាអែលប៉ុណ្ណោះទេ (មើលការពន្យល់ ពច ២០:១) ប៉ុន្តែថែមទាំងជាតំបន់ដែលល្បីខាងការសង់កន្លែងថ្វាយបង្គំរូបព្រះ(មើល ៥:៥ ១ពវ ១២:២៩ និងការពន្យល់) ។

**៩:១** *ខ្ញុំក៏ឃើញព្រះអម្ចាស់* មើលការពន្យល់ ៧:១ ។ *ក្បែរអាសនា* ត្រង់ចំណុចនេះព្រះអម្ចាស់ទ្រង់ហៀបនឹងបំផ្លាញទីកន្លែងដែលពួកគេរំពឹងថានឹងបានឮព្រះបន្ទូលនៃសន្តិភាព និងព្រះពរ ។ *ក្បាលសរសរឱ្យ* ព្រះទ្រង់នឹងបំផ្លាញព្រះវិហារទាំងស្រុង គឺចាប់ពីក្បាលសរសរដែលមានចម្លាក់ រហូតដល់មាត់ទ្វារដែលមានថ្មធំៗ ។ ឃ្លាបន្ទាប់នៅក្នុងខនេះ បកស្រាយអំពីការបំផ្លាញ ។ *ឥតមានអ្នកណា . . . នឹងរួចឡើយ* មើលការពន្យល់ ៧:៨ ។

**៩:២-៤** មើលការពន្យល់ ៧:៨ ។ វគ្គនេះបញ្ជាក់អំពីការដែលមិនអាចគេចពីការជំនុំជម្រះនៃព្រះអម្ចាស់ដែលត្រូវមកដល់ ។ ទោសដែលត្រូវទទួលនៅក្នុងវគ្គនេះ គឺប្រៀបបានទៅនឹងទោសនៅក្នុង ទដ ១៣៩:៧-១២(មើលការពន្យល់វគ្គនេះ)។ ទីកន្លែងដែលត្រូវទទួលការជំនុំជម្រះគឺរួមមានទីកន្លែងនីមួយៗ ហើយទៅដល់សូម្បីតែស្ថានឃុំព្រលឹងមនុស្សស្លាប់ (ខ.២) ។

**៩:៣** *កំពូលភ្នំកើមែល* មើលការពន្យល់ ១:២ ។ *នាគ* នៅក្នុងជំនឿសាសន៍ដទៃ វាគឺជាសត្វបិសាចសមុទ្រដ៏សាហាវ(មើល ទដ ៧៤:១៣-១៤ និងការពន្យល់)។ បើមានអ្នកណាមួយ(ខ.១)ចង់គេចខ្លួនដោយពួននៅក្នុងទីជំរៅ អ្នកនោះមិនគួរនឹងគេចពីព្រះឡើយ ព្រោះគ្មាននរណាអាចគេចពីទ្រង់បានឡើយ ។

**៩:៤** *ចាប់ទៅ . . . នៅពីមុខខ្មាំងសត្រូវ . . . អញនឹងបង្គាប់* សូម្បីតែអ្នក

ហើយដាវនឹងសំឡាប់គេនៅទីនោះដែរ អើ អញនឹងផ្តោត
ភ្នែកទៅឯគេ សំរាប់ការអាក្រក់[ឡ] មិនមែនជាការល្អ
ទេ[ឍ]។[ណ]
៥ដ្បិតព្រះអម្ចាស គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់ជាព្រះដែលគ្រាន់តែពាល់ផែនដី នោះផែនដីក៏រលាយ
ទៅ[ត] ហើយអស់អ្នកដែលអាស្រ័យនៅ ក៏នឹងសោកសៅ
ឯស្រុកគេទាំងមូលនឹងឡើងដូចជាទន្លេធំ រួចស្រកទៅវិញ
ដូចជាទន្លេនៃស្រុកអេស៊ីព្ទ[ថ] ៦ឯព្រះដែលបានសាងអស់
ទាំងស្ថានដ៏ខ្ពស់[ទ]របស់ទ្រង់ នៅលើស្ថានសួគ៌ ហើយតាំង
ជីវិតទាំងឡាយ ឱ្យនៅផែនដី ក៏តែងតែបង្គាប់ទឹកសមុទ្រ
ឱ្យឡើងទៅលើ រួចចាក់មកលើផែនដីវិញ ទ្រង់ព្រះនាម ជា
"ព្រះយេហូវ៉ា"[ធ]។
៧ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱពួកកូនចៅអ៊ីស្រា
អែលអើយ តើឯងរាល់គ្នាមិនមែនដូចជាពួកកូនចៅរបស់
សាសន៍អេធីយ៉ូពីដល់អញទេឬ[ន] តើមិនមែនអញដែលនាំ
ពួកអ៊ីស្រាអែលឡើងចេញពីស្រុកអេស៊ីព្ទ និងពួកភីលីស្ទីន[ប]
ពីស្រុកកាប់ថោរ[ផ] ហើយពួកស៊ីរីពីស្រុកគារទេឬអី[ព] ៨មើល
ព្រះនេត្រនៃព្រះអម្ចាស់យេហូវ៉ា ក៏ទតឃើញនគរនេះដែល
មានបាប ហើយអញនឹងបំផ្លាញ[ភ]ឱ្យសូន្យបាត់ពីផែនដីចេញ
តែព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា អញនឹងមិនបំផ្លាញពួក
វង្សយ៉ាកុបអស់រលីងទេ[ម] ៩ដ្បិតមើល អញនឹងបង្គាប់
ហើយនិងរែងពួកវង្សអ៊ីស្រាអែល ទៅនៅកណ្តាលអស់
ទាំងសាសន៍ ដូចជាគេរែងអង្ករ[យ]នៅក្នុងកញ្ច្រែង[រ] ឥតមាន
គ្រាប់ណាធ្លាក់ដល់ដីឡើយ[ល] ១០អស់អ្នកមានបាបក្នុងរាស្ត្រ
អញ ដែលពោលថា ការអាក្រក់នឹងតាមយើងមិនទាន់
ឬប្រទះនឹងយើងឡើយ[វ] គេនឹងត្រូវស្លាប់ដោយដាវ[ស]។

## ការស្អាងនគរអ៊ីស្រាអែលឡើងវិញ

១១នៅថ្ងៃនោះអញនឹងលើកទីលំនៅរបស់ដាវីឌ[ហ] ឡើង
វិញ[ឡ] គឺជាទីដែលត្រូវរលំ ហើយនឹងបិទចន្លោះបាក់បែក
ឱ្យជិត អញនិងលើកទីខូចបង់ឡើង[អ] ហើយសង់ឡើងឱ្យដូច
ជាកាលពីដើម[ក] ១២ដើម្បីឱ្យគេបានធ្វើជាម្ចាស់ លើសំណល់
នៃសាសន៍អេដំម[ខ] និងអស់ទាំងសាសន៍ផ្សេងៗ ដែលបាន
ហៅតាមឈ្មោះអញ[គ] នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា

**៩:៤** ឡ យរ ២១:១០ ឍ យរ ៣៩:១៦ អគ ១៥:៧ ណ យរ ៤៤:១១
**៩:៥** ត ទដ ៤៦:២ ថ អម ៨:៨
**៩:៦** ទ យរ ៤៣:៩ ធ ទដ ១០៤:១-៣, ៥-៦,១៣ អម ៥:៨
**៩:៧** ន ២រប ១២:៣ អស ២០:៤ ៤៣:៣ ប លប ១០:១៤ ផ ចទ ២:៣៣ ព ២ពវ ១៦:៩ អស ២២:៦ អម ២:១០
**៩:៨** ភ យរ ៤:២៧ ម យរ ៤៤:២៧
**៩:៩** យ លក ២២:៣១ រ អស ៣០:២៨ ល យរ ៣១:៣៦ ដយ ៩:៧
**៩:១០** វ យរ ៥:១២ ២៣:១៧ អគ ២០:៣៨ អម ៦:៣ ស យរ ៤៩:៣៧ **៩:១១** ហ អស ៧:២ ឡ លប ២៦:២២ អ ទដ ៥៣:៦ អស ៤៩:៨ ក ទដ ៨០:១២ អគ ១៧:២៤ មីក ៧:៨,១១ សក ១២:៧ ១៤:១០ **៩:១២** ខ ជណ ២៤:១៨ គ អស ៤៣:៧ យរ ២៥:២៩

ដែលត្រូវខ្ចាត់ខ្ចាយ ហើយវិលរស់នៅក្នុងប្រទេសដទៃក៏ត្រូវទទួលការជំនុំជម្រះរបស់ព្រះអម្ចាស់ដែរ ។ *អញនឹងផ្តោតភ្នែក . . . សម្រាប់ការអាក្រក់* ខុសពី ទដ ៣៣:១៨-១៩ ៣៤:១៥ ។

**៩:៥** *ព្រះអម្ចាស់ . . . ដែល* ខនេះជាការរំឭកថា ព្រះនៃអ៊ីស្រាអែលគឺជាព្រះអាទិករ និងព្រះដែលធ្វើឱ្យសាកលលោកមានចលនា ហើយខនេះនិយាយសង្កត់ធ្ងន់វគ្គមុនៗ (មើល ៤:១៣ ៥:៨-៩ និងការពន្យល់)។ *ផែនដី . . . រលាយ* មើលការពន្យល់ ទដ ៤៦:៦ ។ *ឡើងដូចជាទន្លេធំ* មើល ៨:៨ និងការពន្យល់ ។

**៩:៦** *ស្ថានដ៏ខ្ពស់របស់ទ្រង់* គឺផ្ទុយពីស្ថានរបស់មនុស្ស ដែលសង់ឡើងមិនអាចស្ថិតស្ថេរនៅបាន (ខ.៥)។ មើល ទដ ១០៤:៣ និងការពន្យល់ ។ *ទឹកសមុទ្រ* មើល ៥:៨ និងការពន្យល់ ។

**៩:៧** *សាសន៍អេធីយ៉ូពី* សាសន៍ស្បែកខ្មៅដែលរស់នៅភាគខាងត្បូងស្រុកអេស៊ីព្ទ (មើល យរ ១៣:២៣)។ *តើមិនមែនអញដែលនាំពួកអ៊ីស្រាអែលឡើង . . .* មើលការពន្យល់ នក ២០:២ ។ ពួកអ៊ីស្រាអែលមិនអាចពឹងផ្អែកទៅលើព្រះពរដែលពួកគេបានទទួលកាលពីមុន ដើម្បីធានាដល់អនាគតពួកគេបានទេ ។ ភាពក្បាលរឹង និងការបះបោររបស់ពួកគេបានធ្វើឱ្យការដែលព្រះបានរំដោះពួកគេពីប្រទេសអេស៊ីព្ទមិនមានន័យអ្វីសម្រាប់ពួកគេ ។ *ពួកភីលីស្ទីនពីស្រុកកាប់ថោរ* មើលការពន្យល់ យរ ៤៧:៧ ។ *ស្រុកគារ* មើលការពន្យល់ ១:៥ ។

**៩:៨** *នគរនេះ ដែលមានបាប* គឺនគរអ៊ីស្រាអែល ដែលព្រះបានរើសតាំង ។ ការមិនស្តាប់បង្គាប់ពួកគេបាននាំឱ្យមានអំពើបាបខ្លាំងជាងបាបរបស់សាសន៍ដទៃ (មើល ១:៣-២:១៦ ៣:១-២ និងការពន្យល់ ៣:២)។ *អញនឹងមិនបំផ្លាញពួកវង្សយ៉ាកុបអស់រលីងទេ* មើលការពន្យល់ ខ.១១ ។

**៩:៩** *កញ្ច្រែង* គឺត្រូវបានប្រើសម្រាប់រែងអង្ករចេញពីគ្រួស និងកំទេចអ្វីផ្សេងៗទៀត ។ *ឥតមានគ្រាប់ណា១ធ្លាក់* មានតែគ្រួស និងកំទេចអ្វីផ្សេងទៀតប៉ុណ្ណោះដែលត្រូវធ្លាក់ហើយចោល ។

**៩:១០** *អស់អ្នកមានបាប . . . នឹងត្រូវស្លាប់* គឺដោយសារតែការបះបោរប្រឆាំងមិនឈប់ឈររបស់គេ ។ *រាស្ត្រអញ* មើល ៧:៨ និងការពន្យល់ ។

**៩:១១-១២** ជាបទគម្ពីរដែលដកស្រង់ដោយព្រះគម្ពីរ កច ១៥:១៦-១៧ (មើលការពន្យល់ កច ១៥:១៦)។

**៩:១១** *អញនឹងលើកទីលំនៅរបស់ដាវីឌឡើង* គឺជាព្រះបន្ទូលនៃសេចក្តីសង្ឃឹម ដែលមានចាប់ពី លប ៣:១៥ ។ ព្រះទ្រង់នឹងប្រទានព្រះពរបន្ទាប់ពីជំនុំជម្រះហើយ ហើយទ្រង់នឹងមិនបដិសេធន៍អ៊ីស្រាអែលជារៀងរហូតទេ ។ *ទីលំនៅ* គឺសំដៅទៅលើពូជហ្លួងដាវីឌ (រាជ្យវង្ស) ឬនគរដែលបង្រួមពីពូជអំបូរទាំង១២ (នគរស្តេចដាវីឌ)។ ពាក្យនេះអាចសំដៅទៅលើខ្ទមដែលជាទីកន្លែងដែលស្តេចដាវីឌចាប់ផ្តើមជីវិតដោយការបន្ទាបខ្លួន ។ *ដូចជាកាលពីដើម* គឺដូចនៅសម័យស្តេចដាវីឌ និងសាឡូម៉ូន ។

**៩:១២** *សំណល់នៃសាសន៍អេដំម* គឺជាអ្វីដែលសេសសល់ពីខ្មាំងសត្រូវរបស់អ៊ីស្រាអែល (មើលការពន្យល់ ១:១១) ដែលបានទទួលការជំនុំជម្រះ ។ *អស់ទាំងសាសន៍ផ្សេងៗដែលបានហៅតាមឈ្មោះអញ* គឺសំដៅទៅលើអំណាចរបស់អនាគតមហាក្សត្រដែលព្រះអម្ចាស់ចាក់ប្រេងតាំង និងរំឭកអំពីស្តេចដាវីឌដែលបានគ្រប់គ្រងលើសាសន៍ជាច្រើននៅជុំវិញអ៊ីស្រាអែល ។ ម្យ៉ាងវិញទៀត ការនេះគឺជានិមិត្តរូបនៃការបំពេញសេចក្តីសញ្ញារបស់លោកអ័ប្រាហាំ និងសេចក្តីសញ្ញារបស់ស្តេចដាវីឌ ។ ព្រះមែស៊ីទ្រង់នឹងគ្រប់គ្រងសូម្បីតែខ្មាំងសត្រូវរបស់អ៊ីស្រាអែល ដែលមានប្រទេសអេដំមជានិមិត្តរូប (មើលការពន្យល់ អស ៣៤:៥ យអ ៣:១៩ អប ៨)។ *ធ្វើការទាំងនេះ* ព្រះ

ដែលទ្រង់ធ្វើការទាំងនេះ[ឃ]
១៣ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ថា មើល មានថ្ងៃមក[ង]ដែលអ្នកភ្ជួររាល់នឹងធ្វើការ ដរាប
ដល់ជួបនឹងអ្នកច្រូតកាត់[ច] ហើយអ្នកដែលជាន់[ឆ]ផ្លែទំពាំង
បាយជូរ នឹងធ្វើការដរាបដល់ជួបនឹងអ្នក ដែលសាបព្រោះ
នោះភ្នំធំទាំងប៉ុន្មាន នឹងស្រក់ជាទឹកទំពាំងបាយជូរ[ជ] ហើយ
អស់ទាំងភ្នំតូចនឹងហូរដែរ[ឈ]
១៤អញនឹងនាំ[ដ]ពួកអ៊ីស្រាអែល
ជារាស្ត្រអញ ដែលជាប់ជាឈ្លើយ[ឋ] ឱ្យមកវិញ គេនឹងសង់
អស់ទាំងទីក្រុងខូចបង់ឡើង[ឌ] ព្រមទាំងអាស្រ័យនៅផង គេ
នឹងដាំចំការទំពាំងបាយជូរ[ឍ] ក៏នឹងផឹកស្រាទំពាំងបាយជូរ
ជាផលពីចំការនោះ គេនឹងដាំច្បារ ហើយស៊ីផលនោះ
ដែរ[ណ]
១៥អញនឹងដាំ[ត]គេចុះ នៅក្នុងស្រុករបស់គេ[ថ] ហើយ
គេមិនត្រូវរលើងចេញ[ទ]ពីស្រុករបស់ខ្លួន ដែលអញឱ្យដល់
គេនោះទៀតឡើយ[ធ] នេះជាព្រះបន្ទូល នៃព្រះយេហូវ៉ាជា
ព្រះនៃឯង[ន]។/

**៩:១២** ឃ កច ១៥:១៦–១៧ **៩:១៣** ង យរ ៣១:៣៨ ៣៣:១៤ ច រម ២:៣ ឆ លវ ២៦:៥ ជ ពច ៩:២៧ ឈ យអ ២:២៤ ញ យអ ៣:១៨ **៩:១៤** ដ យរ ២៩:១៤ ឋ យរ ៣៣:៧ ឌ អស ៣២:១៨ ៤៩:៨ ៦១:៤ ឍ ២ពវ ១៩:២៩ ណ អស ៦២:៩ យរ ៣០:១៨ ៣១:២៨ អគ ២៨:២៥–២៦ ៣៤:១៣–១៤ អម ៥:១១ **៩:១៥** ត នក ១៥:១៧ អស ៦០:២១ ថ យរ ២៣:៨ ទ យអ ៣:២០ ធ អស ៦៥:៩ យរ ៣:១៨ អប ១:១៧ ន យរ ១៨:៩ ២៤:៦ ៣២:១៥ អគ ២៨:២៦ ៣៤:២៥–២៨ ៣៧:១២,២៥

ទ្រង់ធ្វើអ្វីដែលទ្រង់បានមានបន្ទូល ។

**៩:១៣–១៥** វគ្គនេះគឺជាពាក្យចុងក្រោយរបស់លោកអេម៉ុស បន្ទាប់ពីបទទំនាយអំពីការបំផ្លាញ ។ នៅក្នុងវគ្គនេះ លោកអេម៉ុសបានបង្ហាញអំពីភាពសម្បូរសប្បាយប្រកបដោយសិរីល្អនៅក្នុងសួនច្បារអេដែន នៅពេលដែលរដូវទាំងឡាយនឹងមកដល់ព្រមៗគ្នា ដើម្បីឱ្យការសាបព្រោះ និងការទទួលផលបានធ្វើឡើងព្រមគ្នាដោយគ្មានចន្លោះពេល ហើយនឹងមានការផ្គត់ផ្គង់ឥតដាច់នូវផលិតផលថ្មីៗ ដូចនេះវគ្គនេះក៏ជាការលើកមកនិយាយឡើងវិញនូវវគ្គ ៤:៦–១១ (មើលការពន្យល់វគ្គនេះ) ។

**៩:១៣** មើល យអ ៣:១៨ និងការពន្យល់ ។

**៩:១៤–១៥** *អញនឹងនាំ . . . គេនឹងសង់ . . . គេនឹងដាំ . . . គេនឹងដាំ* នៅក្នុងទឹកដីសន្យា ព្រះទ្រង់នឹងធ្វើឱ្យរាស្ត្ររបស់ទ្រង់បង្កើតរីកចំរើន មានផលផ្លែ ហើយបានសុខសាន្ត ។

**៩:១៤** *រាស្ត្រអញ* មើលការពន្យល់ ៧:៨ ផ្ទុយនឹង ហស ១:៩ ប៉ុន្តែ ចូរមើល ហស ២:២៣ ។ *សង់អស់ទាំងទីក្រុងខូចបង់* មើល អស ៥៨:១២ និងការពន្យល់ ។

**៩:១៥** *មិនត្រូវ . . . ទៀតឡើយ* មានន័យថា ព្រះទ្រង់នឹងស្អាងអ៊ីស្រាអែលឡើងវិញ ឱ្យបានពេញលេញនៅទីបញ្ចប់ ហើយអ៊ីស្រាអែលនឹងមិនត្រូវទទួលរងការបំផ្លាញទៀតឡើយ ។ *ព្រះនៃឯង* គឺខុសពី ហស ១:៩ ប៉ុន្តែចូរមើល ២:២៣ ។

# ព្រះគម្ពីរអូបាឌា

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ

អ្នកនិពន្ធនៃព្រះគម្ពីរនេះមានឈ្មោះថា អូបាឌា ដែលមានន័យថា "អ្នកបម្រើ (ឬអ្នកថ្វាយបង្គំ) ព្រះអម្ចាស់"។ ឈ្មោះរបស់លោកគឺជាឈ្មោះមួយដ៏សាមញ្ញ (មើល ១ពវ ១៨:៣-១៦ ១រប ៣:២១ ៧:៣ ៨:៣៨ ៩:១៦ ១២:៩ ២៧:១៩ ២រប ១៧:៧ ៣៤:១២ អរ ៨:៩ នហ ១០:៥ ១២:២៥)។ ព្រះគម្ពីរនេះមិនបានបញ្ជាក់ឈ្មោះរបស់ឪពុកគាត់ ឬទីកន្លែងកំណើតរបស់គាត់ទេ ។

### កាលបរិច្ឆេទ និងទីកន្លែងនៃការនិពន្ធ

មានការជជែកពិភាក្សាជាច្រើនអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការនិពន្ធ ។ ការកំណត់កាលបរិច្ឆេទនៃបទទំនាយនេះ គឺត្រូវផ្សាភ្ជាប់វគ្គ ខ.១១-១៤ ជាមួយនឹងព្រឹត្តិការណ៍សំខាន់ៗពីរ នៅក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល ដែលមានដូចជា :

១. ការបះបោររបស់សាសន៍អេដុំមប្រឆាំងនឹងស្រុកយូដា នៅក្នុងរាជ្យនៃស្ដេចយ៉ូរ៉ាម (ឆ្នាំ ៨៥៣ ដល់ ៨៤១ មុនគ.ស.) មើល ២ពវ ៨:២០-២២ ២រប ២១:៨-១៥ ។ នៅក្នុងករណីនេះគេសន្និដ្ឋានថា លោកអូបាឌារស់នៅក្នុងសម័យជាមួយនឹងលោកអេលីសេ ។

២. ចក្រភពបាប៊ីឡូនបានវាយប្រហារទីក្រុងយេរូសាឡិម (ឆ្នាំ ៦០៥ ដល់ ៥៨៦ មុនគ.ស.)។ តាមកាលបរិច្ឆេទនេះ គេសន្និដ្ឋានថា លោកអូបាឌារស់នៅក្នុងសម័យជាមួយនឹងលោកយេរេមា ។ កាលបរិច្ឆេទមួយនេះទំនងជាត្រឹមត្រូវជាង ។

បទគម្ពីរ អប ១-៦ និង យរ ៤៩:៩-១០,១៤-១៦ មានលក្ខណៈស្របគ្នាគួរឱ្យកត់សំគាល់ ជាហេតុនាំឱ្យមានអ្នកកាត់ស្រាយជាច្រើនបានសន្និដ្ឋានថា ព្រះគម្ពីរអូបាឌា និងព្រះគម្ពីរយេរេមា មានការពឹងផ្អែកទៅលើគ្នាទៅវិញទៅមក ប៉ុន្តែ លោកហោរាទាំងពីររូបប្រហែលជាបានបង្កប់នូវប្រភពជារួមមួយដែលយើងមិនទាន់បានរកឃើញ ។

### ខ្លឹមសារ

ព្រះគម្ពីរនេះគឺជាកណ្ឌដែលខ្លីជាងគេបំផុតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ខ្លឹមសារនៃព្រះគម្ពីរនេះគឺ សាសន៍អេដុំមដែលជាសាសន៍មានអំនួតចំពោះសន្តិសុខរបស់ខ្លួន បានឡកឡឺយឱ្យសាសន៍អ៊ីស្រាអែលដែលទទួលរងការបំផ្លិចបំផ្លាញពីបណ្ដាអំណាចបរទេស ។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមរបស់សាសន៍អេដុំមនៅក្នុងការបង្កវិនាសកម្មនេះ នឹងនាំឱ្យសាសន៍នេះទទួលសេចក្ដីក្រោធរបស់ព្រះ ។ សាសន៍នេះនឹងត្រូវទទួលរងការបំផ្លាញ ប៉ុន្តែ ព្រះអម្ចាស់ទ្រង់នឹងរំដោះភ្នំស៊ីយ៉ូន និងប្រទេសអ៊ីស្រាអែល ហើយនគររបស់ទ្រង់នឹងមានជ័យជំនះ ។

សាសន៍អេដុំមធ្វើការប្រឆាំងនឹងសាសន៍អ៊ីស្រាអែលអស់ជាច្រើនសតវត្ស ។ ចំពោះការសិក្សាអំពីទំនាក់ទំនងរវាងសាសន៍អ៊ីស្រាអែល និងសាសន៍អេដុំមតាមព្រះគម្ពីរ សូមមើល លប ២៧:៤១-៤៥ ៣២:១-២១ ៣៣ ៣៦ នក ១៥:១៥ ជន ២០:១៤-២១ ចទ ២:១-៦ ២៣:៧-៨ ១សយ ២២ ជាមួយ ទដ ៥២ ២សយ ៨:១៣-១៤ ២ពវ ៨:២០-២២ ១៤:៧ ទដ ៨៣ អគ ៣៥ យអ ៣:១៨-១៩ អម ១:១១-១២ ៩:១១-១២ ។

ដោយសារសាសន៍អេដុំមជាញាតិនឹងសាសន៍អ៊ីស្រាអែល (ខ.១០) ការដែលសាសន៍អេដុំមតាំងខ្លួនជាខ្មាំងសត្រូវនឹងសាសន៍ជាបងប្អូនឯង គឺកាន់តែសមនឹងទទួលជំនុំជម្រះ ។ ប្រទេសអេដុំមត្រូវមានទំនួលខុសត្រូវចំពោះការមិនព្រមផ្ដល់ជំនួយដល់អ៊ីស្រាអែល និងចំពោះការបំពានរបស់ខ្លួនដោយបើកចំហរ ។ ការពិតដែលព្រះអម្ចាស់ទ្រង់បដិសេធលោកអេសាវ (លប ២៥:២៣ មឡ ១:៣ រម ៩:១៣) គឺមិនមែនមានន័យថា ទ្រង់ចង់ឱ្យសាសន៍អេដុំមទទួលខុសត្រូវចំពោះទង្វើរបស់លោកអេសាវនោះទេ ។ ប្រទេសអេដុំមដែលមានអំណួតចំពោះទីមាំមួនរបស់ខ្លួននៅតំបន់ភ្នំ នឹងត្រូវបានបណ្ដេញចេញ ហើយបំផ្លាញនៅទីកន្លែងនោះ ប៉ុន្តែ ប្រទេសអ៊ីស្រាអែលនឹងបានសម្បូរសប្បាយវិញ ដោយសារព្រះទ្រង់មានវត្តមាននៅជាមួយ ។

### គម្រោងសង្ខេប

I. ចំណងជើង និងសេចក្ដីផ្ដើម (១)

II. ការជំនុំជម្រះសាសន៍អេដុំម (២-១៤)

ក. ការប្រកាសអំពីការបំផ្លាញប្រទេសអេដុំម (២-៧)

១. ការបន្ទាបប្រទេសអេដំម ដោយសារសេចក្ដីអំណួត (២–៤)

២. ការបំផ្លាញប្រទេសនេះទាំងស្រុង (៥–៧)

ខ. ការបញ្ជាក់ម្ដងទៀតអំពីការបំផ្លាញប្រទេសអេដំម (៨–១៤)

១. សេចក្ដីអាម៉ា និងការបំផ្លាញប្រទេសអេដំម (៨–១០)

២. ការបំពានប្រទេសអ៊ីស្រាអែល (១១–១៤)

III. ថ្ងៃនៃព្រះអម្ចាស់ (១៥–២១)

ក. ការជំនុំជម្រះជាតិសាសន៍ទាំងឡាយ និងការរំដោះទីក្រុងស៊ីយ៉ូន (១៥–១៨)

ខ. នគររបស់ព្រះអម្ចាស់ត្រូវបានសាងឡើង (១៩–២១)

១ នេះជាការជាក់ស្តែង[ក] របស់អូបាឌា ។

*ខ.១-៤ – យរ ៤៩:១៤-១៦*

*ខ.៥-៦ – យរ ៤៩:៩-១០*

ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលពីដំណើរសាសន៍
អេដំមដូច្នេះ[ខ] យើងបានឮដំណឹងមកពីព្រះយេហូវ៉ា ហើយ
មានទូត១[គ] បានចាត់ឱ្យមកនៅកណ្តាលសាសន៍ទាំងប៉ុន្មាន
ដោយពាក្យថា ចូរឯងរាល់គ្នាប្រុងប្រៀបឡើង យើងនឹង
លើកគ្នាឡើងទៅច្បាំងនឹងគេ[ឃ] ២ មើល អញបានធ្វើឱ្យឯង
ជានគរយ៉ាងតូច[ង] នៅក្នុងពួកនគរទាំងប៉ុន្មាន គេមើល
ងាយឯងជាខ្លាំង ៣ ម្នាលឯងដែលអាស្រ័យនៅក្នុងក្រហែង
ថ្ម[ច] ដែលមានទីលំនៅយ៉ាងខ្ពស់ ហើយក៏គិតក្នុងចិត្តថា
តើអ្នកណាអាចនឹងនាំអញចុះដល់ដី[ឆ] បាន សេចក្តីអំនួត[ជ] នៅ
ក្នុងចិត្តឯង បានបញ្ឆោតឯងហើយ ៤ ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា ទោះបើឯងហើរឡើងទៅយ៉ាងខ្ពស់ ដូចជាឥន្ទ្រី
ហើយធ្វើសំបុក[ឈ] ឯងនៅកណ្តាលអស់ទាំងផ្កាយក៏ដោយ
គង់តែអញនឹងនាំឯងចុះពីទីនោះមកដែរ[ញ,ដ] ។
៥ បើសិនជាមានចោរមកលួចឯង បើពួកចោរមកប្លន់
ឯង នៅពេលយប់ ឱម្ល៉េះសមឯងនឹងត្រូវអន្តរាយយ៉ាងណា
ហ្ន៎ នោះតើគេមិនគ្រាន់តែលួចឱ្យល្មមតែស្កប់ចិត្តទេឬ
បើពួកស៊ីឈ្នួលដោយបេះផ្លែទំពាំងបាយជូរ បានមកធ្វើការ
ឱ្យឯង នោះតើគេមិនទុកផ្លែខ្លះឱ្យប្រឡេះតាមក្រោយទេឬ[ឋ]
៦ ឱអេសាវត្រូវឆែកឆេរយ៉ាងណាហ្ន៎ គេបានរាវរកទ្រព្យ
សម្បត្តិលាក់ទុករបស់គេយ៉ាងណាហ្ន៎ ៧ គ្រប់អស់អ្នកដែល
បានពួតដៃជាមួយនឹងឯង[ឌ] គេបានបណ្តេញឯងរហូតទៅ
ដល់ព្រំស្រុកហើយ ពួកមនុស្សដែលបានចងស្ពានមេត្រីនឹង
ឯង គេបានបញ្ឆោតឯង ក៏បានឈ្នះផងពួកអ្នកដែល
បរិភោគអាហារ[ឍ] របស់ឯង គេបានដាក់អន្ទាក់ចាប់ឯង
ហើយ ឯងក៏មិនបានយល់ដែរ ៨ ព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា នៅថ្ងៃនោះ តើមិនត្រូវឱ្យអញបំផ្លាញ[ណ] ពួកអ្នក
ប្រាជ្ញ ចេញពីស្រុកអេដំមបង់ ហើយទាំងយោបល់ពីស្រុកភ្នំ
របស់អេសាវផងទេឬអី ៩ ឯពួកមនុស្សខ្លាំងពូកែរបស់ឯង
ឱថេម៉ានអើយ[ត] គេនឹងត្រូវស្រយុតចិត្ត ដើម្បីឱ្យគ្រប់គ្នាបាន
កាត់ចេញពីស្រុកភ្នំរបស់អេសាវ ដោយការប្រហារជីវិត

**១** ក អស ១:១
ខ លប ២៥:១៤
អស ១១:១៤
៣៤:១១ ៦៣:១-៦
យរ ៤៩:៧-២២
អគ ២៥:១២-១៤
៣២:២៩ អម
១:១១-១២
គ អស ១៨:២
ឃ យរ ៦:៤-៥
**២** ង ជន ២៤:១៨
**៣** ច អស ១៦:១
ឆ ២របា ២៥:១១-
១២ ជ អស ១៦:៦
**៤** ឈ អស ១០:១៤
ញ អស ១៤:១៣
ដ យប ២០:៦
**៥** ឋ ចទ ៤:២៧
២៤:២១ អស
២៤:១៣
**៧** ឌ យរ ៣០:១៤
ឍ ទដ ៤១:៩
**៨** ណ យហ ៥:១២ អស ២៩:១៤ **៩** ត លប ៣៦:១១,៣៤

**១-៤** វគ្គនេះមានលក្ខណៈដូចគ្នានឹង យរ ៤៩:១៤-១៦ ។

**១** *ការជាក់ស្តែង* ជាធម្មតាគេប្រើពាក្យនេះនៅក្នុងព្រះគម្ពីរសញ្ញាចាស់សំដៅទៅលើការបើកសំដែងពីព្រះអម្ចាស់ (មើល សភ ២៩:១៨ អស ១:១ និងការពន្យល់) ។ *អូបាឌា* មើលសេចក្តីផ្តើមត្រង់ អ្នកនិពន្ធ ។ *យើង* គឺអាចសំដៅទៅលើ (១) លោកអូបាឌា (២) លោកអូបាឌាជាមួយនឹងពួកអ៊ីស្រា-អែល ឬ (៣).ពួកហោរាដទៃទៀត ដែលថ្លែងព្រះបន្ទូលទាស់នឹងពួកសាសន៍អេដំម ។ ចាប់ពីខ.២ទៅ គឺនិយាយអំពីសេចក្តីទំនាយរបស់លោកអូបាឌា ដែលមានជាដំណាក់កាល ។ *ដំណឹង* គឺជាដំណឹងដែលអ្នកនាំសារបញ្ជូនទៅដល់សាសន៍ជាច្រើន ដើម្បីឱ្យពួកគេលើកទ័ពច្បាំងនឹងសាសន៍អេដំម ។ ការរួមគំនិតក្បត់ប្រហែលកំពុងតែកើតមានឡើងនៅក្នុងចំណោមសម្ព័ន្ធមិត្រមួយចំនួនរបស់សាសន៍អេដំម (ខ.៧) ។ ទោះសាសន៍អេដំមមានអារម្មណ៍ថា ខ្លួនមានសន្តិសុខក៏ដោយ (ដោយជឿជាក់លើបន្ទាយទាហាននៅលើភ្នំ និងពួកអ្នកប្រាជ្ញរបស់ខ្លួន ខ.២-៤,៨-៩) ក៏លោកអូបាឌានៅតែប្រកាសអំពីការជំនុំជម្រះរបស់ព្រះអម្ចាស់ ដែលនឹងកើតឡើងដល់សាសន៍នេះ ដោយសារការទាស់ប្រឆាំងនឹងសាសន៍អ៊ីស្រាអែល ។

**៣** *សេចក្តីអំនួត* មើល ខ.១២ យរ ៤៩:១៦ និងការពន្យល់ ។ *ថ្ម* ទីក្រុងសេឡាគឺជារាជធានីនៃប្រទេសអេដំម ។ ប្រហែលជាក្រោយមកប្តូរឈ្មោះជា "ពេត្រា" វិញ (ឈ្មោះសេឡា និងប៉េត្រា មានន័យថា "ថ្ម" ឬ "ជ្រលងភ្នំ") តំបន់ដែលមានថ្មច្រើននេះស្ថិតនៅភាគខាងត្បូង និងមានចំងាយ ៨០,៥ គីឡូម៉ែត្រ ពីសមុទ្រស្លាប់ (មើលការពន្យល់ ២ពវ ១៤:៧ អស ១៦:១) ។

**៤** *ឥន្ទ្រី* គឺជាបក្សីដែលមានអំនួត និងមានរាង្គស្អាត ហើយគេទទួលស្គាល់ថាមានកំឡាំងខ្លាំង ពូកែសម្លឹងមើល និងពូកែហោះហើរ (មើល ចទ ២៨:៤៩ អស ៤០:៣១ យរ ៤:១៣ ៤៩:២២ អគ ១៧:៣) ។ *ផ្កាយ* គឺប្រៀបបានទៅនឹងទីកន្លែងខ្ពស់ ដែលមិនអាចទៅដល់នៅលើភ្នំ ។

**៥-៦** វគ្គនេះគឺមានលក្ខណៈដូចគ្នានឹង យរ ៤៩:៩ និងការពន្យល់ ។

**៥** *ទុកផ្លែខ្លះឱ្យប្រឡេះតាមក្រោយ* មើល យរ ៤៩:៩ និងការពន្យល់ ។

**៦** *ទ្រព្យសម្បត្តិលាក់ទុក* លោកឌីអូដូរូស ស៊ីគូលូស (Diodorus Siculus) បានបង្ហាញថា ទ្រព្យសម្បត្តិដែលសាសន៍អេដំមរកបានពីជំនួញ ពួកគេលាក់ទុកនៅក្នុងទូដែកនៅក្នុងថ្ម ។

**៧** *បរិភោគអាហាររបស់ឯង* មើល ទដ ៤១:៩ និងការពន្យល់ ។ *ដាក់អន្ទាក់ចាប់ឯង* ត្រង់ចំណុចនេះប្រាកដជាបង្ហាញថា សម្ព័ន្ធមិត្រជិតស្និទ្ធរបស់សាសន៍អេដំមបានរួមគំនិតគ្នាក្បត់ ។

**៨** *នៅថ្ងៃនោះ* គឺនៅថ្ងៃដែលប្រទេសអេដំមត្រូវទទួលរងការបំផ្លិចបំផ្លាញ (មើល ខ.១៥ និងការពន្យល់) ។ ក្នុងសេចក្តីទំនាយនៃព្រះគម្ពីរសញ្ញាចាស់ជាញឹកញាប់ប្រទេសអេដំមគឺជានិមិត្ររូបនៃគ្រប់ទាំងអំណាចលោកិយទាំងអស់ដែលទាស់ប្រឆាំងនឹងព្រះ និងនគរទ្រង់ ដូចនេះការជំនុំជម្រះប្រទេសនេះ គឺជាទំនាយអំពីការដែលព្រះទ្រង់ដកយកចេញទាំងស្រុងនូវអំណាចទាស់ប្រឆាំងទាំងអស់នោះនៅថ្ងៃនៃព្រះអម្ចាស់ (មើលការពន្យល់ អម ៩:១២) ។ *ពួកអ្នកប្រាជ្ញ* គឺជាពួកអ្នកដែលប្រទេសអេដំមានការទុកចិត្តយ៉ាងខ្លាំង នៅក្នុងបញ្ហាសន្តិសុខ (មើល យរ ៤៩:៧ និងការពន្យល់) ។ លោកអេលីផា ដែលជាម្នាក់នៅក្នុងចំណោមសំឡាញ់ទាំងបីនាក់របស់លោកយ៉ូបគឺជាសាសន៍ថេម៉ាន (មើលការពន្យល់ ខ.៩) ។ *អេសាវ* គឺជាឈ្មោះម្យ៉ាងទៀតរបស់ប្រទេសអេដំម (មើល លប ៣៦:១ និងការពន្យល់) ។

**៩** *ថាម៉ាន* ពាក្យនេះប្រើសំដៅទៅលើសាសន៍អេដំមទាំងអស់ ដូចនៅក្នុង យរ ៤៩:៧,២០ (មើលការពន្យល់ យរ ៤៩:៧ អម ១:១២) ។ ថេម៉ានមានន័យថា "ខាងត្បូង" ឈ្មោះនេះប្រហែលជាប្រើសំដៅទៅលើការដែលប្រទេសអេដំមជាទឹកដីខាងត្បូង ។ ទោះជាយ៉ាងណាក៏ដោយ អ្នកខ្លះយល់ថាពាក្យថេម៉ាន គឺសំដៅទៅលើតំបន់តាវីឡាន ដែលស្ថិតនៅចំងាយប្រហែល

យ៉ាងសំបើម ។
១០សេចក្ដីអាម៉ាសខ្មាសនឹងគ្របលើឯង ឯងនឹងត្រូវកាត់
ចេញចារៀងរាបដរាប ដោយព្រោះការច្រឡោត[ថ] ដែល
ឯងបានប្រព្រឹត្តនឹងពួកយ៉ាកុប[ទ]ជាបងប្អូនឯង[ធ] ១១នៅថ្ងៃ
នោះ ដែលឯងបានឈរមើល ក្នុងកាលដែលពួកអ្នកដទៃ
បានចាប់យកកំឡាំងរបស់គេទៅ ហើយមានសាសន៍ដទៃ
លុកចូលទៅក្នុងទ្វារក្រុងរបស់គេ បោះឆ្នោត[ន]ចាប់យក
ក្រុងយេរូសាឡិម នោះឯងក៏ដូចជាពួកគេណាមួយដែរ[ប]
១២ប៉ុន្តែមិនត្រូវឱ្យឯងនឹកឃើញ[ផ]ពីថ្ងៃរបស់បងប្អូន ឯង
ជាថ្ងៃដែលគេត្រូវអន្តរាយ[ព] ដោយមានចិត្តរីករាយ[ភ] ពី
ដំណើរពួកកូនចៅយូដា ក្នុងកាលដែលគេត្រូវបំផ្លាញនោះ
ឡើយ[ម]ក៏មិនត្រូវមានសំដីធំ[យ] នៅថ្ងៃទុក្ខលំបាករបស់គេ
ដែរ[រ] ១៣នៅថ្ងៃដែលរាស្ត្រអញត្រូវអន្តរាយ[ល] នោះមិនត្រូវ
ឱ្យឯងលុកចូលទៅក្នុងទ្វារក្រុងរបស់គេទេ អើ កុំឱ្យគន់
មើលសេចក្ដីវេនារបស់គេ ក្នុងថ្ងៃដែលគេត្រូវអន្តរាយ
ឬលូកដៃទៅ ពាល់ប៉ះនឹងទ្រព្យសម្បត្តិរបស់គេក្នុងថ្ងៃដែល
គេត្រូវអន្តរាយនោះឡើយ ១៤ក៏មិនត្រូវឈររារាំងនៅត្រង់
ផ្លូវខ្វែង ដើម្បីកាត់ពួកគេណាដែលរត់រួចបង់[វ] ឬប្រគល់ពួក
គេ ដែលនៅសល់ក្នុងថ្ងៃទុក្ខលំបាកនោះឡើយ ។

១៥ដ្បិតថ្ងៃរបស់ព្រះយេហូវ៉ា ជិត[ស]នឹងមកលើអស់ទាំង
សាសន៍ហើយ នោះដែលឯងបានប្រព្រឹត្តយ៉ាងណា ក៏នឹង
មានគេប្រព្រឹត្តនឹងឯងយ៉ាងនោះដែរ គឺអំពើរ[ហ]ដែលឯង
ប្រព្រឹត្តនោះ នឹងធ្លាក់មកលើក្បាលឯងវិញ ១៦ដ្បិតដែល
ឯងបានផឹក[ឡ]នៅលើភ្នំបរិសុទ្ធរបស់អញជាយ៉ាងណា[អ] នោះ
អស់ទាំងសាសន៍ដទៃនឹងផឹក[ក]យ៉ាងនោះជានិច្ចដែរ អើ គេ
នឹងផឹក ហើយលេបចុះទៅ រួចនឹងត្រឡប់ដូចជាមិនដែល
កើតមកវិញ[ខ] ។
១៧ប៉ុន្តែនៅភ្នំស៊ីយ៉ូន និងមានពួកអ្នកខ្លះដែលរួចជីវិត[គ]
ហើយភ្នំនោះនឹងបានបរិសុទ្ធ[ឃ] ឯពួកវង្សយ៉ាកុប គេនឹង
បានកេរ្តិ៍អាកររបស់គេវិញ[ង] ១៨នោះពួកវង្សយ៉ាកុបនឹងបាន
ដូចជាភ្លើង ឯពួកវង្សយ៉ូសែបជាអណ្ដាតភ្លើង ចំណែក
ពួកវង្សអេសាវ គេនឹងបានដូចជាជញ្ជ្រាំង ហើយភ្លើង
នោះនឹងឆេះនៅកណ្ដាលគេ[ច] ព្រមទាំងបន្សុស[ឆ]គេអស់
រលីងទៅ ឥតមានអ្នកណាសល់នៅ[ជ]ក្នុងពួកវង្សអេសាវ
ឡើយ ដ្បិតព្រះយេហូវ៉ា ទ្រង់បានចេញវាចាហើយ ១៩គ្រា

**១០** ថ យអ ៣:១៩ ទ ទដ ១៣៧:៧ អម ១:១១–១២ ធ ទដ ១៣៧:៧ អគ ២៥:១២–១៤ ៣៥:៩ **១១** ន យប ៦:២៧ អគ ២៤:៦ ប អម ១:៦ **១២** ផ សភ ២៤:១៧ ព យប ៣១:២៩ ភ អគ ៣៥:១៥ ម សភ ១៧:៥ យ ទដ ១៣៧:៧ រ អគ ២៥:៦ មីក ៤:១១ ៧:៨ **១៣** ល អគ ៣៥:៥ **១៤** វ ១ពវ ១៨:៤ **១៥** ស យរ ៤៦:១០ អគ ៣០:៣ យអ ២:៣១ អម ៥:១៨ ហ យរ ៥០:២៩ ហព ២:៨ **១៦** ឡ អស ៥១:១៧

អ នក ១៥:១៧ ក យរ ២៥:១៥ ៤៩:១២ បទ ៤:២១–២២ ខ បទ ៤:២១ អគ ២៥:១២–១៤ **១៧** គ ទដ ៦៩:៣៥ អស ១៤:១–២ យអ ២:៣២ អម ៩:១១–១៥ ឃ ទដ ៧៤:២ អស ៤:៣ ង សក ៨:១២ **១៨** ច អស ១:៣១ ឆ សក ១២:៦ ជ យរ ៤៩:១០

៤,៨ គីឡូម៉ែត្រពីទីក្រុងពេត្រា ។

**១០** *សេចក្ដីអាម៉ាសខ្មាសនឹងគ្របលើឯង* សេចក្ដីខ្មាសជាធម្មតាមានជាប់ទាក់ទងនឹងភាពអាក្រាត ។ *ពួកយ៉ាកុប ជាបងប្អូនឯង* អំពើអាក្រក់ដែលប្រទេសអេដំមបានធ្វើគឺកាន់តែត្រូវទទួលការជំនុំជម្រះ ពីព្រោះជាការប្រព្រឹត្តមកលើសាសន៍ដែលជាបងប្អូន ។

**១១** មើលសេចក្ដីផ្ដើមត្រង់ កាលបរិច្ឆេទ និងទីកន្លែងសរសេរ ។ *ពួកអ្នកដទៃ . . . សាសន៍ដទៃ* នៅត្រង់ចំណុចនេះចង់បញ្ជាក់ថា ប្រទេសអេដំមមិនបានប្រព្រឹត្តឱ្យដូចជាបងប្អូនទេ (ខ.១២) គឺបានប្រព្រឹត្តឱ្យដូចជាអ្នកដទៃវិញ ។ *បោះឆ្នោតចាប់យកក្រុងយេរូសាឡិម* មើល អគ ២៤:៦ និងការពន្យល់ ។

**១២–១៤** វគ្គនេះគឺជាការស្ដីបន្ទោសឱ្យដល់ការដែលប្រទេសអេដំមតាំងខ្លួនជាសត្រូវសាសន៍អ៊ីស្រាអែល ។ ការស្ដីបន្ទោសទីប្រាំបីនៅក្នុងវគ្គនេះ គឺចាប់ផ្ដើមពីការស្ដីបន្ទោសជាទូទៅដល់ការស្ដីបន្ទោសជាពិសេស ។ សូមមើលឧទាហរណ៍អំពីការឆ្លើយតបរបស់ប្រទេសអេដំមចំពោះហេតុការណ៍អាក្រក់ដែលកើតឡើងចំពោះប្រទេសយូដា នៅក្នុង ទដ ១៣៧:៧ អគ ៣៥:១៣ (មើលការពន្យល់ ទដ ១៣៧:៧ ផងដែរ) ។

**១២** *សំដីធំ* មើល ខ.៣ យរ ៤៩:១៦ និងការពន្យល់ ។

**១៥** *ថ្ងៃរបស់ព្រះយេហូវ៉ា ជិតនឹងមកលើអស់ទាំងសាសន៍ហើយ* ប្រសិនបើ "នៅថ្ងៃនោះ"មានពន្លឺនៃការជំនុំជម្រះ(ខ.៨) នោះគឺជាពន្លឺដ៏ខ្លាំង ។ ថ្ងៃនៃព្រះអម្ចាស់នឹងនាំមកនូវការជំនុំជម្រះដល់ជាតិសាសន៍(គឺមិនគ្រាន់តែជំនុំជម្រះសាសន៍អេដំមប៉ុណ្ណោះទេ) និងសេចក្ដីសង្គ្រោះដល់ពួកវង្សយ៉ាកុប (មើល ខ.១៧ អម ៥:១៨ យអ ១:១៥ និងការពន្យល់) ។ *នឹងធ្លាក់មកលើក្បាលឯងវិញ* សាសន៍អេដំមទទួលសេចក្ដីជំនុំជម្រះដោយសារតែការទាស់ប្រឆាំងនឹងរាស្ត្ររបស់ព្រះ (ខ.១១–១៤) ។ លោកអេសេគាលបានប្រកាសអំពីបាបរបស់សាសន៍អេដំម (ជំពូក ៣៥) និងឆ្លុះបញ្ចាំងអំពីការដាក់ទោសស្រដៀងគ្នាដែលពួកគេសមនឹងទទួលតាមទោសកំហុស ។

**១៦** *ដែលឯងបានផឹក* សាសន៍ទាំងឡាយ"នឹងផឹកហើយ ផឹកទៀត" ដូចដែលសាសន៍អេដំមបានបង្អាប់ភ្នំបរិសុទ្ធដោយការផឹកស៊ីដែរ ។ នោះគឺជាការផឹកគ្រឿងល្វីងជូរចត់ដែលជាការជំនុំជម្រះរបស់ព្រះ ដោយឱ្យពួកគេបន្តរផឹកឥតឈប់ឈរ ។ ចំពោះការផឹកដែលជាទោស សូមមើល យរ ២៥:១៥–១៦ ៤៩:១២ និងការពន្យល់ ។

**១៧** *ប៉ុន្តែនៅភ្នំស៊ីយ៉ូន នឹងមានពួកអ្នកខ្លះដែលរួចជីវិត* ចាប់ពីខនេះទៅ គឺនិយាយអំពីព្រះពរដែលព្រះទ្រង់មានចំពោះពួកវង្សយ៉ាកុប ។ នៅក្នុងការជំនុំជម្រះ មានការសំខាន់ពីរយ៉ាងគឺ ព្រះទ្រង់កាត់ទោសសត្រូវរបស់ទ្រង់ និងទ្រង់ប្រទានព្រះពរដល់រាស្ត្ររបស់ទ្រង់ ។ *កេរ្តិ៍អាករ* គឺជាទឹកដីដែលព្រះទ្រង់បានសន្យាប្រទានដល់ពួកគេ (មើល យរ ៣:១៩ ១២:៧ និងការពន្យល់) ។

**១៨** *យ៉ាកុប . . . យ៉ូសែប* នៅវគ្គមុន ព្រះអម្ចាស់ទ្រង់នឹងបំផ្លាញប្រទេសអេដំមដោយសាសន៍ដទៃ (ខ.៧) ឥឡូវនេះទ្រង់ឱ្យរាស្ត្ររបស់ទ្រង់ជាអ្នកបំផ្លាញ ។ *អ្នកណាសល់នៅ* ព្រះបន្ទូលចុងក្រោយសម្រាប់វង្សអេសាវគឺថាពួកវង្ស(ជាតិសាសន៍)របស់ពួកគេនឹងត្រូវបំផ្លាញទាំងស្រុង ដូចនេះនឹងគ្មានសាសន៍អេដំមណាដែលនៅសល់ជីវិតទេ ។ ធៀប អម ៩:១២ ជាមួយនឹង កច ១៥:១៧ និងការពន្យល់ អម ៩:១២ ។

**១៩** *ពួកមនុស្ស . . . ចាប់យក* ដោយសារសាសន៍អេដំមត្រូវទទួលរងការ

នោះ ពួកមនុស្សនៅស្រុកត្បូង នឹងបានស្រុកភ្នំអេសាវ ជា
របស់ផងខ្លួន ឯពួកមនុស្សនៅស្រុកទ្រនាប គេនឹងបាន
ពួកភីលីស្ទីន[ឈ] គេនឹងចាប់យកស្រុកវាលរបស់អេប្រាអិម
និងស្រុកវាលរបស់សាម៉ារី[ញ] ហើយបេនយ៉ាមីន[ដ]នឹងបាន
ស្រុកកាឡាត់ ជារបស់ផងខ្លួន
២០ ឯពួកពលទ័ពនៃកូនចៅ
អ៊ីស្រាអែល ដែលជាប់ជាឈ្លើយ គេនឹងបានស្រុករបស់ពួក
សាសន៍កាណាន រហូតដល់ក្រុងសារិបតា[ឋ] ហើយពួកក្រុង
យេរូសាឡិមដែលនៅជាឈ្លើយ ត្រង់សេផារ៉ាឌ គេនឹង
បានអស់ទាំងទីក្រុងនៅស្រុកត្បូង[ឌ] នោះនឹងមានពួកអ្នក
ដែលបានសង្គ្រោះ[ឍ]ឡើងមកឯភ្នំស៊ីយ៉ូន ដើម្បីនឹងជំនុំជំរះ
ស្រុកភ្នំរបស់អេសាវ ហើយរាជ្យនោះនឹងបានជារបស់
ផងព្រះយេហូវ៉ា[ណ] ។/

**១៩** ឈ អស ១១:១៤
ញ យរ ៣១:៥
ដ ជន ១:៣៦
**២០** ឋ ១ពវ ១៧:៩–១០ លក ៤:២៦
ឌ យរ ៣៣:១៣
ឍ ចទ ២៨:២៩ ពច ៣:៩
ណ ទដ ២២:២៨ ៤៧:៩ ៦៦:៤ ដយ ២:៤៤ សក ១៤:៩,១៦ មឡ ១:១៤ វវ ១១:១៥

បំផ្លាញ ដូចនេះសាសន៍ដទៃនឹងកាន់កាប់ទឹកដីសាសន៍អេដំម ។ *ស្រុកត្បូង* មើលការពន្យល់ លប ១២:៩ ។ *ស្រុកទ្រនាប* មើលការពន្យល់ មីក ១:១០–១៥ ។ *ពួកភីលីស្ទីន* មើលការពន្យល់ លប ១០:១៤ ។ *ស្រុកកាឡាត* មើលការពន្យល់ លប ៣១:២១ បស ៤:១ ។

**២០** *ក្រុងសារិបតា* មើលការពន្យល់ ១ពវ ១៧:៩ ។ *សេផារ៉ាឌ* តាមធម្មតាពាក្យនេះប្រើសំដៅទៅលើ ក្រុងសើដេសនៅតំបន់អាស៊ីមីន័រ (Asia Minor ប្រទេសទួរគីសព្វថ្ងៃ) ទោះជាមានអ្នកខ្លះយល់ថា អាចជាទីក្រុងស្ពាតា (Sparta ទីក្រុងនៅប្រទេសក្រិក) ក៏ដោយ ។ *ពួកអ្នកដែលបានសង្គ្រោះ* បន្ទាប់ពីការនិយាយអំពីការចាប់យកដីកដីនៅជុំវិញទីក្រុងស៊ីយ៉ូន លោកហោរាអូបាឌាប្តូរមកនិយាយអំពីទីក្រុងនោះវិញម្តង ។ អ្នកសង្គ្រោះនឹងធ្វើដំណើរចុះពីភ្នំស៊ីយ៉ូន ហើយគ្រប់គ្រងភ្នំនៃអេសាវ ។ ភ្នំស៊ីយ៉ូននឹងបានទទួលការតម្កើងឡើងខ្ពស់ជាងភ្នំទាំងឡាយរបស់អេសាវ ។ អ្នកសង្គ្រោះនៅទីបញ្ចប់គឺជាព្រះមែស៊ី ។ *រាជ្យនោះនឹងបានជារបស់ផងព្រះយេហូវ៉ា* ឃ្លានេះគឺជាសេចក្តីសន្និដ្ឋាននៃសេចក្តីទំនាយ និងជាលទ្ធផលចុងក្រោយនៃប្រវត្តិសាស្ត្រ ។ កណ្ឌព្រះគម្ពីរចុងក្រោយបាននិយាយម្តងទៀតអំពីសេចក្តីនេះ (*វវ* ១១:១៥) ។

# ព្រះគម្ពីរយ៉ូណាស

## សេចក្ដីផ្ដើម

### ចំណងជើង

ចំណងជើងព្រះគម្ពីរនេះត្រូវបានដាក់ឡើងតាមឈ្មោះតួអង្គសំខាន់នៃព្រះគម្ពីរនេះ ដែលឈ្មោះរបស់គាត់មានន័យថា "ព្រាប"។ សូមមើល ការប្រើឈ្មោះអេប្រាអិមនៅក្នុង ហស ៧:១១ ដែលបង្ហាញថា នគរខាងជើង "គ្មានយោបល់ និងគ្មានប្រាជ្ញា" ។ មើលការពន្យល់ ទដ ៦៨:១៣ ៧៤:១៩ និងការពន្យល់ ។

### អ្នកនិពន្ធ

ទោះបីជាព្រះគម្ពីរនេះមិនបាននិយាយថា លោកយ៉ូណាសជាអ្នកនិពន្ធក៏ដោយ ក៏តាមប្រពៃណីរបស់សាសន៍យូដាបានទទួលស្គាល់ថា អ្នកនិពន្ធគឺជាលោកយ៉ូណាស ដែលជាកូនរបស់លោកអ័មីថាយ (១:១) ដែលនៅក្រុងកាថ–ហេភើ (២ពវ ១៤:២៥ មើលការពន្យល់ខនេះ) ក្នុងស្រុកសាប់យូល៉ូន (យស ១៩:១០,១៣) ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារព្រះគម្ពីរនេះមានលក្ខណៈស្រដៀងគ្នានឹងការអធិប្បាយ អំពីលោកអេលីយ៉ា និងអេលីសេ នោះព្រះគម្ពីរនេះអាចជាស្នាដៃនិពន្ធរបស់ពួកហោរា ដែលនិយាយអំពីពួកហោរាទាំងប៉ុន្មានរូបនោះ ដែលប្រហែលជានៅសតវត្សទី៨ មុនគ.ស. (មើលសេចក្ដីផ្ដើម ១ ពង្សាវតាក្សត្រ ត្រង់ចំណុច អ្នកនិពន្ធ ប្រភព និងកាលបរិច្ឆេទ)។

### ប្រវត្តិដើម

នៅក្នុងរយៈពេលប្រហែលពាក់កណ្ដាលមួយសតវត្ស ដែលលោកយ៉ូណាសធ្វើការបម្រើព្រះ (ឆ្នាំ ៨០០ ដល់ ៧៥០ មុនគ.ស.) មានព្រឹត្តិការណ៍ដ៏សំខាន់មួយបានកើតឡើងចំពោះនគរខាងជើងនៃអ៊ីស្រាអែល ស្ដេចយេរ៉ូបោមទីពីរ (ឆ្នាំ ៧៩៣ ដល់ ៧៥៣ មុនគ.ស.) បានរៀបចំព្រំដែនឡើងវិញ ដោយបញ្ចប់ជម្លោះជិតមួយសតវត្សដែលកើតឡើងយូរៗម្ដង រវាងប្រទេសអ៊ីស្រាអែល និងក្រុងដាម៉ាស ។

ដោយបានទទួលការរៀបចំមកអំពីព្រះអម្ចាស់ (២ពវ ១៤:២៦–២៧) ស្ដេចយេរ៉ូបោមបានឆ្លៀតឱកាស នៅពេលចក្រភពអាស–ស៊ើរទទួលបរាជ័យនៅក្រុងដាម៉ាស (នៅក្នុងពាក់កណ្ដាលទីពីរនៃសតវត្សទីប្រាំបួន មុនគ.ស.) ដោយបានវាយលុកទីក្រុងនេះដែលជាមជ្ឈមណ្ឌលនៃអំណាចរបស់សាសន៍ស៊ីរីអស់មួយរយៈពេល ។ មុនពេលនោះ ទឹកដីនៃប្រទេសអ៊ីស្រាអែលមិនគ្រាន់តែបានរួមតូចប៉ុណ្ណោះទេ ប៉ុន្តែ ស្ដេចនៃក្រុងដាម៉ាសថែមទាំងអាចគ្រប់គ្រងកិច្ចការផ្ទៃក្នុងរបស់នគរខាងជើង (២ពវ ១៣:៧)។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីស្ដេចចក្រភពអាសស៊ើរបានលើកទ័ពទាស់នឹងក្រុងដាម៉ាសនៅឆ្នាំ ៧៩៧ មុនគ.ស. ស្ដេចយេហូអាស នៃស្រុកអ៊ីស្រាអែលមានឱកាសយកមកវិញនូវទឹកដីដែលស្ដេចក្រុងដាម៉ាសបានវាយយក (២ពវ ១៣:២៥) ។ វិបត្តិផ្ទៃក្នុងនៃចក្រភពអាសស៊ើរបានផ្ដល់ឱកាសឱ្យស្ដេចយេរ៉ូបោមបញ្ចប់ការរៀបចំព្រំដែននៃនគរខាងជើងឡើងវិញ ។ តែទោះជាយ៉ាងណាក៏ដោយ នៅសម័យនោះ ចក្រភពអាសស៊ើរនៅតែជាការគំរាមកំហែងពីទិសខាងជើងដដែល ។

នៅសម័យនោះពួកហោរានៃព្រះអម្ចាស់បានចែកចាយដល់សាសន៍អ៊ីស្រាអែលអំពីបញ្ហាទាំងនេះ ។ នៅឆ្នាំប្រហែល ៧៩៧ មុនគ.ស. លោកអេលីសេបានទូលស្ដេចអ៊ីស្រាអែលអំពីអនាគតដែលត្រូវឈ្នះលើក្រុងដាម៉ាស (២ពវ ១៣:១៤–១៩) ។ ពីរបីឆ្នាំក្រោយមកលោកយ៉ូណាសបានថ្លែងទំនាយអំពីការរៀបចំព្រំដែននគរខាងជើងនៃអ៊ីស្រាអែល ដែលស្ដេចយេរ៉ូបោមបានធ្វើសម្រេច (២ពវ ១៤:២៥)។ ប៉ុន្តែក្រោយពីបានទទួលជ័យជម្នះភ្លាម អ៊ីស្រាអែលក៏មានមោទនភាពចំពោះអំណាចដែលខ្លួនទើបតែមាននោះ ។ អ៊ីស្រាអែលបានធូរស្បើយពីការគៀបសង្កត់របស់សាសន៍ដទៃ គឺជាការធូរស្បើយកើតមានឡើងតាមសេចក្ដីទំនាយលើកទឹកចិត្តដោយលោកអេលីសេ និងលោកយ៉ូណាស ប៉ុន្តែសាសន៍អ៊ីស្រាអែលបែរជាមិនស្កប់ចិត្តនឹងការទាំងអស់នេះដែលព្រះអម្ចាស់បានធ្វើសម្រាប់ពួកគេទៅវិញ (អម ៦:១) ។ ពួកគេបានផ្ដោតសេចក្ដីជំនឿរបស់ពួកគេទៅលើការរង់ចាំ "ថ្ងៃនៃព្រះអម្ចាស់" (អម ៥:១៨–២០) ជាពេលដែលព្រះអម្ចាស់គ្របដណ្ដប់សាសន៍ដទៃដោយសេចក្ដីងងឹត ហើយឱ្យអ៊ីស្រាអែលបានកក់ក្ដៅនៅក្នុងពន្លឺរបស់ទ្រង់វិញ ។

គឺស្ថិតក្នុងពេលយ៉ាងដូចនេះហើយ ដែលព្រះអម្ចាស់ទ្រង់ចាត់ឱ្យលោកហោរា អេម៉ុស និងហូសេ ប្រកាសដល់រាស្ត្រអ៊ីស្រាអែលរបស់ទ្រង់ថា ទ្រង់ "នឹងមិនបន្ធូរបន្ថយដល់ពួកគេទៀតទេ" (អម ៧:៨ ៨:២) គឺទ្រង់នឹងបញ្ជូនពួកគេឱ្យធ្លាក់ចូលក្នុងការនិរទេសដោយក្រុងដាម៉ាស (អម ៥:២៧) និងដោយចក្រភពអាសស៊ើរ (ហស ៩:៣ ១០:៦ ១១:៥)។ នៅក្នុងអំឡុងពេលនោះ ព្រះអម្ចាស់ទ្រង់ក៏បានបញ្ជូន

លោកយ៉ូណាសទៅទីក្រុងនីនីវេដើម្បីព្រមានក្រុងនេះអំពីវិនាសកម្មដែលនឹងកើតឡើងដោយការជំនុំជម្រះនៃព្រះអម្ចាស់ ។

ដោយសារលោកយ៉ូណាសរស់នៅក្នុងសម័យជាមួយនឹងលោកអេម៉ុស សូមមើលសេចក្តីផ្តើមព្រះគម្ពីរអេម៉ុសត្រង់កាលបរិច្ឆេទ ស្ថានភាពប្រវត្តិសាស្ត្រ សម្រាប់សេចក្តីពន្យល់ជាបន្ថែមទៀត ។

**កាលបរិច្ឆេទនៃការនិពន្ធ**

ព្រះគម្ពីរនេះមានគោលបំណងនៃការនិពន្ធជាច្រើន ដែលក្នុងនោះគឺដើម្បីចែកចាយព្រះបន្ទូលដល់សាសន៍ដទៃ ហើយដោយសម្អាងទៅលើគោលបំណងទាំងនោះ គេអាចសន្និដ្ឋានបានថា ព្រះគម្ពីរនេះត្រូវបាននិពន្ធឡើងក្រោយសម័យនិរទេស ។ គេជឿថា យ៉ាងហោចណាស់ ព្រះគម្ពីរនេះត្រូវបាននិពន្ធឡើង បន្ទាប់ពីការបំផ្លាញទីក្រុងនីនីវេនៅឆ្នាំ ៦១២ មុនគ.ស. ប៉ុន្តែការសន្និដ្ឋាននេះមិនមានភាពប្រាកដទាំងស្រុងទេ ។ ការមួយដែលគួរឱ្យកត់សំគាល់នោះគឺថា ព្រះគម្ពីរនេះមានការពិពណ៌នាដូចកណ្ឌដែលពិពណ៌នាអំពីលោកអេលីយ៉ា និងអេលីសេ ។ ការដែលសន្និដ្ឋានថា ការប្រកាសព្រះបន្ទូលដល់សាសន៍ដទៃមិនមាននៅក្នុងសតវត្សទី៨មុនគ.ស. គឺជាការមិនត្រឹមត្រូវទេ ព្រោះជាការពិតណាស់ លោកអេលីយ៉ា និងអេលីសេ បានពង្រីកការងារបម្រើព្រះរហូតដល់ទឹកដីសាសន៍ដទៃនៅក្នុងសតវត្សនោះ(១ពវ ១៧:៧-២៤ ២ពវ ៨:៧-១៥)។ ជាងនេះទៅទៀត លោកហោរាអេម៉ុស(ប្រហែលឆ្នាំ ៧៦០ ដល់ ៧៥០ មុនគ.ស.)បានធ្វើការបម្រើព្រះដោយធ្វើជាតំណាងឱ្យសាសន៍អ៊ីស្រាអែល នៅក្នុងបរិបទដែលត្រូវដោះស្រាយជាមួយនឹងសាសន៍ដទៃ(អម ១:៣-២:១៦ ៩:៧,១២)។ ផ្នែក១ភាគបួនចុងក្រោយនៃសតវត្សទី៨មុនគ.ស. ប្រហែលជាការបរិច្ឆេទដែលទំនងបំផុតនៃការនិពន្ធព្រះគម្ពីរនេះ គឺស្ថិតនៅក្រោយពេលដែលលោកអេម៉ុស និងហូសេធ្វើការបម្រើព្រះជាសាធារណៈ និងមុនពេលទីក្រុងសាម៉ារីត្រូវចក្រភពអាសស៊ើរកាន់កាប់នៅឆ្នាំ ៧២២ ដល់ ៧២១ មុនគ.ស.។

**ការកាត់ស្រាយ**

មានសំណួរជាច្រើនចោទសួរថាតើព្រះគម្ពីរយ៉ូណាសមានលក្ខណៈប្រវត្តិសាស្ត្រដែរឬទេ ។ គេស្គាល់ព្រះគម្ពីរនេះច្រើនដោយសាមាននិយាយអំពីព្រឹត្តិការណ៍មួយចំនួន(ឧទាហរណ៍: វគ្គដែលនិយាយអំពីត្រីធំ) ដែលនាំឱ្យមានការសន្និដ្ឋានថា ព្រះគម្ពីរនេះមានការពិពណ៌នាតាមបែបប្រវត្តិសាស្ត្រ និងជីវប្រវត្តិ ។ ទោះបីជាពួកគេបានសន្និដ្ឋានថា ព្រះគម្ពីរនេះគឺជារឿងប្រឌិតខ្លី ឬរឿងប្រៀបប្រដូចសម្រាប់ជាសេចក្តីបង្រៀនក៏ដោយ ក៏ពួកគេបានធ្វើការសន្និដ្ឋានរួមថា អ្នកនិពន្ធបានសរសេរចេញពីការស្រមៃរបស់ខ្លួន ទោះជាគាត់បានប្រើពាក្យដែលនិយាយជាសេចក្តីធ្ងន់ធ្ងរ និងប្រកបដោយព្រះគុណក៏ដោយ ។

ការកាត់ស្រាយដូចខាងលើនេះគឺបណ្តាលមកពីពួកគេជាអ្នកមិនជឿលើការអស្ចារ្យ ដែលនាំឱ្យបដិសេធចោលនូវ (១).ភាពស្រដៀងគ្នានៃការពិពណ៌នានៃព្រះគម្ពីរយ៉ូណាស និងព្រះគម្ពីរផ្សេងទៀតនៃព្រះគម្ពីរសញ្ញាថ្មី និង (២).ការដែលអ្នកនិពន្ធព្រះគម្ពីរសញ្ញាចាស់ ជាពិសេសពួកហោរា មានការប្រកាន់ខ្ជាប់នូវការនិយាយតាមប្រវត្តិសាស្ត្រ ។ ពួកអ្នកកាត់ស្រាយខាងលើក៏បានមើលរំលងផងដែរចំពោះការដែលអ្នកនិពន្ធព្រះគម្ពីរសញ្ញាចាស់ មានត្រចៀកវៃឆ្លាតម្យ៉ាងដែលអាចដឹងអំពីព្រឹត្តិការណ៍នៅអតីតកាលដែលសាសន៍អ៊ីស្រាអែលមានទំនាក់ ទំនងជាមួយព្រះអម្ចាស់ គឺជាការប្រៀបធៀបទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលកើតឡើងនៅពេលក្រោយទៀត ឧទាហរណ៍: ព្រឹត្តិការណ៍ដែលកើតឡើងជុំវិញកំណើតលោកម៉ូសេគឺជាការប្រៀបធៀបនឹងការភៀសខ្លួនរបស់អ៊ីស្រាអែល(និក្ខមនំ) ហេតុការណ៍ដែលកើតឡើង ជុំវិញកំណើតរបស់លោកសាំយ៉ូអែលគឺជាការប្រៀបធៀបនឹងហេតុការណ៍ជាបន្តបន្ទាប់ដែលរៀបរាប់នៅក្នុងព្រះគម្ពីរសាំយូអែល ហើយការងារបម្រើព្រះរបស់លោកម៉ូសេ និងលោកយ៉ូស្វេប្រៀបធៀបនឹងការងារបម្រើព្រះរបស់លោកអេលីយ៉ា និងលោកអេលីសេ ។ ម្យ៉ាងវិញទៀត ពួកហោរាក៏បានដឹងផងដែរថា ព្រឹត្តិការណ៍នាពេលអនាគតដែលពួកគេបានប្រកាស អាចប្រៀបធៀបនឹងហេតុកាណ៍ ដែលកើតឡើងពីអតីតកាល ។ ដូចនេះ ការដែលពួកគេមើលរំលងចំណុចសំខាន់ៗទាំងនេះហើយ ដែលនាំឱ្យពួកគេសន្និដ្ឋានថា រឿងនេះជារឿងប្រឌិត ដោយសារអ្នកនិពន្ធមានសរសេរត្រូវតាមគោលបំណងរបស់ខ្លួនខ្លាំងពេក ។

ម្យ៉ាងវិញទៀត ត្រូវមានការទទួលស្គាល់ថា អ្នកនិពន្ធព្រះគម្ពីរមិនគ្រាន់តែជាអ្នកប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ។ ពួកគេបានលើកយកព្រឹត្តិការណ៍ពីអតីតកាលមកបកស្រាយ ដោយគោលគំនិតដ៏ច្បាស់លាស់មួយដើម្បីឱ្យឃើញជាក់ស្តែងនៅក្នុងបច្ចុប្បន្នកាល និងអនាគតកាល ហើយគោលបំណងនេះត្រូវបានសម្រេចយ៉ាងមានប្រសិទ្ធិភាព ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេពិតជាមានភាពស្មោះត្រង់ នៅក្នុងការបកស្រាយរឿងពីអតីតកាល ។ ព្រះគម្ពីរយ៉ូណាសបានបកស្រាយអំពីព្រឹត្តិការណ៍ពិតដែលកើតមាននៅក្នុងជីវិត និងការងារបម្រើព្រះរបស់លោកហោរា យ៉ូណាស ។

## លក្ខណៈអក្សរសាស្ត្រ

ព្រះគម្ពីរនេះខុសពីព្រះគម្ពីរហោរាដទៃទៀតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ នៅត្រង់ថា ព្រះគម្ពីរនេះពិពណ៌នាតែអំពីបេសកកម្មរបស់ហោរាម្នាក់ ។ លក្ខណៈនៃការពិពណ៌នាអំពីបេសកកម្មនេះ មានភាពស្រដៀងគ្នានឹងការពិពណ៌នាអំពីការងារបម្រើព្រះរបស់លោកអេលីយ៉ា និងលោកអេលីសេ នៅក្នុងព្រះគម្ពីរពង្សាវតាក្សត្រទីមួយ និងទីពីរ និងស្រដៀងគ្នានឹងផ្នែកខ្លះនៃការពិពណ៌នានៅក្នុងព្រះគម្ពីរអេសាយ យេរេមា និងអេសេគាល ។

ដូចការពិពណ៌នាដទៃទៀតនៅក្នុងព្រះគម្ពីរបរិសុទ្ធ អ្នកនិពន្ធបានសង្ខេបសាច់រឿងឱ្យខ្លី ដោយមានខព្រះគម្ពីរចំនួន៤០ ដែលនិយាយអំពីសាច់រឿងទាំងមូល (ខគម្ពីរចំនួន៨ផ្សេងទៀតគឺជាបទកំណាព្យ ដែលនិយាយអំពីការអរព្រះគុណរបស់លោកយ៉ូណាស)។ ព្រះគម្ពីរនេះដូចព្រះគម្ពីរនាងរស់ច្រើន នៅត្រង់ការកំណត់ព្រំដែននៃការពិពណ៌នា ការនិយាយសង្ខេប ការបង្ហាញនូវរូបភាពច្បាស់ និងការបង្ហាញអំពីលក្ខណៈតួរអង្គច្បាស់លាស់ ។

ព្រះគម្ពីរនេះក៏ដូចព្រះគម្ពីរនាងរស់ផងដែរ នៅត្រង់ការប្រើរចនាសម្ព័ន្ធនៅក្នុងវគ្គនីមួយៗត្រូវគ្នាបានយ៉ាងល្អ ។ រឿងនេះបានបែងចែកជាពីរផ្នែកដែលនាំឱ្យអ្នកអានអាចធ្វើការប្រៀបធៀប និងរកឃើញចំណុចផ្ទុយគ្នា (មើលគម្រោងសង្ខេប)។ ចំណុចសំខាន់បំផុតនៃព្រះគម្ពីរនេះគឺការអធិស្ឋានសារភាពរបស់លោកយ៉ូណាសដែលថា "សេចក្តីសង្គ្រោះគឺបានមកពីព្រះអម្ចាស់" ដែលជាការសារភាពទាំងបីលើកដែលចេញពីមាត់គាត់មក (១:៩ ២:៩ ៤:២)។ ឃ្លាចុងក្រោយបាននិយាយសង្កត់ធ្ងន់ថា ព្រះអម្ចាស់ទ្រង់មានបន្ទូលដែលមិនអាចកែប្រែ និងប្រកែកបានឡើយ នៅក្នុងពេលដែលលោកយ៉ូណាសកំពុងតែអង្គុយនៅទីកន្លែងក្តៅហួតហែង ខាងក្រៅទីក្រុងនីនីវេ ។

អ្នកនិពន្ធបាននិយាយអំពីតួរអង្គដែលជាតំណាង ដោយប្រើន័យធៀប ។ នៅក្នុងសាច់រឿងដែលនិយាយអំពីសេចក្តីស្រឡាញ់ដែលព្រះទ្រង់មានចំពោះមនុស្សទាំងអស់ ទីក្រុងនីនីវេដែលជាការគំរាមកំហែងយ៉ាងខ្លាំងដល់អ៊ីស្រាអែល គឺជាតំណាងឱ្យសាសន៍ដទៃ ។ ទាក់ទងនឹងបញ្ហានេះ លោកយ៉ូណាសដែលមានចិត្តមានះ ហើយស្នាក់ស្ទើរ គឺជាតំណាងឱ្យការច្រណែននៃសាសន៍អ៊ីស្រាអែល ដោយសារទំនាក់ទំនងពិសេសដែលព្រះទ្រង់មានជាមួយពួកគេ និងការមិនព្រមចែកចាយសេចក្តីមេត្តារបស់ព្រះអម្ចាស់ជាមួយនឹងសាសន៍ដទៃ ។

ព្រះគម្ពីរនេះបានបង្ហាញអំពីបំណងព្រះហឫទ័យដែលព្រះអម្ចាស់ទ្រង់មានចំពោះអ៊ីស្រាអែល គឺថា ពួកគេអាចរកឃើញសេចក្តីពិតនៃការយកព្រះទ័យទុកដាក់ចំពោះស្នាព្រះហស្តដែលទ្រង់បានបង្កើត ហើយពួកគេអាចយល់បានកាន់តែច្រើនជាងមុនទៀតថា ពួកគេមានតួនាទីនៅក្នុងការនាំព្រះបន្ទូលនៃសេចក្តីមេត្តានេះដល់សាសន៍ដទៃ ។

## គម្រោងសង្ខេប

I. លោកយ៉ូណាសគេចពីបេសកកម្ម (ជំពូក ១–២)
- ក. បេសកកម្មរបស់លោកយ៉ូណាស និងការរត់គេច (១:១–៣)
- ខ. ការស្រែកដង្ហោយរបស់ពួកនាវិកដែលជិតស្លាប់ ទៅដល់ព្រះរបស់ពួកគេ (១:៤–៦)
- គ. ការមិនស្តាប់បង្គាប់របស់លោកយ៉ូណាសត្រូវបានបើកបង្ហាញ (១:៧–១០)
- ឃ. ការដាក់ទោស និងការសង្គ្រោះលោកយ៉ូណាស (១:១១–២:១ ២:១០)
- ង. ការអធិស្ឋានអរព្រះគុណរបស់លោកយ៉ូណាស (២:២–៩)

II. លោកយ៉ូណាសបំពេញបេសកកម្មដោយចិត្តស្នាក់ស្ទើរ (ជំពូក ៣–៤)
- ក. លោកយ៉ូណាសចាប់ផ្តើមបេសកកម្ម និងស្តាប់បង្គាប់ឡើងវិញ (៣:១–៤)
- ខ. ពួកក្រុងនីនីវេដែលជិតវិនាសលន់តួបាប (៣:៥–៩)
- គ. ព្រះអម្ចាស់ទទួលស្គាល់ការលន់តួបាបរបស់ពួកក្រុងនីនីវេ (៣:១០–៤:៤)
- ឃ. ការសង្គ្រោះ និងការស្តីបន្ទោសលោកយូណាស (៤:៥–១១)

## លោកយ៉ូណាសគេចពីព្រះអម្ចាស់

**១** 1 រីឯព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់យ៉ូណាស[ក]ជា
កូនអ័មីថាយថា[ខ] 2 ចូរក្រោកឡើងទៅឯនីនីវេ[គ] ជាទីក្រុងធំ
ហើយស្រែកប្រកាសទាស់នឹងក្រុងនោះ ពីព្រោះអំពើ
អាក្រក់របស់គេបានសាយឡើង នៅចំពោះមុខអញហើយ
3 ប៉ុន្តែ យ៉ូណាស លោកក្រោកឡើង រត់[ឃ]ទៅឯក្រុងតើស៊ីស
វិញ[ង] ដើម្បីឱ្យរួចពីព្រះភក្ត្រនៃព្រះយេហូវ៉ា គឺលោក
ចុះទៅដល់ក្រុងយ៉ុបប៉េ[ច]បានប្រទះនឹងនាវា១ ដែលរៀប
ចេញទៅឯក្រុងតើស៊ីស នោះលោកចេញប្រាក់ជាដំឡៃជិះ
រួចក៏ចុះនាវានោះ ដើម្បីទៅឯតើស៊ីសជាមួយនឹងគេឱ្យរួច
ពីព្រះភក្ត្រព្រះយេហូវ៉ា[ឆ]។

4 ប៉ុន្តែព្រះយេហូវ៉ាទ្រង់ធ្វើឱ្យមានខ្យល់យ៉ាងខ្លាំងបក់
មកលើសមុទ្រ ដូច្នេះកើតមានព្យុះយ៉ាងធំនៅសមុទ្រ ដល់
ម៉្លេះបានជានាវារកកល់តែនឹងបែកបាក់អស់ទៅ[ជ] 5 ឯពួក
ជើងឈ្នួលក៏ស្លុតចិត្ត ហើយគ្រប់គ្នាបានអំពាវនាវ ដល់
ព្រះរបស់ខ្លួន គេបោះទំនិញទាំងប៉ុន្មាន ដែលនៅក្នុងនាវា
ចោលទៅក្នុងសមុទ្រ ដើម្បីនឹងធ្វើឱ្យនាវាបានស្រាល
ឡើង[ឈ] ឯយ៉ូណាសលោកបានចុះទៅដេកនៅខាងក្នុងនាវា
ហើយក៏លក់ស៊ប់ទៅ 6 ដូច្នេះ នាយនាវាក៏មកឯលោកសួរ
ថា ម្នាលអ្នកទ្រមក់អើយ អ្នកធ្វើដូច្នេះ ចូរក្រោកឡើងអំពាវ
នាវ[ញ]ដល់ព្រះនៃអ្នកទៅ ក្រែងទ្រង់នឹងនឹកចាំពីយើង ដើម្បី

**១:១** ក មថ ១២:៣៩–៤១ ១៦:៤ លក ១១:២៩–៣២ ខ ២ពវ ១៤:២៥ **១:២** គ លប ១០:១១ ណហ ១:១ **១:៣** ឃ ទដ ១៣៩:៧ ង លប ១០:៤ ច យស ១៩:៤៦ កច ៩:៣៦,៤៣ ឆ នក ៤:១៣ យរ ២០:៩ អម ៣:៨ **១:៤** ជ ទដ ១០៧:២៣–២៦ **១:៥** ឈ កច ២៧:១៨–១៩ **១:៦** ញ យហ ៣:៨

**១:១** *ព្រះបន្ទូលនៃព្រះយេហូវ៉ា* មើល ៣:១ ហស ១:១ និងការពន្យល់ ។ *យ៉ូណាស* មើលសេចក្តីផ្តើមត្រង់ចំណងជើង និងអ្នកនិពន្ធ ។ ព្រះគម្ពីរនេះត្រូវបាននិពន្ធឡើង អំពីការបំពេញបេសកកម្មរបស់លោកយ៉ូណាសនៅទីក្រុងនីនីវេ ដើម្បីជាសេចក្តីបង្រៀនអស់សាសន៍អ៊ីស្រាអែល ។ អ្នកនិពន្ធប្រហែលជាចង់លើកយកលោកយ៉ូណាសមកនិយាយ ជាតំណាងនៃសាសន៍អ៊ីស្រាអែល ជារាស្ត្រដែលព្រះអម្ចាស់ទ្រង់បានត្រាសហៅចេញពីចំណោមជាតិសាសន៍ជាច្រើន ដើម្បីប្រកាសពីផែនការនៃសេចក្តីសង្គ្រោះដល់ជាតិសាសន៍នៅទូទាំងពិភពលោក ។ នៅក្នុងរឿងនេះ សាសន៍អ៊ីស្រាអែលត្រូវពិនិត្យមើលខ្លួនឯងឱ្យដូចឆ្លុះមើលកញ្ចក់ ដើម្បីឱ្យបានដឹងថា ពួកគេជាសាសន៍ដែលមានអភ័យឯកសិទ្ធិពិសេស ដោយព្រះទ្រង់បានបង្ហាញអង្គទ្រង់ដល់ពួកគេ ពួកគេមានតួនាទីពិសេសជារាស្ត្រជ្រើសតាំងរបស់ព្រះ ពួកគេមានចិត្តមានះក្នុងការបំពេញតួនាទីនេះ និងមូលហេតុដែលសាសន៍អ៊ីស្រាអែលត្រូវទទួលជិនុំជម្រះ (តាមទំនាយពួកហោរា) ហើយត្រូវបានស្អាងឡើងវិញជាថ្មី (សេចក្តីទំនាយអំពីអនាគតកាលដ៏យូរខាងមុខដែលពួកហោរាគេបានមើលឃើញនោះ) ។ ធៀបនឹង ការពន្យល់ ពច ១៣:១–១៦:៣១ ។

**១:២** *ទីក្រុងធំ* មើល ៣:២ ៤:១១ និងការពន្យល់ ៣:៣ ។ តាម លប ១០:១១ ទីក្រុងនីនីវេត្រូវបានសាងសង់ឡើងដោយស្តេច នីមរូដ ហើយគេមានទម្លាប់ហៅទីក្រុងនេះថា "ទីក្រុងធំ"(មើល លប ១០:១២ និងការពន្យល់)។ ប្រហែលនៅឆ្នាំ ៧00 មុនគ.ស. ស្តេចសេនាចេរិបបានដាក់ទីក្រុងនីនីវេជារាជធានីនៃចក្រភពអាសស៊ើរ ហើយទីក្រុងនេះនៅជារាជធានីរហូតដល់ត្រូវដួលរលំនៅឆ្នាំ ៦១២ មុនគ.ស.(មើលសេចក្តីផ្តើមត្រង់ប្រវត្តិដើម)។ ទីក្រុងនីនីវេមានចម្ងាយប្រហែល ៨00 គីឡូម៉ែត្រពីក្រុងគីតា–ហេភើរ ដែលជាស្រុកកំណើតរបស់លោកយ៉ូណាស ។ *អំពើអាក្រក់របស់គេបានសាយឡើង* ធៀបនឹងក្រុងសូដុំម និងកូម៉ូរ៉ា (មើល លប ១៨:២០–២១ និងការពន្យល់ ១៨:២០)។ ក្រៅពី "អំពើហឹង្សា"(៣:៨)របស់ក្រុងនីនីវេ "ផ្លូវអាក្រក់"(៣:៨,១០)របស់ក្រុងនេះមិនមានរៀបរាប់នៅក្នុងព្រះគម្ពីរយ៉ូណាសទេ ។ នៅពេលក្រោមមកទៀត លោកណាហ៊ុមបានលើកឡើងថា អំពើបាបរបស់ទីក្រុងនីនីវេ គឺរួមមានការរៀបផែនការធ្វើការអាក្រក់ទាស់នឹងព្រះអម្ចាស់ ភាពសាហាវព្រៃផ្សៃ និងការចាប់យករបឹបនៅក្នុងសឹកសង្គ្រាម អំពើពេស្យាចារ អំពើធ្មប់ និងការកេងប្រវ័ញ្ចនៅក្នុងជំនួញ (ណហ ១:១១ ២:១២–១៣ ៣:១,៤,១៦,១៩) ។

**១:៣** *រត់ . . . ដើម្បីឱ្យរួច* លោកយ៉ូណាសបានប្រាប់អំពីហេតុផលដែលត្រូវរត់គេចនៅក្នុង ៤:២ ។ ការដែលខំគេចចេញពីព្រះអម្ចាស់គឺជាការឥតប្រយោជន៍ ដូចដែលមានបង្ហាញនៅក្នុង ទដ ១៣៩:៧–១២ (មើលការពន្យល់វគ្គនេះ) ។ *ក្រុងតើស៊ីស* ប្រហែលជាក្រុងតាតេស៊ុស នៅភាគខាងត្បូងនៃប្រទេសអេស្ប៉ាញ ដែលជាទីកដីចំណុះ និងកន្លែងយករ៉ែរបស់ចក្រភពភេនីស នៅក្បែរតំបន់គីប្រាលតា ។ លោកណាហ៊ុមបានធ្វើដំណើរតាមទិសដៅផ្ទុយនឹងទីក្រុងនីនីវេ ដែលហាក់ដូចជាទៅឱ្យដល់ជើងមេឃ ដើម្បីគេចពីការងារដែលព្រះអម្ចាស់ទ្រង់បង្គាប់ឱ្យធ្វើ ។ *ក្រុងយ៉ុបប៉េ* មើលការពន្យល់ កច ៩:៣៦ ។

**១:៤–១៦** វគ្គនេះនិយាយអំពីខ្យល់ព្យុះនៅសមុទ្រ ដែលប្រហែលជាចង់ប្រៀបធៀបមនុស្សមួយក្រុមតូច(ពួកនាវិក)ទៅនឹងពិភពលោកិយដែលមានជាច្រើនសាសន៍ ដែលទទួលរងការគំរៀមកំហែងដោយការជំនុំជម្រះរបស់ព្រះអម្ចាស់ (តំណាងដោយព្យុះ) ដែលមានពួកអ៊ីស្រាអែលនៅកណ្តាល (តំណាងដោយលោកយ៉ូណាស) ។ បើសិនជាលោកយ៉ូណាស (សាសន៍អ៊ីស្រាអែល)មិនបានបំពេញបេសកកម្មនេះទេ នោះពួកនាវិក(សាសន៍ដទៃ)នឹងត្រូវស្លាប់ដោយស្រែកដង្ហោយដល់ព្រះរបស់ពួកគេ ។ ហើយដោយសារគាត់បានបះបោរប្រឆាំងនឹងបេសកកម្មនោះ គាត់ត្រូវតែ"ស្លាប់"ដើម្បីសង្គ្រោះជីវិតរបស់ពួកគេ ។ មើលការពន្យល់ ១:១ ធៀបនឹង ការពន្យល់ កច ២៧:១៣–៤៤ ។

**១:៤–៥** បេសកកម្មរបស់លោកយ៉ូណាសគឺត្រូវនាំពាក្យព្រមានដល់សាសន៍ដទៃ អំពីការជំនុំជម្រះដែលត្រូវមកដល់ ហើយការដែលគាត់បដិសេធមិនព្រមទៅទីក្រុងនីនីវេ បាននាំឱ្យពួកនាវិកដែលជាសាសន៍ដទៃត្រូវវិនាស ។

**១:៤** *ទ្រង់ធ្វើឱ្យមានខ្យល់យ៉ាងខ្លាំង* ព្រះអម្ចាស់ទ្រង់ធ្វើការអស្ចារ្យជាច្រើនទៀតដូចជា ត្រី (ខ.១៧) ការខ្ជាក់លោកយ៉ូណាសចេញ(២:១០) ដើមវល្លិ (៤:៦) ដង្កូវ(៤:៧) និងខ្យល់ក្តៅបក់ពីទិសខាងកើត(៤:៨)។

**១:៥** *ព្រះរបស់ខ្លួន* ប្រហែលជាពួកនាវិកមកពីកន្លែងផ្សេងៗ ហើយថ្វាយបង្គំព្រះសាសន៍ដទៃជាច្រើន(មើលការពន្យល់ លប ២៨:១៥) ។

**១:៦** *នាយនាវាក៏មកឯលោក* នាយនាវាមានការព្រួយបារម្ភពីសេចក្តីសុខសាន្តរបស់គ្រប់គ្នានៅលើនាវា គឺផ្ទុយពីលោកហោរាដែលជាអ្នកជឿព្រះដែលបដិសេធមិនព្រមនាំការព្រមានរបស់ព្រះអម្ចាស់ទៅឯទីក្រុងនីនីវេ ។

មិនឱ្យយើងត្រូវវិនាសឡើយ[ដ] ៧រួចគេជំនុំគ្នាថា ចូរយើង
ចាប់ឆ្នោតឱ្យបានដឹង ជាការអាក្រក់នេះ កើតដល់យើង
ដោយព្រោះអ្នកណា[ឋ] ដូច្នេះ គេក៏នាំគ្នាចាប់ឆ្នោតហើយ
ឆ្នោតនោះត្រូវលើយ៉ូណាស[ឌ] ៨រួចគេសួរពីដំណើរលោក
ថា ចូរប្រាប់យើង តើអ្នកណាបាននាំឱ្យការអាក្រក់នេះមក
លើយើង តើអ្នករកស៊ីធ្វើការអ្វី ហើយមកពីណា តើអ្នកនៅ
ស្រុកណា ហើយជាសាសន៍អ្វី ៩នោះលោកប្រាប់គេ ថា
ខ្ញុំជាសាសន៍ហេព្រើរ ហើយខ្ញុំកោតខ្លាចដល់ព្រះយេហូវ៉ា[ឍ]
ជាព្រះនៃស្ថានសួគ៌[ណ] ដែលទ្រង់បានបង្កើតសមុទ្រ[ត] និងដី
គោកផង[ថ] ១០ដូច្នេះ គេមានសេចក្ដីស្ញែងខ្លាចក្រៃលែង
ហើយក៏សួរលោកថា តើអ្នកបានធ្វើអ្វីដូច្នេះ ដ្បិតបណ្ដាអ្នក
ទាំងនោះបានដឹងថា លោកកំពុងរត់គេចពីព្រះភក្ត្រព្រះ
យេហូវ៉ា ពីព្រោះលោកបានប្រាប់គេហើយ ។
១១រួចគេសួរលោកថា ដូច្នេះ តើត្រូវឱ្យយើងធ្វើដូច
ម្ដេចដល់អ្នក ដើម្បីឱ្យសមុទ្របានសប់វិញ ដ្បិតសមុទ្រចេះ
តែកំរើកតែខ្លាំងឡើង ១២លោកប្រាប់គេថា ចូរចាប់ខ្ញុំ
បោះទៅក្នុងសមុទ្រចុះ នោះសមុទ្រនឹងសប់ដល់អ្នករាល់គ្នា

**១:៦** ដ ទដ ១០៧:២៨
**១:៧** ឋ ជន ៣២:២៣
យស ៧:១០–១៨
១សយ ១៤:៤២
ឌ សភ ១៦:៣៣
**១:៩** ឍ ទដ ៩៦:៩
ណ ដយ ២:១៨
កច ១៧:២៤
ត នហ ៩:៦
ថ លប ១:៩
**១:១២** ទ ២សយ
២៤:១៧ ១រប
២១:១៧
**១:១៣** ធ សភ
២១:៣០
**១:១៤** ន ចទ ២១:៨
ប ដយ ៤:៣៥
**១:១៥** ផ ទដ
១០៧:២៩ លក
៨:២៤
**១:១៦** ព មក ៤:៤១
ភ ជន ៣០:២

ហើយ ដ្បិតខ្ញុំដឹងថា ខ្យល់ព្យុះយ៉ាងខ្លាំងនេះកើតឡើង ក៏
ដោយព្រោះខ្លួនខ្ញុំនេះឯង[ទ] ១៣ប៉ុន្តែគេនាំគ្នាខំចែវឱ្យបាន
វិលត្រឡប់ទៅឯច្រាំងវិញ តែមិនបានទេ ដ្បិតសមុទ្រចេះ
តែកំរើករឹតតែខ្លាំងឡើងទាស់នឹងគេ[ធ] ១៤ដូច្នេះ គេក៏អំពាវ
នាវដល់ព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ាអើយ យើងខ្ញុំសូម
អង្វរដល់ទ្រង់ សូមកុំឱ្យយើងខ្ញុំរាល់គ្នាត្រូវវិនាស ដោយ
ព្រោះជីវិតមនុស្សនេះឡើយ ក៏កុំឱ្យទំលាក់ទោសជាកំចាយ
ឈាមឥតទោស មកលើយើងខ្ញុំរាល់គ្នាដែរ[ន] ដ្បិតឱព្រះ
យេហូវ៉ាអើយ ទ្រង់បានសំរេចការតាមដែលគាប់ព្រះ
ហឫទ័យទ្រង់[ប] ១៥គេក៏ចាប់យ៉ូណាស បោះទៅក្នុងសមុទ្រ
រួចសមុទ្រក៏ស្ងប់ទៅ[ផ] ១៦ដូច្នេះមនុស្សទាំងនោះ គេកោត
ខ្លាចដល់ព្រះយេហូវ៉ាយ៉ាងក្រៃលែង[ព] ហើយក៏ថ្វាយ
យញ្ញបូជាដល់ព្រះយេហូវ៉ា ព្រមទាំងបន់បំណន់[ភ]ផង ។
**២** ១ឯព្រះយេហូវ៉ា ទ្រង់បំរុងឱ្យមាន[ក]ត្រី១យ៉ាងធំសំរាប់
នឹងលេបយ៉ូណាសទៅ[ខ] ហើយយ៉ូណាសបាននៅក្នុងពោះ
ត្រីនោះ គ្រប់៣ថ្ងៃ៣យប់ ។

ទដ ៦៦:១៣–១៤ **២:១** ក យហ ៤:៦,៧ ខ មថ ១២:៤០ ១៦:៤ លក ១១:៣០

**១:៧** *ចូរយើងចាប់ឆ្នោត* ការចាប់ឆ្នោតគឺជាប្រពៃណីដែលគេនិយមធ្វើនៅតំបន់មជ្ឈិមបូព៌ាសម័យបុរាណ ។ គេមិនដឹងច្បាស់លាស់អំពីរបៀបចាប់ឆ្នោតរបស់ពួកអ្នកនៅលើនាវាទាំងនោះទេ ប៉ុន្តែ គេច្រើនតែដកយកឈើ ឬគ្រាប់ គ្រួសដែលមានគំនូសចំណាំ ពីប្រអប់សម្រាប់ចាប់ឆ្នោត(មើលការពន្យល់ នក ២៨:៣០ នហ ១១:១ សភ ១៦:៣៣ អគ ២១:២១ កច ១:២៦)។ *ឆ្នោតនោះត្រូវលើយ៉ូណាស* ឆ្នោតនោះគឺជាឆ្នោតនៃសេចក្ដីជំនុំជម្រះដែលព្រះអម្ចាស់ទ្រង់បង្ហាញមនុស្សដែលមានកំហុស(មើល យស ៧:១៤–២៦ និងការពន្យល់ ៧:១៤ ១សយ ១៤:៣៧–៤៤ និងការពន្យល់ ១៤:៣៧)។

**១:៩** *សាសន៍ហេព្រើ* មើលការពន្យល់ លប ១៤:១៣ ។ *ព្រះនៃស្ថានសួគ៌ ដែលទ្រង់បានបង្កើតសមុទ្រ និងដីគោក* មើលការពន្យល់ អរ ១:២ ។ ពួកនាវិកប្រហែលជាយល់ថា លោកយ៉ូណាសកំពុងតែនិយាយអំពីព្រះដែលខ្ពស់បំផុត ។ បញ្ហាដែលពួកគេកំពុងជួបប្រទះ បានបញ្ជាក់អំពីសេចក្ដីពិតនេះ ព្រោះនៅតំបន់មជ្ឈិមបូព៌ាសម័យបុរាណ ជាទូទៅ គេជឿថា ព្រះដែលខ្ពស់បំផុតគឺជាម្ចាស់នៃសមុទ្រ (មើលការពន្យល់ យស ៣:១០) ។ នៅក្នុងខនេះ លោកយ៉ូណាសបានសារភាពជាលើកដំបូង ហើយសារភាពជាបន្តទៀតនៅក្នុង ២:៩គ ៤:២ ដែលនេះជាការដែលគាត់ទទួលស្គាល់សេចក្ដីពិត ។ លោកយ៉ូណាសទទួលស្គាល់ការពិតនេះ តែបានបដិសេធមិនព្រមបំពេញបេសកកម្មនៅក្រុងនីនីវេ ។

**១:១០** *តើអ្នកបានធ្វើអ្វីដូច្នេះ* សំណួរនេះគឺជាការចោទប្រកាន់ ។

**១:១២** *ចូរចាប់ខ្ញុំបោះទៅក្នុងសមុទ្រចុះ* នៅក្នុងចំណុចនេះ លោកយ៉ូណាសបានព្រមស្លាប់ដើម្បីជួយដល់ពួកនាវិក គឺផ្ទុយពីការដែលគាត់ខំរត់គេចដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន ដោយទុកឱ្យទីក្រុងនីនីវេត្រូវវិនាស(មើល ៤:៥ និងការពន្យល់)។

**១:១៣** *នាំគ្នាខំចែវ* នាវានោះអាចទៅមុខបានដោយ ក្ដោង ច្រវ៉ា ឬដោយឧបករណ៍ទាំងពីរ ។ ការស្ទាក់ស្ទើររបស់ពួកនាវិកនៅក្នុងការបោះលោកយ៉ូណាសទៅក្នុងទឹកសមុទ្រគឺខុសការស្ទាក់ស្ទើររបស់លោកយ៉ូណាសនៅក្នុងការនាំដំណឹងនៃការជំនុំជម្រះដល់ទីក្រុងនីនីវេ ។

**១:១៤** *អំពាវនាវដល់ព្រះយេហូវ៉ា* កាលពីដំបូងពួកនាវិកបានអំពាវនាវដល់ព្រះរបស់ពួកគេរៀងខ្លួន(មើល ខ.៥ និងការពន្យល់) ប៉ុន្តែ ដោយសារតែអស់សង្ឃឹមពួកគេបានទូលអង្វរសូមជំនួយពីព្រះរបស់លោកយ៉ូណាសវិញ ។

**១:១៦** *កោតខ្លាចដល់ព្រះយេហូវ៉ាយ៉ាងក្រៃលែង* ត្រង់ចំណុចនេះ គ្មានភ័ស្តុតាងបង្ហាញថា ពួកនាវិកបានប្រកាសឈប់ជឿដល់ព្រះផ្សេងៗទៀតនោះទេ(ខុសពីលោកណាម៉ាន មើល ២ពវ ៥:១៥ និងការពន្យល់)។ ពួកសាសន៍ដទៃសម័យបុរាណ បានទទួលស្គាល់ថា អំណាចនៃព្រះជាច្រើន ។ ទោះជាយ៉ាងណាក៏ដោយ យ៉ាងហោចណាស់ ពួកនាវិកបានទទួលស្គាល់ថាព្រះនៃអ៊ីស្រាអែលមានអំណាចគ្រប់គ្រងលើហេតុការណ៍ដែលបានកើតមាននោះ ដោយទ្រង់ជាអ្នកបណ្ដាលឱ្យមានព្យុះ និងអ្នកធ្វើឱ្យព្យុះស្ងប់វិញ ហើយនៅក្នុងពេលនោះ ទ្រង់គឺជាព្រះដែលពួកគេត្រូវទទួលស្គាល់ និងថ្វាយបង្គំ ។

**២:១** *ទ្រង់បំរុង* ពាក្យនេះមាននិយាយនៅក្នុង ៤:៦–៨ ផងដែរ ។ *ត្រី១យ៉ាងធំ* ពាក្យនេះនៅក្នុងព្រះគម្ពីរភាសាហេព្រើ ត្រង់ខនេះ និងនៅក្នុងព្រះគម្ពីរភាសាក្រិក ត្រង់ មថ ៦:៨ គឺប្រើសំដៅទៅលើត្រីធំជាទូទៅ គឺមិនសំដៅតែលើត្រីបាឡែនប៉ុណ្ណោះទេ ។ ត្រីធំនេះគឺខុសពីនាគ នៅក្នុងសមុទ្រ(អម ៩:៣) ឬ "នាគក្ងិកក្ងក់"(អស ២៧:១) "សត្វសម្បើមនៅក្នុងសមុទ្រ"(យរ ៧:១២ មើល ទដ ៧៤:១៣ អគ ៣២:២)។ *៣ថ្ងៃ ៣យប់* ដូចនៅក្នុង មថ ១២:៤០ ឃ្លានេះអាចសំដៅទៅលើរយៈពេលបីថ្ងៃ (មើលការពន្យល់ មថ ១២:៤០ ១កថ ១៥:៤) ។ ព្រះគម្ពីរសញ្ញាថ្មីបានប្រៀបធៀបបទពិសោធន៍របស់លោកយ៉ូណាសទៅនឹង(ទំនាយ)ការបញ្ចុះព្រះសព និងការរស់ឡើងវិញនៃព្រះគ្រីស្ទ ដែលគេបានបញ្ចុះទ្រង់នៅក្នុងផ្នូរអស់រយៈពេល"បីថ្ងៃបី

## សេចក្ដីអធិស្ឋានរបស់លោកយ៉ូណាស

២ក្នុងរវាងនោះ យ៉ូណាសក៏អធិស្ឋានដល់ព្រះយេហូវ៉ា
ជាព្រះនៃខ្លួនពីក្នុងពោះត្រី ៣លោកទូលថា ទូលបង្គំបាន
អំពាវនាវ[គ]ដល់ព្រះយេហូវ៉ា[ឃ] ដោយព្រោះទុក្ខលំបាករបស់
ទូលបង្គំ ទ្រង់ក៏បានឆ្លើយមកទូលបង្គំហើយ ទូលបង្គំបាន
អំពាវនាវ នៅក្នុងពោះនៃស្ថានឃុំព្រលឹងមនុស្សស្លាប់[ង]
ហើយទ្រង់បានឮសំឡេងរបស់ទូលបង្គំ ៤ដ្បិតទ្រង់បានបោះ
ទូលបង្គំទៅក្នុងទីជំរៅ[ច] គឺចុះទៅក្នុងផ្ទៃនៃសមុទ្រ ទឹកបាន
នៅព័ទ្ធជុំវិញទូលបង្គំ ហើយរលកទាំងប៉ុន្មាន និងអស់ទាំង
ខ្សែទឹក[ឆ]របស់ទ្រង់បានហូរពីលើទូលបង្គំ[ជ] ៥នោះទូលបង្គំ
បានពោលថា ទូលបង្គំត្រូវបោះចោលចេញ ពីចំពោះព្រះ
នេត្រទ្រង់ហើយ[ឈ] ប៉ុន្តែទូលបង្គំនឹងមើលទៅឯព្រះវិហារ
បរិសុទ្ធនៃទ្រង់ទៀត[ញ] ៦ទឹកបានឡោមព័ទ្ធទូលបង្គំ សឹងតែ
នឹងផុតជីវិតផង ទីជំរៅបានហ៊ុំទូលបង្គំជិត ហើយសារ៉ាយ
បានរុំព័ទ្ធក្បាលទូលបង្គំ[ដ] ៧ទូលបង្គំបានចុះទៅដល់ឫសនៃ
ភ្នំ[ឋ]ទាំងប៉ុន្មាន រនុកនៃផែនដីបានបិទខ្ទប់ពីលើទូលបង្គំទុក
ជាដរាបតទៅ ប៉ុន្តែឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ
ទ្រង់បាននាំទូលបង្គំ ឡើងចេញពីរណ្តៅមកទាំងរស់[ឌ]
៨កាលព្រលឹងនៅក្នុងខ្លួន ទូលបង្គំបានសន្លប់ទៅ នោះទូល
បង្គំបាននឹក[ឍ]ដល់ព្រះយេហូវ៉ា ហើយសេចក្ដីអធិស្ឋាន[ណ]
របស់ទូលបង្គំបានចូលទៅក្នុងព្រះវិហារបរិសុទ្ធ នៅចំពោះ
ទ្រង់[ត] ៩ពួកអ្នកដែលមើលទៅឯរបស់ឥតប្រយោជន៍ ដែល
មិនទៀងទាត់[ថ] គេរមែងលះបង់ចោលសេចក្ដីអាណិតអា–
សូររបស់ខ្លួនចេញ ១០តែទូលបង្គំនឹងថ្វាយយញ្ញបូជា[ទ]ដល់
ទ្រង់ ដោយសំឡេងនៃពាក្យអរដល់ព្រះគុណ[ធ] ហើយទូល
បង្គំនឹងលាបំណន់[ន]របស់ទូលបង្គំផង ឯសេចក្ដីសង្គ្រោះ[ប]
នោះកើតមកតែពីព្រះយេហូវ៉ាទេ ។

១១លំដាប់នោះ ព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ត្រីនោះ វាក៏
ក្អួលយ៉ូណាសចេញនៅលើដីគោក ។

## លោកយ៉ូណាសធ្វើដំណើរទៅទីក្រុងនីនីវេ

**៣** ១ចំណេរមក ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់
យ៉ូណាស[ក]ម្តងទៀតថា ២ចូរក្រោកឡើងទៅឯនីនីវេ ជាក្រុង
ធំ ហើយប៉ាវប្រកាសដល់គេ តាមសេចក្ដីដែលអញនឹង
បង្គាប់ ៣ដូច្នេះ យ៉ូណាសក៏ក្រោកឡើងទៅឯក្រុងនីនីវេ
តាមព្រះបន្ទូលនៃព្រះយេហូវ៉ា រីឯនីនីវេជាទីក្រុងធំក្រៃ

**២:៣** គ បទ ៣:៥៥ ឃ ទដ ១៨:៦ ១២០:១ ង ទដ ៨៦:១៣ **២:៤** ច ទដ ៨៨:៦ ឆ ២សយ ២២:៥ ជ ទដ ៤២:៧ **២:៥** ឈ ទដ ២១:២២ យរ ៧:១៥ ញ ១ពវ ៨:៤៨ **២:៦** ដ ទដ ៦៩:១–២ **២:៧** ឋ យប ២៨:៩ ឌ យប ១៧:១៦ ៣៣:១៨ ទដ ៣០:៣ **២:៨** ឍ ទដ ៧៧:១១–១២ ណ ២របា ៣០:២៧ ត ទដ ១១:៤ ១៨:៦ **២:៩** ថ ចទ ៣២:២១ ១សយ ១២:២១ **២:១០** ទ ទដ ៥០:១៤,២៣ ហព ១៣:១៥ ធ ទដ ៤២:៤ ន ជន ៣០:២ ទដ ១១៦:១៤ សស ៥:៤–៥ ប នក ១៥:២ ទដ ៣:៨ **៣:១** ក យហ ១:១

យប់"(មថ ១២:៤០ មើល មថ ១៦:៤ លក ១១:២៩–៣០ និងការពន្យល់ ១១:៣០) ។

**២:២–៩** វគ្គនេះគឺជាបទទំនុកតម្កើងអំពីការអរព្រះគុណព្រះដែលទ្រង់បានប្រោសឱ្យរួចពីសេចក្ដីស្លាប់នៅក្នុងសមុទ្រ ។ លោកយ៉ូណាសបាននឹកឃើញអធិស្ឋានសូមជំនួយ នៅពេលដែលគាត់កំពុងលិចលង់កាន់តែជ្រៅទៅៗ ។ គាត់អរព្រះគុណដល់ព្រះ ព្រោះគាត់ដឹងថា គាត់គួរតែទទួលសេចក្ដីស្លាប់ ប៉ុន្តែព្រះទ្រង់បែរជាបង្ហាញដល់គាត់នូវសេចក្ដីមេត្តាករុណាដ៏លើសលប់វិញ

**២:៣** *ទូលបង្គំបានអំពាវនាវ . . . ទ្រង់ក៏បានឆ្លើយ* មើលការពន្យល់ ទដ ១១៨:៥ ។ *ផ្នូរ* លោកយ៉ូណាសបានប្រើពាក្យនេះដើម្បីប្រៀបធៀបនឹងការដែលលោកស្ទើរតែស្លាប់នៅក្នុងសមុទ្រ(មើល ទដ ៣០:៣ និងការពន្យល់) មើលការពន្យល់ លប ៣៧:៣៥ ។

**២:៤** *ទ្រង់បានបោះទូលបង្គំ . . . ខ្សែទឹក* លោកយ៉ូណាសបានទទួលស្គាល់ថា ពួកនាវិក(១:១៥)គឺជាអ្នកដែលព្រះទ្រង់បញ្ជូនមកដើម្បីជំនុំជម្រះខ្លួនគាត់ ។

**២:៥** *ទូលបង្គំនឹងមើលទៅឯព្រះវិហារបរិសុទ្ធនៃទ្រង់ទៀត* ឃ្លាដូចគ្នានេះមាននិយាយនៅក្នុងព្រះគម្ពីរទំនុកតម្កើង (ឧទាហរណ៍ ទដ ៥:៧ ២៧:៤–៦) "ព្រះវិហារ"នៅក្នុងខនេះ ប្រហែលជាសំដៅទៅលើព្រះវិហារនៅក្រុងយេរូសាឡិម រីឯ "ព្រះវិហារ" នៅក្នុង ខ.៨ សំដៅទៅលើព្រះវិហារបរិសុទ្ធនៃព្រះនៅស្ថានសួគ៌ ។ សាសន៍អ៊ីស្រាអែលប្រើពាក្យព្រះវិហារទាំងពីរយ៉ាងនេះផ្សេងពីគ្នា (មើល ១ពវ ៨:៣៨–៣៩) ។

**២:៧** *រណ្តៅ* គឺផ្នូរ (មើលការពន្យល់ ខ.២ មើល ទដ ២៨:១ ៣០:១–៣ និងការពន្យល់ ៣០:១)។

**២:៨** *ព្រះវិហារបរិសុទ្ធ* មើល ខ.៤ និងការពន្យល់ ។

**២:១០** *យញ្ញបូជា . . . បំណន់* សូមធៀបនឹងការអំពាវនាវរបស់ពួកនាវិក (១:១៦)។ *ទូលបង្គំនឹងលាបំណន់* នៅក្នុងព្រះគម្ពីរទំនុកតម្កើង ការអធិស្ឋានត្រូវបានបន្តដោយការលាបំណន់ ដែលតាមធម្មតាគឺជាការថ្វាយដង្វាយអរព្រះគុណ (មើលឧទាហរណ៍ ទដ ៥០:១៤ និងការពន្យល់ ៥៦:១២ ៦១:៨ ៦៥:១ ៦៦:១៣–១៥ ១១៦:១២–១៩)។ *លាបំណន់* មើល ទដ ៧៦:១១ សស ៥:១–៧ ។ *សេចក្ដីសង្គ្រោះ នោះកើតមកតែពីព្រះយេហូវ៉ា* នៅត្រង់ចំណុចនេះ លោកយ៉ូណាសអធិស្ឋានអរព្រះគុណ និងធ្វើការសារភាពជាលើកទីពីរ (មើលការពន្យល់ ១:៩)។ ការនេះគឺជាខ្លឹមសារនៃវិជ្ជាសិក្សាអំពីព្រះនៃព្រះគម្ពីរនេះទាំងមូល ។

**៣:១** *ព្រះបន្ទូលនៃព្រះយេហូវ៉ា* មើល ១:១ និងការពន្យល់ ។

**៣:២** *ក្រុងធំ* មើល ១:២ និងការពន្យល់ ។ *ប៉ាវប្រកាសដល់គេ តាមសេចក្ដីដែលអញនឹងបង្គាប់* លោកយ៉ូណាសគឺជាអ្នកនាំព្រះរាជសាររបស់ព្រះអម្ចាស់ គឺមិនគ្រាន់តែជាហោរាដែលថ្លែងទំនាយអំពីហេតុការណ៍ដែលនឹងកើតឡើងប៉ុណ្ណោះទេ ។

**៣:៣** *តាមព្រះបន្ទូល* ប៉ុន្តែនៅតែមានការស្ទាក់ស្ទើរ ដោយចិត្តនៅតែចង់ឱ្យពួកក្រុងនីនីវេត្រូវវិនាស(មើល ៤:១–៥ និងការពន្យល់)។ *ជាទីក្រុងធំក្រៃលែង* មើល ៤:១១ ដែលនិយាយថា ទីក្រុងនេះមានប្រជាជនជាង១សែន២ម៉ឺននាក់ ។ តាមកំណាយបុរាណវត្ថុវិទ្យាបានបង្ហាញថា ទីក្រុងនីនីវេនៅសម័យក្រោយមកទៀតមានបរិមាត្រប្រហែល ១២,៨ គីឡូម៉ែត្រ ។ តាមបទគម្ពីរលោកយ៉ូណាស "ដើរអស់បីថ្ងៃទើបសព្វ" ដូចនេះទីក្រុងនេះមានបរិមាត្រធំជាង ១២,៨ គីឡូម៉ែត្រ គឺត្រូវរាប់បញ្ចូលបរិវេណទាំងបួននៃទីក្រុងនីនីវេដែលមាន នីនីវេ រេហូបូត កាឡាស និងរេសែន ដែលមាននិយាយនៅក្នុង លប ១០:១១–១២ ។ បរិមាត្រសរុបនៃបរិវេណទាំងបួននេះគឺប្រហែល ៩៦,៥ គីឡូម៉ែត្រ ។ ម្យ៉ាងទៀត រយៈពេល"បីថ្ងៃ"ដែលគាត់បាន

លែង ដែលដើរអស់ចំនួន៣ថ្ងៃ ទើបបានសព្វ ៤កាល
យ៉ូណាស បានចាប់តាំងដើរចូលក្នុងទីក្រុងនោះ ចំងាយ
ដើរអស់១ថ្ងៃហើយ នោះលោកប៉ាវប្រកាសថា[ខ] នៅតែ៤0
ថ្ងៃទៀត ក្រុងនីនីវេនឹងត្រូវបំផ្លាញហើយ ។
៥ពួកបណ្ដាជននៅក្រុងនីនីវេ គេក៏ជឿព្រះអង្គ ដូច្នេះ
គេប្រកាសឱ្យមានពេលតមអត់ ហើយស្លៀកសំពត់ធ្មៃ ចាប់
តាំងពីអ្នកធំបំផុត រហូតដល់អ្នកតូចជាងគេ[គ] ៦ដំណឹងនោះក៏
ឮទៅដល់ស្ដេចនៃក្រុងនីនីវេ រួចទ្រង់ក្រោកចាកពីបល្ល័ង្ក
ដោះព្រះពស្ត្រចេញ ហើយគ្រលុំអង្គដោយសំពត់ធ្មៃ ទៅ
គង់នៅក្នុងផេះវិញ[ឃ] ៧ទ្រង់ក៏ឱ្យគេប្រកាសប្រាប់នៅពេញ
ក្នុងក្រុងនីនីវេ ជាបង្គាប់របស់ស្ដេច និងពួករដ្ឋមន្ត្រីថា
មិនត្រូវឱ្យពួកមនុស្ស ឬសត្វ ហ្វូងគោ ឬហ្វូងចៀមភ្លក់អ្វី
ឡើយ កុំឱ្យស៊ី ឬផឹកឱ្យសោះ[ង] ៨ត្រូវឱ្យទាំងអស់គ្រលុំ
ខ្លួនដោយសំពត់ធ្មៃ គឺទាំងមនុស្សនឹងសត្វផង ហើយត្រូវ
ឱ្យគ្រប់គ្នាអំពាវនាវ[ច]យ៉ាងខ្លាំងដល់ព្រះ អើ ត្រូវឱ្យគេ
លាចេញ[ឆ]ពីផ្លូវ[ជ]អាក្រក់របស់គេរៀងខ្លួន ហើយពីការ
ច្រឡោត ដែលនៅដៃខ្លួនផង[ឈ] ៩ប្រហែលជាព្រះទ្រង់នឹង
ប្រែព្រះហឫទ័យ[ញ] ហើយផ្លាស់គំនិត ព្រមលាកចេញពីសេច
ក្ដីក្រោធដ៏សហ័ស[ដ]របស់ទ្រង់ ដើម្បីមិនឱ្យយើងត្រូវវិនាស
ទៅទេដឹង[ឋ,ឌ] ១0ព្រះទ្រង់ទតឃើញការទាំងប៉ុន្មានដែលគេ
ប្រព្រឹត្តនោះ គឺដែលគេបានលាកចេញពីផ្លូវអាក្រក់របស់
គេ រួចព្រះក៏ប្រែគំនិតពីការអាក្រក់[ឍ] ដែលទ្រង់បានគំរាម
ថានឹងធ្វើដល់គេ[ណ] ហើយទ្រង់លែងធ្វើទៅ[ត]។

**៣:៤** ខ យរ ១៨:៧–១០
**៣:៥** គ ដយ ៩:៣ មថ ១១:២១ ១២:៤១ លក ១១:៣២
**៣:៦** ឃ នអ ៤:១–៣ យប ២:៨,១៣ អគ ២៧:៣0–៣១
**៣:៧** ង ២របា ២0:៣ អរ ១0:៦
**៣:៨** ច ទដ ១៣0:១ យហ ១:៦ ឆ យរ ២៥:៥ ជ យរ ៧:៣ ឈ យប ១៦:១៧
**៣:៩** ញ យរ ១៨:៨ ដ យអ ២:១៤ ឋ ទដ ៨៥:៣ ឌ ២សយ ១២:២២
**៣:១0** ឍ អម ៧:៦ ណ យរ ១៨:៨ ត នក ៣២:១៤
**៤:១** ក ខ.៤ មថ ២0:១១ លក ១៥:២៨
**៤:២** ខ យរ ២0:៧–៨ គ ចទ ៤:៣១

## សេចក្ដីកំហឹងរបស់លោកយ៉ូណាសដែលមានចំពោះការអាណិតអាសូររបស់ព្រះអម្ចាស់

៤ ១តែការនោះជាទីទំនាស់ចិត្តដល់យ៉ូណាសយ៉ាងក្រៃ
លែង ហើយលោកក៏ខឹង[ក] ២រួចលោកអធិស្ឋានដល់ព្រះ
យេហូវ៉ាថា ឱព្រះយេហូវ៉ាអើយ តើមិនមែនជាសេចក្ដី
នេះឯងដែលទូលបង្គំបានថា ក្នុងកាលដែលទូលបង្គំនៅឯ
ស្រុករបស់ទូលបង្គំនៅឡើយទេឬអី គឺដោយហេតុនោះបាន
ជាទូលបង្គំខំរត់ទៅឯក្រុងតើស៊ីសវិញ ពីព្រោះទូលបង្គំ
បានដឹង[ខ]ថា ទ្រង់ជាព្រះដ៏ប្រកបដោយករុណាគុណ[គ] ក៏មាន
ព្រះហឫទ័យអាណិតអាសូរ ទ្រង់យឺតនឹងខ្ញាល់ ហើយមាន
សេចក្ដីសប្បុរសជាបរិបូរ[ឃ]ក៏តែងតែប្រែគំនិត[ង]ចេញពីការ
អាក្រក់ផង[ច] ៣ដូច្នេះ ឱព្រះយេហូវ៉ាអើយ ទូលបង្គំសូម
អង្វរដល់ទ្រង់ សូមដកជីវិតទូលបង្គំចេញចុះ[ឆ] ដ្បិតស៊ូឱ្យ
ទូលបង្គំស្លាប់[ជ]ទៅជាជាងរស់នៅវិញ[ឈ] ៤តែព្រះយេហូវ៉ា
ទ្រង់មានបន្ទូលតបនឹងលោកថា ការដែលឯងខឹងដូច្នេះតើ
គួរឬ[ញ] ៥ខណនោះ យ៉ូណាសក៏ចេញទៅអង្គុយជ្រកនៅ

ទដ ១0៣:៨ ឃ នក ២២:២៧ ទដ ៨៦:៥,១៥ ង ជន ១៤:១៨ ច យអ ២:១៣ **៤:៣** ឆ ជន ១១:១៥ ជ យប ៧:១៥ ឈ យរ ៨:៣ **៤:៤** ញ លប ៤:៦ មថ ២0:១១–១៥

ដើរ អាចជារបៀបរៀបរាប់អំពីចំងាយផ្លូវជាមធ្យម (មើល លប ៣0:៣៦ នក ៣:១៨ និងការពន្យល់, យស ៩:១៦–១៧) ។

**៣:៥–៦** *តមអត់ . . . សំពត់ធ្មៃ . . . ផេះ* គឺជាប្រពៃណីយបន្ទាបខ្លួនដើម្បីប្រែចិត្ត (មើល ១ពវ ២១:២៧ នហ ៩:១ និងការពន្យល់) ។

**៣:៥** *ជឿព្រះអង្គ* នៅត្រង់ចំណុចនេះបញ្ជាក់ថា ពួកក្រុងនីនីវេពិតជាបានប្រែចិត្តមែន (ធៀបនឹង មថ ១២:៤១) ។ ម្យ៉ាងវិញទៀត សេចក្ដីជំនឿដែលពួកគេមានចំពោះព្រះប្រហែលជាមិនច្រើនជាងការកោតខ្លាចនៃពួកនាវិកចំពោះទ្រង់ឡើយ(មើលការពន្យល់ ១:១៦)។ យ៉ាងហោចណាស់ពួកគេបានទទួលការព្រមានដោយយកចិត្តទុកដាក់ខ្ពស់ ហើយបានប្រតិបត្តិតាមការព្រមាននោះ ដែលការនេះពួកអ៊ីស្រាអែលមិនបានធ្វើទេ ។

**៣:៦** *ស្ដេចនៃក្រុងនីនីវេ* គឺស្ដេចនៃចក្រភពអាសស៊ើរ ។

**៣:៨** *សត្វ* ការដែលរាប់បញ្ចូលទាំងពួកសត្វស្រុក (មើល ៤:១១) គឺការមិនធម្មតា ហើយបានបង្ហាញពីភាពបន្ទាន់ ដែលអ្នកក្រុងនីនីវេត្រូវទូលសូមសេចក្ដីមេត្តា ។

**៣:៩** ព្រះទ្រង់តែងតែឆ្លើយតមដោយសេចក្ដីមេត្តាករុណាចំពោះការលន់តួបាបរបស់មនុស្ស ដោយលប់ចោលទោសកំហុសដែលទ្រង់បានគំរាមថានឹងជំនុំជម្រះ(ខ.១0) ។ មើលការពន្យល់ យរ ១៨:៧–១0 ។

**៣:១0** *ព្រះក៏ប្រែគំនិតពីការអាក្រក់ . . . លែងធ្វើទៅ* មើល ១ពវ ២១:២៨–២៩ និងការពន្យល់ ២១:២៩ មើល សេចក្ដីផ្ដើមព្រះគម្ពីរណាហ៊ុមត្រង់សេចក្ដីផ្ដើម ណាហ ៣:១៩ និងការពន្យល់ ។

**៤:១** *ខឹង* លោកយ៉ូណាសខឹង ដោយសារព្រះទ្រង់មានសេចក្ដីមេត្តាដល់សត្រូវរបស់អ៊ីស្រាអែល ។ គាត់ចង់ឱ្យព្រះទ្រង់សំដែងសេចក្ដីល្អរបស់ទ្រង់ចំពោះតែសាសន៍អ៊ីស្រាអែលប៉ុណ្ណោះ គឺមិនមែនចំពោះសាសន៍ដទៃនោះទេ

**៤:២** *អធិស្ឋានដល់ព្រះយេហូវ៉ា* គឺអធិស្ឋានទាំងកំហឹង គឺមិនមែនដោយទុក្ខលំបាកដូចកាលពីមុននោះទេ (មើល ២:១–២ និងការពន្យល់ ២:២) ។ *ដោយហេតុនោះ . . . ខំរត់ទៅឯក្រុងតើស៊ីស* មើល ១:៣ និងការពន្យល់ ។ *ប្រកបដោយករុណាគុណ . . . សេចក្ដីសប្បុរស* មើល នក ៣៤:៦–៧ និងការពន្យល់ ។ នៅក្នុងខនេះលោកយ៉ូណាសបានសារភាពជាលើកទីបី និងលើចុងក្រោយ (មើលការពន្យល់ ១:៩ ២:៩) ។ *យឺតនឹងខ្ញាល់* គឺផ្ទុយពីលោកយ៉ូណាសដែលរហ័សនឹងខឹង (ខ.១,៩) ។

**៤:៣** *ដកជីវិតទូលបង្គំ* មើល ១ពវ ១៩:៤ និងការពន្យល់(លោកអេលីយ៉ា) លោកយ៉ូណាសយល់ថា ការដែលព្រះអម្ចាស់ទ្រង់ផ្ដល់សេចក្ដីមេត្តាដល់ពួកក្រុងនីនីវេ គឺមានន័យថា ព្រះអម្ចាស់ទ្រង់លែងមានសេចក្ដីស្រឡាញ់ចំពោះសាសន៍អ៊ីស្រាអែលទៀតហើយ ។ មុននោះបន្តិច លោកយ៉ូណាសបានអរសប្បាយចំពោះការរួចពីសេចក្ដីស្លាប់(២:២–៩) ប៉ុន្តែឥឡូវនេះគាត់បែរជាសុខចិត្តឱ្យស្លាប់ បើពួកក្រុងនីនីវេនៅរស់ ។

**៤:៥** *ជ្រក* ជម្រកនោះមិនបានផ្ដល់ម្លប់គ្រប់គ្រាន់ទេ ព្រោះខបន្ទាប់បាននិយាយថា ព្រះអម្ចាស់ទ្រង់បម្រុងឱ្យមានដើមវល្លិដុះឡើងគ្របបាំង ដើមឱ្យ

ក្រោមម្លប់នោះ ដើម្បីចាំមើលការអ្វី ដែលនឹងកើតដល់
ទីក្រុង ។
៦ព្រះដ៏ជាព្រះយេហូវ៉ាទ្រង់ក៏បំរុង[ដ]ឱ្យមានដើមវល្លិដុះ
ឡើងគ្របបាំងយ៉ូណាស ដើម្បីឱ្យបានជាម្លប់ពីលើក្បាល
ប្រយោជន៍ឱ្យលោកបានរួចពីសេចក្តីតប់ប្រមល់ទៅ ដូច្នេះ
យ៉ូណាសមានសេចក្តីអំណរជាខ្លាំង ដោយព្រោះដើមវល្លិ
នោះ ៧ប៉ុន្តែដល់ព្រឹកឡើងថ្ងៃក្រោយ ព្រះទ្រង់បំរុងឱ្យមាន
ដង្កូវ១មកស៊ីដើមវល្លិ ឱ្យស្វិតក្រៀមវិញ[ឋ] ៨លុះថ្ងៃបានរះ
ឡើងហើយ ព្រះទ្រង់បំរុងឱ្យមានខ្យល់ក្តៅ បក់មកពីទិស
ខាងកើត ថ្ងៃក៏ចាំងក្បាលលោកដែរ ឱ្យលោកខ្សោះល្វើយ
លោកក៏សូមឱ្យខ្លួនបានស្លាប់ទៅ[ឌ] ដោយពាក្យថា ស៊ូឱ្យទូល
បង្គំស្លាប់ទៅ ជាជាងរស់នៅ ៩នោះព្រះទ្រង់មានបន្ទូលតប
នឹងយ៉ូណាសថា ការដែលឯងខឹងពីដំណើរដើមវល្លិនោះ[ឍ]
តើគួរឬ លោកតបថា ការដែលទូលបង្គំខឹងនេះគួរហើយ
ទោះបើដល់ស្លាប់ក៏ដោយ ១០រួចព្រះយេហូវ៉ាទ្រង់មាន
បន្ទូលថា ឯងបានអាល័យចំពោះដើមវល្លិ ដែលឯងមិន
បានដាំឬធ្វើឱ្យដុះឡើងទេ ជាដើមដែលដុះឡើងក្នុង១យប់
ហើយបានវិនាសទៅ ក្នុង១យប់ដូចគ្នានោះ ១១ដូច្នេះ តើមិន
គួរឱ្យអញអាល័យ[ណ]ចំពោះក្រុងនីនីវេ[ត] ជាទីក្រុងយ៉ាងធំ
នេះ ដែលមានមនុស្សជាង១សែន២ម៉ឺននាក់ ជាពួកអ្នក
ដែលមិនស្គាល់ស្តាំមិនស្គាល់ឆ្វេងសោះ ព្រមទាំងហ្វូងសត្វ
យ៉ាងច្រើនផងទេឬអី ។/

**៤:៦** ដ យហ ១:១៧
**៤:៧** ឋ យអ ១:១២
**៤:៨** ឌ ១ពវ ១៩:៤
**៤:៩** ឍ ខ.៤
**៤:១១** ណ យហ ៣:១០ ត យហ ១:២ ៣:២

មានម្លប់ ។ *ចាំមើល* លោកយ៉ូណាសនៅតែមានសង្ឃឹមថា ទីក្រុងនីនីវេនឹងទទួលរងការបំផ្លាញ ។

**៤:៦** *ទ្រង់ក៏បំរុង* ឃ្លាដូចនេះមាននៅក្នុង ខ.៧–៨ ១:១៧ ផងដែរ ។ *ដើមវល្លិ* អាចជាដើមវល្លិម្យ៉ាងដែលបង្កើតជាតិប្រេង អាចដុះបានប្រហែលប្រវែង ៣,៥ ម៉ែត្រ ហើយមានស្លឹកធំៗ ។ ក្នុងខនេះ ព្រះអម្ចាស់ទ្រង់ផ្តល់ផាសុខភាពជាបន្ថែមទៀត ដល់ហោរាដែលមិនស្តាប់បង្គាប់ទ្រង់ ។

**៤:៨** *សូមឱ្យខ្លួនបានស្លាប់ទៅ* មើលការពន្យល់ ខ.៣ ។

**៤:១០** *ដុះឡើងក្នុង ១ យប់ ហើយបានវិនាសទៅក្នុង១យប់* ត្រង់ចំណុចនេះ គឺបង្ហាញអំពីតម្លៃដែលមិនស្ថិតស្ថេរបានយូរ ។

**៤:១១** *តើមិនគួរឱ្យអញអាល័យចំពោះ . . . ?* ព្រះអម្ចាស់ទ្រង់ជាអ្នកមានបន្ទូលមុន (១:១–២) ហើយក៏ជាអ្នកមានបន្ទូលចុងក្រោយដែរ ។ បេសកកម្មដែលទ្រង់បង្គាប់លោកយ៉ូណាស គឺបង្ហាញអំពីសេចក្តីមេត្តាករុណា និងអាណិតអាសូរដែលទ្រង់មានចំពោះពួកក្រុងនីនីវេ ហើយពាក្យចុងក្រោយដែលទ្រង់មានបន្ទូលមកកាន់លោកយ៉ូណាស គឺបង្ហាញអំពីការដែលទ្រង់មានព្រះទ័យទុកដាក់ចំពោះជីវិតទាំងអស់ ដែលមានទាំងមនុស្ស និងសត្វ ។ "ព្រះទ្រង់មិនគ្រាន់តែទំនុកបំរុងចំពោះមនុស្ស និងសត្វប៉ុណ្ណោះទេ" (ទដ ៣៦:៦ នហ ៩:៦ ទដ ១៤៥:១៦) ប៉ុន្តែទ្រង់ថែមទាំង"មិនរីករាយចំពោះសេចក្តីស្លាប់របស់មនុស្សអាក្រក់ទេ គឺចូលចិត្តឱ្យគេលះចោលផ្លូវរបស់ខ្លួនហើយមានជីវិតរស់នៅវិញ" (អគ ៣៣:១១ អគ ១៦:៦ ១៨:២៣ ៣៣:១១ និងការពន្យល់ ធៀបនឹង ២ពត ៣:៩ និងការពន្យល់) ។ លោកយ៉ូណាស និងពួកអ៊ីស្រាអែលដែលជាជនរួមជាតិរបស់លោក មានទម្លាប់អរសប្បាយចំពោះសេចក្តីមេត្តាករុណាដ៏ពិសេសដែលព្រះអម្ចាស់មានចំពោះសាសន៍អ៊ីស្រាអែល ហើយតែងប្រាថ្នាឱ្យទ្រង់មានសេចក្តីក្រោធចំពោះពួកខ្មាំងសត្រូវរបស់ពួកគេវិញ ។ នៅត្រង់ចំណុចនេះព្រះទ្រង់ស្តីបន្ទោសឱ្យការមានចិត្តដូចនេះ ដោយបង្ហាញអំពីសេចក្តីមេត្តាករុណាប្រកបដោយព្រះគុណរបស់ទ្រង់វិញ ។ *ទីក្រុងយ៉ាងធំ* មើល ១:២ និងការពន្យល់ ។ ព្រះគម្ពីរនេះបានចាប់ផ្តើម និងបញ្ចប់ទៅវិញដោយនិយាយផ្តោតទៅលើទីក្រុងនីនីវេ ដែលជាការ បង្ហាញអំពីសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ ។ *ជាពួកអ្នកដែលមិន ស្គាល់ស្តាំ មិនស្គាល់ឆ្វេងសោះ* ពួកក្រុងនីនីវេ ត្រូវការសេចក្តីមេត្តារបស់ព្រះអម្ចាស់ គឺដូចជាសេចក្តីមេត្តាករុណាដែលឪពុកមាន ចំពោះកូន (មើល ចទ ១:៣៩ និងការពន្យល់) ។ *ព្រមទាំងហ្វូងសត្វយ៉ាងច្រើន* សូម្បីតែសត្វ ស្រុកក៏ព្រះអម្ចាស់ទ្រង់មានព្រះទ័យយកចិត្តទុកដាក់ដែរ (ធៀបនឹង ៣:៨) ។

# ព្រះគម្ពីរមីកា

## សេចក្តីផ្តើម

### អ្នកនិពន្ធ

តាមព្រះគម្ពីរមីកា និងបទគម្ពីរ យរ ២៦:១៨ គេអាចដឹងអំពីអត្តសញ្ញាណខ្លះៗរបស់លោកមីកា ។ លោកមីកាគឺជាអ្នកក្រុងម៉ូរ៉ាស៊ីត (១:១) ប្រហែលជាក្រុងម៉ូរ៉ាស៊ីត–កាថ(១:១៤)ដែលស្ថិតនៅភូមិភាគខាងត្បូងនៃស្រុកយូដា ។ សេចក្តីទំនាយដែលលោកមីកាបានថ្លែងគឺបានបង្ហាញអំពីភាពធ្ងន់ធ្ងរនៃជម្ងឺសង្គមនៅក្នុងសម័យដែលលោករស់នៅ ពីព្រោះជម្ងឺនេះបានឆ្លងរាលដាលដល់ក្រុង និងភូមិតូចៗដែលស្ថិតនៅភូមិកំណើតរបស់លោក ។

### កាលបរិច្ឆេទ

លោកមីកាបានធ្វើការថ្លែងទំនាយក្នុងពេលណាមួយ នៅចន្លោះឆ្នាំ ៧៥០ និង ៦៨៦ មុនគ.ស. នៅក្នុងរាជ្យស្តេចយ៉ូថាម ស្តេចអេហាស និងស្តេចហេសេគា នៃស្រុកយូដា (១:១ យរ ២៦:១៨) ។ ដូចនេះលោកមីកា លោកអេសាយ (មើល អស ១:១) និងលោកហូសេ (មើល ហស ១:១) រស់នៅក្នុងសម័យតែមួយ ។ លោកមីកាបានថ្លែងទំនាយអំពីការដួលរលំនៃក្រុងសាម៉ារី (១:៦) ដែលកើតឡើងនៅឆ្នាំ ៧២២ ដល់ ៧២១ មុនគ.ស.។ តាមកាលបរិច្ឆេទនេះ គេអាចសន្និដ្ឋានថា លោកបានចាប់ផ្តើមធ្វើការបម្រើព្រះនៅក្នុងរាជ្យនៃស្តេចយ៉ូថាម(៧៥០ ដល់ ៧៣២ មុនគ.ស.) និងអេហាស(៧៣៥ ដល់ ៧១៥ មុនគ.ស.)។ បទទំនាយរបស់លោកមីកាបានឆ្លុះបញ្ចាំងអំពីស្ថានភាពសង្គមមុនពេលការធ្វើកំណែទម្រង់ខាងឯសេចក្តីជំនឿដោយស្តេចហេសេគា(៧១៥ ដល់ ៦៨៦ មុនគ.ស.) ។ លោកមីកាទំនងជាបានចាប់ផ្តើមធ្វើការបម្រើព្រះនៅក្នុងចន្លោះឆ្នាំ ៧៣៥ ដល់ ៧០០ មុនគ.ស.។

បើលោកមីកាសរសេរព្រះគម្ពីរនេះដោយខ្លួនលោកផ្ទាល់ នោះកាលបរិច្ឆេទដោយផ្អែកលើរចនាបថនៃការនិពន្ធរបស់លោកគឺប្រហែលជានៅឆ្នាំ ៧០០ មុនគ.ស.។

### ប្រវត្តិដើម

ប្រវត្តិដើមនៃព្រះគម្ពីរនេះ គឺដូចប្រវត្តិដើមនៃផ្នែកដំបូងនៃព្រះគម្ពីរអេសាយ ទោះបីជាលោកមីកាមិនបាននិយាយដូចលោកអេសាយ អំពីស្ថានភាពនយោបាយនៃក្រុងយេរូសាឡិមក៏ដោយ ។ នេះប្រហែលមកពីលោកមានប្រវត្តិជាអ្នកភូមិម្នាក់នៅស្រុកយូដា ។ ចំពោះអត្ថបទព្រះគម្ពីរដែលជាប់ទាក់ទងនឹងរយៈពេលនេះមាន ២ពវ ១៥:៣២–២០:២១ ២រប ២៧–៣២ អស ៧,២០,៣៦–៣៩ ។

សាសន៍អ៊ីស្រាអែលបានងាកបែរចេញពីការថ្វាយបង្គំព្រះអម្ចាស់ ។ លោកមីកាបានថ្លែងទំនាយអំពីការដួលរលំនៃរាជធានីសាម៉ារី នៃប្រទេសអ៊ីស្រាអែល(១:៥–៧) ហើយក៏បានថ្លែងទំនាយសេចក្តីវេទនានៃប្រទេសយូដាដែលជៀសមិនផុត(១:៩–១៦)។

មានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗមួយចំនួនដែលកើតឡើងនៅក្នុងសម័យនោះ ។

១. នៅក្នុងឆ្នាំ ៧៣៤ ដល់ ៧៣២ មុនគ.ស. ស្តេច ទិកឡាថ–ភិលេស័រ ទី៣ នៃចក្រភពអាសស៊ើរបានដឹកនាំទ័ពទាស់នឹងស្រុកអើរ៉ាម(ស៊ីរី)ភីលីស្ទីន និងផ្នែកខ្លះនៃប្រទេសអ៊ីស្រាអែល និងយូដា ។ ក្រុងអាសកាឡូន និងក្រុងកាសាត្រូវទទួលបរាជ័យ ។ ស្រុកយូដា អាំម៉ូន អេដុំម និងម៉ូអាប់ ត្រូវថ្វាយសួយសារអាករដល់ស្តេចអាសស៊ើរ ប៉ុន្តែស្រុកអ៊ីស្រាអែលមិនបានថ្វាយទេ ។ តាមបទគម្ពីរ ២ពវ ១៥:២៩ អាណាចក្រខាងជើងបានបាត់បង់ទឹកដីមួយភាគច្រើនរបស់ខ្លួន ដែលរួមមានតំបន់ទាំងអស់នៃស្រុកកាឡាត និងតំបន់កាលីឡេ ។ ក្រុងដាម៉ាសត្រូវដួលរលំនៅឆ្នាំ ៧៣២ ហើយត្រូវកាត់បញ្ចូលទៅក្នុងទឹកដីនៃចក្រភពអាសស៊ើរ ។

២. នៅឆ្នាំ ៧២២ ដល់ ៧២១ មុនគ.ស. ក្រុងសាម៉ារីត្រូវដួលរលំ ហើយនគរខាងជើងនៃអ៊ីស្រាអែលត្រូវកាន់កាប់ដោយចក្រភពអាសស៊ើរ ។

៣. នៅឆ្នាំ ៧១២ មុនគ.ស. ស្តេចសើកុន ទីពីរនៃចក្រភពអាសស៊ើរបានកាន់កាប់ស្រុកអាសដូឌ (មើល អស ២០:១ និងការពន្យល់) ។

៤. នៅឆ្នាំ ៧០១ មុនគ.ស. ស្រុកយូដាបានចូលរួមនៅក្នុងការបះបោរប្រឆាំងនឹងចក្រភពអាសស៊ើរ ហើយត្រូវស្តេចសាហេរីបដឹកនាំទ័ពបង្ក្រាប តែក្រុងយេរូសាឡិមបានទទួលការលើកលែង ។

### ការវិភាគផ្នែកអក្សរសាស្ត្រ

១. *រចនាសម្ព័ន្ធ* ព្រះគម្ពីរនេះត្រូវបាននិពន្ធឡើងដោយការថ្លែងទំនាយអំពីដំណាក់កាលទាំងបីនៃការជំនុំជម្រះ និងការសង្គ្រោះ

២. *ទម្រង់* ព្រះគម្ពីរនេះមានយ៉ាងហោចណាស់មានទម្រង់អក្សរសាស្ត្រចំនួនប្រាំពីរប្រភេទផ្សេងពីគ្នា ។

៣. *រចនាបថ* រចនាបថនៃព្រះគម្ពីរមីកាមានលក្ខណៈស្រដៀងគ្នានឹងព្រះគម្ពីរអេសាយ ។ ហោរាទាំងពីររូបបានប្រើពាក្យធ្ងន់ៗ និងពាក្យប្រៀបប្រដូចជាច្រើន (មើល ឧទាហរណ៍ មីក ១:៤-៥,៧ ២:៤,៦,១១ ៣:២-៣ ៤:៣-៤,១២-១៣ ៥:១) ដែលសុទ្ធតែបានបង្ហាញ អំពីការជំនុំជម្រះដែលកំពុងគម្រាមកំហែង និងយុត្តិធម៌តាមសេចក្ដីសន្យា ។ លោកមីកាបានលេងពាក្យជាញឹកញាប់ ឧទាហរណ៍ នៅក្នុងបទគម្ពីរ ១:១០-១៥ ។

## ខ្លឹមសារនៃព្រះបន្ទូល

ដូចដែលបានបង្ហាញនៅក្នុងគម្រោងសង្ខេប លោកមីកាថ្លែងទំនាយអំពីសេចក្ដីហិនវិនាស និងសេចក្ដីសង្ឃឹម ដូចដែលមាននិយាយនៅក្នុង រម ១១:២២ ដែលបង្ហាញអំពី"សេចក្ដីក្រោធ" និង"សេចក្ដីមេត្តាករុណា"របស់ព្រះអម្ចាស់។ ខ្លឹមសារសំខាន់ៗនៃព្រះគម្ពីរនេះគឺនិយាយអំពីការជំនុំជម្រះរបស់ព្រះអម្ចាស់ និងសេចក្ដីសង្គ្រោះ ។ លោកមីកាក៏បាននិយាយសង្កត់ធ្ងន់ផងដែរថា ព្រះអម្ចាស់ទ្រង់ស្អប់ការថ្វាយបង្គំរូបព្រះ អំពើអយុត្តិធម៌ ការបះបោរ និងមិនប្រតិបត្តិតាមក្រឹត្យវិន័យ(មើល ៣:៨ និងការពន្យល់) ប៉ុន្តែទ្រង់សព្វព្រះទ័យនឹងអត់ទោសដល់អ្នកដែលប្រែចិត្ត(មើល ៧:១៨-១៩ និងការពន្យល់)។ នៅចុងបញ្ចប់ លោកមីកាប្រកាសថា នៅពេលខាងមុខទីក្រុងស៊ីយ៉ូននឹងមានសិរីល្អដែលប្រសើរជាងមុន(មើលឧទាហរណ៍ ៤:១-២ និងការពន្យល់ ៤:១-៥)។ នគរតាមបែបស្តេចដាវីឌ ដែលហាក់ដូចជាត្រូវដល់ទីបញ្ចប់ នឹងបានឈានឡើងខ្ពស់ជាងមុន តាមរយៈការយាងមកនៃព្រះមែស៊ីដ៏ជួយសង្គ្រោះ(មើលការពន្យល់ ៥:១-៤)។ វគ្គជាគន្លឹះមាន ១:២ ៣:៨-១២ ៥:១-៤ ៦:២,៦-៨ ៧:១៨-២០ ។

### គម្រោងសង្ខេប

I. ចំណងជើង(១:១)

II. ដំណាក់កាលទីមួយ: ការជំនុំជម្រះ និងការស្អាងស្រុកអ៊ីស្រាអែល និងយូដាឡើងវិញ(១:២-២:១៣)

- ក. ការជំនុំជម្រះស្រុកអ៊ីស្រាអែល និងយូដា(១:២-២:១១)
  - ១. បទទំនាយអំពីការបំផ្លិចបំផ្លាញ(១:២-៧)
  - ២. ទុក្ខសោកនឹងការបំផ្លិចបំផ្លាញ(១:៨-១៦)
  - ៣. សេចក្ដីវេទនាដល់ពួកគៀបសង្កត់ដែលឈ្លានពានទឹកដី(២:១-៥)
  - ៤. ការថ្កោលទោសចំពោះពួកអ្នកមានដែលអាក្រក់ និងពួកហោរាក្លែងក្លាយរបស់ពួកគេ(២:៦-១១)
- ខ. ការស្អាងពួកសំណល់ឡើងវិញ(២:១២-១៣)

III. ដំណាក់កាលទីពីរ: ការចោទប្រកាន់អ្នកដឹកនាំស្រុកយូដា និងសេចក្ដីសង្ឃឹមនាពេលអនាគតដល់រាស្ត្រនៃព្រះ(ជំពូក ៣-៥)

- ក. ការចោទប្រកាន់អ្នកដឹកនាំស្រុកយូដា(ជំពូក ៣)
  - ១. អ្នកដឹកនាំដែលមានទោស(៣:១-៤)
  - ២. ពួកហោរានៃសេចក្ដីសុខសាន្តដែលក្លែងក្លាយ និងការឆ្លើយតបរបស់លោកមីកា(៣:៥-៨)
  - ៣. អ្នកដឹកនាំពុករលួយ និងការដួលរលំនៃក្រុងស៊ីយ៉ូន(៣:៩-១២)
- ខ. សេចក្ដីសង្ឃឹមនៅពេលអនាគតសម្រាប់រាស្ត្ររបស់ព្រះ(ជំពូក ៤-៥)
  - ១. នគរដែលត្រូវមកដល់(៤:១-៥)
  - ២. ការស្អាងឡើងវិញនូវ ពួកសំណល់ និងក្រុងស៊ីយ៉ូន(៤:៦-៨)
  - ៣. ការប្តូរពីទុក្ខសោក ទៅជាការរំដោះ(៤:៩-១០)
  - ៤. ការប្តូរពីការលោមព័ទ្ធ ទៅជាជ័យជំនះ(៤:១១-១៣)
  - ៥. ការប្តូរពីអ្នកដឹកនាំចោលម្សៀត ទៅជាមហាក្សត្រដ៏វិសេស(៥:១-៤)
  - ៦. មហាក្សត្រដ៏វិសេសរំដោះរាស្ត្ររបស់ទ្រង់(៥:៤-៥)
  - ៧. ពួកសំណល់នៅក្នុងចំណោមជាតិសាសន៍(៥:៦-៨)
  - ៨. ការរំលាយអំណាចទ័ព និងការថ្វាយបង្គំនៃសាសន៍ដទៃ(៥:៩-១៤)

IV. ដំណាក់កាលទីបីៈ ព្រះអម្ចាស់ចោទប្រកាន់រាស្ត្រទ្រង់ និងជ័យជម្នះនៅទីបញ្ចប់នៃនគររបស់ទ្រង់ (ជំពូក ៦–៧)
- ក. ព្រះអម្ចាស់ចោទប្រកាន់រាស្ត្រទ្រង់ (៦:១–៧:៧)
  - ១. ពាក្យបណ្តឹងមកពីស្ថានសួគ៌ (៦:១–៨)
  - ២. ការចោទប្រកាន់ និងការជំនុំជម្រះបន្ថែមទៀត (៦:៩–១៦)
  - ៣. ទុក្ខសោកចំពោះសង្គមដែលភ្លើតភ្លើន (៧:១–៧)
- ខ. ជ័យជម្នះនៃនគរព្រះនៅទីបញ្ចប់ (៧:៨–១០)
  - ១. ការបង្ហាញអំពីជំនឿ (៧:៨–១០)
  - ២. ការសន្យាថា នឹងស្ដារឡើងវិញ (៧:១១–១៣)
  - ៣. សេចក្ដីអធិស្ឋាន ចម្លើយ និងការឆ្លើយតបរបស់ព្រះអម្ចាស់ (៧:១៤–១៧)
  - ៤. បទទំនុកតម្កើងដល់ព្រះ (៧:១៨–២០)

**១** ១នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលមកដល់មីកា
ជាពួកម៉ូរ៉ាសិត[ក] នៅក្នុងរាជ្យនៃយ៉ូថាម[ខ] អេហាស[គ] និង
ហេសេគា[ឃ] ជាស្តេចយូដា[ង] ជាសេចក្តីដែលលោកបាន
ឃើញ[ច]ពីដំណើរក្រុងសាម៉ារី ហើយនិងក្រុងយេរូសាឡិម។
២ម្នាលជនជាតិទាំងឡាយអើយ ចូរស្តាប់[ឆ]ទាំងអស់គ្នា
ចុះ[ជ] ឱផែនដី[ឈ] និងសព្វសារពើដែលនៅផែនដីអើយ ចូរ
ប្រុងស្តាប់ចុះ ហើយបើកឱកាសឱ្យព្រះអម្ចាស់យេហូវ៉ា ធ្វើ
បន្ទាល់[ញ]ទាស់នឹងឯងរាល់គ្នា គឺឱ្យព្រះអម្ចាស់ធ្វើបន្ទាល់ពី
ព្រះវិហារបរិសុទ្ធរបស់ទ្រង់[ដ]។

## ការជំនុំជម្រះទាស់នឹងទីក្រុងសាម៉ារី និងយេរូសាឡិម

៣ដ្បិតមើល ព្រះយេហូវ៉ា ទ្រង់កំពុងយាងចេញពីទី
កន្លែង[ឋ]របស់ទ្រង់ ក៏នឹងយាងចុះមក[ឌ]ជាន់លើទីខ្ពស់ទាំង
ប៉ុន្មាននៃផែនដីដែរ[ឍ] ៤អស់ទាំងភ្នំនឹងរលាយ[ណ] ពីក្រោម
ទ្រង់ទៅ[ត] ឯច្រកភ្នំទាំងប៉ុន្មាន និងសញ្ញែកចេញ[ថ] ដូចជា
ក្រមួនដែលត្រូវភ្លើង ហើយដូចទឹកដែលចាក់ចុះតាមទី
ចោត ៥នេះគឺដោយព្រោះអំពើរំលងរបស់ពួកយ៉ាកុប និង
អំពើបាបរបស់ពួកវង្សអ៊ីស្រាអែល អំពើរំលងរបស់ពួក
យ៉ាកុបនោះជាអ្វី តើមិនមែនជាក្រុងសាម៉ារីទេឬអី[ទ] ហើយ
អស់ទាំងទីខ្ពស់របស់ពួកយូដាជាអ្វី តើមិនមែនជាក្រុង
យេរូសាឡិមទេឬអី ៦ដូច្នេះ អញនឹងធ្វើឱ្យក្រុងសាម៉ារីបាន
ដូចជាគំនរនៅទីវាល ជាកន្លែងសំរាប់ធ្វើចំការទំពាំង
បាយជូរ[ធ] អញនឹងចាក់ថ្ម[ន]ទាំងប៉ុន្មាននៃទីក្រុងទៅក្នុងច្រកភ្នំ
ហើយនឹងបើកឱ្យឃើញឫសជញ្ជាំង[ប] ៧នោះអស់ទាំងរូប
ឆ្លាក់របស់គេ[ផ] នឹងត្រូវវាយបំបែកខ្ទេចខ្ទីទៅ[ព] ឯអស់ទាំង
រង្វាន់ឈ្នួលរបស់វា នឹងត្រូវដុតដោយភ្លើង អញនឹងបំផ្លាញ
អស់ទាំងរូបព្រះ[ភ]របស់គេបង់ ពីព្រោះគេបានសន្សំអស់

**១:១** ក ខ.១៤ យរ ២៦:១៨ ខ ១រប ៣:១២ គ ១រប ៣:១៣ ឃ ១រប ៣:១៤ ង ហស ១:១ ច អស ១:១ **១:២** ឆ ចទ ៣២:១ ជ ទដ ៥០:៧ ឈ យរ ៦:១៩ ញ លប ៣១:៥០ ចទ ៤:២៦ អស ១:២ ដ ទដ ១១:៤ **១:៣** ឋ អស ១៨:៤ ឌ អស ៦៤:១ ឍ អម ៤:១៣ **១:៤** ណ ទដ ៤៦:២, ៦ ត យប ៩:៥ ថ ជន ១៦:៣១ ណហ ១:៥ **១:៥** ទ អម ៨:១៤ **១:៦** ធ ចទ ២០:៦ ន អម ៥:១១ ប អគ ១៣:១៤ **១:៧** ផ អគ ៦:៦ ព នក ៣២:២០ ភ ចទ ៩:២១

**១:១** *មីកា* ឈ្មោះនេះមានន័យថា "អ្នកដែលដូចព្រះអម្ចាស់" (ធៀបនឹង ៧:១៨ និងការពន្យល់) ។ *ពួកម៉ូរ៉ាសិត* មើលសេចក្តីផ្តើមត្រង់អ្នកនិពន្ធ ។ *យ៉ូថាម អេហាស និងហេសេគា* មើលសេចក្តីផ្តើមត្រង់ កាលបរិច្ឆេទ ។ ចំពោះប្រវត្តិដើមរបស់ពួកស្តេចទាំងនេះ និងព្រះគម្ពីរមីកា មើលសេចក្តីផ្តើមត្រង់ប្រវត្តិសាស្ត្រ ។ លោកហោរា អេសាយ ហូសេ និងមីកា បានថ្លែងទំនាយនៅក្នុងសម័យតែមួយ (អស ១:១ ហស ១:១) ។ *ឃើញ* មើល សកភ ២៩:១៨ អស ១:១ និងការពន្យល់ ។ *ក្រុងសាម៉ារី ហើយនិងក្រុងយេរូសាឡិម* នៅសម័យនោះ សាម៉ារីជារាជធានីនៃប្រទេសអ៊ីស្រាអែល ហើយយេរូសាឡិមគឺជារាជធានីនៃប្រទេសយូដា ។ លោកហោរាមីកាបានទាយអំពីសេចក្តីជំនុំជម្រះដែលមិនគ្រាន់តែជាប់ទាក់ទងនឹងរាជធានីប៉ុណ្ណោះទេ គឺថែមទាំងជាប់ទាក់ទងនឹងប្រទេសទាំងមូលទៀតផង ។

**១:២–២:១៣** គឺជាវគ្គទីមួយនៃសេចក្តីជំនុំជម្រះ (១:២–២:១១) និងសេចក្តីសង្គ្រោះ ឬការស្អាងឡើងវិញ(២:១២–១៣ មើលសេចក្តីផ្តើមត្រង់ គម្រោងសង្ខេប) ។

**១:២–៧** វគ្គនេះគឺជាពាក្យបណ្តឹងនៃព្រះអម្ចាស់ ដែលក្នុងនោះមានរៀបរាប់អំពីរបៀបដែលព្រះទ្រង់នឹងលេចមកដល់រាស្ត្ររបស់ទ្រង់ផងដែរ (ខ.៣–៤)។ តាមបទគម្ពីរនេះ អ្នកប្រយុទ្ធនៃស្ថានសួគ៌ចុះមកកាត់ទោសក្រុងសាម៉ារី និងប្រទេសអ៊ីស្រាអែល ។

**១:២** *ចូរស្តាប់* ពាក្យនេះសម្រាប់ប្រើនៅក្នុងការចាប់ផ្តើមថ្លែងទំនាយ ដើម្បីធ្វើឱ្យអ្នកដែលត្រូវស្តាប់បានដឹងខ្លួន ដូចដែលមានប្រើនៅក្នុង ៣:១ និង ៦:១ ផងដែរ(មើល ៣:៩ ៦:២) ។ *ម្នាលជនជាតិ . . . ផែនដី* មានន័យថាគ្រប់សាសន៍ទាំងអស់ ដែលត្រូវទទួលសេចក្តីប្រកាសថា ថ្ងៃនៃព្រះអម្ចាស់ជិតមកដល់ហើយ(មើល អម ៥:១៨ និងការពន្យល់) ។ លោកមីកាបានថ្លែងទំនាយអំពីសេចក្តីជំនុំជម្រះដែលជិតមកដល់ពួកអ៊ីស្រាអែល និងពួកយូដា ។ *ព្រះវិហារបរិសុទ្ធរបស់ទ្រង់* គឺនគរស្ថានសួគ៌ (ខ.៣) ដូចនៅក្នុង ទដ ១១:៤ យហ ២:៧ ហព ២:២០ ។

**១:៣** *ព្រះយេហូវ៉ាទ្រង់កំពុងយាងចេញ* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពាក្យនេះប្រើសម្រាប់បង្ហាញអំពីអន្តរាគមន៍ ដែលព្រះអម្ចាស់ទ្រង់មាននៅក្នុងប្រវត្តិសាស្ត្រ (ទដ ១៨:៩ ៩៦:១៣ និងការពន្យល់ ១៤៤:៥ អស ២៦:២១ ៣១:៤ ៦៤:១–៣) ។ *ទីខ្ពស់ទាំងប៉ុន្មាននៃផែនដី* អាចសំដៅទៅលើភ្នំ ក៏ដូចជាទីសក្ការៈរបស់សាសន៍ដទៃ (ខ.៤–៥)។ ធៀបនឹង អម ៤:១៣ ។

**១:៤** *អស់ទាំងភ្នំ នឹងរលាយ . . . ដូចជាក្រមួន* មើល ទដ ១៨:៦–៧ ៩៧:៥ ណហ ១:៥ ហព ៣:៣ និងការពន្យល់ ។

**១:៥** *នេះគឺ* មានន័យថា ព្រះអម្ចាស់ទ្រង់យាងមក ដើម្បីជំនុំជម្រះ (ខ.៣–៤)។ *យ៉ាកុប* ពាក្យនេះអាចប្រើជាឈ្មោះម្យ៉ាងទៀតរបស់អ៊ីស្រាអែល (មើល លប ៣២:២៨ និងការពន្យល់, ៣៥:១០) ។ *អ៊ីស្រាអែល* នៅក្នុងខនេះគឺសំដៅទៅលើនគរខាងជើង ប៉ុន្តែលោកមីកាប្រើពាក្យនេះសំដៅទៅលើអាណាចក្រខាងត្បូងផងដែរ(មើល ៣:១,៨–៩ ៥:១,៣ ៦:២) ឬសំដៅទៅលើរាស្ត្រនៃសេចក្តីសញ្ញាទាំងមូល(មើល ខ.១៤–១៥ ២:១២ ៥:២) ។ *ទីខ្ពស់* គឺជាទីកន្លែងថ្វាយបង្គំរូបព្រះដ៏សំខាន់បំផុតរបស់សាសន៍ដទៃ(មើលការពន្យល់ ១ពវ ៣:២) ។

**១:៦–៧** ក្នុងវគ្គនេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ សេចក្តីទំនាយនេះបានសម្រេចនៅក្នុងកាលដែលលោកមីកានៅមានជីវិតនៅឡើយ គឺនៅពេលដែលចក្រភពអាសស៊ើរបំផ្លាញទីក្រុងសាម៉ារីនៅ ៧២២ ដល់ ៧២១ មុន គ.ស (មើល ២ពវ ១៧:៦ និងការពន្យល់) ។

**១:៦** *ទៅក្នុងច្រកភ្នំ* ទីក្រុងសាម៉ារីត្រូវបានសង់ឡើងនៅលើភ្នំ(មើល ១ពវ ១៦:២៤ និងការពន្យល់) ។

**១:៧** *ស្រីសំផឹង* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាញឹកញាប់ពាក្យនេះ ជានិមិត្តរូបនៃការថ្វាយបង្គំរូបព្រះ ឬការមិនស្មោះត្រង់ខាងវិញ្ញាណ (មើល នក ៣៤:១៥ និងការពន្យល់ ពច ២:១៧ អគ ២៣:២៩–៣០)។ *ឈ្នួល* ត្រង់ចំណុចនេះមានន័យថា ទ្រព្យសម្បត្តិរបស់ទីក្រុងសាម៉ារីដែលបានមកពីការថ្វាយបង្គំរូបព្រះ និងត្រូវរឹបអូសដោយចក្រភពអាសស៊ើរ ហើយដាក់នៅក្នុងព្រះវិហាររបស់ពួកគេវិញ ដើម្បីយកមកប្រើប្រាស់ម្តងទៀតនៅក្នុងការថ្វាយបង្គំរូបព្រះ ។

ទាំងរូបនោះ ដោយសាររង្វាន់ឈ្នួលរបស់ស្រីសំផឹង[ម]
ហើយវានឹងត្រូវត្រឡប់ជារង្វាន់ឈ្នួលរបស់ស្រីសំផឹង
វិញទៀត ។

## ការសោយសោក និងការទ្រហោយំ

៨ដោយហេតុនេះបានជាខ្ញុំនឹងសោយសោក[យ]ហើយ
ទ្រហោយំ ខ្ញុំនឹងដើរដោយជើងទទេ[រ] ហើយកាយអាក្រាត
ខ្ញុំនឹងស្រែកលូដូចជាស្វាន ហើយនិងយំរងំដូចជាអូសទ្រីច
៩ដ្បិតរបួស[ល]នៃក្រុងសាម៉ារីនឹងមើលមិនជាឡើយ[វ] ពីព្រោះ
បានរាលរហូតដល់ស្រុកយូដាផង[ស]ក៏ដល់ទ្វារ[ហ]ក្រុងសាសន៍
ខ្ញុំ គឺជាក្រុងយេរូសាឡិមដែរ ។
១០កុំឱ្យថ្លែងប្រាប់រឿងនេះនៅក្រុងកាថឡើយ ក៏កុំឱ្យ
យំឱ្យសោះ ចូរឱ្យឯងននៀលខ្លួននៅក្នុងធូលីដីត្រង់បេត–
លេ–អាប្រាចុះ ១១ឱពួកអ្នកក្រុងសាភាអើយ ចូរដើរបង្ហូស
ទៅ ដោយខ្លួនងាក្រាត ហើយមានសេចក្ដីខ្មាសចុះ ពួក
អ្នកនៅត្រង់ស្អាណាន មិនបានចេញមកសោះ ការយំសោក
នឹងបេត–អេតសែល និងដកទីពឹង[ឡ]របស់ឯងរាល់គ្នា
ចេញ ១២ដ្បិតពួកអ្នកនៅម៉ារូតទន្ទឹងចាំសេចក្ដីល្អ[អ] ពីព្រោះ
សេចក្ដីអាក្រក់[ក]បានចុះពីព្រះយេហូវ៉ា មកដល់ទ្វារក្រុង
យេរូសាឡិមហើយ ១៣ឱពួកអ្នកនៅក្រុងឡាគីសអើយ[ខ]
ចូរទឹមរទេះដោយសេះយ៉ាងលឿន ឯងជាដើមចមនៃអំពើ
បាបដល់កូនស្រីស៊ីយ៉ូន[គ] ដ្បិតអំពើរំលងទាំងប៉ុន្មានរបស់ពួក
អ៊ីស្រាអែលបានឃើញមាននៅក្នុងឯង ១៤ដូច្នេះ ឯងនឹងលះ
លែង[ឃ]ក្រុងម៉ូរ៉ាសិត[ង]–កាថបង់ ឯផ្ទះអាក់ស៊ីប[ច]ទាំងប៉ុន្មាន
នោះនឹងបាននៅជាសេចក្ដីកំភូត[ឆ] ដល់ពួកស្ដេចអ៊ីស្រាអែល
១៥ឱអ្នកក្រុងម៉ារីសាអើយ[ជ] នៅ១ដងទៀតអញនឹងនាំម្នាក់
មកឯឯង ដែលនឹងធ្វើជាម្ចាស់លើឯង សិរីល្អនៃអ៊ីស្រាអែល
នឹងមកដល់អាឌូឡាម[ឈ] ១៦ចូរកោរ[ញ]រំលីងនៅកំពូលក្បាល
ហើយកាត់សក់ចុះ ដោយព្រោះកូនចៅជាទីគាប់ចិត្តរបស់
ឯង ចូរពង្រីកកន្លែងកើតការរំលីងនោះឱ្យធំឡើងដូចជា

**១:៧** ម ចទ ២៣:១៧–១៨
**១:៨** យ អស ១៥:៣ រ អស ២០:២
**១:៩** ល យរ ៤៦:១១ វ យរ ១០:១៩ ស ២ពវ ១៨:១៣ ហ អស ៣:២៦
**១:១១** ឡ អគ ២៣:២៩
**១:១២** អ យរ ១៤:១៩ ក យរ ៤០:២
**១:១៣** ខ យស ១០:៣ គ ទដ ៩:១៤
**១:១៤** ឃ ២ពវ ១៦:៨ ង ខ.១ ច យស ១៥:៤៤ ឆ យរ ១៥:១៨
**១:១៥** ជ យស ១៥:៤៤ ឈ យស ១២:១៥ **១:១៦** ញ លវ ១៣:៤០ យប ១:២០

**១:៨–១៦** នៅក្នុងវគ្គនេះ លោកមីកាមិនគ្រាន់តែបានបង្ហាញអំពីទុក្ខសោក អំពីការជិតមកដល់នៃការបំផ្លាញទីក្រុងសាម៉ារីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពីការត្រូវមកដល់នៃការឈ្លានពានប្រទេសយូដា ដែលសម្រេចដោយស្ដេចសេណាចេរិប (Sennacherib) នៃចក្រភពអាសស៊ើរនៅឆ្នាំ ៧០១ មុនគ.ស. ។

**១:៨** *ដោយហេតុនេះ* គឺដោយសារតែការមកដល់នៃការបំផ្លាញក្រុងសាម៉ារី ។ *ជើងទទេ* គឺជាសញ្ញានៃការសោកសង្រេង (មើល ២សយ ១៥:៣០ និងការពន្យល់) ។ វាជាការដែលអាចទៅរួចដែលថា លោកមីកាបានដើរជើងទទេ នៅទីក្រុងយេរូសាឡិម (ធៀបនឹង អស ២០:២) ។ នៅក្នុង ខ.១៦ និយាយអំពីការសោកសង្រេង ។ *ការអាក្រាត* ប្រហែលជាស្លៀកតែសំពត់ប៊ីង ។

**១:៩** *របួស* គឺជាការកាត់ទោស ដែលហៀបនឹងមកដល់ក្រុងសាម៉ារី ។ *មើលមិនជាឡើយ* មើល អស ១:៦ ១៧:១១ យរ ៣០:១២ និងការពន្យល់ ។ *ទ្វារ* ការដែលចក្រភពអាសស៊ើរបំផ្លាញនគរខាងជើង និងបានដូចជាជម្ងឺបណ្ដាលឱ្យស្លាប់មួយដែលរាលដាលដល់ទ្វាក្រុងយេរូសាឡិម (ខ.១២) ។ ទ្វាគឺជាទីកន្លែងធ្វើការរបស់ថ្នាក់ដឹកនាំប្រទេស (មើល លប ១៩:១ និងការពន្យល់ នរ ៤:១–៤ និងការពន្យល់ ៤:១) ។

**១:១០–១៥** បណ្ដាទីក្រុងដែលមាននិយាយនៅក្នុងវគ្គនេះ មានទីតាំងនៅតំបន់សេផេឡាហ៍ ដែលជាតំបន់ជើងភ្នំ (កម្ពស់ពី ១៥០ ដល់ ៤៥៧ ម៉ែត្រ) នៅចន្លោះតំបន់ទំនាបឆ្នេរមេឌីទែរ៉ាណេ និងភ្នំនៅស្រុកយូដា ។

**១:១០** *កុំឱ្យថ្លែងប្រាប់រឿងនេះនៅក្រុងកាថ* ពាក្យនេះគឺជាការប្រាប់ដំណឹងមរណៈទុក្ខនៃស្រុកយូដា ។ លោកមីកាមិនចង់ឱ្យអ្នកមិនជឿព្រះនៅក្រុងកាថមានការត្រេកអរនឹងការហិនវិនាសនៃរាស្ត្ររបស់ព្រះទេ (មើល ២សយ ១:២០ និងការពន្យល់) ។ *ននៀលខ្លួននៅក្នុងធូលីដី* គឺបង្ហាញពីការសោកសង្រេងនឹងសេចក្ដីហិនវិនាសដែលត្រូវមកដល់ (មើល អស ៤៧:១ និងការពន្យល់) ។

**១:១១** *ខ្លួនអាក្រាត ហើយមានសេចក្ដីខ្មាស* គឺសំដៅទៅលើការអាប់អោនរបស់ពួកគេនៅពេលអនាគត ដោយត្រូវក្លាយជាអ្នកទោស (មើល អស ២០:៤) ។ *មិនបានចេញមកសោះ* ដោយសារតែការឈ្លានពាន ធ្វើឱ្យបណ្ដាជនមិនហ៊ានចេញក្រៅផ្ទះទេ ។

**១:១២** *បានចុះពី* លោកមីកាបានទាយដឹងអំពីអនាគតយ៉ាងច្បាស់ ដែលធ្វើឱ្យលោកយល់ថា ការនោះហាក់ដូចជាបានចុះមករួចហើយ (មើល ខ.៣ និងការពន្យល់) ។

**១:១៣** *ក្រុងឡាគីស* គឺជាក្រុងដែលធំបំផុតនៅស្រុកយូដា (មើល អស ៣៦:២ និងការពន្យល់) ។ ក្រោយមក ស្ដេចសេណាចេរិបមានអំណួតយ៉ាងខ្លាំងចំពោះការកាន់កាប់បានទីក្រុងនេះ ហើយក៏បានឱ្យគេឆ្លាក់រូបរបឹបដែលបានពីក្រុងនេះ ។ *ទឹមរទេះ* ដើម្បីភាសខ្លួន ។ *កូនស្រីស៊ីយ៉ូន* ពាក្យនេះប្រើសំដៅទៅលើក្រុងយេរូសាឡិម (មើលការពន្យល់ ២ពវ ១៩:២១) ។ *អ៊ីស្រាអែល* មើលការពន្យល់ ខ.៥ ។

**១:១៤** *លះលែង* មើល ១ពវ ៩:១៦ ។ ត្រង់ចំណុចនេះមានន័យថា ទីក្រុងយេរូសាឡិមត្រូវបោះបង់ចោលទីក្រុងម៉ូរ៉ាសិត–កាថ ឱ្យពួកអាសស៊ើរ ។ *អាក់ស៊ីប* ពាក្យនេះមានន័យថា សេចក្ដីកំភូត ។ នៅក្នុង យរ ១៥:១៨ បានប្រើពាក្យ សេចក្ដីបញ្ឆោត ដោយប្រៀបប្រដូចទៅនឹង អូរដែលត្រូវរីងស្ងួតនៅរដូវប្រាំង ។ ទីក្រុងអាក់ស៊ីបនឹងលែងមានតទៅទៀត គឺមិនខុសអ្វីពីទឹកអូរដែលរីងស្ងួតនោះទេ ។ *អ៊ីស្រាអែល* មើលការពន្យល់ ខ.៥ ។

**១:១៥** នៅក្នុងខនេះលោកមីកាបានធ្វើជាអ្នកនិយាយតំណាងឱ្យព្រះអម្ចាស់ ដូចនៅក្នុង ខ.៦–៧ ។ *សិរីល្អនៃអ៊ីស្រាអែល* គឺជាព្រះអម្ចាស់ ឬអ្នកដឹកនាំអ៊ីស្រាអែល (មើល អស ៥:១៣ "ពួកអ្នករុងរឿង" ន័យចំគឺ "សិរីល្អ") ។ *នឹងមកដល់អាឌូឡាម* នៅក្នុងការជិះជំរុះ ពាក្យនេះគឺសំដៅទៅលើព្រះអម្ចាស់នៅក្នុងការភាសខ្លួន ពាក្យនេះសំដៅទៅលើអ្នកដឹកនាំអ៊ីស្រាអែល ។

**១:១៦** សាសន៍អ៊ីស្រាអែលត្រូវពួកអាសស៊ើរនិរទេសនៅឆ្នាំ ៧២២ ដល់ ៧២១ មុនគ.ស. ហើយពួកសាសន៍យូដាត្រូវពួកបាប៊ីឡូននិរទេសនៅឆ្នាំ ៥៨៦

ឥន្ទ្រី ពីព្រោះវារាល់គ្នាបានព្រាត់ប្រាសចាកចេញពីឯង
ទៅជាឈ្លើយអស់ហើយ[ដ]។

## ផែនការរបស់មនុស្ស និងផែនការរបស់ព្រះ

**២** ១វេទនាដល់ពួកអ្នកដែលគិតគួរអំពើទុច្ចរិត[ក] ហើយ
បង្កើតការអាក្រក់នៅ លើដំណេករបស់ខ្លួន[ខ] លុះព្រឹកភ្លឺ
ឡើង នោះគេធ្វើការនោះទៅ ពីព្រោះគេមានកំឡាំងដៃ
នឹងធ្វើបាន ២គេលោភចង់បានស្រែចំការ[គ] ក៏ដណ្តើមយក
បាន[ឃ] ព្រមទាំងផ្ទះផង ហើយរឹបយកទៅ គេសង្កត់សង្កិន[ង]
ទាំងមនុស្សនឹងផ្ទះរបស់គេ គឺជាមនុស្សនិងមរដករបស់គេ
ដែរ[ច] ៣ហេតុនោះ ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា
មើល អញក៏គិតគួរបង្កើតការអាក្រក់[ឆ]ទាស់នឹងគ្រួសារនេះ
ដែរ ជាការដែលឯងរាល់គ្នានឹងមិនដែលដកកចេញបាន
ឡើយ ឯងរាល់គ្នាក៏នឹងមិនដើរ ដោយវាយឫកទៀតដែរ[ជ]
ដ្បិតគ្រានោះ និងបានជាគ្រាអាក្រក់ ៤នៅថ្ងៃនោះ គេនឹង
ចាប់តាំងប្រើពាក្យប្រៀបធៀបចាក់ដោតឯង ហើយនឹង
ទួញទំនួញយ៉ាងអាក់អួលដោយពាក្យថា យើងរាល់គ្នាត្រូវ
បំផ្លាញអស់រលីង[ឈ]ហើយ ព្រះទ្រង់បានផ្លាស់មករដករបស់
សាសន៍ខ្ញុំ អើ ទ្រង់បានដករើចេញពីខ្ញុំយ៉ាងណាហ្ន៎ ទ្រង់
បានចែកស្រែចំការរបស់យើង[ញ] ឱ្យដល់ពួកអ្នកបះបោរ
វិញ ៥ដូច្នេះ ឯងនឹងមិនមានអ្នកណាសំរាប់កាន់ខ្សែវាស់[ដ]
តាមឆ្នោត[ឋ] នៅក្នុងពួកជំនុំនៃព្រះយេហូវ៉ាឡើយ ។

## ពួកហោរាក្លែងក្លាយ

៦គេថា កុំឱ្យទាយឱ្យសោះ អើ ពួកហោរានឹងលែងទាយ
ដល់ពួកយ៉ាងនេះហើយ តែសេចក្តីដំនៀល[ឌ]នឹងមិនផុត
ឡើយ[ឍ] ៧ឱពួកវង្សយ៉ាកុបអើយ តើហ៊ាននិយាយយ៉ាងនោះ
ឬ ឯព្រះវិញ្ញាណនៃព្រះយេហូវ៉ា តើទ្រង់ត្រូវទុញទាល់ឬ
តើទ្រង់ឬអ៊ី ដែលធ្វើការទាំងនោះ តើពាក្យអញមិនធ្វើល្អ[ណ]
ដល់អ្នកណាដែលប្រព្រឹត្តដោយទៀងត្រង់ទេឬអី[ត] ៨ពីមុន
មក រាស្ត្រអញបានលើកគ្នាដូចជាខ្មាំងសត្រូវវិញ ឯពួកអ្នក
ដែលដើរតាមផ្លូវ ដោយសុខសាន្តនោះឯងរាល់គ្នាតែងតែ
កន្ត្រាក់យកអាវវែងចេញ ទុកនៅតែអាវខ្លី គឺប្រព្រឹត្តដូចជា
មនុស្សដែលត្រឡប់មកពីចំបាំងវិញ ៩ឯងរាល់គ្នាក៏បណ្តេញ
ពួកស្រីៗ ក្នុងរាស្ត្រអញចេញពីផ្ទះដ៏គាប់ចិត្តរបស់គេ[ថ]
ហើយដកសិរីល្អរបស់អញ ចេញពីពួកកូនតូចៗរបស់គេនៅ
ជានិច្ចដែរ ១០ចូរក្រោកឡើងហើយចេញទៅចុះ ដ្បិតនេះ
មិនមែនជាទីឱ្យឯងរាល់គ្នាបានសំរាកនៅទេ[ទ] ដោយព្រោះ
សេចក្តីស្មោកគ្រោកដែលបំផ្លាញ[ធ] ដោយការបំផ្លាញយ៉ាង
អាក្រក់ ១១បើមានមនុស្សណាដែលប្រព្រឹត្តដោយនិស្ស័យ
កំភូត[ន]មកកុហកថា ខ្ញុំនឹងទាយប្រាប់អ្នកពីស្រាទំពាំងបាយ
ជូរ[ប] ហើយពីគ្រឿងស្រវឹង គឺអ្នកនោះឯងដែលនឹងធ្វើជា
ហោរាដល់ជនជាតិនេះ[ផ]។

## ព្រះបន្ទូលសន្យាអំពីសេចក្តីសង្គ្រោះ

១២យ៉ាកុបអើយ អញនឹងកៀរប្រមូលឯងទាំងអស់គ្នា
មកជាពិត អញនឹងនាំសំណល់[ព]ពួកអ៊ីស្រាអែលមកប្រជុំគ្នា

**១:១៦** ដ ចទ ៤:២៧ អម ៥:២៧
**២:១** ក អស ២៩:២០ ខ ទដ ៣៦:៤
**២:២** គ អស ៥:៨ ឃ សភ ៣០:១៤ ង យរ ២២:១៧ ច ១សយ ៨:១៤ អស ១:២៣ អក ៤៦:១៨
**២:៣** ឆ យរ ១៨:១១ អម ៣:១–២ ជ អស ២:១២
**២:៤** ឈ លវ ២៦:៣១ យរ ៤:១៣ ញ យរ ៦:១២
**២:៥** ដ ចទ ៣២:១៣ យស ១៨:៤ ឋ ជន ៣៤:១៣
**២:៦** ឌ ទដ ៤៤:១៣ យរ ១៨:១៦ ១៩:៨ ២៥:១៨ ២៩:១៨ មីក ៦:១៦ ឍ អម ២:១២
**២:៧** ណ ទដ ១១៩:៦៥ ត ទដ ១៥:២ ៨៤:១១
**២:៩** ថ យរ ១០:២០
**២:១០** ទ ចទ ១២:៩ ធ លវ ១៨:២៥–២៩ ទដ ១០៦:៣៨–៣៩ បទ ៤:១៥
**២:១១** ន ២រប ៣៦:១៦ យរ ៥:៣១ ប លវ ១០:៩ ផ អស ៣០:១០ ព មីក ៤:៧ ៥:៧ ៧:១៨

មុនគ.ស.។

**២:១–៥** សេចក្តីវេទនាដោយការជំនុំជម្រះ បានប្រកាស់ដល់ពួកអ្នកមានអ្នកគៀបសង្កត់យកទឹកដី ។ គឺពួកអ្នកដែលប្រើពាក្យស្លោកថា "អ្នកខ្លាំងជាអ្នកត្រូវ"។

**២:១** *គេធ្វើការនោះទៅ* គឺពួកអ្នកមាន វណ្ណៈជិះជាន់ ដែលកាន់តែមានឡើងៗ ដោយការគៀបសង្កត់អ្នកក្រ ដោយពួកគេបានគ្រប់គ្រងរចនាសម្ព័ន្ធនៃអំណាចនៅក្នុងសង្គមរបស់ពួកគេ ។

**២:២** *គេលោភ* ការនេះគឺជាការរំលងក្រឹត្យវិន័យទាំងដប់ប្រការ (មើល នក ២០:១៧ និងការពន្យល់, ចទ ៥:២១)។ *មរដក* គឺជាដីដែលត្រូវក្លាយជាកម្មសិទ្ធអចិន្ត្រៃរបស់គ្រួសារណាមួយ ។ មើលការពន្យល់ លវ ២៥:១៣(ឆ្នាំសោមនស្ស) ជន ២៧:១–១១ ៣៦:១–១២(កូនស្រីលោកស្លូផិហាត) ១ពវ ២១:៣(ចំការទំពាំងបាយជូររបស់លោកណាបោត) ។

**២:៣** *ហេតុនោះ* គឺដោយសារតែអំពើបាបរបស់ពួកវណ្ណៈដែលមានឥទ្ធិពលនៃពួកអ៊ីស្រាអែល សេចក្តីហិនវិនាសនឹងមកដល់ ។ *គ្រាអាក្រក់* គឺការនិរទេសដែលជិតមកដល់ ។

**២:៤** *យើងរាល់គ្នា . . . ខ្ញុំ* គឺសំដៅទៅលើពួកម្ចាស់ដី ដែលព្រះអម្ចាស់ទ្រង់នឹងកាត់ទោស ។ *ពួកអ្នកបះបោរ* គឺពួកសាសន៍អាសស៊ើរដ៏ទុយ៌ស (មើល អស ៣៣:១ និងការពន្យល់) ដែលនឹងវាយកាន់កាប់ទឹកដី ។

**២:៦–១១** វគ្គនេះគឺនិយាយអំពីការទាស់សម្តីរវាង លោកមីការ និងព្រះអម្ចាស់របស់លោក ដែលត្រូវតទល់ដោយពួកអ្នកមានដែលអាក្រក់ និងពួកហោរាក្លែងក្លាយរបស់ពួកគេ ។ ការខ្វែងសម្តីនេះគឺធ្វើឡើយដោយប្រើពាក្យជាបទទំនាយ ។

**២:៦** *ពួកហោរា* ត្រង់ចំណុចនេះ គឺសំដៅទៅលើពួកហោរាក្លែងក្លាយដែលថ្លែងពាក្យទៅកាន់លោកមីកា ។

**២:៧** ពី ខ.៦ ដល់ ៧ គឺជាពាក្យសម្តីរបស់លោកមីកា ហើយពី ខ.៧ ដល់ ១៣ គឺជាពាក្យសម្តីរបស់ព្រះអម្ចាស់ ។

**២:១០** *ទីឱ្យឯងរាល់គ្នាបានសំរាក* គឺជាទីកន្លែងដែលអាចចាត់ទុកបានថាជាកម្មសិទ្ធរបស់អ្នកណាម្នាក់ ហើយមនុស្សអាចជ្រកកោននៅទីនោះបានដើម្បីសន្តិសុខ (មើល ចទ ៣:២០ និងការពន្យល់, យស ២១:៤៣–៤៤ ២២:៤) ។

**២:១២–១៣** នៅក្នុងវគ្គនេះគឺជាបទទំនាយអំពីសេចក្តីសង្គ្រោះ ។ ទោះបីជាសាសន៍អ៊ីស្រាអែលត្រូវនិរទេសក៏ដោយ ក៏ពួកសំណល់នឹងបានត្រឡប់មកវិញ (មើលការពន្យល់ អស ១:៩)។

**២:១២** *យ៉ាកុប . . . ពួកអ៊ីស្រាអែល* ត្រង់ចំណុចនេះប្រហែលជាសំដៅទៅ

អញនឹងដាក់គេឱ្យនៅជាមួយគ្នា ដូចជាហ្វូងចៀមពីស្រុក
បុសរ៉ា គឺដូចជាសត្វ១ហ្វូងនៅកណ្ដាលវាលស្មៅ គេនឹង
បញ្ចេញសូរអ៊ូអរជាខ្លាំង ដោយមានគ្នាច្រើន[ភ] ១៣ពួកអ្នក
ដែលសំរាប់បុកទំលាយ បានឡើងនាំមុន[ម]គេទៅគេបាន
បំបាក់បំបែកឱ្យមានចន្លោះហើយ រួចរំលងទៅដល់ទ្វារ[យ]
ក្រុង ហើយបានចេញទៅតាមទីនោះ ស្តេចគេបានយាងនាំ
មុខគេ ហើយព្រះយេហូវ៉ាក៏នៅពីមុខគេបង្អស់ ។

## អ្នកដឹកនាំ និងពួកហោរាត្រូវទទួលការស្តីបន្ទោស

៣ ១ខ្ញុំក៏ថាដូច្នេះទៀត ឱពួកជាប្រមុខ[ក]នៃយ៉ាកុប នឹង
ពួកគ្រប់គ្រងលើវង្សអ៊ីស្រាអែលអើយ ខ្ញុំសូមឱ្យអ្នករាល់គ្នា
ស្តាបខ្ញុំចុះ តើមិនគួរគប្បីឱ្យអ្នករាល់គ្នាបានស្គាល់សេចក្ដី
យុត្តិធម៌ទេឬ ២អ្នករាល់គ្នាដែលស្អប់សេចក្ដីល្អ ហើយ
ស្រឡាញ់សេចក្ដីអាក្រក់អើយ ជាពួកអ្នកដែលបកស្បែក
ពីគេចេញ ហើយបេះសាច់ពីឆ្អឹងគេដែរ[ខ] ៣ក៏ស៊ីសាច់របស់
ជនជាតិខ្ញុំ[គ] ហើយពន្លាត់ស្បែកពីខ្លួនគេចេញ រួចបំបាក់
ឆ្អឹង[ឃ] ហើយកាប់[ង]គេជាដុំៗ ដូចជារៀបដាក់ក្នុងឆ្នាំង
ហើយ ដូចជាសាច់ដែលដាក់ចុះក្នុងថ្លាង[ច] ៤នៅគ្រានោះ
គេនឹងអំពាវនាវដល់ព្រះយេហូវ៉ា តែទ្រង់មិនព្រមតប
ឡើយ[ឆ] អើ ទ្រង់នឹងគេចព្រះភក្ត្រ[ជ]ចេញពីគេ ឱ្យសមតាម
អំពើអាក្រក់ទាំងប៉ុន្មាន ដែលគេបានប្រព្រឹត្ត[ឈ]។
៥ឯពួកហោរាដែលនាំឱ្យជនជាតិខ្ញុំវង្វេងចេញ[ញ] ជាពួក
អ្នកដែលទាយជាសេចក្ដីសុខ[ដ] ក្នុងកាលដែលមានអ្វីទំពារ
ស៊ី តែបើអ្នកណាមិនដាក់អ្វីក្នុងមាត់គេទេ នោះគេគិតទាំង
ច្បាំងនឹងអ្នកនោះផង ព្រះយេហូវ៉ាទ្រង់មានបន្ទូល ពីពួក
នោះថា ៦ដោយហេតុនោះ និងមានសុទ្ធតែយប់ដល់ឯង
រាល់គ្នា ឯងនឹងមិនឃើញការជាក់ស្តែងទៀត ហើយនឹង
មានសុទ្ធតែងងឹតដល់ឯងរាល់គ្នា ដើម្បីមិនឱ្យឯងទាយ
ឡើយ[ឋ] ព្រះអាទិត្យនឹងលិចបាត់ពីពួកហោរាទៅ[ឌ] ហើយ
ថ្ងៃនឹងបានងងឹតសូន្យដល់គេ[ឍ] ៧ពួកអ្នកមើលឆុតនឹងត្រូវ
ខ្មាស[ណ] ហើយពួកគ្រូទាយនឹងទាល់គំនិត[ត] អើ គេនឹងបិទខ្ទប់[ថ]
មាត់ទាំងអស់គ្នា[ទ] ដ្បិតគ្មានពាក្យតបមកពីព្រះឡើយ[ធ] ៨តែ
ចំណែកខ្ញុំ ខ្ញុំមានពេញជាព្រះចេស្តា ដោយសារព្រះ
វិញ្ញាណនៃព្រះយេហូវ៉ា ព្រមទាំងសេចក្ដីយុត្តិធម៌ នឹង
អំណាច ដើម្បីនឹងថ្លែងប្រាប់ឱ្យពួកយ៉ាកុបស្គាល់អំពើរំលង
ហើយឱ្យអ៊ីស្រាអែលស្គាល់អំពើបាបរបស់ខ្លួន[ន]។
៩ឱពួកជាប្រមុខនៃវង្សយ៉ាកុប និងពួកគ្រប់គ្រងលើវង្ស
អ៊ីស្រាអែល ជាពួកអ្នកដែលខ្ពើមសេចក្ដីយុត្តិធម៌ ហើយធ្វើ

**២:១២** ភ នហ ១:៩ **២:១៣** ម អស ៥២:១២ យ អស ៦០:១១ **៣:១** ក យរ ៥:៥ **៣:២** ខ ទដ ៥៣:៤ អគ ២២:២៧ **៣:៣** គ ទដ ១៤:៤ ឃ អគ ៣៤:៤ សផ ៣:៣ ង យប ២៤:១៤ ច អគ ១១:៧ ២៤:៤–៥ **៣:៤** ឆ ចទ ១:៤៥ ១សយ ៨:១៨ អស ៥៨:៤ យរ ១១:១១ ជ ចទ ៣១:១៧ ឈ យប ១៥:៣១ អគ ៨:១៨ **៣:៥** ញ អស ៣:១២ ៩:១៦ ៥៣:៦ ដ យរ ៤:១០ **៣:៦** ឋ អស ៨:១៩–២២ អគ ១២:២៤ ឌ អស ២៩:១០ ឍ អគ ៧:២៦ អម ៨:១១ **៣:៧** ណ យរ ៦:១៥ មីក ៧:១៦ ត អស ៤៤:២៥ ថ នអ ៦:១២ ទ លវ ១៣:៤៥ ធ អគ ២០:៣ **៣:៨** ន អស ៥៧:១២ ៦១:២

លើជាតិសាសន៍អ៊ីស្រាអែលទាំងមូល ដែលមាននៅខាងជើង និងខាងត្បូង ។ ខនេះគឺខុសពីខ.១៥ (មើលការពន្យល់ខនេះ)0 ។

**២:១៣** *ពួកអ្នកដែលសំរាប់បុកទំលាយ . . . ស្តេចគេ . . . ព្រះយេហូវ៉ា* ពួកគ្រូក្រឹត្យវិន័យនៃសាសនាយូដាបានកាត់ស្រាយថា ពាក្យទាំងបីនេះគឺនិយាយសំដៅទៅលើព្រះមែស៊ី ។

**៣:១–៥:១៥** គឺជាវគ្គទីពីរនៃការកាត់ទោស (ជំពូក៣) និងសេចក្ដីសង្គ្រោះ ឬការស្អាងឡើងវិញ(ជំពូក ៤–៥ មើលសេចក្ដីផ្ដើមត្រង់ គម្រោងសង្ខេប)។

**៣:១–១២** ខ.១–៤ និយាយអំពីអំពីបាបនៃអ្នកដឹកនាំអ៊ីស្រាអែល ខ.៥–៧ អំពីពួកហោរាក្លែងក្លាយ និងខ.៩–១២ អំពីអ្នកដឹកនាំ ពួកសង្ឃ និងពួកហោរា ។

**៣:១–៤** ប្រហែលជាពាក្យបណ្ដឹងមួយទៀតនៃព្រះអម្ចាស់ (មើល ១:២–៧) ដែលទ្រង់ចោទពួកអ្នកដឹកនាំពីបទប្រព្រឹត្តដោយអមនុស្សធម៌ ដូចពួកស៊ីសាច់មនុស្ស ។

**៣:១** *ស្តាប់* មើលការពន្យល់ ១:២ និងមើល ៦:១ ផងដែរ ។ *យ៉ាកុប . . . អ៊ីស្រាអែល* ត្រង់ចំណុចនេះ ឈ្មោះទាំងពីនេះគឺសំដៅទៅលើពួកយូដា (មើល ខ.៩–១០ ១:៥ និងការពន្យល់) ។

**៣:២–៣** *បកស្បែកពីគេចេញ . . . បេះសាច់ពីឆ្អឹងគេ . . . ដាក់ក្នុងឆ្នាំង* វគ្គនេះនិយាយជាពាក្យប្រៀបប្រដូច ដែលពិពណ៌នាអំពីអំពើសាហាវព្រៃផ្សៃ ដែលអ្នកដឹកនាំបានប្រព្រឹត្តចំពោះបណ្ដាជន ។

**៣:២** *ស្អប់សេចក្ដីល្អ ហើយស្រឡាញ់សេចក្ដីអាក្រក់* គឺខុសពី អម ៥:១៥ រម ១២:៩ ។

**៣:៤** *គេ* គឺពួកអ្នកដឹកនាំ ។ *ទ្រង់មិនព្រមតបឡើយ* មើល ខ.៧ ។ *គេចព្រះភក្ត្រចេញ* មើល ចទ ៣១:១៧ អស ១:១៥ និងការពន្យល់ ។ ការមិនស្តាប់បង្គាប់ព្រះនាំឱ្យដាច់ចេញពីព្រះ ។

**៣:៥–៨** វគ្គនេះគឺជាការទាស់សំដីម្តងទៀត(មើលការពន្យល់ ២:៦–១១) រវាងលោកមីកា និងពួកហោរាក្លែងក្លាយដែលថ្លែងទំនាយអំពីសេចក្ដីសុខសាន្ត ។

**៣:៥** *ទាយជាសេចក្ដីសុខ* ពួកហោរាក្លែងក្លាយថ្លែងទំនាយអំពីសេចក្ដីសុខដែលនឹងកើតមានដល់ស្រុកយូដា នៅពេលដែលលោកមីកាថ្លែងទំនាយអំពីការបំផ្លិចបំផ្លាញ និងការចាប់ជាឈ្លើយ (មើល ខ.១២ ៤:១០) ។ មើល យរ ៦:១៣–១៤ និងការពន្យល់ ៦:១៤ ៨:១០–១១ ។

**៣:៦–៧** *សុទ្ធតែយប់ . . . គ្មានពាក្យតបមកពីព្រះឡើយ* មើល យរ ១៨:១៨ និងការពន្យល់, អម ៨:១១–១២ និងការពន្យល់ ៨:១១ ។

**៣:៧** *ពួកអ្នកមើលឆុត* តាមព្រះគម្ពីរជាភាសាហេព្រើរកាលពីមុន គេហៅ "ពួកហោរា"ថា ពួកអ្នកមើលឆុត (មើលការពន្យល់ ១សយ ៩:៩) ។ *គេនឹងបិទខ្ទប់មាត់* គឺគេបិទខ្ទប់មាត់ ដោយសេចក្ដីខ្មាស និងអាប់អោន ។

**៣:៨** *ពេញ . . . ដោយសារព្រះវិញ្ញាណនៃព្រះ* ពួកហោរាគឺជាអ្នកនាំសាររបស់ព្រះដែលពេញដោយព្រះវិញ្ញាណ (មើល អស ៤៨:១៦ ៦១:១ និងការពន្យល់) ។ *ដើម្បីនឹងថ្លែងប្រាប់ . . . អំពើបាបរបស់ខ្លួន* គោលបំណងជាចំបងរបស់លោកមីកាគឺ ដើម្បីប្រកាសប្រាប់ពួកអ៊ីស្រាអែលឱ្យបានដឹងពីអំពើបាបដែលពួកគេប្រព្រឹត្ត ។

**៣:៩–១២** វគ្គនេះនិយាយអំពីសេចក្ដីទំនាយអំពីការថ្កោលទោស និងការជំនុំ

ឱ្យសេចក្តីត្រឹមត្រូវប្រែប្រួលទៅអើយ ចូរស្តាប់សេចក្តីនេះ
ចុះ[ប] ១០ឯងរាល់គ្នាសង់[ផ]ក្រុងស៊ីយ៉ូនឡើងដោយឈាម[ព]
ហើយក្រុងយេរូសាឡិមដោយសេចក្តីទុច្ចរិត[ភ] ១១ពួកជា
កំពូលលើគេ តែងតែជំនុំជំរះឱ្យបានរង្វាន់[ម]ពួកសង្ឃរបស់
គេបង្រៀនឱ្យបានកំរៃ[យ] ហើយពួកហោរាក៏ទាយឱ្យបាន
ប្រាក់[រ] ប៉ុន្តែ គេពឹងប្អែក[ល]លើព្រះយេហូវ៉ា ដោយពាក្យ
ថា ព្រះយេហូវ៉ាទ្រង់គង់នៅកណ្តាលយើងរាល់គ្នាទេតើ
នឹងគ្មានសេចក្តីអាក្រក់ណាកើតឡើងដល់យើងឡើយ[វ]
១២ដូច្នេះ ក្រុងស៊ីយ៉ូននឹងត្រូវគេភ្ជួររាស់ដូចជាស្រែចំការ
ដោយព្រោះឯងរាល់គ្នា ហើយក្រុងយេរូសាឡិមនឹងត្រឡប់
ជាកងគំនរ[ស] ឯភ្នំជាទីតាំងព្រះវិហារ[ហ] នឹងបានដូចជាទីខ្ពស់
នៅព្រៃវិញ[ឡ]។

## ភ្នំនៃព្រះយេហូវ៉ា

*៤:១–៣ – អស ២:១–៤*

**៤** ១តែនៅជាន់ក្រោយ ភ្នំ[ក]ដែលជាទីតាំងព្រះវិហារនៃព្រះ
យេហូវ៉ា នឹងបានដំកើងឡើងជាកំពូលនៃអស់ទាំងភ្នំធំ[ខ]
ជនជាតិទាំងឡាយនឹងឡើងទៅហូរហែរ[គ] ២ហើយសាសន៍
ជាច្រើននឹងទៅដោយពាក្យថា ចូរមក យើងឡើងទៅឯភ្នំ
នៃព្រះយេហូវ៉ា[ឃ] គឺទៅឯព្រះវិហារនៃព្រះរបស់យ៉ាកុប
ចុះ[ង] ទ្រង់នឹងបង្រៀនឱ្យយើងរាល់គ្នា[ច]ស្គាល់ផ្លូវរបស់ទ្រង់[ឆ]
នោះយើងនឹងដើរតាមអស់ទាំងផ្លូវច្រករបស់ទ្រង់ ដ្បិត
ក្រិត្យវិន័យ[ជ]នឹងផ្សាយចេញពីក្រុងស៊ីយ៉ូនទៅ គឺព្រះបន្ទូល
នៃព្រះយេហូវ៉ាពីក្រុងយេរូសាឡិម ៣ទ្រង់នឹងធ្វើជាចៅ
ក្រម ដល់សាសន៍ជាច្រើន ហើយនឹងសំរេចសេចក្តីពី
ដំណើរ ប្រទេសមានអំណាចខ្លាំងផ្សេងៗដែលនៅទីឆ្ងាយ[ឈ]
នោះគេនឹងដំដាវរបស់គេធ្វើជាផាល ហើយលំពែងគេធ្វើ
ជាដង្កាវវិញ[ញ] អស់ទាំងនគរនឹងលែងលើកដាវច្បាំងគ្នា
ទៀត ក៏មិនរៀនវិជ្ជាចំបាំង[ដ]ទៀតតទៅ[ឋ] ៤គឺគ្រប់គ្នានឹង
អង្គុយក្រោមដើមទំពាំងបាយជូរ ហើយក្រោមដើមល្វា
របស់ខ្លួន[ឌ] ឥតមានអ្នកណាបំភ័យគេឡើយ[ឍ] ដ្បិតព្រះឱស្ឋ
របស់ព្រះយេហូវ៉ានៃពួកពលបរិវារ បានចេញវាចា
ហើយ[ណ] ៥នោះទោះបើអស់ ទាំងសាសន៍ប្រព្រឹត្តតាម
ឈ្មោះរបស់ព្រះនៃគេរៀងខ្លួន[ត] គង់តែយើងរាល់គ្នានឹង
ប្រព្រឹត្តតាមព្រះនាមនៃព្រះយេហូវ៉ា ជាព្រះនៃយើង ជា
ដរាបរៀងតទៅវិញ[ថ]។

## ផែនការរបស់ព្រះអម្ចាស់

៦ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅថ្ងៃនោះអញនឹង
ប្រមូលអស់អ្នកណាដែលខ្វិន[ទ] ហើយនឹងភ្ជុំអស់អ្នកដែល
បានត្រូវបណ្តេញចេញ[ធ] ព្រមទាំងអស់អ្នកដែលអញបាន
ធ្វើទុក្ខផង ឱ្យមកវិញ[ន] ៧ឯពួកដែលខ្វិន នោះនឹងបានតាំង

**៣:៩** ប ទដ ៥៨:១–២ អស ១:២៣ **៣:១០** ផ យរ ២២:១៣ ព អស ៥៩:៧ មីក ៧:២ ណហ ៣:១ ហព ២:១២ ភ យរ ២២:១៧ អគ ២២:២៧ **៣:១១** ម នក ២៣:៨ លវ ១៩:១៥ មឡ ២:៩ យ អគ ១៣:១៩ រ អស ១:២៣ ៥៦:១១ យរ ៦:១៣ បទ ៤:១៣ ហស ៤:៨,១៨ ល អស ១០:២០ វ យរ ៧:៤ អគ ៣៤:២ **៣:១២** ស ២ពវ ២៥:៩ អស ៦:១១ ហ យរ ៥២:១៣ ឡ លវ ២៦:៣១ យរ ១៧:៣ ២២:៦ បទ ៥:១៨ អគ ៥:១៤ **៤:១** ក ទដ ៤៨:១ សក ៨:៣ ខ អគ ១៧:២២ គ ទដ ២២:២៧ ៨៦:៩ យរ ៣:១៧ ៣១:១២ ដយ ២:៣៥

**៤:២** ឃ យរ ៣១:៦ អគ ២០:៤០ ង សក ២:១១ ១៤:១៦ ច ទដ ១១៩:១៧១ ឆ ទដ ២៥:៨–៩ អស ៥៤:១៣ ជ ចទ ១៨:១៨ **៤:៣** ឈ អស ១១:៤ ញ យអ ៣:១០ សក ៩:១០ ដ ទដ ៤៦:៩ ឋ សក ៨:២០–២២ **៤:៤** ឌ ១ពវ ៤:២៥ ឍ លវ ២៦:៦ អគ ៣៩:២៦ ណ អស ១:២០ **៤:៥** ត ២ពវ ១៧:២៩ កច ១៤:១៦ ថ យស ២៤:១៤–១៥ អស ២៦:៨ សក ១០:១២ **៤:៦** ទ យរ ៣១:៨ ធ ទដ ១០៦:៤៧ ន អគ ៣៤:១៣,១៦ ៣៧:២១ សផ ៣:១៩

ជម្រះអ្នកដឹកនាំដែលពុករលួយ ដែលនាំឱ្យក្រុងស៊ីយ៉ូនដួលរលំ ។

**៣:៩** *ចូរស្តាប់* មើលការពន្យល់ ១:២ ។ *វង្សយ៉ាកុប . . . វង្សអ៊ីស្រាអែល* មើល ខ.១ និងការពន្យល់ ។

**៣:១០** *សង់ក្រុងស៊ីយ៉ូនឡើងដោយឈាម* មើល អគ ៧:២៣ និងការពន្យល់

**៣:១១** *ឱ្យបានរង្វាន់* មើល ១សយ ៨:៣ និងការពន្យល់ អស ១:២៣ ៥:២៣

**៣:១២** ការបំផ្លាញទីក្រុងយេរូសាឡិមកើតឡើងនៅឆ្នាំ ៥៨៦ មុនគ.ស. ។ ខនេះក៏មាននិយាយដូចគ្នានៅក្នុង យរ ២៦:១៨ (សូមមើលការពន្យល់ខនេះ) ដែលពីព្រះគម្ពីរមីកា ដល់ព្រះគម្ពីរយេរេមាគឺមានរយៈពេលមួយសតវត្ស ។ បទគម្ពីរ យរ ២៦:១៩ បានបង្ហាញថា ការប្រកាសព្រះបន្ទូលរបស់លោកមីកាអាចជាឧបករណ៍នៃការធ្វើកំណែទម្រង់នៃក្នុងរាជស្តេចហេសេគា (មើល ២ពវ ១៨:១–៦ ២របា ២៩–៣១)។ *ក្រុងយេរូសាឡិម . . . កងគំនរ* គឺមិនខុសពីក្រុងសាម៉ារីទេ (មើល ១:៦)។

**៤:១–៥** វគ្គនេះនិយាយអំពីសេចក្តីទំនាយអំពីសេចក្តីសង្គ្រោះ ("នៅថ្ងៃចុងក្រោយ" ខ.១) ដែលជាការស្អាងទីក្រុងស៊ីយ៉ូនឡើងវិញនៅថ្ងៃអនាគត ។ ទោះបីជាព្រះវិហារនឹងត្រូវទទួលរងការបំផ្លាញក៏ដោយ (៣:១២) ក៏ព្រះវិហារនោះនឹងត្រូវបានស្អាងឡើងវិញ ប្រកបដោយសោភ័ណ្ឌភាពស្រស់ស្អាតជាងមុន ដើម្បីធ្វើជាមជ្ឈមណ្ឌលថ្វាយបង្គំ និងសិក្សាសម្រាប់គ្រប់ជាតិសាសន៍ ។

**៤:១–៣** មើលការពន្យល់ អស ២:២–៤ ដែលវគ្គនៃបទគម្ពីរដែលនិយាយស្ទើរតែដូចគ្នាទាំងស្រុងនឹងវគ្គនេះ ។

**៤:៣** *ផាល* មើលការពន្យល់ អស ២:៤ ។

**៤:៤** *ដើមទំពាំងបាយជូរ . . . ដើមល្វា* ពាក្យនេះប្រើសំដៅទៅលើសេចក្តីសុខសាន្តដែលមាននៅក្នុងនគរព្រះ ។ មើល ១ពវ ៤:២៥ ២ពវ ១៨:៣១ សក ៣:១០ ។ *ឥតមានអ្នកណាបំភ័យគេឡើយ* មើល សផ ៣:១៣ ។ សេចក្តីភ័យខ្លាចនឹងត្រូវក្លាយជារឿងអតីតកាល ។

**៤:៥** *ប្រព្រឹត្តតាមព្រះនាមនៃព្រះយេហូវ៉ា* គឺដោយការសារភាពទោសកំហុស សេចក្តីស្រឡាញ់ ការស្តាប់បង្គាប់ និងការពឹងផ្អែកលើព្រះអម្ចាស់ ។ ផ្ទៀបនឹង សក ១០:១២ ។

**៤:៦–៨** វគ្គនេះនិយាយអំពីបទទំនាយមួយទៀតអំពីសេចក្តីសង្គ្រោះ ("នៅថ្ងៃនោះ" ខ.៦) ដែលនិយាយអំពីការស្អាងឡើងវិញនូវពួកសំណល់នៃក្រុងស៊ីយ៉ូន ។

**៤:៦** *នៅថ្ងៃនោះ* គឺនៅក្នុងសម័យព្រះមែស៊ី (មើល ខ.១ ការពន្យល់ អស ២:១១,១៧,២០, យអ ១:១៥)។

**៤:៧** *សំណល់* គឺរាស្ត្ររបស់ព្រះ (មើល ២:១២ និងការពន្យល់ អស ១:៩)

ទុកជាសំណល់[ប] ហើយពួកដែលត្រូវបោះចោលទៅជា
ឆ្ងាយ ឱ្យបានជានគរ១ខ្លាំងពូកែ[ផ] នោះព្រះយេហូវ៉ាទ្រង់
នឹងសោយរាជ្យលើគេ នៅភ្នំស៊ីយ៉ូន[ព] ចាប់តាំងពីគ្រានោះ
ជាដរាបតទៅ[ភ] ៨ដូច្នេះ ឯងឯង ឱប៉មនៃហ្វូងចៀម ជាទួល
ខ្ពស់របស់កូនស្រីស៊ីយ៉ូនអើយ នេះនឹងមក[ម]ឯងវិញ គឺ
អំណាចគ្រប់គ្រង ដូចដើមនឹងមកឯង ជារាជ្យរបស់កូន
ស្រីយេរូសាឡិម[យ] ។

៩ឥឡូវនេះ ហេតុអ្វីបានជាឯងស្រែកឡើងដូច្នេះ តើ
គ្មានស្តេចនៅក្នុងឯងឬ[រ] តើអ្នកប្រឹក្សារបស់ឯងបានវិនាស
បង់ហើយឬ បានជាឯងឈឺចាប់ដូចជាស្រីដែលឈឺនឹង
សំរាលកូនដូច្នេះ[ល] ១០ឱកូនស្រីស៊ីយ៉ូនអើយ ចូរឈឺចាប់
ហើយខំរមាត់ចុះ ដូចជាស្រីដែលឈឺនឹងសំរាលកូន ដ្បិត
ឯងនឹងត្រូវចេញពីទីក្រុងទៅឥឡូវ ហើយនឹងអាស្រ័យនៅ
ឯទីវាល ព្រមទាំងទៅរហូតដល់ក្រុងបាប៊ីឡូនផង[វ] នៅទី
នោះឯងនឹងបានប្រោសឱ្យរួច គឺនៅទីនោះព្រះយេហូវ៉ា
ទ្រង់នឹងលោះ[ស]ឯង ចេញពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវ
របស់ឯង ១១ឥឡូវនេះ មានសាសន៍ជាច្រើនមូលគ្នាមកទាស់
នឹងឯង គេពោលថា ចូរឱ្យវាត្រូវស្មោកគ្រោកទៅ ហើយ
ឱ្យភ្នែកយើងបានស្កប់[ហ] ដោយមើលស៊ីយ៉ូនចុះ ១២ប៉ុន្តែគេ
មិនស្គាល់គំនិតរបស់ព្រះយេហូវ៉ាទេ ក៏មិនយល់សេចក្តី
ប្រឹក្សារបស់ទ្រង់ដែរ[ឡ] ដ្បិតទ្រង់បានប្រមូលគេនៅទីលាន
ដូចជាកណ្តាប់ស្រូវ ១៣ឱកូនស្រីនៃស៊ីយ៉ូនអើយ ចូរក្រោក
ឡើងបញ្ជាន់ទៅចុះ[អ] ដ្បិតអញនឹងធ្វើឱ្យស្នែងឯងបានទៅជា
ដែក ហើយក្រចកឯងទៅជាលង្ហិន ឯងនឹងបំបែកសាសន៍ជា
ច្រើនឱ្យខ្ទេចខ្ទី[ក] ហើយអញនឹងញែកកំរៃរបស់គេចេញ ទុក
ជាដង្វាយដល់ព្រះយេហូវ៉ា[ខ] គឺទ្រព្យសម្បត្តិរបស់គេ ថ្វាយ
ដល់ព្រះអម្ចាស់នៃផែនដីទាំងមូល ១៤តែឥឡូវនេះ ឱកូន
ស្រីនៃកងទ័ពអើយ ត្រូវឱ្យឯងមូលគ្នាជាកងទ័ពចុះ គេបាន
ឡោមព័ទ្ធច្បាំងនឹងយើងហើយ គេនឹងវាយចៅក្រមនៃ
អ៊ីស្រាអែល ដោយដំបងត្រង់ថ្ពាល់[ក] ។

## ព្រះបន្ទូលសន្យាប្រទានអ្នកដឹកនាំពីបេថ្លេហិម

**៥** ១តែឯង ឱបេថ្លេហិម[ខ]–អេប្រាតាអើយ[គ] ឯងដែលតូច
នៅក្នុងពួកយូដាទាំងពាន់ៗ នឹងមានម្នាក់កើតចេញពីឯង
មកឱ្យអញ អ្នកនោះត្រូវឡើងជាអ្នកគ្រប់គ្រង[ឃ]លើអ៊ីស្រា–
អែល ដើមកំណើតរបស់អ្នកនោះបានចាប់តាំងពីបុរាណ[ង]
គឺពីអស់កល្បរៀងមក[ច] ២ដូច្នេះ អ្នកនោះនឹងប្រគល់គេទៅ[ឆ]
ដរាបដល់កំណត់នៃនាង ដែលឈឺនឹងសំរាល បានកើតកូន
មក នោះសំណល់នៃពួកបងប្អូនរបស់អ្នកនោះ និងបាន
វិលត្រឡប់មកឯពួកកូនចៅអ៊ីស្រាអែលវិញ ៣អ្នកនោះនឹង

**៤:៧** ប យអ ២:៣២ មីក ២:១២ ផ លប ១២:២ ព អស ២:២ ភ ដយ ២:៤៤ ៧:១៤ លក ១:៣៣ វវ ១១:១៥
**៤:៨** ម អស ១:២៦ យ សក ៩:៩
**៤:៩** រ យរ ៨:១៩ ល លប ៣:១៦ យរ ៣០:៦ ៤៨:៤១
**៤:១០** វ ចទ ២១:១០ ២ពវ ២០:១៨ អស ៤៣:១៤ ស អស ៤៨:២០
**៤:១១** ហ បទ ២:១៦ អប ១:១២ មីក ៧:៨
**៤:១២** ឡ លប ៥០:២០ អស ៥៥:៨ រម ១១:៣៣–៣៤
**៤:១៣** អ អស ២១:១០ ក អស ៤៥:១ ដយ ២:៤៤ ខ អស ២៣:១៨
**៤:១៤** ក បទ ៣:៣០
**៥:១** ខ យហ ៧:៤២ គ លប ៣៥:១៦ ៤៨:៧ ឃ ជន ២៤:១៩ ១សយ ១៣:១៤ ២សយ ៦:២១ ២របា ៧:១៨ ង ទដ ១០២:២៥ ច មថ ២:៦ **៥:២** ឆ យរ ៧:២៩

**៤:៨** *ប៉មនៃហ្វូងចៀម* គឺទីក្រុងយេរូសាឡិម ដែលជារាជធានីរបស់ស្តេចដាវីឌ ដែលជាស្តេចដ៏ជាអ្នកគង្វាល ។ *កូនស្រីស៊ីយូន . . . កូនស្រីយេរូសាឡិម* មើល ខ.១០,១៣ ។ កូនស្រីស៊ីយ៉ូនគឺជាទីក្រុងយេរូសាឡិម (មើលការពន្យល់ ២ពវ ១៩:២១)។ *អំណាចគ្រប់គ្រង ដូចដើម* នគរនៃស្តេចដាវីឌនឹងត្រូវបានស្អាងឡើងវិញ ក្នុងរាជព្រះមែស៊ី ។

**៤:៩–១៣** នៅក្នុង ខ.៩–១០ លោកមីកាបានថ្លែងទំនាយអំពីការដួលរលំនៃស្តេចអ៊ីស្រាអែល និងការនិរទេសដែលជិតមកដល់ នៅឆ្នាំ ៥៨៦ មុនគ.ស. ក៏ដូចជាអំពីការស្អាងឡើងវិញដែលចាប់ផ្តើមនៅឆ្នាំ ៥៣៨ មុនគ.ស. ។ ខ.១១–១៣ គឺជាសេចក្តីទំនាយអំពីសេចក្តីជំនុំជម្រះដែលត្រូវធ្លាក់មកលើខ្មាំងសត្រូវនៃក្រុងយេរូសាឡិម ។

**៤:៩–១០** វគ្គនេះគឺជាបទទំនាយអំពីសេចក្តីជំនុំជម្រះ និងសេចក្តីសង្គ្រោះ ។ ហើយបីវគ្គខាងមុខទៀត(ខ.៩–១០, ១១–១៣ ៥:១–៤) សុទ្ធតែចាប់ផ្តើមដោយពាក្យដែលជាភាសាហេព្រើមានន័យថា "ឥឡូវនេះ" ហើយបញ្ចប់ដោយការបញ្ជាក់ថា ស្ថានភាពបច្ចុប្បន្ន ឬស្ថានភាពអាក្រក់ដែលបានទាយទុក នឹងផ្លាស់ប្តូរទៅជាល្អជាងមុន(នៅក្នុងវគ្គនេះគឺនិយាយអំពីសេចក្តីទុក្ខប្រែក្លាយជាការមានសេរីភាព)។

**៤:១១–១៣** វគ្គនេះនិយាយអំពីសេចក្តីទំនាយអំពីសេចក្តីជំនុំជម្រះ និងសេចក្តីសង្គ្រោះ ដែលជាការប្រែពីការដែលគេឡោមព័ទទៅជាជ័យជម្នះ (មើលការពន្យល់ ខ.៩–១០)។

**៤:១៤** ទីក្រុងយេរូសាឡិមនឹងត្រូវបានឡោមព័ទ្ធ ហើយគេនឹងដកស្តេចចេញ ហើយបញ្ជូនទៅចក្រភពបាប៊ីឡូន(ស្តេចចុងក្រោយគឺ ស្តេចសេដេគា ដែលគេធ្វើឱ្យខ្វាក់ភ្នែក មើល ២ពវ ២៥:៧ និងការពន្យល់) ។

**៥:១–៤** វគ្គនេះគឺជាសេចក្តីទំនាយអំពីការជំនុំជម្រះ និងសេចក្តីសង្គ្រោះ ដែលជំនួសអ្នកដឹកនាំចោលម្សៀត ដោយមហាក្សត្រដ៏ឧត្តុង្គឧត្តម្ភ (មើលការពន្យល់ ៤:៩–១០) ដែលនឹងត្រូវប្រសូត្រនៅភូមិបេថ្លេហិម ហើយភាពធំឧត្តម្ភនៃទ្រង់នឹងបានដល់ចុងបំផុតនៃផែនដី (ខ.៣) ។

**៥:១** ព្រះគម្ពីរម៉ាថាយ ២:៦ បានដកស្រង់ផ្នែកខ្លះនៃខនេះ ។ នៅក្នុងខនេះ លោកមីកាបានប្តូរមកនិយាយជាពាក្យវិជ្ជមានដែលខុសពី ៤:១៤។ *អេប្រាតា* ភូមិបេថ្លេហិមមានទីតាំងស្ថិតនៅទីកន្លែងនេះ (មើល នរ ១:២ និងការពន្យល់) ។ *អ្នកគ្រប់គ្រង* គឺព្រះគ្រីស្ទ ដែលទ្រង់នឹងគ្រប់គ្រង(មើល ការពន្យល់ ៤:៨) ថ្វាយព្រះដ៏ជាព្រះវរបិតា ។ *ដើមកំណើត . . . ចាប់តាំងពីបុរាណ* ព្រះទ្រង់មានព្រះ ជន្មគង់នៅជានិច្ច គឺមានមុនពេលទ្រង់ប្រសូត្រតាំងតែពីអស់កល្បជានិច្ច (យហ ៨:៥៨) ។ *ចាប់តាំងពីបុរាណ* គឺចាប់តាំងពីពេលក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ(មើល ២សយ ៧:១២–១៦ អស ៩:៦–៧ និងការពន្យល់ អម ៩:១១) ហើយថែមទាំងចាប់តាំងពីអស់កល្បជានិច្ច ។

**៥:២** *អ្នកនោះនឹងប្រគល់គេទៅ* គឺរហូតដល់ពេលដែលព្រះមែស៊ីទ្រង់ប្រសូត្រ ហើយចាប់ផ្តើមការគ្រប់គ្រងរបស់ទ្រង់ ។ *អ៊ីស្រាអែល* មើលការពន្យល់ ១:៥ ។

ឈរឡើងឃ្វាលហ្វូងចៀម[ជ]របស់ខ្លួន ដោយសារឥទ្ធិឫទ្ធិនៃ
ព្រះយេហូវ៉ា និងឫទ្ធានុភាពរបស់ព្រះនាមព្រះយេហូវ៉ា ជា
ព្រះនៃខ្លួន នោះគេនឹងស្ថិតស្ថេរនៅ ដ្បិតអ្នកនោះនឹងបាន
ជាធំ[ឈ] រហូតដល់ចុងផែនដីបំផុត [៤]អ្នកនោះនឹងបានជាទី
ក្សេមក្សាន្តដល់យើង[ញ]

## ការរំដោះ និងការបំផ្លាញ

ដូច្នេះ កាលណាពួកអាសស៊ើរលុកលុយ[ដ]ចូលក្នុងស្រុក
យើង ឬបើកាលណាគេដាក់ជើងចូល មកក្នុងដំណាក់យើង
នោះយើងនឹងលើកពួកអ្នកគង្វាល៧នាក់ និងពួកជាប្រធាន
៨នាក់ឱ្យទាស់នឹងគេ[ឋ] [៥]ពួកនោះនឹងបំផ្លាញស្រុកអាសស៊ើរ
ដោយដាវ[ឌ] និងស្រុកនីមរ៉ូឌ[ឍ] ត្រង់ទ្វារស្រុកគេផង អ្នកនោះ
នឹងដោះឱ្យយើងរួចពីពួកសាសន៍អាសស៊ើរ ក្នុងកាលដែល
គេទន្រ្ទានចូលក្នុងស្រុកយើង ឬបើកាលណាគេដាក់ជើង
មកក្នុងព្រំស្រុករបស់យើងដែរ[ណ] [៦]គ្រានោះ សំណល់[ត]នៃ
ពួកយ៉ាកុប នឹងនៅកណ្ដាលសាសន៍ជាច្រើន ទុកដូចជាទឹក
សន្សើម[ថ]មកពីព្រះយេហូវ៉ា ហើយដូចទឹកភ្លៀងរ៉ុយៗនៅ
លើស្មៅ[ទ] ដែលមិនរង់ចាំមនុស្សទេ ក៏មិនសង្ឃឹមដល់មនុស្ស
ជាតិដែរ [៧]ហើយសំណល់នៃពួកយ៉ាកុបនឹងនៅកណ្ដាល
ប្រទេសដទៃ គឺនៅក្នុងសាសន៍ផ្សេងៗជាច្រើន ដូចជាសិង្ហ
នៅកណ្ដាលពួកសត្វព្រៃ[ធ] គឺដូចជាសិង្ហស្ទាវ នៅកណ្ដាល
ហ្វូងចៀម ជាសត្វដែលកាលណាដើរកាត់កណ្ដាលហ្វូង
នោះក៏ជាន់ឈ្លីហើយហែកហួរ[ន] ឥតមានអ្នកណាសំរាប់
នឹងជួយឱ្យរួចឡើយ[ប] [៨]យ៉ាងនោះដៃឯងនឹងបានលើកឡើង[ផ]

**៥:៣** ជ អស ៤០:១១ ៤៩:៩ អគ ៣៤:១១–១៥,២៣ មីក ៧:១៤ ឈ អស ៥២:១៣ លក ១:៣២
**៥:៤** ញ អស ៩:៦ លក ២:១៤ កល ១:១៩–២០ ដ អស ៨:៧ ឋ អស ១០:២៤–២៧
**៥:៥** ឌ សផ ២:១៣ ឍ លប ១០:៨ ណ ណហ ២:១១–១៣
**៥:៦** ត អម ៥:១៥ មីក ២:១២ ថ ទដ ១៣៣:៣ ទ អស ៤៤:៤
**៥:៧** ធ លប ៤៩:៩ ន មីក ៤:១៣ សក ១០:៥ ប ទដ ៥០:២២ អស ៥:២៩ ហស ៥:១៤
**៥:៨** ផ ទដ ១០:១២
**៥:៩** ព នក ១៥:៤,១៩ ហស ១៤:៣ ហក ២:២២ សក ៩:១០
**៥:១០** ភ ចទ ២៩:២៣ អស ៦:១១

លើពួកដែលតតាំងនឹងឯង ហើយពួកខ្មាំងសត្រូវរបស់ឯង
នឹងត្រូវកាត់ចេញទៅ ។
[៩]ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា នៅថ្ងៃនោះអញនឹង
កាត់អស់ទាំងសេះរបស់ឯងពីពួកឯងចេញ ហើយនឹង
បំផ្លាញរទេះចំបាំងទាំងប៉ុន្មានរបស់ឯងដែរ[ព] [១០]អញនឹង
កាត់អស់ទាំងទីក្រុង[ភ]នៅស្រុកឯងចេញ ហើយនឹងរំលំគ្រប់
ទាំងទីមាំមួនរបស់ឯងបង់[ម] [១១]អញនឹងកំចាត់អស់ទាំង
របៀនអាបធ្មប់ពីដៃឯងចេញ នោះឯងនឹងគ្មានគ្រូនក្ខត្តឫក្ស
ទៀតទៅ[យ] [១២]អញនឹងបំផ្លាញរូបឆ្លាក់[រ] និងបង្គោល
គោរពចេញពីកណ្ដាលពួកឯង[ល] នោះឯងនឹងលែងថ្វាយ
បង្គំស្នាដៃរបស់ខ្លួនទៅ[វ] [១៣]អញនឹងរំលើងរូបព្រះរបស់
ឯង[ស] ចេញពីកណ្ដាលឯងបង់ ហើយនឹងបំផ្លាញទីក្រុងទាំង
ប៉ុន្មានរបស់ឯង [១៤]អញនឹងសំរេចការសងសឹក[ហ] នៅលើ
អស់ទាំងសាសន៍ដែលមិនព្រមស្ដាប់ ដោយសេចក្ដីកំហឹង
និងសេចក្ដីឃោរឃៅ ។

## រឿងក្ដីរបស់ព្រះអម្ចាស់ទាស់នឹងពួកអ៊ីស្រាអែល

**៦** [១]ចូរឱ្យអ្នករាល់គ្នាស្ដាប់សេចក្ដីដែលព្រះយេហូវ៉ាទ្រង់
មានបន្ទូលឥឡូវថា ចូរក្រោកឡើង អង្វរនៅមុខភ្នំធំទាំង
ឡាយចុះ[ក] ហើយបន្លឺឱ្យភ្នំតូចទាំងប៉ុន្មានឮសំឡេងឯងផង

ម បទ ២:២ ហស ១០:១៤ អម ៥:៩ **៥:១១** យ ចទ ១៨:១០–១២ អស ២:៦ ៨:១៩ **៥:១២** រ ណហ ១:១៤ ល ហស ១០:២ វ អស ២:១៨ អគ ៦:៩ សក ១៣:២ **៥:១៣** ស នក ៣៤:១៣ ពច ៣:៧ ២ពវ ១៧:១០ **៥:១៤** ហ អស ៦៥:១២ **៦:១** ក ទដ ៥០:១ អគ ៦:២

**៥:៣** ព្រះមែស៊ីទ្រង់នឹងធ្វើជាអ្នកគង្វាល និងគ្រប់គ្រងដោយ "ឥទ្ធិឫទ្ធិ" និង "ឫទ្ធានុភាព" នៃព្រះដ៏ជាព្រះវរបិតា ។

**៥:៤–៥** វគ្គនេះនិយាយអំពីបទទំនាយអំពីការរំដោះរាស្ត្រឱ្យរួច ដែលនឹងធ្វើឡើយដោយមហាក្សត្រដ៏ឥតខ្ចោះ (ខ.៥) ។

**៥:៤** *ទីក្សេមក្សាន្ត* ព្រះយេស៊ូវទ្រង់ជា "សេចក្ដីសុខសាន្តដល់យើង" (អភ ២:១៤) ។ ពាក្យក្សេមក្សាន្ត នៅក្នុងភាសាហេព្រើមានន័យថា គ្មានសង្គ្រាម ហើយតាមព្រះគម្ពីរសញ្ញាចាស់ក៏មានន័យថា សម្បូររុងរឿង ។ មើលការពន្យល់ អស ៩:៦, ("ម្ចាស់នៃមេត្រីភាព") លក ២:១៤ ។ *អាសស៊ើរ* ឈ្មោះនេះជានិមិត្តរូបនៃខ្មាំងសត្រូវរបស់រាស្ត្ររបស់ព្រះ នៅក្នុងគ្រប់សម័យកាលទាំងអស់ ។ មើល អស ១១:១១ សក ១០:១០ និងការពន្យល់ ។ *យើង* គឺយើងដែលជារាស្ត្ររបស់ព្រះ ។ *៧ . . . ៨* គឺជាពាក្យប្រៀបប្រដូចទៅនឹងចំនួន "ច្រើន" (មើលការពន្យល់ យប ៥:១៩) ។

**៥:៥** *ស្រុកនីមរ៉ូឌ* គឺស្រុកអាសស៊ើរ ។ មើល លប ១០:៨–១២ ។ *អ្នកនោះ* គឺអ្នកដឹកនាំក្នុង ខ.២ ។ *គេ* គឺ "ពួកសាសន៍អាសស៊ើរ" ។

**៥:៦–៨** វគ្គនេះគឺជាបទទំនាយអំពីការដោះឱ្យរួចចំពោះសំណល់នៃជាតិសាសន៍ទាំងឡាយ ។

**៥:៦–៧** *សំណល់* មើលការពន្យល់ ៤:៧ ។

**៥:៧** *សិង្ហ* ដូចការប្រៀបធៀបនៅក្នុង ខ.៧ ពាក្យនេះគឺជាការប្រៀបធៀបអំពីការរីកចម្រើននៃរាស្ត្ររបស់ព្រះនៅក្នុងការយកជ័យជំនះលើខ្មាំងសត្រូវរបស់ពួកគេ (ខ.៩) ។ នគរព្រះនឹងបានទទួលជោគជ័យ ។

**៥:៨** *របស់ឯង* គឺពួកសំណល់ (ខ.៧–៨) ។

**៥:៩–១៤** វគ្គនេះនិយាយអំពីបទទំនាយអំពីសេចក្ដីសង្គ្រោះ ("នៅថ្ងៃនោះ" ខ.១០) ដោយរំលាយអំណាចទ័ព និងការថ្វាយបង្គំរបស់ពួកសាសន៍ដទៃ ។ នៅក្នុងយុគសម័យនៃព្រះមែស៊ី រាស្ត្ររបស់ព្រះនឹងមិនពឹងផ្អែកលើអាវុធសម្រាប់ប្រើក្នុងសង្គ្រាម និងរូបព្រះរបស់សាសន៍ដទៃ ។ រាស្ត្ររបស់ទ្រង់តែងតែទទួលបានដោយការពឹងផ្អែកលើទ្រង់ (ធៀបនឹង អស ២:៦–៨) ។

**៥:៩** *នៅថ្ងៃនោះ* មើលការពន្យល់ ៤:៦ ។

**៥:១៣** *រូបព្រះ* មើល នក ៣៤:១៣ និងការពន្យល់ ។

**៦:១–៧:២០** គឺជាដំណាក់កាលទីបីនៃការជំនុំជម្រះ (៦:១–៧:៧) និងសេចក្ដីសង្គ្រោះ ឬការស្អាងឡើងវិញ (៧:៨–២០ មើលសេចក្ដីផ្ដើមត្រង់ គម្រោងសង្ខេប) ។

**៦:១–១៦** ក្នុងមួយជំពូកនេះ គឺជាការពិពណ៌នាអំពីទិដ្ឋភាពនៃទីជំនុំជម្រះ ដែលនៅក្នុងនោះ ព្រះទ្រង់ដាក់ពាក្យបណ្ដឹងទាស់នឹងសាសន៍អ៊ីស្រាអែល ។

**៦:១–៨** ក្នុងវគ្គនេះនិយាយអំពីពាក្យបណ្ដឹងមកពីស្ថានសួគ៌ ។ នៅក្នុង ខ.១

២ម្នាលភ្នំទាំងឡាយ និងឯងរាល់គ្នា ជាឫសនៃផែនដីដ៏ស្ថិត
ស្ថេរអើយ ចូរស្តាប់[ខ]រឿងក្តីរបស់ព្រះយេហូវ៉ាចុះ[គ] ដ្បិត
ព្រះយេហូវ៉ាបានកើតក្តី[ឃ]នឹងរាស្ត្រទ្រង់ គឺទ្រង់នឹងតវ៉ា[ង]នឹង
ពួកអ៊ីស្រាអែល ៣ឱរាស្ត្រអញអើយ តើអញបានធ្វើអ្វីដល់
ឯង តើអញបានធ្វើឱ្យឯងធុញទ្រាន់[ច]ដោយសារអ្វី[ឆ] ចូរធ្វើ
បន្ទាល់ទាស់នឹងអញចុះ ៤ដ្បិតអញបាននាំឯងឡើងចេញ
ពីស្រុកអេស៊ីព្ទមក[ជ] កំលោះឯងចេញពីផ្ទះរបស់ពួកបាវ
បំរើ[ឈ] ហើយបានចាត់ម៉ូសេ[ញ] អើរ៉ុន[ដ] និងម៉ារាមឱ្យនាំមុខ
ឯង[ឋ] ៥ឱ រាស្ត្រអញអើយ ឥឡូវនេះ ចូរនឹកចាំពីកិច្ចឧបាយ
ដែលបាឡាក[ឌ] ស្តេចម៉ូអាប បានបង្កើត ហើយពីសេចក្តី
ដែលបាឡាម ជាកូនបេអ៊របានឆ្លើយតបជាយ៉ាងណា
ហើយនឹកពីដំណើរដែលឯងដើរ ចាប់តាំងពីស៊ីទីម[ឍ] រហូត
ដល់គីលកាល[ណ] ដើម្បីឱ្យឯងបានស្គាល់អស់ទាំងកិច្ចការ
សុចរិត[ត] របស់ព្រះយេហូវ៉ាចុះ ។
៦តើត្រូវឱ្យខ្ញុំយកអ្វី ដើម្បីចូលទៅចំពោះ[ថ]ព្រះយេហូវ៉ា
ហើយក្រាបថ្វាយបង្គំនៅមុខព្រះដ៏ខ្ពស់ តើត្រូវឱ្យខ្ញុំយក
ដង្វាយដុត ជាកូនគោអាយុ១ខួប ដើម្បីចូលទៅចំពោះ
ទ្រង់ឬ[ទ] ៧តើព្រះយេហូវ៉ាទ្រង់នឹងសព្វព្រះហឫទ័យ ដោយ
ចៀមទាំងពាន់[ធ] ឬដោយប្រេងទាំងម៉ឺនទន្លេឬអី[ន] តើត្រូវឱ្យ
ខ្ញុំថ្វាយកូនច្បង[ប]ខ្ញុំ ឱ្យបានធួននឹងអំពើរំលងដែលខ្ញុំប្រព្រឹត្ត
គឺជាផលនៃរូបកាយខ្ញុំ ឱ្យបានធួននឹងបាបនៃព្រលឹងខ្ញុំឬ[ផ]
៨ឱមនុស្សអើយ ព្រះបានបង្ហាញឱ្យឯងស្គាល់សេចក្តីដែល
ល្អ តើព្រះយេហូវ៉ាសព្វព្រះហឫទ័យឱ្យឯងប្រព្រឹត្តដូចម្តេច
បើមិនមែនឱ្យប្រព្រឹត្តដោយសុចរិត[ព] ឱ្យស្រឡាញ់សេចក្តី
សប្បុរស ហើយឱ្យដើរជាមួយនឹងព្រះនៃខ្លួន ដោយសុភាព
រាបទាប[ភ]ប៉ុណ្ណោះ[ម]។

## ទោសរបស់អ៊ីស្រាអែល

៩ព្រះសូរសៀងនៃព្រះយេហូវ៉ាបន្លឺដល់ទីក្រុង ហើយ
មនុស្សណាដែលមានប្រាជ្ញា នឹងឃើញព្រះនាមទ្រង់ ចូរ
ស្តាប់តាមដំបង[យ]នឹងតាមព្រះអង្គ ដែលបានដំរូវឱ្យមកឱ្យផង

**៦:២** ខ ចទ ៣២:១
គ ហស ១២:២
ឃ អស ៣:១៣
ង ទដ ៥០:៧
យរ ២:៩
**៦:៣** ច យរ ២:៥
ឆ យរ ២:៥
**៦:៤** ជ នក ៣:១០
៦:៦ ឈ ចទ ៧:៨
ញ នក ៤:១៦
ដ ជន ៣៣:១
ទដ ៧៧:២០
ឋ នក ១៥:២០
**៦:៥** ឌ ជន ២២:២
ឍ ជន ២៥:១
ណ ចទ ១១:៣០
យស ៥:៩–១០
ត ពច ៥:១១
១សយ ១២:៧
**៦:៦** ថ ទដ ៩៥:២
ទ ទដ ៤០:៦–៨
៥១:១៦–១៧

**៦:៧** ធ អស ១:១១ ៤០:១៦ ន ទដ ៥០:៨–១០ ប លវ ១៨:២១ ២ពវ ៣:២៧ ផ ហស ៥:៦ អម ៥:២២ **៦:៨** ព អស ១:១៧ យរ ២២:៣ ភ ២ពវ ២២:១៩ អស ៥៧:១៥ ម លប ៥:២២ ចទ ១០:១២–១៣ ១សយ ១៥:២២ ហស ៦:៦ សក ៧:៩–១០ មថ ៩:១៣ ២៣:២៣មក ១២:៣៣ លក ១១:៤២ **៦:៩** យ លប ១៧:១ អស ១១:៤

ព្រះអម្ចាស់ទ្រង់បង្គាប់ឱ្យរាស្ត្ររបស់ទ្រង់ធ្វើពាក្យបណ្តឹងរបស់ពួកគេ ។ នៅក្នុង ខ.២ ព្រះទ្រង់បានត្រាស់ហៅឱ្យភ្នំទាំងឡាយធ្វើជាទីបន្ទាល់ ដែលស្តាប់ពាក្យចោទប្រកាន់របស់ទ្រង់ ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅកាន់រាស្ត្ររបស់ទ្រង់ម្តងទៀតនៅក្នុង ខ.៣–៥ ដើម្បីរំឭកពួកគេអំពីការដែលទ្រង់បានធ្វើសម្រាប់ពួកគេដោយព្រះគុណរបស់ទ្រង់ ។ នៅក្នុង ខ.៦–៧ ពួកសាសន៍អ៊ីស្រាអែលបាននិយាយ ហើយក្នុង ខ.៨ លោកមីកាបានឆ្លើយតបដោយផ្ទាល់ទៅកាន់ពួកគេ ដោយចម្លើយចំពោះសំណួរក្នុង ខ.៦–៧ ។

**៦:១–២** *ភ្នំ . . . ឫសនៃផែនដី* ព្រះអម្ចាស់បានរាប់វត្ថុដែលគ្មានជីវិត ជាស្មរបន្ទាល់ ដោយសារដែលពួកវាមានធម្មជាតិនៃការអត់ធ្មត់ ហើយជាស្មរ-បន្ទាល់ នៃសេចក្តីសញ្ញារបស់ទ្រង់ (មើល ចទ ៣២:១ យស ២៤:២៧ អស ១:២ និងការពន្យល់) ។

**៦:១** *ស្តាប់* មើលការពន្យល់ ១:២ និង ៣:១ ផងដែរ ។

**៦:២** *ពួកអ៊ីស្រាអែល* ត្រង់ចំណុចនេះគឺសំដៅទៅលើពួកយូដា (មើលការពន្យល់ ១:៥) ។

**៦:៣,៥** *រាស្ត្រអញ* ពាក្យនេះគឺជាភាសាប្រើនៅក្នុងសេចក្តីសញ្ញា (មើលការពន្យល់ ខ.៨) ។

**៦:៤** *នាំឯងឡើងចេញពីស្រុកអេស៊ីព្ទ* មើល នក ២០:២ និងការពន្យល់ ។ *ម៉ូសេ . . . អើរ៉ុន និងម៉ារាម* មើលការពន្យល់ ជន ១២:១–២ និងការពន្យល់ ១២:២ ។

**៦:៥** *បាឡាក . . . បាឡាម* មើល ជន ២២–២៤ និងការពន្យល់ ២២:៨ ។ *ស៊ីទីម . . . គីលកាល* មើល ជន ២៥:១ យស ២:១ ៣:១–៤:២៥ ៤:១៩ និងការពន្យល់ ។ *កិច្ចការសុចរិតរបស់ព្រះយេហូវ៉ា* មើល ១សយ ១២:៧ និងការពន្យល់ ។

**៦:៦** ខនេះមានន័យដូចនៅក្នុង ១សយ ១៥:២២ ទដ ៥១:១៧ អស ១:១១–១៥ ហស ៦:៦ (មើលការពន្យល់ខទាំងនេះ) ។ លោកមីកាមិនបានបដិសេធអំពីបញ្ហាត្រឹមត្រូវនៃការថ្វាយដង្វាយនោះទេ ប៉ុន្តែ លោកចង់បង្ហាញថាការថ្វាយដង្វាយដោយគ្មានការស្តាប់បង្គាប់ គឺគ្មានប្រយោជន៍អ្វីទេ ។

**៦:៨** ខនេះគឺជាពាក្យដែលគួរឱ្យចងចាំបំផុតនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលបង្ហាញអំពីអត្ថន័យនៃទំនាក់ទំនងដ៏ត្រឹមត្រូវដែលមនុស្សត្រូវមានជាមួយនឹងព្រះ (មើល យរ ២២:១៦ ហស ៦:៦ និងការពន្យល់ ធៀបនឹង យក ១:២៧) នៅក្នុងខនេះ លោកមីកាបានសង្ខេបខ្លឹមសារសំខាន់ដែលមាននៅក្នុងបទទំនាយនៃពួកហោរាដែលរស់នៅជៀកនឹងសម័យរបស់លោកដូចជាលោកអេម៉ូស ("ប្រព្រឹត្តដោយសុចរិត" ធៀបនឹង អម ៥:២៤) លោកហូសេ ("ការពេញចិត្តចំពោះសេចក្តីសប្បុរស" ធៀបនឹង ហស ៦:៦) និង អេសាយ ("ដើរជាមួយព្រះអម្ចាស់ដោយបន្ទាបខ្លួន" ធៀបនឹង អស ២៩:១៩)។ ធៀបនឹង មថ ២៣:២៣ ។ *មនុស្ស* គឺសំដៅទៅលើមនុស្សផ្ទាល់ខ្លួនម្នាក់ៗ (មើល ចទ ១០:១២–១៣)។ *ប្រព្រឹត្តដោយសុចរិត . . . ស្រឡាញ់សេចក្តីសប្បុរស* គឺជាប្រភេទនៃការស្តាប់បង្គាប់ ដែលព្រះអម្ចាស់ទ្រង់សព្វព្រះទ័យឱ្យរាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់មាន ។ *ដោយសុភាពរាបទាប* ឬ "ដោយប្រុងប្រយ័ត្ន" ឬក៏ "ដោយប្រាជ្ញា" ។ *ព្រះនៃខ្លួន* ពាក្យនេះប្រើនៅក្នុងសេចក្តីសញ្ញា ឱ្យត្រូវនឹងពាក្យ "រាស្ត្រអញ" នៅក្នុង ខ.៣,៥ ។

**៦:៩–១៦** វគ្គនេះគឺជាពាក្យបណ្តឹង ដែលមានការចោទប្រកាន់ និងជំនុំជម្រះជាបន្ថែមទៀត(ជីវិតដែលគ្មានផលផ្លែ បរាជ័យ គួរឱ្យស្អប់ខ្ពើម និងវិនាស ខ.១៣–១៥)។ វគ្គនេះអាចចែកចេញដូចជា (១).ការចាប់ផ្តើមនៃការថ្លែងសេចក្តី(ខ.៩) (២).បញ្ជីអំពើបាបដែលកើតមាននៅក្នុងជំនួញ និងសង្គម (ខ.១០–១២) (៣).សេចក្តីប្រកាសអំពីការជំនុំជម្រះរបស់ព្រះ (ខ.១៣–១៥) (៤).ការថ្លែងសេចក្តីជាសង្ខេប (ខ.១៦) ។

**៦:៩** *ទីក្រុង* គឺយេរូសាឡិម ។

១០តើនៅតែមានទ្រព្យសម្បត្តិ ជាផលនៃការអាក្រក់នៅក្នុង
ផ្ទះមនុស្សអាក្រក់ នឹងរង្វាល់ឆកោង ដែលជាទីគួរស្អប់
ខ្ពើមឬអី[រ] ១១តើត្រូវឱ្យអញប្រព្រឹត្តដោយបរិសុទ្ធ ចំពោះ
ជញ្ជីងដែលអាក្រក់[ល] និងថង់ពេញដោយកូនជញ្ជីងឆកោង
ឬ[វ] ១២ដ្បិតមនុស្សអ្នកមាននៅក្នុងទីក្រុង គេពេញដោយអំពើ
ច្រឡោត[ស] ហើយពួកអ្នកអាស្រ័យនៅក្នុងក្រុង គេពោល
កុហកទទេ[ហ] អណ្តាតនៅក្នុងមាត់គេក៏ជាគ្រឿងឆបោក
ដែរ[ឡ] ១៣ហេតុនោះអញបានវាយឯងឱ្យរបួសយ៉ាងធ្ងន់
ហើយបានធ្វើឱ្យឯងខូចបង់[អ] ព្រោះអំពើបាបរបស់ឯង
១៤ឯងនឹងស៊ីតែមិនបានឆ្អែតទេ[ក] សេចក្តីស្រេកឃ្លាននឹងនៅ
កណ្តាលឯង ឯងនឹងសន្សំទុក តែមិនគង់នៅទេ[ខ] ឯរបស់អ្វី
ដែលឯងទុកបាន នោះអញនឹងប្រគល់ដល់ដាវវិញ ១៥ឯង
នឹងសាបព្រោះទៅ តែមិនបានច្រូតកាត់ឡើយ[គ] ឯងនឹងជាន់
ផ្លែអូលីវ តែមិនបានប្រេងសំរាប់លាបខ្លួនទេ ក៏នឹងបេះ
ផ្លែទំពាំងបាយជូរដែរ តែមិនបានផឹកស្រាទំពាំងបាយជូរ
សោះ[ឃ] ១៦ពីព្រោះមនុស្សទាំងឡាយកាន់តាមតែបញ្ញត្តិ
ច្បាប់របស់ស្តេចអំរី[ង] ព្រមទាំងតាមអស់ទាំងអំពើរបស់ពួក
វង្សស្តេចអ័ហាប់[ច]ផង ឯងរាល់គ្នាតែងដើរតាមសេចក្តី
ប្រឹក្សារបស់គេដែរ[ឆ] ឱ្យអញបានធ្វើឱ្យឯងត្រូវខូចបង់[ជ]
ហើយឱ្យពួកអ្នកដែលអាស្រ័យនៅក្នុងឯង ត្រឡប់ជាទីដែល
គេធ្វើសឹសស៊ូសឱ្យ ឯងនឹងត្រូវរងទ្រាំសេចក្តីត្មះតិះដៀល[ឈ]
នៃរាស្ត្រអញ ។

## សេចក្តីវេទនានៃអ៊ីស្រាអែល

**៧** ១វរហើយខ្ញុំ ដ្បិតខ្ញុំដូចជានៅវេលាដែលបេះផ្លែរដូវ
ក្តៅរួចហើយ គឺដូចជាបានប្រឡេះផ្លែទំពាំងបាយជូរជាន់
ក្រោយអស់ហើយ គ្មានចង្កោមណាសល់ឱ្យបានស៊ីទេ ចិត្តខ្ញុំ
ប្រាថ្នាចង់បានផ្លែល្វា[ក] ដែលទុំដើមរដូវ ២មនុស្សដែល
គោរពតាមព្រះ បានសូន្យបាត់ពីផែនដីទៅ[ខ] គ្មានអ្នកណា[គ]
ដែលទៀងត្រង់ នៅក្នុងពួកមនុស្សលោកទេ គេសុទ្ធតែលប
ចាំ[ឃ]កំចាយឈាម[ង] គ្រប់គ្នាប្រដេញបងប្អូន[ច]ខ្លួនដោយមង[ឆ]
៣ដៃគេចាប់កាន់អំពើអាក្រក់[ជ]ប្រុងនឹងធ្វើដោយខ្មីឃ្មាត
ឯចៅហ្វាយ គេក៏សូម ហើយចៅក្រមក៏ប្រុងនឹងស៊ីសំណូក
ដែរ[ឈ] ឯអ្នកធំ គេពោលពីសេចក្តីប៉ងប្រាថ្នាអាក្រក់ ដែល
នៅក្នុងចិត្តខ្លួន គឺយ៉ាងនោះឯងដែលគេប្រមុំការអាក្រក់
របស់គេ ៤មនុស្សល្អបំផុតនៅក្នុងពួកគេ ក៏ប្រៀបដូចជា
បន្លា[ញ] ហើយអ្នកដែលរាប់ជាទៀងត្រង់ ក៏អាក្រក់ជាងរបង
ធ្វើពីបន្លា[ដ]ទៅទៀត ថ្ងៃនៃពួកចាំយាមរបស់ឯង គឺជាថ្ងៃធ្វើ
ទោសដល់ឯង បានមកដល់ហើយ គ្រានោះ និងបានជា
គ្រាអាំងឡាំងដល់ឯង[ឋ] ៥កុំឱ្យទុកចិត្តអ្នកជិតខាង ក៏កុំឱ្យជឿ
មិត្រសំឡាញ់ផង[ឌ] សូម្បីតែនាងដែលឯងឱបនៅនាទ្រូង
ក៏ចូររក្សាបបូរមាត់ចំពោះនាងដែរ ៦ដ្បិតកូនប្រុសបង្អាប់
ឪពុក ហើយកូនស្រីក៏ចចើងទាស់នឹងម្តាយ[ឍ] ឯកូនប្រសា
ស្រីទាស់ទទឹងនឹងម្តាយក្មេក ហើយខ្មាំងសត្រូវរបស់អ្នកណា
នោះគឺជាពួកអ្នកនៅផ្ទះរបស់អ្នកនោះឯង[ណ] ។
៧ឯចំណែកខ្លួនខ្ញុំៗនឹងទុកចិត្ត[ត]ដល់ព្រះយេហូវ៉ា ខ្ញុំនឹង
រង់ចាំ[ថ]ព្រះដ៏ជួយសង្គ្រោះខ្ញុំ ព្រះនៃខ្ញុំទ្រង់នឹងស្តាប់[ទ]ខ្ញុំ ។

## អ៊ីស្រាអែលនឹងក្រោកឡើងវិញ

៨ឱ ខ្មាំងសត្រូវអើយ កុំឱ្យសប្បាយចិត្តពីដំណើរខ្ញុំឡើយ[ធ]

**៦:១០** រ អគ ៤៥:៩–១០ អម ៣:១០ ៨:៤–៦ **៦:១១** ល លវ ១៩:៣៦ វ ចទ ២៥:១៣ **៦:១២** ស អស ១:២៣ ហ ទដ ១១៦:១១ អស ៣:៨ ឡ ទដ ៣៥:២០ យរ ៩:៣ **៦:១៣** អ អស ១:៧ ៦:១១ **៦:១៤** ក អស ៩:២០ ហស ៤:១០ ខ អស ៣០:៦ **៦:១៥** គ ចទ ២៨:៣៨ យរ ១២:១៣ ឃ យប ២៤:១១ អម ៥:១១ សផ ១:១៣ **៦:១៦** ង ១ពវ ១៦:២៥ ច ១ពវ ១៦:២៩–៣៣ ឆ យរ ៧:២៤ ជ យរ ២៥:៩ ឈ ចទ ២៨:៣៧ យរ ៥១:៥១ មីក ២:៦

**៧:១** ក បស ២:១៣ **៧:២** ខ ទដ ១២:១ គ យរ ២:២៩ ៨:៦ ឃ ទដ ១០:៨ ង សក ៦:១៧ មីក ៣:១០ ច អស ៣:៥ ឆ យរ ៥:២៦ **៧:៣** ជ សផ ៤:១៦ ឈ នក ២៣:៨ អគ ២២:១២ **៧:៤** ញ ជន ៣៣:៥៥ អគ ២:៦ ដ ២សយ ២៣:៦ ឋ យប ៣១:១៤ អស ២២:៥ ហស ៩:៧ **៧:៥** ឌ យរ ៩:៤ **៧:៦** ឍ អគ ២២:៧ ណ មថ ១០:៣៥–៣៦ មក ១៣:១២ **៧:៧** ត ទដ ១៣០:៥ អស ២៥:៩ ថ អស២១:៨ ទ ទដ ៤:៣ **៧:៨** ធ ទដ ២២:១៧ សភ ២៤:១៧ មីក ៤:១១

**៦:១០** *រង្វាល់ឆកោង* ប្រហែលកន្លះតៅ ។

**៦:១១** មើល លវ ១៩:៣៥ សភ ១១:១ និងការពន្យល់ ហស ១២:៧ អម ៨:៥

**៦:១២** *ក្នុងទីក្រុង* គឺក្នុងទីក្រុងយេរូសាឡិម ។

**៦:១៣** *ហេតុនោះ* មើលការពន្យល់ ២:៣ ។

**៦:១៤–១៥** មើល ហក ១:៦ និងការពន្យល់ ។

**៦:១៦** *ស្តេចអំរី . . . ស្តេចអ័ហាប់* បទគម្ពីរ ១ពវ ១៦:២៥,៣០ បាននិយាយថា ស្តេចពីអង្គនេះបានធ្វើអាក្រក់ជាងស្តេចដែលសោយរាជ្យមុនៗទៅទៀត *ត្រូវខូចបង់* ការមិនស្តាប់បង្គាប់នាំមកនូវសេចក្តីហិនវិនាស ។

**៧:១–២០** អ្នកដែលនិយាយនៅក្នុងជំពូកនេះគឺ លោកមីកា (ខ.១–៧) ក្រុងស៊ីយ៉ូន (ខ.៨–១០) លោកមីកា (ខ.១១–១៣) លោកមីកា ឬក្រុងស៊ីយ៉ូន (ខ.១៤) ព្រះ (ខ.១៥) លោកមីការ (ខ.១៦–២០) ។ ជំពូកនេះបានចាប់ផ្តើមដោយពាក្យទុក្ខសោក ប៉ុន្តែបញ្ចប់ទៅវិញដោយពាក្យនៃសេចក្តីសង្ឃឹម ។

**៧:១–៧** វគ្គនេះគឺជាការថ្លែងដោយទុក្ខសោករបស់លោកមីកាចំពោះសង្គមមួយដែលអាប់ឱន ។

**៧:១–២** វគ្គនេះគឺមានន័យថា ការដែលស្វែងរកអ្នកកោតខ្លាចព្រះ គឺមិនខុសអ្វីពីស្វែងរកផ្លែឈើទុំនៅរដូវក្តៅ នៅពេលដែលចម្រូតបានបញ្ចប់ហើយ (មើល យរ ៥:១ ៨:២០ និងការពន្យល់ផងដែរ) ។

**៧:៣** អំណាចជាញឹកញាប់មានភាពពុករលួយ ។ *ស៊ីសំណូក* មើល ១សយ ៨:៣ និងការពន្យល់, ១២:៣ ។

**៧:៤** *ថ្ងៃនៃពួកចាំយាម* គឺជាថ្ងៃជំនុំជម្រះដែលពួកហោរាបានព្រមាន (មើល អគ ៣:១៧–២១ និងការពន្យល់ ៣:១៧) ។ *បានមកដល់ហើយ* គឺមកដើម្បីជំនុំជម្រះ ។

**៧:៦** ក្រុមគ្រួសារត្រូវបែកបាក់ (ធៀបនឹង មថ ១០:២១,៣៤–៣៦) ។

**៧:៧** លោកមីកាបានបន្តពាក្យតម្អូញរបស់ខ្លួន (ខ.១–៦) ដោយប្រើពាក្យដែលបង្ហាញពីភាពជឿជាក់ ។ ការនិយាយអំពីក្តីសង្ឃឹមដូចនេះគឺជាការធម្មតានៅក្នុងការថ្លែងពីទុក្ខសោកក្នុងព្រះគម្ពីរ (មើល ទដ ៥៥:១៦–១៧) ។

កាលណាខ្ញុំដួល នោះខ្ញុំនឹងក្រោកឡើងវិញ[ន] កាលណាខ្ញុំ
អង្គុយក្នុងទីងងឹត នោះព្រះយេហូវ៉ានឹងជាពន្លឺដល់ខ្ញុំ[ប] ៩ខ្ញុំ
នឹងរងទ្រាំចំពោះសេចក្ដីគ្នាន់ក្នាញ់របស់ព្រះយេហូវ៉ា[ផ] ពី
ព្រោះខ្ញុំបានធ្វើបាបនឹងទ្រង់ហើយ[ព] គឺនឹងរងទ្រាំដរាបដល់
ទ្រង់កាន់ក្ដីជំនួសខ្ញុំ ហើយបានសំរេចសេចក្ដីយុត្តិធម៌ដល់ខ្ញុំ
នោះទ្រង់នឹងនាំខ្ញុំចេញមកឯពន្លឺ[ភ] រួចខ្ញុំនឹងរំពឹងមើល
សេចក្ដីសុចរិតរបស់ទ្រង់[ម] ១០គ្រានោះ ខ្មាំងសត្រូវរបស់ខ្ញុំ
នឹងឃើញដែរ ហើយនឹងមានសេចក្ដីខ្មាសគ្របលើនាង[យ]
ដែលនិយាយមកខ្ញុំថា តើព្រះយេហូវ៉ា ជាព្រះនៃឯងនៅ
ឯណា[រ] ឯភ្នែកខ្ញុំនឹងឃើញបំណងចិត្តកើតដល់នាង[ល] នាង
នឹងត្រូវជាន់ឈ្លី[វ]ឥឡូវ ដូចជាភក់នៅក្នុងផ្លូវ ១១នៅថ្ងៃដែល
កំផែង[ស] ឯងនឹងបានសង់ឡើង ថ្ងៃនោះច្បាប់បង្គាប់នឹង
ឃ្លាតឆ្ងាយពីឯងទៅ ១២នៅគ្រានោះ នឹងមានគេមកឯឯង
ពីស្រុកអាសស៊ើរ[ហ] និងពីគ្រប់ទាំងទីក្រុងនៅស្រុកអេស៊ីព្ទ
ហើយចាប់តាំងពីស្រុកអេស៊ីព្ទ រហូតដល់ទន្លេធំ និងពី
សមុទ្រម្ខាង ទៅដល់សមុទ្រម្ខាង ហើយពីភ្នំ១ទៅដល់ភ្នំ១
ទៀត[ឡ] ១៣ទោះបើយ៉ាងនោះក៏ដោយ គង់តែស្រុកនេះនឹង
ត្រូវនៅស្ងាត់ច្រៀម ដោយព្រោះផលនៃកិរិយារបស់ពួក
អ្នកដែលអាស្រ័យនៅ[អ] ។

## ការអធិស្ឋាន និងសរសើរតម្កើង

១៤"សូមទ្រង់ឃ្វាល[ក]រាស្ត្រទ្រង់ ដោយដំបងរបស់ទ្រង់[ខ] គឺ
ហ្វូងចៀមដ៏ជាមរដករបស់ទ្រង់ ដែលនៅត្រមោចក្នុងព្រៃ
កណ្ដាលស្រុកកើមែល[គ] សូមឱ្យគេរកស៊ីនៅស្រុកបាសាន[ឃ]
និងនៅស្រុកកាឡាត[ង] ដូចកាលពីដើមចុះ[ច] ១៥អញនឹងឱ្យ
គេឃើញការអស្ចារ្យ ដូចនៅគ្រាដែលឯងបានចេញពីស្រុក
អេស៊ីព្ទមក[ឆ] ១៦អស់ទាំងសាសន៍នឹងឃើញ ហើយនឹង
ឡើងមុខស្លាំង[ជ] ដោយព្រោះឥទ្ធិឫទ្ធិរបស់គេ ពួកទាំងនោះ
នឹងដាក់ដៃខ្ទប់មាត់[ឈ] ហើយត្រចៀកគេនឹងត្រូវថ្លង់ទៅដែរ
១៧គេនឹងលិទ្ធធូលីដី[ញ]ដូចជាពស់ គេនឹងញាប់ញ័រ[ដ]ចេញពីទី
មាំមួនរបស់គេ គឺដូចជាសត្វលូនវារនៅផែនដីចេញពីរន្ធ
គេនឹងមកឯព្រះយេហូវ៉ា ជាព្រះនៃយើង ដោយកោតខ្លាច[ឋ]
ហើយនឹងភិតភ័យដោយព្រោះឯង ។

១៨តើមានអ្នកណាជាព្រះ[ឌ]ឱ្យដូចទ្រង់ ដែលទ្រង់អត់
ទោសចំពោះអំពើទុច្ចរិត[ឍ] ហើយក៏បំភ្លេច[ណ]អំពើរំលង
របស់សំណល់[ត]នៃមរដកទ្រង់[ថ] ទ្រង់មិនផ្ដិសេចក្ដីខ្ញាល់[ទ]
ទុកជានិច្ចទេ ពីព្រោះទ្រង់សព្វព្រះហឫទ័យនឹងសេចក្ដី
សប្បុរសវិញ[ធ] ១៩ទ្រង់នឹងមានសេចក្ដីអាណិតអាសូរ ដល់
យើងរាល់គ្នាទៀត ទ្រង់នឹងកំរាបសេចក្ដីទុច្ចរិតរបស់យើង
នៅក្រោមព្រះបាទ ហើយនឹងបោះអស់ទាំងអំពើបាប[ន]

**៧:៨** ន ទដ ២០:៨ ៣៧:២៤ អម ៩:១១ ប ២សយ ២២:២៩ អស ៩:២ **៧:៩** ផ បទ ៣:៣៩–៤០ ព ទដ ១១៩:១៥៤ ភ ទដ ១០៧:១០ ម អស ៤៦:១៣ **៧:១០** យ ទដ ៣៥:២៦ រ ទដ ៤២:៣ ល អស ៥១:២៣ វ ២សយ ២២:៤៣ យប ៤០:១២ អស ៥:៥ សក ១០:៥ **៧:១១** ស អស ៥៤:១១ អម ៩:១១ **៧:១២** ហ អស ១១:១១ ឡ អស ១៩:២៣–២៥ ៦០:៤ **៧:១៣** អ អស ៣:១០–១១ អគ ១២:១៩ ៣៣:២៨–២៩ **៧:១៤** ក ទដ ២៨:៩ មីក ៥:៤ ខ ទដ ២៣:៤ ង បស ៤:១ គ ទដ ៩៥:៧

ឃ អស ៣៣:៩ យរ ៥០:១៩ ច អគ ៣៦:១១ **៧:១៥** ឆ នក ៣:២០ ទដ ៧៨:១២ **៧:១៦** ជ អស ២៦:១១ ឈ ពច ១៨:១៩ **៧:១៧** ញ លប ៣:១៤ ដ ២សយ ២២:៤៦ ឋ អស ២៥:៣ ៥៩:១៩ **៧:១៨** ឌ នក ៨:១០ ១សយ ២:២ ឍ អស ៤៣:២៥ យរ ៥០:២០ សក ៣:៤ ណ ២របា ៦:២១ ទដ ១០៣:៨–១៣ ត យអ ២:៣២ អម ៥:១៥ មីក ២:១២ ថ នក ៣៤:៩ ទ ទដ ១០៣:៩ អស ៥៤:៩ ធ ២របា ៣០:៩ យរ ៣១:២០ ៣២:៤១ អគ ១៨:២៣ **៧:១៩** ន អស ៤៣:២៥

**៧:៨–២០** វគ្គនេះជាវគ្គបញ្ចប់នៃការនិយាយអំពីសេចក្ដីសង្គ្រោះលើកចុងក្រោយ ដែលមានបន្ទាប់ពីការជំនុំជម្រះទាំងបីលើក ។ វគ្គនេះគឺជាសេចក្ដីទំនាយដែលចែកជាបួនផ្នែក (១).ការបង្ហាញពីជំនឿ(ខ.៨–១០) (២).ការសន្យាអំពីការស្អាងឡើងវិញ(ខ.១១–១៣) (៣).ការអធិស្ឋាន និងការឆ្លើយតបរបស់ព្រះអម្ចាស់(ខ.១៤–១៧) (៤).បទទំនុកតម្កើង(ខ.១៨–២០)។

**៧:៨** *ខ្ញុំ* គឺក្រុងស៊ីយ៉ូន ។ *ខ្មាំងសត្រូវ* គឺសាសន៍ដទៃ(មើល ខ.១០)។ *កាលណាខ្ញុំដួល* លោកមីកាបានមើលដឹងជាមុនអំពីការបំផ្លាញក្រុងយេរូសាឡិមនៅឆ្នាំ ៥៨៦ មុនគ.ស.។

**៧:១២** *នៅគ្រានោះ* មើល អស ២:១១,១៧,២០ ១០:២០,២៧ យអ ១:១៥ និងការពន្យល់ ។ *គេមកឯឯង* មើល ៤:២ ។

**៧:១៤–១៧** ខទាំងនេះអាចជាសេចក្ដីអធិស្ឋានទូលសូមឱ្យព្រះទ្រង់ធ្វើការអស្ចារ្យរបស់ទ្រង់ម្ដងទៀត ដូចកាលដែលទ្រង់រំដោះរាស្ត្រអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ ដើម្បីឱ្យសាសន៍ដទៃបានឃើញ ហើយមានសេចក្ដីខ្មាស ហើយដើម្បីឱ្យពួកគេបានវិលបែរមកទ្រង់វិញដោយការកោតខ្លាច ។

**៧:១៤** *ឃ្វាល* មានន័យថា ដឹកនាំ(មើល ៥:៤ ទដ ២៣:១ យរ ២:៨ អគ ៣៤:២ និងការពន្យល់) ។ *មរដក* គឺដីកដី និងរាស្ត្រអ៊ីស្រាអែល (មើល ខ.១៨ ទដ ៩៤:១៤ មើល ទដ ១២៧:៣ យរ ២:៧ និងការពន្យល់ផងដែរ)។ *ស្រុកបាសាន និងនៅស្រុកកាឡាត* គឺជាតំបន់ដែលមានដីជាតិ និងសម្បូរ ទៅដោយវាលស្មៅ(មើល លប ៣១:២១ ទដ ២២:១២ អគ ៣៩:១៨ អម ៤:១ និងការពន្យល់)។

**៧:១៦** នៅពេលដែលសាសន៍ទាំងឡាយបានឃើញការអស្ចារ្យនៃអំណាចព្រះចេស្ដានៃព្រះ(ខ.១៥) ពួកគេនឹងមានការភ្ញាក់ផ្អើល ។

**៧:១៧** *លិទ្ធធូលីដីដូចជាពស់* ត្រង់ចំណុចនេះគឺបង្ហាញពីរូបភាពនៃការទទួលបរាជ័យ និងសេចក្ដីស្លាប់(មើល លប ៣:១៤ និងការពន្យល់) ។

**៧:១៨–២០** វគ្គនេះគឺជាសេចក្ដីសន្និដ្ឋាននៃព្រះគម្ពីរនេះទាំងមូល គឺមិនគ្រាន់តែជាសេចក្ដីសន្និដ្ឋាននៃជំពូកទី៧នោះទេ ។

**៧:១៨–១៩ក** មើល នក ៣៤:៦–៧ក ។

**៧:១៨** *តើមានអ្នកណាជាព្រះឱ្យដូចទ្រង់....មរដកទ្រង់* ឃ្លានេះប្រហែលជាជាប់ទាក់ទងនឹងន័យរបស់ឈ្មោះលោកមីកា(មើលការពន្យល់ ១:១)។ មើល នក ១៥:១១ និងការពន្យល់ ។

**៧:១៩** *កំរាប . . . នៅក្រោមព្រះបាទ* ឬមានន័យថា "បង្ក្រាបពង្រៀប"។ នៅពេលដែលព្រះទ្រង់ដកយកចេញនូវទោសបាបរបស់យើង(ខ.១៨) នោះទ្រង់ក៏ដកយកចេញនូវអំណាចរបស់វាផងដែរ ដើម្បីកុំឱ្យវាគ្រប់គ្រងលើយើងបាន(មើល ទដ ១៩:១៣ ធៀបនឹង រម ៦:១៤)។ *បោះអស់ទាំងអំពើបាបរបស់យើងទៅក្នុងសមុទ្រជ្រៅ* មើលការពន្យល់ អស ៣៨:១៧ និង យរ ៥០:២ ផងដែរ ។

របស់យើងទៅក្នុងសមុទ្រជ្រៅ[ប]
២០ទ្រង់នឹងសំរេចតាម
សេចក្ដីពិតដល់យ៉ាកុប និងតាមសេចក្ដីសប្បុរសដល់
អ័ប្រាហាំ[ផ] ដូចជា ទ្រង់បានស្បថនឹងពួកព្ធយុកោ[ព]យើងរាល់
គ្នា ចាប់តាំងពីបុរាណមកនោះ[ភ]។/

**៧:១៩** ប យរ ៣១:៣៤
**៧:២០** ផ កទ ៣:១៦
ព ចទ ៧:៨ លក ១:៧២ ភ ទដ ១០៨:៤

**៧:២០** *យ៉ាកុប . . . អ័ប្រាហាំ* ព្រះអម្ចាស់ទ្រង់បានស្បថនឹងលោកអ័ប្រាហាំ (មើល លប ១៣:១៦ ១៥:៥ ២២:១៧ និងការពន្យល់) និងលោកយ៉ាកុប (លប ២៨:១៤)ថា ពូករបស់ពួកគាត់នឹងមានគ្នាច្រើនដូចផ្កាយនៅលើមេឃ ធូលីដី និងគ្រាប់ខ្សាច់នៅឆ្នេរសមុទ្រ ហើយទ្រង់បានសន្យានឹងលោកអ័ប្រាហាំថា លោកនឹងក្លាយឪពុកនៃសាសន៍ជាច្រើន(លប ១៧:៥ ធៀបនឹង លក ១:៥៤–៥៥)។ ព្រះទ្រង់បានរាប់បញ្ចូលអ្នកជឿទាំងអស់នៅក្នុងសេចក្ដីសន្យារបស់ទ្រង់ផងដែរ (រម ៤ កទ ៣:៦–២៩ ហព ១១:១២)។

# ព្រះគម្ពីរណាហ៊ុម

## សេចក្តីផ្តើម

### អ្នកនិពន្ធ

នៅក្នុងខដំបូងនៃព្រះគម្ពីរណាហ៊ុមបានប្រើពាក្យ "ការដាក់ស្តែងរបស់ណាហ៊ុម" ។ ឈ្មោះរបស់លោកណាហ៊ុមមានន័យថា "កម្សាន្តចិត្ត" ហើយមានទំនាក់ទំនងនឹងឈ្មោះលោកនេហេមា ដែលមានន័យថា "ព្រះអម្ចាស់ទ្រង់កម្សាន្តចិត្ត" ឬ "ការកម្សាន្តចិត្តរបស់ព្រះអម្ចាស់"(ខ្លឹមសារនៃព្រះគម្ពីរណាហ៊ុមគឺ ការដួលរលំនៃទីក្រុងនីនីវេ ដែលនាំឱ្យមានការកម្សាន្តចិត្តដល់សាសន៍យូដា) ។ គេគ្រាន់តែដឹងថាស្រុកអែលកូស គឺជាស្រុកកំណើតរបស់លោកនេហេមា ហើយទីតាំងនៃស្រុកនេះគេមិនទាន់ដឹងច្បាស់នៅឡើយទេ ។

### កាលបរិច្ឆេទ

នៅក្នុង ៣:៨–១០ អ្នកនិពន្ធបាននិយាយអំពីការដួលរលំនៃក្រុងនរ–អាម៉ូន ដែលកើតឡើងនៅឆ្នាំ ៦៦៣ មុនគ.ស.។ នៅក្នុងជំពូកទាំងបីនៃព្រះគម្ពីរណាហ៊ុមបាននិយាយអំពីសេចក្តីទំនាយនៃការដួលរលំនៃទីក្រុងនីនីវេ ដែលបានសម្រេចនៅក្នុងឆ្នាំ ៦១២ មុនគ.ស. ។ ដូចនេះលោកណាហ៊ុមបានថ្លែងទំនាយនេះ នៅចន្លោះឆ្នាំ ៦៦៣ ដល់ ៦១២ មុនគ.ស. ដែលប្រហែលជិតដល់ចុងបញ្ចប់នៃអំឡុងពេលនេះ ព្រោះលោកបានថ្លែងអំពីការដួលរលំនៃក្រុងនីនីវេថា ជាការដែលជិតមកដល់ (២:១ ៣:១៤,១៩) ។ តាមកាលបរិច្ឆេទនេះ មានន័យថា លោកបានធ្វើការបម្រើព្រះនៅក្នុងរាជ្យស្តេចយូសៀស និងស្ថិតនៅក្នុងសម័យតែមួយ ជាមួយនឹងលោកសេផានា និងលោកយេរេមា ដែលមានវ័យក្មេងនៅឡើយ ។

### ប្រវត្តិដើម

ចក្រភពអាសស៊ើរ (មានទីក្រុងនីនីវេជាតំណាង, ១:១) បានទទួលរងការបំផ្លាញដោយសាសន៍សាម៉ារី (ឆ្នាំ ៧២២ ដល់ ៧២១ មុនគ.ស.) ហើយការនេះនាំឱ្យអាណាចក្រខាងជើងនៃប្រទេសអ៊ីស្រាអែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផងដែរ ដែលនោះជាការគំរាមកំហែងដល់ស្រុកយូដា ។ ពួកសាសន៍អាសស៊ើរមានភាពព្រៃផ្សៃណាស់ ហើយគេបានរៀបរាប់អំពីពួកស្តេចសាសន៍អាសស៊ើរថាចូលចិត្តសប្បាយនឹងការដាក់ទោសធ្ងន់ធ្ងរមកលើប្រជាជននៃប្រទេសដែលពួកខ្លួនបានកាន់កាប់ ។ ពួកគេបានធ្វើសង្គ្រាមយ៉ាងសាហាវព្រៃផ្សៃ ពួកគេមានគោលនយោបាយបណ្តេញចេញនូវប្រជាជនដែលជាម្ចាស់ស្រុក ហើយនិរទេសពួកគេទៅកាន់តំបន់ផ្សេងៗទៀតនៃចក្រភពអាសស៊ើរ ។ អ្នកដឹកនាំនៃទីក្រុងកាន់កាប់ ត្រូវពួកគេធ្វើទារុណកម្មយ៉ាងព្រៃផ្សៃមកលើរូបកាយ មុននឹងប្រហារជីវិត (មើលការពន្យល់ ៣:៣) ។ ដូចនេះហើយ ប្រទេសជិតខាងមានការភ័យខ្លាចយ៉ាងខ្លាំងចំពោះចក្រភពអាសស៊ើរ ។

ប្រហែលជានៅឆ្នាំ ៧០០ មុនគ.ស. ស្តេចសេណាចេរិប (Sennacherib) បានដាក់ទីក្រុងនីនីវេជារាជធានីនៃចក្រភពអាសស៊ើរ ហើយទីក្រុងនេះបានក្លាយជារាជធានីរហូតដល់ចក្រភពនេះទទួលរងការបំផ្លាញនៅឆ្នាំ ៦១២ មុនគ.ស. ។ លោកយ៉ូណាសបានប្រកាសអំពីសេចក្តីហិនវិនាសនៃទីក្រុងនេះ នៅមុនសម័យលោកណាហ៊ុម (យហ ៣:៤) ហើយដោយសារប្រជាជននៅទីក្រុងនោះបានបង្ហាញពីការប្រែចិត្ត ពួកគេអាចបញ្ចៀសសេចក្តីហិនវិនាសនៅសម័យនោះបាន (មើល យណ ៣:១០ និងការពន្យល់) ។ នៅក្រោយសម័យនោះមិនយូរប៉ុន្មាន ពួកក្រុងនីនីវេបានចាប់ផ្តើមប្រព្រឹត្តការអាក្រក់ សាហាវយ៉ាងខ្លាំង និងមានអំណួតឡើងវិញ ។ សាសន៍អាសស៊ើរមានភាពសាហាវបំផុតនៅក្នុងរជ្ជកាលស្តេចអាសស៊ើរបានីប៉ាល (ឆ្នាំ ៦៦៩–៦២៧ មុនគ.ស.) ជាស្តេចខ្លាំងចុងក្រោយបំផុតនៃចក្រភពអាសស៊ើរ ។ បន្ទាប់ពីស្តេចនេះបានស្លាប់ទៅ ចក្រភពនេះបានអន់ថយរហូតដល់ ៦១២ មុនគ.ស. នៅពេលដែលទីក្រុងនីនីវេត្រូវផ្តួលរំលំ (មើលការពន្យល់ ១:១៤ ២:១) ។ (ចំពោះការរៀបរាប់បន្ថែមអំពីប្រវត្តិសាស្ត្រនៃទីក្រុងនេះ សូមមើលសេចក្តីពន្យល់) ។

### អ្នកទទួល

នៅក្នុងព្រះគម្ពីរនេះ មានពាក្យខ្លះដែលនិយាយទៅកាន់ពួកយូដា (មើល ១:១២–១៣,១៥) ប៉ុន្តែភាគច្រើននិយាយទៅកាន់ទីក្រុងនីនីវេ (មើល ១:១១,១៤ ២:១,១៣ ៣:៥–១៧,១៩) ឬស្តេចនៃទីក្រុងនេះ (៣:១៨) ។ ទោះជាយ៉ាងណាក៏ដោយ គោលបំណងនៃការនិពន្ធព្រះគម្ពីរគឺសម្រាប់អ្នកអានជាសាសន៍អ៊ីស្រាអែលដែលរស់នៅស្រុកយូដា ។

### រចនាបថនៃអក្សរសាស្ត្រ

មាតិកានៃព្រះគម្ពីរនេះគឺមានទៅដោយសេចក្តីទំនាយយ៉ាងធ្ងន់ ដែលពិពណ៌នា និងប្រើពាក្យពេចន៍យ៉ាងច្បាស់លាស់ ដោយ

បង្ហាញអំពីអារម្មណ៍ រូបភាព និងសម្លេងបែបធ្ងន់ធ្ងរ ។ អត្ថបទមានលក្ខណៈជាកំណាព្យ ដែលមានប្រើពាក្យប្រៀបប្រដូចជាញឹកញាប់ ពាក្យដែលរៀបរាប់ពីរូបភាពច្បាស់លាស់ ការនិយាយពីពាក្យដដែលៗ និងប្រើឃ្លាខ្លីៗ (៣:១-៣) ។ មានសំនួរចំអកឱ្យជាច្រើនដែលនិយាយសង្កត់ធ្ងន់អំពីការកាត់ទោសចំពោះភាពអយុត្តិធម៌ ។

**ខ្លឹមសារនៃវិជ្ជាសិក្សាអំពីព្រះ**

ខ្លឹមសារសំខាន់នៃព្រះគម្ពីរនេះគឺនិយាយអំពីសេចក្ដីជំនុំជម្រះដែលព្រះអម្ចាស់ទ្រង់ដាក់មកលើទីក្រុងនីនីវេ ដោយសារតែការគៀបសង្កត់ ភាពសាហាវ ការថ្វាយបង្គំរូបព្រះ និងសេចក្ដីអាក្រក់របស់ពួកគេ ។ នៅចុងបញ្ចប់នៃព្រះគម្ពីរនេះគឺនិយាយអំពីការវិនាសបង់នៃទីក្រុងនេះ ។

តាមបទគម្ពីរ រម ១១:២២ ព្រះទ្រង់មិនគ្រាន់តែមានសេចក្ដីសប្បុរសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសេចក្ដីប្រិតប្រៀនផងដែរ។ នៅក្នុងព្រះគម្ពីរណាហ៊ុម ព្រះអម្ចាស់ទ្រង់មិនគ្រាន់តែ"យឺតនឹងខ្ញាល់" (១:៣) និង"ជាទីមាំមួន . . . អស់អ្នកដែលយកទ្រង់ជាទីពឹងផ្អែក" (១:៧)ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង "មិនលះលែងទោសរបស់មនុស្ស" (១:៣)ផងដែរ ។ នគរដ៏សុចរិត ហើយយុត្តិធម៌នៃទ្រង់នឹងមានជ័យជម្នះនៅទីបំផុត ព្រោះនគរដែលសង់ដោយការអាក្រក់ និងផ្តាច់ការនិងត្រូវដួលចុះ ដូចនគរសាសន៍អាសស៊ើរដែរ ។

ម្យ៉ាងទៀត លោកណាហ៊ុមបានប្រកាសអំពីអំណាចដែលព្រះអម្ចាស់គ្រប់គ្រងសាកលលោក ។ ព្រះទ្រង់ជាម្ចាស់នៃប្រវត្តិសាស្ត្រ និងម្ចាស់នៃគ្រប់សាសន៍ទាំងអស់ ដូចនេះទ្រង់ក៏គ្រប់គ្រងជោគវាសនានៃពួកគេផងដែរ ។

**គម្រោងសង្ខេប**

I. ចំណងជើង (១:១)

II. អ្នកកាត់ទោសទីក្រុងនីនីវេ (១:២-១៥)

ក. សេចក្ដីសប្បុរស និងសេចក្ដីប្រិតប្រៀននៃព្រះអម្ចាស់ (១:២-៨)

ខ. ការដួលរលំនៃទីក្រុងនីនីវេ និងសេចក្ដីអំណរនៃសាសន៍យូដា (១:៩-១៥)

III. ចម្លើយរបស់ព្រះ: ពួកសាសន៍បាប៊ីឡូននឹងជំនុំជម្រះពួកសាសន៍យូដា (១:៥-១១)

ក. ការលោមព័ទ្ធទីក្រុងនីនីវេ (២:១-១០)

ខ. ភាពអស់សង្ឃឹមនៃក្រុងនីនីវេ ដែលផ្ទុយនឹងភាពរុងរឿងកាលពីមុន (២:១១-១៣)

IV. ការបំផ្លាញទីក្រុងនីនីវេទាំងស្រុង (ជំពូក៣)

ក. អំពើបាបនៃក្រុងនីនីវេ (៣:១-៤)

ខ. ទីបញ្ចប់នៃក្រុងនីនីវេ (៣:៥-១៩)

**១** ១នេះជាសេចក្ដីទំនាយយ៉ាងធ្ងន់[ក] ពីដំណើរក្រុងនីនីវេ[ខ] គឺ
ជាសៀវភៅ សំដែងចេញជាការជាក់ស្ដែង[គ]របស់ណាហ៊ុម
ជាអ្នកស្រុកអែលកូស ។

## សេចក្ដីក្រោធរបស់ព្រះអម្ចាស់ទាស់នឹងទីក្រុងនីនីវេ

២ព្រះយេហូវ៉ាទ្រង់ជាព្រះប្រចណ្ឌ[ឃ] ទ្រង់ក៏សងសឹកដែរ
ព្រះយេហូវ៉ាទ្រង់សងសឹក ហើយក៏មានពេញដោយសេចក្ដី
ក្រោធ ព្រះយេហូវ៉ាទ្រង់សងសឹក[ង] ដល់ពួកអ្នកតតាំងនឹង
ទ្រង់ ហើយទ្រង់រក្សាទុកនូវសេចក្ដីក្រោធ សំរាប់ពួកខ្មាំង
សត្រូវ[ច] ៣ព្រះយេហូវ៉ាទ្រង់យឺតនឹងខ្ញាល់[ឆ] ហើយមានព្រះ
ចេស្ដាយ៉ាងធំ ទ្រង់មិនលះលែងទោសរបស់មនុស្សឡើយ[ជ]
ឯផ្លូវរបស់ព្រះយេហូវ៉ា នោះនៅក្នុងខ្យល់កួច[ឈ] ហើយក្នុង
ព្យុះសង្ឃរា[ញ] ពពកទាំងឡាយ[ដ]ជាធូលីហុយពីព្រះបាទទ្រង់
៤ទ្រង់ស្ដីបន្ទោស[ឋ]ដល់សមុទ្រ ក៏ធ្វើឱ្យគោកទៅ[ឌ] ទ្រង់ធ្វើ
ឱ្យទន្លេទាំងប៉ុន្មានរីងស្ងួតដែរ ចំណែកឯស្រុកបាសាន ក៏
រោយរៀវចុះ ព្រមទាំងស្រុកកើមែល[ឍ]ផង ឯផ្ការបស់ព្រៃ
ល្បាណូនក៏ស្រពោនដែរ ៥ភ្នំធំទាំងឡាយកក្រើក[ណ]នៅ
ចំពោះទ្រង់ ហើយអស់ទាំងភ្នំតូចក៏រលាយទៅ[ត] ដីរំពើក
ចុះឡើង[ថ] នៅចំពោះព្រះភក្ត្រទ្រង់ អើ ទាំងលោកីយ និងទាំង
អស់ ដែលអាស្រ័យនៅក្នុងលោកដែរ[ទ] ៦តើមានអ្នកណា
ដែលអាចនឹងឈរ[ធ]នៅមុខសេចក្ដីគ្នាន់ក្នាញ់របស់ទ្រង់បាន
តើអ្នកណានឹងធន់នៅ[ន]បាន ក្នុងពេលដែលសេចក្ដីខ្ញាល់ដ៏
សហ័សរបស់ទ្រង់ឆួលឡើង[ប] ឯសេចក្ដីក្រោធរបស់ទ្រង់
នោះក៏ចាក់ចេញដូចជាភ្លើង[ផ] ហើយថ្មទាំងប៉ុន្មានក៏ត្រូវបែក
សព្វែក[ព]ដោយសារទ្រង់ ៧ព្រះយេហូវ៉ាទ្រង់ល្អ[ភ] ទ្រង់ជា
ទីពឹងមាំមួននៅគ្រាលំបាក[ម] ក៏ស្គាល់[យ]អស់អ្នកដែលយកទ្រង់
ជាទីពឹងផ្អែក[រ] ៨តែទ្រង់នឹងរំលីងទីកន្លែងរបស់ពួកតតាំង
ដោយទឹកជន់ហូរលិច[ល] ហើយនឹងដេញពួកខ្មាំងសត្រូវទ្រង់
ទៅក្នុងទីងងឹត ។
៩ឯងរាល់គ្នាគិតបង្កើតអ្វី[វ] ទាស់នឹងព្រះយេហូវ៉ានោះ ឯ
ទ្រង់ នឹងធ្វើឱ្យផុតទៅអស់រលីង សេចក្ដីទុក្ខវេទនានឹងមិន
កើតឡើងដល់ទៅ២ដងទេ ១០ដ្បិតគេនឹងត្រូវឆេះអស់រលីង

**១:១** ក អស ១៣:១ ១៩:១ យរ ២៣:៣៣–៣៤ ខ លប ១០:១១ យរ ៥០:១៨ ណាហ ២:៨ ៣:៧ គ អស ១:១ **១:២** ឃ នក ២០:៥ ង លប ៤:២៤ ចទ ៣២:៤១ ទដ ៩៤:១ ច ចទ ៧:១០ **១:៣** ឆ នហ ៩:១៧ ជ នក ៣៤:៧ ឈ នក ១៤:២១ ២ពវ ២:១ ញ ទដ ៥០:៣ ដ ២សយ ២២:១០ ទដ ១០៤:៣ **១:៤** ឋ ២សយ ២២:១៦ ឌ នក ១៤:២២ ឍ អស ៣៣:៩ **១:៥** ណ នក ១៩:១៨ យប ៩:៦ ត មីក ១:៤ ថ យអ ២:១០ ទ អគ ៣៨:២០ **១:៦** ធ ទដ ១៣០:៣ ន អគ ២២:១៤ ប ទដ ៧៦:៧ ផ អស ៥:២៤–២៥ ៤២:២៥ យរ ១០:១០ ព ១ពវ ១៩:១១ **១:៧** ភ យរ ៣៣:១១ ម យរ ១៧:១៧ យ ទដ ១:៦ រ ទដ ២២:៩ **១:៨** ល អស ៨:៧ ដយ ៩:២៦ **១:៩** វ ហស ៧:១៥

**១:១** ខនេះគឺនិយាយអំពីចំណងជើង ។ *សេចក្ដីទំនាយយ៉ាងធ្ងន់* មើល អស ១៣:១ ហាព ១:១ និងការពន្យល់ ។ *ក្រុងនីនីវេ* មើលសេចក្ដីផ្ដើមត្រង់ ប្រវត្តិដើម មើលការពន្យល់ យណ ១:២ ៣:៣ ។ នៅត្រង់ចំណុចនេះ ឈ្មោះរាជធានីត្រូវបានប្រើជាតំណាងឱ្យចក្រភពអាសស៊ើទាំងមូល ។ *ការជាក់ស្ដែង* មើល សភ ២៩:១៨ អស ១:១ អប ១ និងការពន្យល់ ។ *ណាហ៊ុម ជាអ្នកស្រុកអែលកូស* មើលសេចក្ដីផ្ដើមត្រង់ អ្នកនិពន្ធ ។

**១:២–៣** នៅក្នុងវគ្គនេះបាននិយាយសង្កត់ធ្ងន់អំពីព្រះនាមនៃព្រះអម្ចាស់គឺ "ព្រះយេហូវ៉ា"(មើលការពន្យល់ លប ២:៤ នក ៣:១៤–១៥ ៦:៦ ចទ ២៨:៥៨) ។

**១:២** *ប្រចណ្ឌ* មើលការពន្យល់ នក ២០:៥ ។ *សងសឹក . . . សងសឹក . . . សងសឹក* ព្រះអម្ចាស់ទ្រង់ធ្វើការរបស់ទ្រង់ដោយយុត្តិធម៌ មកលើអស់អ្នកណាដែលទាស់ប្រឆាំងនឹងទ្រង់ និងនគររបស់ទ្រង់ ។ ការដែលមានប្រើពាក្យសងសឹងច្រើនដងគឺដើម្បីបញ្ជាក់ព្រះបន្ទូលទ្រង់ដែលថា "ការសងសឹងគឺស្រេចនៅនឹងអញ" (ចទ ៣២:៣៥ និងការពន្យល់) ។ *សេចក្ដីក្រោធ* មើល ការពន្យល់ ទដ ២:៥ រម ១:១៨ ។

**១:៣** *យឺតនឹងខ្ញាល់ . . . មិនលះលែងទោសរបស់មនុស្សឡើយ* មើល នក ៣៤:៦–៧ និងការពន្យល់ ។ *ទោសរបស់មនុស្ស* គឺទោសរបស់មនុស្សនៅក្រុងនីនីវេជាដើម ។ *ខ្យល់កួច . . . ព្យុះសង្ឃរា . . . ពពក* គឺជាបាតុភូតធម្មជាតិដ៏អស្ចារ្យ ដែលបង្ហាញអំពីអំណាច និងព្រះចេស្ដានៃព្រះ ។ មើលការពន្យល់ យប ៣៨:១ ទដ ១៨:៧–១៥ ៦៨:៤ ៧៧:១៦–១៩ ១០៤:៣–៤ ។

**១:៤** *ស្ដីបន្ទោសដល់សមុទ្រ ក៏ធ្វើឱ្យគោកទៅ* គឺដូចកាលពួកសាសន៍អ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម(មើល នក ១៤:១–១៥:១២ និង ទដ ១៨:១៥ និងការពន្យល់) ។ *ធ្វើឱ្យទន្លេទាំងប៉ុន្មានរីងស្ងួត* គឺដូចកាលសាសន៍អ៊ីស្រាអែលឆ្លងទន្លេយ័រដាន់ (មើល យស ៣:១–៤:២៤ និងការពន្យល់) ។ *ស្រុកបាសាន . . . ស្រុកកើមែល . . . ព្រៃល្បាណូន* មើលការពន្យល់ ទដ ២២:១២ បស ៧:៥ អស ២:១៣ ៣៣:៩ ៣៥:២ អគ ២៩:១៨ អម ៤:១ ។ តំបន់ទាំងបីនេះល្បីថាសំបូរដីជាតិ ចំការទំពាំងបាយជូរ និងព្រៃឈើ ប៉ុន្តែដោយសារទាស់ប្រឆាំងនឹងព្រះបន្ទូលព្រះ តំបន់ទាំងនេះនឹងត្រូវក្រៀមក្រោះហួតហែងវិញ ។

**១:៥** *ភ្នំធំ . . . ភ្នំតូច . . . លោកិយ . . . លោក* គឺជាតំណាងឱ្យស្ថេរភាព និងភាពស្ថិតស្ថេរ ។

**១:៦** *តើមានអ្នកណាដែលអាចនឹងឈរនៅមុខ . . . អ្នកនឹងធន់ . . .* គឺជាប្រភេទសំណួរដែលសម្រាប់ធ្វើឱ្យភ្ញាក់ស្មារតី ។ បើសិនជាភ្នំត្រូវញ័ររញ្ជួយនៅចំពោះព្រះអម្ចាស់(ខ.៥)ទៅហើយ នោះមនុស្សនឹងទទួលស្គាល់ថាខ្លួនគ្មានសមត្ថភាពអ្វីឡើយ (ធៀបនឹង រម ២:៣–៥ វវ ៦:១៧) ។

**១:៧** *អ្នកដែលយកទ្រង់ជាទីពឹងផ្អែក* ដែលមានពួកសាសន៍យូដាជាដើម ។

**១:៨** *ទឹកជន់ហូរលិច* គឺជានិមិត្តរូបនៃការឈ្លានពានដោយកងទ័ព (មើល អស ៨:៧–៨ ២៨:១៧–១៩) ។ *ហើយ . . . ទីងងឹត* នៅឆ្នាំ ៦១២ មុនគ.ស. ទីបញ្ចប់នៃទីក្រុងនីនីវេត្រូវមក ហើយសេចក្ដីងងឹតបានគ្របដណ្ដប់ទីក្រុង ។

**១:៩** *គិតបង្កើត* មើលការពន្យល់ ខ.១១ ។ *សេចក្ដីទុក្ខវេទនានឹងមិនកើតឡើងដល់ទៅ២ដងទេ* ព្រះអម្ចាស់ទ្រង់មិនអនុញ្ញាណឱ្យពួកអាសស៊ើយកឈ្នះពួកយូដាជាលើកទីពីរឡើយ ។ ពួកអាសស៊ើបានឈកឈ្នះលើពួកយូដាលើកទីមួយ ដោយការផ្ដួលរំលំស្រុកសាម៉ារី(ឆ្នាំ ៧២២–៧២១ មុនគ.ស.) និងអាណាចក្រខាងជើង (ការឈ្លានពានដឹកនាំដោយស្ដេចសេណាចេរីប នៅឆ្នាំ ៧០១ មុនគ.ស.មិនបានទទួលជោគជ័យទាំងស្រុងនោះទេ មើល ២ពវ ១៨:១៣–១៩:៣៦) ។

ទៅ ដូចជាជញ្ជ្រាំងស្លួត[ស] ដោយគេស្រេះប្រទាក់គ្នាដូចជា
បន្លា[ហ] ក៏ស្រវឹងដូចជាបានផឹក[ឡ]ស្រាហើយ ១១មានម្នាក់ចេញ
ពីឯងមក ដែលគិតគួរការអាក្រក់ទាស់នឹងព្រះយេហូវ៉ា គឺ
ជាអ្នកដែលប្រឹក្សាសុទ្ធតែអំពើអាក្រក់ ១២ព្រះយេហូវ៉ា ទ្រង់
មានបន្ទូលដូច្នេះថា ទោះបើគេមានពេញកំឡាំង ហើយ
មានគ្នាច្រើនផងក៏ដោយ គង់តែគេនឹងត្រូវកាត់ចុះ[អ] ហើយ
កន្លងបាត់ទៅ អញបានធ្វើទុក្ខឯងម្តងហើយ ដើម្បីមិនឱ្យត្រូវ
ធ្វើទៀតឡើយ[ក] ១៣ឥឡូវនេះ អញនឹងបំបាក់នឹម[ខ]របស់គេ
ចេញពីឯង ហើយបណ្តាច់ចំណងឯងផង[គ]។
១៤ព្រះយេហូវ៉ាទ្រង់បានបង្គាប់ពីដំណើរឯងថា ឯងនឹង
មិនមានពូជបន្តឈ្មោះទៀតឡើយ[ឃ] អញនឹងកាត់អស់ទាំង
រូបឆ្លាក់[ង] នឹងរូបសិតពីវិហាររបស់ព្រះទាំងប៉ុន្មាននៃឯង
ចេញ ហើយនឹងរៀបចំផ្នូរឯង[ច] ដ្បិតឯងគំរក់ណាស់ ។
១៥មើលន៏ នៅលើភ្នំទាំងឡាយ ឃើញជើងរបស់អ្នក
ដែលនាំដំណឹងល្អមក[ឆ] គឺជាអ្នកដែលប្រកាសប្រាប់ពីសេចក្តី
សុខ[ជ] ឱយូដាអើយ ចូររក្សាថ្ងៃបុណ្យទាំងប៉ុន្មានរបស់ឯង[ឈ]
ចូរលាបំណន់ឯងចុះ ដ្បិតមនុស្សអាក្រក់នឹងមិនដែលដើរ

**១:១០** ស ២សយ ២៣:៦ ហ អស ៤៩:២៦ ឡ អស ៥:២៤ មឡ ៤:១ **១:១២** អ អស ១០:៣៤ ក អស ៥៤:៦–៨ បទ ៣:៣១–៣២ **១:១៣** ខ អស ៩:៤ គ យប ១២:១៨ ទដ ១០៧:១៤ **១:១៤** ឃ អស ១៤:២២ ង មីក ៥:១៣ ច យប ២៨:៨ អគ ៣២:២២–២៣ **១:១៥** ឆ អស ៤០:៩ រម ១០:១៥ ជ អស ៥២:៧ កច ១០:៣៦ ឈ លវ ២៣:២–៤ ញ អស ៥២:១ **២:១** ក យរ ៥១:២០

កាត់ឯងទៀតឡើយ[ញ] គេត្រូវកាត់ចេញអស់រលីងហើយ[ដ]។

## ទីក្រុងនីនីវេត្រូវដួលចុះ

**២** ១អ្នកដែលកំចាត់កំចាយ[ក] បានឡើងមកទាស់នឹង
ឯងហើយចូរការពារបន្ទាយ ត្រូវឱ្យចាំយាមផ្លូវ ចូរ
ក្រវាត់ចង្កេះឱ្យខែងរ៉ែង ហើយចំរើនកំឡាំងយ៉ាងសន្ធឹក
ចុះ ២ពីព្រោះព្រះយេហូវ៉ា ទ្រង់កំពុងតាំង[ខ]សេចក្តីរុង
រឿង[គ] នៃយ៉ាកុបឡើងវិញ ឱ្យដូចជាសេចក្តីរុងរឿងរបស់
អ៊ីស្រាអែលដែរ ពីព្រោះពួកផ្តឹងជន បានចាក់គេចេញអស់
ហើយ ក៏បានបំផ្លាញខ្នែងទំពាំងបាយជូររបស់គេដែរ ៣ឯ
ខែលរបស់មនុស្សខ្លាំងពូកែបានប្រឡាក់ក្រហម[ឃ]ពួកមនុស្ស
ក្លាហានស្លៀកពាក់ក្រហមឆ្អៅ ឯរទេះចំបាំង ក៏ភ្លឺផ្លេកៗនៅ
ថ្ងៃរៀបចំ ហើយគេងាលំពែងដងកកោះយ៉ាងគួរស្ញែង
៤អស់ទាំងរទេះចំបាំង[ង]រត់យ៉ាងសំបើម ទៅតាមផ្លូវ ក៏រត់
ចុះឡើងតាមផ្លូវធ្លា មានភាពដូចជាចន្លុះ ហើយក៏រត់លឿន
ដូចជាផ្លេកបន្ទោរ ៥ស្តេចរបស់គេនឹករកអ្នកណាដែល

**២:២** ខ អគ ៣៧:២៣ គ អស ៦០:១៥ **២:៣** ឃ អគ ២៣:១៤–១៥ **២:៤** ង យរ ៤:១៣ អគ ២៣:២៤

**១:១០** *ស្រវឹងដូចជាបានផឹកស្រាហើយ* មើល ៣:១១ និងការពន្យល់ ។

**១:១១** *ម្នាក់ . . . ដែលគិតគួរការអាក្រក់* ម្នាក់នោះ អាចជាស្តេចអាសស៊ើរ ដែលមានព្រះនាម អាស៊ើរបានីប៉ាល (ឆ្នាំ ៦៦៩–៦២៧ មុនគ.ស.) ដែលជាស្តេចចុងក្រោយរបស់ចក្រភពអាសស៊ើរ ។ ស្តេចនេះបានពង្វាតទឹកដីទៅទិសខាងលិច ហើយបានវាយកាន់កាប់ប្រទេសអេស៊ីព្ទយ៉ាងជោគជ័យ ហើយស្តេចម៉ានាសេក៏បានចុះចូលជារដ្ឋចំណុះចំពោះស្តេចនេះផងដែរ (មើល ២របា ៣៣:១១–១៣ និងការពន្យល់ ៣៣:១១ អរ ៤:៩–១០) ។ *គិតគួរការអាក្រក់ទាស់នឹងព្រះយេហូវ៉ា* ធ្វើដូចនេះមិនបានទទួលផលអ្វីក្រៅពីសេចក្តីហិនវិនាសឡើយ (ទដ ២:១–៤) ។

**១:១២** *គេ* គឺសំដៅទៅលើពួកអាសស៊ើរ ។ *អញបានធ្វើទុក្ខឯងម្តងហើយ* ព្រះទ្រង់ប្រើសាសន៍អាសស៊ើរជារំពាត់នៃសេចក្តីក្រោធរបស់ទ្រង់ សម្រាប់វាយផ្ចាលរាស្ត្រដែលក្បត់សេចក្តីសញ្ញា នៅក្នុងសម័យស្តេចអេហាសម្តង (អស ១០:៥) ហើយម្តងទៀតនៅក្នុងសម័យស្តេចម៉ានាសេ ។

**១:១៣** មើល យរ ២៧:២ និងការពន្យល់ ។ *អញនឹងបំបាក់នឹមរបស់គេចេញ* ស្រុកយូដាត្រូវស្ថិតនៅក្រោមនឹមត្រួតត្រារបស់ចក្រភពអាសស៊ើរ ហើយនឹមនេះនឹងត្រូវបំបាក់ ។

**១:១៤** *រៀបចំផ្នូរឯង* ព្រះទ្រង់ប្រើសាសន៍បាប៊ីឡូន និងសាសន៍មេឌីឱ្យជីកផ្នូរសម្រាប់ទីក្រុងនីនីវេនៅក្នុងឆ្នាំ ៦១២ មុនគ.ស. ។ សេចក្តីទំនាយនេះបានសម្រេចនៅក្នុង អគ ៣២:២២–២៣ ។

**១:១៥** *ភ្នំ* គឺភ្នំនៅស្រុកយូដា ។ *ជើងរបស់អ្នកដែលនាំដំណឹងល្អ* ត្រង់ចំណុចនេះគឺនិយាយសំដៅទៅលើការប្រោសលោះ ។ ដំណឹងល្អនេះគឺប្រកាសអំពីការប្រោសលោះពីអំណាចចក្រភពអាសស៊ើរ នៅក្នុង អស ៥២:៧ និយាយអំពីការប្រោសលោះពីការនិរទេសដោយចក្រភពបាប៊ីឡូន នៅក្នុង រម ១០:១៥ និយាយអំពីការប្រោសលោះពីអំពីបាប តាមរយៈដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ ។ *ចូររក្សាថ្ងៃបុណ្យទាំងប៉ុន្មានរបស់ឯង* គឺរក្សាថ្ងៃបុណ្យទាំងប៉ុន្មានដោយអរសប្បាយនឹងការប្រោសលោះដែលពួកគេបានទទួល ។ *ចូរលាបំណន់ឯង* គឺលាបំណន់ដែលបានសន្យានឹងទ្រង់ ក្នុងពេលដែលមានទុក្ខ (មើលការពន្យល់ ទដ ៧:១៧ ៥០:១៤ យហ ២:៩) ។ *មនុស្សអាក្រក់នឹងមិនដែលដើរកាត់ឯងទៀតឡើយ* ពួកសាសន៍អាសស៊ើបានឈ្លានពានជាលើកចុងក្រោយនៅក្នុងរាជស្តេចម៉ានាសេ (មើល ១.១២ និងការពន្យល់) ។ *មនុស្សអាក្រក់* មើលការពន្យល់ ចទ ១៣:១៣ ។ *ត្រូវកាត់ចេញអស់រលីងហើយ* ការនេះបានសម្រេចនៅឆ្នាំ ៦១២ មុនគ.ស. នៅពេលដែលទីក្រុងនីនីវេត្រូវដួលរលំ (មើលការពន្យល់ ១.១៤) ។

**២:១** *អ្នកដែលកំចាត់កំចាយ* គឺសំដៅទៅលើសម្ព័ន្ធមិត្ររវាងសាសន៍មេឌីដែលដឹកនាំដោយស្តេចស៊ីយ៉ាសារេស និងសាសន៍បាប៊ីឡូនដែលដឹកនាំដោយស្តេចណាបូប៉ូឡាសារ ។ *ផ្លូវ* គឺផ្លូវដែលពួកសត្រូវធ្វើដំណើរមក ។

**២:២** *តាំងសេចក្តីរុងរឿងនៃយ៉ាកុប . . . អ៊ីស្រាអែល* ព្រះទ្រង់នឹងស្អាងរាស្ត្ររបស់ទ្រង់ឱ្យមានភាពរុងរឿងឡើងវិញ ។

**២:៣** *មនុស្សខ្លាំងពូកែ* គឺមនុស្សខ្លាំងពូកែរបស់ប្រទេសឈ្លានពាន (ខ.១) ឬប្រហែលជាមនុស្សខ្លាំងពូកែរបស់ទីក្រុងនីនីវេ ។ *ក្រហម* គឺជា (១).ពណ៌របស់ខែល (២).សំដៅទៅលើឈាមដែលពួកគេប្រឡាក់ ឬ(៣).ពណ៌នៅលើខ្លួនពួកគេដែលបណ្តាលមកពីត្រូវពន្លឺថ្ងៃចាំង ។ *យ៉ាងគួរស្ញែង* មានន័យថា បានត្រៀមខ្លួនជាស្រេច ។

**២:៤** *រទេះចំបាំង . . . រត់ចុះឡើង* សំដៅទៅលើ (១).រទេះចំបាំង របស់ពួកអាសស៊ើ ដែលរត់ចុះឡើងយ៉ាងច្រូលច្របល់ ដោយមិនទាន់រៀបចំការពារខ្លួនបានត្រឹមត្រូវ ឬ(២).រទេះចំបាំងរបស់ពួកឈ្លានពានក្រុងនីនីវេ ។

ស្ទាត់ជំនាញក្នុងពលទ័ព តែគេដើរទៅទាំងចំពប់ជើង[ច] គេ
ប្រញាប់ប្រញាល់នឹងឡើងទៅឯកំផែងក្រុង រួចក៏រៀបចំ
ប្រដាប់បាំងខ្លួន ៦ទ្វារ[ឆ]ទន្លេបានបើកឡើង ហើយដំណាក់
ស្ដេចក៏រលាយទៅ ៧ព្រះនាងហ៊ូសាបត្រូវគេចាប់ដឹកទៅ
ជាឈ្លើយ ពួកបាវស្រីរបស់ព្រះនាងក៏ថ្ងូរ[ជ]ដូចជាព្រាប ព្រម
ទាំងគក់ទ្រូងខ្លួនផង[ឈ]។

៨តាំងពីចាស់បុរាណ ក្រុងនីនីវេប្រៀបដូចជាស្រះទឹក
ប៉ុន្តែ ឥឡូវគេរត់ចោលចេញទៅវិញ មានគេស្រែកថា
ឈប់សិន ឈប់សិន តែគ្មានអ្នកណាបែរមើលខាងក្រោយ
ឡើយ ៩ចូរចាប់យករបឹបជាប្រាក់ជាមាសចុះ ដ្បិតរបស់
ទ្រព្យមិនចេះអស់មិនចេះហើយទេ សុទ្ធតែជាប្រដាប់ប្រដា
យ៉ាងល្អវិសេស ១០ទីក្រុងនៅទទេ ក៏សោះសូន្យ ហើយខូច
បង់ ឯចិត្តមនុស្សក៏រលាយទៅ[ញ] ហើយជង្គង់គេប្រដំគ្នា គ្រប់
ទាំងចង្កេះចុកសៀត ហើយមុខគេទាំងអស់ក៏ស្លេកស្លាំង[ដ]
១១តើរូងសិង្ហនោះបាត់ទៅឯណា[ឋ] គឺជាកន្លែងដែលចិញ្ចឹម
ពួកសិង្ហស្ទាវ ហើយសិង្ហឈ្មោល សិង្ហញីបានដើរនៅទីនោះ
ព្រមទាំងកូនសិង្ហឥតមានអ្នកណាបំភ័យវាឡើយ ១២ឯសិង្ហ
ឈ្មោល វាតែងតែហែក[ឌ]រំពាល្មមចំអែតកូន ក៏ខាំកសត្វ
យកមកឱ្យញី ព្រមទាំងបំពេញគុហា[ឍ]របស់វាដោយរំពា
ហើយរូងវាដោយសាច់សត្វ[ណ] ១៣ឯព្រះយេហូវ៉ានៃពួក
ពលបរិវារ ទ្រង់មានបន្ទូលថា នែ អញទាស់[ត]នឹងឯង អញ
នឹងដុតអស់ទាំងរទេះចំបាំងរបស់ឯង ឱ្យឡើងជាផ្សែង[ថ]
ហើយដាវ[ទ]នឹងស៊ីកូនសឹង្ហរបស់ឯង អញនឹងបំបាត់ការចាប់
រំពារបស់ឯងពីផែនដីចេញ ហើយសំឡេងរបស់ពួកទូត
ឯង នឹងឥតមានអ្នកណាឮទៀតឡើង[ធ]។

## សេចក្ដីវេទនាដល់ទីក្រុងនីនីវេ

**៣** ១វេទនាដល់ទីក្រុង ដែលប្រឡាក់ដោយឈាម[ក] វាពេញ
ដោយសេចក្ដីកំភូត[ខ] និងសេចក្ដីច្រឡោត ការរឹបជាន់មិន
ចេះបាត់ចេញឡើយ ២មានសុទ្ធតែសូររំពាត់ សូរសន្ធឹក
នៃកង់ សូរសេះបោល និងសូរយុកយាក់នៃរទេះចំបាំង
៣ឃើញទ័ពសេះបោលសំរុក និងដាវដែលភ្លឺចាំងហើយ
លំពែងផ្លេកៗ មានមនុស្សស្លាប់យ៉ាងសន្ធឹក ជាគំនរសាក
សពយ៉ាងធំ ខ្មោចគេមិនចេះផុតពីភ្នែកឡើង ជើងមនុស្ស
ទង្គិចនឹងខ្មោចទាំងនោះ[គ] ៤នេះគឺដោយព្រោះការកំផិត

**២:៥** ច យរ ៤៦:១២
**២:៦** ឆ អស ៤៥:១ ណាហ ៣:១៣
**២:៧** ជ លប ៨:៨ អស ៥៩:១១ ឈ អស ៣២:១២
**២:១០** ញ យស ២:១១ ៧:៥ ដ យរ ២៩:២២
**២:១១** ឋ អស ៥:២៩
**២:១២** ឌ យរ ៥១:៣៤ ឍ យរ ៤:៧ ណ អស ៣៧:១៨
**២:១៣** ត អស ១០:៥–១៣ យរ ២១:១៣ ណាហ ៣:៥
**២:១៣** ថ ទដ ៤៦:៩ ទ ២សយ ២:២៦ ធ មីក ៥:៦
**៣:១** ក អគ ២២:២ មីក ៣:១០ ខ ទដ ១២:២ **៣:៣** គ ២ពវ ១៩:៣៥ អស ៣៤:៣ យរ ៤៧:៣

**២:៥** *ស្ដេច* គឺប្រហែលជាស្ដេចចក្រភពអាសស៊ើ ឬស្ដេចណាបូប៉ូឡាសា (មើលការពន្យល់ ខ.១) នៃចក្រភពបាប៊ីឡូន ។ *ប្រដាប់បាំងខ្លួន* គឺជាប្រដាប់បាំងខ្លួនដែលមានទំហំធំ ដែលគ្របដណ្ដប់ដោយស្បែកសត្វ ដើម្បីការពារដុំថ្ម និងគ្រាប់ព្រួញ ។

**២:៦** *ទ្វារទន្លេ* ប្រហែលជាទំនប់ទន្លេខូស័រ (Khoser) ដែលហូរកាត់ទីក្រុងនីនីវេទៅដល់ទន្លេទីគ្រីស (Tigris) ។ ទំនប់នេះត្រូវបានគេសង់ហើយតាំងពីមុន ឬទើបតែសាងសង់ភ្លាមនៅពេលសង្គ្រាមដើម្បីទប់ទឹកទន្លេ ហើយបន្ទាប់មកក៏បើកទំនប់នោះភ្លាមៗ ដើម្បីឱ្យទឹកបុកបំផ្លាញកំផែង ។ *ដំណាក់ស្ដេចក៏រលាយទៅ* អ្នកប្រវត្តិសាស្ត្រនៅសម័យបុរាណម្នាក់ (អ្នកនិពន្ធនៃពង្សាវតាក្សត្ររបស់ចក្រភពបាប៊ីឡូន) បាននិយាយអំពីទឹកជំនន់នេះថា បានរំលំផ្នែកខ្លះនៃកំផែងក្រុង ដែលនាំឱ្យមានភាពងាយស្រួលដល់ពួកឈ្លានពានវាយលុកចូលទីក្រុង ។

**២:៧** *ពួកបាវស្រី* មានន័យថា សូម្បីតែអ្នកដែលមានឋានៈទាបបំផុតនៅក្នុងសង្គមក៏មិនអាចគេចផុតពីការជំនុំជម្រះបានដែរ ។

**២:៨** *ប្រៀបដូចជាស្រះទឹក . . . គេរត់ចោលចេញ* អ្នកខ្លះយល់ថា ត្រង់ចំណុចនេះគឺសំដៅទៅលើ ទន្លេទីគ្រីស (Tigris) និងទន្លេតូចៗដែលនៅជុំវិញ និងហូរកាត់ផ្នែកខ្លះនៃទីក្រុង ហើយសំដៅទៅលើប្រព័ន្ធទំនប់ទឹកដែលជួយការពារទីក្រុងមិនឱ្យអាចវាយលុកចូលបាន ។ អ្នកខ្លះទៀតយល់ថា ត្រង់ចំណុចនេះគឺជាន័យធៀបអំពី ការដែលប្រជាជននៅក្រុងនីនីវេត្រូវរត់ភាសខ្លួនដូចជាទឹកដែលហូរ ។

**២:៩** ខនេះគឺជាសម្រែករបស់ពួកឈ្លានពាន ។

**២:១០** *នៅទទេ ក៏សោះសូន្យ ហើយខូចបង់* តាមកំណត់ត្រាពង្សាវតានៃចក្រភពបាប៊ីឡូនបានអោយដឹងថា ពួកឈ្លានពានបានវាយយករបឹបយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ *ចិត្តមនុស្សក៏រលាយ* ពួកនីនីវេដែលធ្លាប់តែខ្លាំង ហើយអួតក្អេងក្អាង ឥឡូវនេះត្រូវក្លាយឥតទីពឹង ដោយភ័យខ្លាច ។

**២:១១–១៣** លោកនេហេមាបង្ហាញពីភាពខុសគ្នានៃទីក្រុងនីនីវេនៅមុននិងក្រោយការបំផ្លាញ ដោយនិយាយជាពាក្យប្រៀបប្រដូច ។

**២:១១** *សឹង្ហឈ្មោល សឹង្ហញី* មើល អស ៥:២៩ យរ ៤:៧ ។ សត្វតោគឺជានិមិត្តរូបនៃចក្រភពអាសស៊ើ ដោយសារគ្រប់គ្រងដោយស្ដេចដែលមានចរិកល្មោភអំណាច ហើយទីក្រុងនីនីវេមានរូបចម្លាក់សត្វតោជាច្រើន ។

**២:១២** *បំពេញគុហា . . . ដោយសាច់សត្វ* ទីក្រុងនីនីវេមានផ្ទុកទៅដោយរបឹបដែលបានពីការធ្វើសង្គ្រាមកាន់កាប់ប្រទេសជាច្រើន ។

**២:១៣** *អញនឹងដុត* ការដួលចុះនៃទីក្រុងនីនីវេគឺជាការជំនុំជម្រះរបស់ព្រះ ។ ទីក្រុងនីនីវេបានទទួលការជំនុំជម្រះ ដោយការបំផ្លាញ ។ *សំឡេង . . . ឥតមានអ្នកណាឮទៀត* ប្រវត្តិសាស្ត្របានបញ្ជាក់ផងដែរអំពីបទទំនាយនេះ ។

**៣:១–៣** មើលការពន្យល់ យអ ២:៣–១១ ។

**៣:១** *ទីក្រុង ដែលប្រឡាក់ដោយឈាម* មានឮល្បីអំពីការសំឡាប់រង្គាលប្រជាជននៃក្រុងនីនីវេ ដោយពួកខ្មាំងសត្រូវដែលវាយកាន់កាប់ ។ *ការរឹបជាន់មិនចេះបាត់ចេញឡើយ* គេបានកត់សំគាល់អំពីពួកសាសន៍អាសស៊ើ ថាជាសាសន៍សាហាវ ព្រៃផ្សៃ គ្មានមេត្តា ។ ជនរងគ្រោះជាច្រើនត្រូវសាសន៍នេះកាត់ក្បាល ចាក់ ឬដុតសម្លាប់ ។

**៣:៣** *គំនរសាកសពយ៉ាងធំ* ស្ដេចអាសស៊ើរព្រះនាម សាលម៉ានេស៊ើរ ទី៣ បានអួតក្អេងក្អាងពីពីរ៉ាមីតដែលខ្លួនបានសង់ដោយកំនរក្បាលមនុស្ស នៅមុខទីក្រុងរបស់សត្រូវខ្លួន ។ ស្ដេចអាសស៊ើរផ្សេងទៀតបានតម្រៀបសាកសពដូចជាគំនរអុសដែលគេបង្គងលើគ្នាជាប្អូនជ្រុង នៅមាត់ទ្វាទីក្រុងដែលបានវាយកាន់កាប់ ។

យ៉ាងសន្ធឹករបស់ស្រីសិំផឹង ដ៏មានរូបឆោមឆាយជាមេនៃ
អស់ទាំងអំពើអាបធ្មប់[ឃ] ជាអ្នកដែលលក់អស់ទាំងសាសន៍
ដោយសារការកំផិតរបស់វា[ង] ព្រមទាំងគ្រួមនុស្សផង
ដោយសារបៀនអាបធ្មប់របស់វា ៥ព្រះយេហូវ៉ានៃពួក
ពលបរិវារ ទ្រង់មានបន្ទូលថា នែ អញទាស់[ច]នឹងឯង អញ
នឹងសើយសំពត់[ឆ]ឯងឡើងគ្របមុខឯង ហើយនឹងបង្ហាញឱ្យ
ពួកសាសន៍ទាំងប៉ុន្មានឃើញកាយអាក្រាត[ជ] នឹងឱ្យអស់ទាំង
នគរឃើញកេរខ្មាសរបស់ឯង ៦ហើយអញនឹងបោះ
អសោចិ៍គួរខ្ពើមទៅលើឯង[ឈ] ឱ្យឯងបានទៅជាស្មោក
គ្រោក[ញ] រួចនឹងតាំងឯងឱ្យមនុស្សមើលលេង[ដ] ៧នោះអស់
អ្នកណាដែលឃើញឯង និងគេចរត់ពីឯងទៅ[ឋ] ដោយពាក្យ
ថា ក្រុងនីនីវេ[ឌ]បានត្រូវខូចបង់[ឍ]ហើយ តើអ្នកណានឹងយំ
សោក[ណ] តើនឹងរកឯណាឱ្យបានអ្នកជួយដោះទុក្ខ[ត]ឯង ៨តើ
ឯងវិសេសជាង[ថ]នរ-អាម៉ូន[ទ] ជាទីក្រុងដែលនៅកណ្ដាល
អស់ទាំងទន្លេ[ធ] ហើយមានទឹកនៅព័ទ្ធជុំវិញនោះ ក៏មាន
សមុទ្រការពារ គឺសមុទ្រទុកជាកំផែងឬអី ៩ឯស្រុក
អេធីយ៉ូពី[ន] និងស្រុកអេស៊ីព្ទជាកំឡាំងរបស់គេ ហើយកំឡាំង
នោះក៏ប្រមាណមិនបានផង ស្រុកពូត[ប] និងស្រុកលីប៊ី[ផ] ជា
ជំនួយរបស់គេដែរ ១០ទោះបើយ៉ាងនោះ គង់តែគេត្រូវដឹក
នាំទៅជាឈ្លើយ[ព] កូនតូចៗរបស់គេត្រូវបោក[ភ]កំទេចនៅ
គ្រប់ទាំងក្បាលផ្លូវ ក៏បានបោះឆ្នោត[ម] ចាប់មនុស្សមាន
ត្រកូលខ្ពស់របស់គេ ហើយអស់អ្នកធំរបស់គេត្រូវជាប់
ច្រវាក់[យ] ១១ឯងនឹងត្រូវស្រវឹង[រ] ឯងនឹងពួនខ្លួន[ល] ហើយ
នឹងស្វែងរកទីពឹងជ្រក ឱ្យរួចពីខ្មាំងសត្រូវដែរ ១២អស់ទាំង
បន្ទាយរបស់ឯងនឹងបានដូចជាដើមល្វា ដែលមានផ្លែទុំជា
ដំបូង[វ] បើអ្នកណាអង្រួន នោះផ្លែ[ស]ក៏ជ្រុះ ចូលក្នុងមាត់របស់
អ្នកដែលស៊ី ១៣មើល ពួកជននៅក្នុងឯង សុទ្ធតែជាស្ត្រី
ទទេ[ហ] ទ្វារ[ឡ]ស្រុកឯងបើកពេញចំហ សំរាប់ខ្មាំងសត្រូវ
ភ្លើងបានឆេះរនុកឯងអស់ទៅ[អ] ១៤ចូរដងទឹកសំរាប់ ពេល
ដែលសត្រូវឡោមព័ទ្ធឯងចុះ[ក] ត្រូវឱ្យរៀបបន្ទាយឯង ឱ្យ
មាំមួនឡើង[ខ] ចូរចុះទៅជាន់លាយដីឥដ្ឋ ហើយជួសជុល
ឡឥដ្ឋឱ្យមាំមួន ១៥នៅទីនោះភ្លើង[គ]នឹងឆេះបន្សុសឯង ហើយ
ដាវ[ឃ]នឹងកាត់ឯងចេញ គឺនឹងស៊ីបង្ហិនឯងដូចជាដង្កូវ ចូរ
ចំរើនគ្នាឱ្យច្រើនឡើងដូចជាដង្កូវទៅ ត្រូវឱ្យមានគ្នាច្រើន
ដូចជាកណ្ដូបផង[ង] ១៦ឯងបានចំរើនពួកជំនួញរបស់ឯង ឱ្យ
មានច្រើនជាងផ្កាយនៅលើមេឃ តែដង្កូវ[ច]បានស៊ីបង្ហិន
រួចទៅបាត់ហើយ ១៧ពួកចៅហ្វាយរបស់ឯងប្រៀបដូច

**៣:៤** ឃ អស ៤៧:៩ ង អស ២៣:១៧ អគ ១៦:២៥–២៩ **៣:៥** ច ណហ ២:១៣ ឆ អស ២០:៤ យរ ១៣:២២ ជ អស ៤៧:៣ **៣:៦** ឈ នក ២៩:១៤ យប ៩:៣១ ញ ១សយ ២:៣០ យរ ៥១:៣៧ ដ អស ១៤:១៦ **៣:៧** ឋ អស ១៣:១៤ ៣១:៩ ឌ ណហ ១:១ ឍ យប ៣:១៤ ណ យរ ១៥:៥ ត អស ៥១:១៩ **៣:៨** ថ អម ៦:២ ទ យរ ៤៦:២៥ ធ អស ១៩:៦–៩ **៣:៩** ន លប ១០:៦ ២របា ១២:៣ ប អគ ២៧:១០ ផ អគ ៣០:៥ **៣:១០** ព អស ២០:៤ ភ ២ពវ ៨:១២ អស ១៣:១៦ ហស ១៣:១៦ ម យប ៦:២៧ អគ ២៤:៦ យ យរ ៤០:១ **៣:១១** រ អស ៤៩:២៦ ល អស ២:១០ **៣:១២** វ បស ២:១៣ ស អស ២៨:៤ **៣:១៣** ហ អស ១៩:១៦ ឡ ណហ ២:៦ អ អស ៤៥:២ **៣:១៤** ក ២របា ៣២:៤ ខ ណហ ២:១ **៣:១៥** គ អស ២៧:១ ឃ ២សយ ២:២៦ ង យរ ៥១:១៤ យអ ១:៤ **៣:១៦** ច នក ១០:១៣

**៣:៤** *ការកំផិត . . . ស្រីសិំផឹង* ការល្បួងនៃទ្រព្យសម្បត្តិ និងភាពហ៊ឺហារបាន នាំឱ្យមនុស្សជាច្រើនមកទីក្រុងនីនីវេ ប៉ុន្តែវាមិនខុសអ្វីពីការលួងលោមរបស់ពួកស្រីសិំផឹងនោះទេ គឺមិនអាចនាំឱ្យមានភាពសប្បាយពិតប្រាកដនៅក្នុងជីវិតបានទេ ។ *អំពើអាបធ្មប់ . . . របៀនអាបធ្មប់* គឺជាការប្រព្រឹត្ត និងជំនឿបែបអ្នកមិនជឿព្រះ (ចទ ១៨:១០ និងការពន្យល់ ១៨:៩) ។

**៣:៥** *សើយសំពត់ឯងឡើងគ្របមុខឯង* គឺជាការកាត់ទោសជាធម្មតាចំពោះពួកស្រីសិំផឹង និងពួកកំផិត (មើលការពន្យល់ អស ៤៧:៣ យរ ១៣:២២ ហស ២:៣,១០) ។

**៣:៧** *តើអ្នកណា . . . ឯណា . . .* គឺជាសំណួរបញ្ឈឺចិត្ត ។ ពួកអ្នកក្រុងនីនីវេនឹងមិនបានទទួលសេចក្ដីអាណិតអាសូរនោះទេ ។

**៣:៨** *នរ-អាម៉ូន* ពាក្យនេះមានន័យថា "ទីក្រុងនៃព្រះ (ព្រះក្លែងក្លាយ)"។ នរ-អាម៉ូន គឺជាទីក្រុងដ៏ធំនៅតំបន់ខាងត្បូងនៃប្រទេសអេស៊ីព្ទ ។ នៅសម័យនោះទីក្រុងនេះត្រូវកាន់កាប់ដោយទីក្រុងល័រស័រ និងកាណាក ។ ពួកសាសន៍អាសស៊ើរបានបំផ្លាញទីក្រុងនេះ នៅឆ្នាំ ៦៦៣ មុនគ.ស.។

**៣:៩** *ស្រុកពូត និងស្រុកលីប៊ី* មើលការពន្យល់ អគ ២៧:១០ ៣០:៥ (មើលការពន្យល់ លប ១០:៦ ផងដែរ) ។

**៣:១០** *កូនតូចៗរបស់គេត្រូវបោកកំទេច* មើល ទដ ១៣៧:៩ អស ១៣:១៦ ហស ១៣:១៦ និងការពន្យល់ ។ *អ្នកធំរបស់គេត្រូវជាប់ច្រវាក់* ស្ដេចស្រុកអាសស៊ើតែងតែធ្វើដូចនេះចំពោះអ្នកធំរបស់សត្រូវ ដោយដាក់ច្រវាក់ដូចផ្ដែ ហើយឃុំក្នុងទ្រុងផ្ដែនៅទ្វារខាងកើតនៃក្រុងនីនីវេ ។

**៣:១១** *នឹងត្រូវស្រវឹង* ប្រហែលជាស្រវឹងដោយផឹកពីពែងនៃសេចក្ដីក្រោធនៃព្រះ (មើល អស ៥១:១៧ យរ ២៥:១៥ និងការពន្យល់) ។

**៣:១២** *ដូចជាដើមល្វា ដែលមានផ្លែទុំជាដំបូង* គឺជាការប្រៀបធៀបអំពីការស្រេកឃ្លានដែលពួកឈ្នះមាននៅក្នុងការប្រមូលរឹបពីក្រុងនីនីវេ ។ *ផ្លែក៏ជ្រុះចូលក្នុងមាត់របស់អ្នកដែលស៊ី* ទីមាំមួននៃក្រុងនីនីវេនឹងត្រូវដួលរលំយ៉ាងងាយដូចផ្លែល្វាជ្រុះ ។

**៣:១៣** *ពួកជននៅក្នុងឯង សុទ្ធតែជាស្ត្រី* គឺជាពួកអ្នកដែលទន់ខ្សោយ មិនអាចទប់ទល់នឹងទាហានឈ្លានពានបានឡើយ ។ *ភ្លើងបានឆេះរនុក* គឺរនុកទ្វារក្រុង ។

**៣:១៤** *ដងទឹក* គឺជាការត្រៀមខ្លួនជាធម្មតាសម្រាប់ការលោមព័ទ្ធរបស់សត្រូវ ។ *ត្រូវរៀបបន្ទាយឯងឱ្យមាំមួនឡើង* គឺជាពាក្យចំអកឱ្យ ដែលមានន័យថា ការរៀបបន្ទាយនោះគឺគ្មានប្រយោជន៍អ្វីទេ (មើល ២:១ និងការពន្យល់) ។

**៣:១៥** *នៅទីនោះ* គឺមានន័យថា នៅក្នុងទីមាំមួនរបស់ឯង ។ *ភ្លើងនឹងឆេះបន្សុសឯង* តាមការបញ្ជាក់របស់ប្រវត្តិសាស្ត្រ និងបុរាណវត្ថុវិទ្យា ស្ដេចអាសស៊ើរត្រូវស្លាប់នៅក្នុងភ្លើងឆេះព្រះរាជវាំងរបស់ទ្រង់ ។

**៣:១៦** *ពួកជំនួញរបស់ឯង ឱ្យមានច្រើនជាងផ្កាយនៅលើមេឃ* ត្រង់ចំណុចនេះគឺនិយាយអំពីជំនួញដ៏ធំមហិមារបស់សាសន៍អាសស៊ើរ ។

ជាចង្រិត[ឆ] ហើយពួកមេទ័ពរបស់ឯងក៏ដូចជាហ្វូងកណ្តូប
ដែលទំនៅរបងក្នុងពេលថ្ងៃរងា តែកាលណាថ្ងៃរះឡើង
នោះវាហើរបាត់ទៅ ហើយកន្លែងដែលទៅទំនៅនោះគ្មាន
អ្នកណាដឹងទេ ១៨ឱស្តេចសាសន៍អាសស៊ើរ អើយពួកអ្នក
គង្វាលរបស់ឯង[ជ] គេដេកលក់អស់ហើយ[ឈ] ពួកអ្នកមាន
ត្រកូលខ្ពស់ ក៏សំរាក រាស្ត្ររបស់ឯងត្រូវខ្ចាត់ខ្ចាយ[ញ] ទៅ
លើភ្នំ ឥតមានអ្នកណានឹងប្រមូលគេឡើយ ១៩គ្មានអ្វីនឹង
ធ្វើឱ្យទីឈឺរបស់ឯងអន់ស្រាកបានទេ[ដ] របួសឯងធ្ងន់ណាស់
អស់អ្នកដែលឮដំណឹងពីឯង គេទះដៃ[ឋ]អរ ដ្បិតតើមានអ្នក
ឯណាដែលមិនត្រូវអំពើកំណាចរបស់ឯងជានិច្ចនោះ[ឌ]។/

**៣:១៧** ឆ យរ ៥១:២៧
**៣:១៨** ជ ទដ ៧៦:៥–៦ យរ ២៥:២៧ ឈ អស ៥៦:១០ ញ ១ពវ ២២:១៧
**៣:១៩** ដ យរ ៣០:១៣ មីក ១:៩ ឋ យប ២៧:២៣ បទ ២:១៥ សផ ២:១៥ ឌ អស ៣៧:១៨

**៣:១៧** *កណ្តូប* ពួកអ្នកស្រែនៅមជ្ឈិមបូព៌ាមានការភ័យខ្លាចចំពោះពួកគេ ដោយសារពួកគេចេញទៅជាហ្វូងធំៗ ហើយស៊ីបំផ្លាញអស់ទាំងអ្វីៗដែលនៅតាមផ្លូវ ។ ការនោះក៏បាននិយាយប្រៀបធៀបផងដែរ អំពីការកេងប្រវ័ញ្ចរបស់ពួកមន្ត្រីក្រុងនីនីវេ នៅពេលដែលទីក្រុងនេះកំពុងតែដួលរលំ ។ *នោះគ្មានអ្នកណាដឹងទេ* មានន័យថាពួកមន្ត្រីទីក្រុងនីនីវេត្រូវបាត់ខ្លួនដោយមិនបន្សល់ដាន ។ ជាក់ស្តែង អស់រយៈពេលជាច្រើនសតវត្ស គ្មាននរណាម្នាក់ដឹងថា ទីក្រុងនីនីវេត្រូវកប់បាត់នៅកន្លែងណាទេ តែនៅទីបញ្ចប់ពួកបុរាណវត្ថុវិទ្យាបានរកឃើញទីក្រុងនេះនៅក្នុងឆ្នាំ ១៨៤៥ (មើលការពន្យល់ សផ ២:១៣) ។

**៣:១៨** *ស្តេច* ស្តេចនៃចក្រភពអាសស៊ើរនៅក្នុងសម័យនោះ មានព្រះនាមស៊ីនសាអ៊ីសគុណ (Shin-Sha-Ishkun ) ។ *ពួកអ្នកគង្វាល* គឺជាអ្នកដឹកនាំ (មើល យរ ២:៨ និងការពន្យល់) ។ *ក៏សំរាក* មានន័យថា ស្លាប់ ។ *រាស្ត្ររបស់ឯងត្រូវខ្ចាត់ខ្ចាយទៅ* ប្រជាជនត្រូវរត់ភាសខ្លួនពីទីក្រុងនីនីវេ នៅក្នុងពេលនៃការបំផ្លាញ ។

**៣:១៩** *របួសឯងធ្ងន់ណាស់* ទីក្រុងនីនីវេត្រូវទទួលរងការបំផ្លិចបំផ្លាញទាំងស្រុង ដែលមិនដែលមានអ្នកណាសង់ឡើងវិញ ហើយត្រូវកប់នៅក្រោមខ្សាច់ដែលរសាត់តាមខ្យល់អស់រយៈពេលពីរបីរសតវត្ស ។ ដូចនេះ "ទីក្រុងដ៏ធំ" នេះ (យណ ១:២ ៣:២ ៤:១១ និងការពន្យល់ យណ ៣:៣) ត្រូវដួលរលំនៅឆ្នាំ ៦១២ មុនគ.ស. ហើយមិនអាចងើបវិញបាន គឺបានបង្ហាញថា ព្រះបន្ទូលព្រះត្រូវបានសម្រេចតាមរយៈហោរារបស់ទ្រង់ គឺលោកណាហ៊ុម ។ *អំពើកំណាចរបស់ឯងជានិច្ចនោះ* អំពើកំណាចរបស់ពួកគេត្រូវទទួលមកវិញនូវសេចក្តីហិនវិនាសជារៀងរហូត ។

# ព្រះគម្ពីរហាបាគុក

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ

លោកហាបាគុកគឺជាហោរាដែលរស់នៅក្នុងសម័យជាមួយនឹងលោកយេរេមា ហើយគឺជាបុរសដែលមានជំនឿខ្លាំង ដែលបានចាក់ឫសចូលជ្រៅក្នុងប្រពៃណីយរបស់សាសន៍អ៊ីស្រាអែល ។

### កាលបរិច្ឆេទ

លោកហាបាគុកបានថ្លែងទំនាយអំពីការជិតមកដល់នៃការឈ្លានពានរបស់ចក្រភពបាប៊ីឡូន (១:៦) ដែលបង្ហាញថា លោករស់នៅក្នុងស្រុកយូដារហូតដល់ចុងបញ្ចប់នៃរាជ្យស្ដេចយ៉ូសៀស (ឆ្នាំ ៦៤០–៦០៩ មុនគ.ស.) ឬនៅដើមរាជ្យនៃស្ដេចយេហូយ៉ាគីម (ឆ្នាំ ៦០៩–៥៩៨ មុនគ.ស.) ។ បទទំនាយនេះត្រូវបានធ្វើឡើងនៅមុនសម័យសង្គ្រាមកើកេមីសបន្តិច ឬនៅក្រោយសម័យសង្គ្រាមនេះ (ឆ្នាំ ៦០៥ មុនគ.ស.) ។ សង្គ្រាមនេះកើតឡើង នៅពេលដែលកងទ័ពអេស៊ីព្ទដែលបញ្ជូនជាជំនួយដល់ស្ដេចប្រទេសអាសស៊ើកាលពីមុន ត្រូវចាំស្កាត់វាយតាមផ្លូវ ដោយកងទ័ពបាប៊ីឡូនដឹកនាំដោយស្ដេចណាបូប៉ូលាសា និងនេប៊ូក្នេសា ហើយត្រូវបានដេញតាមរហូតដល់ព្រំប្រទល់ប្រទេសអេស៊ីព្ទ (យរ ៤៦) ។ លោកហាបាគុកប្រហែលជាបានរស់នៅ ហើយឃើញការសម្រេចបទទំនាយនេះ នៅពេលដែលក្រុងយេរូសាឡិមត្រូវពួកបាប៊ីឡូន វាយលុកនៅឆ្នាំ ៥៩៧ មុនគ.ស. ។

### ខ្លឹមសារនៃវិជ្ជាសិក្សាអំពីព្រះ

នៅក្នុងចំណោមព្រះគម្ពីរពួកហោរា ព្រះគម្ពីរហាបាគុកមានលក្ខណៈខុសពីគេ ដោយសារព្រះគម្ពីរនេះមិនមាននិយាយអំពីព្រះបន្ទូលដ៏ធ្ងន់ដែលព្រះអម្ចាស់មានចំពោះសាសន៍អ៊ីស្រាអែលទេ ។ ព្រះគម្ពីរនេះនិយាយអំពី ការសន្ទនារវាងលោកហោរា និងព្រះអម្ចាស់ (មើលគម្រោងសង្ខេប) ។ នៅក្នុងពីរជំពូកដំបូង លោកហាបាគុកប្រកែកជាមួយនឹងព្រះអម្ចាស់អំពីវិធីដោះស្រាយរបស់ទ្រង់ដែលលោកមិនអាចយល់ដល់ តែលោកមិនបានថាជាវិធីមិនយុត្តិធម៌នោះឡើយ (ព្រះគម្ពីរយ៉ូណាសបានរៀបរាប់អំពីការដែលហោរារបស់ព្រះអម្ចាស់ម្នាក់មាន ការមិនយល់ស្របនឹងព្រះទ័យទ្រង់) ។ នៅពេលដែលលោកបានទទួលចម្លើយពីព្រះអង្គ លោកបានឆ្លើយតបវិញដោយការបង្ហាញយ៉ាងច្បាស់លាស់អំពីសេចក្ដីជំនឿ (ជំពូក ៣) ។

ទោះជាយ៉ាងណាក៏ដោយ លោកហាបាគុកបានកត់ត្រាទុកនូវការដែលលោកសន្ទនាជាមួយនឹងព្រះអម្ចាស់ ហើយបានចែកផ្សាយការនេះទៅដល់រាស្ត្ររបស់ទ្រង់ ។ ការសន្ទនានេះគឺត្រូវបានធ្វើឡើងជាតំណាងឱ្យពួកអ្នកកោតខ្លាចព្រះនៅស្រុកយូដា ដែលខិតខំស្វែងយល់អំពីវិធីដោះស្រាយរបស់ព្រះអម្ចាស់ ។ ព្រះអម្ចាស់ទ្រង់បានប្រទាននូវចម្លើយចំពោះអស់អ្នកដែលមានសេចក្ដីចម្ងល់ដូចជាលោកហាបាគុកដែរ ។ ហើយលោកហាបាគុកក៏បានថ្លែងទំនាយនោះទៅដល់បណ្ដាជន ដូចដែលមាននិយាយជាបទទំនុកតម្កើង (មើលការពន្យល់ ៣:១) ។

លោកហាបាគុកមានចិត្តតប់ប្រមល់ នៅពេលដែលពួកមនុស្សអាក្រក់ ជម្លោះ និងការគាបសង្កត់មានការចំរើនឡើងនៅស្រុកយូដា ប៉ុន្តែព្រះអម្ចាស់ទ្រង់ហាក់ដូចជាធ្វើអ្វីសោះទៅវិញ ។ នៅពេលដែលលោកហាបាគុកបានដឹងថា ព្រះអម្ចាស់ទ្រង់កំពុងតែរៀបចំវិធីដោះស្រាយរបស់ទ្រង់ ដោយប្រើពួកសាសន៍បាប៊ីឡូនដែលគ្មានក្ដីមេត្តា (១:៦) លោកមានការតប់ប្រមល់កាន់តែខ្លាំង ដោយពោលថា ហេតុអ្វីបានជាព្រះអម្ចាស់ "ដែលបរិសុទ្ធ មិនអាចទតមើលការអាក្រក់បាន" (១:១៣) ទ្រង់ចាត់សាសន៍មួយឱ្យធ្វើជា "អ្នកកាត់ទោស" (១:១២) លើរាស្ត្ររបស់ទ្រង់ដែល "បរិសុទ្ធជាងសាសន៍នោះទៅទៀត" (១:១៣)?

ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់ទ្រង់បានបង្ហាញយ៉ាងច្បាស់ថា ពួកបំផ្លាញដែលទុច្ចរិតទាំងនោះ និងត្រូវទទួលរងការបំផ្លាញវិញផងដែរ ។ នៅទីបញ្ចប់ លោកហាបាគុកបានរៀនសម្រាកនៅក្នុងការរៀបចំរបស់ព្រះអម្ចាស់ ហើយរង់ចាំដោយវិញ្ញាណនៃការថ្វាយបង្គំ នៅក្នុងការដែលទ្រង់នឹងធ្វើ ។ លោកបានរៀនរង់ចាំ ដោយអត់ធ្មត់នៅក្នុងសេចក្ដីជំនឿ (២:៣-៤) ចំពោះនគររបស់ព្រះដែលត្រូវបង្ហាញឱ្យឃើញជាសកល (២:១៤) ។ មើលការពន្យល់ ៣:១៨-១៩ ។

### លក្ខណៈអក្សរសាស្ត្រ

អ្នកនិពន្ធបានសរសេរយ៉ាងច្បាស់លាស់ និងដោយចិត្តឆេះឆួលខ្លាំង ហើយលោកបានសរសេរនូវឃ្លាដែលគួរឱ្យចងចាំជាច្រើន (២:២,៤,១៤,២០ ៣:២,១៧-១៩) ។ ព្រះគម្ពីរនេះមានប្រជាប្រិយភាព នៅក្នុងសម័យចន្លោះគ្រាសញ្ញា ហើយគេបានរកឃើញឯកសារ

ពន្យល់អំពីអត្ថបទពីរជំពូកដំបូងនៃព្រះគម្ពីរនេះ នៅក្នុងចំណោមឯកសារក្រាំងសមុទ្រស្លាប់ ។

**គម្រោងសង្ខេប**

I. ចំណងជើង (១:១)

II. ការរអ៊ូរទាំដំបូងរបស់លោកហាបាគុក: ហេតុអ្វីបានជាពួកមនុស្សអាក្រក់នៅស្រុកយូដា មិនបានទទួលទោស (១:២–៤)

III. ចម្លើយរបស់ព្រះ: ពួកសាសន៍បាប៊ីឡូននឹងជំនុំជម្រះពួកសាសន៍យូដា (១:៥–១១)

IV. ការរអ៊ូរទាំទីពីររបស់លោកហាបាគុក: ហេតុអ្វីបានជាព្រះដ៏យុត្តិធម៌ ប្រើសាសន៍មិនសុចរិតឱ្យមកជំនុំជម្រះរាស្ត្រដែលសុចរិតជាង (១:១២–២:១)

V. ចម្លើយរបស់ព្រះ: ពួកសាសន៍បាប៊ីឡូននឹងត្រូវទទួលការជំនុំជម្រះ ហើយអ្នកមានជំនឿនឹងបានទទួលរង្វាន់ (២:២–២០)

VI. សេចក្តីអធិស្ឋានរបស់លោកហាបាគុក: ក្រោយពីបានទូលសូមឱ្យព្រះទ្រង់សម្តែងនូវសេចក្តីក្រោធ និងសេចក្តីមេត្តាករុណារបស់ទ្រង់ហើយ (ដូចដែលលោកបានឃើញកាលពីមុន) លោកបានបញ្ចប់ព្រះគម្ពីរនេះដោយ ការបង្ហាញអំពីសេចក្តីជំនឿ និងសេចក្តីអំណរក្នុងព្រះអម្ចាស់ (ជំពូក៣)

**១** ១ នេះជាសេចក្ដីទំនាយយ៉ាងធ្ងន់[ក] ដែលហោរាហាបាគុក
បានឃើញ ។

## ការត្អូញត្អែររបស់លោកហាបាគុក

២ ឱព្រះយេហូវ៉ាអើយ តើត្រូវឱ្យទូលបង្គំអំពាវនាវដល់
កាលណាទៀត[ខ] ឥតទ្រង់ឆ្លើយតបសោះដូច្នេះ[គ] ទូលបង្គំ
ស្រែកដល់ទ្រង់អំពីការច្រឡោត តែទ្រង់មិនជួយសង្គ្រោះ
ឡើយ[ឃ]
៣ ហេតុអ្វីបានជាទ្រង់ឱ្យទូលបង្គំឃើញអំពើទុច្ចរិត
ហើយឱ្យទូលបង្គំមើលឃើញ[ង]តែសេចក្ដីទំនាស់ចិត្តដូច្នេះ[ច]
ដ្បិតមានសុទ្ធតែការបំផ្លាញ និងការច្រឡោត[ឆ]នៅមុខទូល
បង្គំ ក៏មានសេចក្ដីឈ្លោះប្រកែក[ជ] និងការទាស់ទែងគ្នា
កើតឡើង
៤ ហេតុដូច្នេះ បញ្ញត្តច្បាប់[ឈ]បានអន់ថយទៅ
ហើយសេចក្ដីយុត្តិធម៌មិនលេចមកឱ្យឃើញឡើយ ដ្បិត
មនុស្សអាក្រក់ឡោមព័ទ្ធមនុស្សសុចរិត បានជាសេចក្ដី
យុត្តិធម៌[ញ]ចេញមកខូចហើយ[ដ]។

## ការឆ្លើយតបរបស់ព្រះអម្ចាស់

៥ ចូរពិចារណាមើល ក្នុងសាសន៍ដទៃទាំងប៉ុន្មាន ចូរ
មើលទៅ ហើយមានសេចក្ដីអស្ចារ្យដ៏ពន្លឹកចុះ[ឋ] ដ្បិតនៅ
ក្នុងជំនាន់របស់ឯងនេះ អញកំពុងតែធ្វើការ១ ដែលឯង
រាល់គ្នាមិនព្រមជឿទេ ទោះបើមានគេប្រាប់ក៏ដោយ[ឌ]
៦ ដ្បិត
មើល អញនឹងតាំងសាសន៍ខាល់ដេឡើង[ឍ] ជាសាសន៍ដែល
មួម៉ៅ ហើយរហ័សរហាល់ គេនឹងលើកគ្នាដើរកាត់ផែនដី
ទាំងមូល[ណ] ដើម្បីនឹងចាប់យកទីលំនៅ ដែលមិនមែនជា
របស់ផងខ្លួន[ត]
៧ គេគួរស្ញែងខ្លាច ហើយមានភាពគួរស្ញើម[ថ]
សេចក្ដីយុត្តិធម៌ និងយសសក្តិរបស់គេ នោះមកតែពីខ្លួន
គេទេ
៨ ឯសេះរបស់គេ ក៏លឿនជាង[ទ]ខ្លារខិន ហើយ
សាហាវជាងឆ្កែព្រៃ[ធ] ដែលចេញនៅពេលល្ងាចផង ពួក
ទ័ពសេះរបស់គេ សំរុកចូលដោយឥតញញើត អើ ពួក
ពលសេះរបស់គេមកពីឆ្ងាយ គេលឿនដូចជាឥន្ទ្រីដែល
រហ័សហើរទៅហែកស៊ី
៩ គេសុទ្ធតែមកដើម្បីរឹបជាន់មុខ
គេរកតែទៅខាងមុខទៀត គេប្រមូលបានឈ្លើយ[ន]ដូចជា

**១:១** ក ណហ ១:១
**១:២** ខ ទដ ៦:៣
គ ទដ ១៣:១–២
២២:១–២
ឃ យរ ១៤:៩
សក ១:១២
**១:៣** ង ខ.១៣
ច យប ៩:២៣
ឆ យរ ២០:៨
ជ ទដ ៥៥:៩
**១:៤** ឈ ទដ
១១៩:១២៦
ញ អស ២៩:២១
ដ យប ១៩:៧
អស ១:២៣ ៥:២០
អគ ៩:៩
**១:៥** ឋ អស ២៩:៩
ឌ កច ១៣:៤១
**១:៦** ឍ ចទ ២៨:៤៩
២ពវ ២៤:២
ណ វវ ២០:៩
ត យរ ១៣:២០ ២១:៧ **១:៧** ថ អស ១៨:៧ យរ ៣៩:៥–៩ **១:៨** ទ យរ ៤:១៣
ធ លប ៤៨:២៧ **១:៩** ន ហាព ២:៥

**១:១** *សេចក្ដីទំនាយទាយយ៉ាងធ្ងន់* នៅក្នុងព្រះគម្ពីរនេះមានសេចក្ដីទំនាយយ៉ាងធ្ងន់ពីរ (ខ.៥–១១ ២:២–២០) ។ ជាញឹកញាប់ព្រះគម្ពីរហេព្រើប្រើពាក្យ "សេចក្ដីទំនាយយ៉ាងធ្ងន់"(អាចមានន័យថា "បន្ទុក" ប៉ុន្តែប្រហែលគ្រាន់តែមានន័យថា "សេចក្ដីប្រកាស"ប៉ុណ្ណោះ) សំដៅទៅលើការបើកសំដែងអំពីសេចក្ដីហិនវិនាសដែលជិតមកដល់(មើល ១៣:១ និងការពន្យល់ អស ១៥:១ ១៩:១ ២២:១) ប៉ុន្តែនៅក្នុង សក ៩:១ ១២:១ មឡ ១:១ ពាក្យនេះគឺសំដៅទៅលើព្រះបន្ទូលដែលបង្កប់សេចក្ដីសង្ឃឹម ។ *ហាបាគុក* ឈ្មោះនេះប្រហែលជាភាសាសាសន៍បាប៊ីឡូន ដែលសំដៅទៅលើរុក្ខជាតិម្យ៉ាងនៅក្នុងសួនច្បារ ។ *ហោរា* នៅក្នុង ៣:១ ក៏បានហៅលោកហាបាគុកថាជាហោរាផងដែរ ហើយការនេះបានតភ្ជាប់ជំពូក ៣ ជាមួយនឹងជំពូក ១ និងជំពូក ២ ។ មើលការពន្យល់ នក ៣:៤ ៧:១–២ ១ពវ ២២:១៩ យហ ៣:២ សក ៣:១ ។

**១:២–២:២០** វគ្គនេះគឺនិយាយអំពី សេចក្ដីសន្ទនារវាងលោកហោរា និងព្រះអម្ចាស់ ។ ខ្លឹមសារនៃវគ្គនេះគឺចោទសួរនូវសំណួរដែលធ្លាប់មានតាំងពីយូរណាស់មកហើយថាតើ ហេតុអ្វីបានជាមនុស្សអាក្រក់ហាក់ដូចជាមិនបានទទួលការដាក់ទោសសោះ? ហេតុអ្វីបានជាព្រះអម្ចាស់មិនឆ្លើយតបចំពោះសេចក្ដីអធិស្ឋាន?

**១:២** . . . *ដល់កាលណាទៀត?* មើល ៦:៣ និងការពន្យល់, ១៣:១–២ ២២:១–២ ។ *ការច្រឡោត* នៅពេលនោះ សាសន៍យូដាប្រហែលជាស្ថិតនៅក្រោមការដឹកនាំរបស់ស្តេចយេហូយ៉ាគីម ដែលជាស្តេចលោភលន់សាហាវ និងពុករលួយ ។ លោកហាបាគុកបានបកស្រាយអំពី សេចក្ដីពុករលួយនៅក្នុងសង្គម និងការបោះបង់ចោលសេចក្ដីជំនឿរបស់ពួកយូដានៅក្នុងចុងសតវត្សទី៧ មុនគ.ស.។

**១:៣** *ទ្រង់ឱ្យ* មើល ខ.១៣ ។ លោកហាបាគុកមានការភ្ញាក់ផ្អើល នៅពេលដែលព្រះអម្ចាស់ទ្រង់ហាក់ដូចជាទទួលស្គាល់សេចក្ដីឃោរឃៅ និងអំពើហឹង្សា ។ *ការបំផ្លាញ និងការច្រឡោតនៅមុខទូលបង្គំ* លោកយេរេមាបានទូលនូវពាក្យដ៏អួញអំពីសេចក្ដីស្រដៀងគ្នានេះផងដែរ (យរ ២០:៨) ។

**១:៤** *បញ្ញត្តច្បាប់បានអន់ថយទៅ ហើយសេចក្ដីយុត្តិធម៌* គឺដោយសារពួកម្ចាស់ដីដែលជាអ្នកមានបានកាន់កាប់តុលាការតាមរយៈការសូកប៉ាន់ (មើល មីក ៣:១១ ៧:៣) ។

**១:៥** លោកសាវ័កប៉ុលបានបញ្ចប់ការចែកចាយព្រះបន្ទូលនៅក្រុងអាន់ទីយ៉ូកដោយដកស្រង់នូវខនៃព្រះគម្ពីរនេះ(កច ១៣:៤១) ។ *របស់ឯង . . . ឯងរាល់គ្នា . . .* ពាក្យនេះគឺសំដៅទៅលើពួកយូដាទាំងអស់គ្នា ។ *មិនព្រមជឿទេ* សម្រាប់ពួកសាសន៍យូដា ពួកគេមិនព្រមជឿទេថា ព្រះអម្ចាស់ទ្រង់នឹងប្រគល់ពួកគេទៅក្នុងកណ្ដាប់ដៃពួកសាសន៍បាប៊ីឡូនដ៏ក្រអឺតក្រទមឡើយ ។

**១:៦** *អញនឹងតាំងសាសន៍ខាល់ដេឡើង* មើល អស ១០:៥–៦ និងការពន្យល់ ១០:៥ ។ ការឈ្លានពានរបស់ពួកសាសន៍បាប៊ីឡូននឹងបានជាការជំនុំជម្រះពួកយូដាដែលជាសាសន៍ក្បត់ព្រះអម្ចាស់ ។ ពួកបាប៊ីឡូនគឺជាសាសន៍ដ៏ខ្លាំងពូកែ ដែលបានទាមទារនូវឯករាជ្យពីសាសន៍អាសស៊ើរនៅឆ្នាំ ៦២៦ មុនគ.ស. ហើយបានបំផ្លាញអំណាចរបស់ពួកអាសស៊ើរទាំងស្រុកនៅឆ្នាំ ៦១២ ដល់ ៦០៥ មុនគ.ស. ព្រមទាំងបានមានភាពរុងរឿងឡើងរហូតដល់ឆ្នាំ ៥៣៩ មុនគ.ស.។ នៅក្នុងបទគម្ពីរនេះ សាសន៍ខាល់ដេអាចហៅបានម្យ៉ាងទៀតថាសាសន៍បាប៊ីឡូន ។ *ចាប់យកទីលំនៅ* មើល ២:៦–៨ ។

**១:៧** *យសសក្តិរបស់គេ នោះមកតែពីខ្លួនគេ* ត្រង់ចំណុចនេះគឺបង្ហាញអំពីសេចក្ដីក្រអឺតក្រទមរបស់ពួកគេ ។

**១:៨** ល្បឿននៃការដែលពួកបាប៊ីឡូនវាយកាន់កាប់សត្រូវរបស់ខ្លួនបាននាំឱ្យមានការប្រៀបធៀបដូចជាសុភាសិត ។ *ឥន្ទ្រី* ពាក្យនេះនៅក្នុងព្រះគម្ពីរហេព្រើក៏អាចមានន័យថា "ត្មាតផងដែរ"(មើល ចទ ២៨:៤៩–៥០ និងការពន្យល់ ២៨:៤៩) ។

**១:៩** *រឹបជាន់* សេចក្ដីលោភលន់ និងចរិកឈ្លានពានដ៏ឃោរឃៅរបស់ពួក

ខ្សាច់ ១០អើគេឡកឡឺយឱ្យអស់ទាំងស្តេច ហើយយកពួកចៅ
ហ្វាយជាទីមើលងាយ[ប] គេសើចចំពោះអស់ទាំងទីមាំមួន
ដ្បិតគេនឹងគ្រាន់តែពូនធូលីដី[ផ]ឡើង ចាប់យកបានហើយ
១១រួចបោសហួសទៅដូចជាខ្យល់[ព] ហើយកន្លងទៅ ព្រម
ទាំងនាំឱ្យខ្លួនមានទោស គឺគេនឹងយកកំឡាំងរបស់ខ្លួនទុក
ជាព្រះ[ភ] ។

## ការតូញត្អែរជាលើកទីពីររបស់លោកហាបាគុក

១២ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំ ជាព្រះដ៏បរិសុទ្ធ[ម]
នៃទូលបង្គំអើយ តើទ្រង់មិនគង់នៅតាំងពីអស់កល្បរៀង
មកទេឬអី[យ] យើងខ្ញុំរាល់គ្នានឹងមិនស្លាប់ទេ[រ] ឱព្រះយេហូវ៉ា
អើយ ទ្រង់បានដំរូវទុក[ល]គេឱ្យត្រូវជំនុំជំរះ ហើយឱថ្មដា
អើយ[វ] ទ្រង់បានតាំងគេឡើង ដើម្បីវាយផ្ចាល ១៣ទ្រង់មាន
ព្រះនេត្របរិសុទ្ធក្រៃលែង[ស]នឹងទតមើលការអាក្រក់មិន
បាន ក៏នឹងពិនិត្យមើលការទុច្ចរិតមិនបានដែរ[ហ] ហេតុអ្វីបាន
ជាទ្រង់ទតមើល[ឡ]ចំពោះពួកអ្នកដែលប្រព្រឹត្តកម្បថ[អ] ហើយ
នៅតែសៀម ក្នុងកាលដែលពួកអ្នកអាក្រក់លេបមនុស្ស
ដែលសុចរិតជាងខ្លួនបាត់ទៅដូច្នេះ[ក] ១៤គឺធ្វើឱ្យមនុស្សបាន
ដូចជាត្រីនៅសមុទ្រ ឬដូចជាសត្វលូនវារដែលគ្មានអ្នក
ណាគ្រប់គ្រងរក្សាសោះ ១៥គេ[ខ]ស្ទួចចាប់យកទាំងអស់[គ]
ក៏ចាប់ដោយសំណាញ់ ហើយកៀរយកដោយអួន[ឃ] ដូច្នេះគេ
មានចិត្តរីករាយ ហើយអរសប្បាយ ១៦ហេតុនោះបាន
ជាគេថ្វាយយញ្ញបូជាដល់សំណាញ់របស់គេ ហើយដុត
កំញាន[ង] ថ្វាយដល់អួន ពីព្រោះចំណែករបស់គេបានធំឡើង
ហើយគេមានអាហារជាបរិបូរ ដោយសាររបស់ទាំងនោះ
១៧ដូច្នេះ តើគេនឹងចេះតែចាក់ចេញពីអួន ហើយសំឡាប់
អស់ទាំងសាសន៍ឥតប្រណីជានិច្ចឬ[ច] ។

២ ១ខ្ញុំនឹងនៅត្រង់ទីចាំយាម[ក] ខ្ញុំនឹងឡើងទៅលើប៉ម[ខ]
ហើយខំមើលទៅ ដើម្បីឱ្យដឹងជាទ្រង់នឹងមានបន្ទូល[គ]មក
ដូចម្តេច ហើយនិងឆ្លើយពីដំណើរដែលខ្ញុំចោទប្រកាន់ជា
យ៉ាងណា[ឃ] ។

## ការឆ្លើយតបរបស់ព្រះអម្ចាស់

២នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលតបមកខ្ញុំថា ចូរកត់[ង]
ការជាក់ស្តែងនេះទុក ត្រូវឱ្យចារិកឱ្យច្បាស់នៅលើ ក្តារចុះ
ដើម្បីឱ្យមនុស្សដែលកំពុងរត់ ក៏អាចមើលបានដែរ ៣ដ្បិត
ការជាក់ស្តែងនេះ ទុកសំរាប់ដល់វេលាកំណត់[ច] ក៏កំពុង
ស្រូតឱ្យដល់ពេលនោះហើយ[ឆ] នៅគ្រានោះនឹងមិន កុហក

**១:១០** ប ២រប ៣៦:៦ ផ យរ ៣៣:៤ **១:១១** ព យរ ៤:១១–១២ ភ ដយ ៤:៣០ **១:១២** ម អស ៣១:១ ៣៧:២៣យ លប ២១:៣៣ រ ទដ ១១៨:១៧ ល អស ១០:៦ វ លប ៤៩:២៤ នក ៣៣:២២ **១:១៣** ស ទដ ១៨:២៦ ហ បទ ៣:៣៤–៣៦ ឡ ខ.៣ អ ទដ ២៥:៣ ក យប ២១:៧ **១:១៥** ខ យរ ៥:២៦ គ អស ១៩:៨ ឃ យប ១៨:៨ យរ ១៦:១៦ **១:១៦** ង យរ ៤៤:៨ **១:១៧** ច អស ១៤:៦ ១៩:៨ **២:១** ក អស ២១:៨ ខ ទដ ៤៨:១៣ គ ទដ ៨៥:៨ ឃ ទដ ៥:៣ អគ ៣:១៧ **២:២** ង អស ៣៩:៨ យរ ៣៦:២ អគ ២៤:២ រម ៤:២៤ វវ ១:១៩ **២:៣** ច ដយ ១១:២៧ ឆ ដយ ៨:១៧

បាប៊ីឡូន គឺខ្លាំងជាងពួកសាសន៍យូដាទៅទៀត (មើល ខ.២ និងការពន្យល់, មើល ខ.៣ដែរ) ។ *ប្រមូលបានឈ្លើយដូចជាខ្សាច់* ពួកបាប៊ីឡូនធ្វើនិរទេសប្រជាជនដែលស្ថិតនៅក្រោមការកាន់កាប់ ជាគោលនយោបាយក្នុងប្រទេសដែលមិនខុសអ្វីពីពួកសាសន៍អាសស៊ើរដែលដឹកនាំកាលពីមុននោះទេ ។

**១:១០** *ពូនធូលីដីឡើង* គឺជាវិធីលោមព័ទ្ធម្យ៉ាងនៅក្នុងសឹកសង្គ្រាម ។

**១:១១** *គេនឹងយកកំឡាំងរបស់ខ្លួនទុកជាព្រះ* ពួកសាសន៍បាប៊ីឡូនមានមោទនះភាពយ៉ាងខ្លាំង និងទុកចិត្តចំពោះអំណាចទាហានរបស់ពួកគេ ហើយការនេះត្រូវក្លាយជាព្រះរបស់ពួកគេ (មើល ខ.១៦) ។

**១:១២** លោកហាបាគុកមិនអាចមើលឃើញថា ការកាត់ទោសពួកយូដាដោយសាសន៍ដែលអាក្រក់ជាងសាសន៍យូដា ជាការដែលមានយុត្តិធម៌នោះទេ ហើយលោកយល់ឃើញថា មិនគួរបណ្តោយឱ្យពួកសាសន៍បាប៊ីឡូនគ្រប់គ្រងសាសន៍យូដាទាំងស្រុងនោះឡើយ ។ *អស់កល្បរៀងមក* មើល ទដ ៩០:២ ។ *ទ្រង់បានដំរូវទុកគេឱ្យត្រូវជំនុំជំរះ* លោកហាបាគុកទទួលស្គាល់ថាព្រះអម្ចាស់ទ្រង់បានប្រើសាសន៍បាប៊ីឡូនជាភ្នាក់ងារសម្រាប់ធ្វើការជំនុំជម្រះ (ធៀប អស ៧:១៨–២០ ៤៤:២៨–៤៥:១) ។ *ថ្មដា* មើល ១សយ ២:២ និងការពន្យល់ ។

**១:១៣** បទគម្ពីរនេះលើកឡើងអំពីបញ្ហាដែលបានចោទសួរតាំងពីយូណាស់មកហើយអំពីសេចក្តីអាក្រក់ ដែលទាក់ទងនឹងសេចក្តីជំនឿរបស់ពួកអ៊ីស្រា–អែល ថាតើហេតុអ្វីបានមនុស្សអាក្រក់ហាក់ដូចជាមានការរីកចម្រើនឡើងដោយពុំមានអន្តរាគមន៍ពីព្រះដ៏យុត្តិធម៌ ហើយបរិសុទ្ធ? *ទតមើល* ត្រង់ចំណុច នះគឺមានន័យថា ទ្រង់ទតមើលដោយបណ្តោយឱ្យ ។ មើល ខ.៣ និងការពន្យល់ ។ *ប្រព្រឹត្តកម្បថ . . . ពួកអ្នកអាក្រក់* គឺពួកបាប៊ីឡូន ។ *មនុស្សដែលសុចរិតជាងខ្លួន* គឺពួកសាសន៍យូដា ។

**១:១៥** *ស្ទួចចាប់* មើលការពន្យល់ អម ៤:២ ។ *ចាប់ដោយសំណាញ់* ជនរងគ្រោះដោយសារពួកបាប៊ីឡូន គឺខ្សោយដូចជាសត្វត្រីដែលហែលចូលសំណាញ់ ។

**១:១៦** មើលការពន្យល់ ខ.១១ ។

**២:១** មើល អគ ៣:១៧ និងការពន្យល់ ។ *ខ្ញុំនឹងឡើងទៅលើប៉ម ហើយខំមើលទៅ* គឺជាន័យធៀបអំពី អ្នកយាមដែលត្រូវឈរយាម មើលពីលើប៉មមក ដើម្បីរកមើលហេតុការណ៍អ្វីដែលនឹងអាចកើតឡើង ។ ពាក្យចោទប្រកាន់នៅក្នុងខនេះគឺ ជាពាក្យចោទសួរព្រះអម្ចាស់ អំពីសេចក្តីយុត្តិធម៌ ។ *ប៉ម* គឺប៉មដែលនៅកំផែងក្រុងយេរូសាឡិម ។

**២:២–៣** *ការជាក់ស្តែង* មើល ១រប ១៧:១៥ សភ ២៩:១៨ និងការពន្យល់តាមព្រះគម្ពីរហេព្រើ ពាក្យនេះគឺសំដៅទៅលើ ការបើកសំដែងដែលពួកហោរាបានទទួលពីព្រះ (ឧទាហរណ៍: អស ១:១ និងការពន្យល់) ។

**២:២** *ចារិក* មើល អស ៣០:៨ យរ ៣៦:២ និងការពន្យល់ ។ *ដើម្បីឱ្យមនុស្សដែលកំពុងរត់ ក៏អាចមើលបានដែរ* មានន័យថា អ្នកនាំព្រះបន្ទូលនឹងអាចរត់ ដើម្បីឱ្យព្រះបន្ទូលឆាប់បានជ្រួតជ្រាបដល់អ្នកដែលត្រូវទទួល ។

**២:៣** *ពេលនោះហើយ* គឺពេលចុងបញ្ចប់នៃពួកសាសន៍បាប៊ីឡូន ជាពេលដែលព្រះអម្ចាស់ទ្រង់ធ្វើសម្រេចការប្រោសលោះ ។ *ចូររង់ចាំចុះ* គឺសំដៅទៅលើការដួលចុះនៃចក្រភពបាប៊ីឡូននៅឆ្នាំ ៥៣៩ មុនគ.ស. ប្រហែល ៦៦ ឆ្នាំ ក្រោយពីលោកហាបាគុកថ្លែងទំនាយ ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលឱ្យ

ទេ បើសិនជាបង្អង់យូរ ក៏ចូររង់[ជ]ចាំចុះ ដ្បិតនឹងមក ជាពិត
ឥតរារង់ឡើយ[ឈ] ។
៤មើល ចិត្តគេបានប៉ោងឡើង មិនទៀងត្រង់នៅ ក្នុងខ្លួន
គេទេ តែមនុស្សសុចរិត[ញ]នឹងរស់នៅ ដោយសារសេចក្ដី
ជំនឿរបស់ខ្លួន[ដ] ៥១ទៀត ដែលស្រាទំពាំងបាយជូរ[ឋ] ជា
គ្រឿងបញ្ឆោតយ៉ាងណា មនុស្សអំនួតក៏មិននៅផ្ទះខ្លួន
ដូច្នោះដែរ គេពង្រីកសេចក្ដីប៉ងប្រាថ្នា[ឌ]របស់ខ្លួនឱ្យធំ ដូច
ជាស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយក៏ដូចជាសេចក្ដីស្លាប់
ដែលមិនចេះឆ្អែតឆ្អន់[ឍ] គឺគេកៀរប្រមូលអស់ទាំងសាសន៍
មកឯខ្លួន ក៏បំព្រួម[ណ]ជនជាតិទាំងឡាយទុកសំរាប់ខ្លួនដែរ
៦ឯពួកទាំងនោះ តើមិនចាប់ផ្តើមនិយាយពាក្យប្រៀបធៀប[ត]
នឹងពាក្យប្រស្នាដែលបញ្ឈឺចិត្តទេឬអី ដោយពាក្យថា វេទនា
ដល់មនុស្សដែលចំរើនរបស់ទ្រព្យ ដែលមិនមែនជារបស់
ខ្លួនទេ[ថ] ហើយផ្ទុកខ្លួនដោយរបស់ដែលទទួលបញ្ចាំផង តើ
នឹងបានដូច្នេះដល់កាលណាទៅ ៧តើមិនត្រូវឱ្យមានពួកអ្នក
កើតឡើង ដែលនឹងខាំឯងជា១រំពេចនឹងពួក១ភ្ញាក់ឡើង
ធ្វើទុក្ខឯងទេឬនោះឯងនឹងត្រូវជារបឹបដល់គេវិញ[ទ] ៨ហើយ
ពីព្រោះឯងបានប្លន់សាសន៍ជាច្រើន នោះសំណល់នៃជន
ជាតិទាំងឡាយនឹងប្លន់ឯងវិញ[ធ] ដោយព្រោះឈាមមនុស្ស[ន]
និងការច្រឡោត ដែលបានធ្វើនៅក្នុងស្រុកគេ ហើយដល់ទី
ក្រុង និងអស់មនុស្សដែលនៅក្នុងក្រុងនោះផង[ប] ។
៩វេទនាដល់មនុស្សដែលបានកំរៃ[ផ]ទុច្ចរិត[ព]សំរាប់ផ្ទះ ខ្លួន
ដើម្បីនឹងតាំងសំបុកខ្លួននៅលើទីខ្ពស់[ភ] ឱ្យបានរួចពីកណ្តាប់
ដៃនៃសេចក្ដីអាក្រក់ ១០ឯងគិតគូរបង្កើតសេចក្ដីអាម៉ាស់
ខ្មាស[ម]ដល់ផ្ទះឯងវិញ ដោយផ្តាច់ផ្តិល[យ]ជនជាតិជាច្រើនក៏
មានបាបទាស់នឹងព្រលឹងឯងហើយ ១១ដ្បិតថ្ម[រ]ជញ្ជាំងនឹង
ស្រែកចេញមក ហើយធ្នឹមនៅកណ្តាលអស់ទាំងគ្រឿងឈើ
នឹងឆ្លើយទទួល ។
១២វេទនាដល់អ្នកណាដែលតាំងភូមិ ដោយកំចាយឈាម[ល]
ហើយសង់ទីក្រុងដោយការទុច្ចរិត ១៣មើល ដែលជនជាតិ
ទាំងឡាយខំធ្វើការសំរាប់តែឱ្យភ្លើងឆេះ[វ] ហើយសាសន៍

**២:៣** ជ ទដ ២៧:១៤ ឈ អគ ១២:២៥ **២:៤** ញ អគ ១៨:៩ ដ រម ១:១៧ កទ ៣:១១ ហព ១០:៣៧–៣៨ **២:៥** ឋ សភ ២០:១ ឌ អស ២:១១ ឍ សភ ២៧:២០ ៣០:១៥–១៦ ណ ហព ១:៩ **២:៦** ត អស ១៤:៤ ថ អម ២:៨ **២:៧** ទ សភ ២៩:១ **២:៨** ធ អស ៣៣:១ យរ ៥០:១៧–១៨ អប ១:១៥ សក ២:៨–៩ ន ខ.១៧ ប អគ ៣៩:១០ **២:៩** ផ យរ ២២:១៣ ព យរ ៥១:១៣ ភ យប ៣៩:២៧ អស ១០:១៤ **២:១០** ម ខ.១៦ ណហ ៣:៦ យ យរ ២៦:១៩ **២:១១** រ យស ២៤:២៧ សក ៥:៤ លក ១៩:៤០ **២:១២** ល អគ ២២:២ មីក ៣:១០ **២:១៣** វ អស ៥០:១១

លោកហាបាគុក (និងពួកយូដា) បានដឹងថា បទទំនាយនឹងត្រូវមានពេលជាច្រើនទៀតដើម្បីសម្រេច ប៉ុន្តែ លោកហាបាគុក និងបណ្តាជនត្រូវរង់ចាំការសម្រេចនោះ (មើល ៣:១៦) ។

**២:៤** *គេ* ពាក្យនេះសំដៅទៅលើចក្រភពបាប៊ីឡូន ដែលមានស្តេចជាតំណាងពិសេសរបស់ចក្រភពនោះ ។ *តែ* ពាក្យនេះប្រើសម្រាប់បញ្ជាក់ពីភាពខុសគ្នានៅត្រង់ថា "ពួកសាសន៍បាប៊ីឡូនមិនមានចិត្តទៀតត្រង់ទេ"។ *មនុស្សសុចរិតនឹងរស់នៅ ដោយសារសេចក្ដីជំនឿរបស់ខ្លួន* មើល អគ ១៨:៩, អស ២៦ ជាពិសេស ខ.១–៦ ។ រាស្ត្ររបស់ព្រះត្រូវអត់ធ្មត់ក្នុងការរង់ចាំ និងរស់នៅ ដោយជំនឿលើព្រះដ៏មានគ្រប់ព្រះចេស្តា នៅពេលដែលទ្រង់កំពុងបើកសំដែងអំពីរបៀបនឹងពេលដែលទ្រង់ត្រូវធ្វើការរបស់ទ្រង់ ។ សេចក្ដីនេះមានចែងនៅក្នុងព្រះគម្ពីរសញ្ញាថ្មីជាញឹកញាប់ ដែលបង្រៀនថា មនុស្សយើងបានសង្គ្រោះ ដោយសារព្រះគុណព្រះ ដោយមានជំនឿលើទ្រង់ (រម ១:១៧ កទ ៣:១១ ធៀបនឹង អភ ២:៨ និងការពន្យល់) ហើយពួកគេត្រូវរស់នៅដោយសេចក្ដីជំនឿ (ហព ១០:៣៨–៣៩ ១១:៧)។ សេចក្ដីបង្រៀននេះបានបង្រួមជាមួយបទគម្ពីរ លប ១៥:៦ ហើយនាំឱ្យមានចលនាបដិវត្តន៍ប្រូតេស្តង់នៅក្នុងសតវត្សទី ១៦ ។ ចំពោះគោលការណ៍ដែលគេប្រើនៅក្នុងការរំដោះជាតិ គឺមិនខុសអ្វីអំពីគោលការណ៍នៃការរំដោះព្រលឹងវិញ្ញាណ (សេចក្ដីសង្គ្រោះ) ។

**២:៥** *ពង្រីកសេចក្ដីប៉ងប្រាថ្នារបស់ខ្លួនឱ្យធំ ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់* ស្ថានឃុំព្រលឹងមនុស្សស្លាប់គឺសម្រាប់"ការមិនចេះស្កប់ស្កល់" (មើល អស ៥:១៤ និងការពន្យល់, សភ ៣០:១៥–១៦ និងការពន្យល់ ទដ ៤៩:១៤ សភ ៣០:១៦)។

**២:៦–២០** វគ្គនេះគឺជាសេចក្ដីពន្យល់របស់ខ.៤ (មើលការពន្យល់ ៣:១) ចែកចេញជាពីរផ្នែក (ខ.៦–១៤ និងខ.១៥–២០) ផ្នែកនីមួយៗមានសេចក្ដីសន្និដ្ឋានដោយប្រើន័យក្នុងវិជ្ជាសិក្សាអំពីព្រះ (ខ.១៤,២០) ។ ផ្នែកទាំងពីរនេះរួមគ្នាមកមាន"សេចក្ដីវេទនា"ចំនួន៥ ដែលពួកបាប៊ីឡូនត្រូវជួប (ខ.៦, ៩,១២,១៥,១៩ ធៀបនឹង អស ៥:៨–២៣ មថ ២៣:១៣–៣២ លក ៦:២៤–២៦ វវ ៩:១២ ១១:១៤)។ សេចក្ដីវេទនាទីមួយ និងទីបួនមានលក្ខណៈដូចគ្នា (មើល ខ.៨,១៧) ។

**២:៦** *ពួកទាំងនោះ តើមិនចាប់ផ្តើមនិយាយពាក្យ . . . បញ្ឈឺចិត្ត* ជនរងគ្រោះដោយសារសេចក្ដីឃោរឃៅរបស់ពួកបាប៊ីឡូន ជាពិសេសសាសន៍យូដា នឹងនិយាយពាក្យបញ្ឈឺចិត្តដាក់ពួកបាប៊ីឡូន (អស ១៤:៤) ។ *វេទនា* ត្រង់ចំណុចនេះ ពួកបាប៊ីឡូនត្រូវទទួលការជំនុំជម្រះដោយសារការកាន់កាប់សាសន៍ដទៃ ដោយចិត្តលោភលន់ ។

**២:៨** *ដោយព្រោះឈាមមនុស្ស* មើល ខ.១៧ ។ ពួកបាប៊ីឡូនបានកំចាយឈាមគេ ដូចនេះពួកបាប៊ីឡូនត្រូវទទួលរងការកំចាយឈាមវិញ (មើល លប ៩:៦ និងការពន្យល់) ។

**២:៩** *វេទនា* ត្រង់ចំណុចនេះពួកបាប៊ីឡូនត្រូវទទួលការជំនុំជម្រះដោយសារសេចក្ដីអំណួតនឹងសំណង់របស់ខ្លួន (មើល ខ.១២ ធៀបនឹង យរ ២២:១៣)។ *សំបុកខ្លួននៅលើទីខ្ពស់* ពួកបាប៊ីឡូនបានគិតថាគ្មាននរណាអាចវាយកាន់កាប់ពួកខ្លួនបានទេ គឺធៀបដូចជាសត្វឥន្ទ្រីធ្វើសំបុកនៅទីខ្ពស់ ដែលគ្មានអ្នកណាអាចឡើងទៅដល់បាន (មើល អស ១៤:៤,១៣–១៥ ធៀបនឹង អប ៣–៤) ។

**២:១១** *ថ្មជញ្ជាំងនឹងស្រែកចេញមក ហើយធ្នឹម* ពួកបាប៊ីឡូនរស់នៅក្រោមដំបូលផ្ទះដែលបានប្លន់ពីសាសន៍ដទៃមក ដូចនេះផ្ទះទាំងនោះនឹងធ្វើបន្ទាល់ទាស់នឹងពួកគេវិញ (ធៀបនឹង លក ១៩:៤០) ។

**២:១២** *វេទនា* ត្រង់ចំណុចនេះ ពួកបាប៊ីឡូនបានទទួលការជំនុំជម្រះដោយសារតែមានអំពើអយុត្តិធម៌របស់ពួកគេ ។ សូមធៀបទៅនឹង មីក ៣:១០ ។

**២:១៣** *សំរាប់តែភ្លើងឆេះ* ទីក្រុងដែលពួកបាប៊ីឡូនប្រឹងបញ្ចេញកម្លាំងពល

ទាំងប៉ុន្មាន ក៏ប្រឹងធ្វើនឿយហត់ជាឥតប្រយោជន៍[ស] នោះតើ
មិនមកពីព្រះយេហូវ៉ានៃពួកពលបរិវារទេឬ ¹⁴ដ្បិតមនុស្ស
នឹងស្គាល់ដល់សិរីល្អ[ហ]នៃព្រះយេហូវ៉ា នៅពេញលើផែនដី
ដូចជាទឹកក៏នៅពេញសមុទ្រដែរ[ឡ]។
¹⁵វេទនាដល់អ្នកណា ដែលបំផឹក[អ]ដល់អ្នកជិតខាងខ្លួន គឺ
ដែលចេះតែចាក់ឱ្យគេផឹកដល់ស្រវឹង ដើម្បីឱ្យបានឃើញ
សណ្ឋានអាក្រាតរបស់គេ ¹⁶ឯងឆ្អែតពេញដោយសេចក្តី
អាម៉ាស់ខ្មាស[ក] មិនមែនជាសិរីល្អទេ[ខ] ចូរឱ្យឯងផឹកដែរ[គ]
ហើយឱ្យគេឃើញ[ឃ]ថា ឯងមិនបានកាត់ស្បែកពិត ឯពែង[ង]
នៅព្រះហស្តស្តាំនៃព្រះយេហូវ៉ា នោះនឹងវិលមកដល់ឯង
ដូចគ្នា ហើយសេចក្តីអាម៉ាស់ខ្មាសដ៏ជូជាតិនឹងគ្របលើ
សិរីល្អរបស់ឯងវិញ ¹⁷ដ្បិតការច្រឡោត[ច]ដែលបានធ្វើដល់
ព្រៃល្បាណូន នឹងគ្របលើឯង ព្រមទាំងការបំផ្លាញអស់
ទាំងសត្វ ដែលនាំឱ្យវាភ័យភ្ញាក់ផង[ឆ] ដោយព្រោះឈាម
មនុស្ស[ជ] និងការច្រឡោត ដែលបានធ្វើនៅក្នុងស្រុកគេ
ហើយដល់ទីក្រុង និងមនុស្សទាំងប៉ុន្មាន ដែលនៅក្នុងក្រុង
នោះផង ។
¹⁸ឯរូបឆ្លាក់ តើមានប្រយោជន៍[ឈ]អ្វី[ញ] បានជាជាងឆ្លាក់
ធ្វើវា និងរូបសិត[ដ] គឺជាគ្រូបង្រៀនសេចក្តីកំភូតនោះផង
បានជាជាង ដែលសិតធ្វើរាងរូបនោះ ក៏យកជាទីទុកចិត្ត
របស់ខ្លួន ដើម្បីនឹងបង្កើតរូបព្រះគឡើងដូច្នេះ[ឋ] ¹⁹វេទនា
ដល់អ្នកណាដែលនិយាយដល់ដុំឈើថា សូមតើនឡើង[ឌ]
ហើយដល់ដុំថ្មគថា សូមក្រោកឡើងចុះ តើរូបនោះនឹង
បង្រៀនបានឬ មើល គេស្រោបវាដោយមាសនឹងប្រាក់[ឍ]
តែគ្មានខ្យល់ដង្ហើមនៅខាងក្នុងទេ[ណ] ²⁰ឯព្រះយេហូវ៉ា ទ្រង់
គង់នៅក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់វិញ[ត] ចូរឱ្យផែនដី
ទាំងមូលស្ងៀមនៅ[ថ]ចំពោះទ្រង់ចុះ ។

## សេចក្តីអធិស្ឋានរបស់លោកហាបាគុក

**៣** ¹នេះជាពាក្យអធិស្ឋានរបស់ហោរាបាគុក រៀងជា
ពាក្យលន្លោចចិត្ត[ក]។
²ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានឮ[ខ]សេចក្តីដែលទ្រង់

**២:១៣** ស អស ៤៧:១៣ **២:១៤** ហ នក ១៦:៧ ជន ១៤:២១ ឡ អស ១១:៩ **២:១៥** អ សភ ២៣:២០ **២:១៦** ក ខ.១០ ខ អក ២៣:៣២-៣៤ ហស ៤:៧ គ លវ ១០:៩ ឃ បទ ៤:២១ ង ទដ ១៦:៥ អស ៥១:២២ **២:១៧** ច យរ ៥១:៣៥ ឆ យរ ៥០:១៥ ជ ខ.៨ **២:១៨** ឈ ១សយ ១២:២១ ញ ពច ១០:១៤ អស ៤០:១៩ យរ ៥:២១ ១៤:២២ ដ លវ ២៦:១ ឋ ទដ ១១៥:៤-៥ យរ ១០:១៤ ១កថ ១២:២ **២:១៩** ឌ ១ពវ ១៨:២៧ ឍ យរ ១០:៤ ណ ដយ ៥:៤,២៣ ហស ៤:១២**២:២០** ត ទដ ១១:៤ ថ អស ៤១:១ **៣:១** ក ទដ ៧ ចំណងជើង **៣:២** ខ យប ២៦:១៤ ទដ ៤៤:១

កម្មដើម្បីសាងសង់ (ខ.១២) និងត្រូវដុតបំផ្លាញ (មើល យរ ៥១:៥៨) ។
**២:១៤** ត្រង់ចំណុចនេះលោកហាបាគុកបានដកស្រង់បទគម្ពីរ អស ១១:៩ ហើយបកស្រាយបន្ថែមទៀត។ លោកិយនឹងបានស្គាល់ពីសិរីល្អនៃព្រះអម្ចាស់កាន់តែច្រើនឡើង នៅពេលដែលទ្រង់បំផ្លាញចក្រភពបាប៊ីឡូន និងគ្រប់សិរីល្អរបស់ចក្រភពនេះ (សូមធៀបនឹង នក ១៤:៤,១៧-១៨ *វវ* ១៧:១-១៩:៤) ។
**២:១៥** ធៀបនឹង លប ៩:២០-២២ ។ *វេទនា* ត្រង់ចំណុចនេះពួកបាប៊ីត្រូវទទួលការជំនុំជម្រះដោយសារអំពើហឹង្សាដែលបានប្រព្រឹត្ត ។ ការអាក្រក់ដែលពួកបាប៊ីឡូនប្រព្រឹត្តចំពោះសាសន៍ជិតខាង ដែលមានដូចជាប្រមូលយកទ្រព្យសម្បត្តិអស់ពីសាសន៍ទាំងនោះ (ធៀបនឹងការដែលសាសន៍នេះប្រព្រឹត្តចំពោះក្រុងយេរូសាឡិមនៅពេលក្រោយមកទៀត, ២ពវ ២៥:៨-២១) គឺប្រៀបបានទៅនឹងការដែលមនុស្សម្នាក់បំផឹកអ្នកជិតខាងរបស់ខ្លួនឱ្យស្រវឹង ដើម្បីសើចសប្បាយនឹងភាពអាក្រាតរបស់ពួកគេ ។
**២:១៦** *ឆ្អែតពេញដោយសេចក្តីអាម៉ាស់ខ្មាស . . . ហើយឱ្យគេឃើញ* ព្រះអម្ចាស់ទ្រង់នឹងធ្វើចំពោះពួកសាសន៍បាប៊ីឡូន នូវការអ្វីដែលពួកគេបានធ្វើចំពោះសាសន៍ដទៃ ។ *ពែងនៅព្រះហស្តស្តាំនៃព្រះយេហូវ៉ា* គឺជានិមិត្តរូបនៃសេចក្តីជំនុំជម្រះដែលមកពីព្រះអម្ចាស់ (មើល ទដ ១៦:៥ និងការពន្យល់, អស ៥១:១៧,២១-២២ យរ ២៥:១៥-១៧ បទ ៤:២១ *វវ* ១៤:១០ និងការពន្យល់, ១៦:១៩) ។
**២:១៧** *ការច្រឡោតដែលបានធ្វើដល់ព្រៃល្បាណូន* ពួកបាប៊ីឡូនប្រហែលជាបានកាប់ឆ្ការព្រៃដើមតាត្រាវ ដើម្បីសង់ព្រះវិហារ និងរាជវាំងរបស់ពួកគេ (មើល អស ១៤:៨ និងការពន្យល់) ។ *ការបំផ្លាញអស់ទាំងសត្វ* ពួកសាសន៍អាសស៊ើរបានកត់ត្រានៅក្នុងសិលាចារិកអំពីល្បែងបរបាញ់សត្វនៅក្នុងព្រៃល្បាណូន ហើយល្បែងនេះប្រហែលជាល្បែងកម្សាន្តសប្បាយជាទ្រង់ទ្រាយធំរបស់សាសន៍បាប៊ីឡូនផងដែរ ។ អំពើហឹង្សាដែលពួកបាប៊ីឡូនបង្ករឡើង គឺនាំឱ្យមានការបំផ្លិចបំផ្លាញមិនគ្រាន់តែទៅដល់ទឹកដី និងទីក្រុងនានាប៉ុណ្ណោះទេ ប៉ុន្តែគឺថែមទាំងទៅដល់ជីវិតមនុស្ស សត្វ និងរុក្ខជាតិផងដែរ ។ *ដោយព្រោះឈាមមនុស្ស* មើល ខ.៨ និងការពន្យល់ ។
**២:១៨** *រូបឆ្លាក់* មើល អស ៤១:២៩ ៤៤:៩ យរ ១០:១៥ និងការជំនុំជម្រះការថ្វាយបង្គំរូបព្រះនៅក្នុង នក ២០:៤-៥ មើល ទដ ១១៥:៤-៧ និងការពន្យល់ ។
**២:១៩** *វេទនា* ត្រង់ចំណុចនេះ ពួកសាសន៍បាប៊ីឡូនត្រូវទទួលការជំនុំជម្រះដោយសារការថ្វាយបង្គំរូបព្រះ ។ *សូមតើនឡើង* សូមធៀបនឹងការពោលចំអករបស់លោកអេលីយ៉ា ដល់ពួកហោរានៃព្រះបាល នៅលើភ្នំកើមែល (១ពវ ១៨:២៧) ។
**២:២០** *ព្រះយេហូវ៉ា ទ្រង់គង់នៅក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់* ព្រះទ្រង់គង់នៅលើព្រះវិហារ នៅឯនគរស្ថាន (ធៀបនឹង យហ ២:៧) ហើយជំនុំជម្រះគ្រប់ទាំងមនុស្ស ដោយសេចក្តីសុចរិតរបស់ (មើល ទដ ១១:៤-៧ និងការពន្យល់, មីក ១:២) ។ *ស្ងៀមនៅចំពោះទ្រង់* រូបព្រះថ្ម និងឈើ របស់ពួកសាសន៍ទាំងឡាយ (ខ.១៩) ត្រូវនៅស្ងៀមមិននិយាយស្តី ដោយចុះចូលដោយកោតខ្លាចដល់សេចក្តីជំនុំជម្រះដ៏គួរស្ញែងខ្លាច (មើល សផ ១:៧ សក ២:១៣ ធៀបនឹង អម ៦:១០ ៨:៣ និងការពន្យល់) ។
**៣:១** *ពាក្យអធិស្ឋាន* ពាក្យអធិស្ឋាននេះគឺជាបទគម្ពីរទំនុកតម្កើង ដូចទំនុកនៅក្នុងព្រះគម្ពីរទំនុកតម្កើងដែរ ។ ការអធិស្ឋានរបស់លោកហាបាគុកនៅក្នុងជំពូកនេះ ជាសេចក្តីពន្យល់នៃ ២:៤ខ (ការពន្យល់ ២:៦-២០) ហើយមានលក្ខណៈដូចជាទំនុកតម្កើង ។ *ហោរា* មើល ១:១ និងការពន្យល់ ។ *ពាក្យលន្លោចចិត្ត* មើល ទដ ៧ ចំណងជើង និងការពន្យល់ ។
**៣:២** *ឮសេចក្តីដែលទ្រង់មានបន្ទូលមកនោះ* មើល ទដ ៤៤:១ ៧៨:៣ ។

មានបន្ទូលមកនោះ ហើយទូលបង្គំមានសេចក្ដីភិតភ័យ[គ] ឱ
ព្រះយេហូវ៉ាអើយ[ឃ]កំពុងដែលឆ្នាំទាំងឡាយកន្លងទៅ នោះ
សូមធ្វើឱ្យកិច្ចការរបស់ទ្រង់កើតឡើងជាថ្មី[ង] កំពុងដែលឆ្នាំ
ទាំងឡាយកន្លងទៅ សូមសំដែងឱ្យស្គាល់ការនោះវិញ
ហើយក្នុងគ្រាដែលទ្រង់ក្រោធ សូមនឹកចាំពីសេចក្ដីមេត្តា
ករុណាផង[ច] ៣ ព្រះទ្រង់កំពុងយាងមកពីថេម៉ាន[ឆ] គឺព្រះដ៏
បរិសុទ្ធ[ជ]ទ្រង់យាងមកពីភ្នំប៉ារ៉ាន[ឈ]–បង្អង់–សិរីល្អនៃ ទ្រង់
បិទបាំងផ្ទៃមេឃ[ញ] ហើយផែនដីបានពេញដោយសេចក្ដី
សរសើរដល់ទ្រង់[ដ] ៤ សេចក្ដីរុងរឿងរបស់ទ្រង់ក៏ដូចជាពន្លឺ[ឋ]
មានរស្មីចេញពីព្រះហស្តទ្រង់ នោះឯងជាទីលាក់ទុកនូវ
ព្រះចេស្ដា[ឌ]នៃទ្រង់ ៥ មានអាសន្នរោគ[ឍ]ចេញពីចំពោះទ្រង់
ក៏មានរន្ទះចេញពីដានព្រះបាទទ្រង់ ៦ ទ្រង់ឈរឡើង ក៏វាស់
ផែនដី ទ្រង់ក្រឡេកទតទៅក៏បណ្ដេញសាសន៍ទាំងប៉ុន្មាន
ចេញពីគ្នា ឯភ្នំធំដ៏នៅកល្បរៀងមក នោះត្រូវខ្ទាត់ ខ្ចាយ
ទៅ[ណ] ហើយភ្នំតូចដ៏នៅជាដរាប[ត] ក៏ឱនលំទោនចុះអស់[ថ]
ទាំងដំណើររបស់ទ្រង់មានតាំងពីបុរាណមក[ទ] ៧ ទូលបង្គំ
បានឃើញពួកអ្នកនៅត្រសាលរបស់គូសាន គេមានទុក្ខ
លំបាក ឯរំភាយត្រសាលរបស់ម៉ាឌាន[ធ]ក៏ញ័រ[ន] ៨ តើព្រះ
យេហូវ៉ា ទ្រង់មានព្រះហឫទ័យថ្នាំងថ្នាក់ ចំពោះទន្លេ
ទាំងប៉ុន្មានឬ[ប] តើសេចក្ដីខ្ញាល់របស់ទ្រង់ដំរង់ទាស់នឹងទន្លេ
ឬសេចក្ដីក្រោធរបស់ទ្រង់បានទាស់នឹងសមុទ្រឬអី[ផ] បានជា
ទ្រង់ឡើងគង់លើសេះរបស់ទ្រង់ ហើយលើរថនៃសេចក្ដី
សង្គ្រោះរបស់ទ្រង់ទៅដូច្នេះ[ព] ៩ ធ្នូ[ភ]របស់ទ្រង់បានបើកចេញ
ស្រាប់ ពាក្យសម្បថដល់ពូជអំបូរទាំងឡាយជាព្រះបន្ទូលដ៏
ពិត –បង្អង់– ទ្រង់បានពុះញែកផែនដីឱ្យទន្លេមានផ្លូវហូរ
១០ ភ្នំទាំងប៉ុន្មានបានឃើញទ្រង់ ហើយក៏ភ័យខ្លាច[ម] ព្យុះភ្លៀង
ក៏បង្ហូសទៅ ទីជំរៅក៏បញ្ចេញសំឡេង[យ] ហើយបានលើកដៃ
ឡើង[រ]ទៅលើ ១១ ឯព្រះអាទិត្យ និងព្រះចន្ទ ក៏ឈប់ទ្រឹងនៅ[ល]
ដោយឃើញពន្លឺនៃព្រួញទ្រង់[វ] កំពុងហោះទៅ និងពន្លឺចាំង
ពីលំពែងដ៏ភ្លឺផ្លេកៗ[ស]របស់ទ្រង់ ១២ ទ្រង់បានយាងកាត់ស្រុក
ទៅ ដោយសេចក្ដីគ្នាន់ក្នាញ់ ក៏កិនបញ្ជាន់[ហ]អស់ទាំងសាសន៍
ដោយសេចក្ដីក្រោធ ១៣ ទ្រង់បានយាងចេញមក[ឡ] ដើម្បីជួយ
សង្គ្រោះ[អ]រាស្ត្ររបស់ទ្រង់ គឺដើម្បីសង្គ្រោះអ្នកដែលទ្រង់

**៣:២** គ ទដ ១១៩:១២០ ឃ ទដ ៩០:១៦ ង ទដ ៨៥:៦ ច អស ៥៤:៨ **៣:៣** ឆ លប ៣៦:១១,១៥ ជ អស ៣១:១ ឈ ជន ១០:១២ ញ ទដ ៨:១ ដ ទដ ៤៨:១០ **៣:៤** ឋ អស ១៨:៤ ឌ យប ៩:៦ **៣:៥** ឍ លវ ២៦:២៥ **៣:៦** ណ ទដ ៤៦:២ ត លប ៤៩:២៦ ថ នក ១៩:១៨ ទដ ១៨:៧ ១១៤:១–៦ ទ លប ២១:៣៣ **៣:៧** ធ លប ២៥:២ ជន ២៥:១៥ ពច ៧:២៤–២៥ ន នក ១៥:១៤

**៣:៨** ប នក ៧:២០ ផ ទដ ៧៧:១៦ ព ២ពវ ២:១១ ទដ ៦៨:១៧ **៣:៩** ភ ចទ ៣២:២៣ ទដ ៧:១២–១៣ **៣:១០** ម ទដ ៧៧:១៦ យ ទដ ៩៨:៧ រ ទដ ៩៣:៣ **៣:១១** ល យស ១០:១៣ វ ទដ ១៨:១៤ ស ទដ ១៤៤:៦ សក ៩:១៤ **៣:១២** ហ អស ៤១:១៥ **៣:១៣** ឡ នក ១៣:២១ អ ទដ ២០:៦ ២៨:៨

នៅក្នុង ខ.៣–១៥ លោកហាបាគុកបានពោលជាទំនុកសរសើរដល់ព្រះរាជកិច្ចជួយសង្គ្រោះដ៏អស្ចារ្យនៃព្រះអម្ចាស់ ដែលប្រហែលជាកិច្ចការដែលទ្រង់ធ្វើនៅព្រះវិហារ (មើល ខ.១៦) ។

**៣:៣** *ព្រះទ្រង់កំពុងយាងមក* ដើម្បីអបអរសាទរដល់ការភាសខ្លួនចេញពីស្រុកអេស៊ីព្ទដោយជោគជ័យ បទគម្ពីរទំនុកដំកើង និងពួកហោរាបាននិយាយអំពីការអស្ចារ្យដែលព្រះអម្ចាស់ទ្រង់បានធ្វើ ដោយពិពណ៌នាអំពីរូបភាពដែលគួរឱ្យស្ញែងខ្លាច ។ ព្រះទ្រង់យាងចុះមកជាមួយនឹងពួកពលបរិវ៉ា ហើយទ្រង់គង់នៅលើរាជរថរបស់ទ្រង់ ដែលជាផ្លេកបន្ទោរ ហើយគ្រាប់ព្រួញរបស់ទ្រង់បាញ់ចេញទៅគ្រប់ទិសទាំងអស់ ព្យុះភ្លៀងបានធ្លាក់ចុះមកលើផែនដី ហើយភ្នំទាំងឡាយត្រូវញ័ររញ្ជួយនៅចំពោះទ្រង់ (មើល ពច ៥:៤–៥ ទដ ១៨:៧–១៥ ៦៨:៧–១០ ៧៧:១៦–១៩ មីក ១:៣ និងការពន្យល់) ។ លក្ខណៈនៃការអស្ចារ្យទាំងអស់មាននិយាយនៅក្នុងខជាបន្តបន្ទាប់ទៀត ។ *ថេម៉ាន* មានន័យថា "ទឹកដីខាងត្បូង" ។ ពាក្យនេះត្រូវបានប្រើដើម្បីរៀបរាប់ថា ព្រះអម្ចាស់ទ្រង់យាងពីតំបន់ខាងត្បូងស្រុកយូដា នៅក្នុងអំឡុងពេលពួកអ៊ីស្រាអែលភាសខ្លួនពីស្រុកអេស៊ីព្ទ ។ *ភ្នំប៉ារ៉ាន* មើល ចទ ៣៣:២ និងការពន្យល់ ។ ភ្នំនេះប្រហែលនៅខាងជើងភាគខាងលិចនៃឈូងសមុទ្រអាកាបា និងភាគខាងត្បូងតំបន់កាដេស–បានា ដែលនៅចន្លោះស្រុកអេដំម និងវាលរហោស្ថានស៊ីណាយ ។ *បង្អង់* មើលសេចក្ដីផ្ដើមព្រះគម្ពីរទំនុងតម្កើងត្រង់ការនិពន្ធ និងការដាក់ចំណងជើង ។ *ផែនដីបានពេញ* មើលការពន្យល់ ២:១៤ ។

**៣:៥** *អាសន្នរោគ . . . រន្ទះ* គឺជាពាក្យប្រៀបធៀបអំពីការជំនុំជម្រះដែលមកពីព្រះ (ធៀបនឹង ៧:១៤–១២:៣០ លវ ២៦:២៥ ទដ ៩១:៣,៦) ។

**៣:៦** ជាញឹកញាប់ព្រះវត្តមាននៃព្រះនាំឱ្យមានការរញ្ជួយដី (មើល នក ១៩:១៨ ទដ ១៨:៧ យរ ៤:២៤ ១០:១០ ណាហ ១:៥) ។ ហេតុការណ៍នៅក្នុងខនេះក៏អាចជាការបាក់ស្រុតដីផងដែរ ។

**៣:៧** *គូសាន . . . ម៉ាឌាន* គឺជាពូជអំបូរនៃសាសន៍អារ៉ាប់ ដែលរស់នៅក្បែរស្រុកអេដំម ។ *ទុក្ខលំបាក . . . ញ័រ* នៅពេលដែលសាសន៍អ៊ីស្រាអែលត្រូវបានរំដោះពីសាសន៍អេស៊ីព្ទក្រោមការដឹកនាំរបស់លោកម៉ូសេ សាសន៍ដែលនៅជិតខាងមានពេញដោយសេចក្ដីភ័យខ្លាច(ការពន្យល់ ១៥:១៤–១៦ យស ២:៩–១០) ។

**៣:៨** ខនេះគឺជាទំនុក ដែលនិយាយអំពីសេចក្ដីវេទនាដែលកើតឡើងនៅតាមដងទន្លេនីល (នក ៧:២០–២៤) និងការធ្វើឱ្យទន្លេយ័រដាន់ឈប់ហូរ (យរ ៣:១៥–១៧) និងការញែកសមុទ្រស្លាប់ (នក ១៤:១៥–៣១) ។

**៣:៩** *ធ្នូរ* ប្រហែលជារន្ទះដែលបាញ់ចេញពីស្ថានសួគ៌មក (ទដ ១៨:១៤ និងការពន្យល់ ១៤៤:៦)។ *ទន្លេ* គឺទន្លេដែលកើតឡើងពីព្យុះរន្ទះ ។

**៣:១១** *ព្រះអាទិត្យ និងព្រះចន្ទ ក៏ឈប់ទ្រឹង* ត្រង់ចំណុចនេះ ប្រហែលជានិយាយអំពីជ័យជំនះ នៅក្រុងគីបៀន (មើល យស ១០:១២–១៣ និងការពន្យល់ ១០:១៣) ។ ការនេះបង្ហាញថា ព្រះអម្ចាស់ទ្រង់នឹងមានជ័យជំនះលើខ្មាំងសត្រូវរបស់ទ្រង់ ដូចកាលនោះដែរ ។

**៣:១២** *បញ្ជាន់* មើលការពន្យល់ អម ១:៣ ។

**៣:១៣** *ជួយសង្គ្រោះរាស្ត្ររបស់ទ្រង់* ព្រះអម្ចាស់ទ្រង់បានវាយសាសន៍ទាំងឡាយនៅស្រុកកាណាន (ខ.១២) ប៉ុន្តែ ទ្រង់បានជួយសង្គ្រោះដល់រាស្ត្ររបស់ទ្រង់ ។ *សង្គ្រោះ* គឺទ្រង់សង្គ្រោះដោយប្រទាននូវជ័យជំនះ ។ *អ្នកដែលទ្រង់បានចាក់ប្រេងតាំងឱ្យ* គឺសាសន៍នៃសេចក្ដីសញ្ញា ("រាស្ត្ររបស់ទ្រង់", មើល ទដ ២៨:៨) ជា "នគរនៃពួកសង្ឃ"(នក ១៩:៦ និងការពន្យល់) ដែលព្រះអម្ចាស់ទ្រង់យាងមកជួយសង្គ្រោះ ។ ទ្រង់បំផ្លាញខ្មាំងសត្រូវរបស់

បានចាក់ប្រេងតាំងឱ្យ[ក] ទ្រង់បានវាយ[ខ]អ្នកជាកំពូលលើវង្ស
មនុស្សអាក្រក់ឱ្យរបួស ក៏បំផ្លាញទៅចាប់តាំងពីជើង រហូត
ដល់កំពូលផង –បង្អង់– ១៤ទ្រង់បានចាក់ទំលុះមេទ័ពរបស់
គេ ដោយលំពែងរបស់ទ្រង់ គេបានចេញមកដូចជាខ្យល់
កួច ដើម្បីកំចាត់កំចាយទូលបង្គំ[គ] គេត្រេកអរ ចំពោះតែ
ការស៊ីបំផ្លាញពួកក្រីក្រ[ឃ] ដោយសំងាត់ ១៥ប៉ុន្តែទ្រង់បាន
ជាន់ឈ្លីសមុទ្រ[ង] ដោយសេះទាំងប៉ុន្មានរបស់ទ្រង់ គឺអស់
ទាំងរលក ដែលបោកឡើងយ៉ាងធំ[ច]។

១៦ខ្ញុំបានឮ ហើយពោះខ្ញុំក៏ញ័ររប៉ផុក បបូរមាត់ខ្ញុំក៏ញ័រ
ទទាក់ ដោយឮសំឡេងនោះ មានសេចក្តីពុករលួយចូល
ក្នុងឆ្អឹងរបស់ខ្ញុំ ខ្ញុំក៏ភ័យញ័រ[ឆ]នៅក្នុងខ្លួន ពីព្រោះខ្ញុំត្រូវរង់
ចាំថ្ងៃវេទនាដោយអំណត់[ជ] គឺរង់ចាំសាសន៍ដែលទន្ទ្រាន
ចូលបានមកដល់ ១៧ទោះបើដើមល្វាមិនមានផ្កា ក៏ឥតមាន
ផ្លែទំពាំងបាយជូរ ហើយផលនៃដើមអូលីវក៏ខានមានស្រែ
ចំការឥតបង្កើតបានអាហារ[ឈ] ហ្វូងចៀមត្រូវបាត់ចេញពី
ក្រោល ហើយគ្មានគោនៅក្នុងឃ្នងក៏ដោយ[ញ] ១៨គង់តែខ្ញុំ
នឹងរីករាយ ដោយសារព្រះយេហូវ៉ា[ដ] ខ្ញុំនឹងអរសប្បាយក្នុង
ព្រះដ៏ជួយសង្គ្រោះខ្ញុំដែរ[ឋ] ១៩ព្រះយេហូវ៉ា គឺជាព្រះអម្ចាស់
ទ្រង់ជាកំឡាំងខ្ញុំ[ឌ] ទ្រង់នឹងធ្វើឱ្យជើងនៃខ្ញុំបានលឿន ដូចជា
ជើងឈ្លូស ហើយឱ្យខ្ញុំដើរនៅលើទីខ្ពស់របស់ខ្ញុំ[ឍ]។

នេះលើកសំរាប់មេភ្លេង ឱ្យលេងដោយប្រដាប់មានខ្សែ
របស់ខ្ញុំ។/

**៣:១៣** ក ២សយ ២៣:១ ខ ទដ ៦៨:២១ ១១០:៦ **៣:១៤** គ ពច ៧:២២ ឃ ទដ ៦៤:២-៥ **៣:១៥** ង យប ៩:៨ ច នក ១៥:៨ **៣:១៦** ឆ យប ៤:១៤ ជ ទដ ៣៧:៧ **៣:១៧** ឈ យអ ១:១០-១២,១៨ ញ យប ៥:១៧ **៣:១៨** ដ ទដ ៩៧:១២ អស ៦១:១០ ភល ៤:៤ ឋ នក ១៥:២ លក ១:៤៧ **៣:១៩** ឌ ចទ ៣៣:២៩ ទដ ៤៦:១-៥ ឍ ចទ ៣២:១៣ ទដ ១៨:៣៣

ទ្រង់ ហើយនៅក្នុងគ្រាដែលទ្រង់ក្រោធ (ខ.១២) ទ្រង់នឹកចាំពីសេចក្តីមេត្តាករុណា(ខ.២)។ *កំពូលលើវង្សមនុស្សអាក្រក់* គឺស្តេចផារ៉ោន(មើល នក ១៤:៥-៩)។

**៣:១៤-១៥** វគ្គនេះគឺជាសេចក្តីយោងឱ្យ ការបំផ្លាញសាសន៍អេស៊ីព្ទនៅសមុទ្រក្រហម។ ព្រះទ្រង់នឹងធ្វើឱ្យសត្រូវក្នុងពេលបច្ចុប្បន្នបរាជ័យផងដែរ។

**៣:១៥** *សេះ* មើល ខ.៨ និងការពន្យល់ ។

**៣:១៦** បទទំនុកតម្កើងដែលនិយាយសរសើរកិច្ចការដ៏អស្ចារ្យដែលព្រះទ្រង់បានធ្វើសម្រាប់សាសន៍អ៊ីស្រាអែល(ខ.៣-១៥) បាននាំលោកហាបាគុកមានអារម្មណ៍ថាខ្លួនខ្សោយ ។ ម្យ៉ាងវិញទៀត ការដែលព្រះអម្ចាស់ទ្រង់បានមានបន្ទូលថា និងចាត់ឱ្យពួកបាប៊ីឡូនទាស់នឹងពួកយូដា (១:៥-១១) បានធ្វើឱ្យលោកមានការរន្ធត់ចិត្តយ៉ាងខ្លាំង ដែលនាំឱ្យលោកឈឺរហូតដល់ពេលដែលលោកបានឮព្រះបន្ទូលទ្រង់បន្ថែមទៀត ។ *រង់ចាំ . . . ដោយអំណត់* មើល ២:៣ និងការពន្យល់, ទដ ៣៧:៧ ។

**៣:១៧** ខនេះប្រហែលជាការប្រមើលអំពី លទ្ធផលដ៏អាក្រក់ នៃការឈ្លានពាន និងការបំផ្លិចបំផ្លាញរបស់សាសន៍បាប៊ីឡូន ។

**៣:១៨-១៩** លោកហាបាគុកបានរៀនអំពីសេចក្តីជំនឿ(២:៤) ដែលត្រូវជឿទុកចិត្តលើផែនការរបស់ព្រះ ទោះជាត្រូវស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ។ លោកបានប្រកាសថា ទោះបីជាព្រះអម្ចាស់ទ្រង់ត្រូវបញ្ជូនមកនូវសេចក្តីវេទនា និងការបាត់បង់ក៏ដោយ ក៏លោកនឹងនៅតែមានអំណរនៅក្នុងព្រះដ៏ជាព្រះសង្គ្រោះរបស់លោកដែរ ហើយតាមព្រះគម្ពីរ ការនេះគឺបានបញ្ជាក់អំពីសេចក្តីជំនឿដ៏ខ្លាំងបំផុត ។

**៣:១៨** *រីករាយ ដោយសារព្រះយេហូវ៉ា* សូមមើល ទដ ៣២:១១ ភល ៣:១ ៤:៤ ។ *អរសប្បាយក្នុងព្រះដ៏ជួយសង្គ្រោះខ្ញុំ* មើល លក ១:៤៧ ។

**៣:១៩** *ធ្វើឱ្យជើងនៃខ្ញុំបានលឿន ដូចជាជើងឈ្លូស* គឺមានន័យថា ធ្វើឱ្យជើងបានរឹងមាំជាទីទុកចិត្តបាន (មើល ទដ ១៨:៣៣) ។ *មេភ្លេង* ប្រហែលជាមេភ្លេង នៃពួកអ្នកភ្លេងនៅព្រះវិហារ ។ ត្រង់ចំណុចនេះ និយាយអំពីអ្នកអធិស្ឋាន ដោយមានការប្រគុំតន្ត្រីអម (មើល ១រប ១៦:៤-៧) ។ *ប្រដាប់មានខ្សែ* គឺរួមមាន ស៊ុង និងពិណជាដើម(ទដ ៣៣:២ ៩២:៣ ១៤៤:៩)។

# ព្រះគម្ពីរសេផានា

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ

មានភស្ដុតាងបញ្ជាក់ថា លោកសេផានាគឺជាហោរាមួយរូបដែលមានឋានៈដ៏គួរឱ្យកត់សំគាល់នៅក្នុងសង្គមនៃស្រុកយូដា ហើយគេជឿថាលោកមានជាប់ខ្សែរាជ្យវង្សផងដែរ ។ ព្រះគម្ពីរនេះបានចាប់ផ្ដើមនិយាយអំពីសេចក្ដីទំនាយ ដោយលើកឡើងអំពីពង្សាវតាររបស់អ្នកនិពន្ធ (១:១) ហើយការនេះគឺជាលក្ខណៈមិនធម្មតានៅក្នុងទំនៀមទម្លាប់នៃការថ្លែងទំនាយរបស់សាសន៍ហេព្រើរ ។ លោកសេផានា គឺជាកូនចៅជំនាន់ទីបួនរបស់ស្ដេចហេសេគា ជាស្ដេចដ៏ល្បីឈ្មោះ ដែលដឹកនាំស្រុកយូដាពីឆ្នាំ ៧១៥ ដល់ ៦៨៦ មុនគ.ស.។ ក្រៅពីបទគម្ពីរ ១:១ ព្រះគម្ពីរនេះមិនបាននិយាយអ្វីទៀតអំពីពង្សាវតាររបស់លោកសេផានាឡើយ ។ បើយើងធ្វើការប្រៀបធៀប លោកហោរាមីកាបានដោះស្រាយយ៉ាងប្រុងប្រយ័ត្ន និងអាណិតអាសូរ ចំពោះបញ្ហារបស់មនុស្សធម្មតានៃស្រុកយូដា ចំណែកឯលោកសេផានាបានផ្ដោតទៅលើពួកអ្នកដឹកនាំ និងបញ្ហានយោបាយបច្ចុប្បន្នច្រើនជាង ។ លោកសេផានាប្រហែលជាបានស្គាល់ច្បាស់អំពីស្នាដៃនិពន្ធរបស់ពួកហោរានៅសតវត្សទី៨មុនគ.ស. ដូចជាលោកអេសាយ និងលោកអេម៉ុស លោកសេផានាបាននិយាយឆ្លុះបញ្ចាំងអំពីពាក្យរបស់ពួកគាត់ ហើយប្រហែលជាបានដឹងអំពីការងារបម្រើព្រះរបស់លោកហោរាវ័យក្មេង យេរេមាផងដែរ ។

### កាលបរិច្ឆេទ

តាមបទគម្ពីរ ១:១ លោកសេផានាបានថ្លែងទំនាយនៅក្នុងរជ្ជកាលស្ដេចយូសៀស (ឆ្នាំ ៦៤០ ដល់ ៦០៩ មុនគ.ស.) ដូចនេះលោកសេផានាបានរស់នៅក្នុងសម័យតែមួយ ជាមួយនឹងលោកយេរេមា លោកណាហ៊ុម ហើយក៏ប្រហែលជាមួយនឹងលោកហាបាគុកផងដែរ ។ កាលបរិច្ឆេទនៃការថ្លែងទំនាយរបស់លោកសេផានាប្រហែលជានៅដើមដំបូងនៃរជ្ជកាលស្ដេចយ៉ូសៀស គឺនៅមុនពេលដែលស្ដេចអង្គនេះប៉ុនប៉ងធ្វើកំណែរទម្រង់ (សម័យនោះនៅតែមានស្ថានភាពអាក្រក់ដែលស្ដេចម៉ានាសេ និងស្ដេចអាំម៉ូនបានបន្សល់ទុក) ហើយនៅមុនការស្លាប់របស់ស្ដេចអាសស៊ើរ ព្រះនាម អាសស៊ើរបានីប៉ាល នៅក្នុងឆ្នាំ ៦២៧ មុន គ.ស. (នៅក្នុងអំឡុងពេលដែលចក្រភពអាសស៊ើរនៅខ្លាំងនៅឡើយ ទោះជាទទួលនូវការគម្រាមកំហែងក៏ដោយ) ។

### ប្រវត្តិដើម

មើលសេចក្ដីផ្ដើមព្រះគម្ពីរយេរេមា និងព្រះគម្ពីរណាហ៊ុមត្រង់ ប្រវត្តិដើម, មើល ២ពវ ២២:១–២៣:៣០ ២រប ៣៤:១–៣៦:១ និងការពន្យល់ ។ ការឈ្លានពានរបស់សាសន៍ស៊ី

### គោលបំណង និងខ្លឹមសារនៃវិជ្ជាសិក្សាអំពីព្រះ

គោលបំណងនៃអ្នកនិពន្ធគឺដើម្បីប្រកាសប្រាប់ឱ្យពួកសាសន៍យូដាបានដឹងអំពីសេចក្ដីជំនុំជម្រះដែលជិតមកដល់ ។ ការឈ្លានពានរបស់សាសន៍ស៊ីធាន(Scythian) ចូលទឹកដីកាណានប្រហែលជាផ្ដល់ឱកាសសម្រាប់សរសេរព្រះគម្ពីរនេះឡើង ។ សាសន៍នេះមានជំនាញជិះសេះ ហើយមានដើមកំណើតនៅក្នុងទឹកដី ដែលសព្វថ្ងៃជាតំបន់ខាងត្បូងនៃប្រទេសរូស៊ី ។ នៅសតវត្សទី៧ មុនគ.ស. សាសន៍នេះបានធ្វើអន្ដោប្រវេសន៍ឆ្លងកាត់ទឹកដីកូកាសូស (Caucasus) ហើយតាំងទីលំនៅទឹកដីភាគខាងជើងនៃចក្រភពអាសស៊ើរ ។ ពួកសាសន៍ដែលជាសត្រូវនឹងសម្ព័ន្ធមិត្តរបស់សាសន៍អាសស៊ើរហាក់ដូចជាសម្រុកចូលពីភាគខាងត្បូងជាបន្តបន្ទាប់គ្នា នៅតាមតំបន់មាត់សមុទ្រមេឌីទែរ៉ាណេ នៅរវាងឆ្នាំទស្សវត្ស ៦២០ មុនគ.ស. ពួកគេបានបំផ្លាញអាសកេឡូន (Askelon) និងអាស់ដូឌ (Ashdod) ហើយឈប់ត្រឹមព្រំដែនប្រទេសអេស៊ីព្ទ គឺដោយសារតែបានទទួលប្រាក់សំណូកពីស្ដេចអេស៊ីព្ទព្រះនាម ផារ៉ោន សាមទិក (Psamtik ឬ Psammetichus)។ ទោះជាយ៉ាងណាក៏ដោយ សេចក្ដីទំនាយដែលលោកសេផានាបានថ្លែងគឺត្រូវបានសម្រេចដោយស្នាដៃសាសន៍បាប៊ីឡូន បន្ទាប់ពីសាសន៍នេះបានយកឈ្នះហើយបញ្ចប់អំណាចរបស់ចក្រភពអាសស៊ើរ ។

ខ្លឹមសារនៃព្រះគម្ពីរសេផានា គឺនិយាយអំពីការមកដល់ថ្ងៃនៃព្រះអម្ចាស់ (មើលការពន្យល់ អស ២:១១,១៧,២០ យអ ១:១៥ ២:២ អម ៥:១៨ ៨:៩) ជាពេលដែលត្រូវដាក់ទោសយ៉ាងធ្ងន់ធ្ងរចំពោះសាសន៍ទាំងឡាយ ដែលរួមមានសាសន៍យូដាដែលបានក្បត់ព្រះអម្ចាស់ផងដែរ ។ ព្រះគម្ពីរសេផានាបានពិពណ៌នាអំពីសេចក្ដីវេទនានៃការជំនុំជម្រះនោះ តាមរបៀបដែលមានប្រើនៅក្នុងព្រះគម្ពីរហោរាដទៃទៀតផងដែរ ។ ប៉ុន្ដែ អ្នកនិពន្ធក៏បានបញ្ជាក់ផងដែរថា ព្រះអម្ចាស់ទ្រង់នឹងនៅតែមានសេចក្ដីមេត្តាករុណាចំពោះរាស្ដ្ររបស់ទ្រង់ដដែល ហើយលោកបានបញ្ចប់សេចក្ដីទំនាយដោយប្រកាសប្រាប់អំពីភាពវិជ្ជមានដែលត្រូវមានបន្ទាប់ពីសេចក្ដីហិនវិនាសនោះ គឺការ

ដែលព្រះយ៉ាហ៍វេហ៍ (Yahweh) ទ្រង់ស្ដារសាសន៍យូដាឡើងវិញក្នុងនាមទ្រង់ជា "ស្ដេចនៃអ៊ីស្រាអែល" (៣:១៥ និងការពន្យល់) ។

**គម្រោងសង្ខេប**

**I. សេចក្ដីផ្ដើម (១:១–៣)**

ក. ចំណងជើង: អត្តសញ្ញាណរបស់លោកហោរា (១:១)

ខ. សេចក្ដីផ្ដើម: ការប្រកាសទ្វេដងអំពីសេចក្ដីជំនុំជម្រះជាសរុប (១:២–៣)

**II. ថ្ងៃនៃព្រះអម្ចាស់ដែលត្រូវមកដល់សាសន៍យូដា និងជាសាសន៍ដទៃ (១:៤–១៨)**

ក. ការជំនុំជម្រះពួកថ្វាយបង្គំរូបព្រះនៅស្រុកយូដា (១:៤–៩)

ខ. ការស្រែកយំពេញក្រុងយេរូសាឡិម (១:១០–១៣)

គ. ថ្ងៃនៃសេចក្ដីក្រោធរបស់ព្រះអម្ចាស់ដែលជៀសមិនផុត (១:១៤–១៨)

**III. សេចក្ដីជំនុំជម្រះនៃព្រះអម្ចាស់ចំពោះជាតិសាសន៍ទាំងឡាយ (២:១–៣:៨)**

ក. ការត្រាសហៅសាសន៍យូដាឱ្យប្រែចិត្ត (២:១–៣)

ខ. ការជំនុំជម្រះស្រុកភីលីស្ទីន (២:៤–៧)

គ. ការជំនុំជម្រះស្រុកម៉ូអាប់ និងអាំម៉ូន (២:៨–១១)

ឃ. ការជំនុំជម្រះស្រុកអេធីយ៉ូពី (២:១២)

ង. ការជំនុំជម្រះស្រុកអាសស៊ើរ (២:១៣–១៥)

ច. ការជំនុំជម្រះក្រុងយេរូសាឡិម (៣:១–៥)

ឆ. ក្រុងយេរូសាឡិមបដិសេធមិនព្រមប្រែចិត្ត (៣:៩–២០)

**IV. សេចក្ដីប្រោសលោះដល់ពួកសំណល់ (៣:៩–២០)**

ក. ជាតិសាសន៍ដែលត្រូវបានសម្អាតជាបរិសុទ្ធ ពួកសំណល់ដែលត្រូវស្ដារឡើងវិញ ក្រុងយេរូសាឡិមដែលត្រូវសម្អាតជាបរិសុទ្ធ (៣:៩–១៣)

ខ. សេចក្ដីអំណរនៅក្នុងទីក្រុង (៣:១៤–១៧)

គ. ជាតិសាសន៍ដែលត្រូវស្ដារឡើងវិញ (៣:១៨–២០)

**១** ១នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលបានមកដល់
សេផានា ជាកូនគូស៊ី ដែលជាកូនកេដាលា។ជាកូន
អ័ម៉ារា។ជាកូនហេសេគា នៅក្នុងរាជ្យនៃយ៉ូសៀស[ក] ព្រះ
រាជបុត្រាអាំម៉ូន[ខ] ជាស្តេចយូដា ។

## ការព្រមានអំពីសេចក្តីហិនវិនាសដែលត្រូវមក

២ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញនឹងរំលីងរបស់
ទាំងអស់ឱ្យបាត់ពីលើផែនដីទៅ[គ] ៣អញនឹងរំលីងទាំង
មនុស្ស និងសត្វ[ឃ] ក៏នឹងរំលីងទាំងសត្វហើរលើអាកាស[ង]
និងត្រីនៅសមុទ្រ ព្រមទាំងរបស់អ្វីដែលនាំឱ្យរវាតចិត្ត
ជាមួយនឹងពួកមនុស្សអាក្រក់ផង គឺអញនឹងកាត់ផ្តិលមនុស្ស
ពីលើផែនដីចេញ[ច] នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ឆ]។

## ទាស់នឹងពួកយូដា

៤អញនឹងលូកដៃ[ជ] ទៅលើស្រុកយូដា ហើយលើពួក
អ្នកនៅក្រុងយេរូសាឡិមទាំងប៉ុន្មានដែរ ក៏នឹងកាត់ផ្តិល
សំណល់របស់ព្រះបាល[ឈ] ពីទីនោះចេញ ព្រមទាំងឈ្មោះ
ពួកអ្នកធ្វើការងារចំពោះរូបព្រះជាមួយនឹងពួកសង្ឃផង[ញ]
៥នឹងពួកអ្នកដែលឡើងទៅលើដំបូលផ្ទះ ដើម្បីថ្វាយបង្គំ
ដល់ពលបរិវារនៅលើមេឃ[ដ] ហើយពួកអ្នកដែលថ្វាយបង្គំ
គឺដែលស្បថដល់ទាំងព្រះយេហូវ៉ា និងដល់ព្រះម៉ូឡុកផង[ឋ]
៦ហើយពួកអ្នកដែលបានរាថយ ចេញពីការគោរពតាម[ឌ]
ព្រះយេហូវ៉ា និងពួកអ្នកដែលមិនបានស្វែងរក[ឍ]ព្រះយេ
ហូវ៉ា ឬស៊ើបសួរ[ណ]តាមទ្រង់សោះ ។
៧ចូរឱ្យនៅស្ងៀម[ត]ចំពោះព្រះអម្ចាស់យេហូវ៉ាចុះ ដ្បិត
ថ្ងៃនៃព្រះយេហូវា[ថ]ជិតដល់ហើយ ពីព្រោះព្រះយេហូវ៉ា
ទ្រង់បានចាត់ចែងយញ្ញបូជា[ទ] ទ្រង់បានរើសពួកអ្នកដែល
ត្រូវអញ្ជើញមកហើយ ៨នៅថ្ងៃដែលថ្វាយយញ្ញបូជារបស់
ព្រះយេហូវ៉ា នោះអញនឹងធ្វើទោស[ធ]ដល់ទាំងពួកចៅហ្វាយ
និងពួកកូនស្តេច[ន] ហើយពួកអ្នកដែលតែងខ្លួន ដោយ
សំលៀកបំពាក់របស់សាសន៍ដទៃផង ៩នៅថ្ងៃនោះ អញ

**១:១** ក ២ពវ ២២:១ ២របា ៣៤:១–៣៥:២៥ ខ ១របា ៣:១៤ **១:២** គ លប ៦:៧ **១:៣** ឃ យរ ៥០:៣ ង យរ ៤:២៥ ច ឧ.១៨ ហស ៤:៣ ឆ អគ ១៤:១៧ **១:៤** ជ យរ ៦:១២ ឈ មីក ៥:១៣ សផ ២:១១ ញ យរ ១៥:៦ ហស ១០:៥ **១:៥** ដ យរ ៨:២ ឋ លវ ១៨:២១ យរ ៥:៧ **១:៦** ឌ អស ១:៤ យរ ២:១៣ ឍ អស ៩:១៣ ណ ហស ៧:៧ **១:៧** ត អស ៤១:១ ថ ឧ.១៤ អស ១៣:៦ អគ ៧:១៩ យអ ៣:១៤ អម ៥:១៨–២០ ទ លវ ៣:៩ យរ ៤៦:១០ **១:៨** ធ អស ២៤:២១ ន យរ ៣៩:៦

**១:១** *ព្រះបន្ទូលនៃព្រះយេហូវ៉ា* ពាក្យនេះពួកហោរាតែប្រើនៅក្នុងការផ្តើមថ្លែងព្រះបន្ទូល (មើល យរ ១:២ ហស ១:១ និងការពន្យល់) ។ *សេផានា* មានន័យថា "ព្រះអម្ចាស់ទ្រង់លាក់" ឬ "ព្រះអម្ចាស់ទ្រង់ការពារ" ឈ្មោះនេះប្រហែលជាបង្ហាញពីសេចក្តីអធិស្ឋានសូមដល់ព្រះអម្ចាស់ នូវការការពារ ដល់ក្មេងឈ្មោះសេផានា នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងដ៏អាក្រក់របស់ស្តេចម៉ានាសេ ។ *ជាកូន . . . ហេសេគា* តាមការដែលអ្នកនិពន្ធនិយាយអំពីពង្សាវតាររបស់ខ្លួនដូចនេះ គាត់ប្រហែលជាមានអាយុជាង ២០ ឆ្នាំ នៅពេលចាប់ផ្តើមថ្លែងទំនាយ ។ បើប្រៀបធៀបនឹងលោកអេសាយ គេអាចសំគាល់លោកសេផានាថា មានទំនាក់ទំនងជិតស្និទ្ធនឹងពួកអ្នកដឹកនាំជាងទោះបីជាលោកអេសាយក៏បានចូលរួមនៅក្នុងរោងជំនុំជាទៀងទាត់ ហើយប្រហែលជាកើតនៅក្នុងត្រកូនអភិជនក៏ដោយ ។
**១:២–៣** *រំលីង . . . ឱ្យបាត់* លោកសេផានាបាននិយាយអំពីសេចក្តីហិនវិនាសដែលត្រូវមក ហើយជាការរំឭកអំពីព្រះបន្ទូលដែលព្រះអម្ចាស់ទ្រង់មានមុនពេលទឹកជំនន់(លប ៦:៧) ។ ប៉ុន្តែនៅពេលនេះសេចក្តីហិនវិនាសនោះនឹងកើតឡើងដោយភ្លើងនៃព្រះអម្ចាស់ (ឧ.១៨ ៣:៨) ។
**១:៣** *របស់អ្វីដែលនាំឱ្យរវាតចិត្ត* ព្រះអម្ចាស់ទ្រង់នឹងកាត់ទោសពួកមនុស្សអាក្រក់ដោយដាក់ឧបសគ្គដែលមិនអាចឆ្លងកាត់បាន ហើយពួកគេនឹងត្រូវវិន័យទាំងស្រុង ។
**១:៤–៦** វគ្គនេះហាក់ដូចជាបង្ហាញថា លោកសេផានាបានធ្វើការងារសំខាន់បំផុតរបស់លោកនៅមុនឆ្នាំ ៦២១ មុនគ.ស. ពីព្រោះប្រពៃណីខុសឆ្គងដែលមាននិយាយក្នុងវគ្គនេះ ត្រូវបានលប់បំបាប់នៅក្នុងកំណែទម្រង់របស់ស្តេចយ៉ូសៀសហើយ (មើល ២ពវ ២៣:៤–១៦ និងពន្យល់) ។ ពាក្យរបស់លោកសេផានាប្រហែលជាបានរួមចំណែក នៅក្នុងការជំរុញឱ្យស្តេចយ៉ូសៀសធ្វើកំណែទម្រង់នេះ(ធៀបនឹង ២របា ៣៤:១–៧) ។
**១:៤** ពួកយូដាត្រូវបានបដិសេធន៍ ដោយសារការមិនព្រមប្រែចិត្តពីការថ្វាយបង្គំរូបព្រះបាល ។ *ទីនេះ* គឺក្រុងយេរូសាឡិម ដែលជាកន្លែងដែលលោកសេផានាបានរស់នៅ ។ *រូបព្រះ* មើលការពន្យល់ ពច ២:១៣ ។
**១:៥** *លើដំបូលផ្ទះ* មើល ២ពវ ២៣:១២ យរ ១៩:១៣ និងការពន្យល់ ។ *ថ្វាយបង្គំដល់ពលបរិវារ* មើល ចទ ៤:១៩ ២ពវ ១៧:១៦ និងការពន្យល់ ២១:៣ អស ៤៧:១៣ ។ *ស្បថដល់ទាំងព្រះយេហូវ៉ា នឹងដល់ព្រះម៉ូឡុក* គឺថ្វាយបង្គំព្រះរបស់ខ្លួនផង និងព្រះរបស់សាសន៍ដទៃផង ។ *ព្រះម៉ូឡុក* ពួកអាម៉ូរីថ្វាយបង្គំរូបព្រះនេះ ហើយជួនកាលគេយកក្មេងធ្វើយញ្ញបូជាថ្វាយព្រះនេះ ។ ពួកអ៊ីស្រាអែលបានហាមឃាត់ការថ្វាយបង្គំរូបព្រះម៉ូឡុកនេះ(មើល លវ ១៨:២១ និងការពន្យល់ ២០:១–៥)។ ទោះជាយ៉ាងដូចនេះក៏ដោយ ស្តេចសាឡូម៉ូនបានសង់អាសនាមួយថ្វាយដល់ព្រះម៉ូឡុកនេះនៅលើភ្នំដើមអូលីវ(១ពវ ១១:៧)។ ពួកម៉ានាសេបានធ្វើយញ្ញបូជាកូនក្មេងនៅក្នុងច្រកភ្នំហ៊ីណំម(មើល ២របា ៣៣:៦ យរ ៧:៣១ និងការពន្យល់ ៣២:៣៥)។
**១:៧** *ចូរឱ្យនៅស្ងៀមចំពោះព្រះអម្ចាស់យេហូវ៉ា* មើល ហព ២:២០ និងការពន្យល់ ។ *ថ្ងៃនៃព្រះយេហូវ៉ា* ខ្លឹមសារសំខាន់នៃព្រះគម្ពីរសេផានា (មើល សេចក្តីផ្តើមត្រង់ គោលបំណង និងខ្លឹមសារវិជ្ជាសិក្សាអំពីព្រះ) គឺនិយាយផ្តោតទៅលើការសងសឹករបស់ព្រះចំពោះសាសន៍ដែលថ្វាយបង្គំរូបព្រះ ហើយមិនមែនផ្តោតទៅលើការប្រោសលោះសាសន៍យូដានោះឡើយ ។ *យញ្ញបូជា* មានន័យថា ជនរងគ្រោះគឺសាសន៍យូដា ។ *រើស* ការដែលព្រះអម្ចាស់ទ្រង់កាត់ទោសដោយសំលាប់គឺជាការធ្វើយញ្ញបូជា ហើយការដែលទ្រង់រៀបចំសម្រាប់ភ្ញៀវរបស់ទ្រង់គឺដោយការរើសពួកគេ គឺដើម្បីរៀបចំសម្រាប់ការជប់លៀងពីរបឹប ។ *អ្នក . . . អញ្ជើញមក* គឺពួកសាសន៍ដទៃដែលត្រូវកាន់កាប់អ៊ីស្រាអែល(ជាពិសេសស្រុកបាប៊ីឡូន)។
**១:៨** *សំលៀកបំពាក់របស់សាសន៍ដទៃផង* ការស្លៀកពាក់បង្ហាញថា ពួកគេបានត្រាប់តាមពួកបាប៊ីឡូន ពួកអេស៊ីព្ទ ឬអាសស៊ើរ ។
**១:៩** *លោតរំលងមេទ្វារ* ប្រហែលជាសំដៅទៅលើប្រពៃណីយរបស់

នឹងធ្វើទោសដល់ពួកអ្នកដែលលោតរំលងមេទ្វារ[ប] ហើយ
បំពេញផ្ទះរបស់ចៅហ្វាយគេ ដោយសេចក្ដីច្រឡោតនឹង
សេចក្ដីឆបោក[ផ] ១០ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅថ្ងៃ
នោះ[ព] នឹងឮសូរសំរែកពីទ្វារត្រី[ភ] និងសូរទ្រហោយំ[ម]ពីឃុំ
ទី២ ហើយសូរគ្រាំគ្រេងពីភ្នំទាំងប៉ុន្មាន ១១ម្នាល ពួកអ្នកនៅ
ម៉ាកថេសអើយ ចូរទ្រហោយំចុះ[យ] ពីព្រោះពួកធ្វើជំនួញ
ទាំងប៉ុន្មានត្រូវបំផ្លាញ អស់អ្នកដែលផ្ទុកដោយប្រាក់បាន
ត្រូវវិនាសហើយ[រ] ១២នៅគ្រានោះ អញនឹងឆែកឆេរក្រុង
យេរូសាឡិមដោយពន្លឺចង្កៀង នោះអញនឹងធ្វើទោសដល់
ពួកអ្នកដែលបានរងនៅលើកកររបស់គេ[ល] ជាពួកអ្នកដែល
គិតក្នុងចិត្តថា[វ] ព្រះយេហូវ៉ានឹងមិនធ្វើ[ស] ទោះល្អឬអាក្រក់
ផង[ហ] ១៣ទ្រព្យសម្បត្តិរបស់គេនឹងត្រូវរឹបជាន់[ឡ] ហើយផ្ទះគេ
នឹងត្រូវចោលស្ងាត់ទទេ អើ គេនឹងសង់ផ្ទះ តែមិនបាន
អាស្រ័យនៅទេ គេនឹងដាំចំការទំពាំងបាយជូរ តែមិន
បានផឹកអ្វីពីនោះឡើយ[អ] ។

## ថ្ងៃដ៏ធំរបស់ព្រះអម្ចាស់

១៤ថ្ងៃដ៏ធំរបស់ព្រះយេហូវ៉ា[ក]ជិតមកដល់[ខ] គឺបានមក
ជិតហើយ ក៏ប្រញាប់ណាស់ដែរ គឺឮសូរថ្ងៃនៃព្រះយេហូវ៉ា
ហើយ វេលានោះ ពួកមនុស្សខ្លាំងពូកែ នឹងស្រែកឡើង
យ៉ាងជូរចត់ ១៥ថ្ងៃនោះជាថ្ងៃនៃសេចក្ដីក្រោធ គឺជាថ្ងៃដ៏
វេទនា ហើយមានទុក្ខ ជាថ្ងៃបំផ្លាញ ហើយរំលាង ជាថ្ងៃ
ងងឹត[គ] ហើយស្រអាប់ ជាថ្ងៃមេឃមីរស្រទំ ហើយងងឹត
យ៉ាងក្រាស់[ឃ] ១៦ជាថ្ងៃឮសូរត្រែ នឹងសំរែកដ៏ពន្លឺក[ង] ទាស់
នឹងក្រុងដែលមានគ្រឿងការពារ ហើយទាស់នឹងកំផែង
យ៉ាងខ្ពស់[ច] ១៧អញនឹងធ្វើឱ្យមនុស្សកើតមានទុក្ខលំបាក[ឆ]
ឱ្យគេបានដើរដូចជាមនុស្សខ្វាក់[ជ] ដោយព្រោះគេបានធ្វើ
បាបនឹងព្រះយេហូវ៉ា ឈាមគេនឹងត្រូវចាក់ចេញ[ឈ]ដូចជា
ធូលី ហើយសាច់របស់គេ ដូចជាលាមក[ញ] ១៨ទោះទាំងប្រាក់
និងមាសរបស់គេ ក៏មិនអាចនឹងជួយគេឱ្យរួច ក្នុងថ្ងៃនៃ
សេចក្ដីខ្ញាល់របស់ព្រះយេហូវ៉ាដែរ[ដ] គឺស្រុកទាំងមូលនឹង
ត្រូវឆេះអស់ទៅ ដោយភ្លើងនៃសេចក្ដីប្រចណ្ឌ[ឋ]របស់ទ្រង់
ដ្បិតទ្រង់នឹងធ្វើឱ្យផុតទៅ[ឌ] អើ ទ្រង់នឹងធ្វើឱ្យអស់អ្នក ដែល
អាស្រ័យនៅក្នុងស្រុក បានផុតទៅជាមួយរំពេច[ឍ] ។

**២** ១ម្នាល នគរឥតខ្មាស[ក]អើយ ចូរមូលគ្នាមក[ខ]អើ ចូរ
មូលគ្នា ២មុនកំណត់ដែលត្រូវសំរេចតាមច្បាប់ គឺមុន
ដែលថ្ងៃនោះកន្លងបាត់ទៅដូចជាអង្កាម[គ] មុនដែលសេចក្ដី
ខ្ញាល់ដ៏សហ័ស[ឃ]របស់ព្រះយេហូវ៉ាមកលើអ្នករាល់គ្នា អើ
មុនដែលថ្ងៃមកដល់ ក្នុងកាលដែលសេចក្ដីខ្ញាល់[ង]របស់ព្រះ
យេហូវ៉ាមកលើអ្នករាល់គ្នា ៣អស់អ្នករាបសានៅផែនដី

**១:៩** ប ១សយ ៥:៥ ផ អស ៣:១០ **១:១០** ព អស ២២:៥ ភ ២របា ៣៣:១៤ ម អម ៥:១៦ **១:១១** យ យក ៥:១ រ ហស ៩:៦ **១:១២** ល អម ៦:១ វ យរ ៤៨:១១ ស ២ពវ ២១:១៦ អគ ៨:១២ ហ យប ២២:១៣ **១:១៣** ឡ ២ពវ ២៤:១៣ យរ ១៥:១៣ អ ចទ ២៨:៣០,៣៩ បទ ៥:២ អម ៥:១១ **១:១៤** ក ខ.៧ យអ ១:១៥ ខ អគ ៧:៧ ដយ ៧:១៣ **១:១៥** គ ១សយ ២:៩ ឃ អស ២២:៥ យអ ២:២ មក ១៣:២៤–២៥ **១:១៦** ង យរ ៤:១៩ ច ចទ ២៨:៥២ អស ២:១៥ យអ ២:១ **១:១៤** ក ខ.៧

យអ ១:១៥ ខ អគ ៧:៧ ដយ ៧:១៣ **១:១៥** គ ១សយ ២:៩ ឃ អស ២២:៥ យអ ២:២ មក ១៣:២៤–២៥ **១:១៦** ង យរ ៤:១៩ ច ចទ ២៨:៥២ អស ២:១៥ យអ ២:១ **១:១៧** ឆ ចទ ២៨:៥២ ជ អស ៥៩:១០ ឈ ទដ ៧៩:៣ ញ ទដ ៨៣:១០ **១:១៨** ដ យប ២០:២០ ៤០:១១ យរ ៤:៤ អគ ៧:១៩ ឋ ចទ ២៩:២០ ឌ ខ.២–៣ សផ ៣:៨ ឍ លប ៦:៧ អគ ៧:១១ **២:១** ក យរ ៣:៣ ៦:១៥ ខ ២របា ២០:៤ យអ ១:១៤ **២:២** គ អស ១៧:១៣ ហស ១៣:៣ ឃ យរ ១០:២៥ បទ ៤:១១ ង យរ ៤:៤ អគ ៧:១៩

សាសន៍ដទៃដែលចាប់ផ្ដើមមានតាំងពីសម័យលោកសាំយូអែល (មើល ១សយ ៥:៥ និងការពន្យល់) ។

**១:១០–១៣** វគ្គនេះនិយាយអំពីការស្រែកយំពេញទីក្រុង (គឺផ្ទុយពី ៣:១៤–១៧) ។

**១:១០** ពួកឈ្មួញដែលរកស៊ីមានបានដោយអំពើពុករលួយនឹងត្រូវបំផ្លាញ ។ *ទ្វារត្រី* គឺនៅកំផែងខាងជើងរបស់ទីក្រុង (មើលការពន្យល់ នហ ៣:៣) ។ ទីក្រុងយេរូសាឡិមងាយនឹងត្រូវវាយប្រហារពីភាគខាងជើង ។ *ឃុំទី២* មើលការពន្យល់ នហ ១១:៩ ។

**១:១១** *ម៉ាកថេស* អាចជាតំបន់មួយនៅជ្រលងទីរ៉ូផូអិន (មើលការពន្យល់ នហ ២:១៣) ។

**១:១២** *ឆែកឆេក្រុងយេរូសាឡិមដោយពន្លឺចង្កៀង* នៅពេលក្រោយមកទៀត ពួកបាប៊ីឡូននឹងចាប់អូសបណ្ដាជនចេញពីកន្លែងដែលពួកគេលាក់ខ្លួន ដូចជាផ្ទះ តាមផ្លូវ តាមលូទឹក និងផ្នូរខ្មោច ។ *ពួកអ្នកដែលបានរងនៅលើកកររបស់គេ* មើល អស ២៥:៦ និងការពន្យល់ ។ *ព្រះយេហូវ៉ានឹងមិនធ្វើទោះល្អឬអាក្រក់ផង* ការដែលពួកមនុស្សអាក្រក់យល់ដូចនេះ គឺបង្ហាញអំពីភាពក្រអឺតក្រទមរបស់ពួកគេ (មើលការពន្យល់ ទដ ១០:១១) ។

**១:១៣** ទ្រព្យសម្បត្តិដែលរកបានដោយអំពើទុច្ចរិត និងត្រូវបង្ហាញចេញមកហើយរឹបជាន់ (មើល ចទ ២៨:៣០) ។

**១:១៤–១៨** នៅក្នុងវគ្គនេះ គឺជាប្រភេទបទចំរៀងដែលបង្ហាញអំពីព្រះចេស្ដាដ៏អស្ចារ្យនៃព្រះ ព្រះអម្ចាស់ទ្រង់បកស្រាយអំពីការបំផ្លាញលោកិយដោយសេចក្ដីក្រោធរបស់ទ្រង់ ។

**១:១៥** *ជាថ្ងៃងងឹត . . . ងងឹតយ៉ាងក្រាស* មើល អម ៥:១៨–២០ ។

**១:១៧** *ដូចជាមនុស្សខ្វាក់* មើល ចទ ២៨:២៨–២៩ ។

**១:១៨** *ទោះទាំងប្រាក់ . . .មាស . . . អាចនឹងជួយគេ* នៅថ្ងៃព្រះអម្ចាស់ជំនុំជម្រះ ទ្រព្យសម្បត្តិដែលជាសំភារៈនឹងមិនអាចលោះពួកគេឱ្យរួចពីការជំនុំជម្រះបានឡើយ ។ *ភ្លើងនៃសេចក្ដីប្រច័ណ្ឌរបស់ទ្រង់* មើល ខ.២–៣ និងការពន្យល់, ៣:៨ ។

**២:១–៣** ក្នុងវគ្គនេះលោកសេផានាលើកទឹកចិត្តឱ្យពួកយូដាប្រែចិត្ត ។ នៅចន្លោះវគ្គនេះដែលត្រាសហៅឱ្យលន់តួរបាប ហើយវគ្គក្រោមមកទៀតដែលលើកឡើងពីទោសនៃការមិនព្រមប្រែចិត្ត (មើល ៣:៦–៨ និងការពន្យល់) គឺជាការរៀបរាប់អំពីការជំនុំជម្រះជាច្រើនដែលត្រូវមកដល់នៅក្នុងថ្ងៃនៃព្រះអម្ចាស់ (២:៤–៣:៥) ។

**២:២** *អង្កាម* មើល ទដ ១:៤ និងការពន្យល់ ៣៥:៥ អស ១៧:១៣ ២៩:៥ ហស ១៣:៣ ។

**២:៣** *ស្វែងរកទ្រង់* ទោះជាសេចក្ដីហិនវិនាសហៀបតែនឹងកើតឡើងក៏ដោយ ក៏នៅមានឱកាសរួចពីសេចក្ដីទុក្ខនោះ បើសាសន៍នោះព្រមប្រែចិត្ត

ដែលរក្សាអស់ទាំងបញ្ញត្តិច្បាប់របស់ព្រះយេហូវ៉ាអើយ
ចូរស្វែងរក[ច]ទ្រង់ ចូរស្វែងរកសេចក្ដីសុចរិត[ឆ] ចូរស្វែង
រកសេចក្ដីសុភាពចុះ[ជ]ប្រហែលជាអ្នករាល់គ្នា និងបានបាំង
ទុក[ឈ]នៅក្នុងថ្ងៃនៃសេចក្ដីខ្ញាល់របស់ព្រះយេហូវ៉ាទេដឹង ។

## ទាស់នឹងសាសន៍ភីលីស្ទីន

៤ដ្បិតក្រុងកាសា[ញ]នឹងត្រូវស្ងាត់ច្រៀប ហើយក្រុង
អាសកាឡូន[ដ] នឹងត្រូវខូចបង់ ឯពួកក្រុងអាសដូឌ និងត្រូវ
បណ្ដេញចេញទៅទាំងថ្ងៃត្រង់ ហើយក្រុងអេក្រុននឹងត្រូវ
រំលើងទៅដែរ ៥វេទនាដល់ពួកអ្នកដែលអាស្រ័យនៅតាម
ឆ្នេរសមុទ្រ ជាសាសន៍កេរេធីម[ឋ]នោះ ព្រះបន្ទូលនៃព្រះ
យេហូវ៉ាទាស់នឹងឯងរាល់គ្នា[ឌ] ម្នាលកាណាន ជាស្រុករបស់
ពួកភីលីស្ទីនអើយ អញនឹងបំផ្លាញឯង មិនឱ្យមានអ្នកណា
គង់នៅទៀតឡើយ[ឍ] ៦នោះស្រុកតាមឆ្នេរសមុទ្រនឹងបានជា
ទីសំរាប់ឃ្វាលសត្វ មានទាំងទីលំនៅសំរាប់ពួកអ្នកគង្វាល
និងក្រោលសំរាប់ហ្វូងចៀមដែរ[ណ] ៧ស្រុកនោះនឹងបាន
សំរាប់សំណល់[ត]នៃពួកវង្សយូដា គេនឹងឃ្វាលហ្វូងសត្វ
របស់គេនៅទីនោះ នៅពេលយប់ គេនឹងដេកក្នុងផ្ទះ នៅក្នុង
អាសកាឡូន ពីព្រោះព្រះយេហូវ៉ា ជាព្រះនៃគេ ទ្រង់នឹង
ប្រោសគេ ហើយនាំពួកគេដែលជាប់ជាឈ្លើយមកវិញ[ថ] ។

## ទាស់នឹងសាសន៍ម៉ូអាប់ និងអាំម៉ូន

៨អញបានឮពាក្យដំនៀល[ទ]របស់សាសន៍ម៉ូអាប់[ធ] និង
ពាក្យជេរប្រមាថរបស់ពួកកូនចៅអាំម៉ូន[ន] គឺជាពាក្យដែល
គេត្មះតិះដៀល[ប]ដល់រាស្ត្រអញ ហើយបានដំកើងខ្លួនគេ
ទាស់ និងព្រំស្រុករបស់រាស្ត្រអញផង[ផ] ៩ហេតុនោះ ព្រះ
យេហូវ៉ា នៃពួកពលបរិវារ ជាព្រះនៃសាសន៍អ៊ីស្រាអែល
ទ្រង់ស្បថថា ដូចជាអញរស់នៅ ពិតប្រាកដជាស្រុកម៉ូអាប់[ព]
នឹងបានដូចជាក្រុងសូដុំម[ភ] ហើយពួកកូនចៅអាំម៉ូន[ម]នឹងបាន
ដូចជា ក្រុងកូម៉ូរ៉ាដែរ គឺជាទីមានសុទ្ធតែដើមកន្ទេចអាល
និងអណ្ដូងអំបិល ជាទីខូចបង់នៅជានិច្ច ឯសំណល់នៃរាស្ត្រ
អញ នឹងប្លន់[យ]គេ ហើយសំណល់[រ] នៃនគរអញ នឹងចាប់យក
គេជាមរដក[ល] ១០នេះជាសេចក្ដីដែលនឹងកើតមានដល់គេ
ដោយព្រោះសេចក្ដីអំនួតរបស់គេ[វ] ពីព្រោះគេបានត្មះតិះ
ដៀល[ស] ហើយដំកើងខ្លួន ទាស់នឹងរាស្ត្ររបស់ព្រះយេហូវ៉ា
នៃពួកពលបរិវារ[ហ] ១១ព្រះយេហូវ៉ាទ្រង់នឹងបានជាទីស្ញែង
ខ្លាច[ឡ]ដល់គេ ដ្បិតទ្រង់នឹងធ្វើឱ្យអស់ទាំងរូបព្រះ[អ]នៅផែន
ដី[ក] រៀវសូន្យទៅ នោះមនុស្សទាំងឡាយនឹងថ្វាយបង្គំដល់
ទ្រង់វិញ គ្រប់គ្នានឹងថ្វាយបង្គំនៅកន្លែងរបស់ខ្លួន[ខ] គឺអស់
ទាំងកោះរបស់សាសន៍ផ្សេងៗផង ។

**២:៣** ច អម ៥:៦ ឆ អស ១:១៧ ជ ទដ ៤៥:៤ ឈ ទដ ៥៧:១ **២:៤** ញ លប ១០:១៩ អម ១:៦,៧–៨ សក ៩:៥–៧ ដ យរ ៤៧:៥ **២:៥** ឋ ១សយ ៣០:១៤ ឌ លប ២៦:៣១ អម ៣:១ ឍ អស ១៤:៣០ **២:៦** ណ អស ៥:១៧ **២:៧** ត លប ៤៥:៧ ថ ចទ ៣០:៣ ទដ ១២៦:៤ យរ ៣២:៤៤ ហស ៦:១១ យអ ៣:១ អម ១:៦–៨ **២:៨** ទ យរ ៤៨:២៧ ធ លប ១៩:៣៧ អស ១៦:៦ ន អគ ២១:២៨ ប អគ ២៥:៣ ផ បទ ៣:៦១ **២:៩** ព ចទ ២៣:៦ អស ១៥:១–១៦:១៤ យរ ៤៨:១–៤៧ អគ ២៥:៨–១១ ភ ចទ ២៩:២៣ អស ១៣:១៩ យរ ៤៩:១៨ ម យរ ៤៩:១–៦ អគ ២៥:១–៧ យ អស ១១:១៤ រ ២ពវ ១៩:៣១ ល អម ២:១–៣ **២:១០** វ យប ៤០:១២ អស ១៦:៦ ស យរ ៤៨:២៧ ហ ទដ ៩:៦ **២:១១** ឡ យអ ២:១១ អ សផ ១:៤ ក ១របា ១៩:១ អគ ២៥:៦–៧ ខ ទដ ៨៦:៩ អស ១២:៤ សផ ៣:៩

(អម ៥:៤ និងការពន្យល់) ។ *សេចក្ដីសុភាព* គឺកើតមានពីការលះចោលការអួតអាងនៅក្នុងការថ្វាយបង្គំរូបព្រះ និងសេចក្ដីល្ងង់ខ្លៅ ហើយ "ស្វែងរកការបន្ទាបខ្លួន" ។

**២:៤–៣:៨** វគ្គនេះនិយាយអំពី ការជំនុំជម្រះរបស់ព្រះអម្ចាស់ ចំពោះជាតិសាសន៍ជាច្រើនដែលរួមមានទាំងក្រុងយេរូសាឡិមផងដែរ (មើល អម ១:៣–២:១៦ និងការពន្យល់) ។

**២:៤** *ក្រុងកាសា . . . ក្រុងអាសកាឡូន . . . ពួកក្រុងអាសដូឌ . . . ក្រុងអេក្រុន* គឺជាបណ្ដាទីក្រុងរបស់សាសន៍ភីលីស្ទីន ដែលភាគខាងលិចស្រុកយូដា ជាប់នឹងសមុទ្រ (ខ.៥–៦ មើលការពន្យល់ អម ១:៦,៨) ។

**២:៥** *សាសន៍កេរេធីម* មើលការពន្យល់ ១សយ ៣០:១៤ ។ *ម្នាលកាណាន* មើលការពន្យល់ លប ១០:៦ ។ *អញ . . . នៅទៀតឡើយ* ត្រង់ចំណុចនេះព្រះអម្ចាស់ទ្រង់ប្រកាសអំពីគោលបំណងរបស់ទ្រង់ ។

**២:៦** ទីក្រុងទាំងឡាយរបស់សាសន៍ភីលីស្ទីនដែលធ្លាប់តែល្បីល្បាញនឹងត្រូវក្លាយជាវាលសំរាប់ឃ្វាលសត្វ ។

**២:៧** សំណល់នៃសាសន៍យូដាដែលស្មោះត្រង់នឹងបានកាន់កាប់ទឹកដីនោះ ហើយហ្វូងសត្វរបស់ពួកគេនឹងបានស៊ីស្មៅនៅលើទឹកដីនោះ ។ *ទ្រង់នឹងប្រោសគេ* នៅក្នុងខនេះ និងខ.៩,១១ លោកសេផានាបានប្រាប់ឱ្យដឹងជាមុនអំពីលទ្ធផលចុងក្រោយនៅថ្ងៃព្រះអម្ចាស់ ដែលមានពន្យល់លម្អិតនៅក្នុង វគ្គ ៣:៩–២០ ។

**២:៨** *សាសន៍ម៉ូអាប់ . . . ពួកកូនចៅអាំម៉ូន* គឺពួកអ្នករស់នៅភាគខាងកើតទឹកដីស្រុកយូដា (មើលការពន្យល់ លប ១៩:៣៦–៣៨ អម ១:១៣ ២:៣) ។ ចំពោះការដែលសាសន៍ទាំងពីរនេះជាខ្មាំងសត្រូវនឹងសាសន៍អ៊ីស្រាអែល មើល អម ១:១៣ ២:៣ ។ ជាញឹកញាប់ពួកគេគំរាមថា នឹងវាយកាន់កាប់ទឹកដីអ៊ីស្រាអែល (មើល ពច ១១:១៣ និងការពន្យល់, អគ ២៥:២–៧) ។

**២:៩** *ក្រុងសូដុំម . . . ក្រុងកូម៉ូរ៉ា* មើល លប ១៩ ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ឈ្មោះទីក្រុងទាំងពីរត្រូវបានប្រើតំណាងឱ្យការបំផ្លាញទាំងស្រុងដោយព្រះហស្ដនៃព្រះ (មើល អម ៤:១១ និងការពន្យល់) ហើយការលើកឡើងនៅក្នុងព្រះគម្ពីរនេះគឺដើម្បីបង្ហាញអំពីកម្រិតនៃសេចក្ដីហិនវិនាសនៅថ្ងៃនៃព្រះអម្ចាស់ ។ *ដើមកន្ទេចអាល* គឺជានិមិត្តរូបនៃការធ្លាក់ចុះនៃចំនួនប្រជាជន (ធៀបនឹង អស ៧:២៣–២៥) ។ *សំណល់ . . . នឹងចាប់យកគេជាមរដក* មើលការពន្យល់ ខ.៧ ។

**២:១០** *ដោយព្រោះសេចក្ដីអំនួតរបស់គេ ពីព្រោះគេបានត្មេះតិះដៀល* ជាការឆ្លើយតបទៅវិញ ពួកសំណល់នៃសាសន៍យូដា និងបានកាន់កាប់ទឹកដីស្រុកអាំម៉ូន និងម៉ូអាប់ ។

**២:១១** *មនុស្សទាំងឡាយនឹងថ្វាយបង្គំដល់ទ្រង់វិញ* មើល ៣:៩ និងការពន្យល់ ។

### ទាស់នឹងសាសន៍អេធីយ៉ូពី

១២ឯងរាល់គ្នា ជាសាសន៍អេធីយ៉ូពី[គ] ក៏នឹងត្រូវស្លាប់
ដោយដាវរបស់អញដែរ[ឃ]។

### ទាស់នឹងសាសន៍អាសស៊ើរ

១៣ទ្រង់នឹងលូកព្រះហស្តទៅ ទាស់នឹងស្រុកខាងជើងដែរ
គឺនឹងបំផ្លាញស្រុកអាសស៊ើរ[ង] ហើយធ្វើឱ្យក្រុងនីនីវេ[ច] ខូច
បង់ ជាទីហួតហែង ដូចជាទីរហោស្ថាន[ឆ] ១៤អស់ទាំងហ្វូង
សត្វ[ជ]នឹងដេកនៅកណ្ដាលនោះ ព្រមទាំងសត្វគ្រប់ពូជទាំង
អស់ ទាំងស្មោញ[ឈ]និងខ្វែក[ញ,ដ] នឹងទំលើក្បាលសសរ នឹងឮ
សំឡេងវាយំត្រង់អស់ទាំងបង្អួច ហើយនៅមាត់ទ្វារទាំង
ប៉ុន្មាន នោះសុទ្ធតែខូចបង់ទទេ ដ្បិតឈើតាត្រៅដែល
ស្រោបជញ្ជាំងត្រូវគាស់បើកទាំងអស់ ១៥នោះហើយ ជា
ទីក្រុងដែលតែងតែបានសប្បាយ[ឋ] ហើយឥតកង្វល់[ឌ] ជាក្រុង
ដែលរមែងគិតក្នុងចិត្តថា "មានតែអញទេ ក្រៅពីអញគ្មាន
ទីក្រុងណាសោះ"[ឍ] ទីក្រុងនោះបានត្រឡប់ជាស្ងាត់ច្រៀប
ជាទីសំរាប់ឱ្យអស់ ទាំងសត្វដេកចុះយ៉ាងណាហ្ន៎[ណ] អស់អ្នក
ណាដែលដើរតាមទីនោះ នឹងធ្វើសីសស្ទីសឱ្យ[ត] ហើយរា
ដៃ[ថ]។

### អនាគតនៃក្រុងយេរូសាឡិម

**៣** ១វេទនាដល់ទីក្រុងរឹងចចេស[ក] ហើយស្មោកគ្រោក[ខ]
គឺដល់ទីក្រុងដែលសង្កត់សង្កិនគេ[គ] ២វាមិនបានស្ដាប់តាម[ឃ]
ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មិនព្រមទទួលសេចក្ដីប្រៀន
ប្រដៅ[ង] ហើយមិនទុកចិត្ត[ច]ទ្រង់សោះ ក៏ឥតចូលទៅជិត[ឆ]ព្រះ
នៃខ្លួនឡើយ ៣ពួកចៅហ្វាយនៅកណ្ដាលវា សុទ្ធតែជា
សិង្ហកំពុងគ្រហឹម[ជ] ពួកចៅក្រមរបស់វាជាឆ្កែព្រៃ[ឈ]ដែល
ចេញ មកនៅពេលល្ងាច ហើយមិនទុកអ្វីដល់ព្រឹកឡើយ[ញ]
៤ពួកហោរារបស់វា សុទ្ធតែមានចិត្តស្រាល ហើយកោង
ក្បត់[ដ] ឯពួកសង្ឃរបស់វា ក៏បានបង្អាប់ទីបរិសុទ្ធ គេបានក្បត់
ចំពោះក្រិត្យវិន័យ[ឋ] ៥តែព្រះយេហូវ៉ាដែលគង់នៅកណ្ដាល
វា ទ្រង់សុចរិតទេ[ឌ] ទ្រង់មិនព្រមប្រព្រឹត្តអំពើទុច្ចរិតសោះ[ឍ]
រាល់តែព្រឹក[ណ] ទ្រង់នាំយកសេចក្ដីយុត្តិធម៌របស់ទ្រង់មក
ដាក់នៅពន្លឺឥតខានឡើយ[ត] តែមនុស្សអាក្រក់មិនចេះខ្មាស
ទេ[ថ] ៦អញបានធ្វើឱ្យនគរផ្សេងៗវិនាសទៅ កំផែងរបស់គេ
ត្រូវរលំចុះ អញបានធ្វើឱ្យផ្លូវគេខូចបង់ ដល់ម្ល៉េះបានជា
គ្មានអ្នកណាដើរតាមនោះទៀតឡើយ ទីក្រុងរបស់គេបាន
ត្រូវបំផ្លាញ[ទ] ដល់ម្ល៉េះបានជាគ្មានមនុស្សសោះ គឺគ្មានអ្នក

**២:១២** គ លប ១០:៦ អស ២០:៤ ឃ យរ ៤៦:១០ **២:១៣** ង អស ១០:៥ ច លប ១០:១១ ណាហ ១:១ ឆ មីក ៥:៦ សក ១០:១១ **២:១៤** ជ អស ៥:១៧ ឈ អស ១៤:២៣ ញ វវ ១៨:២ ដ ទដ ១០២:៦ **២:១៥** ឋ អស ៣២:៩ ឌ អស ៤៧:៨ ឍ អគ ២៨:២ ណ យរ ៤៩:៣៣ ត អស ២៨:២២ ណាហ ៣:១៩ ថ អគ ២៧:៣៦ **៣:១** ក ចទ ២១:១៨ ខ អគ ២៣:៣០ គ យរ ៦:៦ **៣:២** ឃ យរ ២២:២១ ង លវ ២៦:២៣ យរ ៧:២៨ ច ចទ ១:៣២ ឆ ទដ ៧៣:២៨ **៣:៣** ជ ទដ ២២:១៣ ឈ លប ៤៩:២៧ ញ មីក ៣:៣ **៣:៤** ដ ទដ ២៥:៣ អស ៤៨:៨ យរ ៣:២០ ៩:៤ មឡ ២:១០ ឋ យរ ២៣:១១ អគ ២២:២៦ **៣:៥** ឌ អរ ៩:១៥ ឍ ចទ ៣២:៤ ណ ទដ ៥:៣ ត បទ ៣:២៣ ថ យរ ៣:៣ អគ ១៨:២៥ **៣:៦** ទ លវ ២៦:៣១

**២:១២** *ឯងរាល់គ្នា . . . ក៏* ឬអាចថាបានម្យ៉ាងទៀតថា ឯងរាល់គ្នាក៏អញ្ចឹងដែរ ។ លោកសេផានាគ្រាន់តែបានប្រកាសអំពីគោលបំណងនៃការជំនុំជម្រះសាសន៍អេស៊ីព្ទ ដែលស្ថិតនៅភាគខាងត្បូងឈាងខាងលិចនៃស្រុកយូដា (មើល ខ.៥,៨ និងការពន្យល់)។ *សាសន៍អេធីយ៉ូពី* ប្រទេសអេស៊ីព្ទត្រូវបានរាជ្យវង្សសាសន៍អេធីយ៉ូពីគ្រប់គ្រងចាប់ពីឆ្នាំ ៧១៥ ដល់ ៦៦៣ មុនគ.ស.។ *ដាវរបស់អញ* ប្រហែលជាសំដៅទៅលើចក្រភពបាប៊ីឡូន (មើល អគ ២១:៩–១៣,១៩ និងការពន្យល់ ទដ ៧:១២–១៣ អស ១០:៥) ។

**២:១៣** *ស្រុកខាងជើង* ទោះបីជាក្រុងនីនីវេស្ថិតនៅភាគខាងកើតនៃស្រុកយូដាក៏ដោយ ក៏កងទ័ពសាសន៍អាសស៊ើរជាធម្មតាឈ្លានពានស្រុកកាណានពីភាគខាងជើង (មើលការពន្យល់ ខ.១២ ១:១០) ដោយធ្វើដំណើរទៅទិសខាងលិចនៅតាមដងទន្លេអឺប្រាតជាមុនសិន ជាជាងធ្វើដំណើរតាមវាលខ្សាច់អារ៉ាប់ ។ *នីនីវេ* មើលព្រះគម្ពីរយ៉ូណាស និងណាហ៊ុម ។ ដោយសារក្រុងនីនីវេទទួលរងការបំផ្លាញនៅឆ្នាំ ៦១២ មុនគ.ស. លោកសេផានាប្រាកដជាបានធ្វើការងារបម្រើព្រះនៅមុនឆ្នាំនេះ ។ *ជាទីហួតហែង ដូចជាទីរហោ–ស្ថាន* សូម្បីតែទីតាំងនៃក្រុងនីនីវេក៏ត្រូវគេបំភ្លេចចេញផងដែរ ហើយបច្ចុប្បន្នគេបានរកឃើញទីក្រុងនេះនៅក្នុងកំណាយបុរាណវត្ថុវិទ្យា (មើល ណាហ ៣:១៧ និងការពន្យល់) ។

**២:១៥** *មានតែអញទេ ក្រៅពីអញគ្មានទីក្រុងណាសោះ* មើល អស ៤៧:១០ និងការពន្យល់ ។ *បានត្រឡប់* ត្រង់ចំណុចនេះ គឺជាសេចក្ដីទំនាយអំពីសេចក្ដីហិនវិនាសដែលហៀបនឹងមកដល់ក្រុងនីនីវេ ។

**៣:១** *ទីក្រុង* ទីក្រុងយេរូសាឡិមដែលបោះបង់ចោលសេចក្ដីជំនឿ ត្រូវបានជំនុំជម្រះដោយសារអំពើបាបរបស់ខ្លួន ។ *ទីក្រុងដែលសង្កត់សង្កិនគេ* មើល យរ ២២:៣ ។

**៣:៣–៤** *ពួកចៅហ្វាយ . . . ពួកចៅក្រម . . . ពួកហោរា . . . ពួកសង្ឃ* ពួកអ្នកដឹកនាំគ្រប់ជាន់ថ្នាក់នៃពួកយូដាត្រូវទទួលការបដិសេធន៍ ដោយសាការបណ្ដោយខ្លួននឹងការប្រព្រឹត្តដែលប្រាសចាកនឹងការងារ និងការទទួលខុសត្រូវរបស់ខ្លួន (មើល យរ ១:៨ និងការពន្យល់) ។

**៣:៣** *សិង្ហកំពុងគ្រហឹម . . . ឆ្កែព្រៃដែលចេញមកនៅពេលល្ងាច* ក្នុងចំណុចនេះ ពួកអ្នកកាន់អំណាចទាំងនោះមានចិត្តលោភលន់យ៉ាងខ្លាំង ។

**៣:៤** *ចិត្តស្រាល . . . គេបានក្បត់* ពួកគេជាអ្នកដែលត្រូវថ្លែងសេចក្ដីទំនាយតែបែរជាថ្លែងពីសេចក្ដីកុហកទៅវិញ (មើល យរ ៥:៣១ និងការពន្យល់ ១៤:១៤ ២៣:១៦,៣២)។ *ពួកសង្ឃ . . . ក្បត់ចំពោះក្រិត្យវិន័យ* មានន័យថាពួកគេបានធ្វើផ្ទុយនឹងការងារបង្រៀនក្រឹត្យវិន័យ (មើល ចទ ៣១:៩–១៣ ២របា ១៧:៨–៩ ១៩:៨ អរ ៧:៦ យរ ២:៨ ១៨:១៨ មឡ ២:៧) ។

**៣:៥** *រាល់តែព្រឹក . . . ឥតខានឡើយ* ធៀបនឹង បទ ៣:២២–២៣ និងការពន្យល់ ។

**៣:៦–៨** ក្នុងវគ្គនេះ ទីក្រុងយេរូសាឡិមប្រកែកមិនព្រមប្រែចិត្ត (មើល ២:១–៣ និងការពន្យល់) ។

**៣:៦** *អញបានធ្វើឱ្យនគរផ្សេងៗវិនាសទៅ* ការបំផ្លាញសាសន៍ដទៃគឺដើម្បីព្រមានដល់សាសន៍យូដាដែលវាចវេ ប៉ុន្តែមិនមែនជួយទេ (មើល ខ.៧) ។

ណាអាស្រ័យនៅទេ ៧អញបានប្រាប់ថា ឱ្យគ្រាន់តែកោត
ខ្លាចដល់អញ ហើយទទួលសេចក្ដីប្រៀនប្រដៅចុះ[ធ] នោះទី
លំនៅរបស់គេមិនត្រូវកាត់ចេញ តាមគ្រប់អស់ទាំងសេចក្ដី
ដែលអញបានដំរូវដល់គេនោះឡើយ តែគេបានក្រោក
ឡើងពីព្រលឹមស្រាង ដើម្បីបង្ខូច[ន]អស់ទាំងកិរិយារបស់ខ្លួន
វិញ ។
៨ដូច្នេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូរឯងរាល់
គ្នារង់ចាំ[ប] ដរាបដល់ថ្ងៃដែលអញក្រោកឡើងសង្គ្រប
លើគេ ពីព្រោះអញបានគិតសំរេច និងប្រមូល[ផ]អស់ទាំង
សាសន៍[ព] ដើម្បីនឹងភ្ជុំនគរទាំងប៉ុន្មាន ប្រយោជន៍នឹងចាក់
សេចក្ដីគ្នាន់ក្នាញ់[ភ]របស់អញ គឺជាសេចក្ដីក្រេវក្រោធដ៏
សហ័សរបស់អញទៅលើគេ[ម] ដ្បិតផែនដីទាំងមូលនឹងត្រូវ
ឆេះ[យ] ដោយភ្លើងនៃសេចក្ដីប្រចណ្ឌរបស់អញ ។
៩នៅគ្រានោះ អញនឹងឱ្យជនជាតិទាំងឡាយ មានបបូរ
មាត់ស្អាត ដើម្បីឱ្យគេបានអំពាវនាវ[រ]ដល់ព្រះនាមព្រះ
យេហូវ៉ា[ល]ទាំងអស់គ្នា ហើយព្រមចិត្តគ្នានឹងគោរព[វ]ដល់
ទ្រង់ ១០ពួកថ្វាយបង្គំអញ គឺកូនស្រីនៃពួកអញដែលត្រូវខ្ចាត់
ខ្ចាយ គេនឹងនាំយកដង្វាយពីខាងនាយអស់ទាំងទន្លេស្រុក
អេធីយ៉ូពី[ស]មកថ្វាយអញ[ហ] ១១នៅថ្ងៃនោះ ឯងមិនត្រូវខ្មាស[ឡ]
ដោយព្រោះអស់ទាំងកិរិយា ដែលឯងបានធ្វើ គឺជាការ
ដែលឯងបានរំលងទាស់នឹងអញទៀតនោះឡើយ[អ] ដ្បិត
នៅគ្រានោះអញនឹងដកយកពួកអ្នកដែលអួតអាង[ក] ដោយ
ឆ្មើងឆ្មៃចេញពីកណ្ដាលឯងទៅ នោះឯងនឹងលែងមានចិត្ត
អំនួត នៅលើភ្នំបរិសុទ្ធរបស់អញតទៅ[ខ] ១២តែអញនឹងទុក
ជនមួយពួកដែលវេទនា[គ] ហើយកំសត់ទុកគ៏នៅកណ្ដាល
ឯង ឯពួកនោះ គេនឹងពឹង[ឃ]ដល់ព្រះនាមនៃព្រះយេហូវ៉ា
១៣ពួកសំណល់[ង]នៃអ៊ីស្រាអែល នឹងមិនប្រព្រឹត្តអំពើទុច្ចរិត[ច]
ឬពោលកុហកទៀតឡើយ[ឆ] ក៏នឹងឥតឃើញមានអណ្ដាត
ឆបោកនៅក្នុងមាត់គេដែរ[ជ] ដ្បិតគេនឹងរកស៊ី ហើយដេក
ចុះ[ឈ] ឥតមានអ្នកណាបំភ័យគេឡើយ[ញ]។
១៤ឱកូនស្រីស៊ីយ៉ូនអើយ[ដ] ចូរច្រៀងឡើង[ឋ] ឱអ៊ីស្រាអែល
អើយ ចូរស្រែកឡើងចុះ[ឌ] ឱកូនស្រីយេរូសាឡិមអើយ ចូរ
អរសប្បាយ ហើយរីករាយឱ្យអស់អំពីចិត្តទៅ ១៥ព្រះ
យេហូវ៉ា ទ្រង់បានលើកទោសឯងចោល ទ្រង់បានបោះ
ខ្មាំងសត្រូវរបស់ឯងចេញហើយ ឯស្ដេចនៃសាសន៍អ៊ីស្រា
អែល គឺព្រះយេហូវ៉ា ទ្រង់គង់នៅកណ្ដាលឯង[ឍ] ឯងមិន
ត្រូវរង[ណ]ការអាក្រក់ទៀតឡើយ[ត] ១៦នៅថ្ងៃនោះ នឹងមាន
ពាក្យពោលដល់ក្រុងយេរូសាឡិមថា កុំឱ្យខ្លាចឡើយ ឱ

**៣:៧** ធ យរ ៧:២៨ ន ហស ៩:៩ **៣:៨** ប ទដ ២៧:១៤ ផ យអ ៣:១១ ព អស ២:៣ ភ ទដ ៧៩:៦ វវ ១៦:១ ម យរ ១០:២៥ បទ ៤:១១ យ សផ ១:១៨ **៣:៩** រ សផ ២:១១ ល លប ៤:២៦ វ អស ១៩:១៨ **៣:១០** ស លប ១០:៦ ទដ ៦៨:៣១ ហ ២រប ៣២:២៣ អស ៦០:៧ **៣:១១** ឡ អស ២៩:២២ យអ ២:២៦-២៧ អ លប ៥០:១៥ ក ទដ ៥៩:១២ ខ នក ១៥:១៧ លវ ២៦:១៩ **៣:១២** គ អស ១៤:៣២ ឃ យរ ២៩:១២ ណហ ១:៧ **៣:១៣** ង អស ១០:២១ ច ទដ ១១៩:៣ អស ៤:៣ ឆ យរ ៣៣:១៦ វវ ១៤:៥ ជ យប ១៦:១៧ ឈ អគ ៣៤:១៥ សផ ២:៧ ញ លវ ២៦:៦ អគ ៣៤:២៥-២៨ **៣:១៤** ដ ទដ ៩:១៤ សក ២:១០ ឋ ទដ ៩៥:១ អស ១២:៦ សក ២:១០ ឌ ទដ ៩:២ អស ៥១:១១ **៣:១៥** ឍ អគ ៣៧:២៦-២៨ ណ អស ៥៤:១៤ ត សក ៩:៩

**៣:៧** *បង្ខូចអស់ទាំងកិរិយារបស់ខ្លួនវិញ* មើល ឧទាហរណ៍ យរ ៧:១៣, ២៥-២៦ ។

**៣:៨** *រង់ចាំ* ពាក្យនេះត្រូវបានប្រើដើម្បីចំអកឱ្យសាសន៍យូដារង់ចាំសេចក្ដីហិនវិនាសដូចដែលបានព្រមានជាស្រេច ។ *សង្គ្រប់លើគេ* គឺដោយចោទប្រកាន់ពីទោសកំហុសរបស់ពួកគេ (ទដ ៥០:៧) រួចហើយកាត់ទោស ។ *អញបានគិតសំរេច* ត្រង់ចំណុចនេះព្រះអម្ចាស់ទ្រង់បញ្ចប់សេចក្ដីប្រកាសអំពីសេចក្ដីជំនុំជម្រះ ដោយសង្កត់ធ្ងន់ថា នោះជាព្រះហឫទ័យទ្រង់ ។ *ត្រូវឆេះដោយភ្លើងនៃសេចក្ដីប្រចណ្ឌរបស់អញ* មើល ១:២-៣ និងការពន្យល់, ១:១៨ បទ ១:១៣ និងការពន្យល់ ។

**៣:៩-២០** វគ្គនៃបទគម្ពីរនេះនិយាយអំពីព្រះបន្ទូលដ៏ធ្ងន់ដែលមានបីចំណុច (ខ.៩-១៣,១៤-១៧,១៨-២០) ដែលប្រកាសអំពីការប្រោសលោះ ដែលនឹងមានបន្ទាប់ពីការជំនុំជម្រះនៃព្រះអម្ចាស់ ។

**៣:៩-១៣** ក្នុងវគ្គនេះព្រះអម្ចាស់ទ្រង់ធានាថា ទ្រង់នឹងសម្អាតជាតិសាសន៍ទាំងឡាយជាបរិសុទ្ធ ស្អាងពួកសំណល់ដែលខ្ចាត់ខ្ចាយ ហើយសម្អាតទីក្រុងយេរូសាឡិម ។

**៣:៩** សេចក្ដីជំនុំជម្រះដ៏គួរស្ញែងខ្លាចនៃព្រះចំពោះជាតិសាសន៍ និងនាំឱ្យមានការសម្អាតជាបរិសុទ្ធ ដើម្បីឱ្យពួកគេស្រែករកព្រះនាមទ្រង់ ហើយបម្រើទ្រង់ ។ ជាតិសាសន៍ទាំងឡាយនឹងទទួលស្គាល់ព្រះនៃអ៊ីស្រាអែល ហើយពួកគេនឹងគោរពដល់រាស្ត្ររបស់ទ្រង់(ធៀបនឹង ខ.១៩-២០) ។

**៣:១០** *ស្រុកអេធីយ៉ូពី* គឺជាស្រុកដែលនៅសែនឆ្ងាយ (មើល ២:១២ អស ១៨:១ និងការពន្យល់) ។ ត្រង់ចំណុចនេះមានន័យថា ព្រះអម្ចាស់ទ្រង់ស្អាងឡើងវិញ សូម្បីតែអ្នកដែលខ្ចាត់ខ្ចាយទៅដល់ទីកន្លែងដែលឆ្ងាយបំផុតក៏ដោយ ។ *នាំយកដង្វាយ* គឺមិនមែននាំយកដង្វាយថ្វាយដល់ព្រះបាល ឬព្រះម៉ូឡុក(ធៀបនឹង ១:៤-៥) ។

**៣:១១** *ភ្នំបរិសុទ្ធរបស់អញ* គឺភ្នំស៊ីយ៉ូន(មើល ទដ ២:៦ និងការពន្យល់) ។

**៣:១៣** *ពួកសំណល់* មើល ២:៧ អស ១:៩ និងការពន្យល់ ។ *ឥតមានអ្នកណាបំភ័យគេឡើយ* មើល មីក ៤:៤ ។

**៣:១៤-១៧** ក្នុងវគ្គនេះ អំណរនឹងកើតមាននៅក្នុងទីក្រុងដែលត្រូវបានស្អាងឡើងវិញ(ចែកជាពីរផ្នែកគឺ ខ.១៤-១៥ និង ខ.១៦-១៧) គឺដោយមានពួកហោរាបញ្ជាក់ជាថ្មី (ខុសពី ១:១០-១៣) ។

**៣:១៤** *កូនស្រីស៊ីយ៉ូន . . . កូនស្រីយេរូសាឡិម* គឺការហៅឈ្មោះក្រុងយេរូសាឡិមដោយប្រៀបធៀបទៅនឹងមនុស្ស(សូមមើលការពន្យល់ ២ពវ ១៩:២១)។

**៣:១៥** *ខ្មាំងសត្រូវរបស់ឯង* គឺអស់អ្នកដែលលើកទ័ពទាស់នឹងសាសន៍អ៊ីស្រាអែល ។ *ឯស្ដេចនៃអ៊ីស្រាអែល គឺព្រះយេហូវ៉ា* មើល អស ៤៤:៦ ។ មើលសេចក្ដីផ្ដើមព្រះគម្ពីរទំនុកដំកើង ត្រង់វិជ្ជាសិក្សាអំពីព្រះ ។

**៣:១៦** *កុំឱ្យដៃឯងអន់ថយឱ្យសោះ* មានន័យថា កុំឱ្យបាក់ទឹកចិត្តឱ្យសោះ (មើល យរ ៤៧:៣ និងការពន្យល់)។

ស៊ីយ៉ូនអើយ កុំឱ្យដៃឯងអន់ថយឱ្យសោះ[ថ] ១៧ព្រះយេហូវ៉ា
ដ៏ជាព្រះនៃឯង ទ្រង់គង់នៅកណ្ដាលឯង ទ្រង់ជាព្រះដ៏
មានឥទ្ធិឫទ្ធិ ដើម្បីជួយសង្គ្រោះ[ទ] ទ្រង់នឹងមានសេចក្ដីរីក
រាយអរសប្បាយ[ធ]ចំពោះឯង ទ្រង់នឹងសំរាកក្នុងសេចក្ដី
ស្រឡាញ់របស់ទ្រង់[ន] ក៏នឹងអរសប្បាយនឹងឯង ដោយ
សំឡេងច្រៀង[ប] ១៨អញនឹងប្រមូលអស់អ្នក ក្នុងពួកឯង
ដែលស្ដាយជំនុំមុតមាំ ជាពួកអ្នកដែលសេចក្ដីដំនៀល
នោះ បានសង្កត់សង្កិនលើ ១៩មើល នៅគ្រានោះ អញនឹង
ធ្វើទោសដល់អស់ពួកអ្នកដែលធ្វើទុក្ខ[ផ]ឯង អញនឹងជួយ
សង្គ្រោះណាដែលខ្វិន ហើយនឹងប្រមូលណាដែលត្រូវ
បណ្ដេញឱ្យមកវិញ[ព] រួចអញនឹងតាំងគេដែលពីដើមមាន
សេចក្ដីខ្មាសនៅពេញលើផែនដី ឱ្យឡើងជាទីសរសើរ[ភ]
នឹងជាកិត្តិសព្ទវិញ ២០នៅគ្រានោះ អញនឹងនាំឯងរាល់
គ្នាចូលមក ហើយនៅគ្រានោះ អញនឹងប្រមូល[ម]ឯងមូល
គ្នា ដ្បិតអញនឹងលើកឯងរាល់គ្នាឱ្យមានឈ្មោះ[យ] ហើយឱ្យ
ជាទីសរសើរ[រ] នៅកណ្ដាលអស់ទាំងសាសន៍នៅផែនដី
គឺក្នុង កាលដែលអញនាំពួកឯងដែលជាប់ជាឈ្លើយមក
វិញ[ល] នៅចំពោះភ្នែកឯងរាល់គ្នា នេះជាព្រះបន្ទូលនៃ
ព្រះយេហូវ៉ា។/

**៣:១៦** ថ ២ពវ ១៩:២៦ យប ៤:៣ អស ៣៥:៣–៤ ហព ១២:១២
**៣:១៧** ទ អស ៦៣:១ យអ ២:២១ ធ ចទ ២៨:៦៣ អស ៦២:៤ ន ហស ១៤:៤ ប អស ៤០:១
**៣:១៩** ផ អស ១៤:២ ព អគ ៣៤:១៦ មីក ៤:៦ ភ អស ៦០:១៨
**៣:២០** ម យរ ២៩:១៤ អគ ៣៧:១២ យ អស ៥៦:៥ ៦៦:២២ រ ចទ ២៦:១៩ អស ៦០:១៨ ល យអ ៣:១

**៣:១៨–២០** វគ្គនៃបទគម្ពីរនេះគឺជា សេចក្ដីប្រកាសជាសង្ខេប អំពីការស្អាង ឡើងវិញ ដែលជាការបញ្ជាក់ចុងក្រោយនៃព្រះអម្ចាស់ ។
**៣:១៨** *ស្ដាយ* ពួកអ៊ីស្រាអែលនាំគ្នាសោកស្ដាយ ដែលមិនបានប្រារព្ធពិធី បុណ្យដែលធំៗរបស់ពួកគេ ។ *ជំនុំមុតមាំ* មើល លវ ២៣ ។
**៣:១៩–២០** *ប្រមូលណា . . . តាំងគេ . . . ប្រមូលឯង . . . លើកឯងរាល់គ្នា* ក្នុងវគ្គនេះព្រះអម្ចាស់ទ្រង់ធ្វើសេចក្ដីសន្និដ្ឋានអំពីព្រះបន្ទូលបញ្ជាក់របស់ទ្រង់ ហើយជាមួយគ្នានោះ ភាពស្និទ្ធស្នាលរបស់ទ្រង់នឹងរាស្ត្រទ្រង់ក៏បានកើន ឡើងផងដែរ ។
**៣:២០** *លើកឯងរាល់គ្នាឱ្យមានឈ្មោះ ហើយឱ្យជាទីសរសើរ* មើល ខ.១៩ មើល លប ១២:២–៣ និងការពន្យល់ផងដែរ ។

# ព្រះគម្ពីរហាកាយ

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ

លោកហាកាយ (១:១) គឺជាហោរា ដែលបានរួមគ្នាជាមួយនឹងលោកសាការី នៅក្នុងការលើកទឹកចិត្តពួកអ្នកត្រឡប់ពីការនិរទេស ឱ្យបានសាងសង់ព្រះវិហារឡើងវិញ (មើល អរ ៥:១-២ ៦:១៤) ។ ឈ្មោះហាកាយមានន័យថា "ទាក់ទងនឹងពិធីបុណ្យ" ហើយន័យនេះអាចបង្ហាញថា លោកហាកាយបានចាប់កំណើតនៅក្នុងអំឡុងពេលបុណ្យមួយ ក្នុងចំណោមបុណ្យទាំងបីដែលសាសន៍អ៊ីស្រាអែលធ្វើដំណើរពីតំបន់ផ្សេងៗទៅប្រារព្ធធ្វើនៅក្នុងក្រុងយេរូសាឡិម (បុណ្យនំបុ័ងឥតដំបែរ បុណ្យថ្ងៃទី៥០ និងបុណ្យបារាំ ផ្ទៀបនឹង ចទ ១៦:១៦) ។ តាមបទគម្ពីរ ២:៣ (មើលការពន្យល់ខនេះ) លោកហាកាយប្រហែលជាបានឃើញការបំផ្លាញព្រះវិហារស្ដេចសាឡូម៉ូនដោយផ្ទាល់ ហើយបើនោះជាការពិតមែន មានន័យថា លោកបានធ្វើការបម្រើព្រះនៅពេលដែលលោកមានអាយុជាង៧០ឆ្នាំហើយ ។

### ប្រវត្តិដើម

នៅឆ្នាំ ៥៣៨ មុនគ.ស. ស្ដេចស៊ីរូស ជាស្ដេចនៃចក្រភពពើស៊ី ដែលបានកាន់កាប់ចក្រភពបាប៊ីឡូន បានចេញព្រះរាជក្រឹត្យមួយច្បាប់អនុញ្ញាតិឱ្យសាសន៍យូដាវិលត្រឡប់ទៅក្រុងយេរូសាឡិម ហើយសាងសង់ព្រះវិហារឡើងវិញ (មើល អរ ១:២-៤ ៦:៣-៥) ។ ស្ដេចសូរ៉ូបាបិល(មើលការពន្យល់ អរ ១:៨ "សេសបាសារ")បានដឹកនាំសាសន៍យូដាប្រហែលប្រាំម៉ឺននាក់ ធ្វើដំណើរត្រឡប់មកមាតុភូមិវិញ ហើយបានចាប់ផ្ដើមសាងសង់ព្រះវិហារ ។ ប្រហែលជាពីរឆ្នាំក្រោយមក (ឆ្នាំ ៥៣៦ មុនគ.ស.) ពួកគេបានបញ្ចប់ការចាក់គ្រឹះនៅក្នុងបរិយាកាសដ៏មានអំណរអស្ចារ្យ(អរ ៣:៨-១១) ។ ជ័យជម្នះរបស់ពួកគេបាននាំឱ្យភ្ញាក់ផ្អើលដល់សាសន៍សាម៉ារី និងសាសន៍ជិតខាងដទៃទៀត ដែលភ័យខ្លាចផលវិបាកនយោបាយ និងជំនឿសាសនា ដែលកើតឡើងពីការសាងសង់ព្រះវិហារនៅក្នុងរដ្ឋដ៏រីកចម្រើននៃសាសន៍យូដា ។ ដូចនេះពួកគេបានប្រឆាំងយ៉ាងខ្លាំងនឹងការសាងសង់ ហើយបាននាំឱ្យការងារសាងសង់ត្រូវផ្អាករហូតដល់ឆ្នាំ ៥២០ មុន គ.ស. ជាឆ្នាំបន្ទាប់ពីស្ដេចដារីយុសអស្ចារ្យ នៃចក្រភពពើស៊ីឡើងគ្រងរាជជាស្ដេចនៅឆ្នាំ ៥២២ (អរ ៤:១-៥,២៤) ។

ស្ដេចដារីយុសមានចំណាប់អារម្មណ៍ចំពោះជំនឿសាសនានៅក្នុងចក្រភពរបស់ទ្រង់ ហើយលោកហាកាយ និងសាការីបានចាប់ផ្ដើមប្រកាសព្រះបន្ទូលព្រះនៅក្នុងឆ្នាំទីពីរនៅរាជស្ដេចនេះ គឺឆ្នាំ ៥២០ មុនគ.ស.(មើល ១:១ សក ១:១) ។ ពួកយូដាត្រូវទទួលការបន្ទោស ដោយសារភាពអសកម្ម ច្រើនជាងត្រូវបន្ទោសដោយសារអ្នកប្រឆាំងនឹងពួកគេ ហើយលោកហាកាយបានព្យាយាមជួយឱ្យពួកគេមានកំឡាំងឡើងវិញ ។ នៅពេលដែលពួកចៅហ្វាយនៅតំបន់អឺប្រាត និងពួកមន្ត្រីដទៃទៀតបានព្យាយាមបង្អាក់ដល់កិច្ចប្រឹងប្រែងសាងសង់នេះ ស្ដេចដារីយ៉ុសបានគាំទ្រពួកយូដាទាំងស្រុង (អរ ៥:៣-៦ ៦:៦-១២) ។ នៅឆ្នាំ ៥១៦ មុនគ.ស. ព្រះវិហារបានបញ្ចប់ការសាងសង់ ហើយបើកសម្ពោត (អរ ៦:១៥-១៨) ។

### កាលបរិច្ឆេទ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ទាំងមូល ព្រះគម្ពីរហាកាយមានការដាក់កាលបរិច្ឆេទយ៉ាងប្រុងប្រយ័ត្ន និងច្បាស់លាស់ជាងគេ ។ លោកហាកាយបានចាប់ផ្ដើមប្រកាសព្រះបន្ទូលនៅក្នុងអំឡុងពេលបួនខែ នៃឆ្នាំ ៥២០ មុនគ.ស. ដែលជាឆ្នាំទីពីរនៃរាជ្យស្ដេចដារីយ៉ុស ។ ការប្រកាសលើកដំបូងគឺបានធ្វើឡើងនៅថ្ងៃទី១ នៃខែ ភទ្របទ (ថ្ងៃទី ២៩ សីហា) ចុងក្រោយបំផុតគឺនៅ ថ្ងៃទី២៤ ខែមិគសិរ (ថ្ងៃទី ១៨ ខែធ្នូ)។ មើលការពន្យល់ ១:១ ២:១,១០, មើលសេចក្ដីផ្ដើមព្រះគម្ពីរសាការីត្រង់កាលបរិច្ឆេទ ។

### ខ្លឹមសារ និងសេចក្ដីបង្រៀនអំពីវិជ្ជាសិក្សាអំពីព្រះ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះគម្ពីរហាកាយគឺជាកណ្ឌដែលខ្លីជាងគេបន្ទាប់ពីព្រះគម្ពីរអូបាឌា ប៉ុន្តែសេចក្ដីបង្រៀននៃព្រះគម្ពីរនេះមានន័យសំខាន់ដូចព្រះគម្ពីរដទៃទៀតផងដែរ ។ ព្រះគម្ពីរហាកាយបានបង្ហាញយ៉ាងច្បាស់អំពីលទ្ធផលនៃការមិនស្ដាប់បង្គាប់ (១:៦,១១ ២:១៦-១៧) និងការស្ដាប់បង្គាប់ (២:៧-៩,១៩) ។ នៅពេលដែលបណ្ដាជនយកព្រះ និងដំណាក់ទ្រង់ជាអាទិភាព នោះពួកគេបានទទួលព្រះពរ មិនមែនបណ្ដាសាឡើយ (ផ្ទៀបនឹង លក ១២:៣១ និងការពន្យល់) ។ ការស្ដាប់បង្គាប់នាំឱ្យមានការលើកទឹកចិត្ត និងកម្លាំងអំពីព្រះវិញ្ញាណនៃព្រះ(២:៤-៥) ។

នៅក្នុងជំពូក២ ព្រះទ្រង់លើកទឹកចិត្តដល់អ្នកដែលខិតខំពុះពារការលំបាកនៅក្នុងការសាងសង់ព្រះវិហាររបស់ទ្រង់ ដោយផ្ដល់ការធានាថា ព្រះវិហារដ៏តូចទាបដែលពួកគេអាចសង់បាននៅពេលនេះ គឺនឹងមានអនាគតដ៏ប្រសើរអស្ចារ្យជាងព្រះវិហារដែលស្ដេច

សាឡូម៉ូនបានសង់នៅក្នុងសម័យដែលអ៊ីស្រាអែលសំបូរសប្បាយ និងខ្លាំងបំផុតទៅទៀត ។ ពួកសាសន៍យូដាក្នុងពេលនេះគឺជាសហគមន៍ដែលតូចជាងមុន ហើយស្ថិតនៅក្រោមការត្រួតត្រានៃប្រទេសមហាអំណាចមែនពិត តែព្រះអម្ចាស់ទ្រង់នឹងអង្រួន៍ការរៀបចំរបស់លោកិយ ហើយប្រកាសថា គ្រប់ទាំងទ្រព្យសម្បត្តិនៃលោកិយនេះជារបស់ទ្រង់ ដើម្បីឱ្យសិរីល្អនៃព្រះវិហារនៅពេលអនាគត និងមិនមែនអ្នកណាប្រជែងបានឡើយ ។ "ទីគាប់ចិត្តនៃសាសន៍ទាំងអស់នឹងមកដល់ ហើយអញនឹងបំពេញព្រះវិហារនេះ ដោយសិរីល្អ" (មើល ២:៦-៧ និងការពន្យល់) ។

### ខ្លឹមសារនៃអក្សរសាស្ត្រ

ព្រះគម្ពីរហាកាយបានប្រើនូវសំណួរមួយចំនួន ដើម្បីគូសបញ្ជាក់អំពីគន្លឹះសំខាន់ៗ (មើល ១:៤,៩ ២:៣,១៩) ដូចព្រះគម្ពីរម៉ាឡាគីផងដែរ ។ លោកហាកាយប្រើរបៀបលើកមកនិយាយម្តងទៀតយ៉ាងមានប្រសិទ្ធភាព នៅត្រង់ចំណុចៈ "ចូរឯងរាល់គ្នាពិចារណា" ឃើញមាននៅក្នុង ១:៥,៧ ២:១៥,១៨ និង "អញនៅជាមួយនឹងឯងរាល់គ្នា" នៅក្នុង ១:១៣ ២:៤ "អញនឹងអង្រួនទាំងផ្ទៃមេឃ និងផែនដី" មាននៅក្នុង ២:៦,២១ ។ ផ្នែកសំខាន់ៗជាងគេនៃព្រះគម្ពីរនេះត្រូវបានគូសចំណាំដោយ កាលបរិច្ឆេទនៃការដែលព្រះបន្ទូលនៃព្រះយេហូវ៉ា មានមក "តាមរយៈ" (ឬ "មកដល់") លោកហាកាយ (១:១ ២:១,១០,២០) ។

លោកហាកាយហាក់ដូចជាបាននិយាយឆ្លុះបញ្ចាំងអំពីវគ្គនៃកណ្ឌព្រះគម្ពីរផ្សេងទៀត (ផ្ទៀប ១:៦ និង ចទ ២៨:៣៨-៣៩ ហើយ ២:១៧ ជាមួយនឹង ចទ ២៨:២២) ។ ការប្រើពាក្យ "ចូរមានកំឡាំង" ចំនួនបីដងនៅក្នុង ២:៤ (មើលការពន្យល់ខនេះ) គឺបានរំឭកពីការលើកទឹកចិត្តនៅក្នុង យស ១:៦-៧,៩,១៨ ។ (ចំពោះភាពខ្វែងគ្នា មើលគម្រោងសង្ខេបខាងក្រោមនេះ) ។

### គម្រោងសង្ខេប

**I. ព្រះបន្ទូលលើកទីមួយៈ ការត្រាស់ហៅឱ្យសង់ព្រះវិហារឡើងវិញ (១:១-១១)**
- ក. ការដោះសាររបស់បណ្ដាជន ដែលមិនអាចទទួលយកបាន (១:១-៤)
- ខ. ភាពក្រីក្ររបស់បណ្ដាជន (១:៥-៦)
- គ. មូលហេតុដែលព្រះអម្ចាស់ដាក់បណ្ដាសាពួកគេ (១:៧-១១)

**II. ការឆ្លើយតបរបស់ស្ដេចសេរូបាបិល និងបណ្ដាជន (១:១២-១៥)**
- ក. អ្នកដឹកនាំ និងពួកសំណល់មានការស្ដាប់បង្គាប់ (១:១២)
- ខ. ព្រះអម្ចាស់ទ្រង់ចម្រើនកម្លាំងដល់អ្នកធ្វើការ (១:១៣-១៥)

**III. ព្រះបន្ទូលលើកទីពីរៈ ព្រះវិហារដែលត្រូវបំពេញដោយសិរីល្អ (២:១-៩)**
- ក. បណ្ដាជនបានទទួលការលើកទឹកចិត្ត (២:១-៥)
- ខ. សេចក្ដីសន្យាប្រទានសិរីល្អ និងសេចក្ដីសុខ (២:៦-៩)

**IV. ព្រះបន្ទូលលើកទី៣ៈ មនុស្សដែលមិនស្អាតបានទទួលការសម្អាតជាបរិសុទ្ធ និងព្រះពរ (២:១០-១៩)**
- ក. អំពើបាបរាលដាលយ៉ាងលឿន (២:១០-១៤)
- ខ. ការបង្ករបង្កើនផលមិនបានល្អដោយសារមិនស្ដាប់បង្គាប់ (២:១៥-១៧)
- គ. ព្រះពរត្រូវទទួល នៅពេលសង់ព្រះវិហារ (២:១៨-១៩)

**V. ព្រះបន្ទូលលើកទី៤ៈ ព្រះបន្ទូលសន្យាចំពោះស្ដេចសូរ៉ូបាបិល (២:២០-២៣)**
- ក. ការជំនុំជម្រះជាតិសាសន៍ (២:២០-២២)
- ខ. គុណសម្បត្តិនៃស្ដេចសូរ៉ូបាបិល (២:២៣)

សាច់រឿងនៃព្រះគម្ពីរនេះទាំងមូលក៏អាចសង្ខេបបានម្យ៉ាងទៀតគឺៈ
- ក. ផលអវិជ្ជមាននៃការមិនសង់ព្រះវិហារ (១:១-១១)
- ខ. ព្រះវត្តមាននៃព្រះអម្ចាស់ចម្រើនកម្លាំងដល់ការសាងសង់ (១:១២-១៥)
- គ. ព្រះវត្តមាននៃព្រះអម្ចាស់ធានាដល់សិរីល្អនៅពេលអនាគត (២:១-៩)
- ឃ. ផលវិជ្ជមាននៃការសាងសង់ព្រះវិហារ (២:១០-២៣)

## ព្រះគ្រាស់ហៅឱ្យសង់ព្រះវិហារទ្រង់

១ ១នៅថ្ងៃទី១ ខែភទ្របទ ក្នុងឆ្នាំទី២ នៃរាជ្យស្តេច
ដារីយុស[ក] នោះព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់
សូរ៉ូបាបិល[ខ] កូនសាលធាល ជាចៅហ្វាយ[គ]លើស្រុក
យូដាហើយដល់យេសួរ[ឃ] ជាកូនយ៉ូសាដាក[ង]ដ៏ជាសង្ឃធំ[ច]
ដោយសារហោរាហាកាយ[ឆ]ថា ២ព្រះយេហូវ៉ានៃពួកពល
បរិវារ[ជ] ទ្រង់មានបន្ទូលដូច្នេះ ជនជាតិនេះ[ឈ]គេពោលថា
វេលាដែលនឹងសង់ព្រះវិហារនៃព្រះយេហូវ៉ាឡើងវិញ មិន
ទាន់មកដល់នៅឡើយ[ញ] ៣ដូច្នេះ ព្រះបន្ទូលនៃព្រះយេហូវ៉ា
ក៏មក ដោយសារហោរាហាកាយថា[ដ] ៤កំពុងដែលព្រះ
វិហារនេះនៅខូចបង់នៅឡើយ[ឋ] នោះតើជាវេលាឱ្យឯង
រាល់គ្នាបានអាស្រ័យ នៅក្នុងផ្ទះដែលបិទភ្ជិតដូច្នេះឬ[ឌ]
៥ឥឡូវ ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលថា
ចូរឯងរាល់គ្នាពិចារណា[ឍ] ផ្លូវប្រព្រឹត្តរបស់ខ្លួនចុះ ៦ឯង
រាល់គ្នាបានព្រោះពូជជាច្រើន តែច្រូតបានតិចទេ[ណ] ក៏បាន
ស៊ីតែមិនចេះឆ្អែត[ត] ហើយបានផឹក តែមិនបានស្កប់ស្កល់[ថ]
ព្រមទាំងស្លៀកពាក់ តែមិនបានកក់ក្តៅឡើយ ឯអ្នកណា
ដែលស៊ីឈ្នួល[ទ] នោះទទួលឈ្នួលឱ្យតែ ដាក់ក្នុងថង់ធ្លុះទេ ។
៧ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះ
ថា ចូរឯងរាល់គ្នាពិចារណា[ធ]ផ្លូវប្រព្រឹត្តរបស់ខ្លួនចុះ ៨ព្រះ
យេហូវ៉ាទ្រង់បង្គាប់ថា ចូរឡើងទៅឯភ្នំ យកឈើ[ន]មកសង់
ព្រះវិហារចុះ នោះអញនឹងរីករាយ[ប] ចំពោះវិហារនោះ
ហើយនឹងបានថ្កើងឡើងផង[ផ] ៩ឯងរាល់គ្នាបានសង្ឃឹម
នឹងបានច្រើន តែមើលបានតែតិចទេ[ព] ហើយកាលណា
ឯងបាននាំយកទៅដល់ផ្ទះ នោះអញបានផ្លុំផាត់[ភ]ទៅ ព្រះ
យេហូវ៉ានៃ ពួកពលបរិវារទ្រង់សួរថា ហេតុអ្វីបានជា
ដូច្នេះ គឺដោយព្រោះវិហាររបស់អញ ដែលនៅខូចបង់[ម]
កំពុងដែលឯងរាល់គ្នារត់ទៅឯផ្ទះឯងរៀងខ្លួននោះ
១០ហេតុដូច្នេះបាន ជាមេឃមិនស្រក់ទំលាក់[យ]សន្សើមមក[រ]
លើឯងទៀត ហើយផែនដីមិនបង្កើតផលទៀតឡើយ[ល]
១១អញក៏បង្គាប់ឱ្យមាន អំណត់អត់ភ្លៀង[វ]នៅក្នុងស្រុក ហើយ

**១:១** ក អរ ៤:២៤ ខ ១រប ៣:១៩ មថ ១:១២–១៣ គ អរ ៥:៣ នហ ៥:១៤ ឃ អរ ២:២ ង ១រប ៦:១៥ អរ ៣:២ ច សក ៣:៨ ឆ អរ ៥:១ **១:២** ជ អស ១៣:៤ ឈ អស ២៩:១៣ ញ អរ ១:២ **១:៣** ដ អរ ៥:១ **១:៤** ឋ ខ.៩ យរ ៣៣:១២ ឌ ២សយ ៧:២ **១:៥** ឍ ខ.៧ បទ ៣:៤០ ហាក ២:១៥,១៨ **១:៦** ណ លវ ២៦:២០ អស ៥:១០ ត អស ៩:២០ ៥៥:២ ថ អម ៤:៨ ទ ហាក ២:១៦ សក ៨:១០ **១:៧** ធ ខ.៥ **១:៨** ន ១រប ១៤:១ ប យប ២២:៣ ទដ ១៣២:១៣–១៤ ផ នក ២៩:៤៣ យរ ១៣:១១ **១:៩** ព ចទ ២៨:៣៨ អស ៥:១០ ភ ទដ ១០៣:១៦ អគ ២២:២១ ម ខ.៤ នហ ១៣:១១ **១:១០** យ ចទ ២៨:២៤ រ លប ២៧:២៨ ១ពវ ១៧:១ ល លវ ២៦:១៩ ចទ ២៨:២៣

**១:១** *ថ្ងៃទី១ ខែភទ្របទ ក្នុងឆ្នាំទី២* គឺត្រូវនឹងថ្ងៃទី ២៩ សីហា ឆ្នាំ ៥២០ មុន គ.ស. ។ *ស្តេចដារីយុស* ស្តេចដារីយុស ហ៊ីស្តាភេស បានដឹកនាំចក្រភពពើរស៊ី ពីឆ្នាំ ៥២២ ដល់ ៤៨៦ មុនគ.ស. ។ ស្តេចអង្គនេះគឺជាអ្នករៀបចំសិលាចារិកជាបីភាសានៅលើជញ្ជាំងជ្រលងភ្នំ បេហ៊ីសទូន (សព្វថ្ងៃមានទីតាំងនៅប្រទេសអ៊ីរ៉ង់) ហើយសិលាចារិកនេះបានផ្តល់ភាពងាយស្រួលដល់ការបកប្រែសិលាចារិកជាច្រើនទៀត ហើយគេអាចសិក្សាអំពីវប្បធម៌ និងប្រវត្តិសាស្ត្រនៃតំបន់មេសូប៉ូតាមៀនៅសម័យបុរាណ ។ *ថ្ងៃទី១* គឺនៅដើមខែថ្មី ជួនកាលពួកហោរាទទួលការបើកសំដែងក្នុងពេលនោះ (មើល ២ពវ ៤:២២–២៣ និងការពន្យល់ ៤:២៣ និងការពន្យល់ អស ១:១៤) ។ *ព្រះបន្ទូលនៃព្រះយេហូវ៉ា* មើល ខ.៣ ២:២ ហស ១:១ និងការពន្យល់ ។ *សូរ៉ូបាបិល* មើលការពន្យល់ អរ ១:៨, ឈ្មោះនេះអាចហៅម្យ៉ាងទៀតថា "សេសបាសារ"។ *កូនសាលធាល* មើល ១រប ៣:១៧–១៩ និងការពន្យល់ ៣:១៩ ។ *ជាចៅហ្វាយ . . . ជាសង្ឃធំ* មានន័យថាជាអ្នកដឹកនាំខាងសង្គម និងវិញ្ញាណ របស់សហគមន៍សាសន៍យូដាដែលត្រូវបានស្អាងឡើងវិញ ។ *យេសួរ* មើលការពន្យល់ អរ ២:២ ។ ឈ្មោះនេះក៏មាននិយាយជាមួយនឹងឈ្មោះសូរ៉ូបាបិលនៅក្នុង ខ.១២,១៤ ២:២,៤ ដែរ ។ *យ៉ូសាដាក* លោកយ៉ូ–សាដាកត្រូវបានចាប់ខ្លួនជាឈ្លើយដោយស្តេចនេប៊ូក្នេសារ (១រប ៦:១៥) ។

**១:២** *ព្រះយេហូវ៉ានៃពួកពលបរិវារ* ពាក្យនេះមានឃើញប្រើលើសពី៩០ដង នៅក្នុងព្រះគម្ពីរហាកាយ សាការី និងមាឡាគី ។ មើលការពន្យល់ ១សយ ១:៣ អស ១៣:៤ ។ *ជនជាតិនេះ* មើល ២:១៤ ។ ដោយសារតែពួកគេមានបាប ព្រះអម្ចាស់ទ្រង់ឈប់ហៅពួកគេថា "រាស្ត្ររបស់អញ" តទៅទៀត(មើល អស ៦:៩–១០ ៨:៦,១១–១២ យរ ១៤:១០–១១ មើលការពន្យល់ នក ១៧:៤ ហស ១:៩) ។ *វេលា . . . មិនទាន់មកដល់* បន្ទាប់ពីព្រះវិហារបានចាក់គ្រឹះហើយនៅឆ្នាំ ៥៣៦ មុន គ.ស.(មើល អរ ៣:៨–១០) ប្រជាជនត្រូវបាក់ទឹកចិត្ត ហើយការងារសាងសង់ត្រូវផ្អាករហូតដល់ឆ្នាំ ៥២០ មុនគ.ស. (មើល អរ ៤:១–៥,២៤) ។

**១:៤** *ផ្ទះដែលបិទភ្ជិត* តាមធម្មតាផ្ទះប្រភេទនេះគឺត្រូវតភ្ជាប់នឹងដំណាក់របស់ស្តេចដែលបិទភ្ជិតទៅដោយដើមតាត្រាវ (សូមមើល ១ពវ ៧:៣,៧ យរ ២២:១៤–១៥ និងការពន្យល់ ២២:១៤) ។

**១:៥** *ពិចារណាផ្លូវប្រព្រឹត្តរបស់ខ្លួនចុះ* ពាក្យនេះមាននិយាយម្តងទៀតនៅក្នុង ខ.៧ ២:១៥,១៨ ។

**១:៦** *ព្រោះពូជច្រើន តែច្រូតបានតិចទេ* គឺជាសេចក្តីបណ្តាសា ដោយសារការមិនស្តាប់បង្គាប់(មើល ចទ ២៣:៣៨–៣៩)។ លវ ២៦:២០ ក៏បានបកស្រាយផងដែរអំពីទឹកដីដែលមិនបង្កើតផល ដែលព្រះអម្ចាស់ទ្រង់ជំនុំជម្រះ។ *ស៊ីតែមិនចេះឆ្អែត* ធៀបនឹង អស ៥៥:១–២ ។ បណ្តាជនត្រូវពិសោធនឹងភាពខកបំណងនៅក្នុងគ្រប់ការដែលគេធ្វើ ទោះជាការដែលត្រឹមត្រូវ ឬមិនត្រឹមត្រូវ(ធៀបនឹង ហស ៤:១០–១១ មីក ៦:១៣–១៥)។ *ថង់ធ្លុះ* ភាពអត់ឃ្លាននាំឱ្យសំភារៈឡើងថ្លៃខ្លាំង ។

**១:៨** *ភ្នំ . . . ឈើ* ប្រហែលជាឈើដែលយកមកពីភ្នំជិតខាង ដើម្បីប្រើជំនួសឈើតាត្រាវ ដែលត្រូវទិញពីស្រុកល្បាណូន(មើល អរ ៣:៧)។ *រីករាយចំពោះវិហារនោះ* គឺរីករាយចំពោះវិហារ និងយញ្ញបូជាដែលថ្វាយនៅឯវិហារនោះ(គឺផ្ទុយនឹង អស ១:១១) ។ *និងបានថ្កើងឡើង* សាសន៍ដែលស្តាប់បង្គាប់ និងនាំឱ្យមានការសរសើរដំកើង និងកិត្តិនាមដល់ព្រះអម្ចាស់ (មើល យរ ១៣:១១) ។

**១:១០** *សន្សើម* ជាធម្មតាធ្លាក់មកជាបរិបូរនៅរដូវបង្ករបង្កើនផល ហើយជាញឹកញាប់មានតម្លៃដូចភ្លៀង (មើល ២សយ ១:២១ ១ពវ ១៧:១) ។

នៅលើភ្នំ[ស] ឱ្យឥតមានស្រូវ ទឹកទំពាំងបាយជូរ[ហ] ប្រេង[ឡ]
ឬផលដែលកើតពីដីមក ក៏មិនឱ្យធ្លាក់លើមនុស្ស លើសត្វ
ឬលើការដែលដៃមនុស្សធ្វើនោះផង[អ]។
១២នៅគ្រានោះ សូរ៉ូបាបិល[ក] ជាកូនសាលធាល និង
យេសួរ ជាកូនយ៉ូសាដាកដ៏ជាសង្ឃធំ ព្រមទាំងសំណល់[ខ]
នៃបណ្ដាជន ក៏ស្ដាប់តាម[គ]ព្រះបន្ទូលនៃព្រះយេហូវ៉ា ជាព្រះ
របស់ខ្លួន ហើយតាមពាក្យទំនាយរបស់ហោរាហាកាយ
ដូចជាព្រះយេហូវ៉ា ជាព្រះនៃគេ បានចាត់លោក ឱ្យមក
ប្រាប់នោះ ជនទាំងឡាយក៏កោតខ្លាច[ឃ] នៅចំពោះព្រះ
យេហូវ៉ា ១៣នោះហាកាយ[ង]ជាទូតរបស់ព្រះយេហូវ៉ា[ច]លោក
ប្រាប់ដល់បណ្ដាជន តាមព្រះបន្ទូលដែលព្រះយេហូវ៉ា ទ្រង់
បង្គាប់មក គឺព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា អញនៅជា
មួយ[ឆ]នឹងឯងរាល់គ្នា ១៤ខណនោះ ព្រះយេហូវ៉ាទ្រង់ដាស់
តឿន[ជ]ចិត្តរបស់សូរ៉ូបាបិល[ឈ] កូនសាលធាល ជាចៅ
ហ្វាយលើស្រុកយូដា ហើយនិងចិត្តរបស់យេសួរ ជាកូន
យ៉ូសាដាក[ញ] ដ៏ជាសង្ឃធំ ព្រមទាំងចិត្តរបស់សំណល់[ដ]នៃ
បណ្ដាជនទាំងឡាយផង នោះគេក៏មកធ្វើការសង់ព្រះ
វិហាររបស់ព្រះយេហូវ៉ា នៃពួកពលបរិវារ ជាព្រះនៃខ្លួន
គេឡើង ១៥គឺនៅ ថ្ងៃ២៤ ខែភទ្របទ[ឋ] ក្នុងឆ្នាំទី២នៃរាជ្យ
ស្ដេចដារីយុស[ឌ]។

**១:១១** វ ចទ ១១:២៦ ២៨:២២ នរ ១:១ ១ពវ ១៧:១ អស ៥:៦ ស អស ៧:២៥ ហ ចទ ២៨:៥១ ទដ ៤:៧ ឡ ជន ១៨:១២ អ ហក ២:១៧
**១:១២** ក ខ.១ ខ ខ.១៤ អស ១:៩ ហក ២:២ គ យប ៣៦:១១ អស ៥០:១០ មថ ២៨:២០ ឃ ចទ ៣១:១២ អស ១:២
**១:១៣** ង ខ.១ ច ជន ២៧:២១ ២រប ៣៦:១៥ ឆ លប ២៦:៣ ជន ១៤:៩ មថ ២៨:២០ រម ៨:៣១
**១:១៤** ជ អរ ១:៥ ឈ អរ ៥:២ ញ ១រប ៦:១៥ ដ ខ.១២
**១:១៥** ឋ ខ.១ ហក ២:១០,២០

## ព្រះបន្ទូលសន្យាប្រទានសិរីល្អដល់ព្រះវិហារថ្មីនោះ

២ ១នៅថ្ងៃ២១ ខែអស្សុជ[ក] នោះព្រះបន្ទូលនៃព្រះយេ
ហូវ៉ាក៏មក ដោយសារហោរហាកាយថា[ខ] ២ឥឡូវនេះ ចូរ
ទៅនិយាយនឹងសូរ៉ូបាបិល[គ] កូនសាលធាល ជាចៅហ្វាយ
លើស្រុកយូដា និងយេសួរ កូនយ៉ូសាដាក[ឃ]ដ៏ជាសង្ឃធំ ព្រម
ទាំងសំណល់[ង]នៃបណ្ដាជនថា ៣ក្នុងពួកឯងរាល់គ្នា តើមាន
សល់អ្នកណាខ្លះ ធ្លាប់បានឃើញព្រះវិហារនេះ[ច]តាមសិរីល្អ
ដាន់ដើមដែរឬ ចុះឥឡូវនេះ តើឃើញជាយ៉ាងណានៅ
ភ្នែកឯងរាល់គ្នាដែលធៀបផ្ទឹមគ្នា តើព្រះវិហារនេះមិន
មែនដូចជាទទេសោះទេឬអី[ឆ] ៤ទោះបើយ៉ាងនោះ គង់តែ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱសូរ៉ូបាបិលអើយ ចូរមាន
កំឡាំងឥឡូវចុះ[ជ] ឱយេសួរ ជាកូនយ៉ូសាដាក[ឈ]ដ៏ជាសង្ឃធំ
អើយ ចូរមានកំឡាំងដែរ ឯឯងរាល់គ្នាជាជនជាតិនៃស្រុក
នេះអើយ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូរឯងរាល់គ្នា
មានកំឡាំង ហើយធ្វើការទៅ ដ្បិតអញនៅជាមួយ[ញ]នឹងឯង
ហើយ នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ

ឌ អរ ៤:២៤ **២:១** ក ខ.១០,២០ លវ ២៣:៣៤ យហ ៧:៣៧ ខ អរ ៥:១ **២:២** គ ហក ១:១ ឃ ១រប ៦:១៥ ង ហក ១:១២ **២:៣** ច អរ ៣:១២ អស ៦០:៧ ឆ សក ៤:១០ **២:៤** ជ ១រប ២៨:២០ សក ៨:៩ អភ ៦:១០ ឈ ១រប ៦:១៥ ញ នក ៣៣:១៤ជន ១៤:៩ ២សយ ៥:១០ កច ៧:៩

**១:១១** *ភ្នំ* គេបង្ករបង្កើនផលនៅតាមផ្ទៃរៀបស្មើនៅតាមជម្រាលភ្នំ (មើល ទដ ១០៤:១៣–១៥ អស ៧:២៥ យអ ៣:១៨) ។ *ស្រូវ ទឹកទំពាំងបាយជូរ ប្រេង* គឺជាផលដំណាំមូលដ្ឋានទាំងបីមុខ ដែលជាញឹកញាប់ត្រូវបានលើកមកនិយាយនៅក្នុងបញ្ញាព្រះពរ និងបណ្ដាសារ (មើល ចទ ៧:១៣ យអ ១:១០ និងការពន្យល់)។ ប្រេងអូលីវត្រូវបានប្រើប្រាស់នៅក្នុងអាហារ ប្រេងលាប និងថ្នាំ ។ *លើមនុស្ស លើសត្វ* ភាពរាំងស្ងួតនាំឱ្យប៉ះពាល់ដល់តាំងមនុស្ស ទាំងសត្វ ។

**១:១២** *សំណល់នៃបណ្ដាជន* មើលការពន្យល់ អស ១:៩ ។ *កោតខ្លាច នៅចំពោះព្រះយេហូវ៉ា* គឺកោតខ្លាចដោយគោរព និងស្ដាប់បង្គាប់ដល់ព្រះអម្ចាស់ (មើល លវ ២០:១១ និងការពន្យល់ ចទ ៣១:១២–១៣ មឡ ១:៦ ៣:៥,១៦) ។

**១:១៣** *ទូតរបស់ព្រះយេហូវ៉ា* គឺជាងារដែលបានដាក់ឱ្យដល់ពួកហោរ (មើល ២រប ៣៦:១៥–១៦ អស ៤២:១៩ និងការពន្យល់) ឬពួកសង្ឃ (មើល មឡ ២:៧ និងការពន្យល់) ។ *អញនៅជាមួយនឹងឯងរាល់គ្នា* គឺជាការធានាអំពីជ័យជំនះ (មើល ២:៤ លប ២៦:៣ ជន ១៤:៩ និងការពន្យល់) ។

**១:១៤** *ដាស់តឿនចិត្ត* នៅក្នុង ១:៥ ព្រះអម្ចាស់ទ្រង់បានបណ្ដាលចិត្តពួកគេឱ្យត្រឡប់មកទឹកដីបរិសុទ្ធ ហើយសាងសង់ព្រះវិហារឡើងវិញ ។

**១:១៥** *ថ្ងៃទី២៤ ខែភទ្របទ* គឺត្រូវនឹងថ្ងៃទី ២១ កញ្ញា ឆ្នាំ ៥២០ មុនគ.ស.។

**២:១** *ថ្ងៃទី២១ ខែអស្សុជ* គឺត្រូវជាថ្ងៃទី ១៧ តុលា ឆ្នាំ ៥២០ មុនគ.ស. ហើយត្រូវជាថ្ងៃបញ្ចប់នៃបុណ្យបារាំ ។ ថ្ងៃនោះគឺជាពេលដែលត្រូវប្រារព្ធពិធីប្រមូលផល (មើល លវ ២៣:៣៤–៤៣) ទោះបីជាបានទទួលផលស្ដួចស្ដើងក៏ដោយ (មើល ១:១១ ធៀបនឹង យហ ៧:៣៧)។ ស្ដេចសាឡូម៉ូនទ្រង់បានសម្ពោធព្រះវិហារនៅក្នុងពេលបុណ្យនេះផងដែរ (មើល ១ពវ ៨:២ និងការពន្យល់)។

**២:៣** *មានសល់អ្នកណា* គឺអ្នកចាស់ទុំមួយចំនួនដែលត្រូវនិរទេស (ប្រហែលរាប់បញ្ចូលទាំងលោកហាកាយផងដែរ) បានឃើញព្រះវិហារដ៏អស្ចារ្យរបស់ស្ដេចសាឡូម៉ូន ដែលត្រូវពួកបាប៊ីឡូនបំផ្លាញកាលពី ៦៦ឆ្នាំកន្លងទៅ ។ *ព្រះវិហារនេះ ក្នុងសិរីល្អដាន់ដើម* មើល ខ.៧,៩ ។ ការដែលស្ដេចសូរ៉ូបាប៊ិលសាងសង់ព្រះវិហារ ត្រូវបានគេចាត់ទុកថាជាការបន្តការសាងសង់ព្រះវិហាររបស់ស្ដេចសាឡូម៉ូន ។ *មិនមែនដូចជាទទេសោះទេឬអី* ធៀបនឹងប្រត្តិកម្មដែលកើតមានបន្ទាប់ពីព្រះវិហារបានចាក់គ្រឹះហើយ (អរ ៣:១២) ។

**២:៤** *ចូរមានកំឡាំង ហើយធ្វើការទៅ* នៅក្នុង ១រប ២៨:២០ ស្ដេចសាឡូម៉ូនបានប្រើពាក្យនេះ ដើម្បីលើកទឹកចិត្តស្ដេចសាឡូម៉ូនឱ្យសាងសង់ព្រះវិហារ ។ ព្រះអម្ចាស់ទ្រង់បានលើកទឹកចិត្តដល់លោកយ៉ូស្វេ ជាកូនរបស់លោកនុន ដោយប្រើពាក្យស្រដៀងគ្នានេះផងដែរ (យស ១:៦–៧,៩,១៨)។ *អញនៅជាមួយនឹងឯង* មើល ១:១៣ និងការពន្យល់, ១រប ២៨:២០ ។ ព្រះអម្ចាស់ទ្រង់នឹងជួយផ្ដល់កម្លាំងដល់ស្ដេចសេរូបាបិល និងរាស្ត្ររបស់ទ្រង់ដូចកាលទ្រង់ជួយស្ដេចសាឡូម៉ូនក្នុងការសាងសង់ព្រះវិហារនោះផងដែរ ។

៥គឺជាពាក្យ ដែលអញតាំងជាសញ្ញានឹងឯងរាល់គ្នា[ដ] ក្នុង
កាលដែលឯងឡើងចេញពីស្រុកអេស៊ីព្ទមក[ឋ] ឯវិញ្ញាណ
របស់អញ[ឌ]ក៏ស្ថិតនៅជាមួយនឹងឯងរាល់គ្នាដែរ កុំឱ្យខ្លាច
ឡើយ[ឍ] ៦ដ្បិតព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូល
ដូច្នេះថា នៅតែបន្តិចទៀត[ណ] អញនឹងអង្រួនទាំងផ្ទៃមេឃ
និងផែនដី[ត] ទាំងសមុទ្រ និងទីគោកផង ៧ក៏នឹងអង្រួនអស់
ទាំងសាសន៍ដែរ នោះទីគាប់ចិត្ត[ថ]របស់អស់ទាំងសាសន៍
នឹងមកដល់ ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូល
ថា នៅគ្រានោះ អញនឹងបំពេញវិហារនេះ[ទ] ដោយសិរីល្អ[ធ]
៨ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលថា អស់
ទាំងប្រាក់ជារបស់ផងអញ ហើយមាស[ន]ទាំងប៉ុន្មានក៏ជា
របស់អញដែរ ៩ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មាន
បន្ទូលថា សិរីល្អ[ប]របស់វិហារ[ផ]ជាន់ក្រោយនេះ នឹងបាន
លើសជាងជាន់មុនទៅទៀត ហើយអញនឹងឱ្យមានសេចក្តី
សុខសាន្ត[ព]នៅទីនេះផង នេះជាព្រះបន្ទូលរបស់ព្រះយេ
ហូវ៉ានៃពួកពលបរិវារ ។

## ព្រះពរសម្រាប់រាស្ត្រមិនបរិសុទ្ធ

១០នៅថ្ងៃ២៤ ខែមិគសិរ[ភ] ក្នុងឆ្នាំទី២ នៃរាជ្យ ដារីយុស
នោះព្រះបន្ទូលនៃព្រះយេហូវ៉ាបានមក ដោយសារហោរា
ហាកាយថា ១១ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មាន
បន្ទូលដូច្នេះ ឥឡូវនេះ ចូរសួរពួកសង្ឃ[ម]ពីដំណើរក្រឹត្យ
វិន័យថា ១២បើអ្នកណាដក់សាច់ដ៏បរិសុទ្ធ[យ]ក្នុងថ្នក់អាវ ទៅ
ឯណា រួចអាវប៉ះនឹងនំបុ័ង សំឡ ស្រាទំពាំងបាយជូរ ប្រេង
ឬម្ហូបអ្វីក៏ដោយ តើរបស់នោះនឹងបានបរិសុទ្ធដែរឬ[រ] នោះ
ពួកសង្ឃបានឆ្លើយថា ទេ ១៣រួចហាកាយសួរថា បើសិនជា
អ្នកណាដែលមិនស្អាត ដោយព្រោះខ្មោចស្លាប់ គេបានប៉ះ
នឹងរបស់ណាមួយនោះ តើរបស់នោះនឹងត្រឡប់ជាមិន
ស្អាតដែរឬ ពួកសង្ឃក៏ឆ្លើយថា និងត្រឡប់ជាមិនស្អាតជា
ពិត[ល] ១៤រួចហាកាយពោលសបរិញថា ព្រះយេហូវ៉ាទ្រង់
មានបន្ទូលដូច្នេះ បណ្តាជននេះ[វ] និងសាសន៍នេះ ក៏ដូច្នោះ
នៅចំពោះអញដែរ ព្រមទាំងការទាំងប៉ុន្មានដែល ដៃគេ
ធ្វើ និងដង្វាយដែលគេថ្វាយ[ស]នៅទីនោះ ក៏សុទ្ធតែមិនស្អាត

**២:៥** ដ លប ៦:១៨ ឋ នក ២៩:៤៦ ឌ នហ ៩:២០ ឍ លប ១៥:១ ១រប ២៨:២០ អរ ៥:២ សក ៨:១៣ **២:៦** ណ អស ១០:២៥ ត នក ១៩:១៨ យប ៩:៦ អស ១៤:១៦ អគ ៣៨:១៩ ហព ១២:២៦ **២:៧** ថ ១សយ ៩:២០ ទ អស ៦០:៧ ធ នក ១៦:៧ ២៩:៤៣ លក ២:៣២ **២:៨** ន ១រប ២៩:២ **២:៩** ប ទដ ៨៥:៩ អស ១១:១០ ផ អរ ៣:១២ អស ៦០:៧ ព លវ ២៦:៦ អស ៦០:១៧ **២:១០** ភ ឧ.១ ហក ១:១៥ **២:១១** ម លវ ១០:១០-១១ ចទ ១៧:៨-១១ ៣៣:៨ យរ ១៨:១៨ **២:១២** យ យរ ១១:១៥ រ លប ៧:២ លវ ៦:២៧ មថ ២៣:១៩ **២:១៣** ល លវ ២២:៤-៦ ជន ១៩:១៣ **២:១៤** វ អស ២៩:១៣ ស ទដ ៥១:១៧ អស ១:១៣

**២:៥** *វិញ្ញាណរបស់អញ* ព្រះវិញ្ញាណបរិសុទ្ធទ្រង់បានសណ្ឋិតលោកម៉ូសេ និងអ្នកចាស់ទុំ ក្នុងការដែលពួកគេដឹកនាំរាស្ត្រទ្រង់ចេញពីស្រុកអេស៊ីព្ទ និងធ្វើដំណើរតាមវាលរហោស្ថាន (មើល ជន ១១:១៦-១៧,២៥ អស ៦៣:១១)។ មើល ទដ ៥១:១១ សក ៤:៦ និងការពន្យល់ ។ *កុំឱ្យខ្លាច* មើលការពន្យល់ ខ.៤ យស ១:១៨ អស ៤១:១០ ។

**២:៦** ខនេះគឺជាបទទំនាយអំពី ការជំនុំជម្រះដែលត្រូវមកដល់សាសន៍ជាច្រើន នៅពេលដែលចក្រភពពើរស៊ីត្រូវដួលរលំ ហើយចក្រភពរបស់ស្តេចអ័ឡេចក្សាន់ឌ័របង្ករវិនាសសកម្ម (ឆ្នាំ ៣៣៣ ដល់ ៣៣០ មុនគ.ស.)។ បទគម្ពី ហព ១២:២៦-២៧ បានតភ្ជាប់ខនេះទៅនឹងការជំនុំជម្រះជាតិសាសន៍ទាំងអស់នៅពេលដែលព្រះគ្រីស្ទយាងត្រឡប់មកវិញជាលើកទីពីរ ។ ការអង្រួនជាតិសាសន៍នៅក្នុងខនេះ និងខ.២១-២២ គឺសំដៅទៅលើសេចក្តីជំនុំសាសន៍អេស៊ីព្ទនៅសមុទ្រក្រហម ។ ធៀបនឹង អស ១៤:១៦-១៧ ។

**២:៧** *ទីគាប់ចិត្ត . . . នឹងមកដល់* ធៀបនឹង ១សយ ៩:២០ ។ ពាក្យ "ទីគាប់ចិត្ត"នេះគឺជាលក្ខណៈសម្បត្តិរបស់ព្រះមែស៊ី (មើល ដយ ១១:៣៧ និងការពន្យល់, មឡ ៣:១) ។ បើពាក្យនេះក៏អាចប្រើសំដៅទៅលើតម្លៃ (មើល ២រប ២០:២៥ ៣២:២៧) នៃការរួមចំណែករបស់ស្តេចដារីយ៉ុសនៅក្នុងការសាងសង់ព្រះវិហារផងដែរ (អរ ៦:៨) ដូចនេះក៏អាចសំដៅផងដែរទៅលើ "សេចក្តីថ្កុំថ្កើងនៃ" ក្រុងស៊ីយ៉ូន នៅក្នុង អស ៦០:៥ (មើលការពន្យល់ខនេះ) *បំពេញ . . . ដោយសិរីល្អ* ពាក្យ "សិរីល្អ"អាចសំដៅទៅលើភាពរុងរឿងខាងផ្នែកសំភារៈ (មើល អស ៦០:៧,១៣ និងការពន្យល់) ឬសំដៅទៅលើវត្តមានព្រះ (នក ៤០:៣៤-៣៥ ១ពវ ៨:១០-១១ អគ ១០:៤)។ ពាក្យសិរីល្អនៅក្នុងបទគម្ពីរផ្សេងទៀតក៏សំដៅផងដែរទៅលើ ពពកដែលមានពាសពេញក្នុងទីបរិសុទ្ធ ។ ការដែលព្រះគ្រីស្ទទ្រង់យាងមកព្រះវិហារនៅឯលោកិយនេះ បង្ហាញអំពីភស្តុតាងនៃព្រះវត្តមានព្រះដែលមិនដែលធ្លាប់មានយ៉ាងដូចនេះពីមុនមក (មើល លក ២:២៧,៣២) ។

**២:៨** *ប្រាក់ . . . មាស* គឺជាសំភារៈសម្រាប់ការសាងសង់ព្រះវិហារស្តេចសាឡូម៉ូន (១រប ២៩:២,៧) និងរបស់ស្តេចសេរូបាបិល (អរ ៦:៥)។

**២:៩** *សិរីល្អ . . . លើសជាង* សិរីល្អនឹងលើសជាងពីព្រោះព្រះមែស៊ីទ្រង់នឹងមានវត្តមាននៅទីនោះ (មើល ខ.៧ និងការពន្យល់)។ *ជាន់មុន* គឺព្រះវិហារស្តេចសាឡូម៉ូន ។ *នៅទីនេះ* ប្រហែលជាក្រុងយេរូសាឡិម (មើល សជ ១:៤ និងការពន្យល់)។ *អញនឹងឱ្យមានសេចក្តីសុខសាន្ត* មើល ជន ៦:២៦ និងការពន្យល់ ។

**២:១០** *ថ្ងៃទី២៤ ខែមិគសិរ* គឺត្រូវនឹងថ្ងៃទី ១៨ ធ្នូ ឆ្នាំ ៥២០ មុនគ.ស. គឺជាពេលដែលគេដាំដុះដំណាំរដូវរងារ ។

**២:១១** *ពួកសង្ឃ* ពួកសង្ឃត្រូវទទួលនូវសេចក្តីប្រឹក្សាអំពីការកាត់ស្រាយលំអិត អំពីអត្ថន័យក្រឹត្យវិន័យ (មើល ចទ ៣១:១១ យរ ១៨:១៨ មឡ ២:៧-៩ និងការពន្យល់)។

**២:១២** *សាច់ដ៏បរិសុទ្ធ* គឺជាសាច់របស់សត្វដែលត្រូវបានញែកសម្រាប់ធ្វើយញ្ញបូជា ។ *តើរបស់នោះនឹងបានបរិសុទ្ធដែរឬ* គឺជាសំណួរអំពីសេចក្តីបរិសុទ្ធដែលឆ្លង ។ សាច់បរិសុទ្ធធ្វើឱ្យក្រណាត់អាវ "បរិសុទ្ធ" ព្រោះសាច់នោះត្រូវប៉ះពាល់ផ្ទាល់នឹងក្រណាត់នោះ (លវ ៦:២៧) ប៉ុន្តែក្រណាត់នោះមិនអាចចម្លងភាពបរិសុទ្ធនោះទៅវត្ថុទីបីឡើយ ។

**២:១៣** *តើរបស់នោះនឹងត្រឡប់ជាមិនស្អាតដែរឬ* ភាពមិនស្អាតអាចឆ្លងងាយជាងភាពបរិសុទ្ធ ។ កាលណាមនុស្សមិនស្អាតប៉ះពាល់របស់អ្វីមួយ របស់នោះត្រូវត្រឡប់ជាមិនស្អាតផងដែរ (ជន ១៩:១១-១៣,២២)។

**២:១៤** *បណ្តាជននេះ* មើល ១:២ និងការពន្យល់ ។ *ការទាំងប៉ុន្មានដែលដៃ*

ដូចគ្នាផង ១៥ដូច្នេះ ចូរឱ្យឯងរាល់គ្នាពិចារណា[ហ] ចាប់
តាំងពីសព្វថ្ងៃនេះសាឡើង ទៅដល់គ្រាមុនដែលមាន ថ្ម
ណារៀបឡើង[ឡ] ត្រួតលើថ្មណារបស់ព្រះវិហារនៃព្រះ
យេហូវ៉ានេះ[អ] ១៦នៅរវាងនោះ កាលណាគេមកដល់គំនរ
ស្រូវ[ក] ដែលត្រូវមាន២០ថាំង នោះឃើញមានតែ១០វិញ
ហើយកាលណាមកដល់ធុងឃ្នាប[ខ] ដើម្បីដងយក៥០រង្វាល់
នោះបានតែ២០វិញ[គ] ១៧គឺអញបានវាយការ ដែលដៃ[ឃ]ឯង
រាល់គ្នាធ្វើ ឱ្យស្រូវស្កក[ង] ហើយល្មាស ព្រមទាំងត្រូវព្រិល
ផង[ច] ទោះបើយ៉ាងណានោះ គង់តែឯងរាល់គ្នាមិនបាន
វិល[ឆ]មកឯអញវិញដែរ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ជ]
១៨ចូរឱ្យឯងរាល់គ្នាពិចារណា[ឈ] ចាប់តាំងពីថ្ងៃនេះសា
ឡើងទៅ គឺចាប់តាំងពីថ្ងៃ២៤ខែមិគសិរ ជាថ្ងៃដែលដាក់
ឫសជញ្ជាំង[ញ] នៃព្រះវិហាររបស់ព្រះយេហូវ៉ា ចូរពិចារ
ណាចុះ ១៩តើពូជពង្រោះបានយកមកដាក់ក្នុងជង្រុកហើយ
ឬនៅ អើ ទោះទាំង ដើមទំពាំងបាយជូរ ដើមល្វា ដើម
ទទឹម[ដ] និងដើមអូលីវ ក៏មិនបានកើតផលដែរ[ឋ] តែចាប់តាំង
ពីថ្ងៃនេះទៅ អញនឹងផ្តល់ពរ[ឌ]ដល់ឯងវិញ ។

**២:១៥** ហ ហាក ១:៥
ឡ អរ ៣:១០
អ អរ ៤:២៤
**២:១៦** ក នរ ៣:៧
ខ យប ២៤:១១
អស ៥:២
គ ចទ ២៨:៣៨
អស ៥:១០ ហាក ១:៦
**២:១៧** ឃ ហាក
១:១១ ង ចទ
២៨:២២ ច នក
៩:១៨ ទដ ៧៨:៤៨
ឆ អស ៩:១៣ យរ
៣:១០ ជ អម ៤:៦
**២:១៨** ឈ ហាក ១:៥
ញ អរ ៣:១១
**២:១៩** ដ នក
២៨:៣៣ ឋ យអ
១:១២ ឌ លប
១២:២ លវ ២៥:២១
ទដ ១២៨:១–៦
យអ ២:១៤
**២:២០** ឍ ឧ.១

## ស្តេចសូរ៉ូបាបិល ជាជញ្ជៀនត្រានៃព្រះអម្ចាស់

២០នៅថ្ងៃ២៤ ខែនោះឯង[ឍ] ព្រះបន្ទូលនៃព្រះយេហូវ៉ា
បានមកដល់ហាកាយ[ណ]ម្តងទៀតដោយថា ២១ចូរប្រាប់ដល់
សូរ៉ូបាបិល[ត] ជាចៅហ្វាយលើស្រុកយូដាថា អញនឹងអង្រួន[ថ]
ផ្ទៃមេឃ ហើយនិងផែនដីផង ២២អញនឹងរំលំ[ទ]បល្ល័ង្កនៃ
រាជ្យផ្សេងៗ ហើយនិងរំលាងបំផ្លាញឥទ្ធិឫទ្ធិរបស់រាជ្យ
នៃសាសន៍ទាំងប៉ុន្មាន[ធ] អញនឹងបំភ្លូកអស់ទាំងរទេះចំបាំង[ន]
ព្រមទាំងមនុស្សដែលជិះផង[ប] ឯសេះ និងពួកដែលជិះ ក៏
នឹងភ្លាត់ធ្លាក់ចុះ ដោយដាវរបស់បងប្អូនគេរៀងរាល់ខ្លួន[ផ]
២៣ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលថា នៅ
ថ្ងៃនោះ[ព] ឱសូរ៉ូបាបិល[ភ] កូនសាលធាល ជាអ្នកបំរើ[ម]របស់
អញ អើយ អញនឹងយកឯង តាំងឡើងជាចិញ្ចៀនត្រា[យ] ដ្បិត
អញបានរើសឯងទុកហើយ នេះហើយជាព្រះបន្ទូលនៃ
ព្រះយេហូវ៉ា ។/

ហាក ១:១៥ ណ អរ ៥:១ **២:២១** ត អរ ៥:២ ថ អស ១៤:១៦ អគ ៣៨:១៩–២០ **២:២២** ទ លប ១៩:២៥ យប ២:១៣ ធ ដយ ២:៤៤ ន មីក ៥:១០ ប នក ១៥:២១ ផ ពច ៧:២២ អគ ៣៨:២១ **២:២៣** ព អស ២:១១ ១០:២០ សក ៤:១០ ភ មថ ១:១២ ម អស ២០:៣ ដយ ៩:២៤–២៦ យ លប ៣៨:១៨ នក ២៨:៩ ២កថ ១:២២

*គេធ្វើ . . . នឹងត្រឡប់ជាមិនស្អាត* ការត្រឡប់មកទឹកដីបរិសុទ្ធវិញ គឺមិនមានន័យថាពួកគេបានបរិសុទ្ធឡើយ ។ ពួកគេត្រូវស្តាប់បង្គាប់ព្រះ ជាពិសេសនៅក្នុងការសាងសង់ព្រះវិហារឡើងវិញ ។ មើលពន្យល់ ឧ.១២–១៣ ។

**២:១៥** *គ្រាមុនដែលមានថ្ម* គឺនៅមុនថ្ងៃទី២៤ ខែភទ្របទ (១:១៤–១៥) ។

**២:១៦** *គំនរស្រូវ* មើល យរ ៥០:២៦ ។ *មាន២០ថាំង . . . មានតែ១០វិញ* ការបង្កបង្កើនផលមិនបានល្អគឺទាក់ទងនឹងអំពើបាបរបស់បណ្តាជន (មើល ១:១១ អស ៥:១០ និងការពន្យល់) ។ *ធុងឃ្នាប* គេធ្វើវា ដោយយកថ្មធំមួយមកចោះជាស្នូក ហើយគេបង្ហូរទឹកទំពាំងបាយជូរចូលក្នុងធុងនោះ ពីកន្លែងបញ្ជាន់ផ្លែទំពាំងបាយជូរ គេរក្សាទឹកទំពាំងបាយជូរក្នុងធុងនោះរហូតដល់វាចាប់ផ្តើមឡើងមេ ។ ក្រោយមកគេផ្តេរទឹកទំពាំងបាយជូរនោះទៅក្នុងក្រឡ ឬថង់ស្បែកវិញ សម្រាប់ការឡើងមេបន្តទៀត និងការរក្សាទុក ។

**២:១៧** *វាយការ ដែលឯងរាល់គ្នាធ្វើ ឱ្យស្រូវស្កក* គឺជាសេចក្តីបណ្តាសាដោយសារការមិនស្តាប់បង្គាប់ ចទ ២៨:២២ (មើល ១ពវ ៨:៣៧ អម ៤:៩) ការស្កកនេះប្រហែលជាបណ្តាលមកពីខ្យល់ស្ងួតដែលបក់មកពីទិសខាងកើត (លប ៤១:៦ និងការពន្យល់) ។ *ព្រិល* ត្រូវបានបញ្ជូនមកដើម្បីបំផ្លាញជីវិតសត្វ និងវាលស្រែរបស់ពួកអេស៊ីព្ទ (មើល នក ៩:២៥ ទដ ៧៨:៤៧–៤៨) ។ *ឯងរាល់គ្នាមិនបានវិលមកឯអញវិញ* មើឡ អម ៤:៦,៨–១១ ។

**២:១៨** *ថ្ងៃដែលដាក់ឫសជញ្ជាំង* ព្រះអម្ចាស់ទ្រង់ប្រទានព្រះពរគឺចាប់តាំងពីពេលចាក់គ្រឹះព្រះវិហារ នៅឆ្នាំ ៥៣៦ មុនគ.ស. (អរ ៣:១១) ។ ការនេះគឺជាការព្រមានមិនឱ្យពួកគេបរាជ័យម្តងទៀត ។

**២:១៩** *ដើមទំពាំងបាយជូរ ដើមល្វា ដើមទទឹម និងដើមអូលីវ* ផ្លែទាំងនេះទុំនៅខែសីលា និងកញ្ញា លើកលែងតែដើមអូលីវ ទុំពីខែកញ្ញាដល់វិច្ឆិការ (មើល ១:១១ និងការពន្យល់) ។ *អញនឹងផ្តល់ពរ* ដោយសារពួកគេបានឆ្លើយតបតាមពាក្យ របស់លោកហាកាយ ។ ធៀបនឹង មទ្ឋ ៣:១០ ។

**២:២០** មើលការពន្យល់ ឧ.១០ ។

**២:២១** *អង្រួន . . ផែនដី* មើល ឧ.៦ និងការពន្យល់ ។

**២:២២** *រំលំបល្ល័ង្ក . . . រំលាងបំផ្លាញ* នៅក្នុង លប ១៩:២៥ អម ៤:១១ ពាក្យនេះត្រូវបានប្រើសំដៅទៅលើក្រុងសូដុំម និងកូម៉ូរ៉ា ។ *រទេះចំបាំង . . . សេះ និងពួកដែលជិះ* ធៀបជាមួយនឹងការបំផ្លាញកងទ័ពស្តេចផារ៉ោននៅសមុទ្រក្រហម (នក ១៥:១,៤,១៩,២១) ។ *របស់បងប្អូនគេរៀងខ្លួន* គ្រោះថ្នាក់នៃកងទ័ពរបស់សាសន៍ម៉ាឌាន (ពច ៧:២២ និងការពន្យល់) សាសន៍កុក (មើល អគ ៣៨:២១ និងការពន្យល់) និងសាសន៍ទាំងប៉ុន្មាន ដែលលើកទ័ពមកទាស់នឹងក្រុងយេរូសាឡិមនៅថ្ងៃចុងក្រោយ (សក ១៤:១៣) ។

**២:២៣** *នៅថ្ងៃនោះ* គឺនៅថ្ងៃនៃព្រះអម្ចាស់ (មើល អស ២:១១,១៧,២០ ១០:២០,២៧ យអ ១:១៥ សក ២:១១ និងការពន្យល់) ។ *អ្នកបំរើរបស់អញ* ពាក្យនេះត្រូបានប្រើសម្រាប់ពួកសង្ឃ (មើល អស ២០:៣ និងការពន្យល់) អ្នកដឹកនាំនយោបាយ (អស ២២:២០) និងព្រះមែស៊ី (មើល អស ៤១:៨–៩ ៤២:១ និងការពន្យល់) ។ *ចិញ្ចៀនត្រា* គឺជាចិញ្ចៀនមួយប្រភេទដែលប្រើសម្រាប់ហត្ថលេខា (មើល នអ ៨:៨) ហើយត្រូវបំពាក់លើម្រាមដៃ (នអ ៣:១០) ។ ជញ្ជៀនត្រានេះអាចប្រើសម្រាប់ធ្វើកិច្ចសន្យា ឬការធានាសង គឺដូចជាត្រាប្រភេទផ្សេងទៀតទេ (មើល លប ៣៨:១៨ និងការពន្យល់) ។ ក្នុងខនេះចិញ្ចៀនត្រូវបានលើកមកនិយាយ ប្រហែលជាដើម្បីរំឭកអំពីបណ្តាសាដែលត្រូវធ្លាក់មកលើស្តេចយេហូយ៉ាគីមនៅក្នុង យរ ២២:២៤ (មើល ពច ១៧:២ និងការពន្យល់) ។ ស្តេចសេរូបាបិល ប្រើចិញ្ចៀនត្រានេះដើម្បីធានាអំពីការលេចមកនៃសិរីល្អនៃព្រះវិហារ (ឧ.៦–៧,៩ សក ៤:៦–៧ និងការពន្យល់) ។ *បានរើសឯងទុក* មើល អស ៤១:៨–៩ ៤២:១ និងការពន្យល់ ។

# ព្រះគម្ពីរសាការី

## សេចក្ដីផ្ដើម

### ប្រវត្តិដើម

លោកសាការីបានធ្វើការបម្រើព្រះជាហោរានៅក្នុងសម័យក្រោយការនិរទេស ដែលជាសម័យស្ដារពួកយូដាឡើងវិញ បន្ទាប់ពីបានរួចពីភាពជាឈ្លើយរបស់ចក្រភពបាប៊ីឡូន ។ ចំពោះសេចក្ដីលំអិតអំពីប្រវត្តិសាស្ត្រ មើលសេចក្ដីផ្ដើមព្រះគម្ពីរហាកាយត្រង់ប្រវត្តិដើម ។

### អ្នកនិពន្ធ និងលក្ខណៈរួម

លោកសាការីមិនគ្រាន់តែជាហោរាប៉ុណ្ណោះទេ(១:១) ប៉ុន្តែលោកថែមទាំងជាសមាជិកម្នាក់នៅក្នុងគ្រួសារពួកសង្ឃ គឺមិនខុសពីលោកយេរេមា (១:១) និងលោកអេសេកាល(១:៣)ឡើយ ។ លោកបានកើតនៅក្នុងចក្រភពបាប៊ីឡូន ហើយស្ថិតនៅក្នុងចំណោមអ្នកដែលវិលត្រឡប់ទៅស្រុកយូដាវិញនៅឆ្នាំ ៥៣៨ ឬ ៥៣៧ មុនគ.ស. នៅក្រោមការដឹកនាំរបស់ស្ដេចសេរូបាបិល និងលោកយេសួ (លោកអេដោដែលជាជីតាស្ថិតនៅក្នុងចំណោមអ្នកដែលត្រឡប់មកវិញនៅក្នុង នហ ១២:៤) ។ នៅពេលក្រោយមកទៀត នៅពេលដែលលោកយ៉ូយ៉ាគីមនៅជាសម្ដេចសង្ឃ (មើលការពន្យល់ នហ ១២:១២-២១) លោកសាការីប្រហែលជាអ្នកស្នងរបស់លោកអេដោ (១:១,៧) ដោយលោក ជាមេគ្រួសារពួកសង្ឃ (នហ ១២:១០-១៦) ។ ដោយសារចៅបានឡើងស្នងជីតារបស់ខ្លួនយ៉ាងដូចនេះ គេសន្និដ្ឋានថាឪពុករបស់លោកសាការី (លោកបេរេគា ១:១,៧) បានស្លាប់កាលមិនទាន់ចាស់នៅឡើយ ។

លោកសាការីបានរស់នៅក្នុងជំនាន់ជាមួយនឹងលោកហាកាយ (អរ ៥:១ ៦:១៤) ប៉ុន្តែលោកសាការីបានបន្តការងាររបស់ខ្លួនបន្ទាប់ពីលោកហាកាយ (ផ្ទៀប ១:១ និង ៧:១ ជាមួយនឹង ហាក ១:១ និងមើល នហ ១២:១-១៦) ។ លោកបានចាប់ផ្ដើមធ្វើការក្នុងកាលនៅមានអាយុតិចនៅឡើយ ការនេះបង្ហាញថា លោកបានបម្រើព្រះសូម្បីតែនៅក្នុងរាជរបស់ស្ដេចអើថាសើកសេសទី១(ឆ្នាំ ៤៦៥ ដល់ ៤២៤ មុនគ.ស.) ។

លោកសាការីបាននិយាយអំពីឈ្មោះរបស់ខ្លួនលោកជាច្រើនដងនៅក្នុងការនិពន្ធព្រះគម្ពីរនេះ ។ មានអ្នកខ្លះបានចោទសួរអំពីភាពជាអ្នកនិពន្ធរបស់លោក នៅក្នុងជំពូក ៩-១៤ ដោយលើកឡើងថា ក្នុងវគ្គនេះមានរចនាបថនៃការសរសេរ និងលក្ខណៈផ្សេងៗទៀតដែលខុសប្លែកពីវគ្គដទៃទៀតក្នុងព្រះគម្ពីរនេះ ហើយបានលើកឡើងពីចំណុចដែលទាក់ទងនឹងប្រវត្តិសាស្ត្រ និងពង្សាវតា ដែលគួរឱ្យសង្ស័យថា វគ្គនេះមានអ្នកនិពន្ធ និងកាលបរិច្ឆេទផ្សេងពីវគ្គនៃជំពូក ១-៨ ។ ទោះជាយ៉ាងណាក៏ដោយ ការបដិសេធន៍ទាំងអស់នេះមិនមានហេតុផលគ្រប់គ្រាន់ដើម្បីចោទសួរអំពីព្រះគម្ពីរនេះឡើយ ។

### កាលបរិច្ឆេទ

ព្រះគម្ពីរសាការីមានកាលបរិច្ឆេទ ដែលទាក់ទងគ្នានឹងព្រះគម្ពីរហាកាយ និងព្រឹត្តការណ៍ប្រវត្តិសាស្ត្រដទៃទៀតដូចជា:

| | |
|---|---|
| ១. សេចក្ដីទំនាយទីមួយរបស់លោកហាកាយ (ហាក ១:១-១១ អរ ៥:១) | ថ្ងៃទី ២៩ ឧសភា ឆ្នាំ ៥២០ មុនគ.ស. |
| ២. ការចាប់សាងសង់ព្រះវិហារឡើងវិញ (ហាក ១:១២-១៥ អរ ៥:២) | ថ្ងៃទី ២១ កញ្ញា ឆ្នាំ ៥២០ មុនគ.ស. |
| (ការសាងសង់ឡើងវិញនេះត្រូវជួបឧបសគ្គចាប់ពីឆ្នាំ ៥៣៦ ដល់ ប្រហែល ៥៣០ មុនគ.ស., អរ ៤:១-៥, ហើយការងារសាងសង់នេះត្រូវបញ្ឈប់ទាំងស្រុងពីឆ្នាំប្រហែល ៥៣០-៥២០ មុនគ.ស.,អរ ៤:២៤) | |
| ៣. សេចក្ដីទំនាយទីពីររបស់លោកហាកាយ(ហាក ២:១-៩) | ថ្ងៃទី ១៧ តុលា ឆ្នាំ ៥២០ មុនគ.ស. |
| ៤. ការចាប់ផ្ដើមចែកចាយព្រះបន្ទូលរបស់លោកសាការី (១:១-៦) | ខែ តុលា ឬវិច្ឆិការ ឆ្នាំ ៥២០ មុនគ.ស. |
| ៥. សេចក្ដីទំនាយទីបីរបស់លោកហាកាយ(ហាក ២:១០-១៩) | ថ្ងៃទី ១៨ តុលា ឆ្នាំ ៥២០ មុនគ.ស. |
| ៦. សេចក្ដីទំនាយទីបួនរបស់លោកហាកាយ(ហាក ២:២០-២៣) | ថ្ងៃទី ១៨ តុលា ឆ្នាំ ៥២០ មុនគ.ស. |
| ៧. លោកថាថ្នាយបានផ្ញើសំបុត្រដល់ស្ដេចដារីយ៉ុស ទាក់ទងនឹងការសាងសង់ឡើងវិញនេះ (អរ ៥:៣-៦:១៤) | ឆ្នាំ ៥១៩-៥១៨ |
| (ប្រាកដជាមានរយៈពេលនៅចន្លោះការសាងសង់ព្រះវិហារឡើងវិញ និងការបង្ហាញខ្លួនរបស់លោកថាថ្នាយ) | |
| ៨. សេចក្ដីទំនាយដែលលោកសាការីទទួលបានក្នុងរយៈពេលប្រាំបីយប់ | ថ្ងៃទី ១៥ កម្ភៈ ឆ្នាំ ៥១៩ មុនគ.ស. |

៩. ការបំពាក់មកុដឱ្យលោកយេសួរ (៦:៩–១៥) ថ្ងៃទី ១៦(?) កម្ពុ: ឆ្នាំ ៥១៩ មុនគ.ស.
១០. ការជំរុញឱ្យប្រែចិត្ត និងការសន្យាប្រទានព្រះពរ (ជំពូក ៧–៨) ថ្ងៃទី ៧ ធ្នូ ឆ្នាំ ៥១៨ មុនគ.ស.
១១. ការសម្ភោធន៍ព្រះវិហារ (អរ ៦:១៥–១៨) ថ្ងៃទី ១២ មិនា ឆ្នាំ ៥១៦ មុនគ.ស.
១២. សេចក្តីទំនាយចុងក្រោយរបស់លោកសាការី (ជំពូក ៩–១៤) នៅក្រោយឆ្នាំ ៤៨០(?) មុនគ.ស.

### ឱកាស និងគោលបំណង

ព្រះគម្ពីរសាការី និងហាកាយត្រូវបាននិពន្ធឡើងក្នុងឱកាសដូចគ្នា (មើលប្រវត្តិដើម និងកាលបរិច្ឆេទ) ។ គោលបំណងសំខាន់បំផុតនៃព្រះគម្ពីរនេះ (និងព្រះគម្ពីរហាកាយ)គឺដើម្បីស្តីបន្ទោសដល់ប្រជាជននៃស្រុកយូដា ហើយដើម្បីលើកទឹកចិត្តឱ្យពួកគេស្អាងព្រះវិហារឡើងវិញរហូតដល់បានសម្រេច (សក ៤:៨–១០ ហក ១–២) ទោះបីជាហោរាទាំងពីរនាក់នេះមានការឆេះឆួលខ្លាំងនៅក្នុងការបំផ្លាស់បំប្រែព្រលឹងវិញ្ញាណជាថ្មីឡើងវិញក៏ដោយ ។ ម្យ៉ាងទៀត គោលបំណងនៃការទទួលសេចក្តីទំនាយក្នុងរយៈពេល៨យប់ (១:៧–៦:៨) ត្រូវបានពន្យល់នៅក្នុង ១:៣,៥–៦ ដែលថា ព្រះអម្ចាស់ទ្រង់មានបន្ទូលថា បើពួកយូដាព្រមត្រឡប់មកឯទ្រង់ នោះទ្រង់នឹងយាងត្រឡប់មកឯពួកគេវិញ ។ ជាងនេះទៅទៀត ព្រះបន្ទូលរបស់ទ្រង់នឹងនៅតែបន្តសម្រេច ។

### សេចក្តីបង្រៀនអំពីវិជ្ជាសិក្សាអំពីព្រះ

នៅក្នុងព្រះគម្ពីរសាការី សេចក្តីបង្រៀនអំពីវិជ្ជាសិក្សាអំពីព្រះគឺមានការទាក់ទងនឹងឈ្មោះរបស់លោកសាការីដែលឈ្មោះនេះមានន័យថា "ព្រះអម្ចាស់(ព្រះយេហូវ៉ា)ទ្រង់នឹកចាំ"។ "ព្រះយេហូវ៉ា" គឺជាព្រះនាមតាមសេចក្តីសញ្ញា ហើយជាសេចក្តីបន្ទាល់អំពីសេចក្តីស្មោះត្រង់ដែលទ្រង់មានចំពោះសេចក្តីសន្យារបស់ទ្រង់ជានិច្ច(មើលការពន្យល់ លប ២:៤ នក ៣:១៤–១៥ ៦:៦ ចទ ២៨:៥៨)។ ព្រះទ្រង់ "នឹកចាំ"ពីសេចក្តីសន្យាដែលទ្រង់មាននៅក្នុងសេចក្តីសញ្ញា ហើយទ្រង់បំពេញសេចក្តីសន្យានោះ ។ នៅក្នុងព្រះគម្ពីរសាការី ព្រះអម្ចាស់ទ្រង់បានសន្យាប្រទានការប្រោសលោះពីការនិរទេសរបស់ពួកបាប៊ីឡូន ដែលរួមមានការស្អាងនគរមួយដែលកើតពីការរួបរួម និងព្រះវិហារដែលមានដំណើរការ (ព្រះវិហារជាបល្ល័ង្កដែលទ្រង់គង់នៅលោកិយ, មើលសេចក្តីផ្តើមព្រះគម្ពីរទំនុកតំកើងត្រង់វិជ្ជាសិក្សាអំពីព្រះ) ការដឹកនាំឆ្ពោះទៅរកសេចក្តីសង្គ្រោះ និងការស្អាងឡើងវិញដែលកើតមានតាមរយៈព្រះមែស៊ី(មើលការពន្យល់ ៣:៨–៩ ៤:៣,១៤ ៦:៩–១៥ ៩:៩–១០ ១០:២,៤ ១១:៤–១៤ ១២:១០–១៣:១ ១៣:៧ ១៤:៤–៩) ។

ព្រះគម្ពីរនេះទាំងមូលក៏បានបង្រៀនផងដែរអំពីអំណាចគ្រប់គ្រង ដែលព្រះអម្ចាស់ទ្រង់មាននៅក្នុងប្រវត្តិសាស្ត្រ គឺគ្រប់គ្រងលើគ្រប់មនុស្សគ្រប់ជាតិសាសន៍ ដែលនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល (មើលឧទាហរណ៍ក្នុង ១:១០–១១ ២:១៣ ៤:១០,១៤ និងការពន្យល់ ៦:៥,៧ ៨:២០–២៣ ៩:១០,១៣–១៤ ១០:១១ ១២:១–៥ ១៤:៩,១៦–១៩) ។

### ទម្រង់ និងខ្លឹមសារនៃអក្សរសាស្ត្រ

ព្រះគម្ពីរនេះមានចម្រុះទៅដោយ ការលើកទឹកចិត្ត(ការត្រាសហៅឱ្យប្រែចិត្ត ១:២–៦), ការទទួលសេចក្តីទំនាយ(១:៧–៦:៨) ព្រះបន្ទូលយ៉ាងធ្ងន់ដែលប្រៀនប្រដៅ និងលើកទឹកចិត្តតាមរយៈសេចក្តីទំនាយ ដែលទាក់ទងនឹងការបំពាក់មកុដជានិមិត្តរូប(៦:៩–១៥) ការលើកទឹកចិត្ត(ដោយកាស្តីបន្ទោស និងផ្តល់ក្តីសង្ឃឹម) ដែលមានជាសំនួរអំពីការអធិស្ឋានតម(ជំពូក ៧–៨) និងព្រះបន្ទូលដ៏ធ្ងន់អំពីការជំនុំជម្រះ និងសេចក្តីសង្គ្រោះ(ជំពូក ៩–១៤) ។ ការនិយាយអំពីការទទួលសេចក្តីទំនាយនៅក្នុង ១:៧–៦:៨ គឺជាអក្សរសាស្ត្របែបបើកសំដែង ដែលត្រូវបានសរសេរឡើងដើម្បីលើកទឹកចិត្តដល់រាស្ត្ររបស់ព្រះ ។ នៅពេលដែលគេតភ្ជាប់វគ្គអក្សរសាស្ត្របែបបើកសម្តែងនេះជាមួយនឹងព្រះបន្ទូលដ៏ធ្ងន់អំពីសេចក្តីសង្គ្រោះ(ឬការប្រោសលោះ)នៃជំពូក ៩–១៤ ឃើញថា ខ្លឹមសាររួម និងសំខាន់បំផុតនៃព្រះគម្ពីរនេះគឺការលើកទឹកចិត្ត ដោយបង្ហាញពីអនាគតដ៏រុងរឿងដែលកំពុងរង់ចាំរាស្ត្ររបស់ព្រះ ។

ជាការពិតណាស់ ខ្លឹមសារសំខាន់បំផុតនៃព្រះគម្ពីរនេះគឺការលើកទឹកចិត្ត ហើយជាបឋមគឺលើកទឹកចិត្តឱ្យបំពេញការងារសាងសង់ព្រះវិហារ ។ ខ្លឹមសារបន្ទាប់បន្សំទៀតត្រូវបានប្រើផងដែរនៅក្នុងព្រះគម្ពីរនេះដើម្បីបំពេញដល់ខ្លឹមសារសំខាន់បំផុតនោះ ។ ឧទាហរណ៍ ព្រះគម្ពីរនេះបាននិយាយសង្កត់ធ្ងន់អំពីការយាងមកនៃព្រះមែស៊ី និងការផ្តួលរំលំពួកដែលប្រឆាំងនឹងនគររបស់ទ្រង់ដោយព្រះអង្គទ្រង់ផ្ទាល់ ដើម្បីឱ្យរាជ្យរបស់ទ្រង់បានមកដល់នៅទីបញ្ចប់ និងពេញទីនៅលើលោកិយនេះ ។ ដូចនេះការនិយាយអំពីការសម្រេចទំនាយនៅក្នុងសាសន៍អ៊ីស្រាអែល គឺជាចំណុចចាប់ផ្តើមនៃនិយាយដល់ការសម្រេចជាទូទៅ និងចុងបញ្ចប់នៃលោកិយទាំងមូល ។

អ្នកកាត់ស្រាយមួយចំនួនបានរៀបចំសេចក្តីទំនាយទាំងប្រាំបីនៃវគ្គ ១:៧–៦:៨ ជាប្រាំបីដំណាក់កាលដូចតទៅ

ក. ព្រះអម្ចាស់ទ្រង់គ្រប់គ្រងព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រ (១:៧–១៧)

ខ. សាសន៍ដែលបំផ្លាញសាសន៍អ៊ីស្រាអែលនឹងត្រូវទទួលការបំផ្លាញវិញ (១:១៨–២០)
គ. សាសន៍អ៊ីស្រាអែលនឹងត្រូវបានស្អាងឡើងវិញទាំងស្រុង (ជំពូក ២)
ឃ. សាសន៍អ៊ីស្រាអែលនឹងត្រូវបានស្អាងឡើងវិញទាំងស្រុងជាសាសន៍នៃសង្ឃ (ជំពូក ៣)
ង. សាសន៍អ៊ីស្រាអែលនឹងត្រូវបានស្អាងឡើងវិញ ក្រោមការដឹកនាំនៃស្តេចដ៏ជាសង្ឃ (ជំពូក ៤)
ច. ប្រព័ន្ធនៃអំពើបាបទាំងមូលនឹងត្រូវបានបោសសំអាតពីទឹកដី (៥:៥–១១)
ឆ. ព្រះអម្ចាស់ទ្រង់គ្រប់គ្រងព្រឹត្តិការណ៍ទាំងអស់នៃប្រវត្តិសាស្ត្រ (៦:១–៨)

**គម្រោងសង្ខេប**

***ផ្នែកទី១ (ជំពូក ១–៨)***

**I. សេចក្តីផ្តើម (១:១–៦)**

ក. កាលបរិច្ឆេទ និងឈ្មោះអ្នកនិពន្ធ (១:១)
ខ. ការត្រាស់ហៅឱ្យប្រែចិត្ត (១:២–៦)

**II. សេចក្តីទំនាយទាំងប្រាំបីដែលទទួលបានក្នុងពេលតែមួយយប់ (១:៧–១៧)**

ក. មនុស្សជិះសេះ នៅកណ្តាលដើមយីថោ (១:៧–១៧)
ខ. ស្នែង៤ និងជាងដែក៤នាក់ (១:១៨–២១)
គ. មនុស្សកាន់ខ្សែរង្វាស់ (ជំពូក ២)
ឃ. សំលៀកបំពាក់ដ៏រុងរឿងសម្រាប់សម្តេចសង្ឃ (ជំពូក ៣)
ង. ជើងចង្កៀងមាស និងដើមអូលីវទាំងពីរដើម (ជំពូក ៤)
ច. ក្រាំងដែលកំពុងហោះ (៥:១–៤)
ឆ. ស្ត្រីដែលអង្គុយក្នុងរង្វាល់ (៥:៥–១១)
ជ. រថទាំង៤ (៦:១–៨)

**III. និមិត្តរូបនៃការបំពាក់មកុដឱ្យលោកយេសួរដ៏ជាសង្ឃ (៦:៩–១៥)**

**IV. បញ្ហានៃការអធិស្ឋានតម និងសេចក្តីសន្យាសម្រាប់អនាគត (ជំពូក ៧–៨)**

ក. សំនួរអំពី គណៈប្រតិភូមកពីស្រុកបេអ៊ែល (៧:១–៣)
ខ. កាស្ត្រីបន្ទោសរបស់ព្រះអម្ចាស់ (៧:៤–៧)
គ. ព្រះរាជបញ្ជាឱ្យប្រែចិត្ត (៧:៨–១៤)
ឃ. ការស្អាងរាស្ត្រអ៊ីស្រាអែលឡើងវិញតាមបំណងព្រះទ័យព្រះអម្ចាស់ (៨:១–១៧)
ង. សេចក្តីអំណរនៃនគរ និងតម្លៃនៃសាសន៍យូដា (៨:១៨–២៣)

***ផ្នែកទី២ (ជំពូក ៩–១៤)***

**V. ព្រះបន្ទូលដ៏ធ្ងន់ទាំងពីរ: អនាគតដ៏អស្ចារ្យនៅក្នុងសម័យនៃព្រះមែស៊ីយាងមក និងការឃើញជាក់ច្បាស់អំពីនគររបស់ព្រះអម្ចាស់ (ជំពូក ៩–១៤)**

ក. ព្រះបន្ទូលដ៏ធ្ងន់ទីមួយ: ការយាងមក និងការបដិសេធន៍ព្រះមែស៊ី (ជំពូក ៩–១១)
១. ការយាងមកនៃមហាក្សត្រដ៏ជាព្រះមែស៊ី (ជំពូក ៩–១០)
១.១. ការបំផ្លាញប្រទេសជិតខាង ប៉ុន្តែថែរក្សាដល់ក្រុងស៊ីយ៉ូន (៩:១–៨)
១.២. ការយាងមកនៃមហាក្សត្រនៃក្រុងស៊ីយ៉ូន (៩:៩–១០)
១.៣ ការប្រោសលោះ និងព្រះពរសម្រាប់រាស្ត្រនៃក្រុងស៊ីយ៉ូន (៩:១១–១០:១)
១.៤ អ្នកដឹកនាំត្រូវបានព្រមាន ហើយអ្នកដឹកនាំត្រូវបានលើកទឹកចិត្ត (១០:២–៤)

១.៥ ជ័យជម្នះ និងការស្តារសាសន៍អ៊ីស្រាអែល (១០:៥–១២)

២. ការបដិសេធន៍ព្រះមហាក្សត្រដ៏ជាអ្នកគង្វាល និងព្រះមែស៊ី (ជំពូក ១១)

២.១ បុព្វកថា (១១:១–៣)

២.២ ការបដិសេធន៍អ្នកគង្វាលល្អ (១១:៤–១៤)

២.៣ ការឡើងកាន់អំណាច និងការដួលរលំនៃអ្នកគង្វាលចោលម្សៀត (១១:១៥–១៧)

ខ. ភាពមិនស្មោះត្រង់នៃបណ្តាជន (២:១០–១៦)

១. ការលោមព័ទ្ធទីក្រុងយេរូសាឡិម (១២:១–៣)

២. ការប្រោសលោះដែលមកពីព្រះ (១២:៤–៩)

៣. សាសន៍អ៊ីស្រាអែលត្រូវបានប្រោះលោះទាំងស្រុងពីអំពើបាប (១២:១០–១៣:៩)

ក. ការយាងមកនៃព្រះមែស៊ី និងការមកដល់នគរព្រះ (ជំពូក ១៤)

១. ការលោមព័ទ្ធទីក្រុងយេរូសាឡិម (១៤:១–២)

២. ការយាងមកវិញនៃព្រះមែស៊ី និងការដែលទ្រង់នឹងធ្វើ (១៤:៣–៨)

៣. ការតាំងនគរនៃព្រះមែស៊ី (១៤:៩–១១)

៤. ការជំនុំជម្រះខ្មាំងសត្រូវនៃសាសន៍អ៊ីស្រាអែល (១៤:១២–១៥)

៥. ការថ្វាយបង្គំព្រះមហាក្សត្រដ៏បរិសុទ្ធនៅគ្រប់ទីកន្លែង (១៤:១៦–២១)

## ការត្រាស់ហៅឱ្យបែរមកព្រះអម្ចាស់វិញ

**១** ១នៅខែកត្តិក ក្នុងឆ្នាំទី២នៃរាជ្យដារីយុស[ក]នោះ ព្រះ
បន្ទូលនៃព្រះយេហូវ៉ាបានមកដល់ហោរាសាការី[ខ] ជាកូន
បេរេគា[គ] ដែលជាកូនអ៊ីដោ ថា[ឃ] ២ព្រះយេហូវ៉ាទ្រង់មាន
សេចក្ដីថ្នាំងថ្នាក់ជាខ្លាំង[ង]នឹងពួកឰយុកោឯងរាល់គ្នា
៣ហេតុនោះ ចូរឯងប្រាប់គេថា ព្រះយេហូវ៉ា ជាព្រះនៃពួក
ពលបរិវារ ទ្រង់មានបន្ទូលដូច្នេះ ចូរវិលមក[ច]ឯអញវិញ
នេះជា ព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ
នោះអញនឹងវិលមក[ឆ]ឯឯងរាល់គ្នាដែរ នេះក៏ជាព្រះបន្ទូល
របស់ព្រះយេហូវ៉ានៃពួកពលបរិវារ ៤កុំឱ្យប្រព្រឹត្តដូចជា
ពួកឰយុកោរបស់ឯងរាល់គ្នា[ជ] ដែលពួកហោរាពីដើម[ឈ]
បានស្រែកប្រាប់ថា ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់
មានបន្ទូលដូច្នេះ ចូរវិលត្រឡប់ពីផ្លូវអាក្រក់[ញ]និងពីការប្រ
ព្រឹត្តអាក្រក់របស់ឯងរាល់គ្នាមកវិញឥឡូវ[ដ] តែគេមិនបាន
ឮ ឬស្ដាប់តាមអញទេ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា[ឋ]
៥ឯពួកឰយុកោរបស់ឯងរាល់គ្នា ឥឡូវតើគេនៅឯណា
ហើយពួកហោរាតើគេនៅជាដរាបឬអី ៦តែចំណែកពាក្យ[ឌ]
និងបញ្ញត្តិច្បាប់ ដែលអញបានបង្គាប់ដល់ពួកហោរា ជាអ្នក
បំរើអញ តើមិនបានតាមពួកឰយុកោឯងរាល់គ្នាទាន់ទេឬ[ឍ]
រួចគេបែរជាទទួលថា ព្រះយេហូវ៉ានៃពួកពលបរិវារបាន
គិតធ្វើដល់យើង តាមផ្លូវប្រព្រឹត្ត និងតាមការដែលយើង
រាល់គ្នាបានធ្វើជាយ៉ាងណា[ណ] នោះទ្រង់ក៏បានធ្វើដល់យើង
យ៉ាងនោះឯង[ត]។

## បុរសដែលឈរនៅកណ្ដាលដើមយីថោ

៧នៅថ្ងៃ២៤ ខែទី១១ គឺខែមាឃ ក្នុងឆ្នាំទី២នៃរាជ្យ
ដារីយុស នោះព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ហោរា
សាការី ជាកូនបេរេគា ដែលជាកូនអ៊ីដោថា[ថ] ៨នៅវេលា
យប់ អញបានមើលទៅ ឃើញមានមនុស្សជិះសេះសម្បុរ
ក្រហម[ទ] ឈរនៅកណ្ដាលដើមយីថោ ដែលដុះនៅទីទំនាប
ឯខាងក្រោយអ្នកនោះ មានសេះជាច្រើន សម្បុរក្រហម

**១:១** ក អរ ៤:២៤ ៦:១៥ ខ អរ ៥:១ គ មថ ២៣:៣៥ លក ១១:៥១ ឃ ខ.៧ នហ ១២:៤ **១:២** ង ២រប ៣៦:១៦ **១:៣** ច យប ២២:២៣ ឆ មឡ ៣:៧ យក ៤:៨ **១:៤** ជ ២រប ៣៦:១៥ ឈ សក ៧:៧ ញ ២ពវ ១៧:១៣ ២រប ៧:១៤ ទដ ១០៦:៦ យរ ២៣:២២ ដ ២រប ២៤:១៩ ទដ ៧៨:៨ យរ ៦:១៧ ១៧:២៣ ឋ អគ ២០:១៨ ៣៣:៤ **១:៥** ឌ អស ៤៤:២៦
ឍ ចទ ២៨:២ ដយ ៩:១២ ហស ៥:៩ **១:៦** ណ យរ ១២:១៤–១៧ បទ ២:១៧
ត យរ ២៣:២០ ៣៩:១៦ ៤៤:១៧ **១:៧** ថ ខ.១ **១:៨** ទ វវ ៦:៤

**១:១** *ខែកត្តិក ក្នុងឆ្នាំទី ២* គឺនៅខែតុលា និងខែវិច្ឆិការ ។ នៅឆ្នាំ ៥២០ មុន គ.ស. លោកហាកាយក៏បានចាប់ផ្ដើមការងារជាហោរារបស់លោក នៅក្នុងឆ្នាំទីពីរនៃរាជស្ដេចដារីយុស នៅថ្ងៃទីមួយនៃខែទីប្រាំមួយ គឺត្រូវជាថ្ងៃទី ២៩ ខែសីហា ឆ្នាំ ៥២០ មុនគ.ស.(ហាក ១:១)។ *ព្រះបន្ទូលនៃព្រះយេហូវ៉ា* គឺជាពាក្យបច្ចេកទេសដែលត្រូវប្រើនៅក្នុងការថ្លែងទំនាយ (មើល ខ.៧ ៩:១ ១២:១ និង ៤:៨ ហស ១:១ និងការពន្យល់) ។ *ហោរា* គឺជាអ្នកដែលព្រះទ្រង់ត្រាសហៅឱ្យថ្លែងព្រះបន្ទូល ជំនួសទ្រង់ (មើលការពន្យល់ នក ៧:១–២)។ *អ៊ីដោ* មើល ខ.៧ អរ ៥:១ ៦:១៤ នហ ១២:៤,១៦ មើលសេចក្ដីផ្ដើមត្រង់ អ្នកនិពន្ធ និងការបង្រួម ។

**១:២** *មានសេចក្ដីថ្នាំងថ្នាក់ជាខ្លាំងនឹងពួកឰយុកោឯងរាល់គ្នា* ព្រះទ្រង់ក្រោធ ដោយសារពួកឰយុកោអ៊ីស្រាអែលនៅមុនសម័យនិទេស បានប្រព្រឹត្តរំលងសេចក្ដីសញ្ញា ដែលជាហេតុនាំឱ្យក្រុងយេរូសាឡិម និងព្រះវិហារត្រូវទទួលរងការបំផ្លាញនៅឆ្នាំ ៥៨៦ មុន គ.ស. ហើយបន្ទាប់ពីនោះចក្រភពបាប៊ីឡូនបាននិរទេសពួកគេ (២រប ៣៦:១៥–២១) ។

**១:៣** *ចូរវិលមកឯអញវិញ . . . នោះអញនឹងវិលមកឯឯងរាល់គ្នាដែរ* សូមផ្ទៀបនឹង ៧:១៣ ៨:៣ មឡ ៣:៧ ។ ប្រសិនបើបណ្ដាជននៅសម័យលោកសាការីព្រមប្រែចិត្តឈប់ប្រព្រឹត្តតាមពួកឰយុកោរបស់ពួកគេ (ខ.៤) ព្រះអម្ចាស់ទ្រង់នឹងត្រឡប់មករកពួកគេវិញ ដោយប្រទាននូវព្រះពរ ជាជាងដាក់បណ្ដាសាពួកគេ (ខ.១៦ យរ ១៨:៧–១០ និងការពន្យល់) ។

**១:៤** *ពួកហោរាពីដើម* មានដូចជាលោកអេសាយ (អស ៤៥:២២ និងការពន្យល់) លោកយេរេមា (យរ ១៨:១១ និងការពន្យល់) និងលោកអេសេគាល (មើល អគ ៣៣:១១ និងការពន្យល់) ។ មើល ៧:៧,១២ យរ ២៥:៤–៥ ៣៥:១៥ ។

**១:៥** *តើគេនៅជាដរាបឬអី* ពួកគេមិននៅជាដរាបទេ ប៉ុន្តែ ព្រះបន្ទូលដែលពួកគេបានថ្លែងនឹងនៅជាដរាបរហូតដល់ពេលសម្រេច (សូមមើល ខ.៦) ។

**១:៦** *ពាក្យ . . . មិនបានតាមពួកឰយុកោឯងរាល់គ្នាទាន់ទេឬ* សូមផ្ទៀបនឹង អស ៤០:៦–៨ ៥៥:១០–១១ ។ ចំពោះពាក្យ "តាមទាន់" សូមមើល ចទ ២៨:២,១៥,៤៥ ។ *ពួកហោរា ជាអ្នកបំរើអញ* មើល ២ពវ ៩:៧ ១៧:១៣, ២៣ ២១:១០ ២៤:២ អរ ៩:១១ យរ ៧:២៥ និងការពន្យល់, ២៥:៤ អគ ៣៨:១៧ ដយ ៩:៦,១០ អម ៣:៧ ។ *គេបែរជាទទួល* គេជឿថាត្រង់ចំណុចនេះសំដៅទៅលើការដែលកើតឡើង ចំពោះពួកឰយុកោមុនសម័យនិរទេស និងកូនចៅរបស់ពួកគេនៅក្នុងសម័យនិទេស និងសម័យបន្ទាប់ (សូមផ្ទៀបនឹង អរ ៩:១–១០:១៧ ដយ ៩:៣–១៩) ។

**១:៧–៦:៨** មើលសេចក្ដីផ្ដើមត្រង់ ទម្រង់អក្សរសាស្ត្រ និងខ្លឹមសារ ។

**១:៧–១៧** សេចក្ដីទំនាយទីមួយ ។ ទោះបីជារាស្ត្រដែលព្រះបានតាំងសញ្ញាជាមួយមានបញ្ហា នៅពេលដែលសាសន៍គៀបសង្កត់កំពុងសម្រាកស្រួលក៏ដោយ ក៏ព្រះទ្រង់នៅតែប្រច័ណ្ឌនឹងរាស្ត្រទ្រង់ (មើលការពន្យល់ នក ២០:៥) ហើយទ្រង់ស្រោចស្រង់បណ្ដាក្រុងរបស់ពួកគេ និងព្រះវិហារឡើងវិញ ។ សេចក្ដីទំនាយទីមួយមានការឆ្លុះបញ្ចាំងនៅក្នុងសេចក្ដីទំនាយទីប្រាំបី និងសេចក្ដីទំនាយចុងក្រោយ (៦:១–៨) ។

**១:៧** *ថ្ងៃទី ២៤ . . . គឺខែមាឃ* គឺត្រូវជាថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ៥១៩ មុន គ.ស. ប្រហែលជាបីខែបន្ទាប់ពីថ្ងៃខែនៅក្នុង ខ.១ ។

**១:៨** *នៅវេលាយប់* លោកសាការីបានទទួលសេចក្ដីទំនាយគ្រប់ទាំងប្រាំបីនៅក្នុងតែមួយយប់នោះ(១:៧–៦:៨)។ *មើលទៅ ឃើញ* គឺមិនមែនឃើញនៅក្នុងការយល់សប្ដិនោះឡើយ(មើល ៤:១ សភ ២៩:១៨ អស ១:១ អប ១ និងការពន្យល់)។ លោកសាការីបានមើលឃើញនៅពេលដែលលោកនៅដឹងខ្លួនទាំងស្រុងនៅឡើយ ។ *មនុស្សជិះសេះ* គឺជាទេវតានៃព្រះយេហូវ៉ា (ខ.១១)។ ទេវតាអង្គនេះមិនមែនជាទេវតាដែលមាននិយាយនៅក្នុង ខ.៩, ១៣–១៤,១៩ ២:៣ ៤:១,៤–៥ ៥:៥,១០ ៦:៤–៥ ។

ពព្លាក់ ហើយស[ធ] ៩នោះខ្ញុំទូលសួរថា ឱព្រះអម្ចាស់នៃ
ទូលបង្គំអើយ ទាំងអស់នេះជាអ្វី រួចទេវតា[ន]ដែលពោល
មកខ្ញុំ ក៏ប្រាប់ថា អញនឹងបង្ហាញឱ្យឯងដឹងថាទាំងអស់
នេះជាអ្វី[ប] ១០រួចមនុស្សដែលឈរនៅកណ្ដាលដើមយីថោ
ក៏ឆ្លើយឡើងថា ទាំងអស់នេះជាពួកដែលព្រះយេហូវ៉ាបាន
ចាត់ឱ្យដើរចុះឡើងនៅផែនដី[ផ] ១១ពួកនោះក៏តបដល់
ទេវតានៃព្រះយេហូវ៉ា[ព] ដែលឈរកណ្ដាលដើមយីថោថា
យើងខ្ញុំរាល់គ្នាបានដើរចុះឡើងនៅផែនដី ហើយក៏ឃើញ
ថា ផែនដីទាំងមូលនៅស្ងប់ស្ងាត់ ហើយស្រាកស្រាន្ត[ភ] ។
១២បន្ទាប់នោះ ទេវតានៃព្រះយេហូវ៉ាក៏ពោលឡើងថា
ឱព្រះយេហូវ៉ានៃពួកពលបរិវារអើយ តើដល់កាលណា[ម]
បានទ្រង់អាណិតមេត្តា[យ]ដល់ក្រុងយេរូសាឡិម និងទីក្រុង
ស្រុកយូដាទាំងប៉ុន្មាន[រ] ដែលទ្រង់បានគ្នាន់ក្នាញ់នឹងគេអស់
៧០[ល]ឆ្នាំហើយនេះ ១៣ព្រះយេហូវ៉ាទ្រង់ឆ្លើយ[វ]ដោយពាក្យ
ល្អ[ស] គឺជាពាក្យកំសាន្ត ដល់ទេវតាដែលពោលមកខ្ញុំនោះ[ហ]
១៤ដូច្នេះ ទេវតាដែលពោលនឹងខ្ញុំ ក៏ប្រាប់ខ្ញុំថា ចូរបន្លឺ
ឡើងថា ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូល
ដូច្នេះ អញមានសេចក្ដីប្រចណ្ឌជាខ្លាំង[ឡ] ចំពោះក្រុងយេរូ
សាឡិមនិងភ្នំស៊ីយ៉ូន ១៥ក៏មានសេចក្ដីថ្នាំងថ្នាក់ជាខ្លាំង
ចំពោះសាសន៍ទាំងប៉ុន្មានដែលនៅដោយស្ងប់រំងាប់ដែរ[អ]
ដ្បិតពីដើមអញបានសេចក្ដីអាក់អន់តែបន្តិចទេ[ក] តែគេ
បានបង្កើនការអាក្រក់នោះជាច្រើនឡើង[ខ] ១៦ហេតុនោះ
ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញបានវិលមក[គ]ឯក្រុង
យេរូសាឡិម ទាំងមានសេចក្ដីអាណិតមេត្តា វិហាររបស់
អញនឹងបានសង់ឡើងវិញនៅទីនេះ ហើយនឹងមានខ្សែ
វាស់[ឃ]សន្ធឹងនៅលើក្រុងយេរូសាឡិម នេះជាព្រះបន្ទូល
របស់ព្រះយេហូវ៉ានៃពួកពលបរិវារ[ង] ១៧ចូរបន្លឺឡើងម្ដង
ទៀតថា ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូល
ដូច្នេះ ទីក្រុងទាំងប៉ុន្មានរបស់អញនឹងមានសេចក្ដីចំរើន
ហូរហៀរឡើងទៀតហើយ ព្រះយេហូវ៉ានឹងកំសាន្តទុក[ច]
ភ្នំស៊ីយ៉ូន ព្រមទាំងរើសតាំង[ឆ]ក្រុងយេរូសាឡិមជាថ្មីផង[ជ] ។

### ស្នែង៤ និងពួកជាងដែក

១៨នោះខ្ញុំក៏ងើបភ្នែកឡើង មើលទៅឃើញស្នែង៤
១៩នោះខ្ញុំសួរទេវតា ដែលពោលនឹងខ្ញុំថា នេះតើជាអ្វី
នោះទេវតាប្រាប់ខ្ញុំថា នេះគឺជាស្នែងទាំងប៉ុន្មាន[ឈ]ដែល
បាន កំចាត់កំចាយពួកយូដា ពួកអ៊ីស្រាអែល និងពួកក្រុង
យេរូសាឡិម ២០រួចព្រះយេហូវ៉ាទ្រង់ឱ្យខ្ញុំឃើញជាងដែក៤
នាក់ ២១ខ្ញុំក៏សួរថា អ្នកទាំងនេះមកធ្វើអ្វី ទេវតាប្រាប់ថា គឺ

**១:៨** ធ សក ៦:២–៧ **១:៩** ន សក ៤:១,៤–៥ ៥:៥ ប ដយ ៧:១៦ **១:១០** ផ សក ៦:៥–៨ **១:១១** ព លប ១៦:៧ ភ អស ១៤:៧ **១:១២** ម ទដ ៦:៣ យ ទដ ៤០:១១ រ យរ ៤០:៥ ល ២របា ៣៦:២១ ដយ ៩:២ **១:១៣** វ អស ៣៥:៤ ស យប ១៥:១១ ហ សក ៤:១ **១:១៤** ឡ អស ២៦:១១ យអ ២:១៨ **១:១៥** អ យរ ៤៨:១១ ក ២រប ២៨:៩ ខ ទដ ៦៩:២៦ ១២៣:៣–៤ អម ១:១១ **១:១៦** គ សក ៨:៣ ឃ យប ៣៨:៥ សក ២:១–២ ង អរ ១:១ **១:១៧** ច អស ៤០:១ ឆ អស ១៤:១ជ អរ ៩:៩ ទដ ៥១:១៨ អស ៥៤:៨–១០ ៦១:៤ **១:១៩** ឈ អម ៦:១៣

**១:៩** *ទេវតា* មើលការពន្យល់ខ្ញុំ ខ.៨ ។

**១:១១** *ទេវតានៃព្រះយេហូវ៉ា* មើល ៣:១ និងការពន្យល់ លប ១៦:៧ ។ *នៅស្ងប់ស្ងាត់* ធៀបនឹង ៦:៨ ។ នៅពេលដែលចក្រភពពើស៊ីទាំងមូលមានសភាពស្ងប់ស្ងាត់នឹងស្រាកស្រាន្តនៅពេលនោះ (ខ.១៥) ពួកយូដានៅស្រុកយូដាត្រូវទទួលរងការគាបសង្កត់ ហើយត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាសន៍ដទៃ(ខ.១២) ។

**១:១២** *អាណិត* គឺសេចក្ដីអាណិតមេត្តា(ខ.១៦)។ *៧០ ឆ្នាំ* មើល ៧:៥ អរ ១:១ យរ ២៥:១១–១២ និងការពន្យល់ ។

**១:១៣** *ពាក្យកំសាន្ត* គឺពាក្យនៅក្នុង ខ.១៤–១៧ ។

**១:១៤** *សេចក្ដីប្រចណ្ឌ* មើល ៨:២ ។ ព្រះអម្ចាស់ទ្រង់បង្ហាញនូវសេចក្ដីស្រឡាញ់ដល់ពួកយូដា តាមរយៈការប្រើពាក្យនេះ (មើលការពន្យល់ នក ២០:៥ ធៀបនឹង យក ៤:៤)។ ចំណុចសំខាន់នៃខនេះគឺ ព្រះអម្ចាស់ទ្រង់ដាក់ទោសពួកយូដា ដោយសារការរំលងរបស់ពួកគេ (ខ.១៥ ចទ ៣២:៣៥,៤១ យរ ៥០:១៥ ៥១:៦,១១) ។

**១:១៥** *សាសន៍ទាំងប៉ុន្មានដែលនៅដោយស្ងប់រំងាប់* ការស្ងប់រំងាប់នេះនឹងត្រូវដកយកចេញទៅ (ហាក ២:៦–៧ និងការពន្យល់) ។ *បង្កើនការអាក្រក់* ព្រះអម្ចាស់ទ្រង់មានសេចក្ដីក្រោធនឹងពួកអ៊ីស្រាអែល ហើយទ្រង់បានប្រើសាសន៍អាសស៊ើរ(អស ១០:៥ និងការពន្យល់) និងសាសន៍បាប៊ីឡូន (អស ៤៧:៦ យរ ២៥:៩ និងការពន្យល់) ឱ្យកាត់ទោសពួកគេ ប៉ុន្តែពួកសាសន៍ទាំងនេះមានចិត្តប៉ងហួសពីការនេះ គឺបានព្យាយាមលប់បំបាត់ជាតិសាសន៍នេះតែម្ដង ។

**១:១៦** *អញបានវិលមក* មើលការពន្យល់ ខ.៣ ។ *សេចក្ដីអាណិតមេត្តា* មើល ខ.១២ និងការពន្យល់ ។ *វិហាររបស់អញនឹងបានសង់ឡើងវិញ* មើល អរ ៦:១៤–១៦ ហាក ១:៨ មើលសេចក្ដីផ្ដើមព្រះគម្ពីរហាកាយត្រង់ប្រវត្តិ ។ *ខ្សែវាស់សន្ធឹង* គឺតំណាងឱ្យការស្អាងឡើងវិញ (យរ ៣១:៣៨–៤០ និងការពន្យល់ ៣១:៣៩) ។

**១:១៧** *កំសាន្ត* មើល ខ.១៣ និងការពន្យល់ ។ *រើសតាំងក្រុងយេរូសាឡិម* ២:១២ ៣:២ ។

**១:១៨–២១** វគ្គនៃបទគម្ពីរនេះគឺជាសេចក្ដីទំនាយទីពីរ ។ សាសន៍ដែលបំផ្លាញសាសន៍អ៊ីស្រាអែល (ខ.១៩) និងត្រូវទទួលរងការបំផ្លាញវិញ ដោយសាសន៍ដទៃៗទៀត ។

**១:១៨** *ស្នែង* គេជឿថា ស្នែងនោះធ្វើអំពីលោហៈ លង្ហិន ឬដែក ជាទូទៅតំណាងឱ្យកម្លាំង (ទដ ១៨:២) ឬអំណាចនៃប្រទេសមួយ ឬអំណាចស្ដេច (ទដ ៨៩:១៧ ដយ ៧:៧–៨ ៨:២០–២១ វវ ១៧:១២) ហើយនៅក្នុងព្រះគម្ពីរនេះជាទូទៅគឺសំដៅទៅលើអំណាចនៃប្រទេស(ខ.២១) ។ *៤* តាមន័យត្រង់គេជឿថា លេខនេះគឺសំដៅទៅលើចក្រភពអាសស៊ើរ អេស៊ីព្ទ បាប៊ីឡូន និងពើស៊ី ។

**១:២០** *ជាងដែក* មើល ១ពវ ២២:១១ ។ *៤* បើតាមន័យត្រង់ ចំនួននេះប្រហែលជាសំដៅទៅលើចក្រភពទាំងបួនដូចជា អេស៊ីព្ទ បាប៊ីឡូន ពើស៊ី និងក្រិច ។ ខ.២១ បង្ហាញ ច្បាស់ថា សត្រូវរបស់សាសន៍អ៊ីស្រាអែលទាំងប៉ុន្មាននឹងត្រូវទទួលបរាជ័យ នៅទីបំផុត ។

**១:២១** *បំភ័យគេ* គឺផ្ទុយនឹងសេចក្ដីក្នុង ខ.១១ ("ស្ងប់ស្ងាត់ ហើយស្រាក

ស្នែងទាំងនេះដែលកំចាត់កំចាយពួកយូដា ដល់ម្ល៉េះបាន
ជាឥតមានអ្នកណាងើបក្បាលឡើងទៀត តែពួកនេះបាន
មក ដើម្បីបំភ័យគេ ហើយវាយទំលាក់ស្នែង[ញ]របស់សាសន៍
ដទៃ ដែលបានលើកស្នែងនេះទាស់នឹងស្រុកយូដា ដើម្បី
នឹងកំចាត់កំចាយគេទៅ[ដ] ។

## មនុស្សម្នាក់កាន់ខ្សែរង្វាស់

**២** ១ខ្ញុំក៏ងើបភ្នែកឡើងក្រឡេកមើលទៅ ឃើញមនុស្ស
ដែលកាន់ខ្សែរង្វាស់នៅដៃ ២ខ្ញុំបានសួរថា តើអញ្ជើញ
ទៅឯណាហ្នឹង អ្នកនោះឆ្លើយមកខ្ញុំថា ទៅវាស់ក្រុងយេ–
រូសាឡិម ដើម្បីឱ្យដឹងទទឹងនឹងបណ្តោយនៃទីក្រុងជាប៉ុន្មាន[ក]
៣នោះឃើញទេវតាដែលពោលនឹងខ្ញុំក៏ចេញទៅ ហើយ
ទេវតា១ទៀតបានមកជួបគ្នា ៤ដោយប្រាប់ថា ចូររត់ទៅ
ប្រាប់មនុស្សកំឡោះនោះថា ក្រុងយេរូសាឡិមនឹងមាន
មនុស្សអាស្រ័យនៅ ដូចជានៅអស់ទាំងភូមិដែលឥតមាន
កំផែង[ខ] ដោយព្រោះមានមនុស្សនិងសត្វយ៉ាងសន្ធឹក[គ]នៅ
ក្នុងនោះ[ឃ] ៥ដ្បិតអញនឹងបានជាកំផែង[ង]ភ្លើង[ច]ដល់ទីក្រុង
នៅព័ទ្ធជុំវិញ ហើយនិងជាសិរីល្អ[ឆ]នៅកណ្តាលនោះ
ដែរ[ជ,ឈ] នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
៦ហើយៗ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូររត់ចេញ
ពីស្រុកខាងជើងមក ដ្បិតអញបានបែងចែក[ញ]ឯងរាល់គ្នា
ទៅ ដូចជាខ្យល់ទាំង៤នៅលើអាកាស[ដ] នេះជាព្រះបន្ទូល
នៃព្រះយេហូវ៉ា[ឋ] ៧ហើយពួកស៊ីយ៉ូន ដែលនៅជាមួយ
និងកូនស្រីក្រុងបាប៊ីឡូនអើយ[ឌ] ចូរដោះខ្លួន[ឍ]ឱ្យរួចចុះ ៨ដ្បិត
ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះថា
ក្រោយសិរីល្អ នោះទ្រង់បានចាត់អញទៅឯសាសន៍ដទៃ
ដែលប្លន់ឯងរាល់គ្នា ពីព្រោះអ្នកណាដែលពាល់ឯងរាល់
គ្នា នោះគឺជាពាល់ដល់ប្រស្រីព្រះនេត្រនៃទ្រង់ហើយ[ណ]
៩ដ្បិតមើល អញនឹងងាដៃពីលើគេ ហើយគេនឹងត្រឡប់ជា
របឹបដល់ពួកអ្នកដែលបំរើគេវិញ[ត] នោះឯងរាល់គ្នានឹង
ដឹងថា ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានចាត់អញ
មក[ថ] ១០ឱកូនស្រីស៊ីយ៉ូនអើយ[ទ] ចូរច្រៀង[ធ]ហើយមានចិត្ត
អរសប្បាយឡើង ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា[ន]
មើល អញមកហើយ[ប]អញនឹងនៅកណ្តាលឯងរាល់គ្នា[ផ]
១១នៅគ្រានោះសាសន៍ជាច្រើននឹងចូលពួកខាងព្រះយេហូ–
វ៉ា គេនឹងបានជារាស្ត្ររបស់អញ[ព] ហើយអញនឹងនៅ
កណ្តាលឯងរាល់គ្នា នោះឯងនឹងដឹងថា ព្រះយេហូវ៉ានៃ
ពួកពលបរិវារ ទ្រង់បានចាត់ឱ្យអញមកឯឯង[ភ] ១២ព្រះ
យេហូវ៉ាទ្រង់នឹងបាន[ម]ស្រុកយូដា[យ] ទុកជាចំណែកមរដក
នៃទ្រង់ នៅក្នុងស្រុកបរិសុទ្ធ ហើយទ្រង់នឹងរើសយក[រ]ក្រុង

**១:២១** ញ ១ពវ ២២:១១ ទដ ៧៥:៤ ដ ទដ ៧៥:១០ អស ៥៤:១៦–១៧ សក ១២:៩
**២:២** ក អគ ៤០:៣ សក ១:១៦ វវ ២១:១៥
**២:៤** ខ អគ ៣៨:១១ គ អស ៤៩:២០ យរ ៣០:១៩ ៣៣:២២ ឃ សក ១៤:១១
**២:៥** ង អស ២៦:១ អគ ៤២:២០ ច អស ១០:១៧ ឆ ទដ ៨៥:៩ អស ១១:១០ ២៤:២៣ វវ ២១:២៣ ជ ទដ ១២៥:២ ឈ ទដ ៤៦:៥ អគ ៣៨:១៤
**២:៦** ញ ទដ ៤៤:១១ ដ អគ ១៧:២១ ៣៧:៩ ឋ មថ ២៤:៣១ មក ១៣:២៧
**២:៧** ឌ អស ៤៨:២០ យរ ៣:១៨ ឍ អស ៤២:៧
**២:៨** ណ ចទ ៣២:១០ **២:៩** ត អស ១៤:២ យរ ១២:១៤ ហព ២:៨ ថ អស ៤៨:១៦ សក ៤:៩ ៦:១៥ **២:១០** ទ អស ២៣:១២ ធ សផ ៣:១៤ ន វវ ២១:៣ ប សក ៩:៩ ផ នក ២៥:៨ លវ ២៦:១២ ជន ២៣:២១ សក ៨:៣ **២:១១** ព យរ ២៤:៧ មីក ៤:២ សក ៨:៨,២០–២២ ភ សក ៤:៩ ៦:១៥ **២:១២** ម នក ៣៤:៩ ទដ ៣៣:១២ យរ ១០:១៦ យ យរ ៤០:៥ រ ចទ ១២:៥ អស ១៤:១

ស្រាន្ត”) និង ខ.១៥ (“ស្ងប់រំងាប់”) ។

**២:១–១៣** វគ្គនៃបទគម្ពីរនេះគឺជាសេចក្តីទំនាយទី៣ ។ ព្រះទ្រង់នឹងស្អាង ហើយប្រទានពរទាំងស្រុងឡើងវិញ ដល់រាស្ត្រនៃសេចក្តីសញ្ញា ទៅដល់ព្រះវិហារ និងទីក្រុងយេរូសាឡិម ។

**២:១** *ខ្សែរង្វាស់* មើលការពន្យល់ ១:១៦ ។

**២:៤** *មនុស្សកំឡោះ* គឺលោកសាការី ។ *ឥតមានកំផែង* ប្រជាជនដែលរស់មករស់នៅក្នុងទីក្រុង និងមានចំនួនកើនឡើងរហូតដល់ពេលមួយដែលគេមើលទៅទីក្រុងហាក់ដូចជាគ្មានជញ្ជាំងអញ្ចឹងដែរ (មើល ១០:៨,១០ និងការពន្យល់ អស ៤៩:១៩–២០) ។

**២:៥** *កំផែងភ្លើង* គឺតំណាងឱ្យការការពាររបស់ព្រះអម្ចាស់ (មើល ៩:៨ និង នក ១៣:១២ អស ៤:៥–៦ និងការពន្យល់) ។ *សិរីល្អ* មើល នក ៤០:៣៤ ហាក ២:៩ និងការពន្យល់ ។

**២:៦** *ស្រុកខាងជើង* គឺស្រុកបាប៊ីឡូន (ខ.៧) ឈ្លានពានចូលស្រុកយូដាពីខាងជើង (មើល អស ៤១:២៥ និងការពន្យល់, យរ ១:១៤ ៤:៦ ៦:១,២២ ១០:២២) ។ *ខ្យល់ទាំង៤* គឺមានន័យថា មកពីគ្រប់ទិស ។ សាសន៍យូដាដែលត្រូវនិរទេស នឹងត្រឡប់មកវិញពីខាងជើង ត្បូង លិច និងកើត (មើល អស ៤៣:៥–៦ ៤៩:១២) ។

**២:៧** *ពួកស៊ីយ៉ូន* គឺពួកអ៊ីស្រាអែលដែលត្រូវនិរទេសទៅតំបន់នាៗនៃចក្រភពបាប៊ីឡូន ។ *កូនស្រីក្រុងបាប៊ីឡូន* គេប្រើពាក្យនេះជំនួសឱ្យក្រុងបាប៊ីឡូនក៏បាន (២ពវ ១៩:២១) ។

**២:៨** *អញ* មើល ខ.៩ ។ ពាក្យនេះទំនងជាសំដៅទៅលើទេវតានៃព្រះយេហូវ៉ា (មើល ១:៨ និងការពន្យល់) ។ *ប្រស្រីព្រះនេត្រ* មើលការពន្យល់ ចទ ៣២:១០ ។

**២:១០** មើល ៩:៩ និងការពន្យល់ ។ *កូនស្រីក្រុងស៊ីយ៉ូន* គេប្រើពាក្យនេះជំនួសឱ្យក្រុងយេរូសាឡិមក៏បាន (ខ.៧ និងការពន្យល់) ។ *អញនឹងនៅកណ្តាលឯងរាល់គ្នា* មើល ខ.១១ ៨:៣ លវ ២៦:១១–១២ អគ ៣៧:២៧ យរ ១:១៤ ២កថ ៦:១៦ វវ ២១:៣ ។

**២:១១** *នៅគ្រានោះ* គឺនៅថ្ងៃនៃព្រះយេហូវ៉ា (៣:១០ ១២:៣ អស ២:១១, ១៧,២០ យអ ១:១៥ អម ៥:១៨ និងការពន្យល់) ។ *សាសន៍ជាច្រើន* គឺជាការសម្រេចសេចក្តីសន្យានឹងលោកអ័ប្រាហាំ (មើល លប ១២:៣ ផ្ទៀបនឹង ៨:២០–២៣ ១៤:១៦ លប ១៨:១៨ ២២:១៨ អស ២:២–៤ និងការពន្យល់ ១៩:២៤–២៥) ។

**២:១២** *ស្រុកបរិសុទ្ធ* មើល ទដ ៧៨:៥៤ ។ ទឹកដីនោះត្រូវហៅថាបរិសុទ្ធ ពីព្រោះព្រះដ៏ជាមហាក្សត្រដ៏បរិសុទ្ធទ្រង់តាំងបល្ល័ង្កទ្រង់នៅលើផែនដី និងទីបរិសុទ្ធនៃទ្រង់នៅកន្លែងនោះ គឺទ្រង់គង់នៅកណ្តាលចំណោមរាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ (មើលការពន្យល់ នក ៣:៥) ។ *រើសយកក្រុង*

យេរូសាឡិមទៀត ១៣មនុស្សទាំងឡាយអើយ ចូរនៅ
ស្ងៀម[ល]ចំពោះព្រះយេហូវ៉ាចុះ ដ្បិតទ្រង់ បានតើនឡើង
ចេញពីទីលំនៅបរិសុទ្ធរបស់ទ្រង់ហើយ[វ] ។

## សម្អាតសំលៀកបំពាក់ឱ្យសម្តេចសង្ឃ

**៣** ១រួចមកទេវតានោះ ក៏បង្ហាញឱ្យខ្ញុំឃើញយេសួរ[ក] ជា
សំដេចសង្ឃ ឈរនៅចំពោះទេវតានៃព្រះយេហូវ៉ា មាន
អារក្សសាតាំង[ខ]ឈរនៅខាងស្តាំលោក ដើម្បីតវ៉ានឹងលោក
២នោះព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងសាតាំងថា ម្នាល
សាតាំង ព្រះយេហូវ៉ាទ្រង់បន្ទោសឯង[គ] អើ ព្រះយេហូវ៉ា
ដែលបានរើស[ឃ]ក្រុងយេរូសាឡិម ទ្រង់ស្តីបន្ទោសដល់ឯង
នេះតើមិនមែនជាកន្ទុយឱស[ង] ដែលបានកញ្ឆក់យកចេញពី
ភ្លើងទេឬ[ច] ៣រីឯយេសួរ លោកកំពុងឈរនៅចំពោះទេវតា
ទាំងស្លៀកពាក់កខ្វក់ ៤ទ្រង់ក៏បង្គាប់ដល់ពួកដែលឈរនៅ
ចំពោះទ្រង់ថា ចូរដោះសំលៀកបំពាក់កខ្វក់ពីលោកចេញ
រួចទ្រង់មានបន្ទូលដល់លោកថា មើល អញបានលើក
ចោលអំពើទុច្ចរិតពីឯងចេញហើយ[ឆ] អញនឹងប្រដាប់
ខ្លួនឯង ដោយសំលៀកបំពាក់[ជ]ដ៏រុងរឿងវិញ ៥នោះខ្ញុំក៏ទូល
ថា សូមឱ្យគេបំពាក់ក្បាំងស្អាត[ឈ] នៅលើក្បាលលោកផង
ដូច្នេះ គេក៏បំពាក់ក្បាំងស្អាត នៅលើក្បាលលោក ព្រម
ទាំងប្រដាប់កាយឱ្យផង មានទាំងទេវតានៃព្រះយេហូវ៉ា
ឈរនៅទីនោះដែរ ។

៦ឯទេវតានៃព្រះយេហូវ៉ា ក៏ធ្វើបន្ទាល់យ៉ាងមុតមាំនឹង
យេសួរថា ៧ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មាន
បន្ទូលដូច្នេះ បើឯងនឹងដើរតាមផ្លូវរបស់អញ ហើយរក្សា
បញ្ញើរបស់អញ[ញ] នោះឯងនឹងជាអ្នកគ្រប់គ្រងលើវិហារ[ដ]
របស់អញ ព្រមទាំងរក្សា[ឋ]ទីលានរបស់អញផង ហើយអញ
នឹងឱ្យឯងបានចូលក្នុងពួកដែលនៅទីនេះដែរ[ឌ] ៨ឱយេសួរ
ជាសំដេចសង្ឃ[ឍ]អើយ ចូរស្តាប់ឥឡូវ ព្រមទាំងពួកអ្នក
ដែលអង្គុយជាមួយនឹងឯងផង ព្រោះគេជាពួកដែលជាទី
អស្ចារ្យ[ណ] ដ្បិតមើល អញនឹងឱ្យអ្នកបំរើរបស់អញឈ្មោះ
"លំពង់" ចេញមក[ត] ៩ចូរមើលថ្ម ដែលអញបានដាក់នៅមុខ
យេសួរ[ថ]ចុះ នៅថ្មតែមួយនោះមានភ្នែក៧[ទ,ធ] ព្រះយេហូវ៉ា
នៃពួកពលបរិវារ ទ្រង់មានបន្ទូលថា មើល អញនឹងចារិក
ចំឡាក់ ដែលត្រូវឆ្លាក់នៅថ្មនោះ ហើយនិងដកយកសេចក្តី

**២:១៣** ល នក ១៤:១៤ អស ៤១:១ វ ចទ ២៦:១៥ **៣:១** ក អរ ២:២ សក ៦:១១ ខ ២សយ ២៤:១ ២របា ១៨:២១ ទដ ១០៩:៦ មថ ៤:១០ **៣:២** គ ពច ១:៩ ឃ អស ១៤:១ ង អស ៧:៤ ច ពច ១:២៣ **៣:៤** ឆ ២សយ ១២:១៣ អគ ៣៦:២៥ មីក ៧:១៨ ជ លប ៤១:៤២ ទដ ១៣២:៩ អស ៥២:១ វវ ១៩:៨ **៣:៥** ឈ នក ២៩:៦ **៣:៧** ញ លវ ៨:៣៥ ដ ចទ ១៧:៨–១១ អគ ៤៤:១៥–១៦ ឋ ២របា ២៣:៦ ឌ យរ ១៥:១៩ សក ៦:១៥ **៣:៨** ឍ ហាក ១:១ ណ ចទ ២៨:៤៦ អគ ១២:១១ ត អស ៤:២ ៤៩:៣ អគ ១៧:២២ **៣:៩** ថ អរ ២:២ ទ ២របា ១៦:៩ ធ អស ២៨:១៦

*យេរូសាឡិម* មើល ១:១៧ ៣:២ ។

**២:១៣** *នៅស្ងៀមចំពោះព្រះយេហូវ៉ា* មើល ហាព ២:២០ និងការពន្យល់ ។ *ទ្រង់បានតើនឡើង* គឺដើម្បីជំនុំជម្រះ (ធៀបនឹង ២.៩) ។

**៣:១–១០** វគ្គនៃបទគម្ពីរនេះគឺជាសេចក្តីទំនាយទីបួន ។ សាសន៍អ៊ីស្រាអែលនឹងត្រូវបានសម្អាតឡើយវិញ ហើយនិងត្រូវស្អាងឡើងវិញជាសាសន៍ដ៏ជាសង្ឃហ្លួង(មើល នក ១៩:៦ និងការពន្យល់) ។

**៣:១** *យេសួរ* មើល អរ ២:២ និងការពន្យល់, នហ ៧:៧ និងការពន្យល់ ហាក ១:១) ។ នៅក្នុងបទគម្ពីរនេះលោកយេសួរគឺជាតំណាងរបស់សាសន៍អ៊ីស្រាអែលដែលមានបាប(ខ.៨–៩)។ ចំពោះឈ្មោះ "យេសួរ" គឺជាភាសាអើរ៉ាម ហើយជាភាសាក្រិកគឺ "យេស៊ូវ"ដែលមានន័យថា "ព្រះអម្ចាស់ទ្រង់សង្គ្រោះ"(មើល មថ ១:២១)។ *ឈរនៅចំពោះ* មានន័យថាបម្រើនៅចំពោះ ក្នុងឋានៈជាសង្ឃ(ចទ ១០:៨ ២របា ២៩:១១ អគ ៤៤:១៥)។ *ទេវតានៃព្រះយេហូវ៉ា* មើល ១:១១ និងការពន្យល់ លប ១៦:៧ ។ *សាតាំង* យប ១:៦–១២ និងការពន្យល់ ១:៦ ២:១–៧ វវ ១២:១០ និងការពន្យល់ ។ *ខាងស្តាំ* មើល ទដ ១០៩:៦ ។

**៣:២** *បន្ទោស . . . ស្តីបន្ទោស* ក្នុងខនេះ ពាក្យបន្ទោសត្រូវប្រើពីរដង ដើម្បីធ្វើការនិយាយសង្កត់ធ្ងន់ (មើល ៤:៧ និងការពន្យល់ អស ៤០:១) ។ *រើសក្រុងយេរូសាឡិម* មើល ១:១៧ ២:១២ ។ *កន្ទុយឱស ដែលបានកញ្ឆក់យកចេញពីភ្លើង* ពួកសាសន៍យូដាបានវិលត្រឡប់ពីភ្លើងនៃការនិទេសរបស់ពួកបាប៊ីឡូនវិញ ដើម្បីបន្តរស់នៅតាមព្រះទ័យព្រះដែលទ្រង់រៀបចំអនាគតឱ្យពួកគេ(អម ៤:១១ និងការពន្យល់ មើល សក ១៣:៨–៩ ដយ ៤:២០ និងការពន្យល់ ៧:៧–៨ យរ ៣០:៧ វវ ១២:១៣–១៦ ធៀបនឹង ១កថ ៣:១៥ យដ ២៣ និងការពន្យល់) ។

**៣:៤** *ពួកដែលឈរនៅចំពោះទ្រង់* ពាក្យនេះទំនងជាសំដៅទៅលើពួកទេវតា(មើល ខ.៧) ។ *ដោះសំលៀកបំពាក់កខ្វក់ពីលោក* គឺដើម្បីដកមុខដំណែងជាសង្ឃរបស់គាត់ ។ ការនេះក៏តំណាងឱ្យការដកយកចេញនូវអំពើបាបផងដែរ (មើល ការពន្យល់ ខ.៩, ប្រៀបធៀបនឹង អស ៦៤:៦) ។

**៣:៥** *បំពាក់ក្បាំងស្អាត នៅលើក្បាលលោក* មានន័យថា លើកគាត់ជាសម្តេចសង្ឃឡើងវិញ ដើម្បីឱ្យពួកអ៊ីស្រាអែលមានអ្នកកណ្តាលដែលទទួលការចាត់តាំងពីព្រះ ។ ក្បាំងដែលត្រូវពាក់នៅលើក្បាលនោះមានសរសេរនៅខាងមុខថា "បរិសុទ្ធដល់ព្រះយេហូវ៉ា"(នក ២៨:៣៦–៣៧ ៣៩:៣០–៣១ សក ១៤:២០ និងការពន្យល់) ។

**៣:៧** បើលោកយេសួរ និងពួកសង្ឃដែលរួមការងារជាមួយលោកស្មោះត្រង់ ពួកគេនឹងបានធ្វើការរួមគ្នាជាមួយនឹងពួកទេវតា នៅក្នុងការបំពេញបំណងព្រះហឫទ័យដែលព្រះទ្រង់មានសម្រាប់ក្រុងស៊ីយ៉ូន និងស្រុកអ៊ីស្រា–អែល ។ *ពួកដែលនៅទីនេះ* មើលការពន្យល់ ខ.៤ ។

**៣:៨** *ពួកអ្នកដែលនៅអង្គុយជាមួយនឹងឯង* គឺពួកសង្ឃដែលរួមការងារជាមួយនឹងលោក ។ *អ្នកបំរើរបស់អញ* មើលការពន្យល់ នក ១៤:៣១ ទដ ១៨ ចំណងជើង, អស ៤១:៨–៩ ៤២:១–៤ ៤២:១ រម ១:១ ។ *លំពង់* គឺជាងារនៃព្រះមែស៊ី (មើល ៦:១២ អស ៤:២ និងការពន្យល់, ១១:១ យរ ២៣:៥ និងការពន្យល់, ៣៣:១៥) ។

**៣:៩** *ថ្ម* គឺជាលក្ខណៈម្យ៉ាងទៀតនៃព្រះមែស៊ី (មើល ទដ ១១៩:២២ អស ៨:១៤ ២៨:១៦ និងការពន្យល់ ដយ ២:៣៥,៤៥) ។ *ភ្នែក ៧* ប្រហែលជានិមិត្តរូបនៃបញ្ញាដ៏ឥតព្រំដែន(សព្វញ្ញូញាណ) ។ មើលការពន្យល់ ៤:១០ ។

ទុច្ចរិត[ន] ពីស្រុកនេះចេញក្នុង១ថ្ងៃ ១០ព្រះយេហូវ៉ានៃពួក
ពលបរិវារ ទ្រង់មានបន្ទូលថា នៅថ្ងៃនោះ ឯងរាល់គ្នានឹង
អញ្ជើញអ្នកជិតខាងរបស់ឯងមក[ប] នៅក្រោមដើមទំពាំង
បាយជូរ ហើយក្រោមដើមល្វារៀងខ្លួន[ផ]។

## ជើងចង្កៀងមាស និងដើមអូលីវទាំងពីរ

**៤** ១ឯទេវតាដែលពោលនឹងខ្ញុំ ក៏មកម្តងទៀត ដាស់ខ្ញុំឡើង
ដូចជាគេដាស់[ក]មនុស្សឱ្យភ្ញាក់ពីដេក[ខ] ២រួចទេវតា សួរខ្ញុំថា
ឯងឃើញអ្វីនោះ[គ] ខ្ញុំឆ្លើយថា ឃើញជើងចង្កៀង[ឃ] ធ្វើពី
មាសទាំងអស់ មានទាំងចានប្រេងនៅលើកំពូល និង
ចង្កៀង៧[ង] ហើយបំពង់៧ សំរាប់បង្ហូរប្រេងដល់ចង្កៀង
និមួយៗ ដែលនៅលើជើងចង្កៀងនោះផង ៣ក៏មានដើម
អូលីវ២[ច] នៅក្បែរនោះ មួយខាងស្តាំចានប្រេង ហើយ
មួយខាងឆ្វេង ៤នោះខ្ញុំក៏សួរដល់ទេវតាដែលពោលនឹងខ្ញុំ
ថា លោកម្ចាស់អើយ នេះតើជាអ្វី ៥ទេវតាដែលពោល
នឹងខ្ញុំក៏ឆ្លើយថា ឯមិនស្គាល់របស់ទាំងនេះទេឬ ខ្ញុំតបថា
លោកម្ចាស់អើយ មិនស្គាល់ទេ[ឆ] ៦នោះទេវតាប្រាប់មកខ្ញុំ
ថា នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ាមានបន្ទូលដល់សូរ៉ូ
បាបិល[ជ] គឺព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូល
ថា មិនមែន[ឈ]ដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ[ញ] គឺដោយ
សារវិញ្ញាណរបស់អញវិញ[ដ] ៧ឱភ្នំធំអើយ តើឯងជាអ្វី
ឯងនឹងត្រូវត្រឡប់ជាដីរាបស្មើវិញ[ឋ] នៅចំពោះសូរ៉ូបាបិល
ហើយលោកនឹងនាំយកថ្ម[ឌ] ជាកំពូលចេញមក ដោយមាន
សំរែកស្រែកហ៊ោ[ឍ]ថា សូមឱ្យបានប្រកបដោយព្រះគុណ អើ

**៣:៩** ន ២សយ ១២:១៣ យរ ៥០:២០ **៣:១០** ប យប ១១:១៨ ផ ជន ១៦:១៤ ១ពវ ៤:២៥ មីក ៤:៤ **៤:១** ក ដយ ៨:១៨ ខ យរ ៣១:២៦ **៤:២** គ យរ ១:១៣ ឃ នក ២៥:៣១ វវ ១:១២ ង វវ ៤:៥ **៤:៣** ច ខ.១១ ទដ ១:៣ វវ ១១:៤ **៤:៥** ឆ សក ១:៩ **៤:៦** ជ ១របា ៣:១៩ អរ ៥:២ ឈ ១សយ ១៣:២២ ១ពវ ១៩:១២ ញ ១សយ ២:៩ ដ នហ ៩:២០ អស ១១:២-៤ ដយ ២:៣៤ ហស ១:៧ **៤:៧** ឋ ទដ ២៦:១២ យរ ៥១:២៥ ឌ ទដ ១១៨:២២ ឍ ១របា ១៥:២៨

*ដកយកសេចក្តីទុច្ចរិតពីស្រុកនេះចេញ* គឺជាការពន្យល់ការប្រៀបធៀបនៅក្នុងខ.៤ ។ ពាក្យ "ស្រុក" គឺតំណាងឱ្យប្រជាជនអ៊ីស្រាអែល ។ ចំពោះអត្ថន័យនៃការសម្អាតបាបនៅក្នុងខនេះ សូមមើល ១២:១០–១៣:១ ធៀបនឹង រម ១១:២៦–២៧ និងការពន្យល់ ។ *ក្នុង ១ ថ្ងៃ* ថ្ងៃនោះគឺនៅថ្ងៃសុក្រដែលជាថ្ងៃដ៏ល្អ ទោះបីជាមានអ្នកខ្លះជឿថា ពាក្យនេះគឺសំដៅទៅលើការយាងមកលើកទីពីរនៃព្រះគ្រីស្ទក៏ដោយ ។

**៣:១០** *នៅថ្ងៃនោះ* មើល ២:១១ និងការពន្យល់ ។ *នៅក្រោមដើមទំពាំងបាយជូរ ហើយក្រោមដើមល្វារៀងខ្លួន* គឺជាការបកស្រាយតាមបែបសុភាសិតអំពី សន្តិភាព សន្តិសុខ និងការស្កប់ចិត្ត (មើល មីក ៤:៤ និងការពន្យល់, ធៀបនឹង ២ពវ ១៨:៣១) ។

**៤:១–១៤** វគ្គនៃបទគម្ពីរនេះគឺជាសេចក្តីទំនាយទីប្រាំ ។ ពួកសាសន៍យូដាបានទទួលការលើកទឹកចិត្តឱ្យសាងសង់ព្រះវិហារ ដោយនឹកចាំពីប្រភពដែលមកពីព្រះ ។ ពន្លឺដែលបានទទួលពីចង្កៀងនៅក្នុងរោងឧបោសថ ឬព្រះវិហារ តំណាងឱ្យសិរីល្អនៃព្រះ នៅក្នុងការញែកជាបរិសុទ្ធ ការបម្រើដ៏បរិសុទ្ធនៃរាស្ត្ររបស់ព្រះ (មើលការពន្យល់ នក ២៥:៣៧) ដែលអាចធ្វើទៅបានដោយសារតែអំណាចនៃព្រះវិញ្ញាណនៃព្រះតែប៉ុណ្ណោះ (មើល ខ.៦ និងពាក្យ "ប្រេង" ក្នុង ខ.១២) ។ អំណាចនេះនឹងជួយឱ្យស្តេចសូរ៉ូបាបិល មានលទ្ធភាពសាងសង់ព្រះវិហារឡើងវិញ (ខ.៦–១០) ។ នៅក្នុងភារៈកិច្ចដ៏សំខាន់នេះ ស្តេចសេរ៉ូបាបិល និងលោកយេសួរនិងបង្ហូរនូវជំនួយរបស់ព្រះទៅដល់រាស្ត្ររបស់ទ្រង់ (ខ.១១–១៤) ក្នុងឋានៈជាស្តេច និងអ្នកតំណាងឱ្យពួកសង្ឃដែលជាអ្នកកណ្តាល ។

**៤:១** *ដាស់ខ្ញុំឡើង* គឺនៅក្នុងយប់ដដែលនោះ (មើលការពន្យល់ ១:៨) ។

**៤:២** *ឯងឃើញអ្វី* មើល ៥:២, យរ ១:១១ និងការពន្យល់ ។ ក្នុងខនេះលោកសាការីបានមើលឃើញចង្កៀងទាំងប្រាំពីរ ដែលតម្រៀបជុំវិញចានក្រឡមមួយដែលផ្ទុកទៅដោយប្រេងដ៏បរិបូរ ។ ប្រេងត្រូវហូរចេញពីចានក្រឡមនោះទៅកាន់ចង្កៀងនោះ តាមបំពង់ទាំង៧ ។ តាមការកាត់ស្រាយម៉្យាងទៀត ចង្កៀងទាំង៧សុទ្ធតែមានបំពង់៧រៀងៗខ្លួនសម្រាប់ដាក់ប្រឆេះចង្កៀង(ដូចនេះសរុបទៅ មានអណ្តាតភ្លើងចំនួន ៤៩ ) ។ ចានក្រឡមនោះមានពេញដោយប្រេងជាបរិបូរ ជាតំណាងឱ្យអំណាចដ៏ពោពេញនៃព្រះដែលបង្ហាញចេញតាមរយៈព្រះវិញ្ញាណ ហើយចំពោះពាក្យ "ទាំង ៧ . . . ទាំង ៧" តំណាងឱ្យពន្លឺដ៏បរិបូរដែលបញ្ចេញពន្លឺពីចង្កៀង (ដូចនេះលេខ ៧ គឺជាលេខនៃភាពពេញបរិបូរ) ។

**៤:៣** *ដើមអូលីវ២* សូមធៀបនឹង វវ ១១:៤ ។ ដើមអូលីវ២ដើមនោះតំណាងឱ្យការងាររបស់ពួកសង្ឃ និងស្តេច និងជាតំណាងឱ្យការបន្តផ្គត់ផ្គង់ប្រេង ។ មែកអូលីវទាំងពីរ (ខ.១២) តំណាងឱ្យលោកយេសួរដ៏ជាសង្ឃ (ជំពូក ៣) និងស្តេចសេរ៉ូបាបិល ដែលមានដើមកំណើតពីតំណាក់ស្តេចដាវីឌ (ជំពូក ៤ សូមធៀបនឹង ខ.១៤) ។ អ្នកដឹកនាំទាំងពីរនាក់នេះត្រូវធ្វើការងាររបស់ព្រះអម្ចាស់ (ឧទាហរណ៍ នៅព្រះវិហារ និងនៅក្នុងជីវិតរបស់បណ្តាជន) ដោយនូវអំណាចព្រះវិញ្ញាណ (ខ.៦) ។ ការរួមបញ្ចូលគ្នានៃខ្សែ និងមុខងាររបស់ស្តេច និងពួកសង្ឃ គឺបង្ហាញពីព្រះមែស៊ីដែលទ្រង់ជាក្សត្រផង និងសង្ឃផង និងពីការងារ និងមុខនាទីរបស់ទ្រង់(ជំពូក ៦:១៣) ។

**៤:៤** *នេះតើជាអ្វី* គឺដើមអូលីវទាំងពីរដើម នៅក្នុង ខ.៣ ដែលមានការបញ្ជាក់ច្បាស់នៅក្នុង ខ.១១ ។ សំណួរនេះត្រូវផ្អាកមិនបានឆ្លើយរហូតដល់ ខ.១៤ ។

**៤:៦** *មិនមែនដោយឫទ្ធិ ឬដោយអំណាចទេ* ស្តេចសេរ៉ូបាបិលមិនមានឫទ្ធិ ឬអំណាច ដូចស្តេចដាវីឌ និងស្តេចសាឡូម៉ូនទេ ហើយឫទ្ធិអំណាចនេះមិនអាចបំពេញបំណងសាងសង់ព្រះវិហារនៃព្រះអម្ចាស់បានទេ ។ *ដោយសារវិញ្ញាណរបស់អញវិញ* នៅត្រង់ចំណុចនេះ គឺជាការកាត់ស្រាយន័យរបស់ប្រេង(ខ.១២)។ ទេវតានៃព្រះអម្ចាស់បានលើកទឹកចិត្តឱ្យស្តេចសេរូបាបិលសម្រេចការសាងសង់ព្រះវិហារឡើងវិញ (ខ.៧–១១) ហើយបានផ្តល់ការធានាថា ព្រះវិញ្ញាណនៃព្រះអម្ចាស់ទ្រង់នឹងជួយ(មើល ហក ២:៥ និងការពន្យល់) ។

**៤:៧** *ភ្នំធំ . . . ដីរាបស្មើ* ជំនឿលើអំណាចនៃព្រះវិញ្ញាណ(ខ.៦)អាចយកឈ្នះលើឧបសគ្គ ដែលធំជាងភ្នំបាន ។ ន័យធៀបនៃពាក្យភ្នំ គឺមានដូចជាការប្រឆាំង (អរ ៤:១–៥,២៤) និងការដែលបណ្តាជនមិនព្រមអត់ទ្រាំ

ដោយព្រះគុណចុះ ៨រួចព្រះបន្ទូលនៃព្រះយេហូវ៉ាក៏
មកដល់ខ្ញុំទៀតថា ៩ដៃនៃសូរ៉ូបាបិលបានដាំឫស[ណ]ព្រះ
វិហារនេះ ហើយដៃលោកនឹងធ្វើបង្ហើយផង[ត] នោះឯង
រាល់គ្នានឹងដឹងថា ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បាន
ចាត់អញ[ថ]មកឯឯង ១០ដ្បិតតើអ្នកណាបានមើលងាយក្នុង
ថ្ងៃ[ទ]នៃការបន្តិចបន្តួចនោះ[ធ] ពីព្រោះទាំង៧នាក់នោះនឹង
រីករាយឡើង ហើយនិងឃើញកូនតឹង នៅក្នុងដៃរបស់
សូរ៉ូបាបិល[ន] ផង ទាំងអស់នេះជាព្រះនេត្រ[ប]នៃព្រះយេហូវ៉ា
ដែលទតចុះ ឡើងនៅពេញលើផែនដីទាំងមូល ។
១១នោះខ្ញុំក៏សួរទេវតាថា ដើមអូលីវ[ផ]ទាំង២ ដែលនៅ
ខាងស្តាំ ហើយខាងឆ្វេងនៃជើងចង្កៀង នោះតើជាអ្វី ១២ខ្ញុំ
ក៏សួរម្តងទៀតថា ឯមែកអូលីវទាំង២នេះ នៅក្បែរបំពង់
មាសទាំង២ ដែលបង្ហូរប្រេងសម្បុរមាសចេញនោះ តើជា
អ្វី ១៣រួចទេវតាក៏សួរតបមកថា តើឯងមិនស្គាល់របស់ទាំង
នេះទេឬ នោះខ្ញុំឆ្លើយថា លោកម្ចាស់អើយ មិនស្គាល់ទេ
១៤ដូច្នេះ ទេវតាប្រាប់ខ្ញុំថា នេះគឺជាអ្នក ទាំង២ ដែលបាន
ចាក់ប្រេងតាំងឱ្យ[ព] ជាអ្នកដែលឈរនៅក្បែរព្រះអម្ចាស់
នៃផែនដីទាំងដុំមូល ។

## ក្រាំងហោះ

**៥** ១រួចមក ខ្ញុំងើបភ្នែកឡើងម្តងទៀត ក្រឡេកមើល ឃើញ
ក្រាំង១ដែលកំពុងហោះ[ក] ២ទេវតាក៏សួរមកខ្ញុំថា ឯងឃើញ
អ្វីនោះ[ខ] ខ្ញុំតបថា ឃើញក្រាំង១កំពុងហោះ មានបណ្តោយ
២០ហត្ថ ហើយទទឹង១០ហត្ថ ៣នោះទេវតា ប្រាប់ខ្ញុំថា នេះ
ជាសេចក្តីបណ្តាសា[គ] ដែលផ្សាយចេញទៅ លើផែនដីទាំង
មូល ដ្បិតតាមក្រាំងនោះ អស់អ្នកដែលលួចប្លន់[ឃ]នឹងត្រូវ
កាត់ចេញ ហើយតាមក្រាំងនោះ អស់អ្នកដែលស្បថរំលាយ
ខ្លួន[ង]និងត្រូវកាត់ចេញដែរ ៤ព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់មានបន្ទូលថា អញនឹងឱ្យសេចក្តីបណ្តាសានោះផ្សាយ
ចេញទៅ នោះនឹងចូលទៅក្នុងផ្ទះរបស់ចោរ ហើយទៅក្នុង
ផ្ទះរបស់អ្នកដែលស្បថកុហក[ច]ដោយនូវឈ្មោះអញ ក៏នឹង
នៅជាប់ក្នុងផ្ទះគេ ព្រមទាំងធ្វើឱ្យផ្ទះនោះសូន្យទៅ ទោះ

**៤:៩** ណ អរ ៣:១១ ត អរ ៣:៨ ៦:១៥ សក ៦:១២ ថ សក ២:៩
**៤:១០** ទ ហក ២:២៣ ធ ហក ២:៣ ន អរ ៥:១ នហ ១២:១ យប ៣៨:៥ ប ២រប ១៦:៩ វវ ៥:៦
**៤:១១** ផ ខ.៣ វវ ១១:៤
**៤:១៤** ព នក ២៩:៧ ៤០:១៥ ទដ ៤៥:៧
**៥:១** ក ទដ ៤០:៧ យរ ៣៦:៤ វវ ៥:១
**៥:២** ខ យរ ១:១៣
**៥:៣** គ អស ២៤:៦ ៣៤:២ ៤៣:២៨ មឡ ៣:៩ ៤:៦ ឃ នក ២០:១៥ មឡ ៣:៨ ង នក ២០:៧ អស ៤៨:១
**៥:៤** ច សក ៨:១៧

(ធៀបនឹង ហក ១:១៤ ២:១–៥) ។ ធៀបនឹងអត្ថន័យដូច ឬស្រដៀងគ្នានៅក្នុង អស ៤០:៤ ៤១:១៥ ៤៩:១១ មថ ១៧:២០ ២១:២១ ១កថ ១៣:២ ២កថ ១០:៤ ។ *ថ្ម ជាកំពូល* គឺថ្មដែលត្រូវដាក់ចុងក្រោយគេ(មើល ទដ ១១៨:២២ និងការពន្យល់) ជាសញ្ញានៃការសម្រេចការស្អាងព្រះវិហារឡើងវិញ ដោយស្តេចសេរ៉ូបាបិល(ខ.៩) ។ *សូមឱ្យបានប្រកបដោយព្រះគុណ អើ ដោយព្រះគុណ* ការឱ្យពរនេះធ្វើឡើងជាច្រើនសារ ដើម្បីនិយាយសង្កត់ធ្ងន់ (មើល ៣:២ មើលការពន្យល់ អស ៤០:១) ។

**៤:៨** ខនេះគឺជាឃ្លានៃការចាប់ផ្តើមថ្លែងទំនាយ (មើល ៦:៩ ៧:៤,៨ ៨:១, ១៨ មើល ការពន្យល់ ហស ១:១) ។

**៤:៩** *ដាំឫសជញ្ជាំង* នៅក្នុងឆ្នាំ ៥៣៦ មុន គ.ស.(អរ ៣:៨–១១ ៥:១៦)។ *ធ្វើបង្ហើយ* ក្នុងឆ្នាំ ៥១៦ មុន គ.ស. (មើល អរ ៦:១៥ និងការពន្យល់) ។

**៤:១០** *ថ្ងៃនៃការបន្តិចបន្តួច* អ្នកខ្លះគិតថាការងារសាងសង់ព្រះវិហារឡើងវិញ ជាការមិនសំខាន់(មើល អរ ៣:១២ ហក ២:៣ និងការពន្យល់) ប៉ុន្តែព្រះទ្រង់មានវត្តមាននៅក្នុងការសាងសង់នោះ ហើយទ្រង់ជួយឱ្យស្តេចសេរ៉ូបាបិលសម្រេចការសាងសង់នោះ ដោយអំណាចព្រះវិញ្ញាណទ្រង់ (ខ.១៦)។ *កូនតឹង* បណ្តាជននឹងមានអំណរឡើង នៅពេលដែលពួកគេបានឃើញស្តេចសេរ៉ូបាបិលកាន់កូនតឹងនៅក្នុងព្រះហស្តទ្រង់ ដើម្បីសម្រេចការងារនោះ ។ ប៉ុន្តែ ពាក្យនេះក៏អាចមានន័យតាមភាសាហេព្រើ "ថ្មដែលត្រូវជ្រើសរើស" ដែលសំដៅទៅលើថ្មដែលជាកំពូល នៅក្នុង ខ.៧ ។ *ទាំង ៧ . . . ព្រះនេត្រ* មើលការពន្យល់ ៣:៩ ។ ព្រះអម្ចាស់ទ្រង់មើលការខុសត្រូវលើផែនទាំងមូល ដូចនេះ ទ្រង់ក៏គ្រប់គ្រងស្ថានការណ៍នៅក្នុងស្រុកយូដាផងដែរ ។

**៤:១៤** ខនេះគឺជាការពន្យល់នៃសេចក្តីទំនាយទី៧ ។ *ទាំង ២ . . . ចាក់ប្រេងតាំង* ស្តេចសេរ៉ូបាបិលជាប់ខ្សែលោហិតស្តេចដាវីឌ និងលោកយេសួរដ៏ជាសង្ឃ ។ ប្រេង(ខ.១២)សម្រាប់ចាក់នោះ គឺតំណាងឱ្យព្រះវិញ្ញាណ(ខ.៦) ។ ការដែលមានការងារជាស្តេចផង និងសង្ឃផង គឺបង្ហាញពីលក្ខណៈនៃព្រះមែស៊ីដែលទ្រង់ជាក្សត្រ និងជាសង្ឃ(ធៀបនឹង ៦:១៣ ទដ ១០០ ហព ៧)។ *ព្រះអម្ចាស់នៃផែនដីទាំងមូល* មើល ៦:៥ ។ គឺមានន័យថា ព្រះទ្រង់ជាម្ចាស់លើកាលៈទេសៈ ហើយស្តេចសេរ៉ូបាបិល និងបណ្តាជនសុទ្ធតែដឹងថាពួកគេស្ថិតក្នុងកាលៈទេសៈនោះ ។

**៥:១–៤** វគ្គនៃបទគម្ពីរនេះគឺជាសេចក្តីទំនាយទី៦ ។ ពួកអ្នកដែលប្រព្រឹត្តរំលងក្រឹត្យវិន័យណា នោះត្រូវកាត់ទោសដោយក្រឹត្យវន័យនោះវិញ ។ អ្នកដែលប្រព្រឹត្តបាបនឹងត្រូវកាត់ចេញពីទឹកដីដែលខ្លួនរស់នៅ ។

**៥:១** *ក្រាំង* មើលការពន្យល់ នក ១៧:១៤ ។ *កំពុងហោះ* ក្រាំងនោះត្រូវលាតត្រដាងឡើងហើយបក់ចុះឡើងដូចបដា ដើម្បីឱ្យមនុស្សគ្រប់គ្នាបានអានមើល ។

**៥:២** *ឯងឃើញអ្វី?* មើល ៤:២ និងការពន្យល់ ។ *២០ . . . ១០ ហត្ថ* បង្ហាញថាជាទំហំធំតាមធម្មតា ដើម្បីឱ្យគ្រប់គ្នាបានអាន ។ ពាក្យពេចន៍នៅក្នុងក្រាំងនោះ គឺនិយាយប្រឆាំងខ្លាំងៗ ហើយច្បាស់ៗ ចំពោះអំពើបាប ដូចនេះក្រាំងនោះជំរុញចិត្តបណ្តាជនឱ្យប្រែចិត្ត និងប្រកាន់យកនូវភាពសុចរិត ។

**៥:៣** *សេចក្តីបណ្តាសា* មើល ចទ ២៧:២៦ និងការពន្យល់ ។ ក្រាំងត្រូវបានសរសេរទាំងសងខាង (អគ ២:១០ និងការពន្យល់) ដូចបន្ទះថ្មក្រឹត្យវិន័យទាំងដប់ប្រការដែរ (នក ៣២:១៥) ។ *អស់អ្នកណាដែលស្បថរំលាយខ្លួន* មើល ៨:១៧ ។ អ្នកនោះបានប្រព្រឹត្តខុសនឹងក្រឹត្យវិន័យទីប្រាំបី(ធៀប ខ.៤ ជាមួយនឹង នក ២០:៧) ។ បណ្តាជននៃស្រុកយូដាបានប្រព្រឹត្តរំលងក្រឹត្យវិន័យទាំងមូល(មើល យក ២:១០ និងការពន្យល់)។

**៥:៤** *ចូលទៅក្នុង . . . ធ្វើឱ្យផ្ទះនោះសូន្យទៅ* គឺសំដៅទៅលើសេចក្តីបណ្តាសានៅក្នុង ខ.៣ ។ ព្រះបន្ទូលព្រះតែងតែសម្រេចជានិច្ច ទោះជាព្រះបន្ទូលសន្យា(ខ.៤) ឬព្រះបន្ទូលព្រមានក៏ដោយ (ធៀបនឹង ទដ ១៤៧:១៥ អស ៥៥:១០–១១ ហព ៤:១២–១៣ និងការពន្យល់) ។

ទាំងឈើនឹងថ្មផង[ឆ] ។

## ស្ត្រីម្នាក់អង្គុយក្នុងរង្វាល់

៥លំដាប់នោះ ទេវតាដែលពោលនឹងខ្ញុំ ក៏ចេញទៅ
ដោយប្រាប់ខ្ញុំថា ចូរងើបភ្នែកឯងឡើងឥឡូវ ដើម្បីនឹង
មើលអ្វីៗដែលចេញទៅនោះ ៦ខ្ញុំក៏សួរថា តើជាអ្វី រួច
ទេវតាប្រាប់ថា នេះគឺរង្វាល់ដែលចេញទៅ[ជ] ក៏ប្រាប់
ទៀតថា នេះជារូបភាពរបស់គេ នៅពេញក្នុងស្រុកនេះ
៧រួចឃើញមានគេលើកសំណទំងន់១ហាបឡើង ហើយ
ឃើញមានស្ត្រីម្នាក់អង្គុយក្នុងរង្វាល់នោះ ៨ទេវតាប្រាប់
ថា នេះគឺជាអំពើអាក្រក់ រួចក៏សង្កត់នាងចុះទៅក្នុងរង្វាល់
ព្រមទាំងដាក់ដុំសំណនោះ គ្របនៅមាត់រង្វាល់ផង[ឈ] ៩នោះ
ខ្ញុំបានងើបភ្នែកឡើងក្រឡេកទៅ ឃើញមានស្ត្រី២នាក់
ចេញមក មានស្លាបដូចជាកុក[ញ] ដែលជក់ដោយខ្យល់ គេ
ក៏លើករង្វាល់នោះឡើង នៅកណ្ដាលផែនដីនឹងផ្ទៃមេឃ
១០រួចខ្ញុំសួរដល់ទេវតាដែលពោលនឹងខ្ញុំថា ស្ត្រីទាំង២
នេះនាំយករង្វាល់ទៅឯណា ១១ទេវតាក៏តបថា គេយក
ទៅធ្វើផ្ទះឱ្យនាង នៅក្នុងស្រុកស៊ីណើរ[ដ] កាលណាផ្ទះ[ឋ]បាន
ស្រេចហើយ នោះនាងនឹងបានតាំងនៅទីនោះ ក្នុងកន្លែង
របស់ខ្លួន[ឌ] ។

## រថទាំងបួន

៦ ១ខ្ញុំក៏ងើបភ្នែកឡើងម្ដងទៀត ក្រឡេកទៅឃើញមាន
រថ[ក]៤ចេញពីកណ្ដាលភ្នំ២មក ឯទាំង២នោះជាភ្នំលង្ហិន
២រថទី១ ទឹមដោយសេះសម្បុរក្រហម រថទី២ ទឹមដោយ
សេះសម្បុរខ្មៅ[ខ] ៣រថទី៣ ទឹមដោយសេះសម្បុរស[គ] ហើយ
រថទី៤ ទឹមដោយសេះសម្បុរពព្លាក់ ដែលមានកំឡាំងខ្លាំង
៤ខ្ញុំក៏សួរដល់ទេវតាដែលពោលនឹងខ្ញុំថា លោកម្ចាស់អើយ
ទាំងអស់នេះតើជាអ្វី ៥នោះទេវតាតបមកខ្ញុំថា នេះគឺជា
ខ្យល់[ឃ]ទាំង៤ទិសនៅលើអាកាស ដែលចេញពីចំពោះព្រះ
អម្ចាស់នៃផែនដីទាំងមូល[ង] ៦ឯរថទឹមសេះសម្បុរខ្មៅ នោះ
ចេញទៅឯស្រុកនៅទិសខាងជើង ហើយសេះសក៏ចេញ
តាមក្រោយទៅ ឯសេះពព្លាក់ នោះចេញទៅឯស្រុកនៅ
ទិសខាងត្បូង ៧រួចសេះដែលមានកំឡាំងខ្លាំងក៏ចេញទៅ
ហើយរកផ្លូវឱ្យបានដើរចុះឡើងនៅលើផែនដី[ច] លំដាប់
នោះទេវតាបង្គាប់វាថា ចូរទៅចុះ ហើយដើរចុះឡើងនៅ
ផែនដី ដូច្នេះ វាក៏ដើរចុះឡើងនៅផែនដីទៅ ៨នោះទេវតា
ស្រែកមកខ្ញុំថា មើល សេះដែលចេញទៅឯស្រុកនៅទិស
ខាងជើង បានរំងាប់ចិត្ត[ឆ]អញចំពោះស្រុកខាងជើងនោះ
ហើយ[ជ] ។

**៥:៤** ឆ លវ ១៤:៣៤–៤៥ សក ៣:៣៣ ហព ២:៩–១១មឡ ៣:៥
**៥:៦** ជ មីក ៦:១០
**៥:៨** ឈ មីក ៦:១១
**៥:៩** ញ លវ ១១:១៩
**៥:១១** ដ លប ១០:១០ ឋ យរ ២៩:៥,២៨ ឌ ដយ ១:២
**៦:១** ក ឧ.៥ ២ពវ ២:១១
**៦:២** ខ វវ ៦:៥
**៦:៣** គ វវ ៦:២
**៦:៥** ឃ អគ ៣៧:៩ មថ ២៤:៣១ វវ ៧:១ ង យស ៣:១១
**៦:៧** ច អស ៤៣:៦ សក ១:៨
**៦:៨** ឆ អគ ៥:១៣ ២៤:១៣ ជ សក ១:១០

**៥:៥–១១** វគ្គនៃបទព្រះគម្ពីរនេះគឺជាសេចក្ដីទំនាយទី ៧ ។ ព្រះអម្ចាស់ទ្រង់មិនគ្រាន់តែកាត់មនុស្សមានបាបចេញពីទឹកដីប៉ុណ្ណោះទេ (ខ.១–៤) ប៉ុន្តែថែមទាំងកាត់ប្រព័ន្ធនៃអំពើបាបទាំងមូលចេញផងដែរ ហើយបញ្ជូនទាំងអស់នោះទៅកាន់ទីកន្លែងថ្មីដែលពួកគេស័ក្តិសមនឹងទៅ (ចក្រភពបាប៊ីឡូន) ។

**៥:៦** *រង្វាល់* រង្វាល់នេះប្រាកដជាធំជាងធម្មតា ព្រោះជារង្វាល់ដែលអាចដាក់មនុស្សម្នាក់ចូលបាន ។ *រូបភាព* មើល ខ.៨ (អំពើអាក្រក់) ។

**៥:៨** *អំពើអាក្រក់* ពាក្យផ្ទុយនៃពាក្យនេះ តាមន័យសីលធម៌ សាសនា និងច្បាប់ គឺពាក្យសុចរិត (ឧទាហរណ៍ សភ ១៣:៦ អគ ៣៣:១២) ។ ប្រព័ន្ធទាំងអស់នៃអំពើអាក្រក់ត្រូវតែបំផ្លាញចោល (ធៀបនឹង ២ថន ២:៦–៨) ។

**៥:៩** *ស្ត្រី២នាក់* គឺជាអ្នកដែលព្រះអម្ចាស់ចាត់ឱ្យបំពេញការងារពិសេស ។ *ខ្យល់* គឺជាឧបករណ៍របស់ព្រះផងដែរ (មើល ទដ ១០៤:៣–៤ និងការពន្យល់) ។ ការយកចេញនូវសេចក្ដីអាក្រក់ គឺជាព្រះរាជកិច្ចរបស់ព្រះអម្ចាស់តែមួយអង្គប៉ុណ្ណោះ ។

**៥:១១** *ស្រុកស៊ីណើរ* មើល លប ១០:១០ ១១:២ វវ ១៧–១៨ ។ គេអាចហៅឈ្មោះស្រុកនេះបានម្យ៉ាងទៀតថា ស្រុកបាប៊ីឡូន ជាទឹកដីដែលថ្វាយបង្គំរូបព្រះ ហើយទឹកដីនេះនៃអំពើអាក្រក់ គឺខុសពីទឹកដីអ៊ីស្រាអែលដែលព្រះទ្រង់បានជ្រើសរើសជាកន្លែងគង់នៅជាមួយរាស្ត្ររបស់ទ្រង់ ។ ទឹកដីសន្យាអាចក្លាយជា"ទឹកដីបរិសុទ្ធ"ទៅបាន ទាល់តែមានការសំអាតសេចក្ដីអាក្រក់ឱ្យអស់ពីទឹកដីនោះ (២:១២) ។

**៦:១–៨** វគ្គនៃបទគម្ពីរនេះគឺជាសេចក្ដីទំនាយទី៨ និងជាសេចក្ដីទំនាយចុងក្រោយ ។ សេចក្ដីទំនាយនេះមានទំនាក់ទំនងនឹងសេចក្ដីទំនាយទី១ (១:៧–១៧) ទោះបីជាមានការរៀបរាប់ខុសគ្នាអំពីពណ៌ និងសត្វសេះក៏ដោយ ។ នៅក្នុងសេចក្ដីទំនាយទី១ ព្រះអម្ចាស់ទ្រង់ជាអ្នកគ្រប់គ្រងគ្រប់ព្រឹត្តិការណ៍ទាំងអស់នៃប្រវត្តិសាស្ត្រ (មើលសេចក្ដីផ្ដើមត្រង់ ទម្រង់អក្សរសាស្ត្រ ខ្លឹម–សារ) ។ ទ្រង់នឹងកាន់កាប់សាសន៍ណាដែលគៀបសង្កត់រាស្ត្រអ៊ីស្រាអែល ។

**៦:១** *រថ៤* ទេវតាជាវិញ្ញាណដែលព្រះទ្រង់ចាត់ឱ្យមកកាត់ទោស (ខ.៥) ។ *ភ្នំទាំង២* អាចជាភ្នំស៊ីយ៉ូន និងភ្នំអូលីវ ដែលមានជ្រលងភ្នំគីដ្រូនស្ថិតនៅចន្លោះភ្នំទាំងពីរនេះ (ធៀបនឹង យអ ៣:២ និងការពន្យល់) ។ *លង្ហិន* ប្រហែលជានិមិត្តរូបនៃការជំនុំជម្រះ (ធៀបនឹង ជន ២១:៩) ។

**៦:២–៣** *ក្រហម . . . ខ្មៅ . . . ស . . . សម្បុរពព្លាក់* សេះទាំងអស់នេះអាចជាសញ្ញានៃការជំនុំជម្រះផ្សេងៗពីគ្នា ដែលព្រះទ្រង់នឹងដាក់មកលើផែនដី (មើលការពន្យល់ ខ.៨ វវ ៦:១–៨ និងការពន្យល់ ៦:២) ។

**៦:៤** *ទាំងអស់នេះ* គឺមានរថ ដែលអូសដោយសេះស ។

**៦:៥** *ខ្យល់ទាំង ៤* មើលការពន្យល់ ខ.១ ។ *ព្រះអម្ចាស់នៃផែនដីទាំងមូល* មើលការពន្យល់ ៤:១៤ ។

**៦:៨** *ស្រុកនៅទិសខាងកើត* គឺសំដៅលើស្រុកបាប៊ីឡូន និងសំដៅទៅលើការដែលស្រុកអ៊ីស្រាអែលត្រូវបានឈ្លានពានពីទិសខាងកើត (មើលការពន្យល់ ២:៦) ។ *ចិត្តអញ* ត្រង់ចំណុចនេះ ទេវតាដែលចេញទៅឯស្រុកនៅទិសខាងជើងបានទទួលជោគជ័យ ហើយបានបំពេញនូវព្រះហឫទ័យព្រះអម្ចាស់ (គឺព្រះហឫទ័យក្រោធធៀបនឹង សស ១០:៤) ។ នៅក្នុង ១:១៥ ព្រះអម្ចាស់ទ្រង់មិនពេញព្រះទ័យនឹងសាសន៍ដែលគៀបសង្កត់ ។ ក្នុងករណីនេះដោយសារមានការប្រកាសពីការកាន់កាប់នៅស្រុកខាងជើង នោះជោគជ័យ

## មកុដសម្រាប់លោកយេសួរ

៩ចូរមក ព្រះបន្ទូលនៃព្រះយេហូវ៉ា ក៏មកដល់ខ្ញុំថា
១០ចូររៃយកពីពួកអ្នកដែលបានជាប់ជាឈ្លើយ គឺត្រូវរៃ
យកពីហេលដាយ ពីថូប៊ីយ៉ា ហើយពីយេដាយ៉ា រួចនៅ
ថ្ងៃដដែលនោះ ឱ្យចូលទៅក្នុងផ្ទះរបស់យ៉ូសៀស ជាកូន
សេផានា ជាកន្លែងដែលគេទើបនឹងមកពីក្រុងបាប៊ីឡូន[ឈ]
ចូលទៅអាស្រ័យនៅនោះ ១១អើ ត្រូវឱ្យទទួលយកប្រាក់
និងមាសពីគេទៅធ្វើមកុដ[ញ] បំពាក់លើក្បាលយេសួរ[ដ] ជា
កូនយ៉ូសាដាកដ៏ជាសំដេចសង្ឃ[ឋ] ១២ហើយប្រាប់លោកថា
ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូលដូច្នេះ មើល
មនុស្សដែលឈ្មោះថា "លំពង់"[ឌ] នឹងពន្លកដុះឡើងពីកន្លែង
របស់ខ្លួន ហើយនឹងសង់ព្រះវិហារនៃព្រះយេហូវ៉ាឡើង[ឍ]
១៣គឺអ្នកនោះឯងនឹងសង់ព្រះវិហារនៃព្រះយេហូវ៉ា ហើយ
នឹងតាំងសិរីល្អនៃទីនោះឡើង ក៏នឹងអង្គុយគ្រប់គ្រង[ណ]នៅ
លើបល្ល័ង្ករបស់ខ្លួន ហើយទាំង២នាក់នឹងមានសេចក្ដីមេត្រី
នឹងគ្នា ១៤ឯមកុដនោះនឹងបានសំរាប់ហេលេម ថូប៊ីយ៉ា
យេដាយ៉ា ហើយសំរាប់ហិន ជាកូនសេផានា ទុកជាទីរំឭក[ត]
នៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា ១៥ចំណែកពួកអ្នកដែល
នៅឆ្ងាយ គេនឹងមកជួយស្អាងព្រះវិហារនៃព្រះយេហូវ៉ា[ថ]
ឡើងដែរ នោះឯងរាល់គ្នានឹងដឹងថា ព្រះយេហូវ៉ានៃពួក
ពលបរិវារទ្រង់បានចាត់ឱ្យអញមកឯឯង[ទ] ហើយការនេះ
នឹងកើតមកមែន បើឯងរាល់គ្នាព្យាយាមស្ដាប់តាម[ធ]ព្រះ
បន្ទូលនៃព្រះយេហូវ៉ា ជាព្រះនៃឯង ។

## សេចក្ដីយុត្តិធម៌ និងសេចក្ដីមេត្តា មិនមែនការតមអត់

៧ ១លុះដល់ឆ្នាំទី៤ ក្នុងរាជ្យស្ដេចដារីយុស នៅថ្ងៃ៤
ខែទី៩ គឺជាខែមិគ្គសិរ[ក] នោះព្រះបន្ទូលនៃព្រះយេហូវ៉ាក៏
មកដល់សាការី[ខ] ២គ្រានោះ ពួកអ្នកនៅបេត-អែលបាន
ចាត់សារេសើរ និងរេគេម-មេលេក ព្រមទាំងពួករបស់
គេមកទូលអង្វរ[គ]ចំពោះព្រះយេហូវ៉ា[ឃ] ៣ហើយនឹងសួរដល់
ពួកសង្ឃ នៅក្នុងព្រះវិហាររបស់ព្រះយេហូវ៉ានៃពួកពល
បរិវារ និងដល់ពួកហោរាថា តើត្រូវឱ្យយើងខ្ញុំយំ[ង]នៅខែ
ស្រាពណ៍[ច] ទាំងញែកខ្លួនចេញ ដូចជាបានធ្វើមកជាយូរ
ឆ្នាំហើយឬ ៤នោះព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពល
បរិវារក៏មកដល់ខ្ញុំថា ៥ចូរប្រាប់ដល់បណ្ដាជននៅក្នុងស្រុក
និងពួកសង្ឃថា កាលឯងរាល់គ្នាបានតមអត់[ឆ] ហើយយំ
សោក នៅខែស្រាពណ៍[ជ] និងខែអស្សុជទាំង៧០ឆ្នាំមក
ហើយនេះ[ឈ] នោះតើបានតមអត់ដោយគោរពដល់អញឬ
គឺដល់អញមែនឬអី ៦ហើយកាលណាឯងរាល់គ្នាស៊ី ឬកាល

**៦:១០** ឈ អរ ៧:១៤–១៦ យរ ២៨:៦ **៦:១១** ញ ទដ ២១:៣ ដ អរ ២:២ សក ៣:១ ឋ ១របា ៦:១៥ អរ ៣:២ **៦:១២** ឌ អស ៤:២ អគ ១៧:២២ ឍ អរ ៣:៨–១០ សក ៤:៦–៩ **៦:១៣** ណ ទដ ១១០:៤ **៦:១៤** ត នក ២៨:១២ **៦:១៥** ថ អស ៦០:១០ ទ សក ២:៩–១១ ធ អស ៥៨:១២ យរ ៧:២៣ សក ៣:៧ **៧:១** ក នហ ១:១ ខ អរ ៥:១ **៧:២** គ យរ ២៦:១៩ សក ៨:២១ ឃ ហក ២:១០–១៤ **៧:៣** ង សក ១២:១២–១៤ ច ២ពវ ២៥:៩ យរ ៥២:១២–១៤ **៧:៥** ឆ អស ៥៨:៥ ជ ២ពវ ២៥:២៥ ឈ ដយ ៩:២

ប្រាកដជាមានលើគ្រប់ទាំងសត្រូវ ។

**៦:៩–១៥** សេចក្ដីទំនាយទី៤ និងទី៥ គឺទាក់ទងនឹងសម្ដេចសង្ឃ និងស្ដេច ។ មើលសេចក្ដីផ្ដើមត្រង់ ទម្រង់អក្សរសាស្ត្រ និងខ្លឹមសារ ។ នៅក្នុងវគ្គនៃបទគម្ពីរនេះ លោកសាការីបាននិយាយភ្ជាប់សេចក្ដីទំនាយទាំងពីរនេះ និងព្រះមែស៊ីដ៏ជាក្សត្រ និងសង្ឃ ។

**៦:៩** មើលការពន្យល់ ៤:៨ ។

**៦:១០** *រៃយក* គឺសម្រាប់ព្រះវិហារ (ធៀបនឹង អរ ៦:៥ ហក ២:៨) ។

**៦:១១** *មកុដ* មកុដគឺខុសពីក្បាំងដែលបំពាក់លើក្បាលសម្ដេចសង្ឃ ព្រោះជាមកុដដែលមានការតាក់តែងពិសេស (ធៀបនឹង *វវ* ១៩:១២) ។ ការបំពាក់មកុដរាជ្យដល់សម្ដេចសង្ឃយ៉ាងដូចនេះ គឺទាក់ទងនឹងបទទំនាយអំពីការបំពាក់មកុដ និងការឡើងគ្រងរាជ្យនៃព្រះមែស៊ីដ៏ជាក្សត្រ និងសង្ឃ (មើលខ.១២–១៣, ធៀប ទដ ១១០:៤ ហាព ៧:១–៣) ។

**៦:១២** *មើលមនុស្ស* សូមធៀបនឹងពាក្យណែនាំរបស់លោកពីឡាត់អំពីព្រះយេស៊ូវនៅក្នុង យហ ១៩:៥ ។ *លំពង់* មើលការពន្យល់ ៣:៨ ។ *ព្រះវិហារ* ធៀបនឹង អស ២:២–៣ អគ ៤០–៤៣ ហក ២:៦–៩ ។

**៦:១៣** *តាំង* មើលការពន្យល់ ទដ ១០៩:២៩ ។ *បល្ល័ង្ក* មើល ២សយ ៧:១១,១៦ អស ៩:៧ លក ១:៣២ និងការពន្យល់ ។ *សង្ឃនៅលើបល្ល័ង្ករបស់ខ្លួន* ស្ដេចនៃវង្សស្ដេចដាវីឌទ្រង់ក៏យាងមកក្នុងឋានៈជាសង្ឃផងដែរ ។ *២* ចំនួននេះបញ្ជាក់ពីការងារស្ដេច និងសង្ឃ ។ តាមធម្មតានៅអ៊ីស្រាអែលមិនអាចមានការបង្រួមការងារតែមួយដូចនេះទេ ។ ដោយសារមូលហេតុនេះពួកនិកាយគូមរ៉ាន (Qumran) នាំគ្នារំពឹងថានឹងមានព្រះមែស៊ីពីរអង្គយាងមក គឺព្រះមែស៊ីដែលជាសម្ដេចសង្ឃ និងព្រះមែស៊ីជាក្សត្រនៃវង្សស្ដេចដាវីឌ ។ ប៉ុន្តែ តាមការពិតការងារទាំងពីរនេះនឹងរួមគ្នា ហើយជាការងាររបស់ព្រះមែស៊ីដែលមានតែមួយអង្គប៉ុណ្ណោះ (ធៀបនឹង ទដ ១១០ ហាព ៧)

**៦:១៤** *ហិន* ឈ្មោះនេះមានន័យថា "ព្រះដ៏ប្រកបដោយព្រះគុណ" ប្រហែលជាឈ្មោះមួយទៀតដែលគេដាក់ឱ្យលោកយ៉ូសៀស ដើម្បីផ្ដល់ការគោរពដល់លោកដែលបានទទួលរាក់ទាក់ (ខ.១០) ។

**៦:១៥** *ពួកអ្នកដែលនៅឆ្ងាយ គេនឹងមកជួយ* សូមធៀបនឹង អស ៦០:៤–៧ ។

**៧:១** *ឆ្នាំទី ៤ . . . ថ្ងៃទី ៤ . . . ខែទី៩* គឺត្រូវនឹងថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ៥១៨ មុន គ.ស. គឺមានរយៈពេលប្រហែលពីរឆ្នាំ បើគិតចាប់ពីយប់នៃសេចក្ដីទំនាយទីប្រាំបី (មើលការពន្យល់ ១:៧) ។

**៧:៣** *ពួកហោរា* គឺរាប់បញ្ចូលលោកសាការីផងដែរ ។ *យើងខ្ញុំ* គឺប្រជាជនស្រុកបេតអែលទាំងមូល ។ *យំនៅខែស្រាពណ៍* មើលការពន្យល់ ៨:១៩ ។ *យូរឆ្នាំហើយ* "គឺតាំងពីប្រាំពីរឆ្នាំមុន" (ខ.៥) ។

**៧:៤–៧** វគ្គនៃបទគម្ពីរនេះគឺជាការស្ដីបន្ទោស ចំពោះភាពអាត្មានិយម និងការអធិស្ឋានតមដោយមិនស្មោះត្រង់ របស់បណ្ដាជន និងពួកសង្ឃ ។

**៧:៤,៨** មើលការពន្យល់ ៤:៨ ។

**៧:៥** *តមអត់ . . . ខែស្រាពណ៍ និងខែអស្សុជ* មើលការពន្យល់ ៨:១៩ ។ *ទាំង៧០ឆ្នាំ* មើល ១:១២ និងការពន្យល់ ។ ដោយសារការអត់តមនេះមានទាក់ទងនឹងការបំផ្លាញក្រុងយេរូសាឡិម និងព្រះវិហារ (មើលការពន្យល់ ៨:១៩) រយៈពេល ៧០ ឆ្នាំដែលនិយាយក្នុងខនេះគឺត្រូវរាប់ចាប់ពីឆ្នាំ ៥៨៦ មុនគ.ស ។

ណាផឹក នោះតើមិនមែនស៊ី និងផឹក ជាប្រយោជន៍ដល់ខ្លួន
ទេឬ[ញ] ៧តើមិនមែនជាសេចក្តីនោះឯងទេឬ ដែលព្រះយេ
ហូវ៉ាបានប្រកាសប្រាប់ ដោយសារពួកហោរាជាន់មុន[ដ] ក្នុង
កាល ដែលក្រុងយេរូសាឡិមមានមនុស្សអាស្រ័យនៅៗ
ឡើយ ហើយមានសេចក្តីចំរើន[ឋ] ព្រមទាំងទីក្រុងនៅជុំវិញ
ផង ហើយស្រុកត្បូង និងស្រុកទំនាប[ឌ] ក៏មានមនុស្សអាស្រ័យ
នៅដែរ[ឍ]។

៨ព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់សាការីថា
៩ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានមានបន្ទូលដូច្នេះ
ចូរសំរេចតាមសេចក្តីយុត្តិធម៌ដ៏ពិត[ណ] ហើយសំដែងសេចក្តី
សប្បុរស និងសេចក្តីអាណិតមេត្តាដល់គ្នាទៅវិញទៅមក
ចុះ[ត] ១០កុំឱ្យសង្កត់សង្កិនស្រីមេម៉ាយ[ថ] ពួកកំព្រា ពួកអ្នក
ស្នាក់នៅ[ទ] ឬមនុស្សទ័លក្រឡើយ[ធ] ក៏កុំឱ្យពួកឯងណាមួយ
គិតគូរបង្កើតការអាក្រក់ នៅក្នុងចិត្ត ទាស់នឹងបងប្អូនខ្លួន
ដែរ[ន] ១១ប៉ុន្តែគេមិនព្រមស្តាប់តាមសោះ[ប] ក៏គេចស្មាចេញ[ផ]
ហើយចុកត្រចៀក ដើម្បីមិនឱ្យឮវិញ[ព] ១២អើ គេបានតាំង
ចិត្តរឹងដូចជាថ្មដែកភ្លើង[ភ] ក្រែងគេឮក្រិត្យវិន័យ នឹងព្រះ
បន្ទូល ដែលព្រះយេហូវ៉ានៃពួកពលបរិវារ បានចាត់ព្រះ
វិញ្ញាណទ្រង់មកប្រាប់ ដោយសារពួកហោរាពីដើម[ម]
ដោយហេតុនោះបានជាមានសេចក្តីក្រោធជាខ្លាំង ចេញពី
ព្រះយេហូវ៉ានៃពួកពលបរិវារមក[យ] ១៣ព្រះយេហូវ៉ានៃពួក
ពលបរិវារទ្រង់មានបន្ទូលថា ដូច្នេះ ទ្រង់បានស្រែកទៅ
តែគេមិនព្រមស្តាប់យ៉ាងណា[រ] គេក៏នឹងស្រែកដែរ តែអញ
មិនព្រមស្តាប់ដូចគ្នា[ល,វ] ១៤គឺអញនឹងកំចាត់កំចាយ[ស]គេ
ដោយខ្យល់កួច[ហ] ឱ្យទៅនៅកណ្តាលអស់ទាំងសាសន៍ ដែល
គេមិនបានស្គាល់ឡើយ ដូច្នេះ ស្រុកក៏បានស្ងាត់ច្រៀប នៅ
ខាងក្រោយគេ ដល់ម្ល៉េះបានជាឥតមានអ្នកណាដើរកាត់
ឬវិលត្រឡប់មកវិញទៀតទេ[ឡ] ដ្បិតគេបានធ្វើឱ្យស្រុកដ៏
លំអរទៅជាទីខូចបង់[អ]។

## ព្រះអម្ចាស់សន្យាប្រទានពរទីក្រុងយេរូសាឡិម

**៨** ១ព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ ក៏មក
ដល់ខ្ញុំថា ២ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូល
ដូច្នេះ អញមានសេចក្តីប្រចណ្ឌ[ក]ជាខ្លាំងចំពោះក្រុងស៊ីយ៉ូន
អញមានសេចក្តីប្រចណ្ឌដោយចិត្តក្រោធជាខ្លាំង ៣ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ អញបានវិលមក[ខ]ឯក្រុង
ស៊ីយ៉ូន[គ] ហើយក៏នឹងអាស្រ័យនៅកណ្តាលក្រុងយេរូសាឡិម[ឃ]

**៧:៦** ញ អស ៤៣:២៣
**៧:៧** ដ អស ១:១១–២០ សក ១:៤ ឋ យរ ២២:២១ ឌ យរ ១៧:២៦ ឍ យរ ៤៤:៤–៥
**៧:៩** ណ យរ ២២:៣ ៤២:៥ សក ៨:១៦ ត ចទ ២២:១
**៧:១០** ថ យរ ៤៩:១១ ទ នក ២២:២១ ធ លវ ២៥:១៧ អស ១:២៣ ន នក ២២:២២ យប ៣៥:៨ អស ១:១៧ អគ ៤៥:៩ មីក ៦:៨
**៧:១១** ប អស ៩:៩ ផ យរ ៣២:៣៣ ព យរ ៥:៣ ៨:៥ ១១:១០ ១៧:២៣ អគ ៥:៦
**៧:១២** ភ យរ ៥:៣ ១៧:១ អគ ១១:១៩ ម នហ ៩:២៩ យ យរ ៤២:២១
ដយ ៩:១២ **៧:១៣** រ យរ ៧:២៧ ល អស ១:១៥ យរ ១១:១១ ១៤:១២ មីក ៣:៤ វ សភ ១:២៨ បទ ៣:៤៤ អគ ២០:៣១ **៧:១៤** ស លវ ២៦:៣៣ ដយ ៤:២៧ ២៨:៦៤–៦៧ ទដ ៤៤:១១ ហ យរ ២៣:១៩ ឡ អស ៣៣:៨ អ យរ ៧:៣៤ ៤៤:៦ អគ ១២:១៩ **៨:២** ក យអ ២:១៨ **៨:៣** ខ សក ១:១៦ គ អស ៥២:៨ យអ ៣:២១ ឃ សក ២:១០

**៧:៦** *ប្រយោជន៍ដល់ខ្លួន* ធៀបនឹង អស ១:១១–១៧ ៥៨:១–៧,១៣–១៤ ។
**៧:៧,១២** *ពួកហោរាជាន់មុន* មើលការពន្យល់ ១:១៤ ។
**៧:៧** *ស្រុកត្បូង* មើលការពន្យល់ ១២:៩ ។ *ស្រុកទំនាប* ស្រុកមានចំណោតទេរទៅរកតំបន់សមុទ្រមេឌីទែរ៉ាណេ ។
**៧:៩–១០** វគ្គនេះនិយាយអំពីរបៀបទាំងបួនយ៉ាងនៃការរស់នៅតាមសេចក្តីសញ្ញា ដែលរួមមានព្រះរាជបញ្ញាសម្រាប់ការរស់នៅក្នុងសង្គម និងការរស់នៅដោយសីលធម៌ ។
**៧:៩** *សេចក្តីយុត្តិធម៌* គឺចាំបាច់ត្រូវតែមាននៅក្នុងសង្គមណាក៏ដោយ(មើល ៨:១៦–១៧ អស ៤២:១៤ មីក ៦:៨ និងការពន្យល់)។ *សេចក្តីសប្បុរស* ឬ "សេចក្តីស្រឡាញ់ដ៏ស្មោះត្រង់" (មើល ហស ១០:១២ ១២:៦ និងការពន្យល់)។ *សេចក្តីអាណិតមេត្តា* មើលការពន្យល់ ១:១២ ។
**៧:១០** *សង្កត់សង្កិន* ពាក្យនេះមានប្រើច្រើនដងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ (ឧទាហរណ៍ អម ២:៦–៨ និងការពន្យល់ ៤:១ ៥:១១–១២,២១–២៤ ៨:៤–៦) ។ *ស្រីមេម៉ាយ កូនកំព្រា ពួកអ្នកស្នាក់នៅ ឬមនុស្សទាល់ក្រឡើយ* មើល ចទ ១០:១៨ អស ១:១៧ និងការពន្យល់, យរ ៥:២៨ យក ១:២៧ ១យហ ៣:១៦–១៨ ។ នៅតំបន់មជ្ឈិមបូព៌ាសម័យដើម ស្តេចដែលល្អជាអ្នកដែលការពារអ្នកដែលត្រូវគេគៀបសង្កត់ និងអ្នកដែលទាល់ក្រ ។ *គិតគូរបង្កើតការអាក្រក់ នៅក្នុងចិត្ត ទាស់នឹងបងប្អូនខ្លួន* មើល ៨:១៧ ។ ពាក្យនេះក៏អាចមានន័យថា គិតអាក្រក់ពីគ្នាទៅវិញទៅមកផងដែរ ។
**៧:១១** *គេ* គឺពួកព្ធយុកោនៅមុនសម័យនិរទេស ដែលមានដូចជា "ពួកហោរាជាន់ដើម" នៅក្នុង ខ.១២ ។ *គេចស្មាចេញ* មើល ចទ ៩:៦,១៣,២៧។ *ហើយចុកត្រចៀក ដើម្បីមិនឱ្យឮវិញ* មើល ទដ ៥៨:៤ អស ៦:១០ និងការពន្យល់ ។ ធៀបនឹង អស ៣៣:១៥ ។
**៧:១២** *រឹងដូចជាថ្មដែកភ្លើង* មើល អគ ៣:៨–៩ ។ *ព្រះបន្ទូល . . . ចាត់ព្រះវិញ្ញាណ* ពាក្យទំនាយដែលពួកហោរាថ្លែង គឺមានព្រះវិញ្ញាណទ្រង់ជាអ្នកបណ្តាល(មើល នហ ៩:៣០ ២ពត ១:២១ និងការពន្យល់)។ *សេចក្តីក្រោធខ្លាំង* មើល ១:២,១៥ ។
**៧:១៣** មើលការពន្យល់ ១:៣ ។
**៧:១៤** *កំចាត់កំចាយគេ* គឺជាបណ្តាសា ចំពោះការល្មើសនឹងសេចក្តីសញ្ញា (ចទ ២៨:៣៦–៣៧,៦៤–៦៨ និងការពន្យល់ ២៨:៦៤) ។ *ខ្យល់កួច* មើល សភ ១:២៧ និងការពន្យល់ អស ៤០:២៤ ហស ៤:១៩ ។ *ស្រុក . . . ទៅជាទីខូចបង់* មើល ចទ ២៨:៤១–៤២,៤៥–៥២ ។ *ដល់ម្ល៉េះបានជា* មានន័យថា ដោយសារតែអំពើបាបរបស់ពួកគេ ។ *ស្រុកដ៏លំអ* មើល ទដ ១០៦:២៤ និងការពន្យល់ ។
**៨:១–២៣** វគ្គនេះនិយាយអំពី សេចក្តីសន្យាទាំងដប់ អំពីព្រះពរ ដែលព្រះពរនីមួយៗចាប់ផ្តើមឡើងដោយពាក្យ "នេះជាព្រះបន្ទូលយ៉ាងធ្ងន់នៃព្រះយេហូវ៉ា"(ខ.២,៣,៤,៦,៧,៩,១៤,១៩,២០,២៣) ។
**៨:១,១៨** មើលការពន្យល់ ៤:៨ ។
**៨:២** *សេចក្តីប្រច័ណ្ឌ* មើល ១:១៤ និងការពន្យល់ ។
**៨:៣** *អញបានវិលមក* មើល ១:៣ និងការពន្យល់, ១:១៦ ។ *អាស្រ័យ* មើល

នោះ ក្រុងយេរូសាឡិមនឹងបានហៅថា ជាទីក្រុងនៃសេចក្តី
ពិត[ង] ហើយភ្នំ[ច]របស់ព្រះយេហូវ៉ានៃពួកពលបរិវារ នឹង
បានហៅថា ជាភ្នំបរិសុទ្ធ[ឆ] ៤ព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់មានបន្ទូលដូច្នេះ នឹងនៅមានបុរសចាស់ និងស្ត្រីចាស់
អង្គុយតាមផ្លូវក្រុងយេរូសាឡិមទៀត[ជ] គ្រប់គ្នាកាន់ឈើច្រត់
នៅដៃរៀងខ្លួន ដោយព្រោះអាយុច្រើនហើយ ៥អស់ទាំង
ផ្លូវទីក្រុងនឹងបានពេញដោយកូនប្រុសកូនស្រី ដែលកំពុងតែ
លេងក្នុងផ្លូវ[ឈ] ៦ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មាន
បន្ទូលដូច្នេះ នៅគ្រានោះ បើការនេះមើលទៅជាទីប្លែក
ភ្នែកដល់សំណល់ជនជាតិនោះ[ញ] នោះតើត្រូវបានជាទីប្លែក
ភ្នែកដល់អញដែរឬ[ដ] នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ា
នៃពួកពលបរិវារ ៧ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់
មានបន្ទូលដូច្នេះថា មើល អញនឹងជួយសង្គ្រោះរាស្ត្រអញ
ឱ្យរួចពីស្រុកខាងកើត ហើយពីស្រុកខាងលិចដែរ[ឋ] ៨អញ
នឹងនាំគេមក[ឌ] នោះគេនឹងអាស្រ័យនៅ[ឍ]ក្នុងក្រុងយេរូ–
សាឡិម គេនឹងបានជារាស្ត្ររបស់អញ[ណ] ហើយអញនឹងបាន
ជាព្រះដល់គេ[ត] ដោយសេចក្តីពិតនឹងសេចក្តីសុចរិត ។
៩ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះ
ថា ចូរឯងរាល់គ្នាមានកំឡាំងដៃចុះ[ថ] គឺឯង ដែលសព្វថ្ងៃ
នេះ ឮពាក្យទាំងប៉ុន្មាន ពីមាត់ពួកហោរា[ទ] ដែលបាននៅ
ក្នុង គ្រាគេដាក់ឫស[ធ]ព្រះវិហាររបស់ព្រះយេហូវ៉ានៃពួក
ពលបរិវារ ដើម្បីឱ្យបានសង់ព្រះវិហារឡើង ១០ដ្បិតកាល
មុនគ្រានោះ គ្មានថ្លៃឈ្នួល[ន]ដល់មនុស្សឬសត្វទេ ក៏គ្មាន
សេចក្តីសុខ[ប] ដល់មនុស្ស ដែលចេញឬចូលផង ដោយព្រោះ
ពួកខ្មាំងសត្រូវ ដ្បិតអញបានធ្វើឱ្យមនុស្សទាំងអស់ ទាស់
ទទឹងនឹងអ្នកជិតខាងរៀងខ្លួន ១១តែព្រះយេហូវ៉ានៃពួកពល
បរិវារ ទ្រង់មានបន្ទូលថា ឥឡូវនេះ អញនឹងមិនប្រព្រឹត្តនឹង
សំណល់ជនជាតិនេះ ដូចកាលជាន់មុនទៀតទេ[ផ] ១២ដ្បិតនឹង
មានពូជនៃសេចក្តីសុខ ឯដើមទំពាំងបាយជូរនឹងបង្កើត
ផល[ព] ហើយដីនឹងចំរើនផលដែរ[ភ] ផ្ទៃមេឃក៏នឹងទំលាក់
សន្សើមមក[ម] ហើយអញនឹងឱ្យសំណល់នៃជនជាតិនេះទទួល
របស់ទាំងនេះទុកជាមរដក[យ,រ] ១៣ឱពួកវង្សយូដា និងពួក
វង្សអ៊ីស្រាអែលអើយ ពីដើមឯងជាទីផ្តាសា[ល] នៅកណ្តាល
អស់ទាំងសាសន៍យ៉ាងណា នោះអញនឹងជួយសង្គ្រោះ[វ]ឯង
រាល់គ្នា ឱ្យបានជាពរវិញយ៉ាងនោះដែរ[ស] កុំឱ្យខ្លាចឡើយ[ហ]
ចូរឱ្យមានកំឡាំងដៃវិញចុះ[ឡ]។

**៨:៣** ង ទដ ១៥:២ អស ១:២៦ ៤៨:១ យរ ៣៣:១៦ ច យរ ២៦:១៨ ឆ អស ១:២៦ មីក ៤:១ **៨:៤** ជ អស ៦៥:២០ **៨:៥** ឈ យរ ៣០:២០ ៣១:១៣ **៨:៦** ញ ទដ ១១៨:២៣ ១២៦:១–៣ ដ យរ ៣២:១៧,២៧ **៨:៧** ឋ ទដ ១០៧:៣ អស ១១:១១ ៤៣:៥ **៨:៨** ឌ អគ ៣៧:១២ សក ១០:១០ ឍ យរ ៣១:២៤ ណ អស ៥១:១៦ អគ ១១:១៩–២០ ៣៦:២៨ សក ២:១១ ហព ៨:១០ ត យរ ១១:៤ សក ១០:៦ **៨:៩** ថ ហាក ២:៤ ទ អរ ៥:១ ធ អរ ៣:១១ **៨:១០** ន អស ៥:១០ ហាក ១:៦ ប ២របា ១៥:៥ **៨:១១** ផ អស ១២:១ **៨:១២** ព ទដ ៨៥:១២ យអ ២:២២ ភ ទដ ៦៧:៦ ម លប ២៧:២៨ យ ទដ ៦៥:១៣ អស ៦០:២១ អប ១:១៧ រ ហស ២:២១ **៨:១៣** ល ជន ៥:២៧ ចទ ១៣:១៥ ទដ ១០២:៨ យរ ៤២:១៨ វ ទដ ៤៨:៨ ស លប ១២:២ ហ យអ ២:១៤ ហ ហាក ២:៥ ឡ ខ.៩

ការពន្យល់ ២:១០ ។ *ទីក្រុងនៃសេចក្តីពិត* ធៀបនឹង ខ.១៦ អស ១:២៦ និងការពន្យល់ ។ *ភ្នំបរិសុទ្ធ* ធៀបនឹង ១៤:២០–២១ ។

**៨:៤–៥** មើល អស ១១:៦–៩ និងការពន្យល់, ៦៥:២០–២៥ ។

**៨:៦,១១–១២** *សំណល់* មើលការពន្យល់ អស ១:៩ ១០:២០–២២ ។

**៨:៦** *តើត្រូវបានជាទីប្លែកភ្នែកដល់អញដែរឬ* មើល យរ ៣២:២៧ និងការពន្យល់ ។

**៨:៧** *ជួយសង្គ្រោះរាស្ត្ររបស់អញ* គឺដោយការរំដោះពួកគេពីការនិរទេសចំណាង និងការខ្ចាត់ខ្ចាយរបស់ពួកគេ(ធៀបនឹង អស ១១:១១–១២ ៤៣:៥–៧ យរ ៣០:៧–១១ ៣១:៧–៨)។ *ពីស្រុកខាងកើត ហើយពីស្រុកខាងលិច* គឺពីជើងមេឃម្ខាងដល់ជើងមេឃម្ខាងទៀត នៅកន្លែងណាដែលមានមនុស្សរស់នៅ(ធៀបនឹង ទដ ៥០:១ ១១៣:៣ មឡ ១:១១) ។

**៨:៨** *គេនឹងបានជារាស្ត្ររបស់អញ ហើយអញនឹងបានជាព្រះដល់គេ* គឺជាព្រះបន្ទូលនៃសេចក្តីសញ្ញា ដែលនាំមកនូវការប្រកបស្និទ្ធស្នាលរវាងព្រះនិងរាស្ត្ររបស់ទ្រង់ តាមសេចក្តីសញ្ញា (មើល ១៣:៩ លប ១៧:៧ និងការពន្យល់ នក ៦:៧ ២៩:៤៥–៤៦ លវ ១១:៤៥ ២២:៣៣ ២៥:៣៨ ២៦:១២,៤៥ ជន ១៥:៤១ ចទ ២៩:១៣ យរ ២៤:៧ និងការពន្យល់ អគ ៣៤:៣០–៣១ ៣៦:៣៨ ៣៧:២៧ ហស ១:៩–១០ ១១:២០ ២កថ ៦:១៦ ហព ៨:១០ វវ ២១:៣)។ *សេចក្តីពិត និងសេចក្តីសុចរិត* ព្រះអម្ចាស់ទ្រង់ស្តារពួកយូដាឡើងវិញ ឱ្យបានរស់នៅតាមសេចក្តីសញ្ញា ប្រកបដោយព្រះពរ ហើយទ្រង់ធ្វើការនេះ ដោយសេចក្តីស្មោះត្រង់ (ជាទីពឹងជ្រក) និងសេចក្តីសុចរិតនៃព្រះ ។

**៨:៩** *ពួកហោរា* គឺមានលោកហាកាយ (១:១) និងសាការី (១:១ មើល អរ ៥:១–២)។ *មានកំឡាំងដៃចុះ* មើល ខ.១៣ ។ នៅក្នុង ពច ៧:១១ តាមព្រះគម្ពីរហេព្រើពាក្យ នេះមានន័យថា "ចូរក្លាហានចុះ" ។

**៨:១០** *មុនគ្រានោះ* គឺមុនពេលចាប់ផ្តើមសាងសង់ព្រះវិហារ (ខ.៩)។ *គ្មានថ្លៃឈ្នួល* មើល ហាក ១:៦–១១ ២:១៥–១៩ ។ *ពួកខ្មាំងសត្រូវ* ឧទាហរណ៍ពួកសាសន៍សាម៉ារី (អរ ៤:១–៥) ។

**៨:១១** *ឥឡូវនេះ* មានន័យថា សេចក្តីបណ្តាសាលែងមានតទៅទៀតហើយ ហើយឥឡូវនេះព្រះអម្ចាស់ទ្រង់ចាប់ផ្តើមស្តារពួកគេឡើងវិញ ។

**៨:១២** ខនេះខុសពី ហាក ១:១០–១១ ។ នៅក្នុង ហាក ២:១៩ ព្រះអម្ចាស់ទ្រង់បានប្រទានសេចក្តីទំនាយដូចនៅក្នុងខនេះផងដែរ ។ ដីដែលមានជីជាតិ និងសេចក្តីសប្បុរស គឺជាព្រះពរដែលព្រះអម្ចាស់ទ្រង់សន្យាប្រទានតាមសេចក្តីសញ្ញានៅក្នុង លវ ២៦:៣–១០ ចទ ២៨:១១–១២ ធៀបនឹង អគ ៣៤:២៥–២៧ ហស ១:២១–២៤ ។

**៨:១៣** *ពួកវង្សយូដា និងពួកវង្សអ៊ីស្រាអែល* សាសន៍អ៊ីស្រាអែលទាំងអស់នឹងបានពិសោធន៍នឹងការដោះឱ្យមានសេរី និងព្រះពរ(ធៀបនឹង យរ ៣១:១–៣១ អគ ៣៧:១៥–២៨)។ *ជាទីផ្តាសា នៅកណ្តាលអស់ទាំងសាសន៍* គឺជាសេចក្តីបណ្តាសាមួយនៅក្នុងចំណោមសេចក្តីបណ្តាសនៅក្នុងសេចក្តីសញ្ញា ហើយជាការដាក់ទោសចំពោះការមិនស្តាប់បង្គាប់ដូចដែលព្រះទ្រង់ព្រមាននៅក្នុង ចទ ២៨:១៥–៦៨ (សូមមើល ចទ ២៨:៣៧ យរ ២៤:៩ ២៥:១៨) ។ *ពរ* មើល ខ.២០–២៣ ធៀបនឹង លប ១២:២ ។ *ចូរឱ្យមានកំឡាំងដៃវិញចុះ* មើលការពន្យល់ ខ.៩ ។

១៤ដ្បិតព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូល
ដូច្នេះថា កាលពួកឰយុកោឯងបានបណ្ដាលឱ្យអញមាន
សេចក្តីក្រោធ[អ] នោះអញបានគិតនឹងធ្វើអាក្រក់ដល់ឯង
រាល់គ្នា ឥតប្រែចិត្តឡើយជាយ៉ាងណា ១៥សព្វថ្ងៃនោះ អញ
បានគិតធ្វើល្អ[ក]ដល់ក្រុងយេរូសាឡិម និងដល់ពួកវង្សយូដា[ខ]
ក៏យ៉ាងនោះដែរ កុំឱ្យខ្លាចឡើយ នេះជាព្រះបន្ទូលរបស់
ព្រះយេហូវ៉ានៃពួកពលបរិវារ ១៦នេះជាការដែលឯង
រាល់គ្នាត្រូវធ្វើ គឺត្រូវឱ្យគ្រប់គ្នានិយាយសេចក្តីពិតនឹងអ្នក
ជិតខាងខ្លួន ហើយត្រូវឱ្យសំរេចតាមសេចក្តីយុត្តិធម៌[គ]ដ៏ពិត[ឃ]
និងសេចក្តីសុខ នៅក្នុងទ្វារក្រុងរបស់ឯងរាល់គ្នា[ង] ១៧កុំ
ឱ្យពួក ឯងណាមួយគិតគូរ បង្កើតការអាក្រក់[ច]ក្នុងចិត្តទាស់
នឹងអ្នកជិតខាងខ្លួនឡើយ ក៏កុំឱ្យចូលចិត្តនឹងពាក្យស្បថកំភូត
ដែរ[ឆ] ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញស្អប់អស់ទាំង
អំពើយ៉ាងនោះណាស់ ។

១៨ព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារក៏មក
ដល់ខ្ញុំថា ១៩ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មាន
បន្ទូលដូច្នេះ ឯពេលតមអត់ក្នុងខែអាសាធ[ឆ] ខែស្រាពណ៍[ជ]
ខែអស្សុជ[ឈ] ហើយនៅខែបុស្ស[ញ] នោះត្រូវបានជាពេលរីក
រាយសប្បាយ[ដ] ហើយជាបុណ្យគ្រឹកគ្រេងដល់ពួកវង្សយូដា
វិញ ដូច្នេះ ចូរស្រឡាញ់សេចក្តីពិត[ឋ]និងសេចក្តីសុខចុះ
២០ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះថា
នឹងនៅមានគ្រាទៀត ដែលសាសន៍ផ្សេង ហើយមនុស្ស
នៅទីក្រុងជាច្រើននឹងមក ២១ពួកអ្នកនៅស្រុក១នឹងទៅឯ
ស្រុក១ទៀតបបួលថា ចូរយើងប្រញាប់ឡើងទៅទូលអង្វរ[ឌ]
ដល់ព្រះយេហូវ៉ា ហើយស្វែងរក[ឍ]ព្រះយេហូវ៉ានៃពួកពល
បរិវារចុះ ឯខ្ញុំក៏នឹងទៅដែរ ២២អើ ជនជាតិជាច្រើន និង
សាសន៍យ៉ាងខ្លាំងពូកែ នឹងមកស្វែងរកព្រះយេហូវ៉ានៃពួក
ពលបរិវារ នៅក្រុងយេរូសាឡិម ដើម្បីទូលអង្វរដល់
ទ្រង់[ណ] ២៣ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូល
ដូច្នេះថា នៅគ្រានោះមនុស្ស១០នាក់ពីភាសាផ្សេងៗ នឹង
ចាប់តោង ជាយអាវរបស់សាសន៍យូដាម្នាក់ ដោយពាក្យថា
យើងខ្ញុំនឹងទៅជាមួយនឹងអ្នកដែរ ពីព្រោះយើងខ្ញុំបានឮថា
ព្រះទ្រង់គង់ជាមួយនឹងអ្នករាល់គ្នា[ត] ។

## ការជំនុំជម្រះខ្មាំងសត្រូវរបស់អ៊ីស្រាអែល

**៩** ១នេះជាព្រះបន្ទូលយ៉ាងធ្ងន់[ក]នៃព្រះយេហូវ៉ា ពីដំណើរ
ស្រុកហាត្រាក ព្រះបន្ទូលនោះនឹងស្ថិតលើក្រុងដាម៉ាស[ខ]

**៨:១៤** អ អគ ២៤:១៤ **៨:១៥** ឡ ខ.១៣ យរ ២៩:១១ មីក ៧:១៨–២០ ក យរ ៣១:២៨ ៣២:៤២ **៨:១៦** ខ អគ ១៨:៨ គ ទដ ១៥:២ យរ ៣៣:១៦ អភ ៤:២៥ ឃ អគ ៤៥:៩ អម ៥:១៥ សក ៧:៩ **៨:១៧** ង សភ ៣:២៩ ច សភ ៦:១៦–១៩ យរ ៧:៩ សក ៥:៤ **៨:១៩** ឆ ២ពវ ២៥:៧ យរ ៣៩:២ ជ យរ ៥២:១២ ឈ ២ពវ ៥២:២៥ ញ យរ ៥២:៤ ដ ទដ ៣០:១១ ឋ ខ.១៦ **៨:២១** ឌ សក ៧:២ ឍ យរ ២៦:១៩ **៨:២២** ណ ទដ ៨៦:៩ ១១៧:១ អស ២:២–៣ ៤៤:៥ ៤៥:១៤ ៤៩:៦ សក ២:១១ **៨:២៣** ត ទដ ១០២:២២ អស ១៤:១ ៤៥:១៤ ៥៦:៣ ១កថ ១៤:២៥ **៩:១** ក អស ១៣:១ យរ ២៣:៣៣ ខ អស ១៧:១ អម ១:៥

**៨:១៤–១៧** ខ.១៤–១៥ បានបញ្ជាក់អំពីផ្នែកដែល ព្រះអម្ចាស់ទ្រង់ត្រូវធ្វើនៅក្នុងការស្អាងរាស្ត្រទ្រង់ដើម្បីឱ្យបានទទួលព្រះពរឡើងវិញ ខ.១៦–១៧ និយាយអំពីការដែលពួកគេត្រូវធ្វើនៅក្នុងការស្អាងនោះ ។

**៨:១៦** *ទ្វារក្រុង* មើល លប ១៩:១ និងការពន្យល់ ២សយ ១៨:២៤ ។

**៨:១៧** *ពាក្យស្បថកំភូត* មើលការពន្យល់ ៥:៣ ។ *អញស្អប់អស់ទាំងអំពើយ៉ាងនោះ* សភ ៦:១៦–១៩ និយាយអំពីការប្រាំពីរយ៉ាងដែលព្រះអម្ចាស់ទ្រង់ស្អប់ ហើយក្នុងនោះមានការបីយ៉ាងដែលមាននិយាយនៅក្នុង ខ.១៦–១៧ ដែលមានដូចជា "អណ្តាតកំភូត" "ចិត្តដែលបង្កើតការអាក្រក់" និង "ស្មរបន្ទាល់ក្លែងក្លាយ"។

**៨:១៩** មើល ៧:២–៦ ។ *ខែអាសាធ* ការតមអត់ក្នុងខែនេះ ជាការសោកសង្រេងចំពោះការរំលំកំផែងក្រុងយេរូសាឡិម ដោយស្តេចនេប៊ូក្នេសា (២ពវ ២៥:៣–៤ យរ ៣៩:២)។ *ខែស្រាពណ៍* ការតមអត់ក្នុងខែនេះគឺដើម្បីរំឭកពីការដុតបំផ្លាញព្រះវិហារ និងសំណង់សំខាន់ៗដទៃទៀត(២ពវ ២៥:៨–១០)។ *ខែអស្សុជ* ការតមក្នុងខែនេះបញ្ជាក់អំពីការធ្វើឃាតលោកកេដាលា(២ពវ ២៥:២២–២៥ យរ ៤១:១–៣)។ *ខែបុស្ស* ការតមក្នុងខែនេះគឺដើម្បីកាន់ទុក្ខការឡោមព័ទ្ធក្រុងយេរូសាឡិម(២ពវ ២៥:១ យរ ៣៩:១ អគ ២៤:១–២) ។ *បុណ្យគ្រឹកគ្រេង* ធៀបនឹង អស ៦៥:១៨–១៩ យរ ៣១:១០–១៤ ។

**៨:២០–២៣** វគ្គនេះនិយាយអំពីទំនាយពីការដែលសាសន៍ដទៃនឹងស្វែងរកព្រះអម្ចាស់ មើល ២:១១ និងការពន្យល់, មីក ៤:១–៥ ។

**៨:២២** *យ៉ាងខ្លាំងពូកែ* ឬមានគ្នាច្រើនសន្ធឹក (ដូចនៅក្នុង នក ១:៩) បង្ហាញពីការដែលព្រះអម្ចាស់សន្យានឹងលោកអ័ប្រាហាំថា នឹងប្រទានពរដល់សាសន៍ដទៃតាមរយៈលោក(លប ១២:៣ កទ ៣:៨,២៦–២៩ អស ៥៥:៥ ៥៦:៦–៧ មក ១១:១៧ និងការពន្យល់) ។

**៨:២៣** *១០នាក់* តាមភាសាហេព្រើ ការប្រើចំនួននេះគឺដើម្បីបង្ហាញពីចំនួនច្រើន និងគ្រប់ (មើល លប ៣១:៧ និងការពន្យល់ លវ ២៦:២៦ ជន ១៤:២២ និងការពន្យល់ ១សយ ១:៨ នហ ៤:១២)។ *សាសន៍យូដា* ពាក្យនេះប្រើដំបូងបំផុតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ សម្រាប់ពួកអ្នករស់នៅក្នុងស្រុកយូដាបន្ទាប់ពីសម័យនិរទេស ។ *យើងខ្ញុំបានឮថា ព្រះទ្រង់គង់ជាមួយនឹងអ្នករាល់គ្នា* ការកោតខ្លាចព្រះអាចនាំឱ្យអ្នកដទៃជឿព្រះផងដែរ (លប ២១:២២ ២៦:២៨ ៣០:២៧ មើលការពន្យល់ លប ៣៩:២–៦ ១កថ ១៤:២៤) ។

**៩:១–៨** វគ្គនៃបទគម្ពីរនេះនិយាយអំពីការដែលព្រះអម្ចាស់ទ្រង់យាងឆ្ពោះទៅរកក្រុងយេរូសាឡិមដែលនៅខាងត្បូង ដើម្បីបំផ្លាញសត្រូវរបស់សាសន៍អ៊ីស្រាអែល ។ តាមប្រវត្តិសាស្ត្រ អ្នកដែលព្រះអម្ចាស់ប្រើនៅក្នុងការបំផ្លាញនេះ គឺស្តេចអ័ឡេចក្សានឌ័រ អស្ចារ្យនៃចក្រភពក្រិច(ឆ្នាំ ៣៣៣–៣៣២ មុន គ.ស.) ។

**៩:១** *ព្រះបន្ទូលយ៉ាងធ្ងន់នៃព្រះយេហូវ៉ា* តាមព្រះគម្ពីរហេព្រើ ឃ្លានេះឃើញមានប្រើតែពីរដងប៉ុណ្ណោះនៅក្នុងព្រះគម្ពីរសញ្ញាចាស់ (១២:១ មទ្ឡ ១:១) នាំឱ្យគេយល់ថា ព្រះគម្ពីរ សក ៩–១៤ និងព្រះគម្ពីរម៉ាឡាគី ហាក់ដូចជាត្រូវបានសរសេរឡើងក្នុងពេលដំណាលគ្នា ។ *ព្រះបន្ទូលនោះ* មើល ១:១ ១២:១ ហស ១:១ និងការពន្យល់ ។ *ស្រុកហាត្រាក* នៅភាគខាងជើង

ដ្បិតព្រះនេត្រនៃព្រះយេហូវ៉ា ទតមើលអស់ទាំងមនុស្សជាតិ
ដូចជាទតមើលពូជអំបូរអ៊ីស្រាអែលទាំងប៉ុន្មានដែរ ២ព្រម
ទាំងស្រុកហាម៉ាត[គ] ជាស្រុកដែលជាប់ព្រំដែននឹងគេ ហើយ
ក្រុងទីរ៉ុស[ឃ]និងក្រុងស៊ីដូន[ង]ផង ទោះបើមានប្រាជ្ញាជាច្រើន
ក៏ដោយ ៣ក្រុងទីរ៉ុសបានធ្វើទីមាំមួនសំរាប់ខ្លួន ក៏បាន
ប្រមូលប្រាក់គរទុក ដូចជាធូលីដី និងមាសយ៉ាងវិសេស
ដូចជាភក់នៅក្នុងផ្លូវ[ច] ៤តែមើល ព្រះអម្ចាស់ ទ្រង់នឹងទំលាក់
គេចេញ ព្រមទាំងវាយ[ឆ]កំឡាំងរបស់គេ ដែលនៅក្នុង
សមុទ្រ ហើយទីក្រុងនោះនឹងត្រូវឆេះដោយភ្លើង[ជ] ៥ឯក្រុង
អាសកាឡូន[ឈ] ក៏នឹងឃើញដែរ ហើយនិងមានសេចក្ដីភ័យ
ព្រមទាំងក្រុងកាសាផង នោះគេនឹងមានសេចក្ដីឈឺចាប់
ជាខ្លាំងនឹងក្រុងអេក្រុន ដ្បិតទីសង្ឃឹមរបស់គេនឹងទៅជាទី
អាម៉ាស់ខ្មាសវិញ ឯស្ដេចនឹងវិនាសបាត់ពីក្រុងកាសា
ហើយក្រុងអាសកាឡូន និងឥតមានមនុស្សអាស្រ័យនៅ
ទៀត ៦និងមានសុទ្ធតែពួកកូនកាត់នៅក្នុងក្រុងអាសដូឌ
ហើយអញនឹងបំផ្លាញ[ញ] សេចក្ដីអំនួត របស់សាសន៍ភីលីស្ទីន
៧អញនឹងដកយកឈាម ចេញពីមាត់គេ ព្រមទាំងសាច់ដែល
គួរស្អប់ខ្ពើម ចេញពីកណ្ដាលធ្មេញគេដែរ នោះគេនឹងបាន
សល់នៅសំរាប់គោរពដល់ព្រះ[ដ]នៃយើង ហើយនឹងបានដូច
ជាចៅហ្វាយនៅស្រុកយូដា ឯពួកក្រុងអេក្រុននឹងបានដូច
ជាពួកក្រុងយេប៊ូសវិញ[ឋ] ៨អញនឹងបោះទ័ពនៅព័ទ្ធជុំវិញ[ឌ]
វិហាររបស់អញ ទាស់នឹងពលទ័ព[ឍ] ដើម្បីមិនឲ្យមានគេដើរ
កាត់ ឬវិលមកវិញឡើយ និងគ្មានពួកសង្កត់សង្កិនណាដើរ
កាត់ពួកគេទៀតឡើយ ដ្បិតឥឡូវនេះ ភ្នែកអញបានឃើញ
ហើយ[ណ]។

## ការយាងមកនៃស្ដេចក្រុងស៊ីយ៉ូន

៩ឱកូនស្រីស៊ីយ៉ូនអើយ[ត] ចូររីករាយជាខ្លាំងឡើង ឱកូន
ស្រីយេរូសាឡិមអើយ ចូរស្រែកហ៊ោចុះ[ថ] មើល ស្ដេច

**៩:២** គ យរ ៤៩:២៣ ឃ អគ ២៨:១–១៩ ង លប ១០:១៥
**៩:៣** ច យប ២៧:១៦ អគ ២៨:៤
**៩:៤** ឆ អស ២៣:១១ ជ អស ២៣:១ យរ ២៥:២២ អគ ២៦:៣–៥ ២៧:៣២–៣៦ ២៨:១៨
**៩:៥** ឈ យរ ៤៧:៥
**៩:៦** ញ អស ១៤:៣០
**៩:៧** ដ យប ២៥:២ ឋ យរ ៤៧:១ យអ ៣:៤ សផ ២:៤
**៩:៨** ឌ អស ២៦:១ ឍ សក ១៤:២១

ណ អស ៥២:១ ៥៤:១៤ យអ ៣:១៧ **៩:៩** ត អស ៦២:១១ ថ ១ពវ ១:៣៩

នៃស្រុកហាម៉ាត ត្រង់តំបន់ស្ទឹងអូរុនតេ (ខ.២) ។ *ក្រុងដាម៉ាស* គឺជារដ្ឋបូរី ដែលឈានមុខគេរបស់សាសន៍ស៊ីរី (មើលការពន្យល់ ចទ ២៦:៥ អស ១៧:១) ។

**៩:២** *ព្រមទាំងស្រុកហាម៉ាត* សេចក្ដីជំនុំជម្រះនឹងធ្លាក់មកលើស្រុកហាម៉ាត ដូចស្រុកហាត្រាក និងដាម៉ាសផងដែរ ។ ស្រុកហាម៉ាតសព្វថ្ងៃ គេហៅថា ហាម៉ា (មើល អស ១០:៩ និងការពន្យល់) ។ *គេ* គឺស្រុកដាម៉ាស ។ *ក្រុងទីរ៉ុស និងក្រុងស៊ីដូន* គឺជាទីក្រុងឆ្នេរសមុទ្រនៃសាសន៍ភេនីស (សព្វថ្ងៃហៅថាសាសន៍លីបង់, មើលការពន្យល់ អស ២៣:១ ២៣:២,៤,១២) ។ ការជំនុំជម្រះក្រុងទាំងនេះ មាននៅក្នុងសេចក្ដីទំនាយ អស ២៣ អគ ២៦:៣–១៤ ២៨:២០–២៤ អម ១:៩–១០ ។

**៩:៣** *ទីមាំមួន* នៅក្នុងភាសាហេព្រើ ពាក្យនេះគឺជាន័យធៀបរបស់ពាក្យ "ទីរ៉ុស" (មានន័យថា "ថ្ម") ។ ទីមាំមួននោះ គឺជាបន្ទាយទាហាននៅលើកោះនៃក្រុងទីរ៉ុស (អស ២៣:៤ អគ ២៦:៥) ។ បន្ទាយទាហាននេះត្រូវស្ដេចអ័ឡេចក្សាន់ឌ័រកាន់កាប់ (ខ.៤) នៅឆ្នាំ ៣៣២ មុន គ.ស. ដោយការឡោមព័ទ្ធអស់រយៈពេលប្រាំពីរខែ (មើលការពន្យល់ អគ ២៦:១–២៨:១៩) ។ *ប្រាក់គរទុក ដូចជាធូលីដី ហើយមាស . . . ដូជជាភក់* ធៀបនឹង ១ពវ ១០:២១, ២៧ ។ ក្រុងទីរ៉ុសគឺជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងជំនួញ ហើយល្បីឈ្មោះខាងទ្រព្យសម្បត្តិសម្បូរហូរហៀរ (អស ២៣:២–៣,៨,១៨ អគ ២៦:១២ ២៧:៣–២៧,៣៣ ២៨:៣–៥,៧,១២–១៤,១៦–១៨) ។

**៩:៤** *កំឡាំងរបស់គេដែលនៅក្នុងសមុទ្រ* ប្រភពនៃទ្រព្យសម្បត្តិរបស់ក្រុងទីរ៉ុសគឺបានមកពីការគេងប្រវ័ញ្ចនៅក្នុងជំនួញនៅតាមសមុទ្រមេឌីទែរ៉ាណេ។

**៩:៥–៧** ទីក្រុងទាំងប៉ុន្មានរបស់សាសន៍ភីលីស្ទីនត្រូវប្រកាសអាសន្ន នៅពេលដែលស្ដេចអ័ឡេក្សាន់ឌ័រកំពុងតែវាយឈ្នះស្រុកជិតខាង ហើយសង្គ្រាមនោះកាន់តែជិតមកដល់ពួកគេ ។

**៩:៥** *ក្រុងអេសកាឡូន . . . ក្រុងកាសា . . . ក្រុងអេក្រុន* គឺជាក្រុងឈានមុខទាំងបីរបស់សាសន៍ភីលីស្ទីន ។ *ទីសង្ឃឹមរបស់គេនឹងទៅជាទីអាម៉ាស់ខ្មាសវិញ* ក្រុងអេក្រុននឹងត្រូវរងគ្រោះដូចក្រុងដែលនៅខាងជើងបំផុតនៃស្រុកភីលីស្ទីនដែរ ។ ក្រុងនេះសង្ឃឹមថាក្រុងទីរ៉ុសអាចទប់ជំនន់នៃការ វាយលុកនោះបាន តែសេចក្ដីសង្ឃឹមនេះនឹងត្រូវក្លាយជាការខកចិត្ត ។

**៩:៦** *ពួកកូនកាត់* នៅសម័យបន្ទាប់ពីសម័យនិរទេស ពួកអ៊ីស្រាអែលមានពួកកូនកាត់ជាច្រើននាក់ (១៣:២៣–២៤) ។ *ក្រុងអាសដូឌ* គឺជាក្រុងទីបួនដែលត្រូវបំផ្លាញក្រោយគេ (មើលការពន្យល់ ខ.៥ អម ១:៨) ។ *អញ* គឺព្រះអម្ចាស់ ។ *សាសន៍ភីលីស្ទីន* មើលការពន្យល់ លប ១០:១៤ ។ នៅសម័យមុនពួកសាសន៍ភីលីស្ទីនបានគ្រប់គ្រងទឹកដីកាណានយ៉ាងធំទូលាយ បណ្ដាលឱ្យគេហៅឈ្មោះទឹកដីនេះថាស្រុកភីលីស្ទីន ។

**៩:៧** *ឈាម* គឺឈាមដែលពួកគេថ្វាយយញ្ញបូជាដល់រូបព្រះ ។ *សាច់ដែលគួរស្អប់ខ្ពើម* គឺជាអាហារដែលហាមឃាត់ក្នុងក្រឹត្យវិន័យ ។ *ពួកក្រុងយេប៊ូស* គឺជាអ្នកស្រុកដើមនៃទឹកដីក្រុងយេរូសាឡិម (ការពន្យល់ លប ១០:១៦ ២សយ ៥:៦) ពួកគេបានចូលមករស់នៅចំរុះនៅក្នុងស្រុកយូដា (ឧទាហរណ៍ លោកអ័រ៉ោណា នៅក្នុង ២សយ ២៤:១៦–២៤) ។ ដូចនេះពួកគេក៏ត្រូវរស់នៅជាមួយសំណល់នៃសាសន៍ភីលីស្ទីនផងដែរ ។

**៩:៨** *ទាស់នឹងពលទ័ព* មើល ២:៥ ។ ស្ដេចអ័ឡេចក្សានឌ័របានលើកលែងការបំផ្លាញចំពោះព្រះវិហារ និងទីក្រុងយេរូសាឡិម ។ *ពួកសង្កត់សង្កិន* តាមព្រះគម្ពីរហេព្រើរពាក្យនេះគឺត្រូវបានបកប្រែថា "មេដំរួត" នៅក្នុង នក ៣:៧ ៥:៦,១០ និងនៅក្នុងបទគម្ពីរផ្សេងទៀតផងដែរ ដូចនេះ ពាក្យនេះត្រូវបានប្រើសម្រាប់រំឭកពីការសង្កត់សង្កិនរបស់ពួកអេស៊ីព្ទផងដែរ ។ *បានឃើញហើយ* មើល នក ៣:៧ ទដ ៣២:៨ ទដ ១២១ ។

**៩:៩** ខនេះមានប្រើនៅក្នុងព្រះគម្ពីរសញ្ញាថ្មីទាក់ទងនឹងព្រះមែស៊ី ហើយនិយាយសំដៅទៅលើក្បួនដង្ហែរនៃជ័យជំនះនៃព្រះយេស៊ូវចូលទៅក្នុងក្រុងយេរូសាឡិមក្នុងឋានៈជាក្សត្រ (មថ ២១:៥ យក ១២:១៥) ។ *កូនស្រីស៊ីយ៉ូន . . . កូនស្រីយេរូសាឡិម* គឺជាពាក្យប្រៀបធៀបរបស់ពាក្យក្រុងយេរូសាឡិម (មើលការពន្យល់ ២ពវ ១៩:២១) ។ *ស្ដេចរបស់នាង* គឺស្ដេចដ៏ជាព្រះមែស៊ី

របស់នាង ទ្រង់យាងមកឯនាង[ទ] ទ្រង់ជាអ្នកសុចរិត ហើយ
មានជ័យជំនះ[ធ] ទ្រង់ក៏សុភាព ទ្រង់គង់លើសត្វលា[ន] គឺជាលា
ជំទង់ ជាកូនរបស់មេលា[ប] ១០អញនឹងកាត់រទេះចំបាំងចេញ
ពីស្រុកអេប្រាអិម និងសេះចេញពីក្រុងយេរូសាឡិម ដែរ
ឯធ្នូចំបាំងនឹងត្រូវកាត់ចេញ[ផ] ហើយទ្រង់នឹងមានបន្ទូល
ជាសេចក្តីសន្តិសុខ[ព]ដល់អស់ទាំងសាសន៍ ឯអំណាចគ្រប់
គ្រងរបស់ទ្រង់ នឹងបានចាប់តាំងពីសមុទ្រម្ខាងដល់សមុទ្រ
ម្ខាង ហើយពីទន្លេធំ រហូតដល់ចុងផែនដីបំផុត[ភ] ។
១១ឯនាងដែរ អញបានលែងពួកជាប់គុក[ម]របស់នាង
ឱ្យរួចចេញពីរណ្តៅដែលគ្មានទឹក[យ] ដោយព្រោះឈាមនៃ
សេចក្តីសញ្ញា[រ]របស់ឯង ១២ឱពួកអ្នកជាប់គុក ដែលមាន
សេចក្តីសង្ឃឹមអើយ ចូរវិលមកឯទីមាំមួនចុះ[ល] នៅថ្ងៃនេះ
ឯង អញប្រកាសថា អញនឹងសងឯង១ជា២[វ] ១៣ដ្បិតអញ
បានដំឡើងយូដាដូចជាធ្នូ[ស] ហើយដាក់អេប្រាអិមនៅធ្នូ[ហ]
អញទុកដូចជាព្រួញ ឱស៊ីយ៉ូនអើយ អញនឹងដាស់តឿន
កូនប្រុសរបស់ឯង ឱ្យទាស់នឹងកូនប្រុសរបស់សាសន៍ក្រេក[ឡ]
ហើយនិងធ្វើឱ្យឯង បានដូចជាដាវរបស់មនុស្សខ្លាំងពូកែ[អ] ។

**៩:៩** ទ ទដ ២៤:៧ ១៤៩:២ មីក ៤:៨ ធ អស ៩:៦–៧ ៤៣:៣–១១ យរ ២៣:៥–៦ សផ ៣:១៤–១៥ សក ២:១០ ន លប ៤៩:១១ ១ពវ ១:៣៣ ប មថ ២១:៥ យហ ១២:១៥ **៩:១០** ផ ហស ១:៧ ២:១៨ មីក ៤:៣ ៥:១០ សក ១០:៤ ព អស ២:៤ ភ ទដ ៧២:៨ **៩:១១** ម អស ១០:៤ ៤២:៧ យ យរ ៣៨:៦ រ នក ២៤:៨ មថ ២៦:២៨ លក ២២:២០ **៩:១២** ល យអ ៣:១៦

## ព្រះអម្ចាស់ទ្រង់នឹងបង្ហាញអង្គទ្រង់

១៤គេនឹងឃើញព្រះយេហូវ៉ា ស្ថិតពីលើពួកកូនប្រុស[ក]
របស់ឯងព្រួញទ្រង់នឹងហោះចេញទៅដូចជាផ្លេកបន្ទោរ[ខ]
ហើយព្រះអម្ចាស់យេហូវ៉ាទ្រង់នឹងផ្លុំត្រែ[គ] ក៏នឹងចេញទៅ
ក្នុងខ្យល់កួច[ឃ]ពីខាងត្បូង ១៥ព្រះយេហូវ៉ានៃពួកពលបរិវារ
ទ្រង់នឹងការពារ[ង]គេ គេនឹងលេបបំបាត់ ហើយឈ្នះគ្រាប់
ក្រួសដែលបាញ់មក[ច] គេនឹងផឹក ហើយធ្វើសូរសព្ទ ដូចជា
សូរដែលកើតដោយសារស្រាទំពាំងបាយជូរ[ឆ] គេនឹងបាន
ពេញដូចជាចាន[ជ] គឺជាចាននៅជ្រុង[ឈ]អាសនា ១៦នៅថ្ងៃ
នោះ[ញ] ព្រះយេហូវ៉ា ជាព្រះនៃគេ ទ្រង់នឹងជួយសង្គ្រោះគេ
ទុកដូចជាហ្វូងចៀម ជារាស្ត្ររបស់ទ្រង់ ដ្បិតគេនឹងបាន

វ ចទ ២១:១៧ អស ៤០:២ **៩:១៣** ស ២សយ ២២:៣៥ ហ អស ៤៩:២ ឡ យអ ៣:៦ អ យរ ៥១:២០ **៩:១៤** ក អស ៣១:៥ខ ទដ ១៨:១៤ ហព ៣:១១ គ លវ ២៥:៩ មថ ២៤:៣១ ឃ អស ២១:១ ៦៦:១៥ **៩:១៥** ង អស ៣១:៥ ៣៧:៣៥ សក ១២:៨ ច សក ១៤:៣ ឆ សក ១០:៧ ជ សក ១៤:២០ ឈ នក ២៧:២ **៩:១៦** ញ អស ១០:២០ ដ យរ ៣១:១១

ដែលមានខ្សែលោហិតពីស្តេចដាវីឌ ។ *អ្នកសុចរិត* ទ្រង់មានលក្ខណៈជាព្រះដែលប្រកបដោយក្រឹត្យក្រមសីលធម៌ ដូចដែលបានបង្ហាញនៅក្នុងក្រឹត្យវិន័យលោកម៉ូសេ អំពីលក្ខណៈសម្បត្តិនៃក្សត្រដ៏ត្រឹមត្រូវ (មើល ២សយ ២៣:៣–៤ និងការពន្យល់ ២៣:៣ ទដ ៤:១ និងការពន្យល់ ៧២:១–៣ អស ៩:៧ និងការពន្យល់ ៥៣:១១ យរ ២៣:៦ និងការពន្យល់) ។ *សុភាព* ឬបន្ទាបខ្លួន (ធៀបនឹង អស ៥៣:២–៣,៧ មថ ១១:២៩) ។ *គង់លើសត្វលា* គឺជាជម្រើសដ៏សមរម្យបំផុត ពីព្រោះសត្វលាគឺជាសត្វតូចទាប ជាសត្វនៃសន្តិភាព (ផ្ទុយនឹងសត្វសេះចម្បាំងនឹងក្នុង ខ.១០) ហើយជាជំនិះសម្រាប់ស្តេច (ពច ១០:៤ ១២:១៤ ២សយ ១៦:២) មុនសម័យដែលគេប្រើសេះជាធម្មតា ។ ជំនិះដែលស្តេចដាវីឌ និងបុត្រាទ្រង់ប្រើ គឺជាសត្វលាកាត់ (មើល ២សយ ១៣:២៩ និងការពន្យល់) ។

**៩:១០** *កាត់រទេះចំបាំង . . . សេះ . . . ធ្នូចំបាំង* ការដកហូតអាវុធស្រដៀងគ្នានេះមាននិយាយនៅក្នុងទំនាយក្នុង អស ២:៤ ៩:៥–៧ ១១:១–១០ មីក ៥:១០–១១ ។ *អេប្រាអិម* មើលការពន្យល់ ខ.១៣ ។ *សេចក្តីសុខដល់អស់ទាំងសាសន៍* ព្រះមែស៊ីដ៏ជាក្សត្រទ្រង់នឹងសាងព្រះរាជាណាចក្រសកលមួយប្រកបដោយសន្តិភាព ដែលជាការបំពេញសេចក្តីសញ្ញាដែលព្រះទ្រង់តាំងជាមួយនឹងលោកអ័ប្រាហាំ គឺផ្ទុយពីស្តេចអ័ឡេចក្សានឌ័រដែលកសាងចក្រភពក្រិចដោយការបង្ហូរឈាម (ធៀបនឹង ១៤:១៦ មើល លប ១២:២–៣ និងការពន្យល់ ប៉ុន្តែធៀបនឹង វវ ៩:១១ និងការពន្យល់) ។ *ពីសមុទ្រម្ខាងដល់សមុទ្រម្ខាង* មានការបកស្រាយផ្សេងៗដូចជា "ពីទន្លេនីល ដល់ទន្លេអឺប្រាត" "ពីសមុទ្រមេឌីទែរ៉ាណេ ដល់សមុទ្រក្រហម" និង "ពីសមុទ្រមេឌីទែរ៉ាណេ ដល់សមុទ្រស្លាប់"។ តែទោះជាយ៉ាងណាក៏ដោយន័យរបស់ ឃ្លានេះមានលក្ខណៈទូលំទូលាយ ដូចនេះគេក៏អាចនិយាយបានម្យ៉ាងទៀតថា "ពីទន្លេ រហូតដល់ចុងផែនដី"។ ចំនុចសំខាន់នៃឃ្លានេះគឺថា ព្រះមែស៊ីដ៏ជាក្សត្រទ្រង់និងគ្រង់គ្រងនៅគ្រប់ទីកន្លែងទាំងអស់ (មើល ទដ ២២:២៧–២៨ និងការពន្យល់ ៧២:៨–១១ ៧២:៨ អស ៤៥:២២ ៥២:១០ ៦៦:១៨) ។

**៩:១១** *ពួកជាប់គុក* ប្រហែលជាពួកអ្នកដែលនៅក្នុងទឹកដីបាប៊ីឡូននៅឡើយគឺទឹកដីដែលត្រូវនិរទេសទៅ ។ *ឈាមនៃសេចក្តីសញ្ញារបស់ឯង* គឺសេចក្តីសញ្ញាដែលលោកម៉ូសេទទួលនៅភ្នំស៊ីណាយ (នក ២៤:៣–៨) ។ *រណ្តៅដែលគ្មានទឹក* ធៀបនឹង លប ៣៧:២៤ យរ ៣៨:៦ ។

**៩:១២** *ទីមាំមួន* គឺ (១).ក្រុងយេរូសាឡិម(ក្រុងស៊ីយ៉ូន) និងតំបន់ជិតខាង ឬ(២).ព្រះអម្ចាស់(ធៀបនឹង ២:៥)។ *សេចក្តីសង្ឃឹម* គឺមហាក្សត្រដ៏ជួយសង្គ្រោះនៅពេលអនាគត(ខ.៩–១០)។ *១ជា២* មានន័យថា ព្រះអម្ចាស់ទ្រង់ស្អាងរាស្ត្ររបស់ទ្រង់ឡើងវិញឱ្យមានលក្ខណៈពេញលេញ ឬគ្រប់លក្ខណៈ (អស ៦១:៧) ។

**៩:១៣** មើលការពន្យល់ ១០:៤ ។ ព្រះអម្ចាស់ទ្រង់ប្រៀបធៀបអង្គទ្រង់ទៅនឹងអ្នកចម្បាំងដែលយកពួកយូដាជាធ្នូ ហើយពួកអេប្រាអិម(រាជាណាចក្រខាងជើង)ជាព្រួញ ។ *ស៊ីយ៉ូន . . . កូនប្រុសរបស់ឯង* គឺពួកម៉ាកាប៊ី(មើលការពន្យល់ ដយ ១១:៣៤ អត្ថបទសម័យនៅចន្លោះគ្រាសញ្ញាចាស់និងសញ្ញាថ្មី)។ *កូនប្រុសរបស់សាសន៍ក្រេក* គឺរាជវង្សសែលើស៊ីឌនៃស្រុកស៊ីរី (កើតឡើងពីការបែងចែកចក្រភពនៃស្តេចអ័ឡេចក្សាឌ័រ) ។

**៩:១៤** មើល ហព ៣:៣–១៥ និងការពន្យល់ ៣:៣ ។ *ត្រែ* ប្រហែលសំដៅទៅលើផ្គរលាន់(មើល នក ១៩:១៦–១៩ និងការពន្យល់ ១៩:១៦) ។ *ខាងត្បូង* គឺនៅក្នុងតំបន់ភ្នំស៊ីណាយដែលព្រះអម្ចាស់ទ្រង់ប្រទាននូវសេចក្តីសញ្ញា (មើល ខ.១១ និងការពន្យល់) និងកន្លែងដែលព្រះអម្ចាស់ទ្រង់គង់នៅ (មើល ពច ៥:៤–៥ ទដ ៦៨:៨ ហព ៣:៣ និងការពន្យល់) ។

**៩:១៥** *គ្រាប់ក្រួសដែលបាញ់មក* គឺបាញ់ដាក់កងទ័ពដែលការពារកំផែងក្រុង និងដាក់ប្រជាជននៅក្នុងក្រុង។ *ចាននៅជ្រុងអាសនា* មើល នក ២៧:១–៣ និងការពន្យល់ ២៧:៣ លវ ៤:៦–៧ ។

**៩:១៦** *នៅថ្ងៃនោះ* មើលការពន្យល់ ២:១១ ។

ដូចជាត្បូងដាំនៅមកុដដែលភ្លឺផ្លេក នៅលើស្រុករបស់ទ្រង់[ដ]
១៧ដ្បិតសេចក្ដីចំរើនរបស់គេធំណាស់ហ្ន៎ ហើយសេចក្ដី
លំអរបស់គេក៏ខ្លាំងក្លាណាស់ហ្ន៎ ឯស្រូវនឹងធ្វើឱ្យពួក
កំឡោះៗចំរើនកំឡាំងឡើង ហើយទឹកទំពាំងបាយជូរឱ្យ
ពួកក្រមុំៗបានចំរើនដូចគ្នា ។

**ព្រះអម្ចាស់ទ្រង់នឹងយកព្រះទ័យទុកដាក់ចំពោះពួកយូដា**

**១០** ១ចូរឱ្យឯងរាល់គ្នាសូមទឹកភ្លៀង ពីព្រះយេហូវ៉ា
នៅវេលាភ្លៀងចុងរដូវ គឺសូមពីព្រះយេហូវ៉ា ដែលទ្រង់ធ្វើ
ឱ្យមានផ្លេកបន្ទោរ នោះទ្រង់នឹងប្រោសប្រទាន ឱ្យមាន
ភ្លៀង[ក]១មេៗដល់ឯង ឱ្យគ្រប់គ្នាមានស្មៅនៅចំការ[ខ]របស់
ខ្លួន ២ពីព្រោះរូបព្រះ[គ]ទាំងប៉ុន្មានបានពោលជាសេចក្ដីឥត
ប្រយោជន៍ ហើយពួកគ្រូទាយ[ឃ]បានឃើញសេចក្ដីភូតភរ ឯ
សប្តិ[ង]ក៏សំដែងជាសេចក្ដីកំភូត ក៏កំសាន្តចិត្តដោយសេចក្ដី
ឥតប្រយោជន៍ដែរ[ច] ហេតុនោះបានជាគេដើរតាមផ្លូវរបស់
ខ្លួនដូចជាហ្វូងចៀម គេរងទុក្ខដោយព្រោះគ្មានអ្នកគង្វាល[ឆ]
៣សេចក្ដីកំហឹងរបស់អញបានឆួលឡើង ទាស់នឹងពួកអ្នក
គង្វាល ហើយអញនឹងវាយផ្ចាលពួកពពែឈ្មោល[ជ] ដ្បិតព្រះ
យេហូវ៉ានៃពួកពលបរិវារ ទ្រង់បានប្រោសហ្វូងចៀម
របស់ទ្រង់ គឺជាពួកវង្សយូដា ហើយទ្រង់នឹងធ្វើឱ្យគេបាន
ដូចជាសេះយ៉ាងល្អរបស់ទ្រង់ ក្នុងការសង្គ្រាម[ឈ] ៤ថ្មជ្រុង
នឹងចេញពីទ្រង់មក[ញ] ហើយទាំងដែកគោល[ដ] ទាំងធ្នូសំរាប់
ច្បាំង[ឋ] និងគ្រប់ទាំងអ្នកគ្រប់គ្រងជាមួយគ្នាផង ៥គេនឹង
បានដូចជាមនុស្សខ្លាំងពូកែ ដែលកំពុងជាន់ឈ្លីភក់នៅត្រង់
ផ្លូវក្នុងការចំបាំង[ឌ] គេនឹងតស៊ូ ពីព្រោះព្រះយេហូវ៉ា ទ្រង់
គង់ជាមួយនឹងគេ ហើយពួកពលសេះនឹងស្រឡាំងកាំង[ឍ]
៦អញនឹងចំរើនកំឡាំង[ណ]ពួកវង្សយូដា អញនឹងជួយសង្គ្រោះ
ពួកវង្សយ៉ូសែប ហើយនឹងនាំគេមកវិញ ដ្បិតអញមាន
សេចក្ដីអាណិតមេត្តា[ត]ដល់គេ[ថ] យ៉ាងនោះគេនឹងមាន
សណ្ឋាន ដូចជាអញមិនបានបោះបង់ចោលគេឡើយ ដ្បិត
អញនេះជាព្រះយេហូវ៉ា គឺជាព្រះនៃគេ ហើយអញនឹង
ស្តាប់[ទ]គេ ៧ឯពួកអេប្រាអិម គេនឹងបានដូចជាមនុស្សខ្លាំង
ពូកែចិត្តគេនឹងបានរីករាយឡើង ដូចជាដោយសារស្រា
ទំពាំងបាយជូរ[ធ] អើ ទាំងពួកកូនរបស់គេនឹងឃើញ ហើយ
និងមានសេចក្ដីអំណរដែរ ចិត្តគេនឹងបានអរសាទរ[ន]ក្នុង
ព្រះយេហូវ៉ា ។
៨អញនឹងហួចហៅ[ប]គេ ហើយប្រមូលគេមក ពីព្រោះ
អញបានលោះគេហើយ នោះគេនឹងចំរើនជាច្រើនឡើង[ផ]
ដូចជាបានចំរើនឡើងពីដើម ៩អញនឹងសាបព្រោះគេនៅ

**១០:១** ក លវ ២០:៤ ១ពវ ៨:៣៦ ទដ ១០៤:១៣ ១៣៥:៧ ខ យប ១៤:៩ **១០:២** គ អគ ២១:២១ ឃ អស ៤៤:២៥ ង យរ ២៣:១៦ ច អស ៤០:១៩ ឆ ជន ២៧:១៧ យរ ២៣:១ ហស ៣:៤ មថ ៩:៣៦ **១០:៣** ជ អស ១៤:៩ យរ ២៥:៣៤ ឈ អគ ៣៤:៨–១០ **១០:៤** ញ ទដ ១១៨:២២ កថ ៤:១១ ដ អស ២២:២៣ ឋ សក ៩:១០ **១០:៥** ឌ ២សយ ២២:៤៣ មីក ៧:១០ ឍ អម ២:១៥ មីក ៥:៨ ហក ២:២២ សក ១២:៤ **១០:៦** ណ អគ ៣០:២៤ ត ទដ ១០២:១៣ អស ១៤:១ ថ អគ ៣៦:៣៧ ៣៧:១៩ សក ៨:៧–៨ ទ ទដ ៣៤:១៧ អស ៥៨:៩ ៦៥:២៤ សក ១៣:៩ **១០:៧** ធ សក ៩:១៥ ន ១សយ ២:១ អស ៦០:៥ យអ ២:២៣ **១០:៨** ប អស ៥:២៦ ផ យរ ៣៣:២២ អគ ៣៦:១១

**១០:១** *គឺព្រះយេហូវ៉ា . . . ឱ្យមានភ្លៀង . . . ស្មៅ* ព្រះយេហូវ៉ាទ្រង់ជាអ្នកគ្រប់គ្រងធាតុអាកាស និងទឹកភ្លៀង ទ្រង់ប្រទានជីវិត និងជីជាតិដល់ដី (មើល យរ ១៤:២២ ហស ២:៨ និងការពន្យល់, ៦:៣ យអ ២:២១–២៧ អម ៥:៨ មថ ៥:៤៥) ។ ដូចនេះ រាស្ត្ររបស់ទ្រង់ត្រូវអធិស្ឋាន និងជឿលើទ្រង់ ។

**១០:២** *រូបព្រះ* គឺរូបព្រះដែលគេថ្វាយបង្គំនៅក្នុងផ្ទះផ្ទាល់ខ្លួន(មើល លប ៣១:១៩ និងការពន្យល់)។ ពួកអ៊ីស្រាអែលថ្វាយបង្គំរូបព្រះនេះនៅសម័យព្រះគម្ពីរចៅហ្វាយ(មើល ពច ១៧:៥ និងការពន្យល់, ១៨:១៤–២០)។ *ពួកគ្រូទាយ* គេរាប់បញ្ចូលពួកនេះនៅក្នុងចំណោមពួកហោរាក្លែងក្លាយផងដែរ ដូចនេះពួកគេគឺជាគូរប្រឆាំងនឹងហោរាដែលត្រឹមត្រូវ ។ មើល យរ ២៧:៩–១០ និងការពន្យល់ ២៧:៩ ។ ព្រះគម្ពីរ ចទ ១៨:៩–១៤ បានហាមឃាត់ការជឿតាមពាក្យរបស់ពួកនេះ ពីព្រោះព្រះអម្ចាស់ទ្រង់បានប្រទានហោរាដែលត្រឹមត្រូវ(គឺហោរាដែលទាយពីព្រះមែស៊ី)ដើម្បីឱ្យពួកគេស្តាប់តាម(ចទ ១៣:១–៥ និងការពន្យល់, ១៨:១៥–២២ និងការពន្យល់, កថ ៣:២២–២៦ និងការពន្យល់ មើលការពន្យល់ លប ៣០:២៧)។ *កំសាន្តចិត្តដោយសេចក្ដីឥតប្រយោជន៍* មានជាឧទាហរណ៍ដូចជានៅពេលដែលពួកគេកុហកថានឹងមានភ្លៀង មានរដូវសម្បូសប្បាយ ដីមានជីជាតិ ប្រទេសសម្បូររុងរឿង សន្តិភាព និងព្រះពរ ។ *ដើរតាមផ្លូវខ្លួនដូចជាហ្វូងចៀម* មើល អស ៥៣:៦ និងការពន្យល់ ។ *គ្មានអ្នកគង្វាល* មានន័យថា ពួកគេបាត់បង់ការដឹកនាំខាងវិញ្ញាណ(ធៀបនឹង មក ៦:៣៤)។ ត្រង់ចំនុចនេះ "អ្នកគង្វាល" គឺជាស្តេច ដែលអាចជាមនុស្ស(មើល អស ៤៤:២៨ យរ ២:៨ និងការពន្យល់) ឬជាព្រះដ៏ជាក្សត្រ (មើល ទដ ២៣:១ និងការពន្យល់) ឬក៏ជាព្រះមែស៊ីដ៏ជាក្សត្រដែលមានខ្សែលោហិតស្តេចដាវីឌ (អគ ៣៤:២៣–២៤ យហ ១០:១១–១៦ ហព ១៣:២០ ១ពវ ៥:៤ វវ ៧:១៧) ។

**១០:៣** *វាយផ្ចាលពួកពពែឈ្មោល* ធៀបនឹង អគ ៣៤:១–១០ ។ *ដូចជាសេះយ៉ាងល្អ* មានន័យថា មានជោគជ័យ ។

**១០:៤** ខនេះអាចនិយាយអំពីព្រះមែស៊ី ។ *ចេញពីទ្រង់* មើល លប ៤៩:១០ យរ ៣០:២១ និងការពន្យល់, មីក ៥:២ ។ *ថ្មជ្រុង* មើល ៣:៩ អភ ២:២០ និងការពន្យល់ ។ *ដែកគោល* គឺជាអ្នកដឹកនាំប្រទេស(មើលការពន្យល់ អស ២២:២៣ និង អស ២២:២៤) ។ *ធ្នូសំរាប់ច្បាំង* សូមធៀបនឹង ៩:១៣ ទដ ៧:១២ ៤៥:៥ បទ ២:៤ ៣:១២ ហព ៣:៩ ។

**១០:៥** *គេ* គឺពួកយូដា (ខ.៤) ។ *ព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងគេ* មើល យស ១:៥ យរ ១:៨ និងការពន្យល់ ។

**១០:៦** *ពួកវង្សយូដា . . . ពួកវង្សយ៉ូសែប* ប្រជាជននៅរាជាណាចក្រខាងជើងនឹងខាងត្បូងរួបរួមគ្នាឡើងវិញ (មើលការពន្យល់ ៨:១៣) ។

**១០:៧** *ពួកគេប្រាអិម* មើលការពន្យល់ ៩:១៣ ។ *រីករាយឡើយ ដូចជាដោយសារស្រាទំពាំងបាយជូរ* មើល ទដ ១០៤:១៥ ។

**១០:៨** *ហួចហៅ* ខនេះបន្តប្រើន័យធៀបពីអ្នកគង្វាលចៀម ដោយប្រើពាក្យនេះ(ខ.២–៣ មើល ពច ៥:១៦)។ *លោះ* ក្នុងភាសារហេព្រើគេប្រើពាក្យនេះជាញឹកញាប់សម្រាប់និយាយអំពីការលោះនរណាម្នាក់ពីភាពជាទាសករ ឬចំណាប់ខ្មាំង(មើល អស ៣៥:១០ មីក ៦:៤ ធៀបនឹង ១ពវ ១:១៨–១៩)។

កណ្ដាលអស់ទាំងសាសន៍ ហើយគេនឹងនឹកចាំពីអញ[ព] នៅ
ក្នុងស្រុកឆ្ងាយ គេនឹងនៅជាមួយនឹងពួកកូនចៅ ហើយនិង
ត្រឡប់មកវិញ ១០ អញនឹងនាំគេចេញពីស្រុកអេស៊ីព្ទម្តង
ទៀត ហើយកៀរប្រមូលគេចេញពីស្រុកអាសស៊ើរ[ភ] អញ
នឹងនាំគេមកឯស្រុកកាឡាត[ម] និងស្រុកល្បាណូន ដល់ទៅ
រកកន្លែង[យ]ល្មមឱ្យគេអាស្រ័យនៅគ្មាន ១១ ទ្រង់នឹងធ្វើទុក្ខដល់
សមុទ្រ ហើយនិងវាយរលកទាំងប៉ុន្មាន នោះអស់ទាំង
ទីជំរៅរបស់ទន្លេធំ និងរីងស្ងួតទៅ[រ] សេចក្ដីអំនួត[ល]របស់
សាសន៍អាសស៊ើរនឹងត្រូវទំលាក់ចុះ ហើយដំបងរាជ្យ[វ]
របស់សាសន៍អេស៊ីព្ទនឹងទៅបាត់ទៅ[ស] ១២ អញនឹងចំរើន
កំឡាំង[ហ]គេក្នុងព្រះយេហូវ៉ា ហើយគេនឹងដើរចុះឡើង
ដោយនូវព្រះនាមទ្រង់[ឡ]នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។
**១១** ១ ឱល្បាណូនអើយ[ក] ចូរបើកទ្វារឯងឡើង ដើម្បីឱ្យ
ភ្លើងបានឆេះ[ខ]ដើមតាត្រៅរបស់ឯង ២ ឱដើមកោះអើយចូរ
ទ្រហោយំចុះ ដ្បិតដើមតាត្រៅបានរលំ ឯអស់ទាំងដើម
យ៉ាងល្អបានត្រូវបំផ្លាញហើយ ឱដើមម៉ៃសាក់[គ] នៅស្រុក
បាសានអើយ ចូរទ្រហោយំចុះ ពីព្រោះព្រៃស្រោង[ឃ]បាន
ត្រូវរលំហើយ[ង] ៣ មានឮសំឡេងពួកគង្វាលទ្រហោយំ
សេចក្ដីរុងរឿងរបស់គេបានត្រូវបំផ្លាញ ក៏ឮសំឡេងស្រែក
គ្រហឹមនៃសិង្ហស្ទាវ[ច] ដ្បិតសេចក្ដីអំនួតរបស់ទន្លេយ័រដាន់
បានត្រូវខូចបង់ទៅ[ឆ]។

## អ្នកគង្វាលទាំងពីរ

៤ ព្រះយេហូវ៉ា ជាព្រះនៃខ្ញុំ ទ្រង់មានបន្ទូលដូច្នេះថា
ចូរឃ្វាលហ្វូងចៀមដែលសំរាប់សំឡាប់[ជ] ៥ ជាហ្វូងដែលពួក
អ្នកទិញក៏សំឡាប់ទៅ ឥតរាប់ខ្លួនជាមានទោសឡើយ ហើយ
ពួកអ្នកដែលលក់វាក៏ថា សូមឱ្យព្រះយេហូវ៉ាក្រុបកដោយ
ព្រះពរ ដ្បិតខ្ញុំបានមានឡើង ហើយទាំងពួក គង្វាលក៏មិន

**១០:៩** ព អស ៤៤:២១ អគ ៦:៩ **១០:១០** ភ អស ១១:១១ សក ៨:៨ ម យរ ៥០:១៩ យ អស ៤៩:១៩ **១០:១១** រ អស ១៩:៥–៧ ៥១:១០ ល សផ ២:១៣ វ អគ ៣០:១៣ ស អគ ២៩:១៥ **១០:១២** ហ អគ ៣០:២៤ ឡ មីក ៤:៥ **១១:១** ក អគ ៣១:៣ ខ ២របា ៣៦:១៩ សក ១២:៦ **១១:២** គ អស ២:១៣ ឃ អស ៣២:១៩ ង អស ១០:៣៤

**១១:៣** ច អស ៥:២៩ ឆ យរ ២:១៥ ៥០:៤៤ អគ ១៩:៩ **១១:៤** ជ យរ ២៥:៣៤

*ហើយនឹងត្រឡប់មកវិញ* មើល នក ១:៦–២០ និងការពន្យល់ ១:៧ ។

**១០:៩** *គេនឹងនឹកចាំពីអញ* ពាក្យសាការីមានន័យថា "ព្រះទ្រង់នឹកចាំ" (គឺនឹកចាំពីរាស្ត្រ និងសេចក្ដីសន្យាក្នុងសេចក្ដីសញ្ញា) ។ ពេលនេះពួកគេនឹងនឹកចាំពីទ្រង់ ។

**១០:១០** *ស្រុកអេស៊ីព្ទ... ស្រុកអាសស៊ើរ* មើល ខ.១១ ហស ៧:១៦ និងការពន្យល់ ។ ឈ្មោះប្រទេសទាំងនេះអាចជាតំណាងឱ្យប្រទេសទាំងអស់ដែលអ៊ីស្រាអែលត្រូវនិរទេសទៅ ហើយឈ្មោះទាំងពីរនេះគឺត្រូវបានប្រើដើម្បីរំឭកពីភាពជាទាសករ និងការនិរទេស ។ *កៀរប្រមូលគេចេញ* មើល អស ១១:១១–១៦ អគ ៣៩:២៧–២៩ ។ *ស្រុកកាឡាត* មើល លប ៣១:២១ និងការពន្យល់, បស ៦:៥ យរ ៥០:១៩ មីក ៧:១៤ និងការពន្យល់ ។ *ស្រុកល្បាណូន* មើល ២ពរ ១៩:២៣ មើល អស ៣៣:៩ ៣៥:២ យរ ២២:៦ និងការពន្យល់ ។ *កន្លែងល្មមឱ្យគេអាស្រ័យនៅគ្មាន* មើល ខ.៨ ២:៤ និងការពន្យល់ អស ៤៩:១៩–២០ ។

**១០:១១** *ធ្វើទុក្ខដល់សមុទ្រ* គឺដូចដែលទ្រង់បានធ្វើដល់សមុទ្រក្រហម (នក ១៤:២២ និងការពន្យល់) ។

**១១:១–៣** អ្នកកាត់ស្រាយខ្លះយល់ថា វគ្គនៃបទគម្ពីរនេះគឺជា កំណាព្យខ្នាតខ្លីមួយដែលត្រូវបានសរសេរឡើងជាចម្រៀងចម្អកឱ្យ ដែលទាក់ទងនឹងការទួញសោកពីប្រទេសដែលមានអំណាច និងភាពក្រអឺតរបស់ខ្លួនត្រូវបានបំផ្លាញ (ជំពូក ១០) ដែលមានដើម្បីតាត្រាវ កកោះ និងម៉ៃសាក់ជាឧទាហរណ៍ (ខ.១–២)។ អ្នកគង្វាល និងសត្វតោគឺជានិមិត្តរូបរបស់ពួកស្ដេចរបស់ពួកគេ (ខ.៣) ។ តាមរយៈការកាត់ស្រាយនេះវគ្គ ខ.១–៣ នេះគឺជាសេចក្ដី សន្និដ្ឋាននៃវគ្គខាងមុខ ។ អ្នកកាត់ស្រាយផ្សេងទៀតមិនបដិសេធន៍ការកាត់ស្រាយដោយប្រៀបធៀបនោះទេ ហើយពួកគេយល់ថា ន័យចំនៃបទគម្ពីរនេះ គឺជាការពិពណ៌នាអំពីការបំផ្លាញពួកសាសន៍ស៊ីរី និងភីលីស្ទីនដែលបដិសេធព្រះមែស៊ីដ៏ជាអ្នកគង្វាលល្អ (ខ.៤–១៤) ។ តាមការកាត់ស្រាយនេះ ខ.១–៣ គឺជាសេចក្ដីផ្ដើមនៃវគ្គបន្ទាប់ ហើយតាមបទគម្ពីរប្រទេសដែលត្រូវបំផ្លាញនោះមានដូចជា ល្បាណូន បាសាន និងយ័រដាន់ ។ បទទំនាយនេះ ត្រូវបានសម្រេចមួយផ្នែកទៀតដោយការកាន់កាប់របស់ពួករ៉ូម៉ាំង ដែលនាំឱ្យមានការដួលរលំនៃក្រុងយេរូសាឡិម នៅក្នុងឆ្នាំ ៧០ នៃគ.ស. និងក្រុង ម៉ាសាដា នៅឆ្នាំ ៧៣ នៃគ.ស.។ ប៉ុន្តែការយល់ដូចនេះមានន័យថា វគ្គនេះខុសពីវគ្គនៃជំពូក១០ ដែលថ្លែងទំនាយថា ព្រះអម្ចាស់ទ្រង់នឹងស្អាងរាស្ត្រអ៊ីស្រាអែលឡើងវិញ ដើម្បីឱ្យបានសេរីភាពនៅលើទឹកដីនៃសេចក្ដីសញ្ញា ។ ដូចនេះនៅក្នុង ខ.១–៣ គឺនិយាយពីការបំផ្លាញទឹកដី ហើយវគ្គនេះត្រូវបន្តដោយការព្រមានពីការជំនុំជម្រះ និងមហន្តរាយដែលនឹងកើតឡើងដល់ទឹកដី និងប្រជាជននៅក្នុងវគ្គ ខ.៤–៦ ។

**១១:១** *ល្បាណូន* មើល ១០:១០ និងការពន្យល់ ។

**១១:២** *ស្រុកបាសាន* មើលការពន្យល់ អស ២:១៣ ។ ពួកអ៊ីស្រាអែលបានដណ្ដើមទឹកដីនេះពីស្ដេចអុក នៃសាសន៍អាម៉ូរី នៅក្នុងពេលចូលកាន់កាប់ស្រុកកាណាន (ជន ២១:៣៣–៣៥) ។ ស្រុកនេះត្រូវបានជាចំណែកដល់ពាក់កណ្ដាលនៃពូជអំបូរម៉ានាសេ (យស ១០:២៩–៣០ ១៧:៥) ។ *ព្រៃស្រោង* គឺព្រៃស្រោងរបស់ស្រុកល្បាណូន ។

**១១:៣** ប្រសិនបើខនេះជាន័យធៀប នោះអ្នកគង្វាល និងសត្វតោគឺជានិមិត្តរូបនៃអ្នកដឹកនាំនៃសាសន៍យូដា (មើល ខ.៥ ១០:៣ ធៀបនឹង យរ ២៥:៣៤–៣៦) ។ *សេចក្ដីអំនួតរបស់ទន្លេយ័រដាន់បានត្រូវខូចបង់* ទន្លេយ័រដាន់នឹងត្រូវក្លាយជាលំនៅរបស់សត្វតោនោះ ។

**១១:៤–១៤** វគ្គនេះនិយាយពីមូលហេតុដែលត្រូវជំនុំជំរះសាសន៍អ៊ីស្រាអែលនៅក្នុង ខ.១–៣ គឺចំពោះអស់អ្នកដែលបដិសេធន៍ព្រះមែស៊ីដ៏ជាក្សត្រ និងអ្នកគង្វាល ។ ក្នុងវគ្គនេះ គេនឹងបដិសេធអ្នកគង្វាលដ៏ល្អ (មានលក្ខណៈជាស្ដេច) ដូចកាលដែលគេបដិសេធអ្នកបំរើនៅក្នុង "ទំនុកអ្នកបម្រើ"ផងដែរ (មើលការពន្យល់ អស ៤២:១–៤) ។

**១១:៤** *មានបន្ទូល* គឺមានបន្ទូលទៅកាន់លោកសាការី ។ *ហ្វូងចៀម* គឺពួកអ៊ីស្រាអែល ។

**១១:៥** *ពួកអ្នកទិញ* ត្រង់ចំណុចនេះ អ្នកស្រុកក្រៅគេបានទិញចៀម (គឺពួកយូដា) យកជាទាសក ។ បទទំនាយនេះបានសម្រេចមួយផ្នែកនៅក្នុងឆ្នាំ ៧០

ប្រណីដល់វាដែរ[ឈ] ៦ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
អញនឹងមិនប្រណីដល់ពួកអ្នកនៅក្នុងស្រុកទៀតឡើយ មើល
អញនឹងប្រគល់គ្រប់ទាំងប្រុសៗ ទៅក្នុងកណ្តាប់ដៃនៃអ្នក
ជិតខាងខ្លួន[ញ] ហើយទៅក្នុងកណ្តាប់ដៃនៃស្តេចរបស់ខ្លួន
ដែរ ពួកទាំងនោះនឹងវាយស្រុក ហើយអញមិនព្រមប្រោស
ឱ្យរួចដែរ[ដ] ៧ដូច្នេះ ខ្ញុំក៏ឃ្វាលហ្វូងចៀមដែលសំរាប់
សំឡាប់[ឋ] ដែលពិតជាចៀមវេទនាបំផុតក្នុងហ្វូង ខ្ញុំក៏យក
ដំបង២មក ដំបងមួយខ្ញុំឱ្យឈ្មោះថា "លំអ" មួយទៀតឱ្យ
ឈ្មោះថា "សម្ពន្ធ" ហើយខ្ញុំក៏ឃ្វាលហ្វូងចៀមទៅ ៨ក្នុង
មួយខែ ខ្ញុំបានបណ្តេញអ្នកគង្វាលអស់៣នាក់ ពីព្រោះចិត្តខ្ញុំ
ធុញថប់[ឌ]នឹងគេ ហើយចិត្តគេក៏ខ្ពើមខ្ញុំដែរ ។
៩នោះខ្ញុំក៏និយាយថា អញលែងឃ្វាលឯងរាល់គ្នា ហើយ
ណាដែលស្លាប់ ឱ្យស្លាប់ចុះ ណាដែលត្រូវវិនាសឱ្យវិនាស
ចុះ[ឍ] ហើយណាដែលសល់នៅ នោះឱ្យវាហែកគ្នាស៊ី[ណ]ទៅ
១០ខ្ញុំក៏យកដំបងរបស់ខ្ញុំ ដែលមានឈ្មោះ "លំអ"[ត] មកកាច់
បំបាក់ ដើម្បីនឹងផ្តាច់[ថ]សេចក្តីសញ្ញារបស់ខ្ញុំ ដែលខ្ញុំបាន
តាំងនឹងជនជាតិទាំងឡាយ ១១សេចក្តីសញ្ញានោះ ក៏ត្រូវដាច់
នៅថ្ងៃនោះឯង យ៉ាងនោះពួកវេទនាបំផុត ក្នុងហ្វូងដែល
ស្តាប់តាមខ្ញុំ គេបានដឹងថាជាព្រះបន្ទូលនៃព្រះយេហូវ៉ា
១២នោះខ្ញុំនិយាយនឹងគេថា បើឯងរាល់គ្នាឃើញថាល្អ នោះ
សូមឱ្យឈ្នួលមកអញ ពុំនោះ កុំរវល់អី ដូច្នេះគេក៏ថ្លឹងប្រាក់
៣០ដួងសំរាប់ជាឈ្នួលរបស់ខ្ញុំ[ទ] ១៣រួចព្រះយេហូវ៉ាទ្រង់
បង្គាប់មកខ្ញុំថា ចូរបោះប្រាក់[ធ]នោះឱ្យដល់ជាងស្មូនចុះ គឺជា
ដំឡៃយ៉ាងល្អ ដែលគេបានកាត់ថ្លៃដល់ខ្ញុំ នោះខ្ញុំក៏យកប្រាក់
៣០ដួងនោះ ទៅបោះឱ្យជាងស្មូនក្នុងព្រះវិហារនៃព្រះ
យេហូវ៉ា[ន] ១៤រួចខ្ញុំក៏បំបាក់ដំបងរបស់ខ្ញុំមួយទៀត ដែល
ឈ្មោះថា "សម្ពន្ធ" នោះបង់ ដើម្បីនឹងផ្តាច់សេចក្តីមេត្រីគ្នា
របស់ពួកយូដា និងពួកអ៊ីស្រាអែលចេញ ។
១៥ព្រះយេហូវ៉ា ទ្រង់មានបន្ទូលមកខ្ញុំថា ចូរឱ្យឯងយក
គ្រឿងប្រដាប់របស់អ្នកគង្វាលល្ងីល្ងើម្តងទៀត ១៦ដ្បិតមើល
អញនឹងឱ្យមានអ្នកគង្វាល១ កើតឡើងក្នុងស្រុកដែលមិន
យកចិត្តទុកដាក់នឹងចៀម ដែលវង្វេងបាត់ឡើយក៏មិនព្រម
ទៅរកណាដែលខ្ចាត់ខ្ចាយ ឬរុំអមណាដែលភ្លាត់បាត់ ឬ

**១១:៥** ឈ យរ ៥០:៧ អគ ៣៤:២-៣
**១១:៦** ញ សក ១៤:១៣ ដ អស ៩:១៩-២១ យរ ១៣:១៤ បទ ២:២១ ៥:៨ មីក ៥:៨ ៧:២-៦
**១១:៧** ឋ យរ ២៥:៣៤
**១១:៨** ឌ អគ ១៤:៥
**១១:៩** ឍ យរ ៤៣:១១ ណ អស ៩:២០
**១១:១០** ត ខ.៧ ថ ទដ ៨៩:៣៩ យរ ១៤:២១
**១១:១២** ទ លប ២៣:១៦ មថ ២៦:១៥
**១១:១៣** ធ នក ២១:៣២ ន មថ ២៧:៩-១០
កច ១:១៨-១៩

នៃគ.ស. និងឆ្នាំបន្ទាប់ ។ *ពួកអ្នកលក់វា* "គឺអ្នកគង្វាលរបស់ពួកគេ(អ្នកគ្រប់គ្រង ឬដឹកនាំ)" ។

**១១:៦** *ស្រុក* គឺស្រុកអ៊ីស្រាអែល ។ *ស្តេច* ប្រហែលជាស្តេចនៃចក្រភពរ៉ូម៉ាំង(ធៀបនឹង យហ ១៩:១៥) ។ *ពួកទាំងនោះ* នៅក្នុងបទទំនាយនោះ ក៏និយាយសំដៅទៅលើពួករ៉ូម៉ាំងផងដែរ ។

**១១:៧** *ខ្ញុំ* គឺលោកសាការីជានិមិត្តរូបនៃក្សត្រដ៏ជាអ្នកគង្វាលនិងព្រះម៉ែស៊ី ។ *ឈ្មោះថា "លំអ"* គឺលម្អនៃហ្វូងចៀម ។ *សម្ព័ន្ធ* មើល អគ ៣៧:១៥-២៨ និងការពន្យល់ ៣៧:១៦ ។ ការបង្រួបបង្រួមនេះគឺដោយសារតែការដឹកនាំប្រកបដោយព្រះគុណនៃអ្នកគង្វាលល្អ ។ ចំពោះផលនៅការធ្វើខុសនឹងសេចក្តីសំខាន់ទាំងពីរខាងលើ មើល ខ.១០,១៤ និងការពន្យល់ ។

**១១:៨** *បណ្តេញអ្នកគង្វាលអស់៣នាក់* អ្នកគង្វាលល្អទ្រង់នឹងបណ្តេញពីការងារចំពោះអ្នកដឹកនាំដែលមិនស័ក្តសម ។ *ចិត្តខ្ញុំធុញថប់នឹងគេ* ធៀបនឹង អស ១:១៣-១៤ ។

**១១:៩** *ណាដែលស្លាប់ ឱ្យស្លាប់ចុះ* ត្រង់ចំណុចនេះ អ្នកគង្វាលល្អទ្រង់នឹងឈប់ឃ្វាលហ្វូងចៀមទ្រង់ ។ *ហែកគ្នាស៊ីទៅ* តាមប្រវត្តិសាស្ត្រនិពន្ធដោយលោកយ៉ូសែបហ្វីស ការនេះកើតឡើងនៅក្នុងពេលពួករ៉ូម៉ាំងលោមព័ទ្ធក្រុងយេរូសាឡិមនៅក្នុង ឆ្នាំ៧០ នៃ គ.ស(មើល យរ ១៩:៩ និងការពន្យល់) ។

**១១:១០** *សេចក្តីសញ្ញា* ប្រហែលជាសេចក្តីសញ្ញាដែលផ្តល់នូវសន្តិសុខនិងការការពារមិនឱ្យសាសន៍ដទៃវាយលុកមកលើរាស្ត្ររបស់ទ្រង់(ធៀបនឹង អគ ៣៤:២៥ ហស ២:១៨)។ តែទោះជាយ៉ាងណាក៏ដោយនៅពេលនេះទ្រង់នឹងបើកឱ្យសាសន៍ដទៃគ្រប់គ្រងពួកគេវិញ ។

**១១:១១** *ពួកវេទនាបំផុត ក្នុងហ្វូង* ប្រហែលជាអ្នកស្មោះត្រង់តែពីរបីនាក់ដែលបានទទួលស្គាល់នូវព្រះបន្ទូលដ៏មានអំណាចរបស់ព្រះអម្ចាស់ (មើល ខ.៧ ដែលប្រើពាក្យ "ចៀមដែលវេទនាបំផុត") ។ *ជាព្រះបន្ទូលនៃព្រះយេហូវ៉ា* អ្នកស្មោះត្រង់ដឹងថា អ្វីដែលបានកើតឡើង (ឧទាហរណ៍ ការជិនុំជិរះក្រុងយេរូសាឡិម និងព្រះវិហារនៅ ឆ្នាំ ៧០ នៃគ.ស.) គឺដើម្បីសម្រេចនូវបទទំនាយនៃព្រះបន្ទូលព្រះ គឺដូចជាលទ្ធផលនៃអ្នកបដិសេធអ្នកគង្វាលល្អនៅ ក្នុង មថ ២៣ ។

**១១:១២** *សូមឱ្យឈ្នួលមកអញ* គឺសំដៅទៅលើសភាពធ្ងន់ធ្ងរនៃទំនាក់ទំនង *កុំរវល់អី* គឺជាការបញ្ជាក់បន្ថែមទៀតការបញ្ចប់ទំនាក់ទំនង ។ *ប្រាក់ ៣០ ដួង* ជាតម្លៃខ្លួនរបស់ទាសករម្នាក់ដែលរស់នៅក្នុងចំណោមពួកអ៊ីស្រាអែលនៅក្នុងសម័យបុរាណ(មើលការពន្យល់ នក ២១:៣២ មថ ២៦:១៥) ។

**១១:១៣** *បោះប្រាក់នោះឱ្យដល់ជាងស្មូនចុះ* ចំពោះសេចក្តីនៃ ខ.១២-១៣ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី មើល មថ ២៦:១៤-១៥ ២៧:៣-១០ និងការពន្យល់ ២៧:៩ ។ *ដំឡៃយ៉ាងល្អ* គឺជាពាក្យចំអក ។

**១១:១៤** *បំបាក់ដំបងរបស់ខ្ញុំមួយទៀតដែលឈ្មោះថា "សម្ពន្ធ"* ការនេះគឺជានិមិត្តសញ្ញានៃការកាត់ផ្តាច់ចំណងនៃសាសន៍នៃសេចក្តីសញ្ញា ជាពិសេសគឺការបែកបាក់រវាងរាជាណាចក្រខាងជើង និងខាងត្បូង ។ ការបែកបាក់នៅក្នុងជាតិសាសន៍ ហើយក្លាយជាសត្រូវនឹងគ្នាដូចនេះ គឺជាលក្ខណៈនៃប្រវត្តិសាស្ត្រពួកយូដានៅសម័យក្រោយមកទៀត គឺនៅពេលដែលពួកគេមិនអាចរួបរួមគ្នាធ្វើសង្គ្រាមទប់ទល់នឹងចក្រភពរ៉ូម៉ាំង(ធៀបនឹង យហ ១១:៤៨) ។

**១១:១៥** *ម្តងទៀត* មើល ខ.៧ ។ *អ្នកគង្វាលល្ងីល្ងើ* នៅពេលដែលអ្នកគង្វាលដែលមកពីព្រះត្រូវចាកចេញទៅ អ្នកគង្វាលដែលល្ងីល្ងើ និងចោលម្សៀត(ខ.១៧)បានមកជំនួស ។ អ្នកដឹកនាំដែលអាត្មានិយម លោភលន់និងពុករលួយនឹងឡើងកាន់អំណាច ហើយធ្វើទុក្ខដល់ហ្វូងចៀម (រាស្ត្រអ៊ីស្រាអែល) ។

**១១:១៦** *ណាដែលខ្ចាត់ខ្ចាយ* ធៀបនឹង លប ៣៣:១៣ អស ៤០:១១ ។ *ហែកក្រចកជើងវា* ប្រហែលជាបង្ហាញពីភាពលោភលន់នៅក្នុងការរុករកសូម្បី

ឃ្វាលណាដែលនៅជាប់តាមហ្វូងផង គឺនឹងស៊ីសាច់សត្វ
ណាដែលនៅជាប់តាមហ្វូងផង គឺនឹងស៊ីសាច់សត្វណា
ដែលធាត់ៗ ហើយហែកក្រចកជើងវាវិញ ១៧ វេទនាដល់អ្នក
គង្វាលចោលម្សៀត ដែលគេបោះបង់ចោលហ្វូងចៀម[ប]
ដ្បិតនឹងមានដាវធ្លាក់មកត្រូវដៃ[ផ] ហើយត្រូវភ្នែកស្តាំរបស់
អ្នកនោះ ដៃនោះនឹងស្វិតជ្រីវអស់ទៅហើយភ្នែកស្តាំ នឹង
ត្រូវងងឹតសូន្យ[ព] ។

## សត្រូវរបស់យេរូសាឡិមត្រូវបំផ្លាញ

**១២** ១ នេះជាព្រះបន្ទូលយ៉ាងធ្ងន់[ក] នៃព្រះយេហូវ៉ា ពី
ដំណើរអ៊ីស្រាអែល ។
ព្រះយេហូវ៉ា ជាព្រះដែលបានលាតផ្ទៃមេឃ[ខ] ហើយដាំ
ឫសនៃផែនដី[គ] ព្រមទាំងបង្កបង្កើតវិញ្ញាណនៅក្នុងខ្លួន
មនុស្ស[ឃ]ផង ទ្រង់មានបន្ទូលដូច្នេះថា ២ មើល អញនឹងធ្វើឱ្យ
ក្រុងយេរូសាឡិមទៅជាពែង[ង] ដែលនាំឱ្យវិលក្រឡាប់ដល់
ជនជាតិនៅព័ទ្ធជុំវិញទាំងប៉ុន្មាន[ច] ហើយដល់ពួកយូដាដែរ[ឆ]
ក្នុងកាលដែលមានគេឡោមព័ទ្ធច្បាំងនឹងក្រុងយេរូសាឡិម
៣ នៅថ្ងៃនោះ អញនឹងធ្វើឱ្យក្រុងយេរូសាឡិមទៅជាថ្ម[ជ]
ដែលសង្កត់លើអស់ទាំងសាសន៍[ឈ] អស់អ្នកណាដែលយក
ជាបន្ទុកលើខ្លួន នោះនឹងត្រូវរបួសជាធ្ងន់[ញ] ហើយគ្រប់ទាំង
សាសន៍នៅផែនដី និងមូលគ្នាទាស់នឹងទីក្រុងនោះ ៤ ព្រះ
យេហូវ៉ាទ្រង់មានបន្ទូលថា នៅថ្ងៃនោះ អញនឹងវាយអស់
ទាំងសេះឱ្យស្លុតស្លាំង ហើយឱ្យពួកអ្នកដែលជិះវាបានវិល
ខ្លួរដែរ អញនឹងបើកភ្នែកមើលពួកវង្សយូដា ហើយនិង
វាយអស់ទាំងសេះរបស់សាសន៍ទាំងប៉ុន្មាន ឱ្យខ្វាក់ភ្នែក[ដ]
៥ ឯពួកចៅហ្វាយនៃសាសន៍យូដា គេនឹងគិតក្នុងចិត្តថា ពួក
ក្រុងយេរូសាឡិមជាកំឡាំងរបស់គេ[ឋ] ដោយនូវព្រះយេហូវ៉ា
នៃពួកពលបរិវារ ជាព្រះនៃគេ ៦ នៅថ្ងៃនោះ អញនឹងធ្វើឱ្យ
ពួកចៅហ្វាយនៃសាសន៍យូដា បានដូចជាជើងក្រានមាន
ភ្លើងឆេះនៅកណ្តាលឧស ហើយដូចជាចន្លុះឆេះ[ឌ]នៅ
កណ្តាលកណ្តាប់ស្រូវ គេនឹងបន្សុស[ឍ]អស់ទាំងសាសន៍នៅ
ព័ទ្ធជុំវិញ ទោះទាំងខាងឆ្វេង និងខាងស្តាំផង រួចពួកក្រុង
យេរូសាឡិមនឹងអាស្រ័យនៅ[ណ]ក្នុងកន្លែងរបស់គេម្តងទៀត
គឺនៅក្រុងយេរូសាឡិមនោះឯង ៧ ព្រះយេហូវ៉ា ទ្រង់នឹងជួយ
សង្គ្រោះទីលំនៅទាំងប៉ុន្មានរបស់ពួកយូដាជាមុន ដើម្បីមិន
ឱ្យសិរីល្អនៃពួកវង្សដាវីឌ និងសិរីល្អរបស់ពួកក្រុងយេរូសា
ឡិម បានដំកើងឡើងលើសជាងពួកយូដាឡើយ[ត] ៨ នៅថ្ងៃ
នោះ ព្រះយេហូវ៉ាទ្រង់នឹងការពារ[ថ]ពួកអ្នកនៅក្រុងយេរូ
សាឡិម ហើយនៅថ្ងៃនោះ អ្នកណាក្នុង ពួកគេដែល

**១១:១៧** ប យរ ២៣:១ ផ អគ ៣០:២១-២២ ព យរ ២៣:១ **១២:១** ក អស ១៣:១ ខ លប ១:៨ ទដ ១០៤:២ យរ ៥១:១៥ គ ទដ ១០២:២៥ ហព ១:១០ ឃ អស ៥៧:១៦ **១២:២** ង ទដ ៧៥:៨ ច ទដ ៦០:៣ អស ៥១:២៣ ឆ សក ១៤:១៤ **១២:៣** ជ អស ២៣:១៦ ដយ ២:៣៤-៣៥ ឈ អស ៦៦:១៨ សក ១៤:២ ញ អស ២៩:៨ **១២:៤** ដ ទដ ៧៦:៦ សក ១០:៥ **១២:៥** ឋ អគ ៣០:២៤ **១២:៦** ឌ អស ១០:១៧-១៨ សក ១១:១ ឍ អប ១:១៨ ណ សក ១១:១ **១២:៧** ត យរ ៣០:១៨ អម ៩:១១ **១២:៨** ថ ទដ ៩១:៤ យអ ៣:១៦ សក ៩:១៥ ទ យអ ៣:១០

បំណែកបន្តិចបន្តួចដែលអាចបរិភោគបាន ។

**១១:១៧** *អ្នកគង្វាលចោលម្សៀត* មើលការពន្យល់ ខ.១៥ ។ អ្នកគង្វាលក្លែងក្លាយនេះប្រហែលជាអាចរកឃើញនៅក្នុងការសម្រេចបទទំនាយនៅក្នុងប្រវត្តិសាស្ត្រ គឺលោកស៊ីម៉ូន បាកូស៊ីបា ឬកូខបា (ដែលបានដឹកនាំពួកយូដាបះបោរប្រឆាំងនឹងចក្រភពរ៉ូម៉ាំង នៅក្នុងឆ្នាំ១៣២-១៣៥ មុនគ.ស. ហើយត្រូវពួកគ្រូក្រឹត្យវិន័យឈ្មោះអាគីបា ប្រកាសថាព្រះមែស៊ី) ។ ប៉ុន្តែដំណាក់កាលចុងក្រោយនៃបទទំនាយនេះហាក់ដូចជា និយាយសំដៅទៅលើការសម្រេចទំនាយអំពីពួកទទឹងនឹងព្រះគ្រីស្ទចុងក្រោយបំផុត (ធៀបនឹង អគ ៣៤:២-៤ ដយ ១១:៣៦-៣៩ យហ ៥:៤៣ ២ថន ២:៣-១០ វវ ១៣:១-៨) ។ *បោះបង់ចោលហ្វូងចៀម* គឺផ្ទុយពីអ្នកគង្វាលល្អ យហ ១០:១១-១៦ ។ *ដៃនោះនឹងស្វិតជ្រីវអស់ទៅ* មានន័យថា អំណាចត្រូវអស់ទៅ ។ *ភ្នែកស្តាំនឹងត្រូវងងឹតសូន្យ* មានន័យថា ប្រាជ្ញាត្រូវប្រើការលែងបាន ។ ដូចនេះអ្នកដឹកនាំនោះនឹងមិនមានលទ្ធភាពប្រយុទ្ធបានទៀតទេ ។

**១២:១-១៤:២១** ព្រះបន្ទូលយ៉ាងធ្ងន់ទីពីរ នៅក្នុងផ្នែកទីពីរនៃព្រះគម្ពីរនេះ គឺចែកជាពីរវគ្គសំខាន់ៗគឺ ការលោមព័ទ្ធក្រុងយេរូសាឡិមជាលើកចុងក្រោយ និងការយាងត្រឡប់មកវិញនៃព្រះមែស៊ី ដើម្បីកំចាត់សត្រូវរបស់សាសន៍អ៊ីស្រាអែល និងស្អាងនគរទ្រង់ ។

**១២:១** *ព្រះបន្ទូលយ៉ាងធ្ងន់* មើលការពន្យល់ ៩:១ ។ *អ៊ីស្រាអែល* គឺសំដៅទៅលើទឹកដីទាំងមូលនៃសាសន៍អ៊ីស្រាអែល គឺមិនគ្រាន់តែរាប់បញ្ចូលនគរខាងជើងប៉ុណ្ណោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ទឹកដីស្រុកយូដា និងក្រុងយេរូសាឡិមមានការផ្តោតសំខាន់ជាងគេ (មើល ខ.២) ។ *ព្រះយេហូវ៉ា ជាព្រះដែលបានលាតផ្ទៃមេឃ . . . ដាំឫស . . . បង្កបង្កើត* ការពិពណ៌នាអំពីអំណាចបង្កបង្កើតនៃព្រះអម្ចាស់បង្ហាញថា ទ្រង់មានអំណាចធ្វើគ្រប់ទាំងអ្វីដែលទ្រង់បានថ្លែងទំនាយ ហើយការពិពណ៌នានេះនាំឱ្យគេឃើញពីអំណាចនៃព្រះបន្ទូល ដែលទ្រង់ជាក្សត្រ និងមានអំណាចគ្រប់គ្រងបានសម្តែង ។

**១២:២** *ពែង ដែលនាំឱ្យវិលក្រឡាប់* មើលការពន្យល់ អស ៥១:១៧ ។

**១២:៣** *នៅថ្ងៃនោះ* មើលការពន្យល់ ២:១១ ។ ឃ្លានេះមានប្រើជាញឹកញាប់នៅក្នុង ជំពូក ១២-១៤ (១២:៤,៦,៨-៩,១១ ១៣:១-២,៤ ១៤:៤,៦,៨-៩,១៣,២០-២១) ។ *គ្រប់ទាំងសាសន៍ . . . មូលគ្នាទាស់នឹងទីក្រុង* មើល ១៤:២,១២ យអ ៣:៩-១៦ ធៀបនឹង វវ ១៦:១៦-២១ ។

**១២:៤** *ស្លុតស្លាំង . . . វិលខ្លួរ . . . ខ្វាក់ភ្នែក* គឺជាសេចក្តីបណ្តាសាដែលមាននិយាយនៅក្នុង ចទ ២៨:២៨ គឺស្ថិតក្នុងចំណោមបណ្តាសាដែលអ៊ីស្រាអែលត្រូវទទួល ដោយសាការមិនធ្វើតាមបង្គាប់នៃសេចក្តីសញ្ញា ។ ពេលនេះសេចក្តីបណ្តាសាទាំងនេះបានត្រឡប់មកធ្លាក់មកលើសត្រូវរបស់អ៊ីស្រាអែលវិញ ។ *បើកភ្នែកមើល* មើល ទដ ៣២:៨ ៣៣:១៨ ទដ ១២១ ។

**១២:៦** អ្នកដឹកនាំស្រុកយូដាដែលមានសុភវិន្និច្ឆ័យ (ខ.៥) នឹងបំផ្លាញសត្រូវរបស់ពួកគេ (ធៀបនឹង ពច ១៥:៣-៥ មីក ៥:៥-៦ ការពន្យល់ អស ១:៣១) ដូចឈើ និងកណ្តាប់ស្រូវត្រូវភ្លើងឆេះយ៉ាងដូច្នោះដែរ ។

**១២:៨** *ដូចជាដាវីឌ* គឺដូចជាអ្នកចម្បាំងដ៏អស្ចារ្យ ។ *ដូចជាព្រះ* ធៀបនឹង នក ៤:១៦ ៧:១ ។ *ដូចជាទេវតានៃព្រះយេហូវ៉ា* មើល លប ៤៨:១៦ និង

ខ្សោយ[ទ] នោះនឹងបានដូចជាដាវីឌវិញ ហើយ ពួកវង្សរបស់
ដាវីឌនឹងបានដូចជាព្រះ[ធ] គឺដូចជាទេវតានៃព្រះយេហូវ៉ា
នៅចំពោះមុខ[ន]គេ ៩នៅថ្ងៃនោះ អញនឹងតាំងចិត្តដើម្បី
បំផ្លាញអស់ទាំងសាសន៍[ប] ដែលមកទាស់នឹងក្រុងយេរូសា
ឡិម[ផ]។

## ការកាន់ទុក្ខសម្រាប់អ្នកដែលគេចាក់សម្លាប់

១០អញនឹងចាក់និស្ស័យមកលើពួកវង្សដាវីឌ និងពួកអ្នក
នៅក្រុងយេរូសាឡិម ឱ្យគេមានចិត្ត[ព]ប្រកបដោយគុណ និង
សេចក្ដីទូលអង្វរ[ភ] នោះគេនឹងគន់មើលអ្នកដែលគេបាន
ចាក់[ម] ហើយគេនឹងយំសោកនឹងអ្នកនោះ ដូចជាយំសោក
នឹងកូនខ្លួនតែមួយ[យ] គេនឹងយំខ្សឹកខ្សួលនឹងអ្នកនោះដូចជាយំ
នឹងកូនច្បងរបស់ខ្លួន[រ] ១១នៅថ្ងៃនោះ នឹងមានការយំ
សោក[ល]យ៉ាងធំនៅក្រុងយេរូសាឡិម ដូចជាការយំសោក
នៅត្រង់ហាដាត-រីម៉ូន ក្នុងច្រកភ្នំមេគីដោនោះដែរ[វ]
១២ស្រុកទាំងមូលនឹងយំសោក[ស] គ្រប់ទាំងគ្រួសារដោយ
ខ្លួនៗ គឺវង្សរបស់ដាវីឌដោយខ្លួន ហើយប្រពន្ធគេដោយខ្លួន
គ្រួពួកវង្សណាថាន់ដោយខ្លួន ហើយប្រពន្ធគេដោយខ្លួន
១៣គ្រួពួកវង្សលេវីដោយខ្លួន ហើយប្រពន្ធគេដោយខ្លួន
គ្រួពួកវង្សស៊ីម៉ាយដោយខ្លួន ហើយប្រពន្ធគេដោយខ្លួន
១៤ឯអស់គ្រួសារឯទៀត នោះគ្រប់ទាំងគ្រួដោយខ្លួននិង
ប្រពន្ធគេដោយខ្លួនដែរ[ហ]។

## ការសម្អាតអំពើបាប

**១៣** ១នៅថ្ងៃនោះ និងមានក្បាលទឹកមួយ[ក]បើកឡើង
សំរាប់ពួកវង្សដាវីឌ និងពួកអ្នកនៅក្រុងយេរូសាឡិម ដើម្បី
ជំរះ[ខ]អំពើបាប និងសេចក្ដីសៅហ្មង ២ព្រះយេហូវ៉ានៃ
ពួកពលបរិវារ ទ្រង់មានបន្ទូលថា នៅថ្ងៃនោះ អញនឹងកាត់
ឈ្មោះអស់ទាំងរូបព្រះ[គ]ឱ្យសូន្យចេញពីស្រុកទៅ ឥតមាន
អ្នកណានឹកចាំតទៅទៀតឡើយ[ឃ] ហើយអញនឹងធ្វើឱ្យពួក
ហោរា[ង] និងវិញ្ញាណអសោចិ៍ចេញផុតពីស្រុកដែរ ៣គ្រា
នោះ បើអ្នកណានឹងនៅតែទាយទៀត នោះទាំងឪពុកម្ដាយ
ដែលបង្កើតអ្នកនោះមក នឹងប្រាប់ថា ឯងមិនត្រូវរស់ទៀត
ទេ ពីព្រោះឯងពោលពាក្យកុហក[ច] ដោយនូវព្រះនាមព្រះ
យេហូវ៉ា ដូច្នេះ ឪពុកម្ដាយដែលបានបង្កើតអ្នកនោះមក
នឹងចាក់ទំលុះកូន ក្នុងកាលដែលទាយនោះ[ឆ] ៤នៅថ្ងៃនោះ
ពួកហោរា និងមានសេចក្ដីខ្មាស[ជ]ចំពោះការជាក់ស្ដែង
របស់គេរៀងខ្លួន ក្នុងកាលដែលទាយនោះ គេនឹងមិនគ្រលុំ

**១២:៨** ធ ទដ ៨២:៦ ន មីក ៧:៨ **១២:៩** ប អស ២៩:៧ ផ សក ១:២១ ១៤:២-៣ **១២:១០** ព អគ ៣៧:៩ ភ អស ៤៤:៣ អគ ៣៩:២៩ យអ ២:២៨-២៩ ម ទដ ២២:១៦ យហ ១៩:៣៤,៣៧ យ ពច ១១:៣៤ រ លប ២១:១៦ យរ ៣១:១៩ **១២:១១** ល យរ ៥០:៤ វ ២ពវ ២៣:២៩ **១២:១២** ស មថ ២៤:៣០ វវ ១:៧ **១២:១៤** ហ សក ៧:៣ **១៣:១** ក យរ ១៧:១៣ ខ លវ ១៦:៣០ ទដ ៥១:២ ហព ៩:១៤

**១៣:២** គ យរ ៤៣:១២ អគ ៦:៦ ៣៦:២៥ ហស ២:១៧ ឃ មីក ៥:១៣ ង ១ពវ ២២:២២ យរ ២៣:១៤-១៥ **១៣:៣** ច យរ ២៨:១៦ ឆ ចទ ១៣:៦-១១ ១៨:២០ នហ ៦:១៤ យរ ២៣:៣៤ អគ ១៤:៩ **១៣:៤** ជ យរ ៦:១៥

ការពន្យល់, នក ១៤:១៩ ២៣:២០ ៣២:៣៤ ៣៣:២ ហស ១២:៣-៤ និង លប ១៦:៧ និងការពន្យល់ ។

**១២:១០** *និស្ស័យ* មើល អស ៣២:១៥ អគ ៣៦:២៦-២៧ និងការពន្យល់, មើល អស ៤៤:៣ ៥៩:២០-២១ អគ ៣៩:២៩ យអ ២:២៨-២៩ ។ *គន់មើល* គឺសំឡឹងមើលឆ្ពោះទៅរកព្រះម៉ែស៊ីដោយជំនឿ (ធៀបនឹង ជន ២១:៩ អស ៤៥:២២ យហ ៣:១៤-១៥) ។ *ចាក់* មើល ទដ ២២:១៦ និងការពន្យល់ ។ យហ ១៩:៣៧ ។ *យំសោកនិងកូនខ្លួនតែមួយ* មើល យរ ៦:២៦ និងការពន្យល់, យហ ១៩:៣៧ ។ *យំសោកនឹងកូនច្បងខ្លួន* ធៀបនឹង ១១:៥-៦ ។

**១២:១១** *ហាដាត-រីម៉ូន* គឺជា (១).ឈ្មោះតបន់នៅក្បែរក្រុងមេគីដោ ដែលប្រជាជនយំសោកនឹងការស្លាប់របស់ស្ដេចយូសៀស (២របា ៣៥:២០-២៧ មើល ខ.២២ ដែលនិយាយអំពីវាលទំនាបមេគីដោ និងខ.២៤-២៥ និយាយអំពីការយំសោក) ឬ(២).ឈ្មោះព្រះព្យុះរបស់ពួកមជ្ឈិមបូពា៌ (២ពវ ៥:១៨ និងការពន្យល់) ដែលឈ្មោះនេះមានន័យថា "ព្រះហាដាតដ៏ជាផ្គរលាន់" នៅស្រុកបាប៊ីឡូន (មើល អគ ៨:១៤ ចំពោះឧទាហរណ៍នៃការយំថ្វាយព្រះរបស់ពួកបាប៊ីឡូន) ។

**១២:១២** *ណាថាន* គឺកូនប្រុសស្ដេចដាវីឌ (២សយ ៥:១៤ លក ៣:៣១) ។

**១២:១៣** *ស៊ីម៉ាយ* គឺកូនប្រុសរបស់លោកកេសុន ដែលជាកូនរបស់លោកលេវី (ជន ៣:១៧-១៨,២១) ។ នៅសម័យនោះ ការលន់តួបាប និងការសោកសង្រេងមានអ្នកដឹកនាំខាងស្រុកទេស និងជំនឿ ។

**១៣:១** *ជំរះអំពើបាប* មើល ៣:៤-៩ និងការពន្យល់ ៣:៩ គឺជាព្រះរាជបញ្ញាមួយក្នុងចំណោមព្រះរាជបញ្ញានៃសេចក្ដីសញ្ញាថ្មី (យរ ៣១:៣៤ អគ ៣៦:៣៥) ។

**១៣:២** *ឈ្មោះអស់ទាំងរូបព្រះ* គឺរួមមាន ឥទ្ធិពល កេរ្តិ៍ឈ្មោះ និងគ្រប់ទាំងលក្ខណៈទាំងអស់នៃរូបព្រះ ។ *ពួកហោរា* ពួកហោរាក្លែងក្លាយនៅតែជាបញ្ហានៅសម័យក្រោយការនិរទេស (មើល នហ ៦:១២-១៤) ហើយនិងក្លាយជាបញ្ហាម្ដងទៀតនៅពេលអនាគត (មើល មថ ២៤:៤-៥,១១,២៣-២៤ ២ថន ២:២-៤) ។

**១៣:៣** *កុហក* គឺពាក្យថ្លែងទំនាយក្លែងក្លាយ ។ *ឪពុកម្ដាយ... នឹងចាក់ទំលុះកូន* មើល ចទ ១៣:៣,៦-១០ ។

**១៣:៤-៦** ពួកហោរាក្លែងក្លាយនឹងស្ទាក់ស្ទើរនៅក្នុងការបន្តធ្វើហោរាតទៅទៀត ហើយនិងគេចចេញពីការទទួលខុសត្រូវនៅចំពោះមុខបណ្ដាជនដែលចោទសួរ ។ ដើម្បីជួយលាក់បាំងពីអត្តសញ្ញាណរបស់ខ្លួន អ្នកនោះនឹងមិនពាក់"អាវមានរោម" (ខ.៤) ដូចដែលលោកអេលីយ៉ាបានពាក់នោះទេ (មើល ២ពវ ១:៨ និងការពន្យល់) ។ ដើម្បីគេចពីទោសប្រហាជីវិត (ខ.៣) អ្នកនោះបដិសេធថាខ្លួនមិនមែនជាហោរាទេ ហើយនឹងអះអាងថាខ្លួនគឺជាអ្នកស្រែតាំងតែពីក្មេងមកម្ល៉េះ (ខ.៥)។ នៅពេលដែលគេចោទសួរពីស្លាកស្នាមនៅលើរូបកាយ (ខ.៦) អ្នកនោះនឹងអះអាងថាជាស្លាកស្នាមនេះមកពីជំលោះនឹងមិត្តសំឡាញ់របស់ខ្លួន (ឬស្លាកស្នាមដែលមកពីឪពុកម្ដាយវាយប្រដៅកាលពីនៅក្មេង) ។ អ្នកដែលចោទប្រកាន់ហោរាក្លែងក្លាយនោះប្រហែលជាសង្ស័យថា ស្លាកស្នាមនៃហោរាក្លែងក្លាយនោះ គឺមកពីការធ្វើបាបខ្លួនឯង ថ្វាយដល់រូបព្រះ (ដូចនេះក្នុង ១ពវ ១៨:២៨ មើល យរ ១៦:៦ និងការពន្យល់, យរ ៤៨:៣៧) ។

ខ្លួន ដោយអាវ[ឈ]មានរោម[ញ] ដើម្បីបញ្ឆោតមនុស្សទៀតទេ[ដ]
៥គឺអ្នកនោះនឹងថា ខ្ញុំមិនមែនជាហោរាទេ ខ្ញុំជាអ្នកធ្វើស្រែ
វិញ ដ្បិតខ្ញុំបានជាប់ជាបាវគេតាំងពីក្មេងមក[ឋ] ៦នោះម្នាក់
នឹងសួរថា ចុះតើរបួសអ្វីនុ៎ះនៅដៃអ្នក រួចអ្នកនោះនឹង
ឆ្លើយថា គឺយ៉ាងនេះដែលខ្ញុំត្រូវរបួស នៅក្នុងផ្ទះរបស់មិត្រ
សំឡាញ់ខ្ញុំ ។

## ពួកអ្នកគង្វាលកម្ចាត់កម្ចាយហ្វូងចៀម

៧ព្រះយេហូវ៉ា នៃពួកពលបរិវារ ទ្រង់មានបន្ទូលថា
ម្នាលដាវ[ឌ] អើយចូរភ្ញាក់ឡើងទាស់នឹងអ្នកគង្វាលរបស់
អញ[ឍ] ហើយទាស់នឹងមនុស្សដែលជាកូកនអញចុះ ចូរវាយ
អ្នកគង្វាល នោះហ្វូងចៀមនឹងត្រូវខ្ចាត់ខ្ចាយទៅ រួចអញនឹង
ប្រែដៃទៅលើកូនតូចៗវិញ[ណ] ៨ព្រះយេហូវ៉ាទ្រង់មានបន្ទូល
ថា នៅសព្វគ្រប់ក្នុងស្រុកនោះ ២ភាគនឹងត្រូវកាត់ចេញ
ហើយស្លាប់ទៅ តែភាគទី៣នឹងសល់នៅក្នុងស្រុកវិញ[ត]
៩ហើយអញនឹងនាំភាគទី៣នោះទៅក្នុងភ្លើង[ថ] អញនឹងសំរង
គេដូចជាសំរងប្រាក់[ទ] ព្រមទាំងសាកគេដូចជាសាកមាស[ធ]
គេនឹងអំពាវនាវ[ន]ដល់ឈ្មោះអញ[ប] ហើយអញនឹងស្តាប់[ផ]គេ
អញនឹងថា គេជារាស្ត្រអញ[ព] ឯគេនឹងថា ព្រះយេហូវ៉ាជា
ព្រះនៃខ្លួន[ភ] ។

## ព្រះអម្ចាស់ទ្រង់យាងមក ហើយសោយរាជ្យ

**១៤** ១មើល ថ្ងៃនៃព្រះយេហូវ៉ា[ក] នឹងមកដល់ ជាវេលា
ដែលគេនឹងចាប់របឹប[ខ]ជារបស់ផងឯង ចែកគ្នានៅកណ្ដាល
ឯង ២ដ្បិតអញនឹងប្រមូល អស់ទាំងសាសន៍[គ]មកច្បាំងនឹង
ក្រុងយេរូសាឡិម[ឃ] គេនឹងចាប់យកទីក្រុងបាន ព្រមទាំងប្លន់
ផ្ទះទាំងប៉ុន្មាន ហើយកំហែងចិត្តពួកស្រីៗផង[ង] នោះពួកអ្នក
ក្រុងពាក់កណ្ដាលនឹងត្រូវនាំចេញទៅជាឈ្លើយ តែបណ្ដា
ជនដែលសល់នៅ និងមិនត្រូវឃ្លាតចេញពីទីក្រុងទេ[ច] ៣គ្រា
នោះ ព្រះយេហូវ៉ាទ្រង់នឹងចេញទៅច្បាំង[ឆ]នឹងសាសន៍ទាំង
នោះ ដូចកាលនៅថ្ងៃចំបាំងដែលទ្រង់បានច្បាំងនឹងគេដែរ[ជ]
៤នៅថ្ងៃនោះ ព្រះបាទទ្រង់នឹងជាន់លើភ្នំដើមអូលីវ[ឈ] ដែល
នៅប្រឈមនឹងក្រុងយេរូសាឡិមខាងកើត ហើយភ្នំដើម
អូលីវនឹងត្រូវពុះញែក[ញ]ជា២ នៅចំពាក់កណ្ដាល ពីទិស
ខាងកើតទៅទិសខាងលិច បង្កើតឱ្យមានចន្លោះយ៉ាងធំ ភ្នំ
មួយចំហៀងនឹងញែកទៅទិសខាងជើង ហើយ១ចំហៀង
ទៀតទៅទិសខាងត្បូង ៥នោះឯងរាល់គ្នានឹងរត់ទៅតាម
ចន្លោះភ្នំរបស់អញ ដ្បិតចន្លោះភ្នំនោះ និងរហូតទៅដល់
អាសែល អើ ឯងរាល់គ្នានឹងរត់ ដូចបានរត់ពីការកក្រើក
ដី[ដ] នៅក្នុងរាជ្យអូសៀស ជាស្តេចយូដា នោះព្រះយេហូវ៉ា
ជាព្រះនៃខ្ញុំ ទ្រង់នឹងយាងមក[ឋ] មានទាំងពួក បរិសុទ្ធទាំង

**១៣:៤** ឈ មថ ៣:៤ ញ ១ពវ ១៨:៧ អស ២០:២ ដ អក ១២:២៤
**១៣:៥** ឋ អម ៧:១៤
**១៣:៧** ឌ អស ៣៤:៥ យរ ៤៧:៦ ឍ អស ៤០:១១ ៥៣:៤ អក ៣៧:២៤ ណ ១សយ ១៧:២ មថ ២៦:៣១ មក ១៤:២៧
**១៣:៨** ត អក ៥:២-៤,១២ សក ១៤:២
**១៣:៩** ថ អស ៤:៤ ៣៣:១៤ មឡ ៣:២ ទ ទដ ១២:៦ ធយ ១១:៣៥ ១ពត ១:៦-៧ ធ យប ៦:២៩ យរ ៦:២៧ ន ទដ ៥០:១៥ ប ទដ ១០៥:១ ផ ទដ ៨៦:៧ អស ៣០:១៩ សក ១០:៦ ព លវ ២៦:១២ យរ ៣០:២២ ភ អស ៤៤:៥ យរ ២៩:១២ អក ២០:៣៨
**១៤:១** ក អស ១៣:៦ យអ ១:១៥ មឡ ៤:១ ខ អស ២៣:១៨ **១៤:២** គ អស ២:៣ សក ១២:៣ ឃ អក ៥:៨ ង លប ៣៤:២៩ បទ៥:១១ ច អស ១៣:៦ សក ១៣:៨ ឆ សក ៩:១៤០១ **១៤:៣** ជ អស ៨:៩ សក ១២:៩ **១៤:៤** ឈ អក ១១:២៣ ញ ជន ១៦:៣១ **១៤:៥** ដ អម ១:១ ឋ អស ២៩:៦ ៦៦:១៥-១៦

**១៣:៥** *ជាប់ជាបាវតាំងពីក្មេងមក* មានន័យថា គេបានលក់គាត់ជាទាសករតាំងពីក្មេងមក ។

**១៣:៧** *អ្នកគង្វាលរបស់អញ* គឺអ្នកគង្វាលល្អរបស់ក្សត្រ (ធៀបនឹងអ្នកគង្វាលល្អក្នុង ១១:៤-១៤ គឺខុសពីអ្នកគង្វាលល្ងីល្ងើ និងចោលម្សៀតក្នុង ១១:១៥-១៧) ។ *វាយអ្នកគង្វាល* នៅក្នុង ១១:១៧ គឺត្រូវវាយអ្នកគង្វាលចោលម្សៀត នៅក្នុងខនេះ គឺត្រូវវាយអ្នកគង្វាលល្អ(ធៀបនឹង ១២:១០ ផងដែរ) ។ *ហ្វូងចៀមនឹងត្រូវខ្ចាត់ខ្ចាយទៅ* គឺជាផ្នែកមួយនៃសេចក្ដីបណ្ដាសាពីការមិនស្ដាប់បង្គាប់តាមសេចក្ដីសញ្ញា (មើល ចទ ២៨:៦៤ និងការពន្យល់ ២៩:២៤-២៥) ។ ព្រះយេស៊ូវទ្រង់មានបន្ទូលដកស្រង់ពីបទគម្ពីរនេះមុនពេលគេចាប់ព្រះអង្គទ្រង់មិនយូរប៉ុន្មាន(មថ ២៦:៣១ មក ១៤:២៧) ហើយទ្រង់ក៏បានយកបទគម្ពីរនេះ មកប្រើជាមួយនឹងការរត់ខ្ចាត់ខ្ចាយរបស់ពួកសាវ័ក(មថ ២៦:៥៦ មក ១៤:៤៩-៥០) ដែលប្រហែលជាការកាត់ស្រាយអំពីការខ្ចាត់ខ្ចាយរបស់ពួកយូដានៅឆ្នាំ៧០នៃគ.ស. និងឆ្នាំក្រោយៗមកទៀត ។

**១៣:៨-៩** វគ្គនេះពិពណ៌នាអំពីការសំអាតពួកអ៊ីស្រាអែលជាបរិសុទ្ធ (មើលការពន្យល់ អស ៤៨:១០) ។

**១៣:៨** *ភាគទី៣* គឺជាសំណល់នៃសាសន៍អ៊ីស្រាអែល ដែលបង្ហាញពីសេចក្ដីមេត្តាករុណានៃព្រះនៅក្នុងការជំនុំជម្រះ ។

**១៣:៩** *អញនឹងសំរងគេ* មើល ទដ ១២:៦ និងការពន្យល់ ។ *រាស្ត្រអញ . . . ព្រះនៃខ្លួន* ពួកគេនឹងត្រូវបានស្អាងឡើងវិញ ដើម្បីឱ្យមានទំនាក់ទំនងជាមួយព្រះអម្ចាស់ឡើងវិញតាមសេចក្ដីសញ្ញា (មើល អក ២០:៣០-៤៤) ។

**១៤:១** *ថ្ងៃនៃព្រះយេហូវ៉ា* ធៀបនឹង អស ២:១២ អក ៣០:៣ យអ ១:១៥ និងការពន្យល់ ។ *របស់ផងឯង . . . ឯង* ក្រុងយេរូសាឡិម(ខ.២) នឹងត្រូវគេចាប់យក ហើយប្លន់ ។

**១៤:២** *អស់ទាំងសាសន៍មកច្បាំងនឹងក្រុងយេរូសាឡិម* មើល ខ.១២ និងការពន្យល់ ១២:៣ ។

**១៤:៣** *ថ្ងៃចំបាំង* គឺនៅពេលដែលព្រះអម្ចាស់ទ្រង់ជួយដល់រាស្ត្រទ្រង់ដោយការអស្ចារ្យ ដូចកាលនៅសមុទ្រក្រហមជាដើម(មើល នក ១៤:១៤ និងការពន្យល់) ។

**១៤:៤** *ភ្នំដើមអូលីវ* ឈ្មោះនេះមានប្រើនៅក្នុងព្រះគម្ពីរសញ្ញាចាស់នៅក្នុងបទគម្ពីរផ្សេងទៀតគឺ ២សយ ១៥:៣០ ។ ភ្នំនេះនៅទុលមុខនឹងទួលនៃព្រះវិហារ ហើយមានកំពស់ ៨២៣ ម៉ែត្រ គឺខ្ពស់ជាងទួលព្រះវិហារប្រហែល ៦០ ម៉ែត្រ ។ ធៀបនឹង អក ១១:២៣ ។ បទទំនាយក្នុងខនេះប្រហែលជាសំដៅទៅលើព្រឹត្តការណ៍ក្នុង កច ១:១១-១២ ។

**១៤:៥** *អាសែល* ជាឈ្មោះទីកន្លែងមួយដែលនៅខាងកើតក្រុងយេរូសាឡិម គឺស្ថិតនៅតាមខាងចុងជ្រលងខាងកើត ។ *ការកក្រើកដី នៅក្នុងរាជ្យអូសៀស* លោកអេម៉ុសបានកំណត់កាលបរិច្ឆេទនៃបទទំនាយរបស់លោក ដោយនិយាយសំដៅទៅលើព្រឹត្តការណ៍នេះ(អម ១:១ និងការពន្យល់) ។ *ពួកបរិសុទ្ធ* អាចរួមមានទាំងអ្នកជឿព្រះ និងពួកទេវតា ។ ពួកគេនឹងរួមដំណើរ

អស់មកជាមួយ[ឱ] ៦នៅថ្ងៃនោះ ពន្លឺនឹងមិនភ្លឺច្បាស់[ឲ] ឬងងឹត
ផង ៧គឺថ្ងៃនោះនឹងបានជាថ្ងៃ១[ណ] ដែលព្រះយេហូវ៉ាទ្រង់
ស្គាល់ មិនមែនជាថ្ងៃ ក៏មិនមែនជាយប់[ត] ប៉ុន្តែលុះដល់
ពេលព្រលប់ នោះនឹងមានពន្លឺវិញ[ថ] ៨នៅថ្ងៃនោះ និងមាន
ទឹករស់[ទ]ហូរចេញ[ធ]ពីក្រុងយេរូសាឡិមទៅ ពាក់កណ្ដាល
នឹងហូរទៅឯសមុទ្រនៅទិសខាងកើត[ន] ហើយពាក់កណ្ដាល
នឹងហូរទៅឯសមុទ្រនៅទិសខាងលិច ទោះទាំងរដូវក្ដៅនឹង
រដូវរងា ក៏នឹងមានដូច្នោះដែរ[ប]។
៩ឯព្រះយេហូវ៉ា ទ្រង់នឹងបានជាមហាក្សត្រ[ផ]លើផែន
ដីទាំងដុំមូល[ព] នៅថ្ងៃនោះ នឹងមានតែព្រះយេហូវ៉ាជាព្រះ
១ព្រះអង្គ ហើយព្រះនាមទ្រង់នឹងមានតែ១ដែរ[ភ] ១០ស្រុក
ទាំងមូលចាប់តាំងពីកេបា[ម] រហូតដល់រីម៉ូន[យ] ខាងត្បូង
ក្រុងយេរូសាឡិម និងត្រឡប់ទៅដូចជាស្រុកវាល នោះ
ក្រុងយេរូសាឡិមនឹងបានដំកើងឡើង[រ] ហើយនិងនៅកន្លែង
ធម្មតា[ល] ចាប់តាំងពីទ្វារ[វ]បេនយ៉ាមីន រហូតទៅដល់កន្លែង
ទ្វារដំបូងនឹងទ្វារជ្រុង[ស] កំផែង ហើយពីប៉មហាណានាល[ហ]
រហូតដល់ធុងឃ្នាបរបស់ស្ដេច ១១ក៏នឹងមានមនុស្សអាស្រ័យ
នៅ[ឡ] ហើយនិងគ្មានសេចក្ដីបណ្ដាសាទៀត គឺក្រុងយេរូ–
សាឡិមនឹងនៅដោយសុខសាន្តវិញ[អ]។

**១៤:៥**
ឱ ចទ ៣៣:២
មថ ១៦:២៧
២៥:៣១ យដ ១៤
**១៤:៦** ឲ អស
១៣:១០ យរ ៤:២៣
**១៤:៧** ណ យរ
៣០:៧ ត វវ
២១:២៣–២៥
២២:៥ ថ អស
១៣:១០ ៣០:២៦
**១៤:៨** ទ អគ ៤៧:១–
១២ យហ ៧:៣៨
វវ ២២:១–២
ធ អស ៣០:២៥
ន យអ ២:២០
ប លប ៨:២២
**១៤:៩** ផ ទដ
២២:២៨ អប
១:២១ ព ចទ ៦:៤
ទដ ៤៧:៧ អស
៤៥:២៤ វវ ១១:១៥
ភ ហាព ២:១៤
អភ ៤:៥–៦
**១៤:១០** ម ១ពវ

១២ព្រះយេហូវ៉ានឹងវាយអស់ទាំងសាសន៍ ដែលបាន
ច្បាំង[ក] នឹងក្រុងយេរូសាឡិម ដោយសេចក្ដីវេទនាយ៉ាងនេះ
គឺសាច់គេនឹងរោយរៀវទៅ កំពុងដែលគេឈរនៅ ភ្នែក
គេនឹងរោយរៀវទៅ នៅក្នុងរង្វង់ភ្នែក អណ្ដាតគេនឹង
រោយរៀវទៅ នៅក្នុងមាត់គេដែរ[ខ] ១៣នៅថ្ងៃនោះ នឹង
មានការចលាចលជាធំ[គ] ដែលមានមកពីព្រះយេហូវ៉ា កើត
ឡើងនៅកណ្ដាលគេ គ្រប់គ្នានឹងចាប់យកអ្នកជិតខាងខ្លួន
ហើយនឹងលើកដៃឡើងទាស់នឹងអ្នកជិតខាងរៀងខ្លួន[ឃ] ១៤ឯ
ពួកយូដា[ង]គេនឹងច្បាំងត្រង់ក្រុងយេរូសាឡិម ហើយទ្រព្យ
សម្បត្តិនៃគ្រប់សាសន៍ជុំវិញ នឹងបានប្រមូលគ្នា[ច] គឺមាស
ប្រាក់ និងសំលៀកបំពាក់យ៉ាងសន្ធឹក ១៥ឯសេចក្ដីវេទនា[ឆ]
របស់សេះ លាកាត់ អូដ្ឋ លា និងសត្វទាំងអស់ ដែលនៅ
ក្នុងទីបោះទ័ព នឹងបានដូច្នោះដែរ គឺដូចជាអាសន្នរោគ ។
១៦រួចមក អស់អ្នកសល់នៅ[ជ]ពីគ្រប់សាសន៍ដែលមកច្បាំង
នឹងក្រុងយេរូសាឡិម គេនឹងឡើងមករាល់តែឆ្នាំ ដើម្បី

១៥:២២ យ យស ១៥:៣២ រ អស ២:២ យរ ៣០:១៨ អម ៩:១១ ល សក ១២:៦ វ យរ ២០:២ ស ២ពវ ១៤:១៣ ហ នហ ៣:១ **១៤:១១** ឡ សក ២:៤ អ ទដ ៤៨:៨ អគ ៣៤:២៥–២៨ **១៤:១២** ក អស ១១:៤ ខ ខ.១៨ លវ ២៦:១៦ ចទ ២៨:២២ យប ១៨:១៣ **១៤:១៣** គ លប ៣៥:៥ ឃ ពច ៧:២២ សក ១១:៦ **១៤:១៤** ង សក ១២:២ ច អស ២៣:១៨ **១៤:១៥** ឆ ខ.១២ **១៤:១៦** ជ ២ពវ ១៩:៣១

ជាមួយនឹងព្រះអម្ចាស់នៃយើង នៅគ្រាដែលទ្រង់យាងមក (ធៀបនឹង មថ ២៥:៣១ ១ថន ៣:១៣ យដ ១៤ វវ ១៩:១៤) ។

**១៤:៧** *បានជាថ្ងៃ១* មើល អស ៦០:១៩–២០ និងការពន្យល់ផងដែរ ។

**១៤:៨** *ទឹករស់ហូរចេញ* ពាក្យនេះប្រហែលជាមានន័យត្រង់ផង និងន័យធៀបផង (មើល អស ៨:៦ យអ ៣:១៨ និងការពន្យល់ យហ ៧:៣៨)។

**១៤:៩** *ព្រះយេហូវ៉ា ទ្រង់នឹងបានជាមហាក្សត្រលើផែនដី* ឃ្លានេះមានខ្លឹមសារជាវិជ្ជាសិក្សាអំពីព្រះ (មើលសេចក្ដីផ្ដើមទំនុកដំកើងត្រង់វិជ្ជាសិក្សាអំពីព្រះ) ។ *ទ្រង់នឹងមានតែ១* មើល ចទ ៦:៤ អស ៤៣:១១ និងការពន្យល់ ។

**១៤:១០** *កេបា* តំបន់នេះនៅភាគខាងជើងឈាងខាងកើតនៃទីក្រុងយេរូ–សាឡិម និងមានចម្ងាយប្រហែល ៩,៦ គីឡូម៉ែត ពីក្រុងនេះ គឺនៅព្រំប្រទល់ខាងជើងនៃស្រុកយូដា (មើល ២ពវ ២៣:៨ និងការពន្យល់)។ *រីម៉ូន* ឈ្មោះនេះអាចហៅម្យ៉ាងទៀតថា អេន–រីម៉ូន (មើល នហ ១១:២៩ និងការពន្យល់) ស្ថិតនៅភាគខាងត្បូងឈាងខាងលិចនៃក្រុងយេរូសាឡិម មានចម្ងាយប្រហែល ៥៦ គីឡូម៉ែត្រ គឺនៅតំបន់នៃស្រុកយូដាដែលមានជិវាលទៅរកស្រុកនីហ្គេវ ។ *ស្រុកវាល* មើលការពន្យល់ ចទ ១:១ ។ ត្រង់តំបន់ជិតខាងរបស់ក្រុងយេរូសាឡិមទាំងអស់គឺត្រូវបំផ្លាញ ។ *ក្រុងយេរូសាឡិមនឹងបានដំកើងឡើង* មើល អស ២:២–៤ និងការពន្យល់ ។ *ទ្វារបេនយ៉ាមីន . . . ទ្វារដំបូង . . . ប៉មហាណានាល* ទីតាំងនៃកន្លែងទាំងអស់នេះប្រហែលជាសុទ្ធតែនៅផ្នែកខាងជើងឈាងខាងកើតនៃកំផែងក្រុង (ធៀបនឹង យរ ៣១:៣៨ ៣៧:១២–១៣ ៣៨:៧)។ *ទ្វារជ្រុងកំផែង* គឺជ្រុងខាងជើងភាគខាងលិច (ធៀបនឹង យរ ៣១:៣៨) ។ *ធុងឃ្នាបរបស់ស្ដេច* គឺនៅភាគខាងត្បូងនៃក្រុង ។ ដូចនេះខនេះបានរៀបរាប់អំពីទីក្រុងនេះទាំងមូល ។

**១៤:១១** *មនុស្សអាស្រ័យនៅ* មើល ២:៤ និងការពន្យល់ ។ *គ្មានសេចក្ដីបណ្ដាសាទៀត* គឺមិនត្រូវបណ្ដាសាដូចកាលនៅសម័យនិរទេសទៅស្រុកបាប៊ីឡូននោះទេ (មើល អស ៤៣:២៨ និងការពន្យល់) ។ *ក្រុងយេរូ–សាឡិមនឹងនៅដោយសុខសាន្ត* មើល យរ ៣១:៤០ ។

**១៤:១២** *សាសន៍ ដែលបានច្បាំងនឹងក្រុងយេរូសាឡិម* មើល ខ.២ និងការពន្យល់ ១២:៣ ។ *សេចក្ដីវេទនា* មើល អស ៣៧:៣៦ និងការពន្យល់ ។

**១៤:១៣** *ការចលាចលជាធំ . . . លើកដៃឡើងទាស់នឹងអ្នកជិតខាង* មើល ពច ៧:២២ និងការពន្យល់ ។

**១៤:១៤** *មាស ប្រាក់ និងសំលៀកបំពាក់* ការលួចប្លន់នៅក្នុងចម្បាំងនេះគឺបានបង្ហាញពីស្ថានភាពនៅក្នុង ខ.១ ។

**១៤:១៥** សេចក្ដីវេទនាស្រដៀងគ្នានេះនឹងវាយប្រហាមកលើសត្វពាហនៈដើម្បីធ្វើឱ្យមនុស្សមិនអាចប្រើសត្វទាំងនោះតទៅទៀត ។

**១៤:១៦** មើល អស ២:២–៤ និងការពន្យល់ ។ *បុណ្យបារាំ* មើលការពន្យល់ នក ២៣:១៦ ទដ ៨១:៣ ។ បុណ្យបារាំស្ថិតនៅក្នុងចំណោមបុណ្យធំបំផុតទាំងបី (មើល នក ២៣:១៤–១៧) គឺជាបុណ្យចុងក្រោយ និងធំបំផុតនៅក្នុងប្រតិទិនរបស់ពួកយូដា (មើលការពន្យល់ អគ ៤៥:២៥)។ បុណ្យនេះគឺជាពេលដែលត្រូវមានអំណរដោយអរព្រះគុណ (មើល លវ ២៣:៤០ ចទ ១៦:១៣–១៥ នហ ៨:១៧ និងការពន្យល់) ។ ចូលមកដល់សម័យលោកអែសរ៉ា និងនេហេមា ការអាន និងការបង្រៀនពី "ព្រះគម្ពីរក្រឹត្យវិន័យ" គឺជាផ្នែកដ៏សំខាន់មួយនៅក្នុងបុណ្យនេះ (នហ ៨:១៨ ធៀបនឹង អស ២:៣)។

ថ្វាយបង្គំ[ឈ] មហាក្សត្រ[ញ] គឺជាព្រះយេហូវ៉ានៃពួកពលបរិវារ
ក៏នឹងកាន់រក្សាបុណ្យបារាំ[ដ] ១៧ ដូច្នេះ ក្នុងអស់ទាំងគ្រួសារ
នៅផែនដី បើមានណាដែលមិនឡើងទៅឯក្រុងយេរូសា–
ឡិម ដើម្បីថ្វាយបង្គំ[ឋ] មហាក្សត្រ គឺព្រះយេហូវ៉ានៃពួកពល
បរិវារទេ នោះនឹងគ្មានភ្លៀងធ្លាក់មកលើគេឡើយ[ឌ] ១៨ បើ
សាសន៍អេស៊ីព្ទមិនឡើងទៅ គឺមិនមកសោះ នោះនឹងគ្មាន
ភ្លៀងធ្លាក់មកលើគេ ហើយនិងមានសេចក្តីវេទនា[ឍ] ដែល
ព្រះយេហូវ៉ាទ្រង់នឹងប្រើវាយអស់ទាំងសាសន៍ ដែលមិន
ឡើងទៅធ្វើបុណ្យបារាំ[ណ] ១៩ នេះហើយជា សេចក្តីវាយ
ផ្ចាលដល់ពួកសាសន៍អេស៊ីព្ទ ហើយជាសេចក្តីវាយផ្ចាល
ដល់អស់ទាំងសាសន៍ ដែលមិនឡើងមកធ្វើបុណ្យបារាំ
នោះ[ត] ។

**១៤:១៦** ឈ ទដ ២២:២៩ ៨៦:៩ អស ១៩:២១ ញ អប ១:២១ ដ នក ២៣:១៦ អស ៦០:៦–៩ មីក ៤:២
**១៤:១៧** ឋ ២រប ៣២:២៣ ឌ យរ ១៤:៤ អម ៤:៧
**១៤:១៨** ឍ លប ២៧:២៩ ណ ខ.១២
**១៤:១៩** ត អរ ៣:៤
**១៤:២០** ថ នក ៣៩:៣០ ទ អគ ៤៦:២០ ធ សក ៩:១៥

២០ នៅថ្ងៃនោះ នឹងមានសេចក្តីចារិកទុក នៅនាចង្រ្កង់
សេះថា "បរិសុទ្ធដល់ព្រះយេហូវ៉ា"[ថ] ហើយថ្លាង[ទ] ទាំង
ប៉ុន្មាននៅក្នុងព្រះវិហារនៃព្រះយេហូវ៉ា និងដូចជាចាន[ធ]
ដែលនៅមុខអាសនាដែរ ២១ អើ គ្រប់ទាំងភាជនៈនៅក្រុង
យេរូសាឡិម ហើយនៅស្រុកយូដា និងបានបរិសុទ្ធ[ន] ដល់
ព្រះយេហូវ៉ានៃពួកពលបរិវារទាំងអស់ អស់ពួកអ្នកដែល
មកថ្វាយយញ្ញបូជា គេនឹងយកភាជនៈទាំងនោះ សំរាប់
ស្ងោរដង្វាយយញ្ញបូជា ហើយនៅថ្ងៃនោះ[ប] និងគ្មានសាសន៍
កាណាន[ផ] ណា នៅក្នុងព្រះវិហារ[ព] របស់ព្រះយេហូវ៉ានៃពួក
ពលបរិវារទៀតឡើយ[ភ] ។/

**១៤:២១** ន យរ ៣១:៤០ រម ១៤:៦–៧ ១កថ ១០:៣១ ប នហ ៨:១០ ផ សក ៩:៨ ព នហ ១១:១ ភ អគ ៤៤:៩

បុណ្យនេះហាក់ដូចជាបានបង្ហាញពី ការប្រមូលផ្តុំ និងការស្អាងរបស់អ៊ីស្រាអែល ជាចុងក្រោយ និងប្រកបដោយអំណរ ។

**១៤:១៧** *គ្មានភ្លៀង* គឺស្ថិតនៅក្នុងចំណោមសេចក្តីបណ្តាសា ដោយសាការមិនស្តាប់បង្គាប់តាមសេចក្តីសញ្ញា (ចទ ២៨:២២–២៤ ធៀបនឹង សក ៩:១១–១០:១) ។

**១៤:១៨** *សាសន៍អេស៊ីព្ទ . . . នឹងគ្មានភ្លៀងធ្លាក់* នៅក្នុងចំណុចនេះប្រហែលជារួមមានការដែលព្រះទ្រង់បង្អត់ភ្លៀងផងដែរ ហើយភាពរាំងស្ងួតនៅផ្នែកខាងលើនៃទន្លេនីល នឹងធ្វើទន្លេនេះមិនអាចជន់ឡើងបាន ។

**១៤:២០** *បរិសុទ្ធ ដល់ព្រះយេហូវ៉ា* ពាក្យនេះត្រូវបានគេចារនៅលើស្លាកធ្វើពីមាស ដាក់នៅលើមួករបស់ពួកសង្ឃ (នក ២៨:៣៦–៣៨) ដើម្បីជាការរំឭកដល់ការញែកជាបរិសុទ្ធរបស់ពួកគេសម្រាប់ការងារបំម្រើព្រះអម្ចាស់ (មើលការពន្យល់ ៣:៥) ។ គោលបំណងដំបូងបំផុតដែលព្រះទ្រង់មានសម្រាប់ពួកអ៊ីស្រាអែល (មើល នក ១៩:៦ និងការពន្យល់) និងត្រូវបានបង្ហាញឱ្យយល់ច្បាស់ ។

**១៤:២១** *គ្រប់ទាំងភាជនៈនៅក្រុងយេរូសាឡិម . . . នឹងបានបរិសុទ្ធ* មើល យអ ៣:១៧ និងការពន្យល់ ។ សូម្បីតែរបស់ធម្មតាៗក៏ត្រូវក្លាយជាបរិសុទ្ធដែរ នៅពេលដែលរបស់ទាំងនោះត្រូវប្រើនៅក្នុងការបម្រើព្រះ ។ *ស្ងោរ* គឺស្ងោរអាហារដែលសល់ពីយញ្ញបូជា ។ *សាសន៍កាណាន* គឺដំណាងឱ្យមនុស្សដែលមិនស្អាតខាងឯសីលធម៌ និងវិញ្ញាណ គឺអ្នកដែលមិនរាប់បញ្ចូលទៅក្នុងចំណោមរាស្ត្ររើសតាំងរបស់ព្រះ (ធៀបនឹង អស ៣៥:៨ អគ ៤៣:៧ ៤៤:៩ វវ ២១:២៧) ។

# ព្រះគម្ពីរម៉ាឡាគី

## សេចក្ដីផ្ដើម

### អ្នកនិពន្ធ

ព្រះគម្ពីរនេះជាស្នាដៃនិពន្ធរបស់លោកម៉ាឡាគី ដែលឈ្មោះរបស់លោកជាភាសាហេព្រើរមានន័យថា "ទូតអញ"។ ដោយសារគេឃើញពាក្យ "ទូតអញ" នៅក្នុង ៣:១ ហើយដោយសារពួកហោរា និងពួកសង្ឃសុទ្ធតែត្រូវបានហៅថា ទូតរបស់ព្រះយេហូវ៉ា (មើល ២:៧ ហាក ១:១៣) មានអ្នកខ្លះយល់ថា ពាក្យ "ម៉ាឡាគី" គ្រាន់តែជាតែជាងារដែលគេដាក់ឱ្យអ្នកនិពន្ធប៉ុណ្ណោះ ។ ទស្សនៈនេះបានទទួលការគាំទ្រ ដោយសំអាងទៅលើព្រះគម្ពីរសញ្ញាចាស់បកប្រែដំបូងមកជាភាសាក្រិច មុនសម័យគ្រីស្ទបរិស័ទ(ព្រះគម្ពីរសេបទូជិន, Septuagint) ដែលបានបកប្រែពាក្យនេះ នៅក្នុង ១:១ ថា "ទូតនៃទ្រង់" ហើយមិនបានប្រើពាក្យ "ម៉ាឡាគី" ដូចជាឈ្មោះនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានៃការប្រើពាក្យនេះនៅតែមិនទាន់ច្បាស់លាស់នៅឡើយ ហើយពាក្យ "ម៉ាឡាគី" នៅតែទំនងជាឈ្មោះអ្នកនិពន្ធដដែល ។

### ប្រវត្តិដើម

ដោយមានការជំរុញពីសកម្មភាពរបស់លោកហាកាយ និងលោកសាការី ពួកសាសន៍អ៊ីស្រាអែលដែលត្រឡប់ពីការនិទេសវិញ បានបញ្ចប់ការសាងសង់ព្រះវិហារ នៅឆ្នាំ ៥១៦ មុនគ.ស. នៅក្រោមការដឹកនាំរបស់ស្ដេចសូរ៉ូបាបិល ។ នៅឆ្នាំ ៤៥៨ មុនគ.ស សហគមន៍នៃសាសន៍អ៊ីស្រាអែលត្រូវបានពង្រឹងឡើងវិញ ដោយការមកដល់របស់សង្ឃ ឈ្មោះអែសរ៉ា និងការមកដល់នៃពួកសាសន៍យូដាប្រហែលពីរបីពាន់នាក់ទៀត ។ ស្ដេចពើស៊ី ព្រះនាមអើថាសើកសេស បានលើកទឹកចិត្តលោកអែសរ៉ាឱ្យចាប់ផ្ដើមការថ្វាយបង្គំព្រះនៅព្រះវិហារឡើងវិញ(អរ ៧:១៧) ហើយបានពង្រឹងការអនុវត្តន៍ក្រឹត្យវិន័យលោកម៉ូសេឡើងវិញផងដែរ (អរ ៧:២៥-២៦) ។

ដប់បួនឆ្នាំក្រោយមក(ឆ្នាំ ៤៤៤ មុន គ.ស.) ព្រះរាជាពើរស៊ីដដែលបានអនុញ្ញាតិឱ្យអ្នកថ្វាយពែងរបស់ទ្រង់ គឺលោកនេហេមាត្រឡប់ទៅក្រុងយេរូសាឡិម ហើយសាងសង់កំផែងក្រុងនេះឡើងវិញ(នេហ ៦:១៥)។ លោកនេហេមាបានទទួលការចាត់តាំងជាចៅហ្វាយថ្មី លោកបានដឹកនាំនៅក្នុងកំណែរទម្រង់ ដើម្បីជួយដល់អ្នកក្រ (នេហ ៥:២-១៣) ហើយបាននាំបណ្ដាជនបដិសេធការរៀបការជាមួយសាសន៍ដទៃ(នេហ ១០:៣០) នាំឱ្យពួកគេកាន់តាមច្បាប់ថ្ងៃឈប់សម្រាប់(នេហ ១០:៣១) ហើយដាក់ដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេងទៀតដោយស្មោះត្រង់ (នេហ ១០:៣៧-៣៩) ។

នៅឆ្នាំ ៤៣៣ មុនគ.ស. លោកនេហេមាបានត្រឡប់ទៅបម្រើស្ដេចពើរស៊ីវិញ ហើយនៅក្នុងពេលដែលលោកអវត្តមាន ពួកសាសន៍យូដាបានធ្លាក់ទៅក្នុងអំពើបាបម្ដងទៀត ។ ទោះជាយ៉ាងណាក៏ដោយ ក្រោយមក លោកនេហេមាបានត្រឡប់នៅក្រុងយេរូសាឡិមវិញ ហើយបានឃើញថា ពួកគេបានអើពើនឹងដង្វាយមួយភាគក្នុងដប់ ពួកគេបានបំពានច្បាប់ថ្ងៃឈប់សម្រាក ពួកបណ្ដាជនបានរៀបការជាមួយសាសន៍ដទៃ ហើយពួកសង្ឃប្រព្រឹត្តអំពើពុករលួយ(នេហ ១៣:៧-៣១) ។ ចំពោះអំពើបាបទាំងប៉ុន្មាននេះ លោកម៉ាឡាគីបានថ្កោលទោស(មើល ១:៦-១៤ ២:១៤-១៦ ៣:៨-១១) ។

### កាលបរិច្ឆេទ

នៅក្នុងព្រះគម្ពីរនេហេមាមានការនិយាយប្រឆាំងនឹងអំពើបាប ស្រដៀងគ្នានឹងព្រះគម្ពីរម៉ាឡាគី ហើយការនេះបាននាំឱ្យគេសន្និដ្ឋានថា អ្នកដឹងនាំទាំងពីររស់នៅក្នុងសម័យតែមួយ ។ ព្រះគម្ពីរម៉ាឡាគីប្រហែលជាត្រូវបាននិពន្ធ បន្ទាប់ពីលោកនេហេមាត្រឡប់ពីចក្រភពពើរស៊ីវិញ នៅឆ្នាំ ៤៣៣ មុនគ.ស. ឬនៅក្នុងរយៈពេលនៃការដឹកនាំរបស់លោកជាលើកទីពីរ ។ ដោយសារគេជឿថា ពាក្យចៅហ្វាយនៅក្នុង ១:៨(មើលការពន្យល់ក្នុងខនេះ) មិនមែនជាលោកនេហេមា ដូចនេះកាលបរិច្ឆេទនៅឆ្នាំ ៤៣៣ មុនគ.ស. ទំនងជាត្រឹមត្រូវជាង ។ ព្រះគម្ពីរម៉ាឡាគីទំនងជាព្រះគម្ពីរហោរាចុងក្រោយបំផុតនៃយុគសម័យសញ្ញាចាស់(ទោះបីជាអ្នកខ្លះបានចាត់ទុកព្រះគម្ពីរយ៉ូអែលជាព្រះគម្ពីរចុងក្រោយបំផុតក៏ដោយ) ។

### ខ្លឹមសារ និងវិជ្ជាសិក្សាអំពីព្រះ

គេអាចសរសេរសង្ខេបការបង្រៀនអំពីវិជ្ជាសិក្សាអំពីព្រះនៅក្នុងព្រះគម្ពីរនេះ ជាប្រយោគមួយគឺ "មហាក្សត្រដ៏ធំ(១:១៤) ទ្រង់នឹងយាងមក មិនគ្រាន់តែដើម្បីកាត់ទោសរាស្ត្ររបស់ទ្រង់ប៉ុណ្ណោះទេ (៣:១-៥ ៤:១) ប៉ុន្តែទ្រង់ថែមទាំងប្រទានពរ ហើយធ្វើឱ្យពួកគេត្រឡប់មករកសភាពដើមវិញ(៣:៦-១២ ៤:២)"។

ទោះបីជាពួកយូដាបានទទួលការអនុញ្ញាតិឱ្យត្រឡប់ពីការនិទេស ហើយសាងសង់ព្រះវិហារឡើងវិញក៏ដោយ ក៏នៅមានកត្តាបង្អាក់ទឹកចិត្តមួយចំនួន ដែលនាំឱ្យមានវិបត្តិជាទូទៅខាងសេចក្តីជំនឿដូចជា (១).ទឹកដីរបស់ពួកគេនៅតែជាអាណាខេត្តតូចមួយនៅក្រោមចំណុះចក្រភពពើរស៊ី (២).អនាគតដ៏រុងរឿងដែលពួកហោរាបានប្រកាស(ហោរាដែលក្រោយសម័យនិរទេសមាន លោកហាកាយ លោកសាការីជាដើម) មិនទាន់ឃើញលេចមកជាក់ស្តែងនៅឡើយ ហើយ(៣).ព្រះរបស់ពួកគេមិនទាន់យាងមកឯព្រះវិហាររបស់ទ្រង់ (៣:១)ដោយព្រះចេស្តា និងអំណាចនៅឡើយ(ដែលមានសរសើរនៅក្នុង ទដ ៦៨) ដើម្បីលើកនគរនៃទ្រង់ឡើងខ្ពស់ ឱ្យសាសន៍ដទៃបានឃើញ ។ ដោយសារពួកសាសន៍យូដាបានសង្ស័យពីសេចក្តីស្រឡាញ់ដែលព្រះទ្រង់មាននៅក្នុងសេចក្តីសញ្ញា(១:២) ហើយឈប់ជឿជាក់លើសេចក្តីយុត្តិធម៌របស់ទ្រង់(២:១៧ ៣:១៤-១៥) ពួកគេដែលបានតាំងឡើងវិញ បានបាត់បង់សេចក្តីសង្ឃឹម ។ ដូចនេះ ពួកគេបានប្រែជាថ្វាយបង្គំតាមបែបធម្មតាៗ ដោយមិនទៀងទាត់ និងគ្មានសេចក្តីរីករាយសាទរ ហើយពួកគេមិនបានកាន់តាមក្រឹត្យវិន័យឱ្យបានហ្មត់ចត់ទៀតឡើយ ។

លោកម៉ាឡាគីបានស្តីបន្ទោសចំពោះការសង្ស័យដែលពួកគេមានអំពីសេចក្តីស្រឡាញ់នៃព្រះ(១:២-៥) ហើយស្តីបន្ទោសភាពមិនស្មោះត្រង់របស់ពួកសង្ឃ(១:៦-២:៩) និងបណ្តាជន(២:១០-១៦) ។ លោកម៉ាឡាគីបានឆ្លើយតបដោយការប្រកាស និងការព្រមានចំពោះការចោទប្រកាន់ដែលពួកគេថាព្រះទ្រង់អយុត្តិធម៌(២:១៧) ដោយសារទ្រង់មិនបានយាងមកជំនុំជម្រះដើម្បីលើករាស្ត្រទ្រង់ឡើង ។ ព្រះអម្ចាស់ដែលពួកគេកំពុងស្វែងរកទ្រង់នឹងយាងមក ប៉ុន្តែទ្រង់នឹងយាងមកដូចជា "ភ្លើងរបស់ជាងសម្រង់"(៣:១-៤)។ ព្រះទ្រង់នឹងយាងមកដើម្បីកាត់ទោស ប៉ុន្តែទ្រង់នឹងកាត់ទោសរាស្ត្ររបស់ទ្រង់មុនគេ(៣:៥) ។

ព្រះអម្ចាស់ទ្រង់មិនផ្លាស់ប្តូរសេចក្តីសន្យា និងព្រះទ័យរបស់ទ្រង់ទេ ដូចនេះសាសន៍អ៊ីស្រាអែលមិនត្រូវបំផ្លាញទាំងស្រុង ដោយសារសេចក្តីមិនស្មោះត្រង់របស់ពួកគេឡើយ(៣:៦) ។ ប៉ុន្តែមានតែប្រែចិត្ត ហើយកែខ្លួនជាថ្មីប៉ុណ្ណោះ ទើបពួកគេអាចពិសោធន៍នឹងព្រះពររបស់ទ្រង់ឡើងវិញ(៣:៦-១២)។ អ្នកដែលកោតខ្លាចដល់ព្រះអម្ចាស់ ទ្រង់នឹងប្រណីដល់គេ នៅពេលដែលទ្រង់យាងមកជំនុំជម្រះ (៣:១៦-១៨) ។

ជាសន្និដ្ឋាន លោកម៉ាឡាគីបានបញ្ជាក់ និងព្រមានអ្នកអានរបស់លោកថា "ថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចរបស់ព្រះយេហូវ៉ា(៤:៥) នឹងមកដល់" ហើយ"ថ្ងៃនោះនឹងឆេះឆ្អៅ ដូចជាគុកភ្លើង"(៤:១) ។ នៅថ្ងៃនោះ ពួកបរិសុទ្ធនឹងបានអរសប្បាយ ហើយ "ឯងរាល់គ្នានឹងជាន់ឈ្លីពួកអាក្រក់"(៤:២-៣) ។ ដូចនេះ "ចូរនឹកចាំពីក្រឹត្យវិន័យរបស់លោកម៉ូសេ ជាអ្នកបំរើអញ"(៤:៤) ។ ដើម្បីរៀបចំរាស្ត្ររបស់ទ្រង់ឡើងវិញ សម្រាប់ថ្ងៃនោះ ព្រះអម្ចាស់ទ្រង់នឹងបញ្ជូន "លោកហោរា អេលីយ៉ា" ដើម្បីហៅឱ្យពួកគេវិលត្រឡប់មករកការរស់នៅដោយកោតខ្លាចព្រះ របស់ពួកឰយុកោពួកគេវិញ(៤:៥-៦) ។

### លក្ខណៈអក្សរសាស្ត្រ

ព្រះគម្ពីរម៉ាឡាគីជាព្រះគម្ពីរហោរា(១:១) ដែលសរសេរជាទម្រង់ធម្មតា ប៉ុន្តែនិយាយអំពីសេចក្តីធ្ងន់ធ្ងរ ។ អត្ថបទនៃព្រះគម្ពីរមានលក្ខណៈសរសេរជាសំណួរដែលបានចោទឡើងជាបន្តបន្ទាប់ ដោយព្រះ និងរាស្ត្ររបស់ទ្រង់ ។ ជារើយៗ ព្រះអម្ចាស់ទ្រង់មានបន្ទូលហើយចោទជាសំនួរក្នុងន័យស្តីបន្ទោស ដែលចាប់ផ្តើមដោយពាក្យ "(ប៉ុន្តែ)ឯងរាល់គ្នាតបថា"(១:២,៦-៧ ២:១៤,១៧ ៣:៧-៨,១៣, ធៀបនឹង ១:១៣)។ នៅក្នុងករណីនីមួយៗ ព្រះអម្ចាស់ទ្រង់បានឆ្លើយតប ។

ការប្រើពាក្យដដែលៗ គឺជាផ្នែកសំខាន់មួយនៃការសរសេរព្រះគម្ពីរនេះ ។ ព្រះនាម "ព្រះយេហូវ៉ានៃពួកពលបរិវារ" មានប្រើនៅក្នុងព្រះគម្ពីរនេះ ២០ ដង(មើលការពន្យល់ ១សយ ១:៣)។ ព្រះគម្ពីរនេះបានចាប់ផ្តើមដោយការពិពណ៌នាអំពីការបំផ្លាញស្រុកអេដំម (១:៣-៤) ហើយបានបញ្ចប់ទៅវិញ ដោយការព្រមានពីការបំផ្លាញស្រុកអ៊ីស្រាអែល(៤:៦) ។

ព្រះគម្ពីរម៉ាឡាគីមានប្រើលក្ខណៈនៃការសរសេរដ៏រស់រវើកមួយចំនួនផងដែរ ។ ពួកសង្ឃបានធ្វើសូរហឺះៗ នៅកន្លែងអាសនានៃព្រះអម្ចាស់(១:១៣) ហើយព្រះអម្ចាស់ទ្រង់យកលាមកពីដង្វាយយញ្ញបូជាទៅជះលើមុខគេ(មើល ២:៣ និងការពន្យល់)។ ក្នុងនាមទ្រង់ជាអ្នកជំនុំជម្រះ "ព្រះទ្រង់នឹងបានដូចជាភ្លើងរបស់ជាងសម្រង់ ឬដូចជាក្បុងរបស់ជាងប្រមោក"(៣:២) ប៉ុន្តែ ចំពោះអ្នកសុចរិតវិញ "ព្រះអាទិត្យនៃសេចក្តីសុចរិត និងរះឡើង ដោយមានអំណាចប្រោសឱ្យជា នៅក្នុងចំអេងស្លាប ហើយឯងរាល់គ្នានឹងចេញទៅ លោតកញ្ឆេងដូចជាកូនគោ ដែលលែងចេញពីក្រោល"(៤:២) ។

**គម្រោងសង្ខេប**

**I. ចំណងជើង (១:១)**

**II. សេចក្ដីផ្ដើម: ការបញ្ជាក់អំពីសេចក្ដីស្រឡាញ់ដែលព្រះទ្រង់បានតាំងសញ្ញាជាមួយរាស្ត្រអ៊ីស្រាអែល (១:២–៥)**

**III. ការស្ដីបន្ទោសឱ្យភាពមិនស្មោះត្រង់នៃសាសន៍អ៊ីស្រាអែល (១:៦–២:១៦)**

ក. ភាពមិនស្មោះត្រង់នៃពួកសង្ឃ (១:៦–២:៩)

១. ពួកសង្ឃប្រមាថព្រះនាមព្រះ នៅក្នុងការថ្វាយយញ្ញបូជា (១:៦–១៤)

២. ពួកសង្ឃបង្រៀនក្រឹត្យវិន័យដោយចិត្តមិនស្មោះត្រង់ (២:១–៩)

ខ. ភាពមិនស្មោះត្រង់នៃបណ្ដាជន (២:១០–១៦)

**IV. ការប្រកាសអំពីការយាងមកនៃព្រះអម្ចាស់ (២:១៧–៤:៦)**

ក. ព្រះអម្ចាស់ទ្រង់នឹងយាងមកដើម្បីសម្អាតពួកសង្ឃជាបរិសុទ្ធ ហើយកាត់ទោសបណ្ដាជន (២:១៧–៣:៥)

ខ. ការហៅឱ្យប្រែចិត្តសម្រាប់ការយាងមករបស់ព្រះអម្ចាស់ (៣:៦–១៨)

១. ការលើកទឹកចិត្តដល់អ្នកដែលថ្វាយដោយស្មោះត្រង់ (៣:៦–១២)

២. ការលើកទឹកចិត្តដល់អ្នកដែលបម្រើដោយស្មោះត្រង់ (៣:១៣–១៨)

គ. ការប្រកាសពីថ្ងៃនៃព្រះអម្ចាស់ (ជំពូក ៤)

**១** [១] នេះជាព្រះបន្ទូល[ក]យ៉ាងធ្ងន់[ខ]នៃព្រះយេហូវ៉ា ដល់អ៊ី–
ស្រាអែល ដោយសារម៉ាឡាគី ។

## ព្រះទ្រង់ស្រឡាញ់យ៉ាកុប ស្អប់អេសាវ

[២] ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញបានស្រឡាញ់[គ]ឯង
រាល់គ្នា ប៉ុន្តែឯងរាល់គ្នាថា[ឃ]ទ្រង់មានស្រឡាញ់យើងរាល់
គ្នាឯណា ព្រះយេហូវ៉ាទ្រង់តបថា ឯអេសាវ តើមិនមែនជា
បងរបស់យ៉ាកុបទេឬអី ទោះបីយ៉ាងនោះ គង់តែអញបាន
ស្រឡាញ់យ៉ាកុប[ង] [៣]តែចំណែកអេសាវនោះ អញបានស្អប់
វិញ[ច] ហើយបានធ្វើឱ្យស្រុកភ្នំរបស់គេបានស្ងាត់ច្រៀប[ឆ] ក៏
ឱ្យមរដករបស់គេដល់ពួកស្វាន នៅទីរហោស្ថាន[ជ] [៤]ហើយ
ទោះបើពួកអេដំម[ឈ] គេពោលថា យើងត្រូវបំផ្លាញហើយ
តែយើងនឹងវិលទៅសង់[ញ] កន្លែងខូចបង់ឡើងវិញ គង់តែ
ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះថា គេ
នឹងសង់ឡើងវិញ តែអញនឹងរំលំចុះទៀត[ដ] នោះមនុស្សនឹង
ហៅគេថា ជាព្រំស្រុកនៃសេចក្តីអាក្រក់ ហើយថាជា
សាសន៍ដែលព្រះយេហូវ៉ាទ្រង់មានសេចក្តីគ្នាន់ក្នាញ់ចំពោះ
គេជាដរាប[ឋ] [៥]ភ្នែកឯងរាល់គ្នានឹងឃើញដែរ ហើយឯង
នឹងពោលថា សូមឱ្យព្រះយេហូវ៉ាបានដំកើងឡើង[ឌ] ក្រៅ
ពីព្រំស្រុកអ៊ីស្រាអែលទៅទៀត[ឍ] ។

## ដង្វាយមិនស្អាត

[៦]ឯកូននោះ រមែងគោរពដល់ឪពុក[ណ] ហើយបាវបំរើក៏
កោតខ្លាចដល់ចៅហ្វាយ[ត] ដូច្នេះ បើអញជាឪពុក នោះ
តើសេចក្តីគោរព[ថ]ដល់អញនៅឯណា ហើយបើអញជា
ចៅហ្វាយ តើសេចក្តីកោតខ្លាចដល់អញនៅឯណា នេះគឺ
ជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ[ទ] ដល់ឯង
រាល់គ្នា ជាពួកសង្ឃដែលមើលងាយឈ្មោះអញ តែឯងថា[ធ]
យើងរាល់គ្នាមានមើលងាយដល់ព្រះនាមទ្រង់ឯណា [៧]គឺ
ឯងរាល់គ្នាថ្វាយនំបុ័ង[ន] ដែលមិនបរិសុទ្ធនៅលើអាសនា
របស់អញ ឯងរាល់គ្នាក៏ពោលថា[ប] តើយើងបានបង្អាប់ដល់
ទ្រង់ឯណា គឺដោយឯងរាល់គ្នាថា តុ[ផ]នៃព្រះយេហូវ៉ាគួរ
មើលងាយ [៨]ហើយកាលណាឯងរាល់គ្នាថ្វាយសត្វ ដែល
ខ្វាក់ជាយញ្ញបូជា នោះក៏មិនអាក្រក់ដែរឬ ហើយកាលណា
ឯងរាល់គ្នាថ្វាយសត្វខ្វិច[ព] និងសត្វដែលឈឺ នោះក៏មិន
អាក្រក់ដែរឬ ចូរជូនដល់ចៅហ្វាយឯងលមើល បើលោក
សុខចិត្ត[ភ]នឹងឯង ឬយ៉ាងណា ឬបើលោកនឹងទទួលឯងឬទេ[ម]
[៩]នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ
ឥឡូវនេះ ខ្ញុំសូមអ្នករាល់គ្នាឱ្យទូលអង្វរដល់ព្រះដើម្បីឱ្យ
ទ្រង់បានផ្តល់ព្រះគុណដល់យើង ការទាំងអស់នេះបានកើត

**១:១** ក កច ៧:៣៨ រម ៣:១–២ ១ពត ៤:១១ ខ ណហ ១:១ **១:២** គ ចទ ៤:៣៧ ឃ ខ.៦,៧ មឡ ២:១៤,១៧ ៣:៧,១៣ ង យរ ៤៦:២៧ រម ៩:១៣ **១:៣** ច លក ១៤:២៦ ឆ អស ៣៤:១០ ជ អស ១៣:២២ **១:៤** ឈ អស ១១:១៤ ៣៤:១១ ញ អស ៩:១០ ដ អស ៣៤:៥ ឋ បទ ៤:២២ អគ ២៥:១២–១៤ ២៦:១៤ **១:៥** ឌ ទដ ៣៥:២៧ ៤៨:១ មីក ៥:៤ ឍ អស ៤៥:២២ ៥២:១០ អម ១:១១–១២ **១:៦** ណ លវ ២០:៩ មថ ១៥:៤ ២៣:៩ ត លក ៦:៤៦ ថ ចទ ៣១:១២ អស ១:២ ទ យប ៥:១៧ ធ ខ.២ **១:៧** ន ខ.១២ លវ ២១:៦ ប ខ.២ ផ អគ ២៣:៤១ **១:៨** ព លវ ១:៣ ចទ ១៥:២១ ភ លប ៣២:២០ ម អស ៤៣:២៣

**១:១** *ព្រះបន្ទូលយ៉ាងធ្ងន់* មើល សក ៩:១ និងការពន្យល់, ១២:១ និងមើល ហព ១:១ និងការពន្យល់ ។ *ព្រះបន្ទូល . . . នៃព្រះយេហូវ៉ា* មើល ហស ១:១ និងការពន្យល់ ។

**១:២** *ស្រឡាញ់ឯងរាល់គ្នា* ព្រះអម្ចាស់ទ្រង់ប្រើពាក្យនេះដើម្បីធ្វើការធានាម្តងទៀតដល់រាស្ត្ររបស់ទ្រង់ដែលកំពុងអស់សង្ឃឹម ។

**១:៣** *អេសាវនោះ អញបានស្អប់វិញ* ប្រសិនបើសាសន៍អ៊ីស្រាអែលសង្ស័យចំពោះសេចក្តីស្រឡាញ់ដែលមាននៅក្នុងសេចក្តីសញ្ញារបស់ទ្រង់ នោះពួកគេគួរតែគិតដល់ភាពខុសគ្នារវាងការដែលទ្រង់ដោះស្រាយជាមួយពួកគេ និងការដែលទ្រង់ដោះស្រាយជាមួយលោកអេសាវ (អេដំម) ដែលជាបងប្រុសលោកយ៉ាកុប (អ៊ីស្រាអែល) ។ លោកប៉ុលបានពន្យល់ពីសេចក្តីស្រឡាញ់ ដែលព្រះទ្រង់មានចំពោះលោកយ៉ាកុប និងការដែលទ្រង់ស្អប់លោកអេសាវដោយអាងទៅលើការដែលទ្រង់ជ្រើសរើស (មើល រម ៩:១០–១៣ និងការ ពន្យល់ ៩:១៣) ។ ព្រះទ្រង់បានជ្រើសរើសលោកយ៉ាកុប តែមិនបានជ្រើស រើសលោកអេសាវទេ ។ ចំពោះអត្ថន័យពាក្យ "ស្រឡាញ់" និង"ស្អប់"ក្នុងខនេះ មើល លប ២៩:៣១–៣៣ លក ១៤:២៦ និងការពន្យល់ ។ *ស្ងាត់ច្រៀប* ពាក្យពេចន៍ទាំងឡាយដែលលោកម៉ាឡាគីប្រើ នៅក្នុងការនិយាយអំពីស្រុកអេដំម បានរំឭកឡើងវិញដល់ពួកហោរានៅមុនលោក (អម ១:១១–១២ អស ៣៤:៥–១៥ យរ ៤៩:៧–២២ អគ ២៥:១២–១៤ ៣៥:១–១៥ និងមើល ព្រះគម្ពីរអូបាឌា) ។ នៅចន្លោះឆ្នាំប្រហែល ៥៥០ និង៤០០ មុនគ.ស. សាសន៍ណាបាធៀន ដែលជាពួកអារ៉ាប់ បានរុញច្រានបន្តិចម្តងៗឱ្យសាសន៍ អេដំមចាកចេញពីទឹកដីរបស់ខ្លួន ។

**១:៤** *ពួកអេដំម គេពោលថា* ត្រង់ចំណុចនេះ ពួកអេដំមបានពោលអួតពីការពឹងពាក់ខ្លួនដែលមិនបានធានាសន្តិសុខដល់ពួកគេ ហើយនឹងមិនធ្វើឱ្យពួកគេមានសេចក្តីសុខនៅពេលអនាគតបានទេ (ធៀបនឹង យរ ៤៩:១៦) ។

**១:៥** *សូមឱ្យ. . .អ៊ីស្រាអែល* នៅពេលដែលអ៊ីស្រាអែលមើលឃើញពីជោគវាសនានៃស្រុកអេដំម ពួកគេប្រាកដជាទទួលស្គាល់ថា ព្រះយេហូវ៉ាទ្រង់គឺជាក្សត្រដ៏អស្ចារ្យ ដែលគ្រប់គ្រងអស់ទាំងសាសន៍ ។

**១:៦–២:៩** ក្នុងវគ្គនេះ ព្រះអម្ចាស់ទ្រង់ស្តីបន្ទោសពួកសង្ឃ ដោយសារការថ្វាយបង្គំមិនត្រឹមត្រូវ ។

**១:៧** *បង្អាប់ដល់ទ្រង់* ពួកគេបង្អាប់ដល់ទ្រង់ ដោយថ្វាយដង្វាយមិនបរិសុទ្ធ ។ *តុនៃព្រះយេហូវ៉ា* គឺអាសនា (ខ.១២ អគ ៤៤:១៦ និងការពន្យល់) ។ ដោយសារពួកសង្ឃត្រូវបរិភោគចំណែកនៃយញ្ញបូជា ដូចនេះអាសនាក៏ជាតុដែលពួកគេទទួលអាហារផងដែរ ។ *គួរមើលងាយ* ពួកសង្ឃបានពោលថា អាសនា និងយញ្ញបូជាដែលថ្វាយនៅលើអាសនា គឺជាទីគួរមើលងាយ (ខ.១២) ដូចនេះព្រះអម្ចាស់ទ្រង់នឹងធ្វើឱ្យពួកបណ្តាជនមើលងាយទៅដល់ពួកគេផងដែរ (២:០ និការពន្យល់) ។

**១:៨** *ខ្វាក់ . . . ខ្វិច* សត្វដែលមិនគ្រប់លក្ខណៈឬមានលក្ខណៈខ្វះខាតខ្លាំងមិនអាចយកទៅធ្វើយញ្ញបូជាបានទេ (លវ ១:៣ និងការពន្យល់ ចទ ១៥:២១) ព្រោះព្រះអម្ចាស់ទ្រង់សព្វព្រះទ័យនឹងដង្វាយដែលល្អបំផុត ។ *ចៅហ្វាយ* គេជឿថាពាក្យនេះសំដៅទៅលើចៅហ្វាយដែលជាសាសន៍ពើរស៊ី ។

ដោយសារ[យ]អ្នករាល់គ្នាហើយ ដូច្នេះ តើទ្រង់នឹងទទួល[រ]មុខ
អ្នករាល់គ្នាណា១ឬ នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃ
ពួលពលបរិវារ ១០ឱបើសិនជា មានអ្នកណាមួយ ក្នុងពួក
ឯងរាល់គ្នានឹងបិទទ្វារទៅអេះ[ល] ដើម្បីមិនឱ្យបង្កាត់ភ្លើង
នៅលើអាសនារបស់អញ ជាអសារឥតការ ព្រះយេហូវ៉ា
នៃពួកពលបរិវារ ទ្រង់មានបន្ទូលថា អញមិនចូលចិត្ត[វ]នឹង
ឯងរាល់គ្នាទេ ក៏មិនព្រមទទួល[ស]ដង្វាយណា[ហ]ពីដៃឯងរាល់
គ្នាដែរ ១១ដ្បិតចាប់តាំងពីទិសខាងកើតរហូតដល់ទិសខាង
លិច[ឡ] នោះឈ្មោះអញនឹងបានជាធំ[អ] នៅកណ្ដាលពួក
សាសន៍ដទៃ[ក] ហើយនៅគ្រប់ទីកន្លែង គេនឹងដុតកំញាន[ខ]
ថ្វាយដល់ឈ្មោះអញ ព្រមទាំងដង្វាយបរិសុទ្ធផង[គ] ដ្បិត
ឈ្មោះអញនឹងបានជាធំ នៅក្នុងពួកសាសន៍ដទៃវិញ នេះជា
ព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួលពលបរិវារ ១២ប៉ុន្តែ
ចំណែកឯងរាល់គ្នា តែងតែបង្អាប់ឈ្មោះអញទេ ដោយ
ពោលថា តុរបស់ព្រះយេហូវ៉ាត្រូវស្មោកគ្រោក[ឃ]ហើយឯ
ផល គឺជាអាហារនៅលើតុនោះ[ង] ក៏គួរមើលងាយដែរ
១៣ឯងរាល់គ្នាក៏ថា យីះ ការនេះរអាចិត្តណាស់[ច] ហើយបាន
ធ្វើសូរហឹះៗដាក់ការនោះ[ឆ] នេះជាព្រះបន្ទូលរបស់ព្រះ
យេហូវ៉ានៃពួកពលបរិវារ ឯងរាល់គ្នានាំយករបស់ដែល
ប្លន់យកពីគេមក ព្រមទាំងសត្វខ្វើច និងសត្វឈឺផង គឺ
យ៉ាងនោះដែលឯងរាល់គ្នានាំដង្វាយមកថ្វាយ[ជ] ដូច្នេះ ព្រះ
យេហូវ៉ាទ្រង់សួរថា តើគួរឱ្យអញទទួលពីដៃឯងរាល់គ្នា
ឬទេ[ឈ] ១៤ត្រូវបណ្ដាសាហើយ អ្នកបញ្ឆោតដែលមានសត្វ
ឈ្មោលនៅក្នុងហ្វូង ហើយក៏បន់ព្រះ រួចយកសត្វ[ញ]មាន

**១:៩** យ លវ ២៣:៣៣–៤៤ ទដ ៥១:១៧ មីក ៦:៦–៨ រម ១២:១ ហព ១៣:១៦ រ យរ ៦:២០
**១:១០** ល ២របា ២៨:២៤ វ ហស ៥:៦ ស លវ ២២:២០ ហ ខ.១៣ អស ១:១១–១៤ យរ ១៤:១២ មឡ ២:១២
**១:១១** ឡ ទដ ១១៣:៣ មថ ៨:១១ អ អស ២៤:១៥ ៥៦:៦ ក អស ៦:៣ ១២:៤ ខ អស ៦០:៦–៧ វវ ៥:៨ ៨:៣ គ អស ១៩:២១ ហព ១៣:១៥
**១:១២** ឃ អគ ៤១:២២ ង ខ.៧
**១:១៣** ច អស ៤៣:២២–២៤ ឆ ជន ១៤:១១ ជ ខ.១០ ឈ ចទ ១៥:២១
**១:១៤** ញ នក ១២:៥ លវ ២២:១៨–២១ ដ ទដ ៩៥:៣ អប ១:២១ ១ធថ ៦:១៥

ស្លាកស្នាមមកថ្វាយជាយញ្ញបូជាដល់ព្រះអម្ចាស់វិញ ដ្បិត
អញជាស្តេចដ៏ធំ[ដ] ហើយឈ្មោះអញជាទីស្ញែងខ្លាច[ឋ] នៅ
កណ្ដាលពួកសាសន៍ដទៃ[ឌ] នេះជាព្រះបន្ទូលរបស់ព្រះយេ
ហូវ៉ានៃពួកពលបរិវារ[ឍ]។

## សេចក្ដីបង្គាប់ដល់ពួកសង្ឃ

**២** ១ហើយឥឡូវនេះ ឱពួកសង្ឃអើយ សេចក្ដីបង្គាប់នេះ គឺ
ដល់ឯងរាល់គ្នា[ក] ២ដូច្នេះ បើឯងរាល់គ្នាមិនព្រមស្តាប់តាម[ខ]
ហើយមិនយកចិត្ត ទុកដាក់នឹងថ្វាយសិរីល្អ[គ]ដល់ឈ្មោះអញ
ទេ នោះព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់មានបន្ទូល
ថា អញនឹងចាត់សេចក្ដីបណ្ដាសា[ឃ] ឱ្យមកលើឯងរាល់គ្នា
អញនឹងដាក់បណ្ដាសាដល់ពររបស់ឯង[ង] អើ អញបានដាក់
បណ្ដាសាហើយ ពីព្រោះឯងរាល់គ្នាមិនយកចិត្តទុកដាក់
សោះ ៣មើល អញនឹងបំផ្លាញពូជពង្រោះរបស់ឯងទៅ អញ
នឹងជះលាមក[ច]ទៅលើមុខឯងរាល់គ្នា គឺជាលាមកពីដង្វាយ
យញ្ញបូជារបស់ឯង ហើយគេនឹងដឹកឯងចេញទៅជាមួយ
ផង[ឆ] ៤នោះឯងរាល់គ្នានឹងដឹងថា អញបានឱ្យសេចក្ដី
បង្គាប់នេះ មកដល់ឯងហើយ ដើម្បីឱ្យសេចក្ដីសញ្ញារបស់
អញបាននៅជាមួយនឹងពួកលេវី[ជ] នេះជាព្រះបន្ទូលរបស់
ព្រះយេហូវ៉ានៃពួកពលបរិវារ ៥ឯសេចក្ដីសញ្ញា[ឈ]ដែល
អញបានតាំងនឹងគេ នោះគឺជាជីវិត ហើយជាសេចក្ដីសុខ[ញ]

ឋ ចទ ២៨:៥៨ ឌ ទដ ៧២:៨–១១ ឍ យរ ៤៦:១៨ **២:១** ក ខ.៧ **២:២** ខ យរ ១៣:១៧ គ មថ ១៥:៧–៩ យហ ៥:២៣ ១ធថ ៦:១៦ វវ ៥:១២–១៣ ឃ ចទ ១១:២៦ ២៨:២០ ង ជន ៦:២៣–២៧ **២:៣** ច នក ២៩:១៤ លវ ៤:១១ យប ៩:៣១ ឆ ១ពវ ១៤:១០ **២:៤** ជ ជន ៣:១២ **២:៥** ឈ ចទ ៣៣:៩ ទដ ២៥:១០ ១០៣:១៨ មថ ២៦:២៨ លក ២២:២០ ហព ៧:២២

**១:១០** *បិតទ្វារ* មានន័យថា ការមិនថ្វាយយញ្ញបូជាសោះ គឺល្អជាងការថ្វាយយញ្ញបូជាដែលគួរឱ្យមើលងាយ (អស ១:១១–១៥ និងការពន្យល់) ។

**១:១១** *ធំ នៅកណ្ដាលពួកសាសន៍ដទៃ* ធៀបនឹង ខ.១៤ ។ ការដែលព្រះអម្ចាស់ទ្រង់កាត់ទោសដល់ពួកស្រុកអេដំម (ខ.៥) និងជាតិសាសន៍ដទៃទៀត បានបង្ហាញពីភាពធំឧត្ដមដែលទ្រង់មានលើសព្រះរបស់ពួកគេ ហើយការជំនុំជម្រះនេះនឹងធ្វើឱ្យពួកគេទទួលស្គាល់ទ្រង់នៅទីបំផុត (សផ ២:១១ ៣:៩ និងការពន្យល់)។ *កំញាន . . . ដង្វាយបរិសុទ្ធ* សូមធៀបនឹងការថ្វាយដង្វាយដែលត្រឹមត្រូវដោយសាសន៍ដទៃ នៅក្នុង ៥៦:៦–៧ ៦០:៧ ។ អ្នកការស្រាយខ្លះយល់ថា ក្នុងខនេះពាក្យ "កំញាន" គឺមានន័យថា "ការអធិស្ឋាន" (ធៀបនឹង វវ ៥:៨) ហើយពាក្យ "ដង្វាយ" មានន័យថា "សរសើរតម្កើង" (ធៀបនឹង ហព ១៣:១៥ និងការពន្យល់)។

**១:១២** *ស្មោកគ្រោក . . . គួរមើលងាយ* មើល ខ.៧ និងការពន្យល់ ។

**១:១៣** *សូរហឹះៗដាក់ការនោះ* ធៀបការនេះនឹងអាកប្បកិរិយារបស់កូនប្រុសលោកអេលី ក្នុង ១សយ ២:១៥–១៧ ។ *សត្វខ្វើច និងសត្វឈឺ* មើល ខ.៨ និងការពន្យល់ ។

**១:១៤** *បន់ព្រះ . . . សត្វមានស្លាកស្នាម* សត្វដែលត្រូវយកមកថ្វាយដើម្បីលាបំណន់ ត្រូវតែជាសត្វឈ្មោលដែលគ្រប់លក្ខណៈ ឬគ្មានស្លាកស្នាម (លវ ២២:១៨–២៣)។ *ស្តេចដ៏ធំ* មើល សក ១៤:៩ និងការពន្យល់ ។ *ឈ្មោះអញ . . . ជាទីស្ញែងខ្លាច* គឺជាទីស្ញែងខ្លាចជាងពួកចៅហ្វាយនៅក្នុង ខ.៨ (មើល ខ.១១ និងការពន្យល់) ។

**២:២** *ដាក់បណ្ដាសាដល់ពរឯង* ការឱ្យពរនៃព្រះដល់បណ្ដាជន គឺជាការងារនៃពួកសង្ឃ (ជន ៦:២៣–២៧) ប៉ុន្តែពរនោះនឹងត្រូវបណ្ដាសា ជាហេតុធ្វើឱ្យមុខនាទីតែមួយនៃពួកសង្ឃត្រូវអាក្រក់ជាងការដែលឥតប្រយោជន៍ទៅទៀត ។

**២:៣** *ជះលាមកទៅលើមុខឯងរាល់គ្នា* ឬមានន័យថា ដើម្បីធ្វើឱ្យឯងអាម៉ាសមុខ (ណាហ ៣:៦) ។ *លាមក* គឺលាមកដែលមាននៅក្នុងពោះវៀនសត្វដែលត្រូវធ្វើយញ្ញបូជា (មើល នក ២៩:១៤ លវ ៨:១៧ ១៦:២៧) ។

**២:៤** *ពួកលេវី* ពួកសង្ឃត្រូវបានជ្រើសរើសពីពូជអំបូរលេវី (ចទ ២១:៥ និងការពន្យល់) ។

**២:៥** *សេចក្ដីសញ្ញា . . . ជីវិត ហើយជាសេចក្ដីសុខ* ឃ្លានេះគឺនិយាយដល់សេចក្ដីសញ្ញាដែលព្រះទ្រង់មានជាមួយនឹងលោកភីនេហាស ដែលជាចៅរបស់លោកអើរ៉ុន នៅក្នុង ជន ២៥:១០–១៣ (ការពន្យល់ ជន ២៥:១១) ។

អញបានឱ្យដល់គេ ដើម្បីឱ្យគេបានកោតខ្លាច[ង] គេក៏បាន
កោតខ្លាចដល់អញ ព្រមទាំងមានសេចក្តីភ័យញ័រ នៅ
ចំពោះឈ្មោះអញ ៦ គេមានច្បាប់[ច]ដ៏ពិតនៅក្នុងមាត់ ហើយ
មិនឃើញមាន សេចក្តីទុច្ចរិតនៅបបូរមាត់គេឡើយ គេ
បានដើរ[ឆ]ជាមួយនឹងអញដោយ សេចក្តីសុខ[ជ]នឹងសេចក្តី
ទៀងត្រង់[ណ] ក៏បានបំបែរមនុស្សជាច្រើនចេញពីសេចក្តី
ទុច្ចរិត[ត] ៧ ដ្បិតគួរឱ្យបបូរមាត់របស់សង្ឃ[ថ]បានរក្សាទុកនូវ
យោបល់ ហើយគួរឱ្យមនុស្សស្វែងរកក្រិត្យវិន័យ[ទ]ពីមាត់គេ
ដ្បិតគេជាទូត[ធ]របស់ព្រះយេហូវ៉ានៃពួកពលបរិវារ ៨ តែ
ឯងរាល់គ្នាបានទាសចេញពីផ្លូវ[ន] ក៏បាននាំឱ្យមនុស្សជា
ច្រើនជំពប់ដួល[ប] ក្នុងក្រិត្យវិន័យដែរ[ផ] ព្រះយេហូវ៉ានៃពួក
ពលបរិវារទ្រង់មានបន្ទូលថា ឯងរាល់គ្នាបានបង្ខូចសេចក្តី
សញ្ញារបស់លេវីហើយ[ព] ៩ ហេតុនោះ អញក៏បានធ្វើឱ្យឯង
រាល់គ្នាជាទីមើលងាយ[ភ,ម] នៅចំពោះមុខជនទាំងឡាយដែរ
ពីព្រោះឯងរាល់គ្នាមិនបានកាន់តាមអស់ទាំងផ្លូវរបស់អញ
គឺបានយោគយល់មុខ[យ]គេក្នុងក្រិត្យវិន័យវិញ[រ] ។

### ពួកយូដាមិនស្មោះត្រង់

១០ យើងទាំងអស់គ្នា តើមិនមានឪពុកតែ១ទេឬ[ល] តើមិន
មែន ជាព្រះតែ១ ដែលបង្កើតយើងរាល់គ្នាមកទេឬអី[វ]
ហេតុអ្វីបានជាយើងប្រព្រឹត្តដោយក្បត់[ស] ចំពោះបងប្អូន
យើងរៀងខ្លួន ទាំងធ្វើបង្អាប់ដល់សេចក្តីសញ្ញា[ហ]របស់ពួក
ឰយុកោយើងផងដូច្នេះ ១១ យូដាបានក្បត់ហើយ ក៏មានគេ
ប្រព្រឹត្តអំពើគួរស្អប់ខ្ពើម[ឡ] នៅក្នុងពួកអ៊ីស្រាអែល ហើយ
នៅក្នុងយេរូសាឡិមដែរ ដ្បិតយូដាបានបង្អាប់សេចក្តីដែល
បរិសុទ្ធដល់ព្រះយេហូវ៉ា ជាសេចក្តីដែលគួរឱ្យគេបាន
ស្រឡាញ់វិញ[អ] គឺបានយក[ក]កូនស្រីរបស់ព្រះដទៃធ្វើជា
ប្រពន្ធ[ខ] ១២ ព្រះយេហូវ៉ា ទ្រង់នឹងកាត់មនុស្សដែលប្រព្រឹត្ត
អំពើយ៉ាងនោះ[គ] ចេញពីត្រសាលយ៉ាកុប[ឃ]ទៅទាំងគ្រូ ទាំង
សិស្ស ហើយទាំងអ្នកដែលយកដង្វាយ[ង]មក ថ្វាយដល់ព្រះ
យេហូវ៉ានៃពួកពលបរិវារផង ១៣ ហើយមានការនេះដែល
ឯងរាល់គ្នាធ្វើទៀត គឺឯងរាល់គ្នាគ្របបាំងអាសនានៃព្រះ

**២:៥** ញ ជន ២៥:១២ ដ ចទ ១៤:២៣ ២៨:៥៨ ទដ ១១៩:១៦១ ហព ១២:២៨ **២:៦** ឋ ចទ ៣៣:១០ ឌ លប ៥:២២ ឍ លក ២:១៤ យហ ១៤:២៧ កទ ៥:២២ ណ ទដ ២៥:២១ ត រម ១១:១៤ យក ៥:១៩-២០ **២:៧** ថ យរ ១៨:១៨ ទ លវ ១០:១១ ២រប ១៧:៧ ធ ជន ២៧:២១ ២រប ៣៦:១៥ មថ ១១:១០ មក ១:២ **២:៨** ន នក ៣២:៨ យរ ២:៨ ប យរ ១៨:១៥ ផ យរ ៣៣:២១ អគ ២២:២៦ ព ហស ៤:៦

**២:៩** ភ ១សយ ២:៣០ ទដ ២២:៦ យរ ៥១:៣៧ ម ទដ ៣៥:៤ យរ ៣:២៥ កច ៨:៣២-៣៣ យ នក ១៨:១៦ យល ១៩:១៥ កច ១០:៣៤ រម ២:១១ រ ១សយ ២:១៧ **២:១០** ល នក ៤:២២ មថ ៥:១៦ ៦:៤,១៨ លក ១១:២ ១កថ ៨:៦ វ យប ៤:១៧ អស ៤៣:១ ស សផ ៣:៣-៤ ហ នក ១៩:៥ ២ពវ ១៧:១៥ យរ ៣១:៣២ **២:១១** ឡ អស ១:១៣ ៤៨:៨ អ ចទ ៤:៣៧ ក នហ ១៣:២៣ ខ នក ៤២:១៦ យរ ៣:៧-៩ **២:១២** គ ១សយ ២:៣០-៣៣ អគ ២៤:២១ ឃ ជន ២៤:៥ ២សយ ២០:១ ង មឡ ១:១០

លោកភីនេហាសបានការពារព្រះនាមនៃព្រះអម្ចាស់ ដោយប្រហារជីវិតជនល្មើសពីរនាក់ ដែលថ្វាយបង្គំរូបព្រះ និងប្រព្រឹត្តអំពើអសីលធម៌ដែលទាក់ទងនឹងព្រះបាល-ពេអរ (ជន ២៥:១-៧) ។ *គេក៏បានកោតខ្លាចដល់អញ* លោកភីនេហាសបានបង្ហាញការកោតខ្លាចនេះ ដោយការប្រព្រឹត្តដោយឈឺឆ្អាលដល់ព្រះយេហូវ៉ា (ជន ២៥:១៣) ។

**២:៦-៧** *ច្បាប់* ពួកសង្ឃត្រូវទទួលខុសត្រូវនៅក្នុងការបង្រៀនក្រឹត្យវិន័យលោកម៉ូសេ (លវ ១០:១១ និងការពន្យល់ សផ ៣:៤ ហក ២:១១) ។

**២:៦** *សេចក្តីសុខ និងសេចក្តីទៀងត្រង់* ពាក្យទាំងពីរមានប្រើជាមួយគ្នាផងដែរ នៅក្នុង ទដ ៣៧:៣៧ ប៉ុន្តែនៅក្នុងខនេះ គេជឿថា ឃ្លា "ដើរជាមួយនឹងអញដោយសេចក្តីសុខ និងសេចក្តីទៀងត្រង់" គឺសំដៅទៅលើសេចក្តីទៀងត្រង់នៅក្នុងសេចក្តីសញ្ញា ។

**២:៧** *ជាទូត* ពួកសង្ឃជាគ្រូបង្រៀនក្រឹត្យវិន័យ ហើយបណ្តាជនទូលសូមដល់ព្រះតាមរយៈពួកគេ ដូចនេះពួកគេក៏ជាទូតដែរ (មើលការពន្យល់ ៣:១ ហក ១:១៣) ។

**២:៨** *បង្ខូចសេចក្តីសញ្ញា* គឺដោយការបង្រៀនដោយមិនស្មោះត្រង់ ហើយក៏ដោយសាការរៀបការជាមួយនឹងសាសន៍ដទៃផងដែរ (អរ ៩:១ និងការពន្យល់ ១០:១៨-២២ នហ ១៣:២៧-២៩) ។ *របស់លេវី* មើល ខ.៤ និងការពន្យល់ ខ.៥ ។

**២:៩** *ជាទីមើលងាយ* មើល ១:៧,១២ និងការពន្យល់ ១:៧ ។ *បានយោគយល់មុខ* ការនេះត្រូវហាមឃាត់នៅក្នុង លវ ១៩:១៥ ។ ពួកសង្ឃត្រូវមានលក្ខណៈមិនយោគយល់មុខដូចព្រះអម្ចាស់ដែរ (ចទ ១០:១៧) ។

**២:១០-១៦** លោកម៉ាឡាគីបានស្តីបន្ទោសដល់បណ្តាជន នៅក្នុងវគ្គនៃបទគម្ពីរនេះ ដោយសំដៅទៅលើការ "ប្រព្រឹត្តដោយក្បត់"។ មានឧទាហរណ៍ពីរដែលបញ្ជាក់ជាពិសេសពីអំពើបាបរបស់ពួកគេគឺ ការរៀបការជាមួយស្ត្រីសាសន៍ដទៃ និងការលែងលះ ។

**២:១០** *ឪពុកតែ១* មើល អស ៦៣:១៦ ។ *បង្កើតយើង* ព្រះទ្រង់បង្កើតពួកគេជារាស្ត្រជ្រើសតាំងពិសេស (អស ៤៣:១ និងការពន្យល់) ។ *សេចក្តីសញ្ញារបស់ពួកឰយុកោយើង* គឺសេចក្តីសញ្ញាដែលព្រះទ្រង់បានតាំងជាមួយពួកឰយុកោរបស់ពួកគេនៅភ្នំស៊ីណាយ ។ *ប្រព្រឹត្តដោយក្បត់* ពួកបណ្តាជនមិនអាចទុកចិត្តបានសូម្បីតែជនរួមជាតិអ៊ីស្រាអែល ឬអ្នកដឹកនាំជាតិរបស់ពួកគេដែលជាពួកសង្ឃ ។

**២:១១** *កូនស្រីរបស់ព្រះដទៃ* ឬស្ត្រីសាសន៍ដទៃ ។ ក្រឹត្យវិន័យនៃសេចក្តីសញ្ញា បានដាក់បម្រាមយ៉ាងតឹងរឹងចំពោះការរៀបការជាមួយសាសន៍ដទៃមិនមែនដោយសារបញ្ហាជាតិសាសន៍ ឬវប្បធម៌នោះទេ ប៉ុន្តែគឺដោយសារតែពួកស្ត្រីទាំងនោះនឹងនាំឱ្យពួកគេបោះបង់ចោលជំនឿរបស់ខ្លួន (មើល នក ៣៤:១៥-១៦ ចទ ៧:២-៥ និងការពន្យល់ យស ២៣:១២-១៣ និងការពន្យល់ ២៣:១២)។ លោកអែសរ៉ា និងនេហេមាសុទ្ធតែបានតយុទ្ធនឹងបញ្ហានេះ (ការពន្យល់ ខ.៨) ។

**២:១២** មើល លប ៣០:៣៣ ចទ ៥:២០ ១សយ ១២:៣ ២សយ ១:១៦ អស ៣:៩ យរ ១៤:៧ ។ នៅក្នុងខនេះអ្នកដែលត្រូវកាត់ចេញ គឺអ្នកដែលនិយាយការពារអ្នកដែលប្រព្រឹត្តខុស ។ *ត្រសាលយ៉ាកុប* ជាន័យធៀបនៃពាក្យសហគមន៍អ៊ីស្រាអែល (យរ ៣០:១៨) ។

**២:១៣** *ដោយយំសោក ហើយស្រែកថ្ងូរ* ព្រះអម្ចាស់ទ្រង់មិនឆ្លើយតបនឹងយញ្ញបូជារបស់ពួកគេ ដោយប្រទានពរទេ ដូចនេះពួកគេបានអធិស្ឋានដោយ

យេហូវ៉ា ដោយទឹកភ្នែក[ច] ដោយយំសោក ហើយស្រែកថ្ងូរ[ឆ]
ដល់ម្ល៉េះបានជាទ្រង់មិនទតមើល[ជ]ដង្វាយទៀតឡើយ ក៏មិន
ទទួលពីដៃឯងរាល់គ្នា[ឈ] ដោយព្រះហឫទ័យស្មោះដែរ
ទោះបើយ៉ាងនោះគង់តែឯងរាល់គ្នាសួរថា[ញ] ចុះព្រោះ
ហេតុអ្វី ១៤គឺពីព្រោះព្រះយេហូវ៉ា ទ្រង់ជាសាក្សី[ដ]ពីឯង និង
ប្រពន្ធដែលឯងបានគ្នាពីកាលក្រមុំកំឡោះនោះ[ឋ] ហើយ
ទោះបើនាងជាគូរបស់ឯអ និងជាប្រពន្ធ ដែលឯងបានចុះ
សញ្ញានឹងគ្នាក៏ដោយគង់តែឯងបានប្រព្រឹត្ត ដោយក្បត់
ចំពោះនាងដែរ[ឌ] ១៥តើទ្រង់មិនបានបង្កើត ឱ្យមានតែ១ទេ
ឬ[ឍ] ទោះបើទ្រង់មានព្រះវិញ្ញាណសល់នៅក៏ដោយ ហើយ
ហេតុអ្វីបានជាបង្កើតតែមួយ ដូច្នេះ គឺពីព្រោះទ្រង់ស្វែង
រកចង់បានពូជបរិសុទ្ធ[ណ] ដូច្នេះ ចូរប្រយ័ត្ន[ត] ចំពោះ
វិញ្ញាណរបស់ឯងចុះ កុំឱ្យប្រព្រឹត្តដោយមានចិត្តក្បត់[ថ] ចំ–
ពោះ ប្រពន្ធដែលបានគ្នាពីកាលនៅក្រមុំកំឡោះនោះឡើយ
១៦ដ្បិតអញស្អប់ការលះលែងគ្នាណាស់[ទ] នេះហើយជាព្រះ
បន្ទូលរបស់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល
អញក៏ស្អប់ទាំងអ្នកដែលគ្រលុំសំលៀកបំពាក់ខ្លួន ដោយ
ការច្រឡោត[ធ]ដែរ នេះហើយជាព្រះបន្ទូលរបស់ព្រះ
យេហូវ៉ា នៃពួកពលបរិវារ ដូច្នេះចូរប្រយ័ត្នចំពោះ
វិញ្ញាណ[ន]របស់ឯងចុះ កុំឱ្យប្រព្រឹត្ត ដោយចិត្តក្បត់ឡើយ ។

**២:១៣** ច យរ ១១:១១ ឆ ទដ ៣៩:១២ ជ ទដ ៦៦:១៨ យរ ១៤:១២ ឈ អស ៥៨:២ ញ មឡ ១:២
**២:១៤** ដ លប ២១:៣០ យស ២៤:២២ ឋ សភ ៥:១៨ ឌ អក ១៦:៨ ហាព ១៣:៤
**២:១៥** ឍ លប ២:២៤ មថ ១៩:៤–៦ ណ ចទ ១៤:២ ១កថ ៧:១៤ ត ចទ ៤:១៥ ថ អស ៥៤:៦ ១កថ ៧:១០ ហាព ១៣:៤
**២:១៦** ទ ចទ ២៤:១ មថ ៥:៣១–៣២ ១៩:៤–៩ មក ១០:៤–៥ ធ លប ៦:១១ ៣៤:២៥ សភ ៤:១៧ អស ៥៨:៤ ន ទដ ៥១:១០
**២:១៧** ប អស

## ថ្ងៃជំនុំជម្រះ

១៧ឯងរាល់គ្នានាំឱ្យព្រះយេហូវ៉ារំខាន[ប]ព្រះហឫទ័យ
ដោយពាក្យសំដីរបស់ឯង ទោះបើយ៉ាងនោះ ក៏ឯងរាល់គ្នា
សួរថា យើងបាននាំឱ្យទ្រង់រំខានព្រះទ័យឯណា[ផ] គឺដោយ
ឯងរាល់គ្នាថា អស់អ្នកណាដែលប្រព្រឹត្តអំពើអាក្រក់នោះ
ល្អនៅចំពោះព្រះនេត្រនៃព្រះយេហូវ៉ាហើយ ទ្រង់ក៏សព្វ
ព្រះហឫទ័យ[ព]នឹងគេ ឬថា តើព្រះនៃសេចក្ដីយុត្តិធម៌ទ្រង់នៅ
ឯណា[ភ] ។

**៣** ១មើល អញចាត់ទូតអញ[ក]ឱ្យទៅ គាត់នឹងរៀបចំផ្លូវនៅ
មុខអញ[ខ] ហើយព្រះអម្ចាស់[គ]ដែលឯងរាល់គ្នាស្វែងរកនោះ
ទ្រង់នឹងលោតែមកដល់ព្រះវិហាររបស់ទ្រង់ភ្លាម ឯទូត
ដែលនាំសេចក្ដីសញ្ញាមក[ឃ] ជាសេចក្ដីសញ្ញាដែលឯងរាល់
គ្នាចង់បានទាំងម្ល៉េះនោះ[ង] មើលន៏ ទ្រង់យាងមក នេះជា
ព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ ២តែមាន
អ្នកឯណាធន់[ច]នៅបាន ក្នុងកាលដែលទ្រង់យាងមកនោះ[ឆ]

១:១៤ ផ មឡ ១:២ ព ទដ ៥:៤ ភ លប ១៨:២៥ យប ៨:៣ អក ១៨:២៥ **៣:១** ក ជន ២៧:២១ ២រប ៣៦:១៥ ខ អស ៤០:៣ មថ ៣:៣ ១១:១០ មក ១:២ លក ៧:២៧ គ មីក ៥:២ ឃ អស ៤២:៦ ង ១សយ ៩:២០ **៣:២** ច អគ ២២:១៤ វវ ៦:១៧ ឆ អគ ៧:៧ ដយ ៧:១៣ យអ ២:៣១ មថ ១៦:២៧ យក ៥:៨ ២ពត ៣:៤ វវ ១:៧

ស្រែកថ្ងូរ ។

**២:១៤** *សាក្សី . . . ចុះសញ្ញានឹងគ្នា* អាពាហ៍ពិពាហ៍គឺជាការតាំងសញ្ញានឹងគ្នា (សភ ២:១៧ អគ ១៦:៨ និងការពន្យល់) ហើយសេចក្ដីសញ្ញានោះត្រូវធ្វើនៅមុខសាក្សី(ការពន្យល់ ចទ ៣០:១៩ ១សយ ២០:២៣ អស ៨:១–២) ។

**២:១៥** *តែ ១* មើល លប ២:២៤ និងការពន្យល់ ។ *ពូជបរិសុទ្ធ* មង្គលការ "ធ្វើឱ្យបរិសុទ្ធ" ដល់កូនដែលកើតមក(មើល ១កថ ៧:១៤ និងការពន្យល់) ។ ខនេះមានទំនាក់ទំនងនឹងលោកអ័ប្រាហាំ ដែលបានរៀបការជាមួយនាងហាកា ដើម្បីឱ្យបានកូនប្រុស(លប ១៦:១–៤) ប៉ុន្ដែ លោកអ័ប្រាហាំមិនបានលែងលះនាងសារ៉ា ដែលជាអ្នកផ្ដើមគំនិត ឱ្យលោកអ័ប្រាហាំយកនាងហាកានោះទេ ។

**២:១៦** *អញស្អប់ការលះលែងគ្នា* មើល អស ៥០:១ និងការពន្យល់ ។ *ការច្រឡោត* មើល ៣:៥ ។

**២:១៧–៤:៦** វគ្គនៃបទគម្ពីរនេះគឺជាផ្នែកពាក់កណ្ដាលទីពីរនៃការថ្លែងទំនាយអំពីការដែលព្រះអម្ចាស់ទ្រង់យាងមកឯរាស្ដ្រទ្រង់ ។ ពួកគេបានឈប់ជឿលើព្រះ (២:១៧) ហើយមានការចម្រើនឡើងខាងឯសេចក្ដីពុករលួយផ្នែកសីលធម៌ និងភាពអាត្មានិយមនៅក្នុងជំនឿ ។ ដូចនេះនៅពេលដែលព្រះទ្រង់យាងមកវិញ ទ្រង់នឹងជំនុំជម្រះ សម្អាតជាបរិសុទ្ធ ក៏ដូចជាប្រោសលោះដល់ពួកគេផងដែរ ។

**២:១៧** *នាំឱ្យព្រះយេហូវ៉ារំខានព្រះហឫទ័យ ដោយពាក្យសំដីរបស់ឯង* នៅក្នុង អស ៤៣:២៤ ពួកអ៊ីស្រាអែលបានធ្វើឱ្យព្រះអម្ចាស់រំខានចិត្ត ។ *អស់អ្នកណាដែលប្រព្រឹត្តអំពើអាក្រក់នោះល្អ* ត្រង់ចំណុចនេះគឺបានបង្ហាញពីការនិយមអាត្មាខ្លួនឯង ។ *តើព្រះនៃសេចក្ដីយុត្តិធម៌ទ្រង់នៅឯណា* សូមផ្ទៀបនឹងការនិយាយចំអករបស់ពួកអ៊ីស្រាអែលក្នុង អស ៥:១៩ ។

**៣:១** *ទូតអញ* ពាក្យនេះជាភាសាហេព្រើរគឺអានថា "*ម៉ាឡាគី*" (Mal´aki) ដែលជាធម្មតាគេប្រើពាក្យនេះសម្រាប់ពួកសង្ឃ ឬពួកហោរា(មើល ហាក ១:១៣ និងការពន្យល់) ។ ពាក្យនេះបានសម្រេចនៅក្នុងលោកយ៉ូហានបាទីស្ទ (មើល មថ ១១:៧–១០ មក ១:២–៤ លក ១:៧៦) ។ *គាត់នឹងរៀបចំផ្លូវ* នៅពេលដែលព្រះអម្ចាស់ទ្រង់យាងមក ទ្រង់នឹងញែកជាបរិសុទ្ធ (ខ.៣) និងជំនុំជម្រះ (ខ.៥) ប៉ុន្ដែ ទ្រង់នឹងបង្ហាញសេចក្ដីមេត្តាករុណា ដោយចាត់ឱ្យមានម្នាក់មកមុនទ្រង់ ដើម្បីនឹងរៀបចំរាស្ដ្ររបស់ទ្រង់ (៤:៥–៦ អស ៤០:៣ និងការពន្យល់) ។ *ព្រះអម្ចាស់ដែលឯងរាល់គ្នាស្វែងរកនោះ ទ្រង់នឹងលោតែមកដល់ព្រះវិហាររបស់ទ្រង់ភ្លាម* មើល ហាក ២:៧ និងការពន្យល់ ។ *ទូតដែលនាំសេចក្ដីសញ្ញា* គឺព្រះមែស៊ី ដែលទ្រង់ជាតំណាងនៃព្រះអម្ចាស់ ទ្រង់នឹងបញ្ជាក់ ហើយតាំងសេចក្ដីសញ្ញាថ្មី(មើលការពន្យល់ អស ៤២:៦) ។

**៣:២** *កាលដែលទ្រង់យាងមក* គឺនៅថ្ងៃនៃព្រះអម្ចាស់ (មើល ៤:១ អស ២:១១,១៧,២០ យអ ១:១៥ និងការពន្យល់) ។ លោកម៉ាឡាគីបានប្រកាសពីការដែលព្រះអម្ចាស់ទ្រង់នឹងយាងមកដើម្បីបំពេញព្រះរាជកិច្ចនៃព្រះនៅក្នុងប្រវត្តិសាស្ដ្រ ជាពិសេសព្រះរាជកិច្ចដែលមាននិយាយនៅក្នុងបទគម្ពីរជាបន្ដរបន្ទាប់ទៀតក្នុងព្រះគម្ពីរនេះ ។ បទទំនាយរបស់លោកម៉ាឡាគីត្រូវបានសម្រេចដោយជ័យជំនះនៃព្រះមែស៊ី ។ *តើអ្នកណានឹងឈរនៅ* អស់អ្នក

តើអ្នកណានឹងឈរនៅ[ជ] ក្នុងកាលដែលទ្រង់លេចមក[ឈ] ដ្បិត
ទ្រង់ប្រៀបដូចជាភ្លើងរបស់ជាងសិរង ហើយដូចជាក្បុង
របស់ជាងប្រមោក[ញ] ៣ទ្រង់នឹងគង់ចុះ ដូចជាជាងសិរង
ហើយនិងដេញអាចម៍ប្រាក់[ដ] ទ្រង់នឹងសំអាត[ឋ]ពួកកូនចៅ
លេវី ហើយសំរងគេដូចជាមាស ហើយនិងប្រាក់[ឌ]នោះ គេ
នឹងថ្វាយដង្វាយដល់ព្រះយេហូវ៉ា ដោយសេចក្ដីសុចរិត[ឍ]
៤គ្រានោះដង្វាយ[ណ]របស់ពួកយូដា និងក្រុងយេរូសាឡិមនឹង
ជាទីគាប់ដល់ព្រះហឫទ័យនៃព្រះយេហូវ៉ា ដូចកាលពីដើម
គឺដូចកាលពីចាស់បុរាណនោះ[ត] ៥ហើយអញនឹងមកជិតឯង
រាល់គ្នា ដើម្បីនឹងសំរេចតាមសេចក្ដីយុត្តិធម៌ អញនឹងធ្វើ
ជាសាក្សីយ៉ាងរហ័ស ទាស់នឹងពួកគ្រូអាបធ្មប់[ថ] ទាស់នឹង
ពួកកំផិត[ទ] ទាស់នឹងពួកអ្នកដែលស្បថបំពាន[ធ] ទាស់នឹងពួក
ដែលកេងបំបាត់ឈ្នួលរបស់កូនឈ្នួល[ន] ព្រមទាំងសង្កត់
សង្កិនស្រីមេម៉ាយ[ប] និងមនុស្សកំព្រាផង ហើយដែលបង្វែរ
សេចក្ដីយុត្តិធម៌ ចេញពីពួកអ្នកដែលស្នាក់នៅ[ផ] ឥតកោត
ខ្លាច[ព]ដល់អញដែរ នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃ
ពួកពលបរិវារ ។

## ការលួចពីព្រះអម្ចាស់

៦ដ្បិតអញ គឺយេហូវ៉ា អញមិនប្រែប្រួលឡើយ[ភ] ហេតុ
នោះ ឱពួកកូនចៅយ៉ាកុបអើយ ឯងរាល់គ្នាមិនបានត្រូវ
វិនាសទេ[ម]។
៧ឯងរាល់គ្នាបានបោះបង់ចោល[យ]សេចក្ដីបញ្ញត្តរបស់
អញ ចាប់តាំងពីគ្រាពួកឰយុកោរៀងមក ឥតកាន់តាម
ឡើយ ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បង្គាប់ថា ចូរ
វិលមក[រ]ឯអញវិញចុះ នោះអញនឹងត្រឡប់មកឯឯងដែរ[ល]
តែឯងរាល់គ្នាថា[វ] តើយើងនឹងវិលទៅយ៉ាងដូចម្ដេច ៨ចុះ
តើមនុស្សនឹងកោតយក[ស]របស់ព្រះឬ ប៉ុន្តែឯងរាល់គ្នាបាន
កោងយករបស់អញហើយ រួចបែរជាសួរថា តើយើងបាន
កោងយករបស់ទ្រង់ឯណា គឺក្នុងដង្វាយ១ភាគក្នុង១០[ហ]
ហើយក្នុងដង្វាយលើកចុះឡើងនោះឯង ៩ឯងរាល់គ្នា គឺ
មនុស្សនៅនគរនេះទាំងមូល ត្រូវបណ្ដាសាហើយ[ឡ] ដោយ
ព្រោះតែងតែកោងយករបស់អញយ៉ាងដូច្នេះ ១០ចូរនាំយក
ដង្វាយ១ភាគក្នុង១០[អ]ទាំងអស់ មកដាក់ក្នុងឃ្លាំងចុះ[ក] ដើម្បី
ឱ្យមានស្បៀងអាហារនៅក្នុងដំណាក់នៃអញ ហើយល្បងល
អញឥឡូវ បើអញមិនបើកទ្វារ[ខ]ស្ថានសួគ៌ ដើម្បីចាក់[គ]ព្រះ
ពរ[ឃ]មកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ[ង] នេះ
ហើយជាព្រះបន្ទូលរបស់ព្រះយេហូវ៉ា នៃពួកពលបរិវារ
១១ដូច្នេះ ដោយយល់ដល់ឯងរាល់គ្នា នោះអញនឹងបន្ទោស
ដល់សត្វដែលស៊ីបង្ខូច[ច] មិនឱ្យវាបំផ្លាញផលដែលកើតពី
ដីឯងឡើយ ឯដើមទំពាំងបាយជូរនៅចំការរបស់ឯង ក៏មិន
ជិរុះផ្លែពីកាលនៅខ្ចីបដែរ[ឆ] នេះហើយជាព្រះបន្ទូលរបស់

**៣:២** ជ ១សយ ៦:២០ ឈ អស ១:៣១ ៣០:៣០ សក ១៣:៩ មថ ៣:១០–១២ ញ យប ៩:៣០ **៣:៣** ដ ដយ ១២:១០ ១កថ ៣:១៣ ឋ ១របា ២៣:២៨ អស ១:២៥ ឌ យប ២៨:១ ទដ ១២:៦ ១ពត ១:៧ វវ ៣:១៨ ឍ ទដ ១៣២:៩ **៣:៤** ណ ២របា ៧:១២ ទដ ៥១:១៩ មឡ ១:១១ ត ២របា ៧:៣ អគ ២០:៤០ **៣:៥** ថ អគ ៧:១១ អស ៤៧:៩ ទ មក ២០:១៤ យក ២:១១ ២ពត ២:១២–១៤ ធ លវ ១៩:១១–១២ យរ ៧:៩ ន លវ ១៩:១៣ យក ៥:៤ ប នក ២២:២២ ផ នក ២២:២១ ចទ ២៤:១៩ អគ ២២:៧ ព ចទ ៣១:១២ អស ១:២ **៣:៦** ភ ជន ២៣:១៨ ហព ៧:២១ យក ១:១៧ ម យប ៣៤:១៥ ហស ១១:៩ **៣:៧** យ នក ៣២:៨ យរ ៧:២៦ កច ៧:៥១ រ អស ៤៤:២២ អគ ១៨:៣២ ល សក ១:៣ យក ៤:៨ វ មឡ ១:២ **៣:៨** ស សក ៥:៣ ហ លវ ២៧:៣០ ជន ១៨:២១ នហ ១៣:១០–១២ លក ១៨:១២ **៣:៩** ឡ ចទ ១១:២៦ ២៨:១៥–៦៨ សក ៥:៣ **៣:១០** អ នក ២២:២៩ ក នហ ១៣:១២ ខ ២ពវ ៧:២ គ អស ៤៤:៣ ឃ លវ ២៥:២១ យអ ២:១៤ ២កថ ៩:៨–១១ ង យអ ២:២៤ **៣:១១** ច នក ១០:១៥ ចទ ២៨:៣៩ ឆ នក ២៣:២៦

ដែលទន្ទឹងរង់ចាំព្រះម៉េស៊ីយាងមកត្រូវដឹងថា ពួកគេត្រូវមានដៃស្អាត និងចិត្តបរិសុទ្ធ (មើល ទដ ២៤:៣–៤ និងការពន្យល់ ២៤:៤ អស ៣៣:១៤–១៥) ។ *ភ្លើងរបស់ជាងសិរង* មើល អស ១:២៥ សផ ១៣:៨–៩ និងការពន្យល់ ។ *ក្បុងរបស់ជាងប្រមោក* មើល អស ៧:៣ និងការពន្យល់ ។ សំលៀកបំពាក់ពណ៌សរតំណាងឱ្យភាពបរិសុទ្ធ (មក ៩:៣ វវ ៣:៥) ។

**៣:៣** *គង់ចុះ ដូចជាជាងសិរង ហើយនឹងដេញអាចម៍ប្រាក់* មើល ទដ ១២:៦ និងការពន្យល់ ។ *សំអាតកូនចៅលេវី* អ្នកដែលមាននាទីជា "ទូតរបស់ព្រះ" និងអ្នកដែលបម្រើនៅទីអាសនា នឹងត្រូវទទួលការសម្អាតអំពើបាប និងភាពមិនស្មោះត្រង់ ដូចជា អ្នកដែលព្រះអម្ចាស់ស្ដីបន្ទោសនៅក្នុង ១:៦–២:៩ ។

**៣:៤** *ជាទីគាប់ដល់ព្រះហឫទ័យ* មើល ១:៨ និងការពន្យល់ ។ *ដូចកាលពីដើម* គេជឿថានោះគឺ សម័យលោកម៉ូសេ និងលោកភីនេហាស (មើលការពន្យល់ ២:៥) ។

**៣:៥** នៅពេលដែលទ្រង់យាងមក ព្រះអម្ចាស់ទ្រង់នឹងញែកពួកលេវីជាបរិសុទ្ធ(ខ.៣–៤) ក៏ដូចជាកាត់ទោសរាស្ត្ររបស់ទ្រង់ផងដែរ ។ *ពួកគ្រូអាបធ្មប់* ពួកនេះមានជាធម្មតានៅក្នុងតំបន់មជ្ឈឹមបូព៌ាសម័យបុរាណ (មើល នក ៧:១១ ចទ ១៨:១០ និងការពន្យល់ ១៨:៩) ។

**៣:៦** *មិនប្រែប្រួល* មើល យក ១:១៧ ។ ព្រះអម្ចាស់ទ្រង់នៅតែស្មោះត្រង់នឹងសេចក្ដីសញ្ញារបស់ទ្រង់ មិនដូចជាការគិតរបស់មនុស្សជាច្រើននៅសម័យលោកម៉ាឡាគីនោះទេ ។ *មិនបានត្រូវវិនាស* នៅក្នុងដំណាក់កាលនេះទោះបីជាសាសន៍អ៊ីស្រាអែលមានប្រវត្តិមិនស្មោះត្រង់ក៏ដោយ ក៏ព្រះអម្ចាស់ទ្រង់នៅតែមិនឱ្យពួកគេត្រូវវិនាសដូចពួកសាសន៍អេដំមដែរ ។

**៣:៧** *ចូរវិល . . . អញនឹងត្រឡប់មកឯឯង* បើព្រះអម្ចាស់ទ្រង់ត្រូវយាងមកដើម្បីប្រោសលោះអ៊ីស្រាអែល ពួកគេត្រូវតែប្រែចិត្ត (សក ១:៣ និងការពន្យល់) ។

**៣:៩–១០** *បណ្ដាសា . . . ព្រះពរ* មើល ចទ ១១:២៦–២៨ ។

**៣:១០** *ឃ្លាំង* គឺឃ្លាំងនៅកន្លែងបរិសុទ្ធ (១ពវ ៧:៥១ ២របា ៣១:១១ នហ ១៣:១២) ។ *ទ្វារស្ថានសួគ៌* នៅក្នុងព្រះគម្ពីរផ្សេងទៀត ពាក្យនេះគឺសំដៅទៅលើអាហារដែលបានប្រទានមកជាបរិបូរណ៍ (២ពវ ៧:២,១៩ ទដ ៧៨:២៣–២៤ និងការពន្យល់ ៧៨:២៣) ។ *ចាក់ព្រះពរ* គឺជាព្រះពរដែលបានសន្យានៅក្នុងសេចក្ដីសញ្ញា (មើល ចទ ២៨:១២, ធៀបនឹង អស ៤៤:៣) ។

**៣:១១** *សត្វដែលស៊ីបង្ខូច . . . មិនឱ្យវាបំផ្លាញផលដែលកើតពីឯង* គឺជាឧទាហរណ៍នៃបណ្ដាសាដែលបានព្រមាននៅក្នុងសេចក្ដីសញ្ញា (មើល ចទ ២៨:៣៩–៤០) ។

ព្រះយេហូវ៉ានៃពួកបរិវារ ១២យ៉ាងនោះគ្រប់ទាំងសាសន៍
នឹងថា ឯងរាល់គ្នាមានពរ[ជ] ដ្បិតស្រុករបស់ឯងរាល់គ្នា
នឹងបានជាស្រុកសប្បាយណាស់[ឈ] នេះជាព្រះបន្ទូលរបស់
ព្រះយេហូវ៉ានៃពួកពលបរិវារ[ញ]។
១៣ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា ពាក្យសំដីរបស់ឯង
រាល់គ្នា បានទាស់នឹងអញជាខ្លាំង[ដ] ទោះបើយ៉ាងនោះក៏ឯង
រាល់គ្នាថា[ឋ] យើងបាននិយាយអ្វីទាស់នឹងទ្រង់ ១៤គឺឯងរាល់
គ្នាពោលថា ការដែលខំគោរពតាមព្រះ នោះឥតអំពើទេ[ឌ]
ហើយដែលយើងបានរក្សាបញ្ញើរ[ឍ]របស់ព្រះយេហូវ៉ានៃ
ពួកពលបរិវារ ព្រមទាំងដើរ[ណ]នៅចំពោះទ្រង់ដោយកាន់
ទុក្ខ[ត] ដូច្នេះ តើមានប្រយោជន៍អ្វី ១៥ឥឡូវនេះ យើងរាប់
មនុស្សឆ្មើងឆ្មៃ[ថ] ទុកជាសប្បាយហើយ អើ ពួកអ្នកដែល
ប្រព្រឹត្តការអាក្រក់[ទ]បានតាំងឡើង[ធ] អើ គេល្បងលព្រះ
ហើយក៏រួចខ្លួនផង ។
១៦គ្រានេះ ពួកអ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ាក៏
និយាយគ្នាទៅវិញទៅមក ហើយព្រះយេហូវ៉ាទ្រង់ប្រុង
ស្តាប់ ក៏បានឮ[ន] រួចមានសៀវភៅរំឭក[ប]បានកត់ទុក នៅ
ចំពោះព្រះយេហូវ៉ា សំរាប់ពួកអ្នកដែលកោតខ្លាច[ផ]ដល់
ទ្រង់នឹងពួកអ្នកដែលនឹកដល់ព្រះនាមទ្រង់ ១៧ព្រះយេហូវ៉ា
នៃពួកពលបរិវារទ្រង់មានបន្ទូលថា នៅថ្ងៃដែលអញ ធ្វើ
ការនេះ នោះគេនឹងបានជារបស់ផងអញ[ព] គឺជារបស់ផង
អញពិត[ភ] ហើយអញនឹងប្រណី[ម]ដល់គេ ដូចជាមនុស្សប្រណី
ដល់កូនខ្លួនដែរ[យ] គឺជាកូនដែលគោរពដល់ខ្លួនពិត ១៨គ្រា
នោះ ឯងរាល់គ្នានឹងត្រឡប់ជាចេះញែកសេចក្ដីសុចរិត[រ]
និងសេចក្ដីអាក្រក់ចេញពីគ្នា ហើយនិងមនុស្សដែលគោរព
ដល់ព្រះ និងមនុស្សដែលមិនគោរពផង[ល]។

## ថ្ងៃនៃព្រះអម្ចាស់

**៤** ១ដ្បិតមើល ថ្ងៃនោះកំពុងតែមកដល់[ក] ថ្ងៃនោះឆេះឆ្លោ
ដូចជាគុកភ្លើង[ខ] នោះអស់ពួកអ្នកឆ្មើងឆ្មៃ[គ] ហើយនឹងអស់
ពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់ គេនឹងដូចជាជញ្ជ្រាំង[ឃ]
ហើយថ្ងៃដែលត្រូវមកដល់នោះ និងឆេះបន្សុសគេទាំងអស់
ទៅ[ង] ឥតទុកឱ្យគេមានឫស ឬមែក[ច]នៅសល់ឡើយ នេះ
ហើយ ជាព្រះបន្ទូលរបស់ព្រះយេហូវ៉ា នៃពួកបរិវារ ២តែ
ព្រះអាទិត្យនៃសេចក្ដីសុចរិត[ឆ]នឹងរះឡើង មានទាំងអំណាច
ប្រោសឱ្យជា[ជ] នៅក្នុងចំអេងស្លាប សំរាប់ឯងរាល់គ្នាដែល
កោតខ្លាចដល់ឈ្មោះអញ[ឈ] នោះឯងរាល់គ្នានឹងចេញទៅ
លោតកញ្ឆែង[ញ] ដូចជាកូនគោ ដែលលែងចេញពីក្រោល

**៣:១២** ជ ចទ ២៨:៣-១២ អស ៦១:៩ ឈ អស ៦២:៤ អគ ២០:៦ ញ ២របា ៣១:១០ **៣:១៣** ដ មឡ ២:១៧ ឋ មឡ ១:២ **៣:១៤** ឌ ទដ ៧៣:១៣ អស ៥៧:១០ ឍ ទដ ១០០:២ យហ ១២:២៦ រម ១២:១១ ណ យស ២២:៥ អស ១:១៤ ត អស ៥៨:៣ **៣:១៥** ថ ទដ ១១៩:២១ ទ ទដ ១៤:១ ៣៦:១-២ យរ ៧:១០ ធ យប ២១:៧ **៣:១៦** ន ទដ ៣៤:១៥ ប នក ៣២:៣២ ទដ ៥៦:៨ ៨៧:៦ លក ១០:២០ ផ ចទ ២៨:៥៨ ៣១:១២ ទដ ៣៣:១៨ សភ ១:៧ វវ ១១:១៨ **៣:១៧** ព អស ៤៣:២១ ភ នក ៨:២២ ចទ ៧:៦ រម ៨:១៤ ទត ២:១៤ ម នហ ១៣:២២ ទដ ១០៣:១៣ អស ២៦:២០ លក ១៥:១-៣២ យ រម ៨:៣២ **៣:១៨** រ លប ១៨:២៥ ល ចទ ៣២:៤ មថ ២៥:៣២ -៣៣,៤១ **៤:១** ក ដយ ៧:១៣ យអ ២:៣១ មថ ១១:១៤ កច ២:២០ ខ អស ៣១:៩ គ អស ២:១២ ឃ អស ៥:២៤ ណាហ ១:១០ ង អស ១:៣១ ច ២ពវ ១០:១១ អគ ១៧:៨ មថ ៣:១០ **៤:២** ឆ ទដ ១១៨:២៧ អស ៩:២ ៤៥:៨ លក ១:៧៨ អភ ៥:១៤ ជ ២របា ៧:១៤ អស ៣០:២៦ មថ ៤:២៣ វវ ២២:២ ឈ ចទ ២៨:៥៨ ទដ ៦១:៥ ១១១:៩ វវ ១៤:១ ញ អស ៣៥:៦

**៣:១២** *ថា ឯងរាល់គ្នាមានពរ* គឺដើម្បីសម្រេចតាមសេចក្ដីសន្យាដែលទ្រង់មានជាមួយលោកអ័ប្រាហាំ (មើល លប ១២:២-៣ អស ៦១:៩ និងការពន្យល់) ។

**៣:១៥** *មនុស្សឆ្មើងឆ្មៃ* គឺពួកធ្វើការអាក្រក់ ទាស់ប្រឆាំងនឹងព្រះ (មើលការពន្យល់ ទដ ១០:១១) ។ *សប្បាយ* ដោយសារពួកគេគ្មានជំនឿ ពួកយូដារាប់ថាសប្បាយចំពោះអស់អ្នក ដែលអ្នកកោតខ្លាចព្រះរាប់ថា ត្រូវបណ្ដាសា (ទស ១១៩:២១ និងការពន្យល់) ប៉ុន្តែ បើពួកគេបានលន់តួបាបវិញនោះ នឹងត្រូវបានរាប់ថាមានពរវិញ (ខ.១២) ។ *ពួកអ្នកដែលប្រព្រឹត្តការអាក្រក់បានតាំងឡើង . . . រួចខ្លួនផង* ព្រះគម្ពីរទំនុកដំកើងមាននិយាយប្រឆាំងនឹងការចម្រើនឡើងនៃពួកប្រព្រឹត្តការអាក្រក់ នៅក្នុង ទដ ៧៣:៣,៩-១២ (មើល ហព ១:២-៤ និងការពន្យល់) ។

**៣:១៦** *ពួកអ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ា* គឺពួកអ្នកដែលមិនសង្ស័យ ហើយមិនអាត្មានិយម ។ *និយាយគ្នាទៅវិញទៅមក* នៅពេលដែលការត្អូញត្អែរចេះតែកើនឡើង(ខ.១៤-១៥) ពួកគេបានស្វែងរកការលើកទឹកចិត្តពីគ្នាទៅវិញទៅមកនៅក្នុងការប្រកបរបស់ពួកគេ ។ *សៀវភៅរំឭក* គឺមិនខុសពីសៀវភៅសម្រាប់កត់ត្រាអំពីការសំខាន់ៗ ហើយមានអ្នកដឹកនាំប្រទេសជាអ្នកគ្រប់គ្រងសៀវភៅនោះ(នអ ៦:១-៣ អស ៤:៣ ដយ ៧:១០ ១២:១)។ *នឹងដល់ព្រះនាមទ្រង់* គឺមិនដូចពួកសង្ឃ (១:១២) និងអ្នកជាច្រើនអ្នកទៀតនៅក្នុងបណ្ដាជន(ខ.១៤-១៥ ២:១៧) ។

**៣:១៧** *របស់ផងអញ* មើលការពន្យល់ នក ១៩:៥ ។ *ប្រណីដល់គេ* នៅថ្ងៃជំនុំជម្រះ(មើល ៤:១-២) ។ *ដែលគោរពដល់ខ្លួនពិត* ធៀបនឹង ១:៦ ។

**៣:១៨** *សេចក្ដីសុចរិត និងសេចក្ដីអាក្រក់* មើល ២:១៧ និងការពន្យល់ ។

**៤:១** *ថ្ងៃនោះ* គឺថ្ងៃនៃព្រះយេហូវ៉ា(ខ.៥ ៣:២ និងការពន្យល់) ។ *ឆេះឆ្លោដូចជាគុកភ្លើង* មើល ៣:២-៣ អស ១:៣១ ៦៦:១៥-១៦ និងការពន្យល់ ។ មើល ៣:១៥ និងការពន្យល់ ។ *ជញ្ជ្រាំង . . . ឆេះបន្សុស* មើល អស ៤៧:១៤ និងការពន្យល់ ។ មើលការថ្លែងទំនាយរបស់លោកយ៉ូហានបាទីស្ទអំពីព្រះរាជកិច្ចរបស់ព្រះគ្រីស្ទនៅក្នុង មថ ៣:១២ ។ *ឥតទុកឱ្យគេមានឫស ឬមែកនៅសល់ឡើយ* មានន័យថា ពួកគេនឹងមិនសល់អ្វីសោះ (មើល អគ ១៧:៨-៩) ។

**៤:២** *ព្រះអាទិត្យ នៃសេចក្ដីសុចរិត* ព្រះអម្ចាស់ និងសិរីល្អនៃទ្រង់គឺប្រៀបដូចជាព្រះអាទិត្យ នៅក្នុង អស ៦០:១៩ (មើលការពន្យល់ខនេះ)។ ព្រះគ្រីស្ទគឺជា"ព្រះអាទិត្យដែលរះ"ពីស្ថានសួគ៌មក (លក ១:៧៨-៧៩ និងការពន្យល់ ១:៧៨ អស ៩:២ និងការពន្យល់) ។ *សេចក្ដីសុចរិត... ប្រោសឱ្យជា* ព្រះទ្រង់សព្វព្រះទ័យប្រទាននូវសេចក្ដីសង្គ្រោះ និងការកើតជាថ្មី (អស ៤៥:៨ ៤៦:១៣ ៥៣:៥ យរ ៣០:១៧ និងការពន្យល់) ។ *ចំអេងស្លាប* គឺកាំរស្មីព្រះអាទិត្យ(ធៀបនឹង ទដ ១៣៩:៩) ។ *ដូចជាកូនគោ ដែលលែង*

៣ហើយព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានបន្ទូលថា
នៅថ្ងៃដែលធ្វើការនោះ ឯងរាល់គ្នានឹងជាន់ឈ្លី[ដ]ពួក
អាក្រក់បង់ ដ្បិតគេនឹងដូចជាផេះ[ឋ]នៅក្រោមបាទជើងរបស់
ឯងរាល់គ្នា ។
៤ចូរនឹកចាំពីក្រិត្យវិន័យ[ឌ]របស់លោកម៉ូសេ ជាអ្នកបំរើ
អញ ដែលអញបានបង្គាប់ដល់លោក នៅលើភ្នំហោរែប[ឍ]
សំរាប់ពួកអ៊ីស្រាអែលទាំងអស់គ្នា[ណ] គឺអស់ទាំងក្រិត្យក្រម
និងបញ្ញត្តិច្បាប់ទាំងប៉ុន្មាននោះ ៥មើល មុនដែលថ្ងៃដ៏ធំ
ហើយគួរស្ញែងខ្លាចរបស់ព្រះយេហូវ៉ាបានមកដល់[ត] នោះ
អញនឹងចាត់អេលីយ៉ា[ថ] ឱ្យមកឯឯងរាល់គ្នា ៦លោកនឹង
បង្វែរចិត្តពួកឪពុកមកឯកូន[ទ] និងចិត្តកូនមកឯឪពុកវិញ
ក្រែងអញមកវាយ[ធ]ផែនដីដោយសេចក្ដីបណ្ដាសា[ន]។/

**៤:៣** ដ យប ៤០:១២ ទដ ១៨:៤០–៤២ ឋ អគ ២៨:១៨ **៤:៤** ឌ ចទ ២៨:៦១ ទដ ១៤៧:១៩ មថ ៥:១៧ ៧:១២ រម ២:១៣ ៤:១៥ កទ ៣:២៤ ឍ នក ៣:១ ណ នក ២០:១
**៤:៥** ត យអ ២:៣១ ថ ១ពវ ១៧:១ មថ ១១:១៤ ១៦:១៤ **៤:៦** ទ លក ១:១៧ ធ អស ១១:៤ វវ ១៩:១៥ ន ចទ ១១:២៦ ១៣:១៥ យអ ៦:១៧ ២៣:១៥ សក ៥:៣

*ចេញពីក្រោល* កូនគោដែលលែងចេញពីក្រោល ច្រើនតែលោតកញ្ឆែង ។
**៤:៣** *ជាន់ឈ្លី . . . ពួកអាក្រក់* គឺបីដូចជាការជាន់ផ្លែទំពាំងបាយជូយកទឹកដែរ (អស ៦៣:២–៣ និងការពន្យល់) ។
**៤:៤** *ចូរនឹកចាំក្រឹត្យវិន័យ* គឺជាការលើកទឹកចិត្តចុងក្រោយ ដល់អ្នកដែលរង់ចាំការយាងមកនៃព្រះអម្ចាស់ដោយអត់ធ្មត់ ។ *លោកម៉ូសេ ជាអ្នកបំរើ* មើល នក ១៤:៣១ ចទ ៣៤:៥ និងការពន្យល់ ។ *ភ្នំហោរែប* គឺភ្នំស៊ីណាយ (មើល នក ៣:១ និងការពន្យល់) ។
**៤:៥** មើល ៣:១ និងការពន្យល់ ។ *ថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាច* មើល ខ.១ ៣:២ យអ ២:១១ និងការពន្យល់ ។ *អេលីយ៉ា* លោកអេលីយ៉ាបានមកមុនលោកអេលីសេ (ការងាររបស់លោកអេលីសេគឺការជំនុំជម្រះ និងការប្រោសលោះ) ដូចនេះព្រះទ្រង់នឹងចាត់លោក "អេលីយ៉ា" ឱ្យរៀបចំរាស្ត្រនៃព្រះសម្រាប់ការយាងមករបស់ទ្រង់ ។ លោកយ៉ូហានបាទីស្ទបានបម្រើព្រះ "ដោយនូវវិញ្ញាណ និងអំណាចរបស់លោកអេលីយ៉ា" (មើល លក ១:១៧ និងការពន្យល់, មថ ១១:១៣–១៤ ១៧:១២–១៣ មក ៩:១១–១៣ និងការពន្យល់ ៩:១៣) ។ អ្នកខ្លះជឿថា លោកអេលីយ៉ាក៏អាចជាម្នាក់ក្នុងចំណោមស្មរបន្ទាល់ទាំងពីរ នៅក្នុង វវ ១១:៣ (មើលការពន្យល់ខនេះ) ។
**៤:៦** *បង្វែរចិត្ត* ធៀបនឹង លប ១៨:១៩ ។ បើតាម លក ១:១៧ លោកយ៉ូហានបាទីស្ទបានធ្វើការបង្វែរចិត្តនេះ ។ *សេចក្ដីបណ្ដាសា* គឺជាបណ្ដាសាដែលនឹងបំផ្លិចបំផ្លាញទាំងស្រុង ។ បើសិនជាសាសន៍អ៊ីស្រាអែលមិនប្រែចិត្តទេ ព្រះទ្រង់នឹងដោះស្រាយជាមួយនឹងសាសន៍នេះ ដូចកាលដែលទ្រង់ដោះស្រាយនឹងសាសន៍អេដំមដែរ (១:៣–៤ អស ៣៤:៥) ។

# សម័យនៅចន្លោះគ្រាសញ្ញាចាស់ និងសញ្ញាថ្មី

សម័យនៅចន្លោះគ្រាសញ្ញាចាស់ និងសញ្ញាថ្មី គឺជាសម័យដែលមានចលាចល និងការប្រែប្រួល ជាពេលរៀបចំឡើងវិញនូវប្រពៃណីយ និងជាពេលផ្សព្វផ្សាយវប្បធម៌មជ្ឈិមបូព៌ា ដែលមានភាពរុងរឿងអស់រយៈពេលជិត ៣០០០ ឆ្នាំ ។

នៅក្នុងប្រវត្តិសាស្ត្រតាមព្រះគម្ពីរ រយៈពេលនៅចន្លោះសម័យលោកនេហេមា និងសម័យដែលព្រះយេស៊ូវយាងមកចាប់កំណើត គឺប្រហែលជា ៤០០ ឆ្នាំ ហើយគេហៅសម័យនេះថា សម័យនៅចន្លោះគ្រាសញ្ញា (ប្រហែលឆ្នាំ ៤៣៣ ដល់ ៥ មុនគ.ស)។ ជួនការគេហៅសម័យនេះថា ឆ្នាំស្ងប់ស្ងាត់ ប៉ុន្តែមិនមែនមានន័យថាគ្មានហេតុការណ៍អ្វីកើតឡើងនោះទេ ។ ព្រឹត្តិការណ៍អក្សរសាស្ត្រ និងកម្លាំងសង្គមនៃសម័យនោះ បានរួមចំណែកនៅក្នុងការបង្កើតសង្គមនៅក្នុងសម័យសញ្ញាថ្មីផងដែរ ។

## ប្រវត្តិសាស្ត្រ

ចាប់តាំងពីពេលដែលចក្រភពបាប៊ីឡូននិរទេសពួកអ៊ីស្រាអែលមក សាសន៍អ៊ីស្រាអែលត្រូវបាត់បង់ឯករាជ្យ ហើយត្រូវក្លាយជាជាតិសាសន៍ដែលមានទឹកដីតូចតាច ស្ថិតនៅក្រោមការគ្រប់គ្រងដោយចក្រភពនៃសាសន៍ដទៃ ។ គេមិនសូវដឹងប៉ុន្មានទេ អំពីសម័យចក្រភពព៌រស៊ីគ្រប់គ្រងសាសន៍អ៊ីស្រាអែល ពីព្រោះលោកយ៉ូសែបហ្វឺស(ប្រហែលឆ្នាំ ៣៧–១០០ នៃគ.ស) ដែលជាអ្នកប្រវត្តិសាស្ត្រសាសន៍យូដា និងជាប្រភពជាបឋមសម្រាប់ការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រនៃសម័យចន្លោះគ្រាសញ្ញា លោកបាននិយាយសរសេរអំពីប្រវត្តិនៃសម័យចន្លោះនោះដែរ តែមិនបានសរសេរពីសម័យគ្រប់គ្រងរបស់ចក្រភពព៌រស៊ីនោះទេ ។

ចាប់ពីសម័យស្តេចអ័ឡេចក្សេនដ័រអស្ចារ្យនៃចក្រភពម៉ាសេដូនគ្រប់គ្រងទឹកដីបរិសុទ្ធ(ឆ្នាំ ៣៣២ មុនគ.ស) សាសន៍អ៊ីស្រាអែលបានទទួលរងនូវការគម្រាមកំហែងថ្មី និងបន្ថែមទៀតដោយមិនដឹងខ្លួន ។ ស្តេចអ័ឡេចក្សេនដ័របានប្តេជ្ញាបង្កើតពិភពលោកថ្មីដែលបង្រួបបង្រួមដោយភាសា និងវប្បធម៌ក្រិច ហើយការប្តេជ្ញានេះបានក្លាយជាគោលនយោបាយដែលបន្តដោយអ្នកស្នងរាជ្យរបស់ទ្រង់ ។ គេហៅគោលនយោបាយនេះថា ក្រិចភាវូនីយកម្ម(Hellenization) វាមានឥទ្ធិពលយ៉ាងខ្លាំងមកលើសាសន៍យូដា ។

នៅពេលដែលស្តេចអ័ឡេចក្សានដ័រសោយទីវង្គត(ឆ្នាំ ៣២៣ មុនគ.ស) ចក្រភពរបស់ទ្រង់ត្រូវបែងចែក ហើយគ្រប់គ្រងដោយពួកមេទ័ពរបស់ទ្រង់ ។ ក្នុងចំណោមពួកមេទ័ពទាំងនោះ មានពីរនាក់ដែលបានបង្កើតការគ្រង់គ្រងដោយរាជ្យវង្ស ដែលមានដូចជារាជវង្សផ្តោលេមីនៃប្រទេសអេស៊ីព្ទ(Ptolemy of Egypt) និងរាជវង្សសេលើស៊ីឌ នៅប្រទេសស៊ីរី និងតំបន់មេសូប៉ូតាមៀ (Seleucids in Syria and Mesopotamia) ដែលបានដណ្តើមគ្នាត្រួតត្រាទឹកដីបរិសុទ្ធ អស់រយៈពេលជាងមួយសតវត្ស ។

គេបានចាត់ទុកការគ្រប់គ្រងរបស់រាជវង្សផ្តោលេមីថាជាការគ្រប់គ្រងដោយផ្តល់សេរីភាពជំនឿដល់ពួកយូដា ប៉ុន្តែ នៅឆ្នាំ ១៩៨ មុនគ.ស រាជវង្សសេលើស៊ីឌបានដណ្តើមកាន់កាប់បានទឹកដីបរិសុទ្ធ ហើយបាននាំឱ្យមានសម័យមួយក្នុងចំណោមសម័យវិរភាពបំផុតក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល ។

នៅដើមដំបូងនៃការគ្រប់គ្រងរបស់រាជវង្សសេលើស៊ីឌគឺត្រូវនឹងពេលដែលរាជវង្សផ្តោលេមីគ្រប់គ្រងដោយត្រាប្រណី ប៉ុន្តែនៅក្នុងរាជ្យស្តេចអាន់ទីយ៉ូកូស ទី៤ អេពីហ្វានី(ឈ្មោះស្តេចអង្គនេះមានន័យថា"ព្រះទ្រង់បើកសំដែង" ទ្រង់ឡើងកាន់អំណាចពី ឆ្នាំ ១៧៥–១៦៤ មុនគ.ស)បានផ្លាស់ប្តូរគោលនយោបាយទៅជា ក្រិចភាវូនីយកម្មជ្រុលនិយម ដើម្បីបង្រួបបង្រួមអាណាចក្រដែលកំពុងដែរចុះខ្សោយរបស់ទ្រង់ ។ នៅពេលដែលក្រុមវណ្ណៈអភិជនរបស់ពួកយូដាមានការរស់នៅតាមបែបពួកក្រិចស្រាប់ទៅហើយ នោះពួកយូដាភាគច្រើនមានការខឹងសម្បា ។

ស្តេចអាន់ទីយ៉ូកូសបានប្រើភាពឃោរឃៅក្នុងគោលបំណងលុបបំបាត់សាសនារបស់ពួកយូដា ។ ស្តេចអង្គនេះបានហាមការអនុវត្តន៍សំខាន់ៗមួយចំនួននៅក្នុងជំនឿរបស់ពួកយូដា បានប៉ុនប៉ងបំផ្លាញគ្រប់ទាំងសំណៅចម្លងទាំងអស់នៃព្រះគម្ពីរតូរាហ៍(Torah,ដែលជាព្រះគម្ពីរទាំងប្រាំកណ្ឌរបស់លោកម៉ូសេ) ហើយបានតម្រូវឱ្យថ្វាយយញ្ញបូជាដល់ព្រះហ្សេអ៊ូស(Zeus) នៃសាសន៍ក្រិច ។ ការដែលទ្រង់ធ្វើឱ្យពួកយូដាខឹងសម្បាបំផុត គឺការសាងសង់រូបចំលាក់ព្រះហ្សេអ៊ូស និងការយកជ្រូកទៅថ្វាយយញ្ញបូជានៅក្នុងព្រះវិហារយេរូសាឡិម ។

ការបះបោរប្រឆាំងនឹងស្តេចអាន់ទីយ៉ូកូសបានកើតមានឡើងក្រោមការដឹកនាំរបស់លោកម៉ាតាធាស(ដែលជាចាស់ទុំនៅក្នុងភូមិមួយ និងមានជាប់ខ្សែលោហិតពួកសង្ឃ) និងកូនប្រុសទាំងប្រាំនាក់របស់គាត់ដែលមានៈ លោកយូដា(ឬម៉ាកាបៀស ដែលប្រហែលជាមានន័យថា "អ្នកកាន់ញញួរ") លោកយ៉ូណាថាន លោកស៊ីម៉ូន លោកយ៉ូហាន និងលោកអេលាសារ ។ លោកម៉ាតាធាសបានបំផ្លាញអាសនារបស់ពួកក្រិចមួយកន្លែងនៅក្នុងភូមិរបស់គាត់ឈ្មោះ ម៉ូដេន ហើយបានសម្លាប់បេសកជនរបស់ស្តេចអាន់ទីយ៉ូកូសម្នាក់ ។ ការនេះ

ជាដើមហេតុនៃការបះបោររបស់ពួកម៉ាកាប៊ី ជាសង្គ្រាមមានរយៈពេល ២៤ ឆ្នាំ (ឆ្នាំ ១៦៦ ដល់ ១៤២ មុនគ.ស) ដែលនាំមកនូវឯករាជ្យដល់ស្រុកយូដា រហូតដល់ពេលស្ថិតនៅក្រោមការត្រួតត្រារបស់ចក្រភពរ៉ូមនៅឆ្នាំ ៦៣ មុនគ.ស ។

ទោះជាយ៉ាងណាក៏ដោយ ជ័យជំនះរបស់គ្រួសារលោកម៉ាថាធាសត្រូវបានចាត់ទុកថាបរិសុទ្ធ ។ ដោយសារការស្លាប់របស់លោកស៊ីម៉ូនជាកូនប្រុសពៅរបស់លោក រាជវង្សហាស់ម៉ូនានដែលពួកគេបានបង្កើតត្រូវប្រែជាការដឹកនាំដោយវណ្ណៈអភិជនក្នុងរយៈពេលដ៏ខ្លី ជួនកាលគេពិបាករកឃើញភាពខុសគ្នានៃរបបក្រិកភាវូនីយកម្មក្នុងសម័យនោះ ពីរបបក្រិកភាវូនីយកម្មនៃរាជវង្សសេលើស៊ីឌ ។ នៅក្នុងរាជ្ជកាលនៃកូនរបស់លោកស៊ីម៉ូន ឈ្មោះ យ៉ូហាន ហ៊ីកាណូស ដែលជាពួកយូដាអភិរក្សនិយមដែលគាំទ្រពួកម៉ាកាប៊ី ត្រូវធ្លាក់ចុះប្រជាប្រិយភាព ។ ពួករាជវង្សហាស់ម៉ូនានសុទ្ធតែជាអ្នកគាំទ្រពួកយូដាដែលប្រកាន់វប្បធម៌ក្រិច លើកដែលតែមនុស្សពីរបីនាក់ប៉ុណ្ណោះ ។ ជាការពិតណាស់ ស្ដេចអ័ឡេក្សានដ័រ ជែននើ (ឆ្នាំ ១០៣–៧៦ មុនគ.ស) បានធ្វើទុក្ខបៀតបៀនដល់ពួកផារិស៊ី ។

រាជវង្សហាស់ម៉ូនានត្រូវបញ្ចប់ នៅឆ្នាំ ៦៣ មុនគ.ស នៅពេលដែលចក្រភពរ៉ូម៉ាំងដែលនិយមការពង្រីកទឹកដីត្រួតត្រា បានលូកដៃចូលទៅក្នុងជំលោះរាជវង្សរវាងកូនប្រុសទាំងពីរនាក់របស់ស្ដេចជែនើ គឺអារីស្តូបូលូសទី២ និងហ៊ីកាណូសទី២។ លោកប៉ុមប៉ី ជាមេទ័ពរ៉ូម៉ាំងម្នាក់ ដែលមានតួនាទីដឹកនាំទ័ពកាន់កាប់តំបន់ខាងកើតសម្រាប់ចក្រភពរ៉ូម៉ាំង បានវាយយកបានក្រុងយេរូសាឡិម បន្ទាប់ពីឡោមព័ទ្ធបរិវេណនៃព្រះវិហារអស់រយៈពេល ៣ ខែ ដោយសម្លាប់រង្គាលពួកសង្ឃនៅពេលដែលពួកគេកំពុងបំពេញតួនាទី និងកំពុង តែចូលទៅក្នុងទីបរិសុទ្ធបំផុត ។ ការប្រមាថដល់ព្រះយ៉ាងដូចនេះ គឺជាការចាប់ផ្ដើមនៃការគ្រប់គ្រងរបស់ពួករ៉ូម៉ាំង តាមរបៀបដែលធ្វើឱ្យពួកយូដាមិនអាចអត់អោនឱ្យ ឬបំភ្លេចបានឡើយ ។

## អក្សរសាស្ត្រ

នៅក្នុងរយៈពេលជាច្រើនឆ្នាំនៃការមិនពេញចិត្តនឹងការគៀបសង្កត់ និងការតស៊ូក្នុងប្រទេស ពួកសាសន៍យូដាបានបង្កើតនូវស្នាដៃអក្សរសាស្ត្រជាច្រើន ដែលបានកត់ត្រា និងលើកឡើងអំពីយុគសម័យរបស់ពួកគេ ។ ស្នាដៃបីដែលសំខាន់ជាងគេមានដូចជា ព្រះគម្ពីរសេបទូជិន (Septuagint) ដែលជាព្រះគម្ពីរសញ្ញាចាស់បកប្រែជាភាសាក្រិចលើកដំបូង ព្រះគម្ពីរទសកណ្ឌ ឬអាប៉ូគ្រីប៉ា (Apocrypha) និងក្រាំងសមុទ្រស្លាប់ (Dead Sea Scrol) ។

*ព្រះគម្ពីរសេបទូជិន ដែលជាព្រះគម្ពីរសញ្ញាចាស់មកប្រែជាភាសាក្រិចលើកដំបូង (Septuagint) :* តាមរឿងព្រេងរបស់ពួកយូដាគឺមានអ្នកប្រាជ្ញ ៧២ នាក់ បានទទួលការធានាពីស្ដេចផ្ដោលេមី ភីឡាដិលផើស (ប្រហែលឆ្នាំ ២៥០ មុនគ.ស) ពួកគេទាំងអស់គ្នាត្រូវបានបញ្ជូនទាំងទៅកាន់កោះបារ៉ូស ដែលនៅក្បែរក្រុងអ័ឡេក្សានឌ្រា ហើយបានធ្វើការបកប្រែព្រះគម្ពីរសញ្ញាចាស់ក្នុងរវាង៧២ថ្ងៃ ។ ចំពោះឈ្មោះនៃស្នាដៃបកប្រែនេះត្រូវបានគេដាក់ឈ្មោះឱ្យតាមភាសាឡាតាំងថា សេបទូជិន (Septuagint) ដែលមានន័យថា ៧0 ។ ហើយលេខ ៧0 ជាលេខរ៉ូម៉ាំងគឺ LXX ត្រូវបានគេប្រើជាអក្សរកាត់សំរាប់ឈ្មោះនៃព្រះគម្ពីរនេះ ។ សេបទូជិន

គេជឿថា តាមរឿងព្រេងនេះ យ៉ាងហោចណាស់ព្រះគម្ពីរតូរ៉ាហ៍ (ព្រះគម្ពីរទាំងប្រាំកណ្ឌរបស់លោកម៉ូសេ) ក៏ត្រូវបានបកប្រែជាភាសាក្រិចផងដែរ ប្រហែលជាក្នុងឆ្នាំ ២៥0 មុនគ.ស សម្រាប់ពួកយូដាដែលនិយាយភាសាក្រិចនៅក្រុងអ័ឡេក្សានឌ្រា ។ ទោះជាគេមិនអាចកំណត់កាលបរិច្ឆេទឱ្យបានពិតប្រាកដដ៏ដោយ ក៏គេអាចកំណត់បានថា នៅមុនការចាប់ផ្ដើមនៃគ្រីស្ទសករាជ មានកណ្ឌព្រះគម្ពីរក្រៅពីកណ្ឌទាំងប្រាំនោះ និងសៀវភៅដែលមិនមែនជាកណ្ឌព្រះគម្ពីរ នៅក្នុងការបកប្រែព្រះគម្ពីរ LXX (ឬសេបទូជិន) ផងដែរ ។

ចាប់តាំងពីបានបកប្រែហើយក្នុងរយៈពេលដ៏ខ្លី ព្រះគម្ពីរសេបទូជិននេះត្រូវក្លាយជាព្រះគម្ពីររបស់ពួកយូដា ដែលរស់នៅក្រៅទឹកដីបរិសុទ្ធ ដែលជាពួកអ្នកឈប់ប្រើភាសាហេព្រើ ដូចពួកក្រុងអ័ឡេក្សាឌ្រាដែរ។ ព្រះគម្ពីរនេះមានឥទ្ធិពលខ្លាំងណាស់ ។ ទាំងពួកយូដាដែលឈប់ប្រើភាសារបស់បុព្វបុរសខ្លួន និងមនុស្សដែលរស់នៅក្នុងចក្រភពក្រិច អាចរកព្រះគម្ពីរនេះប្រើប្រាស់បាន ។ ក្រោយមកទៀតព្រះគម្ពីរនេះបានក្លាយជាព្រះគម្ពីររបស់ពួកជំនុំដំបូង ។ ព្រះគម្ពីរនេះមានប្រជាប្រិយភាព និងការប្រើប្រាស់កាន់តែទូលំទូលាយ ហើយការនេះបានរួមចំណែកនៅក្នុងការនាំឱ្យមានការនិយមព្រះគម្ពីរទសកណ្ឌ (Apocrypha) ដោយគ្រីស្ទបរិស័ទនៃនិកាយមួយចំនួន ។

*ព្រះគម្ពីរទសកណ្ឌ ឬអាប៉ូគ្រីប៉ា (Apocrypha)* ឈ្មោះ អាប៉ូគ្រីប៉ា គឺបានមកពីពាក្យក្រិចដែលមានន័យថា "ត្រូវបានលាក់" ហេតុនេះហើយឈ្មោះអាប៉ូគ្រីប៉ាមានន័យថា "ខុសឆ្គង" ប៉ុន្តែ តាមន័យបច្ចេកទេស ពាក្យនេះគឺចង់បកស្រាយពីភាពជាក់លាក់នៃការនិពន្ធ ។ ព្រះគម្ពីរនេះគឺរួមមានកណ្ឌគម្ពីរផ្សេងៗ ដែលគេបន្ថែមពីលើព្រះគម្ពីរគ្រីស្ទបរិស័ទ ហើយនៅក្នុងកណ្ឌទាំងដប់នោះលើកលែងតែព្រះគម្ពីរអេជ្រាសទី២ (ប្រហែលឆ្នាំ ៩0 នៃ គ.ស) ប៉ុណ្ណោះដែលមិនមានកាលបរិច្ឆេទនៃការនិពន្ធនៅក្នុងសម័យចន្លោះគ្រាសញ្ញា ។ ព្រះគម្ពីរទសកណ្ឌត្រូវបានទទួលស្គាល់ និងប្រើប្រាសដោយគ្រីស្ទបរិស័ទនិកាយរ៉ូម៉ាំងកាតូលិក និងអ័តូដក ដែលនោះគឺបណ្ដាលមកពីបញ្ហាដ៏ស្មុគ្រ

ស្នាញនៃប្រវត្តិសាស្ត្រ ។

ការកំណត់ចំនួនពិតប្រាកដនៃកណ្ឌព្រះគម្ពីរសញ្ញាចាស់ភាសាហេព្រើ គឺទំនងជាធ្វើឡើងនៅដើមសតវត្សទី២នៃគ.ស ហើយគ្រីស្ទបរិស័ទប្រូតេស្តង់បច្ចុប្បន្នភាគច្រើនមានការទទួលស្គាល់ការកំណត់នេះផងដែរ ។ ការកំណត់ចំនួននេះនាំឱ្យអ្នកដឹកនាំពួកជិនុំដំបូងមានការមិនឯកភាពគ្នានៅក្នុងការជ្រើសរើសកណ្ឌដែលត្រឹមត្រូវសម្រាប់គ្រីស្ទបរិស័ទ តែទោះជាយ៉ាងណាក៏ដោយ ពួកជំនុំភាគច្រើននៅតែបន្តប្រើព្រះគម្ពីរកណ្ឌទាំងដប់នេះរហូតដល់សម័យកំណែទម្រង់គ្រីស្ទបរិស័ទ ។ នៅក្នុងអំឡុងពេលនោះ គ្រីស្ទបរិស័ទប្រូតេស្តង់ភាគច្រើនបានសម្រេចចិត្តបដិសេធឈប់ប្រើកណ្ឌទាំងដប់នោះ ហើយគ្រីស្ទបរិស័ទរ៉ូម៉ាំងកាតូលិកបានបើកក្រុមប្រឹក្សានៅទីក្រុងទ្រែន (ឆ្នាំ ១៥៤៦) និងក្រុមប្រឹក្សាក្រុងវ៉ាទីកង់លើកទីមួយ (១៨៦៩–៧០) នៅប្រទេសអ៊ីតាលី ដើម្បីបញ្ជាក់អំពីការកំណត់កណ្ឌព្រះគម្ពីរ "អាឡេក្សាន-ឌ្រាន (Alexandrian)" ដែលរួមមានព្រះគម្ពីរកណ្ឌទាំងដប់ផងដែរ ។

ព្រះគម្ពីរកណ្ឌទាំងដប់មានអ្នកទទួលស្គាល់ជាបឋម គឺដោយសាអំណាចនៃព្រះវិហារកាតូលិកដែលបានរាប់ព្រះគម្ពីរនេះចូលទៅក្នុងព្រះគម្ពីរបរិសុទ្ធ ។ គ្មានភ័ស្តុតាងច្បាស់លាស់បញ្ជាក់ថា ព្រះយេស៊ូវ ឬពួកសាវ័កបានដកស្រង់ការបង្រៀនពីព្រះគម្ពីរកណ្ឌទាំងដប់ដូចព្រះគម្ពីរដែលព្រះវិញ្ញាណទ្រង់បណ្តាលឱ្យតែងនោះឡើយ ។ សហគមន៍ពួកយូដាដែលបានបង្កើតព្រះគម្ពីរនេះ បានបដិសេធព្រះគម្ពីរនេះ តាមប្រវត្តិសាស្ត្រតាមព្រះគម្ពីរកិច្ចការ ពួកសាវ័កបានចែកចាយព្រះបន្ទូល ដោយបដិសេធទាំងស្រុងចំពោះសម័យនៃការនិពន្ធព្រះគម្ពីរនោះ ។ ជាងនេះទៅទៀត នៅក្នុងព្រះគម្ពីរ ១ ម៉ាកាប៊ី មានពេញទៅដោយកំហុសឆ្គង និងការខុសកាលបរិច្ឆេទ ។

នៅក្នុងព្រះគម្ពីរទសកណ្ឌ មិនមានតម្លៃនៃវិជ្ជាសិក្សាអំពីព្រះណាមួយ ដែលមានទំនាក់ទំនងនឹងព្រះគម្ពីរបរិសុទ្ធទេ ហើយព្រះគម្ពីរនេះមានវិជ្ជាសិក្សាអំពីព្រះជាច្រើន ដែលមានទំនាក់ទំនងតែជាមួយនឹងការបង្រៀនរបស់ខ្លួនប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរទសកណ្ឌបានផ្តល់នូវប្រភពពត៌ដ៏មានតម្លៃសម្រាប់ការសិក្សាអំពីសម័យចន្លោះគ្រាសញ្ញា ។

*ក្រាំងសមុទ្រស្លាប់ (Dead Sea Scrolls):* នៅក្នុងរដូវផ្ការីកនៃឆ្នាំ ១៩៤៧ អ្នកគង្វាលចៀមជនជាតិអារ៉ាប់ម្នាក់បានប្រថុយចូលទៅក្នុងរូងភ្នំមួយដើម្បីរកផ្លូវឈ្មោះទៅភូមិភាគនិរតីនៃឆ្នេរសមុទ្រស្លាប់ ហើយនៅក្នុងរូងភ្នំនោះ គាត់បានរកឃើញនូវអ្វីដែលគេហៅថា "ការរកឃើញឯកសារបុរាណដ៏អស្ចារ្យបំផុតនៃសម័យទំនើប"។ គេបានឱ្យឈ្មោះឯកសារ និងបំណែកឯកសារដែលបានរកឃើញនៅក្នុងរូងភ្នំនោះថា "ក្រាំងសមុទ្រស្លាប់" ដែលរួមមានកណ្ឌគម្ពីរសញ្ញាចាស់ កណ្ឌគម្ពីរពីរបីក្បាលរបស់ព្រះគម្ពីរកណ្ឌទាំងដប់ ស្នាដៃនិពន្ធអំពីការបើកសំដែង សៀវភៅដែលគេទទួលស្គាល់ថាជាស្នាដៃនៃវីរបុរសខាងជំនឿនៅសម័យបុរាណ និងសៀវភៅមួយចំនួនរបស់ពួកនិកាយ ។

នៅក្នុងចំណោមឯកសារទាំងនោះ មានប្រហែលមួយភាគបី ដែលជាកណ្ឌព្រះគម្ពីរបរិសុទ្ធ មានដូចជា ទំនុកតម្កើង ចោទិយកថា អេសាយ ជាកណ្ឌព្រះគម្ពីរដែលត្រូវបានដកស្រង់ប្រើញឹកញាប់ជាងគេនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ឯកសារដែលគួរឱ្យកត់សម្គាល់បំផុតគឺក្រាំងព្រះគម្ពីរអេសាយមួយកណ្ឌ ដែលមានប្រវែង ៧,៣ ម៉ែត្រ ។

ក្រាំងនេះបានរួមចំណែកយ៉ាងសំខាន់នៅក្នុងការស្វែងរកទម្រង់អត្ថបទព្រះគម្ពីរសញ្ញាចាស់ ដែលមានលក្ខណៈត្រឹមត្រូវបំផុតតាមអត្ថបទដើម ។ បើប្រៀបធៀបពីការមានអាយុកៀកនឹងអត្ថបទដើម ក្រាំងនេះជាអត្ថបទចម្លងដែលមានចំណាស់ជាងអត្ថបទចម្លងផ្សេងទៀត ១000 ឆ្នាំ ។ ការស្វែងយល់អំពីភាសាហេព្រើ និងអើរ៉ាមតាមព្រះគម្ពីរ និងមានការកើនឡើងនូវការយល់ដឹងអំពីការអភិវឌ្ឍន៍នៃសាសនាយូដា នៅក្នុងសម័យចន្លោះគ្រាសញ្ញា ។ ការសំខាន់បំផុតដែលក្រាំងនេះមានចំពោះអ្នកអានព្រះគម្ពីរ គឺក្រាំងនេះមានទៅដោយអត្ថបទព្រះគម្ពីរសញ្ញាចាស់ដែលមានការចម្លងយ៉ាងត្រឹមត្រូវ ជាភស្តុតាងបញ្ជាក់អំពីភាពអាចទុកចិត្តបាននៃអត្ថបទទាំងនោះ ។

## ការអភិវឌ្ឍន៍នៃសង្គម

សាសនាយូដា នៅសម័យព្រះយេស៊ូវ គឺជាសាសនាដែលមានការផ្លាស់ប្តូរខ្លាំង ដែលនោះបណ្តាលមកពីកម្លាំងគៀបសង្កត់នៅក្នុងសម័យចន្លោះគ្រាសញ្ញា ។

*ការខ្ចាត់ខ្ចាយនៃសាសន៍អ៊ីស្រាអែល ឬដាយស្ព័រ៉ា (Diaspora)* ចាប់ផ្តើម នៅក្នុងការនិរទេសដ៏ឆាប់រហ័សមួយ នៅក្នុងសម័យចន្លោះគ្រាសញ្ញា ដែលអ្នកនិពន្ធសម័យនោះអាចនិយាយបានថា ពួកយូដាបានរស់នៅលើ "គ្រប់ទាំងដី និងសមុទ្រ"។

ពួកយូដាដែលរស់នៅក្រៅទឹកដីបរិសុទ្ធ ត្រូវកាត់ផ្តាច់ទំនាក់ទំនងពីព្រះវិហារ ដូចនេះពួកគេបានផ្តោតការអនុវត្តន៍សេចក្តីជំនឿរបស់ពួកគេនៅក្នុងការសិក្សាព្រះគម្ពីរតូរ៉ាហ៍ (Torah) ឬព្រះគម្ពីរទាំងប្រាំកណ្ឌនៃលោកម៉ូសេ និងការជួបជុំគ្នានៅតាមសាលាប្រជុំ ។ ពួកបេសកជននៃពួកជំនុំដំបូងបានចាប់ផ្តើមការផ្សាយដំណឹងល្អដល់សាសន៍ដទៃ នៅតំបន់ដែលពួកយូដាត្រូវខ្ចាត់ខ្ចាយទៅដល់ ពួកគេបានប្រើ

ព្រះគម្ពីរសញ្ញាចាស់បកប្រែជាភាសាក្រិច ឬព្រះគម្ពីរសេបទូជិន (Septuagint) ។

*ពួកសាឌូស៊ី:* នៅក្នុងទឹកដីបរិសុទ្ធ ចក្រភពក្រិចបានធ្វើឱ្យខ្លួនមានឥទ្ធិពលបំផុត តាមរយៈការងាររបស់បក្ស ឬពួកសាឌូស៊ី ។ ពួកនេះប្រជុំទៅដោយពួកអភិជន ហើយបានក្លាយជាបក្សព្រះវិហារ ។ ពួកសាឌូស៊ីបានបន្តទទួលផលប្រយោជន៍នៅក្រោមការគ្រងរបស់ពួកក្រិចបាន ដោយសារមុខតំណែងរបស់ពួកគេ ។

ពួកសាឌូស៊ីមានគ្នាតិចទេ ដូចនេះពួកគេមានអំណាចនយោបាយមិនសមាមាត្រ ហើយបានកាន់កាប់មុខតំណែងសម្ដេចសង្ឃ។ ក្រៅពីព្រះគម្ពីរតូរ៉ាហ៍ (Torah) ឬព្រះគម្ពីរទាំងប្រាំកណ្ឌនៃលោកម៉ូសេ ពួកគេបដិសេធការនិពន្ធទាំងអស់ដែលទាក់ទងនឹងជំនឿ ព្រមទាំងបដិសេធគ្រប់ទាំងគោលលិទ្ធិ (ដូចជាការរស់ពីស្លាប់ឡើងវិញ) ដែលមិនឃើញមាននៅក្នុងព្រះគម្ពីរកណ្ឌទាំងប្រាំផងដែរ ។

*សាលាប្រជុំ:* នៅក្នុងអំឡុងពេលនិរទេសដោយចក្រភពបាប៊ីឡូន ពួកអ៊ីស្រាអែលត្រូវកាត់ដាច់ចេញឆ្ងាយពីព្រះវិហារ ត្រូវបាត់បង់ភាពជាជាតិសាសន៍ ហើយត្រូវហ៊ុំព័ទ្ធទៅដោយការអនុវត្តន៍ជំនឿសាសន៍ដទៃ ។ សេចក្ដីជំនឿរបស់សាសន៍ខ្លួនត្រូវទទួលរងនូវការគម្រាមលប់បំបាត់ពីសាសន៍ដទៃ ។ ស្ថិតនៅក្នុងស្ថានភាពបែបនេះ ការនិរទេសបានផ្លាស់ប្ដូរការផ្ដោតខាងជំនឿរបស់ពួកគេ ពីអ្វីដែលពួកគេបាត់បង់ ទៅអ្វីដែលពួកគេបានទទួលវិញ ដូចជាជាព្រះគម្ពីរតូរ៉ាហ៍ និងជំនឿថា ពួកគេជារាស្ត្ររបស់ព្រះ ។ ពួកគេបានផ្ដោតអារម្មណ៍ទៅលើក្រិត្យវិន័យ ជាជាងភាពជាជាតិសាសន៍អ៊ីស្រាអែល ការប្រឹងប្រែងផ្ទាល់ខ្លួននៅក្នុងជំនឿ ជាជាងការខំប្រារព្ធពិធីក្នុងជំនឿ ហើយពួកគេបានបដិសេធការជំនួសការថ្វាយយ័ញ្ញបូជា ដោយការអធិស្ឋាន ។

នៅពេលដែលពួកគេវិលត្រឡប់ពីការនិរទេសមកវិញ ពួកគេបាននាំមកនូវទម្រង់ថ្មីនៃសាសនាយូដា និងសាលាប្រជុំផងដែរ (ចំណុចសំខាន់) ហើយសាសនាយូដាបានក្លាយជាជំនឿមួយដែលអាចអនុវត្តបាននៅគ្រប់ទីកន្លែងណាដែលគេអាចប្រើព្រះគម្ពីរតូរ៉ាហ៍ ។ ការសង្កត់ធ្ងន់ទៅលើការប្រឹងប្រែងផ្ទាល់ខ្លួននៅក្នុងជំនឿ និងទំនាក់ទំនងជាមួយនឹងព្រះ គឺជាចារិកលក្ខណៈនៃការថ្វាយបង្គំនៅក្នុងសាលាប្រជុំ ហើយមិនគ្រាន់តែបានជួយការពារសាសនាយូដាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរៀបចំផ្លូវសម្រាប់ដំណឹងល្អរបស់គ្រីស្ទបរិស័ទផងដែរ ។

*ពួកផារិស៊ី:* ដោយសារពួកផារិស៊ីជាបក្សនៃសាលាប្រជុំ ពួកគេបានព្យាយាមកាត់ស្រាយនូវក្រឹត្យវិន័យឡើងវិញ ។ ពួកគេបានសង់របងមួយព័ទ្ធជុំវិញក្រឹត្យវិន័យ ដើម្បីឱ្យពួកសាសនាយូដាអាចរស់នៅដោយសុចរិតនៅចំពោះព្រះ នៅក្នុងលោកិយដែលមានការប្រែប្រួលយ៉ាងខ្លាំងចាប់តាំងពីសម័យលោកម៉ូសេ ។ ទោះជាពួកគេមានគ្នាមិនច្រើនក៏ដោយ ក៏ពួកគេមានអំណរនឹងការគាំទ្ររបស់បណ្ដាជន ហើយនឹងការបញ្ចុះបញ្ចូលបណ្ដាជន ដែលធ្វើឱ្យពួកគេមានឥទ្ធិពល ឬនឹងគោលនយោបាយដែលពួកគេបង្កើតសម្រាប់ជាតិអ៊ីស្រាអែល ។ ពួកផារិស៊ីគឺជាក្រុមដែលគេចផុតពីការវិនាសនៅក្នុងការបំផ្លិចបំផ្លាញព្រះវិហារ នៅឆ្នាំ ៧០ នៃគ.ស ហើយពួកគេជាព្ទយុកោខាងជំនឿរបស់សាសនាយូដាសម័យទំនើបទៀតផង ។

*ពួកអេស៊ែន (Essenes):* គឺជានិកាយមួយនៅក្នុងសាសនាយូដា ដែលគេស្ទើរតែមិននឹកចាំ (ប៉ុន្តែមាននិយាយក្នុងកំណត់ប្រវត្តិសាស្ត្រដោយលោកយ៉ូសែបហ្វីស) មុនពេលដែលគេរកឃើញក្រាំងសមុទ្រស្លាប់ ។ ពួកអេស៊ែនគឺជាក្រុមផ្ដាច់ខ្លួនតូចមួយដែលចាប់កំណើតនៅក្នុងសម័យសង្គ្រាមនៃពួកម៉ាកាប៊ី ។ ពួកនេះបានសង្កត់ធ្ងន់ទៅលើការប្រកាន់តាមក្រឹត្យវិន័យតឹងរឹង ដូចពួកផារិស៊ីដែរ តែពួកគេចាត់ទុកការងារសង្ឃក្នុងព្រះវិហារថាពុករលួយ ហើយបានបដិសេធផ្នែកជាច្រើននៃពិធីបុណ្យ និងប្រព័ន្ធនៃការថ្វាយយ័ញ្ញបូជានៅព្រះវិហារ ។ មានអ្នកនិពន្ធសម័យបុរាណតែពីរបីនាក់ប៉ុណ្ណោះដែលបានបញ្ជាក់អំពីពួកអេស៊ែននេះ ដូចនេះគេមិនទាន់ដឹងច្បាស់ពីលក្ខណៈរបស់ពួកគេនៅឡើយទេ ទោះបីជាមានការឯកភាពជាទូទៅថា ក្រុមរបស់ពួកគេគឺជាសហគមន៍គូមរ៉ាន (Qumran) ដែលបានបង្កើតឱ្យមានក្រាំងសមុទ្រស្លាប់ក៏ដោយ ។

ដោយសារពួកអេស៊ែនមានជំនឿថា ក្រុមខ្លួនជាសំណល់ដ៏ត្រឹមត្រូវតែមួយនៃសាសន៍អ៊ីស្រាអែល ពួកគេបានផ្ដាច់ខ្លួនពីសាសនាយូដាអស់មួយផ្នែកធំ ហើយបានផ្ដោតទៅលើការខំឱ្យបានបរិសុទ្ធផ្ទាល់ខ្លួន និងការត្រៀមខ្លួនសម្រាប់សង្គ្រាមចុងក្រោយរវាង "កូននៃពន្លឺ និងកូននៃសេចក្ដីងងឹត"។ ពួកគេមានជំនឿទៅលើការថ្លែងទំនាយ ដោយក្រលេចមកមើលការរួមចំណែករបស់ពួកគេ នៅក្នុងភាពជា "គ្រូនៃសេចក្ដីសុចរិត" ហើយសម្លឹងឆ្ពោះទៅការយាងមកនៃព្រះមែស៊ី ដែលមានពីរអង្គ ឬអាចដល់បីអង្គ ។ ទោះបីជាយ៉ាងណាក៏ដោយ ការបំផ្លិចបំផ្លាញព្រះវិហារ នៅឆ្នាំ ៧០ គ.ស. ហាក់បីដូចជានាំមកនូវការឈប់ជឿជាក់ទៅលើការថ្លែងទំនាយទាំងប៉ុន្មានរបស់ពួកគេ ។

មានការប៉ុនប៉ងសន្និដ្ឋានថា សហគមន៍គូមរ៉ាន (Qumran) គឺជាប្រភពជំនឿលើព្រះគ្រីស្ទ ។ មានអ្នកខ្លះបានលើកឡើងថា ព្រះយេស៊ូវបានយកគំរូពី "ពួកគ្រូបង្រៀននៃសេចក្ដីសុចរិត" ហើយថា ទាំងលោកយ៉ូហានបាទីស្ទ និងព្រះយេស៊ូវ បានចាត់តាំងសមាជិកភាពនៅក្នុងនិកាយនេះ ។ តែទោះជាយ៉ាងណាក៏ដោយ ការសន្និដ្ឋាននេះគ្មានភស្តុតាងគ្រប់គ្រាន់ ដែលគ្មានការពិតតែប៉ុណ្ណោះ ។